sangham.net
Virtual AccessToInsight

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០០១ - Book 001

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថា លោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០១ - Tipitaka Book 001 [http://forum.sangham.net/index.php/topic,8903.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០០១

ភាគ ទី ១១០ | **មាតិកា** | ភាគ ទី ០០២



គំរូ ឯកសារ ផ្សេងទៀត ៖
book_001.pdf

ឯកសារសំឡេង អានដោយ ព្រះខេមានន្ទ
បឋមសិក្ខាបទ ទុតិយសិក្ខាបទំ តតិយសិក្ខាបទំ ចតុត្ថសិក្ខាបទំ

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី ១

ទ. ១

# វិន័យបិដក

CS vin | ភាគ ទី១

# មហាវិភង្គ (បារាជិក)

CS vin.vbu | ភាគ ទី១

**បឋមភាគ**

**ភាគទី ១**

**វេរញ្ជកណ្ឌ**

**បារាជិកកណ្ឌេ**
**បឋមសិក្ខាបទំ** | **ទុតិយសិក្ខាបទំ** | **តតិយសិក្ខាបទំ** | **ចតុត្ថសិក្ខាបទំ**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ។

# វេរញ្ជកណ្ឌ

CS vin.vbu.ve | ភាគ ទី១

**(វេរញ្ជកណ្ឌំ)**

[១] សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃ មានប្រមាណច្រើន ចំនួន៥០០រូប។ វេរញ្ជព្រាហ្មណ៍ [1)] បានឮច្បាស់ (នូវដំណឹងនោះហើយ ទើបប្រកាសសេចក្តីថា) ម្នាលគ្នាយើង បានឮថា ព្រះសមណគោតម ជាសក្យបុត្រចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវមកគង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន៥០០រូប។ កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយ សុះសាយ យ៉ាង
នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គ
ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ គឺសេចក្តីចេះ ទ. ២
ដឹងនិងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ ទៅកាន់ព្រះនិព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ថា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ចំពោះព្រះអង្គនូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចំពោះព្រះអង្គ ទ្រង់ញុាំងនូវពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ហើយទ្រង់ប្រកាស ទ្រង់សំដែងធម៌ ពីរោះបទដើម បទកណ្តាលនិងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក។

[២] គ្រានោះ វេរញ្ជព្រាហ្មណ៍ក៏ចូលសំដៅទៅត្រង់ទីដែលព្រះដ៏មានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ ទ. ៣
សំណេះសំណាលទៅរកព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកលុមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ។ កាលដែលវេរញ្ជព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ក៏ផ្តើមពាក្យនេះក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏

ចម្រើន ខ្ញុំបានឮពាក្យថា ព្រះសមណគោតម មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់
នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះឲ្យអង្គុយលើអាសនៈ
(ព្រះអង្គក៏មិនធ្វើ) បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំបានឮមកនោះ ជាប្រាកដថា ព្រះសមណគោតមដ៏ចម្រើន មិនសំពះ មិនក្រោកទទួល
ព្រាហ្មណ៍ទាំងឡាយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ថា
សូម្បីត្រឹមតែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះឲ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្វើ) បពិត្រព្រះគោតមដ៏ចម្រើន កិច្ច មានមិនសំពះជាដើម
នោះ ជាទំនងពុំសមគួរឡើយ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុង
ពពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាមួយ ល្មមឲ្យតថាគត ទ. ៤
សំពះ ឬក្រោកទទួល ឬអញ្ជើញហៅរកឲ្យអង្គុយលើអាសនៈនោះឡើយ ម្នាលព្រាហ្មណ៍ ព្រោះថាបើតថាគតសំពះអ្នកណា ឬក្រោកទទួលអ្នកណា
ឬអញ្ជើញហៅរកអ្នកណាឲ្យអង្គុយលើអាសនៈ ក្បាលរបស់អ្នកនោះ នឹងដាច់ធ្លាក់ចេញចាក-ក។ វេរញ្ជព្រាហ្មណ៍ ក៏ពោលពាក្យច្រឡោះបោះទៅ
រកព្រះសាស្តាថា ព្រះគោតមដ៏ចម្រើន ជាមនុស្សសោះកក្រោះ ឥតរសជាតិទេតើ។ ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មាន
ហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតមជាមនុស្សសោះកក្រោះ ឥតរសជាតិ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះរស
ជាតិ គឺ រូប សម្លេង ក្លិន ឱជារស សម្ផស្ស ទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់
កើតទៀតឲ្យអស់រលីងដូចជាដើមត្នោតដែលគេក្រៀលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជា
ធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សសោះកក្រោះ ឥតរសជាតិនោះ
គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន គ្មាន ទ. ៥
គ្រឿងបរិភោគទេតើ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជា
មនុស្សគ្មានគ្រឿងបរិភោគ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះគ្រឿងបរិភោគ គឺ រូប សម្លេង ក្លិន រស សម្ផស្សទាំងប៉ុន្មាននោះ
តថាគតបានលះស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចជាដើមត្នោតដែលគេក្រៀល
គាស់រំលើង ឲ្យលែងដុះតទៅទៀតងហើយ ជាធម៌លែងមានបែប ភាពតទៅទៀតហើយ ជាធម៌មិនមានកំណើតតទៅខាងមុខទៀតទេ ម្នាល
ព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សគ្មានគ្រឿងបរិភោគនោះ គឺជាសំដីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ
ដែលអ្នកឯងនិយាយសំដៅនោះទេ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកពោលពាក្យឃាត់កិច្ចការ ថាមិនត្រូវធ្វើទេតើ។ ព្រះសា ទ. ៦
ស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិន
ត្រូវធ្វើ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រកាន់និយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោ
ទុច្ចរិតឡើយ តថាគតតែងនិយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើនូវធម៌ទាំងឡាយជាអកុសលដ៏អាក្រក់ច្រើនប្រការនោះឡើយ ម្នាល
ព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើនោះ គឺជាសំដីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែន
ត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិលទេតើ។ ព្រះសាស្តា
ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្ដាច់ផ្ដិល ដែលគេ
ថានោះ ត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រកាន់និយាយថា ឲ្យសត្វកាត់ផ្ដាច់ផ្ដិលនូវរាគៈ ទោសៈ មោហៈ តថាគតតែងនិយាយថា ឲ្យសត្វ
កាត់ផ្ដាច់នូវធម៌ទាំងឡាយ ជាអកុសលដ៏អាក្រក់ ច្រើនយ៉ាងនោះចេញ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យ
ផ្ដាច់ផ្ដិលនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន
ជាអ្នកខ្ពើមរអើមណាស់ទេតើ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជា
អ្នកខ្ពើមរអើម ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតខ្ពើមសេចក្ដីប្រព្រឹត្តិអាក្រក់ ដោយកាយ វាចា ចិត្ត តថាគតខ្ពើមសេចក្ដី
ប្រកបចិត្តផ្ដេកផ្ដិតទៅរកអកុសលធម៌ ទាំងឡាយដ៏អាក្រក់ច្រើនប្រការ (នោះណាស់) ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជា
អ្នកខ្ពើមរអើមនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន
ជាអ្នកបំផ្លាញទេតើ។ ព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម
ជាអ្នកបំផ្លាញ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ តថាគតសំដែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលបំផ្លាញបង់នូវរាគៈ ទោសៈ មោហៈ
តថាគតសំដែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែល រំលាងបង់នូវអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះ
សមណគោតម ជាអ្នកបំផ្លាញនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ។ ព្រាហ្មណ៍ពោលថា
ព្រះគោតមដ៏ចម្រើន ជាអ្នកដុតកំដៅទេតើ។ ព្រះសព្វញ្ញូជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា
ព្រះសមណគោតមជាអ្នកដុតកំដៅ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រកាន់និយាយថា ការប្រព្រឹត្តិអាក្រក់ដោយកាយ
វាចា ចិត្ត ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ជាអកុសលធម៌ដ៏អាក្រក់ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ
(នោះ) បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីងដូចដើមត្នោតដែលគេ
ក្រៀលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀត
ហើយ តថាគតហៅអ្នកនោះថា អ្នកដុតកំដៅ ម្នាលព្រាហ្មណ៍ អកុសលធម៌ទាំងឡាយដ៏អាក្រក់ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ (នោះ) តថាគត
ឯងបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេក្រៀល
គាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ
ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកដុតកំដៅនោះគឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯង
និយាយសំដៅនោះទេ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាមនុស្សឥតកំណើតទេតើ។ ព្រះដ៏មានជោគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍
ពិតមែនហើយ មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សឥតកំណើត ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះ
កិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅមុខទៀត បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើ
វត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេក្រៀលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅ
ទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកឥតកំណើត ម្នាលព្រាហ្មណ៍ កិរិយាដេកក្នុង គភ៌
តទៅទៀត ដំណើរកើតក្នុងភពតទៅមុខទៀត (នោះ) តថាគតឯងបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយបានធ្វើវត្ថុសម្រាប់

កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេក្របែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀត ហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សឥតកំណើតនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ។

[៣] ម្នាលព្រាហ្មណ៍ ប្រៀបដូចជាពងមាន់ទាំងឡាយ៨ក្តី ១០ក្តី ១២ក្តី ពងមាន់ទាំងនោះ គឺមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្តៅដោយប្រពៃហើយ ឲ្យចាប់ក្លិនវាជាមេដោយប្រពៃហើយ (លុះដល់វេលាញាស់) ក៏បណ្តាកូនមាន់ទាំងនោះ កូនមាន់ណា ទំលាយសម្បកពងដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលមុនគេបំផុត បើដូច្នេះ តើអ្នកផងគួរហៅកូនមាន់នោះថា កូនច្បង ឬកូនពៅហ៏។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន (កូនមាន់នោះ) គេគួរហៅថា កូនច្បង ព្រោះវាជាបងគេបំផុត។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ កាលបើពពួកសត្វ ដូចជាពងមាន់ កើតហើយ មានអវិជ្ជាគឺសេចក្តីល្ងង់ ដូចជាសម្បកពងកំពុងរួបរឹតក្នុងលោក មានតែតថាគតម្នាក់ឯង ដែលទំលាយសម្បកពង គឺសេចក្តីល្ងង់ ហើយត្រាស់ដឹងខ្លួនឯងដោយប្រពៃនូវសម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតឯទៀត ប្រសើរជាងឡើយ ម្នាលព្រាហ្មណ៍ តថាគតឯងជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក ម្នាលព្រាហ្មណ៍ ព្យាយាម តថាគតបានតាំងផ្តើមហើយ មិនបន្ធូរបន្ថយទេ ទាំងស្មារតី តថាគតក៏ប្រុងមិនឲ្យមានភ្លាត់ កាយសោត ក៏ស្ងប់រំងាប់មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អ ជាចិត្តមានអារម្មណ៍តែមួយ ម្នាលព្រាហ្មណ៍ តថាគតឯង លុះដល់ប្រាកដ ជាស្ងាត់ចាកកាមទាំងឡាយ ប្រាកដជាស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយ ក៏ចូលដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍នៅហើយ។ លុះតថាគត ចូលទៅជិតរំងាប់វិតក្កៈ វិចារៈ រួចហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាទីផូរផង់ប្រព្រឹត្តទៅខាងក្នុង មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈ វិចារៈ មានតែបីតិនិងសុខ កើតពីសមាធិនៅហើយ។ លុះលះបង់បីតិចេញហើយ តថាគតជាបុគ្គលព្រងើយ មានសតិ មានសេចក្តីដឹងច្បាស់នៅហើយ តថាគតសោយសុខដោយកាយផង អរិយបុគ្គលទាំងឡាយ តែងសំដែងនូវបុគ្គល ដែលបានតតិយជ្ឈានណា ថាជាបុគ្គលមានចិត្តព្រងើយ ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ តថាគតក៏បានដល់នូវតតិយជ្ឈាននោះហើយនៅ។ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរំលត់នូវសោមនស្ស និងទោមនស្ស អំពីមុនផង តថាគតបានចូលដល់ចតុត្ថជ្ឈានឥតទុក្ខ ឥតសុខ មានសតិដ៏ស្អាតព្រោះឧបេក្ខាហើយនៅ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ តថាគតឯង ក៏បានបង្អោនចិត្តចូលទៅ ក្នុងបុព្វេនិវាសានុស្សតិញ្ញាណ (ញាណជាគ្រឿងរឭកជាតិមុនបាន)។ តថាគតឯង ក៏រឭកជាតិដែលបានអាស្រ័យនៅមកអំពីមុន ជាអនេកជាតិ។ រឭកជាតិបានដូចម្តេច។ រឭកបាន១ជាតិ ២ជាតិ ៣ជាតិ ៤ជាតិ ៥ជាតិ ១០ជាតិ ២០ជាតិ ៣០ជាតិ ៤០ជាតិ ៥០ជាតិ ១០០ជាតិ ១ពាន់ជាតិ ១សែនជាតិក៏បាន រឭកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា តថាគតបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគតច្យុតចាកអត្តភាពនោះ ហើយបានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ តថាគត ក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគតឯងច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ។ តថាគតរឭកតាមនូវជាតិ ដែលអាស្រ័យនៅពីមុន បានច្រើនជាតិ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសយ៉ាងនេះ។ ម្នាលព្រាហ្មណ៍ បឋមវិជ្ជានេះហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាដំបូងនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្ចាត់បាត់ទៅ សេចក្តីចេះដឹងប្រាកដ ក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលកំពុងអង្គុយប្រុងស្មារតី មិនប្រហែសធ្វេសខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្លុងឥតមាននឹកនាដល់កាយ និងជីវិតឡើយ ដូចជាបណ្ឌិតទាំងឡាយ ដែលបាននូវបឋមវិជ្ជានុ៎ះដូច្នោះដែរ។ ម្នាលព្រាហ្មណ៍ នេះឯងជាបឋមវិជ្ជាដែលតថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ញាស់ចេញចាកសម្បកពង។ កាលដែលចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មងជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ តថាគតទើបបង្អោនចិត្តចូលទៅក្នុងញាណ ដែលនាំឲ្យបានត្រាស់ដឹងនូវចុតិ និងបដិសន្ធិនៃសត្វទាំងឡាយ គឺចុតូបបាតញ្ញាណ។ តថាគតពិចារណាមើលនូវសត្វទាំងឡាយ ដែល ច្យុត និងចាប់បដិសន្ធិទាបថោក និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ឃើញច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ និយាយតិះដៀលអរិយបុគ្គលទាំងឡាយ សត្វទាំងនោះ លុះដល់រំលាងខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើតឯអបាយ[2] ទុគ្គតិ[3] វិនិបាត[4] នរក[5] មួយសោត អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវកម្ម ជាសម្មាទិដ្ឋិ មិនតិះដៀលអរិយបុគ្គលទាំងឡាយ សត្វទាំងអម្បាលនោះ លុះដល់រំលាងខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងលោក គឺសុគតិ[6] និងស្ថានសួគ៌។[7] តថាគតពិចារណាមើលនូវសត្វទាំងឡាយ ដែលច្យុត នឹងចាប់បដិសន្ធិ ទាបថោក និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ឃើញច្បាស់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី២នេះឯងហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជា កណ្តាលនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លៅបាត់ទៅ សេចក្តីចេះដឹងប្រាកដក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្លុងឥតមាននឹកនាដល់កាយ និងជីវិតឡើយ ដូចជាបណ្ឌិតទាំងឡាយដែលបាននូវវិជ្ជាទី២ នុ៎ះដូច្នោះដែរ។ ម្នាលព្រាហ្មណ៍ នេះឯងជាវិជ្ជាទី២ ដែលតថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ដែលញាស់ចេញចាកសម្បកពង។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រ យ៉ាងនេះ ហើយ តថាគតទើបបង្អោនចិត្តចំពោះទៅក្នុងញាណជាហេតុឲ្យបានអស់ទៅនៃ អាសវៈទាំងឡាយ គឺអាសវក្ខយញ្ញាណ តថាគតក៏ដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណេះជាអាសវៈ ដឹងប្រាកដតាមពិតថាធម៌នេះជាហេតុនាំឲ្យ កើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់នៃអាសវៈ កាលដែលតថាគតដឹងយ៉ាងនេះ តថាគតឃើញយ៉ាងនេះ ចិត្តតថាគតក៏ផុតចាកគ្រឿងត្រាំគឺកាមផង គឺភពផង គឺអវិជ្ជាផង កាលបើចិត្តតថាគតបានរួចផុតស្រឡះហើយ ប្រាជ្ញាក៏កើតប្រាកដដល់តថាគតថា ចិត្តរួចផុតស្រឡះចាកអាសវៈហើយ ទាំងតថាគតក៏ដឹងច្បាស់ថា កំណើតរបស់អញអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អញក៏បានធ្វើស្រេចហើយ កិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀត មិនមាន

ឡើយ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី៣ នេះហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាបំផុតនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លៅខ្ចាត់បាត់ទៅ សេចក្តីចេះដឹងប្រាកដក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងអង្គុយប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្លូងឥតមាននឹកនាដល់កាយ និងជីវិតឡើយ ដូចជាបណ្ឌិតទាំងឡាយ ដែលបាននូវវិជ្ជាទី៣ នុ៎ះដូច្នោះដែរ។ ម្នាលព្រាហ្មណ៍ ការត្រាស់ដឹងរបស់តថាគត ជាគំរប់៣នេះ ដូចគ្នានឹងការញាស់ចេញរបស់កូនមាន់អំពីសម្បកពង។

[៤] កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេរញ្ជព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគវិញថា ព្រះគោតមដ៏ចម្រើន ព្រះអង្គជាចម្បងជាងមនុស្ស ប្រសើរបំផុតជាងមនុស្ស បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានភ្នែករមែងមើលឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ចាប់ដើម តាំងពីថ្ងៃនេះទៅសូមព្រះគោតមដ៏ចម្រើនជ្រាប នូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណគមន៍ស្មើដោយជីវិត មិនតែប៉ុណ្ណោះទេ សូមព្រះគោតមដ៏ចម្រើន ទទួលនិមន្តគង់ចាំវស្សាជិតស្រុកវេរញ្ជាមួយអន្លើដោយភិក្ខុសង្ឃ។ ព្រះដ៏មានព្រះភាគក៏ព្រមទទួលនិមន្តដោយតុណ្ហីភាព។[8] លំដាប់នោះ វេរញ្ជព្រាហ្មណ៍ដឹងច្បាស់ថា ព្រះអង្គទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណដើរចេញទៅ។

[៥] សម័យនោះឯង ស្រុកវេរញ្ជាកើតអំណត់អត់បាយ មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ក៏ស្លាប់ មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្សដែលមានទ្រព្យសម្បត្តិល្មមទិញដូរស្រូវអង្ករគេបាន ក៏មិនងាយនឹងទិញដូរ បើលុះតែមានស្លាកកាន់ជាសំគាល់ ទើបទិញដូរបាន ជនទាំងអស់ក្នុងស្រុកនោះព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក។ សម័យនោះ មានពួកឈ្មួញសេះនៅក្នុងឧត្តរាបថប្រទេស នាំសេះចំនួន៥០០ចូលមកនៅសម្រាកក្នុងស្រុកវេរញ្ជា ក្នុងរដូវខែវស្សា។ ពួកឈ្មួញដែលនៅក្នុងរោងសេះទាំងនោះ ក៏បានបញ្ញត្តគ្នាឲ្យប្រគេនបាយក្រៀមចំនួន១នាឡិៗម្នាក់ ដល់ភិក្ខុទាំងឡាយ។ លុះដល់ពេលបុព្វណ្ហសម័យ[9] ភិក្ខុទាំងឡាយស្លៀកស្បង់ទ្រង់ចីវរ និងបាត្រនាំគ្នាចូលទៅបិណ្ឌបាត ក្នុងស្រុកវេរញ្ជា ក៏មិនប្រទះបានអាហារបិណ្ឌបាតសោះឡើយ ទើបទៅបិណ្ឌបាតខាងពួកឈ្មួញឯរោងសេះវិញ ក៏បានបាយក្រៀម១នាឡិៗម្នាក់ ហើយវិលមកអារាមយកបាយក្រៀមនោះបុកក្នុងត្បាល់រួចនាំគ្នាឆាន់។ ចំណែកខាងព្រះអានន្ទដ៏មានអាយុ យកបាយក្រៀម១នាឡិ កិនក្នុងត្បាល់ថ្មហើយយកទៅថ្វាយព្រះដ៏មានព្រះភាគ។ ព្រះអង្គក៏ទ្រង់ទទួលសោយបាយក្រៀមនោះ។ វេលានោះ ព្រះសម្ពុទ្ធទ្រង់បានឮសូរត្បាល់ និងអង្រែនោះដែរ។ ព្រះតថាគតទាំងឡាយ បានជ្រាបនូវហេតុហើយសួរក៏មាន បានជ្រាបហើយមិនសួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយសួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយមិនសួរក៏មាន ឯព្រះតថាគតទាំងឡាយ ព្រះអង្គតែងសួរនូវការណាដែលប្រកបដោយប្រយោជន៍ កម្មដែលមិនប្រកបដោយប្រយោជន៍ ព្រះអង្គមិនសួរឡើយ ព្រោះព្រះតថាគតទាំងឡាយ ទ្រង់បានផ្តាច់បង់នូវកម្មមិនប្រកបដោយប្រយោជន៍ ទាំងឡាយ ដោយអរិយមគ្គជ្រះស្រឡះហើយ។ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគទាំងឡាយ ទ្រង់តែងសួរនូវភិក្ខុទាំងឡាយ ដោយហេតុពីរប្រការ គឺទ្រង់សួរដើម្បីនឹងសម្តែងនូវធម៌១ ដើម្បីនឹងបញ្ញត្តនូវសិក្ខាបទដល់សាវកទាំងឡាយ១។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ហៅព្រះអានន្ទដ៏មានអាយុមក ហើយទ្រង់សួរថា ម្នាលអានន្ទ សូរសម្លេងនោះជាសូរត្បាល់អង្រែឬអ្វី។ ទើបព្រះអានន្ទដ៏មានអាយុ ក្រាបទូលរឿងនុ៎ះឲ្យព្រះដ៏មានព្រះភាគជ្រាបគ្រប់ប្រការ។ ព្រះអង្គត្រាស់សសើរថា ត្រូវហើយអានន្ទ ប្រពៃហើយអានន្ទ អ្នកឯងរាល់គ្នាជាសប្បុរសឈ្នះវិសេសហើយ បណ្តាលជនខាងក្រោយគេនឹងនឹកចង់ឲ្យនូវចង្ហាន់ដែលគេចំអិន ដោយអង្ករស្រូវខ្សាយ ព្រមទាំងម្ហូបលាយដោយសាច់ដ៏ឆ្ងាញ់ពិសារ (ដល់អ្នករាល់គ្នា)។

[៦] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់បានក្រាបថ្វាយបង្គំព្រះអង្គដោយគោរព រួចហើយក៏គង់ក្នុងទីដ៏សមគួរ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលស្នើសេចក្តីនេះចំពោះព្រះដ៏មានព្រះភាគថាសូមទ្រង់ព្រះ មេត្តាប្រោស ឥឡូវនេះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ មនុស្សទាំងឡាយនឹងចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ក៏ស្លាប់មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្សដែលមានទ្រព្យ សម្បត្តិ ល្មមទិញដូរស្រូវអង្ករគេបាន ក៏មិនងាយនឹងទិញដូរ បើលុះតែមានស្លាកកាន់ជាសំគាល់នោះទើបទិញដូរបាន ជនទាំងអស់ក្នុងស្រុកនោះ នឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក សូមទ្រង់ព្រះមេត្តា ប្រោស ផ្ទៃខាងក្រោមនៃផែនដីនេះ មានឱជារសផ្អែមដូចទឹកឃ្មុំ ដែលស្អាតបរិសុទ្ធឥតលាយច្រឡំដោយមេឃ្មុំ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គចង់ប្រែត្រឡប់ផែនដីនេះឲ្យផ្ងារឡើង ដើម្បីនឹងឲ្យភិក្ខុទាំងឡាយឆាន់នូវឱជារស ដែលកើតឡើងអំពីស្រទាប់នៃផែនដីនោះ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ចុះអ្នកនឹងយកមនុស្ស សត្វទាំងឡាយដែលនៅអាស្រ័យលើផែនដីនេះ អោយទៅនៅឯណា។ ព្រះមហាមោគ្គល្លានទូលតបថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងនិម្មិតបាតដៃម្ខាង ឲ្យបានដូចជាផែនដី ធំ នឹងឲ្យសត្វទាំងឡាយដែលនៅអាស្រ័យលើផែនដី មកនៅលើបាតដៃម្ខាងនោះ ហើយខ្ញុំព្រះអង្គនឹងប្រែនូវផែនដីដោយដៃម្ខាង។ ព្រះអង្គទ្រង់ឃាត់ថា មោគ្គល្លាន អ្នកកុំពេញចិត្តនឹងត្រឡប់ផែនដីនោះឡើយ សត្វទាំងឡាយនឹងបាននូវសេចក្តីជ្រួលជ្រើមរបស់។ ព្រះមហាមោគ្គល្លានក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះពុទ្ធដីកាដែលទ្រង់ត្រាស់មកនោះប្រពៃហើយ (បើដូច្នោះ) សូមឲ្យភិក្ខុសង្ឃទាំងអស់ទៅបិណ្ឌបាតឯឧត្តរកុរុទ្វីបវិញ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលមោគ្គល្លាន ចុះភិក្ខុទាំងឡាយឯណាដែលមិនមានឫទ្ធិ អ្នកនឹងធ្វើនូវភិក្ខុទាំងនោះដូចម្តេចទៅ។ ព្រះមហាមោគ្គល្លានក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុទាំងអស់នឹងទៅបានយ៉ាងណា ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់តបថា កុំ មោគ្គល្លាន អ្នកកុំពេញចិត្តឲ្យភិក្ខុសង្ឃទាំងអស់ទៅបិណ្ឌបាតឯឧត្តរកុរុទ្វីប នោះឡើយ។

[៧] គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ លោកចូលទៅនៅក្នុងរហោឋានជាទីចេញចាកពួក ហើយសម្ងំនៅក្នុងកម្មដ្ឋាន មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រហ្មចរិយធម៌[10] របស់ព្រះពុទ្ធដ៏មានជោគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយាធម៌មិនឋិតនៅយូរ ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានជោគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌ឋិតនៅយូរ។ គ្រានោះ ព្រះសារីបុត្តត្ថេរដ៏មានអាយុ ចេញចាកទីសម្ងំពួនក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ បានក្រាបថ្វាយបង្គំព្រះអង្គដោយគោរព ហើយគង់ក្នុងទីដ៏សមគួរ។ លុះព្រះសារីបុត្រដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសួរ ចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គចូលទៅនៅក្នុង

រហោឋានជាទីចេញចាកពួក ហើយសម្ងំនៅក្នុងកម្មដ្ឋាន មានសេចក្ដីត្រិះរិះថា ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានជោគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានជោគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌ឋិតនៅយូរ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី១ ព្រះដ៏មានព្រះភាគព្រះនាមសិខី១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ១ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ម្នាលសារីបុត្ត ឯព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមកកុសន្ធ១ ព្រះដ៏មានព្រះភាគព្រះនាមកោនាគមន១ ព្រះដ៏មានព្រះភាគព្រះនាមកស្សប១ ជាព្រហ្មចរិយធម៌ឋិតនៅបានយូរ។ ព្រះសារីបុត្តត្រៀក្រាបទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី១ ព្រះដ៏មានព្រះភាគព្រះនាមសិខី១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ១ បានជាមិនឋិតនៅយូរ នោះតើព្រោះហេតុ និងបច្ច័យដូចម្ដេច។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី១ ព្រះដ៏មានព្រះភាគព្រះនាមសិខី១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ១ ព្រះអង្គមិនសូវប្រឹងប្រែង [11)] សំដែងធម៌ដល់សាវកទាំងឡាយដោយពិស្ដារប៉ុន្មានទេ ព្រហ្មចរិយធម៌មានអង្គ៩ប្រការ របស់ព្រះពុទ្ធទាំងឡាយនោះគឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ជាធម៌មានចំនួនតិចៗណាស់ សិក្ខាបទក៏ព្រះពុទ្ធទាំងនោះមិនបានបញ្ញត្តដល់សាវកទាំងឡាយទេ អាណាបាតិមោក្ខ ក៏ព្រះពុទ្ធទាំងនោះមិនបានសំដែងឡើយ ដល់អំណើះ ឥតពីព្រះពុទ្ធដ៏មានជោគទាំងឡាយនោះទៅ អំណើះឥតពីសាវកទាំងឡាយជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធនោះទៅ សាវកទាំងឡាយជាខាងក្រោយតមក ដែលមាននាមផ្សេងៗគ្នា មានគោត្តផ្សេងៗគ្នា មានជាតិផ្សេងៗគ្នា ចេញពីត្រកូលផ្សេងៗគ្នា ហើយបួសនោះ ក៏ញុំាងព្រហ្មចរិយធម៌នោះឲ្យសាបសូន្យបាត់អស់ភ្លាមទៅ ម្នាលសារីបុត្ត ឧបមាដូចជាផ្កាឈើផ្សេងៗ ដែលគេមិនបានដោតក្រងចងដោយចេសហើយ គេដាក់លើបន្ទះក្ដារ ខ្យល់ក៏រមែងតែបក់បោកកំចាត់កំចាយផ្កាទាំងនោះឲ្យវិនាសអស់ទៅ ខ្យល់ដែលធ្វើនូវផ្កាទាំងនោះឲ្យវិនាស ព្រោះហេតុអ្វី ពីព្រោះផ្កាទាំងនោះ គេមិនបានដោតក្រង ចងដោយចេស ក៏សេចក្ដីនេះយ៉ាងណាមិញ ម្នាលសារីបុត្ត លុះអំណើះឥតនឹងព្រះសម្ពុទ្ធដ៏ទ្រង់ព្រះភាគ (ទាំង៣ព្រះអង្គ) នោះ និងពួកសាវកដែលជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះទៅហើយ ពួកសាវកជាន់ក្រោយៗ តមក មាននាម គោត្ត ជាតិផ្សេងៗគ្នា ដែលចេញចាកត្រកូលផ្សេងៗគ្នាមកបួសនោះ ក៏ញុំាងព្រហ្មចរិយធម៌នោះឲ្យវិនាសទៅឆាប់ភ្លាម ដូចជាផ្កាឥតកំរងយ៉ាងនោះឯង ម្យ៉ាងទៀត ព្រះពុទ្ធដ៏មានជោគទាំងនោះ លោកមិនសូវប្រឹងប្រែងស្ទង់ចិត្ត (របស់សាវក) ដោយព្រះហឫទ័យ (របស់ព្រះអង្គ) ហើយទូន្មាននូវសាវកទាំងឡាយប៉ុន្មានឡើយ ម្នាលសារីបុត្ត ពីដើមមកមានរឿងដំណាលថា ព្រះអរហំសម្មាសម្ពុទ្ធដ៏មានជោគ ទ្រង់ព្រះនាមវេស្សភូ ព្រះអង្គកំណត់នូវចិត្ត (របស់សាវក) ដោយព្រះហឫទ័យ (របស់ព្រះអង្គ) ហើយទ្រង់ទូន្មានប្រៀនប្រដៅភិក្ខុសង្ឃចំនួន១ពាន់រូបនៅនាដងព្រៃមួយ ជាដងព្រៃគួរស្ញើម ដោយពុទ្ធភាសិតថា អ្នកទាំងឡាយចូររិះគិតយ៉ាងនេះ កុំរិះគិតយ៉ាងនេះឡើយ ចូរយកចិត្តទុកដាក់យ៉ាងនេះ កុំយកចិត្តទុកដាក់យ៉ាងនេះឡើយ ចូរលះបង់អំពើយ៉ាងនេះចេញ ហើយចូរផ្ដេកផ្ដួលចិត្តឲ្យប្រដិតប្រជីទៅរកអំពើនេះវិញ ម្នាលសារីបុត្ត នៅវេលាដែលព្រះអរហំសម្មាសម្ពុទ្ធដ៏មានជោគ ទ្រង់ព្រះនាមវេស្សភូ ទ្រង់បានទូន្មានប្រៀនប្រដៅយ៉ាងនេះៗហើយ ចិត្តរបស់ភិក្ខុទាំង១ពាន់រូបនោះ ក៏បានរួចស្រឡះចាកអាសវក្កិលេស មិនមានសេចក្ដីប្រកាន់មាំឡើយ ម្នាលសារីបុត្ត ដងព្រៃដែលមាននៅទីនោះ មុខគួរឲ្យស្ញើមពេកណាស់ បើបុគ្គលណាមួយមិនទាន់ប្រាសចាករាគៈនៅឡើយទេ លុះបានចូលទៅកាន់ដងព្រៃនោះហើយ បុគ្គលនោះនឹងព្រឺរោមដោយច្រើន ម្នាលសារីបុត្ត ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគ ព្រះនាមវិបស្សី១ ព្រះនាមសិខី១ ព្រះនាមវេស្សភូ១ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ព្រោះហេតុ និងបច្ច័យប៉ុណ្ណោះឯង។ ព្រះសារីបុត្តក្រាបទូលសួរតទៅទៀតថា សូមទ្រង់ព្រះមេត្តាប្រោស ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមកកុសន្ធ១ ព្រះនាមកោនាគមន១ ព្រះនាមកស្សប១ (ទាំង៣ព្រះអង្គនេះ) បានជាឋិតនៅយូរ តើព្រោះហេតុ និងបច្ច័យអ្វី។ ព្រះសព្វញ្ញុពុទ្ធត្រាស់តបថា ម្នាលសារីបុត្ត ឯព្រះដ៏មានព្រះភាគព្រះនាមកកុសន្ធ១ ព្រះនាមកោនាគមន១ ព្រះនាមកស្សប១ (ទាំង៣ព្រះអង្គនោះ) ទ្រង់មានសេចក្ដីឧស្សាហ៍ខ្វល់ខ្វាយសំដែងធម៌ដល់ពួកសាវកដោយពិស្ដារ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ របស់ព្រះពុទ្ធទាំង៣ព្រះអង្គនោះក៏សឹងមានច្រើន ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទ ទ្រង់សំដែងអាណាបាតិមោក្ខដល់ពួកសាវក លុះព្រះសម្ពុទ្ធដ៏មានជោគទាំងអម្បាលនោះ ទ្រង់ចូលនិព្វានទៅ ទាំងសាវកដែលត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះ ក៏និព្វានអស់ទៅទៀត សាវកទាំងឡាយជាន់ក្រោយៗតមក ដែលមាននាមផ្សេងៗគ្នា មានគោត្តផ្សេងៗគ្នា មានជាតិផ្សេងៗគ្នា បានចេញអំពីត្រកូលផ្សេងៗគ្នា ហើយបួសនោះ ក៏បានញុំាងព្រហ្មចរិយធម៌ ឲ្យឋិតថេរអស់កាលជាអង្វែងតមក ម្នាលសារីបុត្ត មានគួរនាដូចជា ផ្កាឈើផ្សេងៗ ដែលគេក្រងដោយចេស ហើយដាក់លើបន្ទះក្ដារ ខ្យល់ក៏មិន (អាច) បក់បោកផ្កាទាំងនោះឲ្យរាត់រាយខ្ចាត់ខ្ចាយវិនាសទៅបានឡើយ សេចក្ដីនោះព្រោះហេតុអ្វី ព្រោះថា ផ្កាទាំងនោះ គេក្រងចងខ្ជាប់ដោយអម្បោះ នេះមានឧបមាយ៉ាងណាមិញ ម្នាលសារីបុត្ត សេចក្ដីឧបមេយ្យក៏ដូចគ្នាដែរ លុះព្រះពុទ្ធដ៏មានជោគទាំងអម្បាលនោះចូលនិព្វានទៅហើយ សាវកទាំងឡាយដែលត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះ ក៏និព្វានទៅហើយដែរ សាវកទាំងឡាយជាខាងក្រោយ ដែលមានឈ្មោះផ្សេងៗគ្នា មានគោត្តផ្សេងៗគ្នា មានជាតិផ្សេងៗគ្នា ចេញចាកត្រកូលផ្សេងៗហើយបួស ក៏ញុំាងព្រហ្មចរិយធម៌ (សាសនា) ឲ្យឋិតនៅជាអង្វែងមក ម្នាលសារីបុត្ត នេះឯងជាហេតុ ជាបច្ច័យ ញុំាងព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមកកុសន្ធក្ដី ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមកោនាគមនក្ដី ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមកស្សបក្ដីឲ្យឋិតនៅបានយូរ។

[៨] លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុក្រោកចាកអាសនៈ ហើយធ្វើសម្ពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ៗគួរបញ្ញត្តសិក្ខាបទ គួរសំដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយ ជាហេតុនឹងឲ្យព្រហ្មចរិយធម៌ឋិតថេរអស់កាលអង្វែងទៅ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងសឹងដឹងកាលគួរក្នុងកិច្ចដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្ដា ក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សំដែងអាណាបាតិមោក្ខ ដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ធម៌ទាំងឡាយខ្លះជាទីតាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សំដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពាររារាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសចាស់វស្សាច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើន មានភិក្ខុបួសចាស់វស្សាច្រើនគ្នាក្នុងកាលណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សំដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររារាំងនូវធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈទាំងអម្បាល នោះ

ក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្តីចំរើន មានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើន មានគ្នាច្រើនក្នុងកាលណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សំដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររារាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្តីចំរើន ដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់មានប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃដល់នូវសេចក្តីចំរើន ដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សំដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររារាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ (ឥឡូវ) ភិក្ខុសង្ឃនៅមិនទាន់មានពុត (ហ៊ានលបលួចធ្វើអាក្រក់) នៅឡើយ មិនទាន់មានទោសមោះមែនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង សុទ្ធសឹងតែផូរផង់ផ្ទង់ចិត្តស្ថិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្តាភិក្ខុទាំង៥០០រូប[12] នេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់ លែងធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលតៗទៅទៀតជាប្រាកដ។

[៩] (លុះដល់ចេញវស្សាហើយ) ព្រះដ៏មានជោគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមក ហើយមានព្រះបន្ទូលថា អានន្ទ ទំនៀមព្រះតថាគតទាំងឡាយ បើអ្នកណាគេនិមន្តឲ្យនៅចាំវស្សាហើយ តែនៅមិនទាន់បានលាអ្នកនោះទេ ក៏មិនដែលចៀសចេញ (ពីទីនោះ) ទៅកាន់ជនបទចារិកឡើយ ចរិតនេះជាទំនៀមរបស់ព្រះតថាគតទាំងឡាយ មកអានន្ទ យើងនឹងទៅលាវេរញ្ជព្រាហ្មណ៍។ ព្រះអានន្ទដ៏មានអាយុក៏ទទួលព្រះពុទ្ធដីកាថា សូមទ្រង់ព្រះមេត្តាប្រោស មែនយ៉ាងនេះហើយ។ លំដាប់នោះ ព្រះភគវា ព្រះអង្គទ្រង់ស្បង់ចីពរ ព្រមទាំងបាត្រស្រេចហើយ ទ្រង់យកព្រះអានន្ទដ៏មានអាយុជាបច្ឆាសមណៈ (ឲ្យនិមន្តតាមក្រោយព្រះអង្គទៅ) ទ្រង់យាងសំដៅទៅរកលំនៅរបស់វេរញ្ជព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេរៀបចំថ្វាយ។ គ្រានោះ វេរញ្ជព្រាហ្មណ៍ ក៏ចូលមកគាល់ព្រះអង្គ លុះមកដល់ទីគំនាល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអង្គដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ។ កាលបើវេរញ្ជព្រាហ្មណ៍អង្គុយស្រួលបួលហើយ ក៏ព្រះដ៏មានព្រះភាគមានព្រះបន្ទូលថា ព្រាហ្មណ៍ អ្នកឯងបាននិមន្តយើងឲ្យនៅចាំវស្សា (ឥឡូវ) ចេញវស្សាហើយ យើងត្រូវលាអ្នកនឹងចេញទៅកាន់ជនបទចារិក។ វេរញ្ជព្រាហ្មណ៍ ក៏ក្រាបទូលតបថា បពិត្រព្រះគោតមដ៏ចំរើន មែនហើយ ខ្ញុំព្រះអង្គបាននិមន្តសូមឲ្យព្រះអង្គគង់ចាំវស្សា តែថាទេយ្យធម៌ដែលខ្ញុំព្រះអង្គបំរុងនឹងថ្វាយនោះ ខ្ញុំព្រះអង្គមិនទាន់បានថ្វាយនៅឡើយ ឯទេយ្យធម៌នោះ មិនមែនជាគ្មានទេ ខ្ញុំព្រះអង្គនឹងបានបំរុងថានឹងមិនថ្វាយនោះក៏ទេ (ចេះតែខានមិនទាន់បានថ្វាយ) ព្រោះជាតិជាគ្រហស្ថអ្នកគ្រប់គ្រងផ្ទះសម្បែង រមែងមានកិច្ចរវល់ច្រើន មានការងារក៏ច្រើន ចំណែកខាងព្រះអង្គសោត ទ្រង់នឹងបានទេយ្យធម៌នោះមកពីណា សូមព្រះគោតមដ៏ចំរើន ព្រមទាំងព្រះភិក្ខុសង្ឃទទួលចង្ហាន់របស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក សិន។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ក៏ត្រាស់សំដែងធម៌ ពន្យល់ណែនាំឲ្យវេរញ្ជព្រាហ្មណ៍យល់ប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោក ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយ ខ្មីឃ្មាតសង្វាតធ្វើការកុសល រួចទ្រង់ក្រោកចាកអាសនៈ ហើយយាងត្រឡប់មកវិញ។ ដល់វេលាព្រឹកឡើង វេរញ្ជព្រាហ្មណ៍ បង្គាប់ជនទាំងឡាយឲ្យចាត់ចែងធ្វើខាទនីយភោជនីយាហារ (បង្អែម និងចំអាប) ដ៏ឆ្ងាញ់ពិសារក្នុងលំនៅរបស់ខ្លួនស្រេចហើយ ទើបចាត់បំរើឲ្យទៅក្រាបទូលព្រះដ៏មានព្រះភាគតាមកំណត់ពេលថា បពិត្រព្រះគោតមដ៏ចំរើន កាលនេះជាកាលគួរហើយ ចង្ហាន់ក៏បានរៀបចំស្រេចហើយ។ លំដាប់នោះ ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ស្បង់ ចីវរព្រមទាំងបាត្រ ហើយយាងចូលទៅកាន់លំនៅនៃវេរញ្ជព្រាហ្មណ៍ ជាមួយនឹងព្រះភិក្ខុសង្ឃក្នុងវេលាព្រឹកនោះ លុះដល់ហើយ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ។ វេលានោះ វេរញ្ជព្រាហ្មណ៍ បានអង្គាសថ្វាយខាទនីយភោជនីយាហារ (បង្អែម និងចំអាប) ដ៏ឆ្ងាញ់ពិសារដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ត្រាតែដល់លោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានជោគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏ថ្វាយចីវរ១ត្រៃ ហើយប្រគេនសម្ពត់ព្រះភិក្ខុសង្ឃ១គូៗរាល់អង្គ។ លំដាប់នោះ ព្រះភគវាទ្រង់ត្រាស់សំដែងធម៌ណែនាំពន្យល់ឲ្យវេរញ្ជព្រាហ្មណ៍យល់ ប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោក ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយខ្មីឃ្មាតសង្វាតធ្វើកុសល រួចព្រះអង្គក្រោកចាកអាសនៈ ហើយទ្រង់យាងត្រឡប់មកវិញ។ លុះព្រះអង្គគង់នៅជិតស្រុកវេរញ្ជា តាមគួរដល់អធ្យាស្រ័យហើយ ទ្រង់ក៏យាងចេញទៅកាន់នគរសោរេយ្យ រួចទៅនគរសង្កស្ស ហើយហួសទៅនគរកណ្ណកុជ្ជៈ (តពីនោះទៅ) ទ្រង់យាងសំដៅទៅស្រុកបយាគបតិដ្ឋាន លុះទៅដល់ហើយ ទ្រង់ឆ្លងគង្គានទីក្នុងស្រុកបយាគបតិដ្ឋាន ហើយយាងទៅដល់នគរពារាណសី។ គ្រានោះ ព្រះអង្គគង់កំសាន្តក្នុងក្រុងពារាណសី ហើយទ្រង់ចៀសទៅកាន់ចារិកនៃក្រុងវេសាលី កាលទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ក៏បានទៅដល់ក្រុងវេសាលី។ បានឮថា ព្រះដ៏មានជោគ ព្រះអង្គទៅគង់សម្រាន្តឥរិយាបថក្នុងកូដាគារសាលា នៅនាមហាវន (ព្រៃធំ) ជិតក្រុងវេសាលីនោះ។

វារៈសំដែងអំពីនិទានវេរញ្ជព្រាហ្មណ៍ ចប់។

# បារាជិកកណ្ឌោ

CS vin.vbu.pr | ភាគ ទី១

**(១. បារាជិកកណ្ឌំ)**

## បារាជិកកណ្ឌោ បឋមសិក្ខាបទំ

CS vin.vbu.pr.01 | ភាគ ទី១

**(១. បឋមបារាជិកំ)**

# សុទិន្នភាណវារោ

CS vin.vbu.pr.01.01 | ភាគ ទី១

## (សុទិន្នភាណវារោ)

[១០] ក្នុងសម័យនោះឯង មានស្រុកមួយឈ្មោះកលន្ទនៅមិនឆ្ងាយប៉ុន្មានអំពីក្រុងវេសាលី។ ក្នុងស្រុកនោះមានកូនសេដ្ឋីម្នាក់ឈ្មោះសុទិន្នកុមារជាបុត្ររបស់ កលន្ទសេដ្ឋី។ គ្រានោះ សុទិន្នកុមារកលន្ទបុត្រជាមួយនឹងសំឡាញ់ទាំងឡាយច្រើននាក់ នាំគ្នាទៅឯក្រុងវេសាលីដោយ មានកិច្ចការអ្វីមួយ។ សម័យនោះឯង ព្រះដ៏មានព្រះភាគជាអង្គម្ចាស់មានពពួកបរិសទ្យច្រើនគាល់ត្រៀបត្រា ទ្រង់កំពុងគង់សំដែងព្រះធម៌។ សុទិន្នកលន្ទបុត្រ ក៏ទៅប្រទះបានឃើញព្រះអង្គមានបរិសទ្យច្រើនគាល់ត្រៀបត្រា កំពុងសំដែងធម៌។ លុះឃើញហើយ សុទិន្នកុមារនោះក៏មានសេចក្តីត្រិះរិះថា អាត្មាអញគួរតែស្តាប់ធម៌សិន។ គ្រានោះសុទិន្នកលន្ទបុត្រក៏ចូលទៅកាន់ទីដែលបរិស័ទ្យអង្គុយនោះ លុះចូលទៅដល់ហើយ បានអង្គុយនៅក្នុងទីមួយដ៏សមគួរ។ កាលដែលសុទិន្នកុមារកលន្ទកបុត្របានអង្គុយនៅក្នុងទីមួយដ៏សមគួរហើយ ក៏មានសេចក្តីត្រិះរិះថា ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយដំណើរយ៉ាងណាៗ អញក៏បានស្តាប់យល់តាមដំណើរទាំងនោះហើយ ប៉ុន្តែបើអញនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌អោយបរិបូណ៌តែម្យ៉ាង អោយបរិសុទ្ធតែម្យ៉ាងដូចជាស័ង្ខដែលគេខាត់ហើយនោះទេ បើលុះតែអញកោរសក់និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សម្ពត់ជ្រលក់អម្ចត់ ហើយចេញចាកផ្ទះទៅបួសប្រតិបត្តិក្នុងផ្នួសដែលគ្មានប្រយោជន៍ ដោយកិច្ចការក្នុងផ្ទះ(នោះទើបប្រព្រឹត្តព្រហ្មចរិយធម៌កើត)។ គ្រានោះ ពួកបរិសទ្យបានស្តាប់ធម្មីកថាដែលព្រះដ៏មានព្រះភាគ ទ្រង់ណែនាំពន្យល់អោយជឿជាក់កុសលធម៌ ឲ្យរីករាយរាល់គ្នាហើយ ក៏ក្រោកចាកទីអង្គុយ ក្រាបថ្វាយបង្គំព្រះអង្គ រួចដើរប្រទក្សិណហើយក៏ចេញអស់ទៅ។ ឯសុទិន្នកលន្ទកបុត្រ កាលបើពួកពុទ្ធបរិស័ទ្យក្រោកទៅអស់ហើយភ្លាម ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្រាបថ្វាយបង្គំព្រះអង្គដោយគោរព រួចអង្គុយក្នុងទីមួយដ៏សមគួរ។ លុះសុទិន្នកលន្ទកបុត្រ អង្គុយនៅក្នុងទីមួយដ៏សមគួរហើយ ក៏ក្រាបទូលព្រះអង្គថា សូមទ្រង់ព្រះមេត្តាប្រោស ធម៌ដែលព្រះអង្គសំដែងហើយ ដោយដំណើរយ៉ាងណាៗ ខ្ញុំព្រះអង្គបានយល់តាមដំណើរទាំងនោះដែរហើយ ប៉ុន្តែបើខ្ញុំព្រះអង្គនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ (យ៉ាងនេះ) ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ សូមទានខ្ញុំព្រះអង្គចង់កោរសក់ និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សម្ពត់ជ្រលក់អម្ចត់ ហើយចេញចាកផ្ទះមកបួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ (នោះណាស់) សូមព្រះដ៏មានជោគ ទ្រង់បំបួសខ្ញុំព្រះអង្គផង។ ព្រះសាស្តាទ្រង់ត្រាស់សួរថា ម្នាលសុទិន្ន ចុះអ្នកឯងមាតាបិតាបានយល់ព្រមឲ្យចេញចាកផ្ទះមកបួសប្រតិបត្តិ ក្នុងបព្វជ្ជា ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះហើយឬ។ សុទិន្នក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមាតាបិតាមិនទាន់បានយល់ព្រមឲ្យចេញចាកផ្ទះមកបួសក្នុង ព្រះពុទ្ធសាសនានៅឡើយទេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលសុទិន្ន ព្រះតថាគតទាំងឡាយ មិនដែលបំបួសកូនដែលមាតាបិតា មិនទាន់អនុញ្ញាតនោះទេ។ សុទិន្នក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងទទួចលាមាតាបិតា ត្រាតែអនុញ្ញាតឲ្យខ្ញុំព្រះអង្គចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនា ឲ្យបាន។

[១១] លំដាប់នោះ សុទិន្នកលន្ទបុត្របានសម្រេចកិច្ចភារៈដែលខ្លួនត្រូវធ្វើក្នុង ក្រុងវេសាលីនោះរួចស្រេចហើយ ក៏វិលត្រឡប់មកស្រុកកលន្ទវិញ បានចូលទៅរកមាតាបិតា ហើយជំរាបមាតាបិតាថា បពិត្រអ្នកម្តាយ អ្នកឪពុក ខ្ញុំបាទបានស្តាប់ធម៌ដែលព្រះដ៏មានជោគទ្រង់សំដែងដោយដំណើរយ៉ាងណាៗ ក៏យល់តាមដំណើរទាំងនោះហើយ ខ្ញុំបាទគិតថា បើខ្ញុំនៅជាគ្រហស្ថគ្រប់គ្រងផ្ទះនោះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាងដូចជាស័ង្ខដែលគេខាត់ហើយនោះទេ ខ្ញុំបាទចង់កោរសក់ និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សម្ពត់ជ្រលក់អម្ចត់ ហើយចេញចាកផ្ទះទៅបួសប្រតិបត្តិក្នុងផ្នួសដែលគ្មានប្រយោជន៍ដោយកិច្ចការ ក្នុងផ្ទះ(នោះណាស់) សូមអ្នកម្តាយ អ្នកឪពុកអនុញ្ញាតឲ្យខ្ញុំបាទចេញចាកផ្ទះទៅបួសក្នុងព្រះពុទ្ធសាសនា ឲ្យទាន។ មាតាបិតារបស់សុទិន្នកលន្ទបុត្រ កាលបើបានឮកូនលាដូច្នេះហើយ ក៏និយាយឃាត់ថា ម្នាលសុទិន្នកូន បាឯងជាបុត្រឯករបស់យើង ជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់បិតនៅក្នុងសេចក្តីសុខ មានអ្នកទំនុកបម្រុងឲ្យបានសេចក្តីសុខ នែសុទិន្នកូន បាឯងមិនដែលស្គាល់ទុក្ខបន្តិចបន្តួចសោះឡើយ ទោះបីបាឯងស្លាប់ក្តី យើងក៏មិនចង់ព្រាត់ប្រាសចាកបាឯងទេ យើងនឹងអនុញ្ញាតបាកំពុងរស់នៅឲ្យចេញចាកផ្ទះទៅបួសក្នុង ព្រះពុទ្ធសាសនាម្តេចបាន។ ទើបសុទិន្នកលន្ទបុត្រនិយាយពាក្យនេះនឹងមាតាបិតាជាគំរប់ពីរដងថា បពិត្រមាតាបិតា ធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយដំណើរយ៉ាងណាៗ ខ្ញុំបានយល់តាមដំណើរទាំងនោះដែរហើយ ប៉ុន្តែបើខ្ញុំនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ(យ៉ាងនេះ) ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ ខ្ញុំចង់កោរសក់និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សម្ពត់ជ្រលក់អម្ចត់ ហើយចេញចាកផ្ទះ មកបួសក្នុងព្រះពុទ្ធសាសនា សូមមាតាបិតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះ ទៅបួសក្នុងព្រះពុទ្ធសាសនាឲ្យទាន។ មាតាបិតារបស់សុទិន្នកលន្ទបុត្រ ទើបនិយាយនឹងសុទិន្នកលន្ទបុត្រជាគំរប់ពីរដងដូច្នេះថា នែសុទិន្នកូន បាឯងជាបុត្រតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង (បាឯង) ធ្លាប់បិតនៅក្នុងសេចក្តីសុខ មានអ្នកថែរក្សាឲ្យបានសេចក្តីសុខ នែបាសុទិន្ន បាមិនធ្លាប់ស្គាល់សេចក្តីទុក្ខបន្តិចបន្តួចសោះ ទោះបីបាឯងស្លាប់ក្តី យើងមិនចង់ព្រាត់ប្រាសចាកបាទេ យើងនឹងអនុញ្ញាតបាកំពុងរស់នៅឲ្យចេញចាកផ្ទះទៅបួសក្នុងព្រះពុទ្ធ សាសនាម្តេចបាន។ សុទិន្នកលន្ទបុត្រ បាននិយាយពាក្យនេះនឹងមាតាបិតាជាគំរប់បីដងថា បពិត្រមាតាបិតា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងដោយអាការ យ៉ាងណាៗ ធម្មតាអ្នកនៅគ្រប់គ្រងផ្ទះនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលបុគ្គលដុសខាត់ហើយ មិនងាយធ្វើទេ ខ្ញុំប្រាថ្នាដើម្បីកោរសក់ និងពុកមាត់ ហើយស្លៀកដណ្តប់សម្ពត់កាសាយៈ ហើយចេញចាកផ្ទះទៅបួសជាបុគ្គលមិនត្រូវការដោយផ្ទះ ហេតុនេះសូមមាតាបិតាអនុញ្ញាតខ្ញុំ ឲ្យចេញចាកផ្ទះទៅបួសជាបុគ្គលមិនត្រូវការដោយផ្ទះវិញចុះ។ មាតាបិតារបស់សុទិន្នកលន្ទបុត្រ បាននិយាយពាក្យនេះនឹងសុទិន្នកលន្ទបុត្រជាគំរប់បីដងថា នែសុទិន្នកូន បាឯងជាបុត្រតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់បិតនៅក្នុងសេចក្តីសុខ មានអ្នកថែទាំឲ្យបានសេចក្តីសុខ នែបាសុទិន្ន បាមិនស្គាល់សេចក្តីទុក្ខបន្តិចសោះ ទោះបីស្លាប់ទៅក្តី យើងក៏មិនប្រាថ្នាឲ្យព្រាត់ប្រាសចាកបា យើងនឹងអនុញ្ញាតបា ដែលកំពុងរស់នៅឲ្យចេញចាកផ្ទះហើយបួសក្នុងសាសនាម្តេចបាន។ គ្រានោះឯងសុទិន្នកលន្ទបុត្រគិតថា មាតាបិតាមិនអនុញ្ញាតអញឲ្យចេញចាកផ្ទះបួសក្នុងសាសនា ដូច្នេះហើយ ក៏ដួលដេកនៅលើផែនដី ប្រាសចាកគ្រឿងកំរាលក្នុងទីនោះឯងដោយគិតថា អញនឹងស្លាប់ឬនឹងបានបួសក្នុងទីនេះជាប្រាកដ។ គ្រានោះ សុទិន្នកលន្ទបុត្រ មិនបានបរិភោគបាយអស់មួយពេល ២ពេលក៏មាន ៣ពេលក៏មាន ៤ពេលក៏មាន ៥ពេលក៏មាន ៦ពេលក៏មាន ៧ពេលក៏មាន។

[១២] លំដាប់នោះ មាតាបិតារបស់សុទិន្នកលន្ទបុត្រនិយាយនឹងសុទិន្នកលន្ទបុត្រថា ម្នាលសុទិន្នកូន បាឯងជាកូនប្រុសតែមួយ ហើយជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់សុខធ្លាប់សប្បាយដោយមានស្រីពីលៀងថែរក្សា សុទិន្នកូន បាឯងមិនធ្លាប់ស្គាល់សេចក្តីទុក្ខតិចតួចសោះទេ ទោះបីបាស្លាប់ទៅក្តី យើងក៏មិនចង់ឲ្យព្រាត់ប្រាសចាកបាឡើយ យើងនឹងអនុញ្ញាតអ្នកកំពុងរស់នៅ ឲ្យចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាដូចម្តេចបាន សុទិន្នកូន អ្នកចូរក្រោកឡើងបរិភោគបាយ ផឹកទឹក និងឲ្យគេបំរើទៅ កាលបើអ្នកបរិភោគបាយ ផឹកទឹក និងឲ្យគេបំរើហើយ ចូរបរិភោគកាមនិងធ្វើបុណ្យចុះ យើងមិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ។ កាលបើមាតាបិតាពោលយ៉ាងនេះហើយ សុទិន្នកលន្ទបុត្រក៏ស្ងៀមនៅ។ ឯមាតាបិតាសុទិន្នកលន្ទបុត្រនិយាយលួងលោមសុទិន្នកលន្ទបុត្រពីរដង។ បេ។ បីដងថា នែសុទិន្នកូន អ្នកឯងជាកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តយើង ធ្លាប់ចំរើនដោយសេចក្តីសុខ មានទាំងស្រីពីលៀងថែរក្សាសប្បាយ សុទិន្នកូន អ្នកឯងមិនដែលស្គាល់សេចក្តីទុក្ខតិចតួចសោះ ទោះបីអ្នកឯងស្លាប់ទៅក្តី យើងមិនចង់ឲ្យព្រាត់ប្រាសចាកអ្នកឯងឡើយ យើងនឹងអនុញ្ញាតដល់អ្នកកំពុងរស់នៅឲ្យចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាដូចម្តេចបាន សុទិន្នកូន អ្នកចូរក្រោកឡើងបរិភោគបាយ ផឹកទឹក និងឲ្យគេបំរើទៅ កាលបរិភោគបាយ ផឹកទឹក និងឲ្យគេបំរើហើយ ចូរបរិភោគកាម និងធ្វើបុណ្យតាមប្រាថ្នាចុះ យើងមិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ។ សុទិន្នកលន្ទបុត្រក៏ស្ងៀមនៅទៅវិញជាគំរប់បីដង។

[១៣] លំដាប់នោះ ពួកសំឡាញ់សុទិន្នកលន្ទបុត្របាននាំគ្នាចូលទៅនិយាយអង្វរសុទិន្នកលន្ទបុត្រ ថា នែសុទិន្នសំឡាញ់ អ្នកឯងជាកូនប្រុសតែមួយ ហើយជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា ធ្លាប់បានសេចក្តីសុខ មានទាំងស្រីពីលៀងថែរក្សាសប្បាយ នែសុទិន្នសំឡាញ់ អ្នកឯងមិនធ្លាប់ស្គាល់សេចក្តីលំបាកតិចតួចសោះទេ ទោះបីអ្នកស្លាប់ទៅក្តី មាតាបិតារបស់អ្នក ក៏មិនចង់ឲ្យព្រាត់ប្រាសចាកអ្នកឡើយ មាតាបិតាទាំងឡាយរបស់អ្នកនឹងអនុញ្ញាតអ្នកដែលកំពុងរស់នៅឲ្យចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាដូចម្តេចបាន នែសុទិន្នសំឡាញ់ ចូរអ្នកក្រោកឡើងបរិភោគបាយ ផឹកទឹក ឲ្យគេបំរើទៅ កាលបើអ្នកបរិភោគបាយចំណី ផឹកទឹកឲ្យគេបំរើខ្លួនហើយ និងបរិភោគនូវកាមទាំងឡាយ ធ្វើបុណ្យ (ឲ្យទាន) រីករាយសប្បាយតាមសេចក្តីប្រាថ្នាចុះ មាតាបិតាទាំងឡាយរបស់អ្នក មិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ។ កាលបើពួកសំឡាញ់របស់សុទិន្នពោលពាក្យយ៉ាងនេះហើយ សុទិន្នកលន្ទបុត្រក៏នៅស្ងៀម។ ពួកសំឡាញ់របស់សុទិន្នកលន្ទបុត្របានពោលនូវពាក្យនេះនឹង សុទិន្នកលន្ទបុត្រពីរដង។ បេ។ បីដងថា នែសុទិន្នសំឡាញ់ អ្នកឯង។ បេ។ សុទិន្នកលន្ទបុត្រក៏នៅស្ងៀមអស់វារៈជាគំរប់បីដង។ គ្រានោះឯង មាតាបិតាទាំងឡាយរបស់សុទិន្នកលន្ទបុត្រនៅក្នុងទីណា សំឡាញ់ទាំងឡាយរបស់សុទិន្នកលន្ទបុត្រក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ បានពោលនូវពាក្យនេះនឹងមាតាបិតាទាំងឡាយនៃសុទិន្នកលន្ទបុត្រថា បពិត្រលោកម្តាយ លោកឪពុក សុទិន្ននេះដេកនៅលើផែនដីរកគ្រឿងកំរាលអ្វីគ្មានសោះទេ ហើយគិតថា សេចក្តីស្លាប់ក្តី បព្វជ្ជាក្តី នឹងមានដល់អញក្នុងទីនេះឯង បើលោកទាំងឡាយមិនព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះហើយបួស ក្នុងព្រះពុទ្ធសាសនាទេ សុទិន្ននឹងដល់នូវសេចក្តីស្លាប់ក្នុងទីនោះមិនខានឡើយ ប្រសិនណាបើលោកទាំងឡាយព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះហើយបួសក្នុង ព្រះពុទ្ធសាសនា គង់តែនឹងបានឃើញមុខសុទិន្ន ដែលនៅជាអ្នកបួសតទៅ បើសុទិន្នមិនត្រេកអរក្នុងបព្វជ្ជាហើយ គតិរបស់សុទិន្ននោះប្រព្រឹត្តទៅក្នុងទីដទៃដូចម្តេចបាន មុខជានឹងត្រឡប់មកក្នុងទីនេះវិញមិនខាន ដូច្នេះសូមលោកទាំងឡាយអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះហើយបួសក្នុង ព្រះពុទ្ធសាសនា។ មាតាបិតាទាំងឡាយនៃសុទិន្នក៏ពោលថា ម្នាលអ្នកទាំងឡាយ យើងទាំងឡាយព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះហើយបួសក្នុង ព្រះពុទ្ធសាសនាចុះ។

[១៤] គ្រានោះឯង សុទិន្នកលន្ទបុត្រនៅក្នុងទីណា សំឡាញ់ទាំងឡាយនៃសុទិន្នកលន្ទបុត្រ ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ បានពោលនូវពាក្យនេះនឹងសុទិន្នកលន្ទបុត្រថា នែសុទិន្នសំឡាញ់ ចូរអ្នកក្រោកឡើង អ្នកឯងមាតាបិតាព្រមព្រៀងអនុញ្ញាតឲ្យចេញចាកផ្ទះបួសក្នុងព្រះពុទ្ធសាសនាហើយ។ គ្រានោះសុទិន្នកលន្ទបុត្របានដឹងថាមាតាបិតាព្រមព្រៀងអនុញ្ញាតឲ្យចេញចាក ផ្ទះ ដើម្បីបួសក្នុងព្រះពុទ្ធសាសនា (ដូច្នោះ) ហើយ ក៏មានចិត្តរីករាយដូចជាអណ្តែតឡើង ជូតសំអាតខ្លួនដោយដៃទាំងឡាយ ហើយក្រោកឡើង។ គ្រានោះ សុទិន្នកលន្ទបុត្រសំរាកកំលាំងបានពីរបីថ្ងៃ ព្រះដ៏មានព្រះភាគគង់ក្នុងទីណា ក៏ចូលទៅកាន់ទីនោះ លុះចូលទៅហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះសុទិន្នកលន្ទបុត្រអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាបុគ្គល គឺមាតាបិតាអនុញ្ញាតឲ្យចេញចាកផ្ទះហើយបួសក្នុងភេទជាបុគ្គលមិន មានប្រយោជន៍ដោយការងារក្នុងផ្ទះហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់បំបួសខ្ញុំព្រះអង្គផងចុះ។ សុទិន្នកលន្ទបុត្របានបព្វជ្ជា និងឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគហើយ។ សុទិន្នភិក្ខុដ៏មានអាយុបានឧបសម្បទាហើយមិនយូរប៉ុន្មាន ក៏ប្រព្រឹត្តសមាទានធុតង្គគុណ មានសភាពយ៉ាងនេះគឺ ជាអ្នកនៅក្នុងព្រៃ ប្រព្រឹត្តបិណ្ឌបាត ប្រើប្រាស់សម្ពត់បំសុកូល និងត្រេចទៅ(បិណ្ឌបាត) តាមលំដាប់ផ្ទះ ហើយចូលទៅអាស្រ័យនៅក្នុងស្រុកវជ្ជីឯណានីមួយ។

[១៥] សម័យនោះឯង ស្រុកវជ្ជីមានអំណត់អត់បាយ មនុស្សទាំងឡាយនឹងចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ ក៏ដល់នូវសេចក្តីស្លាប់មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្សដែលមានទ្រព្យសម្បត្តិល្មមទិញដូរស្រូវអង្ករគេបាន ក៏មិនងាយនឹងទិញដូរដែរ លុះតែមានស្លាកជាទីសំគាល់ទើបទិញដូរបាន ជនទាំងអស់ក្នុងស្រុកនោះនឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក។ លំដាប់នោះឯងសុទិន្នភិក្ខុដ៏មានអាយុមានសេចក្តីត្រិះរិះដូច្នេះថា ក្នុងកាលឥឡូវនេះ ស្រុកវជ្ជីមានអំណត់អត់បាយ មនុស្សទាំងឡាយនឹងចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ ក៏ដល់នូវសេចក្តីស្លាប់មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្សដែលមានទ្រព្យសម្បត្តិល្មមទិញដូរស្រូវអង្ករបាន ក៏មិនងាយនឹងទិញដូរដែរ លុះតែមានស្លាកជាទីសំគាល់ ទើបទិញដូរបាន ជងទាំងអស់ក្នុងស្រុកនោះ នឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក ញាតិទាំងឡាយរបស់អញមានច្រើនក្នុងក្រុងវេសាលី ជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ច្រើន មានទ្រព្យនិងស្រូវច្រើន បើដូច្នោះ មានតែអាត្មាអញគប្បីចូលទៅអាស្រ័យនូវញាតិទាំងឡាយ ហើយនៅ ញាតិទាំងឡាយសោត អាស្រ័យនូវអាត្មាអញហើយ នឹងបានឲ្យទាន និងធ្វើបុណ្យ ភិក្ខុទាំងឡាយនឹងបានលាភផង អាត្មាអញនឹងមិនលំបាកដោយបិណ្ឌបាតផង។ ទើបសុទិន្នភិក្ខុដ៏មានអាយុរៀបចំសេនាសនៈ ហើយកាន់យកបាត្រនិងចីវរ ក្រុងវេសាលីនៅក្នុងទិសណា ក៏ចៀសចេញទៅក្នុងទិសនោះ កាលដែលត្រាច់ទៅកាន់ចារិកដោយលំដាប់ៗ ក្រុងវេសាលីនៅក្នុងទីណា ក៏ចូលទៅដល់ទីនោះ។ មានដំណឹងថា សុទិន្នភិក្ខុដ៏មានអាយុនៅក្នុងកូដាគារសាលាព្រៃមហាវនទៀបក្រុងវេសាលី នោះ។ ពួកញាតិសុទិន្នភិក្ខុដ៏មានអាយុបានឮថាសុទិន្នភិក្ខុជាកលន្ទបុត្រមកដល់ ក្រុងវេសាលីហើយ ពួកញាតិទាំងនោះ ក៏នាំនូវភោជនប្រមាណហុកសិបសម្រាប់ទៅប្រគេនសុទិន្នភិក្ខុដ៏មានអាយុ។ លំដាប់នោះឯងសុទិន្នភិក្ខុដ៏មានអាយុចែកចាយសម្រាប់ប្រមាណហុកសិបថាសនោះ ដល់ភិក្ខុទាំងឡាយ ហើយស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរក្នុងវេលា

ព្រឹក ហើយចូលទៅកាន់កលន្ទគ្រាមដើម្បីបិណ្ឌបាត កាលដើរទៅដើម្បីបិណ្ឌបាតតាមលំដាប់ផ្ទះក្នុងកលន្ទគ្រាម លំនៅនៃបិតារបស់ខ្លួននៅក្នុងទីណា ក៏ចូលទៅក្នុងទីនោះ។ ក៏ក្នុងសម័យនោះឯង ទាសីរបស់ញាតិនៃសុទិន្នភិក្ខុដ៏មានអាយុ មានប្រាថ្នាដើម្បីចោលនំកុម្មាសផ្អូម។ គ្រានោះ សុទិន្នភិក្ខុដ៏មានអាយុនិយាយនឹងខ្ញុំស្រីរបស់ញាតិនោះថា ម្នាលនាងទាសី បើនំនោះជារបស់ចោលហើយ ចូរនាងចាក់ដាក់មកក្នុងបាត្រអាត្មានេះវិញ។ លំដាប់នោះ ខ្ញុំស្រីនៃញាតិរបស់សុទិន្នដ៏មានអាយុ ក៏ចាក់នំកុម្មាសផ្អូមនោះទៅក្នុងបាត្ររបស់សុទិន្ន ហើយបានស្គាល់ជាក់នូវដៃជើង និងសំឡេងរបស់សុទិន្ននោះច្បាស់។ វេលានោះ មាតារបស់សុទិន្នដ៏មានអាយុនៅក្នុងទីណា ខ្ញុំស្រីរបស់ញាតិនៃសុទិន្នដ៏មានអាយុក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងមាតារបស់សុទិន្នដ៏មានអាយុថា បពិត្រអ្នកម្ចាស់ សូមអ្នកជ្រាប សុទិន្នជាអយ្យបុត្រនិមន្តមកដល់ហើយ។ មាតារបស់សុទិន្នឆ្លើយថា នែហង បើហងឯងនិយាយពាក្យពិតមែន អញនឹងឲ្យហងរួចជាអ្នកជា។ សម័យនោះឯង សុទិន្នភិក្ខុដ៏មានអាយុក៏ឆាន់នំកុម្មាសផ្អូមនោះប្របជញ្ជាំងសាលា១។ ចំណែកខាងបិតារបស់សុទិន្នមកពីធ្វើការងារវិញ ក៏បានឃើញសុទិន្នកំពុងឆាន់នំកុម្មាសផ្អូមនោះប្របជញ្ជាំងសាលា លុះឃើញហើយ សុទិន្នភិក្ខុនៅក្នុងទីណា (បិតានោះ) ក៏ចូលទៅក្នុងទីនោះ លុះចូលទៅហើយ ក៏និយាយនឹងសុទិន្នដ៏មានអាយុថា នែសុទិន្នកូន យើងជាអ្នកមានទ្រព្យសម្បត្តិច្រើន ថ្វីក៏លោកមកឆាន់នំកុម្មាសផ្អូមវិញ សុទិន្នកូនគួរតែលោកទៅឯផ្ទះរបស់ខ្លួនវិញ។ សុទិន្នភិក្ខុឆ្លើយថា បពិត្រគហបតី អាត្មាបានទៅឯផ្ទះញោមហើយ នំកុម្មាសផ្អូមនេះ អាត្មាបានពីផ្ទះនោះមក។ លំដាប់នោះ បិតាសុទិន្នភិក្ខុក៏ចាប់កំភួនដៃសុទិន្នភិក្ខុ ហើយនិយាយនឹងសុទិន្នថា សុទិន្នកូន លោកចូរមក យើងនឹងទៅផ្ទះ។ លំដាប់នោះ លំនៅបិតារបស់ខ្លួននៅក្នុងទីណា សុទិន្នដ៏មានអាយុក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេបានក្រាលប្រគេន។ បិតាក៏និយាយនឹងសុទិន្នក្នុងពេលនោះថា សុទិន្នកូន សូមលោកនិមន្តឆាន់ចង្ហាន់។ សុទិន្នឆ្លើយថា ណ្ហើយគហបតី ថ្ងៃនេះអាត្មាភាពឆាន់រួចហើយ។ បិតាឆ្លើយថា សុទិន្ន សូមលោកនិមន្តទទួលចង្ហាន់ក្នុងថ្ងៃស្អែក។ សុទិន្នភិក្ខុក៏ទទួលនិមន្តដោយតុណ្ហីភាព។ សុទិន្នភិក្ខុក៏ក្រោកចាកអាសនៈ ហើយនិមន្តទៅក្នុងពេលនោះឯង។

[១៦] លុះដល់វេលាព្រឹកឡើង មាតាសុទិន្នភិក្ខុប្រើមនុស្សឲ្យបង្អាប់ប្រថពីដោយអាចមន៍គោស្រស់ រួចឲ្យគរគំនរទ្រព្យពីរគំនរ គឺប្រាក់១គំនរ មាស១គំនរ ជាគំនរធំៗ បុរសឈរខាងអាយមើលទៅបុរសឈរខាងនាយមិនឃើញ បុរសឈរខាងនាយមើលមកបុរសឈរខាងអាយក៏មិនឃើញ ហើយឲ្យបិទបាំងគំនរទាំងពីរនោះដោយកន្ទេល ឲ្យក្រាលអាសនៈទុកត្រង់កណ្តាល រួចឲ្យបាំងរនាំជុំវិញពីខាងក្រៅ (គំនរនោះ) ហើយហៅស្រីជាគូពីមុនរបស់សុទិន្នដ៏មានអាយុមកបង្គាប់ថា កូនស្រី បើដូច្នោះ គ្រឿងប្រដាប់ណាដែលឯងស្អិតស្អាងហើយជាទីស្រឡាញ់ពេញចិត្តរបស់សុទិន្ន កូនអញ ត្រូវឯងស្អិតស្អាងគ្រឿងប្រដាប់នោះចុះ។ ស្រីជាគូពីមុនរបស់សុទិន្នដ៏មានអាយុ ក៏ទទួលពាក្យមាតារបស់សុទិន្នដ៏មានអាយុថា ចាសអ្នកមាតា។ គ្រានោះ សុទិន្នដ៏មានអាយុស្លៀកស្បង់រួចកាន់យកបាត្រនិងចីវរក្នុងវេលាព្រឹក លំនៅបិតារបស់ខ្លួននៅត្រង់ទីណា ក៏ចូលទៅត្រង់ទីនោះ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុកបំរុង។ លំដាប់នោះ បិតារបស់សុទិន្នដ៏មានអាយុ សុទិន្នដ៏មានអាយុនៅត្រង់ទីណា ក៏ចូលទៅត្រង់ទីនោះ លុះចូលទៅដល់ហើយ បង្គាប់អ្នកបំរើឲ្យបើកគំនរទ្រព្យទាំងនោះ ហើយប្រាប់សុទិន្នដ៏មានអាយុថា សុទិន្នកូន នេះជាទ្រព្យសម្បាច់ដើមខាងស្រីរបស់មាតាលោក នៅមានទ្រព្យសម្បាច់ដើមខាងប្រុសរបស់បិតានិងមត៌ករបស់ជីតាផ្សេងទៀត សុទិន្នកូន បើលោកបានសឹកចេញជាគ្រហស្ថមក នឹងបានប្រើប្រាស់សម្បត្តិផង ធ្វើបុណ្យទាំងឡាយផង សុទិន្នកូន ចូរលោកសឹកចេញជាគ្រហស្ថមក ហើយនឹងប្រើប្រាស់សម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង។ សុទិន្នតបថា ញោម អាត្មាមិនអាចនឹងសឹកបានទេ ព្រោះអាត្មាពេញចិត្តតែក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌។ បិតាសុទិន្នដ៏មានអាយុនិយាយនឹងសុទិន្នដ៏មានអាយុជាគំរប់ពីរដងផង។ បេ។ ជាគំរប់បីដងផងថា សុទិន្នកូន នេះជាទ្រព្យសម្បាច់ដើមខាងស្រីរបស់មាតាលោក នៅមានទ្រព្យសម្បាច់ដើមខាងប្រុសរបស់បិតានិងមត៌ករបស់ជីតាផ្សេងទៀត សុទិន្នកូន បើលោកបានសឹកចេញជាគ្រហស្ថមក នឹងបានគ្រប់គ្រងសម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង។ សុទិន្នកូន ចូរលោកសឹកចេញជាគ្រហស្ថមក ហើយគ្រប់គ្រងសម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង។ សុទិន្នតបថា គហបតី បើញោមអត់ទោសឲ្យអាត្មាភាព ៗ នឹងសូមជំរាបញោមបន្តិច។ បិតាទទួលព្រមថា សុទិន្នកូន ចូរលោកនិយាយមកចុះ មិនជាអ្វីទេ។ សុទិន្នភិក្ខុក៏ប្រាប់ថា គហបតី បើដូច្នោះ ញោមត្រូវបង្គាប់មនុស្សឲ្យធ្វើការុងធ្មៃធំៗ ហើយឲ្យច្រកប្រាក់និងមាសឲ្យពេញ រួចផ្ទុកដោយរទេះ យកទៅចាក់ចោលក្នុងកណ្តាលខ្សែទឹកទន្លេគង្គា ហេតុអ្វីបានជាអាត្មាថាដូច្នោះ គហបតី ព្រោះថាទ្រព្យទាំងពួងតែងមានដល់អ្នកណាហើយ សេចក្តីខ្លាចក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តី ការថែរក្សាក្តី តែងមានដល់អ្នកនោះមិនខាន ព្រោះតែទ្រព្យទាំងនោះជាហេតុ (បើអ្នកយកមាសប្រាក់ទៅចាក់ចោលក្នុងខ្សែទឹកហើយ) សេចក្តីអន្តរាយមានភ័យជាដើមនោះ នឹងមិនមានដល់អ្នកឡើយ។ កាលសុទិន្នដ៏មានអាយុពោលយ៉ាងនេះហើយ បិតារបស់សុទិន្នដ៏មានអាយុ មានសេចក្តីទោមនស្សតូចចិត្តថា ហេតុដូចម្តេចបានជាលោកសុទិន្នជាកូនពោលយ៉ាងនេះ។ គ្រានោះឯង បិតារបស់សុទិន្នដ៏មានអាយុ ទើបហៅស្រីបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុមកប្រាប់ថា នែនាងក្រមុំ បើដូច្នោះ នាងឯងជាទីស្រឡាញ់ពេញចិត្តរបស់សុទិន្នកូនអញ នាងធ្វើដូចម្តេចនឹងឲ្យសុទិន្នកូនអញធ្វើតាមពាក្យនាងបាន។ គ្រានោះឯង ស្រីបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុបានប្រវាឱបជើងទាំងពីរ របស់សុទិន្នដ៏មានអាយុ ហើយបាននិយាយពាក្យនេះនឹងសុទិន្នភិក្ខុថា បពិត្រអយ្យបុត្រ លោកប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុនៃស្រីអប្សរទាំងឡាយណា ស្រីអប្សរទាំងឡាយនោះមានទ្រង់ទ្រាយប្រពៃដូចម្តេចទៅ។ សុទិន្នភិក្ខុឆ្លើយថា នែប្អូនស្រី អាត្មាមិនបានប្រព្រឹត្តព្រហ្មចរិយធម៌ដើម្បីស្រីអប្សរទាំងនោះទេ។ វេលានោះ ស្រីបុរាណទុតិយិការបស់សុទិន្នភិក្ខុក៏នឹកទោមនស្សតូចចិត្តថា តាំងពីថ្ងៃនេះទៅ លោកសុទិន្នអយ្យបុត្រគ្រាន់តែហៅអញថាប្អូនស្រីៗប៉ុណ្ណោះទេ ដូច្នេះហើយក៏ជ្រប់ដួលដេកក្នុងទីនោះឯង។ គ្រានោះ សុទិន្នដ៏មានអាយុទើបនិយាយពាក្យនេះនឹងបិតាថា គហបតី បើញោមមានភោជន គួរនឹងឲ្យទាន អាត្មាបានសូមញោមឲ្យទានមកចុះ កុំធ្វើអាត្មាឲ្យលំបាកពេកឡើយ។ បិតាសុទិន្នឆ្លើយថា សុទិន្នកូន ភោជនាហារនោះមាន សូមលោកនិមន្តឆាន់ចុះ។ វេលានោះ មាតាបិតារបស់សុទិន្នដ៏មានអាយុបានចាត់ចែងចង្ហាន់ដ៏ឆ្ងាញ់ពិសារឲ្យ សុទិន្នភិក្ខុដ៏មានអាយុឆាន់ដោយដៃខ្លួនឯង។ សម័យនោះឯង មាតារបស់សុទិន្នដ៏មានអាយុបាននិយាយនឹងសុទិន្នភិក្ខុនៅវេលាឆាន់រួចហើយ លែងលូកដៃទៅក្នុងបាត្រហើយថា នែសុទិន្នកូន ត្រកូលនេះស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់បរិបូណ៌ មានគ្រឿងឧបករណ៍បរិបូណ៌ មានស្រូវអង្ករបរិបូណ៌ នែសុទិន្នកូន សូមលោកនិមន្តសឹកចេញជាគ្រហស្ថមក នឹងបានប្រើប្រាស់នូវទ្រព្យសម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង សុទិន្នកូន សូមលោកនិមន្តសឹកចេញជាគ្រហស្ថមក ហើយនឹងចាយវាយនូវសម្បត្តិទាំងឡាយ ធ្វើបុណ្យឲ្យទានចុះ។ សុទិន្នភិក្ខុឆ្លើយថា ញោម អាត្មាមិនអាចហ៊ាន (ធ្វើយ៉ាងនោះទេ) អាត្មាត្រេកអរចំពោះតែត្រង់ប្រព្រឹត្តព្រហ្មចរិយធម៌តែម្យ៉ាង។ មាតារបស់សុទិន្នដ៏មានអាយុបាននិយាយពាក្យនេះនឹងសុទិន្នភិក្ខុដ៏មានអាយុ ជាគំរប់ពីរដងផង។ បេ។ ជាគំរប់បីដងផងថា សុទិន្នកូន ត្រកូលនេះស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់បរិបូណ៌ មានគ្រឿងឧបករណ៍បរិបូណ៌ មានស្រូវអង្ករបរិបូណ៌ សុទិន្នកូន បើដូច្នេះ សូមលោកអាណិតគ្រាន់តែឲ្យពូជបន្តិចចុះ កុំឲ្យពួកស្តេចលិច្ឆវីមករឹបជាន់ យកទ្រព្យសម្បត្តិជារបស់យើង ដែលជាត្រកូលឥតកូននោះឡើយ។ សុទិន្នភិក្ខុឆ្លើយថា ញោម បើគ្រាន់តែធ្វើកិច្ចប៉ុណ្ណោះ អាត្មាអាចធ្វើឲ្យបាន។ មាតាសុទិន្នសួរថា សុទិន្ន

កូន ឥឡូវនេះលោកគង់នៅឯណា។ សុទិន្នភិក្ខុតបថា ញោម អាត្មានៅក្នុងព្រៃមហាវន។ គ្រានោះឯង សុទិន្នដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ហើយចេញដើរទៅ។

[១៧] គ្រានោះ មាតារបស់សុទិន្នដ៏មានអាយុ ហៅនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុមក ហើយនិយាយថា ម្នាលនាងកូនប្រសា បើកាលណានាងមានរដូវហើយ ផ្កាគឺឈាមរបស់នាងកើតឡើងហើយ នាងត្រូវប្រាប់ដល់ម៉ែក្នុងកាលនោះ។ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ បានទទួលពាក្យមាតារបស់សុទិន្នដ៏មានអាយុថា ចាំសម៉ែ។ លំដាប់នោះ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ មិនយូរប៉ុន្មាន នាងក៏មានរដូវ ផ្កាគឺឈាមនៃនាងនោះក៏កើតឡើង។ ទើបនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ បានប្រាប់មាតារបស់សុទិន្នដ៏មានអាយុ យ៉ាងនេះថា ម៉ែ ខ្ញុំមានរដូវហើយ ផ្កាគឺឈាមរបស់ខ្ញុំកើតហើយ។ មាតាតបថា ម្នាលនាងកូនប្រសា បើដូច្នោះ នាងឯងប្រដាប់តាក់តែងដោយគ្រឿងអលង្ការឯណា ដែលជាទីស្រឡាញ់ពេញចិត្តរបស់សុទិន្នកូន (យើង) នាងចូរប្រដាប់តាក់តែងដោយគ្រឿងសម្រាប់ស្អិតស្អាងនោះចុះ។ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ បានទទួលពាក្យមាតារបស់សុទិន្នដ៏មានអាយុថា ចាំសម៉ែ។ លំដាប់នោះ មាតារបស់សុទិន្នដ៏មានអាយុ ក៏នាំនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុចូលទៅកាន់ព្រៃមហាវន ដែលសុទិន្នភិក្ខុនៅនោះឯង លុះចូលទៅហើយ ក៏បានពោលនូវពាក្យនេះនឹងសុទិន្នដ៏មានអាយុថា ម្នាលសុទិន្នកូន ត្រកូលនេះស្ដុកស្ដម្ភ មានទ្រព្យច្រើន មានរបស់សម្រាប់ប្រើប្រាស់ មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីគាប់ចិត្តច្រើន មានធនធានស្រូវអង្ករច្រើន ម្នាលសុទិន្នកូន អ្នកត្រឡប់មកដើម្បីហីនភេទ ក៏គង់នឹងបានបរិភោគនូវភោគសម្បត្តិផង ធ្វើបុណ្យទាំងឡាយផង ម្នាលសុទិន្នកូន អ្នកត្រូវត្រឡប់មកកាន់ហីនភេទជាគ្រហស្ថវិញ ហើយបរិភោគនូវភោគសម្បត្តិផង ធ្វើបុណ្យទាំងឡាយផង។ សុទិន្នតបថា ញោម អាត្មាសឹកមិនកើតទេ អាត្មាមិនព្រមសឹកទេ អាត្មាត្រេកអរតែប្រព្រឹត្តព្រហ្មចរិយធម៌។ មាតារបស់សុទិន្នដ៏មានអាយុ បាននិយាយនឹងសុទិន្នដ៏មានអាយុអស់វារៈ២-៣ដងយ៉ាងនេះថា នែសុទិន្នកូន ត្រកូលនេះស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីគាប់ចិត្តច្រើន មានធនធានស្រូវអង្ករច្រើន នែសុទិន្នកូន បើដូច្នោះ អ្នកចូរអោយត្រឹមតែពូជចុះ កុំឲ្យពួកស្ដេចលិច្ឆវីមករឹបយកសម្បត្តិទ្រព្យយើង ដែលជាត្រកូលឥតកូនទៅបាន។ សុទិន្នឆ្លើយថា ញោម អាត្មាអាចធ្វើកិច្ចនេះជូនបាន ហើយក៏ចាប់ដៃនាងបុរាណទុតិយិកា កៀកចូលទៅកាន់ព្រៃមហាវន យល់ឃើញថាមិនមានទោស ព្រោះសិក្ខាបទព្រះអង្គមិនទាន់បានបញ្ញត្ត ហើយញុំាងមេថុនធម្មឲ្យសម្រេចដោយនាងបុរាណទុតិយិកាអស់វារៈ៣ដង នាងក៏មានគភ៌ដោយមេថុនសេវនៈនោះ។

[១៨] ភុម្មទេវតាទាំងឡាយ ក៏ញុំាងសំឡេងឲ្យឮទូទ័រឡើងទៅថា ម្នាលគ្នាយើងទាំងឡាយ ពួកភិក្ខុមិនដែលវឹកវរ មិនដែលមានទោស (ឥឡូវនេះ) សុទិន្នកលន្ទបុត្រធ្វើសេចក្ដីវឹកវរ និងទោសឲ្យកើតឡើងហើយ។ ចាតុម្មហារាជិកាទេវតាទាំងឡាយឮសំឡេងភុម្មទេវតាទាំងនោះហើយ ក៏ញុំាងសំឡេងឲ្យឮឡើងទៅ ពួកទេវតាជាន់តាវតឹង្ស យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី (រហូតដល់) ពួកព្រហ្ម (បានឮសំឡេងតៗគ្នាមកហើយ) ក៏ញុំាងសំឡេងឲ្យឮឡើងៗទៅថា ម្នាលគ្នាយើងទាំងឡាយ ពួកភិក្ខុមិនដែលវឹកវរ មិនដែលមានទោស (ឥឡូវនេះ) សុទិន្នកលន្ទបុត្រ មកធ្វើសេចក្ដីវឹកវរ និងទោសឲ្យកើតឡើងហើយ។ សូរសព្ទ (យ៉ាងនេះ) ក៏ឮកងរំពងឡើងទៅដរាបដល់ព្រហ្មលោកដោយ១ខណៈ ១រំពេចនោះឯង។ គ្រានោះ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ អាស្រ័យគភ៌នោះកាន់តែចាស់ឡើងជាលំដាប់ ទើបសំរាលនូវកូនប្រុសមួយ។ លំដាប់នោះ ពួកសំឡាញ់សុទិន្នដ៏មានអាយុ បានតាំងឈ្មោះទារកនោះថា ពីជក បានតាំងឈ្មោះនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុថា ពីជកមាតា បានតាំងឈ្មោះសុទិន្នដ៏មានអាយុថាពីជកបិតា។ លុះដល់សម័យខាងក្រោយមក អ្នកទាំងពីរនោះបានចេញចាកផ្ទះ ហើយបួសក្នុងភេទជាបុគ្គលអ្នកមិនមានប្រយោជន៍ដល់ការងារក្នុងផ្ទះ ហើយបានធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផល។

[១៩] គ្រានោះ សេចក្ដីសង្ស័យ និងសេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ក៏កើតមានដល់សុទិន្នដ៏មានអាយុថា អាត្មាអញពេញហៅជាឥតលាភ លាភមិនមានដល់អាត្មាអញទេ ភាពជាមនុស្ស ពេញហៅអាត្មាអញបានដោយអាក្រក់ មិនមែនអាត្មាអញបានដោយល្អទេ ដោយហេតុអាត្មាអញបានបួសក្នុងធម្មវិន័យ ដែលព្រះសាស្ដាទ្រង់សំដែងដោយប្រពៃយ៉ាងនេះ ហើយមិនអាចដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធដរាបដល់អស់ជីវិត។ ព្រោះសេចក្ដីសង្ស័យ និងសេចក្ដីក្ដៅក្រហាយស្ដាយក្រោយនោះឯង សុទិន្នក៏ទៅជាស្គមប្រដក់ មានសម្បុរអាក្រក់កើតទៅជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ មានចិត្តក្រៀមក្រំទ្រមឹងទ្រមើយ កើតទុក្ខតូចចិត្តនឹកស្ដាយក្រោយ សញ្ជប់សញ្ជឹង។ លំដាប់នោះ ភិក្ខុទាំងឡាយជាសំឡាញ់របស់សុទិន្នដ៏មានអាយុ បាននិយាយពាក្យនេះនឹងសុទិន្នដ៏មានអាយុថា អាវុសោសុទិន្ន កាលពីដើម លោកមានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខដ៏ថ្លា មានសម្បុរថ្ងៃស្រស់បស់ផូរផង់ល្អ ឥឡូវនេះលោកទៅជាស្គមសៅហ្មង មានសម្បុរអាក្រក់ កើតរោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃមានចិត្តក្រៀមក្រំទ្រមឹងទ្រមើយ កើតទុក្ខតូចចិត្តក្ដៅក្រហាយសញ្ជប់សញ្ជឹង ម្នាលអាវុសោសុទិន្ន លោកមិនសូវត្រេកអរហើយចេះតែខំប្រព្រឹត្តព្រហ្មចរិយធម៌ទៅទេឬអ្វី។ សុទិន្នឆ្លើយតបថា នែលោកដ៏មានអាយុទាំងឡាយ ខ្ញុំមិនមែនមិនត្រេកអរហើយចេះតែខំប្រព្រឹត្តព្រហ្មចរិយធម៌ទេ ខ្ញុំបានធ្វើបាបកម្ម គឺសេពមេថុនធម្មនឹងស្ត្រីបុរាណទុតិយិកា ម្នាលអាវុសោទាំងឡាយ សេចក្ដីសង្ស័យ និងសេចក្ដីស្ដាយក្រោយក៏កើតមានដល់ខ្ញុំនោះឯងថា អាត្មាអញពេញហៅជាឥតលាភ លាភមិនមានដល់អាត្មាអញទេ ភាពជាមនុស្សពេញហៅអាត្មាអញបានដោយអាក្រក់ មិនមែនអាត្មាអញបានដោយល្អទេ ដោយហេតុអាត្មាអញបានបួសក្នុងធម្មវិន័យដែលព្រះសាស្ដាទ្រង់សំដែង ដោយប្រពៃយ៉ាងនេះ ហើយមិនអាចដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធដរាបដល់អស់ជីវិត។ ភិក្ខុទាំងឡាយជាសំឡាញ់ក៏និយាយថា អាវុសោសុទិន្ន លោកបួសក្នុងធម្មវិន័យ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងល្អហើយយ៉ាងនេះ មិនអាចដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញដរាបដល់អស់ ជីវិតបាន ព្រោះមេថុនធម្មសេវនកិច្ចណា ម្នាលអាវុសោ មេថុនធម្មសេវនកិច្ចនោះ ល្មមឲ្យលោកសង្ស័យ ល្មមឲ្យស្ដាយក្រោយមែន ម្នាលអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយអនេកបរិយាយ (សុទ្ធតែ) ដើម្បីឲ្យប្រាសចាករាគៈ មិនមែនសំដែងដើម្បីឲ្យប្រកបដោយរាគៈទេ ធម៌ដែលព្រះអង្គសំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប មិនមែនសំដែងដើម្បីតម្រូវទៅរកកិលេសជាគ្រឿងប្រកបទេ ធម៌ដែលព្រះអង្គសំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ មិនមែនសំដែងដើម្បីឲ្យប្រកាន់មាំទេ (ក្រែងដូច្នេះ) មិនមែនឬ នែអាវុសោ ត្រង់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីឲ្យប្រាសចាករាគៈ លោកត្រឡប់ជាយល់ក្នុងធម៌នោះថា ប្រកបដោយរាគៈទៅវិញ ត្រង់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប លោកត្រឡប់ជាចូលចិត្តតម្រូវទៅរកកិលេសជាគ្រឿងប្រកបទៅវិញ ត្រង់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ លោកទៅជាចូលចិត្តថាឲ្យប្រកាន់មាំវិញ ម្នាលអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយអនេកបរិយាយ ដើម្បីប្រាសចាករាគៈ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីញុំាញីនូវសេចក្ដីស្រវឹងដើម្បីកំចាត់បង់នូវសេចក្ដីស្រេកឃ្លាន ក្នុងកាម ដើម្បីដកចេញនូវសេចក្ដីអាល័យក្នុងកាម

ដើម្បីផ្តាច់បង់នូវវដ្តៈ ដើម្បីអស់ទៅនៃតណ្ហា ដើម្បីគ្មានរាគៈ ដើម្បីនិរោធ ដើម្បីព្រះនិព្វាន (ក្រែងដូច្នេះ) មិនមែនឬ ម្នាលអាវុសោ កិរិយាលះបង់នូវកាមទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ការកំណត់ដឹងនូវសេចក្តីសំគាល់ក្នុងកាម ព្រះអង្គក៏បានសំដែងហើយ កិរិយាកំចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ព្រះអង្គក៏បានសំដែងហើយ កិរិយាដកចេញនូវសេចក្តីត្រិះរិះក្នុងកាមទាំងឡាយ ក៏ព្រះអង្គបានសំដែងហើយ កិរិយាចូលទៅរម្ងាប់នូវសេចក្តីក្តៅក្រហាយអន្ទះអន្ទែងក្នុងកាមទាំងឡាយ ក៏ព្រះអង្គបានសំដែងហើយដោយអនេកបរិយាយ (យ៉ាងនេះ) មិនមែនឬ ម្នាលអាវុសោ កម្មដ៏លាមករបស់លោកនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា នោះទេ មិនមែនដឹកនាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ម្នាលអាវុសោ កម្មដ៏លាមករបស់លោកនេះ រមែងដឹកនាំសេចក្តីមិនជ្រះថ្លាឲ្យកើតមានដល់ជនទាំងឡាយដែលមិន ទាន់ជ្រះថ្លានៅឡើយ ដឹកនាំជនទាំងឡាយខ្លះដែលជ្រះថ្លាហើយឲ្យទាស់ចិត្តគំនិតទៅវិញទេតើ។ លំដាប់នោះ ភិក្ខុទាំងនោះក៏តិះដៀលសុទិន្នដ៏មានអាយុដោយអនេកបរិយាយ ហើយនាំគ្នាក្រាបទូលនូវសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។

[២០] ព្រោះរឿងនេះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរសុទិន្នដ៏មានអាយុក្នុងកាលនោះថា នែសុទិន្ន ឮថាអ្នកឯងសេពមេថុនធម្មនឹងនាងបុរាណទុតិយិកា ពិតមែនឬ។ សុទិន្នក្រាបទូលថា សូមទានពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស បាបកម្មដែលអ្នកឯងធ្វើនេះមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ នែមោឃបុរស គួរបើដែរ អ្នកឯងបួសក្នុងធម្មវិន័យដែលតថាគតសំដែងហើយ ដោយប្រពៃយ៉ាងនេះត្រឡាំង ទៅជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញដរាបដល់អស់ជីវិត មិនកើត នែមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយអនេកបរិយាយ (សុទ្ធតែ) ដើម្បីប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ ធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប មិនមែនសំដែងដើម្បីតម្រូវទៅរកកិលេសជាគ្រឿងប្រកបទេ ធម៌ដែលតថាគតសំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ មិនមែនសំដែងដើម្បីឲ្យប្រកាន់មាំទេ មិនមែនឬ ម្នាលមោឃបុរស ត្រង់ធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាករាគៈ អ្នកឯងត្រឡប់ចូលចិត្តក្នុងធម៌នោះថាឲ្យប្រកបដោយរាគៈវិញ ត្រង់ធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប អ្នកឯងត្រឡប់ជាចូលចិត្តថា ឲ្យប្រកបដោយកិលេសជាគ្រឿងប្រកបវិញ ត្រង់ធម៌ដែលតថាគតសំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ អ្នកឯងត្រឡប់ទៅជាចូលចិត្តថាឲ្យប្រកាន់មាំវិញ នែមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយអនេកបរិយាយ ដើម្បីឲ្យប្រាសចាករាគៈ ធម៌ដែលតថាគតសំដែងហើយ ដើម្បីញាំញីនូវសេចក្តីស្រវឹង ដើម្បីកំចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ដើម្បីដកចេញនូវសេចក្តីអាល័យក្នុងកាម ដើម្បីផ្តាច់បង់នូវវដ្តៈ ដើម្បីអស់ទៅនៃតណ្ហា ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ ដើម្បីព្រះនិព្វាន មិនមែនឬ នែមោឃបុរស កិរិយាលះបង់នូវកាមទាំងឡាយ តថាគតបានសំដែងហើយ ការកំណត់ដឹងនូវសេចក្តីសំគាល់ក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាកំចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាដកចេញនូវសេចក្តីត្រិះរិះក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាចូលទៅរម្ងាប់នូវសេចក្តីក្តៅក្រហាយក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយដោយអនេកបរិយាយ មិនមែនឬ ម្នាលមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់អាសិរពិស ជាសត្វមានពិសក្លៀវក្លា ប្រសើរជាងអ្នកឯងដាក់អង្គជាតទៅក្នុងអង្គជាតរបស់មាតុគ្រាមមិនប្រសើរ ឡើយ មោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់ពស់វែកប្រសើរជាង អង្គជាតដែលអ្នកឯងដាក់ទៅក្នុងអង្គជាតរបស់មាតុគ្រាមមិនប្រសើរឡើយ មោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងគំនររងើកភ្លើងដែលឆេះភ្លឺច្រាលរន្ទាលប្រសើរ ជាង អង្គជាតដែលអ្នកដាក់ទៅក្នុងអង្គជាតរបស់មាតុគ្រាមមិនប្រសើរឡើយ ហេតុអ្វី បានជាតថាគតពោលដូច្នោះ មោឃបុរស ព្រោះថាមនុស្សដែលដាក់អង្គជាតទៅក្នុងគំនររងើកភ្លើង គ្រាន់តែដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខប្រហែលនឹងស្លាប់ប៉ុណ្ណោះ ឯនឹងបានទំលាយរាងកាយស្លាប់ហើយ ទៅកើតក្នុងតិរច្ឆានកំណើត ប្រេត អសុរកាយ នរក ព្រោះបច្ច័យដែលដាក់អង្គជាតទៅក្នុងគំនររងើកភ្លើងនោះក៏ទេ នែមោឃបុរស ចំណែកខាងភិក្ខុដែលដាក់អង្គជាតទៅក្នុងអង្គជាតរបស់មាតុគ្រាមនោះ តែទំលាយរាងកាយហើយ ត្រូវទៅកើតក្នុងតិរច្ឆានកំណើត ប្រេត អសុរកាយ នរក ម្នាលមោឃបុរស កាលបើកម្មទាំងនោះ (សុទ្ធតែជាកម្មប្រកបដោយទោសធំយ៉ាងនេះ) អ្នកឯងនៅតែប្រព្រឹត្តធ្វើនូវអសទ្ធម្ម ជាធម៌របស់អ្នកស្រុក ជាធម៌របស់មនុស្សថោកថយ អាក្រក់ មានកិច្ចដោយទឹកជាទីបំផុត ជាធម៌លាក់លៀម ជាធម៌របស់ជនពីរៗអ្នកតែងប្រជុំធ្វើតាមតែប្រទះនោះ មោឃបុរស (ក្នុងសាសនានេះ) មានតែអ្នកឯងហើយ ជាអ្នកធ្វើអកុសលខាងដើមនៃអកុសលធម៌ទាំងឡាយមានប្រមាណច្រើន ហៅថាជាអ្នកផ្តើមធ្វើមុនគេ ម្នាលមោឃបុរស កម្មដ៏លាមករបស់អ្នកឯងនេះ មិនបណ្តាលឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាឡើយ មិនមែនដឹកនាំជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាថែមឡើងទៀតទេ ម្នាលមោឃបុរស កម្មដ៏លាមករបស់អ្នកឯងនេះ រមែងបណ្តាលឲ្យកើតសេចក្តីមិនជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា នៅឡើយ ដឹកនាំជនទាំងឡាយខ្លះដែលជ្រះថ្លាហើយ ឲ្យត្រឡប់ទាស់ចិត្តគំនិតទៅវិញ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលសុទិន្នភិក្ខុដ៏មានអាយុដោយអនេកបរិយាយ ហើយទ្រង់សំដែងនូវទោសនៃការចិញ្ចឹមក្រ ថែទាំរក្សាក្រ ប្រាថ្នាច្រើន មិនសន្តោស ច្រឡូកច្រឡំដោយពួកគណៈ និងសេចក្តីខ្ជិលច្រអូស ទើបទ្រង់សំដែងដោយអនេកបរិយាយនូវគុណនៃការដែលគេចិញ្ចឹមងាយ ការដែលគេថែទាំរក្សាងាយ ប្រាថ្នាតិច សន្តោស ចិត្តផូរផង់ ការកំចាត់បង់នូវកិលេស ការនាំឲ្យកើតសេចក្តីជ្រះថ្លា ការមិនសន្សំ និងការប្រារព្ធព្យាយាម ហើយទ្រង់សំដែងធម្មីកថាដ៏ល្មមសមគួរដល់សិក្ខាបទនោះ ដល់សំវរៈនោះចំពោះភិក្ខុទាំងឡាយ ហើយហៅភិក្ខុទាំងឡាយមក (មានព្រះពុទ្ធដីកា)ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍១០យ៉ាងគឺដើម្បីសេចក្តីល្អដល់សង្ឃ១ ដើម្បីនៅសប្បាយដល់សង្ឃ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនអៀនខ្មាស១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់១ ដើម្បីរារាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាច្រើនឡើង១ ដើម្បីឲ្យតំកល់នៅមាំនៃព្រះសទ្ធម្ម១ ដើម្បីអនុគ្រោះដល់វិន័យ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះដូច្នេះថា

**ភិក្ខុណាមួយសេពមេថុនធម្ម (ភិក្ខុនោះ) ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន។**

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយចំពោះភិក្ខុទាំងឡាយដោយប្រការ យ៉ាងនេះ។

វារៈពោលអំពីរឿងសុទិន្នភិក្ខុ ចប់។

## មក្កដីវត្ថុ

CS vin.vbu.pr.01.02 | ភាគ ទី១

(មក្កដីវត្ថុ)

[២១] សម័យនោះ មានភិក្ខុ១រូបប្រលោមលួងមេស្វាដោយអាមិសៈ ក្នុងព្រៃមហាវន ទៀបក្រុងវេសាលី ហើយសេពមេថុនធម្មនឹងមេស្វានោះ។ លំដាប់នោះ ភិក្ខុនោះស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ហើយចូលទៅកាន់ក្រុងវេសាលីដើម្បីបិណ្ឌបាតក្នុងវេលាព្រឹកព្រហាម។ ក្នុងសម័យនោះ ភិក្ខុទាំងឡាយច្រើនរូបដើរទៅកាន់សេនាសនចារិក ក៏នាំគ្នាចូលទៅត្រង់កន្លែងដែលភិក្ខុនោះនៅ។ មេស្វានោះបានឃើញភិក្ខុអម្បាលនោះមកអំពីចម្ងាយ ក៏ចូលទៅត្រង់កន្លែងដែលភិក្ខុទាំងនោះនៅ លុះចូលទៅដល់ហើយ (ក៏សំដែងអាការ) ធ្វើចង្កេះឲ្យញាក់ញ័រផង ធ្វើកន្ទុយឲ្យកំរើកផង ពើងចង្កេះផង បានធ្វើនូវនិមិត្តផង អំពីខាងមុខភិក្ខុទាំងឡាយនោះ។ គ្រានោះ ភិក្ខុទាំងនោះមានសេចក្តីត្រិះរិះយល់ឃើញថា ភិក្ខុនោះសេពមេថុនធម្មនឹងមេស្វានេះដោយពិតឥតសង្ស័យ ទើបនាំគ្នាពួនចាំឃ្លាំមើលក្នុងទីកំបាំង១។ លំដាប់នោះ ភិក្ខុនោះដើរបិណ្ឌបាតក្នុងក្រុងវេសាលី បានបិណ្ឌបាតហើយត្រឡប់មកវិញ។ គ្រានោះ មេស្វានោះក៏ចូលទៅត្រង់កន្លែងដែលភិក្ខុនោះនៅ។ លំដាប់នោះ ភិក្ខុនោះឆាន់បិណ្ឌបាតនោះមួយចំណែក បានឲ្យដល់មេស្វាមួយចំណែក។ គ្រានោះ មេស្វាស៊ីអាហារបិណ្ឌបាតនោះហើយ ក៏ពើងចង្កេះចំពោះទៅភិក្ខុនោះ។ លំដាប់នោះ ភិក្ខុនោះក៏សេពមេថុនធម្មនឹងមេស្វានោះ។ ទើបភិក្ខុទាំងឡាយនោះបានពោលពាក្យនេះនឹងភិក្ខុនោះថា អាវុសោ សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយមិនមែនឬ នែអាវុសោ ហេតុអ្វីក៏បានជាអ្នកមកសេពមេថុនធម្មនឹងមេស្វានេះ។ ភិក្ខុនោះឆ្លើយថា នែអាវុសោទាំងឡាយ សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តពិតមែនហើយ តែសិក្ខាបទនោះ ទ្រង់បញ្ញត្តចំពោះតែស្រីមនុស្ស មិនមែនបញ្ញត្តចំពោះសត្វតិរច្ឆានញីទេ។ ភិក្ខុទាំងឡាយនោះពោលថា នែអាវុសោ សិក្ខាបទដែលព្រះអង្គបញ្ញត្តចំពោះស្រីមនុស្ស ក៏ដូចសត្វតិរច្ឆានញីដែរ មិនមែនឬ នែអាវុសោ (អំពើអាក្រក់ដែលអ្នកធ្វើនោះ) ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ នែអាវុសោ គួរបើដែរ អ្នកឯងបួសក្នុងធម្មវិន័យដែលព្រះដ៏មានព្រះភាគត្រាស់សំដែងល្អហើយ យ៉ាងនេះត្រឡាំង ទៅជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញដរាបអស់ជីវិតមិនកើត នែអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដើម្បីឲ្យប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ។ បេ។ កិរិយារម្ងាប់នូវសេចក្តីក្តៅក្រហាយ អន្ទះអន្ទែងក្នុងកាមទាំងឡាយ ព្រះអង្គទ្រង់សំដែងហើយដោយអនេកបរិយាយ មិនមែនឬ ម្នាលអាវុសោ អំពើអាក្រក់ដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ទេ មិនមែនដឹកនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរិតតែជ្រះថ្លាថែមទៀតទេ នែអាវុសោ អំពើអាក្រក់ដែលអ្នកធ្វើនេះ រមែងនាំឲ្យកើតសេចក្តីមិនជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ដឹកនាំជនទាំងឡាយខ្លះដែលជ្រះថ្លាហើយ ឲ្យបាត់ជ្រះថ្លាទៅវិញ។ គ្រានោះ ភិក្ខុទាំងឡាយនោះ ក៏តិះដៀលភិក្ខុនោះដោយបរិយាយច្រើន ហើយនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។

[២២] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំសង្ឃ ហើយត្រាស់សួរភិក្ខុនោះ ក្នុងវេលានោះថា ម្នាលភិក្ខុ ឮថាអ្នកឯងសេពមេថុនធម្មនឹងមេស្វា ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា សូមទានពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស (អំពើអាក្រក់ដែលអ្នកឯងធ្វើនេះ) ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ នែមោឃបុរស គួរបើដែរ អ្នកឯងបួសក្នុងធម្មវិន័យដែលតថាគត សំដែងហើយដោយល្អយ៉ាងនេះត្រឡាំង ទៅជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញដរាបដល់អស់ជីវិតមិន កើត នែមោឃបុរស ធម៌ដែលតថាគតសំដែងហើយដើម្បីប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ។ បេ។ កិរិយារម្ងាប់នូវសេចក្តីក្តៅក្រហាយ អន្ទះអន្ទែងក្នុងកាមទាំងឡាយ តថាគតសំដែងហើយដោយអនេកបរិយាយ នែមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់អាសិរពិស មានពិសដ៏ក្លៀវក្លាប្រសើរជាង អ្នកឯងដាក់អង្គជាតទៅក្នុងអង្គជាតរបស់មេស្វាមិនប្រសើរសោះឡើយ ម្នាលមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់ពស់វែកប្រសើរជាងដែលអ្នកឯងដាក់អង្គជាត ទៅក្នុងអង្គជាតរបស់មេស្វានោះពុំប្រសើរសោះឡើយ ម្នាលមោឃបុរស សូវអ្នកឯងដាក់អង្គជាតទៅក្នុងគំនររងើកភ្លើងក្តៅ ដែលកំពុងឆេះសន្ធោរសន្ធៅ មានអណ្តាតភ្លើងដ៏រុងរឿងវិញប្រសើរជាង ឯអង្គជាតដែលអ្នកឯងដាក់ទៅក្នុងអង្គជាតរបស់មេស្វានោះ ពុំប្រសើរឡើយ ពាក្យដែលតថាគតពោលនោះ ព្រោះហេតុអ្វី ម្នាលមោឃបុរស ព្រោះថាទោះបីបុគ្គលដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខស្មើរនឹងស្លាប់ដោយហេតុដែលដាក់អង្គជាតទៅ ក្នុងមាត់ពស់វែកជាដើមនោះក៏ដោយ បុគ្គលនោះលុះរំលាងខន្ធនឹងបានចូលទៅកាន់តិរច្ឆានកំណើត ប្រេត អសុរកាយ នរក ព្រោះតែដាក់អង្គជាតទៅក្នុងមាត់ពស់វែកជាដើមនោះក៏ទេ ម្នាលមោឃបុរស (ឯភិក្ខុនោះ) លុះរំលាងខន្ធ ក៏រមែងតែទៅកាន់តិរច្ឆានកំណើត ប្រេត អសុរកាយ នរក ព្រោះហេតុដែលដាក់អង្គជាតទៅក្នុងអង្គជាតមេស្វានេះឯង ម្នាលមោឃបុរស កាលបើកម្មនោះមានទោសធ្ងន់ដល់ម្ល៉ោះហើយ អ្នកឯងមិនគួរបើហ៊ានសេពអសទ្ធម្មជាធម៌របស់អ្នកស្រុក ជាធម៌របស់មនុស្សថោកទាប ក្រាស់ដោយអំពើអាក្រក់ មានកិច្ចដោយទឹកជាទីបំផុតរបស់ជនមានគូស្រករ ជាធម៌លាក់លៀម ដែលគេត្រូវរួបរួមគ្នាតែពីរនាក់នោះសោះ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនោះ មិនប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ ជ្រះថ្លាទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយសេពមេថុនធម្ម ដោយហោចទៅ សូម្បីនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវអាបត្តិបារាជិករកសំវាសគ្មាន។**

ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះ ចំពោះភិក្ខុទាំងឡាយដោយហេតុយ៉ាងនេះឯង។

និទានមេស្វា ចប់។

## សន្ថតភាណវារ

CS vin.vbu.pr.01.03 | ភាគ ទី១

## (សន្ថតភាណវារោ)

[២៣] ក្នុងសម័យនោះ ពួកភិក្ខុវជ្ជីបុត្រនៅក្នុងក្រុងវេសាលីជាច្រើនរូប នាំគ្នាឆាន់ឆ្អែតហើយសឹង ៗស្លប់ហើយស្រង់ទឹក ៗហើយឆាន់ ៗ ហើយសឹង ៗស្លប់ស្កល់ហើយស្រង់ទឹក ឥតបានធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាឡើយ មិនពោលលាសិក្ខា មិនធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ (គឺមិនសឹកសិន) ហើយសេពមេថុនធម្ម។ លុះសម័យតមកខាងក្រោយ ភិក្ខុទាំងនោះប្រទះសេចក្តីព្រាត់ប្រាសចាកញាតិខ្លះ ប្រទះសេចក្តីវិនាសភោគសម្បត្តិខ្លះ ប្រទះរោគមកបៀតបៀនខ្លះ (ក៏នាំគ្នា) ចូលទៅរកព្រះអានន្ទដ៏មានអាយុ ហើយពោលពាក្យយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងខ្ញុំទាំងឡាយមិនមែនជាអ្នកតិះដៀលព្រះពុទ្ធ តិះដៀលព្រះធម៌ តិះដៀលព្រះសង្ឃទេ បពិត្រព្រះអានន្ទដ៏ចម្រើន យើងខ្ញុំទាំងឡាយជាអ្នកតិះដៀលតែខ្លួនឯង មិនមែនតិះដៀលអ្នកដទៃទេ យើងខ្ញុំទាំងឡាយ បានមកបួសក្នុងធម្មវិន័យដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយ ប្រពៃយ៉ាងនេះ ក៏ទៅជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធ ឲ្យបរិបូណ៌អស់មួយជីវិតមិនកើត យើងខ្ញុំទាំងឡាយហៅពេញជាមនុស្សឥតសំណាងវាសនា យើងខ្ញុំពេញជាមនុស្សឥតបុណ្យ បពិត្រព្រះអានន្ទដ៏ចំរើន បើប្រសិនជាយើងខ្ញុំបាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគឥឡូវនេះទៀត នោះយើងខ្ញុំគង់នឹងបានឃើញនូវកុសលធម៌ទាំងឡាយ និងខំប្រឹងប្រកបព្យាយាមជាគ្រឿងញុំាងធម៌ទាំងឡាយដែលជាចំណែកនៃពោធិញាណ ឲ្យចំរើនអស់រាត្រីមុន និងរាត្រីក្រោយ (គឺបឋមយាមនិងបច្ឆិមយាម) ក្នុងកាលឥឡូវនេះឯង បពិត្រព្រះអានន្ទដ៏ចំរើន យើងខ្ញុំសូមអង្វរ សូមលោកម្ចាស់នាំសេចក្តីនេះទៅក្រាបទូលព្រះដ៏មានព្រះភាគឲ្យទានផង។ ព្រះអានន្ទដ៏មានអាយុក៏ទទួលពាក្យរបស់ពួកភិក្ខុវជ្ជីបុត្រអ្នកក្រុង វេសាលីថា អើ អាវុសោ ហើយចូលទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគតគប្បីដកសិក្ខាបទឈ្មោះបារាជិក ដែលតថាគត បានបញ្ញត្តហើយដល់សាវកទាំងឡាយ ព្រោះហេតុនៃជនអ្នកនៅក្នុងដែនវជ្ជីទាំងឡាយក្តី ព្រោះហេតុនៃវជ្ជីបុត្តកភិក្ខុទាំងឡាយក្តី ដោយអំពើណា អំពើនុ៎ះមិនមែនជាហេតុ មិនមែនជាឱកាសឡើយ។

[២៤] ព្រោះនិទាននេះ ព្រោះដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សំដែងធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ហើយមានពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយមិនពោលលាសិក្ខា មិនប្រកាសខ្លួនថាជាអ្នកមានកំឡាំងថយ ហើយសេពមេថុនធម្ម បើភិក្ខុនោះមក (សូមឧបសម្បទានឹងសង្ឃទៀត) សង្ឃមិនត្រូវឲ្យឧបសម្បទាឡើយ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុណាមួយពោលលាសិក្ខាហើយ ប្រកាសខ្លួនថាជាអ្នកមានកំឡាំងថយ ហើយសេពមេថុនធម្ម បើភិក្ខុនោះ(សូមបួសទៀត) សង្ឃគប្បីឲ្យឧបសម្បទាចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយដល់ព្រមដោយសិក្ខានិងសាជីវៈ (ដែលតថាគតបញ្ញត្តហើយ) សម្រាប់ភិក្ខុទាំងឡាយ ហើយមិនពោលលាសិក្ខា មិនធ្វើឲ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ហើយសេពមេថុនធម្ម ដោយហោចទៅសូម្បីតែនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវអាបត្តិបារាជិក រកសំវាសគ្មាន។**

[២៥] ត្រង់ពាក្យថាណាមួយ អធិប្បាយថា ភិក្ខុជាថេរៈក្តី ភិក្ខុបួសថ្មីក្តី ភិក្ខុកណ្តាលក្តីឯណា គឺថាតាមតែភិក្ខុរូបណាដែលប្រកបក្នុងកម្មយ៉ាងណា មានជាតិយ៉ាងណា មានឈ្មោះយ៉ាងណា មានគោត្រយ៉ាងណា មានប្រក្រតីយ៉ាងណា មានគ្រឿងនៅយ៉ាងណា មានគោចរយ៉ាងណាក៏ដោយ ភិក្ខុនេះតថាគតហៅថា (ភិក្ខុ) ណាមួយ។

[២៦] ត្រង់ពាក្យថា ភិក្ខុ មានវិគ្រោះថា សមណៈណាជាអ្នកសូម សមណៈនោះហៅថាភិក្ខុ។ សមណៈណាចូលទៅអាស្រ័យនូវភិក្ខាចរិយវត្តសមណៈនោះហៅថាភិក្ខុ។ ជនណាទ្រទ្រង់សម្ពត់ដែលគេកាត់ហើយ ជននោះហៅថាភិក្ខុ។ ជនដែលហៅថាភិក្ខុ ព្រោះហេតុវោហារបញ្ញត្តិថាសមណៈ។ ហៅថាភិក្ខុ ព្រោះបានប្តេជ្ញាខ្លួន។ ហៅថាភិក្ខុ ព្រោះសម្រេចជាងហិភិក្ខុ។ ហៅថាភិក្ខុ ព្រោះបានឧបសម្បទាដោយសរណគមន៍៣។ ហៅថាភិក្ខុ ព្រោះហេតុជាអ្នកចំរើន។ ហៅថាភិក្ខុ ព្រោះមានសារធម៌។ ហៅថាភិក្ខុព្រោះជាអ្នកសិក្សា។ ហៅថាភិក្ខុ ព្រោះមិនបាច់សិក្សា។ ហៅថាភិក្ខុ ព្រោះបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចាដ៏សមគួរដល់ហេតុដែលមិនមាន សេចក្តីអន្តរាយ ដោយសង្ឃដែលព្រមព្រៀងហើយ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុណាដែលបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា ដ៏សមគួរដល់ហេតុដែលមិនមានវិបត្តិកំរើក ដោយសង្ឃដែលព្រមព្រៀងហើយ ភិក្ខុនេះ តថាគតសំដៅយកក្នុងអត្ថនេះ។

[២៧] ត្រង់ពាក្យថា សិក្ខា សំដៅត្រង់សិក្ខា៣គឺ អធិសីលសិក្ខា១ អធិចិត្តសិក្ខា១ អធិប្បញ្ញសិក្ខា១ បណ្តាសិក្ខាទាំង៣នោះ សិក្ខាណាដែលហៅថា អធិសីលសិក្ខា សិក្ខានេះ តថាគតសំដៅយកក្នុងសេចក្តីនេះ។

[២៨] ត្រង់ពាក្យថា សាជីវៈ គឺសិក្ខាបទណា ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ សិក្ខាបទដែលព្រះដ៏មានព្រះភាគបានបញ្ញត្តហើយនុ៎ះហៅថាសាជីវៈ ភិក្ខុដែលសិក្សាក្នុងសិក្ខាបទ ហៅថាសាជីវៈនោះ តថាគតហៅថា អ្នកដល់ព្រមដោយសាជីវៈដោយហេតុនោះឯង។

[២៩] ត្រង់ពាក្យថា មិនពោលលាសិក្ខា មិនធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ (មានព្រះពុទ្ធភាសិតថា) ម្នាលភិក្ខុទាំងឡាយ កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខាហៅថា ភិក្ខុមិនទាន់ពោលលានៅឡើយក៏មាន។ ម្នាលភិក្ខុទាំងឡាយ កិរិយាដែលភិក្ខុបានធ្វើឲ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយហើយ សិក្ខាហៅថា ភិក្ខុបានពោលលាហើយក៏មាន។

[៣០] ម្នាលភិក្ខុទាំងឡាយ កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា ហៅថា ភិក្ខុមិនទាន់បានពោលលានៅឡើយ នោះតើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អផ្សុកមិនរីករាយ ចង់ដើម្បីឲ្យឃ្លាតផុតចាកភេទជាសមណៈ នឿយណាយ ធុញទ្រាន់ ខ្ពើមរអើមនឹងភាពខ្លួនជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ប្រាថ្នាភាពជាឧបាសក ប្រាថ្នាភាពជាអ្នករក្សាអារាម ប្រាថ្នាភាពជាសាមណេរ ប្រាថ្នាភាពជាតិរ្ថិយ ប្រាថ្នាភាពជាតិរ្ថិយសាវក ប្រាថ្នាភាពនៃខ្លួនមិនមែនជាសមណៈ ប្រាថ្នាភាពនៃខ្លួនមិនមែនជាសក្យបុត្រ ក៏

និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា ហៅថា ភិក្ខុមិនទាន់បានពោលលានៅឡើយ។ ម្យ៉ាងទៀត ភិក្ខុអផ្សុក មិនរីករាយ ចង់ចេញចាកសមណភាព នឿយណាយធុញទ្រាន់ ខ្ពើមរអើមនឹងភាពខ្លួនជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ។ បេ។ ប្រាថ្នានូវភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះធម៌។ បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំលះបង់ព្រះសង្ឃ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់សិក្ខា។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់វិន័យ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់បាតិមោក្ខ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ឧទ្ទេស។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ឧបជ្ឈាយ៍។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់អាចារ្យ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់សទ្ធិវិហារិក។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់អន្តេវាសិក។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នា។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ភិក្ខុដែលមានអាចារ្យស្មើគ្នា។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ភិក្ខុអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នា។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាគ្រហស្ថ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាឧបាសក។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាអ្នករក្សាវត្ត។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាសាមណេរ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាតិរ្ថិយ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាតិរ្ថិយសាវក។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំលែងធ្វើជាសមណៈ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំលែងធ្វើជាសក្យបុត្រ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា មិនទាន់ហៅថាភិក្ខុបានពោលលានៅឡើយ។ មួយវិញទៀត ភិក្ខុអផ្សុក មិនរីករាយ ចង់ឃ្លាតចាកសមណភាព កាលជាទុក្ខធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ។ បេ។ ប្រាថ្នាភាពមិនមែនជាសក្យបុត្រ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើមែន មានតែខ្ញុំត្រូវលះបង់ព្រះពុទ្ធ។ បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើមែន មានតែខ្ញុំត្រូវលែងធ្វើជាសក្យបុត្រ។ បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កាលបើហេតុយ៉ាងនេះមានពិតមែន ខ្ញុំត្រូវលះបង់ព្រះពុទ្ធ។ បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កាលបើយ៉ាងនេះ មានតែខ្ញុំត្រូវលែងធ្វើជាសក្យបុត្រ។ បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ណ្ហើយចុះ ខ្ញុំត្រូវតែលះបង់ព្រះពុទ្ធ។ បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ណ្ហើយចុះ ខ្ញុំត្រូវលែងធ្វើជាសក្យបុត្រ។ បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ហេតុរបស់ខ្ញុំលើកទុកសិនចុះ ខ្ញុំត្រូវលះបង់ព្រះពុទ្ធ។ បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ហេតុរបស់ខ្ញុំលើកទុកសិនចុះ ត្រូវតែខ្ញុំលែងធ្វើជាសក្យបុត្រ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា មិនទាន់ហៅថាភិក្ខុបានពោលលានៅឡើយ។ មួយវិញទៀត ភិក្ខុអផ្សុក មិនរីករាយ ប្រាថ្នាដើម្បីឲ្យឃ្លាតផុតចាកសមណភាព ជាទុក្ខធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ។ បេ។ នឹងចង់ឲ្យខ្លួនទៅជាអសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកមាតា។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបិតា។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបងប្អូនប្រុស។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបងប្អូនស្រី។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកកូនប្រុស។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកកូនស្រី។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកប្រពន្ធ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកពួកញាតិ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកពួកមិត្ត។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកស្រុក។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកនិគម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកស្រែ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកចំការ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកប្រាក់។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកមាស។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកសិល្បសាស្រ្ត។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកជាញឹកញយនូវការសើច ការស្រដីនិងការលេងអំពីមុន។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា មិនចាត់ថាភិក្ខុបានពោលលាឡើយ។ មួយវិញទៀត ភិក្ខុអផ្សុក មិនរីករាយ ប្រាថ្នាឲ្យឃ្លាតផុតចាកសមណភាព ជាទុក្ខធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ពេញចិត្តនឹងភាពគ្រហស្ថ។ បេ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមានមាតា ៗនោះខ្ញុំត្រូវតែចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បិតារបស់ខ្ញុំមាន បិតានោះខ្ញុំត្រូវតែចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនប្រុសរបស់ខ្ញុំមាន បងប្អូនប្រុសនោះខ្ញុំត្រូវតែចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនស្រីរបស់ខ្ញុំមាន បងប្អូនស្រីនោះខ្ញុំត្រូវតែចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនប្រុសរបស់ខ្ញុំមាន កូនប្រុសនោះខ្ញុំត្រូវតែចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនស្រីរបស់ខ្ញុំមាន កូនស្រីនោះខ្ញុំត្រូវតែចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រពន្ធរបស់ខ្ញុំមាន ប្រពន្ធនោះខ្ញុំត្រូវតែចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកញាតិរបស់ខ្ញុំមាន អ្នកទាំងនោះត្រូវតែខ្ញុំចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកមិត្តរបស់ខ្ញុំមាន ពួកមិត្តទាំងនោះខ្ញុំត្រូវតែចិញ្ចឹម។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា មិនទាន់ហៅថាភិក្ខុបានពោលលាឡើយ។ ន័យមួយទៀត ភិក្ខុអផ្សុក មិនរីករាយ ចង់ឃ្លាតចេញចាកសមណភាព ជាទុក្ខធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាភាពគ្រហស្ថ។ បេ។ មិនប្រាថ្នាភាពជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា មាតារបស់ខ្ញុំមាន មាតានោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បិតារបស់ខ្ញុំមាន បិតានោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនប្រុសរបស់ខ្ញុំមាន បងប្អូនប្រុសនោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនស្រីរបស់ខ្ញុំមាន បងប្អូនស្រីនោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនប្រុសរបស់ខ្ញុំមាន កូនប្រុសនោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនស្រីរបស់ខ្ញុំមាន កូនស្រីនោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រពន្ធរបស់ខ្ញុំមាន ប្រពន្ធនោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកញាតិរបស់ខ្ញុំមាន ពួកញាតិទាំងនោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកមិត្តរបស់ខ្ញុំមាន មិត្តទាំងនោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ស្រុករបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយស្រុកនោះក៏បាន។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា និគមរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយនិគមនោះក៏បាន។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ស្រែរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយស្រែនោះក៏បាន។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ចំការរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយចំការនោះក៏បាន។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រាក់របស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយប្រាក់នោះក៏បាន។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា មាសរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយមាសនោះក៏បាន។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា សិល្បសាស្រ្តរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយសិល្បសាស្រ្តនោះក៏បាន។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា មិនទាន់ហៅថាភិក្ខុបានពោលលាឡើយ។ ន័យមួយទៀត ភិក្ខុអផ្សុក មិនរីករាយ ចង់ចេញចាកភាពជាសមណៈ ជាទុក្ខនឹងភាពជាភិក្ខុ ជិនឆ្អន់ ខ្ពើមរអើមភិក្ខុភាព ប្រាថ្នានូវភាពជាគ្រហស្ថ។ បេ។ ប្រាថ្នាភាពមិនមែនជាសក្យបុត្រ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា (អំពើនេះ) កម្រប់បុគ្គលនឹងធ្វើបាន។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា (អំពើនេះ) បុគ្គល

មិនមែនងាយនឹងធ្វើបានទេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា (អំពើនេះ) បុគ្គលប្រព្រឹត្តបានដោយកម្រ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា (អំពើនេះ) បុគ្គលមិនមែនប្រព្រឹត្តបានដោយងាយទេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនអាច (នៅក្នុងភេទបព្វជិតបាន)ទេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនហ៊ាន (នៅក្នុងភេទបព្វជិត) ទេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនត្រេកអរ (នឹងភេទបព្វជិត) ទេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនពេញចិត្ត (នឹងភេទបព្វជិត) ទេ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកំឡាំងថយ ប៉ុន្តែសិក្ខា មិនទាន់ហៅថាភិក្ខុបានពោលលាឡើយ។

[៣១] ម្នាលភិក្ខុទាំងឡាយ កិរិយាដែលភិក្ខុធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមានកំឡាំងថយ ទាំងសិក្ខាក៏ហៅថាភិក្ខុបានពោលលានោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អផ្សុកមិនត្រេកអរ ចង់ឃ្លាតចាកភាពជាសមណៈ នឿយណាយ ជិនឆ្អន់ ខ្ពើមរអើមនឹងភាពជាភិក្ខុ ប្រាថ្នានូវភាពជាគ្រហស្ថ។ បេ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះទើបហៅថា កិរិយាធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមានកំឡាំងថយ ទាំងសិក្ខា ក៏ហៅថាភិក្ខុបានពោលលា។ ម្យ៉ាងទៀត ភិក្ខុអផ្សុក មិនត្រេកអរ ប្រាថ្នាចង់ឃ្លាតចាកភាពជាសមណៈ នឿយណាយ ជិនឆ្អន់ ខ្ពើមរអើមនឹងភាពជាភិក្ខុ ពេញចិត្តនឹងភាពជាគ្រហស្ថ។ បេ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះធម៌។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះសង្ឃ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់សិក្ខា។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់វិន័យ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់បាតិមោក្ខ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់នូវឧទ្ទេស។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ឧបជ្ឈាយ៍។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់អាចារ្យ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់សទ្ធិវិហារិក។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់អន្តេវាសិក។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់បព្វជិត ដែលមានឧបជ្ឈាយ៍ស្មើគ្នា។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់បព្វជិតដែលមានអាចារ្យស្មើគ្នា។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ភិក្ខុដែលប្រព្រឹត្តព្រហ្មចរិយៈជាមួយគ្នា។ បេ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាគ្រហស្ថចុះ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាឧបាសកចុះ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាញោមវត្តចុះ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាសាមណេរចុះ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាតិត្ថិយចុះ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាសាវកនៃតិត្ថិយចុះ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាមិនមែនជាសមណៈទេចុះ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាមិនមែនជាសក្យបុត្រទេ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះទើបហៅថា កិរិយាធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមានកំឡាំងថយ ទាំងសិក្ខា ក៏ហៅថាភិក្ខុបានពោលលាហើយ។ ម្យ៉ាងទៀត ភិក្ខុអផ្សុក មិនត្រេកអរ ចង់ឃ្លាតចាកភាពជាសមណៈ នឿយណាយ ជិនឆ្អន់ ខ្ពើមរអើមនឹងភាពជាភិក្ខុ ពេញចិត្តនឹងភាពជាគ្រហស្ថ។ បេ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំមិនត្រូវការដោយព្រះពុទ្ធទេ។ បេ។ ពោលឲ្យគេដឹងច្បាស់ថា ខ្ញុំមិនត្រូវការដោយបព្វជិតមានព្រហ្មចារ្យស្មើគ្នាទាំងឡាយទេ។ ម្នាលភិក្ខុទាំងឡាយ ក៏យ៉ាងនេះ។ បេ។ ម្យ៉ាងទៀត។ បេ។ និយាយឲ្យគេដឹងច្បាស់ថា ប្រយោជន៍អ្វីដោយព្រះពុទ្ធដល់ខ្ញុំ។ បេ។ និយាយឲ្យគេដឹងច្បាស់ថា ប្រយោជន៍អ្វីដោយសព្រហ្មចារីភិក្ខុទាំងឡាយដល់ខ្ញុំ។ ក៏យ៉ាងនេះ។ បេ។ ម្យ៉ាងទៀត។ បេ។ និយាយឲ្យគេដឹងច្បាស់ថា សេចក្តីត្រូវការដោយព្រះពុទ្ធនៃខ្ញុំមិនមាន។ បេ។ និយាយឲ្យគេដឹងច្បាស់ថា សេចក្តីត្រូវការដោយសព្រហ្មចារីភិក្ខុទាំងឡាយនៃខ្ញុំមិនមាន។ ក៏យ៉ាងនេះ។ បេ។ ម្យ៉ាងទៀត។ បេ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំរួចស្រឡះចាកព្រះពុទ្ធហើយ។ បេ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំរួចស្រឡះចាកសព្រហ្មចារីភិក្ខុទាំងឡាយហើយ។ ម្នាលភិក្ខុទាំងឡាយ ក៏យ៉ាងនេះ ហៅថា ការបានធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមានកំឡាំងថយ ទាំងសិក្ខាក៏ហៅថា ភិក្ខុបានពោលលាហើយ។ ម្យ៉ាងទៀត ពាក្យទាំងឡាយណា សូម្បីដទៃជាពាក្យផ្លាស់ប្តូរដោយពាក្យថាព្រះពុទ្ធក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថាព្រះធម៌ក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថាព្រះសង្ឃក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថាសិក្ខាក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា វិន័យក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា បាតិមោក្ខក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា ឧទ្ទេសក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា ឧបជ្ឈាយ៍ក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា អាចារ្យក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សទ្ធិវិហារិកក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថាអន្តេវាសិកក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថាសមានុបជ្ឈាយកៈក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សមានាចរិយកៈក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សព្រហ្មចារីក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា គ្រហស្ថក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា ឧបាសកក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា អារាមិកៈក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សាមណេរក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា តិត្ថិយក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា តិត្ថិយសាវកក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា មិនមែនជាសមណៈក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា មិនមែនជាសក្យបុត្រក្តី ភិក្ខុនិយាយឲ្យគេដឹងច្បាស់ដោយពាក្យអម្បាលនោះ ដែលជាអាការពោលលាសក្ខា) ដែលជាភេទ ដែលជានិមិត្ត។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា ការធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមានកំឡាំងថយ ទាំងសិក្ខា ក៏ហៅថា ភិក្ខុបានពោលលាហើយ។

[៣២] ម្នាលភិក្ខុទាំងឡាយ សិក្ខាដែលភិក្ខុមិនបានពោលលានោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ សិក្ខាដែលភិក្ខុក្នុងសាសនានេះ បានពោលលាហើយដោយអាការ និងភេទ និងនិមិត្តទាំងឡាយណាៗ ភិក្ខុជាមនុស្សឆ្កួត ក៏បានពោលលាសិក្ខាដោយអាការ និងភេទ និងនិមិត្តទាំងឡាយនោះៗដែរ។ សិក្ខា មិនហៅថាភិក្ខុឆ្កួតនោះបានពោលលាឡើយ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់បុគ្គលឆ្កួត។ សិក្ខាមិនហៅថា ភិក្ខុបានពោលលាទេ។ ភិក្ខុមានចិត្តរវើរវាយ ហើយពោលលាសិក្ខា។ សិក្ខា មិនហៅថាភិក្ខុបានពោលលាទេ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់បុគ្គលមានចិត្តរវើរវាយហើយ។ សិក្ខា មិនហៅថា ភិក្ខុបានពោលលាទេ។ ភិក្ខុដែលវេទនាកំពុងគ្របសង្កត់ ពោលលាសិក្ខា។ សិក្ខា មិនហៅថា ភិក្ខុបានពោលលាទេ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់បុគ្គលដែលវេទនាកំពុងគ្របសង្កត់។ សិក្ខា មិនហៅថា ភិក្ខុបានពោលលាទេ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ទេវតា។ សិក្ខា មិនហៅថា ភិក្ខុបានពោលលាទេ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់សត្វតិរច្ឆាន។ សិក្ខា មិនហៅថា ភិក្ខុបានពោលលាទេ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ជនជាមិលក្ខកជាតិ ដោយអរិយកភាសា។ បើជនជាមិលក្ខកជាតិនោះ មិនដឹងសេចក្តីច្បាស់ទេ សិក្ខាក៏មិនហៅថា ភិក្ខុបានពោលលាទេ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ជនជាអរិយកជាតិដោយមិលក្ខកភាសា។ បើជនជាអរិយកជាតិនោះ មិនដឹងសេចក្តីច្បាស់ទេ សិក្ខាមិនហៅថា ភិក្ខុបានពោលលាទេ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ជនជាអរិយកជាតិដោយអរិយកភាសា។ បើជនជាអរិយកជាតិនោះមិនដឹងសេចក្តីច្បាស់ទេ សិក្ខាមិនហៅថា ភិក្ខុបានពោលលាឡើយ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ជនជាមិលក្ខកជាតិដោយមិលក្ខកភាសា។ បើជនជាមិលក្ខកជាតិនោះមិនដឹងសេចក្តីច្បាស់ទេ សិក្ខា ហៅថា ភិក្ខុមិនបានពោលលាឡើយ។ ភិក្ខុពោលលាសិក្ខាជាល្បែងលេង។ សិក្ខា ហៅថា ភិក្ខុមិនបានពោលលាឡើយ។ ភិក្ខុពោលលាសិក្ខាដោយភ្លាត់មាត់។ សិក្ខា ហៅថា ភិក្ខុមិនបានពោលលាឡើយ។ ភិក្ខុ

មិនមានប្រាថ្នាឲ្យអ្នកដទៃឮ តែបែរជាឲ្យឮវិញ[13] សិក្ខា ហៅថា ភិក្ខុមិនបានពោលលាឡើយ។ ភិក្ខុមានប្រាថ្នាឲ្យអ្នកដទៃឮ តែបែរជាមិនឲ្យឮវិញ[14]។ សិក្ខា ហៅថាភិក្ខុមិនបានពោលលាឡើយ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់មនុស្សដែលមិនដឹងសេចក្តីច្បាស់។ សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ។ ភិក្ខុមិនពោលលាសិក្ខាឲ្យឮដល់មនុស្សដែលដឹងសេចក្តីច្បាស់។ សិក្ខា ហៅថាភិក្ខុមិនបានពោលលាឡើយ។ ម្យ៉ាងទៀត ភិក្ខុពោលលាសិក្ខាខ្សឹបៗ គ្រប់បទមិនឲ្យអ្នកដទៃឮ។ សិក្ខា ហៅថាភិក្ខុមិនបានពោលលាឡើយ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង សិក្ខា ហៅថាភិក្ខុមិនបានពោលលាឡើយ។

[៣៣] ធម៌ដែលហៅថាមេថុននោះ គឺធម៌ដែលជារបស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់មនុស្សថោកទាប ឬអំពើអាក្រក់ មានកិច្ចដោយទឹកជាទីបំផុត ជាអំពើដែលជនពីរនាក់តែងរួបរួមគ្នាក្នុងទីកំបាំង នេះឯងហៅថា មេថុនធម្ម។

[៣៤] បុគ្គលណា ឲ្យនិមិត្តខ្លួនចូលទៅដោយនិមិត្ត(គេ) ឲ្យអង្គកំណើត (ខ្លួន) ចូលទៅដោយអង្គកំណើត(គេ) ដោយហោចទៅសូម្បីអស់ទីត្រឹមតែ១គ្រាប់ល្ង បុគ្គលនោះហៅថាសេព។

[៣៥] ត្រង់ពាក្យថា ដោយហោចទៅសូម្បីដោយសត្វតិរច្ឆានញី អធិប្បាយថា ភិក្ខុសេពចំពោះមេថុនធម្ម សូម្បីដោយសត្វតិរច្ឆានញី ក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្រឡើយ នឹងបាច់និយាយទៅថ្វីដល់ភិក្ខុដែលសេពមេថុនធម្មដោយស្រីមនុស្ស ព្រោះហេតុនោះបានជាហៅថា (ភិក្ខុសេពមេថុនធម្ម) យ៉ាងហោចទៅសូម្បីដោយសត្វតិរច្ឆានញី (ក៏ត្រូវអាបត្តិបារាជិក)។

[៣៦] ត្រង់ពាក្យថា ភិក្ខុត្រូវអាបត្តិបារាជិក អធិប្បាយថា ធម្មតា បុរសដែលមានក្បាលដាច់ មិនអាចនឹងតភ្ជាប់ដោយសរីរៈនោះ ហើយរស់នៅវិញបាន យ៉ាងណាមិញ ភិក្ខុតែសេពមេថុនធម្មហើយ ក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្រ យ៉ាងនោះឯង ព្រោះហេតុនោះ បានជាហៅថា ត្រូវអាបត្តិបារាជិក។

[៣៧] ត្រង់ពាក្យថា រកសំវាសគ្មាន អធិប្បាយថា សង្ឃកម្មជាមួយគ្នាក្តី ឧទ្ទេសជាមួយគ្នាក្តី ការសិក្សាស្មើគ្នាក្តី នេះឯងហៅថាសំវាស សំវាសនោះមិនមានជាមួយនឹងភិក្ខុដែលត្រូវអាបត្តិបារាជិកនោះទេ ព្រោះហេតុនោះ បានជាហៅថា រកសំវាសគ្មាន។

[៣៨] ស្រីមាន៣ពួក គឺស្រីមនុស្ស១ ស្រីអមនុស្ស១ សត្វតិរច្ឆានញី១។ ឧភតោព្យញ្ជនក គឺជនដែលមានភេទពីរ មាន៣ពួក គឺមនុស្សមានភេទពីរ១ អមនុស្សមានភេទពីរ១ តិរច្ឆានមានភេទពីរ១។ បណ្ឌក គឺជនខ្ទើយ មាន៣ពួកគឺ មនុស្សខ្ទើយ១ អមនុស្សខ្ទើយ១ តិរច្ឆានខ្ទើយ១។ ប្រុសមាន៣ពួក គឺមនុស្សប្រុស១ អមនុស្សប្រុស១ តិរច្ឆានឈ្មោល១។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំង៣ គឺវច្ចមគ្គ (ទ្វារធំ)១ បស្សាវមគ្គ (ទ្វារតូច)១ មុខមគ្គ (ទ្វារមាត់)១ (ទ្វារមគ្គណាមួយ) របស់មនុស្សស្រី ត្រូវអាបត្តិបារាជិក។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំង៣ គឺវច្ចមគ្គ១ បស្សាវមគ្គ១ មុខមគ្គ១ (ទ្វារមគ្គណាមួយ) របស់អមនុស្សស្រី។ បេ។ របស់តិរច្ឆានញី ត្រូវអាបត្តិបារាជិក។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំង៣ គឺវច្ចមគ្គ១ បស្សាវមគ្គ១ មុខមគ្គ១ (ទ្វារមគ្គណាមួយ) របស់មនុស្សមានភេទពីរ។ បេ។ របស់អមនុស្សមានភេទពីរ។ បេ។ របស់តិរច្ឆានមានភេទពីរ ត្រូវអាបត្តិបារាជិក។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំងពីរ គឺវច្ចមគ្គ១ មុខមគ្គ១ (ទ្វារមគ្គណាមួយ) របស់មនុស្សខ្ទើយ ត្រូវអាបត្តិបារាជិក។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំងពីរ គឺវច្ចមគ្គ១ មុខមគ្គ១ (ទ្វារមគ្គណាមួយ) របស់អមនុស្សខ្ទើយ។ បេ។ របស់តិរច្ឆានខ្ទើយ។ បេ។ របស់អមនុស្សប្រុស។ បេ។ របស់តិរច្ឆានឈ្មោល ត្រូវអាបត្តិបារាជិក។

[៣៩] ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គមនុស្សស្រី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារបស្សាវមគ្គមនុស្សស្រី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារមុខមគ្គមនុស្សស្រី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គក្តី ទ្វារបស្សាវមគ្គក្តី ទ្វារមុខមគ្គក្តី (ទ្វារមគ្គណាមួយ) របស់អមនុស្សស្រី។ បេ។ របស់តិរច្ឆានញី របស់មនុស្សមានភេទពីរ របស់អមនុស្សមានភេទពីរ របស់តិរច្ឆានមានភេទពីរ ត្រូវអាបត្តិបារាជិក។ ភិក្ខុមានចិត្តចង់សេពតាំងឡើងប្រាកដ ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គក្តី។ បេ។ មុខមគ្គក្តី របស់មនុស្សខ្ទើយ ត្រូវអាបត្តិបារាជិក។ ភិក្ខុមានចិត្តចង់សេពតាំងឡើងប្រាកដ ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គក្តី ទ្វារមុខមគ្គក្តី (ទ្វារមគ្គណាមួយ) របស់អមនុស្សខ្ទើយ។ បេ។ របស់តិរច្ឆានខ្ទើយ របស់មនុស្សប្រុស របស់អមនុស្សប្រុស របស់តិរច្ឆានឈ្មោល ត្រូវអាបត្តិបារាជិក។

[៤០] ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី (១នាក់) មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ (ស្រីនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី (១នាក់) មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ (ស្រីនោះ)។ បើភិក្ខុនោះមិនត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅទេ តែថា ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី (១នាក់) មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ (ស្រីនោះ)។ បើភិក្ខុនោះមិនត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី មិនត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី តែថាត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី (១នាក់) មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ (ស្រីនោះ)។ បើភិក្ខុនោះមិនត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី មិនត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី មិនត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ) ក្តី តែថាត្រេកអរនឹងអង្គជាតដែលបន្ថយចេញ ត្រូវអាបត្តិបារាជិក។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី (១នាក់) មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ (ស្រីនោះ)។ បើភិក្ខុនោះមិនត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី មិនត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី មិនត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី មិនត្រេកអរនឹងអង្គជាតដែល

បន្ថយចេញក្តី មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី (១នាក់) មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារបស្សាវមគ្គក្តី។ បេ។ ទ្វារមុខមគ្គក្តី (របស់ស្រីនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ បើភិក្ខុនោះមិនត្រេកអរ ក៏ពុំត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី(១នាក់) ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយ មានទ្វារមគ្គសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វពុំទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រីស្លាប់(១នាក់) ដែលមានទ្វារមគ្គ សត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ (របស់មនុស្សស្រីស្លាប់នោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ បើភិក្ខុនោះមិនត្រេកអរទេ ក៏ពុំត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកអមនុស្សស្រី។ បេ។ តិរច្ឆានញី មនុស្សមានភេទពីរ អមនុស្សមានភេទពីរ តិរច្ឆានមានភេទពីរ មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ (របស់ជនទាំងនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ បើមិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវ នាំយកតិរច្ឆានមានភេទពីរ ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយ មានទ្វារមគ្គ សត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយ មានទ្វារមគ្គសត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានមានភេទពីរដែលស្លាប់ហើយ មានទ្វារមគ្គសត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ (របស់តិរច្ឆានមានភេទពីរ ដែលស្លាប់ហើយនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សខ្ទើយ។ បេ។ អមនុស្សខ្ទើយ តិរច្ឆានខ្ទើយ មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គក្តី។ បេ។ តាមទ្វារមុខមគ្គក្តី (របស់ជនទាំងនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ បើមិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវ នាំយកតិរច្ឆានខ្ទើយដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីហើយដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវ នាំយកតិរច្ឆានខ្ទើយដែលស្លាប់ហើយមានទ្វារមគ្គសត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គក្តី។ បេ។ ទ្វារមុខមគ្គក្តី (របស់តិរច្ឆានខ្ទើយដែលស្លាប់ហើយនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវ នាំយកមនុស្សប្រុស។ បេ។ អមនុស្សប្រុស។ បេ។ តិរច្ឆានឈ្មោល មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត(ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គក្តី។ បេ។ មុខមគ្គក្តី (របស់ជនទាំងនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវ នាំយកតិរច្ឆានឈ្មោល ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានឈ្មោលដែលស្លាប់ហើយ មានទ្វារមគ្គសត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាតភិក្ខុនោះទៅតាមទ្វារវច្ចមគ្គក្តី។ បេ។ ទ្វារមុខមគ្គក្តី (របស់តិរច្ឆាននោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។

[៤១] ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី (១នាក់) មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (របស់ភិក្ខុនោះ) ដែលគ្មានស្រោមទ្រនាប់តាមទ្វារវច្ចមគ្គ ឬបស្សាវមគ្គ ឬមុខមគ្គ (របស់ស្រី) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ស្រី) ដែលគ្មានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ស្រី) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ស្រី) គ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវ នាំយកមនុស្សស្រី(១នាក់) ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកស្រីដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (របស់ភិក្ខុ) ដែលគ្មានស្រោមទ្រនាប់ តាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ (របស់ស្រី) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ស្រី) គ្មានស្រោមទ្រនាប់ក្តី អង្គជាត(របស់ភិក្ខុ) មានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ស្រី) មានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ស្រី) គ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវ នាំយកអមនុស្សស្រី។ បេ។ តិរច្ឆានញី មនុស្សមានភេទពីរ អមនុស្សមានភេទពីរ តិរច្ឆានមានភេទពីរ មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត (របស់ភិក្ខុ) ដែលគ្មានស្រោមទ្រនាប់ទៅតាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ (របស់ជនទាំងនោះ) ដែលមាន

ស្រោមទ្រនាប់ក្តី អង្គជាតភិក្ខុមានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ជនទាំងនោះ) គ្មានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ជនទាំងនោះ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត(របស់ភិក្ខុ) ដែលគ្មានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ជនទាំងនោះ) ដែលគ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវ នាំយកតិរច្ឆានមានភេទពីរ ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានមានភេទពីរដែលស្លាប់ហើយសត្វស៊ីហើយដោយ ច្រើន (នៅសល់បន្តិចបន្តួច) មកកាន់សំណាក់ភិក្ខុ (១រូប) ហើយបញ្ចូលអង្គជាត (របស់ភិក្ខុ) ដែលគ្មានស្រោមទ្រនាប់ តាមទ្វារវច្ចមគ្គក្តី។ បេ។ តាមទ្វារមុខមគ្គក្តី (របស់តិរច្ឆានមានភេទពីរ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់ តាមទ្វារមគ្គ (របស់តិរច្ឆានមានភេទពីរ) ដែលគ្មានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) មានស្រោមទ្រនាប់តាមទ្វារមគ្គ (របស់តិរច្ឆានមានភេទពីរ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ តាមទ្វារមគ្គ (របស់តិរច្ឆានមានភេទពីរ) ដែលគ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះ ត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សខ្ទើយ អមនុស្សខ្ទើយ តិរច្ឆានខ្ទើយ មនុស្សប្រុស អមនុស្សប្រុស តិរច្ឆានឈ្មោល មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត (របស់ភិក្ខុនោះ) ដែលគ្មានស្រោមទ្រនាប់តាមទ្វារវច្ចមគ្គក្តី។ បេ។ តាមទ្វារមុខមគ្គក្តី (របស់ជនទាំងនោះ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ជនទាំងនោះ) ដែលគ្មានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ជនទាំងនោះ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) ដែលគ្មានស្រោមទ្រនាប់ (តាមទ្វារមគ្គរបស់ជនទាំងនោះ) ដែលគ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះ ត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ (បើភិក្ខុនោះ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានឈ្មោលដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយ សត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានឈ្មោលដែលស្លាប់ហើយសត្វស៊ីហើយ ដោយច្រើន (នៅសល់បន្តិចបន្តួច) មកកាន់សំណាក់ភិក្ខុ(១រូប) ហើយបញ្ចូលអង្គជាត (របស់ភិក្ខុ) ដែលឥតស្រោមទ្រនាប់ទៅតាមទ្វារវច្ចមគ្គក្តី។ បេ។ តាមទ្វារមុខមគ្គក្តី (របស់តិរច្ឆានឈ្មោល) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត(របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់តាមទ្វារមគ្គតិរច្ឆានឈ្មោលដែលគ្មានស្រោមទ្រនាប់ ក្តី អង្គជាត(របស់ភិក្ខុ)ដែលមានស្រោមទ្រនាប់តាមទ្វារមគ្គ (របស់តិរច្ឆានឈ្មោល)ដែលមានស្រោមទ្រនាប់ក្តី អង្គជាត(របស់ភិក្ខុ) ដែលគ្មានស្រោមទ្រនាប់តាមទ្វារមគ្គ (របស់តិរច្ឆានឈ្មោលដែលគ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។

[៤២] ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់មនុស្សស្រី (ម្នាក់) ហើយបញ្ចូលទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ(របស់ស្រីនោះ) ឲ្យចូលទៅដោយអង្គជាត (របស់ភិក្ខុនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ(១រូប) មកកាន់សំណាក់មនុស្សស្រី (ម្នាក់) ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់មនុស្សស្រីដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ (របស់ស្រីនោះ) ឲ្យចូលទៅដោយអង្គជាត (របស់ភិក្ខុនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់អមនុស្សស្រី។ បេ។ តិរច្ឆានញី មនុស្សមានភេទពីរ អមនុស្សមានភេទពី តិរច្ឆានមានភេទពីរ មនុស្សខ្ទើយ អមនុស្សខ្ទើយ តិរច្ឆានខ្ទើយ មនុស្សប្រុស អមនុស្សប្រុស តិរច្ឆានឈ្មោល ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារមុខមគ្គ (របស់ជនទាំងនោះ) ឲ្យចូលទៅដោយអង្គជាត (របស់ភិក្ខុនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ(១រូប) មកកាន់សំណាក់តិរច្ឆានឈ្មោល ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់តិរច្ឆានឈ្មោល ដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារមុខមគ្គ (របស់តិរច្ឆានឈ្មោលនោះ) ឲ្យចូលទៅដោយអង្គជាត (របស់ភិក្ខុនោះ)។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។

[៤៣] ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់មនុស្សស្រី (ម្នាក់) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ(របស់ស្រីនោះ) ដែលគ្មានស្រោមទ្រនាប់ ឲ្យចូលទៅដោយអង្គជាត (របស់ភិក្ខុនោះ) ដែលមានស្រោមទ្រនាប់ក្តី ទ្វារមគ្គរបស់ស្រីដែលមានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) ដែលគ្មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់ស្រី) មានស្រោមទ្រនាប់ អង្គជាត (របស់ភិក្ខុ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ (របស់ស្រី) គ្មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ(១រូប) មកកាន់សំណាក់មនុស្សស្រី (ម្នាក់) ដែល

នៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់មនុស្សស្រីដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ (របស់ស្រីនោះ) ដែលគ្មានស្រោមទ្រនាប់ ឲ្យចូលទៅដោយអង្គជាត (របស់ភិក្ខុ) ដែលមានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់ស្រី) មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់ស្រី) មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់ស្រី) គ្មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់អមនុស្សស្រី។ បេ។ តិរច្ឆានញី មនុស្សមានភេទពីរ អមនុស្សមានភេទពីរ តិរច្ឆានមានភេទពីរ មនុស្សខ្ទើយ អមនុស្សខ្ទើយ តិរច្ឆានខ្ទើយ មនុស្សប្រុស អមនុស្សប្រុស តិរច្ឆានឈ្មោល ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារមុខមគ្គ (របស់ជនទាំងនោះ) ដែលគ្មានស្រោមទ្រនាប់ ឲ្យចូលទៅដោយអង្គជាត (របស់ភិក្ខុនោះ) ដែលមានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់ជនទាំងនោះ) មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់ជនទាំងនោះ) មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់ជនទាំងនោះ) គ្មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់តិរច្ឆានឈ្មោល ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី។ បេ។ ត្រូវអាបត្តិបារាជិក។ បេ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ (១រូប) មកកាន់សំណាក់តិរច្ឆានឈ្មោលដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន (នៅសល់បន្តិចបន្តួច) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារមុខមគ្គ (របស់តិរច្ឆានឈ្មោល) ដែលគ្មានស្រោមទ្រនាប់ ឲ្យចូលទៅដោយអង្គជាត (របស់ភិក្ខុ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់តិរច្ឆានឈ្មោល) មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់តិរច្ឆានឈ្មោល) មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ(របស់តិរច្ឆានឈ្មោល) គ្មានស្រោមទ្រនាប់ អង្គជាត(របស់ភិក្ខុ) គ្មានស្រោមទ្រនាប់ក្តី។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ)ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ (បើភិក្ខុ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ។

[៤៤] ពួកភិក្ខុជាសត្រូវដែលបានសំដែងហើយដោយពិស្តារយ៉ាងណា ពួកស្តេចជាសត្រូវក្តី ពួកចោរជាសត្រូវក្តី ពួកអ្នកលេងជាសត្រូវក្តី ពួកសត្រូវអ្នកពុះទ្រូងអារយកបេះដូងក្តី បណ្ឌិតគប្បីពោលឲ្យពិស្តារយ៉ាងនោះដែរចុះ។

[៤៥] ភិក្ខុញ៉ាំងមគ្គឲ្យចូលទៅដោយមគ្គ[15] ត្រូវអាបត្តិបារាជិក។ ភិក្ខុញ៉ាំងអមគ្គឲ្យចូលទៅដោយមគ្គ[16] ត្រូវអាបត្តិបារាជិក។ ភិក្ខុញ៉ាំងមគ្គឲ្យចូលទៅដោយអមគ្គ[17] ត្រូវអាបត្តិបារាជិក។ ភិក្ខុញ៉ាំងអមគ្គឲ្យចូលទៅដោយអមគ្គ[18] ត្រូវអាបត្តិថុល្លច្ច័យ។

[៤៦] ភិក្ខុសេពមេថុនធម្មនឹងភិក្ខុផងគ្នាដែលកំពុងដេកលក់ បើភិក្ខុនោះភ្ញាក់ឡើងហើយត្រេកអរដែរ សង្ឃត្រូវឲ្យវិនាស (គឺត្រូវផ្សឹកចេញ)ទាំងពីររូប។ បើភិក្ខុនោះភ្ញាក់ឡើង ហើយមិនត្រេកអរទេ សង្ឃត្រូវឲ្យវិនាសតែភិក្ខុដែលប្រទូស្ត (គឺភិក្ខុអ្នកសេពនោះ)។ ភិក្ខុសេពមេថុនធម្មនឹងសាមណេរដែលកំពុងដេកលក់ បើសាមណេរនោះភ្ញាក់ឡើង ហើយត្រេកអរដែរ សង្ឃត្រូវឲ្យវិនាសទាំងពីររូប។ បើសាមណេរនោះភ្ញាក់ឡើងហើយមិនត្រេកអរទេ សង្ឃត្រូវឲ្យវិនាសតែភិក្ខុដែលប្រទូស្ត។ សាមណេរសេពមេថុនធម្មនឹងភិក្ខុដែលកំពុងដេកលក់ បើភិក្ខុនោះភ្ញាក់ឡើងហើយត្រេកអរដែរ សង្ឃត្រូវឲ្យវិនាសទាំងពីររូប។ បើភិក្ខុនោះភ្ញាក់ឡើងហើយមិនត្រេកអរទេ សង្ឃត្រូវឲ្យវិនាសតែសាមណេរដែលប្រទូស្ត។ សាមណេរសេពមេថុនធម្មនឹងសាមណេរផងគ្នាដែលកំពុងដេកលក់ បើសាមណេរនោះភ្ញាក់ឡើងហើយត្រេកអរដែរ សង្ឃត្រូវឲ្យវិនាសទាំងពីររូប។ បើសាមណេរនោះភ្ញាក់ឡើងហើយមិនត្រេកអរទេ សង្ឃត្រូវឲ្យវិនាសតែសាមណេរដែលប្រទូស្ត។

[៤៧] អាបត្តិមិនមាន (ដល់ភិក្ខុ៥ពួក) គឺភិក្ខុមិនដឹង១ ភិក្ខុឆ្កួត១ ភិក្ខុមានចិត្តរវើរវាយ១ ភិក្ខុដែលវេទនាគ្របសង្កត់១ អាទិកម្មិកៈ (គឺភិក្ខុដើមបញ្ញត្តិ)១។

រហៀបសំដែងអំពីអង្គជាត និងទ្វារមគ្គមានស្រោមទ្រនាប់ ចប់។

## (វិនីតវត្ថុឧទ្ទានគាថា បឋមសិក្ខាបទំ)

CS vin.vbu.pr.01.04 | ភាគ ទី១

### (វិនីតវត្ថុឧទ្ទានគាថា)

[៤៨] (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែ ដែលនឹងសំដែងតទៅដូចមានខាងក្រោមនេះគឺ)

រឿងស្វាញី រឿងពួកវជ្ជីបុត្តកភិក្ខុ រឿងភិក្ខុក្លែងភេទជាគ្រហស្ថ រឿងភិក្ខុអាក្រាត រឿងពួកភិក្ខុប្រព្រឹត្តតាមលទ្ធិតិរ្ថិយ រឿងទារិកា រឿងឧប្បលវណ្ណាភិក្ខុនី រឿងជនផ្សេងគ្នាពីររូប គឺភិក្ខុក្លាយភេទជាស្រី និងភិក្ខុនីក្លាយភេទជាបុរស រឿងមាតា រឿងធីតា រឿងប្អូនស្រី រឿងប្រពន្ធ រឿងភិក្ខុខ្នងទន់ រឿងភិក្ខុមានអង្គជាតយារ រឿងស្នាមដម្បៅពីរយ៉ាង រឿងរូបគំនូរ រឿងឈើចំឡាក់ជារូបធីតា រឿងភិក្ខុ៥រូបទាំងសុន្ទរភិក្ខុផង រឿងភិក្ខុ៥រូបនៅក្នុងព្រៃខ្មោច រឿងនាគញី រឿងយក្ខិនី រឿងស្រីប្រេត រឿងភិក្ខុខ្ទើយ រឿងភិក្ខុកើតរោគស្ពឹក រឿងភិក្ខុចាប់មាតុគ្រាមប្រុងនឹងសេព រឿងភិក្ខុសឹងលក់ក្នុងទីស្ងាត់ក្បែរក្រុងភទ្ទិយ រឿងភិក្ខុទាំងឡាយ៤រូបឯទៀតក្នុងក្រុងសាវត្ថី រឿង

អ្នកចំបាប់៣នាក់ក្នុងក្រុងវេសាលី រឿងភារុកច្ឆកភិក្ខុយល់សុបិននិមិត្ត រឿងនាងសុបព្វា រឿងនាងសទ្ធា រឿងភិក្ខុនី រឿងសិក្ខមានា រឿងសាមណេរី រឿងស្រីផ្កាមាស រឿងមនុស្សខ្ទើយ រឿងគ្រហស្ថ រឿងភិក្ខុសេពគ្នានឹងគ្នា រឿងភិក្ខុបួសឯចាស់ រឿងសត្វម្រឹគ។

## (វិនីតវត្ថុ បឋមសិក្ខាបទំ)

CS vin.vbu.pr.01.05 | ភាគ ទី១

### (វិនីតវត្ថុ)

[៤៩] សម័យនោះឯង ភិក្ខុ១រូបបានសេពមេថុនធម្មនឹងស្វាញី។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យថា សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ អញប្រហែលជាត្រូវអាបត្តិបារាជិកហើយដឹង។ ទើបភិក្ខុនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៥០] សម័យនោះឯង ពួកវជ្ជីបុត្តកភិក្ខុច្រើនរូបនៅក្នុងក្រុងវេសាលី មិនបានលាសិក្ខា មិនបានធ្វើឲ្យជាក់ច្បាស់ថាខ្លួនមានកំឡាំងថយ ហើយសេពមេថុនធម្ម។ ភិក្ខុទាំងអម្បាលនោះមានសេចក្តីសង្ស័យថា សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ យើងរាល់គ្នាប្រហែលជាត្រូវអាបត្តិបារាជិកហើយដឹង។ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកឯងទាំងអស់គ្នាត្រូវអាបត្តិបារាជិកហើយ។

[៥១] សម័យនោះឯង ភិក្ខុ១រូបក្លែងខ្លួនជាគ្រហស្ថ ហើយសេពមេថុនធម្មដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៥២] សម័យនោះឯង ភិក្ខុ១រូបធ្វើជាអ្នកអាក្រាត ហើយសេពមេថុនធម្មដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៥៣] សម័យនោះឯង ភិក្ខុ១រូបស្លៀកស្បូវក្រង។ បេ។ ស្លៀកសម្ពត់សម្បកឈើ ស្លៀកសម្ពត់ដែលត្បាញជារូបផ្លែឈើ ស្លៀកសម្ពត់ដែលត្បាញដោយសក់ ស្លៀកសម្ពត់ដែលត្បាញដោយរោមកន្ទុយសត្វ ស្លៀកសម្ពត់ដែលត្បាញដោយស្លាបមៀម ស្លៀកស្បែកខ្លាដែលនៅមានទាំងរោមទាំងក្រចក ហើយសេពមេថុនធម្ម ដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៥៤] សម័យនោះឯង ភិក្ខុ១រូបជាអ្នកប្រព្រឹត្តបិណ្ឌបាត បានឃើញនាងទារិកាម្នាក់ដេកនៅលើតាំង ក៏មានចិត្តត្រេកអរ ហើយយកមេជើង (ខ្លួន) ទៅរុកបញ្ចូលចំអង្គជាតនាងទារិកានោះ។ នាងក៏ធ្វើមរណកាលទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស។

[៥៥] សម័យនោះឯង មាណពម្នាក់មានសេចក្តីប្រតិព័ទ្ធ ចាប់ចិត្តនឹងឧប្បលវណ្ណាភិក្ខុនី។ កាលដែលឧប្បលវណ្ណាភិក្ខុនីចូលទៅបិណ្ឌបាតក្នុងស្រុក មាណពនោះក៏ចូលទៅពួននៅក្នុងកុដិតូចចាំ។ លុះដល់ឧប្បលវណ្ណាភិក្ខុនីត្រឡប់មកពីបិណ្ឌបាតវិញ ឆាន់រួចហើយ ក៏លាងជើងហើយចូលទៅក្នុងកុដិ អង្គុយនៅលើគ្រែ។ ខណៈនោះ មាណពនោះក៏ស្ទុះមកសង្រ្គប់ឧប្បលវណ្ណាភិក្ខុនី ហើយប្រទូស្ត។ ឧប្បលវណ្ណាភិក្ខុនីក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីផងគ្នា។ ភិក្ខុនីទាំងឡាយក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក៏នាំសេចក្តីនុ៎ះទៅក្រាបបង្គំទូលចំពោះ ព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧប្បលវណ្ណាមិនត្រូវអាបត្តិទេ ព្រោះមិនមានសេចក្តីត្រេកត្រអាលឡើយ។

[៥៦] សម័យនោះឯង ភិក្ខុ១រូបក្លាយភេទខ្លួនប្រែទៅជាស្រី។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឧបជ្ឈាយ៍នោះដដែល និងឧបសម្បទានោះដដែល និងវស្សាទាំងនោះ[19] និងអនុញ្ញាតឲ្យនៅរួមជាមួយនឹងភិក្ខុនីទាំងឡាយ (ម្យ៉ាងទៀត) អាបត្តិណា ជារបស់ភិក្ខុដែលទួទៅដល់ភិក្ខុនីទាំងឡាយ តថាគតអនុញ្ញាតនូវអាបត្តិទាំងនោះ ដើម្បីឲ្យភិក្ខុដែលក្លាយភេទជាស្រីនោះនៅក្នុងសំណាក់ភិក្ខុនីទាំងឡាយ បាន អាបត្តិណាជារបស់ភិក្ខុដែលមិនទួទៅដល់ភិក្ខុនីទាំងឡាយ ភិក្ខុនីនោះមិនត្រូវអាបត្តិព្រោះអាបត្តិនោះឡើយ។ សម័យនោះឯង ភិក្ខុនី១រូប ក្លាយភេទខ្លួនទៅជាប្រុស។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឧបជ្ឈាយ៍នោះដដែល និងឧបសម្បទានោះដដែល និងវស្សាទាំងនោះ និងអនុញ្ញាតឲ្យនៅរួមជាមួយនឹងភិក្ខុទាំងឡាយ អាបត្តិណាជារបស់ភិក្ខុនីដែលទួទៅដល់ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវអាបត្តិទាំងនោះ ដើម្បីឲ្យភិក្ខុនីដែលក្លាយភេទខ្លួនជាប្រុសនោះនៅក្នុងសំណាក់ភិក្ខុ ទាំងឡាយបាន អាបត្តិណាជារបស់ភិក្ខុនីដែលមិនទួទៅដល់ភិក្ខុទាំងឡាយទេ (ភិក្ខុនីនេះ) មិនមានអាបត្តិព្រោះអាបត្តិទាំងនោះឡើយ។

[៥៧] សម័យនោះឯងភិក្ខុ១រូបសេពមេថុនធម្មនឹងមាតា(របស់ខ្លួន) ដោយយល់ថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ។ បេ។ សេពមេថុនធម្មនឹងធីតា(របស់ខ្លួន)។ បេ។ សេពមេថុនធម្មនឹងប្អូនស្រី(របស់ខ្លួន)។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទើបក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង ភិក្ខុ១រូបសេពមេថុនធម្មនឹងស្រីដែលមាតាបិតាផ្សំផ្គុំឲ្យអំពីមុន។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៥៨] សម័យនោះឯងភិក្ខុ១រូបមានខ្នងទន់។ ភិក្ខុនោះមានសេចក្ដីអផ្សុកបៀតបៀន ហើយបានយកអង្គជាតខ្លួនមកបៀមនឹងមាត់។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯងភិក្ខុ១រូបមានអង្គជាតយាវវែង។ ភិក្ខុនោះមានសេចក្ដីអផ្សុកបៀតបៀន ក៏ចាប់បំពត់អង្គជាតខ្លួនបញ្ចូលទៅក្នុងវច្ចមគ្គ (គឺទ្វារធំ) របស់ខ្លួន។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៥៩] សម័យនោះឯង ភិក្ខុ១រូបឃើញសរីរមនុស្សស្លាប់។ ឯសរីរនោះ មានដម្បៅជុំវិញអង្គជាត។ ភិក្ខុនោះបានបញ្ចូលអង្គជាត(ខ្លួន)ទៅក្នុងអង្គជាត(សរីរនោះ) ហើយបន្ថយអង្គជាតចេញមកវិញតាមដម្បៅដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ។ ភិក្ខុនោះក៏មានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង ភិក្ខុ១រូបឃើញសរីរមនុស្សស្លាប់។ ឯសរីរនោះ មានដម្បៅជុំវិញអង្គជាត។ ភិក្ខុនោះបានបញ្ចូលអង្គជាត(ខ្លួន)ទៅក្នុងដម្បៅ ហើយបន្ថយចេញមកវិញតាមអង្គជាតិ ដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៦០] សម័យនោះឯង ភិក្ខុ១រូបមានតម្រេក ហើយយកអង្គជាត(ខ្លួន)ទៅញល់នឹងនិមិត្តរបស់រូបគំនូរ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុ១រូបមានតម្រេក ហើយយកអង្គជាត(ខ្លួន)ទៅញល់នឹងនិមិត្តរបស់រូបតុក្កតាស្រីដែលធ្វើដោយ ឈើ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៦១] សម័យនោះឯង ភិក្ខុ១រូបឈ្មោះសុន្ទរៈ ចេញពីក្រុងរាជគ្រឹះទៅបួស ហើយដើរទៅតាមថ្នល់។ មានស្រីម្នាក់បានឃើញភិក្ខុនោះ ហើយក៏និយាយថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្អង់១រំពេចសិន ខ្ញុំព្រះករុណានឹងថ្វាយបង្គំ។ ស្រីនោះកាលដែលថ្វាយបង្គំ ក៏សើយស្បង់ឡើង ហើយយកមាត់ទៅបៀមអង្គជាត(របស់ភិក្ខុនោះ)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងត្រេកអរដែរឬទេ? ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិទេ ព្រោះមិនត្រេកអរ។

[៦២] សម័នោះឯង មានស្រីម្នាក់បានឃើញភិក្ខុ១រូប ហើយនិយាយថា បពិត្រលោកម្ចាស់ សូមនិមន្តលោកម្ចាស់មកសេពមេថុនងនេះ។ ភិក្ខុនោះនិយាយថា កុំនាង ការសេពមេថុនធម្មនេះមិនគួរទេ។ ស្រីនោះអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តមក (កុំប្រកែក) ខ្ញុំព្រះករុណានឹងព្យាយាម លោកម្ចាស់មិនបាច់ព្យាយាមទេ (នៅតែស្ងៀមបានហើយ) សេពយ៉ាងនេះ លោកម្ចាស់មិនត្រូវអាបត្តិទេ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យស្រីនោះ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានស្រីម្នាក់មាននាមមិនប្រាកដ ឃើញភិក្ខុ១រូប ហើយនិយាយថា បពិត្រលោកម្ចាស់ សូមនិមន្តលោក មកសេពមេថុនធម្ម (នឹងខ្ញុំសិន)។ ភិក្ខុនោះឆ្លើយថា កុំនាង អំពើនេះមិនគួរទេ។ ស្រីនោះក៏និយាយអង្វរថា បពិត្រលោកម្ចាស់ សូមនិមន្តមក សូមលោកម្ចាស់ព្យាយាមចុះ ខ្ញុំព្រះករុណាមិនព្យាយាមទេ ធ្វើយ៉ាងនេះ លោកម្ចាស់មិនត្រូវអាបត្តិឡើយ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យស្រីនោះទៅ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានស្រីម្នាក់បានឃើញភិក្ខុ១រូប ក៏និយាយបបួលថា បពិត្រលោកម្ចាស់ សូមនិមន្តមកសេពមេថុនធម្ម (នឹងខ្ញុំព្រះករុណាឯងនេះ)។ ភិក្ខុនោះឆ្លើយថា កុំប្អូនស្រី អំពើនេះមិនគួរទេ។ ស្រីនោះក៏ពន្យល់ថា បពិត្រលោកម្ចាស់ សូមលោកនិមន្តមកព្យាយាមក្នុងអង្គជាតខ្ញុំ រួចបញ្ចេញអសុចិទៅខាងក្រៅអង្គជាតិវិញ។ បេ។ ព្យាយាមខាងក្រៅអង្គជាត ហើយបញ្ចេញអសុចិទៅខាងក្នុងអង្គជាតវិញ ធ្វើយ៉ាងនេះ លោកម្ចាស់មិនត្រូវអាបត្តិឡើយ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យស្រីនោះទៅ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៦៣] សម័យនោះឯង មានភិក្ខុ១រូប ចូលទៅកាន់ព្រៃខ្មោច ឃើញសរីរខ្មោចដែលសត្វមិនទាន់ស៊ី ហើយសេពមេថុនធម្មនឹងសរីរខ្មោចនោះ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុ១រូប ចូលទៅកាន់ព្រៃខ្មោច ឃើញសរីរខ្មោចដែលសត្វមិនទាន់ស៊ីច្រើនអន្លើប៉ុន្មាន ហើយសេពមេថុនធម្មនឹងសរីរខ្មោចនោះ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង ភិក្ខុ១រូបចូលទៅកាន់ព្រៃខ្មោច ឃើញសរីរខ្មោចដែលសត្វស៊ីច្រើនអន្លើ ហើយសេពមេថុនធម្មនឹងសរីរខ្មោចនោះ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុ១រូប ទៅកាន់ព្រៃខ្មោច ឃើញក្បាលខ្មោចដាច់ ក៏បញ្ច្រកអង្គជាត (ខ្លួន) ឲ្យចូលទៅក្នុងមាត់ដែលបើកហា ឲ្យប៉ះទង្គិច(ក្នុងមាត់នោះ)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង ភិក្ខុ១រូប ចូលទៅកាន់ព្រៃខ្មោច ឃើញក្បាលខ្មោចដាច់ ហើយបញ្ច្រកអង្គជាត(ខ្លួន) ទៅក្នុងមាត់ខ្មោចដែលបើកហា មិនឲ្យប៉ះទង្គិច(ក្នុងមាត់នោះ)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង មានភិក្ខុ១រូប មានចិត្តប្រតិព័ទ្ធស្រឡាញ់ស្រីម្នាក់។ ស្រីនោះធ្វើកាលកិរិយាទៅហើយ គេនាំខ្មោចយកទៅចោលក្នុងព្រៃស្មសាន។[20] ឆ្អឹងទាំងឡាយ (នៃខ្មោចស្រីនោះ) ក៏ខ្ចាត់ខ្ចាយរាត់រាយ។ គ្រានោះ ភិក្ខុនោះទៅកាន់ព្រៃខ្មោច ហើយប្រមូលឆ្អឹងទាំងឡាយយកមកដំរៀប ហើយបញ្ចូលអង្គជាត(ខ្លួន)ទៅក្នុងនិមិត្ត(នៃរាងឆ្អឹងនោះ)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៦៤] សម័យនោះឯង មានភិក្ខុ១រូប ទៅសេពមេថុនធម្មនឹងនាគី (នាគញី)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះ មានភិក្ខុ១រូបសេពមេថុនធម្មនឹងយក្ខិនី។ បេ។ សេពមេថុនធម្មនឹងស្រីប្រេត។ បេ។ សេពមេថុនធម្មនឹងមនុស្សខ្ទើយ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[៦៥] សម័យនោះ មានភិក្ខុ១រូប មានឥន្ទ្រិយសាបសូន្យ (គឺមានរោគស្ពឹក)។ ភិក្ខុនោះក៏សេពមេថុនធម្មដោយគិតថា អញមិនដឹងសេចក្តីសុខទុក្ខ អាបត្តិនឹងមិនមានដល់អញឡើយ។ បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុរសសោះសូន្យនោះ ទោះបីដឹង(សេចក្តីសុខទុក្ខ)ក្តី មិនដឹងក្តី ក៏ត្រូវអាបត្តិបារាជិកហើយ។

[៦៦] សម័យនោះឯង មានភិក្ខុ១រូប គិតថាអញនឹងសេពមេថុនធម្មនឹងស្រី គ្រាន់តែយកដៃទៅចាប់ពាល់ ក៏មានសេចក្តីក្តៅក្រហាយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៦៧] សម័យនោះឯង មានភិក្ខុ១រូប ទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃជាតិយាវន ជិតនគរភទ្ទិយ ហើយសឹងលក់ទៅ។ ឯអវយវៈតូចធំរបស់ភិក្ខុនោះ មានខ្យល់បក់មកឧបត្ថម្ភ (នាំឲ្យលោកនោះសឹងលក់ស៊ប់)។ មានស្រីម្នាក់ឃើញហើយ ក៏អង្គុយសង្កត់ពីលើអង្គជាតធ្វើ (សេវនកិច្ច) ស្រេចហើយក៏ចៀសចេញទៅ។ ភិក្ខុនោះ(ភ្ញាក់ឡើង) ឃើញសេចក្តីសៅហ្មង ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្មដោយអាការ៥យ៉ាងគឺ ដោយដម្រេក១ ដោយអាចមន៍១ ដោយទឹកមូត្រ១ ដោយខ្យល់១ ដោយដង្កូវរមាស់រោល១ ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្មដោយអាការ៥យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្ម ព្រោះតម្រេករបស់ភិក្ខុនោះ មិនមែនជាហេតុ មិនមែនជាទីឱកាសឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអរហន្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឥតមានត្រូវអាបត្តិអ្វីឡើយ។

[៦៨] សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងព្រៃអន្ធវន ទៀបនគរសាវត្ថីហើយសឹងលក់ទៅ។ មានស្រីគង្វាលគោម្នាក់ឃើញហើយ ទៅអង្គុយសង្កត់ពីលើអង្គជាតភិក្ខុនោះ។ ភិក្ខុនោះ កាលអង្គជាតកំពុងតែចូលទៅ ក៏ត្រេកអរ ចូលស៊ប់ទៅហើយ ក៏ត្រេកអរ ស្ថិតនៅខាងក្នុង ក៏ត្រេកអរ បន្ថយចេញមកវិញ ក៏ត្រេកអរ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងព្រៃអន្ធវន ទៀបនគរសាវត្ថីហើយសឹងលក់ទៅ។ មានស្រីគង្វាលពពែម្នាក់បានឃើញភិក្ខុនោះ។ បេ។ មានស្រីអ្នករកឧសម្នាក់បានឃើញភិក្ខុនោះ។ បេ។ មានស្រីអ្នកនាំអាចមន៍គោម្នាក់បានឃើញភិក្ខុនោះ ក៏ទៅអង្គុយសង្កត់ពីលើអង្គជាត។ ភិក្ខុនោះ កាលដែលអង្គជាតកំពុងតែចូលទៅ ត្រេកអរ ចូលស៊ប់ទៅហើយ ត្រេកអរ ស្ថិតនៅខាងក្នុង ត្រេកអរ បន្ថយចេញមកវិញ ត្រេកអរ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[៦៩] សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងព្រៃមហាវន ទៀបនគរវេសាលី ហើយសឹងលក់ទៅ។ មានស្រីម្នាក់បានឃើញ ក៏ទៅអង្គុយសង្កត់ពីលើអង្គជាត លុះធ្វើកិច្ចសម្រេចហើយ ក៏មកឈរសើចជិតភិក្ខុនោះ។ ភិក្ខុនោះភ្ញាក់ឡើង ហើយនិយាយទៅនឹងស្រីនោះថា អំពើនេះជាអំពើរបស់នាងឬ។ ស្រីនោះឆ្លើយថា ករុណាលោកម្ចាស់ អំពើនេះជាអំពើរបស់ខ្ញុំករុណា។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងដឹងដែរឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងទេ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងកាលបើមិនដឹង មិនមានអាបត្តិទេ។ សម័យនោះ មានភិក្ខុ១រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងព្រៃមហាវន ជិតនគរវេសាលី ហើយសឹងលក់ផ្អែកនឹងដើមឈើមួយ។ មានស្រីម្នាក់បានឃើញ ក៏ទៅអង្គុយសង្កត់ពីលើអង្គជាត។ ភិក្ខុនោះ ក៏ក្រោកឡើងដោយរហ័ស។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងត្រេកអរដែរឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងកាលបើមិនត្រេកអរ មិនត្រូវអាបត្តិទេ។ សម័យនោះ មានភិក្ខុ១រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងព្រៃមហាវន ជិតនគរវេសាលី ហើយសឹងលក់ផ្អែកនឹងដើមឈើ១។ មានស្រីម្នាក់ឃើញហើយ ក៏ទៅអង្គុយសង្កត់ពីលើអង្គជាត។ ភិក្ខុនោះ ក៏ធាក់ច្រាន (ឲ្យស្រីនោះ) ខ្ទាតចេញទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកត្រេកអរឬទេ។ ភិក្ខុនោះក្រាបទូលវិញថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកកាលបើមិនត្រេកអរ មិនមានអាបត្តិទេ។

[៧០] សម័យនោះ មានភិក្ខុ១រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃក្នុងកូដាគារសាលា ឰដ៏ព្រៃមហាវន ជិតនគរវេសាលី បើកទ្វារហើយ ចូលទៅសឹង។ អវយវៈតូចធំរបស់ភិក្ខុនោះ មានខ្យល់បក់មកឧបត្ថម្ភ (នាំឲ្យសឹងលក់ស៊ប់)។ សម័យនោះ មានស្រីទាំងឡាយច្រើនគ្នា មានប្រាថ្នានឹងទៅវត្ត ទើបកាន់នូវគ្រឿងក្រអូបខ្លះ ផ្កាកម្រងខ្លះ ដើរទៅកាន់អារាម។ គ្រានោះ ស្រីទាំងអស់នោះ បានឃើញភិក្ខុនោះហើយ ក៏អង្គុយសង្កត់ពីលើអង្គជាតធ្វើ (សេវនកិច្ច) ដរាបដល់ហើយស្រេច ទើបនិយាយថា ឱហ្ន៎ ភិក្ខុនេះ ជាបុរសឧសភៈ ដូច្នេះហើយ លើកឡើងនូវគ្រឿងក្រអូប និងផ្កាកម្រង ហើយក៏ដើរចៀសចេញទៅ។ ភិក្ខុនោះឃើញសេចក្តីសៅហ្មង ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្មដោយអាការ៥យ៉ាងគឺ ដោយដម្រេក១ ដោយអាចមន៍១ ដោយទឹកមូត្រ១ ដោយខ្យល់១ ដោយដង្កូវរមាស់រោល១ ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្ម ដោយអាការ៥យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្មព្រោះតម្រេករបស់ភិក្ខុនោះ មិនមែនជាហេតុ ជាទីតាំង មិនមែនជាឱកាសឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអរហន្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនមានអាបត្តិឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ កាលដែលសឹងសម្ងំក្នុងវេលាថ្ងៃ ត្រូវបិទទ្វារ ហើយសិមសឹងសម្ងំចុះ។

[៧១] សម័យនោះ មានភិក្ខុ១រូបជាកូនអ្នកស្រុកភារុកច្ឆកៈ យល់សប្តិឃើញថា សេពមេថុនធម្មនឹងនាងបុរាណទុតិយិកា ហើយគិតថា ខ្លួនអញមិនមែនជាសមណទេ អញនឹងសឹកទៅវិញ ដូច្នេះ ហើយដើរទៅកាន់ជនបទឈ្មោះភារុកច្ឆកៈ ក៏បានឃើញព្រះឧបាលិដ៏មានអាយុក្នុងទីពាក់កណ្តាលផ្លូវ ហើយនិយាយប្រាប់រឿងនុ៎ះ។ ព្រះឧបាលិថេរដ៏មានអាយុបានប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ឥតមានអាបត្តិអ្វីដោយចំណែកនៃយល់សប្តិនោះទេ។

[៧២] សម័យនោះ ក្នុងក្រុងរាជគ្រឹះ មានឧបាសិកាម្នាក់ឈ្មោះសុបព្វា ជាស្រីមានសេចក្តីជ្រះថ្លាខ្សោយ។ នាងមានសេចក្តីយល់ឃើញយ៉ាងនេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ។ លុះដល់នាងបានឃើញភិក្ខុ១រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ។ ភិក្ខុនោះប្រកែកថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ។ នាងសុបព្វាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះភ្លៅចុះ កាលបើលោកព្យាយាមដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះ។

ទើបភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស។ សម័យនោះ ក្នុងក្រុងរាជគ្រឹះ មានឧបាសិកាម្នាក់ឈ្មោះសុបញ្ញា ជាស្រីមានសេចក្តីជ្រះថ្លាខ្សោយ។ នាងមានសេចក្តីយល់ឃើញយ៉ាងនេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ។ លុះដល់នាងបានឃើញភិក្ខុ១រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ។ ភិក្ខុនោះប្រកែកថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ។ នាងសុបញ្ញាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្ចិតចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្ទត់ពោះចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ក្លៀកចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់កចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់រន្ធត្រចៀកចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្នួងសក់ចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះម្រាមដៃចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកចុះ ខ្ញុំព្រះករុណានឹងព្យាយាមឲ្យចេញទឹកសុក្កៈដោយដៃខ្ញុំ កាលបើដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស។

[៧៣] សម័យនោះ ក្នុងក្រុងសាវត្ថី មានឧបាសិកាម្នាក់ឈ្មោះសទ្ធា ជាអ្នកមានសេចក្តីជ្រះថ្លាខ្សោយ។ នាងមានសេចក្តីយល់ឃើញដូច្នេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ។ លុះដល់នាងបានឃើញភិក្ខុ១រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ។ ភិក្ខុនោះប្រកែកថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ។ នាងសទ្ធាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះភ្លៅចុះ កាលបើដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះទៅ។ ទើបភិក្ខុនោះកើតមានសេចក្តីសង្ស័យ។ បេ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស។

[៧៤] សម័យនោះ ក្នុងក្រុងសាវត្ថី មានឧបាសិកាម្នាក់ឈ្មោះសទ្ធា ជាស្រីមានសេចក្តីជ្រះថ្លាខ្សោយ។ នាងមានសេចក្តីយល់ឃើញដូច្នេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ។ លុះនាងបានឃើញភិក្ខុ១រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ។ ភិក្ខុនោះប្រកែកថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ។ នាងសទ្ធាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្ចិតចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្ទត់ពោះចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ក្លៀកចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់កចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់រន្ធត្រចៀកចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្នួងសក់ចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះម្រាមដៃចុះ។ បេ។ លោកម្ចាស់ សូមលោកនិមន្តមកចុះ ខ្ញុំព្រះករុណានឹងព្យាយាមឲ្យចេញទឹកសុក្កៈដោយដៃខ្ញុំ កាលបើដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះទៅ។ ទើបភិក្ខុនោះកើតមានសេចក្តីសង្ស័យ។ បេ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស។

[៧៥] សម័យនោះ ពួកលិច្ឆវិកុមារក្នុងក្រុងវេសាលីនាំភិក្ខុ១រូបទៅ ហើយឲ្យធ្វើមោះមិនគាប់ជាមួយនឹងភិក្ខុនី។ បើអ្នកទាំងពីរមានសេចក្តីត្រេកអរដូចគ្នា សង្ឃគប្បីឲ្យអ្នកទាំងពីរសឹកចេញ។ បើអ្នកទាំងពីរឥតមានសេចក្តីត្រេកអរទេ អ្នកទាំងពីរមិនមានអាបត្តិឡើយ។ សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវិកុមារនាំភិក្ខុ១រូបទៅ ហើយឲ្យធ្វើមោះមិនគាប់ជាមួយនឹងសិក្ខមានា។ បេ។ ឲ្យធ្វើមោះមិនគាប់ជាមួយនឹងសាមណេរី។ បើអ្នកទាំងពីរត្រេកអរដូចគ្នាហើយ សង្ឃត្រូវឲ្យអ្នកទាំងពីរសឹកចេញ។ បើអ្នកទាំងពីរឥតមានសេចក្តីត្រេកអរទេ អ្នកទាំងពីរឥតមានអាបត្តិឡើយ។

[៧៦] សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវិកុមារនាំភិក្ខុ១រូបទៅ ហើយឲ្យធ្វើមោះមិនគាប់ជាមួយនឹងស្រីវេស្យា។ បេ។ ឲ្យធ្វើមោះមិនគាប់ជាមួយនឹងមនុស្សខ្ទើយ។ បេ។ ឲ្យធ្វើមោះមិនគាប់ជាមួយនឹងស្រីគ្រហស្ថ។ បើភិក្ខុមានសេចក្តីត្រេកអរ សង្ឃត្រូវឲ្យភិក្ខុ(នោះ)សឹកចេញ។ បើភិក្ខុឥតមានសេចក្តីត្រេកអរទេ ភិក្ខុនោះ ក៏ឥតមានអាបត្តិអ្វីឡើយ។ សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវិកុមារនាំភិក្ខុ១រូបទៅ ហើយឲ្យធ្វើមោះមិនគាប់ចំពោះគ្នានឹងគ្នា។ បើអ្នកទាំងពីរមានសេចក្តីត្រេកអរដូចគ្នា សង្ឃត្រូវឲ្យអ្នកទាំងពីរសឹកចេញ។ បើអ្នកទាំងពីរឥតមានសេចក្តីត្រេកអរទេ អ្នកទាំងពីរឥតមានអាបត្តិឡើយ។

[៧៧] សម័យនោះឯង មានភិក្ខុមួយរូប បួសខាងឯចាស់ និមន្តទៅសួរភរិយាដែលជាគូស្រករ (របស់ខ្លួន) ពីដើម។ ឯភរិយាក៏និយាយថា បពិត្រលោកដ៏ចម្រើន លោកចូរនិមន្តសឹកចេញទៅ ថាហើយក៏ស្ទុះទៅចាប់។ ភិក្ខុនោះថយដោះខ្លួន ក៏ដួលផ្ងារទៅក្រោយ។ ភរិយាចាស់ក៏ឡើងជិះអង្គុយសង្កត់ពីលើអង្គជាត។ ទើបភិក្ខុនោះមានសេចក្តីសង្ស័យ ហើយបានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះសាស្តាទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងបានត្រេកអរដែរឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរទេ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនបានត្រេកអរ មិនត្រូវអាបត្តិទេ។

[៧៨] សម័យនោះឯង មានភិក្ខុមួយរូបនៅក្នុងព្រៃ។ មានកូនម្រឹគ១ ដើរមកកាន់ទីដែលភិក្ខុនោះកំពុងបន្ទោរបង់បស្សាវៈ ហើយផឹកនូវបស្សាវៈ រួចបៀមនូវអង្គជាតដោយមាត់វា។ ភិក្ខុនោះក៏មានសេចក្តីត្រេកអរ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

បឋមបារាជិក ចប់។

# បារាជិកកណ្ឌេ ទុតិយសិក្ខាបទំ

CS vin.vbu.pr.02 | ភាគ ទី១

### (២. ទុតិយបារាជិកំ)

### (បឋមភាណវារៈ ទុតិយសិក្ខាបទំ)

**(-)**

[៧៩] សម័យនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ។ ក៏ក្នុងសម័យនោះ មានភិក្ខុច្រើនរូបជាមិត្តសម្លាញ់ គ្រាន់តែជួបឃើញគ្នាខ្លះ ជាមិត្តសម្លាញ់នៅរួបរួមជាមួយគ្នាខ្លះ ធ្វើកុដិប្រក់ដោយស្មៅក្បែរជើងភ្នំឥសិគិលិ ហើយចាំវស្សា (នៅនោះ)។ មានភិក្ខុ១រូប ឈ្មោះធនិយដ៏មានអាយុជាកូនស្មូនឆ្នាំង ធ្វើកុដិតូចប្រក់ដោយស្មៅ ហើយចាំវស្សានៅនោះដែរ។ គ្រានោះ ភិក្ខុទាំងនោះ លុះចាំវស្សាគ្រប់៣ខែហើយ ក៏រុះរើកុដិស្មៅនោះ ហើយរៀបចំទុកដាក់ស្មៅ និងឈើ (តាមដោយឡែកស្រួលបួល) ហើយចេញទៅកាន់ជនបទចារិក។ ចំណែកខាងឯធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏នៅតែក្នុងទីនោះអស់វស្សានរដូវ ហើយនៅអស់ហេមន្តរដូវ និងគិម្ហរដូវក្នុងទីនោះ (តទៅទៀត)។ គ្រានោះ កាលដែលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅ និងពួកអ្នករកឧស នាំគ្នារុះកុដិប្រក់ដោយស្មៅ(របស់ធនិយភិក្ខុ) ហើយប្រមូលយកស្មៅ និងឈើទៅអស់។ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏រកស្មៅ និងឈើមកហើយសង់កុដិប្រក់ដោយស្មៅជាគំរប់ពីរដង។ កាលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក ពួកអ្នករកស្មៅ និងពួកអ្នករកឧស ក៏រុះកុដិស្មៅហើយជញ្ជូនយកស្មៅ និងឈើទៅទៀតជាគំរប់ពីរដង។ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏រកស្មៅ និងឈើមកហើយសង់កុដិស្មៅជាគំរប់បីដង។ កាលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក ពួកអ្នករកស្មៅ និងពួកអ្នករកឧស ក៏រុះកុដិស្មៅហើយជញ្ជូនយកស្មៅ និងឈើទៅទៀត ជាគំរប់បីដង។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងត្រិះរិះថា កាលអញចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅ និងពួកអ្នករកឧសមករុះរើកុដិ ហើយយកស្មៅ និងឈើទៅអស់ ដរាបអស់វារៈបីដងហើយ ឯខ្លួនអញជាអ្នកសិក្សារៀនសូត្រដោយពេញលេញ ឥតមានខ្វះខាតដោយសិល្បសាស្រ្តណាមួយឡើយ បានចេះប្រាកដក្នុងសិល្បសាស្រ្តខាងការងារស្មូនឆ្នាំងក្នុងសំណាក់ គ្រូអាចារ្យរបស់ខ្លួនមកហើយដែរ បើដូច្នោះ មានតែអញត្រូវជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិតូច១ ឲ្យសុទ្ធដោយដីទាំងអស់។ លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏ជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិតូចដោយដីសុទ្ធទាំងអស់ រួចហើយយកស្មៅ ឧស និងអាចមន៍គោមកដុតកុដិនោះ (ដើម្បីឲ្យឆ្អិន)។ កុដិនោះមានទ្រង់ទ្រាយល្អ គួរចង់មើល គួរឲ្យកើតសេចក្តីជ្រះថ្លា មានពណ៌ក្រហម ដូចជាពណ៌នៃសត្វមេភ្លៀង។ កុដិនោះ (កាលបើមានខ្យល់បក់មកត្រូវ ក៏មានសម្លេងលាន់ឮ) បីដូចជាសម្លេងកណ្តឹង។ គ្រានោះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ កាលយាងចុះពីភ្នំគិជ្ឈកូដជាមួយនឹងភិក្ខុច្រើនរូប ទ្រង់ទតទៅឃើញកុដិនោះ មានទ្រង់ទ្រាយល្អគួរចង់មើល គួរឲ្យកើតសេចក្តីជ្រះថ្លា មានពណ៌ក្រហម លុះទតហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមក ហើយមានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ កុដិនោះមានទ្រង់ទ្រាយល្អ គួរចង់មើល គួរឲ្យកើតសេចក្តីជ្រះថ្លា មានពណ៌ក្រហម ដូចជាពណ៌នៃសត្វមេភ្លៀងឬអ្វី។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគក្នុងគ្រា នោះ។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ (ការងារ) របស់មោឃបុរសនោះជាការងារមិនសមគួរ មិនមានទំនង មិនមានបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ចុះហេតុដូចម្តេចក៏បានជាមោឃបុរសនោះជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិសុទ្ធដោយដីទាំងអស់ (ដូច្នោះ) ម្នាលភិក្ខុទាំងឡាយ សេចក្តីករុណា សេចក្តីអនុគ្រោះ និងសេចក្តីមិនបៀតបៀនដល់ពួកសត្វមានជីវិត ទំនងជាមិនមានដល់មោឃបុរសនោះទេដឹង ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយទៅទំលាយកុដិនោះចេញ កុំឲ្យបណ្តាជនជាខាងក្រោយបៀតបៀនបំផ្លាញដល់បាណជាតិទៀតឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកុដិឲ្យសុទ្ធដោយដីទាំងអស់ទេ បើភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងនោះទទួលពុទ្ធដីកាថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងនេះ រួចហើយ កុដិនោះនៅក្នុងទីណា នាំគ្នាចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏វាយបំបាក់កុដិនោះទៅ។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង សួរភិក្ខុទាំងនោះថា នែលោកទាំងឡាយ ចុះហេតុអ្វីបានជាលោកនាំគ្នាមកវាយបំបាក់កុដិខ្ញុំដូច្នេះ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ឲ្យវាយបំបាក់។ ធនិយភិក្ខុឆ្លើយតបថា អើ លោកដ៏មានអាយុទាំងឡាយ បើព្រះដ៏មានព្រះភាគជាធម្មសាមី ទ្រង់ត្រាស់ឲ្យវាយបំបាក់ និមន្តវាយបំបាក់ចុះ។

[៨០] លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រមានសេចក្តីត្រិះរិះថា កាលដែលអញចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅ និងពួកអ្នករកឧសមករុះកុដិដែលប្រក់ដោយស្មៅ ហើយជញ្ជូនយកស្មៅ និងឈើអស់ទៅ ដរាបអស់វារៈបីដង កុដិដែលអញធ្វើហើយឲ្យសុទ្ធដោយដីទាំងអស់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ប្រើឲ្យភិក្ខុវាយបំបាក់ចេញអស់ មានបុរសអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំង[21] ហ្លួង (១នាក់) អញធ្លាប់ស្គាល់ដែរ បើដូច្នោះមានតែអញត្រូវសុំឈើនឹងអ្នកដែលកាន់កាប់ថែរក្សាឈើក្នុង ឃ្លាំងរបស់ស្តេច ហើយធ្វើកុដិដោយឈើវិញ។ លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏ចូលទៅរកអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេច លុះចូលទៅដល់ហើយ ក៏និយាយនឹងអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចនោះថា ម្នាលអ្នកដ៏មានអាយុ កាលអាត្មាចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅ និងពួកអ្នករកឧសមករុះកុដិដែលប្រក់ដោយស្មៅ ហើយជញ្ជូនយកស្មៅ និងឈើទៅអស់ (តែដូច្នេះឯង) អស់វារៈបីដងហើយ កុដិដែលអាត្មាធ្វើហើយឲ្យសុទ្ធដោយដីទាំងអស់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ប្រើឲ្យភិក្ខុវាយបំបាក់បំបែកចេញអស់ នែអ្នកដ៏មានអាយុ ចូរអ្នកប្រគេនឈើមកអាត្មា ៗចង់ធ្វើកុដិឈើ។ អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចឆ្លើយថា បពិត្រលោកដ៏ចំរើន ឈើដែលខ្ញុំករុណាល្មមគួរសមនឹងប្រគេនលោកម្ចាស់នោះ គ្មានទេ មានតែឈើព្រះរាជទ្រព្យសម្រាប់ជួសជុលព្រះនគរដែលទុកប្រយោជន៍ ការពារអន្តរាយ លោកម្ចាស់បើព្រះរាជាទ្រង់ត្រាស់ឲ្យប្រគេន (មានអ្វី) លោកម្ចាស់ឲ្យគេមកនាំយកទៅចុះ។ ធនិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ស្តេចប្រគេនហើយតើ។ លំដាប់នោះ អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចគិតថា សមណៈទាំងនេះជាសក្យបុត្ត ជាអ្នកប្រព្រឹត្តនូវធម៌ មានសេចក្តីប្រព្រឹត្តស្មើជាប្រក្រតី មានកិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ លោកនិយាយតែពាក្យពិត លោកជាអ្នកមានសីល និងមានធម៌ដ៏ល្អ សូម្បីស្តេចក៏ជ្រះថ្លានឹងសមណៈទាំងនេះពេញទី (បើដូច្នេះ) របស់ដែលគេមិនទាន់ឲ្យ លោកមិនគួរនឹងនិយាយថាគេឲ្យទេ (លុះគិតដូច្នេះហើយ) ក៏និយាយនឹងធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ឲ្យគេមកនាំយកឈើនោះទៅចុះ។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងឲ្យមនុស្សកាត់ឈើនោះជាកំណាត់ តូចកំណាត់ធំ ហើយឲ្យដឹកនាំយកទៅដោយរទេះទាំងឡាយ ហើយបានចាត់ចែងធ្វើកុដិឈើ។

[៨១] គ្រានោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ កាលដើរពិនិត្យត្រួតត្រាមើលការងារក្នុងក្រុងរាជគ្រឹះ ក៏ចូលទៅរកអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេច លុះចូលទៅដល់ហើយ ក៏និយាយនឹងអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចនោះថា នែនាយឈើព្រះរាជទ្រព្យឯណាសម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍ការពារអន្តរាយ ឈើនោះនៅឯណា។ អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់

ស្តេចឆ្លើយថា បពិត្រលោកជាម្ចាស់ ឈើនោះស្តេចបានប្រគេនទៅធនិយភិក្ខុជាម្ចាស់ជាកូនស្មូនឆ្នាំងហើយ។ លំដាប់នោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈមានសេចក្តីតូចចិត្ត (ដោយគិត) ថា ចុះហេតុអ្វីក៏បានជាស្តេចប្រគេនឈើព្រះរាជទ្រព្យសម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍ការពារអន្តរាយទៅធនិយភិក្ខុជាកូនស្មូនឆ្នាំងវិញ។ គ្រានោះ វស្សការព្រាហ្មណ៍ជាមហាមាត្យ ក្នុងដែនមគធៈ ចូលទៅក្នុងទីដែលព្រះបាទពិម្ពិសារមាគធសេនិយរាជគង់នៅ លុះចូលទៅដល់ហើយ ក៏ក្រាបទូលថា បានឮថា ឈើព្រះរាជទ្រព្យសម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍ការពារអន្តរាយ ព្រះអង្គទ្រង់ប្រគេនទៅធនិយភិក្ខុមែនឬ។ ព្រះបាទពិម្ពិសារសួរថា អ្នកណានិយាយយ៉ាងនេះ។ មហាមាត្យឆ្លើយថា បពិត្រព្រះសម្មតិទេព អ្នកកាន់កាប់ថែរក្សាឈើ។ ព្រះបាទពិម្ពិសារទ្រង់មានព្រះបន្ទូលថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកឯងឲ្យមនុស្សទៅនាំអ្នកកាន់កាប់ថែរក្សាឈើមកមើល។ លំដាប់នោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ក៏ឲ្យមនុស្សទៅចាប់ចងអ្នកកាន់កាប់ថែរក្សាឈើហើយនាំមក។

[៨២] ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង បានឃើញអ្នកកាន់កាប់ថែរក្សាឈើ ដែលជាប់ក្តី ហើយគេកំពុងបណ្តើរទៅ លុះឃើញហើយ ក៏សួរអ្នកកាន់កាប់ថែរក្សាឈើនោះថា ចុះហេតុអ្វីអាវុសោ បានជាអ្នកត្រូវគេចងបណ្តើរទៅដូច្នេះ។ អ្នកកាន់កាប់ថែរក្សាឈើឆ្លើយថា បពិត្រលោកដ៏ចំរើន ព្រោះរឿងឈើនោះ។ ធនិយភិក្ខុឆ្លើយថា អាវុសោ អ្នកទៅចុះ អាត្មានឹងទៅដែរ។ អ្នកកាន់កាប់ថែរក្សាឈើឆ្លើយថា លោកម្ចាស់គួរមក ខ្ញុំព្រះករុណាលំបាកមុនហើយ។ លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រ ក៏ចូលទៅកាន់ព្រះរាជដំណាក់នៃព្រះបាទពិម្ពិសារមាគធសេនិយរាជ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេបានក្រាលប្រគេន។ វេលានោះ ព្រះបាទពិម្ពិសារមាគធសេនិយរាជ ក៏ចូលទៅត្រង់កន្លែងដែលធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំចំពោះធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រ ហើយគង់នៅក្នុងទីដ៏សមគួរ។ លុះព្រះបាទពិម្ពិសារមាគធសេនិយរាជ គង់ក្នុងទីដ៏សមគួរហើយ ទើបទ្រង់មានព្រះបន្ទូលសួរធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងថា បពិត្រលោកដ៏ចំរើន បានឮថា ឈើព្រះរាជទ្រព្យសម្រាប់ជួសជុលព្រះនគរ ដែលទុកបម្រុងការពារអន្តរាយ ខ្ញុំបានប្រគេនលោកពិតមែនឬ។ ធនិយភិក្ខុឆ្លើយថា ថ្វាយព្រះពរមហារាជ ពិតមែន។ ព្រះបាទពិម្ពិសារទ្រង់មានព្រះបន្ទូលថា បពិត្រលោកដ៏ចំរើន ធម្មតាយើងជាស្តេចមានកិច្ចច្រើន ការងារដែលត្រូវធ្វើក៏មានច្រើន បើទុកជាយើងឲ្យមែន ក៏នឹកមិនឃើញដែរ ហេតុនេះសូមលោករំលឹកខ្ញុំផង។ ធនិយភិក្ខុឆ្លើយថា ថ្វាយព្រះពរមហារាជ សូមព្រះអង្គទ្រង់រំពឹងទៅមើល កាលដែលទ្រង់ទើបបានរាជាភិសេកនោះ ទ្រង់មានព្រះបន្ទូល មានសភាពយ៉ាងនេះថា ស្មៅ ឈើ និងទឹក ខ្ញុំបានឲ្យហើយ ដល់សមណៈ និងព្រាហ្មណ៍ទាំងឡាយ ៗចូរប្រើប្រាស់ (នូវស្មៅឈើ និងទឹកនោះចុះ)។ ព្រះបាទពិម្ពិសារមានព្រះបន្ទូលថា បពិត្រលោកដ៏ចំរើន ខ្ញុំនឹកឃើញហើយ (ប៉ុន្តែថា) សមណៈ និងព្រាហ្មណ៍ទាំងឡាយដែលមានសេចក្តីអៀនខ្មាស សេចក្តីសង្ស័យ និងមានសេចក្តីប្រាថ្នាក្នុងសិក្ខា សមណៈ និងព្រាហ្មណ៍ទាំងនោះ រមែងកើតមានសេចក្តីសង្ស័យក្នុងហេតុនីមួយសូម្បីតែបន្តិចបន្តួច ស្មៅ ឈើ និងទឹក ដែលខ្ញុំនិយាយថាឲ្យនោះ គឺឲ្យចំពោះសមណៈ និងព្រាហ្មណ៍ទាំងនោះ ព្រោះថា ស្មៅ ឈើ និងទឹកនោះឯង ដែលមានក្នុងព្រៃតមានអ្នកណាហួងហែងឡើយ បពិត្រលោកដ៏ចំរើន លោកសំគាល់អាងដោយហេតុបន្តិចបន្តួចនោះ ដើម្បីនាំយកឈើដែលគេមិនបានឲ្យយ៉ាងនេះ មនុស្សទាំងឡាយប្រហែលដូចខ្ញុំនឹងសម្លាប់ ឬចង ឬបំបរបង់ នូវសមណៈ ឬព្រាហ្មណ៍ ដូចម្តេចកើត បពិត្រលោកដ៏ចំរើន សូមលោកនិមន្តទៅចុះ លោករួច (ទោស) ហើយដោយសាររោម (គឺភេទនៃបព្វជិត) លោកកុំធ្វើយ៉ាងនេះទៀតឡើយ។

[៨៣] មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈជាសក្យបុត្តទាំងនេះគ្មានសេចក្តីអៀនខ្មាស ជាអ្នកទ្រុស្តសីល និយាយកុហក គួរណាស់តែសមណៈទាំងនេះប្រព្រឹត្តនូវធម៌ មានសេចក្តីប្រព្រឹត្តស្មើជាប្រក្រតី និងប្រព្រឹត្តនូវធម៌ដ៏ប្រសើរ និយាយទៀងត្រង់ មានសីល និងមានធម៌ល្អ ទើបនឹងប្តេជ្ញា (ខ្លួនជាសមណៈបាន) ភាវៈនៃសមណៈរបស់លោកទាំងនេះគ្មានទេ ភាវៈនៃធម៌ដ៏ប្រសើររបស់លោកទាំងនេះគ្មានទេ សាមញ្ញគុណរបស់លោកទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់លោកទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់លោកទាំងនេះនឹងមានមកអំពីឯណា ព្រហ្មញ្ញគុណរបស់លោកទាំងនេះនឹងមានមកអំពីឯណា លោកទាំងនេះប្រាសហើយចាកសាមញ្ញគុណ លោកទាំងនេះប្រាសហើយចាកព្រហ្មញ្ញគុណ សមណៈទាំងនេះហ៊ានបញ្ឆោតដល់ស្តេចផែនដី ចំណង់បើមនុស្សឯទៀតយ៉ាងណាទៅអេះ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នេះហើយ។ ពួកភិក្ខុឯណាមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស អ្នកអៀនខ្មាស មានសេចក្តីរង្កៀស មានប្រាថ្នាក្នុងសិក្ខា ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វីបានជាធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ទៅយករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ស្តេច (ដូច្នោះ)។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងក្នុងវេលានោះថា ធនិយភិក្ខុ ឮថា អ្នកឯងបានយករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ព្រះរាជា មែនឬ។ ធនិយភិក្ខុឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលធនិយភិក្ខុថា នែមោឃបុរស កម្មនេះជាកម្មមិនសមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែមោឃបុរស ហេតុអ្វីក៏បានជាអ្នកឯងទៅយករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ព្រះរាជា (ដូច្នោះ) នែមោឃបុរស អំពើនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ ជ្រះថ្លា និងមិនមែននាំឲ្យរឹងរិតតែជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាស្រាប់ នោះទេ នែមោឃបុរស អំពើនេះប្រាកដជានាំបណ្តាលមនុស្សពួកខ្លះ ដែលមិនទាន់ជ្រះថ្លាឲ្យខាតខានមានសេចក្តីជ្រះថ្លា និងនាំបណ្តាលមនុស្សពួកខ្លះដែលជ្រះថ្លាហើយ ឲ្យបាត់ជ្រះថ្លាទៅវិញ។ សម័យនោះ មានមហាមាត្យម្នាក់ ពីដើមធ្លាប់ធ្វើជាចៅក្រមចាស់ បានបួសក្នុងសំណាក់ពួកភិក្ខុ (ភិក្ខុនោះឯង) បានទៅអង្គុយជិតព្រះដ៏មានព្រះភាគ។ វេលានោះ ព្រះអង្គទ្រង់មានព្រះបន្ទូលសួរភិក្ខុនោះថា ម្នាលភិក្ខុ ព្រះបាទពិម្ពិសារមាគធសេនិយរាជចាប់ចោរបានហើយ សម្លាប់ក្តី ឃុំខាំងក្តី និរទេសក្តី ដោយរបស់មានដម្លៃចំនួនប៉ុន្មាន។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដោយរបស់មានដម្លៃចំនួន១បាទ ឬគួរដល់១បាទ ឬច្រើនជាង១បាទ។ សម័យនោះឯង ក្នុងក្រុងរាជគ្រឹះ គេចាយប្រាក់៥មាសកជា១បាទ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ដោយអនេកបរិយាយ ហើយទ្រង់សំដែងនូវទោសនៃការដែលគេពិបាកចិញ្ចឹម។ បេ។ ហើយទ្រង់ត្រាស់សរសើរគុណនៃការប្រារព្ធព្យាយាម រួចទ្រង់សំដែងនូវធម្មីកថា ដ៏សមគួរដល់សិក្ខាបទនោះ ឲ្យមានទំនងតាមសិក្ខាបទនោះចំពោះភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំ។ បេ។ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះដូច្នេះថា

**ភិក្ខុណាមួយកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចំណែកនៃចិត្តលួច ស្ដេចទាំងឡាយចាប់បានចោរហើយ ត្រូវសម្លាប់ក្ដី ឃុំខាំងក្ដី និរទេសក្ដី ដោយពាក្យថា អាឯងជាចោរ ជាមនុស្សពាលវង្វេង ជាមនុស្សលួចព្រោះអទិន្នាទាន មានសភាពយ៉ាងណា ភិក្ខុកាលដែលកាន់យកទ្រព្យដែលគេមិនបានឲ្យមានសភាពដូច្នោះ ភិក្ខុនេះក្ដី ក៏ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន (គឺឥតមានកិរិយានៅរួបរួមគ្នាបាន)។**

សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយ យ៉ាងនេះ។

[៨៤] សម័យនោះ ឆព្វគ្គិយភិក្ខុទាំងឡាយ នាំគ្នាទៅកាន់កំពង់របស់ជាងជ្រលក់ ហើយលួចយកបង្វិចសំពត់របស់ជាងជ្រលក់ មកកាន់អារាម ហើយចែកគ្នា។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា ម្នាលអាវុសោ លោកទាំងឡាយជាអ្នកមានបុណ្យច្រើន ចីវរកើតឡើងដល់លោកច្រើន។ ឆព្វគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ បុណ្យរបស់យើងមានមកពីណា អម្បាញ់មិញយើងទៅឯកំពង់របស់ជាងជ្រលក់ ហើយយើងបានលួចយកបង្វិចសំពត់របស់ជាងជ្រលក់មកទេតើ។ ភិក្ខុទាំងឡាយនិយាយថា អាវុសោ សិក្ខាបទ ព្រះបរមគ្រូទ្រង់បញ្ញត្តរួចហើយតើ ចុះហេតុអ្វីបានជាលោកនាំគ្នាទៅលួចបង្វិចសំពត់របស់ជាងជ្រលក់មក។ ឆព្វគ្គិយភិក្ខុឆ្លើយតបថា ម្នាលអាវុសោ សិក្ខាបទ ព្រះបរមគ្រូជាម្ចាស់ទ្រង់បញ្ញត្តរួចហើយក៏ពិតមែន តែថាសិក្ខាបទនោះ ទ្រង់បញ្ញត្តចំពោះតែក្នុងស្រុក ត្រង់ក្នុងព្រៃទ្រង់មិនបញ្ញត្តទេ។ ភិក្ខុទាំងនោះនិយាយថា អាវុសោ សិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តហើយក្នុងស្រុកនោះក៏ប្រាកដ ដូចជាក្នុងព្រៃដូច្នោះដែរ មិនមែនឬអ្វី នែអាវុសោ អំពើដែលលោកធ្វើនេះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែអាវុសោទាំងឡាយ ចុះហេតុដូចម្ដេច ក៏បានជាលោកនាំគ្នាទៅលួចបង្វិចសំពត់របស់ជាងជ្រលក់មក ម្នាលអាវុសោ កម្មនេះមិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ ជ្រះថ្លា និងមិនមែននាំឲ្យរឹងរិតតែកើតសេចក្ដីជ្រះថ្លាដល់ជនទាំងឡាយដែលមាន សេចក្ដីជ្រះថ្លាហើយនោះទេ ម្នាលអាវុសោ កម្មនេះប្រាកដជានាំបណ្ដាលឲ្យមនុស្សពួកខ្លះដែលមិនទាន់ជ្រះថ្លា ឲ្យខានបានកើតសេចក្ដីជ្រះថ្លា និងនាំបណ្ដាលមនុស្សពួកខ្លះដែលជ្រះថ្លាហើយ ឲ្យត្រឡប់ជារាយមាយរសាយបាត់សេចក្ដីជ្រះថ្លាទៅវិញ។ គ្រានោះ ភិក្ខុទាំងឡាយនោះក៏តិះដៀលឆព្វគ្គិយភិក្ខុ ដោយអនេកបរិយាយ ហើយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះឆព្វគ្គិយភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកឯងនាំគ្នាទៅកាន់កន្លែងដែលជាងជ្រលក់គេលាត្រដាងសំពត់ ហើយបានលួចបង្វិចសំពត់របស់ជាងជ្រលក់មែនឬ។ ឆព្វគ្គិយភិក្ខុឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលឆព្វគ្គិយភិក្ខុថា នែមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែមោឃបុរសទាំងឡាយ ចុះហេតុអ្វីបានជាអ្នកនាំគ្នាទៅលួចបង្វិចសំពត់របស់ជាងជ្រលក់ នែមោឃបុរស អំពើនេះមិនមែននាំឲ្យកើតជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លានោះ ទេ។ បេ។ នឹងនាំបណ្ដាលឲ្យជនពួកខ្លះដែលជ្រះថ្លាហើយ ត្រឡប់ជារាយមាយរសាយបាត់សេចក្ដីជ្រះថ្លាទៅវិញ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលឆព្វគ្គិយភិក្ខុដោយព្រះពុទ្ធដីកាជាអនេក បរិយាយ ហើយទ្រង់សំដែងទោសនៃការដែលគេពិបាកចិញ្ចឹម។ បេ។ ទើបទ្រង់ត្រាស់សរសើរគុណនៃការប្រារព្ធនូវព្យាយាម រួចហើយទ្រង់សំដែងនូវធម្មីកថាដ៏សមគួរដល់សិក្ខាបទនោះៗ ឲ្យមានទំនងតាមសិក្ខាបទនោះៗ ចំពោះភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំ។ បេ។ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះថា

**ភិក្ខុណាមួយកាន់យកទ្រព្យដែលគេមិនបានឲ្យដោយចំណែកនៃចិត្តលួច អំពីស្រុកក្ដី ព្រៃក្ដី ស្ដេចទាំងឡាយចាប់បានចោរហើយត្រូវសម្លាប់ក្ដី ឃុំខាំងក្ដី និរទេសក្ដី ដោយពាក្យថា ឯងជាចោរ ជាមនុស្សពាលវង្វេង ជាមនុស្សលួច ព្រោះអទិន្នាទាន មានសភាពយ៉ាងណា ភិក្ខុកាលដែលកាន់យកទ្រព្យដែលគេមិនបានឲ្យ មានសភាពយ៉ាងនោះ ភិក្ខុនេះក្ដី ក៏ត្រូវអាបត្តិបារាជិករកសំវាសគ្មាន (គឺឥតមានកិរិយានៅរួបរួមគ្នាបាន)។**

[៨៥] ត្រង់ពាក្យថា ណាមួយ សេចក្ដីថា ឯណា ប្រាកដដូចជាឯណា។ បេ។ ភិក្ខុនេះ តថាគតហៅថា ណាមួយ។ ត្រង់ពាក្យថា ភិក្ខុ។ បេ។ សេចក្ដីថា ភិក្ខុនេះតថាគតអធិប្បាយក្នុងសេចក្ដីនេះ។ ដែលឈ្មោះថា ស្រុក(នោះ) គឺស្រុកដែលមានខ្ទមមួយក្ដី ស្រុកដែលមានខ្ទមពីរក្ដី ស្រុកដែលមានខ្ទមបីក្ដី ស្រុកដែលមានខ្ទមបួនក្ដី ស្រុកដែលមានមនុស្សក្ដី ស្រុកដែលឥតមនុស្សក្ដី ស្រុកដែលមានរបងឬកំផែងក្ដី ស្រុកដែលឥតរបងឬកំផែងក្ដី ស្រុកដែលគេទើបតាំងនៅថ្មី (មានផ្ទះពីរបី) ដូចជាគោឈរក្ដី ពុំនោះសោត ប្រទេសណាដែលមានពួកឈ្មួញបានអាស្រ័យនៅលើសជាង៤ខែឡើងទៅ ប្រទេសនោះក៏លោកហៅថាស្រុក។ ដែលឈ្មោះថាឧបចារនៃស្រុក (នោះ) គឺទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈិមបុរសឈរប្របធរណីទ្វារស្រុកដែល មានរបង ឬកំផែង ចោលទៅ (ឬ) ទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈិមបុរសឈរប្របឧបចារផ្ទះនៃស្រុកដែលឥតរបង ឬកំផែង ចោលទៅ។ ដែលឈ្មោះថាព្រៃ (នោះ) គឺទីដ៏សេស លើកលែងតែស្រុក និងឧបចារនៃស្រុកចេញ ឈ្មោះថាព្រៃ។ ដែលឈ្មោះថា ទ្រព្យដែលគេមិនបានឲ្យ (នោះ) គឺរបស់ណាដែលគេមិនទាន់ឲ្យ មិនទាន់លះបង់ឲ្យ មិនទាន់ដាច់ចិត្តឲ្យ គេរក្សាទុក គេគ្រប់គ្រងទុក គេនៅប្រកាន់ គេនៅហួងហែង ទ្រព្យនោះឈ្មោះថា ទ្រព្យដែលគេមិនបានឲ្យ។ ត្រង់បទថា ដោយចំណែកនៃចិត្តលួច សេចក្ដីថា ភិក្ខុមានចិត្តជាអ្នកលួច គឺថា ភិក្ខុមានចិត្តបម្រុងនឹងលួច។

[៨៦] ត្រង់បទថា គប្បីកាន់យក សេចក្ដីថា ភិក្ខុគប្បីចាប់យក គប្បីនាំទៅ គប្បីលួចយក គប្បីឲ្យកំរើកឥរិយាបថ គប្បីឲ្យឃ្លាតចាកទី គប្បីឈានកន្លងនូវទីដែលកំណត់។

[៨៧] ដែលឈ្មោះថា មានសភាពយ៉ាងណា (នោះ) គឺទ្រព្យចំនួនមួយបាទ ឬទ្រព្យគួរដល់ថ្លៃមួយបាទ ឬថា ក្រៃលែងជាងមួយបាទឡើងទៅ។ ដែលឈ្មោះថា ស្ដេចទាំងឡាយ (នោះ) គឺស្ដេចជាធំលើប្រថពីទាំងអស់ ស្ដេចជាធំក្នុងប្រទេស ពួកអ្នកត្រួតមណ្ឌល (ចៅហ្វាយខេត្ត) ពួកអ្នកបរិភោគស្រុកជាលំដាប់ (ចៅហ្វាយស្រុក) ពួកអ្នកកាត់ក្ដី ពួកមហាមាត្យ ពុំនោះសោត ពួកឥស្សរជនណាជាអ្នកត្រួតត្រាក្នុងការកាប់សម្លាប់

ពួកឥស្សរជនទាំងនោះ ឈ្មោះថាស្តេច។ ដែលឈ្មោះថា ចោរ(នោះ) គឺអ្នកណាដែលកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ មានដម្លៃប្រមាណ ៥មាសក ឬច្រើនជាង៥មាសកឡើងទៅ ដោយចំណែកនៃចិត្តលួច អ្នកនោះឈ្មោះថា ចោរ។ ត្រង់ពាក្យថា គប្បីសម្លាប់ក្តី សេចក្តីថា គប្បីសម្លាប់ ដោយដៃក្តី ដោយជើងក្តី ដោយរំពាត់ខ្សែតីក្តី ដោយផ្តៅក្តី ដោយដម្បងវែងក្តី ដោយកាប់កាត់ក្តី។ ត្រង់ពាក្យថា គប្បីចងក្តី សេចក្តីថា គប្បីចង ដោយចំណងគឺខ្សែក្តី ដោយចំណងគឺខ្នោះក្តី ដោយចំណងគឺច្រវាក់ក្តី ដោយបង្ខាំទុកក្នុងផ្ទះក្តី ដោយបង្ខាំទុកក្នុងក្រុងក្តី ដោយបង្ខាំទុកក្នុងស្រុកក្តី ដោយបង្ខាំទុកក្នុងនិគមក្តី ឬគប្បីធ្វើនូវការឃុំខាំងដោយបុរស។ ត្រង់ពាក្យថា គប្បីបំបរបង់ក្តី ឬថាគប្បីនិរទេសក្តី សេចក្តីថា គប្បីបំបរបង់ចាក ស្រុកក្តី ចាកនិគមក្តី ចាកក្រុងក្តី ចាកជនបទក្តី ចាកប្រទេសក្នុងជនបទក្តី។ ត្រង់ពាក្យ៤ម៉ាត់ថា អ្នកឯងជាចោរ អ្នកឯងជាពាល អ្នកឯងជាបុគ្គល វង្វេង អ្នកឯងជាអ្នកលួចនេះ ជាពាក្យជេរប្រទេច។

[៨៨] ដែលឈ្មោះថា មានសភាពដូច្នោះ (នោះ) គឺទ្រព្យចំនួនមួយបាទ ឬទ្រព្យគួរដល់ដម្លៃមួយបាទ ឬថា ក្រៃលែងជាងមួយបាទឡើងទៅ។ ត្រង់ពាក្យថា កាលកាន់យក សេចក្តីថា កាលចាប់យក កាលនាំទៅ កាលលួច កាលឲ្យកំរើកឥរិយាបថ កាលឲ្យឃ្លាតចាកទី កាលឲ្យកន្លងហួសទី ដែលកំណត់។

[៨៩] ត្រង់បទថា ភិក្ខុនេះដែរ គឺពោលប្រៀបធៀបនឹងភិក្ខុដែលមានក្នុងសិក្ខាបទមុន។ ត្រង់ពាក្យថា ជាបារាជិក អធិប្បាយជាសេចក្តី ឧបមាថា ធម្មតាស្លឹកឈើទុំដែលជ្រុះចាកទងហើយ មិនអាចត្រឡប់ទៅជាមានពណ៌ខៀវវិញបាន ដូចម្តេចមិញ ភិក្ខុកាន់យកទ្រព្យដែលគេមិន បានឲ្យចំនួន១បាទ ឬគួរដល់ដម្លៃ១បាទ ឬថាក្រៃលែងជាង១បាទឡើងទៅ ដោយចំណែកនៃចិត្តលួច ក៏មិនមែនជាសមណៈ មិនមែនជាពូជពង្ស របស់ព្រះពុទ្ធជាសក្យបុត្រ ដូច្នោះដែរ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះជាបារាជិក។ ត្រង់បទថា រកសំវាសគ្មាន (នោះ) សេចក្តីថា សង្ឃកម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា ការសិក្សាស្មើគ្នា នេះឈ្មោះថា សំវាស សំវាសនោះមិនមានជាមួយនឹងភិក្ខុដែលត្រូវបារាជិកនោះឡើយ ព្រោះហេតុនោះ បានជាតថាគតហៅថា រកសំវាសគ្មាន។

[៩០] (មាតិកាវាយឈ្មោះទ្រព្យ) ទ្រព្យដែលស្ថិតនៅក្នុងដី ស្ថិតនៅលើគោក ស្ថិតនៅឰដ៏អាកាស ស្ថិតនៅលើផ្ទើរ ស្ថិតនៅក្នុងទឹក ស្ថិតនៅ ក្នុងទូក ស្ថិតនៅលើយាន ស្ថិតនៅលើភារៈ ស្ថិតនៅក្នុងច្បារ ស្ថិតនៅក្នុងវត្ត ស្ថិតនៅក្នុងស្រែ ស្ថិតនៅក្នុងទីដី ស្ថិតនៅក្នុងស្រុក ស្ថិតនៅក្នុងព្រៃ ទឹក ឈើស្ងួន់ ដើមឈើ របស់ដែលគេកំពុងនាំទៅ របស់ដែលគេផ្ញើ ទីដែលហូតពន្ធ (គយ) សត្វមានជីវិត គឺមនុស្ស សត្វគ្មានជើង សត្វជើងពីរ សត្វជើងបួន សត្វជើងច្រើន អ្នកកំណត់របស់ដើម្បីឲ្យគេលួច អ្នករក្សារបស់ផ្ញើរទុកមួយរំពេច កិរិយាលួចយកដោយបបួលគ្នា សង្កេតកម្ម និមិត្តកម្ម។

[៩១] ដែលឈ្មោះថា ទ្រព្យស្ថិតនៅក្នុងដី (នោះ) គឺទ្រព្យដែលគេកប់លាក់ទុកក្នុងដី។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចនូវទ្រព្យដែលស្ថិត នៅក្នុងដី ហើយស្វែងរកគ្នាឲ្យបានពីរនាក់ក្តី ស្វែងរកចបក្តី កញ្ជើក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុកាត់នូវឈើ ឬវល្លិដែលកើតក្នុងទីនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុជីក ឬកកាយ ឬគាស់នូវអាចមន៍ដី ត្រូវអាបត្តិទុក្កដ។ ភិក្ខុចាប់ពាល់នូវឆ្នាំង ត្រូវអាបត្តិទុក្កដ។ ឲ្យកំរើកត្រូវ អាបត្តិថុល្លច្ច័យ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត បញ្ចូលនូវភាជនៈរបស់ខ្លួនទៅ ហើយចាប់ពាល់នូវវត្ថុមានដំឡៃ ប្រមាណ៥មាសកៈ ឬក្រៃលែងជាង៥មាសកៈឡើងទៅ ត្រូវអាបត្តិទុក្កដ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យឲ្យចូលទៅក្នុងភាជនរបស់ខ្លួនក្តី កាត់ដាច់នូវក្តាប់ដៃក្តី ត្រូវអាបត្តបារាជិក។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់នូវភណ្ឌដែលគេដោតក្រងដោយខ្សែ គឺសង្វារក្តី ខ្សែកក្តី ខ្សែចង្កេះក្តី សម្ពត់សាដកក្តី ឈ្នួតក្តី ត្រូវអាបត្តិទុក្កដ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ចាប់ត្រង់ទីបំផុត ហើយលើកឡើង ត្រូវអាបត្តិថុល្លច្ច័យ។ កាលបើប៉ះ ទង្គក រួចនាំយកចេញ ត្រូវអាបត្តិថុល្លច្ច័យ។ ដោយហោចទៅសូម្បីតែឲ្យផុតអំពីមាត់ឆ្នាំង ប្រមាណប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក។ ភិក្ខុមាន ថេយ្យចិត្ត ផឹកនូវសប្បិក្តី ប្រេងក្តី ទឹកឃ្មុំក្តី ទឹកអំពៅក្តី ជារបស់មានដំឡៃប្រមាណ៥មាសកៈ ឬក្រៃលែងជាង៥មាសកៈឡើងទៅ ដោយប្រយោគ តែមួយ ត្រូវអាបត្តិបារាជិក។ ភិក្ខុទំលាយក្តី ចាក់ចោលក្តី ដុតចោលក្តី ធ្វើ (នូវវត្ថុមានសប្បិជាដើមនោះ) ឲ្យជារបស់ប្រើប្រាស់មិនកើតក្តី ក្នុង ទីនោះឯង ត្រូវអាបត្តិទុក្កដ។

[៩២] ដែលឈ្មោះថា ទ្រព្យស្ថិតនៅលើគោក (នោះ) គឺទ្រព្យដែលគេដម្កល់ទុកលើទីគោក។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចទ្រព្យដែល ស្ថិតនៅលើទីគោក ហើយស្វែងរកគ្នាឲ្យបានពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។

[៩៣] ដែលឈ្មោះថា ទ្រព្យស្ថិតនៅឰដ៏អាកាស (នោះ) គឺភណ្ឌដែលទៅឰដ៏អាកាស ទោះសត្វក្ងោកក្តី ចចាតក្តី ទទាក្តី ចាបក្តី ឬជាសម្ពត់ សាដកក្តី ឈ្នួតក្តី ប្រាក់ក្តី មាសក្តី ដែលដាច់ធ្លាក់ចុះ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចនូវភណ្ឌ ដែលស្ថិតនៅឰដ៏អាកាស ហើយស្វែងរកគ្នាឲ្យ បានជាពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ។ ផ្តាច់បង់នូវដំណើរ ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ។ ឲ្យកំរើក ត្រូវ អាបត្តិថុល្លច្ច័យ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។

[៩៤] ដែលឈ្មោះថា ទ្រព្យស្ថិតនៅលើផ្ទើរ (នោះ) គឺភណ្ឌដែលដម្កល់នៅលើផ្ទើរ (អធិប្បាយថា) ទ្រព្យដែលគេដម្កល់ទុកលើគ្រែក្តី លើតាំងក្តី ឬទ្រព្យដែលគេពាក់លើឈើស្នៀងសម្រាប់ពាក់ចីវរក្តី លើខ្សែសម្រាប់ពាក់ចីវរក្តី លើចម្រឹងជញ្ជាំងក្តី លើដៃកែវក្តី ដែលគេព្យួរទុកលើដើមឈើក្តី ដោយហោចទៅ ទ្រព្យដែលគេដម្កល់ទុកលើជើងបាត្រក៏ដោយ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចយកភណ្ឌដែលស្ថិតនៅលើផ្ទើរ ហើយ ស្វែងរកគ្នាឲ្យបានជាពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យឃ្លាតចាកទី ត្រូវ អាបត្តិបារាជិក។

[៩៥] ដែលឈ្មោះថា ទ្រព្យស្ថិតនៅក្នុងទឹក (នោះ) គឺភណ្ឌដែលគេដម្កល់ទុកក្នុងទឹក។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចយកភណ្ឌដែល ស្ថិតនៅក្នុងទឹក ហើយស្វែងរកគ្នាឲ្យបានជាពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ។ មុជចុះក្តី ងើបឡើងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ ត្រូវ អាបត្តិទុក្កដ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់ផ្កាឧប្បលក្តី ផ្កាឈូកក្រហមក្តី

ផ្កាឈូកសក្តី ក្រអៅឈូកក្តី ត្រីក្តី អណ្តើកក្តី ដែលកើតក្នុងទឹកនោះ មានដំឡៃ៥មាសកក្តី លើសពី៥មាសកក្តី ត្រូវអាបត្តិទុក្កដ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។

[៩៦] គេឆ្លង (នូវទីមានទឹក មានស្ទឹងនិងទន្លេជាដើម) ដោយរបស់អ្វី របស់នោះឈ្មោះថាទូក។[22] ទ្រព្យដែលគេដាក់ទុកនៅក្នុងទូក ឬលើទូក ឈ្មោះថាទ្រព្យស្ថិតនៅក្នុងទូក។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចយកទ្រព្យដែលស្ថិតនៅក្នុងទូក ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់(ទ្រព្យនោះ) ត្រូវអាបត្តិទុក្កដ។ (ធ្វើទ្រព្យនោះ)ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ (ធ្វើទ្រព្យនោះ) ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចយកទូក ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ (ទូកនោះ) ត្រូវអាបត្តិទុក្កដ។ ធ្វើទូកនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ស្រាយចំណង ត្រូវអាបត្តិទុក្កដ។ ស្រាយចំណងរួចហើយ ចាប់ត្រូវ(ទូក) ត្រូវអាបត្តិទុក្កដ។ (ធ្វើទូក)ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ (ធ្វើទូក) ឲ្យអណ្តែតច្រាសទឹកក្តី បណ្តោយទឹកក្តី ទទឹងទឹកក្តី ដោយហោចទៅ សូម្បីធ្វើឲ្យឃ្លាតចាកទីប៉ុនចម្រៀកសក់ ត្រូវអាបត្តិបារាជិក។

[៩៧] អង្រឹងស្នែង រថ រទេះ រថទ្រង់គ្រឿង ឈ្មោះថាយាន។ ទ្រព្យដែលដាក់ក្នុងយាន ឬលើយាន ឈ្មោះថា ទ្រព្យស្ថិតនៅលើយាន។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលស្ថិតនៅលើយាន ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចយកយាន ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់យាននោះ ត្រូវអាបត្តិទុក្កដ។ ធ្វើយាននោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើយាននោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។

[៩៨] ទ្រព្យដែលនៅលើក្បាល (ទ្រនូល) នៅលើ ក (ទ្រព្យដែលរែក ឬលី) នៅលើចង្កេះ (កណ្តៀត) និងទ្រព្យដែលយួរនឹងដៃ ឈ្មោះថាភារៈ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ភារៈដែលនៅលើក្បាល ត្រូវអាបត្តិទុក្កដ។ ធ្វើភារៈនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ដាក់ភារៈនោះចុះមកដល់ត្រឹម-ក ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់ភារៈដែលនៅលើ ក ត្រូវអាបត្តិទុក្កដ។ ធ្វើភារៈនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ដាក់ចុះមកដល់ត្រឹមចង្កេះ ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ភារៈដែលនៅលើចង្កេះ ត្រូវអាបត្តិទុក្កដ។ ធ្វើភារៈនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ដាក់ចុះមកកាន់ជាប់នឹងដៃ ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត ដាក់ចុះនូវភារៈដែលនៅក្នុងដៃមកលើផែនដី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្តកាន់យកទ្រព្យអំពីផែនដីទៅ ត្រូវអាបត្តិបារាជិក។

[៩៩] សួនផ្កាឈើ សួនផ្លែឈើ ឈ្មោះថាអារាម (សួនច្បារ) ទ្រព្យដែលបុគ្គលដំកល់ទុកក្នុងសួនច្បារមាន៤កន្លែង គឺក្នុងដី១ លើគោក១ ឯអាកាស១ លើផ្ទៃ១ ឈ្មោះថា ទ្រព្យស្ថិតនៅក្នុងសួនច្បារ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យនៅក្នុងសួនច្បារ ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់ឫសឈើក្តី សម្បកឈើក្តី ស្លឹកឈើក្តី ផ្កាឈើក្តី ផ្លែឈើក្តី ដែលដុះក្នុងសួនច្បារនោះ ទោះមានដម្លៃប្រមាណ៥មាសកក្តី លើពី៥មាសកទៅក្តី ត្រូវអាបត្តិទុក្កដ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុចោទប្រកាន់យកសួនច្បារ ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យម្ចាស់សួនច្បារសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ។ បើម្ចាស់សួនច្បារដាក់ធុរៈថា សួនច្បារមុខជានឹងមិនបានមកអញវិញទេ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ (គឺកាលដែលជំនុំជំរះក្នុងជំនុំសង្ឃ ឬក្នុងរាជត្រកូល ហើយសូកពួកអ្នកវិនិច្ឆ័យឲ្យយកសាក្សីកោង ធ្វើម្ចាស់សួនច្បារឲ្យចាញ់) ត្រូវអាបត្តិបារាជិក។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ (គឺ បើពួកអ្នកវិនិច្ឆ័យកាត់សេចក្តីនោះតាមធម៌វិន័យជាសត្ថុសាសនា ហើយត្រឡប់ចាញ់លើខ្លួនឯងវិញ) ត្រូវអាបត្តិថុល្លច្ច័យ។

[១០០] ទ្រព្យដែលបុគ្គលដំកល់ទុកក្នុងវិហារ (វត្ត) មាន៤កន្លែង គឺ ក្នុងដី១ លើគោក១ ឯអាកាស១ លើផ្ទៃ១ ឈ្មោះថា ទ្រព្យនៅក្នុងវត្ត។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលឋិតនៅក្នុងវត្ត ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុចោទប្រកាន់យកវត្ត ត្រូវអាបត្តិទុក្កដ។ ធ្វើម្ចាស់វត្តឲ្យកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ។ បើម្ចាស់វត្តដាក់ធុរៈថា វត្តមុខជាមិនបានមកអញវិញទេ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ (គឺកាលដែលជំនុំជំរះក្នុងជំនុំសង្ឃ ឬរាជត្រកូល ភិក្ខុបានសូកដល់ពួកអ្នកវិនិច្ឆ័យឲ្យកាត់សេចក្តីដោយមិនយុត្តិធម៌) ត្រូវអាបត្តិបារាជិក។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់វិញ (គឺពួកអ្នកវិនិច្ឆ័យកាត់ក្តីដោយយុត្តិធម៌ថា ឲ្យភិក្ខុចាញ់វិញ) ត្រូវអាបត្តិថុល្លច្ច័យ។

[១០១] ស្រូវទាំងឡាយ៧យ៉ាង មានស្រូវសាលីជាដើមក្តី ផ្លែឈើទាំងឡាយ មានសណ្តែករាជមាសជាដើមក្តី ដុះក្នុងទីណា ទីនោះឈ្មោះថាខេត្ត (ស្រែ)។ ទ្រព្យដែលបុគ្គលដំកល់ទុកក្នុងស្រែ មាន៤កន្លែង គឺ ក្នុងដី១ លើគោក១ ឯអាកាស១ លើផ្ទៃ១ ឈ្មោះថា ទ្រព្យនៅក្នុងស្រែ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យនៅក្នុងស្រែដូច្នេះ ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់ស្រូវទាំងឡាយ មានស្រូវសាលីជាដើមក្តី ផ្លែឈើទាំងឡាយ មានសណ្តែករាជមាសជាដើមក្តី ដែលដុះក្នុងស្រែនោះ មានដម្លៃប្រមាណ៥មាសកក្តី លើសពី៥មាសកទៅក្តី ត្រូវអាបត្តិទុក្កដ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុចោទប្រកាន់យកស្រែ ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យម្ចាស់ស្រែកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ។ បើម្ចាស់ស្រែដាក់ធុរៈថា ស្រែមុខជានឹងមិនបានមកអញវិញទេ ដូច្នេះ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ (គឺកាលដែលជំនុំជំរះក្នុងជំនុំសង្ឃ ឬក្នុងរាជត្រកូល ហើយសូកពួកអ្នកវិនិច្ឆ័យឲ្យយកសាក្សីកោង ធ្វើម្ចាស់ស្រែឲ្យចាញ់) ត្រូវអាបត្តិបារាជិក។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ (គឺបើពួកអ្នកវិនិច្ឆ័យកាត់ក្តីនោះតាមធម៌ជាសត្ថុសាសនា ហើយត្រឡប់ជាចាញ់លើខ្លួនឯងវិញ) ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុបង្ខិតគោលក្តី ខ្សែក្តី របងក្តី ទំនប់ក្តី ត្រូវអាបត្តិទុក្កដ។ នៅតែប្រយោគមួយមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ។ លុះប្រយោគមួយនោះមកដល់ ត្រូវអាបត្តិបារាជិក។

[១០២] ទីសួនច្បារ និងទីវត្ត ឈ្មោះថាវត្ថុ (ទីដី)។ ទ្រព្យដែលគេដម្កល់ទុកក្នុងទីដី មាន៤កន្លែង គឺ ក្នុងដី១ លើគោក១ ឯអាកាស១ លើផ្ទៃរ១ ឈ្មោះថា ទ្រព្យស្ថិតនៅក្នុងទីដី។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលគេដម្កល់ទុកក្នុងទីដី ស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុចោទប្រកាន់យកទីដី ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យម្ចាស់ដីកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ។ បើម្ចាស់ដីដាក់ធុរៈថា ដីមុខជាមិនបានមកអញវិញទេ ដូច្នេះ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ (គឺកាលដែលជំនុំជំរះក្នុងជំនុំសង្ឃ ឬក្នុងរាជត្រកូល ហើយសូកពួកអ្នកវិនិច្ឆ័យឲ្យយកសាក្សីកោង ធ្វើម្ចាស់ដីឲ្យចាញ់) ត្រូវអាបត្តិបារាជិក។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ (គឺបើពួកអ្នកវិនិច្ឆ័យនោះកាត់តាមធម៌វិន័យជាសត្ថុសាសនា ហើយត្រឡប់ជាចាញ់ខ្លួនឯងវិញ) ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុបង្ខិតគោលក្តី ខ្សែក្តី របងក្តី កំផែងក្តី ត្រូវអាបត្តិទុក្កដ។ នៅតែប្រយោគមួយមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ។ លុះប្រយោគមួយនោះមកដល់[23] ត្រូវអាបត្តិបារាជិក។

[១០៣] ទ្រព្យដែលគេដម្កល់ទុកក្នុងស្រុក មាន៤កន្លែង គឺ ក្នុងដី១ លើគោក១ ឯអាកាស១ លើផ្ទៃរ១ ឈ្មោះថា ទ្រព្យឋិតនៅក្នុងស្រុក។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលឋិតនៅក្នុងស្រុក ដូច្នេះ ហើយស្វែងរកគ្នាឲ្យបានជាគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។

[១០៤] ដែលហៅថាព្រៃ គឺទីណាដែលពួកមនុស្សហួងហែងរក្សា ទីនោះឈ្មោះថាព្រៃ។ ទ្រព្យដែលបុគ្គលដម្កល់ទុកក្នុងព្រៃ មាន៤កន្លែង គឺ ក្នុងដី១ លើគោក១ ឯអាកាស១ លើផ្ទៃរ១ ឈ្មោះថា ទ្រព្យឋិតនៅក្នុងព្រៃ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលឋិតនៅក្នុងព្រៃ ដូច្នេះ ហើយស្វែងរកគ្នាឲ្យបានគំរប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត ហើយចាប់ពាល់ឈើក្តី វល្លិ៍ក្តី ស្មៅក្តី កើតក្នុងព្រៃនោះ មានដំឡៃប្រមាណ៥មាសកក្តី ដែលលើសពី៥មាសកក្តី ត្រូវអាបត្តិទុក្កដ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើរបស់នោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។

[១០៥] ទឹកដែលមាននៅក្នុងភាជនៈក្តី ក្នុងស្រះក្តី ក្នុងបឹងក្តី ឈ្មោះថាទឹក។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់ទឹកនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទឹកនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទឹកនោះឲ្យហូរឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់ទឹកដែលមានដម្លៃប្រមាណ៥មាសកក្តី ដែលលើសពី៥មាសកក្តី ឲ្យចូលទៅក្នុងភាជនៈរបស់ខ្លួន ត្រូវអាបត្តិទុក្កដ។ ធ្វើទឹកនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទឹកនោះឲ្យបានដម្កល់ក្នុងភាជនៈរបស់ខ្លួន ត្រូវអាបត្តិបារាជិក។ ភិក្ខុទំលុះភ្លឺស្រែគេ ត្រូវអាបត្តិទុក្កដ។ ទំលុះភ្លឺស្រែហើយបង្ហូរយកទឹកមានដម្លៃប្រមាណ៥មាសកក្តី លើសពី៥មាសកក្តី ត្រូវអាបត្តិបារាជិក។ ភិក្ខុបង្ហូរយកទឹកមានដម្លៃលើសពី១មាសកក្តី ថយពី៥មាសកចុះមកក្តី ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុបង្ហូរយកទឹកមានដម្លៃ១មាសកក្តី ថយចុះពី១មាសកក្តី ត្រូវអាបត្តិទុក្កដ។

[១០៦] (ឈើសម្រាប់ជំរះធ្មេញ) ទោះគេកាត់ហើយក្តី គេមិនបានកាត់ក្តី ហៅថាឈើស្ទន់។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់ឈើស្ទន់ដែលមានដម្លៃ៥មាសកក្តី លើសពី៥មាសកក្តី ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។

[១០៧] ឈើណាជាគ្រឿងប្រើប្រាស់ ដែលមានពួកមនុស្សថែរក្សាទុក ឈើនោះឈ្មោះថាដើមឈើ។ ភិក្ខុមានថេយ្យចិត្ត កាត់ឈើនោះ ត្រូវអាបត្តិទុក្កដគ្រប់ៗប្រហារ។ នៅប្រហារម្តងទៀតមិនទាន់មកដល់ (គឺថានៅតែប្រហារម្តងទៀតនឹងដាច់) ត្រូវអាបត្តិថុល្លច្ច័យ។ លុះប្រហារម្តងទៀតមកដល់ (គឺថាបានកាត់ដាច់ហើយ) ត្រូវអាបត្តិបារាជិក។

[១០៨] ទ្រព្យដែលបុគ្គលដទៃកំពុងនាំទៅ ឈ្មោះថា ទ្រព្យដែលគេកំពុងនាំទៅ។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុគិតថា អញនឹងលួចយកទ្រព្យព្រមទាំងអ្នកនាំទ្រព្យ ហើយឲ្យមនុស្សនោះដើរទៅ ១ជំហានដំបូង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យមនុស្សនោះដើរទៅបាន២ជំហាន ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យចិត្ត គិតថា អញនឹងយករបស់ដែលជ្រុះចុះ ហើយធ្វើរបស់គេឲ្យជ្រុះ ឬឲ្យធ្លាក់ចុះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់របស់ដែលជ្រុះនោះ មានដម្លៃ៥មាសកក្តី លើសពី៥មាសកក្តី ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ធ្វើឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។

[១០៩] ទ្រព្យដែលគេផ្ញើទុក ឈ្មោះថាបញ្ញើ។ ម្ចាស់បញ្ញើនិយាយថា លោកចូរឲ្យទ្រព្យមកខ្ញុំ ភិក្ខុពោលថា អាត្មាមិនបានទទួលទុកទេ ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យម្ចាស់របស់គេកើតសេចក្តីសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ។ ម្ចាស់របស់ដាក់ធុរៈថា (ភិក្ខុនេះ) នឹងមិនឲ្យអញវិញទេ (ភិក្ខុនោះ) ត្រូវអាបត្តិបារាជិក។ ភិក្ខុពឹងក្រុមវិនិច្ឆ័យឲ្យសម្រេចសេចក្តី ឲ្យម្ចាស់បញ្ញើចាញ់ ត្រូវអាបត្តិបារាជិក។ កាលក្រុមវិនិច្ឆ័យសម្រេចសេចក្តីដោយធម៌ ភិក្ខុត្រឡប់ចាញ់វិញ ត្រូវអាបត្តិថុល្លច្ច័យ។

[១១០] ទីសម្រាប់ហូតពន្ធ ដែលព្រះបរមក្សត្រទ្រង់បញ្ញត្តថា ជនណានាំរបស់ចូលទៅក្នុងទីនោះៗ គឺក្នុងទីភ្នំខណ្ឌក្តី ក្នុងទីកំពង់ទឹកក្តី ក្នុងទីទៀបទ្វារស្រុកក្តី ពួករាជបុរសត្រូវយកពន្ធពីជននោះ ឈ្មោះថាគយ។ ភិក្ខុចូលទៅក្នុងខេត្តគយនោះហើយ មានថេយ្យចិត្ត ចាប់ពាល់នូវទ្រព្យដ៏គួរដល់ព្រះរាជានឹងយកពន្ធ មានដំឡៃ៥មាសកក្តី លើសពី៥មាសកក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុញុំាងរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុឈានជំហានទី១ ឲ្យកន្លងខេត្តគយទៅ ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុឈានជំហានទី២ ឲ្យកន្លងខេត្តគយទៅ ត្រូវអាបត្តិបារាជិក។ ភិក្ខុឋិតនៅខាងក្នុងខេត្តរបស់គយ ហើយបោះផ្លោងរបស់ឲ្យធ្លាក់ចុះទៅខាងក្រៅខេត្តរបស់គយ ត្រូវអាបត្តិបារាជិក។ ភិក្ខុនាំទ្រព្យរត់ពន្ធ (ដោយវាង់ខេត្តគយ) ត្រូវអាបត្តិទុក្កដ។

[១១១] សត្វ គឺមនុស្ស ហៅថាសត្វមានជីវិត។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់មនុស្សនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យផុតចាកទីទៅ ត្រូវអាបត្តិបារាជិក។ ភិក្ខុគិតថា អញនឹងនាំមនុស្សដើរទៅដោយជើង ហើយឲ្យឈានជំហានទី១ទៅ ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យឈានជំហានទី២ទៅ ត្រូវអាបត្តិបារាជិក។

[១១២] ពស់ ត្រី ហៅថា សត្វគ្មានជើង។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់នូវសត្វគ្មានជើង មានដំឡៃ៥មាសកក្តី លើសពី៥មាសកក្តី ត្រូវអាបត្តិទុក្កដ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យផុតចាក់ទី ត្រូវអាបត្តិបារាជិក។

[១១៣] មនុស្ស សត្វស្លាប ហៅថា សត្វមានជើងពីរ។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់នូវសត្វជើងពីរនោះ ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុគិតថា អញនឹងនាំបណ្តើរសត្វជើងពីរទៅដោយជើង ហើយឲ្យឈានជំហានទី១ ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យឈានជំហានទី២ ត្រូវអាបត្តិបារាជិក។

[១១៤] ដំរី សេះ ឱដ្ឋ គោ លា ជាពួកសត្វចិញ្ចឹមហៅថា សត្វមានជើង៤។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់សត្វជើង៤នោះ ត្រូវអាបត្តិទុក្កដ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យផុតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុគិតថា អញនឹងនាំបណ្តើរនូវសត្វជើង៤ទៅដោយជើង ហើយឲ្យឈានជំហានទី១ទៅ ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យឈានជំហានទី២ទៅ ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យឈានជំហានទី៣ទៅ ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យឈានជំហានទី៤ទៅ ត្រូវអាបត្តិបារាជិក។

[១១៥] ខ្ទួយ ក្អែប ដង្កូវរមាស់ ហៅថា ពួកសត្វមានជើងច្រើន។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់សត្វមានជើងច្រើននោះ មានដំឡៃ៥មាសកក្តី ហួសពី៥មាសកក្តី ត្រូវអាបត្តិទុក្កដ។ ឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យផុតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុគិតថា អញនឹងនាំបណ្តើរសត្វមានជើងច្រើនទៅដោយជើង ហើយញុំាងសត្វមានជើងច្រើនឲ្យឈានទៅ ត្រូវអាបត្តិថុល្លច្ច័យ គ្រប់ជំហាន។ ញុំាងជើងទីបំផុតរបស់សត្វនោះឲ្យឈានទៅ ត្រូវអាបត្តិបារាជិក។

[១១៦] ភិក្ខុគយគន់ទ្រព្យដែលគេទុកដាក់ធ្វេសប្រហែស ហើយប្រាប់ (ភិក្ខុដទៃ) ថា លោកចូរលួចទ្រព្យឈ្មោះនេះមក (ភិក្ខុនោះ) ហៅថា អ្នកកំណត់របស់ឲ្យគេលួច ត្រូវអាបត្តិទុក្កដ។ បើភិក្ខុអ្នកទទួលបង្គាប់នោះលួចយកទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីររូប។

[១១៧] ភិក្ខុអ្នកថែរក្សាទ្រព្យដែលគេនាំមកផ្ញើទុកមួយសំណើរ ហៅថា អ្នករក្សាបញ្ញើ។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់នូវទ្រព្យមានដំឡៃ៥មាសកក្តី លើសពី៥មាសកក្តី ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ឲ្យផុតចាកទី ត្រូវអាបត្តិបារាជិក។

[១១៨] ដែលហៅថាកិរិយាលួចយកដោយបបួលគ្នា (នោះ) គឺភិក្ខុដែលរួមគំនិតចូលគ្នាច្រើនរូប ភិក្ខុ១រូបទៅលួចយកទ្រព្យបានមក ត្រូវអាបត្តិបារាជិកទាំងអស់គ្នា។

[១១៩] ភិក្ខុធ្វើសញ្ញាកំណត់ពេលឲ្យលួច ហៅថា សង្កេតកម្ម ភិក្ខុប្រើភិក្ខុឲ្យទៅលួចថា អ្នកចូលលួចយកទ្រព្យនោះ ដោយសង្កេតនោះ ក្នុងពេលព្រឹកក្តី ល្ងាចក្តី យប់ក្តី ថ្ងៃក្តី ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុលួចទ្រព្យនោះបានមកតាមសង្កេតនោះ ត្រូវអាបត្តិបារាជិកទាំងពីររូប។ ភិក្ខុទៅលួចទ្រព្យនោះមុនសង្កេតនោះក្តី ក្រោយក្តី ភិក្ខុអ្នកប្រើដើមមិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច។

[១២០] ភិក្ខុធ្វើនិមិត្តគ្រឿងសំគាល់ឲ្យលួច ហៅថា និមិត្តកម្ម គឺភិក្ខុបង្គាប់ភិក្ខុផងគ្នាថា ខ្ញុំនឹងប៉ប្រិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី អ្នកចូរលួចយកទ្រព្យនោះមកតាមនិមិត្តនោះ ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់ លួចទ្រព្យនោះបានមកតាមនិមិត្តនោះ ត្រូវអាបត្តិបារាជិកទាំងពីរនាក់។ ភិក្ខុអ្នកទទួលបង្គាប់ទៅលួចទ្រព្យនោះបានមកមុននិមិត្តនោះក្តី ក្រោយក្តី ភិក្ខុអ្នកបង្គាប់ដើម មិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច។

[១២១] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់នោះសំគាល់ទ្រព្យនោះបានហើយ ទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់នោះ សំគាល់ទ្រព្យនោះបានហើយ ទៅលួចទ្រព្យដទៃបានមកវិញ ភិក្ខុអ្នកបង្គាប់ដើម មិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់នោះ ត្រឡប់សំគាល់ទ្រព្យដទៃវិញ តែទៅលួចទ្រព្យបានមក ត្រូវពានលើទ្រព្យដែលភិក្ខុប្រើនោះ ត្រូវអាបត្តិបារាជិកទាំងពីរនាក់។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់នោះ សំគាល់នូវទ្រព្យដទៃ ទៅលួចបានទ្រព្យដទៃមកវិញ ភិក្ខុអ្នកបង្គាប់ដើម មិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅប្រាប់តដល់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះឯងទៅប្រាប់តដល់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះចូរទៅលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើដើម ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់ទី១នោះទៅប្រាប់ភិក្ខុអ្នកទទួលបង្គាប់ទី២ ភិក្ខុអ្នកទទួលបង្គាប់ទី១នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈប្រាប់។ (ភិក្ខុអ្នកទទួលបង្គាប់ទី២ ទៅប្រាប់ដល់អ្នកទទួលបង្គាប់ទី៣) ភិក្ខុអ្នកទទួលបង្គាប់ទី៣ ព្រមទទួលនឹងទៅលួច ភិក្ខុអ្នកបង្គាប់ដំបូង ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុអ្នកទទួលបង្គាប់ទី៣នោះទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងអស់គ្នា។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅប្រាប់តដល់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះឯង ទៅប្រាប់តដល់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះចូរទៅលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើដើម ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់ទី១នោះ ទៅប្រើភិក្ខុដទៃ (គឺអ្នកទទួលបង្គាប់ទី៣វិញ) ខ្លួនអ្នកទទួលបម្រើទី១នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈប្រើត។ អ្នកទទួលបង្គាប់ទី៣ ទទួលនឹងទៅលួច អ្នកទទួលបង្គាប់ទី៣នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈទទួល។ អ្នកទទួលបង្គាប់ទី៣នោះទៅលួចទ្រព្យនោះបានមក អ្នកប្រើដើមមិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកទទួលបង្គាប់ទី១ និងភិក្ខុអ្នកលួចទី៣។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដក្នុងខណៈប្រើ។ ភិក្ខុអ្នកទទួលបង្គាប់នោះ ទៅហើយត្រឡប់មកវិញប្រាប់ថា ខ្ញុំមិនអាចនឹងទៅលួចយកទ្រព្យនោះមកទេ។ ភិក្ខុអ្នកបង្គាប់ ប្រើម្តងទៀតថា លោកអាចលួចយកបានក្នុងពេលណា ចូរលួចទ្រព្យនោះក្នុងពេលនោះចុះ ភិក្ខុអ្នកបង្គាប់នោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់លួចយកទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកបង្គាប់នោះ លុះដល់បង្គាប់ភិក្ខុនោះហើយ មានសេចក្តីក្តៅក្រហាយស្តាយក្រោយវិញ តែមិនទាន់បានប្រាប់ភិក្ខុនោះថា អ្នកកុំលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់នោះ ទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកបង្គាប់នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈ

បង្គាប់។ ភិក្ខុអ្នកបង្គាប់នោះ លុះដល់បង្គាប់ភិក្ខុនោះហើយ មានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយវិញ ត្រឡប់ហាមឃាត់ថា លោកកុំលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់នោះ មិនព្រមត្រឡប់ខានលួចតាម ពោលតបថា លោកបង្គាប់ខ្ញុំហើយ រួចទៅលួចយកទ្រព្យនោះបានមក ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកបង្គាប់នោះត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកបង្គាប់នោះ លុះដល់បង្គាប់ភិក្ខុនោះហើយ មានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយវិញ ត្រឡប់ឃាត់ថា លោកកុំទៅលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់ ទទួលពាក្យថា ប្រពៃហើយ ក៏លែងលួចទៅ ភិក្ខុទាំងពីររូបមិនត្រូវអាបត្តិឡើយ។

[១២២] ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិបារាជិក គឺទ្រព្យដែលអ្នកដទៃហួងហែងរក្សា១ សំគាល់ថាទ្រព្យមានអ្នកដទៃហួងហែងរក្សា១ បរិក្ខារមានដំឡៃច្រើន ចំនួន៥មាសក ឬលើសពី៥មាសក១ មានថេយ្យចិត្តតាំងឡើងប្រាកដ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិបារាជិក។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ។ ញុំាងរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិថុល្លច្ច័យ គឺទ្រព្យដែលអ្នកដទៃហួងហែងរក្សា១ សំគាល់ថា ទ្រព្យមានអ្នកដទៃហួងហែងរក្សា១ បរិក្ខារមានដំឡៃតិច ប្រមាណលើសពី១មាសក ឬថយពី៥មាសកចុះមក១ មានថេយ្យចិត្តកើតឡើងប្រាកដ១ ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិថុល្លច្ច័យ។ (បើមិនទាន់ញុំាងរបស់នោះឲ្យឃ្លាតចាកទីទេ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ។ ញុំាងរបស់នោះឲ្យកំរើក ត្រូវអាបត្តិទុក្កដ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃហួងហែងរក្សា១ សំគាល់ថា ទ្រព្យមានអ្នកដទៃហួងហែងរក្សា១ បរិក្ខារមានដំឡៃតិច ប្រមាណ១មាសក ឬថយពី១មាសក១ មានថេយ្យចិត្តតាំងឡើងប្រាកដ១ ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិទុក្កដ។ (សូម្បីមិនទាន់ឲ្យឃ្លាតចាកទី) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ។ ធ្វើឲ្យកំរើក ក៏ត្រូវអាបត្តិទុក្កដ។

[១២៣] ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ៦យ៉ាង ត្រូវអាបត្តិបារាជិក គឺមិនបានសំគាល់ថាជារបស់ខ្លួន១ មិនបានកាន់យកដោយវិស្សាសៈ១ មិនបានកាន់យកជារបស់ខ្ចី១ បរិក្ខារមានដំឡៃច្រើន ប្រមាណ៥មាសក ឬលើសពី៥មាសក១ មានថេយ្យចិត្តតាំងឡើងប្រាកដ១ ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិបារាជិក។ (បើមិនទាន់ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ។ ញុំាងរបស់នោះឲ្យកំរើក ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ៦យ៉ាង ត្រូវអាបត្តិថុល្លច្ច័យ គឺមិនបានសំគាល់ថាជារបស់ខ្លួន១ មិនបានកាន់យកដោយស្និទ្ធស្នាល១ មិនបានកាន់យកជារបស់ខ្ចី១ បរិក្ខារមានដំឡៃតិច ប្រមាណលើសពី១មាសក ឬថយពី៥មាសកមក១ មានថេយ្យចិត្តតាំងឡើងប្រាកដ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិថុល្លច្ច័យ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិទុក្កដ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យដោយអាការ៦យ៉ាង ត្រូវអាបត្តិទុក្កដ គឺមិនបានសំគាល់ថាជារបស់ខ្លួន១ មិនបានកាន់យកដោយស្និទ្ធស្នាល១ មិនបានកាន់យកជារបស់ខ្ចី១ បរិក្ខារមានដំឡៃតិច ប្រមាណ១មាសក ឬថយពី១មាសកមក១ មានថេយ្យចិត្តតាំងឡើងប្រាកដ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិទុក្កដ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ។ ធ្វើរបស់នោះឲ្យកំរើក ត្រូវអាបត្តិទុក្កដ។

[១២៤] ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងរក្សា១ សំគាល់ថាជាទ្រព្យមានអ្នកដទៃហួងហែងរក្សា១ បរិក្ខារមានដំឡៃច្រើន ប្រមាណ៥មាសក ឬលើសពី៥មាសក១ មានថេយ្យចិត្តតាំងឡើងប្រាកដ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិទុក្កដ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ។ ញុំាងទ្រព្យនោះឲ្យកំរើក ក៏ត្រូវអាបត្តិទុក្កដ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងរក្សា១ សំគាល់ថាទ្រព្យមានអ្នកដទៃហួងហែងរក្សា១ បរិក្ខារមានដំឡៃតិច ប្រមាណលើសពី១មាសក ឬថយពី៥មាសកចុះមក១ មានថេយ្យចិត្តតាំងឡើងប្រាកដ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិទុក្កដ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ។ ញុំាងទ្រព្យនោះឲ្យកំរើក ក៏ត្រូវអាបត្តិទុក្កដ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងរក្សា១ សំគាល់ថាទ្រព្យមានអ្នកដទៃហួងហែងរក្សា១ បរិក្ខារមានដំឡៃតិច ប្រមាណ១មាសក ឬថយពី១មាសកចុះមក១ មានថេយ្យចិត្តតាំងឡើងប្រាកដ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី១ ត្រូវអាបត្តិទុក្កដ។ (បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ។ ធ្វើទ្រព្យនោះឲ្យកំរើក ក៏ត្រូវអាបត្តិទុក្កដ។

[១២៥] ភិក្ខុកាន់យកដោយសំគាល់ថាជារបស់ខ្លួន កាន់យកដោយស្និទ្ធស្នាលនឹងគ្នា កាន់យកជារបស់ខ្ចីគ្នា កាន់យករបស់ដែលពួកប្រេតហួងហែងរក្សា កាន់យករបស់ដែលសត្វតិរច្ឆានហួងហែងរក្សា កាន់យកដោយសំគាល់ថាជារបស់បំសុកូល ភិក្ខុឆ្កួត ភិក្ខុអ្នកដើមបញ្ញត្តិ (អម្បាលនេះ) មិនត្រូវអាបត្តិឡើយ។

អទិន្នាទាន បឋមភាណវារៈ ចប់។

## (វិនីតវត្ថុឧទ្ទានគាថា ទុតិយសិក្ខាបទំ)

CS vin.vbu.pr.02.01 | ភាគ ទី១

### (វិនីតវត្ថុឧទ្ទានគាថា)

[១២៦] (មាតិកានុក្រម បញ្ជីរឿងតាមរបៀបដែលនឹងសំដែងតទៅ ដូចមានខាងក្រោមនេះ)

រឿងភិក្ខុ៥រូបលួចភណ្ឌៈរបស់ជាងជ្រលក់ រឿងភិក្ខុ៤រូបលួចគ្រឿងកម្រាល រឿងភិក្ខុ៥រូបលួចទ្រព្យក្នុងវេលាយប់ (ដោយចំណាំទុកពីថ្ងៃ) រឿងភិក្ខុ៥រូបលួចទ្រព្យគេដែលខ្លួនកំពុងជួយនាំទៅ រឿងភិក្ខុ៥រូបពោលតែពាក្យថាលួច (តែគ្មានថេយ្យចិត្ត) រឿងភិក្ខុ២រូបទៀត រើសសម្ពត់សាដក និងឈ្នួតដែលប៉ើងទៅដោយខ្យល់ រឿងភិក្ខុ១រូបទស់យកសម្ពត់បំសុកូលអំពីសាកអសុភដែលមិនទាន់

បែកធ្លាយ រឿងភិក្ខុ១រូបលួចប្តូរស្លាកចីវរ រឿងព្រះអានន្ទត្ថេរច្រឡំស្លៀក់ស្បង់របស់ភិក្ខុដទៃក្នុងរោងភ្លើង រួមទាំងរឿងភិក្ខុ៥ពួកដែលឆាន់រំពា[24] សត្វផង ត្រូវជា១០ រឿងភិក្ខុ៥រូបមិនមានហេតុ កុហកយកខាទនីយភោជនីយាហារ ដែលគេចែកដល់សង្ឃ រឿងភិក្ខុ៥រូបលួចបាយ សាច់ នំ ស្ករក្រាម នំអន្សម ក្នុងវេលាស្រុកអត់បាយ រឿងពួកភិក្ខុលួចបរិក្ខារព្រមទាំងថង់យាម រឿងពួកភិក្ខុលួចពូករបស់សង្ឃ និងចីវរលើខ្សែស្បៀង រឿងភិក្ខុលួចចីវរក្នុងវិហារ ហើយមិនហ៊ានចេញទៅក្រៅ រឿងភិក្ខុឆាន់ខាទនីយរបស់ភិក្ខុជាសំឡាញ់ ព្រោះសេចក្តីស្និទ្ធស្នាល រឿងភិក្ខុ២រូបទៀតយកខាទនីយរបស់ភិក្ខុដទៃឆាន់ ដោយសំគាល់ថា ជារបស់ខ្លួន រឿងភិក្ខុ៧ពួកប្រកែកមិនទទួលខ្លួនថាលួចយក រឿងភិក្ខុ៧ពួកតាំងចិត្តលួចយកពិត រឿងភិក្ខុ៧រូបលួចយកខាទនីយរបស់សង្ឃ រឿងភិក្ខុ២រូបទៀតលួចផ្កា រឿងភិក្ខុ៣រូបទៅនិយាយយករបស់អំពីត្រកូលឧបដ្ឋាកនៃភិក្ខុដទៃ តាមពាក្យដែលលោកម្ចាស់ត្រកូលផ្តាំ រឿងភិក្ខុ៣រូបយកកែវមណីរំលងគយ រឿងពួកភិក្ខុដោះជ្រូកជាប់អន្ទាក់លែង រឿងពួកភិក្ខុដោះម្រឹគជាប់អន្ទាក់លែង រឿងពួកភិក្ខុដោះត្រីជាប់លបលែង រឿងភិក្ខុ១រូប លួចប្រមៀលភណ្ឌនៅក្នុងយាន រឿងភិក្ខុ២រូបលួចយកដុំសាច់ រឿងភិក្ខុ២ពួក លួចយកឈើក្បូនរបស់គេ រឿងភិក្ខុ១រូបបំសុកូលយកសម្ពត់សាដករបស់គេ រឿងភិក្ខុ២រូប រើសយកសម្ពត់សាដកអណ្តែតទឹក រឿងភិក្ខុ១រូបលួចផឹកសប្បិ[25] រឿងពួកភិក្ខុចូលដៃគ្នាលួចទ្រព្យគេ ហើយចែកគ្នាមិនពេញ៥មាសកម្នាក់ រឿងភិក្ខុ៤រូបលួចធញ្ញជាតិម្នាក់១ក្តាប់ វេលាក្រុងសាវត្ថីអត់បាយ រឿងភិក្ខុ២ពួកបំសុកូលយកសាច់ដែលសល់អំពីចោរបរិភោគ រឿងភិក្ខុ២រូបលួចស្មៅគេ រឿងភិក្ខុ៧ពួកយកខាទនីយរបស់សង្ឃចែកគ្នាឆាន់ រឿងភិក្ខុ៧ពួកមិនហ៊ានទទួលខាទនីយដែលមនុស្សមិនមែនម្ចាស់ប្រគេន រឿងភិក្ខុយកឈើរបស់សង្ឃធ្វើជញ្ជាំងកុដិដោយគិតថាខ្ចី រឿងភិក្ខុលួចទឹកសង្ឃ រឿងភិក្ខុលួចដីស្អិតសង្ឃ រឿងភិក្ខុ២រូបលួចស្មៅយាប្លងរបស់សង្ឃ រឿងភិក្ខុ៧រូបលួចគ្រឿងសេនាសនៈរបស់សង្ឃ រឿងភិក្ខុយកសេនាសនៈសម្រាប់វិហារ មានម្ចាស់ទៅប្រើប្រាស់ ហើយចោល រឿងភិក្ខុ១ពួក ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យខ្ចីគ្រឿងសេនាសនៈរបស់គេប្រើប្រាស់បាន រឿងពួកភិក្ខុនីជាសិស្សរបស់ថុល្លនន្ទាភិក្ខុនីក្នុងក្រុងចម្បា និងក្រុងរាជគ្រឹះ ទៅនិយាយយកបបរលាយល្វច្រឡំដោយសណ្តែកបាយ និងក្បាលទឹកឃ្មុំក្នុងត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី រឿងអជ្ជុកត្ថេរក្នុងក្រុងវេសាលី ចែកមត៌កដល់ក្មួយគហបតី រឿងបិលិន្ទវច្ឆត្ថេរក្នុងក្រុងពារាណសីនាំយកក្មេងពីរនាក់របស់ឧបដ្ឋាក អំពីដៃចោរបានមកដោយឫទ្ធិ រឿងភិក្ខុជាសំឡាញ់នឹងគ្នា២នាក់ ក្នុងក្រុងកោសម្ពីរើសរំងកជ្រូក គិតថានឹងឲ្យដល់ម្ចាស់ រឿងភិក្ខុជាសទ្ធិវិហារិករបស់ទឡ្ហិកត្ថេរក្នុងក្រុងសាគល លួចយកឈ្នួតរបស់គេ។

## (វិនីតវត្ថុ ទុតិយសិក្ខាបទំ)

CS vin.vbu.pr.02.02 | ភាគ ទី១

### (វិនីតវត្ថុ)

[១២៧] សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ ទៅកាន់ទីកន្លែងហាលភណ្ឌៈនៃជាងជ្រលក់ ហើយលួចយកទ្រព្យរបស់ជាងជ្រលក់។ ភិក្ខុអម្បាលនោះ មានសេចក្តីសង្ស័យថា សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ យើងទាំងឡាយត្រូវអាបត្តិបារាជិកហើយឬហ្ន៎។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ។

[១២៨] សម័យនោះ មានភិក្ខុ១រូប ទៅកាន់កន្លែងហាលភណ្ឌៈនៃជាងជ្រលក់ បានឃើញសម្ពត់មានដំឡៃច្រើន ហើយញុំាងថេយ្យចិត្តឲ្យកើតឡើង។ ភិក្ខុនោះ មានសេចក្តីសង្ស័យថា អញត្រូវអាបត្តិបារាជិកហើយឬហ្ន៎។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើថេយ្យចិត្តកើតឡើងប៉ុណ្ណោះ អ្នកមិនត្រូវអាបត្តិអ្វីឡើយ។ សម័យនោះ មានភិក្ខុ១រូប ទៅកាន់កន្លែងហាលភណ្ឌៈនៃជាងជ្រលក់ ឃើញសម្ពត់មានដំឡៃច្រើន មានថេយ្យចិត្តគិតលួច ហើយចាប់ពាល់សម្ពត់នោះ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ។ សម័យនោះឯង មានភិក្ខុ១រូប ទៅកាន់កន្លែងហាលភណ្ឌៈនៃជាងជ្រលក់ បានឃើញសម្ពត់មានដំឡៃច្រើន មានថេយ្យចិត្តគិតលួច ហើយធ្វើសម្ពត់នោះឲ្យកំរើក។ ភិក្ខុនោះ មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុ១រូប ទៅកាន់កន្លែងហាលភណ្ឌៈនៃជាងជ្រលក់ បានឃើញសម្ពត់មានដំឡៃច្រើន មានថេយ្យចិត្តគិតលួច ហើយញុំាងសម្ពត់នោះឲ្យឃ្លាតផុតចាកទី។ ភិក្ខុនោះ មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១២៩] សម័យនោះឯង មានភិក្ខុ១រូប អ្នកត្រាច់ទៅបិណ្ឌបាត បានឃើញកំរាលដ៏ប្រសើរមានដំឡៃច្រើន ហើយញុំាងថេយ្យចិត្តឲ្យកើតឡើង។ ភិក្ខុនោះ មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើថេយ្យចិត្តកើតឡើងប៉ុណ្ណោះ អ្នកមិនត្រូវអាបត្តិឡើយ។ សម័យនោះឯង មានភិក្ខុ១រូប អ្នកត្រាច់ទៅបិណ្ឌបាត បានឃើញកំរាលដ៏ប្រសើរមានដំឡៃច្រើន មានថេយ្យចិត្តគិតលួច ហើយចាប់ពាល់។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ។ បេ។ ភិក្ខុមានថេយ្យចិត្ត ធ្វើរបស់នោះឲ្យកំរើក។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុមានថេយ្យចិត្ត ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទី។ ភិក្ខុនោះ មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៣០] សម័យនោះឯង មានភិក្ខុ១រូប ឃើញទ្រព្យក្នុងវេលាថ្ងៃ ហើយបានធ្វើនិមិត្តសំគាល់ថា អញនឹងលួចយកទ្រព្យនោះក្នុងវេលាយប់។ ភិក្ខុនោះ កាលបើសំគាល់ទ្រព្យនោះបានហើយ ក៏លួចយកទ្រព្យនោះមក។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ បេ។ ភិក្ខុសំគាល់ទ្រព្យនោះបាន (ក្នុងវេលាថ្ងៃហើយ ដល់វេលាយប់) លួចយកទ្រព្យដទៃបានមកវិញ។ បេ។ (វេលាថ្ងៃ) សំគាល់ទ្រព្យដទៃទេ (តែដល់វេលាយប់) ត្រឡប់លួចបានទ្រព្យនោះមក។ បេ។ សំគាល់ទ្រព្យដទៃបានហើយ ទៅលួចយកទ្រព្យដទៃបានមក។ បេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុ១រូប ឃើញទ្រព្យក្នុងវេលាថ្ងៃ ហើយបានធ្វើនិមិត្តសំគាល់ថា អញនឹងលួចយកទ្រព្យនោះក្នុងវេលាយប់។ ភិក្ខុនោះ សំគាល់ទ្រព្យនោះបានហើយ

(វេលាយប់) ត្រឡប់លួចបានទ្រព្យរបស់ខ្លួនមកវិញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ។

[១៣១] សម័យនោះឯង មានភិក្ខុ១រូប ទូលនាំយកទ្រព្យរបស់អ្នកដទៃទៅឲ្យគេ (វេលាកំពុងដើរ) កើតមានថេយ្យចិត្ត ហើយចាប់ពាល់របស់តាំងនៅលើក្បាល។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ។ បេ។ ភិក្ខុមានថេយ្យចិត្ត ហើយធ្វើរបស់នោះឲ្យកំរើក។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់របស់ចុះមកត្រង់-ក។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយចាប់ពាល់ភារៈដែលតាំងនៅលើ ក។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយធ្វើភារៈ[26] នោះឲ្យកំរើក។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់ភារៈចុះមកត្រង់ចង្កេះ។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយចាប់ពាល់ភារៈដែលតាំងនៅលើចង្កេះ។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយធ្វើភារៈឲ្យកំរើក។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយបានកាន់យកដោយដៃ។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់ភារៈដែលតាំងនៅនឹងដៃមកលើផ្ទៃផែនដី។ បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយបានចាប់យករបស់អំពីផែនដី។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៣២] សម័យនោះឯង មានភិក្ខុ១រូបហាលចីវរក្នុងទីវាល ហើយចូលទៅកាន់វិហារ។ មានភិក្ខុឯទៀតទុកដាក់ចីវរនោះដោយគិតថា កុំឲ្យចីវរនេះបាត់ទៅឡើយ។ ភិក្ខុនោះ ចេញពីវិហារទៅហើយ សួរភិក្ខុនោះថា អាវុសោ ចីវររបស់ខ្ញុំ លោកណាលួចយកទៅ។ ភិក្ខុនោះពោលតបយ៉ាងនេះថា (ចីវរលោក) យើងលួចយកហើយ។ ភិក្ខុម្ចាស់ចីវរនោះ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្រាន់តែថាដោយពាក្យ (តែគ្មានថេយ្យចិត្តទេ) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើត្រឹមតែថាដោយពាក្យ អ្នកមិនត្រូវអាបត្តិអ្វីឡើយ។ សម័យនោះ មានភិក្ខុ១រូប ទុកដាក់ចីវរលើតាំង។ បេ។ ទុកដាក់សម្ពត់និសីទនលើតាំង។ បេ។ ទុកដាក់បាត្រក្រោមតាំង ហើយចូលទៅកាន់វិហារ។ មានភិក្ខុឯទៀតទុកដាក់បាត្រនោះដោយគិតថា កុំឲ្យបាត្រនេះបាត់ទៅឡើយ។ ភិក្ខុម្ចាស់បាត្រនោះ ចេញពីវិហារ ហើយទៅសួរភិក្ខុនោះថា អាវុសោ បាត្ររបស់ខ្ញុំ លោកណាលួចយកទៅ។ ភិក្ខុនោះពោលតបយ៉ាងនេះថា (បាត្ររបស់លោក) យើងលួចយកហើយ។ ភិក្ខុម្ចាស់បាត្រ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើត្រឹមតែពោលពាក្យទេ មិនត្រូវអាបត្តិអ្វីឡើយ។ សម័យនោះឯង មានភិក្ខុនី១រូប ហាលចីវរនឹងរបង ហើយចូលទៅកាន់វិហារ។ មានភិក្ខុនីឯទៀតទុកដាក់ចីវរនោះដោយគិតថា កុំឲ្យចីវរនេះបាត់ទៅឡើយ។ ភិក្ខុនីជាម្ចាស់ចីវរនោះចេញពីវិហារទៅ ហើយសួរភិក្ខុនីនោះថា នាង ចីវររបស់ខ្ញុំ អ្នកណាលួចយកបាត់ទៅ។ ភិក្ខុនីនោះពោលតបយ៉ាងនេះថា (ចីវរនាង) យើងលួចយកហើយ។ ភិក្ខុនីម្ចាស់ចីវរនោះ ចោទប្រកាន់ភិក្ខុនីនោះថា នាងមិនមែនជាសមណីទេ។ ភិក្ខុនីនោះមានសេចក្តីសង្ស័យ។ ទើបភិក្ខុនីនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយបានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើត្រឹមតែពោលពាក្យទេ (ភិក្ខុនីនេះ) មិនត្រូវអាបត្តិអ្វីឡើយ។

[១៣៣] សម័យនោះឯង មានភិក្ខុ១រូប ឃើញសម្ពត់សាដកប៉ើងទៅដោយខ្យល់កំបុតត្បូង ក៏បានរើសយក ដោយគិតថា អញនឹងឲ្យដល់ជនទាំងឡាយជាម្ចាស់សម្ពត់។ ពួកម្ចាស់សម្ពត់ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានថេយ្យចិត្តគិតលួចទេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនមានថេយ្យចិត្ត ឥតមានអាបត្តិអ្វីឡើយ។ សម័យនោះឯង មានភិក្ខុ១រូប មានថេយ្យចិត្ត ហើយបានរើសយកឈ្នួតក្បាលរបស់គេដែលប៉ើងទៅដោយខ្យល់កំបុតត្បូង ដោយគិតថា ក្រែងម្ចាស់របស់ទាំងឡាយឃើញមុន (ហើយយកទៅ)។ ពួកម្ចាស់របស់ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានថេយ្យចិត្តមែន។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៣៤] សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ទីស្មសាន ហើយបានកាន់យកសម្ពត់បំសុកូលអំពីសរីរៈខ្មោចដែលមិនទាន់បែកធ្លាយ។ ក៏ក្នុងសរីរៈខ្មោចនោះ មានប្រេតមកអាស្រ័យនៅ។ គ្រានោះ ប្រេតនោះបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា បពិត្រលោកដ៏ចំរើន លោកកុំយកសាដករបស់ខ្ញុំឡើយ។ ភិក្ខុនោះមិនអើពើនឹងពាក្យប្រេតនោះ ក៏ចេះតែកាន់យកទៅ។ ខណៈនោះ សរីរៈនោះក្រោកឡើង ហើយដេញជាប់តាមក្រោយខ្នងភិក្ខុនោះ។ លំដាប់នោះឯង ភិក្ខុនោះរត់ចូលទៅក្នុងវិហារហើយបិទទ្វារ។ សរីរៈនោះ ក៏ដួលខ្ពោកក្នុងទីនោះឯង។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ តែតទៅ ពួកភិក្ខុកុំគប្បីកាន់យកសម្ពត់បំសុកូលអំពីសរីរៈខ្មោចដែលមិនទាន់ បែកធ្លាយ ភិក្ខុណាកាន់យក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។

[១៣៥] សម័យនោះឯង មានភិក្ខុ១រូប កាលគេកំពុងចែកចីវរដើម្បីសង្ឃ មានថេយ្យចិត្តគិតលួច ហើយបានផ្លាស់ស្លាកខ្លួន លួចយកចីវរភិក្ខុដទៃ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៣៦] សម័យនោះឯង ព្រះអានន្ទដ៏មានអាយុ សំគាល់ស្បង់របស់ភិក្ខុដទៃថា ជារបស់ខ្លួន ហើយស្លៀកក្នុងរោងភ្លើង។ គ្រានោះឯង ភិក្ខុម្ចាស់ស្បង់នោះ បានសួរព្រះអានន្ទដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោអានន្ទ ហេតុអ្វីបានជាលោកស្លៀកស្បង់របស់ខ្ញុំ។ ព្រះអានន្ទនិយាយតបថា អាវុសោ ខ្ញុំសំគាល់ថាជារបស់ខ្ញុំ។ ពួកភិក្ខុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុអ្នកកាន់យកដោយសំគាល់ថា ជារបស់ខ្លួនទេ។

[១៣៧] សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប ចុះចាកភ្នំគិជ្ឈកូដ បានឃើញរំពាសត្វសីហ ហើយយកមកចំអិនចែកគ្នាឆាន់។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការឆាន់រំពាសត្វសីហ

មិនត្រូវអាបត្តិឡើយ។ សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប ចុះអំពីភ្នំគិជ្ឈកូដ ហើយបានឃើញរំពាសត្វខ្លាធំ។ បេ។ ឃើញរំពាសត្វខ្លាដំបង។ បេ។ ឃើញរំពាសត្វខ្លារខិន។[27] បេ។ ឃើញរំពាសត្វឆ្កែព្រៃ ហើយនាំគ្នាយកមកចំអិនបរិភោគ។ ភិក្ខុទាំងឡាយនោះ មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុជារបស់សត្វតិរច្ឆាន មិនត្រូវអាបត្តិឡើយ។

[១៣៨] សម័យនោះឯង មានភិក្ខុ១រូប កាលគេកំពុងចែកបាយដល់សង្ឃ ខ្លួននិយាយថា លោកចូរឲ្យ១ចំណែកទៀតដើម្បីភិក្ខុដទៃ ថាដូច្នោះហើយ ក៏កាន់យកបាយដោយឥតមានមូល។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហកប៉ុណ្ណោះ។ សម័យនោះឯង មានភិក្ខុ១រូប កាលគេកំពុងចែកខាទនីយាហារដល់សង្ឃ។ បេ។ កាលគេកំពុងចែកនំដល់សង្ឃ។ បេ។ កាលគេកំពុងចែកអំពៅដល់សង្ឃ។ បេ។ កាលគេកំពុងចែកផ្លែទន្លាប់ដល់សង្ឃ បានពោលថា លោកចូរឲ្យ១ចំណែកដើម្បីភិក្ខុឯទៀតផង ថាដូច្នោះហើយក៏កាន់យកចំណែកនោះដោយឥតមានមូល។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហកប៉ុណ្ណោះ។

[១៣៩] សម័យនោះឯង មានភិក្ខុ១រូបចូលទៅកាន់ផ្ទះដែលគេដាំបាយ ក្នុងវេលាស្រុកអត់បាយ មានថេយ្យចិត្តហើយបានលួចយកបាយពេញ១បាត្រ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុ១រូប ចូលទៅកាន់ផ្ទះសម្រាប់ចំអិនសាច់លក់ក្នុងវេលាស្រុកអត់បាយ ហើយមានថេយ្យចិត្តលួចយកសាច់ដាក់ពេញ១បាត្រ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុ១រូប ចូលទៅកាន់ផ្ទះធ្វើនំក្នុងវេលាស្រុកអត់បាយ ហើយមានថេយ្យចិត្តបានលួចយកនំដាក់ពេញ១បាត្រ។ បេ។ មានថេយ្យចិត្តហើយលួចយកនំក្រៀបដាក់ពេញ១បាត្រ។ បេ។ មានថេយ្យចិត្តហើយបានលួចយកនំអន្សមដាក់ពេញ១បាត្រ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៤០] សម័យនោះឯង មានភិក្ខុ១រូបឃើញបរិក្ខារក្នុងវេលាថ្ងៃ ហើយធ្វើនិមិត្តទុកថា អញនឹងលួចយកក្នុងវេលាយប់។ ភិក្ខុនោះសំគាល់របស់នោះបានហើយ លួចយករបស់នោះបានមក។ បេ។ សំគាល់របស់នោះបានហើយ លួចបានរបស់ដទៃមកវិញ។ បេ។ សំគាល់របស់ដទៃទេ ត្រឡប់លួចបានរបស់នោះមកវិញ។ បេ។ សំគាល់របស់ដទៃ លួចបានរបស់ដទៃមក។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុ១រូប ឃើញបរិក្ខារក្នុងវេលាថ្ងៃ ហើយបានធ្វើនិមិត្តទុកថា អញនឹងលួចយកក្នុងវេលាយប់។ ភិក្ខុនោះសំគាល់របស់នោះបានហើយ ត្រឡប់លួចបានបរិក្ខាររបស់ខ្លួនឯងមកវិញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ។

[១៤១] សម័យនោះឯង មានភិក្ខុ១រូបឃើញថង់យាមនៅលើតាំង ហើយគិតថា កាលអញយកថង់យាមអំពីទីនេះ មុខជានឹងត្រូវអាបត្តិបារាជិក ហើយរំកិលយកថង់យាមនោះ ព្រមទាំងតាំងទៅផង។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៤២] សម័យនោះឯង ភិក្ខុ១រូបមានថេយ្យចិត្តហើយលួចយកពូករបស់សង្ឃ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៤៣] សម័យនោះឯង ភិក្ខុ១រូប មានថេយ្យចិត្តហើយលួចយកចីវរដែលពាក់លើខ្សែស្បៀង។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៤៤] សម័យនោះឯង មានភិក្ខុ១រូប លួចយកចីវរក្នុងវិហារ ហើយគិតថា កាលអញចេញអំពីវិហារនេះទៅ អញនឹងត្រូវអាបត្តិបារាជិកមិនខាន ហើយពុំបានចេញអំពីវិហារឡើយ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះគប្បីចេញទៅក្តី មិនគប្បីចេញទៅក្តី គង់តែត្រូវអាបត្តិបារាជិកដែរ។

[១៤៥] សម័យនោះឯង មានភិក្ខុ២រូប ជាសំឡាញ់នឹងគ្នា ភិក្ខុ១រូបចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ឯភិក្ខុទី២ កាលគេចែកខាទនីយាហារដល់សង្ឃ ក៏បានកាន់យកចំណែករបស់ភិក្ខុជាសំឡាញ់ ហើយបរិភោគដោយសេចក្តីស្និទ្ធស្នាលនឹងគ្នា។ ភិក្ខុសំឡាញ់នោះដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គកាន់យកដោយស្និទ្ធស្នាលនឹងគ្នា។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើកាន់យកដោយសេចក្តីស្និទ្ធស្នាលដូច្នោះ អ្នកមិនត្រូវអាបត្តិឡើយ។

[១៤៦] សម័យនោះឯង ភិក្ខុច្រើនរូបធ្វើនូវចីវរកម្ម។ កាលគេចែកខាទនីយាហារដល់សង្ឃ ខាទនីយាហារជាចំណែករបស់ភិក្ខុទាំងអស់នោះ គេក៏បាននាំយកទៅទុកដាក់១កន្លែងហើយ។ មានភិក្ខុ១រូប សំគាល់ចំណែករបស់ភិក្ខុឯទៀត ថាជារបស់ខ្លួន ហើយឆាន់អស់ទៅ។ ភិក្ខុម្ចាស់របស់ដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់ខ្លួន។ សម័យនោះឯង ភិក្ខុច្រើនរូបធ្វើនូវចីវរកម្ម។ កាលគេចែកខាទនីយាហារដល់សង្ឃ ភិក្ខុយកបាត្រភិក្ខុឯទៀតមកទទួលយកចំណែករបស់ភិក្ខុឯទៀត ហើយយកទៅទុក។ ភិក្ខុម្ចាស់បាត្រសំគាល់ថាជារបស់ខ្លួន ហើយឆាន់អស់ទៅ។ ភិក្ខុនោះដឹងហើយ ចោទប្រកាន់ភិក្ខុម្ចាស់បាត្រនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់ខ្លួន។

[១៤៧] សម័យនោះឯង ពួកចោរលួចស្វាយ បេះផ្លែស្វាយបាន ហើយវេចជាសំពាយ ស្ពាយដើរទៅ។ ពួកមនុស្សជាម្ចាស់ស្វាយនាំគ្នាដេញតាមចោរអម្បាលនោះ។ ពួកចោរឃើញម្ចាស់ស្វាយទាំងឡាយដេញតាម ក៏ទំលាក់សំពាយស្វាយរត់ចោលទៅ។ ភិក្ខុទាំងឡាយសំគាល់សំពាយ

ស្វាយនោះ ថាជារបស់បំសុកូល ហើយទស់ឆាន់ទៅ។ ពួកម្ចាស់ស្វាយចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមានចិត្តគិតដូចម្តេច។ ភិក្ខុទាំងឡាយនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយសំគាល់ថាជារបស់បំសុកូល។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូលឡើយ។ សម័យនោះឯង ពួកចោរលួចព្រីង។ បេ។ ពួកចោរលួចខ្នុរសំឡ។ បេ។ ពួកចោរលួចខ្នុរណាំង។ បេ។ ពួកចោរលួចត្នោតទុំ។ បេ។ ពួកចោរលួចអំពៅ។ បេ។ ពួកចោរលួចផ្លែទន្លាប់ នាំគ្នាលួចបេះផ្លែទន្លាប់ទាំងឡាយ បានហើយវេចជាសំពាយ ស្ពាយដើរទៅ។ ពួកម្ចាស់ទន្លាប់ដេញតាមពួកចោរអម្បាលនោះ។ ចោរទាំងឡាយឃើញពួកម្ចាស់ទន្លាប់ហើយ ទំលាក់សំពាយចោល រត់ទៅ។ ភិក្ខុទាំងឡាយឃើញ សំគាល់នូវសំពាយនោះ ថាជារបស់បំសុកូល ហើយនាំគ្នាទស់ឆាន់ទៅ។ ពួកជនជាម្ចាស់នាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូលឡើយ។

[១៤៨] សម័យនោះឯង ពួកចោរលួចស្វាយ បេះផ្លែស្វាយបាន ហើយវេចជាសំពាយ ស្ពាយដើរទៅ។ ពួកម្ចាស់ស្វាយដេញតាមចោរទាំងអម្បាលនោះ។ ចោរទាំងឡាយឃើញពួកម្ចាស់ស្វាយហើយ ទំលាក់សំពាយចោល រត់ទៅ។ ភិក្ខុទាំងឡាយមានថេយ្យចិត្តគិតថា ក្រែងម្ចាស់ស្វាយគេឃើញមុន ទើបនាំគ្នាឆាន់អស់ទៅ។ ពួកម្ចាស់ស្វាយនាំគ្នាចោទប្រកាន់ពួកភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង ពួកចោរលួចព្រីង។ បេ។ ពួកចោរលួចខ្នុរសំឡ។ បេ។ ពួកចោរលួចផ្លែខ្នុរណាំង។ បេ។ ពួកចោរលួចផ្លែត្នោតទុំ។ បេ។ ពួកចោរលួចអំពៅ។ បេ។ ពួកចោរលួចផ្លែទន្លាប់ លួចបេះផ្លែទន្លាប់ទាំងឡាយបាន ហើយវេចជាសំពាយ ស្ពាយដើរទៅ។ ម្ចាស់ទន្លាប់ទាំងឡាយដេញតាមពួកចោរអម្បាលនោះ។ ចោរទាំងឡាយឃើញម្ចាស់ទន្លាប់ហើយ ទំលាក់សំពាយចោល ហើយរត់ទៅ។ ភិក្ខុទាំងឡាយមានថេយ្យចិត្តគិតថា ក្រែងម្ចាស់ទន្លាប់ទាំងឡាយគេមកឃើញមុន ទើបនាំគ្នាឆាន់អស់ទៅ។ ម្ចាស់ទន្លាប់ទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ។

[១៤៩] សម័យនោះឯង ភិក្ខុ១រូប មានថេយ្យចិត្តលួចយកស្វាយរបស់សង្ឃ។ បេ។ លួចយកព្រីងរបស់សង្ឃ។ បេ។ លួចយកផ្លែខ្នុរសំឡរបស់សង្ឃ។ បេ។ លួចយកផ្លែខ្នុរណាំងរបស់សង្ឃ។ បេ។ លួចយកផ្លែត្នោតទុំរបស់សង្ឃ។ បេ។ លួចយកអំពៅរបស់សង្ឃ។ បេ។ មានថេយ្យចិត្តហើយលួចយកផ្លែទន្លាប់របស់សង្ឃ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៥០] សម័យនោះឯង មានភិក្ខុ១រូបទៅកាន់សួនផ្កា ហើយមានថេយ្យចិត្តលួចយកផ្កាមានដំឡៃ៥មាសក ដែលម្ចាស់គេបានបេះទុក។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុ១រូបទៅកាន់សួនផ្កា ហើយមានថេយ្យចិត្តលួចបេះផ្កាមានដំឡៃ៥មាសក។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៥១] សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ស្រុកតូចមួយ ហើយបាននិយាយនឹងភិក្ខុ១រូបថា អាវុសោ លោកផ្តាំខ្ញុំហើយ ខ្ញុំនឹងទៅប្រាប់ត្រកូលជាឧបដ្ឋាករបស់លោក។ ភិក្ខុនោះទៅហើយ បានឲ្យត្រកូលនោះយកសម្ពត់សាដក១មក ហើយប្រើប្រាស់ដោយខ្លួនឯង។ ភិក្ខុអ្នកជិតដិតនឹងត្រកូលដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីពោលថា អ្នកផ្តាំខ្ញុំហើយ ខ្ញុំនឹងប្រាប់ដូច្នេះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ស្រុកតូចមួយ។ ភិក្ខុឯទៀតបាននិយាយពាក្យនេះនឹងភិក្ខុនោះថា អាវុសោ ខ្ញុំផ្តាំហើយ លោកប្រាប់ត្រកូលឧបដ្ឋាករបស់ខ្ញុំចុះ។ ភិក្ខុនោះទៅហើយ ឲ្យត្រកូលឧបដ្ឋាកនោះយកសម្ពត់សាដក១គូមក ហើយប្រើប្រាស់សម្ពត់សាដក១ដោយខ្លួនឯង រួចឲ្យសម្ពត់សាដក១ដល់ភិក្ខុអ្នកជិតដិតនឹងត្រកូលនោះ។ ភិក្ខុនោះដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ តែភិក្ខុកុំគប្បីពោលថា លោកខ្ញុំផ្តាំហើយ ប្រាប់ចុះដូច្នេះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ស្រុកតូចមួយ ហើយបាននិយាយពាក្យនេះនឹងភិក្ខុឯទៀតថា អាវុសោ លោកផ្តាំនឹងខ្ញុំហើយ ខ្ញុំនឹងប្រាប់ត្រកូលឧបដ្ឋាករបស់លោក។ ឯភិក្ខុនោះក៏បាននិយាយយ៉ាងនេះថា ខ្ញុំបានផ្តាំនឹងលោកហើយ លោកប្រាប់ចុះ។ ភិក្ខុនោះទៅហើយ ឲ្យត្រកូលឧបដ្ឋាកនោះយកសប្បិ១អាឡ្ហកៈ[28] ស្ករ អំពៅ១គុលៈ[29] អង្ករ១ទោណៈ[30] មកហើយ បរិភោគដោយខ្លួនឯង។ ភិក្ខុអ្នកជិតដិតនឹងត្រកូលនោះដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីពោលថា លោកផ្តាំនឹងខ្ញុំហើយ ខ្ញុំនឹងប្រាប់ដូច្នេះ ម្យ៉ាងទៀត កុំគប្បីពោលថា ខ្ញុំផ្តាំនឹងលោកហើយ លោកប្រាប់ចុះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

[១៥២] សម័យនោះឯង បុរសម្នាក់នាំយកកែវមណីមានដំឡៃច្រើន ហើយដើរទៅកាន់ផ្លូវឆ្ងាយជាមួយនឹងភិក្ខុឯទៀត។ លំដាប់នោះ បុរសនោះឃើញទីគយហើយ ដាក់កែវមណីក្នុងថង់យាមរបស់ភិក្ខុនោះ ៗឥតដឹងឡើយ លុះកន្លងផុតទីគយហើយ ក៏យកកែវមណីពីថង់យាមមកវិញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្តេច។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនបានដឹងសោះឡើយ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមិនដឹង។ សម័យនោះឯង បុរសម្នាក់នាំយកកែវមណីមានដំឡៃច្រើន ដើរទៅកាន់ផ្លូវឆ្ងាយជាមួយនឹងភិក្ខុឯទៀត។ លំដាប់នោះ បុរសនោះឃើញទីគយហើយ ក៏ធ្វើអាការហាក់ដូចជាឈឺ ហើយបានប្រគល់បង្វិចកែវមណីរបស់ខ្លួនដល់ភិក្ខុនោះ។ គ្រានោះឯង បុរសនោះដើររំលងហួសទីគយទៅហើយ បាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ ចូរលោកយកបង្វិចរបស់ខ្ញុំមក ខ្ញុំមិនឈឺទេ។ ភិក្ខុនោះសួរថា អាវុសោ ចុះហេតុអ្វីបានជាអ្នកធ្វើអាការយ៉ាងនេះ។ ទើបបុរសនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនោះ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្តេច។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងសោះឡើយ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមិនដឹង។ សម័យនោះឯង មានភិក្ខុ១រូប ដើរទៅកាន់ផ្លូវឆ្ងាយជាមួយនឹងឈ្មួញរទេះ។ បុរសម្នាក់ក៏លួងលោមភិក្ខុនោះដោយអាមិស លុះឃើញទីគយហើយ បានឲ្យកែវមណីមាន

ដំឡៃច្រើន ដល់ភិក្ខុនោះដោយពាក្យថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់យកកែវមណីនេះ ឲ្យរំលងទីគយទៅផង។ ភិក្ខុនោះយកកែវមណីនោះ រំលងទីគយទៅក្នុងកាលនោះឯង។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៥៣] សម័យនោះឯង មានភិក្ខុ១រូប ដោះលែងជ្រូកជាប់អន្ទាក់ ដោយសេចក្តីករុណា។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានសេចក្តីប្រាថ្នាដោយសេចក្តីករុណា (ហើយដោះលែងទៅ)។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមានសេចក្តីប្រាថ្នាដោយសេចក្តីករុណាទេ។ សម័យនោះឯង មានភិក្ខុ១រូប ឃើញជ្រូកជាប់អន្ទាក់ ក៏មានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់គេឃើញមុន ហើយដោះលែងជ្រូកនោះទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុ១រូប ដោះលែងសត្វម្រឹគជាប់អន្ទាក់ ដោយសេចក្តីករុណា។ បេ។ ភិក្ខុឃើញម្រឹគជាប់អន្ទាក់ មានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់គេឃើញមុន ហើយដោះលែងម្រឹគនោះទៅ។ បេ។ ភិក្ខុដោះលែងត្រីទាំងឡាយដែលជាប់លបដោយសេចក្តីករុណា។ បេ។ ភិក្ខុឃើញត្រីទាំងឡាយជាប់លប មានថេយ្យចិត្តថា ក្រែងពួកម្ចាស់គេឃើញមុន ហើយដោះលែងត្រីនោះទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៥៤] សម័យនោះឯង មានភិក្ខុ១រូប ឃើញទ្រព្យនៅក្នុងយាន ហើយគិតថា បើអញយកចាកទីនេះ មុខជានឹងត្រូវអាបត្តិបារាជិក ទើបឈូសប្រមៀលឲ្យធ្លាក់ចុះ ហើយក៏កាន់យកទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[១៥៥] សម័យនោះឯង មានភិក្ខុ១រូប បានរើសយកដុំសាច់ដែលសត្វអាតពាំយកទៅ ដោយគិតថា អញនឹងប្រគល់ឲ្យពួកម្ចាស់សាច់។ ពួកម្ចាស់សាច់នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានថេយ្យចិត្ត។ សម័យនោះឯង មានភិក្ខុ១រូបឃើញដុំសាច់ដែលសត្វអាតពាំយកទៅ មានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់គេឃើញមុន ហើយក៏កាន់យកដុំសាច់នោះទៅ។ ពួកម្ចាស់សាច់នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៥៦] សម័យនោះឯង មនុស្សទាំងឡាយចងក្បូន ហើយបណ្តែតតាមស្ទឹងអចិរវតី។ កាលចំណងក្បូនដាច់ ឈើទាំងឡាយក៏អណ្តែតខ្ចាត់ខ្ចាយទៅ។ ភិក្ខុទាំងឡាយសំគាល់ថា ជារបស់បំសុកូល ហើយនាំគ្នាស្រង់យកឡើង។ ពួកម្ចាស់ក្បូននាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូល។ សម័យនោះឯង មនុស្សទាំងឡាយចងក្បូន ហើយបណ្តែតតាមស្ទឹងអចិរវតី។ កាលចំណងក្បូនដាច់ ឈើទាំងឡាយក៏អណ្តែតខ្ចាត់ខ្ចាយទៅ។ ភិក្ខុទាំងឡាយមានថេយ្យចិត្តគិតថា ក្រែងម្ចាស់ឈើគេឃើញមុន ហើយស្រង់យកឡើង ពួកម្ចាស់ឈើនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុទាំងអម្បាលនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ។

[១៥៧] សម័យនោះឯង មានបុរសគង្វាលគោម្នាក់ ពាក់សម្ពត់សាដកនឹងដើមឈើ ហើយក៏ដើរទៅបន្ទោឧច្ចារៈ។ ភិក្ខុ១រូបសំគាល់ថាជារបស់បំសុកូល ហើយក៏កាន់យកទៅ។ គ្រានោះ បុរសគង្វាលគោនោះចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូល។

[១៥៨] សម័យនោះឯង កាលភិក្ខុ១រូបកំពុងឆ្លងស្ទឹង សម្ពត់សាដកក៏របូតអំពីដៃជាងជ្រលក់ទាំងឡាយ ហើយទៅជាប់នឹងជើងភិក្ខុ។ ភិក្ខុនោះបានកាន់យកសម្ពត់សាដកនោះដោយគិតថា អញនឹងឲ្យដល់ម្ចាស់ទាំងឡាយ។ ពួកម្ចាស់សម្ពត់សាដកក៏នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានថេយ្យចិត្ត។ សម័យនោះឯង កាលភិក្ខុ១រូបកំពុងឆ្លងស្ទឹង សម្ពត់សាដករបូតអំពីដៃនៃជាងជ្រលក់ទាំងឡាយ ហើយរសាត់ទៅជាប់នឹងជើងភិក្ខុ។ ភិក្ខុនោះ មានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់សម្ពត់សាដកឃើញមុន ហើយក៏កាន់យកទៅ។ ម្ចាស់សម្ពត់សាដកទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៥៩] សម័យនោះឯង ភិក្ខុ១រូបបានឃើញឆ្នាំងដាក់សប្បិ ហើយបានឆាន់បន្តិចៗម្តង។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ។

[១៦០] កាលណោះ ភិក្ខុទាំងឡាយច្រើនរូបបាននិយាយបបួលគ្នាថា យើងទាំងឡាយនឹងទៅលួចទ្រព្យ ហើយនាំគ្នាទៅ។ ភិក្ខុ១រូបលួចទ្រព្យបានមក។ ភិក្ខុទាំងឡាយនោះ បាននិយាយគ្នាយ៉ាងនេះថា ពួកយើងមិនត្រូវអាបត្តិបារាជិកទេ លោកណាលួចបានមក លោកនោះត្រូវអាបត្តិបារាជិក។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ។ កាលណោះ ភិក្ខុទាំងឡាយច្រើនរូប បបួលគ្នាលួចទ្រព្យបានមកហើយ ក៏ចែកគ្នា។ កាលដែលភិក្ខុអម្បាលនោះកំពុងចែកគ្នា ភិក្ខុ១រូបៗ បានចំណែកមិនពេញ៥មាសក។ ភិក្ខុទាំងនោះបាននិយាយយ៉ាងនេះថា យើងទាំងឡាយមិនត្រូវអាបត្តិបារាជិកទេ។ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ។

[១៦១] សម័យនោះ ភិក្ខុ១រូប កាលក្រុងសាវត្ថីកើតទុរ្ភិក្ស អត់បាយ (ភិក្ខុនោះ) មានថេយ្យចិត្ត ហើយលួចយកអង្ករបស់អ្នកផ្សារប្រមាណ១ក្តាប់។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះ ភិក្ខុ១រូប កាលក្រុងសាវត្ថីកើតទុរ្ភិក្សអត់បាយ មានថេយ្យចិត្ត ហើយលួចយកសណ្តែកបាយរបស់អ្នកផ្សារ១ក្តាប់។ បេ។ សណ្តែករាជមាស១ក្តាប់។ បេ។ ល្ង១ក្តាប់។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៦២] សម័យនោះ ពួកចោរសម្លាប់មេគោ ស៊ីសាច់ហើយ ក៏ទុកដាក់សាច់ដ៏សេសសល់ក្នុងព្រៃអន្ធវន ទៀបក្រុងសាវត្ថី ហើយនាំគ្នាទៅ។ ភិក្ខុទាំងឡាយសំគាល់ថាជារបស់បំសុកូល ហើយនាំគ្នាកាន់យកសាច់នោះបរិភោគទៅ។ ពួកចោរនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុអម្បាលនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូល។ សម័យនោះ ពួកចោរសម្លាប់ជ្រូក ស៊ីសាច់ ហើយទុកដាក់សាច់ដ៏សេសសល់ក្នុងព្រៃអន្ធវន ទៀបក្រុងសាវត្ថី ហើយនាំគ្នាទៅ។ ភិក្ខុទាំងឡាយសំគាល់ថាជារបស់បំសុកូល ហើយនាំគ្នាកាន់យកសាច់នោះមកឆាន់ទៅ។ ពួកចោរនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុអម្បាលនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសំគាល់ថាជារបស់បំសុកូល។

[១៦៣] កាលណោះ ភិក្ខុ១រូបទៅកាន់ស្រែស្មៅ (ចម្ការស្មៅ) មានថេយ្យចិត្ត ហើយបានលួចយកស្មៅដែលគេច្រូតទុក មានដំឡៃ៥មាសក។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៦៤] សម័យនោះ ភិក្ខុ១រូបទៅកាន់ស្រែស្មៅ មានថេយ្យចិត្ត ហើយលួចច្រូតយកស្មៅគេមានដំឡៃ៥មាសក។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៦៥] សម័យនោះ ភិក្ខុទាំងឡាយជាអាគន្តុក (ភិក្ខុអ្នកមកថ្មី) ញុំាងគ្នានឹងគ្នាឲ្យចែកផ្លែស្វាយរបស់សង្ឃ ហើយបរិភោគទៅ។ ភិក្ខុម្ចាស់អាវាសទាំងឡាយ នាំគ្នាចោទប្រកាន់ភិក្ខុជាអាគន្តុកអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុអាគន្តុកអម្បាលនោះមានសេចក្ដីសង្ស័យ។ ទើបនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកគិតដូចម្ដេច។ ភិក្ខុអម្បាលនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយ មានចិត្តប្រាថ្នាដើម្បីនឹងបរិភោគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលប្រាថ្នាដើម្បីនឹងបរិភោគទេ។ សម័យនោះ ភិក្ខុទាំងឡាយជាអាគន្តុក ញុំាងគ្នានឹងគ្នាឲ្យចែកផ្លែព្រីងរបស់សង្ឃ។ បេ។ ផ្លែខ្នុរសំឡរបស់សង្ឃ។ បេ។ ផ្លែខ្នុរណាំងរបស់សង្ឃ។ បេ។ ផ្លែត្នោតទុំរបស់សង្ឃ។ បេ។ អំពៅរបស់សង្ឃ។ បេ។ ផ្លែទន្លាប់របស់សង្ឃ ហើយនាំគ្នាបរិភោគទៅ។ ពួកភិក្ខុដែលជាម្ចាស់អាវាស នាំគ្នាចោទប្រកាន់ភិក្ខុអាគន្តុកអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ។ ភិក្ខុអាគន្តុកអម្បាលនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលប្រាថ្នាដើម្បីនឹងបរិភោគទេ។

[១៦៦] សម័យនោះ ពួកមនុស្សអ្នករក្សាស្វាយ នាំគ្នាប្រគេនផ្លែស្វាយដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយសង្ស័យមិនមានទទួល ដោយគិតថា មនុស្សអម្បាលនេះ ជាឥស្សរៈត្រឹមតែរក្សាថែទាំប៉ុណ្ណោះ មនុស្សអម្បាលនេះ មិនជាឥស្សរៈដើម្បីនឹងឲ្យបានទេ។ ទើបនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើទានដែលបុគ្គលអ្នករក្សាគេឲ្យហើយ (ភិក្ខុអ្នកទទួល) មិនត្រូវអាបត្តិឡើយ។ សម័យនោះឯង មនុស្សអ្នករក្សាព្រីងទាំងឡាយ។ បេ។ អ្នករក្សាខ្នុរសំឡទាំងឡាយ។ បេ។ អ្នករក្សាខ្នុរណាំងទាំងឡាយ។ បេ។ អ្នករក្សាផ្លែត្នោតទុំទាំងឡាយ។ បេ។ អ្នករក្សាអំពៅទាំងឡាយ។ បេ។ អ្នករក្សាផ្លែទន្លាប់ទាំងឡាយ បានប្រគេនផ្លែទន្លាប់ទាំងឡាយដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយសង្ស័យមិនហ៊ានទទួល ដោយគិតថា មនុស្សអម្បាលនេះ ជាឥស្សរៈត្រឹមតែរក្សាប៉ុណ្ណោះ មនុស្សអម្បាលនេះ មិនជាឥស្សរៈដើម្បីនឹងឲ្យទេ។ ទើបនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុ ព្រោះទានដែលអ្នកថែរក្សាឲ្យនោះទេ។

[១៦៧] សម័យនោះ ភិក្ខុ១រូបខ្ចីឈើរបស់សង្ឃយកទៅឧបត្ថម្ភ (ជួសជុល) ជញ្ជាំងវិហាររបស់ខ្លួន។ ភិក្ខុទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ ទើបក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកគិតដូចម្ដេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គតាំងចិត្តថាជារបស់ខ្ចី។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើកាន់យកជារបស់ខ្ចីដូច្នោះ អ្នកមិនមានអាបត្តិឡើយ។

[១៦៨] សម័យនោះ ភិក្ខុ១រូប មានថេយ្យចិត្ត ហើយបានលួចយកទឹករបស់សង្ឃ។ បេ។ មានថេយ្យចិត្ត ហើយបានលួចយកដីរបស់សង្ឃ។ បេ។ មានថេយ្យចិត្ត ហើយបានលួចយកស្មៅយាប្លងរបស់សង្ឃ។ បេ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង ភិក្ខុ១រូប មានថេយ្យចិត្ត ហើយលួចដុតស្មៅយាប្លងរបស់សង្ឃ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ។

[១៦៩] សម័យនោះ ភិក្ខុ១រូប មានថេយ្យចិត្ត ហើយលួចយកគ្រែរបស់សង្ឃ។ សេចក្ដីសង្ស័យមានដល់ភិក្ខុនោះ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង ភិក្ខុ១រូប មានថេយ្យចិត្ត ហើយលួចយកតាំងរបស់សង្ឃ។ បេ។ ពូករបស់សង្ឃ។ បេ។ ខ្នើយរបស់សង្ឃ។ បេ។ សន្ទះទ្វាររបស់សង្ឃ។ បេ។ សន្ទះបង្អួចរបស់សង្ឃ។ បេ។ ឈើបង្កង់របស់សង្ឃ។ សេចក្ដីសង្ស័យមានដល់ភិក្ខុនោះ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ។

[១៧០] សម័យនោះ ភិក្ខុទាំងឡាយយកសេនាសនៈរបស់ឧបាសកម្នាក់ ដែលគេទុកជារបស់សម្រាប់ប្រើប្រាស់ក្នុងវត្ត ទៅប្រើប្រាស់ក្នុងទីដទៃ។ គ្រានោះ ឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកដ៏ចំរើនទាំងឡាយមិនសមនឹងមកយករបស់គេសំរាប់ទុកប្រើប្រាស់ក្នុងទីដទៃ ទៅប្រើប្រាស់ក្នុងទីដទៃវិញ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រឿងប្រើប្រាស់របស់គេក្នុងទីដទៃ ភិក្ខុមិនគប្បីយកទៅប្រើប្រាស់ក្នុងទីដទៃទេ តែភិក្ខុណាយកទៅប្រើប្រាស់ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ សម័យនោះ ភិក្ខុទាំងឡាយប្រុងនឹងនាំយកអាសនៈសំរាប់អង្គុយក្នុងរោងឧបោសថ តែមានសេចក្ដីសង្ស័យ មិនហ៊ាននាំយកទៅ ហើយក៏អង្គុយផ្ទាល់លើផែនដី។ ខ្លួនក្ដី ចីវរក្ដី ក៏ប្រឡាក់ទៅដោយធូលី។ ភិក្ខុទាំងឡាយយកសេចក្ដីនុ៎ះក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយខ្ចីរបស់ទាំងនោះទៅប្រើប្រាស់បាន។

[១៧១] សម័យនោះឯង ភិក្ខុនី១រូប ជាសិស្សរបស់ចុល្លនន្ទាភិក្ខុនីនៅក្នុងក្រុងចម្បា ទៅកាន់ត្រកូលជាឧបដ្ឋាករបស់ចុល្លនន្ទាភិក្ខុនី ហើយបង្គាប់ត្រកូលនោះថា ចុល្លនន្ទាភិក្ខុនីជាម្ចាស់ ចង់ឆាន់បបរដែលលាយសណ្តែកនិងល្ង ហើយក៏យកទៅបរិភោគដោយខ្លួនឯង។ ចុល្លនន្ទាភិក្ខុនីនោះដឹងហើយ ចោទប្រកាន់សិស្សនោះថា នាងឯងមិនមែនជាសមណីទេ។ ភិក្ខុនីនោះមានសេចក្តីសង្ស័យ។ ទើបភិក្ខុនីនោះនាំយករឿងនុ៎ះទៅដំណាលប្រាប់ភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីនាំយករឿងនុ៎ះទៅប្រាប់ដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុនាំយករឿងនុ៎ះទៅក្រាបទូលចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហក។ សម័យនោះឯង ភិក្ខុនី១រូបជាសិស្សចុល្លនន្ទាភិក្ខុនីនៅក្នុងក្រុងរាជគ្រឹះ ទៅកាន់ត្រកូលជាឧបដ្ឋាករបស់ចុល្លនន្ទាភិក្ខុនី ហើយបង្គាប់ត្រកូលនោះថា ចុល្លនន្ទាភិក្ខុនីជាម្ចាស់ ចង់ឆាន់នំមានរសឆ្ងាញ់ក្រៃពេក ហើយក៏យកទៅបរិភោគដោយខ្លួនឯង។ ចុល្លនន្ទាភិក្ខុនីនោះដឹងហើយ ចោទប្រកាន់សិស្សនោះថា នាងឯងមិនមែនជាសមណីទេ។ ភិក្ខុនីនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហក។

[១៧២] សម័យនោះឯង ក្មេងពីរនាក់ គឺកូនប្រុស១ ក្មួយប្រុស១របស់គហបតីជាឧបដ្ឋាករបស់ព្រះអជ្ជុកត្ថេរដ៏មានអាយុ ក្នុងក្រុងវេសាលី។ គ្រានោះ គហបតីនោះបាននិយាយពាក្យនេះនឹងព្រះអជ្ជុកត្ថេរដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ជំនុំក្មេងទាំងពីរនាក់នេះ ក្មេងណាមានសទ្ធាជ្រះថ្លា ព្រះករុណាគប្បីប្រាប់ឱកាសនេះដល់ក្មេងនោះ។ គហបតីនោះធ្វើកាលកិរិយាទៅ។ សម័យនោះឯង ក្មួយរបស់គហបតីនោះមានសទ្ធាជ្រះថ្លា។ លំដាប់នោះ ព្រះអជ្ជុកត្ថេរដ៏មានអាយុ បានប្រាប់ឱកាសនោះដល់ទារកដែលជាក្មួយនោះ។ ទារកដែលជាក្មួយនោះ ក៏បានបីបាច់រក្សានូវទ្រព្យ និងចាត់ចែងនូវទានដោយសម្បត្តិនោះ។ លំដាប់នោះ កូនរបស់គហបតីនោះបាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា បពិត្រព្រះអានន្ទដ៏ចំរើន អ្នកណាជាអ្នកទទួលមត៌ករបស់បិតា កូន ឬក្មួយ។ ព្រះអានន្ទនិយាយតបថា ម្នាលអ្នកដ៏មានអាយុ កូនទើបត្រូវទទួលទ្រព្យមត៌ករបស់បិតាបាន។ កូនរបស់គហបតីនោះ បាននិយាយតទៅទៀតថា បពិត្រលោកដ៏ចំរើន លោកម្ចាស់អជ្ជុកត្ថេរនេះប្រាប់សម្បត្តិរបស់ខ្ញុំដល់បងប្អូនជីដូនមួយ របស់ខ្ញុំហើយ។ ព្រះអានន្ទពោលថា ម្នាលអ្នកដ៏មានអាយុ អជ្ជុកត្ថេរដ៏មានអាយុនេះ មិនមែនជាសមណៈទេ។ គ្រានោះ ព្រះអជ្ជុកត្ថេរដ៏មានអាយុ បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ លោកចូរឲ្យសេចក្តីវិនិច្ឆ័យដល់ខ្ញុំចុះ។ សម័យនោះឯង ព្រះឧបាលីដ៏មានអាយុ ជាបក្ខពួករបស់ព្រះអជ្ជុកត្ថេរដ៏មានអាយុ។ លំដាប់នោះ ព្រះឧបាលីដ៏មានអាយុ បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ ភិក្ខុណាដែលម្ចាស់ទ្រព្យផ្តាំទុកថា លោកចូរប្រាប់ឱកាសនេះដល់អ្នកនេះ ហើយភិក្ខុនោះទៅប្រាប់ដល់អ្នកនោះ ភិក្ខុនោះត្រូវអាបត្តិអ្វី។ ព្រះអានន្ទឆ្លើយតបទៅវិញថា បពិត្រលោកដ៏ចំរើន ភិក្ខុនោះមិនត្រូវអាបត្តិអ្វីបន្តិចទេ ដោយហោចទៅ តែអាបត្តិទុក្កដក៏មិនត្រូវដែរ។ ព្រះឧបាលីឆ្លើយថា ម្នាលអាវុសោ ព្រះអជ្ជុកត្ថេរដ៏មានអាយុនេះ ម្ចាស់ទ្រព្យបានផ្តាំទុកថា លោកចូរប្រាប់ឱកាសនេះដល់ជនឈ្មោះនេះ ក៏បានប្រាប់ដល់អ្នកនោះមែន ម្នាលអាវុសោ អជ្ជុកត្ថេរដ៏មានអាយុមិនត្រូវអាបត្តិទេ។

[១៧៣] សម័យនោះឯង ក្នុងក្រុងពារាណសី ពួកចោរនាំគ្នាប្លន់ត្រកូលឧបដ្ឋាករបស់ព្រះបិលិន្ទវច្ឆត្ថេរដ៏មាន អាយុ ហើយក៏នាំយកកូនក្មេងពីរនាក់ទៅ។ លំដាប់នោះ ព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុ សំដែងឫទ្ធិទៅនាំយកក្មេងទាំងពីរនាក់នោះបានមក ហើយទុកក្នុងប្រាសាទ។ មនុស្សទាំងឡាយបានឃើញក្មេងទាំងពីរនាក់នោះហើយ និយាយថា នេះជាឫទ្ធានុភាពរបស់លោកម្ចាស់បិលិន្ទវច្ឆត្ថេរ ហើយក៏នាំគ្នាជ្រះថ្លានឹងព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុពេកណាស់។ ភិក្ខុទាំងឡាយ នាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា បិលិន្ទវច្ឆត្ថេរដ៏មានអាយុ មិនសមគួរនឹងទៅនាំយកក្មេងពីរនាក់ ដែលពួកចោរវានាំយកទៅហើយ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុអ្នកមានឫទ្ធិទេ ព្រោះវិស័យនៃឫទ្ធិ។

[១៧៤] សម័យនោះឯង ភិក្ខុពីររូបជាសំឡាញ់គ្នា ឈ្មោះបណ្ឌកៈ១ កបិលៈ១។ ភិក្ខុ១រូបនៅស្រុកក្រៅ ១រូបនៅក្នុងក្រុងកោសម្ពី។ គ្រាដែលភិក្ខុនោះចេញពីស្រុកក្រៅ ទៅកាន់ក្រុងកោសម្ពី កាលកំពុងឆ្លងទឹកស្ទឹងក្នុងរវាងពាក់កណ្តាលផ្លូវ កន្សោមខ្លាញ់របូតអំពីដៃនៃមនុស្សអ្នកសម្លាប់ជ្រូកទាំងឡាយ ទៅជាប់នូវជើងរបស់ភិក្ខុនោះ។ ភិក្ខុនោះបានកាន់យកដោយគិតថា នឹងឲ្យដល់ជនទាំងឡាយជាម្ចាស់វិញ។ ពួកម្ចាស់នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ។ ស្រីគង្វាលគោម្នាក់ឃើញភិក្ខុនោះឆ្លងទឹកស្ទឹងរួចហើយ បាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ លោកចូរមកសេពមេថុនធម្មនឹងខ្ញុំ។ ភិក្ខុនោះគិតថា អញមិនមែនជាសមណៈតាមប្រក្រតីទេ ទើបព្រមសេពមេថុនធម្មនឹងស្រីនោះ ហើយទៅកាន់ក្រុងកោសម្ពី ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា នែភិក្ខុទាំងឡាយ ភិក្ខុនោះមិនត្រូវអាបត្តិបារាជិកព្រោះអទិន្នាទានទេ ត្រូវអាបត្តិបារាជិក ព្រោះសេពមេថុនធម្ម។

[១៧៥] សម័យនោះឯង ភិក្ខុជាសទ្ធិវិហារិករបស់ព្រះទឡ្ហិកត្ថេរដ៏មានអាយុ ក្នុងសាគលនគរ មានសេចក្តីមិនសប្បាយមកបៀតបៀន ក៏ទៅលួចយកឈ្នួតរបស់អ្នកផ្សារ ហើយបាននិយាយពាក្យនេះនឹងព្រះទឡ្ហិកត្ថេរដ៏មានអាយុយ៉ាងនេះថា បពិត្រលោកដ៏ចំរើន ខ្ញុំមិនមែនជាសមណៈទេ ខ្ញុំនឹងសឹក (ឥឡូវនេះ)។ ព្រះទឡ្ហិកត្ថេរ បានសួរថា ម្នាលអាវុសោ អំពើដូចម្តេចដែលអ្នកធ្វើហើយ។ ភិក្ខុនោះប្រាប់ថា បពិត្រលោកដ៏ចំរើន ខ្ញុំលួចយកឈ្នួតរបស់អ្នកផ្សារ។ ព្រះទឡ្ហិកត្ថេរ ក៏ឲ្យយកឈ្នួតនោះមក ហើយកាត់ថ្លៃ។ ឈ្នួតនោះកាត់ថ្លៃទៅ ដំឡៃមិនដល់៥មាសក។ ព្រះទឡ្ហិកត្ថេរប្រាប់ថា ម្នាលអាវុសោ អ្នកមិនត្រូវអាបត្តិបារាជិកទេ ដូច្នេះហើយ ក៏បានសំដែងធម្មីកថា។ ឯភិក្ខុនោះមានសេចក្តីត្រេកអរក្រៃពេក។

ទុតិយបារាជិក ចប់។

# បារាជិកកណ្ឌេ តតិយសិក្ខាបទំ

CS vin.vbu.pr.03 | ភាគ ទី១

### (៣. តតិយបារាជិកំ)

### (បឋមភាណវារៈ តតិយសិក្ខាបទំ)

(-)

[១៧៦] សម័យនោះ ព្រះសម្ពុទ្ធដ៏មានជោគ ទ្រង់គង់នៅក្នុងកូដាគារសាលា[31] ក្បែរព្រៃមហាវន[32] ទៀបក្រុងវេសាលី[33]។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងអសុភកថា ទ្រង់សំដែងរៀបរាប់អំពីអសុភ ទ្រង់សំដែងគុណនៃការចំរើនអសុភកម្មដ្ឋាន ទ្រង់សំដែងគុណនៃអសុភសមាបត្តិក្នុងអសុភកម្មដ្ឋានជាញឹកញយ ដោយបរិយាយដ៏ច្រើន។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតចង់គេចចាកអារម្មណ៍ សម្ងំនៅអស់កាលកន្លះខែ (ក្នុងកម្មដ្ឋាន) កុំឲ្យអ្នកណាមួយចូលទៅរកតថាគតឡើយ វៀរលែងតែភិក្ខុមួយរូបជាអ្នកនាំបិណ្ឌបាតទៅឲ្យតថាគត។ ទើបពួកភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ឯវំភន្តេ (យ៉ាងហ្នឹងព្រះអង្គ) តាំងពីកាលនោះមក មិនមានអ្នកណាមួយចូលទៅគាល់ព្រះដ៏មានព្រះភាគឡើយ វៀរលែងតែភិក្ខុមួយរូបជាអ្នកនាំបិណ្ឌបាតទៅថ្វាយព្រះអង្គ។ ភិក្ខុទាំងឡាយគិតគ្នាថា ព្រះដ៏មានព្រះភាគទ្រង់សំដែងអសុភកថា ទ្រង់សំដែងរៀបរាប់អំពីអសុភ ទ្រង់សំដែងគុណនៃការចំរើនអសុភកម្មដ្ឋាន ទ្រង់សំដែងគុណនៃអសុភសមាបត្តិ ក្នុងអសុភកម្មដ្ឋានជាញឹកញយ។ ដោយបរិយាមិនតែមួយ លុះគិតដូច្នេះហើយ ក៏នាំគ្នាប្រកបសេចក្តីព្យាយាមក្នុងការចំរើនអសុភកម្មដ្ឋានជា ច្រើនបែបច្រើនវិធី។ ពួកភិក្ខុទាំងនោះកើតសេចក្តីទុក្ខ នឿយណាយ ខ្ពើមឆ្អើមនឹងរាងកាយរបស់ខ្លួនឯង មានគួរនាដូចជាស្រីក្រមុំ ឬប្រុសកំឡោះ ជាអ្នកមានកិរិយាស្អិតស្អាងជាប្រក្រតី លុះបានងូតទឹក កក់ក្បាលហើយ រមែងជាទុក្ខនឿយណាយ ខ្ពើមឆ្អើមសាកអសុភពស់ សាកអសុភឆ្កែ ឬសាកអសុភមនុស្សដែលគេព្យួរនឹងក យ៉ាងណាមិញ ពួកភិក្ខុទាំងនោះ ក៏ជាទុក្ខនឿយណាយ ខ្ពើមឆ្អើមនឹងកាយរបស់ខ្លួន យ៉ាងនោះឯង ទើបផ្តាច់ជីវិតខ្លួនដោយខ្លួនឯងខ្លះ ផ្តាច់ជីវិតគ្នាទៅវិញទៅមកខ្លះ ភិក្ខុខ្លះចូលទៅរកសមណកុត្តក[34] ឈ្មោះមិគលណ្ឌិក ហើយពោលយ៉ាងនេះថា នែអ្នកដ៏មានអាយុ យើងសូមអង្វរអ្នក ៗចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រនិងចីវរទាំងនេះ នឹងបានជារបស់អ្នក។ គ្រានោះឯង សមណកុត្តកឈ្មោះមិគលណ្ឌិកទទួលស៊ីឈ្នួលយកបាត្រ និងចីវរហើយ ទើបផ្តាច់បង់ជីវិតភិក្ខុទាំងឡាយជាច្រើនរូប ហើយកាន់ដាវប្រឡាក់ឈាមដើរទៅកាន់ស្ទឹងឈ្មោះវគ្គុមុទា កាលដែលសមណកុត្តកឈ្មោះមិគលណ្ឌិកកំពុងលាងដាវប្រឡាក់ឈាមនោះ (គាត់) ក៏មានសេចក្តីសង្ស័យ ក្តៅក្រហាយស្តាយក្រោយក្នុងកាលនោះ ដោយគិតឃើញថា ការនេះមិនមែនជាលាភរបស់អញទេតើ នឹងចាត់ថាជាលាភរបស់អញមិនបានឡើយ ជាតិជាមនុស្សអញបានដោយក្រណាស់ ជាតិជាមនុស្សឈ្មោះថា អញបានដោយងាយមិនមែនឡើយ អញបានបាបច្រើនណាស់ ព្រោះអញបានផ្តាច់បង់ជីវិតពួកភិក្ខុអ្នកមានសីល មានធម៌ល្អ។ លំដាប់នោះ ទេវតា ជាពួករបស់មារ ដើរមកលើទឹកមិនមានបែកធ្លាយ បាននិយាយពាក្យនេះនឹងសមណកុត្តកឈ្មោះមិគលណ្ឌិកថា ល្អហើយៗអ្នកសប្បុរស ការនេះជាលាភរបស់អ្នកហើយ អ្នកសប្បុរស ជាតិជាមនុស្សអ្នកក៏បានដោយប្រពៃហើយ អ្នកសប្បុរស អ្នកបានប្រទះបុណ្យច្រើនហើយ អ្នកសប្បុរស ព្រោះអ្នកបានញុំាងជនទាំងឡាយដែលមិនទាន់ឆ្លងសង្សារវដ្តឲ្យឆ្លងផុត ទៅបាន។ គ្រានោះឯង សមណកុត្តកឈ្មោះមិគលណ្ឌិក ក៏នឹកអរថា ឮថា (ការនេះ) ជាលាភរបស់អញ ឮគេថា ជាតិមនុស្ស អញបានដោយល្អហើយ ឮគេថា អញបានប្រទះបុណ្យជាច្រើន ឮគេថា អញបានញុំាងជនទាំងឡាយដែលមិនទាន់ឆ្លង (សង្សារវដ្ត) ឲ្យឆ្លងផុតទៅបាន លុះគិតដូច្នេះហើយ ក៏កាន់ដាវមុតដើរចេញពីវិហារចូលទៅកាន់វិហារ ចេញពីបរិវេណចូលទៅកាន់បរិវេណ ហើយពោលយ៉ាងនេះថា លោកណាមិនទាន់ឆ្លង (សង្សារវដ្ត) ខ្ញុំនឹងឲ្យលោកណាឆ្លងសង្សារវដ្តបាន។ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណាដែលមិនទាន់ប្រាសចាករាគៈ សេចក្តីខ្លាច សេចក្តីញាប់ញ័រ និងសេចក្តីព្រឺរោម ក៏មានដល់ភិក្ខុទាំងនោះជាប្រាកដក្នុងសម័យនោះ។ ចំណែកភិក្ខុទាំងឡាយណា ដែលប្រាសចាករាគៈហើយ សេចក្តីខ្លាច សេចក្តីញាប់ញ័រ និងសេចក្តីព្រឺរោម ក៏មិនមានដល់ភិក្ខុទាំងនោះក្នុងសម័យនោះឡើយ។ គ្រានោះ សមណកុត្តកឈ្មោះមិគលណ្ឌិក ក៏ផ្តាច់បង់ជីវិតភិក្ខុក្នុងមួយថ្ងៃ១រូបក៏មាន ក្នុង១ថ្ងៃ ផ្តាច់បង់ជីវិតភិក្ខុពីររូបក៏មាន ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុបីរូបក៏មាន ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុបួនរូបក៏មាន ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុប្រាំរូបក៏មាន។ បេ។ ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុដប់រូបក៏មាន ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុម្ភៃរូបក៏មាន ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុសាមសិបរូបក៏មាន ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុសែសិបរូបក៏មាន ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុហាសិបរូបក៏មាន ១ថ្ងៃផ្តាច់បង់ជីវិតភិក្ខុហុកសិបរូបក៏មាន

[១៧៧] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីសម្ងំក្នុងព្រះកម្មដ្ឋានដោយកន្លងកន្លះខែនោះទៅ ទើបទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុ ដោយព្រះពុទ្ធដីកាថា ដូចម្តេចហ្ន៎ អានន្ទ បានជាភិក្ខុសង្ឃហាក់ដូចជាស្តួចស្តើងទៅ។ ទើបព្រះអានន្ទត្ថេរ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតដូចព្រះពុទ្ធដីកាណាស់ ព្រោះព្រះដ៏មានព្រះភាគទ្រង់សំដែងអសុភកថា ដោយបរិយាយជាច្រើន ទ្រង់សរសើររៀបរាប់អំពីអសុភ ទ្រង់សរសើរគុណអសុភភាវនា ទ្រង់សរសើរគុណនៃអសុភសមាបត្តិ ក្នុងអសុភកម្មដ្ឋានជាញឹកញយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុទាំងនោះក៏គិតគ្នាថា ព្រះដ៏មានព្រះភាគ ទ្រង់សំដែងអសុភកថា ដោយបរិយាយដ៏ច្រើន ទ្រង់សរសើររៀបរាប់អំពីអសុភកថា ទ្រង់សរសើរគុណអសុភភាវនា ទ្រង់សរសើរគុណនៃការប្រកបដោយអសុភកម្មដ្ឋានជាញឹកញយ ហើយ (នាំគ្នា) ប្រកបសេចក្តីព្យាយាមក្នុងអសុភភាវនា ជាច្រើនវិធីណាស់។ ទើបភិក្ខុទាំងនោះ ជាទុក្ខនឿយណាយ ខ្ពើមឆ្អើមនឹងកាយរបស់ខ្លួន ប្រៀបដូចជាស្រីក្រមុំ ឬបុរសក្មេងកំឡោះ មានជាតិជាអ្នកស្អិតស្អាងលុះងូតទឹក កក់ក្បាលហើយ រមែងជាទុក្ខនឿយណាយ ខ្ពើមឆ្អើមសាកអសុភពស់ក្តី សាកអសុភឆ្កែក្តី សាកអសុភមនុស្សក្តី ដែលចងភ្ជាប់នឹងកមានឧបមាយ៉ាងណាមិញ ភិក្ខុទាំងអម្បាលនោះ កាលជាទុក្ខនឿយណាយ ខ្ពើមឆ្អើមនឹងកាយរបស់ខ្លួន ក៏មានឧបមេយ្យយ៉ាងនោះ ទើបផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងក៏មាន ខ្លះផ្លាស់គ្នាឲ្យផ្តាច់បង់ជីវិតទៅវិញទៅមកក៏មាន រូបខ្លះបានចូលទៅរកសមណកុត្តកឈ្មោះមិគលណ្ឌិក ហើយពោលយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នក អ្នកចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រ និងចីវរនេះនឹងបានជារបស់អ្នក បពិត្រព្រះអង្គដ៏ចំរើន គ្រានោះឯង សមណកុត្តកឈ្មោះមិគលណ្ឌិក លុះបានទទួលស៊ីឈ្នួលយកបាត្រ និងចីវរហើយ ទើបផ្តាច់បង់ជីវិតភិក្ខុមួយរូបមួយថ្ងៃក៏មាន។ បេ។ មួយថ្ងៃផ្តាច់បង់ជីវិតភិក្ខុហុកសិបរូបក៏មាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ ភិក្ខុសង្ឃនេះគប្បីស្ថិតស្ថេរនៅបានដោយហេតុណា សូមព្រះដ៏មានព្រះភាគ ទ្រង់សំដែងហេតុនោះដទៃទៀត។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ភិក្ខុទាំងអម្បាលមាណដែលអាស្រ័យនៅក្នុងក្រុងវេសាលី អ្នកចូរឲ្យភិក្ខុអម្បាលនោះទាំងអស់ប្រជុំគ្នាក្នុងឧបដ្ឋានសាលាចុះ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ដូច្នេះហើយ ភិក្ខុទាំងឡាយមានប្រមាណប៉ុន្មានដែលអាស្រ័យនៅក្នុងក្រុងវេសាលី ព្រះអានន្ទក៏បង្គាប់ភិក្ខុអម្បាលនោះទាំងអស់ឲ្យប្រជុំគ្នាក្នុង ឧបដ្ឋានសាលា[35] ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃប្រជុំគ្នាព្រមហើយ ព្រះករុណាម្ចាស់ សូមព្រះដ៏មានព្រះភាគទ្រង់សំគាល់កាលដ៏សមគួរក្នុងកាលឥឡូវនេះ។

[១៧៨] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់ប្រថាប់លើអាសនៈដែលគេតាក់តែងថ្វាយ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ប្រថាប់ស្រេចហើយ ទើបត្រាស់នឹងភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនជាប្រក្រតីហើយ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងៗឲ្យសាបសូន្យទៅផង ឲ្យស្ងប់រម្ងាប់ទៅផង ដោយទំនងដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចកំទេចធូលីដែលខ្យល់បក់កួចឡើងក្នុងខែដែលជាចុងគិម្ហន្តរដូវ គឺខែអាសាឍ្ហ មហាអកាលមេឃ (ភ្លៀងធំបង្អុរចុះខុសកាលវេលា) តែងញុំាងកំទេចធូលីនោះឲ្យអន្តរធាន ឲ្យស្ងប់ទៅបាន ដោយទំនងដ៏សមគួរ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានអប់រំ ធ្វើឲ្យច្រើនជាប្រក្រតីហើយ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់រំងាប់ទៅដោយទំនងដ៏សមគួរ ក៏មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិដែលបុគ្គលចំរើនហើយ តើដូចម្តេច ដែលបុគ្គលធ្វើឲ្យច្រើនជាប្រក្រតីហើយ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់រំងាប់ទៅដោយទំនងដ៏សមគួរ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ទីជិតនៃដើមឈើក្តី ទៅកាន់ផ្ទះដ៏ស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ ដំកល់សតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ភិក្ខុនោះមានសតិ ដកដង្ហើមចេញ មានសតិដកដង្ហើមចូល កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អញដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អញដកដង្ហើមចូលខ្លី (ភិក្ខុ) សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចេញ សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចូល សិក្សាថា អញរម្ងាប់កាយសង្ខារ (គឺខ្យល់អស្សាសបស្សាស) សឹមដកដង្ហើមចេញ សិក្សាថា អញនឹងរម្ងាប់កាយសង្ខារ សឹមដកដង្ហើមចូល សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវបីតិ (គឺសេចក្តីឆ្អែតកាយឆ្អែតចិត្ត) សឹមដកដង្ហើមចេញ សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវបីតិ សឹមដកដង្ហើមចូល សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវសុខ (គឺសុខកាយ សុខចិត្ត) សឹមដកដង្ហើមចេញ សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវសុខ សឹមដកដង្ហើមចូល សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ (គឺវេទនា និងសញ្ញា) សឹមដកដង្ហើមចេញ សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ សឹមដកដង្ហើមចូល សិក្សាថា អញនឹងរម្ងាប់ចិត្តសង្ខារ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងរំងាប់ចិត្តសង្ខារ សឹមដកដង្ហើមចូល សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្ត សឹមដកដង្ហើមចេញ សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្ត សឹមដកដង្ហើមចូល សិក្សាថា អញនឹងធ្វើចិត្តឲ្យរីករាយ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងធ្វើចិត្តឲ្យរីករាយ សឹមដកដង្ហើមចូល សិក្សាថា អញនឹងតាំងចិត្តខ្ជាប់ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងតាំងចិត្តខ្ជាប់ សឹមដកដង្ហើមចូល សិក្សាថា អញនឹងដោះចិត្តឲ្យផុតស្រឡះ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងដោះចិត្តឲ្យផុតស្រឡះ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពជារបស់មិនទៀង សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពជារបស់មិនទៀង សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពឥតរាគៈ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពឥតរាគៈ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពរលត់ទៅ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពរលត់ទៅ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណារឿយៗ ដោយកិរិយាលះបង់នូវសេចក្តីប្រកាន់ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណារឿយៗ ដោយកិរិយាលះបង់នូវសេចក្តីប្រកាន់ សឹមដកដង្ហើមចូល ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនហើយយ៉ាងនេះ ដែលបុគ្គលធ្វើឲ្យច្រើនហើយយ៉ាងនេះ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់ទៅ ដោយទំនងដ៏សមគួរ។

[១៧៩] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សាកសួរភិក្ខុទាំងឡាយក្នុងគ្រានោះថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងខ្លះ ផ្លាស់គ្នាឲ្យផ្តាច់បង់ជីវិតទៅវិញទៅមកខ្លះ ភិក្ខុខ្លះចូលទៅរកសមណកុត្តក ឈ្មោះមិគលណ្ឌិក ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នក ៗចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រ និងចីវរទាំងនេះនឹងបានជារបស់អ្នក (យ៉ាងនេះ) ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏ទ្រង់ព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយបានធ្វើហើយនេះ មិនសម មិនទំនង មិនគួរ មិនមែនជាកិច្ចរបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេច បានជាពួកភិក្ខុទាំងនោះទៅផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងខ្លះ ផ្លាស់គ្នាឲ្យផ្តាច់ជីវិតទៅវិញទៅមកខ្លះ ភិក្ខុខ្លះចូលទៅរកសមណកុត្តក ឈ្មោះមិគលណ្ឌិក ហើយពោលយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នក ៗចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រ និងចីវរនេះនឹងបានជារបស់អ្នក ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយក្លែងផ្តាច់បង់រាងកាយរបស់មនុស្សឲ្យឃ្លាតចាកជីវិតក្តី ទោះបីស្វែងរកគ្រឿងសស្ត្រាវុធ (ឲ្យគេសម្លាប់) រាងកាយមនុស្សនោះក្តី ភិក្ខុនេះឯងហៅថា ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន។**

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១៨០] សម័យនោះឯង មានឧបាសកម្នាក់មានជម្ងឺ។ ប្រពន្ធរបស់ឧបាសកនោះ មានរូបល្អស្រស់បស់មុខគួរឲ្យគយគន់ជាទីនាំមកនូវសេចក្តីជ្រះថ្លា។ ពួកឆព្វគ្គិយភិក្ខុមានចិត្តប្រតិព័ទ្ធចំពោះស្រីនោះ។ គ្រានោះសេចក្តីបរិវិតក្កនេះបានមានដល់ពួកឆព្វគ្គិយភិក្ខុដូច្នេះថា ម្នាលអាវុសោទាំងឡាយ បើឧបាសកនោះនឹងរស់នៅ ពួកយើងមុខជានឹងមិនបានស្រីនោះទេ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើង (នាំគ្នា) ពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសកនោះ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាចូលទៅកាន់ទីដែលឧបាសកនោះនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧបាសកនោះថា ម្នាលឧបាសក អ្នកឯងបានធ្វើអំពើល្អមកហើយ បានធ្វើកុសលមកហើយ បានធ្វើកម្មជាគ្រឿងការពារភ័យរួចអស់

ហើយ អ្នកឯងមិនដែលធ្វើបាប មិនដែលធ្វើអំពើលាមក មិនដែលធ្វើអំពើអាក្រក់ អំពើល្អអ្នកបានធ្វើហើយ បាបអ្នកមិនធ្លាប់ធ្វើឡើយ អ្នកឯងមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងរស់នៅ អ្នកធ្វើកាលកិរិយា រំលាងខន្ធស្លាប់ចាកមនុស្សលោកនេះ ទៅកាន់បរលោក នឹងកើតក្នុងមនុស្សសុគតិ ឬស្ថានសួគ៌ អ្នកនឹងបានឆ្អែតស្កប់ស្កល់ (នឹងបានឲ្យស្រីអប្សរទាំងឡាយ) បម្រើដោយកាមគុណទាំង៥ ដ៏ជាទិព្វក្នុងស្ថានសួគ៌នោះ។ គ្រានោះឯង ឧបាសកនោះគិតថា លោកម្ចាស់ទាំងឡាយនិយាយ (នេះ) ពិតណាស់ ដ្បិតខ្លួនអញជាមនុស្សបានធ្វើអំពើល្អមកហើយ បានធ្វើកុសលមកហើយ បានធ្វើវិធីការពារភ័យ (ក្នុងអបាយភូមិ) ហើយ បាប អញមិនដែលធ្វើឡើយ អំពើអាក្រក់ ក៏អញមិនដែលធ្វើ មិនធ្លាប់ធ្វើអំពើអាក្រក់សោះ អំពើប្រពៃ អញបានធ្វើហើយ បាប អញមិនធ្លាប់ធ្វើឡើយ អញមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អញស្លាប់ទៅប្រសើរជាងរស់នៅ អញធ្វើកាលកិរិយា រំលាងខន្ធស្លាប់ចាកមនុស្សលោកនេះ ទៅកាន់បរលោក នឹងកើតក្នុងមនុស្សសុគតិ ឬស្ថានសួគ៌ អញមុខជានឹងបានឆ្អែតស្កប់ស្កល់ (ឲ្យស្រីទេពអប្សរទាំងឡាយ) បម្រើដោយកាមគុណទាំង៥ ដែលជាទិព្វក្នុងស្ថានសួគ៌នោះ។ ឧបាសកនោះបរិភោគភោជនទាំងឡាយដែលមិនសប្បាយ (គឺអាហារដែលស្លែងនាំឲ្យកើតរោគ) ទំពាស៊ីតែខាទនីយ (គ្រឿងទំពា) ដែលមិនសប្បាយផង ជញ្ជាប់ជញ្ជក់តែវត្ថុសម្រាប់ជញ្ជាប់ជញ្ជក់ដែលមិនសប្បាយផង ផឹកទឹកដែលមិនសប្បាយផង។ កាលឧបាសកនោះបរិភោគភោជនដែលមិនសប្បាយតែម្យ៉ាងផង កាលទំពាស៊ីខាទនីយវត្ថុដែលមិនសប្បាយផង កាលជញ្ជាប់ជញ្ជក់វត្ថុសម្រាប់ជញ្ជាប់ជញ្ជក់មិនសប្បាយផង ផឹកទឹកដែលមិនសប្បាយផង អាពាធដ៏ក្លៀវក្លាក៏កើតឡើង។ ឧបាសកនោះក៏ធ្វើកាលកិរិយាស្លាប់ទៅដោយអាពាធនោះឯង។ ទើបប្រពន្ធរបស់ឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈទាំងនេះ ជាសក្យបុត្រ ជាបុគ្គលឥតខ្មាស ជាមនុស្សទ្រុស្តសីល មានប្រក្រតីពោលពាក្យមុសា ពួកសមណៈទាំងនេះនឹងប្ដេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ ជាអ្នកប្រព្រឹត្តរៀបរយ ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ជាអ្នកពោលពាក្យសត្យ ជាអ្នកមានសីល ជាអ្នកមានកល្យាណធម៌ ដូចម្ដេចបាន ភាពសមណៈរបស់ភិក្ខុទាំងនេះគ្មានទេ ព្រហ្មចរិយធម៌របស់ភិក្ខុទាំងនេះក៏គ្មានទេ សាមញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា សមណៈទាំងនេះប្រាសចាកសាមញ្ញគុណហើយ សមណៈទាំងនេះប្រាសចាកព្រហ្មញ្ញគុណហើយ (ព្រោះ) សមណៈទាំងនេះបានពណ៌នាគុណនៃសេចក្ដីស្លាប់ដល់ស្វាមីរបស់អញ ស្វាមីរបស់អញ គឺសមណៈទាំងនេះសម្លាប់ហើយ។ ទាំងពួកមនុស្សឯទៀតក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈពួកនេះ ជាសក្យបុត្រ ជាមនុស្សឥតខ្មាស ជាមនុស្សទ្រុស្តសីល ពោលតែពាក្យមុសា ពួកសមណៈទាំងនេះប្ដេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តរៀបសា ប្រព្រឹត្តព្រហ្មចរិយធម៌ ពោលពាក្យសច្ច មានសីល មានកល្យាណធម៌ ដូចម្ដេចបាន (ព្រោះ) សាមញ្ញគុណរបស់សមណៈទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះក៏គ្មានទេ សាមញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា ពួកសមណៈទាំងនេះប្រាសចាកសាមញ្ញគុណហើយ ពួកសមណៈទាំងនេះប្រាសចាកព្រហ្មញ្ញគុណហើយ (ព្រោះ) សមណៈទាំងនេះបានពណ៌នាគុណនៃសេចក្ដីស្លាប់ដល់ឧបាសក ឧបាសកដែលស្លាប់ ពីព្រោះតែសមណៈទាំងនេះ។ ភិក្ខុទាំងឡាយបានឮមនុស្សពួកនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ ពួកភិក្ខុណាជាអ្នកមានសេចក្ដីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុម្ដេចបានជាពួកឆព្វគ្គិយភិក្ខុទៅពណ៌នាគុណនៃសេចក្ដីស្លាប់ដល់ ឧបាសក (ដូច្នោះ)។ គ្រានោះឯង ពួកភិក្ខុទាំងនោះ បានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះបរមសាស្ដាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយពណ៌នាគុណនៃសេចក្ដីស្លាប់ដល់ឧបាសក មែនឬ។ ពួកភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ (អំពើដែលអ្នកទាំងអស់គ្នាធ្វើហើយនុ៎ះ) មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើសោះ ម្នាលមោឃបុរសទាំងឡាយ ហេតុម្ដេច បានជាអ្នកទាំងឡាយ ទៅពណ៌នាគុណនៃសេចក្ដីស្លាប់ដល់ឧបាសក (ដូច្នោះ) ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះ យ៉ាងនេះថា

**ភិក្ខុណាមួយក្លែងផ្ដាច់បង់រាងកាយរបស់មនុស្ស ឲ្យឃ្លាតចាកជីវិតក្ដី ទោះបីស្វែងរកគ្រឿងសស្ត្រាវុធ (ឲ្យគេសម្លាប់) រាងកាយមនុស្សនោះក្ដី ពណ៌នាគុណនៃសេចក្ដីស្លាប់ក្ដី ឬនិយាយណែនាំដើម្បីសេចក្ដីស្លាប់ថា នែបុរសដ៏ចំរើន អ្នកមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងរស់នៅ (ភិក្ខុ) មានចិត្តគិតដូច្នេះ មានសេចក្ដីត្រិះរិះក្នុងចិត្តដូច្នេះ គប្បីពណ៌នាគុណនៃសេចក្ដីស្លាប់ ឬគប្បីណែនាំដើម្បីសេចក្ដីស្លាប់ដោយអនេកបរិយាយ ភិក្ខុនេះក្ដី ហៅថាត្រូវអាបត្តិបារាជិក មិនមានសំវាសឡើយ។**

[១៨១] ត្រង់ពាក្យថា ភិក្ខុណាមួយ (ក្នុងបេយ្យាលទាំងពីរ មានសេចក្ដីអធិប្បាយដូចក្នុងបារាជិកកណ្ឌទី១)។ ត្រង់បទថា ក្លែង (នោះ) គឺដឹងជាក់ច្បាស់ហើយ ក្លែងសម្លាប់។ ដែលហៅថា រាងកាយនៃមនុស្ស (នោះ) គឺបឋមចិត្តណាដែលកើតឡើងហើយ បឋមវិញ្ញាណណាដែលកើតឡើងប្រាកដហើយ ក្នុងផ្ទៃនៃមាតា ដរាបដល់ពេលស្លាប់ ក្នុងរវាងកាលប៉ុណ្ណោះ នេះឯងហៅថា រាងកាយរបស់មនុស្ស។ ត្រង់ពាក្យថា ផ្ដាច់បង់ចាកជីវិត គឺចូលទៅផ្ដាច់បង់ ញុំាងឥន្ទ្រិយ គឺជីវិតឲ្យរលត់ទៅ គឺថាញុំាងសន្តតិ (ខ្សែតនៃចិត្ត) ឲ្យកំរើក។ ត្រង់ពាក្យថា ទោះបីស្វែងរកគ្រឿងសាស្ត្រាវុធ (ឲ្យគេសម្លាប់) រាងកាយមនុស្សនោះក្ដី សេចក្ដីថា គឺគប្បីស្វែងរកដាវក្ដី លំពែងក្ដី ច្បូកក្ដី ឈើស្រួចក្ដី អន្លូងក្ដី ថ្មក្ដី កាំបិតក្ដី ថ្នាំពិសក្ដី ខ្សែក្ដី។

[១៨២] ត្រង់ពាក្យថា ពណ៌នាគុណនៃសេចក្ដីស្លាប់ក្ដី សេចក្ដីថា សំដែងទោសក្នុងកិរិយារស់នៅ ពោលសរសើរគុណក្នុងការស្លាប់។

[១៨៣] ត្រង់ពាក្យថា និយាយណែនាំដើម្បីសេចក្ដីស្លាប់ក្ដី សេចក្ដីថា និយាយណែនាំថា អ្នកចូរនាំគ្រឿងសស្ត្រាមកក្ដី ថាអ្នកចូរស៊ីថ្នាំពិសក្ដី ថាអ្នកចូរចងរិតដោយខ្សែ ហើយធ្វើមរណកាលទៅក្ដី (យ៉ាងនេះហៅថា និយាយណែនាំដើម្បីសេចក្ដីស្លាប់)។

[១៨៤] ត្រង់ពាក្យថា នែបុរសដ៏ចំរើន (នេះ) ជាឈ្មោះនៃពាក្យអាលបន (ពាក្យសម្រាប់ហៅរក) ថា ម្នាលបុរសដ៏ចំរើន។ ត្រង់ពាក្យថា អ្នកមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងកិរិយារស់នៅ មានអធិប្បាយថា ជីវិតរបស់ពួកមនុស្សកំសត់ បើធៀប

ផ្ទឹមនឹងជីវិតរបស់ពួកមនុស្សស្កុកស្គម្ភ (ក៏ឃើញថា) ជាជីវិតលាមក ជីវិតរបស់ពួកមនុស្សឥតទ្រព្យ បើធៀបផ្ទឹមនឹងជីវិតរបស់ពួកមនុស្សមានទ្រព្យ (ក៏ឃើញថា) ជាជីវិតលាមក ជីវិតរបស់មនុស្សទាំងឡាយ បើធៀបផ្ទឹមគ្នានឹងជីវិតរបស់ទេវតាទាំងឡាយ (ក៏ឃើញថា) ជាជីវិតលាមក (យ៉ាងនេះ) ហៅថា ជីវិតលាមក។ ជីវិតរបស់មនុស្សដាច់ដៃ ដាច់ជើង ដាច់ទាំងដៃទាំងជើង មនុស្សដាច់ត្រចៀក មនុស្សដាច់ច្រមុះ មនុស្សដាច់ទាំងត្រចៀក ទាំងច្រមុះ (ទាំងនេះ) ហៅថា ជីវិតអាក្រក់។ អ្នកមានប្រយោជន៍អ្វីនឹងជីវិតដ៏លាមកនេះ នឹងជីវិតដ៏អាក្រក់នេះ អ្នកស្លាប់ទៅប្រសើរជាងរស់នៅ។ ត្រង់ពាក្យថា មានចិត្តគិតដូច្នេះ សេចក្តីថា ធម្មជាតណាជាចិត្ត ធម្មជាតនោះជាមនោ ធម្មជាតណាជាមនោ ធម្មជាតនោះគឺចិត្ត។ ត្រង់ពាក្យថា មានសេចក្តីត្រិះរិះក្នុងចិត្តដូច្នេះ សេចក្តីថា មានសេចក្តីសំគាល់ក្នុងសេចក្តីស្លាប់ មានចេតនាចង់ឲ្យស្លាប់ មានសេចក្តីប៉ុនប៉ងចង់ឲ្យស្លាប់។ ត្រង់ពាក្យថា ដោយអនេកបរិយាយ គឺដោយអាការទាំងឡាយខ្ពស់និងទាប (ដោយឧបាយច្រើនយ៉ាង)។ ត្រង់ពាក្យថា ពណ៌នាគុណនៃសេចក្តីស្លាប់ក្តី អធិប្បាយថា ភិក្ខុសំដែងទោសក្នុងការរស់នៅ ពោលសរសើរគុណក្នុងការស្លាប់ទៅដូច្នេះថា អ្នកស្លាប់អំពីលោកនេះ គឺអ្នករំលាងខន្ធស្លាប់ទៅកាន់បរលោក នឹងកើតក្នុងមនុស្សសុគតិ ឬស្ថានសួគ៌ អ្នកនឹងបានឆ្អែតស្កប់ស្កល់ (ឲ្យស្រីទេពអប្សរទាំងឡាយ) បម្រើដោយកាមគុណទាំង៥ដ៏ជាទិព្វក្នុងស្ថានសួគ៌នោះ។

[១៨៥] ត្រង់ពាក្យថា ឬនិយាយណែនាំដើម្បីសេចក្តីស្លាប់ សេចក្តីថា (និយាយដឹកនាំ) ថា អ្នកចូរនាំគ្រឿងសស្ត្រាមកក្តី អ្នកចូរស៊ីថ្នាំពិសក្តី អ្នកចូរចងរឹតដោយខ្សែ ហើយធ្វើកាលកិរិយាទៅក្តី អ្នកចូរលោតទម្លាក់ទៅក្នុងបឹងក្តី អណ្តូងក្តី ជ្រោះក្តី។

[១៨៦] ត្រង់ពាក្យថា ភិក្ខុនេះក្តី មានសេចក្តីអធិប្បាយដូចខាងដើម (ត្រង់បារាជិកកណ្ឌទី១)។ ត្រង់ពាក្យថា ត្រូវអាបត្តិបារាជិក អធិប្បាយថា ថ្មក្រាស់បែកជាពីរចំណែក ជាវត្ថុភ្ជាប់គ្នាមិនបានទៀតយ៉ាងណាមិញ ភិក្ខុក្លែងផ្តាច់បង់រាងកាយរបស់មនុស្សឲ្យចាកជីវិត មិនមែនជាសមណៈ មិនមែនជាសក្យបុត្រ មានឧបមេយ្យដូច្នោះឯង ព្រោះហេតុនោះ ទើបហៅថា ត្រូវអាបត្តិបារាជិក។ ត្រង់ពាក្យថា រកសំវាសគ្មាន សេចក្តីថា កម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សិក្ខាស្មើគ្នា នេះហៅថា មានសំវាស ភិក្ខុនោះគ្មានសំវាសដូច្នោះទេ ព្រោះហេតុនោះ ទើបហៅថា រកសំវាសគ្មាន។

[១៨៧] ភិក្ខុស្ថិតនៅក្នុងទីជិត (តាំងចិត្តនឹងសម្លាប់មនុស្ស) ដោយខ្លួនឯង ដោយប្រើបម្រើ ដោយប្រើបម្រើ តៗគ្នា ដោយបម្រើទៅធ្វើការខុសសង្កេត ដោយបម្រើទៅហើយ ត្រឡប់មកវិញ ភិក្ខុនៅក្នុងទីមិនកំបាំង សំគាល់ថាកំបាំង នៅក្នុងទីកំបាំង សំគាល់ថាមិនកំបាំង នៅក្នុងទីមិនកំបាំង សំគាល់ថាមិនកំបាំង នៅក្នុងទីកំបាំង សំគាល់ថាកំបាំង ភិក្ខុពណ៌នា (សេចក្តីស្លាប់) ដោយកាយ ពណ៌នាដោយវាចា ពណ៌នាដោយកាយនិងវាចា ពណ៌នាដោយប្រើបម្រើ ពណ៌នាដោយចារិកអក្សរ ជីករណ្តៅ ធ្វើបង្អែក បង្កប់ចម្រូង ឲ្យភេសជ្ជៈ សម្លាប់ដោយរូប សម្លាប់ដោយសម្លេង សម្លាប់ដោយក្លិន សម្លាប់ដោយរស សម្លាប់ដោយសម្ផស្ស សម្លាប់ដោយធម៌ បង្គាប់ឲ្យស្លាប់ ប្រៀនប្រដៅដើម្បីឲ្យស្លាប់ ធ្វើសង្កេតកម្ម ធ្វើនិមិត្តកម្ម។

[១៨៨] ត្រង់ពាក្យថា ដោយខ្លួនឯង គឺភិក្ខុសម្លាប់ (គេ) ខ្លួនឯង ដោយកាយក្តី ដោយអាវុធដែលជាប់នឹងកាយក្តី ដោយគ្រឿងប្រយោលក្តី។ ត្រង់ពាក្យថា ឋិតនៅក្នុងទីជិត សេចក្តីថា ឋិតនៅ (ក្នុងទីជិត) ក៏បង្គាប់ថា អ្នកចូរចាក់យ៉ាងនេះ អ្នកចូរប្រហារយ៉ាងនេះ អ្នកចូរសម្លាប់យ៉ាងនេះ។

[១៨៩] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់នោះចំណាំមនុស្សនោះបាន ហើយផ្តាច់បង់ជីវិតមនុស្សនោះ ត្រូវអាបត្តិបារាជិកទាំងពីររូប។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សបាន (ប៉ុន្តែ) ទៅផ្តាច់បង់ជីវិតមនុស្សដទៃវិញ ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិឡើយ ភិក្ខុអ្នកសម្លាប់ត្រូវអាបត្តិបារាជិក។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សដទៃវិញ (ប៉ុន្តែ) ទៅផ្តាច់បង់ជីវិតមនុស្សនោះ (គឺមនុស្សដែលអ្នកប្រើ ប្រាប់ឲ្យសម្លាប់នោះ) ត្រូវអាបត្តិបារាជិកទាំងពីររូប។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សដទៃវិញ (លុះវេលា) ទៅផ្តាច់បង់ ៗ ជីវិតមនុស្សដទៃនោះ (បើធ្វើខុសបង្គាប់ដូច្នេះ) ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិឡើយ ភិក្ខុអ្នកសម្លាប់ត្រូវអាបត្តិបារាជិក។

[១៩០] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា[36)] លោកចូរប្រាប់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះប្រាប់ដល់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះចូរផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅប្រាប់អ្នកឯទៀតវិញ (ដូច្នេះ) ក៏ត្រូវអាបត្តិទុក្កដដែរ។ ភិក្ខុអ្នកសម្លាប់ទទួលបង្គាប់ ភិក្ខុអ្នកប្រើដើមត្រូវអាបត្តិថុល្លច្ច័យ។ លុះភិក្ខុអ្នកសម្លាប់បានផ្តាច់បង់ជីវិតបុគ្គលនោះសម្រេច ត្រូវអាបត្តិបារាជិកគ្រប់ទាំងបួនរូប។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅប្រាប់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះទៅប្រាប់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះ ចូរទៅផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់នោះ ទៅបង្គាប់ភិក្ខុឯទៀតវិញ (ធ្វើខុសបង្គាប់ដូច្នេះ) ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកសម្លាប់ទទួលបង្គាប់ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកសម្លាប់នោះ បានផ្តាច់បង់ជីវិតបុគ្គលនោះសម្រេច ភិក្ខុអ្នកបង្គាប់ដើមមិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកបង្គាប់ និងភិក្ខុអ្នកសម្លាប់។

[១៩១] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកទទួលបង្គាប់នោះ ទៅហើយ ត្រឡប់មកប្រាប់វិញថា ខ្ញុំមិនអាចនឹងផ្តាច់បង់ជីវិតបុគ្គលនោះទេ។ ភិក្ខុនោះបង្គាប់ទៀតថា លោកអាចវេលាណា លោកចូរទៅផ្តាច់បង់ជីវិតគេវេលានោះចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះភិក្ខុអ្នកទទួលបង្គាប់នោះ បានផ្តាច់បង់ជីវិតបុគ្គលនោះសម្រេច ក៏ត្រូវអាបត្តិបារាជិកទាំងពីររូប។

[១៩២] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះ លុះបង្គាប់ភិក្ខុផងគ្នានោះហើយ ក៏ស្រាប់តែកើតសេចក្តីក្តៅក្រហាយ (ស្តាយក្រោយ) តែនឹងបានប្រាប់ឲ្យដឹងថា លោកកុំទៅសម្លាប់ដូច្នេះក៏ទេ។ ភិក្ខុអ្នកទទួលបង្គាប់ លុះផ្តាច់បង់ជីវិតបុគ្គលនោះស្រេច ក៏ត្រូវអាបត្តិបារាជិកទាំងពីររូប។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ (តែ) ភិក្ខុនោះ លុះបង្គាប់រួចហើយ ក៏ស្រាប់តែកើតសេចក្តីក្តៅក្រហាយ (ស្តាយក្រោយ) ទើបប្រាប់វិញថា លោកកុំទៅសម្លាប់ឡើយ។ ភិក្ខុនោះអាងថា លោកបង្គាប់ខ្ញុំហើយ ក៏ទៅផ្តាច់ជីវិតបុគ្គលនោះទៅ (យ៉ាងនេះ) ភិក្ខុអ្នកប្រើដើមមិនត្រូវអាបត្តិទេ ត្រូវអាបត្តិបារាជិកតែអ្នកសម្លាប់។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅផ្តាច់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះភិក្ខុនោះ បង្គាប់ហើយ ក៏កើតសេចក្តី

ក្តៅក្រហាយ (ស្តាយក្រោយ) ទើបប្រាប់វិញថា លោកកុំទៅសម្លាប់ឡើយ។ ភិក្ខុអ្នកសម្លាប់នោះទទួលថា សាធុ ហើយឈប់វិញ (ដូច្នេះ) មិនត្រូវអាបត្តិទាំងពីររូប។

[១៩៣] ភិក្ខុសំគាល់ទីដែលមិនស្ងាត់ថាទីស្ងាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះ អញត្រូវតែសម្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ទីដែលស្ងាត់ថាទីមិនស្ងាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះ សូមឲ្យវិនាសទៅចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ទីដែលមិនស្ងាត់ថាទីមិនស្ងាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះ សូមវិនាសទៅចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ទីដែលស្ងាត់ថាស្ងាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះ សូមឲ្យវិនាសទៅចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ។

[១៩៤] ដែលហៅថា ពណ៌នាដោយកាយ (នោះ) គឺភិក្ខុធ្វើវិការដោយកាយដូច្នេះ បុគ្គលណា ស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬនឹងបានយសស័ក្តិ ឬនឹងទៅកាន់ស្ថានសួគ៌ (ភិក្ខុធ្វើយ៉ាងនេះ) ត្រូវអាបត្តិទុក្កដ។ (បើមនុស្សស្តាប់សេចក្តីពណ៌នានោះហើយ) ញុំាងទុក្ខវេទនាឲ្យកើតឡើងដោយគិតថា អញនឹងស្លាប់ដោយកិរិយាពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា ពោលពណ៌នាដោយវាចា (នោះ) គឺភិក្ខុពោលដោយវាចាថា បុគ្គលណាស្លាប់យ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ (បើមនុស្សស្តាប់សេចក្តីពណ៌នានោះហើយ) ញុំាងទុក្ខវេទនាឲ្យកើតឡើងដោយគិតថា អញនឹងស្លាប់ដោយកិរិយាពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើបុគ្គលនោះ) ស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា ពោលពណ៌នាដោយកាយ និងវាចា (នោះ) គឺភិក្ខុធ្វើវិការដោយកាយផង ពោលដោយវាចាផង ដូច្នេះថា បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ (បើមនុស្សស្តាប់សេចក្តីពណ៌នានោះហើយ) ញុំាងទុក្ខវេទនាឲ្យកើតឡើងដោយគិតថា អញនឹងស្លាប់ដោយកិរិយាពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ បើបុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។

[១៩៥] ដែលហៅថា ពោលពណ៌នាដោយប្រើបម្រើ (នោះ) គឺភិក្ខុប្រាប់ដំណឹងដល់បម្រើថា បុគ្គលណាស្លាប់យ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬពុំនោះទៅកាន់ស្ថានសួគ៌ ដូច្នេះ ភិក្ខុត្រូវអាបត្តិទុក្កដ។ (បើ) បុគ្គលនោះបានស្តាប់ដំណឹងរបស់បម្រើ ហើយគិតថា អញនឹងស្លាប់ ហើយក៏ញុំាងទុក្ខវេទនាឲ្យកើតឡើងភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) បុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា ពណ៌នាដោយវិធីសរសេរអក្សរ (នោះ) គឺភិក្ខុឆ្លាក់អក្សរ (ជាសេចក្តី) ថា បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដគ្រប់ៗអក្ខរ។ (បុគ្គលនោះ) ឃើញអក្សរចារិកហើយគិតថា អញនឹងស្លាប់ទៅ ហើយញុំាងទុក្ខវេទនាឲ្យកើតឡើង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) បុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។

[១៩៦] ដែលហៅថា រណ្តៅ (នោះ) គឺភិក្ខុជីករណ្តៅចំពោះមនុស្សដោយតាំងចិត្តថា អ្នកណាមួយធ្លាក់ទៅ គង់ស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ កាលបើអ្នកណាមួយធ្លាក់ទៅហើយ កើតទុក្ខវេទនាឡើង (ដល់អ្នកនោះ) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ បើអ្នកនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុជីករណ្តៅមិនចំពោះ (មនុស្ស ឬអមនុស្ស) ដោយគិតថា ជនណាមួយធ្លាក់ទៅ គង់ស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ (បើ) មនុស្សធ្លាក់ទៅក្នុងរណ្តៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ។ កាលមនុស្សនោះធ្លាក់ទៅ កើតទុក្ខវេទនាឡើង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើមនុស្សនោះ) ស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ (បើ) យក្សក្តី ប្រេតក្តី សត្វតិរច្ឆានដែលមានរាងកាយដូចមនុស្សក្តី ធ្លាក់ទៅក្នុងរណ្តៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ។ កាលបើជន មានយក្សជាដើមនោះធ្លាក់ទៅហើយ កើតទុក្ខវេទនា ភិក្ខុក៏ត្រូវអាបត្តិទុក្កដដែរ។ (បើ) ជនមានយក្សជាដើមនោះស្លាប់ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) សត្វតិរច្ឆានធ្លាក់ទៅក្នុងរណ្តៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ។ កាលបើធ្លាក់ទៅហើយ កើតទុក្ខវេទនា ត្រូវអាបត្តិទុក្កដ។ (បើ) វាស្លាប់ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។

[១៩៧] ដែលហៅថា បង្អែក (នោះ) គឺភិក្ខុបង្កប់សស្ត្រាក្នុងទីសម្រាប់ផ្អែកក្តី លាបដោយថ្នាំពិសក្តី ធ្វើឲ្យទ្រុឌទ្រោមក្តី បង្កប់សស្ត្រាក្នុងត្រពាំងក្តី ក្នុងអណ្តូងក្តី ក្នុងជ្រោះក្តី ដោយគិតថា មនុស្សណាមួយនឹងធ្លាក់ទៅស្លាប់ដោយគ្រឿងប្រហារនេះ ត្រូវអាបត្តិទុក្កដ។ បើមនុស្សនោះមានទុក្ខវេទនាកើតឡើងដោយសស្ត្រាក្តី ដោយថ្នាំពិសក្តី ដោយដំណើរដែលធ្លាក់ចុះទៅ (តាមធម្មតា) ក្តី ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ បើមនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។

[១៩៨] ដែលហៅថា បង្កប់ចម្រូង (នោះ) គឺភិក្ខុបង្កប់ដាវក្តី លំពែងក្តី ច្បូកក្តី ឈើស្រួចក្តី អន្លូងក្តី ថ្មក្តី កាំបិតក្តី ថ្នាំពិសក្តី ខ្សែក្តី ដោយគិតថា មនុស្សណាមួយនឹងស្លាប់ដោយវត្ថុមានដាវជាដើមនេះ (យ៉ាងនេះ) ត្រូវអាបត្តិទុក្កដ។ (បើ) មនុស្សនោះញុំាងទុក្ខវេទនាឲ្យកើតឡើងដោយគិតថា អញនឹងស្លាប់ដោយវត្ថុមានដាវជាដើមនោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។

[១៩៩] ដែលហៅថា ភេសជ្ជៈ (នោះ) គឺភិក្ខុឲ្យសប្បិក្តី នវនីតក្តី ប្រេងក្តី ទឹកឃ្មុំក្តី ស្ករអំពៅក្តី [អដ្ឋកថា ពន្យល់ថា ភិក្ខុឲ្យភេសជ្ជៈ មានសប្បិជាដើម ដល់ភិក្ខុដែលមានជម្ងឺ ដោយមានបំណងថា តែឆាន់ទៅនឹងលាប់ស្លាប់។ ) ដោយតាំងចិត្តថា មនុស្សដែលជញ្ជក់ជញ្ជាប់ (ស៊ី) ភេសជ្ជៈ មានសប្បិជាដើមនេះហើយ គង់នឹងស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ កាលបើមនុស្សស៊ីភេសជ្ជៈ មានសប្បិជាដើមនោះហើយ កើតទុក្ខវេទនា ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។

[២០០] ដែលហៅថា សម្លាប់ដោយរូប (នោះ) គឺភិក្ខុនាំយករូបដែលមិនគាប់ចិត្ត មុខគួរឲ្យខ្លាច ភិតភ័យ ស្ញប់ស្ញែង ដោយតាំងចិត្តថា មនុស្សណាមួយមកឃើញរូបនេះហើយ នឹងតក់ស្លុតស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ (បើ) មនុស្សឃើញរូបនោះហើយតក់ស្លុត ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) មនុស្សស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុនាំយករូបដែលជាទីគាប់ចិត្ត គួរឲ្យស្រឡាញ់ ពេញចិត្ត ដោយបំណងថា មនុស្សណាមួយមកឃើញរូបនេះហើយ តែមិនបាន (រូបនេះ) មុខជានឹងសង្រេងសង្រៃ រីងរៃស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ (បើ) មនុស្សឃើញរូបនោះហើយក្រៀមក្រំ ព្រោះមិនបាន (តាមប្រាថ្នា) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា សម្លាប់ដោយសម្លេង (នោះ) គឺភិក្ខុនាំយកសម្លេងមិនជាទីគាប់ចិត្ត មុខគួរឲ្យខ្លាច ភិតភ័យ ស្ញប់ស្ញែង ដោយបំណងថា មនុស្សណាមួយបានឮសម្លេងនេះ

ហើយ នឹងតក់ស្លុតស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះមនុស្សឮសម្លេងនោះហើយតក់ស្លុត ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុនាំយកសម្លេងជាទីគាប់ចិត្ត មុខគួរស្រឡាញ់ ចូលចាប់ដួងចិត្ត ដោយបំណងថា មនុស្សណាមួយបានឮសម្លេងនេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះចង់បានមិនបាន ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះមនុស្សឮសម្លេងនោះហើយ ក្រៀមក្រំចិត្ត ព្រោះចង់បានមិនបាន ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) មនុស្សនោះស្លាប់ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា សម្លាប់ដោយក្លិន (នោះ) គឺភិក្ខុនាំយកក្លិនមិនគាប់ចិត្ត មុខគួរខ្ពើមឆ្អើម ដោយបំណងថា មនុស្សណាមួយហិតក្លិនហើយ គង់នឹងស្លាប់ ព្រោះជារបស់គួរខ្ពើម គួរឆ្អើម ដូច្នេះ ត្រូវអាបត្តិទុក្កដ។ កាលបើគេហិតក្លិននោះហើយ មានទុក្ខវេទនាកើតឡើង ព្រោះខ្ពើម ព្រោះឆ្អើម ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុនាំយកក្លិនជាទីគាប់ចិត្តចូលទៅ ដោយបំណងថា មនុស្សណាមួយបានហិតក្លិននេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះចង់បានមិនបាន ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះគេហិតក្លិននោះហើយ ក្រៀមក្រំព្រោះមិនបាន ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា សម្លាប់ដោយរស (នោះ) គឺភិក្ខុនាំយករសដែលមិនជាទីគាប់ចិត្ត មុខគួរខ្ពើមឆ្អើម ដោយតាំងចិត្តថា មនុស្សណាមួយបានជញ្ជក់ជញ្ជាប់រសនេះហើយ នឹងស្លាប់ ព្រោះជារសគួរខ្ពើមឆ្អើម ដូច្នេះ ត្រូវអាបត្តិទុក្កដ។ កាលបើគេជញ្ជក់ជញ្ជាប់រសនោះហើយ មានទុក្ខវេទនាកើតឡើង ព្រោះជារបស់គួរខ្ពើមឆ្អើម ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ លុះគេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុនាំយករសជាទីគាប់ចិត្ត ដោយបំណងថា មនុស្សណាមួយបានជញ្ជក់ជញ្ជាប់រសនេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះមិនបាន (ដូចបំណង) ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះគេជញ្ជក់ជញ្ជាប់រសនោះហើយ កើតក្រៀមក្រំ ព្រោះមិនបាន (តាមបំណង) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា សម្លាប់ដោយសម្ផស្ស (នោះ) គឺភិក្ខុនាំយកផោដ្ឋព្វមិនជាទីគាប់ចិត្ត ដែលមានសម្ផស្សនាំមកនូវសេចក្តីទុក្ខ ដែលមានសម្ផស្សរឹង ដោយបំណងថា មនុស្សណាមួយបានពាល់ត្រូវសម្ផស្សនេះ មុខជានឹងស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ (បើ) ទុក្ខវេទនាកើតឡើងដល់បុគ្គលដែលបានពាល់ត្រូវសម្ផស្សនោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ លុះគេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុនាំយកផោដ្ឋព្វជាទីគាប់ចិត្ត ដែលមានសម្ផស្សជាសុខ ដែលមានសម្ផស្សទន់ ដោយបំណងថា បុគ្គលណាមួយមកពាល់ត្រូវសម្ផស្សនេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះមិនបាន (តាមប្រាថ្នា) ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះគេពាល់ត្រូវសម្ផស្សនោះហើយ កើតក្រៀមក្រំ ព្រោះមិនបាន (តាមប្រាថ្នា) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា សម្លាប់ដោយធម៌ (នោះ) គឺភិក្ខុពោលអំពីរឿងនរក នៃសត្វដែលទៅកើតក្នុងនរក ដោយបំណងថា មនុស្សណាមួយបានស្តាប់រឿងនរកនេះហើយ នឹងតក់ស្លុត ហើយស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះគេបានស្តាប់រឿងនរកនោះហើយ កើតតក់ស្លុត ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ភិក្ខុពោលអំពីរឿងស្ថានសួគ៌នៃបុគ្គលដែលបានធ្វើកម្មដ៏ល្អ ដោយបំណងថា មនុស្សណាមួយបានស្តាប់និទានអំពីស្ថានសួគ៌នេះហើយ នឹងអត់ដង្ហើមស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ លុះគេបានស្តាប់និទានអំពីស្ថានសួគ៌នោះហើយ ញុំាងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងអត់ដង្ហើមស្លាប់ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ (បើ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។

[២០១] ដែលហៅថា បង្គាប់ឲ្យស្លាប់ (នោះ) គឺមានមនុស្សសួរភិក្ខុ ៗឆ្លើយថា អ្នកឯងចូរស្លាប់ទៅយ៉ាងនេះចុះ ព្រោះបុគ្គលណាមួយស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ បុគ្គលនោះញុំាងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ តាមបង្គាប់នោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ លុះគេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។ ដែលហៅថា ប្រៀនប្រដៅដើម្បីឲ្យស្លាប់ (នោះ) គឺគេមិនបានសួរភិក្ខុទេ តែភិក្ខុនិយាយថា អ្នកចូរស្លាប់យ៉ាងនេះចុះ (ព្រោះ) បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ព្រោះពាក្យប្រៀនប្រដៅប៉ុណ្ណោះ ទើបបុគ្គលនោះញុំាងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ។ លុះបុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក។

[២០២] ដែលហៅថា ធ្វើសង្កេតកម្ម (នោះ) គឺភិក្ខុកំណត់វេលាថា លោកចូរទៅផ្តាច់បង់ជីវិតបុគ្គលនោះ តាមសេចក្តីកំណត់នោះ ទោះនៅវេលាមុនបាយក្តី ក្រោយបាយក្តី យប់ក្តី ថ្ងៃក្តី ដូច្នេះ ត្រូវអាបត្តិទុក្កដ។ បើភិក្ខុទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះតាមសេចក្តីកំណត់នោះ ត្រូវអាបត្តិបារាជិកទាំងពីររូប។ (បើ) ភិក្ខុទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះ មុនក្តី ក្រោយក្តី អំពីកំណត់នោះ ភិក្ខុអ្នកប្រើដើម មិនត្រូវអាបត្តិទេ ឯអ្នកសម្លាប់ត្រូវអាបត្តិបារាជិក។ ដែលហៅថា ធ្វើនិមិត្តកម្ម (នោះ) គឺភិក្ខុធ្វើនិមិត្តសញ្ញាដូច្នេះថា បើខ្ញុំប៉ប្រិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី លោកចូរផ្តាច់បង់ជីវិតបុគ្គលនោះ តាមនិមិត្តសញ្ញានោះចុះ (ធ្វើនិមិត្តសញ្ញាប៉ុណ្ណោះ) ត្រូវអាបត្តិទុក្កដ។ (បើ) ភិក្ខុអ្នកទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះតាមនិមិត្តសញ្ញានោះ ត្រូវអាបត្តិបារាជិកទាំងពីររូប។ (បើ) ភិក្ខុអ្នកទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះ មុន ឬក្រោយនិមិត្តសញ្ញានោះ ភិក្ខុអ្នកប្រើខាងដើម មិនត្រូវអាបត្តិឡើយ ឯអ្នកសម្លាប់ត្រូវអាបត្តិបារាជិក។

[២០៣] ភិក្ខុមិនក្លែង១ ភិក្ខុមិនដឹង១ ភិក្ខុមិនប្រាថ្នាឲ្យស្លាប់១ ភិក្ខុឆ្កួត១ ភិក្ខុមានចិត្តរវើរវាយ១ ភិក្ខុមានវេទនាគ្របសង្កត់១ ភិក្ខុដើមបញ្ញត្តិ១ (ភិក្ខុទាំងនេះ) មិនត្រូវអាបត្តិទេ។

ចប់ បឋមភាណវារក្នុងមនុស្សវិគ្គហបារាជិក។

## (វិនីតវត្ថុឧទ្ទានគាថា តតិយសិក្ខាបទំ)

CS vin.vbu.pr.03.01 | ភាគ ទី១

### (វិនីតវត្ថុឧទ្ទានគាថា)

[២០៤] (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសំដែងតទៅ ដូចមានខាងក្រោមនេះ)

រឿងភិក្ខុពណ៌នាសេចក្តីស្លាប់ រឿងភិក្ខុអង្គុយសង្កត់ក្មេង រឿងអង្រែនិងត្បាល់ រឿងបិតា និងបុត្របួសឯចាស់ រឿងសាច់ជាប់បំពង់ក រឿងភិក្ខុបិណ្ឌបាតបានចង្ហាន់លាយថ្នាំពិស រឿងភិក្ខុ៣ពួកធ្វើការកសាងទីលំនៅ រឿងភិក្ខុ៣ពួកទៀតធ្វើការកសាងដោយឥដ្ឋ រឿងកាំបិតព្រា រឿងបង្កង់ រឿងរន្ទា រឿងឡើងភ្នំ រឿងនត្ថុថ្នាំឲ្យចេញញើស រឿងច្របាច់ រឿងផ្ងូតទឹក រឿងលាបប្រេង រឿងភិក្ខុធ្វើភិក្ខុមាន

ជម្ងឺឲ្យក្រោក រឿងភិក្ខុផ្តលភិក្ខុមានជម្ងឺ រឿងភិក្ខុសម្លាប់ភិក្ខុដោយបាយនិងទឹក រឿងស្រីមានផ្ទៃពោះព្រោះសហាយ រឿងស្រីរួមប្តី រឿងភិក្ខុសម្លាប់ម្តាយនិងកូនទាំងពីរនាក់ រឿងស្រីពីរនាក់រំលូតកូន តែមិនស្លាប់ រឿងកំដៅផ្ទៃពោះ រឿងស្រីអារ រឿងស្រីមានកូន រឿងភិក្ខុចាក់ក្រឡេក រឿងខ្មោចចូលភិក្ខុ រឿងភិក្ខុបញ្ជូនភិក្ខុទៅកាន់ទីមានខ្មោចលង រឿងភិក្ខុចំណាំភិក្ខុជាសត្រូវហើយប្រហារ រឿងភិក្ខុពោលពីស្ថានសួគ៌ និងនរក រឿងភិក្ខុស្រុកអាឡវីបីរូបនាំគ្នាកាប់ដើមឈើ រឿងភិក្ខុបីរូបទៀតដុតភ្លើងព្រៃ រឿងភិក្ខុនិយាយនឹងមនុស្សសម្លាប់ចោរ រឿងប្រេងខ្លាញ់គោ នឹងថ្នាំត្រាំទុកយូរ។

## (វិនីតវត្ថុ តតិយសិក្ខាបទំ)

CS vin.vbu.pr.03.02 | ភាគ ទី១

### (វិនីតវត្ថុ)

[២០៥] សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ទើបភិក្ខុទាំងឡាយពណ៌នាគុណនៃសេចក្តីស្លាប់ដល់ភិក្ខុមានជម្ងឺនោះ ដោយចិត្តអាណិតអាសូរ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ទើបភិក្ខុទាំងនោះមានសេចក្តីសង្ស័យថា យើងទាំងឡាយត្រូវអាបត្តិបារាជិកទេដឹង។ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគក្នុងកាល នោះឯង។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ។

[២០៦] សម័យនោះឯង មានភិក្ខុមួយរូបកាន់បិណ្ឌបាតចារិកវត្ត អង្គុយសង្កត់ក្មេងដែលគេដណ្តប់ដោយកំណាត់សម្តត់នៅលើតាំងស្លាប់ទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អាត្មាត្រូវអាបត្តិបារាជិកទេដឹង។ ទើបភិក្ខុនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនទាន់បានពិនិត្យទេ កុំអាលអង្គុយលើអាសនៈ ភិក្ខុណាអង្គុយ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ។

[២០៧] សម័យនោះឯង មានភិក្ខុមួយរូបឲ្យគេក្រាលអាសនៈក្នុងរោងភត្តត្រង់ចន្លោះផ្ទះ ហើយបានឈោងទៅចាប់អង្រែមួយត្រង់កន្លែងដែលគេបញ្ឈរអង្រែ។ អង្រែជាគំរប់ពីរ រលំទៅសង្កត់លើក្បាលទារកម្នាក់។ ទារកនោះក៏ធ្វើមរណកាលទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនបានក្លែងទេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនក្លែង មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបឲ្យគេក្រាលអាសនៈក្នុងរោងភត្តត្រង់ចន្លោះផ្ទះ បានទៅជាន់ឈើ ដែលគេសម្រាប់ដម្កល់ត្បាល់ ឲ្យវិលទៅសង្កត់ទារកម្នាក់ស្លាប់។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនក្លែង មិនត្រូវអាបត្តិទេ។

[២០៨] សម័យនោះឯង បិតានិងបុត្របានចេញបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ កាលដល់ពេលចង្ហាន់គេបានប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចំរើន លោកឪពុកនិមន្តទៅចុះ ព្រះសង្ឃនឹងអង្គាសលោកឪពុក (ថាហើយក៏) ចាប់ខ្នងច្រានទៅ។ ភិក្ខុជាបិតានោះក៏ដួលស្លាប់។ ភិក្ខុជាកូននោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គឥតមានបំណងឲ្យស្លាប់ទេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានបំណងឲ្យស្លាប់ទេ មិនត្រូវអាបត្តិទេ។ សម័យនោះឯង បិតានិងបុត្របានមកបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ កាលដល់ពេលឆាន់គេប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចំរើន លោកឪពុកនិមន្តទៅចុះ សង្ឃនឹងអង្គាសលោកឪពុក (ថាហើយ) មានបំណងចង់ឲ្យស្លាប់ ក៏ចាប់ខ្នងច្រានទៅ។ ភិក្ខុជាបិតានោះក៏ដួលចុះហើយស្លាប់ទៅ។ ភិក្ខុជាបុត្រនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង បិតានិងបុត្របានចេញបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ កាលដល់ពេលចង្ហាន់គេបានប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចំរើន លោកឪពុកនិមន្តទៅចុះ សង្ឃនឹងអង្គាសលោកឪពុក (ថាហើយ) មានបំណងចង់ឲ្យស្លាប់ ទើបចាប់ខ្នងច្រានទៅ។ ភិក្ខុជាបិតានោះក៏ដួលទៅ តែមិនស្លាប់។ ភិក្ខុជាបុត្រនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២០៩] សម័យនោះឯង មានភិក្ខុមួយរូបកំពុងឆាន់ចង្ហាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក។ មានភិក្ខុមួយរូបទៀត បានវាយចំបំពង់កនៃភិក្ខុនោះ។ ក៏ធ្លាក់សាច់ដោយទាំងឈាមមកផង។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ភិក្ខុអ្នកវាយនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានបំណងចង់ឲ្យស្លាប់ទេ មិនត្រូវអាបត្តិឡើយ។ សម័យនោះឯង មានភិក្ខុមួយរូបកំពុងឆាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក។ មានភិក្ខុមួយរូបទៀតចង់សម្លាប់ ទើបវាយចំបំពង់កនៃភិក្ខុនោះ។ ក៏ធ្លាក់សាច់ដោយទាំងឈាមមកផង។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ភិក្ខុអ្នកវាយនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុមួយរូបកំពុងឆាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក។ មានភិក្ខុមួយរូបទៀតមានប្រាថ្នាចង់ឲ្យស្លាប់ ទើបវាយបំពង់កនៃភិក្ខុនោះ។ ក៏ធ្លាក់សាច់ដោយទាំងឈាមមកផង តែភិក្ខុនោះមិនស្លាប់។ ភិក្ខុអ្នកវាយនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២១០] សម័យនោះឯង មានបិណ្ឌចារិកភិក្ខុមួយរូប បានចង្ហាន់លាយដោយថ្នាំពិស ហើយនាំចេញទៅ បានប្រគេនភោជនដ៏ឧត្តមដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងនោះក៏ (នាំគ្នាឆាន់) ពុលស្លាប់អស់ទៅ។ ភិក្ខុអ្នកប្រគេនបិណ្ឌបាតនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់សួរថា នែភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងសោះ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនដឹង មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូប មានប្រាថ្នាចង់ល្បងលេង បានឲ្យថ្នាំពិសដល់ភិក្ខុមួយរូប។ ភិក្ខុនោះស្លាប់។ ភិក្ខុអ្នកឲ្យនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងល្បងលេងទេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២១១] សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវីនាំគ្នារៀបចំទីវត្ត។ មានភិក្ខុមួយរូបនៅខាងក្រោមហុចថ្មទៅ ភិក្ខុនៅខាងលើទទួលថ្មមិនមាំ ក៏របូតធ្លាក់មកចំក្បាលភិក្ខុអ្នកនៅខាងក្រោម។ ភិក្ខុត្រូវថ្មធ្លាក់លើនោះក៏ស្លាប់ទៅ។ ភិក្ខុអ្នកទទួលថ្មមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង។ សម័យនោះឯង ពួកភិក្ខុស្រុកអាឡវី (នាំគ្នា) រៀបចំទីវត្ត។ មានភិក្ខុមួយរូបនៅខាងក្រោមហុចថ្មទៅលើ។ ភិក្ខុអ្នកនៅខាងលើ មានបំណងចង់សម្លាប់ ក៏ទម្លាក់ថ្មមកចំក្បាលភិក្ខុអ្នកនៅខាងក្រោម។ ភិក្ខុនោះស្លាប់ទៅ។ ភិក្ខុអ្នកទម្លាក់ថ្មនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី (នាំគ្នា) រៀបចំទីវត្ត។ មានភិក្ខុមួយរូប (ធ្វើការ) នៅខាងក្រោម បានហុចថ្មទៅ។ ភិក្ខុនៅខាងលើមានបំណងចង់សម្លាប់ (ភិក្ខុនៅខាងក្រោម) ទើបទម្លាក់ថ្មមកចំក្បាលភិក្ខុនៅខាងក្រោមនោះ។ ភិក្ខុនោះមិនស្លាប់។ ភិក្ខុអ្នកទម្លាក់ថ្មនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី (នាំគ្នា) លើកជញ្ជាំងវិហារ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចឥដ្ឋទៅខាងលើ។ ឥដ្ឋដែលភិក្ខុនៅខាងលើចាប់មិនមាំ ក៏ធ្លាក់មកចំក្បាលភិក្ខុអ្នកនៅខាងក្រោម។ ភិក្ខុនោះស្លាប់។ ភិក្ខុទទួលឥដ្ឋនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង។ សម័យនោះឯង ពួកភិក្ខុនៅក្នុងដែនអាឡវី (នាំគ្នា) កដញ្ជាំងវិហារ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចឥដ្ឋទៅ។ ភិក្ខុ (អ្នកទទួលឥដ្ឋ) នៅខាងលើ មានបំណងចង់សម្លាប់ ក៏ទម្លាក់ឥដ្ឋមកចំក្បាលភិក្ខុអ្នកនៅខាងក្រោម។ ភិក្ខុនោះស្លាប់។ បេ។ ភិក្ខុនោះមិនស្លាប់។ ភិក្ខុអ្នកទម្លាក់ឥដ្ឋនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ពួកភិក្ខុនៅប្រទេសអាឡវី (នាំគ្នា) ធ្វើនវកម្ម (ការកសាង)។ មានភិក្ខុមួយរូបទៀតនៅខាងក្រោមហុចកាំបិតព្រាទៅខាងលើ។ កាំបិតព្រាដែលភិក្ខុនៅខាងលើចាប់មិនជាប់ ក៏របូតមកចំក្បាលភិក្ខុនៅខាងក្រោម។ ភិក្ខុនោះធ្វើកាលកិរិយាទៅ។ ភិក្ខុអ្នកទទួលកាំបិតនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី (នាំគ្នា) ធ្វើនវកម្ម។ មានភិក្ខុមួយរូបនៅខាងក្រោមហុចកាំបិតព្រាទៅខាងលើ។ ភិក្ខុនៅខាងលើ មានបំណងចង់សម្លាប់ (ភិក្ខុនៅខាងក្រោម) ទើបទម្លាក់កាំបិតព្រាចំក្បាលភិក្ខុនៅខាងក្រោម។ ភិក្ខុនោះធ្វើកាលកិរិយាទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើកាលកិរិយា។ ភិក្ខុអ្នកទម្លាក់កាំបិតនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ពួកភិក្ខុនៅដែនអាឡវី (នាំគ្នា) ធ្វើនវកម្ម។ មានភិក្ខុមួយរូបនៅខាងក្រោម ហុចបង្កង់វិហារទៅខាងលើ។ បង្កង់ដែលភិក្ខុនៅខាងលើចាប់មិនមាំ ក៏ធ្លាក់មកចំក្បាលភិក្ខុអ្នកនៅខាងក្រោម។ ភិក្ខុនោះក៏ធ្វើកាលកិរិយាទៅ។ ភិក្ខុអ្នកទម្លាក់នោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង។ សម័យនោះឯង ពួកភិក្ខុនៅប្រទេសអាឡវី (នាំគ្នា) ធ្វើនវកម្ម។ មានភិក្ខុមួយរូបនៅខាងក្រោមហុចបង្កង់ទៅខាងលើ។ ភិក្ខុនៅខាងលើ មានបំណងចង់សម្លាប់ (ភិក្ខុនៅខាងក្រោម) ទើបទម្លាក់បង្កង់មកចំក្បាលភិក្ខុនៅខាងក្រោម។ ភិក្ខុនោះធ្វើកាលកិរិយាទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើកាលកិរិយា។ ភិក្ខុអ្នកទម្លាក់បង្កង់នោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី (នាំគ្នា) ធ្វើនវកម្មចងរន្ទា។ មានភិក្ខុមួយរូបបាននិយាយនឹងភិក្ខុមួយរូបទៀតថា ម្នាលអាវុសោ លោកចូរឈរក្នុងទីនោះ ហើយចងរន្ទាទៅ។ ភិក្ខុនោះឈរនៅក្នុងទីនោះចងរន្ទា ក៏ភ្លាត់ធ្លាក់មក ហើយធ្វើកាលកិរិយាទៅ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងនឹងសម្លាប់ទេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង ពួកភិក្ខុនៅដែនអាឡវី កាលនឹងធ្វើនវកម្ម (បាននាំគ្នា) ចងរន្ទា។ មានភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ទើបនិយាយនឹងភិក្ខុមួយរូបថា ម្នាលអាវុសោ លោកចូរឈរនៅទីនោះចងរន្ទាទៅ។ ភិក្ខុនោះឈរនៅទីនោះ កំពុងតែចងរន្ទា ក៏ភ្លាត់ធ្លាក់ចុះមក ធ្វើមរណកាលទៅ។ បេ។ (មានភិក្ខុមួយរូបទៀត) ភ្លាត់ធ្លាក់ដែរ តែមិនបានធ្វើមរណកាលទេ។ លោកដែលបង្គាប់នោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ។

[២១២] សម័យនោះឯង មានភិក្ខុមួយរូបប្រក់វិហារ ហើយចុះមក។ មានភិក្ខុមួយរូបទៀត បាននិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរចុះខាងនេះ។ ភិក្ខុនោះកាលចុះមកតាមផ្លូវនោះ ក៏ធ្លាក់ធ្វើមរណកាលទៅ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់អ្នកដែលមិនមានបំណងនឹងសម្លាប់ទេ។ សម័យនោះឯង មានភិក្ខុមួយរូបប្រក់វិហារ ហើយចុះមក។ មានភិក្ខុមួយរូបទៀត មានបំណងនឹងសម្លាប់ ទើបនិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរចុះខាងនេះ។ ភិក្ខុនោះកាលចុះតាមផ្លូវនោះមក ក៏ធ្លាក់ចុះ ធ្វើមរណកាលទៅ។ បេ។ (មានភិក្ខុមួយរូបទៀត) ធ្លាក់ចុះហើយ តែមិនបានធ្វើមរណកាល។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២១៣] សម័យនោះឯង មានភិក្ខុមួយរូបមានសេចក្ដីអផ្សុកមកបៀតបៀន ឡើងទៅកាន់ភ្នំគិជ្ឈកូដ ក៏ទម្លាក់ខ្លួនចុះមកក្នុងជ្រោះសង្កត់លើជាងត្បាញផែងម្នាក់ស្លាប់ទៅ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំគប្បីទម្លាក់សម្លាប់ខ្លួនឯង ភិក្ខុណាទម្លាក់សម្លាប់ខ្លួនឯង (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ (នាំគ្នា) ឡើងទៅកាន់ភ្នំគិជ្ឈកូដ ហើយប្រមៀលថ្មលេង។ ថ្មនោះធ្លាក់មកសង្កត់អ្នកគង្វាលគោម្នាក់ស្លាប់ទៅ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុមិនត្រូវប្រមៀលថ្មដើម្បីជាល្បែងលេងទេ ភិក្ខុណាប្រមៀល (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ។

[២១៤] សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ទើបភិក្ខុទាំងឡាយនាំគ្នាឲ្យភិក្ខុនោះឆ្អង។ ភិក្ខុនោះធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យភិក្ខុនោះឆ្អង។ ភិក្ខុនោះធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបកើតរោគក្ដៅក្បាល។ ទើបភិក្ខុទាំងឡាយឲ្យភិក្ខុនោះនត្ថុថ្នាំ។ ភិក្ខុនោះធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានរោគក្ដៅក្បាល។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យភិក្ខុនោះនត្ថុថ្នាំ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិ

ចុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយនាំគ្នាច្របាច់ភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបនាំគ្នាច្របាច់ភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ទើបភិក្ខុទាំងឡាយឲ្យភិក្ខុនោះងូតទឹក។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ទេ មិនត្រូវអាបត្តិឡើយ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យភិក្ខុនោះស្រង់ទឹក។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ទើបភិក្ខុទាំងឡាយ យកប្រេងមកលាបភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើប (នាំគ្នា) យកប្រេងមកលាបភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ទើបភិក្ខុទាំងឡាយឲ្យភិក្ខុនោះក្រោកឡើង។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ ឥតមានអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបញុំាងភិក្ខុនោះឲ្យស្ទុះក្រោកឡើង។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយចាប់ភិក្ខុនោះផ្តួល។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ ឥតមានអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើប (នាំគ្នា) ផ្តួលភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយបានឲ្យបាយដល់ភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ បានឲ្យបាយដល់ភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយបានឲ្យទឹកសម្រាប់ផឹកដល់ភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យទឹកសម្រាប់ផឹកដល់ភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។

[២១៥] សម័យនោះឯង មានស្រីម្នាក់ព្រាត់ប្រាសចាកប្តីមកយូរហើយ ទើបមានគភ៌នឹងសហាយ។ ស្រីនោះបាននិយាយនឹងភិក្ខុជាជីតុនថា[37] សូមទានមេត្តាចុះ លោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌ (ឲ្យទានខ្ញុំករុណា)។ ភិក្ខុនោះទទួលថា ស្រួលហើយប្អូនស្រី ហើយក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ។ ទារក (ដែលនៅក្នុងគភ៌) ក៏ធ្វើមរណកាលទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ (តែ) ប្រពន្ធម្នាក់នោះជាស្រីអារ ម្នាក់ទៀតជាស្រីមានកូន។ ស្រីអារនិយាយនឹងភិក្ខុជាជីតុនថា បពិត្រលោកម្ចាស់ បើស្រីនោះសម្រាលកូន មុខតែនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមទានមេត្តាចុះ លោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌វាចេញ។ ភិក្ខុទទួលថា ស្រួលហើយប្អូនស្រី (ថាហើយ) ក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ។ ទារក (ដែលនៅក្នុងគភ៌) ក៏ធ្វើមរណកាលទៅ។ ឯម្តាយមិនបានធ្វើមរណកាលទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ ប្រពន្ធម្នាក់ជាស្រីអារ ម្នាក់ជាស្រីមានកូន។ ឯស្រីអារនិយាយនឹងភិក្ខុជាជីតុនថា បពិត្រលោកម្ចាស់ បើស្រីនោះសម្រាលកូន គេនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមទានមេត្តាចុះ លោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌វាចេញ។ ភិក្ខុជាជីតុនទទួលថា ស្រួលហើយប្អូនស្រី (ថាហើយ) ក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ។ ម្តាយក៏ធ្វើមរណកាលទៅ។ ឯទារកមិនធ្វើមរណកាលទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ ប្រពន្ធម្នាក់ជាស្រីអារ ម្នាក់ទៀតជាស្រីមានកូន។ ស្រីអារនិយាយនឹងភិក្ខុជាជីតុនថា បពិត្រលោកម្ចាស់ បើស្រីនោះសម្រាលកូន គេនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមទានមេត្តាចុះ លោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌វាចេញ។ ភិក្ខុទទួលថា ស្រួលហើយប្អូនស្រី (ថាហើយ) ក៏ឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ។ ម្តាយនិងកូនទាំងពីរនាក់ ក៏ធ្វើមរណកាលទៅ។ បេ។ ម្តាយនិងកូនទាំងពីរនាក់មិនបានធ្វើមរណកាល។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានស្រីម្នាក់មានគភ៌ បាននិយាយនឹងភិក្ខុជាជីតុនថា សូមទានមេត្តាចុះ លោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌ (ដល់ខ្ញុំ)។ ភិក្ខុនោះពោលថា នែប្អូនស្រី បើដូច្នោះ នាងចូរច្របាច់ពោះទៅ។ ស្រីនោះក៏ច្របាច់ពោះរំលូតគភ៌មក។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានស្រីម្នាក់មានគភ៌ បាននិយាយនឹងភិក្ខុជាជីតុនថា សូមទានមេត្តាចុះ លោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌ (ឲ្យទានខ្ញុំព្រះករុណា) ភិក្ខុនោះប្រាប់ថា នែប្អូនស្រី បើដូច្នោះ នាងចូរកំដៅផ្ទៃពោះទៅ។ នាងនោះក៏កំដៅគភ៌រំលូតកូនមក។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានស្រីអារម្នាក់បាននិយាយនឹងកុលុបកភិក្ខុជា (ជីតុន) ថា សូមទានមេត្តាចុះ លោកម្ចាស់ ខ្ញុំគប្បីសម្រាលកូនដោយថ្នាំណា (ស្រួល) មេត្តាប្រាប់ថ្នាំនោះ (ដល់ខ្ញុំ)។ ភិក្ខុនោះទទួលថា ស្រួលហើយប្អូនស្រី (ថាហើយ) ក៏បានឲ្យថ្នាំដល់នាងនោះ។ នាងនោះក៏ធ្វើមរណកាលទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិទុក្កដ។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមានកូន

បាននិយាយនឹងភិក្ខុជាជីតុនថា សូមទានមេត្តាចុះ លោកម្ចាស់ ខ្ញុំមិនសម្រាលកូនដោយថ្នាំណា សូមលោកម្ចាស់ឲ្យថ្នាំនោះ (ដល់ខ្ញុំ)។ លោកនោះទទួលថា ស្រួលហើយប្អូនស្រី (ថាហើយ) ក៏បានឲ្យថ្នាំដល់ស្រីនោះ។ នាងនោះក៏ធ្វើមរណកាលទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិទុក្កដ។

[២១៦] សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ បានចាក់ក្រឡេកភិក្ខុ (មួយរូប) ដែលរាប់បញ្ចូលក្នុងពួកសត្តរសវគ្គិយភិក្ខុ ដោយចុងម្រាមដៃ។ ភិក្ខុនោះ (រសើបភ័យខ្លាំង) តក់ស្លុត ផុតដង្ហើមស្លាប់ទៅ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិបាចិត្តិយ។

[២១៧] សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុគិតគ្នាថា យើងនឹងធ្វើកម្ម[38] (គិតហើយ) ក៏ចាប់សង្កត់សម្រុកញឆព្វគ្គិយភិក្ខុមួយរូបទាល់តែស្លាប់ទៅ។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះមានសេចក្តីសង្ស័យកើតឡើង។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិបាចិត្តិយ។

[២១៨] សម័យនោះឯង មានភិក្ខុមួយរូបជាពេទ្យចាប់ខ្មោច បានផ្តាច់បង់ជីវិតយក្ខមួយ។ ភិក្ខុនោះមានសេចក្តីសង្ស័យកើតឡើង។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២១៩] សម័យនោះឯង មានភិក្ខុមួយរូប បានបញ្ជូនភិក្ខុមួយរូបទៅកាន់វិហារដែលមានយក្ខកាច (អាស្រ័យនៅ)។ ពួកយក្ខក៏ (នាំគ្នា) ផ្តាច់បង់ជីវិតភិក្ខុនោះទៅ។ ឯភិក្ខុដែលជាអ្នកបញ្ជូនក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ។ សម័យនោះឯង ភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ក៏បញ្ជូនភិក្ខុមួយរូបទៅកាន់វិហារដែលមានយក្ខកាច។ ពួកយក្ខក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ។ បេ។ ពួកយក្ខមិនបានផ្តាច់បង់ជីវិតភិក្ខុនោះទេ។ ឯភិក្ខុជាអ្នកបញ្ជូននោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ភិក្ខុមួយរូប បញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវលំបាកមានសត្វសាហាវ។ សត្វសាហាវទាំងឡាយ ក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ។ ភិក្ខុអ្នកបញ្ជូនមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ។ សម័យនោះឯង ភិក្ខុមួយរូបមានបំណងនឹងសម្លាប់ បានបញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាលមានសត្វសាហាវ។ សត្វសាហាវទាំងឡាយក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ។ បេ។ ពួកសត្វសាហាវមិនបានផ្តាច់ជីវិតភិក្ខុនោះទេ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូប បានបញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវឆ្ងាយដាច់សង្វែង មានចោរ (អាស្រ័យនៅ)។ ពួកចោរក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង ភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ក៏បញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវឆ្ងាយដាច់សង្វែង ដែលមានចោរ (អាស្រ័យនៅ)។ ពួកចោរក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ។ បេ។ ពួកចោរមិនបានផ្តាច់បង់ជីវិតភិក្ខុនោះទេ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២២០] សម័យនោះឯង មានភិក្ខុមួយរូបចំណាំភិក្ខុជាសត្រូវនោះបាន ហើយក៏ទៅផ្តាច់បង់ជីវិតភិក្ខុជាសត្រូវនោះទៅ។ ចំណាំភិក្ខុជាសត្រូវនោះបាន តែទៅផ្តាច់បង់ជីវិតភិក្ខុដទៃវិញ។ ចូលចិត្តថាជាភិក្ខុដទៃ តែទៅផ្តាច់បង់ជីវិតភិក្ខុជាសត្រូវនោះវិញ។ សំគាល់ថាជាភិក្ខុដទៃ ក៏ទៅផ្តាច់បង់ជីវិតភិក្ខុដទៃ (នោះ)។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[២២១] សម័យនោះឯង មានភិក្ខុមួយរូបខ្មោចចូល។ មានភិក្ខុមួយរូបទៀតបានវាយភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ ភិក្ខុដែលវាយនោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ (បើ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបខ្មោចចូលដែរ។ មានភិក្ខុមួយរូបទៀតមានបំណងនឹងសម្លាប់ បានវាយភិក្ខុនោះ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ។ បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២២២] សម័យនោះឯង មានភិក្ខុមួយរូបពោលសគ្គកថា (ថ្លែងអំពីស្ថានសួគ៌) ដល់បុគ្គលដែលបានធ្វើអំពើល្អ។ បុគ្គលដែលបានស្តាប់នោះក៏អត់ដង្ហើមធ្វើមរណកាលទៅ។ ភិក្ខុអ្នកសំដែង មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ទើបសំដែងសគ្គកថា របស់បុគ្គលដែលបានធ្វើអំពើល្អមកហើយ។ បុគ្គលនោះ ក៏អត់ដង្ហើមធ្វើមរណកាលទៅ។ បេ។ បុគ្គលនោះ បានអត់ដង្ហើមដែរ តែមិនបានធ្វើមរណកាលទេ។ ឯភិក្ខុអ្នកសំដែងមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុមួយរូបសំដែងនិរយកថា (ដំណាលអំពីនរក) នៃសត្វដែលទៅកើតក្នុងនរក។ ភិក្ខុអ្នកស្តាប់នោះតក់ស្លុត ហើយធ្វើមរណកាលទៅ។ ភិក្ខុអ្នកសំដែងនោះ មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានប្រាថ្នានឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង មានភិក្ខុមួយរូបមានប្រាថ្នានឹងសម្លាប់ ទើបពោលនិរយកថា នៃសត្វដែលទៅកើតក្នុងនរក។ បុគ្គលនោះ តក់ស្លុត ហើយធ្វើមរណកាលទៅ។ បេ។ បុគ្គលនោះតក់ស្លុត តែមិនបានធ្វើមរណកាលឡើយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២២៣] សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី កាលធ្វើនវកម្ម ទើបនាំគ្នាកាប់ដើមឈើ។ មានភិក្ខុមួយរូបបាននិយាយនឹងភិក្ខុមួយរូបទៀតថា ម្នាលអាវុសោ លោកចូរឈរត្រង់ទីនេះកាប់ឈើទៅ។ ដើមឈើក៏រលំសង្កត់ភិក្ខុនោះដែលកំពុងឈរកាប់ ស្លាប់ក្នុងទីនោះទៅ។ ភិក្ខុអ្នកបង្គាប់នោះ មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនប្រាថ្នានឹងសម្លាប់មិនត្រូវអាបត្តិទេ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី កាលនឹងធ្វើនវកម្ម បាននាំគ្នាកាប់ដើមឈើ។ មានភិក្ខុមួយរូប មានបំណងនឹងសម្លាប់ ទើបនិយាយនឹងភិក្ខុមួយរូបទៀតថា ម្នាលអាវុសោ លោកចូរឈរត្រង់ទីនេះកាប់ឈើទៅ។ ដើមឈើក៏រលំសង្កត់ភិក្ខុនោះដែលកំពុងឈរកាប់ ស្លាប់ក្នុងទីនោះទៅ។ បេ។ ដើមឈើរលំសង្កត់មិនស្លាប់។ ភិក្ខុអ្នកបង្គាប់នោះ មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២២៤] សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយនាំគ្នាដុតភ្លើងព្រៃ។ មនុស្ស (ដែលនៅក្នុងព្រៃ) ត្រូវភ្លើងឆេះស្លាប់ (ជាច្រើននាក់)។ ភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមានបំណងនឹងសម្លាប់ ក៏នាំគ្នាដុតភ្លើងព្រៃ។ មនុស្សទាំងឡាយ ត្រូវភ្លើងព្រៃឆេះស្លាប់ (ជាច្រើននាក់)។ បេ។ ពួកមនុស្សត្រូវភ្លើងព្រៃឆេះ តែមិនស្លាប់។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២២៥] សម័យនោះឯង មានភិក្ខុមួយរូបដើរទៅកាន់ទីសម្លាប់ចោរ ហើយបាននិយាយនឹងពេជ្ឈឃាតថា ម្នាលអាវុសោ អ្នកកុំធ្វើឲ្យបុរសនេះលំបាកឡើយ អ្នកចូរផ្តាច់បង់ជីវិតដោយប្រហារត្រឹមតែម្តងទៅ។ ពេជ្ឈឃាតទទួលពាក្យថា ស្រួលហើយ លោកម្ចាស់ (ថាហើយ) ក៏ផ្តាច់បង់ជីវិត (ចោរ) ដោយប្រហារតែត្រឹមម្តង។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានភិក្ខុមួយរូបដើរទៅកាន់ទីសម្លាប់ចោរ ហើយបាននិយាយនឹងពេជ្ឈឃាតថា ម្នាលអាវុសោ អ្នកកុំធ្វើបុរសនេះឲ្យលំបាកឡើយ ចូរអ្នកផ្តាច់បង់ជីវិតដោយប្រហារតែត្រឹមម្តងទៅ។ ពេជ្ឈឃាតឆ្លើយថា ខ្ញុំព្រះករុណាមិនធ្វើតាមពាក្យលោកទេ (ថាហើយ) ក៏ផ្តាច់បង់ជីវិតបុរសនោះទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[២២៦] សម័យនោះឯង មានបុរសម្នាក់ គេកាត់ដៃកាត់ជើង (មកនៅ) ក្នុងផ្ទះត្រកូល មានពួកញាតិមកប្រជុំគ្នាព្យាបាល។ មានភិក្ខុមួយរូបបាននិយាយនឹងពួកមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចង់ឲ្យបុរសនេះស្លាប់ទេ។ ពួកមនុស្សឆ្លើយតបថា ករុណា យើងចង់ឲ្យគាត់ស្លាប់ដែរ។ ភិក្ខុនោះប្រាប់ថា បើដូច្នោះ អ្នកទាំងឡាយចូរឲ្យគាត់ផឹកខ្លាញ់ទឹកដោះគោទៅ។ ពួកមនុស្សក៏ឲ្យបុរសនោះផឹកខ្លាញ់ទឹកដោះគោ។ បុរសនោះក៏ធ្វើមរណកាលទៅ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះឯង មានបុរសម្នាក់ គេកាត់ដៃកាត់ជើង (មកនៅ) ក្នុងផ្ទះត្រកូល ពួកញាតិក៏ប្រជុំគ្នាមកព្យាបាល។ មានភិក្ខុនី (មួយរូប) និយាយនឹងពួកមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចង់ឲ្យបុរសនេះស្លាប់ឬទេ។ ពួកមនុស្សឆ្លើយថា ករុណា លោកម៉ែម្ចាស់ យើងចង់ឲ្យស្លាប់ដែរ។ ភិក្ខុនីនោះប្រាប់ថា បើដូច្នោះ អ្នកទាំងឡាយចូរឲ្យគាត់ផឹកថ្នាំត្រាំដោយអំបិលទៅ។ មនុស្សទាំងនោះក៏ឲ្យបុរសនោះផឹកថ្នាំត្រាំដោយអំបិលនោះ។ បុរសនោះធ្វើមរណកាលទៅ។ ភិក្ខុនីនោះមានសេចក្តីសង្ស័យ។ លំដាប់នោះឯង ភិក្ខុនីនោះបានប្រាប់ដំណឹងនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីក៏ដំណាលសេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះ ត្រូវអាបត្តិបារាជិកហើយ។

បារាជិកទី ៣ ចប់។

# បារាជិកកណ្ឌេ ចតុត្ថសិក្ខាបទំ

CS vin.vbu.pr.04 | ភាគ ទី១

### (៤. ចតុត្ថបារាជិកំ)

## (បឋមភាណវារៈ ចតុត្ថសិក្ខាបទំ)

CS vin.vbu.pr.04.00 | ភាគ ទី១

(-)

[២២៧] សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅកូដាគារសាលា ព្រៃមហាវន ទៀបក្រុងវេសាលី។ គ្រានោះ មានភិក្ខុច្រើនរូបជាមិត្របានជួបប្រទះគ្នាថ្មី និងមិត្រស្និទ្ធស្នាលមាំមួន បាននៅចាំវស្សាប្របច្រាំងស្ទឹងវគ្គមុទា។ កាលនោះ ស្រុកវជ្ជីកើតទុរ្ភិក្សអត់បាយ មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្ស (ដែលក្រលំបាកស្រាប់ ក៏ដល់នូវសេចក្តីស្លាប់) មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្ស (ដែលមានទ្រព្យសម្បត្តិល្មមទិញដូរស្រូវអង្ករគេបាន) ក៏មិនងាយនឹងទិញដូរដែរ លុះតែមានស្លាកកាន់ជាសំគាល់ ទើបទិញដូរបាន មនុស្សទាំងអស់ក្នុងស្រុកនោះនឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក។ វេលានោះឯង ភិក្ខុទាំងនោះក៏គិតគ្នាថា ឥឡូវនេះ ស្រុកវជ្ជីកើតទុរ្ភិក្សអត់បាយ មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្ស (ដែលក្រលំបាកស្រាប់ ក៏ដល់នូវសេចក្តីស្លាប់) មានឆ្អឹងស (ដេរដាសលើផែនដី) មនុស្ស (ដែលមានទ្រព្យសម្បត្តិល្មមទិញដូរស្រូវអង្ករគេបាន) ក៏មិនងាយនឹងទិញដូរដែរ លុះតែមានស្លាកកាន់ជាសំគាល់ ទើបទិញដូរបាន មនុស្សទាំងអស់ក្នុងស្រុកនោះនឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក តើយើងនឹងគិតធ្វើឧបាយដូចម្តេចឲ្យបានសាមគ្គីស្មោះសរ កុំឲ្យមានវិវាទទាស់ទែងគ្នា នៅចាំវស្សាឲ្យបានស្រួលផង កុំឲ្យលំបាកដោយអាហារបិណ្ឌបាតផង។ ភិក្ខុខ្លះឆ្លើយថា ម្នាលអាវុសោ បើដូច្នោះ យើងត្រូវទទួលរ៉ាប់រងការងាររបស់ពួកគ្រហស្ថចុះ កាលបើយើងធ្វើយ៉ាងនេះហើយ ពួកគ្រហស្ថទាំងនោះ គង់នឹងនឹកនាឲ្យអាហារដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងក៏បានសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង។ ភិក្ខុខ្លះឆ្លើយថា ម្នាលអាវុសោ កុំ ប្រយោជន៍អ្វីនឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថ (នោះ) ម្នាលអាវុសោ ណ្ហើយចុះ យើងត្រូវធ្វើជាអ្នកបំរើ នាំដំណឹងដល់ពួកគ្រហស្ថវិញ កាលបើយើងធ្វើយ៉ាងនេះហើយ ពួកជនទាំងនោះ គង់នឹងនឹកនាឲ្យអាហារបិណ្ឌបាតដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះ យើងនឹងព្រមព្រៀងស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង។ ភិក្ខុខ្លះឆ្លើយថា ម្នាលអាវុសោ កុំ ប្រយោជន៍អ្វីនឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថ ប្រយោជន៍អ្វីនឹងធ្វើជាអ្នកបំរើនាំដំណឹងដល់ពួកគ្រហស្ថ (នោះ) ម្នាលអាវុសោ ណ្ហើយចុះ យើងត្រូវពោលអួតឧត្តរិមនុស្សធម្មគ្នាយើងទៅវិញទៅមក ឲ្យពួកគ្រហស្ថ (គេស្តាប់វិញ) ថា ភិក្ខុឯណោះបានឈានទី១ ភិក្ខុឯណោះបានឈានទី២ ភិក្ខុឯណោះបានឈានទី៣ ភិក្ខុឯណោះបានឈានទី៤ ភិក្ខុឯណោះជាសោតាបន្ន ភិក្ខុឯណោះជាសកទាគាមី ភិក្ខុឯណោះជាអនាគាមី ភិក្ខុឯណោះជាព្រះអរហន្ត ភិក្ខុឯណោះបានត្រៃវិជ្ជា ភិក្ខុឯណោះបានអភិញ្ញា៦

កាលបើយើងពោលយ៉ាងនេះហើយ ពួកជនទាំងនោះ គង់នឹងនឹកនា ឲ្យអាហារបិណ្ឌបាតដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងក៏នឹងមានសាមគ្គីស្មោះសរនឹងគ្នា មិនវិវាទទាស់ទែងគ្នាឡើយ នៅចាំវស្សាក៏ស្រួល ហើយមិនលំបាកដោយបិណ្ឌបាតផង។ ភិក្ខុទាំងនោះក៏យល់ព្រមថា ម្នាលអាវុសោទាំងឡាយ ការពោលអួតឧត្តរិមនុស្សធម្មរបស់គ្នាយើងទៅវិញទៅមកដល់ពួកគ្រហស្ថ ដែលលោកថាមកនឹងយើង (អម្បាញ់មិញនេះ) ស្រួលហើយ។ ក្នុងកាលជាខាងក្រោយមក ភិក្ខុទាំងនោះក៏បានពោលអួតឧត្តរិមនុស្សធម្មទៅវិញទៅមកដល់ពួកគ្រហស្ថថា ភិក្ខុឯណោះបានឈានទី១។ បេ។ ភិក្ខុឯណោះបានឈានទី៤ ភិក្ខុឯណោះជាសោតាបន្ន។ បេ។ ភិក្ខុឯណោះបានអភិញ្ញា៦។ គ្រានោះ មនុស្សទាំងនោះក៏និយាយគ្នាថា យើងរាល់គ្នាបានភិក្ខុបែបនេះមកនៅចាំវស្សា អើហ្ន៎ ហៅពេញជាលាភរបស់យើង ឈ្មោះថាយើងបានបុណ្យដោយងាយណាស់ហ្ន៎ ពីដើមយើងរាល់គ្នាមិនដែលបានពួកភិក្ខុមានសីល មានធម៌ជាកុសល ដូចជាពួកភិក្ខុនេះមកនៅចាំវស្សា (ដល់ម្តង) សោះឡើយ។ មនុស្សទាំងនោះ (កាលបើបាន) ភោជនាហារដែលឆ្ងាញ់ពីសា ក៏បំរុងទុកតែនឹងប្រគេនភិក្ខុទាំងនោះ មិនហ៊ានបរិភោគមាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតា កូន ប្រពន្ធ ខ្ញុំកំដរ កម្មករបុរស[39] មិត្រ អមាត្យ មន្ត្រី និងញាតិសាលោហិតសោះឡើយ ឬបានខាទនីយាហារដែលឆ្ងាញ់ពីសា ក៏បំរុងទុកតែនឹងប្រគេនភិក្ខុទាំងនោះ មិនហ៊ានបរិភោគមាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតាទេ។ បេ។ មិនដែលបានឲ្យទៅញាតិសាលោហិតឡើយ ឬបានគ្រឿងសម្រាប់ជញ្ជក់ជញ្ជាប់ ដែលឆ្ងាញ់ពីសា ក៏បំរុងទុកតែនឹងប្រគេនភិក្ខុទាំងនោះ មិនហ៊ានជញ្ជក់ជញ្ជាប់មាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតាទេ។ បេ។ មិនដែលបានឲ្យទៅញាតិសាលោហិតឡើយ ឬបានទឹកដែលមានរសល្អ ក៏បំរុងទុកតែនឹងប្រគេនភិក្ខុទាំងនោះ មិនហ៊ានផឹកមាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតា កូន ប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្រ អមាត្យ ញាតិសាលោហិតឡើយ។ គ្រានោះ ភិក្ខុទាំងនោះ (លុះបានអាហារឆាន់បរិបូណ៌) ក៏មានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានទឹកមុខស្រស់បស់ សម្បុរស្បែកក៏ជ្រះថ្លា។ ភិក្ខុទាំងឡាយ កាលបើចេញវស្សារួចហើយ តែងនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ នេះជាទំនៀមមិនដែលខានឡើយ។ វេលានោះឯង ភិក្ខុទាំងនោះ លុះបាននៅចាំវស្សាគ្រប់៣ខែហើយ ក៏រៀបចំទុកដាក់គ្រឿងសេនាសនៈរួចហើយ នាំយកបាត្រ និងចីវរចូលទៅក្រុងវេសាលី ដើរទៅកាន់ចារិកតាមលំដាប់ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ដែលគង់នៅកូដាគារសាលាព្រៃមហាវនទៀបក្រុងវេសាលី លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។

[២២៨] សម័យនោះឯង ពួកភិក្ខុដែលនៅចាំវស្សាក្នុងទិសទាំងឡាយ (រាល់ដំបន់ឯទៀត) សឹងដ៏មានកាយស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ឯពួកភិក្ខុដែលនៅទៀបត្រើយស្ទឹងវគ្គមុទា សឹងដ៏មានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានមុខមាត់ស្រស់បស់ សម្បុរស្បែកក៏ជ្រះថ្លាទាំងអស់គ្នា។ មានសេចក្តីថា ការស្មោះសរចំពោះជាមួយនឹងអាគន្តុកភិក្ខុ គឺភិក្ខុដែលទើបនឹងមកដល់ថ្មី នេះជាទំនៀមរបស់ព្រះពុទ្ធដ៏មានព្រះភាគគ្រប់ព្រះអង្គ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរទៅពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាល្មមអត់ធន់បានទេឬ[40] អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលទេឬ[41] អ្នកទាំងឡាយមានសេចក្តីសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាតទេឬ។ ពួកភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នា ល្មមប្រព្រឹត្តទៅបានដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងអស់គ្នាមានសេចក្តីសាមគ្គីស្មោះសរ ឥតមានវិវាទទាស់ទែងគ្នាទេ នៅចាំវស្សា ក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាតទេ។ (មានសេចក្តីថា) ព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវហេតុ ហើយត្រាស់សួរក៏មាន ជ្រាបច្បាស់ហើយមិនត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយ ត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយ មិនត្រាស់សួរក៏មាន ព្រះតថាគតទាំងឡាយ ទ្រង់សួរចំពោះតែអំពើដែលមានប្រយោជន៍ អំពើដែលមិនមានប្រយោជន៍ ទ្រង់មិនសួរឡើយ ព្រោះព្រះតថាគតទាំងឡាយ ទ្រង់ផ្តាច់បង់នូវអំពើដែលមិនមានប្រយោជន៍ដោយអរិយមគ្គអស់ហើយ។ ព្រះសម្ពុទ្ធជាម្ចាស់ទាំងឡាយដ៏មានជោគ ទ្រង់សួរពួកភិក្ខុដោយហេតុពីរប្រការ គឺទ្រង់សួរដើម្បីនឹងសំដែងធម៌១ ដើម្បីនឹងបញ្ញត្តសិក្ខាបទដល់ពួកសាវក១។ កាលនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា បានជាមានសេចក្តីសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាត នោះតើដោយហេតុអ្វី។ គ្រានោះ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ (ដោយសព្វគ្រប់)។ ទើបព្រះអង្គត្រាស់សួរថា នែភិក្ខុទាំងឡាយ ហេតុនេះពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលតបវិញថា បពិត្រព្រះដ៏មានព្រះភាគ ហេតុនេះមិនពិតទេ។

[២២៩] ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងអស់គ្នាធ្វើនេះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើសោះ នែមោឃបុរសទាំងឡាយ គួរបើដែរ អ្នកឯងរាល់គ្នាហ៊ានពោលអួតឧត្តរិមនុស្សធម្មទៅវិញទៅមកចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ចំអែតផ្ទៃ នែមោឃបុរសទាំងឡាយ បើអ្នករាល់គ្នាយកកាំបិតយ៉ាងមុត ដែលសំរាប់ពន្លះសាច់គោ មកវះពោះ (របស់ខ្លួន) វិញប្រសើរជាង ឯការពោលអួតឧត្តរិមនុស្សធម្មរបស់គ្នានឹងគ្នាចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ចំអែតផ្ទៃ ដែលអ្នកឯងទាំងអស់គ្នាពោលរួចទៅហើយ (នោះ) ពុំប្រសើរសោះឡើយ ហេតុអ្វីបានជាតថាគតពោលយ៉ាងនោះ ម្នាលមោឃបុរសទាំងឡាយ ពីព្រោះបុគ្គលដែលវះពោះខ្លួនឯងនោះ ជាហេតុបានតែត្រឹមសេចក្តីស្លាប់ ឬលំបាកទៀបស្លាប់ប៉ុណ្ណោះ កាលបើរំលាងខន្ធតអំពីមរណកាលទៅ ក៏មិនទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ នរក ព្រោះហេតុដែលវះពោះនោះឡើយ ម្នាលមោឃបុរសទាំងឡាយ ឯចំណែកខាងភិក្ខុដែលពោលអួតឧត្តរិមនុស្សធម្ម ជាហេតុ ជាទីតាំងនេះ កាលបើរំលាងខន្ធតអំពីមរណកាលទៅហើយ ទៀងតែទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ នរក មិនខានឡើយ ម្នាលមោឃបុរសទាំងឡាយ ការដែលពោលអួតឧត្តរិមនុស្សធម្មនេះ នឹងបាននាំមនុស្សដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា ឬមនុស្សដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងក៏ទេ។ បេ។ ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់តិះដៀលពួកភិក្ខុទាំងនោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំហើយ ទើបទ្រង់សំដែងធម្មីកថា តទៅថា

[២៣០] ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ មានភិក្ខុជាមហាចោរ៥ពួក។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមហាចោរ៥ពួកនោះ ដូចម្តេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះរបស់មហាចោរខ្លះដែលមានក្នុងលោកនេះថា បើដល់វេលាណាអញបានបរិសទ្យ១រយ ឬ១ពាន់ចោមរោមជាគ្នាហើយ នឹងលើកចូលទៅក្នុងស្រុកនិគមរាជធានី ហើយនឹងវាយសំពង ផ្តាច់ជីវិតពួកអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យផ្តាច់ជីវិត ដុតរោលអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យដុតរោល។ លុះដល់សម័យខាងក្រោយមក មហាចោរនោះ បានបរិសទ្យ១រយ ឬ១ពាន់ចោមរោមជាគ្នាហើយ ក៏លើកចូលទៅក្នុងស្រុកនិគមរាជធានី វាយសំពង ផ្តាច់ជីវិតអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យ

ផ្តាច់ជីវិត ដុតរោលអ្នកស្រុកទាំងនោះដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យដុតរោល យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះរបស់ភិក្ខុបាបខ្លះដែលមានក្នុងសាសនានេះ ក៏យ៉ាងនោះដែរ (ត្រិះរិះ) ថាបើដល់កាលណាអញបានបរិសទ្យ១រយ ឬ១ពាន់ចោមរោមជាគ្នាហើយ នឹងត្រេចទៅកាន់ចារិក ក្នុងស្រុកនិគមរាជធានី ក៏នឹងបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថក្តី ពួកបព្វជិតក្តី ធ្វើសក្ការគោរពរាប់អានបូជាកោតក្រែង។ លុះដល់សម័យខាងក្រោយមក ភិក្ខុបាបនោះបានបរិសទ្យ១រយ ឬ១ពាន់ចោមរោមជាគ្នាហើយ ក៏ត្រេចទៅកាន់ចារិក ក្នុងស្រុកនិគមរាជធានី បានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថក្តី បព្វជិតក្តី ធ្វើសក្ការគោរពរាប់អានបូជាកោតក្រែង។ ម្នាលភិក្ខុទាំឡាយ ភិក្ខុនេះហៅថា មហាចោរទី១ ដែលមានប្រាកដក្នុងលោក។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះរៀនសូត្រធម្មវិន័យដែលតថាគតបានសំដែងហើយ ដុតកំដៅខ្លួនឯងចោល[42] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មហាចោរទី២ ដែលមានប្រាកដក្នុងលោក។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះពោលចោទភិក្ខុដែលប្រព្រឹត្តធម៌ប្រសើរដ៏ស្អាត ដែលកំពុងប្រព្រឹត្តធម៌ប្រសើរដ៏បរិសុទ្ធ ចោទដោយការប្រព្រឹត្តមិនប្រសើរ[43] រកមូលគ្មាន។[44] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មហាចោរទី៣ មានប្រាកដក្នុងលោក។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះសង្គ្រោះផ្គាប់ផ្គុនគ្រហស្ថដោយគ្រឿងគរុភណ្ឌរបស់សង្ឃ ឬគ្រឿងគរុណបរិក្ខារ គ្រឿងគរុភណ្ឌ គឺអ្វីខ្លះ គ្រឿងគរុភណ្ឌនោះគឺ គុម្ពផ្កា និងដើមឈើ១ ទីដែលសំរាប់ដាំគុម្ពផ្កា និងដើមឈើ១ កុដិ១ ទីដែលសំរាប់សង់កុដិ១ គ្រែ១ តាំង១ ពូក១ ខ្នើយ១ ឆ្នាំងលោហៈ១ ស្នូកលោហៈ១ ក្អមលោហៈ១ ផើងលោហៈ១[45] កាំបិត១ ពូថៅ១ ដឹង១ ចប១ ពន្លាក (ឬដែកកណ្តារ)១ វល្លិប្រវែងមួយលូកឡើងទៅ១ ឫស្សីប្រវែង៨ធ្នាប់ឡើងទៅ១ ស្មៅដំណេកទន្សាយ១ ស្មៅយាប្លង១ ស្មៅធម្មតា១ ដីស្អិត១ គ្រឿងធ្វើនឹងឈើ១ គ្រឿងធ្វើនឹងដី១។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មហាចោរទី៤ មានប្រាកដក្នុងលោក។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនប្រាកដក្នុងខ្លួន ភិក្ខុនេះជាមហាចោរទី៥ ជាចោរធំបំផុតក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ នឹងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហេតុអ្វីបានជាតថាគតពោលដូច្នោះ ម្នាលភិក្ខុទាំងឡាយ ពីព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន គឺភិក្ខុនោះឯងលួចយកមកបរិភោគ។ (ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រាថ្នានឹងធ្វើសេចក្តីនោះឲ្យច្បាស់លាស់ឡើង ទើបត្រាស់សំដែងសេចក្តីជាគាថាតទៅទៀតថា) ភិក្ខុណាមានខ្លួនតាំងនៅដោយអាការដទៃ គឺថាខ្លួនមានកាយសមាចារមិនបរិសុទ្ធជាដើម ហើយញុំាងអ្នកដទៃឲ្យដឹងថាខ្លួនតាំងនៅដោយអាការដទៃ គឺថាខ្លួនមានកាយសមាចារជាដើមស្អាតវិញ ភិក្ខុនោះឯងហៅថា លួចភោជនគេមកបរិភោគ ដូចជាព្រានសត្វស្លាប លបលាក់ខ្លួនប្របគុម្ពឈើ បម្រុងចាំបាញ់សត្វ។ ភិក្ខុដែលយកសម្ពត់កាសាវមកព័ទ្ធព័ន្ធក តែប្រព្រឹត្តធម៌អាក្រក់ជាធម្មតា គ្មានសង្រួម (តាមធម៌វិន័យ) ឡើយ ជាបុគ្គលលាមកក្រៃលែងសឹងមានច្រើន ភិក្ខុនោះទៀងតែទៅនរក ព្រោះអំពើដែលខ្លួនធ្វើអាក្រក់។ បរិភោគដុំដែកដែលកំពុងឆេះក្តៅឧបមាដូចជាអណ្តាតភ្លើងវិញ ប្រសើរជាង ឯភិក្ខុដែលទ្រុស្តសីល មិនសង្រួម (តាមធម៌វិន័យ) នឹងបរិភោគនូវដុំអាមិសរបស់ជនអ្នកនៅក្នុងដែន (នោះ) ពុំប្រសើរសោះឡើយ។

[២៣១] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទា ដោយអនេកបរិយាយ ហើយទ្រង់សំដែងនូវទោសនៃការដែលគេពិបាកចិញ្ចឹម ពិបាកថែទាំ។ បេ។ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនដឹងចំពោះ ហើយពោលអួតឧត្តរិមនុស្សធម្ម ជាធម៌គួរឃើញដោយញាណដ៏ប្រសើរ បង្អោនមកដាក់ក្នុងខ្លួនថា ខ្ញុំដឹងដូច្នេះ ខ្ញុំឃើញដូច្នេះ លុះដល់សម័យដទៃពីនោះមក ទោះមានគេសាកសួរក្តី ឥតមានគេសាកសួរក្តី ក៏ហៅថា ត្រូវអាបត្តិបារាជិកហើយ (ទោះបី) មានប្រាថ្នាចង់ឲ្យបរិសុទ្ធ ហើយត្រឡប់ជានិយាយកែសំនួនយ៉ាងនេះវិញថា នែអាវុសោ ខ្ញុំមិនដឹងយ៉ាងនេះទេ (ប៉ុន្តែ) ពោលថា ដឹង ខ្ញុំមិនឃើញយ៉ាងនេះទេ (ប៉ុន្តែ) ពោលថា ឃើញ ខ្ញុំពោលកុហកសោះទេ ភិក្ខុនេះឯងក៏នៅជាត្រូវអាបត្តិបារាជិក រកសំវាសគ្មាន។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ពួកភិក្ខុរួចជាស្រេចយ៉ាងនេះ។

[២៣២] វេលានោះឯង មានភិក្ខុច្រើនរូបមានសេចក្តីសំគាល់ថាឃើញ ក្នុងហេតុដែលខ្លួនមិនឃើញ សំគាល់ថាដល់ ក្នុងហេតុដែលខ្លួនឥតបានដល់ សំគាល់ថាត្រាស់ដឹង ក្នុងហេតុដែលខ្លួនឥតបានត្រាស់ដឹង សំគាល់ថាធ្វើឲ្យច្បាស់លាស់ ក្នុងហេតុដែលខ្លួនឥតបានធ្វើឲ្យច្បាស់លាស់ ហើយបានពោលអួតអរហត្តផលដោយសំគាល់ថាខ្លួនបានត្រាស់ដឹង។ លុះដល់សម័យដទៃមក ចិត្តរបស់ភិក្ខុទាំងនោះ ក៏ឱនទៅរករាគៈខ្លះ ចិត្តឱនទៅរកទោសៈខ្លះ ចិត្តឱនទៅរកមោហៈខ្លះ។ សេចក្តីសង្ស័យក៏កើតឡើងដល់ភិក្ខុទាំងនោះថា សិក្ខាបទព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តរួចជាស្រេចហើយ ម្តេចឡើយក៏យើងមកសំគាល់ថាឃើញក្នុងហេតុដែលយើងឥតបានឃើញ សំគាល់ថាដល់ក្នុងហេតុដែលយើងឥតបានដល់ សំគាល់ថាត្រាស់ដឹង ក្នុងហេតុដែលយើងឥតបានត្រាស់ដឹង សំគាល់ថាធ្វើឲ្យច្បាស់លាស់ ក្នុងហេតុដែលយើងឥតបានធ្វើឲ្យច្បាស់លាស់ ហើយបានពោលអួតអរហត្តផល ដោយសំគាល់ថាខ្លួនយើងបានត្រាស់ដឹង (ដូច្នេះ) យើងប្រហែលជាត្រូវអាបត្តិបារាជិកទេដឹង។ ភិក្ខុទាំងនោះបានប្រាប់សេចក្តីនេះ ដល់ព្រះអានន្ទដ៏មានអាយុ។ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលអានន្ទ ភិក្ខុទាំងឡាយដែលមានសេចក្តីសំគាល់ថា ឃើញក្នុងហេតុដែលខ្លួនឥតឃើញ សំគាល់ថាបានដល់ក្នុងហេតុដែលខ្លួនឥតបានដល់ សំគាល់ថាបានត្រាស់ដឹង ក្នុងហេតុដែលខ្លួនឥតបានត្រាស់ដឹង សំគាល់ថាធ្វើឲ្យច្បាស់លាស់ ក្នុងហេតុដែលខ្លួនឥតបានធ្វើឲ្យច្បាស់លាស់ ហើយពោលអួតអរហត្តផល ដោយសេចក្តីសំគាល់ថា ខ្លួនបានត្រាស់ដឹង ក៏អំពើដែលពោលអួតនេះជាអព្វោហារិក (មិនហៅថាជាអង្គនៃអាបត្តិឡើយ)។ ព្រោះនិទាននេះ ព្រោះដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយទ្រង់សំដែងធម្មីកថាក្នុងគ្រានោះ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ មិនដឹងច្បាស់ ហើយពោលអួតឧត្តរិមនុស្សធម្ម ជាធម៌មានញាណ (សេចក្តីដឹង) និងទស្សនៈ (កិរិយាឃើញ) ដ៏ប្រសើរ អាចកំចាត់នូវកិលេស គួរបង្អោនមកដាក់ក្នុងខ្លួនដោយពាក្យថា ខ្ញុំដឹងដូច្នេះ ខ្ញុំឃើញដូច្នេះ លុះដល់សម័យដទៃអំពីនោះមក ទោះមានគេសាកសួរក្តី ឥតមានគេសាកសួរក្តី ក៏ហៅថា ត្រូវអាបត្តិបារាជិកហើយ (ទោះបី) មានប្រាថ្នាចង់ឲ្យបរិសុទ្ធ ហើយត្រឡប់ជានិយាយកែសំនួនយ៉ាងនេះវិញថា នែអាវុសោ ខ្ញុំមិនដឹងយ៉ាងនេះទេ (ប៉ុន្តែ) ពោលថាដឹង ខ្ញុំមិនឃើញយ៉ាងនេះទេ (ប៉ុន្តែ) ពោលថាឃើញ ខ្ញុំពោលកុហកសោះទេ ភិក្ខុនេះក្តី ក៏ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន វៀរលែងតែ សំគាល់ថាខ្លួនបានត្រាស់ដឹង។**

[២៣៣] ត្រង់ពាក្យថា ណាមួយ សេចក្តីថា ណាក៏ដោយ។ បេ។ ត្រង់ពាក្យថា ភិក្ខុ។ បេ។ ភិក្ខុដែលបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា នេះ សំដៅឲ្យឈ្មោះថា ភិក្ខុ ក្នុងអត្ថនេះ។ ត្រង់ពាក្យថា មិនដឹងច្បាស់ សេចក្តីថា មិនដឹងមិនឃើញនូវកុសលធម៌ដែលមិនមាន មិនពិត មិន ប្រាកដក្នុងខ្លួន (ហើយចូលចិត្តថា) កុសលធម៌ទាំងឡាយរបស់អញមាន។ ឈាន (គុណជាតសំរាប់ដុតបង់នូវកិលេស)១ វិមោក្ខ (គុណធម៌ ដែលផុតស្រឡះចាករាគៈជាដើម)១ សមាធិ (សភាពដែលដំកល់ចិត្តស្មើមាំល្អក្នុងអារម្មណ៍)១ សមាបត្តិ (គុណជាតិដែលដល់ព្រម)១ ញាណ ទស្សនៈ (កិរិយាឃើញដោយបញ្ញា)១ មគ្គភាវនា (កិរិយាចំរើននូវមគ្គ)១ ផលសច្ឆិកិរិយា (ដំណើរធ្វើឲ្យច្បាស់លាស់នូវផល)១ កិលេសប្បហាន (កិរិយាលះបង់កិលេស)១ វិនីវរណតា ចិត្តស្ស ចិត្តមាននីវរណធម៌ប្រាសហើយ១ សុញ្ញាគារេ អភិរតិ សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់១ (ធម៌ទាំង ១០នេះ) ហៅថា ឧត្តរិមនុស្សធម្ម។ ត្រង់ពាក្យថា បង្អោនមកដាក់ក្នុងខ្លួន សេចក្តីថា បង្អោនកងកុសលធម៌ទាំងនោះមកដាក់ក្នុងចិត្ត ឬបង្អោនចិត្ត ទៅក្នុងកងកុសលធម៌ទាំងនោះ។ ត្រង់ពាក្យថា ញាណ បានដល់វិជ្ជា គឺសេចក្តីដឹងវិសេស៣យ៉ាង។ ត្រង់ពាក្យថា ទស្សនៈ សេចក្តីថា ធម្មជាត ណា ហៅថា ញាណ ធម្មជាតនោះហៅថា ទស្សនៈ ធម្មជាតណាហៅថា ទស្សនៈ ធម្មជាតនោះហៅថា ញាណ។ ត្រង់ពាក្យថា ពោលអួត សេចក្តីថា ប្រាប់ដល់ស្រីក្តី ប្រុសក្តី គ្រហស្ថក្តី បព្វជិតក្តី។ ត្រង់ពាក្យថា ខ្ញុំដឹងដូច្នេះ ខ្ញុំឃើញដូច្នេះ សេចក្តីថា ខ្ញុំដឹងធម៌នេះ ខ្ញុំឃើញធម៌នេះ ម្យ៉ាង ទៀត ធម៌នេះជារបស់ខ្ញុំ ៗក៏យល់ជាក់ច្បាស់ក្នុងធម៌នេះហើយ។

[២៣៤] ត្រង់ពាក្យថា លុះដល់សម័យដទៃពីនោះមក សេចក្តីថា កិរិយាពោលអួតក្នុងខណៈណា លុះដល់សម័យដែលកន្លងនូវខណៈ នូវ ស្របក់ នូវពេលមួយរំពេចនោះមក។ ត្រង់ពាក្យថា ទោះមានគេសាកសួរក្តី សេចក្តីថា វត្ថុណាដែលខ្លួនបានប្តេជ្ញាហើយ ក៏មានអ្នកឯទៀតគេសាក សួរចំពោះវត្ថុនោះថា ធម៌អ្វីខ្លះដែលលោកបានត្រាស់ដឹង ព្រោះហេតុដូចម្តេច បានជាលោកបានត្រាស់ដឹង លោកបានត្រាស់ដឹងពីអង្គាល់ លោក បានត្រាស់ដឹងក្នុងទីណា កិលេសណាខ្លះដែលលោកបានលះរួចហើយ លោកបានធម៌ដូចម្តេចខ្លះ។ ត្រង់ពាក្យថា ទោះឥតមានគេសាកសួរក្តី សេចក្តីថា ឥតមានអ្នកណាមួយសួររដណ្តឹងឡើយ។ ត្រង់ពាក្យថា ក៏ហៅថា ត្រូវអាបត្តិបារាជិកហើយ សេចក្តីថា (ភិក្ខុ) មានសេចក្តីប្រាថ្នាអាក្រក់ គឺសេចក្តីប្រាថ្នាគ្របសង្កត់ ហើយពោលអួតឧត្តរិមនុស្សធម៌ដែលមិនពិត មិនប្រាកដ ក៏ហៅថា ត្រូវអាបត្តិបារាជិកហើយ។ ត្រង់ពាក្យថា មាន ប្រាថ្នាចង់ឲ្យបរិសុទ្ធ សេចក្តីថា (ភិក្ខុនោះ) ទោះមានប្រាថ្នាចង់ទៅជាគ្រហស្ថក្តី ចង់ទៅជាឧបាសកក្តី ចង់ទៅជាញោមវត្តក្តី ចង់ទៅជាសាមណេរ ក្តី។ ត្រង់ពាក្យថា ម្នាលអាវុសោ ខ្ញុំមិនដឹងយ៉ាងនេះ ហើយពោលថាដឹង ខ្ញុំមិនបានឃើញយ៉ាងនេះ ហើយពោលថាបានឃើញ សេចក្តីថា ខ្ញុំមិន បានដឹងធម៌នេះទេ ខ្ញុំមិនបានឃើញធម៌នេះទេ ធម៌នេះ ខ្ញុំគ្មានទេ ខ្ញុំនឹងបានឃើញច្បាស់ក្នុងធម៌នេះក៏ទេ។ ត្រង់ពាក្យថា ខ្ញុំពោលកុហកសោះទេ សេចក្តីថា ខ្ញុំពោលសោះទទេ ខ្ញុំពោលកុហកទេ ខ្ញុំពោលមិនពិតទេ ខ្ញុំពោលមិនប្រាកដទេ ខ្ញុំបានជាជ្រុលពោល មកពីហេតុមិនដឹងសោះទេ។ ត្រង់ ពាក្យថា វៀរលែងតែសំគាល់ថាខ្លួនបានត្រាស់ដឹង សេចក្តីថា លើកលែងតែខ្លួនបានត្រាស់ដឹងមែន។

[២៣៥] ត្រង់ពាក្យថា ភិក្ខុនេះក្តី ពោលប្រៀបធៀបនឹងភិក្ខុដែលមានក្នុងសិក្ខាបទមុន។ ត្រង់ពាក្យថា បារាជិក សេចក្តីថា ធម្មតាដើមត្នោត តែមានកកំបុតហើយ មិនអាចនឹងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ ភិក្ខុដែលមានប្រាថ្នាអាក្រក់ គឺសេចក្តីប្រាថ្នាគ្របសង្កត់ ហើយ ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនកើតក្នុងខ្លួន មិនមែនជាសមណៈ មិនមែនជាសក្យបុត្រ ក៏មានឧបមេយ្យដូច្នោះឯង ព្រោះហេតុនោះ ទើបតថាគតពោលថា ត្រូវអាបត្តិបារាជិក។ ត្រង់ពាក្យថា រកសំវាសគ្មាន ដែលហៅថា សំវាសនោះ គឺសង្ឃកម្មជាមួយគ្នា បាតិមោក្ខុទ្ទេសជាមួយ គ្នា សេចក្តីសិក្សាស្មើគ្នា នេះហៅថា សំវាស។ ភិក្ខុនោះគ្មានសំវាសដូច្នេះទេ ព្រោះហេតុនោះ បានជាតថាគតពោលថា រកសំវាសគ្មាន។

[២៣៦] ដែលហៅថា ឧត្តរិមនុស្សធម្ម (នោះសំដៅយក) ឈាន១ វិមោក្ខ១ សមាធិ១ សមាបត្តិ១ ញាណទស្សនៈ១ មគ្គភាវនា១ ផល សច្ឆិកិរិយា១ កិលេសប្បហាន១ វិនីវរណតា ចិត្តស្ស១ សុញ្ញាគារេ អភិរតិ១។ ត្រង់ពាក្យថា ឈាន បានខាងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន។ ត្រង់ពាក្យថា វិមោក្ខ (នោះ) បានខាងឯសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ។ ត្រង់ពាក្យថា សមាធិ (នោះ) បានខាង ឯ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ។ ត្រង់ពាក្យថា សមាបត្តិ (នោះ) បានខាង សុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិត សមាបត្តិ។ ត្រង់ពាក្យថា ញាណ (នោះ) បានខាង ត្រៃវិជ្ជា។ ត្រង់ពាក្យថា មគ្គភាវនា (នោះ) បានខាង សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពល៥ ពោជ្ឈង្គ៧ មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរ។ ត្រង់ពាក្យថា ផលសច្ឆិកិរិយា (នោះ) បានខាង ធ្វើឲ្យច្បាស់លាស់នូវសោតា បត្តិផល ធ្វើឲ្យច្បាស់លាស់នូវសកទាគាមិផល ធ្វើឲ្យច្បាស់លាស់នូវនូវអនាគាមិផល ធ្វើឲ្យច្បាស់លាស់នូវអរហត្តផល។ ត្រង់ពាក្យថា កិលេសប្បហាន (នោះ) បានខាង កិរិយាលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ។ ត្រង់ពាក្យថា វិនីវរណតា ចិត្តស្ស (នោះ) បានខាង ការហាមឃាត់ចិត្តចាករាគៈ ហាមឃាត់ចិត្តចាកទោសៈ ហាមឃាត់ចិត្តចាកមោហៈ។ ត្រង់ពាក្យថា សុញ្ញាគារេ អភិរតិ (នោះ) បានខាង ឯសេចក្តី ត្រេកអរក្នុងផ្ទះស្ងាត់ ដោយបឋមជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ដោយទុតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ដោយតតិយជ្ឈាន សេចក្តី ត្រេកអរក្នុងផ្ទះស្ងាត់ដោយចតុត្ថជ្ឈាន។

[២៣៧] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ៣យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹង និយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ ត្រូវអាបត្តិ បារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ៤យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនិយាយ កុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តី ឃើញ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ៥យ៉ាងគឺ មុននឹងនិយាយ ដឹង ខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួច ហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ហើយ ដោយអាការ៦យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ ត្រូវ អាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ៧យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹង

និយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ ត្រូវអាបត្តិបារាជិក។

[២៣៨] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ៣យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ៤យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ៥យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ៦យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ៧យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ ត្រូវអាបត្តិបារាជិក។

[២៣៩] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ៣យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ៤យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ៥យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ៦យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ៧យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ ត្រូវអាបត្តិបារាជិក។

[២៤០] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយ ដោយអាការ៣យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយ ដោយអាការ៤យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយ ដោយអាការ៥យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយ ដោយអាការ៦យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយ ដោយអាការ៧យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ ត្រូវអាបត្តិបារាជិក។

[២៤១] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ៣យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ៤យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ៥យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ៦យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ៧យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយ

កុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ ត្រូវអាបត្តិបារាជិក។

[២៤២] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ៣យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ៤យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ៥យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ៦យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ៧យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ ត្រូវអាបត្តិបារាជិក (បឋមជ្ឈាននេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែង ឲ្យពិស្តារហើយយ៉ាងណា ឈានទាំងពួងមាន ទុតិយជ្ឈានជាដើម បណ្ឌិតត្រូវសំដែងឲ្យពិស្តារ យ៉ាងនោះផងចុះ)។

[២៤៣] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន កាន់ចតុត្ថជ្ឈាន អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងចតុត្ថជ្ឈាន ចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយដោយអាការ៣[46] យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ ត្រូវអាបត្តិបារាជិក។

[២៤៤] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់សុញ្ញតវិមោក្ខ កាន់អនិមិត្តវិមោក្ខ កាន់អប្បណិហិតវិមោក្ខ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងអប្បណិហិតវិមោក្ខ អប្បណិហិតវិមោក្ខ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៤៥] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់សុញ្ញតសមាធិ កាន់អនិមិត្តសមាធិ កាន់អប្បណិហិតសមាធិ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងអប្បណិហិតសមាធិ អប្បណិហិតសមាធិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៤៦] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់សុញ្ញតសមាបត្តិ កាន់អនិមិត្តសមាបត្តិ កាន់អប្បណិហិតសមាបត្តិ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងអប្បណិហិតសមាបត្តិ អប្បណិហិតសមាបត្តិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៤៧] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវត្រៃវិជ្ជា អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងត្រៃវិជ្ជា ត្រៃវិជ្ជាអាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៤៨] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវសតិបដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងឥទ្ធិបាទ៤ ឥទ្ធិបាទ៤ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៤៩] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវឥន្ទ្រិយ៥ ពល៥ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងពល៥ ពល៥ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥០] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានត្រាស់ដឹងហើយ កំពុងត្រាស់ដឹង បានត្រាស់ដឹងនូវពោជ្ឈង្គ៧ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងពោជ្ឈង្គ៧ ពោជ្ឈង្គ៧ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥១] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានត្រាស់ដឹងហើយ កំពុងត្រាស់ដឹង បានត្រាស់ដឹងនូវមគ្គប្រកបដោយអង្គ៨ដ៏ប្រសើរ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងមគ្គប្រកបដោយអង្គ៨ដ៏ប្រសើរ មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥២] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានសម្រេចហើយ កំពុងសម្រេច បានសម្រេចនូវសោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងអរហត្តផល អរហត្តផល អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥៣] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា រាគៈអាត្មាបានកំចាត់បង់ហើយ រាគៈអាត្មាបានខ្ជាក់ចោលហើយ រាគៈអាត្មាបាន (ធ្វើ) ឲ្យផុតហើយ រាគៈអាត្មាបានបន្សាត់ចេញហើយ រាគៈអាត្មាបានរលាស់ចោលហើយ រាគៈអាត្មាបានរើចោលហើយ រាគៈអាត្មាបានគាស់រំលើងហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ទោសៈអាត្មាបានកំចាត់បង់ហើយ។ បេ។ មោហៈអាត្មាបានកំចាត់បង់ហើយ បានខ្ជាក់ចោលហើយ បាន (ធ្វើ) ឲ្យផុតហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានរើចោលហើយ បានគាស់រំលើងហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥៤] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ចិត្តរបស់អាត្មាមានសេចក្តីរារាំងប្រាស គឺផុតស្រឡះហើយចាករាគៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ ត្រូវអាបត្តិបារាជិក។

សុទ្ធិកវារ ចប់។

[២៥៥] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង កាន់ទុតិយជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង ទុតិយជ្ឈានផង បឋមជ្ឈាន និងទុតិយជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង តតិយជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង តតិយជ្ឈានផង បឋមជ្ឈាន និងតតិយជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង ចតុត្ថជ្ឈានផង បឋមជ្ឈាន និងចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥៦] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង សុញ្ញតវិមោក្ខផង បឋមជ្ឈានផង អនិមិត្តវិមោក្ខផង បឋមជ្ឈានផង អប្បណិហិតវិមោក្ខផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង អប្បណិហិតវិមោក្ខផង បឋមជ្ឈាន និងអប្បណិហិតវិមោក្ខ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥៧] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង សុញ្ញតសមាធិផង បឋមជ្ឈានផង អនិមិត្តសមាធិផង បឋមជ្ឈានផង អប្បណិហិតសមាធិផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង អប្បណិហិតសមាធិផង បឋមជ្ឈាន និងអប្បណិហិតសមាធិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥៨] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង សុញ្ញតសមាបត្តិផង បឋមជ្ឈានផង អនិមិត្តសមាបត្តិផង បឋមជ្ឈានផង អប្បណិហិតសមាបត្តិផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង អប្បណិហិតសមាបត្តិផង បឋមជ្ឈាន និងអប្បណិហិតសមាបត្តិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៥៩] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានចូលកាន់បឋមជ្ឈានផង ត្រៃវិជ្ជាផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង ត្រៃវិជ្ជាផង បឋមជ្ឈាន និងត្រៃវិជ្ជា អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៦០] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង សតិបដ្ឋាន៤ផង បឋមជ្ឈានផង សម្មប្បធាន៤ផង បឋមជ្ឈានផង ឥទ្ធិបាទ៤ផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង ឥទ្ធិបាទ៤ផង បឋមជ្ឈាន និងឥទ្ធិបាទ៤ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៦១] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង ឥន្ទ្រិយ៥ផង បឋមជ្ឈានផង ពល៥ផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈានផង ពល៥ផង បឋមជ្ឈាន និងពល៥ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៦២] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង ពោជ្ឈង្គ៧ផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈានផង ពោជ្ឈង្គ៧ផង បឋមជ្ឈាន និងពោជ្ឈង្គ៧ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៦៣] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈានផង ក្នុងមគ្គប្រកបដោយអង្គ៨ដ៏ប្រសើរផង បឋមជ្ឈាននិង មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៦៤] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង សោតាបត្តិផលផង បឋមជ្ឈានផង សកទាគាមិផលផង បឋមជ្ឈានផង អនាគាមិផលផង បឋមជ្ឈានផង អរហត្តផលផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈានផង អរហត្តផលផង បឋមជ្ឈាន និងអរហត្តផល អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៦៥] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន ទាំងរាគៈ អាត្មាក៏បានកំចាត់ចេញហើយ។ បេ។ អាត្មាបានចូលហើយ កាន់បឋមជ្ឈាន។ បេ។ ទាំងទោសៈ អាត្មាក៏បានកំចាត់ចេញហើយ។ បេ។ អាត្មាបានចូលហើយ កាន់បឋមជ្ឈាន។ បេ។ ទាំងមោហៈ អាត្មាក៏បានកំចាត់ចេញហើយ បានខ្ជាក់ចោលហើយ បានធ្វើឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

[២៦៦] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន ចិត្តរបស់អាត្មាផុតស្រឡះហើយចាករាគៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ដោយអាការ៣យ៉ាង គឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ បិទបាំងសេចក្តីឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ត្រូវអាបត្តិបារាជិក។ បេ។

ខណ្ឌចក្ក ចប់។

[២៦៧] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈានផង តតិយជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងទុតិយជ្ឈានផង តតិយជ្ឈានផង ទុតិយជ្ឈាន និងតតិយជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងទុតិយជ្ឈានផង ចតុត្ថជ្ឈានផង ទុតិយជ្ឈាន និងចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវទុតិយជ្ឈានផង សុញ្ញតវិមោក្ខផង ទុតិយជ្ឈានផង អនិមិត្តវិមោក្ខផង ទុតិយជ្ឈានផង អប្បណិហិតវិមោក្ខផង ទុតិយជ្ឈានផង សុញ្ញតសមាធិផង ទុតិយជ្ឈានផង អនិមិត្តសមាធិផង ទុតិយជ្ឈានផង អប្បណិហិតសមាធិផង ទុតិយជ្ឈានផង សុញ្ញតសមាបត្តិផង ទុតិយជ្ឈានផង អនិមិត្តសមាបត្តិផង ទុតិយជ្ឈានផង អប្បណិហិតសមាបត្តិផង ទុតិយជ្ឈានផង តេ្រវិជ្ជាផង ទុតិយជ្ឈានផង សតិប្បដ្ឋាន៤ផង ទុតិយជ្ឈានផង សម្មប្បធាន៤ផង ទុតិយជ្ឈានផង ឥទ្ធិបាទ៤ផង ទុតិយជ្ឈានផង ឥន្ទ្រិយ៥ផង ទុតិយជ្ឈានផង ពល៥ផង ទុតិយជ្ឈានផង ពោជ្ឈង្គ៧ផង ទុតិយជ្ឈានផង មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរផង ទុតិយជ្ឈានផង សោតាបត្តិផលផង ទុតិយជ្ឈានផង សកទាគាមិផលផង ទុតិយជ្ឈានផង អនាគាមិផលផង ទុតិយជ្ឈានផង អរហត្តផលផង។ បេ។ អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន ទាំងរាគៈ អាត្មាក៏បានកំចាត់ចេញហើយ។ បេ។ ទាំងទោសៈ អាត្មាក៏បានកំចាត់ចេញហើយ។ បេ។ ទាំងមោហៈ អាត្មាក៏បានកំចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន (ធ្វើ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន ទាំងចិត្តរបស់អាត្មាក៏បានផុតស្រឡះហើយចាករាគៈ អាត្មាបានចូលហើយ កាន់ទុតិយជ្ឈាន ទាំងចិត្តរបស់អាត្មាក៏បានផុតស្រឡះហើយចាកទោសៈ អាត្មាបានចូលហើយ កាន់ទុតិយជ្ឈាន ទាំងចិត្តរបស់អាត្មាក៏បានផុតស្រឡះហើយចាកមោហៈ ត្រូវអាបត្តិបារាជិក។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងទុតិយជ្ឈានផង បឋមជ្ឈានផង ទុតិយជ្ឈាន និងបឋមជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

ពទ្ធចក្ក ចប់។

បណ្ឌិតត្រូវធ្វើពទ្ធចក្កឲ្យមានបទផ្លាស់ប្តូរគ្នា ធ្វើតាមមូលមួយៗដូចន័យដែលព្រះសម្ពុទ្ធ ទ្រង់សំដែងហើយនោះផងចុះ។

## នេះជាសេចក្តីសង្ខេប

[២៦៨] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាកមោហៈផង អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងបឋមជ្ឈានផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ទាំងបឋមជ្ឈាន អាត្មាក៏បានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង អាត្មាបានចូលហើយកាន់ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង សុញ្ញតសមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង តេ្រវិជ្ជាផង សតិប្បដ្ឋាន៤ផង សម្មប្បធាន៤ផង ឥទ្ធិបាទ៤ផង ឥន្ទ្រិយ៥ផង ពល៥ផង ពោជ្ឈង្គ៧ផង មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង ដោយអាការ៣យ៉ាង។ បេ។ រាគៈអាត្មាបានកំចាត់ចេញហើយផង។ បេ។ ទោសៈអាត្មាបានកំចាត់ចេញហើយផង។ បេ។ ទាំងមោហៈ អាត្មាក៏បានកំចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន (ធ្វើ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាករាគៈផង ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាកទោសៈផង ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាកមោហៈផង ដោយអាការ៣យ៉ាង ត្រូវអាបត្តិបារាជិក។ បេ។

ចក្កមានមូល១ ចប់ដោយសង្ខេប។

[២៦៩] ចក្កមានមូល១ ដែលព្រះសម្ពុទ្ធទ្រង់សំដែងដោយពិស្តារហើយយ៉ាងណា ចក្កមានមូល២ក្តី មានមូល៣ក្តី មានមូល៤ក្តី មានមូល៥ក្តី មានមូល៦ក្តី មានមូល៧ក្តី មានមូល៨ក្តី មានមូល៩ក្តី មានមូល១០ក្តី បណ្ឌិតត្រូវសំដែងឲ្យពិស្តារយ៉ាងនោះផងចុះ។

## ឥទំ សព្វមូលកំ

នេះចក្កមានមូលគ្រប់ទាំងអស់ (ដូចមានសេចក្ដីតទៅនេះ)

[២៧០] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង សុញ្ញតសមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង ត្រៃវិជ្ជាផង សតិប្បដ្ឋាន៤ផង សម្មប្បធាន៤ផង ឥទ្ធិបាទ៤ផង ឥន្ទ្រិយ៥ផង ពល៥ផង ពោជ្ឈង្គ៧ផង មគ្គមានអង្គ៨ដ៏ប្រសើរផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង។ បេ។ រាគៈអាត្មាបានកំចាត់ចេញហើយផង។ បេ។ ទោសៈអាត្មាបានកំចាត់ចេញហើយផង។ បេ។ ទាំងមោហៈ អាត្មាក៏បានកំចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន (ធ្វើ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ចិត្តរបស់អាត្មាផុតស្រឡះហើយ ចាករាគៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយ ចាកទោសៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយ ចាកមោហៈផង ដោយអាការ៣យ៉ាង។ បេ។ ដោយអាការ៧យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក១ លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្ដីឃើញ១ បិទបាំងសេចក្ដីគាប់ចិត្ត១ បិទបាំងសេចក្ដីពេញចិត្ត១ បិទបាំងសេចក្ដីពិតត្រង់១ ត្រូវអាបត្តិបារាជិក។

ចក្កមានមូលគ្រប់ទាំងអស់ ចប់។

សុទ្ធិកវារកថា ចប់។

[២៧១] ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈាន ដូច្នេះទៅវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់តតិយជ្ឈាន ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់ចតុត្ថជ្ឈាន ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់សុញ្ញតវិមោក្ខ កាន់អនិមិត្តវិមោក្ខ កាន់អប្បណិហិតវិមោក្ខ កាន់សុញ្ញតសមាធិ កាន់អនិមិត្តសមាធិ កាន់អប្បណិហិតសមាធិ កាន់សុញ្ញតសមាបត្តិ កាន់អនិមិត្តសមាបត្តិ កាន់អប្បណិហិតសមាបត្តិ កាន់ត្រៃវិជ្ជា កាន់សតិប្បដ្ឋាន៤ កាន់សម្មប្បធាន៤ កាន់ឥទ្ធិបាទ៤ កាន់ឥន្ទ្រិយ៥ កាន់ពល៥ កាន់ពោជ្ឈង្គ៧ កាន់មគ្គមានអង្គ៨ដ៏ប្រសើរ កាន់សោតាបត្តិផល កាន់សកទាគាមិផល កាន់អនាគាមិផល កាន់អរហត្តផល ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា រាគៈអាត្មាបានកំចាត់ចេញហើយ។ បេ។ ទោសៈអាត្មាបានកំចាត់ចេញហើយ។ បេ។ ទាំងមោហៈអាត្មាក៏បានកំចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន (ធ្វើ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាករាគៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ដូច្នេះវិញ ដោយអាការ៣យ៉ាង គឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ ដូច្នេះ បិទបាំងសេចក្ដីឃើញ បិទបាំងសេចក្ដីគាប់ចិត្ត បិទបាំងសេចក្ដីពេញចិត្ត បិទបាំងសេចក្ដីពិតត្រង់ បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។

ខណ្ឌចក្ក នៃនិក្ខេបបទ ជាវត្ថុនិស្សារក ចប់។

[២៧២] ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់តតិយជ្ឈាន ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។

**ពទ្ធចក្កមានមូលមួយ នៃវត្ថុនិស្សារក និយាយពីមូល ដែលព្រះសម្ពុទ្ធសំដែងហើយដោយសង្ខេប**

(ដូចមានសេចក្ដីតទៅនេះ)

[២៧៣] ភិក្ខុចង់និយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវត្រឹមអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ កាលដែលនិយាយ ក៏និយាយ

កុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈ ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។

ចក្កមានមូល១ នៃវត្ថុនិស្សារក ដែលព្រះសម្ពុទ្ធសំដែងដោយសង្ខេប ចប់។

[២៧៤] ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈានផង ទុតិយជ្ឈានផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់តតិយជ្ឈានផង ចតុត្ថជ្ឈានផង ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈានផង ទុតិយជ្ឈានផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាកមោហៈ ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។

**ខណ្ឌចក្កមានមូលពីរ នៃវត្ថុនិស្សារក។**

[២៧៥] ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈានផង កាន់តតិយជ្ឈានផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់ចតុត្ថជ្ឈាន ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈានផង កាន់តតិយជ្ឈានផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈានផង កាន់តតិយជ្ឈានផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។

**ពទ្ធចក្កមានមូលពីរ នៃវត្ថុនិស្សារក។**

[២៧៦] ភិក្ខុចង់និយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។ ភិក្ខុចង់និយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាករាគៈ ដូច្នេះវិញ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ។ បេ។

ចក្កមានមូលពីរនៃវត្ថុនិស្សារក ដែលព្រះសម្ពុទ្ធសំដែងដោយសង្ខេប ចប់។

[២៧៧] ចក្កមានមូលមួយៗ នៃបទទាំងឡាយដែលព្រះសង្គីតិកាចារ្យបានដំកល់ទុកហើយ បណ្ឌិតគប្បីសំដែងយ៉ាងណា ចក្កមានមូល៣ក្តី មានមូល៤ក្តី មានមូល៥ក្តី មានមូល៦ក្តី មានមូល៧ក្តី មានមូល៨ក្តី មានមូល៩ក្តី មានមូល១០ក្តី បណ្ឌិតគប្បីធ្វើយ៉ាងនោះផងចុះ។ (ម្យ៉ាងទៀត) ចក្កមានមូលមួយ ព្រះសម្ពុទ្ធទ្រង់សំដែងហើយដោយពិស្តារយ៉ាងណា (ចក្កមានមូលបីជាដើម) បណ្ឌិតគប្បីសំដែងដោយពិស្តារយ៉ាងនោះផងចុះ។

**ឥទំ សព្វមូលកំ**

នេះចក្កមានមូលគ្រប់ទាំងអស់ (ដូចមានសេចក្តីតទៅនេះ)

[២៧៨] ភិក្ខុនិយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈានផង កាន់ទុតិយជ្ឈានផង កាន់តតិយជ្ឈានផង កាន់ចតុត្ថជ្ឈានផង កាន់សុញ្ញតវិមោក្ខផង កាន់អនិមិត្តវិមោក្ខផង កាន់អប្បណិហិតវិមោក្ខផង កាន់សុញ្ញតសមាធិផង កាន់អនិមិត្តសមាធិផង កាន់អប្បណិហិតសមាធិផង កាន់សុញ្ញតសមាបត្តិផង កាន់អនិមិត្តសមាបត្តិផង កាន់អប្បណិហិតសមាបត្តិផង កាន់ត្រៃវិជ្ជាផង កាន់សតិប្បដ្ឋាន៤ផង កាន់សម្មប្បធាន៤ផង កាន់ឥទ្ធិបាទ៤ផង កាន់ឥន្ទ្រិយ៥ផង កាន់ពល៥ផង កាន់ពោជ្ឈង្គ៧ផង កាន់មគ្គមានអង្គ៨ដ៏ប្រសើរផង កាន់សោតាបត្តិផលផង កាន់សកទាគាមិផលផង កាន់អនាគាមិផលផង កាន់អរហត្តផលផង រាគៈអាត្មាបានកំចាត់ចេញហើយផង។ បេ។ ទោសៈអាត្មាបានកំចាត់ចេញហើយផង។ បេ។ ទាំងមោហៈអាត្មាក៏បានកំចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន (ធ្វើ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ចិត្តរបស់អាត្មាផុតស្រឡះហើយចាករាគៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង ដូច្នេះវិញ ដោយអាការ៣យ៉ាង។ បេ។ ដោយអាការ៧យ៉ាងគឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក១ និយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ។ បេ។

ចក្កបេយ្យាល នៃវត្ថុនិស្សារក ចប់។

វត្ថុកាមវារកថា ចប់។

[២៧៩] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្ថុរបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន ភិក្ខុនោះជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈាន បឋមជ្ឈាន ភិក្ខុអង្គនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ដោយអាការ៣យ៉ាង គឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ លុះនិយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្ថុរបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន ភិក្ខុនោះជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈាន បឋមជ្ឈាន ភិក្ខុអង្គនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ដោយអាការ៤-៥-៦-៧យ៉ាង គឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក១ លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ១ បិទបាំងសេចក្តីយល់ឃើញ១ បិទបាំងសេចក្តីគាប់ចិត្ត១ បិទបាំងសេចក្តីពេញចិត្ត១ បិទបាំងសេចក្តីពិតត្រង់១ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្ថុរបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន កាន់ចតុត្ថជ្ឈាន កាន់សុញ្ញតវិមោក្ខ កាន់អនិមិត្តវិមោក្ខ កាន់អប្បណិហិតវិមោក្ខ កាន់សុញ្ញតសមាធិ កាន់អនិមិត្តសមាធិ កាន់អប្បណិហិតសមាធិ កាន់សុញ្ញតសមាបត្តិ កាន់អនិមិត្តសមាបត្តិ កាន់អប្បណិហិតសមាបត្តិ កាន់ត្រៃវិជ្ជា កាន់សតិប្បដ្ឋាន៤ កាន់សម្មប្បធាន៤ កាន់ឥទ្ធិបាទ៤ កាន់ឥន្ទ្រិយ៥ កាន់ពល៥ កាន់ពោជ្ឈង្គ៧ កាន់មគ្គមានអង្គ៨ដ៏ប្រសើរ កាន់សោតាបត្តិផល កាន់សកទាគាមិផល កាន់អនាគាមិផល កាន់អរហត្តផល ភិក្ខុនោះជាអ្នកបាន ជាអ្នកស្ទាត់ ក្នុងអរហត្តផល អរហត្តផល ភិក្ខុអង្គនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្ថុរបស់អ្នក រាគៈភិក្ខុនោះបានកំចាត់ចេញហើយ។ បេ។ ទោសៈភិក្ខុនោះបានកំចាត់ចេញហើយ។ បេ។ ទាំងមោហៈភិក្ខុនោះបានកំចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន (ធ្វើ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ដោយអាការ៣យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្ថុរបស់អ្នក ចិត្តរបស់ភិក្ខុនោះផុតស្រឡះហើយចាករាគៈ ចិត្តរបស់ភិក្ខុនោះផុតស្រឡះហើយចាកទោសៈ ចិត្តរបស់ភិក្ខុនោះផុតស្រឡះហើយចាកមោហៈ ដោយអាការ៣យ៉ាង គឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ បិទបាំងសេចក្តីយល់ឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្ថុរបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន កាន់ចតុត្ថជ្ឈាន ក្នុងផ្ទះស្ងាត់ ភិក្ខុនោះជាអ្នកបាន ជាអ្នកស្ទាត់ ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈាន ភិក្ខុអង្គនោះបានធ្វើឲ្យជាក់ច្បាស់ហើយក្នុងផ្ទះដ៏ស្ងាត់ ដោយអាការ៣-៧យ៉ាង គឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ បិទបាំងសេចក្តីយល់ឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ។

[២៨០] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណាបានប្រើចីវររបស់អ្នក ភិក្ខុណាបានឆាន់បិណ្ឌបាតរបស់អ្នក ភិក្ខុណាបានប្រើប្រាស់ទីសេនាសនៈរបស់អ្នក ភិក្ខុណាបានបរិភោគភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺរបស់អ្នក វត្ថុរបស់អ្នកដែលភិក្ខុណាបាននៅហើយ ចីវររបស់អ្នកដែលភិក្ខុបានប្រើប្រាស់ហើយ បិណ្ឌបាតរបស់អ្នកដែលភិក្ខុណាបានឆាន់ហើយ ទីសេនាសនៈរបស់អ្នកដែលភិក្ខុណាបានប្រើប្រាស់ហើយ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺដែលភិក្ខុណាបានបរិភោគហើយ អ្នកអាស្រ័យនឹងភិក្ខុណា ហើយបានប្រគេនវត្ថុ បានប្រគេនចីវរ បានប្រគេនបិណ្ឌបាត បានប្រគេនទីសេនាសនៈ បានប្រគេនភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន កាន់ចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាន ជាអ្នកស្ទាត់ ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈាន ភិក្ខុអង្គនោះបានធ្វើឲ្យជាក់ច្បាស់ហើយក្នុងផ្ទះដ៏ស្ងាត់ ដោយអាការ៣យ៉ាង គឺ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក លុះនិយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ បិទបាំងសេចក្តីយល់ឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ។

បេយ្យាលចំនួន១៥ ចប់។

បច្ចយប្បដិសំយុត្តវារកថា ចប់។

[២៨១] ភិក្ខុនិយាយស្មានថា ខ្លួនបានមគ្គផល១ ភិក្ខុនិយាយពីមគ្គផលដោយឥតមានប្រាថ្នានឹងពោលអួតកុហក១ ភិក្ខុឆ្កួត១ ភិក្ខុមានចិត្តរវើរវាយ១ ភិក្ខុមានវេទនាគ្របសង្កត់១ ភិក្ខុជាខាងដើមបញ្ញត្តិ១ (ភិក្ខុប៉ុណ្ណោះ) ឥតមានអាបត្តិឡើយ។

## (វិនីតវត្ថុឧទ្ទានគាថា ចតុត្ថសិក្ខាបទំ)

CS vin.vbu.pr.04.01 | ភាគ ទី១

### (វិនីតវត្ថុឧទ្ទានគាថា)

[២៨២] (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសំដែងតទៅ ដូចមានសេចក្តីខាងក្រោមនេះ)

រឿងអធិមានភិក្ខុ រឿងភិក្ខុនៅក្នុងព្រៃ រឿងភិក្ខុទៅបិណ្ឌបាត រឿងសទ្ធិវិហារិកនៃឧបជ្ឈាយ៍ រឿងពួកភិក្ខុដំកល់ឥរិយាបថ រឿងភិក្ខុអួតថាលះសញ្ញោជនធម៌បាន រឿងភិក្ខុនៅក្នុងទីស្ងាត់ រឿងភិក្ខុនៅក្នុងវត្ត រឿងភិក្ខុដែលឧបាសកផ្គត់ផ្គង់ រឿងភិក្ខុនិយាយអួតអរហត្តផលថាគ្មានក្រ រឿងភិក្ខុព្យាយាម រឿងពួកភិក្ខុនិយាយថា អាវុសោទាំងឡាយ ភិក្ខុដែលមានសេចក្ដីស្ដាយក្រោយ ទើបត្រូវខ្លាចមច្ចុ រឿងពួកភិក្ខុនិយាយថា ធម៌តែបុគ្គលប្រកបព្យាយាមត្រូវហើយ អាចឲ្យប្រោសប្រាណបាន រឿងភិក្ខុ២រូបជាអ្នកអត់ធន់វេទនា រឿងភិក្ខុ៥រូបដែលព្រាហ្មណ៍និមន្ត រឿងភិក្ខុ៣រូបនិយាយអួតអរហត្តផល រឿងភិក្ខុឃាត់បង់នូវផ្ទះ រឿងភិក្ខុឃាត់បង់កាមទាំងឡាយ រឿងភិក្ខុអ្នកត្រេកអរ រឿងភិក្ខុចៀសចេញទៅ រឿងជនពិឃាតគោ២នាក់ ម្នាក់កើតជាអដ្ឋិសង្ខលិកប្រេត ម្នាក់កើតជាមំសបេសីប្រេត រឿងព្រានសត្វស្លាបកើតជាមំសបិណ្ឌប្រេត រឿងអ្នកសម្លាប់សត្វចៀម កើតជានិច្ឆវិប្រេត រឿងអ្នកសម្លាប់ជ្រូកកើតជាអសិលោមប្រេត រឿងព្រានម្រឹគកើតជាសត្តិលោមប្រេត រឿងពេជ្ឈឃាតកើតជាឧសុលោមប្រេត រឿងនាយសារថីកើតជាសូចិលោមប្រេត រឿងបុរសដែលនិយាយពាក្យញុះញង់កើតជាសូចកប្រេត[47] រឿងអមាត្យកាត់ក្ដីអ្នកស្រុករៀច កើតជាអណ្ឌភារិប្រេត[48] រឿងអ្នកដែលធ្វើបរទារកម្ម កើតជាប្រេតលិចទៅក្នុងរណ្ដៅលាមក រឿងព្រាហ្មណ៍កំណាចកើតជាប្រេតស៊ីតែលាមកជាប្រក្រតី រឿងស្រីប្រព្រឹត្តកន្លងចិត្តប្ដី កើតជានិច្ឆវិប្រេត រឿងស្រីមេមត់ កើតជាមង្គុលិប្រេត រឿងស្រីមកកើតជាឱកិលិនីប្រេត ព្រោះចាក់ស្រោចរងើកភ្លើងលើស្រីរួមប្ដី រឿងអ្នកពិឃាតចោរ កើតជាប្រេតដាច់ក្បាល រឿងភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរីដែលបួសក្នុងសាសនាព្រះពុទ្ធទ្រង់ព្រះនាមកស្សប ប្រព្រឹត្តធ្វើតែបាបកម្មជាដរាប រឿងស្ទឹងតបោទា រឿងចំបាំងក្នុងក្រុងរាជគ្រឹះរឿងដែលចុះឡើងនៃពួកដំរី រឿងសោភិតភិក្ខុជាអរហន្ត រលឹកជាតិបាន៥០០កល្ប។

## (វិនីតវត្ថុ ចតុត្ថសិក្ខាបទំ)

CS vin.vbu.pr.04.02 | ភាគ ទី១

### (វិនីតវត្ថុ)

[២៨៣] សម័យនោះ ភិក្ខុមួយរូប ពោលអួតអរហត្តផល ដោយនឹកស្មានថាខ្លួនបានសម្រេចពិតហើយ។ ភិក្ខុនោះមានសេចក្ដីសង្ស័យថា សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តជាស្រេចហើយ អញត្រូវអាបត្តិបារាជិកហើយដឹង។ ភិក្ខុនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគក្នុងកាលនោះឯង។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ (ដំណើរនិយាយអួតអរហត្តផល) ដោយនឹកស្មានថាខ្លួនបានសម្រេចពិត មិនត្រូវអាបត្តិទេ។

[២៨៤] គ្រានោះ មានភិក្ខុមួយរូបនៅក្នុងព្រៃដោយតាំងចិត្តថា កាលបើអញនៅក្នុងព្រៃយ៉ាងនេះ អ្នកផងគង់នឹងសរសើរអញ។ អ្នកផងក៏បានសរសើរភិក្ខុនោះ (មែន)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែអ្នកទាំងឡាយមិនត្រូវតាំងចិត្តនឹងនៅក្នុងព្រៃឲ្យគេសរសើរឡើយ ភិក្ខុណានៅ (ដោយតាំងចិត្តយ៉ាងនេះ) ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ សម័យនោះ មានភិក្ខុមួយរូបដើរទៅដើម្បីបិណ្ឌបាត ដោយតាំងចិត្តថា កាលបើអញដើរទៅបិណ្ឌបាតយ៉ាងនេះ អ្នកផងនឹងសរសើរអញ។ អ្នកផងក៏បានសរសើរភិក្ខុនោះ (មែន)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែអ្នកទាំងឡាយមិនត្រូវតាំងចិត្តនឹងដើរទៅបិណ្ឌបាតឲ្យគេសរសើរឡើយ ភិក្ខុណាដើរទៅ (ដោយគិតយ៉ាងនោះ) ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

[២៨៥] សម័យនោះឯង មានភិក្ខុមួយរូបបានពោលពាក្យនឹងភិក្ខុមួយរូបថា ម្នាលអាវុសោ ពួកភិក្ខុណាដែលជាសទ្ធិវិហារិករបស់ឧបជ្ឈាយ៍នៃយើង ភិក្ខុទាំងនោះសុទ្ធតែជាអរហន្តទាំងអស់។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានប្រាថ្នានឹងអួតអាង។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះ ភិក្ខុមួយរូបបានពោលពាក្យនឹងភិក្ខុមួយរូបថា ម្នាលអាវុសោ ពួកភិក្ខុណាដែលជាអន្តេវាសិកនៃឧបជ្ឈាយ៍របស់យើង ភិក្ខុទាំងអស់នោះសុទ្ធតែជាអ្នកមានឫទ្ធិធំ មានអានុភាពច្រើន។ ភិក្ខុនោះក៏មានសេចក្ដីសង្ស័យ។ ទើបក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានបុណ្យ ខ្ញុំព្រះអង្គមានបំណងនឹងពោលអួត។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២៨៦] សម័យនោះ មានភិក្ខុមួយរូបដើរចង្ក្រម ដោយតាំងចិត្តថា កាលបើអញចង្ក្រមយ៉ាងនេះ បណ្ដាជននឹងសរសើរអញ។ បណ្ដាជនក៏បានសរសើរភិក្ខុនោះ (មែន)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ បេ។ ទើបក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែអ្នកទាំងឡាយមិនត្រូវដើរចង្ក្រមដោយតាំងចិត្ត (នឹងឲ្យគេសរសើរដូច្នោះ)ឡើយ ភិក្ខុណាដើរចង្ក្រម (ដោយគិតយ៉ាងនោះ) ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ សម័យនោះ មានភិក្ខុមួយរូបឈរ ដោយតាំងចិត្ត។ បេ។ អង្គុយដោយតាំងចិត្ត។ បេ។ ដេកដោយតាំងចិត្តថា កាលបើអញប្រព្រឹត្តយ៉ាងនេះ អ្នកផងនឹងសរសើរអញ។ អ្នកផងក៏សរសើរភិក្ខុនោះ (មែន)។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។ ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែអ្នកទាំងឡាយមិនត្រូវសម្រេចឥរិយាបថដេក ដោយតាំងចិត្ត (នឹងឲ្យគេសរសើរដូច្នោះ) ឡើយ ភិក្ខុណាសម្រេច (ឥរិយាបថយ៉ាងនោះ) ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

[២៨៧] សម័យនោះ មានភិក្ខុមួយរូបពោលអួតឧត្តរិមនុស្សធម្មដល់ភិក្ខុមួយរូប។ ភិក្ខុដែលអួតនោះ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ សញ្ញោជនធម៌ទាំងឡាយ ខ្ញុំលះបង់អស់ហើយ។ ភិក្ខុអ្នកអួតនោះ ក៏មានសេចក្ដីសង្ស័យ។ បានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[២៨៨] សម័យនោះ មានភិក្ខុមួយរូបទៅនៅក្នុងទីស្ងាត់ ក៏ពោលអួតឧត្តរិមនុស្សធម្ម។ មានភិក្ខុអ្នកបានបរចិត្តវិជ្ជា គឺកិរិយាកំណត់ដឹងចិត្តរបស់អ្នកដទៃ លោកបានហាមប្រាមភិក្ខុនោះថា ម្នាលអាវុសោ លោកកុំនិយាយអួតឧត្តរិមនុស្សធម្មយ៉ាងនេះឡើយ (ព្រោះ) ឧត្តរិមនុស្សធម្មនុ៎ះ មិនមានដល់ខ្លួនលោកទេ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ។ ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ ក្នុងសម័យនោះ មានភិក្ខុមួយរូបទៅនៅក្នុងទីស្ងាត់ ហើយពោលអួតឧត្តរិមនុស្សធម្ម។ ទេវតាបានពោលឃាត់ហាមភិក្ខុនោះថា បពិត្រលោកម្ចាស់ លោកកុំពោលអួតឧត្តរិមនុស្សធម្មយ៉ាងនេះ (ពីព្រោះ) ឧត្តរិមនុស្សធម្មនុ៎ះ មិនទាន់មានដល់ខ្លួនលោកទេ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ។ ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[២៨៩] សម័យនោះ មានភិក្ខុមួយរូបបាននិយាយនឹងឧបាសកម្នាក់ថា ម្នាលអ្នកដ៏មានអាយុ ភិក្ខុណាគង់នៅក្នុងវត្តរបស់អ្នក ភិក្ខុនោះជាព្រះអរហន្ត។ ឯភិក្ខុនោះតែងនៅក្នុងវត្តរបស់ឧបាសកនោះ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងពោលអួត។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ គ្រានោះ មានភិក្ខុមួយរូបបានពោលពាក្យនេះនឹងឧបាសកម្នាក់ថា ម្នាលអ្នកដ៏មានអាយុ អ្នកបានទំនុកបំរុងភិក្ខុអង្គណាដោយចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សមានជម្ងឺ ភិក្ខុអង្គនោះជាព្រះអរហន្ត។ ឯឧបាសកនោះក៏តែងទំនុកបំរុងភិក្ខុនោះដោយចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សមានជម្ងឺ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ។ ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងពោលអួត។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២៩០] សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា លោកដ៏មានអាយុបានសម្រេចដល់ឧត្តរិមនុស្សធម្មហើយឬ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ កិរិយាដែលនឹងធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល មិនមែនក្រឡើយ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យថា ភិក្ខុទាំងឡាយឯណា ដែលជាសាវករបស់ព្រះដ៏មានព្រះភាគ លោកទាំងអម្បាលនោះ ទើបគួរពោលយ៉ាងនេះ ក៏ខ្លួនអញមិនទាន់បានជាសាវករបស់ព្រះដ៏មានព្រះភាគនៅឡើយ អញប្រហែលត្រូវអាបត្តិបារាជិកហើយដឹង។ (លុះគិតដូច្នេះហើយ) ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងនឹងពោលអួតទេ។ ទើបព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ។ ក្នុងសម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា លោកដ៏មានអាយុមានឧត្តរិមនុស្សធម្មដែរឬ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ធម្មតា អ្នកមានព្យាយាមប្រារព្ធហើយ រមែងញុំាងព្រះធម៌ឲ្យប្រោសប្រាណបាន។ សេចក្តីសង្ស័យក៏កើតមានដល់ភិក្ខុនោះ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានបំណងនឹងអួត មិនត្រូវអាបត្តិឡើយ។ សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះថា នែអាវុសោ លោកកុំគប្បីខ្លាចឡើយ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនខ្លាចសេចក្តីស្លាប់ទេ។ សេចក្តីសង្ស័យក៏កើតមានដល់ភិក្ខុនោះ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានបំណងនឹងអួត មិនត្រូវអាបត្តិឡើយ។ សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយបានពោលពាក្យនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកកុំខ្លាចឡើយ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ភិក្ខុណានៅមានសេចក្តីក្តៅក្រហាយ ស្តាយក្រោយដោយពិតនៅឡើយ ភិក្ខុនោះទើបត្រូវខ្លាច។ សេចក្តីសង្ស័យក៏កើតមានដល់ភិក្ខុនោះ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ។ សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា លោកដ៏មានអាយុមានឧត្តរិមនុស្សធម្មដែរឬ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ធម្មតា អ្នកដែលប្រកបដោយព្យាយាមត្រូវហើយ រមែងញុំាងព្រះធម៌ឲ្យប្រោសប្រាណបាន។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិឡើយ។ គ្រានោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា លោកដ៏មានអាយុមានឧត្តរិមនុស្សធម្មដែរឬ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកមានព្យាយាមប្រារព្ធហើយ រមែងញុំាងព្រះធម៌ឲ្យប្រោសប្រាណបាន។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ។ សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា លោកដ៏មានអាយុមានឧត្តរិមនុស្សធម្មដែរឬ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកមានព្យាយាមប្រកបត្រូវហើយ រមែងញុំាងព្រះធម៌ឲ្យប្រោសប្រាណបាន។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ។ សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា ម្នាលអាវុសោ លោកល្មមអត់ធន់បានទេឬ លោកល្មមឲ្យប្រព្រឹត្តទៅបានឬទេ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ បុគ្គលក្រៅការមិនអាចនឹងអត់ធន់បានឡើយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ។ សម័យនោះ មានភិក្ខុមួយរូបមានជម្ងឺ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា ម្នាលអាវុសោ លោកល្មមអត់ធន់បានទេឬ លោកល្មមឲ្យប្រព្រឹត្តទៅបានទេឬ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ បុគ្គលជាបុថុជ្ជន មិនអាចនឹងអត់ធន់បានឡើយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ បានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងពោលអួត។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[២៩១] សម័យនោះ មានព្រាហ្មណ៍ម្នាក់បាននិមន្តពួកភិក្ខុ ហើយបានទទួលពាក្យទូលថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តចូលមក។ ភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យថា យើងទាំងឡាយ មិនមែនជាព្រះអរហន្តទេ ប៉ុន្តែ ព្រាហ្មណ៍នេះនិយាយលើកយើងទាំងឡាយដោយពាក្យថា ព្រះអរហន្ត យើងរាល់គ្នាត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ទើបភិក្ខុទាំងនោះក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថាម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ពោលដោយសេចក្តីជ្រះថ្លា មិនត្រូវអាបត្តិទេ។ សម័យនោះ មានព្រាហ្មណ៍ម្នាក់និមន្តភិក្ខុទាំងឡាយហើយបានពោលពាក្យថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តគង់។ បេ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តឆាន់។ បេ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តឆាន់ឲ្យឆ្អែត។ បេ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តទៅចុះ។ ភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យថា យើងទាំង

ឡាយមិនមែនជាអរហន្តទេ ក៏ព្រាហ្មណ៍នេះនិយាយលើកយើងដោយពាក្យថា ព្រះអរហន្ត យើងគួរប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ពោលដោយសេចក្តីជ្រះថ្លា មិនត្រូវអាបត្តិទេ។

[២៩២] សម័យនោះ មានភិក្ខុមួយរូបពោលអួតឧត្តរិមនុស្សធម្មចំពោះភិក្ខុមួយរូប។ ភិក្ខុដែលពោលអួតនោះបាននិយាយយ៉ាងនេះថាម្នាលអាវុសោ អាសវធម៌ទាំងឡាយខ្ញុំបានលះបង់អស់ហើយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុអ្នកឯងត្រូវអាបត្តិបារាជិកហើយ។ គ្រានោះ មានភិក្ខុមួយរូប ពោលអួតឧត្តរិមនុស្សធម្មចំពោះភិក្ខុមួយរូប។ ភិក្ខុដែលពោលអួតនោះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ ក៏ឧត្តរិមនុស្សធម្មទាំងនេះ ខ្ញុំករុណាមានសព្វគ្រប់។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។ សម័យនោះ មានភិក្ខុមួយរូប ពោលអួតឧត្តរិមនុស្សធម្មចំពោះភិក្ខុមួយរូប។ ភិក្ខុដែលពោលអួតនោះបានពោលយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំឃើញចំពោះខ្លួនឯងក្នុងធម៌ទាំងនោះ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[២៩៣] សម័យនោះ ជនទាំងឡាយជាញាតិបាននិមន្តភិក្ខុមួយរូបថា បពិត្យលោកដ៏ចម្រើន សូមលោកនិមន្តមកនៅគ្រប់គ្រងផ្ទះ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអាវុសោទាំងឡាយបុគ្គលដូចជាអាត្មា មិនគួរដើម្បីនឹងនៅគ្រប់គ្រងផ្ទះទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានបំណងនឹងពោលអួតទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលគ្មានបំណងនឹងពោលអួតមិនត្រូវអាបត្តិទេ។ សម័យនោះ ជនទាំងឡាយជាញាតិបាននិមន្តភិក្ខុមួយរូបថា បពិត្រលោកដ៏ចម្រើន សូមលោកនិមន្តមកបរិភោគកាមទាំងឡាយចុះ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ឯកាមទាំងឡាយ អាត្មាឃាត់រាំងរាបានហើយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគខ្ញុំព្រះអង្គមិនមានបំណងនឹងពោលអួតទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុអ្នកដែលគ្មានបំណងនឹងអួត មិនត្រូវអាបត្តិទេ។ សម័យនោះ ជនទាំងឡាយជាញាតិបានសួរភិក្ខុមួយរូបថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ត្រេកសប្បាយ ដែរឬទេ។ ភិក្ខុនោះនិយាយថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អាត្មាត្រេកសប្បាយដែរ (តែត្រេក សប្បាយ) ដោយសេចក្តីសប្បាយដ៏ឧត្តម។ ភិក្ខុនោះមានសេចក្តីសង្ស័យថា ភិក្ខុទាំងឡាយណា មួយដែលជាសាវករបស់ព្រះដ៏មានព្រះភាគ ភិក្ខុទាំងនោះទើបគួរពោលពាក្យយ៉ាងនេះបាន ក៏ខ្លួនអញមិនមែនជាសាវករបស់ព្រះដ៏មានព្រះភាគទេ អញត្រូវអាបត្តិបារាជិកហើយដឹង។ ភិក្ខុនោះក៏ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក៏ទូលតបថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានបំណងនឹងពោលអួតទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុអ្នកដែលគ្មានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ។

[២៩៤] សម័យនោះ មានភិក្ខុច្រើនរូបនៅចាំវស្សាក្នុងអាវាសមួយ បានធ្វើកតិកា (ណាត់គ្នា) ថា ភិក្ខុអង្គណានឹងចេញចាកអាវាសនេះជាមុនគេ យើងទាំងឡាយនឹងដឹងថា ភិក្ខុអង្គនោះជាព្រះអរហន្ត។ មានភិក្ខុមួយរូបចេញចាកអាវាសនោះទៅមុនគេ ដោយគិតថា ភិក្ខុទាំងនោះចូរដឹងនូវអញថាជាព្រះអរហន្តចុះ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិបារាជិកហើយដឹង។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។

[២៩៥] គ្រានោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់នៅក្នុងវត្តវេឡុវនកលន្ទកនិវាបស្ថាន។ សម័យនោះ ព្រះលក្ខណត្ថេរនឹងព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ គង់នៅលើភ្នំគិជ្ឈកូដ។ គ្រានោះឯង ព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ ស្លៀកស្បង់ទ្រង់បាត្រនិងចីវរចូលសំដៅទៅឯទីដែលព្រះលក្ខណត្ថេរគង់ ក្នុងវេលាបុព្វណ្ហសម័យ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះលក្ខណត្ថេរដ៏មានអាយុថា ម្នាលអាវុសោលក្ខណៈ មកយើងនឹងចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត។ ព្រះលក្ខណត្ថេរដ៏មានអាយុ ក៏ទទួលពាក្យព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុថា ករុណា អាវុសោ។ គ្រាដែលព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ កំពុងតែចុះអំពីភ្នំគិជ្ឈកូដ(ដល់មក)ត្រង់កន្លែងមួយក៏បានធ្វើនូវញញឹម ឲ្យប្រាកដ។ លំដាប់នោះ ព្រះលក្ខណត្ថេរដ៏មានអាយុ ក៏សួរព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុថា ម្នាលអាវុសោមហាមោគ្គល្លានអ្វីជាហេតុ អ្វីជាបច្ច័យ ចំពោះកិរិយាធ្វើនូវញញឹមឲ្យប្រាកដ(នេះ)។ ព្រះមហាមោគ្គល្លានត្ថេរឆ្លើយតបថា ម្នាលអាវុសោលក្ខណៈ កាលនេះមិនមែនជាកាលគួរនឹងព្យាករប្រស្នានេះទេ លោកចូរសួរប្រស្នានេះនឹងខ្ញុំក្នុងសំណាក់ព្រះដ៏មានព្រះភាគចុះ។ លំដាប់នោះ ព្រះលក្ខណត្ថេរដ៏មានអាយុ និងព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ ក៏និមន្តទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ហើយត្រឡប់អំពីបិណ្ឌបាតក្នុងវេលាក្រោយភត្ត ទើបចូលទៅ គាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគរួចហើយ ក៏អង្គុយ ក្នុងទីដ៏សមគួរ។ ព្រះលក្ខណត្ថេរដ៏មានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹង ព្រះមហាមោគ្គល្លានដ៏មានអាយុថា ក្នុងថ្ងៃនេះ មហាមោគ្គល្លានដ៏មានអាយុ កាលដែលចុះអំពីភ្នំគិជ្ឈកូដបានធ្វើនូវញញឹមឲ្យប្រាកដក្នុងកន្លែងមួយ ម្នាលអាវុសោមោគ្គល្លាន អ្វីជាហេតុ អ្វីជាបច្ច័យ ចំពោះកិរិយាធ្វើនូវញញឹមឲ្យប្រាកដនោះ។ ព្រះមហាមោគ្គល្លានត្ថេរឆ្លើយតបថា ម្នាលអាវុសោ ក្នុងថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញអដ្ឋិសង្ខលិកប្រេត[49) ] កំពុងតែអណ្តែតឯអាកាស ពពួកត្មាត ពពួកខ្លែង ពពួករអាត[50)] ដេញតាម ចោមឆាបចឹកចោះភើចជញ្ជែងអដ្ឋិសង្ខលិកប្រេតនោះតាមចន្លោះនៃឆ្អឹងជំនីទាំង ឡាយ អដ្ឋិសង្ខលិក ប្រេតនោះចេះតែស្រែកថ្ងូរ ម្នាលអាវុសោ ទើបខ្ញុំមានបរិវិតក្កថា យីអើហ្ន៎ (នេះហៅពេញ) ជាអស្ចារ្យ យីអើហ្ន៎ មិនធ្លាប់កើតមានសោះឡើយ សត្វបែបនេះនឹងត្រឡប់ទៅជាមានខ្លះតើ យក្សបែបនេះនឹង ត្រឡប់ទៅជាមានខ្លះ ប្រេតបែបនេះនឹងត្រឡប់ទៅជាមានខ្លះ កិរិយាត្រឡប់បានរូបរាងបែបនេះ នឹងត្រឡប់ទៅជាមានខ្លះដែរតើ។ ភិក្ខុទាំងឡាយទើបពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះមហាមោគ្គល្លានដ៏មានអាយុពោលអួតឧត្តរិមនុស្សធម្ម។ គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ហៅពួកភិក្ខុ មកហើយត្រាស់ប្រាប់ថា ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយមានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយមានញាណកើតពិតហើយ ព្រោះហេតុថា សាវកនឹងដឹង ឬនឹងឃើញ ប្រេតបែបនេះ ឬថានឹងធ្វើប្រេតបែបនេះឲ្យជាបន្ទាល់ (របស់តថាគត) ម្នាលភិក្ខុទាំងឡាយ សត្វនោះ តថាគតបានឃើញពីក្នុងកាលមុនរួចមកហើយ ប៉ុន្តែតថាគតមិនបានសំដែង ព្រោះថា បើតថាគត សំដែងទៅ ពពួកជនដទៃមិនជឿ (ពាក្យ) តថាគត ពពួកជនណាដែលមិនជឿតថាគត សេចក្តីដែលមិនជឿនោះនឹងនាំឲ្យខានបានប្រយោជន៍ នាំឲ្យបានសេចក្តីទុក្ខអស់កាលយូរអង្វែងដល់ពពួកជនទាំងនោះ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកពិឃាតគោ ក្នុងក្រុងរាជគ្រឹះនេះឯង ដោយកម្មវិបាកនោះ អ្នកពិឃាតគោនោះទៅឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយពាន់

សែនឆ្នាំ ដ៏ច្រើន ដោយសេសសល់នៃកម្មវិបាកនោះ ក៏ត្រឡប់មកទទួលផលគឺ ត្រឡប់បាននូវអត្តភាព បែបនេះឯង។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ។ បេ។ ម្នាលអាវុសោលក្ខណ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញមំសបេសីប្រេត[51] កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ខ្លែង រអាត ដេញតាមចោមឆាបចឹកចោះជញ្ជែងមំសបេសីប្រេតនោះឯង មំសបេសីប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយសត្វនុ៎ះ (កាលពីដើម) ជាអ្នកពិឃាតគោ ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញមំសបិណ្ឌប្រេត[52] កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ខ្លែង រអាត ដេញតាមចោម ឆាបចឹកចោះជញ្ជែងមំសបិណ្ឌប្រេតនោះឯង មំសបិណ្ឌប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយសត្វនុ៎ះ (កាលពីដើម) ជាព្រានសត្វស្លាប ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោ លក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជានិច្ឆចវិប្រេត[53] កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ខ្លែង រអាត ដេញតាមចោមឆាបចឹកចោះជញ្ជែងនិច្ឆវិប្រេតនោះឯង និច្ឆប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកសម្លាប់សត្វចៀម ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាអសិលោមប្រេត[54] កំពុងតែអណ្តែតទៅឯអាកាស ដាវទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មកដោតជាប់ព្ធដ៏កាយនៃប្រេតនោះឯង អសិលោមប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកពិឃាតជ្រូកចិញ្ចឹមជីវិត ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញបុរសដែលកើតជាសត្តិលោមប្រេត[55] កំពុងតែអណ្តែតទៅឯអាកាស លំពែងទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មកដោតជាប់ព្ធដ៏កាយនៃប្រេតនោះឯង សត្តិលោមប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាព្រានម្រឹគ ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោល្ខណៈ ថ្ងៃនេះខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញបុរសដែលកើតជាឧសុលោមប្រេត[56] កំពុងតែអណ្តែតទៅឯអាកាស ព្រួញទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មកដោតជាប់ព្ធដ៏កាយនៃប្រេតនោះឯង ឧសុលោមប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាពេជ្ឈឃាត[57] ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោល្ខណៈ ថ្ងៃនេះខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញបុរសដែលកើតជាសូចិលោមប្រេត[58] កំពុងតែអណ្តែតទៅឯអាកាស ម្ជុលទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មកដោតជាប់ព្ធដ៏កាយនៃប្រេតនោះឯង សូចិលោមប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជានាយសារថី ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណៈថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញបុរសដែលកើតជាសូចិលោមប្រេត[59] កំពុងតែអណ្តែតទៅឯអាកាស ដែកស្រួចទាំងឡាយរបស់ប្រេតនោះដោតចូលទៅតាមក្បាល ហើយធ្លាយចេញមកតាមមាត់ ដោតចូលទៅតាមមាត់ ហើយធ្លាយចេញមកខាងទ្រូង ដោតចូលទៅតាមទ្រូង ហើយធ្លាយចេញមកខាងពោះ ដោតចូលទៅតាមពោះ ហើយធ្លាយចេញមកខាងភ្លៅ (ទាំងពីរ) ដោតចូលទៅតាមភ្លៅ (ទាំងពីរ) ហើយធ្លាយចេញមកខាងស្មង (ទាំងពីរ) ដោតចូលទៅតាមស្មង (ទាំងពីរ) ហើយធ្លាយចេញមកខាងជើង (ទាំងពីរ) សូចិលោមប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកញុះញង់គេ ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណៈថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញបុរសដែលកើតជាកុម្ភណ្ឌប្រេត[60] កំពុងតែអណ្តែតទៅឯអាកាស ប្រេតនោះកាល បើដើរលុះតែលើកអណ្ឌៈទាំងនោះលី ទើបដើរទៅបាន កាលបើអង្គុយ ក៏ចេះតែអង្គុយសង្កត់លើអណ្ឌៈទាំងនោះឯង ពពួកត្មាត ខ្លែង រអាត ដេញតាមចោមឆាប ចឹកចោះជញ្ជែង កុម្ភណ្ឌប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអមាត្យអ្នកវិនិច្ឆ័យក្តីនៃអ្នកស្រុកដោយអំពើវៀច ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញបុរសដែលលិចចុះទាំងក្បាល ទៅក្នុងរណ្តៅលាមក។[61] បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកធ្វើបរទារកម្ម ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញបុរសដែលលិចចុះទាំង ក្បាលទៅក្នុងរណ្តៅលាមក[62] កំពុងតែ (ចាប់) លាមកដោយដៃទាំងពីរស៊ី។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាព្រាហ្មណ៍កំណាចក្នុងក្រុងរាជគ្រឹះនេះឯង ព្រហ្មណ៍នោះ កាលក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប បាននិមន្តភិក្ខុសង្ឃដោយ (ពាក្យថានិមន្តឆាន់) ភត្តាហារ ក៏ចាក់លាមកពេញក្នុងស្នូក រួចហើយប្រើគេឲ្យប្រាប់ភត្តកាលថា[63] បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកម្ចាស់និមន្តឆាន់ (ចង្ហាន់)ទាល់ឆ្អែតក្នុងទីនេះផង សូមនិមន្តយក (ចង្ហាន់) អំពីទីនេះទៅផង ដោយកម្មវិបាកនោះ ព្រាហ្មណ៍កំណាចនោះក៏ឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយ ពាន់ សែនឆ្នាំដ៏ច្រើន ដោយសំណល់នៃកម្មវិបាកនោះឯង ក៏បានមកសោយនូវផលកម្មដែលត្រឡប់បាននូវអត្តភាពបែបនេះ ម្នាលភិក្ខុទាំងឡាយមោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញស្រីដែលកើតជានិច្ឆវិប្រេត[64] កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ខ្លែង រអាត ដេញតាមចោមឆាប ចឹកចោះ ជញ្ជែងនិច្ឆវិប្រេតនោះឯង និច្ឆវិប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (កាលពីដើម)ជាស្រីប្រព្រឹត្តកន្លងចិត្តប្តីក្នុងក្រុងរាជគ្រឹះ នេះឯង។ បេ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញស្រីដែលកើតជាមង្គុលីប្រេត[65] មានក្លិនស្អុយកំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ខ្លែង រអាត ដេញតាមចោមឆាប ចឹកចោះ ជញ្ជែងមង្គុលីប្រេតប្រេតនោះឯង មង្គុលីប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (កាលពីដើម) ជាស្រីមេមត់ក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញស្រីដែលកើតជាឱកិលិនីប្រេត[66] ឆេះរោលដោយរងើកភ្លើង មានរងើកភ្លើងធ្លាក់ស្រោចលើខ្លួន (ក្តៅអន្ទះសារ) កំពុងតែអណ្តែតទៅឯអាកាស ឱកិលិនីប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (កាលពីដើម) ជាអគ្គមហេសីនៃស្តេចក្នុងដែនកលិង្គ ជាស្រីមានចិត្តឫស្យា បានចាក់រងើកភ្លើងមួយអម្បែងលើស្រីជាសត្រូវ។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញអសីសកពន្ធប្រេត[67] កំពុងតែ អណ្តែតទៅឯអាកាស ប្រេតនោះមានភ្នែក និងមុខនៅត្រង់ទ្រូង ពពួកត្មាត ខ្លែង រអាត ដេញតាមចោមឆាបចឹក ចោះជញ្ជែងនូវអសីសកពន្ធប្រេតនោះឯង ប្រេតនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកពិឃាតចោរឈ្មោះទារមិកក្នុងក្រុងរាជគ្រឹះនេះឯង។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុ[68] កំពុងតែ អណ្តែតទៅឯអាកាស សង្ឃាដិរបស់ភិក្ខុនោះក្តី មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះភ្លឺ វត្ថពន្ធចង្កេះក្តីក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ រាងកាយរបស់ភិក្ខុនោះក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ ភិក្ខុនោះចេះតែស្រែកថ្ងូរ។ បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនុ៎ះ ជាភិក្ខុបាបក្នុង

សាសនានៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប។ បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុនី[69] បានឃើញសាមណេរ[70] បានឃើញសាមណេរី[71] កំពុងតែ អណ្តែតទៅឯអាកាស សង្ឃាដិរបស់សាមណេរីនោះក្តី មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ វត្តពន្ធចង្កេះក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ សាមណេរីនោះចេះតែស្រែកថ្ងូរ ម្នាលអាវុសោលក្ខណៈ ខ្ញុំក៏មានបរិវិតក្កថា យីអើហ្ន៎ (នេះហៅពេញ) ជាអស្ចារ្យ យីអើហ្ន៎ មិនដែលកើតមានសោះឡើយ សត្វបែបនេះ នឹងត្រឡប់ទៅជាមានខ្លះទេតើ យក្សបែបនេះ នឹងត្រឡប់ទៅជាមានខ្លះ ប្រេតបែបនេះ នឹងត្រឡប់ទៅជាមានខ្លះ កិរិយាត្រឡប់បាននូវអត្តភាពបែបនេះ ក៏សឹងមានខ្លះដែរតើ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះមហាមោគ្គល្លានដ៏មានអាយុ ពោលអួតឧត្តរិមនុស្សធម្ម។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះសាវកទាំងឡាយមានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយសាវកទាំងឡាយមានញាណកើតពិតហើយ ព្រោះហេតុថាសាវកនឹងដឹង ឬឃើញសាមណេរីបែបនេះ ឬថានឹងធ្វើនូវសាមណេរីបែបនេះឲ្យជាបន្ទាល់ ម្នាលភិក្ខុទាំងឡាយ សាមណេរីនោះ តថាគតបានឃើញតាំងពីក្នុងកាលមុនរួចមកហើយដែរ តែតថាគតមិនបានសំដែងប្រាប់ ព្រោះថាបើតថាគតសម្តែងប្រាប់ទៅជនទាំងឡាយឯទៀតគេក៏មិនជឿ ពួកជនណាដែលមិនជឿពាក្យតថាគត សេចក្តីដែលមិនជឿនោះនឹងនាំឲ្យបាននូវកម្មមិនមែនជាប្រយោជន៍ នឹងនាំឲ្យបានសេចក្តីទុក្ខអស់កាលយូរអង្វែងដល់ជនទាំងនោះ ម្នាលភិក្ខុទាំងឡាយ សាមណេរីនុ៎ះ ជាសាមណេរីបាបក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ដោយកម្មវិបាកនោះ សាមណេរីនោះឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺថាអស់រយ-ពាន់-សែនឆ្នាំដ៏ច្រើន ដោយសំណល់នៃកម្មវិបាកនោះ ទើបបានមកសោយផលកម្មដែលត្រឡប់បាននូវអត្តភាពបែបនេះ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ។

[២៩៦] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុហៅភិក្ខុទាំងឡាយមកហើយនិយាយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ស្ទឹងតបោទានេះហូរមកអំពីអន្លង់ទឹកណា អន្លង់នោះមានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ដ៏ល្អគួរជាទីរីករាយមានត្រី និងអណ្តើកដ៏ច្រើនមានទាំងផ្កាឈូកប៉ុនៗកង់ (នៃរថ) រីកស្គុះស្គាយ តែថាស្ទឹងតបោទានេះ មានទឹកក្តៅហូរមក។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ស្ទឹងតបោទានេះហូរមកអំពីអន្លង់ទឹកណាអន្លង់នោះមានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ដ៏ល្អគួរជាទីរីករាយ មានត្រី និងអណ្តើកដ៏ច្រើន មានទាំងផ្កាឈូកប៉ុនៗកង់ (នៃរថ) រីកស្គុះស្គាយ តែថាស្ទឹងតបោទានេះមានទឹកក្តៅហូរមក ព្រះមហាមោគ្គល្លានដ៏មានអាយុពោលអួតឧត្តរិមនុស្សធម្ម (ទេតើ)។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្ទឹងតបោទានេះហូរមកអំពីអន្លង់ទឹកណា អន្លង់នោះមានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ដ៏ល្អគួរជាទីរីករាយ មានត្រី និងអណ្តើកដ៏ច្រើន មានទាំងផ្កាឈូកប៉ុនៗកង់ (នៃរថ) រីកស្គុះស្គាយ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែស្ទឹងតបោទានេះមកតាមចន្លោះនៃមហានរកទាំងពីរ[72] ព្រោះហេតុនោះ បានជាស្ទឹងតបោទានេះមានទឹកក្តៅហូរមក ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ។

[២៩៧] សម័យនោះព្រះរាជាទ្រង់ព្រះនាមពិម្ពិសារជាឥស្សរៈក្នុងដែនមគធៈ ជាអធិបតីលើសេនាកំពុងតែតសង្គ្រាមជាមួយនឹងពពួកស្តេចលិច្ឆវី ក៏ទ្រង់បាក់ទ័ព (បរាជ័យ)។ លុះកាលជាខាងក្រោយមក ព្រះរាជាទ្រង់ត្រាស់ឲ្យកេណ្ឌប្រមូលពួកសេនា ហើយទ្រង់ផ្តាញ់ពពួកស្តេចលិច្ឆវីបានវិញ។ ស្តេចក៏ទ្រង់ឲ្យទូងវិជយភេរីទៅក្នុទីសង្គ្រាមដោយប្រកាសសេចក្តីថា ពពួកស្តេចលិច្ឆវី ព្រះរាជាទ្រង់ឲ្យបាក់ទ័ព (បរាជ័យ) បានហើយ។ គ្រានោះព្រះមហាមោគ្គល្លានដ៏មានអាយុបានហៅពួកភិក្ខុមក ហើយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ព្រះបាទពិម្ពិសារទ្រង់ផ្តាញ់ពួកស្តេចលិច្ឆវីបានហើយ ទើបទ្រង់ឲ្យទូងវិជយភេរីទៅក្នុងទីសង្គ្រាមដោយប្រកាសសេចក្តីថា ពពួកស្តេចលិច្ឆវី ព្រះរាជាទ្រង់ឲ្យបាក់ទ័ព (បរាជ័យ) បានហើយ។ ភិក្ខុទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីបានជាព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះបាទពិម្ពិសារ ទ្រង់ផ្តាញ់ពួកស្តេចលិច្ឆវីបានហើយ ក៏ទ្រង់ឲ្យទូងវិជយភេរីទៅក្នុងទីសង្គ្រាម ដោយប្រកាសសេចក្តីថា ពពួកស្តេចលិច្ឆវី ព្រះរាជាទ្រង់ឲ្យបាក់ទ័ព (បរាជ័យ) បានហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុពោលអួតឧត្តរិមនុស្សធម្ម (ទេតើ)។ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទពិម្ពិសារទ្រង់បាក់ទ័ព (បរាជ័យចាញ់) ពួកស្តេចលិច្ឆវីជាន់ដំបូង លុះកាលជាខាងក្រោយ ស្តេចទ្រង់ឲ្យកេណ្ឌប្រមូលពួកសេនាបាន ទើបផ្តាញ់ពួកស្តេចលិច្ឆវីបានវិញ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ។

[២៩៨] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ហៅភិក្ខុទាំងឡាយមក ហើយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ថ្ងៃនេះ ខ្ញុំបានចូលសមាធិឥតមានកំរើកប្រែប្រួល ទៀបឆ្នេរស្ទឹងឈ្មោះសប្បិនិកា បានឮសូរសម្រែកដំរីទាំងឡាយ ដែលកំពុងតែចុះឡើង ស្រែកបន្លឺកោញ្ចនាទ។[73] ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីបានជាព្រះមហាមោគ្គល្លានដ៏មានអាយុពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ថ្ងៃនេះ ខ្ញុំបានចូលសមាធិ ឥតមានកំរើកប្រែប្រួល ទៀបឆ្នេរស្ទឹងឈ្មោះសប្បិនិកា បានឮសូរសម្រែកដំរីទាំងឡាយ ដែលកំពុងចុះឡើង ស្រែកបន្លឺកោញ្ចនាទ ព្រះមហាមោគ្គល្លានដ៏មានអាយុពោលអួតឧត្តរិមនុស្សធម្ម (ទេតើ)។ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមាធិនុ៎ះមាន ប៉ុន្តែសមាធិនោះមិនបរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ។

[២៩៩] គ្រានោះព្រះសោភិតត្ថេរដ៏មានអាយុហៅភិក្ខុទាំងឡាយមកហើយនិយាយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ខ្ញុំរឭកជាតិបានប្រមាណ ៥០០កប្ប។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វី បានជាព្រះសោភិតត្ថេរដ៏មានអាយុ ពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំរឭកជាតិបានប្រមាន៥០០កប្ប ព្រះសោភិតត្ថេរដ៏មានអាយុពោលអួតឧត្តរិមនុស្សធម្ម (ទេតើ)។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយសោភិតភិក្ខុរឭកជាតិបានមែន តែថារឭកបានត្រឹមតែជាតិ១ប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុមិនត្រូវអាបត្តិទេ។

បារាជិកទី ៤ ចប់។

[៣០០] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះបារាជិកទាំង៤ ដែលខ្ញុំបានសំដែងហើយនេះ បណ្តាអាបត្តិទាំង៤នុ៎ះ ភិក្ខុណាត្រូវអាបត្តិណាមួយហើយ ក៏មិនបាននូវកិរិយានៅរួបរួមជាមួយនឹងភិក្ខុទាំងឡាយឡើយ ភិក្ខុនោះជាបារាជិក រកសំវាសគ្មាន កាលពីមុនយ៉ាងណាមិញ ខាងក្រោយក៏ដូច្នោះដែរ។[74] ខ្ញុំព្រះករុណា សូមសួរលោកដ៏មានអាយុទាំងឡាយ ក្នុងអាបត្តិបារាជិកទាំង៤នោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំព្រះករុណា សូមសួរគំរប់ពីរដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំព្រះករុណា សូមសួរគំរប់៣ដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងបារាជិកាបត្តិទាំង៤នុ៎ះ ព្រោះហេតុដូច្នោះ បានជាស្ងៀម។ ខ្ញុំព្រះករុណាដឹងថា លោកទាំងឡាយបរិសុទ្ធហើយ ដោយហេតុដែលស្ងៀមយ៉ាងនេះ។

បារាជិកកណ្ឌ ចប់។

**ចំនួនសិក្ខាបទរបស់បារាជិកកណ្ឌនោះ**

បារាជិកសិក្ខាបទទាំង៤ គឺ សេពមេថុន១ លួចទ្រព្យគេ១ សម្លាប់មនុស្ស១ ពោលអួតឧត្តរិមនុស្សធម្ម១ ហៅថាឆេជ្ជវត្ថុ (វត្ថុដាច់ចាកភិក្ខុភាវៈ) មិនត្រូវសង្ស័យឡើយ។

# មាតិកា

I-XI is missing here. Remove text and picture when transciption is given


| តេរសកណ្ឌ | លេខ ទំព័រ |
|---|---|
| **វេរញ្ជកណ្ឌ** | **១** |
| សំដែងអំពីវេរញ្ជព្រាហ្មណ៍ពោលបង្អាច់ព្រះដ៏មានព្រះភាគ | ៣ |
| សំដែងអំពីសេចក្តីប្រៀបធៀបដោយកូនមាន់ | ១១ |
| សំដែងអំពីត្រៃវិជ្ជា | ១៣ |
| សំដែងអំពីស្រុកវេរញ្ជាអត់បាយ | ១៩ |
| សំដែងអំពីព្រហ្មចរិយធម៌មិនស្ថិតនៅយូរ | ២៣ |
| ពាក្យពោលប្រារព្ធនូវសេចក្តីបញ្ញត្តិសិក្ខាបទ | ២៧ |
| សំដែងអំពីពុទ្ធដំណើរទៅកាន់ផ្ទះវេរញ្ជព្រាហ្មណ៍ | ៣១ |
| **បារាជិកកណ្ឌ សិក្ខាបទទី ១** | **៣៥** |
| និទានសុទិន្នភិក្ខុ | ៣៥ |
| សេចក្តីបញ្ញត្តិជាដំបូង | ៥៩ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ទី ១ និទានមេស្វា | ៦៥ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ទី ២ និទានវជ្ជីបុត្តកភិក្ខុ | ៧១ |
| ចំណែកសិក្ខាបទ | ៧៣ |
| លក្ខណៈមិនពោលលាសិក្ខា | ៧៥ |
| លក្ខណៈពោលលាសិក្ខា | ៨៣ |
| លក្ខណៈមិនពោលលាសិក្ខា | ៨៧ |
| របៀបសំដែងអំពីអង្គជាត និងទ្វារមគ្គឥតស្រោមទ្រនាប់ | ៩១ |
| របៀបសំដែងអំពីអង្គជាត និងទ្វារមគ្គមានស្រោមទ្រនាប់ | ១០៧ |
| វិនីតវត្ថុ រឿងភិក្ខុមិនបានពោលលាសិក្ខា ជាដើម | ១១៣ |
| **បារាជិកកណ្ឌសិក្ខាបទទី ២** | **១៣៥** |
| និទានធនិយភិក្ខុ | ១៣៥ |
| | |

| | |
|---|---|
| សេចក្តីបញ្ញត្តិជាដំបូង | ១៤៧ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ | ១៤៧ |
| ចំណែកសិក្ខាបទ | ១៥១ |
| និយាយអំពីទ្រព្យដែលស្ថិតនៅក្នុងផែនដី | ១៥៥ |
| និយាយអំពីប្រយោគបង្គាប់ | ១៧៣ |
| អាការនៃអវហារ | ១៧៥ |
| វិនីតវត្ថុ រឿងភិក្ខុត្រេចទៅបិណ្ឌបាត ជាដើម | ១៨៥ |
| **បារាជិកកណ្ឌសិក្ខាបទទី ៣** | **២២២** |
| និទានក្នុងសេចក្តីបញ្ញត្តិជាដំបូង | ២២២ |
| និយាយអំពីអានាបានស្សតិសមាធិ | ២២៩ |
| និទានក្នុងសេចក្តីបញ្ញត្តិជាបន្ទាប់ | ២៣៣ |
| ចំណែកសិក្ខាបទ | ២៣៩ |
| និយាយអំពីប្រយោគបង្គាប់ | ២៤៣ |
| និយាយអំពីពណ៌នាសេចក្តីស្លាប់ | ២៤៧ |
| និយាយអំពីដំណើរសម្លាប់ដោយរូប ជាដើម | ២៥១ |
| និយាយអំពីដំណើរបង្គាប់ឲ្យស្លាប់ ជាដើម | ២៥៥ |
| វិនីតវត្ថុ រឿងភិក្ខុពណ៌នាសេចក្តីស្លាប់ ជាដើម | ២៥៧ |
| **បារាជិកកណ្ឌសិក្ខាបទទី ៤** | **២៨៥** |
| រឿងភិក្ខុពោលអួតឧត្តរិមនុស្សធម្ម | ២៨៧ |
| រឿងពួកភិក្ខុនៅទៀបឆ្នេរស្ទឹងវគ្គុមុទា | ២៨៩ |
| និយាយអំពីមហាចោរ ៥ពួក | ២៩៣ |
| សេចក្តីបញ្ញាតិជាដំបូង | ២៩៧ |
| សេចក្តីបញ្ញាតិជាបន្ទាប់ | ២៩៧ |
| ចំណែកសិក្ខាបទ | ២៩៩ |
| និយាយអំពីឧត្តរិមនុស្សធម្ម មានឈាន ជាដើម | ៣០៣ |
| និយាយអំពីសុទ្ធិកជ្ឈាន | ៣១១ |
| និយាយអំពីមគ្គ ជាដើម | ៣១៣ |
| និយាយអំពីខណ្ឌចក្ក | ៣១៩ |
| និយាយអំពីពទ្ធចក្ក | ៣២៥ |
| និយាយអំពីបេយ្យាល ១៥ | ៣៣៩ |
| វិនីតវត្ថុ និយាយអំពីសេចក្តីតាំងចិត្ត ជាដើម | ៣៤៧ |
| វិនីតវត្ថុ និទានអដ្ឋិសង្ខលិកប្រេត ជាដើម | ៣៦១ |




*ប្រធានបទនៅក្នុងវេទិកាពិភាក្សា [http://forum.sangham.net/index.php/topic,8903.html]*

---

1)
ក្នុងអដ្ឋកថា ព្រាហ្មណ៍នេះ ឈ្មោះឧទយៈ ដែលហៅថា វេរញ្ជៈ គឺហៅតាមនាមស្រុកវេរញ្ជា ជាស្រុករបស់គាត់នៅ

2)

កំណើតសត្វតិរច្ឆាន

3)

ប្រេតវិស័យ

4)

អសុរកាយដែលមានមហិទ្ធិឫទ្ធិដូចរាហូអសុរិន្ទជាដើម

5)

លោកដែលគ្មានសេចក្ដីចំរើនមានប្រការច្រើន មានអវចីនរកជាដើម

6)

សង្គ្រោះយកគតិរបស់មនុស្សចូលផង

7)

ចំពោះយកគតិនៃទេវតាតែម្យ៉ាង

8)

ទទួលនិមន្តដោយស្ងៀម

9)

សម័យជាចំណែកខាងដើមនៃថ្ងៃ គឺពេលព្រឹកព្រលឹម

10)

ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធជាម្ចាស់ ចំពោះត្រង់ត្រៃសិក្ខា គឺ សីល សមាធិ បញ្ញា។

11)

ប្រែចេញ ពីបាលីថា កិលាសុនោ សព្ទនេះប្រែថាខ្ជិល ប៉ុន្តែក្នុងទីនេះ បើប្រែថាខ្ជិល នឹងទៅជាឆ្គងសេចក្ដី មិនសមតាមន័យក្នុងអដ្ឋកថា ៗប្រាប់សេចក្ដីថា ព្រះពុទ្ធគ្មានសេចក្ដីខ្ជិលទេ។

12)

ភិក្ខុទាំង៥០០រូប ដែលមកនៅចាំវស្សាជាមួយនឹងព្រះអង្គ ជិតក្រុងវេរញ្ជានោះឯង។

13)

សំដៅភិក្ខុដែលកំពុងបង្ហាញក្ដី សាកសួរក្ដី រៀនក្ដី ទន្ទេញក្ដី ពណ៌នាក្ដី នូវបាឡីសូត្រលាសិក្ខា គឺសូត្របាឡីសឹក។

14)

សំដៅភិក្ខុដែលមិនបញ្ចេញវចីភេទឲ្យអ្នកដទៃឮ

15)

គឺភិក្ខុញុំាំងអង្គជាតិរបស់ខ្លួនឲ្យចូលទៅតាមទ្វារមគ្គទាំង៣ ទ្វារមគ្គណាមួយ។

16)

គឺបញ្ចូលអង្គជាតទៅតាមទ្វាមគ្គ ហើយបន្លយអង្គជាតចេញតាមមុខដំបៅដែលមានជុំវិញទ្វារមគ្គនោះ។

17)

គឺបញ្ចូលអង្គជាតទៅតាមមុខដំបៅ ហើយបន្លយចេញតាមទ្វារមគ្គវិញ។

18)

គឺបញ្ចូលអង្គជាតទៅតាមមុខដំបៅមួយ ហើយបន្លយចេញតាមមុខដំបៅផ្សេងវិញ។

19)

គឺទ្រង់អនុញ្ញាត មិនបាច់ឲ្យសូមឧបជ្ឈាយ៍ និងឧបសម្បទាជាថ្មីទៀត វស្សាក៏មិនបាច់ឲ្យរាប់ជាថ្មី ត្រូវរាប់តាំងពីឧបសម្បទាជាភិក្ខុនោះមកដដែល។

20)

ស្មសាន គឺព្រៃសម្រាប់ចោលខ្មោច ជាពាក្យសំស្ក្រឹតឲ្យអានថា ស្មៈសានៈ ដែលអានក្លាយមកថា សំសាន។ ពាក្យបាលីថា សុសាន។

21)

ទីនេះ ច្រើនប្រែថា នាយស្មៀន តែតាមន័យក្នុងអដ្ឋកថា ប្រែថា អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងឈើរបស់ស្ដេច (នាយឃ្លាំងឈើ)។

22)

ក្នុងអដ្ឋកថាថា ស្នូកសម្រាប់ជ្រលក់ក្ដី បាច់ឫស្សីក្ដី ក្បូនក្ដី ឲ្យឈ្មោះថា នាវា ដែលប្រែជា ទូកក្នុងទីនេះ

23)

អដ្ឋកថា ថា បណ្ដាកិរិយាបង្ហិតទាំងឡាយ មានបង្ហិតគោលជាដើម នោះមានអធិប្បាយថា ធម្មតាផែនដីជារបស់កាត់ថ្លៃមិនបាន ព្រោះហេតុដូច្នោះ បើសណ្ដានដីនោះ គេបោះគោលតែមួយស្រេច ភិក្ខុបង្ហិតគោលឲ្យចូលទៅក្នុងដីគេ សូម្បីប៉ុនចម្រៀកសក់ ទោះបីម្ចាស់គេឃើញក្ដី មិនឃើញក្ដី ត្រូវបារាជិក បើសណ្ដានដីនោះ គេបោះគោលពីរ ភិក្ខុបង្ហិតគោលទី១ ត្រូវថុល្លច្ច័យ ទី២ ត្រូវបារាជិក បើសណ្ដានដីនោះ គេបោះគោលបី ភិក្ខុបង្ហិតគោលទី១ ត្រូវទុក្កដ ទី២ ត្រូវថុល្លច្ច័យ ទី៣ ត្រូវបារាជិក។

24)

របស់ដែលសល់អំពីសត្វស៊ី

25)

ទឹកដោះគោដែលគេចំរាញ់ឲ្យទៅជាខ្លាញ់បែបយ៉ាងរាវៗ។

26)

បានដល់របស់ដែលគេនាំទៅ ដោយអវយវមានក្បាលជាដើម គឺទ្រនូល ឬអម្រែក។

27)

ប្រែថា ឆ្កែព្រៃក៏បាន

28)

មាត្រាវាល់ក្នុងដែនមគធៈ ៤នាឡិជា ១អាឡ្ហកៈ។

29)

ទម្ងន់២០ដំឡឹង

30)

គ្រឿងវាល់ ៤អាឡ្ហកៈ ត្រូវជា១ទោណៈ។

31)

សាលា គឺផ្ទះមានកំពូល។ តាមអដ្ឋកថា ថា ក្នុងព្រៃមហាវននោះ គេសាងវត្ត សង់សាលា ធ្វើគន្ធកុដិ សម្រាប់ជាទីប្រថាប់នៃព្រះបរមសាស្តា។

32)

គឺព្រៃធំមួយក្បែរកបិលវត្ថុបុរី ជិតជាប់គ្នាមិនមានដាច់នឹងព្រៃហេមពាន្តទៅទល់នឹងមហាសមុទ្រ(ឥណ្ឌា)។

33)

ឈ្មោះក្រុងរបស់ដែនវជ្ជី ពីដើមមកជាទីក្រុងធំមួយ មានកំពែងព័ទ្ធជុំវិញដល់៣ជាន់។ (សេចក្តីនេះមាននិយាយពិស្តារក្នុងគម្ពីរបរមត្ថជោតិកា អដ្ឋកថាខុទ្ទកនិកាយ)។

34)

តាមន័យក្នុងអដ្ឋកថា ថា សមណកុត្តក ប្រែថា អ្នកទ្រង់នូវភេទប្រហែលនឹងសមណៈ។ ក្នុងដីកា ថា អ្នកធ្វើកិច្ចការបម្រើសមណៈ។ មានសេចក្តីពន្យល់ក្នុងអដ្ឋកថា ថា គាត់កោរសក់ឡៅ ឲ្យមានសល់បន្តិចទុកជាជុក គាត់ស្លៀកសម្ពត់ជ្រលក់អម្ពត់មួយ បង់កមួយ ចិញ្ចឹមជីវិតដោយសារអាហារដែលសេសសល់អំពីភិក្ខុសង្ឃ។ ឯពាក្យថា មិគលណ្ឌិក គឺជាឈ្មោះរបស់គាត់។

35)

សាលាជាទីបម្រើ គឺសាលាសម្រាប់ប្រើប្រាស់ដោយកិច្ចផ្សេងៗ មានឆាន់ចង្ហាន់ជាដើម។

36)

ក្នុងអដ្ឋកថា ពន្យល់សេចក្តីថា ភិក្ខុជាអាចារ្យប្រើភិក្ខុឈ្មោះពុទ្ធរក្ខិតឲ្យទៅប្រាប់ភិក្ខុឈ្មោះ ធម្មរក្ខិតឲ្យប្រាប់ភិក្ខុឈ្មោះសង្ឃរក្ខិត ឲ្យទៅសម្លាប់មនុស្សឈ្មោះនេះ។ ត្រង់ពាក្យថា ឈ្មោះនេះ គឺមនុស្សនោះឈ្មោះអ្វី ក៏ចេញឈ្មោះនោះឯង។

37)

ភិក្ខុអ្នកចូលទៅកាន់ត្រកូល គឺភិក្ខុដែលជិតដិតស្និទ្ធស្នាលនឹងត្រកូល។

38)

ធ្វើបាបឲ្យពិបាក។

39)

បុរសអ្នកធ្វើការស៊ីឈ្នួល។

40)

ក្នុងអដ្ឋកថា ពន្យល់ថា ព្រះអង្គត្រាស់សួរដោយសំដៅសេចក្តីដូច្នេះថា យន្ត គឺសរីររបស់អ្នកទាំងអស់គ្នា ដែលមានចក្រ៤ មានទ្វារ៩នេះ អ្នករាល់គ្នាអាចធន់ទ្រាំថែរក្សា មិនមានទុក្ខលំបាកណាស់ទេឬ។

41)

យន្ត គឺសរីរនេះ អ្នករាល់គ្នាអាចឲ្យប្រព្រឹត្តទៅបានគ្រប់កិច្ចទាំងពួងមិនមានអន្តរាយ ទើសទាស់អ្វីទេឬ។

42)

ក្នុងអដ្ឋកថា អធិប្បាយថា ភិក្ខុដែលចេះប្រៀបធៀបបាលី និងអដ្ឋកថា ក្នុងកណ្តាលបរិសទ្យ ហើយប្រសប់ធ្វើសំឡេងទេសនាផ្លូវព្រះសូត្រឲ្យយ៉ាងពីរោះ កាលបើចប់ធម៌ហើយ មានគេសួរថា លោកម្ចាស់រៀនពីលោកគ្រូអាចារ្យណាមក ភិក្ខុនោះក៏លាក់មិនប្រាប់នាមគ្រូអាចារ្យ ឆ្លើយថា អាត្មាគ្មានគ្រូអាចារ្យណាអាចនឹងបង្រៀនបានទេ រៀនចេះដឹងតែខ្លួនឯង យ៉ាងនេះហៅថា ដុតកំដៅខ្លួនឯងចោល។

43)

អដ្ឋកថា អធិប្បាយថា ចោទដល់ទីមេថុនធម្ម។

44)

ចោទដោយមិនបានឃើញនឹងភ្នែក មិនបានឮនឹងត្រចៀក ឬមិនបានរង្កៀសក្នុងចិត្ត។

45)

ពាក្យថា លោហៈ ជាពាក្យសំរាប់ហៅពួកគ្រឿងដែក ស្ពាន់ ទង់ដែងជាដើម។

46)

ត្រង់ឈានទាំង៣ គឺទុតិយជ្ឈាន១ តតិយជ្ឈាន១ ចតុត្ថជ្ឈាន១ នេះ ក្នុងឈានមួយៗ ត្រូវប្រែជា៥លើកៗ ដូចជាបឋមជ្ឈានដែរ គឺទុតិយជ្ឈាន ប្រកបដោយអាការ៣យ៉ាង ទុតិយជ្ឈានប្រកបដោយអាការ៤យ៉ាង ទុតិយជ្ឈានប្រកបដោយអាការ៥យ៉ាង ទុតិយជ្ឈានប្រកបដោយអាការ៦យ៉ាង ទុតិយជ្ឈានប្រកបដោយអាការ៧យ៉ាង។ តតិយជ្ឈាន ប្រកបដោយអាការ៣យ៉ាង ៤យ៉ាង ៥យ៉ាង ៦យ៉ាង ៧យ៉ាង។ ចតុត្ថជ្ឈានប្រកបដោយ អាការ៣យ៉ាង ៤យ៉ាង ៥យ៉ាង ៦យ៉ាង ៧យ៉ាង។

47)

គឺសូចិលោមប្រេតទីពីរ ដែលមានសំដែងទៅខាងមុខ។

48)

គឺកុម្ភណ្ឌប្រេត ដែលមានសំដែងទៅខាងមុខនោះឯង។

49)

ប្រេតឥតមានសាច់ឈាមឡើយ មានតែរោងឆ្អឹង

50)

បានពិនិត្យ មើលក្នុងគម្ពីរទាំងពួងមានអភិធានប្បទីបិកាជាដើម ឃើញថា កង្ក ប្រែថា ខ្លែង កុលល ប្រែថា រអាត ឬ ប្រមង់។ ត្រង់កង្កាបិ ក្នុងទីនេះ ឱ.ម.ជា កាកាបិ(ក្អែក)។ សត្វទាំង៣ពួកនេះមិនមែនសត្វធម្មតាមែនទែនទេ គឺសត្វដែលកើតអំពីបាបកម្មរបស់ប្រេតនុ៎ះឯង

51)

ប្រេតមានរាងកាយដូចជាចម្រៀកសាច់

52)

ប្រេតមានរាងកាយដូចជាដុំសាច់

53)

ប្រេតមានរាងកាយរងាលឥតស្បែក

54)

ប្រេតមានដាវដោតជាប់នឹងរាងកាយដូចជារោម

55)

ប្រេតមាន លំពែងដោតជាប់នឹងរាងកាយដូចជារោម

56)

ប្រេតមានព្រួញដោតជាប់នឹងរាងកាយដូចជារោម

57)

ជាពេជ្ឈឃាតបាញ់មនុស្សទោសដោយព្រួញ។

58)

ប្រេតមានម្ជុលដោតជាប់នឹងរាងកាយដូចជារោម

59)

ប្រេតមានដែកស្រួចចាក់ខ្ទាស់ច្រូងច្រាងនារាងកាយដូចជារោម

60)

ប្រេតមានអណ្ឌៈ (ពងស្វាស) ប៉ុនក្អមយ៉ាងធំ។

61) , 62)

ហៅគូថខាទិប្រេត

63)

ពេលដែលចាត់ចែងចង្ហាន់ស្រេចហើយ ត្រូវនិមន្តឆាន់

64)

ប្រេតមានរាងកាយរងាលឥតស្បែក

65)

ប្រេតមានរាងកាយអាក្រក់គួរខ្ពើមឆ្អើម

66)

ប្រេតមានរាងកាយស្រោចដោយរងើកភ្លើង

67)

ប្រេតឥតក្បាល មានរូបសណ្ឋានដូចសាកអសុភដាច់ក្បាល

68)

ហៅភិក្ខុប្រេត គឺប្រេតមានភេទដូចជាភិក្ខុ

69)

ហៅសិក្ខមានាប្រេត

70)

ហៅសាមណេរប្រេត

71)

ហៅសាមណេរីប្រេត

72)

អដ្ឋកថា ពន្យល់សេចក្តីថា មានមហាបេតលោវា គឺលោកជាស្ថានលំនៅដ៏ធំសម្រាប់ពួកប្រេត នៅចំក្រុងរាជគ្រឹះ ស្ទឹងតបោទានេះមកតាមចន្លោះនៃមហាលោហកុម្ភីនរកទាំងពីរត្រង់មកលើមហាបេតលោក នោះ ព្រោះហេតុដូច្នោះ បានជាមានទឹកក្តៅហូរមក

73)

ដាក់ប្រមោយក្នុងមាត់ ជញ្ជួចឮសូរដូចជាសម្រែកក្រៀល។

74)

អដ្ឋកថា ពន្យល់សេចក្តីថា កាលដែលបុគ្គលនោះនៅជាគ្រហស្ថ ឬនៅជាសាមណេរ មិនអាចរួបរួមសង្ឃកម្មជាមួយនឹងភិក្ខុទាំងឡាយបាន យ៉ាងណា លុះដល់ត្រូវអាបត្តិបារាជិកហើយ ក៏ដូច្នោះដែរ។

sangham.net
Virtual AccessToInsight

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០០២ - Book 002

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថាលោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០២ - Tipitaka Book 002 [http://forum.sangham.net/index.php/topic,8907.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០០២





# ព្រះត្រៃបិដក ភាគ ទី២

ទ. ៤

# វិន័យបិដក

CS vin | ភាគ ទី២

# មហាវិភង្គ

CS vin.vbu | ភាគ ទី២

**ទុតិយភាគ**

**ភាគទី ២**

**សង្ឃាទិសេសកណ្ឌ**
សង្ឃាទិសេស ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ | ទី៦ | ទី៧ | ទី៨ | ទី៩ | ទី១០ | ទី១១ | ទី១២ | ទី១៣

**អនិយតកណ្ឌ**
អនិយតទី ១ | អនិយតទី ២

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ។

# តេរសកណ្ឌ

CS vin.vbu.sg | ភាគ ទី២

**(២. សង្ឃាទិសេសកណ្ឌំ)**

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះ សង្ឃាទិសេសទាំង១៣ សិក្ខាបទនេះមកកាន់ឧទ្ទេស។[1)]

## សង្ឃាទិសេស ទី១

CS vin.vbu.sg.01 | ភាគ ទី២

**(១. សុក្កវិស្សដ្ឋិសិក្ខាបទំ)**

[១] សម័យនោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់នៅក្នុងវត្តជេតពន ជារបស់អានាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះ សេយ្យសកភិក្ខុដ៏មានអាយុ មិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ (ចង់សឹក)។ ដោយហេតុនោះ សេយ្យសកភិក្ខុ ក៏ទៅជាស្គាំងស្គម មានសម្បុរអាប់អន់ កើតមានរោគស្គមលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ឧទាយិត្ថេរ[2)] ដ៏មានអាយុឃើញសេយ្យសកភិក្ខុដ៏មានអាយុស្គាំងស្គម មានសម្បុរអាប់អន់ កើតមានរោគស្គមលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ លុះឃើញហើយ ទើបសួរសេយ្យសកភិក្ខុថា ម្នាលអាវុសោសេយ្យសក ហេតុអ្វី បានជាលោកស្គាំស្គម មានសម្បុរអាប់អន់ កើតមានរោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ (ដូច្នេះ) ម្នាលអាវុសោសេយ្យសក លោកមិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឬអ្វី។ សេយ្យសកភិក្ខុឆ្លើយថា ករុណា អាវុសោ។ ឧទាយិក៏បង្គាប់ថា ម្នាលអាវុសោសេយ្យសក បើដូច្នោះ លោកចូរឆាន់ឲ្យឆ្អែត សិងឲ្យស្កប់ ស្រង់ឲ្យពេញចំណង់ទៅ លុះដល់ឆាន់ឆ្អែត សិងស្កប់ ស្រង់ពេញចំណង់ហើយ កាលណាបើសេចក្ដីអផ្សុកកើតមានដល់លោក រាគៈគ្របសង្កត់ចិត្តលោក លោកចូរព្យាយាមដោយដៃ ញុំាងទឹកអសុចិឲ្យឃ្លាតចេញក្នុងកាលនោះចុះ។

ទើបសេយ្យសកភិក្ខុសួរថា ម្នាលអាវុសោ កិរិយាដែលសមណៈធ្វើយ៉ាងហ្នឹងគួរដែរឬ។ ឧទាយិឆ្លើយថា ករុណា អាវុសោ ទុកជាខ្ញុំក៏ធ្វើយ៉ាងហ្នឹងដែរ។ លំដាប់តពីនោះមក សេយ្យសកដ៏មានអាយុ ក៏ឆាន់ទាល់តែឆ្អែត សិងទាល់តែស្កប់ ស្រង់ទាល់តែពេញចំណង់ លុះដល់ឆាន់ឆ្អែត សិងស្កប់ ស្រង់ពេញចំណង់ហើយ កាលណាសេចក្តីអផ្សុកកើតឡើង រាគៈគ្របសង្កត់ចិត្ត ក៏ព្យាយាមដោយដៃ ញុំាងទឹកអសុចិឲ្យឃ្លាតចេញក្នុងកាលនោះ។ គ្រាតមក សេយ្យសកភិក្ខុក៏ត្រឡប់មានសម្បុរ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខស្រស់បស់ មានសម្បុរស្បែកដ៏ផូរផង់ឡើងវិញ។ គ្រានោះ ពួកភិក្ខុដែលជាសំឡាញ់របស់សេយ្យសកដ៏មានអាយុ ក៏សួរសេយ្យសកដ៏មានអាយុថា ម្នាលអាវុសោសេយ្យសក កាលពីដើម លោកស្គាំងស្គម មានសម្បុរអាប់អន់ កើតទៅជារោគស្លមលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ឥឡូវនេះ លោកមានសម្បុរ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខស្រស់បស់ មានសម្បុរស្បែកផូរផង់ឡើងវិញ លោកបានធ្វើថ្នាំអ្វី (ឆាន់) អាវុសោសេយ្យសក។ សេយ្យសកភិក្ខុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ ខ្ញុំគ្មានធ្វើថ្នាំអ្វី (ឆាន់) ទេ តែខ្ញុំបានឆាន់ឆ្អែត សិងស្កប់ ស្រង់ទឹកពេញចំណង់ លុះបានឆាន់ឆ្អែត សិងស្កប់ ស្រង់ទឹកពេញចំណង់ហើយ កាលណាសេចក្តីអផ្សុកកើតឡើង រាគគ្របសង្កត់ចិត្តខ្ញុំ ៗព្យាយាមបញ្ចេញទឹកអសុចិដោយដៃក្នុងកាលនោះ។ ទើបពួកភិក្ខុជាសំឡាញ់សួរថា ម្នាលអាវុសោសេយ្យសក លោកទទួលបរិភោគនូវរបស់ដែលគេឲ្យដោយសទ្ធា ដោយដៃណា លោកព្យាយាមបញ្ចេញទឹកអសុចិដោយដៃនោះឯង ឬអ្វី។ សេយ្យសកឆ្លើយថា ម្នាលអាវុសោទាំងឡាយ ពិតដូច្នោះឯង។ ភិក្ខុទាំងឡាយណាដែលជាអ្នកមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោសត្មះតិះដៀលថា ហេតុអ្វីបានជាសេយ្យសកដ៏មានអាយុ ព្យាយាមបញ្ចេញទឹកអសុចិដោយដៃ (ដូច្នោះ)។ គ្រានោះ ពួកភិក្ខុទាំងនោះក៏តិះដៀលសេយ្យសកដ៏មានអាយុ ដោយអនេកបរិយាយ ហើយបានក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទើបព្រះដ៏មានព្រះភាគ អាស្រ័យហេតុនេះ អាស្រ័យដំណើរនេះ ទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះទៅសេយ្យសកដ៏មានអាយុថា ម្នាលសេយ្យសក បានឮថាអ្នកឯងព្យាយាមញុំាងទឹកអសុចិឲ្យឃ្លាតចេញដោយដៃមែនឬ។ សេយ្យសកទូលតបថា សូមទ្រង់ព្រះមេត្តាប្រោសពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលបុរសឥតអំពើ កម្មនុ៎ះមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាលមោឃបុរស ហេតុអ្វីបានជាអ្នកឯងព្យាយាមបញ្ចេញទឹកអសុចិដោយដៃ (ដូច្នោះ) ម្នាលមោឃបុរស ធម៌ដែលតថាគតសំដែងហើយ ដោយបរិយាយដ៏ច្រើន (សុទ្ធតែ) ដើម្បីឲ្យប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ ធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកគ្រឿងប្រកប មិនមែនដើម្បីគ្រឿងប្រកបទេ ធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកសេចក្តីប្រកាន់មាំ មិនមែនដើម្បីសេចក្តីប្រកាន់មាំទេ (ដូច្នេះ) មិនមែនឬ ម្នាលមោឃបុរស កាលបើ ធម៌ដែលតថាគតសំដែងហើយ (សុទ្ធតែ) ដើម្បីឲ្យប្រាសចាករាគៈ អ្នកឯងបែរជារិះគិតត្រង់ធម៌នោះ ដើម្បីប្រកបដោយរាគៈទៅវិញ កាលបើធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកគ្រឿងប្រកប អ្នកឯងបែរជារិះគិតដើម្បីគ្រឿងប្រកបវិញ កាលបើធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកសេចក្តីប្រកាន់មាំ អ្នកឯងបែរជារិះគិតដើម្បីប្រកបដោយសេចក្តីប្រកាន់មាំវិញ ម្នាលមោឃបុរស ធម៌ដែលតថាគតសំដែងហើយ ដោយបរិយាយដ៏ច្រើន (សុទ្ធតែ) ដើម្បីនឿយណាយចាករាគៈ ដើម្បីញាំញីនូវសេចក្តីស្រវឹង ដើម្បីបន្ទោបង់នូវសេចក្តីស្រេក ដើម្បីដករំលើងនូវសេចក្តីអាល័យ ដើម្បីកាត់ផ្តាច់នូវវដ្ត ដើម្បីឲ្យអស់ទៅនៃតណ្ហា ដើម្បីឲ្យប្រាសចាករាគៈ ដើម្បីកិរិយារលត់ ដើម្បីនិព្វាន (ដូច្នេះ) មិនមែនឬ ម្នាលមោឃបុរស កិរិយាលះបង់នូវកាមទាំងឡាយ តថាគតបានសំដែងហើយដោយអនេកបរិយាយ កិរិយាកំណត់ដឹងនូវសេចក្តីសំគាល់ក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាបន្ទោបង់នូវសេចក្តីស្រេកក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាដករំលើងនូវកាមវិតក្កទាំងឡាយ តថាគតបានសំដែងហើយ កិរិយារម្ងាប់បង់នូវសេចក្តីក្តៅក្រហាយព្រោះកាមទាំងឡាយ តថាគតបានសំដែងហើយ មិនមែនឬ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនុ៎ះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា (នោះ) ទេ មិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាឡើងដល់ជនទាំងឡាយដែលមានសេចក្តីជ្រះថ្លាហើយ (នោះ)ទេ ម្នាលមោឃបុរស អំពើរបស់អ្នកឯងនុ៎ះ បានតែខាងនាំមិនឲ្យជ្រះថ្លាដល់ពួកជនខ្លះដែលមិនទាន់មានសេចក្តីជ្រះថ្លា នាំឲ្យរវាយមាយរសាយចិត្តបាត់សេចក្តីជ្រះថ្លាដល់ជនពួកខ្លះដែលមានសេចក្តីជ្រះថ្លាហើយ (នោះ) ប៉ុណ្ណោះឯង។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលសេយ្យសកភិក្ខុដ៏មានអាយុដោយអនេកបរិយាយ ហើយទ្រង់សំដែងទោសនៃកោសជ្ជ ដែលជាហេតុនាំឲ្យគេចិញ្ចឹមបីបាច់រក្សាបានដោយកម្រ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុមានចិត្តក្លែង ញុំាងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស។

សិក្ខាបទនេះព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះឯង។

[២] សម័យនោះ ភិក្ខុទាំងឡាយបានឆាន់បណីតភោជនទាំងឡាយ ហើយភ្លេចស្មារតី មិនដឹងខ្លួន សិងលក់ទៅ។ កាលបើភិក្ខុទាំងនោះកំពុងតែភ្លេចស្មារតី មិនដឹងខ្លួន សិងលក់ ទឹកអសុចិក៏ឃ្លាតចេញដោយយល់សប្តិ។ ភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យដូច្នេះថា សិក្ខាបទព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តហើយថា ភិក្ខុក្លែងញុំាងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស ក៏ទឹកអសុចិរបស់យើងទាំងឡាយឃ្លាតចេញដោយយល់សប្តិ ឯចេតនាក៏មានក្នុងកាលដែលយល់សប្តិនោះដែរ យើងត្រូវអាបត្តិសង្ឃាទិសេសហើយដឹង។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចេតនានោះមានមែន ប៉ុន្តែចេតនានោះជាអព្វោហារិកា។[3] ព្រះដ៏មានព្រះភាគទ្រង់អាស្រ័យដំណើរនេះជាហេតុ អាស្រ័យដំណើរនេះជាទីតាំង ទើបទ្រង់សំដែងធម្មកថាហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុក្លែងញុំាងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស លើកលែងតែយល់សប្តិ។**

[៣] ត្រង់ពាក្យថា ភិក្ខុក្លែង សេចក្តីថា ភិក្ខុកំពុងដឹង កំពុងចាំច្បាស់ ហើយក្លែងបំពានធ្វើឲ្យកន្លង។ ត្រង់ពាក្យថា ទឹកសុក្ក សេចក្តីថា ទឹកសុក្កមាន១០យ៉ាងគឺ ទឹកសុក្កពណ៌ខៀវ១ ទឹកសុក្កពណ៌លឿង១ ទឹកសុក្កពណ៌ក្រហម១ ទឹកសុក្កពណ៌ស១ ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ១ ទឹកសុក្កពណ៌ដូចទឹក១ ទឹកសុក្កពណ៌ដូចប្រេង១ ទឹកសុក្កពណ៌ដូចទឹកដោះស្រស់១ ទឹកសុក្កពណ៌ដូចទឹកដោះជូរ១ ទឹកសុក្កពណ៌ដូចទឹកដោះ

ថ្លា១។ ត្រង់ពាក្យថា ឲ្យឃ្លាតចេញសេចក្តីថាឲ្យកគ្រើកឃ្លាតចេញចាកទីកន្លែង (ដើម) តថាគតហៅថា ឲ្យឃ្លាតចេញ។ ត្រង់ពាក្យថា លើកលែងតែយល់សប្តិ (នោះ) សេចក្តីថា វៀរលែងតែយល់សប្តិ។ ត្រង់ពាក្យថា សង្ឃាទិសេស (នោះ) សេចក្តីថា សង្ឃតែម្យ៉ាងដែលឲ្យនូវបរិវាស ព្រោះអាបត្តិនោះ ត្រឡប់សើរើចាកមូលាបត្តិ ឲ្យនូវមានត្ត ឲ្យនូវអព្ភាន មិនមែនភិក្ខុច្រើនរូប មិនមែនបុគ្គលតែ១រូប ព្រោះហេតុនោះបានជាតថាគតហៅថា សង្ឃាទិសេស។ ម្យ៉ាងទៀតថា ជានាមកម្ម គឺថាជាឈ្មោះរបស់កងអាបត្តិនោះឯង ព្រោះហេតុនោះ បានជាហៅថាសង្ឃាទិសេស។

[៤] ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្នុង (អវយវខ្លួនឯង) ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្រៅ (អវយវអ្នកដទៃ) ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្នុង និងរូបខាងក្រៅ ភិក្ខុធ្វើចង្កេះឲ្យញ័រក្នុងអាកាស ញុំាងទឹកសុក្កឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញព្រោះសេចក្តីឧបត្ថម្ភដោយរាគៈ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីឧបត្ថម្ភដោយលាមក ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីឧបត្ថម្ភដោយមូត្រ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីឧបត្ថម្ភដោយខ្យល់ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីឧបត្ថម្ភដោយដង្កូវរមាស់រោល ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍មិនឲ្យមានរោគ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ឲ្យបានសេចក្តីសុខ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីត្រូវការដោយភេសជ្ជៈ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ទាន ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់បុណ្យ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការបូជា ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ស្ថានសួគ៌ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ពូជ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការល្បងមើល ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការលេង ភិក្ខុញុំាងទឹកសុក្កពណ៌ខៀវឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌លឿងឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ក្រហមឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌សឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ដូចទឹកឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ដូចប្រេងឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ដូចទឹកដោះជូរឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ដូចទឹកដោះថ្លាឲ្យឃ្លាតចេញ។

[៥] ត្រង់ពាក្យថា ក្នុងរូបខាងក្នុង សេចក្តីថា ក្នុងរូបដែលមានវិញ្ញាណចូលទៅអាស្រ័យនៅជាខាងក្នុង។ ត្រង់ពាក្យថា ក្នុងរូបខាងក្រៅ សេចក្តីថា ក្នុងរូបដែលមានវិញ្ញាណក្តី ក្នុងរូបដែលឥតវិញ្ញាណក្តីជាខាងក្រៅ។ ត្រង់ពាក្យថា ក្នុងរូបខាងក្នុង និងរូបខាងក្រៅ សេចក្តីថា ក្នុងរូបទាំង២នោះ។ ត្រង់ពាក្យថា ធ្វើចង្កេះឲ្យញ័រក្នុងអាកាស សេចក្តីថា អង្គជាតរបស់ភិក្ខុដែលកំពុងព្យាយាមទៅក្នុងអាកាស ក៏ជាអវយវៈគួរដល់កម្ម។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយរាគៈ សេចក្តីថា អង្គជាតរបស់ភិក្ខុដែលរាគៈបៀតបៀនហើយ ជាអវយវៈគួរដល់កម្ម។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយលាមក សេចក្តីថា អង្គជាតរបស់ភិក្ខុដែលលាមកបៀតបៀនហើយ ជាអវយវៈគួរដល់កម្ម។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយមូត្រ សេចក្តីថា អង្គជាតរបស់ភិក្ខុដែលមូត្របៀតបៀនហើយ ជាអវយវៈគួរដល់កម្ម។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយខ្យល់ សេចក្តីថា អង្គជាតរបស់ភិក្ខុដែលខ្យល់បក់ត្រូវហើយ ជាអវយវៈគួរដល់កម្ម។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយដង្កូវរមាស់រោល សេចក្តីថា អង្គជាតរបស់ភិក្ខុដែលដង្កូវរមាស់រោលបៀតបៀនហើយ ជាអវយវៈគួរដល់កម្ម។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍មិនឲ្យមានរោគ សេចក្តីថា ភិក្ខុគិតថា អញនឹងជាអ្នកមិនមានរោគ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ឲ្យបានសេចក្តីសុខ សេចក្តីថា ភិក្ខុគិតថា អញនឹងញុំាងសុខវេទនាឲ្យកើតឡើង។ ត្រង់ពាក្យថា ដើម្បីត្រូវការដោយភេសជ្ជៈ សេចក្តីថា ភិក្ខុគិតថា ទឹកសុក្កនេះនឹងបានជាថ្នាំ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ទាន សេចក្តីថា ភិក្ខុគិតថា អញនឹងឲ្យទឹកសុក្កជាទាន។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់បុណ្យ សេចក្តីថា ភិក្ខុគិតថា ទឹកសុក្កនេះនឹងជាបុណ្យ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការបូជា សេចក្តីថា ភិក្ខុតាំងចិត្តថា អញនឹងបូជាទឹកសុក្កជាគ្រឿងយញ្ញ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ស្ថានសួគ៌ សេចក្តីថា ភិក្ខុគិតថា អញនឹងទៅកាន់ស្ថានសួគ៌។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ពូជ សេចក្តីថា ភិក្ខុគិតថា ទឹកសុក្កនេះនឹងជាពូជ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការល្បងមើល សេចក្តីថា ភិក្ខុគិតថា អញនឹងល្បងមើល ទឹកសុក្កនេះនឹងជាពណ៌ខៀវ នឹងជាពណ៌លឿង នឹងជាពណ៌ក្រហម នឹងជាពណ៌ស។បេ។ ទឹកសុក្កនេះនឹងជាពណ៌ដូចទឹកដោះថ្លា។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការលេង សេចក្តីថា ភិក្ខុមានបំណងក្នុងការលេង។

[៦] ភិក្ខុគិតចំពោះរូបខាងក្នុង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតចំពោះរូបខាងក្រៅ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតចំពោះរូបខាងក្នុង និងរូបខាងក្រៅ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតនឹងធ្វើចង្កេះឲ្យញ័រទៅក្នុងអាកាស ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយរាគៈ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយលាមក ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយមូត្រ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយខ្យល់ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយសត្វដង្កូវរមាស់រោល ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតដើម្បីប្រយោជន៍មិនឲ្យមានរោគ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតដើម្បីប្រយោជន៍ឲ្យបានសេចក្តីសុខ។បេ។ ដើម្បីត្រូវការដោយភេសជ្ជៈ ដើម្បីប្រយោជន៍ដល់ទាន ដើម្បីប្រយោជន៍ដល់បុណ្យ ដើម្បីប្រយោជន៍ដល់ការបូជា ដើម្បីប្រយោជន៍ដល់ស្ថានសួគ៌ ដើម្បីប្រយោជន៍ដល់ពូជ ដើម្បីប្រយោជន៍ដល់ការល្បងមើល ដើម្បីប្រយោជន៍ដល់ការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតចំពោះទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតចំពោះទឹកសុក្កពណ៌លឿង ចំពោះទឹកសុក្កពណ៌ក្រហម ចំពោះទឹកសុក្កពណ៌ស ចំពោះទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ចំពោះទឹកសុក្កពណ៌ដូចទឹក ចំពោះទឹកសុក្កពណ៌ដូចប្រេង ចំពោះទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ចំពោះទឹកសុក្កពណ៌ដូចទឹកដោះជូរ ចំពោះទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

បទភាជនីយសុទ្ធិក ចប់។

[៧] ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ និងដើម្បីសេចក្តីសុខ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ និងដើម្បីជាភេសជ្ជ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាទាន។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាបុណ្យ។ ដើម្បីមិនឲ្យមានរោគ

និងដើម្បីជាគ្រឿងយញ្ញ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីស្ថានសួគ៌។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាពូជ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីល្បួងមើល។ ដើម្បីមិនឲ្យមានរោគ និងដើម្បីការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្កមានមូល១ ចប់។

[៨] ភិក្ខុគិតដើម្បីសេចក្តីសុខ និងដើម្បីជាភេសជ្ជៈ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតដើម្បីសេចក្តីសុខ និងដើម្បីជាទាន។ ដើម្បីសេចក្តីសុខ និងដើម្បីជាបុណ្យ។ ដើម្បីសេចក្តីសុខ និងដើម្បីជាគ្រឿងយញ្ញ។ ដើម្បីសេចក្តីសុខ និងដើម្បីស្ថានសួគ៌។ ដើម្បីសេចក្តីសុខ និងដើម្បីជាពូជ។ ដើម្បីសេចក្តីសុខ និងដើម្បីល្បួងមើល។ ដើម្បីសេចក្តីសុខ និងដើម្បីការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតដើម្បីសេចក្តីសុខ និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

[៩] ភិក្ខុគិត ដើម្បីភេសជ្ជៈ និងដើម្បីជាទាន ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត ដើម្បីជាភេសជ្ជៈ និងដើម្បីជាបុណ្យ។ ដើម្បីជាភេសជ្ជៈ និងដើម្បីជាគ្រឿងយញ្ញ។ ដើម្បីជាភេសជ្ជៈ និងដើម្បីស្ថានសួគ៌។ ដើម្បីជាភេសជ្ជៈ និងដើម្បីជាពូជ។ ដើម្បីជាភេសជ្ជៈ និងដើម្បីល្បួងមើល។ ដើម្បីជាភេសជ្ជៈ និងដើម្បីការលេង។ ដើម្បីជាភេសជ្ជៈ និងដើម្បីមិនឲ្យមានរោគ។ ដើម្បីជាភេសជ្ជៈ និងដើម្បីសេចក្តីសុខ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

[១០] ភិក្ខុគិត ដើម្បីជាទាន និងដើម្បីជាបុណ្យ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត ដើម្បីជាទាន និងដើម្បីជាគ្រឿងយញ្ញ។ ដើម្បីជាទាន និងដើម្បីស្ថានសួគ៌។ ដើម្បីជាទាន និងដើម្បីជាពូជ។ ដើម្បីជាទាន និងដើម្បីល្បួងមើល។ ដើម្បីជាទាន និងដើម្បីការលេង។ ដើម្បីជាទាន និងដើម្បីមិនឲ្យមានរោគ។ ដើម្បីជាទាន និងដើម្បីសេចក្តីសុខ។ ដើម្បីជាទាន និងដើម្បីជាភេសជ្ជៈ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

[១១] ភិក្ខុគិត ដើម្បីជាបុណ្យ និងដើម្បីជាគ្រឿងយញ្ញ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត ដើម្បីជាបុណ្យ និងដើម្បីស្ថានសួគ៌។ ដើម្បីជាបុណ្យ និងដើម្បីជាពូជ។ ដើម្បីជាបុណ្យ និងដើម្បីល្បួងមើល។ ដើម្បីជាបុណ្យ និងដើម្បីការលេង។ ដើម្បីជាបុណ្យ និងដើម្បីមិនឲ្យមានរោគ។ ដើម្បីជាបុណ្យ និងដើម្បីសេចក្តីសុខ។ ដើម្បីជាបុណ្យ និងដើម្បីជាភេសជ្ជៈ។ ដើម្បីជាបុណ្យ និងដើម្បីជាទាន ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

[១២] ភិក្ខុគិត ដើម្បីជាគ្រឿងយញ្ញ និងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាពូជ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីល្បួងមើល។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីការលេង។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីមិនឲ្យមានរោគ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីសេចក្តីសុខ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាភេសជ្ជៈ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាទាន។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាបុណ្យ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៣] ភិក្ខុគិត ដើម្បីស្ថានសួគ៌ និងដើម្បីជាពូជ។ ដើម្បីស្ថានសួគ៌ និងដើម្បីល្បួងមើល។ ដើម្បីស្ថានសួគ៌ និងដើម្បីការលេង។ ដើម្បីស្ថានសួគ៌ និងដើម្បីមិនឲ្យមានរោគ។ ដើម្បីស្ថានសួគ៌ និងដើម្បីសេចក្តីសុខ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាភេសជ្ជៈ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាទាន។ ដើម្បីស្ថានសួគ៌ និងដើម្បីជាបុណ្យ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាគ្រឿងយញ្ញ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៤] ភិក្ខុគិត ដើម្បីជាពូជ និងដើម្បីល្បួងមើល។ ដើម្បីជាពូជ និងដើម្បីការលេង។ ដើម្បីជាពូជ និងដើម្បីមិនឲ្យមានរោគ។ ដើម្បីជាពូជ និងដើម្បីសេចក្តីសុខ។ ដើម្បីជាពូជ និងដើម្បីជាភេសជ្ជៈ។ ដើម្បីជាពូជ និងដើម្បីជាទាន។ ដើម្បីជាពូជ និងដើម្បីជាបុណ្យ។ ដើម្បីជាពូជ និងដើម្បីជាគ្រឿងយញ្ញ។ ដើម្បីជាពូជ និងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៥] ភិក្ខុគិត ដើម្បីល្បួងមើល និងដើម្បីការលេង។ ដើម្បីល្បួងមើល និងដើម្បីមិនឲ្យមានរោគ។ ដើម្បីល្បួងមើល និងដើម្បីសេចក្តីសុខ។ ដើម្បីល្បួងមើល និងដើម្បីជាភេសជ្ជៈ។ ដើម្បីល្បួងមើល និងដើម្បីជាទាន។ ដើម្បីល្បួងមើល និងដើម្បីជាបុណ្យ។ ដើម្បីល្បួងមើល និងដើម្បីជាគ្រឿងយញ្ញ។ ដើម្បីល្បួងមើល និងដើម្បីស្ថានសួគ៌។ ដើម្បីល្បួងមើល និងដើម្បីជាពូជ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៦] ភិក្ខុគិត ដើម្បីការលេង និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត ដើម្បីការលេង និងដើម្បីសេចក្តីសុខ។ ដើម្បីការលេង និងដើម្បីជាភេសជ្ជៈ។ ដើម្បីការលេង និងដើម្បីជាទាន។ ដើម្បីការលេង និងដើម្បីជាបុណ្យ។ ដើម្បីការលេង និងដើម្បីជាគ្រឿងយញ្ញ។ ដើម្បីការលេង និងដើម្បីស្ថានសួគ៌។ ដើម្បីការលេង និងដើម្បីជាពូជ។ ដើម្បីការលេង និងដើម្បីល្បួងមើល ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក មានមូលមួយ ចប់។

ឯចក្កមានមូលពីរជាដើម បណ្ឌិតគប្បីនាំមក (សំដែង) ដូចគ្នាផងចុះ។

[១៧] ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីសេចក្តីសុខ និងដើម្បីជាភេសជ្ជៈ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីសេចក្តីសុខ និងដើម្បីការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក មានមូលពីរ។

[១៨] ភិក្ខុគិត ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ និងដើម្បីជាទាន ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ និងដើម្បីការលេង។បេ។ ភិក្ខុគិត ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ ភិក្ខុគិត ដើម្បីល្បងមើល ដើម្បីការលេង និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ ភិក្ខុគិត ដើម្បីល្បងមើល ដើម្បីការលេង និងដើម្បីជាពូជ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កមានមូលពីរ ចប់។

[១៩] ពទ្ធចក្កមានមូល៣ មូល៤ មូល៥ មូល៦ មូល៧ មូល៨ មូល៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះឯង។

នេះចក្កមានមូលគ្រប់ទាំងអស់ (ដូចមានសេចក្តីខាងក្រោយនេះ)។

[២០] ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ ដើម្បីជាពូជ ដើម្បីល្បងមើល និងដើម្បីការលេង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូលគ្រប់ទាំងអស់ ចប់។

[២១] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌លឿង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌ក្រហម។បេ។ ពណ៌ខៀវ និងពណ៌ស។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះជូរឡើងពពុះ។ ពណ៌ខៀវ និងពណ៌ដូចទឹក។ ពណ៌ខៀវ និងពណ៌ដូចប្រេង។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះស្រស់។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះជូរ។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្កមានមូលមួយ ចប់។

[២២] ភិក្ខុគិត បញ្ចេញទឹកសុក្ក ពណ៌លឿង និងពណ៌ក្រហម ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌លឿង និងពណ៌ស។បេ។ ពណ៌លឿង និងពណ៌ដូចទឹកដោះជូរឡើងពពុះ។ ពណ៌លឿង និងពណ៌ដូចទឹក។ ពណ៌លឿង និងពណ៌ដូចប្រេង។ ពណ៌លឿង និងពណ៌ដូចទឹកដោះស្រស់។ ពណ៌លឿង និងពណ៌ដូចទឹកដោះជូរ។ ពណ៌លឿង និងពណ៌ដូចទឹកដោះថ្លា។ ពណ៌លឿង និងពណ៌ខៀវ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ក្រហម និងពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ក្រហម និងពណ៌ដូចទឹកដោះជូរឡើងពពុះ។ ពណ៌ក្រហម និងពណ៌ដូចទឹក។ ពណ៌ក្រហម និងពណ៌ដូចប្រេង។ ពណ៌ក្រហម និងពណ៌ដូចទឹកដោះស្រស់។ ពណ៌ក្រហម និងពណ៌ដូចទឹកដោះជូរ។ ពណ៌ក្រហម និងពណ៌ដូចទឹកដោះថ្លា។ ពណ៌ក្រហម និងពណ៌ខៀវ។ ពណ៌ក្រហម និងពណ៌លឿង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ស និងពណ៌ដូចទឹកដោះជូរឡើងពពុះ។ ពណ៌ស និងពណ៌ដូចទឹក។ ពណ៌ស និងពណ៌ដូចប្រេង។ ពណ៌ស និងពណ៌ដូចទឹកដោះស្រស់។ ពណ៌ស និងពណ៌ដូចទឹកដោះជូរ។ ពណ៌ស និងពណ៌ដូចទឹកដោះថ្លា។ ពណ៌ស និងពណ៌ខៀវ។ ពណ៌ស និងពណ៌លឿង។ ពណ៌ស និងពណ៌ក្រហម ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹក។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចប្រេង។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹកដោះស្រស់។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹកដោះជូរ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹកដោះថ្លា។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ខៀវ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌លឿង។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ក្រហម។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹក និងពណ៌ដូចប្រេង។ ពណ៌ដូចទឹក និងពណ៌ដូចទឹកដោះស្រស់។ ពណ៌ដូចទឹក និងពណ៌ដូចទឹកដោះជូរ។ ពណ៌ដូចទឹក និងពណ៌ដូចទឹកដោះថ្លា។ ពណ៌ដូចទឹក និងពណ៌ខៀវ។ ពណ៌ដូចទឹក និងពណ៌លឿង។ ពណ៌ដូចទឹក និងពណ៌ក្រហម។ ពណ៌ដូចទឹក និងពណ៌ស។ ពណ៌ដូចទឹក និងពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះស្រស់។ ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះជូរ។ ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះថ្លា។ ពណ៌ដូចប្រេង និងពណ៌ខៀវ។ ពណ៌ដូចប្រេង និងពណ៌លឿង។ ពណ៌ដូចប្រេង និងពណ៌ក្រហម។ ពណ៌ដូចប្រេង និងពណ៌ស។ ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះជូរឡើងពពុះ។ ពណ៌ដូចប្រេង និងពណ៌ដូចទឹក ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះជូរ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះថ្លា។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ខៀវ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌លឿង។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ក្រហម។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ស។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះជូរឡើងពពុះ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹក។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចប្រេង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះថ្លា។ ពណ៌ដូចទឹកដោះជូរ និងពណ៌ខៀវ។ ពណ៌ដូចទឹកដោះជូរ និងពណ៌លឿង។ ពណ៌ដូចទឹកដោះជូរ និងពណ៌ក្រហម។ ពណ៌ដូចទឹកដោះជូរ និងពណ៌ស។ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះជូរឡើងពពុះ។ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹក។ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចប្រេង។ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា និងពណ៌ខៀវ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា និងពណ៌លឿង។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ក្រហម។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ស។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូច

ទឹកដោះជូរឡើងពពុះ។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹក។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចប្រេង។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹកដោះស្រស់។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កមានមូលមួយ ចប់។

ឯចក្កមានមូលពីរ ជាដើម បណ្ឌិតគប្បីនាំមក (សំដែង) ដូចគ្នាផងចុះ។

[២៣] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង និងពណ៌ក្រហម ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង និងពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង និងពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្កមានមូលពីរ ចប់។

[២៤] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌លឿង ពណ៌ក្រហម និងពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌លឿង ពណ៌ក្រហម និងពណ៌ខៀវ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា និងពណ៌ខៀវ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កមានមូលពីរ ចប់។

[២៥] ចក្កមានមូល៣ មូល៤ មូល៥ មូល៦ មូល៧ មូល៨ មូល៩ បណ្ឌិតគប្បីធ្វើយ៉ាងនោះផងចុះ។

នេះចក្កមានមូលគ្រប់ទាំងអស់ (ដូចមានសេចក្តីខាងក្រោយនេះ)។

[២៦] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូលគ្រប់ទាំងអស់ ចប់។

[២៧] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវតែម្យ៉ាង ដើម្បីមិនឲ្យមានរោគតែម្យ៉ាង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌លឿង ដើម្បីមិនឲ្យមានរោគ និងដើម្បីឲ្យស្រួលខ្លួន ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង និងពណ៌ក្រហម ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន និងដើម្បីជាភេសជ្ជៈ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម និងពណ៌ស ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ និងដើម្បីជាទាន ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស និងពណ៌ដូចទឹកដោះជូរឡើងពពុះ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន និងដើម្បីជាបុណ្យ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹក ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ និងដើម្បីជាគ្រឿងបូជា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក និងពណ៌ដូចប្រេង ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា និងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះស្រស់ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ និងដើម្បីជាពូជ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះជូរ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ ដើម្បីជាពូជ និងដើម្បីល្បងមើល ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះថ្លា ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ ដើម្បីជាពូជ ដើម្បីល្បងមើល និងដើម្បីការលេង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។

ឧភតោពទ្ធមិស្សកចក្ក ចប់។

[២៨] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹង

បញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចប្រេងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[២៩] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌សឃ្លាតចេញវិញ។បេ។ (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ។ ពណ៌ដូចទឹកឃ្លាតចេញវិញ។ ពណ៌ដូចប្រេងឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ។ ពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

[៣០] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ។បេ។ (បែរជា) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញវិញ។ ពណ៌ដូចប្រេងឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ។ ពណ៌ខៀវឃ្លាតចេញវិញ។ ពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ (បែរជា) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ (ចក្កទាំងឡាយ បណ្ឌិតគប្បីដឹងដោយអាការយ៉ាងនេះ) ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ។បេ។ (បែរជា) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ។ ពណ៌សឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ។ ពណ៌ដូចទឹកឃ្លាតចេញវិញ។ ពណ៌ដូចប្រេងឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ។ ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

កុច្ឆិចក្ក ចប់។

[៣១] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹក ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចប្រេង ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ១ ចប់។

[៣២] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ២ ចប់។

[៣៣] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ៣ ចប់។

[៣៤] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ៤ ចប់។

[៣៥] ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹក ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង។ ពណ៌ក្រហម។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ៥ ចប់។

[៣៦] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចប្រេង ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ៦ ចប់។

[៣៧] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចប្រេងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹក ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចប្រេងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ៧ ចប់។

[៣៨] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចប្រេង ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ៨ ចប់។

[៣៩] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ៩ ចប់។

[៤០] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។ ទឹកសុក្កពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស។

ដំណើរនៃបិដ្ឋិចក្កទី ១០ ចប់។

បិដ្ឋិចក្ក ចប់ហើយ។

[៤១] ភិក្ខុគិត ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុគិត ក៏ព្យាយាម (ប៉ុន្តែ) ទឹកសុក្កមិនឃ្លាតចេញ ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុគិត (តែ) មិនព្យាយាម (ក៏ស្រាប់តែ) ទឹកសុក្កឃ្លាតចេញឯង មិនត្រូវអាបត្តិឡើយ។ ភិក្ខុគិត (តែ) មិនព្យាយាម ទឹកសុក្កក៏មិនឃ្លាតចេញ មិនត្រូវអាបត្តិឡើយ។ ភិក្ខុមិនគិតទេ (តែ) ព្យាយាម ទឹកសុក្កឃ្លាតចេញ មិនត្រូវអាបត្តិឡើយ។ ភិក្ខុមិនគិតទេ (តែ) ព្យាយាម ទឹកសុក្កមិនឃ្លាតចេញ មិនត្រូវអាបត្តិឡើយ។ ភិក្ខុមិនគិត មិនព្យាយាម (តែ) ទឹកសុក្កឃ្លាតចេញ មិនត្រូវអាបត្តិឡើយ។ ភិក្ខុមិនគិត មិនព្យាយាម ទឹកសុក្កក៏មិនឃ្លាតចេញ មិនត្រូវអាបត្តិឡើយ។

[៤២] (ភិក្ខុ ៦ពួក) គឺ ភិក្ខុយល់សប្តិ១ ភិក្ខុមិនមានបំណងឲ្យទឹកសុក្កឃ្លាតចេញ១ ភិក្ខុឆ្កួត១ ភិក្ខុមានចិត្តរវើរវាយ១ ភិក្ខុដែលទុក្ខវេទនាគ្របសង្កត់១ ភិក្ខុជាអាទិកម្មិក (អ្នកធ្វើខុសមុនបញ្ញត្តិ)១ មិនត្រូវអាបត្តិឡើយ។

## (វិនីតវត្ថុឧទ្ទានគាថា)

CS vin.vbu.sg.01.01 | ភាគ ទី២

### (វិនីតវត្ថុឧទ្ទានគាថា)

[៤៣] (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសំដែងតទៅដូចមានខាងក្រោយនេះ)

រឿង ភិក្ខុយល់សប្តិ១ (§៤៤) ភិក្ខុបន្ទោបង់ឧច្ចារ១ (§៤៥) ភិក្ខុបន្ទោបង់បស្សាវ១ (§៤៦) ភិក្ខុត្រិះរិះចំពោះកាមវិតក្ក១ (§៤៧) ភិក្ខុងូតទឹកក្តៅ១ (§៤៨) ភិក្ខុលាបថ្នាំ១ (§៤៩) ភិក្ខុអេះរមាស់ត្រង់អណ្ឌ១ (§៥០) ភិក្ខុដើរតាមផ្លូវ១ (§៥១) ភិក្ខុកាន់ស្បែកចុងអង្គជាត១ (§៥២) ភិក្ខុកំដៅដម្បារពោះក្នុងរោងភ្លើង១ (§៥៣, §៥៤) ភិក្ខុដដុសអង្គជាតនឹងភ្លៅ១ (§៥៥) ភិក្ខុឲ្យសាមណេរកាន់អង្គជាត១ (§៥៦) ភិក្ខុចាប់អង្គជាតសាមណេរកំពុងដេកលក់១ (§៥៧) ភិក្ខុគៀបអង្គជាតនឹងភ្លៅទាំងពីរ១ (§៥៨) ភិក្ខុក្តាប់អង្គជាតនឹងដៃ១ (§៥៩) ភិក្ខុពើងចង្កេះឰដ៏អាកាស១ (§៦០) ភិក្ខុមិតពត់កាយ១ (§៦១) ភិក្ខុសំឡឹងមើលអង្គជាតមាតុគ្រាម១ (§៦២) ភិក្ខុបញ្ចូលអង្គជាតក្នុងប្រហោងដាន១[4] (§៦៣) ភិក្ខុដដុសអង្គជាតនឹងកំណាត់ឈើ១ (§៦៤) ភិក្ខុងូតទឹកក្នុងទីច្រាសខ្សែទឹក១ (§៦៥) ភិក្ខុលេងទឹកដែលមានល្បាប់១ (§៦៦) ភិក្ខុស្ទុះចុះទៅក្នុងទឹក១ (§៦៧) ភិក្ខុលេងកងធ្វើដោយផ្កា១ (§៦៨) ភិក្ខុស្ទុះចូលទៅក្នុងព្រៃឈូក១ (§៦៩) ភិក្ខុបញ្ចូលអង្គជាតក្នុងដីខ្សាច់១ (§៧០) ភិក្ខុបញ្ចូលអង្គជាតក្នុងភក់១ (§៧១) ភិក្ខុស្រោចអង្គជាតនឹងទឹក១ (§៧២) ភិក្ខុផ្ទាប់អង្គជាតនឹងកន្លែងដេក១ (§៧៣) ភិក្ខុដដុសអង្គជាតនឹងមេដើង១ (§៧៤)។

## (វិនីតវត្ថុ)

CS vin.vbu.sg.01.02 | ភាគ ទី២

### (វិនីតវត្ថុ)

[៤៤] សម័យនោះឯង ភិក្ខុ១រូប កំពុងយល់សប្តិ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយដឹង។ ទើបភិក្ខុនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិព្រោះយល់សប្តិទេ។

[៤៥] សម័យនោះឯង ភិក្ខុ១រូប កំពុងបន្ទោបង់ឧច្ចារ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយដឹង។ ភិក្ខុនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានប្រាថ្នាឲ្យអសុចិឃ្លាតចេញ (នោះ)ទេ។

[៤៦] សម័យនោះឯង ភិក្ខុមួយរូប កំពុងបន្ទោបង់បស្សាវ អសុចិក៏ឃ្លាតចេញ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានប្រាថ្នាឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។

[៤៧] សម័យនោះឯង ភិក្ខុមួយរូប កំពុងត្រិះរិះចំពោះកាមវិតក្ក អសុចិក៏ឃ្លាតចេញ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលត្រិះរិះចំពោះកាមវិតក្កទេ។

[៤៨] សម័យនោះឯង ភិក្ខុមួយរូប កំពុងងូតទឹកក្តៅ អសុចិក៏ឃ្លាតចេញ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងឲ្យអសុចិឃ្លាតចេញទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងនឹងឲ្យអសុចិឃ្លាតចេញ កំពុងតែងូតទឹកក្តៅ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងនឹងឲ្យអសុចិឃ្លាតចេញ កំពុងងូតទឹកក្តៅដែរ (តែ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៤៩] សម័យនោះឯង ភិក្ខុមួយរូប កើតដម្បៅត្រង់អង្គជាត។ កាលដែលភិក្ខុនោះលាបថ្នាំដម្បៅ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គនឹងមានបំណងចង់ឲ្យអសុចិឃ្លាតចេញក៏ទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប កើតដម្បៅត្រង់អង្គជាត។ ភិក្ខុនោះមានបំណងនឹងឲ្យអសុចិឃ្លាតចេញ កាលដែលលាបថ្នាំដម្បៅ អសុចិ[5] ក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៥០] សម័យនោះឯង ភិក្ខុមួយរូប អេះត្រង់អណ្ឌ[6] អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ហើយអេះអណ្ឌ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៥១] សម័យនោះឯង ភិក្ខុមួយរូប កំពុងដើរទៅតាមផ្លូវ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ កំពុងដើរទៅតាមផ្លូវ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៥២] សម័យនោះឯង ភិក្ខុមួយរូប កំពុងកាន់ស្បែកខាងចុងនៃអង្គជាតធ្វើបស្សាវ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិ

ឃ្លាតចេញ កំពុងចាប់ស្បែកខាងចុងនៃអង្គជាតធ្វើបស្សាវ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៥៣] សម័យនោះឯង ភិក្ខុមួយរូប កំពុងកំដៅដំបារពោះក្នុងរោងភ្លើង អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ កំពុងកំដៅដំបារពោះក្នុងរោងភ្លើង អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៥៤] សម័យនោះឯង ភិក្ខុមួយរូប កំពុងគក់ច្របាច់ខ្នងឲ្យឧបជ្ឈាយ៍ក្នុងរោងភ្លើង អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ កំពុងគក់ច្របាច់ខ្នងឲ្យឧបជ្ឈាយ៍ក្នុងរោងភ្លើង អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៥៥] សម័យនោះឯង ភិក្ខុមួយរូប យកអង្គជាតដដុសនឹងភ្លៅ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ក៏យកអង្គជាតដដុសនឹងភ្លៅ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៥៦] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ បានពោលពាក្យនេះនឹងសាមណេរមួយរូបថា នែអាវុសោសាមណេរ អ្នកចូរមកនេះ ចូរកាន់អង្គជាតអញចុះ។ សាមណេរនោះ បានកាន់អង្គជាតភិក្ខុនោះ។ អសុចិរបស់ភិក្ខុនោះក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។

[៥៧] សម័យនោះឯង ភិក្ខុមួយរូប បានចាប់អង្គជាតសាមណេរដែលកំពុងដេកលក់។ អសុចិភិក្ខុនោះក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៥៨] សម័យនោះឯង ភិក្ខុមួយរូប តៀ្បតនូវអង្គជាតដោយភ្លៅទាំងពីរ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ តៀ្បតនូវអង្គជាតដោយភ្លៅទាំងពីរ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៥៩] សម័យនោះឯង ភិក្ខុមួយរូប ក្តាប់អង្គជាតដោយកណ្តាប់ដៃ អសុចិឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ក្តាប់អង្គជាតដោយកណ្តាប់ដៃ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦០] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ប្រឹងបំពើងចង្កេះឰដ៏អាកាស អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦១] សម័យនោះឯង ភិក្ខុមួយរូប ប្រឹងមឹតពត់កាយ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ប្រឹងមឹតពត់កាយ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦២] សម័យនោះឯង ភិក្ខុមួយរូប ត្រេកអរ សំឡឹងមើលអង្គជាតមាតុគ្រាម។ អសុចិភិក្ខុនោះក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ម្នាលភិក្ខុទាំងឡាយ តែថាភិក្ខុមិនគួរត្រេកអរ សំឡឹងមើលអង្គជាតមាតុគ្រាមឡើយ ភិក្ខុណាសំឡឹងមើល ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

[៦៣] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ក៏បញ្ចូលអង្គជាតទៅនឹងប្រហោងដាន អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦៤] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដដុសអង្គជាតនឹងកំណាត់ឈើ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦៥] សម័យនោះឯង ភិក្ខុមួយរូប ងូតទឹកក្នុងទីច្រាសខ្សែទឹក អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ងូតទឹកក្នុងទីច្រាសខ្សែទឹក អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦៦] សម័យនោះឯង ភិក្ខុមួយរូប លេងទឹកដែលមានល្បាប់ អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ លេងទឹកដែលមានល្បាប់ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦៧] សម័យនោះឯង ភិក្ខុមួយរូប ស្ទុះចុះទៅក្នុងទឹក អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ស្ទុះចុះទៅក្នុងទឹក អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦៨] សម័យនោះឯង ភិក្ខុមួយរូប លេងកងផ្កា អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ លេងកងធ្វើដោយផ្កា អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៦៩] សម័យនោះឯង ភិក្ខុមួយរូប ស្ទុះចូលទៅក្នុងព្រៃឈូក អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ស្ទុះចូលទៅក្នុងព្រៃឈូក អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៧០] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដាក់បញ្ចូលអង្គជាតទៅក្នុងដីខ្សាច់ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៧១] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដាក់បញ្ចូលអង្គជាតទៅក្នុងភក់ អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៧២] សម័យនោះឯង ភិក្ខុមួយរូប ស្រោចអង្គជាតដោយទឹក អសុចិក៏ឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ស្រោចអង្គជាតដោយទឹក អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៧៣] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ផ្ទប់អង្គជាតលើទីដេក អសុចិក៏ឃ្លាតចេញ។បេ។ (មានភិក្ខុខ្លះ) អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៧៤] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដដុសអង្គជាតនឹងមេជើង អសុចិក៏ឃ្លាតចេញ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង។ ក៏ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដដុសអង្គជាតនឹងមេជើង អសុចិមិនឃ្លាតចេញ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង។ ក៏ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

សង្ឃាទិសេស ទី១ ចប់។

# សង្ឃាទិសេស ទី២

CS vin.vbu.sg.02 | ភាគ ទី២

### (២. កាយសំសគ្គសិក្ខាបទំ)

[៧៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុ សម្រេចឥរិយាបថនៅក្នុងព្រៃ។ លំនៅឧទាយិភិក្ខុដ៏មានអាយុនោះ ល្អគួរឲ្យចង់មើល គួរឲ្យជ្រះថ្លា មានបន្ទប់ខាងក្នុង មានរបៀងជុំវិញ គ្រែ តាំង ពូក ខ្នើយ ក៏រៀបចំល្អ ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ក៏ដម្កល់ទុកស្រួល ទាំងទីបរិវេណសោតក៏បោសរលីងស្អាត។ មានមនុស្សជាច្រើននាក់ ដែលត្រូវការមើលលំនៅរបស់ឧទាយិភិក្ខុដ៏មានអាយុ ក៏តែងតែមកមើល។ (កាលនោះ) មានព្រាហ្មណ៍ម្នាក់នាំប្រពន្ធចូលទៅរកឧទាយិភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងឧទាយិដ៏មានអាយុថា យើងខ្ញុំចង់មើលលំនៅរបស់លោកម្ចាស់ឧទាយិ។ ឧទាយិក៏និយាយតបថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរមើលចុះ (ថាហើយ) ក៏កាន់កូនសោរ ដក់គន្លឹះហើយច្រានសន្ទះទ្វារ ចូលទៅកាន់កុដិលំនៅ។ ឯព្រាហ្មណ៍នោះឯង ក៏ដើរចូលទៅតាមក្រោយឧទាយិដ៏មានអាយុទៅ។ ចំណែកខាងនាងព្រាហ្មណីនោះឯង ក៏ដើរចូលតាមក្រោយព្រាហ្មណ៍នោះទៅ។ គ្រានោះឯង ឧទាយិដ៏មានអាយុ ក៏បើកបង្អួចកន្លែងខ្លះ បិទបង្អួចកន្លែងខ្លះ ដើរក្រឡឹងតាមបន្ទប់ហើយ មកពីក្រោយខ្នងហើយក៏ស្ទាបអង្អែលអវយវតូចធំនៃនាងព្រាហ្មណីនោះ។ គ្រានោះឯង ព្រាហ្មណ៍នោះនិយាយរួសរាយជាមួយនឹងឧទាយិដ៏មានអាយុ ហើយក៏លា

ទៅ។ លំដាប់តមក ព្រាហ្មណ៍នោះពេញចិត្ត ក៏បញ្ចេញវាចាតាមសេចក្តីពេញចិត្តថា ពួកសមណដែលនៅក្នុងព្រៃមានសភាពយ៉ាងនេះ សុទ្ធសឹងតែពួកសមណ ជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រថ្លៃថ្នូរណាស់ លោកឧទាយិដែលនៅក្នុងព្រៃ មានសភាពយ៉ាងនេះ លោកឧទាយិដ៏ចំរើននុ៎ះក៏ថ្លៃថ្នូរដែរ។ កាលបើព្រាហ្មណ៍ពោលពាក្យសរសើរយ៉ាងនេះហើយ នាងព្រាហ្មណីនោះបានពោលពាក្យនេះនឹងព្រាហ្មណ៍នោះថា សេចក្តីថ្លៃថ្នូររបស់លោកឧទាយិនោះមានពីណា (ឥតមានថ្លៃថ្នូរអ្វីទេ) ខ្លួនអ្នកស្ទាបអង្អែលអវយវតូចធំរបស់ខ្ញុំយ៉ាងណា សមណឈ្មោះឧទាយិ ក៏ស្ទាបអង្អែលអវយវតូចធំរបស់ខ្ញុំយ៉ាងនោះដែរ។ គ្រានោះឯង ព្រាហ្មណ៍នោះ ក៏និយាយពោលទោស ដៀលត្មះថា សមណជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រពួកនេះមិនមានខ្មាស ជាមនុស្សទ្រុស្តសីល តែងពោលពាក្យមុសា ព្រោះសមណអម្បាលនេះ ប្តេជ្ញាខ្លួនថា យើងសុទ្ធតែជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តព្រហ្មចារ្យ ពោលតែពាក្យសត្យ ជាអ្នកមានសីល មានធម៌ល្អ (ឥឡូវនេះ) សាមញ្ញគុណរបស់សមណពួកនេះមិនមានទេ ព្រហ្មញ្ញគុណរបស់សមណពួកនេះមិនមានទេ សាមញ្ញគុណរបស់សមណពួកនេះវិនាសហើយ ព្រហ្មញ្ញគុណរបស់សមណពួកនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណពួកនេះមានពីណា ព្រហ្មញ្ញគុណរបស់សមណពួកនេះមានពីណា សមណពួកនេះឃ្លាតផុតចាកសាមញ្ញគុណអស់ហើយ សមណពួកនេះឃ្លាតផុតចាកព្រហ្មញ្ញគុណអស់ហើយ ដូចយ៉ាង សមណឈ្មោះឧទាយិ ហ៊ានស្ទាបអង្អែលអវយវតូចធំរបស់ភរិយាអញទៅហើយ ពួកស្ត្រីក្នុងត្រកូល[7]) ធីតារបស់ត្រកូល កុមារីរបស់ត្រកូល ស្ត្រីជាកូនប្រសាររបស់ត្រកូល ទាសីរបស់ត្រកូលទាំងឡាយ ម្តេចនឹងហ៊ានទៅកាន់អារាម ឬវិហារបាន ព្រោះថា បើពួកស្ត្រីក្នុងត្រកូល ធីតារបស់ត្រកូល កុមារីរបស់ត្រកូល ស្ត្រីជាកូនប្រសាររបស់ត្រកូល ទាសីរបស់ត្រកូលទាំងឡាយខំទៅកាន់អារាម ឬវិហារ មុខជាសមណទាំងឡាយជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រនឹងប្រទុស្តចំពោះស្ត្រីទាំងអម្បាលនោះមិនខាន។ ភិក្ខុទាំងឡាយ ក៏បានឮពាក្យដែលព្រាហ្មណ៍ពោលទោស ដៀលត្មះនិយាយដើម (នោះ)។ ភិក្ខុទាំងឡាយឯណា ដែលមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្តីអៀនខ្មាសក្រែងរអែងបាប ពេញចិត្តនឹងការសិក្សា ភិក្ខុអម្បាលនោះ ក៏ពោលទោស ត្មះតិះដៀលថា ភិក្ខុឈ្មោះឧទាយិដ៏មានអាយុមិនសមបីបើនឹងហ៊ានដល់ស្ទាបអង្អែលកាយមាតុគ្រាមសោះ។ ទើបភិក្ខុអម្បាលនោះក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រោះហេតុដំណើរនុ៎ះ ទើបព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះឧទាយិភិក្ខុដ៏មានអាយុថា ម្នាលឧទាយិ ឮថាអ្នកឯងស្ទាបអង្អែលកាយមាតុគ្រាមមែនឬ។ ឧទាយិក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ (ដំណើរនុ៎ះ) ពិតមែន។ ព្រះពុទ្ធដ៏មានជោគទ្រង់ត្មះតិះដៀលថា ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនជារបស់សមណ មិនគប្បីសោះ មិនគួរធ្វើសោះ នែមោឃបុរស មិនគួរបើអ្នកឯងនឹងហ៊ានដល់ស្ទាបអង្អែលកាយមាតុគ្រាមសោះ នែមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយបរិយាយដ៏ច្រើន (សុទ្ធតែ) ដើម្បីប្រាសចាកតម្រេក មិនមែនដើម្បីប្រកបដោយតម្រេកឡើយ មិនមែនឬ។បេ។ ដំណើរស្ងប់រម្ងាប់នៃសេចក្តីក្តៅក្រហាយព្រោះកាមទាំងឡាយ តថាគតក៏បានសំដែងហើយ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ក៏អ្នកទាំងឡាយត្រូវសំដែងសិក្ខាបទនេះឡើងយ៉ាងនេះថា

**ភិក្ខុណាមួយគឺកាមរាគគ្របសង្កត់ហើយ មានចិត្តប្រែប្រួលហើយ ដល់ព្រមនូវកាយសំសគ្គមួយអន្លើដោយមាតុគ្រាម ទោះចាប់ដៃក្តី ចាប់ផ្នួងសក់ក្តី ឬស្ទាបអង្អែលអវយវត្រង់ណាៗក្តី ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស។**

[៧៦] ត្រង់ពាក្យថា ណាមួយ សេចក្តីថា ឯណា គឺថា ដូចជាឯណា។បេ។ ត្រង់ពាក្យថា ភិក្ខុ។បេ។ ភិក្ខុដែលបានសម្រេចឧបសម្បទាដោយញត្តិចតុត្ថកម្មវាចាដ៏ត្រឹមត្រូវ តថាគតសំដៅយកឲ្យឈ្មោះថាភិក្ខុ ក្នុងអត្ថនេះ។ ភិក្ខុដែលត្រេកអរ មានសេចក្តីអាឡោះអាល័យ មានចិត្តប្រតិព័ទ្ធ ហៅថា (ភិក្ខុ) គឺកាមរាគគ្របសង្កត់ហើយ។ ត្រង់ពាក្យថា ប្រែប្រួលហើយ សេចក្តីថា ចិត្តដែលត្រេកអរក៏ហៅថា ប្រែប្រួលហើយ ចិត្តដែលខឹង ក៏ហៅថាប្រែប្រួលហើយ ចិត្តដែលវង្វេង ក៏ហៅថាប្រែប្រួលហើយ ប៉ុន្តែក្នុងអត្ថនេះ តថាគតសំដៅយកចិត្តដែលត្រេកអរ ឲ្យឈ្មោះថា ចិត្តប្រែប្រួលហើយ។ មនុស្សស្រី ហៅថា មាតុគ្រាម ឯយក្សស្រី ប្រេតស្រី សត្វតិរច្ឆានញី មិនហៅថា មាតុគ្រាមទេ (ក្នុងសិក្ខាបទនេះ) ដោយហោចទៅ ទោះក្មេងស្រីសូម្បីកើតក្នុងថ្ងៃនោះ ក៏ហៅថា មាតុគ្រាមដែរ មិនបាច់ពោលដល់ស្ត្រីដែលធំជាងនោះទេ។ ត្រង់ពាក្យថា មួយអន្លើ គឺជាមួយគ្នា។ សេចក្តីប្រព្រឹត្តល្មើស តថាគតហៅថា គប្បីដល់ព្រមដោយកាយសំសគ្គ។ សរីរប្រទេសរាប់តាំងពីត្រឹមជុំដៃដរាបដល់ចុងក្រចក ហៅថាដៃ។ សក់សុទ្ធក្តី សក់លាយដោយអម្បោះក្តី លាយដោយផ្កាកម្រងក្តី លាយដោយប្រាក់ក្តី លាយដោយមាសក្តី លាយដោយកែវមុក្តាក្តី លាយដោយកែវមណីក្តី ហៅថាផ្នួងសក់។ ត្រង់ពាក្យថាអវយវ (នោះ) គឺ សរីរដ៏សេស លើកលែងតែដៃ និងផ្នួងសក់ចេញ ហៅថា អវយវ។

[៧៧] (ប្រភេទ១២យ៉ាង) គឺ កិរិយាស្ទាប អង្អែល ស្ទាប់ចុះ ស្ទាបឡើង ផ្ទុបចុះ ផ្ងើយឡើង ទាញមក ទាញត្រឡប់ ចាប់សង្កត់ ចាប់ឈ្លេច កាន់ ពាល់។

[៧៨] កិរិយាគ្រាន់តែលូកពាល់ ហៅថា ស្ទាប។ កិរិយាស្ទាបបន្លើរពីខាងនេះខាងនោះ ហៅថា អង្អែល។ កិរិយាពាល់ចុះក្រោម ហៅថា ស្ទាបចុះ។ កិរិយាពាល់ខាងលើ ហៅថា ស្ទាបឡើង។ កិរិយាចាប់បន្ទន់ទៅក្រោម ហៅថា ផ្ទុបចុះ។ កិរិយាចាប់ផ្ងារទៅខាងលើ ហៅថា ផ្ងើយឡើង។ កិរិយាទាញចូលមក ហៅថា ទាញមក។ កិរិយាបង្អោនត្រឡប់ (ទាញពីក្រោយ) ហៅថា ទាញត្រឡប់។ កិរិយាចាប់អវយវហើយច្របាច់ឈ្លេច ហៅថា ចាប់សង្កត់។ កិរិយាតៀ្បត គាបដោយអវយវណានីមួយ ហៅថា ចាប់ឈ្លេច។ កិរិយាគ្រាន់តែចាប់ ហៅថាកាន់។ កិរិយាប៉ះត្រូវ ហៅថា ពាល់។

[៧៩] ត្រង់ពាក្យថា សង្ឃាទិសេស (សេចក្តីក្នុងបេយ្យាល មានអធិប្បាយក្នុងសង្ឃាទិសេសទី១ រួចហើយ)។

[៨០] មនុស្សស្រីពិត ភិក្ខុសំគាល់ថាជាស្រី មានសេចក្តីត្រេកអរ ក៏យកកាយ (ខ្លួន) ស្ទាប អង្អែល ស្ទាបចុះ ស្ទាបឡើង ផ្ទុបចុះ ផ្ងើយឡើង ទាញមក ទាញត្រឡប់ ចាប់សង្កត់ ចាប់ឈ្លេច កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិសង្ឃាទិសេស។ មនុស្សស្រីពិត តែភិក្ខុមានសេចក្តីសង្ស័យ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ។ មនុស្សស្រីពិត ភិក្ខុសំគាល់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ។ មនុស្សស្រីពិត តែភិក្ខុសំគាល់ថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ។ មនុស្សស្រីពិត តែភិក្ខុសំគាល់ថាសត្វតិរច្ឆាន ត្រេកអរ ក៏យកកាយស្ទាប អង្អែល។

បេ។ កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ។ មនុស្សខ្ទើយពិត ភិក្ខុក៏សំគាល់ថាជាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សខ្ទើយនោះ ត្រូវអាបត្តិថុល្លច្ច័យ។ មនុស្សខ្ទើយពិត តែភិក្ខុសង្ស័យ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សខ្ទើយនោះ ត្រូវអាបត្តិទុក្កដ។ មនុស្សខ្ទើយពិត តែភិក្ខុសំគាល់ថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សខ្ទើយនោះ ត្រូវអាបត្តិទុក្កដ។ មនុស្សខ្ទើយពិត តែភិក្ខុសំគាល់ថាសត្វតិរច្ឆាន ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សខ្ទើយនោះ ត្រូវអាបត្តិទុក្កដ។ មនុស្សខ្ទើយពិត តែភិក្ខុសំគាល់ថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សខ្ទើយនោះ ត្រូវអាបត្តិទុក្កដ។ មនុស្សប្រុសពិត ភិក្ខុសំគាល់ថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ។ មនុស្សប្រុសពិត តែភិក្ខុសង្ស័យ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ។ មនុស្សប្រុសពិត តែភិក្ខុសំគាល់ថាសត្វតិរច្ឆាន ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ។ មនុស្សប្រុសពិត តែភិក្ខុសំគាល់ថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ។ មនុស្សប្រុសពិត តែភិក្ខុសំគាល់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ។ សត្វតិរច្ឆានឈ្មោលពិត ភិក្ខុសំគាល់ថាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ។ សត្វតិរច្ឆានឈ្មោលពិត តែភិក្ខុសង្ស័យ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ។ សត្វតិរច្ឆានឈ្មោលពិត តែភិក្ខុសំគាល់ថាមនុស្សស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆានឈ្មោលនោះ ត្រូវអាបត្តិទុក្កដ។ សត្វតិរច្ឆានឈ្មោលពិត តែភិក្ខុសំគាល់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆានឈ្មោលនោះ ត្រូវអាបត្តិទុក្កដ។ សត្វតិរច្ឆានឈ្មោលពិត តែភិក្ខុសំគាល់ថាមនុស្សប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ។

[៨១] ស្រីពីរនាក់ ភិក្ខុសំគាល់ថាជាស្រីទាំងពីរនាក់ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេសពីរ។ ស្រីពីរនាក់ ភិក្ខុសង្ស័យនឹងស្រីទាំងពីរនាក់ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាខ្ទើយ។បេ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាប្រុស។បេ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសំគាល់មនុស្សខ្ទើយទាំងពីរនាក់ថាខ្ទើយ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយខ្ទើយទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសង្ស័យមនុស្សខ្ទើយទាំងពីរនាក់។បេ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសំគាល់មនុស្សខ្ទើយទាំងពីរនាក់ថាប្រុស។បេ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសំគាល់មនុស្សខ្ទើយទាំងពីរនាក់ថាសត្វតិរច្ឆានឈ្មោល។បេ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសំគាល់មនុស្សខ្ទើយទាំងពីរនាក់ថាស្រី ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយខ្ទើយទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ មនុស្សប្រុសពីរនាក់ ភិក្ខុសំគាល់ប្រុសទាំងពីរនាក់ថាជាប្រុស ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយប្រុសទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ ប្រុសពីរនាក់ ភិក្ខុសង្ស័យប្រុសទាំងពីរនាក់។បេ។ ប្រុសពីរនាក់ ភិក្ខុសំគាល់ប្រុសទាំងពីរនាក់ថាសត្វតិរច្ឆានឈ្មោល។បេ។ ប្រុសពីរនាក់ ភិក្ខុសំគាល់ប្រុសទាំងពីរនាក់ថាជាស្រី។បេ។ ប្រុសពីរនាក់ ភិក្ខុសំគាល់ប្រុសទាំងពីរនាក់ថាជាខ្ទើយ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយប្រុសពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសំគាល់សត្វតិរច្ឆានឈ្មោលទាំងពីរថាជាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆានឈ្មោលទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសង្ស័យនឹងសត្វតិរច្ឆានទាំងពីរ។បេ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសំគាល់សត្វតិរច្ឆានឈ្មោលទាំងពីរថាមនុស្សស្រី។បេ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសំគាល់សត្វតិរច្ឆានឈ្មោលទាំងពីរថាខ្ទើយ។បេ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសំគាល់សត្វតិរច្ឆានឈ្មោលទាំងពីរថាមនុស្សប្រុស ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆានឈ្មោលទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។

[៨២] ស្រីនិងខ្ទើយ ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាស្រី ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយជនទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេសនិងទុក្កដ។ ស្រីនិងខ្ទើយ ភិក្ខុសង្ស័យនឹងមនុស្សទាំងពីរនាក់ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យនិងទុក្កដ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាខ្ទើយ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាប្រុស ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យនិងទុក្កដ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យនិងទុក្កដ។ ស្រីនិងប្រុស ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាស្រី ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ។ ស្រីនិងប្រុស ភិក្ខុសង្ស័យនឹងមនុស្សទាំងពីរនាក់ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រីនិងប្រុស ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រីនិងប្រុស ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រីនិងប្រុស ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រីនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់មនុស្សស្រី និងសត្វតិរច្ឆានទាំងពីរថាមនុស្សស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រី និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ។ ស្រី និងតិរច្ឆានឈ្មោល ភិក្ខុសង្ស័យស្រីនិងតិរច្ឆានទាំងពីរ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រី និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រី និងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ស្រីនិងតិរច្ឆានទាំងពីរថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រី និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រី និងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ស្រីនិងសត្វតិរច្ឆានទាំងពីរថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រី និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រី និងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ស្រីនិងសត្វតិរច្ឆានទាំងពីរថាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយស្រី និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ មនុស្សខ្ទើយ និងប្រុស ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ មនុស្សខ្ទើយ និងប្រុស ភិក្ខុសង្ស័យនឹងមនុស្សទាំងពីរនាក់។បេ។ ត្រូវអាបត្តិទុក្កដពីរ។ មនុស្សខ្ទើយ

និងប្រុស ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាប្រុស។បេ។ មនុស្សខ្ទើយ នឹងប្រុស ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាសត្វតិរច្ឆានឈ្មោល។បេ។ មនុស្សខ្ទើយ និងប្រុស ភិក្ខុសំគាល់មនុស្សទាំងពីរនាក់ថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។ ខ្ទើយនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ខ្ទើយនិងសត្វតិរច្ឆានទាំងពីរថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយខ្ទើយ និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ខ្ទើយនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសង្ស័យខ្ទើយ និងសត្វតិរច្ឆានឈ្មោលទាំងពីរ។បេ។ ខ្ទើយនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ខ្ទើយ និងសត្វតិរច្ឆានទាំងពីរថាប្រុស។បេ។ ខ្ទើយនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ខ្ទើយនិងសត្វតិរច្ឆានទាំងពីរថាសត្វតិរច្ឆានឈ្មោល។បេ។ ខ្ទើយនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ខ្ទើយនិងសត្វតិរច្ឆានទាំងពីរថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយខ្ទើយនិងសត្វតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។ ប្រុសនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ប្រុសនិងតិរច្ឆានទាំងពីរថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយប្រុសនិងសត្វតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។ ប្រុសនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសង្ស័យប្រុសនិងសត្វតិរច្ឆានទាំងពីរ។បេ។ ប្រុសនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ប្រុសនិងសត្វតិរច្ឆានទាំងពីរថា សត្វតិរច្ឆានឈ្មោល។បេ។ ប្រុសនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ប្រុសនិងសត្វតិរច្ឆានទាំងពីរថាស្រី។បេ។ ប្រុសនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសំគាល់ ប្រុសនិងសត្វតិរច្ឆានទាំងពីរថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល។បេ។ កាន់ ពាល់ កាយមនុស្សប្រុសនិងសត្វតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។

[៨៣] ស្រីជាប្រាកដ ភិក្ខុសំគាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីនោះដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីទាំងពីរនាក់នោះដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយជនទាំងពីរនាក់នោះដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យនិងទុក្កដ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល។បេ។ កាន់ ពាល់កាយស្រីនោះដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល។បេ។ កាន់ ពាល់កាយស្រីទាំងនោះដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់ជនទាំងពីរនាក់នោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល។បេ។ កាន់ ពាល់កាយជនទាំងពីរនាក់នោះដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យនិងទុក្កដ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីនោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីទាំងពីរនាក់នោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយជនទាំងពីរនាក់នោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដពីរ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែលកាយស្រីនោះដោយនិស្សគ្គិយវត្ថុ[១] (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល កាយស្រីទាំងពីរនាក់នោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់ជនទាំងពីរនោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែលកាយជនទាំងពីរនាក់នោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដពីរ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែលនូវវត្ថុដែលជាប់នឹងកាយស្រីនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល នូវវត្ថុដែលជាប់នឹងកាយស្រីទាំងពីរនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដពីរ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់នោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែលនូវវត្ថុដែលជាប់នឹងកាយជនទាំងពីរនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដពីរ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែលនូវនិស្សគ្គិយវត្ថុរបស់ស្រីនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរស្ទាប អង្អែល នូវនិស្សគ្គិយវត្ថុរបស់ស្រីទាំងពីរនាក់នោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដពីរ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់នោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែលនូវនិស្សគ្គិយវត្ថុរបស់ជនទាំងពីរនាក់នោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដពីរ។

ភិក្ខុបេយ្យាល ចប់។

[៨៤] ស្រីជាប្រាកដ ភិក្ខុសំគាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីនោះសោត ក៏ស្ទាបអង្អែល ស្ទាបចុះ ស្ទាបឡើង ផ្ទបចុះ ផ្ងើយឡើង ទាញមក ទាញត្រឡប់ ចាប់សង្កត់ ចាប់ឈ្លេច កាន់ ពាល់ នូវកាយរបស់ភិក្ខុនោះដោយកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នានឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិសង្ឃាទិសេស។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងនោះសោត ក៏ស្ទាបអង្អែល ស្ទាបចុះ ស្ទាបឡើង ផ្ទបចុះ ផ្ងើយឡើង ទាញមក ទាញត្រឡប់ ចាប់សង្កត់ ចាប់ឈ្លេច កាន់ ពាល់ នូវកាយរបស់ភិក្ខុនោះដោយកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិសង្ឃាទិសេសពីរ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ជនទាំងពីរនាក់សោត ក៏ស្ទាបអង្អែល។បេ។ កាន់ ពាល់ កាយរបស់ភិក្ខុនោះដោយកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិសង្ឃាទិសេសនិងទុក្កដ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីសោត ក៏ស្ទាបអង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិថុល្លច្ច័យ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងនោះសោត ក៏ស្ទាបអង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយរបស់ភិក្ខុនោះ ដោយកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិថុល្លច្ច័យពីរ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ជនទាំងពីរនាក់សោត ក៏ស្ទាបអង្អែល។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នានឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិថុល្លច្ច័យនិងទុក្កដ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីសោត ក៏ស្ទាបអង្អែល។

បេ។ ចាប់ ពាល់ នូវ កាយរបស់ភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នានឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិថុល្លច្ច័យ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងនោះសោត ក៏ស្ទាបអង្អែល។បេ។ ចាប់ ពាល់ នូវកាយរបស់ភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិថុល្លច្ច័យពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ជនទាំងពីរនាក់សោត ក៏ស្ទាបអង្អែល។បេ។ ចាប់ ពាល់ កាយរបស់ភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិថុល្លច្ច័យនិងទុក្កដ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីសោត ក៏ស្ទាបអង្អែល។បេ។ ចាប់ ពាល់ នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងពីរនាក់នោះ ស្ទាបអង្អែល។បេ។ ចាប់ ពាល់ នូវវត្ថុដែលជាប់នឹងកាយរបស់ភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់ជនទាំងពីរនោះថាជាស្រីពិតមែន ហើយមានសេចក្តីត្រេកអរ ជនទាំងពីរនោះ ស្ទាបអង្អែល។បេ។ ចាប់ ពាល់ នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដពីរ។ ស្រីជាប្រាកដ ភិក្ខុក៏សំគាល់ថាស្រីពិតមែន ហើយមានសេចក្តីត្រេកអរ ស្រីនោះ ស្ទាបអង្អែល នូវកាយរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុក៏សំគាល់ស្រីទាំងពីរនាក់នោះថាជាស្រីពិតមែន ហើយមានសេចក្តីត្រេកអរ ស្រី(ទាំងពីរនាក់នោះ) ស្ទាប អង្អែលនូវកាយរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដពីរ។ ស្រីនិងខ្ទើយ ភិក្ខុក៏សំគាល់ជនទាំងពីរនោះថាជាស្រី មានសេចក្តីត្រេកអរ ជនទាំងពីរនោះ ស្ទាប អង្អែលកាយរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដពីរ។ ស្រីជាប្រាកដ ភិក្ខុក៏សំគាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីនោះសោតក៏ស្ទាប អង្អែល នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងនោះសោត ក៏ស្ទាប អង្អែលនូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់ជនទាំងពីរនោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ជនទាំងពីរនោះសោត ក៏ស្ទាប អង្អែលនូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដពីរ។ ស្រីជាប្រាកដ ភិក្ខុសំគាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីនោះសោត ក៏ស្ទាប អង្អែល នូវនិស្សគ្គិយវត្ថុរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដ។[9] ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់នោះថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងនោះសោត ក៏ស្ទាប អង្អែលនូវនិស្សគ្គិយវត្ថុរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដពីរ។ ស្រីនិងខ្ទើយ ភិក្ខុសំគាល់ជនទាំងពីរនោះថាជាស្រី ហើយមានសេចក្តីត្រេកអរ ជនទាំងពីរនោះ ស្ទាប អង្អែលនូវនិស្សគ្គិយវត្ថុរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ (របស់ខ្លួន) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដពីរ។

[៨៥] ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ តែមិនដឹងច្បាស់នូវផស្ស ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព តែមិនព្យាយាមដោយកាយ គ្រាន់តែដឹងច្បាស់នូវផស្ស មិនត្រូវអាបត្តិឡើយ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព តែមិនព្យាយាមដោយកាយ មិនដឹងច្បាស់នូវផស្ស មិនត្រូវអាបត្តិឡើយ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងដោះខ្លួនឲ្យរួច ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្ស មិនត្រូវអាបត្តិឡើយ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងដោះខ្លួនឲ្យរួច ក៏ព្យាយាមដោយកាយ តែមិនដឹងច្បាស់នូវផស្ស មិនត្រូវអាបត្តិឡើយ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងដោះខ្លួនឲ្យរួច តែមិនព្យាយាមដោយកាយ គ្រាន់តែដឹងច្បាស់នូវផស្ស មិនត្រូវអាបត្តិឡើយ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងដោះខ្លួនឲ្យរួច តែមិនព្យាយាមដោយកាយ មិនដឹងច្បាស់នូវផស្ស មិនត្រូវអាបត្តិឡើយ។

[៨៦] អាបត្តិមិនមាន (ដល់ភិក្ខុ៨ពួក) គឺ ភិក្ខុមិនក្លែង១ ភិក្ខុភ្លេចស្មារតី១ ភិក្ខុមិនដឹង១ ភិក្ខុមិនត្រេកអរ១ ភិក្ខុឆ្កួត១ ភិក្ខុមានចិត្តរវើរវាយ១ ភិក្ខុដែលវេទនាគ្របសង្កត់១ ភិក្ខុជាខាងដើមបញ្ញត្តិ១។

## (វិនីតវត្ថុឧទ្ទានគាថា)

CS vin.vbu.sg.02.01 | ភាគ ទី២

### (វិនីតវត្ថុឧទ្ទានគាថា)

[៨៧] (មាតិកានុក្រម គឺបញ្ជីរឿងតាមរបៀបដូចមានសេចក្តីខាងក្រោយនេះ)

រឿងមាតា រឿងធីតា រឿងបងប្អូនស្រី រឿងប្រពន្ធ រឿងយក្សស្រី រឿងខ្ទើយ រឿងស្រីដេកលក់ រឿងស្រីស្លាប់ រឿងតិរច្ឆានញី រឿងរូបចំឡាក់ឈើ (រូបតុក្កតា) រឿងស្រីចាប់កៀកភិក្ខុ រឿងស្រីឡើងលើស្ពាន រឿងផ្លូវ រឿងដើមឈើ រឿងទូក រឿងខ្សែ រឿងដំបង រឿងភិក្ខុច្រានស្រីដោយបាត្រ រឿងស្រីថ្វាយបង្គំភិក្ខុ រឿងភិក្ខុព្យាយាមចាប់ស្រីតែចាប់មិនត្រូវ។

# (វិនីតវត្ថុ)

CS vin.vbu.sg.02.02 | ភាគ ទី២

### (វិនីតវត្ថុ)

[៨៨] សម័យនោះឯង ភិក្ខុមួយរូប ចាប់ពាល់មាតាដោយសេចក្ដីស្រឡាញ់មាតា។ ភិក្ខុនោះមានសេចក្ដីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសទេដឹង។ ទើបក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ពាល់កូនស្រីដោយសេចក្ដីស្រឡាញ់កូនស្រី។បេ។ ចាប់ពាល់បងប្អូនស្រីដោយសេចក្ដីស្រឡាញ់បងប្អូនស្រី។បេ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ។ ទើបក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៨៩] សម័យនោះឯង ភិក្ខុមួយរូប ចាប់កាយស្រីជាប្រពន្ធដើម។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវកាយយក្សស្រី។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវកាយមនុស្សខ្ទើយ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវកាយស្រីដែលកំពុងដេកលក់។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវកាយស្រីដែលស្លាប់ហើយ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវកាយសត្វតិរច្ឆានញី។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវរូបឈើធ្វើជារូបស្រី។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៩០] សម័យមួយនោះ មានស្រីច្រើននាក់ចាប់កៀកភិក្ខុ១រូប នាំទៅដោយដើមដៃតៗគ្នា។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គមានព្រះបន្ទូលសួរថា ម្នាលភិក្ខុ អ្នកឯងត្រេកអរដែរឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ (បើ) មិនត្រេកអរ មិនត្រូវអាបត្តិទេ។

[៩១] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្ដីត្រេកអរ ក៏ចាប់អង្រួនស្ពានដែលស្រីកំពុងឡើង។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៩២] សម័យនោះឯង ភិក្ខុមួយរូប ប្រទះស្រីក្នុងផ្លូវជួបគ្នា មានសេចក្ដីត្រេកអរ ក៏ទង្គិចស្រីនោះដោយចង្កូយស្មា។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។

[៩៣] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្ដីត្រេកអរ ក៏អង្រួនដើមឈើដែលស្រីឡើង។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៩៤] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្ដីត្រេកអរ ក៏អង្រួនទូកដែលស្រីឡើងជិះ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[៩៥] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្ដីត្រេកអរ ក៏ចាប់ទាញខ្សែដែលស្រីកំពុងកាន់។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ភិក្ខុមួយរូប មានសេចក្ដីត្រេកអរ ក៏ចាប់ទាញដំបងដែលស្រីកំពុងកាន់។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[៩៦] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្ដីត្រេកអរ ក៏ច្រានស្រីដោយបាត្រ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ សម័យនោះឯង ភិក្ខុមួយរូប កាលស្រីកំពុងថ្វាយបង្គំ មានសេចក្ដីត្រេកអរ ក៏លើកជើងឡើងរងឲ្យចំពប់។ ភិក្ខុនោះមានសេចក្ដីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង ភិក្ខុមួយរូប គិតថា អញនឹងចាប់ស្រី ក៏ព្យាយាម តែចាប់មិនត្រូវ។ ភិក្ខុនោះមានសេចក្ដីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយដឹង។ ទើបក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

សង្ឃាទិសេស ទី២ ចប់។

# សង្ឃាទិសេស ទី៣

CS vin.vbu.sg.03 | ភាគ ទី២

### (៣. ទុដ្ឋុល្លវាចាសិក្ខាបទំ)

[៩៧] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុសម្រេចឥរិយាបថនៅក្នុងព្រៃ។ គ្រានោះ មានស្រីច្រើននាក់ ជាពួកអ្នកត្រូវការមើលវិហារ ហើយក៏នាំគ្នាទៅកាន់អារាម។ ស្រីទាំងនោះក៏ចូលទៅរកឧទាយិភិក្ខុដ៏មានអាយុក្នុងពេលនោះ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចំរើន យើងទាំងឡាយចង់មើលវិហាររបស់លោកម្ចាស់។ លំដាប់នោះ ឧទាយិភិក្ខុដ៏មានអាយុ ក៏នាំស្រីទាំងនោះមើលវិហាររួចហើយ ពោលសរសើរខ្លះ ពោលបង្អាប់ខ្លះ សូមខ្លះ អង្វរខ្លះ សួរខ្លះ សួរតបខ្លះ ប្រាប់ខ្លះ ប្រៀនប្រដៅខ្លះ ជេរខ្លះ ចំពោះវច្ចមគ្គ និងបស្សាវមគ្គនៃស្រីទាំងនោះ។ ស្រីណាដែលគ្មានសេចក្ដីខ្លាច ជាស្រីអ្នកលេងឥតមានអៀនខ្មាស ស្រីនោះក៏ញញឹមញញែម និយាយបញ្ចោរ សើចក្អាកក្អាយចំអន់ជាមួយនឹងឧទាយិភិក្ខុដ៏មានអាយុ ចំណែកខាងស្រីណាដែលមានសេចក្ដីអៀនខ្មាស ស្រីនោះចេញមក ក៏ពោលទោសឧទាយិប្រាប់ភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ដ៏ចំរើន ការនេះគ្មានលាក់បាំង គ្មានគួរសមសោះ ចុះហេតុអ្វីក៏លោកម្ចាស់ឧទាយិនិយាយយ៉ាងនេះ សូម្បីដល់ទៅប្ដី បើនិយាយយ៉ាងនេះ ក៏យើងទាំងឡាយមិនប្រាថ្នាដែរ។ ភិក្ខុទាំងឡាយឯណាដែលមានសេចក្ដីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្ដីអៀនខ្មាស ជាអ្នករង្កៀស ប្រាថ្នាតែខាងការរៀនសូត្រ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វី បានជាឧទាយិភិក្ខុដ៏មានអាយុ ពោលចង់មាតុគ្រាមដោយសំដីអាក្រក់ (ដូច្នោះ)។ កាលនោះ ភិក្ខុទាំងនោះ យកសេចក្ដីនុ៎ះក្រាបទូលដល់ព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរឧទាយិភិក្ខុដ៏មានអាយុក្នុងកាលនោះថា ម្នាលឧទាយិ បានឮថា អ្នកឯងពោលចង់មាតុគ្រាមដោយសំដីអាក្រក់មែនឬ។ ឧទាយិភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ (សេចក្ដីនុ៎ះ) ពិតមែន។ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលបុរសសោះសូន្យ ដំណើរនេះមិនទំនង មិនសមគួរ មិនត្រូវបែប មិនមែនជារបស់សមណ មិនគប្បីសោះ មិនគួរធ្វើសោះ នែមោឃបុរស ចុះហេតុអ្វី បានជាអ្នកឯងពោលចង់មាតុគ្រាមដោយសំដីអាក្រក់ (ដូច្នោះ) ម្នាលមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយអនេកបរិយាយ (សុទ្ធតែ) ដើម្បីប្រាសចាកតម្រេក មិនមែនសំដែងឲ្យប្រកបដោយតម្រេកឡើយ។បេ។ ការរម្ងាប់សេចក្ដីក្ដៅក្រហាយព្រោះកាមទាំងឡាយ ក៏តថាគតសំដែងរួចអស់ហើយតើ មិនមែនឬ នែមោឃបុរស ដំណើរនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លា (នោះ) ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះដូច្នេះថា

**ភិក្ខុណាមួយ គឺរាគគ្របសង្កត់ហើយ មានចិត្តប្រែប្រួល និយាយចង់មាតុគ្រាមដោយសំដីអាក្រក់ ដូចប្រុសកំឡោះនិយាយចង់ស្រីក្រមុំដោយសំដីដែលប្រកបដោយមេថុន ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស។**

[៩៨] ត្រង់ពាក្យថា ណាមួយ អធិប្បាយថា ឯណាក៏ដោយ។បេ។ ត្រង់ពាក្យថា ភិក្ខុ។បេ។ (ភិក្ខុដែលបានសម្រេចឧបសម្បទាដោយញត្តិចតុត្ថកម្មវាចាដ៏ត្រឹមត្រូវ) តថាគតសំដៅឲ្យឈ្មោះថា ភិក្ខុក្នុងអត្ថនេះ។ ត្រង់ពាក្យថា គឺរាគគ្របសង្កត់ហើយ សេចក្ដីថា ភិក្ខុដែលត្រេកអរ មានសេចក្ដីអាឡោះអាឡ័យ មានចិត្តប្រតិព័ទ្ធ។ ត្រង់ពាក្យថា មានចិត្តប្រែប្រួល សេចក្ដីថា ចិត្តដែលត្រេកអរ ក៏ហៅថាប្រែប្រួល ចិត្តដែលខឹង ក៏ហៅថាប្រែប្រួល ចិត្តដែលវង្វេង ក៏ហៅថាប្រែប្រួល ប៉ុន្តែក្នុងអត្ថនេះ តថាគតសំដៅយកចិត្តដែលត្រេកអរ ឲ្យឈ្មោះថា ចិត្តប្រែប្រួល។ មនុស្សស្រីដែលដឹងសេចក្ដី ឆ្លៀវឆ្លាស អាចដឹងច្បាស់នូវពាក្យដែលគេនិយាយល្អនិងអាក្រក់ សំដីគួរនិងមិនគួរ ហៅថាមាតុគ្រាម (ក្នុងសិក្ខាបទនេះ) ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថាមាតុគ្រាមទេ។ ឯសំដីដែលហៅថាអាក្រក់នោះ បានដល់សំដីដែលប្រកបដោយមេថុនធម្ម ចំពោះវច្ចមគ្គនិងបស្សាវមគ្គ។ សេចក្ដីប្រព្រឹត្តិល្មើស តថាគតត្រាស់ហៅថា និយាយចង់។ ត្រង់ពាក្យថា ដូចប្រុសកំឡោះនិយាយចង់ស្រីក្រមុំ សេចក្ដីថា ប្រុសកំឡោះនិយាយចង់ស្រីក្រមុំ ប្រុសជំទង់និយាយចង់ស្រីជំទង់ ប្រុសអ្នកបរិភោគកាមនិយាយចង់ស្រីអ្នកបរិភោគកាម។ ត្រង់ពាក្យថា ដោយសំដីដែលប្រកបដោយមេថុន គឺសំដីដែលប្រកបព្រមចំពោះដោយមេថុនធម្ម។ ត្រង់ពាក្យថា ត្រូវអាបត្តិសង្ឃាទិសេស មានអធិប្បាយពិស្តារក្នុងសង្ឃាទិសេសទី១ រួចហើយ។

[៩៩] ពោលសរសើរក្ដី ពោលបង្អាប់ក្ដី សូមក្ដី អង្វរក្ដី សួរក្ដី សួរបញ្ជាក់ក្ដី ប្រាប់ក្ដី ប្រៀនប្រដៅក្ដី ជេរក្ដី ចំពោះទ្វារមគ្គទាំងពីរ។

[១០០] ភិក្ខុនិយាយស្ញើចពណ៌នាសរសើរទ្វារមគ្គទាំងពីរ ហៅថា ពោលសរសើរ។ ភិក្ខុជេរតិះដៀលនិន្ទាទ្វារមគ្គទាំងពីរ ហៅថា ពោលបង្អាប់។ ភិក្ខុនិយាយថា នាងចូរឲ្យ (មេថុនធម្ម) ដល់អាត្មា នាងចូរដាក់ទាន (មេថុនធម្ម) ដល់អាត្មា នាងគួរឲ្យ (មេថុនធម្ម) ដល់អាត្មា ហៅថាសូម។ ភិក្ខុនិយាយថា មាតារបស់នាងនឹងជ្រះថ្លាក្នុងកាលណា បិតារបស់នាងនឹងជ្រះថ្លាក្នុងកាលណា ទេវតាទាំងឡាយរបស់នាងនឹងជ្រះថ្លាក្នុងកាលណា ពេលល្អ ស្របក់ល្អ យាមល្អ របស់នាងនឹងមានក្នុងកាលណា អាត្មានឹងបាននូវមេថុនធម្មរបស់នាងក្នុងកាលណា (និយាយយ៉ាងនេះ) ហៅថា អង្វរ។ ភិក្ខុនិយាយថា នាងឲ្យ (មេថុនធម្ម) ដល់ប្ដីដូចម្ដេច នាងឲ្យ (មេថុនធម្ម) ដល់សហាយដូចម្ដេច (យ៉ាងនេះ) ហៅថា សួរ។ ភិក្ខុនិយាយថា បានឮថា នាងឲ្យ (មេថុនធម្ម) ដល់ប្ដីយ៉ាងនេះ នាងឲ្យ (មេថុនធម្ម) ដល់សហាយយ៉ាងនេះ ដូច្នេះ ហៅថាសួរបញ្ជាក់។ ភិក្ខុដែលស្រីសួរហើយ និយាយថា នាងចូរឲ្យ (មេថុនធម្ម) យ៉ាងនេះ កាលបើឲ្យ (មេថុនធម្ម) យ៉ាងនេះ នាងឯងនឹងជាទីស្រឡាញ់ផង ជាទីគាប់ចិត្តផងរបស់ប្ដី ដូច្នេះ ហៅថាប្រាប់។ ភិក្ខុដែលស្រីមិនសួរសោះទេ ស្រាប់តែនិយាយថា នាងចូរឲ្យ (មេថុនធម្ម) យ៉ាងនេះ កាលបើឲ្យ (មេថុនធម្ម) យ៉ាងនេះ នាងឯងនឹងជាទីស្រឡាញ់ផង ជាទីគាប់ចិត្តផងរបស់ប្ដី ដូច្នេះ ហៅថា ប្រៀនប្រដៅ។ ភិក្ខុពោលពាក្យថា មេគ្មាននិមិត្ត មេមានហេតុគ្រាន់តែជានិមិត្ត មេគ្មានឈាម មេមានឈាមជានិច្ច មេមានកំណាត់សម្ពត់ជានិច្ច មេហូរឈាមជានិច្ច មេសិខរណី[10] មេស្រីខ្ទើយ មេស្រីមានរូបដូចប្រុស មេមានទ្វារមគ្គរលាយចូលគ្នា មេឧភតោព្យញ្ជនក ដូច្នេះ ហៅថាជេរ។

[១០១] ស្រីជាប្រាកដ ភិក្ខុសំគាល់ថាស្រីពិតមែន ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី សូមក្ដី អង្វរក្ដី សួរក្ដី សួរបញ្ជាក់ក្ដី ប្រាប់ក្ដី ប្រៀនប្រដៅក្ដី ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គរបស់ស្រីនោះ ត្រូវអាបត្តិសង្ឃាទិសេស។ ស្រីជាប្រាកដ ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គរបស់ស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ។ ខ្ទើយជាប្រាកដ ភិក្ខុសំគាល់ថាខ្ទើយពិតមែន ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គរបស់ខ្ទើយនោះ ត្រូវអាបត្តិថុល្លច្ច័យ។ ខ្ទើយជាប្រាកដ ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) សំគាល់ថាស្រី (ក្ដី) ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ

(ឬ) បស្សាវមគ្គរបស់ខ្ទើយនោះ ត្រូវអាបត្តិទុក្កដ។ ប្រុសជាប្រាកដ ភិក្ខុសំគាល់ថាប្រុសពិតមែន មានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) សំគាល់ថាស្រី (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃប្រុសនោះ ត្រូវអាបត្តិទុក្កដ។ សត្វតិរច្ឆានឈ្មោលជាប្រាកដ ភិក្ខុសំគាល់ថាសត្វតិរច្ឆានឈ្មោលពិតមែន មានសេចក្ដីសង្ស័យក្ដី សំគាល់ថាស្រី (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) សំគាល់ថាប្រុស (ក្ដី) ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃសត្វតិរច្ឆានឈ្មោលនោះ ត្រូវអាបត្តិទុក្កដ។

[១០២] ស្រីពីរនាក់ពិតមែន ភិក្ខុក៏សំគាល់ស្រីទាំងពីរនាក់ថាស្រី មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេសពីរ។ ស្រីពីរនាក់ ភិក្ខុមានសេចក្ដីសង្ស័យ(ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) សំគាល់ថាប្រុសក្ដី សំគាល់ថាតិរច្ឆានក្ដី ចំពោះស្រីទាំងពីរនាក់ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ ខ្ទើយពីរនាក់ ភិក្ខុសំគាល់ខ្ទើយទាំងពីរនាក់ថាខ្ទើយ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃខ្ទើយទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ ខ្ទើយពីរនាក់ ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន(ក្ដី) សំគាល់ថាស្រី (ក្ដី) ចំពោះខ្ទើយទាំងពីរនាក់ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃខ្ទើយទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ ប្រុសពីរនាក់ ភិក្ខុសំគាល់ថាប្រុសក្ដី មានសេចក្ដីសង្ស័យក្ដី សំគាល់ថាតិរច្ឆានក្ដី សំគាល់ថាស្រីក្ដី សំគាល់ថាខ្ទើយក្ដី ចំពោះប្រុសទាំងពីរនាក់ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃប្រុសទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ តិរច្ឆានពីរ ភិក្ខុសំគាល់ថាតិរច្ឆានក្ដី មានសេចក្ដីសង្ស័យ(ក្ដី) សំគាល់ថាស្រី(ក្ដី) សំគាល់ថាខ្ទើយ(ក្ដី) សំគាល់ថាប្រុស (ក្ដី) ចំពោះតិរច្ឆានទាំងពីរ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។

[១០៣] ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុមានសេចក្ដីសង្ស័យចំពោះជន ទាំងពីរនាក់។បេ។ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។បេ។ ភិក្ខុសំគាល់ថាខ្ទើយ។បេ។ ត្រូវអាបត្តិថុល្លច្ច័យពីរ។បេ។ ភិក្ខុសំគាល់ថាប្រុស។បេ។ ភិក្ខុសំគាល់ថាតិរច្ឆាន ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) ចំពោះជនទាំងពីរនាក់ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុសំគាល់ជនទាំងពីរថាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាខ្ទើយ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) ចំពោះជនទាំងពីរ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាខ្ទើយ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) សំគាល់ថាស្រី (ក្ដី) ចំពោះជនទាំងពីរនាក់ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ ខ្ទើយម្នាក់ តិរច្ឆានមួយ ភិក្ខុសំគាល់នូវជនទាំងពីរថាខ្ទើយ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ខ្ទើយម្នាក់ តិរច្ឆានមួយ ភិក្ខុមានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាប្រុស (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) សំគាល់ថាស្រី (ក្ដី) ចំពោះជនទាំងពីរ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។ ប្រុសម្នាក់ តិរច្ឆានមួយ ភិក្ខុសំគាល់ថាប្រុស (ក្ដី) មានសេចក្ដីសង្ស័យ (ក្ដី) សំគាល់ថាតិរច្ឆាន (ក្ដី) សំគាល់ថាស្រី (ក្ដី) សំគាល់ថាជាខ្ទើយ (ក្ដី) ចំពោះជនទាំងពីរ ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី ចំពោះវច្ចមគ្គ (ឬ) បស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។

[១០៤] ស្រីពិតមែន ភិក្ខុសំគាល់ថាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី (ចំពោះកាយ) ខាងក្រោមពីត្រឹមដងកាំបិតចុះមក ខាងលើពីត្រឹមមណ្ឌលជង្គង់ឡើងទៅ វៀរលែងតែវច្ចមគ្គ ឬបស្សាវមគ្គនៃស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ។ ខ្ទើយពិតមែន ភិក្ខុសំគាល់ថាជាស្រី។បេ។ ប្រុសពិតមែន ភិក្ខុសំគាល់ថាជាស្រី។បេ។ តិរច្ឆានពិតមែន ភិក្ខុសំគាល់ថាស្រី។បេ។ ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី (ចំពោះកាយ) ខាងក្រោមពីត្រឹមដងកាំបិតចុះមក ខាងលើពីត្រឹមមណ្ឌលជង្គង់ឡើងទៅ វៀរលែងតែវច្ចមគ្គ ឬបស្សាវមគ្គនៃស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរថាជាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី (ចំពោះកាយ) ខាងក្រោមពីត្រឹមដងកាំបិតចុះមក ខាងលើពីត្រឹមមណ្ឌលជង្គង់ឡើងទៅ វៀរលែងតែវច្ចមគ្គ ឬបស្សាវមគ្គស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។

[១០៥] ស្រីពិតមែន ភិក្ខុសំគាល់ថាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី (ចំពោះកាយ) ខាងលើពីត្រឹមដងកាំបិតឡើងទៅ ខាងក្រោមពីត្រឹមមណ្ឌលជង្គង់ចុះមកនៃស្រីនោះ ត្រូវអាបត្តិទុក្កដ។ ខ្ទើយពិតមែន ភិក្ខុសំគាល់ថាជាស្រី។បេ។ ប្រុសពិតមែន ភិក្ខុសំគាល់ថាជាស្រី។បេ។ តិរច្ឆានឈ្មោលពិតមែន ភិក្ខុសំគាល់ថាស្រី។បេ។ ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី (ចំពោះកាយ) ខាងលើពីត្រឹមដងកាំបិតឡើងទៅ ខាងក្រោមពីត្រឹមមណ្ឌលជង្គង់ចុះមកនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរថាជាស្រី ក៏មានសេចក្ដីត្រេកអរ ពោលសរសើរក្ដី ពោលបង្អាប់ក្ដី។បេ។ ជេរក្ដី (ចំពោះកាយ) ខាងលើពីត្រឹមដងកាំបិតឡើងទៅ ខាងក្រោមពីត្រឹមមណ្ឌលជង្គង់ចុះមកនៃជនទាំងពីរនាក់

នោះ ត្រូវអាបត្តិទុក្កដពីរ។បេ។ ស្រីពិតមែន ភិក្ខុសំគាល់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី។បេ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយស្រីនោះ ត្រូវអាបត្តិទុក្កដ។ ខ្ទើយពិតមែន។បេ។ ប្រុសពិតមែន។បេ។ តិរច្ឆានឈ្មោលពិតមែន។បេ។ ត្រូវអាបត្តិទុក្កដ។ ស្រីពីរនាក់ ភិក្ខុសំគាល់ស្រីទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី។បេ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី។បេ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។

[១០៦] អាបត្តិមិនមាន (ដល់ភិក្ខុ៥ពួក) គឺ ភិក្ខុដែលកំពុងអធិប្បាយសេចក្តី[11] ១ ភិក្ខុដែលកំពុងបង្រៀនធម៌[12] ១ ភិក្ខុដែលកំពុងប្រៀនប្រដៅ[13] ១ ភិក្ខុឆ្កួត១ ភិក្ខុជាខាងដើមបញ្ញត្តិ១។

## (វិនីតវត្ថុឧទ្ទានគាថា)

CS vin.vbu.sg.03.01 | ភាគ ទី២

### (វិនីតវត្ថុឧទ្ទានគាថា)

[១០៧] (មាតិកានុក្រម គឺបញ្ជីរឿងតាមរបៀបហូរហែ ដែលនឹងសំដែងតទៅដូចមានខាងក្រោយនេះ)

សម្ពត់កម្ពលក្រហម១ សម្ពត់កម្ពលមានរោមខ្លី១ សម្ពត់កម្ពលមានរោមក្រញាញ់១ សម្ពត់កម្ពលមានរោមរឹង១ សម្ពត់កម្ពលមានរោមវែង១ ស្រីព្រោះស្រូវ១ ភិក្ខុសួរថាផ្លូវប្រព្រឹត្តទៅស្រួលទេឬ១ សទ្ធា១ ទានដ៏ប្រសើរ១ ស្រីកំពុងធ្វើការងារ១។

## (វិនីតវត្ថុ)

CS vin.vbu.sg.03.02 | ភាគ ទី២

### (វិនីតវត្ថុ)

[១០៨] សម័យនោះឯង មានស្រីម្នាក់ដណ្តប់សម្ពត់កម្ពលជ្រលក់ថ្មី។ ភិក្ខុ១រូបមានសេចក្តីត្រេកអរ ក៏និយាយនូវពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងក្រហមឬ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សម្ពត់កម្ពលខ្ញុំជ្រលក់ថ្មី។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង។ ទើបក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង មានស្រីម្នាក់ដណ្តប់សម្ពត់កម្ពលមានរោមខ្លី។ ភិក្ខុមួយរូបមានសេចក្តីត្រេកអរ ក៏និយាយនូវពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមខ្លីឬ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សម្ពត់កម្ពលខ្ញុំមានរោមខ្លី។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង មានស្រីម្នាក់ដណ្តប់សម្ពត់កម្ពលទើបតែនឹងលាងថ្មី។ ភិក្ខុ១រូបមានសេចក្តីត្រេកអរ ក៏និយាយនូវពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមក្រញាញ់ឬ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សម្ពត់កម្ពលខ្ញុំទើបតែលាងថ្មី។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង មានស្រីម្នាក់ដណ្តប់សម្ពត់កម្ពលមានរោមរឹង។ មានភិក្ខុ១រូបមានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមរឹងឬ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សម្ពត់កម្ពលខ្ញុំមានរោមរឹង។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[១០៩] សម័យនោះឯង មានស្រីម្នាក់ដណ្តប់សម្ពត់បាវារមានរោមវែង។ មានភិក្ខុ១រូបមានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមវែងឬ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សម្ពត់បាវារខ្ញុំមានរោមវែង។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[១១០] សម័យនោះឯង មានស្រីម្នាក់ ប្រើគេឲ្យព្រោះស្រូវស្រែរួចហើយ ត្រឡប់មកវិញ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងឲ្យគេព្រោះហើយឬ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ ស្រែខ្ញុំគេមិនទាន់ព្រោះទេ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[១១១] សម័យនោះឯង មានភិក្ខុ១រូប ប្រទះនឹងនាងបរិញ្វជិកាត្រង់ផ្លូវជួបគ្នា មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងបរិញ្វជិកានោះថា ម្នាលប្អូនស្រី ផ្លូវរបស់នាងប្រព្រឹត្តទៅស្រួលទេឬ។ នាងនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោក លោកនឹងដើរទៅបាន។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

[១១២] សម័យនោះឯង មានភិក្ខុ១រូប មានសេចក្តីត្រេកអរ និយាយពាក្យនេះនឹងស្រីម្នាក់ថា ម្នាលប្អូនស្រី នាងជាស្រីមានសទ្ធា ប៉ុន្តែនាងឲ្យវត្ថុណាដល់ស្វាមី នាងមិនឲ្យវត្ថុនោះដល់អាត្មាផងសោះ។ ស្រីនោះសួរថា អ្វីលោកម្ចាស់។ ភិក្ខុនោះឆ្លើយថា មេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីម្នាក់ថា ម្នាលប្អូនស្រី នាងជាស្រីមានសទ្ធា ប៉ុន្តែទានណាដ៏ប្រសើរ នាងមិនឲ្យទាននោះដល់អាត្មាផងសោះ។ ស្រីនោះសួរថា

បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះ តើដូចម្តេច។ ភិក្ខុនោះឆ្លើយថា ទានដ៏ប្រសើរនោះ គឺមេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។

[១១៣] សម័យនោះឯង មានស្រីម្នាក់កំពុងធ្វើការងារ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី នាងឈប់ចុះចាំអាត្មាធ្វើឲ្យ។ ស្រីនោះមិនដឹងច្បាស់។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង មានស្រីម្នាក់កំពុងធ្វើការងារ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី នាងចូរអង្គុយទៅ អាត្មានឹងធ្វើឲ្យ។ ស្រីនោះមិនដឹងច្បាស់។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង មានស្រីម្នាក់កំពុងធ្វើការងារ។ មានភិក្ខុ១រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី នាងចូរដេកទៅ អាត្មានឹងធ្វើឲ្យ។ ស្រីនោះមិនដឹងច្បាស់។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

សង្ឃាទិសេស ទី៣ ចប់។

# សង្ឃាទិសេស ទី៤

CS vin.vbu.sg.04 | ភាគ ទី២

### (៤. អត្តកាមបារិចរិយសិក្ខាបទំ)

[១១៤] សម័យនោះឯង ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុ ជាអ្នកចូលទៅកាន់ត្រកូល[14)] ក៏ចូលទៅរកត្រកូលមានប្រមាណច្រើន ក្នុងក្រុងសាវត្ថី។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមេម៉ាយស្លាប់ប្តី មានរូបល្អគួរពិតពិលរមិលមើល ជាទីនាំមកនូវសេចក្តីជ្រះថ្លា។ គ្រានោះ ឧទាយិភិក្ខុដ៏មានអាយុ ស្លៀកស្បង់ ទ្រង់បាត្រចីវរ ហើយចូលទៅកាន់លំនៅរបស់ស្រីនោះក្នុងពេលព្រឹកព្រហាម។ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនដែលគេក្រាលប្រគេន។ ស្រីនោះក៏ចូលមករកឧទាយិភិក្ខុដ៏មានអាយុក្នុងពេលនោះ លុះចូលមកជិតហើយ ក៏ឱនកាយថ្វាយបង្គំឧទាយិភិក្ខុដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ។ ឧទាយិភិក្ខុដ៏មានអាយុ ក៏ញុំាងស្រីនោះ ដែលអង្គុយនៅក្នុងទីដ៏សមគួរ ឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយវាចាដ៏ប្រកបដោយធម៌។ ឯស្រីនោះ លុះឧទាយិភិក្ខុដ៏មានអាយុឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយដោយវាចាដ៏ប្រកបដោយធម៌ដូច្នោះហើយ ក៏បាននិយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការដោយវត្ថុណាដែលខ្ញុំព្រះករុណាល្មមនឹងប្រគេនលោកម្ចាស់បាន ដូចជាចីវរ បិណ្ឌបាត គ្រឿងសេនាសន គ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្សឈឺនោះ លោកម្ចាស់និមន្តប្រាប់មកចុះ។ ឧទាយិភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ចីវរ បិណ្ឌបាត គ្រឿងសេនាសន គ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្សមានជម្ងឺដែលជារបស់នាង យើងមិនមែនបានដោយកម្រទេ តែថារបស់ណាដែលយើងបានដោយកម្រ នាងចូរឲ្យរបស់នោះដល់យើងវិញចុះ។ ស្រីនោះសួរថា ឲ្យអ្វីលោកម្ចាស់។ ឧទាយិភិក្ខុឆ្លើយថា ឲ្យមេថុនធម្ម។ ស្រីនោះសួរថា លោកម្ចាស់ត្រូវការឬ។ ឧទាយិភិក្ខុឆ្លើយថា ម្នាលប្អូនស្រី អាត្មាត្រូវការដែរ។ ស្រីនោះឆ្លើយថា លោកម្ចាស់និមន្តមកចុះ ថាហើយ ក៏ចូលទៅក្នុងបន្ទប់តូច ដោះសំពត់សាដកចេញ ហើយដេកផ្ងាលើគ្រែ។ ឧទាយិភិក្ខុដ៏មានអាយុ ក៏ចូលទៅជិតស្រីនោះក្នុងពេលនោះឯង លុះចូលទៅដល់ហើយ ក៏ស្តីឲ្យថា អ្នកណានឹងហ៊ានស្ទាបអង្អែលស្រីអាក្រក់មានក្លិនស្អុយយ៉ាងនេះ ថាហើយក៏ខាកស្តោះដើរចេញទៅ។ គ្រានោះឯង ស្រីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណទាំងនេះជាកូនចៅព្រះពុទ្ធ ជាសក្យបុត្តគ្មានសេចក្តីអៀនខ្មាស ទ្រុស្តសីល និយាយពាក្យកុហក ព្រោះថាសមណទាំងនេះប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តត្រឹមត្រូវ ប្រព្រឹត្តធម៌ ប្រព្រឹត្តដ៏ប្រសើរ និយាយពាក្យពិត មានសីល មានធម៌ជាកុសល សាមញ្ញគុណរបស់សមណទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់សមណទាំងនេះគ្មានទេ សាមញ្ញគុណរបស់សមណទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណទាំងនេះមានពីណា ព្រហ្មញ្ញគុណរបស់សមណទាំងនេះមានពីណា សមណទាំងនេះប្រាសចាកសាមញ្ញគុណហើយ សមណទាំងនេះប្រាសចាកព្រហ្មញ្ញគុណអស់ហើយ មិនសមបីបើ សមណឈ្មោះឧទាយិសុំមេថុនធម្មនឹងអញដោយខ្លួនឯង ហើយស្តីថា អ្នកណានឹងហ៊ានស្ទាបអង្អែលស្រីអាក្រក់មានក្លិនស្អុយយ៉ាងនេះ ថាហើយក៏ខាកស្តោះចៀសចេញទៅ (ដូច្នេះសោះ) ការលាមករបស់អញដូចម្តេច ក្លិនអញអាក្រក់ដូចម្តេច អញដូចម្តេច អញអន់ (ជាងស្រីឯទៀត) ដោយអ្វី។ ស្រីទាំងឡាយឯទៀតក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណទាំងនេះជាកូនចៅព្រះពុទ្ធជាសក្យបុត្រ គ្មានសេចក្តីអៀនខ្មាស ទ្រុស្តសីល និយាយកុហក ព្រោះថា សមណទាំងនេះប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តត្រឹមត្រូវ ប្រព្រឹត្តធម៌ ប្រព្រឹត្តដ៏ប្រសើរ និយាយពាក្យពិត មានសីល មានធម៌ជាកុសល សាមញ្ញគុណរបស់សមណទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់សមណទាំងនេះគ្មានទេ សាមញ្ញគុណរបស់សមណទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណទាំងនេះមានពីណា ព្រហ្មញ្ញគុណរបស់សមណទាំងនេះមានពីណា សមណទាំងនេះប្រាសចាកសាមញ្ញគុណហើយ សមណទាំងនេះប្រាសចាកព្រហ្មញ្ញគុណហើយ មិនសមបីបើ សមណឈ្មោះឧទាយិសុំមេថុនធម្មនឹងស្រីនេះដោយខ្លួនឯង ហើយបែរជាស្តីថា អ្នកណានឹងហ៊ានស្ទាបអង្អែលស្រីអាក្រក់មានក្លិនស្អុយយ៉ាងនេះ ហើយខាកស្តោះចៀសចេញទៅ (ដូច្នេះសោះ) ការលាមករបស់ស្រីនេះដូចម្តេច ក្លិនរបស់ស្រីនេះអាក្រក់ដូចម្តេច ស្រីនេះដូចម្តេច ស្រីនេះថោកថយ (ជាងស្រីឯទៀត) ដោយអ្វី។ ភិក្ខុទាំងឡាយបានឮស្រីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះហើយ) ភិក្ខុទាំងឡាយណាដែលមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្តីខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាតែការសិក្សា ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបីបើ ឧទាយិភិក្ខុដ៏មានអាយុពោលសរសើរការបម្រើខ្លួនដោយកាមក្នុងសំណាក់មាតុគ្រាមសោះ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគក្នុងពេលនោះ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ឧទាយិភិក្ខុដ៏មានអាយុក្នុងពេលនោះថា ម្នាលឧទាយិ បានឮថា អ្នកឯងពោលសរសើរការបម្រើខ្លួនដោយកាមក្នុងសំណាក់មាតុគ្រាមមែនឬ។ ឧទាយិភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនុ៎ះពិតមែន។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលបុរសសាបសូន្យ ដំណើរនេះមិនទំនង មិនសមគួរ មិនត្រូវបែប មិនមែនជារបស់សមណ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាលមោឃបុរស មិនសមបីបើ អ្នកឯងពោលសរសើរការបម្រើខ្លួនដោយកាមក្នុងសំណាក់មាតុគ្រាម (ដូច្នោះទេ) ម្នាលមោឃបុរស ធម៌ដែល

តថាគតសំដែងហើយដោយអនេកបរិយាយ (សុទ្ធតែ) ដើម្បីឲ្យប្រាសចាករាគ មិនមែនសំដែងឲ្យប្រកបដោយរាគទេ។បេ។ ការរម្ងាប់សេចក្តីក្តៅក្រហាយព្រោះកាម តថាគតក៏បានសំដែងហើយ ម្នាលមោឃបុរស អំពើលាមករបស់អ្នកឯងនុ៎ះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លានោះទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ គឺរាគគ្របសង្កត់ហើយ មានចិត្តប្រែប្រួល ពោលសរសើរការបម្រើជាកាមដើម្បីខ្លួនក្នុងសំណាក់នៃមាតុគ្រាម ដោយសំដីប្រកបដោយមេថុនធម្មថា ស្រីណាគប្បីបម្រើនូវភិក្ខុមានសីល មានធម៌ជាកុសល ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរប្រហែលដូចអាត្មាដោយធម៌នេះ ម្នាលប្អូនស្រី ការបម្រើនេះរបស់ស្រីនោះ ជាការប្រសើរជាងការបម្រើទាំងអស់ (ពោលពាក្យដូច្នោះ) ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស។**

[១១៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីអធិប្បាយក្នុងបារាជិកកណ្ឌសិក្ខាបទទី១រួចហើយ។ ភិក្ខុមានសេចក្តីត្រេកអរ ក្រឡេកមៀងមើល មានចិត្តប្រតិព័ទ្ធ ហៅថា មានចិត្តគឺរាគគ្របសង្កត់ហើយ។ ត្រង់ពាក្យថា ប្រែប្រួល សេចក្តីថា ចិត្តត្រេកអរក៏ហៅថា ប្រែប្រួល ចិត្តគឺទោសប្រទុស្ត ក៏ហៅថាប្រែប្រួល ចិត្តវង្វេង ក៏ហៅថាប្រែប្រួល តែថាព្រះដ៏មានព្រះភាគសំដៅយកចិត្តដែលត្រេកអរថាជាចិត្តប្រែប្រួល ក្នុងអត្ថនេះ។ មនុស្សស្រីដែលដឹងសេចក្តី ឆ្លៀវឆ្លាស អាចដឹងច្បាស់នូវពាក្យដែលគេនិយាយល្អ និងអាក្រក់ សំដីគួរ នឹងមិនគួរ ហៅថា មាតុគ្រាម (ក្នុងសិក្ខាបទនេះ) ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថាមាតុគ្រាមទេ។ ត្រង់ពាក្យថា ក្នុងសំណាក់នៃមាតុគ្រាម សេចក្តីថា ជិតខាងមាតុគ្រាម គឺមិនឆ្ងាយអំពីមាតុគ្រាម។ ត្រង់ពាក្យថា កាមដើម្បីខ្លួន សេចក្តីថា ចំណង់ដើម្បីខ្លួន ហេតុដើម្បីខ្លួន សេចក្តីប្រាថ្នាដើម្បីខ្លួន ការបម្រើដើម្បីខ្លួន។ ត្រង់ពាក្យថា ការបម្រើនេះប្រសើរ សេចក្តីថា ការបម្រើនេះប្រសើរ ការបម្រើនេះប្រសើរបំផុត ការបម្រើនេះជាគ្រឿងដោះខ្លួនឲ្យរួចចាកទុក្ខ ការបម្រើនេះខ្ពង់ខ្ពស់ ការបម្រើនេះ គួរប្រាថ្នាណាស់។ ត្រង់ពាក្យថា ស្រីណា សេចក្តីថា ស្រីក្សត្រិយ៍ក្តី ស្រីព្រាហ្មណ៍ក្តី ស្រីអ្នកឈ្មួញក្តី ស្រីអ្នកគ្រួក្តី។ ត្រង់ពាក្យថា ប្រហែលដូចអាត្មា សេចក្តីថាក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី អ្នកឈ្មួញក្តី អ្នកគ្រួក្តី។ ត្រង់ពាក្យថា មាសីល សេចក្តីថា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកមុសាវាទ។ ត្រង់ពាក្យថា ប្រព្រឹត្តធម៌ដ៏ប្រសើរ គឺវៀរចាកមេថុនធម្ម។ មានធម៌ជាកុសលដោយសីលនោះផង ដោយព្រហ្មចរិយនោះផង ហៅថា មានធម៌ជាកុសល។ ត្រង់ពាក្យថា ដោយធម៌នេះ គឺដោយមេថុនធម្ម។ ត្រង់ពាក្យថា គប្បីបម្រើ គឺគប្បីត្រេកអរចំពោះ។ ត្រង់ពាក្យថា ប្រកបដោយមេថុន គឺប្រកបព្រមចំពោះដោយមេថុនធម្ម។ ត្រង់ពាក្យថា ត្រូវអាបត្តិសង្ឃាទិសេសនោះ មានអធិប្បាយពិស្តារក្នុងសង្ឃាទិសេសសិក្ខាបទទី១រួចហើយ។

[១១៦] ស្រីពិតមែន ភិក្ខុសំគាល់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីនោះ ត្រូវអាបត្តិសង្ឃាទិសេស។ ស្រីពិតមែន ភិក្ខុមានសេចក្តីសង្ស័យក្តី សំគាល់ថាខ្ទើយក្តី សំគាល់ថាប្រុសក្តី សំគាល់ថាតិរច្ឆានក្តី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ។ ខ្ទើយពិតមែន ភិក្ខុសំគាល់ថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយនោះ ត្រូវអាបត្តិថុល្លច្ច័យ។ ខ្ទើយពិតមែន ភិក្ខុមានសេចក្តីសង្ស័យ(ក្តី) សំគាល់ថាប្រុស(ក្តី) សំគាល់ថាតិរច្ឆាន(ក្តី) សំគាល់ថាស្រី(ក្តី) ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយនោះ ត្រូវអាបត្តិទុក្កដ។ ប្រុសពិតមែន ភិក្ខុសំគាល់ថាប្រុស(ក្តី) មានសេចក្តីសង្ស័យ(ក្តី) សំគាល់ថាតិរច្ឆានក្តី សំគាល់ថាស្រី(ក្តី) សំគាល់ថាខ្ទើយ(ក្តី) ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃប្រុសនោះ ត្រូវអាបត្តិទុក្កដ។ តិរច្ឆានពិតមែន ភិក្ខុសំគាល់ថាតិរច្ឆាន(ក្តី) មានសេចក្តីសង្ស័យ(ក្តី) សំគាល់ថាស្រី(ក្តី) សំគាល់ថាខ្ទើយ(ក្តី) សំគាល់ថាប្រុស(ក្តី) ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃតិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ។

[១១៧] ស្រីពីនាក់ ភិក្ខុសំគាល់ស្រីទាំងពីរថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេសពីរ។ ស្រីពីរនាក់ ភិក្ខុមានសេចក្តីសង្ស័យ(ក្តី) សំគាល់ថាខ្ទើយ(ក្តី) សំគាល់ថាប្រុស(ក្តី) សំគាល់ថាតិរច្ឆាន(ក្តី) ចំពោះស្រីទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ ខ្ទើយពីរនាក់ ភិក្ខុសំគាល់ខ្ទើយទាំងពីរថាជាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ។ ខ្ទើយពីរនាក់ ភិក្ខុមានសេចក្តីសង្ស័យ(ក្តី) សំគាល់ថាប្រុស(ក្តី) សំគាល់ថាតិរច្ឆាន(ក្តី) សំគាល់ថាស្រី(ក្តី) ចំពោះខ្ទើយទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។ ប្រុសពីរនាក់ ភិក្ខុសំគាល់ប្រុសទាំងពីរ។បេ។ តិរច្ឆានពីរ ភិក្ខុសំគាល់ថាតិរច្ឆាន(ក្តី) មានសេចក្តីសង្ស័យ(ក្តី) សំគាល់ថាស្រី(ក្តី) សំគាល់ថាខ្ទើយ(ក្តី) សំគាល់ថាប្រុស(ក្តី) ចំពោះតិរច្ឆានទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់តិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសំគាល់ជនទាំងពីរថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុមានសេចក្តីសង្ស័យចំពោះជនទាំងពីរនាក់។បេ។ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។បេ។ ភិក្ខុសំគាល់ថាខ្ទើយ។បេ។ ត្រូវអាបត្តិថុល្លច្ច័យពីរ។បេ។ ភិក្ខុសំគាល់ថាប្រុស។បេ។ ភិក្ខុសំគាល់ថាតិរច្ឆាន ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងអាបត្តិទុក្កដ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាខ្ទើយ(ក្តី) សំគាល់ថាប្រុស(ក្តី) សំគាល់ថាតិរច្ឆាន(ក្តី) ចំពោះជនទាំងពីរនាក់ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុសំគាល់ជនទាំងពីរថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុមានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាខ្ទើយ(ក្តី) សំគាល់ថាប្រុស(ក្តី) សំគាល់ថាតិរច្ឆាន(ក្តី) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុសំគាល់ជនទាំងពីរនាក់ថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្តីសង្ស័យ (ក្តី) សំ

គាល់ថាប្រុស(ក្តី) សំគាល់ថាតិរច្ឆាន(ក្តី) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ។ ខ្ទើយម្នាក់ តិរច្ឆានមួយ ភិក្ខុសំគាល់ជនទាំងពីរនោះថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ខ្ទើយម្នាក់ តិរច្ឆានមួយ ភិក្ខុមានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាប្រុស(ក្តី) សំគាល់ថាតិរច្ឆាន(ក្តី) សំគាល់ថាស្រី(ក្តី) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។ ប្រុសម្នាក់ តិរច្ឆានមួយ ភិក្ខុសំគាល់ថាប្រុស(ក្តី) មានសេចក្តីសង្ស័យ (ក្តី) សំគាល់ថាតិរច្ឆាន(ក្តី) សំគាល់ថាស្រី(ក្តី) សំគាល់ថាខ្ទើយ(ក្តី) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ។

[១១៨] អាបត្តិមិនមាន (ដល់ភិក្ខុ៣ពួក) គឺ ភិក្ខុពោលថា នាងចូរបម្រើអាត្មាដោយចីវរ បិណ្ឌបាត សេនាសន និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកមានជម្ងឺ១ ភិក្ខុឆ្កួត១ ភិក្ខុជាខាងដើមបញ្ញត្តិ១។

## (វិនីតវត្ថុឧទ្ទានគាថា)

CS vin.vbu.sg.04.01 | ភាគ ទី២

### (វិនីតវត្ថុឧទ្ទានគាថា)

[១១៩] (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសំដែងតទៅ ដូចមានខាងក្រោយនេះ គឺ)

> ស្រីអារ ស្រីបានកូន ស្រីចង់ឲ្យប្តីស្រឡាញ់ ស្រីចង់បានរូបល្អ សួរភិក្ខុថាធ្វើដូចម្តេច ស្រីចង់ឲ្យទាន ស្រីចង់បម្រើ សួរភិក្ខុថាធ្វើដូចម្តេច ស្រីចង់ទៅសុគតិ សួរភិក្ខុថាធ្វើដូចម្តេច។

## (វិនីតវត្ថុ)

CS vin.vbu.sg.04.02 | ភាគ ទី២

### (វិនីតវត្ថុ)

[១២០] សម័យនោះឯង មានស្រីម្នាក់ជាស្រីអារ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណានឹងគិតធ្វើដូចម្តេចឲ្យមានកូន។ ភិក្ខុនោះឆ្លើយថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ។ ស្រីអារនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះ តើដូចម្តេច។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ទើបយកសេចក្តីនោះក្រាបទូលដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមានកូន បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាត្រូវធ្វើដូចម្តេចដើម្បីកុំឲ្យបានកូន។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះ តើដូចម្តេច។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាត្រូវធ្វើដូចម្តេចឲ្យជាទីស្រឡាញ់នៃប្តី។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះ តើដូចម្តេច។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាត្រូវធ្វើដូចម្តេចឲ្យជាស្រីមានរូបល្អ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះ តើដូចម្តេច។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណានឹងឲ្យទានដូចម្តេចដល់លោកម្ចាស់។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី នាងចូរឲ្យទានដ៏ប្រសើរចុះ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះ តើដូចម្តេច។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាផ្គត់ផ្គង់លោកម្ចាស់ដោយទានដូចម្តេច។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី ចូរនាងផ្គត់ផ្គង់ដោយទានដ៏ប្រសើរចុះ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះ តើដូចម្តេច។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាគប្បីទៅកាន់សុគតិដោយកុសលដូចម្តេច។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ។ ស្រីនោះសួរថា បពិត្រលោកដ៏ចំរើន ទានដ៏ប្រសើរនោះ តើដូចម្តេច។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង។ ទើបយកសេចក្តីនោះក្រាបទូលដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ។

សង្ឃាទិសេស ទី៤ ចប់។

# សង្ឃាទិសេស ទី៥

## (៥. សញ្ចរិត្តសិក្ខាបទំ)

[១២១] សម័យនោះឯង ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុ ជាអ្នកចូលទៅកាន់ត្រកូល ក្នុងក្រុងសាវត្ថី តែងចូលទៅកាន់ត្រកូលទាំងឡាយមានប្រមាណច្រើន ឃើញកុមារដែលគ្មានប្រពន្ធក្តី ឃើញនាងកុមារីដែលគ្មានប្តីក្តីក្នុងទីណា ក៏និយាយសរសើរនាងកុមារីក្នុងសំណាក់នៃមាតាបិតារបស់កុមារ (ក្នុងទីនោះ)ថា នាងកុមារីរបស់ត្រកូលឯណោះ មានរូបល្អ គួរគយគន់មើល ល្មមជ្រះថ្លា ជាស្រីមានប្រាជ្ញាអង់អាច ឆ្លៀវឆ្លាស វាងវៃ មិនខ្ជិលច្រអូស នាងកុមារីនោះ សមគ្នានឹងកុមារនេះណាស់។ មាតាបិតារបស់កុមារនោះ ក៏និយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ អ្នកអស់នោះ គេមិនធ្លាប់ស្គាល់យើងខ្ញុំថា អ្នកអស់ទាំងនុ៎ះជាអ្វីក្តី ជាកូនចៅអ្នកណាក្តី ដូច្នេះឡើយ បពិត្រលោកដ៏ចម្រើន ប្រសិនបើលោកម្ចាស់ឲ្យគេឲ្យ យើងខ្ញុំគួរនាំនាងកុមារីនោះមកផ្សំឲ្យកុមារនេះដែរ។ ឧទាយិភិក្ខុដ៏មានអាយុ ពោលសរសើរកុមារក្នុងសំណាក់មាតាបិតារបស់នាងកុមារីថា កុមាររបស់ត្រកូលឯណោះ មានរូបល្អគួរគយគន់មើល ល្មមជ្រះថ្លា ជាប្រុសមានប្រាជ្ញាអង់អាច ឆ្លៀវឆ្លាស់ វាងវៃ មិនខ្ជិលច្រអូស កុមារនោះ សមគ្នានឹងកុមារីនេះណាស់។ ម្តាយអាពុកនាងកុមារីនោះឆ្លើយថា បពិត្រលោកម្ចាស់ អ្នកអស់នោះ គេមិនធ្លាប់ស្គាល់យើងថា អ្នកអស់នុ៎ះជាអ្វីក្តី ជាកូនចៅអ្នកណាក្តី ការដែលយើងនិយាយព្រោះនាងកុមារីដូចជាអៀនមាត់ពេកណាស់ បពិត្រលោកដ៏ចម្រើន បើលោកម្ចាស់ឲ្យគេមកដណ្តឹងយើង ៗគួរឲ្យនាងកុមារីនេះដល់កុមារនោះដែរ។ ឧទាយិភិក្ខុតែងឲ្យត្រកូលរៀបចំអាវាហមង្គលផង វិវាហមង្គលផង ឲ្យស្តីដណ្តឹងគ្នានឹងគ្នាផង សុទ្ធតែដោយឧបាយនេះឯង។

[១២២] សម័យនោះឯង មានកូនក្រមុំនៃស្រីមេម៉ាយម្នាក់ជាប្រពន្ធហោរាចាស់ មានរូបឆោមស្រស់បស់ គួរគយគន់មើលនាំឲ្យជ្រះថ្លា។ ពួកសាវករបស់អាជីវកនៅស្រុកក្រៅ បានចូលមកនិយាយនឹងប្រពន្ធហោរានោះថា ម្នាលអ្នកស្រី អ្នកចូរឲ្យនាងកុមារីនេះមកកុមាររបស់យើងទៅ។ ប្រពន្ធហោរាក៏និយាយយ៉ាងនេះថា បពិត្រអ្នកម្ចាស់ទាំងឡាយ ខ្ញុំឯងមិនធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ ហើយថាត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ។ មនុស្សទាំងឡាយសួរទៅពួកសាវករបស់អាជីវកនោះថា បពិត្រអ្នកម្ចាស់ទាំងឡាយ អស់អ្នកមកនេះមានការអ្វី។ ពួកសាវករបស់អាជីវកនោះប្រាប់ថា យើងមកដណ្តឹងធីតារបស់អ្នកស្រីប្រពន្ធហោរាឈ្មោះឯណោះក្នុងស្រុកនេះ ឲ្យកុមាររបស់យើង តែនាងនោះនិយាយថា បពិត្រអ្នកម្ចាស់ទាំងឡាយ ខ្ញុំឯងមិនធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ ហើយថាត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ។ មនុស្សទាំងឡាយនោះប្រាប់ទៅពួកសាវករបស់អាជីវកវិញថា បពិត្រអ្នកម្ចាស់ទាំងឡាយ ថ្វីបានជាអ្នកទៅដណ្តឹងធីតារបស់ប្រពន្ធហោរានោះ ក្រែងត្រូវអ្នកទាំងឡាយពិតលោកម្ចាស់ឧទាយិ លោកម្ចាស់ឧទាយិនឹងបង្គាប់ឲ្យគេឲ្យទេឬ។ គ្រានោះឯង ពួកសាវករបស់អាជីវក ក៏ចូលទៅឯទីដែលឧទាយិភិក្ខុនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចំរើន យើងមកដណ្តឹងធីតារបស់ប្រពន្ធហោរាឈ្មោះឯណោះក្នុងស្រុកនេះ ឲ្យកុមាររបស់យើង តែនាងនោះនិយាយយ៉ាងនេះថា ខ្ញុំឯងមិនធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ ហើយថាត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ បពិត្រលោកដ៏ចំរើន យើងសូមពឹងលោកម្ចាស់ សូមលោកម្ចាស់និយាយនឹងប្រពន្ធហោរាឲ្យៗកូនស្រីមកកុមាររបស់យើងទៅ។ គ្រានោះឯង ឧទាយិភិក្ខុដ៏មានអាយុ ក៏ចូលទៅត្រង់ទីដែលប្រពន្ធហោរានៅ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងប្រពន្ធហោរានោះថា ហេតុអ្វីបានជានាងមិនឲ្យធីតាដល់អ្នកអស់នេះ។ ប្រពន្ធហោរាក៏ឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណា មិនធ្លាប់ស្គាល់អ្នកអស់នេះថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ ហើយថាត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ។ ឧទាយិភិក្ខុក៏និយាយថា នាងចូរឲ្យទៅអ្នកទាំងនេះចុះ អាត្មាធ្លាប់ស្គាល់គេដែរ។ ប្រពន្ធហោរានិយាយថា បពិត្រលោកដ៏ចំរើន បើលោកម្ចាស់ស្គាល់ ខ្ញុំព្រះករុណានឹងឲ្យ។ គ្រានោះឯង ប្រពន្ធហោរានោះ ក៏បានឲ្យធីតាទៅពួកសាវករបស់អាជីវកនោះ។ លំដាប់នោះ ពួកសាវករបស់អាជីវកនោះឯង ក៏បាននាំនាងកុមារីនោះទៅ ហើយប្រើប្រាស់នាងដោយការបម្រើជាកូនប្រសាបានតែត្រឹម១ខែ តពីនោះមក ប្រើប្រាស់នាងដោយការបម្រើជាទាសីទៅវិញ។

[១២៣] គ្រានោះឯង នាងកុមារីនោះក៏ប្រើបម្រើទៅឯសំណាក់ម្តាយដោយពាក្យថា ខ្លួនខ្ញុំដល់នូវសេចក្តីក្រីក្រលំបាក មិនបានសេចក្តីសុខទេ ព្រោះពួកសាវករបស់អាជីវកប្រើប្រាស់ខ្ញុំ ដោយការបម្រើជាកូនប្រសាបានតែត្រឹម១ខែទេ តពីនោះមក ក៏ប្រើប្រាស់ខ្ញុំដោយការបម្រើជាទាសីទៅវិញ សូមឲ្យអ្នកម្តាយខ្ញុំ មកនាំយកខ្ញុំទៅផង។ គ្រានោះឯង ប្រពន្ធហោរានោះ ក៏ចូលទៅត្រង់ទីដែលពួកសាវករបស់អាជីវកនៅ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងពួកសាវករបស់អាជីវកនោះថា បពិត្រអ្នកម្ចាស់ទាំងឡាយ អ្នកទាំងឡាយកុំប្រើប្រាស់នាងកុមារីនេះដោយការបម្រើជាទាសីឡើយ ត្រូវប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាកូនប្រសាវិញ។ ពួកសាវករបស់អាជីវកក៏និយាយថា យើងគ្មានទាក់ទងជាមួយនឹងនាងឯងទេ យើងមានទាក់ទងតែនឹងសមណរបស់យើងទេតើ នាងឯងទៅៗ យើងមិនស្គាល់នាងឯងទេ។ ឯប្រពន្ធហោរានោះ កាលបើពួកសាវករបស់អាជីវកទាំងនោះធ្វើមិនឲ្យជ្រះថ្លាហើយ ក៏ត្រឡប់មកក្រុងសាវត្ថីវិញ។ នាងកុមារីក៏ប្រើបម្រើទៅឯសំណាក់ម្តាយ ក្នុងលើកទី២ទៀតថា ខ្លួនខ្ញុំដល់នូវសេចក្តីក្រីក្រលំបាក មិនបានសេចក្តីសុខទេ ព្រោះពួកសាវករបស់អាជីវកប្រើប្រាស់ខ្ញុំ ដោយការបម្រើជាកូនប្រសាបានតែត្រឹម១ខែទេ តពីនោះមក ក៏ប្រើប្រាស់ខ្ញុំដោយការបម្រើជាទាសីទៅវិញ សូមឲ្យអ្នកម្តាយខ្ញុំ មកនាំយកខ្ញុំទៅផង។ ឯប្រពន្ធហោរា ក៏ចូលទៅត្រង់ទីដែលឧទាយិភិក្ខុដ៏មានអាយុនៅ លុះចូលទៅដល់ហើយ និយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ឮដំណឹងថា នាងកុមារីនោះ ដល់នូវសេចក្តីក្រីក្រលំបាក មិនបានសេចក្តីសុខសោះ ព្រោះពួកសាវករបស់អាជីវកប្រើប្រាស់វា ដោយការបម្រើជាកូនប្រសាបានតែត្រឹម១ខែទេ តពីនោះមក ក៏ប្រើប្រាស់ដោយការបម្រើជាទាសីទៅវិញ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និយាយនឹងគេដូច្នេះថា ម្នាលអ្នកទាំងឡាយ អ្នកទាំងអស់គ្នា កុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាទាសីឡើយ ចូរប្រើប្រាស់នាងកុមារីនេះដោយការបម្រើជាកូនប្រសាវិញ។ គ្រានោះឯង ឧទាយិដ៏មានអាយុចូលទៅត្រង់ទីដែលពួកសាវករបស់អាជីវកនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងពួកសាវករបស់អាជីវកនោះថា ម្នាលអ្នកទាំងឡាយ អ្នកទាំងអស់គ្នា កុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាទាសីឡើយ ចូរប្រើប្រាស់នាងកុមារីនេះដោយការបម្រើជាកូនប្រសាវិញ។ ពួកសាវករបស់អាជីវកនោះឆ្លើយថា យើងគ្មានទាក់ទងជាមួយនឹងលោកទេ យើងមានទាក់ទងតែនឹងប្រពន្ធហោរាទេតើ សមណមិនត្រូវខ្វល់ខ្វាយទេ សមណត្រូវតែជាសមណល្អ លោកចូរទៅវិញទៅ យើងមិនស្គាល់លោកទេ។ ឯឧទាយិភិក្ខុដ៏មានអាយុ កាលដែលពួកសាវករបស់អាជីវកមិនឲ្យជ្រះថ្លាហើយ ក៏ត្រឡប់មកកាន់ក្រុងសាវត្ថីវិញ។ នាងកុមារីនោះ ក៏ប្រើបម្រើទៅឯសំណាក់ម្តាយ

ក្នុងលើកទី៣ទៀតថា ខ្លួនខ្ញុំដល់នូវសេចក្តីក្រីក្រលំបាកណាស់ មិនបានសេចក្តីសុខទេ ព្រោះពួកសាវករបស់អាជីវកប្រើប្រាស់ខ្ញុំ ដោយការបម្រើជាកូនប្រសាបានតែត្រឹម១ខែទេ តពីនោះមក ក៏ប្រើប្រាស់ខ្ញុំដោយការបម្រើជាទាសីទៅវិញ សូមឲ្យអ្នកម្តាយខ្ញុំ អញ្ជើញមកនាំយកខ្ញុំទៅផង។ ប្រពន្ធហោរានោះ ចូលទៅឯទីដែលឧទាយិភិក្ខុនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុក្នុងលើកទី២ថា បពិត្រលោកម្ចាស់ ឮដំណឹងថា នាងកុមារីនោះ ជាស្រ្តីដល់នូវសេចក្តីក្រីក្រលំបាកណាស់ មិនបានសេចក្តីសុខទេ ព្រោះពួកសាវករបស់អាជីវកប្រើប្រាស់វា ដោយការបម្រើជាកូនប្រសាបានតែត្រឹម១ខែទេ តពីនោះមក ក៏ប្រើប្រាស់ដោយការបម្រើជាទាសីទៅវិញ បពិត្រលោកដ៏ចំរើន គួរលោកម្ចាស់ទៅនិយាយនឹងគេថា ម្នាលអ្នកទាំងឡាយ អ្នកទាំងអស់គ្នា កុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាខ្ញុំស្រី ចូរប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាកូនប្រសាវិញ។ ឧទាយិភិក្ខុឆ្លើយថា កាលពីមុន ពួកសាវករបស់អាជីវក ធ្វើអាត្មាមិនឲ្យជ្រះថ្លាម្តងទៅហើយ ឥឡូវនេះ នាងចូលទៅចុះ អាត្មាមិនទៅទៀតទេ។

[១២៤] គ្រានោះឯង ប្រពន្ធហោរានោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ឧទាយិភិក្ខុថា នាងកុមារីកូនអញ ដល់នូវសេចក្តីក្រីក្រលំបាក មិនបានសេចក្តីសុខយ៉ាងណាៗ ក៏ព្រោះតែម្តាយក្មេកអាក្រក់ ព្រោះតែអាពុកក្មេកអាក្រក់ ព្រោះតែប្តីអាក្រក់ ចូរឲ្យលោកម្ចាស់ឧទាយិក្រីក្រដូចយ៉ាងកូនអញ ចូរឲ្យលោកម្ចាស់ឧទាយិលំបាកដូចយ៉ាងកូនអញ ចូរឲ្យលោកម្ចាស់ឧទាយិកុំបានសេចក្តីសុខដូចយ៉ាងកូនអញទៅចុះ ទាំងនាងកុមារីសោត ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ឧទាយិភិក្ខុថា អញដល់នូវសេចក្តីក្រីក្រលំបាក មិនបានសេចក្តីសុខយ៉ាងណាៗ ក៏ព្រោះតែម្តាយក្មេកអាក្រក់ ព្រោះតែអាពុកក្មេកអាក្រក់ ព្រោះតែប្តីអាក្រក់ ចូរឲ្យលោកម្ចាស់ឧទាយិក្រីក្រដូចយ៉ាងអញ ឲ្យលោកម្ចាស់ឧទាយិលំបាកដូចយ៉ាងអញ ឲ្យលោកម្ចាស់ឧទាយិកុំបានសេចក្តីសុខដូចយ៉ាងអញទៅចុះ។ ទាំងពួកស្រីដទៃ ដែលម្តាយក្មេកក្តី អាពុកក្មេកក្តី ប្តីក្តី មិនត្រេកអរ ស្រីទាំងនោះក៏ផ្តន់ទាថា យើងដល់នូវសេចក្តីក្រីក្រលំបាក មិនបានសេចក្តីសុខយ៉ាងណាៗ ក៏ព្រោះតែម្តាយក្មេកអាក្រក់ ព្រោះតែអាពុកក្មេកអាក្រក់ ព្រោះតែប្តីអាក្រក់ ឲ្យលោកម្ចាស់ឧទាយិក្រីក្រដូចយ៉ាងយើង ឲ្យលោកម្ចាស់ឧទាយិលំបាកដូចយ៉ាងយើង ឲ្យលោកម្ចាស់ឧទាយិកុំបានសេចក្តីសុខដូចយ៉ាងយើងទៅចុះ។ ឯពួកស្រីណាដែលម្តាយក្មេកក្តី អាពុកក្មេកក្តី ប្តីក្តី ត្រេកអរហើយ ពួកស្រីទាំងនោះក៏បន់ស្រន់យ៉ាងនេះថា យើងដល់នូវសេចក្តីសុខបរិបូណ៌ដោយគ្រឿងស្អិតស្អាង ដល់នូវសេចក្តីសប្បាយយ៉ាងណាៗ ក៏ព្រោះតែម្តាយក្មេកល្អ ព្រោះតែអាពុកក្មេកល្អ ព្រោះតែប្តីល្អ សូមឲ្យលោកម្ចាស់ឧទាយិដល់នូវសេចក្តីសុខដូចយ៉ាងយើង សូមឲ្យលោកម្ចាស់ឧទាយិបរិបូណ៌ដោយគ្រឿងស្អិតស្អាងដូចយ៉ាងយើង សូមឲ្យលោកម្ចាស់ឧទាយិដល់នូវសេចក្តីសប្បាយដូចយ៉ាងយើងចុះ។

[១២៥] ភិក្ខុទាំងឡាយឮស្រីខ្លះកាលផ្តន់ទាឲ្យវិនាស ស្រីខ្លះកាលបន់ស្រន់ឲ្យចំរើន (ដល់ឧទាយិភិក្ខុនោះ)។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស។បេ។ ពួកភិក្ខុនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើឧទាយិភិក្ខុដ៏មានអាយុប្រព្រឹត្តនិយាយដឹកនាំស្រីឲ្យប្រុស ដឹកនាំប្រុសឲ្យស្រីសោះ។ គ្រានោះឯង ភិក្ខុទាំងឡាយនោះក៏ក្រាបទូលរឿងនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃមកក្នុងពេលនោះ ហើយទ្រង់សួរបញ្ជាក់ឧទាយិភិក្ខុដ៏មានអាយុដូច្នេះថា ម្នាលឧទាយិ ឮថាអ្នកឯង ប្រព្រឹត្តនិយាយដឹកនាំស្រីប្រុសពិតមែនឬ។ ឧទាយិភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនុ៎ះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណ មិនគួរសោះ មិនគប្បីធ្វើសោះឡើយ ម្នាលមោឃបុរស គួរបើដែរ អ្នកឯងហ៊ានប្រព្រឹត្តនិយាយដឹកនាំស្រីប្រុស ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លានោះទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយ ប្រព្រឹត្តនិយាយដឹកនាំ គឺប្រាប់សេចក្តីប្រាថ្នាប្រុសដល់ស្រីក្តី ប្រាប់សេចក្តីប្រាថ្នាស្រីដល់ប្រុសក្តី ឲ្យបានគ្នាជាប្រពន្ធក្តី ជាប្តីឬជាសហាយក្តី ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយដោយប្រការដូច្នេះឯង។

[១២៦] សម័យនោះឯង មានពួកអ្នកលេងច្រើនអ្នក ជាអ្នកញុំាងស្រីឲ្យបម្រើក្នុងឱទ្យាន បានប្រើបម្រើទៅឯសំណាក់ស្រីផ្កាមាសម្នាក់ថាឲ្យនាងមក យើងទាំងឡាយនឹងឲ្យនាងបម្រើយើងក្នុងឱទ្យាន។ ស្រីផ្កាមាសនោះ បាននិយាយតបយ៉ាងនេះថា ម្នាលអ្នកទាំងឡាយ ខ្ញុំឯងឥតស្គាល់អស់អ្នករាល់គ្នាថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ខ្ញុំជាអ្នកមានទ្រព្យច្រើន មានបរិក្ខារច្រើន ទាំងមានកិច្ចត្រូវទៅខាងក្រៅក្រុងផង ខ្ញុំនឹងទៅមិនបានទេ។ លំដាប់នោះឯង អ្នកបម្រើនោះក៏បានប្រាប់សេចក្តីនុ៎ះដល់ពួកអ្នកលេងទាំងនោះវិញ។ កាលបើអ្នកបម្រើប្រាប់យ៉ាងនេះហើយ មានបុរសម្នាក់និយាយពាក្យនេះនឹងពួកអ្នកលេងនោះថា នែអ្នកទាំងឡាយ ចុះអ្នកទាំងអស់គ្នាអង្វរស្រីផ្កាមាសនោះធ្វើអ្វី គួរតែអ្នកទាំងឡាយនិយាយនឹងលោកម្ចាស់ឧទាយិទេតើ លោកម្ចាស់ឧទាយិនឹងបញ្ជូន (ស្រីផ្កាមាសនោះ) មកឲ្យ។ កាលបើបុរសនោះនិយាយយ៉ាងនេះហើយ មានឧបាសកម្នាក់ពោលពាក្យនេះនឹងបុរសនោះថា អ្នកកុំនិយាយយ៉ាងនេះ កិរិយាធ្វើនូវអំពើមានសភាពយ៉ាងនេះ មិនគួរដល់ពួកសមណ ជាកូនចៅព្រះពុទ្ធជាសក្យបុត្រទេ លោកម្ចាស់ឧទាយិក៏មិនធ្វើអំពើយ៉ាងនេះដែរ។ កាលបើឧបាសកនោះពោលដូច្នេះហើយ ជនទាំងឡាយក៏តាំងភ្នាល់គ្នាថា លោកម្ចាស់ឧទាយិនឹងធ្វើអំពើនេះ នឹងមិនធ្វើអំពើនេះ។ គ្រានោះឯង ពួកអ្នកលេងក៏ចូលទៅត្រង់ទីដែលឧទាយិភិក្ខុនៅ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ពួកយើងកាលឲ្យស្រីបម្រើក្នុងឱទ្យាននេះ បានប្រើបម្រើទៅឯសំណាក់ស្រីផ្កាមាសឈ្មោះឯណោះថា ឲ្យស្រីផ្កាមាសមក យើងនឹងឲ្យនាងបម្រើក្នុងឱទ្យាន តែស្រីផ្កាមាសនោះឆ្លើយតបយ៉ាងនេះថា ម្នាលអ្នកទាំងឡាយ ខ្លួនខ្ញុំមិនធ្លាប់ស្គាល់អ្នកទាំងឡាយថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ខ្ញុំជាអ្នកមានទ្រព្យច្រើន មានគ្រឿងបរិក្ខារច្រើន ទាំងមានកិច្ចត្រូវទៅខាងក្រៅក្រុងផង ខ្ញុំនឹងមិនទៅទេ បពិត្រលោកដ៏ចំរើន យើងសូមពឹងលោកម្ចាស់ សូមលោកម្ចាស់បញ្ជូនស្រីផ្កាមាសនោះមកឲ្យយើង។ គ្រានោះឯង ឧទាយិភិក្ខុដ៏មានអាយុក៏ចូលទៅត្រង់ទីដែលស្រីផ្កាមាសនោះនៅ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងស្រីផ្កាមាសនោះថា ហេតុដូចម្តេច បានជានាងឯងមិនទៅរកអ្នកលេងទាំងនេះ។ ស្រីផ្កាមាសនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាមិនស្គាល់អ្នកអស់នេះថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ខ្ញុំព្រះករុណាជាអ្នកមានទ្រព្យច្រើន មានគ្រឿងបរិក្ខារច្រើន ទាំងមានកិច្ចត្រូវទៅខាងក្រៅក្រុងផង ខ្ញុំនឹងមិនទៅទេ។ ឧទាយិភិក្ខុឆ្លើយថា នាងចូរទៅរកអ្នកទាំងនេះចុះ អាត្មាធ្លាប់ស្គាល់អ្នក

ទាំងនេះដែរ។ ស្រីផ្កាមាសឆ្លើយថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ស្គាល់គេ ខ្ញុំព្រះករុណានឹងទៅ។ គ្រានោះឯង ពួកអ្នកលេងនោះ ក៏នាំស្រីផ្កាមាសនោះទៅឯឱទ្យាន។ វេលានោះ ឧបាសកនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកម្ចាស់ឧទាយិប្រព្រឹត្តនិយាយដឹកនាំស្រី ដែលបុរសគប្បីសេពមួយរំពេចនោះសោះ។ ភិក្ខុទាំងឡាយបានឮពាក្យឧបាសកនោះពោលទោស តិះដៀលបន្តុះបង្អាប់ (ដូច្នោះ)។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើឧទាយិដ៏មានអាយុប្រព្រឹត្តនិយាយដឹកនាំស្រីដែលបុរសគប្បីសេពមួយរំពេចនោះសោះ។ គ្រានោះឯង ពួកភិក្ខុនោះ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ឲ្យប្រជុំភិក្ខុសង្ឃក្នុងពេលនោះ ហើយទ្រង់សួរបញ្ជាក់ឧទាយិភិក្ខុដ៏មានអាយុដូច្នេះទៀតថា ម្នាលឧទាយិ ឮថាអ្នកឯង ប្រព្រឹត្តនិយាយដឹកនាំស្រីដែលបុរសគប្បីសេពមួយរំពេចនោះមែនឬ។ ឧទាយិ ភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនសមគួរទេ មិនត្រូវទំនងទេ។បេ។ ម្នាលមោឃបុរស គួរបើដែរ អ្នកឯងប្រព្រឹត្តនិយាយដឹកនាំស្រីដែលបុរសគប្បីសេពមួយរំពេចនោះ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយប្រព្រឹត្តនិយាយដឹកនាំ គឺប្រាប់សេចក្ដីប្រាថ្នាប្រុសដល់ស្រីក្ដី ប្រាប់សេចក្ដីប្រាថ្នាស្រីដល់ប្រុសក្ដី ឲ្យបានគ្នាជាប្រពន្ធក្ដី ជាប្ដីឬជាសហាយក្ដី ដោយហោចទៅសូម្បីតែស្រីដែលបុរសគប្បីនៅរួមអសទ្ធម្មមួយរំពេច[15] នោះ ត្រូវអាបត្តិសង្ឃាទិសេស។**

[១២៧] ត្រង់ពាក្យថា ភិក្ខុណាមួយ បានអធិប្បាយក្នុងសិក្ខាបទទី១នៃបឋមបារាជិករួចហើយ។ ត្រង់ពាក្យថា ប្រព្រឹត្តនិយាយដឹកនាំ សេចក្ដីថា ភិក្ខុដែលស្រីបង្គាប់ឲ្យទៅកាន់សំណាក់ប្រុសក្ដី ភិក្ខុដែលប្រុសបង្គាប់ឲ្យទៅកាន់សំណាក់ស្រីក្ដី។ ត្រង់ពាក្យថា ប្រាប់សេចក្ដីប្រាថ្នាប្រុសដល់ស្រីក្ដី គឺប្រាប់បំណងរបស់ប្រុសដល់ស្រីក្ដី។ ត្រង់ពាក្យថា ប្រាប់សេចក្ដីប្រាថ្នាស្រីដល់ប្រុសក្ដី គឺប្រាប់គំនិតរបស់ស្រីដល់ប្រុសក្ដី។ ត្រង់ពាក្យថា ឲ្យបានគ្នាជាប្រពន្ធក្ដី គឺប្រាប់ថា នាងឯងនឹងជាប្រពន្ធគេ។ ត្រង់ពាក្យថា ជាប្ដីឬជាសហាយក្ដី គឺប្រាប់ថា អ្នកឯងនឹងជាសហាយគេ។ ត្រង់ពាក្យថា ដោយហោចទៅ សូម្បីតែស្រីដែលបុរសគប្បីសេពមួយរំពេចនោះ គឺប្រាប់ថា នាងឯងនឹងជាស្រីដែលបុរសគប្បីសេពមួយស្របក់។ ត្រង់ពាក្យថា សង្ឃាទិសេស បានអធិប្បាយក្នុងសង្ឃាទិសេសទី១រួចហើយ។

[១២៨] ស្រីមាន១០ពួក គឺមាតុរក្ខិតា១ បិតុរក្ខិតា១ មាតាបិតុរក្ខិតា១ ភាតុរក្ខិតា១ ភគិនីរក្ខិតា១ ញាតិរក្ខិតា១ គោត្តរក្ខិតា១ ធម្មរក្ខិតា១ សារក្ខា១ សបរិទណ្ឌា១។

[១២៩] ភរិយាមាន១០ពួកគឺ ធនក្កីតា១ ឆន្ទវាសិនី១ ភោគវាសិនី១ បដវាសិនី១ ឱទបត្តកិនី១ ឱភតចុម្ពដា១ ទាសីភរិយា១ កម្មការីភរិយា១ ធជាហដា១ មុហុត្តិកា១។

[១៣០] ស្រីដែលម្ដាយថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថាមាតុរក្ខិតា។ ស្រីដែលឪពុកថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា បិតុរក្ខិតា។ ស្រីដែលម្ដាយឪពុកថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា មាតាបិតុរក្ខិតា។ ស្រីដែលបងប្អូនប្រុសថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា ភាតុរក្ខិតា។ ស្រីដែលបងប្អូនស្រីថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា ភគិនីរក្ខិតា។ ស្រីដែលពួកញាតិថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា ញាតិរក្ខិតា។ ស្រីដែលជនមានគោត្រវង្សស្មើគ្នាថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា គោត្តរក្ខិតា។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នាថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា ធម្មរក្ខិតា។ ស្រីដែលប្រុសថែរក្សាទុកតាំងពីក្នុងផ្ទៃ ដោយតាំងចិត្តថា នាងនេះជារបស់អញ ដោយហោចទៅសូម្បីតែស្រីដែលប្រុសបំពាក់ផ្កាកម្រង (ស្រីនេះឯង) ហៅថា សារក្ខា។ អាជ្ញាដែលស្ដេចអង្គណា១ ទ្រង់តាំងទុកដូច្នេះថា បើបុរសណាមករួមនឹងស្រីឈ្មោះនេះ នឹងត្រូវពិន័យប៉ុណ្ណេះដល់បុរសនោះ (ស្រីនេះ) ហៅថា សបរិទណ្ឌា។

[១៣១] ភរិយាដែលបុរសលោះនឹងទ្រព្យ ហើយឲ្យនៅរួមជាមួយ ហៅថា ធនក្កីតា។ ប្រុសជាទីស្រឡាញ់របស់ស្រី ឲ្យស្រីជាទីស្រឡាញ់នៅរួមជាមួយ ហៅថា ឆន្ទវាសិនី។ ភរិយាដែលប្រុសឲ្យភោគ[16] ហើយឲ្យនៅរួមជាមួយ ហៅថា ភោគវាសិនី។ ភរិយាដែលប្រុសឲ្យសម្ពត់ស្លៀកដណ្ដប់ ហើយឲ្យនៅរួមជាមួយ ហៅថា បដវាសិនី។ ភរិយាដែលញាតិចាប់ដៃផ្ដុំជាមួយនឹងបុរសជ្រលក់ក្នុងភាជនទឹក ហើយគេផ្សំឲ្យនៅរួមជាមួយ ហៅថា ឱទបត្តកិនី។ ភរិយាដែលប្រុសដាក់ទ្រនូលឲ្យ ហើយឲ្យនៅរួមជាមួយគ្នា ហៅថាឱភតចុម្ពដា។ ស្រីដែលប្រើប្រាស់ជាខ្ញុំផង ជាភរិយាផង ហៅថា ទាសីភរិយា។ ស្រីដែលធ្វើការឈ្នួលផង ជាភរិយាផង ហៅថា កម្មការីភរិយា។ ស្រីដែលគេចាប់ពីកងទ័ព យកមកធ្វើជាភរិយា ហៅថា ធជាហដា។ ស្រីដែលប្រុសបាននៅរួមគ្នាមួយរំពេចនោះ ហៅថា មុហុត្តិកា។

[១៣២] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលមាតារក្សាដូច្នេះថា គេថានាងឯងចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបិតារក្សា។បេ។ សូមលោកទៅនិយាយនឹងស្រីដែលមាតានិងបិតារក្សា។ សូមលោកទៅនិយាយនឹងស្រីដែលបងប្អូនប្រុសរក្សា។ សូមលោកទៅនិយាយនឹងស្រីដែលបងប្អូនស្រីរក្សា។ សូមលោកទៅនិយាយនឹងស្រីដែលញាតិរក្សា។ សូមលោកទៅនិយាយនឹងស្រីដែលជនមានគោត្រវង្សស្មើគ្នារក្សា។ សូមលោកទៅនិយាយនឹងស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សា។ សូមលោកទៅនិយាយនឹងស្រីដែលប្រុសប្រកាន់ទុក។ សូមលោកទៅនិយាយនឹងស្រីដែលមានអាជ្ញាស្ដេចតាំងទុកដូច្នេះថា គេថានាងឯងចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយវិលមក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

និក្ខេបបទទាំងឡាយ ចប់។

[១៣៣] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលមាតារក្សាផង និងស្រីឈ្មោះនេះដែលបិតារក្សាផងថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលមាតារក្សាផង និងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង។បេ។ ស្រីដែលមាតារក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលញាតិរក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលប្រុសហួងហែងផង។សូមលោកទៅនិយាយនឹងស្រីដែលមាតារក្សាផង និង ស្រីដែលស្តេចដាក់អាជ្ញាផងដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[១៣៤] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបិតារក្សាផង និងស្រីឈ្មោះនេះដែលមាតាបិតារក្សាផងដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ។ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបិតារក្សាផង និងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលញាតិរក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលប្រុសហួងហែងផង។ ស្រីដែលបិតារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាផងដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបិតារក្សាផង និងស្រីឈ្មោះនេះដែលមាតារក្សាផងដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

[១៣៥] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលមាតាបិតារក្សាផង និងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលញាតិរក្សាផង។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលប្រុសហួងហែងផង។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាផង។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលមាតារក្សាផង។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលបិតារក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កទី ២ ចប់។

[១៣៦] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបងប្អូនប្រុសរក្សាផង និងស្រីឈ្មោះនេះដែលបងប្អូនស្រីរក្សាផង។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលញាតិរក្សាផង។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលប្រុសហួងហែងផង។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលស្តេចដាក់អាជ្ញាផង។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលមាតារក្សាផង។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលបិតារក្សាផង។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលមាតាបិតារក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កទី ៣ ចប់។

[១៣៧] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបងប្អូនស្រីរក្សាផង និងស្រីឈ្មោះនេះដែលញាតិរក្សាផង។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលប្រុសហួងហែងផង។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលស្តេចដាក់អាជ្ញាផង។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលមាតារក្សាផង។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលបិតារក្សាផង។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលមាតាបិតារក្សាផង។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កទី ៤ ចប់។

[១៣៨] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលញាតិរក្សាផង និងស្រីឈ្មោះនេះដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលញាតិរក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលញាតិរក្សាផង ស្រីដែលប្រុសហួងហែងផង។ ស្រីដែលញាតិរក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង។ ស្រីដែលញាតិរក្សាផង ស្រីដែលមាតារក្សាផង។ ស្រីដែលញាតិរក្សាផង ស្រីដែលបិតារក្សាផង។ ស្រីដែលញាតិរក្សាផង ស្រីដែលមាតាបិតារក្សាផង។ ស្រីដែលញាតិរក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង ស្រី

ដែលញាតិរក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កទី ៥ ចប់។

[១៣៩] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលជនមានគោត្រស្មើគ្នារក្សាផង និងស្រីឈ្មោះនេះដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលប្រុសហ្មងហែងផង។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលមាតារក្សាផង។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលបិតារក្សាផង។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលមាតាបិតារក្សាផង។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលញាតិរក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កទី ៦ ចប់។

[១៤០] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង និងស្រីឈ្មោះនេះដែលបុរសហ្មងហែងផង។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលមាតារក្សាផង។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលបិតារក្សាផង។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលមាតាបិតារក្សាផង។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលញាតិរក្សាផង។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កទី ៧ ចប់។

[១៤១] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលប្រុសហ្មងហែងផង និងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង។ ស្រីដែលប្រុសហ្មងហែងផង ស្រីដែលមាតារក្សាផង។ ស្រីដែលប្រុសហ្មងហែងផង ស្រីដែលបិតារក្សាផង។ ស្រីដែលប្រុសហ្មងហែងផង ស្រីដែលមាតាបិតារក្សាផង។ ស្រីដែលប្រុសហ្មងហែងផង ស្រីដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលប្រុសហ្មងហែងផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលប្រុសហ្មងហែងផង ស្រីដែលញាតិរក្សាផង។ ស្រីដែលប្រុសហ្មងហែងផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលប្រុសហ្មងហែងផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កទី ៨ ចប់។

[១៤២] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង និងស្រីឈ្មោះនេះដែលមាតារក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបិតារក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលមាតាបិតារក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលញាតិរក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលប្រុសហ្មងហែងផង ដូច្នេះថា គេថា នាងទាំងពីរ ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្កមានមូល៩ ចប់។

ចក្កមានមូល១ ចប់។

[១៤៣] ចក្កមានមូល២ មូល៣ មូល៤ មូល៥ មូល៦ មូល៧ មូល៨ មូល៩ ត្រូវធ្វើដូចចក្កមានមូល១ផងចុះ។

នេះចក្កមានមូល១០ (ដូចមានសេចក្តីតទៅនេះ)

[១៤៤] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង នឹងស្រីឈ្មោះនេះដែលបិតារក្សាផង នឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនស្រីរក្សាផង នឹងស្រីឈ្មោះនេះដែលញាតិរក្សាផង នឹងស្រីឈ្មោះនេះដែលជនមានគោត្រស្មើគ្នារក្សាផង នឹងស្រីឈ្មោះនេះដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង នឹងស្រីឈ្មោះនេះដែលប្រុសហ្មងហែងផង នឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង ដូច្នេះថា គេថា នាងទាំងអស់គ្នា ចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ធនក្កីតាចក្ក ចប់។

[១៤៥] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ដូច្នេះថា គេថា នាងចូរជាធនក្កីតាភរិយា ជាឆន្ទវាសិនីភរិយា ជាភោគវាសិនីភរិយា ជាបដវាសិនីភរិយា ជាឱទបត្តកិនីភរិយា ជាឱភដចុម្ពដាភរិយា ជាទាសីផង ជាភរិយាផង ជាកម្មការីផង ជាភរិយាផង ជាធជាហដាភរិយា ជាមុហុត្តិកាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។បេ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលបិតារក្សា។ សូមលោកទៅនិយាយនឹងស្រីដែលមាតាបិតារក្សា។ សូមលោកទៅនិយាយនឹងស្រីដែលបងប្អូនប្រុសរក្សា។ សូមលោកទៅនិយាយនឹងស្រីដែលញាតិរក្សា។ សូមលោកទៅនិយាយនឹងស្រីដែលជនមានគោត្រស្មើគ្នារក្សា។ សូមលោកទៅនិយាយនឹងស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សា។ សូមលោកទៅនិយាយនឹងស្រីដែលប្រុសហួងហែង។ សូមលោកទៅនិយាយនឹងស្រីដែលស្តេចដាក់អាជ្ញាទុកថាដូច្នេះ គេថា នាងចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

និក្ខេបបទទាំងឡាយ ចប់។

[១៤៦] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង និងស្រីឈ្មោះនេះដែលបិតារក្សាផង ថាដូច្នេះ គេថា នាងទាំងពីរនាក់ ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង និងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលញាតិរក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលមាតារក្សាផង ស្រីដែលប្រុសហួងហែងផង។ ស្រីដែលមាតារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង ថាដូច្នេះ គេថា នាងរាល់គ្នា ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[១៤៧] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលបិតារក្សាផង និងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង ថាដូច្នេះ គេថា នាងរាល់គ្នា ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលបិតារក្សាផង និងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលញាតិរក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលបិតារក្សាផង ស្រីដែលបុរសហួងហែងផង។ ស្រីដែលបិតារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង។ ស្រីដែលបិតារក្សាផង ស្រីដែលមាតារក្សាផង ថាដូច្នេះ គេថា នាងរាល់គ្នា ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

នេះជាមូលដែលព្រះដ៏មានព្រះភាគសំដែងដោយសង្ខេប។

[១៤៨] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង និងស្រីឈ្មោះនេះដែលមាតារក្សាផង ថាដូច្នេះ គេថា នាងទាំងពីរនាក់ ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង និងស្រីឈ្មោះនេះដែលបិតារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលមាតាបិតារក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបងប្អូនប្រុសរក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបងប្អូនស្រីរក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលញាតិរក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលប្រុសហួងហែងផង ថាដូច្នេះ គេថា នាងរាល់គ្នា ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូល១ ចប់។

[១៤៩] ចក្កមានមូល២ មានមូល៣ មានមូល៤ មានមូល៥ មានមូល៦ មានមូល៧ មានមូល៨ មានមូល៩ បណ្ឌិតគប្បីធ្វើដូចចក្កដែលមានមូល១ផងចុះ។

នេះចក្កមានមូល១០ (ដូចមានសេចក្តីតទៅនេះ)

[១៥០] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង នឹងស្រីឈ្មោះនេះដែលបិតារក្សាផង នឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនស្រីរក្សាផង នឹងស្រីឈ្មោះនេះដែលញាតិរក្សាផង នឹងស្រីឈ្មោះនេះដែលជនមានគោត្រស្មើគ្នារក្សាផង នឹងស្រីឈ្មោះនេះដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង នឹង

ស្រីឈ្មោះនេះដែលប្រុសហ្លួងហែងផង នឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង ថាដូច្នេះ គេថា នាងទាំងអស់គ្នា ចូរជាមុហុត្តិកាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

មុហុត្តិកាចក្ក ចប់។

[១៥១] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ដូច្នេះថា គេថា នាងចូរជាធនក្កីតាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ថាដូច្នេះ គេថា នាងចូរជាឆន្ទវាសិនីភរិយា ចូរជាភោគវាសិនីភរិយា ចូរជាបដវាសិនីភរិយា ចូរជាឱទបត្តកិនីភរិយា ចូរជាឱភតចុម្ពដាភរិយា ចូរជាទាសីផង ភរិយាផង ចូរជាកម្មការីផង ជាភរិយាផង ចូរជាធជាហដាភរិយា ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

និក្ខេបបទទាំងឡាយ ចប់។

[១៥២] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ថាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផងនៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ថាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយាផង ជាភោគវាសិនីភរិយាផង។ ជាធនក្កីតាភរិយាផង ជាបដវាសិនីភរិយាផង។ ជាធនក្កីតាភរិយាផង ជាឱទបត្តកិនីភរិយាផង។ ជាធនក្កីតាភរិយាផង ជាឱភតចុម្ពដាភរិយាផង។ ជាធនក្កីតាភរិយាផង និងជាទាសីផង ភរិយាផង។ ជាធនក្កីតាភរិយាផង និងជាកម្មការីផង ភរិយាផង។ ជាធនក្កីតាភរិយាផង ជាធជាហដាភរិយាផង។ ជាធនក្កីតាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[១៥៣] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ថាដូច្នេះ គេថា នាងចូរជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ។បេ។ ជាឆន្ទវាសិនីភរិយាផង ជាមុហុត្តិកាភរិយាផង។ ជាឆន្ទវាសិនីភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

នេះជាមូលដែលព្រះដ៏មានព្រះភាគសំដែងដោយសង្ខេប។

[១៥៤] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ថាដូច្នេះ គេថា នាងចូរជាមុហុត្តិកាភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះទៅ។ ជាមុហុត្តិកាភរិយាផង ជាឆន្ទវាសិនីភរិយាផង។បេ។ ជាមុហុត្តិកាភរិយាផង ជាធជាហដាភរិយាផង នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូល១ ចប់។

[១៥៥] ចក្កមានមូល២ មានមូល៣ មានមូល៤ មានមូល៥ មានមូល៦ មានមូល៧ មានមូល៨ មានមូល៩ បណ្ឌិតគប្បីធ្វើដូចចក្កមានមូល១ផងចុះ។

នេះចក្កមានមូល១០ (ដូចមានសេចក្តីតទៅនេះ)។

[១៥៦] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលម្តាយរក្សា ថាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៥៧] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីបិតុរក្ខិតា[17] ឈ្មោះនេះ។ សូមលោកទៅនិយាយនឹងស្រីមាតាបិតុរក្ខិតា។ សូមលោកទៅនិយាយនឹងស្រីភាតុរក្ខិតា។ សូមលោកទៅនិយាយនឹងស្រីភគិនីរក្ខិតា។ សូមលោកទៅនិយាយនឹងស្រីញាតិរក្ខិតា។ សូមលោកទៅនិយាយនឹងស្រីគោត្តរក្ខិតា។ សូមលោកទៅនិយាយនឹងស្រីធម្មរក្ខិតា។ សូមលោកទៅនិយាយនឹងស្រីសារក្ខា។ សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះ ថាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះ ថាដូច្នេះ គេថា នាងចូរជាឆន្ទវាសិនីភរិយា ជាភោគវាសិនីភរិយា ជាបដវាសិនីភរិយា ជាឱទបត្តកិនីភរិយា

ជាឱភតចុម្ពដាភរិយា និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយា ជាមុហុត្តិកាភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

និក្ខេបបទទាំងឡាយ ចប់។

[១៥៨] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះ ថាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះ ថាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ។ ជាធនក្កីតាភរិយាផង ជាបដវាសិនីភរិយាផង។ ជាធនក្កីតាភរិយាផង ជាឱទបត្តកិនីភរិយាផង។ ជាធនក្កីតាភរិយាផង ជាឱភតចុម្ពដាភរិយាផង។ ជាធនក្កីតាភរិយាផង និងជាទាសីផងភរិយាផង។ ជាធនក្កីតាភរិយាផង និងជាកម្មការីផងភរិយាផង។ ជាធនក្កីតាភរិយាផង ជាធជាហដាភរិយាផង។ ជាធនក្កីតាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[១៥៩] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះ ថាដូច្នេះ គេថា នាងចូរជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាបដវាសិនីភរិយាផង។បេ។ ជាឆន្ទវាសិនីភរិយាផង ជាមុហុត្តិកាភរិយា ជាឆន្ទវាសិនីភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

នេះជាមូលដែលព្រះដ៏មានព្រះភាគសំដែងដោយសង្ខេប។

[១៦០] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះ ថាដូច្នេះ គេថា នាងចូរជាមុហុត្តិកាភរិយាផង ជាធនក្កីតាភរិយាផង។បេ។ ជាមុហុត្តិកាភរិយាផង ជាធជាហដាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូល១ ចប់។

[១៦១] ចក្កមានមូល២ មានមូល៣ មានមូល៤ មានមូល៥ មានមូល៦ មានមូល៧ មានមូល៨ មានមូល៩ បណ្ឌិតគប្បីធ្វើដូចចក្កមានមូល១ផងចុះ។

នេះចក្កមានមូល១០ (ដូចមានសេចក្តីតទៅនេះ)។

[១៦២] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះ ថាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៦៣] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីមាតុរក្ខិតាឈ្មោះនេះ ថាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីមាតុរក្ខិតាឈ្មោះនេះផង បិតុរក្ខិតាឈ្មោះនេះផង ថាដូច្នេះ គេថា នាងរាល់គ្នាចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីមាតុរក្ខិតាឈ្មោះនេះផង បិតុរក្ខិតាឈ្មោះនេះផង ស្រីមាតាបិតុរក្ខិតាឈ្មោះនេះផង ថាដូច្នេះ គេថា នាងរាល់គ្នា ចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ឧភតោពទ្ធចក្ក បណ្ឌិតគប្បីធ្វើយ៉ាងនេះ។

នេះចក្កមានមូលគ្រប់ទាំងអស់[18] (ដូចមានសេចក្តីតទៅនេះ)។

[១៦៤] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីមាតុរក្ខិតាឈ្មោះនេះផង បិតុរក្ខិតាឈ្មោះនេះផង មាតាបិតុរក្ខិតាឈ្មោះនេះផង ភាតុរក្ខិតាឈ្មោះនេះផង ភគិនីរក្ខិតាឈ្មោះនេះផង ញាតិរក្ខិតាឈ្មោះនេះផង គោត្តរក្ខិតាឈ្មោះនេះផង ធម្មរក្ខិតាឈ្មោះនេះផង សារក្ខាឈ្មោះនេះផង សបរិទណ្ឌាឈ្មោះនេះផង ថាដូច្នេះ គេថា នាងរាល់គ្នា ចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង និងជាទាសីផងភរិយាផង និងជាកម្មការីផង

ភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់បុរសនោះ) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ឧភតោពទ្ធចក្ក ចប់។

[១៦៥] ម្តាយបុរសបញ្ជូនភិក្ខុទៅ។បេ។ ឪពុកបុរសបញ្ជូនភិក្ខុទៅ។បេ។ ម្តាយឪពុកបុរសបញ្ជូនភិក្ខុទៅ។បេ។ បងប្អូនប្រុសរបស់បុរសបញ្ជូនភិក្ខុទៅ។បេ។ បងប្អូនស្រីរបស់បុរសបញ្ជូនភិក្ខុទៅ។បេ។ ពួកញាតិរបស់បុរសបញ្ជូនភិក្ខុទៅ។បេ។ ពួកគោត្ររបស់បុរសបញ្ជូនភិក្ខុទៅ។បេ។ ពួកជនប្រព្រឹត្តធម៌ត្រូវគ្នារបស់បុរសបញ្ជូនភិក្ខុទៅ។បេ។ (សេចក្តីបំប្រួញអំពីរឿងបុរស បណ្ឌិតគប្បីឲ្យពិស្តារចុះ។ ឧភតោពទ្ធក[19] ដែលព្រះសង្គីតិកាចារ្យឲ្យពិស្តារហើយយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះផងចុះ។

[១៦៦] ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើនចូរជាធនក្កីតាភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើនចូរជាឆន្ទវាសិនីភរិយា ជាភោគវាសិនីភរិយា ជាបដវាសិនីភរិយា ជាឱទបត្តកិនីភរិយា ជាឱភតចុម្ពដាភរិយា និងជាទាសីផង ជាភរិយាផង ជាកម្មការីផងជាភរិយាផង ជាធជាហដាភរិយា ជាមុហុត្តិកាភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

និក្ខេបបទទាំងឡាយ ចប់។

[១៦៧] ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាធនក្កីតាភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ។ ជាធនក្កីតាភរិយាផង ជាបដវាសិនីភរិយាផង។ ជាធនក្កីតាភរិយាផង ជាឱទបត្តកិនីភរិយាផង។ ជាធនក្កីតាភរិយាផង ជាឱភតចុម្ពដាភរិយាផង។ ជាធនក្កីតាភរិយាផង និងជាទាសីផងភរិយាផង។ ជាធនក្កីតាភរិយាផង និងជាកម្មការីផងភរិយាផង។ ជាធនក្កីតាភរិយាផង ជាធជាហដាភរិយាផង។ ជាធនក្កីតាភរិយាផង ជាមុហុត្តិកាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[១៦៨] ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ។បេ។ ជាឆន្ទវាសិនីភរិយាផង ជាមុហុត្តិកាភរិយាផង។ ជាឆន្ទវាសិនីភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

នេះជាមូលដែលព្រះដ៏មានព្រះភាគសំដែងដោយសង្ខេប។

[១៦៩] ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាមុហុត្តិកាភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះទៅ។បេ។ ជាមុហុត្តិកាភរិយាផង ជាធជាហដាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូល១ ចប់។

តាំងពីចក្កមានមូល២ ដរាបដល់ចក្កមានមូល៩ បណ្ឌិតគប្បីធ្វើដូចចក្កមានមូល១ផងចុះ។

នេះចក្កមានមូល១០ (ដូចមានសេចក្តីតទៅនេះ)។

[១៧០] ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៧១] បិតារបស់ស្រីបិតុរក្ខិតា បញ្ជូនភិក្ខុទៅ។ មាតាបិតារបស់ស្រីមាតាបិតុរក្ខិតា បញ្ជូនភិក្ខុទៅ។ បងប្អូនប្រុសរបស់ស្រីភាតុរក្ខិតា បញ្ជូនភិក្ខុទៅ។ បងប្អូនស្រីរបស់ស្រីភគិនីរក្ខិតា បញ្ជូនភិក្ខុទៅ។ ពួកញាតិរបស់ស្រីញាតិរក្ខិតា បញ្ជូនភិក្ខុទៅ។ ពួកគោត្ររបស់ស្រីគោត្តរក្ខិតា បញ្ជូនភិក្ខុទៅ។ ពួកជនប្រព្រឹត្តធម៌ត្រូវគ្នារបស់ស្រីធម្មរក្ខិតា បញ្ជូនភិក្ខុទៅ។ ស្រីដែលអ្នកណាបានប្រកាន់ទុកហើយ អ្នកនោះបញ្ជូនភិក្ខុទៅ ដើម្បីស្រីដែលខ្លួនប្រកាន់ទុក (នោះ)។ អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅ ដើម្បីស្រីដែលព្រះអង្គដាក់កំហិតហើយ (នោះ) ថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាធនក្កីតាភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏

ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅ ដើម្បីស្រីដែលទ្រង់បានដាក់កំហិតហើយ (នោះ) ថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាឆន្ទវាសិនីភរិយា ជាភោគវាសិនីភរិយា ជាបដវាសិនីភរិយា ជាឱទបត្តកិនីភរិយា ជាឱភតចុម្ពដាភរិយា និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយា ជាមុហុត្តិកាភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

និក្ខេបបទទាំងឡាយ ចប់។

[១៧២] អាជ្ញា ដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅ ដើម្បីស្រីដែលទ្រង់ដាក់កំហិតហើយ (នោះ) ថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ។ បេ។ ជាធនក្កីតាភរិយាផង ជាមុហុត្តិកាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[១៧៣] អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅ ដើម្បីស្រីដែលទ្រង់ដាក់កំហិតហើយ (នោះ) ថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ ។បេ។ ជាឆន្ទវាសិនីភរិយាផង ជាមុហុត្តិកាភរិយាផង។ ជាឆន្ទវាសិនីភរិយាផង ជាធនក្កីតាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

នេះជាមូលដែលព្រះដ៏មានព្រះភាគសំដែងដោយសង្ខេប។

[១៧៤] អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅ ដើម្បីស្រីដែលទ្រង់ដាក់កំហិតហើយ (នោះ) ថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាមុហុត្តិកាភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះ។បេ។ ជាមុហុត្តិកាភរិយាផង ជាធជាហដាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូល១ ចប់។

តាំងពីចក្កមានមូល២ ដរាបដល់ចក្កមានមូល៩ បណ្ឌិតគប្បីធ្វើដូចចក្កមានមូល១ផងចុះ។

នេះចក្កមានមូល១០ (ដូចមានសេចក្តីតទៅនេះ)។

[១៧៥] អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចំរើន ចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៧៦] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ខ្ញុំជាធនក្កីតាភរិយានៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ខ្ញុំជាឆន្ទវាសិនីភរិយា ជាភោគវាសិនីភរិយា ជាបដវាសិនីភរិយា ជាឱទបត្តកិនីភរិយា ជាឱភតចុម្ពដាភរិយា និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយា ជាមុហុត្តិកាភរិយា នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

និក្ខេបបទទាំងឡាយ ចប់។

[១៧៧] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង នៃបុរសឈ្មោះនេះ។បេ។ ជាធនក្កីតាភរិយាផង ជាមុហុត្តិកាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[១៧៨] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ខ្ញុំជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះ។បេ។ ជាឆន្ទវាសិនីភរិយាផង ជាមុហុត្តិកាភរិយាផង។ ជាឆន្ទវាសិនីភរិយាផង ជាធនក្កីតាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

នេះជាមូលដែលព្រះដ៏មានព្រះភាគសំដែងដោយសង្ខេប។

[១៧៩] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាមុហុត្តិកាភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះ។បេ។ ជាមុហុត្តិកាភរិយាផង ជាធជាហដាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូល១ ចប់។

ចក្កដ៏សេសមានចក្កមានមូល២ជាដើម បណ្ឌិតគប្បីធ្វើឲ្យដូចចក្កមានមូល១ផងចុះ។

នេះចក្កមានមូល១០ (ដូចមានសេចក្តីតទៅនេះ)។

[១៨០] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

[១៨១] ស្រីបិតុរក្ខិតាបញ្ជូនភិក្ខុទៅ។ ស្រីមាតាបិតុរក្ខិតាបញ្ជូនភិក្ខុទៅ។ ស្រីភាតុរក្ខិតាបញ្ជូនភិក្ខុទៅ។ ស្រីភគិនីរក្ខិតាបញ្ជូនភិក្ខុទៅ។ ស្រីញាតិរក្ខិតាបញ្ជូនភិក្ខុទៅ។ ស្រីគោត្តរក្ខិតាបញ្ជូនភិក្ខុទៅ។ ស្រីធម្មរក្ខិតាបញ្ជូនភិក្ខុទៅ។ ស្រីសារក្ខាបញ្ជូនភិក្ខុទៅ។ ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនក្កីតាភរិយា របស់បុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាឆន្ទវាសិនីភរិយា ជាភោគវាសិនីភរិយា ជាបដវាសិនីភរិយា ជាឱទបត្តកិនីភរិយា ជាឱភតចុម្ពដាភរិយា និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយា ជាមុហុត្តិកាភរិយា នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

និក្ខេបបទទាំងឡាយ ចប់។

[១៨២] ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង នៃបុរសឈ្មោះនេះ។បេ។ ជាធនក្កីតាភរិយាផង ជាមុហុត្តិកាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ខណ្ឌចក្ក ចប់។

[១៨៣] ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះ។បេ។ ជាឆន្ទវាសិនីភរិយាផង ជាមុហុត្តិកាភរិយាផង។ ជាឆន្ទវាសិនីភរិយាផង ជាធនក្កីតាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ពទ្ធចក្ក ចប់។

នេះជាមូលដែលព្រះដ៏មានព្រះភាគសំដែងដោយសង្ខេប។

[១៨៤] ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាមុហុត្តិកាភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះ។បេ។ ជាមុហុត្តិកាភរិយាផង ជាធជាហដាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កមានមូល១ ចប់។

ចក្កមានមូល២ជាដើម បណ្ឌិតគប្បីធ្វើដូចចក្កមានមូល១ផងចុះ។

នេះចក្កមានមូល១០ (ដូចមានសេចក្តីតទៅនេះ)។

[១៨៥] ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ខ្ញុំជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង និងជាទាសីផងភរិយាផង និងជាកម្មការីផងភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។

ចក្កបេយ្យាលគ្រប់ទាំងអស់ ចប់។

[១៨៦] ភិក្ខុទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុទទួលពាក្យ ទៅនិយាយល្បួងមើល តែមិនបានវិលមក (ប្រាប់) វិញ ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុទទួលពាក្យ រួចមិនបាននិយាយល្បួងមើលឡើយ គ្រាន់តែត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុទទួលពាក្យ តែមិនបាននិយាយល្បួងមើល មិនបានត្រឡប់មក (ប្រាប់) វិញឡើយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនទទួលពាក្យ តែបាននិយាយល្បួងមើល ហើយនាំសេចក្តីមក (ប្រាប់) វិញ ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុមិនបានទទួលពាក្យ តែបាននិយាយល្បួងមើល ហើយមិនបានត្រឡប់មក (ប្រាប់) វិញឡើយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនបានទទួលពាក្យ មិនបាននិយាយល្បួងមើល តែបាននាំសេចក្តីមក (ប្រាប់) ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនទទួលពាក្យ មិនបាននិយាយល្បួងមើល មិនបានត្រឡប់មក (ប្រាប់) វិញទេ មិនត្រូវអាបត្តិឡើយ។

[១៨៧] បុរសបង្គាប់ភិក្ខុច្រើនរូបថា បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកគ្រប់អង្គទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ ភិក្ខុទាំងអស់ក៏ទទួលពាក្យ ភិក្ខុទាំងអស់និយាយល្បួងមើល ភិក្ខុទាំងអស់នាំសេចក្តីមក (ប្រាប់) វិញ ភិក្ខុទាំងអស់(នោះ) ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបង្គាប់ភិក្ខុច្រើនរូបថា បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកគ្រប់អង្គទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ ភិក្ខុទាំងអស់ ក៏ទទួលពាក្យ ភិក្ខុទាំងអស់ទៅនិយាយល្បួងមើល ហើយបានឲ្យភិក្ខុមួយរូបវិលមក (ប្រាប់) វិញ ភិក្ខុទាំងអស់(នោះ) ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបង្គាប់ភិក្ខុច្រើនរូបថា បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកគ្រប់អង្គទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ ភិក្ខុទាំងអស់ ក៏ទទួលពាក្យ បានឲ្យភិក្ខុមួយរូបទៅនិយាយល្បួងមើល ហើយភិក្ខុទាំងអស់ក៏វិលមក (ប្រាប់) វិញ ភិក្ខុទាំងអស់(នោះ) ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបង្គាប់ភិក្ខុច្រើនរូបថា បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកគ្រប់អង្គទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ ភិក្ខុទាំងអស់ក៏ទទួលពាក្យ បានចាត់ភិក្ខុមួយរូបឲ្យទៅនិយាយល្បួងមើល ហើយឲ្យភិក្ខុមួយរូបនាំដំណឹងមក (ប្រាប់) វិញ ភិក្ខុទាំងអស់(នោះ) ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបង្គាប់ភិក្ខុថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយវិលមក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបង្គាប់ភិក្ខុថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បួងមើល ហើយប្រើកូនសិស្សឲ្យវិលមក (ប្រាប់) វិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបង្គាប់ភិក្ខុថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ រួចប្រើកូនសិស្សឲ្យទៅនិយាយល្បួងមើល ហើយវិលមក (ប្រាប់) ដោយខ្លួនឯងវិញ ត្រូវអាបត្តិសង្ឃាទិសេស។ បុរសបង្គាប់ភិក្ខុថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ បានប្រើកូនសិស្សឲ្យទៅនិយាយល្បួងមើល ឯកូនសិស្សនោះបាននិយាយល្បួងមើល ហើយក៏ត្រឡប់មក ទៅប្រាប់បុរសដើម ក្រៅពីអាចារ្យដែលប្រើនោះ ត្រូវអាបត្តិថុល្លច្ច័យទាំងពីររូប។

[១៨៨] ភិក្ខុទទួលពាក្យ ទៅនិយាយល្បួងមើល ហើយត្រឡប់មកប្រាប់វិញដោយពាក្យកុហក[20] ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុកាលទៅមិនទទួលបង្គាប់ តែបាននិយាយល្បួងផង វិលមកប្រាប់វិញផង ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុកាលទៅ ក៏បានទទួលបង្គាប់ និយាយល្បួងមើល ហើយវិលមកប្រាប់វិញ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុកាលទៅ ក៏មិនបានទទួលបង្គាប់ កាលមក មិននាំដំណឹងមកប្រាប់វិញ មិនត្រូវអាបត្តិឡើយ។

[១៨៩] ភិក្ខុដែលទៅ (កាន់សំណាក់ស្រីនិងប្រុស) ដោយកិច្ចដែលត្រូវធ្វើ ចំពោះសង្ឃក្តី ចំពោះចេតិយក្តី ចំពោះបុគ្គលឈឺក្តី ភិក្ខុឆ្កួត ភិក្ខុដើមបញ្ញត្តិ មិនត្រូវអាបត្តិឡើយ។

## (វិនីតវត្ថុឧទ្ទានគាថា)

CS vin.vbu.sg.05.01 | ភាគ ទី២

### (វិនីតវត្ថុឧទ្ទានគាថា)

[១៩០] (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសំដែងតទៅ ដូចមានខាងក្រោមនេះគឺ)

> រឿងស្រីដេកលក់ រឿងស្រីស្លាប់ រឿងស្រីចេញពីលំនៅទៅ រឿងប្រុសច្រឡំជាស្រី រឿងស្រីខ្ទើយ រឿងឈ្លោះគ្នា ភិក្ខុបាននិយាយផ្សះផ្សា រឿងភិក្ខុនាំការឲ្យមនុស្សខ្ទើយ។

## (វិនីតវត្ថុ)

CS vin.vbu.sg.05.02 | ភាគ ទី២

### (វិនីតវត្ថុ)

[១៩១] សម័យនោះឯង បុរសម្នាក់បង្គាប់ភិក្ខុមួយរូបថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ។ ភិក្ខុនោះក៏ទៅហើយសួរមនុស្សទាំងឡាយថា ស្រីឈ្មោះនេះនៅឯណា។ មនុស្សទាំងឡាយឆ្លើយថា នាងនោះដេកលក់ទៅហើយ លោកម្ចាស់។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយដឹង។ ភិក្ខុនោះក៏ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង បុរសម្នាក់បង្គាប់ភិក្ខុមួយរូបថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ។ ភិក្ខុនោះក៏ទៅហើយសួរមនុស្សទាំងឡាយថា ស្រីឈ្មោះនេះនៅឯណា។ មនុស្សទាំងឡាយឆ្លើយថា បពិត្រលោកម្ចាស់ស្រីនោះស្លាប់ហើយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះដ៏មានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។ សម័យនោះឯង បុរសម្នាក់បង្គាប់ភិក្ខុមួយរូបថា បពិត្រលោកដ៏ចំរើន សូមលោកទៅនិយាយល្បួងមើលនឹងស្រីឈ្មោះនេះ។ ភិក្ខុនោះក៏ទៅ ហើយសួរមនុស្សទាំងឡាយថា ស្រីឈ្មោះនេះនៅឯណា។ មនុស្សទាំងឡាយឆ្លើយថា នាងនោះចេញពីទីនេះទៅហើយ

លោកម្ចាស់។បេ។ មនុស្សនោះមិនមែនជាស្រីទេ លោកម្ចាស់។បេ។ មនុស្សនោះជាស្រីខ្ទើយទេ លោកម្ចាស់។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ។

[១៩២] សម័យនោះឯង ស្រីម្នាក់ឈ្លោះគ្នានឹងប្តី ហើយរត់ទៅផ្ទះម្តាយ។ ភិក្ខុជាអ្នកចូលទៅកាន់ត្រកូល បាននិយាយផ្សះផ្សា។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ស្រីនោះប្តីបានលែងលះគ្នាដាច់ខាតហើយឬ។ ភិក្ខុនោះឆ្លើយថា សូមទ្រង់ព្រះមេត្តាប្រោស មិនទាន់លែងដាច់ទេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិទេ ព្រោះគេមិនទាន់លែងគ្នាដាច់ខាត។

[១៩៣] សម័យនោះឯង ភិក្ខុមួយរូបប្រព្រឹត្តនិយាយដឹកនាំការឲ្យមនុស្សខ្ទើយទាំងឡាយ។ ភិក្ខុនោះមានសេចក្តីសង្ស័យ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។

សង្ឃាទិសេស ទី៥ ចប់។

# សង្ឃាទិសេស ទី៦

CS vin.vbu.sg.06 | ភាគ ទី២

### (៦. កុដិការសិក្ខាបទំ)

[១៩៤] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅវត្តវេឡុវន កលន្ទកនិវាបស្ថាន (កន្លែងដែលស្តេចប្រទានអភ័យនិងចំណីដល់សត្វកង្ហែន) ជិតក្រុងរាជគ្រឹះ។ គ្រានោះឯង ពួកភិក្ខុនៅក្នុងដែនអាឡវី ប្រើគេឲ្យសាងនូវកុដិទាំងឡាយ ដែលមានគ្រឿងឧបករណ (គ្រឿងប្រដាប់សង់ផ្ទះ) សូមពីគេមកខ្លួនឯង ឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ធំហួសប្រមាណ។ កុដិទាំងនោះមិនទាន់សម្រេច។ ភិក្ខុទាំងនោះក៏ចេះតែសូមញឹកៗ ញយៗ ដោយពាក្យសូមថា អ្នកទាំងឡាយចូរឲ្យនូវបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោ ឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក ឲ្យវល្លិ ឲ្យឫស្សី ឲ្យស្មៅយ៉ាប្លង ឲ្យស្មៅដំណេកទន្សាយ ឲ្យស្មៅ ឲ្យដីស្អិត (ដល់យើងទាំងឡាយ)។ ពួកមនុស្សដែលភិក្ខុទាំងនោះចេះតែបៀតបៀនដោយការសូមញឹកញយហួសពេក លុះដល់ឃើញពួកភិក្ខុហើយ ក៏ភ្ញាក់ផ្អើលខ្លះ តក់ស្លុតខ្លះ លបរត់ទៅខ្លះ គេចទៅទីដទៃខ្លះ បែរមុខទៅទីដទៃខ្លះ បិទទ្វារផ្ទះខ្លះ សូម្បីគ្រាន់តែឃើញនូវគោញីទាំងឡាយ ក៏គេចរត់ដោយស្មានថាជាពួកភិក្ខុ។

[១៩៥] ខណៈនោះ ព្រះមហាកស្សបដ៏មានអាយុ គង់ចាំវស្សាក្នុងក្រុងរាជគ្រឹះ (គ្រប់ត្រៃមាស) ហើយ ក៏និមន្តចេញទៅឯដែនអាឡវី ត្រេចទៅកាន់ចារិកតាមលំដាប់ សំដៅទៅកាន់ដែនអាឡវីនោះ។ មានសេចក្តីដំណាលថា ព្រះមហាកស្សដ៏មានអាយុ សម្រេចឥរិយាបថនៅនាអគ្គាឡវចេតិយក្នុងដែនអាឡវីនោះ។ គ្រានោះជាវេលាព្រឹក ព្រះមហាកស្សបដ៏មានអាយុ ស្លៀកស្បង់ ទ្រង់បាត្រនិងចីវរចូលទៅកាន់ដែនអាឡវីដើម្បីបិណ្ឌបាត។ មនុស្សទាំងឡាយបានឃើញព្រះមហាកស្សបដ៏មានអាយុ ក៏ភ្ញាក់ផ្អើលខ្លះ តក់ស្លុតខ្លះ លបរត់ទៅខ្លះ គេចទៅទីដទៃខ្លះ បែរមុខទៅទីដទៃខ្លះ បិទទ្វារផ្ទះខ្លះ។ គ្រានោះ ព្រះមហាកស្សបដ៏មានអាយុត្រាច់ទៅបិណ្ឌបាតក្នុងដែនអាឡវីធ្វើភត្តកិច្ចស្រេចហើយ ដល់កាលជាខាងក្រោយអំពីភត្តកិច្ច ក៏ហៅពួកភិក្ខុមកហើយសួរថា ម្នាលលោកដ៏មានអាយុទាំងឡាយ កាលពីដើម ដែនអាឡវីនេះសម្បូណ៌ចង្ហាន់ បិណ្ឌបាតបានងាយងាយនឹងព្យាយាមស្វែងរកការចិញ្ចឹមជីវិត ប៉ុន្តែឥឡូវនេះ ដែនអាឡវីនេះ ប្រែជាកើតទុរ្ភិក្ស បិណ្ឌបាតបានដោយកម្រ លំបាកនឹងព្យាយាមស្វែងរកការចិញ្ចឹមជីវិតទៅវិញ ម្នាលលោកដ៏មានអាយុទាំងឡាយ អ្វីហ្ន៎ជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យដែនអាឡវីនេះប្រែជាកើតទុរ្ភិក្ស បិណ្ឌបាតបានដោយកម្រ លំបាកនឹងព្យាយាមស្វែងរកការចិញ្ចឹមជីវិតទៅវិញ។ ទើបភិក្ខុទាំងនោះពិតរឿងនុ៎ះដល់ព្រះមហាកស្សបដ៏មានអាយុ។

[១៩៦] គ្រានោះ ព្រះដ៏មានព្រះភាគ គង់នៅក្នុងក្រុងរាជគ្រឹះ គួរដល់ពុទ្ធអធ្យាស្រ័យ ហើយក៏យាងចេញទៅឯដែនអាឡវី យាងទៅកាន់ចារិកតាមលំដាប់ សំដៅទៅកាន់ដែនអាឡវីនោះ។ មានសេចក្តីដំណាលថា ព្រះដ៏មានព្រះភាគ ទ្រង់សម្រេចឥរិយាបថនៅនាអគ្គាឡវចេតិយក្នុងដែនអាឡវីនោះ។ ខណៈនោះ ព្រះមហាកស្សបដ៏មានអាយុ ចូលទៅគាល់ព្រះអង្គ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយខាងទីដ៏សមគួរ។ លុះអង្គុយក្នុងទីដ៏សមគួររួចហើយ ព្រះមហាកស្សបដ៏មានអាយុបានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរបញ្ជាក់ពួកភិក្ខុដែនអាឡវីថា ម្នាលភិក្ខុទាំងឡាយ បានឮថាអ្នករាល់គ្នាឲ្យគេធ្វើនូវកុដិទាំងឡាយដែលមានគ្រឿងឧបករណ៍ សូមអំពីគេមកដោយខ្លួនឯង មិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ធំហួសប្រមាណ។ កុដិទាំងនោះមិនទាន់សម្រេច អ្នករាល់គ្នាចេះតែសូមគេញយៗថា អ្នកទាំងឡាយចូរឲ្យនូវបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោ ឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក ឲ្យវល្លិ ឲ្យឫស្សី ឲ្យស្មៅយ៉ាប្លង ឲ្យស្មៅដំណេកទន្សាយ ឲ្យស្មៅ ឲ្យដីស្អិត ពួកមនុស្សដែលអ្នកទាំងឡាយចេះតែបៀតបៀនដោយការសូមញឹកញយហួសពេក លុះដល់ឃើញភិក្ខុទាំងឡាយហើយ ក៏ភ្ញាក់ផ្អើលខ្លះ តក់ស្លុតខ្លះ លបរត់ទៅខ្លះ គេចទៅទីដទៃខ្លះ បែរមុខទៅទីដទៃខ្លះ បិទទ្វារផ្ទះខ្លះ សូម្បីគ្រាន់តែឃើញនូវគោញីទាំងឡាយហើយសំគាល់ថាភិក្ខុ ក៏គេចរត់ សេចក្តីនេះពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ដំណើរនេះមិនសមគួរទេ។បេ។ មិនមែនជាកិច្ចដែលត្រូវធ្វើទេ ម្នាលមោឃបុរសទាំងឡាយ មិនសមបីបើ អ្នកឯងរាល់គ្នាប្រើគេឲ្យសាងកុដិទាំងឡាយ ដែលមានគ្រឿងឧបករណ៍ សូមពីគេមកខ្លួនឯង ឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ធំហួសប្រមាណ កុដិទាំងនោះមិនទាន់សម្រេច អ្នកទាំងឡាយចេះតែសូមញយៗ ដោយពាក្យសូមថា អ្នកទាំងឡាយចូរឲ្យនូវបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោ ឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក ឲ្យវល្លិ ឲ្យឫស្សី ឲ្យស្មៅយ៉ាប្លង ឲ្យស្មៅដំណេកទន្សាយ ឲ្យស្មៅ ឲ្យដីស្អិត (ដល់យើងទាំងឡាយ) ម្នាលមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា(នោះ)ទេ។បេ។ មានតែនាំឲ្យខូចចិត្ត ដល់ជនទាំងឡាយដែលមានសេចក្តីជ្រះថ្លាហើយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលពួកភិក្ខុដែនអាឡវីដោយអនេកបរិយាយ។បេ។ ហើយទ្រង់សំដែងធម្មីកថាតាមសមគួរដល់ហេតុនោះៗ ដល់ភិក្ខុទាំងឡាយ ហើយត្រាស់ហៅពួកភិក្ខុមក ហើយ(ត្រាស់ថា)។

[១៩៧] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើម មានឥសីពីរនាក់ ជាបងប្អូននឹងគ្នា សំណាក់នៅអាស្រ័យនឹងស្ទឹងគង្គា។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មានស្តេចនាគមួយឈ្មោះមណិកណ្ឋ ឡើងមកអំពីស្ទឹងគង្គា ហើយចូលមករកឥសីជាប្អូន លុះចូលមកដល់ហើយ ក៏ព័ទ្ធព័ន្ធឥសីប្អូន ដោយភ្នែន៧ជុំ ហើយបើកពពារដ៏ធំបាំងពីខាងលើសីរ្សនៃឥសីប្អូននោះ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ឥសីប្អូនហេតុតែមានសេចក្តីខ្លាចអំពីនាគនោះ ក៏ចេះតែស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតទៅជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ម្នាលភិក្ខុទាំងឡាយ ឥសីជាបងបានឃើញឥសីប្អូនស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ លុះឃើញហើយ ដ៏សួរទៅឥសីប្អូនថា ម្នាលអ្នកដ៏ចំរើន ហេតុអ្វីក៏អ្នក ស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ (ដូច្នេះ)។ ឥសីប្អូនប្រាប់ថា បពិត្រលោកបងដ៏ចំរើន នាគរាជឈ្មោះមណិកណ្ឋ ឡើងមកអំពីស្ទឹងគង្គា ហើយចូលមករកខ្ញុំក្នុងទីនេះ លុះចូលមកដល់ហើយ ក៏ព័ទ្ធព័ន្ធខ្ញុំដោយភ្នែន៧ជុំ ហើយបើកពពារដ៏ធំបាំងពីខាងលើក្បាលខ្ញុំ ព្រោះសេចក្តីខ្លាចនាគរាជនោះ បានជាខ្ញុំស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ឥសីបងសួរថា ម្នាលអ្នកដ៏ចំរើន អ្នកចង់មិនឲ្យនាគរាជនោះមកដែរឬ។ ឥសីប្អូនតបថា បពិត្រលោកបងដ៏ចំរើន ខ្ញុំចង់មិនឲ្យនាគរាជនោះមកទេ។ ឥសីបងសួរថា ម្នាលអ្នកដ៏ចំរើន ចុះអ្នកឯងបានឃើញវត្ថុអ្វីជារបស់នាគរាជនោះខ្លះ។ ឥសីប្អូនតបថា បពិត្រលោកបងដ៏ចំរើន ខ្ញុំបានឃើញកែវមណី ជាគ្រឿងប្រដាប់ព្ធដ៏កនៃនាគរាជនោះ។ ឥសីបងក៏បង្គាប់ថា ម្នាលអ្នកដ៏ចំរើន បើដូច្នោះ អ្នកចូរសូមកែវមណីចំពោះនាគរាជនោះថា អ្នកដ៏ចំរើន សូមអ្នកឲ្យកែវមណីដល់អាត្មា អាត្មាត្រូវការដោយកែវមណី។ ម្នាលភិក្ខុទាំងឡាយ ខណៈនោះ មណិកណ្ឋនាគរាជ ក៏ឡើងអំពីស្ទឹងគង្គា ហើយចូលមករកឥសីប្អូន លុះចូលមកដល់ហើយ ក៏ស្ថិតនៅក្នុងទីដ៏សមគួរ។ ម្នាលភិក្ខុទាំងឡាយ ឥសីប្អូនក៏បានពោលពាក្យនេះនឹងមណិកណ្ឋនាគរាជដែលស្ថិតនៅក្នុងទីដ៏សមគួរហើយ ថា ម្នាលអ្នកដ៏ចំរើន សូមអ្នកឲ្យកែវមណីដល់អាត្មា អាត្មាត្រូវការដោយកែវមណី។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មណិកណ្ឋនាគរាជគិតថា ភិក្ខុចេះតែសូមកែវមណី ភិក្ខុត្រូវការដោយកែវមណី គិតដូច្នេះហើយ ក៏វិលទៅវិញយ៉ាងឆាប់។ ម្នាលភិក្ខុទាំងឡាយ គ្រាទី២ មណិកណ្ឋនាគរាជឡើងមកអំពីស្ទឹងគង្គា ហើយចូលមករកឥសីប្អូន។ ម្នាលភិក្ខុទាំងឡាយ ឥសីប្អូនបានឃើញមណិកណ្ឋនាគរាជមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលពាក្យសូមកែវមណីនឹងមណិកណ្ឋនាគរាជថា ម្នាលអ្នកដ៏ចំរើន សូមអ្នកឲ្យកែវមណីដល់អាត្មា អាត្មាត្រូវការដោយកែវមណី។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មណិកណ្ឋនាគរាជក៏រំពឹងថា ភិក្ខុចេះតែសូមកែវមណី ភិក្ខុត្រូវការដោយកែវមណី ហើយត្រឡប់អំពីទីនោះបាត់ទៅ។ ម្នាលភិក្ខុទាំងឡាយ គ្រាទី៣ មណិកណ្ឋនាគរាជ ក៏ឡើងមកអំពីស្ទឹងគង្គា។ ម្នាលភិក្ខុទាំងឡាយ ឥសីប្អូនបានឃើញមណិកណ្ឋនាគរាជឡើងអំពីស្ទឹងគង្គា លុះឃើញហើយ ក៏ពោលពាក្យសូមកែវមណីនឹងមណិកណ្ឋនាគរាជថា ម្នាលអ្នកដ៏ចំរើន សូមអ្នកឲ្យកែវមណីដល់អាត្មា អាត្មាត្រូវការដោយកែវមណី។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មណិកណ្ឋនាគរាជពោលនឹងឥសីប្អូន ដោយគាថាទាំងឡាយថា បាយនិងទឹកដ៏ផ្ចិតផ្ចង់ជាច្រើន តែងកើតឡើងដល់ខ្ញុំ ព្រោះអាស្រ័យកែវមណីនេះ ខ្ញុំនឹងឲ្យកែវមណីនោះដល់លោកមិនបានទេ លោកជាអ្នកស្ទួរសូមហួសពេក ខ្ញុំនឹងលែងមកកាន់អាស្រមរបស់លោកទៀតហើយ។ មនុស្សកំឡោះដែលមានដាវសំលៀងដោយថ្មខ្មៅយ៉ាងមុតក្នុងដៃ នឹងគំប្បីធ្វើនរណាៗ ឲ្យស្លុតខ្លាចបាន ដូចម្តេចមិញ លោកសូមកែវមណីនឹងខ្ញុំ ធ្វើខ្ញុំឲ្យស្លុតខ្លាច ក៏ដូច្នោះដែរ ខ្ញុំនឹងឲ្យកែវមណីនោះដល់លោកមិនបានទេ លោកជាអ្នកស្ទួរសូមហួសពេក ខ្ញុំនឹងលែងមកកាន់អាស្រមរបស់លោកទៀតហើយ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មណិកណ្ឋនាគរាជក៏រំពឹងថា ភិក្ខុចេះតែសូមកែវមណី ភិក្ខុត្រូវការដោយកែវមណី ហើយចៀសចេញទៅ។ មណិកណ្ឋនាគរាជ កាលដែលចៀសចេញទៅដូច្នោះហើយ ក៏លែងត្រឡប់មកវិញទៀត។ ម្នាលភិក្ខុទាំងឡាយ លុះកាលតមក ឥសីប្អូន ព្រោះមិនបានឃើញនាគដែលគួរឃើញនោះ ក៏រឹងរឹតតែស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ម្នាលភិក្ខុទាំងឡាយ ឥសីបងបានឃើញឥសីប្អូនរឹងរឹតតែស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ លុះឃើញហើយ បានសួរឥសីប្អូនថា ម្នាលអ្នកដ៏ចំរើន ហេតុអ្វីបានជាអ្នករឹងរឹតតែស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ឥសីប្អូនឆ្លើយថា បពិត្រលោកបងដ៏ចំរើន ព្រោះមិនបានឃើញនាគនោះដែលគួរឃើញ បានជាខ្ញុំរឹងរឹតតែស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ឥសីបងបានពោលគាថានឹងឥសីប្អូនថា

> បុគ្គលដឹងថារបស់ណាជាទីស្រឡាញ់របស់គេ មិនគួរសូមរបស់នោះអំពីគេ បុគ្គលជាទីស្អប់ខ្ពើមរបស់គេ ក៏ព្រោះសូមហួសពេក នាគដែលព្រាហ្មណ៍សូមកែវមណីហើយ លែងត្រឡប់មកកាន់ទីនោះឲ្យឃើញទៀត។
>
> ម្នាលភិក្ខុទាំងឡាយ អម្បាលយ៉ាងពួកសត្វតិរច្ឆានទាំងនោះ ក៏មិនពេញចិត្តនឹងការសូម មិនពេញចិត្តនឹងការរែអង្គាស នឹងបាច់ពោលថ្វីដល់មនុស្ស។

[១៩៨] (រឿងទី២ថា ) ម្នាលភិក្ខុទាំងឡាយ រឿងដែលមានអំពីអតីតកាល មានភិក្ខុមួយរូប សម្រេចឥរិយាបថនៅក្នុងដងព្រៃមួយ នាខាងភ្នំហិមវន្ត។ ម្នាលភិក្ខុទាំងឡាយ ក្នុងទីជិតដងព្រៃនោះឯង មានបឹងមួយជាទំនាបធំ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មានហ្វូងសត្វស្លាបជាច្រើន វេលាថ្ងៃត្រាច់រកអាហារព្ធដ៏បឹងដែលនៅជិតដងព្រៃនោះ ដល់វេលាល្ងាច នាំគ្នាមកអាស្រ័យនៅនាដងព្រៃនោះ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ភិក្ខុនោះធុញទ្រាន់ អផ្សុកដោយសំឡេងនៃហ្វូងសត្វស្លាបនោះ ក៏ចូលមករកតថាគត លុះចូលមកដល់ហើយ ថ្វាយបង្គំតថាគត ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ម្នាលភិក្ខុទាំងឡាយ លុះដល់ភិក្ខុនោះអង្គុយស៊ប់ហើយ តថាគតបានពោលពាក្យនេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ ខន្ធបញ្ចកដែលមានចក្ក៤ មានទ្វារ៩ អ្នកល្មមអត់ធន់បានទេឬ ខន្ធបញ្ចកដែលមានចក្ក៤ មានទ្វារ៩ អ្នកល្មមឲ្យប្រព្រឹត្តទៅបានទេឬ អ្នកជាបុគ្គលមកកាន់ផ្លូវឆ្ងាយដោយឥតមានលំបាកទេឬ ម្នាលភិក្ខុ ចុះអ្នកមកអំពីទីណា។ ភិក្ខុនោះពោលថា បពិត្រព្រះដ៏មានព្រះភាគ ខន្ធបញ្ចកដែលមានចក្ក៤ មានទ្វារ៩ ខ្ញុំព្រះអង្គល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ ខន្ធបញ្ចកដែលមានចក្ក៤ មានទ្វារ៩ ខ្ញុំព្រះអង្គល្មមឲ្យប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចំរើន មួយសោត ខ្ញុំព្រះអង្គជាបុគ្គលមកកាន់ផ្លូវឆ្ងាយដោយឥតមានលំបាកឡើយ បពិត្រព្រះអង្គដ៏ចំរើន ខាងភ្នំហិមវន្ត មានដងព្រៃមួយធំ បពិត្រព្រះអង្គដ៏ចំរើន ក៏ក្នុងទីជិតនៃដងព្រៃនោះ មានបឹងទំនាបធំ បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ មានហ្វូងសត្វស្លាបច្រើន វេលាថ្ងៃ ត្រាច់រកអាហារនៅបឹងនោះ លុះដល់វេលាល្ងាច នាំគ្នាមកអាស្រ័យនៅនាដងព្រៃនោះ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានជាមកអំពីទីនោះ ព្រោះអផ្សុកនឹងសំឡេងនៃហ្វូងសត្វស្លាបនោះ។ តថាគតបានសួរថា ម្នាលភិក្ខុ ចុះអ្នកចង់មិនឲ្យហ្វូងសត្វស្លាបនោះមកទេឬ ភិក្ខុនោះពោលថា បពិត្រ

ព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនចង់ឲ្យហ្វូងសត្វស្លាបនោះមកទេ។ ទើបតថាគតពោលថា ម្នាលភិក្ខុ បើដូច្នោះ អ្នកឯងទៅដល់ទីនោះហើយ ៗចូលទៅកាន់ដងព្រៃនោះ ហើយប្រកាសនូវសំឡេងបីដង អស់បឋមយាមនៃរាត្រីថា នែសត្វស្លាបដ៏ចំរើនទាំងឡាយ បណ្ដាសត្វស្លាបដែលអាស្រ័យនៅក្នុងដងព្រៃនេះទាំងអម្បាលម៉ាណ ចូរស្ដាប់យើង ៗត្រូវការដោយស្លាបរបស់សត្វស្លាបទាំងឡាយ អ្នករាល់គ្នាចូរឲ្យស្លាបមួយៗម្នាក់ដល់យើង (តពីនោះមក) ចូរប្រកាសនូវសំឡេងបីដង អស់មជ្ឈិមយាមនៃរាត្រីថា។បេ។ រួចចូរប្រកាសនូវសំឡេងបីដង អស់បច្ឆិមយាមនៃរាត្រីថា នែសត្វស្លាបដ៏ចំរើនទាំងឡាយ បណ្ដាសត្វស្លាបដែលអាស្រ័យនៅក្នុងដងព្រៃនេះទាំងអម្បាលម៉ាណ ចូរស្ដាប់យើង ៗត្រូវការដោយស្លាបរបស់សត្វបក្សីទាំងឡាយ ម្នាលសត្វបក្សីដ៏ចំរើនទាំងឡាយ អ្នករាល់គ្នាចូរឲ្យស្លាបមួយៗម្នាក់ដល់យើង។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ភិក្ខុនោះក៏ទៅក្នុងទីនោះ ហើយទើបចូលទៅកាន់ដងព្រៃនោះ ហើយប្រកាសនូវសំឡេងបីដង អស់បឋមយាមនៃរាត្រីថា នែសត្វបក្សីដ៏ចំរើនទាំងឡាយ បណ្ដាសត្វបក្សីដែលអាស្រ័យនៅក្នុងដងព្រៃនេះទាំងអម្បាលម៉ាណ ចូរស្ដាប់យើង ៗត្រូវការដោយស្លាបរបស់សត្វបក្សីទាំងឡាយ ម្នាលសត្វបក្សីដ៏ចំរើនទាំងឡាយ អ្នករាល់គ្នាចូរឲ្យស្លាបមួយៗម្នាក់ដល់យើង (តពីនោះមក) ក៏ប្រកាសនូវសំឡេងបីដង អស់មជ្ឈិមយាមនៃរាត្រី។បេ។ រួចបានប្រកាសនូវសំឡេងបីដង អស់បច្ឆិមយាមនៃរាត្រីថា នែសត្វបក្សីដ៏ចំរើនទាំងឡាយ បណ្ដាសត្វបក្សីដែលអាស្រ័យនៅក្នុងដងព្រៃនេះទាំងអម្បាលម៉ាណ ចូរស្ដាប់យើង ៗត្រូវការដោយស្លាបរបស់សត្វបក្សីទាំងឡាយ ម្នាលសត្វបក្សីដ៏ចំរើនទាំងឡាយ អ្នករាល់គ្នាចូរឲ្យស្លាបមួយៗម្នាក់ដល់យើង។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ហ្វូងសត្វបក្សីក៏គិតគ្នាថា ភិក្ខុចេះតែសូមស្លាប ភិក្ខុត្រូវការដោយស្លាប (លុះគិតហើយ) ក៏ចៀសចេញទៅចាកដងព្រៃនោះ កាលដែលហ្វូងសត្វបក្សីចៀសចេញទៅដូច្នោះហើយ ក៏លែងត្រឡប់វិលមកទៀត។ ម្នាលភិក្ខុទាំងឡាយ អម្បាលយ៉ាងសត្វតិរច្ឆានទាំងឡាយនោះ ម្ដេចគង់មិនពេញចិត្តនឹងការសូម មិនពេញចិត្តនឹងការរែអង្គាស ចំណង់បើមនុស្សទាំងឡាយ នឹងបាច់និយាយទៅថ្វី។

[១៩៩] ម្នាលភិក្ខុទាំងឡាយ មានរឿងពីដើមមកថា បិតារបស់កុលបុត្តឈ្មោះរដ្ឋបាល បានពោលគាថានឹងរដ្ឋបាលកុលបុត្តថា

> ម្នាលរដ្ឋបាល ជនទាំងឡាយណាច្រើននាក់ រមែងមកចោមរោមសូមអ្វីៗនឹងញោម តែញោមមិនស្គាល់ជនទាំងនោះឡើយ ហេតុអ្វីបានជាអ្នកមិនសូមអ្វីៗនឹងញោមខ្លះ។

រដ្ឋបាលកុលបុត្តក៏និយាយថា

> អ្នកសូមរមែងមិនជាទីស្រឡាញ់របស់អ្នកឲ្យ អ្នកមិនឲ្យរបស់ដែលគេសូម ក៏មិនជាទីស្រឡាញ់របស់អ្នកសូម ព្រោះហេតុនោះ ទើបខ្ញុំមិនសូមអ្វីៗនឹងអ្នក ដោយគិតថា មិនឲ្យជាទីស្អប់ខ្ពើមដល់ខ្ញុំ។
>
> ម្នាលភិក្ខុទាំងឡាយ អម្បាលយ៉ាងរដ្ឋបាលកុលបុត្តនោះ ម្ដេចគង់បានពោលយ៉ាងនេះនឹងបិតារបស់ខ្លួន នឹងបាច់ពោលទៅថ្វីដល់ជននឹងជន (នឹងខានស្ដីថាឲ្យគ្នាឯណាបាន)។

[២០០] ម្នាលភិក្ខុទាំងឡាយ ក៏ភោគទាំងឡាយដែលពួកគ្រហស្ថសន្សំរកបានដោយកម្រ សូម្បីរកបានមកហើយ ក៏កម្រនឹងថែរក្សាទុកឲ្យគង់បាន ម្នាលមោឃបុរសទាំងឡាយ កាលបើភោគទាំងឡាយដែលពួកគ្រហស្ថសន្សំ រកបានដោយកម្រ សូម្បីរកបានមកហើយ ក៏កម្រនឹងថែរក្សាយ៉ាងនេះ អ្នកទាំងឡាយប្រព្រឹត្តតែសូមហួសពេក រែអង្គាសហួសពេក ចំពោះភោគទាំងនោះថា អ្នកទាំងឡាយចូរឲ្យបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោ ឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក ឲ្យវល្លិ ឲ្យឫស្សី ឲ្យស្មៅយ៉ាប្លង ឲ្យស្មៅដំណេកទន្សាយ ឲ្យស្មៅ (ធម្មតា) ឲ្យដីស្អិត។ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងអស់គ្នាធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់បានជ្រះថ្លា។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **កាលភិក្ខុឲ្យគេធ្វើកុដិដែលមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍មកខ្លួនឯង គប្បីធ្វើឲ្យប្រកបដោយប្រមាណ ប្រមាណកុដិនោះគឺ បណ្ដោយ១២ចំអាម ទទឹង៧ចំអាម ដោយចំអាមព្រះសុគតវាស់ខាងក្នុង ត្រូវនាំពួកភិក្ខុមកដើម្បីសំដែងទីឲ្យ ភិក្ខុទាំងនោះគប្បីសំដែងទីដែលមិនមានអន្តរាយ និងមានឧបចារ បើភិក្ខុឲ្យគេធ្វើកុដិដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ក្នុងទីដែលមានអន្តរាយ និងមិនមានឧបចារក្តី មិនបាននាំពួកភិក្ខុមកដើម្បីសំដែងទីឲ្យក្តី ធ្វើឲ្យកន្លងហួសប្រមាណក្តី ត្រូវអាបត្តិសង្ឃាទិសេស។**

[២០១] ភិក្ខុបានសូមបុរសក្តី គ្រឿងហត្ថកម្មនៃបុរសក្តី គោក្តី រទេះក្តី កាំបិតក្តី ពូថៅក្តី ដឹងក្តី ចបក្តី ពន្លាកក្តី។បេ។ ស្មៅក្តី ដីស្អិតក្តី ដោយខ្លួនឯង ឈ្មោះថាសូមគ្រឿងឧបករណ៍គេមកខ្លួនឯង។ ដែលឈ្មោះថាកុដិនោះ គឺកុដិដែលលាបខាងក្នុង ឬកុដិដែលលាបខាងក្រៅ ឬកុដិដែលលាបទាំងខាងក្នុង ទាំងខាងក្រៅ។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី។ ត្រង់ពាក្យថា មិនមានទាយកជាម្ចាស់របស់ សេចក្តីថា មិនមានអ្នកដទៃណាមួយទោះស្រីក្តី ប្រុសក្តី គ្រហស្ថក្តី បព្វជិតក្តី ជាម្ចាស់របស់។ ត្រង់ពាក្យថា ចំពោះជាទីនៅនៃខ្លួន គឺដើម្បីជាប្រយោជន៍ដល់ខ្លួន។ ត្រង់ពាក្យថា គប្បីធ្វើឲ្យប្រកបដោយប្រមាណ ប្រមាណកុដិនោះគឺ បណ្ដោយ១២ចំអាម ដោយចំអាមព្រះសុគត គឺវាស់តាមទីដែលជាខាងក្រៅកុដិ។ ត្រង់ពាក្យថា ទទឹង៧ចំអាម វាស់ខាងក្នុង គឺវាស់តាមទីដែលជាខាងក្នុងកុដិ។

[២០២] ត្រង់ពាក្យថា ត្រូវនាំពួកភិក្ខុមកដើម្បីសំដែងទីឲ្យ សេចក្តីថា រូបភិក្ខុអ្នកធ្វើកុដិនោះ ត្រូវជំរះទីកុដិរួចចូលទៅរកសង្ឃ ហើយធ្វើចីវរឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យអញ្ជលីពោលពាក្យយ៉ាងនេះថា ខ្ញុំករុណាចង់ធ្វើកុដិមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួនដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង បពិត្រលោកដ៏ចំរើនទាំងឡាយ ខ្ញុំករុណាឯង សូមឲ្យ

សង្ឃពិនិត្យមើលទីធ្វើកុដិឲ្យទាន។ ភិក្ខុអ្នកធ្វើកុដិនោះ គប្បីសូមជាគំរប់ពីរដងផង គប្បីសូមជាគំរប់បីដងផង។ បើសង្ឃទាំងអស់ អាចដើម្បីពិនិត្យមើលទីធ្វើកុដិបាន សង្ឃទាំងអស់គប្បីពិនិត្យមើល។ បើសង្ឃទាំងអស់មិនអាចដើម្បីពិនិត្យមើលទីធ្វើកុដិបានទេ ភិក្ខុទាំងឡាយឯណាមាននៅក្នុងទីនោះ ជាអ្នកឆ្លាសអាចនឹងដឹងនូវទីដែលមានហេតុទាស់ និងទីដែលមិនមានហេតុទាស់ និងទីដែលមានឧបចារ និងមិនមានឧបចារ សង្ឃគប្បីអារាធនា ហើយសម្មតិភិក្ខុទាំងនោះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសម្មតិភិក្ខុទាំងនោះយ៉ាងនេះ គឺភិក្ខុដែលឆ្លាសប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹង (ដោយញត្តិទុតិយកម្មវាចា) ថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុរូបនេះ ឈ្មោះនេះ ចង់ធ្វើកុដិដែលឥតមានទាយកម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ភិក្ខុនោះសូម ការពិនិត្យមើលទីធ្វើកុដិនិងសង្ឃ។ បើការពិនិត្យមើលទីធ្វើកុដិមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសម្មតិភិក្ខុទាំងឡាយឈ្មោះនេះផងៗ ដើម្បីឲ្យពិនិត្យមើលនូវទីធ្វើកុដិរបស់ភិក្ខុឈ្មោះនេះ។ នេះជាវាចាសម្រាប់ញុំាងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុរូបនេះ ឈ្មោះនេះ ចង់ធ្វើកុដិដែលឥតមានទាយកជាម្ចាស់របស់ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ភិក្ខុនោះសូមការពិនិត្យមើលទីធ្វើកុដិនឹងសង្ឃ។ សង្ឃសម្មតិភិក្ខុទាំងឡាយមានឈ្មោះនេះផងៗ ដើម្បីឲ្យពិនិត្យមើលទីធ្វើកុដិរបស់ភិក្ខុឈ្មោះនេះ។ ការសម្មតិនូវភិក្ខុទាំងឡាយឈ្មោះនេះផងៗ ដើម្បីឲ្យពិនិត្យមើលទីធ្វើកុដិរបស់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោល។ ភិក្ខុទាំងឡាយឈ្មោះនេះផងៗ សង្ឃបានសម្មតិដើម្បីឲ្យពិនិត្យមើលទីធ្វើកុដិរបស់ភិក្ខុឈ្មោះនេះ។ កិរិយាសម្មតិនេះសមគួរដល់សង្ឃ ព្រោះហេតុនោះ សង្ឃទើបស្ងៀម។ ខ្ញុំករុណា សូមចាំទុកនូវសេចក្តីនេះដោយកិរិយាស្ងៀមយ៉ាងនេះ។

[២០៣] ពួកភិក្ខុដែលសង្ឃបានសម្មតិហើយទាំងនោះ ត្រូវទៅក្នុងទីនោះហើយ ពិនិត្យមើលទីធ្វើកុដិ រួចត្រូវដឹងថាជាទីមានហេតុទាស់ ទីឥតមានហេតុទាស់ ទីមានឧបចារ ទីឥតមានឧបចារ។ បើទីមានហេតុទាស់ ទីមិនមានឧបចារ គប្បីប្រាប់ថា លោកកុំធ្វើក្នុងទីនេះឡើយ។ បើទីឥតមានហេតុទាស់ ទីមានឧបចារ គប្បីប្រាប់សង្ឃថា ទីនេះឥតមានហេតុទាស់ មានឧបចារ។ ភិក្ខុអ្នកធ្វើកុដិនោះត្រូវចូលទៅរកសង្ឃ ហើយធ្វើចីវរឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យអញ្ជលី ពោលពាក្យយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំករុណាចង់ធ្វើកុដិមិនមានទាយកជាម្ចាស់របស់ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំករុណាសូមការសំដែងទីធ្វើកុដិនឹងសង្ឃ។ ភិក្ខុអ្នកធ្វើកុដិនោះ គប្បីសូមជាគំរប់ពីរដងផង គប្បីសូមជាគំរប់បីដងផង។ ភិក្ខុអ្នកឆ្លាសប្រតិពល គប្បីញុំាងសង្ឃឲ្យដឹង (ដោយញត្តិទុតិយកម្មវាចា) ថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុរូបនេះ ឈ្មោះនេះ ចង់ធ្វើកុដិឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួនដោយសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ភិក្ខុនោះសូមការសំដែងទីធ្វើកុដិនឹងសង្ឃ។ បើការសំដែងទីធ្វើកុដិមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសំដែងទីធ្វើកុដិ ដើម្បីភិក្ខុឈ្មោះនេះ។ នេះជាញត្តិ (វាចាប្រកាសឲ្យសង្ឃដឹង)។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុរូបនេះ ឈ្មោះនេះ ចង់ធ្វើកុដិឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ភិក្ខុនោះសូមការសំដែងទីធ្វើកុដិនឹងសង្ឃ សង្ឃសំដែងទីធ្វើកុដិដើម្បីភិក្ខុឈ្មោះនេះ។ ការសំដែងទីធ្វើកុដិដើម្បីភិក្ខុឈ្មោះនេះសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោល។ សង្ឃបានសំដែងទីធ្វើកុដិដើម្បីភិក្ខុឈ្មោះនេះហើយ។ ការនេះសមគួរដល់សង្ឃ ព្រោះហេតុនោះ សង្ឃទើបស្ងៀម ខ្ញុំករុណា សូមចាំទុកសេចក្តីនេះ ដោយកិរិយាស្ងៀមយ៉ាងនេះ។

[២០៤] ដែលហៅថា ទីមានហេតុទាស់នោះ គឺបាននឹងកន្លែងជាទីអាស្រ័យនៅនៃពួកសត្វស្រមោចក្រហមក្តី ជាទីអាស្រ័យនៅនៃពួកសត្វកណ្តៀរក្តី ជាទីអាស្រ័យនៅនៃពួកសត្វកណ្តុរក្តី ជាទីអាស្រ័យនៅនៃពួកសត្វពស់ក្តី ជាទីអាស្រ័យនៅនៃពួកសត្វខ្ទួយក្តី ជាទីអាស្រ័យនៅនៃពួកសត្វក្អែបក្តី ជាទីអាស្រ័យនៅនៃពួកដំរីក្តី ជាទីអាស្រ័យនៅនៃពួកសេះក្តី ជាទីអាស្រ័យនៅនៃពួកសីហក្តី ជាទីអាស្រ័យនៅនៃពួកខ្លាធំក្តី ជាទីអាស្រ័យនៅនៃពួកខ្លាដំបងក្តី ជាទីអាស្រ័យនៅនៃពួកខ្លាឃ្មុំក្តី ជាទីអាស្រ័យនៅនៃពួកខ្លារខិនក្តី ជាទីអាស្រ័យនៅនៃពួកសត្វតិរច្ឆានណាមួយក្តី ជាទីតាំងនៅនៃបុព្វណ្ណ[21] ជាតិក្តី ជាទីតាំងនៅនៃអបរណ្ណ[22] ជាតិក្តី ជាទីដែលគេសម្លាប់ចោរក្តី ជាទីសម្រាប់ផ្តាលទោស[23] ក្តី ជាទីព្រៃស្មសានក្តី ជាទីឱទ្យានក្តី ជាទីស្រែចំការស្តេចក្តី ជាទីដែលគេសង់រោងដំរីក្តី ជាទីដែលគេសង់រោងសេះក្តី ជាទីដែលគេធ្វើគុកក្តី ជាទីដែលគេធ្វើរោងសុរាក្តី ជាទីអាស្រ័យនៅនៃផ្ទះលក់សាច់ក្តី ជាទីច្រកក្តី ជាទីវាលសម្រាប់លេងក្តី ជាទីរោងប្រជុំក្តី ជាកន្លែងផ្លូវទៅមកក្តី ទីប៉ុណ្ណោះ ហៅថាទីមានហេតុទាស់ គឺទីមានសេចក្តីអន្តរាយ។

[២០៥] ដែលហៅថា ទីមិនមានឧបចារនោះ គឺបាននឹងទីដែលមិនអាចនឹងបង្វិលរទេះ បង្វិលបង្អោងជុំវិញដោយស្រួលបាន ទីប៉ុណ្ណោះ ហៅថាទីមិនមានឧបចារ។

[២០៦] ដែលហៅថា ទីមិនមានអន្តរាយនោះ គឺបាននឹងទីដែលមិនមែនជាទីអាស្រ័យនៅនៃពួកសត្វស្រមោចក្រហមក្តី មិនមែនជាទីអាស្រ័យនៅនៃពួកសត្វកណ្តៀរក្តី មិនមែនជាទីអាស្រ័យនៅនៃពួកសត្វកណ្តុរក្តី មិនមែនជាទីអាស្រ័យនៅនៃពួកសត្វពស់ក្តី មិនមែនជាទីអាស្រ័យនៅនៃពួកសត្វខ្ទួយក្តី មិនមែនជាទីអាស្រ័យនៅនៃពួកសត្វក្អែបក្តី។បេ។ មិនមែនជាកន្លែងផ្លូវទៅមកក្តី ទីប៉ុណ្ណោះ ហៅថាទីមិនមានអន្តរាយ។

[២០៧] ដែលហៅថា ទីមានឧបចារនោះ គឺបាននឹងទីដែលអាចបង្វិលរទេះ បង្វិលបង្អោងដោយជុំវិញតាមស្រួលបាន ទីប៉ុណ្ណោះ ហៅថាទីមានឧបចារ។

[២០៨] ភិក្ខុសូមបុរសក្តី គ្រឿងហត្ថកម្មនៃបុរសក្តី។បេ។ ពន្លាកក្តី ដោយខ្លួនឯង ហៅថាសូមគ្រឿងឧបករណ៍គេមកខ្លួនឯង។ លំនៅរបស់ភិក្ខុដែលលាបខាងក្នុង ឬលាបខាងក្រៅ ឬដែលលាបទាំងខាងក្នុងទាំងខាងក្រៅ ហៅថាកុដិ។ ត្រង់ពាក្យថា ឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី។ ត្រង់ពាក្យថា មិនបាននាំពួកភិក្ខុមកដើម្បីសំដែងទីឲ្យក្តី ធ្វើឲ្យកន្លងហួសប្រមាណក្តី សេចក្តីថា មិនបានឲ្យសង្ឃសំដែងទីធ្វើកុដិ ដោយបណ្តោយក្តី ដោយទទឹងក្តី ដោយញត្តិទុតិយកម្ម ហើយធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ឲ្យកន្លងហួសប្រមាណ សូម្បីប្រមាណប៉ុនចុងសក់ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបូក១ដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ កាលបើបូក១ដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ ត្រង់ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយពិស្តារក្នុងសង្ឃាទិសេសសិក្ខាបទទី១ រួចហើយ។

[២០៩] ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ គឺទីមានអន្តរាយ មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ និង អាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ តែមានឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មិនមានហេតុទាស់ មិនមានឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មិនមានហេតុទាស់ តែមានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ តែមានឧបចារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ មិនមានហេតុទាស់ មិនមានឧបចារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ មិនមានហេតុទាស់ តែមានឧបចារ ជាអនាបត្តិ (មិនត្រូវអាបត្តិឡើយ)។

[២១០] ភិក្ខុធ្វើកុដិហួសប្រមាណ មានហេតុទាស់ មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិហួសប្រមាណ មានហេតុទាស់ តែមានឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិហួសប្រមាណ មិនមានហេតុទាស់ និងមិនមានឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិហួសប្រមាណ តែមិនមានហេតុទាស់ មានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិត្រូវប្រមាណ តែមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ។ ភិក្ខុធ្វើកុដិប្រកបដោយប្រមាណ តែមានហេតុទាស់ មានទីឧបចារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុធ្វើកុដិប្រកបដោយប្រមាណ ឥតមានហេតុទាស់ តែឥតមានទីឧបចារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុធ្វើកុដិប្រកបដោយប្រមាណ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។

[២១១] ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ និង អាបត្តិសង្ឃាទិសេសពីរ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដមួយ និងអាបត្តិសង្ឃាទិសេសពីរ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ ឥតមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដមួយ និងអាបត្តិសង្ឃាទិសេសពីរ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ តែឥតមានហេតុទាស់ មានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេសពីរ។

[២១២] ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ មានទីឧបចារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ ឥតមានហេតុទាស់ តែមិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។

[២១៣] ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស។បេ។ មានហេតុទាស់ មានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ ឥតមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ ឥតមានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ ឥតមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ មិនមានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលប្រកបដោយប្រមាណ មានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមិនមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេសពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដមួយ និងអាបត្តិសង្ឃាទិសេសពីរ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដមួយ និងអាបត្តិសង្ឃាទិសេសពីរ។បេ។ មិនមានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេសពីរ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ មានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។

[២១៤] ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានបង្គាប់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង មិនមានហេតុទាស់ផង មានទីឧបចារផងដូច្នេះឡើយ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ មិនមានហេតុទាស់ មានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផងដូច្នេះឡើយ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះត្រូវប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផងដូច្នេះឡើយ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលហួសប្រមាណ មានហេតុ

ទាស់ មិនមានទីឧបចារ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ ឥតមានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផងដូច្នេះឡើយ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលប្រកបដោយប្រមាណ មានហេតុទាស់ មិនមានទីឧបចារ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ មានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផងដូច្នេះឡើយ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមិនមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេសពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសពីរ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសពីរ។បេ។ មិនមានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេសពីរ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង មិនមានហេតុទាស់ផង មានទីឧបចារផងដូច្នេះឡើយ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ មិនមានទីឧបចារ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានហេតុទាស់ មានទីឧបចារ មិនត្រូវអាបត្តិឡើយ។

[២១៥] ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដែលមិនមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារ ដើម្បីអាត្មាអញ។ ភិក្ខុនោះ គប្បីទៅខ្លួនឯងក្តី ប្រើបម្រើទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ តែមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញដែលឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ តែមានទីឧបចារ។ ភិក្ខុនោះ គប្បីទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង។ បើភិក្ខុនោះមិនទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលឥតមានពួកភិក្ខុសំដែងទីឲ្យ ឥតមានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញ ដែលឥតមានពួកភិក្ខុសំដែងទីឲ្យ ឥតមានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះ គប្បីទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង មានទីឧបចារផង។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមិនមានពួកភិក្ខុសំដែងទីឲ្យ ឥតមានហេតុទាស់ មានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញ ដែលមិនមានពួកភិក្ខុសំដែងទីឲ្យ ឥតមានហេតុទាស់ មានទីឧបចារ។ ភិក្ខុនោះ គប្បីទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសំដែងទីឲ្យ តែមានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញ ដែលមានពួកភិក្ខុសំដែងទីឲ្យ តែមានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះ គប្បីទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិឥតមានហេតុទាស់ផង មានទីឧបចារផង។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសំដែងទីឲ្យ តែមានហេតុទាស់ មានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញ ដែលមានពួកភិក្ខុសំដែងទីឲ្យ តែមានហេតុទាស់ មានទីឧបចារ។ ភិក្ខុនោះ ត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិឥតមានហេតុទាស់។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសំដែងទីឲ្យ ឥតមានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញ មានពួកភិក្ខុសំដែងទីឲ្យ ឥតមានហេតុទាស់ តែឥតមានទីឧបចារ។ ភិក្ខុនោះ ត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិមានទីឧបចារ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសំដែងទីឲ្យ ឥតមានហេតុទាស់ មានទីឧបចារ មិនត្រូវអាបត្តិឡើយ។

[២១៦] ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ធំហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញ ធំហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារ។ ភិក្ខុនោះ ត្រូវទៅខ្លួនឯងក្តី ប្រើ

បម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។បេ។ គួរប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង។បេ។ គួរប្រកបដោយប្រមាណផង គួរមានទីឧបចារផង។បេ។ គួរប្រកបដោយប្រមាណ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិឲ្យអាត្មាអញ ប្រកបដោយប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះ ត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិឥតមានហេតុទាស់ផង មានទីឧបចារផង។បេ។ គួរជាកុដិឥតមានហេតុទាស់។បេ។ មានទីឧបចារ។បេ។ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិឥតមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិឲ្យអាត្មាអញ ជាកុដិឥតមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះ ត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។បេ។ គួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង។បេ។ គួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង មានទីឧបចារ។បេ។ គួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង។ បើភិក្ខុនោះ មិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិឲ្យអាត្មាអញ ជាកុដិមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារ។ ភិក្ខុនោះត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិឥតមានហេតុទាស់ផង មានទីឧបចារផង។បេ។ ឥតមានហេតុទាស់ផង។បេ។ មានទីឧបចារ។បេ។ ជាអនាបត្តិ។

[២១៧] ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដបី។បេ។ មានហេតុទាស់ មានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិមានពួកភិក្ខុសំដែងទីឲ្យ តែមានហេតុទាស់ ឥតមានទីឧបចារ ភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ មានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដបី។បេ។ មានហេតុទាស់ មានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ឥតមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ៤។បេ។ មានហេតុទាស់ តែមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដបី។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដបី។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិមានពួកភិក្ខុសំដែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារផង។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ មានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។

[២១៨] ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ ឥតមានទីឧបចារ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់។ ភិក្ខុនោះត្រូវឲ្យកុដិនោះដល់ភិក្ខុដទៃ ឬត្រូវទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀត។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ឥតមានពួកភិក្ខុសំដែងទីឲ្យ មានហេតុទាស់ តែមានទីឧបចារ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់។ ភិក្ខុនោះត្រូវឲ្យកុដិនោះដល់ភិក្ខុដទៃ ឬត្រូវទំលាយបង់ ហើយឲ្យធ្វើជាថ្មី។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារ...ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ មានពួកភិក្ខុសំដែងទីឲ្យ តែមានហេតុទាស់ ឥតមានទីឧបចារ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់។ ភិក្ខុនោះត្រូវឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀត។ បើភិក្ខុនោះមិន

បានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ...ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារ... ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់។ ភិក្ខុនោះគប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬត្រូវទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀត។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស។បេ។ មានហេតុទាស់ តែមានទីឧបចារ...ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារ... ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស។បេ។ ឥតមានហេតុទាស់ មានទីឧបចារ...ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ប្រកបដោយប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់។ ភិក្ខុនោះគប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀត។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទំលាយបង់ ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ...ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារ... ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ មិនមានពួកភិក្ខុសំដែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់។ ភិក្ខុនោះគប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីរុះរើធ្វើជាថ្មីទៀត។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេសពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ...ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសពីរ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារ... ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសពីរ។ ឥតមានហេតុទាស់ មានទីឧបចារ...ត្រូវអាបត្តិសង្ឃាទិសេសពីរ។ ភិក្ខុបង្គាប់ (ពួកភិក្ខុផងគ្នា) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ មានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់។ ភិក្ខុនោះគប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីឲ្យរុះរើធ្វើជាថ្មីទៀត។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិន ឲ្យរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ។បេ។ មានហេតុទាស់ តែមានទីឧបចារ...ត្រូវអាបត្តិទុក្កដ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារ... ត្រូវអាបត្តិទុក្កដ។ ឥតមានហេតុទាស់ មានទីឧបចារ ជាអនាបត្តិ។

[២១៩] ភិក្ខុធ្វើកុដិមិនទាន់ស្រេចដោយខ្លួនឯង ហើយធ្វើបង្ហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើកុដិមិនទាន់ស្រេចដោយខ្លួនឯង ហើយឲ្យភិក្ខុដទៃធ្វើបង្ហើយ (ភិក្ខុអ្នកប្រើ) ត្រូវអាបត្តិសង្ឃាទិសេស។ ពួកភិក្ខុដទៃធ្វើកុដិ (ឲ្យភិក្ខុរូបណា) មិនទាន់ស្រេច ហើយភិក្ខុ (រូបនោះ) ធ្វើបង្ហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស។ ពួកភិក្ខុដទៃធ្វើកុដិ (ឲ្យភិក្ខុរូបណា) មិនទាន់ស្រេច ហើយភិក្ខុ (រូបនោះ) ឲ្យពួកភិក្ខុដទៃធ្វើបង្ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[២២០] ដំណើរដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើលេណ[24] គុហា[25] កុដិស្មៅ និងកុដិសម្រាប់ភិក្ខុដទៃ (មានឧបជ្ឈាយ៍ជាដើម) និងទីសេនាសនទាំងពួង (មានរោងឧបោសថជាដើម) វៀរលែងតែធ្វើកុដិសម្រាប់នៅរបស់ខ្លួន (ម្យ៉ាងទៀត) ដំណើរដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុឆ្កួត និងភិក្ខុដើមបញ្ញត្តិ។

សង្ឃាទិសេស ទី៦ ចប់។

# សង្ឃាទិសេស ទី៧

CS vin.vbu.sg.07 | ភាគ ទី២

### (៧. វិហារការសិក្ខាបទំ)

[២២១] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម[26] ទៀបក្រុងកោសម្ពី។ សម័យនោះឯង មានគហបតីជាឧបដ្ឋាកឆន្នភិក្ខុដ៏មានអាយុ បាននិយាយពាក្យនេះនឹងឆន្នភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ជ្រាបទីសម្រាប់សង់វិហារ[27] ខ្ញុំព្រះករុណានឹងឲ្យមនុស្សធ្វើវិហារប្រគេនលោកម្ចាស់។ ឆន្នភិក្ខុដ៏មានអាយុ កាលដែលជម្រះទីសម្រាប់សង់វិហារ ក៏ឲ្យមនុស្សកាប់ឈើមួយដើម ដែលគេសន្មតជាចេតិយ ជាឈើដែលអ្នកស្រុក អ្នកនិគម អ្នកក្រុង អ្នកជនបទ អ្នកដែន ធ្លាប់គោរពបូជា។ មនុស្សទាំងឡាយពោលទោស និន្ទា តិះដៀលថា ចុះហេតុអ្វី បានជាសមណទាំងឡាយ ជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ ឲ្យមនុស្សកាប់ឈើ ដែលគេសន្មតជាចេតិយ ជាឈើដែលអ្នកស្រុក អ្នកនិគម អ្នកក្រុង អ្នកជនបទ អ្នកដែន ធ្លាប់គោរពបូជា សមណទាំងឡាយ ជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ បៀតបៀនដើមឈើរស់ដែលមានឥន្ទ្រីយតែមួយ។ ពួកភិក្ខុបានឮពាក្យមនុស្សទាំងឡាយនោះ ពោលទោស និន្ទា តិះដៀល (ដូច្នោះ) ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោស និន្ទា តិះដៀលថា ចុះហេតុអ្វី បានជាឆន្នភិក្ខុដ៏មានអាយុ ឲ្យមនុស្សកាប់ឈើដែលគេសន្មតថា ជាចេតិយ ជាឈើដែលអ្នកស្រុកគេបូជា។បេ។ អ្នកដែនធ្លាប់គោរពបូជា។ គ្រានោះ ភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្តីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឆន្ន ឮថាអ្នកឯងឲ្យមនុស្សកាប់ឈើ ដែលគេសន្មតថា ជាចេតិយ ដែលអ្នកស្រុកគេបូជា។បេ។ អ្នកដែនធ្លាប់គោរពបូជា មែនឬ។ ឆន្នភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា។បេ។ នែបុរសទទេ ចុះហេតុអ្វី បានជាអ្នកឯងឲ្យមនុស្សកាប់ដើមឈើ ដែលគេសន្មតថា ជាចេតិយ ជាឈើដែលអ្នកស្រុក អ្នកនិគម អ្នកក្រុង អ្នកជនបទ អ្នកដែនតែងគោរពបូជា (ដូច្នោះ) ម្នាលមោឃបុរស ព្រោះមនុស្សទាំងឡាយ មានសេចក្តីសំគាល់ថា ឈើជាសភាវមានជីវិត នែបុរសសោះសូន្យ ហេតុនេះមិននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា

**ភិក្ខុកាលឲ្យគេធ្វើវិហារ[28] មានម្ចាស់ចំពោះជាទីនៅរបស់ខ្លួន ត្រូវនាំភិក្ខុទាំងឡាយមកសំដែងទីឲ្យ ភិក្ខុទាំងឡាយនោះត្រូវសំដែងទីដែលមិនមានសេចក្តីរង្កៀស មានឧបចារ ថាបើទីដីប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារហើយ ភិក្ខុគប្បីឲ្យធ្វើវិហារធំ ឬមិននាំភិក្ខុទាំងឡាយទៅដើម្បីសំដែងទីឲ្យ ត្រូវអាបត្តិសង្ឃាទិសេស។**

[២២២] វិហារដែលមានម្ចាស់ តថាគតត្រាស់ហៅថា វិហារធំ។ (ទីនៅរបស់សង្ឃ) គឺទីដែលលាបខាងក្នុងក្តី លាបខាងក្រៅក្តី លាបទាំងខាងក្នុង ទាំងខាងក្រៅក្តី ហៅថា វិហារ។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ សេចក្តីថា ធ្វើឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី។ ត្រង់ពាក្យថា មានម្ចាស់ គឺអ្នកណាមួយដទៃ ទោះស្រីក្តី ប្រុសក្តី គ្រហស្ថក្តី អ្នកបួសក្តី ជាម្ចាស់។ ត្រង់ពាក្យថា ចំពោះជាទីនៅរបស់ខ្លួន គឺដើម្បីជាប្រយោជន៍ដល់ខ្លួន។

[២២៣] ត្រង់ពាក្យថា ត្រូវនាំភិក្ខុទាំងឡាយមកសំដែងទីឲ្យ គឺត្រូវភិក្ខុអ្នកធ្វើវិហារនោះ ជម្រះទីសម្រាប់ធ្វើវិហារ រួចហើយចូលទៅរកសង្ឃ ហើយធ្វើសម្ពត់ឧត្តរាសង្គ[29] ឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងរបស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី ហើយពោលយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណាមានសេចក្តីប្រាថ្នាដើម្បីធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណានោះ សូមសង្ឃត្រួតត្រាមើលទីសម្រាប់ធ្វើវិហារឲ្យ។ ភិក្ខុអ្នកធ្វើវិហារ ត្រូវសូមជាគំរប់ពីរដងផង សូមជាគំរប់បីដងផង។ បើសង្ឃទាំងអស់អាចត្រួតត្រាមើលទីសម្រាប់សង់វិហារបាន ត្រូវសង្ឃទាំងអស់ត្រួតមើល។ បើសង្ឃទាំងអស់មិនអាចត្រួតមើលទីសម្រាប់សង់វិហារបានទេ ហើយក្នុងទីនោះ មានភិក្ខុទាំងឡាយណា ឈ្លាសប្រតិពល ដឹងទីដែលមានសេចក្តីរង្កៀស[30] ទីដែលមិនមានសេចក្តីរង្កៀស ទីមានឧបចារ ទីមិនមានឧបចារ ភិក្ខុសង្ឃត្រូវសូមភិក្ខុទាំងឡាយនោះ ហើយសន្មត។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ សង្ឃត្រូវសន្មតយ៉ាងនេះ។ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវឲ្យសង្ឃដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះ ចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមសង្ឃត្រួតមើលទីសម្រាប់សង់វិហារឲ្យ។ បើការត្រួតមើលទីសម្រាប់សង់វិហារមានកាលដ៏គួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីត្រួតមើលនូវទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ។ ពាក្យនេះជាពាក្យសម្រាប់ញុំាងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះ ចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមការត្រួតមើលទីសម្រាប់ធ្វើវិហារនឹងសង្ឃ។ ព្រះសង្ឃសន្មតនូវភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ។ ការសន្មតិនូវភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង សង្ឃបានសន្មតហើយ ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ។ (ការសន្មតិ ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ) គួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម។ ខ្ញុំព្រះករុណា ចាំទុកនូវដំណើរនេះ ដោយកិរិយាស្ងៀមយ៉ាងនេះ។

[២២៤] ភិក្ខុទាំងឡាយដែលសង្ឃបានសន្មតហើយនោះ ត្រូវទៅក្នុងទីនោះ ហើយត្រួតមើលទីដីសម្រាប់សង់វិហារ។ ភិក្ខុទាំងនោះត្រូវដឹងទីដែលមានសេចក្តីរង្កៀស និងទីដែលមិនមានសេចក្តីរង្កៀស ទីមានឧបចារ ទីមិនមានឧបចារ។ បើទីមានសេចក្តីរង្កៀស មិនមានឧបចារ គប្បីប្រាប់ថា លោកកុំធ្វើក្នុងទីនេះ។ បើទីមិនមានសេចក្តីរង្កៀស មានឧបចារ គប្បីប្រាប់ដល់សង្ឃថា ទីមិនមានសេចក្តីរង្កៀស មានឧបចារ។ ភិក្ខុអ្នកធ្វើវិហារនោះ គប្បីចូលទៅរកសង្ឃ ហើយធ្វើនូវចីពរឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងនៃភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលី ពោលយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណាមានសេចក្តីប្រាថ្នាធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណានោះ សូមសង្ឃសំដែងទីសម្រាប់សង់វិហារឲ្យ។ ភិក្ខុអ្នកធ្វើវិហារ ត្រូវសូមជាគំរប់ពីរដងផង សូមជាគំរប់បីដងផង។ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវឲ្យសង្ឃដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះ ចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមឲ្យសង្ឃសំដែងទីសម្រាប់សង់វិហារឲ្យ។ បើការសំដែងទីសម្រាប់សង់វិហារមានកាលដ៏គួរដល់សង្ឃហើយ សង្ឃគប្បីសំដែងទីសម្រាប់ធ្វើវិហាររបស់ភិក្ខុឈ្មោះនេះ។ ពាក្យនេះជាពាក្យសម្រាប់ញុំាងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះ ចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមសង្ឃសំដែងទីសម្រាប់ធ្វើវិហារឲ្យ។ ព្រះសង្ឃសំដែងទីសម្រាប់ធ្វើវិហារដល់ភិក្ខុឈ្មោះនេះ។ ការដែលសង្ឃសំដែងទីសម្រាប់ធ្វើវិហាររបស់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ សង្ឃបានសំដែងហើយ។ ការសំដែងទីសម្រាប់សង់វិហារនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំព្រះករុណា ចាំទុកនូវដំណើរនេះ ដោយកិរិយាស្ងៀមយ៉ាងនេះ។

[២២៥] ទីដែលហៅថា ប្រកបដោយសេចក្តីរង្កៀស (នោះ) គឺទីជាលំនៅនៃពួកស្រមោចក្រហមក្តី ជាលំនៅនៃពួកកណ្តៀរក្តី ជាលំនៅនៃពួកកណ្តុរក្តី ជាលំនៅនៃពួកពស់ក្តី ជាលំនៅនៃពួកខ្ទួយក្តី ជាលំនៅនៃពួកក្អែបក្តី ជាលំនៅនៃពួកដំរីក្តី ជាលំនៅនៃពួកសេះក្តី ជាលំនៅនៃពួកខ្លាធំក្តី ជាលំនៅនៃពួកខ្លាដំបងក្តី ជាលំនៅនៃពួកខ្លាឃ្មុំក្តី ជាលំនៅនៃពួកខ្លារខិន[31] ក្តី ជាលំនៅរបស់ពួកសត្វតិរច្ឆានឯណានីមួយក្តី ទីសម្រាប់ដាំបុព្វណ្ណ[32] ជាតិក្តី ទីសម្រាប់ដាំអបរណ្ណ[33] ជាតិក្តី កន្លែងសម្រាប់សម្លាប់ចោរក្តី កន្លែងសម្រាប់ផ្តាលទោស[34] ក្តី កន្លែងព្រៃស្មសានក្តី កន្លែងឧទ្យានក្តី កន្លែងស្រែស្តេចក្តី កន្លែងរោងដំរីក្តី កន្លែងរោងសេះក្តី កន្លែងសម្រាប់ឃុំឃាំងមនុស្សទោសក្តី កន្លែងរោងសុរាក្តី កន្លែងផ្ទះលក់សាច់ក្តី កន្លែងជាច្រកល្ហកក្តី កន្លែងវាលសម្រាប់លេងក្តី កន្លែងរោងប្រជុំនិយាយក្តី កន្លែងផ្លូវជាទីដើរទៅមកក្តី ទីទាំងប៉ុន្មាននេះ ហៅថាទីប្រកបដោយសេចក្តីរង្កៀស។

[២២៦] ទីដែលហៅថា មិនមានឧបចារ (នោះ) គឺទីដែលរទេះគេទឹមស្រេចហើយ បត់មិនបាន ឬបង្វិលបង្អោងជុំវិញមិនបាន ទីទាំងនេះ ហៅថា ទីមិនមានឧបចារ។

[២២៧] ទីដែលហៅថា មិនមានសេចក្តីរង្កៀស (នោះ) គឺទីដែលមិនមែនជាលំនៅនៃពួកស្រមោចក្រហមក្តី។បេ។ ទីមិនមែនជាផ្លូវដែលគេដើរទៅមកក្តី ទីទាំងនេះ ហៅថាទីមិនមានសេចក្តីរង្កៀស។

[២២៨] ទីដែលហៅថា មានឧបចារ (នោះ) គឺទីដែលរទេះគេទឹមស្រេចហើយ បត់បាន ឬបង្វិលបង្អោងជុំវិញបាន ទីទាំងនេះហៅថា ទីមានឧបចារ។

[២២៩] វិហារដែលមានទាយកជាម្ចាស់ តថាគតហៅថាវិហារធំ។ ទីដែលគេលាបខាងក្នុងក្តី លាបខាងក្រៅក្តី លាបទាំងខាងក្នុងទាំងខាងក្រៅក្តី ហៅថាវិហារ។ ត្រង់ពាក្យថា គប្បីឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី។ ត្រង់ពាក្យថា ឬមិននាំភិក្ខុទាំងឡាយទៅដើម្បីសំដែងទីឲ្យ សេចក្តីថា ភិក្ខុអ្នកធ្វើវិហារ មិនឲ្យភិក្ខុទាំងឡាយសំដែងទីសម្រាប់សង់វិហារដោយកម្មមានញត្តិជាគំរប់ពីរ ហើយធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគ នៅបាយអ១ដុំទៀតនឹងសម្រេច ត្រូវអាបត្តិថុល្លច្ច័យ លុះយកដុំនោះបូកសម្រេច ត្រូវអាបត្តិសង្ឃាទិសេស។ ត្រង់ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយក្នុងសង្ឃាទិសេសសិក្ខាបទទី១រួចហើយ។

[២៣០] ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ និងសង្ឃាទិសេស។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស តែជាទីមានឧបចារ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ជាទីមិនមានសេចក្តីរង្កៀស តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ជាទីមិនមានសេចក្តីរង្កៀស មានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើវិហារដែលសង្ឃបានសំដែងទីឲ្យ ជាទីប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសំដែងទីឲ្យ ជាទីប្រកបដោយសេចក្តីរង្កៀស តែមានឧបចារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសំដែងទីឲ្យ ជាទីមិនមានសេចក្តីរង្កៀស តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសំដែងទីឲ្យ ជាទីមិនមានសេចក្តីរង្កៀស មានឧបចារ មិនត្រូវអាបត្តិឡើយ។

[២៣១] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ (ភិក្ខុអ្នកប្រើនោះ) ត្រូវអាបត្តិទុក្កដពីរ និងសង្ឃាទិសេស។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស និងអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស មិនមានឧបចារ ត្រូវទុក្កដ និងសង្ឃាទិសេស។បេ។ មិនមានសេចក្តីរង្កៀស តែមានឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃបានសំដែងទីឲ្យ ជាទីប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស មានឧបចារ មិនត្រូវអាបត្តិឡើយ។

[២៣២] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែមិនបានពន្យល់ថា វិហារនោះគួរជាវិហារដែលសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានទីឧបចារផង។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ និងសង្ឃាទិសេស។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានឧបចារ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស។បេ។ មិនមានសេចក្តីរង្កៀស តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស។បេ។ មិនមានសេចក្តីរង្កៀស មានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែមិនបានពន្យល់ថា វិហារនោះ គួរជាវិហារដែលសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានឧបចារផង ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ ត្រូវអាបត្តិទុក្កដពីរ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស មានឧបចារ មិនត្រូវអាបត្តិឡើយ។

[២៣៣] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែបានពន្យល់ថា វិហារនោះ គួរជាវិហារមានសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានឧបចារផង។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ។ ភិក្ខុនោះ ឮដំណឹងថា បានឮថា វិហារគេធ្វើឲ្យអាត្មាអញ សង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ។ ភិក្ខុនោះ ត្រូវទៅដោយខ្លួនឯងក្តី បញ្ជូនបម្រើឲ្យទៅក្តី ដោយពាក្យថា វិហារនោះ គួរជាវិហារដែលមានសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានទីឧបចារផង។ បើភិក្ខុមិនទៅដោយខ្លួនឯងក្តី មិនបញ្ជូនបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។បេ។ វិហារនោះ គួរជាវិហារដែលសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង។បេ។ វិហារនោះ គួរជាវិហារដែលសង្ឃបានសំដែងទីឲ្យផង មិនមានឧបចារផង។បេ។ វិហារនោះ គួរជាវិហារដែលសង្ឃសំដែងទីឲ្យផង។ បើភិក្ខុមិនទៅដោយខ្លួនឯងក្តី មិនបញ្ជូនបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែភិក្ខុនោះបានពន្យល់ថា វិហារនោះ គួរជាវិហារដែលសង្ឃបានសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានទីឧបចារផង។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសំដែងទីឲ្យ តែប្រកបដោយសេចក្តីរង្កៀស មិនមានទីឧបចារ។ ភិក្ខុនោះ ឮដំណឹងថា បានឮថា គេធ្វើវិហារឲ្យអាត្មាអញ ជាវិហារដែលសង្ឃបានសំដែងទីឲ្យ ដែលប្រកបដោយសេចក្តីរង្កៀស មិនមានទីឧបចារ។ ភិក្ខុនោះគប្បីទៅដោយខ្លួនឯង ឬប្រើបម្រើឲ្យទៅដោយពាក្យថា វិហារនោះ គួរជាវិហារមិនមានសេចក្តីរង្កៀសផង មានទីឧបចារផង។បេ។ គួរជាវិហារមិនមានសេចក្តីរង្កៀស។បេ។ គួរជាវិហារមានទីឧបចារ។បេ។ មិនត្រូវអាបត្តិឡើយ។

[២៣៤] ភិក្ខុបង្គាប់ពួកភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែបានពន្យល់ថា វិហារនោះ គួរជាវិហារដែលសង្ឃសំដែងទីឲ្យផង មិនប្រកបដោយសេចក្តីរង្កៀសផង មានឧបចារផង ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានទីឧបចារ។ (ភិក្ខុទាំងឡាយអ្នកធ្វើ) ត្រូវអាបត្តិទុក្កដបី។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ មិនមានសេចក្តីរង្កៀស តែមិនមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ មិនមានសេចក្តីរង្កៀស មានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែបាន

ពន្យល់ថា វិហារនោះ គួរជាវិហារមានសង្ឃសំដែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានទីឧបចារផង។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស មិនមានទីឧបចារ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស មានទីឧបចារ មិនត្រូវអាបត្តិឡើយ។

[២៣៥] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃមិនបានសំដែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានទីឧបចារ បើវិហារនោះមិនទាន់ហើយស្រេច ស្រាប់តែភិក្ខុនោះមកដល់។ ភិក្ខុនោះ គប្បីឲ្យវិហារនោះទៅភិក្ខុដទៃ ឬរុះរើវិហារនោះធ្វើជាថ្មីទៀត។ បើភិក្ខុនោះ មិនឲ្យវិហារនោះដល់ភិក្ខុដទៃទេ ឬមិនឲ្យគេរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ និងសង្ឃាទិសេស។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស។បេ។ មិនប្រកបដោយសេចក្តីរង្កៀស តែមិនមានឧបចារ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស។បេ។ មិនមានសេចក្តីរង្កៀស មានទីឧបចារ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសំដែងទីឲ្យ តែប្រកបដោយសេចក្តីរង្កៀស មិនមានទីឧបចារ។ បើភិក្ខុនោះមកដល់ ក្នុងពេលដែលវិហារមិនទាន់ហើយ។ ភិក្ខុនោះ គប្បីឲ្យវិហារនោះទៅភិក្ខុដទៃ ឬរុះរើធ្វើជាថ្មីទៀត។ បើភិក្ខុនោះ មិនឲ្យវិហារនោះទៅភិក្ខុដទៃ មិនឲ្យគេរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស តែមិនមានទីឧបចារ ត្រូវអាបត្តិទុក្កដ។បេ។ មិនមានសេចក្តីរង្កៀស មានទីឧបចារ មិនត្រូវអាបត្តិឡើយ។

[២៣៦] ភិក្ខុធ្វើ(វិហារ) ដោយខ្លួនឯងមិនទាន់ហើយ (គ្រាក្រោយ) ក៏ធ្វើបង្ហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុធ្វើ(វិហារ) ដោយខ្លួនឯងមិនទាន់ហើយ ឲ្យអ្នកដទៃធ្វើបង្ហើយ ត្រូវអាបត្តិសង្ឃាទិសេស។ អ្នកដទៃធ្វើ(វិហារ) មិនទាន់ហើយ ភិក្ខុ (ម្ចាស់វិហារ) ធ្វើបង្ហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស។ អ្នកដទៃធ្វើ(វិហារ) មិនទាន់ហើយ ភិក្ខុឲ្យអ្នកដទៃធ្វើបង្ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[២៣៧] ដំណើរដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើលេណ[35] (ទីសម្រាប់ជ្រកលួមនៅបាន) គូហា (ទីបិទបាំងល្មមនៅបាន) កុដិស្មៅ និងកុដិសម្រាប់ភិក្ខុដទៃ មានឧបជ្ឈាយ៍ជាដើម ម្យ៉ាងទៀត ដំណើរដែលមិនត្រូវអាបត្តិដល់ភិក្ខុអ្នកធ្វើសេនាសន មានរោងឧបោសថជាដើម និងភិក្ខុឆ្កួត នឹងភិក្ខុដើមបញ្ញត្តិ វៀរលែងតែធ្វើទីសម្រាប់នៅរបស់ខ្លួនចេញ។

សង្ឃាទិសេស ទី៧ ចប់។

# សង្ឃាទិសេស ទី៨

CS vin.vbu.sg.08 | ភាគ ទី២

### (៨. ទុដ្ឋទោសសិក្ខាបទំ)

[២៣៨] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង ព្រះទព្វមល្លបុត្ត[36] ដ៏មានអាយុ មានអាយុ៧ឆ្នាំអំពីកំណើត បានសម្រេចព្រះអរហត្តផល គុណជាតឯណានីមួយដែលសាវកត្រូវដល់ គុណជាតទាំងអស់ (នោះ) ក៏ព្រះទព្វមល្លបុត្តនោះបានដល់ដោយលំដាប់ហើយ កិច្ចអ្វីបន្តិចបន្តួច (សោឡសកិច្ច) ដែលព្រះទព្វមល្លបុត្តនោះគប្បីធ្វើតទៅទៀត ឬកិច្ចដែលព្រះទព្វមល្លបុត្តបានធ្វើរួចហើយ នឹងធ្វើកិច្ចនោះឲ្យចំរើនឡើងទៅទៀតក៏មិនមានឡើយ។

[២៣៩] លំដាប់នោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ ទៅកាន់ទីស្ងាត់ សម្ងំនៅក្នុងកម្មដ្ឋាន មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា អញកើតឡើងបាន៧ឆ្នាំ បានសម្រេចអរហត្តផល គុណជាតឯណានីមួយដែលសាវកត្រូវដល់ គុណជាតទាំងអស់ (នោះ) ក៏អញបានដល់ដោយលំដាប់ហើយ ម្យ៉ាងទៀត កិច្ចអ្វីនីមួយ ដែលអញត្រូវធ្វើតទៅទៀត ឬកិច្ចដែលអញបានធ្វើរួចហើយ នឹងធ្វើកិច្ចនោះឲ្យចំរើនឡើងទៅទៀតក៏មិនមានឡើយ (បើដូច្នោះ) អញគប្បីធ្វើការខ្វល់ខ្វាយ បម្រើដល់សង្ឃឬអ្វីហ្ន៎។ កាលនោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ បានត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអញត្រូវរៀបចំសេនាសនផង ត្រូវចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ចេញអំពីទីសម្ងំក្នុងកម្មដ្ឋាននៅពេលសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងពេលនោះ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ លុះព្រះទព្វមល្លបុត្តដ៏មានអាយុគង់ក្នុងទីដ៏សមគួរមួយហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទៅក្នុងទីស្ងាត់ សម្ងំនៅក្នុងកម្មដ្ឋានក្នុងថ្ងៃនេះ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា អាត្មាឯងកើតឡើងបាន៧ឆ្នាំ បានសម្រេចអរហត្តផល គុណជាតឯណានីមួយដែលសាវកត្រូវដល់ គុណជាតទាំងអស់ (នោះ) ក៏អាត្មាបានដល់ដោយលំដាប់ហើយ ម្យ៉ាងទៀត កិច្ចអ្វីនីមួយ ដែលអាត្មាគប្បីធ្វើតទៅទៀត ឬកិច្ចដែលអាត្មាបានធ្វើរួចហើយ នឹងធ្វើកិច្ចនោះឲ្យចំរើនឡើងតទៅទៀតក៏មិនមានឡើយ (បើដូច្នោះ) អាត្មាគប្បីធ្វើការខ្វល់ខ្វាយ បម្រើដល់សង្ឃឬអ្វីហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីត្រិះរិះនេះកើតមានដល់ខ្ញុំព្រះអង្គនោះថា បើដូច្នោះ មានតែអាត្មាត្រូវរៀបចំសេនាសនផង ត្រូវចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់រៀបចំសេនាសនផង ចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃ។ ព្រះបរមគ្រូ ទ្រង់ត្រាស់ថា ម្នាលទព្វ ប្រពៃណាស់ហើយៗ បើដូច្នោះ អ្នកចូររៀបចំសេនាសនៈផង ចូរចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃចុះ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគ ដោយពាក្យថា ករុណាព្រះអង្គ។

[២៤០] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរសម្មតិទព្វមល្លបុត្ត ឲ្យជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងចង្ហាន់ផងចុះ។ ម្នាលភិក្ខុទាំងឡាយ ទព្វភិក្ខុត្រូវសង្ឃសម្មតិយ៉ាងនេះ មុនដំបូង ត្រូវសង្ឃអង្វរទព្វភិក្ខុ លុះអង្វររួចហើយ ត្រូវភិក្ខុមួយរូបដែលឆ្លាសវាងវៃផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើការសម្មតិមានកាលដ៏គួរដល់សង្ឃហើយ សូមព្រះសង្ឃសម្មតិទព្វមល្លបុត្តដ៏មានអាយុ ឲ្យជាអ្នករៀបចំ

សេនាសនផង ជាអ្នកចាត់ចែងចង្ហាន់ផង។ ពាក្យនេះជាពាក្យសម្រាប់ញ៉ាំងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ព្រះសង្ឃសម្មតិទព្វមល្លបុត្តដ៏មានអាយុ ឲ្យជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងចង្ហាន់ផង។ ការសម្មតិទព្វមល្លបុត្តដ៏មានអាយុ ឲ្យជាអ្នករៀបចំសេនាសនផង ជាអ្នកចាត់ចែងចង្ហាន់ផង គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម (បើ) មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង។ ទព្វមល្លបុត្តដ៏មានអាយុ ជាអ្នករៀបចំសេនាសនផង ជាអ្នកចាត់ចែងចង្ហាន់ផង សង្ឃបានសន្មតរួចហើយ។ ការសម្មតិនេះ គួរដល់សង្ឃ ព្រោះហេតុនោះ ព្រះសង្ឃទើបស្ងៀម។ ខ្ញុំព្រះករុណាចាំទុកនូវសេចក្តីស្ងៀមរបស់សង្ឃនេះយ៉ាងនេះ។

[២៤១] ទព្វមល្លបុត្តដ៏មានអាយុដែលសង្ឃបានសន្មតរួចហើយ ក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយដែលមានគុណធម៌ស្មើគ្នា ភិក្ខុទាំងឡាយឯណា ជាអ្នករៀនព្រះសូត្រ ទព្វមល្លបុត្តដ៏មានអាយុ ក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុទាំងឡាយនោះនឹងរួបរួមគ្នា ស្វាធ្យាយនូវព្រះសូត្រ។ ភិក្ខុទាំងឡាយឯណា ជាអ្នកទ្រទ្រង់វិន័យ ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នកទ្រទ្រង់វិន័យទាំងឡាយនោះ នឹងវិនិច្ឆ័យវិន័យជាមួយគ្នាទៅវិញទៅមក ភិក្ខុទាំងឡាយឯណា ជាអ្នករៀនព្រះអភិធម្ម ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នករៀនព្រះអភិធម្ម នឹងសាកសួរព្រះអភិធម្មទៅវិញទៅមក ភិក្ខុទាំងឡាយឯណា ជាអ្នកចំរើនឈាន ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នកចំរើនឈានទាំងឡាយនោះមិនបៀតបៀនគ្នាទៅវិញទៅមក ភិក្ខុទាំងឡាយឯណា ជាអ្នកពោលតិរច្ឆានកថា[37] ច្រើនដោយការថ្នមខ្លួន ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយនោះ ដោយគិតថា លោកដ៏មានអាយុទាំងឡាយនេះ នឹងនៅទាល់ភ្លឺដោយពោលនូវតិរច្ឆានកថានេះ ភិក្ខុទាំងឡាយឯណា មកដល់ក្នុងពេលដែលងងិត ព្រះទព្វមល្លបុត្ត ក៏ចូលកាន់តេជោធាតុ[38] ហើយរៀបចំសេនាសនដោយពន្លឺនៃតេជោធាតុ ដើម្បីភិក្ខុទាំងឡាយនោះ។ ជួនកាលមានភិក្ខុទាំងឡាយក្លែងក្លាយហើយមកក្នុងពេលងងិត ដោយគិតថា យើងទាំងឡាយនឹងឃើញឥទ្ធិបាដិហារិយ៍របស់ទព្វមល្លបុត្តដ៏មានអាយុ។ ភិក្ខុទាំងនោះ ចូលទៅរកព្រះទព្វមល្លបុត្តដ៏មានអាយុ ហើយពោលយ៉ាងនេះថា ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនដើម្បីយើងទាំងឡាយ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ពោលនូវពាក្យយ៉ាងនេះនឹងភិក្ខុទាំងឡាយនោះថា លោកទាំងឡាយដ៏មានអាយុចង់បានក្នុងទីណា ខ្ញុំត្រូវរៀបចំក្នុងទីដូចម្តេច។ ភិក្ខុទាំងឡាយនោះ (ខ្លះ) ក៏ក្លែងចង្អុលទៅរកទីឆ្ងាយដោយពាក្យថា ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនលើភ្នំគិជ្ឈកូដ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនជិតជ្រោះសម្រាប់ទម្លាក់ចោរ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនលើកាឡសិលានាខាងភ្នំឥសិគិលិ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនក្នុងសត្តបណ្ណគុហាខាងភ្នំវេភារ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនទៀបញកភ្នំ ឈ្មោះសប្បសោណ្ឌិកក្នុងព្រៃត្រជាក់ (ព្រៃជាំ) ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនទៀបច្រកភ្នំឈ្មោះគោមដ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនទៀបច្រកភ្នំឈ្មោះតិន្ទុក ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនទៀបច្រកភ្នំឈ្មោះកបោត ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនក្នុងតបោទារាម ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនក្នុងជីវកម្ពវន ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនក្នុងព្រៃឈ្មោះមទ្ទកុច្ឆិ ជាទីឲ្យអភ័យដល់ម្រឹគ ដើម្បីយើងទាំងឡាយចុះ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ចូលកាន់តេជោធាតុ (ចំរើនតេជោកសិណ) ហើយមានម្រាមដៃដ៏ភ្លឺរុងរឿង ដើរទៅក្នុងទីខាងមុខៗ។ ភិក្ខុទាំងឡាយនោះ ក៏ដើរទៅអំពីខាងក្រោយៗនៃព្រះទព្វមល្លបុត្តដោយពន្លឺនោះឯង។ ព្រះទព្វមល្លបុត្តដ៏មានអាយុ រៀបចំក្រាលសេនាសនដល់ភិក្ខុទាំងឡាយនោះដោយរបៀបយ៉ាងនេះគឺ នេះគ្រែ នេះតាំង នេះពូក នេះខ្នើយ នេះទីសម្រាប់ដោះទុក្ខសត្វធំ នេះទីសម្រាប់ដោះទុក្ខសត្វតូច នេះទឹកសម្រាប់ផឹក នេះទឹកសម្រាប់ប្រើប្រាស់ នេះឈើច្រត់ នេះទីកតិកសញ្ញារបស់សង្ឃ ពេលនេះត្រូវអ្នកទាំងឡាយចូល ពេលនេះត្រូវអ្នកទាំងឡាយចេញ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ រៀបចំសេនាសនយ៉ាងនេះដល់ភិក្ខុទាំងឡាយនោះ ហើយក៏និមន្តត្រឡប់មកវត្តវេឡុវនវិញ។

[២៤២] សម័យនោះឯង មេត្តិយភិក្ខុ និងភុម្មជក[39] ភិក្ខុទាំងឡាយ ជាអ្នកបួសថ្មីផង មានបុណ្យតិចផង សេនាសនទាំងឡាយឯណា ដែលថោកទាប ជាសេនាសនរបស់សង្ឃ សេនាសនទាំងឡាយនោះតែងបានមកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ទាំងភត្តណាដែលថោកទាប ក៏តែងបានមកភិក្ខុទាំងពីររូបនោះដែរ។ សម័យនោះឯង មនុស្សទាំងឡាយ ក្នុងក្រុងរាជគ្រឹះ ចង់ឲ្យសប្បិផង ប្រេងផង សម្លឧត្តរិភង្គ[40] ផង ដែលគេតាក់តែងដើម្បីភិក្ខុទាំងឡាយជាថេរ តែមនុស្សទាំងឡាយនោះ ឲ្យបាយចុងអង្ករ មានទឹកជ្រក់ជាគំរប់ពីរ ដែលខ្លួនប្រារព្ធហើយយ៉ាងណាជាប្រក្រតី ដល់មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ឆាន់ចង្ហាន់រួចហើយ ក៏សួរភិក្ខុទាំងឡាយជាថេរថា ម្នាលអាវុសោទាំងឡាយ ក្នុងរោងភត្តរបស់ពួកលោក មានអ្វីខ្លះ ម្នាលអាវុសោទាំងឡាយ វត្ថុអ្វីខ្លះ មានក្នុងរោងភត្តរបស់លោកទាំងឡាយ។ ព្រះថេរទាំងឡាយពួកខ្លះប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ក្នុងរោងយើងមានសប្បិ ក្នុងរោងយើងមានប្រេង ក្នុងរោងយើងមានសម្លឧត្តរិភង្គ។ ឯមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ និយាយប្រាប់យ៉ាងនេះថា ម្នាលអាវុសោ យើងគ្មានវត្ថុអ្វីបន្តិចបន្តួចទេ មានតែបាយចុងអង្ករ និងទឹកជ្រក់ជាគំរប់ពីរ តាមដំណើរដែលគេប្រារព្ធជាប្រក្រតីប៉ុណ្ណោះ។

[២៤៣] សម័យនោះឯង មានគហបតី (ម្នាក់) ឈ្មោះកល្យាណភត្តិក[41] តែងប្រគេននិច្ចភត្ត (ក្នុងមួយថ្ងៃ) ៤សម្រាប់ ដល់ព្រះសង្ឃ។ គហបតីនោះ ព្រមទាំងកូនប្រពន្ធ ចូលទៅបម្រើអង្គាស (ព្រះសង្ឃ) ក្នុងរោងភត្ត។ ភិក្ខុទាំងឡាយដទៃខ្លះសួររកបាយ ខ្លះសួររកសម្ល ខ្លះសួររកប្រេង ខ្លះសួររកសម្លឧត្តរិភង្គ។ សម័យនោះឯង មេត្តិយ និងភុម្មជកភិក្ខុត្រូវវេនទទួលចង្ហាន់ក្នុងថ្ងៃស្អែករបស់គហបតីឈ្មោះកល្យាណភត្តិក ជាចង្ហាន់ដែលភត្តុទ្ទេសក[42] ភិក្ខុសំដែងឲ្យ។ គ្រានោះ គហបតីឈ្មោះកល្យាណភត្តិក បានទៅកាន់អារាមដោយមានកិច្ចការអ្វីមួយដែលខ្លួនត្រូវធ្វើ។ គហបតីនោះចូលទៅរកព្រះទព្វមល្លបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះទព្វមល្លបុត្តដ៏មានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ បាននិយាយពន្យល់គហបតីឈ្មោះកល្យាណភត្តិកឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យខ្មីឃ្មាត ឲ្យរីករាយព្រមដោយពាក្យដ៏ប្រកបដោយធម៌។ លំដាប់នោះ គហបតីឈ្មោះកល្យាណភត្តិក កាលដែលព្រះទព្វមល្លបុត្តដ៏មានអាយុ និយាយពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យខ្មីឃ្មាត ឲ្យរីករាយព្រម ដោយពាក្យដ៏ប្រកបដោយធម៌ (ដូច្នោះ) ពោលនូវពាក្យនេះនឹងព្រះទព្វមល្លបុត្តដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ភត្តក្នុងផ្ទះរបស់យើងក្នុងថ្ងៃស្អែក លោកម្ចាស់បានចាត់ឲ្យលោកអង្គណា។ ព្រះទព្វមល្លបុត្តឆ្លើយថា ម្នាលគហបតី ភត្ត

ក្នុងផ្ទះរបស់អ្នកក្នុងថ្ងៃស្អែក អាត្មាបានចាត់ឲ្យដល់មេត្តិយ និងភុម្មជកភិក្ខុទាំងឡាយ។ គ្រានោះ គហបតីឈ្មោះកល្យាណភត្តិក ក៏មានសេចក្តីអាក់អន់ចិត្ត ដោយគិតថា ចុះហេតុអ្វីបានជាភិក្ខុអាក្រក់ទាំងឡាយ នឹងត្រូវឆាន់ចង្ហាន់ក្នុងផ្ទះយើងដែរ (លុះគិតដូច្នេះហើយ) ក៏ទៅផ្ទះ បង្គាប់ទាសីថា នែហាង ស្អែកត្រូវពួកលោកណាមកទទួលចង្ហាន់ ហាងឯងចូរក្រាលអាសនក្នុងជង្រុក ហើយអង្គាសលោកទាំងនោះដោយបាយចុងអង្ករមានទឹកជ្រក់ជាគំរប់ពីរចុះ។ ខ្ញុំស្រីនោះទទួលស្តាប់ពាក្យគហបតីឈ្មោះកល្យាណភត្តិកដោយពាក្យថា ចាះ អ្នកម្ចាស់។ កាលនោះមេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយគិតគ្នាថា ម្នាលអាវុសោ ចង្ហាន់ក្នុងផ្ទះគហបតីឈ្មោះកល្យាណភត្តិក សង្ឃបានសំដែងឡើងដល់យើងទាំងឡាយអំពីថ្ងៃម្សិលមិញហើយ វេលាព្រឹកស្អែក គហបតីឈ្មោះកល្យាណភត្តិកព្រមទាំងកូនប្រពន្ធ នឹងចូលមកជិតបម្រើបម្រាស់អង្គាសយើង ភិក្ខុទាំងឡាយដទៃៗខ្លះនឹងសួររកបាយ ខ្លះនឹងសួររកសម្ល ខ្លះនឹងសួររកប្រេង ខ្លះនឹងសួររកសម្លឧត្តរិភង្គ។ ដោយសេចក្តីសោមនស្សនោះឯង មេត្តិយភិក្ខុ និងភុម្មជកភិក្ខុនោះ ទុកជាចង់ដេកយ៉ាងណា ដ៏ដេកមិនលក់អស់មួយយប់។ គ្រានោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ព្រឹកឡើងក៏ស្លៀកដណ្តប់ ហើយទ្រង់បាត្រនិងចីវរ ចូលទៅកាន់ទីលំនៅរបស់គហបតីឈ្មោះកល្យាណភត្តិក។ ខ្ញុំស្រីនោះបានឃើញមេត្តិយភិក្ខុនិងភុម្មជកភិក្ខុតាំងពីនិមន្តមកពីចម្ងាយ លុះឃើញហើយ ក៏ក្រាលអាសនក្នុងជង្រុក ហើយបាននិយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុ (ទាំងពីររូប) ថា បពិត្រលោកដ៏ចំរើន សូមលោកទាំងឡាយគង់ (ក្នុងទីនេះ)ចុះ។ កាលនោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមានសេចក្តីត្រិះរិះថា ប្រហែលជាចង្ហាន់មិនទាន់ឆ្អិនទេដឹងបានជាគេឲ្យយើងអង្គុយក្នុងជង្រុក (នេះ)។ ខ្ញុំស្រីនោះ ក៏លើកបាយចុងអង្ករ ជាគំរប់ពីរមុខនឹងទឹកជ្រក់ ហើយនិយាយនឹងមេត្តិយភិក្ខុ និងភុម្មជកភិក្ខុក្នុងពេលនោះថា បពិត្រលោកដ៏ចំរើន សូមលោកទាំងឡាយឆាន់ចុះ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី យើងទាំងឡាយសុទ្ធតែជាអ្នកត្រូវវេនបាននិច្ចភត្ត។ ខ្ញុំស្រីនោះឆ្លើយថា ខ្ញុំព្រះករុណាដឹងថា លោកម្ចាស់ទាំងឡាយជាអ្នកត្រូវវេនបាននិច្ចភត្តហើយ តែថាម្សិលមិញ គហបតីបង្គាប់ខ្ញុំព្រះករុណាថា នែហាង លោកទាំងឡាយឯណាត្រូវការដោយចង្ហាន់និមន្តមកក្នុងថ្ងៃស្អែក ហាងឯងចូរក្រាលអាសនក្នុងជង្រុកចុះ ហើយអង្គាស់លោកទាំងនោះ ដោយបាយចុងអង្ករជាគំរប់ពីរមុខនឹងទឹកជ្រក់ (ហេតុនោះ) បពិត្រលោកដ៏ចំរើនទាំងឡាយ សូមលោកឆាន់ចុះ។ លំដាប់នោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុគិតគ្នាថា ម្នាលអាវុសោ កាលពីថ្ងៃម្សិល គហបតីឈ្មោះកល្យាណភត្តិក បានទៅកាន់សំណាក់ព្រះទព្វមល្លបុត្ត ឯអារាមយើង ប្រាកដជាទព្វមល្លបុត្តញុះញង់ក្នុងសំណាក់នៃគហបតីនោះហើយ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងនោះក៏ឆាន់ចង្ហាន់ដ៏សមគួរដល់ចិត្តមិនបាន ព្រោះតែសេចក្តីទោមនស្សនោះឯង។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆាន់ចង្ហាន់រួចហើយ ត្រឡប់ទៅអារាមក្នុងពេលនោះ ក៏រៀបទុកដាក់បាត្រ និងចីវរ ហើយអង្គុយរឹបសង្ឃាដីខាងក្រៅខ្លោងទ្វារវត្តវេឡុវន អង្គុយស្ងៀម មានសេចក្តីអៀនអន់ ឱនកសំយុងមុខចុះជ្រប់ ឥតមាននិយាយពីអ្វីសោះ។

[២៤៤] គ្រានោះ មេត្តិយាភិក្ខុនីចូលទៅរកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់សូមថ្វាយបង្គំ។ កាលបើមេត្តិយាភិក្ខុនី និយាយយ៉ាងនេះហើយ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិននិយាយតបតសោះឡើយ។ មេត្តិយាភិក្ខុនីបាននិយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុជាគំរប់ពីរដង។បេ។ ជាគំរប់បីដងថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់សូមថ្វាយបង្គំ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិននិយាយតជាគំរប់បីដងដែរ។ ទើបមេត្តិយាភិក្ខុនីសួរថា ខ្ញុំម្ចាស់បានប្រទូស្តដល់លោកម្ចាស់រាល់អង្គដូចម្តេចខ្លះ បានជាលោកម្ចាស់រាល់អង្គមិននិយាយនឹងខ្ញុំម្ចាស់។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី បានជាយើងមិននិយាយនឹងនាង ព្រោះយើង ទព្វមល្លបុត្តគេបៀតបៀន ហើយនាងឯងធ្វើព្រងើយកន្តើយ។ មេត្តិយាភិក្ខុនីសួរថា (បើដូច្នោះ) លោកម្ចាស់ឲ្យខ្ញុំធ្វើដូចម្តេច។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី បើនាងចង់ឲ្យព្រះដ៏មានព្រះភាគធ្វើឲ្យទព្វមល្លបុត្តវិនាស (នោះ) ព្រះដ៏មានព្រះភាគនឹងធ្វើទព្វមល្លបុត្តឲ្យវិនាសក្នុងថ្ងៃនេះពុំខាន។ មេត្តិយាភិក្ខុនីសួរថា ចុះលោកម្ចាស់រាល់អង្គឲ្យខ្ញុំធ្វើដូចម្តេច ខ្ញុំអាចធ្វើម្តេច។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ចូរនាងមក ចូរនាងចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅគាល់ហើយ ចូរនាងក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ការនេះមិនមែនជាការបិទបាំង មិនមែនជាការសមគួរសោះឡើយ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះត្រឡប់ជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពវិញ ទីកន្លែងណាដែលមិនធ្លាប់មានខ្យល់ ទីកន្លែងនោះត្រឡប់ជាមានខ្យល់វិញ ដូចជាទឹកធ្លាប់ត្រជាក់ ប្រែជាក្តៅ ឥឡូវព្រះទព្វមល្លបុត្តជាម្ចាស់ លោកប្រទូស្ត[43] នឹងខ្ញុំម្ចាស់ហើយ។ មេត្តិយាភិក្ខុនីទទួលស្តាប់ពាក្យមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ដោយពាក្យថា យ៉ាងហ្នឹងហើយលោកម្ចាស់ រួចហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយស្ថិតនៅក្នុងទីដ៏សមគួរ។ មេត្តិយាភិក្ខុនី លុះស្ថិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ការនេះមិនមែនជាការបិទបាំង មិនមែនជាការសមគួរសោះឡើយ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនធ្លាប់មានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះត្រឡប់ជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពវិញ ទីកន្លែងណាដែលមិនធ្លាប់មានខ្យល់ ទីកន្លែងនោះត្រឡប់ជាមានខ្យល់វិញ ដូចជាទឹកធ្លាប់ត្រជាក់ ប្រែជាក្តៅ ឥឡូវព្រះទព្វមល្លបុត្តជាម្ចាស់ លោកប្រទូស្តនឹងខ្ញុំព្រះអង្គហើយ។

[២៤៥] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ព្រះទព្វមល្លបុត្តដ៏មានអាយុក្នុងពេលនោះថា ម្នាលទព្វៈ អ្នករលឹកឃើញឬទេ នាងភិក្ខុនីនេះថាយ៉ាងណា អ្នកឯងបានធ្វើយ៉ាងនោះមែនឬទេ។ ព្រះទព្វមល្លបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគជ្រាបនូវខ្ញុំព្រះអង្គដោយពិតហើយ។ ព្រះដ៏មានព្រះភាគមានបន្ទូលសួរព្រះទព្វមល្លបុត្តដ៏មានអាយុជាគំរប់ពីរដង។បេ។ ជាគំរប់បីដងថា ម្នាលទព្វៈ អ្នករលឹកឃើញឬ នាងភិក្ខុនីនេះថាយ៉ាងណា អ្នកឯងបានធ្វើយ៉ាងនោះមែនឬ។ ព្រះទព្វមល្លបុត្តក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គដោយពិតហើយ។ ព្រះបរមគ្រូត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយ មិនពោលបណ្តោះបណ្តែយ៉ាងនេះទេ បើអំពើដែលអ្នកបានធ្វើហើយ អ្នកចូរប្រាប់ថា ខ្ញុំធ្វើហើយ បើអំពើដែលអ្នកមិនបានធ្វើទេ អ្នកចូរប្រាប់ថា ខ្ញុំមិនបានធ្វើទេ។ ព្រះទព្វមល្លបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គតាំងពីដួចកើតមក សូម្បីតែយល់សប្តិសេពមេថុនធម្ម ក៏មិនដែលស្គាល់សោះឡើយ នឹងបាច់ពោលទៅថ្វីដល់ការរលឹក (នោះ)។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមក ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរឲ្យមេត្តិយាភិក្ខុនីសឹកចេញ ម្យ៉ាងទៀត អ្នកទាំងឡាយចូរសាកសួរភិក្ខុទាំងឡាយនេះមើល។ លុះព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះហើយ ក៏ក្រោកចាកអាសនៈចូលទៅកាន់វិហារវិញ។ ភិក្ខុទាំងឡាយនោះ ក៏ឲ្យមេត្តិយាភិក្ខុនីសឹកក្នុងពេលនោះ។ ទើបមេត្តិយភិក្ខុ និងភុម្មជកភិក្ខុនិយាយពាក្យនេះនឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោ ចូរលោកកុំផ្សឹកមេត្តិយាភិក្ខុនីៗនោះឥតមានកំហុសសោះទេ (ហេតុដើមមកពី) យើងខឹង មិនសប្បាយចិត្ត (យើង) ចង់ឲ្យទព្វមល្លបុត្តឃ្លាតចាកសមណភេទ ទើបឲ្យមេត្តិយាភិក្ខុនី

នោះប្រឹងប្រែងឡើង។ ភិក្ខុទាំងឡាយសួរថា ម្នាលអាវុសោ អ្នកហ៊ានចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយអាបត្តិបារាជិកមិនមានមូល[44] ឬ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលអាវុសោ យ៉ាងហ្នឹងមែនហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស និន្ទា តិះដៀលថា ចុះហេតុអ្វី បានជាមេត្តិយភិក្ខុ និងភុម្មជកភិក្ខុចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយអាបត្តិបារាជិកមិនមានមូល (ដូច្នោះ)។ ទើបភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះមេត្តិយភិក្ខុ និងភុម្មជកភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយចោទទព្វមល្លបុត្ត ដោយអាបត្តិបារាជិកមិនមានមូល ពិតមែនឬ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន។ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ចុះហេតុអ្វីបានជា អ្នកទាំងឡាយចោទទព្វមល្លបុត្តដោយអាបត្តិបារាជិកមិនមានមូល (ដូច្នោះ) ម្នាលមោឃបុរសទាំងឡាយ ហេតុនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លានោះទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា

**ភិក្ខុណាមួយ មានសេចក្តីក្រោធប្រទូស្ត មានចិត្តអាក់អន់ ចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិកមិនមានមូល ដោយបំណងថា អញត្រូវធ្វើដូចម្តេចឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌[45] នេះបាន លុះសម័យខាងក្រោយតពីនោះមក ទោះគេសាកសួរក្តី គេមិនសាកសួរក្តី អធិករណ៍នោះប្រាកដជាគ្មានមូល ភិក្ខុអ្នកចោទនោះ ក៏ប្តេជ្ញាទោស (ដោយខ្លួនឯង) ត្រូវអាបត្តិសង្ឃាទិសេស។**

[២៤៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ។ ត្រង់ពាក្យថា មានសេចក្តីក្រោធប្រទូស្ត អធិប្បាយថា ខឹង អន់ចិត្ត មិនត្រេកអរ មានចិត្តគឺទោសខ្ញាំងខ្ញប់ មានចិត្តចង្អៀតចង្អល់។ ត្រង់ពាក្យថា មានចិត្តអាក់អន់ គឺមានចិត្តមិនរីករាយ ព្រោះសេចក្តីខឹងនោះផង ព្រោះទោសនោះផង ព្រោះសេចក្តីអន់ចិត្តនោះផង ព្រោះសេចក្តីមិនត្រេកអរនោះផង។ ដែលហៅថា មិនមានមូល គឺមិនឃើញ មិនឮ មិនរង្កៀស។ ត្រង់ពាក្យថា ដោយអាបត្តិបារាជិក គឺបណ្តាអាបត្តិបារាជិកទាំង៤ អាបត្តិបារាជិកណាមួយ។ ត្រង់ពាក្យថា ចោទ គឺចោទខ្លួនឯងក្តី ឲ្យអ្នកដទៃចោទក្តី។ ពាក្យថា អញត្រូវធ្វើដូចម្តេច ឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌នេះបាន អធិប្បាយថា អញគប្បីឲ្យភិក្ខុនោះឃ្លាតចាកភិក្ខុភាព ឃ្លាតចាកសមណធម៌ ឃ្លាតចាកកងសីល ឃ្លាតចាកតបោគុណ។[46]

[២៤៧] ត្រង់ពាក្យថា លុះសម័យខាងក្រោយតពីនោះមក សេចក្តីថា (រូបភិក្ខុនោះ) ចោទគេក្នុងខណៈណា ក្នុងខណៈនោះ ស្របក់នោះ ពេលនោះកន្លងទៅ។ ត្រង់ពាក្យថា ទោះគេសាកសួរក្តី សេចក្តីថា (រូបភិក្ខុនោះ) គេចោទដោយវត្ថុណា គេសាកសួរក្នុងវត្ថុនោះក្តី។ ត្រង់ពាក្យថា គេមិនសាកសួរក្តី សេចក្តីថា ឥតមានអ្នកណាមួយសាកសួរ។

[២៤៨] ដែលហៅថា អធិករណៈៗ នោះមាន៤យ៉ាងគឺ វិវាទាធិករណៈ១ អនុវាទាធិករណៈ១ អាបត្តាធិករណៈ១ កិច្ចាធិករណៈ១។

[២៤៩] ត្រង់ពាក្យថា ភិក្ខុអ្នកចោទនោះ ក៏ប្តេជ្ញាទោស (ដោយខ្លួនឯង) សេចក្តីថា អញពោលពាក្យទទេ អញពោលពាក្យព្រាង អញពោលពាក្យមិនពិត អញមិនដឹងហើយពោល។ ត្រង់ពាក្យថា អាបត្តិសង្ឃាទិសេស មានអធិប្បាយក្នុងសង្ឃាទិសេសសិក្ខាបទទី១រួចហើយ។

[២៥០] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញទេ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា ខ្ញុំបានឃើញអ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធ ជាសក្យបុត្តទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា ខ្ញុំបានឮថាអ្នកឯងត្រូវបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធ ជាសក្យបុត្តទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទនោះមិនមានសេចក្តីរង្កៀស បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា ខ្ញុំមានសេចក្តីរង្កៀសថា អ្នកឯងត្រូវបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។

[២៥១] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវបារាជិកហើយ ខ្ញុំបានឃើញហើយផង បានឮផង។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវបារាជិកហើយ ខ្ញុំបានឃើញហើយផង រង្កៀសហើយផង អ្នកឯងមិនមែនជាសមណៈ។បេ។ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយផង ឮហើយផង រង្កៀសហើយផង។បេ។ (ភិក្ខុចោទដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទមិនបានឮ ព្រោះហេតុនោះ ថាបើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ យើងបានឮផង រង្កៀសផង។បេ។ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា យើងបានឮផង បានឃើញផងថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា ខ្ញុំហើយឮផង រង្កៀសហើយផង ឃើញហើយផងថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឃើញហើយផង។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឮ

ហើយផង។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឃើញហើយផង ខ្ញុំឮហើយផង។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។

[២៥២] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះបានឃើញមែន បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវបារាជិកហើយ ខ្ញុំបានឮហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទបានឃើញមែន បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវបារាជិកហើយ ខ្ញុំរង្កៀសហើយ។បេ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឮហើយផង រង្កៀសហើយផង។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ (ភិក្ខុអ្នកចោទនោះ) បានឮ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយ។បេ។ (បើភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឃើញហើយ។បេ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ឃើញហើយផង។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយ។បេ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឮហើយ។បេ។ បើ (ភិក្ខុអ្នកចោទនោះ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយផង ខ្ញុំឮហើយផង អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។

[២៥៣] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះបានឃើញមែន តែមានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនបានឃើញហើយ (គឺ) កំណត់មិនបាននូវភិក្ខុដែលខ្លួនឃើញហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនឃើញហើយ ភ្លេចនូវភិក្ខុដែលខ្លួនឃើញហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឃើញផង ខ្ញុំបានឮផង។បេ។ ខ្ញុំបានឃើញផង ខ្ញុំមានសេចក្តីរង្កៀសផង។បេ។ ខ្ញុំបានឃើញផង ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង។បេ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះបានឮ តែមានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនបានឮហើយ (គឺ) កំណត់មិនបាននូវភិក្ខុដែលខ្លួនឮហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនឮហើយ ភ្លេចនូវភិក្ខុដែលខ្លួនឮហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង។បេ។ ខ្ញុំបានឮផង ខ្ញុំបានឃើញផង។បេ។ ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឃើញផង។បេ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមានសេចក្តីរង្កៀស ក៏មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនមានសេចក្តីរង្កៀសហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ ភ្លេចនូវភិក្ខុដែលខ្លួនរង្កៀសហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឃើញផង។បេ។ ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឮផង។បេ។ ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឃើញផង ខ្ញុំបានឮផង អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូននៃព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។

[២៥៤] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ (ភិក្ខុអ្នកចោទ) ប្រើបុគ្គលដទៃឲ្យចោទភិក្ខុដែលត្រូវអាបត្តិបារាជិកនោះថា អ្នកឯងខ្ញុំឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ (ភិក្ខុអ្នកចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមិនបានឮ បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឮថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមិនបានរង្កៀស បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្តីរង្កៀសថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។

[២៥៥] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទមិនឃើញទេ បើ (ភិក្ខុអ្នកចោទ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំបានឮហើយ។បេ។ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ។បេ។អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទថា អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ។បេ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំបានឃើញហើយ។បេ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមិនបានរង្កៀស បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ។បេ។ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឮហើយ។បេ។ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។

[២៥៦] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះបានឃើញហើយ បើ(ភិក្ខុអ្នកចោទ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុដែលត្រូវអាបត្តិបារាជិកនោះថា អ្នកឯងខ្ញុំបានឮហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ (ភិក្ខុអ្នកចោទ) បានឮហើយ បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ។បេ។ បើ(ភិក្ខុអ្នកចោទ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំឃើញហើយ។បេ។ បើ(ភិក្ខុអ្នកចោទ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្តីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមានសេចក្តីរង្កៀស បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឃើញហើយថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំឃើញហើយ

អ្នកឯងខ្ញុំឮហើយ។បេ។ បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំឃើញហើយ អ្នកឯងខ្ញុំឮហើយថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ។បេ។ (ភិក្ខុចោទគេដូច្នេះ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។

[២៥៧] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះក៏ឃើញមែន តែ (ភិក្ខុអ្នកចោទ) មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនឃើញហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនឃើញហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនឃើញហើយ ភ្លេចនូវភិក្ខុដែលខ្លួនឃើញហើយ។បេ។ មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនឮហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនឮហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនឮហើយ ភ្លេចនូវភិក្ខុដែលខ្លួនឮហើយ។បេ។ មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនរង្កៀស កំណត់មិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ រលឹកមិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ ភ្លេចនូវភិក្ខុដែលខ្លួនរង្កៀសហើយ បើភិក្ខុអ្នកចោទ ប្រើបុគ្គលដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឃើញហើយ។បេ។ អ្នកឯង ខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឮហើយ។បេ។ អ្នកឯងខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឃើញហើយ អ្នកឯងខ្ញុំឮហើយថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តឡើយ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ ភិក្ខុចោទគេដូច្នេះនេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់។

[២៥៨] (មាតិកានុក្រម គឺបញ្ជីរឿងដែលនឹងត្រូវសំដែងតាមលំដាប់ហូរហែដូចមានខាងក្រោមនេះគឺ)

> ភិក្ខុយល់ឃើញថាបរិសុទ្ធក្នុងបុគ្គលដែលមិនបរិសុទ្ធ១ យល់ឃើញថាមិនបរិសុទ្ធក្នុងបុគ្គលដែលបរិសុទ្ធ១ យល់ឃើញថាមិនបរិសុទ្ធក្នុងបុគ្គលដែលមិនបរិសុទ្ធ១ យល់ឃើញថាបរិសុទ្ធក្នុងបុគ្គលដែលបរិសុទ្ធ១។

[២៥៩] បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកឯណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថា ភិក្ខុនោះបរិសុទ្ធល្អទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានសេចក្តីប្រាថ្នាឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទភិក្ខុនោះ (ដោយអាបត្តិបារាជិក ភិក្ខុអ្នកចោទ) ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថា ភិក្ខុនោះបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទភិក្ខុនោះ (ដោយអាបត្តិបារាជិក ភិក្ខុអ្នកចោទ) ត្រូវអាបត្តិសង្ឃាទិសេស។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថា ភិក្ខុនោះបរិសុទ្ធល្អទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងជេរភិក្ខុនោះ ទើបជេរ (ភិក្ខុអ្នកជេរ) ត្រូវអាបត្តិទុក្កដ និងបាចិត្តិយៈ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ។

[២៦០] បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថា ភិក្ខុនោះមិនបរិសុទ្ធទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិទុក្កដ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ មិនត្រូវអាបត្តិ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីនឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដ និងបាចិត្តិយៈ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីនឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ។

[២៦១] បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ ភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិទុក្កដ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ មិនត្រូវអាបត្តិឡើយ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដ និងបាចិត្តិយ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ ភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីនឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ។

[២៦២] បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេស។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដ និងបាចិត្តិយ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ។

[២៦៣] អាបត្តិមិនមានដល់ភិក្ខុដែលយល់ឃើញថា មិនបរិសុទ្ធក្នុងបុគ្គលដែលបរិសុទ្ធ ដល់ភិក្ខុដែលយល់ឃើញថា មិនបរិសុទ្ធក្នុងបុគ្គលដែលមិនបរិសុទ្ធ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុខាងដើមបញ្ញត្តិ។

សង្ឃាទិសេស ទី៨ ចប់។

# សង្ឃាទិសេស ទី៩

CS vin.vbu.sg.09 | ភាគ ទី២

### (៩. ទុតិយទុដ្ឋទោសសិក្ខាបទំ)

[២៦៤] សម័យនោះ ព្រះពុទ្ធដ៏មានជោគជាម្ចាស់ ទ្រង់គង់នៅក្នុងអារាមវេឡុវន[47] ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ។ សម័យនោះឯង មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយ កាលនាំគ្នាចុះអំពីភ្នំគិជ្ឈកូដ បានឃើញពពែឈ្មោលកំពុងរួមសន្ធវៈនឹងពពែញី លុះឃើញហើយ ទើបនិយាយគ្នាយ៉ាងនេះថា អើអាវុសោ ពួកយើងនឹងសន្មតពពែឈ្មោលនេះឲ្យជាឈ្មោះទព្វមល្លបុត្ត (បុត្តមល្លក្សត្រ) សន្មតពពែញីនេះឲ្យជាឈ្មោះនាងមេត្តិយាភិក្ខុនី យើងនឹងនាំគ្នាហៅយ៉ាងនេះ ម្នាលអាវុសោ កាលអំពីដើម យើងបានចោទទព្វមល្លបុត្តដោយពាក្យថា យើងបានឮ ប៉ុន្តែឥឡូវនេះ ទព្វមល្លបុត្តសេពមេថុនធម្មនឹងនាងមេត្តិយាភិក្ខុនី យើងបានឃើញដោយខ្លួនឯង។ ភិក្ខុទាំងពីររូបនោះ ក៏បានតាំងសន្មតពពែឈ្មោលនោះជាឈ្មោះទព្វមល្លបុត្ត សន្មតពពែញីនោះជាឈ្មោះនាងមេត្តិយាភិក្ខុនី។ ភិក្ខុទាំងនោះទៅនិយាយប្រាប់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ កាលពីដើមយើងបានចោទទព្វមល្លបុត្តដោយបានឮ ប៉ុន្តែឥឡូវនេះ ទព្វមល្លបុត្តសេពមេថុនធម្មនឹងនាងមេត្តិយាភិក្ខុនី យើងបានឃើញដោយខ្លួនឯង។ ភិក្ខុទាំងឡាយបានឆ្លើយយ៉ាងនេះថា នែអាវុសោ លោកកុំនិយាយយ៉ាងហ្នឹង ឯទព្វមល្លបុត្តដ៏មានអាយុមុខជានឹងមិនធ្វើដូចលោកថាទេ។ គ្រានោះ ពួកភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះដំណើរនេះ រឿងនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ទព្វមល្លបុត្តដ៏មានអាយុថា នែទព្វៈ អ្នករលឹកឃើញឬទេ ពួកភិក្ខុទាំងនេះពោលយ៉ាងណា អ្នកបានធ្វើយ៉ាងនោះឬទេ។ ទព្វមល្លបុត្តទូលថា បពិត្រព្រះអង្គដ៏ចំរើន (រឿងអ្វីៗ) ព្រះដ៏មានព្រះភាគទ្រង់ជ្រាបខ្ញុំព្រះអង្គដោយពិតហើយ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរពាក្យនេះនឹងទព្វមល្លបុត្តដ៏មានអាយុជាគំរប់ពីរដងផង។បេ។ ជាគំរប់បីដងផងថា នែទព្វៈ អ្នករលឹកបានឬទេ ពួកភិក្ខុទាំងនេះពោលយ៉ាងណា អ្នកបានធ្វើយ៉ាងនោះឬ។ ទព្វមល្លបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគទ្រង់ជ្រាបខ្ញុំព្រះអង្គដោយពិតហើយ។ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថា នែទព្វៈ អ្នកប្រាជ្ញទាំងឡាយមិនពោលបណ្តោះបណ្តែយ៉ាងនេះទេ បើ (អំពើអ្វី) ដែលអ្នកបានធ្វើហើយ អ្នកចូរឆ្លើយថាខ្ញុំបានធ្វើហើយ បើអ្នកមិនបានធ្វើទេ អ្នកចូរឆ្លើយថាខ្ញុំមិនបានធ្វើទេ។ ទព្វមល្លបុត្តទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គតាំងពីដូចកើតមកវេលាណា មិនដែលសេពមេថុនធម្មទេ សូម្បីតែយល់សប្តិ ក៏មិនដែលឃើញទេ បាច់និយាយថ្វីដល់ការភ្ញាក់រលឹក។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកតាំងឡាយចូរជំរះសួរភិក្ខុពួកនេះមើល។ លុះព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ទ្រង់ក៏ក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ។ គ្រានោះ ភិក្ខុទាំងឡាយបានជំរះសួរមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ។ ភិក្ខុទាំងនោះ កាលបើភិក្ខុទាំងឡាយជំរះសួរ ទើបប្រាប់សេចក្តីនេះដល់ភិក្ខុទាំងឡាយ (តាមពិតត្រង់)។ ភិក្ខុទាំងឡាយសួរថា នែអាវុសោ អ្នកទាំងពីរកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ដ៏ជាចំណែកដទៃមកជាគ្រឿងអាង ហើយចោទទព្វមល្លបុត្តដ៏មានអាយុ ដោយអាបត្តិបារាជិកឬ។ ភិក្ខុទាំងពីររូបឆ្លើយថា យ៉ាងហ្នឹងហើយ អាវុសោ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះពោលទោសតិះដៀល និន្ទាថា មេត្តិយភិក្ខុនិងភុម្មជកភិក្ខុមិនសម្បីបើនឹងកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងអាង ហើយចោទទព្វមល្លបុត្តដ៏មានអាយុ ដោយអាបត្តិបារាជិកសោះ។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ ឮថាអ្នករាល់គ្នាកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងអាង ហើយចោទទព្វមល្លបុត្ត ដោយអាបត្តិបារាជិក ពិតមែនឬ។ ភិក្ខុទាំងពីររូបក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នករាល់គ្នាមិនសម្បីបើនឹងកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងអាង ហើយចោទទព្វមល្លបុត្ត ដោយអាបត្តិបារាជិកសោះ នែមោឃបុរស អំពើដែលអ្នកបានធ្វើមកនេះ មិននាំឲ្យកើតជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយ មានទោសទ្រុស្តហើយ មានសេចក្តីក្រោធ មានចិត្តមិនរីករាយ បានកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ជាចំណែកដទៃមកជាគ្រឿងអាង ហើយចោទភិក្ខុ ដោយអាបត្តិបារាជិក ដោយបំណងថា ធ្វើម្តេចហ្ន៎ អញគប្បីញ៉ាំងភិក្ខុនោះឲ្យឃ្លាតចាកព្រហ្មចរិយធម៌ (សាសនា) នេះបាន លុះសម័យខាងក្រោយតពីនោះមក ភិក្ខុអ្នកចោទនោះ មានគេសាកសួរក្តី មិនមានគេសាកសួរក្តី តែអធិករណ៍នោះជាចំណែកដទៃទេ ភិក្ខុកាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង ហើយភិក្ខុប្តេជ្ញាទោស ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស។**

[២៦៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ភិក្ខុ គឺ ភិក្ខុដទៃ។ ពាក្យថា មានទោសទ្រុស្តហើយ មានសេចក្តីក្រោធ គឺមានចិត្តក្រោធខឹង មានចិត្តមិនជារបស់ខ្លួន មិនត្រេកអរ មានចិត្តគុមគួន ចង្អៀតចង្អល់។ ពាក្យថា មានចិត្តមិនរីករាយ គឺមានចិត្តអាក់អន់ ព្រោះក្រោធខឹងនោះផង ព្រោះទោសនោះផង ព្រោះសេចក្តីអន់ចិត្តនោះផង ព្រោះសេចក្តីមិនត្រេកអរនោះផង។

[២៦៦] ពាក្យថា របស់អធិករណ៍ជាចំណែកដទៃ គឺចំណែកដទៃនៃអាបត្តិ ឬចំណែកដទៃនៃអធិករណ៍។

[២៦៧] (សួរថា) អធិករណ៍[48] ដែលមានចំណែកផ្សេងពីអធិករណ៍នោះដូចម្តេច។ (ប្រាប់ថា) វិវាទាធិករណ៍[49] មានចំណែកផ្សេងអំពីអនុវាទាធិករណ៍[50] អាបត្តាធិករណ៍[51] និងកិច្ចាធិករណ៍[52] អនុវាទាធិករណ៍ ចាត់ដោយឡែកផ្សេងអំពីអាបត្តាធិករណ៍ កិច្ចាធិករណ៍ និងវិវាទាធិករណ៍ អាបត្តាធិករណ៍ ចាត់ដោយឡែកផ្សេងអំពីកិច្ចាធិករណ៍ វិវាទាធិករណ៍ និងអនុវាទាធិករណ៍ កិច្ចាធិករណ៍ ចាត់ដោយឡែកផ្សេងអំពីវិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍។ អធិករណ៍យ៉ាងនេះ ហៅថា មានចំណែកផ្សេងគ្នាអំពីអធិករណ៍។

[២៦៨] (សួរថា) អធិករណ៍ដែលមានចំណែកដូចគ្នានឹងអធិករណ៍នោះដូចម្តេច។ (ប្រាប់ថា) វិវាទាធិករណ៍មានចំណែកដូចគ្នានឹងវិវាទាធិករណ៍ អនុវាទាធិករណ៍មានចំណែកដូចគ្នានឹងអនុវាទាធិករណ៍ អាបត្តាធិករណ៍មានចំណែកដូចគ្នានឹងអាបត្តាធិករណ៍ក៏មាន មានចំណែកផ្សេងអំពីគ្នាក៏មាន។ (សួរថា) អាបត្តាធិករណ៍មានចំណែកផ្សេងគ្នាអំពីអាបត្តាធិករណ៍នោះដូចម្តេច។ (ប្រាប់ថា) មេថុនធម្ម[53] បារាជិកាបត្តិមានចំណែកផ្សេងគ្នាអំពីអទិន្នាទាន[54] បារាជិកាបត្តិ មនុស្សវិគ្គហ[55] បារាជិកាបត្តិ និងឧត្តរិមនុស្សធម្ម[56] បារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិ មានចំណែកផ្សេងគ្នាអំពីមនុស្សវិគ្គហបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិ និងមេថុនធម្មបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិ មានចំណែកផ្សេងគ្នាអំពីឧត្តរិមនុស្សធម្មបារាជិកាបត្តិ មេថុនធម្មបារាជិកាបត្តិ និងអទិន្នាទានបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិ មានចំណែកផ្សេងគ្នាអំពីមេថុនធម្មបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិ និងមនុស្សវិគ្គហបារាជិកាបត្តិ។ អាបត្តាធិករណ៍យ៉ាងនេះ (ហៅថា) មានចំណែកផ្សេងគ្នាអំពីអាបត្តាធិករណ៍។ (សួរថា) អាបត្តាធិករណ៍មានចំណែកដូចគ្នានឹងអាបត្តាធិករណ៍នោះដូចម្តេច។ (ប្រាប់ថា) មេថុនធម្មបារាជិកាបត្តិមានចំណែកជាមួយគ្នានឹងមេថុនធម្មបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិ មានចំណែកជាមួយគ្នានឹងអទិន្នាទានបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិ មានចំណែកជាមួយគ្នានឹងមនុស្សវិគ្គហបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិ មានចំណែកជាមួយគ្នានឹងឧត្តរិមនុស្សធម្មបារាជិកាបត្តិ។ អាបត្តាធិករណ៍យ៉ាងនេះ (ហៅថា) មានចំណែកជាមួយគ្នានឹងអាបត្តាធិករណ៍។ កិច្ចាធិករណ៍ ក៏មានចំណែកជាមួយគ្នានឹងកិច្ចាធិករណ៍ដែរ។ អធិករណ៍យ៉ាងនេះ (ហៅថា) មានចំណែកជាមួយគ្នានឹងអធិករណ៍។

[២៦៩] ត្រង់ពាក្យថា កាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង ដែលហៅថាគ្រឿងអាងនោះ បានដល់គ្រឿងអាង១០យ៉ាង គឺគ្រឿងអាងជាតិ១ នាម១ គោត្រ១ ភេទ១ អាបត្តិ១ បាត្រ១ ចីវរ១ ឧបជ្ឈាយ៍១ អាចារ្យ១ សេនាសនៈ១។

[២៧០] ដែលហៅថា គ្រឿងអាងគឺជាតិនោះ បានដល់ភិក្ខុអ្នកចោទឃើញភិក្ខុជាក្សត្រត្រូវអាបត្តិបារាជិក (តែមិនបានចោទភិក្ខុជាក្សត្រនោះក្នុងខណៈនោះ) លុះបានឃើញភិក្ខុដទៃជាជាតិក្សត្រដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញលោកជាក្សត្រត្រូវអាបត្តិបារាជិកហើយ លោកមិនមែនជាសមណៈ លោកមិនមែនជាកូនចៅព្រះពុទ្ធបុត្តសក្យរាជ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី មិនមានជាមួយនឹងអ្នកទេដូច្នេះ ភិក្ខុអ្នកចោទត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។ ភិក្ខុអ្នកចោទ ឃើញភិក្ខុជាតិជាព្រាហ្មណ៍។បេ។ ឃើញភិក្ខុជាវេស្ស (អ្នកជំនួញ)។បេ។ ឃើញភិក្ខុជាសុទ្ទ (អ្នកធ្វើការគុលី) ត្រូវអាបត្តិបារាជិក (តែអ្នកចោទមិនបានចោទ) លុះបានឃើញភិក្ខុដទៃជាជាតិសុទ្ទដែរ ទើប (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកជាតិជាសុទ្ទ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធបុត្តសក្យរាជទេ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧១] ដែលហៅថា គ្រឿងអាងគឺនាមនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុឈ្មោះពុទ្ធរក្ខិត។បេ។ ឃើញភិក្ខុឈ្មោះធម្មរក្ខិត។បេ។ ឃើញភិក្ខុឈ្មោះសង្ឃរក្ខិត ត្រូវអាបត្តិបារាជិក (តែភិក្ខុអ្នកចោទមិនបានចោទ) លុះបានឃើញភិក្ខុដទៃឈ្មោះសង្ឃរក្ខិតដែរ ហើយ (ក្លែង) ចោទថា ខ្ញុំឃើញអ្នកឈ្មោះសង្ឃរក្ខិតត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧២] ដែលហៅថា គ្រឿងអាងគឺគោត្រនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុដែលមានគោត្រជាគោតម។បេ។ ឃើញភិក្ខុមានគោត្រជាមោគ្គល្លាន។បេ។ ឃើញភិក្ខុមានគោត្រជាកច្ចាយន។បេ។ ឃើញភិក្ខុមានគោត្រជាវាសិដ្ឋ ត្រូវអាបត្តិបារាជិក (តែមិនបានចោទ) លុះបានឃើញភិក្ខុដទៃមានគោត្រជាវាសិដ្ឋដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកមានគោត្រជាវាសិដ្ឋ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧៣] ដែលហៅថា គ្រឿងអាងគឺភេទនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុមានរាងខ្ពស់។បេ។ ឃើញភិក្ខុមានរាងទាប។បេ។ ឃើញភិក្ខុមានសម្បុរខ្មៅ។បេ។ ឃើញភិក្ខុមានសម្បុរស ត្រូវអាបត្តិបារាជិក (តែមិនបានចោទ) លុះឃើញភិក្ខុដទៃមានសម្បុរសដែរ ហើយ(ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកមានសម្បុរស ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧៤] ដែលហៅថា គ្រឿងអាងគឺអាបត្តិនោះ គឺភិក្ខុអ្នកចោទ ឃើញភិក្ខុត្រូវអាបត្តិស្រាល បើភិក្ខុអ្នកចោទ ៗភិក្ខុនោះដោយអាបត្តិបារាជិកថា ខ្ញុំបានឃើញលោកត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧៥] ដែលហៅថា គ្រឿងអាងគឺបាត្រនោះ គឺភិក្ខុអ្នកចោទ ឃើញភិក្ខុប្រើបាត្រទង់ដែង។បេ។ ឃើញភិក្ខុប្រើបាត្រដី។បេ។ ឃើញភិក្ខុប្រើបាត្រសម្ពត់សាដក។[57] បេ។ ឃើញភិក្ខុប្រើបាត្រដី[58] ដែលមានសម្បុរលើប ត្រូវអាបត្តិបារាជិក (តែមិនបានចោទ) លុះឃើញភិក្ខុដទៃប្រើបាត្រដីដែរ ហើយ (ក្លែង) ចោទថា ខ្ញុំឃើញអ្នកឯងប្រើបាត្រដី ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧៦] ដែលហៅថា គ្រឿងអាងគឺចីវរនោះ គឺភិក្ខុអ្នកចោទ ឃើញភិក្ខុប្រើចីវរបង្សុកូល។បេ។ ឃើញភិក្ខុប្រើចីវររបស់គហបតី ត្រូវអាបត្តិបារាជិក (តែមិនបានចោទ) លុះឃើញភិក្ខុដទៃប្រើចីវររបស់គហបតីដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកឯងប្រើចីវររបស់គហបតី ត្រូវ

អាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧៧] ដែលហៅថា គ្រឿងអាងគឺព្រះឧបជ្ឈាយ៍នោះ គឺភិក្ខុអ្នកចោទបាន ឃើញភិក្ខុសទ្ធិវិហារិករបស់ឧបជ្ឈាយ៍មានឈ្មោះយ៉ាងនេះ ត្រូវអាបត្តិបារាជិក (តែមិនបានចោទ) លុះឃើញភិក្ខុដទៃជាសទ្ធិវិហារិករបស់ព្រះឧបជ្ឈាយ៍មានឈ្មោះយ៉ាងហ្នឹងដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកឯងជាសទ្ធិវិហារិករបស់ឧបជ្ឈាយ៍ឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧៨] ដែលហៅថា គ្រឿងអាងគឺអាចារ្យនោះ គឺភិក្ខុអ្នកចោទ ឃើញអន្តេវាសិករបស់អាចារ្យឈ្មោះនេះ ត្រូវអាបត្តិបារាជិក (តែមិនចោទ) លុះឃើញភិក្ខុដទៃជាអន្តេវាសិករបស់អាចារ្យឈ្មោះហ្នឹងដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកឯងជាអន្តេវាសិករបស់អាចារ្យឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៧៩] ដែលហៅថា គ្រឿងអាងគឺសេនាសនៈនោះ គឺភិក្ខុអ្នកចោទ ឃើញភិក្ខុនៅក្នុងសេនាសនៈរបស់ភិក្ខុឈ្មោះនេះ ត្រូវអាបត្តិបារាជិក (តែមិនចោទ) លុះឃើញភិក្ខុដទៃជាអ្នកនៅក្នុងសេនាសនៈរបស់ភិក្ខុឈ្មោះហ្នឹងដែរ ហើយ (ក្លែង) ចោទថា ខ្ញុំបានឃើញអ្នកឯងនៅក្នុងសេនាសនៈរបស់ភិក្ខុឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី មិនមានជាមួយនឹងអ្នកឯងទេ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៨០] ពាក្យថា ដោយអាបត្តិបារាជិក គឺបានដល់អាបត្តិបារាជិកទាំង៤ អាបត្តិបារាជិកណាមួយ។ ពាក្យថា ចោទ គឺចោទឯងក្តី ឲ្យអ្នកដទៃចោទក្តី។ ពាក្យថា ធ្វើដូចម្តេចហ្ន៎ អញគប្បីញុំាងភិក្ខុនោះឲ្យឃ្លាតចាកព្រហ្មចរិយធម៌នេះ គឺថាអញគប្បីញុំាងភិក្ខុនេះឲ្យឃ្លាតចាកភាវៈជាភិក្ខុ ឲ្យឃ្លាតចាកសមណធម៌ ឲ្យឃ្លាតចាកសីលក្ខន្ធ ឲ្យឃ្លាតចាកគុណគឺធម៌ជាគ្រឿងដុតកិលេស។

[២៨១] ពាក្យថា លុះសម័យខាងក្រោយ តអំពីនោះមក គឺភិក្ខុចោទគេក្នុងខណៈណា ខណៈនោះ ពេលនោះ ស្របក់នោះកន្លងទៅហើយ។ ពាក្យថា មានគេសាកសួរ គឺថាភិក្ខុចោទគេដោយវត្ថុណា គេសាកសួរចំពោះវត្ថុនោះ។ ពាក្យថា មិនមានគេសាកសួរ គឺមិនមានអ្នកណាមួយនិយាយឡើយ។

[២៨២] ដែលហៅថា អធិករណ បានដល់អធិករណៈ៤ គឺ វិវាទាធិករណៈ១ អនុវាទាធិករណៈ១ អាបត្តាធិករណៈ១ កិច្ចាធិករណៈ១។

[២៨៣] ពាក្យថា កាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង គឺបណ្តាគ្រឿងអាងទាំង១០យ៉ាងនោះ ភិក្ខុកាន់យកគ្រឿងអាងណាមួយ។

[២៨៤] ពាក្យថា ភិក្ខុប្តេជ្ញាទោស គឺ(ភិក្ខុប្តេជ្ញាថា) ខ្ញុំនិយាយពាក្យទទេសោះ ខ្ញុំនិយាយពាក្យកុហកសោះ ខ្ញុំនិយាយពាក្យមិនពិត ខ្ញុំនិយាយដោយមិនដឹង។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយពិស្តារក្នុងសង្ឃាទិសេសសិក្ខាបទទី១រួចហើយ។

[២៨៥] ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេស ថាជាអាបត្តិសង្ឃាទិសេសមែន តែបើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកវិញថា អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ ឯអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេស[59] សោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេស ថាជាអាបត្តិថុល្លច្ច័យវិញ តែបើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ។បេ។ ឯអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាចិត្តិយវិញ តែបើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ។បេ។ ឯអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាដិទេសនីយវិញ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុក្កដវិញ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុព្ភាសិតវិញ តែបើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ។បេ។ ឯអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៨៦] ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិថុល្លច្ច័យ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាចិត្តិយវិញ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាដិទេសនីយវិញ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុក្កដវិញ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុព្ភាសិតវិញ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិសង្ឃាទិសេសវិញ បើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ។បេ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ និងលេសសោត ភិក្ខុអ្នកចោទក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។បេ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយ។បេ។ ភិក្ខុត្រូវអាបត្តិទុក្កដ។បេ។ ភិក្ខុត្រូវអាបត្តិទុព្ភាសិត ភិក្ខុអ្នកចោទ ក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុព្ភាសិត។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិសង្ឃាទិសេស។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិថុល្លច្ច័យ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិបាចិត្តិយ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិបាដិទេសនីយ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុក្កដទៅវិញ បើក្លែងចោទភិក្ខុនោះដោយ

អាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ។បេ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

បណ្ឌិតគប្បីធ្វើអធិករណៈនោះៗ ឲ្យមានមូលមួយៗ ហើយចងជាចក្ក (ដូចគ្នា)។

[២៨៧] ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្ដីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិសង្ឃាទិសេសដែរ បើឲ្យអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ។បេ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្ដីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិថុល្លច្ច័យទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាចិត្តិយវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាដិទេសនីយវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុក្កដទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុព្ភាសិតទៅវិញ បើឲ្យអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ។បេ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៨៨] ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិថុល្លច្ច័យ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាចិត្តិយទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាដិទេសនីយទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុក្កដទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុព្ភាសិតទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិសង្ឃាទិសេសទៅវិញ បើឲ្យអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ។បេ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ អ្នកចោទក៏បានឃើញ។បេ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយ។បេ។ ភិក្ខុត្រូវអាបត្តិទុក្កដ។បេ។ ភិក្ខុត្រូវអាបត្តិទុព្ភាសិត ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុព្ភាសិតដែរ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិសង្ឃាទិសេសទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិថុល្លច្ច័យទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិបាចិត្តិយទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិបាដិទេសនីយទៅវិញ។បេ។ មានសេចក្ដីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុក្កដទៅវិញ បើឲ្យអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្ដី បវារណាកម្មក្ដី សង្ឃកម្មក្ដី ជាមួយនឹងអ្នកឯងគ្មានទេ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវាចា។

[២៨៩] អាបត្តិមិនមានដល់ភិក្ខុអ្នកចោទមានសេចក្ដីសំគាល់ពិត ហើយចោទឯង ឬឲ្យអ្នកដទៃចោទ ដល់ភិក្ខុខូចស្មារតី ដល់ភិក្ខុអាទិកម្មិក។

សង្ឃាទិសេស ទី៩ ចប់។

# សង្ឃាទិសេស ទី១០

CS vin.vbu.sg.10 | ភាគ ទី២

### (១០. សង្ឃភេទសិក្ខាបទំ)

[២៩០] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់ជោគ ប្រថាប់នៅក្នុងអារាមវេឡុវន ជាទីដែលស្ដេចប្រទានចំណីដល់សត្វកង្ហែន ក្បែរក្រុងរាជគ្រឹះ។ គ្រានោះ ភិក្ខុឈ្មោះទេវទត្ត បានចូលទៅរកភិក្ខុឈ្មោះកោកាលិក ភិក្ខុឈ្មោះកដមោរកតិស្សក ភិក្ខុឈ្មោះខណ្ឌទេវីបុត្ត និងភិក្ខុឈ្មោះសមុទ្ទទត្ត ហើយបាននិយាយពាក្យនេះនឹងភិក្ខុឈ្មោះកោកាលិក ភិក្ខុឈ្មោះកដមោរកតិស្សក ភិក្ខុឈ្មោះខណ្ឌទេវីបុត្ត និងភិក្ខុឈ្មោះសមុទ្ទទត្តថា ម្នាលអាវុសោ អ្នកទាំងឡាយចូរមក ពួកយើងនឹងធ្វើការបំបែកសង្ឃ នឹងទំលាយចក្រ[60] របស់ព្រះសមណគោតម។ កាលទេវទត្តពោលយ៉ាងនេះហើយ ទើបភិក្ខុឈ្មោះកោកាលិកនិយាយពាក្យនេះនឹងទេវទត្តថា អាវុសោ ព្រះសមណគោតមមានឫទ្ធិច្រើន មានអានុភាពធំ ពួកយើងនឹងធ្វើការបំបែកសង្ឃ នឹងទំលាយចក្ររបស់ព្រះសមណគោតមដូចម្ដេចបាន។ ទេវទត្តឆ្លើយថា ម្នាលអាវុសោ អ្នកទាំងឡាយចូរមក ពួកយើងនាំគ្នាចូលទៅគាល់ព្រះសមណគោតម ទូលសូមវត្ថុ៥ប្រការថា បពិត្រព្រះសម្មទ្ធជាម្ចាស់ ព្រះដ៏មានព្រះភាគទ្រង់សរសើរគុណនៃបុគ្គលអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ដុសខាត់ចិត្ត ទ្រទ្រង់ធុតង្គវត្ត ប្រកបដោយសេចក្ដីជ្រះថ្លា មិនចំរើនកិលេសវដ្ដ ប្រារព្ធសេចក្ដីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះសម្មទ្ធជាម្ចាស់ វត្ថុ៥ប្រការនេះ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ដើម្បីសន្តោស ដើម្បីដុសខាត់ចិត្ត ដើម្បីធុតង្គវត្ត ដើម្បីសេចក្ដីជ្រះថ្លា ដើម្បីមិនចំរើនកិលេសវដ្ដ ដើម្បីប្រារព្ធសេចក្ដីព្យាយាមដោយបរិយាយជាច្រើន បពិត្រព្រះសម្មទ្ធជាម្ចាស់ សូមទ្រង់ព្រះមេត្តាករុណាចុះ សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ កាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ ប្រើប្រាស់សម្ពត់បង្សុកូលជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយគហបតីចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ នៅទៀបគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណាទៅនៅក្នុងទីប្រក់ទីបាំង ភិក្ខុនោះត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រីនិងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះត្រូវទោស បើយើងសូមយ៉ាងនេះ ព្រះសមណគោតមមុខជានឹងមិនអនុញ្ញាតឲ្យទេ ហើយពួកយើងឯងនឹងពន្យល់ជន (ឲ្យត្រេកអរនឹងយើង) ដោយវត្ថុ៥ប្រការទាំងនេះ។ ទើបកោកាលិកភិក្ខុពោលថា ម្នាលអាវុសោ ពួកយើងអាចនឹងធ្វើការបំបែកសង្ឃ និងទំលាយចក្ររបស់ព្រះសមណគោតមដោយវត្ថុ៥ប្រការនេះបាន ព្រោះមនុស្សទាំងឡាយដែលជ្រះថ្លាក្នុងវត្ថុសៅហ្មង (មានច្រើន) អាវុសោ។

[២៩១] គ្រានោះ ទេវទត្តភិក្ខុព្រមទាំងបរិសទ្យ ចូលទៅគាល់ព្រះដ៏មានព្រះភាគម្ចាស់ ហើយក្រាបថ្វាយបង្គំ រួចអង្គុយក្នុងទីដ៏សមគួរ។ លុះទេវទត្តភិក្ខុអង្គុយស្រួលបួលហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គដ៏ទ្រង់ជោគ ទ្រង់សរសើរគុណរបស់បុគ្គលប្រាថ្នាតិច ជាអ្នកសន្តោស ដុសខាត់ចិត្ត ទ្រទ្រង់ធុតង្គ មានសេចក្តីជ្រះថ្លា មិនចំរើនកិលេសវដ្ដ ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ វត្ថុ៥ប្រការទាំងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច សន្តោស ដុសខាត់ចិត្ត កំចាត់ធម៌គ្រឿងសៅហ្មង ដើម្បីសេចក្តីជ្រះថ្លា មិនចំរើនកិលេសវដ្ដ ប្រារព្ធសេចក្តីព្យាយាម បពិត្រព្រះសម្ពុទ្ធជាម្ចាស់ សូមទានទ្រង់ព្រះមេត្តាករុណាចុះ សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណាចូលមកកាន់ស្រុក ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយប្រើប្រាស់សម្ពត់បង្សុកូលជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយគហបតីចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ នៅទៀបគល់ឈើអស់មួយជីវិត ភិក្ខុណាចូលជ្រកទីប្រក់ទីបាំង ភិក្ខុនោះត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រីនិងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះត្រូវទោស។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា កុំទេវទត្ត ភិក្ខុណាចង់នៅព្រៃ ភិក្ខុនោះចូរនៅចុះ ភិក្ខុណាចង់នៅស្រុក ភិក្ខុនោះចូរនៅចុះ ភិក្ខុណាចង់ប្រព្រឹត្តបិណ្ឌបាតជាវត្ត ភិក្ខុនោះចូរប្រព្រឹត្តចុះ ភិក្ខុណាត្រូវការដោយកិច្ចនិមន្ត ភិក្ខុនោះចូរត្រេកអរចុះ ភិក្ខុណាចង់ប្រើប្រាស់សម្ពត់បង្សុកូល ភិក្ខុនោះចូរប្រើប្រាស់ចុះ ភិក្ខុណាចង់បានគហបតីចីវរ ភិក្ខុនោះចូរត្រេកអរនូវចីវរនោះចុះ នែទេវទត្ត តថាគតអនុញ្ញាតសេនាសនៈទៀបគល់ឈើអស់កាល៨ខែ អនុញ្ញាតត្រីសាច់ ដែលបរិសុទ្ធដោយទីបំផុត៣ប្រការ គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស (ឲ្យភិក្ខុទាំងឡាយឆាន់បាន)។

[២៩២] លំដាប់នោះ ទេវទត្តភិក្ខុព្រមទាំងបរិសទ្យត្រេកអររីករាយថា ព្រះដ៏មានព្រះភាគមិនព្រមអនុញ្ញាតវត្ថុ៥ប្រការនេះទេ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើបទក្សិណចៀសចេញទៅ។ ទើបទេវទត្តភិក្ខុព្រមទាំងបរិសទ្យ ចូលទៅក្រុងរាជគ្រឹះ ញុំាងជនឲ្យយល់ដោយវត្ថុ៥ប្រការ ហើយពោលថា អាវុសោទាំងឡាយ ពួកយើងបានចូលទៅគាល់ព្រះសមណគោតម ហើយទូលសូមវត្ថុ៥ប្រការថា បពិត្រព្រះសម្ពុទ្ធជាម្ចាស់ ព្រះដ៏មានព្រះភាគមានប្រក្រតីសរសើរគុណរបស់បុគ្គលអ្នកប្រាថ្នាតិច សន្តោស ដុសខាត់ចិត្ត កំចាត់ធម៌គ្រឿងសៅហ្មង មានសេចក្តីជ្រះថ្លា មិនចំរើនកិលេសវដ្ដ ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ វត្ថុ៥ប្រការនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសេចក្តីសន្តោស ដើម្បីសេចក្តីប្រតិបត្តិដ៏ផូរផង់ ដើម្បីកំចាត់កិលេសធម៌ ដើម្បីសេចក្តីជ្រះថ្លា ដើម្បីមិនចំរើនកិលេសវដ្ដ ដើម្បីប្រារព្ធសេចក្តីព្យាយាម បពិត្រព្រះសម្ពុទ្ធជាម្ចាស់ សូមទ្រង់ព្រះមេត្តា សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណាចូលមកកាន់ស្រុក ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយត្រាច់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយប្រើប្រាស់សម្ពត់បង្សុកូលជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរចំពោះគហបតីចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយនៅក្បែរគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណាចូលជ្រកទីប្រក់ទីបាំង ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកុំឆាន់ត្រីនិងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះត្រូវទោស ព្រះសមណគោតមមិនទ្រង់អនុញ្ញាតវត្ថុ៥ប្រការនេះទេ តែពួកយើងទាំងនោះនាំគ្នាសមាទានវត្ថុ៥នេះវិញ។

[២៩៣] បណ្តាមនុស្សទាំងនោះ មនុស្សទាំងឡាយណាជាអ្នកឥតសទ្ធា មិនជ្រះថ្លា មានប្រាជ្ញាថោកថយ ទើបមនុស្សទាំងនោះពោលយ៉ាងនេះថា ពួកសមណៈទាំងនេះឯងជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ជាអ្នកកំចាត់កិលេសធម៌ ជាអ្នកប្រព្រឹត្តក្នុងធម៌ដ៏ផូរផង់ ចំណែកព្រះសមណគោតម ជាអ្នកប្រព្រឹត្តល្មោភដោយបច្ច័យ មានចីវរបច្ច័យជាដើម តែងត្រិះរិះដោយបច្ច័យ មានចីវរបច្ច័យជាដើមដ៏ច្រើន។ ពួកមនុស្សណា ជាអ្នកមានសទ្ធាជ្រះថ្លា ជាបណ្ឌិតមានប្រាជ្ញា ពួកមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តភិក្ខុមិនគួរសោះនឹងខំប្រឹងទំលាយសង្ឃ ទំលាយចក្ររបស់ព្រះដ៏មានព្រះភាគម្ចាស់។ ពួកភិក្ខុបានឮពួកមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ)។ ភិក្ខុទាំងឡាយឯណា ជាអ្នកប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តភិក្ខុមិនសម្បីបើខំខ្នះខ្នែង ដើម្បីទំលាយសង្ឃ ដើម្បីទំលាយចក្រសោះ។ ទើបភិក្ខុទាំងនោះ ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏ទ្រង់ជោគ ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ទេវទត្តភិក្ខុក្នុងពេលនោះ។បេ។ នែទេវទត្ត គេថាអ្នកឯងព្យាយាមទំលាយសង្ឃ ទំលាយចក្រពិតមែនឬ។ ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគតិះដៀលថា នែមោឃបុរស មិនសមគួរសោះ។បេ។ មោឃបុរស ហេតុម្តេចហ្ន៎ បានជាអ្នកឯងខំព្យាយាមទំលាយសង្ឃ ទំលាយចក្រ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយព្យាយាមដើម្បីទំលាយសង្ឃដ៏ព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈ ដែលដឹកនាំឲ្យសង្ឃបែកគ្នាហើយតាំងនៅ ភិក្ខុទាំងឡាយត្រូវពោល (ហាម) ភិក្ខុនោះដោយពាក្យយ៉ាងនេះថា លោកម្ចាស់កុំព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នាឡើយ ឬប្រកាន់ផ្គងឡើងនូវអធិករណៈ ដែលដឹកនាំឲ្យសង្ឃបែកគ្នាហើយតាំងនៅ សូមលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះថា ព្រះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ។ ភិក្ខុនោះ កាលភិក្ខុទាំងឡាយពោល (ហាម) យ៉ាងនេះហើយ នៅប្រកាន់លទ្ធិយ៉ាងនោះដដែល ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម (ពោលប្រដៅហាមប្រាម) ជាកំណត់បីដង ដើម្បីឲ្យលះបង់សង្ឃភេទកម្មនោះ។ កាលបើភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់បីដងហើយ ភិក្ខុនោះបានលះបង់សង្ឃភេទកម្មនោះចេញ ការលះបង់បាននេះជាការប្រពៃ បើភិក្ខុនោះមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស។**

[២៩៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយពិស្តារក្នុងបារាជិកកណ្ឌសិក្ខាបទទី១រួចហើយ។ សង្ឃដែលមានសំវាសស្មើគ្នា ស្ថិតនៅក្នុងសីមាជាមួយគ្នា ហៅថាព្រមព្រៀងគ្នា។ ពាក្យថា ព្យាយាមដើម្បីបំបែក គឺភិក្ខុស្វែងរកបក្ខពួក ចងជាគណៈដោយចិត្តបំណងថា ធ្វើម្តេចឲ្យភិក្ខុពួកនេះនៅផ្សេងៗគ្នា បែកគ្នាជាពួកជាកង។ ពាក្យថា អធិករណៈ ដែលដឹកនាំឲ្យសង្ឃបែកគ្នា គឺបានដល់រឿងដែលជាហេតុធ្វើឲ្យបែកគ្នាមាន១៨[61]) ប្រការ។ ពាក្យថា ប្រកាន់ គឺកាន់យក។ ពាក្យថា ផ្គងឡើង គឺសំដែង។ ពាក្យថា តាំងនៅ គឺមិនលះបង់។

[២៩៥] ពាក្យថា ភិក្ខុនោះ គឺភិក្ខុអ្នកបំបែកសង្ឃនោះឯង។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយឯទៀត (ក្រៅពីភិក្ខុដែលបំបែកសង្ឃនោះ)។ ភិក្ខុណាបានឃើញ ឬបានឮ ពួកភិក្ខុទាំងនោះ ត្រូវនិយាយនឹងភិក្ខុដែលបំបែកសង្ឃនោះថា លោកម្ចាស់ កុំព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឲ្យសង្ឃបែកគ្នា សូមឲ្យលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ។ ភិក្ខុទាំងឡាយត្រូវពោល (ហាម) ជាគំរប់ពីរដងផង ត្រូវពោល (ហាម) ជាគំរប់បីដងផង។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះ ជាការល្អណាស់ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងឡាយបានឮហើយ មិនពោល(ហាម) ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះ ត្រូវតែភិក្ខុទាំងឡាយចាប់ទាញមកកាន់កណ្តាលជំនុំសង្ឃ ហើយពោល (ហាម)ថា លោកម្ចាស់ កុំព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឲ្យសង្ឃបែកគ្នាឡើយ សូមឲ្យលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ។ ភិក្ខុទាំងឡាយត្រូវពោល (ហាម) ភិក្ខុជាអ្នកបំបែកសង្ឃនោះ ជាគំរប់ពីរដងផង ត្រូវពោល (ហាម) ជាគំរប់បីដងផង។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះ ជាការប្រពៃ បើមិនលះបង់ទេ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។

[២៩៦] ភិក្ខុទាំងឡាយគប្បីសូត្រសមនុភាសនកម្មដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសូត្រសមនុភាសនកម្មយ៉ាងនេះ គឺភិក្ខុដែលឆ្លៀវឆ្លាស អង់អាច គប្បីប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា។ ភិក្ខុនោះមិនលះបង់រឿងនោះទេ។ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ។ នេះជាញត្តិ (វាចាប្រកាសដល់សង្ឃ)។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា។ ភិក្ខុនោះមិនលះបង់រឿងនោះទេ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ។ ការសូត្រសមនុភាសនកម្មដល់ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកម្ចាស់អង្គណា សូមឲ្យលោកម្ចាស់អង្គនោះពោលឡើង។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា។ ភិក្ខុនោះមិនលះបង់រឿងនោះទេ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះចេញ។ ការសូត្រប្រាប់ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវពោលឡើង។ ភិក្ខុឈ្មោះនេះ ព្រះសង្ឃបានសូត្រសមនុភាសនកម្មហើយ ដើម្បីឲ្យលះបង់រឿងនោះ។ សមនុភាសនកម្មនេះ សមគួរដល់សង្ឃ ហេតុនោះព្រះសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវពាក្យនេះដោយកិរិយាស្ងៀមនៅយ៉ាងនេះ។

[២៩៧] (កាលសង្ឃ)សូត្រញត្តិចប់ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ (កាលសង្ឃ) សូត្រកម្មវាចាពីរដង (ភិក្ខុនោះ) ត្រូវអាបត្តិថុល្លច្ច័យ (កាលសង្ឃ) សូត្រកម្មវាចាចប់ (ភិក្ខុនោះ) ត្រូវអាបត្តិសង្ឃាទិសេស។ កាលបើភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលភិក្ខុនោះត្រូវក្នុងខណៈចប់ញត្តិក្តី និងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុនោះត្រូវក្នុងខណៈចប់កម្មវាចាជាគំរប់ពីរដងក្តី ក៏តែងរំងាប់ទៅឯង។ ពាក្យថា អាបត្តិសង្ឃាទិសេស មានអធិប្បាយក្នុងសិក្ខាបទទី១សង្ឃាទិសេសខាងដើមមកហើយ។

[២៩៨] ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ ថាកម្មធ្វើត្រូវតាមធម៌ តែមិនលះបង់ (សង្ឃភេទកម្មនោះ) ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ តែមិនលះបង់ (គឺនៅប្រកាន់) ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេសដែរ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ ថាកម្មមិនត្រូវតាមធម៌ មិនលះបង់ ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើមិនត្រូវតាមធម៌ ថាកម្មធ្វើត្រូវតាមធម៌ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មមិនមែនជាធម៌ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដដែរ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មមិនមែនជាធម៌ ថាកម្មមិនមែនជាធម៌ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។

[២៩៩] អាបត្តិ មិនមានដល់ភិក្ខុដែលសង្ឃមិនទាន់សូត្រប្រកាសហាម ដល់ភិក្ខុដែលបានលះបង់ (សង្ឃភេទកម្ម) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក។

សង្ឃាទិសេស ទី១០ ចប់។

# សង្ឃាទិសេស ទី១១

CS vin.vbu.sg.11 | ភាគ ទី២

### (១១. ភេទានុវត្តកសិក្ខាបទំ)

[៣០០] សម័យនោះ ព្រះពុទ្ធដ៏មានឥស្សរិយយស ទ្រង់ប្រថាប់ក្នុងវត្តវេឡុវន ជាទីដែលស្តេចប្រទានចំណីដល់សត្វកង្ហែន ក្បែរក្រុងរាជគ្រឹះ។ សម័យនោះឯង ទេវទត្តភិក្ខុព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីបំបែកចក្រ។ ភិក្ខុទាំងឡាយពោលយ៉ាងនេះថា ទេវទត្តជាអ្នកពោលខុសធម៌ ទេវទត្តជាអ្នកពោលខុសវិន័យ ទេវទត្តមិនគួរបើនឹងព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីបំបែកចក្រ។ កាលភិក្ខុទាំងឡាយពោលយ៉ាងនេះហើយ ទើបកោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ខណ្ឌទេវីបុត្តភិក្ខុ និងសមុទ្ទទត្តភិក្ខុ ក៏ពោលពាក្យនេះនឹងពួកភិក្ខុទាំងនោះថា សូមលោកម្ចាស់ទាំងឡាយកុំពោលយ៉ាងហ្នឹង ទេវទត្តពោលត្រូវតាមធម៌ ទេវទត្តពោលត្រូវតាមវិន័យ ម្យ៉ាងទៀត ទេវទត្តកាន់យកសេចក្តីពេញចិត្ត និងសេចក្តីគាប់ចិត្តរបស់ពួកយើង ហើយទើបពោល លោកដឹង (សេចក្តីពេញចិត្តជាដើមរបស់ពួកយើង) ទើបពោល អំពើដែលលោកបានធ្វើមកនេះ ក៏សមគួរដល់យើងទាំងឡាយ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុម្តេចហ្ន៎ បានជាភិក្ខុទាំងឡាយប្រព្រឹត្តតាមទេវទត្ត ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក។ ខណៈនោះ ពួកភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគម្ចាស់។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគម្ចាស់ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ភិក្ខុ

ទាំងឡាយក្នុងខណៈនោះថា នែភិក្ខុទាំងឡាយ ឮថា មានពួកភិក្ខុប្រព្រឹត្តតាមទេវទត្តភិក្ខុ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះ ពិតមែន។ ព្រះពុទ្ធជាម្ចាស់មានឥស្សរិយយស ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើដែលមោឃបុរសទាំងនោះបានធ្វើ មិនសមគួរទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ហេតុម្តេច ក៏ពួកមោឃបុរសទាំងនោះ ប្រព្រឹត្តតាមទេវទត្ត ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក នែភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុទាំងឡាយមួយរូបក្តី ពីររូបក្តី បីរូបក្តី ជាអ្នកប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃនោះឯង និងជាអ្នកពោលប្រកាន់ពួក ហើយពួកភិក្ខុទាំងនោះពោលហាម ភិក្ខុទាំងឡាយ (ដែលជាភិក្ខុបរិសុទ្ធ) យ៉ាងនេះថា ម្នាលលោកម្ចាស់ទាំងឡាយ លោកទាំងឡាយកុំពោលពាក្យបន្តិចបន្តួចនឹងភិក្ខុនេះ ព្រោះភិក្ខុនេះ ជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះ ជាអ្នកពោលត្រូវតាមវិន័យផង ម្យ៉ាងទៀត ភិក្ខុនេះកាន់យកសេចក្តីពេញចិត្ត និងសេចក្តីគាប់ចិត្តរបស់ពួកយើង ទើបពោល លោកដឹងសេចក្តីពេញចិត្តជាដើមរបស់ពួកយើង ទើបពោល អំពើនេះក៏គាប់ចិត្ត ដល់យើងទាំងឡាយ។ ពួកភិក្ខុទាំងនោះ ត្រូវតែភិក្ខុទាំងឡាយ (ដែលបរិសុទ្ធ) ពោលយ៉ាងនេះថា ម្នាលលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងហ្នឹង ព្រោះភិក្ខុនេះ មិនមែនជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះ មិនមែនជាអ្នកពោលត្រូវតាមវិន័យផង សូមលោកម្ចាស់ទាំងឡាយកុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះព្រះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅសប្បាយ។ ពួកភិក្ខុទាំងនោះ កាលដែលភិក្ខុទាំងឡាយពោលហាមយ៉ាងនេះ ក៏នៅប្រកាន់លទ្ធិយ៉ាងនោះដដែល ពួកភិក្ខុទាំងនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈគំរប់បីដង ដើម្បីលះបង់នូវកម្មនោះ។ កាលបើភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្មដល់គំរប់បីដងហើយ ពួកភិក្ខុទាំងនោះលះបង់នូវរឿងនោះចេញ ការលះបង់បានយ៉ាងនេះ ជាការល្អណាស់ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស។**

[៣០១] ត្រង់ពាក្យថា ភិក្ខុនោះឯង គឺភិក្ខុជាអ្នកបំបែកសង្ឃនោះ។ ពាក្យថា ភិក្ខុទាំងឡាយ បានដល់ពួកភិក្ខុដទៃ។ ពាក្យថា ជាអ្នកប្រព្រឹត្តតាម គឺភិក្ខុអ្នកបំបែកសង្ឃយល់ឃើញ ត្រូវចិត្ត គាប់ចិត្តកម្មណា ភិក្ខុទាំងនោះក៏យល់តាម ត្រូវចិត្តតាម គាប់ចិត្តតាមនូវកម្មនោះដែរ។ ពាក្យថា ជាអ្នកពោលប្រកាន់ពួក គឺតាំងនៅក្នុងសេចក្តីសរសើរនូវភិក្ខុជាអ្នកបំបែកសង្ឃនោះផង ក្នុងពួកនៃភិក្ខុនោះផង។ ពាក្យថា មួយរូបក្តី ពីររូបក្តី បីរូបក្តី គឺភិក្ខុមួយរូបក្តី ពីររូបក្តី បីរូបក្តី ភិក្ខុទាំងនោះពោលនឹងភិក្ខុទាំងឡាយយ៉ាងនេះថា នែលោកម្ចាស់ទាំងឡាយ លោកកុំពោលពាក្យបន្តិចបន្តួចនឹងភិក្ខុនេះ ភិក្ខុនេះ ជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះជាអ្នកពោលត្រូវតាមវិន័យផង ម្យ៉ាងទៀត ភិក្ខុនេះកាន់យកសេចក្តីពេញចិត្ត និងសេចក្តីគាប់ចិត្តរបស់ពួកយើងហើយ ទើបពោល លោកដឹង (សេចក្តីពេញចិត្តជាដើម) របស់ពួកយើងហើយ ទើបពោល អំពើដែលលោកធ្វើនេះ ក៏សមគួរដល់ពួកយើង។

[៣០២] ពាក្យថា ភិក្ខុទាំងនោះ គឺពួកភិក្ខុអ្នកប្រព្រឹត្តតាមអម្បាលនោះឯង។ ពាក្យថា ភិក្ខុទាំងឡាយ បានដល់ភិក្ខុឯទៀត (ក្រៅពីសង្ឃភេទកភិក្ខុនោះ)។ ពួកភិក្ខុដែលបានឃើញ បានឮ គប្បីពោលថា នែលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងហ្នឹង ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមវិន័យផង សូមលោកម្ចាស់ទាំងឡាយ កុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ។ ភិក្ខុទាំងឡាយត្រូវពោលជាគំរប់ពីរដងផង ត្រូវពោលជាគំរប់បីដងផង។ បើពួកភិក្ខុទាំងនោះ លះបង់រឿងនោះបាន ការលះបង់បានយ៉ាងនេះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។ ពួកភិក្ខុឯទៀតឮហើយ មិនពោលហាមប្រាម ត្រូវអាបត្តិទុក្កដដែរ។ ភិក្ខុទាំងឡាយ ត្រូវនាំគ្នាចាប់ទាញភិក្ខុទាំងនោះមកកាន់កណ្តាលជំនុំសង្ឃ ហើយពោលហាមថា នែលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងហ្នឹង ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមធម៌ទេ ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមវិន័យទេ សូមលោកម្ចាស់ទាំងឡាយ កុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនទាស់ទែងគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ។ ភិក្ខុទាំងឡាយគប្បីពោលហាមជាគំរប់ពីរដងផង ជាគំរប់បីដងផង។ បើលោកទាំងនោះ លះបង់រឿងនោះបាន ការលះបង់បាននេះ ជាការឥតទោស បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ។

[៣០៣] ភិក្ខុទាំងឡាយ គប្បីសូត្រសមនុភាសនកម្មហាមពួកភិក្ខុទាំងនោះ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុទាំងនោះ គឺភិក្ខុសង្ឃគប្បីសូត្រសមនុភាសនកម្មយ៉ាងនេះ គឺភិក្ខុដែលឆ្លាសប្រតិពល គប្បីផ្ទៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុទាំងឡាយមានឈ្មោះនេះផង ឈ្មោះនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះនេះ ជាអ្នកព្យាយាមបំបែកសង្ឃ ហើយជាអ្នកពោលប្រកាន់ពួក។ ពួកភិក្ខុទាំងនោះ មិនលះបង់វត្ថុនោះទេ។ បើសមនុភាសនកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្មហាមពួកភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះលែងនូវរឿងនោះចេញ។ វាចានេះសម្រាប់ញ៉ាំងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុទាំងឡាយមានឈ្មោះនេះផង ឈ្មោះនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះនេះ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ហើយជាអ្នកពោលប្រកាន់ពួក។ ពួកភិក្ខុទាំងនោះ មិនលះបង់នូវរឿងនោះទេ។ សង្ឃសូត្រសមនុភាសនកម្មហាមភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ។ ការសូត្រសមនុភាសនកម្មដល់ភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ សមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនសមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះនេះ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក។ ពួកភិក្ខុទាំងនោះ មិនលះបង់នូវរឿងនោះទេ។ ព្រះសង្ឃសូត្រសមនុភាសនកម្មហាមភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ។ ការសូត្រសមនុភាសនកម្មហាមភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ សមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនសមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង។ ភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង គឺព្រះសង្ឃ

បានសូត្រសមនុភាសនកម្មរួចហើយ ដើម្បីឲ្យលះបង់នូវរឿងនោះ។ (សមនុភាសនកម្មនោះ) សមគួរដល់សង្ឃ ហេតុនោះ ព្រះសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ។

[៣០៤] (កាលសង្ឃ) សូត្រញត្តិចប់ (ភិក្ខុទាំងនោះ) ត្រូវអាបត្តិទុក្កដ (កាលសង្ឃ) សូត្រកម្មវាចាពីរដង (ភិក្ខុទាំងនោះ) ត្រូវអាបត្តិថុល្លច្ច័យ (កាលសង្ឃ) សូត្រកម្មវាចាចប់ (ភិក្ខុទាំងនោះ) ត្រូវអាបត្តិសង្ឃាទិសេស។ កាលបើភិក្ខុទាំងនោះត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែល ភិក្ខុទាំងនោះត្រូវក្នុងខណៈចប់ញត្តិក្តី និងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុទាំងនោះត្រូវក្នុងខណៈចប់កម្មវាចាពីរដងក្តី ក៏តែងរំងាប់ទៅឯង។ សង្ឃគប្បីសូត្រសមនុភាសនកម្មហាមប្រាមភិក្ខុពីរ (ឬ) បីអង្គក្នុងទីជាមួយគ្នាបាន បើភិក្ខុច្រើនជាងចំនួននោះឡើងទៅ សង្ឃមិនគប្បីសូត្រទេ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយពិស្តារក្នុងសិក្ខាបទទី១ខាងដើមរួចហើយ។

[៣០៥] ភិក្ខុទាំងឡាយ (ជាអ្នកប្រព្រឹត្តតាមភិក្ខុបំបែកសង្ឃ) មានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ថា កម្មធ្វើត្រូវតាមធម៌ តែមិនលះបង់ចោល (គឺនៅប្រព្រឹត្តដដែល) ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យក្នុងកម្មដែលត្រូវតាមធម៌ តែមិនលះបង់ចោល ត្រូវអាបត្តិសង្ឃាទិសេសដែរ។ ភិក្ខុទាំងនោះមានសេចក្តីសំគាល់ក្នុងកម្មដែលត្រូវតាមធម៌ថា កម្មមិនត្រូវតាមធម៌វិញ តែមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេសដែរ។ ភិក្ខុទាំងនោះមានសេចក្តីសំគាល់ក្នុងកម្មដែលមិនត្រូវតាមធម៌ ថាកម្មត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យក្នុងកម្មមិនត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងនោះមានសេចក្តីសំគាល់ក្នុងកម្មដែលមិនត្រូវតាមធម៌ ថាកម្មមិនត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដ។

[៣០៦] អាបត្តិ មិនមានដល់ពួកភិក្ខុដែលសង្ឃមិនទាន់សូត្រសមនុភាសនកម្ម ដល់ពួកភិក្ខុដែលបានលះបង់ ដល់ពួកភិក្ខុឆ្កួត ដល់ពួកភិក្ខុមានចិត្តរវើរវាយ ដល់ពួកភិក្ខុមានទុក្ខវេទនាគ្របសង្កត់ ដល់ពួកភិក្ខុជាអាទិកម្មិក។

សង្ឃាទិសេស ទី១១ ចប់។

# សង្ឃាទិសេស ទី១២

CS vin.vbu.sg.12 | ភាគ ទី២

### (១២. ទុព្ពចសិក្ខាបទំ)

[៣០៧] សម័យនោះឯង ព្រះសម្ពុទ្ធអ្នកមានឥស្សរិយយស ទ្រង់ប្រថាប់នៅឃោសិតារាម ក្បែរក្រុងកោសម្ពី។ សម័យនោះឯង ឆន្នភិក្ខុដ៏មានអាយុប្រព្រឹត្តអនាចារ (មារយាទមិនសមគួរផ្សេងៗ)។ ភិក្ខុទាំងឡាយពោលប្រដៅយ៉ាងនេះថា ម្នាលអាវុសោឆន្ន លោកកុំធ្វើអំពើមានសភាពយ៉ាងនេះ អំពើនេះមិនសមគួរទេ។ ឆន្នភិក្ខុនោះឆ្លើយទៅវិញថា អាវុសោ លោកទាំងឡាយសំគាល់ថាលោកត្រូវពោលប្រដៅខ្ញុំឬ ខ្ញុំឯងទេតើ ទើបត្រូវប្រដៅលោកទាំងឡាយ (ព្រោះថា) ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង ព្រះអយ្យបុត្តរបស់យើង បានត្រាស់ដឹងនូវព្រះធម៌ដូចខ្យល់ព្យុះធំបក់បោក ប្រមូលយកស្មៅ កំណាត់ឈើ ស្លឹកឈើ និងសំណាត់មកមូលជាមួយគ្នា ឬថាដូចជា ទឹកស្ទឹងដែលហូរចុះចាកភ្នំ តែងប្រមូលគួចយកនូវចកធំសារាយ និងចកបាយទាមករួមជាមួយគ្នាបាន មានឧបមាយ៉ាងណាមិញ លោកទាំងឡាយមានឈ្មោះផ្សេងៗ មានគោត្រផ្សេងៗ មានជាតិផ្សេងៗ ចេញចាកត្រកូលផ្សេងៗហើយបួស គឺគេប្រមូលមកឲ្យមូលត្រកូលគ្នា ក៏មានឧបមេយ្យដូច្នោះឯង នែអាវុសោទាំងឡាយ លោកទាំងឡាយនៅសំគាល់ថាលោកត្រូវពោលប្រដៅខ្ញុំឬ ខ្ញុំឯងទេតើ ទើបត្រូវប្រដៅលោកទាំងឡាយ (ព្រោះថា) ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង ព្រះអយ្យបុត្តរបស់យើងបានត្រាស់ដឹងនូវព្រះធម៌។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីអៀនខ្មាស មានសេចក្តីរំខាន ប្រាថ្នាការសិក្សា ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុទាំងឡាយពោលប្រដៅដោយធម៌ ឬដោយសិក្ខាបទដែលព្រះពុទ្ធទ្រង់បញ្ញត្តទុក មិនសម្បីបើនឹងធ្វើខ្លួនឲ្យគេពោលប្រដៅមិនបាន។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគម្ចាស់។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគម្ចាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ឆន្នភិក្ខុដ៏មានអាយុក្នុងពេលនោះថា ឆន្ន ឮថា អ្នកឯង កាលពួកភិក្ខុពោលប្រដៅដោយធម៌ ត្រឡប់ធ្វើខ្លួនឲ្យគេប្រដៅមិនបានវិញ មែនឬ។ ឆន្នភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធអ្នកមានឥស្សរិយយស ទ្រង់តិះដៀលថា នែមោឃបុរស មិនទំនងសោះ។បេ។ មិនគួរធ្វើសោះ នែមោឃបុរស ហេតុម្តេចបានជាអ្នកឯង កាលពួកភិក្ខុពោលប្រដៅដោយធម៌ (ត្រឡប់) ជាធ្វើខ្លួនឲ្យគេពោលប្រដៅមិនបានទៅវិញ នែមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុមានជាតិដែលគេប្រដៅក្រ កាលភិក្ខុទាំងឡាយពោលប្រដៅ (ខ្លួន) ដោយធម៌ ក្នុងសិក្ខាបទទាំងឡាយដែលរាប់ចូលក្នុងឧទ្ទេស (បាតិមោក្ខ) ធ្វើខ្លួនឲ្យគេប្រដៅមិនបាន ដោយពាក្យថា លោកម្ចាស់ទាំងឡាយ លោកកុំនិយាយពាក្យបន្តិចបន្តួចទោះល្អក្តី អាក្រក់ក្តី នឹងខ្ញុំឡើយ ចំណែកខ្ញុំក៏នឹងមិនពោលពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តី នឹងលោកម្ចាស់ទាំងឡាយដែរ បពិត្រលោកម្ចាស់ទាំងឡាយ ចូរលោកលែងនិយាយប្រដៅខ្ញុំទៅ។ ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយពោល (ហាម) យ៉ាងនេះថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេប្រដៅមិនបានឡើយ លោកម្ចាស់ត្រូវតែធ្វើខ្លួនឲ្យគេពោលប្រដៅបានផង ចំណែកលោកម្ចាស់ ចូរប្រដៅភិក្ខុទាំងឡាយដោយសហធម៌ (ពុទ្ធប្បញ្ញត្តិ) សូម្បីពួកភិក្ខុក៏ពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិសទ្យរបស់ព្រះដ៏មានព្រះភាគម្ចាស់នោះ តែងចំរើនឡើងដោយពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា និងដោយញុំាងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិយ៉ាងនេះ។ កាលភិក្ខុទាំងឡាយពោលប្រដៅភិក្ខុនោះយ៉ាងនេះ (ភិក្ខុនោះ) ក៏នៅប្រកាន់យ៉ាងហ្នឹងដដែល ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម (ហាម) ជាគំរប់បីដង ដើម្បីឲ្យលះបង់នូវកម្មនោះ បើភិក្ខុនោះ**

**កាលពួកភិក្ខុសូត្រសមនុភាសនកម្ម ជាគំរប់បីដង ហើយលះបង់រឿងនោះបាន ការលះបង់បានយ៉ាងនេះ ជាការរួចទោស បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស។**

[៣០៨] ត្រង់ពាក្យថា ភិក្ខុមានជាតិដែលគេប្រដៅក្រ គឺជាអ្នកដែលគេស្តីប្រដៅបានដោយក្រ ប្រកបដោយធម៌ជាហេតុធ្វើឲ្យប្រដៅក្រ មិនអត់ធន់ មិនកាន់យកពាក្យប្រៀនប្រដៅដោយខាងស្តាំ (មិនកាន់យកពាក្យប្រៀនប្រដៅដោយគោរព)។ ពាក្យថា ក្នុងសិក្ខាបទទាំងឡាយដែលរាប់បញ្ចូលក្នុងឧទ្ទេស គឺក្នុងសិក្ខាបទទាំងឡាយ ដែលរាប់បញ្ចូលក្នុងព្រះបាតិមោក្ខ។ ពាក្យថា ពួកភិក្ខុ គឺភិក្ខុទាំងឡាយដទៃ។ បទដែលឈ្មោះថា សហធម៌ គឺសិក្ខាបទណាដែលព្រះដ៏មានព្រះភាគបញ្ញត្តទុក សិក្ខាបទនេះឈ្មោះថា សហធម៌។ ភិក្ខុនោះគេស្តីប្រដៅដោយសហធម៌នោះ ត្រឡប់ជាធ្វើខ្លួនមិនឲ្យគេស្តីប្រដៅបាន ដោយពាក្យថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយ កុំនិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តី នឹងខ្ញុំ ចំណែកខ្ញុំក៏មិននិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តីនឹងពួកលោកម្ចាស់ សូមពួកលោកម្ចាស់វៀរចាកការពោលប្រដៅខ្ញុំ។

[៣០៩] ពាក្យថា ភិក្ខុនោះ គឺភិក្ខុមានជាតិដែលគេប្រដៅបានដោយក្រនោះឯង។ ពាក្យថាភិក្ខុទាំងឡាយ បានដល់ពួកភិក្ខុដទៃ។ មានអធិប្បាយថា ពួកភិក្ខុណាឃើញ ពួកភិក្ខុណាបានស្តាប់ (ដំណឹង)ពួកភិក្ខុទាំងនោះត្រូវពោលថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន លោកម្ចាស់ត្រូវតែធ្វើខ្លួនឲ្យគេស្តីប្រដៅបាន សូម្បីលោកម្ចាស់សោត ក៏ចូរពោលប្រដៅភិក្ខុទាំងឡាយដោយសហធម៌ សូម្បីភិក្ខុទាំងឡាយក៏នឹងពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិសទ្យរបស់ព្រះដ៏មានព្រះភាគម្ចាស់នោះ តែងចំរើនឡើងដោយអាការយ៉ាងនេះ គឺដោយកិរិយាពោលជាប្រយោជន៍ដល់គ្នានឹងគ្នា ដោយញុំាងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិ។ ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយពោល (ហាម) ជាគំរប់ពីរដងផង ត្រូវពោល (ហាម) ជាគំរប់បីដងផង។ បើភិក្ខុនោះលះបង់បាន ការលះបង់បានយ៉ាងនេះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងឡាយបានឮហើយមិនពោល (ហាម) ត្រូវអាបត្តិទុក្កដដែរ។ ភិក្ខុទាំងឡាយ គប្បីចាប់ភិក្ខុនោះមកកាន់កណ្តាលប្រជុំសង្ឃ ហើយពោល (ហាម) ថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន លោកម្ចាស់ចូរធ្វើខ្លួនឲ្យគេស្តីប្រដៅបានផង សូម្បីលោកម្ចាស់សោត ក៏ចូរពោលប្រដៅពួកភិក្ខុដោយសហធម៌ ចំណែកពួកភិក្ខុក៏នឹងពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិសទ្យរបស់ព្រះដ៏មានព្រះភាគម្ចាស់នោះ តែងចំរើនឡើងដោយអាការយ៉ាងនេះ គឺដោយកិរិយាពោលពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា ដោយកិរិយាញុំាងគ្នីគ្នាឲ្យចេញចាកអាបត្តិ។ ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយពោលហាមជាគំរប់ពីរដងផង ត្រូវពោលហាមជាគំរប់បីដងផង។ បើភិក្ខុលះបង់បាន ការលះបង់យ៉ាងនេះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។

[៣១០] ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុត្រូវសូត្រសមនុភាសនកម្មយ៉ាងនេះ។ គឺភិក្ខុដែលឆ្លាសអង់អាច គប្បីប្រកាសឲ្យសង្ឃជ្រាបដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ កាលភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ ត្រឡប់ជាធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបានវិញ។ ភិក្ខុនោះ មិនលះបង់រឿងនោះទេ។ ថាបើកម្មមានកាលសមគួរដល់សង្ឃហើយ ព្រះសង្ឃគប្បីសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ។ នេះជាញត្តិ (គឺវាចាប្រកាសឲ្យសង្ឃដឹង)។ បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ កាលភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ ត្រឡប់ជាធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន។ ភិក្ខុនោះ មិនលះបង់រឿងនោះទេ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ។ ការសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ គាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ កាលភិក្ខុទាំងឡាយ ពោលពាក្យប្រកបដោយធម៌ នៅធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន។ ភិក្ខុនោះ មិនលះបង់រឿងនោះទេ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់នូវរឿងនោះ។ ការសូត្រសមនុភាសនកម្ម (ហាម) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់នូវរឿងនោះ គាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង។ ភិក្ខុមានឈ្មោះនេះ គឺព្រះសង្ឃបានសូត្រសមនុភាសនកម្មហើយ ដើម្បីឲ្យលះបង់រឿងនោះ។ សមនុភាសនកម្មនោះ គាប់ចិត្តដល់ព្រះសង្ឃ ហេតុនោះ ព្រះសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ។

[៣១១] (កាលសង្ឃ) សូត្រញត្តិចប់ (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ (កាលសង្ឃ) សូត្រកម្មវាចាពីរដង (ភិក្ខុនោះ) ត្រូវអាបត្តិថុល្លច្ច័យ (កាលសង្ឃ) សូត្រកម្មវាចាចប់ (ភិក្ខុនោះ) ត្រូវអាបត្តិសង្ឃាទិសេស។ កាលបើភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែល ភិក្ខុនោះត្រូវក្នុងខណៈចប់ញត្តិក្តី និងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុនោះត្រូវក្នុងខណៈចប់កម្មវាចាពីរដងក្តី ក៏តែងរំងាប់ទៅឯង។ ពាក្យថា អាបត្តិសង្ឃាទិសេស មានអធិប្បាយពិស្តារក្នុងសិក្ខាបទខាងដើមរួចហើយ។

[៣១២] ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មដែលប្រកបដោយធម៌ថា កម្មប្រកបដោយធម៌ តែមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មដែលប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេសដែរ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មប្រកបដោយធម៌ថា កម្មមិនប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដដែរ។

[៣១៣] អាបត្តិ មិនមានដល់ភិក្ខុដែលសង្ឃមិនទាន់សូត្រសមនុភាសនកម្ម ដល់ភិក្ខុលះបង់ស្រឡះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក។

សង្ឃាទិសេស ទី១២ ចប់។

# សង្ឃាទិសេស ទី១៣

## (១៣. កុលទូសកសិក្ខាបទំ)

[៣១៤] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានបុញ្ញសិរី គង់នៅក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុពីររូបឈ្មោះអស្សជិ និងបុនព្វសុក ជាអ្នកនៅក្នុងអាវាសទៀបកិដាគិរិជនបទ ជាភិក្ខុលាមកឥតខ្មាស។ អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុនោះ ប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាដោយខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទង[62] ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើដែលដោតជាចង្កោម[63] ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ។ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះ នាំផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ ដើម្បីស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ នាំផ្កាកម្រងមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើចាប់រំលេចទងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាឈើដែលដោតជាចង្កោមទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាកម្រងប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ប្រើគេនាំទៅឲ្យខ្លះ។ អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុនោះឆាន់ (ភោជន) ក្នុងភាជន៍មួយជាមួយនឹងស្រីត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយខ្លះ ផឹក (ទឹក)ក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ ដេកលើកម្រាល និងដណ្តប់ជាមួយគ្នាខ្លះ ស៊ីខុសពេលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូបនឹងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡាប្រាំបី[64] ខ្លះ លេងបាស្កាមានក្រឡាដប់[65] ខ្លះ លេងបាស្កាក្នុងអាកាស[66] ខ្លះ លេងផ្លូវវាងដែលខ្លួនគូរវាង[67] ខ្លះ លេងផ្ទាត់គ្រាប់ មានក្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងដោយរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ លេងអង្គុញខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងនង្គ័លតូចខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ (បាយឡុកបាយឡ) ខ្លះ លេងរថតូចខ្លះ លេងធ្នូតូចខ្លះ លេងសរសេរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត (ស្តេចចង់) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់ដំរីខ្លះ ហាត់សេះខ្លះ ហាត់រថខ្លះ ហាត់ធ្នូខ្លះ ហាត់ដងមានដងដាវជាដើមខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលរាំ យ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួន និងលើថ្ងាសស្រីរបាំខ្លះ ប្រព្រឹត្តអនាចារផ្សេងៗខ្លះ។

[៣១៥] សម័យនោះឯង ភិក្ខុមួយរូបចាំវស្សាក្នុងដែនឈ្មោះកាសី រួចហើយទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ក៏ដើរទៅត្រង់កិដាគិរិជនបទ។ ភិក្ខុនោះឯង ក៏ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរក្នុងពេលព្រឹកព្រហាម មានដំណើរឈានដើរទៅមុខ ឈានថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលចំហៀង បត់ចូល និងលាចេញ គួរជាទីជ្រះថ្លា ព្រោះភិក្ខុអង្គនោះ មានភ្នែកសង្រួមចុះ និងមានឥរិយាបថរំទំ ចូលទៅកាន់កិដាគិរិជនបទ ដើម្បីបិណ្ឌបាត។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយ និយាយយ៉ាងនេះថា លោកអ្វីនេះ ដូចជាសង្រួមហួស ដូចជាទន់ល្វន់ពេក ដូចជាមុខស្រពោនពេក អ្នកណាគេនឹងឲ្យដុំបាយដល់លោកនេះដែលចូលទៅរក (គេនោះ) ចំណែកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុជាម្ចាស់យើងពោលពាក្យផ្អែម ពោលពាក្យពីរោះ ពោលពាក្យជាសុខ មានញញឹមញញែមជាមុន តែងនិយាយថា អ្នកចូរមក អ្នកមកល្អហើយ មានមុខមិនស្រពោន មានមុខងើប តែងនិយាយមុន យើងគួរប្រគេនដុំបាយដល់លោកម្ចាស់អស់នោះ។ ឧបាសកមួយនាក់បានឃើញភិក្ខុនោះត្រាច់ទៅក្នុងកិដាគិរិជនបទ ដើម្បីបិណ្ឌបាត លុះឃើញហើយ ក៏ចូលទៅរកភិក្ខុនោះ ថ្វាយបង្គំហើយនិយាយពាក្យនេះថា មេត្តាប្រោស លោកម្ចាស់បានអាហារបិណ្ឌបាតខ្លះដែរឬ។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ អាហារបិណ្ឌបាតមិនទាន់បានទេ។ ឧបាសកនោះនិយាយថា លោកម្ចាស់ សូមនិមន្តមក យើងនឹងទៅផ្ទះ។ ទើបឧបាសកនោះ នាំភិក្ខុនោះទៅផ្ទះ ឲ្យឆាន់ហើយ និយាយពាក្យនេះថា លោកម្ចាស់នឹងនិមន្តទៅក្នុងទីណា។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ អាត្មានឹងទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ។ ឧបាសកនោះពោលថា បើដូច្នោះ សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទនៃព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យនៃខ្ញុំ ម្យ៉ាងទៀត សូមលោកម្ចាស់ក្រាបទូលយ៉ាងនេះថា សូមទ្រង់មេត្តាប្រោស អាវាសក្នុងកិដាគិរិជនបទខូចហើយ ព្រោះភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក ជាចៅអាវាស ក្នុងកិដាគិរិជនបទ ជាភិក្ខុលាមកឥតខ្មាស ភិក្ខុពីររូបនោះ ប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាដោយខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ។បេ។ ប្រព្រឹត្តអនាចារមានប្រការផ្សេងៗទៀត សូមទ្រង់ព្រះមេត្តាប្រោស ពួកមនុស្សណាមានសទ្ធាជ្រះថ្លាក្នុងកាលមុន ឥឡូវនេះមនុស្សអស់នោះ គ្មានសទ្ធា មិនជ្រះថ្លា ហើយទានទាំងឡាយណា (ដែលគេធ្លាប់ឲ្យ) ដល់សង្ឃក្នុងកាលមុន ឥឡូវនេះ ទានទាំងនោះ គេឈប់ឲ្យហើយ ភិក្ខុមានសីលជាទីស្រឡាញ់ ក៏រត់ខ្ចាត់ខ្ចាយ នៅតែពួកភិក្ខុលាមក សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគបញ្ជូនពួកភិក្ខុទៅកិដាគិរិជនបទ ប្រយោជន៍ឲ្យអាវាសក្នុងកិដាគិរិជនបទនេះរៀបរយល្អឡើងវិញ។ ភិក្ខុនោះទទួលស្តាប់ពាក្យឧបាសកនោះហើយថា អើអាវុសោ រួចក៏ចៀសចេញទៅកាន់ក្រុងសាវត្ថីដោយលំដាប់ ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងវត្តជេតពនជារបស់អនាថបិណ្ឌិកគហបតី ទៀបក្រុងសាវត្ថី លុះចូលទៅហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។

[៣១៦] ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ព្រះអង្គតែធ្វើសេចក្តីរីករាយជាមួយនឹងភិក្ខុជាអាគន្តុកទាំងឡាយយ៉ាងនេះ។ ហេតុដូច្នោះ បានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ សរីរយន្តអ្នកល្មមអត់ធន់បានឬទេ អ្នកល្មមប្រព្រឹត្តទៅបានស្រួលឬទេ[68]

អ្នកមកកាន់ផ្លូវឆ្ងាយដោយមិនសូវនឿយហត់ទេឬ ម្យ៉ាងទៀត អ្នកទើបនឹងមកពីទីណា។ ភិក្ខុនោះឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ សរីរយន្តខ្ញុំព្រះអង្គល្មមអត់ធន់បាន ខ្ញុំព្រះអង្គល្មមប្រព្រឹត្តទៅបានស្រួលទេ បពិត្រព្រះអង្គដ៏ចំរើន ម្យ៉ាងទៀតខ្ញុំព្រះអង្គមកកាន់ផ្លូវឆ្ងាយដោយមិនសូវនឿយហត់ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនៅចាំវស្សាក្នុងដែនកាសីនេះ ហើយមកកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ បានដើរទៅត្រង់កិដាគិរិជនបទ បពិត្រព្រះអង្គដ៏ចំរើន ក្នុងគ្រានោះ ខ្ញុំព្រះអង្គស្លៀកស្បង់ ហើយប្រដាប់បាត្រនិងចីវរ ចូលទៅកាន់កិដាគិរិជនបទ ដើម្បីបិណ្ឌបាតក្នុងពេលព្រឹកព្រហាម សូមទ្រង់ព្រះមេត្តាប្រោស ឧបាសកមួយនាក់ បានឃើញខ្ញុំព្រះអង្គកំពុងត្រាច់ទៅបិណ្ឌបាតក្នុងកិដាគិរិជនបទ លុះឃើញហើយ ក៏ចូលមករកខ្ញុំព្រះអង្គ លុះចូលមកហើយ ថ្វាយបង្គំខ្ញុំព្រះអង្គ រួចនិយាយពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់បានអាហារបិណ្ឌបាតខ្លះដែរឬ ខ្ញុំព្រះអង្គនិយាយថា ម្នាលអាវុសោ អាត្មាមិនទាន់បានអាហារបិណ្ឌបាតទេ ឧបាសកនោះនិយាយថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ចូរនិមន្តមក យើងនឹងទៅផ្ទះ សូមទ្រង់ព្រះមេត្តាប្រោស ទើបឧបាសកនោះ នាំខ្ញុំព្រះអង្គទៅផ្ទះ ហើយឲ្យឆាន់ រួចហើយប្រាប់ពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់នឹងទៅក្នុងទីណា ខ្ញុំព្រះអង្គប្រាប់ថា ម្នាលអាវុសោ អាត្មានឹងទៅក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ឧបាសកនោះពោលថា បពិត្រលោកដ៏ចំរើន បើដូច្នោះ សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទនៃព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យនៃខ្ញុំ ម្យ៉ាងទៀត សូមលោកម្ចាស់ទូលព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស អាវាសក្នុងកិដាគិរិជនបទវិនាសខូចអស់ហើយ ព្រោះភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ជាចៅអាវាសក្នុងកិដាគិរិជនបទ ជាភិក្ខុលាមកឥតខ្មាស ភិក្ខុពីររូបនោះប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាដោយខ្លួនឯងខ្លះ ប្រើគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេស្រោចខ្លះ។បេ។ ប្រព្រឹត្តអនាចារមានប្រការផ្សេងៗទៀត សូមទ្រង់ព្រះមេត្តាប្រោស កាលមុន មនុស្សទាំងឡាយណាធ្លាប់មានសទ្ធាជ្រះថ្លាហើយ ឥឡូវនេះមនុស្សអម្បាលនោះ មិនមានសទ្ធា មិនជ្រះថ្លាទេ ទានទាំងឡាយណាដែលទាយកធ្លាប់ឲ្យដល់សង្ឃក្នុងកាលមុន ឥឡូវនេះ ទានទាំងនោះ គេឈប់ឲ្យហើយ ភិក្ខុទាំងឡាយមានសីលបរិសុទ្ធស្អាត ចៀសចេញទៅ ចំណែកពួកភិក្ខុលាមកក៏នៅ (ក្នុងទីនោះ) សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ចាត់ពួកភិក្ខុ (ពីសំណាក់ព្រះអង្គ) ទៅកិដាគិរិជនបទ ប្រយោជន៍ឲ្យអាវាសក្នុងកិដាគិរិជនបទបានរៀបរយល្អ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទើបនឹងមកពីកិដាគិរិជនបទនោះ។

[៣១៧] ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុពីររូបឈ្មោះអស្សជិនិងបុនព្វសុកជាចៅអាវាស ក្នុងកិដាគិរិជនបទ ជាភិក្ខុលាមកឥតខ្មាស ភិក្ខុពីររូបនោះប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទង[69] ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់ស៊កក្នុងបំពង់[70] ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ។បេ។ ប្រព្រឹត្តអនាចារផ្សេងទៀត មនុស្សទាំងឡាយណា ធ្លាប់មានសទ្ធាជ្រះថ្លាហើយក្នុងកាលមុន ឥឡូវនេះមនុស្សទាំងឡាយនោះ មិនមានសទ្ធា មិនជ្រះថ្លាទេ ទានទាំងឡាយណាដែលទាយកគេធ្លាប់ប្រគេនដល់សង្ឃក្នុងកាលមុន ឥឡូវនេះទានទាំងនោះ គេឈប់ឲ្យអស់ហើយ ភិក្ខុទាំងឡាយមានសីលស្អាតបរិសុទ្ធចៀសចេញទៅ ចំណែកខាងពួកភិក្ខុលាមកក៏នៅក្នុងទីនោះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ រឿងនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះ មិនសមគួរទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ម្ដេចឡើយ ពួកមោឃបុរសនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាចាក់រំលេចទងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ភិក្ខុទាំងឡាយនោះ នាំផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ ដើម្បីស្រីនៃត្រកូលទាំងឡាយ ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ នាំផ្កាកម្រងមានទងទាំងពីរខាងទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាចាក់រំលេចទងទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាសម្រាប់ប្រដាប់ក្បាលទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាសម្រាប់ប្រដាប់ត្រចៀកទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាកម្រងប្រដាប់ទ្រូងទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ ភិក្ខុអម្បាលនោះ ឆាន់ក្នុងភាជន៍មួយជាមួយនឹងពួកស្រីនៃត្រកូល ពួកធីតានៃត្រកូល ពួកកុមារីនៃត្រកូល ពួកស្រីជាកូនប្រសានៃត្រកូល ពួកទាសីនៃត្រកូលខ្លះ ផឹក ក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ មានគ្រឿងកម្រាល និងដេកដណ្តប់ជាមួយគ្នាខ្លះ ស៊ីខុសពេលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូបនិងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡា៨ខ្លះ លេងបាស្កាមានក្រឡា១០ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងផ្លូវវាងដែលខ្លួនគួរវាង[71] ខ្លះ លេងផ្ទាត់គ្រាប់ មានក្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ លេងអង្គុញខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងកូននង្គ័លខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ (បាយឡកបាយឡ) ខ្លះ លេងដោយរថតូចខ្លះ លេងដោយធ្នូតូចខ្លះ លេងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត (ស្តេចចង់) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់សេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់ដងមានដងដាវជាដើមខ្លះ រត់ពីមុខដំរីខ្លះ រត់ទៅពីមុខសេះខ្លះ រត់ទៅពីមុខរថខ្លះ រត់ទៅខ្លះ រត់ត្រឡប់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់ខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលរាំ យ៉ាងនេះថា នែប្អូនស្រី នាងចូររាំក្នុងទីនេះចុះខ្លះ ដាក់ម្រាមដៃលើថ្ងាស (ខ្លួន និងថ្ងាសស្រីរបាំ) ខ្លះ ប្រព្រឹត្តអនាចារផ្សេងទៀត ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់មនុស្សដែលមិនទាន់ជ្រះថ្លាហើយផង។បេ។

[៣១៨] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ដោយបរិយាយច្រើន ហើយព្រះអង្គសំដែងធម្មីកថា រួចទ្រង់ហៅព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរមក ហើយត្រាស់ថា ម្នាលសារីបុត្ត និងមោគ្គល្លាន អ្នកទាំងឡាយចូរទៅកាន់កិដាគិរិជនបទ លុះទៅហើយ ចូរធ្វើបព្វាជនីយកម្ម[72) ] ភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកចេញពីកិដាគិរិជនបទ (ព្រោះ) ភិក្ខុអម្បាលនោះ ជាសទ្ធិវិហារិករបស់អ្នកទាំងឡាយ។ ព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរក្រាបទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គទាំងឡាយនឹងធ្វើបព្វាជនីយកម្ម ភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកចេញពីកិដាគិរិជនបទដូចម្តេចបាន (ព្រោះ) ភិក្ខុទាំងនោះជាមនុស្សកាចអាក្រក់។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្តនិងមោគ្គល្លាន បើដូច្នោះ អ្នកទាំងឡាយ ចូរទៅជាមួយនឹងភិក្ខុជាច្រើនរូប។ ព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគ ហើយឆ្លើយថា យ៉ាងហ្នឹងហើយព្រះអង្គ។

[៣១៩] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវធ្វើយ៉ាងនេះគឺ ដម្បូងពួកអ្នកត្រូវដាស់តឿនភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកសិន លុះដាស់តឿនហើយ គួរឲ្យរលឹក លុះឲ្យរលឹកហើយ គួរលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឆ្លាសអង់អាច គួរឲ្យសង្ឃដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃចូរស្តាប់ពាក្យខ្ញុំ ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកនេះ ជាអ្នកទ្រុស្តត្រកូល គឺញុំាងសេចក្តីជ្រះថ្លារបស់ត្រកូលឲ្យវិនាស ព្រោះសេចក្តីប្រព្រឹត្តិអាក្រក់។ សេចក្តីប្រព្រឹត្តិអាក្រក់របស់ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកនេះ ប្រាកដជាគេឃើញផង គេឮផង ម្យ៉ាងទៀត ត្រកូលទាំងឡាយដែលពួកភិក្ខុនេះទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង។ បើបព្វាជនីយកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើបព្វាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកឲ្យចេញពីកិដាគិរិជនបទថា ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរិជនបទទេ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃចូរស្តាប់ពាក្យខ្ញុំ ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក ជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តិអាក្រក់។ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកអម្បាលនេះ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលភិក្ខុអម្បាលនេះទ្រុស្តហើយសោត ប្រាកដជាគេឃើញផង គេឮផង។ សង្ឃធ្វើបព្វាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកឲ្យចេញពីកិដាគិរិជនបទថា ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរិជនបទទេ។ ការធ្វើបព្វាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក ឲ្យចេញពីកិដាគិរិជនបទថា ភិក្ខុទាំងឡាយជាពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកមិនត្រូវនៅក្នុងកិដាគិរិជនបទទេ សមគួរដល់លោកដ៏មានអាយុអង្គណា លោកអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកអង្គណា លោកអង្គនោះត្រូវពោលឡើង។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈពីរដងផង។បេ។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈបីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃសូមស្តាប់ពាក្យខ្ញុំ។បេ។ លោកអង្គនោះត្រូវពោលឡើង។ សង្ឃបានធ្វើបព្វាជនីយកម្ម ដល់ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ឲ្យចេញពីកិដាគិរិជនបទថា ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ។ ការធ្វើបព្វាជនីយកម្មនោះសមគួរដល់សង្ឃ ហេតុនោះសង្ឃស្ងៀមនៅ។ ខ្ញុំចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៣២០] លំដាប់នោះ ភិក្ខុសង្ឃ មានព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរជាប្រធាន ទៅកាន់កិដាគិរិជនបទ ហើយបានធ្វើបព្វាជនីយកម្ម ដល់ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ចេញពីកិដាគិរិជនបទថា ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ។ ភិក្ខុអម្បាលនោះដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល មិនសម្លបរោម គឺមិនព្រមតាម មិនព្រមប្រតិបត្តិតាមទំនងជាទីរើខ្លួនចេញ មិនអង្វរភិក្ខុទាំងឡាយឲ្យអត់ទោស ត្រឡប់ជាជេរប្រទេច បន្ទោសការកសង្ឃថា សង្ឃលុះក្នុងសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីល្ងង់ សេចក្តីខ្លាច ហើយភិក្ខុទាំងនោះចៀសចេញទៅខ្លះ សឹកទៅខ្លះ។ ពួកភិក្ខុណាប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល មិនសម្លបរោម មិនព្រមប្រតិបត្តិតាមទំនងជាទីរលាស់ខ្លួនចេញ មិនអង្វរភិក្ខុទាំងឡាយឲ្យអត់ទោស ត្រឡប់ជាជេរប្រទេច បន្ទោសការកសង្ឃថា សង្ឃលុះក្នុងសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីល្ងង់ សេចក្តីខ្លាច ហើយភិក្ខុទាំងនោះចៀសចេញទៅខ្លះ សឹកទៅខ្លះ។

[៣២១] លំដាប់នោះ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ ភិក្ខុទាំងឡាយក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បានឮថាពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល។បេ។ ហើយភិក្ខុទាំងនោះសឹកទៅខ្លះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធដ៏មានបុញ្ញសិរី តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះ មិនសមគួរ។បេ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេចក៏មោឃបុរសទាំងនោះ ដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល។បេ។ ភិក្ខុទាំងនោះសឹកទៅខ្លះ ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងឡាយនេះ មិននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាហើយផង។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុចូលទៅជិតអាស្រ័យស្រុក ឬនិគម កន្លែងណាមួយ ហើយនៅ ជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តិអាក្រក់។ សេចក្តីប្រព្រឹត្តិអាក្រក់របស់ភិក្ខុនោះឯង ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលភិក្ខុនោះទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយត្រូវនិយាយស្តីឲ្យយ៉ាងនេះថា លោកដ៏មានអាយុជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលលោកដ៏មានអាយុទ្រុស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរនៅក្នុងទីនេះទេ។ ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះ ត្រឡប់ថាឲ្យភិក្ខុទាំងឡាយនោះយ៉ាងនេះវិញថា ភិក្ខុទាំងឡាយលុះក្នុងសេចក្តីស្រឡាញ់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខឹងផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីល្ងង់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខ្លាចផង (ព្រោះ) ភិក្ខុទាំងឡាយនោះ បណ្តេញភិក្ខុពួកខ្លះ មិនបណ្តេញភិក្ខុពួកខ្លះដោយអាបត្តិដូចគ្នាទេ។ ភិក្ខុនោះ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា លោកដ៏មានអាយុចូរកុំនិយាយយ៉ាងនេះ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីស្រឡាញ់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីស្អប់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីល្ងង់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្តីខ្លាច លោកដ៏មានអាយុឯង ជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តិអាក្រក់ សេចក្តីប្រព្រឹត្តិអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោត ដែលលោកដ៏មានអាយុ**

**ទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញចាកអាវាសនេះទៅ លោកកុំនៅក្នុងអាវាសនេះ។ ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះ នៅតែប្រកាន់លទ្ធិយ៉ាងនេះដដែល ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មប្រកាសហាម ដើម្បីឲ្យលះបង់អំពើអាក្រក់នោះកំណត់បីដង។ ភិក្ខុនោះ បើភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មកំណត់បីដង លះអំពើអាក្រក់នោះបាន សេចក្តីលះបង់បាននេះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស។**

[៣២២] ត្រង់ពាក្យថា ភិក្ខុ (ចូលទៅជិតអាស្រ័យនៅ) ស្រុក ឬនិគម កន្លែងណាមួយ សេចក្តីថា ស្រុកក្តី និគមក្តី នគរក្តី ក៏គឺស្រុក គឺនិគមហ្នឹងឯង។ ពាក្យថា ចូលទៅជិតអាស្រ័យនៅ (គឺភិក្ខុចូលទៅជិតអាស្រ័យនៅក្នុងស្រុកនិគមណា) ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានបច្ចយភេសជ្ជបរិក្ខារជាប់ចំពោះមាននៅហើយ ក្នុងស្រុក និងនិគមនោះ។ ត្រកូល៤ពួក គឺ ត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ត្រកូលអ្នកឈ្មួញ (ត្រកូលអ្នករកស៊ីធម្មតា) ត្រកូលអ្នកគ្រួ (អ្នកស៊ីឈ្នួល) ហៅថា ត្រកូល។ ពាក្យថា ជាអ្នកទ្រុស្តត្រកូល គឺភិក្ខុទ្រុស្តត្រកូលទាំងឡាយដោយ (ឲ្យ) ផ្កាខ្លះ (ឲ្យ)ផ្លែខ្លះ (ឲ្យ)គ្រឿងលំអិតសម្រាប់ងូតខ្លះ (ឲ្យ)ដីស្អិតខ្លះ (ឲ្យ)ឈើស្ទន់ខ្លះ (ឲ្យ)ឫស្សីខ្លះ ដោយកិរិយាធ្វើពេទ្យខ្លះ ដោយការបម្រើដោយស្មងខ្លះ។ ពាក្យថា មានសេចក្តីប្រព្រឹត្តអាក្រក់ គឺភិក្ខុដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ។

[៣២៣] ពាក្យថា ប្រាកដជាគេឃើញផង គេឮផង គឺអ្នកណានៅក្នុងទីចំពោះមុខ អ្នកនោះឃើញ អ្នកណានៅក្នុងទីកំបាំងមុខ អ្នកនោះឮ។ ពាក្យថា ត្រកូលទាំងឡាយសោត ដែលភិក្ខុនោះទ្រុស្តហើយ គឺពីមុន មនុស្សទាំងឡាយមានសទ្ធា ឥឡូវនេះជាមនុស្សមិនមានសទ្ធាវិញ ធ្លាប់ជ្រះថ្លា លែងជ្រះថ្លាទៅវិញ ព្រោះអាស្រ័យនឹងភិក្ខុនោះ។ ពាក្យថា ប្រាកដជាគេឃើញផង គេឮផង គឺអ្នកណានៅក្នុងទីចំពោះមុខ អ្នកនោះឃើញ អ្នកណានៅក្នុងទីកំបាំងមុខ អ្នកនោះឮ។

[៣២៤] ពាក្យថា ភិក្ខុនោះ គឺភិក្ខុណាមួយ ជាអ្នកទ្រុស្តត្រកូល។ ពាក្យថា គឺភិក្ខុទាំងឡាយ បានដល់ភិក្ខុទាំងឡាយដទៃ។ ភិក្ខុទាំងឡាយណាឃើញ ណាឮ ភិក្ខុទាំងឡាយនោះត្រូវនិយាយប្រដៅថា លោកដ៏មានអាយុជាអ្នកទ្រុស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តិអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោត ដែលលោកដ៏មានអាយុទ្រុស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ។ ម្យ៉ាងទៀត ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះហើយ ត្រឡប់ថាឲ្យភិក្ខុទាំងឡាយនោះយ៉ាងនេះថា ភិក្ខុទាំងឡាយលុះក្នុងសេចក្តីស្រឡាញ់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីស្អប់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីល្ងង់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខ្លាចផង ទើបបណ្តេញភិក្ខុពួកខ្លះ មិនបណ្តេញភិក្ខុពួកខ្លះ ព្រោះអាបត្តិដូចគ្នាទេ។

[៣២៥] ពាក្យថា ភិក្ខុនោះ គឺភិក្ខុដែលបានធ្វើកម្មនោះ។ ពាក្យថា គឺភិក្ខុទាំងឡាយ បានដល់ភិក្ខុទាំងឡាយឯទៀត។ ភិក្ខុណាឃើញ ភិក្ខុណាឮ ភិក្ខុទាំងឡាយនោះត្រូវនិយាយប្រដៅថា លោកដ៏មានអាយុ ចូរកុំនិយាយយ៉ាងនេះ ភិក្ខុទាំងឡាយមិនលុះក្នុងឆន្ទាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងទោសាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងមោហាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងភយាគតិ លោកដ៏មានអាយុ ជាអ្នកទ្រុស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តិអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោត ដែលលោកដ៏មានអាយុទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ។ ភិក្ខុទ្រុស្តត្រកូលនោះ ត្រូវភិក្ខុទាំងឡាយនិយាយប្រដៅអស់វារៈជាគំរប់ពីរដងផង ត្រូវនិយាយប្រដៅអស់វារៈជាគំរប់បីដងផង។ បើភិក្ខុនោះលះបង់(កម្មនោះ) បាន ការលះបាននេះ ជាការល្អ បើភិក្ខុនោះមិនលះបង់ទេ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ ពួកភិក្ខុឮហើយ មិននិយាយប្រដៅ ត្រូវអាបត្តិទុក្កដ។ ភិក្ខុ (ទ្រុស្តត្រកូល) នោះ គឺភិក្ខុទាំងឡាយត្រូវទាញមកកាន់ទីកណ្តាលសង្ឃ ហើយនិយាយប្រដៅថា លោកដ៏មានអាយុ កុំពោលពាក្យយ៉ាងនេះ ភិក្ខុទាំងឡាយមិនមែនលុះក្នុងឆន្ទាគតិទេ ភិក្ខុទាំងឡាយមិនមែនលុះក្នុងទោសាគតិទេ ភិក្ខុទាំងឡាយមិនមែនលុះក្នុងមោហាគតិទេ ភិក្ខុទាំងឡាយមិនមែនលុះក្នុងភយាគតិទេ លោកដ៏មានអាយុ ជាអ្នកទ្រុស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តិអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោត ដែលលោកដ៏មានអាយុទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយត្រូវនិយាយប្រដៅ អស់វារៈជាគំរប់ពីរដងផង ត្រូវនិយាយប្រដៅអស់វារៈជាគំរប់បីដងផង។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះ ជាការល្អ បើភិក្ខុនោះលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ។

[៣២៦] ភិក្ខុនោះ សង្ឃត្រូវសូត្រប្រកាសហាម។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះសង្ឃត្រូវសូត្រប្រកាសហាមយ៉ាងនេះ។ ភិក្ខុដ៏ឆ្លាសអង់អាចត្រូវប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ត្រឡប់ជាបន្ទោសភិក្ខុសង្ឃថា ភិក្ខុសង្ឃលុះក្នុងឆន្ទាគតិ លុះក្នុងទោសាគតិ លុះក្នុងមោហាគតិ លុះក្នុងភយាគតិ។ ភិក្ខុ (អ្នកទ្រុស្តត្រកូល) នោះ មិនលះបង់វត្ថុនោះ។ បើកម្មរបស់សង្ឃមានកាលដ៏គួរដល់ហើយ សង្ឃគប្បីសូត្រប្រកាសហាមភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ។ នេះញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ត្រឡប់ជាបន្ទោសភិក្ខុសង្ឃថា ភិក្ខុសង្ឃលុះក្នុងសេចក្តីស្រឡាញ់ លុះក្នុងសេចក្តីស្អប់ លុះក្នុងសេចក្តីល្ងង់ លុះក្នុងសេចក្តីខ្លាច។ ភិក្ខុ (អ្នកទ្រុស្តត្រកូល) នោះ មិនលះបង់វត្ថុនោះ។ សង្ឃសូត្រសមនុភាសនកម្ម (ប្រកាសហាម) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ។ ការសូត្រសមនុភាសនកម្ម (ប្រកាសហាម) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំពោលសេចក្តីនេះអស់វារៈពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះអស់វារៈបីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃសូមស្តាប់ពាក្យខ្ញុំ។បេ។ លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ភិក្ខុឈ្មោះនេះ សង្ឃសូត្រសមនុភាសនកម្ម (ប្រកាសហាម) ដើម្បីឲ្យលះបង់វត្ថុនោះហើយ។ សមនុភាសនកម្មនោះ សមគួរដល់សង្ឃហើយ ហេតុនោះ សង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៣២៧] (កាលសង្ឃ) សូត្រញត្តិចប់ (ភិក្ខុអ្នកទ្រុស្តត្រកូលនោះ) ត្រូវអាបត្តិទុក្កដ (កាលសង្ឃ) សូត្រកម្មវាចាចប់ជាគំរប់ពីរដង (ភិក្ខុអ្នកទ្រុស្តត្រកូលនោះ) ត្រូវអាបត្តិថុល្លច្ច័យ (កាលសង្ឃ) សូត្រកម្មវាចាចប់ (ភិក្ខុអ្នកទ្រុស្តត្រកូលនោះ) ត្រូវអាបត្តិសង្ឃាទិសេស។ កាលបើភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលភិក្ខុនោះត្រូវក្នុងខណៈចប់ញត្តិក្តី និងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុនោះត្រូវក្នុងខណៈចប់កម្មវាចាជាគំរប់ពីរដងក្តី ក៏តែងរំងាប់ទៅឯង។ ត្រង់ពាក្យថា សង្ឃាទិសេស គឺសង្ឃ[73] ពិត ទើបឲ្យបរិវាសដើម្បីអាបត្តិនោះបានរើចេញចាកអាបត្តិខាងដើម ឲ្យនូវមានត្ត សូត្រអព្ភាន (រាប់ភិក្ខុនោះចូលពួកកង)គណៈ[74] ឲ្យមិនបាន បុគ្គល[75] ម្នាក់ឲ្យមិនបាន ហេតុនោះ ព្រះដ៏មានព្រះភាគត្រាស់ថា សង្ឃាទិសេស។ នាមកម្ម[76] ជាឈ្មោះពួកអាបត្តិនោះឯង ហេតុនោះ បានជាព្រះដ៏មានព្រះភាគត្រាស់ថា សង្ឃាទិសេស។

[៣២៨] ភិក្ខុសំគាល់ក្នុងកម្មប្រកបដោយធម៌ ថាកម្មប្រកបដោយធម៌ តែមិនលះបង់ (សេចក្តីប្រព្រឹត្តិអាក្រក់នោះ) ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុសំគាល់ក្នុងកម្មប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុសំគាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៣២៩] អាបត្តិមិនមានដល់ភិក្ខុដែលសង្ឃមិនទាន់សូត្រសមនុភាសនកម្ម ដល់ភិក្ខុដែលបានលះបង់ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុមានចិត្តរវើរវាយ ដល់ភិក្ខុមានទុក្ខវេទនាគ្របសង្កត់ ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សង្ឃាទិសេស ទី១៣ ចប់។

[៣៣០] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិទាំងឡាយឈ្មោះសង្ឃាទិសេសទាំង១៣ ខ្ញុំសំដែងឡើងហើយ អាបត្តិទាំងឡាយ៩ ហៅថាបឋមាបត្តិកា គឺត្រូវអាបត្តិក្នុងវេលាធ្វើឲ្យកន្លងបញ្ញត្តិជាដម្បូង អាបត្តិទាំងឡាយ៤ ហៅថា យាវតតិយកា គឺត្រូវអាបត្តិក្នុងវេលាដែលសង្ឃសូត្រប្រកាសហាមជាគំរប់បីដង ហើយមិនលះបង់ការអាក្រក់នោះ បណ្តាអាបត្តិទាំង១៣ បើភិក្ខុណាត្រូវអាបត្តិណានីមួយ ហើយដឹងច្បាស់ បិទបាំងទុកអស់ប៉ុន្មានថ្ងៃ ភិក្ខុនោះត្រូវនៅបរិវាសអស់ប៉ុណ្ណោះថ្ងៃ ព្រោះខ្លួនមិនមានសេចក្តីប្រាថ្នានឹងនៅបរិវាស។ ភិក្ខុដែលនៅបរិវាសហើយ ត្រូវប្រព្រឹត្តភិក្ខុមានត្ត[77] អស់៦រាត្រីតទៅទៀត។ ភិក្ខុប្រព្រឹត្តមានត្តហើយ ភិក្ខុសង្ឃពួក២០រូបមានក្នុងទីណា ភិក្ខុនោះ គឺភិក្ខុសង្ឃពួក២០រូប គប្បីឲ្យអព្ភាន[78] កម្មក្នុងទីនោះ។ បើភិក្ខុសង្ឃមិនគ្រប់២០រូបទេ សូម្បីខ្វះតែមួយរូប ហើយខំតែឲ្យអព្ភានកម្មដល់ភិក្ខុនោះ។ ឯភិក្ខុនោះ មិនបានឈ្មោះថា សង្ឃឲ្យអព្ភានកម្មផង ទាំងពួកភិក្ខុ (ជាការកសង្ឃ) នោះ ឈ្មោះថា ត្រូវព្រះពុទ្ធជាម្ចាស់តិះដៀលបានផង។ សេចក្តីប្រតិបត្តិនេះ ជាការដ៏សមគួរក្នុងកម្មនោះ។ ខ្ញុំសូមសួរលោកដ៏មានអាយុទាំងឡាយក្នុងរឿងនោះ លោកទាំងឡាយ ជាភិក្ខុបរិសុទ្ធហើយឬ ខ្ញុំសួរអស់វារៈពីរដងផង លោកទាំងឡាយ ជាភិក្ខុបរិសុទ្ធហើយឬ ខ្ញុំសួរអស់វារៈបីដងផង លោកទាំងឡាយ ជាភិក្ខុបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយជាភិក្ខុបរិសុទ្ធក្នុងរឿងនេះហើយ ហេតុនោះ បានជាស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវដំណើរនេះដោយអាការស្ងៀមនៅយ៉ាងនេះ។

សង្ឃាទិសេសទាំង១៣ ចប់។

បញ្ជីរឿងនៃសង្ឃាទិសេសនោះ

សង្ឃាទិសេស ទាំង១៣គឺ

វិសដ្ឋិ ការបញ្ចេញទឹកសុក្ក១

កាយសំសគ្គោ ស្ទាបអង្អែលកាយស្រី១

ទុដ្ឋុល្លំ ពោលពាក្យអាក្រក់១

អត្តកាមំ ឲ្យស្រីបម្រើខ្លួនដោយកាម១

សញ្ចរិត្តំ ដឹកនាំបុរសស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ១

កុដិ ធ្វើកុដិ១

វិហារោ ធ្វើទីលំនៅ១

អមូលកំ ចោទអាបត្តិរកដើមហេតុគ្មាន១

កញ្ចិលេសំ ចោទអាងលេសនីមួយ១

ភេទោ បំបែកសង្ឃ១

តស្សេវអនុវត្តកា ពួកភិក្ខុប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃនោះឯង១

ទុព្វចំ ប្រដៅក្រ១

# អនិយតកណ្ឌ

CS vin.vbu.ay | ភាគ ទី២

### (៣. អនិយតកណ្ឌំ)

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិទាំងឡាយពីរ ឈ្មោះអនិយតនេះ មកកាន់ឧទ្ទេស។

## អនិយតទី ១

CS vin.vbu.ay.1 | ភាគ ទី២

### (១. បឋមអនិយតសិក្ខាបទំ)

[៣៣១] សម័យនោះ ព្រះពុទ្ធដ៏មានបុញ្ញសិរី គង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ កាលណោះ ឧទាយិដ៏មានអាយុ ជាភិក្ខុចូលទៅរកត្រកូល តែងចូលទៅរកត្រកូលទាំងឡាយជាច្រើនក្នុងក្រុងសាវត្ថី។ សម័យនោះ កុមារិកានៃត្រកូលជាឧបដ្ឋាកលោកឧទាយិដ៏មានអាយុ មាតាបិតាបានផ្សំឲ្យដល់កុមារម្នាក់នៃត្រកូល។ គ្រាក្រោយ ឧទាយិដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់ដោយបាត្រចីវរក្នុងពេលព្រឹកព្រហាម ហើយចូលទៅរកត្រកូលនោះ លុះចូលទៅហើយ ក៏សួរមនុស្សទាំងឡាយថា កុមារិកាឈ្មោះនេះទៅណាហើយ។ មនុស្សអម្បាលនោះ បាននិយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន កុមារិកានោះ យើងខ្ញុំឲ្យទៅកុមារនៃត្រកូលឯណោះហើយ។ ឯត្រកូលនោះឯង ក៏ជាឧបដ្ឋាកឧទាយិដ៏មានអាយុដែរ។ គ្រានោះឯង ឧទាយិដ៏មានអាយុ ចូលទៅរកត្រកូលនោះ លុះចូលទៅហើយ ក៏សួរមនុស្សទាំងឡាយថា កុមារិកាឈ្មោះនេះនៅឯណា។ មនុស្សទាំងឡាយឆ្លើយថា លោកម្ចាស់ចូររកមើលចុះ កុមារិកានោះនៅក្នុងបន្ទប់តូច។ ទើបឧទាយិដ៏មានអាយុ តែម្នាក់ឯងចូលទៅរកកុមារិកានោះ លុះចូលទៅហើយ ក៏អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បាន ជាមួយនឹងកុមារិកាតែម្នាក់ឯងនោះ ហើយនិយាយគ្នាអស់កាលដ៏គួរ[79] និងនិយាយធម៌អស់កាលដ៏គួរ។[80]

[៣៣២] សម័យនោះឯង នាងវិសាខា ជាម្តាយនៃមិគារសេដ្ឋី នាងមានកូនច្រើន មានចៅច្រើន ទាំងកូនក៏មិនសូវមានរោគ ចៅក៏មិនសូវមានរោគ ជាស្រីមានមង្គលដ៏ប្រសើរ។ មនុស្សទាំងឡាយ កាលបើមានធ្វើទានធំ កាលបើមានអាវាហៈ និងវិវាហមង្គលជាដើម កាលបើមានមហោស្រព មានថ្ងៃចូលវស្សា និងចេញវស្សាជាដើម តែងឲ្យនាងវិសាខាជាម្តាយនៃមិគារសេដ្ឋី បរិភោគមុនគេជាដរាប។ គ្រានោះឯង នាងវិសាខាជាមិគារមាតា គេបានអញ្ជើញឲ្យទៅកាន់ត្រកូល ជាឧបដ្ឋាកនៃឧទាយិនោះ។ ឯនាងវិសាខាជាមិគារមាតា បានឃើញឧទាយិដ៏មានអាយុតែម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បាន ជាមួយនឹងកុមារិកាតែម្នាក់ឯងនោះ លុះឃើញហើយ ក៏បាននិយាយពាក្យនេះនឹងឧទាយិដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ការនេះ មិនមែនជាការស្ងាត់កំបាំងទេ មិនសមគួរទេ លោកម្ចាស់តែមួយអង្គ មកអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់មិនត្រូវការដោយធម៌នោះក៏ពិតមែនហើយ តែថា មនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា នឹងឲ្យជឿបានដោយក្រ។ ចំណែកឧទាយិដ៏មានអាយុ ទុកជានាងវិសាខាជាមិគារមាតាថាឲ្យយ៉ាងនេះ ក៏នៅមិនអើពើសោះ។ ទើបនាងវិសាខាជាមិគារមាតាចេញទៅ ហើយពិតរឿងនោះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណា ជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេចក៏ឧទាយិដ៏មានអាយុ ម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង។ លំដាប់នោះឯង ភិក្ខុទាំងនោះ ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ឮថាអ្នកឯង តែម្នាក់ឯង ទៅអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ពិតមែនឬ។ ឧទាយិក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធដ៏មានបុញ្ញសិរី ទ្រង់តិះដៀលថា ម្នាលមោឃបុរស ការដែលអ្នកធ្វើនោះ មិនស្រួល មិនទំនង។បេ។ ម្នាលមោឃបុរស ហេតុដូចម្តេចក៏អ្នកឯង តែម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ម្នាលមោឃបុរស ការដែលអ្នកធ្វើនោះ មិននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយ តែម្នាក់ឯង អង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បាន ជាមួយនឹងមាតុគ្រាម មានឧបាសិកាដែលមានវាចាគួរជឿបាន ឃើញភិក្ខុនោះ ហើយគប្បីចោទដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុទទួលប្តេជ្ញាការអង្គុយ (នោះមែន) វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺ អាបត្តិបារាជិក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ម្យ៉ាងទៀត ឧបាសិកានោះមានវាចាគួរជឿបាន ចោទដោយអាបត្តិណា វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះចំពោះភិក្ខុនោះ។ អាបត្តិនេះ ឈ្មោះថា អនិយត (មិនទៀង)។**

[៣៣៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងបារាជិកកណ្ឌសិក្ខាបទទី១រួចហើយ។ មនុស្សស្រី ហៅថា មាតុគ្រាម យក្សស្រី ប្រេតស្រី តិរច្ឆានញី មិនឈ្មោះថាមាតុគ្រាមទេ ដោយហោចទៅ សូម្បីទារិកាកើតក្នុងថ្ងៃនោះ ក៏ហៅថា មាតុគ្រាមដែរ មិនបាច់ពោលដល់ស្រីធំទេ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយគ្នា។ ពាក្យថា តែម្នាក់និងម្នាក់ គឺភិក្ខុម្នាក់ មាតុគ្រាមម្នាក់។ កំបាំងភ្នែក ស្ងាត់ត្រចៀក ហៅថា ស្ងាត់។ ដែល

ហៅថា ទីកំបាំងភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី បុគ្គលមិនអាចនឹងឃើញបាន។ ដែលហៅថា ទីស្ងាត់ត្រចៀក គឺបុគ្គលមិនអាចស្តាប់ពាក្យជាប្រក្រតីបាន។ ដែលហៅថា អាសនៈកំបាំង គឺអាសនៈដែលបិទបាំងដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយកន្ទេលក្តី ដោយការពន្ធព័ទ្ធដោយវាំងននក្តី ដោយឈើក្តី ដោយសសរក្តី ដោយស៊ុមក្តី ដោយវត្ថុឯណានីមួយក្តី។ ពាក្យថា ល្មមធ្វើ (សេវនកិច្ច)បាន គឺភិក្ខុអាចសេពមេថុនធម្មបាន។ ពាក្យថា អង្គុយ គឺកាលបើមាតុគ្រាមអង្គុយហើយ ភិក្ខុទៅអង្គុយជិតក្តី ដេកជិតក្តី កាលបើភិក្ខុអង្គុយហើយ មាតុគ្រាមទៅអង្គុយជិតក្តី ដេកជិតក្តី អ្នកទាំងពីរអង្គុយក្តី អ្នកទាំងពីរដេកក្តី។

[៣៣៤] ស្រីដែលមានផលមកហើយ (សម្រេចសោតាបត្តិផល) ត្រាស់ដឹងសច្ចៈ៤ ស្គាល់សាសនាច្បាស់ ហៅថា មានវាចាគួរជឿបាន។ ស្រីដែលដល់ព្រះពុទ្ធជាទីរលឹក ដល់ព្រះធម៌ជាទីរលឹក ដល់ព្រះសង្ឃជាទីរលឹក ហៅថា ឧបាសិកា។ ពាក្យថា ឃើញ គឺមើលឃើញ។

[៣៣៥] ឧបាសិកានោះ ចោទដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺ អាបត្តិបារាជិក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី កាលភិក្ខុទទួលប្តេជ្ញាការអង្គុយ (នោះមែន) វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺ អាបត្តិបារាជិក្តី សង្ឃាទិសេសក្តី បាចិត្តិយក្តី ម្យ៉ាងទៀត ម្យ៉ាងទៀតឧបាសិកាមានវាចាគួរជឿបាននោះ គប្បីចោទដោយអាបត្តិណា ភិក្ខុនោះ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ។

[៣៣៦] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ហើយ លោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម។ ឯភិក្ខុនោះទទួលប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ (ដល់ភិក្ខុនោះ)។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាមហើយ ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាអង្គុយមែន តែមិនសេពមេថុនធម្មទេ វិនយធរត្រូវវិនិច្ឆ័យអាបត្តិដោយការអង្គុយ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនមែនអង្គុយទេ តែថាអាត្មាដេក វិនយធរត្រូវវិនិច្ឆ័យអាបត្តិដោយការដេក។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនមែនអង្គុយទេ អាត្មាគ្រាន់តែឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ។

[៣៣៧] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះទទួលប្តេជ្ញាការដេក[81] នោះ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាដេកមែន តែអាត្មាមិនសេពមេថុនធម្មទេ វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនដេកទេ អាត្មាគ្រាន់តែអង្គុយ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកសេពមេថុនធម្មនឹងមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាមិនដេកទេ អាត្មាគ្រាន់តែឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ។

[៣៣៨] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយចាប់ពាល់រាងកាយមាតុគ្រាម ឯភិក្ខុនោះទទួលប្តេជ្ញានូវការចាប់នោះ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយចាប់ពាល់រាងកាយ មាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាអង្គុយមែន តែអាត្មាមិនបានចាប់ពាល់រាងកាយមាតុគ្រាមទេ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ។បេ។ អាត្មាមិនមែនអង្គុយទេ តែថាអាត្មាដេក វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក។បេ។ អាត្មាមិនមែនអង្គុយទេ តែថាអាត្មាឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ។

[៣៣៩] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកចាប់ពាល់រាងកាយមាតុគ្រាម ឯភិក្ខុនោះទទួលប្តេជ្ញាតាមពាក្យចោទនោះ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកចាប់ពាល់រាងកាយមាតុគ្រាម ឯភិក្ខុនោះពោលយ៉ាងនេះថា អាត្មាដេកមែន តែអាត្មាមិនចាប់ពាល់រាងកាយមាតុគ្រាមទេ វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក។បេ។ ភិក្ខុពោលថា អាត្មាមិនមែនដេកទេ តែថាអាត្មាអង្គុយ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ។បេ។ អាត្មាមិនមែនដេកទេ តែថាអាត្មាឈរ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ។

[៣៤០] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯងអង្គុយលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បានជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ឯភិក្ខុនោះទទួលប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ។បេ។ អាត្មាមិនមែនអង្គុយទេ តែថា អាត្មាដេក វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក។បេ។ ថាអាត្មាមិនមែនអង្គុយទេ តែថាអាត្មាឈរ វិនយធរមិនត្រូវ ឡើយ។

[៣៤១] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯងដេកលើអាសនៈដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បានជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ឯភិក្ខុនោះទទួលប្តេជ្ញាការដេកនោះ វិនយធរត្រូវវិនិច្ឆ័យទោសដោយការដេក។បេ។ អាត្មាមិនមែនដេកទេ តែថាអាត្មាអង្គុយ វិនយធរត្រូវវិនិច្ឆ័យទោសដោយការអង្គុយ។បេ។ អាត្មាមិនមែនដេកទេ តែថាអាត្មាឈរ វិនយធរមិនត្រូវ ឡើយ។

[៣៤២] ពាក្យថា អនិយត គឺមិនប្រាកដជាអាបត្តិបារាជិក ឬសង្ឃាទិសេស ឬបាចិត្តិយ។

[៣៤៣] ភិក្ខុទទួលប្តេជ្ញានូវកិរិយាដើរ ប្តេជ្ញានូវកិរិយាអង្គុយ ប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ។ ភិក្ខុទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ ប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ។ ភិក្ខុទទួលប្តេជ្ញានូវកិរិយាដើរ ប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសដោយកិរិយាអង្គុយ។ ភិក្ខុទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ តែប្តេជ្ញានូវកិរិយាអង្គុយ ប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ តែប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមអាបត្តិ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ តែប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិនយធរត្រូវវិនិច្ឆ័យទោសតាមការអង្គុយ។ ភិក្ខុមិនទទួលប្តេជ្ញានូវកិរិយាដើរ មិនប្តេជ្ញានូវកិរិយាអង្គុយ មិនប្តេជ្ញានូវអាបត្តិ វិនយធរមិនត្រូវវិនិច្ឆ័យឡើយ។

អនិយតទី ១ ចប់។

# អនិយតទី ២

CS vin.vbu.ay.2 | ភាគ ទី២

### (២. ទុតិយអនិយតសិក្ខាបទំ)

[៣៤៤] សម័យនោះ ព្រះពុទ្ធដ៏មានបុញ្ញសិរី គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ឧទាយិដ៏មានអាយុគិតថា ការដែលភិក្ខុម្នាក់ឯងទៅអង្គុយលើអាសនដ៏ស្ងាត់កំបាំង ល្មមធ្វើ (សេវនកិច្ច) បាន ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (ក៏ខ្លួនឧទាយិនោះ) តែម្នាក់ឯង ទៅអង្គុយក្នុងទីស្ងាត់ ជាមួយនឹងកុមារិកាតែម្នាក់ឯងដដែលនោះ និយាយសមគួរតាមកាល និយាយធម៌សមគួរតាមកាល។ នាងវិសាខាជាមិគារមាតា គេបានអញ្ជើញទៅកាន់ត្រកូលនោះ អស់វារៈជាគំរប់ពីរដងទៀត។ នាងវិសាខាជាមិគារមាតា បានឃើញឧទាយិដ៏មានអាយុម្នាក់ឯង អង្គុយក្នុងទីស្ងាត់ ជាមួយនឹងកុមារិកាម្នាក់ឯងដដែលនោះ លុះឃើញឧទាយិដ៏មានអាយុហើយ បានពោលពាក្យនេះថា បពិត្រលោកម្ចាស់ដ៏ចំរើន កម្មដែលលោកធ្វើនេះ មិនមែនជាកម្មស្ងាត់កំបាំង មិនសមគួរទេ លោកម្ចាស់ម្នាក់ឯងទៅអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់មិនត្រូវការដោយ (មេថុន) ធម៌នោះក៏ពិតមែន តែថា មនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា នឹងឲ្យជឿបានដោយក្រ។ ឧទាយិដ៏មានអាយុ ទុកជានាងវិសាខាជាមិគារមាតាស្តីឲ្យយ៉ាងនេះក៏ដោយ ក៏នៅតែមិនអើពើឡើយ។ គ្រានោះឯង នាងវិសាខាជាមិគារមាតាចេញទៅ ហើយពិតដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនគួរសោះ ឧទាយិដ៏មានអាយុ ម្នាក់ឯង នឹងទៅអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង។ ទើបភិក្ខុទាំងឡាយនោះ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧទាយិ ឮថាអ្នកឯង តែម្នាក់ឯង ទៅអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមតែម្នាក់ឯង ពិតមែនឬ។ បពិត្រព្រះអង្គដ៏ចំរើន ដំណើរនោះពិតមែន។ ព្រះពុទ្ធដ៏មានបុញ្ញសិរី ទ្រង់តិះដៀលថា។បេ។ នែមោឃបុរស អ្នកតែម្នាក់ឯង មិនសមបើទៅអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមតែម្នាក់ឯងសោះ នែមោឃបុរស កម្មដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **អាសនៈដែលគេមិនបានបិទបាំងមែន មិនល្មមធ្វើ (សេវនកិច្ច) បានមែន តែថា គួរអាចនឹងនិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់បាន។ ភិក្ខុណាមួយ តែម្នាក់និងម្នាក់ អង្គុយក្នុងទីកំបាំង លើអាសនៈមានសភាពយ៉ាងនោះ ជាមួយនឹងមាតុគ្រាម មានឧបាសិកាដែលមានវាចាគួរជឿបាន ឃើញភិក្ខុនោះ ហើយចោទដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុទទួលប្តេជ្ញាការអង្គុយ (នោះ) វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី ឬបាចិត្តិយក្តី ម្យ៉ាងទៀត ឧបាសិកាដែលមានសំដីគួរជឿបាននោះ ចោទដោយអាបត្តិណា វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះចំពោះភិក្ខុនោះ។ សូម្បីធម៌នេះ ក៏ឈ្មោះ អនិយតដែរ។**

[៣៤៥] ត្រង់ពាក្យថា អាសនៈដែលគេមិនបានបិទបាំងមែន សេចក្តីថា អាសនៈដែលមិនបិទបាំងដោយជញ្ជាំងក្តី សន្ទះទ្វារក្តី កន្ទេលផែងក្តី ពន្ធព័ទ្ធដោយវាំងននក្តី ដោយដើមឈើក្តី ដោយសសរក្តី ដោយស៊ុមក្តី ឬអាសនៈមិនបានបិទបាំងដោយរបស់ណាមួយ។ ពាក្យថា មិនល្មមធ្វើ (សេវនកិច្ច)បាន គឺភិក្ខុមិនអាចនឹងសេពមេថុនធម្មបាន។ ពាក្យថា តែថាល្មមនិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់បាន គឺភិក្ខុអាចនិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់បាន។

[៣៤៦] ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយរួចហើយក្នុងបារាជិកកណ្ឌសិក្ខាបទទី១។ ពាក្យថា លើអាសនៈមានសភាពយ៉ាងនោះ គឺលើអាសនៈបែបយ៉ាងនោះ។ មនុស្សស្រី ហៅថា មាតុគ្រាម ឯយក្សស្រី ប្រេតស្រី សត្វតិរច្ឆានញី មិនហៅថាមាតុគ្រាមទេ គឺស្រីដែលដឹងក្តី អង់អាចយល់ពាក្យជាសុភាសិត និងទុព្ភាសិត ពាក្យអាក្រក់ និងពាក្យល្អបាន ហៅថា មាតុគ្រាមក្នុងទីនេះ។ ពាក្យថា ជាមួយគ្នា គឺក្នុងទីជាមួយគ្នា។ ពាក្យថា តែម្នាក់និងម្នាក់ គឺមានតែភិក្ខុ និងមាតុគ្រាមប៉ុណ្ណោះ។ ទីកំបាំងភ្នែក ទីស្ងាត់ត្រចៀក ឈ្មោះថា ទីកំបាំង។ បុគ្គលមិនអាចនឹងឃើញជនទាំងឡាយ កាលមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី ក្នុងទីណា ទីនោះហៅថា កំបាំងភ្នែក។ ទីដែលបុគ្គលមិនអាចឮសំដីជាប្រក្រតីបាន ហៅថាទីស្ងាត់ត្រចៀក។ ពាក្យថា ទៅអង្គុយ គឺកាលបើមាតុគ្រាមអង្គុយ ភិក្ខុអង្គុយជិតក្តី ដេកជិតក្តី ឬថា កាលបើភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិតក្តី ដេកជិតក្តី ឬថាអង្គុយទាំងពីរនាក់ក្តី ដេកអ្នកទាំងពីរនាក់ក្តី។

[៣៤៧] ឧបាសិកាដែលមានផលមកហើយ (សម្រេចសោតាបត្តិផល) ត្រាស់ដឹងសច្ចៈ៤ ស្គាល់សាសនាច្បាស់ ហៅថា ឧបាសិកាមានសំដីគួរជឿបាន។ ស្រីដែលដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង ហៅថា ឧបាសិកា។ ពាក្យថា ឃើញ គឺបានប្រទះឃើញ។

[៣៤៨] ឧបាសិកាចោទដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ភិក្ខុក៏ទទួលប្តេជ្ញាការអង្គុយ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិពីរយ៉ាង ចំពោះអាបត្តិណាមួយ គឺសង្ឃាទិសេសក្តី បាចិត្តិយក្តី ម្យ៉ាងទៀត ឧបាសិកាមានសំដីគួរជឿបាននោះ ចោទដោយអាបត្តិណា វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិនោះ ចំពោះភិក្ខុនោះ។

[៣៤៩] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយប៉ះពាល់កាយមាតុគ្រាម ឯភិក្ខុនោះប្តេជ្ញាការអង្គុយនោះ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំអង្គុយមែន តែថាខ្ញុំមិនប៉ះពាល់កាយទេ វិនយធរត្រូវវិនិច្ឆ័យចំពោះតែការអង្គុយ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ប៉ះ

ពាល់កាយមាតុគ្រាម បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំដេក វិនយធរត្រូវវិនិច្ឆ័យចំពោះការដេក។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់អង្គុយប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំឈរ វិនយធរមិនគួរនឹងកាត់ (ឲ្យត្រូវអាបត្តិអ្វីឡើយ)។

[៣៥០] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ដេកប៉ះពាល់កាយមាតុគ្រាម បើភិក្ខុនោះប្តេជ្ញាការដេកនោះ វិនយធរត្រូវកាត់ទោសតាមអាបត្តិ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំបានដេកមែន តែថាខ្ញុំមិនបានប៉ះពាល់កាយមាតុគ្រាមទេទេ វិនយធរត្រូវវិនិច្ឆ័យចំពោះការដេក។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំអង្គុយ វិនយធរត្រូវកាត់ទោសចំពោះការអង្គុយ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំឈរ វិនយធរមិនគួរកាត់ (អាបត្តិអ្វីឡើយ)។

[៣៥១] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំបានឮថា លោកម្ចាស់អង្គុយនិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់ បើភិក្ខុនោះប្តេជ្ញាតាមពាក្យនោះ វិនយធរត្រូវវិនិច្ឆ័យតាមអាបត្តិ។ បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំបានឮថា លោកម្ចាស់អង្គុយនិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់ បើភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំអង្គុយមែន តែថាខ្ញុំមិនបាននិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់ទេ នោះវិនយធរត្រូវវិនិច្ឆ័យដោយការអង្គុយ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំដេក វិនយធរត្រូវវិនិច្ឆ័យតាមការដេក។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំឈរ វិនយធរមិនគួរវិនិច្ឆ័យ (ឲ្យត្រូវអាបត្តិអ្វីឡើយ)។

[៣៥២] បើឧបាសិកានោះ ចោទយ៉ាងនេះថា ខ្ញុំបានឮថា លោកម្ចាស់ដេកនិយាយចែចង់មាតុគ្រាមដោយវាចាអាក្រក់ បើភិក្ខុនោះប្តេជ្ញាតាមពាក្យចោទនោះ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ។បេ។ បើភិក្ខុនោះឆ្លើយថា ខ្ញុំដេកមែន តែថាខ្ញុំមិនបាននិយាយចែចង់ (មាតុគ្រាម)ដោយវាចាអាក្រក់ទេ វិនយធរត្រូវវិនិច្ឆ័យតាមការដេក។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំអង្គុយ វិនយធរត្រូវវិនិច្ឆ័យតាមការអង្គុយ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំឈរ វិនយធរមិនគួរវិនិច្ឆ័យ (ឲ្យត្រូវអាបត្តិអ្វីឡើយ)។

[៣៥៣] បើឧបាសិកានោះឆ្លើយយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯងអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាម គឺស្រីតែម្នាក់ បើភិក្ខុប្តេជ្ញាតាមពាក្យចោទនោះ វិនយធរត្រូវកាត់អាបត្តិចំពោះការអង្គុយ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថា ខ្ញុំដេក វិនយធរត្រូវវិនិច្ឆ័យតាមការដេក។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនអង្គុយទេ តែថាខ្ញុំឈរ វិនយធរមិនគួរកាត់(ឲ្យត្រូវអាបត្តិអ្វីឡើយ)។

[៣៥៤] បើឧបាសិកានោះឆ្លើយយ៉ាងនេះថា ខ្ញុំឃើញលោកម្ចាស់ម្នាក់ឯង ដេកក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាម គឺស្រីតែម្នាក់ បើភិក្ខុនោះប្តេជ្ញាការដេកនោះ វិនយធរត្រូវវិនិច្ឆ័យដោយការដេក។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថា ខ្ញុំអង្គុយ វិនយធរត្រូវកាត់អាបត្តិតាមអង្គុយ។បេ។ បើភិក្ខុឆ្លើយថា ខ្ញុំមិនដេកទេ តែថាខ្ញុំឈរ វិនយធរមិនគួរកាត់ (ឲ្យត្រូវអាបត្តិអ្វីឡើយ)។

[៣៥៥] ត្រង់ពាក្យថា សូម្បីធម៌ គឺតថាគតពោលប្រៀបធៀបនឹងសិក្ខាបទមុន។ ត្រង់ពាក្យថា អនិយត គឺមិនប្រាកដជាអាបត្តិសង្ឃាទិសេស ឬបាចិត្តិយ។

[៣៥៦] ភិក្ខុប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ។ ភិក្ខុប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ។ ភិក្ខុប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយការអង្គុយ។ ភិក្ខុប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ វិនយធរមិនគួរវិនិច្ឆ័យអ្វីឡើយ។ ភិក្ខុមិនប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ។ ភិក្ខុមិនប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ ប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយអាបត្តិ។ ភិក្ខុមិនប្តេជ្ញាការទៅ ប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ វិនយធរត្រូវវិនិច្ឆ័យដោយការអង្គុយ។ ភិក្ខុមិនប្តេជ្ញាការទៅ មិនប្តេជ្ញាការអង្គុយ មិនប្តេជ្ញាអាបត្តិ នោះវិនយធរមិនគួរវិនិច្ឆ័យ (អ្វីឡើយ)។

អនិយតទី ២ ចប់។

[៣៥៧] លោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះអនិយតពីរ ខ្ញុំសំដែងឡើងហើយ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈពីរដងផង លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈបីដងផង លោកម្ចាស់ជាអ្នកបរិសុទ្ធហើយឬ លោកម្ចាស់បរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះ បានជាលោកម្ចាស់ស្ងៀមនៅ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ។

អនិយតកណ្ឌ ចប់។

ឧទ្ទាននៃអនិយតកណ្ឌនោះ

អនិយតាបត្តិ (ពីរ) គឺ អលំកម្មនិយ១ នាលំកម្មនិយ១ ដែលព្រះពុទ្ធជាម្ចាស់ដ៏ប្រសើរ មានព្រះគុណធម៌មាំមួន ទ្រង់បញ្ញត្តទុកល្អហើយ។

ចប់ ភាគ២។

# មាតិកា

| តេរសកណ្ឌ | លេខ ទំព័រ |
| --- | --- |
| **សង្ឃាទិសេស ទី** | **១** |
| រឿងសេយ្យសកភិក្ខុ | ១ |
| សេចក្តីបញ្ញត្តិជាដម្បូង | ៦ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ | ៧ |
| បទភាជនីយ សុទ្ធិក | ៧ |
| បទភាជនីយ និយាយអំពីខណ្ឌចក្ក | ១៣ |
| បទភាជនីយ និយាយអំពីពទ្ធចក្ក | ១៥ |
| បទភាជនីយ និយាយអំពីចក្កមានមូលគ្រប់ទាំងអស់ ជាដើម | ១៩ |
| វារៈសំដែងអំពីអនាបត្តិ | ៣៧ |
| វិនីតវត្ថុគាថា (មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែ) | ៣៨ |
| វិនីតវត្ថុ សំដែងអំពីភិក្ខុ ១ រូប កំពុងយល់សប្តិ ជាដើម | ៣៩ |
| **សង្ឃាទិសេស ទី២** | **៥៣** |
| រឿង ឧទាយិភិក្ខុ | ៥៣ |
| សេចក្តីបញ្ញត្តិ | ៥៧ |
| ចំណែកសិក្ខាបទ | ៥៧ |
| បទភាជនីយ និយាយអំពីភិក្ខុបេយ្យាល | ៥៩ |
| បទភាជនីយ និយាយអំពីស្រីពីរនាក់ ជាដើម | ៦៣ |
| សំដែងអំពីវារៈ ដែលមិនត្រូវអាបត្តិ | ៨០ |
| វិនីតវត្ថុគាថា (មាតិកានុក្រម គឺបញ្ជីរឿងតាមរបៀបហូរហែ) | ៨០ |
| វិនីតវត្ថុ រឿងភិក្ខុចាប់ពាល់ម្តាយដោយសេចក្តីស្រឡាញ់ ជាដើម | ៨១ |
| **សង្ឃាទិសេស ទី៣** | **៨៦** |
| រឿងឧទាយិភិក្ខុ | ៨៦ |
| សេចក្តីបញ្ញត្តិ | ៨៨ |
| ចំណែកសិក្ខាបទ | ៨៨ |
| បទភាជនីយ | ៩៩ |
| និយាយអំពីវារៈដែលមិនត្រូវអាបត្តិ | ៩៩ |
| វិនីតវត្ថុគាថា (មាតិកានុក្រម គឺបញ្ជីរឿងតាមរបៀបហូរហែ) | ១០០ |
| វិនីតវត្ថុ សំដែងអំពីស្រីម្នាក់ដណ្តប់សំពត់កម្ពលជ្រលក់ថ្មី ជាដើម | ១០១ |
| **សង្ឃាទិសេស ទី៤** | **១០៥** |
| និទានឧទាយិភិក្ខុ | ១០៥ |
| សេចក្តីបញ្ញត្តិសិក្ខាបទ | ១០៩ |
| សិក្ខាបទវិភង្គ បទភាជនីយ | ១១១ |
| បទភាជនីយ និយាយអំពីភិក្ខុសង្ស័យ ជាដើម | ១១៣ |
| សំដែងអំពីវារៈដែលមិនត្រូវអាបត្តិ | ១១៦ |
| វិនីតវត្ថុគាថា (មាតិកានុក្រម គឺបញ្ជីរឿងតាមរបៀបហូរហែ) | ១១៦ |
| វិនីតវត្ថុ និយាយអំពី ស្រីអារ ជាដើម | ១១៧ |

| | |
|---|---|
| **សង្ឃាទិសេស ទី ៥** | **១២០** |
| និទានឧទាយិភិក្ខុ | ១២០ |
| សេចក្តីបញ្ញត្តិជាដម្បូង | ១២៩ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ | ១៣៣ |
| បទភាជនីយ និយាយអំពីនិក្ខេបបទ | ១៣៣ |
| ស្រី មាន១០ពួក | ១៣៤ |
| ភរិយា មាន១០ពួក | ១៣៤ |
| និយាយអំពី ខណ្ឌចក្ក | ១៣៧ |
| និយាយអំពី ពទ្ធចក្ក | ១៣៩ |
| និយាយអំពីវារៈដែលមិនត្រូវអាបត្តិ | ១៧៦ |
| វិនីតវត្ថុគាថា (មាតិកានុក្រម គឺបញ្ជីរឿងតាមរបៀបហូរហែ) | ១៧៦ |
| វិនីតវត្ថុ និយាយអំពីរឿងស្រីដេកលក់ ជាដើម | ១៧៦ |
| **សង្ឃាទិសេស ទី៦** | **១៧៩** |
| រឿងភិក្ខុនៅក្នុងដែនអាឡវី | ១៧៩ |
| រឿងមណិកណ្ឋនាគរាជ | ១៨៣ |
| និយាយអំពីរឿងហ្វូងសត្វស្លាប | ១៨៨ |
| និយាយអំពីរឿងកុលបុត្តឈ្មោះ រដ្ឋបាល | ១៩១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៩៣ |
| សិក្ខាបទវិភង្គ និងសម្មតិវិធី | ១៩៥ |
| និយាយអំពីការសំដែងទីសង់កុដិ | ១៩៧ |
| បទភាជនីយ និយាយអំពីទីមិនមានសេចក្តីអន្តរាយ ជាដើម | ១៩៩ |
| សំដែងអំពីវារៈដែលមិនត្រូវអាបត្តិ | ២២២ |
| **សង្ឃាទិសេស ទី៧** | **២២៣** |
| រឿងឆន្នត្ថេរ | ២២៣ |
| សេចក្តីបញ្ញត្តិ | ២២៥ |
| សិក្ខាបទវិភង្គ និយាយអំពីការសូមសង្ឃ ឱ្យមើលទីសង់វិហារ | ២២៥ |
| សិក្ខាបទវិភង្គ និយាយអំពីវិធីសន្មតិ | ២២៧ |
| បទភាជនីយ និយាយអំពីវិហារ សង្ឃមិនបានសំដែងទីឲ្យ ជាដើម | ២៣៣ |
| សំដែងអំពីវារៈដែលមិនត្រូវអាបត្តិ | ២៣៨ |
| **សង្ឃាទិសេស ទី៨** | **២៣៩** |
| និទានព្រះទព្វត្ថេរ | ២៣៩ |
| និយាយអំពីការសន្មតិព្រះទព្វត្ថេរ ឲ្យជាអ្នករៀបចំសេនាសនៈ និងសំដែងឡើងនូវភត្ត | ២៤១ |
| និទានមេត្តិយភុម្មជកភិក្ខុ | ២៤៥ |
| និទានមេត្តិយាភិក្ខុនី | ២៥០ |
| សេចក្តីបញ្ញត្តិ | ២៥៥ |
| ចំណែកសិក្ខាបទ | ២៥៥ |
| និយាយអំពីអធិករណ៍ ៤យ៉ាង | ២៥៦ |

| | |
|---|---|
| បទភាជនីយ និយាយអំពីការចោទដោយការមិនឃើញ ជាដើម | ២៥៧ |
| និយាយអំពីវារៈដែលមិនត្រូវអាបត្តិ | ២៧០ |
| **សង្ឃាទិសេស ទី៩** | **២៧១** |
| និទានមេត្តិយភុម្មជកភិក្ខុ | ២៧១ |
| សេចក្ដីបញ្ញត្តិ | ២៧៥ |
| សិក្ខាបទវិភង្គ អធិករណ៍ជាចំណែកដទៃ | ២៧៥ |
| សិក្ខាបទវិភង្គ និយាយអំពីលេស ១០យ៉ាង | ២៧៨ |
| បទភាជនីយ និយាយអំពីចំណែកដទៃនៃអាបត្តាធិករណ៍ | ២៨៥ |
| បទភាជនីយ និយាយអំពីអធិករណ៍មានមូលមួយៗ | ២៨៧ |
| សំដែងអំពីវារៈដែលមិនត្រូវអាបត្តិ | ២៩០ |
| **សង្ឃាទិសេស ទី១០** | **២៩១** |
| និទានទេវទត្តភិក្ខុ | ២៩១ |
| និយាយអំពី វត្ថុ ៥យ៉ាង | ២៩២ |
| សេចក្ដីបញ្ញត្តិ | ២៩៨ |
| ចំណែកសិក្ខាបទ | ២៩៨ |
| ការសូត្រសមនុភាសនកម្ម | ៣០១ |
| បទភាជនីយ | ៣០២ |
| និយាយអំពីអនាបត្តិ | ៣០៣ |
| **សង្ឃាទិសេស ទី១១** | **៣០៤** |
| និទានភេទានុវត្តកភិក្ខុ | ៣០៤ |
| សេចក្ដីបញ្ញត្តិ | ៣០៦ |
| សិក្ខាបទវិភង្គ | ៣០៧ |
| ការសូត្រសមនុភាសនកម្ម | ៣០៩ |
| បទភាជនីយ និយាយអំពីវារៈដែលត្រូវអាបត្តិ | ៣១១ |
| សំដែងអំពីវារៈដែលមិនត្រូវអាបត្តិ | ៣១២ |
| **សង្ឃាទិសេស ទី១២** | **៣១៣** |
| និទានឆន្នភិក្ខុ | ៣១៣ |
| សេចក្ដីបញ្ញត្តិ | ៣១៦ |
| ការចែកសិក្ខាបទ | ៣១៧ |
| វិធីសូត្រសមនុភាសនកម្ម | ៣១៩ |
| បទភាជនីយ | ៣២០ |
| វារៈដែលមិនត្រូវអាបត្តិ | ៣២២ |
| **សង្ឃាទិសេស ទី១៣** | **៣២២** |
| និទានអស្សជិបុនព្វសុកភិក្ខុ | ៣២២ |
| និទានព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរ | ៣៣៤ |
| និយាយអំពីបព្វាជនីយកម្ម | ៣៣៥ |
| និយាយអំពីសេចក្ដីបញ្ញត្តិ | ៣៤០ |

| | |
|---|---|
| សិក្ខាបទវិភង្គ | ៣៤១ |
| និយាយអំពីសមនុភាសនកម្ម | ៣៤៥ |
| បទភាជនីយ | ៣៤៦ |
| និយាយអំពីវារៈមិនត្រូវអាបត្តិ | ៣៤៧ |
| បញ្ជីរឿងនៃសង្ឃាទិសេសនោះ | ៣៤៩ |
| **អនិយតកណ្ឌ** | **៣៥០** |
| **អនិយតទី ១** | **៣៥០** |
| និទានឧទាយិភិក្ខុ | ៣៥០ |
| និទានឧបាសិកា ឈ្មោះនាងវិសាខា | ៣៥១ |
| សេចក្តីបញ្ញត្តិ | ៣៥៣ |
| ការចែកសិក្ខាបទ | ៣៥៥ |
| បទភាជនីយ | ៣៥៥ |
| **អនិយតទី ២** | **៣៦១** |
| និទានឧទាយិភិក្ខុ | ៣៦១ |
| និទានឧបាសិកាឈ្មោះនាងវិសាខា | ៣៦២ |
| សេចក្តីបញ្ញត្តិ | ៣៦៣ |
| សិក្ខាបទវិភង្គ | ៣៦៣ |
| បទភាជនីយ | ៣៦៩ |


1)
បាលីដែលសំដែងឡើងទុកជាគោលដើមនៃសិក្ខាបទ ហៅថាឧទ្ទេស។
2)
អដ្ឋកថា ពន្យល់សេចក្តីថា ឧទាយិត្ថេរនេះជាឧបជ្ឈាយ៍របស់សេយ្យសកភិក្ខុ។
3)
អព្វោហារិកា ប្រែថា មិនប្រកបដោយវោហារ គឺថា មិនប្រកបដោយហេតុដែលគួរនិយាយបានឡើយ ឬថា មិនមែនជាហេតុឲ្យទាស់ខុសនឹងបញ្ញត្តិណាមួយឡើយ
4)
ប្រហោង ឬរន្ធអ្វីៗ ហៅថាប្រហោងដាន។
5)
ភិក្ខុដែលមានអសុចិឃ្លាតចេញនោះ ត្រូវអាបត្តិសង្ឃាទិសេស។
6)
ពងល្វា។
7)
ស្ត្រីជាម្ចាស់ផ្ទះ ឬស្ត្រីមេផ្ទះ (អដ្ឋកថា
8)
របស់ដែលសម្រាប់ចោល ឬបោះ។
9)
មិនមែនត្រូវអាបត្តិទុក្កដ ព្រោះនិស្សគ្គិយវត្ថុប៉ះគ្នានោះទេ ត្រូវអាបត្តិទុក្កដព្រោះព្យាយាមដោយកាយ គឺកាយវិការ មានផ្ទាត់ម្រាមដៃ ញាក់ចិញ្ចើម ងក់ក្បាល ប៉ប្រិចភ្នែកជាដើម (អដ្ឋកថា)
10)
ពាក្យជេរលើកអាស
11)
ភិក្ខុដែលកំពុងសំដែងនូវសេចក្តីពន្យល់ ឬដែលកំពុងស្វាធ្យាយនូវអដ្ឋកថា នៃបទមានពាក្យថា ឯងជាមនុស្សគ្មាននិមិត្ត ដូច្នេះជាដើម។

12)

ភិក្ខុដែលកំពុងបង្ហាញ ឬកំពុងស្វាធ្យាយនូវបាឡី។

13)

ភិក្ខុដែលកំពុងនិយាយប្រៀនប្រដៅ មនុស្សខ្ជើយថា ឥឡូវនេះ ឯងជាមនុស្សគ្មាននិមិត្ត ឯងជាមនុស្សឧភតោព្យញ្ជនក ក៏តាំងពីឥឡូវនេះទៅ ឯងត្រូវកុំប្រមាទ ទៅខាងមុខទៅ កុំឲ្យជាមនុស្សយ៉ាងហ្នឹងទៀត។ (អដ្ឋកថា)

14)

កុលុបក ប្រែថា ជីតុន ក៏បាន គឺភិក្ខុដែលជិតដិតស្និទ្ធស្នាលនឹងត្រកូល។

15)

បានដល់ស្រីអ្នកលេង គឺស្រីឈ្នួល ស្រីផ្កាមាស

16)

គ្រឿងឧបករណសម្រាប់ផ្ទះ មានត្បាល់អង្រែជាដើម។

17)

ស្រីទាំង១០ចំពូក យើងបានប្រែជាសេចក្ដីពីខាងដើមរៀងមកហើយ តពីត្រឹមនេះទៅ មិនបាច់ប្រែទៀតទេ ត្រូវហៅជាបាឡីវិញ ដើម្បីឲ្យសាធុជនហៅជាបាឡីផងក៏បាន។

18)

ស្រី១០ចំពូក ហៅថាមានមូល១០ ភរិយា១០ចំពូក ហៅថាមានមូល១០ រួមមូលទាំងពីរពួក ហៅថាមានមូលគ្រប់ទាំងអស់។

19)

ប្រែថា បទជាប់គ្នាដោយមូលទាំងពីរ ឯមូលទាំងពីរនោះគឺ ស្រី១០ចំពូក មានមាតុរក្ខិតាជាដើម ហៅថាមូល១ ភរិយា១០ចំពូក មានធនក្កីតាភរិយាជាដើម ហៅថាមូល១ រួមមូលទាំងពីរនេះចូលគ្នា ជាន័យ១ ហៅថា ឧភតោពទ្ធក។

20)

តាមន័យក្នុងអដ្ឋកថាថា មិនបានវិលមកប្រាប់វិញទេ។

21)

វត្ថុសម្រាប់បរិភោគមុន បានដល់ស្រូវ៧យ៉ាង មានស្រូវស ស្រូវក្រហមជាដើម។

22)

វត្ថុសម្រាប់បរិភោគខាងក្រោយ បានដល់ល្ង សណ្ដែក ចេក អំពៅ ជាដើម។

23)

ទីសម្រាប់ផ្ចាលទោស គឺទីដែលគេសម្រាប់វាយមនុស្សផ្ចាល។

24)

ទីសម្រាប់ជ្រក ល្មមនៅបាន។

25)

ទីបិទបាំង ល្មមនៅបាន។ ពាក្យថា លេណ និងគុហា ទាំងពីរនេះ ជាវេវចន គឺពាក្យនិយាយផ្លាស់ប្ដូរគ្នាបាន។

26)

បានជាហៅថា ឃោសិតារាម ព្រោះអារាមនេះ ឃោសិតសេដ្ឋីសង់ថ្វាយព្រះបរមគ្រូ។

27)

គឺទីសេនាសនសម្រាប់នៅរបស់ខ្លួន ដែលមានទាយកជាម្ចាស់របស់ គេធ្វើឲ្យ។

28)

ពាក្យដែលហៅថាវិហារនោះ តាមភាសាបាឡី សំដៅយកទីនៅទាំងអស់របស់សង្ឃ គឺកុដិដែលធំៗសម្រាប់សង្ឃនៅ ឬទីវត្តទាំងមូលនោះឯងហៅថាវិហារ។

29)

សម្ពត់សម្រាប់ពាក់ព័ទ្ធឆៀងលើស្មាខាងឆ្វេងក្រោមស្មាស្ដាំ (ចីពរ)។

30)

សព្ទនេះប្រែមកពីបាឡីថា សារម្ភ ៗនេះ ប្រែថា ប្រកបដោយសេចក្ដីអន្តរាយ ថាមានហេតុទាស់ ថាប្រកបដោយសេចក្ដីរង្កៀស ឬមានសេចក្ដីរង្កៀស។

31)

តរច្ឆ ជូនប្រែថា ឆ្កែព្រៃ។

32)

វត្ថុដែលត្រូវបរិភោគមុន បានដល់ស្រូវ៧យ៉ាង មានស្រូវសាលីជាដើម ហៅថា បុព្វណ្ណជាតិ។

33)

វត្ថុដែលត្រូវបរិភោគក្រោយ បានដល់ សណ្ដែក ល្ង ជាដើម ហៅថា អបរណ្ណជាតិ។

34)

គឺទីដែលគេចងវាយរ៉ាវ។

35)

១.២ពាក្យថាលេណា និងគូហានេះ ជាវេវចន គឺជាពាក្យនិយាយផ្លាស់ប្តូរគ្នា ជាជំនួសគ្នាបាន (អដ្ឋកថា)។

36)

ព្រះទព្វត្ថេរ ជាបុត្តស្តេចមល្ល ហៅដោយរួបរួមថា ទព្វមល្លបុត្ត។

37)

ពាក្យពោលដូចជាពាក្យតិរច្ឆាន គឺនិយាយពាក្យឥតប្រយោជន៍ ជាពាក្យក្រៅធម៌វិន័យ។

38)

ព្រះទព្វមល្លបុត្តចូលឈានក្នុងពេលនោះ យកភ្លើងជាអារម្មណ៍ ឬជាកសិណ។

39)

មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងពីររូបនេះ ជាមេពួកមួយៗ រាប់បញ្ចូលក្នុងឆព្វគ្គិយភិក្ខុ ប៉ុន្តែភិក្ខុពីររូបនេះ ជាមនុស្សរឹងត្អឹង ក្លៀវក្លាជាងគេ។

40)

ប្រែតាមសព្ទថា សម្លកាច់បង់នូវរសជាតិនៃសាច់ដ៏ក្រៃលែង។ ជាឈ្មោះសម្លម្យ៉ាង ដែលអ្នកមជ្ឈិមបទេសប្រើក្នុងជាន់នោះ។

41)

គហបតីនេះ មានចង្ហាន់ឧត្តមប្រពៃ ឆ្ងាញ់ពីសារណាស់។

42)

ភិក្ខុដែលសង្ឃសន្មតឲ្យជាអ្នកសំដែងភត្តដល់ភិក្ខុទាំងពួង។

43)

ជាពាក្យបញ្ចៀស សំដៅសេចក្តីថាសេពមេថុន។

44)

មិនបានឃើញ ឬមិនបានឮ ឬក៏ឥតមានរង្កៀសឡើយ។

45)

សាសនព្រហ្មចារី

46)

ក្នុងអភិធានប្បទីបិកាសូចិ មានវិគ្រោះថា “គុណធម៌ជាគ្រឿងដុតកិលេសឲ្យរីងស្ងួតទៅ”។

47)

អារាមវេឡុវន ប្រែតាមសព្ទថា វត្តព្រៃឫស្សី កន្លែងនេះពីដើមជាឱទ្យានព្រះរាជទ្រព្យព្រះបាទពិម្ពិសារ ៗទ្រង់វេរថ្វាយដល់ព្រះពុទ្ធជាម្ចាស់កាលយាងចូលទៅកាន់ក្រុងរាជគ្រឹះជាដម្បូង ដើម្បីទ្រង់សំដែងព្រះធម៌ទេសនា ព្រះបាទពិម្ពិសារបានដល់សោតាបត្តិផល មានព្រះហឫទ័យជឿជាក់ក្នុងព្រះពុទ្ធសាសនា ហើយក៏វេរឱទ្យានឈ្មោះវេឡុវននោះថ្វាយជាព្រះអារាមសម្រាប់សង្ឃ មានព្រះពុទ្ធជាប្រធាន ជាអារាមដម្បូងមុនអារាមទាំងអស់។ ដែលហៅថា កលន្ទកនិវាបស្ថាន ព្រោះកន្លែងនោះឯង មនុស្សទាំងឡាយធ្លាប់ឲ្យអាហារចំណីដល់ពួកសត្វកង្ហែន មានរឿងដំណាលក្នុងអដ្ឋកថាវិន័យថា ពីដើមមកមានស្តេចមួយព្រះអង្គចេញទៅប្រពាតឱទ្យាននោះ ទ្រង់សោយសុរាស្រវឹងផ្ទំលក់ទៅ។ ឯរាជបរិវារក៏នាំគ្នាទៅបេះផ្លែឈើ ផ្កាឈើ កំសាន្តតាមអធ្យាស្រ័យ។ មានពស់វែក វាធំក្លិនសុរា ក៏លូនចេញមកពីរន្ធឈើ ហើយបែរមុខទៅចំពោះស្តេច។ មានរុក្ខទេវតានៅ។ទីជិតនោះ ឃើញហេតុដូច្នោះ ចង់ជួយឲ្យស្តេចរួចអំពីមរណ ទើបនិមិត្តជាសត្វកង្ហែនទៅស្រែកខាងព្រះកាណ៌ស្តេច ៗតើនឡើង ទ្រង់ឃើញសត្វទាំងពីរ ទ្រង់ត្រិះរិះថា សត្វកង្ហែនឲ្យជីវិតព្រះអង្គ តាំងពីនោះមក បានទ្រង់ប្រទានអភ័យ ប្រទានអាហារចំណីដល់សត្វកង្ហែនទួទៅ ទើបមនុស្សទាំងឡាយហៅកន្លែងនោះថា កលន្ទកនិវាបស្ថាន រៀងមក។

48)

រឿងដែលកើតឡើងហើយ ត្រូវតែចាត់ ត្រូវតែធ្វើឲ្យស្រេចទៅ ហៅថា អធិករណ៍។

49)

ការវិវាទគ្នាព្រោះធម្មវិន័យ ចាត់ជាវិវាទាធិករណ៍។

50)

ការចោទគ្នាដោយរឿងអាបត្តិ ឬវិបត្តិ ចាត់ជាអនុវាទាធិករណ៍។

51)

កិរិយាដែលត្រូវអាបត្តិ ចាត់ជាអាបត្តាធិករណ៍។

52)

កិច្ចធុរៈរបស់សង្ឃ មានកិច្ចឧបសម្បទាជាដើម ចាត់ជាកិច្ចាធិករណ៍។

53)

ត្រូវអាបត្តិបារាជិកព្រោះសេពមេថុនធម្ម។

54)

ត្រូវអាបត្តិបារាជិក ព្រោះលួចទ្រព្យគេមានដម្លៃតាំងពី៥មាសកឡើងទៅ។

55)

ត្រូវអាបត្តិបារាជិក ព្រោះសម្លាប់មនុស្ស។
56)
ត្រូវអាបត្តិបារាជិក ព្រោះអួតគុណវិសេសដែលមិនមានក្នុងខ្លួន។
57)
តាមអដ្ឋកថាសមន្តប្បាសាទិកា ថា បាត្រដីនោះឯង តែមានទ្រង់ទ្រាយល្អ មានសម្បុររលោង ហាក់ដូចពណ៌សត្វកំភេម រលីងស្អាតដូចបាត្រទង់ដែងដែរ។
58)
បាឡីថា “សុម្ភកបត្ត” តាមអដ្ឋកថាថា បានដល់បាត្រដីតាមធម្មតានោះឯង។
59)
លិសធាតុ ក្នុងអត្ថថា តិច-តួច គឺការជាបន្ទាប់បន្សំ។
60)
បំបែកផ្លូវប្រតិបត្តិផ្សេងចាកធម្មវិន័យរបស់ព្រះសម្មាសម្ពុទ្ធ។
61)
១.សំដែងអធម៌ថាជាធម៌ ២.សំដែងធម៌ថាជាអធម៌ ៣.សំដែងអវិន័យថាជាវិន័យ ៤.សំដែងវិន័យថាជាអវិន័យ ៥.ពាក្យដែលព្រះតថាគតមិនបានសំដែង ថាព្រះតថាគតបានសំដែង ៦. ពាក្យដែលព្រះតថាគតបានសំដែង ថាព្រះតថាគតមិនបានសំដែង ៧.អំពើដែលព្រះតថាគតមិនបានសន្សំទុកមក ថាព្រះតថាគតបានសន្សំទុកមក ៨.ដែលព្រះតថាគតបានសន្សំទុកមក ថាព្រះតថាគតមិនបានសន្សំទុកមក ៩.សេចក្ដីដែលព្រះតថាគតមិនបានបញ្ញត្ត ថាព្រះតថាគតបានបញ្ញត្ត ១០.ដែលព្រះតថាគតបានបញ្ញត្ត ថាមិនបានបញ្ញត្ត ១១.សំដែងអំពីអនាបត្តិ ថាជាអាបត្តិ។ ១២.សំដែងអំពីអាបត្តិ ថាអនាបត្តិ។ ១៣.សំដែងលហុកាបត្តិ ថាជាគរុកាបត្តិ។ ១៤.សំដែងគរុកាបត្តិ ថាជាលហុកាបត្តិ។ ១៥.សំដែងសាវសេសាបត្តិ (អាបត្តិ៥កង លើកអាបត្តិបារាជិក និងសង្ឃាទិសេសចេញ) ថាជាអនវសេសាបត្តិ (គឺបារាជិក និងសង្ឃាទិសេស)។ ១៦.សំដែងអនវសេសាបត្តិ ថាជាសាវសេសាបត្តិ។ ១៧.សំដែងទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ។ ១៨.សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ។ (មានក្នុងគម្ពីរចុលវគ្គ ត្រង់សង្ឃភេទខន្ធក
62)
តាមក្នុងអដ្ឋកថា គួរប្រែថា ក្បាច់ក្បូរផ្កាដែលគេធ្វើឲ្យដូចជាវល្លិ៍ដែលមានផ្កា។
63)
ក្នុងអដ្ឋកថា ថា ផ្កាកម្រងដែលគេដោតដោយម្ជុល ឬកន្លះ
64)
ចត្រង់មានក្រឡា៨។
65)
ចត្រង់មានក្រឡា១០ ន័យខ្លះប្រែថា បាយខុំ។
66)
ចត្រង់គ្មានក្ដារ លេងថាតែមាត់ទទេ។
67) , 71)
ប្រហែលជាលេង បិទមុខ បិទពួន។
68)
សួរសេចក្ដីសុខទុក្ខ។
69)
តាមក្នុងអដ្ឋកថា គួរប្រែថា ក្បាច់ក្បូរផ្កាដែលគេធ្វើឲ្យដូចជាវល្លិ៍ដែលមានផ្កា។
70)
ក្នុងអដ្ឋកថា ថាផ្កាកម្រងដែលគេដោតដោយម្ជុល ឬកន្លះ។
72)
ការបណ្ដេញភិក្ខុអលជ្ជី មិនប្រព្រឹត្តតាមធម៌វិន័យឲ្យចេញពីទីកន្លែង។
73)
ភិក្ខុ៤រូបឡើងទៅ ហៅថាសង្ឃ។
74)
ភិក្ខុពីររូប ឬបីរូប ហៅថាគណៈ។
75)
សំដៅយកភិក្ខុតែមួយរូប។
76)
ពួកអាបត្តិទាំង១៣សិក្ខាបទ តាំងអំពីសញ្ចេតនិកសិក្ខាបទ រហូតដល់កុលទូសកសិក្ខាបទនោះ ព្រះដ៏មានព្រះភាគឲ្យឈ្មោះថា សង្ឃាទិសេស។
77)

កម្មជាគ្រឿងប្រព្រឹត្ត ដើម្បីឲ្យជាទីរាប់អានរបស់ភិក្ខុ។
78)

កម្មដែលសង្ឃសូត្រប្រកាសហៅភិក្ខុដែលបានបរិវាសហើយនោះមកបញ្ចូលជាពួកវិញ។
79)

ភិក្ខុអង្គុយជាមួយនឹងស្រីអស់ពេលដែលគ្មានអ្នកណាទៅមក ហើយនិយាយពាក្យស្និទ្ធស្នាលនឹងគ្នាថា សព្វថ្ងៃនាងឯងមិនអផ្សុកទេឬ នាងឯងមិនលំបាកចិត្តទេឬ នាងឯងមិនស្រេកឃ្លានទេឬ ដូច្នេះជាដើម។
80)

ភិក្ខុអង្គុយជាមួយនឹងស្រីអស់ពេលដែលគ្មានអ្នកណាទៅមក ហើយនិយាយធម៌ប្រាប់ស្រីនោះថា នាងឯងត្រូវរក្សាឧបោសថសីល នាងឯងត្រូវឲ្យសលាកភត្តដូច្នេះជាដើម។
81)

នៅក្នុងព្រះត្រ័យបិដកខ្មែរ ឃើញដាក់ថា “ភិក្ខុប្ដេជ្ញាការអង្គុយនោះ” តែបើតាមសេចក្ដីក្នុងព្រះបាលី ក្នុងប្រយោគនេះមានន័យថា “ឯភិក្ខុនោះទទួលប្ដេជ្ញាការដេកនោះ ព្រោះមានព្រះបាលីថា សោ ចេ តំ បដិជានាតិ”។ ត្រង់សេចក្ដីនេះ ភិក្ខុនោះទទួលប្ដេជ្ញាតាមការចោទនោះមែន។ ដូច្នេះ សូមអ្នកអានទាំងឡាយពិចារណាផងចុះ។

---

sangham.net
Virtual AccessToInsight

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០០៣ - Book 003

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថា លោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០៣ - Tipitaka Book 003 [http://forum.sangham.net/index.php/topic,8911.0.html], for change log on ati.eu see here: រាយការណ៍ ភាគ ០០៣

ភាគ ទី ០០២ | **មាតិកា** | ភាគ ទី ០០៤




គំរូ ឯកសារ ផ្សេងទៀត ៖
ព្រះត្រៃបិដក ភាគ ទី៣

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី៣

ទ. ៖

# វិន័យបិដក

CS vin | ភាគ ទី៣

# មហាវិភង្គ

CS vin.vbu | ភាគ ទី៣

**តតិយភាគ**

**ភាគទី ៣**

**និស្សគ្គិយកណ្ឌ | បាចិត្តិយកណ្ឌ**

**និស្សគ្គិយកណ្ឌ**
ចីវរវគ្គ៖ និស្សគ្គិយ សិក្ខាបទ ទី ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០
កោសិយវគ្គ៖ និស្សគ្គិយ សិក្ខាបទ ទី ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០
បត្តវគ្គ៖ និស្សគ្គិយ សិក្ខាបទ ទី ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០

**បាចិត្តិយកណ្ឌ**
មុសាវាទវគ្គ៖ បាចិត្តិយ សិក្ខាបទ ទី ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០
ភូតគាមវគ្គ៖ និស្សគ្គិយ សិក្ខាបទ ទី ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦-៩២ មើល ភាគ ទី៤

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ។

# និស្សគ្គិយកណ្ឌ

### (៤. និស្សគ្គិយកណ្ឌំ)

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិនិស្សគ្គិយបាចិត្តិយទាំង៣០នេះឯង មកកាន់ឧទ្ទេស (គឺព្រះបាតិមោក្ខដែលសង្ឃត្រូវសំដែងរាល់កន្លះខែ)។

# ចីវរវគ្គ (ទី១)



### (១. ចីវរវគ្គោ)

## (និស្សគ្គិយ) សិក្ខាបទ ទី១



### (១. បឋមកថិនសិក្ខាបទំ)

[១] សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងគោតមកចេតិយ ទៀបក្រុងវេសាលី។ វេលានោះឯង ត្រៃចីវរដែលព្រះដ៏មានព្រះភាគ ទ្រង់បានអនុញ្ញាតដល់ភិក្ខុទាំងឡាយរួចស្រេចហើយ។ ពួកឆព្វគ្គិយភិក្ខុ (ភិក្ខុមានពួក៦) បានដឹងថា ត្រៃចីវរ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ (ក៏ប្រើប្រាស់ចីវរហួសពុទ្ធានុញ្ញាត គឺប្រើប្រាស់ចីវរបីត្រៃ) ចូលទៅកាន់ស្រុក (ស្លៀកដណ្តប់) ចីវរមួយត្រៃ នៅក្នុងអារាម (ស្លៀកដណ្តប់) ចីវរមួយត្រៃ ចុះកាន់កំពង់ងូតទឹក (ស្លៀកដណ្តប់) ចីវរមួយត្រៃ។ ភិក្ខុទាំងឡាយណាដែលជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកមានសេចក្តីអៀនខ្មាស ជាអ្នកក្តៅក្រហាយនឹងបាប ជាអ្នកពេញចិត្តខាងការរៀនសូត្រ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបីបើនឹងប្រើប្រាស់អតិរេកចីវរ (ចីវរច្រើន) លើសកំណត់។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ រួចត្រាស់សួរបញ្ជាក់ទៅពួកឆព្វគ្គិយភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានប្រើប្រាស់អតិរេកចីវរមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងរាល់គ្នាធ្វើនេះ មិនទំនង មិនសមបែប មិនសមគួរ មិនមែនជារបស់សមណៈ ជាការមិនគប្បី មិនគួរបើនឹងធ្វើសោះ ម្នាលមោឃបុរសទាំងឡាយ គួរបើដែរ អ្នកឯងរាល់គ្នានឹងប្រើប្រាស់អតិរេកចីវរ (យ៉ាងនេះ) ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងរាល់គ្នាធ្វើនេះ នឹងបាននាំមនុស្សដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬមនុស្សដែលបានជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀត (នោះ) ក៏ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយប្រើប្រាស់ អតិរេកចីវរ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ[1] ឯសិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ។

[២] គ្រានោះ អតិរេកចីវរ កើតឡើងដល់ព្រះអានន្ទដ៏មានអាយុ។ ព្រះអានន្ទដ៏មានអាយុចង់ប្រគេនចីវរនោះទៅព្រះសារីបុត្តដ៏មានអាយុ។ តែព្រះសារីបុត្តដ៏មានអាយុ លោកគង់នៅឯនគរសាកេត (មិនទាន់និមន្តមកដល់)។ វេលានោះ ព្រះអានន្ទដ៏មានអាយុ ត្រិះរិះគិតថា ព្រះដ៏មានព្រះភាគបានបញ្ញត្តសិក្ខាបទថា ភិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរឡើយ ឥឡូវអតិរេកចីវរ កើតឡើងដល់អញហើយ អញមានបំណងនឹងប្រគេនចីវរនេះទៅព្រះសារីបុត្តដ៏មានអាយុ តែព្រះសារីបុត្តដ៏មានអាយុ លោកគង់នៅឯនគរសាកេត តើអញត្រូវប្រតិបត្តិដូចម្តេចអេះ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលអានន្ទ ចុះសារីបុត្តនៅយូរប៉ុន្មានថ្ងៃទៀតនឹងមកដល់។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ ប្រហែលជាប្រាំបួនថ្ងៃឬដប់ថ្ងៃទៀត (ទើបលោកនឹងនិមន្តមកដល់)។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឱ្យអ្នករាល់គ្នាទុកអតិរេកចីវរ កំណត់ត្រឹមដប់ថ្ងៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសម្តែងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើចីវរសម្រេចហើយ (ក្តី) កឋិនដោះហើយ (ក្តី) ភិក្ខុត្រូវទុកអតិរេកចីវរ បានតែត្រឹមដប់ថ្ងៃ បើឱ្យកន្លងហួសពីដប់ថ្ងៃនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ។

[៣] ត្រង់ពាក្យថា ចីវរសម្រេចហើយ អធិប្បាយថា ចីវរដែលភិក្ខុបានធ្វើរួចហើយក្តី ចីវរដែលបាត់ដោយចោរជាដើមលួចយកទៅក្តី ចីវរវិនាសដោយសត្វកណ្តៀរជាដើមកាត់ក្តី ចីវរដែលភ្លើងឆេះក្តី សេចក្តីប្រាថ្នាក្នុងចីវរ (របស់ភិក្ខុនោះ) ដាច់ស្រឡះក្តី។ ពាក្យថា កឋិនដោះហើយ គឺកឋិនដែលដោះដោយបណ្តាមាតិកា៨យ៉ាង មាតិកាណាមួយ ឬសង្ឃបានប្រជុំគ្នាសូត្រដោះក្នុងកាលជាចន្លោះ។ ពាក្យថា កំណត់ត្រឹមដប់ថ្ងៃ គឺភិក្ខុត្រូវទុក (អតិរេកចីវរ) កំណត់យ៉ាងយូរបានត្រឹមតែដប់ថ្ងៃ។ ចីវរដែលភិក្ខុមិនបានអធិដ្ឋាន មិនបានវិកប្ប ឈ្មោះថាអតិរេកចីវរ។ បណ្តាចីវរទាំង៦ ចីវរណាមួយដែលតូចបំផុត គួរល្មមភិក្ខុវិកប្បបាន ឈ្មោះថាចីវរ។ ពាក្យថា បើទុកឱ្យកន្លង ហួសពីដប់ថ្ងៃនោះទៅ ត្រូវនិស្សគ្គិយ អធិប្បាយថា ចីវរកាលបើអរុណរះឡើងក្នុងថ្ងៃទី ១១ (ឡើងទៅ) ភិក្ខុត្រូវលះចេញ គឺត្រូវលះដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះ (ចីវរដល់ជំនុំសង្ឃ) បែបយ៉ាងនេះ។

[៤] ភិក្ខុនោះឯង ត្រូវ (យកចីវរដែលជានិស្សគ្គិយនោះ) ចូលទៅរកជំនុំសង្ឃ ហើយធ្វើឧត្តរាសង្គ (ចីពរ) ឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណមអញ្ជលីឡើង ពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន នេះចីវររបស់ខ្ញុំកន្លងដប់ថ្ងៃ ត្រូវនិស្សគ្គិយហើយ ឥឡូវខ្ញុំសូមលះចីវរនេះដល់ជំនុំសង្ឃ។ លុះ (ភិក្ខុនោះ) លះរួចហើយ ត្រូវសម្តែងអាបត្តិចេញ។ ភិក្ខុអ្នកឆ្លាសអង់អាចត្រូវ

ទទួលអាបត្តិ ត្រូវប្រគល់ចីវរដែលលះបង់ឱ្យដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ដ្បិតភិក្ខុឈ្មោះនេះ[2] បានលះចីវរនេះ ដែលត្រូវនិស្សគ្គិយដល់ជំនុំសង្ឃហើយ បើកម្មមាន កាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវប្រគល់ចីវរនេះឱ្យទៅភិក្ខុឈ្មោះនេះ[3] វិញចុះ។

[៥] (បើលះចីវរដល់គណៈ) ភិក្ខុនោះត្រូវចូលទៅរកភិក្ខុច្រើនអង្គ (គឺភិក្ខុបីរូប ឬពីររូប) ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាងសំពះទៀបបាទា ភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងប្រណមអញ្ជលីឡើង ពោលនឹងភិក្ខុទាំងនោះយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន នេះចីវររបស់ខ្ញុំកន្លងដប់ថ្ងៃ ត្រូវនិស្សគ្គិយហើយ ឥឡូវខ្ញុំសូមលះចីវរនេះដល់លោកដ៏មានអាយុទាំងឡាយ។ ភិក្ខុនោះលះរួចហើយ ត្រូវសម្ដែងអាបត្តិចេញ។ ភិក្ខុអ្នកឆ្លាសអង់អាចត្រូវទទួលអាបត្តិ រួចត្រូវឱ្យចីវរដែលភិក្ខុលះនោះដោយពាក្យថា សូមលោកដ៏មានអាយុទាំងឡាយស្ដាប់ពាក្យខ្ញុំ ចីវរនេះ របស់ភិក្ខុឈ្មោះនេះ ជានិស្សគ្គិយ លោកបានលះបង់ដល់លោកដ៏មានអាយុទាំងឡាយហើយ។ បើកម្មមានកាលដ៏សមគួរដល់លោកដ៏មានអាយុទាំងឡាយហើយ អស់លោកដ៏មានអាយុត្រូវប្រគល់ចីវរនេះឱ្យទៅភិក្ខុឈ្មោះនេះវិញចុះ។

[៦] (បើលះដល់បុគ្គល) ភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុមួយរូប ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួចអង្គុយច្រហោងប្រណមអញ្ជលីឡើង ហើយពោលនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ នេះចីវររបស់ខ្ញុំ កន្លងដប់ថ្ងៃហើយត្រូវតែលះបង់ ឥឡូវខ្ញុំសូមលះចីវរនេះដល់លោក

ដ៏មានអាយុ។ ភិក្ខុនោះ លុះលះរួចហើយត្រូវសម្ដែងអាបត្តិចេញ។ ភិក្ខុនោះត្រូវទទួលអាបត្តិ ហើយត្រូវប្រគល់ចីវរដែលលះបង់ដោយពាក្យថា ខ្ញុំឱ្យចីវរនេះទៅលោកដ៏មានអាយុវិញ។

[៧] (កាលបើចីវរ) កន្លងហួសដប់ថ្ងៃហើយ ភិក្ខុដឹងច្បាស់ថាកន្លង ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) កន្លងហួសដប់ថ្ងៃហើយ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) ដែលកន្លងហួសដប់ថ្ងៃហើយ ភិក្ខុសំគាល់ថាមិនទាន់កន្លងទេ ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) ដែលមិនទាន់បានអធិដ្ឋាន ហើយភិក្ខុសំគាល់ថាបានអធិដ្ឋានហើយ ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) ដែលភិក្ខុមិនទាន់បានវិកប្ប ហើយភិក្ខុសំគាល់ថាបានវិកប្ប ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) ដែលភិក្ខុមិនទាន់បានលះ ហើយភិក្ខុដឹងច្បាស់ថាបានលះ ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) មិនបាត់ទេ ហើយភិក្ខុសំគាល់ថាបាត់ ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) មិនខូចទេ ហើយភិក្ខុសំគាល់ថាខូច ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) ភ្លើងមិនឆេះទេ ហើយភិក្ខុសំគាល់ថាភ្លើងឆេះ

ត្រូវនិស្សគ្គិយបាចិត្តិយ។ (កាលបើចីវរ) ចោរឥតបានប្លន់យកទេ តែភិក្ខុសំគាល់ថាចោរប្លន់យក ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមិនបានលះចីវរដែលត្រូវនិស្សគ្គិយ ហើយយកមកប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ (កាលបើចីវរ) មិនទាន់កន្លងហួសដប់ថ្ងៃទេ ភិក្ខុសំគាល់ថាកន្លងហើយ ត្រូវអាបត្តិទុក្កដ។ (កាលបើចីវរ) មិនទាន់កន្លងហួសដប់ថ្ងៃទេ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ (កាលបើចីវរ) មិនទាន់កន្លងហួស ដប់ថ្ងៃ ហើយភិក្ខុក៏សំគាល់ថាមិនទាន់កន្លងទេ មិនត្រូវអាបត្តិឡើយ។

[៨] វារៈដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុបានអធិដ្ឋាន បានវិកប្បក្នុងខាងក្នុងដប់ថ្ងៃ១ ភិក្ខុបានលះ១ ចីវរបាត់១ ចីវរខូច១ ចីវរភ្លើងឆេះ១ ចីវរចោរដណ្ដើមយក១ ចីវរដែលភិក្ខុយកដោយសេចក្ដីស្និទ្ធស្នាល១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

[៩] ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រគល់ចីវរដែលលះ ឱ្យទៅភិក្ខុ (ម្ចាស់ចីវរ) នោះវិញ។ ភិក្ខុទាំងឡាយណាដែលជាអ្នកមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏លើកទោស តិះដៀល បន្ទោសថា គួរបើដែរ ពួកឆព្វគ្គិយភិក្ខុមិនឱ្យចីវរដែលលះ (ទៅភិក្ខុម្ចាស់ចីវរ) វិញ។ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរទៅពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយមិនបានឱ្យចីវរដែលលះ (ទៅភិក្ខុម្ចាស់ចីវរ) វិញ មែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា មែនព្រះអង្គ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោស។បេ។ រួចទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំមិនឱ្យចីវរដែលលះ (ទៅភិក្ខុម្ចាស់ចីវរ) វិញ ភិក្ខុណាមិនឱ្យ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

សិក្ខាបទ ទី១ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី២

CS vin.vbu.ni.02 | ភាគ ទី៣

### (២. ឧទោសិតសិក្ខាបទំ)

[១០] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង មានភិក្ខុច្រើនរូបបានផ្ញើចីវរទុកនៅដៃភិក្ខុទាំងឡាយ (រួចស្លៀកដណ្ដប់) តែស្បង់និងចីវរ ចេញទៅកាន់ជនបទចារិកទៅ។ ឯចីវរដែលភិក្ខុផ្ញើទុកនោះយូរពេកក៏ដាមឆ្កកជាំអស់។ ភិក្ខុទាំងឡាយក៏យកចីវរទាំងអម្បាលនោះទៅ ហាលសំដិល។ ព្រះអានន្ទដ៏មានអាយុបាននិមន្តទៅកាន់សេនាសនចារិក ក្រឡេកទៅឃើញភិក្ខុទាំងនោះកំពុងហាលសំដិលចីវរទាំងនោះ ក៏ដើរចូលទៅជិតភិក្ខុទាំងឡាយនោះ លុះចូលទៅជិតហើយ ក៏សួរភិក្ខុទាំងនោះថា ម្នាលអាវុសោទាំងឡាយ ចីវរទាំងនេះដាមឆ្កកជាំអស់ តើជារបស់លោកណា។ គ្រានោះឯង ភិក្ខុទាំងអម្បាលនោះក៏បានប្រាប់សេចក្ដីនុ៎ះដល់ព្រះអានន្ទដ៏មានអាយុ។ ព្រះអានន្ទដ៏មានអាយុក៏លើកទោស តិះដៀល បន្ទោសថា ភិក្ខុទាំងឡាយមិនគួរបើនឹងផ្ញើចីវរទុកដាក់ដៃរបស់ភិក្ខុទាំងឡាយ ហើយ (ស្លៀកដណ្ដប់) តែស្បង់នឹងចីពរចេញទៅកាន់ជនបទចារិកសោះ។ ទើបព្រះអានន្ទដ៏មានអាយុ ក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់។ លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរតបទៅពួកភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយបានផ្ញើចីវរ ទុកនៅដៃភិក្ខុទាំងឡាយ ហើយ (ស្លៀកដណ្ដប់) តែស្បង់និងចីពរ ចេញដើរទៅកាន់ជនបទចារិក មែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះ មេត្តាប្រោស ហេតុនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរ មោឃបុរសទាំងនោះ ហ៊ានផ្ញើចីវរទុកនៅដៃភិក្ខុទាំងឡាយ (ហើយស្លៀកដណ្ដប់) តែស្បង់ និងចីពរ ចេញដើរទៅកាន់ជនបទចារិក ម្នាលភិក្ខុ

ទាំងឡាយ អំពើដែល អ្នកធ្វើនេះ នឹងបាននាំមនុស្សដែលមិនទាន់ជ្រះថ្លា ឱ្យបានជ្រះថ្លាឡើង ឬមនុស្សដែលបានជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើង (នោះ) ក៏ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងសិក្ខាបទនេះ យ៉ាងនេះថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ កឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តដល់ពួកភិក្ខុយ៉ាងនេះហើយ។

[១១] គ្រានោះឯង ក្នុងក្រុងកោសម្ពី មានភិក្ខុមួយរូបមានជំងឺ។ ពួកជនជាញាតិក៏បានចាត់ប្រើបម្រើទៅក្នុងសំណាក់ភិក្ខុនោះថា សូមឱ្យលោកម្ចាស់និមន្តមក យើងនឹងផ្គត់ផ្គង់បម្រើ។ ទាំងភិក្ខុទាំងឡាយក៏ជួយនិយាយថា ម្នាលអាវុសោ លោកចូរនិមន្តទៅចុះ ពួកញាតិគេនឹងបាន ផ្គត់ផ្គង់បម្រើលោក។ ភិក្ខុនោះនិយាយតបយ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយរួចហើយថា ភិក្ខុមិនត្រូវនៅប្រាសចាកត្រៃចីវរទេ ក៏ឥឡូវខ្លួនខ្ញុំមានជម្ងឺ មិនអាចនឹងយកត្រៃចីវរចេញដើរទៅបានឡើយ ខ្ញុំនឹងទៅមិនកើតទេ។ ភិក្ខុទាំងឡាយក៏បានទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ក៏ធ្វើធម្មីកថា ក្នុងវេលានោះ ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យជំនុំសង្ឃ ឱ្យនូវសម្មតិ ដើម្បីឱ្យនៅប្រាសចាកត្រៃចីវរដល់ភិក្ខុដែលមានជម្ងឺ។ ម្នាលភិក្ខុទាំងឡាយ (សង្ឃ) ត្រូវឱ្យសម្មតិយ៉ាងនេះ។ ភិក្ខុដែលមានជម្ងឺនោះ ត្រូវចូលទៅកាន់ជំនុំសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើង ពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចម្រើន ឥឡូវខ្ញុំមានជម្ងឺ មិនអាចនឹងយកត្រៃចីវរចេញដើរទៅបានទេ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំនោះសូមសម្មតិ ដើម្បីនៅប្រាសចាកត្រៃចីវរនឹងសង្ឃ។ ភិក្ខុត្រូវសូមគំរប់ពីរដងផង សូមគំរប់បីដងផង។ ភិក្ខុអ្នកឆ្លាសអង់អាចត្រូវញ៉ាំងសង្ឃឱ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន

សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ (ញ្ញ័ត្ត) ភិក្ខុនេះ ឈ្មោះនេះ មានជម្ងឺមិនអាចនឹងយកត្រៃចីវរចេញដើរទៅបានទេ។ ភិក្ខុនោះ មកសូមសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរនឹងជំនុំសង្ឃ។ បើកម្មមានកាលល្មមសមគួរដល់សង្ឃហើយ សង្ឃត្រូវឱ្យសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរដល់ភិក្ខុឈ្មោះនេះចុះ។ វាចានេះ (ជាពាក្យផ្ដើម) ញ៉ាំងសង្ឃឱ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជម្ងឺ មិនអាចនឹងយកត្រៃចីវរចេញដើរទៅបាន។ ភិក្ខុនោះសូមសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរនឹងសង្ឃ។ សង្ឃឱ្យនូវសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរដល់ភិក្ខុ ឈ្មោះនេះ។ ការឱ្យនូវសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុអង្គនោះស្ងៀម (បើ)មិនគួរដល់លោកដ៏មានអាយុអង្គណា សូមឱ្យលោកដ៏មានអាយុអង្គនោះនិយាយឡើង។ ការសម្មតិដើម្បីនៅប្រាសចាកត្រៃចីវរ សង្ឃបានឱ្យដល់ភិក្ខុឈ្មោះនេះហើយ។ ការឱ្យសម្មតិគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម។ ខ្ញុំចាំទុកនូវហេតុនេះដោយកិរិយាស្ងៀមយ៉ាងនេះ (ទុកជាការស្រេច)។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ

កឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ។

[១២] ត្រង់ពាក្យថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ អធិប្បាយថា ចីវរដែលភិក្ខុបានធ្វើរួចជាស្រេចហើយក្ដី ចីវរបាត់ក្ដី ចីវរដែលខូចក្ដី ចីវរភ្លើងឆេះក្ដី បំណងក្នុងចីវរដាច់ស្រឡះក្ដី។ ពាក្យថា កឋិនដោះហើយ អធិប្បាយថា កឋិនដោះហើយ បណ្ដាមាតិកាទាំង៨យ៉ាង ដោយ មាតិកាណាមួយ ម្យ៉ាងទៀត កឋិនដែលសង្ឃបានដោះក្នុងចន្លោះ។ ពាក្យថា បើភិក្ខុនៅប្រាសចាកត្រៃចីវរ សូម្បីតែមួយយប់ អធិប្បាយថា បើភិក្ខុនៅប្រាសចាកសង្ឃាដិក្ដី ឧត្តរាសង្គក្ដី ស្បង់ក្ដី សូម្បីតែមួយយប់។ ពាក្យថា វៀរលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ អធិប្បាយថា លើកលែងតែភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ។ ពាក្យថា និស្សគ្គិយ អធិប្បាយថា ចីវរជានិស្សគ្គិយដំណាលនឹងពេលដែលអរុណរះឡើង ភិក្ខុនោះឯងត្រូវលះ (ចីវរនោះ) ដល់សង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះ ភិក្ខុត្រូវលះបង់យ៉ាងនេះ។ ភិក្ខុ នោះត្រូវចូលទៅកាន់ជំនុំសង្ឃ។បេ។ ហើយពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះ ខ្ញុំនៅប្រាសឃ្លាតមួយរាត្រីហើយ ជានិស្សគ្គិយ ព្រោះឥតមានភិក្ខុសម្មតិទេ ខ្ញុំសូមលះចីវរនេះដល់សង្ឃ។បេ។ (ត្រង់បេយ្យាលទាំងបី មានអធិប្បាយត្រង់សិក្ខាបទទី១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ)។

[១៣] ស្រុកមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ផ្ទះមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ឃ្លាំងមានឧបចារតែមួយ មានឧបចារផ្សេងគ្នា បញ្ចាមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ឃ្លាំងមានឧបចារតែមួយ មានឧបចារផ្សេងគ្នា បញ្ចាមានឧបចារតែមួយ មានឧបចារផ្សេងគ្នា រោងមានជ្រុងបួនមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ប្រាសាទមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ប្រាសាទមានដំបូលត្រងិលមានឧបចារតែមួយ មានឧបចារផ្សេងគ្នា នាវាមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ពួកឈ្មួញរទេះមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ស្រែមានឧបចារតែមួយ មានឧបចារផ្សេងគ្នា លានស្រូវមានឧបចារតែមួយ មានឧបចារផ្សេងគ្នា សួនច្បារមានឧបចារតែមួយ មានឧបចារផ្សេងគ្នា វិហារមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ទីជិតដើមឈើមានឧបចារតែមួយ មានឧបចារផ្សេងគ្នា ទីវាលមានឧបចារតែមួយ មានឧបចារផ្សេងគ្នា។

[១៤] ស្រុកដែលឈ្មោះថាមានឧបចារតែមួយ (នោះសំដៅយក) ស្រុករបស់ត្រកូលតែមួយ ដែលគេរាំងព័ទ្ធ (របង) ជុំវិញ ភិក្ខុត្រូវទុកចីវរក្នុងខាងក្នុងស្រុក ហើយនៅក្នុងខាងក្នុងស្រុក។ ស្រុកដែលគេមិនបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ម្យ៉ាងទៀតមិនត្រូវលះហត្ថបាសឡើយ។ ស្រុកដែលឈ្មោះថា មានឧបចារផ្សេងគ្នា គឺស្រុករបស់ត្រកូលផ្សេងគ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ឬនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។ កាលបើភិក្ខុទៅក្នុងរោងជាទីប្រជុំ ត្រូវទុកចីវរក្នុងហត្ថបាស ហើយនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ។ បើភិក្ខុទុកចីវរក្នុងរោងជាទីប្រជុំ ត្រូវឱ្យនៅក្នុងរោងជាទីប្រជុំ ឬទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។ បើស្រុកដែលគេមិនបានរាំងព័ទ្ធទេ ភិក្ខុទុកចីវរក្នុងផ្ទះណា ត្រូវនៅក្នុងផ្ទះនោះ ហើយមិនត្រូវ លះហត្ថបាសឡើយ។

[១៥] បើផ្ទះរបស់ត្រកូលតែមួយ ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុត្រូវទុកចីវរខាងក្នុងផ្ទះ ហើយត្រូវនៅខាងក្នុងផ្ទះ។ ផ្ទះដែលគេមិនបានរាំងព័ទ្ធជុំវិញទេ (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាស ឡើយ។ ម្យ៉ាងទៀត ផ្ទះរបស់ត្រកូលផ្សេងៗគ្នា ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅ

ក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។ ផ្ទះដែលគេមិនបានរាំងព័ទ្ធជុំវិញទេ (ភិក្ខុ) ទុកចីវរ ក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ។

[១៦] ឃ្លាំងរបស់ត្រកូលតែមួយ ដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា (ភិក្ខុ) ត្រូវទុកចីវរខាងក្នុងឃ្លាំង ហើយត្រូវនៅខាងក្នុងឃ្លាំង។ ឃ្លាំងដែលគេមិនបានរាំងព័ទ្ធជុំវិញទេ (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ។ ម្យ៉ាងទៀត ឃ្លាំងរបស់ត្រកូលផ្សេងៗគ្នាដែលគេបានរាំងព័ទ្ធជុំវិញ មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា (ភិក្ខុ) ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។ ឃ្លាំងដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ហើយមិនត្រូវលះហត្ថបាសឡើយ។

[១៧] បញ្ចាររបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងបញ្ចារហើយ ត្រូវនៅខាងក្នុងបញ្ចារ។ បញ្ចាររបស់ត្រកូលផ្សេងៗគ្នា មានល្វែងក៏ផ្សេងៗគ្នា មានបន្ទប់ក៏ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។

[១៨] ប្រាសាទមានជ្រុង៤របស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទមានជ្រុង៤ ហើយត្រូវនៅខាងក្នុងប្រាសាទមានជ្រុង៤។ ប្រាសាទមានជ្រុង៤របស់ត្រកូលផ្សេងៗគ្នា មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារមួយទៀតមិនត្រូវលះហត្ថបាសឡើយ។

[១៩] ប្រាសាទវែងរបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទវែង ហើយត្រូវនៅខាងក្នុងប្រាសាទវែង។ ប្រាសាទវែងរបស់ត្រកូលផ្សេងគ្នា មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា (ភិក្ខុ)ទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។

[២០] ប្រាសាទមានដំបូលត្រងិលរបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងប្រាសាទត្រងិល ហើយត្រូវនៅខាងក្នុងប្រាសាទត្រងិល។ ប្រាសាទមានដំបូលត្រងិលរបស់ត្រកូលផ្សេងៗគ្នា មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងល្វែងណា ត្រូវនៅក្នុងល្វែងនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។

[២១] នាវារបស់ត្រកូលតែមួយ ភិក្ខុទុកចីវរខាងក្នុងនាវា ហើយត្រូវនៅខាងក្នុងនាវា។ នាវារបស់ត្រកូលផ្សេងៗគ្នា មានល្វែងផ្សេងៗគ្នា មានបន្ទប់ផ្សេងៗគ្នា ភិក្ខុទុកចីវរក្នុងបន្ទប់ណា ត្រូវនៅក្នុងបន្ទប់នោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។

[២២] ពួកឈ្មួញរទេះរបស់ត្រកូលតែមួយ ភិក្ខុផ្ញើចីវរទុកនឹងពួកឈ្មួញរទេះ (នោះ) ទោះបីដើរ ខាងមុខរទេះក្តី ខាងក្រោយរទេះក្តី មិនត្រូវលះបង់ចម្ងាយ៧អព្ភន្តរ[4] ឡើយ (ដើរឱ្យល្មមតែ) ក្រឡេក មើលទៅឃើញ (រទេះ) ទើបមិនត្រូវលះបង់អព្ភន្តរ។ ពួកឈ្មួញរទេះរបស់ត្រកូលផ្សេងគ្នា ភិក្ខុផ្ញើចីវរទុកនឹងពួកឈ្មួញរទេះហើយ មិនត្រូវលះហត្ថបាសឡើយ។

[២៣] ស្រែរបស់ត្រកូលតែមួយ គេបានបិទរាំងជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃស្រែ (នោះ) ត្រូវនៅក្នុងខាងក្នុងនៃស្រែ (នោះ)។ (បើ)ស្រែគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ។ បើស្រែរបស់ត្រកូលផ្សេងៗគ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃស្រែ (នោះ) ហើយត្រូវនៅខាងក្នុងនៃស្រែ (នោះ) ឬ (ត្រូវនៅ) ទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ។ (បើស្រែ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ។

[២៤] លានស្រូវរបស់ត្រកូលតែមួយ គេរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃលានហើយ ត្រូវនៅក្នុងខាងក្នុងនៃលាននោះ។ (បើលានស្រូវ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ។ លានស្រូវរបស់ត្រកូលផ្សេងៗគ្នា គេបិទរាំងជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងនៃលានហើយ ត្រូវនៅទៀបទ្វារ មិនត្រូវលះហត្ថបាសឡើយ។ (បើលានស្រូវ) គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវ លះហត្ថបាសឡើយ។

[២៥] សួនច្បាររបស់ត្រកូលតែមួយ គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងសួនច្បារហើយ ត្រូវនៅខាងក្នុងនៃសួនច្បារ។ សួនច្បារ គេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ។ សួនច្បាររបស់ត្រកូលផ្សេងៗគ្នា គេបានរាំងជុំវិញ ភិក្ខុទុកចីវរក្នុងខាងក្នុងសួនច្បារហើយ ត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។ សួនច្បារគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុមិនត្រូវលះហត្ថបាសឡើយ។

[២៦] លំនៅរបស់ត្រកូលតែមួយ គេបានរាំងព័ទ្ធជុំវិញ ភិក្ខុ ទុកចីវរក្នុងខាងក្នុងលំនៅហើយ ត្រូវនៅខាងក្នុងលំនៅ។ លំនៅដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅក្នុងលំនៅនោះ ហើយមិនត្រូវលះហត្ថបាសឡើយ។ លំនៅរបស់ត្រកូលផ្សេងៗគ្នា គេបានរាំងព័ទ្ធជុំវិញ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅក្នុងលំនៅនោះ ឬត្រូវនៅទៀបទ្វារ ហើយមិនត្រូវលះហត្ថបាសឡើយ។ លំនៅដែលគេមិនបានរាំងព័ទ្ធជុំវិញទេ ភិក្ខុទុកចីវរក្នុងលំនៅណា ត្រូវនៅ ក្នុងលំនៅនោះ ហើយមិនត្រូវលះហត្ថបាសឡើយ។

[២៧] ម្លប់ឈើរបស់ត្រកូលតែមួយ ក្នុងពេលថ្ងៃត្រង់ម្លប់ឈើនោះផ្សាយទៅជុំវិញត្រឹមណា ភិក្ខុទុកចីវរក្នុងខាងក្នុងម្លប់ ហើយត្រូវនៅត្រឹមតែខាងក្នុងម្លប់ (នោះ)។ ម្លប់ឈើរបស់ត្រកូលផ្សេងៗគ្នា ភិក្ខុមិនត្រូវលះហត្ថបាសឡើយ។

[២៨] ដែលហៅថា ទីវាលមានឧបចារតែមួយ មានឧបចារផ្សេងៗគ្នា គឺទីក្នុងព្រៃដែលឥតមានស្រុក ចំនួន៧អព្ភន្តរដោយជុំវិញ (ទីវាលនោះ) ហៅថាមានឧបចារតែមួយ លំដាប់តអំពីអព្ភន្តរនោះទៅ ហៅថាមានឧបចារផ្សេងៗគ្នា។

[២៩] ភិក្ខុមានសេចក្តីដឹងច្បាស់ថាចីវរដែលខ្លួននៅប្រាស ត្រង់ចីវរដែលខ្លួននៅប្រាសហើយ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។ ភិក្ខុមានសេចក្តីសង្ស័យ ត្រង់ចីវរដែលខ្លួននៅប្រាស ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។ ភិក្ខុសំគាល់ថា ចីវរ គឺខ្លួនមិន

បាននៅប្រាសទេ ត្រង់ចីវរដែលខ្លួននៅប្រាសហើយ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។ ភិក្ខុសំគាល់ថា ចីវរ គឺខ្លួនបានដកអធិដ្ឋានហើយ ត្រង់ចីវរដែលខ្លួនមិនបានដកអធិដ្ឋានទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។ ភិក្ខុសំគាល់ថា ចីវរ គឺខ្លួន បានលះបង់ហើយ ត្រង់ចីវរដែលខ្លួនមិនបានលះបង់ទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។ ភិក្ខុសំគាល់ថា ចីវរបាត់ ត្រង់ចីវរដែលមិនមែនបាត់ទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។ ភិក្ខុសំគាល់ថា ចីវរវិនាស ត្រង់ចីវរដែលមិនមែនវិនាសទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។ ភិក្ខុសំគាល់ថា ចីវរភ្លើងឆេះ ត្រង់ចីវរដែលភ្លើងមិនមែនឆេះទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។ ភិក្ខុសំគាល់ថា ចីវរចោរប្លន់យក ត្រង់ចីវរដែលចោរមិនមែនប្លន់យកទេ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែបានភិក្ខុសម្មតិ។

[៣០] ភិក្ខុមិនបានលះចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ថា ចីវរ គឺខ្លួននៅប្រាសហើយ ត្រង់ចីវរ ដែលខ្លួនមិនមែននៅប្រាសទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងចីវរដែលមិនបាននៅប្រាស ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ថា ចីវរ គឺខ្លួនមិនមែននៅប្រាសទេ ត្រង់ចីវរដែលខ្លួនមិនមែននៅប្រាសពិត មិនត្រូវអាបត្តិឡើយ។

[៣១] ហេតុដែលមិនត្រូវអាបត្តិនោះគឺ ភិក្ខុបានដកអធិដ្ឋានក្នុងខាងក្នុងនៃអរុណ១ ភិក្ខុបានលះចីវរ១ ចីវរបាត់១ ចីវរវិនាស១ ចីវរភ្លើងឆេះ១ ចីវរចោរដណ្តើមយក១ អ្នកដទៃយកដោយស្និទ្ធស្នាល១ ភិក្ខុដែលបានអវិប្បវាសសម្មតិអំពីសង្ឃ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី២ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៣

CS vin.vbu.ni.03 | ភាគ ទី៣

### (៣. តតិយកឋិនសិក្ខាបទំ)

[៣២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅនាវត្តព្រះជេតពន ជាអារាមរបស់អនាថបិណ្ឌិកមហាសេដ្ឋី ជិតក្រុងសាវត្ថី។ កាលនោះឯង អកាលចីវរ[5] កើតឡើងដល់ភិក្ខុ១រូបមានឈ្មោះមិនប្រាកដ លុះភិក្ខុនោះធ្វើចីវរនោះមិនល្មមគ្រាន់។ គ្រានោះ ភិក្ខុនោះ ក៏លើកចីវរនោះឡើង ហើយទាញឱ្យតឹង ធ្វើឱ្យយឺតសាច់សំពត់នោះរឿយៗ។ ព្រះដ៏មានព្រះភាគបានយាងទៅកាន់សេនាសនចារិក ទ្រង់ទតទៅឃើញភិក្ខុនោះកំពុងតែលើកចីវរឡើងទាញរឿយៗ លុះទ្រង់ទតឃើញហើយ ទ្រង់យាងចូលទៅជិត ហើយត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានជាអ្នកលើកចីវរឡើង ហើយទាញរឿយៗនោះ តើព្រោះហេតុអ្វី។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន នេះជាអកាលចីវរកើតមានដល់ខ្ញុំព្រះអង្គៗ ធ្វើទៅមិនគ្រាន់ ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គលើកចីវរនេះឡើងហើយទាញរឿយៗ ដើម្បីឱ្យយឺតសាច់។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមានបំណងនឹងរកចីវរថែមទៀតដែរឬទេ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មានបំណងដែរ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងកាលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឱ្យអ្នកទាំងឡាយទទួលនូវអកាលចីវរ ហើយទុកដាក់បាន ព្រោះមានសង្ឃឹមថា នឹងបានចីវរថែមទៀត។

[៣៣] សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគបានអនុញ្ញាតឱ្យទទួលអកាលចីវរទុកដាក់បាន ព្រោះមានសង្ឃឹមថានឹងបានចីវរថែមទៀត ហើយក៏ទទួលអកាលចីវរទុកដាក់ឱ្យលើសជាង១ខែឡើងទៅ។ ចីវរទាំងនោះក៏ជាប់គ្នាដូចជាបង្វេចនៅលើឈើស្បៀង។ ព្រះអានន្ទដ៏មានអាយុនិមន្តទៅកាន់សេនាសនចារិក ជួនជាក្រឡេកមើលទៅឃើញ ចីវរទាំងឡាយនោះជាប់គ្នាដូចជាបង្វេចនៅលើឈើស្បៀង លុះឃើញហើយក៏ហៅភិក្ខុទាំងឡាយ (នោះ) មកសួរថា ម្នាលអាវុសោទាំងឡាយ នេះចីវររបស់លោកណាក៏ជាប់គ្នាដូចជាបង្វេចនៅលើឈើស្បៀង (ដូច្នេះ)។ ភិក្ខុទាំងឡាយប្រាប់ថា ម្នាលអាវុសោ នេះអកាលចីវររបស់យើង យើងទុក

ដោយមានបំណងនឹងរកចីវរថែមទៀត។ ព្រះអានន្ទសួរថា ម្នាលអាវុសោទាំងឡាយ ចុះចីវរទាំងនេះ លោកទុកយូរប៉ុន្មានថ្ងៃហើយ។ ភិក្ខុទាំងឡាយប្រាប់ថា ចីវរទាំងនេះយើងទុកជាង១ខែហើយ។ ព្រះអានន្ទដ៏មានអាយុ ក៏បន្ទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ ពួកភិក្ខុហ៊ានទទួលអកាលចីវរយកមកទុកឱ្យលើសជាង១ខែឡើងទៅសោះ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបទូលសេចក្តីនុះដល់ព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឱ្យប្រជុំភិក្ខុសង្ឃក្នុងកាលនោះ ហើយត្រាស់សួរទៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុបានទទួលអកាលចីវរទុកឱ្យលើសជាង១ខែ មែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរ ពួកមោឃបុរសទាំងនោះហ៊ានទទួលអកាលចីវរ ហើយទុកឱ្យលើសជាង១ខែ (ដូច្នេះ) ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកទាំង ឡាយធ្វើនេះ នឹងបានដឹកនាំមនុស្សដែលមិនទាន់បានជ្រះថ្លាឱ្យជ្រះថ្លាឡើង ឬនាំមនុស្សដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងទៀតក៏ទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ កឋិនដោះហើយ បើអកាលចីវរកើតឡើងចំពោះភិក្ខុ ទាំងភិក្ខុសោតក៏ត្រូវការ (អកាលចីវរនោះ) ត្រូវទទួលចុះ លុះទទួលរួចហើយ ត្រូវរវៀសរវៃធ្វើឱ្យឆាប់ បើចីវរនោះខ្វះធ្វើមិនគ្រប់ទេ ភិក្ខុនោះមានបំណងថានឹងរកចីវរមកបំពេញនូវចីវរដែលខ្វះ (នោះ) ត្រូវទុកចីវរនោះបានយ៉ាងយូរបំផុតត្រឹម១ខែ បើទុកឱ្យលើសពី១ខែនោះទៅ បើទុកជាមានបំណងថានឹងរកចីវរមកបំពេញទៀតក៏ដោយ គង់ត្រូវនិស្សគ្គិយបាចិត្តិយ។

[៣៤] ត្រង់ពាក្យថា កាលបើចីវររបស់ភិក្ខុសម្រេចហើយ អធិប្បាយថា ចីវរដែលភិក្ខុធ្វើរួចហើយក្តី ចីវរបាត់ក្តី ចីវរខូចក្តី ចីវរភ្លើងឆេះក្តី សេចក្តីចង់បានចីវរដាច់ស្រឡះហើយក្តី។ ពាក្យថា កឋិនដោះហើយ អធិប្បាយថា កឋិនដែលដោះហើយ បណ្តាមាតិកាទាំង៨យ៉ាង ដោយមាតិកាណាមួយ ឬពុំនោះ ជំនុំសង្ឃបានដោះហើយក្នុងចន្លោះ (ខេត្តកឋិន)។ (បើ) ភិក្ខុមិនបានក្រាលគ្រងកឋិនទេ ចីវរដែលកើតឡើងក្នុងឱកាស១១ខែ ហៅថា អកាលចីវរ (បើ) ភិក្ខុបានក្រាលគ្រងកឋិន ចីវរដែលកើតឡើងក្នុងឱកាស៧ខែ ហៅថា អកាលចីវរ បើទុកជា គេពោលថាជាកាលចីវរ

ហើយក៏ដោយ គង់ហៅថា អកាលចីវរដូចគ្នា។ ពាក្យថា កើតឡើង អធិប្បាយថា គប្បីកើតឡើងអំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្តក្តី អំពីបំសុកូលក្តី អំពីទ្រព្យរបស់ខ្លួនក្តី។

[៣៥] ពាក្យថា ត្រូវការ អធិប្បាយថា កាលបើចង់បាន ត្រូវទទួលចុះ។ ពាក្យថា លុះទទួលរួចហើយត្រូវរៀសរវៃធ្វើឱ្យឆាប់ អធិប្បាយថា ត្រូវធ្វើឱ្យទាន់ក្នុងរវាង១០ថ្ងៃ។

[៣៦] ពាក្យថា បើចីវរនោះខ្វះ ធ្វើមិនគ្រាន់ទេ អធិប្បាយថា ចីវរដែលភិក្ខុធ្វើទៅហើយមិនគ្រាន់។ ពាក្យថា ភិក្ខុនោះត្រូវទុកចីវរនោះបានយ៉ាងយូរបំផុតត្រឹម១ខែ អធិប្បាយថា ភិក្ខុត្រូវទុក (ចីវរ) ជាយូរបំផុតត្រឹមតែ១ខែ។ ពាក្យថា ដើម្បីនឹងបំពេញនូវចីវរដែលខ្វះ អធិប្បាយថា ដើម្បីសេចក្តីត្រូវការនឹងបំពេញនូវចីវរដែលខ្វះ។ ពាក្យថា បើទុកជាមានបំណង អធិប្បាយថា មានសេចក្តីសង្ឃឹមថានឹងបានអំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្តក្តី អំពីបង្សុកូលក្តី អំពីទ្រព្យរបស់ខ្លួនក្តី។

[៣៧] ពាក្យថា បើទុកឱ្យលើសពី១ខែនោះទៅ ទុកជា មានបំណងថានឹងរកចីវរមកបំពេញទៀតក៏ដោយ អធិប្បាយថា កាលបើមូលចីវរ[6] កើតឡើងក្នុងថ្ងៃនោះហើយ បច្ចាសាចីវរ[7] ក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង១០ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន ២ថ្ងៃ... ៣ថ្ងៃ... ៤ថ្ងៃ... ៥ថ្ងៃ... ៦ថ្ងៃ... ៧ថ្ងៃ... ៨ថ្ងៃ... ៩ថ្ងៃ... ១០ថ្ងៃ... បច្ចាសាចីវរ ក៏កើតឡើងក្នុងថ្ងៃទី ១០ ភិក្ខុគប្បីធ្វើចីវរឱ្យហើយ ក្នុងរវាង១០ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន ១១ថ្ងៃ... ១២ថ្ងៃ... ១៣ថ្ងៃ... ១៤ថ្ងៃ... ១៥ថ្ងៃ... ១៦ថ្ងៃ... ១៧ថ្ងៃ ... ១៨ថ្ងៃ ... ១៩ថ្ងៃ ... ២០ថ្ងៃ ... បច្ចាសាចីវរ ក៏កើតឡើងក្នុងថ្ងៃទី២០ ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង១០ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន ២១ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង៩ថ្ងៃ។ កាលបើ មូលចីវរកើតឡើងបាន២២ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ ក្នុងរវាង៨ថ្ងៃ។ កាលបើមូលចីវរ កើតឡើងបាន២៣ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង៧ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន២៤ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង៦ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន២៥ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង៥ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន ២៦ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង៤ថ្ងៃ។ កាលបើ មូលចីវរកើតឡើងបាន២៧ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង៣ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន២៨ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង២ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន២៩ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុត្រូវធ្វើឱ្យទាន់ក្នុងរវាង១ថ្ងៃ។ កាលបើមូលចីវរកើតឡើងបាន៣០ថ្ងៃ បច្ចាសាចីវរក៏កើតឡើង (ក្នុងថ្ងៃនោះដែរ) ភិក្ខុនោះត្រូវអធិដ្ឋាន ត្រូវវិកប្ប ត្រូវលះបង់ក្នុងថ្ងៃនោះឯង។ បើភិក្ខុ មិនបានអធិដ្ឋានក្តី មិនបានវិកប្បក្តី មិនបានលះបង់ក្តី តែអរុណរះឡើងក្នុងថ្ងៃទី៣១ (ចីវរនោះ) ត្រូវនិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះយ៉ាងនេះ។បេ។ ថាបពិត្រព្រះសង្ឃដ៏ចំរើន នេះជាអកាលចីវររបស់ខ្ញុំ ទុកកន្លងហួស១ខែ

ត្រូវនិស្សគ្គិយហើយ ឥឡូវនេះខ្ញុំសូមលះចីវរនេះដល់សង្ឃ។ (ត្រង់ បេយ្យាលទាំងបីមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ ក្នុងវគ្គជាមួយគ្នានេះ)។

[៣៨] កាលបើមូលចីវរដែលមានចំណែកមិនស្មើគ្នា[8] កើតឡើងហើយ បច្ចាសាចីវរក៏កើតឡើងដែរ តែរាត្រីសល់នៅច្រើន (បើ) ភិក្ខុមិនចង់ធ្វើទេ ក៏មិនត្រូវធ្វើ (ចីវរនោះឡើយ)។

[៣៩] ចីវរកន្លងទៅ១ខែហើយ ភិក្ខុសម្គាល់ថាកន្លងទៅមែន ត្រូវនិស្សគ្គិយបាចិត្តិយ។ ចីវរកន្លងទៅ១ខែហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវនិស្សគ្គិយបាចិត្តិយ។ ចីវរកន្លងទៅ១ខែហើយ ភិក្ខុសំគាល់ថា មិនទាន់កន្លងទេ ត្រូវនិស្សគ្គិយបាចិត្តិយ។ ចីវរដែលមិនបានអធិដ្ឋាន ភិក្ខុសំគាល់ថាបានអធិដ្ឋានហើយ (ក្តី) ចីវរដែលមិនបានវិកប្ប ភិក្ខុសំគាល់ថាបានវិកប្បហើយ (ក្តី) ចីវរដែលមិនបានលះបង់ ភិក្ខុសំគាល់ថាបានលះបង់ហើយ (ក្តី) ចីវរដែលមិនបាត់ ភិក្ខុសំគាល់ថាបាត់ (ក្តី) ចីវរដែលមិនខូចទេ ភិក្ខុសំគាល់ថាខូច (ក្តី) ចីវរភ្លើងមិនឆេះ ភិក្ខុ សំគាល់ថាភ្លើងឆេះ (ក្តី) ចីវរចោរឥតបានយកទេ ភិក្ខុសំគាល់ថា ចោរយក (ក្តី) ត្រូវនិស្សគ្គិយបាចិត្តិយ (ដូចគ្នាទាំងអស់)។

[៤០] ភិក្ខុមិនបានលះចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ ចីវរមិនទាន់កន្លងទៅ១ខែទេ ហើយភិក្ខុសំគាល់ថាកន្លងទៅហើយ ត្រូវអាបត្តិទុក្កដ។ ចីវរមិនទាន់កន្លងទៅ១ខែទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ចីវរមិនទាន់កន្លង១ខែទេ ភិក្ខុសំគាល់ថា មិនទាន់កន្លងមែន មិនត្រូវអាបត្តិឡើយ។

[៤១] វារៈសំដែងអំពីមិនមានអាបត្តិ គឺភិក្ខុបានអធិដ្ឋានចីវរនោះក្នុងរវាងមួយខែ១ បានវិកប្បចីវរ១ បានលះ១ ចីវរបាត់១ ចីវរខូច១ ចីវរភ្លើងឆេះ១ ចីវរដែលចោរដណ្តើមយកទៅ១ គេយកចីវរដោយសេចក្តីស្និទ្ធស្នាល១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី៣ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៤

CS vin.vbu.ni.04 | ភាគ ទី៣

### (៤. បុរាណចីវរសិក្ខាបទំ)

[៤២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានស្រីជាបុរាណទុតិយិការបស់ឧទាយិភិក្ខុដ៏មានអាយុ បួសក្នុងសំណាក់នាងភិក្ខុនី។ នាងភិក្ខុនីនោះតែងមកសំណាក់ឧទាយិភិក្ខុដ៏មានអាយុជារឿយៗ។ ចំណែកខាងឧទាយិភិក្ខុដ៏មានអាយុក៏តែងទៅកាន់សំណាក់ នាងភិក្ខុនីនោះជារឿយៗដែរ។ វេលានោះឯង ឧទាយិភិក្ខុដ៏មានអាយុបរិភោគភត្តិក្នុងសំណាក់នាងភិក្ខុនីនោះ។ លំដាប់នោះ ឧទាយិភិក្ខុដ៏មានអាយុ ក៏ស្លៀកដណ្តប់រួចក៏យកបាត្រនិងចីវរ ចូលសំដៅ ទៅរកទីដែល

នាងភិក្ខុនីនោះនៅក្នុងវេលាព្រឹកព្រហាម លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈខាងមុខនាងភិក្ខុនីនោះ បើកអង្គជាតបង្ហាញ។ ឯនាងភិក្ខុនីនោះក៏អង្គុយលើអាសនៈខាងមុខឧទាយិដ៏មានអាយុ បើកអង្គជាតបង្ហាញដែរ។ វេលានោះ ឧទាយិភិក្ខុដ៏មានអាយុមានតម្រេក ក៏សំឡឹងមើលទៅអង្គជាតនាងភិក្ខុនីនោះ។ ទឹកអសុចិក៏ហូរធ្លាក់ពីអង្គជាតរបស់ឧទាយិភិក្ខុនោះ។ លំដាប់នោះ ឧទាយិភិក្ខុដ៏មានអាយុក៏និយាយទៅនឹងភិក្ខុនីនោះថា នែប្អូនស្រី ឯងចូរទៅនាំយកទឹកមក អញនឹងលាងស្បង់។ នាងភិក្ខុនីនោះតបវិញថា លោកម្ចាស់ សូមលោកម្ចាស់ឱ្យស្បង់មកខ្ញុំវិញ ខ្ញុំនឹងលាងប្រគេន។ វេលានោះឯង នាងភិក្ខុនីនោះ ក៏បានយកទឹកអសុចិ របស់ឧទាយិភិក្ខុនោះបន្តិចដាក់ក្នុងមាត់ យកបន្តិចដាក់ក្នុងអង្គជាត។ នាងភិក្ខុនីនោះក៏មានគភ៌ដោយសារទឹកអសុចិនោះ។ ពួកនាងភិក្ខុនីក៏បាននិយាយយ៉ាងនេះថា នាងភិក្ខុនីនេះមិនមែនប្រព្រឹត្តធម៌ដ៏ប្រសើរទេ ទើបបាននាងភិក្ខុនីនេះមានគភ៌។ នាងភិក្ខុនីនោះតបវិញថា ម្នាលនាងទាំងឡាយ ខ្លួនខ្ញុំមិនបានប្រព្រឹត្តធម៌ដ៏ប្រសើរទេ។ វេលានោះ នាងភិក្ខុនីនោះបានប្រាប់ សេចក្តីនុ៎ះដល់នាងភិក្ខុនីផងគ្នា។ នាងភិក្ខុនីទាំងឡាយ ក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកម្ចាស់ឧទាយិប្រើនាងភិក្ខុនីឱ្យលាងចីវរចាស់ (របស់ខ្លួនសោះ)។ លំដាប់នោះ ពួកនាងភិក្ខុនីទាំងនោះបានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុណាដែលមានប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ឧទាយិដ៏មានអាយុ ប្រើនាងភិក្ខុនីឱ្យលាងចីវរចាស់។ គ្រានោះ ពួកភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មាន ព្រះភាគ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ។បេ។ ទ្រង់សួរឧទាយិភិក្ខុដ៏មានអាយុថា ម្នាលឧទាយិ ឮថាអ្នកបានប្រើនាងភិក្ខុនីឱ្យលាងចីវរចាស់ មែនឬ។ ឧទាយិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មែន។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលឧទាយិ នាងភិក្ខុនីនោះ ត្រូវជាញាតិ ឬមិនមែនជាញាតិនឹងអ្នកទេ។ ឧទាយិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស (នាងភិក្ខុនីនោះ) មិនត្រូវជាញាតិនឹងខ្ញុំព្រះអង្គទេ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា នែមោឃបុរស ជនមិនមែន ជាញាតិ មិនស្គាល់អំពើសមគួរ ឬមិនសមគួរ អំពើនាំមកនូវសេចក្តីជ្រះថ្លា ឬមិននាំមកនូវសេចក្តីជ្រះថ្លារបស់នាងភិក្ខុនីដែលមិនមែនជាញាតិ (នោះទេ) នែមោឃបុរស មិនសមបើអ្នកទៅប្រើនាងភិក្ខុនី ដែលមិនមែនជាញាតិ ឱ្យលាងចីវរចាស់សោះ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំពួកមនុស្សដែលមិនទាន់ជ្រះថ្លាឱ្យបានជ្រះថ្លាឡើង ឬមនុស្សដែលជ្រះថ្លាស្រាប់ហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងទៀត (នោះ) ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រើនាងភិក្ខុនីដែលមិនមែនជាញាតិឱ្យលាងក្តី ឱ្យជ្រលក់ក្តី ឱ្យគក់ឬបោកក្តី នូវចីវរចាស់ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។

[៤៣] ត្រង់ពាក្យថា ភិក្ខុណាមួយ (ត្រង់បេយ្យាលទាំងពីរ)មានអធិប្បាយត្រង់សិក្ខាបទទី១ ក្នុងបារាជិកកណ្ឌ រួចហើយ។ នាងភិក្ខុនី ដែលឥតមានជាប់ទងគន្លងអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាជាគំរប់៧ ហៅថាមិនមែនជាញាតិ។ ដែលហៅថា នាងភិក្ខុនី (នោះសំដៅយក) ស្រីដែលបានឧបសម្បទាក្នុងសំណាក់សង្ឃទាំងពីរ (ភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ)។ សម្ពត់ដែលភិក្ខុស្លៀកម្តងក្តី ដណ្តប់ម្តងក្តី ហៅថា ចីវរចាស់។ ភិក្ខុប្រើនាងភិក្ខុនីថា នាងចូរលាងចីវរឱ្យអាត្មា (យ៉ាងនេះ) ត្រូវអាបត្តិទុក្កដ។ ចីវរដែលនាងភិក្ខុនីលាងហើយនោះ ជានិស្សគ្គិយ។ ភិក្ខុបង្គាប់នាងភិក្ខុនីថា នាងចូរជ្រលក់ចីវរឱ្យអាត្មា ត្រូវអាបត្តិទុក្កដ។ ចីវរដែលនាងភិក្ខុនីជ្រលក់ហើយនោះ ជានិស្សគ្គិយ។ ភិក្ខុប្រើនាងភិក្ខុនីថា នាងចូរបោកចីវរឱ្យអាត្មា ត្រូវ អាបត្តិទុក្កដ។ កាលបើចីវរដែលនាងភិក្ខុនីយកមកបោកដោយដៃក្តី ដោយដំបងក្តី អស់វារៈតែម្តង ចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវលះចីវរនោះដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវ លះចីវរយ៉ាងនេះ។បេ។ ថា បពិត្រព្រះសង្ឃដ៏ចំរើន ចីវរចាស់នេះ ខ្ញុំបានប្រើនាងភិក្ខុនីមិនមែនជាញាតិឱ្យលាង ជានិស្សគ្គិយហើយ ខ្ញុំសូមលះចីវរនេះដល់ជំនុំសង្ឃ។ (ត្រង់បេយ្យាលទាំងបី មានអធិប្បាយត្រង់សិក្ខាបទទី១ ក្នុងវគ្គជាមួយគ្នារួចហើយ)។

[៤៤] នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឱ្យលាងនូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនជាញាតិ ហើយប្រើឱ្យលាង ឱ្យជ្រលក់នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនញាតិ ហើយប្រើឱ្យលាង ឱ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនញាតិ ហើយប្រើឱ្យលាង ឱ្យជ្រលក់ ឱ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនជាញាតិ ហើយប្រើឱ្យជ្រលក់ នូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនជាញាតិ ហើយប្រើឱ្យជ្រលក់ ឱ្យបោក នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនជាញាតិ ហើយប្រើឱ្យជ្រលក់ឱ្យលាងនូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនញាតិ ហើយប្រើឱ្យជ្រលក់ ឱ្យបោក ឱ្យលាង នូវចីវរចាស់ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយប្រើឱ្យបោកនូវចីវរចាស់ ត្រូវនិស្សគ្គិយបាចិត្តិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនញាតិ ហើយប្រើឱ្យបោក ឱ្យលាងនូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនជាញាតិ ហើយប្រើឱ្យបោក ឱ្យជ្រលក់ នូវចីវរចាស់ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនញាតិ ហើយប្រើឱ្យបោក ឱ្យលាង ឱ្យជ្រលក់នូវចីវរចាស់ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ។បេ។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនញាតិ។បេ។ ហើយប្រើឱ្យលាងនូវចីវរចាស់របស់ភិក្ខុឯទៀត ត្រូវអាបត្តិទុក្កដ។ ភិក្ខុប្រើ (នាងភិក្ខុនីមិនមែនជាញាតិ) ឱ្យលាងសម្ពត់និសីទនៈ និងគ្រឿងកម្រាល ត្រូវអាបត្តិទុក្កដ។ ភិក្ខុប្រើនាងភិក្ខុនីដែលជាឯកតោឧបសម្បន្នាឱ្យលាង ត្រូវអាបត្តិទុក្កដ។ នាងភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ ត្រូវអាបត្តិទុក្កដ។ នាងភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ នាងភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិឡើយ។

[៤៥] អាបត្តិ (មិនមានដល់ភិក្ខុមាន៨យ៉ាង) គឺនាងភិក្ខុនី ដែលជាញាតិរបស់ភិក្ខុកំពុងលាងចីវររបស់ភិក្ខុ ហើយស្រាប់តែមាននាងភិក្ខុនីទីពីរ ដែលមិនមែនជាញាតិ មកយកចីវរអំពីដៃនាងភិក្ខុនីនោះ ទៅលាងឱ្យ១ នាងភិក្ខុនីឃើញចីវររបស់ភិក្ខុមានមន្ទិលសៅហ្មង ហើយយកមកលាងឱ្យ មិនបាច់ចាំប្រើ១ ភិក្ខុប្រើនាងភិក្ខុនីឱ្យលាងចីវរថ្មីដែលមិនទាន់បានប្រើប្រាស់១ ភិក្ខុប្រើនាងភិក្ខុនីឱ្យលាងគ្រឿងបរិក្ខារឯទៀតក្រៅពីចីវរ១ ភិក្ខុប្រើនាងសិក្ខមានាឱ្យលាងចីវរឱ្យ១ ភិក្ខុប្រើសាមណេរីឱ្យលាងចីវរឱ្យ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី៤ ចប់។

# (និស្សគ្គិយ) សិក្ខាបទ ទី៥

CS vin.vbu.ni.05 | ភាគ ទី៣

## (៥. ចីវរបដិគ្គហណសិក្ខាបទំ)

[៤៦] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់គង់នៅវត្តវេឡុវនកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ គ្រានោះឯង នាងឧប្បលវណ្ណាភិក្ខុនីនៅក្នុងអន្ធវន ទៀបក្រុងសាវត្ថី។ វេលានោះឯង នាងឧប្បលវណ្ណាភិក្ខុនី លុះពេលព្រឹកឡើង ក៏បានស្លៀកដណ្តប់រួចនាំយកបាត្រ និងចីវរ ចូលទៅឯក្រុងសាវត្ថីដើម្បីបិណ្ឌបាត លុះដើរទៅបិណ្ឌបាតក្នុង ក្រុងសាវត្ថី រួចត្រឡប់មកអំពីបិណ្ឌបាតក្នុងកាលជាខាងក្រោយនៃភត្ត ហើយក៏ចូលសំដៅទៅក្នុងអន្ធវន (ព្រៃងងឹត) ដើម្បីសម្រាកក្នុងវេលាថ្ងៃ លុះចូលទៅដល់ព្រៃអន្ធវនហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃទៀបគល់ឈើនីមួយ។ សម័យនោះ មានពួកចោរអ្នកធ្វើនូវចោរកម្ម បានសម្លាប់មេគោ១ អារយកសាច់រួចនាំយកទៅកាន់ព្រៃអន្ធវន។ ឯមេចោរជាធំ បានក្រឡេកមើលទៅឃើញនាងឧប្បលវណ្ណាភិក្ខុនីកំពុងអង្គុយសម្រាកក្នុងវេលាថ្ងៃទៀបគល់ឈើនីមួយ។ លុះឃើញហើយ ចោរនោះក៏មានសេចក្តីត្រិះរិះថា បើប្រសិនណាពួកចោរជាកូន និងបងប្អូនអញឃើញ នាងភិក្ខុនីនេះហើយ មុខជាបៀតបៀននាងភិក្ខុនីនេះមិនខាន (លុះគិតយ៉ាងនេះហើយ) មេចោរក៏នាំពួកចោរទាំងនោះដើរទៅតាមផ្លូវដទៃវិញ វេលានោះឯង មេចោរនោះកាលបើដុំសាច់គេចំអិនរួចស្រេចហើយ ក៏យកសាច់យ៉ាងល្អ ខ្ចប់នឹងស្លឹកឈើយកទៅព្យួរនឹងដើមឈើជិតនាងឧប្បលវណ្ណាភិក្ខុនី ហើយពោលថា នរណាមួយ ទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី បានឃើញដុំសាច់ដែលអញទុកឱ្យនេះហើយ ចូរនាំយកទៅចុះ រួចហើយក៏ចេញដើរទៅ។ នាងឧប្បលវណ្ណាភិក្ខុនីចេញពីសមាធិ ហើយបានឮសំដីនេះរបស់មេចោរដែលកំពុងពោលនោះ។ លំដាប់នោះ នាងឧប្បលវណ្ណាភិក្ខុនីក៏បានយកសាច់នោះទៅឯកន្លែងនៅរបស់ខ្លួន។ វេលានោះឯង នាងឧប្បលវណ្ណាភិក្ខុនី លុះកន្លងរាត្រីនោះទៅហើយ នាងក៏ចាត់ចែងយកសាច់នោះមកវេចជាបង្វេចដោយចីពរ រួចហើយក៏ហោះទៅឯអាកាស ទៅចុះក្នុងវត្តវេឡុវន។

[៤៧] សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់យាង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត។ ឧទាយិភិក្ខុដ៏មានអាយុជាអ្នកនៅចាំរក្សាវត្ត។ លំដាប់នោះ នាងឧប្បលវណ្ណាភិក្ខុនី បានចូលទៅរកឧទាយិភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏សួរទៅឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់យាងទៅណា។ ឧទាយិប្រាប់ថា ម្នាលប្អូនស្រី ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅបិណ្ឌបាតឯស្រុកហើយ។ នាងឧប្បលវណ្ណាភិក្ខុនី និយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាថ្វាយសាច់នេះដល់ព្រះដ៏មានព្រះភាគឱ្យទានផង។ ឧទាយិនិយាយថា ម្នាលប្អូនស្រី នាងឱ្យព្រះដ៏មានព្រះភាគទ្រង់ឆ្អែតដោយសាច់ (យ៉ាងណា) ប្រសិនបើនាងឱ្យស្បង់ដល់អាត្មាៗក៏ឈ្មោះថា នាងឱ្យឆ្អែតដោយស្បង់ក៏យ៉ាងនោះដែរ។ នាងឧប្បលវណ្ណាភិក្ខុនីតបវិញថា បពិត្រលោកម្ចាស់ដ៏ចម្រើនយើងខ្ញុំជាមាតុគ្រាម មានលាភបានដោយកម្រណាស់។ មួយទៀតចីវររបស់ខ្ញុំនេះ ជាចីវរគំរប់៥ជាទីបំផុត ខ្ញុំមិនប្រគេនលោកម្ចាស់ទេ។ ឧទាយិនិយាយថា ម្នាលប្អូនស្រី ដូចជាបុរសដែលឱ្យដំរី (ទៅគេ) គួរលះខ្សែដង្កន់ផងយ៉ាងណាមិញ ម្នាលប្អូនស្រី បើនាងថ្វាយសាច់ដល់ព្រះដ៏មានព្រះភាគហើយ ចូរលះស្បង់របស់នាងដល់អាត្មា ក៏យ៉ាងនោះដែរ។ គ្រានោះ នាងឧប្បលវណ្ណាភិក្ខុនី កាលបើ ឧទាយិដ៏មានអាយុចេះតែទទូចសូម ក៏ប្រគេនស្បង់ហើយត្រឡប់ទៅឯលំនៅរបស់ខ្លួនវិញ។ ពួកនាងភិក្ខុនីកាលទទួលយកបាត្រនិងចីវរពីនាងឧប្បលវណ្ណាភិក្ខុនី ក៏សួរនាងឧប្បលវណ្ណាភិក្ខុនីថា បពិត្រនាងជាម្ចាស់ ស្បង់របស់នាងតើនៅឯណា។ នាងឧប្បលវណ្ណាភិក្ខុនីក៏បានប្រាប់សេចក្តីនុ៎ះ ដល់នាងភិក្ខុនីទាំងឡាយ។ នាងភិក្ខុនីទាំងឡាយក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧទាយិ មិនសមបើនឹងទទួលយកចីវរពីដៃនាងភិក្ខុនីសោះ មាតុគ្រាមសុទ្ធតែមានលាភបានដោយកម្រ។ គ្រានោះ នាងភិក្ខុនីទាំងនោះក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុណាដែលមានប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុ មិនគួរបើនឹងទទួលយកចីវរពីដៃនាងភិក្ខុនីសោះ។ ទើបភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧទាយិ បានឮថា អ្នកឯងបាន ទទួលចីវរពីដៃនាងភិក្ខុនី មែនឬ។ឧទាយិភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មែន។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលឧទាយិ នាងភិក្ខុនីនោះត្រូវជាញាតិនឹងអ្នកឯង ឬមិនមែនជាញាតិទេ។ ឧទាយិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស (នាងភិក្ខុនីនោះ) មិនមែនជាញាតិទេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលមោឃបុរស បុរសដែលមិនមែនជាញាតិ មិនស្គាល់អំពើគួរ ឬមិនគួរ ល្អិតល្អ ឬមិនល្អិតល្អ របស់ស្ត្រី ដែលមិនមែនជាញាតិ (នោះ) ទេ ម្នាលមោឃបុរស អ្នកឯងហេតុអ្វីក៏ទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលមិនមែនជាញាតិ (ដូច្នេះ) ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ នឹងបានដឹកនាំមនុស្សដែលមិនទាន់ជ្រះថ្លា ឱ្យបានជ្រះថ្លាឡើង ឬមនុស្សដែលជ្រះថ្លាហើយ ឱ្យកាន់តែជ្រះថ្លាឡើងក៏ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយទទួលយកចីវរអំពីដៃនាង ភិក្ខុនីដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយ យ៉ាងនេះ។

[៤៨] សម័យនោះឯង មានពួកភិក្ខុសង្ស័យ មិនហ៊ានទទួលយកចីវរដែលត្រូវការផ្លាស់ប្តូររបស់នាងភិក្ខុនីទាំងឡាយ។ នាងភិក្ខុនីទាំងឡាយក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនគួរបើនឹងមិនទទួលយកចីវរដែលត្រូវការផ្លាស់ប្តូររបស់យើងសោះ។ កាលពួកនាងភិក្ខុនីទាំងនោះកំពុងលើកទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ វេលានោះ ភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឱ្យអ្នកទាំងឡាយទទួលយកចីវរដែលត្រូវការផ្លាស់ប្តូរគ្នារបស់សហធម្មិកបុគ្គល៥ពួកគឺ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ

សាមណេរី ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យអ្នកទាំងឡាយ ទទួលយកចីវរដែលត្រូវការផ្លាស់ប្តូរគ្នានឹងពួកសហធម្មិកទាំង៥ នេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយទទួលយកចីវរអំពីដៃនាងភិក្ខុនី ដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា។

[៤៩] ត្រង់ពាក្យថា ភិក្ខុណាមួយ (ត្រង់បេយ្យាលទាំងពីរ មានអធិប្បាយក្នុងបឋមបារាជិកសិក្ខាបទរួចហើយ)។ នាងភិក្ខុនីដែលឥតមានជាប់ទងគន្លងអំពីចំណែកខាងមាតាក្តី ចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាជាគំរប់៧ ហៅថាមិនមែនជាញាតិ។ ស្រីដែលបាន ឧបសម្បទា

អំពីសំណាក់ឧភតោសង្ឃ ហៅថានាងភិក្ខុនី។ បណ្ដាចីវរទាំង៦ ចីវរណាមួយ ដែលតូចបំផុតគួរល្មមភិក្ខុនឹងវិកប្បបាន ហៅថា ចីវរ។ ពាក្យថា វៀរលែងតែផ្លាស់ប្ដូរគ្នា សេចក្ដីថា លើកលែងតែចីវរដែលផ្លាស់ប្ដូរគ្នា។ ភិក្ខុទទួលយកចីវរ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលទទួល ចីវរនោះ ជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះចីវរនោះដល់ជំនុំសង្ឃ ឬគណៈ ឬបុគ្គល ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះចីវរយ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន

ចីវរនេះដែលខ្ញុំបានទទួលយកអំពីដៃនាងភិក្ខុនី ដែលមិនមែនជាញាតិ ជានិស្សគ្គិយហើយ វៀរលែងតែផ្លាស់ប្ដូរគ្នា ឥឡូវខ្ញុំសូមលះចីវរនេះដល់ជំនុំសង្ឃ។ (ត្រង់បេយ្យាលទាំងបី មានអធិប្បាយត្រង់សិក្ខាបទទី១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ)។

[៥០] នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនជាញាតិ ទទួលយកចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្ដូរគ្នា។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុមានសេចក្ដីសង្ស័យ ទទួលយកចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្ដូរគ្នា។ នាងភិក្ខុនីមិនមែនជាញាតិ ភិក្ខុសម្គាល់ថាជាញាតិ ទទួលចីវរអំពីដៃ ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែផ្លាស់ប្ដូរគ្នា។

[៥១] ភិក្ខុទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលបានឧបសម្បទាអំពីសំណាក់ឯកតោសង្ឃ (គឺអំពីចំណែកខាងភិក្ខុនីសង្ឃតែម្យ៉ាង) ត្រូវអាបត្តិទុក្កដ វៀរលែងតែផ្លាស់ប្ដូរគ្នា។ នាងភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ។ នាងភិក្ខុនីជាញាតិ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ នាងភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិឡើយ។

[៥២] អាបត្តិមិនមានដល់ភិក្ខុក្នុងសិក្ខាបទនោះមាន៨យ៉ាងគឺ ភិក្ខុទទួលយកចីវរអំពីដៃនាងភិក្ខុនីដែលជាញាតិ១ ភិក្ខុទទួលយកចីវរ ដោយការផ្លាស់ប្ដូរគ្នា១ ភិក្ខុទទួលយកចីវរមានដម្លៃច្រើន ដោយចីវរមានដម្លៃតិច ឬភិក្ខុទទួលយកចីវរមានដម្លៃតិចដោយចីវរមានដម្លៃច្រើន១ ភិក្ខុយកចីវរដោយសេចក្ដីស្និទ្ធស្នាល គឺយកដោយអាងសេចក្ដីទុកចិត្តគ្នា១ ភិក្ខុយកចីវរជារបស់ខ្ចីគ្នា១ ភិក្ខុទទួលយកគ្រឿងបរិក្ខារឯទៀតរបស់សិក្ខមានា និងសាមណេរី លើកលែងតែចីវរចេញ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី៥ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៦

CS vin.vbu.ni.06 | ភាគ ទី៣

### (៦. អញ្ញាតកវិញ្ញត្តិសិក្ខាបទំ)

[៥៣] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ ក៏សម័យនោះឯង ភិក្ខុឈ្មោះឧបនន្ទដ៏មានអាយុ ជាសក្យបុត្ត ជាអ្នកឈ្លាសវៃក្នុងការសម្ដែងធម៌។ គ្រានោះ កូនសេដ្ឋីម្នាក់មាននាម និងគោត្រមិនប្រាកដ ចូលទៅឯកន្លែងដែលឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្តលោកគង់នៅ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត ហើយអង្គុយក្នុងទីសមគួរ។ ឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្តបានញុំាងសេដ្ឋីបុត្តនោះដែលអង្គុយក្នុងទីសមគួរ ឱ្យឃើញច្បាស់លាស់ ឱ្យកាន់យកល្អ ឱ្យកើតសេចក្ដីប្រឹងប្រែងឡើង ឱ្យរីករាយស្រួល ដោយធម្មីកថា។ គ្រានោះ សេដ្ឋីបុត្តនោះ កាលបើព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត ឱ្យឃើញច្បាស់លាស់ ឱ្យកាន់យកល្អ ឱ្យក្លាហានឡើងព្រម ឱ្យរីករាយស្រួល ដោយធម្មីកថាហើយ ក៏បានបវារណាពាក្យនេះនឹងឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្តថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការដោយបច្ច័យណា ដែលយើងខ្ញុំអាចប្រគេនដល់លោកម្ចាស់បាន ដូចជាចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យ ជាភេសជ្ជបរិក្ខារ លោកម្ចាស់ត្រូវប្រាប់បច្ច័យទាំងនោះមកចុះ។ ព្រះឧបនន្ទថា នែអ្នកដ៏មានអាយុ បើអ្នកប្រាថ្នានឹងប្រគេនអាត្មា ចូរអ្នកប្រគេនសាដកមួយអំពីពួកសាដកដែល អ្នកកំពុងប្រើអស់នេះចុះ។ សេដ្ឋីបុត្តនិយាយថា ទានប្រោសយើងខ្ញុំជាកូនអ្នកមានត្រកូល នឹងមានតែសាដកមួយដើរទៅ ហាក់ដូចជាមិនសម (មុខគួរឱ្យអៀនខ្មាស) ទានប្រោស សូមលោកម្ចាស់បង្អង់ចាំសិន ទំរាំខ្ញុំទៅផ្ទះ ខ្ញុំដល់ទៅផ្ទះហើយ នឹងបញ្ជូននូវសាដកមួយអំពីពួកសាដកដែលខ្ញុំកំពុងប្រើអស់នេះ ឬសាដកដែលល្អគ្រាន់ជាងសាដកអស់នេះមកប្រគេនលោកម្ចាស់។ ឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្ត បាននិយាយពាក្យនេះនឹងសេដ្ឋីបុត្តនោះអស់វារៈពីរដងថា នែអ្នកដ៏មានអាយុ បើអ្នកមានប្រាថ្នានឹងប្រគេនអាត្មា ចូរអ្នកប្រគេនសាដកមួយអំពីពួកសាដកដែលអ្នកកំពុងប្រើអស់នេះ ចុះ។ សេដ្ឋីបុត្តនិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំជាកុលបុត្ត មានតែសាដកមួយដើរទៅ ហាក់ដូចជាមិនសម (គួរឱ្យអៀនខ្លួនណាស់) ទានប្រោស លោកម្ចាស់សូមបង្អង់ចាំសិន ទំរាំខ្ញុំទៅផ្ទះ ខ្ញុំដល់ទៅផ្ទះហើយ នឹងបញ្ជូនសាដកមួយ អំពីសាដកអស់នេះ ឬសាដកដែលល្អគ្រាន់បើជាងសាដកអស់នេះ មកប្រគេនលោកម្ចាស់។ ឧបនន្ទភិក្ខុដ៏មានអាយុជាសក្យបុត្ត បានពោលពាក្យនេះនឹងសេដ្ឋីបុត្តនោះ អស់វារៈបីដងថា នែអ្នកដ៏មានអាយុ បើអ្នកចង់ប្រគេនអាត្មា ចូរអ្នកប្រគេនសាដកមួយអំពីសាដកអស់នេះចុះ។ សេដ្ឋីបុត្តនិយាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងខ្ញុំជាកុលបុត្ត មានសាដកតែមួយដើរទៅ ហាក់ដូចជាមិនសម ទានប្រោស លោកម្ចាស់សូមបង្អង់ចាំសិន ទំរាំខ្ញុំទៅផ្ទះ ខ្ញុំទៅដល់ផ្ទះហើយ នឹងបញ្ជូនសាដកមួយអំពីសាដកដែលខ្ញុំកំពុងប្រើអស់នេះ ឬសាដកដែលល្អ គ្រាន់បើជាងសាដកអស់នេះមកប្រគេនលោកម្ចាស់។ ឧបនន្ទភិក្ខុនិយាយថា នែអ្នកដ៏មានអាយុ អាត្មាមានប្រយោជន៍អ្វី ដោយអ្នកដែលមិនចង់ប្រគេនសោះ ហើយបវារណា (ព្រោះ) អ្នកបវារណានូវបច្ច័យណាហើយ មិនឱ្យបច្ច័យនោះ។ សេដ្ឋីបុត្តនោះ កាលឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្តបង្ខិតបង្ខំ (ញយៗ) ក៏ប្រគេនសំពត់សាដកមួយហើយ ទៅក្នុងកាលនោះឯង។ មនុស្សទាំងឡាយឃើញសេដ្ឋីបុត្តនោះហើយ បាននិយាពាក្យនេះថា អ្នកម្ចាស់ ព្រោះហេតុអ្វីបានជាអ្នកមានសាដកតែមួយដើរមកដូច្នេះ។ គ្រានោះ សេដ្ឋីបុត្តបានប្រាប់ដំណើរនោះ ដល់មនុស្សទាំងឡាយនោះ។ មនុស្សទាំងឡាយក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធ ជាសក្យបុត្តនេះមានប្រាថ្នាច្រើន ឥតមានសន្ដោស សមណៈពួកនេះ គេមិនងាយនឹងនិមន្តដោយធម៌បានទេ កាលបើសេដ្ឋីបុត្តនិមន្តដោយធម៌ មិនសមបីបើនឹងទទួលយកសាដកសោះ។ ភិក្ខុទាំងឡាយបានឮពាក្យ មនុស្សទាំងនោះលើកទោសតិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាដែលមានប្រាថ្នាតិច ជាអ្នកសន្ដោស។បេ។ ភិក្ខុទាំងនោះ ក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តមិនសមបីបើនឹងសុំចីវរពីសេដ្ឋីបុត្តសោះ។ ទើបភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូល ដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ទ្រង់ត្រាស់សួរថា នែឧបនន្ទ ឮថា

អ្នកសុំចីវរពីសេដ្ឋីបុត្ត មែនឬ។ ព្រះឧបនន្ទទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន។ ព្រះអង្គត្រាស់សួរថា នែឧបនន្ទ គេត្រូវជាញាតិរបស់អ្នក ឬមិនមែនជាញាតិទេ។ ព្រះឧបនន្ទទូលថា បពិត្រព្រះដ៏មានព្រះភាគ គេមិនមែនជាញាតិទេ។ ទ្រង់ត្រាស់ថា នែមោឃបុរស មនុស្សមិនមែនជាញាតិ មិនដឹងការគួរ ឬមិនគួរ ល្អិតល្អ ឬមិនល្អិតល្អរបស់មនុស្សដែលមិនមែនជាញាតិនឹងគ្នា (នោះ) ទេ នែមោឃបុរស មិនគួរបើអ្នកឯងសុំចីវរពីសេដ្ឋីបុត្តដែលមិនមែនជាញាតិ (ដូច្នេះ) សោះ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់មនុស្សដែលនៅមិនទាន់ជ្រះថ្លាទេ មិនមែននាំមនុស្សដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសុំចីវរចំពោះគហបតីក្តី គហបតានីក្តី ដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ។

[៥៤] សម័យនោះឯង ពួកភិក្ខុជាច្រើនចេញអំពីក្រុងសាកេត ដើរតាមផ្លូវឆ្ងាយទៅកាន់ក្រុងសាវត្ថី។ ពួកចោរចេញមកដណ្តើម (យកបាត្រនិងចីវរ) របស់ភិក្ខុទាំងនោះក្នុងពាក់កណ្តាលផ្លូវ។ លំដាប់នោះ ភិក្ខុអម្បាលនោះរង្កៀសក្នុងចិត្តថា ការសុំចីវរចំពោះគហបតីក្តី គហបតានីក្តី ដែលមិនមែនជាញាតិ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហើយមិនហ៊ានសុំចីវរ ក៏ដើរទាំងអាក្រាត ឆ្ពោះទៅកាន់ក្រុងសាវត្ថី ហើយថ្វាយបង្គំភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក៏ពោលពាក្យយ៉ាងនេះថា នែអាវុសោទាំងឡាយ អាជីវកអស់នេះល្អ ចេះសំពះភិក្ខុទាំងឡាយដែរ។ ភិក្ខុ អាក្រាតទាំងនោះនិយាយថា ម្នាលអាវុសោ យើងមិនមែនអាជីវកទេ យើងក៏ភិក្ខុដែរ។ ពួកភិក្ខុក៏និយាយពាក្យនេះនឹងព្រះឧបាលិដ៏មានអាយុថា នែឧបាលិដ៏មានអាយុ និមន្តលោកសង្កេតសួរមនុស្សអាក្រាតអស់នេះមើល។ ភិក្ខុអាក្រាតទាំងឡាយនេះ លុះព្រះឧបាលិដ៏មានអាយុសង្កេតសួរ ក៏បានប្រាប់ដំណើរនុ៎ះ (ដោយសព្វគ្រប់)។ ព្រះឧបាលិដ៏មានអាយុ លុះបានសង្កេតសួរភិក្ខុ (អាក្រាត) ទាំងនោះហើយ ក៏ពោលពាក្យនេះនឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងនេះជាភិក្ខុហើយ លោកទាំងឡាយចូរឱ្យចីវរដល់ភិក្ខុ (អាក្រាត) ទាំងនោះផងចុះ។ ភិក្ខុទាំងឡាយណាដែលមានប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏លើកទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបីបើនឹងមានខ្លួនអាក្រាតដើរមកសោះ គួរតែភិក្ខុទាំងនោះបិទបាំង (រាងកាយ) ដោយស្មៅ ឬស្លឹកឈើហើយសឹមមកទៅអេះ។ ទើបភិក្ខុទាំងឡាយនោះ ក្រាបទូលដំណើរនុ៎ះ ដល់ព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគក៏ទ្រង់សម្តែងធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលចោរដណ្តើមយកចីវរទៅក្តី ដែលមានចីវរបាត់ក្តី សុំចីវរចំពោះគហបតី ឬគហបតានី ដែលមិនមែនជាញាតិបាន ភិក្ខុ (ដែលមានចីវរអន្តរាយ)នោះ ចូលដល់អាវាសណាមុន បើចីវរក្នុងវត្តក្តី សម្ពត់កម្រាលគ្រែក្តី សម្ពត់កម្រាលផែនដីក្តី ស្រោមពូកក្តី របស់សង្ឃមានក្នុងអាវាសនោះ ឱ្យយកសម្ពត់នោះស្លៀកដណ្តប់ដោយគិតថា អញបានសម្ពត់នោះ (ស្លៀកដណ្តប់សិន) ហើយនឹងទុកវិញ បើចីវរក្នុងវត្តក្តី សំពត់សម្រាប់ក្រាលគ្រែក្តី សំពត់សម្រាប់ក្រាលផែនដីក្តី ស្រោមពូកក្តី របស់សង្ឃមិនមានទេ ភិក្ខុនោះ ត្រូវបិទបាំង (រាងកាយ) ដោយស្មៅ ឬស្លឹកឈើហើយសឹមមក មិនត្រូវដើរមកទាំងអាក្រាតឡើយ ភិក្ខុឯណាមក (ទាំងអាក្រាត) ភិក្ខុនោះ ត្រូវ អាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សុំចីវរចំពោះគហបតី ឬគហបតានីដែលមិនមែនជាញាតិ (ភិក្ខុនោះ) ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះ គឺភិក្ខុមានចីវរដែលចោរដណ្តើមយកទៅ ឬភិក្ខុមានចីវរខូច នេះជាសម័យក្នុងសិក្ខាបទនោះ។

[៥៥] ត្រង់ពាក្យថា ភិក្ខុណាមួយ (ត្រង់បេយ្យាលទាំងពីរ មានអធិប្បាយដូចសេចក្តីក្នុងបឋមបារាជិកសិក្ខាបទ)។ ជនដែលឥតមានជាប់ទងគន្លងអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាទី៧ ហៅថា មិនមែនជាញាតិ។ បុរសណាមួយនៅគ្រប់គ្រងផ្ទះ (បុរសនោះ) ហៅថា គហបតី (ប្រុសមេផ្ទះ)។ ស្រីណាមួយនៅគ្រប់គ្រងផ្ទះ (ស្រីនោះ) ហៅថាគហបតានី (ស្រីមេផ្ទះ)។ ដែលហៅថា ចីវរ (នោះ) គឺបណ្តាចីវរទាំង៦យ៉ាង តាមតែចីវរណាមួយក៏ដោយ ដែលមានខ្នាតបើយ៉ាងតូចណាស់ត្រឹមល្មមវិកប្បបាន។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកនូវសម័យចេញ។ ចីវររបស់ភិក្ខុដែលស្តេចទាំងឡាយរឹបយកទៅក្តី ចោរទាំងឡាយដណ្តើម យកទៅក្តី អ្នកលេងទាំងឡាយដណ្តើមយកទៅក្តី អ្នកណាមួយដណ្តើមយកទៅក្តី (ភិក្ខុនោះ) ហៅថា មានចីវរគេដណ្តើមយកហើយ។ ចីវររបស់ភិក្ខុដែលភ្លើងឆេះក្តី ដែលទឹកបន្សាត់ទៅក្តី ដែលកណ្តុរកាត់ ឬកណ្តៀរកោរកាត់ក្តី ដែលចាស់ព្រោះប្រើប្រាស់ក្តី (ភិក្ខុនោះ) ហៅថា មានចីវរខូចហើយ។ ឥតមានសម័យទេ ភិក្ខុសុំ (ចីវរ) ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសុំចីវរ (នោះ) ជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះចីវរនោះដល់សង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះចីវរ យ៉ាងនេះ។បេ។ ថា បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះខ្ញុំសុំចំពោះគហបតីមិនមែនជាញាតិដោយឥតមានសម័យទេ ជានិស្សគ្គិយហើយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ។ (ត្រង់បេយ្យាលទាំងបី មានអធិប្បាយក្នុងសិក្ខាបទទី១ ក្នុងវគ្គជាមួយគ្នានេះរួចហើយ)។

[៥៦] គហបតិមិនមែនញាតិ ភិក្ខុដឹងច្បាស់ថា មិនមែនញាតិ ហើយសុំចីវរ ដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយសុំចីវរដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនញាតិ សុំចីវរដោយឥតមានសម័យទេ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិជាញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ ត្រូវអាបត្តិទុក្កដ។ គហបតិជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ គហបតិជាញាតិ ភិក្ខុដឹងច្បាស់ថាជាញាតិ មិនមានអាបត្តិឡើយ។

[៥៧] អាបត្តិមិនមានដល់ភិក្ខុកាលសុំចីវរក្នុងសម័យគួរ ក្នុងសំណាក់ជនទាំងឡាយជាញាតិ ក្នុងសំណាក់ជនទាំងឡាយដែលបវារណាហើយ សុំឱ្យអ្នកដទៃ (ដូរ) ដោយទ្រព្យខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិកៈ។

សិក្ខាបទ ទី៦ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៧

CS vin.vbu.ni.07 | ភាគ ទី៣

### (៧. តតុត្តរិសិក្ខាបទំ)

[៥៨] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ (ភិក្ខុមានពួក៦) ចូលទៅរកពួកភិក្ខុដែលមានចីវរចោរដណ្តើមយកទៅ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតដល់ភិក្ខុមានចីវរ ដែលចោរដណ្តើមយកទៅក្តី ដែលមានចីវរវិនាសទៅក្តី ឱ្យសុំចីវរនឹងគហបតិ ឬគហបតានី ដែលមិនមែនជាញាតិបាន ម្នាលអាវុសោ អ្នកទាំងឡាយចូរសុំចីវរទៅ។ ពួកភិក្ខុដែលចោរដណ្តើមចីវរនោះឆ្លើយថា ណ្ហើយអាវុសោ យើងបានចីវរហើយ។ ពួកឆព្វគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ យើងនឹងសុំចីវរឱ្យលោកដ៏មានអាយុទាំងឡាយ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលអាវុសោ អ្នកទាំងឡាយចូរសុំចុះ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុចូលទៅរកពួកគហបតិដែលមិនមែនជាញាតិ ហើយបានពោលពាក្យនេះថា ម្នាលអាវុសោ ភិក្ខុទាំងឡាយដែលមានចីវរចោរដណ្តើមយកទៅ ឥឡូវនេះលោកនិមន្តមក អ្នកទាំងឡាយចូរប្រគេនចីវរដល់លោកទាំងនោះផងចុះ ហើយក៏សុំចីវរមានចំនួនច្រើន។ ក៏ក្នុងសម័យនោះឯងមានបុរសម្នាក់អង្គុយក្នុងរោងសម្រាប់ប្រជុំ បានពោលពាក្យនេះនឹងបុរសម្នាក់ថា លោកម្ចាស់ទាំងឡាយដែលមានចីវរចោរដណ្តើមយកទៅ ឥឡូវលោកនិមន្តមក ខ្ញុំបានប្រគេនចីវរដល់លោកម្ចាស់ទាំងនោះហើយ។ បុរស នោះឯងពោលយ៉ាងនេះថា ខ្ញុំក៏បានប្រគេនចីវរដែរ។ បុរសឯទៀតនិយាយយ៉ាងនេះថា ខ្ញុំក៏បានប្រគេនដែរ។ ជនទាំងឡាយអម្បាលនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្ត មិនសមបើនឹងមិនដឹងប្រមាណ ហើយសុំចីវរមានចំនួនច្រើន (យ៉ាងនេះសោះ) ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្តនឹងធ្វើជំនួញសំពត់ ឬថា នឹងតាំងរានផ្សារលក់សម្ពត់ (ទេដឹង)។ ពួកភិក្ខុបានឮពាក្យមនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាមានប្រាថ្នាតិច ជាអ្នកសន្តោស។បេ។ ភិក្ខុអម្បាលនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយមិនសមបើនឹងមិនដឹងប្រមាណ ហើយសុំចីវរមានចំនួនច្រើន (យ៉ាងនេះ) សោះ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយមិនដឹងប្រមាណ ហើយសុំចីវរមានចំនួនច្រើន មែនឬ។ បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់ តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងមិនដឹងប្រមាណ សុំចីវរមានចំនួនច្រើន នែមោឃបុរសទាំងឡាយ អំពើនេះ មិនមែននាំឱ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាហើយ ឬមិនមែននាំឱ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលជ្រះថ្លាហើយទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា បើគហបតិក្តី គហបតានីក្តី បវារណាដល់ភិក្ខុនោះ ដើម្បីឱ្យកាន់យកតាមត្រូវការដោយចីវរដ៏ច្រើន ភិក្ខុនោះគប្បីត្រេកអរចំពោះចីវរនោះតែត្រឹមអន្តរវាសក និងឧត្តរាសង្គ បើភិក្ខុត្រេកអរឱ្យលើសជាងកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ។

[៥៩] ត្រង់ពាក្យថា ដល់ភិក្ខុនោះ គឺភិក្ខុមានចីវរដែលចោរដណ្តើមយកទៅ។ ជនដែលមិនជាប់អំពីចំណែកមាតាក្តី អំពីចំណែកបិតាក្តី ដរាបដល់គូនៃជីដូនជីតាជាគំរប់៧ ហៅថា មិនមែនញាតិ។ មនុស្សប្រុសណាមួយនៅគ្រប់គ្រងផ្ទះ មនុស្សប្រុសនោះហៅថា គហបតិ។ មនុស្សស្រីណាមួយនៅគ្រប់គ្រងផ្ទះ មនុស្សស្រីនោះហៅថា គហបតានី។ ពាក្យថា ចីវរច្រើន គឺជាចីវរមានប្រមាណច្រើន។ ពាក្យថា នាំមកបវារណា គឺគ្រហស្ថពោលថា លោកម្ចាស់ត្រូវការចីវរប៉ុន្មានចូរទទួលយកប៉ុណ្ណោះចុះ។ ពាក្យថា ភិក្ខុនោះគប្បីត្រេកអរនឹងចីវរ ចំពោះចីវរដែលគេនាំមកនោះ កំណត់ត្រឹមអន្តរវាសក និងឧត្តរាសង្គ គឺថា បើចីវរទាំងបីវិនាសទៅហើយ ភិក្ខុគប្បីត្រេកអរត្រឹមតែចីវរពីរ (បើ) ចីវរពីរវិនាសទៅ ភិក្ខុគប្បីត្រេកអរត្រឹមតែចីវរមួយ (បើ) ចីវរវិនាសទៅតែមួយ ភិក្ខុកុំគប្បីត្រេកអរ (នឹងចីវរឯទៀត) ឡើយ។ ពាក្យថា បើភិក្ខុត្រេកអរឱ្យលើសជាងកំណត់នោះ គឺភិក្ខុសុំចីវរលើសជាងកំណត់នោះ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសុំ។ ចីវរដែលបានមកជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ចីវរនោះដល់សង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះ ភិក្ខុគប្បីលះបង់យ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះ ខ្ញុំសូមពីគហបតិមិនមែនជាញាតិឱ្យលើសពីកំណត់នោះ ជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ។បេ។ គប្បីឱ្យ។បេ។ គប្បីឱ្យ។បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[៦០] គហបតិមិនមែនជាញាតិ ភិក្ខុសម្គាល់ថាមិនមែនជាញាតិ ហើយសូមចីវរឱ្យលើសជាងកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយសូមចីវរឱ្យលើសពីកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនជាញាតិ ភិក្ខុសម្គាល់ថាជាញាតិ ហើយសូមចីវរឱ្យលើសពីកំណត់នោះ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិជាញាតិ ភិក្ខុសម្គាល់ថាមិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ។ គហបតិជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ គហបតិជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិ។

[៦១] អាបត្តិមិនមានដល់ភិក្ខុដែលនាំចីវរទៅដោយមិនគិតថា អញនឹងនាំចីវរដែលសល់មក ដល់ភិក្ខុដែលទាយកប្រគេនដោយពាក្យថា ចីវរដែលសល់ ចូរមានដល់លោកចុះ ដល់ភិក្ខុដែលទាយកប្រគេន ដោយឥតមានហេតុ គឺចោរដណ្តើមយកចីវរ ដល់ភិក្ខុដែលទាយកប្រគេន ដែលឥតមានហេតុ គឺចីវរបាត់ ដល់ភិក្ខុត្រេកអរនឹងចីវររបស់ញាតិទាំងឡាយ ដល់ភិក្ខុត្រេកអរនឹងចីវររបស់ជនដែលគេបវារណាឱ្យ ដល់ភិក្ខុត្រេកអរនឹងចីវរដែលបានដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៧ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៨

CS vin.vbu.ni.08 | ភាគ ទី៣

### (៨. ឧបក្ខដសិក្ខាបទំ)

[៦២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ ក៏ក្នុងសម័យនោះ បុរសម្នាក់បាននិយាយពាក្យនេះនឹងប្រពន្ធថា អញនឹងឱ្យលោកម្ចាស់ឧបនន្ទស្លៀកដណ្តប់ចីវរ។ កាលដែលបុរសនោះកំពុងនិយាយពាក្យយ៉ាងនេះ ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាតមួយអង្គបានឮ (ពាក្យនោះច្បាស់)។ ទើបភិក្ខុនោះចូលទៅរកព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត លុះចូលទៅដល់ ហើយ ក៏និយាយពាក្យនេះនឹងព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យច្រើន (ព្រោះ) ក្នុងឱកាសឯណោះមានបុរសម្នាក់និយាយពាក្យនេះនឹងប្រពន្ធថា អញនឹងឱ្យលោកម្ចាស់ឧបនន្ទស្លៀកដណ្តប់ចីវរ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បុរសនោះជាឧបដ្ឋាកខ្ញុំ។ ព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្ត ចូលទៅរកបុរសនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងបុរសនោះថា ម្នាលអ្នកដ៏មានអាយុ ឮថាអ្នកមានប្រាថ្នានឹងឱ្យអាត្មាស្លៀកដណ្តប់ចីវរ មែនឬ។ បុរសនោះនិយាយថា មែន លោកម្ចាស់ ខ្ញុំគិតយ៉ាងនេះថា អញនឹងឱ្យ

លោកម្ចាស់ឧបនន្ទស្លៀកដណ្តប់ចីវរ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បើអ្នកមានប្រាថ្នាឱ្យអាត្មាស្លៀកដណ្តប់ចីវរ ចូរឱ្យអាត្មាស្លៀកដណ្តប់ចីវរបែបយ៉ាងនេះចុះ (ព្រោះថា) បើអាត្មាមិនប្រើប្រាស់ចីវរណា អាត្មានឹងធ្វើខ្លួនឱ្យជាអ្នកស្លៀកដណ្តប់នូវចីវរនោះ ដូចម្តេចបាន។ ឯបុរសនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាកូនចៅព្រះពុទ្ធជាសក្យបុត្តអស់នេះ មានសេចក្តីប្រាថ្នាច្រើន មិនមានសន្តោស ពួកសមណៈអស់នេះ ទាយកមិនងាយនឹងឱ្យស្លៀកដណ្តប់ចីវរទេ មិនសមបើលោកម្ចាស់ឧបនន្ទដែលអញមិនទាន់បវារណាមុន ហើយមកកំណត់ចីវរ (យ៉ាងនេះ) ឡើយ។ ភិក្ខុទាំងឡាយបានឮពាក្យបុរសនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុទាំងឡាយណា មានប្រាថ្នាតិចជាអ្នកសន្តោស។បេ។ ភិក្ខុអម្បាលនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្ត គេមិនទាន់បវារណាមុន ហើយចូលទៅរកគហបតិ ហើយកំណត់ចីវរ (យ៉ាងនេះ) ទេ។ គ្រានោះ ភិក្ខុអម្បាលនោះ ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯង គេមិនបានបវារណាមុន ហើយចូលទៅរកគហបតិ ហើយកំណត់ចីវរ មែនឬ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ម្នាលឧបនន្ទ គ្រហស្ថនោះជាញាតិរបស់អ្នក ឬមិនមែនជាញាតិទេ។ បពិត្រព្រះដ៏មានព្រះភាគ គ្រហស្ថនោះ មិនមែនជាញាតិទេ។ ទ្រង់ត្រាស់ថា ម្នាលមោឃបុរស ជនមិនមែនជាញាតិ រមែងមិនដឹងការសមគួរក្តី មិនសមគួរក្តី ការល្អិតល្អក្តី មិនល្អិតល្អក្តី របស់ជនដែលមិនមែនជាញាតិទេ ម្នាលមោឃបុរស អ្នកឯង ដែលគេមិនបានបវារណាមុន ហើយចូលទៅរកគហបតិមិនមែនជាញាតិ ហើយកំណត់ចីវរដូចម្តេចបាន ម្នាលមោឃបុរសអំពើនេះ មិនមែននាំឱ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬមិនមែននាំឱ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាហើយទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ដម្លៃចីវរដែលគហបតិក្តី គហបតានីក្តី មិនមែនជាញាតិចំពោះភិក្ខុ ហើយតាំងទុកថា ខ្ញុំនឹងទិញចីវរដោយដម្លៃចីវរនេះ ហើយនឹងឱ្យភិក្ខុឈ្មោះនេះ ស្លៀកដណ្តប់ចីវរ។ បើភិក្ខុនោះ ដែលគេមិនបានបវារណាមុន ហើយចូលទៅក្នុងទីនោះ ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ ហើយកំណត់ចីវរដោយពាក្យថា ល្អហើយអ្នកដ៏មានអាយុ អ្នកចូរទិញចីវរមានបែបយ៉ាងនេះក្តីៗ ដោយដម្លៃចីវរនេះ ហើយឱ្យអាត្មាស្លៀកដណ្តប់ចុះ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។

[៦៣] ត្រង់ពាក្យថា ចំពោះភិក្ខុ គឺដើម្បីប្រយោជន៍ដល់ភិក្ខុ ធ្វើភិក្ខុឱ្យជាអារម្មណ៍ មានប្រាថ្នាឱ្យភិក្ខុស្លៀកដណ្តប់ចីវរ។ ជនដែលមិនជាប់អំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាទី៧ ហៅថា មិនមែនជាញាតិ។ បុរសណាមួយនៅគ្រប់គ្រងផ្ទះ បុរសនោះហៅថា គហបតិ។ ស្រីណាមួយនៅគ្រប់គ្រងផ្ទះ ស្រីនោះហៅថា គហបតានី។ ប្រាក់ក្តី មាសក្តី កែវមណីក្តី កែវមុក្តាក្តី កែវមក៌តក្តី កែវផលិកក្តី សម្ពត់ ឬសក្លាតក្តី អម្បោះក្តី កប្បាសក្តី ហៅថាតម្លៃចីវរ។ ពាក្យថា ដោយដម្លៃចីវរនេះ គឺដោយដម្លៃចីវរដែលតាំងឡើងចំពោះ។ ពាក្យថា ទិញ គឺប្តូរគ្នា។ ពាក្យថា អញនឹងឱ្យស្លៀកដណ្តប់ គឺថា អញនឹងប្រគេន។ ពាក្យថា បើភិក្ខុនោះ គឺដម្លៃចីវរដែលទាយកតម្កល់ទុកចំពោះភិក្ខុណា គឺភិក្ខុនោះឯង។ ពាក្យថា គេមិនបានបវារណាមុន គឺគេមិនទាន់និយាយមុនថា បពិត្រលោកដ៏ចម្រើន លោកត្រូវការដោយចីវរដូចម្តេច ខ្ញុំនឹងទិញចីវរដូចម្តេចប្រគេនលោក។ ពាក្យថា ចូលទៅ គឺទៅកាន់ផ្ទះ(គេ) ឬចូលទៅរកគេក្នុងទីណាមួយ។ ពាក្យថា កំណត់ចីវរ គឺចីវរវែងក្តី ធំក្តី សាច់ជិតក្តី សាច់ម៉ត់ក្តី។ ពាក្យថា ដោយដម្លៃចីវរនេះ គឺដោយដម្លៃចីវរដែលតាំងឡើងចំពោះ។ ពាក្យថា បែបយ៉ាងនេះក្តីៗ គឺចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ត់ក្តី។ ពាក្យថា ទិញ គឺប្តូរគ្នា។ ពាក្យថា ចូរឱ្យស្លៀកដណ្តប់ គឺចូរឱ្យ។ ពាក្យថា ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ គឺជាអ្នកត្រូវការចីវរល្អ ជាអ្នកត្រូវការចីវរមានដម្លៃច្រើន។ ទាយកទិញចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ ម៉ត់ក្តី តាមសម្តីភិក្ខុនោះ ភិក្ខុនោះត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលប្រើ ចីវរនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះដល់សង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ចីវរ ភិក្ខុត្រូវលះយ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរខ្ញុំនេះ គេមិនបានបវារណាមុន ខ្ញុំចូលទៅរកគហបតិមិនមែនជាញាតិ ហើយកំណត់ចីវរ ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ។បេ។ សង្ឃគប្បីឱ្យ។បេ។ ភិក្ខុទាំងឡាយគប្បីឱ្យ។បេ។ ខ្ញុំឱ្យចីវរដល់លោកដ៏មានអាយុ។

[៦៤] គហបតិមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតិ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិនបានបវារណាមុន ចូលទៅរកគហបតិ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនញាតិ ភិក្ខុសំគាល់ថាជាញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតិ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិជាញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ ត្រូវ អាបត្តិទុក្កដ។ គហបតិជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ គហបតិជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិ។

[៦៥] អាបត្តិ មិនមានដល់ភិក្ខុដែលកំណត់ចីវរក្នុងសំណាក់ជនជាញាតិ ជនដែលបានបវារណាហើយ ដល់ភិក្ខុដែលកំណត់ចីវរដើម្បីប្រយោជន៍ភិក្ខុដទៃ ដល់ភិក្ខុដែលកំណត់ចីវរដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលទាយកមានប្រាថ្នានឹងទិញចីវរមានដម្លៃច្រើនប្រគេន ឱ្យទិញចីវរមានដម្លៃតិចវិញ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៨ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៩

CS vin.vbu.ni.09 | ភាគ ទី៣

### (៩. ទុតិយឧបក្ខដសិក្ខាបទំ)

[៦៦] សម័យនោះព្រះពុទ្ធដ៏មានជោគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ ក៏ក្នុងសម័យនោះឯង បុរសម្នាក់បាននិយាយពាក្យនេះនឹងបុរសម្នាក់ថា ខ្ញុំនឹងឱ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរ។ ឯបុរសនោះបានពោលយ៉ាងនេះថា ខ្ញុំឯងក៏នឹងឱ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរដែរ។ ភិក្ខុមួយរូបជាអ្នកប្រព្រឹត្តបិណ្ឌបាត បានឮពាក្យចរចារគ្នានៃបុរសទាំងឡាយនោះ។ ភិក្ខុនោះក៏ចូលទៅរកព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្ត លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្តថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យច្រើន (ព្រោះ) ក្នុងឱកាសឯណោះ មានបុរសម្នាក់បាននិយាយពាក្យនេះនឹងបុរសម្នាក់ថា ខ្ញុំនឹងឱ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរ ឯបុរសនោះក៏និយាយយ៉ាងនេះថា ខ្ញុំឯងក៏នឹងឱ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរដែរ។ ព្រះឧបនន្ទ

បាននិយាយថា ម្នាលអាវុសោ បុរសទាំងនោះជាឧបដ្ឋាករបស់ខ្ញុំ។ លំដាប់នោះ ព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តចូលទៅរកបុរសទាំងនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងបុរសទាំងនោះថា ម្នាលអាវុសោ ឮថាអ្នកទាំងឡាយចង់ឱ្យអាត្មាស្លៀកដណ្តប់ចីវរ មែនឬ។ បុរសទាំងនោះឆ្លើយថា មែនលោកម្ចាស់ យើងទាំងឡាយបានគិតយ៉ាងនេះថា យើងខ្ញុំនឹងឱ្យព្រះឧបនន្ទជាម្ចាស់ស្លៀកដណ្តប់ចីវរទាំងឡាយ។ ព្រះឧបនន្ទនិយាយថា ម្នាលអាវុសោ បើអ្នកទាំងឡាយចង់ឱ្យអាត្មាស្លៀកដណ្តប់ចីវរទាំងឡាយ អ្នកទាំងឡាយចូរឱ្យអាត្មាស្លៀកដណ្តប់ដោយចីវរបែបយ៉ាងនេះចុះ បើអាត្មាមិនត្រូវប្រើប្រាស់ចីវរទាំងឡាយណា អាត្មានឹងស្លៀកដណ្តប់ចីវរទាំងឡាយនោះ ដូចម្តេចបាន។ គ្រានោះ បុរសទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយ ជាកូនចៅព្រះពុទ្ធជាសក្យបុត្តនេះមានប្រាថ្នាច្រើន មិនមានសន្តោស សមណៈទាំងនេះគេមិនងាយនឹងប្រគេនចីវរទេ មិនសមបីបើព្រះឧបនន្ទជាម្ចាស់ដែលយើងទាំងឡាយមិនបានបវារណាជាមុន ហើយចូលមកកំណត់ចីវរសោះ។ ភិក្ខុទាំងឡាយ បានឮពាក្យបុរសទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ ភិក្ខុទាំងឡាយណាមានប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្ត ដែលគេឥតបានបវារណាមុន ហើយចូលទៅរកគហបតិហើយកំណត់ចីវរសោះ។ ភិក្ខុទាំងនោះក៏ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងគេមិនបានបវារណាជាមុន ហើយចូលទៅរកគហបតិ កំណត់ចីវរ មែនឬ។ បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន។ ម្នាលឧបនន្ទ ជនទាំងឡាយនោះជាញាតិ ឬមិនមែនជាញាតិទេ។ បពិត្រព្រះដ៏មានព្រះភាគ ជនទាំងនោះមិនមែនជាញាតិទេ។ ម្នាលមោឃបុរស ជនដែលមិនមែនជាញាតិ រមែងមិនដឹងការសមគួរ ឬមិនសមគួរ ការល្អិតល្អ ឬមិនល្អិតល្អ របស់ជនទាំងឡាយមែនមែនជាញាតិទេ ម្នាលមោឃបុរស អ្នកឯង គេមិនបានបវារណាជាមុន ហើយចូលទៅរកគហបតិមិនមែនជាញាតិ កំណត់ចីវរដូចម្តេចបាន ម្នាលមោឃបុរស អំពើនេះ មិនមែននាំឱ្យកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយមិនទាន់ ជ្រះថ្លាទេ ឬមិនមែននាំឱ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលជ្រះថ្លាហើយទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ដម្លៃចីវរផ្សេងគ្នា ដែលគហបតិក្តី គហបតានីក្តី មិនមែនជាញាតិទាំងពីរនាក់ចំពោះភិក្ខុមួយរូប ហើយដំកល់ទុកថា យើងទាំងឡាយនឹងទិញចីវរទាំងឡាយមួយម្នាក់ដោយដម្លៃចីវរផ្សេងគ្នាទាំងនេះ ហើយនឹងឱ្យភិក្ខុឈ្មោះនេះ ស្លៀកដណ្តប់ចីវរទាំងឡាយ។ បើភិក្ខុនោះគេមិនបានបវារណាជាមុន ហើយចូលទៅក្នុងទីនោះ ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ ហើយកំណត់ចីវរដោយពាក្យថា ស្រួលហើយ អ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងពីរចូររួបរួមជាមួយគ្នា ទិញចីវរបែបយ៉ាងនេះផងៗ ដោយដម្លៃចីវរម្នាស់ផ្សេងគ្នាយ៉ាងនេះ ហើយឱ្យអាត្មាស្លៀកដណ្តប់ចុះ ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។

[៦៧] ត្រង់ពាក្យថា ចំពោះភិក្ខុមួយរូប គឺដើម្បីប្រយោជន៍ដល់ភិក្ខុ ធ្វើភិក្ខុឱ្យជាអារម្មណ៍ មានប្រាថ្នាឱ្យភិក្ខុស្លៀកដណ្តប់។ ពាក្យថា ទាំងពីរនាក់ គឺជនទាំងពីរ។ ជនទាំងឡាយមិនបានជាប់អំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបដល់គូនៃជីដូនជីតាទី៧ ហៅថា មិនមែនញាតិ។ ប្រុសទាំងឡាយឯណាមួយនៅគ្រប់គ្រងផ្ទះ ប្រុសទាំងនោះហៅថា គហបតិ។ ស្រីទាំងឡាយឯណាមួយនៅគ្រប់គ្រងផ្ទះ ស្រីទាំងនោះហៅថា គហបតានី។ ប្រាក់ក្តី មាសក្តី កែវមណីក្តី កែវមុក្តាក្តី កែវមក៌តក្តី ឬកែវពព្រុស ពេជ្រភ្នែកឆ្មារក្តី កែវផលិកក្តី សម្ពត់ ឬសក្លាតក្តី អម្បោះក្តី កប្បាសក្តី ហៅថាដម្លៃចីវរ។ ពាក្យថា ដោយដម្លៃចីវរទាំងឡាយ គឺដោយដម្លៃចីវរដែលដំកល់ក្នុងទីចំពោះមុខ។ ពាក្យថា ទិញ គឺ ដូរ។ ពាក្យថា នឹងឱ្យស្លៀកដណ្តប់ គឺនឹងឱ្យ។ ពាក្យថា បើភិក្ខុនោះ គឺដម្លៃចីវរដែលទាយកចំពោះភិក្ខុរូបណា ហើយដម្កល់ទុក គឺភិក្ខុរូបនោះឯង។ ពាក្យថា គេមិនបានបវារណាមុន គឺទាយកមិនបាននិយាយមុនថា ទានប្រោស លោកម្ចាស់ត្រូវការចីវរបែបដូចម្តេច។ យើងទាំងឡាយនឹងទិញចីវរបែបដូចម្តេចប្រគេនលោកម្ចាស់។ ពាក្យថា ចូលទៅ គឺទៅកាន់ផ្ទះ ឬចូលទៅរកគេក្នុងទីណាមួយ។ ពាក្យថា កំណត់ចីវរ គឺចីវរវែងក្តី ធំក្តី មាន សាច់ជិតក្តី មានសាច់ម៉ត់ក្តី។ ពាក្យថា ដោយដម្លៃចីវរទាំងនេះ គឺដម្លៃចីវរទាំងឡាយដែលដំកល់ក្នុងទីចំពោះមុខ។ ពាក្យថា បែបយ៉ាងនេះផងៗ គឺចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ម៉ត់ក្តី។ ពាក្យថា ទិញ គឺដូរ។ ពាក្យថា ចូរឱ្យស្លៀកដណ្តប់ គឺចូរប្រគល់ឱ្យ។ ពាក្យថា អ្នកទាំងពីរចូររួបរួមជាមួយគ្នា គឺអ្នកទាំងពីរ ចូររួបរួមគ្នា។ ពាក្យថា ព្រោះអាស្រ័យសេចក្តីចង់បានចីវរល្អ គឺភិក្ខុ មានសេចក្តីត្រូវការដោយចីវរស្អាត ត្រូវការដោយចីវរមានដម្លៃច្រើន។ ទាយកទាំងឡាយទិញចីវរវែងក្តី ធំក្តី មានសាច់ជិតក្តី មានសាច់ល្អិតក្តី តាមពាក្យភិក្ខុនោះ ភិក្ខុនោះ ត្រូវទុក្កដក្នុងប្រយោគដែលប្រើ ចីវរនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះដល់សង្ឃក្តី ដល់គណៈក្តី ដល់បុគ្គលក្តី។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះភិក្ខុត្រូវលះយ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរខ្ញុំនេះ គេមិនបានបវារណាជាមុន ខ្ញុំចូលទៅរកគហបតិមិនមែនជាញាតិ ហើយកំណត់ចីវរ ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ។បេ។ សង្ឃគប្បីឱ្យ។បេ។ លោកដ៏មានអាយុ ទាំងឡាយគប្បីឱ្យ។បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[៦៨] គហបតិមិនមែនជាញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ គេមិនបានបវារណាមុន ចូលទៅរកគហបតិទាំងឡាយ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិនបានបវារណាមុន ចូលទៅរកគហបតិទាំងឡាយ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនជាញាតិ ភិក្ខុសំគាល់ថាជាញាតិ គេមិនបានបវារណាមុន ហើយចូលទៅរកគហបតិទាំងឡាយ ហើយកំណត់ចីវរ ត្រូវនិស្សគ្គិយបាចិត្តិយ។ គហបតិជាញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ។ គហបតិជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ គហបតិជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនជាអាបត្តិ។

[៦៩] អាបត្តិមិនមានដល់ភិក្ខុដែលកំណត់ចីវរក្នុងសំណាក់ជនជាញាតិទាំងឡាយ ដល់ភិក្ខុដែលជនបានបវារណាហើយ ដល់ភិក្ខុដែលកំណត់ចីវរដើម្បីភិក្ខុដទៃ ដល់ភិក្ខុដែលកំណត់ចីវរដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលញុំាងទាយកមានប្រាថ្នាទិញចីវរមានដម្លៃច្រើន ឱ្យទិញចីវរមានដម្លៃតិចវិញ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៩ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី១០

CS vin.vbu.ni.10 | ភាគ ទី៣

### (១០. រាជសិក្ខាបទំ)

[៧០] សម័យនោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង អមាត្យធំជាឧបដ្ឋាករបស់ព្រះឧបនន្ទដ៏មានអាយុ ជាសក្យបុត្ត បញ្ជូនដម្លៃចីវរទៅដោយបម្រើ ដើម្បីព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តដោយពាក្យថា អ្នកចូរទិញចីវរដោយដម្លៃចីវរនេះ ហើយចូរឱ្យព្រះឧបន័ន្ទជាម្ចាស់ស្លៀកដណ្ដប់ចីវរចុះ។ ឯបម្រើនោះក៏ចូលទៅរកព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្ត លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទដ៏មានអាយុជាសក្យបុត្តថា បពិត្រលោកម្ចាស់ដ៏ចម្រើន ដម្លៃចីវរនេះ ខ្ញុំនាំមកចំពោះលោកដ៏មានអាយុ សូមលោកដ៏មានអាយុ ទទួលយកដម្លៃចីវរ (នេះ)ចុះ។ កាលបើបម្រើនោះនិយាយយ៉ាងនេះហើយ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ បានពោលពាក្យនេះនឹងបម្រើនេះថា ម្នាលអាវុសោ យើងទទួលដម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរដ៏សមគួរដោយកាលគួរ។ កាលបើព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ ពោលយ៉ាងនេះហើយ បម្រើនោះបានពោលពាក្យនេះនឹងព្រះឧបនន្ទសក្យបុត្តដ៏មានអាយុថា អ្នកណាមួយជាវេយ្យាវច្ចករ[9] របស់លោកដ៏មានអាយុ មានដែរឬ។ សម័យនោះ ឧបាសកម្នាក់បានទៅកាន់អារាមដោយមានកិច្ចការនីមួយ។ គ្រានោះ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ បានពោលពាក្យនេះនឹងបម្រើនោះថា ម្នាលអាវុសោ ឧបាសកនេះឯង ជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ។ ឯបម្រើនោះក៏ពន្យល់ឧបាសកនោះ ហើយចូលទៅរកព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទសក្យបុត្តដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន វេយ្យាវច្ចករដែលលោកដ៏មានអាយុចង្អុរប្រាប់នោះ ខ្ញុំបានពន្យល់ហើយ សូមលោកដ៏មានអាយុចូរទៅរកគេចុះ វេយ្យាវច្ចករនោះនឹងឱ្យលោកម្ចាស់ស្លៀកដណ្ដប់ចីវរ ដោយកាលដ៏គួរ។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុមិនបាននិយាយពាក្យអ្វីនីមួយនឹងឧបាសកឡើយ។ អាមាត្យធំនោះបញ្ជូនបម្រើទៅក្នុងសំណាក់ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ អស់វារៈជាគំរប់ពីរដងថា លោកម្ចាស់ចូរប្រើប្រាស់ចីវរនោះ យើងខ្ញុំចង់ឱ្យលោកម្ចាស់ប្រើប្រាស់ចីវរនោះ។ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុក៏មិនបាននិយាយពាក្យអ្វីនីមួយនឹងឧបាសកនោះអស់វារៈពីរដង។ មហាមាត្យនោះបញ្ជូនបម្រើទៅក្នុងសំណាក់ព្រះឧបបន្ទសក្យបុត្តដ៏មានអាយុអស់វារៈបីដងថា លោកម្ចាស់ចូរប្រើប្រាស់ចីវរនោះ យើងខ្ញុំចង់ឱ្យលោកម្ចាស់ប្រើប្រាស់ចីវរនោះ។ សម័យនោះឯង ជាសម័យនៃអ្នកនៅក្នុងនិគម។ ក៏អ្នកនិគមបានធ្វើកតិកា (ប្តេជ្ញា) គ្នាថា អ្នកណាមកក្រោយគេ ត្រូវលក់អ្នកនោះហាសិបកហាបណៈ។ លំដាប់នោះ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ ចូលទៅរកឧបាសកនោះ លុះចូលទៅជិតហើយ បានពោលពាក្យនេះនឹងឧបាសកនោះថា ម្នាលអាវុសោ អាត្មាត្រូវការចីវរ។ ឧបាសកនោះតបថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់សូមបង្អង់ថ្ងៃនេះមួយថ្ងៃសិន (ព្រោះ) ថ្ងៃនេះជាសម័យ (ប្តេជ្ញាគ្នា) នៃអ្នកនៅក្នុងនិគម អ្នកនិគមធ្វើប្តេជ្ញាគ្នាថា អ្នកណាមកក្រោយគេ ត្រូវលក់អ្នកនោះហាសិបកហាបណៈ ព្រះឧបនន្ទក៏លូកចាប់ថ្នក់ថា ម្នាលអាវុសោ ចូរអ្នកឱ្យចីវរដល់អាត្មាក្នុងថ្ងៃនេះឯង។ ឯឧបាសកដែលព្រះឧបនន្ទសក្យបុត្តដ៏មានអាយុជំរឹតទារ ក៏ទិញចីវរប្រគេនឧបនន្ទសក្យបុត្តដ៏មានអាយុ ហើយបានទៅដល់ (និគមនោះ) ជាខាងក្រោយគេ។ មនុស្សទាំងឡាយ បានពោលពាក្យនេះនឹងឧបាសកនោះថា អ្នកជាម្ចាស់ អ្នកមកក្នុងកាលជាខាងក្រោយគេ ព្រោះហេតុអ្វី យើងឈ្នះអ្នកហាសិបកហាបណៈហើយ។ ទើបឧបាសកនោះប្រាប់ដំណើរនុ៎ះដល់មនុស្សទាំងអម្បាលនោះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធ ជាសក្យបុត្តអម្បាលនេះ មានសេចក្តីប្រាថ្នាធំ ឥតមានសន្តោស មិនងាយអ្នកណានឹងធ្វើការខ្វល់ខ្វាយបម្រើដល់សមណៈអម្បាលនេះទេ ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ កាលបើឧបាសកពោលថា លោកម្ចាស់ សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះមួយថ្ងៃសិន មិនគួរបើមិនព្រមបង្អង់ចាំសោះ។ ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សទាំងឡាយពោលទោស តិះដៀលបន្តុះបង្អាប់ហើយ ភិក្ខុទាំងឡាយណាមានប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ កាលបើឧបាសកនិយាយថា លោកម្ចាស់ សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះមួយថ្ងៃសិន មិនគួរបើមិនព្រមបង្អង់ ឱ្យសោះ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងកាលឧបាសកពោលថា លោកម្ចាស់ សូមលោកម្ចាស់បង្អង់ក្នុងថ្ងៃនេះមួយថ្ងៃសិន មិនព្រមបង្អង់ចាំ មែនឬ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងកាលដែលឧបាសកពោលថា លោកម្ចាស់ សូមលោកបង្អង់ក្នុងថ្ងៃនេះមួយថ្ងៃសិន មិនសមបើមិនបង្អង់ឱ្យគេទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឱ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬមិនមែននាំឱ្យរឹងរឹតតែកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាហើយទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ស្តេចក្តី រាជអាមាត្យក្តី ព្រាហ្មណ៍ក្តី គហបតិក្តី បញ្ជូនដម្លៃចីវរទៅ ដោយបម្រើចំពោះភិក្ខុមួយរូបថា អ្នកឯងចូរទិញចីវរដោយដម្លៃចីវរនេះ ហើយចូរឱ្យភិក្ខុឈ្មោះនេះស្លៀកដណ្តប់ចីវរចុះ។ បើបម្រើនោះ ចូលទៅរកភិក្ខុនោះ ហើយពោលយ៉ាងនេះថា លោកម្ចាស់ដម្លៃចីវរនេះ ខ្ញុំនាំមកចំពោះលោកដ៏មានអាយុ លោកដ៏មានអាយុសូមទទួលយកដម្លៃចីវរចុះ ភិក្ខុនោះត្រូវនិយាយពាក្យយ៉ាងនេះនឹងបម្រើនោះថា ម្នាល អាវុសោ យើងទទួលយកដម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរសមគួរដោយកាលដ៏គួរ។ បើបម្រើនោះពោលនឹងភិក្ខុនោះយ៉ាងនេះថា អ្នកណាមួយជាវេយ្យាវច្ចកររបស់លោកដ៏មានអាយុ មានដែរឬ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីបង្ហាញវេយ្យាវច្ចករ គឺញោមវត្ត ឬឧបាសកថា ម្នាលអាវុសោ អ្នកនេះឯងជាវេយ្យាវច្ចករ របស់ភិក្ខុទាំងឡាយ។ បើបម្រើនោះពន្យល់វេយ្យាវច្ចករនោះហើយ ក៏ចូលទៅរកភិក្ខុនោះ ហើយពោលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន លោកដ៏មានអាយុបង្ហាញនូវវេយ្យាវច្ចករណា វេយ្យាវច្ចករនោះខ្ញុំព្រះករុណាបានពន្យល់ហើយ សូមលោកដ៏មានអាយុចូលទៅរក (គេ)ចុះ គេនឹងឱ្យលោកម្ចាស់ស្លៀកដណ្តប់ចីវរដោយកាលដ៏គួរ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីចូលទៅតឹងទារ ដាស់តឿនវេយ្យាវច្ចករពីរ បីលើកថា ម្នាលអាវុសោ អាត្មាត្រូវការចីវរ។ កាលបើភិក្ខុទៅតឹងទារ ទៅដាស់តឿនអស់ពីរបីលើក ក៏ញ៉ាំងចីវរនោះឱ្យសម្រេចបាន ការនេះជាការល្អ បើញ៉ាំងចីវរនោះឱ្យសម្រេចមិនបានទេ ភិក្ខុគប្បីទៅឈរស្ងៀមចំពោះមុខបួនលើក ប្រាំលើក ប្រាំមួយលើកយ៉ាងច្រើន កាលបើភិក្ខុឈរស្ងៀមនៅចំពោះមុខបួនលើក ប្រាំលើក ប្រាំមួយលើក យ៉ាងច្រើន ញ៉ាំងចីវរនោះឱ្យសម្រេចបាន ការនេះជាការល្អ បើធ្វើចីវរនោះឱ្យសម្រេចមិនបានទេ ហើយភិក្ខុនោះចេះតែព្យាយាមឱ្យលើសអំពីកំណត់នោះ ទាល់តែបានចីវរនោះមក ភិក្ខុនោះ ត្រូវនិស្សគ្គិយបាចិត្តិយ បើភិក្ខុញ៉ាំងចីវរនោះឱ្យសម្រេចមិនបានទេ បម្រើនោះនាំដម្លៃចីវរមកដើម្បីភិក្ខុនោះ អំពីសំណាក់អ្នកណា ភិក្ខុគប្បីទៅខ្លួនឯង ឬប្រើបម្រើទៅក្នុងសំណាក់អ្នកនោះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយបញ្ជូនដម្លៃចីវរណាទៅចំពោះភិក្ខុរូបណា ដម្លៃចីវរនោះ មិនសម្រេចប្រយោជន៍បន្តិចបន្តួចដល់ភិក្ខុរូបនោះទេ អ្នកដ៏មានអាយុចូរទារយករបស់ខ្លួនវិញចុះ ទ្រព្យរបស់អ្នកទាំងឡាយចូរកុំឱ្យវិនាស ការនេះជាសាមីចិកម្ម (សេចក្តីប្រព្រឹត្តគួរ) ក្នុងសិក្ខាបទនោះ។

[៧១] ត្រង់ពាក្យថា ចំពោះភិក្ខុមួយរូប សេចក្តីថា ដើម្បីប្រយោជន៍ដល់ភិក្ខុ គឺធ្វើភិក្ខុឱ្យជាអារម្មណ៍ មានប្រាថ្នាឱ្យភិក្ខុស្លៀកដណ្តប់ចីវរ។ អ្នកណាមួយសោយរាជសម្បត្តិ អ្នកនោះឈ្មោះថា ស្តេច។ អ្នកណាមួយ គួរទទួលបាយនឹងបៀវត្សរបស់ស្តេច អ្នកនោះឈ្មោះថា រាជអមាត្យ។ ជនជាព្រាហ្មណ៍ដោយជាតិ ឈ្មោះថា ព្រាហ្មណ៍។ ដែលហៅថា គហបតិ គឺជនដ៏សេស វៀរលែងស្តេច រាជអមាត្យ និងព្រាហ្មណ៍ចេញ ហៅថា

គហបតិ។ ប្រាក់ក្តី មាសក្តី កែវមណីក្តី កែវមុក្តាក្តី កែវមក៌តក្តី កែវផលិកក្តី ហៅថាថ្លៃចីវរ។ ពាក្យថា ដោយដម្លៃចីវរនេះ គឺដម្លៃចីវរដែល គេដំកល់ទុកចំពោះ។ ពាក្យថា ទិញ គឺដូរ។ ពាក្យថា ឱ្យស្លៀកដណ្តប់ គឺឱ្យ។ ពាក្យថាបើបំរើនោះចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា លោកម្ចាស់ដម្លៃចីវរនេះ ខ្ញុំនាំមកចំពោះលោកដ៏មានអាយុ។ លោកដ៏មានអាយុ ចូរទទួលយកដម្លៃចីវរចុះ។ ភិក្ខុនោះគប្បីនិយាយយ៉ាងនេះនឹងបម្រើនោះថា ម្នាលអាវុសោ យើងទទួលយកដម្លៃចីវរមិនបានទេ យើងទទួលបានតែចីវរសមគួរដោយកាលដ៏គួរ។ បើបម្រើនោះនិយាយនឹងភិក្ខុនោះយ៉ាងនេះថា អ្នកណាមួយជាវេយ្យាវច្ចកររបស់ លោកដ៏មានអាយុ មានដែរឬ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ គប្បីបង្ហាញវេយ្យាវច្ចករ គឺញោមវត្ត ឬឧបាសក (ប្រាប់គេ) ថា ម្នាលអាវុសោ បុគ្គលនេះឯង ជាវេយ្យាវច្ចកររបស់ភិក្ខុទាំងឡាយ។ មិនគប្បីពោលនឹងបម្រើនោះថា អ្នកចូរឱ្យដល់បុគ្គលនោះក្តី ថា បុគ្គលនោះនឹងទុកដាក់ក្តី ថា បុគ្គលនោះនឹងដូរក្តី ថា បុគ្គលនោះនឹងទិញក្តី បើបម្រើនោះពន្យល់វេយ្យាវច្ចករនោះ ហើយចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន លោកដ៏មានអាយុ បង្ហាញនូវវេយ្យាវច្ចករណា វេយ្យាវច្ចករនោះខ្ញុំបានពន្យល់ហើយ សូមលោកដ៏មានអាយុ ចូលទៅរក (គេ) ចុះ វេយ្យាវច្ចករនោះនឹងឱ្យលោកស្លៀកដណ្តប់ចីវរដោយកាលគួរ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកត្រូវការចីវរ ត្រូវចូលទៅរកវេយ្យាវច្ចករ ហើយដាស់តឿនរំលឹកពីរ បីលើកថា ម្នាលអ្នកដ៏មានអាយុ អាត្មាត្រូវការចីវរ។ មិនគប្បីនិយាយថា អ្នកចូរឱ្យចីវរដល់អាត្មា ចូរនាំចីវរមកឱ្យអាត្មា ចូរដូរចីវរឱ្យអាត្មា ចូរចាត់ចែងចីវរឱ្យអាត្មា។ ភិក្ខុគប្បីនិយាយនឹងវេយ្យាវច្ចករនោះ អស់វារៈពីរដងផង គប្បីនិយាយអស់វារៈបីដងផង។ បើភិក្ខុញ៉ាំងចីវរនោះឱ្យសម្រេចបាន ការនេះជាការល្អ បើភិក្ខុញ៉ាំងចីវរនោះឱ្យសម្រេចមិនបានទេ ភិក្ខុគប្បីទៅក្នុងទីនោះ ហើយឈរនៅស្ងៀមក្នុងទីចំពោះមុខ មិនគប្បីអង្គុយលើអាសនៈ មិនគប្បីទទួលអាមិស មិនគប្បីនិយាយធម៌។ កាលបើវេយ្យាវច្ចករនោះសួរថា លោកមកព្រោះហេតុអ្វី ភិក្ខុគប្បីនិយាយថា ម្នាលអ្នកដ៏មានអាយុ អ្នកចូរដឹងចុះ ថាបើភិក្ខុអង្គុយលើអាសនៈក្តី ទទួលអាមិសក្តី និយាយធម៌ក្តី ឈ្មោះថាកាច់កិរិយាឈរ។ ភិក្ខុគប្បីឈរអស់វារៈពីរដងផង គប្បីឈរអស់វារៈបីដងផង គប្បីទារបួនដងផង ហើយឈរបួនដងផង (បើ) ទារប្រាំដងហើយ គប្បីឈរពីរដង (បើ)ទារប្រាំមួយដងហើយ មិនគប្បីឈរ (ទៀត)ទេ។ កាលបើភិក្ខុព្យាយាមឱ្យលើសពីកំណត់នោះ ឱ្យចីវរនោះសម្រេចបាន ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលព្យាយាម ចីវរដែលបានមកជានិស្សគ្គិយ ចីវរនោះភិក្ខុត្រូវលះដល់សង្ឃក្តី ដល់គណៈក្តី ដល់បុគ្គលក្តី។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះ ភិក្ខុគប្បីលះយ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន ចីវរនេះខ្ញុំឱ្យសម្រេចបានដោយទារលើសពី៣ដង ដោយឈរលើសពី៦ដង ជានិស្សគ្គិយ ខ្ញុំសូមលះចីវរនេះដល់សង្ឃ។បេ។ សង្ឃគប្បីឱ្យ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឱ្យ។បេ។ ខ្ញុំឱ្យលោកដ៏មានអាយុ។ បើភិក្ខុឱ្យចីវរនោះសម្រេចមិនបានទេ ថ្លៃចីវរដែលគេនាំមកដើម្បីភិក្ខុនោះអំពីសំណាក់បុគ្គលណា ភិក្ខុគប្បីទៅក្នុងសំណាក់បុគ្គលនោះខ្លួនឯងក្តី ប្រើបម្រើឱ្យទៅក្តី ដោយពាក្យថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយបញ្ជូនដម្លៃចីវរណាទៅចំពោះភិក្ខុ ដម្លៃចីវរនោះមិនសម្រេចប្រយោជន៍បន្តិចបន្តួចដល់ភិក្ខុនោះទេ អ្នកដ៏មានអាយុទាំងឡាយ ចូរតឿនទារយករបស់ខ្លួនចុះ ទ្រព្យរបស់អ្នកទាំងឡាយ ចូរកុំឱ្យវិនាស។ ពាក្យថា ការនេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ គឺថាការនេះ ជាសភាពដ៏សមគួរតាមធម៌ក្នុងសិក្ខាបទនោះ។

[៧២] ភិក្ខុទារលើសពី៣ដង ឈរលើសពី៦ដង មានសេចក្តីសម្គាល់ថាលើសមែន (ហើយ) ឱ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុទារលើសពីបីដង ឈរលើសពីប្រាំមួយដង មានសេចក្តីសង្ស័យ ហើយឱ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុទារលើសពី៣ដង ឈរលើសពី៦ដង មានសេចក្តីសំគាល់ថានៅខ្វះ ហើយឱ្យចីវរនោះសម្រេចបាន ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុទារថយពី៣ដង ឈរថយពី៦ដង មានសេចក្តីសំគាល់ថាលើស ត្រូវអាបត្តិទុក្កដ។ ភិក្ខុទារថយពី៣ដង ឈរថយពី៦ដង មានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទារថយពី៣ដង ឈរថយពី៦ដង មានសេចក្តីសំគាល់ថាថយ ជាអនាបត្តិ។

[៧៣] អាបត្តិមិនមានដល់ភិក្ខុញ៉ាំងចីវរឱ្យសម្រេចដោយទារ (ត្រឹម) ៣ដង ឈរ (ត្រឹម) ៦ដង ដល់ភិក្ខុញ៉ាំងចីវរឱ្យសម្រេចដោយទារខ្វះពី៣ដង ឈរខ្វះពី៦ដង ដល់ភិក្ខុដែលមិនបានតឹងទារ វេយ្យាវច្ចករគេឱ្យ (ឯង) ដល់ភិក្ខុដែលម្ចាស់របស់ទារឱ្យ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី១០ ចប់។

ចីវរវគ្គ ទី១ ចប់។

ឧទ្ទាន[10)] នៃចីវរវគ្គនោះ ដូច្នេះគឺ

សំពត់អតិរេកចីវរដែលភិក្ខុបានមកហើយ មិនបានវិកប្បអធិដ្ឋានក្នុងវេលា ដែលអស់អំណាចអានិសង្សកឋិន ហើយទុកឱ្យកន្លងដប់រាត្រី១ ក្នុងវេលា ដែលអស់អំណាចអានិសង្សកឋិនហើយ ភិក្ខុនៅប្រាសចាកត្រៃចីវរឱ្យកន្លងមួយរាត្រី១ ភិក្ខុទុកអកាលចីវរឱ្យហួសពីមួយខែ១ ភិក្ខុប្រើនាងភិក្ខុនីមិនមែនជាញាតិឱ្យលាងចីវរចាស់១ ភិក្ខុទទួលចីវរពីដៃនាងភិក្ខុនីមិនមែនជាញាតិ១ ភិក្ខុសូមចីវរពីគ្រហស្ថមិនមែនជាញាតិ១ ភិក្ខុសូមចីវរហួសពីអន្តរវាសក (ស្បង់) និងឧត្តរាសង្គ (ចីពរ)១ ភិក្ខុទៅនិយាយនឹងគ្រហស្ថ ដែលមិនមែនជាញាតិ មិនបានបវារណា ដែលគេបម្រុងនឹងប្រគេនចីវរ ឱ្យគេប្រគេនចីវរឱ្យល្អ១ ភិក្ខុទៅនិយាយនឹងគ្រហស្ថច្រើនរូបមិនមែនជាញាតិ មិនមែនជនដែលបានបវារណា ឱ្យគេរួបរួមថ្លៃជាមួយគ្នាដើម្បីទិញចីវរល្អ១ ភិក្ខុទៅតឹងទារចីវរអំពីវេយ្យាវច្ចករហួសពីបីដង និងឈរហួសពីប្រាំមួយដង១។

# កោសិយវគ្គ (ទី២)

CS vin.vbu.ni.v2 | ភាគ ទី៣

### (២. កោសិយវគ្គោ)

### (និស្សគ្គិយ) សិក្ខាបទ ទី១ (១១)

CS vin.vbu.ni.11 | ភាគ ទី៣

### (១. កោសិយសិក្ខាបទំ)

[៧៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងអគ្គាឡវចេតិយ ទៀបក្រុងអាឡវី។ ក៏ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ចូលទៅរកពួកជនអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយចូរស្ងោរនាងទាំងឡាយឱ្យច្រើន នឹង ឱ្យយើងខ្លះ យើងក៏ចង់ធ្វើសន្ថ័តលាយដោយសូត្រដែរ។ ជនអ្នកធ្វើសូត្រទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយ ជាកូនចៅព្រះពុទ្ធ ជាសក្យបុត្ត មិនសមបើនឹងចូលទៅរកយើង ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរស្ងោរនាងឱ្យច្រើន នឹងឱ្យយើងខ្លះ យើងចង់ធ្វើសន្ថ័តលាយដោយសូត្រដែរ ពួកយើងណាធ្វើសត្វមានជីវិតតូចៗ ជាច្រើនឱ្យដល់នូវសេចក្ដីវិនាស ព្រោះហេតុសេចក្ដីចិញ្ចឹមជីវិតខ្លួន និងកូនប្រពន្ធ ពួកយើងទាំងនោះ ឈ្មោះថាមិនមានញាតិផង ឈ្មោះថាបានទ្រព្យដោយអាក្រក់ផង។ ភិក្ខុទាំងឡាយបានឮពាក្យជនអម្បាលនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាមានប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងចូលទៅរកជនអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុ អ្នកទាំងឡាយ ចូរស្ងោរនាងឱ្យច្រើន នឹងឱ្យយើងខ្លះ យើងចង់ធ្វើសន្ថ័តលាយដោយសូត្រដែរ។ ភិក្ខុទាំងឡាយនោះ ក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយចូលទៅរកពួកអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរស្ងោរនាងឱ្យច្រើន នឹងឱ្យយើងខ្លះ យើងចង់ធ្វើសន្ថ័តលាយដោយសូត្រដែរ ពិតមែនឬ។ បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន។ ព្រះពុទ្ធដ៏មានជោគតិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនសមបើនឹងចូលទៅរកពួកអ្នកធ្វើសូត្រ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយចូរស្ងោរនាងឱ្យច្រើន នឹងឱ្យយើងខ្លះ យើងចង់ធ្វើសន្ថ័តលាយដោយសូត្រដែរ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង មិនមែននាំឱ្យរឹងរឹតតែជ្រះថ្លាដល់ជនដែលជ្រះថ្លាហើយផង។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ឱ្យគេធ្វើសន្ថ័តលាយដោយសូត្រ សន្ថ័តនោះជានិស្សគ្គិយ[11] ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[៧៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១ ក្នុងបារាជិកកណ្ឌ រួចហើយ។ គ្រឿងកម្រាលដែលមិនបានត្បាញ គេស្មាច់សម្រេចតែម្ដង ហៅថា សន្ថ័ត។ ពាក្យថា ឱ្យគេធ្វើ គឺភិក្ខុលាយដោយសរសៃសូត្រសូម្បីមួយសរសៃ ហើយធ្វើខ្លួនឯងក្ដី ប្រើគេឲ្យធ្វើក្ដី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ។ សន្ថ័តដែលបានមក ជានិស្សគ្គិយ ភិក្ខុត្រូវលះដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ សន្ថ័តនោះ ភិក្ខុត្រូវលះយ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថ័តលាយដោយសូត្រនេះ ខ្ញុំឱ្យគេធ្វើ ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថ័តនេះដល់សង្ឃ។បេ។ សង្ឃគប្បីឱ្យ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឱ្យ។បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[៧៦] សន្ថ័ត ភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ភិក្ខុឱ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ សន្ថ័តដែលភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ឱ្យអ្នកដទៃសម្រេច សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ សន្ថ័តដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឱ្យសម្រេចដោយខ្លួនឯង សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ សន្ថ័តដែលអ្នកដទៃធ្វើមិនទាន់សម្រេច ភិក្ខុឱ្យអ្នកដទៃសម្រេច សន្ថ័តនោះ ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើខ្លួនឯងក្ដី ប្រើគេឱ្យធ្វើក្ដី ដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានសន្ថ័តដែលអ្នកដទៃធ្វើហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៧៧] អាបត្តិ មិនមានដល់ភិក្ខុដែលធ្វើសម្ពត់ពិតានក្ដី សម្ពត់កម្រាលលើទីដែលគេបូកលាបក្ដី រនាំងក្ដី ពូកក្ដី ខ្នើយក្ដី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី១ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី២ (១២)

CS vin.vbu.ni.12 | ភាគ ទី៣

### (២. សុទ្ធកាឡកសិក្ខាបទំ)

[៧៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងកូដាគារសាលា ក្នុងមហាវន ទៀបក្រុងវេសាលី។ ក៏ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឱ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ។ មនុស្សទាំងឡាយ ដើរទៅកាន់ចារិកវិហារ ឃើញហើយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈទាំងនេះ ជាកូនចៅព្រះពុទ្ធជាសក្យបុត្ត មិនសមបើនឹងឱ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ ដូចជាពួកគ្រហស្ថ ជាអ្នកបរិភោគកាមសោះ។ ភិក្ខុទាំងឡាយបានឮពាក្យពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាមានប្រាថ្នាតិច។បេ។ ភិក្ខុអម្បាល នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹង ឱ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធសោះ។ ភិក្ខុអម្បាលនោះក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយឱ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ

ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនសមបើនឹងឱ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធទេ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នករាល់គ្នាធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាហើយផង មិនមែននាំឱ្យរឹងរឹតតែជ្រះថ្លាដល់ជនដែលជ្រះថ្លាហើយផង។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ឱ្យគេធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវ អាបត្តិបាចិត្តិយ។

[៧៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា រោមចៀមខ្មៅ ( នោះសំដៅយក) រោមចៀមខ្មៅទាំង ២យ៉ាង គឺ រោមចៀមខ្មៅពីកំណើត១ រោមចៀមខ្មៅពីគ្រឿងជ្រលក់១។ គ្រឿងកម្រាលដែលគេមិនត្បាញ គ្រាន់តែគេស្មាច់ ហើយធ្វើឱ្យសម្រេច ហៅថា សន្ថត។ ពាក្យថា ឱ្យគេធ្វើ គឺភិក្ខុធ្វើខ្លួនឯងក្តី ឱ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ សន្ថត ដែលបានមកជានិស្សគ្គិយ ភិក្ខុត្រូវលះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះយ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតនេះ ខ្ញុំឱ្យគេធ្វើដោយរោមចៀមខ្មៅសុទ្ធ ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថតនេះដល់សង្ឃ។បេ។ សង្ឃត្រូវឱ្យ។បេ។ លោកដ៏មានអាយុទាំងឡាយត្រូវឱ្យ។បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[៨០] សន្ថតដែលភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ឱ្យសម្រេចដោយ ខ្លួនឯង សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ សន្ថតដែល ភិក្ខុធ្វើខ្លួនឯងមិនទាន់ស្រេច ឱ្យអ្នកដទៃសម្រេច សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ សន្ថតដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឱ្យសម្រេចដោយខ្លួនឯង សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ សន្ថតដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឱ្យអ្នកដទៃសម្រេច សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើសន្ថតខ្លួនឯងក្តី ប្រើគេឱ្យធ្វើក្តី ដើម្បីប្រយោជន៍បុគ្គលដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានសន្ថតដែលបុគ្គលដទៃធ្វើ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៨១] អាបត្តិមិនមានដល់ភិក្ខុធ្វើសម្ពត់ពិតានក្តី គ្រឿងកម្រាលផែនដីក្តី រនាំងក្តី ពូកក្តី ខ្នើយក្តី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី២ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៣ (១៣)

CS vin.vbu.ni.13 | ភាគ ទី៣

### (៣. ទ្វេភាគសិក្ខាបទំ)

[៨២] សម័យនោះ ព្រះសម្ពុទ្ធដ៏មានបុញ្ញសិរី ព្រះអង្គគង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ ក៏គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា ព្រះដ៏មានព្រះភាគទ្រង់ឃាត់ហាមមិនឱ្យភិក្ខុប្រើគេឲ្យធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធ ក៏នាំគ្នាប្រើឱ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធដូច្នោះ តែលាយដោយរោមចៀមសបន្តិចត្រង់ជាយ។ ភិក្ខុទាំងឡាយណា អ្នកមានប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើ នឹងទៅឱ្យគេធ្វើសន្ថតដោយរោមចៀមខ្មៅសុទ្ធដូច្នោះ ហើយយករោម ចៀមសលាយបន្តិចត្រង់ជាយប៉ុណ្ណោះទេ។ គ្រានោះ ភិក្ខុទាំងឡាយ នោះក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ មានព្រះបន្ទូលសួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកប្រើឱ្យគេធ្វើ សន្ថតដោយរោមចៀមខ្មៅសុទ្ធដូច្នោះ ហើយលាយរោមចៀមសបន្តិច ត្រង់ជាយ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលបុរសសោះសូន្យ ហេតុដូចម្តេចបានជាពួកអ្នកឱ្យគេធ្វើសន្ថតដោយ រោមចៀមខ្មៅសុទ្ធដូច្នោះ ហើយលាយរោមចៀមសបន្តិចត្រង់ជាយដូច្នោះ ម្នាលបុរសសោះសូន្យ អំពើនេះមិនមែននាំឱ្យកើតសេចក្តីជ្រះថ្លាដល់អ្នក ដែលមិនទាន់ជ្រះថ្លាទេ ឬនាំអ្នកដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទ នេះយ៉ាងនេះថា ភិក្ខុកាលឱ្យគេធ្វើសន្ថតថ្មី គប្បីកាន់យករោមចៀមខ្មៅសុទ្ធពីរភាគ រោមចៀមសភាគទីបី (១ ភាគ) រោមចៀមក្រហមភាគទី៤ (១ ភាគ)។ បើភិក្ខុឱ្យគេធ្វើសន្ថតថ្មី មិនកាន់យករោមចៀមខ្មៅសុទ្ធពីរភាគ រោមចៀមសភាគទីបី រោមចៀមក្រហមភាគទីបួនទេ សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[៨៣] សន្ថតដែលធ្វើជាដំបូង ហៅថា សន្ថតថ្មី។ គ្រឿងកម្រាល ដែលមិនបានត្បាញ គេស្មាច់សម្រេចតែម្តង ហៅថា សន្ថត។ ត្រង់ពាក្យថា កាលឱ្យគេធ្វើ គឺធ្វើឯងក្តី ប្រើឱ្យគេធ្វើក្តី។ ពាក្យថា គប្បីកាន់យករោមចៀមខ្មៅសុទ្ធពីរភាគនោះ គឺភិក្ខុត្រូវថ្លឹងរោមចៀមខ្មៅសុទ្ធពីរ ជញ្ជីង ហើយសឹមកាន់យក។ ពាក្យថា រោមចៀមសភាគទីបីនោះ គឺរោមចៀមសមួយជញ្ជីង។ ពាក្យថា រោមចៀមក្រហមភាគទីបួននោះ គឺរោមចៀមក្រហមមួយជញ្ជីង។ ពាក្យថា បើភិក្ខុឱ្យគេធ្វើសន្ថតថ្មី មិនកាន់យករោមចៀមខ្មៅសុទ្ធពីរភាគ រោមចៀមសភាគទី ៣ រោមចៀម ក្រហមភាគទីបួន គឺថាភិក្ខុធ្វើឯងក្តី ប្រើឱ្យគេធ្វើក្តី នូវសន្ថតថ្មីមិនលាយរោមចៀមសមួយជញ្ជីង រោមចៀមក្រហមមួយជញ្ជីងទេ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ វេលាបានមក សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវលះ ដល់សង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះថា។បេ។ បពិត្រព្រះសង្ឃដ៏ចម្រើន សន្ថតនេះ ខ្ញុំឱ្យគេធ្វើមិនបានលាយ ដោយរោមចៀមសមួយជញ្ជីង រោមចៀមក្រហមមួយជញ្ជីង ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថតនេះដល់សង្ឃ។បេ។ សង្ឃគប្បីឱ្យ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឱ្យ។ បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[៨៤] ភិក្ខុធ្វើសន្ថតដោយខ្លួនឯងមិនទាន់ស្រេច ( គ្រាក្រោយ ) ឱ្យសម្រេចដោយខ្លួនឯង សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើសន្ថតដោយខ្លួនឯងមិនទាន់ស្រេច ឱ្យអ្នកដទៃសម្រេច សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ អ្នកដទៃធ្វើសន្ថតមិនទាន់ស្រេច ភិក្ខុឱ្យសម្រេចដោយខ្លួនឯង សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ អ្នកដទៃធ្វើសន្ថតមិនទាន់ស្រេច ភិក្ខុឱ្យអ្នកដទៃសម្រេច សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើឯងក្តី ឱ្យអ្នកដទៃធ្វើក្តី ដើម្បីប្រយោជន៍ដល់អ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុ បានសន្ថតដែលអ្នកដទៃគេធ្វើហើយយកមកប្រើប្រាស់ក៏ត្រូវអាបត្តិទុក្កដ។

[៨៥] អាបត្តិមិនមានដល់ភិក្ខុធ្វើសន្ថតយករោមចៀមសមួយជញ្ជីង (១ភាគ) រោមចៀមក្រហមមួយជញ្ជីង (១ភាគ) មិនមានដល់ភិក្ខុធ្វើសន្ថត យករោមចៀមសច្រើន យករោមចៀមក្រហមច្រើនជាងកំណត់នោះ មិន មានដល់ភិក្ខុធ្វើសន្ថតយករោមចៀមសសុទ្ធ ក្រហមសុទ្ធ មិនមានដល់ភិក្ខុយករោមចៀមធ្វើពិតានក្តី ជាកម្រាលផ្ទៃដែលគេបូកលាបក្តី ជា រនាំងបាំងក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៣ ចប់។

# (និស្សគ្គិយ) សិក្ខាបទ ទី៤ (១៤)



## (៤. ឆព្ពស្សសិក្ខាបទំ)

[៨៦] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ ក៏គ្រានោះឯង ភិក្ខុទាំងឡាយឱ្យគេធ្វើសន្ថតរាល់ឆ្នាំ។ ភិក្ខុទាំងនោះជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយចូរឱ្យរោមចៀមដល់អាត្មា។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្ត មិនគួរបើនឹងឱ្យគេធ្វើសន្ថតរាល់ឆ្នាំយ៉ាងនេះ ពួកសមណៈជាកូនចៅព្រះពុទ្ធជា សក្យបុត្តជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយចូរឱ្យរោមចៀមដល់អាត្មា ក៏ពួកយើងធ្វើ សន្ថតម្តងប្រើបាន៥ឆ្នាំខ្លះ ៦ឆ្នាំខ្លះ ក្មេងរបស់យើងទាំងឡាយជុះដាក់ខ្លះ នោមដាក់ខ្លះ កណ្តុរកាត់ខ្លះ (ក៏គង់ប្រើបានយូរដល់ត្រឹមនោះ) ចំណែកពួក សមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្តទាំងនេះ ឱ្យគេធ្វើសន្ថតរាល់ៗឆ្នាំ សមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្តនេះ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយចូរឱ្យរោមចៀមដល់អាត្មា។ ភិក្ខុទាំងឡាយបានឮ ពាក្យមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណា អ្នកមានប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនគួរបើនឹងឱ្យគេធ្វើសន្ថតរាល់ឆ្នាំឡើយ ពួកភិក្ខុទាំងនេះជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយចូរឱ្យរោមចៀមដល់អាត្មា។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយ ឱ្យគេធ្វើសន្ថតរាល់ឆ្នាំ ភិក្ខុទាំងឡាយជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើន ដោយពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយចូរឱ្យរោមចៀមដល់អាត្មាដូច្នេះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រ ព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ឯបុរសសោះសូន្យទាំងនោះមិនគួរបើនឹងឱ្យគេធ្វើសន្ថតរាល់ឆ្នាំឡើយ ជាអ្នកអង្វរច្រើន ជាអ្នកសូមច្រើនដោយ ពាក្យថា អាត្មាត្រូវការដោយរោមចៀម អ្នកទាំងឡាយចូរឱ្យរោមចៀម ដល់អាត្មាដូច្នេះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឱ្យកើត សេចក្តីជ្រះថ្លាដល់អ្នកដែលមិនទាន់ជ្រះថ្លាទេ ឬនាំអ្នកដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុឱ្យគេធ្វើសន្ថតថ្មី គប្បី ប្រើប្រាស់ឱ្យដល់ប្រាំមួយឆ្នាំ។ បើប្រើប្រាស់មិនទាន់ដល់ប្រាំមួយឆ្នាំទេ លះចោលក្តី មិនបានលះចោលក្តីនូវសន្ថតនោះ ហើយឱ្យគេធ្វើសន្ថតថ្មី ដទៃទៀត សន្ថតនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះ ដល់ភិក្ខុទាំងឡាយហើយ ដោយប្រការដូច្នេះ។

[៨៧] សម័យនោះឯង ភិក្ខុមួយរូបមានជម្ងឺឈឺ នៅក្នុងនគរកោសម្ពី។ ពួកញាតិបានប្រើបម្រើទៅក្នុងសំណាក់ភិក្ខុនោះ ដោយពាក្យថា សូមលោកដ៏ចម្រើននិមន្តមក យើងខ្ញុំទាំងឡាយនឹងបានទំនុកបម្រុង។ ភិក្ខុទាំងឡាយក៏បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ លោកចូរទៅចុះ ពួកញាតិនឹងបានថែរទាំលោក។ ភិក្ខុនោះនិយាយតបយ៉ាងនេះថា អាវុសោ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទហើយថា ភិក្ខុឱ្យគេធ្វើសន្ថតថ្មីគប្បីប្រើប្រាស់ឱ្យដល់ ៦ឆ្នាំ ក៏ខ្លួនខ្ញុំមានជំងឺ មិនអាចនឹងនាំយកសន្ថតទៅបាន ខ្លួនខ្ញុំលះសន្ថតចេញហើយមិនសប្បាយទេ (ហេតុនេះ) ខ្ញុំមិនទៅទេ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយក្នុងខណៈនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យសង្ឃឲ្យសន្ថតសម្មតិដល់ភិក្ខុឈឺ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីឱ្យដោយសន្ថតសម្មតិយ៉ាងនេះ ភិក្ខុឈឺនោះគប្បីចូលទៅរកសង្ឃ គ្រងចីវរឆៀងស្មាម្ខាងហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីពោលយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាមានជម្ងឺ មិនអាចនឹងនាំយកសន្ថតទៅផងបានទេ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា នោះសូមសន្ថតសម្មតិនឹងសង្ឃ។ ភិក្ខុឈឺនោះគប្បីសូមសម្មតិអស់វារៈពីរដងផង គប្បីសូមសម្មតិអស់វារៈបីដងផង។ ភិក្ខុអ្នកឆ្លាសអង់អាចគប្បីញុំាងសង្ឃឱ្យដឹងថា បពិត្រព្រះសង្ឃ ដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជម្ងឺ មិនអាចកាន់យក សន្ថតទៅផងបានទេ។ ភិក្ខុនោះសូមសន្ថតសម្មតិនឹងសង្ឃ។ បើការសម្មតិ សន្ថតនេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឱ្យសន្ថតសម្មតិ ដល់ភិក្ខុឈ្មោះនេះ។ នេះជាវាចាប្រកាសឱ្យសង្ឃដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះមានជម្ងឺ មិនអាចកាន់ យកសន្ថតទៅផងបាន។ ភិក្ខុឈឺនោះសូមសន្ថតសម្មតិនឹងសង្ឃ។ សង្ឃឱ្យការសម្មតិសន្ថតដល់ភិក្ខុឈ្មោះនេះ។ ការឱ្យសម្មតិសន្ថតដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ សង្ឃបានឱ្យការសន្មតិសន្ថត ដល់ភិក្ខុឈ្មោះនេះហើយ។ ការសន្មតិសន្ថតនេះគួរដល់សង្ឃ ហេតុនោះ សង្ឃស្ងៀមនៅ។ ខ្ញុំចាំទុកនូវរឿងនេះដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុឱ្យគេធ្វើសន្ថតថ្មីគប្បីប្រើប្រាស់ឱ្យអស់៦ឆ្នាំ។ បើមិន ទាន់ដល់៦ឆ្នាំទេ លះចោលសន្ថតនោះក្តី មិនលះចោលក្តី ហើយឱ្យគេ ធ្វើសន្ថតថ្មីដទៃទៀត វៀរលែងតែភិក្ខុបានសម្មតិ (អំពីសង្ឃ) សន្ថតនោះ ជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[៨៨] សន្ថតដែលទើបនឹងធ្វើ ហៅថា សន្ថតថ្មី។ គ្រឿង កម្រាលដែលគេគ្រាន់តែស្មាច់មិនបានត្បាញ ហៅថា សន្ថត។ ត្រង់ពាក្យថា ឱ្យគេធ្វើនោះ គឺធ្វើឯង ឬឱ្យគេធ្វើ។ ពាក្យថា គប្បីប្រើប្រាស់ ឱ្យអស់៦ឆ្នាំ គឺគប្បីប្រើប្រាស់យ៉ាងច្រើនត្រឹម៦ឆ្នាំ។ ពាក្យថា បើមិន ទាន់ដល់៦ឆ្នាំទេ គឺថយពី៦ឆ្នាំចុះមក។ ពាក្យថា លះចោលសន្ថតនោះក្តី គឺបានឱ្យសន្ថតនោះទៅអ្នកដទៃ។ ពាក្យថា មិនលះចោលក្តី គឺ មិនបានឱ្យដល់អ្នកណានីមួយ។ ពាក្យថា វៀរលែងតែភិក្ខុដែលបាន សម្មតិ (អំពីសង្ឃ) គឺលើកលែងនូវភិក្ខុដែលបានសម្មតិ (អំពីសង្ឃ)។ (កាលប្រើប្រាស់សន្ថតចាស់មិនទាន់គ្រប់៦ឆ្នាំ) ភិក្ខុធ្វើឯងក្តី ឱ្យគេធ្វើក្តី នូវសន្ថតដទៃថ្មីទៀត ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ សន្ថតនោះជា និស្សគ្គិយក្នុងខណៈដែលបានមកភិក្ខុត្រូវលះដល់សង្ឃ ឬគណៈឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះថា។ បេ។ បពិត្រព្រះសង្ឃ ដ៏ចំរើន សន្ថតនេះខ្ញុំឱ្យគេធ្វើថ្មី (តែខ្ញុំប្រើប្រាស់សន្ថតចាស់) មិនទាន់ ដល់៦ឆ្នាំនៅឡើយ (សន្ថតថ្មី) ជានិស្សគ្គិយ ព្រោះគ្មានភិក្ខុសម្មតិ ខ្ញុំសូមលះនូវសន្ថតនេះដល់សង្ឃ។ បេ។ សង្ឃគប្បីឱ្យ។ បេ។ លោក ដ៏មានអាយុទាំងឡាយគប្បីឱ្យ។បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[៨៩] ភិក្ខុធ្វើសន្ថតដោយខ្លួនឯងមិនទាន់ហើយ (គ្រាក្រោយ) ទើបបង្ហើយដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុធ្វើសន្ថត ដោយខ្លួនឯងមិនទាន់ហើយ ឱ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុធ្វើបង្ហើយដោយខ្លួនឯង ក៏ត្រូវនិស្សគ្គិយបាចិត្តិយ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុឱ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ។

[៩០] អាបត្តិមិនមានដល់ភិក្ខុប្រើប្រាស់សន្ថតចាស់ដល់៦ឆ្នាំ ហើយធ្វើសន្ថតថ្មីទៀត មិនមានដល់ភិក្ខុប្រើប្រាស់សន្ថតចាស់លើសពី៦ឆ្នាំ ហើយធ្វើសន្ថតថ្មី មិនមានដល់ភិក្ខុធ្វើដោយខ្លួនឯង ឬឱ្យអ្នកដទៃធ្វើ ដើម្បីប្រយោជន៍ដល់អ្នកដទៃ មិនមានដល់ភិក្ខុបានសន្ថតដែលអ្នកដទៃធ្វើយកមកប្រើប្រាស់ មិនមានដល់ភិក្ខុយកសន្ថតធ្វើជាពិតានក្តី ជាកម្រាលផ្ទៃដែលគេបូកលាបក្តី ជាវាំងននក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុដែលបានសម្មតិ មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៤ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៥ (១៥)

CS vin.vbu.ni.15 | ភាគ ទី៣

### (៥. និសីទនសន្ថតសិក្ខាបទំ)

[៩១] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីនឹងលាក់ខ្លួនសម្ងំបានបីខែ អ្នកណាមួយកុំគប្បីចូល ទៅរកតថាគត លើកលែងតែភិក្ខុ១រូប ដែលជាអ្នកនាំយកនូវបិណ្ឌបាតទៅឱ្យ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាថា ព្រះករុណា ព្រះអង្គ ភិក្ខុនីមួយមិនបានចូលមករកព្រះដ៏មានព្រះភាគក្នុងទីនេះជាប្រាកដ លើកលែងតែភិក្ខុ១ រូបដែលជាអ្នកនាំយកបិណ្ឌបាតទៅថ្វាយ។ ក៏វេលានោះឯង សង្ឃក្នុងក្រុងសាវត្ថីបានប្តេជ្ញាគ្នាថា ម្នាលអាវុសោ ព្រះដ៏មានព្រះ ភាគ ប្រាថ្នាដើម្បីនឹងសម្រាកព្រះអង្គនៅបានបីខែ ភិក្ខុណាមួយកុំគប្បីចូលទៅគាល់ព្រះអង្គ លើកលែងតែភិក្ខុ១ រូប ដែលជាអ្នកនាំយកបិណ្ឌបាត ទៅថ្វាយនោះ ភិក្ខុណាចូលទៅគាល់ព្រះអង្គ ភិក្ខុដទៃត្រូវឱ្យភិក្ខុនោះសំដែងអាបត្តិបាចិត្តិយចេញ។

[៩២] គ្រានោះ ភិក្ខុឧបសេនវង្គន្តបុត្រដ៏មានអាយុព្រមដោយបរិសទ្យ បានចូលទៅគាល់សម្តេចព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយបានថ្វាយបង្គំគាល់ព្រះអង្គក្នុងទីដ៏សមគួរ។ សេចក្តីស្រុះស្រួលរាក់ទាក់មួយអន្លើដោយពួកអាគន្តុកភិក្ខុនេះ ជាកិច្ចដែលព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ ទ្រង់ប្រព្រឹត្តសន្សំទុកមកហើយ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរពាក្យនេះនឹងឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុថា ម្នាលឧបសេន អ្នករាល់គ្នាល្មមធន់ទ្រាំបានដែរឬ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលដែរឬ អ្នករាល់គ្នាដើរផ្លូវឆ្ងាយមក មិនលំបាកទេឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មាន ព្រះភាគ យើងខ្ញុំទាំងឡាយល្មមធន់ទ្រាំបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួល ម្យ៉ាងទៀត បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយដើរផ្លូវឆ្ងាយមកមិនបានលំបាកទេ។ ក៏សម័យនោះឯង ភិក្ខុជាសទ្ធិវិហារិករបស់ឧបសេនវង្គន្តបុត្រដ៏មានអាយុអង្គុយជិតព្រះដ៏មានព្រះភាគ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុនោះយ៉ាងនេះថា ម្នាលភិក្ខុ បំសុកូលទាំងឡាយជាទីគាប់ចិត្តរបស់អ្នក ដែរឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន បំសុកូលទាំងឡាយ មិនជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គទេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ក៏អ្នកប្រព្រឹត្តបំសុកូល(នោះ) ដើម្បីអ្វី។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន (ព្រោះ) ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គប្រព្រឹត្តបំសុកូល ខ្ញុំព្រះអង្គក៏ត្រូវប្រព្រឹត្តបំសុកូលយ៉ាងនោះដែរ។ គ្រានោះ ព្រះដ៏មាន ព្រះភាគទ្រង់ត្រាស់សួរភិក្ខុឧបសេនវង្គន្តបុត្រដ៏មានអាយុយ៉ាងនេះថា ម្នាលឧបសេន បរិសទ្យរបស់អ្នកនេះប្រកបដោយសេចក្តីជ្រះថ្លា ម្នាលឧបសេន អ្នកទូន្មានបរិសទ្យដូចម្តេច។ ឧបសេនភិក្ខុដ៏មានអាយុក្រាប ទូលថា បពិត្រព្រះអង្គដ៏ចំរើន កុលបុត្រណាមកសូមឧបសម្បទានឹងខ្ញុំព្រះអង្គ ៗរមែងប្រាប់កុលបុត្រនោះយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបំសុកូល បើអ្នកនឹងជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបំសុកូលដែរ ខ្ញុំនឹងឱ្យអ្នកបានឧបសម្បទា បើអ្នកណាទទួលស្តាប់ខ្ញុំព្រះអង្គ ៗនឹងឱ្យអ្នកនោះបានឧបសម្បទា បើអ្នកណាមិនទទួលស្តាប់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គមិនឱ្យអ្នកនោះបានឧបសម្បទាទេ អ្នកណាសូមនិស្ស័យនឹងខ្ញុំព្រះអង្គ ៗនឹងប្រាប់អ្នកនោះយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាអ្នក ប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបំសុកូល បើអ្នកឯងនឹងជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបំសុកូលដែរ ខ្ញុំនឹងឱ្យនិស្ស័យដល់អ្នក បើអ្នកណាទទួលស្តាប់ ខ្ញុំព្រះអង្គ ៗនឹងឱ្យនិស្ស័យដល់អ្នកនោះ បើមិនទទួលស្តាប់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គមិនឱ្យនិស្ស័យដល់អ្នកនោះទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ រមែងណែនាំបរិសទ្យដោយអាការយ៉ាងនេះឯង។ ព្រះដ៏មានព្រះភាគ ត្រាស់ប្រទានពរសាធុការថា ឧបសេន ល្អហើយៗ ឧបសេន អ្នកណែនាំបរិសទ្យល្អពិតហើយ ឧបសេន អ្នកដឹងសេចក្តីប្តេជ្ញារបស់សង្ឃ ក្នុងក្រុងសាវត្ថីដែរឬទេ។ ឧបសេនភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ។ ព្រះដ៏ មានព្រះភាគទ្រង់ត្រាស់ថាម្នាលឧបសេន សង្ឃបានប្តេជ្ញាហើយក្នុងក្រុងសាវត្ថីថា អាវុសោ ព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នាដើម្បីនឹងសម្ងំសម្រាកព្រះអង្គនៅអស់បីខែ ភិក្ខុណាមួយកុំគប្បីចូលទៅគាល់ព្រះអង្គ លើកលែងតែភិក្ខុ១ រូប អ្នកនាំយកបិណ្ឌបាតទៅថ្វាយ ភិក្ខុណាចូលទៅគាល់ព្រះអង្គ ភិក្ខុដទៃគប្បីឱ្យភិក្ខុនោះសំដែងអាបត្តិបាចិត្តិយចេញ។ ភិក្ខុឧបសេន ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃក្នុងក្រុងសាវត្ថីបានបញ្ញត្តដោយ សេចក្តីប្តេជ្ញារបស់ខ្លួន ខ្ញុំព្រះអង្គទាំងឡាយនឹងមិនបញ្ញត្តនូវហេតុដែល ព្រះអង្គមិនទាន់បានបញ្ញត្តទេ ម្យ៉ាងទៀត នឹងមិនដកចេញនូវសិក្ខាបទ ដែលទ្រង់បានបញ្ញត្តទុកហើយទេ នឹងប្រព្រឹត្តកាន់យកតាមសិក្ខាបទដែល ទ្រង់បញ្ញត្តទុកមកហើយ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ល្អណាស់ហើយឧបសេន ភិក្ខុមិនត្រូវបញ្ញត្តនូវសិក្ខាបទដែលតថាគតមិនទាន់បានបញ្ញត្តហើយ ម្យ៉ាងទៀតមិនត្រូវដកនូវសិក្ខាបទដែលតថាគតបញ្ញត្តហើយ ត្រូវប្រព្រឹត្តកាន់យកតាមសិក្ខាបទដែលតថាគតបានបញ្ញត្តទុកហើយ ឧបសេន តថាគតអនុញ្ញាតឱ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ អ្នកប្រព្រឹត្តបិណ្ឌបាត នឹងប្រព្រឹត្តបំសុកូលចូលទៅរកតថាគតតាមសប្បាយចុះ។ ក៏គ្រានោះឯង ភិក្ខុច្រើនរូបឈរនៅជិតក្លោងទ្វារខាងក្រៅបាននិយាយគ្នាថា យើងទាំងឡាយ ត្រូវឱ្យលោកឧបសេនវង្គន្តបុត្រដ៏មានអាយុសំដែងអាបត្តិបាចិត្តិយចេញ។ វេលានោះ ឧបសេនភិក្ខុវង្គន្តបុត្រដ៏មានអាយុព្រមទាំងបរិសទ្យ ក្រោកចេញចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ

ហើយចៀសចេញទៅ។ ភិក្ខុទាំងនោះបាននិយាយពាក្យនេះនឹងឧបសេនវង្គន្តបុត្រដ៏មានអាយុក្នុងវេលានោះថា អាវុសោឧបសេន អ្នកដឹង សេចក្តីប្តេជ្ញា របស់សង្ឃក្នុងក្រុងសាវត្ថីដែរឬ។ ឧបសេនភិក្ខុបាននិយាយតបថា អាវុសោ ព្រះដ៏មានព្រះភាគក៏បានត្រាស់សួរខ្ញុំយ៉ាងនេះថា ម្នាលឧបសេន អ្នកបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ខ្ញុំទូលតបថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានដឹងសេចក្តីប្តេជ្ញារបស់សង្ឃក្នុងក្រុងសាវត្ថីទេ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសេន សេចក្តីប្តេជ្ញាសង្ឃបានធ្វើហើយក្នុងក្រុងសាវត្ថីថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់ប្រាថ្នានឹងសម្ងំសម្រាកព្រះអង្គនៅអស់បីខែ ភិក្ខុ ណាមួយកុំគប្បីចូលទៅគាល់ព្រះដ៏មានព្រះភាគ លើកលែងតែភិក្ខុ១ រូប អ្នកនាំយកបិណ្ឌបាតទៅថ្វាយប៉ុណ្ណោះ ភិក្ខុណាចូលទៅគាល់ព្រះដ៏មានព្រះភាគ ភិក្ខុដទៃត្រូវឱ្យភិក្ខុនោះសំដែងអាបត្តិបាចិត្តិយចេញ ខ្ញុំទូលតបថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃក្នុងក្រុងសាវត្ថីបានបញ្ញត្តដោយសេចក្តីប្តេជ្ញារបស់ខ្លួន ខ្ញុំព្រះអង្គទាំងឡាយ នឹងមិនបញ្ញត្តនូវហេតុដែលព្រះអង្គមិនទាន់បានបញ្ញត្ត ម្យ៉ាងទៀត នឹងមិនដកនូវពុទ្ធប្បញ្ញត្តិដែលព្រះអង្គ បានបញ្ញត្តទុកស្រេចហើយ នឹងប្រព្រឹត្តកាន់យកតាមសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ម្នាលអាវុសោ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយថា ភិក្ខុទាំងឡាយណាជាអ្នកប្រព្រឹត្តនៅព្រៃ ជាអ្នក ប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តបង្សុកូល ភិក្ខុទាំងឡាយនោះចូលមករក តថាគតតាមសប្បាយចុះ។ គ្រានោះ ភិក្ខុទាំងនោះបានពោលថា ឧបសេនភិក្ខុ វង្គន្តបុត្រដ៏មានអាយុ បានពោលពាក្យពិតមែន ភិក្ខុមិនត្រូវបញ្ញត្ត នូវសិក្ខាបទដែលព្រះអង្គមិនទាន់បានបញ្ញត្ត ម្យ៉ាងទៀត មិនត្រូវដកនូវ សិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ ត្រូវប្រព្រឹត្តកាន់យកតាម សិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុកមកហើយ។

[៩៣] ភិក្ខុទាំងឡាយបានឮ (ដំណឹង)ថា ឮថាព្រះដ៏មាន ព្រះភាគទ្រង់អនុញ្ញាតឱ្យភិក្ខុអ្នកប្រព្រឹត្តនៅព្រៃ អ្នកប្រព្រឹត្តបិណ្ឌបាត អ្នកប្រព្រឹត្តបំសុកូល ចូលទៅរកតថាគតតាមសប្បាយចុះ។ ភិក្ខុទាំងនោះកាលប្រាថ្នានឹងឃើញព្រះដ៏មានព្រះភាគ ទើបលះចោលនូវសន្ថ័តទាំងឡាយ ហើយសមាទានអារញ្ញកង្គធុតង្គ បិណ្ឌបាតិកង្គធុតង្គ និងបំសុកូលិកង្គធុតង្គ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ ចារិកសេនាសនៈ ព្រមដោយភិក្ខុទាំងឡាយច្រើនរូប បានទតព្រះនេត្រឃើញនូវសន្ថ័តទាំងឡាយ ដែលពួកភិក្ខុចោលរាត់រាយក្នុងទីនោះ ៗ លុះ ទតឃើញហើយទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ហេតុអ្វី ពួកអ្នកក៏លះចោលសន្ថ័តទាំងឡាយនេះក្នុងទីនោះៗ។ ទើបភិក្ខុទាំងនោះក្រាបទូលព្រះដ៏មានព្រះភាគតាមដំណើរនុ៎ះ។ ព្រោះនិទាននេះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគទើបទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះតថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ដប់យ៉ាង គឺ ដើម្បីសេចក្តីប្រពៃដល់សង្ឃ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ១ ដើម្បីនឹងសង្កត់សង្កិននូវបុគ្គលទាំងឡាយអ្នកមានគំនិតអាក្រក់ ១ ដើម្បី នៅសប្បាយនៃភិក្ខុទាំងឡាយអ្នកមានសីលជាទីស្រឡាញ់១ ដើម្បីឃាត់ ហាមនូវអាសវៈទាំងឡាយជាបច្ចុប្បន្ន១ ដើម្បីឃាត់ហាមនូវអាសវៈទាំង ឡាយដែលនឹងមានទៅខាងមុខ១ដើម្បីសេចក្តីជ្រះថ្លានៃបុគ្គលទាំងឡាយអ្នកមិនទាន់ជ្រះថ្លា១ ដើម្បីញុំាងបុគ្គលអ្នកជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លា ឡើង១ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម ១ ដើម្បីសេចក្តីអនុគ្រោះដល់ព្រះ វិន័យ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុកាលឱ្យគេធ្វើសន្ថ័តសម្រាប់ទ្រាប់អង្គុយ គប្បីយកសន្ថ័តចាស់១ ចំអាមព្រះសុគតដោយជុំវិញ (មកផ្សំលាយនឹងសន្ថ័តថ្មី) ដើម្បីនឹងធ្វើសន្ថ័តថ្មីនោះឱ្យខូចពណ៌។ បើភិក្ខុឱ្យគេធ្វើនិសីទនសន្ថ័តថ្មី មិនយកសន្ថ័តចាស់១ ចំអាមព្រះសុគតដោយជុំវិញ (មកផ្សំលាយនឹង សន្ថ័តថ្មីទេ) សន្ថ័តនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។

[៩៤] ដែលហៅថា និសីទនៈនោះ គឺកម្រាលដែលប្រកបដោយជាយ។ ដែលហៅថា សន្ថ័តនោះ គឺកម្រាលដែលគេគ្រាន់តែស្មាច់ មិនបានត្បាញ។ ត្រង់ពាក្យថា ឱ្យគេធ្វើគឺធ្វើឯងឬឱ្យគេធ្វើ។ សន្ថ័តសូម្បីស្លៀកម្តង សូម្បីដណ្តប់ម្តង[12] ហៅថាសន្ថ័តចាស់។ ពាក្យថា គប្បីយកសន្ថ័តចាស់១ ចំអាមព្រះសុគតដោយជុំវិញ (មកលាយនឹងសន្ថ័តថ្មី) ដើម្បីធ្វើសន្ថ័តថ្មីនោះឱ្យខូចពណ៌ គឺថា ភិក្ខុត្រូវកាត់ (សន្ថ័តចាស់) ជារង្វង់មូលក្តី ជាបួនជ្រុងក្តី ហើយយកមកលាតក្រាលលាយចុះក្នុងទីមួយ ឬសិតហើយលាតក្រាលក្តី ដើម្បីធ្វើឱ្យជារបស់ខ្វាប់ខ្ជួន។ ពាក្យថា បើភិក្ខុមិនយកសន្ថ័តចាស់១ ចំអាមព្រះសុគតដោយជុំវិញ (មកលាយនឹងសន្ថ័តថ្មីទេ ) គឺថា ភិក្ខុធ្វើឯងក្តី ឱ្យគេធ្វើក្តី នូវសន្ថ័តសម្រាប់ទ្រាប់អង្គុយថ្មី មិនយកសន្ថ័តចាស់១ ចំអាមព្រះសុគតដោយជុំវិញមកលាយ ត្រូវអាបត្តិ ទុក្កដក្នុងប្រយោគដែលធ្វើ សន្ថ័តនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុគប្បីលះដល់សង្ឃ ឬគណៈ ឬបុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះ។ បេ។ បពិត្រព្រះសង្ឃដ៏ចំរើន សន្ថ័តសម្រាប់ទ្រាប់អង្គុយនេះ ខ្ញុំឱ្យគេធ្វើមិនបានកាត់យកសន្ថ័តចាស់១ ចំអាមព្រះសុគតដោយជុំវិញមកលាយ ជានិស្សគ្គិយ ខ្ញុំសូមលះសន្ថ័តនេះដល់សង្ឃ។ បេ។ សង្ឃគប្បីឱ្យ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឱ្យ។បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[៩៥] ភិក្ខុធ្វើសន្ថ័តដោយខ្លួនឯងនៅមិនទាន់ហើយ (គ្រាក្រោយ) ធ្វើឱ្យហើយដោយខ្លួនឯងម្តងទៀត ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុធ្វើខ្លួនឯងមិនទាន់ហើយ ឱ្យអ្នកដទៃបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុធ្វើឱ្យហើយដោយខ្លួនឯង ក៏ត្រូវនិស្សគ្គិយបាចិត្តិយ។ អ្នកដទៃធ្វើមិនទាន់ហើយ ភិក្ខុឱ្យអ្នកដទៃធ្វើបង្ហើយ ក៏ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុធ្វើខ្លួនឯងក្តី ឱ្យអ្នកដទៃធ្វើក្តី ដើម្បី ប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ។

[៩៦] អាបត្តិមិនមានដល់ភិក្ខុធ្វើសន្ថ័តថ្មីយកសន្ថ័តចាស់១ចំអាម ព្រះសុគតដោយជុំវិញមកលាយ មិនមានដល់ភិក្ខុកាលរកសន្ថ័តចាស់មិនបាន១ ចំអាមធ្វើលាយតែបន្តិច មិនមានដល់ភិក្ខុកាលរកសន្ថ័តចាស់បន្តិច មិនបានធ្វើ មិនបានលាយ មិនមានដល់ភិក្ខុបានសន្ថ័តដែលអ្នកដទៃធ្វើយកមកប្រើប្រាស់ មិនមានដល់ភិក្ខុធ្វើជាពិតានក្តី ជាកម្រាលផ្ទៃដែលគេ បូកលាបក្តី ជារនាំងបាំងក្តី ជាពូកក្តី ជាខ្នើយក្តី មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៥ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៦ (១៦)

CS vin.vbu.ni.16 | ភាគ ទី៣

### (៦. ឯឡកលោមសិក្ខាបទំ)

[៩៧] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ ក៏គ្រានោះឯង កាលភិក្ខុមួយរូបទៅកាន់ក្រុងសាវត្ថី ក្នុងកោសលជនបទ ក៏បានរោមចៀមជាច្រើនក្នុងពាក់កណ្តាលផ្លូវ (ដោយទាយកប្រគេន)។ ភិក្ខុនោះក៏ចង់វេចរោមចៀមទាំងឡាយនោះជាបង្វេចដោយឧត្តរាសង្គ (ចីពរ) ហើយទៅ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយនាំគ្នានិយាយចំអកថា ព្រះករុណារោមចៀមព្រះករុណាទិញមកថ្លៃប៉ុន្មាន នឹងបានចំណេញប៉ុន្មាន។ កាលមនុស្សទាំងឡាយនោះ និយាយចំអកដូច្នោះហើយ ភិក្ខុនោះក៏មានសេចក្តីអៀនខ្មាស។ លុះភិក្ខុនោះទៅដល់ក្រុងសាវត្ថី ក៏ឈរទំលាក់រោមចៀមទាំងនោះ។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកឈរទំលាក់ចោលនូវរោមចៀមទាំងនេះដើម្បីអ្វី។ ភិក្ខុនោះនិយាយតបថា អាវុសោ ព្រោះហេតុតែរោមចៀមទាំងនេះ បានជាមនុស្សទាំងឡាយនាំគ្នានិយាយចំអកខ្ញុំ ហេតុនេះឯង (ទើបខ្ញុំទំលាក់ចោលចេញ)។ ភិក្ខុទាំងឡាយនោះសួរថា ម្នាលអាវុសោ ក៏លោកនាំយករោមចៀមទាំងនេះមកអំពីទីមានចម្ងាយប៉ុន្មាន។ ភិក្ខុនោះឆ្លើយថា អាវុសោ ខ្ញុំនាំរោមចៀមទាំងនេះមកអស់ទីឆ្ងាយជាងបីយោជន៍។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមបើនឹងនាំយករោមចៀមមកឆ្ងាយជាងបីយោជន៍ដូច្នេះឡើយ។ គ្រានោះ ភិក្ខុទាំងនោះ ក៏ក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងនាំយករោមចៀមមកឆ្ងាយជាងបីយោជន៍ ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស ហេតុដូចម្តេចបានជាអ្នកឯងនាំយករោមចៀមមកកាន់ចម្ងាយផ្លូវជាងបីយោជន៍ដូច្នេះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឱ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ មិនមែនញុំាងអ្នកដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា រោមចៀមទាំងឡាយកើតឡើងដល់ភិក្ខុអ្នកដើរផ្លូវឆ្ងាយ កាលបើភិក្ខុប្រាថ្នា គប្បីទទួលយកបាន លុះទទួលហើយ បើមិនមានអ្នកនាំយកទៅឱ្យទេ គប្បីនាំយកទៅដោយដៃខ្លួនឯងកាន់ចម្ងាយផ្លូវយ៉ាងច្រើនត្រឹមបីយោជន៍ កាលបើមិនមានអ្នកនាំយកទៅឱ្យទេ ភិក្ខុនាំយករោមចៀមទៅដោយខ្លួនឯងលើសពីកំណត់នោះទៅ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[៩៨] ត្រង់ពាក្យថា ភិក្ខុអ្នកដើរផ្លូវឆ្ងាយ គឺភិក្ខុអ្នកដើរទៅតាមផ្លូវ។ ពាក្យថា រោមចៀមទាំងឡាយកើតឡើង គឺថារោមចៀមទាំងឡាយកើតឡើងអំពីសង្ឃក្តី អំពីគណៈក្តី អំពីញាតិក្តី អំពីមិត្រក្តី អំពីបង្សុកូលក្តី ដោយទ្រព្យរបស់ខ្លួនក្តី។ ពាក្យថា កាលបើភិក្ខុប្រាថ្នា គឺថា កាលបើភិក្ខុចង់បាន ត្រូវទទួលយកបាន។ ពាក្យថាលុះទទួលហើយ គប្បីនាំទៅដោយដៃខ្លួន ឯងកាន់ចម្ងាយផ្លូវយ៉ាងច្រើនត្រឹមបីយោជន៍ គឺថាភិក្ខុគប្បីនាំទៅដោយដៃខ្លួនឯងត្រឹមបីយោជន៍យ៉ាងច្រើន។ ពាក្យថា បើមិនមានអ្នកនាំយកទៅឱ្យ គឺគ្មានអ្នកដទៃនីមួយ ស្រីក្តី ប្រុសក្តី គ្រហស្ថក្តី បព្វជិតក្តី នាំយកទៅឱ្យ។ ពាក្យថា កាលបើមិនមានអ្នកនាំយកទៅឱ្យទេ ភិក្ខុនាំយករោមចៀមទៅ ដោយខ្លួនឯងលើសពីកំណត់នោះទៅ គឺថា ភិក្ខុឈានជំហ៊ានទី១ ឱ្យលើសអំពីបីយោជន៍ទៅ ត្រូវអាបត្តិទុក្កដ ឈានជំហ៊ានទី២ ឱ្យលើសទៅ រោមចៀមទាំងនោះជានិស្សគ្គិយ កាលភិក្ខុឋិតនៅក្នុងខាងក្នុងបីយោជន៍ តែចោលរោមចៀមឱ្យធ្លាក់ចុះខាងក្រៅបីយោជន៍ រោមចៀមទាំងនោះ ក៏ជានិស្សគ្គិយ ភិក្ខុដាក់ចុះនូវរោមចៀមក្នុងយានក្តី ក្នុងបង្វេចក្តី នៃអ្នកដទៃគេមិនដឹង ឱ្យកន្លងបីយោជន៍ទៅ រោមចៀមទាំងនោះ ក៏ជានិស្សគ្គិយ ភិក្ខុគប្បីលះដល់សង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីលះយ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន រោមចៀមទាំងឡាយនេះ ខ្ញុំបាននាំមកឱ្យលើសអំពីបីយោជន៍ទៅហើយ ជានិស្សគ្គិយ ខ្ញុំសូមលះនូវរោមចៀមទាំងឡាយនេះដល់សង្ឃ។បេ។ សង្ឃគប្បីឱ្យ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឱ្យ។បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[៩៩] ទីលើសអំពីបីយោជន៍ ភិក្ខុសំគាល់ថាលើសមែន ហើយនាំ រោមចៀមឱ្យលើសអំពីបីយោជន៍ទៅ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុ នោះត្រូវអាបត្តិបាចិត្តិយ។ ទីលើសអំពីបីយោជន៍ ភិក្ខុសង្ស័យហើយនាំ រោមចៀមឱ្យលើសអំពីបីយោជន៍ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ទីលើសអំពីបីយោជន៍ ភិក្ខុសំគាល់ថាមិនទាន់លើស ហើយនាំរោមចៀមឱ្យលើសអំពីបីយោជន៍ទៅ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ទីខ្វះអំពីបីយោជន៍ ភិក្ខុសំគាល់ថាលើស ត្រូវអាបត្តិទុក្កដ។ ទីខ្វះអំពីបីយោជន៍ ភិក្ខុសង្ស័យត្រូវអាបត្តិទុក្កដ។ ទីខ្វះអំពីបីយោជន៍ ភិក្ខុសំគាល់ថាខ្វះមែន មិនត្រូវអាបត្តិ។

[១០០] អាបត្តិមិនមានដល់ភិក្ខុនាំយករោមចៀមទៅត្រឹមបីយោជន៍ មិនមានដល់ភិក្ខុនាំយកទៅថយអំពីបីយោជន៍ មិនមានដល់ភិក្ខុនាំយកទៅក្តី នាំត្រឡប់មកក្តី ត្រឹមបីយោជន៍ មិនមានដល់ភិក្ខុប្រាថ្នាដើម្បីនឹងនៅ តែត្រូវទៅកាន់ទីមានចម្ងាយផ្លូវបីយោជន៍ ហើយនាំយករោមចៀមទៅកាន់ទី ដទៃចាកទីនោះ[13] មិនមានដល់ភិក្ខុត្រឡប់បានរោមចៀមដែលចោរលួចយកទៅហើយនាំយកទៅ មិនមានដល់ភិក្ខុត្រឡប់បានរោមចៀមដែលលះបង់ដោយវិនយកម្មហើយនាំយកទៅ មិនមានដល់ភិក្ខុឱ្យអ្នកដទៃនាំយកទៅ មិនមានដល់ភិក្ខុនាំយករបស់ដែលធ្វើហើយ (ធ្វើសម្រេចជាសម្ពត់កម្ពល និងព្រំ និងសន្ថ័តជាដើម) មិនមានដល់ភិក្ខុឆ្កួត មិនមានដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៦ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៧ (១៧)

CS vin.vbu.ni.17 | ភាគ ទី៣

### (៧. ឯឡកលោមធោវាបនសិក្ខាបទំ)

[១០១] សម័យនោះ សម្តេចព្រះសម្ពុទ្ធដ៏ទ្រង់យស ទ្រង់គង់ ក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងសក្កជនបទ។ គ្រានោះឯង ពួកភិក្ខុឆព្វគ្គិយប្រើនាងភិក្ខុនីទាំងឡាយឱ្យលាងខ្លះ ឱ្យជ្រលក់ខ្លះ ឱ្យសិត ឬត្រដោះខ្លះ នូវរោមចៀមទាំងឡាយ។ ភិក្ខុនីទាំងឡាយ កាល (ធ្វើកិច្ច) លាង ជ្រលក់ សិត នូវរោមចៀម (ដូច្នោះ) ទើប លះចោលនូវការរៀនសូត្របាលី អដ្ឋកថា និងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា។ គ្រានោះ នាងមហាបជាបតិគោតមីភិក្ខុនីចូល ទៅគាល់សម្តេចព្រះដ៏មានព្រះភាគ លុះចូលទៅហើយថ្វាយបង្គំព្រះដ៏ មានព្រះភាគ ហើយបានឋិតក្នុងទីដ៏សមគួរ។ ព្រះដ៏មានព្រះភាគ មានបន្ទូលនឹងនាងមហាបជាបតិគោតមី ដែលកំពុងឋិតនៅក្នុងទីដ៏សមគួរ យ៉ាងនេះថា នែព្រះនាងគោតមី នាងភិក្ខុនីទាំងឡាយជាអ្នកមិនប្រមាទ ជា អ្នកមានព្យាយាមដុតកំដៅបាប ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែរឬទេ។ ព្រះនាងមហាបជាបតិ

គោតមីទូលថា បពិត្រព្រះអង្គ ពួក នាងភិក្ខុនីមិនប្រមាទឯណាបាន លោកម្ចាស់ឆព្វគ្គិយទាំងឡាយប្រើពួក នាងភិក្ខុនីឱ្យលាងខ្លះ ឱ្យជ្រលក់ខ្លះ ឱ្យសិតខ្លះ នូវរោមចៀមទាំងឡាយ កាលបើភិក្ខុនីទាំងឡាយមានរវល់ លាង ជ្រលក់ សិត នូវរោមចៀមទាំងឡាយ (ដូច្នោះហើយ) ទើបលះចោលការរៀនសូត្របាលី អដ្ឋកថា និងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា។ លំដាប់នោះ ព្រះដ៏មាន

ព្រះភាគទ្រង់ពន្យល់ព្រះនាងមហាបជាបតិគោតមីឱ្យឃើញ ឱ្យកាន់យក ឱ្យក្លាហាន ឱ្យរីករាយ ដោយធម្មីកថា។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី កាលបើព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឱ្យឃើញ ឱ្យកាន់យក ឱ្យក្លាហាន ឱ្យរីករាយ ដោយធម្មីកថាហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅ។ ព្រោះនិទាននេះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឱ្យប្រជុំនូវភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ពួកភិក្ខុឆព្វគ្គិយថា នែភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយប្រើពួកនាងភិក្ខុនីឱ្យលាងខ្លះ ឱ្យជ្រលក់ខ្លះ ឱ្យសិតខ្លះ នូវរោមចៀមទាំងឡាយ ពិតមែនឬទេ។ ពួកភិក្ខុឆព្វគ្គិយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះ ពិតមែន។ ព្រះដ៏មានព្រះភាគ ត្រាស់សួរថា នែភិក្ខុទាំងឡាយ ពួកនាងភិក្ខុនីទាំងនោះ ជាញាតិរបស់អ្នកទាំងឡាយ ឬមិនមែន ជាញាតិ ទេ។ ពួកភិក្ខុឆព្វគ្គិយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនីទាំងនោះ មិនមែនជាញាតិទេ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែមោឃបុរសទាំងឡាយ ជនទាំងឡាយ ដែលមិនមែនជាញាតិ រមែងមិនដឹងនូវកម្មដ៏សមគួរ ឬមិនសមគួរ និងកម្មជាទីជ្រះថ្លា ឬមិនជាទីជ្រះថ្លានៃស្ត្រីទាំងឡាយដែល មិនមែនជាញាតិទេ នែមោឃបុរសទាំងឡាយ កាលបើអំពើដែលប្រកបដោយទោសយ៉ាងនេះ ពួកអ្នកក៏ហ៊ានប្រើភិក្ខុនីទាំងឡាយដែលមិនមែនជាញាតិឱ្យលាងខ្លះ ឱ្យជ្រលក់ខ្លះ ឱ្យសិតខ្លះ នូវរោមចៀមទាំងឡាយ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនមែននាំឱ្យកើត សេចក្តីជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលដែល ជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រើនាងភិក្ខុនីមិនមែនជាញាតិឱ្យលាងក្តី ឱ្យជ្រលក់ក្តី ឱ្យសិតឬត្រដោះក្តី នូវរោមចៀមទាំងឡាយ រោមចៀមនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[១០២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនីដែលមិនជាប់សាច់ញាតិអំពីចំណែកខាងមាតាក្តី អំពីចំណែកខាងបិតាក្តី ដរាបអំពីគូនៃជីដូនជីតាជាគំរប់៧ត ឈ្មោះថា មិនមែនជាញាតិ។ ស្រីបានឧបសម្បទាក្នុងឧភតោសង្ឃ[14] ឈ្មោះថា នាងភិក្ខុនី។ ភិក្ខុបង្គាប់ថា នាងចូរលាង ដូច្នេះត្រូវអាបត្តិទុក្កដ រោមចៀមដែលលាងហើយនោះ ជានិស្សគ្គិយ។ ភិក្ខុបង្គាប់ថា នាងចូរជ្រលក់ដូច្នេះ ត្រូវអាបត្តិទុក្កដ រោមចៀមដែល ជ្រលក់ហើយនោះ ជានិស្សគ្គិយ។ ភិក្ខុបង្គាប់ថា នាងចូរសិត ឬត្រដោះ ដូច្នេះ ត្រូវអាបត្តិទុក្កដ រោមចៀមដែលសិតឬត្រដោះហើយ ជានិស្សគ្គិយ រោមចៀមដែលជានិស្សគ្គិយនោះ ភិក្ខុគប្បីលះដល់សង្ឃ ឬគណៈ ឬបុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីលះយ៉ាងនេះ។ បេ។ បពិត្រព្រះសង្ឃដ៏ចំរើន រោមចៀមទាំងនេះ ខ្ញុំបានប្រើនាងភិក្ខុនីមិនមែនជាញាតិ ឱ្យលាងហើយ ជានិស្សគ្គិយ ខ្ញុំសូមលះរោមចៀមទាំងនេះដល់សង្ឃ។បេ។ សង្ឃគប្បីឱ្យ។ បេ។ លោកដ៏មានអាយុទាំងឡាយ គប្បីឱ្យ។ បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[១០៣] ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យលាងនូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឱ្យលាង ឱ្យជ្រលក់ នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដនឹងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុ សំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យលាង ឱ្យសិត នូវរោមចៀម ទាំងឡាយ ត្រូវអាបត្តិទុក្កដនិងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យលាង ឱ្យជ្រលក់ ឱ្យសិតនូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យជ្រលក់នូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវ អាបត្តិបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យជ្រលក់ ឱ្យសិត នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដ និងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យជ្រលក់ ឱ្យលាងនូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដនិងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យជ្រលក់ ឱ្យសិត ឱ្យលាង នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិ ទុក្កដពីរនឹងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនជាញាតិ ហើយប្រើឱ្យសិត នូវរោមចៀមទាំងឡាយ រោមចៀមនោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យសិត ឱ្យលាង នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដនឹងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យសិត ឱ្យជ្រលក់នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដនឹងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ហើយប្រើឱ្យសិត ឱ្យលាង ឱ្យជ្រលក់ នូវរោមចៀមទាំងឡាយ ត្រូវអាបត្តិទុក្កដពីរ និងនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសង្ស័យ។ បេ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថាជាញាតិ។ បេ។ ភិក្ខុប្រើភិក្ខុនីឱ្យលាងនូវរោមចៀមភិក្ខុដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុប្រើភិក្ខុនីដែលបានឧបសម្បទាអំពីឯកតោសង្ឃឱ្យលាង ត្រូវ អាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិអ្វីឡើយ។

[១០៤] អាបត្តិមិនមានដល់ភិក្ខុដែលឱ្យភិក្ខុនីជាញាតិលាងរោមចៀម ស្រាប់តែមានភិក្ខុនីឯទៀតមិនមែនជាញាតិ (មកកាន់យករោមចៀមអំពីដៃ ភិក្ខុនីនោះទៅលាងឱ្យ) មិនមានដល់ភិក្ខុដែលមិនប្រើ ស្រាប់តែភិក្ខុនីមិនមែនជាញាតិ យករោមចៀមទៅលាងឱ្យ មិនមានដល់ភិក្ខុដែលប្រើភិក្ខុនី មិនមែនជាញាតិឱ្យលាងភណ្ឌដទៃ ដែលធ្វើហើយនៅមិនទាន់ប្រើប្រាស់ មិនមានដល់ភិក្ខុដែលប្រើនាងសិក្ខមានាឱ្យលាង មិនមានដល់ភិក្ខុដែល ប្រើនាងសាមណេរីឱ្យលាង (នូវរោមចៀមទាំងឡាយ) មិនមានដល់ភិក្ខុ ឆ្កួត មិនមានដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី៧ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៨ (១៨)

CS vin.vbu.ni.18 | ភាគ ទី៣

### (៨. រូបិយសិក្ខាបទំ)

[១០៥] សម័យនោះ សម្តេចព្រះសម្ពុទ្ធដ៏មានបុញ្ញសិរី ទ្រង់គង់ក្នុងអារាមវេឡុវន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ គ្រានោះឯង ឧបនន្ទភិក្ខុដ៏មានអាយុ ជាសក្យបុត្តជាជីតូនរបស់ត្រកូលមួយ ជាអ្នកទទួលភត្តជានិច្ច។ ខាទនីយក្តី ភោជនីយក្តី ឯណាមួយ កើតឡើងក្នុង ត្រកូលនោះ ត្រកូលនោះតោងបែងចំណែកអំពីនោះទុកឱ្យឧបនន្ទភិក្ខុសក្យបុត្ត។ ក៏វេលានោះឯង ត្រកូលនោះបានសាច់មកក្នុងវេលាល្ងាច។ ត្រកូលនោះបានបែងចំណែកសាច់នោះទុកប្រគេនឧបនន្ទសក្យបុត្តដ៏មានអាយុ។ ក្មេងតូចនៃត្រកូលនោះភ្ញាក់ពីព្រលឹមហើយស្រែកយំទារសាច់ថា ឱ្យសាច់មកខ្ញុំ។ បុរសប្តីនោះ ទើបនិយាយនឹងប្រពន្ធយ៉ាងនេះថា នាងចូរឱ្យចំណែកសាច់របស់លោកម្ចាស់ដល់ក្មេងនេះទៅ យើងចំាទិញ សាច់ដទៃប្រគេនលោកវិញ។ វេលានោះ ឧបនន្ទសក្យបុត្តដ៏មាន អាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រចីវរ ក្នុងសម័យព្រឹកព្រហាម ហើយដើរចូលទៅកាន់ត្រកូលនោះ លុះទៅដល់ហើយ បានអង្គុយលើអាសនៈដែលគេតាក់តែងបម្រុងទុក។ បុរសនោះទើបចូលទៅរកឧបនន្ទសក្យបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ បានថ្វាយបង្គំឧបនន្ទសក្យបុត្តដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ។ កាលបុរសនោះអង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងឧបនន្ទសក្យបុត្តដ៏មានអាយុយ៉ាងនេះថា ព្រះករុណា ខ្ញុំករុណាបានសាច់ក្នុងពេលល្ងាចម្សិលមិញ ខ្ញុំបានបែង ចំណែកសាច់នោះទុកប្រគេនលោកម្ចាស់ បពិត្រលោកម្ចាស់ ក្មេងតូចនេះ ភ្ញាក់ពីព្រលឹមឡើងស្រែកយំទារថា ឱ្យសាច់មកខ្ញុំ ខ្ញុំករុណាបានយក សាច់ចំណែករបស់លោកម្ចាស់ឱ្យក្មេងតូចទៅហើយ ព្រះករុណា លោកម្ចាស់នឹងឱ្យខ្ញុំទិញអ្វីមកដោយកហាបណៈ(នេះ)។ ឧបនន្ទដ៏មានអាយុ សួរថា អាវុសោ អ្នកបរិច្ចាគកហាបណៈដល់អាត្មាឬ។ បុរសនោះ តបថា ព្រះករុណាលោកម្ចាស់ ខ្ញុំករុណាបរិច្ចាគដល់លោកម្ចាស់។ ឧបនន្ទភិក្ខុ និយាយថា អាវុសោ អ្នកចូរប្រគេនកហាបណៈនោះដល់អាត្មាចុះ។ បុរស នោះទើបប្រគេនកហាបណៈទៅឧបនន្ទសក្យបុត្តដ៏មានអាយុ ហើយពោលទោស តិះដៀល បន្តោកបន្ទាបថា យើងទាំងឡាយទទួលរូបិយ[15] បានយ៉ាងណា ពួកសមណសក្យបុត្តអម្បាលនេះ ក៏ទទួលរូបិយបានយ៉ាងនោះដែរ។ ភិក្ខុទាំងឡាយ បានឮបុរសនោះពោលទោស តិះដៀល បន្តោកបន្ទាបហើយ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ រមែងពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេចក៏ឧបនន្ទសក្យបុត្តដ៏មានអាយុទទួលយករូបិយ។ ភិក្ខុទាំងនោះ នាំគ្នាក្រាបទូលដំណើរនេះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែឧបនន្ទ ឮថាអ្នកទទួលរូបិយ ពិតមែនឬទេ។ ឧបនន្ទភិក្ខុ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទើបទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិន សមបើនឹងទទួលរូបិយទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ ឬធ្វើបុគ្គលដែល ជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ទទួលខ្លួនឯងក្តី ប្រើគេឱ្យទទួលក្តី នូវមាសប្រាក់ ឬមួយត្រេកអរនូវមាសប្រាក់ដែលគេទុកដាក់ឱ្យ មាសប្រាក់នោះ ជានិស្សគ្គិយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ។

[១០៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទ ទី១នៃបារាជិកកណ្ឌរួចហើយ។ (លោហវិសេសមានពណ៌លឿង) បីដូចជាពណ៌នៃព្រះសាស្តា ឈ្មោះថា មាស។ កហាបណៈក្តី មាសក ដែលធ្វើដោយជាតិលោហៈក្តី មាសកធ្វើដោយឈើក្តី មាសកធ្វើដោយជ័រក្តី រមែងដល់នូវវោហារ (គេចាយវាយបាន)ហៅថា ប្រាក់។ ពាក្យថា ទទួល ដោយខ្លួនឯង គឺកាន់យកដោយខ្លួនឯង មាសប្រាក់ដែលកាន់យកដោយខ្លួនឯងនោះជានិស្សគ្គិយ។ ពាក្យថា ប្រើគេឱ្យទទួល គឺញុំាងអ្នកដទៃ ឱ្យកាន់យក មាសប្រាក់នោះជានិស្សគ្គិយ។ ពាក្យថា ឬត្រេកអរនូវមាសប្រាក់ដែលគេទុកដាក់ឱ្យនោះ សេចក្តីថា ភិក្ខុត្រេកអរនូវមាសប្រាក់ដែល គេទុកដាក់ឱ្យដោយវាចាថា មាសប្រាក់នេះ ចូរជារបស់លោកម្ចាស់ចុះ មាសប្រាក់នោះជានិស្សគ្គិយ។ មាសប្រាក់នោះភិក្ខុគប្បីលះក្នុងកណ្តាលនៃសង្ឃ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះ។ ភិក្ខុនោះត្រូវចូលទៅរកសង្ឃហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីពោលយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបានទទួលនូវរូបិយ រូបិយនេះខ្ញុំត្រូវលះបង់ ខ្ញុំសូមលះបង់នូវរូបិយនេះដល់សង្ឃ។ ភិក្ខុលះហើយគប្បីសំដែងអាបត្តិចេញ។ ភិក្ខុដែលឆ្លាសអង់អាចគប្បីទទួលដឹងនូវអាបត្តិ។ បើញោមវត្តក្តី ឧបាសកក្តីមកក្នុងទីនោះ ភិក្ខុគប្បីពោលនឹងគេថា អាវុសោ អ្នកចូរដឹង នូវរូបិយនេះចុះ។ បើគេពោលថា លោកម្ចាស់ឱ្យនាំយកនូវវត្ថុអ្វីមកដោយរូបិយនេះ។ ភិក្ខុកុំគប្បីពោលថា អ្នកចូរនាំយកនូវវត្ថុនេះឬរបស់នេះមក។ ភិក្ខុគប្បីប្រាប់វត្ថុដែលគួរ គឺ សប្បិ ឬប្រេង ឬទឹកឃ្មុំ ឬស្ករអំពៅ។ បើញោមវត្ត ឬឧបាសកអ្នកចាត់ការនោះ ផ្លាស់ប្តូរដោយរូបិយនោះហើយ នាំយកវត្ថុដ៏គួរមក ភិក្ខុទាំងពួង គប្បីបរិភោគបានទាំងអស់ លើក លែងតែភិក្ខុអ្នកទទួលរូបិយមួយចេញ បើអ្នកចាត់ការនោះបានវត្ថុដែលគួរយ៉ាងនោះមក នេះជាការល្អ បើមិនបានទេ ភិក្ខុគប្បីពោលនឹងគេថា នែអ្នកដ៏មានអាយុ អ្នកចូរចោលរូបិយនេះទៅ។ បើគេចោលរូបិយនោះទៅ នេះជាការល្អ បើគេមិនចោលទេ ភិក្ខុទាំងឡាយគប្បីសន្មតភិក្ខុ (មួយរូប) ប្រកបដោយអង្គ ៥ ឱ្យជាអ្នកចោលនូវរូបិយ គឺភិក្ខុដែលមិនដល់នូវ ឆន្ទាគតិ ១ មិនដល់នូវទោសាគតិ១ មិនដល់នូវមោហាគតិ១ មិនដល់នូវ ភយាគតិ១ ស្គាល់រូបិយដែលចោលហើយ ឬនៅមិនទាន់ចោល១។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសន្មតភិក្ខុជាអ្នកចោលរូបិយយ៉ាងនេះ។ ភិក្ខុអ្នកឆ្លាសត្រូវអង្វរភិក្ខុ(អ្នកចោលរូបិយ) ជាមុន។ ភិក្ខុអ្នកឆ្លាសអង់អាចលុះអង្វររួចហើយត្រូវផ្សៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃចូរស្តាប់ខ្ញុំ បើសម្មតិកម្មនេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតិភិក្ខុឈ្មោះនេះឱ្យជាអ្នកចោលនូវរូបិយ។ នេះជាវាចាដែលប្រកាសឱ្យសង្ឃជ្រាប។ បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃចូរស្តាប់ខ្ញុំ សង្ឃសន្មតិនូវភិក្ខុឈ្មោះនេះ ឱ្យជាអ្នកចោលនូវរូបិយ។ ការសន្មតិភិក្ខុឈ្មោះនេះឱ្យជាអ្នកចោលនូវរូបិយគួរដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុ អង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មាន អាយុអង្គនោះគប្បីពោលឡើង។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតិឱ្យជាអ្នកចោលនូវរូបិយហើយ។ ការសន្មតិគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវកម្មនេះដោយអាការស្ងៀមនៅយ៉ាងនេះ។ ភិក្ខុដែលសង្ឃសន្មតិហើយនោះ មិនត្រូវកំណត់ទីហើយទើបចោលរូបិយនោះទេ។ បើភិក្ខុនោះកំណត់ទីហើយទើបទម្លាក់ចោល ត្រូវអាបត្តិទុក្កដ។

[១០៧] រូបិយ ភិក្ខុសំគាល់ថារូបិយមែន ហើយទទួលនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ រូបិយ ភិក្ខុសង្ស័យ ហើយទទួលនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ រូបិយ ភិក្ខុសំគាល់ថាមិនមែនរូបិយ ហើយទទួលនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ របស់មិនមែនរូបិយ ភិក្ខុសំគាល់ថាជារូបិយ ត្រូវអាបត្តិទុក្កដ។ របស់មិនមែនរូបិយ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ របស់មិនមែនរូបិយ ភិក្ខុសំគាល់ថា មិនមែនរូបិយ មិនត្រូវអាបត្តិ។

[១០៨] អាបត្តិមិនមានដល់ភិក្ខុដែលរើសយក ដោយខ្លួនឯងឬ ប្រើគេឱ្យរើសយកនូវរូបិយដែលធ្លាក់ចុះក្នុងអារាមក្តី ក្នុងលំនៅរបស់ខ្លួនក្តី ដោយគិតថា រូបិយនេះរបស់អ្នកណា អ្នកនោះនឹងនាំយកទៅចុះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៨ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៩ (១៩)

CS vin.vbu.ni.19 | ភាគ ទី៣

### (៩. រូបិយសំវោហារសិក្ខាបទំ)

[១០៩] សម័យនោះ ព្រះសម្ពុទ្ធដ៏ទ្រង់យស ទ្រង់គង់ក្នុងអារាមជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកភិក្ខុឆព្វគ្គិយប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្ត មិនសមបើនឹងប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ ដូចជាពួកគ្រហស្ថអ្នកបរិភោគនូវកាមទេ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះរមែងពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយមិនសមនឹងប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗទេ។ ទើបភិក្ខុទាំងនោះនាំគ្នា ក្រាបទូល ដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គមានបន្ទូលសួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ ពិតមែនឬទេ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ សម្តេចព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ពួកអ្នកមិនសមបើនឹងប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេងៗ ដូច្នោះទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លា នោះទេ ឬមួយនាំពួកអ្នកដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងមិន បានទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវ សិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយប្រព្រឹត្តទិញដូរដោយរូបិយ មានប្រការផ្សេងៗ វត្ថុដែលទិញមកនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[១១០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ មាសប្រាក់ដែលធ្វើសំរេចជារូបហើយក្តី មិនទាន់បានធ្វើជារូបក្តី ធ្វើខ្លះ មិនបានធ្វើខ្លះក្តី ហៅថា រូបិយមានប្រការផ្សេងៗ។ រូបិយដែលគេធ្វើសម្រាប់ពាក់លើក្បាលក្តី ពាក់ឰដ៏កក្តី ពាក់នឹងដៃក្តី ពាក់នឹងជើងក្តី ពាក់នឹងចង្កេះក្តី ហៅថា រូបិយធ្វើសំរេចហើយ។ រូបិយដែលនៅជាដុំ ហៅថា រូបិយគេមិនទាន់ធ្វើសំរេច។ រូបិយដែលធ្វើសំរេច ជារូបនឹងមិនទាន់ធ្វើសំរេចជារូបទាំងពីរយ៉ាងនេះ ហៅថា រូបិយគេបានធ្វើខ្លះ មិនបានធ្វើខ្លះ។ មាសក្តី កហាបណៈក្តី មាសកធ្វើដោយជាតិ លោហៈក្តី មាសកធ្វើដោយឈើក្តី មាសកធ្វើដោយជ័រក្តីនៅចាយវាយបាន ហៅថា រូបិយ។ ពាក្យថា ប្រព្រឹត្ត សេចក្តីថា ភិក្ខុទិញដូរនូវរូបិយ ដែលធ្វើសំរេចហើយ ដោយរូបិយដែលធ្វើសំរេចហើយ រូបិយនោះជា និស្សគ្គិយ។ ភិក្ខុទិញដូរនូវរូបិយដែលគេមិនទាន់ធ្វើសំរេចហើយ ដោយ រូបិយដែលគេធ្វើសំរេចហើយ រូបិយនោះជានិស្សគ្គិយ។ ភិក្ខុទិញដូរនូវ រូបិយដែលធ្វើសំរេចហើយខ្លះមិន ទាន់ធ្វើសំរេចហើយខ្លះដោយរូបិយដែល ធ្វើសំរេចហើយ រូបិយនោះជានិស្សគ្គិយ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើ សំរេចហើយ ដោយរូបិយដែលមិនទាន់ធ្វើសំរេចហើយ រូបិយនោះជា និស្សគ្គិយ។ ភិក្ខុទិញដូរនូវរូបិយដែលមិនទាន់ធ្វើសំរេចហើយ ដោយរូបិយ ដែលមិនទាន់ធ្វើសំរេចហើយ រូបិយនោះជានិស្សគ្គិយ។ ភិក្ខុទិញដូរនូវ រូបិយដែលធ្វើសំរេចហើយខ្លះ មិនទាន់ធ្វើសំរេចខ្លះ ដោយរូបិយដែលមិនទាន់ធ្វើសំរេចហើយ រូបិយនោះជានិស្សគ្គិយ។ ភិក្ខុទិញដូរនូវរូបិយដែល គេធ្វើសំរេចហើយ ដោយរូបិយដែលគេធ្វើសំរេចហើយខ្លះ មិនទាន់ធ្វើសំរេចហើយខ្លះ រូបិយនោះជានិស្សគ្គិយ។ ភិក្ខុទិញដូរនូវរូបិយដែលមិនទាន់ធ្វើសំរេច ដោយរូបិយដែលធ្វើសំរេចហើយខ្លះ នឹងមិនទាន់ធ្វើសំរេចខ្លះ រូបិយនោះជានិស្សគ្គិយ។ ភិក្ខុទិញដូរនូវរូបិយដែលធ្វើសំរេចហើយខ្លះ មិនទាន់ធ្វើសំរេចហើយខ្លះ ដោយរូបិយដែលធ្វើសំរេចហើយខ្លះ មិនទាន់ធ្វើសំរេចហើយខ្លះ រូបិយនោះជានិស្សគ្គិយ។ រូបិយដែលជានិស្សគ្គិយនោះ ភិក្ខុគប្បីលះក្នុងទីកណ្តាលនៃសង្ឃ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុគប្បីលះយ៉ាងនេះឯង។ ភិក្ខុនោះគប្បីចូលទៅរកសង្ឃហើយពាក់ចីពរឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីពោលយ៉ាងនេះ(នឹងសង្ឃ) ថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកប្រព្រឹត្តទិញដូរដោយរូបិយមានប្រការផ្សេង ៗ រូបិយវត្ថុរបស់ខ្ញុំនេះជា និស្សគ្គិយ ខ្ញុំសូមលះនូវរូបិយវត្ថុនេះដល់សង្ឃ។ លុះលះស្រេចហើយគប្បី សំដែងអាបត្តិចេញ។ ភិក្ខុអ្នកឆ្លាសអង់អាចគប្បីទទួលសំដែងអាបត្តិ។ បើញោមវត្តឬឧបាសកមកក្នុងទីនោះ ភិក្ខុទាំងឡាយគប្បីពោលនឹងគេថា អាវុសោ អ្នកចូរដឹងនូវរូបិយវត្ថុនេះចុះ។ បើគេពោលថា ពួកលោកម្ចាស់ ត្រូវការឱ្យខ្ញុំនាំយកវត្ថុអ្វីមកដោយរូបិយវត្ថុនេះ។ ភិក្ខុទាំងឡាយមិនគប្បី ពោលថា អ្នកចូរនាំយកនូវវត្ថុនេះ ឬរបស់នេះមកឡើយ។ គប្បីប្រាប់តែរបស់ដែលគួរ គឺជាសប្បិ ឬប្រេង ឬទឹកឃ្មុំ ឬស្ករអំពៅក៏បាន។ បើគេផ្លាស់ប្តូរដោយរូបិយវត្ថុនោះ ហើយនាំយករបស់ដែលគួរមក ភិក្ខុទាំងពួងគប្បីបរិភោគបាន វៀរលែងតែភិក្ខុអ្នកទិញដូរដោយរូបិយចេញ។ បើភិក្ខុបានរបស់គួរយ៉ាងនេះ នេះជាការល្អ បើមិនបានទេ គប្បីពោលនឹងគេថា អាវុសោ អ្នកចូរចោលនូវរូបិយវត្ថុនេះទៅ។ បើគេចោលទៅ នេះជាការល្អ បើគេមិនចោលទេ ភិក្ខុទាំងឡាយគប្បីសន្មតភិក្ខុ (មួយរូប) ដែលប្រកប ដោយអង្គ៥ ឱ្យជាអ្នកចោលនូវរូបិយ គឺភិក្ខុមិនដល់នូវឆន្ទាគតិ១ មិនដល់នូវទោសាគតិ១ មិនដល់នូវមោហាគតិ១ មិនដល់នូវភយាគតិ១ ដឹងនូវរូបិយ ដែលខ្លួនបានចោល និងមិនទាន់ចោល១។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បី សន្មតយ៉ាងនេះ។ ភិក្ខុអ្នកឆ្លាសត្រូវអង្វរភិក្ខុ (ជាអ្នកចោលនូវរូបិយ) ជាមុន។ ភិក្ខុអ្នកឆ្លាសអង់អាចលុះអង្វររួចហើយ ត្រូវប្រកាសសង្ឃឱ្យដឹង ដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃចូរស្តាប់ខ្ញុំ បើសម្មតិកម្មនេះ មានកាលដ៏គួរដល់សង្ឃហើយសោត សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះឱ្យជាអ្នកចោលនូវរូបិយ។ នេះជាវាចាដែលប្រកាសឱ្យសង្ឃជ្រាប។ បពិត្រព្រះ សង្ឃដ៏ចំរើន សង្ឃចូរស្តាប់ខ្ញុំ សង្ឃសន្មតនូវភិក្ខុឈ្មោះនេះ ឱ្យជាអ្នក ចោលនូវរូបិយ។ ការសន្មតិភិក្ខុឈ្មោះនេះឱ្យជាអ្នកចោលនូវរូបិយ គួរ ដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុអង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ភិក្ខុឈ្មោះនេះសង្ឃបានសន្មតឱ្យជាអ្នកចោលនូវរូបិយហើយ។ សម្មតិកម្មនេះគួរដល់សង្ឃ ហេតុនោះសង្ឃទើបស្ងៀម នៅ។ ខ្ញុំសូមចាំទុកនូវសម្មតិកម្មនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ ភិក្ខុដែលសង្ឃសន្មតនោះ កុំគប្បីកំណត់ទី ហើយចោលនូវរូបិយនោះ។ បើភិក្ខុនោះកំណត់ទីហើយចោល ត្រូវអាបត្តិទុក្កដ។

[១១១] រូបិយ ភិក្ខុសំគាល់ថារូបិយមែន ហើយទិញដូរនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ រូបិយ ភិក្ខុសង្ស័យ ហើយទិញដូរនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ រូបិយ ភិក្ខុសំគាល់ថាមិនមែនរូបិយ ហើយទិញដូរនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ មិនមែនរូបិយ ភិក្ខុសំគាល់ថារូបិយ ហើយទិញដូរនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ មិនមែនរូបិយ ភិក្ខុសង្ស័យ ហើយទិញដូរនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ មិន មែនរូបិយ ភិក្ខុសំ

គាល់ថាមិនមែនរូបិយ ហើយទិញដូរនូវរូបិយ រូបិយនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ មិនមែនរូបិយ ភិក្ខុសំគាល់ថារូបិយ ត្រូវអាបត្តិទុក្កដ។ មិនមែនរូបិយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនរូបិយ ភិក្ខុសំគាល់ថាមិនមែនរូបិយ មិនត្រូវអាបត្តិ។

[១១២] អាបត្តិមិនមានដល់ភិក្ខុឆ្កួត និងភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៩ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី១០ (២០)

CS vin.vbu.ni.20 | ភាគ ទី៣

### (១០. កយវិក្កយសិក្ខាបទំ)

[១១៣] សម័យនោះ ព្រះសម្ពុទ្ធដ៏មានយស ទ្រង់គង់ក្នុងអារាម ជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯងព្រះឧបនន្ទដ៏មានអាយុជាបុត្តនៃសក្យ ប្រសប់ធ្វើចីវរកម្ម។ ឧបនន្ទភិក្ខុនោះយកកំណាត់សម្ពត់ចាស់ៗទៅធ្វើជាសង្ឃាដិ ធ្វើកិច្ចជ្រលក់គក់បោកល្អហើយយកមកដណ្តប់។ គ្រានោះឯង បរិព្វាជកម្នាក់ដណ្តប់សម្ពត់ដ៏មានដម្លៃ ច្រើនហើយចូលទៅរកឧបនន្ទសក្យបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងឧបនន្ទសក្យបុត្តដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោ សង្ឃាដិរបស់លោកនេះល្អមែន លោកចូរប្តូរនឹងសម្ពត់របស់យើងចុះ។ ឧបនន្ទភិក្ខុនិយាយតបថា ម្នាលអាវុសោ អ្នកចូរដឹងចុះ (អ្នកមើលសិន)។ បរិព្វាជកនិយាយថា អើអាវុសោ យើងដឹង។ ឧបនន្ទភិក្ខុបានឱ្យនូវសង្ឃាដិនោះដោយវាចាថា ហ៍អាវុសោ។ បរិព្វាជកនោះទើបដណ្តប់នូវសង្ឃាដិនោះ ហើយបានទៅកាន់អារាមរបស់បរិព្វាជក។ បរិព្វាជកទាំងឡាយបាននិយាយពាក្យនេះនឹងបរិព្វាជកនោះថា ម្នាលអាវុសោ សង្ឃាដិរបស់អ្នកនេះល្អមែន អ្នកបានមកអំពីណា។ បរិព្វាជកនោះតបថា ម្នាលអាវុសោ យើងបានប្តូរដោយសម្ពត់របស់យើងនោះមក។ ពួកបរិព្វាជកសួរថា ម្នាលអាវុសោ សង្ឃាដិរបស់អ្នកនេះនឹងធន់នៅបានប៉ុន្មានថ្ងៃ ឯសម្ពត់របស់អ្នកពីមុននោះប្រសើរជាង។ បរិព្វាជកនោះទើប គិតថា បរិព្វាជកទាំងឡាយបានពោលនូវពាក្យនោះ ជាពាក្យពិតមែន សង្ឃាដិរបស់អញនេះនឹងធន់នៅបានប៉ុន្មានថ្ងៃ សម្ពត់របស់អញនោះឯងប្រសើរ ទើបចូលទៅរកឧបនន្ទសក្យបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧបនន្ទដ៏មានអាយុជាសក្យបុត្តថា ណ្ហើយចុះ អ្នកចូរយកសង្ឃាដិរបស់អ្នកទៅវិញចុះ ចូរឱ្យសម្ពត់មកយើងវិញ។ ឧបនន្ទភិក្ខុបាននិយាយថា ម្នាលអាវុសោ យើងបានប្រាប់អ្នកហើយថា អ្នកចូរដឹង (ចូរមើលសិន) ដូច្នេះ មិនមែនទេឬ យើងមិនឱ្យទេ។ ឯបរិព្វាជកនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សូម្បីគ្រហស្ថ ក៏រមែងឱ្យនូវវត្ថុនោះដល់គ្រហស្ថ ដែលមានសេចក្តីក្តៅក្រហាយដែរ ចុះហេតុអ្វី បព្វជិតត្រទ្បាំង ក៏មិនឱ្យដល់បព្វជិតដូចគ្នា។ ភិក្ខុទាំងឡាយបានឮបរិព្វាជកនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទសក្យបុត្តដ៏មានអាយុ មិនគួរនឹងប្រព្រឹត្ត ទិញដូររបស់មួយអន្លើដោយបរិព្វាជកទេ។ ភិក្ខុទាំងនោះក៏នាំគ្នាក្រាបទូលដំណើរនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ឧបនន្ទ ឮថាអ្នកឯងប្រព្រឹត្តទិញដូររបស់មួយអន្លើដោយបរិព្វាជក ពិតមែនឬ។ ឧបនន្ទភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ សម្តេចព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិនគួរនឹងប្រព្រឹត្តទិញដូររបស់មួយអន្លើដោយបរិព្វាជកទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងមិនបានទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយប្រព្រឹត្តទិញដូររបស់មានប្រការផ្សេងៗ របស់នោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[១១៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ បរិក្ខារទាំងឡាយ គឺចីវរបិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារទាំងឡាយ ដោយហោចទៅ សូម្បីតែដុំនៃលំអិត[16] សូម្បីឈើស្ទន់ សូម្បីអម្បោះរងជើង ហៅថា វត្ថុមានប្រការផ្សេងៗ។ ពាក្យថា ប្រព្រឹត្តទិញដូរ សេចក្តីថា ភិក្ខុពោលពាក្យមិនសមគួរថា អ្នកចូរឱ្យនូវវត្ថុនេះ[17] ដោយរបស់នេះចុះ អ្នកចូរនាំយកវត្ថុនេះដោយរបស់នេះចុះ អ្នកចូរប្តូរវត្ថុនេះ ដោយរបស់នេះចុះ អ្នកចូរទិញនូវវត្ថុនេះដោយរបស់នេះចុះ ត្រូវអាបត្តិទុក្កដ កាលណាបើភិក្ខុធ្វើទ្រព្យរបស់ខ្លួនឱ្យតាំងនៅក្នុងដៃនៃអ្នកដទៃ ធ្វើទ្រព្យរបស់អ្នកដទៃឱ្យមក តាំងនៅក្នុងដៃរបស់ខ្លួនវិញ ហៅថា ទិញ ហៅថា លក់ ទ្រព្យដែលភិក្ខុទិញលក់នោះជានិស្សគ្គិយ ភិក្ខុគប្បីលះដល់សង្ឃ ឬដល់គណៈ ឬដល់បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះយ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំប្រព្រឹត្តទិញដូរនូវទ្រព្យមានប្រការផ្សេងៗ ទ្រព្យរបស់ខ្ញុំនេះជានិស្សគ្គិយ ខ្ញុំសូមលះទ្រព្យនេះដល់សង្ឃ។បេ។ សង្ឃគប្បីឱ្យ។បេ។ លោកដ៏មានអាយុទាំងឡាយគប្បីឱ្យ។បេ។ ខ្ញុំឱ្យដល់លោកដ៏មានអាយុ។

[១១៥] ទ្រព្យដែលខ្លួនទិញដូរ ភិក្ខុសំគាល់ថាទិញដូរ ទ្រព្យនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសង្ស័យក្នុងទ្រព្យ ដែលខ្លួនទិញដូរ ទ្រព្យនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ទ្រព្យដែលខ្លួនទិញដូរ ភិក្ខុសំគាល់ថាមិនមែនទ្រព្យទិញដូរវិញ ទ្រព្យនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ទ្រព្យដែលខ្លួនមិនបានទិញដូរ ភិក្ខុសំគាល់ថាទ្រព្យទិញដូរវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសង្ស័យក្នុងទ្រព្យដែលខ្លួនមិនបានទិញដូរ ត្រូវអាបត្តិទុក្កដ។ ទ្រព្យដែលខ្លួនមិនបានទិញដូរ ភិក្ខុសំគាល់ថាទ្រព្យមិនបានទិញដូរ មិនត្រូវអាបត្តិ។

[១១៦] អាបត្តិមិនមាន ដល់ភិក្ខុដែលគ្រាន់តែសួរដម្លៃ ដល់ភិក្ខុដែលប្រាប់ដល់កប្បិយការក ដល់ភិក្ខុដែលពោលថា ទ្រព្យនេះរបស់យើងមាន យើងត្រូវការដោយទ្រព្យនេះផងនេះផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី១០ ចប់។

កោសិយវគ្គ ទី២ ចប់។

ចំនួននៃសិក្ខាបទក្នុងកោសិយវគ្គនោះ គឺ

ភិក្ខុធ្វើសន្ថ័តដោយរោមចៀមលាយសូត្រ១ ភិក្ខុធ្វើសន្ថ័តដោយរោមចៀមខ្មៅសុទ្ធ១ ភិក្ខុធ្វើសន្ថ័តត្រូវយករោមចៀមខ្មៅពីរភាគមកលាយ១ ភិក្ខុធ្វើសន្ថ័តថ្មីហើយត្រូវប្រើប្រាស់ឱ្យបាន៦ឆ្នាំ១ ភិក្ខុធ្វើសន្ថ័តសម្រាប់ទ្រាប់អង្គុយត្រូវកាត់យកសន្ថ័តចាស់មកលាយ១ ភិក្ខុកាន់យករោមចៀមដែលកើតឡើងពាក់កណ្តាលផ្លូវ បានតែត្រឹមបីយោជន៍១ ភិក្ខុប្រើនាងភិក្ខុនីឱ្យលាងជ្រលក់គក់រោមចៀម១ ភិក្ខុទទួលរូបិយ៍១ ភិក្ខុលក់ទិញដោយរូបិយ១ ភិក្ខុលក់ទិញផ្លាស់ប្តូរដោយកប្បិយវត្ថុ១។

# បត្តវគ្គ (ទី៣)

CS vin.vbu.ni.v3 | ភាគ ទី៣

### (៣. បត្តវគ្គោ)

## (និស្សគ្គិយ) សិក្ខាបទ ទី១ (២១)

CS vin.vbu.ni.21 | ភាគ ទី៣

### (១. បត្តសិក្ខាបទំ)

[១១៧] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានយស ទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតវន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសន្សំបាត្រទុកជាច្រើន។ មនុស្សទាំងឡាយដើរទៅវិហារបានឃើញ នាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្ត មិនសមបីបើ នឹងសន្សំបាត្រទុកជាច្រើនទេ សមណៈទាំងឡាយជាកូនចៅរបស់ព្រះពុទ្ធ ជាសក្យបុត្ត នឹងធ្វើនូវជំនួញបាត្រ ឬនឹងតាំងរានផ្សារលក់ភាជន៍ដី។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ)។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងប្រើប្រាស់អតិរេកបាត្រ[18] ឡើយ។ ខណៈនោះភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើប្រាស់អតិរេកបាត្រ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលតបថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធដ៏ទ្រង់ឥស្សរិយយស ត្រាស់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងប្រើប្រាស់អតិរេកបាត្រទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឱ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬថានាំឱ្យជ្រះថ្លាក្រៃលែង ដល់ពួកជនដែល មានសេចក្តីជ្រះថ្លារួចហើយទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយទ្រទ្រង់នូវអតិរេកបាត្រ អតិរេកបាត្រនោះជានិស្សគ្គិយ ភិក្ខុនោះត្រូវ អាបត្តិបាចិត្តិយ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគបញ្ញត្តដល់ភិក្ខុទាំងឡាយដោយប្រការដូច្នេះ។

[១១៨] សម័យនោះឯង អតិរេកបាត្រកើតឡើងដល់ព្រះអានន្ទដ៏មានអាយុ ឯព្រះអានន្ទដ៏មានអាយុប្រាថ្នានឹងប្រគេនបាត្រនោះដល់ព្រះសារីបុត្តដ៏មានអាយុ។ ចំណែកព្រះសារីបុត្តដ៏មានអាយុនៅក្រុងសាកេត។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ក៏មានបរិវិតក្កថា សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តរួចហើយថា អតិរេកបាត្រ ភិក្ខុមិនគប្បីទ្រទ្រង់ ក៏អតិរេកបាត្រនេះកើតឡើងដល់អញ ហើយអញក៏ចង់ប្រគេនបាត្រនេះដល់ព្រះសារីបុត្តដ៏មានអាយុ ឯព្រះសារីបុត្តដ៏មានអាយុគង់នៅក្រុងសាកេត (កិច្ចនេះ) ខ្លួនអញត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ខណៈនោះ អានន្ទដ៏មានអាយុបានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលអានន្ទ ប៉ុន្មានថ្ងៃទៀតសារីបុត្តនឹងមក។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ប្រហែលជា៩ ថ្ងៃ ឬ១០ថ្ងៃទៀត ទើបលោកនិមន្តមក។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ ទ្រទ្រង់នូវអតិរេកបាត្របាន១០ថ្ងៃជាកំណត់ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា អតិរេកបាត្រ ភិក្ខុទ្រទ្រង់ទុកបានត្រឹមកំណត់១០ថ្ងៃ កន្លងហួសអំពីនោះទៅ អតិរេកបាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។

[១១៩] ត្រង់ពាក្យថា ត្រឹមកំណត់១០ថ្ងៃនោះ គឺភិក្ខុគប្បីរក្សាទុកបានត្រឹម១០ថ្ងៃជាយ៉ាងច្រើន។ បាត្រដែលភិក្ខុមិនបានអធិដ្ឋាន មិនបានវិកប្បហៅថា អតិរេកបាត្រ។ ដែលហៅថាបាត្រៗនោះ មានពីរយ៉ាង គឺបាត្រដែក១ បាត្រដី១។ ខ្នាតនៃបាត្រមាន៣យ៉ាង គឺបាត្រយ៉ាងធំ បាត្រយ៉ាងកណ្តាល បាត្រយ៉ាងតូច។ បាត្រចំណុះបាយនៃអង្ករកន្លះអាឡ្ហក (គឺ២នាឡិមគធ) ចំណុះខាទនីយស្មើចំណែកបាយជាគំរប់៤ និងចំណុះម្ហូបល្មមសមគួរនឹងបាយនោះ ហៅថាបាត្រយ៉ាងធំ។ បាត្រចំណុះបាយនៃអង្ករ១នាឡិមគធៈ ចំណុះខាទនីយស្មើចំណែកបាយជាគំរប់៤ និងចំណុះម្ហូបល្មមសមគួរដល់បាយនោះ ហៅថា បាត្រយ៉ាងកណ្តាល។ បាត្រចំណុះបាយនៃអង្ករ១បត្ថ គឺកន្លះនាឡិមគធៈចំណុះ ខាទនីយស្មើចំណែកបាយជាគំរប់៤ និងចំណុះម្ហូបល្មមសមគួរដល់បាយនោះ ហៅថាបាត្រយ៉ាងតូច។ បាត្រដែលធំហួស ឬតូចហួសជាងប្រមាណនោះ មិនហៅថាបាត្រទេ។

[១២០] កាលភិក្ខុទុកបាត្រឱ្យកន្លងហួសអំពីកំណត់នោះទៅ បាត្រនោះជានិស្សគ្គិយ គឺជានិស្សគ្គិយក្នុងពេលអរុណទី១១ រះឡើងហើយ ភិក្ខុត្រូវលះបង់ដល់សង្ឃ ឬគណៈ ឬបុគ្គល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់បាត្រយ៉ាងនេះឯង។

[១២១] ភិក្ខុនោះគប្បីចូលទៅរកសង្ឃ ហើយធ្វើចីពរឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុទាំងឡាយដែលជាចាស់ រួចហើយអង្គុយច្រហោង ប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន បាត្ររបស់ខ្ញុំនេះកន្លងហួស១០ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះដល់សង្ឃ។ ភិក្ខុនោះលុះលះបង់ហើយ ត្រូវសំដែងអាបត្តិចេញ។ ភិក្ខុដែលឆ្លាសប្រតិពលគប្បីទទួលដឹងអាបត្តិ (របស់ភិក្ខុនោះ) បាត្រដែលភិក្ខុនោះលះបង់ហើយ សង្ឃត្រូវឲ្យ (ដល់លោកជាម្ចាស់ដើមវិញ) ដោយពោលពាក្យប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បាត្រនេះជារបស់ភិក្ខុឈ្មោះនេះ ជានិស្សគ្គិយ លោកបានលះបង់ហើយដល់សង្ឃ។ បើកម្មនេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឱ្យនូវបាត្រនេះដល់ភិក្ខុឈ្មោះនេះវិញ។

[១២២] ភិក្ខុអង្គនោះគប្បីចូលទៅរកពួកភិក្ខុច្រើន ហើយធ្វើចីពរឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះនឹងគណភិក្ខុថា បពិត្រលោកទាំងឡាយដ៏ចំរើន បាត្ររបស់ខ្ញុំនេះកន្លងហួស១០ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះដល់លោកដ៏មានអាយុទាំងឡាយ។ ភិក្ខុនោះលុះលះបង់ហើយ ត្រូវសំដែងអាបត្តិចេញ។ ភិក្ខុអ្នកឆ្លាសប្រតិពល គប្បីទទួលដឹងអាបត្តិ (របស់ភិក្ខុនោះ)។ បាត្រដែលភិក្ខុលះបង់ហើយ គណភិក្ខុត្រូវឱ្យ(ដល់លោកវិញ) ដោយពោលពាក្យយ៉ាងនេះថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ បាត្រនេះជារបស់ភិក្ខុឈ្មោះនេះ ជានិស្សគ្គិយ លោកបានលះបង់ហើយដល់លោកដ៏មានអាយុទាំងឡាយ។ បើកម្មនេះមានកាលដ៏សមគួរដល់លោកដ៏មានអាយុទាំងឡាយ លោកដ៏មានអាយុទាំងឡាយ គប្បីឱ្យបាត្រនេះដល់ភិក្ខុឈ្មោះនេះវិញ។

[១២៣] ភិក្ខុនោះគប្បីចូលទៅរកភិក្ខុមួយអង្គ ហើយធ្វើចីពរឆៀងស្មាម្ខាង ហើយអង្គុយច្រហោងប្រណម្យអញ្ជលី ហើយត្រូវពោលពាក្យយ៉ាងនេះ នឹងភិក្ខុមួយអង្គថា ម្នាលអ្នកដ៏មានអាយុ បាត្ររបស់ខ្ញុំនេះ កន្លងហួស១០ថ្ងៃ ជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះ ដល់លោកដ៏មានអាយុ។ លុះភិក្ខុនោះលះបង់ហើយត្រូវសំដែងអាបត្តិចេញ។ ភិក្ខុមួយអង្គនោះត្រូវទទួលដឹងអាបត្តិ (របស់ភិក្ខុនោះ)។ បាត្រដែលភិក្ខុនោះលះបង់ហើយ ត្រូវបុគ្គលនោះឱ្យវិញដោយពោលថា ខ្ញុំឱ្យបាត្រនេះដល់លោកដ៏មានអាយុវិញ។

[១២៤] បាត្រដែលកន្លងហួស១០ថ្ងៃហើយ ភិក្ខុសំគាល់ថាកន្លងហើយមែន បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលកន្លងហួស១០ថ្ងៃ តែភិក្ខុមានសេចក្តីសង្ស័យ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលកន្លងហួស១០ថ្ងៃហើយ តែភិក្ខុសំគាល់ថាមិនទាន់កន្លង បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលមិនទាន់បានអធិដ្ឋាន ភិក្ខុសំគាល់ថាបានអធិដ្ឋានហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលមិនទាន់បានវិកប្ប ភិក្ខុសំគាល់ថា បានវិកប្បហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលមិនទាន់បានលះបង់ ភិក្ខុសំគាល់ថាបានលះបង់ហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលមិនទាន់បាត់ ភិក្ខុសំគាល់ថាបាត់ហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលមិនទាន់ខូចទេ តែភិក្ខុសំគាល់ថាខូចហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលមិនទាន់បែក ភិក្ខុសំគាល់ថាបែកហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ បាត្រដែលចោរមិនទាន់ដណ្តើម ភិក្ខុសំគាល់ថាចោរដណ្តើមយកទៅហើយ បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។

[១២៥] ភិក្ខុមិនលះបង់បាត្រដែលជានិស្សគ្គិយ ហើយប្រើប្រាស់ (បាត្រនោះ) ត្រូវអាបត្តិទុក្កដ។ បាត្រដែលមិនទាន់កន្លងហួស១០ថ្ងៃភិក្ខុ សំគាល់ថាកន្លងហើយ ត្រូវអាបត្តិទុក្កដ។ បាត្រដែលមិនទាន់កន្លងហួស១០ ថ្ងៃ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ បាត្រដែលមិនទាន់កន្លងហួស១០ថ្ងៃ ភិក្ខុសំគាល់ថាមិនទាន់កន្លង ជាអនាបត្តិ។

[១២៦] អាបត្តិមិនមានដល់ភិក្ខុដែលបានអធិដ្ឋាន បានវិកប្ប បានលះបង់ឱ្យទៅគេ ដល់ភិក្ខុដែលមានបាត្របាត់វិនាសបែកទៅ ចោរដណ្តើមយកទៅ ភិក្ខុដទៃកាន់យកដោយវិស្សាសៈ ក្នុងរវាង១០ថ្ងៃ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

[១២៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ មិនបានឱ្យនូវបាត្រ ដែលភិក្ខុលះបង់ហើយទៅម្ចាស់បាត្រវិញ។ ភិក្ខុទាំងឡាយបានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាត្រដែលគេលះបង់ហើយ ភិក្ខុមិនឱ្យវិញ មិនគួរទេ ភិក្ខុណាមិនឱ្យវិញ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

សិក្ខាបទ ទី១ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី២ (២២)

CS vin.vbu.ni.22 | ភាគ ទី៣

### (២. ឩនបញ្ចពន្ធនសិក្ខាបទំ)

[១២៨] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលសំរេចឥរិយាបថក្នុងនិគ្រោធារាម ជិតក្រុងកបិលវត្ថុ នាដែនសក្កៈ។ សម័យនោះឯង ស្មូនឆ្នាំងម្នាក់បវារណាភិក្ខុទាំងឡាយដោយពាក្យថា លោកម្ចាស់ទាំងឡាយណាមានសេចក្តីត្រូវការដោយបាត្រ ខ្ញុំព្រះករុណានឹងប្រគេនបាត្រដល់លោកម្ចាស់នោះៗ។ ខណៈនោះឯង ភិក្ខុទាំងឡាយមិនដឹងប្រមាណ សូមបាត្រទាំងឡាយជាច្រើន។ ពួកភិក្ខុណាមានបាត្រតូចៗ ភិក្ខុទាំងនោះក៏សូមបាត្រធំៗ។ ពួកភិក្ខុណាដែលមានបាត្រធំៗ ភិក្ខុ ទាំងនោះក៏សូមបាត្រតូចៗ។ គ្រានោះឯង ស្មូនឆ្នាំងនោះរវល់ធ្វើបាត្រជាច្រើនប្រគេនពួកភិក្ខុ ក៏មិនអាចដើម្បីនឹងធ្វើភាជន៍សម្រាប់ចំណាយឯទៀតបាន សូម្បីនឹងរកចិញ្ចឹមខ្លួនក៏មិនបាន កូននឹងប្រពន្ធទាំងឡាយរបស់ស្មូនឆ្នាំងនោះសោតក៏ព្រួយលំបាក។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ពួកសមណៈជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្តមិនដឹងប្រមាណហើយសូមបាត្រជាច្រើន ស្មូនឆ្នាំងនេះរវល់តែធ្វើបាត្រជាច្រើនប្រគេនភិក្ខុទាំងនេះ ក៏មិនអាចដើម្បីនឹងធ្វើនូវភាជន៍ សម្រាប់ចំណាយឯទៀតបាន សូម្បីនឹងរកចិញ្ចឹមជីវិតខ្លួនក៏មិនបាន កូននឹងប្រពន្ធទាំងឡាយរបស់ស្មូនឆ្នាំងនោះសោតក៏ព្រួយលំបាក។ ភិក្ខុ ទាំងឡាយបានស្តាប់ច្បាស់ពាក្យដែលមនុស្សទាំងឡាយនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាដែលមានសេចក្តី ប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ភិក្ខុទាំងឡាយមិនដឹងប្រមាណហើយសូមបាត្រជាច្រើន។ ខណៈនោះ ពួកភិក្ខុនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយមិនដឹងប្រមាណហើយសូមបាត្រជាច្រើន ពិតមែនឬ។ ភិក្ខុទាំងឡាយទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះ ភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ គួរបើដែរ មោឃបុរសទាំងនោះមិនដឹងប្រមាណហើយសូមបាត្រជាច្រើន ម្នាលភិក្ខុទាំងឡាយ អំពើ នេះមិនមែននាំឱ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនឹងបាននាំឱ្យ រឹងរឹតតែជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាហើយក៏ទេ។ បេ។ លុះត្រាស់តិះដៀលហើយ ក៏ធ្វើនូវធម្មីកថា ត្រាស់ហៅពួកភិក្ខុមក ទើបទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសូមបាត្រឡើយ ភិក្ខុណាសូម ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

[១២៩] សម័យនោះឯង ភិក្ខុ១រូបមានបាត្របែក។ ឯភិក្ខុនោះសង្ស័យថា ការសូមបាត្រព្រះដ៏មានព្រះភាគទ្រង់ហាមហើយ មិនហ៊ានសូមបាត្រ ក៏ប្រព្រឹត្តបិណ្ឌបាតដោយដៃទទេ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅរបស់ព្រះ ពុទ្ធជាសក្យបុត្ត មិនសមបីបើនឹងចរទៅបិណ្ឌបាតដោយដៃទទេ ដូចជាពួកតិរ្ថិយសោះ។ ភិក្ខុទាំងឡាយបានស្តាប់ច្បាស់នូវពាក្យដែលមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់(ដូច្នោះ)។ ទើបភិក្ខុទាំងនោះ ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះ និទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើ ធម្មីកថា ត្រាស់ហៅពួកភិក្ខុមកហើយទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលមានបាត្របាត់ ឬមានបាត្របែក ត្រូវសូមបាត្របាន។

[១៣០] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា ព្រះដ៏មានព្រះភាគ បានទ្រង់អនុញ្ញាតឱ្យភិក្ខុដែលមានបាត្របាត់ ឬមានបាត្របែក គួរសូមបាត្របានដូច្នេះ សូម្បីមានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះគ្រាន់តែបន្តិចបន្តួច ក៏គ្មានដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន គ្រានោះ ស្មូនឆ្នាំងនោះរវល់ធ្វើបាត្រជាច្រើនប្រគេនភិក្ខុទាំងឡាយដូចកាលជាន់មុន ក៏មិនអាចនឹងធ្វើភាជន៍សម្រាប់ចំណាយឯទៀតបាន សូម្បីរកចិញ្ចឹមជីវិតខ្លួនក៏មិនកើត កូននឹងប្រពន្ធទាំងឡាយ របស់ស្មូនឆ្នាំងនោះក៏ព្រួយលំបាក។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ ដូចកាលជាន់មុនទៀតថា ហេតុអ្វីបានជាសមណៈទាំងឡាយ ជាកូនចៅរបស់ព្រះពុទ្ធជាសក្យបុត្ត មិនដឹងប្រមាណ សូមបាត្រគេជាច្រើន ស្មូនឆ្នាំងនេះរវល់តែធ្វើបាត្រជាច្រើនប្រគេនភិក្ខុទាំងនេះ ក៏មិនអាចដើម្បីនឹងធ្វើភាជន៍ដទៃសម្រាប់ចំណាយបាន សូម្បីនឹងរកចិញ្ចឹមជីវិតខ្លួនក៏មិនកើត កូននិងប្រពន្ធទាំងឡាយរបស់ស្មូនឆ្នាំងនោះសោត ក៏ព្រួយលំបាក។ ភិក្ខុទាំងឡាយ បានឮពាក្យដែលពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់(ដូច្នោះ)។ ពួកភិក្ខុណា ដែលមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីបានជាពួកឆព្វគ្គិយភិក្ខុ មានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះ គ្រាន់តែបន្តិចបន្តួច មិនដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន។ ទើបភិក្ខុទាំងនោះក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយមានបាត្របែក ឬធ្លុះ ឬដាច់ ឬស្នាមប្រេះគ្រាន់តែបន្តិចបន្តួច ក៏មិនដឹងប្រមាណ ចេះតែសូមបាត្រគេជាច្រើន ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ហេតុអ្វីបានជាអ្នកទាំងឡាយមានបាត្របែកតែបន្តិចបន្តួចខ្លះ ធ្លុះតែបន្តិចបន្តួចខ្លះ ដាច់តែបន្តិចបន្តួចខ្លះ ស្នាមប្រេះតែបន្តិចបន្តួចខ្លះ ក៏មិនដឹងប្រមាណហើយនាំគ្នាសូមបាត្រជាច្រើន ម្នាលមោឃបុរសទាំងឡាយ កម្មដែលអ្នកធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនឹងបាននាំឱ្យរឹងរឹតតែជ្រះថ្លាដល់ជនទាំងឡាយ ដែលជ្រះថ្លាហើយក៏ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមានបាត្រមិនទាន់មានចំណងគ្រប់៥អន្លើ ឱ្យគេរកបាត្រថ្មីទៀត (បាត្រនោះ) ជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនោះត្រូវលះបង់បាត្រនោះក្នុងភិក្ខុបរិសទ្យ។ បាត្រណាជាទីបំផុតរបស់ភិក្ខុបរិសទ្យនោះ បាត្រនោះភិក្ខុដែលបានសន្មត ត្រូវប្រគល់បាត្រនោះ ឱ្យដល់ភិក្ខុនោះដោយពាក្យថា ម្នាលភិក្ខុ នេះបាត្ររបស់លោកៗ គប្បីប្រើប្រាស់ត្រាតែបែក។ នេះជាសាមីចិកម្ម(គឺការប្រពៃ) ក្នុងការលះបង់បាត្រនោះ។

[១៣១] ត្រង់ពាក្យថា ភិក្ខុណាមួយមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌ។ បាត្រដែលគ្មានចំណង ឬមានចំណងតែមួយអន្លើ ឬពីរអន្លើ បីអន្លើ បួនអន្លើ ហៅថាបាត្រមានចំណងមិនទាន់ដល់៥អន្លើ។ បាត្រដែលមានស្នាមប្រេះបែកមិនទាន់ដល់ពីរធ្នាប់ ហៅថាបាត្រមិនទាន់មានឱកាសនៃចំណង។ បាត្រដែលមានស្នាមប្រេះបែកប្រមាណដល់ពីរធ្នាប់ ហៅថាបាត្រមានឱកាសនៃចំណង (មួយអន្លើ)។ ដែលហៅថាបាត្រថ្មី សំដៅយកការសូមបាត្រជាប្រមាណ។ ពាក្យថា ឱ្យគេរក សេចក្តីថា ភិក្ខុសូមបាត្រ ត្រូវអាបត្តិទុក្កដតាមប្រយោគ បាត្រនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ក្នុងកណ្តាលសង្ឃ។ ភិក្ខុទាំងពួងត្រូវយកបាត្រដែលភិក្ខុបានអធិដ្ឋានហើយទៅប្រជុំគ្នា។ ភិក្ខុមិនត្រូវអធិដ្ឋានបាត្រអាក្រក់ទុកដោយគិតថា អញនឹងយកបាត្រថ្លៃច្រើន។ បើភិក្ខុអធិដ្ឋានបាត្រអាក្រក់ទុកដោយគិតថា អញនឹងយកបាត្រថ្លៃច្រើន ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់បាត្រយ៉ាងនេះ

[១៣២] ភិក្ខុនោះត្រូវចូលទៅរកសង្ឃ ធ្វើចីពរឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យ អញ្ជលីហើយពោលនឹងសង្ឃយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើនបាត្រ(ថ្មី) របស់ខ្ញុំនេះ គឺខ្ញុំមានបាត្រ (ចាស់) មិនទាន់មានចំណងគ្រប់៥អន្លើ ខ្ញុំឱ្យគេរកបាត្រទៀត បាត្រនេះជានិស្សគ្គិយ ខ្ញុំសូមលះបង់បាត្រនេះដល់សង្ឃ។ លុះភិក្ខុលះបង់បាត្ររួចហើយ ត្រូវសំដែងអាបត្តិចេញ។ ភិក្ខុអ្នកឈ្លាសអង់អាចត្រូវទទួលអាបត្តិ។ សង្ឃត្រូវសន្មតភិក្ខុ ដែលប្រកបដោយអង្គ៥ ឱ្យជាអ្នកប្រគល់បាត្រ គឺភិក្ខុណាមួយដែលមិនបានប្រព្រឹត្តទៅដោយឆន្ទាគតិ១ ទោសាគតិ១ មោហាគតិ១ ភយាគតិ១ ដឹងនូវបាត្រដែលគេបានទទួល និងមិនទាន់បានទទួល១។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ។ ភិក្ខុឈ្លាសត្រូវអង្វរភិក្ខុ (នោះ) ជាមុន។ លុះភិក្ខុឈ្លាសប្រតិពលអង្វររួចហើយ គប្បីប្រកាសឱ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មនេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះឱ្យជាអ្នកប្រគល់បាត្រ។ នេះវាចាប្រកាសសង្ឃឱ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ព្រះសង្ឃសន្មតភិក្ខុឈ្មោះនេះ ឱ្យជាអ្នកប្រគល់បាត្រ។ ការសន្មតិភិក្ខុឈ្មោះនេះ ឱ្យជាអ្នកប្រគល់បាត្រ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវពោលឡើង។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះឱ្យជាអ្នកប្រគល់បាត្រហើយ។ ការសន្មតិនេះសមគួរដល់សង្ឃ ហេតុនោះបានជាព្រះសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ។ ភិក្ខុដែលសង្ឃសន្មតហើយនោះ ត្រូវប្រគល់បាត្រ (ឱ្យព្រះថេរៈ)។ ភិក្ខុនោះត្រូវប្រាប់ព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈទទួលយកបាត្រចុះ។ បើព្រះថេរៈទទួល (បាត្រនោះ ) ភិក្ខុនោះត្រូវយកបាត្ររបស់ព្រះថេរៈប្រគល់ឱ្យភិក្ខុទីពីរ ព្រះថេរៈមិនត្រូវខានទទួលយកបាត្រនោះទេ ដោយសេចក្តីអាណិតភិក្ខុនោះ ភិក្ខុណាមួយមិនទទួល ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះមិនត្រូវប្រគល់បាត្រដល់ភិក្ខុដែលគ្មានបាត្រទេ។ ភិក្ខុនោះត្រូវប្រគល់បាត្រដោយឧបាយនេះ ត្រាតែដល់ភិក្ខុខ្ចីក្នុងសង្ឃ។ បាត្រណាមួយដែលជាទីបំផុតរបស់ភិក្ខុបរិសទ្យនោះ ភិក្ខុដែលសង្ឃបានសន្មតនោះត្រូវប្រគល់បាត្រឱ្យទៅភិក្ខុនោះដោយពាក្យថា នែភិក្ខុ បាត្ររបស់លោកនេះ លោកចូរប្រើប្រាស់ត្រាតែបែក។ ភិក្ខុនោះមិនត្រូវទុកបាត្រនោះក្នុងទីមិនគួរ មិនត្រូវប្រើប្រាស់បាត្រនោះ ដោយការប្រើប្រាស់មិនសមគួរ មិនត្រូវចោលបាត្រនោះឡើយ ដោយពាក្យថា បាត្រនេះអប្រិយណាស់ បាត់ទៅចុះ ខូចទៅចុះ ឬបែកទៅចុះ បើភិក្ខុទុកដាក់ក្នុងទីមិនគួរក្តី ប្រើប្រាស់ដោយការប្រើប្រាស់មិនសមគួរក្តី លះបង់ចោលទៅក្តី ត្រូវអាបត្តិទុក្កដ។ ពាក្យថា នេះជាសាមីចិកម្ម (គឺការប្រពៃ) ក្នុងការលះបង់បាត្រនោះ គឺថាពាក្យនេះជាពាក្យសមគួរតាមធម៌ក្នុងរឿងលះបង់បាត្រនោះ។

[១៣៣] ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រគ្មានចំណាងត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង(បើ) សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រមានចំណាងតែពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមិនទាន់មានចំណាង (បើ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រគ្មានចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រមានចំណាងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ (បើ) សុំបាត្រគ្មានចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ (បើ)សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ (បើ) សុំបាត្រមានចំណាងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ (បើ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ (បើ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ (បើ) សុំបាត្រឥតចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ (បើ) សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ(បើ)សុំបាត្រមានចំណាងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ (បើ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ (បើ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបួនអន្លើ (បើ) សុំបាត្រឥតចំណាង ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបួនអន្លើ (បើ) សុំបាត្រមានចំណាងតែមួយអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបួនអន្លើ (បើ) សុំបាត្រមានចំណាងពីរអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបួនអន្លើ (បើ) សុំបាត្រមានចំណាងបីអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបួនអន្លើ (បើ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។

[១៣៤] ភិក្ខុមានបាត្រគ្មានចំណាង (បើ) សុំបាត្រគ្មានឱកាសនៃចំណាង... (បើ) សុំបាត្រមានឱកាសនៃចំណាងតែមួយអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងពីរអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបីអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងតែមួយអន្លើ (បើ) សុំបាត្រគ្មានឱកាសនៃចំណាង... (បើ) សុំបាត្រមានឱកាសនៃចំណាងតែមួយអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងពីរអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបីអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងពីរអន្លើ (បើ) សុំបាត្រគ្មានឱកាសនៃចំណាង... (បើ) សុំបាត្រមានឱកាសនៃចំណាងតែមួយអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងពីរអន្លើ... (បើ)សុំបាត្រមានឱកាសនៃចំណាងបីអន្លើ...(បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបីអន្លើ (បើ) សុំបាត្រគ្មានឱកាសនៃចំណាង...(បើ) សុំបាត្រមានឱកាសនៃចំណាងតែមួយអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងពីរអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបីអន្លើ...(បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានចំណាងបួនអន្លើ (បើ) សុំបាត្រគ្មានឱកាសនៃចំណាង...(បើ) សុំបាត្រមានឱកាសនៃចំណាងតែមួយអន្លើ...(បើ) សុំបាត្រមានឱកាសនៃចំណាងពីរអន្លើ...(បើ) សុំបាត្រមានឱកាសនៃចំណាងបីអន្លើ...(បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។

[១៣៥] ភិក្ខុមានបាត្រគ្មានឱកាសនៃចំណាង (បើ)សុំបាត្រឥតចំណាង...បាត្រមានចំណាងតែមួយអន្លើ... បាត្រមានចំណាងពីរអន្លើ...បាត្រមានចំណាងបីអន្លើ...(បើ)សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាងតែមួយអន្លើ (បើ)សុំបាត្រគ្មានចំណាង...បាត្រមានចំណាងតែមួយអន្លើ...បាត្រមានចំណាងពីរអន្លើ...បាត្រមានចំណាងបីអន្លើ... (បើ)សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាងពីរអន្លើ (បើ) សុំបាត្រឥតចំណាង...បាត្រមានចំណាងតែមួយអន្លើ... បាត្រមានចំណាងពីរអន្លើ...បាត្រមានចំណាងបីអន្លើ... (បើ)សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាងបីអន្លើ(បើ) សុំបាត្រឥតចំណាង...បាត្រមានចំណាងតែមួយអន្លើ... បាត្រមានចំណាងពីរអន្លើ...បាត្រមានចំណាងបីអន្លើ...(បើ)សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាងបួនអន្លើ (បើ) សុំបាត្រឥតចំណាង...បាត្រមានចំណាងតែមួយអន្លើ... បាត្រមានចំណាងពីរអន្លើ...បាត្រមានចំណាងបីអន្លើ...(បើ) សុំបាត្រមានចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។

[១៣៦] ភិក្ខុមានបាត្រឥតឱកាសនៃចំណាង(បើ) សុំបាត្រឥតឱកាសនៃចំណាង...បាត្រមានឱកាសនៃចំណាងតែមួយអន្លើ... បាត្រមានឱកាសនៃចំណាងពីរអន្លើ...បាត្រមានឱកាសនៃចំណាងបីអន្លើ... (បើ)សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាងតែមួយអន្លើ (បើ) សុំបាត្រឥតឱកាសនៃចំណាង...បាត្រមានឱកាសនៃចំណាងតែមួយអន្លើ... បាត្រមានឱកាសនៃចំណាងពីរអន្លើ... បាត្រមានឱកាសនៃចំណាងបីអន្លើ...(បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រ មានឱកាសនៃចំណាងពីរអន្លើ (បើ) សុំបាត្រឥតឱកាសនៃចំណាង. . .។ មានឱកាសនៃចំណាងមួយអន្លើ ... បាត្រមានឱកាសនៃចំណាងពីរអន្លើ... បាត្រមានឱកាសនៃចំណាងបីអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាងបីអន្លើ(បើ) សុំបាត្រឥតឱកាសនៃចំណាង... បាត្រមានឱកាសនៃចំណាងតែមួយអន្លើ... បាត្រមានឱកាសនៃចំណាងពីរអន្លើ... បាត្រមានឱកាសនៃចំណាងបីអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិបាចិត្តិយ។ ភិក្ខុមានបាត្រមានឱកាសនៃចំណាងបួនអន្លើ (បើ) សុំបាត្រឥតឱកាសនៃចំណាង... បាត្រមានឱកាសនៃចំណាងតែមួយអន្លើ...បាត្រមានឱកាសនៃចំណាងពីរអន្លើ... បាត្រមានឱកាសនៃចំណាងបីអន្លើ... (បើ) សុំបាត្រមានឱកាសនៃចំណាងបួនអន្លើ ត្រូវនិស្សគ្គិយបាចិត្តិយ។

[១៣៧] អាបត្តិមិនត្រូវដល់ភិក្ខុដែលមានបាត្របាត់ ដល់ភិក្ខុមានបាត្របែក ដល់ភិក្ខុសុំបាត្រអំពីសំណាក់ពួកញាតិ ដល់ភិក្ខុសុំបាត្រអំពីសំណាក់ពួកជនដែលបវារណា ដល់ភិក្ខុសុំបាត្រដើម្បីឱ្យអ្នកដទៃ ដល់ភិក្ខុបានបាត្រមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី២ ចប់។

# (និស្សគ្គិយ) សិក្ខាបទ ទី៣ (២៣)

CS vin.vbu.ni.23 | ភាគ ទី៣

### (៣. ភេសជ្ជសិក្ខាបទំ)

[១៣៨] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលគង់ក្នុងវិហារជេតពន ដែលជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ក្បែរក្រុងសាវត្ថី។ គ្រានោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុប្រាថ្នានឹងធ្វើទីជ្រកកោន ទើបឱ្យគេជម្រះសំអាតញកភ្នំក្បែរក្រុងរាជគ្រឹះ។ លំដាប់នោះ ព្រះបាទពិម្ពិសារ សេនិយរាជ[19] ជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុ លុះព្រះរាជដំណើរទៅដល់ហើយ ក៏បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរ។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់គង់នៅក្នុងទីសមគួរហើយ ទើបមានព្រះរាជឱង្ការនឹងបិលិន្ទវច្ឆត្ថេរដ៏មានអាយុថា លោកម្ចាស់ លោកឱ្យគេធ្វើអ្វី។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ អាត្មាភាពចង់ធ្វើកន្លែងជ្រកកោន បានជាឱ្យគេជម្រះសំអាតញកភ្នំ។ ទ្រង់ក៏សួរថា លោកម្ចាស់ដ៏ចំរើន លោកម្ចាស់ត្រូវការអារាមិកជន (មនុស្សថែទាំរក្សាអារាម) ឬទេ។ ព្រះថេរថ្វាយព្រះពរថា បពិត្រមហារាជ អារាមិកជន ព្រះដ៏ទ្រង់ព្រះភាគ មិនទាន់ទ្រង់អនុញ្ញាតនៅឡើយទេ។ ទ្រង់ត្រាស់ថា លោកម្ចាស់ បើដូច្នោះ លោកម្ចាស់គួរទូលសួរព្រះដ៏ទ្រង់ព្រះភាគ ហើយសិមមកប្រាប់ញោម។ បិលិន្ទវច្ឆត្ថេរដ៏មានអាយុក៏ទទួលព្រះរាជឱង្ការព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈថា ថ្វាយព្រះពរមហារាជ។ ខណៈនោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុបានពន្យល់ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈឱ្យទ្រង់ឃើញច្បាស់ ឱ្យទ្រង់សមាទាន ឱ្យទ្រង់ក្លៀវក្លាឱ្យ ទ្រង់រីករាយដោយធម្មីកថា។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ដែលបិលិន្ទវច្ឆត្ថេរដ៏មានអាយុបានឱ្យទ្រង់ឃើញជាក់ស្តែង ឱ្យទ្រង់សមាទាន ឱ្យទ្រង់ក្លៀវក្លា ឱ្យទ្រង់រីករាយ ដោយធម្មីកថាហើយ ទ្រង់ក៏ក្រោកចាកអាសនៈបង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយទ្រង់ធ្វើប្រទក្សិណយាត្រាចេញទៅ។ លំដាប់នោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុប្រើបម្រើទៅកាន់សំណាក់ព្រះដ៏មានព្រះភាគម្ចាស់ថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទពិម្ពិសារ សេនិយរាជ ជាធំក្នុងដែនមគធៈទ្រង់ចង់ប្រទានអារាមិកជនឱ្យបពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគួរបដិបត្តិដូចម្តេច។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគម្ចាស់ឱ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សំដែងធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតអារាមិកជន។ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុជាគំរប់ពីរដង លុះយាងចូលទៅហើយ ទើបទ្រង់បង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយគង់នៅក្នុងទីសមគួរមួយ។ លុះព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈគង់ស្រួលបួលហើយ មានព្រះបន្ទូលនឹងបិលិន្ទវច្ឆត្ថេរដ៏មានអាយុថា បពិត្រលោកម្ចាស់ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់អនុញ្ញាតអារាមិកជនហើយឬ។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ ព្រះអង្គបានអនុញ្ញាតហើយ។ ទ្រង់ត្រាស់ថា បពិត្រលោកដ៏ចំរើន បើដូច្នោះញោមប្រគេនអារាមិកជនម្នាក់ដល់លោកម្ចាស់។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈទ្រង់ប្តេជ្ញាថាប្រគេនអារាមិកជនដល់បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយក៏ភ្លេចព្រះស្មារតី យូរបន្តិចទៅ ទ្រង់រលឹកឃើញវិញ ទើបទ្រង់ត្រាស់ហៅមហាអាមាត្យម្នាក់ជាអ្នកសម្រេចរាជការទាំងពួងថា នែមហាអាមាត្យ អារាមិកជនណាដែលយើងបម្រុងនឹងប្រគេនលោកម្ចាស់ អារាមិកជននោះ យើងបានប្រគេនលោកហើយឬ។ មហាអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព អារាមិកជន ទ្រង់មិនទាន់ប្រគេនដល់លោកម្ចាស់នៅឡើយទេ។ ស្តេចត្រាស់សួរថា នែមហាអាមាត្យ រាប់ពីរាត្រីនេះទៅ បានប៉ុន្មានរាត្រីហើយ។ លំដាប់នោះ មហាអាមាត្យនោះបានរាប់រាត្រីសព្វគ្រប់ហើយ ក្រាបទូលព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព បាន៥០០ រាត្រីហើយ។ ស្តេចត្រាស់ថា នែមហាអមាត្យ បើដូច្នេះ អ្នកចូរប្រគេនអារាមិកជន៥០០នាក់ទៅលោកម្ចាស់ចុះ។ មហាអមាត្យនោះទទួលព្រះរាជឱង្ការព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈថា សូមទ្រង់មេត្តាប្រោសយ៉ាងហ្នឹងហើយ ៗបានប្រគេនអារាមិកជន៥០០នាក់ ដល់បិលិន្ទវច្ឆត្ថេរដ៏មានអាយុ។ ទីនោះបានជាស្រុកមួយផ្សេងដោយឡែក។ ជនទាំងឡាយហៅស្រុកនោះថា អារាមិកគ្រាមខ្លះ ហៅថាបិលិន្ទវច្ឆគ្រាមខ្លះ។

[១៣៩] សម័យនោះឯង បិលិន្ទវច្ឆត្ថេរដ៏មានអាយុជាជីតុនក្នុងស្រុកនោះ។ គ្រានោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរចូលទៅបិណ្ឌបាតក្នុងបិលិន្ទវច្ឆគ្រាម នាវេលាព្រឹកព្រហាម។ សម័យនោះឯង មានល្បែងមហោរស្រពក្នុងស្រុកនោះ។ ពួកក្មេងៗបានប្រដាប់តាក់តែងដោយផ្កាកម្រងលេងមហោរស្រព។ លំដាប់នោះបិលិន្ទវច្ឆត្ថេរដ៏មានអាយុ កំពុងត្រេចទៅបិណ្ឌបាត តាមលំដាប់ច្រកក្នុងបិលិន្ទវច្ឆគ្រាម បានចូលទៅកាន់លំនៅរបស់អារាមិកជនម្នាក់ លុះចូលទៅហើយ ទើបអង្គុយលើអាសនៈដែលគេរៀបចំប្រគេន។ សម័យនោះឯង ធីតារបស់ស្រីរក្សាអារាមនោះឃើញទារកឯទៀតៗ ប្រដាប់តាក់តែងដោយផ្កាកម្រង ហើយក៏យំសុំថា ម៉ែចូរឱ្យផ្កាកម្រងមកខ្ញុំ ម៉ែចូរឱ្យគ្រឿងប្រដាប់ មកខ្ញុំ។ គ្រានោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ បាននិយាយពាក្យនេះនឹងស្រីរក្សាអារាមនោះថា នាងទារិកានេះយំទារអ្វី។ ស្រីរក្សាអារាម ទូលថាលោកម្ចាស់ នាងទារិកានេះឃើញទារកឯទៀត ៗប្រដាប់តាក់តែង ដោយផ្កាកម្រង បានជាយំទារថា ម៉ែចូរឱ្យផ្កាកម្រងមកខ្ញុំ ម៉ែចូរឱ្យគ្រឿងប្រដាប់មកខ្ញុំ យើងខ្ញុំជាអ្នកក្រលំបាក នឹងបានផ្កាកម្រងមកពីណា នឹងបានគ្រឿងប្រដាប់មកពីណា។ ខណៈនោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុចាប់រង្វេលស្មៅ១ ហើយនិយាយពាក្យនេះនឹងស្រីរក្សាអារាមនោះថា ហ៏! នាងចូរបំពាក់រង្វេលស្មៅនេះលើក្បាលរបស់ក្មេងស្រីនោះចុះ។ ពេលនោះ ស្រីរក្សាអារាមនោះ យករង្វេលស្មៅនោះបំពាក់លើក្បាលរបស់នាងទារិកានោះ។ រង្វេលស្មៅនោះក៏ក្លាយជាកម្រងមាសល្អល្អះ មុខគួរពិតពិលរមិលមើល ជារបស់គួរស្រឡាញ់។ កម្រងមាសបែបនោះ សូម្បីក្នុងព្រះរាជវាំងស្តេច ក៏រកគ្មានដែរ។ មនុស្សទាំងឡាយទៅក្រាបទូលព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈថា បពិត្រសម្មតិទេព កម្រងមាសក្នុងផ្ទះរបស់អារាមិកជនឯណោះល្អល្អះ មុខគួរពិតពិលរមិលមើល ជារបស់គួរស្រឡាញ់ សូម្បីក្នុងព្រះរាជវាំងរបស់ព្រះអង្គក៏ពុំមានកម្រងមាសដូច្នេះដែរមនុស្សខ្សត់ទុរគតនោះនឹងបានកម្រងមាសមកពីណា ច្បាស់ជាវាលួចយករបស់គេ ជាប្រាកដ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែលមគធៈទ្រង់ឱ្យរាជបុរស ទៅកោះពួកត្រកូលអារាមិកជននោះមក។ វេលាព្រឹកព្រហាម បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រ នឹងចីវរចូលទៅបិណ្ឌបាតនាបិលិន្ទវច្ឆគ្រាមជាគំរប់ពីរដង កាលដើរទៅបិណ្ឌបាត ក្នុង បិលិន្ទវច្ឆគ្រាមជាលំដាប់ៗទៅ ទើបចូលទៅកាន់លំនៅរបស់អារាមិកជននោះ លុះចូលទៅដល់ហើយ សួរពួកជនដែលជាទីស្និទ្ធស្នាលថា ត្រកូលអារាមិកជននេះទៅណាទៅ។ ពួកជនពិតថា លោកម្ចាស់ស្តេចឱ្យរាជបុរស មកចាប់ចងយកទៅហើយ ព្រោះហេតុតែកម្រងមាសនោះឯង។ លំដាប់នោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុ ក៏ចូលទៅកាន់ព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារសេនិយរាជធំក្នុងដែនមគធៈ លុះទៅដល់ហើយគង់លើអាសនៈដែលគេតាក់តែងប្រគេន។ គ្រានោះព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ទ្រង់យាងចូលទៅរកបិលិន្ទវច្ឆត្ថេរដ៏មានអាយុ លុះដល់ហើយក៏ថ្វាយបង្គំបិលិន្ទវច្ឆត្ថេរដ៏មានអាយុហើយគង់នៅក្នុងទីសមគួរ។ លុះព្រះបាទពិម្ពិសារសេនិយរាជជា

ធំក្នុងដែនមគធៈ ទ្រង់គង់ស្រួលបួលហើយ ទើបបិលិន្ទវច្ឆត្ថេរដ៏មានអាយុថ្វាយព្រះពរថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គឱ្យរាជបុរសទៅចាប់ត្រកូលអារាមិកជនមកឃុំ។ ព្រះបាទពិម្ពិសារត្រាស់ថា លោកម្ចាស់ នាផ្ទះរបស់ អារាមិកជននោះ មានកម្រងមាសល្អល្អះ មុខគួរពិតពិលរមិលមើលជារបស់មានដំឡៃ សូម្បីក្នុងរាំងរបស់ញោម ក៏មិនមានកម្រងមាសដូច្នោះដែរ អ្នកខ្សត់ទុរគតនោះ នឹងបានកម្រងមាសមកពីណា ច្បាស់ជាវាលួចយករបស់គេហើយ។ ខណៈនោះ បិលិន្ទវច្ឆត្ថេរដ៏មានអាយុក៏អធិដ្ឋាន ប្រាសាទរបស់ព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈ ឱ្យក្លាយជាមាសទៅ។ ប្រាសាទទាំងនោះក៏ក្លាយទៅជាមាសទាំងអស់។ បិលិន្ទវច្ឆត្ថេរថ្វាយព្រះពរថា បពិត្រមហារាជ មាសនេះច្រើនដល់ម្ល៉េះ ព្រះអង្គបានមកពីណា។ ស្តេចត្រាស់ថាខ្ញុំមិនដឹងទេ លោកម្ចាស់ របស់ទាំងនេះប្រហែលជាសម្រេចដោយឥទ្ធានុភាព[20] របស់លោកម្ចាស់ទេដឹង ហើយត្រាស់ឱ្យដោះលែងត្រកូលអារាមិកជននោះទៅ។

[១៤០] មនុស្សទាំងឡាយឮដំណឹងថា បិលិន្ទវច្ឆត្ថេរជាម្ចាស់ បានសំដែងឥទ្ធិបាដិហារិយៈ (ឥទ្ធិឫទ្ធិដ៏អស្ចារ្យចំឡែក) ជាមនុស្សធម៌ដ៏ខ្ពង់ខ្ពស់ដល់បរិស័ទ្យ ព្រមទាំងព្រះរាជា ហើយក៏មានចិត្តត្រេកអរជ្រះថ្លា នាំយកនូវភេសជ្ជៈ៥ យ៉ាងមកបូជាបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ភេសជ្ជៈ ៥ នោះគឺ សប្បិ(ទឹកដោះរាវ) នវនីតៈ(ទឹកដោះខាប់) តេលៈ(ប្រេង) មធុ(ទឹកឃ្មុំ) ផាណិតៈ(ទឹកអំពៅ ឬស្ករអំពៅ)។ ឯបិលិន្ទវច្ឆត្ថេរដ៏មានអាយុតែងបានភេសជ្ជៈ៥ ហើយរមែងចែករបស់ដែលលោកបានមកៗ ទៅដល់បរិស័ទ្យ (សិស្សរបស់លោក) ដោយប្រក្រតី។ ឯបរិស័ទ្យរបស់ លោកនោះតែងបានភេសជ្ជៈទាំងនោះច្រើនរឿយៗ បានដាក់ទុករបស់ដែលបានមកៗ ក្នុងថ្លាងផង ក្នុងក្អមផង ខ្ចប់នឹងសម្ពត់សម្រាប់ត្រងទឹកផង ទុកក្នុងថង់យាមផង ត្រាតែពេញ ហើយព្យួរទុកតាមបង្អួចដេរដាស។ ភេសជ្ជៈទាំងនោះក៏សើមលេចហៀរចេញពាសពេញ។ វិហារទាំងឡាយក៏ដេរដាសពាសពេញដោយសត្វកណ្តុរទាំងឡាយ។ មនុស្សទាំងឡាយ កាលដើរទៅកាន់វិហារចារិក បានឃើញហើយទើបពោលទោស តិះដៀលបន្តុះបង្អាប់ថា សមណៈពួកនេះជាកូនចៅព្រះពុទ្ធសក្យបុត្រមានភណ្ឌៈដំកល់ទុកក្នុងឃ្លាំងដូចជាព្រះបាទពិម្ពិសារសេនិយរាជជាធំក្នុងដែនមគធៈដែរ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកភិក្ខុមកព្យាយាមដើម្បីសេចក្តីល្មោភច្រើនមានសភាពដូច្នេះឡើយ។ ទើបពួកភិក្ខុទាំងនោះនាំសេចក្តីនុ៎ះទៅក្រាបទូលដល់ព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុព្យាយាមដើម្បីសេចក្តីល្មោភច្រើនមានសភាពដូច្នេះ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មិនសមបីបើពួកមោឃបុរសទាំងនោះមកព្យាយាមដើម្បីសេចក្តីល្មោភច្រើនមានសភាពដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកបានធ្វើមកនេះ មិនមែននាំឱ្យកើតជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬថែមសេចក្តីជ្រះ ថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទៅទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភេសជ្ជៈណាមួយ ដែលពួកភិក្ខុមានជម្ងឺគប្បីឆាន់បាន ភេសជ្ជៈនេះគឺ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ។ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយ គួរទុកឆាន់បានយ៉ាងយូរត្រឹម៧ថ្ងៃ បើភិក្ខុទុកឱ្យកន្លងកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។

[១៤១] ត្រង់ពាក្យថា ភេសជ្ជៈណាមួយដែលពួកភិក្ខុមានជម្ងឺគប្បីឆាន់បាន គឺ សប្បិ[21] របស់គោក្តី សប្បិរបស់ពពែក្តី សប្បិរបស់ក្របីក្តី ឈ្មោះថាសប្បិ (ទឹកដោះរាវ)។ សាច់របស់សត្វទាំងឡាយណាដែលសមគួរដល់ពុទ្ធានុញ្ញាត សប្បិរបស់សត្វទាំងឡាយនោះ ក៏សមគួរដែរ។ ដែលហៅថា ទឹកដោះខាប់ គឺទឹកដោះខាប់របស់សត្វទាំងនោះឯង។ ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្វែរ ប្រេងធ្វើពីខ្លាញ់រាវ ឈ្មោះថា ប្រេង។ ទឹកផ្អែមកើតពីមេឃ្មុំជាដើម ឈ្មោះថាទឹកឃ្មុំ។ ទឹកកើតពីដើមអំពៅ ឈ្មោះថាទឹកអំពៅ។ ពាក្យថា ភិក្ខុទទួលភេសជ្ជៈនោះហើយ គួរទុកឆាន់បានយ៉ាងយូរត្រឹម៧ថ្ងៃ មានអធិប្បាយថា ភេសជ្ជៈទាំងនោះគប្បីទុកឆាន់បានយ៉ាងយូរត្រឹម៧ថ្ងៃ។ បើទុកឱ្យកន្លងកំណត់នោះទៅ ភេសជ្ជៈនោះជានិស្សគ្គិយ គឺថា ជានិស្សិគ្គិយក្នុងកាលអរុណរះឡើងក្នុងថ្ងៃទី៨ ភេសជ្ជៈដែលជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ភេសជ្ជៈរបស់ខ្ញុំនេះកន្លងហួស៧ថ្ងៃហើយ ជានិស្សគ្គិយវត្ថុ ខ្ញុំសូមលះបង់ភេសជ្ជៈនេះដល់សង្ឃ។ សេចក្តីអំពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃចីវរវគ្គ។

[១៤២] កាលភេសជ្ជៈកន្លងហួស៧ថ្ងៃទៅហើយ ភិក្ខុសំគាល់ថា កន្លងហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ កាលភេសជ្ជៈកន្លង៧ថ្ងៃ ហួសទៅហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ កាលភេសជ្ជៈកន្លងហួស៧ថ្ងៃទៅហើយ ភិក្ខុសំគាល់ថាមិនទាន់កន្លង ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ (ភេសជ្ជៈនោះ) ភិក្ខុមិនទាន់បានតាំងចិត្តទុកទេ ភិក្ខុសំគាល់ថាបានតាំងចិត្តទុកហើយ ត្រូវអាបត្តិនិស្សគ្គិយ បាចិត្តិយ។ ភេសជ្ជៈមិនទាន់បានលះបង់ទេ តែភិក្ខុសំគាល់ថាបានលះបង់ហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភេសជ្ជៈមិនទាន់បាត់ទៅទេ ភិក្ខុសំគាល់ថាបាត់ទៅហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភេសជ្ជៈ មិនទាន់វិនាសទៅទេ តែភិក្ខុសំគាល់ថាវិនាសហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភេសជ្ជៈភ្លើងមិនទាន់ឆេះទេ តែភិក្ខុសំគាល់ថាភ្លើងឆេះហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភេសជ្ជៈចោរមិនទាន់លួចយកទៅទេ តែភិក្ខុសំគាល់ថាចោរលួចយកទៅហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។

[១៤៣] ភិក្ខុត្រឡប់បានភេសជ្ជៈដែលខ្លួនលះបង់ហើយ មិនត្រូវយក មកបរិភោគប្រើប្រាស់ដោយកាយ មិនត្រូវយកមកឆាន់។ (ភេសជ្ជៈនោះ) ភិក្ខុគប្បីបង្អោនចូលទៅក្នុងប្រទីប ឬក្នុងវត្ថុមានពណ៌ខ្មៅ។[22] ភិក្ខុដទៃគប្បីបរិភោគប្រើប្រាស់ដោយកាយបាន តែមិនត្រូវយកមកឆាន់។ ភេសជ្ជៈ មិនទាន់កន្លង៧ ថ្ងៃទេ ភិក្ខុសំគាល់ថាកន្លងហើយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុ មានសេចក្តីសង្ស័យក្នុងភេសជ្ជៈដែលមិនទាន់កន្លង៧ថ្ងៃ ត្រូវអាបត្តិទុក្កដ។ ភេសជ្ជៈមិនទាន់កន្លង៧ ថ្ងៃ ភិក្ខុសំគាល់ថាមិនទាន់កន្លង មិនត្រូវអាបត្តិឡើយ។

[១៤៤] អាបត្តិមិនមានដល់ភិក្ខុដែលតាំងចិត្តទុក[23] (ក្តី) លះបង់ចោល(ក្តី) នូវភេសជ្ជៈដល់ភិក្ខុដែលមានភេសជ្ជៈបាត់ទៅ(ក្តី) វិនាសទៅ(ក្តី) ភ្លើងឆេះ(ក្តី) ចោរលួចយកទៅ(ក្តី) គេយកទៅដោយសេចក្តីស្និទ្ធស្នាល (ក្តី) ដល់ភិក្ខុដែលបរិច្ចាគលះបង់ដាច់ស្រឡះឥតអាល័យឱ្យអនុបសម្បន្ន ហើយទទួលយកមកបរិភោគវិញ ក្នុងរវាង៧ថ្ងៃ ដល់ភិក្ខុខ្ចូចចរិត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៣ ចប់។

# (និស្សគ្គិយ) សិក្ខាបទ ទី៤ (២៤)

CS vin.vbu.ni.24 | ភាគ ទី៣

## (៤. វស្សិកសាដិកសិក្ខាបទំ)

[១៤៥] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់យស កាលទ្រង់គង់នៅវត្តជេតវនមហាវិហារ ជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី។ ពេលនោះឯង ព្រះទ្រង់យសជាម្ចាស់ទ្រង់អនុញ្ញាតវស្សិកសាដិក (សម្ពត់ងូតទឹកភ្លៀង) ដល់ភិក្ខុទាំងឡាយហើយ។ ពួកភិក្ខុឆព្វគ្គិយបានដំណឹងថា ព្រះទ្រង់យសជាម្ចាស់ទ្រង់អនុញ្ញាតវស្សិកសាដិកហើយ ក៏នាំគ្នាស្វែងរកចីវរ សម្រាប់ងូតទឹកភ្លៀងមុនគេ ហើយ ធ្វើប្រើប្រាស់ក៏មុនគេដែរ កាលសម្ពត់ងូតទឹកភ្លៀង ចាស់ខូចខាតហើយ (ឆព្វគ្គិយភិក្ខុ) ក៏ងូតទឹកភ្លៀងដោយខ្លួនទទេ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយមិនសមបីបើនឹងប្រញាប់ស្វែងរកចីវរ សម្រាប់ងូតទឹកភ្លៀង ហើយប្រញាប់ធ្វើប្រើប្រាស់សោះ កាលសម្ពត់វស្សិកសាដិកចាស់ខូចខាតហើយ ក៏ត្រឡប់ងូតទឹកភ្លៀងដោយខ្លួនទទេទៅវិញ។ គ្រានោះ ពួកភិក្ខុទាំងនោះ ក៏នាំសេចក្តីនុ៎ះក្រាប ទូលចំពោះព្រះទ្រង់ជោគ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ គេថាពួកអ្នកឯងប្រញាប់ស្វែងរកចីវរសម្រាប់ងូតទឹកភ្លៀងមុនគេ ប្រញាប់ធ្វើប្រើប្រាស់មុនគេ លុះសម្ពត់វស្សិកសាដិក ចាស់ខូចហើយ ត្រឡប់ជាងូតទឹកភ្លៀងដោយខ្លួនទទេទៅវិញ ពិតមែនឬ។ ឆព្វគ្គិយភិក្ខុ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះសម្ពុទ្ធ ដ៏មានជោគជាម្ចាស់ទ្រង់តិះដៀលថា ម្នាលពួកមោឃបុរស មិនសមបីបើ ពួកអ្នកឯង ប្រញាប់ស្វែងរកចីវរសម្រាប់ងូតទឹកភ្លៀងមុនគេ ប្រញាប់ធ្វើ ប្រើប្រាស់មុនគេ លុះសម្ពត់ងូតទឹកភ្លៀងចាស់គ្រាំគ្រា ត្រឡប់ជានាំគ្នាងូតទឹកភ្លៀងដោយខ្លួនទទេសោះ ម្នាលមោឃបុរសទាំងឡាយអំពើនេះមិននាំឱ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាង នេះថា ភិក្ខុកំណត់ដឹងថាខែមួយជាខាងចុងនៃគិម្ហរដូវ[24] គប្បីស្វែងរកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង ភិក្ខុកំណត់ដឹងថានៅកន្លះខែជាខាងចុងនៃគិម្ហរដូវទៀត គប្បីធ្វើឱ្យស្រេចហើយប្រើប្រាស់ចុះ។ បើមិនទាន់ដល់ខែមួយជាខាងចុងនៃគិម្ហរដូវទេ ភិក្ខុស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង និងមិនទាន់ដល់កន្លះខែជាខាងចុងគិម្ហរដូវទេ ភិក្ខុធ្វើឱ្យស្រេច ហើយប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។

[១៤៦] ត្រង់ពាក្យថា ភិក្ខុកំណត់ដឹងថា ខែមួយជាខាងចុងនៃគិម្ហរដូវ ត្រូវស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង មានអធិប្បាយ ថា អំពីដើមមកមនុស្សទាំងឡាយណាធ្លាប់ប្រគេនសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ពួកភិក្ខុគប្បីចូលទៅរកមនុស្សទាំងឡាយនោះ ហើយពោលយ៉ាងនេះថា ពេលនេះជាកាលនៃវស្សិកសាដិក ពេលនេះជាសម័យនៃ វស្សិកសាដិក សូម្បីពួកមនុស្សឯទៀតគេតែងប្រគេនសាដិកចីវរសម្រាប់ ងូតទឹកភ្លៀងដែរ។ ពួកភិក្ខុមិនត្រូវនិយាយថា អ្នកទាំងឡាយចូរឱ្យ សាដិកចីវរសម្រាប់ងូតទឹកភ្លៀងដល់អាត្មា ចូរនាំយកសាដិកចីវរសម្រាប់ ងូតទឹកភ្លៀងមកឱ្យអាត្មា ចូរផ្លាស់ប្តូរសាដិកចីវរសម្រាប់ងូតទឹកភ្លៀងឱ្យអាត្មា ចូរទិញសាដិកចីវរសម្រាប់ងូតទឹកភ្លៀងឱ្យអាត្មា។ ពាក្យថាភិក្ខុកំណត់ដឹងថា នៅកន្លះខែជាខាងចុងគិម្ហរដូវទៀត គប្បីធ្វើឱ្យស្រេចហើយប្រើប្រាស់ ចុះ គឺភិក្ខុគប្បីធ្វើឱ្យស្រេចហើយប្រើប្រាស់ក្នុងកន្លះខែជាខាងចុងគិម្ហរដូវ។ ពាក្យថា បើមិនទាន់ដល់ខែ១ ជាខាងចុងនៃគិម្ហរដូវទេ គឺថ្ងៃមុនពីមួយ ខែជាខាងចុងគិម្ហរដូវ ភិក្ខុស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ចីវរ នោះជានិស្សគ្គិយ។ ពាក្យថា មិនទាន់ដល់កន្លះខែជាខាងចុងគិម្ហរដូវទេ គឺថ្ងៃមុនពីកន្លះខែជាខាងចុងគិម្ហរដូវ ភិក្ខុធ្វើស្រេចហើយប្រើប្រាស់ សម្ពត់នោះ ជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ឱ្យស្រឡះដល់សង្ឃក៏បាន គណៈ ក៏បាន បុគ្គលដ៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន វស្សិកសាដិកចីវររបស់ខ្ញុំនេះ ខ្ញុំស្វែងរកបានមកក្នុងមុនពីមួយខែជាខាងចុងគិម្ហរដូវ ធ្វើស្រេចហើយប្រើ ប្រាស់ក្នុងកាលមុនពីកន្លះខែជាខាងចុងគិម្ហរដូវ សម្ពត់នេះជានិស្សគ្គិយ ខ្ញុំសូមលះបង់នូវវស្សិកសាដិកចីវរនេះដល់សង្ឃ។ បេ។ ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃចីវរវគ្គ។

[១៤៧] ខាងចុងគិម្ហរដូវនៅលើសមួយខែ ភិក្ខុសំគាល់ថាលើស មែន ហើយស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ត្រូវអាបត្តិនិស្សគ្គិយ បាចិត្តិយ។ ខាងចុងគិម្ហរដូវនៅលើសមួយខែ តែភិក្ខុមានសេចក្តីសង្ស័យ ហើយស្វែងរកវស្សិកសាដិកចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ខាងចុងគិម្ហរដូវនៅលើសមួយខែ ភិក្ខុសំគាល់ថានៅខ្វះ ហើយស្វែងរកវស្សិកសាដិកចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត ភិក្ខុសំគាល់ថាលើសមែន ហើយធ្វើឱ្យស្រេចប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត ភិក្ខុមានសេចក្តីសង្ស័យ ហើយធ្វើឱ្យស្រេចប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ខាងចុងគិម្ហរដូវនៅលើសកន្លះខែទៀត ភិក្ខុសំគាល់ថានៅខ្វះ ហើយធ្វើឱ្យស្រេចប្រើប្រាស់ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ វស្សិកសាដិកចីវររបស់ភិក្ខុមាន តែភិក្ខុស្រាតងូតទឹកភ្លៀង ត្រូវអាបត្តិទុក្កដ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់មួយខែ ភិក្ខុសំគាល់ថា លើសទៅវិញ ត្រូវអាបត្តិទុក្កដ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់មួយខែ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់មួយខែ ភិក្ខុសំគាល់ថានៅខ្វះមិនដល់មួយខែមែន មិនត្រូវអាបត្តិ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់កន្លះខែ ភិក្ខុសំគាល់ថាលើសទៅវិញ ត្រូវអាបត្តិទុក្កដ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់កន្លះខែ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ខាងចុងគិម្ហរដូវនៅខ្វះមិនដល់កន្លះខែ ភិក្ខុសំគាល់ថាមិនដល់កន្លះខែមែន មិនត្រូវអាបត្តិឡើយ។

[១៤៨] អាបត្តិមិនមានដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅសល់មួយខែ ហើយស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅសល់កន្លះខែទៀត ហើយធ្វើឱ្យស្រេចប្រើប្រាស់ ដល់ភិក្ខុដែលដឹងថា ខាងចុងគិម្ហរដូវនៅខ្វះមិនដល់មួយខែ ហើយស្វែងរកសាដិកចីវរសម្រាប់ងូតទឹកភ្លៀង ដល់ភិក្ខុដែលដឹងថាខាងចុងគិម្ហរដូវនៅខ្វះមិនដល់កន្លះខែ ហើយធ្វើឱ្យស្រេចប្រើប្រាស់ ដល់ភិក្ខុដែលស្វែងរកវស្សិកសាដិកចីវរបានស្រេចហើយ (ស្រាប់តែដឹងជាខាងក្រោយថា) គេលើកខែមួយជាខាងដើមនៃវស្សានរដូវ (ឆ្នាំមានខែអធិកមាស) ដល់ភិក្ខុដែលស្លៀកវស្សិកសាដិកនោះហើយ (ទើបដឹងថា) គេលើកខែមួយជាខាងដើមនៃវស្សានរដូវដល់ភិក្ខុដែលលាងវស្សិកសាដិក ហើយដម្កល់ទុក ដល់ភិក្ខុដែលប្រើប្រាស់វស្សិកសាដិកក្នុងកាលដ៏គួរ ដល់ភិក្ខុមានចីវរ[25] ដែលចោរដណ្តើមយកទៅ ដល់ភិក្ខុមានចីវរបាត់[26] ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ[27] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៤ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៥ (២៥)

CS vin.vbu.ni.25 | ភាគ ទី៣

### (៥. ចីវរអច្ឆិន្ទនសិក្ខាបទំ)

[១៤៩] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់ក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឧបនន្ទសក្យបុត្រដ៏មានអាយុ បាននិយាយពាក្យនេះនឹងភិក្ខុដែលជាសទ្ធិវិហារិករបស់ព្រះថេរជាបងថា នែអាវុសោ អ្នកចូរមក យើងនឹងចៀសទៅកាន់ចារិកក្នុងជនបទ។ ភិក្ខុនោះឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាទៅមិនបានទេ (ដ្បិត)ខ្ញុំករុណាមានចីវរចាស់គ្រាំគ្រាហើយ។ ឧបនន្ទភិក្ខុនិយាយថា មកចុះអាវុសោ ខ្ញុំនឹងឱ្យចីវរលោក ហើយបានឱ្យចីវរទៅភិក្ខុនោះ។ ភិក្ខុនោះបានឮថា ព្រះដ៏មានព្រះភាគម្ចាស់នឹងទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងជនបទ។ ទើបភិក្ខុនោះត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អញមិនចៀសទៅកាន់ចារិកក្នុងជនបទជាមួយនឹងឧបនន្ទសក្យបុត្រដ៏មានអាយុទេ អញមុខជានឹងទៅកាន់ចារិកក្នុងជនបទជាមួយនឹងព្រះដ៏មានព្រះភាគវិញ។ លំដាប់នោះ ឧបនន្ទសក្យបុត្រដ៏មានអាយុនិយាយពាក្យនេះនឹងភិក្ខុនោះថា ឥឡូវនេះ អាវុសោ លោកចូរមក យើងនឹងនាំគ្នាទៅកាន់ចារិកក្នុងជនបទ។ ភិក្ខុនោះឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំករុណាមិនទៅកាន់ចារិកក្នុងជនបទជាមួយនឹងលោកទេ ខ្ញុំករុណាមុខជាទៅកាន់ចារិកក្នុងជនបទជាមួយនឹងព្រះដ៏មានព្រះភាគវិញ។ ឧបនន្ទខឹងអន់ចិត្តហើយពោលថា អាវុសោ ខ្ញុំបានឱ្យចីវរណាដល់លោក(ព្រោះ) លោកថានឹងទៅកាន់ចារិកជាមួយនឹងខ្ញុំ(ថាដូច្នោះហើយ) ក៏ដណ្តើមយកចីវរមកវិញ។ គ្រានោះ ភិក្ខុនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។ បេ។ ទើបភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនទំនងសោះ ឧបនន្ទសក្យបុត្រដ៏មានអាយុឱ្យចីវរទៅដោយខ្លួនឯងហើយ ត្រឡប់ជាខឹងអន់ចិត្ត ដណ្តើមយកមកវិញ។ លំដាប់នោះ ភិក្ខុទាំងនោះនាំសេចក្តីនុ៎ះក្រាបទូល ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងបានឱ្យចីវរទៅភិក្ខុដោយខ្លួនឯងហើយ ត្រឡប់ក្រោធខឹងអន់ចិត្តដណ្តើមយកពីគេមកវិញ មែនឬ។ ឧបនន្ទសក្យបុត្រក្រាបទូល ថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះសម្ពុទ្ធដ៏ទ្រង់យសជាម្ចាស់ទ្រង់តិះដៀលថា ម្នាលមោឃបុរស មិនសមបីបើអ្នកឯងបានឱ្យចីវរទៅភិក្ខុដោយខ្លួនឯងហើយ ត្រឡប់ក្រោធខឹងអន់ចិត្តដណ្តើមយកចីវរពីគេមកវិញសោះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំ ឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំឱ្យជនទាំងឡាយ ដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឱ្យចីវរដល់ភិក្ខុ(ដទៃ)ដោយខ្លួនឯងហើយ ខឹងអន់ចិត្តដណ្តើមយក(ចីវរ) មកវិញក្តី ប្រើឱ្យគេដណ្តើមយកមកវិញក្តី ភិក្ខុនោះត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។

[១៥០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដល់ភិក្ខុ គឺដល់ភិក្ខុដទៃ។ ពាក្យថា ខ្លួនឯង គឺបានឱ្យទៅខ្លួនឯង។ ដែលហៅថា ចីវរនោះ បានដល់ចីវរ៦យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមសម្រេចកិច្ចវិកប្បបាន។ ពាក្យថា ខឹងអន់ចិត្ត គឺមិនត្រេកអរ មានចិត្តក្តួលក្តៅ រឹងរូស។ ពាក្យថា ដណ្តើមយកមកវិញ គឺដណ្តើមយកមកដោយខ្លួនឯងវិញ ចីវរនោះជានិស្សគ្គិយ។ ពាក្យថា ប្រើឱ្យគេដណ្តើម យកមកវិញ គឺភិក្ខុបង្គាប់អ្នកដទៃ (ឱ្យដណ្តើមយកមកវិញ) ត្រូវអាបត្តិទុក្កដ។ ភិក្ខុបង្គាប់ទៅតែម្តងទេ អ្នកទទួលបង្គាប់ទៅដណ្តើមយកច្រើនដង ចីវរទាំងនោះជានិស្សគ្គិយ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ។បេ។ ថាបពិត្រព្រះសង្ឃដ៏ចំរើន ចីវររបស់ខ្ញុំនេះ ខ្ញុំបានឱ្យទៅភិក្ខុ (ដទៃ) ដោយខ្លួនឯងហើយ ខ្ញុំត្រឡប់ដណ្តើមយកមកវិញ ជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ។ ពាក្យតអំពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ ក្នុងចីវរវគ្គ។

[១៥១] ភិក្ខុសំគាល់បុគ្គលដែលជាឧបសម្បន្ន[28] ថាឧបសម្បន្នពិតមែន ហើយឱ្យចីវរទៅដោយខ្លួនឯង ក៏ត្រឡប់ក្រោធខឹងអន់ចិត្តដណ្តើមយកវិញក្តី ប្រើឱ្យអ្នកដទៃដណ្តើមយកមកវិញក្តី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងបុគ្គលដែលជាឧបសម្បន្ន ហើយឱ្យចីវរទៅដោយខ្លួនឯង ក៏ត្រឡប់ជាក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឱ្យអ្នកដទៃដណ្តើមមកវិញក្តី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុសំគាល់បុគ្គលដែលជាឧបសម្បន្នថា អនុបសម្បន្ន[29] ទៅវិញហើយឱ្យចីវរទៅដោយខ្លួនឯង ក៏ត្រឡប់ក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឱ្យអ្នកដទៃដណ្តើមយកមកវិញក្តី ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុឱ្យបរិក្ខារដទៃហើយត្រឡប់ក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឱ្យអ្នកដទៃដណ្តើមយកមកវិញក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុឱ្យចីវរក្តី បរិក្ខារដទៃក្តី ទៅអនុបសម្បន្ន ហើយក្រោធខឹងអន់ចិត្ត ដណ្តើមយកមកខ្លួនឯងវិញក្តី ប្រើឱ្យអ្នកដទៃដណ្តើមយកមកវិញក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់អនុបសម្បន្នថាជាឧបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងបុគ្គលដែលជាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់អនុបសម្បន្នថា អនុបសម្បន្នពិតមែន ត្រូវអាបត្តិទុក្កដ។

[១៥២] អាបត្តិមិនមានដល់ភិក្ខុដែលភិក្ខុអ្នកទទួលចីវរនោះគេឱ្យត្រឡប់វិញ ឬភិក្ខុដែលមានសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកទទួលចីវរនោះហើយកាន់យកមកវិញ ដល់ភិក្ខុដែលខូចចរិត ដល់ភិក្ខុដែលជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៥ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៦ (២៦)

CS vin.vbu.ni.26 | ភាគ ទី៣

### (៦. សុត្តវិញ្ញត្តិសិក្ខាបទំ)

[១៥៣] សម័យនោះ ព្រះសម្ពុទ្ធដ៏ទ្រង់យស កាលគង់ក្នុងវិហារវេឡុវន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុបានសូមអម្បោះមកជាច្រើន ក្នុងសម័យធ្វើចីវរកម្ម។ លុះធ្វើចីវរសម្រេចហើយ មានអម្បោះសេសសល់ជាច្រើន។ ទើបពួកឆព្វគ្គិយភិក្ខុបានជំនុំគ្នាដូច្នេះថា ម្នាលអាវុសោ បើដូច្នេះ មានតែពួកយើងនឹងសូមអម្បោះដទៃ មកថែមទៀត ហើយឱ្យពួកជាងដម្បាញត្បាញចីវរ។ លំដាប់នោះ

ពួកឆព្វគ្គិយភិក្ខុទៅសូមអម្បោះឯទៀតមក ហើយក៏ឱ្យជាងដម្បាញត្បាញចីវរ។ កាលត្បាញចីវររួចហើយ អម្បោះនៅសេសសល់ ជាច្រើន ពួកឆព្វគ្គិយភិក្ខុក៏ទៅសូមអម្បោះដទៃ ៗមកថែមទៀត ហើយ ឱ្យពួកជាងដម្បាញចីវរជាគំរប់ពីរដង។ កាលគេត្បាញរួចហើយ អម្បោះនៅសល់ជាច្រើន។ ពួកឆព្វគ្គិយភិក្ខុទៅសូមអម្បោះដទៃៗ មក ថែមទៀត ហើយឱ្យពួកជាងដម្បាញត្បាញចីវរជាគំរប់បីដង។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនសមនឹងទៅសូមអម្បោះមកដោយខ្លួនឯង ហើយឱ្យពួកជាងដម្បាញត្បាញចីវរឱ្យសោះ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់(ដូច្នោះ) ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោល ទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងទៅសូម អម្បោះមកដោយខ្លួនឯង ហើយឱ្យពួកជាងដម្បាញត្បាញចីវរឱ្យ(ដូច្នេះ) សោះ។ ទើបភិក្ខុទាំងនោះនាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងទៅសូមអម្បោះមកនឹងខ្លួនឯង ហើយឱ្យពួកជាងដម្បាញត្បាញចីវរឱ្យ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាល មោឃបុរស ពួកអ្នកឯងមិនសមបើហ៊ានទៅសូមអម្បោះមកនឹងខ្លួនឯង ហើយឱ្យពួកជាងដម្បាញត្បាញចីវរឱ្យ(ដូច្នេះ) សោះ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើមកនេះ មិននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា នឹងមិននាំពួកជនដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទ នេះយ៉ាងនេះថា ភិក្ខុណាមួយសូមអម្បោះមកដោយខ្លួនឯង ហើយឱ្យពួក ជាងដម្បាញត្បាញចីវរឱ្យ ភិក្ខុនោះត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។

[១៥៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌឯនោះ។ ពាក្យថា ដោយខ្លួនឯង គឺសូមមកខ្លួនឯង។ ដែលហៅថា អម្បោះ បានដល់អម្បោះ៦យ៉ាងគឺ អម្បោះដែលកើតពីសម្បកឈើ១ អម្បោះដែលកើតពីកប្បាស១ សូត្រ១ អម្បោះដែលកើតពីរោមសត្វ១ អម្បោះដែលកើតឡើងពីធ្មៃ១ អម្បោះកើត ពីភង្គ (គឺយករបស់ខាងដើមទាំង ៥ មកធ្វើជាអម្បោះ) ១។ ពាក្យថា ឱ្យពួកជាងដម្បាញត្បាញ គឺប្រើពួកជាងដម្បាញឱ្យត្បាញ ត្រូវអាបត្តិទុក្កដតាមប្រយោគ។ ចីវរនោះ ជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុគប្បីលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន។ ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះ។បេ។ ថា បពិត្រព្រះសង្ឃដ៏ចំរើន ចីវររបស់ខ្ញុំនេះ ខ្ញុំបានសូមអម្បោះមកដោយខ្លួនឯង ហើយឱ្យពួកជាងដម្បាញត្បាញ ចីវរនោះជានិស្សគ្គិយ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ។ពាក្យតពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃចីវរវគ្គ។

[១៥៥] ភិក្ខុសំគាល់ចីវរដែលឱ្យគេត្បាញរួចហើយថា ឱ្យគេត្បាញរួចហើយពិតមែន ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងចីវរដែលឱ្យគេត្បាញរួចហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុសំគាល់ចីវរដែលឱ្យគេត្បាញរួចហើយថា មិនមែនចីវរ ដែលឱ្យគេត្បាញទេ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុសំគាល់ចីវរដែលមិនមែនឱ្យគេត្បាញថា ចីវរដែលឱ្យគេត្បាញហើយ ត្រូវអាបត្តិទុក្កដ។ មិនមែនចីវរដែលឱ្យគេត្បាញទេ តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ចីវរដែលមិនមែនឱ្យគេត្បាញថា មិនមែន ចីវរដែលឱ្យគេត្បាញពិតមែន មិនត្រូវអាបត្តិឡើយ។

[១៥៦] អាបត្តិមិនមានដល់ភិក្ខុដែលសូមអម្បោះមកដើម្បីដេរចីវរ ដើម្បីធ្វើសម្ពត់អាយោគ ដើម្បីធ្វើវត្ថពន្ធចង្កេះ ដើម្បីធ្វើយោគបាត្រ ដើម្បីធ្វើស្លោកបាត្រ ដើម្បីធ្វើសម្ពត់ត្រងទឹក ដល់ភិក្ខុដែលសូមអម្បោះ អំពីពួកញាតិ ដល់ភិក្ខុដែលសូមអម្បោះពីពួកជនដែលបានបវារណាទុក ដល់ភិក្ខុដែលសូមអម្បោះដើម្បីជាប្រយោជន៍ដល់ភិក្ខុដទៃ ដល់ភិក្ខុដែល បានមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលខូចចរិត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៦ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៧ (២៧)

CS vin.vbu.ni.27 | ភាគ ទី៣

### (៧. មហាបេសការសិក្ខាបទំ)

[១៥៧] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលទ្រង់គង់នៅវត្តជេតវន ជារបស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯងមានបុរសម្នាក់ កាលចេញទៅកាន់និវាសស្ថាន បាននិយាយពាក្យនេះនឹងប្រពន្ធថា ចូរនាងថ្លឹងអម្បោះយកទៅឱ្យជាងដម្បាញ ឯណោះ ហើយប្រាប់ឱ្យគេត្បាញចីវរទុកទៅ ចាំអញត្រឡប់មកវិញ នឹងប្រគេនចីវរ (នោះ) ឱ្យព្រះឧបនន្ទជាម្ចាស់គ្រង។ ភិក្ខុមួយរូបជាអ្នកកាន់បិណ្ឌចារិកវត្តបានឮពាក្យដែលបុរសនោះនិយាយហើយ។ ទើបភិក្ខុនោះចូលទៅរកឧបនន្ទសក្យបុត្រដ៏មានអាយុ លុះដល់ហើយបាន និយាយពាក្យនេះនឹងឧបនន្ទសក្យបុត្រដ៏មានអាយុថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យធំ ព្រោះបុរសម្នាក់នៅទីឯណោះ កាលគាត់ចេញទៅកាន់និវាសស្ថាន បាននិយាយនឹងប្រពន្ធគាត់ថា ចូរនាងថ្លឹងអម្បោះ(សម្រាប់ត្បាញចីវរ) ហើយយកទៅឱ្យជាងដម្បាញឯណោះ ឱ្យគេត្បាញចីវរទុកឱ្យ(អញ) ចាំអញត្រឡប់មកវិញ នឹងប្រគេនចីវរឱ្យព្រះឧបនន្ទជាម្ចាស់គ្រង។ ឧបនន្ទដ៏មានអាយុឆ្លើយថា ម្នាលអាវុសោ ការនោះពិតមែនហើយ ព្រោះបុរសនោះជាញោមឧបដ្ឋាករបស់ខ្ញុំ។ ឯជាងដម្បាញនោះជាញោមឧបដ្ឋាករបស់ឧបនន្ទសក្យបុត្រដ៏មានអាយុ មែន។ លំដាប់នោះឧបនន្ទសក្យបុត្រដ៏មានអាយុ ចូលទៅរកជាងដម្បាញនោះ លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងជាងដម្បាញនោះថា ម្នាលអ្នកដ៏មានអាយុ ចីវរនេះគេត្បាញចំពោះអាត្មា អ្នកចូរធ្វើឱ្យវែង ឱ្យទូលាយ ឱ្យណែន ត្បាញឱ្យស្មើល្អ រឹតដំបាញ ឱ្យតឹង កួតឱ្យល្អ សិតឱ្យស្អាត។ ជាងដម្បាញឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចំរើន គេថ្លឹងអម្បោះទាំងនេះមកឱ្យខ្ញុំករុណាថា អ្នកឯងចូរត្បាញចីវរដោយអម្បោះនេះ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំករុណាមិនអាចធ្វើឱ្យវែង ឱ្យទូលាយ ឱ្យណែនបានទេ បពិត្រលោកម្ចាស់ ប៉ុន្តែខ្ញុំករុណាអាចត្បាញឱ្យស្មើល្អ រឹតដំបាញឱ្យតឹង កួតឱ្យល្អ សិត ឱ្យស្អាតបាន។ ឧបនន្ទដ៏មានអាយុពោលថា ណ្ហើយចុះ ម្នាលអ្នកដ៏មានអាយុ អ្នកចូរធ្វើឱ្យវែង ឱ្យទូលាយ ឱ្យណែនល្អចុះ អម្បោះនោះមិនខ្វះទេ។ លំដាប់នោះ ជាងដម្បាញនោះបញ្ចូលអម្បោះដែលបានមកទាំងប៉ុន្មានទៅក្នុងដម្បាញអស់ហើយ ទើបចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងស្រីនោះថា នែនាងដ៏ចំរើន ឥឡូវត្រូវការអម្បោះ ( ថែមទៀត )។ នាងនោះត្រឡប់សួរថា នែអ្នកខ្ញុំបាន

ប្រាប់អ្នកហើយថា អ្នកចូរត្បាញចីវរដោយអម្បោះប៉ុណ្ណេះឱ្យគ្រាន់។ ជាងដម្បាញឆ្លើយថា នែនាងដ៏ចំរើន នាងបានប្រាប់ខ្ញុំថា អ្នកចូរត្បាញ ចីវរដោយអម្បោះប៉ុណ្ណោះក៏ពិតមែនហើយ តែព្រះឧបនន្ទជាម្ចាស់លោកនិយាយយ៉ាងនេះនឹងខ្ញុំថា ណ្ហើយចុះ ម្នាលអ្នកដ៏មានអាយុ អ្នកចូរធ្វើ ឱ្យវែង ឱ្យទូលាយ ឱ្យណែនល្អ អម្បោះនោះមិនខ្វះទេ។ ស្រីនោះក៏ឱ្យអម្បោះទៅជាងដម្បាញក្នុងជាន់ក្រោយនេះ ប្រហែលអម្បោះដែលបានឱ្យ ជាន់មុនដែរ។ ឯឧបនន្ទសក្យបុត្រដ៏មានអាយុបានដំណឹងថា បុរសនោះ ត្រឡប់មកពីនិវាសស្ថានហើយ។ ឧបនន្ទសក្យបុត្រដ៏មានអាយុចូលទៅកាន់លំនៅរបស់បុរសនោះ លុះចូលទៅហើយ ក៏អង្គុយលើអាសនៈ ដែលគេចាត់ចែងស្រាប់។ ឯបុរសនោះក៏ចូលទៅរកឧបនន្ទសក្យបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយថ្វាយបង្គំឧបនន្ទសក្យបុត្រដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះបុរសនោះអង្គុយស្រួលបួលហើយ ក៏និយាយពាក្យនឹងប្រពន្ធថា នាងឯងបានឱ្យជាងដម្បាញត្បាញចីវររួចហើយឬ។ ប្រពន្ធឆ្លើយថា ចា៎ះ អ្នកជាម្ចាស់ ខ្ញុំបានឱ្យគេត្បាញចីវររួចហើយ។ ប្តីទាររកថា ចូរនាងយកមក អញនឹងប្រគេនចីវរឱ្យព្រះឧបនន្ទជាម្ចាស់គ្រង។ លំដាប់នោះ ស្រីនោះបាននាំយកចីវរនោះទៅឱ្យស្វាមី ហើយក៏ប្រាប់សេចក្តីនុ៎ះឱ្យដឹង។ ទើបបុរសនោះប្រគេនចីវរនោះដល់ ឧបនន្ទសក្យបុត្រដ៏មានអាយុ ហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រទាំងនេះ ជាអ្នកប្រាថ្នាច្រើន មិនសន្តោស យើងមិនងាយនឹងឱ្យសមណៈពួកនេះស្លៀកដណ្តប់ចីវរបានទេ អញមិនបានបវារណាព្រះឧបនន្ទជាម្ចាស់មកពីមុនទេ មិនសមបើនឹងហ៊ានចូលទៅរកជាងដម្បាញ ហើយដល់នូវកិរិយាកំណត់ ក្នុងចីវរ (គឺរិះគន់ចង់បានហួសហេតុ)។ ភិក្ខុទាំងឡាយបានឮបុរសនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទសក្យបុត្រដ៏មានអាយុ គេមិនបានបវារណាមក ពីមុនសោះ មិនសមបើនឹងហ៊ានចូលទៅរកពួកជាងដម្បាញរបស់គហបតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ( គឺរិះគន់ចង់បានហួសហេតុ )។ លំដាប់នោះ ភិក្ខុទាំងនោះនាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ជាម្ចាស់។ ព្រះអង្គត្រាស់ថា ឧបនន្ទ គេថាអ្នកឯង ជនជាម្ចាស់ចីវរគេមិនបានបវារណាមកពីមុនសោះ ហ៊ានចូលទៅរកពួកជាងដម្បាញរបស់គហបតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺរិះគន់ចង់បានហួសហេតុ) ពិតមែនឬ។ ឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះអង្គត្រាស់សួរថា នែឧបនន្ទ បុរសនោះ ជាញាតិរបស់អ្នកឯង ឬមិនមែនជាញាតិទេ។ ឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគជាម្ចាស់ បុរសនោះមិនមែនជាញាតិទេ។ ម្នាលមោឃបុរស បុគ្គលមិនមែនជាញាតិតែងមិនទទួលដឹងនូវការសមគួរ និងមិនសមគួរ ការល្អិតល្អ និងមិនល្អិតល្អ របស់បុគ្គលដែលមិនមែនជា ញាតិទេ នែមោឃបុរស ក្នុងរឿងចីវរនោះ (បើ) ម្ចាស់ចីវរគេមិនបានបវារណាមកពីដើមទេ អ្នកឯងមិនសមបើនឹងហ៊ានចូលទៅរកពួកជាងដម្បាញ របស់គហបតិដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺរិះគន់ចង់បានល្អឱ្យហួសហេតុដូច្នេះសោះ) នែមោឃបុរស អំពើដែល អ្នកឯងធ្វើមកនេះ មិនមែននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឱ្យជនដែលជ្រះថ្លាស្រាប់ហើយ ឱ្យរឹងរឹតតែ ជ្រះថ្លាឡើងទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បី សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា គហបតិ (គឺបុរសជាម្ចាស់ផ្ទះ)ក្តី គហបតានី (គឺស្រីជាម្ចាស់ផ្ទះ)ក្តីដែលមិនមែនជាញាតិឱ្យជាងដម្បាញត្បាញចីវរចំពោះភិក្ខុណាមួយ។ បើភិក្ខុនោះ ដែលអ្នកម្ចាស់ចីវរគេមិនបានបវារណាមកពីមុនក្នុងរឿងចីវរនោះ អាចហ៊ានចូលទៅរកជាងដម្បាញ ហើយដល់នៅកិរិយាកំណត់ក្នុងចីវរ (គឺរិះគន់ចង់បានល្អឱ្យហួសហេតុ) គឺពោលថានែអ្នកដ៏មានអាយុ ចីវរនេះគេឱ្យត្បាញចំពោះអាត្មា អ្នកទាំង ឡាយចូរធ្វើឱ្យវែង ឱ្យទូលាយ ឱ្យមានសាច់ញឹក ឱ្យស្មើល្អ រឹតឱ្យ តឹងល្អ ចូរត្រដោះកួតហើយសិតឱ្យល្អ សឹមអាត្មាថែមរង្វាន់ឱ្យអ្នកបន្តិចបន្តួច។ ភិក្ខុនោះលុះនិយាយយ៉ាងនេះហើយ ក៏ថែមរង្វាន់បន្តិចបន្តួចឱ្យដោយហោចទៅ ទុកជាគ្រាន់តែចង្ហាន់បិណ្ឌបាត(១ឆ្អែត) ក៏ត្រូវអាបត្តិ និស្សគ្គិយបាចិត្តិយ។

[១៥៨] ត្រង់ពាក្យថា ចំពោះភិក្ខុណាមួយ គឺដើម្បីជាប្រយោជន៍ដល់ភិក្ខុ គឺធ្វើភិក្ខុឱ្យជាអារម្មណ៍ ហើយចង់ឱ្យភិក្ខុស្លៀកដណ្តប់ចីវរ។ គហបតិដែលមិនជាប់ចំពាក់ (ជាសាច់ញាតិ) ពីចំណែកខាងមាតាក្តី បិតាក្តី រៀងរាល់ដល់គូជីដូនជីតាទី៧ ហៅថា មិនមែនជាញាតិ។ បុគ្គលណា មួយដែលគ្រប់គ្រងគេហស្ថាន បុគ្គលនោះហៅថា គហបតិ។ ស្រីណាមួយដែលគ្រប់គ្រងគេហស្ថាន ស្រីនោះហៅថា គហបតានី។ ពាក្យថា ជាងដម្បាញ បានដល់ពួកអ្នកធ្វើការត្បាញ។ បណ្តាចីវរ ៦ យ៉ាង ចីវរយ៉ាងណានីមួយយ៉ាងតូចបំផុតល្មមសម្រេចកិច្ចវិកប្បបាន ហៅថា ចីវរ។ ពាក្យថា ឱ្យត្បាញ គឺថាឱ្យចាក់អម្បោះឬសូត្រធ្វើសម្ពត់។ ពាក្យថា បើភិក្ខុនោះ សេចក្តីថាម្ចាស់ចីវរឱ្យត្បាញចីវរចំពោះភិក្ខុអង្គណា សំដៅយកភិក្ខុនោះ។ ពាក្យថា គេមិនបានបវារណាមកពីមុន គឺមិនបាននិយាយគ្នាទុកមកពីមុនថា បពិត្រលោកម្ចាស់ លោកត្រូវការចីវរយ៉ាងណា ខ្ញុំករុណានឹងឱ្យជាងដម្បាញត្បាញចីវរយ៉ាងណា ប្រគេនលោក។ ពាក្យថា ចូលទៅរកជាងដម្បាញ គឺទៅផ្ទះជាងដម្បាញ ឬចូលទៅរកគេក្នុងកន្លែងណាមួយ។ ពាក្យថា ដល់នូវកិរិយាកំណត់ក្នុងចីវរ គឺនិយាយថា នែអ្នកដ៏មានអាយុ ចីវរនេះគេឱ្យត្បាញចំពោះអាត្មាហើយ អ្នកទាំងឡាយចូរធ្វើឱ្យវែង ឱ្យទូលាយ ឱ្យសាច់ញឹក ធ្វើឱ្យស្មើល្អ រឹតឱ្យ តឹងល្អ ត្រដោះកួតឱ្យល្អ និងសិតឱ្យល្អ សឹមអាត្មាឯងនឹងថែមរបស់អ្វី ៗ ឱ្យពួកអ្នកដ៏មានអាយុខ្លះមិនខាន។ ពាក្យថា ភិក្ខុនោះ លុះនិយាយយ៉ាងនេះហើយ ក៏ថែមរង្វាន់បន្តិចបន្តួចឱ្យ ដោយហោចទៅទុកជាគ្រាន់តែចង្ហាន់បិណ្ឌបាត អធិប្បាយថាបបរក្តី បាយក្តីរបស់គួរទំពារស៊ីក្តី ហៅថា បិណ្ឌបាត ដោយហោចទៅ សូម្បីដុំលំអិតសម្រាប់ងូតក្តី ឈើស្ទន់ក្តី អម្បោះរងជើងក្តី ភិក្ខុសំដែងធម៌ឱ្យស្តាប់(ក៏ហៅថាបិណ្ឌបាតក្នុងសិក្ខាបទ នេះដែរ) បើជាងដម្បាញត្បាញចីវរឱ្យវែងក្តី ឱ្យទូលាយក្តី ឱ្យមានសាច់ញឹកក្តី តាមពាក្យ(បង្គាប់) របស់ភិក្ខុនោះ ត្រូវអាបត្តិទុក្កដតាមប្រយោគ។ ចីវរនោះជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បានគណៈក៏បាន បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវ លះបង់យ៉ាងនេះថា។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ចីវររបស់ខ្ញុំករុណានេះ ម្ចាស់ចីវរមិនបានបវារណាមកពីមុនទេ ខ្ញុំករុណាបានចូលទៅរកពួកជាងដម្បាញរបស់គហបតីដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (គឺចង់បានល្អហួសហេតុ) ចីវរនេះជានិស្សគ្គិយ ខ្ញុំករុណា សូមលះបង់ចីវរនេះដល់សង្ឃ។ ពាក្យថាអំពីនេះទៅមានសេចក្តី ដូចគ្នានឹងសិក្ខាបទទី១ នៃចីវរវគ្គខាងដើមនោះហើយ។

[១៥៩] ភិក្ខុសំគាល់គហបតិមិនមែនជាញាតិ ថាមិនមែនជាញាតិពិតមែន គេមិនបានបវារណាមកពីដើមទេ ចូលទៅរកជាងដម្បាញរបស់គហបតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ គហបតិមិនមែនជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ គេមិន បានបវារណាមកពីមុន ចូលទៅរកជាងដម្បាញរបស់គហបតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុសំគាល់គហបតិដែលមិនមែនជាញាតិ ថាជាញាតិ គេមិនបានបវារណាទុកមុន ចូលទៅរកពួកជាងដម្បាញរបស់គហបតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុសំគាល់គហបតិដែលជាញាតិ ថាមិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យនឹងគហបតិ ដែលជាញាតិ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់គហបតិដែលជាញាតិ ថាជាញាតិពិតមែន មិនត្រូវអាបត្តិអ្វីឡើយ។

[១៦០] អាបត្តិមិនមានដល់ភិក្ខុដែលកំណត់ចីវរ ក្នុងសំណាក់នៃពួកគហបតិដែលជាញាតិ ដល់ភិក្ខុដែលកំណត់ចីវរក្នុងសំណាក់នៃពួកគហបតិដែលបានបវារណា ដល់ភិក្ខុដែលកំណត់ចីវរដើម្បីជាប្រយោជន៍ដល់ភិក្ខុឯទៀត ដល់ភិក្ខុដែលធ្វើចីវរដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុដែលម្ចាស់ចីវរគេចង់ឱ្យត្បាញចីវរមានដំឡៃច្រើន តែភិក្ខុឱ្យគេត្បាញចីវរមានដំឡៃតិចវិញ ដល់ភិក្ខុដែលខូចចរិត ដល់ភិក្ខុដែលជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៧ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៨ (២៨)

CS vin.vbu.ni.28 | ភាគ ទី៣

### (៨. អច្ចេកចីវរសិក្ខាបទំ)

[១៦១] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មហាអាមាត្យម្នាក់ កាលចេញទៅកាន់ទីនិវាស្ថានជាទីព្រាត់ប្រាស បានប្រើបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយដោយពាក្យថា លោកម្ចាស់ទាំងឡាយចូរនិមន្តខ្ញុំនឹងថ្វាយសម្ពត់ចំណាំវស្សា។ ឯពួកភិក្ខុសង្ស័យថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់អនុញ្ញាតសម្ពត់ចំណាំវស្សាដល់ពួកភិក្ខុដែលចាំវស្សាហើយ ទើបមិននាំគ្នាមក (ព្រោះវេលានៅមិនទាន់ចេញវស្សា)។ លំដាប់នោះ មហាអាមាត្យនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា អញបានប្រើបម្រើទៅហើយ មិនសមបីបើលោកម្ចាស់ទាំងឡាយមិននិមន្តមក ខ្លួនអញចេញទៅក្នុងកងទ័ព ការរស់នៅ ឬស្លាប់ទៅមិនងាយដឹងទេ។ ភិក្ខុទាំងឡាយបានឮមហាអាមាត្យនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបពួកភិក្ខុ ទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សំដែងធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយក្នុងខណៈនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយទទួលអច្ចេកចីវរទុកដាក់បាន។ សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់អនុញ្ញាតឱ្យភិក្ខុទាំងឡាយទទួលអច្ចេកចីវរទុកដាក់បាន ហើយក៏ទទួលអច្ចេកចីវរទុកឱ្យកន្លងហួសចីវរកាលទៅ។ ភិក្ខុទាំងឡាយបានវេចខ្ចប់នូវចីវរទាំងនោះ ព្យួរទុកនឹងខ្សែស្បៀង។ អានន្ទត្ថេរដ៏មានអាយុដើរទៅកាន់ចារិកនៃសេនាសនៈ ក៏បានឃើញចីវរទាំងនោះដែលភិក្ខុខ្ចប់ព្យួរទុកនឹងខ្សែស្បៀង លុះឃើញហើយទើបហៅភិក្ខុទាំងឡាយមកសួរថា ម្នាលអាវុសោទាំងឡាយ ចីវរទាំងនេះដែលគេព្យួរទុកនឹងខ្សែស្បៀង តើជារបស់អ្នកណា។ ពួកភិក្ខុឆ្លើយថា អាវុសោ អច្ចេកចីវររបស់យើងខ្ញុំទាំងឡាយ។ អានន្ទត្ថេរសួរទៀតថា ម្នាលអាវុសោ ចីវរទាំងនេះលោករាល់គ្នាបានដាក់ទុកមកយូរអស់កាលប៉ុន្មានហើយ។ ទើបភិក្ខុទាំងនោះ បានប្រាប់កាលដែលខ្លួនបានដាក់ទុកចីវរនោះ ដល់ព្រះអានន្ទត្ថេរដ៏មានអាយុ។ អានន្ទត្ថេរដ៏មានអាយុក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុមិនសមបើនឹងទទួលអច្ចេកចីវរ ហើយទុកឱ្យកន្លងហួសចីវរកាលទៅ។ លំដាប់នោះ អានន្ទត្ថេរដ៏មានអាយុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុទទួលអច្ចេកចីវរ ហើយបណ្តោយឱ្យកន្លងហួសចីវរកាលទៅ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មិនសមបី បើពួកមោឃបុរសនោះ ទទួលអច្ចេកចីវរ ហើយបណ្តោយឱ្យកន្លងហួសចីវរកាលទៅទេ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាផង មិននាំឱ្យជនដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងផង។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ថ្ងៃពេញបូណ៌មីខែកត្តិក[30] ដែលជាខែទី ៣ នៃវស្សានរដូវនៅខ្វះ១០ថ្ងៃ[31] ទៀតនឹងគ្រប់ (គឺថ្ងៃ៥កើតខែអស្សុជ) បើអច្ចេកចីវរកើតឡើងដល់ភិក្ខុៗសំគាល់ថាជាអច្ចេកចីវរ គប្បីទទួលទុក លុះទទួលហើយគប្បីទុកដាក់ដរាបអស់សម័យចីវរកាល បើភិក្ខុទុកយូរឱ្យហួសកំណត់នោះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។

[១៦២] ត្រង់ពាក្យថា ខ្វះ១០ថ្ងៃទៀត គឺនៅខ្វះ១០ថ្ងៃទៀតនឹងដល់ថ្ងៃបវារណា។ ថ្ងៃបវារណាក្នុងខែកត្តិក តថាគតត្រាស់ហៅថា ថ្ងៃពេញបូណ៌មីនៃខែកត្តិកដែលជាខែទី ៣ នៃវស្សានរដូវ។ ដែលហៅថា អច្ចេកចីវរនោះ គឺសម្ពត់ដែលបុគ្គលណាមួយត្រូវការនឹងចេញទៅក្នុងកងទ័ពក្តី ត្រូវការនឹងចេញទៅកាន់និវាស្ថានក្តី មនុស្សមានជម្ងឺក្តី ស្រីមានគភ៌ក្តី បុគ្គលឥតសទ្ធាត្រឡប់មានសទ្ធាភ្លាកើតឡើងក្តី បុគ្គលគ្មានសេចក្តីជ្រះថ្លាត្រឡប់ជាមានសេចក្តីជ្រះថ្លាកើតឡើងក្តី។ បើបុគ្គលនោះប្រើបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយ (ចំពោះចីវរណា) ដោយពាក្យ ថាលោកម្ចាស់ទាំងឡាយសូមនិមន្តមក ខ្ញុំព្រះករុណានឹងប្រគេនសម្ពត់ វស្សាវាសិក (សម្ពត់ចំណាំវស្សា)។ ចីវរនេះឈ្មោះថា អច្ចេកចីវរ (គឺចីវរដែលបុគ្គលធ្វើដោយរួសរាន់)។ ពាក្យថា ភិក្ខុសំគាល់ថាជាអច្ចេកចីវរ គប្បីទទួលទុក លុះទទួលរួចហើយ គប្បីទុកដរាបអស់សម័យចីវរកាល សេចក្តីថា ភិក្ខុត្រូវធ្វើសេចក្តីសំគាល់ថានេះជាអច្ចេកចីវរ ហើយទុកដាក់ចុះ។ ដែលហៅថា សម័យចីវរកាលនោះ គឺថា បើភិក្ខុមិនបានក្រាលកឋិនទេ នោះត្រូវកំណត់យកខែចុង[32] នៃវស្សានរដូវ១ ខែ បើបានក្រាលកឋិនត្រូវកំណត់យក៥ខែ។ ពាក្យថា ថាបើភិក្ខុទុកដាក់ឱ្យហួសកំណត់នោះទៅ គឺថាបើមិនបានក្រាលកឋិន ភិក្ខុបណ្តោយឱ្យអច្ចេកចីវរកន្លងថ្ងៃខាងចុងនៃវស្សានរដូវ គឺថ្ងៃពេញបូណ៌មីខែកត្តិកទៅ អច្ចេកចីវរនោះជានិស្សគ្គិយ។ បើភិក្ខុក្រាលកឋិនរួចហើយ បណ្តោយឱ្យ អច្ចេកចីវរកន្លងហួសថ្ងៃដែលភិក្ខុដោះកឋិនទៅ អច្ចេកចីវរនោះជានិស្សគ្គិយដែរ ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីលះបង់យ៉ាងនេះថា។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន អច្ចេកចីវររបស់ខ្ញុំនេះ ខ្ញុំទុកឱ្យកន្លងសម័យចីវរកាលទៅហើយ ចីវរនេះជានិស្សគ្គិយ ខ្ញុំករុណាសូមលះបង់អច្ចេកចីវរនេះ ដល់សង្ឃ សេចក្តីអំពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១នៃចីវរវគ្គខាងដើមហើយ។

[១៦៣] អច្ចេកចីវរពិតមែន ភិក្ខុក៏សំគាល់ថាជាអច្ចេកចីវរ បើភិក្ខុទុកឱ្យកន្លងសម័យចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងអច្ចេកចីវរ ហើយទុកឱ្យកន្លងសម័យចីវរកាលទៅ ត្រូវនិស្សគ្គិយបាចិត្តិយ។ អច្ចេកចីវរមែន ភិក្ខុសំគាល់ថាមិនមែនជាអច្ចេកចីវរ ទុកឱ្យកន្លងហួសសម័យចីវរកាលទៅត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុសំគាល់អច្ចេកចីវរដែលមិនបានអធិដ្ឋាន ថាបានអធិដ្ឋានហើយក្តី សំគាល់អច្ចេកចីវរដែលមិនបានវិកប្ប ថាបានវិកប្បរួចហើយក្តី សំគាល់អច្ចេកចីវរដែលមិនបានលះបង់ថាបានលះបង់ហើយក្តី សំគាល់អច្ចេកចីវរដែលមិនបាត់ ថាបាត់បង់ទៅហើយក្តី សំគាល់អច្ចេកចីវរដែលមិនវិនាស ថាវិនាសហើយក្តី សំគាល់អច្ចេកចីវរដែលភ្លើងមិនឆេះ ថាភ្លើងឆេះហើយក្តី សំគាល់អច្ចេកចីវរ ដែលចោរមិនបានប្លន់ ថាចោរប្លន់យកទៅហើយក្តី ហើយទុកឱ្យកន្លងហួសចីវរកាលទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ។ ភិក្ខុ

មិនលះបង់ចីវរដែលជានិស្សគ្គិយហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់សម្គត់ដែលមិនមែនអច្ចេកចីវរ ថាជាអច្ចេកចីវរ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងសម្គត់ដែលមិនមែនអច្ចេកចីវរ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់សម្គត់ ដែលមិនមែនជាអច្ចេកចីវរ ថាមិនមែនអច្ចេកចីវរ មិនត្រូវអាបត្តិឡើយ។

[១៦៤] អាបត្តិមិនមានដល់ភិក្ខុដែលបានអធិដ្ឋានអច្ចេកចីវរ(ក្តី) វិកប្បទុក(ក្តី) លះបង់ឱ្យគេ(ក្តី) ដល់ភិក្ខុដែលមានអច្ចេកចីវរបាត់ទៅ(ក្តី) វិនាសទៅ(ក្តី) ភ្លើងឆេះ(ក្តី) ចោរដណ្តើមយកទៅ(ក្តី) សហធម្មិកកាន់យកទៅដោយសេចក្តីស្និទ្ធស្នាល(ក្តី) ខាងក្នុងសម័យចីវរកាល ដល់ភិក្ខុឆ្កួត ដល់ភិក្ខុខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៨ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី៩ (២៩)

CS vin.vbu.ni.29 | ភាគ ទី៣

### (៩. សាសង្កសិក្ខាបទំ)

[១៦៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគកាលគង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកមហាសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុទាំងឡាយនៅចាំវស្សាហើយ ទៅនៅក្នុងសេនាសនៈដែលឋិតនៅក្នុងព្រៃ។ ពួកចោរខែកត្តិក[33] គិតគ្នាថា ពួកភិក្ខុបានលាភ(ច្រើន) ហើយក៏នាំគ្នាមកបៀតបៀន។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សំដែងធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអាស្រ័យនៅសេនាសនៈក្នុងព្រៃ តថាគតអនុញ្ញាតឱ្យទុក បណ្តាចីវរទាំង ៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះបាន។ សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់អនុញ្ញាតឱ្យភិក្ខុដែលអាស្រ័យនៅសេនាសនៈក្នុងព្រៃទុកដាក់បណ្តាចីវរទាំង៣ ចីវរណាមួយ ក្នុងចន្លោះផ្ទះបាន។ ពួកភិក្ខុនោះក៏បានទុកដាក់បណ្តាចីវរទាំង ៣ ចីវរណាមួយក្នុងចន្លោះផ្ទះហើយនៅប្រាសចាកហួស៦រាត្រី។ ចីវរទាំងនោះបាត់ទៅខ្លះ ខូចខាតទៅខ្លះ ភ្លើងឆេះខ្លះ កណ្តុរកាត់ខ្លះ។ ភិក្ខុទាំងឡាយមានសម្គត់អាក្រក់មានចីវរសៅហ្មង។ ពួកភិក្ខុ(ឯទៀត) សួរយ៉ាងនេះថា នែអាវុសោ ហេតុម្តេចបានជាអ្នកទាំងឡាយមានសម្គត់អាក្រក់ មានចីវរសៅហ្មង។ ភិក្ខុទាំងនោះក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វីបានជាភិក្ខុទាំងឡាយទុក បណ្តាចីវរទាំង៣ ចីវរណាមួយក្នុងចន្លោះផ្ទះ(គឺក្នុងភូមិ ឬក្នុងស្រុក) ហើយនៅប្រាសចាក(ត្រៃចីវរ)នោះហួស៦រាត្រី។ ខណៈនោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុទុក បណ្តាចីវរទាំង៣ ចីវរណាមួយក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកហួស៦រាត្រី ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធដ៏មានយសជាម្ចាស់ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចុះហេតុអ្វី បានជាពួកមោឃបុរសទាំងនោះទុក បណ្តាចីវរទាំង៣ ចីវរណាមួយក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកហួស៦រាត្រីទៅ នែភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិនមែននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាផង មិនមែននាំពួកជនដែលជ្រះ ថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទៀតផង។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើភិក្ខុទាំងឡាយចាំវស្សារួចហើយ លុះដល់មកពេញបូណ៌មីខែកត្តិក។ សេនាសនៈទាំងឡាយណាដែលតាំងនៅក្នុងព្រៃ ដែលគេសម្មតិថាជាទីមានសេចក្តីរង្កៀស មានភ័យចំពោះមុខ កាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយមានសភាពដូច្នោះ បើមានចំណង់នឹងទុកចីវរ គប្បីទុកបណ្តាចីវរទាំង៣ចីវរណាមួយក្នុងចន្លោះផ្ទះ។ តែបើភិក្ខុនោះមានហេតុអ្វីនីមួយល្មមឱ្យនៅប្រាសចាកចីវរនោះបាន ភិក្ខុនោះគប្បីនៅ ប្រាសចាកចីវរនោះយ៉ាងយូរត្រឹម៦រាត្រី។ បើនៅប្រាសចាកឱ្យហួសពីកំណត់នោះទៅ ត្រូវអាបត្តិ និស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសេចក្តីសម្មតិអំពីសង្ឃ។

[១៦៦] ត្រង់ពាក្យថា ចាំវស្សារួចហើយ គឺចេញវស្សាហើយ។ ពាក្យថា ពេញបូណ៌មីខែកត្តិក គឺថាព្រះដ៏មានព្រះភាគត្រាស់សំដៅយកខែទី៤ (ខែវស្សានរដូវ) ឈ្មោះថា កត្តិក។[34] ពាក្យថាសេនាសនៈ ទាំងឡាយណាដែលតាំងនៅក្នុងព្រៃ គឺសេនាសនដែលតាំងនៅក្នុងព្រៃ មានចម្ងាយពីស្រុក៥០០ ជួរធ្នូកំណត់យ៉ាងជិតបំផុត។ ដែលហៅថា ទីមានសេចក្តីរង្កៀសនោះ បានដល់ឱកាសដែលពួកចោរអាស្រ័យនៅ បរិភោគ ឈរ អង្គុយ ដេក មានប្រាកដក្នុងអារាម ឬឧបចារនៃអារាម។ ដែលហៅថា ទីមានភ័យចំពោះមុខនោះ គឺ ក្នុងអារាមឬ ឧបចារនៃអារាម ប្រាកដថាមានពួកចោរសម្លាប់មនុស្សទាំងឡាយ ប្រាកដថាមានពួកចោរប្លន់ ប្រាកដថាមានពួកចោរវាយដំ។ ពាក្យថា កាលភិក្ខុនៅក្នុងសេនាសនៈ ទាំងឡាយមានសភាពដូច្នោះ គឺថាកាលភិក្ខុនៅក្នុងសេនាសនៈទាំងឡាយមានសភាពយ៉ាងនេះ។ ពាក្យថា បើមានចំណង់ គឺកាលប្រាថ្នា (នឹងទុកចីវរ)។ ពាក្យថា បណ្តាចីវរទាំង៣ ចីវរណាមួយ គឺភិក្ខុទុកសង្ឃាដិ ឬឧត្តរាសង្គ (ចីពរ) ឬអន្តរវាសក (ស្បង់)។ ពាក្យថា គប្បីទុកក្នុងចន្លោះផ្ទះ គឺគប្បីទុកក្នុងស្រុកជាទីគោចរដោយជុំវិញបាន។ ពាក្យថា តែបើភិក្ខុនោះមានហេតុអ្វីល្មមឱ្យនៅប្រាសចាកចីវរនោះបានគឺ មានហេតុមានកិច្ចដែលត្រូវធ្វើ។ ពាក្យថា ភិក្ខុនោះគប្បីនៅប្រាសចាកចីវរនោះយ៉ាងយូរត្រឹម ៦រាត្រី គឺភិក្ខុគប្បីនៅប្រាសចាកត្រឹម៦រាត្រីយ៉ាងយូរ។ ពាក្យថា វៀរលែងតែភិក្ខុដែលបានសេចក្តីសម្មតិ អំពីសង្ឃ គឺលើកទុកតែភិក្ខុដែលបានសេចក្តីសម្មតិអំពីសង្ឃ។ ពាក្យថា បើនៅប្រាសចាកឱ្យហួសពីកំណត់នោះទៅ មានអធិប្បាយថា កាលអរុណរះឡើងក្នុងថ្ងៃទី៧ ចីវរនោះជានិស្សគ្គិយ ភិក្ខុម្ចាស់ចីវរត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុម្ចាស់ចីវរត្រូវលះបង់យ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ចីវររបស់ខ្ញុំនេះដែលខ្ញុំនៅប្រាសហើយអស់កាលជាង៦រាត្រី ជានិស្សគ្គិយ ព្រោះមិនមានភិក្ខុសម្មតិ ខ្ញុំសូមលះបង់ចីវរនេះដល់សង្ឃ។បេ។ ពាក្យត អំពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃចីវរវគ្គខាងដើមហើយ។

[១៦៧] ចីវរកន្លងហួសជាង៦រាត្រី ភិក្ខុសំគាល់ថាហួសជាង ហើយនៅប្រាសចាកចោល ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងចីវរដែល កន្លងហួស៦ រាត្រី ហើយនៅប្រាសចាកចោល ត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ។ ចីវរកន្លងហួស ៦ រាត្រី ភិក្ខុសំគាល់ថានៅខ្វះ ហើយនៅប្រាសចាកចោល ត្រូវនិស្សិគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុ

ដែលបានសម្មតិអំពីសង្ឃ។ ចីវរដែលភិក្ខុមិនទាន់បានដកអធិដ្ឋាន ភិក្ខុសំគាល់ថាបានដកអធិដ្ឋានហើយ (ក្តី) ចីវរដែលភិក្ខុមិនទាន់លះបង់ទេ សំគាល់ថាបានលះបង់ហើយ (ក្តី) ចីវរមិនបាត់ទេ ភិក្ខុសំគាល់ថាបាត់ទៅហើយ (ក្តី) ចីវរមិនវិនាសទេ សំគាល់ថាវិនាសទៅហើយ (ក្តី) ចីវរភ្លើងមិនឆេះទេ ភិក្ខុសំគាល់ថាភ្លើងឆេះហើយ (ក្តី) ចីវរដែលចោរមិនបានលួចយកទេ ភិក្ខុសំគាល់ថាចោរលួចយកទៅ ហើយ(ក្តី) បើនៅប្រាសចាកត្រូវនិស្សគ្គិយបាចិត្តិយ វៀរលែងតែភិក្ខុដែលបានសម្មតិអំពីសង្ឃ។ ភិក្ខុមិនលះបង់ចីវរដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ ចីវរមិនទាន់ដល់៦រាត្រី តែភិក្ខុសំគាល់ថាលើសហើយ ត្រូវអាបត្តិទុក្កដ។ ចីវរមិនទាន់ដល់៦រាត្រី តែភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ ចីវរមិនទាន់ដល់៦រាត្រី ភិក្ខុសំគាល់ថាមិនទាន់ដល់៦រាត្រី មិនត្រូវអាបត្តិ។

[១៦៨] អាបត្តិមិនមានដល់ភិក្ខុដែលនៅប្រាសចាកចីវរត្រឹម៦រាត្រី ដល់ភិក្ខុដែលនៅប្រាសចាកខ្វះពី ៦ រាត្រីចុះមក ដល់ភិក្ខុដែលនៅប្រាសចាក៦រាត្រី ហើយត្រឡប់មកកាន់ដែននៃស្រុកនោះវិញឈប់នៅកន្លែងណាមួយ ហើយចៀសចេញទៅ ដល់ភិក្ខុដកអធិដ្ឋាន(ក្តី) លះបង់(ក្តី) ក្នុង៦រាត្រីចុះមក ចីវរបាត់ទៅ(ក្តី) វិនាសទៅ(ក្តី) ភ្លើងឆេះ(ក្តី) ចោរដណ្តើមយកទៅ(ក្តី) សហធម្មិកកាន់យកទៅដោយស្និទ្ធស្នាល(ក្តី) ក្នុង៦រាត្រីចុះមក ដល់ភិក្ខុដែលបានសម្មតិ (អំពីសង្ឃ) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី៩ ចប់។

## (និស្សគ្គិយ) សិក្ខាបទ ទី១០ (៣០)

CS vin.vbu.ni.30 | ភាគ ទី៣

### (១០. បរិណតសិក្ខាបទំ)

[១៦៩] សម័យនោះ ព្រះពុទ្ធដ៏មានយសជាម្ចាស់ កាលគង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកមហាសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯងមានប្រជុំជនមួយពួកក្នុងក្រុងសាវត្ថីតាក់តែងភត្ត ព្រមទាំងចីវរប្រគេនដល់សង្ឃដោយសេចក្តីព្រមព្រៀងគ្នាថា ពួកយើងនឹងនិមន្តឱ្យសង្ឃឆាន់ហើយប្រគេនចីវរឱ្យគ្រង់។ លំដាប់នោះ ពួកភិក្ខុឆព្វគ្គិយចូលទៅ រកប្រជុំជនពួកនោះ លុះចូលទៅដល់បាននិយាយពាក្យនេះនឹងប្រជុំជនពួកនោះថា នែអ្នកមានអាយុទាំងឡាយ ពួកអ្នកឯងចូរប្រគេនចីវរទាំងនេះមកពួកអាត្មាចុះ។ ជនពួកនោះនិយាយថា លោកម្ចាស់ ពួកខ្ញុំករុណាមិនបានប្រគេនទេ ឯចង្ហាន់ព្រមទាំងចីវរ ពួកខ្ញុំករុណាធ្លាប់ចាត់ចែងទុកប្រគេនដល់សង្ឃតែរាល់ឆ្នាំ។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា នែអាវុសោ ពួកទាយករបស់សង្ឃក៏មានច្រើន ចង្ហាន់របស់សង្ឃក៏មានច្រើន ពួកយើងអាស្រ័យពឹងពាក់នឹងអ្នកទាំងឡាយ ទើបនៅក្នុងទីនេះបាន បើអ្នកទាំងឡាយមិនឱ្យមកពួកអាត្មា អ្នកណាហ្ន៎គេនឹងឱ្យដល់ពួកអាត្មា ម្នាលអ្នកដ៏មាន អាយុទាំងឡាយ ពួកអ្នកចូរឱ្យចីវរទាំងនេះមកពួកអាត្មាចុះ។ លំដាប់នោះ ប្រជុំជនពួកនោះ កាលបើពួកឆព្វគ្គិយភិក្ខុនិយាយឆ្កឹះឆ្កៀលណាស់ទៅ ទើបប្រគេនចីវរដែលខ្លួនតាក់តែងទាំងប៉ុន្មានទៅពួកឆព្វគ្គិយភិក្ខុ ហើយអង្គាសសង្ឃដោយចង្ហាន់ (តែម្យ៉ាង)។ ពួកភិក្ខុណាដឹងថាចង្ហាន់ព្រមទាំងចីវរដែលគេតាក់តែងទុកសម្រាប់ប្រគេនសង្ឃ តែមិនដឹងថាចីវរគេប្រគេនដល់ពួកភិក្ខុឆព្វគ្គិយទៅហើយ ភិក្ខុទាំងនោះទើបពោលយ៉ាងនេះថា នែអ្នកដ៏មានអាយុទាំងឡាយ ពួកអ្នកចូរវេរប្រគេនចីវរដល់សង្ឃទៅ។ ឯប្រជុំជនពួកនោះឆ្លើយថា បពិត្រលោកម្ចាស់ទាំងឡាយ ចីវរដែលតាក់តែងទុកប្រគេនសង្ឃគ្មានទេ (ព្រោះ) ពួកភិក្ខុឆព្វគ្គិយបង្អោនទៅដើម្បីខ្លួនលោកអស់ហើយ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុឆព្វគ្គិយដឹងថាលាភគេបង្អោនទៅដើម្បីសង្ឃហើយ ហេតុអ្វីបានជាត្រឡប់បង្អោនមកដើម្បីខ្លួនវិញ។ លំដាប់នោះ ពួកភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ឮថាពួកអ្នកឯងដឹងថាលាភគេបង្អោនទៅ ដើម្បីសង្ឃហើយ ត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគជាម្ចាស់ទ្រង់បន្ទោសថា នែពួកមោឃបុរស ពួកអ្នកឯងដឹងថាលាភគេបង្អោនទៅដើម្បីរបស់សង្ឃហើយ ចុះហេតុអ្វីបានជាបង្អោនមកដើម្បីខ្លួនវិញ នែពួកមោឃបុរស ដំណើរនេះមិននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើងទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយកាលដឹង ហើយបង្អោននូវលាភរបស់សង្ឃដែលគេនឹងបង្អោនទៅ (ដើម្បីសង្ឃ) មកដើម្បីខ្លួនវិញ ភិក្ខុនោះត្រូវនិស្សគ្គិយបាចិត្តិយ។

[១៧០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទបឋមបារាជិករួចហើយ។ ដែលហៅថា ដឹង (ក្នុងសិក្ខាបទនេះ) គឺដឹងខ្លួនឯងក្តី អ្នកដទៃមកប្រាប់ភិក្ខុនោះក្តី អ្នកម្ចាស់ទាននោះមកប្រាប់ (ដល់ភិក្ខុនោះ)ក្តី។ ដែលហៅថារបស់សង្ឃនោះ គឺទាយកបានវេរ ប្រគេន បរិច្ចាគដល់សង្ឃហើយ។ ដែលហៅថា លាភនោះ បានដល់ ចីវរ បិណ្ឌបាត សេនាសនៈនិងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្ស ជម្ងឺ ដោយហោចទៅ ដុំនៃលំអិតក្តី ឈើស្ទន់ក្តី អម្បោះរងជើងក្តី ក៏ហៅថាលាភដែរ។ ដែលហៅថា បង្អោននោះ គឺម្ចាស់ទានបញ្ចេញ វាចាថា ពួកយើងនឹងឱ្យ ពួកយើងនឹងធ្វើ។ ភិក្ខុបង្អោន (លាភ)មកដើម្បីខ្លួន ត្រូវអាបត្តិទុក្កដតាមប្រយោគ។ លាភនោះជានិស្សគ្គិយ ក្នុងខណៈដែលបានមក ភិក្ខុត្រូវលះបង់ដល់សង្ឃក៏បាន គណៈក៏បាន បុគ្គលក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវលះបង់យ៉ាងនេះ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំដឹងថាលាភនេះ ទាយកបង្អោនទៅដើម្បីរបស់ សង្ឃហើយ ខ្ញុំត្រឡប់បង្អោនមកដើម្បីខ្លួនវិញ (លាភនេះ) ជានិស្សគ្គិយ ខ្ញុំសូមលះបង់លាភនេះដល់សង្ឃ។ បេ។ ពាក្យតអំពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃចីវរវគ្គខាងដើមហើយ។ ភិក្ខុសំគាល់ក្នុងលាភ ដែលទាយកបានបង្អោនហើយថាទាយកបានបង្អោនមកមែន ហើយបង្អោនមកដើម្បីខ្លួនវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងលាភដែលទាយកបានបង្អោនទៅហើយ ត្រឡប់បង្អោនមកដើម្បីខ្លួនវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ក្នុងលាភដែលទាយកបានបង្អោនទៅហើយ ថាមិនទាន់បង្អោនទៅទេ ត្រឡប់បង្អោនមកដើម្បីខ្លួន មិនត្រូវអាបត្តិ។ លាភដែលទាយកបង្អោនទៅដើម្បីសង្ឃហើយ ភិក្ខុបង្អោនទៅដើម្បីសង្ឃដទៃក្តី ដើម្បីចេតិយក្តី ត្រូវអាបត្តិទុក្កដ។ លាភដែលទាយកបង្អោនទៅដើម្បី ចេតិយហើយ ភិក្ខុត្រឡប់បង្អោនទៅដើម្បីចេតិយដទៃក្តី សង្ឃក្តី គណៈក្តី បុគ្គលក្តី ត្រូវអាបត្តិទុក្កដ។ លាភដែលទាយកបង្អោនទៅដើម្បីបុគ្គល ភិក្ខុត្រឡប់បង្អោនទៅដើម្បីបុគ្គលឯទៀតក្តី សង្ឃក្តី គណៈក្តី ចេតិយក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ក្នុងលាភដែលទាយកមិនបានបង្អោនទៅ ថាបានបង្អោនទៅហើយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងលាភដែលទាយកមិនបានបង្អោនទៅ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ ក្នុងលាភដែលគេមិនបានបង្អោនទៅ ថាគេមិនបានបង្អោនទៅ មិនត្រូវអាបត្តិឡើយ។

[១៧១] អាបត្តិមិនមានដល់ភិក្ខុដែលទាយកគេសួរថា យើងទាំងឡាយនឹងវេរប្រគេនក្នុងទីណា ហើយប្រាប់គេថា ទេយ្យធម៌របស់អ្នកទាំងឡាយគួរបាននូវការបរិភោគក្ដី គួរបាននូវការជួសជុលក្ដី គួរតាំងនៅអស់កាលដ៏យូរក្ដីក្នុងទីណា ម្យ៉ាងទៀត បើចិត្តរបស់អ្នកទាំងឡាយជ្រះថ្លាក្នុងទីណា អ្នកទាំងឡាយចូរវេរប្រគេនក្នុងទីនោះៗចុះ ដល់ភិក្ខុខូចចរិត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី១០ ចប់។

បត្តវគ្គ ទី៣ ចប់។

ចំនួនសិក្ខាបទក្នុងបត្តវគ្គនោះ គឺ

សិក្ខាបទទី១ ២ និយាយអំពីបាត្រ សិក្ខាបទទី ៣ និយាយអំពីថ្នាំសិក្ខាបទទី ៤ និយាយអំពីសម្ពត់ងូតទឹកភ្លៀង សិក្ខាបទទី ៥ និយាយអំពីការឱ្យចីវរ សិក្ខាបទទី ៦ និយាយអំពីការសូមអម្បោះគេមកខ្លួនឯង សិក្ខាបទទី៧ និយាយអំពីការប្រើឱ្យគេត្បាញ សិក្ខាបទទី៨ និយាយអំពីអច្ចេកចីវរ សិក្ខាបទទី៩ និយាយអំពីទីមានសេចក្ដីរង្កៀស សិក្ខាបទទី១០ និយាយអំពីការបង្អោនលាភរបស់សង្ឃ។

[១៧២] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិនិស្សគ្គិយបាចិត្តិយទាំង ៣០ ខ្ញុំសំដែងឡើងហើយ។ ខ្ញុំសូមសួរលោកដ៏មានអាយុទាំងឡាយក្នុងអាបត្តិទាំងនោះ លោកទាំងឡាយ បរិសុទ្ធហើយឬ ខ្ញុំសួរជាគំរប់ពីរដងផង លោកទាំងឡាយ បរិសុទ្ធហើយឬ ខ្ញុំសួរជាគំរប់បីដងផង លោកទាំងឡាយ បរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះបានជាស្ងៀមនៅ ខ្ញុំចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ។

និស្សគ្គិយកណ្ឌ ចប់។

# បាចិត្តិយកណ្ឌ

CS vin.vbu.pc | ភាគ ទី៣

### (៥. បាចិត្តិយកណ្ឌំ)

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាចិត្តិយ៩២ទាំងនេះឯងតែងមកកាន់ឧទ្ទេស។

## មុសាវាទវគ្គ (ទី១)

CS vin.vbu.pc.v1 | ភាគ ទី៣

### (១. មុសាវាទវគ្គោ)

## (បាចិត្តិយ) បឋមសិក្ខាបទ (ទី១)

CS vin.vbu.pc.01 | ភាគ ទី៣

### (១. មុសាវាទសិក្ខាបទំ)

[១៧៣] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ព្រះអង្គគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ហត្ថកភិក្ខុជាសក្យបុត្រជាអ្នកហុចពាក្យសំដី។ ហត្ថកភិក្ខុនោះចរចាជាមួយនឹងតិរ្ថិយទាំងឡាយ គេចកែសំដី[35] ហើយទទួលដឹង[36] ទទួលដឹងហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុ ដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្ដីកំណត់ហើយពោលឱ្យខុសពីកំណត់នោះវិញ។ តិរ្ថិយទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វីបានជាហត្ថកភិក្ខុ ជាសក្យបុត្រពោលចរចាជា មួយនឹងយើងទាំងឡាយ គេចកែសំដីទទួលដឹង ទទួលដឹងហើយ ត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្ដីកំណត់ហើយពោលឱ្យខុសពីកំណត់នោះវិញ។ ភិក្ខុទាំងឡាយបានឮតិរ្ថិយទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបភិក្ខុទាំងនោះចូលទៅរកហត្ថកភិក្ខុជាសក្យបុត្រ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងហត្ថកភិក្ខុ ជាសក្យបុត្រថា ម្នាលអាវុសោហត្ថក បានឮថា អ្នកពោលចរចាមួយអន្លើដោយតិរ្ថិយទាំងឡាយ គេចកែសំដីហើយទទួលដឹង ទទួលដឹង ហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្ដីកំណត់ហើយពោលឱ្យខុសពីកំណត់នោះវិញ មែនឬដូចម្ដេច។ ហត្ថកភិក្ខុឆ្លើយថា ម្នាលអាវុសោ ធម្មតាតិរ្ថិយទាំងឡាយនុ៎ះ ត្រូវតែបុគ្គលឯណានីមួយផ្ចាញ់ផ្ចាលចេញ មិន ត្រូវឱ្យការឈ្នះទៅតិរ្ថិយទាំងឡាយនោះទេ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វីបានជាហត្ថកភិក្ខុជាសក្យបុត្រ ពោលចរចាមួយអន្លើដោយតិរ្ថិយទាំងឡាយ គេចកែសំដីហើយទទួលដឹង ទទួលដឹងហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ និយាយពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្ដីកំណត់ហើយពោលឱ្យខុសពីកំណត់នោះវិញ។ ទើបភិក្ខុទាំងឡាយនោះយកសេចក្ដីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មាន ព្រះភាគជាម្ចាស់ទ្រង់ឱ្យប្រជុំភិក្ខុ

សង្ឃ ហើយសួរចំពោះហត្ថកភិក្ខុជាសក្យបុត្រក្នុងពេលនោះថា ម្នាលហត្ថកភិក្ខុ បានឮថា អ្នកពោលចរចាមួយអន្លើ ដោយតិរ្ថិយទាំងឡាយ គេចកែសំដីហើយទទួលដឹង ទទួលដឹងហើយ ត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃដោយហេតុដទៃ ពោលពាក្យកុហកដោយដឹងខ្លួន ធ្វើនូវសេចក្ដីកំណត់ហើយពោលឱ្យខុសពីកំណត់នោះវិញ តើពិតមែនឬ។ ហត្ថកភិក្ខុឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា នែបុរសទទេ ចុះហេតុអ្វី បានជាអ្នកឯងពោលចរចាមួយអន្លើដោយតិរ្ថិយទាំងឡាយ គេចកែសំដីហើយទទួលដឹងហើយ ទទួលដឹងហើយត្រឡប់គេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលពាក្យកុហក ដោយដឹងខ្លួន ធ្វើនូវសេចក្ដីកំណត់ហើយពោលឱ្យខុសពីកំណត់នោះវិញ នែមោឃបុរស ការនេះមិនមែននាំឱ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លា ឬថានឹងនាំជនដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាង នេះថា ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួន ត្រូវអាបត្តិបាចិត្តិយ។

[១៧៤] ដែលហៅថា ពោលពាក្យកុហក ដោយដឹងខ្លួននោះ បានដល់វាចា សំដីគន្លងពាក្យវចីភេទ វិញ្ញត្តិប្រព្រឹត្តទៅក្នុងវាចារបស់បុគ្គលដែលធ្វើគំនិតនឹងពោលឱ្យខុសជាប្រធាន នឹងវោហារមិនមែនរបស់ព្រះអរិ យ៨យ៉ាងគឺ ការដែលមិនឃើញនិយាយថាអញឃើញ១ មិនឮនិយាយថាអញឮ ១ មិនបានពាល់ត្រូវនិយាយថាអញបានពាល់ត្រូវ ១ មិនដឹងច្បាស់និយាយថាអញដឹងច្បាស់ ១ ឃើញនិយាយថាអញមិនឃើញ ១ ឮនិយាយថាអញមិនឮ១ បានពាល់ត្រូវនិយាយថាអញមិនបានពាល់ត្រូវ ១ ដឹងច្បាស់និយាយថាអញមិនដឹងច្បាស់ ១។

[១៧៥] ដែលហៅថា មិនឃើញ គឺមិនឃើញដោយភ្នែក។ ដែលហៅថា មិនឮគឺមិនឮដោយត្រចៀក។ ដែលហៅថា មិនពាល់ត្រូវ គឺមិនហិតដោយច្រមុះ មិនលិតដោយអណ្ដាត មិនប៉ះពាល់ដោយកាយ។ ដែលហៅថា មិនដឹងច្បាស់ គឺមិនដឹងច្បាស់ដោយចិត្ត។ ដែលហៅថា ឃើញ គឺឃើញដោយភ្នែក។ ដែលហៅថាឮ គឺឮដោយត្រចៀក។ ដែលហៅថា ពាល់ត្រូវ គឺហិតដោយច្រមុះលិតដោយអណ្ដាត ប៉ះពាល់ ដោយកាយ។ ដែលហៅថា ដឹងច្បាស់ គឺដឹងច្បាស់ដោយចិត្ត។

[១៧៦] ភិក្ខុនិយាយកុហក ដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញដូច្នេះ ដោយអាការ ៣ យ៉ាងគឺ មុននឹងពោល គិតថាអញនឹងពោលកុហក ១ កំពុងពោលដឹងថា អញពោលកុហក១ ពោលរួចហើយដឹងថាអញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញដោយអាការ៤យ៉ាងគឺ មុននឹងពោលគិតថាអញនឹងពោលកុហក១ កំពុងពោលដឹងថាអញពោលកុហក១ ពោលរួចហើយ ដឹងថា អញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ[37] ១ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញ ដោយអាការ ៥ យ៉ាងគឺ មុននឹងពោលដឹងថាអញនឹងពោលកុហក ១ កំពុងពោលដឹងថាអញពោលកុហក១ ពោលរួចហើយ ដឹងថាអញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្ដីគាប់ចិត្ត១ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញ ដោយអាការ ៦យ៉ាង គឺមុននឹងពោល គិតថាអញនឹងពោលកុហក១ កំពុងពោលដឹងថា អញពោលកុហក១ ពោលរួចហើយដឹងថាអញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្ដីគាប់ចិត្ត ១ បិទបាំងនូវសេចក្ដីពេញចិត្ត ១ ត្រូវអាបត្តិ បាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញ ថាអាត្មាឃើញ ដោយអាការ៧យ៉ាង គឺមុននឹងពោលគិតថាអញនឹងពោលកុហក១ កំពុងពោលដឹងថាអញពោលកុហក១ ពោលរួចហើយដឹងថាអញពោលកុហកហើយ១ បិទបាំងនូវទិដ្ឋិ១ បិទបាំងនូវសេចក្ដីគាប់ចិត្ត១ បិទបាំងនូវសេចក្ដីចូលចិត្ត ១ បិទបាំងនូវសេចក្ដីពិតត្រង់១ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលមិនឮថា អាត្មាឮ។ បេ។ វត្ថុដែលមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវ។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ ដោយអាការ ៣ យ៉ាង គឺ មុននឹងពោលគិត ថាអញនឹងពោលកុហក១ កំពុងពោលដឹងថាអញពោលកុហក១ ពោល រួចហើយ ដឹងថាអញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនមិនដឹងច្បាស់ថា អាត្មា ដឹងច្បាស់ ដោយអាការ ៤យ៉ាង។ បេ។ អាការ ៥យ៉ាង។ បេ។ អាការ ៦ យ៉ាង។ បេ។ អាការ៧ យ៉ាង គឺ មុននឹងពោលគិតថា អញនឹងពោលកុហក១ កំពុងពោលដឹងថាអញពោលកុហក១ ពោលរួច ហើយដឹងថាអញពោលកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវ សេចក្ដីគាប់ចិត្ត ១ បិទបាំងនូវសេចក្ដីចូលចិត្ត ១ បិទបាំងនូវសេចក្ដីពិតត្រង់១ ត្រូវអាបត្តិបាចិត្តិយ។

[១៧៧] ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ថាអាត្មាឮផង ដោយអាការ ៣យ៉ាង ត្រូវអាបត្តិបាចិត្តិយ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ថាអាត្មាពាល់ត្រូវផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ។បេ។ ភិក្ខុនិយាយកុហកដោយ ដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ថាអាត្មាដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មាឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មា ឃើញផង ឮផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឃើញថា អាត្មា ឃើញផង ឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ពាល់ត្រូវផង ដោយអាការ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលខ្លួនមិនឮថា អាត្មាឮផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ឃើញ ផង ដោយអាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹង ខ្លួន ចំពោះវត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះ វត្ថុដែលខ្លួនមិនឮថា អាត្មាឮផង ពាល់ត្រូវផង ឃើញផង ដោយ អាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុ ដែលខ្លួនមិនឮថា អាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាពាល់ត្រូវផង ឃើញផង ដោយអាការ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាពាល់ត្រូវផង ឮផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវផង ដឹង ច្បាស់ផង ឮផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិនបានពាល់ត្រូវថា អាត្មាបានពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ឮផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិន

ដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឮផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាង។បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឃើញផង ពាល់ ត្រូវផង ដោយអាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនមិនដឹងច្បាស់ថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ៣ យ៉ាងត្រូវអាបត្តិបាចិត្តិយ។បេ។

[១៧៨] ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនបានឃើញថា អាត្មាមិនឃើញ ដោយអាការ៣យ៉ាង គឺមុននឹងពោល គិតថាអញនឹងពោលកុហក ១ កំពុងពោលដឹងថាអញពោលកុហក ១ ពោលរួចហើយដឹងថាអញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនបានឃើញថា អាត្មា មិនឃើញ ដោយអាការ ៤ យ៉ាង។ បេ។ អាការ ៥យ៉ាង។ បេ។ អាការ ៦ យ៉ាង។ បេ។ អាការ ៧ យ៉ាងគឺ មុននឹងពោលគិតថា អញនឹងពោលកុហក១ កំពុងពោលដឹងថាអញពោលកុហក១ ពោល រួចហើយដឹងថាអញកុហកហើយ ១ បិទបាំងនូវទិដ្ឋិ ១ បិទបាំងនូវសេចក្តីគាប់ចិត្ត ១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះពាក្យដែលខ្លួនបានឮថា អាត្មាមិនបានឮ ដោយអាការ ៣ យ៉ាង។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនបាន ពាល់ត្រូវថា អាត្មាមិនបានពាល់ត្រូវ។ បេ។ ភិក្ខុនិយាយកុហកដោយ ដឹងខ្លួន ចំពោះហេតុដែលខ្លួនបានដឹងច្បាស់ថា អាត្មាមិនបានដឹងច្បាស់ ដោយអាការ ៣ យ៉ាងគឺ មុននឹងពោលគិតថាអញនឹងពោលកុហក ១ កំពុងពោលដឹងថាអញពោលកុហក១ ពោលរួចហើយដឹងថាអញពោលកុហកហើយ ១ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះហេតុដែលខ្លួនដឹងច្បាស់ថា អាត្មាមិនដឹងច្បាស់ ដោយអាការ ៤ យ៉ាង។ បេ។ អាការ ៥ យ៉ាង។ បេ។ អាការ ៦ យ៉ាង។ បេ។ អាការ ៧ យ៉ាង មុននឹងពោលគិតថា អញនឹងពោលកុហក ១ កំពុងពោលដឹងថាអញពោលកុហក១ ពោលរួចហើយដឹងថាអញពោលកុហក ហើយ១ បិទបាំងនូវទិដ្ឋិ១ បិទបាំងនូវសេចក្តីគាប់ចិត្ត១ បិទបាំងនូវសេចក្តីចូលចិត្ត ១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ។

[១៧៩] ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួន ឃើញថា អាត្មាឮវិញ ដោយអាការ ៣យ៉ាង។ បេ។ វត្ថុដែលខ្លួនឃើញ ថា អាត្មាបានពាល់ត្រូវវិញ ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួន ឃើញថា អាត្មាដឹងច្បាស់វិញ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឃើញថា អាត្មាឮផង ពាល់ត្រូវផង ដោយអាការ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនឃើញ ថា អាត្មាឮផង ដឹងច្បាស់ផង ដោយអាការ៣ យ៉ាង។ បេ។ វត្ថុដែល ខ្លួនឃើញថា អាត្មាឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ។ បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឮថា អាត្មាពាល់ត្រូវ ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនឮថា អាត្មាដឹងច្បាស់។ បេ។ វត្ថុដែលខ្លួនឮថា អាត្មាឃើញ ដោយអាការ៣យ៉ាង ត្រូវអាបត្តិបាចិត្តិយ។ បេ។ ភិក្ខុនិយាយកុហក ដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនឮថា អាត្មាពាល់ត្រូវផង ដឹងច្បាស់ផង ដោយអាការ៣ យ៉ាង។បេ។ វត្ថុដែលខ្លួនឮថា អាត្មាពាល់ត្រូវផង ឃើញផង។ បេ។ វត្ថុដែលខ្លួនឮថា អាត្មាពាល់ត្រូវផង ដឹងច្បាស់ផង ឃើញផង ដោយអាការ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ។ បេ។ ភិក្ខុនិយាយ កុហក ដោយដឹងខ្លួន ចំពោះវត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាដឹងច្បាស់ ដោយអាការ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាឃើញ។ បេ។ វត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាឮ។ បេ។ វត្ថុដែលខ្លួនពាល់ត្រូវថា អាត្មាដឹងច្បាស់ផង ឃើញផង ដោយអាការ៣ យ៉ាង។បេ។ វត្ថុដែល ខ្លួនពាល់ត្រូវថា អាត្មាដឹងច្បាស់ផង ឮផង។ បេ។ វត្ថុដែលខ្លួនពាល់ ត្រូវថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង។ បេ។ វត្ថុដែលខ្លួនដឹង ច្បាស់ថា អាត្មាឃើញ ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនដឹង ច្បាស់ថា អាត្មាឮ។ បេ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាពាល់ត្រូវវិញ។ បេ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាឃើញផង ឮផង ដោយអាការ ៣ យ៉ាង។ បេ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាឃើញផង ពាល់ត្រូវ ផង។ បេ។ វត្ថុដែលខ្លួនដឹងច្បាស់ថា អាត្មាឃើញផង ឮផង ពាល់ត្រូវ ផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ។បេ។

[១៨០] ភិក្ខុមានសេចក្តីសង្ស័យក្នុងវត្ថុដែលខ្លួនឃើញ (ក្តី) មិន ជឿវត្ថុដែលខ្លួនបានឃើញ (ក្តី) រលឹកមិនបាននូវវត្ថុដែលខ្លួនឃើញហើយ (ក្តី) ភ្លេចនូវវត្ថុដែលខ្លួនបានឃើញ (ក្តី) ហើយពោលពាក្យកុហកដោយ ដឹងខ្លួនថាអាត្មាឃើញផង ឮផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបាចិត្តិយ។ បេ។ ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួនថា អាត្មាឃើញផង ឮផង ពាល់ត្រូវផង ដឹងច្បាស់ផង ត្រូវអាបត្តិបាចិត្តិយ។ បេ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងពាក្យដែលខ្លួនបានឮ (ក្តី) មិនជឿពាក្យដែលខ្លួនបាន ឮ (ក្តី) រលឹកមិនបាននូវពាក្យដែលខ្លួនបានឮ (ក្តី) ភ្លេចពាក្យដែលខ្លួនឮហើយ (ក្តី)។ បេ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវត្ថុដែលខ្លួនបាន ពាល់ត្រូវ (ក្តី) មិនជឿវត្ថុដែលខ្លួនបានពាល់ត្រូវ (ក្តី) រលឹកមិនបាននូវ វត្ថុដែលខ្លួនបានពាល់ត្រូវ (ក្តី) ភ្លេចវត្ថុដែលខ្លួនបានពាល់ត្រូវ(ក្តី)។ បេ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងហេតុដែលខ្លួនដឹងច្បាស់ (ក្តី) មិនជឿ ហេតុដែលខ្លួនបានដឹងច្បាស់(ក្តី) រលឹកមិនបាននូវហេតុដែលខ្លួនដឹងច្បាស់ (ក្តី) ភ្លេចហេតុដែលខ្លួនដឹងច្បាស់ (ក្តី) ហើយពោលពាក្យកុហកដោយ ដឹងខ្លួនថា អាត្មាដឹងច្បាស់ផង ឃើញផង ដោយអាការ ៣ យ៉ាង។ បេ។ ថាអាត្មាដឹងច្បាស់ផង ឮផង។ បេ។ ថាអាត្មាដឹងច្បាស់ផង ពាល់ត្រូវផង។ បេ។ ថាអាត្មាដឹងច្បាស់ផង ឃើញផង ឮផង។ បេ។ ថាអាត្មាដឹង ច្បាស់ផង ឃើញផង ពាល់ត្រូវផង។ បេ។ ភិក្ខុពោលពាក្យកុហក ដោយដឹងខ្លួនថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ត្រូវផង ដោយអាការ ៣ យ៉ាងគឺ មុននឹងពោលគិតថាអញនឹងពោលកុហក១កំពុង ពោលដឹងថាអញពោលកុហក១ ពោលរួចហើយដឹងថាអញពោលកុហកហើយ ១។ ភិក្ខុមានសេចក្តីសង្ស័យក្នុងហេតុដែលខ្លួនដឹងច្បាស់ (ក្តី) មិនជឿហេតុដែលខ្លួនដឹងច្បាស់ (ក្តី) រលឹកមិនបាននូវហេតុដែលខ្លួនដឹង ច្បាស់(ក្តី) ភ្លេចហេតុដែលខ្លួនដឹងច្បាស់ (ក្តី) ហើយពោលពាក្យកុហកដោយដឹងខ្លួនថា អាត្មាដឹងច្បាស់ផង ឃើញផង ឮផង ពាល់ ត្រូវផង ដោយអាការ ៤យ៉ាង។ បេ។ អាការ ៥ យ៉ាង។ បេ។ អាការ ៦ យ៉ាង។ បេ។ អាការ ៧ យ៉ាង គឺ មុននឹងពោលដឹងថាអញ នឹងពោលកុហក១ កំពុងពោលដឹងថាអញពោលកុហក១ ពោលរួច ហើយដឹងថាអញពោលកុហកហើយ១ បិទបាំងនូវទិដ្ឋិ១ បិទបាំងនូវសេចក្តីគាប់ចិត្ត១ បិទបាំងនូវសេចក្តីចូលចិត្ត១ បិទបាំងនូវសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបាចិត្តិយ។

[១៨១] អាបត្តិមិនមានដល់ភិក្ខុពោលដោយញាប់មាត់ ដល់ភិក្ខុពោលដោយភ្លាត់មាត់ (ភិក្ខុពោលដោយរហ័សឈ្មោះថាពោលដោយញាប់មាត់។ ភិក្ខុគិតថា អញនឹងពោលពាក្យដទៃ ហើយត្រឡប់ពោលពាក្យដទៃក្រៅអំពីគំនិតនោះវិញ ឈ្មោះថា ពោលដោយភ្លាត់មាត់ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

បឋមសិក្ខាបទ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី២

CS vin.vbu.pc.02 | ភាគ ទី៣

### (២. ឱមសវាទសិក្ខាបទំ)

[១៨២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ ឈ្លោះនឹងពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោតភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេចដោយជាតិខ្លះ ឈ្មោះខ្លះ គោត្តខ្លះ ការងារខ្លះ សិល្បសាស្រ្តខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោកទាបខ្លះ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏បានជាឆព្វគ្គិយភិក្ខុទាំងឡាយ ឈ្លោះនឹងភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោតភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេចដោយជាតិខ្លះ ឈ្មោះខ្លះ គោត្តខ្លះ ការងារខ្លះ សិល្បសាស្រ្តខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោក ទាបខ្លះ។ ភិក្ខុទាំងនោះ យកសេចក្តីនុ៎ះក្រាបទូលដល់ព្រះដ៏មានព្រះភាគ។ ព្រះបរមគ្រូត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថាអ្នកទាំងឡាយ ឈ្លោះនឹងភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោត ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេចដោយជាតិខ្លះ ឈ្មោះខ្លះ គោត្តខ្លះ ការងារខ្លះ សិល្បសាស្រ្តខ្លះ អាពាធខ្លះ ភេទខ្លះ កិលេសខ្លះ អាបត្តិខ្លះ ពាក្យជេរដ៏ថោកទាបខ្លះ ពិតមែនឬ។ ឆព្វគ្គិយភិក្ខុទាំងនោះក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះ ពិតមែន។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែ បុរសសាបសូន្យចាកមគ្គផលទាំងឡាយ ចុះហេតុអ្វីបានជាអ្នកទាំងឡាយ ឈ្លោះនឹងភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ពោលចាក់ដោត ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ គឺជេរប្រទេចដោយជាតិខ្លះ។ បេ។ ដោយពាក្យជេរដ៏ថោកទាបខ្លះ នែពួកមោឃបុរស ការនេះមិន មែននាំឱ្យកើតសេចក្តីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ នឹងមិនមែននាំជនដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ។ បេ។ លុះព្រះអង្គទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយ មកថា។

[១៨៣] ម្នាលភិក្ខុទាំងឡាយ កាលពីដើម មានព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងតក្កសិលា (ព្រាហ្មណ៍នោះ) មានគោ១ឈ្មោះនន្ទិវិសាល។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ គោឈ្មោះនន្ទិវិសាលបាននិយាយពាក្យនេះនឹងព្រាហ្មណ៍នោះថា បពិត្រព្រាហ្មណ៍ ចូរអ្នកទៅនិយាយភ្នាល់នឹងសេដ្ឋីដាក់មួយពាន់កហាបណៈថា គោរបស់ខ្ញុំនឹងទាញរទេះមួយរយ ដែលចងភ្ជាប់គ្នាឱ្យរួចបាន។ ម្នាលភិក្ខុទាំងឡាយ ទើបព្រាហ្មណ៍នោះ បានភ្នាល់នឹងសេដ្ឋីដាក់មួយពាន់កហាបណៈថា គោរបស់ខ្ញុំនឹងទាញរទេះចំនួនមួយរយដែលចងភ្ជាប់គ្នាបាន។ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នោះចងរទេះមួយរយភ្ជាប់គ្នា រួចក៏ទឹមគោឈ្មោះនន្ទិវិសាល ហើយនិយាយពាក្យនេះថា នែគោគៀច ឯងខំទាញទៅ នែគោគៀច ឯងខំអូសទៅ។ ម្នាលភិក្ខុទាំងឡាយ កាលនោះ គោឈ្មោះនន្ទិវិសាល ក៏ឈរទ្រឹងក្នុងទី នោះឯង ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍នោះក៏ចាញ់សេដ្ឋីអស់មួយពាន់កហាបណៈ ហើយក៏សុបសៅក្នុងកាលនោះឯង។ ម្នាលភិក្ខុទាំងឡាយ ទើបគោនន្ទិវិសាលបាននិយាយពាក្យនេះនឹងព្រាហ្មណ៍នោះថា បពិត្រព្រាហ្មណ៍ ហេតុអ្វីក៏អ្នកសុបសៅ។ ព្រាហ្មណ៍ឆ្លើយថា នែគោដ៏ចំរើន បានជាសុបសៅ ព្រោះអ្នកឯងឱ្យខ្ញុំចាញ់សេដ្ឋីអស់មួយពាន់កហាបណៈ។ គោនន្ទិវិសាលសួរថា ព្រាហ្មណ៍ ខ្ញុំមិនមែនជាសត្វគៀច ចុះហេតុអ្វី ក៏អ្នកឯងហៅខ្ញុំថាសត្វគៀច ព្រាហ្មណ៍ចូរអ្នកឯងទៅភ្នាល់នឹងសេដ្ឋីដាក់ពីរពាន់កហាបណៈថា គោរបស់ខ្ញុំទាញរទេះចំនួនមួយរយ ដែលគេចងភ្ជាប់គ្នាបាន តែថាអ្នកឯងកុំហៅខ្ញុំថាគោគៀចទៀត ព្រោះខ្ញុំ មិនមែនជាគោគៀចទេ។ ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍នោះភ្នាល់នឹងសេដ្ឋីដាក់ពីរពាន់កហាបណៈដោយពាក្យថា គោរបស់ខ្ញុំអាចទាញរទេះ ចំនួនមួយរយដែលគេចងភ្ជាប់គ្នាបាន។ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ នោះក៏ចងរទេះ ចំនួនមួយរយភ្ជាប់គ្នា រួចទឹមគោនន្ទិវិសាលហើយបាន និយាយពាក្យនេះក្នុងពេលនោះថា ម្នាលគោដ៏ចំរើន ចូរអ្នកឯងទាញទៅ ម្នាលគោដ៏ចំរើន ចូរអ្នកឯងអូសទៅ។ ម្នាលភិក្ខុទាំងឡាយ កាលនោះគោនន្ទិវិសាលក៏ទាញរទេះចំនួនមួយរយដែលគេចងភ្ជាប់គ្នាឱ្យវិលទៅបាន។

[១៨៤] បុគ្គលត្រូវពោលតែពាក្យដែលជាទីគាប់ចិត្តម្យ៉ាង ពាក្យដែលមិនជាទីគាប់ចិត្ត សូម្បីតែម្តង ក៏មិនត្រូវពោលឡើយ (ព្រាហ្មណ៍)ពោលពាក្យជាទីគាប់ចិត្ត (គោនន្ទិវិសាល) ក៏នាំទៅនូវភារៈជាទម្ងន់រួច ហើយញុំាងព្រាហ្មណ៍នោះឱ្យបានទ្រព្យផង មានសេចក្តីពេញចិត្តព្រោះព្រាហ្មណ៍នោះបានទ្រព្យផង ព្រោះការងាររបស់ខ្លួនផង។

[១៨៥] ម្នាលភិក្ខុទាំងឡាយ ពាក្យជេរប្រទេច មិនជាទីគាប់ចិត្តដល់តថាគតក្នុងកាលនោះ សំដីជេរប្រទេចនឹងជាទីគាប់ចិត្តក្នុងកាលឥឡូវនេះដូចម្តេចបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឱ្យជ្រះថ្លា ដល់អ្នកដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុពោលពាក្យចាក់ដោត ត្រូវអាបត្តិបាចិត្តិយ។

[១៨៦] ដែលហៅថា ពាក្យចាក់ដោតនោះ គឺភិក្ខុពោលចាក់ដោតដោយអាការ១០យ៉ាងគឺ ជាតិ១ ឈ្មោះ១ គោត្ត ១ ការងារ១ សិល្បសាស្រ្ត១ អាពាធ១ភេទ១ កិលេស១ អាបត្តិ១ ពាក្យជេរដ៏ថោកទាប១។

[១៨៧] ដែលហៅថា ជាតិ គឺ ជាតិមានពីរយ៉ាង បានដល់ហីនជាតិ[38] ១ ឧក្កដ្ឋជាតិ[39] ១។ ដែលហៅថា ហីនជាតិ គឺជាតិមនុស្សចណ្ឌាល[40] ជាតិជាងត្បាញផែង[41] ជាតិអ្នកនេសាទ[42] ជាតិអ្នកធ្វើរទេះ ជាតិអ្នកចោលសម្រាម ជាតិទាំងនេះហៅថា ហីនជាតិ។ ដែលហៅថា ឧក្កដ្ឋជាតិ គឺជាតិក្សត្រិយ៍ ជាតិព្រាហ្មណ៍ ជាតិទាំងនេះហៅថា ឧក្កដ្ឋជាតិ។

[១៨៨] ដែលហៅថា នាម គឺនាមមានពីរយ៉ាង បានខាងឯហីននាម១ ឧក្កដ្ឋនាម១។ ដែលហៅថា ហីននាម គឺ អវកណ្ណកនាម[43] (១) ជវកណ្ណកនាម (២) ធនិដ្ឋកនាម (៣) សវិដ្ឋកនាម (៤) កុលវឌ្ឍកនាម (៥) ពុំនោះសោត នាមណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ នាមទាំងនេះហៅថា ហីននាម។ ដែលហៅថា ឧក្កដ្ឋនាម គឺ នាមដែលប្រកបព្រមចំពោះដោយព្រះពុទ្ធ ប្រកបព្រមចំពោះដោយព្រះធម៌ ប្រកបព្រមចំពោះដោយព្រះសង្ឃ ពុំនោះសោត នាមណាដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះ ៗ នាមទាំងនេះហៅថា ឧក្កដ្ឋនាម។

[១៨៩] ដែលហៅថា គោត្ត គឺគោត្តមានពីរយ៉ាង បានខាងហីនគោត្ត ១ ឧក្កដ្ឋគោត្ត ១។ ដែលហៅថា ហីនគោត្ត គឺ ភារទ្វាជគោត្ត ពុំនោះសោត គោត្តណាដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ គោត្តទាំងនេះហៅថា ហីនគោត្ត។ ដែលហៅថា ឧក្កដ្ឋគោត្ត គឺគោតមគោត្ត មោគ្គល្លានគោត្ត កច្ចាយនគោត្ត វាសេដ្ឋគោត្ត ពុំនោះសោត គោត្តណា ដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះ។ គោត្តទាំងនេះហៅថា ឧក្កដ្ឋគោត្ត។

[១៩០] ដែលហៅថា ការងារ គឺការងារមានពីរយ៉ាង បានដល់ការងារដ៏ថោកទាប១ ការងារដ៏ខ្ពង់ខ្ពស់១។ ដែលហៅថា ការងារដ៏ថោកទាប គឺការងាររបស់អ្នកចាំងឈើ ការងាររបស់អ្នកចោលផ្កា (ចោលសម្រាម) ពុំនោះសោត ការងារណាដែលគេមើលងាយ គេបន្ទាប បន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះៗ ការងារទាំងនេះហៅថា ការងារដ៏ថោកទាប។ ដែលហៅថាការងារដ៏ខ្ពង់ខ្ពស់ គឺការភ្ជួររាស់ ការជួញប្រែ ការរក្សាគោ ពុំនោះសោត ការងារណាដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ ការងារទាំងនេះ ហៅថា ការងារដ៏ខ្ពង់ខ្ពស់។

[១៩១] ដែលហៅថា សិល្បសាស្ត្រ គឺសិល្បសាស្ត្រ មានពីរយ៉ាង បានដល់សិល្បសាស្ត្រដ៏ថោកទាប១ សិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់១។ ដែលហៅថា សិល្បសាស្ត្រដ៏ថោកទាប គឺសិល្បសាស្ត្រ អ្នកត្បាញផែង សិល្បសាស្ត្រអ្នកធ្វើឆ្នាំង សិល្បសាស្ត្រអ្នកត្បាញសម្ពត់ សិល្បសាស្ត្រអ្នកធ្វើស្បែក[44] សិល្បសាស្ត្រខ្ជាន់ព្រះកេស ពុំនោះសោត សិល្បសាស្ត្រណា ដែលគេមើលងាយ គេបន្ទាបបន្ថោក គេខ្ពើម គេពេបជ្រាយ គេមិនគោរព មានក្នុងជនបទនោះ ៗ សិល្បសាស្ត្រទាំងនេះ ហៅថា សិល្បសាស្ត្រដ៏ថោកទាប។ ដែលហៅថាសិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់គឺរាប់ដោយដៃទទេ រាប់ដោយវិធីនព្វន្ត ការសរសេរអក្សរ ពុំនោះសោត សិល្បសាស្ត្រណា ដែលគេមិនមើលងាយ គេមិនបន្ទាបបន្ថោក គេមិនខ្ពើម គេមិនពេបជ្រាយ គេគោរព មានក្នុងជនបទនោះៗ សិល្បសាស្ត្រទាំងនេះ ហៅថា សិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់។

[១៩២] បណ្ដាអាពាធទាំងឡាយ សុទ្ធតែថោកទាបទាំងអស់ ចំណែកខាងអាពាធទឹកនោមផ្អែម (រោគប្រមេះ) ហៅថា អាពាធយ៉ាងស្រាល។

[១៩៣] ដែលហៅថា ភេទ គឺភេទមានពីរយ៉ាង បានដល់ភេទដ៏ថោកទាប១ ភេទដ៏ខ្ពង់ខ្ពស់១។ ដែលហៅថា ភេទថោកទាប គឺភេទខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ភេទទាំងនេះ ហៅថា ភេទថោកទាប។ ដែលហៅថា ភេទខ្ពង់ខ្ពស់គឺ ភេទមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ភេទទាំងនេះ ហៅថា ភេទខ្ពង់ខ្ពស់។

[១៩៤] ឯកិលេសទាំងឡាយ សុទ្ធតែថោកទាបទាំងអស់។

[១៩៥] ឯអាបត្តិទាំងឡាយសុទ្ធតែថោកទាបទាំងអស់ ចំណែកខាងសោតាបត្តិ និងសមាបត្តិ សុទ្ធតែខ្ពង់ខ្ពស់ទាំងអស់។

[១៩៦] ដែលហៅថាជេរ គឺជេរមានពីរយ៉ាង បានដល់ជេរយ៉ាងថោកទាប១ ជេរយ៉ាងខ្ពង់ខ្ពស់១។ ដែលហៅថា ជេរយ៉ាងថោកទាបគឺជេរថា លោកជាសត្វឱដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក[45] លោកគ្មានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ជេរដោយយអក្ខរ[46] (២)ក្ដី ដោយ ភអក្ខរ(៣)ក្ដី ដោយនិម្មិតបុរសនិងនិម្មិតស្រីក្ដី ជេរទាំងនេះហៅថា ជេរយ៉ាងថោកទាប។ ដែលហៅថា ជេរយ៉ាងខ្ពង់ខ្ពស់ គឺ ជេរថា លោកជាបណ្ឌិត លោកឆ្លៀវឆ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត[47] លោកជាធម្មកថិក[48] លោកគ្មានគតិអាក្រក់ទេ លោកមានតែគតិល្អម្យ៉ាង ជេរទាំងនេះ ហៅថា ជេរយ៉ាងខ្ពង់ខ្ពស់។

[១៩៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យមានមុខចុះក្រោម[49] ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិថោកទាប ដោយពាក្យថោកទាប គឺថានិយាយចំពោះឧបសម្បន្នជាតិចណ្ឌាល ជាតិអ្នកធ្វើផែងឫស្សី ជាតិអ្នកនេសាទ ជាតិអ្នកធ្វើរថ ជាតិអ្នកចោលសម្រាម ដោយពាក្យថា លោកជាមនុស្សចណ្ឌាល ជាអ្នកធ្វើផែង ជាអ្នកនេសាទ ជាអ្នកធ្វើរថ ជាអ្នកចោលសម្រាម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[១៩៨] ឧបសម្បន្នភិក្ខុប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថានិយាយចំពោះឧបសម្បន្នជាតិក្សត្រិយ៍ ជាតិព្រាហ្មណ៍ ដោយពាក្យថា អ្នកឯងជា អ្នកចណ្ឌាល ជាជាងផែង ជាអ្នកនេសាទ ជាអ្នកធ្វើរថ ជាអ្នកចោលសម្រាម ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា។

[១៩៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺនិយាយចំពោះឧបសម្បន្នជាតិអ្នកចណ្ឌាល ជាតិអ្នកជាងផែង ជាតិអ្នកនេសាទ ជាតិ អ្នកធ្វើរថ ជាតិអ្នកចោលសម្រាម ដោយពាក្យថា លោកជាក្សត្រិយ៍ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២០០] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះបុគ្គលដែលមានជាតិខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺនិយាយចំពោះឧបសម្បន្នដែលមានជាតិជាក្សត្រិយ៍ ជាតិព្រាហ្មណ៍ ដោយពាក្យថា លោកជាក្សត្រិយ៍ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២០១] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះនាមថោកទាប ដោយពាក្យថោកទាប គឺនិយាយចំពោះឧបសម្បន្នដែលមាននាមជាអវកណ្ណក ជាជវកណ្ណក ជាធនិដ្ឋក ជាសវិដ្ឋក ជាកុលវឌ្ឍក ដោយពាក្យថា លោកជាអវកណ្ណក លោកជាជវកណ្ណក លោកជាធនិដ្ឋក លោកជាសវិដ្ឋក លោកជាកុលវឌ្ឍក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២០២] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលចំពោះនាមខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺនិយាយចំពោះឧបសម្បន្នដែលមាននាមជាពុទ្ធរក្ខិត ជាធម្មរក្ខិត ជាសង្ឃរក្ខិត ដោយពាក្យថា លោកជាអវកណ្ណក លោកជាជវកណ្ណក លោកជាធនិដ្ឋក លោកជាសវិដ្ឋក លោកជាកុលវឌ្ឍក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២០៣] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នផងគ្នា ពោលចំពោះនាមថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺនិយាយចំពោះឧបសម្បន្នមាននាមជាអវកណ្ណក ជាជវកណ្ណក ជាធនិដ្ឋក ជាសវិដ្ឋក ជាកុលវឌ្ឍក ដោយពាក្យថា លោកឈ្មោះពុទ្ធរក្ខិត លោកឈ្មោះធម្មរក្ខិត លោកឈ្មោះសង្ឃរក្ខិត ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២០៤] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅនាមដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នដែលមាននាមជាពុទ្ធរក្ខិត ជាធម្មរក្ខិត ជាសង្ឃរក្ខិត ដោយពាក្យថា លោកឈ្មោះ ពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២០៥] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្តថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នជាកោសិយគោត្ត ភារទ្វាជគោត្ត ដោយពាក្យថា លោកជាកោសិយគោត្ត លោកជាភារទ្វាជគោត្ត ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២០៦] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្តដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នជាគោតមគោត្ត ជាមោគ្គល្លានគោត្ត ជាកច្ចាយនគោត្ត ជាវាសេដ្ឋគោត្ត ដោយពាក្យថា លោកជាកោសិយគោត្ត លោកជាភារទ្វាជគោត្ត ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២០៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្តដ៏ថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នជាកោសិយគោត្ត ជាភារទ្វាជគោត្ត ដោយពាក្យថា លោកជាគោតមគោត្ត លោកជាមោគ្គល្លានគោត្ត លោកជាកច្ចាយនគោត្ត លោកជាវាសេដ្ឋគោត្ត ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២០៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅគោត្តដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នជាគោតមគោត្ត ជាមោគ្គល្លានគោត្ត ជាកច្ចាយនគោត្ត ជាវាសេដ្ឋគោត្ត ដោយពាក្យថា លោកជាគោតមគោត្ត លោកជាមោគ្គល្លានគោត្ត លោកជាកច្ចាយនគោត្ត លោកជាវាសេដ្ឋគោត្ត ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២០៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្ន ថាអ្នកចាំងឈើ ជាអ្នកចោលសម្រាម ដោយពាក្យថា លោកជាជាង ចាំងឈើ លោកជាអ្នកចោលសម្រាម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២១០] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧសម្បន្នថាជាអ្នកភ្ជួររាស់ ជាអ្នកជួញប្រែ ជាអ្នករក្សាគោ ដោយពាក្យថា លោកជាជាងចាំងឈើ លោកជាអ្នកចោលសម្រាម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២១១] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីធ្វើឱ្យអៀនអន់ ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន ថាជាជាងចាំងឈើ ជាអ្នកចោលសម្រាម ដោយពាក្យថា លោកជាអ្នកភ្ជួររាស់ លោកជាអ្នកជំនួញ លោកជាអ្នករក្សាគោ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២១២] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅការងារដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នថាជាអ្នកភ្ជួររាស់ អ្នកជំនួញ អ្នករក្សាគោ ដោយពាក្យថា លោកជាអ្នក ភ្ជួររាស់ លោកជាអ្នកជំនួញ លោកជាអ្នករក្សាគោ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២១៣] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រដ៏ថោកទាប ដោយពាក្យដ៏ថោកទាប គឺថាពោលសំដៅឧបសម្បន្នថាជាជាងត្បាញផែង ជាស្មូនឆ្នាំង ជាជាងដម្បាញ ជាជាង ស្បែក ជាខ្មាន់ព្រះកេស ដោយពាក្យថា លោកជាជាងត្បាញផែង លោកជាស្មូនឆ្នាំង លោកជាជាងដម្បាញ លោកជាជាងស្បែក លោកជាខ្មាន់ព្រះកេស ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២១៤] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថា ពោលសំដៅឧបសម្បន្ន ជាអ្នករាប់ដៃទទេ អ្នករាប់ដោយវិធីនព្វន្ត អ្នកសរសេរអក្សរ (នាយស្មេរ) ដោយពាក្យថា លោកជាជាងត្បាញផែង លោកជាស្មូនឆ្នាំង លោកជាជាងដម្បាញ លោកជាអ្នកធ្វើស្បែក លោកជាខ្មាន់ព្រះកេស ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា។

[២១៥] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន ជាជាងត្បាញផែង ស្មូនឆ្នាំង ជាងដម្បាញ អ្នកធ្វើស្បែក ខ្មាន់ព្រះកេស

ដោយពាក្យថា លោកជាអ្នករាប់ដោយដៃទទេ លោកជាអ្នករាប់ដោយវិធីនព្វន្ត លោកជាអ្នកសរសេរអក្សរ (នាយស្មេរ) ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២១៦] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅសិល្បសាស្ត្រដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្ន ជាអ្នករាប់ដោយដៃទទេ អ្នករាប់ដោយវិធីនព្វន្ត អ្នកសរសេរ អក្សរ (នាយស្មេរ) ដោយពាក្យថា លោកជាអ្នករាប់ដោយដៃទទេ លោកជាអ្នករាប់ដោយវិធីនព្វន្ត លោកជាអ្នកសរសេរអក្សរ (នាយស្មេរ) ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២១៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធថោកទាប ដោយពាក្យដ៏ថោកទាប គឺថាពោលសំដៅឧបសម្បន្នបុគ្គលដែលកើតឃ្លង់ បូស ស្រែង រោគរីងរៃ ឆ្កួតជ្រូក ដោយពាក្យ ថា លោកជាមនុស្សឃ្លង់ លោកជាមនុស្សកើតបូស លោកជាមនុស្សសម្រែង លោកជាមនុស្សកើតរោគរីងរៃ លោកជាមនុស្សឆ្កួតជ្រូក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ វាចា។

[២១៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធដ៏ខ្ពង់ខ្ពស់ (អាពាធស្រាល) ដោយពាក្យដ៏ថោកទាប គឺថាពោលសំដៅឧបសម្បន្នបុគ្គលដែលមានអាពាធទឹកនោមផ្អែម (កើតប្រមេះផ្អែមមាត់) ដោយពាក្យថា លោកជាមនុស្សឃ្លង់ លោកជាមនុស្សកើតបូស លោក ជាមនុស្សកើតស្រែង លោកជាមនុស្សកើតរោគរីងរៃ លោកជាមនុស្សឆ្កួតជ្រូក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២១៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធថោកទាប ដោយពាក្យ ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុ ដែលជាមនុស្សឃ្លង់ មនុស្សកើតបូស មនុស្សកើតស្រែង មនុស្សកើតរោគរីងរៃ មនុស្សឆ្កួតជ្រូក ដោយពាក្យថា លោកជាមនុស្សមានអាពាធ ទឹកនោមផ្អែម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២២០] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅអាពាធខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នបុគ្គលដែលជាអ្នកមានអាពាធទឹកនោមផ្អែម ដោយពាក្យថា លោកជាមនុស្សមានអាពាធទឹកនោមផ្អែម ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវាចា។

[២២១] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅភេទថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ដោយពាក្យថា លោក ខ្ពស់ពេក លោកទាបពេក លោកខ្មៅពេក លោកសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២២២] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ពោលសំដៅភេទដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ដោយ ពាក្យថា លោកខ្ពស់ពេក លោកទាបពេក លោកខ្មៅពេក លោកសពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២២៣] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភេទថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ដោយពាក្យថា លោកមិនខ្ពស់ពេក លោកមិនទាបពេក លោកមិនខ្មៅពេក លោកមិនសពេក ត្រូវអាបត្តិ បាចិត្តិយគ្រប់ៗ វាចា។

[២២៤] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភេទដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ដោយពាក្យថា លោកមិនខ្ពស់ពេក លោកមិនទាបពេក លោកមិនខ្មៅពេក លោកមិន សពេក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២២៥] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកិលេសដែលជាធម៌ដ៏ថោកទាប ដោយពាក្យដ៏ថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលរាគៈគ្របសង្កត់ហើយ ទោសៈគ្របសង្កត់ហើយ មោហៈគ្របសង្កត់ហើយ ដោយពាក្យថា លោកត្រូវរាគៈ គ្របសង្កត់ហើយ លោកត្រូវទោសៈគ្របសង្កត់ហើយ លោកត្រូវមោហៈគ្របសង្កត់ហើយ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២២៦] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកិលេសដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ដោយពាក្យថា លោកត្រូវរាគៈគ្របសង្កត់ហើយ លោកត្រូវទោសៈគ្រប សង្កត់ហើយ លោកត្រូវមោហៈគ្របសង្កត់ហើយ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២២៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោនចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅកិលេសដែលជាធម៌ដ៏ថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុ ដែលត្រូវរាគៈ គ្របសង្កត់ហើយ ត្រូវទោសៈគ្របសង្កត់ហើយ ត្រូវមោហៈគ្របសង្កត់ហើយ ដោយពាក្យថា លោកប្រាសចាក រាគៈ លោកប្រាសចាកទោសៈ លោកប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២២៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅធម៌ដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែល ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ដោយពាក្យថា លោកប្រាសចាករាគៈ លោកប្រាសចាកទោសៈ លោកប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២២៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលត្រូវអាបត្តិបារាជិក ត្រូវអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិថុល្លច្ច័យ ត្រូវអាបត្តិបាចិត្តិយ ត្រូវអាបត្តិបាដិទេសនីយ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិទុព្ភាសិត ដោយពាក្យថា លោក ត្រូវអាបត្តិបារាជិក លោកត្រូវអាបត្តិសង្ឃាទិសេស លោកត្រូវអាបត្តិថុល្លច្ច័យ លោក ត្រូវអាបត្តិបាចិត្តិយ លោកត្រូវអាបត្តិបាដិទេសនីយ លោកត្រូវអាបត្តិទុក្កដ លោក ត្រូវអាបត្តិទុព្ភាសិត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២៣០] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលជាសោតាបន្ន ដោយពាក្យថា លោក ត្រូវអាបត្តិបារាជិក។ បេ។ លោកត្រូវអាបត្តិទុព្ភាសិត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២៣១] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលត្រូវអាបត្តិបារាជិក។បេ។ ត្រូវអាបត្តិទុព្ភាសិត ដោយពាក្យថា លោកជាសោតាបន្នបុគ្គល ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២៣២] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលជាសោតាបន្ន ដោយពាក្យថា លោកជាសោតាបន្នបុគ្គល ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២៣៣] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យថោកទាប គឺថាពោលសំដៅសត្វឱដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក ដោយពាក្យថា លោកជាសត្វឱដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក លោកមិនមានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២៣៤] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យថោកទាប គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាសត្វឱដ្ឋ លោកជាសត្វពពែ លោកជាសត្វគោ លោកជាសត្វលា លោកជាសត្វតិរច្ឆាន លោកជាសត្វនរក លោកគ្មានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២៣៥] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅសត្វឱដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក ដោយពាក្យថា លោកជាបណ្ឌិត លោកជាមនុស្សឈ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជាធម្មកថិក លោកគ្មានគតិអាក្រក់ទេ លោកមានគតិល្អតែម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២៣៦] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលសំដៅភិក្ខុដ៏ខ្ពង់ខ្ពស់ ដោយពាក្យខ្ពង់ខ្ពស់ គឺថាពោលសំដៅឧបសម្បន្នភិក្ខុដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាបណ្ឌិត លោកជាមនុស្សឈ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជាធម្មកថិក លោកគ្មានគតិអាក្រក់ទេ លោកមានតែគតិល្អម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗ វាចា។

[២៣៧] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះ គឺនិយាយថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាចណ្ឌាល ជាជាងត្បាញផែង ជាអ្នកនេសាទ ជាជាងធ្វើរទេះ ជាអ្នកចោលសម្រាម ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។

[២៣៨] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាក្សត្រិយ៍ ជាព្រាហ្មណ៍ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា។

[២៣៩] ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ឈ្មោះអវកណ្ណក ឈ្មោះជវកណ្ណក ឈ្មោះធនិដ្ឋក ឈ្មោះសវិដ្ឋក ឈ្មោះកុលវឌ្ឍក ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ឈ្មោះពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗវាចា។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាកោសិយគោត្ត ជាភារទ្វាជគោត្ត។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាគោតមគោត្ត ជាមោគ្គល្លានគោត្ត ជាកច្ចាយនគោត្ត ជាវាសេដ្ឋគោត្ត។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាជាងចាំង ជាអ្នកចោលផ្កា។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាអ្នកភ្ជួររាស់ ជាឈ្មួញ ជាអ្នករក្សាគោ។ បេ។ ថាក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាជាងត្បាញផែងបបុស ជាស្មូនឆ្នាំង ជាជាងដម្បាញ ជាអ្នកធ្វើស្បែក ជាខ្មាន់ ព្រះកេស។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាអ្នករាប់ដៃទទេ ជាអ្នករាប់ដោយវិធីនព្វន្ត ជាអ្នកសរសេរអក្សរ

(ស្មេរ)។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាមនុស្សគំលង់ ជាមនុស្សកើតបូស ជាមនុស្សសម្រែង ជាមនុស្សកើត រោគរីងរៃ ជាមនុស្សឆ្កួតជ្រូក។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ កើតរោគប្រមេះទឹកនោមផ្អែម។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ មិនខ្ពស់ពេក មិនទាបពេក មិនខ្មៅ ពេក មិនសពេក។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ត្រូវរាគៈ គ្របសង្កត់ ត្រូវទោសៈគ្របសង្កត់ ត្រូវមោហៈគ្របសង្កត់។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ត្រូវអាបត្តិបារាជិក។ បេ។ ត្រូវអាបត្តិទុក្កដសិត។ បេ។ ថាក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាសោតាបន្នបុគ្គល។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាសត្វឱដ្ឋ សត្វពពែ សត្វគោ សត្វលា សត្វតិរច្ឆាន សត្វនរក មនុស្សទាំងនោះគ្មានគតិល្អទេ មនុស្ស ទាំងនោះមានតែគតិអាក្រក់ម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។

[២៤០] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ជនទាំងនោះគ្មានគតិអាក្រក់ទេ មនុស្សទាំងនោះមានតែគតិ ល្អម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។

[២៤១] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសម្រាម ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗវាចា។ បេ។ ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះគ្មានគតិអាក្រក់ មនុស្សទាំងនោះមានតែគតិល្អម្យ៉ាងទេ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។

[២៤២] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោនចំពោះឧបសម្បន្នភិក្ខុផងគ្នា ក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាងត្បាញផែងឫស្សី មិនមែនអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនអ្នកចោលសម្រាម។ បេ។ ថា យើង ទាំងឡាយ មិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់ យើងទាំងឡាយទេ ដំណើរល្អតែម្យ៉ាង ប្រាកដដល់យើងទាំងឡាយ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។

[២៤៣] ឧបសម្បន្នភិក្ខុចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោនចំពោះអនុបសម្បន្ន[50] បុគ្គល ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប។ បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប។ បេ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយ ពាក្យដ៏ខ្ពង់ខ្ពស់។ បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅអនុបសម្បន្នបុគ្គល ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា អ្នកឯងជា បណ្ឌិត អ្នកឯងជាអ្នកឈ្លាស អ្នកឯងជាអ្នកប្រាជ្ញ អ្នកឯងជាពហុស្សូត អ្នកឯងជាធម្មកថិក ដំណើរអាក្រក់មិនមានដល់អ្នកឯងទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់អ្នកឯង ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។

[២៤៤] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោនចំពោះអនុបសម្បន្នបុគ្គល ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសម្រាម។ បេ។ ថា ក្នុងលោកនេះ មាន មនុស្សពួកខ្លះ ជាបណ្ឌិត ជាមនុស្សឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះគ្មានគតិអាក្រក់ទេ មនុស្សទាំងនោះមានតែគតិល្អម្យ៉ាង ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។

[២៤៥] ឧបសម្បន្នភិក្ខុ ចង់ជេរ ចង់ប្រទេច ចង់បង្អាប់បង្អោនចំពោះអនុបសម្បន្ន ហើយពោលយ៉ាងនេះ គឺនិយាយថា មនុស្សទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសម្រាម ត្រូវអាបត្តិទុក្កដគ្រប់ ៗ វាចា។ បេ។ ថា មនុស្សទាំងឡាយណាមួយ ជាបណ្ឌិត ជាអ្នក ឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ត្រូវអាបត្តិទុក្កដគ្រប់ៗវាចា។ ឧបសម្បន្នភិក្ខុ ប្រាថ្នាដើម្បីជេរ ប្រាថ្នាដើម្បីប្រទេច ប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ក៏ពោលយ៉ាងនេះ ថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនជាអ្នកចោល សម្រាម។ បេ។ ថា យើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់យើងទាំងឡាយ ដំណើរល្អតែម្យ៉ាងប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដគ្រប់ៗ វាចា។

[២៤៦] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប ក៏ពោលសំដៅបុគ្គលជាមនុស្សចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសម្រាម ដោយពាក្យថា លោកជាចណ្ឌាល លោកជាជាងត្បាញផែងឫស្សី លោកជាអ្នកនេសាទ លោកជាជាងធ្វើរថ លោកជាអ្នកចោលសម្រាម ត្រូវអាបត្តិទុព្ភាសិតគ្រប់ៗ វាចា។ ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្ន ភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប គឺនិយាយសំដៅឧបសម្បន្នភិក្ខុដែលជាជាតិក្សត្រ ជាតិព្រាហ្មណ៍ ដោយពាក្យថា លោកជាចណ្ឌាល លោកជាជាងត្បាញផែងឫស្សី លោកជាអ្នកនេសាទ លោកជាជាងធ្វើរថ លោកជាអ្នកចោលសម្រាម ត្រូវអាបត្តិទុព្ភាសិតគ្រប់ៗ វាចា។ ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់ បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោល សំដៅបុគ្គលថោកទាប ដោយពាក្យខ្ពង់ខ្ពស់ គឺថានិយាយសំដៅឧបសម្បន្នភិក្ខុជាចណ្ឌាល ជាជាងត្បាញផែង ជាអ្នកនេសាទ ជាជាងធ្វើរថ អ្នកចោលសម្រាម ដោយពាក្យថា លោកជាក្សត្រ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិទុព្ភាសិតគ្រប់ៗ វាចា។ ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ខ្ពងខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅឧបសម្បន្នភិក្ខុដែលជាក្សត្រ ជាព្រាហ្មណ៍ ដោយពាក្យថា លោកជាក្សត្រ លោកជាព្រាហ្មណ៍ ត្រូវអាបត្តិទុព្ភាសិតគ្រប់ៗ វាចា។ បេ។ ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាប

ដោយពាក្យដ៏ថោកទាប។បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប។ បេ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យ ដ៏ខ្ពង់ខ្ពស់។ បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅឧបសម្បន្នភិក្ខុដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដោយពាក្យថា លោកជាបណ្ឌិត លោកជាអ្នកឈ្លាស លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត លោកជាធម្មកថិក ដំណើរអាក្រក់មិនមានដល់លោកទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់លោក ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា។

[២៤៧] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសម្រាម។បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក មនុស្សទាំងនោះគ្មានគតិអាក្រក់ទេ មនុស្សទាំងនោះមានតែគតិល្អម្យ៉ាង ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា។

[២៤៨] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយ ជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងធ្វើរថ ជាអ្នកចោលសម្រាម។ បេ។ ថា មនុស្សទាំងឡាយណាមួយជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា។

[២៤៩] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះឧបសម្បន្នភិក្ខុផងគ្នា ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនជាអ្នកចោលសម្រាម។ បេ។ ថា យើងទាំងឡាយមិនមែនជា បណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមានដល់យើងទាំងឡាយទេដំណើរ ល្អតែម្យ៉ាងប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា។

[២៥០] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេង ក៏ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ថោកទាប។ បេ។ ពោលសំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ថោកទាប។ បេ។ ពោលសំដៅបុគ្គលដ៏ថោកទាប ដោយពាក្យដ៏ខ្ពង់ខ្ពស់។ បេ។ ពោល សំដៅបុគ្គលដ៏ខ្ពង់ខ្ពស់ ដោយពាក្យដ៏ខ្ពង់ខ្ពស់ គឺនិយាយសំដៅអនុបសម្បន្នបុគ្គលដែលជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជា ធម្មកថិក ដោយពាក្យថា អ្នកឯងជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដំណើរអាក្រក់មិនមានដល់អ្នកឯងទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់អ្នកឯង ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា។

[២៥១] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គលប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាង រថ ជាអ្នកចោលសម្រាម។ បេ។ ថា ក្នុងលោកនេះ មានមនុស្សពួកខ្លះជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ដំណើរអាក្រក់មិនមានដល់មនុស្សទាំងឡាយនោះទេ ដំណើរល្អតែម្យ៉ាង ប្រាកដដល់មនុស្សទាំងឡាយនោះ ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា។

[២៥២] ឧបសម្បន្នភិក្ខុ មិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា មនុស្សទាំងឡាយណាមួយជាចណ្ឌាល ជាជាងត្បាញផែងឫស្សី ជាអ្នកនេសាទ ជាជាងរថ ជាអ្នក ចោលសម្រាម។បេ។ ថា មនុស្សទាំងឡាយណាមួយ ជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា។

[២៥៣] ឧបសម្បន្នភិក្ខុមិនប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោនចំពោះអនុបសម្បន្នបុគ្គល ប្រាថ្នាតែនិយាយលេង ក៏ពោលយ៉ាងនេះថា យើងទាំងឡាយមិនមែនជាចណ្ឌាល មិនមែនជាជាងត្បាញផែងឫស្សី មិនមែនជាអ្នកនេសាទ មិនមែនជាជាងធ្វើរថ មិនមែនជាអ្នកចោលសម្រាម។បេ។ ថា យើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ដំណើរអាក្រក់មិនមាន ដល់យើងទាំងឡាយទេ ដំណើរល្អតែម្យ៉ាងប្រាកដដល់យើងទាំងឡាយ ត្រូវអាបត្តិទុក្កដសិតគ្រប់ៗ វាចា។

[២៥៤] អាបត្តិមិនមានដល់ភិក្ខុធ្វើសេចក្តីអធិប្បាយជាប្រធាន[51)] ដល់ភិក្ខុធ្វើធម៌ជាប្រធាន[52)] ដល់ភិក្ខុធ្វើពាក្យប្រៀនប្រដៅជាប្រធាន[53)] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុមានចិត្តអណ្តែតអណ្តូង ដល់ភិក្ខុដែលវេទនាគ្របសង្កត់ ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី២ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៣

CS vin.vbu.pc.03 | ភាគ ទី៣

### (៣. បេសុញ្ញសិក្ខាបទំ)

[២៥៥] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន ជារបស់អនាថបិណ្ឌិក ជិតក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុតែងពាំនាំពាក្យញុះញង់របស់ភិក្ខុទាំងឡាយដែលបង្កហេតុប្រកួតប្រកាន់ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅ និយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីកហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីកហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែចំរើនដោយក្រៃ

លែងឡើងផង។ ពួកភិក្ខុណាមួយដែលជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីបានជាពួកឆព្វគ្គិយភិក្ខុតែងពាំនាំពាក្យញុះញង់របស់ភិក្ខុទាំងឡាយ ដែលបង្កហេតុប្រកួតប្រកាន់ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះ ហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីបង្កហេតុទាំងឡាយ ដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយដែលបាន កើតឡើងហើយ ក៏រឹងរឹតតែចំរើនដោយក្រៃលែងផង។ គ្រានោះ ពួកភិក្ខុទាំងនោះក៏បានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថាអ្នកទាំងឡាយតែងពាំនាំពាក្យញុះញង់របស់ភិក្ខុទាំងឡាយដែលបង្កហេតុប្រកួតប្រកាន់ ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះ ហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ព្រោះហេតុនោះ សេចក្តីបង្កហេតុទាំងឡាយដែលមិនទាន់កើតក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយដែលបានកើតឡើងហើយ ក៏រឹងរឹតតែចំរើន ដោយក្រៃលែងឡើងផង(រឿងនេះ) ពិតឬ។ ពួកឆព្វគ្គិយភិក្ខុក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ មិនសមបើអ្នកទាំងឡាយនឹងពាំនាំពាក្យញុះញង់ របស់ពួកភិក្ខុដែលបង្កហេតុ ប្រកួតប្រកាន់ ឈ្លោះវិវាទគ្នា ឮពាក្យភិក្ខុខាងណេះហើយយកទៅនិយាយប្រាប់ភិក្ខុខាងណោះ ដើម្បីបំបែកភិក្ខុខាងណេះ ឮពាក្យភិក្ខុខាងណោះហើយយកមកនិយាយប្រាប់ភិក្ខុខាងណេះ ដើម្បីបំបែកភិក្ខុខាងណោះ ម្ល៉ោះហើយ សេចក្តីបង្កហេតុទាំងឡាយដែលមិនទាន់កើត ក៏កើតឡើងផង សេចក្តីបង្កហេតុទាំងឡាយដែលបានកើតឡើងហើយ ក៏រឹងរឹតតែចំរើនដោយក្រៃលែងឡើងផង ម្នាលមោឃបុរសទាំងឡាយ កម្មដែលអ្នករាល់គ្នាធ្វើនេះ មិននាំឱ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាផង។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិ បាចិត្តិយ ព្រោះពោលពាក្យញុះញង់ភិក្ខុផងគ្នា។

[២៥៦] ដែលហៅថា ពាក្យញុះញង់ គឺញុះញង់ដោយអាការពីរយ៉ាង បានខាងឯបុគ្គលចង់ឱ្យគេស្រឡាញ់ខ្លួន១ ចង់បំបែកគេ១។ ភិក្ខុពាំនាំពាក្យញុះញង់ដោយអាការ ១០ យ៉ាង គឺដោយជាតិក្តី ដោយ នាមក្តី ដោយគោត្តក្តី ដោយការងារក្តី ដោយសិល្បសាស្ត្រក្តី ដោយ អាពាធក្តី ដោយភេទក្តី ដោយធម៌ជាគ្រឿងសៅហ្មងក្តី ដោយអាបត្តិក្តី ដោយពាក្យជេរក្តី។ ដែលហៅថា ជាតិ គឺជាតិមានពីរយ៉ាង បានខាងជាតិថោកទាប១ ជាតិខ្ពង់ខ្ពស់ ១ ដែលហៅថា ជាតិថោកទាបនោះ គឺ ជាតិចណ្ឌាល ជាតិជាងផែង ជាតិអ្នកនេសាទ ជាតិជាងរថ ជាតិអ្នកចោលសម្រាម ប៉ុណ្ណេះ ឈ្មោះថា ជាតិថោកទាប។ ដែលហៅថា ជាតិខ្ពង់ខ្ពស់នោះ គឺ ជាតិក្សត្រ ជាតិព្រាហ្មណ៍ ប៉ុណ្ណេះ ឈ្មោះថា ជាតិខ្ពង់ខ្ពស់។ បេ។ ដែលហៅថា ពាក្យជេរនោះ គឺពាក្យ ជេរមានពីរយ៉ាង បានខាងពាក្យជេរដ៏ថោកទាប ១ ពាក្យជេរ ដ៏ខ្ពង់ខ្ពស់ ១។ ដែលហៅថា ពាក្យជេរដ៏ថោកទាបនោះ គឺជេរថា អ្នកឯងជាសត្វឱដ្ឋ អ្នកឯងជាពពែ អ្នកឯងជាគោ អ្នកឯងជាលា អ្នកឯងសត្វតិរច្ឆាន អ្នកឯងជាសត្វនរក សុគតិរបស់អ្នកឯងគ្មានទេ ទុគ្គតិតែម្យ៉ាងនឹងប្រាកដដល់អ្នកឯង ពុំនោះសោត ជេរដោយ យអក្ខរៈ[54] ឬដោយ ភអក្ខរៈ ឬមួយដោយបុរិសនិមិត្ត និងឥត្ថីនិមិត្ត ប៉ុណ្ណេះឈ្មោះថា ពាក្យជេរដ៏ថោកទាប។ ដែលហៅថា ពាក្យជេរដ៏ខ្ពង់ខ្ពស់នោះ គឺជេរថា អ្នកឯងជាបណ្ឌិត អ្នកឯងជាមនុស្សឈ្លាស អ្នកឯងជាអ្នកប្រាជ្ញ អ្នកឯងជាពហុស្សូត អ្នកឯងជាធម្មកថិក ទុគ្គតិរបស់អ្នកឯងគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់អ្នកឯង ប៉ុណ្ណេះឈ្មោះថា ពាក្យជេរដ៏ខ្ពង់ខ្ពស់។

[២៥៧] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុហើយ នាំ ពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយ ចំពោះលោកថា លោកជាជាតិចណ្ឌាល ជាតិជាងផែង ជាតិអ្នកនេសាទ ជាតិជាងរថ ជាតិអ្នកចោលសម្រាម (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗម៉ាត់។

[២៥៨] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាក្សត្រ ជាព្រាហ្មណ៍ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៥៩] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកឈ្មោះអវកណ្ណក[55] ឈ្មោះជវកណ្ណក ឈ្មោះធនិដ្ឋក ឈ្មោះសវិដ្ឋក ឈ្មោះកុលវឌ្ឍក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៦០] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកឈ្មោះពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត(ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗម៉ាត់។

[២៦១] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាកោសិយគោត្ត ភារទ្វាជគោត្ត (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៦២] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាគោតមគោត្ត មោគ្គល្លានគោត្ត កច្ចាយនគោត្ត វាសេដ្ឋគោត្ត (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយៗម៉ាត់។

[២៦៣] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាជាងចាំង ជាអ្នកចោលនូវផ្កា (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តយរាល់ៗម៉ាត់។

[២៦៤] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាអ្នកភ្ជួររាស់ ជាអ្នកជួញ ជាអ្នករក្សាគោ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗម៉ាត់។

[២៦៥] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាជាងផែងបបុស ជាស្មូនឆ្នាំង ជាជាងដម្បាញ ជាជាងស្បែក ជាខ្មាន់ព្រះកេស (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៦៦] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាអ្នករាប់ដៃទទេ ជាហោរ ជាស្មៀន (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៦៧] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះពោលចំពោះលោកថា លោកជាមនុស្សឃ្លង់ ជាមនុស្សដំបៅពក ជាមនុស្សស្រែង ជាមនុស្សកើតរោគរីងរៃ ជាមនុស្សឆ្កួតជ្រូក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវ អាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៦៨] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាមនុស្សកើតរោគប្រមេះផ្អែម (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិ បាចិត្តិយរាល់ ៗ ម៉ាត់។

[២៦៩] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបុគ្គលខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៧០] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបុគ្គលមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៧១] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបុគ្គលមានរាគៈរួបរឹតហើយ មានទោសៈរួបរឹតហើយ មានមោហៈរួបរឹតហើយ ( ភិក្ខុអ្នកញុះញង់នោះ ) ត្រូវអាបត្តិបាចិត្តិយ រាល់ៗ ម៉ាត់។

[២៧២] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាមនុស្សប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់។

[២៧៣] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យញុះញង់ទៅប្រាប់ ឧបសម្បន្នភិក្ខុថាភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកត្រូវអាបត្តិបារាជិកហើយ ត្រូវអាបត្តិសង្ឃាទិសេសហើយ ត្រូវអាបត្តិថុល្លច្ច័យហើយ ត្រូវអាបត្តិបាចិត្តិយហើយ ត្រូវអាបត្តិ បាដិទេសនីយហើយ ត្រូវអាបត្តិទុក្កដហើយ ត្រូវអាបត្តិទុព្ភាសិតហើយ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៧៤] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបុគ្គលដល់ហើយនូវសោតាបត្តិផល (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ ៗ ម៉ាត់។

[២៧៥] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុ នាំពាក្យ ញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាសត្វឱដ្ឋ ជាសត្វពពែ ជាសត្វគោ ជាសត្វលា ជាសត្វតិរច្ឆាន ជាសត្វនរក សុគតិរបស់លោកគ្មានទេ ទុគ្គតិតែម្យ៉ាងនឹងប្រាកដដល់លោក (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៧៦] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នានាំ ពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយចំពោះលោកថា លោកជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ទុគ្គតិរបស់លោកគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់លោក(ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់។

[២៧៧] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នានាំ ពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះ និយាយថា ក្នុងលោកនេះ ជនពួកខ្លះ ជាចណ្ឌាល ជាជាងផែង ជាអ្នកនេសាទ ជាជាងរថ ជាអ្នកចោលសម្រាម ក៏សឹងមាន ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ ) មិនមែនពោលឱ្យអ្នកដទៃទេ ពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ៗ ម៉ាត់។

[២៧៨] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នានាំ ពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ក្នុងលោកនេះ ជនពួកខ្លះជាក្សត្រ ជាព្រាហ្មណ៍ ក៏សឹងមាន ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឱ្យអ្នកដទៃទេ គឺពោលចំពោះ លោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ)ត្រូវអាបត្តិទុក្កដរាល់ៗ ម៉ាត់។ បេ។

[២៧៩] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នានាំ ពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ក្នុងលោកនេះជនទាំងឡាយពួកខ្លះជាបណ្ឌិត ជាអ្នកឈ្លាសជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ក៏សឹងមាន ទុគ្គតិរបស់លោកទាំងនោះគ្មានទេ សុគតិតែម្យ៉ាង នឹងប្រាកដដល់លោកទាំងនោះ ឯភិក្ខុនោះ (ដែល ពោលពាក្យដូច្នេះ ) មិនមែនពោលឱ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ៗម៉ាត់។

[២៨០] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នានាំ ពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ជនពួកណា ពិតជាចណ្ឌាល ជាជាងផែង ជាអ្នកនេសាទ ជាជាងរថ ជាអ្នកចោលសម្រាម ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឱ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ៗ ម៉ាត់។ បេ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា ហើយនាំពាក្យញុះញង់ទៅ ប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា ជនពួកណា ពិតជាបណ្ឌិត ជាអ្នកឈ្លាស ជាអ្នកប្រាជ្ញ ជាពហុស្សូត ជាធម្មកថិក ទុគ្គតិរបស់ជនទាំងនោះគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់ជនទាំងនោះ ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ ) មិនមែនពោលឱ្យអ្នកដទៃទេ គឺពោលចំពោះលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ៗម៉ាត់។

[២៨១] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នានាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា យើងទាំងឡាយ មិនមែនជាចណ្ឌាល មិនមែនជាជាងផែង មិនមែនជាអ្នកនេសាទ មិនមែនជាជាងរថ មិនមែនជាអ្នកចោលសម្រាម ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឱ្យអ្នកដទៃទេ គឺពោលសំដៅលោកជាប្រាកដ(ភិក្ខុអ្នកញុះញង់នោះ)ត្រូវអាបត្តិទុក្កដរាល់ៗ ម៉ាត់។ បេ។ ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នាហើយនាំពាក្យញុះញង់ ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀតថា ភិក្ខុឈ្មោះនេះនិយាយថា យើងទាំងឡាយមិនមែនជាបណ្ឌិត មិនមែនជាអ្នកឈ្លាស មិនមែនជាអ្នកប្រាជ្ញ មិនមែនជាពហុស្សូត មិនមែនជាធម្មកថិក ទុគ្គតិរបស់ពួកយើងគ្មានទេ សុគតិតែម្យ៉ាងនឹងប្រាកដដល់ពួកយើង ឯភិក្ខុនោះ (ដែលពោលពាក្យដូច្នេះ) មិនមែនពោលឱ្យអ្នកដទៃទេ គឺពោលសំដៅលោកជាប្រាកដ (ភិក្ខុអ្នកញុះញង់នោះ) ត្រូវអាបត្តិទុក្កដរាល់ៗ ម៉ាត់។

[២៨២] ឧបសម្បន្នភិក្ខុ ឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នានាំ ពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុឯទៀត ត្រូវអាបត្តិបាចិត្តិយរាល់ៗម៉ាត់។ ឧបសម្បន្នភិក្ខុឮពាក្យរបស់ឧបសម្បន្នភិក្ខុផងគ្នា ហើយនាំពាក្យញុះ ញង់ទៅប្រាប់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ។ ឧបសម្បន្នភិក្ខុឮពាក្យរបស់អនុបសម្បន្នបុគ្គលហើយ នាំពាក្យញុះញង់ទៅប្រាប់ឧបសម្បន្នភិក្ខុ ត្រូវអាបត្តិទុក្កដ។ ឧបសម្បន្នភិក្ខុឮពាក្យរបស់អនុបសម្បន្នបុគ្គលហើយ នាំពាក្យញុះញង់ទៅប្រាប់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ។

[២៨៣] អាបត្តិមិនមានដល់ភិក្ខុអ្នកមិនចង់ឱ្យគេស្រឡាញ់ខ្លួន ដល់ភិក្ខុមិនប្រាថ្នាឱ្យគេបែកគ្នា ដល់ភិក្ខុឆ្កួត ដល់ភិក្ខុខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៣ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៤

CS vin.vbu.pc.04 | ភាគ ទី៣

### (៣. បេសុញ្ញសិក្ខាបទំ)

[២៨៤] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគកាលគង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបង្ហាញធម៌ជាបទចំពោះពួកឧបាសក។ ឧបាសកទាំងឡាយក៏ទៅជាមិនមានសេចក្ដីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោសតិះដៀល បន្ទុះបង្អាប់ថា មិនសមរបីបើពួកឆព្វគ្គិយភិក្ខុបង្ហាញធម៌ជាបទចំពោះឧបាសកទាំងឡាយ ៗក៏ទៅជាមិនមានសេចក្ដីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ។ គ្រានោះឯង ពួកភិក្ខុទាំងនោះ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយបង្ហាញ ធម៌ជាបទចំពោះឧបាសកទាំងឡាយ ៗ ក៏ទៅជាមិនមានសេចក្ដីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ (រឿងនេះ) ពិតឬ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ មិនសមរបីអ្នកទាំងឡាយបង្ហាញធម៌ជាបទចំពោះ ពួកឧបាសកៗក៏ទៅជាមិនមានសេចក្ដីគោរព មិនកោតក្រែង ប្រព្រឹត្តមិនសមគួរដល់ភិក្ខុទាំងឡាយ ម្នាលបុរសទទេទាំងឡាយ កម្មដែលអ្នកទាំងឡាយធ្វើនេះ មិននាំឱ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ បង្រៀនធម៌ជាបទចំពោះអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ។

[២៨៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌ។ ដែលហៅថា អនុបសម្បន្ននោះ គឺជនទាំងអស់ លើកលែងតែភិក្ខុនឹងភិក្ខុនីចេញ ហៅថា អនុបសម្បន្ន។

[២៨៦] ដែលហៅថា បទនោះ គឺបទ១ អនុបទ១ អន្វក្ខរៈ១ អនុព្យញ្ជនៈ[56] ១។ ដែលហៅថា ជាបទនោះ គឺឧបសម្បន្នទាំងអនុបសម្បន្នផ្ដើមតាំងព្រមគ្នា បញ្ចប់ព្រមគ្នា។ ដែលហៅថា ជាអនុបទនោះគឺ ឧបសម្បន្នទាំងអនុបសម្បន្នផ្ដើមតាំងផ្សេងគ្នា បញ្ចប់ព្រមគ្នា ដែលហៅថា អន្វក្ខរៈនោះ គឺឧបសម្បន្នប្រាប់អនុបសម្បន្នថា រូបំ អនិច្ចំ អនុបសម្បន្នទទួលថារូព្រមគ្នា។ ដែលហៅថា ជាអនុព្យញ្ជនៈនោះ គឺឧបសម្បន្នប្រាប់អនុបសម្បន្នថា រូបំ អនិច្ចំ អនុបសម្បន្នបញ្ចេញសំឡេង (ដោយរហ័ស) ថា វេទនា អនិច្ចា[57] ដូច្នេះ ឈ្មោះថា បង្រៀនជាអនុព្យញ្ជនៈ។ បទណាក្ដី អនុបទណាក្ដី អន្វក្ខរៈណាក្ដី អនុព្យញ្ជនៈណាក្ដី ទាំងអស់នុ៎ះ ឈ្មោះថាធម៌ជាបទ (គឺជាចំណែក)។ ពាក្យដែលជាពុទ្ធភាសិត សាវកភាសិត ឥសិភាសិត ទេវតាភាសិត ដែលអាស្រ័យនូវអដ្ឋកថា អាស្រ័យនូវបាលី ឈ្មោះថាធម៌។ ពាក្យថា បង្រៀន សេចក្ដីថា ភិក្ខុបង្រៀនដោយបទ ត្រូវអាបត្តិបាចិត្តិយរាល់ៗបទ។ ភិក្ខុបង្រៀនដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយរាល់ៗ អក្ខរៈ។

[២៨៧] អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្នពិតមែន ហើយបង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ។ អនុបសម្បន្នពិតមែន តែភិក្ខុមានសេចក្ដីសង្ស័យ ហើយបង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ។ អនុបសម្បន្ន តែភិក្ខុសំគាល់ថាឧបសម្បន្នទៅវិញ ហើយបង្រៀនធម៌ជាបទ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន តែភិក្ខុសំគាល់ថាអនុបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ។ ឧបសម្បន្ន តែភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្នពិតមែន មិនត្រូវអាបត្តិ។

[២៨៨] អាបត្តិមិនមានដល់ភិក្ខុរៀនបាលីជាមួយ[58] (នឹងអនុបសម្បន្ន) ដល់ភិក្ខុស្វាធ្យាយជាមួយ[59] (នឹងអនុបសម្បន្ន) ដល់ភិក្ខុ កំពុងសូត្រគម្ពីរដែលស្ទាត់ដោយច្រើន[60] ដល់ភិក្ខុថាជាមួយនឹងអនុបសម្បន្នកំពុងសូត្រធម៌[61] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុអ្នកដើមបញ្ញត្តិ។

សិក្ខាបទ ទី៤ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៥

CS vin.vbu.pc.05 | ភាគ ទី៣

### (៣. បេសុញ្ញសិក្ខាបទំ)

[២៨៩] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគកាលគង់នៅ អគ្គាឡវចេតិយ ជិតក្រុងអាឡវី។ សម័យនោះឯង ពួកឧបាសកតែងមកកាន់អារាមដើម្បីនឹងស្តាប់ធម៌។ កាលបើធម្មកថិកសំដែងធម៌ចប់ហើយ ពួកភិក្ខុជាថេរក៏ទៅកាន់ទីដែលខ្លួននៅ។ ភិក្ខុបួសថ្មីទាំងឡាយ ក៏ភ្លេចសតិ មិនដឹងខ្លួន ជាអ្នកអាក្រាតកាយថ្ងូរស្រមុកដេកលក់ជាមួយនឹងឧបាសក ទាំងឡាយក្នុងសាលាសម្រាប់ធ្វើបុណ្យនោះឯង។ ឧបាសកទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយមិនទំនងជាមនុស្សភ្លេចសតិ មិនដឹងខ្លួន ជាអ្នកអាក្រាតកាយថ្ងូរស្រមុកសឹងលក់ឡើយ។ ភិក្ខុទាំងឡាយបានឮពាក្យរបស់ឧបាសកទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសម្បី ភិក្ខុទាំងឡាយសឹងជាមួយនឹងអនុបសម្បន្នឡើយ។ ខណៈនោះឯង ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុទៅសឹងជាមួយ នឹងអនុបសម្បន្ន (រឿងនេះ)ពិតឬ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រ ព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះមិនទំនងដេកជាមួយនឹងអនុបសម្បន្នសោះ ម្នាលភិក្ខុទាំងឡាយ កម្មនេះមិននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដេកជាមួយនឹងអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ។ សិក្ខាបទនេះព្រះ ដ៏មានព្រះភាគបានទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះឯង។

[២៩០] គ្រានោះឯង ព្រះដ៏មានព្រះភាគកាលគង់នៅក្រុងអាឡវី គួរដល់ពុទ្ធអធ្យាស្រ័យហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិកនាក្រុងកោសម្ពី ទ្រង់យាងដោយលំដាប់ទៅក៏បានដល់ក្រុងកោសម្ពីនោះឯង។ បានឮថា ព្រះដ៏មានព្រះភាគទ្រង់សម្រេចឥរិយាបថនៅពទរិការាមជិតក្រុងកោសម្ពីនោះ។ ភិក្ខុទាំងឡាយបានពោលពាក្យនេះនឹងរាហុលដ៏មានអាយុថា ម្នាលរាហុលដ៏មានអាយុ សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់ត្រាស់បញ្ញត្តដូច្នេះថា ភិក្ខុមិនត្រូវដេកជាមួយនឹងអនុបសម្បន្នទេ ម្នាលរាហុល (សាមណេរ) ដ៏មានអាយុ អ្នកចូរដឹងនូវទីសឹងចុះ។ គ្រានោះ រាហុលដ៏មានអាយុរកទីសឹងមិនបាន ក៏ទៅសឹងក្នុងវច្ចកុដិ(បង្គន់)។ ខណៈនោះ ព្រះដ៏មានព្រះភាគទ្រង់តើនអំពីយប់ក្នុងវេលា បច្ចូសសម័យនៃរាត្រី ហើយយាងចូលទៅទីវច្ចកុដិ លុះយាងចូលទៅដល់ហើយ ទ្រង់ឱ្យនូវព្រះសូរសៀង (គឺគ្រហែមតាមទំនៀមវច្ចកុដិវត្ត)។ ឯរាហុលដ៏មានអាយុក៏គ្រហែមត។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សួរថា នរណានៅក្នុងវច្ចកុដីនេះ។ រាហុលក៏ក្រាបទូលថា បពិត្រ ព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះរាហុល។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលរាហុល ហេតុអ្វីបានជាអ្នកមកដេក ក្នុងវច្ចកុដិនេះ។ គ្រានោះ រាហុលដ៏មានអាយុក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មាន ព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយសំដែង ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឱ្យអ្នកទាំងឡាយសម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្នអស់ពីរយប់ ឬបីយប់បាន។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្ន លើសជាងពីរយប់ ឬបីយប់ឡើងទៅ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[២៩១] ត្រង់ពាក្យថា ភិក្ខុណាមួយ បានអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា អនុបសម្បន្ននោះ គឺលើកលែងតែភិក្ខុចេញ ក្រៅអំពីនោះជាអនុបសម្បន្នទាំងអស់។ ពាក្យថា លើសជាងពីរយប់ឬបីយប់ឡើងទៅ គឺច្រើនជាងពីរយប់បីយប់។ ពាក្យថា ជាមួយ សេចក្តីថា ជាមួយគ្នា។ ដែលហៅថាទីដេក គឺទីដែលគេប្រក់ទាំងអស់ ដែលគេបិទបាំងទាំងអស់ ដែលគេប្រក់ដោយច្រើន ដែលគេបិទបាំងដោយច្រើន។ ពាក្យថា សម្រេចនូវទីដេក សេចក្តីថា កាលបើព្រះអាទិត្យក្នុងថ្ងៃជាគំរប់ ៤ អស្តង្គតទៅហើយ កាល បើអនុបសម្បន្នដេក ភិក្ខុក៏នៅដេក ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ កាលបើភិក្ខុដេក អនុបសម្បន្នក៏នៅដេក ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ ពុំនោះសោត នៅដេកទាំងពីរនាក់ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ អ្នកទាំងពីរនាក់ក្រោកឡើងហើយដេកទៅវិញរឿយៗ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។

[២៩២] អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន សម្រេចនូវទី ដេករួមគ្នាលើសជាងពីរយប់ ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ។ អនុបសម្បន្ន តែភិក្ខុមានសេចក្តីសង្ស័យ ហើយសម្រេចនូវទីដេករួមគ្នាលើសជាងពីរយប់ ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្នទៅវិញ ហើយសម្រេចនូវទីដេករួមគ្នាលើស ជាងពីរយប់ ឬបីយប់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុត្រូវអាបត្តិទុក្កដ ក្នុងទីដែលប្រក់បានពាក់កណ្តាល បិទបាំងពាក់កណ្តាល។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ ឧបសម្បន្ន តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ពិតមែន ជាអនាបត្តិ។

[២៩៣] អាបត្តិមិនមានដល់ភិក្ខុនៅអស់ពីររាត្រី ឬបីរាត្រី (គឺដេក នៅជាមួយអនុបសម្បន្ន) ដល់ភិក្ខុដែលដេកនៅថយអំពីពីរ ឬបីរាត្រីចុះមកដល់ភិក្ខុដែលដេកនៅបានពីររាត្រីរួច ហើយចេញទៅអំពីពេលមុនអរុណរះ នៃរាត្រីជាគំរប់បី ហើយទើបមកដេកនៅជាថ្មីទៀត ដល់ភិក្ខុដែលដេកនៅ ក្នុងទីដែលគេប្រក់ទាំងអស់ តែគេមិនបានបិទបាំងទាំងអស់ ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេបិទបាំងជិត តែគេប្រក់មិនពេញ ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេមិនបានប្រក់ដោយច្រើន (គឺប្រក់បានបន្តិចបន្តួច) ដល់ភិក្ខុដែលដេកនៅក្នុងទីដែលគេមិនបានបិទបាំងដោយច្រើន (គឺបិទបាំងបន្តិចបន្តួច) ដល់ភិក្ខុអ្នកអង្គុយ អនុបសម្បន្នដេក ដល់ភិក្ខុដេកអនុបសម្បន្នអង្គុយ ឬភិក្ខុដែលអង្គុយពីរនាក់នឹងអនុបសម្បន្ន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុអ្នកដើមបញ្ញត្តិ។

សិក្ខាបទ ទី៥ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៦

CS vin.vbu.pc.06 | ភាគ ទី៣

### (៦. ទុតិយសហសេយ្យសិក្ខាបទំ)

[២៩៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគកាលគង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ព្រះអនុរុទ្ធដ៏មានអាយុនិមន្តទៅក្រុងសាវត្ថី ក្នុងកោសលជនបទ បានចូលទៅ កាន់ស្រុកមួយក្នុវេលាល្ងាច។ សម័យនោះឯង ក្នុងស្រុកនោះ មានផ្ទះសម្រាប់សំណាក់ដែលស្រីម្នាក់បានសង់ទុកហើយ។ គ្រានោះឯង ព្រះ អនុរុទ្ធដ៏មានអាយុចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយបានពោលពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រីបើនាងមិនមានសេចក្តីចង្អៀតចង្អល់ទេ អាត្មាសូមនៅក្នុងផ្ទះសំណាក់បានមួយយប់។ ស្រីនោះទូលតបថា និមន្តគង់នៅចុះលោកម្ចាស់។ ស្ងួម្បីពួកជនអ្នកដំណើរដទៃទៀតក៏ចូលទៅរកស្រីនោះ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងស្រីនោះថា បពិត្រនាងជាម្ចាស់ បើនាងមិនមានសេចក្តីចង្អៀតចិត្តទេ យើងទាំងឡាយសូមនៅក្នុងផ្ទះសំណាក់បានមួយយប់។ ស្រីនោះប្រាប់ថា មានសមណៈជាម្ចាស់១អង្គនុ៎ះលោកចូលទៅមុនហើយ បើសមណៈនោះលោកព្រម អ្នកទាំងឡាយចូរនៅចុះ។ គ្រានោះឯង អ្នកដំណើរទាំងនោះ ក៏ចូលទៅ រកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ បានទូលពាក្យនេះនឹង ព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចំរើន បើលោកមិនមានសេចក្តីចង្អៀតចិត្តទេ ខ្ញុំករុណា ទាំងឡាយសូមនៅក្នុងផ្ទះសំណាក់(នេះ)បានមួយយប់ផង។ ព្រះអនុរុទ្ធប្រាប់ថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយនៅចុះ។ ឯស្រីនោះក៏មានចិត្តប្រតិព័ទ្ធក្នុងព្រះអនុរុទ្ធដ៏មានអាយុតាំងអំពីបានឃើញ។ លំដាប់នោះ ស្រីនោះក៏ចូលទៅរកព្រះអនុរុទ្ធដ៏មានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចំរើន លោកម្ចាស់នឹងគង់នៅច្រឡូកច្រឡំដោយមនុស្សទាំងឡាយនេះមិនស្រួលទេ បពិត្រលោកដ៏ចំរើន ចាំខ្ញុំករុណារៀបចំគ្រែតូចមួយខាងក្នុងដើម្បីលោកម្ចាស់។ ព្រះអនុរុទ្ធដ៏ មានអាយុក៏ទទួលព្រមដោយតុណ្ហីភាព។ ឯស្រីនោះក៏រៀបចំគ្រែតូច ខាងក្នុងដោយខ្លួនឯងដើម្បីព្រះអនុរុទ្ធដ៏មានអាយុ ហើយប្រដាប់តាក់តែង អាយុ លុះចូលទៅដល់ហើយ បានពិតពាក្យនេះនឹងព្រះអនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចំរើន លោកម្ចាស់មានរូបល្អ គួរទស្សនាការ នាំមកនូវសេចក្តីជ្រះថ្លា ឯខ្ញុំករុណាក៏ជាស្រីមានរូបល្អដែរ គួររមិលមើលនាំមកនូវសេចក្តីជ្រះថ្លាដែរ បពិត្រលោកដ៏ចំរើន ខ្ញុំករុណាសូមធ្វើជាប្រពន្ធរបស់លោកម្ចាស់។ កាលដែលស្រីនោះនិយាយយ៉ាងនេះហើយ ព្រះ អនុរុទ្ធដ៏មានអាយុក៏ស្ងៀមនៅ។ ស្រីនោះបាននិយាយពាក្យនេះនឹងព្រះ អនុរុទ្ធដ៏មានអាយុជាគំរប់ពីរដងទៀត។ បេ។ ជាគំរប់បីដងទៀតថា បពិត្រលោកដ៏ចំរើន លោកម្ចាស់មានរូបល្អ គួរទស្សនាការ នាំមកនូវសេចក្តីជ្រះថ្លា ឯខ្ញុំករុណាក៏ជាស្រីមានរូបល្អគួររមិលមើល នាំមកនូវសេចក្តីជ្រះថ្លាដែរ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ព្រមទទួលយកនូវខ្ញុំករុណា នឹងសម្បត្តិទាំងពួងចុះ។ ព្រះអនុរុទ្ធដ៏មានអាយុក៏ស្ងៀមនៅអស់វារៈជាគំរប់បីដង។ ឯស្រីនោះក៏ដាក់សម្ពត់សាដកទាំងអស់ផុតចេញ (ពីខ្លួន) ហើយដើរខ្លះ ឈរខ្លះ អង្គុយខ្លះ ដេកខ្លះ ខាងមុខនៃព្រះអនុរុទ្ធដ៏មាន អាយុ។ ខណៈនោះ ព្រះអនុរុទ្ធដ៏មានអាយុក៏សង្រួមនូវឥន្ទ្រិយទាំងឡាយ ហើយមិនបានក្រឡេកមើល មិនបានចរចានឹងស្រីនោះឡើយ។ ឯស្រីនោះ ក៏លាន់មាត់ថា អើហ្ន៎គួរឱ្យអស្ចារ្យពេកណាស់ អើហ្ន៎មិនដែលឃើញទេតើ មនុស្សទាំងឡាយជាច្រើនរមែងបញ្ជូនមក ដោយរយកហាបណៈខ្លះដោយពាន់កហាបណៈខ្លះ ដើម្បីរួបអញ ឯសមណៈនេះអញខំលួងលោមដល់ម្ល៉េះ ដោយខ្លួនឯង ក៏ឥតមានត្រូវការចំពោះខ្លួនអញ នឹងទ្រព្យសម្បត្តិទាំងពួង ដល់តិចសោះ(ថាដូច្នេះ) ហើយក៏ស្លៀកសម្ពត់សាដក ហើយក្រាបចុះដោយត្បូងទៀបបាទានៃព្រះអនុរុទ្ធដ៏មានអាយុ ហើយសូមខមាទោសនឹងព្រះ អនុរុទ្ធដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាជាស្រីមានកំហុស ហើយព្រោះខ្ញុំព្រះករុណាជាស្រីពាល ជាស្រីល្ងង់ ជាស្រីមិនឈ្លាស ខ្ញុំ ឯណាដែលបានធ្វើនូវកំហុសមានសភាពយ៉ាងនេះហើយ បពិត្រលោកដ៏ ចំរើន សូមលោកម្ចាស់ទទួលនូវកំហុសតាមទោសរបស់ខ្ញុំព្រះករុណានោះ ដើម្បីនឹងសង្រួមតទៅទៀត។ ព្រះអនុរុទ្ធក៏តបថា ម្នាលប្អូនស្រី ណ្ហើយចុះ នាងមានកំហុសហើយ ព្រោះនាងជាស្រីពាល ជាស្រីល្ងង់ ជាស្រីមិន ឈ្លាស នាងណាដែលបានធ្វើនូវកំហុស មានសភាពយ៉ាងនេះហើយ ម្នាលប្អូនស្រី តែនាងឯងបានឃើញនូវកំហុសដោយកំហុសពិត ហើយសំដែងដោយសមគួរតាមធម៌ យើងនឹងទទួលនូវកំហុសរបស់នាងឯងនោះបាន អ្នកណាមួយបានឃើញនូវកំហុស ដោយកំហុសពិត ហើយសំដែងដោយសមគួរតាមធម៌ ហើយតាំងនៅក្នុងសេចក្តីសង្រួមតទៅ ម្នាលប្អូន ស្រី ការនេះជាសេចក្តីចំរើនរបស់អ្នកនោះ ក្នុងអរិយវិន័យ។ ឯស្រីនោះ លុះកន្លងរាត្រីនោះទៅក៏បវារណា និមន្តព្រះអនុរុទ្ធដ៏មានអាយុឱ្យឆាន់ បង្អែម និងចំអាបដ៏ផ្ចិតផ្ចង់ដោយដៃខ្លួនឯង ហើយអង្គុយនៅក្នុងទីដ៏សមគួរ ជាមួយនឹងព្រះអនុរុទ្ធដ៏មានអាយុដែលឆាន់ហើយ និងលាងបាត្រលាងដៃរួចហើយ។ ព្រះអនុរុទ្ធដ៏មានអាយុបានពន្យល់ស្រីដែលអង្គុយក្នុងទីដ៏សមគួរនោះឱ្យយល់ច្បាស់ ឱ្យទទួលយក ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយវាចាប្រកបដោយធម៌។ ឯស្រីនោះ លុះព្រះអនុរុទ្ធដ៏មានអាយុបានពន្យល់ឱ្យយល់ច្បាស់ ឱ្យទទួលយក ឱ្យអាចហ៊ាន ឱ្យរីករាយ ដោយវាចាប្រកបដោយធម៌ហើយ ក៏បាននិយាយពាក្យនេះនឹងព្រះអនុរុទ្ធដ៏មាន អាយុថា បពិត្រលោកដ៏ចំរើន ពាក្យនេះ ភ្លឺច្បាស់ណាស់ បពិត្រលោកដ៏ចំរើន ពាក្យនេះ ភ្លឺច្បាស់ណាស់ បពិត្រលោកដ៏ចំរើន បុគ្គលផ្ងាឡើងនូវភាជន៍ដែលគេផ្កាប់ចុះ ឬបើកចេញនូវវត្ថុដែលគេបិទបាំងទុក ពុំនោះសោតដូចបុគ្គលប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវ ឬដូចបុគ្គល កាន់ប្រទីបទ្រោលក្នុងទីងងឹត បំភ្លឺដល់មនុស្សដែលមានចក្ខុឱ្យឃើញរូប គ្នាបានសេចក្តីនេះមានឧបមាដូចម្តេចមិញ ព្រះអនុរុទ្ធជាម្ចាស់បានប្រកាសធម៌ដោយបរិយាយដ៏ច្រើន ក៏មានឧបមេយ្យដូច្នោះដែរ បពិត្រលោក ដ៏ចំរើន ខ្ញុំព្រះករុណានេះសូមដល់នូវព្រះដ៏មាន ព្រះភាគនោះព្រមទាំងព្រះ ធម៌ និងព្រះភិក្ខុសង្ឃថាជាទីពឹងទីរលឹក សូមលោកម្ចាស់ចាំទុកនូវខ្ញុំព្រះករុណា ថាជាឧបាសិកាដល់នូវ(ត្រៃ) សរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះជាដើមទៅ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុនិមន្តទៅក្រុងសាវត្ថីហើយបានប្រាប់សេចក្តីនេះដល់ភិក្ខុទាំងឡាយ។ ភិក្ខុ ទាំងឡាយណាដែលមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ ពោលទោសតិះដៀល បន្តុះបង្អាប់ថា ព្រះអនុរុទ្ធដ៏មានអាយុមិនគួរនឹងទៅ អាស្រ័យទីដេកនៅជាមួយនឹងមាតុគ្រាមសោះ។ ខណៈនោះ ភិក្ខុទាំងនោះ ក៏បានទូលរឿងនុ៎ះចំព្រោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះអង្គទ្រង់ត្រាស់ សួរថា ម្នាលអនុរុទ្ធ បានឮថា អ្នកសម្រេចនូវទីដេកជាមួយនឹងមាតុគ្រាមពិតមែនឬ។ ព្រះអនុរុទ្ធក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលអនុរុទ្ធ អ្នកមិនគួរនឹងសម្រេចនូវទីដេកជាមួយនឹងមាតុគ្រាមទេ ម្នាលអនុរុទ្ធ អំពើ ដែលអ្នកឯងធ្វើនេះមិននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសម្រេចនូវទីដេកជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ។

[២៩៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌ។ បេ។ ដែលហៅថា មាតុគ្រាមនោះ គឺស្រីមនុស្ស ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថាមាតុគ្រាមទេ ដោយហោចទៅសូម្បីតែក្មេងស្រីដែលកើតក្នុងថ្ងៃនោះ (ក៏ហៅថាមាតុគ្រាមដែរ)

នឹងបាច់ពោលថ្វី ដល់មនុស្សស្រីដែលធំ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយគ្នា។ ដែលហៅថា ទីដេក គឺទីដេកដែលគេប្រក់ទាំងអស់ គេបិទបាំងទាំងអស់ គេប្រក់ដោយច្រើន គេបិទបាំងដោយច្រើន។ ពាក្យថា សម្រេចទីដេក សេចក្តីថា វេលាព្រះអាទិត្យអស្តង្គតហើយមាតុគ្រាមដេក ភិក្ខុក៏ដេកដែរ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ កាលភិក្ខុដេក មាតុគ្រាមក៏ដេក ដែរ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ ពុំនោះសោតជនទាំងពីរគឺភិក្ខុនឹងមាតុគ្រាមដេកព្រមគ្នា ភិក្ខុត្រូវអាបត្តិបាចិត្តិយ។ ជនទាំងពីរនោះក្រោកឡើងហើយ ដេកទៅវិញរឿយ ៗ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។

[២៩៦] មាតុគ្រាម ភិក្ខុសំគាល់ថា មាតុគ្រាមពិតមែន ហើយសម្រេចទីដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម តែភិក្ខុមានសេចក្តីសង្ស័យ ហើយសម្រេចទីដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម ហើយសម្រេចទីដេកជាមួយ គ្នា ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុត្រូវអាបត្តិទុក្កដ (ព្រោះដេក) ក្នុងទីដេក ដែលគេប្រក់បានពាក់កណ្តាល គេបិទបាំងបានពាក់កណ្តាល។ ភិក្ខុ សម្រេចទីដេកជាមួយនឹងយក្សស្រីក្តី ប្រេតស្រីក្តី ជនខ្ទើយក្តី តិរច្ឆានញីក្តី ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាមត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម មិនត្រូវអាបត្តិឡើយ។

[២៩៧] (អាបត្តិមិនមានដល់ភិក្ខុសម្រេចទីដេកជាមួយនឹងមាតុគ្រាម) ក្នុងទីដែលគេប្រក់ទាំងអស់ តែមិនបានបិទបាំងជុំវិញ ដល់ភិក្ខុដែលដេកជាមួយនឹងមាតុគ្រាមក្នុងទីដែលគេបិទបាំងជុំវិញ តែគេមិនបានប្រក់សោះឡើយ ដល់ភិក្ខុដែលដេកជាមួយនឹងមាតុគ្រាមក្នុងទីដែលគេមិនបានប្រក់ ដោយច្រើន គឺប្រក់បានបន្តិចបន្តួច គេមិនបានបិទបាំងដោយច្រើន គឺបិទ បាំងបន្តិចបន្តួច ដល់ភិក្ខុដែលអង្គុយ មាតុគ្រាមដេក ដល់ភិក្ខុដេក មាតុគ្រាមអង្គុយ ដល់ភិក្ខុដែលអង្គុយ មាតុគ្រាមក៏អង្គុយទាំងពីរនាក់ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៦ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៧

CS vin.vbu.pc.07 | ភាគ ទី៣

### (៧. ធម្មទេសនាសិក្ខាបទំ)

[២៩៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់គង់នៅវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ កាលណោះឯង ឧទាយិដ៏មានអាយុ ជាអ្នកចូលទៅកាន់ត្រកូលក្នុងក្រុង សាវត្ថី តែងចូលទៅរកត្រកូលទាំងឡាយច្រើន។ លំដាប់នោះ ឧទាយិដ៏មានអាយុ វេលាព្រឹកព្រហាមក៏ស្លៀកស្បង់ហើយប្រដាប់ដោយ បាត្រចីវរចូលទៅរកត្រកូលមួយ។ គ្រានោះឯង ស្រីជាមេផ្ទះអង្គុយជិតទ្វារផ្ទះ។ ស្រីជាកូនប្រសានៃស្រីមេផ្ទះនោះ ក៏អង្គុយជិតទ្វារផ្ទះសំណាក់។ លំដាប់នោះ ឧទាយិដ៏មានអាយុ ចូលទៅរកស្រីជាមេផ្ទះ លុះចូលទៅហើយក៏សំដែងធម៌ជិតត្រចៀកស្រីជាមេផ្ទះ។ ទើបស្រីជាកូនប្រសានៃស្រីមេផ្ទះនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះ ថា សមណៈនោះជាសហាយរបស់ម្តាយក្មេក ឬនិយាយចង់គ្នា។ ពេលនោះ ឧទាយិដ៏មានអាយុ លុះសំដែងធម៌ជិតត្រចៀកស្រីជាមេផ្ទះ ហើយ ក៏ចូលទៅរកស្រីជាកូនប្រសានៃស្រីមេផ្ទះ លុះចូលទៅហើយ ក៏សំដែងធម៌ជិតត្រចៀកស្រីជាកូនប្រសានៃស្រីមេផ្ទះ (នោះទៀត)។ ទើបស្រីជាមេផ្ទះមានសេចក្តីត្រិះរិះដូច្នេះថា សមណៈនោះជាសហាយ របស់ស្រីជាកូនប្រសានៃអញជាមេផ្ទះ ឬថានិយាយចង់គ្នា។ លំដាប់នោះ ឧទាយិដ៏មានអាយុ លុះសំដែងធម៌ជិតត្រចៀកស្រីជាកូនប្រសានៃស្រី មេផ្ទះហើយ ក៏ចៀសចេញទៅ។ គ្រានោះឯង ស្រីជាមេផ្ទះបាននិយាយពាក្យនេះនឹងស្រីជាកូនប្រសានៃខ្លួនជាមេផ្ទះថា នែហង សមណៈនោះ បាននិយាយពាក្យអ្វីខ្លះនឹងហងឯង។ ស្រីជាកូនប្រសាតបថា បពិត្រអ្នកម៉ែ សមណៈនោះសំដែងធម៌ដល់ខ្ញុំចំណែកឯអ្នកម៉ែ សមណៈ នោះ បាននិយាយពាក្យអ្វីឱ្យខ្លះ។ ម្តាយក្មេកប្រាប់ថា សមណៈនោះសំដែងធម៌ដល់អញដែរ។ ស្រីទាំងពីរនាក់នោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧទាយិ មិនសម្បីបើនឹងសំដែង ធម៌(ខ្សិប) ជិតត្រចៀកមាតុគ្រាមសោះ ធម្មតាសមណៈគួរតែសំដែងធម៌ ដោយសំឡេងក្បស់ក្បាយដោយច្បាស់លាស់ទេតើ។ ភិក្ខុទាំង ឡាយបានឮពាក្យស្រីទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុមិនសម្បីបើនឹងសំដែងធម៌ដល់មាតុគ្រាមសោះ។ ឯភិក្ខុទាំងនោះ ក៏នាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគម្ចាស់។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧទាយិ បានឮថាអ្នកឯងសំដែងធម៌ដល់មាតុគ្រាម ពិតមែនឬទេ។ ឧទាយិភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែនហើយ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងសំដែងធម៌ដល់មាតុគ្រាមទេ ម្នាលមោឃបុរស អំពើនេះមិននាំឱ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសំដែងធម៌ដល់មាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ។

[២៩៩] សម័យនោះឯង ពួកឧបាសិកាឃើញភិក្ខុទាំងឡាយ ក៏និយាយពាក្យនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកខ្ញុំករុណា សូមអារាធនា សូមលោកម្ចាស់ទាំងឡាយមេត្តាសំដែងធម៌ឱ្យទាន។ ពួកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ការសំដែងធម៌ដល់មាតុគ្រាមមិនគួរទេ។ ពួកឧបាសិកាទូលថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកខ្ញុំករុណាសូមអារាធនា សូមលោកម្ចាស់ទាំងឡាយមេត្តាសំដែងធម៌ត្រឹមប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឱ្យ ទានចុះ ពួកខ្ញុំករុណា អាចចាំធម៌បានដោយពាក្យមានប្រមាណប៉ុណ្ណេះ។ ពួកភិក្ខុនិយាយថា ម្នាលប្អូនស្រី ការសំដែងធម៌ដល់មាតុគ្រាមមិនគួរទេ ថាដូច្នោះហើយ ក៏មានសេចក្តីរង្កៀសខានសំដែងធម៌ទៅ។ ពួកឧបាសិកាក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបីបើ លោកម្ចាស់ទាំងឡាយ ពួកយើងខំអង្វរទាំងម្ល៉េះ ក៏មិនសំដែងធម៌ឱ្យទានសោះ។ ភិក្ខុទាំងឡាយបានឮពាក្យឧបាសិកាទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកា ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុសំដែងធម៌ដល់មាតុគ្រាម បានតែត្រឹមប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង ឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសំដែង ធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ត្រូវអាបត្តិបាចិត្តិយ។ ព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ។

[៣០០] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបានដឹងថា ព្រះដ៏មាន ព្រះភាគបានអនុញ្ញាតឱ្យភិក្ខុសំដែងធម៌ដល់មាតុគ្រាមបានត្រឹមប្រាំម៉ាត់ឬប្រាំមួយម៉ាត់ហើយ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះក៏ឱ្យបុរសដែលមិនដឹងក្តី អង្គុយជិត ហើយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុ ទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសម្បីបើពួកឆព្វគ្គិយភិក្ខុឱ្យបុរសដែលមិនដឹងក្តីអង្គុយជិត ហើយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅសោះ។ ឯភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយឱ្យបុរស

ដែលមិនដឹងក្តីអង្គុយជិត ហើយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ មិនសមប្បីបើអ្នកទាំងឡាយឱ្យបុរសដែលមិនដឹងក្តីអង្គុយជិត ហើយសំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំ ម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅទេ។ ម្នាលមោឃបុរសទាំងឡាយ អំពើនេះ មិននាំឱ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។ បេ។ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សំដែងធម៌ដល់មាតុគ្រាមលើសពីប្រាំម៉ាត់ ឬប្រាំមួយម៉ាត់ឡើងទៅ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានបុរសដែលដឹងក្តី (អង្គុយជិត)។

[៣០១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌ។ ដែលហៅថា មាតុគ្រាម គឺមនុស្សស្រី ដែលដឹងក្តីអាចដឹងពាក្យល្អពាក្យអាក្រក់ ពាក្យទ្រគោះពាក្យមិនទ្រគោះ ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថាមាតុគ្រាមទេ។ ពាក្យថា លើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ គឺច្រើនជាងប្រាំម៉ាត់ឬប្រាំមួយ ម៉ាត់។ ដែលហៅថា ធម៌ គឺធម៌ដែល ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងទុកហើយ សាវកសំដែងទុកហើយ ឥសីសំដែងទុកហើយ ទេវតាសំដែងទុកហើយ ដែលអាស្រ័យនូវអដ្ឋកថា អាស្រ័យនូវបាលី។ ពាក្យថា សំដែង គឺភិក្ខុសំដែងដោយបទ ត្រូវអាបត្តិបាចិត្តិយ រាល់ៗបទ។ ភិក្ខុសំដែង ដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយ រាល់ៗអក្ខរៈ។ ពាក្យថា វៀរលែងតែមានបុរសដែលដឹងក្តី គឺលើកលែងតែបុរសដែលដឹងក្តី។ ដែលហៅថា អ្នកដឹងក្តី គឺបុរសដែលអាចដឹងនូវពាក្យល្អពាក្យអាក្រក់ ពាក្យទ្រគោះ ពាក្យមិនទ្រគោះ។

[៣០២] មាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ហើយសំដែងធម៌ ឱ្យលើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ដោយគ្មានបុរសដឹងក្តី (នៅជិតខាង) ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុមានសេចក្តីសង្ស័យ ហើយសំដែងធម៌ឱ្យលើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ដោយគ្មានបុរសដឹងក្តី (នៅជិតខាង) ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុសំគាល់ ថា មិនមែនមាតុគ្រាម ហើយសំដែងធម៌ឱ្យលើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅដោយគ្មានបុរសដឹងក្តី (នៅជិតខាង) ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសំដែងធម៌ឱ្យលើសពីប្រាំម៉ាត់ឬប្រាំមួយម៉ាត់ឡើងទៅ ដល់យក្សស្រី ក្តី ប្រេតស្រីក្តី ជនខ្ទើយក្តី តិរច្ឆានញីមានរាងកាយដូចមនុស្សស្រីក្តី ដោយគ្មានបុរសដឹងក្តី (នៅជិតខាង) ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាជាមាតុគ្រាម ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំ- គាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិអ្វីឡើយ។

[៣០៣] អាបត្តិមិនមានដល់ភិក្ខុដែលសំដែងធម៌(ដល់មាតុគ្រាម)មានបុរសដឹងក្តី (នៅជិតខាង) ដល់ភិក្ខុសំដែងធម៌ត្រឹមប្រាំម៉ាត់ឬប្រាំមួយម៉ាត់ ដល់ភិក្ខុសំដែងធម៌តិចជាងប្រាំម៉ាត់ឬប្រាំមួយម៉ាត់ ដល់ភិក្ខុសំដែងធម៌ប្រាំម៉ាត់ឬប្រាំមួយម៉ាត់ក្រោកឡើង ហើយអង្គុយទៅវិញសំដែងទៀត ដល់ភិក្ខុសំដែងធម៌ដល់មាតុគ្រាមដែលក្រោកឡើងហើយ អង្គុយទៅវិញក្នុងខណៈនោះ ដល់ភិក្ខុសំដែងធម៌ដល់មាតុគ្រាមឯទៀត (ក្រៅពីមាតុគ្រាមដែលបានសំដែងឱ្យស្តាប់ហើយ) ដល់ភិក្ខុដែលមាតុគ្រាមសួរ ប្រស្នាហើយឆ្លើយដោះប្រស្នា (នោះ) ដល់ភិក្ខុសំដែងធម៌ឱ្យអ្នកដទៃស្តាប់ មាតុគ្រាមអង្គុយស្តាប់ផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី៧ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៨

CS vin.vbu.pc.08 | ភាគ ទី៣

### (៨. ភូតារោចនសិក្ខាបទំ)

[៣០៤] សម័យនោះ ព្រះភគវន្តសម្ពុទ្ធជាម្ចាស់កាលគង់នៅកូដា គារសាលា ព្រៃមហាវន ទៀបក្រុងវេសាលី។ គ្រានោះឯងមានភិក្ខុ ច្រើនរូបជាមិត្របានជួបប្រទះគ្នាថ្មី និងមិត្រស្និទ្ធស្នាលមាំមួន បាននៅចាំវស្សាប្របធ្លេរស្ទឹងវគ្គមុទា។ វេលានោះឯង ដែនវជ្ជីកើតទុរ្ភិក្ស(អត់បាយ) មនុស្សទាំងឡាយ ចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក ក៏ដល់នូវសេចក្តី ស្លាប់មានឆ្អឹងស (ដេរដាសលើផែនដី) នឹងទិញដូរស្រូវអង្ករ លុះតែមាន ស្លាកកាន់ជាសំគាល់ ទើបទិញដូរបាន មនុស្សទាំងអស់ក្នុងដែននោះ មិនងាយនឹងចិញ្ចឹមជីវិតដោយការព្យាយាមស្វែងរកអាហារ។ ខណៈនោះ ភិក្ខុទាំងនោះគិតគ្នាដូច្នេះថា ឥឡូវនេះ ដែនវជ្ជីកើតទុរ្ភិក្ស (អត់បាយ) មនុស្សទាំងឡាយ ចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក ក៏ដល់នូវសេចក្តី ស្លាប់មានឆ្អឹងស (ដេរដាសលើផែនដី) នឹងទិញដូរស្រូវអង្ករលុះតែមាន ស្លាកកាន់ជាសំគាល់ ទើបទិញដូរបាន មនុស្សទាំងអស់ក្នុងដែននោះ មិនងាយនឹងចិញ្ចឹមជីវិតដោយការព្យាយាមស្វែងរកអាហារឡើយ តើយើងនឹងគិតធ្វើឧបាយដូចម្តេចហ្ន៎ ឱ្យបានសាមគ្គីស្មោះសរ កុំឱ្យមានវិវាទទាស់ទែងគ្នានៅចាំវស្សាឱ្យបានស្រួលផង កុំឱ្យលំបាកដោយអាហារបិណ្ឌបាតផង។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ បើដូច្នោះ យើងត្រូវទទួលរ៉ាប់រងការងាររបស់គ្រហស្ថចុះ កាលបើយើងធ្វើយ៉ាងនេះហើយ គ្រហស្ថទាំងនោះ គង់នឹងនឹកនាឱ្យអាហារដល់យើង មិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងក៏បានសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ កុំឡើយ ប្រយោជន៍អ្វី នឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថនោះ អាវុសោ ណ្ហើយចុះ យើងត្រូវធ្វើជាអ្នកបម្រើ នាំដំណឹងដល់ពួកគ្រហស្ថវិញ កាលបើយើងធ្វើយ៉ាងនេះហើយ គ្រហស្ថទាំងនោះគង់នឹងនឹកនាឱ្យអាហារបិណ្ឌបាតដល់យើងមិនខាន កាលបើបានអាហារ យ៉ាងនេះហើយ យើងនឹងព្រមព្រៀងស្មោះសរ មិនវិវាទទាស់ទែងគ្នានៅចាំវស្សាក៏ស្រួលផង ហើយមិនលំបាក ដោយអាហារបិណ្ឌបាតផង។ ភិក្ខុពួកខ្លះឆ្លើយថា អាវុសោ កុំឡើយ ប្រយោជន៍អ្វីនឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថ ប្រយោជន៍អ្វីនឹងធ្វើជាអ្នកបម្រើ នាំ ដំណឹងដល់ពួកគ្រហស្ថ អាវុសោ ណ្ហើយចុះ យើងនឹងពោលសរសើរនូវឧត្តរិមនុស្សធម៌របស់គ្នានឹងគ្នាដល់ពួកគ្រហស្ថវិញថា ភិក្ខុឯណោះ បានឈានទី ១ ភិក្ខុឯណោះបានឈានទី ២ ភិក្ខុឯណោះបានឈានទី ៣ ភិក្ខុឯណោះបានឈានទី ៤ ភិក្ខុឯណោះជាសោតាបន្ន ភិក្ខុឯណោះជាសកទាគាមី ភិក្ខុឯណោះជាអនាគាមី ភិក្ខុឯណោះជាព្រះអរហន្ត ភិក្ខុឯណោះបានវិជ្ជា ៣ ភិក្ខុឯណោះបានអភិញ្ញា៦ កាលបើយើងពោលយ៉ាងនេះហើយ គ្រហស្ថទាំងនេះគង់នឹងនឹកនាឱ្យអាហារបិណ្ឌបាតដល់យើងមិនខាន បើបានអាហារយ៉ាងនេះហើយ យើងក៏នឹងមានសេចក្តីសាមគ្គី ស្មោះសរ មិនវិវាទទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួលហើយមិនលំបាកដោយបិណ្ឌបាតផង។ ភិក្ខុទាំងនោះក៏យល់ព្រមថា អាវុសោ ពួកយើងពោលសរសើរគុណឧត្តរិមនុស្សធម៌ណារបស់គ្នាយើង ទៅវិញទៅ មក ដល់ពួកគ្រហស្ថ ការពោលសរសើរគុណឧត្តរិមនុស្សធម៌នេះស្រួល ហើយ។ លំដាប់នោះ ភិក្ខុទាំងនោះ

ក៏បានពោលសរសើរគុណឧត្តរិមនុស្សធម៌ទៅវិញទៅមកដល់ពួកគ្រហស្ថថា ភិក្ខុឯណោះបានឈានទី ១។ បេ។ ភិក្ខុឯណោះបានអភិញ្ញា ៦។ គ្រានោះ មនុស្សទាំងឡាយនោះក៏និយាយគ្នាថា អើហ្ន៎យើងរាល់គ្នាបានភិក្ខុបែបនេះមកនៅចាំវស្សា ហៅពេញ ជាលាភរបស់យើង ឈ្មោះថាយើងបានបុណ្យដោយងាយណាស់ហ្ន៎ តាំង ពីដើមមកដល់ឥឡូវនេះ យើងរាល់គ្នាមិនដែលបានពួកភិក្ខុមានសីលមានធម៌ជាកុសលដូចបែបនេះមកនៅចាំវស្សាសោះឡើយ។ មនុស្សទាំងនោះតែងប្រគេនភោជនាហារ[62] យ៉ាងណាដល់ភិក្ខុទាំងឡាយ ភោជនាហារយ៉ាងនោះមិនហ៊ានបរិភោគមាត់ខ្លួនឡើយ ហើយមិនបានជូនទៅមាតាបិតា កូនប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្ត អាមាត្យ និងញាតិសាលោហិតសោះឡើយ (ម្យ៉ាងទៀត) ធ្លាប់ប្រគេនខាទនីយ[63] គ្រឿងសម្រាប់ភ្លក់[64] និងទឹកបាន[65] យ៉ាងណា ដល់ពួកភិក្ខុ ខាទនីយ និងគ្រឿងភ្លក់ ទឹកបានយ៉ាងនោះ ក៏មិនហ៊ានបរិភោគផឹកខ្លួនឯងឡើយ ហើយមិនបានជូនទៅមាតាបិតា កូនប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្ត អាមាត្យ និងញាតិសាលោហិតសោះឡើយ។ គ្រានោះឯង ភិក្ខុ ទាំងនោះ (លុះបានអាហារឆាន់បរិបូណ៌) ក៏មានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខស្រស់បស់ សម្បុរស្បែកក៏ផូរផង់។

[៣០៥] ភិក្ខុទាំងឡាយកាលបើចេញវស្សារួចហើយ តែងនាំគ្នា ចូលទៅគាល់ព្រះដ៏មានព្រះភាគជាទំនៀមមិនដែលខានឡើយ។ វេលានោះឯង ភិក្ខុទាំងនោះលុះបាននៅចាំវស្សាគ្រប់៣ ខែហើយ ក៏រៀបចំទុក ដាក់គ្រឿងសេនាសនៈ រួចនាំយកបាត្រនិងចីវរចូលទៅក្រុងវេសាលី ដើរទៅតាមលំដាប់ ចូលទៅគាល់ព្រះដ៏មានព្រះភាគដែលគង់នៅឯកូដាគារ សាលាក្នុងព្រៃមហាវនទៀបក្រុងវេសាលី លុះចូលទៅដល់ហើយ ក៏ក្រាប ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ។ សម័យនោះ ឯង ពួកភិក្ខុដែលនៅចាំវស្សាក្នុងទិសទាំងឡាយ សឹងមានកាយស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់កើតជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ចំណែកខាងពួកភិក្ខុដែលនៅទៀបត្រើយស្ទឹងវគ្គមុទា មានសម្បុរល្អមានឥន្ទ្រិយពេញលេញ មានសម្បុរមុខក៏ស្រស់បស់ សម្បុរ ស្បែកក៏ផូរផង់។ ឯទំនៀមរបស់ព្រះភគវន្តសម្ពុទ្ធទាំងឡាយ ព្រះអង្គតែង ស្មោះសរចំពោះជាមួយនឹងអាគន្តុកភិក្ខុគឺភិក្ខុដែលទើបនឹងមកដល់ថ្មី។ គ្រា នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សួរទៅពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាល្មមអត់ធន់បានឬទេ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលឬទេ អ្នកទាំងឡាយមានសេចក្តីសាមគ្គីស្មោះសរមិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេឬ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំរាល់គ្នាល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគយើងខ្ញុំ រាល់គ្នាល្មមប្រព្រឹត្តទៅបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំរាល់គ្នាមាន នៅចាំវស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាតផង។ ព្រះតថាគតទាំងឡាយទ្រង់ជ្រាប នូវហេតុហើយត្រាស់សួរក៏មាន ជ្រាបហើយមិនត្រាស់សួរក៏មាន ជ្រាប ច្បាស់នូវកាលគួរហើយត្រាស់រួចក៏មាន ជ្រាបច្បាស់នូវកាលគួរហើយ មិនត្រាស់សួរក៏មាន ព្រះតថាគតទាំងឡាយទ្រង់ត្រាស់សួរតែកម្មដែលប្រកបព្រមដោយប្រយោជន៍ កម្មដែលមិនប្រកបព្រមដោយប្រយោជន៍ ព្រះអង្គមិនទ្រង់ត្រាស់សួរឡើយ ព្រះតថាគតទាំងឡាយ ព្រះអង្គផ្តាច់បង់ នូវកម្មមិនប្រកបដោយប្រយោជន៍ដោយអរិយមគ្គជ្រះស្រលះអស់ហើយ។ ព្រះភគវន្តសម្ពុទ្ធទាំងឡាយ ទ្រង់សួរបញ្ជាក់ពួកភិក្ខុដោយហេតុពីរប្រការ គឺសួរដោយទ្រង់ព្រះដំរិះថា តថាគតនឹងសំដែងធម៌១ នឹងបញ្ញត្តនូវសិក្ខាបទដល់ពួកសាវក១។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរទៅពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំង ឡាយបានជាមានសេចក្តីសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំ វស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាត តើដោយហេតុ អ្វី។ គ្រានោះ ភិក្ខុអម្បាលនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ (ដោយសព្វគ្រប់)។ ទើបព្រះអង្គទ្រង់ត្រាស់ថា នែភិក្ខុទាំងឡាយ ពាក្យរបស់អ្នកទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះភគវន្តសម្ពុទ្ធ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាមិនសមបើនឹងហ៊ាន ពោលសរសើគុណឧត្តរិមនុស្សធម៌របស់គ្នានឹងគ្នា ចំពោះពួកគ្រហស្ថព្រោះហេតុតែចង់ឆ្អែតផ្ទៃទេ ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកធ្វើនេះមិនបាននាំឱ្យកើតសេចក្តីជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយប្រាប់ឧត្តរិមនុស្សធម៌ ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ព្រោះឧត្តរិមនុស្សធម៌នោះភិក្ខុបានពិតមែន។

[៣០៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹង បារាជិកកណ្ឌសិក្ខាបទទី១ហើយ។ ដែលហៅថា អនុបសម្បន្ននោះ គឺលើកលែងតែភិក្ខុនិងភិក្ខុនីចេញ ក្រៅអំពីនោះហៅថា អនុបសម្បន្នទាំងអស់។

[៣០៧] ដែលហៅថា ឧត្តរិមនុស្សធម្ម[66] នោះ សំដៅយកឈាន១ វិមោក្ខ១ សមាធិ១ សមាបត្តិ១ ញាណទស្សនៈ១ មគ្គភាវនា១ ផលសច្ឆិកិរិយា១ កិលេសប្បហាន១ ចិត្តវិនីវរណៈ១ សុញ្ញាគារអភិរតិ១។

[៣០៨] បទថា ឈាន គឺសំដៅយកបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន។ បទថា វិមោក្ខ គឺសំដៅយកសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ។ បទថា សមាធិ គឺសំដៅយកសុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ។ បទថា សមាបត្តិ គឺសំដៅយកសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ។ បទថា ញាណ គឺសំដៅយកវិជ្ជា៣។ បទថា មគ្គភាវនា គឺសំដៅយក សតិបដ្ឋាន ៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ។ បទថា ផលសច្ឆិកិរិយា គឺកិរិយាធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល កិរិយាធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល កិរិយាធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល កិរិយាធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល។ បទថា កិលេសប្បហាន គឺកិរិយាលះរាគៈ លះទោសៈ លះមោហៈ។ បទថា ចិត្តវិនីវរណៈ គឺចិត្តដែលប្រាសចាករាគៈ ចិត្តដែលប្រាសចាកទោសៈ ចិត្តដែលប្រាសចាកមោហៈ។ សុញ្ញាគារអភិរតិ គឺសេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ដោយបឋមជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ដោយទុតិយជ្ឈាន សេចក្តី ត្រេកអរក្នុងផ្ទះដ៏ស្ងាត់ដោយតតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ដោយចតុត្ថជ្ឈាន។

[៣០៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្ន ថា អាត្មាបានចូលបឋមជ្ឈានរួចហើយ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាកំពុងចូលបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នកចូលបឋមជ្ឈានហើយ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នក បានបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈាន ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់ អនុបសម្បន្នថា បឋមជ្ឈានអាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១០] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាត្មាជាអ្នកបាននូវចតុត្ថជ្ឈាន អាត្មាជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ចតុត្ថជ្ឈានអាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១១] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ជាអ្នកដល់ នូវសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ អាត្មាជាអ្នកបាននូវអប្បណិហិតសមាធិ អាត្មាជាអ្នកស្ទាត់ក្នុងអប្បណិហិតសមាធិ អប្បណិហិតសមាធិ អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១២] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូល កំពុងចូល ជាអ្នកចូល នូវសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ អាត្មាជាអ្នកបាននូវអប្បណិហិតសមាបត្តិ អាត្មាជាអ្នកស្ទាត់ក្នុងអប្បណិហិតសមាបត្តិ អប្បណិហិតសមាបត្តិអាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១៣] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវត្រៃវិជ្ជា អាត្មាជាអ្នកបាននូវត្រៃវិជ្ជា អាត្មាជាអ្នកស្ទាត់ក្នុងត្រៃវិជ្ជា ត្រៃវិជ្ជា អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១៤] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់ នូវសតិបដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ អាត្មាជាអ្នកបាននូវឥទ្ធិបាទទាំង៤ អាត្មាជាអ្នកស្ទាត់ក្នុងឥទ្ធិបាទទាំង៤ ឥទ្ធិបាទទាំង៤ អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១៥] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវឥន្ទ្រិយ៥ពលៈ៥ អាត្មាជាអ្នកបាននូវពលៈ៥ អាត្មាជាអ្នកស្ទាត់ក្នុងពលៈ៥ ពលៈ៥ អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១៦] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវពោជ្ឈង្គទាំង៧ អាត្មាជាអ្នកបាននូវពោជ្ឈង្គទាំង៧ អាត្មាជាអ្នកស្ទាត់ក្នុងពោជ្ឈង្គទាំង៧ ពោជ្ឈង្គទាំង៧ អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១៧] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវមគ្គប្រកបដោយអង្គទាំង៨ដ៏ប្រសើរ អាត្មាជាអ្នកបាននូវមគ្គប្រកបដោយអង្គទាំង៨ ដ៏ប្រសើរ អាត្មាជាអ្នកស្ទាត់ក្នុងមគ្គប្រកបដោយអង្គទាំង៨ដ៏ប្រសើរ មគ្គប្រកបដោយអង្គទាំង៨ ដ៏ប្រសើរអាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១៨] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានដល់ កំពុងដល់ ជាអ្នកដល់នូវសោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល អាត្មាជាអ្នកបាននូវអរហត្តផល អាត្មាជាអ្នកស្ទាត់ក្នុងអរហត្តផល អរហត្តផលអាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣១៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា រាគៈអាត្មាបានលះបង់ហើយ ទោសៈអាត្មាបានលះបង់ហើយ មោហៈអាត្មាបានលះបង់ហើយ បានខ្ជាក់ចោលហើយ បានជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣២០] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាករាគៈ ចិត្តរបស់អាត្មាប្រាសចាកទោសៈ ចិត្តរបស់អាត្មាប្រាសចាកមោហៈ ត្រូវអាបត្តិបាចិត្តិយ។

[៣២១] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ អាត្មាជាអ្នកបាននូវចតុត្ថជ្ឈាន អាត្មាជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈាន អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ក្នុងផ្ទះដ៏ស្ងាត់ ត្រូវអាបត្តិបាចិត្តិយ។

[៣២២] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ទុតិយជ្ឈានផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ទុតិយជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ទុតិយជ្ឈានផង បឋមជ្ឈានផង ទុតិយជ្ឈានផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង តតិយជ្ឈានផង។បេ។ បឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ចតុត្ថជ្ឈានផង បឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣២៣] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង អាត្មាជាអ្នកបាននូវបឋមជ្ឈាន ផង អប្បណិហិតសមាធិផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង អប្បណិហិតសមាធិផង បឋមជ្ឈានផង អប្បណិហិតសមាធិផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣២៤] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង សុញ្ញតសមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង អប្បណិហិតសមាបត្តិផង អាត្មាជាអ្នក

ស្ពាត់ក្នុងបឋមជ្ឈានផង អប្បណិហិតសមាបត្តិផង បឋមជ្ឈានផង អប្បណិហិតសមាបត្តិផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣២៥] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ត្រៃវិជ្ជាផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ត្រៃវិជ្ជាផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ត្រៃវិជ្ជាផង បឋមជ្ឈានផង ត្រៃវិជ្ជាផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣២៦] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង សតិបដ្ឋាន៤ផង សម្មប្បធាន៤ផង ឥទ្ធិបាទ៤ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ឥទ្ធិបាទ៤ផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ឥទ្ធិបាទ៤ផង បឋមជ្ឈានផង ឥទ្ធិបាទ៤ផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣២៧] ពាក្យថា ប្រាប់ គឺភិក្ខុប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង ឥន្ទ្រិយ៥ផង ពលៈ៥ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ពលៈ៥ផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ពលៈ៥ផង បឋមជ្ឈានផង ពលៈ៥ផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣២៨] ពាក្យថាប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង ពោជ្ឈង្គ៧ផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង ពោជ្ឈង្គ៧ផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ពោជ្ឈង្គ៧ផង បឋមជ្ឈានផង ពោជ្ឈង្គ៧ផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣២៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង មគ្គប្រកបដោយអង្គ៨ ដ៏ប្រសើរផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរផង បឋមជ្ឈានផង មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣៣០] ពាក្យថា ប្រាប់គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈានផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង អរហត្តផលផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង អរហត្តផលផង បឋមជ្ឈានផង អរហត្តផលផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣៣១] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង អាត្មាលះបង់រាគៈហើយផង អាត្មាលះបង់ទោសៈហើយផង អាត្មាលះបង់មោហៈហើយផង រាគៈ ទោសៈ មោហៈ អាត្មាបានខ្ជាក់ចោលហើយ បានជម្រុះហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣៣២] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ចិត្តរបស់អាត្មាប្រាសចាករាគៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ។

[៣៣៣] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល ទុតិយជ្ឈានផង តតិយជ្ឈានផង។ បេ។ ទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបាននូវទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងទុតិយជ្ឈាន ផង ចតុត្ថជ្ឈានផង ទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈានផង។ បេ។ ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាជាអ្នកបាននូវទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងទុតិយជ្ឈានផង បឋមជ្ឈានផង ទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។ បេ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ចិត្តរបស់អាត្មា ប្រាសចាកមោហៈផង អាត្មាបានចូលហើយ កំពុងចូល ជាអ្នកចូល បឋមជ្ឈានផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង អាត្មាជាអ្នកបាននូវបឋមជ្ឈានផង អាត្មាជាអ្នកស្ទាត់ក្នុងបឋមជ្ឈានផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង បឋមជ្ឈាន អាត្មាបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិបាចិត្តិយ។ បេ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ត្រូវអាបត្តិបាចិត្តិយ។

[៣៣៤] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អាត្មាបានដល់ហើយនូវបឋមជ្ឈានផង ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង សុញ្ញតសមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង វិជ្ជា៣ផង សតិបដ្ឋាន៤ផង សម្មប្បធាន៤ផង ឥទ្ធិបាទ ៤ផង ឥន្ទ្រិយ ៥ផង ពលៈ៥ផង ពោជ្ឈង្គ៧ផង មគ្គប្រកបដោយអង្គ៨ ដ៏ប្រសើរផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង។ បេ។ រាគៈអាត្មាបានកំចាត់ចេញហើយផង ទោសៈអាត្មាបានកំចាត់ចេញហើយផង មោហៈអាត្មាបានកំចាត់ចេញហើយផង រាគៈទោសៈមោហៈ អាត្មាបានខ្ជាក់ចោលហើយ បាន ជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់អាត្មាប្រាសចាក រាគៈផង ចិត្តរបស់អាត្មាប្រាសចាកទោសៈផង ចិត្តរបស់អាត្មាប្រាសចាកមោហៈផង ត្រូវអាបត្តិបាចិត្តិយ។

[៣៣៥] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ចំពោះ អនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានហើយ តែត្រឡប់ជាពោល ថា អាត្មាបានចូលទុតិយជ្ឈានទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្ន មិនដឹងសេចក្តីច្បាស់ ភិក្ខុនោះត្រូវ

ត្រឹមអាបត្តិទុក្កដ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់អនុបសម្បន្នថា អាត្មាបានចូលបឋមជ្ឈានហើយ ត្រឡប់ ជាពោលថា អាត្មាបានចូលតតិយជ្ឈាន ចតុត្ថជ្ឈាន សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ សុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិត សមាបត្តិ ត្រៃវិជ្ជា សតិបដ្ឋាន ៤ សម្មប្បធាន៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៥ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល រាគៈ អាត្មាបានលះបង់ហើយ ទោសៈអាត្មាបានលះបង់ហើយ មោហៈអាត្មា បានលះបង់ហើយ រាគៈទោសៈមោហៈអាត្មាបានខ្ជាក់ចោលហើយ បាន ជម្រុះចោលហើយ បានបន្សាត់ចោលហើយ បាលរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់អាត្មាប្រាសចាក រាគៈ ចិត្តរបស់អាត្មាប្រាសចាកទោសៈ ចិត្តរបស់អាត្មា ប្រាសចាកមោហៈ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ បើអនុប- សម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ។

[៣៣៦] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលទុតិយជ្ឈានហើយ។បេ។ តែត្រឡប់ជាពោលថា ចិត្តរបស់អាត្មាប្រាសចាកមោហៈទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹង សេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា អាត្មាបានចូលទុតិយជ្ឈានហើយ តែត្រឡប់ជាពោលថា អាត្មាបានចូលបឋមជ្ឈានទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ។ បេ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈ តែត្រឡប់ជាពោលថា អាត្មាបានចូលបឋមជ្ឈានហើយទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ។បេ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា ចិត្តរបស់អាត្មាប្រាសចាកមោហៈ តែត្រឡប់ជាពោលថា ចិត្តរបស់អាត្មា ប្រាសចាកទោសៈទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិ បាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិទុក្កដ។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងពោលដល់អនុបសម្បន្នថា អាត្មាបាន ចូលបឋមជ្ឈានផង ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង។បេ។ ចិត្តរបស់អាត្មាប្រាសចាកទោសៈ តែត្រឡប់ជាពោលថា ចិត្តរបស់អាត្មាប្រាសចាកមោហៈទៅវិញ បើអនុបសម្បន្នដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹម អាបត្តិទុក្កដ។

[៣៣៧] ពាក្យថា ប្រាប់ គឺភិក្ខុប្រាថ្នានឹងនិយាយប្រាប់ដល់អនុបសម្បន្នថា អាត្មាបានចូលទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង។បេ។ ចិត្តរបស់អាត្មាប្រាសចាកមោហៈផង តែត្រឡប់ជានិយាយថា អាត្មាបានចូលបឋមជ្ឈានហើយទៅវិញ បើអនុបសម្បន្នដឹង សេចក្តីច្បាស់ ត្រូវអាបត្តិបាចិត្តិយ បើអនុបសម្បន្នមិនដឹងសេចក្តីច្បាស់ ត្រូវត្រឹមអាបត្តិទុក្កដ។

[៣៣៨] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ដល់អនុបសម្បន្នថា ភិក្ខុអង្គណានៅក្នុងវិហាររបស់អ្នក ភិក្ខុអង្គនោះបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈាន ភិក្ខុនោះជាអ្នកបាននូវបឋមជ្ឈាន ភិក្ខុនោះជាអ្នក ស្ទាត់ក្នុងបឋមជ្ឈានបឋមជ្ឈានភិក្ខុនោះបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយ ប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូលទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ភិក្ខុនោះ ជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈាន ចតុត្ថជ្ឈាន ភិក្ខុនោះបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបានដល់ហើយ កំពុងដល់ ជាអ្នកដល់នូវសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ ភិក្ខុនោះជាអ្នកបាននូវអប្បណិហិតសមាធិ ភិក្ខុនោះ ជាអ្នកស្ទាត់ក្នុងអប្បណិហិតសមាធិ អប្បណិហិតសមាធិ ភិក្ខុនោះ បានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបានដល់ហើយនូវសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ ត្រៃវិជ្ជា សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល។បេ។ រាគៈភិក្ខុនោះ បានលះបង់ហើយ ទោសៈភិក្ខុនោះបានលះបង់ហើយ មោហៈភិក្ខុនោះបាន លះបង់ហើយ រាគៈទោសៈមោហៈភិក្ខុនោះបានខ្ជាក់ចោលហើយ បាន ជម្រុះចោលហើយ បានបន្សាត់ចោលហើយ បានរលាស់ចោលហើយ បានរើឡើងហើយ បានគាស់រំលើងហើយ ចិត្តរបស់ភិក្ខុនោះប្រាសចាករាគៈចិត្តរបស់ភិក្ខុនោះប្រាសចាកទោសៈ ចិត្តរបស់ភិក្ខុនោះប្រាស ចាកមោហៈ ត្រូវអាបត្តិទុក្កដ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូលបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជា អ្នកស្ទាត់ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះ បានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ។ ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា ភិក្ខុណានៅគ្រប់គ្រងវិហាររបស់ អ្នក ភិក្ខុណាប្រើប្រាស់ចីវររបស់អ្នក ភិក្ខុណាបរិភោគបិណ្ឌបាតរបស់អ្នក ភិក្ខុណាប្រើប្រាស់សេនាសនៈរបស់អ្នក ភិក្ខុណាបរិភោគគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល ជាអ្នកចូល ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ។

[៣៣៩] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា វិហាររបស់អ្នក ភិក្ខុណាបាននៅគ្រប់គ្រងហើយ ចីវររបស់អ្នកភិក្ខុណា បានប្រើប្រាស់ហើយ បិណ្ឌបាតរបស់អ្នកភិក្ខុណា បានបរិភោគហើយ សេនាសនៈរបស់អ្នកភិក្ខុណា បានប្រើប្រាស់ហើយ គិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អ្នកភិក្ខុណា បានបរិភោគហើយ ភិក្ខុនោះបានចូលហើយ កំពុង ចូល ជាអ្នកចូល ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាននូវចតុត្ថជ្ឈាន ភិក្ខុនោះជាអ្នកស្ទាត់ក្នុងចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ។

[៣៤០] ពាក្យថា ប្រាប់ គឺភិក្ខុនិយាយប្រាប់ចំពោះអនុបសម្បន្នថា អ្នកឯងបានឱ្យវិហារ អ្នកឯងបានឱ្យចីវរ អ្នកឯងបានឱ្យបិណ្ឌបាត អ្នកឯងបានឱ្យសេនាសនៈ អ្នកឯងបានឱ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រោះអាស្រ័យនូវភិក្ខុណា ភិក្ខុនោះបានចូលហើយនូវចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់។បេ។ ចតុត្ថជ្ឈានក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះបានធ្វើឱ្យច្បាស់លាស់ហើយ ត្រូវអាបត្តិទុក្កដ។

[៣៤១] អាបត្តិមិនមានដល់ភិក្ខុដែលប្រាប់ឧត្តរិមនុស្សធម៌ដែលខ្លួនបានពិតប្រាកដ ដល់ឧបសម្បន្នបុគ្គល១ ដល់ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី៨ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៩

CS vin.vbu.pc.09 | ភាគ ទី៣

### (៩. ទុដ្ឋុល្លារោចនសិក្ខាបទំ)

[៣៤២] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឧបនន្ទសក្យបុត្រ ដ៏មានអាយុបានឈ្លោះនឹងពួកឆព្វគ្គិយភិក្ខុ (គឺភិក្ខុមានពួក៦)។ ឧបនន្ទនោះ ត្រូវអាបត្តិសញ្ចេតនិកៈ (សង្ឃាទិសេស) គឺធ្វើទឹកសុក្កឱ្យ ឃ្លាតចេញ ហើយបានសូមបរិវាសអំពីជំនុំសង្ឃ ដើម្បីអាបត្តិនោះ។ ជំនុំ សង្ឃក៏បានឱ្យបរិវាសដល់ឧបនន្ទនោះ ដើម្បីអាបត្តិនោះ។ វេលានោះឯង ក្រុងសាវត្ថីមានជនមួយពួក ( គេបានចាត់ចែង ) ភត្តថ្វាយសង្ឃ។ ឯឧបនន្ទនោះ កំពុងនៅក្នុងបរិវាសបានអង្គុយចុងអាសនៈក្នុងរោងភត្ត។ ពួកឆព្វគ្គិយភិក្ខុក៏បាននិយាយប្រាប់ឧបាសកទាំងនោះថា អាវុសោ ឧប នន្ទសក្យបុត្រដ៏មានអាយុនេះជាទីសរសើរ ជាជីតុនរបស់អ្នកទាំងឡាយ តែងឆាន់ភោជន់ដែលគេឱ្យ ដោយសទ្ធា ដោយដៃណា យកដៃនោះ ឯងព្យាយាមធ្វើឱ្យទឹកអសុចិហូរចេញ ឧបនន្ទនោះត្រូវអាបត្តិសញ្ចេតនិកៈ ព្រោះធ្វើទឹកសុក្កឱ្យឃ្លាតចេញហើយបានសូមបរិវាសអំពីជំនុំសង្ឃ ដើម្បីអាបត្តិនោះ ជំនុំសង្ឃក៏បានឱ្យបរិវាសដល់ឧបនន្ទនោះ ដើម្បីអាបត្តិនោះ ឧបនន្ទនោះឥឡូវកំពុងនៅបរិវាស ហើយអង្គុយនៅក្នុងទីបំផុតអាសនៈ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។ បេ។ ពួកភិក្ខុនោះក៏ពោលទោសតិះ ដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងហ៊ាន ប្រាប់ទុដ្ឋុល្លាបត្តិ របស់ភិក្ខុផងគ្នាដល់អនុបសម្បន្នបុគ្គលសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះដ៏មានព្រះ ភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយបាន ប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គល ពិតមែនឬ។ ពួក ឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងហ៊ានប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ដល់អនុបសម្បន្នបុគ្គលសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំពួកមនុស្សដែលមិនទាន់ជ្រះថ្លា ឱ្យបានជ្រះថ្លាឡើងក៏ទេដែរ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នាដល់អនុបសម្បន្នបុគ្គល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឱ្យប្រាប់។

[៣៤៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបារាជិកសិក្ខាបទទី១។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ។ អាបត្តិបារាជិក៤ និងអាបត្តិសង្ឃាទិសេស ១៣ ឈ្មោះថា ទុដ្ឋុល្លាបត្តិ។ ដែលហៅថា អនុបសម្បន្ននោះ គឺលើកលែងភិក្ខុនិងភិក្ខុនីចេញ ក្រៅអំពីនោះ ហៅថា អនុបសម្បន្នទាំងអស់។ ពាក្យថា ប្រាប់ គឺភិក្ខុប្រាប់ដល់ស្រីក្តី ដល់ប្រុសក្តី ដល់គ្រហស្ថក្តី ដល់អ្នកបួសក្តី។ ពាក្យថា វៀរលែងតែភិក្ខុដែលសង្ឃសម្មតឱ្យប្រាប់ គឺលើកលែងតែភិក្ខុដែលបាន សេចក្តីសម្មតិអំពីសង្ឃ។

[៣៤៤] ឯសេចក្តីសម្មតិរបស់ភិក្ខុដែលសង្ឃកំណត់ឱ្យមាន៤យ៉ាង គឺសម្មតិកំណត់អាបត្តិ មិនកំណត់ត្រកូល១ សម្មតិកំណត់ត្រកូល មិនកំណត់អាបត្តិ ១ សម្មតិកំណត់អាបត្តិនិងត្រកូល១ សម្មតិមិនកំណត់អាបត្តិ មិនកំណត់ត្រកូល១។ ដែលហៅថាកំណត់អាបត្តិនោះ គឺអាបត្តិ (ប៉ុន្មាន) ដែលសង្ឃកំណត់ឱ្យហើយ ភិក្ខុដែលសង្ឃសន្មតត្រូវ ប្រាប់អាបត្តិប៉ុណ្ណោះ។ ដែលហៅថា កំណត់ត្រកូល (នោះ) គឺត្រកូល (ប៉ុន្មាន) ដែលសង្ឃកំណត់ឱ្យហើយ ភិក្ខុដែលសង្ឃសន្មត ត្រូវប្រាប់ (អាបត្តិ)ដល់ត្រកូលប៉ុណ្ណោះ។ ដែលហៅថា កំណត់អាបត្តិនិងកំណត់ ត្រកូល (នោះ) គឺអាបត្តិ(ប៉ុន្មាន) ដែលសង្ឃកំណត់ឱ្យហើយ និងត្រកូល (ប៉ុន្មាន) ដែលសង្ឃកំណត់ឱ្យហើយ ភិក្ខុដែលសង្ឃសន្មតត្រូវប្រាប់ (អាបត្តិប៉ុណ្ណោះ) ដល់ត្រកូលប៉ុណ្ណោះបាន។ ដែលហៅថា មិនកំណត់ អាបត្តិមិនកំណត់ត្រកូល (នោះ) គឺអាបត្តិ(ប៉ុន្មាន) ដែលសង្ឃមិនកំណត់ឱ្យហើយនិងត្រកូល (ប៉ុន្មាន) ដែលសង្ឃមិនកំណត់ឱ្យហើយ ភិក្ខុដែលសង្ឃ សន្មតត្រូវប្រាប់អាបត្តិដែលសង្ឃមិនកំណត់ឱ្យប៉ុណ្ណោះ ដល់ត្រកូលដែល សង្ឃមិនកំណត់ឱ្យប៉ុណ្ណោះបាន។

[៣៤៥] (ម្យ៉ាងទៀត) ត្រង់ពាក្យថា កំណត់អាបត្តិ គឺពួកអាបត្តិ ណាដែលសង្ឃបានកំណត់ឱ្យហើយ ភិក្ខុមិនប្រាប់អាបត្តិទាំងនោះ ទៅ ប្រាប់ពួកអាបត្តិដទៃវិញ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា កំណត់ ត្រកូល គឺពួកត្រកូលណាដែលសង្ឃបានកំណត់ឱ្យហើយ ភិក្ខុមិនប្រាប់ពួកត្រកូលនោះ បែជាប្រាប់ត្រកូលទាំងឡាយដទៃវិញ ត្រូវអាបត្តិ បាចិត្តិយ។ ពាក្យថា កំណត់អាបត្តិនិងកំណត់ត្រកូល គឺពួកអាបត្តិណា ដែលសង្ឃបានកំណត់ឱ្យក្តី ពួកត្រកូលណាដែលសង្ឃបានកំណត់ឱ្យក្តី ភិក្ខុនោះមិនប្រាប់អាបត្តិទាំងនោះ មិនប្រាប់ត្រកូលទាំងនោះ ទៅប្រាប់អាបត្តិឯទៀត ត្រកូលឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា មិនកំណត់អាបត្តិ មិនកំណត់ត្រកូល (នោះ) គឺភិក្ខុនោះប្រាប់អនុបសម្បន្នដោយអាបត្តិណា ៗ ត្រកូលណាៗ ក៏ដោយ មិនត្រូវអាបត្តិឡើយ។

[៣៤៦] ទុដ្ឋុល្លាបត្តិ ភិក្ខុដឹងច្បាស់ថា ទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសម្មតឱ្យប្រាប់។ ភិក្ខុមានសេចក្តីសង្ស័យក្នុងទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឱ្យ ប្រាប់។ ទុដ្ឋុល្លាបត្តិ ភិក្ខុសំគាល់ថាអទុដ្ឋុល្លាបត្តិ ហើយប្រាប់ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែភិក្ខុដែលសង្ឃសន្មតឱ្យប្រាប់។

[៣៤៧] ភិក្ខុប្រាប់អទុដ្ឋុល្លាបត្តិ (ដល់អនុបសម្បន្ន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុប្រាប់អជ្ឈាចារអាក្រក់ក្តី[67] មិនសូវអាក្រក់ក្តី[68] របស់អនុបសម្បន្ន គឺសាមណេរ (ដល់អនុបសម្បន្នដទៃ) ត្រូវអាបត្តិទុក្កដ។ អទុដ្ឋុល្លាបត្តិ ភិក្ខុសំគាល់ថា ទុដ្ឋុល្លាបត្តិវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យ ក្នុងអទុដ្ឋុល្លាបត្តិ ត្រូវអាបត្តិទុក្កដ។ អទុដ្ឋុល្លាបត្តិ ភិក្ខុសំគាល់ថា អទុដ្ឋុល្លាបត្តិ ត្រូវអាបត្តិទុក្កដ។

[៣៤៨] អាបត្តិមិនមានដល់ភិក្ខុដែលប្រាប់តែវត្ថុ[69] មិនប្រាប់អាបត្តិដល់ភិក្ខុដែលប្រាប់តែអាបត្តិ[70] មិនប្រាប់វត្ថុដល់ភិក្ខុដែលបានសេចក្តីសម្មតិអំពីសង្ឃ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទទី ៩ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី១០

CS vin.vbu.pc.10 | ភាគ ទី៣

### (១០. បឋវីខណនសិក្ខាបទំ)

[៣៤៩] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅអគ្គាឡវចេតិយ ក្បែរក្រុងអាឡវី។ គ្រានោះឯង ពួកអាឡវិកភិក្ខុ កាលធ្វើនវកម្ម ក៏ជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យជីកខ្លះ នូវផែនដី។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រមិនសមបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យជីកខ្លះ នូវផែនដីសោះ ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ ហ៊ានបៀតបៀនវត្ថុរស់ដែលមានឥន្រ្ទិយមួយ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។ បេ។ ពួកភិក្ខុនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកអាឡវិកភិក្ខុ មិនគួរបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យជីកខ្លះ នូវផែនដីសោះ។ វេលានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យជីកខ្លះ នូវផែនដី ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលតបវិញថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរបើនឹងហ៊ានជីកដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យជីកខ្លះនូវផែនដីទេ នែមោឃបុរសទាំងឡាយ ព្រោះពួកមនុស្សមាន សេចក្តីសំគាល់ថាផែនដីជាវត្ថុមានជីវិត នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឱ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យជីកក្តី នូវផែនដីត្រូវអាបត្តិបាចិត្តិយ។

[៣៥០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹង សិក្ខាបទទី ១ នៃបារាជិកកណ្ឌ។ ដែលហៅថា ផែនដី បានដល់ផែនដីមានពីរយ៉ាង គឺជាតបឋវី ផែនដីមានដីច្រើនជាងវត្ថុឯទៀត១ អជាតបឋវី ផែនដីមានដីតិចជាងវត្ថុឯទៀត១។ ដែលហៅថា ជាតបឋវី (នោះ) គឺអាចម៍ដីសុទ្ធ ដីស្អិតសុទ្ធ ដីមានថ្មតិច មានក្រួសតិច មាន បំណែកអម្បែងតិច មានក្រួសរវានតិច មានខ្សាច់តិច មានអាចម៍ដីច្រើន មានដីស្អិតច្រើន ឬជាផែនដីគេមិនដែលដុត តថាគតហៅថា ជាតបឋវី។ ម្យ៉ាងទៀតគំនរអាចម៍ដីណាក្តី គំនរដីស្អិតណាក្តី ដែលមានភ្លៀងធ្លាក់ត្រូវជាង៤ខែ គំនរនេះឯង តថាគតហៅថា ជាតបឋវីដែរ។ ដែលហៅថា អជាតបឋវី (នោះ) គឺផែនដីដែលមានថ្មសុទ្ធ មានក្រួសសុទ្ធ មានបំណែកអម្បែងសុទ្ធ មានក្រួសរវានសុទ្ធ មានខ្សាច់សុទ្ធ មានអាចម៍ដីតិច មានដីស្អិតតិច មានថ្មច្រើន មានក្រួសច្រើន មានបំណែកអម្បែងច្រើន មានក្រួសរវានច្រើន មានខ្សាច់ច្រើន ជាផែនដីដែលគេដុតហើយ តថាគតក៏ហៅថា អជាតបឋវី។ ម្យ៉ាងទៀតគំនរអាចម៍ដីណាក្តី គំនរដីស្អិតណាក្តី ដែលមានភ្លៀងធ្លាក់ចុះថយ ពី៤ ខែមក ផែនដីនេះតថាគតក៏ ហៅថា អជាតបឋវីដែរ។

[៣៥១] ត្រង់ពាក្យថា ជីកដោយខ្លួនឯង គឺភិក្ខុជីកដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រើអ្នកដទៃឱ្យជីក គឺភិក្ខុបង្គាប់អ្នកដទៃឱ្យជីក ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុបង្គាប់មនុស្សឱ្យជីកតែម្តង មនុស្សនោះទៅជីកច្រើនផង ត្រូវអាបត្តិបាចិត្តិយ។

[៣៥២] ផែនដីមែន ភិក្ខុសំគាល់ថាផែនដី ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យជីកក្តី ទំលាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទំលាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យដុតក្តី ត្រូវអាបត្តិបាចិត្តិយ។ ផែនដីមែន តែភិក្ខុមានសេចក្តីសង្ស័យ ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យជីកក្តី ទំលាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទំលាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យដុតក្តី ត្រូវអាបត្តិទុក្កដ។ ផែនដីមែន ភិក្ខុមានសេចក្តីសំគាល់ថាមិនមែនផែនដី ហើយជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យជីកក្តី ទំលាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទំលាយក្តី ដុតដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យដុតក្តី មិនត្រូវអាបត្តិឡើយ។ ទីដែលមិនមែនជាផែនដី ភិក្ខុមានសេចក្តីសំគាល់ថាផែនដី ត្រូវអាបត្តិទុក្កដ។ ទីមិនមែនជាផែនដី ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ទីមិនមែនជាផែនដី ភិក្ខុសំគាល់ថាមិនមែនផែនដី មិនត្រូវអាបត្តិឡើយ។

[៣៥៣] អាបត្តិមិនមានដល់ភិក្ខុដែលពោលថា អ្នកឯងចូរដឹងនូវវត្ថុនេះ អ្នកឯងចូរឱ្យនូវវត្ថុនេះ អ្នកឯងចូរនាំមកនូវវត្ថុនេះ អាត្មាត្រូវការដោយវត្ថុនេះ អ្នកឯងចូរធ្វើនូវវត្ថុនេះឱ្យជារបស់សមគួរ ដល់ភិក្ខុមិនបានក្លែង ដល់ភិក្ខុភ្លាត់ស្មារតី ដល់ភិក្ខុកាលមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។ ចំនួនសិក្ខាបទក្នុងមុសាវាទវគ្គនោះ គឺ

សម្បជានមុសាវាទ១ ឱមសវាទ១ បេសុញ្ញវាទ១ បទសោធម្ម១ បឋមសហសេយ្យ១ ទុតិយសហសេយ្យ១ ធម្មទេសនា១ ភូតារោចនៈ១ ទុដ្ឋុល្លាបត្តិ១ បឋវីខណនៈ១។

សិក្ខាបទ ទី១០ ចប់។

មុសាវាទវគ្គជាដម្បូង។

## ភូតគាមវគ្គ

CS vin.vbu.pc.v2 | ភាគ ទី៣

## (២. ភូតគាមវគ្គោ)

## (បាចិត្តិយ) សិក្ខាបទ ទី១ (១១)

CS vin.vbu.pc.11 | ភាគ ទី៣

### (១. ភូតគាមសិក្ខាបទំ)

[៣៥៤] សម័យនោះ ព្រះភគវន្តសម្ពុទ្ធ កាលគង់នៅអគ្គាឡវចេតិយ ទៀបក្រុងអាឡវី។ គ្រានោះឯង ពួកភិក្ខុនៅក្នុងក្រុងអាឡវី កាលធ្វើនវកម្ម ក៏កាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យកាប់ខ្លះ នូវដើមឈើ។ មានភិក្ខុ១រូបនៅក្រុងអាឡវីកាប់ឈើមួយដើម។ មានទេវតា១អង្គអាស្រ័យនៅលើដើមឈើនោះបាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ លោកចង់ធ្វើទីនៅរបស់ខ្លួន មិនត្រូវកាប់ទីនៅរបស់ខ្ញុំទេ។ ភិក្ខុនោះមិនអើពើ (នឹងពាក្យទេវតានោះ) ក៏ចេះតែកាប់ឈើនោះទៅ ក៏ត្រូវដៃទារករបស់ទេវតានោះ។ វេលានោះឯង ទេវតានោះត្រិះរិះដូច្នេះថា បើដូច្នោះ ខ្លួនអញត្រូវសម្លាប់ភិក្ខុនេះក្នុងទីនេះ។ ខណៈនោះឯង ទេវតានោះត្រិះរិះដូច្នេះវិញថា ខ្លួនអញសម្លាប់ភិក្ខុនេះក្នុងទីនេះដោយអំពើណា អំពើនេះមិនសមគួរដល់ខ្លួនអញសោះឡើយ បើដូច្នោះ អញត្រូវក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគសិន។ គ្រានោះឯង ទេវតានោះក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ (ដោយសព្វគ្រប់)។ ព្រះសាស្តាជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលទេវតា ពាក្យដែលអ្នកថាប្រពៃពេកណាស់ ម្នាលទេវតា អ្នកឯងមិនបានសម្លាប់ភិក្ខុនោះត្រូវពិតហើយ ម្នាលទេវតា បើអ្នកសម្លាប់ភិក្ខុនោះក្នុងថ្ងៃនេះហើយ ម្នាលទេវតា អ្នកឯងត្រូវបាននូវបាបជាច្រើន នែទេវតា អ្នកឯងចូរត្រឡប់ទៅវិញចុះ ក្នុងទីឯណោះមានឈើមួយដើមយ៉ាងស្ងាត់ អ្នកឯងចូរទៅនៅអាស្រ័យនូវឈើនោះចុះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនគួរនឹងហ៊ានកាប់ដោយខ្លួនឯងផង ប្រើអ្នកដទៃឱ្យកាប់ផង នូវដើមឈើសោះ ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ រមែងបៀតបៀននូវវត្ថុដែលមានជីវិតមានឥន្ទ្រិយតែ១។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនៅក្នុងក្រុងអាឡវី មិនគួរនឹងហ៊ានកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យកាប់ខ្លះ នូវដើមឈើសោះ។ គ្រានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យកាប់ខ្លះនូវដើមឈើ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ការនោះមិនមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយមិនគួរបើនឹងហ៊ានកាប់ដោយខ្លួនឯងខ្លះ ប្រើអ្នកដទៃឱ្យកាប់ខ្លះ នូវដើមឈើទេ នែមោឃបុរស ទាំងឡាយ ព្រោះពួកមនុស្សមានសេចក្តីសំគាល់ថាដើមឈើមានជីវិត នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំពួកមនុស្ស ដែលមិនទាន់ជ្រះថ្លាឱ្យជ្រះថ្លាឡើង ឬពួកមនុស្សដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថាភិក្ខុធ្វើភូតគាម[71] មានឈើ និងស្មៅជាដើមឱ្យវិនាស ត្រូវអាបត្តិបាចិត្តិយ។

[៣៥៥] ពូជមាន៥យ៉ាងគឺ ពូជកើតពីមើម ឬឫស១ ពូជកើតពីដើម១ ពូជកើតពីថ្នាំង១ ពូជកើតពីចុង ឬគល់១ ពូជកើតពីពូជ (គឺផ្លែ)១ ពូជទាំង៥នេះហៅថា ភូតគាម។ ដែលហៅថា ពូជកើតពីមើម ឬឫស (នោះសំដៅយក) រមៀត ខ្ញី លំពាន់ ប្រស់ អាច់ឆ្អឹស រំដេង ស្បូវភ្លាំង និងក្រវាញជ្រូក មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយដទៃណាកើតពីមើម ឬឫស ដុះពីមើម ឬឫស វត្ថុប៉ុណ្ណោះឈ្មោះថា ពូជកើតពីមើម ឬឫស (ដូចគ្នា)។ ដែលហៅថា ពូជកើតពីដើម (នោះសំដៅយក) ដើមពោធិ ដើមជ្រៃ ដើមល្វៀប ដើមល្វា ដើមជ្រៃក្រិម ដើមក្រសាំង មិនតែប៉ុណ្ណោះ សូម្បីវត្ថុទាំងឡាយដទៃណាកើតពីដើម ដុះពីដើម វត្ថុប៉ុណ្ណោះហៅថាពូជកើតពីដើម។ ដែលហៅថា ពូជកើតពីថ្នាំង (នោះសំដៅយក) អំពៅ ឫស្សី និងបបុស មិនតែប៉ុណ្ណោះ សូម្បីវត្ថុ ទាំងឡាយដទៃណាកើតពីថ្នាំង ដុះពីថ្នាំង វត្ថុប៉ុណ្ណោះហៅថាពូជកើតពីថ្នាំង។ ដែលហៅថា ពូជកើតពីចុង ឬគល់ (នោះសំដៅយក) ជីរលីងលាក់ ស្លឹកគ្រៃ វល្លិអណ្តាតត្រកួត ម្យ៉ាងទៀតសូម្បីវត្ថុទាំងឡាយណាកើតពីចុង ឬគល់ ដុះពីចុង ឬគល់ វត្ថុប៉ុណ្ណោះហៅថាពូជកើតពីចុង ឬគល់ (ដូចគ្នា)។ ដែលហៅថា ពូជកើតពីពូជ (នោះសំដៅយក) បុព្វណ្ណជាតិ បានដល់ស្រូវ៧ប្រការ មានស្រូវស ស្រូវក្រហម និងពោតជាដើម អបរណ្ណជាតិ បានដល់សណ្តែកបាយ សណ្តែករាជមាសជាដើម ម្យ៉ាងទៀត សូម្បីវត្ថុទាំងឡាយណាកើតពីពូជ ដុះពីពូជ វត្ថុប៉ុណ្ណោះហៅថា ពូជកើតពីពូជគំរប់៥។

[៣៥៦] វត្ថុជាពូជមែន ភិក្ខុសំគាល់ថាពូជ ហើយកាប់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទម្លាយក្តី ចំអិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យចំអិនក្តី ត្រូវអាបត្តិបាចិត្តិយ។ពូជមែន ភិក្ខុមានសេចក្តីសង្ស័យ ហើយកាប់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃទម្លាយក្តី ចំអិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យចំអិនក្តី ត្រូវអាបត្តិទុក្កដ។ ពូជមែន ភិក្ខុសំគាល់ថា មិនមែនពូជ ហើយកាប់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យកាប់ក្តី ទម្លាយដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទម្លាយក្តី ចំអិនដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យចំអិនក្តី មិនត្រូវអាបត្តិឡើយ។ វត្ថុមិនមែនពូជ ភិក្ខុសំគាល់ថាពូជ ត្រូវអាបត្តិទុក្កដ។ វត្ថុមិនមែនពូជ តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ វត្ថុមិនមែនពូជ ភិក្ខុសំគាល់ថា មិនមែនពូជ មិនត្រូវអាបត្តិឡើយ។

[៣៥៧] អាបត្តិមិនមានដល់ភិក្ខុដែលនិយាយថា អ្នកចូរដឹងនូវវត្ថុនេះ អ្នកចូរឱ្យនូវវត្ថុនេះ អ្នកចូរនាំមកនូវវត្ថុនេះ អាត្មាត្រូវការដោយវត្ថុនេះ អ្នកចូរធ្វើនូវវត្ថុនេះឱ្យសមគួរ ដល់ភិក្ខុមិនបានក្លែង ដល់ភិក្ខុភ្លាត់ស្មារតី ដល់ភិក្ខុកាលមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី១ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី២ (១២)

CS vin.vbu.pc.12 | ភាគ ទី៣

### (២. អញ្ញវាទកសិក្ខាបទំ)

[៣៥៨] សម័យនោះ ព្រះដ៏ទ្រង់យសកាលគង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី។ គ្រានោះឯង ឆន្នភិក្ខុដ៏មានអាយុប្រព្រឹត្តអនាចារដោយខ្លួនឯង កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃ (គឺពោលពាក្យបន្លែបន្លប់) ទៅវិញដោយពាក្យថា នរណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលចំពោះបុគ្គលណា លោកទាំងឡាយពោលថាអ្វី។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃហើយ មិនសមបើនឹងពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃថា នរណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលចំពោះបុគ្គល ណា លោកទាំងឡាយពោលថាអ្វី។ គ្រានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់សួរបញ្ជាក់ទៅនឹងឆន្នភិក្ខុដ៏មានអាយុថា ម្នាលឆន្ន បានឮថាអ្នកឯងកាលដែលភិក្ខុសាកសួរដោយ អាបត្តិក្នុងកណ្តាលជំនុំសង្ឃ ហើយពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញថា នរណាត្រូវអាបត្តិ។បេ។ លោកទាំងឡាយពោលថាដូចម្តេច ពាក្យនេះពិតមែនឬ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពាក្យនេះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯង កាលដែលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ហើយមិនគួរបើ នឹងពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃថា នរណាត្រូវអាបត្តិ។បេ។ លោកទាំងឡាយពោលដូចម្តេច នែមោឃបុរស អំពើដែលអ្នកធ្វើ នេះនឹងបានដឹងនាំមនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា ឱ្យបានជ្រះថ្លា ឡើងក៏ទេ។ បេ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោស រួចទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅថាភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរលើកនូវអញ្ញវាទកកម្ម[72] ដល់ឆន្នភិក្ខុចុះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវលើកនូវអញ្ញវាទកកម្មយ៉ាងនេះ ភិក្ខុដែលឈ្លាសអង់អាចត្រូវប្រកាសសង្ឃឱ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ (ដ្បិត) ឆន្នភិក្ខុនេះ កាលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃវិញ។ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃត្រូវលើកនូវអញ្ញវាទកកម្មដល់ឆន្នភិក្ខុ។ នេះជាវាចាសម្រាប់ផ្តៀងសង្ឃឱ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ (ដ្បិត) ឆន្នភិក្ខុនេះ កាលភិក្ខុសាកសួរដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ក៏ពោលបិទ បាំងនូវពាក្យដទៃដោយពាក្យដទៃវិញ។ ឥឡូវនេះ ព្រះសង្ឃលើកនូវអញ្ញវាទកកម្មដល់ឆន្នភិក្ខុ។ ការលើកនូវអញ្ញវាទកកម្មដល់ឆន្នភិក្ខុ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះគួរស្ងៀម (បើ) មិនសមគួរដល់លោកម្ចាស់អង្គណាទេ លោកម្ចាស់អង្គនោះ ត្រូវពោលឡើង។ អញ្ញវាទកកម្ម សង្ឃបានលើកដល់ឆន្នភិក្ខុហើយ។ អញ្ញវាទកកម្មគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាព្រះសង្ឃស្ងៀមនៅ។ ខ្ញុំចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ។

[៣៥៩] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសឆន្នភិក្ខុដ៏មានអាយុ ដោយអនេកបរិយាយ។ បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលនូវពាក្យដទៃ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ។

[៣៦០] សម័យនោះឯង ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុកំពុង សាកសួរ ដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏គិតដោយអាត្មាអញកាលពោលបិទបាំងនូវពាក្យដទៃដោយពាក្យដទៃ មុខជានឹងត្រូវអាបត្តិ (មិនខានឡើយ) ហើយក៏ស្ងៀមនៅមិនស្តី នាំឱ្យសង្ឃលំបាក។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុ សាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ មិនសមបើនឹងស្ងៀមនៅមិន ស្តីនាំឱ្យសង្ឃលំបាកសោះ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ បេ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរឆន្នភិក្ខុដ៏មានអាយុថា នែឆន្ន បានឮថាអ្នកឯងកាលដែលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ហើយស្ងៀមនៅមិនស្តី នាំឱ្យសង្ឃលំបាក ពិតមែនឬ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯង កាលដែលភិក្ខុសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ មិនសមបើនឹងស្ងៀមនៅមិនស្តីនាំឱ្យសង្ឃ លំបាកទេ នែមោឃបុរស អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំមនុស្សទាំងឡាយដែលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លាឡើងក៏ទេដែរ។ បេ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោស រួចទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរលើកនូវវិហេសកកម្ម[73] ដល់ឆន្នភិក្ខុចុះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវលើកនូវវិហេសកកម្មយ៉ាងនេះ គឺភិក្ខុដែលវាងវៃអង់អាចគួរផ្តៀងសង្ឃឱ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ(ដ្បិត) ឆន្នភិក្ខុនេះ កាលដែលភិក្ខុសាកសួរ ដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ស្ងៀមនៅមិនស្តី នាំឱ្យសង្ឃលំបាក។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុ។ នេះជាពាក្យផ្តៀងសង្ឃឱ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូម ព្រះសង្ឃស្តាប់នូវពាក្យខ្ញុំ(ដ្បិត) ឆន្នភិក្ខុនេះ កាលដែលសង្ឃសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏ស្ងៀមនៅមិនស្តី នាំឱ្យសង្ឃលំបាក។ ឥឡូវសង្ឃលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុ។ ការដែលលើកនូវវិហេសកកម្មដល់ឆន្នភិក្ខុ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀមនៅ (បើ) មិនសមគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ ត្រូវពោលឡើង។

វិហេសកកម្ម សង្ឃបានលើកដល់ឆន្នភិក្ខុរួចហើយ។ ការដែលលើកនូវវិហេសកកម្ម សមគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅមិនស្តី។ ខ្ញុំចាំទុកនូវរឿងនេះ ដោយភាវៈស្ងៀមនៅយ៉ាងនេះ។

[៣៦១] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសឆន្នភិក្ខុដ៏មានអាយុដោយអនេកបរិយាយ។ បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះពោលនូវពាក្យដទៃ(ឬ)ព្រោះធ្វើឱ្យសង្ឃបានសេចក្តីលំបាក។

[៣៦២] ដែលហៅថា ពោលនូវពាក្យដទៃ (នោះ) គឺភិក្ខុ (ណាមួយ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើប ឡើងនូវវត្ថុនិងអាបត្តិនោះ ត្រឡប់ជាបិទបាំងនូវពាក្យដទៃដោយពាក្យ ដទៃវិញថា នរណាបានត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលនឹងនរណា លោកទាំងឡាយពោលដូចម្តេច ភិក្ខុនេះឈ្មោះថាពោលនូវពាក្យដទៃ។

[៣៦៣] ដែលហៅថា ធ្វើឱ្យសង្ឃបានសេចក្តីលំបាក (នោះ) គឺភិក្ខុ(ណាមួយ)ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបនូវវត្ថុនិងអាបត្តិនោះ ហើយស្ងៀមមិនស្តី នាំឱ្យសង្ឃបានសេចក្តីលំបាក ភិក្ខុនេះឈ្មោះថាធ្វើឱ្យសង្ឃបានសេចក្តីលំបាក។

[៣៦៤] កាលបើអញ្ញវាទកកម្មសង្ឃមិនបានលើកឡើងទេ ភិក្ខុ (ណាមួយ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបឡើងនូវវត្ថុនិងអាបត្តិនោះ ត្រឡប់ជាពោលបិទបាំងនូវ ពាក្យដទៃដោយដទៃវិញថា នរណាបានត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិ ព្រោះវត្ថុអ្វី ត្រូវអាបត្តិដោយប្រការដូចម្តេច លោកទាំងឡាយពោលនឹងនរណា លោកទាំងឡាយពោលដូចម្តេច ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ កាលបើវិហេសកកម្មដែលសង្ឃមិនបានកើតឡើងទេ ភិក្ខុណា ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបឡើង នូវវត្ថុនិងអាបត្តិនោះ ស្ងៀមមិនស្តី នាំឱ្យសង្ឃបានសេចក្តីលំបាក ភិក្ខុ នោះត្រូវអាបត្តិទុក្កដ។

[៣៦៥] កាលបើអញ្ញវាទកម្មដែលសង្ឃបានលើកឡើងហើយ ភិក្ខុ(ណាមួយ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តីក្នុងកណ្តាលជំនុំសង្ឃ ហើយមិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិន ប្រាថ្នានឹងបើកឡើងនូវវត្ថុនិងអាបត្តិនោះ ត្រឡប់ជាពោលបិទបាំងនូវពាក្យ ដទៃដោយពាក្យដទៃវិញថា នរណាត្រូវអាបត្តិ។ បេ។ លោកទាំង ឡាយពោលដូចម្តេច ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ កាលបើវិហេសកកម្មដែលសង្ឃបានលើកឡើងហើយ ភិក្ខុ(ណាមួយ) ដែលភិក្ខុកំពុងសាកសួរចំពោះវត្ថុក្តី ចំពោះអាបត្តិក្តី ក្នុងកណ្តាលជំនុំសង្ឃ មិនប្រាថ្នានឹងពោលនូវវត្ថុនិងអាបត្តិនោះ មិនប្រាថ្នានឹងបង្ហើបនូវវត្ថុនិងអាបត្តិនោះស្ងៀម មិនស្តី នាំឱ្យសង្ឃបានសេចក្តីលំបាក ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[៣៦៦] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ តែពោលនូវពាក្យដទៃ នាំឱ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិ បាចិត្តិយ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មប្រកបដោយធម៌ ហើយ ពោលនូវពាក្យដទៃ នាំឱ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសំគាល់ថាកម្មមិនប្រកបដោយធម៌វិញ ហើយពោលនូវពាក្យដទៃ នាំឱ្យសង្ឃបានសេចក្តីលំបាក ត្រូវអាបត្តិ បាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៣៦៧] អាបត្តិមិនត្រូវដល់ភិក្ខុដែលមិនដឹងសេចក្តីហើយសួរ ដល់ភិក្ខុដែលមានជម្ងឺហើយមិននិយាយ ដល់ភិក្ខុដែលមិននិយាយដោយគិតថា ការបង្កហេតុប្រកួតប្រកាន់ ជម្លោះ វិវាទនឹងនាំឱ្យរវល់ដល់សង្ឃ ដល់ភិក្ខុដែលមិននិយាយដោយគិតថា ក្រែងសង្ឃបែកគ្នា (ឬ)ក្រែងសង្ឃថ្នាំងថ្នាក់នឹងគ្នា ដល់ភិក្ខុដែលមិននិយាយដោយគិតថា សង្ឃមុខជានឹងធ្វើ កម្ម មិនត្រូវតាមធម៌ផង ជាពួកផង ចំពោះភិក្ខុដែលមិនគួរដល់កម្មផង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី២ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៣ (១៣)

CS vin.vbu.pc.13 | ភាគ ទី៣

### (៣. ឧជ្ឈាបនកសិក្ខាបទំ)

[៣៦៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ គ្រានោះឯង ព្រះទព្វមល្លបុត្តដ៏មានអាយុ តែងក្រាលនូវសេនាសនៈផង តែងឧទ្ទិសនូវភត្តផងដល់សង្ឃ។ លំដាប់នោះ ពួកមេត្តិយភុម្មជកភិក្ខុ ទើបនឹងបួសថ្មីផង ជាមនុស្សមានបុណ្យតិចផង អស់ទាំងសេនាសនៈណា ដ៏ថោកថយរបស់សង្ឃ សេនាសនៈទាំងនោះ ត្រូវបានមកពួកភិក្ខុទាំងនោះ មួយទៀតភត្តទាំងឡាយណាដ៏ថោកថយ ក៏ត្រូវបានមកពួកភិក្ខុទាំងនោះដែរ។ ពួកមេត្តិយភុម្មជកភិក្ខុនោះ ក៏បង្គាប់ភិក្ខុទាំងឡាយឱ្យពោលទោសព្រះ ទព្វមល្លបុត្តដ៏មានអាយុថា ព្រះទព្វមល្លបុត្ត ក្រាលសេនាសនៈតាមសេចក្តីគាប់ចិត្តរបស់ខ្លួន ម្យ៉ាងទៀត លោកឧទ្ទិសនូវភត្តតាមសេចក្តីគាប់ចិត្តរបស់ខ្លួន។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្ទះបង្អាប់ថា មេត្តិយភុម្មជកភិក្ខុទាំងឡាយមិនសមបើនឹងបង្គាប់ភិក្ខុទាំងឡាយឱ្យពោលទោស ព្រះទព្វមល្លបុត្តដ៏មានអាយុសោះ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ លំដាប់នោះ ព្រះដ៏មានព្រះភាគ។បេ។ ទ្រង់ត្រាស់សួរចំពោះពួកមេត្តិយភុម្មជកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថាអ្នកទាំងឡាយ បង្គាប់ភិក្ខុទាំងឡាយឱ្យពោលទោសទព្វមល្លបុត្ត ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងបង្គាប់ពួកភិក្ខុ (ដទៃ) ឱ្យពោលទោសទព្វមល្លបុត្តសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លាឡើងក៏ទេ។ បេ។ ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុបង្គាប់ភិក្ខុ ( ដទៃ ) ឱ្យពោលទោសភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយ សិក្ខាបទនេះព្រះដ៏មានព្រះភាគបានបញ្ញត្តដល់ពួកភិក្ខុយ៉ាងនេះ។

[៣៦៩] សម័យនោះឯង ពួកមេត្តិយភុម្មជកភិក្ខុគិតគ្នាថា ការដែលប្រើភិក្ខុ (ដទៃ) ឱ្យពោលទោស ព្រះដ៏មានព្រះភាគបានហាមរួចហើយ ព្រោះហេតុនោះភិក្ខុទាំងឡាយមុខជានឹងបានឮ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ហើយក៏តិះដៀល ព្រះទព្វមល្លបុត្តដ៏មានអាយុជិតពួកភិក្ខុ (ដទៃ) ថា ព្រះទព្វមល្លបុត្តរៀបចំសេនាសនៈតាមសេចក្តីគាប់ចិត្ត (របស់ខ្លួន) ផង ចាត់ចែងភត្តតាមសេចក្តីគាប់ចិត្ត (របស់ខ្លួន) ផង។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទះបង្អាប់ថា ពួកមេត្តិយភុម្មជកភិក្ខុមិនសមបើនឹងហ៊ានតិះដៀល ព្រះទព្វមល្លបុត្តដ៏មានអាយុសោះ។ គ្រានោះ ភិក្ខុទាំងឡាយនោះក្រាបទូលសេចក្តី នុ៎ះចំពោះព្រះដ៏មានព្រះភាគ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ។ បេ។ ទ្រង់ត្រាស់សួរចំពោះនឹងពួកមេត្តិយភុម្មជកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយតិះដៀលទព្វមល្លបុត្ត ពិត

មែនឬ។ ភិក្ខុ ទាំងនោះក្រាបទូលថា សូមទ្រង់មេត្តារប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំង ឡាយ មិនសមបើនឹងតិះដៀលទព្វមល្លបុត្តទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឱ្យបាន ជ្រះថ្លាឡើងក៏ទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុបង្គាប់ភិក្ខុដទៃឱ្យពោល ទោស ( ភិក្ខុផងគ្នាឬ ) តិះដៀល ( ភិក្ខុផងគ្នា ) ត្រូវអាបត្តិបាចិត្តិយ។

[៣៧០] ដែលហៅថា ភិក្ខុបង្គាប់ភិក្ខុដទៃឱ្យពោលទោស(នោះ) គឺភិក្ខុមានប្រាថ្នានឹងធ្វើនូវសេចក្ដីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្ដី បង្អាប់យស មានប្រាថ្នានឹងធ្វើនូវសេចក្ដីបង្អាប់បង្អោនចំពោះឧបសម្បន្នបុគ្គលដែលសង្ឃសន្មតឱ្យជាអ្នកក្រាលនូវសេនាសនៈក្ដី ឱ្យជាអ្នក ចាត់ចែងនូវភត្តក្ដី ឱ្យជាអ្នកចែកនូវបបរក្ដី ឱ្យជាអ្នកចែកនូវផ្លែឈើក្ដី ឱ្យជាអ្នកចែកនូវបង្អែមក្ដី ឱ្យជាអ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្ដី ហើយបង្គាប់ភិក្ខុដទៃឱ្យពោលទោស ឬតិះដៀលឧបសម្បន្នបុគ្គល (នោះ) ត្រូវអាបត្តិបាចិត្តិយ។

[៣៧១] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយបង្គាប់ភិក្ខុដទៃទៀតពោលទោស(ឬ) តិះដៀល(ភិក្ខុផងគ្នា) ត្រូវ អាបត្តិបាចិត្តិយ។ ភិក្ខុមានសេចក្ដីសង្ស័យក្នុងកម្មប្រកបដោយធម៌ ហើយបង្គាប់ភិក្ខុដទៃឱ្យពោលទោស (ឬ) តិះដៀល (ភិក្ខុផងគ្នា) ត្រូវអាបត្តិបា ចិត្តិយ។ កម្មប្រកបដោយធម៌ តែភិក្ខុសំគាល់ថាកម្មមិនប្រកបដោយ ធម៌វិញ ហើយបង្គាប់ភិក្ខុដទៃឱ្យពោលទោស (ឬ) តិះដៀល (ភិក្ខុផងគ្នា) ត្រូវអាបត្តិបាចិត្តិយ។

[៣៧២] ភិក្ខុបង្គាប់ភិក្ខុដទៃឱ្យពោលទោសក្ដី តិះដៀលដោយ ខ្លួនឯងក្ដី នូវអនុបសម្បន្នបុគ្គល ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានប្រាថ្នានឹងធ្វើនូវ សេចក្ដីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្ដីបង្អាប់យស មាន ប្រាថ្នានឹងធ្វើនូវសេចក្ដីបង្អាប់បង្អោនចំពោះឧបសម្បន្នបុគ្គល ដែលសង្ឃ មិនបាន សន្មតឱ្យជាអ្នកក្រាលសេនាសនៈក្ដី ឱ្យជាអ្នកចាត់ចែងនូវភត្តក្ដី ឱ្យជាអ្នកចែកនូវបបរក្ដី ឱ្យជាអ្នកចែកនូវផ្លែឈើក្ដី ឱ្យជាអ្នកចែកនូវបង្អែមក្ដី ឱ្យ ជាអ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្ដី ហើយបង្គាប់ភិក្ខុដទៃឱ្យពោលទោសក្ដី តិះដៀលដោយខ្លួនឯងក្ដី នូវឧបសម្បន្នបុគ្គលក្ដី នូវ អនុបសម្បន្នបុគ្គលក្ដី ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានប្រាថ្នានឹងធ្វើនូវសេចក្ដីតិះដៀល មានប្រាថ្នានឹងធ្វើនូវសេចក្ដីបង្អាប់ដោយ មានប្រាថ្នានឹងធ្វើនូវ សេចក្ដីបង្អាប់បង្អោនចំពោះអនុបសម្បន្នបុគ្គល ដែលសង្ឃបានសន្មត ឬ មិនបានសន្មត ឱ្យជាអ្នកក្រាលនូវសេនាសនៈក្ដី ឱ្យជាអ្នកចាត់ចែង នូវភត្តក្ដី ឱ្យជាអ្នកចែកនូវបបរក្ដី ឱ្យជាអ្នកចែកផ្លែឈើក្ដី ឱ្យជាអ្នកចែកនូវបង្អែមក្ដី ឱ្យជាអ្នកចែកចាយនូវវត្ថុមានប្រមាណតិចតួចក្ដី ហើយបង្គាប់ ភិក្ខុដទៃឱ្យពោលទោស ឬតិះដៀលដោយខ្លួនឯង នូវឧបសម្បន្នបុគ្គលក្ដី អនុបសម្បន្នបុគ្គលក្ដី ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុ មានសេចក្ដីសំគាល់ថា កម្មប្រកបដោយធម៌វិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្ដីសង្ស័យ ក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្ម មិនប្រកបដោយធម៌ ភិក្ខុសំគាស់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៣៧៣] អាបត្តិមិនមានដល់ភិក្ខុដែលបង្គាប់ភិក្ខុដទៃ ឱ្យពោល ទោសក្ដី តិះដៀលដោយខ្លួនឯងក្ដី នូវភិក្ខុដែលជាអ្នកធ្វើការសង្ឃ ដោយ ឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិជាប្រក្រតី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី៣ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៤ (១៤)

CS vin.vbu.pc.14 | ភាគ ទី៣

### (៤. បឋមសេនាសនសិក្ខាបទំ)

[៣៧៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ វត្តព្រះជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ លំដាប់នោះ ភិក្ខុទាំងឡាយបានតែងតាំងគ្រឿងសេនាសនៈ នៅទីវាល ហើយកំដៅកាយ ក្នុងកាលហេមន្តរដូវ (សម័យដែលមានទឹកសន្សើម) កាលបើគេ ប្រាប់ភត្តកាលគឺនិមន្តឆាន់ ហើយកាលនឹងដើរចេញទៅចាកទី នោះ មិនរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវសេនាសនៈ នោះ ហើយឥតទាំងបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ។ ឯគ្រឿងសេនាសនៈទទឹកដោយទឹកសន្សើមជោកអស់។ ពួកភិក្ខុណាដែល មាន សេចក្ដីប្រាថ្នាតិច។ បេ។ ពួកភិក្ខុនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងតែងតាំងគ្រឿងសេនាសនៈនៅ ទីវាល ហើយកាលនឹងដើរចេញទៅ មិនរើយកមកទុកដាក់មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំងបានប្រាប់ (អ្នក ដទៃ) ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈក៏ជោកជាំដោយទឹកសន្សើម គ្រានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្ដីនុ៎ះចំពោះ ព្រះដ៏មាន ព្រះភាគ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់បានត្រាស់សួរនូវភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុបានតែងតាំងគ្រឿង សេនាសនៈនៅទីវាល កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយឥតទាំង បានប្រាប់(អ្នកដទៃ) ស្រាប់តែដើរចេញទៅ គ្រឿងសេនាសនៈដ៏ជោកជាំដោយទឹកសន្សើម។ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគទ្រង់បន្ទោសថា ម្នាលអ្នកទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងតែងតាំងគ្រឿង សេនាសនៈនៅទីវាល ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើ គេឱ្យរើយកមកទុកដាក់ នូវសេនាសនៈនោះ ហើយ ឥតទាំងបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ឯគ្រឿងសេនាសនៈ ក៏ជោកជាំដោយ ទឹកសន្សើម ម្នាលភិក្ខុទាំងឡាយ អំពើនេះនឹងបាន ដឹកនាំពួកជន ដែលមិនទាន់ជ្រះថ្លា ឱ្យបានជ្រះថ្លាឡើងក៏ទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាង នេះថា ភិក្ខុណាមួយលាតឬសន្ធឹងខ្លួនឯងក្ដី ឱ្យគេលាតក្ដី នូវគ្រែក្ដី តាំងក្ដី ពូកក្ដី កៅអីក្ដី ដែលជារបស់សង្ឃក្នុងទីវាល ហើយកាលនឹងដើរ ចេញទៅ មិនបានរើយកគ្រឿងសេនាសនៈ មានគ្រែជាដើមនោះ មកទុកដាក់ឯង មិនបានប្រើគេឱ្យរើយកមកទុកដាក់ ហើយឥតបានប្រាប់(អ្នក ដទៃ)ស្រាប់ តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តិហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៣៧៥] សម័យនោះ មានភិក្ខុច្រើនរូបនៅក្នុងទីវាល លុះព្រឹក ឡើងក៏នាំគ្នាជញ្ជូនយកគ្រឿងសេនាសនៈទៅ។ ព្រះដ៏មានព្រះភាគទ្រង់បានទតឃើញភិក្ខុទាំងនោះ កំពុងតែជញ្ជូនយកគ្រឿងសេនាសនៈទៅ អពីព្រឹក។ លុះទ្រង់បានទតឃើញ ទើបទ្រង់ធ្វើនូវធម្មីកថា ព្រោះរឿង នេះ ដំណើរនេះ ហើយត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វក្អែកក្តី ពួកសត្វខ្លែងក្តី មិនបានបន្ទោបង់ នូវឧច្ចារៈដាក់ក្នុងទីណា តថាគតអនុញ្ញាតឱ្យទុកដាក់គ្រឿងសេនាសនៈក្នុង ទីនោះ គឺដូចជាមណ្ឌល ឬ រុក្ខមូល (ម្លប់ឈើ) អស់កាល៨ខែ គឺកំណត់យកខែដែលគ្មានភ្លៀង។

[៣៧៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌ។ សេនាសនៈដែលគេបានប្រគេន ឬបានលះដល់សង្ឃ ហៅថាសេនាសនៈរបស់សង្ឃ។ ដែលហៅថា គ្រែ បានដល់គ្រែ៤យ៉ាង គឺគ្រែដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង ១ គ្រែដែលមានមេជាប់នឹងជើង១ គ្រែដែលមានជើងដូចជាដើមក្តាម[74] ១ គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ១។ ដែលហៅថា តាំង បានដល់តាំងមាន ៤ យ៉ាង គឺតាំងដែលគេបញ្ចូល មេទៅក្នុងដំណាប់ជើង ១ តាំងដែលមានមេគេបង្ខាំជាប់នឹងជើង១ តាំងដែលមានជើងដូចជាជើងក្តាម[75] ១ តាំងដែលមានជើងចុច ឬតាំងដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ១។ ដែលហៅថា ពូក បានដល់ពូក៥យ៉ាង គឺពូកដែលគេញាត់ដោយរោមសត្វ១ ពូកដែលគេញាត់សម្បកឈើ ១ ពូកដែលគេញាត់កំណាត់សំពត់ ១ ពូកដែលគេញាត់ស្មៅ១ ពូកដែលគេញាត់ស្លឹកឈើ ១។ ដែលហៅថា កៅអី គឺកៅអីដែលគេធ្វើដោយសម្បកឈើក្តី ធ្វើដោយស្បូវភ្លាំងក្តី ធ្វើដោយស្មៅយ៉ាប្លងក្តី ធ្វើដោយស្មៅដំណេកទន្សាយក្តី ដែលគេរុំហើយចងភ្ជាប់គ្នាខាងក្នុង។ ពាក្យថា លាត គឺដម្កល់ទុកដោយខ្លួនឯង។ ពាក្យថា ប្រើគេឱ្យលាត គឺប្រើបុគ្គលដទៃឱ្យដម្កល់ទុក។ ភិក្ខុប្រើអនុបសម្បន្នបុគ្គលឱ្យដម្កល់ទុក សេចក្តីខ្វល់នឹងមានដល់ភិក្ខុអ្នកប្រើនោះ។ ភិក្ខុប្រើឧបសម្បន្នបុគ្គលឱ្យដម្កល់ទុក សេចក្តីខ្វល់នឹងមានដល់អ្នកដម្កល់ទុកនោះ។ ពាក្យថា កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់នូវគ្រឿងសេនាសនៈនោះ គឺមិនបានរើយកមកទុកដាក់ដោយខ្លួនឯង។ ពាក្យថា មិនបានប្រើគេឱ្យរើយកមកទុកដាក់ គឺមិនបានប្រើអ្នកដទៃឱ្យរើយកមកទុកដាក់។ ពាក្យថា ឥតបានប្រាប់ (អ្នកដទៃ) ហើយដើរចេញទៅ គឺកាលដែលភិក្ខុមិនបានប្រាប់ភិក្ខុផងគ្នាក្តី សាមណេរក្តី ញោមវត្តក្តី ហើយដើរកន្លង១ លេឌ្ឌុបាត[76] របស់មជ្ឈិមបុរសទៅ ត្រូវអាបត្តិបាចិត្តិយ។

[៣៧៧] របស់សង្ឃ ភិក្ខុសំគាល់ថារបស់សង្ឃ ហើយដម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យដម្កល់ទុកនៅក្នុងទីវាល កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង។ មិនបានប្រើអ្នកដទៃឱ្យរើយកមកទុកដាក់នូវគ្រឿងសេនាសនៈនោះឬមិនបានប្រាប់ (អ្នកដទៃ) ហើយដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងរបស់សង្ឃ ហើយដម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យដម្កល់ទុកក្នុងទី វាល កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដោយខ្លួនឯង មិនបានប្រើអ្នកដទៃឱ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬមិនបានប្រាប់ (អ្នកដទៃ) ហើយចេញដើរទៅ ត្រូវអាបត្តិបាចិត្តិយ។ របស់សង្ឃ ភិក្ខុមានសេចក្តីសំគាល់ថាជារបស់បុគ្គលទៅវិញ ហើយដម្កល់ទុកដោយ ខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យដម្កល់ទុកក្តី នៅក្នុងទីវាល កាលនឹងចៀសចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃឱ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬមិនបានប្រាប់ (អ្នកដទៃ) ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដម្កល់ទុកដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យដម្កល់ទុក នូវគ្រឿងទ្រនាប់ក្តី គ្រឿងកម្រាលគ្រែឬតាំងក្តី គ្រឿងកម្រាលផែនដីក្តី កន្ទេលទន់ក្តី ច្រមខណ្ឌ គឺគ្រឿងកម្រាលដែលគេធ្វើដោយស្បែកខ្លាជាដើមក្តី គ្រឿងសម្រាប់ជូតជើងក្តី តាំងដែលគេ ធ្វើដោយផែនក្តារក្តី នៅក្នុងទីវាល កាលនឹងចៀសចេញទៅ មិនបានរើយកមកទុកដាក់ដោយខ្លួនឯង មិនបានប្រើអ្នកដទៃឱ្យរើយកមកទុកដាក់នូវគ្រឿងសេនាសនៈទាំងនោះ ឬមិនបានប្រាប់ (អ្នកដទៃ) ហើយចៀសចេញទៅ ត្រូវអាបត្តិទុក្កដ។ របស់បុគ្គល ភិក្ខុមានសេចក្តីសំគាល់ថា ជារបស់សង្ឃវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងរបស់បុគ្គល ត្រូវអាបត្តិទុក្កដ។ របស់បុគ្គល ភិក្ខុមានសេចក្តីសំគាល់ថា ជារបស់បុគ្គល វត្ថុជារបស់បុគ្គលនៃភិក្ខុឯទៀត(ដែលមិនមែនជាវិស្សាសៈ) ត្រូវអាបត្តិទុក្កដ។ វត្ថុជារបស់បុគ្គល ភិក្ខុកាន់យកដោយសេចក្តី (ស្និទ្ធស្នាល ) ដូចជារបស់ខ្លួន មិនត្រូវអាបត្តិឡើយ។

[៣៧៨] អាបត្តិមិនមានដល់ភិក្ខុដែលបានរើយកគ្រឿងសេនាសនៈ មកទុកដាក់ដោយខ្លួនឯងហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រើអ្នកដទៃឲ្យរើយកគ្រឿងសេនាសនៈមកទុកដាក់ ហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រាប់(អ្នកដទៃ) ហើយដើរចេញទៅ ដល់ភិក្ខុដែលហាលគ្រឿងសេនាសនៈហើយដើរចេញទៅ(ដោយគិតថានឹងត្រឡប់មកយកទុកវិញ) ដល់ភិក្ខុដែលមានគ្រឿងសេនាសនៈ ដែលមានបុគ្គលណាមួយមកបៀតបៀន[77] ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ[78] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី៤ ចប់។

## (បាចិត្តិយ) សិក្ខាបទ ទី៥ (១៥)

CS vin.vbu.pc.15 | ភាគ ទី៣

### (៥. ទុតិយសេនាសនសិក្ខាបទំ)

[៣៧៩] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុមានពួក១៧ ជាសំឡាញ់នឹងគ្នា។ ភិក្ខុទាំងនោះកាលនឹងនៅ ក៏នៅជាមួយគ្នា កាលនឹងដើរ ក៏ដើរជាមួយគ្នា។ ភិក្ខុទាំងនោះឯង បានក្រាលគ្រឿងកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃណាមួយ ហើយ កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើអ្នកដទៃឱ្យរើយកមកទុកដាក់វិញ នូវគ្រឿងកម្រាលសម្រាប់ដេកនោះ ហើយឥតទាំងប្រាប់ (អ្នកដទៃ) ឡើយ ស្រាប់តែចៀសចេញទៅ។ ឯពួកសត្វកណ្តៀរក៏កោរកាត់គ្រឿងសេនាសនៈខូចអស់។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទំាងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា កោតតែភិក្ខុទាំង១៧រូបហ៊ានក្រាលគ្រឿងកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃ ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវគ្រឿងកម្រាលសម្រាប់ដេកនោះ ហើយឥតទាំងប្រាប់ (អ្នកដទៃ) ឡើយ ស្រាប់តែចៀសចេញទៅ ឯពួក សត្វកណ្តៀរក៏កោរកាត់គ្រឿងសេនាសនៈខូចអស់។ លំដាប់នោះ ភិក្ខុទាំងអម្បលនោះ ក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ (ដោយសព្វ

គ្រប់)។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរចំពោះ ភិក្ខុទាំងនោះថា នែភិក្ខុទាំងឡាយ ឮថាភិក្ខុមានពួក ១៧ រូបបាន ក្រាលកម្រាលសម្រាប់ដេកក្នុងវិហារជារបស់សង្ឃ ហើយកាលដែលដើរ ចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវកម្រាលសម្រាប់ដេលនោះ ឥតទាំងបាន ប្រាប់(អ្នកដទៃ)ឡើយ ស្រាប់តែ ដើរចេញទៅ គ្រឿងសេនាសនៈពួកសត្វកណ្តៀរវាក៏កោរកាត់ខូចអស់ ជា ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះ មិនសមបើនឹងក្រាលគ្រឿងកម្រាលសម្រាប់ដេកក្នុងវិហារជា របស់សង្ឃ ហើយកាលដែលដើរចេញទៅ ក៏មិនបានរើយមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់នូវគ្រឿងសេនាសនៈនោះ ហើយឥតទាំងប្រាប់ ( អ្នកដទៃ ) សោះឡើយ ស្រាប់តែដើរចេញទៅ គ្រឿង សេនាសនៈទាំងនោះ ពួកសត្វកណ្តៀរវាក៏កោរកាត់ខូចអស់ ម្នាលភិក្ខុទាំងឡាយ អំពើនេះនឹងបានដឹកនាំពួកមនុស្សដែលមិនទាន់ជ្រះថ្លា ឱ្យបានជ្រះថ្លាឡើងក៏ទេ។ បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយក្រាល ឬប្រើគេឱ្យក្រាលនូវកម្រាលសម្រាប់ដេកក្នុងវិហារជារបស់សង្ឃ ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវគ្រឿងសេនាសនៈនោះ ឬឥតបានប្រាប់(អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ។

[៣៨០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទខាងដើមហើយ។ វិហារដែលគេបានវេប្រគេន ឬគេបានលះបង់ដល់សង្ឃហើយ ហៅថាវិហាររបស់សង្ឃ។ ពូក គ្រឿងទ្រនាប់ កម្រាលគ្រែ ឬតាំង កម្រាលផែនដី កន្ទេលទន់ ច្រមខណ្ឌ (កំណាត់ស្បែក) និសីទនៈ (សំពត់សម្រាប់ទ្រាប់អង្គុយ) កម្រាលដែល គេធ្វើដោយស្មៅ កម្រាលដែលគេធ្វើដោយស្លឹក ហៅថាកម្រាលសម្រាប់ដេក។ ពាក្យថា ក្រាល គឺក្រាលដោយខ្លួនឯង។ ពាក្យថា ប្រើគេឱ្យក្រាល គឺប្រើអ្នកដទៃឱ្យក្រាល។ ពាក្យថា កាលនឹងដើរចេញទៅ មិនបានរើយកគ្រឿងកម្រាលនោះមកទុកដាក់ដោយខ្លួនឯង គឺមិន បានរើយមកទុកដាក់ដោយខ្លួនឯង។ ពាក្យថា មិនបានប្រើគេឱ្យរើយកមកទុកដាក់ គឺមិនបានប្រើអ្នកដទៃឱ្យរើយកមកទុកដាក់ឡើយ។ ពាក្យថា ឥតបានប្រាប់(អ្នកដទៃ) ហើយដើរចេញទៅ គឺមិនបានប្រាប់ភិក្ខុក្តី សាមណេរក្តី ញោមវត្តក្តី ហើយដើរទៅកន្លងរបងវត្ត ដែលគេបិទបាំង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុកាលបើដើរកន្លងឧបចារវត្តដែល គ្មានរបង ត្រូវអាបត្តិបាចិត្តិយ។

[៣៨១] វិហាររបស់សង្ឃ ភិក្ខុសំគាល់ថាជារបស់សង្ឃ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឱ្យក្រាលនូវកម្រាលសម្រាប់ដេក កាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវកម្រាលសម្រាប់ដេកនោះ ឬឥតប្រាប់(អ្នកដទៃ)ឡើយ ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវិហារជា របស់សង្ឃ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឱ្យក្រាលនូវកម្រាលសម្រាប់ដេក កាលដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវកម្រាលសម្រាប់ដេកនោះ ឬឥតបានប្រាប់(អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ វិហាររបស់ សង្ឃ ភិក្ខុសំគាល់ថាជារបស់បុគ្គលទៅវិញ ហើយក្រាលដោយខ្លួនឯង ឬប្រើគេឱ្យក្រាលនូវកម្រាលសម្រាប់ដេក ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនប្រាប់គេឱ្យរើយកមកទុកដាក់ នូវកម្រាល សម្រាប់ដេកនោះ ឬឥតមានប្រាប់(អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុក្រាលដោយខ្លួនឯង ឬប្រើគេឱ្យក្រាលនូវកម្រាលសម្រាប់ដេក ក្នុងឧបចារវិហារក្តី ក្នុងរោងសម្រាប់ឆាន់ក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ហើយកាលនឹងដើរចេញទៅ មិនបានរើយមកទុកដាក់ មិនបានប្រាប់គេឱ្យរើយមកទុកដាក់នូវកម្រាលសម្រាប់ដេកនោះ ឬឥតបានប្រាប់(អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិទុក្កដ។ ភិក្ខុក្រាលដោយខ្លួនឯងក្តី ប្រើគេឱ្យក្រាលក្តី នូវគ្រែ ឬតាំងក្នុងវិហារក្តី ក្នុងឧបចារវិហារក្តី ក្នុងរោងសម្រាប់ឆាន់ក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ហើយកាលនឹងដើរចេញទៅ មិនបានរើយកមកទុកដាក់ មិនបានប្រើគេឱ្យរើយកមកទុកដាក់ នូវគ្រែនឹងតាំងនោះ ឬឥតបានប្រាប់ (អ្នកដទៃ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថាជារបស់សង្ឃទៅវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងវិហារ ជារបស់បុគ្គល ត្រូវអាបត្តិទុក្កដ។ វិហារជារបស់បុគ្គល ភិក្ខុដឹងច្បាស់ថា ជារបស់បុគ្គល គឺវិហារដែលជារបស់បុគ្គលនៃភិក្ខុដទៃ (ដែលមិនមែនជា វិស្សាសៈ) ត្រូវអាបត្តិទុក្កដ។ វិហារជារបស់បុគ្គល(ដែលជាទីស្និទ្ធស្នាល នឹងខ្លួន មិនត្រូវអាបត្តិឡើយ។

[៣៩២] អាបត្តិមិនមានដល់ភិក្ខុដែលបានរើកម្រាលយកមកទុកដាក់ដោយខ្លួនឯង រួចហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រើគេឱ្យរើយកមកទុកដាក់ ហើយដើរចេញទៅ ដល់ភិក្ខុដែលបានប្រាប់(អ្នកដទៃ)រួចហើយដើរចេញទៅ ដល់ភិក្ខុមានកម្រាលដែលមានបុគ្គលណាមួយចូលទៅបៀតបៀន[79] ដល់ភិក្ខុដែលមានសេចក្តីអាឡោះអាល័យ[80] បានដើរចេញទៅឈរក្នុងទីនោះប្រាប់ (បុគ្គលណាម្នាក់) ថា ភិក្ខុនោះមានសេចក្តីអន្តរាយនីមួយបៀតបៀនហើយ ដល់ភិក្ខុមានសេចក្តីអន្តរាយ[81] កើតឡើង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី៥ ចប់។

ចប់ ភាគ៣។

# មាតិកា


| | លេខ ទំព័រ |
|---|---|
| **និស្សគ្គិយកណ្ឌ** | ១ |
| **ចីវរវគ្គ** | ១ |
| *សិក្ខាបទ ទី ១* | ១ |
| និទានឆព្វគ្គិយភិក្ខុ | ១ |
| សេចក្តីបញ្ញត្តិជាដម្បូង | ៣ |
| | |

| | |
|---|---|
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ៤ |
| បទភាជនីយ និងវារៈដែលត្រូវអាបត្តិ | ៧ |
| វារៈដែលមិនត្រូវអាបត្តិ | ៨ |
| **សិក្ខាបទ ទី ២** | ១០ |
| និទានភិក្ខុច្រើនរូប | ១០ |
| សេចក្ដីបញ្ញត្តិជាដម្បូង | ១១ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ១៤ |
| បទភាជនីយ | ១៥ |
| វារៈដែលមិនត្រូវអាបត្តិ | ២៣ |
| **សិក្ខាបទ ទី ៣** | ២៤ |
| និទានភិក្ខុ ១ រូប | ២៤ |
| សេចក្ដីបញ្ញត្តិជាដម្បូង | ២៦ |
| សិក្ខាបទវិភង្គ | ២៧ |
| វារៈដែលត្រូវអាបត្តិ | ៣១ |
| វារៈដែលមិនត្រូវអាបត្តិ | ៣២ |
| **សិក្ខាបទ ទី ៤** | ៣៣ |
| និទានស្រីបុរាណទុតិយិកា របស់ឧទាយិភិក្ខុ | ៣៣ |
| សេចក្ដីបញ្ញត្តិ | ៣៥ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ៣៦ |
| វារៈដែលត្រូវអាបត្តិ | ៣៧ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៩ |
| **សិក្ខាបទ ទី ៥** | ៤០ |
| និទាននាងឧប្បលវណ្ណាភិក្ខុនី | ៤០ |
| សេចក្ដីបញ្ញត្តិជាដម្បូង | ៤៤ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ៤៥ |
| វារៈដែលមិនត្រូវអាបត្តិ | ៤៧ |
| **សិក្ខាបទ ទី ៦** | ៤៨ |
| និទានឧបនន្ទសក្យបុត្ត | ៤៨ |
| សេចក្ដីបញ្ញត្តិជាដម្បូង | ៥២ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ៥៤ |
| វារៈដែលមិនត្រូវអាបត្តិ | ៥៦ |
| **សិក្ខាបទ ទី ៧** | ៥៧ |
| និទានឆព្វគ្គិយភិក្ខុ | ៥៧ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៥៩ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៦១ |
| **សិក្ខាបទ ទី ៨** | ៦២ |
| និទានឧបនន្ទសក្យបុត្ត | ៦២ |

| | |
|---|---|
| សេចក្តីបញ្ញត្តិ | ៦៤ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ៦៥ |
| វារៈដែលមិនត្រូវអាបត្តិ | ៦៧ |
| **សិក្ខាបទ ទី ៩** | ៦៨ |
| និទានឧបនន្ទសក្យបុត្ត | ៦៨ |
| សេចក្តីបញ្ញត្តិ | ៧០ |
| សិក្ខាបទវិភង្គ | ៧១ |
| វារៈដែលត្រូវអាបត្តិ | ៧៣ |
| វារៈដែលមិនត្រូវអាបត្តិ | ៧៤ |
| **សិក្ខាបទ ទី ១០** | ៧៥ |
| និទានឧបនន្ទសក្យបុត្ត | ៧៥ |
| សេចក្តីបញ្ញត្តិ | ៧៩ |
| សិក្ខាបទវិភង្គ | ៨១ |
| វារៈដែលមិនត្រូវអាបត្តិ | ៨៥ |
| ឧទ្ទាននៃចីវរវគ្គ | ៨៦ |
| **កោសិយវគ្គ** | **៨៧** |
| **សិក្ខាបទ ទី ១** | ៨៧ |
| និទានឆព្វគ្គិយភិក្ខុ | ៨៧ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៨៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៩០ |
| **សិក្ខាបទ ទី ២** | ៩១ |
| និទានឆព្វគ្គិយភិក្ខុ | ៩១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៩២ |
| វារៈដែលមិនត្រូវអាបត្តិ | ៩៣ |
| **សិក្ខាបទ ទី ៣** | ៩៤ |
| និទានឆព្វគ្គិយភិក្ខុ | ៩៤ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៩៥ |
| វារៈដែលមិនត្រូវអាបត្តិ | ៩៧ |
| **សិក្ខាបទ ទី ៤** | ៩៨ |
| និទានភិក្ខុច្រើនរូប | ៩៨ |
| សេចក្តីបញ្ញត្តិជាដម្បូង | ១០០ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ១០២ |
| វារៈដែលមិនត្រូវអាបត្តិ | ១០៤ |
| **សិក្ខាបទ ទី ៥** | ១០៥ |
| និទានឧបសេនវង្គន្តបុត្តភិក្ខុ | ១០៥ |
| ប្រយោជន៍ ១០ យ៉ាង នៃការបញ្ញត្តិព្រះវិន័យ | ១១១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១១២ |

| | |
|---|---|
| វារៈដែលត្រូវអាបត្តិ | ១១៣ |
| វារៈដែលមិនត្រូវអាបត្តិ | ១១៤ |
| **សិក្ខាបទ ទី ៦** | ១១៥ |
| និទានភិក្ខុ ១ រូប | ១១៥ |
| សេចក្ដីបញ្ញត្តិ | ១១៦ |
| សិក្ខាបទវិភង្គ | ១១៧ |
| បទភាជនីយ | ១១៨ |
| វារៈដែលមិនត្រូវអាបត្តិ | ១១៩ |
| **សិក្ខាបទ ទី ៧** | ១២០ |
| និទានឆព្វគ្គិយភិក្ខុ | ១២០ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១២២ |
| បទភាជនីយ | ១២៣ |
| វារៈដែលមិនត្រូវអាបត្តិ | ១២៥ |
| **សិក្ខាបទ ទី ៨** | ១២៦ |
| និទានឧបនន្ទសក្យបុត្ត | ១២៦ |
| សេចក្ដីបញ្ញត្តិ | ១២៨ |
| សិក្ខាបទវិភង្គ | ១២៩ |
| បទភាជនីយ | ១៣១ |
| វារៈដែលមិនត្រូវអាបត្តិ | ១៣២ |
| **សិក្ខាបទ ទី ៩** | ១៣៣ |
| និទានឆព្វគ្គិយភិក្ខុ | ១៣៣ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៣៤ |
| បទភាជនីយ | ១៣៥ |
| វារៈដែលមិនត្រូវអាបត្តិ | ១៣៨ |
| **សិក្ខាបទ ទី ១០** | ១៣៩ |
| និទានឧបនន្ទសក្យបុត្ត | ១៣៩ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៤១ |
| បទភាជនីយ | ១៤២ |
| វារៈដែលមិនត្រូវអាបត្តិ | ១៤៣ |
| ឧទ្ទាននៃកោសិយវគ្គ | ១៤៤ |
| **បត្តវគ្គ** | **១៤៥** |
| **សិក្ខាបទ ទី ១** | ១៤៥ |
| និទានឆព្វគ្គិយភិក្ខុ | ១៤៥ |
| សេចក្ដីបញ្ញត្តិជាដម្បូង | ១៤៦ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ១៤៧ |
| បទភាជនីយ | ១៤៨ |
| វារៈដែលមិនត្រូវអាបត្តិ | ១៥១ |

| | |
|---|---|
| **សិក្ខាបទ ទី ២** | ១៥៣ |
| និទានភិក្ខុច្រើនរូប | ១៥៣ |
| សេចក្តីបញ្ញត្តិ | ១៥៧ |
| សិក្ខាបទវិភង្គ | ១៥៨ |
| ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់បាត្រ | ១៥៩ |
| បទភាជនីយ | ១៦១ |
| វារៈដែលមិនត្រូវអាបត្តិ | ១៦៦ |
| **សិក្ខាបទ ទី ៣** | ១៦៧ |
| និទានបិលិន្ទវច្ឆត្ថេរ | ១៦៧ |
| សេចក្តីបញ្ញត្តិ | ១៧៥ |
| សិក្ខាបទវិភង្គ | ១៧៦ |
| វារៈដែលត្រូវអាបត្តិ | ១៧៧ |
| វារៈដែលមិនត្រូវអាបត្តិ | ១៧៨ |
| **សិក្ខាបទ ទី ៤** | ១៧៩ |
| និទានឆព្វគ្គិយភិក្ខុ | ១៧៩ |
| សេចក្តីបញ្ញត្តិ | ១៨០ |
| សិក្ខាបទវិភង្គ | ១៨១ |
| បទភាជនីយ | ១៨២ |
| វារៈដែលមិនត្រូវអាបត្តិ | ១៨៣ |
| **សិក្ខាបទ ទី ៥** | ១៨៥ |
| និទានឧបនន្ទសក្យបុត្ត | ១៨៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៨៧ |
| បទភាជនីយ | ១៨៨ |
| វារៈដែលមិនត្រូវអាបត្តិ | ១៨៩ |
| **សិក្ខាបទ ទី ៦** | ១៩០ |
| និទានឆព្វគ្គិយភិក្ខុ | ១៩០ |
| សេចក្តីបញ្ញត្តិ | ១៩១ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ១៩២ |
| វារៈដែលមិនត្រូវអាបត្តិ | ១៩៣ |
| **សិក្ខាបទ ទី ៧** | ១៩៤ |
| និទានឧបនន្ទសក្យបុត្ត | ១៩៤ |
| សេចក្តីបញ្ញត្តិ | ១៩៨ |
| សិក្ខាបទវិភង្គ | ១៩៩ |
| បទភាជនីយ | ២០១ |
| វារៈដែលមិនត្រូវអាបត្តិ | ២០២ |
| **សិក្ខាបទ ទី ៨** | ២០៣ |

| | |
|---|---|
| និទានមហា អមាត្យម្នាក់ | ២០៣ |
| សេចក្តីបញ្ញត្តិ | ២០៥ |
| សិក្ខាបទវិភង្គ | ២០៦ |
| បទភាជនីយ | ២០៧ |
| វារៈដែលមិនត្រូវអាបត្តិ | ២០៨ |
| **សិក្ខាបទ ទី ៩** | ២០៩ |
| និទានភិក្ខុច្រើនរូប | ២០៩ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២១១ |
| បទភាជនីយ | ២១៣ |
| វារៈដែលមិនត្រូវអាបត្តិ | ២១៤ |
| **សិក្ខាបទ ទី ១០** | ២១៥ |
| និទានឆព្វគ្គិយភិក្ខុ | ២១៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២១៧ |
| វារៈដែលមិនត្រូវអាបត្តិ | ២១៩ |
| ឧទ្ទាននៃបត្តវគ្គ | ២២០ |
| **បាចិត្តិយកណ្ឌ** | **២២១** |
| **មុសាវាទវគ្គ** | **២២១** |
| **សិក្ខាបទ ទី ១** | ២២១ |
| និទានហត្ថកភិក្ខុសក្យបុត្ត | ២២១ |
| សេចក្តីបញ្ញត្តិ | ២២៣ |
| សិក្ខាបទវិភង្គ | ២២៤ |
| បទភាជនីយ | ២២៥ |
| វារៈដែលមិនត្រូវអាបត្តិ | ២៣៥ |
| **សិក្ខាបទ ទី ២** | ២៣៦ |
| និទានឆព្វគ្គិយភិក្ខុ | ២៣៦ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៤០ |
| បទភាជនីយ | ២៤០ |
| វារៈដែលមិនត្រូវអាបត្តិ | ២៧១ |
| **សិក្ខាបទ ទី ៣** | ២៧២ |
| និទានឆព្វគ្គិយភិក្ខុ | ២៧២ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៧៤ |
| បទភាជនីយ | ២៧៥ |
| វារៈដែលមិនត្រូវអាបត្តិ | ២៨៤ |
| **សិក្ខាបទ ទី ៤** | ២៨៥ |
| និទានឆព្វគ្គិយភិក្ខុ | ២៨៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៨៦ |
| បទភាជនីយ | ២៨៧ |

| | |
|---|---|
| វារៈដែលមិនត្រូវអាបត្តិ | ២៨៨ |
| **សិក្ខាបទ ទី ៥** | ២៨៩ |
| និទាននវកភិក្ខុច្រើនរូប | ២៨៩ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៩២ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២៩៣ |
| **សិក្ខាបទ ទី ៦** | ២៩៥ |
| និទានព្រះអនុរុទ្ធត្ថេរ | ២៩៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣០០ |
| បទភាជនីយ | ៣០១ |
| វារៈដែលមិនត្រូវអាបត្តិ | ៣០២ |
| **សិក្ខាបទ ទី ៧** | ៣០៣ |
| និទានឧទាយិភិក្ខុ | ៣០៣ |
| សេចក្តីបញ្ញត្តិជាដម្បូង | ៣០៥ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ | ៣០៦ |
| សិក្ខាបទវិភង្គ | ៣០៨ |
| បទភាជនីយ | ៣០៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៣១០ |
| **សិក្ខាបទ ទី ៨** | ៣១១ |
| និទានភិក្ខុច្រើនរូប | ៣១១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣១៧ |
| បទភាជនីយ | ៣១៨ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៣៥ |
| **សិក្ខាបទ ទី ៩** | ៣៣៦ |
| និទានឧបនន្ទសក្យបុត្ត | ៣៣៦ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៣៨ |
| បទភាជនីយ | ៣៣៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៤១ |
| **សិក្ខាបទ ទី ១០** | ៣៤២ |
| និទានអាឡវិកភិក្ខុទាំងឡាយ | ៣៤២ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៤៣ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៣៤៥ |
| ឧទ្ទាននៃមុសាវាទវគ្គ | ៣៤៦ |
| **ភូតគាមវគ្គ** | **៣៤៧** |
| **សិក្ខាបទ ទី ១** | ៣៤៧ |
| និទានអាឡវិកភិក្ខុទាំងឡាយ | ៣៤៧ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៤៩ |
| បទភាជនីយ | ៣៥១ |

| | |
|---|---|
| វារៈដែលមិនត្រូវអាបត្តិ | ៣៥២ |
| **សិក្ខាបទ ទី ២** | ៣៥៣ |
| និទានឆន្នភិក្ខុ | ៣៥៣ |
| សេចក្តីបញ្ញត្តិជាដម្បូង | ៣៥៥ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ៣៥៨ |
| បទភាជនីយ | ៣៥៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៦១ |
| **សិក្ខាបទ ទី ៣** | ៣៦២ |
| និទានទព្វមល្លបុត្តភិក្ខុ | ៣៦២ |
| សេចក្តីបញ្ញត្តិជាដម្បូង | ៣៦៣ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ | ៣៦៤ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ៣៦៥ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៦៧ |
| **សិក្ខាបទ ទី ៤** | ៣៦៨ |
| និទានភិក្ខុច្រើនរូប | ៣៦៨ |
| សេចក្តីបញ្ញត្តិ | ៣៦៩ |
| សិក្ខាបទវិភង្គ | ៣៧០ |
| បទភាជនីយ | ៣៧២ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៧៤ |
| **សិក្ខាបទ ទី ៥** | ៣៧៥ |
| និទានសត្តរសវគ្គិយភិក្ខុ | ៣៧៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៧៧ |
| បទភាជនីយ | ៣៧៨ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៨១ |


1)

គឺ អតិរេកចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវអាបត្តិបាចិត្តិយ។

2)

ត្រង់នេះត្រូវដាក់ឈ្មោះ បញ្ចូលមក គឺបើភិក្ខុនោះឈ្មោះអ្វី ត្រូវចេញឈ្មោះនោះ ដូចឈ្មោះថា ពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ជាដើម។

3)

ត្រង់នេះត្រូវដាក់ឈ្មោះ បញ្ចូលមក គឺបើភិក្ខុនោះឈ្មោះអ្វី ត្រូវចេញឈ្មោះនោះ ដូច ឈ្មោះថា ពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ជាដើម។

4)

អដ្ឋកថា ពន្យល់សេចក្តីថា ២៨ហត្ថ ហៅថាមួយអព្ភន្តរ (ចម្ងាយ៧អព្ភន្តរត្រូវជា១៩៦ហត្ថ)។

5)

គឺចីវរកើតឡើងក្នុងឱកាស១១ខែ គឺតាំងពីត្រឹមថ្ងៃ ១រោច ខែកត្តិក ទៅដល់ថ្ងៃ ១៥កើត ខែអស្សុជ នេះជាអកាលចីវររបស់ភិក្ខុដែលឥតបានក្រាលកឋិន។ ឯភិក្ខុដែលបានក្រាលកឋិន អកាលចីវរមានកំណត់ ៧ខែ គឺតាំងពីត្រឹមថ្ងៃ ១រោច ខែផគ្គុណ ទៅដល់ថ្ងៃ ១៥កើត ខែអស្សុជ។

6)

ចីវរដើម

7)

ចីវរដែលកើតឡើងដោយសេចក្តីចង់បានជាខាងក្រោយ។

8)

មូលចីវរ ឬបច្ចាសាចីវរដែលមានសាច់ក្រាស់ស្តើងមិនស្មើគ្នា ភិក្ខុមិនអាចនឹងដេរជាមួយគ្នាបាន ហៅថា មានចំណែកមិនស្មើគ្នា។

9)

អ្នកទទួលធ្វើការខ្វល់ខ្វាយបម្រើ។

10)

ពាក្យរួបរួម ជាគ្រឿងរក្សាសេចក្តីដែលពោលហើយមិនឱ្យសេចក្តីនោះវិនាសខ្ចាត់ខ្ចាយទៅ (បានដល់បញ្ជីរឿង)។

11)

ត្រង់ពាក្យថា និស្សគ្គិយំ បាចិត្តិយំ ប្រែបានជាពីរន័យ គឺប្រែដូចសិក្ខាបទទាំងអស់ ក្នុងចីវរវគ្គមួយន័យ ដូចសិក្ខាបទក្នុងកោសិយវគ្គនេះមួយន័យ តាមន័យក្នុងអដ្ឋកថា។

12)

អដ្ឋកថា ពន្យល់ថា អង្គុយម្តងដេកម្តង។

13)

ភិក្ខុនាំរោមចៀមទៅនៅក្នុងទីណាៗ មានចម្ងាយបីៗយោជន៍ ហើយមិនបានប្រកបដោយកិច្ច មានឧទ្ទេស និងបរិបុច្ឆាជាដើម ឬដោយសក្ការមានបច្ច័យជាដើមក្នុងទីនោះ ហើយនឹងនាំរោមចៀមចេញ អំពីទីនោះ ទៅកាន់ទីដទៃៗ កំណត់ត្រឹមតែបីៗយោជន៍ក៏បាន ដរាបដល់រយយោជន៍ក៏បាន។

14)

បានដល់សង្ឃពីរចំណែក គឺភិក្ខុសង្ឃមួយចំណែក ភិក្ខុនីសង្ឃមួយចំណែក។

15)

រូបិយ បានដល់ មាសប្រាក់។

16)

បានដល់ដុំកំទេច ដែលគេប្រើសម្រាប់ដុសខ្លួនវេលាងូតទឹក ដើម្បីឱ្យជ្រះក្អែល ឬជារោគជាដើម។

17)

បានដល់គ្រឿងប្រើប្រាស់ទាំងអស់។

18)

បាត្រដែលលើស គឺបាត្រដែលមិនបានវិកប្ប មិនបានអធិដ្ឋាន។

19)

ស្តេចជាធំលើសេនាទាហ៊ាន គង់សំដៅសេចក្តីថា ព្រះបាទពិម្ពិសារទ្រង់ជាមហាក្សត្រិយ៍សឹក បានជាមានគុណសព្ទមេទ័ពនាំមុខថា សេនិយោ មាគធោ រាជា។

20)

គឺសម្រេចដោយឫទ្ធិដែលព្រះថេរៈអធិស្ឋាន។

21)

ទឹកដោះរាវរបស់គោ កេះ ពពែជាដើម ហៅថា សប្បិ។

22)

យកទៅលាយនឹងវត្ថុទាំងឡាយមានធ្យូងជាដើម សម្រាប់លាប មានលាបជញ្ជាំងជាដើម។

23)

គឺរវាង ៧ថ្ងៃ ភិក្ខុផ្ទេរភេសជ្ជៈនោះឱ្យទៅជារបស់ដទៃក្រៅពីរបស់ឆាន់ គឺធ្វើជាថ្នាំលាបក្បាល លាបដំបៅ លាបភ្នែកជាដើម។

24)

តាំងតែ១ រោចខែជេស្ឋ ទៅដល់ថ្ងៃពេញបូណ៌មីខែអាសាឍ្ហ ហៅថា ខែមួយជាខាងចុងគិម្ហរដូវ។ តាំងតែ១កើតខែអាសាឍ្ហទៅដល់ថ្ងៃពេញបូណ៌មី ហៅថាកន្លះខែជាខាងចុងគិម្ហរដូវ។

25)

ពាក្យថា ចីវរក្នុងទីនេះសំដៅយកវស្សិកសាដិកចីវរ បើចោរដណ្តើមយកសម្ពត់របស់ភិក្ខុនោះទៅ ហើយភិក្ខុនោះងូតទឹកភ្លៀងដោយខ្លួនទទេ មិនត្រូវអាបត្តិទុក្កដ ព្រោះស្រាតនឹងងូតទឹកភ្លៀង។

26)

បើភិក្ខុមានចីវរដទៃៗ ក្រៅពីវស្សិកសាដិកចីវរដែលបាត់ទៅនោះ នឹងស្លៀកក្តី នឹងស្វែងរកក្តី នូវសម្ពត់វស្សិកសាដិក ក្នុងសម័យក្រៅពីពុទ្ធានុញ្ញាត មិនត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ បើភិក្ខុមានវស្សិកសាដិកចីវរបាត់វិញ ហើយស្រាតងូតទឹក មិនត្រូវអាបត្តិទុក្កដឡើយ។

27)

បើភិក្ខុស្លៀកសម្ពត់វស្សិកសាដិកមានដម្លៃច្រើនងូតទឹក ហើយមានចោរមកដណ្តើមយកទៅ ភិក្ខុស្រាតងូតទឹក មិនត្រូវអាបត្តិទុក្កដទេ។ ម្យ៉ាងទៀត ពួកចោរលួចយកសម្ពត់ដទៃ ក្រៅអំពីវស្សិកសាដិកចីវរដែលភិក្ខុមិនទាន់បានស្លៀកហើយ បើភិក្ខុស្លៀកសម្ពត់វស្សិកសាដិកក្នុងសម័យក្រៅពីពុទ្ធានុញ្ញាត មិនត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយទេ។

28)

អ្នកដែលបានឧបសម្បទាជាភិក្ខុភាវៈដោយត្រឹមត្រូវហើយ ហៅថា ឧបសម្បន្ន។

29)
បានដល់បុគ្គលក្រៅពីភិក្ខុ មានសាមណេរជាដើម។
30)
ថ្ងៃពេញបូណ៌មីខែបឋមកត្តិក គឺថ្ងៃ ១៥ កើតខែអស្សុជ។
31)
គិតពីត្រឹមថ្ងៃ ៥ កើត ទៅដល់ថ្ងៃ ១៥ កើតខែអស្សុជ។ បើភិក្ខុមិនបានក្រាលកឋិនទេ ត្រូវទុកអច្ចេកចីវរបានត្រឹម១ខែ ១១ថ្ងៃ បើបានក្រាលកឋិន ត្រូវទុកបាន៥ខែ ១១ថ្ងៃ ទុកឱ្យហួសអំពីកំណត់នោះទៅ សូម្បីត្រឹមតែ១ថ្ងៃក៏ពុំបានឡើយ (អដ្ឋកថា)។
32)
បើភិក្ខុមិនបានក្រាលកឋិនទេ ចីវរកាលមានតែ១ខែ គឺរាប់តាំងពីថ្ងៃ ១ រោចខែអស្សុជ ទៅដល់ថ្ងៃ១៥កើត ខែកត្តិក បើបានក្រាលកឋិន ចីវរកាលមាន៥ខែ គឺរាប់តាំងពីថ្ងៃ១រោច ខែអស្សុជ ទៅដល់ថ្ងៃ១៥កើតខែផល្គុន នេះហៅថា ចីវរកាលសម័យ។
33)
អដ្ឋកថា ប្រាប់ថា ពួកចោរដែលធ្វើចោរកម្មក្នុងខែកត្តិក។
34)
តាមអដ្ឋកថា ហៅថា បច្ឆិមកត្តិក។
35)
១ គឺពាក្យណាដែលខ្លួននិយាយទៅហើយមានទោស ជាពាក្យខុសមិនល្អ ក៏បដិសេធ ពាក្យនោះថាមិនមែនជាពាក្យរបស់ខ្លួន ហៅថា គេចកែសំដី។
36)
២ គឺពាក្យណាដែលខ្លួននិយាយទៅ ហើយជាពាក្យល្អត្រឹមត្រូវ ក៏ប្តេជ្ញាថាជាពាក្យរបស់ខ្លួន នេះហៅថា ទទួលដឹង។អដ្ឋកថា។
37)
១ គឺលាក់បំបិទបំបាំងសេចក្តីឃើញខុសរបស់ខ្លួន។
38)
ជាតិថោកទាប។
39)
ជាតិខ្ពង់ខ្ពស់។
40)
ជាតិមនុស្សច្រលោងខាម។
41)
អាចារ្យខ្លះពោលថាជាងចាំង។
42)
ជាតិព្រានម្រឹគជាដើម។
43)
១-២-៣-៤-៥ នាមទាំង៥នេះ តាមអដ្ឋកថា ថាជាឈ្មោះពួកមនុស្សដែលជាខ្ញុំបម្រើគេ។
44)
១ ឬសិល្បសាស្រ្តអ្នកធ្វើរថ។
45)
សត្វកើតក្នុងស្ថានគ្មានសេចក្តីចំរើន។
46)
២-៣ យ អក្ខរ និង ភ អក្ខរនោះ ជាឈ្មោះមេថុនធម្ម។
47)
អ្នកចេះដឹងធម្មវិន័យច្រើន។
48)
អ្នកសំដែងធម៌។
49)
ធ្វើមិនឱ្យមានអំណាចតេជៈ។
50)
បានដល់សិក្ខមានា សាមណេរ សាមណេរី និងគ្រហស្ថ។
51)
ភិក្ខុពណ៌នានូវសេចក្តីអធិប្បាយរបស់បាលី។

52)

ភិក្ខុបង្រៀនបាលី។

53)

ភិក្ខុអាស្រ័យ ពាក្យប្រៀនប្រដៅ ហើយនិយាយដោយន័យជាដើមថា អ្នកឯងជាចណ្ឌាល អ្នកឯងកុំធ្វើបាប អ្នកឯងបានជាងធីតហើយ កុំឱ្យងធីតទៅទៀតឡើយ។

54)

ត្រង់យ អក្ខរ និង ភអក្ខរ ជាឈ្មោះមេចុនធម្ម។

55)

ពាក្យទាំងនេះជាឈ្មោះរបស់មនុស្សដែលជាខ្ញុំបម្រើគេ។

56)

អក្សរមួយៗ ហៅថា អន្វក្ខរៈ ប្រជុំនៃអក្ខរៈមួយសព្ទៗ ហៅថា អនុព្យញ្ជនៈ ប្រជុំនៃអក្ខរៈ នឹងអនុព្យញ្ជនៈហោថា បទ បទទី ១ ហោថា បទ បទទី ២ ហៅថា អនុបទ។

57)

ភិក្ខុប្រាប់ថា រូបំ អនិច្ចំ សាមណេរចាប់សូត្រថា វេទនា អនិច្ចា បទខាងដើមគឺ រូបំ និងវេទនានោះថាផ្សេងគ្នា ដល់បទខាងចុងគឺ អនិច្ចំនិងអនិច្ចានោះថាត្រូវស្មើគ្នា គឺស្មើត្រង់ថា អនិច្ច អនិច្ចនោះឯង។

58)

ក្នុងអដ្ឋកថា ថា ១ ភិក្ខុរៀនបាលីជាមួយនឹងអនុបសម្បន្ន ថាព្រមគ្នា មិនត្រូវអាបត្តិឡើយ។ ល។

59)

ភិក្ខុស្វាធ្យាយជាមួយនឹងអនុបសម្បន្ន សូត្រព្រមគ្នាជាមួយនឹងអនុបសម្បន្ននោះ មិនត្រូវអាបត្តិឡើយ។ល។

60)

បើក្នុងគាថាមួយ (បួនបាទ) អនុបសម្បន្នបានចេះ ស្ទាត់បីបាទហើយ នៅមិនទាន់ស្ទាត់តែមួយបាទ អនុបសម្បន្នចេះ ហៅថា មានគន្លស្ទាត់ហើយ ដោយច្រើន។ ល។

61)

កាលបើអនុបសម្បន្នកំពុងសូត្រនូវសុត្ត រអាក់រអួលក្នុងកណ្តាល បរិសទ្យ ភិក្ខុបង្គាប់ថា អ្នកឯងចូរសូត្រយ៉ាងនេះទៅ (បង្គាប់យ៉ាងនេះហើយ) ទុកជាថាព្រមគ្នា ជាមួយនឹងអនុបសម្បន្ននោះទៅ ក៏មិនត្រូវអាបត្តិឡើយ។

62)

១ ភោជនមាន ៥យ៉ាង គឺបាយ ១ នំ ១ សត្តុ ១ ត្រី ១ សាច់ ១។

63)

ខាទនីយ បានខាងឯមើមឈើ ផ្លែឈើជាដើម។

64)

បានខាងឯគ្រឿងសម្រាប់បរិភោគ គឺទឹកដោះរាវ ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ១ ទឹកអំពៅ ១។

65)

ទឹកបាននោះ បានខាងទឹកបាន ៨ យ៉ាង មានទឹកបានធ្វើពីផ្លែស្វាយ ផ្លែព្រីងជាដើម។

66)

១ ពួកឧត្តរិមនុស្សធម្មនេះ បានអធិប្បាយក្នុងបារាជិកទី ៤ រួចហើយ។

67)

សាមណេរប្រព្រឹត្តខុសក្នុងសិក្ខាបទ៥ខាងដើម ឈ្មោះថាអជ្ឈាចារអាក្រក់

68)

សាមណេរប្រព្រឹត្តខុសក្នុងសិក្ខាបទ៥ ខាងចុង ឈ្មោះថាអជ្ឈាចារមិនសូវអាក្រក់។

69)

ភិក្ខុប្រាប់ថា ភិក្ខុនេះត្រូវសុក្កវិសដ្ឋិ (គឺធ្វើសុក្កឱ្យឃ្លាតចេញ) ជាដើម ហៅថា ប្រាប់តែវត្ថុ។

70)

ភិក្ខុប្រាប់ថា ភិក្ខុនេះត្រូវអាបត្តិបារាជិក ត្រូវអាបត្តិសង្ឃាទិសេសជាដើម ហៅថា ប្រាប់តែអាបត្តិ។

71)

អដ្ឋកថា សំដៅយកស្មៅ និងដើមឈើស្រស់ ដែលមានពូជដុសទៅទៀតបានជាដើម។

72)

អំពើដែលសង្ឃត្រូវធ្វើដល់ភិក្ខុអ្នកពោលពាក្យដទៃ គឺពោលពាក្យបន្លែបន្លប់។

73)

អំពើដែលសង្ឃត្រូវធ្វើដល់ភិក្ខុអ្នកនាំសង្ឃ ឱ្យបានសេចក្តីលំបាក។

74)

១-២ គ្រែដែលមានជើងដូចជាជើងសេះ ជើងពពែជាដើម ឯតាំងក៏មានជើងដូចជាគ្រែដែរ។
75) , 80)
២
76)
ចម្ងាយមួយបោះដុំដី ដែលមជ្ឈិមបុរសបោះចោលទៅ។
77)
បើមានភិក្ខុចាស់បង្គាប់ភិក្ខុនោះឱ្យក្រោកចេញចាកទីសេនាសនៈ ហើយកាន់យកដោយខ្លួនលោកក្ដី ឬមានយក្សក្ដី ប្រេតក្ដី វាមកអង្គុយនៅលើសេនាសនៈនោះ ឬមានជនជាធំណាមួយមកដល់ ហើយកាន់យកគ្រឿងសេនាសនៈនោះ គ្រឿងសេនាសនៈនោះ ឈ្មោះថាមានបុគ្គលណាមួយមកបៀតបៀន។ ម្យ៉ាងទៀត កាលបើមានពួកសត្វ មានរាជសីហ៍និងខ្លាជាដើម វាមកក្នុងប្រទេសហើយ ឈរនៅជិតគ្រឿងសេនាសនៈនោះ គ្រឿងសេនាសនៈនោះឈ្មោះថាមានបុគ្គលណាមួយមកបៀតបៀនដូចគ្នាដែរ។ តែមានបុគ្គលណាមួយមកបៀតបៀនយ៉ាងនេះហើយ ទុកជាភិក្ខុមិនបានរើយកគ្រឿងសេនាសនៈមកទុកដាក់ ក៏មិនត្រូវអាបត្តិឡើយ។
78)
គឺអន្តរាយជីវិត ឬអន្តរាយព្រហ្មចរិយធម៌។
79)
១-២ បានអធិប្បាយក្នុងសិក្ខាបទទី ៤ ខាងដើមរួចជាស្រេច។
81)
តាមន័យក្នុងអដ្ឋកថា ថាភិក្ខុកាលចេញដើរទៅ គិតថាអាត្មាអញនឹងត្រឡប់មករៀបចំទុកដាក់កម្រាលវិញក្នុងថ្ងៃនេះ លុះទៅដល់ទីដែលខ្លួនប្រាថ្នានឹងទៅនៅនោះ ក៏មានសេចក្ដីអន្តរាយកើតឡើង មិនអាចនឹងត្រឡប់មកវិញបាន។

sangham.net Virtual AccessToInsight

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០០៤ - Book 004

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថា លោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០៤ - Tipitaka Book 004 [http://forum.sangham.net/index.php/topic,8913.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០០៤




គំរូ ឯកសារ ផ្សេងទៀត ៖
book_004.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី៤

ទ. ១

# វិន័យបិដក

CS vin | ភាគ ទី៤

# មហាវិភង្គ

CS vin.vbu | ភាគ ទី៤

**ចតុត្ថភាគ**

**ភាគ ទី៤**

**បាចិត្តិយកណ្ឌ**
បាចិត្តិយ (សិក្ខាបទ ទី១-១៥ មើល ភាគ ទី៣)
ភូតគាមវគ្គ៖ សិក្ខាបទ ទី ១៦ | ១៧ | ១៨ | ១៩ | ២០
ឱវាទវគ្គ៖ សិក្ខាបទ ទី ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០
ភោជនវគ្គ៖ សិក្ខាបទ ទី ៣១ | ៣២ | ៣៣ | ៣៤ | ៣៥ | ៣៦ | ៣៧ | ៣៨ | ៣៩ | ៤០
អចេលកវគ្គ៖ សិក្ខាបទ ទី ៤១ | ៤២ | ៤៣ | ៤៤ | ៤៥ | ៤៦ | ៤៧ | ៤៨ | ៤៩ | ៥០
សុរាបានវគ្គ៖ សិក្ខាបទ ទី ៥១ | ៥២ | ៥៣ | ៥៤ | ៥៥ | ៥៦ | ៥៧ | ៥៨ | ៥៩ | ៦០
សប្បាណកវគ្គ៖ សិក្ខាបទ ទី ៦១ | ៦២ | ៦៣ | ៦៤ | ៦៥ | ៦៦ | ៦៧ | ៦៨ | ៦៩ | ៧០
សហធម្មិកវគ្គ៖ សិក្ខាបទ ទី ៧១ | ៧២ | ៧៣ | ៧៤ | ៧៥ | ៧៦ | ៧៧ | ៧៨ | ៧៩ | ៨០ | ៨១ | ៨២
រតនវគ្គ៖ សិក្ខាបទ ទី ៨៣ | ៨៤ | ៨៥ | ៨៦ | ៨៧ | ៨៨ | ៨៩ | ៩០ | ៩១ | ៩២

**បាដិទេសនីយកណ្ឌ**
សិក្ខាបទ ទី ១ | ២ | ៣ | ៤

**សេក្ខិយកណ្ឌ**
បរិមណ្ឌលវគ្គ | ឧជ្ជគ្ឃិកវគ្គ | ខម្ភកតវគ្គ | សក្កច្ចវគ្គ | កពឡវគ្គ | សុរុសុរុវគ្គ | បាទុកាវគ្គ

អធិករណសមថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ។

# បាចិត្តិយកណ្ឌ

CS vin.vbu.pc | ភាគ ទី៤

### (៥. បាចិត្តិយកណ្ឌំ)

## ភូតគាមវគ្គ (ទី២)

CS vin.vbu.pc.v2 | ភាគ ទី៤

### (២. ភូតគាមវគ្គោ)

## (បាចិត្តិយ ភូតគាមវគ្គ) សិក្ខាបទ ទី៦ (១៦)

CS vin.vbu.pc.16 | ភាគ ទី៤

### (៦. អនុបខជ្ជសិក្ខាបទំ)

[១] សម័នោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ បៀតបៀនយកទីដេកល្អៗ ញុំាងភិក្ខុចាស់ទាំងឡាយឲ្យក្រោកចេញទៅ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា យើងទាំងឡាយនៅចាំវស្សាក្នុងទីនេះដោយឧបាយដូចម្ដេចហ្ន៎។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុចូលទៅដេកច្រៀតបៀតភិក្ខុចាស់ទាំងឡាយដោយគិតថា ភិក្ខុណាមានសេចក្ដីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបីនឹងចូលទៅដេកច្រៀតបៀតពួកភិក្ខុចាស់សោះ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នករាល់គ្នាចូលទៅដេកច្រៀតបៀតភិក្ខុចាស់ទាំងឡាយ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ការនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងចូលទៅដេកច្រៀតបៀតពួកភិក្ខុចាស់សោះឡើយ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយដឹងហើយ ចូលទៅច្រៀតបៀតនូវភិក្ខុដែលចូលទៅនៅមុន ហើយសម្រេចនូវទីដេកក្នុងវិហាររបស់សង្ឃដោយគិតថា ភិក្ខុណាមានសេចក្ដីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើនូវសេចក្ដីច្រៀតបៀតនោះឯងឲ្យជាបច្ច័យ មិនមែនហេតុដទៃទេ។**

[២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ វិហារដែលគេលះប្រគេនដល់សង្ឃ ហៅថាវិហាររបស់សង្ឃ។ ដែលហៅថា ដឹង គឺភិក្ខុដឹងថា ភិក្ខុនេះចាស់ ដឹងថាភិក្ខុនេះឈឺ ដឹងថា វិហារនេះសង្ឃបានឲ្យហើយ។ ពាក្យថា ចូលទៅច្រៀតបៀត គឺចូលទៅច្រៀតជ្រែក។ ពាក្យថា សម្រេចនូវទីដេក សេចក្ដីថា ភិក្ខុក្រាលឯងក្ដី ប្រើគេឲ្យក្រាលក្ដី នូវទីដេកក្នុងឧបចារ[1] នៃគ្រែក្ដី នៃតាំងក្ដី នៃភិក្ខុចូលទៅក្ដី ចេញមកក្ដី ត្រូវអាបត្តិទុក្កដ ភិក្ខុអង្គុយសង្កត់ក្ដី ដេកសង្កត់ក្ដី (លើទីដេកនោះ) ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ព្រោះធ្វើនូវសេចក្ដីច្រៀតបៀតនេះឯងឲ្យជាបច្ច័យ មិនមែនហេតុដទៃទេ សេចក្ដីថា គ្មានហេតុដទៃនីមួយដែលក្រៅពីការចូលទៅដេកច្រៀតបៀតនោះឡើយ។

[៣] វិហាររបស់សង្ឃ ភិក្ខុសំគាល់ថា វិហាររបស់សង្ឃមែន ហើយចូលទៅដេកច្រៀតបៀត ត្រូវអាបត្តិបាចិត្តិយ។ វិហាររបស់សង្ឃ ភិក្ខុមានសេចក្ដីសង្ស័យ ហើយចូលទៅដេកច្រៀតបៀត ត្រូវអាបត្តិបាចិត្តិយ។ វិហាររបស់សង្ឃ ភិក្ខុសំគាល់ថារបស់បុគ្គលវិញ ហើយចូលទៅដេកច្រៀតបៀត ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុក្រាលឯងក្ដី ប្រើគេឲ្យក្រាលក្ដី នូវទីដេក វៀរលែងតែឧបចារនៃគ្រែក្ដី នៃតាំងក្ដី នៃភិក្ខុចូលទៅក្ដី ចេញមកក្ដី ត្រូវអាបត្តិទុក្កដ។ ភិក្ខុអង្គុយសង្កត់ក្ដី ដេកសង្កត់ក្ដី ត្រូវអាបត្តិទុក្កដ។ ភិក្ខុក្រាលឯងក្ដី ប្រើគេឲ្យក្រាលក្ដី នូវទីដេក ក្នុងឧបចារនៃវិហារក្ដី ក្នុងឧបដ្ឋានសាលាក្ដី[2] ក្នុងមណ្ឌបក្ដី ទៀបគល់ឈើក្ដី ក្នុងទីវាលក្ដី ត្រូវអាបត្តិទុក្កដ។ ភិក្ខុអង្គុយសង្កត់ក្ដី ដេកសង្កត់ក្ដី ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថារបស់សង្ឃ ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថារបស់បុគ្គលដដែល ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះជារបស់បុគ្គល គឺវិហារនៃភិក្ខុដទៃ។ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារជារបស់បុគ្គល គឺវិហាររបស់ខ្លួនឯង។

[៤] អាបត្តិមិនមានដល់ភិក្ខុដែលមានជម្ងឺចូលទៅដេក ដល់ភិក្ខុដែលត្រូវត្រជាក់ ឬក្ដៅបៀតបៀនហើយចូលទៅក្ដី ដល់ភិក្ខុមានសេចក្ដីអន្តរាយក្ដី ដល់ភិក្ខុឆ្កួតក្ដី ដល់ភិក្ខុដើមបញ្ញត្តិក្ដី។

សិក្ខាបទ ទី ៦ ចប់។

## (បាចិត្តិយ ភូតគាមវគ្គ) សិក្ខាបទ ទី៧ (១៧)

CS vin.vbu.pc.17 | ភាគ ទី៤

### (៧. និក្កឌ្ឍនសិក្ខាបទំ)

[៥] សម័នោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកសត្តរសវគ្គិយភិក្ខុ (ភិក្ខុមានពួក១៧រូប) នាំគ្នាជួសជុលវិហារធំ១ មាននៅក្នុងបច្ចន្តប្រទេស ដោយគិតគ្នាថា យើងទាំងឡាយនឹងនៅចាំវស្សាក្នុងទីនេះ។ ពួកឆព្វគ្គិយភិក្ខុ (ភិក្ខុមានពួក៦រូប) បានឃើញពួកសត្តរសវគ្គិយភិក្ខុនាំគ្នាជួសជុលវិហារ លុះឃើញហើយបាននិយាយគ្នាយ៉ាងនេះថា ម្នាលអាវុសោ ពួកសត្តរសវគ្គិយភិក្ខុនេះនាំគ្នាជួសជុលវិហារ បើដូច្នោះ យើងទាំងឡាយនឹងធ្វើឲ្យភិក្ខុទាំងនោះចៀសចេញទៅ។ ឆព្វគ្គិយភិក្ខុពួកខ្លះ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ សូមលោកទាំងឡាយបង្អង់ចាំឲ្យសត្តរសវគ្គិយភិក្ខុទាំងឡាយជួសជុលវិហាររួចសិន លុះជួសជុលស្រេចហើយ យើងទាំងឡាយនឹងធ្វើភិក្ខុទាំងនោះឲ្យចៀសចេញទៅ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុបាននិយាយពាក្យនេះនឹងពួកសត្តរសវគ្គិយភិក្ខុថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ ហេតុដូចម្តេច ក៏ពួកលោកមិនប្រាប់យើងជាមុនសិន យើងទាំងឡាយនឹងបានជួសជុលវិហារឯទៀតវិញ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោ ក្រែងវិហារនោះជារបស់សង្ឃទេដឹង។ ពួកសត្តរសវគ្គិយភិក្ខុនិយាយតបថា អើអាវុសោ វិហារជារបស់សង្ឃ។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ វិហារជាវិហារធំ ពួកលោកក៏នៅបាន ពួកយើងក៏នៅបាន។ ពួកឆព្វគ្គិយភិក្ខុនិយាយដដែលទៀតថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ ហើយមានចិត្តកម្រើកខឹងឡើង នាំគ្នាចាប់កក្រន្ទាក់ទាញចេញទៅ។ ពួកសត្តរសវគ្គិយភិក្ខុនោះ កាលត្រូវពួកឆព្វគ្គិយភិក្ខុកន្ត្រាក់កទាញចេញ ក៏នាំគ្នាយំ។ ទើបភិក្ខុទាំងឡាយ (ភិក្ខុដទៃចាកភិក្ខុពីរពួកនោះ) បាននាំគ្នាសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាពួកលោកយំ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយតបថា ម្នាលអាវុសោ ឆព្វគ្គិយភិក្ខុទាំងនេះមានចិត្តកម្រើកខឹង នាំគ្នាបណ្តេញពួកយើងចេញចាកវិហាររបស់សង្ឃ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបីនឹងមានចិត្តក្រោធខឹង ទង់ទាញភិក្ខុទាំងឡាយចេញចាកវិហាររបស់សង្ឃសោះ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់សួរពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយមានចិត្តក្រោធខឹង ទង់ទាញភិក្ខុទាំងឡាយចេញចាកវិហាររបស់សង្ឃ មែនឬទេ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបីនឹងមានចិត្តក្រោធខឹង ទង់ទាញភិក្ខុទាំងឡាយចេញចាកវិហាររបស់សង្ឃសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លានោះទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយមានចិត្តក្រោធខឹងនឹងភិក្ខុផងគ្នា ហើយទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ចេញចាកវិហាររបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ។**

[៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា នឹងភិក្ខុ គឺនឹងភិក្ខុដទៃ។ ពាក្យថា មានចិត្តក្រោធខឹង សេចក្តីថា មានចិត្តមិនត្រេកអរ មានចិត្តដែលទោសកំចាត់បង់ មានចិត្តរឹងរូស។

[៧] វិហារដែលគេបរិច្ចាគប្រគេនដល់សង្ឃ ឈ្មោះថា វិហាររបស់សង្ឃ។ ពាក្យថា ទង់ទាញឯង គឺភិក្ខុចាប់យកពីក្នុងបន្ទប់ ហើយទង់ទាញទៅឯរបៀងវិហារ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុចាប់យកពីក្នុងរបៀង ហើយទង់ទាញទៅខាងក្រៅ ក៏ត្រូវអាបត្តិបាចិត្តិយ។ ទុកជាភិក្ខុទង់ទាញភិក្ខុឲ្យកន្លងទ្វារទាំងឡាយជាច្រើន តែដោយប្រយោគមួយ ក៏ត្រូវអាបត្តិបាចិត្តិយតែមួយ។ ពាក្យថា ប្រើគេឲ្យទង់ទាញនោះ គឺបង្គាប់អ្នកដទៃ (ភិក្ខុអ្នកបង្គាប់នោះ) ក៏ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុបង្គាប់តែវារៈម្តង អ្នកទទួលបង្គាប់ ទៅទង់ទាញភិក្ខុដទៃឲ្យកន្លងទ្វារសូម្បីច្រើន ក៏ត្រូវអាបត្តិបាចិត្តិយតែមួយ។

[៨] វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថាជារបស់សង្ឃដដែល ហើយមានចិត្តក្រោធខឹង ទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ។ វិហាររបស់សង្ឃ ភិក្ខុមានសេចក្តីសង្ស័យ ហើយមានចិត្តក្រោធខឹង ទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ។ វិហាររបស់សង្ឃ ភិក្ខុសំគាល់ថាជារបស់បុគ្គលទៅវិញ ហើយមានចិត្តក្រោធខឹង ទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវបរិក្ខាររបស់ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវភិក្ខុឲ្យចាកឧបចារនៃវិហារក្តី ចាកឧបដ្ឋានសាលាក្តី ចាកមណ្ឌបក្តី ចាកម្លប់ឈើក្តី ចាកទីវាលក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវបរិក្ខារនៃភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវអនុបសម្បន្នឲ្យចាកវិហារក្តី ចាកឧបចារនៃវិហារក្តី ចាកឧបដ្ឋានសាលាក្តី ចាកមណ្ឌបក្តី ចាកម្លប់ឈើក្តី ចាកទីវាលក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុទង់ទាញឯងក្តី ប្រើគេឲ្យទង់ទាញក្តី នូវបរិក្ខាររបស់អនុបសម្បន្ននោះ ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថាជារបស់សង្ឃ ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថាជារបស់បុគ្គល ត្រូវអាបត្តិទុក្កដ ព្រោះវិហារជារបស់បុគ្គលនៃភិក្ខុដទៃ គឺវិហាររបស់គេ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារជារបស់បុគ្គលនៃខ្លួន គឺវិហាររបស់ខ្លួនឯង។

[៩] អាបត្តិមិនមានដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវភិក្ខុអលជ្ជី ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់ភិក្ខុអលជ្ជីនោះ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវភិក្ខុឆ្កួត ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់ភិក្ខុឆ្កួតនោះ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវភិក្ខុជាអ្នកធ្វើនូវសេចក្តីបង្ករហេតុក្តី អ្នកធ្វើនូវសេចក្តីប្រកួតប្រកាន់ក្តី អ្នកធ្វើនូវសេចក្តីទាស់ទែងក្តី អ្នកធ្វើនូវពាក្យឡោះឡោះតាមតែរួចពីមាត់ក្តី[3] អ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃក្តី ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់ភិក្ខុនោះចេញ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវអន្តេវាសិក ឬសទ្ធិវិហារិក ដែលប្រព្រឹត្តមិនត្រឹមត្រូវ ដល់ភិក្ខុដែលទង់ទាញឯង ឬប្រើគេឲ្យទង់ទាញនូវបរិក្ខាររបស់អន្តេវាសិក ឬសទ្ធិវិហារិកដែលប្រព្រឹត្តមិនត្រឹមត្រូវនោះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៧ ចប់។

## (បាចិត្តិយ ភូតគាមវគ្គ) សិក្ខាបទ ទី៨ (១៨)

CS vin.vbu.pc.18 | ភាគ ទី៤

### (៨. វេហាសកុដិសិក្ខាបទំ)

[១០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុ២រូប ១រូបនៅថ្នាក់ខាងក្រោម ១រូបនៅថ្នាក់ខាងលើ ក្នុងវិហាររបស់សង្ឃ។ ភិក្ខុដែលនៅខាងលើ អង្គុយចុះដោយរហ័ស សង្កត់គ្រែដែលមានជើងគ្រាន់តែស៊កទុក (ដោយបណ្តោះអាសន្ន)។ ជើងគ្រែ (នោះ) ក៏របូតធ្លាក់ចុះមកទង្គិចក្បាលភិក្ខុអ្នកនៅខាងក្រោម។ ភិក្ខុនោះបានស្រែកសំឡេងព្រប្លែក។ ភិក្ខុទាំងឡាយបានស្ទុះទៅសួរភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីក៏លោកស្រែក។ ភិក្ខុនោះបានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមបើនឹងមកអង្គុយចុះដោយរហ័សសង្កត់គ្រែដែលមានជើងគ្រាន់តែស៊កទុក (ដោយបណ្តោះអាសន្ន) លើថ្នាក់ក្នុងវិហាររបស់សង្ឃសោះ។ ទើបភិក្ខុទាំងឡាយនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ឮថាអ្នកឯងអង្គុយចុះដោយរហ័សសង្កត់គ្រែដែលមានជើងគ្រាន់តែស៊កទុក (ដោយបណ្តោះអាសន្ន) លើថ្នាក់ក្នុងវិហាររបស់សង្ឃ ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងមកអង្គុយចុះ ដោយរហ័សសង្កត់គ្រែដែលមានជើងគ្រាន់តែស៊កទុក (ដោយបណ្តោះអាសន្ន) លើថ្នាក់ក្នុងវិហាររបស់សង្ឃទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលអ្នកមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយអង្គុយចុះ ដោយរហ័សសង្កត់ ឬដេកសង្កត់នូវគ្រែក្តី នូវតាំងក្តី ដែលមានជើងគ្រាន់តែស៊កទុក (ដោយបណ្តោះអាសន្ន) លើថ្នាក់ក្នុងវិហាររបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ។**

[១១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ វិហារដែលគេបរិច្ចាគប្រគេនដល់សង្ឃ ហៅថា វិហាររបស់សង្ឃ។

[១២] ធ្នើរ (ដែលគេធ្វើខ្ពស់) មិនទង្គិចក្បាលមជ្ឈិមបុរស ហៅថាថ្នាក់។ គ្រែដែលមានជើងគ្រាន់តែស៊កចូលក្នុងមេ ហើយតាំងទុក ហៅថា គ្រែដែលមានជើងគ្រាន់តែស៊កទុក។ តាំងដែលមានជើងគ្រាន់តែស៊កចូលក្នុងមេ ហៅថា តាំងដែលមានជើងគ្រាន់តែស៊កទុក។ ពាក្យថា អង្គុយសង្កត់ គឺភិក្ខុអង្គុយសង្កត់លើគ្រែ ឬតាំងនោះ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ដេកសង្កត់ គឺភិក្ខុដេកសង្កត់លើគ្រែ ឬតាំងនោះ ត្រូវអាបត្តិបាចិត្តិយ។

[១៣] វិហាររបស់សង្ឃ ភិក្ខុសម្គាល់ថាជារបស់សង្ឃមែន ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែក្តី លើតាំងក្តី ដែលមានជើងគ្រាន់តែស៊កទុកក្នុងមេ (ដែលគេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ។ វិហាររបស់សង្ឃ ភិក្ខុមានសេចក្តីសង្ស័យ ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែក្តី លើតាំងក្តី ដែលមានជើងគ្រាន់តែស៊កទុកក្នុងមេ (ដែលគេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ។ វិហាររបស់សង្ឃ ភិក្ខុសំគាល់ថាជារបស់បុគ្គលវិញ ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែក្តី លើតាំងក្តី ដែលមានជើងគ្រាន់តែស៊កទុកក្នុងមេ (ដែលគេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថាជារបស់សង្ឃវិញ ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថាជារបស់បុគ្គលដដែល ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះ ជារបស់បុគ្គលនៃភិក្ខុដទៃ គឺវិហាររបស់គេ។ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារជារបស់ខ្លួន គឺវិហាររបស់ខ្លួនឯង។

[១៤] អាបត្តិមិនមានដល់ភិក្ខុដែលអង្គុយ ឬដេកសង្កត់លើគ្រែក្តី តាំងក្តី ដែលគេតម្កល់ទុកលើទីដែលមិនមែនថ្នាក់ លើទីទាបដែលដើរទង្គិចក្បាល ទីដែលមិនបានប្រើប្រាស់ខាងក្រោមឲ្យជាទីនៅ ទីដែលគេក្រាលជិតដោយរនាប លើគ្រែ ឬតាំងនោះ ដែលគេដាក់គន្លឹះហើយ ដល់ភិក្ខុដែលឈរនៅលើគ្រែ ឬតាំងនោះ ហើយកាន់យក ឬព្យួរនូវបរិក្ខារ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៨ ចប់។

## (បាចិត្តិយ ភូតគាមវគ្គ) សិក្ខាបទ ទី៩ (១៩)

CS vin.vbu.pc.19 | ភាគ ទី៤

### (៩. មហល្លកវិហារសិក្ខាបទំ)

[១៥] សម័នោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី។ គ្រានោះឯង មហាមាត្យជាឧបដ្ឋាករបស់ឆន្នភិក្ខុដ៏មានអាយុ បានឲ្យគេធ្វើវិហារប្រគេនឆន្នភិក្ខុដ៏មានអាយុ។ លំដាប់នោះ ឆន្នភិក្ខុដ៏មានអាយុ បានឲ្យគេប្រក់ និងបូកលាបវិហារដែលគេធ្វើស្រេចហើយនោះញយៗ វិហារនោះធ្ងន់ហួសកំណត់ ក៏បាក់រលំចុះមក។ គ្រានោះ ឆន្នភិក្ខុដ៏មានអាយុ ក៏ជញ្ជូនយកស្មៅ និងឈើទៅធ្វើ (វិហារទៀត) ប្រៀតបៀនស្រែស្រូវរបស់ព្រាហ្មណ៍ម្នាក់ឲ្យខូចខាតទៅ។ ទើបព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនសមបើនឹងមកបៀតបៀនស្រែស្រូវរបស់យើងឲ្យខូចខាតទៅសោះ។ ភិក្ខុទាំងឡាយបានឮពាក្យរបស់ព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ មិនគួរនឹងឲ្យគេប្រក់រឿយៗ បូកលាបរឿយៗ នូវវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះធ្ងន់ហួសកំណត់ បាក់រលំចុះមកសោះ។ ភិក្ខុអម្បាលនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឆន្ន ឮថាអ្នកឯងឲ្យគេប្រក់រឿយៗ និងបូកលាបរឿយៗ នូវវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះធ្ងន់ហួសកំណត់ បាក់រលំចុះមក ពិតមែនឬ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិនសមបើនឹងឲ្យគេប្រក់រឿយៗ និងបូកលាបរឿយៗ នូវវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះធ្ងន់ហួសកំណត់ បាក់រលំចុះមកទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុកាលឲ្យគេធ្វើវិហារធំ គប្បីឈរ (លាបបូកញយៗបាន) កំណត់ទីមានឱកាសត្រឹមតែសន្លឹកទ្វារ[4] (និងសន្លឹកបង្អួច) ដើម្បីទុកប្រើប្រាស់នូវទ្វារ និងដើម្បីបរិកម្មនូវសន្លឹកបង្អួច ឯដំបូល ភិក្ខុត្រូវឈរក្នុងទីដែលគ្មានដំណាំ (នោះទើប) ប្រក់បានត្រឹមពីរ ឬបីជាន់ បើភិក្ខុប្រក់ឲ្យច្រើនលើសជាងកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានដំណាំ ក៏គង់ត្រូវអាបត្តិបាចិត្តិយ។**

[១៦] ដែលហៅថាវិហារធំ សំដៅយកវិហារដែលមានទាយកជាម្ចាស់របស់។ ដែលហៅថាវិហារ គឺវិហារដែលគេបូកខាងក្នុងក្តី បូកខាងក្រៅក្តី បូកទាំងខាងក្នុង ខាងក្រៅក្តី។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី។ ពាក្យថា កំណត់ទីមានឱកាសត្រឹមតែសន្លឹកទ្វារ គឺកំណត់ត្រឹមហត្ថបាសដោយជុំវិញនៃក្របទ្វារ។ ពាក្យថា ដើម្បីទុកប្រើប្រាស់នូវទ្វារ គឺដើម្បីបើកបិទនូវទ្វារ។ ពាក្យថា ដើម្បីបរិកម្មនូវសន្លឹកបង្អួច សេចក្តីថា (តថាគតអនុញ្ញាត) នូវវត្ថុមានពណ៌ស ពណ៌ខ្មៅ ពណ៌រង់ ក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ និងក្បាច់ឈ្មោះបញ្ចបដ្ឋិក[5] ដើម្បីបរិកម្មនូវសន្លឹកបង្អួច។ ពាក្យថា ឯដំបូល ភិក្ខុត្រូវឈរក្នុងទីដែលគ្មានដំណាំ (នោះទើប) ប្រក់បានត្រឹមពីរបីជាន់ ឯដំណាំនោះ បានដល់វត្ថុដែលត្រូវស៊ីមុន (គឺស្រូវ៧ប្រការ មានស្រូវស ស្រូវក្រហមជាដើម) និងវត្ថុដែលត្រូវស៊ីក្រោយ (បានដល់សណ្តែកបាយ សណ្តែករាជមាសជាដើម)។ បើភិក្ខុឈរធ្វើការប្រក់ក្នុងទីមានដំណាំ ត្រូវអាបត្តិទុក្កដ។ កាលភិក្ខុប្រើឲ្យគេប្រក់ម្តងរួចទៅហើយ ត្រូវប្រក់ខ្លួនឯងបានត្រឹមពីរដង ដល់គ្រាទីបី ត្រូវបង្គាប់គេហើយ ចៀសចេញទៅ។ កាលភិក្ខុប្រើឲ្យគេប្រក់មួយជាន់រួចហើយ ត្រូវប្រក់ខ្លួនឯងបានត្រឹមពីរជាន់ ដល់ជាន់ទីបី ត្រូវបង្គាប់គេហើយចៀសចេញទៅ។

[១៧] ត្រង់ពាក្យថា បើភិក្ខុប្រក់ឲ្យច្រើន លើសជាងកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានដំណាំ សេចក្តីថា កាលភិក្ខុប្រើគេឲ្យប្រក់ដោយក្បឿង ត្រូវអាបត្តិបាចិត្តិយគ្រប់ៗផែនក្បឿង។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយថ្ម ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗផែនថ្ម។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយកំបោរ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗដុំកំបោរ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយស្មៅ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗកណ្តាប។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយស្លឹកឈើ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗសន្លឹក។

[១៨] វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសម្គាល់ថាលើសមែន ហើយនៅតែធ្វើថែម ត្រូវអាបត្តិបាចិត្តិយ។ វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសង្ស័យ ហើយនៅតែធ្វើថែម ត្រូវអាបត្តិបាចិត្តិយ។ វិហារបូកប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសម្គាល់ថាខ្វះវិញ ហើយធ្វើថែម ត្រូវអាបត្តិបាចិត្តិយ។ វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសំគាល់ថាលើស ហើយ (ធ្វើថែម) ត្រូវអាបត្តិទុក្កដ។ វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ វិហារបូកប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសំគាល់ថាមិនទាន់ដល់មែន មិនត្រូវអាបត្តិ។

[១៩] អាបត្តិមិនមានដល់ភិក្ខុដែលបូកប្រក់វិហារត្រឹមពីរបីជាន់ ដល់ភិក្ខុដែលបូកប្រក់វិហារមិនដល់ពីរបីជាន់ ដល់ភិក្ខុដែលបូកប្រក់លេណ (ទីពួន) គុហា កុដិប្រក់ដោយស្មៅ ធ្វើដើម្បីប្រយោជន៍ដល់អ្នកដទៃ ធ្វើដោយទ្រព្យរបស់ខ្លួន ទីសេនាសនៈទាំងពួង វៀរលែងតែកុដិសម្រាប់នៅរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៩ ចប់។

## (បាចិត្តិយ ភូតគាមវគ្គ) សិក្ខាបទ ទី១០ (២០)

CS vin.vbu.pc.20 | ភាគ ទី៤

### (១០. សប្បាណកសិក្ខាបទំ)

[២០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងអគ្គាលវចេតិយ ទៀបស្រុកអាឡវី។ គ្រានោះឯង ភិក្ខុស្រុកអាឡវីទាំងឡាយកាលធ្វើនូវនវកម្ម (កម្មទើបតែកសាងថ្មី) ដឹងថាទឹកមានសត្វ ក៏ស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុស្រុកអាឡវីដឹងថាទឹកមានសត្វហើយ មិនសមបី

នឹងយកមកស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះសោះឡើយ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយដឹងថាទឹកមានសត្វហើយ ស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងដឹងថាទឹកមានសត្វហើយ មិនសមបើនឹងយកមកស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬមួយញ៉ាំងបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរិតតែជ្រះថ្លាឡើងមិនបានទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយដឹងថាទឹកមានសត្វហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅឬដី ត្រូវអាបត្តិបាចិត្តិយ។**

[២១] ត្រង់ពាក្យថា ភិក្ខុណាមួយមានសេចក្តីដូចគ្នាក្នុងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ។ ភិក្ខុដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ដល់ភិក្ខុនោះក្តី ឈ្មោះថា ភិក្ខុដឹង។

[២២] ត្រង់ពាក្យថា ស្រោចឯង គឺភិក្ខុស្រោចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រើគេឲ្យស្រោច គឺភិក្ខុបង្គាប់អ្នកដទៃឲ្យស្រោច ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុប្រើតែម្តង ហើយអ្នកទទួលបង្គាប់ទៅស្រោចច្រើនដង ភិក្ខុអ្នកប្រើត្រូវអាបត្តិបាចិត្តិយ។ (ទឹក) មានសត្វ ភិក្ខុសំគាល់ថា (ទឹក) មានសត្វមែន ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅ ឬដី ត្រូវអាបត្តិបាចិត្តិយ។ (ទឹក) មានសត្វ ភិក្ខុមានសេចក្តីសង្ស័យ ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅឬដី ត្រូវអាបត្តិទុក្កដ។ (ទឹក) មានសត្វ ភិក្ខុសំគាល់ថាគ្មានសត្វវិញ ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅឬដី មិនត្រូវអាបត្តិអ្វីឡើយ។ (ទឹក) មិនមានសត្វ ភិក្ខុសំគាល់ថា មានសត្វ ត្រូវអាបត្តិទុក្កដ។ (ទឹក) មិនមានសត្វ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ (ទឹក) មិនមានសត្វ ភិក្ខុសំគាល់ថា មិនមានសត្វ មិនត្រូវអាបត្តិអ្វីឡើយ។

[២៣] អាបត្តិមិនមានដល់ភិក្ខុមិនក្លែង ដល់ភិក្ខុមិនមានស្មារតី ដល់ភិក្ខុមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ១០ ចប់។

ភូតគាមវគ្គ ទី ២ ចប់។

ចំនួនសិក្ខាបទក្នុងភូតគាមវគ្គនោះគឺ

ភិក្ខុធ្វើភូតគាមឲ្យដាច់ចាកទី១ ភិក្ខុយករឿងដទៃមកបន្លប់ដើម្បីបិទបាំងទោសខ្លួន១ ភិក្ខុលើកទោសភិក្ខុអ្នកធ្វើការសង្ឃ១ ភិក្ខុយកគ្រែតាំង ពូកកៅអីរបស់សង្ឃទៅចោលក្នុងទីវាល ហើយចៀសចេញទៅ១ ភិក្ខុយកកម្រាលរបស់សង្ឃទៅក្រាលចោល ហើយចៀសចេញទៅ១ ភិក្ខុដេកបៀតច្រៀតភិក្ខុអ្នកនៅមុនក្នុងកុដិសង្ឃ១ ភិក្ខុខឹងនឹងភិក្ខុឯទៀត ហើយបណ្តេញចាកវិហាររបស់សង្ឃ១ ភិក្ខុអង្គុយ ឬដេកលើគ្រែមានជើងស៊កទុក១ ភិក្ខុលាបបូកវិហារញយៗ បានកំណត់ត្រឹមសន្លឹកទ្វារ ឬសន្លឹកបង្អួចដោយជុំវិញ១ ភិក្ខុយកទឹកមានសត្វស្រោចស្មៅ ឬដី១។

# ឱវាទវគ្គ (ទី៣)

CS vin.vbu.pc.v3 | ភាគ ទី៤

**(៣. ឱវាទវគ្គោ)**

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី១ (២១)

CS vin.vbu.pc.21 | ភាគ ទី៤

**(១. ឱវាទសិក្ខាបទំ)**

[២៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយទូន្មានភិក្ខុនីទាំងឡាយ ក៏បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុបានគិតគ្នាយ៉ាងនេះថា ម្នាលអាវុសោ ឥឡូវនេះ ភិក្ខុជាថេរៈទាំងឡាយទូន្មានពួកភិក្ខុនី បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើងទាំងឡាយក៏ទូន្មានពួកភិក្ខុនីដែរ។ វេលានោះ ពួកឆព្វគ្គិយភិក្ខុនាំគ្នាចូលទៅរកភិក្ខុនីទាំងឡាយ ហើយបាននិយាយយ៉ាងនេះថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរមករកពួកយើង ៗនឹងទូន្មាន។ គ្រានោះ ភិក្ខុនីទាំងឡាយនោះក៏ចូលទៅរកឆព្វគ្គិយភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយ បានថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយ ហើយអង្គុយក្នុងទីគួរមួយ។ ពួកឆព្វគ្គិយភិក្ខុធ្វើធម៌ីកថាបន្តិចបន្តួចដល់ពួកភិក្ខុនី ហើយក៏ពោលតិរច្ឆានកថាឲ្យកន្លងអស់១ថ្ងៃ រួចបញ្ជូនពួកភិក្ខុនីឲ្យត្រឡប់ទៅវិញ ដោយពាក្យថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរទៅវិញចុះ។ គ្រានោះ ភិក្ខុនីទាំងឡាយនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរពួកភិក្ខុនីនោះដែលឈរក្នុងទីដ៏សមគួរដោយពុទ្ធដីកាយ៉ាងនេះថា ម្នាលភិក្ខុនីទាំងឡាយ ឱវាទ (នោះ) បានបរិបូណ៌សម្រេចហើយឬ។ ភិក្ខុនីទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចំរើន ឱវាទ (នោះ) នឹង

បរិបូណ៌សម្រេចមកពីណា ព្រោះលោកម្ចាស់ឆព្វគ្គិយទាំងឡាយធ្វើធម្មីកថាតែបន្តិចបន្តួចប៉ុណ្ណោះ ហើយពោលតិរច្ឆានកថាឲ្យកន្លងអស់១ថ្ងៃ រួចក៏បញ្ជូនខ្ញុំព្រះអង្គទាំងឡាយឲ្យត្រឡប់មកវិញ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ភិក្ខុនីទាំងឡាយនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា។ លំដាប់នោះ ភិក្ខុនីទាំងឡាយនោះ លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ឆព្វគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយតិចណាស់ ពោលតែតិរច្ឆានកថា ឲ្យកន្លងអស់១ថ្ងៃ ហើយក៏បញ្ជូនភិក្ខុនីទាំងនោះឲ្យត្រឡប់ទៅវិញ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនសមបើនឹងធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយតិចពេក ពោលតែតិរច្ឆានកថាឲ្យកន្លងអស់១ថ្ងៃ ហើយបញ្ជូនភិក្ខុនីទាំងឡាយឲ្យត្រឡប់ទៅវិញសោះ នែមោឃបុរសទាំងឡាយ អំពើដែលអ្នករាល់គ្នាធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលអ្នកដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាមិនបាន។បេ។ លុះព្រះដ៏មានព្រះភាគទ្រង់តិះដៀលហើយ ក៏ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតភិក្ខុឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីយ៉ាងនេះ សង្ឃត្រូវអារាធនាភិក្ខុ (នោះ) ជាមុនសិន។ លុះអារាធនារួចហើយ ភិក្ខុអ្នកឈ្លាសអង់អាច គប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើសម្មតិកម្មនេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី។ នេះជាវាចាប្រកាសសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី។ ការសម្មតិភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះអស់វារៈពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះអស់វារៈបីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី។ ការសម្មតិភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីហើយ។ សម្មតិកម្មនេះគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលនូវឆព្វគ្គិយភិក្ខុទាំងឡាយដោយបរិយាយជាច្រើន។បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយដែលសង្ឃមិនបានសន្មត ហើយទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ។**

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយដោយប្រការយ៉ាងនេះ។

[២៥] សម័យនោះឯង ភិក្ខុជាថេរៈទាំងឡាយដែលសង្ឃបានសន្មតរួចហើយ ក៏ទៅប្រដៅភិក្ខុនីទាំងឡាយ ក៏បានចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់ភិក្ខុឈឺយ៉ាងនោះដដែល។ គ្រានោះ ឆព្វគ្គិយភិក្ខុទាំងឡាយ បានគិតគ្នាថា អាវុសោ ឥឡូវនេះ ភិក្ខុជាថេរៈទាំងឡាយដែលសង្ឃបានសន្មតហើយ ក៏ទៅប្រដៅភិក្ខុនីទាំងឡាយ បានចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់ភិក្ខុឈឺយ៉ាងនោះដដែល អាវុសោ បើដូច្នោះ មានតែពួកយើងទៅកាន់ទីគ្មានសីមា ហើយសន្មតគ្នាទៅវិញទៅមកឲ្យជាអ្នកប្រដៅភិក្ខុនី រួចប្រដៅពួកភិក្ខុនី។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុនាំគ្នាទៅកាន់ទីគ្មានសីមា ហើយសន្មតគ្នាទៅវិញទៅមកឲ្យជាអ្នកប្រដៅភិក្ខុនី ហើយចូលទៅរកភិក្ខុនីទាំងឡាយ ពោលយ៉ាងនេះថា ម្នាលប្អូនស្រីទាំងឡាយ សង្ឃបានសន្មតពួកយើងហើយ នាងទាំងឡាយចូរមករកពួកយើងចុះ យើងនឹងប្រដៅឲ្យទាន់។ ទើបភិក្ខុនីទាំងឡាយនោះចូលទៅរកឆព្វគ្គិយភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយ ថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ គ្រានោះ ឆព្វគ្គិយភិក្ខុទាំងឡាយធ្វើធម្មីកថាបន្តិចបន្តួចដល់ភិក្ខុនីទាំងឡាយ ហើយពោលតិរច្ឆានកថាឲ្យកន្លងអស់១ថ្ងៃទៅ រួចក៏បញ្ជូនភិក្ខុនីទាំងឡាយនោះឲ្យត្រឡប់ទៅវិញដោយពាក្យថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរទៅវិញចុះ។ ទើបភិក្ខុនីទាំងនោះនាំគ្នាចូលទៅកាន់ទីគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុនីទាំងឡាយ ដែលឈរនៅក្នុងទីដ៏សមគួរនោះថា ម្នាលភិក្ខុនីទាំងឡាយ ឱវាទបានសម្រេចបរិបូណ៌ឬទេ។ ភិក្ខុនីទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចំរើន ឱវាទនឹងបានសម្រេចបរិបូណ៌មកពីឯណា លោកម្ចាស់ឆព្វគ្គិយទាំងឡាយធ្វើធម្មីកថាបន្តិចបន្តួច ហើយពោលតែតិរច្ឆានកថាឲ្យកន្លងអស់១ថ្ងៃ រួចក៏បញ្ជូនយើងខ្ញុំឲ្យត្រឡប់មកវិញ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ភិក្ខុនីទាំងឡាយនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា។ ភិក្ខុនីអម្បាលនោះ លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយព្រះធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ រួចសួរបញ្ជាក់ពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយបន្តិចបន្តួច ហើយពោលតិរច្ឆានកថាឲ្យកន្លងអស់មួយថ្ងៃ រួចក៏បញ្ជូនភិក្ខុនីទាំងនោះឲ្យត្រឡប់ទៅវិញ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកមិនសមបីនឹងធ្វើធម្មីកថាបន្តិចបន្តួចដល់ភិក្ខុនី ហើយពោលតិរច្ឆានកថាឲ្យកន្លងអស់មួយថ្ងៃ រួចបញ្ជូនភិក្ខុនីទាំងនោះឲ្យត្រឡប់ទៅវិញសោះ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬមួយញុំាងបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងមិនបានទេ។បេ។ ទ្រង់តិះដៀលហើយ ក៏ធ្វើនូវធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុដែលប្រកបដោយអង្គ៨ ឲ្យជាអ្នកប្រដៅភិក្ខុនី គឺ

- ភិក្ខុជាអ្នកមានសីលសង្រួមតាមបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ (មារយាទ) និងទីគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយមានប្រមាណតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ១

- ភិក្ខុជាពហុស្សុត ទ្រទ្រង់ពុទ្ធវចនៈ សន្សំនូវពុទ្ធវចនធម៌ទាំងឡាយណា ពីរោះខាងដើម ពីរោះកណ្តាល ពីរោះខាងចុង តែងប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈឲ្យបរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពយ៉ាងនេះ ភិក្ខុនោះចាំច្រើនហើយ ទ្រទ្រង់ហើយ សន្សំហើយ ដោយវាចាដ៏ស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ យល់ត្រូវល្អដោយទិដ្ឋិ១
- ចំណែកបាតិមោក្ខទាំងពីរ ភិក្ខុនោះក៏ចេះចាំដោយពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អ ដោយសុត្ត (គឺខន្ធកៈ និងបរិវារៈ) ដោយអនុព្យញ្ជនៈ១
- ភិក្ខុនោះមានវាចាពោលត្រឹមត្រូវដោយសិថិលធនិតជាដើម មានសំឡេងពីរោះ១ ភិក្ខុនោះជាទីស្រឡាញ់ពេញចិត្តនៃភិក្ខុនីទាំងឡាយដោយច្រើន១
- ភិក្ខុនោះជាអ្នកអាចដើម្បីនឹងប្រដៅភិក្ខុនីបាន១
- ភិក្ខុនោះមិនធ្លាប់ប្រព្រឹត្តកន្លងគរុធម៌នឹងភិក្ខុនីដែលស្លៀកដណ្តប់សម្ពត់ជ្រលក់ដោយទឹកចត់ បួសចំពោះព្រះដ៏មានព្រះភាគនេះ១
- ភិក្ខុនោះមានវស្សា២០ ឬមានវស្សាជាង២០១

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតនូវភិក្ខុដែលប្រកបដោយអង្គទាំងឡាយ៨នេះ ឲ្យជាអ្នកប្រដៅភិក្ខុនី។

[២៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ភិក្ខុដែលឈ្មោះថាសង្ឃមិនបានសន្មតនោះ គឺសង្ឃមិនបានសន្មតដោយញត្តិចតុត្ថកម្មវាចា។ ពួកស្រីដែលឈ្មោះថាភិក្ខុនីនោះ បានដល់ស្រីដែលបានឧបសម្បទាហើយក្នុងឧភតោសង្ឃ។

[២៧] ត្រង់ពាក្យថា ប្រដៅ គឺភិក្ខុទូន្មានដោយគរុធម៌៨ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុប្រដៅដោយធម៌ដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុប្រដៅភិក្ខុនីដែលបានឧបសម្បទាក្នុងសំណាក់សង្ឃតែមួយចំណែក ត្រូវអាបត្តិទុក្កដ។

[២៨] ភិក្ខុដែលសង្ឃសន្មតនោះ គប្បីបោសច្រាសនូវទីបរិវេណ រួចត្រូវតាំងទឹកឆាន់ និងទឹកប្រើប្រាស់ តែងតាំងនូវអាសនៈទុក ហើយនាំយកភិក្ខុជាគំរប់ពីរទៅអង្គុយនៅចុះ។ ភិក្ខុនីទាំងឡាយគប្បីទៅក្នុងទីនោះ ហើយថ្វាយបង្គំនូវភិក្ខុនោះ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ ភិក្ខុដែលសង្ឃសន្មតនោះ គប្បីសួរភិក្ខុនីទាំងឡាយថា ម្នាលនាងទាំងឡាយ ពួកនាងព្រមព្រៀងគ្នាហើយឬ។ បើភិក្ខុនីទាំងឡាយពោលថា លោកម្ចាស់ យើងខ្ញុំទាំងឡាយព្រមព្រៀងគ្នាហើយ ភិក្ខុគប្បីសួរថា ម្នាលនាងទាំងឡាយ គរុធម៌៨ចាំស្ទាត់រត់មាត់ហើយឬ។ បើភិក្ខុនីទាំងឡាយពោលតបថា បពិត្រលោកម្ចាស់ ចាំស្ទាត់រត់មាត់ហើយ ភិក្ខុគប្បីប្រគល់ឱវាទដោយពាក្យថា ម្នាលនាងទាំងឡាយ នេះហើយជាឱវាទ។ បើភិក្ខុនីទាំងឡាយពោលថា គរុធម៌មិនទាន់ស្ទាត់ទេលោកម្ចាស់ ភិក្ខុគប្បីសូត្រប្រាប់ភិក្ខុនីថា ភិក្ខុនីឧបសម្បទាហើយបានមួយរយវស្សា ត្រូវធ្វើអភិវាទនកម្ម បច្ចុបដ្ឋានកម្ម អញ្ជលីកម្ម និងសាមីចិកម្មដល់ភិក្ខុ (សូម្បី) ឧបសម្បទាហើយក្នុងថ្ងៃនោះ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជាកុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត១។ ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជាកុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត១។ ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរប្រការ គឺការសាកសួរនូវឧបោសថ១ ការចូលទៅទទួលឱវាទ១ អំពីភិក្ខុសង្ឃគ្រប់ៗកន្លះខែ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជាកុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត១។ ភិក្ខុនីនៅចាំវស្សារួចហើយ ត្រូវបវារណាក្នុងឧភតោសង្ឃដោយហេតុ៣យ៉ាង គឺដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត១។ ភិក្ខុនីត្រូវគរុកាបត្តិ (ជាសតេកិច្ឆា) ហើយត្រូវប្រព្រឹត្តបក្ខមានត្តក្នុងឧភតោសង្ឃ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត១។ ភិក្ខុនីត្រូវស្វែងរកឧបសម្បទាក្នុងឧភតោសង្ឃដល់សិក្ខមានាដែលមានសិក្ខាសិក្សាក្នុងធម៌ទាំងឡាយ៦ អស់ពីរវស្សាហើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជាកុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត១។ ភិក្ខុនីមិនត្រូវជេរមិនត្រូវប្រទេចផ្តាសាភិក្ខុដោយបរិយាយណាមួយឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជាកុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត១។ ពួកភិក្ខុនីមិនត្រូវស្តីប្រដៅពួកភិក្ខុឡើយ ពួកភិក្ខុត្រូវស្តីប្រដៅដល់ពួកភិក្ខុនីបាន តាំងអំពីថ្ងៃនេះជាដើម នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជាកុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត១។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយព្រមព្រៀងគ្នាហើយ ភិក្ខុពោលធម៌ដទៃវិញ ត្រូវអាបត្តិទុក្កដ។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយបែកគ្នាជាពួកៗ ភិក្ខុចេះតែពោលនូវគរុធម៌៨ដដែល ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនបានប្រគល់ឱវាទឲ្យដល់ភិក្ខុនី ត្រឡប់ពោលធម៌ដទៃវិញ ត្រូវអាបត្តិទុក្កដ។

[២៩] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ។

[៣០] ភិក្ខុសង្ស័យក្នុងកម្មមិនជាធម៌ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ។

[៣១] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ។

[៣២] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ។

[៣៣] កម្មមិនមែនជាធម៌ ភិក្ខុសង្ស័យ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ។

[៣៤] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ។

[៣៥] កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។ កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។ កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។

[៣៦] កម្មជាធម៌ ភិក្ខុសង្ស័យ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។

[៣៧] កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។

[៣៨] កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនមែនជាធម៌វិញ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។

[៣៩] កម្មជាធម៌ ភិក្ខុមានសេចក្តីសង្ស័យ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។

[៤០] កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។ កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ។ កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាព្រមព្រៀងគ្នាមែន ហើយប្រដៅ មិនត្រូវអាបត្តិអ្វីឡើយ។

[៤១] អាបត្តិមិនមានដល់ភិក្ខុដែលសំដែងនូវបាឡីនៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលសំដែងនូវអដ្ឋកថានៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយដោះ ដល់ភិក្ខុដែលសំដែងធម៌ឲ្យអ្នកដទៃស្តាប់ ហើយភិក្ខុនីចូលស្តាប់ផង ដល់ភិក្ខុប្រដៅធម៌ដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ១ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី២ (២២)

CS vin.vbu.pc.22 | ភាគ ទី៤

### (២. អត្ថង្គតសិក្ខាបទំ)

[៤២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនីដោយវេនជាលំដាប់ៗ។ សម័យនោះឯង ព្រះចូឡបន្ថកដ៏មានអាយុត្រូវវេនប្រដៅភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីនិយាយគ្នាថា ថ្ងៃនេះឱវាទគង់នឹងមិនសម្រេចបរិបូណ៌ទេ លោកម្ចាស់ចូឡបន្ថកគង់នឹងពោលនូវឧទាននោះឯងដដែលៗ ឥឡូវហ្នឹង។ ភិក្ខុនីទាំងនោះនាំគ្នាចូលទៅរកព្រះចូឡបន្ថកដ៏មានអាយុ លុះទៅដល់ហើយ ក៏ថ្វាយបង្គំព្រះចូឡបន្ថកដ៏មានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ឯព្រះចូឡបន្ថកដ៏មានអាយុ បាននិយាយនឹងភិក្ខុនីទាំងនោះ ដែលអង្គុយនៅហើយក្នុងទីដ៏សមគួរ ដោយពាក្យយ៉ាងនេះថា ម្នាលនាងទាំងឡាយ ពួកនាងព្រមព្រៀងគ្នាហើយឬ។ ពួកភិក្ខុនីតបថា ព្រមព្រៀងគ្នាហើយលោកម្ចាស់។ ព្រះចូឡបន្ថកសួរថា ម្នាលនាងទាំងឡាយ គរុធម៌៨ចាំស្ទាត់ហើយឬ។ ពួកភិក្ខុនីតបថា ចាំស្ទាត់ហើយលោកម្ចាស់។ ព្រះចូឡបន្ថកប្រាប់ថា ម្នាលនាងទាំងឡាយ នេះហើយជាឱវាទ ហើយបានពោលនូវឧទាននេះដដែលថា សេចក្តីសោកទាំងឡាយ រមែងមិនមានដល់មុនីដែលមានអធិចិត្តមិនប្រមាទ សិក្សានៅក្នុងផ្លូវនៃមោនធម៌ (គឺអរហត្តញាណ) មិនញាប់ញ័រ (ដោយលោកធម៌) មានចិត្តស្ងប់ (ចាកកិលេស) តែងមានស្មារតីជានិច្ច។

[៤៣] ភិក្ខុនីទាំងឡាយ បាននិយាយគ្នាយ៉ាងនេះថា យើងទាំងឡាយបាននិយាយគ្នាទុកមកហើយថា វេលាថ្ងៃនេះឱវាទគង់នឹងមិនសម្រេចបរិបូណ៌ទេ លោកម្ចាស់ចូឡបន្ថកគង់នឹងពោលនូវឧទាននោះឯងដដែលក្នុងកាលឥឡូវហ្នឹង។ ព្រះចូឡបន្ថកដ៏មានអាយុបានស្តាប់ពាក្យនិយាយចរចានេះរបស់ភិក្ខុនីទាំងឡាយនោះហើយ។ គ្រានោះ ព្រះចូឡបន្ថកដ៏មានអាយុហោះទៅកាន់វិហាសស្ថានហើយចង្ក្រមខ្លះ ឈរខ្លះ អង្គុយខ្លះ ដេកខ្លះ បង្ហុយផ្សែងខ្លះ បញ្ចេញពន្លឺភ្លើងខ្លះ បំបាត់ខ្លួនទៅខ្លះ ហើយពោលឧទាននោះទៀតផង និងពុទ្ធវចនៈដទៃជាច្រើនផង ឰដ៏អាកាសវាលទទេ។ ភិក្ខុនីទាំងឡាយបាននិយាយគ្នាយ៉ាងនេះថា ម្នាលគ្នាយើងទាំងឡាយ សេចក្តីអស្ចារ្យ(នេះ) ចំឡែកពេកណាស់ ម្នាលគ្នាយើងទាំងឡាយ ហេតុមិនធ្លាប់កើត ៗហើយ ឱវាទដែលសម្រេចបរិបូណ៌ដូចជាឱវាទរបស់លោកម្ចាស់ចូឡបន្ថកយ៉ាងនេះ កាលពីដើម យើងមិនធ្លាប់បាន(ស្តាប់)ទេ។ លំដាប់នោះ ព្រះចូឡបន្ថកដ៏មានអាយុប្រដៅភិក្ខុនីអម្បាលនោះដរាបដល់យប់ ហើយបញ្ជូនទៅវិញថា ម្នាលនាងទាំងឡាយ ពួកនាងចូរទៅចុះ។ វេលានោះ ទ្វារនគរគេបិទហើយ ភិក្ខុនីទាំងនោះក៏នៅខាងក្រៅនគរ លុះព្រឹកឡើងទើបចូលទៅកាន់នគរ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយនេះ មិនមែនជាព្រហ្មចារិនី (មិនមែនជាអ្នកប្រព្រឹត្តល្អ)ទេ នៅជាមួយនឹងភិក្ខុទាំងឡាយក្នុងអារាម ហើយទើបតែចូលមកកាន់នគរក្នុងកាលឥឡូវនេះ។ ភិក្ខុទាំងឡាយបានឮមនុស្សអម្បាលនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ចូឡបន្ថកដ៏មានអាយុ កាលព្រះអាទិត្យអស្តង្គតហើយ មិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយទេ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលចូឡបន្ថកៈ ឮថា កាលព្រះអា

ទិត្យអស្តង្គតហើយ អ្នកឯងទៅប្រដៅភិក្ខុនីទាំងឡាយ ពិតមែនឬ។ ព្រះចូឡបន្ថកដ៏មានអាយុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលចូឡបន្ថកៈ កាលព្រះអាទិត្យអស្តង្គតទៅហើយ អ្នកឯងមិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយទេ ម្នាលចូឡបន្ថៈ អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុបើទុកជាសង្ឃបានសន្មតហើយ កាលបើព្រះអាទិត្យអស្តង្គតហើយ ទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ។**

[៤៤] ដែលហៅថា សង្ឃបានសន្មតនោះ គឺសង្ឃសន្មតដោយញត្តិចតុត្ថកម្មវាចា។ ត្រង់ពាក្យថា ព្រះអាទិត្យអស្តង្គតហើយ សេចក្តីថា ព្រះអាទិត្យលិចចុះហើយ។ ពួកស្រីដែលបានឧបសម្បទាក្នុងជំនុំសង្ឃពីរចំណែក ហៅថាភិក្ខុនី។ ពាក្យថា ប្រដៅ សេចក្តីថា ភិក្ខុប្រដៅភិក្ខុនីដោយគរុធម៌៨ក្តី ដោយធម៌ដទៃក្តី ត្រូវអាបត្តិបាចិត្តិយ។

[៤៥] ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុសំគាល់ថា អស្តង្គតមែន ហើយទៅប្រដៅ (ភិក្ខុនី) ត្រូវអាបត្តិបាចិត្តិយ។ ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយទៅប្រដៅ ត្រូវអាបត្តិបាចិត្តិយ។ ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុសំគាល់ថាមិនទាន់អស្តង្គត ហើយទៅប្រដៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុប្រដៅភិក្ខុនីដែលឧបសម្បទាហើយក្នុងជំនុំសង្ឃមួយចំណែក ត្រូវអាបត្តិទុក្កដ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុសំគាល់ថាអស្តង្គតហើយ ត្រូវអាបត្តិទុក្កដ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុសំគាល់ថាមិនទាន់អស្តង្គត មិនត្រូវអាបត្តិអ្វីឡើយ។

[៤៦] អាបត្តិមិនមានដល់ភិក្ខុដែលសំដែងនូវបាលីនៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលសំដែងនូវអដ្ឋកថានៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយដោះ ដល់ភិក្ខុដែលសំដែងធម៌ឲ្យអ្នកដទៃស្តាប់ ហើយភិក្ខុនីចូលស្តាប់ផង ដល់ភិក្ខុប្រដៅធម៌ដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ២ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី៣ (២៣)

CS vin.vbu.pc.23 | ភាគ ទី៤

### (៣. ភិក្ខុនុបស្សយសិក្ខាបទំ)

[៤៧] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនឈ្មោះសក្កៈ។ គ្រានោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ ចូលទៅកាន់លំនៅរបស់ភិក្ខុនី ហើយប្រដៅឆព្វគ្គិយភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយបាននិយាយបបួលឆព្វគ្គិយភិក្ខុនីយ៉ាងនេះថា ម្នាលនាងទាំងឡាយ ពួកនាងចូរមក យើងនឹងទៅទទួលឱវាទ (ជាមួយគ្នា)។ ឆព្វគ្គិយភិក្ខុនីនិយាយថា ម្នាលនាងទាំងឡាយ យើងទាំងឡាយនាំគ្នាទៅព្រោះហេតុនៃឱវាទធ្វើអ្វី ដ្បិតឆព្វគ្គិយភិក្ខុជាម្ចាស់ទាំងឡាយមកប្រដៅពួកយើងក្នុងលំនៅនេះហើយ។ ភិក្ខុនីទាំងឡាយនាំគ្នា ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងចូលដល់លំនៅភិក្ខុនី ហើយប្រដៅភិក្ខុនីទាំងឡាយទេ។ លំដាប់នោះ ភិក្ខុនីអម្បាលនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនី។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយប្រដៅភិក្ខុនីទាំងឡាយចូលដល់លំនៅភិក្ខុនី ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយ ចូលដល់លំនៅភិក្ខុនីទេ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនីទាំងឡាយ ត្រូវអាបត្តិបាចិត្តិយ។

ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៤៨] សម័យនោះឯង ព្រះមហាបជាបតិគោតមីភិក្ខុនីមានជម្ងឺ។ ភិក្ខុជាថេរៈទាំងឡាយ ចូលទៅកាន់លំនៅព្រះមហាបជាបតិគោតមីភិក្ខុនី លុះចូលទៅដល់ហើយ បាននិយាយសួរព្រះមហាបជាបតិគោតមីភិក្ខុនីយ៉ាងនេះថា ម្នាលព្រះនាងគោតមី សរីរយន្តព្រះនាងល្មមអត់ទ្រាំបានដែរឬទេ ល្មមប្រព្រឹត្តទៅបានស្រួលដែរឬទេ។ ព្រះមហាបជាបតិគោតមីភិក្ខុនីតបថា លោកម្ចាស់ សរីរយន្តខ្ញុំមិនអាចអត់ទ្រាំបានទេ ខ្ញុំមិនអាចប្រព្រឹត្តទៅបានស្រួលទេ បពិត្រលោកម្ចាស់ទាំងឡាយ ណ្ហើយចុះ សូមពួកលោកម្ចាស់សំដែងធម៌ឲ្យទាន។ ភិក្ខុទាំងនោះនិយាយថា ម្នាលនាង កិរិយាដែលភិក្ខុចូលមកកាន់លំនៅរបស់ភិក្ខុនី ហើយសំដែងធម៌ដល់ភិក្ខុនី មិនគួរឡើយ ហើយមានសេចក្តីសង្ស័យ (យ៉ាងនេះ) ក៏មិនហ៊ានសំដែងធម៌ឡើយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរក្នុងវេលាព្រឹក ហើយទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់ព្រះមហាបជាបតិគោតមី លុះដល់ហើយ ទ្រង់គង់លើអាសនៈដែលតែងតាំងទុក។ ព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ទ្រង់ត្រាស់សួរព្រះមហាបជាបតិគោតមីយ៉ាងនេះថា ព្រះនាងគោតមី សរីរយន្តព្រះនាងល្មមអត់ទ្រាំបានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានស្រួលដែរឬ។ ព្រះនាងទូលតបថា បពិត្រព្រះអង្គដ៏ចំរើន កាលមុនភិក្ខុជាថេរៈទាំងឡាយ មកសំដែងធម៌ដល់ខ្ញុំព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គមានសេចក្តីសប្បាយ ក៏

ឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់ហើយ ព្រោះហេតុនោះ ភិក្ខុជាថេរៈទាំងឡាយមានសេចក្ដីខ្លាចក្រែង ទើបមិនហ៊ានសំដែង សេចក្ដីមិនសប្បាយមានដល់ខ្ញុំព្រះអង្គ ព្រោះហេតុនោះឯង។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ព្រះមហាបជាបតិគោតមីឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់សំដែងធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនីដែលមានជម្ងឺបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ឯសម័យក្នុងសិក្ខាបទនេះ គឺភិក្ខុនីមានជម្ងឺ នេះជាសម័យក្នុងសិក្ខាបទនោះ។**

[៤៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ភិក្ខុនីទាំងឡាយនៅក្នុងទីណា សូម្បីអស់រាត្រី១ ទៅនោះហៅថាទីនៅរបស់ភិក្ខុនី។ ពាក្យថា ចូលដល់ គឺទៅក្នុងទីនោះ។ ពួកស្រីដែលបានឧបសម្បទាក្នុងសង្ឃពីរចំណែក ហៅថាភិក្ខុនី។ ពាក្យថា ប្រដៅ គឺភិក្ខុប្រដៅដោយគរុធម៌៨ ត្រូវអាបត្តិអាចិត្តិយ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកលែងតែមានសម័យ។ ភិក្ខុនីមិនអាចទៅទទួលឱវាទ ឬទៅនៅរួមសង្ឃកម្មបាន ហៅថាមានជម្ងឺ។

[៥០] ភិក្ខុសំគាល់ភិក្ខុនីដែលបានឧបសម្បទាហើយ ថាបានឧបសម្បទាមែន ហើយចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុសង្ស័យក្នុងភិក្ខុនីដែលបានឧបសម្បទាហើយ ចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុនីឧបសម្បទាហើយ ភិក្ខុសំគាល់ថា មិនទាន់បានឧបសម្បទាទេ ហើយចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុប្រដៅភិក្ខុនីដោយធម៌ដទៃ (ក្រៅពីគរុធម៌) ត្រូវអាបត្តិទុក្កដ។ ភិក្ខុប្រដៅភិក្ខុនីដែលបានឧបសម្បទាក្នុងសង្ឃតែមួយចំណែក ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ក្នុងស្រីមិនទាន់បានឧបសម្បទា ថាបានឧបសម្បទាហើយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសង្ស័យក្នុងស្រីដែលមិនទាន់បានឧបសម្បទា ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ក្នុងស្រីដែលមិនទាន់បានឧបសម្បទា ថាមិនទាន់ឧបសម្បទាមែន មិនត្រូវអាបត្តិអ្វីឡើយ។

[៥១] អាបត្តិមិនមានដល់ភិក្ខុដែលប្រដៅភិក្ខុនីក្នុងសម័យ ដល់ភិក្ខុដែលសំដែងបាឡីនៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលសំដែងអដ្ឋកថានៃគរុធម៌ប្រាំបី ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយដោះ ដល់ភិក្ខុដែលសំដែងធម៌ដើម្បីអ្នកដទៃ ហើយភិក្ខុនីចូលស្ដាប់ផង ដល់ភិក្ខុដែលប្រដៅធម៌ដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៣ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី៤ (២៤)

CS vin.vbu.pc.24 | ភាគ ទី៤

### (៤. អាមិសសិក្ខាបទំ)

[៥២] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី តែងបាននូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ។ ពួកឆព្វគ្គិយភិក្ខុ និយាយគ្នាយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយ មិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ថ្វីឡើយ ពួកឆព្វគ្គិយភិក្ខុមកនិយាយយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយ មិនសូវយកចិត្តទុកដាក់នឹងប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយនិយាយគ្នាយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយមិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីប៉ុន្មានទេ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ក៏ថ្វីឡើយ ពួកអ្នកឯងមកពោលយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយមិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស នែមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយពោលយ៉ាងនេះថា ភិក្ខុទាំងឡាយ ប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ត្រូវអាបត្តិបាចិត្តិយ។**

[៥៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ព្រោះហេតុតែអាមិស សេចក្ដីថា ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា។

[៥៤] ពាក្យថា ពោលយ៉ាងនេះ សេចក្ដីថា ភិក្ខុណាប្រាថ្នាដើម្បីនឹងធ្វើនូវពាក្យដំនៀល ប្រាថ្នាដើម្បីនឹងធ្វើបង្អាប់យស ប្រាថ្នាដើម្បីនឹងធ្វើនូវសេចក្ដីបង្អាប់បង្អោន ចំពោះឧបសម្បន្នដែលសង្ឃសន្មត ឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺនិយាយថា ភិក្ខុប្រដៅភិក្ខុនី ព្រោះ

ហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ។

[៥៥] កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ។ កម្មជាធម៌ ភិក្ខុសង្ស័យ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ។ កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មមិនមែនជាធម៌វិញ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ។

[៥៦] ភិក្ខុណាប្រាថ្នាដើម្បីធ្វើនូវពាក្យដំនៀល ប្រាថ្នាដើម្បីធ្វើបង្អាប់យស ប្រាថ្នាដើម្បីធ្វើនូវសេចក្តីបង្អាប់បង្អោនចំពោះឧបសម្បន្នដែលសង្ឃមិនបានសន្មតឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺនិយាយថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ។

[៥៧] ភិក្ខុណា ប្រាថ្នាដើម្បីធ្វើនូវពាក្យដំនៀល ប្រាថ្នាដើម្បីធ្វើបង្អាប់យស ប្រាថ្នាដើម្បីធ្វើនូវសេចក្តីបង្អាប់បង្អោន ចំពោះអនុបសម្បន្នបុគ្គលដែលសង្ឃសន្មតក្តី មិនបានសន្មតក្តី ឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺពោលថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជា (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ។

[៥៨] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនមែនជាធម៌ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថាកម្មមិនមែនជាធម៌ ត្រូវអាបត្តិទុក្កដ។

[៥៩] អាបត្តិមិនមានដល់ភិក្ខុដែលពោលចំពោះភិក្ខុផងគ្នាដែលជាអ្នកប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ គ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន កិរិយាថ្វាយបង្គំ និងកិរិយាបូជាដោយប្រក្រតី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៤ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី៥ (២៥)

CS vin.vbu.pc.25 | ភាគ ទី៤

### (៥. ចីវរទានសិក្ខាបទំ)

[៦០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុមួយរូបត្រាច់ទៅបិណ្ឌបាតតាមផ្លូវ ឬច្រកមួយ ក្នុងក្រុងសាវត្ថី។ មានភិក្ខុនីមួយរូបទៀតក៏ត្រាច់ទៅបិណ្ឌបាតតាមផ្លូវ ឬច្រកនោះដែរ។ ទើបភិក្ខុនោះនិយាយនឹងភិក្ខុនីនោះយ៉ាងនេះថា ម្នាលនាង នាងចូរទៅក្នុងឱកាសឯណោះ គេប្រគេនភិក្ខា។ ឯភិក្ខុនីនោះ ក៏និយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់ចូរទៅក្នុងឱកាសឯណោះចុះ គេប្រគេនចង្ហាន់។ ភិក្ខុ និងភិក្ខុនីនោះបានស្គាល់គ្នា ព្រោះបានឃើញគ្នាញឹកញយ។ គ្រានោះឯង សង្ឃកំពុងចែកចីវរគ្នា។ លំដាប់នោះ ភិក្ខុនីនោះកាលទៅទទួលឱវាទ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ថ្វាយបង្គំភិក្ខុនោះហើយ បានឋិតនៅក្នុងទីដ៏សមគួរ។ ភិក្ខុនោះបាននិយាយនឹងភិក្ខុនីដែលឋិតនៅក្នុងទីដ៏សមគួរនោះយ៉ាងនេះថា ម្នាលនាង ចំណែកចីវរនេះរបស់យើង នាងនឹងត្រូវការដែរឬទេ។ ភិក្ខុនីនោះឆ្លើយថា ករុណាលោកម្ចាស់ ខ្ញុំករុណាមានចីវរចាស់ហើយ។ ភិក្ខុនោះឲ្យចីវរដល់ភិក្ខុនីនោះ។ ចំណែកភិក្ខុនោះជាអ្នកមានចីវរទុព្វលភាព។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរធ្វើចីវររបស់អ្នកក្នុងកាលឥឡូវនេះចុះ។ ភិក្ខុនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមគួរនឹងឲ្យចីវរដល់ភិក្ខុនីទេ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងបានឲ្យចីវរដល់ភិក្ខុនី ពិតមែនឬ។ ភិក្ខុនោះក្រាបទូលតបថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ភិក្ខុនីនោះជាញាតិរបស់អ្នកឯង ឬមិនមែនញាតិទេ។ ភិក្ខុនោះទូលថា សូមទ្រង់មេត្តាប្រោស ភិក្ខុនីនោះមិនជាញាតិទេ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែមោឃបុរស បុរសមិនមែនជាញាតិ រមែងមិនដឹងនូវកម្មដ៏សមគួរ ឬមិនសមគួរ ល្អិតល្អ ឬមិនល្អិតល្អរបស់ស្ត្រីដែលមិនមែនជាញាតិទេ នែមោឃបុរស អ្នកឯងមិនគួរនឹងឲ្យចីវរដល់ភិក្ខុនីមិនមែនញាតិទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកបុគ្គល ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយឲ្យចីវរដល់ភិក្ខុនីដែលមិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៦១] សម័យនោះឯង ភិក្ខុទាំងឡាយសង្ស័យ មិនហ៊ានផ្លាស់ប្តូរចីវរនឹងភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយមិនសមបីនឹងមិនហ៊ានផ្លាស់ប្តូរចីវរនឹងពួកយើងសោះ។ ភិក្ខុទាំងឡាយបានឮពួកភិក្ខុនីនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្លាស់ប្តូរចីវរនឹងសហធម្មិកទាំង៥ គឺ ភិក្ខុ១ ភិក្ខុនី១ សិក្ខមានា១ សាមណេរ១ សាមណេរី១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្លាស់ប្តូរចីវរនឹងសហធម្មិកទាំង៥ នេះបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយឲ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ វៀរតែផ្លាស់ប្ដូរគ្នា។**

[៦២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ភិក្ខុនីដែលមិនបានសម្ពន្ធជាប់វង្សគ្នាមកអំពីចំណែកខាងមាតាក្ដី អំពីចំណែកខាងបិតាក្ដី ដរាបអំពីគូនៃជីដូនជីតាជាគំរប់៧ ហៅថាមិនមែនជាញាតិ។ ស្រីដែលបានឧបសម្បទាហើយក្នុងសង្ឃពីរចំណែក ហៅថា ភិក្ខុនី។ បណ្ដាចីវរ៦យ៉ាងចីវរណាមួយ យ៉ាងតូចបំផុតដ៏គួរដល់វិកប្បបាន ហៅថា ចីវរ។ ពាក្យថា វៀរលែងតែផ្លាស់ប្ដូរគ្នា សេចក្ដីថា ភិក្ខុឲ្យ (ចីវរដល់ភិក្ខុនីមិនមែនញាតិ) ត្រូវអាបត្តិបាចិត្តិយ លើកលែងតែផ្លាស់ប្ដូរគ្នា។

[៦៣] ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែផ្លាស់ប្ដូរគ្នា។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសង្ស័យ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែផ្លាស់ប្ដូរគ្នា។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថាជាញាតិ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែផ្លាស់ប្ដូរគ្នា។ ភិក្ខុឲ្យចីវរដល់ភិក្ខុនីដែលបានឧបសម្បទាអំពីសង្ឃមួយចំណែក ត្រូវអាបត្តិទុក្កដ វៀរលែងតែផ្លាស់ប្ដូរគ្នា។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិអ្វីឡើយ។

[៦៤] អាបត្តិមិនមានដល់ភិក្ខុដែលឲ្យចីវរដល់ភិក្ខុនីជាញាតិ ដល់ភិក្ខុដែលផ្លាស់ប្ដូរចីវរគ្នា ដល់ភិក្ខុដែលប្ដូរយកចីវរមានដំឡៃច្រើនដោយចីវរមានដំឡៃតិច ឬចីវរមានដំឡៃតិចដោយចីវរមានដំឡៃច្រើន ដល់ភិក្ខុដែលភិក្ខុនីកាន់យកចីវររបស់ខ្លួនដោយសេចក្ដីស្និទ្ធស្នាល ដល់ភិក្ខុដែលភិក្ខុនីកាន់យកចីវរជារបស់ខ្ចីគ្នា ដល់ភិក្ខុដែលឲ្យបរិក្ខារដទៃ វៀរលែងតែចីវរ ដល់ភិក្ខុដែលឲ្យចីវរដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៥ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី៦ (២៦)

CS vin.vbu.pc.26 | ភាគ ទី៤

### (៦. ចីវរសិព្វនសិក្ខាបទំ)

[៦៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ឧទាយិដ៏មានអាយុ ជាអ្នកប្រសប់ធ្វើចីវរកម្ម។ មានភិក្ខុនី១រូបចូលទៅកាន់ទីដែលឧទាយិដ៏មានអាយុនៅ លុះចូលទៅដល់ហើយ បាននិយាយនឹងឧទាយិដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ដេរចីវរឲ្យខ្ញុំផង។ គ្រានោះ ឧទាយិដ៏មានអាយុក៏ដេរចីវរ ហើយធ្វើកិច្ចជ្រលក់គក់ បោកដ៏ល្អ រួចធ្វើរូបគំនូរ[6] ត្រង់កណ្ដាលចីវរ ស្រេចហើយ បត់ទុកឲ្យភិក្ខុនីនោះ។ គ្រានោះ ភិក្ខុនីនោះទៅកាន់លំនៅឧទាយិដ៏មានអាយុ លុះទៅដល់ហើយ បាននិយាយនឹងឧទាយិដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ ចីវររបស់លោកម្ចាស់នោះ ដូចម្ដេចទៅ។ ឧទាយិឆ្លើយថា ម្នាលប្អូនស្រី ហ៏ នាងចូរនាំយកចីវរនេះទៅទាំងផ្នត់ហើយទុក កាលណាភិក្ខុនីសង្ឃមកទទួលឱវាទ ចូរដណ្ដប់ចីវរនេះដើរទៅតាមក្រោយៗភិក្ខុនីសង្ឃក្នុងកាលណោះ។ លំដាប់នោះ ភិក្ខុនីនោះនាំយកចីវរនោះទៅទាំងផ្នត់ហើយទុក កាលណាភិក្ខុនីសង្ឃមកទទួលឱវាទ នាងក៏ដណ្ដប់ចីវរនោះដើរទៅតាមក្រោយៗភិក្ខុនីសង្ឃក្នុងកាលណោះ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីអម្បាលនេះជាស្រីគ្មានកោតញញើត ជាស្រីអ្នកលេង គ្មានអៀនខ្មាស មិនសមបើនឹងគូរគំនូរក្នុងចីវរសោះ។ ភិក្ខុនីទាំងឡាយបាននិយាយសួរគ្នាយ៉ាងនេះថា នេះជាការងាររបស់អ្នកណា។ ភិក្ខុនីទាំងឡាយឆ្លើយថា នេះជាការងាររបស់លោកម្ចាស់ឧទាយិ។ ពួកភិក្ខុនីនិយាយគ្នាថា ជនទាំងឡាយណាជាអ្នកគ្មានសេចក្ដីកោតញញើត ជាអ្នកលេង ជាអ្នកគ្មានសេចក្ដីអៀនខ្មាស កម្មមានសភាពយ៉ាងនេះ ក៏គង់មិនល្អដល់ជនទាំងឡាយនោះ នឹងពោលទៅថ្វីដល់លោកម្ចាស់ឧទាយិ។ ពួកភិក្ខុនីនោះនាំគ្នាប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុ មិនគួរនឹងដេរចីវរដល់ភិក្ខុនីសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧទាយិ ឮថាអ្នកឯងដេរចីវរឲ្យភិក្ខុនី ពិតមែនឬ។ ឧទាយិភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះដ៏មានព្រះភាគត្រាស់សួរថា នែឧទាយិ ភិក្ខុនីនោះជាញាតិរបស់អ្នកឯង ឬមិនមែនជាញាតិទេ។ ឧទាយិភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស មិនមែនជាញាតិទេ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែមោឃបុរស បុរសដែលមិនមែនជាញាតិ រមែងមិនស្គាល់កម្មដ៏សមគួរក្ដី មិនសមគួរក្ដី កម្មជាទីជ្រះថ្លាក្ដី មិនជាទីជ្រះថ្លាក្ដី របស់ស្ត្រីដែលមិនមែនជាញាតិទេ នែមោឃបុរស អ្នកឯងមិនសមគួរនឹងដេចីវរឲ្យភិក្ខុនីមិនមែនញាតិទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ ដេរឯង ឬប្រើគេឲ្យដេរនូវចីវរឲ្យភិក្ខុនីមិនមែនញាតិ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ។**

[៦៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ភិក្ខុនីដែលមិនបានជាប់តវង្សគ្នាមកអំពីចំណែកខាងមាតាក្ដី អំពីចំណែកខាងបិតាក្ដី ដរាបអំពីគូនៃជីដូនជីតាជាគំរប់៧ ហៅថាមិនមែនញាតិ។ ស្រីដែលបានឧបសម្បទាហើយក្នុងសង្ឃពីរចំណែក ហៅថា ភិក្ខុនី។ បណ្ដាចីវរ៦យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមវិកប្បបាន ហៅថា ចីវរ។ ពាក្យថា ដេរឯង គឺភិក្ខុដេរដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយរាល់ៗផ្លូវម្ជុល។ ពាក្យថា ប្រើគេឲ្យដេរ គឺភិក្ខុបង្គាប់អ្នកដទៃឲ្យដេរ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុបង្គាប់តែម្ដង អ្នកទទួលបង្គាប់ ដេរច្រើនដង ត្រូវអាបត្តិបាចិត្តិយ (តែមួយ)។

[៦៧] ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិមែន ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាជាញាតិ ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរដើម្បីភិក្ខុនីដែលបានឧបសម្បទាអំពីសង្ឃតែមួយចំណែក ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិមែន មិនត្រូវអាបត្តិអ្វីឡើយ។

[៦៨] អាបត្តិមិនមានដល់ភិក្ខុដែលដេរចីវរដល់ភិក្ខុនីជាញាតិ ដល់ភិក្ខុដែលដេរឯង ឬប្រើគេឲ្យដេរនូវបរិក្ខារដទៃក្រៅពីចីវរ (ឲ្យភិក្ខុនី) ឲ្យសិក្ខមានា ឬឲ្យសាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៦ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី៧ (២៧)

CS vin.vbu.pc.27 | ភាគ ទី៤

### (៧. សំវិធានសិក្ខាបទំ)

[៦៩] សម័យនោះឯង ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា យើងទាំងឡាយមានប្តីប្រពន្ធ ដើរទៅយ៉ាងណា សមណៈទាំងឡាយនេះ ជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ ដើរទៅមួយអន្លើដោយភិក្ខុនីទាំងឡាយ យ៉ាងនោះឯង។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបីបើឆព្វគ្គិយភិក្ខុទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នាទេ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ពិតមែនឬ។ ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នាទេ ម្នាលមោឃបុរសទាំងឡាយ ការនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ដោយហោចទៅ សូម្បីកាន់ទីជាលង្វែកនៃស្រុក១ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៧០] សម័យនោះឯង ភិក្ខុ និងភិក្ខុនីទាំងឡាយច្រើនរូប ដើរទៅកាន់ផ្លូវឆ្ងាយអំពីក្រុងសាកេត ទៅកាន់ក្រុងសាវត្ថី។ កាលនោះ ភិក្ខុនីទាំងឡាយនោះ ឃើញពួកភិក្ខុនោះហើយ បានពោលពាក្យនេះថា យើងទាំងឡាយនឹងទៅជាមួយនឹងលោកម្ចាស់ទាំងឡាយ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលនាង ការដែលភិក្ខុបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា មិនគួរទេ នាងទាំងឡាយទៅមុនឬ ៗយើងទាំងឡាយនឹងទៅមុន។ ភិក្ខុនីទាំងនោះឆ្លើយថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ទាំងឡាយជាបុរសដ៏ប្រសើរ គួរតែលោកម្ចាស់ទាំងឡាយនិមន្តទៅមុន។ កាលភិក្ខុនីទាំងនោះដើរទៅជាខាងក្រោយនៃភិក្ខុទាំងឡាយដល់ពាក់កណ្តាលផ្លូវ ចោរទាំងឡាយក៏ដណ្តើមយក (បាត្រ និងចីវរ) ផង ប្រទុស្តផង (កំហែងធ្វើសេវនកិច្ច) ក្នុងកាលនោះឯង។ ទើបភិក្ខុនីទាំងនោះទៅដល់ក្រុងសាវត្ថី ក៏ប្រាប់សេចក្តីនុ៎ះដល់ពួកភិក្ខុនី។ ពួកភិក្ខុនីប្រាប់សេចក្តីនុ៎ះដល់ពួកភិក្ខុ។ ពួកភិក្ខុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយជាមួយគ្នា ក្នុងផ្លូវដែលគួរនឹងទៅ ដោយមានគ្នីគ្នាជាពួកដែលគេសន្មតថា ប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ដោយហោចទៅ សូម្បីទៅកាន់ទីជាលង្វែកនៃស្រុក១ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ ផ្លូវដែលគួរនឹងទៅដោយមានគ្នីគ្នាជាពួក១ ដែលគេសន្មតថាប្រកបដោយសេចក្តីរង្កៀស១ ដែលប្រកបដោយភ័យចំពោះមុខ១ នេះជាសម័យក្នុងសិក្ខាបទនោះ។**

[៧១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថាភិក្ខុនី គឺស្ត្រីដែលបានឧបសម្បទាក្នុងឧភតោសង្ឃ។ ពាក្យថា ជាមួយគ្នា សេចក្តីថា ពួកជាមួយគ្នា។ ពាក្យថា បបួល គឺបបួលគ្នាថា ម្នាលនាង យើងទាំងឡាយនឹងទៅ បពិត្រលោកម្ចាស់ យើងទាំងឡាយនឹងទៅ បពិត្រលោកម្ចាស់ យើងទាំងឡាយនឹងទៅ ម្នាលនាង យើងទាំងឡាយនឹងទៅ យើងទាំងឡាយនឹងទៅក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក ក្នុងថ្ងៃខានស្អែក ត្រូវអាបត្តិទុក្កដ។ ពាក្យថា ដោយហោចទៅ សូម្បីទៅកាន់ទីជាលង្វែកនៃស្រុក១ សេចក្តីថា (ភិក្ខុបបួលភិក្ខុនីដើរជាមួយគ្នាទៅ) ក្នុងទីជាចន្លោះនៃស្រុក ក្នុងស្រុកមានចម្ងាយល្មមមាន់ហើរទៅដល់ (គឺ១រយៈមាន់ហើរ) ត្រូវអាបត្តិបាចិត្តិយ។ (ភិក្ខុបបួលភិក្ខុនីដើរជាមួយគ្នាទៅ) ក្នុងព្រៃដែលមិនមែនស្រុក ត្រូវអាបត្តិបាចិត្តិយគ្រប់ៗកន្លះយោជន៍។ ពាក្យថា វៀរលែងតែមានសម័យ សេចក្តីថា លើកទុកតែមានសម័យ។ ដែលហៅថា ផ្លូវដែលគួរនឹងទៅ ដោយមានគ្នីគ្នាជាពួក គឺផ្លូវដែលបុគ្គលឥតមានគ្នីគ្នា មិនអាចដើរទៅបាន។ ដែលហៅថា ផ្លូវ

ប្រកបដោយសេចក្តីរង្កៀស គឺកន្លែងដែលចោរអាស្រ័យនៅក៏ប្រាកដ កន្លែងដែលចោរបរិភោគអាហារក៏ប្រាកដ កន្លែងដែលចោរឈរនៅក៏ប្រាកដ កន្លែងដែលចោរអង្គុយក៏ប្រាកដ កន្លែងដែលចោរដេកក៏ប្រាកដ ក្នុងផ្លូវនោះ។ ដែលហៅថា ផ្លូវប្រកបដោយភ័យចំពោះមុខ គឺផ្លូវនោះដែលចោរទាំងឡាយសម្លាប់មនុស្សក៏ប្រាកដ ប្លន់មនុស្សក៏ប្រាកដ វាយដំមនុស្សក៏ប្រាកដ។ ភិក្ខុដើរទៅកាន់ផ្លូវដែលប្រកបដោយភ័យចំពោះមុខ ហើយឃើញផ្លូវមិនប្រកបដោយភ័យចំពោះមុខវិញ ត្រូវបញ្ជូនភិក្ខុនីទៅ ដោយពាក្យថា ម្នាលនាងទាំងឡាយ នាងទាំងឡាយចូរទៅចុះ។

[៧២] ភិក្ខុបបួលគ្នាហើយ សំគាល់ថាបបួលមែន ដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅ សូម្បីទៅកាន់ទីជាលង្វែកនៃស្រុក១ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុសង្ស័យក្នុងការដែលបានបបួលគ្នា ហើយដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅ សូម្បីទៅកាន់ទីជាចន្លោះនៃស្រុក១ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុបបួលគ្នា ហើយសំគាល់ថាមិនបានបបួល ដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅ សូម្បីទៅកាន់ទីជាចន្លោះនៃស្រុក១ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុបបួល តែភិក្ខុនីមិនបបួល (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនបានបបួលគ្នា ហើយសំគាល់ថាបានបបួល ត្រូវអាបត្តិទុក្កដ។ ភិក្ខុសង្ស័យក្នុងការដែលមិនបានបបួល ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ថា មិនបានបបួលក្នុងការដែលមិនបានបបួល មិនត្រូវអាបត្តិឡើយ។

[៧៣] អាបត្តិមិនមានដល់ភិក្ខុដែលមានសម័យ ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនីហើយដើរទៅ ដល់ភិក្ខុដែលភិក្ខុនីបបួល តែភិក្ខុមិនបានបបួល ដល់ភិក្ខុនិងភិក្ខុនីដែលទៅដោយខុសសង្កេត ដល់ភិក្ខុដែលទៅ (ជាមួយនឹងភិក្ខុនី) ដោយមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ៧ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី៨ (២៨)

CS vin.vbu.pc.28 | ភាគ ទី៤

### (៨. នាវាភិរុហនសិក្ខាបទំ)

[៧៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយបបួលពួកភិក្ខុនីឡើងជិះទូក១ជាមួយគ្នា។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា យើងទាំងឡាយមានប្តីប្រពន្ធ ជិះលេងលើទូក១យ៉ាងណា សមណៈទាំងឡាយនេះជាកូនចៅព្រះពុទ្ធ ជាសក្យបុត្រ បបួលពួកភិក្ខុនីជិះលេងលើទូក១ជាមួយគ្នា យ៉ាងនោះឯង។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុទាំងឡាយមិនគួរបើនឹង បបួលពួកភិក្ខុនីឡើងជិះទូក១ជាមួយគ្នាទេ។ ទើបភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សួរចំពោះឆព្វគ្គិយភិក្ខុទាំងឡាយក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយបបួលភិក្ខុនីឡើងជិះទូកជាមួយគ្នា ពិតមែនឬ។ ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងបបួលភិក្ខុនីឡើងជិះទូក១ជាមួយគ្នាទេ ម្នាលមោឃបុរសទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយ បបួលភិក្ខុនីឡើងជិះទូក១ជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៧៥] សម័យនោះឯង ភិក្ខុ និងភិក្ខុនីទាំងឡាយច្រើនរូប ដើរទៅកាន់ផ្លូវឆ្ងាយអំពីក្រុងសាកេត ទៅកាន់ក្រុងសាវត្ថី។ ក្នុងទីកណ្តាលផ្លូវមានស្ទឹង១ដែលគេតែងតែឆ្លង។ ទើបភិក្ខុនីទាំងឡាយនោះបានពោពាក្យនេះនឹងភិក្ខុទាំងឡាយនោះថា យើងទាំងឡាយនឹងឆ្លងមួយអន្លើដោយលោកម្ចាស់ទាំងឡាយដែរ។ ភិក្ខុទាំងឡាយនោះឆ្លើយថា ម្នាលនាង ការដែលភិក្ខុបបួលភិក្ខុនីឡើងជិះទូក១ជាមួយគ្នា មិនគួរទេ (បើដូច្នោះ) នាងទាំងឡាយឆ្លងទៅមុនឬ ៗយើងទាំងឡាយនឹងឆ្លងទៅមុន។ ភិក្ខុនីទាំងឡាយឆ្លើយថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ទាំងឡាយជាបុរសដ៏ប្រសើរ លោកម្ចាស់ទាំងឡាយចូរឆ្លងទៅមុនចុះ។ កាលភិក្ខុនីទាំងឡាយនោះឆ្លងទៅជាខាងក្រោយ ចោរទាំងឡាយក៏ដណ្តើមយក (បាត្រ និងចីវរ) ផង ប្រទុស្តផង ក្នុងកាលណោះ។ លុះភិក្ខុនីទាំងឡាយនោះទៅដល់ក្រុងសាវត្ថីហើយ ក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបបួលភិក្ខុនីឡើងជិះទូក១ជាមួយគ្នា ដើម្បីឆ្លងទទឹង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយបបួលភិក្ខុនីឡើងជិះទូក១ជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែការឆ្លងទទឹង។**

[៧៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។បេ។ ដែលហៅថាភិក្ខុនី គឺស្ត្រីដែលបានឧបសម្បទាក្នុងសំណាក់នៃឧភតោសង្ឃ។[7] ពាក្យថា ជាមួយគ្នា គឺពួកជាមួយគ្នា។ ពាក្យថា បបួល គឺបបួលគ្នាថា ម្នាលនាង យើងទាំងឡាយនឹងឡើងជិះទូក

បពិត្រលោកម្ចាស់ យើងទាំងឡាយនឹងឡើងជិះទូក បពិត្រលោកម្ចាស់ យើងទាំងឡាយនឹងឡើងជិះទូក ម្នាលនាង យើងទាំងឡាយនឹងឡើងជិះទូក យើងទាំងឡាយនឹងឡើងជិះទូកក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក ក្នុងថ្ងៃខានស្អែក ត្រូវអាបត្តិទុក្កដ។ កាលភិក្ខុនីឡើងជិះទូក ភិក្ខុក៏ឡើងជិះដែរ ត្រូវអាបត្តិបាចិត្តិយ។ កាលភិក្ខុឡើងជិះទូក ភិក្ខុនីក៏ឡើងជិះដែរ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិងភិក្ខុនីឡើងជិះទូកស្មើគ្នា ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ទៅច្រាសទឹក សេចក្តីថា នាំវាទៅទីខាងលើទឹក។ ពាក្យថា ទៅបណ្តោយទឹក សេចក្តីថា នាវាទៅទីខាងក្រោមទឹក។ ពាក្យថា វៀរលែងតែការឆ្លងទទឹង សេចក្តីថា លើកទុកតែការឆ្លងទទឹង។ (ភិក្ខុបបួលភិក្ខុនីឡើងជិះទូក) ទៅក្នុងស្រុកចម្ងាយមាន់លុមហើរទៅដល់ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗចន្លោះស្រុក។ (ភិក្ខុបបួលភិក្ខុនីឡើងជិះទូក) ទៅក្នុងព្រៃមិនមែនជាស្រុក ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗកន្លះយោជន៍។

[៧៧] ការដែលបានបបួលហើយ ភិក្ខុសំគាល់ថាបានបបួលគ្នាមែន ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែការឆ្លងទទឹង។ ភិក្ខុមានសេចក្តីសង្ស័យក្នុងការដែលបានបបួលគ្នា ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែឆ្លងទទឹង។ ការដែលបានបបួលគ្នា ភិក្ខុសំគាល់ថាមិនបានបបួលគ្នា ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែឆ្លងទទឹង។ ភិក្ខុបបួល ភិក្ខុនីមិនបានបបួល ត្រូវអាបត្តិទុក្កដ។ មិនបានបបួលគ្នាទេ តែភិក្ខុសំគាល់ថាបានបបួលគ្នាហើយ ត្រូវអាបត្តិទុក្កដ។ មិនបានបបួលគ្នាទេ តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនបានបបួលគ្នាទេ ភិក្ខុសំគាល់ថា មិនបានបបួលគ្នាមែន មិនត្រូវអាបត្តិ។

[៧៨] អាបត្តិមិនមានដល់ភិក្ខុដែលឆ្លងទទឹង ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនីហើយឡើងជិះទូក ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនី តែភិក្ខុនីបបួល ដល់ភិក្ខុដែលឡើងជិះទូកជាមួយនឹងភិក្ខុនីដោយខុសសង្កេតគ្នា ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ៨ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី៩ (២៩)

CS vin.vbu.pc.29 | ភាគ ទី៤

### (៩. បរិបាចិតសិក្ខាបទំ)

[៧៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង ភិក្ខុនីឈ្មោះថុល្លនន្ទា ជាជីតុនរបស់ត្រកូល១ ជាភិក្ខុនីប្រកបដោយនិច្ចភត្ត។ ចំណែកគហបតីនោះ ក៏បាននិមន្តពួកភិក្ខុជាថេរៈទៅផង។ គ្រានោះឯង ភិក្ខុនីឈ្មោះថុល្លនន្ទាស្លៀកស្បង់ ប្រដាប់ដោយបាត្រនិងចីវរក្នុងវេលាព្រឹក ហើយចូលទៅកាន់ត្រកូលនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងគហបតីនោះថា ម្នាលគហបតី ខាទនីយភោជនីយាហារមានប្រមាណច្រើននេះ គេចាត់ចែងដើម្បីអ្វី។ គហបតីឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំបាននិមន្តព្រះថេរៈទាំងឡាយមកឆាន់។ ភិក្ខុនីឈ្មោះថុល្លនន្ទាសួរថា ម្នាលគហបតី ព្រះថេរៈទាំងនោះ គឺព្រះថេរៈណាខ្លះ។ គហបតីឆ្លើយថា ព្រះសារីបុត្តជាម្ចាស់ ព្រះមោគ្គល្លានជាម្ចាស់ ព្រះមហាកច្ចានៈជាម្ចាស់ ព្រះមហាកោដ្ឋិតៈជាម្ចាស់ ព្រះមហាកប្បិនជាម្ចាស់ ព្រះមហាចុន្ទជាម្ចាស់ ព្រះអនុរុទ្ធជាម្ចាស់ ព្រះរេវតជាម្ចាស់ ព្រះឧបាលិជាម្ចាស់ ព្រះអានន្ទជាម្ចាស់ ព្រះរាហុលជាម្ចាស់។ ភិក្ខុនីឈ្មោះថុល្លនន្ទាឆ្លើយថា ម្នាលគហបតី កាលព្រះថេរៈមហានាគដ៏ប្រសើរមាននៅទេតើ ហេតុដូចម្តេចក៏អ្នកទៅនិមន្តពួកកូនក្មេងមកវិញ។ គហបតីសួរថា បពិត្រលោកម្ចាស់ ព្រះថេរៈមហានាគដ៏ប្រសើរទាំងនោះ មានព្រះនាមដូចម្តេចខ្លះ។ ភិក្ខុនីឈ្មោះថុល្លនន្ទាឆ្លើយថា លោកម្ចាស់ទេវទត្ត លោកម្ចាស់កោកាលិក លោកម្ចាស់កតមោរកតិស្សកៈ លោកម្ចាស់ខណ្ឌទេវីបុត្រ លោកម្ចាស់សមុទ្ទទត្ត។ កាលភិក្ខុនីឈ្មោះថុល្លនន្ទាកំពុងតែនិយាយពាក្យនេះមិនទាន់អស់នៅឡើយ។ ស្រាប់តែភិក្ខុជាថេរៈទាំងឡាយចូលមកក្នុងពេលនោះ។ ភិក្ខុនីឈ្មោះថុល្លនន្ទាសួរថា ម្នាលគហបតី ព្រះថេរៈមហានាគដ៏ប្រសើរទាំងឡាយ អ្នកបាននិមន្តហើយ ពិតមែនឬ។ គហបតីឆ្លើយថា បពិត្រលោកម្ចាស់ ឥឡូវនេះ លោកម្ចាស់បានធ្វើនូវព្រះថេរៈមហានាគដ៏ប្រសើរទាំងឡាយថាជាកូនក្មេង លោកម្ចាស់ត្រឡប់ធ្វើពួកភិក្ខុជាកូនក្មេងថាជាមហានាគដ៏ប្រសើរទៅវិញ (ថាដូច្នោះហើយ) ក៏ចាប់ទាញភិក្ខុនីឈ្មោះថុល្លនន្ទាចេញពីផ្ទះផង និច្ចភត្ត (គឺចង្ហាន់ដែលផ្គត់ផ្គង់ជានិច្ច) ក៏ផ្តាច់បង់ចេញ គឺឈប់ឲ្យតទៅទៀតផង។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តបានដឹងហើយ មិនគួរនឹងឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែងទេ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលទេវទត្ត ឮថាអ្នកដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ពិតមែនឬ។ ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងដឹងហើយ មិនគួរនឹងឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែងទេ ម្នាលមោឃបុរស ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយ កាលដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៨០] សម័យនោះឯង មានភិក្ខុ១រូបចេញពីក្រុងរាជគ្រឹះទៅបួស ហើយទៅកាន់ត្រកូលញាតិ។ មនុស្សទាំងឡាយនិយាយគ្នាថា លោកម្ចាស់ដ៏ចំរើនខាននិមន្តមកយូរហើយ (ថាដូច្នោះហើយ) ក៏នាំគ្នាធ្វើចង្ហាន់ប្រគេនដោយគោរព។ មានភិក្ខុនីម្នាក់ជាជីតុនរបស់ត្រកូលនោះ បាននិយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចូរឲ្យចង្ហាន់ដល់លោកម្ចាស់ចុះ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា កាលដឹងហើយបរិភោគបិណ្ឌបាតដែលភិក្ខុនីចាត់ចែង ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (សង្ស័យដូច្នោះហើយ) ក៏មិនទទួល (បិណ្ឌបាតនោះ) ហើយមិនអាចនឹងត្រាច់ទៅដើម្បីបិណ្ឌបាតទៀតផង ក៏អត់ចង្ហាន់ក្នុងពេលនោះឯង។ ទើបភិក្ខុនោះទៅអារាម ហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុ

ទាំងឡាយ។ ពួកភិក្ខុក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលចង្ហាន់មានគ្រហស្ថប្រារព្ធជាមុនហើយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលដឹងឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែងបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយកាលដឹងហើយ ឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែចង្ហាន់ដែលគ្រហស្ថបានប្រារព្ធជាមុន។**

[៨១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថាដឹង គឺភិក្ខុដឹងឯងក្ដី ជនទាំងឡាយដទៃដឹងហើយប្រាប់ដល់ភិក្ខុនោះក្ដី ភិក្ខុនីនោះប្រាប់ក្ដី។ ដែលហៅថា ភិក្ខុនី គឺស្ត្រីដែលបានឧបសម្បទាក្នុងសំណាក់ឧភតោសង្ឃ។ ដែលហៅថា ចាត់ចែង (គឺភិក្ខុនីនិយាយប្រាប់ដល់ជន) ដែលមិនចង់ឲ្យ មិនចង់ធ្វើទានក្នុងកាលមុនថា លោកម្ចាស់នេះជាអ្នកពោល លោកម្ចាស់នេះជាពហុស្សូត លោកម្ចាស់នេះជាអ្នកចេះព្រះសូត្រ លោកម្ចាស់នេះទ្រទ្រង់វិន័យ លោកម្ចាស់នេះជាធម្មកថិក អ្នកទាំងឡាយចូរឲ្យ (ចង្ហាន់) ដល់លោកម្ចាស់អង្គនេះ ចូរធ្វើ(ចង្ហាន់) ដល់លោកម្ចាស់នេះ ភិក្ខុនីនេះ ហៅថា ចាត់ចែង។ ដែលហៅថា បិណ្ឌបាត បានដល់ភោជនទាំង៥ ភោជនណាមួយ។ ពាក្យថា វៀរលែងតែចង្ហាន់ដែលគ្រហស្ថប្រារព្ធជាមុន សេចក្ដីថា លើកទុកតែចង្ហាន់ដែលគ្រហស្ថគេផ្ដើមជាមុន។ ដែលហៅថា គ្រហស្ថប្រារព្ធ គឺជនទាំងឡាយជាញាតិក្ដី បិណ្ឌបាតដែលគេបវារណាក្ដី ចង្ហាន់ដែលគេតាក់តែងជាប្រក្រតីក្ដី។ ភិក្ខុទទួលបិណ្ឌបាតដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែបិណ្ឌបាត ដែលគ្រហស្ថប្រារព្ធជាមុន។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលលេបចូល។

[៨២] ចង្ហាន់ដែលភិក្ខុនីចាត់ចែង ភិក្ខុសំគាល់ថាភិក្ខុនីចាត់ចែង ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែចង្ហាន់ដែលគ្រហស្ថប្រារព្ធជាមុន។ ចង្ហាន់ដែលភិក្ខុនីចាត់ចែង ភិក្ខុមានសេចក្ដីសង្ស័យ ហើយឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែចង្ហាន់ដែលគ្រហស្ថប្រារព្ធជាមុន។ ចង្ហាន់ដែលភិក្ខុនីចាត់ចែង ភិក្ខុសំគាល់ថាមិនបានចាត់ចែងទេ នឹងចង្ហាន់ដែលគ្រហស្ថប្រារព្ធជាមុន ហើយឆាន់ មិនត្រូវអាបត្តិឡើយ។ ភិក្ខុឆាន់ភោជនដែលភិក្ខុនីបានឧបសម្បទាក្នុងឯកតោសង្ឃបានចាត់ចែង ត្រូវអាបត្តិទុក្កដ វៀរលែងតែភោជនដែលគ្រហស្ថគេប្រារព្ធឡើងជាមុន។ ភិក្ខុសំគាល់ភោជនដែលភិក្ខុនីមិនបានចាត់ចែងថា បានចាត់ចែងទៅវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសង្ស័យក្នុងភោជនដែលភិក្ខុនីមិនបានចាត់ចែង ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ភោជនដែលភិក្ខុនីមិនបានចាត់ចែងថា មិនបានចាត់ចែង មិនត្រូវអាបត្តិ។

[៨៣] អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ភោជនដែលគ្រហស្ថប្រារព្ធឡើងជាមុន ដល់ភិក្ខុដែលឆាន់ភោជនដែលសិក្ខមានាចាត់ចែង ដល់ភិក្ខុដែលឆាន់ភោជនដែលសាមណេរីចាត់ចែង អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ភោជនទាំងពួងក្រៅពីភោជន៥យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ៩ ចប់។

## (បាចិត្តិយ ឱវាទវគ្គ) សិក្ខាបទ ទី១០ (៣០)

CS vin.vbu.pc.30 | ភាគ ទី៤

### (១០. រហោនិសជ្ជសិក្ខាបទំ)

[៨៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ស្ត្រីជាគូពីដើមរបស់ឧទាយិដ៏មានអាយុ បួសក្នុងសំណាក់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីនោះតែងមកក្នុងសំណាក់ឧទាយិដ៏មានអាយុរឿយៗ។ ចំណែកខាងឧទាយិដ៏មានអាយុ តែងទៅក្នុងសំណាក់ភិក្ខុនីនោះរឿយៗ។ គ្រានោះ ឧទាយិដ៏មានអាយុម្នាក់ឯង អង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីនោះតែម្នាក់ឯង។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វី បានជាឧទាយិដ៏មានអាយុម្នាក់ឯងសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីតែម្នាក់ឯង។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧទាយិភិក្ខុ ឮថាអ្នកឯងតែម្នាក់ឯងសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីម្នាក់ឯង ពិតមែនឬ។ ឧទាយិភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងតែម្នាក់ឯងមិនគួរនឹងសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីតែម្នាក់ឯងទេ នែមោឃបុរស ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាក្រៃលែងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ សម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីតែម្នាក់នឹងម្នាក់ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ។**

[៨៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទាក្នុងសំណាក់ឧភតោសង្ឃ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយ។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺភិក្ខុនិងភិក្ខុនី។ ដែលហៅថា ទីស្ងាត់ គឺទីកំបាំងភ្នែក១ ទីកំបាំងត្រចៀក១។ ដែលហៅថាទីកំបាំងភ្នែក គឺទីដែលគេមិចភ្នែកក្ដី ញាក់ចិញ្ចើមក្ដី ងក់ក្បាលក្ដី ក៏មិនអាចមើលឃើញបាន។ ដែលហៅថា ទីកំបាំងត្រចៀក គឺទីដែលគេមិនអាចដើម្បីស្ដាប់ពាក្យពោលជាប្រក្រតីបាន។ ពាក្យថា សម្រេចការអង្គុយ សេចក្ដីថា កាលភិក្ខុនីអង្គុយ ភិក្ខុអង្គុយជិតក្ដី ដេកជិតក្ដី ត្រូវអាបត្តិបាចិត្តិយ។ កាលភិក្ខុអង្គុយ ភិក្ខុនីអង្គុយជិតក្ដី ដេកជិតក្ដី ត្រូវអាបត្តិបាចិត្តិយ។ ជនទាំងពីររូប (គឺភិក្ខុនិងភិក្ខុនី) អង្គុយក្ដី ជនទាំងពីររូប (គឺភិក្ខុនិងភិក្ខុនី) ដេកក្ដី ត្រូវអាបត្តិបាចិត្តិយ។

[៨៦] ទីស្ងាត់ ភិក្ខុក៏សំគាល់ថាទីស្ងាត់ ហើយអង្គុយជាមួយនឹងភិក្ខុនីតែមួយនឹងមួយ ត្រូវអាបត្តិបាចិត្តិយ។ ទីស្ងាត់ តែភិក្ខុសង្ស័យ ហើយអង្គុយជាមួយនឹងភិក្ខុនីតែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ។ ទីស្ងាត់ ភិក្ខុសំគាល់ថាមិនស្ងាត់ ហើយអង្គុយជាមួយនឹងភិក្ខុនីតែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ។ ទីមិនស្ងាត់ ភិក្ខុសំគាល់ថាទីស្ងាត់ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងទីមិនស្ងាត់ ត្រូវអាបត្តិទុក្កដ។ ទីមិនស្ងាត់ ភិក្ខុក៏សំគាល់ថាមិនស្ងាត់ មិនត្រូវអាបត្តិឡើយ។

[៨៧] អាបត្តិមិនមានដល់ភិក្ខុដែលមានបុរសណានីមួយដែលដឹងសេចក្តីនៅជាពីរនាក់នឹងខ្លួន ដល់ភិក្ខុដែលឈរ មិនអង្គុយ ដល់ភិក្ខុដែលមានបំណងនូវទីមិនស្ងាត់ ហើយ(អង្គុយ) ដល់ភិក្ខុដែលមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃអង្គុយនៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ១០ ចប់។

ឱវាទវគ្គ ជាគំរប់៣ ចប់។

ចំនួនសិក្ខាបទនៃឱវាទវគ្គនោះមាន១០គឺ

អសម្មតសិក្ខាបទ (ភិក្ខុនោវាទសិក្ខាបទ)១ អដ្ឋង្គតសិក្ខាបទ១ ឧបស្សយសិក្ខាបទ (ភិក្ខុនូបស្សយ)១ អាមិសសិក្ខាបទ១ ទានសិក្ខាបទ (ចីវរទានសិក្ខាបទ)១ សិព្វនសិក្ខាបទ (ចីវរសិព្វនសិក្ខាបទ)១ អទ្ធានសិក្ខាបទ (សំវិធានសិក្ខាបទ)១ នាវាភិរុហនសិក្ខាបទ១ ភុញ្ជនសិក្ខាបទ (បរិបាចនសិក្ខាបទ)១ ឯកោឯកាយសិក្ខាបទ (រហោនិសជ្ជសិក្ខាបទ)១។

# ភោជនវគ្គ (ទី៤)

CS vin.vbu.pc.v4 | ភាគ ទី៤

## (៤. ភោជនវគ្គោ)

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី១ (៣១)

CS vin.vbu.pc.31 | ភាគ ទី៤

### (១. អាវសថបិណ្ឌសិក្ខាបទំ)

[៨៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង មានពួកជន១ពួកនៅជិតក្រុងសាវត្ថីបាននាំគ្នាតាក់តែងបិណ្ឌបាតក្នុងផ្ទះសំណាក់ ឬរោងទាន។ ឆព្វគ្គិយភិក្ខុទាំងឡាយនាំគ្នាស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរអំពីព្រឹក ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ដល់មិនបានបិណ្ឌបាត ក៏នាំគ្នាទៅកាន់ផ្ទះសំណាក់ ឬរោងទាន (នោះ)។ មនុស្សទាំងឡាយនិយាយគ្នាថា លោកម្ចាស់ទាំងឡាយខាននិមន្តមកយូរណាស់ហើយ (ថាដូច្នោះហើយ) ក៏នាំគ្នាអង្គាសដោយគោរព។ កាលនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ នាំគ្នាស្លៀកស្បង់ហើយប្រដាប់ដោយបាត្រនិងចីវរអំពីព្រឹក ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ដល់មិនបាន ក៏នាំគ្នាទៅកាន់ផ្ទះសំណាក់ ឬរោងទាន (នោះ) ហើយឆាន់ ក្នុងថ្ងៃជាគំរប់ពីរផង ក្នុងថ្ងៃជាគំរប់បីផង។ ទើបឆព្វគ្គិយភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយទៅអារាមធ្វើអ្វី យើងគួរតែមកក្នុងផ្ទះសំណាក់ ឬរោងទាននេះប៉ុណ្ណោះបានហើយ។ ឆព្វគ្គិយភិក្ខុទាំងឡាយនៅហើយនៅទៀតក្នុងផ្ទះសំណាក់នោះឯង នាំគ្នាឆាន់នូវអាវសថបិណ្ឌបាត (គឺបិណ្ឌបាតក្នុងផ្ទះសំណាក់ ឬរោងទាននោះ)។ តិរ្ថិយទាំងឡាយក៏ចៀសចេញទៅ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនគួរនឹងនៅត្រាំត្រែងឆាន់អាវសថបិណ្ឌបាត អាវសថបិណ្ឌបាត មិនមែនជនតាក់តែងដើម្បីតែពួកសមណៈនេះទេ អាវសថបិណ្ឌបាត ជនតាក់តែងដើម្បីជនទាំងឡាយទាំងពួងរាល់គ្នា។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ)ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុទាំងឡាយ មិនគួរនឹងនៅត្រាំត្រែងឆាន់អាវសថបិណ្ឌបាតសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយនៅត្រាំត្រែងឆាន់អាវសថបិណ្ឌបាត ពិតមែនឬ។ ឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងនៅត្រាំត្រែងឆាន់អាវសថបិណ្ឌបាតទេ ម្នាលមោឃបុរសទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិននាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

អាហារក្នុងផ្ទះសំណាក់ ឬរោងទាន ភិក្ខុត្រូវឆាន់បានតែម្តង បើឆាន់ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៨៩] សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុនិមន្តទៅក្រុងសាវត្ថីក្នុងកោសលជនបទ បានចូលទៅកាន់ផ្ទះសំណាក់ ឬរោងទាន១។ មនុស្សទាំងឡាយនិយាយគ្នាថា ព្រះថេរៈខាននិមន្តមកយូរណាស់ហើយ (ថាដូច្នោះហើយ) ក៏នាំគ្នាអង្គាសដោយគោរព។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុឆាន់រួចហើយ ក៏មានអាពាធជាទម្ងន់។ លោកមិនអាចនឹងចៀសចេញពីផ្ទះសំណាក់ ឬរោងទាននោះទៅបាន។ ទើបមនុស្ស

ទាំងឡាយនោះ បានពោលពាក្យនេះនឹងព្រះសារីបុត្តដ៏មានអាយុក្នុងថ្ងៃជាគំរប់ពីរថា បពិត្រព្រះថេរដ៏ចំរើន សូមលោកនិមន្តឆាន់ចុះ។ ព្រះសារីបុត្តដ៏មានអាយុមានសេចក្តីសង្ស័យថា ការដែលនៅត្រាំត្រែងឆាន់បិណ្ឌបាតក្នុងផ្ទះសំណាក់ ឬរោងទាន ព្រះដ៏មានព្រះភាគបានហាមហើយ ហើយមិនទទួលបិណ្ឌបាត ក៏អត់ចង្ហាន់ក្នុងពេលនោះ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុនិមន្តទៅកាន់ក្រុងសាវត្ថី ហើយដំណាលសេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ៗក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជម្ងឺអាស្រ័យនៅរឿយៗ ឆាន់ភោជនក្នុងរោងទានបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**បិណ្ឌបាតក្នុងរោងទាន ភិក្ខុមិនមានជម្ងឺត្រូវឆាន់បានតែម្តង បើឆាន់ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។**

[៩០] ភិក្ខុដែលអាចដើម្បីចៀសចេញពីរោងទាននោះទៅបាន ហៅថា មិនមានជម្ងឺ។ ភិក្ខុដែលមិនអាចដើម្បីចៀសចេញពីរោងទាននោះទៅបាន ហៅថា មានជម្ងឺ។ ដែលហៅថា បិណ្ឌបាតក្នុងរោងទាន បានដល់ភោជនទាំង៥យ៉ាង ភោជនណាមួយដែលគេតាក់តែងក្នុងសាលាក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងទីវាលក្តី មិនចំពោះបុគ្គលណា គេតាក់តែងកំណត់ល្មមមួយឆ្អែត (គ្រប់ៗគ្នា)។ ភិក្ខុមិនមានជម្ងឺត្រូវឆាន់បានតែម្តង បើទទួលឲ្យហួសពីកំណត់នោះទៅ ដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលលេបចូលទៅ។

[៩១] ខ្លួនមិនមានជម្ងឺ ភិក្ខុសំគាល់ថាមិនមានជម្ងឺ ហើយបរិភោគអាវសថបិណ្ឌបាតឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។ ខ្លួនមិនមានជម្ងឺ ភិក្ខុមានសេចក្តីសង្ស័យ ហើយបរិភោគអាវសថបិណ្ឌបាតឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។ ខ្លួនមិនមានជម្ងឺ ភិក្ខុសំគាល់ថាមានជម្ងឺ ហើយឆាន់អាវសថបិណ្ឌបាតឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។ ខ្លួនមានជម្ងឺ ភិក្ខុសំគាល់ថាមិនមានជម្ងឺ ត្រូវអាបត្តិទុក្កដ។ ខ្លួនមានជម្ងឺ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ ខ្លួនមានជម្ងឺ ភិក្ខុសំគាល់ថាមានជម្ងឺ មិនត្រូវអាបត្តិឡើយ។

[៩២] អាបត្តិមិនមានដល់ភិក្ខុមានជម្ងឺ ដល់ភិក្ខុមិនមានជម្ងឺឆាន់តែម្តង ដល់ភិក្ខុដែលដើរទៅក្តី ដើរមកក្តី ហើយឆាន់[8] ដល់ភិក្ខុដែលជនជាម្ចាស់ទានគេនិមន្តឲ្យឆាន់ ដល់ភិក្ខុដែលឆាន់បិណ្ឌបាតដែលគេតាក់តែងចំពោះ ដល់ភិក្ខុដែលឆាន់បិណ្ឌបាតដែលគេតាក់តែងមិនដល់មួយចំអែត អាបត្តិមិនមានដល់ភិក្ខុព្រោះឆាន់ភោជនទាំងពួងក្រៅពីភោជន៥យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ១ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី២ (៣២)

CS vin.vbu.pc.32 | ភាគ ទី៤

### (២. គណភោជនសិក្ខាបទំ)

[៩៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង ទេវទត្តមានលាភសក្ការៈសាបសូន្យហើយ ព្រមទាំងបរិស័ទក៏នាំគ្នាដើរសូមរឿយៗក្នុងពួកត្រកូលហើយឆាន់។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធបុត្រសក្យរាជ មិនគួរនឹងនាំគ្នាដើរសូមរឿយៗក្នុងពួកត្រកូលហើយឆាន់សោះ (ធម្មតាមនុស្ស) អ្នកណាមួយដែលមិនគាប់ចិត្តនឹងភោជនល្អ អ្នកណាមួយដែលមិនពេញចិត្តនឹងភោជនដ៏ឆ្ងាញ់ពីសារ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ)ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តព្រមទាំងបរិសទ្យ មិនគួរនឹងនាំគ្នាដើរសូមរឿយៗក្នុងត្រកូលទាំងឡាយហើយឆាន់សោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលទេវទត្ត ឮថាអ្នកឯងព្រមទាំងបរិសទ្យនាំគ្នាដើរសូមរឿយៗក្នុងត្រកូលទាំងឡាយ ហើយឆាន់ ពិតមែនឬ។ ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងព្រមទាំងបរិសទ្យ មិនគួរនឹងដើរសូមរឿយៗក្នុងត្រកូលទាំងឡាយ ហើយឆាន់ទេ ម្នាលមោឃបុរស ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិននាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាក្រៃលែងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុឆាន់គណភោជន ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៩៤] សម័យនោះឯង មនុស្សទាំងឡាយនិមន្តពួកភិក្ខុដែលមានជម្ងឺដោយភត្ត។ ពួកភិក្ខុសង្ស័យ មិនទទួល ដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ ទើបពួកភិក្ខុ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជម្ងឺឆាន់គណភោជនបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៩៥] សម័យនោះឯង មនុស្សទាំងឡាយតាក់តែងចង្ហាន់ព្រមទាំងចីវរ ក្នុងសម័យចីវរទាន ហើយនិមន្តភិក្ខុទាំងឡាយថា យើងទាំងឡាយនឹងនិមន្តលោកម្ចាស់ទាំងឡាយឲ្យឆាន់ រួចហើយនឹងប្រគេនចីវរឲ្យស្លៀកដណ្តប់។ ភិក្ខុទាំងឡាយ សង្ស័យមិនទទួលដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ ចីវរក៏កើតឡើងដល់ភិក្ខុដោយស្តួចស្តើង។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយឆាន់គណភោជនបានក្នុងសម័យនៃចីវរទាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ១ សម័យដែលគេឲ្យចីវរ១ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៩៦] សម័យនោះឯង មនុស្សទាំងឡាយ និមន្តពួកភិក្ខុដែលជាអ្នកធ្វើចីវរ ដោយចង្ហាន់។ ភិក្ខុទាំងឡាយសង្ស័យ មិនទទួលដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណភោជនបានក្នុងសម័យដែលធ្វើចីវរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ១ សម័យដែលគេប្រគេនចីវរ១ សម័យដែលធ្វើចីវរ១ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៩៧] សម័យនោះឯង ភិក្ខុទាំងឡាយទៅកាន់ផ្លូវឆ្ងាយ មួយអន្លើដោយមនុស្សទាំងឡាយ។ ឯភិក្ខុទាំងនោះ និយាយពាក្យនេះនឹងមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចូរបង្អង់ចាំ១រំពេច យើងទាំងឡាយនឹងត្រាច់ទៅដើម្បីបិណ្ឌបាត។ មនុស្សទាំងឡាយនោះ និយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយនិមន្តឆាន់ក្នុងទីនេះចុះ។ ភិក្ខុទាំងឡាយ សង្ស័យ មិនទទួលដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណភោជន ក្នុងសម័យដែលដើរផ្លូវឆ្ងាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ១ សម័យដែលគេប្រគេនចីវរ១ សម័យដែលធ្វើនូវចីវរ១ សម័យដែលទៅកាន់ផ្លូវឆ្ងាយ១ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៩៨] សម័យនោះឯង ភិក្ខុទាំងឡាយទៅដោយទូក មួយអន្លើដោយមនុស្សទាំងឡាយ។ ឯភិក្ខុទាំងនោះ និយាយពាក្យនេះនឹងមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចូរអែបទូកទៀបឆ្នេរមួយរំពេចសិន យើងទាំងឡាយនឹងត្រាច់ទៅដើម្បីបិណ្ឌបាត។ មនុស្សទាំងឡាយនោះ និយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយឆាន់ចង្ហាន់ក្នុងទីនេះចុះ។ ភិក្ខុទាំងឡាយ សង្ស័យ មិនហ៊ានទទួលដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណភោជន ក្នុងសម័យឡើងជិះទូកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ១ សម័យដែលគេប្រគេនចីវរ១ សម័យដែលធ្វើចីវរ១ សម័យដែលទៅកាន់ផ្លូវឆ្ងាយ១ សម័យដែលឡើងជិះទូក១ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៩៩] សម័យនោះឯង ភិក្ខុទាំងឡាយនៅចាំវស្សាក្នុងទិសទាំងឡាយ លុះចេញវស្សារួចហើយ ក៏នាំគ្នាមកឯក្រុងរាជគ្រឹះដើម្បីគាល់ព្រះដ៏មានព្រះភាគ។ ពួកមនុស្សឃើញភិក្ខុទាំងឡាយមកពីរដ្ឋសីមា[9] ផ្សេងៗគ្នា ហើយក៏និមន្តឆាន់។ ភិក្ខុទាំងឡាយ សង្ស័យ មិនទទួលដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយឆាន់គណភោជន ក្នុងមហាសម័យបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ១ សម័យដែលគេប្រគេនចីវរ១ សម័យដែលធ្វើនូវចីវរ១ សម័យដែលទៅកាន់ផ្លូវឆ្ងាយ១ សម័យដែលឡើងជិះទូក១ សម័យដែលមានភិក្ខុច្រើន១ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១០០] សម័យនោះឯង (មានបុរសម្នាក់) ត្រូវជាញាតិសាលោហិតរបស់ព្រះបាទមាគធសេនិយពិម្ពិសាររាជ បានបួសក្នុងសំណាក់អាជីវកទាំងឡាយ។ លំដាប់នោះ អាជីវកនោះចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសាររាជ ហើយបានទូលពាក្យនេះចំពោះព្រះបាទមាគធសេនិយពិម្ពិសាររាជថា បពិត្រមហារាជ អាត្មាប្រាថ្នាដើម្បីធ្វើនូវភត្តជារបៀបបាសណ្ឌសុទ្ធ។[10] ព្រះបាទមាគធសេនិយពិម្ពិសាររាជត្រាស់ថា បពិត្រលោកដ៏ចំរើន បើលោកនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឆាន់មុនសិន (ទើប) យើងត្រូវធ្វើយ៉ាងនេះ (បាន)។ អាជីវកនោះក៏ប្រើបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយក្នុងពេលនោះថា ភិក្ខុទាំងឡាយសូមទទួលចង្ហាន់របស់ខ្ញុំដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក។ ភិក្ខុទាំងឡាយសង្ស័យ មិនទទួលដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ គ្រានោះ អាជីវកនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ដល់ហើយ ក៏ពោលពាក្យជាទីរាក់ទាក់ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលបុគ្គលគប្បីរីករាយ ដែលបុគ្គលគប្បីរលឹកស្រេចហើយ ក៏ស្ថិតនៅក្នុងទីដ៏សមគួរ។ អាជីវកនោះ លុះស្ថិតនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា ព្រះគោតមដ៏ចំរើនជាអ្នកបួស ខ្ញុំព្រះអង្គក៏ជាអ្នកបួសដែរ អ្នកបួសគួរទទួលដុំបាយរបស់អ្នកបួសផងគ្នា ព្រះគោតមដ៏ចំរើន សូមទទួលចង្ហាន់របស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក មួយអន្លើដោយភិក្ខុសង្ឃ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតណ្ហីភាព។ អាជីវកនោះដឹងច្បាស់ជាព្រះដ៏មានព្រះភាគទទួលនិមន្តហើយ ក៏ចៀសចេញទៅក្នុងពេលនោះ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកជួបជុំក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណភោជន ក្នុងសម័យនៃសមណភត្តបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ១ សម័យដែលគេប្រគេនចីវរ១ សម័យដែលធ្វើនូវចីវរ១ សម័យដែលដើរផ្លូវឆ្ងាយ១ សម័យដែលឡើងជិះទូក១ សម័យដែលមានភិក្ខុច្រើនអង្គ១ សម័យនៃសមណភត្ត១ នេះជាសម័យក្នុងសិក្ខាបទនោះ។**

[១០១] ដែលហៅថា គណភោជន គឺភិក្ខុ៤រូបដែលគេនិមន្តចេញ ឈ្មោះភោជនទាំង៥ ដោយភោជនណាមួយ ហើយឆាន់ភោជនណា ភោជននុ៎ះហៅថា គណភោជន។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកទុកតែមានសម័យ (គឺហេតុដែលគួរនឹងឆាន់បាន)។ ដែលហៅថា សម័យមានជម្ងឺ ដោយហោចទៅ សូម្បីតែជើងទាំងឡាយដែលបែក (បាក់ផ្តៅក៏ហៅថាមានជម្ងឺ)។ ភិក្ខុដឹងថាខ្លួនមានសម័យឈឺថ្កាត់ហើយ គប្បីឆាន់គណភោជនបាន។ ដែលហៅថា សម័យដែលគេប្រគេនចីវរ គឺថាកាលបើភិក្ខុមិនបានក្រាលកឋិនទេ (សម័យនៃចីវរទាន) បានត្រឹមតែ១ខែ គឺខែជាខាងចុងនៃវស្សានរដូវ[11] បើភិក្ខុបានក្រាលកឋិន (សម័យនៃចីវរទាន) បាន៥ខែ។[12] ភិក្ខុដឹងថាមានសម័យនៃចីវរទានហើយ គប្បីឆាន់គណភោជនបាន។ ដែលហៅថា សម័យដែលធ្វើនូវចីវរ គឺកាលដែលភិក្ខុកំពុងធ្វើចីវរ។ ភិក្ខុដឹងថាមានសម័យជាទីធ្វើនូវចីវរហើយ គប្បីឆាន់គណភោជនបាន។ ដែលហៅថា សម័យដែលដើរផ្លូវឆ្ងាយ គឺភិក្ខុដឹងថា អញនឹងដើរផ្លូវឆ្ងាយប្រមាណកន្លះយោជន៍ហើយ គប្បីឆាន់គណភោជនបាន។ កាលភិក្ខុកំពុងដើរទៅ ក៏គប្បីឆាន់គណភោជនបាន។ កាលភិក្ខុមកវិញ ក៏គប្បីឆាន់គណភោជនបាន។ ដែលហៅថា សម័យឡើងជិះទូក គឺភិក្ខុដឹងថា អញនឹងឡើងជិះទូក ហើយគប្បីឆាន់គណភោជនបាន។ ភិក្ខុឡើងជិះទូកហើយគប្បីឆាន់គណភោជនបាន។ កាលភិក្ខុចុះអំពីទូកហើយគប្បីឆាន់គណភោជនបាន។ ដែលហៅថា សម័យមានភិក្ខុច្រើនអង្គ គឺសម័យដែលភិក្ខុទាំងឡាយពីរ ឬបីអង្គត្រាច់ទៅដើម្បីបិណ្ឌបាត ហើយបានឆាន់ឆ្អែតក្នុងទីណា ដល់ភិក្ខុមួយអង្គមកទៀត ត្រូវជាបួនអង្គ ឆាន់មិនឆ្អែត។ ភិក្ខុដឹងថា សម័យមានភិក្ខុច្រើនអង្គដូច្នេះ ហើយគប្បីឆាន់គណភោជនបាន។ ដែលហៅថា សម័យនៃសមណភត្ត គឺអ្នកណាមួយដែលរាប់បញ្ចូលក្នុងពួកអ្នកបួស (ក្រៅព្រះពុទ្ធសាសនា) ធ្វើភត្ត។ ភិក្ខុដឹងថា សម័យនៃសមណភត្ត ហើយគប្បីឆាន់គណភោជនបាន។ ភិក្ខុទទួលគណភោជនដោយគិតថា អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសម័យ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលលេបចូលក្នុងក។

[១០២] គណភោជន ភិក្ខុសំគាល់ថាគណភោជនមែន ហើយបរិភោគ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុសង្ស័យក្នុងគណភោជនហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុសំគាល់ក្នុងគណភោជនថា មិនមែនគណភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ មិនមែនគណភោជន ភិក្ខុសំគាល់ថាគណភោជន ត្រូវអាបត្តិទុក្កដ។ មិនមែនគណភោជន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនគណភោជន ភិក្ខុសំគាល់ថា មិនមែនគណភោជន មិនត្រូវអាបត្តិ។

[១០៣] អាបត្តិមិនមានដល់ភិក្ខុមានសម័យ ដល់ភិក្ខុទាំងឡាយពីរឬបីអង្គដែលឆាន់ជាមួយគ្នា ដល់ភិក្ខុទាំងឡាយដែលត្រាច់ទៅដើម្បីបិណ្ឌបាត ហើយប្រជុំគ្នាឆាន់ក្នុងទីជាមួយគ្នា ដល់ភិក្ខុដែលឆាន់និច្ចភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត អាបត្តិមិនមាន

ដល់ភិក្ខុដែលឆាន់ភោជនទាំងពួងក្រៅពីភោជន៥យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ២ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី៣ (៣៣)

CS vin.vbu.pc.33 | ភាគ ទី៤

### (៣. បរម្បរភោជនសិក្ខាបទំ)

[១០៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅកូដាគារសាលា ក្នុងមហាវន ក្បែរក្រុងវេសាលី។ សម័យនោះឯង ក្រុងវេសាលី គេបានចាត់ចែងភត្តដ៏ឧត្តមទាំងឡាយតាំងនៅជានិច្ច។ គ្រានោះ អ្នកធ្វើការម្នាក់ជាមនុស្សទាល់ក្រ មានសេចក្តីត្រិះរិះដូច្នេះថា មនុស្សទាំងឡាយនេះធ្វើភត្តដោយគោរព តាមទំនងយ៉ាងណា (ទំនង) នេះមិនមែនជាថោកទាបឡើយ បើដូច្នោះ មានតែអញត្រូវធ្វើភត្តនឹងគេដែរ។ ឯអ្នកធ្វើការងារដែលជាមនុស្សទាល់ក្រនោះ ចូលទៅរកបុរសឈ្មោះកិរបតិក លុះចូលទៅហើយ ក៏បាននិយាយពាក្យនេះនឹងបុរសឈ្មោះកិរបតិកនោះថា បពិត្រអយ្យបុត្រ ខ្ញុំប្រាថ្នាដើម្បីធ្វើភត្តដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន សូមអ្នកឲ្យថ្លៃឈ្នួលមកខ្ញុំចុះ។ បុរសឈ្មោះកិរបតិកនោះឯង ក៏ជាមនុស្សមានសទ្ធាជ្រះថ្លាដែរ។ ឯបុរសឈ្មោះកិរបតិកនោះ បានឲ្យថ្លៃឈ្នួលច្រើនគ្រាន់បើដល់អ្នកធ្វើការងារដែលជាមនុស្សទាល់ក្រនោះ។ គ្រានោះ អ្នកធ្វើការងារដែលជាមនុស្សទាល់ក្រនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ បុរសអ្នកធ្វើការងារដែលជាមនុស្សទ័លក្រនោះ លុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគសូមទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែកមួយអន្លើដោយភិក្ខុសង្ឃ។ ព្រះអង្គត្រាស់សួរថា ម្នាលអាវុសោ ភិក្ខុសង្ឃច្រើនណាស់ អ្នកចូរដឹងចុះ។ បុរសកំសត់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃច្រើនក៏ច្រើនចុះ (ព្រោះ) ផ្លែពទ្រាមានប្រមាណច្រើន ខ្ញុំព្រះអង្គបានចាត់ចែងហើយ គ្រឿងផឹកទាំងឡាយនឹងបរិបូណ៌ដោយបបរលាយដោយផ្លែពទ្រា។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព។ គ្រានោះ បុរសអ្នកធ្វើការងារដ៏កំសត់នោះដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ ភិក្ខុទាំងឡាយបានដំណឹងថា ឮថា ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន អ្នកធ្វើការងារដ៏កំសត់បាននិមន្តហើយដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក គ្រឿងផឹកទាំងឡាយនឹងបរិបូណ៌ដោយបបរលាយដោយផ្លែពទ្រា។ ភិក្ខុទាំងនោះត្រាច់ទៅ ដើម្បីបិណ្ឌបាត ហើយឆាន់តាំងអំពីព្រឹក។ មនុស្សទាំងឡាយបានដំណឹងថា ឮថា ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន អ្នកធ្វើការងារដ៏កំសត់បាននិមន្តហើយ។ មនុស្សទាំងនោះនាំយកខាទនីយភោជនីយមានប្រមាណច្រើន ទៅដើម្បីអ្នកធ្វើការងារដ៏កំសត់ (នោះ)។ លុះព្រឹកឡើង ទើបអ្នកធ្វើការងារដ៏កំសត់នោះឲ្យមនុស្សតាក់តែងខាទនីយភោជនីយដ៏ឧត្តម ហើយឲ្យគេក្រាបទូលនូវភត្តកាលចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តសម្រេចហើយ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរអំពីព្រឹក រួចហើយយាងចូលទៅកាន់លំនៅអ្នកធ្វើការងារដ៏កំសត់នោះ លុះចូលទៅដល់ហើយក៏គង់លើអាសនៈដែលគេតាក់តែងថ្វាយមួយអន្លើដោយភិក្ខុសង្ឃ។ ទើបអ្នកធ្វើការងារដ៏កំសត់នោះក៏អង្គាសភិក្ខុទាំងឡាយក្នុងរោងភត្ត។ ពួកភិក្ខុពោលយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចហើយ ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចហើយ។ អ្នកធ្វើការងារដ៏កំសត់នោះឆ្លើយថា បពិត្រលោកទាំងឡាយដ៏ចំរើន លោកទាំងឡាយសូមកុំទទួលនូវវត្ថុបន្តិចៗ ដោយគិតថា អ្នកធ្វើការងារនេះជាមនុស្សកំសត់ឡើយ (ព្រោះ) ខាទនីយភោជនីយមានប្រមាណច្រើន ខ្ញុំព្រះករុណាឲ្យគេតាក់តែងហើយ បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកទាំងឡាយទទួល (ឆាន់) ត្រាតែឆ្អែត។ ពួកភិក្ខុឆ្លើយថា ម្នាលអាវុសោ យើងទាំងឡាយទទួលវត្ថុបន្តិចៗ ព្រោះតែហេតុនេះ ក៏មិនមែនទេ មកពីយើងទាំងឡាយត្រាច់ទៅដើម្បីបិណ្ឌបាតឆាន់តាំងអំពីព្រឹកហើយ ហេតុនោះបានជាយើងទាំងឡាយទទួលតែបន្តិចៗម្នាក់។ លំដាប់នោះ អ្នកធ្វើការងារដ៏កំសត់នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកទាំងឡាយដ៏ចំរើន ខ្ញុំបាននិមន្តហើយ មិនគួរនឹងឆាន់ក្នុងទីដទៃសោះ ឬខ្ញុំមិនអាចដើម្បីប្រគេនឲ្យឆាន់ឆ្អែតទេដឹង។ ភិក្ខុទាំងឡាយឮអ្នកធ្វើការងារដ៏កំសត់នោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុដែលគេបាននិមន្តក្នុងទីដទៃហើយ មិនគួរនឹងឆាន់ក្នុងទីដទៃសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុ ជនគេបាននិមន្តក្នុងទីដទៃហើយ ត្រឡប់ឆាន់ក្នុងទីដទៃវិញ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ គេបាននិមន្តក្នុងទីដទៃហើយ មិនគួរនឹងឆាន់ក្នុងទីដទៃ ម្នាលភិក្ខុទាំងឡាយ ការនេះនឹងនាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន[13] (គឺភោជនដែលគេនិមន្តខាងក្រោយ)

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១០៥] សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺ។ ភិក្ខុ១រូបទៀតកាន់យកចង្ហាន់បិណ្ឌបាតចូលទៅរកភិក្ខុនោះ លុះចូលទៅហើយ បាននិយាយពាក្យនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរឆាន់។ ភិក្ខុមានជម្ងឺឆ្លើយថា ម្នាលអាវុសោ កុំឡើយ ចង្ហាន់ដែលគេបម្រុងឲ្យខ្ញុំមានហើយ។ បិណ្ឌបាតដែលគេនាំយកមកប្រគេនភិក្ខុនោះក្នុងពេលថ្ងៃពេក។ ភិក្ខុមានជម្ងឺនោះឆាន់មិនបានដោយស្រួលសោះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជម្ងឺឆាន់បរម្បរភោជនបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលភិក្ខុមានជម្ងឺ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១០៦] សម័យនោះឯង មនុស្សទាំងឡាយតាក់តែងភត្តព្រមទាំងចីវរ ក្នុងសម័យនៃចីវរទាន ហើយនិមន្តភិក្ខុទាំងឡាយថា ពួកយើងនឹងនិមន្តលោកម្ចាស់ទាំងឡាយឆាន់ រួច(នឹងប្រគេន)ចីវរឲ្យស្លៀកដណ្តប់។ ភិក្ខុទាំងឡាយសង្ស័យ មិនទទួលដោយគិតថា បរម្បរភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ ចីវរក៏កើតឡើងដល់ភិក្ខុដោយស្តួចស្តើង។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់បរម្បរភោជនក្នុងសម័យនៃចីវរទានបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលភិក្ខុមានជម្ងឺ១ សម័យនៃចីវរទាន១ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១០៧] សម័យនោះឯង មនុស្សទាំងឡាយ និមន្តពួកភិក្ខុជាអ្នកធ្វើចីវរ ឲ្យឆាន់ចង្ហាន់។ ភិក្ខុទាំងឡាយសង្ស័យ មិនទទួលដោយគិតថា បរម្បរភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់បរម្បរភោជនក្នុងសម័យជាទីធ្វើនូវចីវរបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលភិក្ខុមានជម្ងឺ១ សម័យនៃចីវរទាន១ សម័យជាទីធ្វើនូវចីវរ១ នេះជាសម័យក្នុងសិក្ខាបទនោះ។**

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១០៨] គ្រានោះ ពេលបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរ មានព្រះអានន្ទដ៏មានអាយុជាបច្ឆាសមណៈ ព្រះអង្គទ្រង់យាងចូលទៅកាន់ត្រកូល១ លុះចូលទៅហើយ ក៏ទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយ។ ទើបមនុស្សទាំងឡាយនោះបានថ្វាយភោជនដល់ព្រះដ៏មានព្រះភាគផង ដល់ព្រះអានន្ទដ៏មានអាយុផង។ ព្រះអានន្ទដ៏មានអាយុសង្ស័យ មិនហ៊ានទទួល ព្រះអង្គត្រាស់ថា ម្នាលអានន្ទ អ្នកទទួលចុះ។ ព្រះអានន្ទក្រាបទូលថា សូមទ្រង់មេត្តាប្រោស ក្រែងមិនគួរ ព្រោះខ្ញុំព្រះអង្គមានចង្ហាន់គេបម្រុងនឹងប្រគេនហើយ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរកំណត់ (ចង្ហាន់នោះដល់ភិក្ខុឯទៀត) ហើយទទួលយក (ចង្ហាន់នេះ) ចុះ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកំណត់នូវចង្ហាន់ដែលគេបម្រុងដើម្បីខ្លួនដល់ភិក្ខុឯទៀត ហើយឆាន់បរម្បរភោជនបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីកំណត់ដោយពាក្យយ៉ាងនេះថា ខ្ញុំឲ្យនូវភត្តដែលគេបម្រុងទុកដើម្បីខ្ញុំដល់ភិក្ខុឈ្មោះនេះ។

[១០៩] ដែលហៅថា បរម្បរភោជន គឺ(ភិក្ខុ)ដែលគេនិមន្តដោយភោជន៥យ៉ាង ភោជនណាមួយ ហើយវៀរភោជននោះ បែរទៅឆាន់ភោជន៥យ៉ាង ភោជនណាមួយនៅទីដទៃ ភោជននុ៎ះហៅថា បរម្បរភោជន។ ពាក្យថា វៀរតែមានសម័យ គឺលើកទុកតែមានសម័យ (គឺហេតុដែលគួរនឹងឆាន់បាន)។ ដែលហៅថា សម័យដែលភិក្ខុមានជម្ងឺ គឺភិក្ខុមិនអាចនឹងអង្គុយឆាន់ដរាបទាល់ឆ្អែតលើអាសនៈមួយ។ ភិក្ខុដឹងថាខ្លួនមានសម័យឈឺថ្កាត់ហើយ គប្បីឆាន់(បរម្បរភោជនបាន)។ ដែលហៅថាសម័យនៃចីវរទាន គឺបើភិក្ខុមិនបានក្រាលកឋិនទេ សម័យចីវរទាន មានតែ១ខែ គឺខែជាទីបំផុតនៃវស្សានរដូវ បើភិក្ខុបានក្រាលកឋិន សម័យនៃចីវរទាន មាន៥ខែ។ ភិក្ខុដឹងថាសម័យនៃចីវរទាន គប្បីឆាន់(បរម្បរភោជនបាន)។ ដែលហៅថា សម័យជាទីធ្វើនូវចីវរ គឺកាលដែលភិក្ខុកំពុងធ្វើចីវរ។ ភិក្ខុដឹងថាសម័យជាទីធ្វើនូវចីវរ គប្បីឆាន់(បរម្បរភោជនបាន)។ ភិក្ខុទទួល(បរម្បរភោជន)ដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសម័យ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលលេប។

[១១០] ភិក្ខុសំគាល់ក្នុងបរម្បរភោជនថាបរម្បរភោជនមែន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងបរម្បរភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ភិក្ខុសំគាល់ក្នុងបរម្បរភោជនថា មិនមែនបរម្បរភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ មិនមែនបរម្បរភោជន ភិក្ខុសំគាល់ថាបរម្បរភោជន ត្រូវអាបត្តិទុក្កដ។ មិនមែនបរម្បរភោជន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនបរម្បរភោជន ភិក្ខុសំគាល់ថា មិនមែនជាបរម្បរភោជន មិនត្រូវអាបត្តិឡើយ។

[១១១] អាបត្តិមិនមានដល់(ភិក្ខុដែលឆាន់បរម្បរភោជន)ក្នុងសម័យ ដល់ភិក្ខុដែលបានកំណត់ (បរម្បរភោជនដល់ភិក្ខុឯទៀត) ហើយឆាន់ ដល់ភិក្ខុពីរបីអង្គឆាន់ជាមួយគ្នាក្នុងទីដែលគេនិមន្ត ដល់ភិក្ខុឆាន់តាមលំដាប់លំដោយដែលគេនិមន្ត ដល់ភិក្ខុដែលអ្នកស្រុកទាំងអស់និមន្ត ហើយឆាន់ក្នុងទីណាមួយក្នុងស្រុកនោះ ដល់ភិក្ខុដែលប្រជុំជនទាំងអស់និមន្ត ហើយឆាន់ក្នុងទីណាមួយក្នុងប្រជុំជននោះ ដល់ភិក្ខុដែលគេនិមន្តហើយ

ពោលថា អាត្មានឹងទទួលតែចង្ហាន់ (ដែលបានមកដោយត្រាច់បិណ្ឌបាត) ដល់ភិក្ខុដែលឆាន់និច្ចភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ភោជនទាំងពួងក្រៅពីភោជន៥យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ៣ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី៤ (៣៤)

CS vin.vbu.pc.34 | ភាគ ទី៤

### (៤. កាណមាតុសិក្ខាបទំ)

[១១២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀតក្រុងសាវត្ថី។ គ្រានោះឯង ឧបាសិកាជាមាតារបស់នាងកាណា ជាស្ត្រីមានសទ្ធាជ្រះថ្លា។ (ឧបាសិកានោះ) បានឲ្យនាងកាណាជាកូនទៅបុរស១នាក់នៅក្នុងស្រុកតូច១។ គ្រានោះ នាងកាណាបានទៅផ្ទះមាតាដោយកិច្ចអ្វីនីមួយដែលខ្លួនត្រូវធ្វើ។ ទើបប្តីនាងកាណាប្រើបម្រើទៅក្នុងសំណាក់នាងកាណាថា នាងកាណាចូរមក អញចង់ឲ្យនាងកាណាត្រឡប់មកវិញ។ កាលនោះ ឧបាសិកាជាមាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេដូចម្តេចនឹងកើត (គិតដូច្នោះហើយ) នាងក៏ចំអិននំ។ ដល់នំឆ្អិន មានភិក្ខុអ្នកត្រាច់បិណ្ឌបាត១អង្គចូលទៅកាន់លំនៅរបស់ឧបាសិកាជាមាតានាងកាណា។ ទើបឧបាសិកាជាមាតារបស់នាងកាណាឲ្យគេប្រគេននំដល់ភិក្ខុនោះ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុដទៃ។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត។ នំដែលមាតារបស់នាងកាណាបានចាត់ចែងហើយយ៉ាងណា ក៏អស់គ្មានសល់។ ស្វាមីរបស់នាងកាណាប្រើបម្រើទៅក្នុងសំណាក់នាងកាណាជាគំរប់ពីរដងថា នាងកាណាចូរមកវិញ អញចង់ឲ្យនាងកាណាត្រឡប់មកវិញ។ ឧបាសិកាជាមាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេដូចម្តេចនឹងកើត (គិតដូច្នោះហើយ) ក៏ចំអិននំអស់វារៈជាគំរប់ពីរដង។ កាលនំឆ្អិន មានភិក្ខុ១អង្គ អ្នកត្រាច់ទៅដើម្បីបិណ្ឌបាត ចូលទៅកាន់លំនៅរបស់ឧបាសិកាជាមាតានាងកាណា។ ទើបឧបាសិកាជាមាតារបស់នាងកាណាឲ្យគេប្រគេននំដល់ភិក្ខុនោះ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត។ (ឧបាសិកា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត។ (ឧបាសិកា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត។ នំដែលឧបាសិកាបានចាត់ចែងហើយទាំងប៉ុន្មាន ក៏អស់គ្មានសល់។ ស្វាមីរបស់នាងកាណាក៏ប្រើបម្រើទៅក្នុងសំណាក់នាងកាណា ជាគំរប់បីដងថា នាងកាណាចូរមកវិញ អញចង់ឲ្យនាងកាណាត្រឡប់មកវិញ ថាបើនាងកាណាមិនត្រឡប់មកវិញទេ អញនឹងយកប្រពន្ធឯទៀតហើយ។ ឧបាសិកាជាមាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេដូចម្តេចនឹងកើត (គិតដូច្នោះហើយ) ក៏ចំអិននំអស់វារៈជាគំរប់បីដង។ កាលនំឆ្អិន មានភិក្ខុអ្នកត្រាច់ទៅដើម្បីបិណ្ឌបាត១អង្គ ចូលទៅកាន់លំនៅរបស់ឧបាសិកាជាមាតារបស់នាងកាណា។ ទើបឧបាសិកាជាមាតារបស់នាងកាណាឲ្យគេប្រគេននំដល់ភិក្ខុនោះ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត។ នំដែលមាតារបស់នាងកាណាបានចាត់ចែងហើយទាំងប៉ុន្មាន ក៏អស់គ្មានសល់។ កាលនោះ ស្វាមីរបស់នាងកាណាក៏យកប្រពន្ធ១ទៀត។ នាងកាណាបានដឹងច្បាស់ថា ឮថាបុរសនោះយកប្រពន្ធទៀតហើយ។ នាងកាណានោះក៏ឈរយំ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរអំពីព្រឹក យាងទៅកាន់លំនៅរបស់ឧបាសិកាជាមាតានាងកាណា លុះយាងទៅដល់ហើយ ក៏គង់លើអាសនៈដែលគេបានចាត់ចែងថ្វាយ។ ទើបឧបាសិកាជាមាតារបស់នាងកាណាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅក្នុងទីដ៏សមគួរ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកានេះនឹងឧបាសិកាជាមាតារបស់នាងកាណាដែលបានអង្គុយនៅក្នុងទីដ៏សមគួរថា នាងកាណានេះ ហេតុអ្វីបានជាយំ។ ឧបាសិកាជាមាតារបស់នាងកាណាក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគក្នុងពេលនោះ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឧបាសិកាជាមាតារបស់នាងកាណាឲ្យឃើញព្រម ឲ្យកាន់យកព្រម ឲ្យឧស្សាហ៍ ឲ្យរីករាយ ដោយពុទ្ធដីកាដ៏ប្រកបដោយធម៌ ហើយក្រោកចាកអាសនៈយាងទៅវិញ។

[១១៣] សម័យនោះឯង មានពួករទេះ១ពួក មានសេចក្តីប្រាថ្នាដើម្បីចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ប្រទេសឈ្មោះបដិយាលោក[14)] មានភិក្ខុអ្នកត្រាច់ទៅដើម្បីបិណ្ឌបាតមួយអង្គចូលទៅរកពួករទេះនោះដើម្បីបិណ្ឌបាត។ មានឧបាសកម្នាក់បានឲ្យគេប្រគេនសដូវដល់ភិក្ខុនោះ។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត។ ឧបាសកនោះឲ្យគេប្រគេនសដូវដល់ភិក្ខុនោះទៀត។ ភិក្ខុនោះចេញទៅ ប្រាប់ដល់ភិក្ខុឯទៀត។ ឧបាសកនោះឲ្យគេប្រគេនសដូវដល់ភិក្ខុនោះទៀត។ ស្បៀងដែលឧបាសកនោះបានចាត់ចែងហើយទាំងប៉ុន្មាន ក៏អស់គ្មានសល់។ ទើបឧបាសកនោះបាននិយាយពាក្យនេះនឹងមនុស្សទាំងនោះថា បពិត្រអ្នកម្ចាស់ទាំងឡាយ សូមអ្នកម្ចាស់រង់ចាំក្នុងថ្ងៃនេះ១ថ្ងៃសិន (ព្រោះ) ស្បៀងដែលខ្ញុំបានចាត់ចែងហើយទាំងប៉ុន្មាន ខ្ញុំប្រគេនដល់លោកម្ចាស់ទាំងឡាយអស់ទៅហើយ ខ្ញុំនឹងចាត់ចែងស្បៀង(ថ្មីទៀត)។ មនុស្សទាំងនោះឆ្លើយថា បពិត្រអ្នកម្ចាស់ យើងមិនអាចនឹងរង់ចាំបានទេ (ព្រោះ) ពួករទេះចេញទៅហើយ (ថាដូច្នោះហើយ) ក៏នាំគ្នាទៅ។ កាលឧបាសកនោះចាត់ចែងស្បៀងហើយ ក៏ទៅក្រោយគេ ចោរទាំងឡាយក៏ដណ្តើមយក (របស់ទ្រព្យ) ក្នុងពេលនោះ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាសក្យបុត្រ មិនសមបើនឹងមិនដឹងប្រមាណ ហើយទទួលសោះ ឧបាសកនេះប្រគេនសដូវដល់សមណៈទាំងនេះ ហើយទៅកាលជាខាងក្រោយ ចោរទាំងឡាយក៏ដណ្តើមយក (របស់ទ្រព្យ)។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ)ហើយ។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍១០យ៉ាង គឺដើម្បីការប្រពៃដល់សង្ឃ ដើម្បីនៅសប្បាយដល់សង្ឃ។បេ។ ដើម្បីសេចក្តីអនុគ្រោះដល់ព្រះវិន័យ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ជនបវារណានូវភិក្ខុដែលចូលទៅកាន់ត្រកូលដោយនំទាំងឡាយក្តី ដោយសដូវទាំងឡាយក្តី ដើម្បីនាំទៅបានតាមប្រាថ្នា។ ភិក្ខុមានសេចក្តីប្រាថ្នា ត្រូវទទួលបានត្រឹមពេញពីរបីបាត្រ។ បើទទួលឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដែលបានទទួលនំ ឬសត្តុវកំណត់ពេញត្រឹមពីរបីបាត្រហើយ ត្រូវនាំចេញអំពីទីនោះមកចែកមួយអន្លើដោយភិក្ខុទាំងឡាយ ការចែកនំ ឬសដូវនេះជាសាមីចិកម្មក្នុង សិក្ខាបទនេះ។**

[១១៤] ត្រង់ពាក្យថា ភិក្ខុដែលចូវទៅកាន់ត្រកូល សេចក្តីថា ដែលហៅថាត្រកូល បានដល់ត្រកូលមាន៤យ៉ាង គឺត្រកូលក្សត្រ១ ត្រកូលព្រាហ្មណ៍១ ត្រកូលអ្នកជំនួញ១ ត្រកូលអ្នកគ្រួ១។ ពាក្យថាចូលទៅ គឺចូលទៅក្នុងត្រកូលទាំងនោះ។ ដែលហៅថានំ បានដល់វត្ថុអ្វីនីមួយដែលគេចាត់ចែងដើម្បីបញ្ជូនទៅ។ ដែលហៅថាសដូវ បានដល់វត្ថុអ្វីនីមួយដែលគេចាត់ចែងដើម្បីជាស្បៀង។ ពាក្យថា បវារណាដើម្បីនាំទៅតាមប្រាថ្នា សេចក្តីថា (ទាយកនាំមកបវារណាដោយពាក្យថា) លោកប្រាថ្នានូវវត្ថុប៉ុន្មាន លោកយកវត្ថុប៉ុណ្ណោះចុះ។ ពាក្យថា មានសេចក្តីប្រាថ្នា គឺមានបំណង។ ពាក្យថា ត្រូវទទួលបានត្រឹមពេញពីរបីបាត្រ សេចក្តីថា គប្បីទទួលយកបានត្រឹមពេញពីរបីបាត្រ។ ពាក្យថា បើទទួលឲ្យហួសពីកំណត់នោះទៅ សេចក្តីថា ភិក្ខុទទួលឲ្យលើសលុបពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។ (បើ) ភិក្ខុទទួល (នំ ឬសដូវ) កំណត់ពេញពីរបីបាត្រហើយ ចេញពីទីនោះមក ឃើញភិក្ខុ (ឯទៀត) ត្រូវប្រាប់ថា ក្នុងទីឯណោះ ខ្ញុំទទួល (នំឬសដូវ) ពេញពីរបីបាត្រមកហើយ លោកកុំទៅទទួលក្នុងទីនោះឡើយ។ បើភិក្ខុឃើញហើយមិនប្រាប់ ត្រូវអាបត្តិទុក្កដ។ បើប្រាប់ហើយ ភិក្ខុនៅតែទទួល ត្រូវអាបត្តិទុក្កដ។

[១១៥] ត្រង់ពាក្យថា ត្រូវនាំចេញអំពីទីនោះហើយ ចែកមួយអន្លើដោយភិក្ខុទាំងឡាយ សេចក្តីថា ក្នុងពេលដែលត្រឡប់មក ត្រូវនាំយក (នំឬសដូវ)នោះមកចែកគ្នា។ ពាក្យថា ការចែកនំឬសដូវនេះ ជាសាមីចិកម្មក្នុងសិក្ខាបទនោះ សេចក្តីថា ការចែកនំឬសដូវនេះ ជាទំនៀមដ៏សមគួរក្នុងសិក្ខាបទនោះ។ ភិក្ខុសំគាល់ក្នុងនំឬសដូវដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រ ថាច្រើនជាងមែន ហើយទទួល ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសង្ស័យក្នុងនំ ឬសដូវដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រ ហើយទទួល ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសំគាល់នំ ឬសដូវដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រ ថាខ្វះទៅវិញ ហើយទទួល ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសំគាល់ក្នុងនំ ឬសដូវដែលមិនពេញកំណត់ពីរបីបាត្រ ថាលើសទៅវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសង្ស័យក្នុងនំ ឬសដូវដែលមិនពេញពីរបីបាត្រ ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ក្នុងនំ ឬសដូវដែលមិនពេញពីរបីបាត្រ ថាមិនពេញមែន មិនត្រូវអាបត្តិ។

[១១៦] អាបត្តិមិនមានដល់ភិក្ខុដែលទទួលនំ ឬសដូវកំណត់ពេញត្រឹមតែពីរបីបាត្រ ដល់ភិក្ខុដែលទទួលនំ ឬសដូវមិនពេញពីរបីបាត្រ ដល់ភិក្ខុដែលទទួលវត្ថុ (ឯណានីមួយ) ដែលជនមិនតាក់តែង ដើម្បីបញ្ជូនទៅ (ញាតិ) មិនតាក់តែង ដើម្បីជាស្បៀង ដល់ភិក្ខុដែលទទួលវត្ថុដ៏សេសសល់អំពីនំ ឬសដូវដែលគេចាត់ចែងដើម្បីបញ្ជូនទៅ (ញាតិ)ក្តី ដើម្បីជាស្បៀងក្តី ដល់ភិក្ខុដែលទទួលនំ ឬសដូវអំពីជនដែលគេមានដំណើរប្រុងនឹងទៅហើយខានវិញ ដល់ភិក្ខុដែលទទួលនំ ឬសដូវរបស់ញាតិ ដល់ភិក្ខុដែលទទួលនំ ឬសដូវរបស់ជនដែលបវារណា ដល់ភិក្ខុដែលទទួលនំ ឬសដូវដើម្បីអ្នកដទៃ ដល់ភិក្ខុដែលទទួលនំ ឬសដូវដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ៤ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី៥ (៣៥)

CS vin.vbu.pc.35 | ភាគ ទី៤

### (៥. បឋមបវារណាសិក្ខាបទំ)

[១១៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀតក្រុងសាវត្ថី។ គ្រានោះឯង មានព្រាហ្មណ៍ម្នាក់និមន្តភិក្ខុទាំងឡាយឲ្យឆាន់។ ពួកភិក្ខុឆាន់ហើយ បានហាមភត្តហើយ ក៏ទៅកាន់ត្រកូលញាតិទាំងឡាយ ភិក្ខុពួកខ្លះក៏ឆាន់ ភិក្ខុពួកខ្លះកាន់យកបិណ្ឌបាតទៅ។ គ្រានោះ ព្រាហ្មណ៍នោះបានពោលពាក្យនេះនឹងពួកជនជាអ្នកស្និទ្ធស្នាលថា បពិត្រអ្នកម្ចាស់ទាំងឡាយ ភិក្ខុទាំងឡាយខ្ញុំបានប្រគេនចង្ហាន់ឆាន់បរិបូណ៌ហើយ សូមអ្នកទាំងឡាយអញ្ជើញមក ខ្ញុំនឹងអង្គាសអ្នករាល់គ្នាទៀត។ អ្នកស្និទ្ធស្នាលទាំងនោះពោលយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកនឹងអង្គាសយើងទាំងឡាយឲ្យឆ្អែតដូចម្តេចបាន អម្បាលភិក្ខុទាំងឡាយណាដែលអ្នកនិមន្តមកហើយ ភិក្ខុទាំងនោះមកកាន់ផ្ទះពួកយើង ខ្លះឆាន់ ខ្លះកាន់យកបិណ្ឌបាតហើយទៅ។ ទើបព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកដ៏ចំរើនទាំងឡាយ មិនសមនឹងឆាន់ក្នុងផ្ទះយើងទាំងឡាយហើយ ទៅឆាន់ក្នុងទីដទៃទៀតសោះ ហាក់ដូចជាខ្ញុំមិនអាចដើម្បីប្រគេនលោកឆាន់ឲ្យឆ្អែតបាន។ ពួកភិក្ខុឮព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ)ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយឆាន់ហើយ ហាមភត្តរួចហើយ មិនគួរនឹងទៅឆាន់ក្នុងទីដទៃទៀតសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយឆាន់ហើយ ហាមភត្តហើយ រួចទៅឆាន់ក្នុងទីដទៃទៀត ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះឆាន់ហើយ ហាមភត្តរួចហើយ ហេតុអ្វីក៏ទៅឆាន់ក្នុងទីដទៃទៀត ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយឆាន់ហើយ ហាមភត្តហើយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១១៨] សម័យនោះឯង ភិក្ខុទាំងឡាយនាំយកបិណ្ឌបាតដ៏ឧត្តមទៅឲ្យពួកភិក្ខុឈឺ។ ពួកភិក្ខុឈឺឆាន់មិនបានដោយស្រួល។ ពួកភិក្ខុនាំគ្នាចោលបិណ្ឌបាតដ៏ឧត្តមទាំងនោះ។ ព្រះដ៏មានព្រះភាគបានឮសំឡេងខ្លាំង សំឡេងធំ សំឡេងកញ្ច្រៀវនៃក្អែក លុះឮហើយ ទ្រង់ហៅព្រះអានន្ទដ៏មានអាយុ ហើយត្រាស់សួរថា ម្នាលអានន្ទ សំឡេងខ្លាំង សំឡេងធំ សំឡេងកញ្ច្រៀវនៃក្អែក សំឡេងនោះ ជាសំឡេងអ្វីហ្ន៎។ គ្រានោះ ព្រះអានន្ទដ៏មានអាយុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់សួរថា ម្នាលអានន្ទ ពួកភិក្ខុឆាន់ភោជនដ៏សល់អំពីភិក្ខុឈឺ ពិតមែនឬ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពួកភិក្ខុមិនឆាន់ទេ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម៌ីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ភោជនដ៏សល់អំពីភិក្ខុឈឺក្តី ភិក្ខុមិនឈឺក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវធ្វើភោជនដ៏សល់ (អំពីភិក្ខុឈឺ) ដោយពាក្យយ៉ាងនេះថា ភោជនទាំងអស់នេះសមគួរហើយ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយឆាន់ហើយ បានហាមភោជនហើយ ទំពាស៊ីក្តី ឆាន់ក្តី នូវខាទនីយាហារ ឬភោជនីយាហារដែលជាអនតិរិត្ត គឺជាវត្ថុដែលមិនបានធ្វើវិនយកម្ម និងមិនមែនសល់អំពីភិក្ខុឈឺ ត្រូវអាបត្តិបាចិត្តិយ។**

[១១៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។បេ។ ដែលហៅថាឆាន់ហើយ គឺឆាន់ភោជន៥យ៉ាង ភោជនណាមួយ ដោយហោចទៅ សូម្បីតែភោជនប្រមាណប៉ុនចុងស្បូវ។ ដែលហៅថា ហាមភោជន (គឺហាមប្រកបដោយអង្គ៥យ៉ាង) គឺភិក្ខុកំពុងឆាន់១ គេយកភោជនមកប្រគេនទៀត១ គេនៅក្នុងហត្ថបាស១ គេបង្អោនភោជនមកចំពោះ១ ភិក្ខុហាមភោជន១។ ដែលហៅថា អនតិរិត្ត [15] បានដល់វត្ថុដែលមិនបានធ្វើវិនយកម្ម (ដោយអាការ៧យ៉ាង) គឺ របស់ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរ១ របស់ដែលភិក្ខុមិនបានទទួល ហើយធ្វើឲ្យជារបស់គួរ១ របស់ដែលភិក្ខុមិនបានលើកឡើង (ឬ) មិនបានបង្អោនចូលទៅជិតដើម្បីឲ្យភិក្ខុធ្វើឲ្យជារបស់គួរ១ ភិក្ខុមិនឋិតនៅខាងក្នុងហត្ថបាសហើយធ្វើ១ ភិក្ខុមិនទាន់បានឆាន់ហើយធ្វើ១ ភិក្ខុឆាន់ហើយ បានហាមភោជនហើយ ក្រោកចាកអាសនៈហើយធ្វើ១ របស់ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ១ និងវត្ថុដែលមិនមែនជារបស់សល់អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះហៅថា អនតិរិត្ត។ ដែលហៅថា អតិរិត្តនោះ បានដល់វត្ថុដែលបានធ្វើវិនយកម្ម (ដោយអាការ៧យ៉ាង) គឺ របស់ដែលគេធ្វើឲ្យជាវត្ថុគួរ១ របស់ដែលភិក្ខុបានទទួល ហើយធ្វើឲ្យជារបស់គួរ១ របស់ដែលភិក្ខុលើកឡើង ឬបានបង្អោនទៅជិត ដើម្បីធ្វើឲ្យជារបស់គួរ១ ភិក្ខុនៅក្នុងហត្ថបាសហើយធ្វើ១ ភិក្ខុឆាន់រួចហើយទើបធ្វើ១ របស់ដែលភិក្ខុឆាន់ហើយ ហាមភោជនហើយ មិនទាន់ក្រោកចាកអាសនៈហើយធ្វើ១ របស់ដែលភិក្ខុពោលថា របស់អស់ទាំងនេះគួរហើយ១ និងរបស់ដែលសល់អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះហៅថា អតិរិត្ត។ ដែលហៅថា ខាទនីយាហារនោះ បានដល់របស់ទាំងអស់ វៀរលែងតែភោជន៥យ៉ាង និងរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយាហារ។ ដែលហៅថា ភោជនីយាហារនោះបានដល់ ភោជន៥យ៉ាង គឺ បាយ នំស្រស់ នំក្រៀម ត្រី សាច់។ ភិក្ខុទទួលដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ៗវារៈដែលលេបចូល។

[១២០] ខាទនីយភោជនីយាហារ ជាអនតិរិត្ត ភិក្ខុសំគាល់ថាជាអនតិរិត្តពិតមែន ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសង្ស័យក្នុងខាទនីយភោជនីយាហារ ជាអនតិរិត្ត ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសំគាល់ក្នុងខាទនីយភោជនីយាហារ ជាអនតិរិត្ត ថាជាអតិរិត្តទៅវិញ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុទទួលរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗវារៈដែលលេបចូលទៅ។ ភិក្ខុសំគាល់ក្នុងខាទនីយភោជនីយាហារដែលជាអតិរិត្ត ថាជាអនតិរិត្តទៅវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងខាទនីយភោជនីយាហារដែលជាអតិរិត្ត ត្រូវអាបត្តិទុក្កដ។ ភិក្ខុសំគាល់ក្នុងខាទនីយភោជនីយាហារដែលជាអតិរិត្ត ថាជាអតិរិត្តពិតមែន មិនត្រូវអាបត្តិ។

[១២១] អាបត្តិមិនមានដល់ភិក្ខុដែលឲ្យគេធ្វើវិនយកម្មហើយឆាន់ ដល់ភិក្ខុដែលទទួលរបស់ដោយគិតថា អញនឹងឲ្យគេធ្វើវិនយកម្មហើយឆាន់ ដល់ភិក្ខុដែលនាំយករបស់ទៅដើម្បីភិក្ខុដទៃ ដល់ភិក្ខុដែលឆាន់របស់ដ៏សេសសល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលឆាន់របស់ជាយាមកាលិក សត្តាហកាលិក យាវជីវិកដោយមានហេតុ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ៥ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី៦ (៣៦)

CS vin.vbu.pc.36 | ភាគ ទី៤

### (៦. ទុតិយបវារណាសិក្ខាបទំ)

[១២២] កាលណោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង មានភិក្ខុពីររូបដើរផ្លូវឆ្ងាយទៅក្រុងសាវត្ថីក្នុងកោសលជនបទ។ ភិក្ខុ១រូបប្រព្រឹត្តអនាចារ។ ភិក្ខុជាគំរប់ពីរបាននិយាយពាក្យនេះ (ឃាត់) ភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកកុំធ្វើអំពើយ៉ាងនេះ អំពើដែលលោកធ្វើនេះ មិនគួរទេ។ ភិក្ខុដែលប្រព្រឹត្តអនាចារនោះក៏ចងពៀរនឹងភិក្ខុអ្នកឃាត់នោះ។ គ្រានោះ ភិក្ខុទាំងនោះបានទៅកាន់ក្រុងសាវត្ថី។ សម័យនោះឯង ក្នុងក្រុងសាវត្ថីមានប្រជុំជនមួយពួក (ធ្វើ) សង្ឃភត្ត។ ភិក្ខុជាគំរប់ពីរបានឆាន់សង្ឃភត្តរួចហើយ ហាមភត្តហើយ។ ភិក្ខុដែលចងពៀរ ទៅកាន់ត្រកូលជាញាតិ ហើយទទួលបិណ្ឌបាត រួចហើយក៏ចូលទៅរកភិក្ខុដែលហាមភត្តនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងភិក្ខុអ្នកហាមភត្តនោះថា ម្នាលលោកដ៏មានអាយុ លោកចូរឆាន់ (ចង្ហាន់នេះ) ចុះ។ ភិក្ខុ

អ្នកហាមភត្តក៏ប្រកែកថា កុំអាវុសោ ខ្ញុំឆាន់បរិបូណ៌ហើយ។ ភិក្ខុដែលចងពៀរក៏អង្វរថា ម្នាលអាវុសោ បិណ្ឌបាត (នេះ) ល្អ លោកចូរឆាន់ទៅ។ កាលបើភិក្ខុអ្នកចងពៀរនោះជម្រុលខ្លាំងពេក ភិក្ខុអ្នកហាមភត្តនោះ (ទ្រាំមិនបាន) ក៏ឆាន់បិណ្ឌបាតនោះទៅ។ ភិក្ខុដែលចងពៀរក៏ពោលពាក្យនេះនឹងភិក្ខុអ្នកហាមភត្តនោះថា ម្នាលអាវុសោ លោកសំគាល់មកខ្ញុំថាជាបុគ្គលដែលគេត្រូវតែស្តីថា ឬអ្វី ក៏រូបលោកឆាន់រួចហើយ ហាមភត្តហើយ ម្តេចឡើយក៏នៅតែឆាន់អនតិរិត្តភោជន។ ភិក្ខុអ្នកហាមភត្តនោះតបថា ម្នាលអាវុសោ ហេតុម្តេច លោកមិនប្រាប់(ខ្ញុំ)ផង។ ភិក្ខុអ្នកចងពៀរក៏ឆ្លើយថា ហេតុម្តេច លោកមិនសួរ(ខ្ញុំជាមុន)។ ភិក្ខុអ្នកហាមភត្តនោះក៏ដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយក្នុងខណៈនោះ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងនាំភត្តទៅ ហើយបវារណា បង្ខំភិក្ខុដែលឆាន់ហើយ ហាមភត្តហើយ ឲ្យឆាន់នូវអនតិរិត្តភោជន (ដូច្នេះ) សោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងបាននាំភត្តទៅបវារណា បង្ខំភិក្ខុដែលឆាន់ហើយ ហាមភោជនហើយ ឲ្យឆាន់អនតិរិត្តភោជន ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងនាំភត្តទៅបវារណា បង្ខំភិក្ខុដែលឆាន់ហើយ ហាមភត្តហើយ ឲ្យឆាន់អនតិរិត្តភោជនទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ កាលដឹងហើយ រំពៃរកទោស នាំភត្តទៅបវារណា បង្ខំភិក្ខុដែលឆាន់ហើយ ហាមភត្តហើយ ឲ្យទំពាស៊ីក្តី បរិភោគក្តី នូវអនតិរិត្តភោជន ដោយពាក្យថា នែភិក្ខុ អ្នកចូរទំពាស៊ីក្តី បរិភោគក្តី ដូច្នេះ និមិត្តតែភិក្ខុនោះឆាន់ហើយ ត្រូវអាបត្តិបាចិត្តិយ។**

[១២៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ។ ដែលហៅថាឆាន់ហើយ គឺភិក្ខុបានឆាន់នូវភោជនទាំង៥យ៉ាង ភោជនណាមួយ ដោយហោចទៅ សូម្បីតែប៉ុនចុងស្បូវភ្លាំង។ ដែលហៅថា ហាមភត្ត (គឺហាមប្រកបដោយអង្គ៥យ៉ាង) គឺភិក្ខុកំពុងឆាន់១ គេយកភោជនមកប្រគេនទៀត១ គេឋិតនៅក្នុងហត្ថបាស១ គេបង្អោនភោជនមកចំពោះ១ ភិក្ខុហាមភោជន១។ ដែលហៅថា អនតិរិត្ត បានដល់វត្ថុដែលមិនបានធ្វើវិនយកម្មដោយ(អាការ៧យ៉ាង) គឺរបស់ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរ១ របស់ដែលភិក្ខុមិនបានទទួល ហើយធ្វើឲ្យជារបស់គួរ១ របស់ដែលភិក្ខុមិនបានលើកឡើង (ឬមិនបានបង្អោនចូលទៅជិតដើម្បីធ្វើឲ្យជារបស់គួរ)១ ភិក្ខុមិនស្ថិតនៅខាងក្នុងហត្ថបាសហើយធ្វើ១ ភិក្ខុមិនទាន់ឆាន់ហើយធ្វើ១ ភិក្ខុឆាន់ហើយ ហាមភោជនហើយ ក្រោកចាកអាសនៈហើយធ្វើ១ របស់ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ១ និងវត្ថុដែលមិនមែនជារបស់សល់អំពីភិក្ខុឈឺ វត្ថុទាំងពីរយ៉ាងនេះហៅថា អនតិរិត្ត។ ដែលហៅថា ខាទនីយ(នោះ) បានដល់វត្ថុទាំងអស់ លើកលែងភោជនទាំង៥យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិក និងយាវជីវិកចេញ ហៅថា ខាទនីយ។ ដែលហៅថា ភោជនីយ បានដល់ ភោជន៥យ៉ាង គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១។ ពាក្យថា នាំភត្តទៅបវារណា (នោះ) គឺភិក្ខុនិយាយថា លោកចង់បានប៉ុន្មាន និមន្តយកប៉ុណ្ណោះចុះ។ ដែលហៅថា ដឹង(នោះ) គឺភិក្ខុដឹងខ្លួនឯង ឬពួកជនដទៃប្រាប់ដល់ភិក្ខុអ្នកចោទនោះ ឬក៏ភិក្ខុអ្នកហាមភោជននោះប្រាប់។ ពាក្យថា រំពៃរកទោស (នោះ) គឺភិក្ខុនាំយក (ខាទនីយ ឬភោជនីយ) ទៅដោយគិតថា អញនឹងចោទនឹងរំលឹកភិក្ខុនេះដោយវត្ថុនេះ អញនឹងចោទចំពោះ នឹងរំលឹកចំពោះភិក្ខុនេះ ដោយវត្ថុនេះ អញនឹងធ្វើភិក្ខុនេះឲ្យអាប់មុខដោយវត្ថុនេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកហាមភោជន ទទួលដោយគិតថា អញនឹងទំពាស៊ី នឹងឆាន់តាមពាក្យរបស់លោកអ្នកចោទ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះត្រូវអាបត្តិទុក្កដ គ្រប់ៗខណៈដែលលេប។ លុះភិក្ខុនោះឆាន់រួចស្រេច ភិក្ខុអ្នកបង្ខំ ត្រូវអាបត្តិបាចិត្តិយ។

[១២៤] ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទសំគាល់ថាហាមហើយ ក៏នាំខាទនីយ ឬភោជនីយដែលជាអនតិរិត្តទៅបង្ខំ (ភិក្ខុនោះ) ឲ្យឆាន់ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទមានសេចក្តីសង្ស័យ ក៏នាំខាទនីយ ឬភោជនីយដែលជាអនតិរិត្តទៅបង្ខំ ឲ្យឆាន់ ត្រូវអាបត្តិទុក្កដ។ ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកចោទសំគាល់ថាមិនទាន់ហាម ក៏នាំខាទនីយ ឬភោជនីយដែលជាអនតិរិត្តទៅបង្ខំឲ្យឆាន់ មិនត្រូវអាបត្តិ។ ភិក្ខុអ្នកចោទបង្អោនរបស់ដែលជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីជាអាហារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុអ្នកហាមភោជន ទទួលវត្ថុទាំងនោះ ដោយគិតថា អញនឹងទំពាស៊ី នឹងឆាន់ តាមពាក្យរបស់លោកអ្នកចោទនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះត្រូវអាបត្តិទុក្កដរាល់ៗខណៈដែលលេប។ ភិក្ខុមិនហាមភោជនទេ តែភិក្ខុអ្នកចោទសំគាល់ថាហាម ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនហាមភោជនទេ ភិក្ខុអ្នកចោទសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនទាន់ហាមភោជន ភិក្ខុអ្នកចោទសំគាល់ថាមិនទាន់ហាមមែន មិនត្រូវអាបត្តិ។

[១២៥] អាបត្តិមិនមានដល់ភិក្ខុដែលឲ្យភិក្ខុផងគ្នាធ្វើវិនយកម្មហើយឲ្យ ដល់ភិក្ខុដែលឲ្យដោយ ពាក្យថា លោកចូរឲ្យគេធ្វើឲ្យជាវិនយកម្មហើយនិមន្តឆាន់ចុះ ដល់ភិក្ខុដែលឲ្យ ដោយពាក្យថា លោកចូរនាំ (ខាទនីយភោជនីយាហារនេះ) ទៅដើម្បីប្រយោជន៍ដល់អ្នកដទៃចុះ ដល់ភិក្ខុដែលឲ្យរបស់ដ៏សល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលឲ្យរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិក ដោយពាក្យថា កាលបើមានហេតុ ចូរលោកឆាន់ចុះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៦ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី៧ (៣៧)

CS vin.vbu.pc.37 | ភាគ ទី៤

### (៧. វិកាលភោជនសិក្ខាបទំ)

[១២៦] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ។ សម័យនោះឯង ក្រុងរាជគ្រឹះលេងមហោស្រពលើកំពូលភ្នំ។ ពួកសត្តរសវគ្គិយភិក្ខុ ក៏បានទៅដើម្បីមើលមហោស្រពដែលគេលេងលើកំពូលភ្នំ(នោះ)។ មនុស្សទាំងឡាយបាន

ឃើញពួកសត្តរសវគ្គិយភិក្ខុហើយ និមន្តឲ្យស្រង់ទឹក ឲ្យលាប ឲ្យឆាន់ស្រេចហើយ ក៏ប្រគេននូវខាទនីយ។ ពួកសត្តរសវគ្គិយភិក្ខុកាន់យកខាទនីយទៅអារាម ហើយនិយាយពាក្យនេះប្រាប់ពួកឆព្វគ្គិយភិក្ខុថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយចូរទទួលយកខាទនីយទៅឆាន់ចុះ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះសួរថា ម្នាលអាវុសោទាំងឡាយ ពួកលោកបានខាទនីយមកពីណា។ ពួកសត្តរសវគ្គិយភិក្ខុបានប្រាប់រឿងនុ៎ះដល់ឆព្វគ្គិយភិក្ខុទាំងឡាយ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយបានឆាន់ភោជនក្នុងពេលដែលមិនគួរ មែនឬ។ ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា មែនអាវុសោទាំងឡាយ។ ពួកឆព្វគ្គិយភិក្ខុពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសត្តរសវគ្គិយភិក្ខុ មិនគួរនឹងឆាន់ភោជនក្នុងពេលវិកាល (ដូច្នេះ) សោះ។ ខណៈនោះឯង ពួកឆព្វគ្គិយភិក្ខុបានប្រាប់រឿងនុ៎ះដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសត្តរសវគ្គិយភិក្ខុមិនគួរឆាន់ភោជនក្នុងពេលវិកាល (ដូច្នេះ) សោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថាអ្នកទាំងឡាយឆាន់ភោជនក្នុងពេលវិកាល ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងឆាន់ភោជនក្នុងពេលវិកាលទេ នែមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះដូច្នេះថា

**ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយក្នុងពេលវិកាល ត្រូវអាបត្តិបាចិត្តិយ។**

[១២៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងបឋមបារាជិកសិក្ខាបទ។ វេលាដែលព្រះអាទិត្យជ្រេពីត្រង់ទៅទល់នឹងអរុណរះឡើង ហៅថាពេលវិកាល។ ដែលហៅថា ខាទនីយ(នោះ) បានដល់របស់ទាំងអស់ វៀរលែងភោជនទាំង៥យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយ។ ដែលហៅថា ភោជនីយ បានដល់ ភោជន៥យ៉ាង គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១។ ភិក្ខុទទួលវត្ថុទាំងនោះ ដោយគិតថា អញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ គ្រប់ៗវារៈដែលលេបចូលទៅ។

[១២៨] ពេលវិកាល ភិក្ខុក៏សំគាល់ថា ពេលវិកាល ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ។ ពេលវិកាល ភិក្ខុមានសេចក្តីសង្ស័យ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ។ ពេលវិកាល ភិក្ខុសំគាល់ថា កាលគួរ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុទទួលវត្ថុជាយាមកាលិក សត្តាហកាលិក និងយាវជីវិក ទុកសម្រាប់ជាប្រយោជន៍ដល់អាហារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះត្រូវអាបត្តិទុក្កដគ្រប់ៗខណៈដែលលេបចូលទៅ។ ពេលជាកាលគួរ ភិក្ខុសំគាល់ថា ពេលវិកាល ត្រូវអាបត្តិទុក្កដ។ ពេលជាកាលគួរ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ ពេលជាកាលគួរ ភិក្ខុសំគាល់ថា កាលគួរមែន មិនត្រូវអាបត្តិឡើយ។

[១២៩] អាបត្តិមិនមានដល់ភិក្ខុដែលឆាន់តែវត្ថុជាយាមកាលិក សត្តាហកាលិក និងយាវជីវិកដោយមានហេតុដែលគួរឆាន់បាន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៧ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី៨ (៣៨)

CS vin.vbu.pc.38 | ភាគ ទី៤

### (៨. សន្និធិការកសិក្ខាបទំ)

[១៣០] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង ព្រះវេឡដ្ឋសីសៈដ៏មានអាយុ ជាឧបជ្ឈាយ៍របស់ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងព្រៃ។ ព្រះថេរៈនោះត្រាច់ទៅបិណ្ឌបាត លុះបានអាហារបិណ្ឌបាតជាច្រើនហើយ ក៏នាំយកបាយសុទ្ធ[16)] មកកាន់អារាម រួចហាលបាយនោះឲ្យស្ងួតក្រៀម ហើយទុកដាក់ កាលណាមានសេចក្តីត្រូវការដោយអាហារ ទើបយកបាយក្រៀមនោះមកត្រាំទឹក ហើយក៏ឆាន់ក្នុងកាលនោះ យូរៗបានលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្តង។ ភិក្ខុទាំងឡាយបាននិយាយពាក្យនេះនឹងព្រះវេឡដ្ឋសីសៈដ៏មានអាយុថា ម្នាលអាវុសោ ចុះហេតុអ្វីបានជាយូរៗទើបលោកចូលទៅកាន់ក្រុងដើម្បីបិណ្ឌបាតម្តង។ ទើបព្រះវេឡដ្ឋសីសៈដ៏មានអាយុក៏ដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ។ ពួកភិក្ខុទាំងនោះក៏សួរថា ម្នាលអាវុសោ បើដូច្នោះ មានតែលោកឆាន់ភោជនដែលខ្លួនទុកដាក់ឲ្យកន្លងរាត្រីឬអ្វី។ ព្រះវេឡដ្ឋសីសៈឆ្លើយថា យ៉ាងហ្នឹងហើយ អាវុសោ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះវេឡដ្ឋសីសៈដ៏មានអាយុ មិនសមបើនឹងឆាន់ភោជនដែលខ្លួនទុកដាក់ឲ្យកន្លងរាត្រី (ដូច្នេះ)ទេ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលវេឡដ្ឋសីសៈ ឮថាអ្នកឯងបានឆាន់ភោជនដែលខ្លួនទុកដាក់ឲ្យកន្លងរាត្រី ពិតមែនឬ។ ព្រះវេឡដ្ឋសីសៈក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលវេឡដ្ឋសីសៈ អ្នកឯងមិនសមបើនឹងឆាន់ភោជនដែលខ្លួនទុកដាក់ឲ្យកន្លងរាត្រី (ដូច្នេះ)ទេ ម្នាលវេឡដ្ឋសីសៈ អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិនមែននាំពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយជាសន្និធិការកៈ គឺវត្ថុដែលខ្លួនទុកដាក់ឲ្យកន្លងរាត្រី ត្រូវអាបត្តិបាចិត្តិយ។**

[១៣១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ។ ដែលហៅថាខ្លួនទុកដាក់ឲ្យកន្លងរាត្រី (បានដល់ខាទនីយ ឬភោជនីយ) ដែលខ្លួនទទួលទុកក្នុងថ្ងៃនេះ ហើយឆាន់ក្នុងថ្ងៃខាងក្រោយ។ ដែលហៅថា ខាទនីយ(នោះ) បានដល់វត្ថុទាំងអស់សម្រាប់ទំពាស៊ី វៀរលែងតែភោជនទាំង៥យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយ។ ដែលហៅថា ភោជនីយ បានដល់ភោជនទាំង៥យ៉ាង គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១។ ភិក្ខុទទួល ដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ គ្រប់ៗវារៈដែលលេបចូលទៅ។

[១៣២] របស់ដែលជាសន្និធិការកៈ ភិក្ខុក៏សំគាល់ថា ជាសន្និធិការកៈមែន ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ។ របស់ដែលជាសន្និធិការកៈ ភិក្ខុមានសេចក្តីសង្ស័យ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ។ របស់ដែលជាសន្និធិការកៈ ភិក្ខុសំគាល់ថា មិនមែនជាសន្និធិការកៈ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុទទួលវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗខណៈដែលលេបចូលទៅ។ របស់ដែលមិនមែនជាសន្និធិការកៈ ភិក្ខុសំគាល់ថា ជាសន្និធិការកៈ ត្រូវអាបត្តិទុក្កដ។ របស់មិនមែនជាសន្និធិការកៈ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ របស់មិនមែនជាសន្និធិការកៈ ភិក្ខុក៏សំគាល់ថា មិនមែនជាសន្និធិការកៈ មិនត្រូវអាបត្តិឡើយ។

[១៣៣] អាបត្តិមិនមានដល់ភិក្ខុដែលទុកដាក់វត្ថុជាយាវកាលិក[17)] ហើយឆាន់ត្រូវតាមកំណត់កាល ដល់ភិក្ខុដែលទុកដាក់វត្ថុជាយាមកាលិក[18)] ហើយឆាន់ត្រូវតាមកំណត់យាម (គឺថ្ងៃ១យប់១) ដល់ភិក្ខុដែលទុកដាក់វត្ថុជាសត្តាហកាលិក[19)] ហើយឆាន់អស់ត្រឹម៧ថ្ងៃ ដល់ភិក្ខុដែលឆាន់វត្ថុជាយាវជីវិក[20)] ព្រោះមានហេតុដែលគួរឆាន់បាន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៨ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី៩ (៣៩)

CS vin.vbu.pc.39 | ភាគ ទី៤

### (៩. បណីតភោជនសិក្ខាបទំ)

[១៣៤] កាលនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនសមនឹងសូមភោជនដ៏ឧត្តមទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់សោះ អ្នកណាមួយមិនគាប់ចិត្តនឹងភោជនដែលសម្បូរ អ្នកណាមួយមិនចូលចិត្តនឹងភោជនដែលមានរសឆ្ងាញ់។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមនឹងសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ដូច្នោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយក៏នាំគ្នាឆាន់ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលពួកបុរសសោះសូន្យ អ្នកទាំងឡាយមិនសមនឹងសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ដូច្នេះទេ នៃពួកបុរសសោះសូន្យ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាតទៅទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះ ដូចម្តេច ភោជនដ៏ឧត្តមទាំងនោះគឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ។ ភិក្ខុណាមួយសូមភោជនដ៏ឧត្តមទាំងឡាយមានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១៣៥] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺ។ ពួកភិក្ខុអ្នកសួរជម្ងឺបាននិយាយពាក្យនេះនឹងភិក្ខុឈឺទាំងឡាយថា ម្នាលអាវុសោ លោកអាចអត់ទ្រាំបានឬទេ អាចប្រព្រឹត្តទៅបានឬទេ។ ពួកភិក្ខុឈឺឆ្លើយថា ម្នាលអាវុសោ ក្នុងកាលមុនយើងទាំងឡាយបានសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ព្រោះហេតុនោះ ទើបយើងទាំងឡាយមានសេចក្តីសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ យើងទាំងឡាយខ្លាចក្រែង មិនហ៊ានសូមទៀត ទើបសេចក្តីមិនសប្បាយមានដល់យើងទាំងឡាយដោយហេតុនោះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺ សូមភោជនដ៏ឧត្តមទាំងឡាយ មកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះដូចម្តេច ភោជនដ៏ឧត្តមទាំងនោះគឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ។ ភិក្ខុណាមួយគ្មានជម្ងឺ សូមភោជនដ៏ឧត្តមទាំងឡាយមានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ។**

[១៣៦] ត្រង់ពាក្យថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះ គឺទឹកដោះថ្លារបស់គោក្តី ទឹកដោះថ្លារបស់ពពែក្តី ទឹកដោះថ្លារបស់ក្របីក្តី ហៅថា ទឹកដោះថ្លា ឬសប្បិ និងសាច់របស់ពួកសត្វណាដ៏គួរ (ដល់វិន័យបញ្ញត្តិ) ទឹកដោះថ្លារបស់ពួកសត្វនោះ ហៅថា ទឹកដោះថ្លា ឬសប្បិ។ ទឹកដោះខាប់របស់សត្វអម្បាលនោះឯង ហៅថា ទឹកដោះខាប់ ឬនវនីត។ ប្រេងល្ង ប្រេងស្លៃ ប្រេងស្រគំ ប្រេងល្ហុងខ្វែ និងប្រេង គឺខ្លាញ់រាវ ហៅថា ប្រេង។ ទឹកផ្អែមរបស់មេឃ្មុំ ហៅថា ទឹកឃ្មុំ។ ទឹកផ្អែមដែលកើតអំពីអំពៅ ហៅថា ទឹកអំពៅ ឬស្ករអំពៅ។ សត្វដែលត្រាច់ទៅក្នុងទឹក ហៅថា ត្រី ឬមច្ឆជាតិ។ សាច់នៃពួកសត្វណាក៏គួរ(ដល់វិន័យបញ្ញត្តិ) សាច់នៃពួកសត្វទាំងនោះ ហៅថា សាច់ ឬមំសៈ។ ទឹកដោះស្រស់របស់គោក្តី ទឹកដោះស្រស់របស់ពពែក្តី ទឹកដោះស្រស់របស់ក្របីក្តី ហៅថា ទឹកដោះស្រស់ ឬខីរៈ សាច់របស់ពួកសត្វណាដ៏គួរ (ដល់វិន័យបញ្ញត្តិ) ទឹកដោះស្រស់របស់ពួកសត្វទាំងនោះ ហៅថា ទឹកដោះស្រស់ ឬខីរៈ។ ទឹកដោះជូររបស់ពួកសត្វទាំងនោះ ហៅថា ទឹកដោះជូរ ឬទធិ។

[១៣៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ។ ពាក្យថា ភោជនដ៏ឧត្តមទាំងឡាយមានសភាពយ៉ាងនេះ គឺភោជនដ៏ថ្លៃថ្លាទាំងឡាយមានសភាពដូច្នោះ។ ភិក្ខុណាវៀរភោជនដ៏ឧត្តមទាំងឡាយ ហើយនៅជាសប្បាយបាន ភិក្ខុនោះហៅថា គ្មានជម្ងឺ។ ភិក្ខុណាវៀរចាកភោជនដ៏ឧត្តមទាំងឡាយ ហើយនៅសប្បាយមិនបាន ភិក្ខុនោះហៅថា មានជម្ងឺ។ ភិក្ខុគ្មានជម្ងឺ សូមភោជនទាំងនោះ ដើម្បីប្រយោជន៍ដល់ខ្លួន ត្រូវអាបត្តិទុក្កដរាល់ប្រយោគ។ ភិក្ខុទទួលដោយតាំងចិត្តថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដក្នុងខណៈដែលបានមក។ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលលេបចូលទៅ។

[១៣៨] ខ្លួនមិនឈឺ ភិក្ខុសំគាល់ថាខ្លួនមិនឈឺ ហើយសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ។ ខ្លួនមិនឈឺ ភិក្ខុមានសេចក្តីសង្ស័យ ហើយសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ។ ខ្លួនមិនឈឺ ភិក្ខុសំគាល់ថាខ្លួនឈឺ ហើយសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ។ ខ្លួនឈឺ ភិក្ខុសំគាល់ថាខ្លួនមិនឈឺ ត្រូវអាបត្តិទុក្កដ។ ខ្លួនឈឺ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ខ្លួនឈឺ ភិក្ខុសំគាល់ថាខ្លួនឈឺ មិនត្រូវអាបត្តិ។

[១៣៩] អាបត្តិមិនមានដល់ភិក្ខុឈឺ ដល់ភិក្ខុដែលមានជម្ងឺ ហើយសូម លុះសូមបានមកក៏បាត់ជម្ងឺនោះ ហើយឆាន់ ដល់ភិក្ខុដែលឆាន់ភោជនដ៏សល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលឆាន់ភោជនរបស់ពួកញាតិ ដល់ភិក្ខុដែលឆាន់ភោជនរបស់ពួកជនដែលបានបវារណា ដល់ភិក្ខុដែលសូមដើម្បីប្រយោជន៍ដល់អ្នកឯទៀត ដល់ភិក្ខុដែលឆាន់ភោជនដែលកើតដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ៩ ចប់។

## (បាចិត្តិយ ភោជនវគ្គ) សិក្ខាបទ ទី១០ (៤០)

CS vin.vbu.pc.40 | ភាគ ទី៤

### (១០. ទន្តបោនសិក្ខាបទំ)

[១៤០] កាលនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ កាលគង់នៅកូដាគារសាលា ក្នុងមហាវន ក្បែរក្រុងវេសាលី។ សម័យនោះឯង មានភិក្ខុ១រូបជាអ្នកប្រព្រឹត្តបំសុកូលនូវរបស់គ្រប់យ៉ាង[21] នៅក្នុងព្រៃស្មសាន។ ភិក្ខុនោះមិនប្រាថ្នានឹងទទួលយកវត្ថុដែលមនុស្សទាំងឡាយឲ្យឡើយ។ ភិក្ខុនោះកាន់យកនូវសំណែនក្នុងព្រៃស្មសានខ្លះ ទៀបគល់ឈើខ្លះ ទៀបធរណីទ្វារខ្លះ ដោយខ្លួនឯង ហើយឆាន់។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនេះមិនគួរបើនឹងកាន់យកសំណែនរបស់យើងទាំងឡាយដោយខ្លួនឯង ហើយឆាន់ទេ ភិក្ខុជាថេរៈនេះមានកាយធាត់ទំនងជាស៊ីសាច់មនុស្សទេដឹង។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងស៊ីលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេនសោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងស៊ីលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេនពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងស៊ីលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន (ដូច្នេះ)ទេ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងតទៅទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១៤១] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យក្នុងទឹក និងឈើស្ទន់។ ពួកភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកទឹក និងឈើស្ទន់ឆាន់ដោយខ្លួនឯងបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹក និងឈើស្ទន់។**

[១៤២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថាគេមិនបានប្រគេន គឺសំដៅយកវត្ថុដែលភិក្ខុមិនបានទទួលប្រគេន។ ដែលហៅថា របស់ដែលគេប្រគេន គឺកាលបើទាយកឲ្យរបស់ណាដោយកាយក្តី ដោយរបស់ដែលជាប់នឹងកាយក្តី ដោយបោះឲ្យក្តី ភិក្ខុក៏ស្ថិតនៅក្នុងហត្ថបាស បានទទួល[22] ដោយកាយ ឬដោយរបស់ដែលជាប់នឹងកាយ របស់នេះហៅថា គេប្រគេន។ ដែលហៅថា អាហារ គឺរបស់ណាមួយដែលគួរលេបចូលទៅបាន វៀរលែងតែទឹក និងឈើស្ទន់ របស់នេះហៅថា អាហារ។ ពាក្យថា វៀរលែងតែទឹក និងឈើស្ទន់ គឺលើកលែងតែទឹក និងឈើស្ទន់។ ភិក្ខុទទួលយកដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ គ្រប់ៗវារៈដែលលេបចូលទៅ។

[១៤៣] វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុក៏សំគាល់ថា មិនបានទទួលប្រគេន ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹក និងឈើស្ទន់។ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុសង្ស័យ ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹក និងឈើស្ទន់។ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុសំគាល់ថា បានទទួលប្រគេន ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹក និងឈើស្ទន់។ វត្ថុដែលភិក្ខុបានទទួលប្រគេន ភិក្ខុសំគាល់ថា មិនទាន់បានទទួលប្រគេន ត្រូវអាបត្តិទុក្កដ។ វត្ថុដែលភិក្ខុទទួលប្រគេន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ វត្ថុដែលភិក្ខុទទួលប្រគេនហើយ ភិក្ខុក៏សំគាល់ថា បានទទួលប្រគេនហើយ មិនត្រូវអាបត្តិឡើយ។

[១៤៤] អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ទឹក និងឈើស្ទន់ ដល់ភិក្ខុដែលកាន់យកថ្នាំមហាវិកត៤យ៉ាង[23] ដោយខ្លួនឯង ហើយឆាន់ ព្រោះមានហេតុ ហើយគ្មានកប្បិយការក ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ។

សិក្ខាបទ ទី ១០ ចប់។

ភោជនវគ្គ ទី ៤ ចប់។

ចំនួនសិក្ខាបទក្នុងភោជនវគ្គនោះមាន១០យ៉ាង គឺ

បិណ្ឌ (សិក្ខាបទ)១ គណ(សិក្ខាបទ)១ បរ(សិក្ខាបទ)១ បូវ(សិក្ខាបទ)១ បវារណា(សិក្ខាបទ)ពីរ ព្រះដ៏មានព្រះភាគពោលហើយ វិកាល(សិក្ខាបទ)១ សន្និធិការ(សិក្ខាបទ)១ បណីត(សិក្ខាបទ)១ ទ្វារក(សិក្ខាបទ)១។

# អចេលកវគ្គ (ទី៥)

CS vin.vbu.pc.v5 | ភាគ ទី៤

### (៥. អចេលកវគ្គោ)

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី១ (៤១)

CS vin.vbu.pc.41 | ភាគ ទី៤

### (១. អចេលកសិក្ខាបទំ)

[១៤៥] កាលនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ គង់នៅកូដាគារសាលា ក្នុងព្រៃមហាវន ទៀបក្រុងវេសាលី។ សម័យនោះឯង របស់ដែលបុគ្គលគប្បីទំពាស៊ីកើតឡើងដល់សង្ឃ។ ព្រះអានន្ទដ៏មានអាយុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរឲ្យនំដល់ពួកមនុស្សអ្នកស៊ីដែលចុះ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះពុទ្ធដីកាថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងហ្នឹងហើយៗ ក៏ឲ្យពួកមនុស្សដែលជាអ្នកស៊ីដែលអង្គុយជាជួរ ហើយក៏ឲ្យនំមួយៗ (ដល់មនុស្សដែលជាអ្នកស៊ីដែល) រួចឲ្យនំពីរទៅនាងបរិព្វាជិកាម្នាក់ ដោយសំគាល់ថាឲ្យនំមួយដូចគេទាំងពួងដែរ។ ពួកនាងបរិព្វាជិកា(ដែលនៅ)ជុំវិញ បាននិយាយពាក្យនេះនឹងនាងបរិព្វាជិកានោះថា សមណនោះជាសហាយរបស់នាងឬ។ នាងបរិព្វាជិកានោះឆ្លើយថា សមណនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថាឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ។ វារៈជាគំរប់ពីរដង ព្រះអានន្ទដ៏មានអាយុឲ្យនំមួយៗ (ដល់មនុស្សដែលជាអ្នកស៊ីដែល) រួចឲ្យនំពីរទៅនាងបរិព្វាជិកាដដែលនោះ ដោយសំគាល់ថាឲ្យនំមួយដូចគេទាំងពួងដែរ។ ពួកនាងបរិព្វាជិកា(ដែលនៅ)ជុំវិញ ក៏និយាយពាក្យនេះនឹងនាងបរិព្វាជិកានោះថា សមណនុ៎ះជាសហាយរបស់នាងឬ។ នាងបរិព្វាជិកានោះឆ្លើយថា សមណនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថាឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ។ វារៈជាគំរប់បីដងទៀត ព្រះអានន្ទដ៏មានអាយុឲ្យនំមួយៗ (ដល់មនុស្សដែលជាអ្នកស៊ីដែល) រួចឲ្យនំពីរទៅនាងបរិព្វាជិកាដដែលនោះ ដោយសំគាល់ថាឲ្យនំមួយដូចគេទាំងពួងដែរ។ ពួកនាងបរិព្វាជិកា(ដែលនៅ)ជុំវិញ ក៏និយាយពាក្យនេះនឹងនាងបរិព្វាជិកានោះថា សមណនុ៎ះជាសហាយរបស់នាងឬ។ នាងបរិព្វាជិកានោះឆ្លើយថា សមណនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថាឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ។ ពួកនាងបរិព្វាជិកាទាំងនោះ ក៏នាំគ្នានិយាយចមអកថា (សមណនុ៎ះ) សហាយ ឬមិនមែនសហាយ។ (វេលានោះ) មានអាជីវកម្នាក់ដើរទៅកាន់ទីដែលគេអង្គាស ឬចែក(នំ)។ (ពេលនោះ) មានភិក្ខុ១រូបកំពុងច្របាច់បាយលាយដោយទឹកដោះថ្លាដ៏ច្រើន ហើយក៏ឲ្យដុំបាយ១ដុំធំដល់អាជីវកនោះ។ លំដាប់នោះ អាជីវកនោះក៏កាន់យកដុំបាយនោះ ហើយដើរទៅ។ (ពេលនោះ) មានអាជីវកម្នាក់ទៀតបានពោលពាក្យនេះនឹងអាជីវកនោះថា ម្នាលអាវុសោ អ្នកឯងបានដុំបាយមកពីទីណា។ អាជីវកដែលបានដុំបាយនោះឆ្លើយតបថា ម្នាលអាវុសោ ដុំបាយខ្ញុំបានមកអំពីទីដែលគេអង្គាសនៃមុណ្ឌកគហបតី (គហបតីត្រងោល) របស់ព្រះសមណគោតមនោះ។ ពួកឧបាសកបានឮពាក្យ

ចរចារនេះ នៃពួកអាជីវកនោះច្បាស់លាស់ហើយ។ ទើបពួកឧបាសកទាំងនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានបុណ្យ ហើយក៏អង្គុយក្នុងទី១ដ៏សមគួរ។ ឧបាសកទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពួកតិរ្ថិយអម្បាលនេះ ប្រាថ្នានឹងពោលទោសដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បពិត្រព្រះអង្គដ៏ចំរើន សូមកុំឲ្យលោកម្ចាស់ទាំងឡាយឲ្យ (វត្ថុអ្វីៗ) ដល់ពួកតិរ្ថិយដោយដៃរបស់ខ្លួនឡើយ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឧបាសកទាំងនោះឲ្យឃើញច្បាស់លាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ។ ឯពួកឧបាសកទាំងនោះ កាលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់លាស់ ទ្រង់ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ទ្រង់ធ្វើធម្មីកថាដ៏ល្មមសមគួរតាមហេតុនោះដល់ពួកភិក្ខុ ហើយទ្រង់ហៅភិក្ខុទាំងឡាយមក ត្រាស់ថា នែភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍១០យ៉ាង គឺ ដើម្បីសេចក្ដីល្អដល់សង្ឃ១ ដើម្បីសេចក្ដីសប្បាយដល់សង្ឃ១។បេ។ ដើម្បីញ៉ាំងព្រះសទ្ធម្មឲ្យស្ថិតស្ថេរ១ ដើម្បីអនុគ្រោះដល់វិន័យ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ***ភិក្ខុណាមួយឲ្យវត្ថុដែលបុគ្គលគួរទំពាស៊ី ឬវត្ថុដែលបុគ្គលគួរបរិភោគដល់អចេលកក្ដី បរិព្វាជកក្ដី បរិព្វាជិកាក្ដី ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ។***

[១៤៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថាអចេលក គឺបុគ្គលដែលបួសជាបរិព្វាជក មានកាយអាក្រាតទាំងអស់។ ដែលហៅថា បរិព្វាជក គឺបុរសដែលបួសជាបរិព្វាជកទាំងអស់ វៀរលែងតែភិក្ខុ និងសាមណេរចេញ។ ដែលហៅថា បរិព្វាជិកា គឺស្ត្រីដែលបួសជាបរិព្វាជិកាទាំងអស់ វៀរលែងតែភិក្ខុនី សិក្ខមានា និងសាមណេរីចេញ។ ដែលហៅថា វត្ថុដែលបុគ្គលគួរទំពាស៊ី គឺលើកទុកតែភោជន៥យ៉ាង ព្រមទាំងទឹក និងឈើស្ទន់ចេញ ក្រៅពីនោះ ហៅថា វត្ថុដែលបុគ្គលគួរទំពាស៊ីទាំងអស់។ ដែលហៅថា វត្ថុដែលបុគ្គលគួរបរិភោគ បានដល់ភោជន៥យ៉ាង គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១។ ពាក្យថា ឲ្យ គឺភិក្ខុឲ្យដោយកាយក្ដី ដោយវត្ថុដែលជាប់នឹងកាយក្ដី ដោយបោះឲ្យក្ដី ត្រូវអាបត្តិបាចិត្តិយ។

[១៤៧] ជនជាតិរ្ថិយ ភិក្ខុក៏សំគាល់ថា ជាតិរ្ថិយ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ។ ជនជាតិរ្ថិយ ភិក្ខុមានសេចក្ដីសង្ស័យ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ។ ជនជាតិរ្ថិយ ភិក្ខុសំគាល់ថា មិនមែនជាតិរ្ថិយ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុឲ្យទឹក និងឈើស្ទន់ ត្រូវអាបត្តិទុក្កដ។ បុគ្គលមិនមែនជាតិរ្ថិយ ភិក្ខុសំគាល់ថាជាតិរ្ថិយ ត្រូវអាបត្តិទុក្កដ។ ជនមិនមែនជាតិរ្ថិយ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ ជនមិនមែនជាតិរ្ថិយ ភិក្ខុសំគាល់ថាមិនមែនជាតិរ្ថិយ មិនត្រូវអាបត្តិឡើយ។

[១៤៨] អាបត្តិមិនមានដល់ភិក្ខុដែលប្រើគេឲ្យឲ្យ មិនឲ្យដោយខ្លួនឯង ដល់ភិក្ខុដែលដាក់[24] វត្ថុទុកឲ្យ ដល់ភិក្ខុដែលឲ្យរបស់ជាគ្រឿងលាបខាងក្រៅ[25] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ១ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី២ (៤២)

CS vin.vbu.pc.42 | ភាគ ទី៤

### (២. ឧយ្យោជនសិក្ខាបទំ)

[១៤៩] កាលនោះ ព្រះសព្វញ្ញូពុទ្ធដ៏មានជោគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បាននិយាយពាក្យនេះនឹងភិក្ខុជាសទ្ធិវិហារិករបស់ព្រះថេរៈជាបងប្អូនថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ថាដូច្នេះហើយ ក៏មិនឲ្យគេប្រគេន(អ្វីៗ) ដល់ភិក្ខុនោះឡើយ (បែរជា) ប្រើឲ្យត្រឡប់ទៅវិញថា ម្នាលអាវុសោ លោកចូរទៅចុះ ខ្ញុំនឹងនិយាយ ឬនឹងអង្គុយជាមួយនឹងលោកមិនសប្បាយទេ ខ្ញុំនឹងនិយាយ ឬនឹងអង្គុយតែម្នាក់ឯងស្រួលជាង។ គ្រានោះ កាលបើពេលដែលត្រូវឆាន់កាន់តែចូលមកជិតហើយ ភិក្ខុនោះមិនអាចនឹងត្រាច់ទៅបិណ្ឌបាតបាន សូម្បីគ្រាន់តែត្រឡប់មកធ្វើភត្តកិច្ចវិញ ក៏មិនទាន់ ជាអ្នកអត់ចង្ហាន់ (មួយពេលនោះឯង)។ ទើបភិក្ខុនោះទៅកាន់អារាម ហើយដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើមកបបួលភិក្ខុថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ហើយមិនឲ្យគេប្រគេនអ្វីៗដល់ភិក្ខុនោះ ស្រាប់តែបញ្ជូនឲ្យត្រឡប់ទៅវិញ (ដូច្នេះ)សោះ។បេ។ ព្រះអង្គត្រាស់សួរថា នែឧបនន្ទ បានឮថា អ្នកឯងបបួលភិក្ខុថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ហើយមិនឲ្យគេ (ឲ្យអ្វីៗ)ដល់ភិក្ខុនោះ (បែរជា) បញ្ជូនឲ្យត្រឡប់ទៅវិញ ពិតមែនឬ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្ដីនេះពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងមិនគួរនឹងបបួលភិក្ខុផងគ្នាថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ហើយមិនឲ្យគេឲ្យ(អ្វីៗ)ដល់ភិក្ខុនោះ (បែរជា) បញ្ជូនឲ្យត្រឡប់ទៅវិញ ដូច្នេះឡើយ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយនិយាយនឹងភិក្ខុយ៉ាងនេះថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងទៅកាន់ស្រុក ឬនិគមដើម្បីបិណ្ឌបាត ហើយឲ្យគេឲ្យ ឬមិនឲ្យគេឲ្យ (អ្វីៗ)ដល់ភិក្ខុនោះ ហើយបញ្ជូនឲ្យត្រឡប់ទៅវិញដោយពាក្យថា នែអាវុសោ លោកចូរទៅវិញចុះ ខ្ញុំនិយាយ ឬអង្គុយជាមួយនឹងលោកមិនសប្បាយទេ ខ្ញុំនិយាយ ឬអង្គុយតែម្នាក់ឯងស្រួលជាង ដូច្នេះ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើនូវហេតុនុ៎ះឯងឲ្យជាបច្ច័យ មិនមែនជាហេតុដទៃឡើយ។**

[១៥០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា នឹងភិក្ខុ គឺនឹងភិក្ខុដទៃ។ ពាក្យថា ម្នាលអាវុសោ លោកចូរមក (យើងនឹងទៅ)កាន់ស្រុក ឬនិគម (ដើម្បីបិណ្ឌបាត) គឺស្រុកក្តី និគមក្តី នគរក្តី ក៏ហៅថាស្រុក និងនិគម (ក្នុងសិក្ខាបទនេះ)។ ពាក្យថា ឲ្យគេឲ្យ(អ្វីៗ) ដល់ភិក្ខុនោះ គឺប្រើគេឲ្យឲ្យយាគូក្តី ភត្តក្តី ខាទនីយក្តី ភោជនីយក្តី (ដល់ភិក្ខុនោះ)។ ពាក្យថា មិនឲ្យគេឲ្យ គឺមិនឲ្យនរណាឲ្យ(អ្វីៗ)សោះ។ ពាក្យថា បញ្ជូនឲ្យត្រឡប់ទៅវិញ សេចក្តីថា ភិក្ខុប្រាថ្នាដើម្បីសើច ប្រាថ្នាដើម្បីលេង ប្រាថ្នាដើម្បីអង្គុយក្នុងទីស្ងាត់ ប្រាថ្នាដើម្បីប្រព្រឹត្តអនាចារជាមួយនឹងមាតុគ្រាម ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ លោកចូរទៅវិញចុះ ខ្ញុំនិយាយ ឬអង្គុយជាមួយនឹងលោកមិនស្រួលទេ ខ្ញុំនិយាយ ឬអង្គុយតែម្នាក់ឯងស្រួលជាង ថាហើយ ក៏បញ្ជូនឲ្យត្រឡប់ទៅវិញ ត្រូវអាបត្តិទុក្កដ។ កាលភិក្ខុនោះកំពុងលះបង់ទីល្មមមើលគ្នាឃើញ ឬទីល្មមស្តាប់ឮ ត្រូវអាបត្តិទុក្កដ។ កាលភិក្ខុនោះលះបង់ផុត (នូវទីល្មមមើលឃើញ ឬទីល្មមស្តាប់ឮ) ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ព្រោះធ្វើនូវហេតុនុ៎ះឯងឲ្យជាបច្ច័យ មិនមែនជាហេតុដទៃឡើយ សេចក្តីថា មិនមានហេតុនីមួយដទៃជាបច្ច័យ ក្រៅអំពីហេតុដែលបញ្ជូនទៅនោះឡើយ។

[១៥១] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន តែភិក្ខុសង្ស័យ ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាមិនមែនឧបសម្បន្ន ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុលើកឡើងនូវពាក្យបញ្ឈឺចិត្ត (ចំពោះឧបសម្បន្ន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុបញ្ជូនអនុបសម្បន្នទៅ ត្រូវអាបត្តិទុក្កដ។ ភិក្ខុលើកនូវពាក្យបញ្ឈឺចិត្ត (ចំពោះអនុបសម្បន្ន) ត្រូវអាបត្តិទុក្កដ។ មិនមែនជាឧបសម្បន្ន ភិក្ខុសំគាល់ថាជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ មិនមែនជាឧបសម្បន្ន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនជាឧបសម្បន្ន ភិក្ខុក៏សំគាល់ថាមិនមែនជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[១៥២] អាបត្តិមិនមានដល់ភិក្ខុដែលបញ្ជូនភិក្ខុផងគ្នាឲ្យត្រឡប់ទៅដោយគិតថា យើងទាំងពីររូបនឹងញុំាងជីវិតឲ្យប្រព្រឹត្តទៅក្នុងទីជាមួយគ្នាមិនបាន ដល់ភិក្ខុដែលបញ្ជូនភិក្ខុផងគ្នាឲ្យទៅដោយគិតថា ក្រែងភិក្ខុនោះបានឃើញរបស់មានដំឡៃច្រើនហើយ នឹងញុំាងលោភចិត្តឲ្យកើតឡើង ដល់ភិក្ខុបញ្ជូនភិក្ខុផងគ្នាឲ្យទៅដោយគិតថា ក្រែងភិក្ខុនោះបានឃើញមាតុគ្រាមហើយ នឹងញុំាងសេចក្តីអផ្សុកឲ្យកើតឡើង ដល់ភិក្ខុបញ្ជូនភិក្ខុផងគ្នាឲ្យទៅដោយពាក្យថា លោកចូរនាំយាគូក្តី ភត្តក្តី ខាទនីយក្តី ភោជនីយក្តី ទៅឲ្យដល់ភិក្ខុមានជម្ងឺ ឬភិក្ខុដែលនៅក្នុងវត្ត ឬអ្នកដែលរក្សាវត្ត ដល់ភិក្ខុមិនប្រាថ្នានឹងប្រព្រឹត្តអនាចារទេ (តែ) កាលបើមានកិច្ចហើយ ក៏បញ្ជូនភិក្ខុផងគ្នាទៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ២ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី៣ (៤៣)

CS vin.vbu.pc.43 | ភាគ ទី៤

### (៣. សភោជនសិក្ខាបទំ)

[១៥៣] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បានដើរទៅផ្ទះរបស់សំឡាញ់ ហើយក៏អង្គុយនៅក្នុងផ្ទះសម្រាប់ដេកជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះ។ ឯបុរសនោះក៏ចូលសំដៅទៅត្រង់ទីដែលព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុអង្គុយនោះ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ហើយក៏អង្គុយក្នុងទីដ៏សមគួរ។ លុះបុរសនោះអង្គុយក្នុងទីដ៏សមគួរហើយ និយាយពាក្យនេះនឹងប្រពន្ធថា នាងចូរប្រគេនចង្ហាន់ដល់លោកម្ចាស់ចុះ។ ស្ត្រីនោះក៏ប្រគេនចង្ហាន់ដល់ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុក្នុងគ្រានោះ។ លំដាប់នោះ បុរសនោះក៏និយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់និមន្តទៅចុះ ព្រោះយើងខ្ញុំបានប្រគេនចង្ហាន់ដល់លោកម្ចាស់ហើយ។ ឯស្ត្រីនោះកំណត់ដឹងថា បុរសនេះមានរាគៈគ្របសង្កត់ហើយ ក៏និយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គង់សិន កុំអាលនិមន្តទៅ។ បុរសនោះ(បាននិយាយ)ជាគំរប់ពីរដង។បេ។ បុរសនោះបាននិយាយពាក្យនេះ នឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុជាគំរប់បីដងថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់និមន្តទៅវិញចុះ ព្រោះយើងខ្ញុំបានប្រគេនចង្ហាន់ដល់លោកម្ចាស់ហើយ។ ឯស្ត្រីនោះសោត ក៏និយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុជាគំរប់បីដងថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គង់សិន កុំអាលនិមន្តទៅឡើយ។ ឯបុរសនោះ ក៏ដើរចេញអំពីផ្ទះទៅ ហើយពោលទោសនឹងភិក្ខុទាំងឡាយថា បពិត្រលោកទាំងឡាយដ៏ចំរើន លោកម្ចាស់ឧបនន្ទនេះទៅអង្គុយក្នុងផ្ទះសម្រាប់ដេកជាមួយនឹងប្រពន្ធរបស់ខ្ញុំ ព្រះឧបនន្ទនោះកាលខ្ញុំបញ្ជូនឲ្យទៅវិញ ក៏មិនចង់ទៅ យើងខ្ញុំទាំងឡាយជាអ្នកមានកិច្ចច្រើន មានរវល់ច្រើន។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុអម្បាលនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ (គឺតែប្រុស និងស្រី) (ដូច្នោះ) សោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងបានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ ពិតមែនឬ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ដំណើរនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ (ដូច្នោះ)ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នេះ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយចូលទៅសម្រេចការអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ។**

[១៥៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា ត្រកូលដែលមានជនតែពីរនាក់ គឺមានតែស្រីនិងប្រុសប៉ុណ្ណោះ។ ជនទាំងពីរនាក់មិនទាន់ចេញទៅ ហើយជនទាំងពីរនាក់នោះ ជាមនុស្សមានរាគៈនៅឡើយ។ ពាក្យថា ចូលទៅ គឺដើរចូលទៅ។ ពាក្យថា សម្រេចការអង្គុយ សេចក្តីថា ភិក្ខុលះហត្ថបាសនៃមេទ្វារ ឬធរណីក្នុងផ្ទះធំ ហើយអង្គុយនៅ ត្រូវអាបត្តិបាចិត្តិយ។ (បើ) ក្នុងផ្ទះតូច ភិក្ខុចូលហួសមេដំបូល[26] ទៅ ហើយអង្គុយ ត្រូវអាបត្តិបាចិត្តិយ។

[១៥៥] ផ្ទះសម្រាប់ដេក ភិក្ខុក៏សំគាល់ថាផ្ទះសម្រាប់ដេក ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ។ ផ្ទះសម្រាប់ដេក ភិក្ខុសង្ស័យ ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ។ ផ្ទះសម្រាប់ដេក ភិក្ខុសំគាល់ថាមិនមែនផ្ទះសម្រាប់ដេក ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុសំគាល់ថាផ្ទះសម្រាប់ដេក ត្រូវអាបត្តិទុក្កដ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុក៏សំគាល់ថាមិនមែនផ្ទះសម្រាប់ដេក មិនត្រូវអាបត្តិ។

[១៥៦] អាបត្តិមិនមានដល់ភិក្ខុដែលអង្គុយក្នុងផ្ទះធំ មិនលះហត្ថបាសនៃមេទ្វារ ឬធរណី ដល់ភិក្ខុអង្គុយក្នុងផ្ទះតូច មិនហួសមេដំបូល ដល់ភិក្ខុដែលមានភិក្ខុជាគំរប់ពីរអង្គុយនៅផង ដល់ភិក្ខុដែលអង្គុយនៅ តែជនទាំងពីរនាក់គេចេញទៅហើយ ដល់ភិក្ខុដែលអង្គុយនៅជាមួយនឹងជនទាំងពីរនាក់ជាបុគ្គលមិនមានរាគៈ ដល់ភិក្ខុអង្គុយនៅក្នុងផ្ទះ ដែលមិនមែនជាផ្ទះសម្រាប់ដេក ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៣ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី៤ (៤៤)

CS vin.vbu.pc.44 | ភាគ ទី៤

### (៤. រហោបដិច្ឆន្នសិក្ខាបទំ)

[១៥៧] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបទនៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បានទៅកាន់ផ្ទះរបស់បុរសជាសំឡាញ់ ហើយក៏សម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះ។ គ្រានោះ បុរសនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាម្ចាស់ មិនគួរបើនឹងហ៊ានមកសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងប្រពន្ធរបស់ខ្ញុំ (ដូច្នេះ) សោះ។ ភិក្ខុទាំងឡាយបានឮសំដីនៃបុរសនោះ និយាយពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងមាតុគ្រាម(ដូច្នេះ) ទេ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងទៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងមាតុគ្រាម ពិតមែនឬ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងមាតុគ្រាម (ដូច្នេះ)ទេ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង មួយអន្លើដោយមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ។**

[១៥៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា មាតុគ្រាម គឺស្រីមនុស្ស មិនមែនជាយក្សស្រី មិនមែនជាប្រេតស្រី មិនមែនតិរច្ឆានញី ដោយហោចទៅ សូម្បីតែក្មេងស្រីដែលទើបនឹងកើតបាន១ថ្ងៃ មិនបាច់និយាយទៅថ្វីដល់ស្រីធំទេ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា។ ដែលហៅថា ទីស្ងាត់ គឺទីដែលស្ងាត់ភ្នែក ស្ងាត់ត្រចៀក។ ដែលហៅថា ទីស្ងាត់ភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី បុគ្គលដទៃមិនអាចឃើញបាន។ ដែលហៅថា ទីស្ងាត់ត្រចៀក គឺទីដែលបុគ្គលដទៃមិនអាចស្តាប់ពាក្យជាប្រក្រតីបាន។ ដែលហៅថាអាសនៈជាទីកំបាំង គឺអាសនៈដែលគេបិទបាំងដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយកន្ទេលផែងក្តី ដោយវាំងនន ឬរាំងននក្តី ដោយឈើក្តី ដោយសសរក្តី ដោយស៊ុំក្តី ឬដោយវត្ថុណាមួយ។ ពាក្យថា សម្រេចការអង្គុយ គឺកាលបើមាតុគ្រាមអង្គុយ ភិក្ខុអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ។ កាលបើភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ។ ជនទាំងពីរអង្គុយក្តី ជនទាំងពីរដេកក្តី (ឯភិក្ខុ) ត្រូវអាបត្តិបាចិត្តិយ។

[១៥៩] មាតុគ្រាម ភិក្ខុក៏សំគាល់ថាមាតុគ្រាម ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងយក្សស្រីក្តី ប្រេតស្រីក្តី ខ្ទើយក្តី តិរច្ឆានញីដែលមានរាងកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម មិនត្រូវអាបត្តិឡើយ។

[១៦០] អាបត្តិមិនមានដល់ភិក្ខុដែលអង្គុយនៅ មានបុរសណាមួយដែលជាមនុស្សដឹងក្តី (នៅ) ជាគំរប់ពីរ ដល់ភិក្ខុឈរ មិនបានអង្គុយ ដល់ភិក្ខុបានក្រឡេកគយគន់រកទីមិនស្ងាត់ ហើយអង្គុយ ដល់ភិក្ខុមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃ ហើយអង្គុយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៤ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី៥ (៤៥)

CS vin.vbu.pc.45 | ភាគ ទី៤

### (៥. រហោនិសជ្ជសិក្ខាបទំ)

[១៦១] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ដើរទៅកាន់ផ្ទះរបស់សំឡាញ់ ហើយក៏សម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះតែម្នាក់និងម្នាក់។ គ្រានោះ បុរសនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាម្ចាស់ មិនសមបើនឹងហ៊ានមកសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងប្រពន្ធរបស់ខ្ញុំតែម្នាក់និងម្នាក់ (ដូច្នេះ) សោះ។ ភិក្ខុទាំងឡាយបានឮពាក្យសំដីនៃបុរសនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ)ហើយ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់និងម្នាក់ទេ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងទៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់និងម្នាក់ ពិតមែនឬ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់និងម្នាក់ (ដូច្នោះ)ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយសម្រេចការអង្គុយក្នុងទីស្ងាត់ មួយអន្លើដោយមាតុគ្រាមតែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ។**

[១៦២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា មាតុគ្រាម គឺចំពោះតែស្រីមនុស្ស មិនមែនជាយក្សស្រី មិនមែនជាប្រេតស្រី មិនមែនជាតិរច្ឆានញី ជាអ្នកដឹងក្តី ជាអ្នកអាចដើម្បីស្គាល់ពាក្យសំដី ដែលបុគ្គលនិយាយល្អ ឬអាក្រក់ ពាក្យអាសគ្រាម ឬមិនមែនអាសគ្រាម។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា។ ពាក្យថា តែម្នាក់និងម្នាក់ គឺមានតែភិក្ខុ និងមាតុគ្រាមប៉ុណ្ណោះ។ ដែលហៅថា ទីស្ងាត់ គឺទីស្ងាត់ភ្នែក ស្ងាត់ត្រចៀក។ ដែលហៅថា ទីស្ងាត់ភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី ជនដទៃមិនអាចឃើញបាន។ ដែលហៅថា ទីស្ងាត់ត្រចៀក គឺទីដែលបុគ្គលមិនអាចស្តាប់ពាក្យជាប្រក្រតីបាន។ ពាក្យថា សម្រេចការអង្គុយ គឺកាលដែលមាតុគ្រាមអង្គុយហើយ ភិក្ខុអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិត ឬដេកជិត (ភិក្ខុ) ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនិងស្រីទាំងពីរនាក់អង្គុយក្តី ដេកក្តី (ភិក្ខុ) ត្រូវអាបត្តិបាចិត្តិយ។

[១៦៣] មាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ហើយសម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយសម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម ហើយសម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់និងម្នាក់ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងយក្សស្រីក្តី ប្រេតស្រីក្តី ខ្ទើយក្តី តិរច្ឆានញីដែលមានរាងកាយដូចមនុស្សក្តីតែម្នាក់និងម្នាក់ ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម មិនមានអាបត្តិ។

[១៦៤] អាបត្តិមិនមានដល់ភិក្ខុដែលអង្គុយនៅ មានបុរសណាម្នាក់ជាអ្នកដឹងសេចក្តី នៅ ជាគំរប់ពីរ ដល់ភិក្ខុឈរ មិនបានអង្គុយ ដល់ភិក្ខុបានក្រឡេកគយគន់រកទីមិនស្ងាត់ ហើយអង្គុយនៅ ដល់ភិក្ខុមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃ អង្គុយនៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៥ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី៦ (៤៦)

CS vin.vbu.pc.46 | ភាគ ទី៤

### (៦. ចារិត្តសិក្ខាបទំ)

[១៦៥] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ។ សម័យនោះឯង ត្រកូលជាឧបដ្ឋាករបស់ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ និមន្តព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុដោយភត្ត ហើយក៏និមន្តពួកភិក្ខុឯទៀតដោយភត្តដែរ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ អាល័យតែចូលទៅរកត្រកូលទាំងឡាយ ក្នុងពេលមុនឆាន់។ ឯភិក្ខុទាំងឡាយនោះ ក៏បាននិយាយពាក្យនេះនឹងមនុស្សអម្បាលនោះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់(មក)។ ពួកមនុស្សអម្បាលនោះ ក៏និយាយឃាត់ថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយរង់ចាំសិន ទម្រាំព្រះឧបនន្ទជាម្ចាស់លោកនិមន្ត

មក។ ភិក្ខុទាំងឡាយនោះ បាននិយាយពាក្យនេះនឹងពួកមនុស្សអម្បាលនោះជាគំរប់ពីរដងថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់(មក)។ ពួកមនុស្សអម្បាលនោះ ក៏និយាយឃាត់ថា បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន សូមព្រះករុណាទាំងឡាយរង់ចាំសិនចុះ ទម្រាំតែព្រះឧបនន្ទជាម្ចាស់និមន្តមក។ ពួកភិក្ខុអម្បាលនោះ ក៏និយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះជាគំរប់បីដងថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់មក (នឹងបង្អង់នៅ) ក្រែងហួសពេលឆាន់។ មនុស្សទាំងឡាយ ក៏និយាយថា បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន យើងខ្ញុំទាំងឡាយបានធ្វើភត្តទាំងប៉ុន្មាន ព្រោះតែព្រះឧបនន្ទជាម្ចាស់ (ទេតើ) បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន សូមព្រះករុណាទាំងឡាយរង់ចាំ ទម្រាំតែព្រះឧបនន្ទជាម្ចាស់និមន្តមកសិន។ លំដាប់នោះ ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុអាល័យតែចូលទៅគួរសមនឹងត្រកូលទាំងឡាយក្នុងពេលមុនឆាន់ ហើយក៏មកក្នុងវេលាថ្ងៃពេក។ ភិក្ខុទាំងឡាយក៏ឆាន់ចង្ហាន់មិនឆ្អែតដល់ចិត្ត។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បានទទួលនិមន្តគេជាអ្នកមានភត្តហើយ មិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយ (ដទៃ) ក្នុងពេលមុនឆាន់ (ដូច្នេះ)សោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯង បានទទួលនិមន្តគេជាអ្នកមានភត្តហើយ ៗត្រាច់ទៅក្នុងត្រកូលទាំងឡាយ (ដទៃ) ក្នុងពេលមុនឆាន់ ពិតមែនឬ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីនោះពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងបានទទួលនិមន្តគេជាអ្នកមានភត្តហើយ មិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយ (ដទៃ) ក្នុងពេលមុនឆាន់ (ដូច្នេះ) ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយបានទទួលនិមន្តគេជាអ្នកមានភត្តហើយ ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនឆាន់ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១៦៦] កាលនោះ ត្រកូលឧបដ្ឋាករបស់ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បានបញ្ជូនខាទនីយាហារទៅដើម្បីប្រគេនដល់សង្ឃដោយពាក្យថា ខាទនីយនេះ អ្នកឯងត្រូវបង្ហាញដល់ព្រះឧបនន្ទជាម្ចាស់ ហើយសិមប្រគេនដល់សង្ឃចុះ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត។ ឯពួកមនុស្សអម្បាលនោះ ទៅកាន់អារាម ហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន ព្រះឧបនន្ទជាម្ចាស់និមន្តទៅឯណា។ ពួកភិក្ខុអម្បាលនោះប្រាប់ថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុនុ៎ះនិមន្តទៅកាន់ស្រុក ដើម្បីបិណ្ឌបាតហើយ។ មនុស្សទាំងឡាយក៏និយាយថា បពិត្រលោកម្ចាស់ដ៏ចំរើន ខាទនីយាហារនេះ សូមលោកម្ចាស់ទាំងឡាយបង្ហាញដល់ព្រះឧបនន្ទដ៏មានអាយុ ហើយសិមប្រគេនដល់សង្ឃចុះ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយត្រូវទទួលហើយ ដម្កល់ទុក ទម្រាំឧបនន្ទត្រឡប់មកវិញ។ គ្រានោះ ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុគិតថា ព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់មិនឲ្យត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងវេលាមុនភត្ត (គិតដូច្នោះហើយ) ក៏ចូលទៅរកត្រកូលទាំងឡាយក្នុងវេលាក្រោយភត្ត ហើយត្រឡប់មកក្នុងវេលាហួសពេល។ ខាទនីយាហារគេក៏ផ្ញើរត្រឡប់ទៅវិញ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនគួរបើនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងវេលាក្រោយភត្ត (ដូច្នោះ) សោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងវេលាក្រោយភត្ត ពិតមែនឬ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងពេលក្រោយភត្ត (ដូច្នេះ) ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយបានទទួលនិមន្តគេជាអ្នកមានភត្តហើយ ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១៦៧] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យក្នុងសម័យនៃចីវរទាន ហើយមិនបានចូលទៅរកត្រកូលទាំងឡាយ។ ចីវរក៏កើតឡើងតិចស្តួចស្តើង។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលទៅរកត្រកូលទាំងឡាយក្នុងសម័យនៃចីវរទាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយបានទទួលនិមន្តគេ ជាអ្នកមានភត្តហើយ ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ កាលដែលទាយកប្រគេនចីវរ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១៦៨] សម័យនោះឯង ភិក្ខុទាំងឡាយធ្វើចីវរកម្ម គឺការដេរចីវរ ក៏មានសេចក្តីត្រូវការដោយម្ជុលខ្លះ ដោយចេសខ្លះ ដោយកាំបិតខ្លះ។ ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យ មិនបានចូលទៅរកត្រកូលទាំងឡាយឡើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលទៅរកត្រកូលទាំងឡាយក្នុងសម័យធ្វើចីវរបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយបានទទួលនិមន្តគេ ជាអ្នកមានភត្តហើយ ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ កាលដែលទាយកប្រគេនចីវរ១ កាលដែលភិក្ខុធ្វើចីវរ១ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១៦៩] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺ ក៏មានសេចក្តីត្រូវការដោយភេសជ្ជៈទាំងឡាយ។ ភិក្ខុទាំងឡាយក៏សង្ស័យ មិនបានចូលទៅរកត្រកូលទាំងឡាយឡើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលា ឬប្រាប់ភិក្ខុដែលមាននៅ ហើយសឹមចូលទៅរកត្រកូលទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយបានទទួលនិមន្តគេ ជាអ្នកមានភត្តហើយ មិនបានលា ឬប្រាប់ភិក្ខុដែលមាននៅ ហើយដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ កាលដែលទាយកប្រគេនចីវរ១ កាលដែលភិក្ខុធ្វើចីវរ១ នេះជាសម័យក្នុងសិក្ខាបទនោះ។**

[១៧០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា គេនិមន្ត គឺជននិមន្តដោយភោជនទាំង៥យ៉ាង ភោជនណាមួយ។ ដែលហៅថា ជាអ្នកមានភត្ត គឺភិក្ខុដែលគេនិមន្តដោយភត្តណា ឈ្មោះថាជាអ្នកមានភត្ត ព្រោះភត្តនោះឯង។ ដែលហៅថា ភិក្ខុមាននៅនោះ គឺភិក្ខុអាចនឹងលាភិក្ខុផងគ្នា ហើយចូលទៅកាន់ (ត្រកូល)បាន។ ភិក្ខុដែលមិនមាននៅនោះ គឺភិក្ខុមិនអាចលាភិក្ខុផងគ្នា ហើយចូលទៅកាន់(ត្រកូល)ឡើយ។ ដែលហៅថា ក្នុងពេលមុនភត្ត គឺជននិមន្តដោយភត្តណា ហើយភិក្ខុមិនទាន់បានឆាន់ភត្តនោះ។ ដែលហៅថា ក្នុងពេលក្រោយភត្ត គឺជននិមន្តដោយភត្តណា ភិក្ខុបានឆាន់ភត្តនោះហើយ ដោយហោចទៅសូម្បីប៉ុន់ចុងនៃស្បូវ។ ដែលហៅថា ត្រកូល គឺត្រកូលទាំងឡាយ៤ គឺត្រកូលក្សត្រ១ ត្រកូលព្រាហ្មណ៍១ ត្រកូលវេស្សៈ (អ្នករកស៊ីជួញប្រែធ្វើស្រែចំការ)១ ត្រកូលសុទ្ទៈ (អ្នកធ្វើការស៊ីឈ្នួល)១។ ពាក្យថា ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ គឺកាលដែលភិក្ខុឈានចូលទៅដល់ឧបចារផ្ទះរបស់បុគ្គលដទៃទៅ ត្រូវអាបត្តិទុក្កដ។ ឈានជើងជាដម្បូងឲ្យកន្លងហួសធរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ។ ឈានជើងជាគំរប់ពីរឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកទុកតែមានសម័យ។ ដែលហៅថា កាលដែលទាយកប្រគេនចីវរនោះ គឺថា បើភិក្ខុមិនបានក្រាលកឋិន កំណត់កាលត្រឹម១ខែជាទីបំផុតនៃវស្សានរដូវ (គឺតាំងពី១រោចខែអស្សុជ ទៅដល់១៥កើត ខែកត្តិក) បើភិក្ខុបានក្រាលកឋិន កំណត់កាលត្រឹម៥ខែ (តាំងតែពី១រោចខែអស្សុជ ទៅដល់១៥កើតខែផល្គុន)។ ដែលហៅថា កាលដែលភិក្ខុធ្វើចីវរនោះ គឺភិក្ខុកំពុងធ្វើចីវរ។

[១៧១] មានគេនិមន្តហើយ ភិក្ខុសំគាល់ថាគេនិមន្តហើយ មិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ មានគេនិមន្តហើយ ភិក្ខុសង្ស័យ មិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ មានគេនិមន្តហើយ ភិក្ខុសំគាល់ថាមិនទាន់និមន្ត ហើយមិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងពេលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ គេមិនបាននិមន្ត ភិក្ខុសំគាល់ថានិមន្តហើយ ត្រូវអាបត្តិទុក្កដ។ គេមិនបាននិមន្ត ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ គេមិនបាននិមន្ត ភិក្ខុសំគាល់ថាមិនបាននិមន្ត មិនមានអាបត្តិ។

[១៧២] អាបត្តិមិនមានដល់ភិក្ខុដែលមានសម័យ ដល់ភិក្ខុដែលបានលាភិក្ខុផងគ្នាដែលមាននៅ ហើយចូលទៅ ដល់ភិក្ខុដែលមិនបានលាភិក្ខុផងគ្នា ព្រោះមិនមានភិក្ខុផងគ្នា ហើយចូលទៅ ដល់ភិក្ខុដែលដើរទៅតាមផ្លូវក្បែរផ្ទះនៃបុគ្គលដទៃ ដល់ភិក្ខុដែលដើរទៅដោយផ្លូវតាមឧបចារនៃផ្ទះ ដល់ភិក្ខុដែលទៅកាន់អារាមដែលមានក្នុងចន្លោះស្រុក ដល់ភិក្ខុដែលទៅកាន់លំនៅនៃនាងភិក្ខុនី ដល់ភិក្ខុដែលទៅកាន់លំនៅនៃតិត្ថិយ ដល់ភិក្ខុដែលដើរត្រឡប់មកវិញ ដល់ភិក្ខុទៅកាន់ផ្ទះនៃទាយកជាម្ចាស់ភត្ត ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៦ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី៧ (៤៧)

CS vin.vbu.pc.47 | ភាគ ទី៤

### (៧. មហានាមសិក្ខាបទំ)

[១៧៣] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងនិគ្រោធារាម ក្បែរក្រុងកបិលពស្តុ ក្នុងដែនសក្កៈ។ សម័យនោះឯង មហានាមសក្យៈ[27] មានថ្នាំសម្រាប់កែរោគដ៏បរិបូណ៌។ លំដាប់នោះ មហានាមសក្យៈក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយ

បង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ លុះមហានាមសក្យៈអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃដោយថ្នាំសម្រាប់កែរោគកំណត់៤ខែ។ ព្រះអង្គត្រាស់ថា មហានាម ការនេះប្រពៃពេកហើយ មហានាម បើដូច្នោះ ចូរព្រះអង្គបវារណាសង្ឃ ដោយថ្នាំសម្រាប់កែរោគកំណត់៤ខែចុះ។ ពួកភិក្ខុមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនោះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះការបវារណាដោយបច្ច័យកំណត់ត្រឹម៤ខែ។ សម័យនោះឯង ភិក្ខុទាំងឡាយទៅសូមភេសជ្ជៈនឹងមហានាមសក្យៈតែបន្តិចៗ ភេសជ្ជៈរបស់មហានាមសក្យៈ ក៏ជារបស់នៅតែបរិបូណ៌ដដែល។ ឯមហានាមសក្យៈក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគជាគំរប់ពីរដងទៀត លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ លុះមហានាមសក្យៈអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃដោយភេសជ្ជៈកំណត់៤ខែតទៅទៀត។ ព្រះអង្គត្រាស់ថា មហានាម ការនេះប្រពៃហើយៗ មហានាម បើដូច្នោះ ចូរព្រះអង្គបវារណាសង្ឃ ដោយភេសជ្ជៈកំណត់៤ខែតទៅទៀតចុះ។ ពួកភិក្ខុមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរនឹងការបវារណាថែមម្ដងទៀត។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយទៅសូមភេសជ្ជៈនឹងមហានាមសក្យៈតែបន្តិចៗ។ ដោយហេតុនោះឯង ភេសជ្ជៈរបស់មហានាមសក្យៈក៏នៅតែបរិបូណ៌ដដែល។ មហានាមសក្យៈក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគជាគំរប់បីដងទៀត លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ លុះមហានាមសក្យៈអង្គុយនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃដោយភេសជ្ជៈដរាបដល់អស់ជីវិត។ ព្រះអង្គត្រាស់តបថា មហានាម ការនោះប្រពៃហើយៗ មហានាម បើដូច្នោះ ចូរមហារាជបវារណាសង្ឃ ដោយភេសជ្ជៈដរាបដល់អស់ជីវិតចុះ។ ពួកភិក្ខុមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរនឹងការបវារណាអស់កាលជានិច្ចក៏បាន។

[១៧៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកដណ្ដប់មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ មហានាមសក្យៈក៏និយាយថា បពិត្រលោកម្ចាស់ដ៏ចំរើន ហេតុដូចម្ដេច បានជាលោកម្ចាស់ទាំងឡាយស្លៀកដណ្ដប់សំពត់មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ (ដូច្នេះ) ធម្មតា អ្នកបួសគេត្រូវស្លៀកដណ្ដប់សំពត់ឲ្យត្រឹមត្រូវល្អ ហើយមានអាកប្បកិរិយាដ៏សមគួរទេតើ។ ពួកឆព្វគ្គិយភិក្ខុក៏ចងទោសនឹងមហានាមសក្យៈ។ សេចក្ដីត្រិះរិះនេះកើតមានដល់ពួកឆព្វគ្គិយភិក្ខុក្នុងវេលានោះថា យើងទាំងឡាយគួរធ្វើមហានាមសក្យៈឲ្យអាប់អោនដោយឧបាយដូចម្ដេចអេះ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុក៏បានប្រឹក្សាគ្នាដូច្នេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ មហានាមសក្យៈបានបវារណាសង្ឃដោយភេសជ្ជៈហើយ ណ្ហើយចុះ ម្នាលលោកដ៏មានអាយុទាំងឡាយ យើងទាំងឡាយទៅសូមសប្បិអំពីមហានាមសក្យៈចុះ។ ទើបពួកឆព្វគ្គិយភិក្ខុចូលទៅរកមហានាមសក្យៈ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងមហានាមសក្យៈថា ម្នាលអាវុសោ ពួកអាត្មាត្រូវការដោយសប្បិមួយទោណៈ។ ឯមហានាមសក្យៈឆ្លើយតបថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ១ថ្ងៃសិន មនុស្សទាំងឡាយ គេទៅឯក្រោលគោដើម្បីនាំសប្បិមក លោកម្ចាស់ទាំងឡាយនឹងយកសប្បិនោះទៅក្នុងកាលដ៏គួរ។ ពួកឆព្វគ្គិយភិក្ខុនិយាយសូមជាគំរប់ពីរដង។បេ។ ឆព្វគ្គិយភិក្ខុនិយាយពាក្យនេះនឹងមហានាមសក្យៈជាគំរប់បីដងថា ម្នាលអាវុសោ ពួកអាត្មាត្រូវការដោយសប្បិមួយទោណៈ។ មហានាមសក្យៈឆ្លើយតបថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ១ថ្ងៃសិន មនុស្សទាំងឡាយ គេទៅឯក្រោលគោដើម្បីនាំសប្បិមក លោកម្ចាស់នឹងយកសប្បិនោះទៅក្នុងកាលដ៏គួរ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោ អ្នកបវារណាដោយភេសជ្ជៈណា ហើយមិនឲ្យវិញ ប្រយោជន៍អ្វីដោយភេសជ្ជៈដែលអ្នកបវារណា តែមិនចង់ឲ្យនោះ។ គ្រានោះ មហានាមសក្យៈក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកដ៏ចំរើនទាំងឡាយ ខ្ញុំបានអង្វរថា លោកម្ចាស់ដ៏ចំរើន សូមពួកលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ១ថ្ងៃសិន ចុះហេតុដូចម្ដេចបានជាមិនរង់ចាំ។ ភិក្ខុទាំងឡាយបានឮមហានាមសក្យៈពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ កាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចំរើន សូមពួកលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ១ថ្ងៃសិន មិនគួរនឹងមិនរង់ចាំសោះ។បេ។ ព្រះពុទ្ធជាម្ចាស់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ កាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចំរើន សូមពួកលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ១ថ្ងៃសិនដូច្នេះ ហើយមិនរង់ចាំ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលពួកមោឃបុរស អ្នកទាំងឡាយ កាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចំរើន សូមពួកលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ១ថ្ងៃសិន ហើយមិនសមនឹងមិនរង់ចាំ (ដូច្នេះ) សោះ នែមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាស្រាប់ហើយនោះទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុដែលគ្មានជម្ងឺ ត្រូវត្រេកអរនឹងការបវារណាដោយបច្ច័យកំណត់ត្រឹម៤ខែ បើភិក្ខុត្រេកអរក្រៃលែងជាងនោះទៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែគេបានបវារណាថែមទៀត វៀរលែងតែគេបានបវារណាជានិច្ច។**

[១៧៥] ត្រង់ពាក្យថា ភិក្ខុដែលគ្មានជម្ងឺត្រូវត្រេកអរនឹងការបវារណាដោយបច្ច័យកំណត់ត្រឹម៤ខែ សេចក្ដីថា ភិក្ខុគួរត្រេកអរនឹងការបវារណាដោយគិលានបច្ច័យ ម្យ៉ាងទៀត ភិក្ខុគួរត្រេកអរនឹងការបវារណាថែមទៀត ដោយគិតថា អញជាអ្នកមានជម្ងឺក្នុងកាលណា អញនឹងសូមក្នុងកាលណោះ ម្យ៉ាងទៀត ភិក្ខុគួរត្រេកអរនឹងការបវារណាជាប់ជានិច្ច ដោយគិតថា អញជាអ្នកមានជម្ងឺក្នុងកាលណា អញនឹងសូមក្នុងកាលណោះ។

[១៧៦] ត្រង់ពាក្យថា បើភិក្ខុត្រេកអរក្រៃលែងជាងនោះ សេចក្ដីថា បវារណាកំណត់ភេសជ្ជៈ មិនកំណត់រាត្រី បវារណាកំណត់រាត្រី មិនកំណត់ភេសជ្ជៈ បវារណាកំណត់ទាំងភេសជ្ជៈ កំណត់ទាំងរាត្រី បវារណាមិនកំណត់ទាំងភេសជ្ជៈ មិនកំណត់ទាំងរាត្រី។ ដែលហៅថា បវារណាកំណត់ភេសជ្ជៈ (នោះ) គឺភេសជ្ជៈដែលគេកំណត់ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណាដោយភេសជ្ជៈទាំងឡាយមានប្រមាណប៉ុណ្ណេះ។ ដែលហៅថា បវារណាកំណត់រាត្រី គឺរាត្រីដែលគេកំណត់ដោយពាក្យថា ខ្ញុំព្រះករុណាបវារណាអស់រាត្រីទាំងឡាយមានប្រមាណប៉ុណ្ណេះ។ ដែលហៅថា បវារណាកំណត់ទាំងភេសជ្ជៈ កំណត់ទាំងរាត្រីនោះ គឺគេកំណត់ភេសជ្ជៈទាំងឡាយផង កំណត់រាត្រីទាំងឡាយផង ដោយពាក្យថា ខ្ញុំព្រះ

ករុណាសូមបវារណាដោយភេសជ្ជៈទាំងឡាយមានប្រមាណប៉ុណ្ណេះ អស់រាត្រីទាំងឡាយមានប្រមាណប៉ុណ្ណេះ។ ដែលហៅថា បវារណាមិនកំណត់ភេសជ្ជៈ មិនកំណត់រាត្រី (នោះ) គឺគេមិនកំណត់ភេសជ្ជៈទាំងឡាយ និងមិនកំណត់រាត្រីទាំងឡាយ ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណាដោយភេសជ្ជៈទាំងឡាយមានប្រមាណប៉ុណ្ណេះ និងអស់រាត្រីទាំងឡាយមានប្រមាណប៉ុណ្ណេះ។

[១៧៧] ឯពាក្យដែលថា កំណត់ភេសជ្ជៈនោះ អធិប្បាយថា គេបវារណាភិក្ខុដោយភេសជ្ជៈណា ភិក្ខុត្រឡប់ទៅសូមភេសជ្ជៈទាំងឡាយដទៃវិញ ក្រៅពីភេសជ្ជៈដែលគេបវារណានោះ ត្រូវអាបត្តិបាចិត្តិយ។ ឯកំណត់រាត្រីនោះ គឺគេបវារណាភិក្ខុក្នុងរាត្រីទាំងឡាយណា ភិក្ខុត្រឡប់សូមក្នុងរាត្រីទាំងឡាយឯទៀតវិញ ក្រៅពីរាត្រីដែលគេបវារណានោះ ត្រូវអាបត្តិបាចិត្តិយ។ ឯកំណត់ទាំងភេសជ្ជៈ កំណត់ទាំងរាត្រីនោះ គឺគេបវារណាភិក្ខុដោយភេសជ្ជៈទាំងឡាយណា ភិក្ខុវៀរលែងភេសជ្ជៈទាំងនោះ គេបវារណាភិក្ខុក្នុងរាត្រីណា ភិក្ខុវៀរលែងរាត្រីទាំងនោះ ហើយត្រឡប់ទៅសូមភេសជ្ជៈទាំងឡាយដទៃ និងក្នុងរាត្រីទាំងឡាយឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ។ ឯមិនកំណត់ភេសជ្ជៈ និងមិនកំណត់រាត្រី មិនមានអាបត្តិឡើយ។

[១៧៨] កាលបើមិនមានកិច្ចដោយភេសជ្ជៈ ហើយភិក្ខុទៅសូមភេសជ្ជៈ ត្រូវអាបត្តិបាចិត្តិយ។ កាលបើមានកិច្ចដោយភេសជ្ជៈឯទៀត ហើយភិក្ខុទៅសូមភេសជ្ជៈឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសំគាល់ថា ហួសកំណត់ដែលគេបវារណាមែនហើយទៅសូមភេសជ្ជៈ ត្រូវអាបត្តិបាចិត្តិយ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសង្ស័យ ហើយទៅសូមភេសជ្ជៈ ត្រូវអាបត្តិបាចិត្តិយ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសំគាល់ថា មិនហួសកំណត់បវារណាទេ ហើយទៅសូមភេសជ្ជៈ ត្រូវអាបត្តិបាចិត្តិយ។ មិនទាន់ហួសកំណត់ដែលគេបវារណាទេ ភិក្ខុសំគាល់ថា ហួសកំណត់ដែលគេបវារណាហើយ ត្រូវអាបត្តិទុក្កដ។ មិនទាន់ហួសកំណត់ដែលគេបវារណាទេ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនទាន់ហួសកំណត់ដែលគេបវារណាទេ ភិក្ខុសំគាល់ថា មិនទាន់ហួសកំណត់បវារណា មិនមានអាបត្តិ។

[១៧៩] អាបត្តិមិនមានដល់ភិក្ខុដែលគេបវារណាដោយភេសជ្ជៈទាំងឡាយណា ភិក្ខុសូមភេសជ្ជៈទាំងឡាយនោះ ដល់ភិក្ខុដែលគេបវារណាក្នុងរាត្រីទាំងឡាយណា ភិក្ខុសូមក្នុងរាត្រីទាំងឡាយនោះ ដល់ភិក្ខុដែលនិយាយប្រាប់គេថា យើងទាំងឡាយ គឺអ្នកបានបវារណាហើយ ដោយភេសជ្ជៈទាំងឡាយនេះ (ឥឡូវនេះ) យើងទាំងឡាយត្រូវការដោយភេសជ្ជៈនេះផង នេះផង ហើយសូម ដល់ភិក្ខុដែលនិយាយប្រាប់គេថា យើងទាំងឡាយគឺអ្នកបានបវារណាហើយក្នុងរាត្រីទាំងឡាយណា ឯរាត្រីទាំងឡាយនោះកន្លងហួសទៅហើយ (ឥឡូវនេះ) យើងទាំងឡាយត្រូវការដោយភេសជ្ជៈ ហើយសូម ដល់ភិក្ខុដែលសូមអំពីពួកញាតិ ដល់ភិក្ខុដែលសូមអំពីពួកទាយកដែលគេបានបវារណា ដល់ភិក្ខុដែលសូមដើម្បីជាប្រយោជន៍ដល់ភិក្ខុឯទៀត ដល់ភិក្ខុដែលបានមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៧ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី៨ (៤៨)

CS vin.vbu.pc.48 | ភាគ ទី៤

### (៨. ឧយ្យុត្តសេនាសិក្ខាបទំ)

[១៨០] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ព្រះបាទបសេនទិកោសលរាជ ទ្រង់លើកកងទ័ពចេញទៅ។ ពួកឆព្វគ្គិយភិក្ខុក៏បានទៅមើលកងទ័ពដែលស្តេចលើកចេញទៅហើយ។ ព្រះបាទបសេនទិកោសលរាជ បានទតឃើញពួកឆព្វគ្គិយដើរមកពីចម្ងាយ លុះទ្រង់ឃើញហើយ ក៏មានបន្ទូលឲ្យនិមន្តមក ហើយទ្រង់ត្រាស់សួរដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចំរើន ពួកលោកនាំគ្នាមកធ្វើអ្វី។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា ពួកអាត្មាមានប្រាថ្នាដើម្បីនឹងមើលមហាបពិត្រ។ ស្តេចក៏ទ្រង់ត្រាស់ថា បពិត្រលោកម្ចាស់ ការមើលខ្ញុំព្រះករុណាជាអ្នកត្រេកអរក្នុងការច្បាំងនឹងមានប្រយោជន៍អ្វី ពួកលោកត្រូវតែរមិលមើលព្រះដ៏មានព្រះភាគទេតើ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រ មិនគួរនឹងមកមើលកងទ័ព ដែលស្តេចលើកចេញទៅសោះ ពួកយើងឯណាមកក្នុងកងទ័ព ព្រោះហេតុតែការចិញ្ចឹមជីវិត និងបុត្រភរិយា យើងនោះឈ្មោះថាគ្មានលាភផង ឈ្មោះថាបានរបស់អាក្រក់ផង។ ភិក្ខុទាំងឡាយបានឮពួកមនុស្សនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងនាំគ្នាទៅមើលកងទ័ពដែលស្តេចលើកចេញទៅសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ នាំគ្នាទៅមើលកងទ័ពដែលស្តេចលើកទៅ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងទៅមើលកងទ័ពដែលស្តេចលើកចេញទៅទេ នែមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយ ទៅដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[១៨១] សម័យនោះឯង ឪពុកធំរបស់ភិក្ខុមួយរូបមានជម្ងឺក្នុងកងទ័ព។ អ្នកនោះក៏បញ្ជូនទូតទៅកាន់សំណាក់ភិក្ខុនោះថា ខ្ញុំព្រះករុណាមានជម្ងឺក្នុងកងទ័ព សូមលោកម្ចាស់និមន្តមក ខ្ញុំព្រះករុណាចង់ឲ្យលោកម្ចាស់និមន្តមកណាស់។ លំដាប់នោះ ភិក្ខុនោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយថា ភិក្ខុមិនត្រូវទៅមើលកងទ័ពដែលគេលើកចេញទៅទេ តែឥឡូវឪពុកធំអញនេះមានជម្ងឺនៅក្នុងកងទ័ព អញត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ទើបភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគម្ចាស់។ ព្រោះនិទាននេះ ដំណើរ

នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យទៅកាន់កងទ័ពបាន ព្រោះហេតុមានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយទៅដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ។**

[១៨២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា កងទ័ពដែលគេលើកចេញទៅ គឺកងទ័ពលើកចេញពីស្រុក ទៅតាំងសំចតនៅក្ដី ចេញទៅហើយ ចេះតែដើរទៅទៀតក្ដី។ ដែលហៅថា កងទ័ព គឺពលដំរី ពលសេះ ពលរថ ពលថ្មើរជើង។ ពលដំរី (មួយៗ) មានបុរស១២នាក់។ ពលសេះ (មួយៗ)មានបុរសបីនាក់។ ពលរថ (មួយៗ)មានបុរសបួននាក់។ ពលថ្មើរជើង(មួយៗ)មានបុរសបួននាក់កាន់ធ្នូសរ។ ភិក្ខុដើរទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ។ ភិក្ខុឈរមើល (កងទ័ពនោះ) នៅទីណា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ (ក្នុងទីនោះ)។ ភិក្ខុលះបង់ឧបចារសម្រាប់មើលឃើញ ហើយមើលរឿយៗ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ គឺលើកលែងនូវហេតុមានសភាពយ៉ាងហ្នឹង។

[១៨៣] កងទ័ពលើកចេញទៅហើយ ភិក្ខុសំគាល់ថា កងទ័ពលើកចេញទៅមែន ហើយដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ។ កងទ័ពលើកចេញទៅហើយ ភិក្ខុមានសេចក្ដីសង្ស័យ ហើយនៅតែដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ។ កងទ័ពលើកចេញទៅហើយ ភិក្ខុសំគាល់ថា កងទ័ពមិនទាន់លើកចេញទៅទេ ហើយដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ។ ភិក្ខុដើរទៅដើម្បីមើលកងទ័ពមួយៗ (ក្នុងកងទ័ពទាំង៤) ត្រូវអាបត្តិទុក្កដ។ ភិក្ខុឈរមើលកងទ័ពនៅទីណា ត្រូវអាបត្តិទុក្កដនៅ (ទីនោះ)។ ភិក្ខុលះបង់នូវឧបចារសម្រាប់មើលឃើញ ហើយមើលរឿយៗ ត្រូវអាបត្តិទុក្កដ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុសំគាល់ថា លើកចេញទៅហើយ ត្រូវអាបត្តិទុក្កដ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កងទ័ពមិនទាន់លើកចេញទៅទេ ភិក្ខុសំគាល់ថា មិនទាន់លើកចេញទៅមែន មិនត្រូវអាបត្តិ។

[១៨៤] អាបត្តិមិនមានដល់ភិក្ខុដែលឈរនៅក្នុងអារាម ហើយមើលឃើញ ដល់ភិក្ខុដែលកងទ័ពនោះលើកមកកាន់ទីដែលភិក្ខុឈរនៅ (ក្ដី) អង្គុយនៅ(ក្ដី) ដេកនៅ (ក្ដី) ដល់ភិក្ខុដែលដើរទៅជួបផ្លូវគ្នាបានឃើញកងទ័ព ដល់ភិក្ខុដែលមានហេតុមានសភាពយ៉ាងនោះ ដល់ភិក្ខុដែលមានសេចក្ដីអន្តរាយកើតឡើង[28] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៨ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី៩ (៤៩)

CS vin.vbu.pc.49 | ភាគ ទី៤

### (៩. សេនាវាសសិក្ខាបទំ)

[១៨៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមានកិច្ចធុរៈ ក៏នាំគ្នាទៅកាន់កងទ័ព ហើយឈប់នៅក្នុងកងទ័ពច្រើនជាងបីរាត្រីឡើងទៅ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈសក្យបុត្រ មិនគួរនឹងនៅក្នុងកងទ័ពទេ ពួកយើងឯណាមកអាស្រ័យនៅក្នុងកងទ័ព ក៏ព្រោះតែការចិញ្ចឹមជីវិតខ្លួន និងបុត្រភរិយា យើងទាំងនោះឈ្មោះថាគ្មានលាភផង ឈ្មោះថាបានរបស់អាក្រក់ផង។ ពួកភិក្ខុបានឮពួកមនុស្សនោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះហើយ។ ពួកភិក្ខុណាជាអ្នកមានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងនៅក្នុងកងទ័ពឲ្យច្រើនជាងបីរាត្រីទៅសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងទៅនៅក្នុងកងទ័ពឲ្យច្រើនជាងបីរាត្រីទៅ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងនៅក្នុងកងទ័ពឲ្យច្រើនជាងបីរាត្រីទៅទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា (បើ)

**ភិក្ខុនោះមានហេតុអ្វីៗ គួរនឹងទៅកាន់កងទ័ពនោះ ភិក្ខុនោះត្រូវនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី។ បើនៅឲ្យហួសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។**

[១៨៦] ត្រង់ពាក្យថា (បើ) ភិក្ខុនោះមានហេតុអ្វីៗគួរនឹងទៅកាន់កងទ័ព គឺថា ភិក្ខុមានហេតុ មានកិច្ចធុរៈ (ដែលគួរខានមិនបាន)។ ពាក្យថា ភិក្ខុនោះគប្បីនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី គឺភិក្ខុត្រូវនៅបានត្រឹមពីរបីយប់។ ពាក្យថា បើនៅឲ្យហួសពីកំណត់នោះទៅ សេចក្ដីថា កាលព្រះអាទិត្យ អស្តង្គតក្នុងថ្ងៃជាគំរប់៤ ភិក្ខុចេះតែនៅក្នុងកងទ័ពនោះ ត្រូវអាបត្តិបាចិត្តិយ។

[១៨៧] កាលហួសកំណត់បីរាត្រីហើយ ភិក្ខុសំគាល់ថាហួសមែន ហើយចេះតែនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ។ កាលហួសកំណត់បីរាត្រីហើយ ភិក្ខុមានសេចក្ដីសង្ស័យ ហើយចេះតែនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ។ កាលហួសកំណត់បីរាត្រីហើយ ភិក្ខុសំគាល់ថានៅខ្វះ

ហើយប្រឹងតែនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ។ កាលមិនទាន់ដល់បីរាត្រី ភិក្ខុសំគាល់ថាហួសហើយ ត្រូវអាបត្តិទុក្កដ។ កាលមិនទាន់ដល់បីរាត្រីទេ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កាលមិនទាន់ដល់បីរាត្រីទេ ភិក្ខុក៏សំគាល់ថាមិនទាន់ដល់ មិនត្រូវអាបត្តិ។

[១៨៨] អាបត្តិមិនមានដល់ភិក្ខុដែលនៅត្រឹមពីរបីរាត្រី ដល់ភិក្ខុដែលនៅមិនទាន់ដល់ពីរបីរាត្រី ដល់ភិក្ខុដែលនៅត្រឹមពីររាត្រីហើយ ក្នុងរាត្រីជាគំរប់បី បានចេញទៅមុនអរុណរះ ហើយត្រឡប់ទៅនៅវិញទៀត ដល់ភិក្ខុដែលមានជម្ងឺនៅ (ក្នុងកងទ័ព) ដល់ភិក្ខុដែលនៅដោយកិច្ចរបស់ភិក្ខុមានជម្ងឺ ដល់ភិក្ខុដែលនៅក្នុងកងទ័ព ហើយមានកងទ័ពជាសត្រូវមកចោមព័ទ្ធកងទ័ព (នោះឯង) ដល់ភិក្ខុដែលជាប់ជំពាក់ (ដោយបុគ្គលមានពៀរ ឬឥស្សរជន) ណាមួយ ដល់ភិក្ខុដែលមានសេចក្ដីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ៩ ចប់។

## (បាចិត្តិយ អចេលកវគ្គ) សិក្ខាបទ ទី១០ (៥០)

CS vin.vbu.pc.50 | ភាគ ទី៤

### (១០. ឧយ្យោធិកសិក្ខាបទំ)

[១៨៩] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលនៅក្នុងកងទ័ពអស់ពីរបីរាត្រី បាននាំគ្នាទៅកាន់ទីដែលគេច្បាំងគ្នាខ្លះ ទីគេត្រួតពលខ្លះ ទីតាំងនៅនៃកងទ័ពខ្លះ ទីសម្រាប់មើលគេចាត់ក្បួនទ័ពខ្លះ។ មានឆព្វគ្គិយភិក្ខុមួយរូប ទៅកាន់ទីដែលគេច្បាំង ហើយភិក្ខុនោះត្រូវសរ។ មនុស្សទាំងឡាយក៏ឡកឡឺយឲ្យភិក្ខុនោះថា លោកម្ចាស់លោកច្បាំងស្រួលឬទេ លោកបានខ្ទាច់ប៉ុន្មានហើយ។ កាលមនុស្សទាំងឡាយនោះចំអកចំអន់ឲ្យ ភិក្ខុនោះក៏អៀនអន់។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រមិនគួរនឹងនាំគ្នាមកមើលចម្បាំងសោះ ឯពួកយើងមកកាន់ចម្បាំងក៏ព្រោះតែការចិញ្ចឹមជីវិត និងបុត្រភរិយា អំពើនេះមិនមែនជាលាភរបស់យើងទេ គឺទ្រព្យដែលពួកយើងបានមក ឈ្មោះថាបានហើយដោយអាក្រក់ទេតើ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាជាអ្នកមានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងទៅមើលចម្បាំងសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយទៅមើលចម្បាំង ពិតមែនឬ។ ពួកភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នករាល់គ្នាមិនគួរនឹងទៅមើលចម្បាំងទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **កាលបើភិក្ខុនៅក្នុងកងទ័ពកំណត់ពីរបីរាត្រីហើយ ទៅកាន់ទីដែលគេច្បាំងគ្នាក្ដី ទីដែលគេត្រួតពលក្ដី ទីតាំងនៅនៃកងទ័ពក្ដី ទីសម្រាប់គេចាត់ក្បួនទ័ពក្ដី ត្រូវអាបត្តិបាចិត្តិយ។**

[១៩០] ត្រង់ពាក្យថា បើភិក្ខុនៅក្នុងកងទ័ពកំណត់ពីរបីរាត្រីហើយ សេចក្ដីថា ភិក្ខុនៅក្នុងកងទ័ពបានត្រឹមពីរបីយប់។ ដែលហៅថា ទីដែលគេច្បាំងគ្នានោះ គឺទីដែលគេប្រហារគ្នា។ ដែលហៅថា ទីដែលគេត្រួតពលនោះ គឺទីដែលគេរាប់ពលថា ពលដំរីមានប៉ុណ្ណេះ ពលសេះមានប៉ុណ្ណេះ ពលរថមានប៉ុណ្ណេះ ពលថ្មើរជើងមានប៉ុណ្ណេះ។ ដែលហៅថា ទីតាំងនៅនៃកងទ័ពនោះ គឺពលដំរីនៅត្រង់កន្លែងនេះ ពលសេះនៅត្រង់កន្លែងនេះ ពលរថនៅត្រង់កន្លែងនេះ ពលថ្មើរជើងនៅត្រង់កន្លែងនេះ។ ដែលហៅថា ក្បួនទ័ពនោះ គឺពួកសេនាដំរី១ ពួកសេនាសេះ១ ពួកសេនារថ១ ពួកសេនាថ្មើរជើង១។ ដំរីបី ហៅថា សេនាដំរីយ៉ាងតិចបំផុត។ សេះបី ហៅថា ពួកសេនាសេះយ៉ាងតិចបំផុត។ រថបី ហៅថា ពួកសេនារថយ៉ាងតិចបំផុត។ បុរសបួននាក់កាន់សរគ្រប់ដៃ ហៅថា ពួកសេនាថ្មើរជើងយ៉ាងតិចបំផុត។

[១៩១] ភិក្ខុទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ។ ភិក្ខុឈរមើលឃើញក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុលះបង់ឧបចារនៃទីមើល ហើយក៏នៅមើលឃើញរឿយៗ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុទៅដើម្បីមើលកងទ័ពមួយៗ ត្រូវអាបត្តិទុក្កដ។ ភិក្ខុឈរមើលឃើញក្នុងទីណា ត្រូវអាបត្តិទុក្កដ។ ភិក្ខុលះបង់ឧបចារនៃទីមើលហើយ ក៏នៅមើលឃើញរឿយៗ ត្រូវអាបត្តិទុក្កដ។

[១៩២] អាបត្តិមិនមានដល់ភិក្ខុដែលឈរមើលនៅក្នុងអារាម ដល់ភិក្ខុដែលឃើញចម្បាំងជាដើមដែលគេមកកាន់ទីដែលខ្លួនឈរក្ដី អង្គុយក្ដី ដេកក្ដី ដល់ភិក្ខុដែលដើរទៅប្រទះឃើញតាមផ្លូវ ដល់ភិក្ខុដែលមានកិច្ច (ត្រូវទៅ) ហើយប្រទះឃើញ ដល់ភិក្ខុដែលមានសេចក្ដីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ។

សិក្ខាបទ ទី ១០ ចប់។

អចេលកវគ្គ ជាគំរប់៥ ចប់។

ឧទ្ទាននៃអចេលកវគ្គនោះមាន១០ សិក្ខាបទគឺ

បូវសិក្ខាបទ១ កថាសិក្ខាបទ១

ឧបនន្ទ ៣ សិក្ខាបទ ឧបដ្ឋាកសិក្ខាបទ១

មហានាមសិក្ខាបទ១ បសេនទិសិក្ខាបទ១

សេនាសិក្ខាបទ១ វិទ្ធសិក្ខាបទ១។

# សុរាបានវគ្គ (ទី៦)

CS vin.vbu.pc.v6 | ភាគ ទី៤

### (៦. សុរាបានវគ្គោ)

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី១ (៥១)

CS vin.vbu.pc.51 | ភាគ ទី៤

### (១. សុរាបានសិក្ខាបទំ)

[១៩៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងចេតិយជនបទ ហើយយាងទៅកាន់ស្រុកភទ្ទវតិកា។ ពួកអ្នកឃ្វាលគោ ពួកអ្នកឃ្វាលបសុសត្វ (សត្វសម្រាប់ចិញ្ចឹមជាអាហារ) ពួកអ្នកស្រែ ពួកអ្នកដើរផ្លូវ បានឃើញព្រះដ៏មានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយ ក៏នាំគ្នាក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគកុំយាងទៅកាន់កំពង់ឈ្មោះអម្ពៈឡើយ បពិត្រព្រះអង្គដ៏ចំរើន នាគមានរិទ្ធិជាសត្វអាសិរ្វិស មានពិសដ៏ក្លៀវក្លាអាស្រ័យនៅក្នុងអាស្រមរបស់ជដិល ទៀបកំពង់ឈ្មោះអម្ពៈ កុំឲ្យនាគនោះបៀតបៀនព្រះដ៏មានព្រះភាគបានឡើយ។ កាលពួកជនទាំងនោះក្រាបទូលយ៉ាងនេះហើយ ព្រះទ្រង់ជោគជាម្ចាស់ក៏ស្ងៀម។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកស្រែ អ្នកដើរផ្លូវ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាគំរប់ពីរដងផង។បេ។ បីដងផងថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គកុំយាងទៅកាន់កំពង់អម្ពៈឡើយ បពិត្រព្រះអង្គដ៏ចំរើន (ព្រោះមាន) នាគមានរិទ្ធិជាសត្វអាសិរ្វិស មានពិសដ៏ក្លៀវក្លាអាស្រ័យនៅក្នុងអាស្រមរបស់ជដិល ទៀបកំពង់អម្ពៈ កុំឲ្យនាគនោះបៀតបៀនព្រះដ៏មានព្រះភាគបានឡើយ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ស្ងៀមជាគំរប់បីដង។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ក៏បានយាងទៅដល់ស្រុកភទ្ទវតិកា។ មានដំណឹងល្បីទៅថា ព្រះដ៏មានព្រះភាគគង់នៅក្នុងស្រុកភទ្ទវតិកានោះ។ គ្រានោះឯង ព្រះសាគតៈដ៏មានអាយុបានចូលទៅកាន់អាស្រមរបស់ជដិល ទៀបកំពង់អម្ពៈ លុះចូលទៅដល់ហើយ ក៏ដើរចូលទៅក្នុងរោងភ្លើង ក្រាលកម្រាលស្មៅ ហើយក៏អង្គុយពែនភ្នែន តាំងកាយដ៏ត្រង់ ដម្កល់សតិផ្ចិតផ្ចង់។ ឯនាគនោះបានឃើញព្រះសាគតៈដ៏មានអាយុចូលមកហើយ លុះឃើញហើយ ក៏កើតទុក្ខទោមនស្ស បង្ហុយផ្សែង (ពិសចំពោះសាគតត្ថេរ)។ ចំណែកខាងព្រះសាគតៈដ៏មានអាយុ ក៏បង្ហុយផ្សែងតបទៅវិញ។ លំដាប់នោះ នាគនោះខំអត់ទ្រាំនូវសេចក្តីរំលុបលើ (នោះ) មិនបាន ក៏បណ្តាលឲ្យកើតភ្លើងឡើង។ ឯព្រះសាគតៈដ៏មានអាយុ ក៏បានចូលតេជោធាតុ ហើយបណ្តាលភ្លើងតបទៅវិញ។ គ្រានោះឯង ព្រះសាគតៈដ៏មានអាយុ ក៏បានគ្របសង្កត់តេជៈរបស់នាគនោះ ដោយតេជៈ (របស់លោក) ហើយក៏ចូលទៅកាន់ស្រុកភទ្ទវតិកា។ កាលដែលព្រះដ៏មានព្រះភាគ គង់នៅក្នុងស្រុកភទ្ទវតិកាតាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកឯក្រុងកោសម្ពី។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពីបានឮគេនិយាយថា លោកម្ចាស់សាគតៈបានច្បាំងគ្នានឹងនាគឈ្មោះអម្ពតិត្ថកៈ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ហើយទ្រង់សំដៅទៅឯក្រុងកោសម្ពីនោះ។ គ្រានោះឯង ពួកឧបាសកនៅក្នុងក្រុងកោសម្ពីនាំគ្នាទៅទទួលព្រះដ៏មានព្រះភាគ ហើយក៏ចូលទៅរកព្រះសាគតៈដ៏មានអាយុ លុះចូលទៅហើយ ក៏ថ្វាយបង្គំព្រះសាគតៈដ៏មានអាយុ ហើយក៏ឋិតនៅក្នុងទីដ៏សមគួរ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពី លុះឋិតនៅក្នុងទីដ៏សមគួរហើយ ទើបនិយាយពាក្យនេះនឹងព្រះសាគតៈដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន វត្ថុអ្វីដែលលោកម្ចាស់បានដោយកម្រផង ជាទីគាប់ចិត្តផង ពួកយើងខ្ញុំនឹងតាក់តែងវត្ថុអ្វីប្រគេន។ លុះឧបាសកទាំងនោះបានពោលពាក្យយ៉ាងនេះហើយ ពួកឆព្វគ្គិយភិក្ខុ បាននិយាយពាក្យនេះនឹងពួកឧបាសកដែលនៅក្រុងកោសម្ពីថា ម្នាលអ្នកទាំងឡាយ សុរាថ្លាឈ្មោះកាបោតិកា (មានពណ៌ក្រហមដូចជើងព្រាប) ដែលភិក្ខុទាំងឡាយរកបានដោយកម្រផង ជាទីគាប់ចិត្តរបស់ពួកភិក្ខុផង ពួកអ្នកឯងចូរតាក់តែងវត្ថុនោះប្រគេនលោកចុះ។ លំដាប់នោះឯង ពួកឧបាសកនៅក្រុងកោសម្ពីនាំគ្នាតាក់តែងសុរាថ្លាឈ្មោះកាបោតិកាគ្រប់ៗផ្ទះ បានឃើញព្រះសាគតៈដ៏មានអាយុកំពុងដើរទៅបិណ្ឌបាត ហើយបាននិយាយពាក្យនេះនឹងព្រះសាគតៈដ៏មានអាយុថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់សាគតៈនិមន្តឆាន់សុរាថ្លាឈ្មោះកាបោតិកាចុះ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់សាគតៈនិមន្តឆាន់សុរាថ្លាឈ្មោះកាបោតិកាចុះ។ លំដាប់នោះ ព្រះសាគតៈដ៏មានអាយុ លុះបានឆាន់សុរាថ្លាឈ្មោះកាបោតិកាគ្រប់ៗផ្ទះហើយចេញចាកនគរទៅ ក៏ដួលដេកទៀបទ្វារនគរ។ គ្រានោះ ព្រះដ៏មានព្រះភាគ កាលចេញចាកនគរជាមួយនឹងពួកភិក្ខុជាច្រើនអង្គ បានទតឃើញព្រះសាគតៈដ៏មានអាយុដួលដេកនៅទៀបទ្វារនគរ លុះទ្រង់ឃើញហើយក៏ត្រាស់បង្គាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឯងចូរគ្រាហ៍សាគតភិក្ខុឡើង។ ភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងហ្នឹងហើយៗ ក៏គ្រាហ៍ព្រះសាគតៈដ៏មានអាយុទៅកាន់អារាម ហើយផ្តេកបែរក្បាលទៅរកព្រះដ៏មានព្រះភាគ។ លំដាប់នោះ ព្រះសាគតៈដ៏មានអាយុប្រែត្រឡប់ដេកដាក់ជើងទៅរកព្រះដ៏មានព្រះភាគវិញ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពីដើមមក សាគតភិក្ខុមានសេចក្តីគោរពកោតក្រែងដល់តថាគតមែនឬទេ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតយ៉ាងហ្នឹងហើយ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះ សាគតភិក្ខុមានសេចក្តីគោរពកោតក្រែងដល់តថាគតឬទេ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស មិនគោរពទេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ សាគតភិក្ខុបានច្បាំងនឹងអម្ពតិត្ថកនាគ ពិតមែនឬទេ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះ សាគតភិក្ខុ (ដែលដួលដេកមិនដឹងខ្លួនយ៉ាងនេះ) អាចច្បាំងនឹងពស់ទឹក[29] បានឬទេ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស មិនបានទេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រាសចាកសញ្ញាព្រោះផឹកទឹកណា ទឹកនោះភិក្ខុគួរផឹកឬទេ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស មិនគួរផឹកទេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កម្មរបស់សាគតភិក្ខុមិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ ម្នាលភិក្ខុទាំងឡាយ សាគតភិក្ខុមិនគួរនឹងផឹកទឹកស្រវឹងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់

ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុផឹកសុរានិងមេរ័យ ត្រូវអាបត្តិបាចិត្តិយ។**

[១៩៤] ដែលហៅថាសុរា គឺសុរាធ្វើដោយម្សៅ១ សុរាធ្វើដោយនំ១ សុរាធ្វើដោយបាយ១ សុរាដែលគេដាក់ពូជសុរា១ សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ១។ ដែលហៅថា មេរ័យនោះ គឺទឹកត្រាំដែលគេធ្វើដោយផ្កាឈើ១ ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ១ ទឹកត្រាំដែលគេធ្វើដោយផ្លែចន្ទន៍ ឬគេធ្វើដោយទឹកឃ្មុំ១ ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ១ ទឹកត្រាំដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ១។ ត្រង់ពាក្យថា ផឹក សេចក្តីថា ដោយហោចទៅ សូម្បីតែភិក្ខុផឹកប្រមាណប៉ុនចុងស្បូវ ក៏ត្រូវអាបត្តិបាចិត្តិយ។

[១៩៥] ទឹកស្រវឹង ភិក្ខុសំគាល់ថា ទឹកស្រវឹង ហើយផឹក ត្រូវអាបត្តិបាចិត្តិយ។ ទឹកស្រវឹង ភិក្ខុមានសេចក្តីសង្ស័យ ហើយផឹក ត្រូវអាបត្តិបាចិត្តិយ។ ទឹកស្រវឹង ភិក្ខុសំគាល់ថា មិនមែនទឹកស្រវឹង ហើយផឹក ត្រូវអាបត្តិបាចិត្តិយ។ មិនមែនទឹកស្រវឹង ភិក្ខុសំគាល់ថាទឹកស្រវឹង ត្រូវអាបត្តិទុក្កដ។ មិនមែនទឹកស្រវឹង ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនទឹកស្រវឹង ភិក្ខុសំគាល់ថាមិនមែនទឹកស្រវឹង មិនត្រូវអាបត្តិឡើយ។

[១៩៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុផឹកទឹកមិនស្រវឹង តែទឹកនោះមានពណ៌ដូចជាទឹកស្រវឹង មានក្លិនដូចជាទឹកស្រវឹង មានរសដូចជាទឹកស្រវឹង១ ទឹកស្រវឹងដែលគេចំអិនលាយនឹងសម្ល១ ទឹកស្រវឹងដែលគេចំអិនលាយនឹងសាច់១ ទឹកស្រវឹងដែលគេចំអិនលាយនឹងប្រេង១ ទឹកអំពៅដែលគេត្រាំនឹងផ្លែកន្ទួតព្រៃ១ ភិក្ខុផឹកថ្នាំអរិដ្ឋ[30] មិនស្រវឹង១ ដល់ភិក្ខុឆ្កួត១ ដល់ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី២ (៥២)

CS vin.vbu.pc.52 | ភាគ ទី៤

### (២. អង្គុលិបតោទកសិក្ខាបទំ)

[១៩៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើសត្តរសវគ្គិយភិក្ខុមួយរូបឲ្យសើចដោយជន្លួញ គឺម្រាមដៃ។[31] ភិក្ខុនោះសើចគាំងដកដង្ហើមមិនរួច ក៏ធ្វើកាលកិរិយាទៅ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុមិនគួរនឹងធ្វើភិក្ខុផងគ្នាឲ្យសើចដោយជន្លួញគឺម្រាមដៃសោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងធ្វើភិក្ខុផងគ្នាឲ្យសើចដោយជន្លួញគឺម្រាមដៃ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានជោគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងធ្វើភិក្ខុផងគ្នាឲ្យសើចដោយជន្លួញគឺម្រាមដៃទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុចាក់ក្រលេកប្រលែងគ្នាដោយជន្លួញ គឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ។**

[១៩៨] ដែលហៅថាជន្លួញ គឺម្រាមដៃនោះ គឺភិក្ខុចាក់ដោយម្រាមដៃ។ ឧបសម្បន្ន ប៉ងដើម្បីសើចលេង ហើយប៉ះត្រូវកាយរបស់ឧបសម្បន្នផងគ្នា ដោយកាយរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ។

[១៩៩] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយធ្វើឲ្យសើចដោយជន្លួញគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយធ្វើឲ្យសើចដោយជន្លួញគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាជាអនុបសម្បន្នទៅវិញ ហើយធ្វើឲ្យសើចដោយជន្លួញគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ។

[២០០] ភិក្ខុពាល់ត្រូវនូវវត្ថុដែលជាប់ដោយកាយ (របស់ភិក្ខុផងគ្នា) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវកាយ (របស់ភិក្ខុផងគ្នា) ដោយវត្ថុដែលជាប់នឹងកាយ(របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹងកាយ (របស់ភិក្ខុផងគ្នា) ដោយវត្ថុដែលជាប់នឹងកាយ(របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវកាយ(របស់ភិក្ខុផងគ្នា) ដោយវត្ថុសម្រាប់បោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹងកាយ (របស់ភិក្ខុផងគ្នា) ដោយវត្ថុសម្រាប់បោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវវត្ថុសម្រាប់បោះចោល (របស់ភិក្ខុផងគ្នា) ដោយវត្ថុសម្រាប់បោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។

[២០១] ភិក្ខុពាល់ត្រូវកាយរបស់អនុបសម្បន្នដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹងកាយ (របស់អនុបសម្បន្ន) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវកាយ(របស់អនុបសម្បន្ន) ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់ដោយកាយរបស់អនុបសម្បន្ន ដោយវត្ថុដែលជាប់ដោយកាយរបស់ខ្លួន ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវកាយ (របស់អនុបសម្បន្ន) ដោយវត្ថុសម្រាប់បោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹងកាយ (របស់អនុបសម្បន្ន)

ដោយវត្ថុសម្រាប់បោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។ ភិក្ខុពាល់ត្រូវវត្ថុសម្រាប់បោះចោល(របស់អនុបសម្បន្ន) ដោយវត្ថុសម្រាប់បោះចោល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។

[២០២] អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[២០៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុគ្មានបំណងនឹងសើចលេង១ ភិក្ខុមានកិច្ចហើយពាល់ត្រូវ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ២ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី៣ (៥៣)

CS vin.vbu.pc.53 | ភាគ ទី៤

### (៣. ហសធម្មសិក្ខាបទំ)

[២០៤] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុលេងទឹកក្នុងស្ទឹងឈ្មោះអចិរវតី។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់គង់នៅលើប្រាសាទដ៏ប្រសើរ ជាមួយនឹងព្រះទេពីព្រះនាមមល្លិកា។ ព្រះបាទបសេនទិកោសលទ្រង់ទតឃើញពួកសត្តរសវគ្គិយភិក្ខុកំពុងលេងទឹក ក្នុងស្ទឹងអចិរវតី លុះទ្រង់ឃើញហើយក៏មានព្រះបន្ទូលនឹងនាងមល្លិកាទេវីយ៉ាងនេះថា នែនាងមល្លិកា ព្រះអរហន្តទាំងនេះលេងទឹកទេតើ។ នាងមល្លិកាទេវីក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គកុំសង្ស័យ ព្រះដ៏មានព្រះភាគមិនទាន់បញ្ញត្តសិក្ខាបទទេ ពុំនោះសោត ភិក្ខុទាំងនោះជាអ្នកមិនដឹងនូវសិក្ខាបទ ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តរួចហើយ។ លំដាប់នោះ ព្រះបាទបសេនទិកោសលទ្រង់ត្រិះរិះយ៉ាងនេះថា ដោយឧបាយដូចម្តេចហ្ន៎ ដែលអញមិនបាច់ក្រាបទូលព្រះដ៏មានព្រះភាគផង ទាំងព្រះដ៏មានព្រះភាគ ក៏ទ្រង់ជ្រាបថា ភិក្ខុទាំងនេះលេងទឹកផង។ កាលនោះ ព្រះបាទបសេនទិកោសល ទ្រង់ឲ្យនិមន្តពួកសត្តរសវគ្គិយភិក្ខុមក ហើយប្រគេនដុំស្ករអំពៅមួយដុំធំដល់ពួកភិក្ខុទាំងនោះ ដោយព្រះតម្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយថ្វាយដុំស្ករអំពៅនេះដល់ព្រះដ៏មានព្រះភាគផង។ ពួកសត្តរសវគ្គិយភិក្ខុយកដុំស្ករអំពៅនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ស្តេចថ្វាយដុំស្ករអំពៅនេះចំពោះព្រះអង្គ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្តេចឃើញពួកអ្នកឯងនៅទីណា។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ស្តេចទតឃើញពួកខ្ញុំព្រះអង្គកំពុងលេងទឹកក្នុងស្ទឹងអចិរវតី។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងនាំគ្នាលេងទឹកទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុលេងទឹក ត្រូវអាបត្តិបាចិត្តិយ។**

[២០៥] ដែលហៅថាលេងទឹកនោះ គឺភិក្ខុមានបំណងនឹងលេងទឹកដែលជ្រៅជាងភ្នែកគោឡើងទៅ ទោះមុជចុះក្តី ងើបឡើងក្តី ហែលក្តី ត្រូវអាបត្តិបាចិត្តិយ។

[២០៦] លេងទឹក ភិក្ខុសំគាល់ថាលេងទឹក ត្រូវអាបត្តិបាចិត្តិយ។ លេងទឹក ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិបាចិត្តិយ។ លេងទឹក ភិក្ខុសំគាល់ថាមិនបានលេងវិញ ត្រូវអាបត្តិបាចិត្តិយ។

[២០៧] ភិក្ខុលេងទឹករាក់ជាងភ្នែកគោ ត្រូវអាបត្តិទុក្កដ។ ភិក្ខុលេងទឹកដោយទូក ត្រូវអាបត្តិទុក្កដ។ ភិក្ខុប្រហារទឹកដោយដៃក្តី ជើងក្តី កំណាត់ឈើក្តី អំបែងក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុលេងទឹកដែលមានក្នុងភាជន៍ក្តី លេងទឹកបាយក្តី ទឹកដោះស្រស់ក្តី ទឹកដោះជូរក្តី ទឹកជ្រលក់ក្តី ទឹកនោមក្តី ភក់ក្តី ត្រូវអាបត្តិទុក្កដ។

[២០៨] មិនបានលេងទឹកទេ ភិក្ខុសំគាល់ថាលេង ត្រូវអាបត្តិទុក្កដ។ មិនបានលេងទឹកទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនបានលេងទឹកទេ ភិក្ខុសំគាល់ថាមិនបានលេង មិនត្រូវអាបត្តិឡើយ។

[២០៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺ ភិក្ខុគ្មានបំណងនឹងលេង១ ភិក្ខុមានកិច្ចហើយចុះទឹកមុជចុះក្តី ងើបក្តី ហែលក្តី១ ភិក្ខុឆ្លងទៅត្រើយនាយ មុជចុះក្តី ងើបក្តី ហែលក្តី១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៣ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី៤ (៥៤)

CS vin.vbu.pc.54 | ភាគ ទី៤

### (៤. អនាទរិយសិក្ខាបទំ)

[២១០] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅឃោសិតារាម ជិតក្រុងកោសម្ពី។ សម័យនោះឯង ឆន្នដ៏មានអាយុតែងតែប្រព្រឹត្តអនាចារ។ ភិក្ខុទាំងឡាយក៏និយាយយ៉ាងនេះថា ម្នាលឆន្នដ៏មានអាយុ លោកកុំធ្វើអំពើមានសភាពដូច្នេះឡើយ អំពើនេះមិនសមគួរទេ។ ឆន្នភិក្ខុនោះអាស្រ័យនូវសេចក្ដីមិនអើពើ ហើយចេះតែធ្វើ(កម្មនោះ)ដដែល។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នដ៏មានអាយុ មិនគួរនឹងធ្វើនូវសេចក្ដីមិនអើពើសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែឆន្ន ឮថាអ្នកឯងធ្វើនូវសេចក្ដីមិនអើពើ ពិតមែនឬ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងធ្វើនូវសេចក្ដីមិនអើពើទេ ម្នាលមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុមិនអើពើ ត្រូវអាបត្តិបាចិត្តិយ។**

[២១១] ដែលហៅថាមិនអើពើ បានដល់សេចក្ដីមិនអើពើពីរយ៉ាង គឺមិនអើពើនឹងបុគ្គល១ មិនអើពើនឹងធម៌១។ ដែលហៅថាមិនអើពើនឹងបុគ្គលនោះ គឺឧបសម្បន្ន កាលបើមានឧបសម្បន្នផងគ្នាពោលដាស់តឿនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយៗគិតថា ភិក្ខុនេះសង្ឃបានលើកវត្តហើយក្ដី សង្ឃផ្ដាសាហើយក្ដី សង្ឃតិះដៀលហើយក្ដី ពាក្យរបស់ភិក្ខុនេះ អញនឹងមិនធ្វើតាមទេ ហើយក៏ធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ។ ដែលហៅថា មិនអើពើនឹងធម៌នោះ គឺឧបសម្បន្ន កាលបើមានឧបសម្បន្នផងគ្នាពោលដាស់តឿនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តទុកហើយៗគិតថា ធ្វើដូចម្ដេចហ្ន៎ ធម៌នេះបាត់ទៅក្ដី សាបសូន្យទៅក្ដី អន្តរធានទៅក្ដី ឬមិនចង់សិក្សាធម៌នោះ ហើយក៏ធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ។

[២១២] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ហើយធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្នទៅវិញ ហើយធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ។

[២១៣] ឧបសម្បន្ន កាលបើមានឧបសម្បន្នផងគ្នាពោលដាស់តឿនដោយពាក្យឯទៀត ដែលមិនមែនជាវិនយប្បញ្ញត្តិ ហើយគិតថា ពាក្យនេះមិននាំឲ្យចិត្តផូរផង់ មិននាំឲ្យកំចាត់បង់កិលេសវដ្ដ មិននាំឲ្យកើតសេចក្ដីជ្រះថ្លា មិនមែននាំឲ្យកើតសេចក្ដីមិនសន្សំនូវកិលេសវដ្ដ មិននាំឲ្យប្រារព្ធសេចក្ដីព្យាយាម ហើយធ្វើនូវសេចក្ដីមិនអើពើ ត្រូវអាបត្តិទុក្កដ។ ឧបសម្បន្ន កាលបើមានអនុបសម្បន្នពោលដាស់តឿនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយក្ដី មិនបញ្ញត្តហើយ[32] ក្ដី ហើយគិតថា ពាក្យនេះមិននាំឲ្យចិត្តផូរផង់ មិននាំឲ្យកំចាត់បង់កិលេសវដ្ដ មិននាំឲ្យកើតសេចក្ដីជ្រះថ្លា មិនមែននាំឲ្យកើតសេចក្ដីមិនសន្សំនូវកិលេសវដ្ដ មិននាំឲ្យប្រារព្ធសេចក្ដីព្យាយាម ហើយធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិទុក្កដ។

[២១៤] អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[២១៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺ ភិក្ខុពោលថា បាឡីអដ្ឋកថានៃអាចារ្យទាំងឡាយរបស់យើងយ៉ាងនេះ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៤ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី៥ (៥៥)

CS vin.vbu.pc.55 | ភាគ ទី៤

### (៥. ភិំសាបនសិក្ខាបទំ)

[២១៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើសត្តរសវគ្គិយភិក្ខុឲ្យខ្លាច។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះ កាលបើគេធ្វើឲ្យខ្លាច ក៏ស្រែកយំ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាអ្នកទាំងឡាយស្រែកយំ។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះធ្វើយើងរាល់គ្នាឲ្យខ្លាច។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងធ្វើភិក្ខុផងគ្នាឲ្យខ្លាចសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នករាល់គ្នាធ្វើភិក្ខុផងគ្នាឲ្យខ្លាច ពិតមែនឬ។ ឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នករាល់គ្នាមិនគួរនឹងបន្លាចភិក្ខុផងគ្នាទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយធ្វើភិក្ខុផងគ្នាឲ្យខ្លាច ត្រូវអាបត្តិបាចិត្តិយ។**

[២១៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងបឋមបារាជិក។ ពាក្យថា ភិក្ខុផងគ្នា គឺភិក្ខុដទៃ (ក្រៅពីខ្លួន)។ ពាក្យថា ឲ្យខ្លាច គឺឧបសម្បន្នមានបំណងនឹងធ្វើឧបសម្បន្នឲ្យខ្លាច ហើយសំដែងរូបក្ដី សំឡេងក្ដី ក្លិនក្ដី រសក្ដី ផ្សព្វក្ដី ទោះបីឧបសម្បន្ននោះខ្លាចក្ដី មិនខ្លាចក្ដី ក៏ត្រូវ

អាបត្តិបាចិត្តិយ។ (ឧបសម្បន្ន មានសេចក្តីប្រាថ្នាដើម្បីបន្លាចឧបសម្បន្នផងគ្នា) ហើយប្រាប់ផ្លូវលំបាកដោយចោរក្តី ផ្លូវលំបាកដោយម្រឹគសាហាវក្តី ផ្លូវលំបាកដោយខ្មោចក្តី ទោះបីឧបសម្បន្ននោះខ្លាចក្តី មិនខ្លាចក្តី ត្រូវអាបត្តិបាចិត្តិយ។

[២១៨] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយបន្លាច ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសង្ស័យ ហើយបន្លាច ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្នទៅវិញ ហើយបន្លាច ត្រូវអាបត្តិបាចិត្តិយ។

[២១៩] ឧបសម្បន្ន មានបំណងនឹងបន្លាចអនុបសម្បន្ន ហើយសំដែងរូបក្តី សំឡេងក្តី ក្លិនក្តី ផ្សព្វក្តី រសក្តី ទោះបីអនុបសម្បន្ននោះខ្លាចក្តី មិនខ្លាចក្តី ក៏ត្រូវអាបត្តិទុក្កដ។ (ឧបសម្បន្នមានសេចក្តីប្រាថ្នាដើម្បីបន្លាចអនុបសម្បន្ន) ហើយប្រាប់ផ្លូវលំបាកដោយចោរក្តី ផ្លូវលំបាកដោយម្រឹគសាហាវក្តី ផ្លូវលំបាកដោយខ្មោចក្តី ទោះបីអនុបសម្បន្ននោះខ្លាចក្តី មិនខ្លាចក្តី ត្រូវអាបត្តិទុក្កដ។

[២២០] អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[២២១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុគ្មានបំណងនឹងបន្លាច ហើយសំដែងរូបក្តី សំឡេងក្តី ក្លិនក្តី រសក្តី ផ្សព្វក្តី១ ភិក្ខុ(គ្មានបំណងនឹងបន្លាចហើយ) ប្រាប់ផ្លូវលំបាកដោយចោរក្តី ផ្លូវលំបាកដោយម្រឹគសាហាវក្តី ផ្លូវលំបាកដោយខ្មោចក្តី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៥ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី៦ (៥៦)

CS vin.vbu.pc.56 | ភាគ ទី៤

### (៦. ជោតិកសិក្ខាបទំ)

[២២២] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅភេសកលាវន ជាទីឲ្យអភ័យដល់សត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ។ សម័យនោះឯង ភិក្ខុទាំងឡាយនាំគ្នាបង្កាត់ភ្លើងនឹងឈើដែលមានប្រហោង១ដុំធំ ហើយនាំគ្នាអាំងក្នុងខែរងា។ មានពស់ខ្មៅ១នៅក្នុងប្រហោងឈើនោះ លុះត្រូវកំដៅភ្លើង ក៏លូនចេញមក ហើយធ្វើភិក្ខុទាំងឡាយឲ្យដួលដាសពាស។ ភិក្ខុទាំងឡាយក៏ស្ទុះរត់ទៅក្នុងទីនោះៗ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនគួរនឹងបង្កាត់ភ្លើងអាំងសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយបង្កាត់ភ្លើងអាំង ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា នែភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនគួរនឹងបង្កាត់ភ្លើងអាំងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងក៏ទេដែរ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយមានបំណងនឹងអាំងភ្លើង បង្កាត់ខ្លួនឯងក្តី ប្រើគេឲ្យបង្កាត់ក្តី នូវភ្លើង ត្រូវអាបត្តិបាចិត្តិយ។

ព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ។

[២២៣] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺ។ ឯពួកភិក្ខុអ្នកសួរជម្ងឺក៏និយាយពាក្យនេះនឹងភិក្ខុដែលមានជម្ងឺថា ម្នាលអាវុសោ អ្នកទាំងឡាយល្មមអត់ធន់បានឬទេ ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ។ ពួកភិក្ខុមានជម្ងឺប្រាប់ថា ម្នាលអាវុសោ ពីដើមយើងរាល់គ្នាបង្កាត់ភ្លើងអាំង បានជាយើងបានសេចក្តីសុខសប្បាយរាល់គ្នា ដោយហេតុបានអាំងភ្លើងនោះ ទេឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហេតុនោះទើបយើងមានសេចក្តីខ្លាចក្រែង មិនហ៊ានអាំងភ្លើង បានជាយើងមិនមានសេចក្តីសុខសប្បាយដោយហេតុនោះឯង។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជម្ងឺបង្កាត់ភ្លើងខ្លួនឯងក្តី ប្រើគេឲ្យបង្កាត់ក្តី ហើយអាំងបាន ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយមិនមានជម្ងឺ ប្រាថ្នានឹងអាំងភ្លើង ហើយបង្កាត់ខ្លួនឯងក្តី ប្រើគេឲ្យបង្កាត់ក្តីនូវភ្លើង ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[២២៤] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យក្នុងការអុជប្រទីបខ្លះ បង្កាត់ភ្លើងដុតបាត្រជាដើមខ្លះ រោងភ្លើងខ្លះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានហេតុយ៉ាងនោះ តថាគតអនុញ្ញាតឲ្យភិក្ខុបង្កាត់ភ្លើងខ្លួនឯង ឬប្រើគេឲ្យបង្កាត់បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយមិនមានជម្ងឺ មានបំណងនឹងអាំងភ្លើង ហើយបង្កាត់ខ្លួនឯងក្តី ប្រើគេឲ្យបង្កាត់ក្តីនូវភ្លើង ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ។**

[២២៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិក។ ភិក្ខុណាវៀរចាកភ្លើង ហើយសប្បាយ ភិក្ខុនោះហៅថា ជាអ្នកមិនមានជម្ងឺ។ ភិក្ខុណាវៀរចាកភ្លើង ហើយមិនសប្បាយ ភិក្ខុនោះហៅថា អ្នកមានជម្ងឺ។ ពាក្យថាមានបំណងនឹងអាំងភ្លើង គឺចង់កំដៅកាយ។ ដែលហៅថាភ្លើង គឺភ្លើងធម្មតានោះឯង។ ពាក្យថា បង្កាត់ខ្លួនឯង គឺភិក្ខុបង្កាត់ខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រើឲ្យគេបង្កាត់ គឺភិក្ខុបង្គាប់អ្នកដទៃ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុបង្គាប់តែម្តង អ្នកទទួលបង្គាប់ទៅបង្កាត់ភ្លើងច្រើនដង (ភិក្ខុអ្នកបង្គាប់) ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា វៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ គឺលើកទុកចំពោះហេតុមានសភាពយ៉ាងនោះ។

[២២៦] ខ្លួនមិនមានជម្ងឺ ភិក្ខុសំគាល់ថាមិនមានជម្ងឺ មានបំណងនឹងអាំងភ្លើង ហើយបង្កាត់ភ្លើងឯងក្តី ប្រើអ្នកដទៃឲ្យបង្កាត់ក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ។ ខ្លួនមិនមានជម្ងឺ ភិក្ខុមានសេចក្តីសង្ស័យ មានបំណងនឹងអាំងភ្លើង ហើយបង្កាត់ភ្លើងឯងក្តី ប្រើអ្នកដទៃឲ្យបង្កាត់ក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ។ ខ្លួនមិនមានជម្ងឺ ភិក្ខុសំគាល់ថាមានជម្ងឺ មានបំណងនឹងអាំងភ្លើង ហើយបង្កាត់ភ្លើងឯងក្តី ប្រើអ្នកដទៃឲ្យបង្កាត់ក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ។ ភិក្ខុចាប់អង្កត់ភ្លើងលើកឡើង ត្រូវអាបត្តិទុក្កដ។ ខ្លួនមានជម្ងឺ ភិក្ខុសំគាល់ថា មិនមានជម្ងឺ ត្រូវអាបត្តិទុក្កដ។ ខ្លួនមានជម្ងឺ ភិក្ខុមានសេចក្តីសង្ស័យ មិនមានជម្ងឺ ត្រូវអាបត្តិទុក្កដ។ ខ្លួនមានជម្ងឺ ភិក្ខុសំគាល់ថា មានជម្ងឺ មិនត្រូវអាបត្តិឡើយ។

[២២៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺ ភិក្ខុមានជម្ងឺ១ ភិក្ខុអាំងភ្លើងដែលអ្នកដទៃបង្កាត់១ ភិក្ខុអាំងរងើកភ្លើងដែលគ្មានអណ្តាត១ ភិក្ខុមានហេតុមានសភាពយ៉ាងនោះ គឺអុជប្រទីបក្តី បង្កាត់ភ្លើង (ដើម្បីដុតបាត្រជាដើម)ក្តី បង្កាត់ភ្លើងក្នុងរោងភ្លើងក្តី១ ភិក្ខុមានសេចក្តីអន្តរាយ[33] ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៦ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី៧ (៥៧)

CS vin.vbu.pc.57 | ភាគ ទី៤

### (៧. នហានសិក្ខាបទំ)

[២២៨] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ សម័យនោះឯង ពួកភិក្ខុនាំគ្នាទៅស្រង់ទឹកឯកំពង់ទឹកឈ្មោះតបោទ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរក្នុងដែនមគធៈ ទ្រង់យាងទៅកាន់កំពង់ទឹកឈ្មោះតបោទ ដោយតាំងព្រះហឫទ័យថានឹងស្រង់ជម្រះព្រះសិរ្ស ហើយក៏ទ្រង់ប្រថាប់ចាំ ក្នុងទីដ៏សមគួរ ដោយតាំងព្រះហឫទ័យថា ចាំលោកម្ចាស់ទាំងឡាយស្រង់ទឹករួចសិន។ ភិក្ខុទាំងឡាយក៏ស្រង់ទឹកទាល់តែយប់ងងឹត។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈ ស្រង់ជម្រះព្រះសិរ្សក្នុងវេលាវិកាល ពួកជនបិទទ្វារនគរ (ហួស)ទៅ ស្តេចក៏ថិតនៅខាងក្រៅនគរ លុះដល់ព្រឹកឡើង ស្តេចមានគ្រឿងលាបព្រះអង្គមិនទាន់បានសំអាត ហើយទ្រង់ព្រះដំណើរទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ។ លុះព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈ គង់ក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គមានគ្រឿងលាបមិនទាន់បានសំអាត ហើយស្តេចមកក្នុងវេលាព្រឹក (យ៉ាងនេះ)។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈឲ្យយល់ច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយក្នុងពេលនោះ ដោយធម្មីកថា។ លំដាប់នោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈ លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យយល់ច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកពីអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុបានឃើញស្តេចហើយ ងូតទឹកមិនដឹងប្រមាណកាល ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះ បានឃើញស្តេចហើយ មិនគួរនឹងងូតទឹកមិនដឹងប្រមាណកាលសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ។

[២២៩] សម័យនោះឯង ភិក្ខុទាំងឡាយសង្ស័យក្នុងសម័យក្តៅ ក្នុងសម័យស្អុះស្អាប់ ក៏មិនហ៊ានងូតទឹកឡើយ មានខ្លួនប្រឡាក់ដោយញើសក្អែល ហើយក៏ចេះតែសឹងទៅ។ ចីវរក្តី សេនាសនៈក្តី ក៏ប្រឡាក់ប្រឡូស (ដោយហេតុនោះ)។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មាន

ព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យក្តៅ សម័យស្អុះស្អាប់ ទុកជាមិនទាន់ដល់កន្លះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺមួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះ ត្រូវជា២ខែកន្លះ ហៅថាសម័យក្តៅ[34] សម័យស្អុះស្អាប់[35] នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ។

[២៣០] សម័យនោះឯង ភិក្ខុមានជម្ងឺជាច្រើនអង្គ។ ឯពួកភិក្ខុជាអ្នកសួរជម្ងឺបាននិយាយពាក្យនេះនឹងភិក្ខុដែលមានជម្ងឺថា ម្នាលអាវុសោ អ្នកទាំងឡាយល្មមអត់ធន់បានឬទេ ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ។ ពួកភិក្ខុមានជម្ងឺប្រាប់ថា ម្នាលអាវុសោ ពីដើម យើងទាំងឡាយមិនទាន់ដល់កំណត់កន្លះខែ ក៏តែងតែងូតទឹក ព្រោះហេតុនោះ ទើបពួកយើងមានសេចក្តីសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហេតុនេះយើងទាំងឡាយមានសេចក្តីសង្ស័យ មិនហ៊ានងូតទឹកឡើយ បានជាយើងមិនបានសេចក្តីសប្បាយដោយហេតុនោះឯង។ ទើបភិក្ខុទាំងឡាយនាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានជម្ងឺ ទុកជាមិនទាន់ដល់កន្លះខែ តថាគតអនុញ្ញាតឲ្យងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ មួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះ ត្រូវជា២ខែកន្លះ ហៅថាសម័យក្តៅ សម័យស្អុះស្អាប់ សម័យភិក្ខុមានជម្ងឺ នេះហៅថា សម័យក្នុងសិក្ខាបទនោះ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ។ [២៣១] សម័យនោះឯង ភិក្ខុទាំងឡាយ ធ្វើនវកម្ម ហើយមានសេចក្តីរង្កៀស (ខ្លាចក្រែងត្រូវទោស) មិនហ៊ានងូតទឹកឡើយ ហើយក៏សឹងទាំងខ្លួនប្រឡាក់ ដោយញើសក្អែល។ ចីវរក្តី សេនាសនៈក្តី ក៏សៅហ្មងទៅ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យធ្វើការងារ ទោះមិនទាន់ដល់កំណត់កន្លះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ មួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះ ត្រូវជា២ខែកន្លះ ហៅថាសម័យក្តៅ សម័យស្អុះស្អាប់ សម័យភិក្ខុមានជម្ងឺ សម័យធ្វើការងារ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ពួកភិក្ខុយ៉ាងនេះហើយ។

[២៣២] សម័យនោះឯង ភិក្ខុទាំងឡាយ ដើរផ្លូវឆ្ងាយ មានសេចក្តីរង្កៀស (ខ្លាចក្រែងត្រូវទោស) ក៏មិនហ៊ានងូតទឹក ហើយសិងទាំងខ្លួនដែលសៅហ្មងដោយញើសក្អែល។ ចីវរក្តី សេនាសនៈក្តី ក៏សៅហ្មងទៅ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យដើរផ្លូវឆ្ងាយ ទោះមិនទាន់ដល់កំណត់កន្លះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ មួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហរដូវ និងមួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះ ត្រូវជា២ខែកន្លះ ហៅថាសម័យក្តៅ សម័យស្អុះស្អាប់ សម័យមានជម្ងឺ សម័យធ្វើការងារ សម័យដើរផ្លូវឆ្ងាយ នេះជាសម័យក្នុងសិក្ខាបទនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ។

[២៣៣] សម័យនោះឯង ភិក្ខុជាច្រើនរូប ធ្វើចីវរកម្មក្នុងទីវាល ត្រូវខ្យល់បក់ដោយទាំងធូលីមក ទាំងភ្លៀងក៏ធ្លាក់ចុះមកត្រូវបន្តិចៗផង។ ភិក្ខុទាំងឡាយមានសេចក្តីរង្កៀស (ខ្លាចក្រែងត្រូវទោស) ក៏មិនហ៊ានងូតទឹក សឹងទាំងខ្លួនប្រឡាក់ប្រឡូស (នោះឯង)។ ចីវរក្តី សេនាសនៈក្តី ក៏សៅហ្មងទៅ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យខ្យល់និងភ្លៀង ទុកជាមិនទាន់ដល់កំណត់កន្លះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ ឯសម័យក្នុងសិក្ខាបទនោះគឺ មួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហរដូវ និងមួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះ ត្រូវជា២ខែកន្លះ ហៅថាសម័យក្តៅ សម័យស្អុះស្អាប់ សម័យមានជម្ងឺ[36] សម័យធ្វើការងារ[37] សម័យដើរផ្លូវឆ្ងាយ[38] សម័យខ្យល់និងភ្លៀង[39] នេះជាសម័យក្នុងសិក្ខាបទនោះ។**

[២៣៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងបឋមបារាជិក។ ពាក្យថា មិនទាន់ដល់កំណត់កន្លះខែ គឺខ្វះកន្លះខែ។ ពាក្យថា ងូតទឹក គឺភិក្ខុកំពុងងូតទឹកដុសដោយផង់លំអិតក្ដី ដោយដីស្អិតក្ដី ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគ។ លុះងូតរួចស្រេច ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកលែងចំពោះសម័យដែលគួរ។ មួយខែកន្លះដ៏សេស (ខាងចុង)នៃគិម្ហរដូវ ហៅថា សម័យក្ដៅ។ មួយខែខាងដើមនៃវស្សានរដូវ ហៅថា សម័យស្អុះស្អាប់។ រួមខែទាំងនេះ ត្រូវជាពីរខែកន្លះ ហៅថា សម័យក្ដៅ សម័យស្អុះស្អាប់ ភិក្ខុដឹងដូច្នេះហើយ គប្បីងូតទឹកចុះ។ ភិក្ខុណាវៀរចាកការងូតទឹកមានសេចក្ដីមិនសប្បាយ ភិក្ខុនោះហៅថាមានសម័យមានជម្ងឺ ឬថាមានសម័យឈឺថ្កាត់។ ភិក្ខុដឹងខ្លួនថា មានសម័យឈឺថ្កាត់ហើយ គប្បីងូតទឹកចុះ។ ការងារដោយហោចទៅ សូម្បីតែបោសច្រាសសំអាតបរិវេណ ក៏ហៅថាសម័យធ្វើការងារ។ ភិក្ខុដឹងខ្លួនថាសម័យធ្វើការងារហើយ គប្បីងូតទឹកចុះ។ ដែលហៅថា សម័យដើរផ្លូវឆ្ងាយ គឺភិក្ខុគិតថា អញនឹងដើរផ្លូវប្រមាណកន្លះយោជន៍ ហើយគប្បីងូតទឹកបាន ភិក្ខុអ្នកដំណើរគប្បីងូតទឹកបាន ភិក្ខុដើរទៅហើយ គប្បីងូតទឹកបាន។ ដែលហៅថា សម័យខ្យល់និងភ្លៀង គឺពួកភិក្ខុត្រូវខ្យល់ប្រកបដោយធូលីហើយ មានដំណក់ទឹកពីរដំណក់ក្ដី បីដំណក់ក្ដី ធ្លាក់ត្រូវកាយ។ ភិក្ខុដឹងថា មានសម័យខ្យល់និងភ្លៀង គប្បីងូតទឹកបាន។

[២៣៥] មិនទាន់ដល់កន្លះខែ ភិក្ខុក៏សំគាល់ថាមិនទាន់ដល់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ មិនទាន់ដល់កន្លះខែ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ មិនទាន់ដល់កន្លះខែ ភិក្ខុក៏សំគាល់ថាលើស ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ។ កាលលើសជាងកន្លះខែ ភិក្ខុសំគាល់ថាខ្វះវិញ ត្រូវអាបត្តិទុក្កដ។ កាលលើសជាងកន្លះខែ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កាលលើសជាងកន្លះខែ ភិក្ខុសំគាល់ថា លើសមែន មិនត្រូវអាបត្តិឡើយ។

[២៣៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមានសម័យ១ កន្លះខែភិក្ខុងូតទឹកម្ដង១ លើសជាងកន្លះខែភិក្ខុងូតទឹក១ ភិក្ខុឆ្លងទៅត្រើយម្ខាងហើយងូត១ ភិក្ខុនៅក្នុងជនបទចុងដែនបង្អស់១ ភិក្ខុមានសេចក្ដីអន្តរាយ[40] ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៧ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី៨ (៥៨)

CS vin.vbu.pc.58 | ភាគ ទី៤

### (៨. ទុព្វណ្ណករណសិក្ខាបទំ)

[២៣៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ កាលនោះឯង ពួកភិក្ខុខ្លះ ពួកបរិព្វាជកខ្លះ ជាច្រើនរូបនាំគ្នាដើរផ្លូវឆ្ងាយ ពីក្រុងសាកេតទៅក្រុងសាវត្ថី។ លុះដល់ពាក់កណ្ដាលផ្លូវ មានពួកចោរចេញមកប្លន់ពួកភិក្ខុ និងពួកបរិព្វាជកទាំងនោះ។ រាជអាមាត្យទាំងឡាយនាំគ្នាចេញពីក្រុងសាវត្ថី មកចាប់ចោរទាំងនោះបាន ព្រមទាំងទ្រព្យរបស់ ហើយប្រើបម្រើទៅក្នុងសំណាក់ពួកភិក្ខុថា លោកម្ចាស់ទាំងឡាយចូរនិមន្តមកយកចីវររបស់ខ្លួនៗតាមស្គាល់ចុះ។ ភិក្ខុទាំងឡាយក៏មិនស្គាល់ចីវរ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយមិនគួរនឹងមិនស្គាល់ចីវររបស់ខ្លួនៗសោះ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយធ្វើធម្មីកថាដ៏ល្មមសមគួរដល់រឿងនោះៗ ដល់ភិក្ខុទាំងឡាយ ហើយទ្រង់ត្រាស់ហៅពួកភិក្ខុដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍១០យ៉ាង គឺដើម្បីប្រពៃដល់សង្ឃ១ ដើម្បីសប្បាយដល់សង្ឃ១។បេ។ ដើម្បីឋិតនៅនៃព្រះសទ្ធម្ម១ ដើម្បីអនុគ្រោះព្រះវិន័យ១។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុបានចីវរថ្មីមកហើយ គប្បីកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌៣យ៉ាង គឺពណ៌ខៀវក្ដី ពណ៌ភក់ក្ដី ពណ៌ខ្មៅជាំក្ដី វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ បើភិក្ខុមិនកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌៣យ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ ហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយ។**

[២៣៨] ដែលហៅថា ថ្មី គឺចីវរដែលមិនទាន់បានធ្វើកប្ប។ ដែលហៅថា ចីវរ គឺបណ្ដាចីវរទាំង៦ ចីវរណាមួយ។ ត្រង់ពាក្យថា គប្បីកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌៣យ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ សេចក្ដីថា ភិក្ខុត្រូវធ្វើកប្បពិន្ទុដោយកំណត់យ៉ាងតូចបំផុតត្រឹមប៉ុនចុងស្បូវ។ ដែលហៅថា ពណ៌ខៀវ គឺវត្ថុមានពណ៌ខៀវពីរយ៉ាង បានដល់ពណ៌ខៀវដូចសម្រិត១ ពណ៌ខៀវដូចស្លឹកឈើ១។ ដែលហៅថា ពណ៌ភក់ គឺសំដៅយកភក់ដែលនៅក្នុងទឹក។ ដែលហៅថា ពណ៌ខ្មៅជាំ គឺវត្ថុមានពណ៌ខ្មៅណាមួយ។ ពាក្យថា បើភិក្ខុមិនកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌៣យ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ សេចក្ដីថា ភិក្ខុមិនធ្វើកប្បពិន្ទុ បណ្ដាវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌៣យ៉ាង ដោយវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ ដោយកំណត់ប្រមាណយ៉ាងតូចបំផុតត្រឹមប៉ុនចុងស្បូវ ហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយ។

[២៣៩] ចីវរដែលភិក្ខុមិនធ្វើកប្បពិន្ទុ ភិក្ខុសំគាល់ថាមិនទាន់ធ្វើកប្បពិន្ទុ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ចីវរមិនទាន់ធ្វើកប្បពិន្ទុ ភិក្ខុមានសេចក្ដីសង្ស័យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ចីវរមិនទាន់ធ្វើកប្បពិន្ទុ ភិក្ខុសំគាល់ថាធ្វើកប្បពិន្ទុហើយ ៗប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុសំគាល់ថាមិនទាន់បានធ្វើកប្បពិន្ទុ ត្រូវអាបត្តិទុក្កដ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុសំគាល់ថាបានធ្វើកប្បពិន្ទុ មិនត្រូវអាបត្តិឡើយ។

[២៤០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុបានធ្វើកប្បពិន្ទុ ហើយប្រើប្រាស់១ កប្បពិន្ទុខូចខាតទៅ១ កន្លែងដែលធ្វើកប្បពិន្ទុគ្រាំគ្រាទៅ១ ភិក្ខុដេរចីវរដែលមិនបានធ្វើកប្បពិន្ទុភ្ជាប់ជាមួយនឹងចីវរដែលបានធ្វើកប្បពិន្ទុហើយ១ ចីវរដែលប៉ះដោយបំណះថ្មី១ ចីវរដែលដាក់អនុវាតថ្មី១ ចីវរចាស់ប្រក់ថែមថ្មី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៨ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី៩ (៥៩)

CS vin.vbu.pc.59 | ភាគ ទី៤

### (៩. វិកប្បនសិក្ខាបទំ)

[២៤១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ឧបនន្ទសក្យបុត្រដ៏មានអាយុបានវិកប្បចីវររបស់ខ្លួនដោយខ្លួនឯង រួចធ្វើរនឹងភិក្ខុជាសទ្ធិវិហារិករបស់ព្រះថេរៈជាបងប្អូន ហើយមិនបានឲ្យដកវិកប្បចេញ ក៏ចេះតែប្រើប្រាស់ទៅ។ ទើបភិក្ខុនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ឧបនន្ទសក្យបុត្រដ៏មានអាយុនេះ បានវិកប្បចីវររបស់ខ្លួនដោយខ្លួនឯង ធ្វើនឹងខ្ញុំ ហើយមិនឲ្យដកវិកប្ប (ជាមុន) ហើយចេះតែប្រើប្រាស់ទៅ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទសក្យបុត្រដ៏មានអាយុមិនគួរនឹងវិកប្បចីវររបស់ខ្លួនដោយខ្លួនឯង នឹងភិក្ខុផងគ្នា ហើយមិនបានឲ្យដកវិកប្បចេញសិន ចេះតែប្រើប្រាស់ទៅសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែឧបនន្ទ ឮថា អ្នកឯងបានវិកប្បចីវររបស់ខ្លួនដោយខ្លួនឯងនឹងភិក្ខុផងគ្នា ហើយមិនឲ្យដកវិកប្បចេញសិន ចេះតែប្រើប្រាស់ទៅ ពិតមែនឬ។ ឧបនន្ទដ៏មានអាយុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងមិនគួរនឹងវិកប្បចីវររបស់ខ្លួនដោយខ្លួនឯងនឹងភិក្ខុផងគ្នា ហើយប្រើប្រាស់ចីវរ ដែលមិនបានឲ្យគេដកវិកប្បចេញសិនទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយបានវិកប្បចីវរដោយខ្លួនឯងចំពោះភិក្ខុផងគ្នាក្តី ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី ហើយប្រើប្រាស់ចីវរដែលមិនទាន់ឲ្យគេដកវិកប្បចេញសិន ត្រូវអាបត្តិបាចិត្តិយ។**

[២៤២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ។ ពាក្យថា ភិក្ខុផងគ្នា គឺភិក្ខុឯទៀត។ ដែលហៅថាភិក្ខុនី គឺភិក្ខុនីដែលបានឧបសម្បទាក្នុងសង្ឃទាំងពីរពួក។ ដែលហៅថាសិក្ខមានា គឺស្រីដែលបានសិក្សាសិក្ខាក្នុងធម៌ទាំង៦ គ្រប់ពីរឆ្នាំហើយ។ ដែលហៅថា សាមណេរ គឺកុលបុត្រ (ដែលបានសម្រេចបព្វជ្ជាកម្មហើយ) ទ្រទ្រង់នូវសិក្ខាបទទាំង១០។ ដែលហៅថា សាមណេរី គឺស្រី(ដែលបានសម្រេចបព្វជ្ជាកម្មហើយ) ទ្រទ្រង់នូវសិក្ខាបទទាំង១០។ ពាក្យថា ដោយខ្លួនឯង គឺវិកប្បដោយខ្លួនឯង។ ដែលហៅថា ចីវរ គឺបណ្តាចីវរទាំង៦ ចីវរណាមួយ យ៉ាងតូចបំផុតល្មមសម្រេចកិច្ចវិកប្បបាន។ ដែលហៅថា វិកប្ប គឺវិកប្បមានពីរយ៉ាង បានដល់វិកប្បចំពោះមុខ១ វិកប្បកំបាំងមុខ១។ ដែលហៅថា វិកប្បចំពោះមុខ គឺភិក្ខុកំណត់ដោយពាក្យថា ខ្ញុំវិកប្បចីវរនេះចំពោះលោក ឬចំពោះភិក្ខុឈ្មោះនេះ។ ដែលហៅថា វិកប្បកំបាំងមុខ គឺភិក្ខុកំណត់ដោយពាក្យថា ខ្ញុំឲ្យចីវរនេះដល់លោក ដើម្បីវិកប្បទុក។ ភិក្ខុនោះត្រូវសួរភិក្ខុជាម្ចាស់ចីវរថា លោកណាជាមិត្ររបស់លោក ឬលោកស្គាល់លោកណា។ ភិក្ខុម្ចាស់ចីវរត្រូវប្រាប់ថា ភិក្ខុឈ្មោះនេះផង ភិក្ខុឈ្មោះនេះផង។ ភិក្ខុអ្នកទទួលវិកប្បនោះ ត្រូវនិយាយនឹងភិក្ខុម្ចាស់ចីវរថា ខ្ញុំឲ្យចីវរដល់ភិក្ខុទាំងនោះ លោកចូរប្រើប្រាស់ក្តី ឬលោកចូរលះបង់ក្តី លោកចូរធ្វើតាមសមគួរដល់បច្ច័យក្តី នូវចីវររបស់ភិក្ខុទាំងនោះចុះ។ ដែលហៅថា មិនបានឲ្យគេដកវិកប្ប គឺភិក្ខុជាម្ចាស់ចីវរប្រើប្រាស់ចីវរដែលភិក្ខុអ្នកទទួលវិកប្បនោះមិនបានប្រគល់ឲ្យក្តី មិនស្និទ្ធស្នាលនឹងភិក្ខុជាអ្នកទទួលវិកប្បនោះ ហើយប្រើប្រាស់ក្តី ត្រូវអាបត្តិបាចិត្តិយ។

[២៤៣] ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុសំគាល់ថាមិនបានឲ្យគេដកវិកប្ប ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុមានសេចក្តីសង្ស័យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុសំគាល់ថាបានឲ្យគេដកវិកប្ប ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុអធិដ្ឋានក្តី លះបង់ចោលក្តី ត្រូវអាបត្តិទុក្កដ។ ចីវរដែលបានឲ្យគេដកវិកប្ប ភិក្ខុសំគាល់ថា មិនបានឲ្យគេដកវិកប្បវិញ ត្រូវអាបត្តិទុក្កដ។ ចីវរដែលបានឲ្យគេដកវិកប្បហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ចីវរដែលបានឲ្យគេដកវិកប្បហើយ ភិក្ខុសំគាល់ថា បានឲ្យគេដកវិកប្បហើយ មិនត្រូវអាបត្តិឡើយ។

[២៤៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុប្រើប្រាស់ចីវរដែលភិក្ខុអ្នកទទួលវិកប្បនោះឲ្យក្តី ភិក្ខុម្ចាស់របស់ស្និទ្ធស្នាលនឹងភិក្ខុជាអ្នកទទួលវិកប្បនោះក្តី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៩ ចប់។

## (បាចិត្តិយ សុរាបានវគ្គ) សិក្ខាបទ ទី១០ (៦០)

CS vin.vbu.pc.60 | ភាគ ទី៤

### (១០. ចីវរអបនិធានសិក្ខាបទំ)

[២៤៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងអារាមជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុមិនបានទុកគ្រឿងបរិក្ខារដោយស្រួល។ ពួកឆព្វគ្គិយភិក្ខុលាក់ទុកបាត្រខ្លះ ចីវរខ្លះ របស់ពួកសត្តរសវគ្គិយភិក្ខុ។ ពួកសត្តរសវគ្គិយភិក្ខុក៏និយាយពាក្យនេះនឹងពួកឆព្វគ្គិយភិក្ខុថា ម្នាលអាវុសោ អ្នកទាំងឡាយចូរឲ្យបាត្រខ្លះ ចីវរខ្លះដល់យើង។ ពួកឆព្វគ្គិយភិក្ខុក៏នាំគ្នាសើច។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះក៏យំ។ ភិក្ខុទាំងឡាយសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាអ្នកទាំងឡាយយំ។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះ លាក់ទុកនូវបាត្រខ្លះ ចីវរខ្លះ របស់យើង។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកឆព្វគ្គិយភិក្ខុលាក់ទុកបាត្រខ្លះ ចីវរខ្លះ របស់ភិក្ខុផងគ្នាសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយលាក់ទុកនូវបាត្រខ្លះ ចីវរខ្លះ របស់ភិក្ខុផងគ្នា ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ មិនសមបើអ្នកឯងរាល់គ្នាមកលាក់ទុកនូវបាត្រខ្លះ ចីវរខ្លះរបស់ភិក្ខុផងគ្នាសោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងរាល់គ្នាធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុកនូវបាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី របស់ភិក្ខុផងគ្នា ដោយហោចទៅសូម្បីគ្រាន់តែមានបំណងនឹងសើចលេង ត្រូវអាបត្តិបាចិត្តិយ។**

[២៤៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ។ ពាក្យថា ភិក្ខុផងគ្នា គឺភិក្ខុឯទៀត។ ដែលហៅថាបាត្រ គឺបាត្រមានពីរយ៉ាង បានដល់បាត្រដែក១ បាត្រដី១។ ដែលហៅថាចីវរ គឺបណ្តាចីវរទាំង៦ ចីវរណាមួយ យ៉ាងតូចបំផុតល្មមវិកប្បបាន។ ដែលហៅថា និសីទនៈ សំដៅយកនិសីទនៈដែលមានជាយ។ ដែលហៅថា បំពង់ម្ជុល គឺបំពង់ម្ជុលដែលមានម្ជុលក្តី ឥតម្ជុលក្តី។ ដែលហៅថា វត្ថពន្ធចង្កេះ គឺវត្ថពន្ធចង្កេះមានពីរយ៉ាង បានដល់វត្ថពន្ធចង្កេះឈ្មោះបដ្ដិកៈ (ចំរៀក់សម្ពត់)១ វត្ថពន្ធឈ្មោះសូករន្តកៈ (គឺវត្ថពន្ធមានសណ្ឋានដូចពោះវៀនជ្រូក)១។ ពាក្យថាលាក់ទុកឯង គឺភិក្ខុលាក់ទុកដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ប្រើគេឲ្យលាក់ គឺភិក្ខុបង្គាប់អ្នកដទៃ (ឲ្យលាក់ទុក) ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុបង្គាប់គេតែម្តង អ្នកទទួលបង្គាប់លាក់ទុកច្រើនដង ត្រូវអាបត្តិបាចិត្តិយ១។ ពាក្យថា ដោយហោចទៅ សូម្បីគ្រាន់តែមានបំណងនឹងសើចលេង គឺភិក្ខុមានសេចក្តីប្រាថ្នានឹងលេង។

[២៤៧] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី ដោយហោចទៅ សូម្បីគ្រាន់តែមានបំណងនឹងសើចលេង ក៏ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី ដោយហោចទៅ សូម្បីគ្រាន់តែមានបំណងនឹងសើចលេង ត្រូវអាបត្តិបាចិត្តិយ។។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្នទៅវិញ ហើយលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី ដោយហោចទៅ សូម្បីគ្រាន់តែមានបំណងនឹងសើចលេង ក៏ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបរិក្ខារដទៃ ដោយហោចទៅ សូម្បីគ្រាន់តែមានបំណងនឹងសើចលេង ត្រូវអាបត្តិទុក្កដ។ ភិក្ខុលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី បរិក្ខារដទៃក្តី របស់អនុបសម្បន្ន ដោយហោចទៅ សូម្បីគ្រាន់តែមានបំណងនឹងសើចលេង ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្នទៅវិញ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[២៤៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុមិនប្រាថ្នានឹងសើចលេង ហើយទុកដាក់បាត្រជាដើមដែលគេទុកដាក់មិនល្អ១ ភិក្ខុទុកដាក់ដោយគិតថា អញនឹងធ្វើធម្មីកថាហើយសឹមឲ្យវិញ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១០ ចប់។

សុរាបានវគ្គ ទី ៦ ចប់។

ឧទ្ទាននៃសុរាបានវគ្គនោះ (មាន១០សិក្ខាបទ) គឺ

សុរាសិក្ខាបទ១ អង្គុលិសិក្ខាបទ១ ហាសសិក្ខាបទ១ អនាទរិយសិក្ខាបទ១ ភឹសនសិក្ខាបទ១ ជោតិសិក្ខាបទ១ ន្ហានសិក្ខាបទ១ ទុព្វណ្ណសិក្ខាបទ១ សាមសិក្ខាបទ១ អបនិធសិក្ខាបទ១។

# សប្បាណកវគ្គ (ទី៧)

CS vin.vbu.pc.v7 | ភាគ ទី៤

### (៧. សប្បាណកវគ្គោ)

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី១ (៦១)

CS vin.vbu.pc.61 | ភាគ ទី៤

### (១. សញ្ចិច្ចសិក្ខាបទំ)

[២៤៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ឧទាយិដ៏មានអាយុ (ធ្លាប់) ជានាយខ្មាន់ធ្នូ។ លោកនោះមិនពេញចិត្តនឹងសត្វក្អែកទាំងឡាយ។ ឧទាយិនោះក៏បាញ់សត្វក្អែកទាំងឡាយ កាត់ក្បាល ហើយដោតលើឈើអណ្តោត ដោយលំដាប់គ្នា។ ភិក្ខុទាំងឡាយសួរយ៉ាងនេះថា ម្នាលអាវុសោ លោកណាសម្លាប់សត្វក្អែកទាំងនេះ។ ឧទាយិឆ្លើយថា ម្នាលអាវុសោ ខ្ញុំសម្លាប់ (ព្រោះ) សត្វក្អែក ខ្ញុំមិនចូលចិត្តសោះ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុ មិនគួរនឹងក្លែងផ្តាច់បង់សត្វចាកជីវិតសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧទាយិ ឮថា អ្នកឯងក្លែងផ្តាច់បង់សត្វចាកជីវិត ពិតមែនឬ។ ឧទាយិក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងមិនគួរនឹងក្លែងផ្តាច់បង់សត្វចាកជីវិតទេ ម្នាលមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយក្លែងផ្តាច់បង់សត្វចាកជីវិត ត្រូវអាបត្តិបាចិត្តិយ។**

[២៥០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ។ ពាក្យថាក្លែង គឺដឹងស្គាល់ជាក់ ហើយក្លែងប្រព្រឹត្តល្មើស ប្រព្រឹត្តកន្លង។ ដែលហៅថាសត្វ គឺសំដៅយកសត្វតិរច្ឆាន។ ពាក្យថាផ្តាច់បង់នូវសត្វចាកជីវិត គឺផ្តាច់បង់ បំបាត់បង់នូវជីវិតិន្ទ្រិយ គឺធ្វើតំណជីវិតរបស់សត្វឲ្យកក្រើក ត្រូវអាបត្តិបាចិត្តិយ។

[២៥១] សត្វ (តិរច្ឆាន) ភិក្ខុសំគាល់ថាសត្វ(តិរច្ឆាន) ហើយដាក់ចុះចាកជីវិត (សម្លាប់) ត្រូវអាបត្តិបាចិត្តិយ។ សត្វ (តិរច្ឆាន) ភិក្ខុមានសេចក្តីសង្ស័យ ហើយដាក់ចុះចាកជីវិត ត្រូវអាបត្តិទុក្កដ។ សត្វ (តិរច្ឆាន) ភិក្ខុសំគាល់ថាមិនមែនសត្វ(តិរច្ឆាន) ហើយដាក់ចុះចាកជីវិត មិនត្រូវអាបត្តិឡើយ។ មិនមែនសត្វ (តិរច្ឆាន) ភិក្ខុសំគាល់ថាសត្វ(តិរច្ឆាន) ត្រូវអាបត្តិទុក្កដ។ មិនមែនសត្វ (តិរច្ឆាន) ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនសត្វ (តិរច្ឆាន) ភិក្ខុសំគាល់ថាមិនមែនសត្វ(តិរច្ឆាន) មិនត្រូវអាបត្តិឡើយ។

[២៥២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុមិនក្លែង១ មិនមានស្មារតី១ មិនដឹង១ មិនប៉ងនឹងសម្លាប់១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី២ (៦២)

CS vin.vbu.pc.62 | ភាគ ទី៤

### (២. សប្បាណកសិក្ខាបទំ)

[២៥៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថាទឹកមានសត្វហើយ យកទៅប្រើប្រាស់។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងថាទឹកមានសត្វហើយ មិនគួរនឹងយកទៅប្រើប្រាស់សោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយដឹងថាទឹកមានសត្វហើយ យកទៅប្រើប្រាស់ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងដឹងថាទឹកមានសត្វហើយ មិនគួរនឹងយកទៅប្រើប្រាស់ទេ នែមោឃបុរសទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយដឹងហើយ បរិភោគទឹកដែលមានសត្វមានជីវិត (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ។**

[២៥៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថាដឹង គឺភិក្ខុដឹងខ្លួនឯង ឬពួកអ្នកដទៃប្រាប់ដល់ភិក្ខុនោះ។ ភិក្ខុដឹងថាទឹកមានសត្វមានជីវិត (ឬ) ដឹងថាពួកសត្វនឹងស្លាប់ដោយការប្រើប្រាស់ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។

[២៥៥] ទឹកមានសត្វមានជីវិត ភិក្ខុសំគាល់ថាទឹកមានសត្វមានជីវិត ហើយប្រើប្រាស់ទឹកនោះ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុសង្ស័យក្នុងទឹកដែលមានសត្វមានជីវិត ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ ទឹកមានសត្វមានជីវិត ភិក្ខុសំគាល់ថាទឹកគ្មានសត្វ ហើយប្រើប្រាស់ មិនត្រូវអាបត្តិ។ ទឹកគ្មានសត្វ ភិក្ខុសំគាល់ថាមានសត្វ ត្រូវអាបត្តិទុក្កដ។ ទឹកគ្មានសត្វ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ទឹកគ្មានសត្វ ភិក្ខុសំគាល់ថាគ្មានសត្វ មិនត្រូវអាបត្តិ។

[២៥៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុមិនដឹងថាទឹកមានសត្វ(ក្តី) ដឹងថាទឹកគ្មានសត្វរស់(ក្តី) ដឹងថាពួកសត្វនឹងមិនស្លាប់ដោយការប្រើប្រាស់ (ក្តី) ហើយប្រើប្រាស់១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ២ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី៣ (៦៣)

CS vin.vbu.pc.63 | ភាគ ទី៤

### (៣. ឧក្កោដនសិក្ខាបទំ)

[២៥៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថាអធិករណៈ[41] ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ សើរើដើម្បីធ្វើជាថ្មីទៀតថា កម្ម(នោះ) គឺសង្ឃមិនបានធ្វើ កម្ម(នោះ) គឺសង្ឃធ្វើមិនត្រឹមត្រូវ ពួកយើងត្រូវធ្វើជាថ្មីទៀត កម្មឈ្មោះថា សង្ឃរម្ងាប់ហើយមិនស្រេច រម្ងាប់ហើយមិនល្អ ពួកយើងត្រូវរម្ងាប់ជាថ្មីទៀត។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងថាអធិករណៈ ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ មិនគួរនឹងសើរើដើម្បីធ្វើជាថ្មីទៀតសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកឯងដឹងថាអធិករណៈ ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ សើរើដើម្បីធ្វើជាថ្មីទៀត ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកដឹងថាអធិករណៈ ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ មិនគួរនឹងសើរើដើម្បីធ្វើជាថ្មីទៀតទេ នែមោឃបុរសទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយកាលដឹងថាអធិករណៈដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ សើរើដើម្បីធ្វើជាថ្មីទៀត ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ។**

[២៥៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ។ ដែលហៅថាដឹង គឺភិក្ខុដឹងខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ដល់ភិក្ខុនោះក្តី ភិក្ខុដែលមានរឿងនោះប្រាប់ក្តី។ ដែលហៅថា សមគួរតាមធម៌ គឺអធិរណៈដែលសង្ឃធ្វើ (គឺរម្ងាប់) ហើយតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅព្រះសាស្តា នេះហៅថា សមគួរតាមធម៌។

[២៥៩] ដែលហៅថា អធិករណៈ គឺអធិករណៈមាន៤យ៉ាង គឺវិវាទាធិករណៈ១ អនុវាទាធិករណៈ១ អាបត្តាធិករណៈ១ កិច្ចាធិករណៈ១។ ពាក្យថា សើរើដើម្បីធ្វើជាថ្មីទៀត គឺភិក្ខុសើរើថា សង្ឃធ្វើកម្មមិនស្រេច សង្ឃធ្វើកម្មមិនល្អ យើងត្រូវធ្វើជាថ្មីទៀត សង្ឃរម្ងាប់កម្មមិនស្រេច សង្ឃរម្ងាប់កម្មមិនល្អ យើងត្រូវរម្ងាប់ជាថ្មីទៀត ដូច្នេះ ត្រូវអាបត្តិបាចិត្តិយ។

[២៦០] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយសើរើឡើង ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយសើរើ ត្រូវអាបត្តិទុក្កដ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយសើរើ មិនត្រូវអាបត្តិ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ មិនត្រូវអាបត្តិ។

[២៦១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុដឹងថា កម្មដែលសង្ឃធ្វើហើយដោយកិច្ចដែលមិនមែនជាធម៌ក្តី[42] ដោយពួកក្តី[43] សង្ឃធ្វើកម្មដល់ភិក្ខុដែលមិនគួរដល់កម្មក្តី ហើយសើរើ ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៣ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី៤ (៦៤)

CS vin.vbu.pc.64 | ភាគ ទី៤

### (៤. ទុដ្ឋុល្លសិក្ខាបទំ)

[២៦២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ ត្រូវអាបត្តិឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ[44] ហើយប្រាប់ដល់ភិក្ខុជាសទ្ធិវិហារិក របស់ព្រះថេរៈជាបងប្អូនថា នែអាវុសោ ខ្ញុំត្រូវអាបត្តិសញ្ចេតនិកសុក្កវិសដ្ឋិហើយ លោកកុំប្រាប់ដល់អ្នកណាឡើយ។ សម័យនោះឯង ភិក្ខុ១រូបត្រូវអាបត្តិសញ្ចេតនិកសុក្កវិសដ្ឋិហើយសូមនៅបរិវាសដើម្បីអាបត្តិនោះនឹងសង្ឃ។ សង្ឃបានឲ្យបរិវាស ដើម្បីអាបត្តិនោះដល់ភិក្ខុនោះ។ ភិក្ខុនោះកំពុងនៅបរិវាស ក៏បានឃើញភិក្ខុដែលព្រះឧបនន្ទប្រាប់អាបត្តិនោះ ហើយបានពោលពាក្យនេះថា នែអាវុសោ ខ្ញុំត្រូវអាបត្តិសញ្ចេតនិកសុក្កវិសដ្ឋិ ហើយសុំបរិវាស ដើម្បីអាបត្តិនោះនឹងសង្ឃ សង្ឃបានឲ្យបរិវាស ដើម្បីអាបត្តិនោះដល់ខ្ញុំនោះឯង ខ្ញុំនោះកំពុងនៅបរិវាស នែអាវុសោ ខ្ញុំសូមប្រាប់ឲ្យដឹង លោកដ៏មានអាយុចូរចាំទុកនូវខ្ញុំថា ភិក្ខុនេះបានប្រាប់ឲ្យដឹង។ ភិក្ខុនោះសួរវិញថា នែអាវុសោ ទុកជាភិក្ខុដទៃណា តែត្រូវអាបត្តិនេះ ភិក្ខុនោះតែងធ្វើយ៉ាងហ្នឹងឬ។ ភិក្ខុដែលនៅបរិវាសតបថា យ៉ាងហ្នឹងហើយ អាវុសោ។ ភិក្ខុនោះនិយាយថា នែអាវុសោ លោកឧបនន្ទសក្យបុត្រដ៏មានអាយុនេះ ត្រូវអាបត្តិសញ្ចេតនិកសុក្កវិសដ្ឋិហើយ លោកឧបនន្ទនោះបានប្រាប់ខ្ញុំថា នែអាវុសោ ខ្ញុំត្រូវអាបត្តិសញ្ចេតនិកសុក្កវិសដ្ឋិហើយ លោកកុំប្រាប់ដល់អ្នកណាឡើយ។ ភិក្ខុដែលនៅបរិវាសនោះនិយាយថា នែអាវុសោ អ្នកបិទបាំងអាបត្តិនោះឬអ្វី។ ភិក្ខុនោះប្រាប់ថា យ៉ាងហ្នឹងហើយ អាវុសោ។ លំដាប់នោះឯង ភិក្ខុនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះ

បង្អាប់ថា ភិក្ខុកាលដឹងហើយ មិនគួរនឹងបិទបាំងអាបត្តិអាក្រក់របស់ភិក្ខុផងគ្នាសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថា អ្នកឯងកាលដឹងហើយ បិទបាំងអាបត្តិអាក្រក់របស់ភិក្ខុផងគ្នា ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងកាលបើដឹងហើយ មិនគួរនឹងបិទបាំងអាបត្តិអាក្រក់របស់ភិក្ខុផងគ្នាទេ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ កាលដឹងហើយ បិទបាំងទុកនូវអាបត្តិអាក្រក់របស់ភិក្ខុផងគ្នា (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ។**

[២៦៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ។ ពាក្យថា ភិក្ខុផងគ្នា បានដល់ភិក្ខុដទៃ។ ដែលហៅថា ដឹងនោះ គឺភិក្ខុដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ភិក្ខុនោះក្តី ភិក្ខុដែលត្រូវអាបត្តិនោះប្រាប់ក្តី។ ដែលហៅថា អាបត្តិអាក្រក់ បានដល់អាបត្តិបារាជិកទាំង៤ផង អាបត្តិសង្ឃាទិសេសទាំង១៣ផង។ ពាក្យថា បិទបាំងទុក សេចក្តីថា (ភិក្ខុណា) គ្រាន់តែដាក់ធុរៈថា ភិក្ខុទាំងឡាយដឹងនូវភិក្ខុនេះហើយ នឹងចោទ នឹងរលឹក នឹងជេរ នឹងប្រទេច នឹងបង្អាប់បង្អោន (ហេតុនោះ) អញមិនបាច់ប្រាប់ឡើយ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ។

[២៦៤] អាបត្តិអាក្រក់(ធ្ងន់) ភិក្ខុសំគាល់ថាអាបត្តិអាក្រក់ ហើយបិទបាំងទុក ត្រូវអាបត្តិបាចិត្តិយ។ អាបត្តិអាក្រក់ ភិក្ខុសង្ស័យ ហើយបិទបាំងទុក ត្រូវអាបត្តិទុក្កដ។ អាបត្តិអាក្រក់ ភិក្ខុសំគាល់ថាមិនមែនអាបត្តិអាក្រក់ (ស្រាល) ហើយបិទបាំងទុក ត្រូវអាបត្តិទុក្កដ។ ភិក្ខុបិទបាំងអាបត្តិមិនអាក្រក់ទុក ត្រូវអាបត្តិទុក្កដ។ ភិក្ខុបិទបាំងសេចក្តីប្រព្រឹត្តល្មើសអាក្រក់ (ធ្ងន់)ក្តី មិនអាក្រក់ (ស្រាល)ក្តី របស់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អាបត្តិមិនអាក្រក់ ភិក្ខុសំគាល់ថាអាបត្តិអាក្រក់ ត្រូវអាបត្តិទុក្កដ។ អាបត្តិមិនអាក្រក់ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អាបត្តិមិនអាក្រក់ ភិក្ខុសំគាល់ថាអាបត្តិមិនអាក្រក់ ត្រូវអាបត្តិទុក្កដ។

[២៦៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនប្រាប់ដោយគិតថា សេចក្តីបង្កហេតុក្តី ជំលោះក្តី ប្រកួតប្រកាន់ក្តី វិវាទក្តី នឹងមានដល់សង្ឃ១ ភិក្ខុមិនប្រាប់ដោយគិតថា សង្ឃនឹងបែកបាក់ ឬសង្ឃនឹងប្រេះឆា១ ភិក្ខុមិនប្រាប់ដោយគិតថា ភិក្ខុនេះ កាចអាក្រក់ នឹងធ្វើនូវសេចក្តីអន្តរាយដល់ជីវិត ឬនូវសេចក្តីអន្តរាយដល់ព្រហ្មចារ្យ១ ភិក្ខុមិនឃើញភិក្ខុទាំងឡាយដទៃដ៏សមគួរ (នឹងប្រាប់) ហើយខានប្រាប់១ ភិក្ខុមិនប្រាថ្នានឹងបិទបាំង ហើយមិនទាន់បានប្រាប់១ ភិក្ខុមិនប្រាប់ដោយសង្ឃឹមថា ភិក្ខុដែលត្រូវអាបត្តិនោះ នឹងប្រាកដដោយកម្មជារបស់ខ្លួន១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៤ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី៥ (៦៥)

CS vin.vbu.pc.65 | ភាគ ទី៤

### (៥. ឩនវីសតិវស្សសិក្ខាបទំ)

[២៦៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង កូនក្មេងទាំងឡាយមានពួក១៧នាក់ ជាសំឡាញ់នឹងគ្នានៅក្នុងក្រុងរាជគ្រឹះ។ ក្មេងឈ្មោះឧបាលិជាប្រធាននៃក្មេងទាំងនោះ។ លំដាប់នោះឯង មាតាបិតាឧបាលិកុមារបានគិតគ្នាដូច្នេះថា កាលបើឥតអំពីយើងទៅ ឧបាលិគប្បីរស់នៅសប្បាយផង មិនលំបាកផង ដោយឧបាយដូចម្តេចហ្ន៎។ មាតាបិតារបស់ឧបាលិកុមារបានគិតគ្នា ក្នុងរឿងនេះទៀតថា បើឧបាលិរៀនសរសេរអក្សរ ដល់ឥតអំពីយើងទៅ ឧបាលិគប្បីរស់នៅសប្បាយផង មិនលំបាកផង ដោយប្រការដូច្នេះ។ មាតាបិតារបស់ឧបាលិកុមារ បានគិតគ្នា (ថែម) ក្នុងរឿងនេះថា បើឧបាលិនឹងរៀនសរសេរអក្សរ ម្រាមដៃនឹងរួយ បើឧបាលិរៀនរាប់ ដល់ឥតអំពីយើងទៅ ឧបាលិគប្បីរស់នៅសប្បាយផង មិនលំបាកផង ដោយអាការយ៉ាងនេះឯង។ ទើបមាតាបិតារបស់ឧបាលិកុមារ បានគិតគ្នាទៅទៀតថា បើឧបាលិនឹងរៀនរាប់ នឹងលំបាកដល់ទ្រូង បើឧបាលិរៀនមើលរូបនិមិត្ត ដល់ឥតអំពីយើងទៅ ឧបាលិគប្បីរស់នៅជាសុខផង មិនលំបាកផង ដោយអាការយ៉ាងនេះឯង។ មាតាបិតាឧបាលិបានគិតគ្នាក្នុងរឿងនេះទៀតថា បើឧបាលិរៀនមើលរូបនិមិត្ត ភ្នែករបស់ឧបាលិនោះនឹងលំបាក ឃើញតែពួកសមណៈ ជាសក្យបុត្រនេះ មានសីលជាសុខ មានសេចក្តីប្រព្រឹត្តល្អជាសុខ ឆាន់ចង្ហាន់ល្អ សិងលើសំណិងដែលខ្យល់មិនបានចូលទៅ បើឧបាលិបួសក្នុងសំណាក់សមណៈទាំងឡាយ ជាសក្យបុត្រ ដល់ឥតអំពីយើងទៅ ឧបាលិគប្បីរស់នៅជាសុខផង មិនលំបាកផង ដោយអាការយ៉ាងនេះឯង។

[២៦៧] ទារកឈ្មោះឧបាលិ បានស្តាប់ពាក្យមាតាបិតាចរចាគ្នាយ៉ាងនេះហើយ។ ទើបឧបាលិទារក ចូលទៅរកពួកក្មេងទាំងនោះ លុះចូលទៅហើយ បាននិយាយពាក្យនេះនឹងពួកក្មេងទាំងនោះថា នែអ្នកទាំងឡាយ ពួកអ្នកចូរមក យើងនឹងទៅបួសក្នុងសំណាក់សមណៈទាំងឡាយ ជាសក្យបុត្រ។ ក្មេងទាំងនោះនិយាយថា នែអ្នក បើអ្នកនឹងបួស យើងនឹងបួសយ៉ាងហ្នឹងដែរ។ ទើបក្មេងទាំងនោះចូលទៅរកមាតាបិតារៀងរាល់ខ្លួន ហើយបាននិយាយពាក្យនេះថា សូមលោកម្តាយ លោកឪពុកអនុញ្ញាតឲ្យយើងខ្ញុំចេញពីផ្ទះទៅបួស ក្នុងព្រះពុទ្ធសាសនា។ ទើបមាតាបិតាក្មេងទាំងនោះក៏បានអនុញ្ញាតដោយគិតឃើញថា ក្មេងទាំងអស់នេះមានចំណង់ស្មើគ្នា មានសេចក្តីប្រាថ្នាល្អ។ ពួកក្មេងទាំងនោះចូលទៅរកភិក្ខុទាំងឡាយហើយសូមបព្វជ្ជា។ ភិក្ខុទាំងនោះក៏បានឲ្យបព្វជ្ជាឧបសម្បទា។ ពួកភិក្ខុ (បួសថ្មី) នោះ ក្រោកឡើងក្នុងរាត្រីសម័យជិតភ្លឺហើយយំទារថា អ្នកទាំងឡាយចូរឲ្យបបរ ចូរឲ្យបាយ ចូរឲ្យខាទនីយៈ (នំចំណី)។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា នែអាវុសោ អ្នកទាំងឡាយចូរបង្អង់ចាំភ្លឺសិន បើមានបបរ អ្នកទាំងឡាយនឹងបានហុតបបរ បើមានបាយ អ្នកទាំងឡាយនឹងបានឆាន់ បើខាទនីយៈមាន ពួកអ្នកនឹងបានទំពា បើបបរ ឬបាយ

ឬខាទនីយៈគ្មានទេ ពួកអ្នកនឹងត្រាច់ទៅបិណ្ឌបាតហើយឆាន់។ ពួកភិក្ខុក្មេងទាំងនោះដែលភិក្ខុទាំងឡាយនិយាយយ៉ាងនេះក៏ដោយ នៅតែយំទារថា អ្នកទាំងឡាយចូរឲ្យបបរ ចូរឲ្យបាយ ចូរឲ្យខាទនីយៈ ជុះដាក់សេនាសនៈខ្លះ នោមដាក់ខ្លះ។

[២៦៨] ព្រះដ៏មានព្រះភាគទ្រង់ក្រោកក្នុងរាត្រីសម័យជិតភ្លឺបានឮសម្លេងក្មេង លុះឮហើយ ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ សម្លេងនោះជាសម្លេងក្មេងឬអ្វី។ ទើបព្រះអានន្ទដ៏មានអាយុក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយដឹងហើយ ឲ្យឧបសម្បទាដល់បុគ្គលមានអាយុខ្វះពី២០ឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា នែភិក្ខុទាំងឡាយ មោឃបុរសទាំងនោះដឹងហើយ មិនគួរនឹងឲ្យឧបសម្បទាដល់បុគ្គលមានអាយុខ្វះពី២០ឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ (ធម្មតា) បុគ្គលមានអាយុមិនគ្រប់២០ឆ្នាំ តែងមិនធន់ទ្រាំ ត្រជាក់ក្តៅ ឃ្លានស្រេកសម្ផស្សរបោមមូសខ្យល់កំដៅថ្ងៃសត្វទីឃជាតិ[45] ទាំងឡាយនឹងគន្លងពាក្យដែលបុគ្គលពោលអាក្រក់ នឹងគន្លងពាក្យអាក្រក់ដែលបុគ្គលនាំមកប្រាប់ និងទុក្ខវេទនាប្រជុំក្នុងសរីរៈដ៏ក្លៀវក្លា រឹងអាក្រក់ មិនស្រួល មិនជាទីគាប់ចិត្ត ជាទីនាំបង់នូវជីវិតដែលកើតឡើងហើយ ចាត់ជាអ្នកមានជាតិមិនអត់ទ្រាំ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងបុគ្គលមានវស្សាគ្រប់២០ ទើបទ្រាំត្រជាក់ ក្តៅ ឃ្លាន ស្រេក សម្ផស្សរបោមមូស ខ្យល់កំដៅថ្ងៃ សត្វទីឃជាតិទាំងឡាយ នឹងគន្លងពាក្យដែលបុគ្គលពោលអាក្រក់មានមក នឹងគន្លងពាក្យអាក្រក់ដែលបុគ្គលនាំមកប្រាប់ នឹងទុក្ខវេទនាប្រជុំក្នុងសរីរៈដ៏ក្លៀវក្លារឹងអាក្រក់ មិនស្រួល មិនជាទីគាប់ចិត្ត ជាទីនាំបង់នូវជីវិតដែលកើតឡើងហើយ ចាត់ជាអ្នកមានជាតិអត់ទ្រាំបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ កាលដឹងហើយ ឲ្យឧបសម្បទាដល់បុគ្គលដែលមានអាយុមិនទាន់គ្រប់២០ឆ្នាំ[46] បុគ្គលដែលមានអាយុមិនទាន់គ្រប់២០ឆ្នាំនោះ ក៏នៅជាអនុបសម្បន្នដដែល ចំណែកភិក្ខុទាំងឡាយនោះ អ្នកប្រាជ្ញគប្បីតិះដៀល នេះជាអាបត្តិបាចិត្តិយ ក្នុងរឿងនោះ។**

[២៦៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ។ ដែលហៅថាដឹង គឺភិក្ខុនោះដឹងដោយខ្លួនឯងក្តី ពួកភិក្ខុដទៃប្រាប់ដល់ភិក្ខុនោះក្តី កុលបុត្រដែលនឹងឧបសម្បទានោះប្រាប់ក្តី។ បុគ្គលដែលមានវស្សាមិនទាន់ដល់២០ឆ្នាំ ហៅថា មានវស្សាមិនទាន់គ្រប់២០ឆ្នាំ។ ភិក្ខុគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈសង្ឃក្តី អាចារ្យក្តី បាត្រក្តី ចីវរក្តី សន្មតសីមា (ថ្មី)ក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ។ ភិក្ខុត្រូវអាបត្តិទុក្កដទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរដង។ ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈសង្ឃនឹងអាចារ្យ ត្រូវអាបត្តិទុក្កដក្នុងខណៈចប់កម្មវាចាស្រេច។

[២៧០] កុលបុត្រមានវស្សាមិនគ្រប់២០ ភិក្ខុសំគាល់ថាមានវស្សាមិនគ្រប់២០ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កុលបុត្រមានវស្សាមិនគ្រប់២០ ភិក្ខុមានសេចក្តីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ កុលបុត្រមានវស្សាមិនគ្រប់២០ ភិក្ខុសំគាល់ថាមានវស្សាគ្រប់២០ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ។ កុលបុត្រមានវស្សាគ្រប់២០ ភិក្ខុសំគាល់ថា មានវស្សាមិនគ្រប់២០ ត្រូវអាបត្តិទុក្កដ។ កុលបុត្រមានវស្សាគ្រប់២០ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កុលបុត្រមានវស្សាគ្រប់២០ ភិក្ខុសំគាល់ថា មានវស្សាគ្រប់២០ មិនត្រូវអាបត្តិ។

[២៧១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុសំគាល់បុគ្គលដែលមានវស្សាមិនទាន់គ្រប់២០ ថាមានវស្សាគ្រប់២០ ហើយឲ្យឧបសម្បទា១ ភិក្ខុសំគាល់បុគ្គលដែលមានវស្សាគ្រប់២០ថាមានវស្សាគ្រប់២០ ហើយឲ្យឧបសម្បទា១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៥ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី៦ (៦៦)

CS vin.vbu.pc.66 | ភាគ ទី៤

### (៦. ថេយ្យសត្ថសិក្ខាបទំ)

[២៧២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង មានពួកឈ្មួញរទេះ១ពួក មានសេចក្តីប្រាថ្នាចេញពីក្រុងរាជគ្រឹះ ហើយទៅកាន់ប្រទេសឈ្មោះបដិយាលោក។ ភិក្ខុ១រូបបាននិយាយពាក្យនេះនឹងមនុស្សទាំងនោះថា អាត្មានឹងទៅជាមួយនឹងអ្នកដ៏មានអាយុទាំងឡាយដែរ។ ពួកមនុស្សទាំងនោះនិយាយវិញថា សូមទាន ពួកយើងនឹងគេចវាងឲ្យរួចពន្ធទេតើ។ ភិក្ខុនោះនិយាយថា នែអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយចូរដឹងចុះ។ ពួកអ្នកធ្វើការគយបានឮគេនិយាយថា ពួកឈ្មួញនឹងគេចវាងឲ្យរួចពន្ធ ហើយចាំស្កាត់ពួកមនុស្សទាំងនោះក្នុងផ្លូវ។ ឯពួកអ្នកធ្វើការគយនោះ ក៏ចាប់រឹបយកពួកឈ្មួញរទេះនោះ ហើយបាននិយាយពាក្យនេះនឹងភិក្ខុនោះថា ទានប្រោស លោកដឹងហើយ ហេតុអ្វីបានជាទៅជាមួយនឹងពួកឈ្មួញរទេះដែលគេចវាងឲ្យរួចពន្ធ ថាដូច្នោះហើយ ក៏ចាប់ឃាត់ភិក្ខុនោះទុក ហើយលែងទៅ។ លំដាប់នោះឯង ភិក្ខុនោះទៅកាន់ក្រុងសាវត្ថី ហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាមានសេចក្តី ប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុដឹងហើយ មិនគួរនឹងបបួលគ្នាដើរទៅកាន់ផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយពួកឈ្មួញគេចវាងឲ្យរួចពន្ធសោះ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា នែភិក្ខុ ឮថា អ្នកដឹងហើយ បបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយពួកឈ្មួញដែលគេចវាងឲ្យរួចពន្ធ ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកដឹងហើយ មិនគួរនឹងបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយពួកឈ្មួញដែល

គេចវាងឲ្យរួចពន្ធទេ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយដឹងហើយ បបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយពួកឈ្មួញជាចោរ ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ។**

[២៧៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ។ ដែលហៅថាដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ភិក្ខុនោះក្តី ពួកឈ្មួញនោះប្រាប់ក្តី។ ដែលហៅថាពួកឈ្មួញជាចោរ គឺពួកចោរដែលធ្វើការ (លួច) ហើយក្តី មិនបានធ្វើការ(លួច)ហើយក្តី ដល់នូវកិរិយាលួច(របស់)ស្តេចក្តី គេចវាងឲ្យរួចពន្ធក្តី។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា។ ពាក្យថា បបួល គឺភិក្ខុនឹងឈ្មួញបបួលគ្នាថា នែអាវុសោ យើងនឹងទៅ បពិត្រលោកដ៏ចំរើន យើងនឹងទៅ បពិត្រលោកដ៏ចំរើន យើងនឹងទៅ នែអាវុសោ យើងនឹងទៅ យើងនឹងទៅក្នុងថ្ងៃនេះក្តី ស្អែកក្តី ខានស្អែកក្តី ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។ ពាក្យថា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ សេចក្តីថា ភិក្ខុដើរទៅក្នុងស្រុកមានចម្ងាយល្មមមាន់ហើរដល់ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗចន្លោះស្រុក។ ភិក្ខុដើរទៅក្នុងព្រៃមិនមែនជាស្រុក ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗកន្លះយោជន៍។

[២៧៤] ពួកឈ្មួញដែលជាចោរ ភិក្ខុសំគាល់ថាពួកឈ្មួញជាចោរ ហើយបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ។ ពួកឈ្មួញដែលជាចោរ ភិក្ខុមានសេចក្តីសង្ស័យ ហើយបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិទុក្កដ។ ពួកឈ្មួញដែលជាចោរ ភិក្ខុសំគាល់ថាមិនមែនពួកឈ្មួញជាចោរ ហើយបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ មិនត្រូវអាបត្តិ។ ភិក្ខុបបួល តែមនុស្សទាំងឡាយមិនបបួល (ភិក្ខុនោះ)ត្រូវអាបត្តិទុក្កដ។ ពួកឈ្មួញមិនមែនជាចោរ ភិក្ខុសំគាល់ថាពួកឈ្មួញជាចោរ ត្រូវអាបត្តិទុក្កដ។ ពួកឈ្មួញមិនមែនជាចោរ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ។ ពួកឈ្មួញមិនមែនជាចោរ ភិក្ខុសំគាល់ថាពួកឈ្មួញមិនមែនជាចោរ មិនត្រូវអាបត្តិ។

[២៧៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុមិនបបួល ហើយទៅ១ មនុស្សទាំងឡាយបបួល ភិក្ខុមិនបបួល១ ភិក្ខុទៅដោយខុសសង្កេត[47] ១ ភិក្ខុទៅព្រោះមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៦ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី៧ (៦៧)

CS vin.vbu.pc.67 | ភាគ ទី៤

### (៧. សំវិធានសិក្ខាបទំ)

[២៧៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុ១រូប ទៅកាន់ក្រុងសាវត្ថីក្នុងកោសលជនបទ បានចេញទៅតាមទ្វារមួយ។ ស្រី១នាក់ឈ្លោះនឹងប្តី ហើយចេញពីស្រុកទៅ ឃើញភិក្ខុនោះហើយ បាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់នឹងទៅទីណា។ ភិក្ខុនោះនិយាយថា នែនាង អាត្មានឹងទៅក្រុងសាវត្ថី។ ស្រីនោះនិយាយថា ខ្ញុំម្ចាស់នឹងទៅជាមួយលោកម្ចាស់ដែរ។ ភិក្ខុនោះឆ្លើយថា មកចុះនាង។ ខណៈនោះឯង ប្តីនៃស្រីនោះចេញពីស្រុកទៅ ហើយសួរមនុស្សទាំងឡាយថា នែអ្នកទាំងឡាយ អ្នកទាំងឡាយបានឃើញស្រីមានរូបរាងយ៉ាងនេះទេ។ គេប្រាប់ថា នែអ្នក ស្រីនោះទៅជាមួយនឹងអ្នកបួសទៅហើយ។ ទើបបុរសនោះទៅតាមចាប់ភិក្ខុនោះ វាយ ហើយលែងទៅ។ ភិក្ខុនោះទ្រមគ្រាំគ្រាអង្គុយនៅក្បែរគល់ឈើ១ដើមក្នុងកាលនោះ។ ឯស្រីនោះ បាននិយាយពាក្យនេះនឹងបុរសនោះថា នែអ្នក ភិក្ខុនោះមិនមែនបបួលណែនាំខ្ញុំមកទេ តែថា ខ្ញុំឯងទៅជាមួយនឹងភិក្ខុនោះទេតើ ភិក្ខុនោះមិនមែនជាអ្នកធ្វើ (សេចក្តីខុស)ទេ អ្នកចូរទៅឲ្យភិក្ខុនោះអត់ទោសទៅ។ ទើបបុរសនោះសូមទោសនឹងភិក្ខុនោះ។ លំដាប់នោះ ភិក្ខុនោះទៅកាន់ក្រុងសាវត្ថី ហើយប្រាប់ដំណើរនុះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាមានសេចក្តី ប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀលបន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងបបួលគ្នា ហើយដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយមាតុគ្រាមសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថា អ្នកឯងបបួលគ្នា ហើយដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយមាតុគ្រាម ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងមិនគួរនឹងបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយមាតុគ្រាមទេ។ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ បបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយមាតុគ្រាម ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ។**

[២៧៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ។ ដែលហៅថាមាតុគ្រាម សំដៅយកមនុស្សស្រី មិនសំដៅយកយក្សស្រី ប្រេតស្រី តិរច្ឆានញីទេ មនុស្សស្រីនោះតោងជាអ្នកដឹងក្តីអាចដឹងសព្វ នូវពាក្យដែលគេពោលល្អ ពោលអាក្រក់ ពាក្យទ្រគោះ មិនមែនពាក្យទ្រគោះ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា។ ពាក្យថា បបួលគ្នា គឺភិក្ខុ និងមាតុគ្រាមបបួលគ្នាថា នែនាង យើងនឹងទៅ លោកម្ចាស់ យើងនឹងទៅ លោកម្ចាស់ យើងនឹងទៅ នែនាង យើងនឹងទៅ យើងនឹងទៅថ្ងៃនេះ ថ្ងៃស្អែក ឬខានស្អែក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។

ពាក្យថា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ គឺភិក្ខុទៅក្នុងស្រុកមានចម្ងាយល្មមមាន់ហើរដល់ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗចន្លោះស្រុក។ ភិក្ខុដើរទៅក្នុងព្រៃមិនមែនជាស្រុក ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗកន្លះយោជន៍។

[២៧៨] មាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ហើយបបួលដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយបបួលដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ។ មាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម ហើយបបួលដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុបបួល មាតុគ្រាមមិនបបួល ភិក្ខុត្រូវអាបត្តិទុក្កដ។ ភិក្ខុបបួលដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយយក្សស្រី ប្រេតស្រី មនុស្សខ្ទើយ និងតិរច្ឆានញីមានរាងដូចមនុស្ស ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិ។

[២៧៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុមិនបបួល ហើយទៅ១ មាតុគ្រាមបបួល ភិក្ខុមិនបបួល១ ភិក្ខុទៅដោយខុសសង្កេត១ ភិក្ខុទៅព្រោះមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៧ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី៨ (៦៨)

CS vin.vbu.pc.68 | ភាគ ទី៤

### (៨. អរិដ្ឋសិក្ខាបទំ)

[២៨០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុឈ្មោះអរិដ្ឋជាកូននៃត្រកូលអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងដូច្នេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយប្រការដូច្នោះ។ ភិក្ខុជាច្រើនរូបបានឮពាក្យនោះថា ឮថា ភិក្ខុឈ្មោះអរិដ្ឋជាកូននៃត្រកូលអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងដូច្នេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយប្រការដូច្នោះ។ ទើបភិក្ខុទាំងនោះ ចូលទៅរកអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតនោះ លុះចូលទៅហើយ បាននិយាយពាក្យនេះនឹងអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតថា ម្នាលអាវុសោអរិដ្ឋ ឮថា អ្នកមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងដូច្នេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា តែងធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ មែនឬ។ អរិដ្ឋភិក្ខុឆ្លើយថា នែអាវុសោ ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា តែងធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ។ ភិក្ខុទាំងឡាយនិយាយថា នែអាវុសោអរិដ្ឋ អ្នកចូរកុំនិយាយយ៉ាងហ្នឹង អ្នកកុំពោលបង្អាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្អាច់ព្រះដ៏មានព្រះភាគ មិនល្អទេ ព្រោះថា ព្រះដ៏មានព្រះភាគមិនបានត្រាស់ថាយ៉ាងនេះទេ នែអាវុសោអរិដ្ឋ ធម៌ទាំងឡាយដែលធ្វើសេចក្តីអន្តរាយ ព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះសោត អាចធ្វើសេចក្តីអន្តរាយដល់អ្នកសេពពិតមែន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានសេចក្តីរីករាយតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងធ្វើពីស្មៅ។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នកយល់សប្តិ។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងជ្រញ់។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន។ អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត ទុកជាភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះ ក៏នៅតែប្រកាន់ទិដ្ឋិលាមកនោះដោយសេចក្តីប្រកាន់មាំដោយកំលាំង ហើយពោលយ៉ាងនោះដដែលថា នែអាវុសោ ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថាធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ។ ភិក្ខុទាំងឡាយនោះ មិនអាចដោះភិក្ខុឈ្មោះអរិដ្ឋជាកូននៃត្រកូលអ្នកសម្លាប់ត្មាតចេញពីទិដ្ឋិអាក្រក់យ៉ាងនេះក្នុងកាលណា ភិក្ខុទាំងឡាយនោះក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងកាលនោះឯង លុះចូលទៅហើយ ក៏ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតថា នែអរិដ្ឋ ឮថា អ្នកមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងដូច្នេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថាធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ពិតមែនឬ។ អរិដ្ឋភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើនូវសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះឯង។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយយ៉ាងនេះ មកពីអ្នកណា

នែមោឃបុរស ធម៌ធ្វើសេចក្តីអន្តរាយ តថាគតសំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះសោត អាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពបានពិតមែន តថាគតសំដែងហើយថា កាមទាំងឡាយមានសេចក្តីរីករាយតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុះសាច់។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងធ្វើពីស្មៅ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នកយល់សប្តិ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងជ្រញ់។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន នែមោឃបុរស កាលបើហេតុមានទំនងយ៉ាងនេះ អ្នកឯងហៅថាពោលបង្កាច់យើងផង ជីកគាស់ខ្លួនឯងផង បានបាបជាច្រើនផង ដោយទិដ្ឋិដែលខ្លួនប្រកាន់ខុស នែមោឃបុរស ព្រោះថាទិដ្ឋិរបស់អ្នកឯងនោះ នឹងប្រព្រឹត្តទៅដើម្បីទោសមិនមែនជាប្រយោជន៍ និងទុក្ខអស់កាលជាអង្វែង នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ ពោលយ៉ាងនេះថា ធម៌ទាំងឡាយណាតែងធ្វើនូវសេចក្តីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយ ធម៌ទាំងឡាយនោះមិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ដោយប្រការយ៉ាងណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការយ៉ាងនោះ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះថា លោកដ៏មានអាយុ លោកចូរកុំពោលយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ ព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោ ធម៌ទាំងឡាយតែងធ្វើនូវសេចក្តីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះអាចធ្វើនូវសេចក្តីអន្តរាយដល់អ្នកសេពមែន។ ឯភិក្ខុនោះ កាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះហើយ ក៏នៅតែប្រកាន់មាំយ៉ាងនោះដដែល ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈបីដង ដើម្បីឲ្យលះទិដ្ឋិនោះចេញ។ បើភិក្ខុនោះ កាលភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈបីដង ហើយលះបង់នូវទិដ្ឋិនោះបាន។ ការលះបង់បាននេះ ជាការល្អ បើភិក្ខុនោះមិនលះបង់ទេ ត្រូវអាបត្តិបាចិត្តិយ។**

[២៨១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទ ទី ១ នៃបារាជិកកណ្ឌ។ ពាក្យថា ភិក្ខុនោះពោលយ៉ាងនេះ គឺភិក្ខុនោះពោលថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ។

[២៨២] ពាក្យថា ភិក្ខុនោះ គឺភិក្ខុដែលនិយាយយ៉ាងនេះនោះឯង។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយដទៃ។ ភិក្ខុទាំងឡាយណាឃើញ ភិក្ខុទាំងឡាយណាឮ ភិក្ខុទាំងឡាយនោះ ត្រូវនិយាយឲ្យភិក្ខុដែលមានទិដ្ឋិអាក្រក់នោះថា នែលោកដ៏មានអាយុ លោកកុំនិយាយយ៉ាងហ្នឹង កុំពោលបង្កាច់ព្រះដ៏មានព្រះភាគយ៉ាងហ្នឹង ការពោលបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ ព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ ម្នាលអាវុសោ ធម៌ទាំងឡាយធ្វើនូវសេចក្តីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពមែន។ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅឲ្យភិក្ខុមានទិដ្ឋិអាក្រក់នោះអស់វារៈពីរដងផង ត្រូវនិយាយប្រដៅឲ្យអស់វារៈបីដងផង។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងឡាយឮហើយ មិននិយាយប្រដៅ ត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងឡាយត្រូវទាញភិក្ខុនោះមកកាន់ទីកណ្តាលសង្ឃ ហើយនិយាយប្រដៅថា លោកដ៏មានអាយុ លោកកុំពោលយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគ ការពោលបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោ ធម៌ទាំងឡាយតែងធ្វើសេចក្តីអន្តរាយ ព្រះដ៏មានព្រះភាគសំដែងហើយ ដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយដល់អ្នកសេពមែន។ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅភិក្ខុមានទិដ្ឋិអាក្រក់នោះអស់វារៈពីរដងផង ត្រូវនិយាយប្រដៅអស់វារៈបីដងផង។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។

[២៨៣] ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយត្រូវសូត្រសមនុភាសនកម្ម (ដល់ភិក្ខុមានទិដ្ឋិអាក្រក់) យ៉ាងនេះ។ ភិក្ខុដែលឈ្លាស អង់អាច ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ មានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ)ថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ។ ភិក្ខុនោះមិនលះបង់ទិដ្ឋិនោះ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ)ថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ។ ភិក្ខុនោះ មិនលះបង់ទិដ្ឋិនោះ។ (ឥឡូវនេះ) សង្ឃសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះ។ ការសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈបីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ)ថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ។ ភិក្ខុនោះ មិនលះបង់ទិដ្ឋិនោះទេ។ (ឥឡូវនេះ) សង្ឃសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ

ដើម្បីឲ្យលះបង់ទិដ្ឋិនោះហើយ។ ការសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ សង្ឃសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះដើម្បីឲ្យលះបង់ទិដ្ឋិនោះហើយ។ ការសូត្រសមនុភាសនកម្មនេះ គួរដល់សង្ឃ ហេតុនោះសង្ឃស្ងៀម។ ខ្ញុំចាំទុកនូវសង្ឃកម្មនេះដោយអាការស្ងៀមនៅយ៉ាងនេះ។

[២៨៤] ភិក្ខុត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ។ ភិក្ខុត្រូវអាបត្តិទុក្កដទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរ (លើក)។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ក្នុងខណៈចប់កម្មវាចាស្រេច។

[២៨៥] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ តែមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ តែមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ តែមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[២៨៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺសង្ឃមិនសូត្រសមនុភាសនកម្ម១ ភិក្ខុលះបង់១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៨ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី៩ (៦៩)

CS vin.vbu.pc.69 | ភាគ ទី៤

### (៩. ឧក្ខិត្តសម្ភោគសិក្ខាបទំ)

[២៨៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងហើយ បរិភោគរួមខ្លះ នៅរួមខ្លះ សម្រេចឥរិយាបថដេករួមខ្លះ ជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ មិនបានធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះចេញ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងហើយ មិនគួរនឹងបរិភោគរួមខ្លះ នៅរួមខ្លះ សម្រេចឥរិយាបថដេករួមខ្លះ ជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ ជាអ្នកមិនធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយដឹងហើយ បរិភោគរួមខ្លះ នៅរួមខ្លះ សម្រេចឥរិយាបថដេករួមខ្លះ ជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ ជាអ្នកមិនបានធ្វើតាមធម៌ ជាអ្នកមិនលះបង់ទិដ្ឋិនោះចេញ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយដឹងហើយ មិនគួរនឹង បរិភោគរួមខ្លះ នៅរួមខ្លះ សម្រេចឥរិយាបថដេករួមខ្លះ ជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ មិនធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយដឹងហើយ បរិភោគរួមក្តី នៅរួមក្តី សម្រេចឥរិយាបថដេករួមក្តី ជាមួយនឹងភិក្ខុដែលមានប្រក្រតីពោលយ៉ាងនោះ ជាអ្នកមិនធ្វើតាមធម៌ ជាអ្នកមិនលះបង់ទិដ្ឋិនោះ ត្រូវអាបត្តិបាចិត្តិយ។**

[២៨៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិក។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី ពួកភិក្ខុដទៃប្រាប់ភិក្ខុនោះក្តី ភិក្ខុមានទិដ្ឋិអាក្រក់នោះប្រាប់ក្តី។ ពាក្យថា មានប្រក្រតីពោលយ៉ាងនោះ គឺនៅតែនិយាយយ៉ាងនេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តី អន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌នោះដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ។ ភិក្ខុណាដែលសង្ឃលើកវត្ត[48] ហើយសង្ឃមិនបានហៅចូលពួកទេ ភិក្ខុនោះហៅថាមិនធ្វើតាមធម៌។ ពាក្យថា ជាមួយនឹង (ភិក្ខុ) មិនលះបង់ទិដ្ឋិនោះ គឺជាមួយនឹង(ភិក្ខុ) ដែលមិនលះបង់នូវទិដ្ឋិនោះឲ្យដាច់ស្រឡះ។ ពាក្យថា បរិភោគរួមក្តី[49] សេចក្តីថា ដែលហៅថា បរិភោគរួម គឺបរិភោគរួមមានពីរយ៉ាង បរិភោគរួមដោយអាមិសៈ១ បរិភោគរួមដោយធម៌១។ ដែលហៅថា បរិភោគរួមដោយអាមិសៈនោះគឺ ភិក្ខុឲ្យអាមិសៈ (ដល់ភិក្ខុនោះក្តី) ទទួលអាមិសៈអំពីភិក្ខុនោះក្តី ត្រូវអាបត្តិបាចិត្តិយ។ ដែលហៅថា បរិភោគរួមដោយធម៌ គឺភិក្ខុសំដែងធម៌ (ដល់ភិក្ខុនោះ)ក្តី ឲ្យ (ភិក្ខុនោះ)សំដែងធម៌ឲ្យស្តាប់ក្តី។ ភិក្ខុសំដែងធម៌ (ដល់ភិក្ខុនោះ)ក្តី ឲ្យ(ភិក្ខុនោះ)សំដែងធម៌ឲ្យស្តាប់ក្តី ដោយបទ ត្រូវអាបត្តិបាចិត្តិយ រាល់ៗបទ។ ភិក្ខុសំដែងធម៌ (ដល់ភិក្ខុនោះ)ក្តី ឲ្យ(ភិក្ខុនោះ)សំដែងធម៌ឲ្យស្តាប់ក្តី ដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយ រាល់ៗអក្ខរៈ។ ពាក្យថា នៅរួមក្តី គឺភិក្ខុធ្វើឧបោសថក្តី បវារណាក្តី សង្ឃកម្មក្តី ជាមួយនឹងភិក្ខុដែលសង្ឃលើកវត្ត ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា សម្រេចឥរិយាបថដេករួមក្តី គឺកាលបើភិក្ខុដែលសង្ឃលើកវត្តបានដេកហើយ ភិក្ខុក៏ដេកក្នុងទីបិទបាំងជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ។ កាលបើភិក្ខុដេកហើយ ភិក្ខុដែលសង្ឃលើកវត្តក៏ដេកដែរ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ឬថាភិក្ខុទាំងពីររូបដេក (ជាមួយគ្នា) ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុក្រោកឡើង ហើយដេកវិញញយៗ ត្រូវអាបត្តិបាចិត្តិយ។

[២៨៩] ភិក្ខុដែលសង្ឃលើកវត្តហើយ ភិក្ខុសំគាល់ថាសង្ឃលើកវត្តហើយ ៗបរិភោគរួមក្តី នៅរួមក្តី សម្រេចឥរិយាបថដេករួមក្តី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដែលសង្ឃលើកវត្តហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយបរិភោគរួមក្តី នៅរួមក្តី សម្រេចឥរិយាបថដេករួមក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុដែលសង្ឃលើកវត្តហើយ ភិក្ខុសំគាល់ថាសង្ឃមិនបានលើកវត្តទេ ហើយបរិភោគរួមក្តី នៅរួមក្តី សម្រេចឥរិយាបថដេករួមក្តី មិនត្រូវអាបត្តិ។ ភិក្ខុ

ដែលសង្ឃមិនបានលើកវត្ត ភិក្ខុសំគាល់ថាសង្ឃលើកវត្តហើយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុដែលសង្ឃមិនលើកវត្ត ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុដែលសង្ឃមិនលើកវត្ត ភិក្ខុសំគាល់ថាសង្ឃមិនលើកវត្ត មិនត្រូវអាបត្តិ។

[២៩០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុដឹងថា ភិក្ខុនោះសង្ឃមិនលើកវត្ត១ ភិក្ខុដឹងថា ភិក្ខុដែលសង្ឃលើកវត្តហើយ ដែលសង្ឃបានសូត្រហៅចូលពួកវិញ១ ភិក្ខុដឹងថា ភិក្ខុដែលសង្ឃលើកវត្តហើយ ៗបានលះបង់ទិដ្ឋិនោះចេញហើយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៩ ចប់។

## (បាចិត្តិយ សប្បាណកវគ្គ) សិក្ខាបទ ទី១០ (៧០)

CS vin.vbu.pc.70 | ភាគ ទី៤

### (១០. កណ្ដកសិក្ខាបទំ)

[២៩១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង សមណុទ្ទេស[50] ឈ្មោះកណ្ដកៈ មានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើង(ដូច្នេះ)ថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពនោះទេ។ ភិក្ខុជាច្រើនបានឮដំណឹងថា សមណុទ្ទេសឈ្មោះកណ្ដកៈ មានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើង(ដូច្នេះ)ថា ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ។ ទើបភិក្ខុទាំងឡាយនោះចូលទៅរកសមណុទ្ទេឈ្មោះកណ្ដកៈ លុះចូលទៅហើយ បាននិយាយពាក្យនេះនឹងកណ្ដកសមណុទ្ទេសថា នែអាវុសោកណ្ដកៈ ឮថា អ្នកឯងមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើង(ដូច្នេះ)ថា ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ ពិតមែនឬ។ កណ្ដកៈសមណុទ្ទេសឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំករុណាដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគសំដែងយ៉ាងនេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេព ពិតមែន។ ភិក្ខុទាំងឡាយនិយាយថា នែអាវុសោកណ្ដកៈ អ្នកកុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ ព្រះដ៏មានព្រះភាគមិនបានត្រាស់ថាយ៉ាងនេះទេ នែអាវុសោកណ្ដកៈ ធម៌ទាំងឡាយធ្វើសេចក្ដីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពមែន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងដែលធ្វើពីស្មៅ។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្ដៅរងើកភ្លើង។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នកយល់សប្តិ។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងជ្រញ់។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច។បេ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន។ សមណុទ្ទេសកណ្ដកៈ កាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះ ក៏នៅប្រកាន់ទិដ្ឋិអាក្រក់នោះដោយសេចក្ដីប្រកាន់ដ៏មាំ ហើយពោលយ៉ាងនោះដដែលថា បពិត្រលោកដ៏ចំរើន ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយយ៉ាងនេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថាជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ។ ភិក្ខុទាំងឡាយនោះ មិនអាចនឹងដោះសមណុទ្ទេសឈ្មោះកណ្ដកៈចេញពីទិដ្ឋិអាក្រក់នោះក្នុងកាលណា ភិក្ខុទាំងឡាយនោះចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងកាលនោះ លុះចូលទៅហើយ ក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះកណ្ដកសមណុទ្ទេសក្នុងពេលនោះថា នែកណ្ដកៈ ឮថា អ្នកឯងមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើង(ដូច្នេះ)ថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ ពិតមែនឬ។ កណ្ដកសមណុទ្ទេសនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយយ៉ាងនេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពពិតមែន។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយយ៉ាងនេះ អំពីបុគ្គលណាមក នែមោឃបុរស ធម៌ទាំងឡាយដែលធ្វើសេចក្ដីអន្តរាយ តថាគតសំដែងហើយដោយបរិយាយជាច្រើន ក៏ធម៌ទាំងឡាយនោះ អាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេព (មែន) តថាគតសំដែងហើយថា កាមទាំងឡាយមានសេចក្ដីសុខតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុះសាច់។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងធ្វើដោយស្មៅ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្ដៅរងើកភ្លើង។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នកយល់សប្តិ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងជ្រញ់។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន

មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន នែមោឃបុរស កាលបើដូច្នោះហើយ អ្នកឯងហៅថាពោលបង្កាច់យើងផង គាស់កកាយខ្លួនឯងផង សោយបាបជាច្រើនផង ព្រោះទិដ្ឋិដែលខ្លួនកាន់យកខុស នែមោឃបុរស ទិដ្ឋិដែលអ្នកឯងកាន់យកអាក្រក់នោះ នឹងបង្កទោសមិនជាប្រយោជន៍ ជាទុក្ខដល់អ្នកឯងអស់កាលជាអង្វែង នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ម្នាលមោឃបុរស ទិដ្ឋិអាក្រក់របស់អ្នកឯងនេះ មានតែនាំមិនឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងដើម្បីសេចក្តីរាយមាយដល់មនុស្សពួកខ្លះដែលជ្រះថ្លាហើយផង។ ព្រះដ៏មានព្រះភាគបន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរញុំាងកណ្ឌកសមណុទ្ទេសឲ្យវិនាសចុះ[51] ម្នាលភិក្ខុទាំងឡាយ កណ្ឌកសមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវឲ្យវិនាសយ៉ាងនេះថា នែអាវុសោកណ្ឌកៈ កាលមានថ្ងៃនេះជាដើម អ្នកឯងមិនត្រូវអាងព្រះដ៏មានព្រះភាគអង្គនោះថាជាសាស្តារបស់អ្នកឡើយ សមណុទ្ទេសទាំងឡាយដទៃតែងបាននូវកិរិយាដេករួមឯណា អស់រាត្រីពីរនិងរាត្រីបីជាមួយនឹងភិក្ខុទាំងឡាយ កិរិយាដេកនៅរួមនោះមិនមានដល់អ្នកទេ នែមនុស្សក្រៅការ អ្នកឯងចូរចៀសចេញទៅ អ្នកចូរវិនាសទៅ។ ក្នុងកាលនោះឯង សង្ឃបានឲ្យកណ្ឌកសមណុទ្ទេសវិនាសហើយ។

[២៩២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា កណ្ឌកសមណុទ្ទេស សង្ឃឲ្យវិនាសយ៉ាងនោះហើយ បញ្ចុះបញ្ចូលខ្លះ ឲ្យបម្រើខ្លះ បរិភោគរួមខ្លះ សម្រេចឥរិយាបថដេករួមខ្លះ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងថា កណ្ឌកសមណុទ្ទេស ដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ មិនគួរនឹងបញ្ចុះបញ្ចូលខ្លះ ឲ្យបម្រើខ្លះ បរិភោគរួមខ្លះ សម្រេចឥរិយាបថដេករួមខ្លះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយដឹងថា កណ្ឌកសមណុទ្ទេស ដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ បញ្ចុះបញ្ចូលខ្លះ ឲ្យបម្រើខ្លះ បរិភោគរួមខ្លះ សម្រេចឥរិយាបថដេករួមខ្លះ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយដឹងថា កណ្ឌកសមណុទ្ទេស ដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ មិនគួរនឹងបញ្ចុះបញ្ចូលខ្លះ ឲ្យបម្រើខ្លះ បរិភោគរួមខ្លះ សម្រេចឥរិយាបថដេករួមខ្លះទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**បើសមណុទ្ទេសពោលយ៉ាងនេះថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសំដែងហើយ ថាជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ។ សមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា នែអាវុសោសមណុទ្ទេស អ្នកឯងកុំនិយាយយ៉ាងនេះឡើយ អ្នកកុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោសមណុទ្ទេស ធម៌ទាំងឡាយធ្វើសេចក្តីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព (មែន)។ សមណុទ្ទេសនោះ កាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះហើយ ក៏នៅតែប្រកាន់ដដែល សមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា នែអាវុសោសមណុទ្ទេស កាលមានថ្ងៃនេះជាដើម អ្នកមិនត្រូវអាងព្រះដ៏មានព្រះភាគនោះថាជាសាស្តារបស់អ្នកឡើយ សាមណេរទាំងឡាយដទៃតែងបានកិរិយាដេករួមឯណា អស់រាត្រីពីរបីជាមួយនឹងភិក្ខុទាំងឡាយ ការដេកនៅរួមនោះមិនមានដល់អ្នកទេ នែមនុស្សក្រៅការ អ្នកចូរចៀសចេញទៅ ចូរវិនាសទៅ។ ភិក្ខុណាមួយដឹងថា សមណុទ្ទេសដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ បញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគក្តី សម្រេចឥរិយាបថដេករួមក្តី ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។**

[២៩៣] ដែលហៅថា សមណុទ្ទេស គឺសំដៅយកសាមណេរ។ ពាក្យថា ពោលយ៉ាងនេះ គឺពោលថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ។

[២៩៤] ពាក្យថា សមណុទ្ទេសនោះ គឺសមណុទ្ទេសដែលជាអ្នកពោលយ៉ាងនេះនោះឯង។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយឯទៀត។ ភិក្ខុទាំងឡាយណាឃើញ ភិក្ខុទាំងឡាយណាឮ ភិក្ខុទាំងឡាយនោះត្រូវពោលនឹងសមណុទ្ទេសនោះថា នែអាវុសោសមណុទ្ទេស អ្នកកុំពោលយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនសម្រេចប្រយោជន៍ទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោសមណុទ្ទេស ធម៌ទាំងឡាយ ដែលធ្វើសេចក្តីអន្តរាយ ព្រះដ៏មានព្រះភាគសំដែងហើយ ដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព(មែន)។ សមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវពោលអស់វារៈពីរដងផង ត្រូវពោលអស់វារៈបីដងផង។ បើសមណុទ្ទេសនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ សមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវនិយាយយ៉ាងនេះថា នែអាវុសោសមណុទ្ទេស កាលមានថ្ងៃនេះជាដើម អ្នកមិនត្រូវអាងព្រះដ៏មានព្រះភាគនោះថាជាសាស្តារបស់អ្នកឡើយ សមណុទ្ទេសទាំងឡាយដទៃ តែងបានការដេកនៅរួមឯណាអស់រាត្រីពីរនិងរាត្រីបីជាមួយនឹងភិក្ខុទាំងឡាយ ការដេកនៅរួមនោះមិនមានដល់អ្នកទេ នែមនុស្សឥតគេរាប់ អ្នកចូរចៀសចេញទៅ ចូរវិនាសទៅ។

[២៩៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី ភិក្ខុទាំងឡាយដទៃប្រាប់ភិក្ខុនោះក្តី ឬសមណុទ្ទេសនោះប្រាប់ក្តី។ ពាក្យថា ដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ គឺសង្ឃឲ្យខូចយ៉ាងនេះហើយ។ ដែលហៅថា សមណុទ្ទេស គឺសំដៅយកសាមណេរ។ ពាក្យថា បញ្ចុះបញ្ចូលក្តី គឺភិក្ខុបញ្ចុះបញ្ចូលដោយគិតថា អញនឹងឲ្យបាត្រក្តី ចីវរក្តី បាលីក្តី អដ្ឋកថាក្តី ដល់សមណុទ្ទេសនោះ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ឲ្យបម្រើក្តី គឺភិក្ខុត្រេកអរនឹងគ្រឿងលំអិតក្តី ដីស្អិតក្តី ឈើស្ទន់ក្តី ទឹកខ្ពុរមាត់ក្តី របស់សមណុទ្ទេសនោះ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា បរិភោគរួមក្តី គឺបរិភោគរួមមានពីរយ៉ាង បានដល់បរិភោគរួមដោយអាមិសៈ១ បរិភោគរួម

ដោយធម៌១ ហៅថាបរិភោគរួម។ ដែលហៅថា បរិភោគរួមដោយអាមិសៈ គឺភិក្ខុឲ្យអាមិសៈក្តី ទទួលក្តី ត្រូវអាបត្តិបាចិត្តិយ។ ដែលហៅថា បរិភោគរួមដោយធម៌ គឺភិក្ខុសំដែងធម៌ដល់សមណុទ្ទេសនោះក្តី ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី។ ភិក្ខុសំដែងធម៌ដល់សមណុទ្ទេសនោះក្តី ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី ដោយបទ ត្រូវអាបត្តិបាចិត្តិយរាល់ៗបទ។ ភិក្ខុសំដែងធម៌ដល់សមណុទ្ទេសនោះក្តី ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី ដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយរាល់ៗអក្ខរៈ។ ពាក្យថា សម្រេចកិរិយាដេកនៅរួមក្តី គឺកាលបើសមណុទ្ទេសដែលសង្ឃឲ្យវិនាសនោះបានដេកហើយ ភិក្ខុក៏ដេកក្នុងទីបិទបាំងជាមួយ ត្រូវអាបត្តិបាចិត្តិយ។ កាលបើភិក្ខុដេកហើយ សមណុទ្ទេសដែលសង្ឃឲ្យវិនាសក៏ដេកនៅ (ដែរ) ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ឬដេកទាំងពីរនាក់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុក្រោកឡើងហើយ ដេកញយៗ ត្រូវអាបត្តិបាចិត្តិយ។

[២៩៦] សមណុទ្ទេសដែលសង្ឃឲ្យវិនាសហើយ ភិក្ខុសំគាល់ថាសង្ឃឲ្យវិនាសហើយ ៗបញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយាដេករួមក្តី ត្រូវអាបត្តិបាចិត្តិយ។ សមណុទ្ទេសដែលសង្ឃឲ្យវិនាសហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយបញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយាដេករួមក្តី ត្រូវអាបត្តិទុក្កដ។ សមណុទ្ទេសដែលសង្ឃឲ្យវិនាសហើយ ភិក្ខុសំគាល់ថាសង្ឃមិនបានឲ្យវិនាសទៅវិញ ហើយបញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយាដេករួមក្តី មិនត្រូវអាបត្តិ។ សមណុទ្ទេសដែលសង្ឃមិនឲ្យវិនាស ភិក្ខុសំគាល់ថាសង្ឃឲ្យវិនាស ត្រូវអាបត្តិទុក្កដ។ សមណុទ្ទេសដែលសង្ឃមិនឲ្យវិនាស ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ សមណុទ្ទេសដែលសង្ឃមិនឲ្យវិនាស ភិក្ខុសំគាល់ថាសង្ឃមិនឲ្យវិនាស មិនត្រូវអាបត្តិ។

[២៩៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុដឹងថា សមណុទ្ទេសនោះ សង្ឃមិនបានឲ្យវិនាស១ ភិក្ខុដឹងថា សមណុទ្ទេសនោះ លះបង់ទិដ្ឋិនោះហើយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១០ ចប់។

សប្បាណកវគ្គ ទី ៧ ចប់។

ឧទាននៃសប្បាណកវគ្គនោះ មាន១០សិក្ខាបទនេះគឺ

សញ្ចិច្ចវធសិក្ខាបទ១ សប្បាណសិក្ខាបទ១ ឧក្កោសិក្ខាបទ១ ទុដ្ឋុលឆាទនសិក្ខាបទ១ ឩនវីសតិសិក្ខាបទ១ សត្ថសិក្ខាបទ១ សំវិធានសិក្ខាបទ១ អរិដ្ឋកសិក្ខាបទ១ ឧក្ខិត្តសិក្ខាបទ១ កណ្ដកសិក្ខាបទ១។

# សហធម្មិកវគ្គ (ទី៨)

CS vin.vbu.pc.v8 | ភាគ ទី៤

### (៨. សហធម្មិកវគ្គោ)

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី១ (៧១)

CS vin.vbu.pc.71 | ភាគ ទី៤

### (១. សហធម្មិកសិក្ខាបទំ)

[២៩៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅឃោសិតារាម ទៀបក្រុងកោសម្ពី។ សម័យនោះឯង ឆន្នៈដ៏មានអាយុតែងប្រព្រឹត្តអនាចារ។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា នែអាវុសោឆន្នៈ អ្នកកុំធ្វើកម្មមានសភាពយ៉ាងនេះ កម្មដែលអ្នកធ្វើនេះ មិនគួរទេ។ ឆន្នភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់សាកសួរភិក្ខុដទៃដែលឈ្លាស ដែលទ្រទ្រង់វិន័យ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នៈដ៏មានអាយុ កាលបើភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ មិនគួរនឹងពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃដែលឈ្លាស ដែលទ្រទ្រង់វិន័យនៅឡើយ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា នែឆន្នៈ ឮថា អ្នកឯង កាលបើភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ និយាយ(នឹងភិក្ខុទាំងឡាយ) យ៉ាងនេះវិញថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃដែលឈ្លាស ដែលទ្រទ្រង់វិន័យនៅឡើយ ពិតមែនឬ។ ឆន្នៈភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា នែមោឃបុរស កាលបើភិក្ខុទាំងឡាយនិយាយពាក្យប្រកបដោយធម៌ អ្នកឯងមិនគួរនឹងពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃដែលឈ្លាស ដែលទ្រទ្រង់វិន័យនៅឡើយ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ កាលភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ ហើយពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សាកសួរភិក្ខុដទៃ ដែលឈ្លាស ដែលទ្រទ្រង់វិន័យដរាបណា ខ្ញុំនឹងមិនសិក្សាសិក្ខាបទនេះដរាបនោះ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកសិក្សា គួរដឹងច្បាស់ គួរសាកសួរ គួរពិចារណា។ នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ។**

[២៩៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយដទៃ។ ដែលហៅថា ពាក្យប្រកបដោយធម៌ គឺសិក្ខាបទណា ដែលព្រះដ៏មានព្រះភាគបញ្ញត្តហើយ សិក្ខាបទនោះហៅថា ពាក្យប្រកបដោយធម៌។ ភិក្ខុនោះ កាលភិក្ខុទាំងឡាយពោលតាមសិក្ខាបទនោះ ត្រឡប់ជាពោលយ៉ាងនេះ គឺពោលថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាក្នុងសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃដែលឈ្លាស ជាវិនយធរ ជាបណ្ឌិតមានប្រាជ្ញ ជាពហុស្សូត ជាធម្មកថិកនៅឡើយ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ។

[៣០០] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្នពិតមែន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាមិនមែនឧបសម្បន្ន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុកាលភិក្ខុទាំងឡាយពោលតាមពាក្យដែលមិនមែនជាវិនយបញ្ញត្តិ ហើយពោលយ៉ាងនេះថា ពាក្យនេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីផូរផង់ចាកកិលេស មិនប្រព្រឹត្តទៅដើម្បីកំចាត់បង់កិលេស មិនប្រព្រឹត្តទៅដើម្បីនាំមកនូវសេចក្តីជ្រះថ្លា មិនប្រព្រឹត្តទៅដើម្បីមិនសន្សំនូវកិលេសវដ្ត មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាមទេ (ម្យ៉ាងទៀត) ពោលថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនោះទេ ព្រោះខ្ញុំមិនទាន់សាកសួរភិក្ខុដទៃ ដែលឈ្លាសទ្រទ្រង់វិន័យ ជាបណ្ឌិតមានប្រាជ្ញា ជាពហុស្សូត ជាធម្មកថឹក នៅឡើយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុ កាលអនុបសម្បន្នពោលដោយវិនយបញ្ញត្តិក្តី ដោយពុទ្ធវចនៈដែលមិនមែនជាវិនយបញ្ញត្តិក្តី ត្រឡប់ពោលយ៉ាងនេះថា ពាក្យនេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីផូរផង់ចាកកិលេស មិនប្រព្រឹត្តទៅដើម្បីកំចាត់កិលេស មិនប្រព្រឹត្តទៅដើម្បីនាំមកនូវសេចក្តីជ្រះថ្លា មិនប្រព្រឹត្តទៅដើម្បីមិនសន្សំនូវកិលេសវដ្ត មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាមទេ (ម្យ៉ាងទៀត) ពោលថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្លាសទ្រទ្រង់វិន័យ ជាបណ្ឌិតមានប្រាជ្ញា ជាពហុស្សូត ជាធម្មកថឹកនៅឡើយ ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថាមិនមែនឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[៣០១] ត្រង់ពាក្យថា អ្នកសិក្សា គឺអ្នកមានសេចក្តីប្រាថ្នាដើម្បីនឹងសិក្សា។ ពាក្យថា គួរដឹងច្បាស់ គឺគួរចេះ។ ពាក្យថា គួរសាកសួរ គឺគួរសាកសួរថា បពិត្រលោកដ៏ចំរើន ពាក្យនេះដូចម្តេច ពាក្យនេះមានសេចក្តីដូចម្តេច។ ពាក្យថា គួរពិចារណា គឺគួរគិត គួរថ្លឹង។ ពាក្យថា នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ គឺថានេះតាមទំនៀមក្នុងសិក្ខាបទនោះ។

[៣០២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុពោលថា ខ្ញុំនឹងដឹង ខ្ញុំនឹងសិក្សា១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី២ (៧២)

CS vin.vbu.pc.72 | ភាគ ទី៤

### (២. វិលេខនសិក្ខាបទំ)

[៣០៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់សំដែងវិនយកថា សំដែងគុណនៃវិន័យ ទ្រង់សំដែងគុណនៃការរៀនវិន័យ ទ្រង់កំណត់រឿយៗ ហើយទ្រង់សំដែងគុណរបស់ព្រះឧបាលិដ៏មានអាយុដល់ភិក្ខុទាំងឡាយដោយបរិយាយជាច្រើន។ ភិក្ខុទាំងឡាយនិយាយថា ព្រះដ៏មានព្រះភាគទ្រង់សំដែងវិនយកថា ទ្រង់សំដែងគុណនៃវិន័យ ទ្រង់សំដែងគុណនៃការរៀនវិន័យ ទ្រង់កំណត់រឿយៗ ហើយទ្រង់សំដែងគុណរបស់ព្រះឧបាលិដ៏មានអាយុដោយបរិយាយជាច្រើន នែអាវុសោទាំងឡាយ បើដូច្នោះយើងនឹងរៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ។ ទើបភិក្ខុទាំងឡាយនោះ ជាថេរៈខ្លះ ជាភិក្ខុថ្មីខ្លះ ជាភិក្ខុកណ្តាលខ្លះច្រើនរូប រៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ។ លំដាប់នោះឯង ពួកឆព្វគ្គិយភិក្ខុមានគំនិតដូច្នេះថា នែអាវុសោទាំងឡាយថ ឥឡូវនេះឯង ភិក្ខុច្រើនអង្គ ជាថេរៈខ្លះ ជាភិក្ខុថ្មីខ្លះ ជាភិក្ខុកណ្តាលខ្លះ រៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ បើភិក្ខុទាំងឡាយនេះជាអ្នកចេះស្ទាត់ក្នុងវិន័យ នឹងទាញមក នឹងច្រានទៅនូវយើងទាំងឡាយតាមគាប់ចិត្ត នែអាវុសោទាំងឡាយ ណ្ហើយចុះ យើងគួរពោលបង្អាប់វិន័យវិញ។ ទើបពួកឆព្វគ្គិយភិក្ខុចូលទៅជិតភិក្ខុទាំងឡាយ ហើយនិយាយយ៉ាងនេះថា ប្រយោជន៍អ្វីដោយសិក្ខាបទតូចៗទាំងនេះ ដែលបុគ្គលណាមួយសំដែងឡើងហើយ សិក្ខាបទទាំងឡាយនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីក្តៅក្រហាយចិត្ត ដើម្បីសេចក្តីលំបាកចិត្ត ដើម្បីសេចក្តីសាញ៉ាំចិត្ត។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងពោលបង្អាប់វិន័យសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយពោលបង្អាប់វិន័យ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងពោលបង្អាប់វិន័យទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយ កាលបើភិក្ខុសំដែងឡើងនូវបាតិមោក្ខ ហើយពោលយ៉ាងនេះថា ប្រយោជន៍អ្វីដោយសិក្ខាបទតូចៗទាំងនេះ ដែលភិក្ខុណាមួយសំដែងឡើងហើយ សិក្ខាបទទាំងឡាយនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីក្តៅក្រហាយចិត្ត ដើម្បីសេចក្តីលំបាកចិត្ត ដើម្បីសេចក្តីវសេមរសាមចិត្តប៉ុណ្ណោះឯង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះពោលបង្អាប់សិក្ខាបទ។**

[៣០៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា កាលបើភិក្ខុសំដែងឡើងនូវបាតិមោក្ខ គឺកាលបើភិក្ខុសំដែងឡើងឯងក្តី ឲ្យគេសំដែងឡើងក្តី ធ្វើស្វាធ្យាយក្តី។ ពាក្យថា ពោលយ៉ាងនេះ គឺភិក្ខុណាពោលបង្អាប់វិន័យដល់ឧបសម្បន្នផង

គ្នាថា ប្រយោជន៍អ្វីដោយសិក្ខាបទតូចៗទាំងនេះ ដែលភិក្ខុណាមួយសំដែងឡើងហើយ សិក្ខាបទទាំងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីរសេមរសាមចិត្តប៉ុណ្ណោះឯង ភិក្ខុណារៀនសិក្ខាបទនេះ ភិក្ខុនោះមានសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីរសេមរសាមចិត្ត ភិក្ខុណាមិនរៀនសិក្ខាបទនេះ ភិក្ខុនោះមិនមានសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីរសេមរសាមចិត្តទេ សិក្ខាបទនេះ បើមិនមានអ្នកណាសំដែងឡើង ក៏ជាការល្អ សិក្ខាបទនេះ បើមិនមានអ្នកណាសិក្សា ក៏ជាការល្អ សិក្ខាបទនេះ បើមិនមានអ្នកណារៀន ក៏ជាការល្អ សិក្ខាបទនេះ បើមិនមានអ្នកណាទ្រទ្រង់ ក៏ជាការល្អ វិន័យចូរអន្តរធានទៅ ឬភិក្ខុទាំងឡាយនេះ ចូរកុំឲ្យចេះដឹងអ្វីសោះ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[៣០៥] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយពោលបង្អាប់វិន័យ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយពោលបង្អាប់វិន័យ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាមិនមែនឧបសម្បន្ន ហើយពោលបង្អាប់វិន័យ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុពោលបង្អាប់ធម៌ដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុពោលបង្អាប់វិន័យក្តី ធម៌ដទៃក្តី ចំពោះអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថាមិនមែនឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[៣០៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុមិនចង់ពោលបង្អាប់១ ភិក្ខុពោលថា ណ្ហើយចុះ អ្នកចូររៀនព្រះសូត្រទាំងឡាយក្តី គាថាទាំងឡាយក្តី អភិធម្មក្តី ជាមុនសិន ចាំរៀនវិន័យជាខាងក្រោយវិញ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ២ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី៣ (៧៣)

CS vin.vbu.pc.73 | ភាគ ទី៤

### (៣. មោហនសិក្ខាបទំ)

[៣០៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាប្រព្រឹត្តអនាចារ ហើយគិតថា ភិក្ខុទាំងឡាយចូរដឹងថា យើងទាំងឡាយត្រូវអាបត្តិដោយសេចក្តីល្ងង់ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ក៏នាំគ្នាពោលយ៉ាងនេះថា យើងទាំងឡាយទើបតែនឹងដឹងឥឡូវនេះថា ធម៌នេះមកហើយក្នុងសុត្តៈ រាប់ចូលហើយក្នុងសុត្តៈ មកកាន់ឧទ្ទេស (ការសូត្រ) រាល់កន្លះខែ។ ភិក្ខុទាំងឡាយណាជាអ្នកមានប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុកាលភិក្ខុកំពុងសំដែងបាតិមោក្ខ ម្តេចក៏នាំគ្នាពោលយ៉ាងនេះថា យើងទាំងឡាយទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ធម៌នេះមកហើយក្នុងសុត្តៈ រាប់ចូលហើយក្នុងសុត្តៈ មកកាន់ឧទ្ទេស រាល់កន្លះខែ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ក៏នាំគ្នាពោលយ៉ាងនេះថា យើងទាំងឡាយទើបតែនឹងដឹងឥឡូវនេះថា ធម៌នេះមកហើយក្នុងសុត្តៈ រាប់ចូលហើយក្នុងសុត្តៈ មកកាន់ឧទ្ទេសរាល់កន្លះខែ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ មិនគួរនឹងមកពោលយ៉ាងនេះថា យើងទាំងឡាយទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ធម៌នេះមកហើយក្នុងសុត្តៈ រាប់ចូលហើយក្នុងសុត្តៈ មកកាន់ឧទ្ទេសរាល់កន្លះខែ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយ កាលភិក្ខុកំពុងសំដែងបាតិមោក្ខរាល់កន្លះខែ ហើយពោលយ៉ាងនេះថា ខ្ញុំទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ឮថា ធម៌នេះមកហើយក្នុងសុត្តៈ រាប់ចូលហើយក្នុងសុត្តៈ មកកាន់ឧទ្ទេសរាល់កន្លះខែ។ បើភិក្ខុទាំងឡាយដទៃដឹងនូវភិក្ខុនោះថា ភិក្ខុនេះធ្លាប់អង្គុយស្តាប់បាតិមោក្ខ ដែលភិក្ខុសំដែងអស់វារៈពីរបីដងហើយ នឹងពោលទៅថ្វីទៀតដល់ការស្តាប់ច្រើនដង សេចក្តីរួច (ចាកអាបត្តិ) ដោយអាការដែលមិនដឹង មិនមានដល់ភិក្ខុនោះទេ ភិក្ខុនោះត្រូវអាបត្តិណា ក្នុងរឿងអនាចារនោះ សង្ឃគប្បីញ៉ាំងភិក្ខុនោះឲ្យធ្វើនូវអាបត្តិនោះ ដោយគួរតាមធម៌ ម្យ៉ាងទៀត គប្បីលើកមោហារោបនកម្មដល់ភិក្ខុនោះថែមទៀតថា ម្នាលអាវុសោ (ការនេះ) មិនជាលាភរបស់អ្នកឯងទេ អ្នកឯងបាននូវរបស់អាក្រក់ ដោយហេតុថា កាលភិក្ខុកំពុងសំដែងបាតិមោក្ខ អ្នកមិនបានធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ដ៏ល្អឡើយ។ នេះជាអាបត្តិបាចិត្តិយ ព្រោះក្លែងធ្វើវង្វេងនោះ (ធ្វើពើរ)។**

[៣០៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា រាល់កន្លះខែ គឺរាល់ថ្ងៃឧបោសថ។ ពាក្យថា ភិក្ខុកំពុងសំដែងបាតិមោក្ខ សេចក្តីថា កាលភិក្ខុកំពុងសូត្របាតិមោក្ខ។ ពាក្យថា ពោលយ៉ាងនេះ សេចក្តីថា ភិក្ខុណាប្រព្រឹត្តអនាចារ ហើយប្រាថ្នាថា ភិក្ខុទាំងឡាយចូរដឹងថា យើងត្រូវអាបត្តិដោយអាការមិនដឹង កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ភិក្ខុនោះពោលយ៉ាងនេះថា ខ្ញុំទើបតែនឹងដឹងឥឡូវនេះថា ឮថាធម៌នេះមកហើយក្នុងសុត្តៈ រាប់ចូលហើយក្នុងសុត្តៈ មកកាន់ឧទ្ទេសរាល់កន្លះខែដូច្នេះ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

[៣០៩] ពាក្យថា បើ(ភិក្ខុទាំងឡាយដទៃដឹង)នូវភិក្ខុនោះ សេចក្តីថា ភិក្ខុទាំងឡាយដទៃដឹងនូវភិក្ខុអ្នកប្រាថ្នានូវសេចក្តីវង្វេងថា ភិក្ខុនេះធ្លាប់អង្គុយ(ស្តាប់)បាតិមោក្ខដែលភិក្ខុសំដែងអស់វារៈពីរបីដងហើយ នឹងពោលទៅថ្វីទៀតដល់ការស្តាប់ច្រើនដង សេចក្តីរួច (ចាកអាបត្តិ) ដោយអាការដែលមិនដឹង មិនមានដល់ភិក្ខុនោះទេ ភិក្ខុនោះត្រូវអាបត្តិណាក្នុងរឿងអនាចារនោះ សង្ឃគប្បីញ៉ាំងភិក្ខុនោះឲ្យធ្វើនូវអាបត្តិនោះ ដោយគួរតាមធម៌ ម្យ៉ាងទៀត គប្បីលើកសេចក្តីវង្វេង គឺមោហារោបនកម្មដល់ភិក្ខុនោះថែមទៀត។ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីលើកមោហារោបនកម្ម

ឡើងយ៉ាងនេះ។ ភិក្ខុដែលជាអ្នកឈ្លាស អង់អាច គប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ មិនបានធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ដ៏ល្អឡើយ។ បើមោហារោបនកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីលើកមោហារោបនកម្មដល់ភិក្ខុឈ្មោះនេះ។ នេះជាវាចាប្រកាសឲ្យសង្ឃដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនេះឈ្មោះនេះ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ មិនបានធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ដ៏ល្អទេ។ ឥឡូវនេះ សង្ឃលើកនូវមោហារោបនកម្មដល់ភិក្ខុឈ្មោះនេះ។ ការលើកមោហារោបនកម្មដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ មោហារោបនកម្ម សង្ឃបានលើកឡើងហើយដល់ភិក្ខុឈ្មោះនេះ។ ការលើកមោហារោបនកម្មនេះ សមគួរដល់សង្ឃ ហេតុនោះសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវមោហារោបនកម្មនេះ ដោយការស្ងៀមនៅយ៉ាងនេះ។

[៣១០] កាលមោហារោបនកម្ម សង្ឃមិនទាន់លើកឡើងទេ បើភិក្ខុក្លែងធ្វើវង្វេង ត្រូវអាបត្តិទុក្កដ។ កាលមោហារោបនកម្ម សង្ឃលើកឡើងហើយ ភិក្ខុនៅក្លែងធ្វើវង្វេងទៀត ត្រូវអាបត្តិបាចិត្តិយ។

[៣១១] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ហើយក្លែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយក្លែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយក្លែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ហើយ(ក្លែងធ្វើវង្វេង) ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៣១២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុមិនទាន់បានស្តាប់បាតិមោក្ខដោយពិស្តារ១ ភិក្ខុស្តាប់បាតិមោក្ខដោយពិស្តារអស់វារៈមិនទាន់ដល់ពីរបីដង១ ភិក្ខុមិនប៉ងនឹងក្លែងធ្វើវង្វេង១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៣ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី៤ (៧៤)

CS vin.vbu.pc.74 | ភាគ ទី៤

### (៤. បហារសិក្ខាបទំ)

[៣១៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុក្រោធខឹង ហើយឲ្យប្រហារដល់ពួកសត្តរសវគ្គិយភិក្ខុ (ភិក្ខុមានពួក១៧)។ សត្តរសវគ្គិយភិក្ខុទាំងនោះនាំគ្នាស្រែកយំ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ អ្នកទាំងឡាយ ហេតុអ្វីបានជាយំ។ ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះក្រោធខឹងបានឲ្យប្រហារដល់ពួកយើង។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរក្រោធខឹង ហើយទៅប្រហារភិក្ខុទាំងឡាយសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយក្រោធខឹង ហើយនាំគ្នាប្រហារភិក្ខុទាំងឡាយ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរក្រោធខឹង ហើយនាំគ្នាប្រហារភិក្ខុទាំងឡាយទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ ក្រោធខឹង ហើយឲ្យប្រហារដល់ភិក្ខុផងគ្នា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។**

[៣១៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ដល់ភិក្ខុផងគ្នា គឺដល់ភិក្ខុដទៃ។ ពាក្យថា ក្រោធខឹង សេចក្តីថា មានចិត្តមិនត្រេកអរ មានចិត្តគុំគួន មានចិត្តរឹងត្អឹង។ ពាក្យថា ឲ្យប្រហារ គឺឲ្យប្រហារដោយកាយក្តី ដោយវត្ថុជាប់នឹងកាយក្តី ដោយវត្ថុសម្រាប់ចោលក្តី ដោយហោចទៅ សូម្បីតែដោយស្លឹកព្រលិត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។

[៣១៥] ឧបសម្បន្ន[52] ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយក្រោធខឹង ឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយក្រោធខឹង ឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា ជាអនុបសម្បន្ន[53] ហើយក្រោធខឹង ឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុក្រោធខឹង ហើយឲ្យប្រហារដល់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ (ហើយឲ្យប្រហារ) ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[៣១៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុដែលជនណាមួយបៀតបៀន ហើយមានសេចក្តីប្រាថ្នាដើម្បីនឹងឲ្យរួចខ្លួន ក៏ឲ្យប្រហារទៅវិញ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៤ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី៥ (៧៥)

## (៥. តលសត្តិកសិក្ខាបទំ)

[៣១៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ ក្រោធខឹង ហើយងាលំពែង គឺបាតដៃឡើងសំដៅពួកសត្តរសវគ្គិយភិក្ខុ (ធ្វើអាការបីដូចជានឹងវាយ) សត្តរសវគ្គិយភិក្ខុទាំងនោះទើបតែនឹងរួចអំពីប្រហារមកហើយ (មានសេចក្តីភិតភ័យ) ក៏នាំគ្នាយំ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាពួកអ្នកយំ។ ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះក្រោធខឹង ហើយងាបាតដៃឡើងដូចជាលំពែងសំដៅពួកយើង។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរក្រោធខឹង ហើយងាបាតដៃឡើងដូចជាលំពែងសំដៅភិក្ខុផងគ្នាសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយក្រោធខឹង ហើយងាបាតដៃឡើងដូចជាលំពែងសំដៅភិក្ខុទាំងឡាយ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងក្រោធខឹង ហើយងាបាតដៃឡើងដូចជាលំពែងសំដៅភិក្ខុទាំងឡាយទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយក្រោធខឹង ហើយងាឡើងនូវលំពែង គឺបាតដៃ សំដៅភិក្ខុផងគ្នា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។**

[៣១៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា សំដៅភិក្ខុផងគ្នា គឺសំដៅភិក្ខុដទៃ។ ពាក្យថា ក្រោធខឹង គឺមានចិត្តមិនត្រេកអរ មានចិត្តគុំគួន មានចិត្តរឹងត្អឹង។ ពាក្យថា ងាឡើងនូវលំពែងគឺបាតដៃ សេចក្តីថា ភិក្ខុលើកកាយក្តី លើកវត្ថុជាប់នឹងកាយក្តី ឡើងជន្ល ដោយហោចទៅ សូម្បីតែស្លឹកព្រលិត ត្រូវអាបត្តិបាចិត្តិយ។

[៣១៩] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយក្រោធខឹង ងាលំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយក្រោធខឹង ងាលំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ហើយក្រោធខឹង ងាលំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុក្រោធខឹងដល់អនុបសម្បន្ន ហើយងាលំពែងគឺបាតដៃឡើង ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[៣២០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុដែលជនណាមួយបៀតបៀន ហើយមានសេចក្តីប្រាថ្នាដើម្បីនឹងឲ្យរួចខ្លួន ក៏ងាលំពែងគឺបាតដៃឡើង១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៥ ចប់។

# (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី៦ (៧៦)



## (៦. អមូលកសិក្ខាបទំ)

[៣២១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ នាំគ្នាកំចាត់ (គឺចោទ) ភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូល។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូលសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូល ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូលទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ។**

[៣២២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ភិក្ខុផងគ្នា គឺភិក្ខុដទៃ។ ដែលហៅថា មិនមានមូល គឺអាបត្តិសង្ឃាទិសេសដែលខ្លួនមិនបានឃើញ មិនបានឮ មិនបានរង្កៀស។ ពាក្យថា ដោយអាបត្តិសង្ឃាទិសេស គឺបណ្តាសង្ឃាទិសេសទាំង១៣សិក្ខាបទ សិក្ខាបទណាមួយ។ ពាក្យថា ចោទ សេចក្តីថា ភិក្ខុចោទឯងក្តី ប្រើគេឲ្យចោទក្តី ត្រូវអាបត្តិបាចិត្តិយ។

[៣២៣] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយចោទដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយចោទដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ហើយចោទដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុចោទដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុចោទអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន (ហើយចោទ) ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[៣២៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុមានសេចក្តីសំគាល់ពិតមែន ហើយចោទឯងក្តី ប្រើគេឲ្យចោទក្តី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៦ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី៧ (៧៧)

CS vin.vbu.pc.77 | ភាគ ទី៤

### (៧. សញ្ចិច្ចសិក្ខាបទំ)

[៣២៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ ក្លែងបង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យកើតដល់ពួកសត្តរសវគ្គិយភិក្ខុថា ម្នាលអាវុសោ សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តទុកហើយថា បុគ្គលមានឆ្នាំថយពី២០ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ ចំណែកពួកលោក មានអាយុមិនទាន់ដល់២០ឆ្នាំ មកទទួលឧបសម្បទា ពួកលោក មិនមែនជាឧបសមប្បន្នទេដឹង។ សត្តរសវគ្គិយភិក្ខុទាំងនោះក៏នាំគ្នាយំ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ ពួកលោកយំ ព្រោះអ្វី។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា អាវុសោ ឆព្វគ្គិយភិក្ខុទាំងនេះ ក្លែងបង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យដល់ពួកយើង។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងបង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យ ដល់ភិក្ខុទាំងឡាយផងគ្នាសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកឯងក្លែងបង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យ ដល់ភិក្ខុទាំងឡាយផងគ្នា ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងក្លែងបង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យ ដល់ភិក្ខុទាំងឡាយផងគ្នាទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

***ភិក្ខុណាមួយក្លែងបង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យ ដល់ភិក្ខុផងគ្នាដោយគិតថា (សេចក្តីរង្កៀសសង្ស័យនេះ)កើតឡើង ការមិនសប្បាយចិត្តនឹងមានដល់ភិក្ខុនោះ១រំពេចមិនខាន ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើសេចក្តីរង្កៀសសង្ស័យនោះឯងជាហេតុពិត មិនមែនហេតុដទៃឡើយ។***

[៣២៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ដល់ភិក្ខុផងគ្នា គឺដល់ភិក្ខុដទៃ។ ពាក្យថា ក្លែង សេចក្តីថា ភិក្ខុដឹងគឺដឹងជាក់ ក្លែងល្មើសប្រព្រឹត្តកន្លង។ ពាក្យថា បង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យ សេចក្តីថា ភិក្ខុណាបង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យថា លោកទំនងជាមានឆ្នាំមិនទាន់គ្រប់២០ ហើយឧបសម្បទាទេដឹង លោកបរិភោគអាហារក្នុងវេលាវិកាលទេដឹង លោកផឹកទឹកស្រវឹងទេដឹង លោកអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមទេដឹង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ព្រោះធ្វើសេចក្តីរង្កៀសសង្ស័យនោះឯងជាហេតុពិត មិនមែនហេតុដទៃឡើយ សេចក្តីថា ហេតុណាមួយដទៃគ្មាន ចំពោះត្រង់បង្កហេតុឲ្យមានសេចក្តីរង្កៀសសង្ស័យកើតឡើងប៉ុណ្ណោះឯង។

[៣២៧] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយក្លែងផ្តើមសេចក្តីរង្កៀសសង្ស័យឲ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយក្លែងផ្តើមសេចក្តីរង្កៀសសង្ស័យឲ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ហើយក្លែងផ្តើមសេចក្តីរង្កៀសសង្ស័យឲ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុក្លែងផ្តើមសេចក្តីរង្កៀសសង្ស័យឲ្យកើតឡើងដល់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[៣២៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុមិនមានបំណងនឹងផ្តើមសេចក្តីរង្កៀសសង្ស័យឲ្យកើតឡើង តែពោល (តាមសេចក្តីយល់)ថា លោកប្រហែលមានឆ្នាំមិនទាន់ដល់២០ ហើយឧបសម្បទាទេដឹង លោកបរិភោគអាហារក្នុងវេលាវិកាលទេដឹង លោកផឹកទឹកស្រវឹងទេដឹង លោកអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមទេដឹង ណ្ហើយចុះ លោកចូរដឹងចុះ លោកកុំរង្កៀសសង្ស័យស្តាយក្រោយឡើយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៧ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី៨ (៧៨)

CS vin.vbu.pc.78 | ភាគ ទី៤

### (៨. ឧបស្សុតិសិក្ខាបទំ)

[៣២៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ ឈ្លោះនឹងភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់។ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ និយាយគ្នាយ៉ាងនេះថា ម្នាលអាវុសោ ឆព្វគ្គិយភិក្ខុទាំងនេះជាពួកអលជ្ជីទេ ពួកយើងមិនអាចឈ្លោះនឹងពួកនេះទេ។ ពួកឆព្វគ្គិយភិក្ខុ(បានឮ) ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រោះហេតុអ្វី អ្នកទាំងឡាយញុំាងពួកយើងឲ្យដល់ដោយពាក្យថាអលជ្ជី។ ពួកភិក្ខុមានសីលជាទីស្រឡាញ់សួរថា ម្នាលអាវុសោ ចុះពួកអ្នកបានឮក្នុងទីណា។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា យើងទាំងឡាយឈរអែបស្ដាប់ពួកលោកដ៏មានអាយុ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ កាលភិក្ខុទាំងឡាយបង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា មិនគួរនឹងឈរអែបស្ដាប់សោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា កាលភិក្ខុទាំងឡាយបង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ពួកអ្នកឯងឈរអែបស្ដាប់ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ កាលភិក្ខុទាំងឡាយបង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ពួកអ្នកឯងមិនគួរនឹងឈរអែបស្ដាប់ទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយកាលបើភិក្ខុទាំងឡាយ បង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ទៅឈរអែបស្ដាប់ ដោយគិតថា ភិក្ខុទាំងនេះនឹងពោលពាក្យណា អញនឹងស្ដាប់ពាក្យនោះ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើកិរិយាឈរអែបស្ដាប់នោះជាហេតុពិត មិនមែនហេតុដទៃឡើយ។**

[៣៣០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា កាលបើភិក្ខុទាំងឡាយ គឺកាលបើភិក្ខុទាំងឡាយដទៃ។ ពាក្យថា បង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា គឺភិក្ខុទាំងនោះមានអធិករណៈកើតឡើងហើយ។ ពាក្យថា ឈរអែបស្ដាប់ គឺភិក្ខុដើរទៅដោយគិតថា អញស្ដាប់ភិក្ខុទាំងនេះហើយ នឹងចោទ នឹងឲ្យរលឹក នឹងចោទចំពោះ នឹងឲ្យរលឹកចំពោះ នឹងធ្វើឲ្យអៀនខ្មាស ត្រូវអាបត្តិទុក្កដ។ ភិក្ខុនោះឈរស្ដាប់ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ក្នុងទីនោះ។ ភិក្ខុដើរទៅតាមក្រោយ បើដើរទៅដោយរហ័សដោយគិតថា អញនឹងស្ដាប់ ត្រូវអាបត្តិទុក្កដ។ ភិក្ខុឈរស្ដាប់ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយក្នុងទីនោះ។ ភិក្ខុដើរទៅមុន ហើយឈប់ ដោយគិតថា អញនឹងស្ដាប់ ត្រូវអាបត្តិទុក្កដ។ ភិក្ខុឈរស្ដាប់ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយក្នុងទីនោះ។ ភិក្ខុណាមកកាន់ទីឈរក្ដី ទីអង្គុយក្ដី ទីដេកក្ដី របស់ភិក្ខុផងគ្នា ភិក្ខុនោះគប្បីក្អកគប្បីញុំាងភិក្ខុដែលកំពុងប្រឹក្សាគ្នានោះឲ្យដឹង។ បើភិក្ខុនោះមិនក្អកក្រហែមក្ដី មិនឲ្យគេដឹងក្ដី ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ព្រោះធ្វើកិរិយាឈរអែបស្ដាប់នោះជាហេតុពិត មិនមែនហេតុដទៃឡើយ សេចក្ដីថា ហេតុឯណានីមួយដទៃគ្មានទេ ចំពោះត្រង់ការឈរអែបស្ដាប់ប៉ុណ្ណោះឯង។

[៣៣១] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយឈរអែបស្ដាប់ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ហើយឈរអែបស្ដាប់ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ហើយឈរអែបស្ដាប់ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុឈរអែបស្ដាប់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្នដដែល ត្រូវអាបត្តិទុក្កដ។

[៣៣២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុដើរទៅ ដោយគិតថា អញនឹងស្ដាប់ភិក្ខុទាំងនេះហើយ នឹងថយចេញ នឹងវៀរ នឹងរម្ងាប់ (សេចក្ដីប្រកួតប្រកាន់) នឹងដោះខ្លួន១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៨ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី៩ (៧៩)

CS vin.vbu.pc.79 | ភាគ ទី៤

### (៩. កម្មបដិពាហនសិក្ខាបទំ)

[៣៣៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុបានប្រព្រឹត្តអនាចារ កាលសង្ឃធ្វើកម្ម (ដើម្បីដាក់ទោស) ដល់ភិក្ខុមួយរូបៗ ក៏នាំគ្នានិយាយខ្ទាស់។ គ្រានោះឯង សង្ឃបានប្រជុំគ្នាដោយសង្ឃកិច្ចនីមួយ។ ទើបពួកឆព្វគ្គិយភិក្ខុ កំពុងធ្វើចីវរកម្ម បានឲ្យឆន្ទៈ (សេចក្ដីគាប់ចិត្តរបស់ខ្លួន) ដល់ភិក្ខុមួយរូប។ គ្រានោះឯង សង្ឃប្រឹក្សាគ្នាថា ម្នាលអាវុសោ ឆព្វគ្គិយភិក្ខុនេះមកតែម្នាក់ឯង បើដូច្នោះ ពួកយើងត្រូវធ្វើកម្មដល់ភិក្ខុនោះចុះ ហើយបានធ្វើកម្មដល់ភិក្ខុនោះ។ ទើបភិក្ខុនោះចូលទៅរកពួកឆព្វគ្គិយភិក្ខុ។ ពួកឆព្វគ្គិយភិក្ខុបានសួរភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ សង្ឃបានធ្វើអ្វី។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ សង្ឃបានធ្វើកម្មដល់ខ្ញុំ។ ពួកឆព្វគ្គិយភិក្ខុបាននិយាយថា ម្នាលអាវុសោ យើងទាំងឡាយបានឲ្យឆន្ទៈ ដើម្បីជាប្រយោជន៍ដល់កម្មនេះ ដោយគិតថា សង្ឃនឹងធ្វើកម្មដល់លោក ក៏ទេ បើយើងទាំងឡាយដឹងថា សង្ឃនឹងធ្វើកម្មដល់លោកសោត យើងទាំងឡាយមិនឲ្យឆន្ទៈទេ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងឲ្យឆន្ទៈដល់សង្ឃកម្មទាំងឡាយដែលប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងរាល់គ្នាឲ្យឆន្ទៈ ដើម្បីសង្ឃកម្មដែលប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងឲ្យឆន្ទៈ ដើម្បីសង្ឃកម្មដែលប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់

ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយឲ្យឆន្ទៈ ដើម្បីកម្មទាំងឡាយដែលប្រកបដោយធម៌ ហើយពោលតិះដៀលជាខាងក្រោយ (ភិក្ខុនោះ)ត្រូវអាបត្តិបាចិត្តិយ។**

[៣៣៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ កម្មដែលហៅថា ប្រកបដោយធម៌នោះ គឺ អបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១ ដែលសង្ឃធ្វើតាមធម៌ តាមវិន័យ តាមពាក្យប្រដៅរបស់ព្រះសាស្តា កម្មនេះហៅថា កម្មប្រកបដោយធម៌។ ភិក្ខុព្រមឲ្យឆន្ទៈ ហើយត្រឡប់តិះដៀល (ជាខាងក្រោយវិញ) ត្រូវអាបត្តិបាចិត្តិយ។

[៣៣៥] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយឲ្យឆន្ទៈ ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយឲ្យឆន្ទៈ ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិទុក្កដ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយឲ្យឆន្ទៈ ត្រឡប់តិះដៀល មិនត្រូវអាបត្តិអ្វី។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ (ហើយឲ្យឆន្ទៈ ត្រឡប់តិះដៀល) ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ មិនត្រូវអាបត្តិអ្វី។

[៣៣៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុដឹងថាកម្មដែលសង្ឃធ្វើដោយមិនជាធម៌ក្តី ដោយពួកក្តី ដល់ភិក្ខុអ្នកមិនគួរដល់កម្មក្តី ហើយតិះដៀល១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៩ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី១០ (៨០)

CS vin.vbu.pc.80 | ភាគ ទី៤

### (១០. ឆន្ទំអទត្វាគមនសិក្ខាបទំ)

[៣៣៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង សង្ឃបានប្រជុំគ្នាដោយសង្ឃកិច្ចឯណានីមួយ។ ពួកឆព្វគ្គិយភិក្ខុកំពុងធ្វើចីវរ ហើយបានឲ្យឆន្ទៈដល់ភិក្ខុមួយរូប។ គ្រានោះឯង សង្ឃប្រជុំគ្នាដើម្បីប្រយោជន៍ដល់កម្មណា ហើយតាំងញត្តិឡើងដោយប្រឹក្សាគ្នាថា យើងទាំងឡាយនឹងធ្វើនូវកម្មនោះ។ ខណៈនោះ ភិក្ខុនោះបាននិយាយថា ភិក្ខុទាំងនេះតែងធ្វើកម្មដល់ភិក្ខុមួយរូបៗ យ៉ាងនេះឯង (ឥឡូវ) លោកទាំងឡាយនឹងធ្វើកម្មដល់អ្នកណាបាន ហើយមិនឲ្យឆន្ទៈ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា កាលសង្ឃកំពុងប្រឹក្សាវិនិច្ឆ័យ ភិក្ខុមិនបានឲ្យឆន្ទៈ មិនគួរនឹងក្រោកចាកអាសនៈ ចៀសចេញទៅសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថា កាលសង្ឃកំពុងប្រឹក្សាវិនិច្ឆ័យ (គឺសង្ឃកំពុងវិនិច្ឆ័យរឿងអ្វីមួយមិនទាន់ហើយ) អ្នកឯងមិនបានឲ្យឆន្ទៈ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស កាលសង្ឃកំពុងប្រឹក្សាវិនិច្ឆ័យ ហេតុអ្វីក៏អ្នកឯងមិនឲ្យឆន្ទៈ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ កាលពាក្យវិនិច្ឆ័យកំពុងប្រព្រឹត្តទៅក្នុងសង្ឃ មិនឲ្យឆន្ទៈ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។**

[៣៣៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ រឿងដែលសង្ឃប្រាប់ហើយ តែមិនទាន់បានវិនិច្ឆ័យក្តី ញត្តិសង្ឃតាំងទុកហើយក្តី កម្មវាចាសង្ឃធ្វើមិនទាន់ហើយក្តី ឈ្មោះថាពាក្យវិនិច្ឆ័យ (កំពុងប្រព្រឹត្តទៅ)ក្នុងសង្ឃ។ ពាក្យថា ភិក្ខុមិនឲ្យឆន្ទៈ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ សេចក្តីថា ភិក្ខុចេញទៅដោយគិតថា មិនដឹងជាការអ្វី កម្មនេះជាកម្មកំរើកទេ ជាពួកទេ សង្ឃមិនត្រូវធ្វើទេ ត្រូវអាបត្តិទុក្កដ។ កាលភិក្ខុកំពុងលះហត្ថបាសបរិសទ្យ ត្រូវអាបត្តិទុក្កដ។ កាលលះហត្ថបាសហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣៣៩] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយមិនឲ្យឆន្ទៈ ក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយមិនឲ្យឆន្ទៈ ក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិទុក្កដ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយមិនឲ្យឆន្ទៈ ក្រោកចាកអាសនៈចៀសចេញទៅ មិនត្រូវអាបត្តិ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ (ហើយមិនឲ្យឆន្ទៈ ក្រោកចាកអាសនៈចៀសចេញទៅ) ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ មិនត្រូវអាបត្តិ។

[៣៤០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុទៅ ដោយគិតថា សេចក្ដីបង្កហេតុក្ដី សេចក្ដីប្រកួតប្រកាន់ក្ដី សេចក្ដីប្រកាន់ខុសគ្នាក្ដី សេចក្ដីទាស់ទែងក្ដី នឹងមានដល់សង្ឃ១ ភិក្ខុទៅដោយគិតថា ការបែកធ្លាយនៃសង្ឃក្ដី ការប្រេះឆានៃសង្ឃក្ដី នឹងមាន១ ភិក្ខុទៅដោយគិតថា សង្ឃនឹងធ្វើកម្មមិនប្រកបដោយធម៌ក្ដី នឹងធ្វើកម្មជាពួកក្ដី នឹងធ្វើកម្មដល់ភិក្ខុដែលមិនគួរដល់កម្មក្ដី១ ភិក្ខុមានជម្ងឺចៀសចេញទៅ១ ភិក្ខុទៅដោយកិច្ចដែលគួរធ្វើដល់ភិក្ខុឈឺ១ ភិក្ខុដែលឧច្ចារៈក្ដី បស្សាវៈក្ដីបៀតបៀនហើយទៅ១ ភិក្ខុមិនប្រាថ្នាដើម្បីនឹងញ៉ាំងកម្មឲ្យកម្រើក ហើយចេញទៅដោយគិតថា អញនឹងត្រឡប់មកវិញទៀត១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១០ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី១១ (៨១)

CS vin.vbu.pc.81 | ភាគ ទី៤

### (១១. ទុព្ពលសិក្ខាបទំ)

[៣៤១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ គ្រានោះឯង ទព្វមល្លបុត្រដ៏មានអាយុ ចាត់ចែងសេនាសនៈ និងសំដែងភត្តដល់សង្ឃ។ ទព្វមល្លបុត្រដ៏មានអាយុនោះជាអ្នកមានចីវរទុព្វលភាព។ សម័យនោះឯង ចីវរ១បានកើតឡើងដល់សង្ឃ។ សង្ឃឲ្យចីវរនោះដល់ទព្វមល្លបុត្រដ៏មានអាយុ។ ពួកឆព្វគ្គិយភិក្ខុនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយបង្អោនលាភរបស់សង្ឃទៅតាមសេចក្ដីគាប់ចិត្ត។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា កាលបើសង្ឃព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយ ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងមកតិះដៀលជាខាងក្រោយសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាសង្ឃព្រមព្រៀងគ្នាឲ្យចីវរ(ដល់ភិក្ខុ)ហើយ អ្នកទាំងឡាយត្រឡប់មកតិះដៀលជាខាងក្រោយវិញពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ (កាលបើ) សង្ឃព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយ មិនគួរនឹងពួកអ្នកឯងតិះដៀលជាខាងក្រោយវិញទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ***ភិក្ខុណាមួយ (កាលបើ)សង្ឃព្រមព្រៀងគ្នាឲ្យចីវរ(ដល់ភិក្ខុ)ហើយ ក៏ដល់នូវធម៌ គឺកិរិយាតិះដៀលជាខាងក្រោយវិញថា ភិក្ខុទាំងឡាយបង្អោនលាភរបស់សង្ឃ តាមសេចក្ដីគាប់ចិត្ត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។***

[៣៤២] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ សង្ឃមានសំវាសស្មើគ្នា ឋិតនៅក្នុងសីមាស្មើគ្នា ហៅថា ព្រមព្រៀងគ្នា។ ដែលហៅថា ចីវរ គឺបណ្ដាចីវរ៦យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមសម្រេចកិច្ចវិកប្បបាន[54] ពាក្យថា ឲ្យ គឺឲ្យដោយខ្លួនឯង។ ដែលហៅថា តាមសេចក្ដីគាប់ចិត្តនោះ គឺតាមបុគ្គលដែលជាមិត្ត តាមបុគ្គលដែលធ្លាប់ស្គាល់គ្នា តាមបុគ្គលដែលធ្លាប់គប់គ្នា តាមបុគ្គលដែលមានឧបជ្ឈាយ៍ស្មើគ្នា តាមបុគ្គលដែលមានអាចារ្យស្មើគ្នា។ ដែលហៅថា របស់សង្ឃនោះ បានខាងលាភដែលគេលះបង់ប្រគេនដល់សង្ឃ។ ដែលហៅថា លាភនោះ បានខាងចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ដោយហោចទៅ សូម្បីតែដុំលំអិតក្ដី ឈើស្ទន់ក្ដី អម្បោះរងជើងក្ដី (ក៏ហៅថាលាភ)។ ពាក្យថា ដល់នូវធម៌ គឺកិរិយាតិះដៀល ជាខាងក្រោយ សេចក្ដីថា ភិក្ខុតិះដៀលសង្ឃដែលបានឲ្យចីវរដល់ឧបសម្បន្នដែលសង្ឃសន្មតឲ្យជាអ្នកក្រាលនូវសេនាសនៈក្ដី ជាអ្នកសំដែងនូវភត្តក្ដី ជាអ្នកចែកនូវបបរក្ដី ជាអ្នកចែកនូវផ្លែឈើក្ដី ជាអ្នកចែកនូវបង្អែមក្ដី ជាអ្នកចាត់ចែងនូវវត្ថុបន្តិចបន្តួចក្ដី ត្រូវអាបត្តិបាចិត្តិយ។

[៣៤៣] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយតិះដៀលសង្ឃដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្ដីសង្ស័យ ហើយតិះដៀលសង្ឃដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយតិះដៀលសង្ឃដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុតិះដៀលសង្ឃដែលបានឲ្យបរិក្ខារដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុតិះដៀលសង្ឃដែលបានឲ្យចីវរ ឬបរិក្ខារដទៃដល់ឧបសម្បន្នដែលសង្ឃមិនបានសន្មតឲ្យជាអ្នកក្រាលនូវសេនាសនៈក្ដី ជាអ្នកសំដែងនូវភត្តក្ដី ជាអ្នកចែកនូវបបរក្ដី ជាអ្នកចែកនូវផ្លែឈើក្ដី ជាអ្នកចែកនូវបង្អែមក្ដី ជាអ្នកចាត់ចែងនូវវត្ថុបន្តិចបន្តួចក្ដី ត្រូវអាបត្តិទុក្កដ។ ភិក្ខុតិះដៀលសង្ឃដែលបានឲ្យចីវរ ឬបរិក្ខារដទៃដល់អនុបសម្បន្នដែលសង្ឃសន្មត ឬមិនបានសន្មត ឲ្យជាអ្នកក្រាលនូវសេនាសនៈក្ដី ជាអ្នកសំដែងនូវភត្តក្ដី ជាអ្នកចែកនូវបបរក្ដី ជាអ្នកចែកនូវផ្លែឈើក្ដី ជាអ្នកចែកនូវបង្អែមក្ដី ជាអ្នកចាត់ចែងនូវវត្ថុបន្តិចបន្តួចក្ដី ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ មិនត្រូវអាបត្តិ។

[៣៤៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុតិះដៀលសង្ឃអ្នកធ្វើ ព្រោះឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ ដោយប្រក្រតីថា ប្រយោជន៍អ្វីដោយលាភដែលសង្ឃឲ្យដល់ភិក្ខុនោះ ភិក្ខុនោះទុកជាបានហើយ ក៏គង់ធ្វើលាភនោះឲ្យវិនាសទៅដដែល នឹងមិនបាននាំយកទៅដោយប្រពៃទេ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១១ ចប់។

## (បាចិត្តិយ សហធម្មិកវគ្គ) សិក្ខាបទ ទី១២ (៨២)

CS vin.vbu.pc.82 | ភាគ ទី៤

(១២. បរិណាមនសិក្ខាបទំ)

[៣៤៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ប្រជុំជនពួកមួយក្នុងក្រុងសាវត្ថី នាំគ្នាតាក់តែងចង្ហាន់ ព្រមទាំងចីវរទុកដើម្បីថ្វាយសង្ឃ ដោយគិតគ្នាថា យើងទាំងឡាយនឹងនិមន្តឲ្យលោកឆាន់ ហើយនឹងប្រគេនចីវរ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុចូលទៅកាន់ទីប្រជុំជននោះ លុះចូលទៅហើយ បាននិយាយពាក្យនេះនឹងប្រជុំជននោះថា ម្នាលអាវុសោ ពួកអ្នកចូរឲ្យចីវរទាំងនេះដល់ភិក្ខុទាំងឡាយនេះ។ ពួកជនទាំងឡាយនោះបាននិយាយតបវិញថា ព្រះករុណា ពួកខ្ញុំមិនថ្វាយទេ ពួកខ្ញុំធ្លាប់តាក់តែងចង្ហាន់ ព្រមទាំងចីវរទុកដើម្បីថ្វាយសង្ឃរាល់ៗឆ្នាំ។ ពួកឆព្វគ្គិយភិក្ខុនិយាយលួងលោមថា ម្នាលអាវុសោ ទាយករបស់សង្ឃមានច្រើន ភត្តរបស់សង្ឃក៏មានច្រើន ភិក្ខុអម្បាលនេះបានអាស្រ័យលើអ្នកទាំងឡាយ បានជួបប្រសព្វអ្នកទាំងឡាយ ទើបមកគង់នៅក្នុងទីនេះបាន បើអ្នកទាំងឡាយមិនប្រគេនដល់លោកទាំងនេះ ចុះអ្នកណា តើគេនឹងប្រគេនដល់លោកទាំងនេះបាន ម្នាលអាវុសោ ចូរអ្នកទាំងឡាយឲ្យនូវចីវរទាំងឡាយនេះដល់ភិក្ខុអម្បាលនេះចុះ។ ប្រជុំជននោះ កាលត្រូវពួកឆព្វគ្គិយភិក្ខុទ្ទឹះឆ្លៀល ទើបថ្វាយចីវរដែលខ្លួនតាក់តែងទុក ដល់ពួកឆព្វគ្គិយភិក្ខុអស់ទៅ ហើយអង្គាសសង្ឃតែភត្តប៉ុណ្ណោះ។ ភិក្ខុទាំងឡាយណាដឹងថាភត្ត ព្រមទាំងចីវរដែលប្រជុំជនតាក់តែងទុកដើម្បីថ្វាយសង្ឃ តែមិនដឹងថាគេថ្វាយដល់ពួកឆព្វគ្គិយភិក្ខុទៅហើយ ភិក្ខុទាំងឡាយនោះបាននិយាយយ៉ាងនេះ(នឹងប្រជុំជននោះ)ថា ម្នាលអាវុសោ អ្នកទាំងឡាយចូរបង្អោនថ្វាយចីវរដល់សង្ឃចុះ។ ប្រជុំជននោះបាននិយាយប្រាប់ថា បពិត្រព្រះករុណា ចីវរដែលតាក់តែងទុកនោះគ្មានទេ លោកម្ចាស់ឆព្វគ្គិយទាំងឡាយបង្អោនទៅដើម្បីពួកលោកម្ចាស់ឆព្វគ្គិយអស់ទៅហើយ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ កាលបើដឹងថា លាភរបស់សង្ឃគេបង្អោន(ដើម្បីសង្ឃ)ទៅហើយ មិនគួរនឹងបង្អោនទៅដើម្បីបុគ្គលសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយកាលបើដឹងថា លាភរបស់សង្ឃដែលគេបង្អោនទៅដើម្បីសង្ឃហើយ ត្រឡប់បង្អោនទៅដើម្បីបុគ្គលវិញ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ កាលបើដឹងថា លាភរបស់សង្ឃ គេបង្អោនទៅ(ដើម្បីសង្ឃហើយ) ហេតុអ្វីបានជាបង្អោនទៅដើម្បីបុគ្គលវិញ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយដឹងថាលាភរបស់សង្ឃ គេបង្អោនទៅ (ដើម្បីសង្ឃហើយ) ត្រឡប់បង្អោនទៅដើម្បីបុគ្គលវិញ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ។**

[៣៤៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថាដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្ដី ពួកអ្នកដទៃប្រាប់ភិក្ខុនោះក្ដី អ្នកម្ចាស់ទាននោះប្រាប់ (ដល់ភិក្ខុនោះ)ក្ដី។ ដែលហៅថា របស់សង្ឃ គឺលាភដែលទាយកបានថ្វាយ បានបរិច្ចាគដល់សង្ឃ។ ដែលហៅថាលាភនោះ បានដល់ចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្សឈឺ ដោយហោចទៅ សូម្បីតែដុំនៃលំអិតក្ដី ឈើស្ទន់ក្ដី អម្បោះរងជើងដម្បាញក្ដី (ក៏ហៅថាលាភក្នុងសិក្ខាបទនេះ)។ ដែលហៅថា គេបង្អោនទៅ គឺម្ចាស់របស់ គេបញ្ចេញវាចាថា ពួកខ្ញុំនឹងថ្វាយ ពួកខ្ញុំនឹងធ្វើ។ ភិក្ខុបង្អោនទៅដើម្បីបុគ្គលវិញ ត្រូវអាបត្តិបាចិត្តិយ។

[៣៤៧] លាភគេបង្អោនទៅហើយ ភិក្ខុសំគាល់ថាគេបង្អោនទៅហើយ ត្រឡប់បង្អោនមកដើម្បីបុគ្គលវិញ ត្រូវអាបត្តិបាចិត្តិយ។ លាភគេបង្អោនទៅហើយ ភិក្ខុមានសេចក្ដីសង្ស័យ ហើយបង្អោនមកដើម្បីបុគ្គលវិញ ត្រូវអាបត្តិទុក្កដ។ លាភគេបង្អោនទៅហើយ ភិក្ខុសំគាល់ថា គេមិនទាន់បង្អោនទៅទេ ហើយបង្អោនមកដើម្បីបុគ្គល មិនត្រូវអាបត្តិអ្វីឡើយ។ លាភគេបង្អោនទៅដើម្បីសង្ឃ តែភិក្ខុបង្អោនមកដើម្បីសង្ឃដទៃវិញក្ដី ដើម្បីចេតិយក្ដី ត្រូវអាបត្តិទុក្កដ។ លាភគេបង្អោនទៅហើយដើម្បីចេតិយ ភិក្ខុបង្អោនមកដើម្បីចេតិយដទៃវិញក្ដី ដើម្បីសង្ឃក្ដី ដើម្បីបុគ្គលក្ដី ត្រូវអាបត្តិទុក្កដ។ លាភគេបង្អោនទៅដើម្បីបុគ្គលហើយ ភិក្ខុត្រឡប់បង្អោនមកដើម្បីបុគ្គលដទៃវិញក្ដី ដើម្បីសង្ឃក្ដី ដើម្បីចេតិយក្ដី ត្រូវអាបត្តិទុក្កដ។ លាភគេមិនទាន់បង្អោនទៅទេ ភិក្ខុសំគាល់ថា គេបង្អោនទៅហើយ ត្រូវអាបត្តិទុក្កដ។ លាភគេមិនទាន់បង្អោនទៅទេ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ លាភគេមិនទាន់បង្អោនទៅទេ ភិក្ខុសំគាល់ថា គេមិនទាន់បង្អោនទេ មិនត្រូវអាបត្តិ។

[៣៤៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺកាលបើទាយកសួរថា ពួកខ្ញុំនឹងថ្វាយក្នុងទីណា ភិក្ខុប្រាប់ថា ទេយ្យធម៌របស់អ្នកទាំងឡាយ គប្បីបានបរិភោគក្ដី គប្បីបានការជួសជុលក្ដី គប្បីឋិតនៅយូរអង្វែងក្ដី ក្នុងទីណា ម្យ៉ាងទៀត ចិត្តរបស់អ្នកទាំងឡាយជ្រះថ្លាក្នុងទីណា អ្នកទាំងឡាយចូរថ្វាយក្នុងទីនោះចុះ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១២ ចប់។

សហធម្មិកវគ្គ ទី ៨ ចប់។

ឧទ្ទាននៃសហធម្មិកវគ្គនោះ (មាន១២សិក្ខាបទ) គឺ

សហធម្មិកសិក្ខាបទ១ វិវណ្ណនសិក្ខាបទ១ មោហាបនសិក្ខាបទ១ បហារកសិក្ខាបទ១ តលសត្តិកសិក្ខាបទ១ អមូលកសិក្ខាបទ១ សញ្ចិច្ចសិក្ខាបទ១ ឧបស្សុតិសិក្ខាបទ១ បដិពាហនសិក្ខាបទ១ ឆន្ទសិក្ខាបទ១ ទព្វសិក្ខាបទ១ បរិណាមនសិក្ខាបទ១។

# រតនវគ្គ (ទី៩)

### (៩. រតនវគ្គោ)

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី១ (៨៣)



### (១. អន្តេបុរសិក្ខាបទំ)

[៣៤៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ស្តេចព្រះនាមបសេនទិកោសល បានត្រាស់បង្គាប់នាយឧយ្យានបាល (អ្នករក្សាឧទ្យាន)ថា ម្នាលនាយ ឯងចូរទៅជម្រះសំអាតឧទ្យាន យើងនឹងទៅឧទ្យាន។ នាយឧយ្យានបាលនោះបានទទួលព្រះឱង្ការរបស់ព្រះបាទបសេនទិកោសលថា បពិត្រព្រះសម្មតិទេព យ៉ាងហ្នឹងហើយ ៗ ក៏ជម្រះឧទ្យាន ទទួលបានឃើញព្រះដ៏មានព្រះភាគគង់នៅក្រោមម្លប់ឈើមួយ លុះឃើញហើយ ក៏ចូលទៅគាល់ព្រះបាទបសេនទិកោសល លុះចូលទៅដល់ហើយ បានក្រាបទូលព្រះបាទបសេនទិកោសលយ៉ាងនេះថា សូមទ្រង់មេត្តាប្រោស ឧទ្យានរៀបចំស្អាតហើយ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ក៏គង់ក្នុងទីនោះដែរ។ ព្រះបាទបសេនទិកោសល ទ្រង់មានបន្ទូលថា ម្នាលនាយ បើដូច្នោះ យើងនឹងទៅគាល់ព្រះដ៏មានព្រះភាគ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់យាងទៅកាន់ឧទ្យាន ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគជាម្ចាស់។ វេលានោះឯង មានឧបាសកម្នាក់កំពុងអង្គុយគាល់ជិតព្រះដ៏មានព្រះភាគ។ ទើបព្រះបាទបសេនទិកោសលទ្រង់ទតឃើញឧបាសកនោះកំពុងអង្គុយគាល់ជិតព្រះដ៏មានព្រះភាគ លុះទតច្បាស់ហើយ ទ្រង់មានសេចក្តីភិតភ័យ ហើយក៏ទ្រង់ឋិតនៅ (បង្អង់ឈរសិន)។ លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រិះរិះយ៉ាងនេះថា បុរសនេះមិនមែនជាមនុស្សអាក្រក់ទេ បានជាអង្គុយគាល់ជិតព្រះដ៏មានព្រះភាគ។ ឯព្រះបាទបសេនទិកោសល ស្តេចក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគដែរ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ។ ចំណែកឧបាសកនោះមិនបានថ្វាយបង្គំ មិនក្រោកទទួលព្រះបាទបសេនទិកោសលឡើយ ព្រោះគោរពដល់ព្រះដ៏មានព្រះភាគ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់តូចព្រះទ័យថា បុរសនេះ កាលបើអញមកហើយ មិនគួរនឹងមិនថ្វាយបង្គំ មិនក្រោកទទួល(អញ)សោះ។ ខណៈនោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ព្រះបាទបសេនទិកោសល ស្តេចមានព្រះទ័យអាក់អន់ហើយ ទើបទ្រង់ត្រាស់នឹងព្រះបាទបសេនទិកោសលយ៉ាងនេះថា បពិត្រមហារាជ ឧបាសកនេះឯងជាពហុស្សូត ជាអ្នកស្ទាត់ក្នុងបិដក មានរាគៈក្នុងកាមទាំងឡាយទៅប្រាសអស់ហើយ។ ព្រះបាទបសេនទិកោសល ទ្រង់ត្រិះរិះយ៉ាងនេះថា ឧបាសកនេះមិនមែនជាមនុស្សថោកទាបទេ សូម្បីព្រះដ៏មានព្រះភាគ ក៏ទ្រង់សរសើរគេដែរ។ ព្រះបាទបសេនទិកោសល ទ្រង់មានព្រះឱង្ការចំពោះនឹងឧបាសកនោះយ៉ាងនេះថា ម្នាលឧបាសក អ្នកត្រូវការដោយរបស់ណា គប្បីប្រាប់ដល់យើងចុះ។ ឧបាសកនោះទូលថា បពិត្រព្រះសម្មតិទេព ប្រពៃហើយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ស្តេចបសេនទិកោសល ឲ្យឃើញ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថា។ ព្រះបាទបសេនទិកោសល លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថាហើយ ស្តេចក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយទ្រង់ធ្វើប្រទក្សិណចៀសចេញទៅ។

[៣៥០] គ្រានោះឯង ព្រះបាទបសេនទិកោសល ស្តេចគង់ក្នុងថ្នាក់ខាងលើនៃប្រាសាទដ៏ប្រសើរ។ ព្រះបាទបសេនទិកោសលបានទតឃើញឧបាសកនោះដើរបាំងឆត្រទៅតាមថ្នល់ លុះទតឃើញហើយ ទ្រង់ឲ្យហៅមក ហើយមានព្រះឱង្ការយ៉ាងនេះថា ម្នាលឧបាសក ឮថាអ្នកឯងជាពហុស្សូត ស្ទាត់ក្នុងបិដក ម្នាលឧបាសក ល្អហើយ អ្នកចូរបង្ហាញធម៌ក្នុងផ្ទះនៃពួកស្រីរបស់យើងផង។ ឧបាសកនោះទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គដឹងធម៌ណា ព្រោះហេតុតែលោកម្ចាស់ទាំងឡាយ លោកម្ចាស់ទាំងឡាយគង់នឹងបង្ហាញធម៌នោះក្នុងផ្ទះនៃពួកស្រី (គឺពួកព្រះស្នំ) របស់ព្រះអង្គបាន។ លំដាប់នោះ ព្រះបាទបសេនទិកោសលទ្រង់ត្រិះរិះថា ឧបាសកពោលពិតមែន ទើបទ្រង់រាជដំណើរទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទ្រង់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ។ ព្រះបាទបសេនទិកោសល លុះគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ប្រើភិក្ខុមួយរូបដែលអាចនឹងបង្ហាញធម៌ក្នុងផ្ទះនៃពួកស្រីរបស់ខ្ញុំព្រះអង្គ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ព្រះបាទបសេនទិកោសលឲ្យឃើញ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថា។ ព្រះបាទបសេនទិកោលស លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរបង្ហាញធម៌ក្នុងផ្ទះនៃពួកស្រីរបស់ស្តេច។ ព្រះអានន្ទដ៏មានអាយុបានទទួលព្រះតម្រាស់ព្រះដ៏មានព្រះភាគថា សូមទ្រង់មេត្តាប្រោស យ៉ាងហ្នឹងហើយ ៗចូលទៅបង្ហាញធម៌ក្នុងផ្ទះនៃពួកស្រីរបស់ស្តេចសព្វៗវេលាតាមសមគួរ។ វេលាព្រឹក ព្រះអានន្ទដ៏មានអាយុស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ហើយចូលទៅកាន់រាជនិវេសន៍របស់ព្រះបាទបសេនទិកោសល។ វេលានោះឯង ព្រះបាទបសេនទិកោសល ស្តេចកំពុងផ្ទំជាមួយព្រះទេវីព្រះនាមមល្លិកា។ នាងមល្លិកាទេវី បានឃើញព្រះអានន្ទដ៏មានអាយុមកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រោកឡើងដោយប្រញាប់។ សំពត់មានពណ៌លឿងរលីងស្អាតក៏របូតចុះ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុត្រឡប់ចាកទីនោះមកកាន់អារាម ប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះអានន្ទដ៏មានអាយុ ស្តេចមិនទាន់ទ្រង់ជ្រាបជាមុន មិនគួរនឹងចូលទៅខាងក្នុងព្រះរាជវាំងរបស់ស្តេចសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលអានន្ទ ឮថាស្តេចមិនទាន់ជ្រាបជាមុន អ្នកឯងស្រាប់តែចូលទៅខាងក្នុងព្រះរាជវាំងរបស់ស្តេច ពិតមែនឬ។ ព្រះអានន្ទទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលអានន្ទ ស្តេចមិនទាន់ជ្រាបជាមុន អ្នកឯងមិនគួរនឹងចូលទៅខាងក្នុងព្រះរាជវាំងរបស់ស្តេចទេ ម្នាលអានន្ទ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមក ដោយព្រះពុទ្ធដីកាថា។

[៣៥១] ម្នាលភិក្ខុទាំងឡាយ ទោសទាំង១០យ៉ាងនេះរមែងមានក្នុងកិរិយាចូលទៅខាងក្នុងបុរីរបស់ស្តេច។ ទោសទាំង១០យ៉ាងនោះ ដូចម្តេចខ្លះ។

- ម្នាលភិក្ខុទាំងឡាយ ស្តេចក្នុងលោកនេះ ទ្រង់ប្រថាប់លើក្រឡាព្រះបន្ទំជាមួយមហេសី។ ភិក្ខុចូលទៅក្នុងទីនោះ។ មហេសីបានឃើញភិក្ខុ រមែងធ្វើកិរិយាញញឹមឲ្យប្រាកដខ្លះ ភិក្ខុឃើញមហេសី រមែងធ្វើកិរិយាញញឹមឲ្យប្រាកដខ្លះ។ ស្តេចរមែងរង្កៀសក្នុងរឿងនោះយ៉ាងនេះថា ការមិនគួរអ្នកទាំងពីរនាក់នេះបានធ្វើហើយ ឬថាអ្នកទាំងពីរនេះនឹងធ្វើនូវការមិនគួរ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេចជាបឋម។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្តេចជាបុគ្គលមានកិច្ចច្រើន មានការងារគួរធ្វើច្រើន ទ្រង់យាងទៅប្រោសស្រីដទៃ ហើយក៏ភ្លេច។ ឯស្រីនោះ ក៏មានគភ៌ដោយស្តេចនោះ។ ស្តេចរមែងរង្កៀសក្នុងរឿងនោះយ៉ាងនេះថា ជននីមួយដទៃចូលទៅក្នុងទីនេះមិនបានទេ វៀរមួយតែបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីពីរ ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត រតនៈណាមួយក្នុងបុរីនៃស្តេចបាត់ទៅ។ ស្តេចរមែងរង្កៀសក្នុងរឿងនោះយ៉ាងនេះថា ជននីមួយដទៃចូលទៅក្នុងទីនេះមិនមានទេ វៀរលែងតែបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីបី ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត រឿងរ៉ាវទាំងឡាយដែលស្តេចត្រូវបិទបាំងទុកខាងក្នុង មាននៅខាងក្នុងបុរីនៃស្តេច ត្រឡប់បែកសាយទៅខាងក្រៅ។ ស្តេចរមែងទ្រង់រង្កៀសក្នុងរឿងនោះយ៉ាងនេះថា ជននីមួយដទៃចូលទៅក្នុងទីនេះមិនមានទេ វៀរលែងតែបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីបួន ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ព្រះរាជបុត្រប្រាថ្នានឹងបៀតបៀនចំពោះព្រះរាជបិតាក្នុងបុរីនៃស្តេចក្តី ព្រះរាជបិតាប្រាថ្នានឹងបៀតបៀនចំពោះព្រះរាជបុត្រក្តី។ ព្រះរាជបុត្រព្រះរាជបិតានោះរមែងទ្រង់រង្កៀសយ៉ាងនេះថា ជននីមួយដទៃចូលទៅក្នុងទីនេះមិនមានទេ វៀរលែងតែបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីប្រាំ ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្តេចទ្រង់តាំងមន្ត្រីដែលតាំងនៅក្នុងទីទាបឲ្យឡើងកាន់ទីខ្ពស់។ ការតាំងនោះមិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះរមែងរង្កៀសយ៉ាងនេះថា ស្តេចតែងច្រឡូកច្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីប្រាំមួយ ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្តេចទ្រង់បន្ថយមន្ត្រីដែលតាំងនៅក្នុងទីខ្ពស់ ឲ្យតាំងនៅក្នុងទីទាប។ ការតាំងនោះមិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះរមែងរង្កៀសយ៉ាងនេះថា ស្តេចតែងច្រឡូកច្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីប្រាំពីរ ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្តេចទ្រង់បញ្ជូនកងទ័ពទៅក្នុងកាលមិនសមគួរ។ ការបញ្ជូនកងទ័ពនោះ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះរមែងរង្កៀសយ៉ាងនេះថា ស្តេចតែងច្រឡូកច្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីប្រាំបី ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្តេចទ្រង់ឲ្យបញ្ជូនកងទ័ពទៅក្នុងកាលដ៏សមគួរ ហើយទ្រង់ឲ្យត្រឡប់វិលវិញពាក់កណ្តាលផ្លូវ។ ការត្រឡប់វិលវិញនោះ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះរមែងរង្កៀសយ៉ាងនេះថា ស្តេចតែងច្រឡូកច្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីប្រាំបួន ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។
- ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ខាងក្នុងរាជបុរីតែងជ្រួលជ្រើមទៅដោយដំរី ជ្រួលជ្រើមទៅដោយសេះ ជ្រួលជ្រើមទៅដោយរថ និងរូប សំឡេងក្លិនរស ផោដ្ឋព្វៈ ជាហេតុនៃសេចក្តីត្រេកអរ សុទ្ធតែជារបស់មិនសមគួរដល់បព្វជិត។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីដប់ ក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។

ម្នាលភិក្ខុទាំងឡាយ ទោស១០យ៉ាងនេះឯង ជាទោសក្នុងកិរិយាចូលទៅខាងក្នុងបុរីនៃស្តេច។

[៣៥២] លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសព្រះអានន្ទដ៏មានអាយុដោយបរិយាយជាច្រើន។បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយ(បើ)ស្តេចជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ មិនទាន់ជ្រាបជាមុន ឈានកន្លងធរណីចូលទៅក្នុងក្រឡាព្រះបន្ទំដែលស្តេចមិនទាន់យាងចេញ ស្រីកែវក៏មិនទាន់ចេញ ត្រូវអាបត្តិបាចិត្តិយ។**

[៣៥៣] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថាក្សត្រិយ៍នោះ បានដល់ជនអ្នកមានជាតិល្អទាំងសងខាង គឺខាងមាតានិងខាងបិតា ជាអ្នកកាន់យកជាតិដ៏បរិសុទ្ធល្អ ដរាបអំពីគូនៃជីដូនជីតាគំរប់៧ គេមិនបានបោះបង់ចោល មិនបានតិះដៀលដោយជាតិ។ ដែលហៅថា បានមុទ្ធាភិសេកហើយ គឺស្តេចដែលគេបានអភិសេក ដោយអភិសេកឲ្យជាក្សត្រិយ៍។ ពាក្យថា ស្តេចមិនទាន់យាងចេញ គឺស្តេចមមិនទាន់ចេញអំពីក្រឡាព្រះបន្ទំ។ ពាក្យថា ស្រីកែវមិនទាន់ចេញ គឺមហេសី មិនទាន់ចេញអំពីក្រឡាព្រះបន្ទំ ឬមួយស្តេចនិងមហេសីទាំងពីរ មិនទាន់ចេញអំពីក្រឡាព្រះបន្ទំ។ ពាក្យថា មិនទាន់ទ្រង់ជ្រាបជាមុន គឺស្តេចមិនទាន់បាននិមន្តជាមុន។ ដែលហៅថា ធរណី គឺសំដៅយកធរណីនៃក្រឡាព្រះបន្ទំ (បានដល់ក្រុបទ្វារខាងក្រោម)។ ទីក្រឡាព្រះបន្ទំរបស់ស្តេចដែលគេតែងតាំងទុក ក្នុងទីណាមួយ ដោយហោចទៅសូម្បីតែទីដែលគេបិទបាំងព័ន្ធព័ទ្ធដោយរនាំង ក៏ហៅថាក្រឡាព្រះបន្ទំទាំងអស់។ ពាក្យថា ឈានកន្លងធរណីចូលទៅ សេចក្តីថា ភិក្ខុឈានជំហានទី១ឲ្យកន្លងធរណីចូលទៅ ត្រូវអាបត្តិទុក្កដ។ ឈានជំហានទី២ចូលទៅ ត្រូវអាបត្តិបាចិត្តិយ។

[៣៥៤] ស្តេចមិនបាននិមន្ត ភិក្ខុសំគាល់ថាស្តេចមិនបាននិមន្ត ហើយដើរកន្លងធរណីចូលទៅ ត្រូវអាបត្តិបាចិត្តិយ។ ស្តេចមិនបាននិមន្ត ភិក្ខុមានសេចក្តីសង្ស័យ ហើយដើរកន្លងធរណីចូលទៅ ត្រូវអាបត្តិបាចិត្តិយ។ ស្តេចមិនបាននិមន្ត ភិក្ខុសំគាល់ថាស្តេចនិមន្ត ហើយដើរកន្លងធរណីចូលទៅ ត្រូវអាបត្តិបាចិត្តិយ។ ស្តេចនិមន្តហើយ ភិក្ខុសំគាល់ថាស្តេចមិនបាននិមន្ត ត្រូវអាបត្តិទុក្កដ។ ស្តេចនិមន្តហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ស្តេចនិមន្តហើយ ភិក្ខុសំគាល់ថាស្តេចនិមន្តហើយ មិនត្រូវអាបត្តិ។

[៣៥៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺស្តេចបាននិមន្ត១ ជននោះមិនមែនជាក្សត្រិយ៍១ ជាស្តេច តែមិនបានទទួលអភិសេកដោយអភិសេកជាក្សត្រិយ៍១ ស្តេចយាងចេញពីក្រឡាព្រះបន្ទំ១ មហេសីចេញពីក្រឡាព្រះបន្ទំ១ ឬមួយស្តេចនឹងមហេសីទាំងពីរ ចេញពីក្រឡាព្រះបន្ទំ១ ស្តេចនិងមហេសីមិនបាននៅក្នុងក្រឡាព្រះបន្ទំ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី២ (៨៤)

CS vin.vbu.pc.84 | ភាគ ទី៤

### (២. រតនសិក្ខាបទំ)

[៣៥៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុមួយរូបងូតទឹកក្នុងស្ទឹងអចិរវតី។ មានព្រាហ្មណ៍ម្នាលទៀតបានទុកថង់ប្រាក់ចំនួន៥០០កហាបណៈលើគោក ហើយចុះងូតទឹកក្នុងស្ទឹងអចិរវតី (ឡើងមកហើយ) ក៏ភ្លេចថង់ប្រាក់ ដើរចៀសចេញទៅ។ លំដាប់នោះ ភិក្ខុនោះក៏រើសយកដោយគិតថា ថង់នេះប្រាកដជាថង់ប្រាក់របស់ព្រាហ្មណ៍នោះ កុំបីវិនាសបាត់ឡើយ។ ឯព្រាហ្មណ៍នោះនឹកឃើញ ក៏ត្រឡប់វិលមកវិញដោយប្រញាប់ ហើយបានសួរភិក្ខុនោះយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់បានឃើញថង់ប្រាក់របស់ខ្ញុំដែរឬ។ ភិក្ខុនោះបានឲ្យថង់ប្រាក់នោះទៅដោយពាក្យថា យកចុះព្រាហ្មណ៍។ ទើបព្រាហ្មណ៍នោះបានគិតយ៉ាងនេះថា អញមិនគប្បីឲ្យរង្វាន់ដល់ភិក្ខុនេះ ដោយឧបាយដូចម្តេចហ្ន៎។ ព្រាហ្មណ៍នោះចោទប្រកាន់ថា បពិត្រលោកម្ចាស់ កហាបណៈរបស់ខ្ញុំមិនមែន៥០០ទេ របស់ខ្ញុំប្រាកដជា១០០០ រួចចាប់ភិក្ខុនោះហើយ ក៏លែងទៅ។ ចំណែកភិក្ខុនោះទៅកាន់អារាមហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងរើសយករតនៈ មានមាសប្រាក់ជាដើមសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងរើសយករតនៈ ពិតមែនឬ។ ភិក្ខុនោះទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងរើសយករតនៈទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយរើសយកឯងក្តី ឲ្យគេរើសយកក្តីនូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៣៥៧] សម័យនោះឯង មានមហោស្រពក្នុងក្រុងសាវត្ថី។ មនុស្សទាំងឡាយប្រដាប់តាក់តែងខ្លួនទៅកាន់ឧទ្យាន។ សូម្បីនាងវិសាខាមិគារមាតា ក៏បានប្រដាប់តាក់តែងកាយ ហើយក៏ចេញចាកស្រុកទៅដោយគិតថា អញនឹងទៅកាន់ឧទ្យានដែរ ហើយគិតតទៅទៀតថា ចុះអញនឹងទៅកាន់ឧទ្យានធ្វើអ្វី បើដូច្នោះ គួរតែអញចូលគាល់ព្រះដ៏មានព្រះភាគវិញ ហើយក៏ដោះនូវគ្រឿងអាភរណៈចងជាបង្វិចដោយសំពត់បង្គ ហើយបានហុចឲ្យទៅទាសីថា ហ៏ហង ឯងចូរយកបង្វិចនេះទៅ។ លំដាប់នោះ នាងវិសាខាមិគារមាតា បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងវិសាខាមិគារមាតាដែលអង្គុយនៅក្នុងទីដ៏សមគួរហើយ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ។ ឯនាងវិសាខាមិគារមាតា លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ។ ឯទាសីនោះ ក៏ភ្លេចចោលនូវបង្វិចនោះ ហើយដើរចេញទៅ។ ភិក្ខុទាំងឡាយឃើញហើយ បានក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូររើសយកទុកចុះ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរើសឯង ឬប្រើគេឲ្យរើសនូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ក្នុងអារាម ហើយទុកដោយគិតថា រតនៈរបស់អ្នកណា អ្នកនោះនឹងយកទៅ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុណាមួយរើសឯងក្តី ឲ្យគេរើសក្តី នូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ (រើសយកនូវរតនៈដែលគេភ្លេច) នៅក្នុងវត្ត។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៣៥៨] គ្រានោះឯង ក្នុងកាសីជនបទ មានស្រុក១ ជាទីធ្វើការងាររបស់អនាថបិណ្ឌិកគហបតី។ គហបតីនោះបានបង្គាប់អន្តេវាសី (កូនក្មួយ) ថា បើលោកម្ចាស់ទាំងឡាយនិមន្តមក អ្នកឯងគប្បីធ្វើភត្តប្រគេនផង។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូបត្រាច់ទៅកាន់ចារិកក្នុងកាសីជនបទ

ហើយហួសទៅកាន់ស្រុកជាទីធ្វើការងាររបស់អនាថបិណ្ឌិកគហបតី។ បុរសនោះបានឃើញភិក្ខុទាំងនោះមកអំពីចម្ងាយ លុះបានឃើញច្បាស់ហើយ បានចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ បានថ្វាយបង្គំភិក្ខុទាំងនោះ ហើយពោលនូវពាក្យនេះថា បពិត្រព្រះករុណា សូមលោកម្ចាស់ទាំងឡាយទទួលចង្ហាន់របស់គហបតីក្នុងថ្ងៃស្អែក។ ភិក្ខុទាំងនោះបានទទួលដោយភាវៈស្ងៀមនៅ។ លុះកន្លងរាត្រីនោះទៅ បុរសនោះបានឲ្យគេតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ហើយបានឲ្យពិតភត្តកាល(ពេលឆាន់) រួចក៏ដោះនូវចិញ្ចៀនចេញ ហើយអង្គាសភិក្ខុទាំងនោះដោយភត្តស្រេចហើយពិតថា លោកម្ចាស់ទាំងឡាយឆាន់ហើយ សូមនិមន្តទៅចុះ ចំណែកខ្ញុំ នឹងទៅធ្វើការងារដែរ (និយាយដូច្នេះហើយ) ក៏ភ្លេចចិញ្ចៀន(នោះ) ហើយទៅ។ ភិក្ខុទាំងឡាយបានឃើញហើយ ក៏ឈប់នៅក្នុងទីនោះដោយគិតគ្នាថា បើយើងទាំងឡាយនឹងដើរចេញទៅ ចិញ្ចៀននេះនឹងបាត់បង់ទៅពុំខាន។ ឯបុរសនោះ កាលមកអំពីធ្វើការងារ បានឃើញភិក្ខុទាំងនោះហើយសួរយ៉ាងនេះថា បពិត្រព្រះករុណា ពួកលោកម្ចាស់ឈប់នៅក្នុងទីនេះធ្វើអ្វី។ ទើបភិក្ខុទាំងនោះប្រាប់សេចក្តីនុ៎ះដល់បុរសនោះ ហើយទៅកាន់ក្រុងសាវត្ថី បានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរើសឯង ឬឲ្យគេរើសនូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ខាងក្នុងវត្តក្តី ខាងក្នុងទីស្នាក់ក្តី ហើយទុកដាក់ ដោយគិតថា រតនៈរបស់ជនណា ជននោះនឹងនាំយកទៅ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុណាមួយរើសឯងក្តី ឲ្យគេរើសក្តី នូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែខាងក្នុងវត្ត ឬខាងក្នុងទីស្នាក់។ ម្យ៉ាងទៀត ភិក្ខុគប្បីរើសឯង ឬឲ្យគេរើសនូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ខាងក្នុងអារាមក្តី ខាងក្នុងទីស្នាក់ក្តី ហើយទុកដាក់ដោយគិតថា រតនៈរបស់ជនណា ជននោះនឹងនាំយកទៅ។ នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ។**

[៣៥៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថារតនៈនោះ បានដល់កែវមុក្តា កែវមណិ កែវពៃទូរ សង្ខ កែវសិលា កែវបវាឡ ប្រាក់ មាស កែវក្រហម (កែវទទឹម) កែវមរកដ (កែវពព្រួស) នេះឈ្មោះថា រតនៈ។ ដែលហៅថា វត្ថុដែលគេសន្មតជារតនៈនោះ បានដល់វត្ថុឯណាមួយជាគ្រឿងឧបភោគបរិភោគរបស់មនុស្សទាំងឡាយ វត្ថុនេះឈ្មោះថា គេសន្មតជារតនៈ។ ពាក្យថា វៀរលែងតែខាងក្នុងអារាមក្តី ខាងក្នុងទីស្នាក់ក្តី គឺលើកលែងតែខាងក្នុងវត្ត និងខាងក្នុងទីស្នាក់។ ដែលហៅថា ខាងក្នុងវត្តនោះ គឺវត្តដែលមានរបងសំដៅយកទីខាងក្នុងនៃរបងវត្ត (បើ) វត្តដែលមិនមានរបង សំដៅយកត្រឹមទីឧបចារនៃវត្ត។ ដែលហៅថា ខាងក្នុងទីស្នាក់នោះ គឺទីស្នាក់ដែលមានរបង សំដៅយកទីខាងក្នុងនៃទីស្នាក់ (បើ) ទីស្នាក់ដែលឥតរបង សំដៅយកត្រឹមទីឧបចារនៃទីស្នាក់។ ពាក្យថា រើសឯង សេចក្តីថា ភិក្ខុកាន់យកដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ឲ្យគេរើស សេចក្តីថា ភិក្ខុឲ្យអ្នកដទៃកាន់យក ត្រូវអាបត្តិបាចិត្តិយ។

[៣៦០] ពាក្យថា ម្យ៉ាងទៀត ភិក្ខុគប្បីរើសឯង ឬឲ្យគេរើសនូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ខាងក្នុងវត្តក្តី ខាងក្នុងទីស្នាក់ក្តី ហើយទុកដាក់ សេចក្តីថា ភិក្ខុធ្វើសញ្ញា[55] (គ្រឿងកំណត់ដឹង) ដោយរូបក្តី ដោយនិមិត្តគ្រឿងសំគាល់ក្តី គប្បីទុកដាក់ហើយប្រាប់ថា ជនណាបាត់ភណ្ឌ ជននោះចូរមកយកចុះ។ បើម្ចាស់របស់នោះមកក្នុងទីនោះ ភិក្ខុគប្បីសួរគេថា អាវុសោ ភណ្ឌរបស់អ្នកដូចម្តេច។ បើគេប្រាប់ត្រូវតាមរូបក្តី តាមនិមិត្តគ្រឿងសំគាល់ក្តី ភិក្ខុគប្បីឲ្យចុះ។ បើគេប្រាប់មិនត្រូវ ភិក្ខុគប្បីពោលថា អាវុសោ អ្នកចូររកខ្លួនឯងចុះ។ កាលភិក្ខុនោះនឹងចៀសចេញចាកទីស្នាក់នោះទៅ ភិក្ខុទាំងឡាយណាដ៏សមគួរមាននៅក្នុងទីនោះ គប្បីផ្ញើទុកក្នុងដៃភិក្ខុទាំងឡាយនោះ ហើយចៀសចេញទៅ។ បើមិនមានភិក្ខុដ៏សមគួរទេ ភិក្ខុនោះត្រូវផ្ញើទុកនៅដៃរបស់ពួកគហបតីដ៏សមគួរ ដែលមាននៅក្នុងទីនោះ ហើយគប្បីចៀសចេញទៅ។ ពាក្យថា នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ គឺនេះតាមធម្មតាក្នុងរឿងនោះ។

[៣៦១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុរើសឯង ឬឲ្យគេរើសនូវរតនៈក្តី នូវវត្ថុដែលគេសន្មតជារតនៈក្តី ខាងក្នុងវត្តក្តី ខាងក្នុងទីស្នាក់ក្តី ហើយទុកដាក់ដោយគិតថា រតនៈរបស់អ្នកណា អ្នកនោះនឹងនាំយកទៅ១ ភិក្ខុកាន់យកវត្ថុដែលគេសន្មតជារតនៈដោយស្និទ្ធស្នាល១ ភិក្ខុកាន់យកជារបស់ខ្ចី១ ភិក្ខុសំគាល់ថាជារបស់បង្សុកូល១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ២ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី៣ (៨៥)

CS vin.vbu.pc.85 | ភាគ ទី៤

### (៣. វិកាលគាមប្បវិសនសិក្ខាបទំ)

[៣៦២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុចូលទៅកាន់ស្រុកក្នុងវេលារសៀល ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗជាច្រើនក្នុងរោងជាទីប្រជុំនិយាយ តិរច្ឆានកថានោះដូចម្តេចខ្លះ តិរច្ឆានកថានោះ គឺពោលអំពីរឿងស្តេច ពោលអំពីចោរ ពោលអំពីមហាមាត្យ ពោលអំពីសេនាទាហាន ពោលអំពីភ័យ (និងសត្វសាហារជាដើម) ពោលអំពីចម្បាំង ពោលអំពីបាយ ពោលអំពីទឹក ពោលអំពីសំពត់ ពោលអំពីទីដេក ពោលអំពីផ្កាកម្រង ពោលអំពីគ្រឿងក្រអូប ពោលអំពីញាតិ ពោលអំពីយាន ពោលអំពីស្រុក ពោលអំពីនិគម ពោលអំពីក្រុង ពោលអំពីជនបទ ពោលអំពីស្ត្រី ពោលអំពីសុរា ពោលអំពីច្រក ពោលអំពីទីដំកល់នៃក្អម គឺកំពង់ទឹក ពោលអំពីញាតិដែលស្លាប់ទៅកាន់បរលោក ពោលអំពីរឿងផ្សេងៗដែលឥតប្រយោជន៍ ពោលអំពីលោក (លទ្ធិកុហកក្នុងលោក) ពោលអំពីសមុទ្រ ពោលអំពីភវៈ[56] និងអភវៈ[57] ដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនគួរនឹងមកចូលស្រុកក្នុងវេលាវិកាល ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗជាច្រើន

ក្នុងរោងជាទីប្រជុំនិយាយ ដូចពួកគ្រហស្ថអ្នកបរិភោគនូវកាមសោះ តិរច្ឆានកថានោះដូចម្ដេចខ្លះ តិរច្ឆានកថានោះគឺ ពោលអំពីរឿងស្ដេច ពោលអំពីចោរ ពោលអំពីមហាមាត្យ ពោលអំពីសេនាទាហាន ពោលអំពីភ័យ (និងសត្វសាហារជាដើម) ពោលអំពីចម្បាំង ពោលអំពីបាយ ពោលអំពីទឹក ពោលអំពីសំពត់ ពោលអំពីទីដេក ពោលអំពីកម្រងផ្កា ពោលអំពីគ្រឿងក្រអូប ពោលអំពីញាតិ ពោលអំពីយាន ពោលអំពីស្រុក ពោលអំពីនិគម ពោលអំពីនគរ ពោលអំពីជនបទ ពោលអំពីស្រី ពោលអំពីសុរា ពោលអំពីច្រក ពោលអំពីទីដំកល់នៃក្អម គឺកំពង់ទឹក ពោលអំពីញាតិដែលស្លាប់ទៅកាន់បរលោក ពោលអំពីរឿងផ្សេងៗ ពោលអំពីលោក (លទ្ធិកុហកក្នុងលោក) ពោលអំពីសមុទ្រ ពោលអំពីភវៈ និងអភវៈដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងមកចូលស្រុកក្នុងវេលាវិកាល ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗជាច្រើនក្នុងរោងជាទីប្រជុំពោលសោះ តិរច្ឆានកថានោះដូចម្ដេចខ្លះ តិរច្ឆានកថានោះគឺ ពោលអំពីរឿងស្ដេច។បេ។ ពោលអំពីភវៈ និងអភវៈដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងរាល់គ្នាចូលស្រុកក្នុងវេលាវិកាល ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗជាច្រើន តិរច្ឆានកថានោះដូចម្ដេចខ្លះ តិរច្ឆានកថានោះគឺ ពោលអំពីរឿងស្ដេច។បេ។ ពោលអំពីភវៈ និងអភវៈដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងចូលស្រុក ក្នុងវេលាវិកាល ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗជាច្រើនទេ តិរច្ឆានកថានោះដូចម្ដេចខ្លះ តិរច្ឆានកថានោះគឺ ពោលអំពីរឿងស្ដេច។បេ។ ពោលអំពីភវៈ និងអភវៈដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយចូលស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ។

ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៣៦៣] សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូបទៅកាន់ក្រុងសាវត្ថីក្នុងកោសលជនបទ ក៏បានចូលទៅកាន់ស្រុកមួយ ក្នុងវេលាល្ងាច។ មនុស្សទាំងឡាយឃើញភិក្ខុទាំងនោះហើយ ក៏បានពោលនូវពាក្យនេះថា សូមលោកម្ចាស់ទាំងឡាយនិមន្តចូលមក។ ចំណែកភិក្ខុទាំងនោះសង្ស័យថា ព្រះដ៏មានព្រះភាគទ្រង់ឃាត់ហាមនូវការចូលស្រុកក្នុងវេលាវិកាលហើយ បានជាមិនហ៊ានចូលទៅ។ ចោរទាំងឡាយបានប្លន់ភិក្ខុទាំងនោះ។ ភិក្ខុទាំងនោះទៅក្រុងសាវត្ថី ហើយប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលបានលាភិក្ខុផងគ្នា ហើយចូលស្រុកក្នុងវេលាវិកាលបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយមិនបានលា ហើយចូលទៅកាន់ស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ។

ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៣៦៤] សម័យនោះឯង ភិក្ខុមួយរូបទៅកាន់ក្រុងសាវត្ថីក្នុងកោសលជនបទ វេលាល្ងាចបានចូលទៅកាន់ស្រុកមួយ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយ បានពោលនូវពាក្យនេះថា សូមលោកម្ចាស់និមន្តចូលមក។ ចំណែកភិក្ខុនោះរង្កៀសថា ព្រះដ៏មានព្រះភាគទ្រង់ឃាត់ហាមការដែលមិនបានលាភិក្ខុផងគ្នា ហើយចូលស្រុកក្នុងវេលាវិកាល ទើបមិនហ៊ានចូលទៅ។ ពួកចោរក៏ប្លន់ភិក្ខុនោះ។ ភិក្ខុនោះទៅដល់ក្រុងសាវត្ថី ក៏ប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាភិក្ខុដែលមាននៅជាមុន ហើយទើបចូលស្រុកក្នុងវេលាវិកាលបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុណាមួយមិនលាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ។

ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ។

[៣៦៥] សម័យនោះឯង មានពស់ចឹកភិក្ខុមួយរូប។ ភិក្ខុមួយរូបទៅកាន់ស្រុកដោយគិតថា អញនឹងទៅយកភ្លើងមក។ តែភិក្ខុនោះរង្កៀសថា ព្រះដ៏មានព្រះភាគទ្រង់ឃាត់ហាមការមិនបានលាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាល ទើបមិនហ៊ានចូលទៅ។ ភិក្ខុនោះក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានកិច្ចប្រញាប់ដូច្នោះ មិនបាច់លាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាលបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយមិនបានលាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ។**

[៣៦៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា ភិក្ខុមាននៅ គឺភិក្ខុដែលគេគួរនឹងលាហើយចូលទៅ (កាន់ស្រុក)បាន។ ដែលហៅថា ភិក្ខុមិនមាននៅ គឺមិនមានភិក្ខុដែលគេគួរនឹងលាហើយចូលទៅ (កាន់ស្រុក)។ ដែលហៅថា វេលាវិកាលនោះ គឺតាំងពីថ្ងៃជ្រេពីត្រង់ទៅដរាបទល់នឹងអរុណរះឡើង។ ពាក្យថា ចូលទៅកាន់ស្រុក សេចក្តីថា ភិក្ខុឈានរំលងរបងនៃស្រុកដែលមានរបង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុឈានជំហានចូលទៅកាន់ឧបចារស្រុកដែលគ្មានរបង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ សេចក្តីថា លើកលែងតែកិច្ចប្រញាប់មានសភាពដូច្នោះ។

[៣៦៧] វេលាវិកាល (កាលមិនគួរ) ភិក្ខុសំគាល់ថាវេលាវិកាល ហើយមិនបានលាភិក្ខុដែលមាននៅ ចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ។ វេលាវិកាល ភិក្ខុមានសេចក្តីសង្ស័យ ហើយមិនលាភិក្ខុផងគ្នាដែលមាននៅ ចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ។ កាលមិនគួរ ភិក្ខុសំគាល់ថាកាលគួរ ហើយមិនលាភិក្ខុផងគ្នាដែលមាននៅ ចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់មានសភាពដូច្នោះ។ កាលគួរ ភិក្ខុសំគាល់ថាកាលមិនគួរ ហើយ(មិនលាភិក្ខុផងគ្នា ចូលទៅកាន់ស្រុក) ត្រូវអាបត្តិទុក្កដ។ កាលគួរ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កាលគួរ ភិក្ខុសំគាល់ថាកាលគួរ មិនត្រូវអាបត្តិឡើយ។

[៣៦៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១១យ៉ាង) គឺភិក្ខុមានកិច្ចប្រញាប់មានសភាពដូច្នោះ១ ភិក្ខុបានលាភិក្ខុផងគ្នាដែលមាននៅហើយចូលទៅ១ ភិក្ខុមិនបានលាព្រោះគ្មានភិក្ខុ ហើយចូលទៅ១ ភិក្ខុដើរទៅកាន់ចន្លោះអារាម១ ភិក្ខុទៅកាន់លំនៅភិក្ខុនី១ ភិក្ខុទៅកាន់លំនៅពួកតិរ្ថិយ១ ភិក្ខុទៅកាន់ទីឆាន់ហើយត្រឡប់វិញ១ ភិក្ខុដើរតាមផ្លូវមាននៅក្នុងស្រុក១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៣ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី៤ (៨៦)

CS vin.vbu.pc.86 | ភាគ ទី៤

### (៤. សូចិឃរសិក្ខាបទំ)

[៣៦៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ។ វេលានោះឯង មានជាងធ្វើភ្លុកម្នាក់ បានបវារណាភិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយណាត្រូវការបំពង់ម្ជុល ខ្ញុំព្រះករុណានឹងប្រគល់បំពង់ម្ជុល។ គ្រានោះ ភិក្ខុទាំងឡាយក៏បានសូមបំពង់ម្ជុលជាច្រើន។ ពួកភិក្ខុណាមានបំពង់ម្ជុលតូច ភិក្ខុទាំងនោះសូមបំពង់ម្ជុលធំទៀត ពួកភិក្ខុណាមានបំពង់ម្ជុលធំ ភិក្ខុទាំងនោះសូមយកបំពង់ម្ជុលតូចទៀត។ លំដាប់នោះ ជាងធ្វើភ្លុករវល់តែធ្វើបំពង់ម្ជុលច្រើនប្រគេនភិក្ខុទាំងឡាយ ក៏មិនអាចនឹងធ្វើរបស់សម្រាប់លក់ដូរឯទៀតបានឡើយ ហើយមិនអាចនឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានផង ទាំងកូននិងប្រពន្ធរបស់ជាងនោះសោត ក៏នឿយព្រួយលំបាក។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រ មិនគួរនឹងមិនដឹងប្រមាណ សូមបំពង់ម្ជុលច្រើន ឯជាងធ្វើភ្លុកនេះរវល់តែធ្វើបំពង់ម្ជុលច្រើនប្រគេនភិក្ខុទាំងនេះ ក៏មិនអាចធ្វើរបស់សម្រាប់លក់ដូរឯទៀតបាន ហើយមិនបានញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានផង ទាំងកូននិងប្រពន្ធរបស់ជាងនោះសោត ក៏នឿយព្រួយលំបាក។ កាលមនុស្សទាំងនោះកំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនគួរនឹងមិនដឹងប្រមាណ សូមបំពង់ម្ជុលច្រើន (ហួសកំណត់)។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយមិនស្គាល់ប្រមាណ សូមបំពង់ម្ជុលច្រើន ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះ មិនគួរនឹងមិនដឹងប្រមាណ សូមបំពង់ម្ជុលច្រើនទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយឲ្យគេធ្វើបំពង់ម្ជុលជាវិការនៃឆ្អឹងក្តី ជាវិការនៃភ្លុកក្តី ជាវិការនៃស្នែងក្តី ត្រូវភេទនកបាចិត្តិយ។**[58)]

[៣៧០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា ឆ្អឹង គឺឆ្អឹងណាមួយ។ ដែលហៅថា ភ្លុក សំដៅយកភ្លុកដំរីជាប្រមាណ។ ដែលហៅថា ស្នែង គឺស្នែងណាមួយ។ ពាក្យថាឲ្យគេធ្វើ គឺធ្វើដោយខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ត្រូវបំបែកបំពង់ម្ជុលដែលខ្លួនបានមកនោះ ហើយសឹមសំដែងអាបត្តិបាចិត្តិយ។

[៣៧១] ភិក្ខុញុំាងបំពង់ម្ជុលដែលខ្លួនធ្វើមិនទាន់ស្រេច ឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុបង្គាប់អ្នកដទៃឲ្យសម្រេចនូវបំពង់ម្ជុលដែលខ្លួនធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ។ បំពង់ម្ជុលដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី នូវបំពង់ម្ជុលដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានបំពង់ម្ជុលដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៣៧២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុយកឆ្អឹងជាដើមមកធ្វើជាឡេវវក្ខ១ ធ្វើជារបស់សម្រាប់ពួតភ្លើង១ ធ្វើជាក្រវិលវត្តពន្ធចង្កេះ១ ធ្វើជាខ្លាស់សម្រាប់ដាក់ថ្នាំបន្តក់ភ្នែក១ ធ្វើជាចង្កឹះនៃខ្លាក់នោះ១ ធ្វើជាមៀនកាំបិត១ ធ្វើជារបស់សម្រាប់ជូតទឹក១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៤ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី៥ (៨៧)

CS vin.vbu.pc.87 | ភាគ ទី៤

### (៥. មញ្ចបីឋសិក្ខាបទំ)

[៣៧៣] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុសិងលើគ្រែដ៏ខ្ពស់។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់សេនាសនចារិកជាមួយនឹងពួកភិក្ខុច្រើនរូប ហើយចូលទៅកាន់វិហារដែលព្រះឧបនន្ទសក្យបុត្តដ៏មានអាយុនៅ។ ឯព្រះឧបនន្ទសក្យបុត្តដ៏មានអាយុបានក្រឡេកទៅឃើញព្រះដ៏មានព្រះភាគកំពុងយាងមកពីចម្ងាយ លុះបានឃើញហើយ ក៏បានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ចូលមកទតមើលទីដេករបស់ខ្ញុំព្រះអង្គសិន។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ត្រឡប់មកពីទីនោះវិញ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឯមោឃបុរស អ្នកទាំងឡាយគប្បីដឹងដោយទីអាស្រ័យ។[59] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្ទោសព្រះឧបនន្ទសក្យបុត្តដ៏មានអាយុដោយអនេកបរិយាយ។បេ។ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុឲ្យគេធ្វើគ្រែក្តី តាំងក្តីដ៏ថ្មី ត្រូវឲ្យធ្វើឲ្យមានជើង៨ធ្នាប់ដោយធ្នាប់ព្រះសុគត វាស់ពីត្រឹមមេគ្រែខាងក្រោមចុះទៅ (បើធ្វើ) ឲ្យកន្លងហួសពីនោះទៅ ត្រូវឆេទនកបាចិត្តិយ។[60]**

[៣៧៤] ដែលហៅថា ថ្មី គឺសំដៅយកការធ្វើឡើងជាប្រមាណ។ ដែលហៅថាគ្រែ គឺគ្រែមាន៤យ៉ាង បានដល់គ្រែដែលគេដាប់ជើង ហើយបញ្ចូលមេគ្រែទៅក្នុងដំណាប់នោះ១ គ្រែដែលគេបង្ខាំជើងគ្រែដោយមេគ្រែ ហើយធ្វើដោយសង្ខេបជាបល្លង្ក១ គ្រែដែលគេធ្វើជើងប្រហែលនឹងជើងសត្វសេះ សត្វពពែជាដើម១ គ្រែដែលគេបានបញ្ចុះពន្លួញទៅក្នុងមេ១។ ដែលហៅថា តាំង គឺតាំងមាន៤យ៉ាង តាំងដែលគេដាប់ជើងហើយបញ្ចូលមេតាំងទៅក្នុងដំណាប់នោះ១ តាំងដែលគេបង្ខាំជើងតាំងដោយមេតាំង ហើយធ្វើដោយសង្ខេបជាបល្លង្ក១ តាំងដែលគេធ្វើជើងប្រហែលនឹងជើងសត្វសេះ សត្វពពែជាដើម១ តាំងដែលគេបានបញ្ចុះពន្លួញទៅក្នុងមេ១។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្តី ឲ្យគេធ្វើក្តី។ ពាក្យថា ឲ្យធ្វើឲ្យមានជើង៨ធ្នាប់ ដោយធ្នាប់ព្រះសុគត វៀរចាកមេគ្រែខាងក្រោម គឺវៀរមេគ្រែខាងក្រោមចុះទៅ គឺវាស់ពីត្រឹមមេគ្រែខាងក្រោម ភិក្ខុធ្វើដោយខ្លួនឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ត្រូវកាត់គ្រែក្នុងខណៈដែលបានមកចេញ ហើយសឹមសំដែងអាបត្តិបាចិត្តិយ។

[៣៧៥] គ្រែដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ គ្រែដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ គ្រែដែលអ្នកដទៃធ្វើមិនទាន់សម្រេច ភិក្ខុធ្វើឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ គ្រែដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើគ្រែដោយខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានគ្រែ ឬតាំងដែលអ្នកដទៃធ្វើ (ហើយយកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៣៧៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុធ្វើត្រូវតាមប្រមាណ១ ភិក្ខុធ្វើឲ្យថយចុះពីប្រមាណ១ ភិក្ខុបានគ្រែ ឬតាំងដែលអ្នកដទៃធ្វើឲ្យហួសប្រមាណ (យកមក) កាត់ចេញហើយប្រើប្រាស់១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៥ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី៦ (៨៨)

CS vin.vbu.pc.88 | ភាគ ទី៤

### (៦. តូលោនទ្ធសិក្ខាបទំ)

[៣៧៧] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេធ្វើគ្រែខ្លះ តាំងខ្លះ ញាត់ដោយសំឡីគរ ឬសំឡីកប្បាស(ជាដើម)។ ពួកមនុស្សនាំគ្នាដើរទៅកាន់វិហារចារិក បានឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តមិនគួរនឹងឲ្យគេធ្វើគ្រែខ្លះ តាំងខ្លះ ញាត់ដោយសំឡីដូចជាពួកគ្រហស្ថអ្នកបរិភោគកាមគុណសោះ។ កាលមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងឲ្យគេធ្វើគ្រែខ្លះ តាំងខ្លះ ញាត់ដោយសំឡីសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយឲ្យគេធ្វើគ្រែខ្លះ តាំងខ្លះ ញាត់ដោយសំឡី ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងឲ្យគេធ្វើគ្រែខ្លះ តាំង

ខ្លះ ញាត់ដោយសំឡីទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយឲ្យគេធ្វើគ្រែក្តី តាំងក្តីញាត់ដោយសំឡី ត្រូវឧទ្ទាលនកបាចិត្តិយ។**[61)]

[៣៧៨] ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា គ្រែ គឺគ្រែមាន៤យ៉ាង បានដល់គ្រែដែលគេដាប់ជើង ហើយបញ្ចូលមេគ្រែទៅក្នុងដំណាប់នោះ១ គ្រែដែលគេបង្ខាំជើងគ្រែដោយមេគ្រែ ហើយធ្វើដោយសង្ខេបជាបល្លង្ក១ គ្រែដែលគេធ្វើជើងប្រហែលនឹងជើងសេះ ជើងពពែជាដើម១ គ្រែដែលគេបានបញ្ចុះពន្លួញទៅក្នុងមេ១។ ដែលហៅថា តាំង គឺតាំងមាន៤យ៉ាង បានដល់តាំងដែលគេដាប់ជើងហើយបញ្ចូលមេតាំងទៅក្នុងដំណាប់នោះ១ តាំងដែលគេបង្ខាំជើងតាំងដោយមេតាំងទាំងឡាយ ហើយធ្វើដោយសង្ខេបជាបល្លង្ក១ តាំងដែលគេធ្វើជើងប្រហែលនឹងជើងសេះ ជើងពពែជាដើម១ តាំងដែលគេបានបញ្ចុះជើងទៅក្នុងមេ១។ ដែលហៅថា សំឡី គឺសំឡីមាន៣យ៉ាង គឺសំឡីកើតពីដើមឈើ (មានដើមរកាជាដើម)១ សំឡីកើតពីវល្លិ(មានវល្លិ៍ទឹកដោះជាដើម)១ សំឡីកើតអំពីស្មៅ១។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុធ្វើដោយខ្លួនឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវរើកកាយសំឡីក្នុងគ្រែក្នុងខណៈដែលបានមក ហើយសឹមសំដែងអាបត្តិចេញ។

[៣៧៩] គ្រែឬតាំងដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ គ្រែឬតាំងដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ គ្រែឬតាំងដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ គ្រែឬតាំងដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើគ្រែឬតាំងដោយខ្លួនឯងក្តី អ្នកដទៃធ្វើក្តី ដើម្បីបុគ្គលដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានគ្រែឬតាំងដែលអ្នកដទៃធ្វើឲ្យ (ហើយយកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៣៨០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុធ្វើជាសំពត់អាយោគ១ ធ្វើជាវត្ថពន្ធចង្កេះ១ ធ្វើជាយោគបាត្រ១ ធ្វើជាស្លោកបាត្រ១ ធ្វើជាតម្រងទឹក១ ធ្វើជាខ្នើយ១ ភិក្ខុបានគ្រែឬតាំងដែលអ្នកដទៃធ្វើឲ្យ (ហើយយកមក) ទម្លាយចេញទើបប្រើប្រាស់១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៦ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី៧ (៨៩)

CS vin.vbu.pc.89 | ភាគ ទី៤

### (៧. និសីទនសិក្ខាបទំ)

[៣៨១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង សំពត់និសីទនៈ (សំពត់សម្រាប់ទ្រាប់អង្គុយ) ព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយ។ ឯពួកឆព្វគ្គិយភិក្ខុគិតថា សំពត់និសីទនៈព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតហើយ ៗក៏ប្រើប្រាស់សំពត់និសីទនៈទាំងឡាយមិនសមប្រមាណ ធ្វើឲ្យសំពត់និសីទនៈទាំងនោះសំយុងចុះពីខាងមុខខ្លះ ពីខាងក្រោយខ្លះនៃគ្រែនិងតាំង។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងប្រើប្រាស់សំពត់និសីទនៈមិនសមប្រមាណសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើប្រាស់សំពត់និសីទនៈមិនសមប្រមាណ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងប្រើប្រាស់សំពត់និសីទនៈមិនសមតាមប្រមាណទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុឲ្យគេធ្វើសំពត់និសីទនៈ គប្បីឲ្យគេធ្វើឲ្យត្រូវប្រមាណ។ ឯប្រមាណក្នុងសំពត់និសីទនៈនោះយ៉ាងនេះ គឺបណ្តោយ២ចំអាម ទទឹង១ចំអាមកន្លះ ដោយចំអាមព្រះសុគត។ បើភិក្ខុធ្វើឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៣៨២] សម័យនោះឯង ឧទាយិដ៏មានអាយុមានរាងកាយធំ។ ឧទាយិនោះបានក្រាលសំពត់និសីទនៈចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគរួចទាញឲ្យយឺតដោយជុំវិញ ហើយអង្គុយនៅ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងឧទាយិដ៏មានអាយុយ៉ាងនេះថា នែឧទាយិ អ្នកបានជាក្រាលសំពត់និសីទនៈហើយទាញឲ្យយឺតដោយជុំវិញ ដូចជាជាងស្បែកពីដើម ព្រោះហេតុអ្វី។ ឧទាយិនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន បានជាខ្ញុំព្រះអង្គធ្វើដូច្នោះ ព្រោះសំពត់និសីទនៈដែលព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតដល់ភិក្ខុទាំងឡាយតូចពេកណាស់។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត(ឲ្យត)នូវជាយនៃសំពត់និសីទនៈ១ចំអាមទៀត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនឹងឲ្យគេធ្វើសំពត់និសីទនៈ ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ។ ឯប្រមាណក្នុងសំពត់និសីទនៈនោះយ៉ាងនេះ គឺបណ្តោយ២ចំអាម ទទឹង១ចំអាមកន្លះ ដោយចំអាមព្រះសុគត និងជាយ១ចំអាម។ (បើភិក្ខុធ្វើ) ឲ្យកន្លងហួសពីនោះទៅ ត្រូវឆេទនកបាចិត្តិយ។**

[៣៨៣] ដែលហៅថា សំពត់និសីទនៈនោះ គឺសំដៅយកសំពត់និសីទនៈដែលមានជាយ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្តី ឲ្យគេធ្វើក្តី។ ភិក្ខុត្រូវធ្វើឲ្យត្រូវនឹងប្រមាណ។ ឯប្រមាណក្នុងសំពត់និសីទនៈនោះយ៉ាងនេះ គឺបណ្តោយ២ចំអាម ទទឹង១ចំអាមកន្លះ ដោយចំអាមព្រះសុគត និងជាយ១ចំអាម។[62] ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់សំពត់និសីទនៈក្នុងខណៈដែលបានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ។

[៣៨៤] សំពត់និសីទនៈដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ សំពត់និសីទនៈដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ សំពត់និសីទនៈដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ សំពត់និសីទនៈដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេច ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានសំពត់និសីទនៈដែលបុគ្គលដទៃធ្វើហើយ(យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៣៨៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុធ្វើសំពត់និសីទនៈត្រូវតាមប្រមាណ១ ភិក្ខុធ្វើសំពត់និសីទនៈថយចុះពីប្រមាណ១ ភិក្ខុបានសំពត់និសីទនៈដែលអ្នកដទៃធ្វើឲ្យលើសហួសប្រមាណ ហើយកាត់ចេញទើបប្រើប្រាស់១ ភិក្ខុធ្វើសំពត់និសីទនៈឲ្យជាពិតានក្តី ឲ្យជាកម្រាលនៃផែនដីក្តី ឲ្យជារនាំងក្តី ឲ្យជាពូកក្តី ឲ្យជាខ្នើយក្តី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៧ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី៨ (៩០)

CS vin.vbu.pc.90 | ភាគ ទី៤

### (៨. កណ្ឌុប្បដិច្ឆាទិសិក្ខាបទំ)

[៣៨៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ព្រះដ៏មានព្រះភាគបានអនុញ្ញាតសំពត់សម្រាប់គ្របកម(ជាដើម)ដល់ភិក្ខុទាំងឡាយ។ ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា សំពត់សម្រាប់គ្របកម ព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតហើយ ៗក៏ប្រើប្រាស់នូវសំពត់សម្រាប់គ្របកមទាំងឡាយមិនសមប្រមាណ ទាញពីមុខខ្លះ ពីក្រោយខ្លះហើយចេញដើរទៅ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងប្រើប្រាស់ សំពត់សម្រាប់គ្របកមមិនសមប្រមាណសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើប្រាស់សំពត់សម្រាប់គ្របកមទាំងឡាយមិនសមប្រមាណ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយមិនគួរនឹងប្រើប្រាស់សំពត់សម្រាប់គ្របកមមិនសមប្រមាណទេ នែពួកមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុឲ្យគេធ្វើសំពត់សម្រាប់គ្របកម ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ។ ឯប្រមាណក្នុងសំពត់សម្រាប់គ្របកមនោះយ៉ាងនេះគឺ បណ្តោយ៤ចំអាម ទទឹង២ចំអាម ដោយចំអាមព្រះសុគត។ បើភិក្ខុធ្វើឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ។**

[៣៨៧] សំពត់ដែលគេធ្វើដើម្បីបិទ ឬគ្របនូវអាពាធ គឺកម ឬរមាស់ក្តី បូសតូចក្តី ទឹករងៃក្តី បូសធំក្តី តាំងពីខាងក្រោមផ្ចិតចុះមក តាំងពីមណ្ឌលជង្គង់ឡើងទៅរបស់ភិក្ខុ ហៅថា សំពត់សម្រាប់គ្របកម។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្តី ឲ្យគេធ្វើក្តី។ ភិក្ខុត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ។ ឯប្រមាណក្នុងសំពត់សម្រាប់គ្របកមនោះយ៉ាងនេះ គឺបណ្តោយ៤ចំអាម ទទឹង២ចំអាម ដោយចំអាមព្រះសុគត។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្លងហួសប្រមាណនោះ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់សំពត់សម្រាប់គ្របកមក្នុងខណៈដែលបានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ។

[៣៨៨] សំពត់សម្រាប់គ្របកមដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ សំពត់សម្រាប់គ្របកមដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ សំពត់សម្រាប់គ្របកមដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ សំពត់សម្រាប់គ្របកមដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានសំពត់សម្រាប់គ្របកមដែលអ្នកដទៃធ្វើហើយ(យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៣៨៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុធ្វើសំពត់សម្រាប់គ្របកមត្រូវតាមប្រមាណ១ ភិក្ខុធ្វើសំពត់សម្រាប់គ្របកមថយចុះពីប្រមាណ១ ភិក្ខុបានសំពត់សម្រាប់គ្របកមដែលអ្នកដទៃធ្វើឲ្យកន្លងហួសប្រមាណ ហើយកាត់ចេញ ទើបប្រើប្រាស់១ ភិក្ខុធ្វើសំពត់សម្រាប់គ្របកមឲ្យជាពិតានក្តី ជាគ្រឿងកម្រាលផែនដីក្តី ជារនាំងក្តី ជាពូកក្តី ជាខ្នើយក្តី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៨ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី៩ (៩១)

CS vin.vbu.pc.91 | ភាគ ទី៤

### (៩. វស្សិកសាដិកាសិក្ខាបទំ)

[៣៩០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង សំពត់វស្សិកសាដក ព្រះដ៏មានព្រះភាគបានអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយ។ ឯពួកឆព្វគ្គិយភិក្ខុគិតគ្នាថា សំពត់វស្សិកសាដក ព្រះដ៏មានព្រះភាគបានអនុញ្ញាតហើយ ៗក៏ប្រើប្រាស់សំពត់វស្សិកសាដកមិនសមប្រមាណ ទាញពីមុខខ្លះ ពីក្រោយខ្លះហើយចេញដើរទៅ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងប្រើប្រាស់សំពត់វស្សិកសាដកមិនសមប្រមាណសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើប្រាស់សំពត់វស្សិកសាដកមិនសមប្រមាណ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយមិនគួរនឹងប្រើប្រាស់សំពត់វស្សិកសាដកមិនសមប្រមាណទេ នែពួកមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុឲ្យគេធ្វើសំពត់វស្សិកសាដក ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ។ ឯប្រមាណក្នុងសំពត់វស្សិកសាដកនោះយ៉ាងនេះ គឺបណ្តោយ៦ចំអាម ទទឹង២ចំអាមកន្លះ ដោយចំអាមព្រះសុគត។ បើភិក្ខុធ្វើឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ។**

[៣៩១] ដែលហៅថា សំពត់វស្សិកសាដកនោះ គឺសំពត់ដែលភិក្ខុធ្វើសម្រាប់ងូតទឹកភ្លៀងអស់៤ខែនៃវស្សានរដូវ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្តី ឲ្យគេធ្វើក្តី។ ភិក្ខុត្រូវឲ្យគេធ្វើឲ្យត្រូវតាមប្រមាណ។ ឯប្រមាណក្នុងសំពត់វស្សិកសាដកនោះយ៉ាងនេះ គឺបណ្តោយ៦ចំអាម ទទឹង២ចំអាមកន្លះ ដោយចំអាមព្រះសុគត។ បើភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់សំពត់វស្សិកសាដកក្នុងខណៈដែលបានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ។

[៣៩២] សំពត់វស្សិកសាដកដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ សំពត់វស្សិកសាដកដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ សំពត់វស្សិកសាដកដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ សំពត់វស្សិកសាដកដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានសំពត់វស្សិកសាដកដែលអ្នកដទៃធ្វើហើយ(យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៣៩៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុធ្វើសំពត់វស្សិកសាដកត្រូវតាមប្រមាណ១ ភិក្ខុធ្វើសំពត់វស្សិកសាដកថយចុះពីប្រមាណ១ ភិក្ខុបានសំពត់វស្សិកសាដកដែលអ្នកដទៃធ្វើឲ្យហួសប្រមាណ ហើយ(យកមក)កាត់ចេញ ទើបប្រើប្រាស់១ ភិក្ខុធ្វើសំពត់វស្សិកសាដក(នោះ)ឲ្យជាពិតានក្តី ជាកម្រាលផែនដីក្តី ជាវនាំងក្តី ជាពូកក្តី ជាខ្នើយក្តី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៩ ចប់។

## (បាចិត្តិយ រតនវគ្គ) សិក្ខាបទ ទី១០ (៩២)

CS vin.vbu.pc.92 | ភាគ ទី៤

### (១០. នន្ទសិក្ខាបទំ)

[៣៩៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ព្រះនន្ទដ៏មានអាយុ ជាបុត្តនៃព្រះមាតុច្ឆានៃព្រះដ៏មានព្រះភាគ មានរូបល្អគួរនឹងរមិលមើល នាំឲ្យជ្រះថ្លា មានកំពស់ទាបជាងព្រះដ៏មានព្រះភាគ៤ធ្នាប់។ ព្រះនន្ទនោះទ្រង់ចីវរប៉ុនគ្នានឹងចីវរព្រះសុគត។ ពួកភិក្ខុជាថេរៈបានឃើញព្រះនន្ទដ៏មានអាយុដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏នាំគ្នាក្រោកឡើងអំពីអាសនៈ ដោយគិតថា ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរមក។ លុះព្រះនន្ទចូលមកជិតហើយ ភិក្ខុទាំងនោះក៏ស្គាល់ច្បាស់ ទើបពោលទោស តិះដៀល បន្ទះបង្អាប់ថា ព្រះនន្ទដ៏មានអាយុមិនគួរនឹងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគតសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែនន្ទ ឮថាអ្នកឯងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគត ពិតមែនឬ។ ព្រះនន្ទនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែនន្ទ អ្នកឯងមិនគួរនឹងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគតទេ នែនន្ទ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយឲ្យគេធ្វើចីវរប៉ុនចីវរព្រះសុគតឬធំជាង ត្រូវឆេទនកបាចិត្តិយ។ ឯប្រមាណសុគតចីវររបស់ព្រះសុគតនោះយ៉ាងនេះ គឺបណ្តោយ៩ចំអាម ទទឹង៦ចំអាម ដោយចំអាមព្រះសុគត។ នេះជាប្រមាណសុគតចីវររបស់ព្រះសុគត។**

[៣៩៥] ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ដែលហៅថា ប្រមាណសុគតចីវរ គឺបណ្តោយ៩ចំអាម ទទឹង៦ចំអាម ដោយចំអាមព្រះសុគត។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់ចីវរក្នុងខណៈដែលបានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ។

[៣៩៦] ចីវរដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ចីវរដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ ចីវរដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ចីវរដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុបានចីវរដែលអ្នកដទៃធ្វើហើយ(យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៣៩៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុធ្វើចីវរថយចុះពីប្រមាណ១ ភិក្ខុបានចីវរដែលអ្នកដទៃធ្វើហើយ(យកមក)កាត់ចេញ ទើបប្រើប្រាស់១ ភិក្ខុធ្វើចីវរនោះឲ្យជាពិតានក្តី ជាកម្រាលផែនដីក្តី ជារនាំងក្តី ជាពូកក្តី ជាខ្នើយក្តី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១០ ចប់។

រតនវគ្គ ទី ៩ ចប់។

ឧទាននៃរតនវគ្គនោះ (មាន១០សិក្ខាបទ)គឺ

> រាជសិក្ខាបទ១ រតនសិក្ខាបទ១ សន្តសិក្ខាបទ១ សូចិសិក្ខាបទ១ មញ្ចសិក្ខាបទ១ តូលិកសិក្ខាបទ១ និសីទនសិក្ខាបទ១ កណ្ឌុសិក្ខាបទ១ វស្សិកសិក្ខាបទ១ សុគតសិក្ខាបទ១។

[៣៩៨] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាចិត្តិយទាំង៩២ ខ្ញុំបានសំដែងរួចហើយ។ ខ្ញុំសូមសួរអស់លោកដ៏មានអាយុក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយសុទ្ធតែជាអ្នកបរិសុទ្ធហើយ ក្នុងអាបត្តិទាំងនេះ ព្រោះហេតុនោះបានជាអស់លោកស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវសេចក្តីបរិសុទ្ធនេះ ដោយការស្ងៀមនៅយ៉ាងនេះឯង។

បាចិត្តិយកណ្ឌ ចប់។

# បាដិទេសនីយកណ្ឌ

CS vin.vbu.pd | ភាគ ទី៤

### (៦. បាដិទេសនីយកណ្ឌំ)

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាដិទេសនីយៈទាំង៤នេះ តែងមកកាន់ឧទ្ទេស។

## (បាដិទេសនីយ) សិក្ខាបទ ទី១

CS vin.vbu.pd.1 | ភាគ ទី៤

### (១. បឋមបាដិទេសនីយសិក្ខាបទំ)

[៣៩៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានភិក្ខុនី១រូបទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី កាលដែលត្រឡប់មកវិញ បានឃើញភិក្ខុ១រូប ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលចង្ហាន់សិន។ ភិក្ខុនោះតបថា នែនាង ប្រពៃហើយៗ ក៏ទទួលយកចង្ហាន់ទាំងអស់។ កាលបើវេលាជិត (ថ្ងៃត្រង់ហើយ) ភិក្ខុនីនោះក៏មិនអាចនឹងដើរទៅបិណ្ឌបាតបានឡើយ ក៏ដាច់ចង្ហាន់។ លុះគ្រាខាងក្រោយមក ភិក្ខុនីនោះទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី អស់ថ្ងៃជាគំរប់ពីរដងផង។ បេ។ អស់ថ្ងៃជាគំរប់បីដងផង ក្នុងវេលាដែលត្រឡប់មកវិញ ក៏បានឃើញភិក្ខុនោះទៀត ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលយកចង្ហាន់សិន។ ភិក្ខុនោះតបថា នែនាង ប្រពៃហើយៗ ក៏ទទួលយកចង្ហាន់ទាំងអស់។ កាលបើវេលាជិត(ថ្ងៃត្រង់ហើយ) ភិក្ខុនីនោះក៏មិនអាចនឹងដើរទៅបិណ្ឌបាតបានឡើយ ក៏ដាច់ចង្ហាន់។ លំដាប់នោះ លុះដល់ថ្ងៃទី៤ ភិក្ខុនីនោះក៏ធេងធោងដើរទៅតាមច្រក។ មានសេដ្ឋីគហបតីម្នាក់ កាលបររថមកដល់ផ្លូវប្រសព្វគ្នា ក៏បាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ លោកចូរចៀសចេញ។ ភិក្ខុនីនោះកាលចៀសចេញទៅ ក៏ដួលជិតកន្លែងនោះឯង។ សេដ្ឋីគហបតីក៏បានញ៉ាំងភិក្ខុនីនោះឲ្យអត់ទោសថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោស (ដ្បិត) លោកម្ចាស់ ខ្ញុំបានធ្វើឲ្យដួលហើយ។ ភិក្ខុនីនោះតបថា នែគហបតី ខ្លួនអាត្មា អ្នកឯងនឹងបានធ្វើឲ្យដួលក៏ទេ ខ្លួនអាត្មាជាស្រីមានកំលាំងអន់ស្រាប់ទេតើ។ សេដ្ឋីគហបតីសួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វីបានជាលោកមានកំលាំងអន់ថយ។ ខណៈនោះ ភិក្ខុនីនោះ ក៏បានប្រាប់សេចក្តីនុ៎ះដល់សេដ្ឋីគហបតី (ដោយសព្វគ្រប់)។ សេដ្ឋីគហបតីក៏បាននាំយកភិក្ខុនីនោះទៅឯផ្ទះឲ្យឆាន់ចង្ហាន់ រួចហើយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយមិនគួរនឹងទទួលអាមិសៈអំពីដៃភិក្ខុនីសោះ ដ្បិតមាតុគ្រាមតែងបានលាភដោយកម្រ។ កាលដែល

សេដ្ឋីគហបតីពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងទទួលយកអាមិសៈអំពីដៃភិក្ខុនីសោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងទទួលយកអាមិសៈអំពីដៃភិក្ខុនី ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា នែភិក្ខុ ភិក្ខុនីនោះត្រូវជាញាតិរបស់អ្នកដែរ ឬមិនត្រូវជាញាតិទេ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ភិក្ខុនីនោះមិនត្រូវជាញាតិទេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែមោឃបុរស បុគ្គលដែលមិនមែនជាញាតិ តែងមិនដឹងនូវអំពើសមគួរ ឬមិនសមគួរ អំពើល្អិតល្អ ឬមិនល្អិតល្អរបស់ស្រីដែលមិនមែនជាញាតិឡើយ នែមោឃបុរស អ្នកឯងមិនគួរនឹងទទួលយកអាមិសៈអំពីដៃភិក្ខុនីដែលមិនមែនជាញាតិទេ នែមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុណាមួយទទួលយកខាទនីយៈ ឬភោជនីយៈដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលមិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះ ហើយទំពាស៊ីក្តី បរិភោគក្តី ភិក្ខុនោះត្រូវសំដែងអាបត្តិបាដិទេសនីយៈថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិបាដិទេសនីយៈ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀលហើយ មិនជាទីសប្បាយ ឥឡូវខ្ញុំសូមសំដែងអាបត្តិនោះចេញ។**

[៤០០] ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ភិក្ខុនីដែលមិនបានជាប់ទាក់ទងគ្នាអំពីចំណែកខាងមាតា ឬបិតាដរាបតាំងពីគូនៃជីដូនជីតាទី៧ ហៅថាមិនមែនជាញាតិ។ ស្រីដែលបានឧបសម្បទាក្នុងសំណាក់សង្ឃទាំងពីរពួក ហៅថា ភិក្ខុនី។ ច្រករហូត(ក្តី) ច្រកទាល់(ក្តី) ទីប្រជុំផ្លូវមានជ្រុង៤ ឬមានជ្រុង៣(ក្តី) ផ្ទះរបស់ត្រកូល(ក្តី) ហៅថាចន្លោះផ្ទះ។ ដែលហៅថា ខាទនីយៈ គឺលើកលែងភោជនទាំង៥ និងរបស់ដែលជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ក្រៅពីនោះហៅថា ខាទនីយៈទាំងអស់។ ដែលហៅថា ភោជនីយៈនោះ គឺភោជនមាន៥យ៉ាង បានដល់បាយ១ នំកុម្មាស១ សដូវ១ ត្រី១ សាច់១។ ភិក្ខុទទួលយកខាទនីយៈ ឬភោជនីយៈ ដោយបំណងថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗវារៈដែលលេបចូលទៅ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនជាញាតិ ហើយទទួលយកខាទនីយៈ ឬភោជនីយៈដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្លោះផ្លូវ យកមកទំពាស៊ីក្តី បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុមានសេចក្តីសង្ស័យនឹងភិក្ខុនីដែលមិនមែនជាញាតិ ហើយទទួលយកខាទនីយៈ ឬភោជនីយៈដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្លោះផ្ទះ យកមកទំពាស៊ីក្តី បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថាជាញាតិ ហើយទទួលយកខាទនីយៈ ឬភោជនីយៈដោយដៃរបស់ខ្លួនអំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្លោះផ្ទះ យកមកទំពាស៊ីក្តី បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុទទួលយករបស់ដែលជាយាមកាលិក សត្តាហកាលិក និងរបស់ដែលជាយាវជីវិក ដើម្បីជាអាហារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗវារៈដែលលេបចូលទៅ។ ភិក្ខុទទួលយកខាទនីយៈ ឬភោជនីយៈអំពីដៃភិក្ខុនីដែលបានឧបសម្បទាក្នុងសំណាក់សង្ឃតែម្ខាង ដោយបំណងថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗវារៈដែលលេបចូលទៅ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិឡើយ។

[៤០១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១១យ៉ាង) គឺភិក្ខុនីជាញាតិ១ ភិក្ខុនីមិនមែនជាញាតិឲ្យគេឲ្យនូវខាទនីយៈ និងភោជនីយៈមិនបានឲ្យដោយខ្លួនឯង១ ភិក្ខុនីមិនមែនជាញាតិ បានដាក់ចុះនូវខាទនីយៈនិងភោជនីយៈហើយឲ្យ១ ភិក្ខុនីមិនមែនជាញាតិ បានឲ្យនូវខាទនីយៈនិងភោជនីយៈក្នុងលំនៅរបស់ភិក្ខុនីខាងក្នុងអារាម១ ភិក្ខុនីមិនមែនជាញាតិ បានឲ្យនូវខាទនីយៈនិងភោជនីយៈក្នុងដំណេករបស់តិរ្ថិយ១ ភិក្ខុនីមិនមែនជាញាតិ បាននាំយកខាទនីយៈនិងភោជនីយៈអំពីស្រុក ហើយឲ្យក្នុងវេលាដែលត្រឡប់មកវិញ១ ភិក្ខុនីបាននាំយករបស់ដែលជាយាមកាលិក សត្តាហកាលិក និងរបស់ដែលជាយាវជីវិក ឲ្យដោយពាក្យថា កាលបើហេតុមាន សូមលោកម្ចាស់និមន្តឆាន់ចុះ១ ភិក្ខុទទួលយកខាទនីយៈ និងភោជនីយៈអំពីដៃរបស់សិក្ខមានា១ ភិក្ខុទទួលយកខាទនីយៈនិងភោជនីយៈអំពីដៃសាមណេរី១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ១ ចប់។

## (បាដិទេសនីយ) សិក្ខាបទ ទី២

CS vin.vbu.pd.2 | ភាគ ទី៤

### (២. ទុតិយបាដិទេសនីយសិក្ខាបទំ)

[៤០២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវនជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ គ្រានោះឯង មានពួកភិក្ខុដែលគេបាននិមន្តមកឆាន់ក្នុងសំណាក់របស់ត្រកូលទាំងឡាយ។ ពួកឆព្វគ្គិយភិក្ខុនីទៅឈរបង្គាប់គេថា អ្នកទាំងឡាយចូរប្រគេនសម្លមកក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះដូច្នេះ ចំពោះឆព្វគ្គិយភិក្ខុទាំងឡាយ។ ឯពួកឆព្វគ្គិយភិក្ខុក៏បានឆាន់ដរាបទាល់តែឆ្អែត។ ពួកភិក្ខុឯទៀតក៏ឆាន់ចង្អាន់មិនបានបរិបូណ៌។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងមិនឃាត់ពួកភិក្ខុនីដែលជាអ្នកបង្គាប់គេសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយមិនបានឃាត់ពួកភិក្ខុនីដែលកំពុងបង្គាប់គេ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងមិនឃាត់ពួកភិក្ខុនីដែលកំពុងបង្គាប់គេទេ ម្នាលមោឃបុរសទាំងឡាយ អំពើ

នេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុទាំងឡាយដែលជនបាននិមន្តហើយ ឆាន់ក្នុងសំណាក់របស់ត្រកូលទាំងឡាយ។ បើមានភិក្ខុនីមកឈរបង្គាប់គេជិតទីនោះថា អ្នកទាំងឡាយចូរប្រគេនសម្លមកក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះ។ ភិក្ខុទាំងនោះត្រូវបណ្តេញភិក្ខុនីនោះថា នែនាង ៗចូរថយចេញទៅសិន ទម្រាំតែពួកភិក្ខុឆាន់រួចសព្វគ្រប់។ ភិក្ខុសូម្បី១រូប បើមិនបានពោលបណ្តេញភិក្ខុនីនោះដោយពាក្យថា នែនាង ៗចូរថយចេញទៅ ទម្រាំតែពួកភិក្ខុឆាន់រួចសព្វគ្រប់ ដូច្នេះសិនទេ ភិក្ខុទាំងនោះត្រូវសំដែងដោយពាក្យថា ម្នាលអាវុសោ យើងត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយៈ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល មិនជាទីសប្បាយចិត្ត ឥឡូវយើងសូមសំដែងអាបត្តិនោះចេញ។**

[៤០៣] ពាក្យថា ភិក្ខុទាំងឡាយដែលជនបាននិមន្តឆាន់ក្នុងសំណាក់របស់ត្រកូលទាំងឡាយ សេចក្តីថា ដែលហៅថា ត្រកូល បានដល់ត្រកូល៤ពួក គឺត្រកូលក្សត្រ១ ត្រកូលព្រាហ្មណ៍១ ត្រកូលឈ្មួញ១ ត្រកូលអ្នកគ្រួ១។ ពាក្យថា ដែលគេនិមន្តឆាន់ គឺភិក្ខុដែលពួកជនបាននិមន្តឆាន់ដោយភោជនទាំង៥ ភោជនណាមួយ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទាក្នុងសំណាក់សង្ឃទាំងពីរពួក។ ដែលហៅថាបង្គាប់ គឺភិក្ខុនីណាពោលថា អ្នកទាំងឡាយចូរប្រគេនសម្លមកក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះ តាមសមគួរដល់ភិក្ខុដែលជាមិត្ត ភិក្ខុដែលធ្លាប់ស្គាល់ ភិក្ខុដែលធ្លាប់ស្និទ្ធស្នាល ភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នា ភិក្ខុដែលមានអាចារ្យស្មើគ្នា ភិក្ខុនីនេះហៅថាជាអ្នកបង្គាប់។ ពាក្យថា ភិក្ខុទាំងនោះ គឺពួកភិក្ខុដែលកំពុងឆាន់ (នោះឯង)។ ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីដែលកំពុងបង្គាប់នោះឯង។ ភិក្ខុទាំងនោះ ត្រូវបណ្តេញភិក្ខុនីនោះដោយពាក្យថា នែនាង ៗចូរថយចេញទៅសិន ទម្រាំតែពួកភិក្ខុឆាន់រួចសព្វគ្រប់។ ភិក្ខុសូម្បី១រូប បើមិនបានបណ្តេញភិក្ខុនីទេ ហើយទទួលយកដោយគិតថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗវារៈដែលលេបចូលទៅ។

[៤០៤] ឧបសម្បន្នា[63] កំពុងបង្គាប់ ភិក្ខុដឹងច្បាស់ថា ឧបសម្បន្នាមែន តែមិនបានពោលហាម ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងឧបសម្បន្នាកំពុងបង្គាប់ ហើយមិនបានពោលហាម ត្រូវអាបត្តិបាដិទេសនីយៈ។ ឧបសម្បន្នាកំពុងបង្គាប់ ភិក្ខុមានសេចក្តីសំគាល់ថាអនុបសម្បន្នាទៅវិញ ហើយមិនបានពោលហាម ត្រូវអាបត្តិបាដិទេសនីយៈ។ ស្រីដែលបានឧបសម្បទាក្នុងសំណាក់ភិក្ខុនីសង្ឃតែម្ខាងកំពុងពោលបង្គាប់ ភិក្ខុមិនបានពោលហាម ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុសំគាល់ថាឧបសម្បនាទៅវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុសំគាល់ថាអនុបសម្បន្នាមែន មិនត្រូវអាបត្តិឡើយ។

[៤០៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១០យ៉ាង) គឺភិក្ខុនីបង្គាប់ទាយកឲ្យប្រគេនភត្តរបស់ខ្លួន មិនប្រគេនដោយខ្លួនឯង១ ភិក្ខុនីប្រគេនភត្តរបស់ពួកជនដទៃ មិនបានប្រើអ្នកដទៃឲ្យប្រគេន១ វត្ថុណាដែលទាយកមិនទាន់ប្រគេន ភិក្ខុនីក៏បង្គាប់គេឲ្យប្រគេនវត្ថុនោះ១ ទាយកមិនទាន់ប្រគេនក្នុងទីណា ភិក្ខុនីបង្គាប់គេឲ្យប្រគេនក្នុងទីនោះ១ ភិក្ខុនីបង្គាប់គេឲ្យប្រគេនភត្តដ៏ស្មើគ្នាដល់ពួកភិក្ខុទាំងពួង១ សិក្ខមានាពោលបង្គាប់១ សាមណេរីពោលបង្គាប់១ អាបត្តិមិនមានដល់ភិក្ខុ ព្រោះភោជនទាំងពួង វៀរលែងតែភោជន៥យ៉ាងចេញ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ២ ចប់។

## (បាដិទេសនីយ) សិក្ខាបទ ទី៣

CS vin.vbu.pd.3 | ភាគ ទី៤

### (៣. តតិយបាដិទេសនីយសិក្ខាបទំ)

[៤០៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ក្នុងក្រុងសាវត្ថី មានត្រកូល១មានសេចក្តីជ្រះថ្លាទាំងពីរនាក់[64] (ប្តីប្រពន្ធ) បានចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យសម្បត្តិ។ ខាទនីយៈ ឬភោជនីយៈណា ដែលកើតឡើងក្នុងត្រកូលនោះក្នុងវេលាមុនភត្ត ជនទាំងនោះជួនកាលខានបរិភោគខ្លួនឯង ព្រោះចាត់ចែងខាទនីយៈ ឬភោជនីយៈទាំងអស់នោះប្រគេនដល់ភិក្ខុទាំងឡាយ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្ត មិនគួរនឹងមិនស្គាល់ប្រមាណ ហើយទទួលយកសោះ ជនទាំងឡាយនេះបានប្រគេននូវខាទនីយៈ និងភោជនីយៈដល់ភិក្ខុទាំងនេះ ហើយជួនកាលខានបរិភោគខ្លួនឯង។ កាលពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ វេលានោះ ភិក្ខុទាំងនោះក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងគ្រានោះ ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ត្រកូលណាដែលចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យសម្បត្តិ តថាគតអនុញ្ញាតដើម្បីឲ្យៗនូវសេក្ខសម្មតិ គឺសម្មតិត្រកូលនោះថា ជាសេក្ខត្រកូល ដោយកម្មមានញត្តិជាគំរប់ពីរ ចំពោះត្រកូលបែបនេះចុះ ម្នាលភិក្ខុទាំងឡាយ (សេក្ខសម្មតិ) សង្ឃត្រូវឲ្យយ៉ាងនេះ។ ភិក្ខុ១រូបដែលជាអ្នកឈ្លាសប្រតិពល ត្រូវផ្តៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃសូមស្តាប់នូវពាក្យខ្ញុំ (ដ្បិត) ត្រកូលឈ្មោះនេះតែងចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យសម្បត្តិ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវសេក្ខសម្មតិដល់ត្រកូលឈ្មោះនេះចុះ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃសូមស្តាប់នូវពាក្យខ្ញុំ (ដ្បិត) ត្រកូលឈ្មោះនេះ ចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យ។ ឥឡូវសង្ឃឲ្យនូវសេក្ខសម្មតិដល់ត្រកូលឈ្មោះនេះ។ កិរិយាឲ្យនូវសេក្ខសម្មតិដល់ត្រកូលឈ្មោះនេះ បើសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម បើមិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ សេក្ខសម្មតិ សង្ឃបានឲ្យដល់ត្រកូលមានឈ្មោះនេះរួចស្រេចហើយ។ ការឲ្យសេក្ខសម្មតិសមគួរដល់សង្ឃ

ហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ត្រង់ហេតុដែលស្ងៀមនៅយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ពួកត្រកូលណាមួយដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ ភិក្ខុណាមួយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានឲ្យសេក្ខសម្មតិបែបនោះ ហើយទំពាស៊ីក្តី បរិភោគក្តី ភិក្ខុនោះត្រូវសំដែងថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិឈ្មោះបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ឥឡូវខ្ញុំសូមសំដែងនូវអាបត្តិនោះចេញ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ពួកភិក្ខុយ៉ាងនេះ។

[៤០៧] សម័យនោះឯង មហោស្រព (គេលេង) នៅក្រុងសាវត្ថី។ ពួកមនុស្ស គេបាននិមន្តភិក្ខុទាំងឡាយឲ្យឆាន់។ ចំណែកខាងត្រកូលនោះឯង ក៏បាននិមន្តភិក្ខុទាំងឡាយឲ្យ(ឆាន់ចង្ហាន់)។ ភិក្ខុទាំងឡាយនឹករង្កៀស មិនហ៊ានទទួលនិមន្ត ព្រោះគិតថា ការដែលទទួល យកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានសន្មតថាសេក្ខហើយ (យកមក)ទំពាស៊ី ឬបរិភោគ ព្រះដ៏មានព្រះភាគឃាត់ហើយ។ មនុស្សទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា យើងនឹងរស់នៅប្រយោជន៍អ្វី ដ្បិតលោកម្ចាស់ទាំងឡាយមិនហ៊ានទទួលយកខាទនីយៈភោជនីយៈរបស់យើង កាលមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ពួកភិក្ខុក៏បានឮច្បាស់។ វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យភិក្ខុដែលមានគេនិមន្ត ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូល ហើយ(យកមក) ទំពាស៊ី ឬបរិភោគបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ពួកត្រកូលណាមួយដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ ភិក្ខុណាមួយ ឥតមានគេនិមន្តក្នុងកាលមុន ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូល មានសភាពបែបនោះហើយ (យកមក) ទំពាស៊ីក្តី បរិភោគក្តី ភិក្ខុនោះត្រូវសំដែងថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងនូវអាបត្តិនោះចេញ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ។

[៤០៨] សម័យនោះឯង មានភិក្ខុ១រូប ជាជីតុនរបស់ត្រកូលនោះ។ លំដាប់នោះ ក្នុងវេលាព្រឹកព្រហាម ភិក្ខុនោះបានស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរ ដើរចូលទៅកាន់ត្រកូលនោះ លុះចូលទៅហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក។ វេលានោះ ភិក្ខុនោះជួនជាមានជម្ងឺផង។ គ្រានោះ មនុស្សទាំងឡាយ ក៏បាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ដ៏ចំរើន ចូរលោកម្ចាស់និមន្តឆាន់សិន។ វេលានោះ ភិក្ខុនោះនឹករង្កៀសថា ភិក្ខុដែលគេមិនបាននិមន្ត ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ (យកមក)ទំពាស៊ី ឬបរិភោគ ព្រះដ៏មានព្រះភាគហាមហើយ បានជាមិនហ៊ានទទួល ហើយមិនអាចដើម្បីដើរទៅបិណ្ឌបាតបាន ក៏អត់ចង្ហាន់។ វេលានោះ ភិក្ខុនោះត្រឡប់ទៅវត្តវិញ បានដំណាលប្រាប់រឿងនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជម្ងឺ ទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូល ហើយ(យកមក) ទំពាស៊ី ឬបរិភោគបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ពួកត្រកូលណាមួយដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ ភិក្ខុណាមួយ ឥតមានគេនិមន្តក្នុងកាលមុន ហើយឥតទាំងមានជម្ងឺ បានទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលបែបនោះហើយ (យកមក) ទំពាស៊ី ឬបរិភោគ ភិក្ខុនោះត្រូវសំដែងថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងអាបត្តិនោះចេញ។**

[៤០៩] ពាក្យថា ពួកត្រកូលណាមួយដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ សេចក្តីថា ត្រកូលណាដែលចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យសម្បត្តិ សង្ឃបានឲ្យសេក្ខសម្មតិដោយញត្តិទុតិយកម្មចំពោះត្រកូលបែបនេះ (ត្រកូលនោះ) ឈ្មោះថាសង្ឃបានសន្មតថាជាសេក្ខត្រកូល។ ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា អំពីពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលបែបនោះ គឺអំពីពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូល មានសភាពយ៉ាងនោះ។ ដែលហៅថា ឥតគេនិមន្ត គឺឥតគេនិមន្តដើម្បីឆាន់ក្នុងថ្ងៃនេះ ឬដើម្បីឆាន់ក្នុងថ្ងៃស្អែក ទោះបីភិក្ខុដើរទៅកាន់ឧបចាររបស់ផ្ទះ ទើបមានពួកជននិមន្ត ភិក្ខុនេះក៏ហៅថា ឥតមានគេនិមន្តដែរ។ ដែលហៅថា មានគេនិមន្ត គឺមានគេនិមន្តដើម្បីឆាន់ក្នុងថ្ងៃនេះ ឬដើម្បីឆាន់ក្នុងថ្ងៃស្អែក កាលភិក្ខុមិនទាន់បានដើរទៅកាន់ឧបចាររបស់ផ្ទះនៅឡើយ ស្រាប់តែមានពួកជននិមន្ត ភិក្ខុនេះហៅថា មានគេនិមន្ត។ ភិក្ខុណាដែលអាច ដើម្បីនឹងដើរទៅបិណ្ឌបាតបាន ភិក្ខុនោះហៅថា មិនមានជម្ងឺ។ ភិក្ខុណាដែលមិនអាចនឹងដើរទៅបិណ្ឌបាតបានទេ ភិក្ខុនោះហៅថា មានជម្ងឺ។ ដែលហៅថា ខាទនីយៈ គឺវៀរលែងតែភោជន៥យ៉ាង និង

របស់ជាយាមកាលិក សត្តាហកាលិក និងរបស់ជាយាវជីវិកចេញ ក្រៅពីនោះហៅថា ខាទនីយៈទាំងអស់។ ដែលហៅថា ភោជនីយៈ បានដល់ភោជន៥យ៉ាង គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១។ ភិក្ខុឥតមានគេនិមន្ត ឥតមានជម្ងឺ ទទួលយកនូវខាទនីយៈ ឬភោជនីយៈដោយគិតថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗវារៈដែលលេបចូលទៅ។

[៤១០] ត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខៈ ភិក្ខុសំគាល់ថា ត្រកូល សង្ឃបានសន្មតថាជាសេក្ខៈមែន ឥតមានគេនិមន្ត ឥតមានជម្ងឺ ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តីដោយដៃរបស់ខ្លួន (យកមក) ទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុសង្ស័យក្នុងត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខៈ ឥតមានគេនិមន្ត ឥតទាំងមានជម្ងឺ ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តីដោយដៃរបស់ខ្លួន (យកមក) ទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ។ ត្រកូលដែលសង្ឃសន្មតថាជាសេក្ខៈ ភិក្ខុសំគាល់ថាត្រកូលដែលសង្ឃមិនបានសន្មតជាសេក្ខៈ ឥតមានគេនិមន្ត ឥតទាំងមានជម្ងឺ ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តីដោយដៃរបស់ខ្លួន (យកមក) ទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុទទួលរបស់ជាយាមកាលិក សត្តាហកាលិក និងរបស់ជាយាវជីវិក ដើម្បីប្រយោជន៍ដល់អាហារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗវារៈដែលលេបចូលទៅ។ ត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈ ភិក្ខុសំគាល់ថាត្រកូល សង្ឃបានសន្មតជាសេក្ខៈវិញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈ ត្រូវអាបត្តិទុក្កដ។ ត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈ ភិក្ខុសំគាល់ថាត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈមែន មិនត្រូវអាបត្តិឡើយ។

[៤១១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១៣យ៉ាង) គឺភិក្ខុមានគេនិមន្ត១ ភិក្ខុមានជម្ងឺ១ ភិក្ខុឆាន់របស់ដែលសល់អំពីភិក្ខុដែលគេបាននិមន្ត ឬរបស់ដែលសល់អំពីភិក្ខុមានជម្ងឺ១ ចង្ហាន់ដែលគេបានតាក់តែងទុកក្នុងទីនោះចំពោះពួកភិក្ខុដទៃ១ ពួកជនបាននាំយកខាទនីយៈ ឬភោជនីយៈមកពីផ្ទះហើយប្រគេន១ ភិក្ខុទទួលឆាន់និច្ចភត្ត១ សលាកភត្ត១ បក្ខិកភត្ត១ ឧបោសថិកភត្ត១ បាដិបទិកភត្ត១ ជនបានប្រគេននូវរបស់ជាយាមកាលិក សត្តាហកាលិក និងរបស់ជាយាវជីវិកដោយវាចាថា កាលបើមានហេតុ និមន្តលោកម្ចាស់ឆាន់ចុះ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សិក្ខាបទ ទី ៣ ចប់។

## (បាដិទេសនីយ) សិក្ខាបទ ទី៤

CS vin.vbu.pd.4 | ភាគ ទី៤

### (៤. ចតុត្ថបាដិទេសនីយសិក្ខាបទំ)

[៤១២] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលគង់នៅនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ។ គ្រានោះឯង មានពួកទាសៈរបស់សាកិយជន ជាមនុស្សខូចកាច។ ពួកស្រីសាកិយៈប្រាថ្នាដើម្បីនឹងធ្វើនូវភត្ត (ប្រគេនពួកភិក្ខុដែលនៅ) ក្នុងទីសេនាសនៈដែលតាំងនៅក្នុងព្រៃ។ ពួកទាសៈរបស់សាកិយជនបានឮដំណឹងថា ឥឡូវ ឮថាពួកស្រីសាកិយៈមានសេចក្តីប្រាថ្នាដើម្បីនឹងធ្វើនូវភត្ត (ប្រគេនពួកភិក្ខុដែលនៅ) ក្នុងទីសេនាសនៈដែលតាំងនៅក្នុងព្រៃ។ ពួកទាសៈទាំងនោះនាំគ្នាទៅពួនសម្ងំចាំស្ទាក់ជិតផ្លូវ។ (លុះ) ពួកស្រីសាកិយៈនាំយកខាទនីយៈ និងភោជនីយៈដ៏ឧត្តមចេញដើរតម្រង់ទីសេនាសនៈ ដែលតាំងក្នុងព្រៃ ឯពួកទាសៈរបស់សាកិយៈជន ក៏ស្ទុះចេញទៅប្លន់ពួកស្រីសាកិយៈ ហើយប្រទូស្តថែមទៀតផង។ ពួកសាកិយជនក៏បានចេញទៅចាប់ពួកចោរទាំងនោះព្រមទាំងពស្តុតាង ហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា កាលពួកចោរវានៅជិតវត្ត លោកម្ចាស់ទាំងឡាយមិនគួរនឹងមិនប្រាប់ (យើងឲ្យដឹងផងសោះ)។ កាលពួកសាកិយជនពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះតថាគតនឹងបញ្ញត្តសិក្ខាបទដល់ពួកភិក្ខុព្រោះអាស្រ័យអំណាចប្រយោជន៍ទាំង១០យ៉ាង គឺដើម្បីជាការស្រួលដល់សង្ឃ។បេ។ ដើម្បីញុំាងព្រះសទ្ធម្មឲ្យឋិតថេរ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ទីសេនាសនៈទាំងឡាយណាដែលមាននៅក្នុងព្រៃ ដែលគេសន្មតថាទីប្រកបដោយរង្កៀស ប្រកបដោយភ័យចំពោះមុខ ភិក្ខុណាមួយនៅក្នុងទីសេនាសនៈទាំងឡាយមានសភាពដូច្នោះ ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឲ្យដំណឹងជាមុន ដោយដៃរបស់ខ្លួនខាងក្នុងអារាម (យកមក) ទំពាស៊ី ឬបរិភោគ ភិក្ខុនោះត្រូវសំដែងអាបត្តិថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងអាបត្តិនោះចេញ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ពួកភិក្ខុដោយន័យដូចបានពោលមកយ៉ាងនេះ។

[៤១៣] សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺនៅក្នុងទីសេនាសនៈទាំងឡាយដែលតាំងនៅក្នុងព្រៃ។ មនុស្សទាំងឡាយបាននាំយកខាទនីយភោជនីយាហារដើរសំដៅទៅត្រង់ទីសេនាសនៈដែលតាំងនៅក្នុងព្រៃ(នោះ)។ គ្រានោះឯង មនុស្សទាំងនោះក៏បាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ចូរនិមន្តឆាន់។ វេលានោះ ភិក្ខុនោះនឹករង្កៀសថា ការដែលភិក្ខុទទួលយកខាទនីយៈ ឬភោជនីយៈ ដោយដៃរបស់ខ្លួនក្នុងទីសេនាសនៈទាំងឡាយដែលតាំងនៅក្នុងព្រៃ (ហើយយកមក) ទំពាស៊ី ឬបរិភោគ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ហាមហើយ ក៏មិនហ៊ានទទួលយក ហើយមិនអាចនឹងទៅបិណ្ឌបាតបានឡើយ ក៏អត់ចង្ហាន់។ លុះគ្រាខាងក្រោយមក ភិក្ខុនោះបានដំណាលរឿងនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ

ភិក្ខុដែលមានជម្ងឺទទួលយកខាទនីយៈ ឬភោជនីយៈ ដោយដៃរបស់ខ្លួនក្នុងទីសេនាសនៈទាំងឡាយដែលតាំងនៅក្នុងព្រៃ (យកមក)ទំពាស៊ី ឬបរិភោគបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ទីសេនាសនៈទាំងឡាយណាមួយដែលមាននៅក្នុងព្រៃ ដែលគេសន្មតថាជាទីប្រកបដោយរង្កៀស ប្រកបដោយភ័យចំពោះមុខ ភិក្ខុណាមួយ ឥតមានជម្ងឺនៅក្នុងទីសេនាសនៈទាំងឡាយមានសភាពដូច្នោះ បានទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឲ្យដំណឹងជាមុន ដោយដៃរបស់ខ្លួនក្នុងអារាម (ហើយយកមក) ទំពាស៊ី ឬបរិភោគ ភិក្ខុនោះត្រូវសំដែងអាបត្តិថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងនូវអាបត្តិនោះចេញ។**

[៤១៤] ពាក្យថា ទីសេនាសនៈទាំងឡាយណាមួយដែលមាននៅក្នុងព្រៃ គឺទីសេនាសនៈយ៉ាងជិតបំផុតត្រឹម៥០០ជួរធ្នូអំពីស្រុក ហៅថា សេនាសនៈតាំងនៅក្នុងព្រៃ។ ដែលហៅថា ទីប្រកបដោយរង្កៀស គឺឱកាសជាទីនៅ ឱកាសសម្រាប់បរិភោគ ឱកាសសម្រាប់ឈរនៅ ឱកាសសម្រាប់អង្គុយនៅ ឱកាសសម្រាប់ដេកនៅ របស់ពួកចោរក៏ប្រាកដក្នុងអារាម ឬក្នុងឧបចារនៃអារាម។ ដែលហៅថា ទីប្រកបដោយភ័យចំពោះមុខ គឺមនុស្សទាំងឡាយដែលពួកចោរវាសម្លាប់ វាប្លន់ វាវាយ ឬសំពងក៏ប្រាកដក្នុងអារាម ឬឧបចាររបស់អារាម។ ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នា្ននឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ក្នុងទីសេនាសនៈទាំងឡាយមានសភាពដូច្នោះ គឺទីសេនាសនៈទាំងឡាយមានសភាពបែបនេះឯង។ ដែលហៅថា គេមិនបានឲ្យដំណឹង ទោះបីសហធម្មិកបុគ្គលទាំង៥ បានឲ្យដំណឹងហើយក្តី ការឲ្យដំណឹងនេះ ក៏គង់ហៅថា គេមិនបានឲ្យដំណឹងដដែល។ ការឲ្យដំណឹងក្នុងទីដទៃក្រៅពីអារាម ឬឧបចាររបស់អារាមក្តី ការឲ្យដំណឹងយ៉ាងនេះក៏ឈ្មោះថាគេមិនបានឲ្យដំណឹងដដែល។ ដែលហៅថា មានគេឲ្យដំណឹង គឺបុគ្គលណាមួយទោះស្រីក្តី ប្រុសក្តី មកកាន់អារាម ឬឧបចាររបស់អារាមប្រាប់ (ចំពោះភិក្ខុ) ថា បពិត្រលោកម្ចាស់ដ៏ចំរើន ត្រកូលឈ្មោះនេះគេនឹងនាំយកខាទនីយៈ ឬភោជនីយៈ (មកប្រគេន)។ បើទីប្រកបដោយរង្កៀស ភិក្ខុត្រូវប្រាប់ថា ទីប្រកបដោយរង្កៀស។ បើទីប្រកបដោយភ័យចំពោះមុខ ភិក្ខុត្រូវប្រាប់ថា ទីប្រកបដោយភ័យចំពោះមុខ។ បើទាយកនិយាយថា បពិត្រលោកម្ចាស់ដ៏ចំរើន សេចក្តីរង្កៀសក្តី សេចក្តីភ័យក្តី ក៏លើកទុកចុះ ជនមុខជានឹងនាំយកខាទនីយៈ ឬភោជនីយៈមកមិនខានទេ (នោះ) ភិក្ខុត្រូវនិយាយនឹងពួកចោរថា ដ្បិតមានពួកមនុស្ស គេនឹងចូលមកក្នុងទីនេះ អ្នកទាំងឡាយចូរថយចេញសិន។ កាលទាយកឲ្យដំណឹងថានឹងប្រគេនបបរ តែទាយកនោះត្រឡប់ជានាំយកបរិវាររបស់បបរនោះមកប្រគេនវិញ នេះហៅថា មានគេឲ្យដំណឹងដែរ។ កាលទាយកឲ្យដំណឹងថានឹងប្រគេនភត្ត តែទាយកនោះត្រឡប់ជានាំយកបរិវាររបស់ភត្តនោះប្រគេនវិញ នេះហៅថា មានគេឲ្យដំណឹងដែរ។ កាលបើទាយកបានឲ្យដំណឹងថានឹងប្រគេនខាទនីយៈ តែទាយកនោះត្រឡប់ជានាំយកបរិវាររបស់ខាទនីយៈនោះប្រគេនវិញ នេះក៏ហៅថា គេបានឲ្យដំណឹងដែរ។ កាលបើទាយកគេបានឲ្យដំណឹងថា ត្រកូលនោះនឹងប្រគេន មានពួកមនុស្សណាក្នុងត្រកូលនោះ គេនាំយកខាទនីយៈ ឬភោជនីយៈមកប្រគេន នេះក៏ហៅថា គេបានឲ្យដំណឹងដែរ។ កាលបើទាយកគេបានឲ្យដំណឹងថា អ្នកស្រុកគេនឹងប្រគេន មានពួកមនុស្សណាក្នុងស្រុកនោះគេនាំយកខាទនីយៈ ឬភោជនីយៈមកប្រគេន នេះក៏ហៅថា គេបានឲ្យដំណឹងដែរ។ កាលបើទាយកគេបានឲ្យដំណឹងថា ប្រជុំជនគេនឹងប្រគេន មានពួកមនុស្សណាក្នុងប្រជុំជននោះ គេនាំយកខាទនីយៈ ឬភោជនីយៈមកប្រគេន នេះក៏ហៅថាគេបានឲ្យដំណឹងដែរ។ ដែលហៅថា ខាទនីយៈ គឺវៀរលែងភោជនទាំង៥យ៉ាង និងរបស់ជាយាមកាលិក សត្តាហកាលិក និងយាវជីវិកចេញ ក្រៅពីនោះហៅថាខាទនីយៈទាំងអស់។ ដែលហៅថា ភោជនីយៈ បានដល់ភោជន៥យ៉ាង គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១។ ដែលហៅថា ខាងក្នុងអារាម គឺខាងក្នុងអារាមនៃអារាមដែលមានរបង ឬឧបចារនៃអារាមដែលឥតរបង។ ភិក្ខុណាដែលអាចនឹងដើរទៅបិណ្ឌបាតបាន ភិក្ខុនោះឈ្មោះថាគ្មានជម្ងឺ។ ភិក្ខុណាដែលមិនអាចនឹងដើរទៅបិណ្ឌបាតបានទេ ភិក្ខុនោះឈ្មោះថាមានជម្ងឺ។ ភិក្ខុមិនមានជម្ងឺទទួលយកខាទនីយៈ ឬភោជនីយៈដែលទាយកឥតឲ្យដំណឹង ដោយគិតថាអាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗវារៈដែលលេបចូលទៅ។

[៤១៥] ទាយកមិនបានឲ្យដំណឹង ភិក្ខុមិនមានជម្ងឺសំគាល់ថាទាយកមិនបានឲ្យដំណឹង ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តីដោយដៃរបស់ខ្លួនខាងក្នុងអារាម (យកមក) ទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុមិនមានជម្ងឺ មានសង្ស័យក្នុងរបស់ដែលទាយកមិនទាន់បានឲ្យដំណឹង ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តីដោយដៃរបស់ខ្លួនខាងក្នុងអារាម (យកមក) ទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ។ ទាយកមិនបានឲ្យដំណឹង ភិក្ខុមិនមានជម្ងឺសំគាល់ថាទាយកបានឲ្យដំណឹង ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តីដោយដៃរបស់ខ្លួនខាងក្នុងអារាម (យកមក) ទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុទទួលរបស់ជាយាមកាលិក សត្តាហកាលិក និងរបស់ជាយាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗវារៈដែលលេបចូលទៅ។ របស់ដែលទាយកបានឲ្យដំណឹងហើយ ភិក្ខុសំគាល់ថាគេមិនបានឲ្យដំណឹងទៅវិញ ត្រូវអាបត្តិទុក្កដ។ របស់ដែលទាយកបានឲ្យដំណឹងហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ របស់ដែលទាយកបានឲ្យដំណឹងហើយ ភិក្ខុសំគាល់ថាគេបានឲ្យដំណឹងមែន មិនត្រូវអាបត្តិឡើយ។

[៤១៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺរបស់ដែលទាយកបានឲ្យដំណឹង១ ភិក្ខុមានជម្ងឺ១ ភិក្ខុឆាន់ខាទនីយៈ ឬភោជនីយៈដែលសល់អំពីភិក្ខុដែលគេបានឲ្យដំណឹង ឬអំពីភិក្ខុមានជម្ងឺ១ ភិក្ខុទទួលយកខាទនីយៈ ឬភោជនីយៈពីខាងក្រៅអារាម (ហើយយកមក) ឆាន់ខាងក្នុងអារាម១ ភិក្ខុឆាន់មើមឈើក្តី សំបកឈើក្តី ស្លឹកឈើក្តី ផ្កាឈើក្តី ផ្លែឈើក្តី ដែលដុះនៅខាងក្នុងអារាមនោះ១ កាលបើមានហេតុ ភិក្ខុឆាន់របស់ជាយាមកាលិក សត្តាហកាលិក និងរបស់ជាយាវជីវិកបាន១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១[65] ។

[៤១៧] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាដិទេសនីយៈទាំង៤ ខ្ញុំបានសំដែងរួចហើយ។ ខ្ញុំសូមសួរអស់លោកដ៏មានអាយុក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងអាបត្តិទាំងនេះ ព្រោះហេតុនោះបានជាលោកស្ងៀមនៅ។ ខ្ញុំចាំទុកនូវសេចក្តីបរិសុទ្ធ ត្រង់ការស្ងៀមនៅនេះឯង។

បាដិទេសនីយកណ្ឌ ចប់ប៉ុណ្ណេះ។

# សេក្ខិយកណ្ឌ

CS vin.vbu.sk | ភាគ ទី៤

**(៧. សេខិយកណ្ឌំ)**

បពិត្រលោកដ៏មានអាយុទាំងឡាយ វត្ថុដែលគប្បីសិក្សាទាំងនេះ តែងមកកាន់ឧទ្ទេស។

## (សេក្ខិយ) បរិមណ្ឌលវគ្គ (ទី១)

CS vin.vbu.sk.v1 | ភាគ ទី៤

**(១. បរិមណ្ឌលវគ្គោ)**

**សារុប្ប មាន២៦**

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី១)

CS vin.vbu.sk.01 | ភាគ ទី៤

**(បឋមសិក្ខាបទំ)**

[៤១៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលសម្រេចឥរិយាបថនៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកស្បង់ឲ្យស្លយមុខខ្លះ ស្លយក្រោយខ្លះ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាសក្យបុត្រ មិនសមបើនឹងស្លៀកស្បង់ឲ្យស្លយមុខខ្លះ ស្លយក្រោយខ្លះ ដូចជាពួកគ្រហស្ថដែលជាអ្នកបរិភោគកាមសោះ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា គួរបើដែរ ពួកឆព្វគ្គិយភិក្ខុហ៊ានស្លៀកស្បង់ឲ្យស្លយមុខខ្លះ ស្លយក្រោយខ្លះ។ ខណៈនោះ ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរចំពោះទៅពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយស្លៀកស្បង់ឲ្យស្លយមុខខ្លះ ស្លយក្រោយខ្លះ ពិតមែនឬ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានជោគទ្រង់ត្រាស់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងស្លៀកស្បង់ឲ្យស្លយមុខខ្លះ ស្លយក្រោយខ្លះទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះ នឹងបាននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំឲ្យរឹងរឹតតែជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លារួចហើយក៏ទេដែរ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងស្លៀក(ស្បង់)ឲ្យជាបរិមណ្ឌល។**

ភិក្ខុត្រូវស្លៀកឲ្យជាបរិមណ្ឌល គឺបិទបាំងមណ្ឌលផ្ចិត[66] មណ្ឌលជង្គង់។[67] ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយស្លៀកឲ្យស្លយមុខ ឬស្លយក្រោយ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី២)

CS vin.vbu.sk.02 | ភាគ ទី៤

**(ទុតិយសិក្ខាបទំ)**

[៤១៩] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដណ្ដប់(ចីពរ) ស្លយមុខខ្លះ ស្លយក្រោយខ្លះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងដណ្ដប់ (ចីពរ) ឲ្យជាបរិមណ្ឌល។**

ភិក្ខុគប្បីដណ្ដប់ឲ្យជាបរិមណ្ឌលគឺ ធ្វើនូវជាយទាំងពីរឲ្យត្រឹមស្មើគ្នា។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ដណ្ដប់(ចីពរ)ឲ្យស្លយមុខខ្លះ ស្លយក្រោយខ្លះ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី៣)

CS vin.vbu.sk.03 | ភាគ ទី៤

### (តតិយសិក្ខាបទំ)

[៤២០] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយបើកចំហនូវកាយ[68] ហើយដើរទៅក្នុងចន្លោះផ្ទះ (គឺក្នុងស្រុក)។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងបិទបាំងឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុត្រូវបិទបាំង[69] ឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយបើកចំហកាយ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី៤)

CS vin.vbu.sk.04 | ភាគ ទី៤

### (ចតុត្ថសិក្ខាបទំ)

[៤២១] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយបើកចំហកាយអង្គុយក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងបិទបាំង(កាយ)ឲ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុត្រូវបិទបាំង[70] ឲ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយបើកចំហកាយអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុដែលចូលទៅកាន់លំនៅ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី៥)

CS vin.vbu.sk.05 | ភាគ ទី៤

### (បញ្ចមសិក្ខាបទំ)

[៤២២] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយវាសដៃខ្លះ វាសជើងខ្លះ ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងសង្រួមឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុត្រូវតែសង្រួមឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយគ្រវាត់គ្រវែងដៃខ្លះ ជើងខ្លះ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី៦)

CS vin.vbu.sk.06 | ភាគ ទី៤

### (ឆដ្ឋសិក្ខាបទំ)

[៤២៣] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយវាសដៃខ្លះ វាសជើងខ្លះ អង្គុយក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងសង្រួមដោយល្អអង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុត្រូវតែសង្រួមឲ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយវាសដៃ ឬវាសជើងអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី៧)

CS vin.vbu.sk.07 | ភាគ ទី៤

### (សត្តមសិក្ខាបទំ)

[៤២៤] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុក្រឡេកមើលត្រង់ទីនោះៗ ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមានភ្នែកសំឡឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុត្រូវតែមានភ្នែកសំឡឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ ក្រឡេកមើលត្រឹមតែមួយជួរនឹម។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយក្រឡេកមើលត្រង់ទីនោះៗ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី៨)

CS vin.vbu.sk.08 | ភាគ ទី៤

### (អដ្ឋមសិក្ខាបទំ)

[៤២៥] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុក្រឡេកមើលត្រង់ទីនោះៗ អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមានភ្នែកសំឡឹងចុះ អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុត្រូវតែមានភ្នែកសំឡឹងចុះត្រឹមមួយជួរនឹម អង្គុយនៅក្នុងចន្លោះផ្ទះ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយក្រឡេកមើលត្រង់ទីនោះៗ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី៩)

CS vin.vbu.sk.09 | ភាគ ទី៤

### (នវមសិក្ខាបទំ)

[៤២៦] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនបានសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយសើយចីវរខាងម្ខាង ឬទាំងពីរខាង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

### (សេក្ខិយ បរិមណ្ឌលវគ្គ សិក្ខាបទ ទី១០)

CS vin.vbu.sk.10 | ភាគ ទី៤

#### (ទសមសិក្ខាបទំ)

[៤២៧] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយសើយចីវរ អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសើយចីវរ អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវសើយចីវរ អង្គុយនៅក្នុងចន្លោះផ្ទះទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយសើយចីវរខាងម្ខាង ឬទាំងពីរខាង អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុដែលចូលទៅក្នុងអាវាស១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

បរិមណ្ឌលវគ្គជាបឋម ចប់។

## (សេក្ខិយ) ឧជ្ជគ្ឃិកវគ្គ (ទី២)

CS vin.vbu.sk.v2 | ភាគ ទី៤

#### (២. ឧជ្ជគ្ឃិកវគ្គោ)

### (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី១ (១១))

CS vin.vbu.sk.11 | ភាគ ទី៤

#### (បឋមសិក្ខាបទំ)

[៤២៨] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុគ្រាន់តែធ្វើញញឹមក្នុងវត្ថុដែលគួរញញឹម១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

### (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី២ (១២))

CS vin.vbu.sk.12 | ភាគ ទី៤

#### (ទុតិយសិក្ខាបទំ)

[៤២៩] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះឡើយ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុគ្រាន់តែធ្វើញញឹមក្នុងវត្ថុដែលគួរញញឹម១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី៣ (១៣))

CS vin.vbu.sk.13 | ភាគ ទី៤

### (តតិយសិក្ខាបទំ)

[៤៣០] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើនូវសំឡេងហ៊ោ សំឡេងឮដ៏ខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងនិយាយសំដីតិច ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុត្រូវមានសំឡេងតិច ដើរទៅក្នុងចន្លោះផ្ទះ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវសំឡេងហ៊ោ សំឡេងឮខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី៤ (១៤))

CS vin.vbu.sk.14 | ភាគ ទី៤

### (ចតុត្ថសិក្ខាបទំ)

[៤៣១] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើនូវសំឡេងហ៊ោ សំឡេងឮដ៏ខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងនិយាយសំដីតិច អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុត្រូវតែមានសំឡេងតិច អង្គុយនៅក្នុងចន្លោះផ្ទះ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវសំឡេងហ៊ោ សំឡេងឮដ៏ខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី៥ (១៥))

CS vin.vbu.sk.15 | ភាគ ទី៤

### (បញ្ចមសិក្ខាបទំ)

[៤៣២] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគ្រលែងកាយ យោលកាយ ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនគ្រលែងកាយ ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវធ្វើកាយឲ្យគ្រលែង ដើរទៅក្នុងចន្លោះផ្ទះទេ ត្រូវផ្គត់ផ្គង់កាយដើរទៅ (ក្នុងចន្លោះផ្ទះ)។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយគ្រលែងកាយ យោលកាយ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី៦ (១៦))

CS vin.vbu.sk.16 | ភាគ ទី៤

### (ឆដ្ឋសិក្ខាបទំ)

[៤៣៣] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយគ្រលែងកាយ យោលកាយ អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនគ្រលែងកាយ អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវគ្រលែងកាយ អង្គុយនៅក្នុងចន្លោះផ្ទះទេ ត្រូវតែផ្គត់ផ្គង់កាយ ហើយអង្គុយនៅ (ក្នុងចន្លោះផ្ទះ)។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឃ្លោងកាយ យោលកាយ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុដែលចូលទៅកាន់ទីនៅ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី៧ (១៧))

CS vin.vbu.sk.17 | ភាគ ទី៤

### (សត្តមសិក្ខាបទំ)

[៤៣៤] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយបង់បោយ វាសដៃ ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនបង់បោយ ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវបង់បោយ ដើរទៅក្នុងចន្លោះផ្ទះទេ ត្រូវដាក់ដៃឲ្យស្រួល ដើរទៅ (ក្នុងចន្លោះផ្ទះ)។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយបង់បោយ វាសដៃ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី៨ (១៨))

CS vin.vbu.sk.18 | ភាគ ទី៤

### (អដ្ឋមសិក្ខាបទំ)

[៤៣៥] សាវត្ថីនិទាន។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយឆ្កាដៃ វាសដៃ អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆ្កាដៃ អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវឆ្កាដៃ អង្គុយនៅក្នុងចន្លោះផ្ទះទេ ត្រូវដាក់ដៃឲ្យស្រួល អង្គុយនៅ ក្នុងចន្លោះផ្ទះ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆ្កាដៃ វាសដៃ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុចូលទៅកាន់ទីនៅ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី៩ (១៩))

CS vin.vbu.sk.19 | ភាគ ទី៤

### (នវមសិក្ខាបទំ)

[៤៣៦] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគ្រលែងក្បាល រេក្បាល ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនបានគ្រលែងក្បាល ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវគ្រលែងក្បាល ដើរទៅក្នុងចន្លោះផ្ទះទេ ត្រូវតែផ្គង់តម្រង់ក្បាលឲ្យស្រួល ដើរទៅ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ គ្រលែងក្បាល រេក្បាល ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានសតិ១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ឧជ្ជគ្ឃិកវគ្គ សិក្ខាបទ ទី១០ (២០))

CS vin.vbu.sk.20 | ភាគ ទី៤

### (ទសមសិក្ខាបទំ)

[៤៣៧] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគ្រលែងក្បាល វេក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនគ្រលែងក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវគ្រលែងក្បាល អង្គុយនៅក្នុងចន្លោះផ្ទះទេ ត្រូវតែផ្គង់តម្រង់ក្បាលឲ្យស្រួល អង្គុយនៅ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយគ្រលែងក្បាល វេក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុចូលទៅកាន់ទីនៅ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

ឧជ្ជគ្ឃិកវគ្គ ទី ២ ចប់។

# (សេក្ខិយ) ខម្ភកតវគ្គ (ទី៣)

CS vin.vbu.sk.v3 | ភាគ ទី៤

### (៣. ខម្ភកតវគ្គោ)

## (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី១ (២១))

CS vin.vbu.sk.21 | ភាគ ទី៤

### (បឋមសិក្ខាបទំ)

[៤៣៨] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ (យកដៃ) ស្ទឹមចង្កេះ ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិន (យកដៃ) ស្ទឹមចង្កេះ ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវស្ទឹមចង្កេះ ដើរទៅក្នុងចន្លោះផ្ទះទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវកិរិយាស្ទឹមចង្កេះតែម្ខាងក្តី ទាំងពីរខាងក្តី ហើយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី២ (២២))

CS vin.vbu.sk.22 | ភាគ ទី៤

### (ទុតិយសិក្ខាបទំ)

[៤៣៩] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ (យកដៃ) ស្ទឹមចង្កេះ អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិន (យកដៃ) ស្ទឹមចង្កេះ អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវ(យកដៃ)ស្ទឹមចង្កេះ ហើយអង្គុយនៅក្នុងចន្លោះផ្ទះទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវកិរិយាស្ទឹមចង្កេះតែម្ខាងក្តី ទាំងពីរខាងក្តី អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុចូលទៅកាន់ទីនៅ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី៣ (២៣))

CS vin.vbu.sk.23 | ភាគ ទី៤

### (តតិយសិក្ខាបទំ)

[៤៤០] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះឡើយ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុគ្មានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី៤ (២៤))

CS vin.vbu.sk.24 | ភាគ ទី៤

### (ចតុត្ថសិក្ខាបទំ)

[៤៤១] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុចូលទៅកាន់ទីនៅ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី៥ (២៥))

CS vin.vbu.sk.25 | ភាគ ទី៤

### (បញ្ចមសិក្ខាបទំ)

[៤៤២] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដើរចំអើតជើង ទៅក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនចំអើតជើង ហើយដើរទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវចំអើតជើង ដើរទៅក្នុងចន្លោះផ្ទះទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយដើរចំអើតជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុចូលទៅកាន់ទីនៅ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី៦ (២៦))

CS vin.vbu.sk.26 | ភាគ ទី៤

### (ឆដ្ឋសិក្ខាបទំ)

[៤៤៣] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុអង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនអង្គុយត្របោមក្បាលជង្គង់ ក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវអង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះឡើយ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ អង្គុយត្របោមក្បាលជង្គង់ដោយដៃក្តី ត្របោមដោយរឹតនឹងសំពត់ក្តី ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុចូលទៅកាន់ទីនៅ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## ភោជនប្បដិសំយុត្ត

CS vin.vbu.sk.v3.1 | ភាគ ទី៤

(-)

**មាន ៣០ សិក្ខាបទ**

### (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី៧ (២៧))

CS vin.vbu.sk.27 | ភាគ ទី៤

**(សត្តមសិក្ខាបទំ)**

[៤៤៤] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទួលអាហារបិណ្ឌបាតមិនគោរព ធ្វើដូចជាមានសេចក្តីប្រាថ្នានឹងចាក់ចោល។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងទទួលអាហារបិណ្ឌបាតដោយគោរព។**

ភិក្ខុត្រូវទទួលអាហារបិណ្ឌបាតដោយគោរព។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយទទួលអាហារបិណ្ឌបាតមិនគោរព ធ្វើដូចជាមានសេចក្តីប្រាថ្នានឹងចាក់ចោល ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

### (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី៨ (២៨))

CS vin.vbu.sk.28 | ភាគ ទី៤

**(អដ្ឋមសិក្ខាបទំ)**

[៤៤៥] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំឡឹងមើលទៅក្នុងទីនោះៗ ទទួលបិណ្ឌបាត កាលបើមានជនកំពុងដាក់បាត្រក្តី ដាក់រួចហើយដើរទៅក្តី ក៏មិនបានដឹងសោះ (ព្រោះមិនសង្រួមរវល់តែមើលទៅទីផ្តេសផ្តាស)។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងសំគាល់ក្នុងបាត្រ ហើយទទួលបិណ្ឌបាត។**

ភិក្ខុត្រូវសំគាល់ក្នុងបាត្រ ហើយទទួលបិណ្ឌបាត។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំឡឹងមើលទៅក្នុងទីនោះៗ ទទួលបិណ្ឌបាត ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

### (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី៩ (២៩))

CS vin.vbu.sk.29 | ភាគ ទី៤

**(នវមសិក្ខាបទំ)**

[៤៤៦] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលទទួលបិណ្ឌបាត ទទួលយកសម្លច្រើនជាង។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងទទួលបិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល។**[71)]

ដែលហៅថា សម្ល បានដល់សម្លពីរយ៉ាង គឺសម្លសណ្តែកបាយ១ សម្លសណ្តែករាជមាស១ ដែលគួរជននឹងនាំទៅដោយដៃបាន។ ភិក្ខុត្រូវទទួលបិណ្ឌបាតល្មមគ្នានឹងសម្ល។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយទទួលយកសម្លច្រើនជាង ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១២យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ សម្លមានរសដ៏ក្រៃលែង១[72] ភិក្ខុទទួលយករបស់ជនជាញាតិ១ របស់ជនដែលបានបវារណា១ ភិក្ខុទទួលយកដើម្បីប្រយោជន៍ដល់អ្នកដទៃ១ ភិក្ខុទទួលយកដោយទ្រព្យរបស់ខ្លួន១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ ខម្ភកតវគ្គ សិក្ខាបទ ទី១០ (៣០))

CS vin.vbu.sk.30 | ភាគ ទី៤

### (ទសមសិក្ខាបទំ)

[៤៤៧] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទួលបិណ្ឌបាតពេញកំពុងបាត្រ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងទទួលបិណ្ឌបាតឲ្យស្មើត្រឹមកណ្តាប់មាត់បាត្រ។**

ភិក្ខុត្រូវទទួលបិណ្ឌបាតឲ្យពេញស្មើត្រឹមកណ្តាប់មាត់បាត្រ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយទទួលបិណ្ឌបាតឲ្យកំពុងលើសកណ្តាប់មាត់បាត្រទៅ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

ខម្ភកតវគ្គ ទី ៣ ចប់។

# (សេក្ខិយ) សក្កច្ចវគ្គ (ទី៤)

CS vin.vbu.sk.v4 | ភាគ ទី៤

### (៤. សក្កច្ចវគ្គោ)

## (សេក្ខិយ សក្កច្ចវគ្គ សិក្ខាបទ ទី១ (៣១))

CS vin.vbu.sk.31 | ភាគ ទី៤

### (បឋមសិក្ខាបទំ)

[៤៤៨] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់បិណ្ឌបាតមិនគោរព ធ្វើដូចជាមិនចង់ឆាន់។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងឆាន់បិណ្ឌបាតដោយគោរព។**

ភិក្ខុត្រូវឆាន់បិណ្ឌបាតដោយគោរព។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់បិណ្ឌបាតមិនគោរព ធ្វើហាក់ដូចជាមិនចង់ឆាន់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សក្កច្ចវគ្គ សិក្ខាបទ ទី២ (៣២))

CS vin.vbu.sk.32 | ភាគ ទី៤

### (ទុតិយសិក្ខាបទំ)

[៤៤៩] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបែរមើលទៅទីនោះៗឆាន់បិណ្ឌបាត កាលបើទាយកកំពុងអង្គាសក្តី អង្គាសរួចហើយចេញដើរទៅក្តី ក៏មិនដឹងអ្វីឡើយ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងសំគាល់តែក្នុងបាត្រឆាន់បិណ្ឌបាត។**

ភិក្ខុត្រូវសំគាល់តែក្នុងបាត្រ ហើយឆាន់បិណ្ឌបាត។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ សំឡឹងមើលទៅទីនោះៗ ឆាន់បិណ្ឌបាតបណ្ដើរ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សក្កច្ចវគ្គ សិក្ខាបទ ទី៣ (៣៣))

CS vin.vbu.sk.33 | ភាគ ទី៤

### (តតិយសិក្ខាបទំ)

[៤៥០] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកកាយបាយឲ្យខូងក្នុងទីនោះៗ ឆាន់បិណ្ឌបាត។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងឆាន់បិណ្ឌបាតវាចឲ្យស្មើ។**

ភិក្ខុត្រូវឆាន់បិណ្ឌបាតវាចឲ្យស្មើ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ កកាយបាយឲ្យខូងក្នុងទីនោះៗ ឆាន់បិណ្ឌបាត ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១០យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុកកាយបិណ្ឌបាតឲ្យខូងឲ្យដល់ពួកជនដទៃ១ ភិក្ខុកកាយបិណ្ឌបាតឲ្យខូងរោយរាយចុះក្នុងភាជនដទៃ១ ភិក្ខុកកាយសម្លឧត្តរិភង្គ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សក្កច្ចវគ្គ សិក្ខាបទ ទី៤ (៣៤))

CS vin.vbu.sk.34 | ភាគ ទី៤

### (ចតុត្ថសិក្ខាបទំ)

[៤៥១] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាលឆាន់បិណ្ឌបាត ក៏ឆាន់សម្លច្រើនជាង។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងឆាន់បិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល។**

ដែលហៅថា សម្ល បានដល់សម្លពីរយ៉ាង គឺសម្លសណ្ដែកបាយ១ សម្លសណ្ដែករាជមាស១ ដែលជនគួរនឹងនាំទៅដោយដៃបាន។ ភិក្ខុត្រូវឆាន់បិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់សម្លឲ្យច្រើនជាង ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១២យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ សម្លមានរសដ៏ក្រៃលែង១ ភិក្ខុឆាន់សម្លរបស់ញាតិ១ ភិក្ខុឆាន់សម្លរបស់ជនដែលបានបវារណា១ ភិក្ខុឆាន់សម្លដើម្បីជាប្រយោជន៍ដល់ជនដទៃ[73)] ១ ភិក្ខុឆាន់សម្លដែលបានមកដោយទ្រព្យរបស់ខ្លួន១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សក្កច្ចវគ្គ សិក្ខាបទ ទី៥ (៣៥))

CS vin.vbu.sk.35 | ភាគ ទី៤

### (បញ្ចមសិក្ខាបទំ)

[៤៥២] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុច្រមត្រង់កំពូលបាយ ហើយឆាន់បិណ្ឌបាត។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនបានច្រមត្រង់កំពូលបាយ ហើយឆាន់បិណ្ឌបាត។**

ភិក្ខុមិនត្រូវច្រមត្រង់កំពូលបាយ ហើយឆាន់បិណ្ឌបាតទេ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ច្រមត្រង់កំពូលបាយ ហើយឆាន់បិណ្ឌបាត ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុប្រមូលបិណ្ឌបាតដែលសេសសល់បន្តិចបន្តួច ឲ្យមូលជាមួយគ្នា ហើយច្រមឆាន់១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេខិយ សក្កច្ចវគ្គ សិក្ខាបទ ទី៦ (៣៦))

CS vin.vbu.sk.36 | ភាគ ទី៤

### (ឆដ្ឋសិក្ខាបទំ)

[៤៥៣] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកកាយបាយលុបសម្លខ្លះ ម្ហូបខ្លះ ព្រោះអាស្រ័យសេចក្តីល្មោភច្រើន។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនកកាយបាយលុបសម្ល ឬម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើន។**

ភិក្ខុមិនត្រូវកកាយបាយលុបសម្ល ឬម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើនទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយកកាយបាយលុបសម្ល ឬម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើន ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ពួកជនជាម្ចាស់របស់គេលុបសម្ល ឬម្ហូប ហើយប្រគេន១ ភិក្ខុមិនអាស្រ័យសេចក្តីល្មោភច្រើន១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេខិយ សក្កច្ចវគ្គ សិក្ខាបទ ទី៧ (៣៧))

CS vin.vbu.sk.37 | ភាគ ទី៤

### (សត្តមសិក្ខាបទំ)

[៤៥៤] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសូមសម្លខ្លះ បាយខ្លះ ដើម្បីប្រយោជន៍ខ្លួនឯង ហើយឆាន់។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្ត មិនសមបើនឹងហ៊ានសូមសម្លខ្លះ បាយខ្លះ ដើម្បីប្រយោជន៍ខ្លួនឯង ហើយឆាន់សោះ អ្នកណាហើយដែលមិនគាប់ចិត្តនឹងអាហារដ៏បរិបូណ៌ អ្នកណាហើយដែលមិនគាប់ចិត្តនឹងអាហារដែលមានរសឆ្ងាញ់។ ពួកភិក្ខុបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងហ៊ានសូមសម្លខ្លះ បាយខ្លះ ដើម្បីប្រយោជន៍ខ្លួនឯង ហើយឆាន់សោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយសូមសម្លខ្លះ បាយខ្លះ ដើម្បីប្រយោជន៍ខ្លួន ហើយឆាន់ ពិតមែនឬ។ ភិក្ខុទាំងនោះក៏ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរបើនឹងហ៊ានសូមសម្លខ្លះ បាយខ្លះ ដើម្បីប្រយោជន៍ខ្លួន ហើយឆាន់សោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ នឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសូមសម្ល ឬបាយ ដើម្បីប្រយោជន៍ខ្លួនឯង ហើយឆាន់ទេ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ពួកភិក្ខុយ៉ាងនេះ។

[៤៥៥] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺ។ ឯពួកភិក្ខុអ្នកសួរជម្ងឺបានពោលពាក្យនេះនឹងភិក្ខុដែលមានជម្ងឺថា ម្នាលអាវុសោ អ្នកទាំងឡាយល្មមអត់ធន់បានឬទេ អ្នកទាំងឡាយល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលអាវុសោ ពីដើម យើងតែងសូមសម្លខ្លះ បាយខ្លះ ដើម្បីប្រយោជន៍ខ្លួនឯង ហើយឆាន់ ហេតុនោះបានជាយើងសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់ហើយ ពួកយើងមានសេចក្តីរង្កៀស ដូច្នេះ បានជាមិនហ៊ានសូមគេ ហេតុនោះបានជាយើងមិនសប្បាយ។ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យភិក្ខុដែលមានជម្ងឺសូមសម្លក្តី បាយក្តី ដើម្បីប្រយោជន៍ខ្លួន ហើយឆាន់បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុគួរធ្វើសេចក្តីសិក្សាថា អញឥតមានជម្ងឺ នឹងមិនបានសូមសម្ល ឬបាយ ដើម្បីប្រយោជន៍ខ្លួន ហើយឆាន់។**

ភិក្ខុឥតមានជម្ងឺ មិនត្រូវសូមសម្ល ឬបាយ ដើម្បីប្រយោជន៍ខ្លួន ហើយឆាន់ទេ។ ភិក្ខុណាឥតមានជម្ងឺ អាស្រ័យសេចក្តីមិនអើពើ សូមសម្ល ឬបាយ ដើម្បីប្រយោជន៍ខ្លួន ហើយឆាន់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១១យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុសូមក្នុងសំណាក់ញាតិ១ ភិក្ខុសូមក្នុងសំណាក់ជនដែលបានបវារណា១ ភិក្ខុសូមដើម្បីប្រយោជន៍អ្នកដទៃ១ ភិក្ខុបាន់មកដោយទ្រព្យរបស់ខ្លួន១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សក្កច្ចវគ្គ សិក្ខាបទ ទី៨ (៣៨))

CS vin.vbu.sk.38 | ភាគ ទី៤

### (អដ្ឋមសិក្ខាបទំ)

[៤៥៦] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រុងនឹងលើកទោស ហើយសំឡឹងមើលបាត្រពួកភិក្ខុដទៃ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនប្រុងលើកទោស ហើយសំឡឹងមើលបាត្រពួកភិក្ខុដទៃ។**

ភិក្ខុមិនត្រូវសំឡឹងមើលបាត្រពួកភិក្ខុដទៃ ដោយប្រុងនឹងលើលទោសទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយប្រុងនឹងលើកទោស ក៏សំឡឹងមើលបាត្រពួកភិក្ខុឯទៀត ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុសំឡឹងមើលដោយគិតថា អញនឹងឲ្យ ឬអញនឹងប្រើគេឲ្យឲ្យ១ ភិក្ខុមិនបានប្រុងនឹងលើកទោស ហើយសំឡឹងមើល១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សក្កច្ចវគ្គ សិក្ខាបទ ទី៩ (៣៩))

CS vin.vbu.sk.39 | ភាគ ទី៤

### (នវមសិក្ខាបទំ)

[៤៥៧] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើពំនូតបាយធំពេក។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនធ្វើពំនូតបាយឲ្យធំពេក។**

ភិក្ខុមិនត្រូវធ្វើពំនូតបាយឲ្យធំពេកទេ។[74] ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើពំនូតបាយឲ្យធំពេក ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១០យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុឆាន់បង្អែម១ ផ្លែឈើតូចធំ១ សម្លឧត្តរិភង្គ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សក្កច្ចវគ្គ សិក្ខាបទ ទី១០ (៤០))

CS vin.vbu.sk.40 | ភាគ ទី៤

### (ទសមសិក្ខាបទំ)

[៤៥៨] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើពំនូតបាយវែងពេក ហើយឆាន់។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងធ្វើពំនូតបាយឲ្យជាបរិមណ្ឌល គឺឲ្យមូល។**

ភិក្ខុត្រូវធ្វើពំនូតបាយឲ្យជាបរិមណ្ឌល។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើពំនូតបាយឲ្យវែង ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១០យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុឆាន់បង្អែម១ ផ្លែឈើតូចធំ១ សម្លឧត្តរិភង្គ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សក្កច្ចវគ្គ ទី ៤ ចប់។

# (សេក្ខិយ) កពឡវគ្គ (ទី៥)

CS vin.vbu.sk.v5 | ភាគ ទី៤

### (៥. កពឡវគ្គោ)

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី១ (៤១))

CS vin.vbu.sk.41 | ភាគ ទី៤

### (បឋមសិក្ខាបទំ)

[៤៥៩] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាលពំនូតបាយនៅមិនទាន់ដល់មាត់ ក៏ហារមាត់ចាំ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា កាលពំនូតបាយមិនទាន់មកដល់ អញនឹងមិនបើទ្វារមាត់ចាំ។**

ភិក្ខុមិនត្រូវហារមាត់ចាំពំនូតបាយដែលមិនទាន់បានមកដល់មាត់ទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយហារមាត់ចាំពំនូតបាយដែលមិនទាន់មកដល់មាត់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី២ (៤២))

CS vin.vbu.sk.42 | ភាគ ទី៤

### (ទុតិយសិក្ខាបទំ)

[៤៦០] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាលឆាន់បាយ ក៏ញាត់(ម្រាម)ដៃទាំងអស់ចូលទៅក្នុងមាត់។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញកាលឆាន់បាយ នឹងមិនញាត់(ម្រាម)ដៃទាំងអស់ចូលទៅក្នុងមាត់។**

ភិក្ខុកាលឆាន់បាយមិនត្រូវញាត់(ម្រាម)ដៃទាំងអស់ចូលទៅក្នុងមាត់ទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់បាយញាត់(ម្រាម)ដៃទាំងអស់ចូលទៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី៣ (៤៣))

CS vin.vbu.sk.43 | ភាគ ទី៤

### (តតិយសិក្ខាបទំ)

[៤៦១] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនិយាយទាំងពំនូតបាយនៅក្នុងមាត់។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់។**

ភិក្ខុមិនត្រូវនិយាយទាំងពំនូតបាយនៅក្នុងមាត់ទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយនិយាយទាំងពំនូតបាយនៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី៤ (៤៤))

CS vin.vbu.sk.44 | ភាគ ទី៤

### (ចតុត្ថសិក្ខាបទំ)

[៤៦២] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់បោះដុំបាយ(ទៅក្នុងមាត់)។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់បោះដុំបាយ(ទៅក្នុងមាត់)។**

ភិក្ខុមិនត្រូវឆាន់បោះដុំបាយ(ទៅក្នុងមាត់)ទេ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់បោះដុំបាយ(ទៅក្នុងមាត់) ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុឆាន់បង្អែម១ ផ្លែឈើតូចធំ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី៥ (៤៥))

CS vin.vbu.sk.45 | ភាគ ទី៤

### (បញ្ចមសិក្ខាបទំ)

[៤៦៣] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់កាត់ពំនូតបាយ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់កាត់ពំនូតបាយ។**

ភិក្ខុមិនត្រូវឆាន់កាត់ពំនូតបាយទេ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់កាត់ពំនូតបាយ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១០យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុឆាន់បង្អែម១ ផ្លែឈើតូចធំ១ សម្លឧត្តរិភង្គ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី៦ (៤៦))

CS vin.vbu.sk.46 | ភាគ ទី៤

### (ឆដ្ឋសិក្ខាបទំ)

[៤៦៤] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់បៀមពំនូតបាយក្នុងថ្ពាល់(គឺបៀមដូចស្វា)។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់បៀមពំនូតបាយក្នុងថ្ពាល់។**

ភិក្ខុមិនត្រូវឆាន់បៀមពំនូតបាយក្នុងថ្ពាល់ទេ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់បៀមពំនូតបាយក្នុងថ្ពាល់ម្ខាង ឬទាំងពីរខាង ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុឆាន់ផ្លែឈើតូចធំ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី៧ (៤៧))

CS vin.vbu.sk.47 | ភាគ ទី៤

### (សត្តមសិក្ខាបទំ)

[៤៦៥] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់រលាស់ដៃ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់រលាស់ដៃ។**

ភិក្ខុមិនត្រូវឆាន់រលាស់ដៃទេ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់រលាស់ដៃបណ្ដើរ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុចោលសម្រាមហើយរលាស់ដៃ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី៨ (៤៨))

CS vin.vbu.sk.48 | ភាគ ទី៤

(អដ្ឋមសិក្ខាបទំ)

[៤៦៦] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់ធ្វើគ្រាប់បាយឲ្យជ្រុះរោយរាយ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់គ្រាប់បាយឲ្យជ្រុះរោយរាយ។**

ភិក្ខុមិនត្រូវឆាន់ធ្វើគ្រាប់បាយឲ្យជ្រុះរោយរាយទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ឆាន់ធ្វើគ្រាប់បាយឲ្យជ្រុះរោយរាយ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុចោលសម្រាមដោយទៅទាំងគ្រាប់បាយ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី៩ (៤៩))

CS vin.vbu.sk.49 | ភាគ ទី៤

(នវមសិក្ខាបទំ)

[៤៦៧] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់លៀនអណ្តាត។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លៀនអណ្តាត។**

ភិក្ខុមិនត្រូវឆាន់លៀនអណ្តាតទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ឆាន់លៀនអណ្តាត ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ កពឡវគ្គ សិក្ខាបទ ទី១០ (៥០))

CS vin.vbu.sk.50 | ភាគ ទី៤

(ទសមសិក្ខាបទំ)

[៤៦៨] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់ធ្វើសំឡេងព្ធផ្លប់ៗ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់ធ្វើសំឡេងឲ្យឮផ្លប់ៗ។**

ភិក្ខុមិនត្រូវឆាន់ធ្វើសំឡេងឲ្យឮផ្លប់ៗទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ឆាន់ធ្វើសំឡេងឲ្យឮផ្លប់ៗ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

កពឡវគ្គ ទី ៥ ចប់។

# (សេក្ខិយ) សុរុសុរុវគ្គ (ទី៦)

CS vin.vbu.sk.v6 | ភាគ ទី៤

(៦. សុរុសុរុវគ្គោ)

## (សេក្ខិយ សុរុសុរុវគ្គ សិក្ខាបទ ទី១ (៥១))

CS vin.vbu.sk.51 | ភាគ ទី៤

(បឋមសិក្ខាបទំ)

[៤៦៩] សម័យនោះឯង ព្រះពុទ្ធដ៏មានជោគ កាលគង់នៅឃោសិតារាម ជិតក្រុងកោសម្ពី។ វេលានោះឯង មានព្រាហ្មណ៍ម្នាក់បានតាក់តែងទឹកដោះចំពោះសង្ឃ។ អស់ទាំងពួកភិក្ខុក៏ឆាន់ទឹកដោះធ្វើសំឡេងឲ្យឮគ្រូកៗ។ មានភិក្ខុ១រូបធ្លាប់ជាអ្នករបាំ (ពីដើម) បានពោលពាក្យនេះថា

សង្ឃទាំងអស់នេះទំនងជាធ្វើទឹកដោះឲ្យត្រជាក់ទេដឹង។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុ(នេះ) មិនសមបើនឹងហ៊ានពោលកំប្លែងប្រារព្ធព្រះសង្ឃ (ដូច្នេះ)សោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកឯងពោលកំប្លែងប្រារព្ធសង្ឃ ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានពោលកំប្លែងប្រារព្ធសង្ឃ (ដូច្នេះ)សោះ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យបានជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើនូវធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនិយាយកំប្លែងប្រារព្ធព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃទេ ភិក្ខុណានិយាយ ត្រូវអាបត្តិទុក្កដ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសភិក្ខុនោះដោយអនេកបរិយាយ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនបានឆាន់ធ្វើសំឡេងឲ្យឮគ្រូកៗ។**

ភិក្ខុមិនត្រូវឆាន់ធ្វើសំឡេងឲ្យឮគ្រូកៗទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ឆាន់ធ្វើសំឡេងឲ្យឮគ្រូកៗ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សុរុសុរុវគ្គ សិក្ខាបទ ទី២ (៥២))

CS vin.vbu.sk.52 | ភាគ ទី៤

### (ទុតិយសិក្ខាបទំ)

[៤៧០] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់លិទ្ធដៃ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លិទ្ធដៃ។**

ភិក្ខុមិនត្រូវឆាន់លិទ្ធដៃទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់លិទ្ធដៃ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សុរុសុរុវគ្គ សិក្ខាបទ ទី៣ (៥៣))

CS vin.vbu.sk.53 | ភាគ ទី៤

### (តតិយសិក្ខាបទំ)

[៤៧១] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់លិទ្ធបាត្រ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លិទ្ធបាត្រ។

**ភិក្ខុមិនត្រូវឆាន់លិទ្ធបាត្រទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់លិទ្ធបាត្រ ត្រូវអាបត្តិទុក្កដ។**

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុប្រមូលភោជនទាំងឡាយដែលសេសសល់បន្តិចបន្តួចមកក្នុងទីជាមួយគ្នាលិទ្ធ ហើយឆាន់១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សុរុសុរុវគ្គ សិក្ខាបទ ទី៤ (៥៤))

CS vin.vbu.sk.54 | ភាគ ទី៤

### (ចតុត្ថសិក្ខាបទំ)

[៤៧២] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់លិទ្ធបបូរមាត់។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លិទ្ធបបូរមាត់។**

ភិក្ខុមិនត្រូវឆាន់លិទ្ធបបូរមាត់ទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់លិទ្ធបបូរមាត់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេខិយ សុរុសុរុវគ្គ សិក្ខាបទ ទី៥ (៥៥))

CS vin.vbu.sk.55 | ភាគ ទី៤

### (បញ្ចមសិក្ខាបទំ)

[៤៧៣] សម័យនោះឯង ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅភេសកឡាវន (ព្រៃសម៉) ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងដែនភគ្គៈ។ សម័យនោះឯង ពួកភិក្ខុនៅលើកោកនទប្រាសាទ (ប្រាសាទមានសណ្ឋានដូចផ្កាឈូក) មានដៃប្រឡាក់ដោយអាមិសៈ ទទួលភាជនៈទឹកសម្រាប់ឆាន់។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្ត មានដៃប្រឡាក់ដោយអាមិសៈ មិនសមបើនឹងទទួលចាប់ភាជនៈទឹកសម្រាប់ឆាន់ដូចជាពួកគ្រហស្ថដែលបរិភោគកាមគុណសោះ។ ពួកភិក្ខុបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយ មានដៃប្រឡាក់ដោយអាមិសៈ មិនសមបើនឹងហ៊ានទទួលភាជនៈទឹកសម្រាប់ឆាន់សោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ភិក្ខុទាំងឡាយមានដៃប្រឡាក់ដោយអាមិសៈ ទទួលភាជនៈទឹកសម្រាប់ឆាន់ ពិតមែនឬ។ ភិក្ខុទាំងនោះក៏ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះមានដៃប្រឡាក់ដោយអាមិសៈ មិនសមបើនឹងទទួលភាជនៈទឹកសម្រាប់ឆាន់សោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញមានដៃប្រឡាក់ដោយអាមិសៈ នឹងមិនទទួលភាជនៈទឹកសម្រាប់ឆាន់។**

ភិក្ខុមានដៃប្រឡាក់ដោយអាមិសៈ មិនត្រូវទទួលភាជនៈទឹកសម្រាប់ឆាន់ទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ មានដៃប្រឡាក់ដោយអាមិសៈ ទទួលភាជនៈទឹកសម្រាប់ឆាន់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុទទួលភាជនៈទឹកសម្រាប់ឆាន់ដោយប៉ង់ថា អញនឹងលាង ឬអញនឹងប្រើគេឲ្យលាង១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេខិយ សុរុសុរុវគ្គ សិក្ខាបទ ទី៦ (៥៦))

CS vin.vbu.sk.56 | ភាគ ទី៤

### (ឆដ្ឋសិក្ខាបទំ)

[៤៧៤] សម័យនោះឯង ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងភេសកឡាវន (ព្រៃសម៉) ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងដែនភគ្គៈ។ សម័យនោះឯង ពួកភិក្ខុនៅលើកោកនទប្រាសាទ (ប្រាសាទមានសណ្ឋានដូចផ្កាឈូក) ចាក់ទឹកដែលលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្ត មិនសមបើនឹងហ៊ានចាក់ទឹកដែលលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះ ដូចជាគ្រហស្ថដែលបរិភោគកាមគុណសោះ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយ មិនសមបើនឹងហ៊ានចាក់ទឹកដែលលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះសោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ភិក្ខុទាំងឡាយចាក់ទឹកលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងហ៊ានចាក់ទឹកលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនចាក់ទឹកលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះ។**

ភិក្ខុមិនត្រូវចាក់ទឹកលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ចាក់ទឹកលាងបាត្រទាំងគ្រាប់បាយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុប្រមូលគ្រាប់បាយមកផ្តុំគ្នា ហើយសម្រិតចោលតែទឹកក្តី ភិក្ខុច្របាច់គ្រាប់បាយឲ្យរលាយជាទឹកហើយ ចាក់ចោលទាំងអស់ក្តី ភិក្ខុចាក់ទឹកលាងបាត្រទាំងគ្រាប់

បាយទៅក្នុងភាជនៈ (កន្ថោរ)ក្តី ភិក្ខុនាំយកទឹកលាងបាត្រទាំងគ្រាប់បាយទៅចាក់ចោលក្រៅក្តី១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## ធម្មទេសនាបដិសំយុត្ត

CS vin.vbu.sk.v6.1 | ភាគ ទី៤

(-)

**មាន ១៦ សិក្ខាបទ**

### (សេក្ខិយ សុរុសុរុវគ្គ សិក្ខាបទ ទី៧ (៥៧))

CS vin.vbu.sk.57 | ភាគ ទី៤

**(សត្តមសិក្ខាបទំ)**

[៤៧៥] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សមានឆត្រនៅក្នុងដៃ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងហ៊ានសំដែងធម៌ដល់មនុស្សមានឆត្រនៅក្នុងដៃសោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយសំដែងធម៌ដល់មនុស្សមានឆត្រនៅក្នុងដៃ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងសំដែងធម៌ដល់មនុស្សមានឆត្រនៅក្នុងដៃទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សមានឆត្រនៅក្នុងដៃ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ពួកភិក្ខុយ៉ាងនេះ។

[៤៧៦] សម័យនោះឯង ភិក្ខុទាំងឡាយរង្កៀសក្នុងការសំដែងធម៌ដល់មនុស្សឈឺមានឆត្រនៅក្នុងដៃ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្តមិនសមបើនឹងមិនសំដែងធម៌ដល់មនុស្សឈឺមានឆត្រនៅក្នុងដៃសោះ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យភិក្ខុសំដែងធម៌ដល់មនុស្សឈឺមានឆត្រនៅក្នុងដៃបាន (ឥតមានទោស) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺមានឆត្រនៅក្នុងដៃ។**

ដែលហៅថា ឆត្រ បានដល់ឆត្រ៣យ៉ាងគឺ ឆត្រដែលគេពាសដោយសំពត់មានពណ៌ស១ ឆត្រដែលគេធ្វើដោយផែង១ ឆត្រដែលគេធ្វើដោយស្លឹកឈើ១ (ឆត្រទាំង៣នេះ) ដែលគេចងឲ្យមានរាងមូល[75] ចងឲ្យជាប់មាំដោយឆ្អឹងឆត្រ[76] ។ ដែលហៅថា ធម៌ គឺធម៌ដែលព្រះពុទ្ធទ្រង់សំដែង សាវកសំដែង ឥសីសំដែង ទេវតាសំដែង ប្រកបដោយអដ្ឋកថា ប្រកបដោយបាឡី។ ត្រង់ពាក្យថា សំដែង គឺភិក្ខុសំដែងដោយបទ ត្រូវអាបត្តិទុក្កដគ្រប់ៗបទ។ ភិក្ខុសំដែងដោយអក្ខរៈ ត្រូវអាបត្តិទុក្កដគ្រប់ៗអក្ខរៈ។

ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានឆត្រនៅក្នុងដៃទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានឆត្រនៅក្នុងដៃ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

### (សេក្ខិយ សុរុសុរុវគ្គ សិក្ខាបទ ទី៨ (៥៨))

CS vin.vbu.sk.58 | ភាគ ទី៤

**(អដ្ឋមសិក្ខាបទំ)**

[៤៧៧] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សមានដំបងនៅក្នុងដៃ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺមានដំបងនៅក្នុងដៃ។**

ដែលហៅថា ដំបង បានដល់ដំបងប្រវែង៤ហត្ថមជ្ឈិមបុរស។ វែងជាង៤ហត្ថនោះ ក៏មិនហៅថាដំបង ខ្លីជាង៤ហត្ថនោះ ក៏មិនហៅថាដំបងដែរ។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានដំបងនៅក្នុងដៃទេ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានដំបងនៅក្នុងដៃ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សុរុសុរុវគ្គ សិក្ខាបទ ទី៩ (៥៩))

CS vin.vbu.sk.59 | ភាគ ទី៤

### (នវមសិក្ខាបទំ)

[៤៧៨] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សមានគ្រឿងសស្ត្រានៅក្នុងដៃ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺមានគ្រឿងសស្ត្រានៅក្នុងដៃ។**

គ្រឿងដែលសម្រាប់ប្រហារ មានមុខមុតតែម្ខាង ឬមានមុខមុតទាំងពីរខាង ហៅថា គ្រឿងសស្ត្រា។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងសស្ត្រានៅក្នុងដៃទេ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងសស្ត្រានៅក្នុងដៃ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ សុរុសុរុវគ្គ សិក្ខាបទ ទី១០ (៦០))

CS vin.vbu.sk.60 | ភាគ ទី៤

### (ទសមសិក្ខាបទំ)

[៤៧៩] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សមានគ្រឿងអាវុធនៅក្នុងដៃ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺមានគ្រឿងអាវុធនៅក្នុងដៃ។**

ធ្នូមានដងរាងដំបា (ដូចដងរែក) ឬធ្នូមានដងមូល ហៅថា គ្រឿងអាវុធ។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងអាវុធនៅក្នុងដៃទេ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងអាវុធនៅក្នុងដៃ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្ដីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

សុរុសុរុវគ្គ ទី ៦ ចប់។

# (សេក្ខិយ) បាទុកាវគ្គ (ទី៧)

CS vin.vbu.sk.v7 | ភាគ ទី៤

### (៧. បាទុកវគ្គោ)

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី១ (៦១))

CS vin.vbu.sk.61 | ភាគ ទី៤

### (បឋមសិក្ខាបទំ)

[៤៨០] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សពាក់ទ្រនាប់ជើង។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺពាក់ទ្រនាប់ជើង។**

ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ទ្រនាប់ជើងទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ជាន់ទ្រនាប់ជើងក្តី ពាក់ក្តី ដោះបង្ហើបកែងបន្តិចក្តី ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេខិយ បាទុកាវគ្គ សិក្ខាបទ ទី២ (៦២))

CS vin.vbu.sk.62 | ភាគ ទី៤

### (ទុតិយសិក្ខាបទំ)

[៤៨១] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សពាក់ស្បែកជើង។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺពាក់ស្បែកជើង។**

ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ស្បែកជើងទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ជាន់លើស្បែកជើងក្តី ពាក់ក្តី ដោះបង្ហើបកែងបន្តិចក្តី ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេខិយ បាទុកាវគ្គ សិក្ខាបទ ទី៣ (៦៣))

CS vin.vbu.sk.63 | ភាគ ទី៤

### (តតិយសិក្ខាបទំ)

[៤៨២] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សនៅលើយាន។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺនៅលើយានទេ។**

ដែលហៅថា យាន គឺសំដៅយក វ[77] រថ រទេះ រថទ្រង់គ្រឿង[78] គ្រែស្នែង និងអង្រឹង។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើយានទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើយាន ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេខិយ បាទុកាវគ្គ សិក្ខាបទ ទី៤ (៦៤))

CS vin.vbu.sk.64 | ភាគ ទី៤

### (ចតុត្ថសិក្ខាបទំ)

[៤៨៣] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សនៅលើដំណេក។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺនៅលើដំណេក។**

ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើដំណេកទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដោយហោចទៅ សូម្បីដេកនៅលើផែនដី ក៏ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី៥ (៦៥))

CS vin.vbu.sk.65 | ភាគ ទី៤

### (បញ្ចមសិក្ខាបទំ)

[៤៨៤] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សអង្គុយត្របោមក្បាលជង្គង់។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយត្របោមក្បាលជង្គង់។**

ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយត្របោមក្បាលជង្គង់ទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយត្របោមក្បាលជង្គង់ដោយដៃក្តី អង្គុយត្របោមក្បាលជង្គង់ដោយសំពត់ក្តី ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី៦ (៦៦))

CS vin.vbu.sk.66 | ភាគ ទី៤

### (ឆដ្ឋសិក្ខាបទំ)

[៤៨៥] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សជួតក្បាល។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺជួតក្បាល។**

ដែលហៅថា មនុស្សជួតក្បាល គឺសំដៅយកមនុស្សដែលជួតក្បាល មិនឲ្យឃើញចុងសក់។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ជួតក្បាលទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ជួតក្បាល ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុបង្គាប់មនុស្សនោះឲ្យបើកឈ្នួតឲ្យលេចចុងសក់ចេញ ហើយទើបសំដែង១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី៧ (៦៧))

CS vin.vbu.sk.67 | ភាគ ទី៤

### (សត្តមសិក្ខាបទំ)

[៤៨៦] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សទទូរក្បាល។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺទទូរក្បាល។**

ដែលហៅថា មនុស្សទទូរក្បាល គឺសំដៅយកមនុស្សដណ្តប់សំពត់គ្របទាំងក្បាល។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ទទូរក្បាលទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ទទូរក្បាល ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុបង្គាប់គេឲ្យបើកឈ្នួតក្បាលហើយទើបសំដែង១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី៨ (៦៨))

CS vin.vbu.sk.68 | ភាគ ទី៤

### (អដ្ឋមសិក្ខាបទំ)

[៤៨៧] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុអង្គុយផ្ទាល់នឹងដី ហើយសំដែងធម៌ដល់មនុស្សអង្គុយនៅលើអាសនៈ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនអង្គុយផ្ទាល់នឹងផែនដី ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយនៅលើអាសនៈ។**

ភិក្ខុមិនត្រូវអង្គុយផ្ទាល់នឹងផែនដី ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយនៅលើអាសនៈទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ អង្គុយនៅលើផែនដី ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយនៅលើអាសនៈ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី៩ (៦៩))

CS vin.vbu.sk.69 | ភាគ ទី៤

### (នវមសិក្ខាបទំ)

[៤៨៨] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សអង្គុយនៅលើអាសនៈខ្ពស់។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈខ្ពស់សោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈខ្ពស់ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈខ្ពស់ទេ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិនបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើនូវធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា។

[៤៨៩] ម្នាលភិក្ខុទាំងឡាយ កាលពីដើមក្នុងក្រុងពារាណសី មានស្រីជាប្រពន្ធរបស់បុរសចណ្ឌាលម្នាក់ ជាស្រីមានគភ៌។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្រីចណ្ឌាលនោះបានពោលពាក្យនេះនឹងបុរសចណ្ឌាលនោះថា បពិត្រអ្នកជាអយ្យបុត្រ ឥឡូវខ្លួនខ្ញុំមានគភ៌ហើយ ខ្ញុំចង់ទទួលទានផ្លែស្វាយណាស់។ ឯប្តីនោះតបវិញថា ផ្លែស្វាយគ្មានទេ (ព្រោះ) កាលនេះ មិនមែនជាកាលមានផ្លែស្វាយ។ ប្រពន្ធនោះនិយាយថា បើខ្ញុំមិនបានផ្លែស្វាយទេ ខ្ញុំមុខជានឹងស្លាប់ (ពុំខានឡើយ)។ គ្រានោះឯង មានដើមស្វាយរបស់ស្តេច (១ដើម) តែងមានផ្លែជាប់ជានិច្ច។ ម្នាលភិក្ខុទាំងឡាយ សម័យនោះ បុរសចណ្ឌាលនោះក៏ចូលទៅរកដើមស្វាយនោះ លុះចូលទៅដល់ហើយ ក៏ឡើងទៅពួនលើដើមស្វាយនោះ។ ម្នាលភិក្ខុទាំងឡាយ វេលានោះឯង ស្តេចបានទ្រង់រាជដំណើរទៅកាន់ដើមស្វាយនោះជាមួយនឹងព្រាហ្មណបុរោហិត លុះដល់ហើយ ក៏គង់លើអាសនៈដ៏ខ្ពស់ ហើយក៏រៀននូវមន្ត។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ បុរសចណ្ឌាលនោះមានសេចក្តីរិះគិតយ៉ាងនេះថា ស្តេចណាគង់លើអាសនៈខ្ពស់ហើយរៀននូវមន្ត ស្តេចនេះឯង ហៅថាមិនប្រកបដោយធម៌ឡើយ។ ម្យ៉ាងទៀត ព្រាហ្មណ៍ណាអង្គុយលើអាសនៈទាប ហើយបង្ហាញមន្តដល់មនុស្សដែលអង្គុយលើអាសនៈខ្ពស់ ព្រាហ្មណ៍នេះឯងហៅថា មិនប្រកបដោយធម៌ដែរ ចំណែកខ្លួនអញដែលមកលួចផ្លែស្វាយរបស់ស្តេច ព្រោះហេតុអំពីស្រី អញនេះឯង ក៏ហៅថាមិនប្រកបដោយធម៌ដែរ ឯច្បាប់ទាំងនេះ វាច្រឡូកច្រឡំគ្នាអស់ហើយ។ បុរសនោះគិតដូច្នោះហើយ ក៏លោតចុះពីដើមស្វាយមកក្នុងទីនោះឯង (ហើយពោលគាថា) ថា

ព្រាហ្មណ៍ណាបង្ហាញមន្ត(ដល់ស្តេច)ក្តី

ស្តេចអង្គណារៀនមន្តមិនប្រកបដោយធម៌ក្តី

ជនទាំងពីរនោះ ឈ្មោះថាមិនស្គាល់នូវហេតុ

ជនទាំងពីរនោះឈ្មោះថា មិនដឹងនូវផល។

ព្រាហ្មណ៍ក៏ពោលគាថាតបវិញថា

(នែអ្នកចណ្ឌាល) ខ្ញុំបានទទួលទានបាយអង្ករស្រូវសាលីដែលលាយដោយសាច់ដ៏ស្អាតរបស់ស្តេច (ជារាល់ថ្ងៃ) ព្រោះហេតុនោះ ខ្ញុំនឹងប្រព្រឹត្តទៅក្នុងធម៌នោះមិនបានទេ (តែខ្ញុំដឹងថា) ធម៌នេះពួកព្រះអរិយៈតែងសរសើរហើយ។

ឯបុរសចណ្ឌាលក៏ពោលគាថាតបវិញថា

បពិត្រព្រាហ្មណ៍ ការដែលបានទ្រព្យ និងបានយសបែបនោះ ពាក្យនិន្ទាតែងមាន (ជាធម្មតា) ម្យ៉ាងទៀត ការចិញ្ចឹមជីវិតដែលមិនប្រព្រឹត្តតាមធម៌ ជាហេតុនាំឲ្យធ្លាក់ចុះទៅក្នុងអបាយ បពិត្រមហាព្រហ្ម អ្នកឯងចូរវៀរចេញ សូម្បីពួកសត្វដទៃក៏គង់តែចំអិនបាយបរិភោគ (ដូចគ្នាទេ) អ្នកកុំប្រព្រឹត្តឲ្យខុសធម៌នោះឡើយ បើអ្នកប្រព្រឹត្តខុសធម៌ហើយ មុខជានឹងបែកធ្លាយដូចជាក្អមទឹកមិនខានទេ។

[៤៩០] ម្នាលភិក្ខុទាំងឡាយ សូម្បីតែក្នុងគ្រានោះ បុគ្គលអង្គុយលើអាសនៈទាប ហើយបង្ហាញមន្តដល់បុគ្គលដែលអង្គុយលើអាសនៈខ្ពស់នោះ ម្តេចក៏គង់ជាទីមិនគាប់ចិត្តដល់តថាគត នឹងនិយាយទៅថ្វីដល់បុគ្គលដែលអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់បុគ្គលដែលអង្គុយលើអាសនៈខ្ពស់ ក្នុងកាលឥឡូវនេះ ក៏រឹងរឹតតែមិនបានជាទីគាប់ចិត្តតថាគតក្រៃពេក ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយលើអាសនៈខ្ពស់។**

ភិក្ខុមិនគប្បីអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយលើអាសនៈខ្ពស់ទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ អង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយលើអាសនៈខ្ពស់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី១០ (៧០))

CS vin.vbu.sk.70 | ភាគ ទី៤

### (ទសមសិក្ខាបទំ)

[៤៩១] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឈរសំដែងធម៌ដល់មនុស្សអង្គុយ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឈរសំដែងធម៌ដល់មនុស្សគ្មានជម្ងឺដែលអង្គុយ។**

ភិក្ខុមិនត្រូវឈរសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឈរសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយនៅ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី១១ (៧១))

CS vin.vbu.sk.71 | ភាគ ទី៤

### (ឯកាទសមសិក្ខាបទំ)

[៤៩២] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដើរខាងក្រោយ សំដែងធម៌ដល់មនុស្សដើរខាងមុខ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនដើរខាងក្រោយ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរខាងមុខ។**

ភិក្ខុមិនត្រូវដើរខាងក្រោយ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដើរខាងមុខទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ដើរខាងក្រោយ ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដើរខាងមុខ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី១២ (៧២))

CS vin.vbu.sk.72 | ភាគ ទី៤

(ទ្វាទសមសិក្ខាបទំ)

[៤៩៣] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដើរក្រៅផ្លូវ សំដែងធម៌ដល់មនុស្សដើរតាមផ្លូវ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនដើរក្រៅផ្លូវ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរតាមផ្លូវ។**

ភិក្ខុមិនត្រូវដើរក្រៅផ្លូវ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដើរតាមផ្លូវទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយដើរក្រៅផ្លូវ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដើរតាមផ្លូវ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## បកិណ្ណកៈ

CS vin.vbu.sk.v7.1 | ភាគ ទី៤

(-)

មាន ៣ សិក្ខាបទ

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី១៣ (៧៣))

CS vin.vbu.sk.73 | ភាគ ទី៤

(តេរសមសិក្ខាបទំ)

[៤៩៤] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឈរបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញគ្មានជម្ងឺ នឹងមិនឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ។**

ភិក្ខុគ្មានជម្ងឺ មិនត្រូវឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈទេ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ គ្មានជម្ងឺ ហើយឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

## (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី១៤ (៧៤))

CS vin.vbu.sk.74 | ភាគ ទី៤

(ចុទ្ទសមសិក្ខាបទំ)

[៤៩៥] សាវត្ថីនិទាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ លើស្មៅស្រស់ ឬឈើស្រស់។បេ។ ទ្រង់ត្រាស់ថា

**ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញគ្មានជម្ងឺ នឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់។**

ភិក្ខុគ្មានជម្ងឺ មិនត្រូវបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់លើស្មៅស្រស់ និងឈើស្រស់ទេ។ ភិក្ខុណាគ្មានជម្ងឺ អាស្រ័យសេចក្តីមិនអើពើ ហើយបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់ ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ឧច្ចារៈ ឬបស្សាវៈ ឬទឹកមាត់ដែលភិក្ខុបន្ទោបង់ទៅលើទីដែលប្រាសចាកវត្ថុស្រស់ ហើយហូរទៅត្រង់ទីដែលមានស្មៅស្រស់ ឬឈើស្រស់១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

# (សេក្ខិយ បាទុកាវគ្គ សិក្ខាបទ ទី១៥ (៧៥))



## (បន្ទុរសមសិក្ខាបទំ)

[៤៩៦] សម័យនោះ ព្រះពុទ្ធដ៏មានជោគ កាលទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ វេលានោះឯង ពួកឆព្វគ្គិយភិក្ខុបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ដាក់លើទឹក។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្ត មិនសមបើនឹងហ៊ានបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះដាក់លើទឹក ដូចជាពួកគ្រហស្ថអ្នកបរិភោគកាមគុណសោះ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះដាក់លើទឹកសោះ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះដាក់លើទឹក ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះដាក់លើទឹកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនជាទីជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនបានបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ដាក់លើទឹក។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តចំពោះពួកភិក្ខុយ៉ាងនេះ។

[៤៩៧] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺ នឹករង្កៀសនឹងការបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ដាក់លើទឹក។ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជម្ងឺ បន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះដាក់លើទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញគ្មានជម្ងឺ នឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ដាក់លើទឹក។**

ភិក្ខុគ្មានជម្ងឺ មិនត្រូវបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ដាក់លើទឹកទេ។ ភិក្ខុណាគ្មានជម្ងឺ អាស្រ័យសេចក្តីមិនអើពើ ហើយបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ដាក់លើទឹក ត្រូវអាបត្តិទុក្កដ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ឧច្ចារៈ ឬបស្សាវៈ ឬទឹកមាត់ដែលភិក្ខុបន្ទោបង់ដាក់លើគោក ហើយហូរទៅក្នុងទឹក១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១។

បាទុកាវគ្គ ទី ៧ ចប់។

ចំនួនសិក្ខាបទក្នុងសេក្ខិយវគ្គ[79] នោះគឺ

> បរិមណ្ឌលនិវាសន១ បរិមណ្ឌលបារុបន១ សុបដិច្ឆន្នគមន១ សុបដិច្ឆន្ននិសីទន១ សុសំវុតគមន១ សុសំវុតនិសីទន១ ឱក្ខិត្តចក្ខុគមន១ ឱក្ខិត្តចក្ខុនិសីទន១ នឧក្ខិត្តកគមន១ នឧក្ខិត្តកនិសីទន១ នឧជ្ជគ្ឃិកគមន១ នឧជ្ជគ្ឃិកនិសីទន១ អប្បសទ្ទគមន១ អប្បសទ្ទនិសីទន១ នកាយប្បចាលកគមន១ នកាយប្បចាលកនិសីទន១ នពាហុប្បចាលកគមន១ នពាហុប្បចាលកនិសីទន១ នសីសប្បចាលកគមន១ នសីសប្បចាលកនិសីទន១ នខម្ភកតគមន១ នខម្ភកតនិសីទន១ នឱគុណ្ឋិតគមន១ នឱគុណ្ឋិតនិសីទន១ នឧក្កុដិកគមន១ នបល្លត្ថិកនិសីទន១ សក្កច្ចបិណ្ឌបាតបដិគ្គហណ១ បត្តសញ្ញីបដិគ្គហណ១ សមសូបកបដិគ្គហណ១ សមតិត្តិកបដិគ្គហណ១ សក្កច្ចបិណ្ឌបាតភុញ្ជន១ បត្តសញ្ញីបិណ្ឌបាតភុញ្ជន១ សបទានបិណ្ឌបាតភុញ្ជន១ សមសូបកបិណ្ឌបាតភុញ្ជន១ នថូបិកតោមទ្ទនភុញ្ជន១ សូបព្យញ្ជនោទនបដិច្ឆាទន១ សូបោទនវិញ្ញត្តិ១ ឧជ្ឈានសញ្ញីបត្តោលោកន១ នាតិមហន្តកពឡករណ១ បរិមណ្ឌលអាលោបករណ១ នអនាហដទ្វារវិវរណ១ នសព្វហត្ថបក្ខិបន១ នសកពឡព្យាហរណ១ នបិណ្ឌុក្ខេបកភុញ្ជន១ នកពឡាវច្ឆេទក១ នអវគណ្ឌការភុញ្ជន១ នហត្ថនិទ្ធុនកភុញ្ជន១ នសិត្ថាវការកភុញ្ជន១ នជិវ្ហានិច្ឆារកភុញ្ជន១ នចបុចបុការកភុញ្ជន១ នសុរុសុរុការកភុញ្ជន១ នហត្ថនិល្លេហកភុញ្ជន១ នបត្តនិល្លេហកភុញ្ជន១ នឱដ្ឋនិល្លេហកភុញ្ជន១ នសាមិសបដិគ្គហណ១ នសសិត្ថកឆឌ្ឌន១ នឆត្តបាណិទេសន១ នទណ្ឌបាណិទេសន១ នសត្ថបាណិទេសន១ នអាវុធបាណិទេសន១ នបាទុការុឡ្ហទេសន១ នឧបាហនទេសន១ នយានគតទេសន១ នសយនគតទេសន១ នបល្លត្ថិកទេសន១ នវេឋិតសីសទេសន១ នឱគុណ្ឋិតសីសទេសន១ នឆមាទេសន១ ននីចាសនទេសន១ នឋិតទេសន១ នបច្ឆតោទេសន១ នឧប្បថទេសន១ នឋិតករណ១ នហរិតករណ១ នឧទកករណ១។

វគ្គទាំង៧នេះគឺ បរិមណ្ឌលវគ្គ១ នឧជ្ជគ្ឃិកវគ្គ១ នខម្ភកតវគ្គ១ នសក្កច្ចវគ្គ១ នាហជវគ្គ១ នសុរុសុរុវគ្គ១ នបាទុកាវគ្គ១។

សេក្ខិយវត្តទាំង៧៥សិក្ខាបទ(នេះ) ព្រះគោតមដ៏មានយស ជាទេវតាក្រៃលែងជាងទេវតា បានបញ្ញត្តហើយ ដើម្បីឲ្យពួកសាវកសិក្សាតាម។

បពិត្រលោកដ៏មានអាយុទាំងឡាយ វត្តដែលគប្បីសិក្សាទាំងឡាយ ខ្ញុំបានសំដែងឡើងហើយ។ ខ្ញុំសូមសួរអស់លោកដ៏មានអាយុក្នុងសេក្ខិយវត្តទាំងនោះ លោកទាំងឡាយបរិសុទ្ធហើយឬ ខ្ញុំសួរជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសួរជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ អស់លោកដ៏មានអាយុជាអ្នកបរិសុទ្ធក្នុងសេក្ខិយវត្តទាំងនេះហើយ ព្រោះហេតុនោះ បានជាអស់លោកស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវសេចក្តី បរិសុទ្ធនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

សេក្ខិយកណ្ឌ ចប់។

# (អធិករណសមថា) ពួកធម៌សម្រាប់រម្ងាប់នូវអធិករណៈ

CS vin.vbu.ad | ភាគ ទី៤

**(៨. អធិករណសមថា)**

[៤៩៨] បពិត្រលោកដ៏មានអាយុទាំងឡាយ ពួកធម៌៧យ៉ាងសម្រាប់រម្ងាប់នូវអធិករណៈនេះ តែងមកកាន់ឧទ្ទេស (គឺការដែលសំដែងឡើង)។ (ឯធម៌៧យ៉ាងនោះគឺ)

- សង្ឃត្រូវឲ្យសម្មុខាវិន័យ[80] ១
- សង្ឃត្រូវឲ្យសតិវិន័យ[81] ១
- សង្ឃត្រូវឲ្យអមុឡ្ហវិន័យ[82] ១
- សង្ឃត្រូវវិនិច្ឆ័យកាត់ទោសតាមពាក្យប្តេជ្ញារបស់ភិក្ខុអ្នកឆ្លើយ ១
- សង្ឃត្រូវវិនិច្ឆ័យតាមពាក្យខាងច្រើនជាប្រមាណ ១
- សង្ឃត្រូវធ្វើទោសតាមកម្មរបស់ភិក្ខុដែលប្រព្រឹត្តលាមក[83] ១
- សង្ឃត្រូវវិនិច្ឆ័យឲ្យពួកភិក្ខុដែលវិវាទទាស់ទែងគ្នា សង្រួបសង្រួម អត់ឱនគ្នាទៅវិញទៅមក ដូចគេគ្របមូត្រលាមកដោយស្មៅ ដើម្បីស្ងប់រម្ងាប់នៃអធិករណៈ (ទាំងនោះ) ដែលកើតឡើងហើយ១។

បពិត្រលោកដ៏មានអាយុទាំងឡាយ ធម៌សម្រាប់រម្ងាប់អធិករណៈមាន៧យ៉ាងនេះ ខ្ញុំបានសំដែងរួចហើយ។ ខ្ញុំសូមសួរអស់លោកដ៏មានអាយុក្នុងធម៌៧យ៉ាងនោះ អស់លោកជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសួរជាគំរប់ពីរដងផង អស់លោកជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសួរជាគំរប់បីដងផង អស់លោកជាអ្នកបរិសុទ្ធហើយឬ អស់លោកដ៏មានអាយុជាអ្នកបរិសុទ្ធក្នុងធម៌ទាំងនោះហើយ ហេតុនោះ បានជាអស់លោកស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

ធម៌សម្រាប់រម្ងាប់នូវអធិករណៈ ចប់។

[៤៩៩] បពិត្រលោកម្ចាស់ទាំងឡាយ និទានខ្ញុំសំដែងឡើងហើយ អាបត្តិបារាជិក៤ ខ្ញុំសំដែងឡើងហើយ អាបត្តិសង្ឃាទិសេស១៣ ខ្ញុំសំដែងឡើងហើយ អនិយតសិក្ខាបទ២ ខ្ញុំសំដែងឡើងហើយ អាបត្តិនិស្សគ្គិយបាចិត្តិយ៣០ ខ្ញុំសំដែងឡើងហើយ អាបត្តិបាចិត្តិយ៩២ ខ្ញុំសំដែងឡើងហើយ អាបត្តិបាដិទេសនីយៈ៤ ខ្ញុំសំដែងឡើងហើយ សេក្ខិយវត្ត ខ្ញុំសំដែងឡើងហើយ ធម៌សម្រាប់រម្ងាប់អធិករណៈមាន៧យ៉ាង ខ្ញុំក៏សំដែងឡើងហើយ។ សិក្ខាបទមានប្រមាណប៉ុណ្ណោះ របស់ព្រះដ៏មានព្រះភាគនោះ មកហើយក្នុងសុត្តៈ (មាតិកា) រាប់បញ្ចូលហើយក្នុងសុត្តៈ តែងមកកាន់ឧទ្ទេស (គឺការសំដែងបាតិមោក្ខ) រាល់កន្លះខែ។ អស់លោករាល់អង្គគប្បីព្រមព្រៀងគ្នា គប្បីរីករាយរកគ្នា កុំវិវាទគ្នា គប្បីសិក្សាក្នុងសិក្ខាបទទាំងនោះទៅហោង។

មហាវិភង្គ ចប់។

# មាតិកា


| **បាចិត្តិយកណ្ឌ** | លេខ ទំព័រ |
|---|---|
| **ភូតគាមវគ្គ ទី ២** | ១ |
| **សិក្ខាបទ ទី ៦** | ១ |
| | |

| | |
|---|---|
| និទានឆព្វគ្គិយភិក្ខុ | ១ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២ |
| បទភាជនីយ | ៣ |
| វារៈដែលមិនត្រូវអាបត្តិ | ៤ |
| **សិក្ខាបទ ទី ៧** | ៥ |
| និទានសត្តរសវគ្គិយភិក្ខុ | ៥ |
| សេចក្ដីបញ្ញត្តិ | ៧ |
| សិក្ខាបទវិភង្គ | ៨ |
| បទភាជនីយ | ៩ |
| វារៈដែលមិនត្រូវអាបត្តិ | ១០ |
| **សិក្ខាបទ ទី ៨** | ១១ |
| និទានភិក្ខុ ២ រូប | ១១ |
| សេចក្ដីបញ្ញត្តិ សិក្ខាបទវិភង្គ | ១២ |
| បទភាជនីយ | ១៣ |
| វារៈដែលមិនត្រូវអាបត្តិ | ១៤ |
| **សិក្ខាបទ ទី ៩** | ១៥ |
| និទានឆន្នភិក្ខុ | ១៥ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៧ |
| បទភាជនីយ | ១៨ |
| វារៈដែលមិនត្រូវអាបត្តិ | ១៩ |
| **សិក្ខាបទ ទី ១០** | ២០ |
| និទានភិក្ខុស្រុកអាឡវីទាំងឡាយ | ២០ |
| សេចក្ដីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ២១ |
| វារៈដែលមិនត្រូវអាបត្តិ | ២២ |
| **ឧទ្ទាននៃភូតគាមវគ្គ** | **២៣** |
| ឱវាទវគ្គ សិក្ខាបទ ទី១ | ២៤ |
| និទានឆព្វគ្គិយភិក្ខុ | ២៤ |
| ការសន្មតិភិក្ខុ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី | ២៦ |
| សេចក្ដីបញ្ញត្តិ | ២៧ |
| ការសន្មតិភិក្ខុដែលប្រកបដោយអង្គ ៨ ប្រការ ឲ្យជាអ្នកប្រដៅភិក្ខុនី | ៣០ |
| សិក្ខាបទវិភង្គ | ៣១ |
| គរុធម៌ ៨ ប្រការ | ៣៣ |
| បទភាជនីយ | ៣៤ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៨ |
| **សិក្ខាបទ ទី ២** | ៣៩ |
| និទានព្រះចូឡបន្ថក | ៣៩ |
| សេចក្ដីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ៤២ |

| | |
|---|---|
| វារៈដែលមិនត្រូវអាបត្តិ | ៤៣ |
| **សិក្ខាបទ ទី ៣** | ៤៤ |
| និទានឆព្វគ្គិយភិក្ខុ | ៤៤ |
| សេចក្ដីបញ្ញត្តិជាដំបូង | ៤៥ |
| និទានព្រះមហាបជាបតីគោតមី | ៤៦ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ៤៧ |
| បទភាជនីយ | ៤៨ |
| វារៈដែលមិនត្រូវអាបត្តិ | ៤៩ |
| **សិក្ខាបទ ទី ៤** | ៥០ |
| និទានឆព្វគ្គិយភិក្ខុ | ៥០ |
| សេចក្ដីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ៥១ |
| វារៈដែលមិនត្រូវអាបត្តិ | ៥៣ |
| **សិក្ខាបទ ទី ៥** | ៥៤ |
| និទានភិក្ខុ ១ រូប ត្រាច់ទៅបិណ្ឌបាត្រ | ៥៤ |
| សេចក្ដីបញ្ញត្តិជាដំបូង | ៥៥ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ | ៥៦ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ៥៧ |
| វារៈដែលមិនត្រូវអាបត្តិ | ៥៨ |
| **សិក្ខាបទ ទី ៦** | ៥៩ |
| និទានឧទាយិភិក្ខុ | ៥៩ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៦១ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៦២ |
| **សិក្ខាបទ ទី ៧** | ៦៣ |
| និទានឆព្វគ្គិយភិក្ខុ | ៦៣ |
| សេចក្ដីបញ្ញត្តិជាដំបូង | ៦៤ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ៦៥ |
| បទភាជនីយ | ៦៧ |
| វារៈដែលមិនត្រូវអាបត្តិ | ៦៨ |
| **សិក្ខាបទ ទី ៨** | ៦៩ |
| និទានឆព្វគ្គិយភិក្ខុ | ៦៩ |
| សេចក្ដីបញ្ញត្តិជាដំបូង | ៧០ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ៧១ |
| បទភាជនីយ | ៧២ |
| វារៈដែលមិនត្រូវអាបត្តិ | ៧៣ |
| **សិក្ខាបទ ទី ៩** | ៧៤ |
| និទានថុល្លនន្ទាភិក្ខុនី | ៧៤ |
| សេចក្ដីបញ្ញត្តិជាដំបូង | ៧៦ |

| | |
|---|---|
| សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ៧៧ |
| បទភាជនីយ | ៧៨ |
| វារៈដែលមិនត្រូវអាបត្តិ | ៧៩ |
| **សិក្ខាបទ ទី ១០** | ៨០ |
| និទានឧទាយិភិក្ខុ | ៨០ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៨១ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៨២ |
| **ឧទ្ទាននៃឱវាទវគ្គ** | **៩៣** |
| ភោជនវគ្គ បឋមសិក្ខាបទ | ៨៤ |
| និទានឆព្វគ្គិយភិក្ខុ | ៨៤ |
| សេចក្តីបញ្ញត្តិជាដំបូង និងនិទានព្រះសារីបុត្តត្ថេរ | ៨៦ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ និងបទភាជនីយ | ៨៧ |
| វារៈដែលមិនត្រូវអាបត្តិ | ៨៨ |
| **សិក្ខាបទ ទី ២** | ៨៩ |
| និទានទេវទត្តភិក្ខុ | ៨៩ |
| បឋមប្បញ្ញត្តិ និងបឋមានុប្បញ្ញត្តិ | ៩០ |
| ទុតិយានុប្បញ្ញត្តិ | ៩១ |
| តតិយានុប្បញ្ញត្តិ | ៩២ |
| ចតុត្ថានុប្បញ្ញត្តិ | ៩៣ |
| បញ្ចមានុប្បញ្ញត្តិ | ៩៤ |
| ឆដ្ឋានុប្បញ្ញត្តិ | ៩៥ |
| សត្តមានុប្បញ្ញត្តិ | ៩៧ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៩៩ |
| **សិក្ខាបទ ទី ៣** | ១០០ |
| និទានបុរសធ្វើការម្នាក់ ជាមនុស្សទ័លក្រ | ១០០ |
| បឋមប្បញ្ញត្តិ | ១០៣ |
| និទានភិក្ខុ ១ រូប មានជម្ងឺ និង បឋមានុប្បញ្ញត្តិ | ១០៤ |
| ទុតិយានុប្បញ្ញត្តិ | ១០៥ |
| តតិយានុប្បញ្ញត្តិ | ១០៦ |
| និយាយពីអនុញ្ញាតឲ្យភិក្ខុកំណត់ភត្តដែលគេបម្រុងដើម្បីខ្លួន ឲ្យដល់ភិក្ខុឯទៀត និង សិក្ខាបទវិភង្គ | ១០៨ |
| បទភាជនីយ | ១០៨ |
| វារៈដែលមិនត្រូវអាបត្តិ | ១០៩ |
| **សិក្ខាបទ ទី ៤** | ១១០ |
| និទានឧបាសិកាជាមាតារបស់នាងកាណា | ១១០ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១១៥ |
| បទភាជនីយ | ១១៦ |
| | |

| | |
|---|---|
| វារៈដែលមិនត្រូវអាបត្តិ | ១១៧ |
| **សិក្ខាបទ ទី ៥** | ១១៨ |
| និទានភិក្ខុច្រើនរូប | ១១៨ |
| សេចក្ដីបញ្ញត្តិជាដម្បូង | ១១៩ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ១២១ |
| បទភាជនីយ | ១២៣ |
| វារៈដែលមិនត្រូវអាបត្តិ | ១២៤ |
| **សិក្ខាបទ ទី ៦** | ១២៥ |
| និទានភិក្ខុពីររូបដើរផ្លូវឆ្ងាយ | ១២៥ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១២៧ |
| បទភាជនីយ | ១២៩ |
| វារៈដែលមិនត្រូវអាបត្តិ | ១៣០ |
| **សិក្ខាបទ ទី ៧** | ១៣១ |
| និទានសត្តរសវគ្គិយភិក្ខុ | ១៣១ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៣២ |
| បទភាជនីយ | ១៣៣ |
| វារៈដែលមិនត្រូវអាបត្តិ | ១៣៤ |
| **សិក្ខាបទ ទី ៨** | ១៣៥ |
| និទានព្រះវេឡដ្ឋសីសត្ថេរ | ១៣៥ |
| សេចក្ដីបញ្ញត្តិ | ១៣៦ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ១៣៧ |
| វារៈដែលមិនត្រូវអាបត្តិ | ១៣៨ |
| **សិក្ខាបទ ទី ៩** | ១៣៩ |
| និទានឆព្វគ្គិយភិក្ខុ | ១៣៩ |
| សេចក្ដីបញ្ញត្តិជាដំបូង | ១៤០ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ១៤០ |
| បទភាជនីយ | ១៤២ |
| វារៈដែលមិនត្រូវអាបត្តិ | ១៤៤ |
| **សិក្ខាបទ ទី ១០** | ១៤៥ |
| និទានភិក្ខុ ១ រូប ជាអ្នកប្រព្រឹត្តបង្សុកូលនូវរបស់គ្រប់យ៉ាង | ១៤៥ |
| សេចក្ដីបញ្ញត្តិជាដម្បូង និងសេចក្ដីបញ្ញត្តិជាបន្ទាប់ | ១៤៦ |
| សិក្ខាបទវិភង្គ | ១៤៧ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ១៤៨ |
| **ឧទ្ទាននៃភោជនវគ្គ** | **១៥០** |
| អចេលកវគ្គ សិក្ខាបទ ទី១ | ១៥០ |
| និទានព្រះអានន្ទដ៏មានអាយុ | ១៥០ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៥៣ |

| | |
|---|---|
| បទភាជនីយ | ១៥៤ |
| វារៈដែលមិនត្រូវអាបត្តិ | ១៥៥ |
| **សិក្ខាបទ ទី ២** | ១៥៦ |
| និទានព្រះឧបនន្ទសក្យបុត្រ | ១៥៦ |
| សេចក្តីបញ្ញត្តិ | ១៥៧ |
| សិក្ខាបទវិភង្គ | ១៥៨ |
| បទភាជនីយ | ១៥៩ |
| វារៈដែលមិនត្រូវអាបត្តិ | ១៦០ |
| **សិក្ខាបទ ទី ៣** | ១៦១ |
| និទានព្រះឧបនន្ទសក្យបុត្រ | ១៦១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៦៣ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ១៦៤ |
| **សិក្ខាបទ ទី ៤** | ១៦៥ |
| និទានព្រះឧបនន្ទសក្យបុត្រ | ១៦៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៦៦ |
| បទភាជនីយ | ១៦៧ |
| វារៈដែលមិនត្រូវអាបត្តិ | ១៦៨ |
| **សិក្ខាបទ ទី ៥** | ១៦៩ |
| និទានព្រះឧបនន្ទសក្យបុត្រ | ១៦៩ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៧០ |
| បទភាជនីយ | ១៧០ |
| វារៈដែលមិនត្រូវអាបត្តិ | ១៧២ |
| **សិក្ខាបទ ទី ៦** | ១៧៣ |
| និទានព្រះឧបនន្ទសក្យបុត្រ | ១៧៣ |
| សេចក្តីបញ្ញត្តិជាដំបូង | ១៧៥ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី ១ និង ទី ២ | ១៧៧ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី ៣ | ១៧៦ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី ៤ និងសិក្ខាបទវិភង្គ | ១៧៩ |
| បទភាជនីយ | ១៨១ |
| វារៈដែលមិនត្រូវអាបត្តិ | ១៨២ |
| **សិក្ខាបទ ទី ៧** | ១៨៣ |
| និទានមហានាមសក្យ | ១៨៣ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបវារណា ៤ យ៉ាង | ១៨៨ |
| បទភាជនីយ | ១៨៩ |
| វារៈដែលមិនត្រូវអាបត្តិ | ១៩១ |
| **សិក្ខាបទ ទី ៨** | ១៩២ |
| និទានឆព្វគ្គិយភិក្ខុ | ១៩២ |

| | |
|---|---|
| សេចក្តីបញ្ញត្តិជាដំបូង | ១៩៣ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ | ១៩៤ |
| បទភាជនីយ | ១៩៥ |
| វារៈដែលមិនត្រូវអាបត្តិ | ១៩៦ |
| **សិក្ខាបទ ទី ៩** | ១៩៧ |
| និទានឆព្វគ្គិយភិក្ខុ | ១៩៧ |
| សេចក្តីបញ្ញត្តិជាដំបូង សិក្ខាបទវិភង្គ និងបទភាជនីយ | ១៩៨ |
| វារៈដែលមិនត្រូវអាបត្តិ | ១៩៩ |
| **សិក្ខាបទ ទី ១០** | ២០០ |
| និទានឆព្វគ្គិយភិក្ខុ | ២០០ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២០០ |
| បទភាជនីយ | ២០២ |
| វារៈដែលមិនត្រូវអាបត្តិ និងឧទ្ទាននៃអចេឡកវគ្គ | ២០៣ |
| **សុរាបានវគ្គ** | **២០៤** |
| **សិក្ខាបទ ទី១** | ២០៤ |
| និទានពួកអ្នកឃ្វាលគោ និងឃ្វាលពពែ | ២០៤ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ២០៩ |
| វារៈដែលមិនត្រូវអាបត្តិ | ២១០ |
| **សិក្ខាបទ ទី ២** | ២១១ |
| និទានឆព្វគ្គិយភិក្ខុ និងសេចក្តីបញ្ញត្តិ | ២១១ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ២១២ |
| វារៈដែលមិនត្រូវអាបត្តិ | ២១៣ |
| **សិក្ខាបទ ទី ៣** | ២១៤ |
| និទានសត្តរសវគ្គិយភិក្ខុ | ២១៤ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២១៥ |
| បទភាជនីយ | ២១៦ |
| វារៈដែលមិនត្រូវអាបត្តិ | ២១៧ |
| **សិក្ខាបទ ទី ៤** | ២១៨ |
| និទានឆន្នភិក្ខុ និងសេចក្តីបញ្ញត្តិ | ២១៨ |
| សិក្ខាបទវិភង្គ បទភាជនីយ | ២១៩ |
| វារៈដែលមិនត្រូវអាបត្តិ | ២២០ |
| **សិក្ខាបទ ទី ៥** | ២២១ |
| និទានឆព្វគ្គិយភិក្ខុ និងសេចក្តីបញ្ញត្តិ | ២២១ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ២២២ |
| វារៈដែលមិនត្រូវអាបត្តិ | ២២៣ |
| **សិក្ខាបទ ទី ៦** | ២២៤ |

| | |
|---|---|
| និទានភិក្ខុច្រើនរូប | ២២៤ |
| សេចក្តីបញ្ញត្តិជាដំបូង និងសេចក្តីបញ្ញត្តិជាបន្ទាប់ ទី១ | ២២៥ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ទី ២ និងសិក្ខាបទវិភង្គ | ២២៦ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២២៧ |
| **សិក្ខាបទ ទី ៧** | ២២៨ |
| និទានព្រះបាទពិម្ពិសារសេនីយរាជ | ២២៨ |
| សេចក្តីបញ្ញត្តិជាដំបូង | ២២៩ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី១ | ២៣០ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី២ | ២៣១ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី៣ | ២៣២ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី៤ | ២៣៣ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី៥ | ២៣៤ |
| សិក្ខាបទវិភង្គ | ២៣៥ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២៣៦ |
| **សិក្ខាបទ ទី ៨** | ២៣៧ |
| និទានភិក្ខុច្រើនរូប | ២៣៧ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៣៨ |
| បទភាជនីយ | ២៣៩ |
| វារៈដែលមិនត្រូវអាបត្តិ | ២៤០ |
| **សិក្ខាបទ ទី ៩** | ២៤១ |
| និទានព្រះឧបនន្ទសក្យបុត្រ | ២៤១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៤២ |
| បទភាជនីយ | ២៤៣ |
| វារៈដែលមិនត្រូវអាបត្តិ | ២៤៤ |
| **សិក្ខាបទ ទី ១០** | ២៤៥ |
| និទានសត្តរសវគ្គិយភិក្ខុ | ២៤៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៤៦ |
| បទភាជនីយ | ២៤៧ |
| វារៈដែលមិនត្រូវអាបត្តិ និងឧទ្ទានៃសុរាបានវគ្គ | ២៤៨ |
| **សប្បាណកវគ្គ** | **២៤៩** |
| **សិក្ខាបទ ទី១** | ២៤៩ |
| និទានឧទាយិភិក្ខុ | ២៤៩ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ២៥០ |
| វារៈដែលមិនត្រូវអាបត្តិ | ២៤១ |
| **សិក្ខាបទ ទី ២** | ២៥២ |
| និទានឆព្វគ្គិយភិក្ខុ និងសេចក្តីបញ្ញត្តិ | ២៥២ |
| សិក្ខាបទវិភង្គ បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២៥៣ |

| | |
|---|---|
| **សិក្ខាបទ ទី ៣** | ២៥៤ |
| និទានឆព្វគ្គិយភិក្ខុ | ២៥៤ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងអធិករណៈ ៤ យ៉ាង | ២៥៥ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២៥៦ |
| **សិក្ខាបទ ទី ៤** | ២៥៧ |
| និទានព្រះឧបនន្ទសក្យបុត្រ | ២៥៧ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ២៥៩ |
| វារៈដែលមិនត្រូវអាបត្តិ | ២៦០ |
| **សិក្ខាបទ ទី ៥** | ២៦១ |
| និទានឧបាលិទារក | ២៦១ |
| សេចក្តីបញ្ញត្តិ | ២៦៥ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ២៦៦ |
| វារៈដែលមិនត្រូវអាបត្តិ | ២៦៧ |
| **សិក្ខាបទ ទី ៦** | ២៦៨ |
| និទានភិក្ខុ ១ រូប | ២៦៨ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៦៩ |
| បទភាជនីយ | ២៧០ |
| វារៈដែលមិនត្រូវអាបត្តិ | ២៧១ |
| **សិក្ខាបទ ទី ៧** | ២៧២ |
| និទានភិក្ខុ ១ រូប | ២៧២ |
| សេចក្តីបញ្ញត្តិ | ២៧៣ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ២៧៤ |
| វារៈដែលមិនត្រូវអាបត្តិ | ២៧៥ |
| **សិក្ខាបទ ទី ៨** | ២៧៦ |
| និទានភិក្ខុឈ្មោះអរិដ្ឋ ជាភិក្ខុមិច្ឆាទិដ្ឋិ | ២៧៦ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៨២ |
| ការសូត្រសមនុភាសនកម្ម | ២៨៤ |
| បទភាជនីយ | ២៨៦ |
| វារៈដែលមិនត្រូវអាបត្តិ | ២៨៧ |
| **សិក្ខាបទ ទី ៩** | ២៨៨ |
| និទានឆព្វគ្គិយភិក្ខុ | ២៨៨ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៨៩ |
| ការបរិភោគរួម មានពីរយ៉ាង | ២៩០ |
| បទភាជនីយ | ២៩១ |
| វារៈដែលមិនត្រូវអាបត្តិ | ២៩២ |
| **សិក្ខាបទ ទី ១០** | ២៩៣ |
| និទានសមណុទ្ទេសឈ្មោះកណ្តក មានទិដ្ឋិអាក្រក់ | ២៩៣ |

| | |
|---|---|
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣០១ |
| បទភាជនីយ | ៣០២ |
| វារៈដែលមិនត្រូវអាបត្តិ និងឧទ្ទាននៃសប្បាណកវគ្គ | ៣០៥ |
| **សហធម្មិកវគ្គ** | **៣០៦** |
| **សិក្ខាបទ ទី១** | ៣០១ |
| និទានភិក្ខុឈ្មោះឆន្ន | ៣០៦ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣០៧ |
| បទភាជនីយ | ៣០៨ |
| វារៈដែលមិនត្រូវអាបត្តិ | ៣១០ |
| **សិក្ខាបទ ទី ២** | ៣១១ |
| និទានព្រះដ៏មានព្រះភាគសំដែងអានិសង្សវិន័យ និងនិទានឆព្វគ្គិយភិក្ខុ | ៣១១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣១៣ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៣១៤ |
| **សិក្ខាបទ ទី ៣** | ៣១៥ |
| និទានឆព្វគ្គិយភិក្ខុ | ៣១៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣១៧ |
| មោហារោបនកម្ម | ៣១៨ |
| បទភាជនីយ | ៣១៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៣២០ |
| **សិក្ខាបទ ទី ៤** | ៣២១ |
| និទានឆព្វគ្គិយភិក្ខុ | ៣២១ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ៣២២ |
| វារៈដែលមិនត្រូវអាបត្តិ | ៣២៣ |
| **សិក្ខាបទ ទី ៥** | ៣២៤ |
| និទានឆព្វគ្គិយភិក្ខុ | ៣២៤ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ២៣៥ |
| វារៈដែលមិនត្រូវអាបត្តិ | ៣២៦ |
| **សិក្ខាបទ ទី ៦** | ៣២៧ |
| និទានឆព្វគ្គិយភិក្ខុ | ៣២៧ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ៣២៨ |
| វារៈដែលមិនត្រូវអាបត្តិ | ៣២៩ |
| **សិក្ខាបទ ទី ៧** | ៣៣០ |
| និទានឆព្វគ្គិយភិក្ខុ | ៣៣០ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៣១ |
| បទភាជនីយ | ៣៣២ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៣៣ |

| | |
|---|---|
| **សិក្ខាបទ ទី ៨** | ៣៣៤ |
| និទានឆព្វគ្គិយភិក្ខុ | ៣៣៤ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៣៥ |
| បទភាជនីយ | ៣៣៦ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៣៧ |
| **សិក្ខាបទ ទី ៩** | ៣៣៨ |
| និទានឆព្វគ្គិយភិក្ខុ | ៣៣៨ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៣៩ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៣៤០ |
| **សិក្ខាបទ ទី ១០** | ៣៤១ |
| និទានឆព្វគ្គិយភិក្ខុ | ៣៤១ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៤២ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២៤៣ |
| **សិក្ខាបទ ទី ១១** | ៣៤៥ |
| និទានទព្វមល្លបុត្រ | ៣៤៥ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៤៦ |
| បទភាជនីយ | ៣៤៧ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៤៨ |
| **សិក្ខាបទ ទី ១២** | ៣៤៩ |
| និទានឆព្វគ្គិយភិក្ខុ | ៣៤៩ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៥១ |
| បទភាជនីយ | ៣៥២ |
| វារៈដែលមិនត្រូវអាបត្តិ និងឧទ្ទាននៃសហធម្មិកវគ្គ | ៣៥៣ |
| **រតនវគ្គ** | **៣៥៤** |
| **សិក្ខាបទ ទី១** | ៣៥៤ |
| និទានស្ដេចព្រះនាមបសេនទិកោសល | ៣៥២ |
| និយាយពីទោសចូលទៅកាន់រាជត្រកូល មាន ១០ យ៉ាង | ៣៥៩ |
| សេចក្ដីបញ្ញត្តិ | ៣៦២ |
| សិក្ខាបទវិភង្គ | ៣៦៣ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៣៦៤ |
| **សិក្ខាបទ ទី ២** | ៣៦៥ |
| និទានភិក្ខុ ១ រូប | ៣៦៥ |
| សេចក្ដីបញ្ញត្តិជាដំបូង និងនិទាននាងវិសាខាមិគារមាតា | ៣៨៨ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ ទី១ និងនិទានកូនក្មួយអនាថបិណ្ឌិកសេដ្ឋី | ៣៦៧ |
| សេចក្ដីបញ្ញត្តិជាបន្ទាប់ ទី ២ និងសិក្ខាបទវិភង្គ | ៣៧០ |
| បទភាជនីយ | ៣៧១ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៧២ |

| | |
|---|---|
| **សិក្ខាបទ ទី ៣** | ៣៧៣ |
| និទានឆព្វគ្គិយភិក្ខុ និយាយតិរច្ឆានកថា | ៣៧៣ |
| សេចក្តីបញ្ញត្តិជាដំបូង និទានភិក្ខុច្រើនរូប និងសេចក្តីបញ្ញត្តិជាបន្ទាប់ ទី ១ | ៣៧៦ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី២ | ៣៧៧ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី៣ និងសិក្ខាបទវិភង្គ | ៣៧៨ |
| បទភាជនីយ | ៣៧៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៨០ |
| **សិក្ខាបទ ទី ៤** | ៣៨១ |
| និទានភិក្ខុច្រើនរូប | ៣៨១ |
| សេចក្តីបញ្ញត្តិ | ៣៨២ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ៣៨៣ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៨៤ |
| **សិក្ខាបទ ទី ៥** | ៣៨៥ |
| និទានព្រះឧបនន្ទសក្យបុត្រ | ៣៨៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៨៦ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៣៨៧ |
| **សិក្ខាបទ ទី ៦** | ៣៨៨ |
| និទានឆព្វគ្គិយភិក្ខុ | ៣៨៨ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣៨៩ |
| បទភាជនីយ | ៣៩០ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៩១ |
| **សិក្ខាបទ ទី ៧** | ៣៩២ |
| និទានឆព្វគ្គិយភិក្ខុ | ៣៩២ |
| សេចក្តីបញ្ញត្តិជាដំបូង និងនិទានឧទាយិភិក្ខុ | ៣៩៣ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ សិក្ខាបទវិភង្គ និងបទភាជនីយ | ៣៩៤ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៩៥ |
| **សិក្ខាបទ ទី ៨** | ៣៩៦ |
| និទានឆព្វគ្គិយភិក្ខុ | ៣៩៦ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ៣៩៧ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៩៨ |
| **សិក្ខាបទ ទី ៩** | ៣៩៩ |
| និទានឆព្វគ្គិយភិក្ខុ | ៣៩៩ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ៤០០ |
| វារៈដែលមិនត្រូវអាបត្តិ | ៤០១ |
| **សិក្ខាបទ ទី ១០** | ៤០២ |
| និទាននន្ទភិក្ខុ | ៤០២ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ៤០៣ |

| | |
|---|---|
| វារៈដែលមិនត្រូវអាបត្តិ | ៤០៤ |
| **ឧទ្ទាននៃរតនវគ្គ** | **៤០៥** |
| **បាដិទេសនីយកណ្ឌ** | **៤០៦** |
| **សិក្ខាបទ ទី១** | ៤០៦ |
| និទានភិក្ខុនី ១ រូប ទៅបិណ្ឌបាត | ៤០៦ |
| សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ | ៤០៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៤១១ |
| **សិក្ខាបទ ទី ២** | ៤១២ |
| និទានឆព្វគ្គិយភិក្ខុនី | ៤១២ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៤១៣ |
| បទភាជនីយ | ៤១៤ |
| វារៈដែលមិនត្រូវអាបត្តិ | ៤១៥ |
| **សិក្ខាបទ ទី ៣** | ៤១៦ |
| និទានត្រកូល ១ មានសេចក្តីជ្រះថ្លាទាំងពីរនាក់ប្តីប្រពន្ធ | ៤១៦ |
| សេក្ខសម្មតិ | ៤១៧ |
| សេចក្តីបញ្ញត្តិជាដំបូង និងនិទានភិក្ខុច្រើនរូប | ៤១៨ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី១ | ៤១៩ |
| និទានភិក្ខុ ១ រូប | ៤២០ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ ទី២ និងសិក្ខាបទវិភង្គ | ៤២១ |
| បទភាជនីយ | ៤២២ |
| វារៈដែលមិនត្រូវអាបត្តិ | ៤២៤ |
| **សិក្ខាបទ ទី ៤** | ៤២៥ |
| និទានពួកទាសរបស់សាកិយជន | ៤២៥ |
| សេចក្តីបញ្ញត្តិជាដំបូង | ៤២៦ |
| និទានភិក្ខុ ១ រូប និងសេចក្តីបញ្ញត្តិជាបន្ទាប់ | ៤២៧ |
| សិក្ខាបទវិភង្គ | ៤២៨ |
| បទភាជនីយ | ៤៣១ |
| វារៈដែលមិនត្រូវអាបត្តិ | ៤៣២ |
| **សេក្ខិយកណ្ឌ** | **៤៣៤** |
| **បរិមណ្ឌលវគ្គ** | **៤៣៤** |
| **សារុប្ប ២៦** | **៤៣៤** |
| **ឧជ្ជគ្ឃិកវគ្គ** | **៤៤៣** |
| **ខម្ភកតវគ្គ** | **៤៤៨** |
| **ភោជនប្បដិសំយុត្ត ៣០** | **៤៥១** |
| **សក្កច្ចវគ្គ** | **៤៥៥** |
| **ភពឡវគ្គ** | **៤៦៤** |
| | |

| | |
|---|---|
| **សុរុសុរុវគ្គ** | **៤៧០** |
| **ធម្មទេសនាបដិសំយុត្ត ១៦ សិក្ខាបទ** | **៤៧៦** |
| **បាទុកាវគ្គ** | **៤៨២** |
| បកិណ្ណក ៣ សិក្ខាបទ | ៤៩៣ |
| ពួកធម៌សម្រាប់រម្ងាប់នូវអធិករណៈ | ៥០១ |


1)

ឧបចារគ្រែនិងតាំង តាមអដ្ឋកថា ថា កំណត់ពីរហត្ថមួយចំអាម។

2)

ប្រែថា សាលាសម្រាប់បម្រើ តែអដ្ឋកថាថា បានដល់សាលាសម្រាប់ឆាន់ ឬរោងឆាន់។

3)

ពោលពាក្យជាតិរច្ឆានកថា ឬនិយាយសរសើរពីស្រីនិងប្រុសជាដើម។ ន័យអដ្ឋកថា។

4)

ក្នុងមហាបច្ចរីថា មានទំហំមួយហត្ថមួយចំអាម រាប់អំពីមេទ្វារចេញទៅ ក្នុងកុរុន្ទិថា កំណត់ត្រឹមសន្លឹកទ្វារទាំងពីរជាប្រមាណ ក្នុងមហាអដ្ឋកថាថា សន្លឹកទ្វារនោះមួយហត្ថមួយចំអាមក៏មាន ពីរហត្ថក៏មាន ពីរហត្ថមួយចំអាមក៏មាន។

5)

ក្បាច់ដែលមានស្រទាប់៥ ឬជាន់៥។

6)

អដ្ឋកថា ថា គូរូបភាពបុរសស្ត្រី ធ្វើសណ្ឋានវៈគ្នា មានឧបាយលាយដោយវត្ថុពណ៌ផ្សេងៗតាមគំនិតរបស់ខ្លួន ត្រង់កណ្តាលចីវរ។

7)

សង្ឃពីរពួក គឺភិក្ខុសង្ឃ១ ភិក្ខុនីសង្ឃ១

8)

បានដល់ភិក្ខុមានដំណើរចេញពីស្រុក១ទៅស្រុក១ ចម្ងាយផ្លូវទៅមួយថ្ងៃ មកមួយថ្ងៃ ថ្ងៃទីមួយទៅឆាន់ម្តង ថ្ងៃទីពីរត្រឡប់មកវិញឆាន់ម្តងទៀត។

9)

រាជអាណាចក្រដទៃ ប្រទេសដទៃ ដែនដទៃ។

10)

គឺរបៀបធ្វើភត្តរបស់មិច្ឆាទិដ្ឋិ ក្រៅពីព្រះពុទ្ធសាសនា។

11)

គឺគិតពី ១រោចខែអស្សុជ្ជ ទៅដល់ថ្ងៃពេញបូណ៌មីខែកត្តិក។

12)

គឺគិតពី ១រោជខែអស្សុជ្ជ ទៅដល់ថ្ងៃពេញបូណ៌មីខែផគ្គុណ។

13)

ព្រោះភិក្ខុនោះទទួលនិមន្តឆាន់ភោជន៥យ៉ាង ភោជនណាមួយក្នុងទីឯណេះ ហើយត្រឡប់ទៅឆាន់ក្នុងទីឯណោះវិញ ឬទទួលនិមន្តឆាន់ក្នុងទីឯណោះ ហើយត្រឡប់មកឆាន់ក្នុងទីឯណេះវិញ។

14)

គឺប្រទេសនៅទិសខាងលិចចំព្រះអាទិត្យអស្តង្គត។

15)

អដ្ឋកថា ដែលហៅថា អនតិរិត្តភោជន បានដល់ភោជនដែលមិនគួរដល់អាការនៃវិនយកម្ម៧យ៉ាង និងភោជនដែលមិនមែនសល់អំពីភិក្ខុឈឺ។ ឯអាការដែលមិនគួរដល់វិនយកម្ម៧យ៉ាងនោះ អធិប្បាយថា ១. វត្ថុទាំងឡាយមានផ្លែ និងមើមជាដើម ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរដល់សមណកប្បក្តី និងសាច់ដែលមិនគួរក្តី ភោជនដែលមិនគួរក្តី ហៅថា អកប្បិយទាំងអស់ ភិក្ខុអ្នកធ្វើវិនយកម្ម យកអកប្បិយវត្ថុទាំងនេះមកធ្វើជាវិនយកម្មថា វត្ថុទាំងនេះជារបស់គួរហើយ។ ២. វត្ថុដែលភិក្ខុអ្នកធ្វើវិនយកម្មមិនទាន់បានទទួលមកទេ ហើយធ្វើវិនយកម្មថា វត្ថុទាំងអស់នេះគួរហើយ។ ៣.វត្ថុដែលភិក្ខុកាន់មកដើម្បីឲ្យភិក្ខុអ្នកធ្វើវិនយកម្ម ធ្វើឲ្យជារបស់គួរ តែមិនបានលើកឡើង ឬមិនបានបង្អោនទៅ ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ។ ៤.ភិក្ខុកាន់យកវត្ថុមកដើម្បីឲ្យភិក្ខុផងគ្នាធ្វើវិនយកម្មឲ្យ តែភិក្ខុអ្នកធ្វើវិនយកម្មនោះឋិតនៅខាងក្រៅហត្ថបាស ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ។ ៥.ភិក្ខុណាមួយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ តែភិក្ខុអ្នកធ្វើវិនយកម្មនោះឯង មិនទាន់ឆាន់ភោជននៅឡើយ ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ។ ៦. ភិក្ខុអ្នកធ្វើវិនយកម្មបានឆាន់ហើយ ហាមភោជនហើយ ក្រោកចាកអាសនៈហើយ ទៅធ្វើវិនយកម្មឲ្យគេថា របស់ទាំងអស់នេះគួរហើយ។ ៧. ភិក្ខុអ្នកធ្វើវិនយកម្ម មិនបានបញ្ចេញវចីភេទថា របស់ទាំងអស់នេះគួរហើយ។ និងភោជន៥យ៉ាង ភោជនណាមួយដែលមិនមែនសល់អំពីភិក្ខុឈឺ។ វត្ថុដែលមិនគួរដល់អាការនៃវិនយកម្មទាំង៧យ៉ាងនេះក្តី ភោជនដែលមិនមែនសល់អំពីភិក្ខុឈឺក្តី ទាំងពីរចំណែកនេះ ហៅថា អនតិរិត្តភោជន។

16)

អដ្ឋកថា គឺបាយតែម្យ៉ាង មិនមានសម្លនិងម្ហូបក្រៀមលាយជាមួយផង។

17)

អដ្ឋកថា អាហារមានបាយជាដើម ដែលអ្នកបួសគប្បីឆាន់បានតាំងពីព្រឹកទៅដល់ថ្ងៃត្រង់ ហៅថាយាវកាលិក។

18)

ទឹក៨យ៉ាង មានទឹកស្វាយជាដើម ដែលអ្នកបួសគប្បីឆាន់បានត្រឹមថ្ងៃ១យប់១ ហៅថាយាមកាលិក។

19)

ភេសជ្ជៈ៥យ៉ាង មានទឹកដោះថ្លាជាដើម ដែលអ្នកបួសគប្បីទុកឆាន់បានក្នុងរវាង៧ថ្ងៃ ហៅថាសត្តាហកាលិក។

20)

វត្ថុឯទៀតក្រៅពីកាលិកទាំង៣ខាងដើម ដែលអ្នកបួសគប្បីរក្សាទុកឆាន់បានដរាបទាល់អស់មួយជីវិត ហៅថា យាវជីវិក។

21)

អដ្ឋកថា ភិក្ខុនោះប្រព្រឹត្តបំសុកូលគ្រប់ជំពូក ដោយហោចទៅសូម្បីឈើស្ទន់ ក៏បំសុកូលយកដែរ។

22)

អដ្ឋកថា កិរិយាទទួលប្រគេនប្រកបដោយអង្គ៥ គឺ១.វត្ថុដែលបុរសមានកំលាំងយ៉ាងកណ្តាល ល្មមលើកឡើងបាន។ ២.អ្នកប្រគេនស្ថិតនៅក្នុងហត្ថបាស។ ៣.អ្នកប្រគេនបានបង្អោនខ្លួនចូលមក។៤.ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តីប្រគេន។ ៥.ភិក្ខុទទួលវត្ថុនោះដោយកាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី។

23)

មហាវិកត៤គឺ មូត១ គូថ១ ផេះ១ ដី១។

24)

ភិក្ខុដាក់របស់ក្នុងភាជន៍ ហើយលើកយកភាជន៍នោះទៅដម្កល់ទុកលើដី ជិតតិរ្ថិយទាំងនោះ ហើយឲ្យដោយវាចា។

25)

បានដល់គ្រឿងលាបកាយគ្រប់យ៉ាង មានម្សៅជាដើម។

26)

អដ្ឋកថា អធិប្បាយថា ភិក្ខុចូលទៅហួសពាក់កណ្តាលផ្ទះ គឺហួសមេដំបូលផ្ទះ។

27)

អដ្ឋកថាថា មហានាមសក្យៈនេះ ជាបុត្រនៃចូឡបិតារបស់ព្រះដ៏មានព្រះភាគ ចាស់ជាងព្រះដ៏មានព្រះភាគប្រមាណ១ខែ ជាអរិយសាវក បានដម្កល់នៅក្នុងផលទាំងពីរ គឺសោតាបត្តិផល និងសកទាគាមិផល។

28)

បើមានសេចក្តីអន្តរាយដល់ជីវិត ដល់ព្រហ្មចរិយធម៌ ភិក្ខុគិតថា អញទៅក្នុងកងទ័ពនឹងបានរួចសេចក្តីអន្តរាយ ហើយដើរចូរទៅក្នុងកងទ័ព មិនត្រូវអាបត្តិ។

29)

ពស់ឥតពិស បានដល់ពស់ចន្ទមម និងពស់ព្រលិតជាដើម។

30)

ថ្នាំដែលគេធ្វើដោយរសនៃផ្លែឈើ មានផ្លែកន្ទួតព្រៃជាដើម។

31)

គឺយកម្រាមដៃចាក់ក្រលេកលេង

32)

គឺពាក្យដែលមានមកក្នុងព្រះសូត្រ និងព្រះអភិធម្ម។

33)

ភិក្ខុពស់ចឹក ចោរ ឬម្រឹគសាហាវបៀតបៀនជាដើម ហៅថា មានសេចក្តីអន្តរាយ។

34)

១.២.មួយខែកន្លះខាងចុងគិម្ហរដូវ គឺតាំងពី១កើតខែជេស្ឋទៅដល់១៥កើតខែអាសាឍ្ហ នេះជាខេត្តរបស់សម័យក្តៅ។ ឯមួយខែខាងដើមនៃវស្សានរដូវ គឺតាំងពី១រោចខែអាសាឍ្ហ ទៅដល់១៥កើតខែស្រាពណ៍ នេះជាខេត្តរបស់សម័យស្អុះស្អាប់។

35) , 37) , 67)

២

36)

១.២.៣.៤.សម័យទាំង៤យ៉ាងនេះមិនចំពោះខែណា ថ្ងៃណាទេ ដែលមានកំណត់ពីរខែកន្លះនោះ តែសម័យពីរយ៉ាងខាងដើម។

38)

៣

39)

40)

គឺភិក្ខុមានសត្វឃ្មុំជាដើមដេញទិច ហើយមុជទៅក្នុងទឹក ដើម្បីឲ្យផុតពីសេចក្តីអន្តរាយនោះ ហៅថា មានសេចក្តីអន្តរាយក្នុងសិក្ខាបទនេះ

41)

មានសេចក្តីអធិប្បាយក្នុងសិក្ខាបទ ទី ៨ តេរសកណ្ឌសៀវភៅទី២រួចហើយ។

42)

បានដល់កម្មដែលធ្វើមិនត្រឹមត្រូវតាមច្បាប់។

43)

បានដល់កម្មដែលធ្វើបែកខ្ញែកជាពួក មិនព្រមព្រៀងគ្នា។

44)

បានប្រែក្នុងសិក្ខាបទទី១ នៃសង្ឃាទិសេសរួចហើយ។

45)

បានដល់សត្វមានខ្លួនវែង មានពស់ក្អែបជាដើម។

46)

គឺរាប់ឆ្នាំបានគ្រប់២០ហើយ តែនៅខ្វះខែ និងថ្ងៃ ដូចមនុស្សណាមួយ កាលនៅក្នុងផ្ទៃមាតាបានតែ៧ខែ កាលដែលសម្រាល ៗនៅថ្ងៃ១៥កើតខែពិសាខ ឆ្នាំជូត លុះដល់មកថ្ងៃ១៥កើត ខែពិសាខ ឆ្នាំមមែ បាន២០ឆ្នាំខ្វះ៣ខែ លុះតែបង្អង់ឲ្យហួសដល់ថ្ងៃ១៥កើត ខែស្រាពណ៌ ឆ្នាំមមែ ហើយរាប់យក៧ខែ ក្នុងផ្ទៃនិងអធិកមាស២ខែ មកផ្សំផង ទើបបានគ្រប់២០ឆ្នាំគត់។

47)

បានដល់ភិក្ខុបបួលថាទៅថ្ងៃនេះ ពេលនេះ តែមិនបានទៅតាមថ្ងៃ តាមពេលដែលបានកំណត់នោះ។

48)

គឺភិក្ខុដែលសង្ឃលើកវត្ត ដោយសូត្រញត្តិចតុត្ថកម្មវាចា ព្រោះភិក្ខុនោះមិនឃើញអាបត្តិ មិនសំដែងអាបត្តិ មិនលះបង់ទិដ្ឋិ ហៅថា ភិក្ខុដែលសង្ឃលើកវត្ត ឯរូបភិក្ខុនោះ មិនត្រូវបរិភោគរួមនឹងសង្ឃឡើយ។ សេចក្តីពិស្តារក្នុងកម្មក្ខន្ធកៈ គម្ពីរចុល្លវគ្គ។

49)

បរិភោគ ក្នុងទីនេះចំពោះយកការសេពគប់។

50)

សមណុទ្ទេស ជាពាក្យផ្លាស់ប្តូរគ្នានឹងពាក្យថា សមណេរ នឹងហៅថាសមណុទ្ទេសក៏បាន ថាសាមណេរក៏បាន។

51)

អដ្ឋកថា វិនាសនោះមានបីយ៉ាង គឺសំវាសនាសនា វិនាសទីខានបាននៅរួមជាមួយនឹងសង្ឃ១ លិង្គនាសនា វិនាសចាកភេទ គឺត្រូវផ្សឹកចេញ១ ទណ្ឌកម្មនាសនា វិនាសដោយត្រូវទណ្ឌកម្ម មានមិនឲ្យដេកនៅរួមនឹងភិក្ខុអស់ពីរបីរាត្រីជាដើម១ កណ្ឌកៈនេះត្រូវទណ្ឌកម្មនាសនា។

52)

បានដល់ភិក្ខុ

53)

បានដល់ជនមិនមែនភិក្ខុ

54)

អដ្ឋកថា បានដល់សម្លត់ខ្នាតតូច បណ្តោយ៨ធ្នាប់ ទទឹង៤ធ្នាប់ ដោយធ្នាប់ព្រះសុគតឡើងទៅ ហៅថា សម្លត់គួរដល់ការវិកប្ប។

55)

ភិក្ខុដែលបានរើសកែវ៧ប្រការ មានមាសប្រាក់ជាដើម ដែលគេភ្លេចនៅក្នុងវត្តក្តី ក្នុងលំនៅរបស់ភិក្ខុក្តី ត្រូវធ្វើស្លាកយកទៅបិទទុកនៅទីណាមួយ គឺទ្វារវត្ត ឬទីជិតកន្លែងដែលខ្លួននៅ ឯសេចក្តីក្នុងស្លាកនោះ ដូច្នេះ អ្នកណាបាត់របស់អ្វី អ្នកនោះចូរមកទទួលយក។

56)

ភវៈ គឺសស្សតទិដ្ឋិ

57)

អភវៈ គឺឧច្ឆេទទិដ្ឋិ ម្យ៉ាងទៀត ភវៈ គឺសេចក្តីចំរើន អភវៈ គឺសេចក្តីសាបសូន្យ ឬភវៈ គឺសេចក្តីសុខក្នុងកាម អភវៈ គឺសេចក្តីព្យាយាមធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍។

58)

អាបត្តិបាចិត្តិយនេះមានកិច្ចត្រូវបំបែកបំពង់ម្ជុលនោះមុនជាវិនយកម្ម ទើបសំដែងបាន បើមិនបានធ្វើវិនយកម្មទេ សំដែងមិនបានឡើយ។

59)

បានដល់ទីនៅ

60)

អាបត្តិបាចិត្តិយនេះមានកិច្ចត្រូវកាត់ (ជើងគ្រែ) នោះមុនជាវិនយកម្មទើបសំដែងបាន បើមិនបានធ្វើវិនយកម្មទេ សំដែងមិនបានឡើយ

61)

អាបត្តិបាចិត្តិយនេះ មានកិច្ចត្រូវទំលាយ (សំឡី)នោះមុនជាវិនយកម្ម ទើបសំដែងបាន បើមិនបានធ្វើវិនយកម្មទេ សំដែងមិនបានឡើយ។
62)

Correction of wrong translation.
63)

ស្រីដែលបានឧបសម្បទាអំពីឧភតោសង្ឃ ដែលហៅថា ភិក្ខុនីនោះឯង។
64)

អដ្ឋកថា បានឮថាក្នុងត្រកូលនោះមានជនពីរនាក់បានសម្រេចព្រះសោតាបត្តិផល។
65)

តអំពីនេះទៅ មានបាលីប្រាកដក្នុងគម្ពីរខ្លះថា ឧទ្ទាននៃបាដិទេសនិយកណ្ឌនោះថា (មាន៤សិក្ខាបទ)គឺ ភិក្ខុចូលទៅកាន់ចន្លោះស្រុក ហើយទទួលយកចង្ហាន់អំពីដៃភិក្ខុនីដែលមិនមែនជាញាតិ១ ភិក្ខុមិនហាមឃាត់ភិក្ខុនីដែលកំពុងបង្គាប់បញ្ជាគ្រហស្ថ១ ការឲ្យនូវសេក្ខសម្មតិ១ ការឆាន់ចង្ហាន់ក្នុងសេនាសនៈតាំងនៅក្នុងព្រៃ១
66)

១.២.អដ្ឋកថា ភិក្ខុត្រូវស្លៀកស្បង់ឲ្យជាបរិមណ្ឌល ខាងលើបិទមណ្ឌលផ្ចិត ខាងក្រោម បិទមណ្ឌលជង្គង់ គឺស្រុងចុះទៅខាងក្រោមអំពីជង្គង់ប្រមាណ៨ធ្នាប់។
68)

គឺភិក្ខុមិនបានបិទបាំងកាយឲ្យជាបរិមណ្ឌល
69)

អដ្ឋកថា ថាបិទបាំងឲ្យល្អ គឺមិនទទូរក្បាល អធិប្បាយថា ភិក្ខុនឹងចូលទៅក្នុងស្រុក ត្រូវយកចីពរមកដាក់គ្របលើស្មា ពាក់កំភ្លៅហើយយកជាយទាំងពីរបិទបាំងក រួចហើយធ្វើចុងមុំទាំងពីរឲ្យត្រឹមស្មើគ្នា ហើយប្រមូលចូលមក រួចបិទបាំងដរាបដល់ភ្នែកដៃ ហើយគប្បីដើរទៅ។
70)

អដ្ឋកថា ថា ភិក្ខុវេលានឹងអង្គុយនៅក្នុងស្រុក ត្រូវបើកកាយខាងលើតាំងពីកញ្ចឹងករហូតដល់ក្បាល ខាងដៃ តាំងពីត្រឹមភ្នែកដៃទៅចុងម្រាម ខាងជើង តាំងពីចុងកំភួនជើងទៅខាងក្រោម ហើយគប្បីអង្គុយចុះ។
71)

អដ្ឋកថា សម្លដែលមានប្រមាណប៉ុនភាគទី៤នៃភត្ត ហៅថា សម្លល្មមនឹងបិណ្ឌបាត
72)

អដ្ឋកថា ម្ហូបអាហារដទៃៗ មានសម្លបន្លែ ត្រីសាច់ជាដើម ដែលក្រៅពីសម្លសណ្តែកបាយ និងសម្លសណ្តែករាជមាសចេញ។
73)

បទត្រង់នេះហាក់ដូចជាលើស ប្រហែលចំឡងតាមសិក្ខាបទខាងដើមត្រង់អដ្ឋថា ភិក្ខុទទួលសម្លដើម្បីអ្នកដទៃទេដឹង តែសិក្ខាបទនេះ និយាយពីឆាន់សម្ល ភិក្ខុឆាន់ដើម្បីអ្នកដទៃ ដូចម្តេចបាន បាលីបទនេះ មិនមានក្នុងច្បាប់ឱរូបទេ។
74)

អដ្ឋកថា ពំនូតបាយធំពេកប៉ុនពងក្ងោក តូចពេកប៉ុនពងមាន់ មិនគួរ បើពូតឲ្យទៅជាកណ្តាល គួរ
75)

ដីកាវិន័យ ឆត្រនេះគេធ្វើឆ្អឹងទទឹង មានវង់មូលដូចជាកង់ ហើយយកមកភ្ជាប់នឹងឆ្អឹងបណ្តោយចងរឹតនឹងចេស។
76)

ឆត្រនេះ គេធ្វើឆ្អឹងបណ្តោយ និងឆ្អឹងទទឹងឲ្យត្រង់ ចងឲ្យមាំ មានដងវែង (ឆ្អឹងលុត) គេប្រើបើកបិទបាន។
77)

អដ្ឋកថា យានជំនិះដែលគេប្រក់ដំបូលខាងលើមានសណ្ឋានដូចជាមណ្ឌប។
78)

ទាំងពីរខាងនៃរថនោះ គេពាក់បង្កង់សុទ្ធសឹងតែធ្វើពីរបស់ល្អៗ មានមាសប្រាក់ជាដើម មានទ្រង់ទ្រាយដូចជាស្លាបគ្រុឌ។
79)

ព្រះត្រៃបិដក អក្សរឱរុប និងភូមា មិនមានគាថាប្រាប់ចំនួនសិក្ខាបទក្នុងសេក្ខិយកណ្ឌនេះ ដូចក្នុងកណ្ឌឯទៀតៗខាងដើមនោះទេ ឯកណ្ឌខាងដើម គឺបារាជិកកណ្ឌក្តី តេរសកណ្ឌក្តី រហូតដល់បាចិត្តិយកណ្ឌ ក៏សុទ្ធតែមានគាថាប្រាប់ចំនួនសិក្ខាបទទាំងអស់ ប្លែកគ្នាតែកន្លែងដាក់គាថា កណ្ឌខ្លះដាក់ត្រង់ចុងបំផុតវគ្គ កណ្ឌខ្លះដាក់ត្រង់ចុងបំផុតកណ្ឌ ឯក្នុងបាលីស្លឹករឹតអក្សរខម មានគាថាប្រាប់ចំនួនសិក្ខាបទគ្រប់កន្លែង តាំងពីបារាជិកកណ្ឌដល់សេក្ខិយកណ្ឌ។
80)

ធម្មវាទីបុគ្គលពន្យល់បង្ហាញអធម្មវាទីបុគ្គលដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាសត្ថុសាសនៈ លោកចូរកាន់យកធម៌វិន័យនេះចុះ លោកចូរស្រឡាញ់ធម៌វិន័យនេះចុះ បើអធិករណៈរម្ងាប់បានដូច្នេះជាដើម ហៅថា សម្មុខាវិន័យ។
81)

សង្ឃត្រូវឲ្យសតិវិន័យដល់ភិក្ខុដែលបរិសុទ្ធចាកអាបត្តិ មានសតិបរិបូណ៌ ដោយញត្តិចតុត្ថកម្មវាចា។
82)

សង្ឃត្រូវឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលជាពីឆ្កួតហើយ ដោយញត្តិចតុត្ថកម្មវាចា ដើម្បីមិនឲ្យភិក្ខុណាមួយចោទភិក្ខុនោះដោយអាបត្តិអ្វីឡើយ។
83)
ភិក្ខុប្រព្រឹត្តលាមក ភិក្ខុឯទៀតចោទដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ត្រឡប់គេចកែ ប្រែសំដី ពោលពាក្យកុហក សង្ឃត្រូវធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុនោះ ដោយញត្តិចតុត្ថកម្មវាចា ហើយភិក្ខុនោះត្រូវប្រព្រឹត្តវត្ត មាន មិនត្រូវឲ្យៗឧបសម្បទា និងនិស្ស័យជាដើម។ (ស្រង់យកពីចុល្លវគ្គ សមថក្ខន្ធកៈ)។

---

sangham.net
Virtual AccessToInsight

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០០៥ - Book 005

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថាលោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០៥ - Tipitaka Book 005 [http://forum.sangham.net/index.php/topic,8914.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០០៥

ភាគ ទី ០០៤ | **មាតិកា** | ភាគ ទី ០០៦




គំរូ ឯកសារ ផ្សេងទៀត ៖
book_005.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី៥

ទ. ៖

# វិន័យបិដក

CS vin | ភាគ ទី៥

# ភិក្ខុនីវិភង្គ

CS vin.vbi | ភាគ ទី៥

**ភិក្ខុនីវិភង្គោ**

**ភាគ ទី៥**

បារាជិកកណ្ឌ | សង្ឃាទិសេសកណ្ឌ | និស្សគ្គិយកណ្ឌ | បាចិត្តិយកណ្ឌ | បាដិទេសនីយកណ្ឌ | សេក្ខិយកណ្ឌ | អធិករណសមថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ។

# បារាជិក

CS vin.vbi.pr | ភាគ ទី៥

**(១. បារាជិកកណ្ឌំ (ភិក្ខុនីវិភង្គោ))**

**បារាជិក ទី១**

CS vin.vbi.pr.1 | ភាគ ទី៥

**(១. បឋមបារាជិកំ)**

[១] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់សម្រេចឥរិយាបថនៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង មានបុរសម្នាក់ឈ្មោះសាឡ្ហ ជាចៅនៃមិគារមាតា[1] មានសេចក្ដីប្រាថ្នានឹងសាងវិហារ (ប្រគេន) ភិក្ខុនីសង្ឃ។ ទើបសាឡ្ហ ជាចៅមិគារមាតា (នោះ) ចូលទៅរកភិក្ខុនីទាំងឡាយ ហើយនិយាយពាក្យនេះថា បពិត្រលោកម្ចាស់ ខ្ញុំប្រាថ្នានឹងសាងវិហារ (ប្រគេន) ភិក្ខុនីសង្ឃ សូមលោកម្ចាស់ទាំងឡាយ ចាត់ភិក្ខុនីដែលជាអ្នកចេះត្រួតត្រានវកម្មឲ្យខ្ញុំ។ សម័យនោះឯង មានស្រីជាបងប្អូនគ្នា៤នាក់ ឈ្មោះ នន្ទា១ នន្ទវតី១ សុន្ទរីនន្ទា១ ថុល្លនន្ទា១ បានមកបួសក្នុងសំណាក់ពួកភិក្ខុនី។ បណ្ដាភិក្ខុនីទាំងនោះ សុន្ទរីនន្ទាភិក្ខុនី បួសតាំងអំពីក្មេង ជាភិក្ខុនីមានរូបល្អល្អះ គួរគយគន់មើល គួរជាទីជ្រះថ្លា ជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ មានប្រាជ្ញាឆ្លៀវឆ្លាស ឥតមានសេចក្ដីខ្ជិលច្រអូស ប្រកបដោយយោបល់ជាគ្រឿងយល់ក្នុងកិច្ចនោះៗ អាចធ្វើ និងអាចចាត់ចែង (នូវនវកម្ម)បាន។ ទើបភិក្ខុនីសង្ឃសន្មតសុន្ទរីនន្ទាភិក្ខុនីឲ្យជាអ្នកត្រួតត្រានវកម្ម ដល់សាឡ្ហជាចៅមិគារមាតា។ សម័យនោះឯង សុន្ទរីនន្ទាភិក្ខុនីតែងដើរទៅកាន់លំនៅរបស់សាឡ្ហជាចៅមិគារមាតាញយៗ តែងនិយាយថា ចូរអ្នកឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក (ដល់អាត្មា)។ ឯសាឡ្ហជាចៅមិគារមាតា ក៏តែងទៅកាន់លំនៅរបស់ភិក្ខុនីជាញឹកញយ ដើម្បីដឹងការងារដែលធ្វើរួចហើយ និងមិនទាន់ធ្វើ។ ជនទាំងពីរនោះ ជាមនុស្សមានចិត្តប្រតិព័ទ្ធ(នឹងគ្នា) ដោយសារឃើញគ្នារឿយៗ។ ឯសាឡ្ហជាចៅមិគារមាតា មិនមានឱកាសដើម្បីធ្វើសេវនកិច្ចនឹងសុន្ទរីនន្ទាភិក្ខុនីបាន ហើយក៏ធ្វើភត្ត (ប្រគេន) ភិក្ខុនីសង្ឃ ដើម្បីត្រូវការសុន្ទរីនន្ទាភិក្ខុនីនុ៎ះឯង។ ក្នុងវេលាដែលសាឡ្ហជាចៅមិគារមាតា រៀបនឹងក្រាលអាសនៈក្នុងរោងឆាន់ ក៏ក្រាលអាសនៈខាងម្ខាង (ដើម្បីភិក្ខុនីចាស់ៗ) ដោយគិតថា ពួកភិក្ខុនីប៉ុណ្ណេះរូបចាស់ជាងសុន្ទរីនន្ទាជាម្ចាស់ ហើយក៏ក្រាលអាសនៈខាងម្ខាង(ទៀតដើម្បីភិក្ខុនីក្មេងៗ) ដោយគិតថា ពួកភិក្ខុនីប៉ុណ្ណេះរូបក្មេងជាងសុន្ទរីនន្ទាជាម្ចាស់ ទើបក្រាលអាសនៈសម្រាប់សុន្ទរីនន្ទាភិក្ខុនីក្នុងឱកាសកំបាំងភ្នែក ត្រង់កៀនជញ្ជាំង ធ្វើឲ្យពួកភិក្ខុនីចាស់ៗដឹងថា សុន្ទរីនន្ទាភិក្ខុនីអង្គុយជិតពួកភិក្ខុនីក្មេងៗ ធ្វើឲ្យពួកភិក្ខុនីក្មេងៗដឹងថា សុន្ទរីនន្ទាភិក្ខុនីអង្គុយជិតភិក្ខុនីចាស់ៗ។ ទើបសាឡ្ហជាចៅមិគារមាតាប្រើមនុស្សឲ្យទៅទូលភត្តកាលដល់ភិក្ខុនីសង្ឃថា បពិត្រលោកម្ចាស់ កាលគួរហើយ ភត្តសម្រេចហើយ។ សុន្ទរីនន្ទាភិក្ខុនីកំណត់(ក្នុងចិត្ត)ថា សាឡ្ហជាចៅមិគារមាតាធ្វើភត្តដល់ភិក្ខុនីសង្ឃ មិនមែនធ្វើដោយការរាប់អានច្រើនប៉ុន្មានទេ គាត់ប្រាថ្នាតែនឹងប្រទុស្តដល់អញ បើប្រសិនជាអញទៅ សំឡេងឆោឡោ (វឹកវរ) មុខជានឹងមានដល់អញ (មិនខាន) គិតហើយ ក៏បង្គាប់ភិក្ខុនីជាសិស្សថា លោកចូរទៅចុះ ចូរនាំយកចង្ហាន់ (មកឲ្យ)ខ្ញុំផង ម្យ៉ាងទៀត បើមានអ្នកណាសួររកខ្ញុំ ចូរប្រាប់គេថា ខ្ញុំឈឺ។ ឯភិក្ខុនីនោះ បានស្ដាប់ពាក្យសុន្ទរីនន្ទាភិក្ខុនីហើយ ក៏ទទួលពាក្យថា ករុណាលោកម្ចាស់។ សម័យនោះឯង សាឡ្ហជាចៅមិគារមាតាឈរនៅខាងក្រៅខ្លោងទ្វារ ហើយសួររកសុន្ទរីនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ឈ្មោះសុន្ទរីនន្ទាទៅឯណា បពិត្រលោកម្ចាស់ លោកម្ចាស់ឈ្មោះសុទ្ទរីនន្ទាទៅឯណា។ កាលសាឡ្ហជាចៅមិគារមាតានិយាយយ៉ាងនេះហើយ ភិក្ខុនីជាសិស្សរបស់សុន្ទរីនន្ទាភិក្ខុនីក៏និយាយពាក្យនេះនឹងសាឡ្ហជាចៅមិគារមាតាថា ម្នាលអ្នកដ៏មានអាយុ សុន្ទរីនន្ទាភិក្ខុនីឈឺ អាត្មាឯងនឹងនាំយកចង្ហាន់ទៅ (ប្រគេនលោក)។ លំដាប់នោះ សាឡ្ហជាចៅមិគារមាតាគិតថា អញបានធ្វើភត្តណា (ប្រគេន)ភិក្ខុនីសង្ឃ ភត្តនោះ អញធ្វើព្រោះហេតុតែសុន្ទរីនន្ទាជាម្ចាស់ (ទេតើ) គិតហើយ ក៏បង្គាប់ពួកមនុស្សថា អ្នកទាំងឡាយចូរអង្គាសភត្ត (ប្រគេន) ភិក្ខុនីសង្ឃចុះ ថាហើយ ក៏ដើរទៅកាន់លំនៅរបស់ភិក្ខុនី។ លំដាប់នោះឯង សុន្ទរីនន្ទាភិក្ខុនីឈរខាងក្រៅខ្លោងទ្វារអារាម គយគន់មើលសាឡ្ហជាចៅមិគារមាតា។ សុន្ទរីនន្ទាភិក្ខុនីបានឃើញសាឡ្ហជាចៅមិគារមាតាដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ស្ទុះចូលទៅកាន់លំនៅ ហើយដេកលើគ្រែ ទទូរសម្ពត់រហូតដល់ក្បាល។ លំដាប់នោះ សាឡ្ហជាចៅមិគារមាតាក៏ចូលសំដៅទៅរកសុន្ទរីនន្ទាភិក្ខុនី លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងសុន្ទរីនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនសូវសប្បាយឬ ហេតុដូចម្ដេចបានជាសិង។ ឯសុន្ទរីនន្ទាភិក្ខុនីឆ្លើយតបថា ម្នាលអ្នកដ៏មានអាយុ ស្រីណាប្រាថ្នាគេ ៗមិនប្រាថ្នាវិញ ហេតុនេះបានជាយ៉ាងនុ៎ះឯង។ សាឡ្ហជាចៅមិគារមាតាជាបុរសមានតម្រេក ក៏និយាយតបថា បពិត្រលោកម្ចាស់ ខ្ញុំមិនមែនមិនប្រាថ្នាលោកម្ចាស់ទេ តែថាខ្ញុំមិនបានឱកាសនឹងធ្វើសេវនកិច្ចនឹងលោកម្ចាស់ (ទេតើ) ថាហើយ ក៏លូកចាប់ពាល់កាយសុន្ទរីនន្ទាភិក្ខុនី ដែលជាស្រីមានតម្រេកដែរ។ សម័យនោះឯង មានភិក្ខុនីមួយរូបជាភិក្ខុនីមានកំឡាំងថយ ព្រោះជរា ឈឺជើង សិងជិតសុន្ទរីនន្ទាភិក្ខុនី។ ឯភិក្ខុនីចាស់នោះ បានឃើញពិតនូវសាឡ្ហជាចៅមិគារមាតាដែលមានតម្រេក កំពុងតែលូកចាប់ពាល់កាយសុន្ទរីនន្ទាភិក្ខុនីដែលមានតម្រេកដែរ លុះឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សុន្ទរីនន្ទាជាម្ចាស់មានតម្រេក មិនគួរនឹងត្រេកអរ ឲ្យបុរសបុគ្គលដែលមានតម្រេកមកចាប់ពាល់កាយខ្លួនសោះ។ ទើបភិក្ខុនីចាស់នោះ ដំណាលរឿងនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីណា ដែលមានសេចក្ដីប្រាថ្នាតិច មានសេចក្ដីសន្ដោស មានសេចក្ដីអៀនខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាក្នុងសិក្ខា ពួកភិក្ខុនីអម្បាលនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សុន្ទរីនន្ទាជាម្ចាស់មានតម្រេក មិនគួរនឹងត្រេកអរឲ្យបុរសបុគ្គល ដែលមានតម្រេក មកស្ទាបអង្អែលកាយខ្លួនទេ។ ទើបភិក្ខុនីអម្បាលនោះ ដំណាលរឿងនុ៎ះដល់ភិក្ខុទាំងឡាយ។ ឯភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សុន្ទរីនន្ទាភិក្ខុនីមានតម្រេក មិនគួរនឹងត្រេកអរនឹងឲ្យបុរសបុគ្គល ដែលមានតម្រេក ស្ទាបអង្អែលកាយខ្លួនសោះ។ ភិក្ខុទាំងនោះ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាសុន្ទរីនន្ទាភិក្ខុនីមានតម្រេក ហើយត្រេកអរនឹងបុរសបុគ្គល ដែលមានតម្រេក មកស្ទាបអង្អែលកាយ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើនៃសុន្ទរីនន្ទាភិក្ខុនីនេះ មិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បីធ្វើ មិនគួរធ្វើទេ ម្នាលភិក្ខុទាំងឡាយ សុន្ទរីនន្ទាភិក្ខុនីមានតម្រេក មិនគួរនឹងត្រេកអរឲ្យបុរសបុគ្គលដែលមានតម្រេក ស្ទាបអង្អែលកាយ (ដូច្នេះ)ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ ច្បាស់ជានាំបណ្ដាលឲ្យមនុស្សពួកខ្លះដែលមិនទាន់ជ្រះថ្លា ឲ្យខានជ្រះថ្លា និងនាំបណ្ដាលមនុស្សពួកខ្លះដែលជ្រះថ្លាហើយ ឲ្យត្រឡប់ជារាយមាយចិត្តបាត់ជ្រះថ្លាទៅវិញ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលសុន្ទរីនន្ទាភិក្ខុនីដោយអនេកបរិយាយ ហើយទ្រង់សំដែងទោសនៃបុគ្គលមានសភាពដែលគេចិញ្ចឹមបានដោយកម្រ រក្សាដោយកម្រ មានសេចក្ដីប្រាថ្នាច្រើន មិនសន្ដោស ច្រឡូកច្រឡំដោយពួកគណៈ និងសេចក្ដីខ្ជិលច្រអូស ហើយទ្រង់សំដែងសរសើរគុណនៃបុគ្គលមានសភាពដែលគេចិញ្ចឹមងាយ រក្សាងាយ មានសេចក្ដីប្រាថ្នាតិច ជាអ្នកសន្ដោស តែងដុសខាត់ចិត្ត កំចាត់បង់នូវកិលេស មានសេចក្ដីជ្រះថ្លា មិនសន្សំនូវកិលេសវដ្ដ និងមានសេចក្ដីប្រារព្ធព្យាយាម ដោយអនេកបរិយាយ ហើយទ្រង់សំដែងធម្មីកថាដ៏ល្មមសមគួរដល់ការបញ្ញត្តិសិក្ខាបទនោះៗ ចំពោះពួកភិក្ខុ ហើយទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ពួកភិក្ខុនី ព្រោះអាស្រ័យអំណាចប្រយោជន៍១០យ៉ាង គឺ ដើម្បីសេចក្ដីល្អដល់សង្ឃ១ ដើម្បីការស្រួលដល់សង្ឃ១ ដើម្បីញាំញីពួកភិក្ខុនីដែលទ្រុស្តសីល១ ដើម្បីនៅជាសុខដល់ពួកភិក្ខុនីដែលមានសីលជាទីស្រឡាញ់១ ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយក្នុងបរលោក១ ដើម្បីញុំាងពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា១

ដើម្បីញុំាងពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើង១ ដើម្បីញុំាងព្រះសទ្ធម្មឲ្យស្ថិតស្ថេរ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ (បួនយ៉ាង មានសំវរវិន័យជាដើម)១ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយមានតម្រេក ហើយត្រេកអរនឹងការស្ទាបក្តី អង្អែលក្តី កាន់ក្តី ពាល់ក្តី ឱបរឹតក្តី ខាងក្រោមតាំងពីដងកាំបិតចុះមក ខាងលើតាំងពីមណ្ឌលជង្គង់ឡើងទៅ នៃបុរសបុគ្គលដែលមានតម្រេក ភិក្ខុនីនេះ ត្រូវអាបត្តិបារាជិក ឈ្មោះឧព្ភជានុមណ្ឌលិក (ព្រោះឲ្យបុរសស្ទាបសរីរប្រទេស ខាងលើតាំងពីមណ្ឌលជង្គង់ឡើងទៅ) ជាស្រីមិនមានសំវាស។**

[២] ត្រង់ពាក្យថា ណាមួយ អធិប្បាយថា (ភិក្ខុនី)ណាមួយ ទោះចាស់ក្តី ក្មេងក្តី កណ្តាលក្តី ដែលប្រកបកម្មយ៉ាងណា មានជាតិយ៉ាងណា មានឈ្មោះយ៉ាងណា មានគោត្រយ៉ាងណា មានសីលយ៉ាងណា មានធម៌ជាគ្រឿងនៅយ៉ាងណា មានគោចរយ៉ាងណា ភិក្ខុនីនោះ ហៅថា ណាមួយ។ ពាក្យថា ភិក្ខុនី សេចក្តីថា ដែលហៅថា ភិក្ខុនី ព្រោះជាអ្នកសូម ហៅថា ភិក្ខុនី ព្រោះជាអ្នកចូលទៅអាស្រ័យនឹងការត្រេចទៅដើម្បីសូម ហៅថាភិក្ខុនី ព្រោះទ្រទ្រង់នូវសំពត់ដែលកាត់ដាច់ ហៅថាភិក្ខុនី ព្រោះមានសភាពជាសមណី ហៅថាភិក្ខុនី ព្រោះបានប្តេជ្ញាខ្លួន (ថាជាអ្នកបួស) ហៅថាភិក្ខុនី ព្រោះសម្រេចដោយឯហិភិក្ខុនី ហៅថាភិក្ខុនី ព្រោះឧបសម្បទាដោយត្រៃសរណគមន៍ ហៅថាភិក្ខុនី ព្រោះជាស្រីចំរើន ហៅថាភិក្ខុនី ព្រោះមានធម៌ជាខ្លឹម ហៅថា ភិក្ខុនី ព្រោះជាអ្នកសិក្សា ហៅថាភិក្ខុនី ព្រោះមិនបាច់សិក្សា ហៅថាភិក្ខុនី ព្រោះឧភតោសង្ឃ[2] ដ៏ព្រមព្រៀងគ្នា ឲ្យឧបសម្បទាដោយញត្តិចតុត្ថកម្មវាចាដ៏សមគួរដល់ហេតុ ឥតមានកម្រើក (អន្តរាយ) បណ្តាភិក្ខុនីទាំងឡាយនោះ ភិក្ខុនីណាដែលឧភតោសង្ឃព្រមព្រៀងគ្នាឲ្យឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា សមគួរដល់ហេតុឥតមានកម្រើក (អន្តរាយ) ភិក្ខុនីនេះ តថាគតហៅថា ភិក្ខុនីក្នុងសេចក្តីនេះ។ ភិក្ខុនីមានសេចក្តីត្រេកអរព្រម លបសំឡឹងមើល មានចិត្តប្រតិព័ទ្ធ ហៅថាមានតម្រេក។ បុរស មានសេចក្តីត្រេកអរព្រម លបសំឡឹងមើល មានចិត្តប្រតិព័ទ្ធ ហៅថាបុរសមានតម្រេក។ មនុស្សប្រុសដែលដឹងក្តី អាចដើម្បីលូកស្ទាបអង្អែលកាយបាន មិនមែនយក្ស មិនមែនប្រេត មិនមែនតិរច្ឆាន ហៅថា បុរសបុគ្គល។ ពាក្យថា ខាងក្រោម តាំងពីដងកាំបិតចុះមក គឺអវយវៈជាខាងក្រោមនៃដងកាំបិត។ ពាក្យថា ខាងលើ តាំងពីមណ្ឌលជង្គង់ឡើងទៅ គឺអវយវៈជាខាងលើមណ្ឌលនៃជង្គង់។ ដែលហៅថាស្ទាប គឺគ្រាន់តែប៉ះពាល់។ ដែលហៅថាអង្អែល គឺបបោសអង្អែលខាងនេះផង ខាងនោះផង។ ដែលហៅថា កាន់ គឺគ្រាន់តែចាប់។ ដែលហៅថា ពាល់ គឺគ្រាន់តែប៉ះត្រូវ។ ពាក្យថា ត្រេកអរនឹងការឱបរឹត គឺភិក្ខុនីត្រេកអរនឹងការចាប់ខ្លួនឱបរឹត។ ពាក្យថា ភិក្ខុនីនេះក្តី គឺតថាគតប្រៀបផ្ទឹមគ្នានឹងពួកភិក្ខុនីមានហើយក្នុងកាលមុន។ ពាក្យថា ត្រូវអាបត្តិបារាជិក អធិប្បាយថា បុរសដែលដាច់ក្បាល មិនអាចដើម្បីរស់នៅ ដោយការតភ្ជាប់សរីរនោះវិញ យ៉ាងណាមិញ ភិក្ខុនីដែលមានតម្រេក កាលបើចូលចិត្តនឹងស្ទាបក្តី អង្អែលក្តី កាន់ក្តី ពាល់ក្តី ឱបរឹតក្តី ខាងក្រោមតាំងពីដងកាំបិតចុះមក ខាងលើតាំងពីមណ្ឌលនៃជង្គង់ឡើងទៅ នៃបុរសបុគ្គលដែលមានតម្រេកដែរ ក៏មិនមែនជាសមណី មិនមែនជាសក្យធីតាឡើយ ភិក្ខុនីនោះ តថាគតហៅថា ត្រូវអាបត្តិបារាជិក ដោយហេតុនោះឯង។ ពាក្យថា ជាស្រីមិនមានសំវាស សេចក្តីថា ដែលហៅថាសំវាស (នោះ) គឺសង្ឃកម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សភាពជាបុគ្គលមានសិក្ខាស្មើគ្នា នេះហៅថាសំវាស សំវាសនោះ មិនមានមួយអន្លើដោយភិក្ខុនីនោះទេ ព្រោះហេតុដូច្នោះ ទើបតថាគតហៅថា ជាស្រីមិនមានសំវាស (គឺមិនមានកិរិយារួបរួមជាមួយនឹងសង្ឃ)។

[៣] កាលបើជនទាំងពីរ[3] (គឺភិក្ខុនី និងបុរស) មានតម្រេកដូចគ្នា ហើយភិក្ខុនី ឬបុរសស្ទាបកាយ ដោយកាយ ខាងក្រោមតាំងពីដងកាំបិតចុះមក ខាងលើតាំងពីមណ្ឌលនៃជង្គង់ឡើងទៅ (ភិក្ខុនី)ត្រូវអាបត្តិបារាជិក។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយដោយកាយ (ភិក្ខុនី)ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុនី ឬបុរសស្ទាបកាយដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល (ភិក្ខុនី) ត្រូវអាបត្តិទុក្កដ។

[៤] ភិក្ខុនី ឬបុរសស្ទាបកាយដោយកាយ ខាងលើតាំងពីដងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលនៃជង្គង់ចុះមក (ភិក្ខុនី) ត្រូវអាបត្តិថុល្លច្ច័យ[4] ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយដោយកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល (ភិក្ខុនី) ត្រូវអាបត្តិទុក្កដ។

[៥] កាលបើមានតម្រេកតែម្ខាង[5] (គឺតែភិក្ខុនីម្ខាង) ហើយភិក្ខុនី ឬបុរសស្ទាបកាយដោយកាយ ខាងក្រោម តាំងពីដងកាំបិតចុះទៅ ខាងលើតាំងពីមណ្ឌលនៃជង្គង់ឡើងមក (ភិក្ខុនី) ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយដោយកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបកាយដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។

[៦] ភិក្ខុនី ឬបុរសស្ទាបកាយដោយកាយ ខាងលើ តាំងពីដងកាំបិតឡើងទៅ ខាងក្រោមតាំងពីមណ្ឌលនៃជង្គង់ចុះមក (ភិក្ខុនី) ត្រូវអាបត្តិទុក្កដ[6] ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយដោយកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបកាយ ដោយវត្ថុដែល

សម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនី ឬបុរសស្ទាបវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។

[៧] កាលបើជនទាំងពីរខាង (គឺភិក្ខុនី និងយក្សជាដើម) មានតម្រេកដូចគ្នា ហើយភិក្ខុនី ស្ទាបកាយ ដោយកាយ ខាងក្រោម តាំងពីដងកាំបិតចុះមក ខាងលើ តាំងពីមណ្ឌលនៃជង្គង់ឡើងទៅ របស់យក្សក្តី ប្រេតក្តី ខ្ទើយក្តី តិរច្ឆានដែលមានរាងកាយដូចមនុស្សក្តី ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបកាយដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។

[៨] ភិក្ខុនីស្ទាបកាយដោយកាយ ខាងលើ តាំងពីដងកាំបិតឡើងទៅ ខាងក្រោម តាំងពីមណ្ឌលនៃជង្គង់ចុះមក ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។

[៩] កាលបើមានតម្រេកតែម្ខាង (គឺខាងភិក្ខុនីតែម្ខាង) ហើយភិក្ខុនីស្ទាបកាយ(របស់យក្សជាដើម) ដោយកាយរបស់ខ្លួន ខាងក្រោម តាំងពីដងកាំបិតចុះមក ខាងលើ តាំងពីមណ្ឌលនៃជង្គង់ឡើងទៅ (ភិក្ខុនី) ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។

[១០] ភិក្ខុនីស្ទាបកាយ ដោយកាយ ខាងលើ តាំងពីដងកាំបិតឡើងទៅ ខាងក្រោម តាំងពីមណ្ឌលនៃជង្គង់ចុះមក ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលជាប់នឹងកាយ ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ទាបវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ដោយវត្ថុដែលសម្រាប់បោះ ឬសម្រាប់ចោល ត្រូវអាបត្តិទុក្កដ។

[១១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺ ភិក្ខុនីមិនក្លែង១ មិនមានស្មារតី១ មិនដឹងខ្លួន១ មិនត្រេកអរ១ ឆ្កួត១ មានចិត្តរវើរវាយ១ វេទនាគ្របសង្កត់១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

បារាជិក ទី ១ ចប់។

## បារាជិក ទី២

CS vin.vbi.pr.2 | ភាគ ទី៥

### (២. ទុតិយបារាជិកំ)

[១២] សម័យនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ គង់នៅវត្តជេតវនរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង សុន្ទរីនន្ទាភិក្ខុនីមានគភ៌ដោយសាឡ្ហជាចៅមិគារមាតា។ កាលគភ៌ខ្ចីនៅឡើយ ក៏អាចបិទបាំងទុកបាន។ លុះគភ៌(នោះ)ចាស់(ជិតគ្រប់ខែ) ភិក្ខុនីនោះក៏សឹកទៅហើយសម្រាលកូន។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ សុន្ទរីនន្ទាសឹកទៅមិនទាន់បានយូរប៉ុន្មានក៏សម្រាល (កូនភ្លាម) សុន្ទរីនន្ទានោះ មានគភ៌តាំងអំពីនៅជាភិក្ខុនីនៅឡើយទេឬ។ ថុល្លនន្ទាភិក្ខុនីឆ្លើយតបថា យ៉ាងហ្នឹងហើយ លោកម្ចាស់។ ពួកភិក្ខុនីអម្បាលនោះ ក៏និយាយថា បពិត្រលោកម្ចាស់ (បើ) លោកម្ចាស់ដឹងថា ភិក្ខុនីត្រូវអាបត្តិបារាជិកហើយ ចុះហេតុដូចម្តេចបានជាលោកម្ចាស់មិនចោទដោយខ្លួនឯង និងមិនប្រាប់ដល់ពួកគណៈ។ ឯថុល្លនន្ទាភិក្ខុនីក៏និយាយថា ទោសណាដែលកើតឡើងដល់សុន្ទរីនន្ទានុ៎ះ ទោសនោះនឹងមានដល់ខ្ញុំ កេរ្តិ៍អាក្រក់ណាដែលកើតឡើងដល់សុន្ទរីនន្ទានោះ កេរ្តិ៍អាក្រក់នោះនឹងមានដល់ខ្ញុំ សេចក្តីអាប់យស[7] ណាដែលកើតឡើងដល់សុន្ទរីនន្ទានុ៎ះ សេចក្តីអាប់យសនោះនឹងមានដល់ខ្ញុំ សេចក្តីសូន្យលាភណាដែលកើតឡើងដល់សុន្ទរីនន្ទានុ៎ះ សេចក្តីសូន្យលាភនោះនឹងមានដល់ខ្ញុំ (មិនខាន) បពិត្រលោកម្ចាស់ (បើដូច្នេះ) ខ្ញុំនឹងប្រាប់ទោសរបស់ខ្លួន កេរ្តិ៍អាក្រក់របស់ខ្លួន សេចក្តីអាប់យសរបស់ខ្លួន សេចក្តីសូន្យលាភរបស់ខ្លួនដល់ពួកជនដទៃដូចម្តេចបាន។ ពួកភិក្ខុនីណាដែលមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីអម្បាលនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ ដឹងថា ភិក្ខុនីត្រូវអាបត្តិបារាជិកហើយ មិនគួរនឹងមិនចោទដោយខ្លួនឯង និងមិនប្រាប់ដល់ពួកគណៈសោះ។ លំដាប់នោះ ពួកភិក្ខុនីអម្បាលនោះ ដំណាលរឿងនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ប្រជុំភិក្ខុសង្ឃ ទ្រង់សំដែងធម្មីកថា ហើយទ្រង់សួរបញ្ជាក់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីដឹងថា ភិក្ខុនីត្រូវអាបត្តិបារាជិកហើយ មិនចោទដោយខ្លួនឯង និង មិនប្រាប់ដល់ពួកគណៈ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីដឹងថា ភិក្ខុនីត្រូវអាបត្តិបារាជិកហើយ មិនគួរនឹងមិនចោទដោយខ្លួនឯង និងមិនប្រាប់ដល់ពួកគណៈទេ នែភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែល

មិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យរឹតតែជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាហើយនោះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះច្បាស់ជានាំបណ្តាលឲ្យមនុស្សពួកខ្លះដែលមិនទាន់ជ្រះថ្លាឲ្យខានជ្រះថ្លា និងនាំបណ្តាលពួកមនុស្សខ្លះដែលជ្រះថ្លាហើយឲ្យត្រឡប់ជាទាស់ចិត្តបាត់ជ្រះថ្លាទៅវិញ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយដឹងថា ភិក្ខុនីផងគ្នាត្រូវអាបត្តិបារាជិក ហើយមិនចោទដោយខ្លួនឯង និងមិនប្រាប់ដល់ពួកគណៈ កាលណាបើភិក្ខុនីនោះស្ថិតនៅក្តី ច្យុតហើយក្តី វិនាសហើយក្តី ចៀសទៅកាន់លទ្ធិដទៃហើយក្តី ទោះភិក្ខុនីដែលដឹងរឿងនោះ និយាយយ៉ាងនេះក្នុងកាលជាខាងក្រោយថា បពិត្រលោកម្ចាស់ ខ្ញុំបានដឹង (រឿង) ភិក្ខុនីនោះថា នាងនោះមានសភាពយ៉ាងនេះមួយយ៉ាងនេះមួយ ក្នុងកាលមុនដែរ ប៉ុន្តែខ្ញុំមិនបានចោទចំពោះខ្លួនឯង និងមិនបានប្រាប់ដល់ពួកគណៈទេ ដូច្នេះភិក្ខុនីនេះ ក៏ត្រូវអាបត្តិបារាជិក ឈ្មោះវជ្ជបដិច្ឆាទិកា (ព្រោះជួយបិទបាំងទោសគេ) ជាស្រីមិនមានសំវាស។**

[១៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌនេះ។ ដែលហៅថាដឹង គឺភិក្ខុនីដឹងខ្លួនឯងក្តី មានពួកអ្នកដទៃមកប្រាប់ដល់ភិក្ខុនីនោះក្តី ភិក្ខុនីដែលត្រូវបារាជិកនោះប្រាប់ក្តី។ ពាក្យថា ត្រូវអាបត្តិបារាជិក អធិប្បាយថា បណ្តាបារាជិកទាំង៨ (ដឹងថា) ត្រូវបារាជិកណាមួយ។ ពាក្យថា មិនចោទដោយខ្លួនឯង គឺមិនប្តឹង (ជំនុំសង្ឃ) នឹងខ្លួនឯង។ ពាក្យថា មិនប្រាប់ដល់ពួកគណៈ គឺមិនប្រាប់ដល់ពួកភិក្ខុនីឯទៀត។

[១៤] ត្រង់ពាក្យថា កាលណាបើភិក្ខុនីនោះស្ថិតនៅក្តី គឺដែលហៅថា ស្ថិតនៅ បានដល់ភិក្ខុនីស្ថិតនៅក្នុងភេទនៃខ្លួនដដែល។ ដែលហៅថា ច្យុត គឺធ្វើកាលកិរិយាស្លាប់ទៅហើយ។ សឹកខ្លួនឯងក្តី ពួកភិក្ខុនីឯទៀតឲ្យវិនាសក្តី ហៅថា វិនាសហើយ។ ចៀសទៅកាន់លទ្ធិតិរ្ថិយ ហៅថា ចៀសទៅកាន់លទ្ធិដទៃ។

[១៥] ត្រង់ពាក្យថា ទោះភិក្ខុនីដែលដឹងរឿងនោះនិយាយយ៉ាងនេះក្នុងកាលជាខាងក្រោយថា បពិត្រលោកម្ចាស់ ខ្ញុំបានដឹង (រឿង) ភិក្ខុនីនោះថា នាងនេះមានសភាពយ៉ាងនេះមួយ យ៉ាងនេះមួយ ក្នុងកាលមុនដែរ ប៉ុន្តែខ្ញុំមិនបានចោទចំពោះខ្លួនឯង សេចក្តីថា ខ្ញុំមិនបានប្តឹង (ជំនុំសង្ឃ) នឹងខ្លួនឯង។ ពាក្យថា ខ្ញុំមិនបានប្រាប់ដល់ពួកគណៈ អធិប្បាយថា ខ្ញុំមិនប្រាប់ដល់ពួកភិក្ខុនីដទៃឡើយ។

[១៦] ត្រង់ពាក្យថា ភិក្ខុនីនេះក្តី តថាគតពោលប្រៀបផ្ទឹមនឹងពួកភិក្ខុនីដែលត្រូវអាបត្តិបារាជិកមុនៗ។ ពាក្យថា ត្រូវអាបត្តិបារាជិក អធិប្បាយថា ធម្មតាស្លឹកឈើទុំដែលជ្រុះផុតអំពីទងហើយ មិនគួរលូតលាស់ឡើងវិញបាន មានឧបមាយ៉ាងណាមិញ ភិក្ខុនីដែលដឹងថា ភិក្ខុនីផងគ្នាត្រូវអាបត្តិបារាជិកហើយ គ្រាន់តែដាក់ធុរៈថា អញមិនចោទចំពោះខ្លួនឯង អញមិនប្រាប់ដល់ពួកគណៈដូច្នេះ ក៏មិនមែនជាសមណី មិនមែនជាធីតារបស់ព្រះពុទ្ធជាសក្យត្រកូលឡើយ ព្រោះហេតុនោះ ភិក្ខុនីនោះ បានជាតថាគតហៅថា ត្រូវអាបត្តិបារាជិក។ ពាក្យថា មិនមានសំវាស អធិប្បាយថា ដែលហៅថា សំវាស (នោះ) គឺសង្ឃកម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សភាពជាបុគ្គលមានសិក្ខាស្មើគ្នា នេះហៅថា សំវាស សំវាសនុ៎ះមិនមានជាមួយនឹងភិក្ខុនីនោះ ព្រោះហេតុដូច្នោះ បានជាតថាគតហៅថា ជាភិក្ខុនីមិនមានសំវាស។

[១៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺ ភិក្ខុនីមិនប្រាប់ព្រោះគិតថា សេចក្តីកហេតុក្តី សេចក្តីឈ្លោះប្រកែកក្តី សេចក្តីប្រកាន់ផ្សេងគ្នាក្តី សេចក្តីវិវាទក្តី នឹងកើតមានដល់សង្ឃ១ មិនប្រាប់ព្រោះគិតថា សង្ឃបែកបាក់គ្នា ឬសេចក្តីប្រេះឆានៃសង្ឃនឹងកើតមាន១ មិនប្រាប់ព្រោះគិតថា ភិក្ខុនីនេះកោងកាចអាក្រក់ ក្រែងនឹងធ្វើអន្តរាយដល់ជីវិត ឬអន្តរាយដល់ព្រហ្មចរិយធម៌១ ភិក្ខុនីនោះមិនទាន់ឃើញពួកភិក្ខុនីឯទៀតដ៏សមគួរ ទើបមិនប្រាប់១ ភិក្ខុនីនោះមិនមានសេចក្តីប្រាថ្នានឹងបិទបាំងមិនប្រាប់១ ភិក្ខុនីមិនប្រាប់ព្រោះគិតថា ភិក្ខុនីនោះនឹងប្រាកដដោយកម្មជារបស់ខ្លួន(មិនខាន)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីខាងដើមបញ្ញត្តិ១។

បារាជិក ទី ២ ចប់។

## បារាជិក ទី៣

CS vin.vbi.pr.3 | ភាគ ទី៥

### (៣. តតិយបារាជិកំ)

[១៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ថុល្លនន្ទាភិក្ខុនីប្រព្រឹត្តតាមភិក្ខុឈ្មោះអរិដ្ឋ ជាអ្នកកើតក្នុងត្រកូលអ្នកសម្លាប់ត្មាត ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងប្រព្រឹត្តតាមអរិដ្ឋភិក្ខុ ជាអ្នកកើតក្នុងត្រកូលអ្នកសម្លាប់ត្មាត ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីប្រព្រឹត្តតាមអរិដ្ឋភិក្ខុ ជាអ្នកកើតក្នុងត្រកូលអ្នកសម្លាប់ត្មាត ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងប្រព្រឹត្តតាមអរិដ្ឋភិក្ខុ ជាអ្នកកើតក្នុងត្រកូលអ្នកសម្លាប់ត្មាត ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាហើយទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយជ្រោមជ្រែងមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ ភិក្ខុនីនោះ ត្រូវភិក្ខុនី**

**ទាំងឡាយនិយាយយ៉ាងនេះថា នៃលោកម្ចាស់ ភិក្ខុនេះឯង ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយជ្រោមជ្រែងមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ នៃលោកម្ចាស់ លោកកុំប្រព្រឹត្តតាមភិក្ខុនេះឡើយ ភិក្ខុនីនោះ កាលភិក្ខុនីទាំងឡាយនិយាយឲ្យយ៉ាងនេះ នៅតែប្រកាន់យ៉ាងនោះដដែល ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មជាគំរប់បីដង ដើម្បីឲ្យលះបង់វត្ថុនោះ បើភិក្ខុនីនោះ កាលត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មជាគំរប់បីដង លះបង់វត្ថុនោះបាន ការលះបង់បាននោះ ជាការល្អ បើមិនលះបង់ទេ ភិក្ខុនីនេះ ក៏ត្រូវបារាជិក ឈ្មោះឧក្ខិត្តានុវត្តិក (ព្រោះប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត) ជាស្រីមិនមានសំវាស។**

[១៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌនេះរួចហើយ។ សង្ឃដែលមានសំវាសស្មើគ្នា ស្ថិតនៅក្នុងសីមាស្មើគ្នា ឈ្មោះថា ព្រមព្រៀងគ្នា។ ភិក្ខុដែលឈ្មោះថា សង្ឃលើកវត្តហើយ គឺភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនធ្វើតបអាបត្តិក្តី[8] ព្រោះមិនលះបង់ (ទិដ្ឋិអាក្រក់)ក្តី។ ពាក្យថា តាមធម៌ តាមវិន័យ គឺតាមធម៌ឯណា តាមវិន័យឯណា។ ពាក្យថា តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា គឺតាមពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គឺតាមពុទ្ធសាសនា។ ដែលហៅថា មិនអើពើ គឺភិក្ខុមិនអើពើនឹងសង្ឃក្តី គណៈក្តី បុគ្គលក្តី កម្មក្តី។ ភិក្ខុដែលសង្ឃលើកវត្តហើយ មិនហៅចូលពួក ឈ្មោះថា ជាភិក្ខុដែលសង្ឃជួយជ្រោមជ្រែងមិនបាន។ ដែលហៅថា មិនមានការរួបរួមជាមួយនឹងសង្ឃ គឺភិក្ខុទាំងឡាយដែលមានសំវាសស្មើគ្នា តថាគតហៅថា មានការរួបរួមជាមួយគ្នា ការរួបរួមជាមួយគ្នានោះ មិនមានមួយអន្លើដោយភិក្ខុទាំងឡាយនោះទេ ហេតុនោះ ភិក្ខុនោះ ទើបតថាគតហៅថា ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ។ ពាក្យថា ប្រព្រឹត្តតាមភិក្ខុនោះ គឺភិក្ខុនោះមានទិដ្ឋិយ៉ាងណា មានសេចក្តីចូលចិត្តយ៉ាងណា មានសេចក្តីគាប់ចិត្តយ៉ាងណា ភិក្ខុនីនោះ ក៏មានទិដ្ឋិយ៉ាងនោះ មានសេចក្តីចូលចិត្តយ៉ាងនោះ មានសេចក្តីគាប់ចិត្តយ៉ាងនោះដែរ។

[២០] ត្រង់ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីដែលប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តហើយនោះ។ ពាក្យថា ដែលភិក្ខុនីទាំងឡាយ គឺភិក្ខុនីទាំងឡាយដទៃ។ ភិក្ខុនីទាំងឡាយឯណាឃើញ ភិក្ខុនីឯណាឮ ភិក្ខុនីទាំងឡាយនោះត្រូវនិយាយនឹងភិក្ខុនីនោះថា នៃលោកម្ចាស់ ភិក្ខុនេះឯង ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា គឺជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយជ្រោមជ្រែងមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ នៃលោកម្ចាស់ លោកកុំប្រព្រឹត្តតាមភិក្ខុនេះឡើយ។ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយនិយាយអស់វារៈគំរប់ពីរដងផង ត្រូវនិយាយអស់វារៈគំរប់បីដងផង។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះ ជាការល្អ បើលះបង់មិនបានទេ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទាំងឡាយ(ឯទៀត) ឮហើយ មិននិយាយ ត្រូវអាបត្តិទុក្កដ។ ត្រូវសង្ឃទាញភិក្ខុនីនោះ មកកាន់ទីកណ្តាលសង្ឃ ហើយនិយាយថា នែនាងភិក្ខុនី ភិក្ខុនេះឯង ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយជ្រោមជ្រែងមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ នែនាងភិក្ខុនី នាងកុំប្រព្រឹត្តតាមភិក្ខុនេះឡើយ។ ត្រូវសង្ឃនិយាយឲ្យភិក្ខុនីនោះអស់វារៈជាគំរប់ពីរដងផង ត្រូវនិយាយអស់វារៈជាគំរប់បីដងផង។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះ ជាការល្អ បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ។

[២១] ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធី។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសូត្រសមនុភាសនវិធី (ចំពោះភិក្ខុនីឈ្មោះនោះ) យ៉ាងនេះ។ ភិក្ខុនីដែលឆ្លាស់ប្រតិពល ត្រូវផ្ទៀងសង្ឃឲ្យដឹងថា បពិត្រលោកម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះប្រព្រឹត្តតាមភិក្ខុនោះ ដែលសង្ឃព្រមព្រៀងគ្នាលើកវត្ត តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ សង្ឃជួយជ្រោមជ្រែងមិនបាន មិនមានការរួបរួមជាមួយនឹងសង្ឃ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ នេះជាញត្តិ។ បពិត្រព្រះភិក្ខុនីសង្ឃជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះប្រព្រឹត្តតាមភិក្ខុដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ សង្ឃជួយជ្រោមជ្រែងមិនបាន មិនមានការរួបរួមជាមួយនឹងសង្ឃ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ។ ឥឡូវនេះ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ ការសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈពីរដងផង។បេ។ ខ្ញុំសូត្រសេចក្តីនេះ អស់វារៈបីដងផង។បេ។ ភិក្ខុនីឈ្មោះនេះ សង្ឃសូត្រសមនុភាសនវិធីហើយ ដើម្បីឲ្យលះបង់វត្ថុនោះ។ ការសូត្រសមនុភាសនវិធីនោះ គួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[២២] ភិក្ខុនីនោះ ត្រូវទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាទាំងឡាយពីរ ត្រូវអាបត្តិបារាជិកក្នុងពេលចប់កម្មវាចា។

[២៣] ត្រង់ពាក្យថា ភិក្ខុនីនេះក្តី តថាគតពោលប្រៀបធៀបពួកភិក្ខុនីដែលត្រូវអាបត្តិបារាជិកមុនៗ។ ពាក្យថា ត្រូវបារាជិក សេចក្តីថា ថ្មដ៏ក្រាសដែលបែកជាពីរចំណែកហើយ ជាធម្មជាតិតភ្ជាប់វិញមិនបាន មានឧបមាយ៉ាងណាមិញ ភិក្ខុនីដែលសង្ឃសូត្រសមនុភាសនវិធីអស់វារៈគំរប់បីដងហើយ នៅមិនលះបង់ ក៏មិនមែនជាសមណី[9] មិនមែនជាធីតារបស់ព្រះពុទ្ធជាសក្យត្រកូល ក៏មានឧបមេយ្យដូច្នោះដែរ ហេតុនោះ ទើបតថាគតហៅភិក្ខុនីនោះថា ត្រូវបារាជិក។ ពាក្យថា គ្មានសំវាស ដែលហៅថា សំវាស គឺកម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា ការសិក្សាស្មើគ្នា នេះឈ្មោះថា សំវាស សំវាសនោះមិនមានជាមួយនឹងភិក្ខុនីនោះទេ ហេតុនោះ ទើបតថាគតហៅភិក្ខុនីនោះថា មិនមានសំវាស។

[២៤] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិបារាជិក។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិបារាជិក។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិបារាជិក។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[២៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុនី(ដែលសង្ឃ)មិនសូត្រសមនុភាសនវិធី១ ភិក្ខុនីបានលះបង់១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាដើមបញ្ញត្តិ១។

បារាជិក ទី ៣ ចប់។

## បារាជិក ទី៤

CS vin.vbi.pr.4 | ភាគ ទី៥

### (៤. ចតុត្ថបារាជិកំ)

[២៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ ក៏សម័យនោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយ (ភិក្ខុនីពួក៦នាក់) មានសេចក្តីត្រេកអរនឹងការចាប់ដៃខ្លះ នឹងការចាប់ជាយសង្ឃាដីខ្លះ របស់បុរសដែលមានតម្រេកឈរជាមួយខ្លះ ចរចាជាមួយខ្លះ ទៅកាន់ទីសង្កេតខ្លះ ត្រេកអរនឹងប្រុសដើរចូលមកជិតខ្លះ ចូលទៅកាន់ទីបិទបាំងខ្លះ ពិចារណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីនឹងសេពអសទ្ធម្មនុ៎ះ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមានតម្រេក មិនគួរនឹងត្រេកអរនឹងការចាប់ដៃខ្លះ ត្រេកអរនឹងការចាប់ជាយសង្ឃាដីខ្លះ របស់បុរសបុគ្គលដែលត្រេកត្រអាលឈរជាមួយខ្លះ ចរចាជាមួយខ្លះ ទៅកាន់ទីសង្កេតខ្លះ ត្រេកអរនឹងប្រុសដើរចូលមកជិតខ្លះ ចូលទៅកាន់ទីកំបាំងខ្លះ ពិចារណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីសេពអសទ្ធម្មនុ៎ះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីមានតម្រេក ត្រេកអរនឹងការចាប់ដៃខ្លះ ត្រេកអរនឹងការចាប់ជាយសង្ឃាដីខ្លះ របស់បុរសបុគ្គលដែលត្រេកត្រអាលឈរជាមួយខ្លះ ចរចាជាមួយខ្លះ ទៅកាន់ទីសង្កេតខ្លះ ត្រេកអរនឹងប្រុសដើរចូលមកជិតខ្លះ ចូលទៅកាន់ទីកំបាំងខ្លះ ពិចារណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីនឹងសេពអសទ្ធម្មនុ៎ះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយមានតម្រេក មិនគួរនឹងត្រេកអរនឹងការចាប់ដៃខ្លះ ត្រេកអរនឹងការចាប់ជាយសង្ឃាដីខ្លះ របស់បុរសបុគ្គលដែលមានតម្រេកឈរជាមួយខ្លះ ចរចាជាមួយខ្លះ ទៅកាន់ទីសង្កេតខ្លះ ត្រេកអរនឹងប្រុសដើរចូលមកជិតខ្លះ ចូលទៅកាន់ទីកំបាំងខ្លះ ពិចារណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីនឹងសេពអសទ្ធម្មនុ៎ះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយមានតម្រេក ហើយត្រេកអរនឹងការចាប់ដៃក្តី ត្រេកអរនឹងការចាប់ជាយសង្ឃាដីក្តី របស់បុរសបុគ្គលដែលមានតម្រេកឈរជាមួយក្តី ចរចាជាមួយក្តី ទៅកាន់ទីសង្កេតក្តី ត្រេកអរនឹងប្រុសដើរចូលមកជិតក្តី ចូលទៅកាន់ទីកំបាំងក្តី ពិចារណាកាយដើម្បីអសទ្ធម្មនោះខ្លះ ដើម្បីនឹងសេពអសទ្ធម្មនុ៎ះ ភិក្ខុនីនេះក្តី ត្រូវបារាជិក ឈ្មោះអដ្ឋវត្ថុកា (ព្រោះប្រកបដោយវត្ថុ៨[10]) រកសំវាសគ្មាន។**

[២៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌនេះរួចហើយ។ ភិក្ខុនីដែលត្រេកអរ មានសេចក្តីគយគន់រំពៃ មានចិត្តប្រតិព័ទ្ធ ឈ្មោះថាមានតម្រេក។ បុរសដែលត្រេកអរ គយគន់រំពៃ មានចិត្តប្រតិព័ទ្ធ ឈ្មោះថាមានតម្រេក។ មនុស្សប្រុសដែលដឹងក្តី អាចស្ទាបអង្អែលកាយបាន ឈ្មោះថា បុរសបុគ្គល មិនមែនយក្សប្រុស ប្រេតប្រុស តិរច្ឆានឈ្មោះទេ។ ពាក្យថា ត្រេកអរនឹងការចាប់ដៃក្តី សេចក្តីថា ដែលហៅថាដៃ គឺវាស់តាំងពីដុំដៃ រហូតដល់ចុងក្រចក។ ភិក្ខុនីត្រេកអរនឹងការចាប់ ខាងលើ តាំងពីដងកាំបិតឡើងទៅ ខាងក្រោម តាំងពីមណ្ឌលជង្គង់ចុះមក ប្រយោជន៍សេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច័យ។ ពាក្យថា ត្រេកអរនឹងការចាប់ជាយសង្ឃាដី គឺភិក្ខុនីត្រេកអរនឹងការចាប់សំពត់ដែលស្លៀកក្តី ដែលដណ្តប់ក្តី ប្រយោជន៍នឹងសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច័យ។ ពាក្យថា ឈរជាមួយក្តី គឺភិក្ខុនីឈរក្នុងហត្ថបាសប្រុស ប្រយោជន៍នឹងសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច័យ។ ពាក្យថា ចរចាជាមួយក្តី គឺភិក្ខុនីឈរក្នុងហត្ថបាសប្រុស ហើយចរចារជាមួយ ប្រយោជន៍នឹងសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច័យ។ ពាក្យថា ទៅកាន់ទីសង្កេត គឺភិក្ខុនីដែលប្រុសនិយាយថា លោកចូរមកកាន់ទីឱកាសឈ្មោះនេះដូច្នេះ ប្រយោជន៍ដល់ការសេពអសទ្ធម្មនុ៎ះ ហើយក៏ទៅ ត្រូវអាបត្តិទុក្កដ គ្រប់ៗជំហាន លុះចូលទៅដល់ហត្ថបាសប្រុសហើយក៏ត្រូវអាបត្តិថុល្លច្ច័យ។ ពាក្យថា ត្រេកអរនឹងប្រុសដើរចូលមកជិតក្តី គឺភិក្ខុនីត្រេកអរនឹងប្រុសដើរចូលមកជិត ប្រយោជន៍ដល់ការសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិទុក្កដ លុះដើរចូលមកដល់ហត្ថបាសកាលណា ក៏ត្រូវអាបត្តិថុល្លច្ច័យ។ ពាក្យថា ចូលទៅកាន់ទីកំបាំងក្តី គឺភិក្ខុនីគ្រាន់តែចូលទៅកាន់ទីឱកាសដ៏បិទបាំងដោយរបស់ណាមួយ ប្រយោជន៍ដល់ការសេពអសទ្ធម្មនុ៎ះ ក៏ត្រូវអាបត្តិថុល្លច្ច័យ។ ពាក្យថា ពិចារណាកាយ ប្រយោជន៍ដល់អសទ្ធម្មនោះក្តី គឺភិក្ខុនីឈរក្នុងហត្ថបាសប្រុស ហើយពិចារណារាងកាយ ប្រយោជន៍ដល់ការសេពអសទ្ធម្មនុ៎ះ ត្រូវអាបត្តិថុល្លច្ច័យ។

[២៨] ត្រង់ពាក្យថា ភិក្ខុនីនេះក្តី គឺភិក្ខុនីនេះឯង តថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីមុនៗ។ ពាក្យថា ត្រូវអាបត្តិបារាជិក សេចក្តីថា ដើមត្នោតដែលកំបុតចុង មិនគួរដុះឡើងទៀតបាន មានឧបមាយ៉ាងណាមិញ ភិក្ខុនីដែលញុំាងវត្ថុជាគំរប់៨ឲ្យពេញ ក៏មិនមែនជាសមណី មិនមែនជាធីតារបស់ព្រះពុទ្ធជាសក្យត្រកូល ក៏មានឧបមេយ្យយ៉ាងនោះដែរ ហេតុនោះ បានជាតថាគតហៅថា ភិក្ខុនីនោះ ត្រូវអាបត្តិបារាជិក (ជាអ្នកចាលចាញ់)។ ពាក្យថា រកសំវាសគ្មាន គឺដែលហៅថា សំវាស គឺបានដល់កម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សេចក្តីសិក្សាស្មើគ្នា នេះឈ្មោះថា សំវាស សំវាសនោះមិនមានជាមួយនឹងភិក្ខុនីនោះទេ ហេតុនោះ បានជាតថាគតហៅថា ភិក្ខុនីនោះជាស្រីមិនមានសំវាស។

[២៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺ ភិក្ខុនីមិនក្លែងឲ្យកន្លង១ ភិក្ខុនីមិនមានសតិ១ ភិក្ខុនីមិនដឹងខ្លួន១ ភិក្ខុនីមិនត្រេកអរ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីមានចិត្តរវើរវាយ១ ភិក្ខុនីដែលវេទនាគ្របសង្កត់១ ភិក្ខុនីជាដើមបញ្ញត្តិ១។

បារាជិក ទី ៤ ចប់។

[៣០] បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិបារាជិកទាំងឡាយ៨ ខ្ញុំសំដែងឡើងហើយ បណ្ដាអាបត្តិបារាជិកទាំងឡាយ៨នុ៎ះ ភិក្ខុនីណាត្រូវអាបត្តិបារាជិកណាមួយ ភិក្ខុនីនោះមិនបាននៅរួមជាមួយនឹងភិក្ខុនីទាំងឡាយឡើយ (ព្រោះ) ខ្លួនត្រូវអាបត្តិបារាជិក រកសំវាសគ្មាន កាលអំពីមុន គឺកាលដែលខ្លួននៅជាគ្រហស្ថមានសភាពយ៉ាងណា កាលខាងក្រោយ ដែលខ្លួនត្រូវបារាជិកហើយ ក៏មានសភាពដូច្នោះដែរ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងរឿងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធក្នុងរឿងនុ៎ះហើយ ហេតុនោះ បានជានៅស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

បារាជិកកណ្ឌ ចប់។

# សត្តរសកណ្ឌ

CS vin.vbi.sg | ភាគ ទី៥

### (២. សង្ឃាទិសេសកណ្ឌំ (ភិក្ខុនីវិភង្គោ))

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិសង្ឃាទិសេសទាំង១៧នេះឯង តែងមកកាន់ឧទ្ទេស។

## សង្ឃាទិសេស ទី១

CS vin.vbi.sg.01 | ភាគ ទី៥

### (១. បឋមសង្ឃាទិសេសសិក្ខាបទំ)

[៣១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ឧបាសកម្នាក់ប្រគេនឃ្លាំង (រោងដាក់របស់) ដល់ភិក្ខុនីសង្ឃ ហើយធ្វើមរណកាលទៅ។ ឧបាសកនោះមានកូនពីរនាក់ ម្នាក់មិនមានសទ្ធាមិនជ្រះថ្លា ម្នាក់មានសទ្ធាជ្រះថ្លា។ កូនទាំងពីរនាក់នោះយកសម្បត្តិដែលជារបស់បិតាមកចែកគ្នា។ ឯបុរសដែលគ្មានសទ្ធា គ្មានជ្រះថ្លានោះបាននិយាយពាក្យនេះនឹងបុរសដែលមានសទ្ធាជ្រះថ្លានោះថា ឃ្លាំងរបស់យើងមាន យើងនឹងចែកនូវឃ្លាំងនោះ។ កាលបើបុរសដែលឥតសទ្ធាឥតជ្រះថ្លានោះនិយាយយ៉ាងនេះហើយ បុរសដែលមានសទ្ធាជ្រះថ្លានោះបាននិយាយពាក្យនេះនឹងបុរសដែលមិនមានសទ្ធាមិនជ្រះថ្លានោះថា អ្នកម្ចាស់កុំនិយាយយ៉ាងនេះឡើយ ឃ្លាំងនោះបិតាយើងប្រគេនដល់ភិក្ខុនីសង្ឃទៅហើយ។ បុរសដែលមិនមានសទ្ធាមិនជ្រះថ្លានិយាយពាក្យនេះនឹងបុរសដែលមានសទ្ធាជ្រះថ្លានោះអស់វារៈពីរដងថា ឃ្លាំងរបស់យើងមាន យើងនឹងចែកនូវឃ្លាំងនោះ។ ទើបបុរសដែលមានសទ្ធាជ្រះថ្លានោះបាននិយាយពាក្យនេះនឹងបុរសដែលគ្មានសទ្ធាមិនជ្រះថ្លានោះថា អ្នកម្ចាស់កុំនិយាយយ៉ាងនេះឡើយ ឃ្លាំងនោះបិតាយើងប្រគេនដល់ភិក្ខុនីសង្ឃហើយ។ បុរសដែលគ្មានសទ្ធាឥតជ្រះថ្លានោះ បាននិយាយពាក្យនេះនឹងបុរសដែលមានសទ្ធាជ្រះថ្លានោះអស់វារៈគំរប់បីដងផងថា ឃ្លាំងរបស់យើងមាន យើងនឹងចែកនូវឃ្លាំងនោះ។ លំដាប់នោះ បុរសដែលមានសទ្ធាជ្រះថ្លាក៏គិតថា បើឃ្លាំងនឹងបានមកអញ អញនឹងប្រគេនភិក្ខុនីសង្ឃ ហើយក៏បាននិយាយពាក្យនេះនឹងបុរសដែលមិនមានសទ្ធាមិនជ្រះថ្លានោះថា យើងចែកគ្នាចុះ។ ឯឃ្លាំងនោះ កាលដែលអ្នកទាំងពីរនាក់នោះចែកគ្នា ក៏បានទៅលើកូនដែលមិនមានសទ្ធាមិនជ្រះថ្លានោះ។ ទើបកូនដែលឥតសទ្ធា ឥតជ្រះថ្លានោះចូលទៅរកភិក្ខុនីទាំងឡាយ ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ លោកទាំងឡាយចូរចេញទៅ ឃ្លាំងជារបស់យើងទេ។ កាលបើបុរសដែលគ្មានសទ្ធាគ្មានជ្រះថ្លានោះនិយាយយ៉ាងនេះហើយ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងបុរសនោះថា នែអ្នកម្ចាស់ អ្នកកុំនិយាយយ៉ាងនេះឡើយ ឃ្លាំងនេះ បិតារបស់អ្នកប្រគេនដល់ភិក្ខុនីសង្ឃហើយតើ។ ជនទាំងពីរនោះសួរមហាមាត្យជាចៅក្រមថា ឃ្លាំងនោះគេបានប្រគេនភិក្ខុនីសង្ឃហើយ ឬមិនបានប្រគេន(ទេ)។ មហាមាត្យទាំងឡាយបាននិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ មានអ្នកណាដឹងថា ឃ្លាំងនោះគេប្រគេនភិក្ខុនីសង្ឃហើយ (ខ្លះដែរ)។ កាលបើមហាមាត្យទាំងឡាយនិយាយយ៉ាងនេះហើយ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងមហាមាត្យទាំងឡាយនោះថា កាលដែលគេឲ្យទាន(នោះ) សឹងមានសំអាងសាក្សីអ្នកទាំងឡាយក៏បានឃើញ បានឮខ្លះដែរ។ ទើបមហាមាត្យទាំងឡាយនោះបាននិយាយថា លោកម្ចាស់និយាយពាក្យនេះមែនពិត ហើយក៏វិនិច្ឆ័យឲ្យឃ្លាំងនោះដល់ភិក្ខុនីសង្ឃវិញ។ ឯបុរសនោះ លុះចាញ់គេហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ស្រីផ្គាមាសត្រងោលទាំងនេះមិនមែនជាសមណីទេ មិនសមបើនឹងឲ្យគេដណ្ដើមយកឃ្លាំងរបស់យើងសោះ។ ថុល្លនន្ទាភិក្ខុនីប្រាប់ដំណើរនុ៎ះដល់មហាមាត្យទាំងឡាយ។ មហាមាត្យទាំងឡាយក៏ពិន័យបុរសនោះ។ ឯបុរសនោះ លុះត្រូវពិន័យហើយ ក៏ឲ្យគេសាងលំនៅអាជីវកក្នុងទីជិតលំនៅភិក្ខុនី ហើយបញ្ជូនពួកអាជីវកទៅដោយពាក្យថា អ្នកទាំងឡាយចូរជេរភិក្ខុនីទាំងឡាយនុ៎ះ។ ថុល្លនន្ទាភិក្ខុនីប្រាប់ដំណើរនុ៎ះដល់មហាមាត្យទាំងឡាយ។ មហាមាត្យទាំងឡាយក៏ចាប់ចងបុរសនោះធ្វើទោស (ដាក់គុក)។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរនឹង (ប្រព្រឹត្តល្មើសដោយស្ថាន៣យ៉ាង) គឺ១ឲ្យមហាមាត្យដណ្ដើមយកឃ្លាំងរបស់គេ ២ឲ្យមហាមាត្យពិន័យលក់គេ ៣ឲ្យមហាមាត្យធ្វើទោសដាក់គុកគេ ឥឡូវនេះមុខជានឹងឲ្យមហាមាត្យសម្លាប់គេ។ ភិក្ខុនីទាំងឡាយបានឮពាក្យមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងពោលពាក្យដោយសេចក្ដីច្រណែន (ប្ដឹងផ្ដល់)សោះ។ ទើបភិក្ខុនីទាំងឡាយនោះ ប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីជាអ្នកប្ដឹងផ្ដល់ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរនឹងជាអ្នកប្ដឹងផ្ដល់គេទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយជាអ្នកប្តឹងផ្តល់ ពីគហបតិក្តី កូនគហបតិក្តី ខ្ញុំគេក្តី អ្នកធ្វើការងារក្តី ដោយហោចទៅ សូម្បីតែសមណបរិព្វាជក ភិក្ខុនីនេះក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ។**

[៣២] ត្រង់បទថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ប្តឹងផ្តល់ គឺសំដៅយកភិក្ខុនីជាអ្នកក្តី។ ជនណាមួយនៅគ្រប់គ្រងផ្ទះ ជននោះឈ្មោះថា គហបតិ។ ដែលហៅថា កូនគហបតិ គឺជនទាំងឡាយណាមួយជាកូននឹងបងប្អូនប្រុស (របស់គហបតិនោះ)។ ដែលហៅថា ខ្ញុំ គឺខ្ញុំដែលកើតខាងក្នុង ឬខ្ញុំដែលលោះដោយទ្រព្យ ឬមនុស្សឈ្លើយ ដែលគេចាប់បានក្នុងទ័ព។ ដែលហៅថា អ្នកធ្វើការងារ គឺអ្នកធ្វើការងារស៊ីឈ្នួល អ្នកធ្វើការដឹកនាំគ្រឿងឧបករណ៍។ ជនណាមួយដែលបួសក្នុងសំណាក់បរិព្វាជក លើកទុកតែភិក្ខុនី សិក្ខមានា សាមណេរ និងសាមណេរីចេញ ហៅថា សមណបរិព្វាជក។ ភិក្ខុនីគិតថា អញនឹងធ្វើ គឺកើតក្តី ហើយស្វែងរក (គ្នា) ជាគំរប់ពីរក្តី ដើរទៅក្តី ត្រូវអាបត្តិទុក្កដ ប្តឹងចៅក្រមម្តង ត្រូវអាបត្តិទុក្កដ ប្តឹងចៅក្រមពីរដង ត្រូវអាបត្តិថុល្លច្ច័យ សម្រេចក្តី ត្រូវអាបត្តិសង្ឃាទិសេស។

[៣៣] ត្រង់ពាក្យថា ជាបឋមាបត្តិក គឺភិក្ខុនីត្រូវ(អាបត្តិ)មួយអន្លើដោយការប្រព្រឹត្តកន្លងវត្ថុ (ជាដម្បូង) មិនមែនដោយសូត្រសមនុភាសនកម្មទេ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីនោះត្រូវភិក្ខុនីឯទៀតនាំចេញអំពីសង្ឃ។ ពាក្យថា សង្ឃាទិសេស គឺសង្ឃពិតអាចឲ្យមានត្តដើម្បីអាបត្តិនោះ នឹងទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិឲ្យអព្ភានបាន ភិក្ខុនីទាំងឡាយច្រើនប្រមាណ (២-៣រូប) ឲ្យមិនបាន ភិក្ខុនី១រូបក៏ឲ្យមិនបាន ហេតុនោះ បានជាតថាគតហៅពួកអាបត្តិនោះថា សង្ឃាទិសេស។ ពាក្យថា សង្ឃាទិសេស ជានាមកម្ម គឺថាជាឈ្មោះនៃអាបត្តិនិកាយនោះឯង ព្រោះហេតុនោះ បានជាតថាគតហៅអាបត្តិនិកាយនោះថា សង្ឃាទិសេស។

[៣៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ ភិក្ខុនីដែលមនុស្សទាំងឡាយកោះនាំទៅ១ ភិក្ខុនីសូមអារក្ខា គឺសូមឲ្យរាជការជួយរក្សាការពារ១ ភិក្ខុនីប្តឹងមិនចំពោះឈ្មោះ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## សង្ឃាទិសេស ទី២

CS vin.vbi.sg.02 | ភាគ ទី៥

### (២. ទុតិយសង្ឃាទិសេសសិក្ខាបទំ)

[៣៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ភរិយារបស់ស្តេចលិច្ឆវី១អង្គប្រព្រឹត្តកន្លងចិត្ត(ប្តី)។ ទើបស្តេចលិច្ឆវីនោះបាននិយាយពាក្យនេះនឹងស្រីនោះថា អញសុំរំលឹកនាងឯង ចូរនាងឯងលះ(អំពើនោះ)ចេញ ខំអញនឹងធ្វើសេចក្តីវិនាសដល់នាងឯង។ ស្រីនោះទុកជាស្តេចលិច្ឆវីនោះនិយាយយ៉ាងនេះ ក៏មិនអើពើឡើយ។ សម័យនោះឯង ជួនជាមានការប្រជុំពួកស្តេចលិច្ឆវីក្នុងក្រុងវេសាលីដោយកិច្ចនីមួយ។ ទើបស្តេចលិច្ឆវីនោះបាននិយាយពាក្យនេះនឹងស្តេចលិច្ឆវីទាំងឡាយនោះថា នែព្រះអង្គទាំងឡាយ សូមព្រះអង្គទាំងឡាយអនុញ្ញាតស្រីម្នាក់ដល់ខ្ញុំ។ ស្តេចលិច្ឆវីទាំងឡាយនោះសួរថា ស្រីនោះជាអ្វី។ ស្តេចលិច្ឆវីនោះឆ្លើយថា ជាប្រពន្ធខ្ញុំ វាក្បត់ចិត្តខ្ញុំ ខ្ញុំនឹងសម្លាប់វានោះចោល។ ស្តេចលិច្ឆវីទាំងឡាយនិយាយថា ព្រះអង្គចូរដឹងចុះ។ ស្រីនោះក៏បានឮពណ៌ដ៏មានថា ប្តីចង់សម្លាប់អញ ហើយក៏យករបស់ដែលមានដំឡៃទៅកាន់ក្រុងសាវត្ថី ចូលទៅរកពួកតិរ្ថិយ ហើយក៏សូមបព្វជ្ជា។ តិរ្ថិយទាំងឡាយមិនចូលចិត្តឲ្យស្រីនោះបួសឡើយ។ ស្រីនោះចូលទៅរកពួកភិក្ខុនី ហើយសូមបព្វជ្ជា(ទៀត)។ ភិក្ខុនីទាំងឡាយក៏មិនចូលចិត្តឲ្យនាងនោះបួសដែរ។ ស្រីនោះចូលទៅរកថុល្លនន្ទាភិក្ខុនី បង្ហាញបង្វេចរបស់ហើយ សូមបព្វជ្ជា។ ថុល្លនន្ទាភិក្ខុនីទទួលយកបង្វេចរបស់ ហើយឲ្យស្រីនោះបួស។ ឯស្តេចលិច្ឆវីនោះកាលស្វែងរកស្រីនោះ បានទៅកាន់ក្រុងសាវត្ថី ឃើញស្រីនោះបួសក្នុងសំណាក់ភិក្ខុនីទាំងឡាយ ហើយក៏ចូលទៅគាល់ស្តេចបសេនទិកោសល លុះចូលទៅដល់ហើយ ក្រាបទូលពាក្យនេះនឹងព្រះបាទបសេនទិកោសលថា បពិត្រព្រះសម្មតិទេព ភរិយារបស់ខ្ញុំនាំយករបស់មានដំឡៃ ហើយមកកាន់ក្រុងសាវត្ថីនេះ (ឥឡូវនេះ) សូមព្រះអង្គអនុញ្ញាតស្រីនោះឲ្យទាន។ ស្តេចមានព្រះរាជឱង្កាថា នែនាយ បើដូច្នោះ ចូរអ្នកពិនិត្យរក ហើយមកប្រាប់យើងចុះ។ ស្តេចលិច្ឆវីនោះទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គបានឃើញស្រីនោះបួសក្នុងសំណាក់ភិក្ខុនីទាំងឡាយហើយ។ ស្តេចមានព្រះឱង្កាថា នែនាយ បើស្រីនោះបួសក្នុងសំណាក់ភិក្ខុនីទាំងឡាយហើយ អ្នកធ្វើអ្វីតិចតួចដល់ភិក្ខុនីនោះមិនបានទេ ព្រោះថា ធម៌ គឺព្រះដ៏មានព្រះភាគសំដែងល្អហើយ ចូរភិក្ខុនីនោះប្រព្រឹត្តព្រហ្មចារ្យ ដើម្បីធ្វើនូវទីបំផុតទុក្ខដោយប្រពៃចុះ។ ទើបស្តេចលិច្ឆវីនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមនឹងបំបួសស្រីជាចោរនោះសោះ។ ភិក្ខុនីទាំងឡាយបានឮពាក្យស្តេចលិច្ឆវីនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងបំបួសស្រីចោរសោះ។ ទើបភិក្ខុនីទាំងឡាយនោះ ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីបំបួសស្រីជាចោរ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងបំបួសស្រីចោរទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយដឹងថាស្រីជាចោរដែលគេដឹងច្បាស់ថា ត្រូវសម្លាប់ ហើយមិនប្រាប់ស្តេចក្តី សង្ឃក្តី គណៈក្តី ប្រជុំជនក្តី សេនាក្តី ហើយបំបួស (ស្រីនោះ) វៀរតែកប្ប (គឺមានសំបុត្រច្បាប់) ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ។**

[៣៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលឈ្មោះថាដឹង គឺភិក្ខុនីដឹងខ្លួនឯងក្តី ជនទាំងឡាយដទៃប្រាប់ភិក្ខុនីនោះក្តី ស្រីចោរនោះប្រាប់ក្តី។ ដែលហៅថា ស្រីចោរ គឺស្រីណាមានថេយ្យចិត្ត លួចយកទ្រព្យមានដំឡៃប្រាំមាសកក្តី

លើសពីប្រាំមាសកក្តី ដែលគេមិនបានឲ្យ ស្រីនេះ ឈ្មោះថា ស្រីចោរ។ ស្រីដល់នូវទោសត្រូវសម្លាប់ ព្រោះធ្វើអំពើឯណា អំពើនេះឈ្មោះថា ទោសត្រូវសម្លាប់។ ដែលហៅថា គេដឹងច្បាស់ គឺស្រីដែលមនុស្សទាំងឡាយដទៃដឹងថា ស្រីនេះមានទោសត្រូវសម្លាប់។ ពាក្យថា មិនបានប្រាប់ គឺមិនបានជំរាប។ ដែលហៅថា ស្តេច គឺស្តេចត្រួតត្រាក្នុងទីណា ត្រូវភិក្ខុនីថ្វាយដំណឹងស្តេច (ក្នុងទីនោះ)។ ដែលហៅថា សង្ឃ សំដៅយកភិក្ខុនីសង្ឃ ភិក្ខុនីត្រូវប្រាប់ភិក្ខុនីសង្ឃ(នោះឯង)។ ដែលហៅថាគណៈ គឺគណៈភិក្ខុនីត្រួតត្រាក្នុងទីណា ភិក្ខុនីត្រូវប្រាប់គណភិក្ខុនី(ក្នុងទីនោះដែរ)។ ដែលហៅថា ប្រជុំជន គឺចំណោមមនុស្សត្រួតត្រាក្នុងទីណា ភិក្ខុនីត្រូវប្រាប់ចំណោមមនុស្ស(ក្នុងទីនោះ)។ ដែលហៅថា សេនា គឺសេនាត្រួតត្រាក្នុងទីណា ភិក្ខុនីត្រូវប្រាប់សេនា(ក្នុងទីនោះ)។ ពាក្យថា វៀរលែងតែកប្ប គឺមានសំបុត្រច្បាប់ សេចក្តីថា លើកទុកតែមានសំបុត្រច្បាប់។ ដែលហៅថា កប្ប បានដល់កប្បពីរយ៉ាង (ថាដូច្នេះ) ស្រីនេះបានបួសក្នុងសំណាក់តិរ្ថិយទាំងឡាយក្តី ស្រីនេះបានបួសក្នុងសំណាក់ភិក្ខុនីទាំងឡាយដទៃក្តី។ ភិក្ខុនីគិតថា អញនឹងបំបួស (ស្រីនោះ) ហើយស្វែងរកគណៈក្តី ភិក្ខុនីជាអាចារ្យក្តី បាត្រក្តី ចីវរក្តី សម្មតិសីមាក្តី ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសំបុត្រច្បាប់ ភិក្ខុនីជាឧបជ្ឈាយ៍ត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយក្នុងខណៈចប់កម្មវាចាពីរលើក ចប់កម្មវាចាស្រេច ត្រូវអាបត្តិសង្ឃាទិសេស ចំណែកគណៈនឹងភិក្ខុនីជាអាចារ្យ ត្រូវត្រឹមអាបត្តិទុក្កដ។

[៣៧] ពាក្យថា ភិក្ខុនីនេះក្តី តថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីដែលត្រូវអាបត្តិមុនៗ។ ពាក្យថា បឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិមួយអន្លើដោយកិរិយាប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសនកម្មទេ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីនោះត្រូវភិក្ខុនីឯទៀតនាំចេញអំពីសង្ឃ។ ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយក្នុងសង្ឃាទិសេសទី១រួចហើយ។

[៣៨] ស្រីចោរ ភិក្ខុនីសំគាល់ថាស្រីចោរ ហើយបំបួស (ស្រីនោះ) ត្រូវអាបត្តិសង្ឃាទិសេស វៀរលែងតែមានសំបុត្រច្បាប់។ ស្រីចោរ ភិក្ខុនីសង្ស័យ ហើយបំបួស (ស្រីនោះ) ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសំបុត្រច្បាប់។ ស្រីចោរ ភិក្ខុនីសំគាល់ថាមិនមែនចោរ ហើយបំបួស (ស្រីនោះ) មិនត្រូវអាបត្តិ វៀរលែងតែមានសំបុត្រច្បាប់។ មិនមែនស្រីចោរ ភិក្ខុនីសំគាល់ថាស្រីចោរ ត្រូវអាបត្តិទុក្កដ។ មិនមែនស្រីចោរ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនស្រីចោរ ភិក្ខុនីសំគាល់ថាមិនមែនស្រីចោរ មិនត្រូវអាបត្តិ។

[៣៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ ភិក្ខុនីមិនដឹង ហើយបំបួស១ ភិក្ខុនីជំរាបដល់អ្នករាជការ មានស្តេចជាដើម ហើយទើបបំបួស១ ភិក្ខុនីបំបួសស្រីដែលមានសំបុត្រច្បាប់ពីក្នុងកាលមុនរួចហើយ (គឺស្រីដែលធ្លាប់បួសក្នុងសំណាក់តិរ្ថិយ ឬភិក្ខុនីឯទៀត)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ១។

## សង្ឃាទិសេស ទី៣

CS vin.vbi.sg.03 | ភាគ ទី៥

### (៣. តតិយសង្ឃាទិសេសសិក្ខាបទំ)

[៤០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីជាសិស្សរបស់ភទ្ទាកាបិលានីថេរីឈ្លោះនឹងភិក្ខុនីទាំងឡាយ ហើយក៏បានទៅកាន់ត្រកូលញាតិក្នុងស្រុក។ ភទ្ទាកាបិលានីថេរី កាលមិនឃើញភិក្ខុនីនោះ ក៏សួរភិក្ខុនីទាំងឡាយថា ភិក្ខុនីឈ្មោះនេះទៅណា មិនឃើញ។ ភិក្ខុនីទាំងឡាយប្រាប់ថា បពិត្រលោកម្ចាស់ ភិក្ខុនីនោះឈ្លោះនឹងភិក្ខុនីទាំងឡាយ ហើយ(ស្រាប់តែ)មិនឃើញ។ ភទ្ទាកាបិលានីថេរីនិយាយថា នែនាងទាំងឡាយ ត្រកូលញាតិរបស់ភិក្ខុនីនេះ មាននៅក្នុងស្រុកឈ្មោះឯណោះ ចូរនាងទាំងឡាយទៅពិនិត្យរកក្នុងត្រកូលនោះមើល។ ភិក្ខុនីទាំងឡាយទៅក្នុងទីនោះ ឃើញភិក្ខុនីនោះ ហើយបាននិយាយពាក្យនេះថា នែលោកម្ចាស់ ហេតុអ្វីក៏លោកមកតែម្នាក់ឯង មិនមានគេបៀតបៀនលោកទេឬ។ ភិក្ខុនីនោះនិយាយថា នែលោកម្ចាស់ ខ្ញុំមិនមានអ្នកណាបៀតបៀនទេ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនី មិនសមនឹងទៅកាន់ចន្លោះស្រុកតែម្នាក់ឯងសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទៅកាន់ចន្លោះស្រុកតែម្នាក់ឯង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនគួរបើនឹងទៅកាន់ចន្លោះស្រុកតែម្នាក់ឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុនីណាមួយទៅកាន់ចន្លោះស្រុកតែម្នាក់ឯង ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ។ ឯសិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ។

[៤១] សម័យនោះឯង ភិក្ខុនីទាំងឡាយពីររូបចេញអំពីក្រុងសាកេត ហើយដើរផ្លូវឆ្ងាយទៅកាន់ក្រុងសាវត្ថី។ ក្នុងចន្លោះផ្លូវមានស្ទឹងដែលភិក្ខុនីទាំងឡាយនោះត្រូវឆ្លង។ ទើបភិក្ខុនីទាំងឡាយនោះចូលទៅរកពួកអ្នកទូក ហើយបាននិយាយពាក្យនេះថា នែអ្នកដ៏មានអាយុ សូមឲ្យអ្នកទាំងឡាយអាណិតចម្លងយើង (បន្តិច)។ ពួកអ្នកទូកនិយាយថា បពិត្រលោកម្ចាស់ យើងខ្ញុំមិនអាចចម្លងលោកម្ចាស់ទាំងពីររូបតែម្តងបានទេ។ អ្នកទូកម្នាក់ចម្លងភិក្ខុនី១រូប។ អ្នកទូកដែលឆ្លងរួចទៅហើយ ក៏ទ្រុស្ត(សេពសន្ថវ) នឹងភិក្ខុនីដែលឆ្លងរួចទៅហើយ។ អ្នកទូកដែលមិនទាន់ឆ្លង ក៏ទ្រុស្តនឹងភិក្ខុនីដែលមិនទាន់ឆ្លង។ ភិក្ខុនីទាំងពីរនោះមកប្រជុំគ្នាក្នុងពេលក្រោយ ហើយសួរគ្នាថា នែលោកម្ចាស់ អ្នកទូកមិនបៀតបៀនលោកទេឬ។ ភិក្ខុនីនោះនិយាយថា នែលោកម្ចាស់ ខ្ញុំអ្នកទូកវាបៀតបៀនទៅហើយ ចុះចំណែកខាងលោកម្ចាស់ អ្នកទូកវាមិនបៀតបៀនលោកទេឬ។ ភិក្ខុនីនោះ ក៏និយាយថា លោកម្ចាស់ ខ្ញុំអ្នកទូកបៀតបៀនហើយដែរ។ លំដាប់នោះ ភិក្ខុនីទាំងឡាយនោះទៅកាន់ក្រុងសាវត្ថី ហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹងទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងសោះ។ ទើបភិក្ខុនីទាំងឡាយនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយទូល

ដំណើររន្ទំះចំពោះព្រះដ៏មានព្រះភាគ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនគួរបើនឹងទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុនីណាមួយទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី ទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងក្តី ភិក្ខុនីនេះឯង ក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ។ ព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ។

[៤២] សម័យនោះឯង ភិក្ខុនីទាំងឡាយច្រើនរូប ទៅកាន់ក្រុងសាវត្ថី ក្នុងជនបទកោសល ទើបចូលទៅកាន់ស្រុក១ ក្នុងពេលល្ងាច។ បណ្តាភិក្ខុនីទាំងឡាយនោះ ភិក្ខុនី១រូប មានរូបល្អ គួរពិតពិលរមិលមើល នាំមកនូវសេចក្តីជ្រះថ្លា។ បុរសម្នាក់មានចិត្តប្រតិព័ទ្ធតាំងពីឃើញភិក្ខុនីនោះ។ ឯបុរសនោះបានក្រាលទីសិងដល់ភិក្ខុនីទាំងឡាយនោះ ក៏ក្រាលទីសិងដើម្បីភិក្ខុនីនោះក្នុងទីម្ខាងដោយឡែក។ ទើបឯភិក្ខុនីនោះកំណត់យល់ឃើញហើយ ក៏គិតថា បុរសនេះមានរាគៈគ្របសង្កត់ហើយ បើគាត់នឹងមកក្នុងវេលាយប់ អញមុខជានឹងមានសម្រែកខុសប្រក្រតី ហើយក៏មិនបានលាភិក្ខុនីទាំងឡាយ ស្រាប់តែទៅកាន់ត្រកូលមួយ ហើយក៏សម្រេចឥរិយាបថដេក។ លំដាប់នោះ បុរសនោះមកក្នុងវេលារាត្រី ស្វែងរកភិក្ខុនីនោះ ក៏បៀតបៀនភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយ កាលបើមិនឃើញភិក្ខុនីនោះ បាននិយាយយ៉ាងនេះថា ភិក្ខុនីនោះចេញទៅជាមួយនឹងប្រុសជាប្រាកដហើយ។ ឯភិក្ខុនីនោះ លុះកន្លងរាត្រីនោះទៅ បានចូលទៅរកភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា នែលោកម្ចាស់ ហេតុអ្វីបានជាលោកចេញទៅជាមួយនឹងប្រុស។ ភិក្ខុនីនោះនិយាយថា នែលោកម្ចាស់ ខ្ញុំមិនបានចេញទៅជាមួយនឹងប្រុសទេ ហើយក៏ប្រាប់ដំណើររន្ទំះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនី មិនសមបើនឹងនៅប្រាសចាកគ្នាក្នុងវេលារាត្រីតែម្នាក់ឯងសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីនៅប្រាសចាក(គ្នា)ក្នុងវេលារាត្រីតែម្នាក់ឯង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនគួរបើនឹងនៅប្រាសចាក(គ្នា)ក្នុងវេលារាត្រីតែម្នាក់ឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬនាំឲ្យរឹងរឹតតែជ្រះថ្លាឡើងដល់ជនទាំងឡាយដែលជ្រះថ្លាស្រាប់ហើយទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុនីណាមួយទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី ទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងក្តី ប្រាសចាកគ្នាក្នុងវេលារាត្រីតែម្នាក់ឯងក្តី ភិក្ខុនីនេះឯង ក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុនីទាំងឡាយហើយយ៉ាងនេះ។

[៤៣] សម័យនោះឯង ភិក្ខុនីទាំងឡាយច្រើនរូប ដើរផ្លូវឆ្ងាយ ទៅកាន់ក្រុងសាវត្ថី ក្នុងកោសលជនបទ។ បណ្តាភិក្ខុនីទាំងឡាយនោះ ភិក្ខុនីមួយរូប មានឧច្ចារបៀតបៀន (ឈឺដោះទុក្ខសត្វ) បង្អង់នៅតែម្នាក់ឯង ហើយបានទៅក្នុងកាលជាខាងក្រោយ។ មនុស្សទាំងឡាយឃើញភិក្ខុនីនោះហើយទ្រុស្ត។ ទើបភិក្ខុនីនោះចូលទៅរកភិក្ខុនីទាំងឡាយនោះ។ ភិក្ខុនីទាំងឡាយបានពោលពាក្យនេះនឹងភិក្ខុនីនោះថា នែលោកម្ចាស់ ហេតុអ្វីក៏លោកបង្អង់ឈប់នៅតែម្នាក់ឯង ហើយលោកមិនមានអ្នកណាបៀតបៀនខ្លះទេឬ។ ភិក្ខុនីនោះប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំប្រុសបៀតបៀនទៅហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនី មិនសមបើនឹងឈប់បង្អង់ឲ្យឃើតយូរជាងពួកតែម្នាក់ឯងសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីបង្អង់ឲ្យឃើតយូរជាងពួកតែម្នាក់ឯង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនគួរបើនឹងបង្អង់ឲ្យឃើតយូរជាងពួកតែម្នាក់ឯងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី ទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងក្តី នៅប្រាសចាកគ្នាក្នុងវេលារាត្រីតែម្នាក់ឯងក្តី ឈប់ឲ្យឃ្លាតអំពីពួកតែម្នាក់ឯងក្តី ភិក្ខុនីនេះឯង ក៏ត្រូវអាបត្តិឈ្មោះសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញ។**

[៤៤] ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី គឺភិក្ខុនីឈានជំហានដម្បូងចូលទៅកាន់របងនៃស្រុកដែលមានរបង ត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានទី២ ទៅ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុនីឈានជំហានដម្បូងចូលទៅកាន់ឧបចារស្រុកដែលមិនមានរបង ត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានទី២ ត្រូវអាបត្តិសង្ឃាទិសេស។ ពាក្យថា ទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯង គឺភិក្ខុនីបិទបាំងមណ្ឌល៣ ហើយឆ្លងឡើងក្នុងទីណាមួយ ស្បង់នៃភិក្ខុនីនោះក៏ទទឹកបាន ទីនោះហៅថាស្ទឹង។ ភិក្ខុនីឆ្លងផុតជំហានដម្បូង ត្រូវអាបត្តិថុល្លច្ច័យ ឆ្លងផុតជំហានទី២ ត្រូវអាបត្តិសង្ឃាទិសេស។ ពាក្យថា នៅប្រាសចាកគ្នាក្នុងវេលារាត្រីតែម្នាក់ឯង គឺភិក្ខុនីកំពុងលះហត្ថបាសនៃភិក្ខុនីទី២ ត្រូវអាបត្តិថុល្លច្ច័យ ព្រមគ្នានឹងអរុណរះឡើង លុះលះហត្ថបាសស្រេចឡះហើយ ត្រូវអាបត្តិសង្ឃាទិសេស។ ពាក្យថា ឈប់ឲ្យឃ្លាតអំពីពួកតែម្នាក់ឯង គឺភិក្ខុនីកំពុងលះទស្សនុបចារ (កន្លែងដែលមើលគ្នាឃើញ)ក្តី សវនុបចារ (កន្លែងដែលស្តាប់ឮ)ក្តី របស់ភិក្ខុនីទី២ ក្នុងព្រៃមិនមែនជាស្រុក ត្រូវអាបត្តិថុល្លច្ច័យ លុះលះបង់ដាច់ស្រេចឡះហើយ ត្រូវសង្ឃាទិសេស។

[៤៥] ពាក្យថា ភិក្ខុនីនេះឯង តថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីដែលត្រូវអាបត្តិមុនៗ។ ពាក្យថា បឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិព្រមគ្នានឹងពេលដែលប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសនវិធីទេ។ ពាក្យថា គួរបណ្តេញចេញ គឺភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយបណ្តេញចេញចាកសង្ឃ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយក្នុងសង្ឃាទិសេសទី១រួចហើយ។

[៤៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុនីទី២ចៀសចេញទៅក្តី សឹកទៅក្តី ស្លាប់ទៅក្តី ចូលទៅកាន់ពួកតិរ្ថិយក្តី១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើមុនបញ្ញត្តិ១។

## សង្ឃាទិសេស ទី៤

CS vin.vbi.sg.04 | ភាគ ទី៥

### (៤. ចតុត្ថសង្ឃាទិសេសសិក្ខាបទំ)

[៤៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ចណ្ឌកាលីភិក្ខុនីជាអ្នកធ្វើសេចក្តីបង្កហេតុឈ្លោះទាស់ទែងគ្នា ធ្វើនូវតិរច្ឆានកថា ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃ។ ថុល្លនន្ទាភិក្ខុនីរារាំងនូវកម្មទាំងឡាយដែលចណ្ឌកាលីភិក្ខុនីនោះធ្វើ។ ទទួលសម័យនោះឯង ថុល្លនន្ទាភិក្ខុនីបានទៅកាន់ស្រុកតូច ដោយកិច្ចអ្វីម្យ៉ាង។ លំដាប់នោះ ភិក្ខុនីសង្ឃដឹងថា ថុល្លនន្ទាភិក្ខុនីចៀសចេញទៅហើយ ៗលើកវត្តចំពោះចណ្ឌកាលីភិក្ខុនី ព្រោះសេចក្តីមិនឃើញអាបត្តិ។ ថុល្លនន្ទាភិក្ខុនីពិចារណាកិច្ចដែលខ្លួនត្រូវធ្វើក្នុងស្រុកនោះហើយ ក៏វិលមកកាន់ក្រុងសាវត្ថីវិញ។ ចណ្ឌកាលីភិក្ខុនី កាលបើថុល្លនន្ទាភិក្ខុនីមកដល់ ក៏មិនក្រាលអាសនៈឲ្យ មិនចូលទៅដម្កល់ទឹកលាងជើង តាំងរងជើង និងឈើទ្រាប់ជើងឡើយ មិនក្រោកទទួលយកបាត្រចីវរ មិនអើពើដោយទឹកផឹក។ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងចណ្ឌកាលីភិក្ខុនីថា នែលោកម្ចាស់ កាលបើយើងមកដល់ ហេតុអ្វីក៏លោកមិនក្រាលអាសនៈឲ្យ មិនចូលមកដម្កល់ទឹកលាងជើង តាំងរងជើង និងឈើទ្រាប់ជើងឲ្យ មិនក្រោកទទួលយកបាត្រចីវរ មិនអើពើដោយទឹកផឹក។ ចណ្ឌកាលីភិក្ខុនីនិយាយថា បពិត្រលោកម្ចាស់ ការនេះបានជាយ៉ាងហ្នឹង ព្រោះខ្ញុំជាមនុស្សអនាថា។ ថុល្លនន្ទាភិក្ខុនីសួរថា នែលោកម្ចាស់ ហេតុអ្វីក៏លោកជាមនុស្សអនាថា។ ចណ្ឌកាលីភិក្ខុនីនិយាយថា នែលោកម្ចាស់ ភិក្ខុនីទាំងឡាយនេះ គិតគ្នាថា ភិក្ខុនីនេះជាមនុស្សអនាថា មិនមានអ្នកណាស្គាល់ គ្មានភិក្ខុនីណាមួយជាអ្នកប្រតិបត្តិភិក្ខុនីនេះទេ ដូច្នេះហើយ ក៏លើកវត្តចំពោះខ្ញុំ ព្រោះសេចក្តីមិនឃើញអាបត្តិ។ ថុល្លនន្ទាភិក្ខុនីនិយាយថា ភិក្ខុនីទាំងឡាយនេះល្ងង់ ភិក្ខុនីអស់នេះមិនឆ្លាស ភិក្ខុនីទាំងឡាយនេះមិនស្គាល់កម្មក្តី ទោសរបស់កម្មក្តី កម្មវិបត្តិក្តី កម្មសម្បត្តិក្តី ឯយើងទើបដឹងកម្មផង ទោសរបស់កម្មផង កម្មវិបត្តិផង កម្មសម្បត្តិផង យើងហ្នឹងឯងត្រូវធ្វើកម្មដែលសង្ឃមិនបានធ្វើផង ត្រូវញុំាងកម្មដែលសង្ឃធ្វើហើយឲ្យកម្រើកផង ដូច្នេះហើយ ប្រជុំភិក្ខុនីសង្ឃភ្លាមៗហើយសូត្រ(ដកកម្ម) បញ្ចូលចណ្ឌកាលីភិក្ខុនីមកវិញ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងមិនប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនីជាអ្នកធ្វើ ហើយសូត្របញ្ចូលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅព្រះសាស្តាទេ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី មិនបានប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនីជាអ្នកធ្វើ សូត្របញ្ចូលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅព្រះសាស្តា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងមិនប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនីជាអ្នកធ្វើ ហើយសូត្របញ្ចូលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅព្រះសាស្តាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មិនបានប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់គណៈ ហើយសូត្របញ្ចូលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ។**

[៤៨] ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ សង្ឃដែលមានសំវាសស្មើគ្នា ឋិតនៅក្នុងសីមាស្មើគ្នា ឈ្មោះថា ព្រមព្រៀងគ្នា។ ភិក្ខុនីដែលឈ្មោះថាសង្ឃលើកវត្ត គឺភិក្ខុនីដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី មិនសំដែងអាបត្តិក្តី មិនលះបង់(ទិដ្ឋិអាក្រក់)ក្តី។ ពាក្យថា តាមធម៌ តាមវិន័យ គឺតាមធម៌យ៉ាងណា តាមវិន័យយ៉ាងណា។ ពាក្យថា តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា គឺតាមពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី គឺតាមពុទ្ធសាសនា។ ពាក្យថា មិនប្រាប់ការកសង្ឃ គឺមិនប្រាប់សង្ឃជាអ្នកធ្វើកម្ម។ ពាក្យថា មិនដឹងសេចក្តីប្រាថ្នារបស់គណៈ គឺមិនដឹងសេចក្តីពេញចិត្តរបស់ពួក។ ភិក្ខុនីគិតថា អញនឹងសូត្របញ្ចូលពួក ហើយស្វែងរកពួកក្តី សម្មតិសីមាក្តី ត្រូវអាបត្តិទុក្កដ ភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយក្នុងខណៈចប់កម្មវាចាពីរលើក ត្រូវអាបត្តិសង្ឃាទិសេសក្នុងខណៈសូត្រចប់កម្មវាចាស្រេច។

[៤៩] ពាក្យថា ភិក្ខុនីនេះក្តី តថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីដែលប្រព្រឹត្តល្មើសមុនៗ។ ពាក្យថា បឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសនវិធីទេ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីនោះ ត្រូវភិក្ខុនីដទៃទៀតបណ្តេញចេញអំពីសង្ឃ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយក្នុងសង្ឃាទិសេសទី១នៃសត្តរសកណ្ឌរួចហើយ។

[៥០] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ហើយសូត្របញ្ចូលពួក ត្រូវអាបត្តិសង្ឃាទិសេស។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយសូត្របញ្ចូលពួក ត្រូវអាបត្តិសង្ឃាទិសេស។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយសូត្រ

បញ្ចូលពួក ត្រូវអាបត្តិសង្ឃាទិសេស។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៥១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ ភិក្ខុនីប្រាប់សង្ឃជាអ្នកធ្វើសង្ឃកម្ម ហើយទើបសូត្របញ្ចូលពួក១ ភិក្ខុនីដឹងសេចក្តីប្រាថ្នារបស់គណៈ ហើយទើបសូត្របញ្ចូល១ ភិក្ខុនីសូត្របញ្ចូលភិក្ខុនីដែលប្រព្រឹត្តតាមវត្ត កាលបើគ្មានសង្ឃជាអ្នកធ្វើសង្ឃកម្ម ទើបភិក្ខុនីសូត្របញ្ចូលពួក១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើខុសមុនបញ្ញត្តិ១។

## សង្ឃាទិសេស ទី៥

CS vin.vbi.sg.05 | ភាគ ទី៥

### (៥. បញ្ចមសង្ឃាទិសេសសិក្ខាបទំ)

[៥២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង សុន្ទរីនន្ទាភិក្ខុនីមានរូបល្អ គួរពិតពិលរមិលមើល នាំមកនូវសេចក្តីជ្រះថ្លា។ មនុស្សទាំងឡាយឃើញសុន្ទរីនន្ទាភិក្ខុនីក្នុងរោងភត្តហើយ មានសេចក្តីតម្រេក ក៏ប្រគេនភោជនទាំងឡាយសុទ្ធតែប្រសើរដល់សុន្ទរីនន្ទាភិក្ខុនីដែលមានតម្រេកដែរ។ សុន្ទរីនន្ទាភិក្ខុនីឆាន់ (តែឯង) ទាល់តែឆ្អែត។ ភិក្ខុនីទាំងឡាយដទៃមិនបានអាហារដ៏សមគួរដល់ចិត្តផងឡើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោសតិះដៀល បន្តុះបង្អាប់ថា នាងសុន្ទរីនន្ទាភិក្ខុនី មិនសមបើនឹងមានតម្រេក ទទួលខាទនីយភោជនីយាហារអំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃខ្លួន ហើយទំពាស៊ី ឬឆាន់សោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាសុន្ទរីនន្ទាភិក្ខុនីមានតម្រេក ទទួលខាទនីយភោជនីយាហារអំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃរបស់ខ្លួន ហើយទំពាស៊ី ឬបរិភោគ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ សុន្ទរីនន្ទាភិក្ខុនី មិនគួរបើនឹងមានតម្រេក ហើយទទួលខាទនីយភោជនីយាហារអំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃរបស់ខ្លួន ហើយទំពាស៊ី ឬឆាន់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ មានតម្រេកទទួលយកខាទនីយក្តី ភោជនីយក្តី អំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃនៃខ្លួន ហើយទំពាស៊ីក្តី បរិភោគក្តី ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ។**

[៥៣] ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ។ ភិក្ខុនីដែលឈ្មោះថា មានតម្រេក គឺភិក្ខុនីដែលត្រេកអរអាឡោះអាល័យ មានចិត្តប្រតិព័ទ្ធ។ បុរសដែលឈ្មោះថា មានតម្រេក គឺប្រុសដែលត្រេកត្រអាល សំឡឹងគយគន់ មានចិត្តប្រតិព័ទ្ធ។ ដែលហៅថា បុរសបុគ្គល សំដៅយកមនុស្សប្រុសដែលដឹងក្តី អាចត្រេកអរបាន មិនមែនយក្សប្រុស ប្រេតប្រុស តិរច្ឆានឈ្មោលទេ។ ដែលហៅថា ខាទនីយ គឺលើកលែងតែភោជន៥យ៉ាងចេញ និងទឹក និងឈើស្ទន់ ក្រៅពីនោះឈ្មោះថា ខាទនីយទាំងអស់។ ភោជន៥យ៉ាង គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១ ឈ្មោះថា ភោជនីយ។ ភិក្ខុនីគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគ ហើយទទួលយក ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុនីនោះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗវារៈដែលលេបចូលទៅ។

[៥៤] ពាក្យថា ភិក្ខុនីនេះក្តី គឺតថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីទាំងឡាយមុនៗ។ ពាក្យថា បឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសនវិធីទេ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយបណ្តេញចេញអំពីសង្ឃ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ។ ភិក្ខុនីទទួលទឹក និងឈើស្ទន់ ត្រូវអាបត្តិទុក្កដ។

[៥៥] កាលបើមានតម្រេកតែម្ខាង ហើយភិក្ខុនីគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគ ក៏ទទួលយក ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះត្រូវអាបត្តិថុល្លច្ច័យគ្រប់ៗវារៈដែលលេបចូលទៅ។ ភិក្ខុនីទទួលទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ។ កាលបើបុគ្គលមានតម្រេកទាំងពីរខាង ហើយភិក្ខុនីគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគដូច្នេះ ក៏ទទួលយកអំពីដៃយក្សប្រុសក្តី ប្រេតក្តី បណ្ឌក (ខ្ទើយ)ក្តី តិរច្ឆានដែលមានរូបរាងដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះត្រូវអាបត្តិថុល្លច្ច័យគ្រប់ៗវារៈដែលលេបចូលទៅ។ ភិក្ខុនីទទួលទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ។ កាលបើមានតម្រេកតែម្ខាង ហើយភិក្ខុនីគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគដូច្នេះ ក៏ទទួលយក ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដគ្រប់ៗវារៈដែលលេបចូលទៅ។ ភិក្ខុនីទទួលយកទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ។

[៥៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ជនទាំងឡាយ (ភិក្ខុនីនិងប្រុស) មិនមានតម្រេកទាំងពីរខាង១ ភិក្ខុនីដឹងថាប្រុសនោះមិនមានតម្រេក ទើបទទួលយក១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើខុសមុនបញ្ញត្តិ១។

## សង្ឃាទិសេស ទី៦

CS vin.vbi.sg.06 | ភាគ ទី៥

### (៦. ឆដ្ឋសង្ឃាទិសេសសិក្ខាបទំ)

[៥៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង សុន្ទរីនន្ទាភិក្ខុនីមានរូបល្អ គួរពិតពិលរមិលមើល នាំមកនូវសេចក្តីជ្រះថ្លា។ មនុស្សទាំងឡាយបានឃើញសុន្ទរីនន្ទាភិក្ខុនីក្នុងរោងភត្តក៏មានតម្រេក ហើយឲ្យភោជនទាំងឡាយដ៏ឧត្តុង្គឧត្តមដល់សុន្ទរីនន្ទាភិក្ខុនីដែលមានតម្រេកដែរ។ សុន្ទរីនន្ទាភិក្ខុនីរង្កៀស ក៏មិនទទួលយក។ ភិក្ខុនីដែលអង្គុយលើអាសនៈបន្ទាប់ បានពោលពាក្យនេះនឹងសុន្ទរីនន្ទាភិក្ខុនីថា នែលោកម្ចាស់ ហេតុអ្វីក៏នាងមិនទទួលយក។ សុន្ទរីនន្ទាភិក្ខុនីនិយាយថា នែលោកម្ចាស់ បុរសនេះមានតម្រេក។ ភិក្ខុនីទាំងឡាយនោះសួរថា នែលោកម្ចាស់ ចំណែកខាងលោកមានតម្រេកឬទេ។ សុន្ទរីនន្ទាភិក្ខុនីនិយាយថា នែលោកម្ចាស់ ខ្ញុំមិនមានតម្រេកទេ។ ភិក្ខុនីនោះនិយាយថា នែលោកម្ចាស់ បុគ្គលប្រុសនេះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកហើយ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណា ជាខាទនីយក្តី ជាភោជនីយក្តី ដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ី ឬបរិភោគចុះ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ធម្មតាភិក្ខុនីមិនសមបើនឹងពោលយ៉ាងនេះថា នែលោកម្ចាស់ បុគ្គលប្រុសនេះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនោះឲ្យវត្ថុឯណា ជាខាទនីយក្តី ភោជនីយក្តី ដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ី ឬបរិភោគចុះ។បេ។ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីពោលយ៉ាងនេះថា នែលោកម្ចាស់ បុគ្គលប្រុសនេះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណា ជាខាទនីយក្តី ភោជនីយក្តី ដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ី ឬបរិភោគចុះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុនីមិនសមបើនឹងពោលយ៉ាងនេះថា នែលោកម្ចាស់ បុគ្គលប្រុសនេះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណា ជាខាទនីយក្តី ជាភោជនីយក្តី ដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ី ឬបរិភោគចុះទេ ម្នាលភិក្ខុទាំងឡាយ អំពើរបស់ភិក្ខុនីនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយពោលយ៉ាងនេះថា នែលោកម្ចាស់ បុគ្គលប្រុសនេះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណា ជាខាទនីយក្តី ជាភោជនីយក្តី ដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ី ឬបរិភោគចុះ ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ។**

[៥៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ។ ពាក្យថា ពោលយ៉ាងនេះ គឺភិក្ខុនីនិយាយបញ្ចួនដោយពាក្យថា នែលោកម្ចាស់ បុគ្គលប្រុសនេះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់លោកបាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនេះឲ្យវត្ថុឯណា ជាខាទនីយក្តី ភោជនីយក្តី ដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ី ឬបរិភោគចុះដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទទួលយកដោយគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគតាមពាក្យភិក្ខុនីដែលពោលបញ្ចួននោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះ ត្រូវអាបត្តិថុល្លច្ច័យគ្រប់ៗវារៈដែលលេបចូលទៅ។ ភិក្ខុនីនោះត្រូវអាបត្តិសង្ឃាទិសេសក្នុងពេលដែលឆាន់រួចហើយ។ ពាក្យថា ភិក្ខុនីនេះក្តី គឺតថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីទាំងឡាយមុនៗ។ ពាក្យថា ជាបឋមាបត្តិក គឺភិក្ខុនីត្រូវអាបត្តិព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុ មិនមែនដោយសូត្រសមនុភាសនវិធីទេ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយបណ្តេញចេញអំពីសង្ឃ។ ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ។ ភិក្ខុនីបញ្ចួនដោយពាក្យថា លោកចូរទទួលយកទឹកនិងឈើស្ទន់ចុះដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះទទួលដោយគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគតាមពាក្យភិក្ខុនីដែលពោលបញ្ចួននោះ ត្រូវអាបត្តិទុក្កដ។

[៥៩] កាលបើមានតម្រេកតែម្ខាង ភិក្ខុនីបញ្ចួនដោយពាក្យថា លោកចូរ(ទទួល) ខាទនីយក្តី ភោជនីយក្តី អំពីដៃយក្សក្តី ប្រេតក្តី បណ្ឌកក្តី តិរច្ឆានមានរូបរាងដូចមនុស្សក្តី ហើយទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះទទួលដោយគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគតាមពាក្យភិក្ខុនីដែលពោលបញ្ចួននោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដគ្រប់ខណៈដែលលេបចូលទៅ។ ភិក្ខុនីនោះត្រូវអាបត្តិថុល្លច្ច័យក្នុងពេលដែលឆាន់រួចហើយ។ ភិក្ខុនីពោលបញ្ចួនថា លោកចូរទទួលយកទឹកនិងឈើស្ទន់ចុះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទទួលដោយគិតថា អញនឹងទំពាស៊ី ឬនឹងបរិភោគតាមពាក្យភិក្ខុនីជាអ្នកពោលបញ្ចួននោះ ត្រូវអាបត្តិទុក្កដ។

[៦០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ ភិក្ខុនីដឹងថា បុរសនោះមិនមានតម្រេក ទើបបញ្ចួន១ ភិក្ខុនីបញ្ចួនដោយគិតថា ភិក្ខុនីនេះក្រោធ ហើយគង់មិនទទួលយក១ ភិក្ខុនីបញ្ចួនដោយគិតថា ភិក្ខុនីនេះគង់មិនទទួលយក ព្រោះខ្លួនមានសេចក្តីអនុគ្រោះត្រកូល១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ១។

## សង្ឃាទិសេស ទី៧

CS vin.vbi.sg.07 | ភាគ ទី៥

### (៧. សត្តមសង្ឃាទិសេសសិក្ខាបទំ)

[៦១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ចណ្ឌកាលីភិក្ខុនីឈ្លោះខឹងអាក់អន់ចិត្តនឹងភិក្ខុនីទាំងឡាយ ហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយ

ឯណាជាសមណី[11] ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សមណីទាំងឡាយដទៃដែលមានខ្មាស មានសេចក្ដីរង្កៀស ជាអ្នកប្រាថ្នាការសិក្សាក៏មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្អាប់ថា លោកម្ចាស់ចណ្ឌកាលីខឹងអាក់អន់ចិត្ត មិនសមបើនឹងពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយឯណាជាសមណី ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីអម្បាលនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស មានសេចក្ដីប្រាថ្នាការសិក្សាក៏មានដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនីខឹងអាក់អន់ចិត្ត ហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយឯណាជាសមណី ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីអម្បាលនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃជាអ្នកមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាក៏មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនីខឹងអាក់អន់ចិត្តហើយ មិនគួរបើនឹងពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ជាអ្នកប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះដូច្នេះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ខឹងអាក់អន់ចិត្ត ហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាធីតាព្រះពុទ្ធជាសក្យ ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះ។ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា នៃលោកម្ចាស់ លោកកុំខឹងអាក់អន់ ហើយនិយាយយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះ ដូច្នេះឡើយ។ នៃលោកម្ចាស់ ចូរលោកត្រេកអរ (ព្រោះ)ធម៌ព្រះដ៏មានព្រះភាគសំដែងល្អហើយ ចូរលោកប្រព្រឹត្តព្រហ្មចារ្យដើម្បីធ្វើនូវទីបំផុតទុក្ខដោយប្រពៃចុះ ឯភិក្ខុនីនោះ កាលបើត្រូវភិក្ខុនីទាំងឡាយពោលយ៉ាងនេះ នៅប្រកាន់យ៉ាងនោះដដែល ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីចំពោះភិក្ខុនីនោះអស់វារៈជាគំរប់បីដង ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ បើភិក្ខុនីនោះ កាលត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីគំរប់បីដង(ហើយ) លះបង់វត្ថុនោះបាន ការលះបង់បាននោះជាការល្អ បើលះបង់មិនបានទេ ភិក្ខុនីនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាយាវតតិយក គួរបណ្ដេញចេញចាកសង្ឃ។**

[៦២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ។ ពាក្យថា ខឹងអាក់អន់ចិត្ត គឺភិក្ខុនីមានចិត្តមិនត្រេកអរ មានចិត្តដែលទោសខ្ទាំងខ្ទប់ហើយ មានចិត្តរឹងរូស។ ពាក្យថា ភិក្ខុនីពោលយ៉ាងនេះ គឺភិក្ខុនីពោលថា ខ្ញុំលាព្រះពុទ្ធ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះដូច្នេះ។

[៦៣] ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីដែលពោលយ៉ាងនេះជាប្រក្រតីនោះឯង។ ពាក្យថា ត្រូវភិក្ខុនីទាំងឡាយ គឺត្រូវភិក្ខុនីទាំងឡាយដទៃ។ ភិក្ខុនីទាំងឡាយឯណាឃើញ ឯណាឮ ភិក្ខុនីទាំងឡាយនោះត្រូវពោលហាមភិក្ខុនីនោះថា នៃលោកម្ចាស់ លោកកុំខឹងអាក់អន់ចិត្ត ហើយនិយាយយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនោះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះដូច្នេះឡើយ នៃលោកម្ចាស់ លោកចូរត្រេកអរចុះ (ព្រោះ)ធម៌ គឺព្រះដ៏មានព្រះភាគសំដែងល្អហើយ ចូរលោកប្រព្រឹត្តព្រហ្មចារ្យដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃចុះ។ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយនិយាយអស់វារៈពីរដងផង ត្រូវនិយាយអស់វារៈបីដងផង។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទាំងឡាយឮហើយ មិននិយាយ ត្រូវអាបត្តិទុក្កដ។ ត្រូវភិក្ខុនីទាំងឡាយទាញភិក្ខុនីនោះមកកាន់ទីកណ្ដាលសង្ឃ ហើយនិយាយហាមថា នៃលោកម្ចាស់ លោកកុំខឹងអាក់អន់ចិត្ត ហើយនិយាយយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ។បេ។ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះដូច្នេះ។ នៃលោកម្ចាស់ លោកចូរត្រេកអរចុះ (ព្រោះ)ធម៌ គឺព្រះដ៏មានព្រះភាគសំដែងល្អហើយ ចូរលោកប្រព្រឹត្តព្រហ្មចារ្យដើម្បីធ្វើនូវទីបំផុតទុក្ខដោយប្រពៃចុះ។ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយនិយាយហាមអស់វារៈពីរដងផង ត្រូវនិយាយហាមអស់វារៈបីដងផង។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ។

[៦៤] ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធី។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីយ៉ាងនេះ។ ភិក្ខុនីដែលឆ្លាសប្រតិពល ត្រូវផ្ទៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃម្ចាស់ សូមព្រះសង្ឃស្ដាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះខឹងអាក់អន់ចិត្ត ពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្ដេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្ដីខ្មាស មានសេចក្ដីរង្កៀស ប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់សមណីទាំងឡាយនោះ ដូច្នេះ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ។ បើសមនុភាសនកម្ម មានកាលសមគួរដល់សង្ឃហើយ ត្រូវសង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃជាម្ចាស់ សូម

សង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះខឹងអាក់អន់ចិត្ត ហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះនឹងហៅថាសមណីដូចម្តេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្តីខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សាក៏មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់ភិក្ខុនីទាំងឡាយនោះដូច្នេះ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ។ (ឥឡូវនេះ) សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ ការសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀមនៅ មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវពោលឡើង។ ខ្ញុំពោលសេចក្តីនេះអស់វារៈគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ អស់វារៈគំរប់បីដងផង។បេ។ សង្ឃបានសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះហើយ ដើម្បីឲ្យលះបង់វត្ថុនោះ។ ការសូត្រសមនុភាសនវិធីនោះ គួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៦៥] ភិក្ខុនី ត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះចប់កម្មវាចាស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ កាលបើភិក្ខុនីត្រូវអាបត្តិសង្ឃាទិសេសហើយ អាបត្តិទុក្កដដែលត្រូវក្នុងខណៈចប់ញត្តិក្តី អាបត្តិថុល្លច្ច័យទាំងឡាយដែលត្រូវក្នុងខណៈចប់កម្មវាចាពីរលើកក្តី រមែងរម្ងាប់ទៅឯង។

[៦៦] ពាក្យថា ភិក្ខុនីនេះក្តី (គឺភិក្ខុនីនេះឯង) ដែលតថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីដែលត្រូវសង្ឃាទិសេសមុនៗ។ ពាក្យថា ជាយាវតតិយក គឺភិក្ខុនីត្រូវអាបត្តិដោយ(សង្ឃ)សូត្រសមនុភាសនវិធីអស់វារជាគំរប់បីដង មិនមែនត្រូវព្រមគ្នាដោយការប្រព្រឹត្តល្មើសវត្ថុទេ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយបណ្តេញចេញអំពីសង្ឃ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយខាងដើមរួចហើយ។

[៦៧] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៦៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុនីដែលសង្ឃមិនបានសូត្រសមនុភាសនវិធី១ ភិក្ខុនីលះបង់ឯង១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ១។

## សង្ឃាទិសេស ទី៨

CS vin.vbi.sg.08 | ភាគ ទី៥

### (៨. អដ្ឋមសង្ឃាទិសេសសិក្ខាបទំ)

[៦៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនីដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍អ្វីនីមួយ ហើយខឹងតូចចិត្ត ពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្អប់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្តីល្ងង់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចណ្ឌកាលីជាម្ចាស់ដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍នីមួយហើយ មិនគួរនឹងខឹងអាក់អន់ចិត្ត ហើយពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះសោះ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនី ដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍នីមួយ ហើយខឹងតូចចិត្ត ពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនី ដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍នីមួយហើយ មិនគួរបើនឹងខឹងអាក់អន់ចិត្ត ហើយពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ដែលភិក្ខុនីសង្ឃធ្វើឲ្យចាញ់ព្រោះអធិករណ៍នីមួយ ហើយខឹងអាក់អន់ចិត្ត ពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង។ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា នែលោកម្ចាស់ លោក ដែលភិក្ខុនីសង្ឃឲ្យចាញ់ព្រោះអធិករណ៍នីមួយ ហើយខឹងអាក់អន់ចិត្ត កុំនិយាយយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះ ថា លោកម្ចាស់ហ្នឹងឯង លុះដោយសេចក្តីស្រឡាញ់ខ្លះ លុះដោយសេចក្តីស្អប់ខ្លះ លុះដោយសេចក្តីល្ងង់ខ្លះ លុះដោយសេចក្តីខ្លាចខ្លះ។ ភិក្ខុនីនោះ កាលដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ នៅប្រកាន់យ៉ាងនោះដដែល ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីដរាបដល់គំរប់បីដង ដើម្បីឲ្យលះបង់កម្មនោះចេញ។ ភិក្ខុនីនោះ កាលបើត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីដរាបដល់គំរប់បីដង លះបង់កម្មនោះបាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាយាវតតិយក គួរបណ្តេញចេញចាកសង្ឃ។**

[៧០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីដូចគ្នាក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ព្រោះអធិករណ៍នីមួយ ដែលហៅថា អធិករណ៍ បានដល់អធិករណ៍ទាំងឡាយបួន គឺវិវាទាធិករណ៍១ អនុវាទាធិករណ៍១ អាបត្តាធិករណ៍១ កិច្ចាធិករណ៍១។ ដែលហៅថា ភិក្ខុនីសង្ឃធ្វើឲ្យចាញ់ គឺសំដៅយកភិក្ខុនីដែលភិក្ខុនីសង្ឃផ្ចាញ់ផ្ចាលហើយ។ ពាក្យថា ខឹងអាក់អន់ចិត្ត គឺភិក្ខុនីមិនត្រេកអរ មានចិត្តគឺទោសខ្ទាំងខ្ទប់ហើយ មានចិត្តរឹងត្អឹង។ ពាក្យថា ពោលយ៉ាងនេះ គឺពោលថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង។

[៧១] ត្រង់ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីជាអ្នកពោលយ៉ាងនេះជាប្រក្រតីនោះឯង។ ពាក្យថា ភិក្ខុនីទាំងឡាយ គឺភិក្ខុនីទាំងឡាយដទៃ។ ភិក្ខុនីទាំងឡាយឯណាឃើញ ឯណាឮ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយនោះនិយាយហាមប្រាមថា នែលោកម្ចាស់ កាលបើភិក្ខុនីសង្ឃឲ្យចាលចាញ់ព្រោះអធិករណ៍នីមួយ ហើយខឹងអាក់អន់ចិត្ត កុំពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះថា លោកម្ចាស់ហ្នឹងឯង លុះដោយសេចក្តីស្រឡាញ់ខ្លះ។បេ។ លុះដោយសេចក្តីខ្លាចខ្លះ។ ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីនោះអស់វារៈពីរដងផង ត្រូវនិយាយនឹងភិក្ខុនីនោះអស់វារៈបីដងផង។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទាំងឡាយឯណាឮហើយ មិននិយាយ ភិក្ខុនីទាំងនោះត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទាំងឡាយត្រូវចាប់ទាញភិក្ខុនីនោះមកកាន់ទីកណ្តាលសង្ឃ ហើយនិយាយថា នែលោកម្ចាស់ បើភិក្ខុនីសង្ឃផ្ចាញ់ផ្ចាលព្រោះអធិករណ៍នីមួយ លោកខឹងអាក់អន់ចិត្តហើយ កុំពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផងដូច្នេះ ថា លោកម្ចាស់ហ្នឹងឯង លុះដោយសេចក្តីស្រឡាញ់ខ្លះ។បេ។ លុះដោយសេចក្តីខ្លាចខ្លះ ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីនោះអស់វារៈពីរដងផង ត្រូវនិយាយអស់វារៈបីដងផង។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។

[៧២] ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធី។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយត្រូវសូត្រសមនុភាសនវិធី យ៉ាងនេះ គឺភិក្ខុនីដែលឆ្លាសប្រតិពល ត្រូវផ្តៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះ ភិក្ខុនីសង្ឃបានផ្ចាញ់ព្រោះអធិករណ៍នីមួយ ហើយខឹងអាក់អន់ចិត្ត ពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ។ បើសង្ឃមានកាលគួរដល់ហើយ សង្ឃត្រូវសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនីនេះឈ្មោះនេះ ភិក្ខុនីសង្ឃបានផ្ចាញ់អធិករណ៍នីមួយ ខឹងអាក់អន់ចិត្ត ហើយពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្តីស្រឡាញ់ផង។បេ។ ភិក្ខុនីទាំងឡាយលុះដោយសេចក្តីខ្លាចផង។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះទេ។ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ ការសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង។ ខ្ញុំពោលសេចក្តីនេះអស់វារៈជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះអស់វារៈជាគំរប់បីដងផង។បេ។ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះហើយ។ ការសូត្រសមនុភាសនវិធីនោះគាប់ចិត្តដល់សង្ឃ ហេតុនោះ សង្ឃទើបស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៧៣] ភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រចប់កម្មវាចាស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ កាលបើភិក្ខុនីនោះត្រូវអាបត្តិសង្ឃាទិសេស អាបត្តិទុក្កដដែលត្រូវក្នុងខណៈចប់ញត្តិ(ក្តី) អាបត្តិថុល្លច្ច័យទាំងឡាយដែលត្រូវក្នុងខណៈចប់កម្មវាចាពីរលើក(ក្តី) រមែងរម្ងាប់ទៅ(ឯង)។

[៧៤] ត្រង់ពាក្យថា ភិក្ខុនីនេះក្តី គឺភិក្ខុនីនេះឯង ដែលតថាគតពោលប្រៀបផ្ទឹមនឹងភិក្ខុនីមុនៗដែលត្រូវអាបត្តិនោះដែរ។ ពាក្យថា ជាយាវតតិយក គឺភិក្ខុនីនោះត្រូវសង្ឃាទិសេសក្នុងខណៈដែលសូត្រសមនុភាសនវិធីកំណត់បីដង មិនត្រូវព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុទេ។ ពាក្យថា គួរបណ្តេញចេញចាកសង្ឃ គឺភិក្ខុនីទាំងឡាយឲ្យភិក្ខុនីនោះចៀសចេញពីសង្ឃ។ ពាក្យថា សង្ឃាទិសេស មានសេចក្តីដូចគ្នានឹងបឋមសង្ឃាទិសេសខាងដើម។

[៧៥] កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសំគាល់ថា កម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវ អាបត្តិ ទុក្កដ។

[៧៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុនី(ដែលសង្ឃ)មិនបានសូត្រសមនុភាសនវិធី១ ភិក្ខុនីដែលលះបង់១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## សង្ឃាទិសេស ទី៩

CS vin.vbi.sg.09 | ភាគ ទី៥

### (៩. នវមសង្ឃាទិសេសសិក្ខាបទំ)

[៧៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកភិក្ខុនីជាអន្តេវាសិនី[12)] របស់ថុល្លនន្ទាភិក្ខុនីនៅច្រឡូកច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសភិក្ខុនីផងគ្នា។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងនោះ ពោលទោស តិះដៀលបន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជា

អ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីផងគ្នាសោះ។បេ។ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីផងគ្នា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនគួរបើនឹងនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីផងគ្នាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជន ដែលមិនទាន់ជ្រះថ្លាហើយទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ចំណែកភិក្ខុនីទាំងឡាយនៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីផងគ្នា។ ភិក្ខុនីទាំងឡាយនោះ គួរភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ នៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្វាត់(ចាកពួក) សង្ឃតែងសរសើរសេចក្តីស្វាត់ (ចាកពួក) របស់បងប្អូនស្រ្តីទាំងឡាយ។ ភិក្ខុនីទាំងឡាយនោះ កាលភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះហើយ ក៏នៅប្រកាន់យ៉ាងនោះដដែល ភិក្ខុនីទាំងឡាយនោះ គួរភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីជាគំរប់បីដង ដើម្បីឲ្យលះបង់នូវវត្ថុនោះ។ បើភិក្ខុនីទាំងឡាយនោះ កាលភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីជាគំរប់បីដង លះបង់វត្ថុនោះបាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីទាំងឡាយនេះក្តី ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយក គួរបណ្តេញចេញ។**

[៧៨] ត្រង់ពាក្យថា ចំណែកភិក្ខុនីទាំងឡាយ គឺសំដៅយកស្រ្តីដែលបានឧបសម្បទាហើយ។ ពាក្យថា នៅច្រឡំដោយគ្រសហ្ថ គឺនៅច្រឡំដោយកាយកម្ម វចីកម្ម (របស់គ្រហស្ថ) ដែលមិនសមគួរ (ដល់បព្វជិត)។ ពាក្យថា មានមារយាទអាក្រក់ គឺប្រកបដោយមារយាទអាក្រក់។ ពាក្យថា មានកិត្តិសព្ទអាក្រក់ គឺល្បីឮដោយកិត្តិសព្ទអាក្រក់។ ពាក្យថា មានការចិញ្ចឹមជីវិតអាក្រក់ គឺសម្រេចជីវិតដោយមិច្ឆាជីវដ៏អាក្រក់។ ពាក្យថា បៀតបៀនភិក្ខុនីសង្ឃ គឺរាំងរាកម្មដែលភិក្ខុនីផងគ្នាធ្វើ។ ពាក្យថា បិទបាំងទោសរបស់ភិក្ខុនីផងគ្នា គឺបិទបាំងទោសគ្នីគ្នា។

[៧៩] ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយនោះ គឺភិក្ខុនីដែលច្រឡំ(ដោយគ្រហស្ថ)នោះឯង។ ពាក្យថា ដែលភិក្ខុនីទាំងឡាយ គឺដែលភិក្ខុនីទាំងឡាយដទៃ។ ភិក្ខុនីទាំងឡាយណាបានឃើញ បានឮ ភិក្ខុនីទាំងឡាយនោះគួរនិយាយហាមប្រាមថា បងប្អូនស្រ្តីទាំងឡាយនៅច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្វាត់(ចាកពួក) សង្ឃតែងសរសើរសេចក្តីស្វាត់ (ចាកពួក) របស់ភិក្ខុនីជាបងប្អូនស្រ្តីទាំងឡាយ។ ភិក្ខុនីទាំងឡាយគួរនិយាយនឹងភិក្ខុនីទាំងឡាយនោះអស់វារៈជាគំរប់ពីរដងផង គួរនិយាយអស់វារៈជាគំរប់បីដងផង។ បើភិក្ខុនីទាំងឡាយនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទាំងឡាយដទៃឮហើយ មិននិយាយ ត្រូវអាបត្តិទុក្កដ។ ត្រូវភិក្ខុនីទាំងឡាយចាប់ទាញភិក្ខុនីទាំងឡាយនោះមកកាន់ទីកណ្តាលសង្ឃ ហើយពោលថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយនៅច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីផងគ្នា បពិត្រលោកម្ចាស់ សូមលោកទាំងឡាយស្វាត់(ចាកពួក) សង្ឃតែងសរសើរសេចក្តីស្វាត់របស់ភិក្ខុនីជាបងប្អូនស្រ្តីទាំងឡាយ។ ភិក្ខុនីទាំងឡាយគួរនិយាយនឹងភិក្ខុនីទាំងឡាយនោះអស់វារៈជាគំរប់ពីរដងផង គួរនិយាយអស់វារៈជាគំរប់បីដងផង។ បើភិក្ខុនីទាំងឡាយនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។

[៨០] គប្បីភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយគប្បីសូត្រសមនុភាសនវិធី យ៉ាងនេះ គឺភិក្ខុនីដែលឆ្លាសប្រតិពល ត្រូវប្រកាសឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីទាំងឡាយឈ្មោះនេះផងៗ នៅច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីផងគ្នា។ ភិក្ខុនីទាំងឡាយនោះមិនលះបង់វត្ថុនោះឡើយ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយឈ្មោះនេះផងៗ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីទាំងឡាយឈ្មោះនេះផងៗ នៅច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីផងគ្នា។ ភិក្ខុនីទាំងឡាយនោះមិនលះបង់វត្ថុនោះឡើយ។ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយឈ្មោះនេះផងៗ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ ការសូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយឈ្មោះនេះផងៗ ដើម្បីឲ្យលះបង់វត្ថុនោះចេញ គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈជាគំរប់ពីរដងផង។បេ។ ខ្ញុំសូត្រសេចក្តីនេះ អស់វារៈជាគំរប់បីដងផង។បេ។ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីទាំងឡាយឈ្មោះនេះផងៗ ដើម្បីឲ្យលះបង់វត្ថុនោះហើយ។ ការសូត្រសមនុភាសនវិធីនោះ គាប់ចិត្តដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុករឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ។

[៨១] ភិក្ខុនីទាំងឡាយ ត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរដង ត្រូវអាបត្តិសង្ឃាទិសេស ក្នុងខណៈចប់កម្មវាចាស្រេច។ កាលបើភិក្ខុនីទាំងឡាយ ត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលត្រូវក្នុងខណៈចប់ញត្តិ(ក្តី) អាបត្តិថុល្លច្ច័យទាំងឡាយដែលត្រូវក្នុងខណៈចប់កម្មវាចាពីរដង(ក្តី) ក៏រម្ងាប់ទៅឯង។ ភិក្ខុនីទាំងឡាយគប្បីសូត្រសមនុភាសនវិធីចំពោះភិក្ខុនីពីរបីរូបជាមួយគ្នាបាន មិនត្រូវសូត្រសមនុភាសនវិធីឲ្យលើសអំពីពីរបីរូបនោះឡើយ។

[៨២] ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយនេះក្តី គឺភិក្ខុនីទាំងឡាយ ដែលតថាគតពោលប្រៀបធៀបនឹងភិក្ខុនីទាំងឡាយមុនៗ។ ពាក្យថា ឈ្មោះយាវតតិយក សេចក្តីថា ភិក្ខុនីទាំងឡាយនោះត្រូវអាបត្តិ(សង្ឃាទិសេស)ដោយសូត្រសមនុភាសនវិធីដរាបដល់គំរប់បីដង មិនមែនត្រូវព្រមគ្នានឹងប្រព្រឹត្តកន្លងវត្ថុទេ។ ពាក្យថា គួរបណ្តេញចេញ គឺភិក្ខុនីទាំងឡាយ គួរនាំភិក្ខុនីដែលត្រូវអាបត្តិសង្ឃាទិសេសនោះចេញអំពីសង្ឃ។ ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយក្នុង សង្ឃាទិសេសទី១រួចហើយ។

[៨៣] កម្មប្រកបដោយធម៌ ភិក្ខុនីទាំងឡាយសំគាល់ថា កម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ កម្មប្រកបដោយធម៌ ភិក្ខុនីទាំងឡាយមានសេចក្តីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេ។ កម្មប្រកបដោយធម៌ ភិក្ខុនីទាំងឡាយសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីទាំងឡាយសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីទាំងឡាយសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៨៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺ ភិក្ខុនីទាំងឡាយដែលភិក្ខុនីសង្ឃមិនបានសូត្រសមនុភាសនវិធី១ ភិក្ខុនីទាំងឡាយលះបង់ចេញ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីមានចិត្តរវើរវាយ១ ភិក្ខុនីដែលវេទនាគ្របសង្កត់១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## សង្ឃាទិសេស ទី១០

CS vin.vbi.sg.10 | ភាគ ទី៥

### (១០. ទសមសង្ឃាទិសេសសិក្ខាបទំ)

[៨៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ ក៏សម័យនោះឯង ចុល្លនន្ទាភិក្ខុនីពោលពាក្យយ៉ាងនេះនឹងភិក្ខុនីទាំងឡាយ ដែលសង្ឃសូត្រសមនុភាសនវិធីហើយថា នែលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយដទៃដែលមានមារយាទយ៉ាងនេះ មានកិត្តិសព្ទយ៉ាងនេះ ចិញ្ចឹមជីវិតយ៉ាងនេះ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ សង្ឃមិនបានពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ ដោយពេបជ្រាយ ដោយគ្មានអំណត់ (ក្រោធ) ដោយសំដីបង្អប ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង ជាអ្នកច្រឡូកច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា បពិត្រលោកម្ចាស់ សូមលោកទាំងឡាយស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ចុល្លនន្ទា មិនសមបើនឹងពោលយ៉ាងនេះ នឹងភិក្ខុនីទាំងឡាយដែលសង្ឃសូត្រសមនុភាសនវិធីហើយថា នែលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ។បេ។ នែលោកម្ចាស់ទាំងឡាយ ចូរលោកទាំងឡាយស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចុល្លនន្ទាភិក្ខុនីនិយាយយ៉ាងនេះនឹងភិក្ខុនីទាំងឡាយ ដែលសង្ឃសូត្រសមនុភាសនវិធីហើយថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ។បេ។ បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចុល្លនន្ទាភិក្ខុនីមិនគួរបើនឹងពោលយ៉ាងនេះនឹងភិក្ខុនីទាំងឡាយដែលសង្ឃសូត្រសមនុភាសនវិធីហើយថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ។បេ។ បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយរូបដទៃដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការចិញ្ចឹមជីវិតដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ សង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ ដោយពេបជ្រាយ ដោយគ្មានអំណត់ ដោយសំដីបង្អប ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង ជាអ្នកនៅច្រឡូកច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។ ភិក្ខុនីនោះ គប្បីភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ ចូរលោកកុំនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយដទៃ ដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការចិញ្ចឹមជីវិតដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ សង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ ដោយពេបជ្រាយ ដោយគ្មានអំណត់ ដោយសំដីបង្អប ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង ជាអ្នកនៅច្រឡូកច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់**

**មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។ ភិក្ខុនីនោះ កាលដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ ក៏នៅតែប្រកាន់ដដែល ភិក្ខុនីនោះ គប្បីភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធី ដើម្បីឲ្យលះបង់នូវវត្ថុនោះដរាបដល់គំរប់បីដង។ បើភិក្ខុនីនោះ កាលដែលភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធីដរាបដល់គំរប់បីដង លះបង់វត្ថុនោះបាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីនេះក្តី (ក៏) ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយក គួរបណ្តេញចេញ។**

[៨៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ។ ពាក្យថា ពោលយ៉ាងនេះ គឺពោលថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំចុះ លោកទាំងឡាយកុំនៅផ្សេងៗគ្នាឡើយ(ព្រោះ) ភិក្ខុនីទាំងឡាយសូម្បីរូបដទៃដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការចិញ្ចឹមជីវិតដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ (តែ)សង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ គឺដោយសេចក្តីមាក់ងាយ។ ពាក្យថា ដោយសេចក្តីពេបជ្រាយ គឺដោយសេចក្តីស្អប់ខ្ពើម។ ពាក្យថា ដោយគ្មានអំណត់ គឺដោយសេចក្តីខឹង។ ពាក្យថា ដោយសំដីបង្អប គឺដោយធ្វើសំដីឲ្យវិសេសជាង។ ពាក្យថា ដោយលោកទាំងឡាយមានកំឡាំងថយ គឺដោយលោកទាំងឡាយគ្មានបក្ខពួក។ ចុល្លនន្ទាភិក្ខុនីពោលយ៉ាងនេះថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង ជាអ្នកនៅច្រឡូកច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។ ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីឯណាដែលពោលជាប្រក្រតីយ៉ាងនេះនោះឯង។ ពាក្យថា ដែលភិក្ខុនីទាំងឡាយ គឺដែលភិក្ខុនីទាំងឡាយដទៃ។ ភិក្ខុនីទាំងឡាយឯណាឃើញ ឯណាឮ ភិក្ខុនីទាំងឡាយនោះគប្បីនិយាយនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ ចូរលោកកុំនិយាយពាក្យយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំ(ដោយគ្រហស្ថ)ចុះ កុំនៅបែកខ្ញែកគ្នាឡើយ។បេ។ បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។ ភិក្ខុនីនោះ គឺភិក្ខុនីទាំងឡាយពោលអស់វារៈគំរប់ពីរដងផង គប្បីពោលអស់វារៈគំរប់បីដងផង។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទាំងឡាយដទៃឮហើយ មិននិយាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះ គួរភិក្ខុនីទាំងឡាយនាំយកមកកាន់ទីកណ្តាលសង្ឃ ហើយពោលថា បពិត្រលោកម្ចាស់ លោកចូរកុំពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំ(ដោយគ្រហស្ថ)ចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ។បេ។ បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។ ភិក្ខុនីនោះ គួរភិក្ខុនីទាំងឡាយនិយាយអស់វារៈគំរប់ពីរដងផង គួរនិយាយអស់វារៈគំរប់បីដងផង។ បើភិក្ខុនីនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ។

[៨៧] ភិក្ខុនីនោះ គួរភិក្ខុនីទាំងឡាយសូត្រសមនុភាសនវិធី។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះ គួរភិក្ខុនីទាំងឡាយគប្បីសូត្រសមនុភាសនវិធីយ៉ាងនេះ គឺភិក្ខុនីដែលឈ្លាសប្រតិពល គប្បីផ្តៀងសង្ឃឲ្យដឹងថា បពិត្រសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះ ពោលយ៉ាងនេះនឹងភិក្ខុនីដែលសង្ឃសូត្រសមនុភាសនវិធីហើយថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយដទៃដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការចិញ្ចឹមជីវិតដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ តែសង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ ដោយសេចក្តីពេបជ្រាយ ដោយគ្មានអំណត់ ដោយសំដីបង្អប ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង នៅច្រឡូកច្រឡំ(ដោយគ្រហស្ថ)។បេ។ បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះចេញ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ នេះជាញត្តិ។ បពិត្រសង្ឃជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះឈ្មោះនេះពោលយ៉ាងនេះ នឹងភិក្ខុនីទាំងឡាយដែលសង្ឃសូត្រសមនុភាសនវិធីហើយថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំ(ដោយគ្រហស្ថ)ចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយដទៃដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការចិញ្ចឹមជីវិតដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ តែសង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះតែនឹងលោកទាំងឡាយដោយសេចក្តីមើលងាយ ដោយពេបជ្រាយ ដោយមិនអត់ឱនគ្នា ដោយសំដីបង្អប ដោយលោកទាំងឡាយមានកំឡាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង នៅច្រឡូកច្រឡំ(ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ។ ភិក្ខុនីនោះមិនលះបង់វត្ថុនោះចេញទេ។ សង្ឃសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញ។ ការសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈគំរប់ពីរដងផង។បេ។ ខ្ញុំសូត្រសេចក្តីនេះ អស់វារៈគំរប់បីដងផង។បេ។ សង្ឃបានសូត្រសមនុភាសនវិធីចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះចេញហើយ។ ការសូត្រសមនុភាសនវិធីនោះសមគួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៨៨] ភិក្ខុនីនោះ ត្រូវទុក្កដដោយសូត្រញត្តិ ត្រូវថុល្លច្ច័យទាំងឡាយ ដោយសូត្រកម្មវាចាពីរលើក ចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស។ កាលភិក្ខុនីត្រូវអាបត្តិសង្ឃាទិសេស អាបត្តិទុក្កដត្រូវដោយសូត្រញត្តិ និងអាបត្តិថុល្លច្ច័យទាំងឡាយដែលត្រូវដោយសូត្រកម្មវាចាពីរលើក តែងរម្ងាប់ទៅឯង។

[៨៩] ត្រង់ពាក្យថា ភិក្ខុនីនេះក្តី គឺភិក្ខុនីនេះឯង ដែលតថាគតពោលប្រៀបផ្ទឹមនូវភិក្ខុនីទាំងឡាយមុនៗ។ ពាក្យថា ឈ្មោះយាវតតិយក គឺភិក្ខុនីត្រូវ(សង្ឃាទិសេស) ដោយការសូត្រសមនុភាសនដរាបអស់វារៈគំរប់បីដង មិនមែនត្រូវមួយអន្លើដោយសេចក្តីប្រព្រឹត្តិកន្លងវត្ថុទេ។ ពាក្យថា គួរបណ្តេញចេញ គឺភិក្ខុនីទាំងឡាយ គួរនាំភិក្ខុនីនោះចេញអំពីសង្ឃ។ ពាក្យថា សង្ឃាទិសេស គឺទាល់តែសង្ឃឲ្យមានត្តដើម្បីអាបត្តិនោះ ទាញត្រឡប់អន្តរាបត្តិមកដាក់ក្នុងមូលាបត្តិបាន រួចឲ្យអព្ភានកម្ម ភិក្ខុនីច្រើនរូបឲ្យមិនបាន ភិក្ខុនីមួយរូបក៏ឲ្យមិនបាន ហេតុនោះ បានជាអាបត្តិនិកាយនោះ តថាគតឲ្យឈ្មោះថា សង្ឃាទិសេស។ ពាក្យថា អាបត្តិសង្ឃាទិសេស ជានាមកម្ម គឺថាជាឈ្មោះនៃអាបត្តិនិកាយនោះឯង ព្រោះហេតុនោះ អាបត្តិនិកាយនោះ តថាគតហៅថា សង្ឃាទិសេស។

[៩០] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៩១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ (សង្ឃ)មិនបានសូត្រសមនុភាសនវិធី១ ភិក្ខុនីបានលះបង់១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១[13)] ។

[៩២] បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិសង្ឃាទិសេសទាំង១៧ ខ្ញុំសំដែងឡើងហើយ អាបត្តិ៩ ឈ្មោះបឋមាបត្តិកា អាបត្តិ៨ ឈ្មោះយាវតតិយកា បណ្តាអាបត្តិទាំង១៧នេះ ភិក្ខុនីអង្គណាត្រូវអាបត្តិណាៗ ភិក្ខុនីអង្គនោះត្រូវប្រព្រឹត្តបក្ខមានត្តក្នុងឧភតោសង្ឃ ភិក្ខុនីដែលប្រព្រឹត្តមានត្តហើយ បើភិក្ខុនីសង្ឃពួក២០រូបមានក្នុងទីណា ភិក្ខុនីសង្ឃត្រូវឲ្យអព្ភានកម្មចំពោះភិក្ខុនីនោះ ក្នុងទីនោះ បើភិក្ខុនីសង្ឃពួក២០រូប ខ្វះសូម្បីតែភិក្ខុនី១រូប ឲ្យអព្ភានកម្មចំពោះភិក្ខុនីនោះ ភិក្ខុនីនោះឈ្មោះថា ភិក្ខុនីសង្ឃមិនឲ្យអព្ភានកម្មផង ភិក្ខុនីទាំងឡាយនោះឈ្មោះថា ត្រូវព្រះដ៏មានព្រះភាគតិះដៀលផង។ នេះជាសាមីចិកម្មក្នុងរឿងនោះ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយ ក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងអាបត្តិទាំងនេះ ហេតុនោះទើបលោកម្ចាស់ទាំងឡាយស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

សង្ឃាទិសេសកណ្ឌ១៧សិក្ខាបទ ចប់។

# និស្សគ្គិយកណ្ឌ (ភិក្ខុនីវិភង្គ)

CS vin.vbi.ni | ភាគ ទី៥

**(៣. និស្សគ្គិយកណ្ឌំ (ភិក្ខុនីវិភង្គោ))**

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះនិស្សគ្គិយបាចិត្តិយមានចំនួន៣០នេះឯង តែងមកកាន់ឧទ្ទេស។

## (និស្សគ្គិយ) បត្តវគ្គ (ទី១)

CS vin.vbi.ni.v1 | ភាគ ទី៥

**(១. បត្តវគ្គោ)**

### (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី១

CS vin.vbi.ni.01 | ភាគ ទី៥

**(១. បឋមសិក្ខាបទំ)**

[៩៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយមានពួក៦ ធ្វើនូវសេចក្តីសន្សំបាត្រជាច្រើន។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ បានឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីក៏ភិក្ខុនីទាំងឡាយធ្វើនូវសេចក្តីសន្សំបាត្រទុកច្រើនម្ល៉េះ ឬភិក្ខុនីទាំងឡាយនឹងធ្វើជំនួញបាត្រ ឬនឹងដាក់រានផ្សារលក់ភាជន៍ដី។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមានពួក៦ មិនសមបើនឹងធ្វើសេចក្តីសន្សំបាត្រទុកសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមានពួក៦ ធ្វើនូវសេចក្តីសន្សំបាត្រទុក ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមានពួក៦ មិនគួរបើនឹងធ្វើសេចក្តីសន្សំបាត្រទុកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយធ្វើសេចក្តីសន្សំបាត្រ ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[៩៤] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ បាត្រ២យ៉ាង គឺបាត្រដែក១ បាត្រដី១ ឈ្មោះថាបាត្រ។ ប្រមាណរបស់បាត្រមាន៣យ៉ាង គឺបាត្រខ្នាតធំ១ បាត្រខ្នាតកណ្តាល១ បាត្រខ្នាតតូច១។ ដែលហៅថា បាត្រខ្នាតធំ គឺបាត្រចំណុះបាយនៃអង្ករកន្លះអាឡ្ហក និងបង្អែមភាគទី៤ និងម្ហូបសមគួរនឹងបាយនោះ។ ដែលហៅថា បាត្រខ្នាតកណ្តាល គឺបាត្រចំណុះបាយនៃអង្ករ១នាឡិ និងបង្អែមភាគទី៤ និងម្ហូបសមគួរដល់បាយនោះ។ ដែលហៅថា បាត្រខ្នាតតូច គឺបាត្រចំណុះបាយនៃអង្ករ១បត្ថ និងបង្អែមភាគទី៤ និងម្ហូបសមគួរដល់បាយនោះ។ បាត្រដែលមានខ្នាតធំ ឬតូចជាងកំណត់ដែលពោលហើយនោះ មិនហៅថាបាត្រ។ ពាក្យថា ធ្វើសេចក្តីសន្សំ (បាត្រ) គឺបានដល់បាត្រ(ឯទៀតៗ) ដែលភិក្ខុនីមិនបានអធិដ្ឋាន មិនបានវិកប្ប។ បាត្រនោះជានិស្សគ្គិយ គឺជានិស្សគ្គិយព្រមគ្នានឹងអរុណរះឡើង បាត្រនោះ ភិក្ខុនីត្រូវលះដល់សង្ឃក៏បាន គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ បាត្រនោះភិក្ខុនីត្រូវលះយ៉ាងនេះ។

[៩៥] ភិក្ខុនីនោះត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងភិក្ខុនីចាស់ៗ អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ បាត្ររបស់ខ្ញុំនេះកន្លងរាត្រីហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបាត្រនេះដល់សង្ឃ។ លុះភិក្ខុនីនោះលះរួចហើយ ត្រូវសំដែងអាបត្តិចេញ។ ភិក្ខុនីដែលឆ្លាស ប្រតិពល គប្បីទទួលអាបត្តិ។ ភិក្ខុនីសង្ឃត្រូវឲ្យបាត្រដែលភិក្ខុនីលះហើយនោះវិញ ដោយពាក្យថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ បាត្រនេះជានិស្សគ្គិយ ភិក្ខុនីឈ្មោះនេះបានលះដល់សង្ឃហើយ។ បើការលះបង់នេះសមគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យបាត្រនេះដល់ភិក្ខុនីឈ្មោះនេះវិញ។

[៩៦] ភិក្ខុនីនោះត្រូវចូលទៅរកភិក្ខុនីទាំងឡាយច្រើនរូប (២-៣រូប) ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងភិក្ខុនីចាស់ៗ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ បាត្ររបស់ខ្ញុំនេះកន្លងរាត្រីហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបាត្រនេះដល់លោកម្ចាស់ទាំងឡាយ។ លុះភិក្ខុនីនោះលះបាត្រហើយ ត្រូវសំដែងអាបត្តិចេញ។ ភិក្ខុនីដែលឆ្លាស ប្រតិពល គប្បីទទួលអាបត្តិ។ ភិក្ខុនីទាំងឡាយត្រូវឲ្យបាត្រដែលភិក្ខុនីនោះលះហើយ ដោយពាក្យថា សូមលោកម្ចាស់ទាំងឡាយស្តាប់ខ្ញុំ បាត្រនេះរបស់ភិក្ខុនីឈ្មោះនេះ ជានិស្សគ្គិយ បានលះដល់លោកម្ចាស់ទាំងឡាយហើយ។ បើការលះបង់នេះសមគួរដល់លោកម្ចាស់ទាំងឡាយហើយ លោកម្ចាស់ទាំងឡាយត្រូវឲ្យបាត្រនេះដល់ភិក្ខុនីឈ្មោះនេះវិញ។

[៩៧] ភិក្ខុនីនោះត្រូវចូលទៅរកភិក្ខុនី១រូប ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ បាត្ររបស់ខ្ញុំនេះកន្លងរាត្រីហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបាត្រនេះដល់លោកម្ចាស់។ លុះភិក្ខុនីនោះលះរួចហើយ ត្រូវសំដែងអាបត្តិចេញ។ ភិក្ខុនី១រូបនោះ គប្បីទទួលអាបត្តិ។ ភិក្ខុនី១រូបត្រូវឲ្យបាត្រដែលភិក្ខុនីនោះលះហើយ ដោយពាក្យថា ខ្ញុំឲ្យបាត្រនេះដល់លោកម្ចាស់វិញ។

[៩៨] បាត្រកន្លងរាត្រីហើយ ភិក្ខុនីសំគាល់ថាកន្លងហើយ ត្រូវនិស្សគ្គិយបាចិត្តិយ។ បាត្រកន្លងរាត្រីហើយ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវនិស្សគ្គិយបាចិត្តិយ។ បាត្រកន្លងរាត្រីហើយ ភិក្ខុនីសំគាល់ថាមិនទាន់កន្លងទេ ត្រូវនិស្សគ្គិយបាចិត្តិយ។ បាត្រមិនបានអធិដ្ឋានទេ ភិក្ខុនីសំគាល់ថាអធិដ្ឋានហើយ ត្រូវនិស្សគ្គិយបាចិត្តិយ។ បាត្រមិនបានវិកប្បទេ ភិក្ខុនីសំគាល់ថាវិកប្បហើយ ត្រូវនិស្សគ្គិយបាចិត្តិយ។ បាត្រមិនបានលះទេ ភិក្ខុនីសំគាល់ថាលះហើយ ត្រូវនិស្សគ្គិយបាចិត្តិយ។ បាត្រមិនបានខូចទេ ភិក្ខុនីសំគាល់ថាបាត្រខូចហើយ បាត្រមិនបានវិនាសទេ ភិក្ខុនីសំគាល់ថាវិនាសហើយ... បាត្រមិនបានបែកទេ ភិក្ខុនីសំគាល់ថាបែកហើយ... បាត្រចោរមិនបានដណ្តើមយកទេ ភិក្ខុនីសំគាល់ថាចោរដណ្តើមយកហើយ ត្រូវនិស្សគ្គិយបាចិត្តិយ។

[៩៩] ភិក្ខុនីមិនលះបាត្រដែលជានិស្សគ្គិយ ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ បាត្រមិនបានកន្លងរាត្រីទេ ភិក្ខុនីសំគាល់ថាកន្លងហើយ ត្រូវអាបត្តិទុក្កដ។ បាត្រមិនបានកន្លងរាត្រីទេ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ បាត្រមិនបានកន្លងរាត្រីទេ ភិក្ខុនីសំគាល់ថាមិនកន្លងរាត្រីមែន មិនត្រូវអាបត្តិ។

[១០០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១០យ៉ាង) គឺ ភិក្ខុនីអធិដ្ឋានក្នុងអរុណ១ វិកប្បទុកក្នុងអរុណ១ លះបង់ (បាត្រនោះ) ខាងក្នុងអរុណ១ បាត្រខូចខាងក្នុងអរុណ១ វិនាសខាងក្នុងអរុណ១ បែកខាងក្នុងអរុណ១ ពួកចោរដណ្តើមយកខាងក្នុងអរុណ១ គេកាន់យកដោយវិស្សាសខាងក្នុងអរុណ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

[១០១] សម័យនោះឯង ភិក្ខុនីទាំងឡាយមានពួក៦ មិនឲ្យបាត្រដែលភិក្ខុនីដទៃលះបង់នោះវិញ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវមិនឲ្យបាត្រដែលភិក្ខុនីដទៃលះបង់ហើយនោះទេ ភិក្ខុនីឯណាមិនឲ្យ ភិក្ខុនីនោះត្រូវអាបត្តិទុក្កដ។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី២

CS vin.vbi.ni.02 | ភាគ ទី៥

### (២. ទុតិយសិក្ខាបទំ)

[១០២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ ក៏សម័យនោះឯង ភិក្ខុនីទាំងឡាយច្រើនរូបនៅចាំវស្សាក្នុងអាវាសដែលតាំងនៅស្រុកក្រៅ រួចហើយក៏ដើរទៅកាន់ក្រុងសាវត្ថី ជាអ្នកមានវត្តល្អ មានឥរិយាបថល្អ តែមានសំពត់អាក្រក់ មានចីវរសៅហ្មង។ ពួកឧបាសកឃើញភិក្ខុនីទាំងឡាយនោះហើយ ក៏គិតគ្នាថា ភិក្ខុនីទាំងឡាយនេះបរិបូណ៌ដោយវត្ត បរិបូណ៌

ដោយឥរិយាបថ តែមានសំពត់អាក្រក់ មានចីវរសៅហ្មង ភិក្ខុនីទាំងនេះ ប្រហែលជាចោរដណ្តើមយក(ចីវរ)ទេដឹង ហើយក៏បានថ្វាយអកាលចីវរដល់ភិក្ខុនីសង្ឃ។ ថុល្លនន្ទាភិក្ខុនីក៏អធិដ្ឋានថា ពួកយើងបានក្រាលកឋិនហើយ សំពត់នេះជាកាលចីវរ ហើយក៏ប្រើគ្នាឲ្យចែក (អកាលចីវរនោះ)។ ពួកឧបាសកបានឃើញភិក្ខុនីទាំងឡាយនោះហើយ បានពោលពាក្យនេះថា លោកម្ចាស់ទាំងឡាយបានចីវរហើយឬ។ ភិក្ខុនីទាំងឡាយនោះឆ្លើយថា នែអាវុសោ ពួកយើងមិនបានចីវរទេ ថុល្លនន្ទាជាម្ចាស់អធិដ្ឋានថា យើងបានក្រាលកឋិនហើយ (សំពត់នេះ) ជាកាលចីវរ ក៏ប្រើគ្នាឲ្យចែក (អកាលចីវរនោះ)។ ឧបាសកទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរដូច្នេះ ហើយប្រើគ្នាឲ្យចែក (អកាលចីវរនោះ)សោះ។ ភិក្ខុនីទាំងឡាយបានឮឧបាសកទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់មិនសមបើនឹងអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរ ហើយប្រើគ្នាឲ្យចែកសោះ។ ទើបភិក្ខុនីទាំងនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរ ហើយប្រើគ្នាឲ្យចែក ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងអធិដ្ឋានអកាលចីវរឲ្យជាកាលចីវរ ហើយប្រើគ្នាឲ្យចែកសោះ ម្នាលភិក្ខុទាំងឡាយ អំពើដែលថុល្លនន្ទាភិក្ខុនីធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ អធិដ្ឋានអកាលចីវរឲ្យជាកាលចីវរ ហើយប្រើគ្នាឲ្យចែក ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១០៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថាអកាលចីវរ គឺកាលបើភិក្ខុនីមិនបានក្រាលកឋិន ចីវរដែលកើតឡើងក្នុង១១ខែ (គិតតាំងពី១រោចខែកត្តិក ទៅដល់១៥កើតខែអស្សុជ) កាលបើភិក្ខុនីបានក្រាលកឋិន ចីវរដែលកើតឡើងក្នុង៧ខែ (គិតតាំងពី១រោចខែផល្គុន ទៅដល់១៥កើតខែអស្សុជ) ចីវរនេះ បើទុកជាទាយកប្រគេនចំពោះថាជាកាលចីវរ ក៏នៅតែហៅថា អកាលចីវរដដែល។ ភិក្ខុនីអធិដ្ឋានជាកាលចីវរហើយ ប្រើគ្នាឲ្យចែក ត្រូវអាបត្តិទុក្កដរាល់ប្រយោគ ចីវរនោះជានិស្សគ្គិយក្នុងពេលដែលបានមក ភិក្ខុនីត្រូវលះដល់សង្ឃក៏បាន គណៈក៏បាន ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ឯចីវរនោះត្រូវភិក្ខុនីលះយ៉ាងនេះ។បេ។ បពិត្រលោកជាម្ចាស់ ចីវរនេះជាអកាលចីវរ ខ្ញុំអធិដ្ឋានជាកាលចីវរហើយប្រើគ្នាឲ្យចែក ជានិស្សគ្គិយ (ត្រូវតែលះ) ខ្ញុំសូមលះចីវរនេះដល់សង្ឃ (ពាក្យតពីនេះទៅមានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះហើយ)។

[១០៤] អកាលចីវរ ភិក្ខុនីសំគាល់ថា អកាលចីវរ ហើយអធិដ្ឋានឲ្យជាកាលចីវរ ហើយប្រើគ្នាឲ្យចែក ត្រូវនិស្សគ្គិយបាចិត្តិយ។ អកាលចីវរ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយអធិដ្ឋានឲ្យជាកាលចីវរ ហើយប្រើគ្នាឲ្យចែក ត្រូវនិស្សគ្គិយបាចិត្តិយ។ អកាលចីវរ ភិក្ខុនីសំគាល់ថា កាលចីវរ ហើយអធិដ្ឋានឲ្យជាកាលចីវរ ហើយប្រើគ្នាឲ្យចែក ត្រូវនិស្សគ្គិយបាចិត្តិយ។ កាលចីវរ ភិក្ខុនីសំគាល់ថា អកាលចីវរ ត្រូវអាបត្តិទុក្កដ។ កាលចីវរ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កាលចីវរ ភិក្ខុនីសំគាល់ថា កាលចីវរ មិនត្រូវអាបត្តិ។

[១០៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ អកាលចីវរ ភិក្ខុនីសំគាល់ថាអកាលចីវរមែន ហើយប្រើគ្នាឲ្យចែក (អកាលចីវរនោះ)១ កាលចីវរ ភិក្ខុនីសំគាល់ថាកាលចីវរមែន ហើយប្រើគ្នាឲ្យចែក(កាលចីវរនោះ)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.ni.03 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[១០៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីប្តូរចីវរនឹងភិក្ខុនីមួយរូប ហើយប្រើប្រាស់ ទើបភិក្ខុនីនោះបត់ចីវរនោះហើយទុកដាក់ទៅ។ ថុល្លនន្ទាភិក្ខុនី បានពោលពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ ចីវរដែលលោកប្តូរនឹងខ្ញុំ ចីវរនោះនៅឯណា។ ឯភិក្ខុនីនោះយកចីវរនោះចេញមកបង្ហាញដល់ថុល្លនន្ទាភិក្ខុនី។ ថុល្លនន្ទាភិក្ខុនីបានពោលពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ លោកចូរយកចីវររបស់លោកទៅវិញចុះ លោកចូរឲ្យចីវរនុ៎ះមកខ្ញុំ ចីវរណារបស់លោក ចីវរនោះជារបស់លោកដដែល ចីវរណារបស់ខ្ញុំ ចីវរនោះជារបស់ខ្ញុំដដែលវិញ លោកចូរឲ្យចីវរនោះមកខ្ញុំ លោកចូរនាំយកចីវររបស់លោកទៅវិញចុះ ហើយក៏ដណ្តើមយកទៅ។ ទើបភិក្ខុនីនោះបានប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើមកប្តូរចីវរនឹងភិក្ខុនីផងគ្នា ហើយដណ្តើមយកទៅវិញសោះ។ ភិក្ខុនីទាំងឡាយនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយក្នុងកាលនោះឯង។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ប្តូរចីវរនឹងភិក្ខុនីផងគ្នា ហើយដណ្តើមយកទៅវិញ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើមកប្តូរចីវរនឹងភិក្ខុនីផងគ្នា ហើយដណ្តើមយកទៅវិញទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ប្តូរចីវរនឹងភិក្ខុនីផងគ្នា ហើយភិក្ខុនីនោះត្រឡប់ពោលយ៉ាងនេះក្នុងកាលជាខាងក្រោយថា បពិត្រលោកម្ចាស់ ណ្ហើយចុះ លោកចូរយកចីវររបស់លោកទៅវិញចុះ លោកចូរឲ្យចីវរនោះមកខ្ញុំវិញ ចីវរណារបស់លោក ចីវរនោះជា**

**របស់លោកដដែល ចីវរណារបស់ខ្ញុំ ចីវរនោះជារបស់ខ្ញុំដដែលវិញ លោកចូរឲ្យចីវរនោះមកខ្ញុំ លោកចូរនាំយកចីវររបស់លោកទៅវិញចុះ (ហើយ)ដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១០៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា នឹងភិក្ខុនីផងគ្នា គឺមួយអន្លើដោយភិក្ខុនីដទៃ។ ដែលហៅថា ចីវរ គឺចីវរ៦យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតដែលគួរវិកប្បបាន។ ពាក្យថាប្តូរ គឺប្តូរនូវចីវរថ្លៃច្រើនដោយចីវរថ្លៃតិចក្តី នូវចីវរថ្លៃតិចដោយចីវរថ្លៃច្រើនក្តី។ ពាក្យថាដណ្តើមយកឯង គឺភិក្ខុនីដណ្តើមខ្លួនឯង ចីវរនោះជានិស្សគ្គិយ។ ពាក្យថា ប្រើគេឲ្យដណ្តើមយក គឺភិក្ខុនីបង្គាប់អ្នកដទៃ ត្រូវអាបត្តិទុក្កដ ភិក្ខុនីបង្គាប់តែម្តង អ្នកទទួលបង្គាប់ដណ្តើមច្រើនដង ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះត្រូវលះដល់សង្ឃក៏បាន គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ចីវរនោះភិក្ខុនីត្រូវលះយ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ ចីវរនេះ ខ្ញុំប្តូរនឹងភិក្ខុនីផងគ្នា ហើយដណ្តើមយកមកវិញ ជានិស្សគ្គិយ (ត្រូវតែលះ) ខ្ញុំសូមលះចីវរនេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះហើយ)។

[១០៨] ឧបសម្បន្នា[14] ភិក្ខុនីសំគាល់ថា ឧបសម្បន្នា ប្តូរចីវរ ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ប្តូរចីវរ ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថា មិនមែនឧបសម្បន្នា ប្តូរចីវរ ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីប្តូរបរិក្ខារដទៃ ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីប្តូរចីវរក្តី បរិក្ខារដទៃក្តី នឹងអនុបសម្បន្នា ហើយដណ្តើមយកឯងក្តី ប្រើគេឲ្យដណ្តើមយកក្តី ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថា ឧបសម្បន្នា ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថា អនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។

[១០៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុនី (ដែលទទួលប្តូរ) នោះឲ្យវិញ១ ភិក្ខុនី(ជាអ្នកប្តូរ)ស្និទ្ធស្នាលនឹងភិក្ខុនី(ជាអ្នកទទួលប្តូរ)នោះ កាន់យកទៅ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.ni.04 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[១១០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីមានជម្ងឺ។ លំដាប់នោះ ឧបាសកម្នាក់ចូលទៅរកថុល្លនន្ទាភិក្ខុនីដែលនៅក្នុងទីនោះ លុះចូលទៅជិតហើយ បានពោលពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ សេចក្តីមិនសប្បាយកើតមានដល់លោកឬ លោកម្ចាស់ឲ្យខ្ញុំរករបស់អ្វីមក។ ថុល្លនន្ទាភិក្ខុនីនិយាយថា នែអាវុសោ អាត្មាត្រូវការដោយទឹកដោះរាវ។ ទើបឧបាសកនោះនាំយកទឹកដោះរាវមានដំឡៃ១កហាបណៈអំពីផ្ទះអ្នកផ្សារម្នាក់ ហើយបានប្រគេនដល់ថុល្លនន្ទាភិក្ខុនី។ ថុល្លនន្ទាភិក្ខុនីបាននិយាយយ៉ាងនេះថា នែអាវុសោ អាត្មាមិនត្រូវការដោយទឹកដោះរាវទេ អាត្មាត្រូវការដោយប្រេងវិញ។ ទើបឧបាសកនោះចូលទៅរកអ្នកផ្សារនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងអ្នកផ្សារនោះថា នែអ្នកម្ចាស់ ឮថាលោកម្ចាស់មិនត្រូវការដោយទឹកដោះរាវទេ ត្រូវការតែប្រេង អ្នកចូរយកទឹកដោះរាវរបស់អ្នកទៅវិញចុះ ចូរឲ្យប្រេងដល់ខ្ញុំវិញ។ អ្នកផ្សារឆ្លើយថា នែអ្នកម្ចាស់ បើយើងនឹងទទួលរបស់ដែលយើងលក់ទៅហើយយកមកវិញ កាលណាយើងនឹងលក់របស់ដាច់ អ្នកនាំយកទឹកដោះរាវទៅដោយដម្លៃទិញទឹកដោះរាវហើយ ចូរអ្នកនាំដម្លៃទិញប្រេងមក ទើបនឹងនាំយកប្រេងទៅបាន។ ឧបាសកនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងសុំរបស់ដទៃ ហើយសុំរបស់ឯទៀតសោះ។ ភិក្ខុនីទាំងឡាយបានឮឧបាសកនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងសុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញសោះ។ ទើបភិក្ខុនីទាំងឡាយនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី សុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងសុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ សុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញ ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១១១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា សុំរបស់ដទៃ គឺបានសុំរបស់ណាមួយរួចហើយ។ ពាក្យថា សុំរបស់ឯទៀតវិញ គឺភិក្ខុនីវៀរលែងរបស់ដែលសុំនោះ ហើយសុំរបស់ឯទៀតវិញ ត្រូវទុក្កដក្នុងប្រយោគសុំ របស់នោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះរបស់នោះដល់សង្ឃក៏បាន គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះយ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ របស់ដទៃនេះ ខ្ញុំសុំហើយ ខ្ញុំទៅសុំរបស់ឯទៀតវិញ ជានិស្សគ្គិយ ខ្ញុំសូមលះរបស់នេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះហើយ)។

[១១២] របស់ដទៃ ភិក្ខុនីសំគាល់ថា របស់ដទៃ ហើយសុំរបស់ដទៃថែមទៀត ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយសុំរបស់ដទៃថែមទៀត ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់ដទៃ ភិក្ខុនីសំគាល់ថា មិនមែនរបស់ដទៃ ហើយសុំរបស់ដទៃថែមទៀត ត្រូវ

និស្សគ្គិយបាចិត្តិយ។ មិនមែនរបស់ដទៃ ភិក្ខុនីសំគាល់ថា របស់ដទៃ ហើយសុំរបស់មិនមែនដទៃ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយសុំរបស់មិនមែនដទៃ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដទៃ ភិក្ខុនីសំគាល់ថា មិនមែនរបស់ដទៃ មិនត្រូវអាបត្តិ។

[១១៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ ភិក្ខុនី (សុំរបស់ណាមុនហើយ របស់នោះតិចពេក មិនល្មម) សុំរបស់នោះដដែល (ថែមទៀត)១ ភិក្ខុនី (សុំរបស់អ្វីម្យ៉ាងហើយ) សុំរបស់ដទៃ (ទៀតព្រោះត្រូវផ្សំថ្នាំខានមិនបាន)១ ភិក្ខុនីសំដែងអានិសង្សហើយសុំ (ពន្យល់របស់មួយ ថាថោកជាងរបស់មួយ ហើយសុំរបស់ថោកនោះ)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.ni.05 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[១១៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីមានជម្ងឺ។ ឧបាសកម្នាក់ចូលទៅរកថុល្លនន្ទាភិក្ខុនីក្នុងវេលានោះ លុះចូលទៅជិតហើយ បាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់អាចអត់ទ្រាំសេចក្តីទុក្ខបានឬទេ លោកម្ចាស់អាចញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានឬទេ។ ថុល្លនន្ទាភិក្ខុនីឆ្លើយថា នែអាវុសោ អាត្មាមិនអាចអត់ទ្រាំសេចក្តីទុក្ខបានទេ មិនអាចញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានទេ។ ឧបាសកនោះនិយាយថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទុកកហាបណៈក្នុងផ្ទះអ្នកផ្សារឯណោះ លោកត្រូវការរបស់ណា លោកគប្បីឲ្យបុគ្គលណាមួយទៅនាំយករបស់នោះអំពីផ្ទះនោះមកចុះ។ ថុល្លនន្ទាភិក្ខុនីបង្គាប់សិក្ខមានា១រូបថា នែសិក្ខមានា នាងចូរទៅនាំយកប្រេង១កហាបណៈអំពីផ្ទះអ្នកផ្សារឯណោះមក។ ទើបនាងសិក្ខមានានោះទៅនាំយកប្រេង១កហាបណៈអំពីផ្ទះអ្នកផ្សារនោះមកប្រគេនថុល្លនន្ទាភិក្ខុនី។ ថុល្លនន្ទាភិក្ខុនីបានពោលយ៉ាងនេះថា នែសិក្ខមានា យើងមិនត្រូវការនឹងប្រេងទេ យើងត្រូវការតែទឹកដោះរាវ។ ឯសិក្ខមានានោះ ចូលទៅរកអ្នកផ្សារនោះ លុះចូលទៅហើយ បានពោលពាក្យនេះនឹងអ្នកផ្សារនោះថា នែអាវុសោ ឮថាលោកម្ចាស់មិនត្រូវការនឹងប្រេងទេ ត្រូវការតែទឹកដោះរាវ ហ៏អ្នកចូរយកប្រេងរបស់អ្នកទៅចុះ ចូរឲ្យទឹកដោះរាវមកខ្ញុំវិញ។ អ្នកផ្សារនោះនិយាយថា បពិត្រលោកម្ចាស់ បើខ្ញុំករុណានឹងទទួលយករបស់ដែលលក់ទៅហើយមកវិញ កាលណាខ្ញុំករុណានឹងលក់របស់ដាច់ លោកនាំយកប្រេងតាមដំឡៃរបស់ប្រេងទៅ ហើយលោកចូរនាំយកដំឡៃទិញទឹកដោះរាវមក (ទៀត) ទើបលោកនាំយកទឹកដោះរាវទៅបាន។ សិក្ខមានានោះក៏ឈរយំ។ ភិក្ខុនីទាំងឡាយបានពោលពាក្យនេះនឹងសិក្ខមានានោះថា នែសិក្ខមានា ហេតុអ្វីក៏នាងយំ។ ទើបសិក្ខមានានោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងឲ្យគេទិញរបស់ដទៃ ហើយត្រឡប់ឲ្យគេទិញរបស់ឯទៀតសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឲ្យគេទិញរបស់ដទៃ ហើយត្រឡប់ឲ្យគេទិញរបស់ឯទៀតវិញ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងឲ្យគេទិញរបស់ដទៃហើយត្រឡប់ឲ្យគេទិញរបស់ឯទៀតសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យគេទិញរបស់ដទៃហើយ ត្រឡប់ឲ្យគេទិញរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១១៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ឲ្យគេទិញរបស់ដទៃហើយ គឺឲ្យគេទិញរបស់ណាមួយហើយ។ ពាក្យថា ត្រឡប់ឲ្យគេទិញរបស់ឯទៀតវិញ គឺភិក្ខុនីមិនឲ្យគេទិញរបស់នោះ ហើយឲ្យគេទិញរបស់ដទៃវិញ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យគេទិញ របស់នោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះរបស់នោះដល់សង្ឃក៏បាន គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះយ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ របស់ដទៃនេះ ខ្ញុំឲ្យគេទិញរួចហើយ ត្រឡប់ឲ្យគេទិញរបស់ដទៃវិញទៀត ជានិស្សគ្គិយ ខ្ញុំសូមលះរបស់នេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះហើយ)។

[១១៦] របស់ដទៃ ភិក្ខុនីសំគាល់ថារបស់ដទៃ ហើយឲ្យគេទិញរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យគេទិញរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់ដទៃ ភិក្ខុនីសំគាល់ថា មិនមែនរបស់ដទៃ ហើយឲ្យគេទិញរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ មិនមែនរបស់ដទៃ ភិក្ខុនីសំគាល់ថារបស់ដទៃ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដទៃ ភិក្ខុនីសំគាល់ថា មិនមែនរបស់ដទៃ មិនត្រូវអាបត្តិ។

[១១៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ ភិក្ខុនី (ឲ្យគេទិញរបស់ណាមុនហើយ របស់នោះតិចពេក មិនល្មម) ហើយឲ្យគេទិញរបស់នោះដដែល (ថែមទៀត)១ ភិក្ខុនី (ឲ្យគេទិញរបស់អ្វីម្យ៉ាងមុនហើយ) ឲ្យគេទិញរបស់មួយដទៃទៀត ដោយត្រូវការផ្សំថ្នាំជាដើម១ ភិក្ខុនីសំដែងអានិសង្សហើយឲ្យគេទិញ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.ni.06 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[១១៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ឧបាសកទាំងឡាយប្រមូលបរិក្ខារដែលរៃបានមក ដើម្បីប្រយោជន៍ចាត់ចែងចីវរដល់ភិក្ខុនីសង្ឃ ហើយផ្ញើទុកបរិក្ខារ(នោះ)ក្នុងផ្ទះអ្នកលក់សំពត់បាវារម្នាក់ ហើយចូលទៅរកភិក្ខុនីទាំងឡាយ រួចពោលពាក្យនេះថា បពិត្រលោកម្ចាស់ទាំងឡាយ យើងផ្ញើទុកបរិក្ខារប្រយោជន៍ដើម្បីចាត់ចែងចីវរក្នុងផ្ទះអ្នកលក់សំពត់បាវារឯណោះហើយ ចូរ លោកទាំងឡាយឲ្យគេនាំចីវរអំពីផ្ទះនោះមកចែកគ្នាចុះ។ ភិក្ខុនីទាំងឡាយឲ្យគេទិញភេសជ្ជៈខ្លួនឯង ដោយបរិក្ខារនោះ ហើយបរិភោគ។ ឧបាសកទាំងឡាយដឹងហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលទាយកប្រគេនដើម្បីប្រយោជន៍វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃជារបស់សង្ឃសោះ។ ភិក្ខុនីទាំងឡាយបានឮឧបាសកទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលទាយកប្រគេនដើម្បីប្រយោជន៍វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃ ជារបស់សង្ឃសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលទាយកប្រគេនដើម្បីប្រយោជន៍វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃ ជារបស់សង្ឃ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃជារបស់សង្ឃទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលទាយកប្រគេនដើម្បីប្រយោជន៍វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃ ជារបស់សង្ឃ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១១៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដោយបរិក្ខារដែលទាយកប្រគេនដើម្បីប្រយោជន៍វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃ គឺទាយកគេឲ្យដើម្បីវត្ថុដទៃ។ ពាក្យថា ជារបស់សង្ឃ គឺទាយកប្រគេនចំពោះតែសង្ឃ មិនចំពោះគណៈ មិនចំពោះភិក្ខុនី១រូបទេ។ ពាក្យថា ឲ្យគេទិញរបស់ដទៃ គឺរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុណា ហើយភិក្ខុនីវៀរលែងវត្ថុនោះ ឲ្យគេទិញរបស់ដទៃវិញ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យទិញ របស់នោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះរបស់នោះដល់សង្ឃក៏បាន គណៈក៏បាន ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះវត្ថុនោះយ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ វត្ថុដទៃនេះ ខ្ញុំឲ្យគេទិញដោយបរិក្ខារដែលទាយកគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ (របស់នេះ) ជានិស្សគ្គិយ ខ្ញុំសូមលះវត្ថុនេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះ)។

[១២០] របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃទេ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីនោះបានវត្ថុដែលខ្លួនលះនោះមកវិញ ហើយត្រូវបង្អោនទៅក្នុងវត្ថុដែលទាយកគេឲ្យចំពោះយ៉ាងណា។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាវត្ថុដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ មិនត្រូវអាបត្តិ។

[១២១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ (ទាយកប្រគេនដើម្បីវត្ថុណា) ភិក្ខុនី (ឲ្យគេទិញវត្ថុនោះហើយ) បង្អោនវត្ថុដែលសល់ (ពីនោះទៅដើម្បីវត្ថុឯទៀត)១ ភិក្ខុនីប្រាប់ម្ចាស់ទានហើយ ទើបបង្អោនទៅ១ ភិក្ខុនីឲ្យគេចាត់ចែងខុសបំណងទាយកក្នុងពេលដែលមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី៧

CS vin.vbi.ni.07 | ភាគ ទី៥

### (៧. សត្តមសិក្ខាបទំ)

[១២២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ឧបាសកទាំងឡាយប្រមូលបរិក្ខារដែលរៃបានមក ហើយផ្ញើទុកបរិក្ខារ(នោះ)ក្នុងផ្ទះអ្នកលក់សំពត់បាវារម្នាក់ ដើម្បីចាត់ចែងចីវរដល់ភិក្ខុនីសង្ឃ ហើយចូលទៅរកភិក្ខុនីទាំងឡាយ ពោលពាក្យនេះថា បពិត្រលោកម្ចាស់ យើងទាំងឡាយផ្ញើទុកបរិក្ខារដើម្បីចាត់ចែងចីវរក្នុងផ្ទះអ្នកលក់សំពត់បាវារឈ្មោះឯណោះហើយ លោកទាំងឡាយចូរឲ្យអ្នកណាមួយនាំចីវរអំពីផ្ទះនោះមកចែកគ្នាចុះ។ ភិក្ខុនីទាំងឡាយឲ្យគេទិញភេសជ្ជៈដោយបរិក្ខារនោះផង ដោយវត្ថុដែលសូមគេខ្លួនឯងផង ហើយក៏បរិភោគ។ ឧបាសកទាំងឡាយដឹងហើយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ និងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ។ ភិក្ខុនីទាំងឡាយបានឮឧបាសកទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ និងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ

និងដោយវត្ថុដែលសូមដោយខ្លួនឯង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ និងដោយវត្ថុដែលសូមដោយខ្លួនឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ ដោយវត្ថុដែលសូមដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១២៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ គឺដោយវត្ថុដែលទាយកឲ្យដើម្បីវត្ថុដទៃ។ ពាក្យថា ជារបស់សង្ឃ គឺទាយកបរិច្ចាគចំពោះតែសង្ឃ មិនមែនចំពោះគណៈ មិនមែនចំពោះភិក្ខុនី១រូបទេ។ ពាក្យថា ដោយវត្ថុដែលសូមដោយខ្លួនឯង គឺដោយវត្ថុដែលសូម (គេ) ដោយខ្លួនឯង។ ពាក្យថា ឲ្យគេទិញវត្ថុដទៃ គឺរបស់ដែលទាយកឲ្យដើម្បីចាត់ចែងវត្ថុឯណា ភិក្ខុនីវៀរលែងរបស់នោះ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវទុក្កដក្នុងប្រយោគដែលឲ្យទិញ វត្ថុនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវលះវត្ថុនោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះយ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ វត្ថុដទៃនេះ ខ្ញុំឲ្យគេទិញដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់សង្ឃ និងដោយវត្ថុដែលសូមដោយខ្លួនឯង (វត្ថុនេះ) ជានិស្សគ្គិយ (ត្រូវតែលះបង់) ខ្ញុំសូមលះវត្ថុនេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះ)។

[១២៤] របស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃមែន ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីនោះបានវត្ថុដែលលះដល់សង្ឃមកវិញហើយ ត្រូវបង្អោនទៅក្នុងវត្ថុដែលទាយកគេឲ្យចំពោះយ៉ាងណា។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ មិនត្រូវអាបត្តិ។

[១២៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីបង្អោនរបស់ដែលសល់ទៅ១ ភិក្ខុនីប្រាប់ម្ចាស់ទានហើយ ទើបបង្អោនទៅ១ ភិក្ខុនីឲ្យគេចាត់ចែងខុសបំណងទាយកក្នុងសម័យដែលមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី៨

CS vin.vbi.ni.08 | ភាគ ទី៥

### (៨. អដ្ឋមសិក្ខាបទំ)

[១២៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយជាអ្នកនៅក្នុងបរិវេណរបស់ប្រជុំជន១ពួក ជាពួកភិក្ខុនីលំបាកដោយបបរ។ គ្រានោះឯង ប្រជុំជននោះក៏ប្រមូលបរិក្ខារដែលរៃបានមក ហើយធ្វើទុកបរិក្ខារ(នោះ)ក្នុងផ្ទះអ្នកផ្សារម្នាក់ ដើម្បីចាត់ចែងបបរដល់ភិក្ខុនីទាំងឡាយ ទើបចូលទៅរកភិក្ខុនីទាំងឡាយ ហើយបានពោលពាក្យនេះថា បពិត្រលោកម្ចាស់ យើងទាំងឡាយទុកបរិក្ខារដើម្បីចាត់ចែងបបរក្នុងផ្ទះអ្នកផ្សារឈ្មោះឯណោះ ចូរលោកទាំងឡាយឲ្យអ្នកណាមួយនាំយកអង្ករទាំងឡាយអំពីផ្ទះនោះ ហើយឲ្យគេចំអិនបបរឆាន់ចុះ។ ភិក្ខុនីទាំងឡាយឲ្យគេទិញភេសជ្ជៈដោយបរិក្ខារនោះ ហើយក៏បរិភោគ។ ទើបប្រជុំជននោះដឹងហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈសោះ។ ភិក្ខុនីទាំងឡាយបានឮឧបាសក[15] នោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់គណៈទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១២៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃ គឺដោយបរិក្ខារដែលទាយកប្រគេនប្រយោជន៍ដើម្បីចាត់ចែងវត្ថុឯទៀត។ ពាក្យថា ជារបស់គណៈ (គឺទាយកលះចំពោះ) តែគណៈ មិនមែនលះចំពោះសង្ឃ មិនមែនលះចំពោះភិក្ខុនី១រូប។ ពាក្យថា ឲ្យគេទិញវត្ថុដទៃ គឺរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុណា ភិក្ខុនីមិនឲ្យទិញវត្ថុនោះ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យទិញ របស់នោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវតែលះរបស់នោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវតែលះរបស់នោះយ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ របស់ដទៃនេះ ខ្ញុំឲ្យគេទិញដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ ជានិស្សគ្គិយ ខ្ញុំសូមលះរបស់នេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះ)។

[១២៨] របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីបានវត្ថុដែលខ្លួនលះនោះមកវិញហើយ ត្រូវបង្អោនទៅក្នុងវត្ថុដែលគេឲ្យចំពោះយ៉ាងណា។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ មិនត្រូវអាបត្តិ។

[១២៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីបង្អោនទៅនូវរបស់ដែលសល់១ ភិក្ខុនីប្រាប់ម្ចាស់ទានហើយ ទើបបង្អោនទៅ១ ភិក្ខុនីឲ្យគេចាត់ចែងខុសបំណងទាយកក្នុងសម័យមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.ni.09 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[១៣០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយនៅក្នុងបរិវេណរបស់ប្រជុំជន១ពួក ជាពួកភិក្ខុនីលំបាកដោយបបរ។ គ្រានោះឯង ប្រជុំជននោះ ប្រមូលបរិក្ខារដែលរៃបានមក ដើម្បីចាត់ចែងបបរដល់ភិក្ខុនីទាំងឡាយ ហើយទុកបរិក្ខារ(នោះ)ក្នុងផ្ទះអ្នកផ្សារម្នាក់ ទើបចូលទៅរកភិក្ខុនីទាំងឡាយ ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ យើងទាំងឡាយទុកបរិក្ខារដើម្បីចាត់ចែងបបរក្នុងផ្ទះអ្នកផ្សារឈ្មោះឯណោះ ចូរលោកទាំងឡាយឲ្យគេនាំយកអង្ករទាំងឡាយអំពីផ្ទះនោះមក ហើយចំអិនបបរឆាន់ចុះ។ តែភិក្ខុនីទាំងឡាយឲ្យគេទិញភេសជ្ជៈដោយបរិក្ខារនោះផង ដោយរបស់ដែលសូមគេដោយខ្លួនឯងផង ហើយក៏បរិភោគ។ ឯប្រជុំជននោះដឹងហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ និងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ។ ភិក្ខុនីទាំងឡាយបានឮប្រជុំជននោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ និងដោយរបស់ដែលសូមដោយខ្លួនឯងសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយឲ្យគេទិញរបស់ដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ និងដោយវត្ថុដែលសូមដោយខ្លួនឯង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនគួរបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ និងដោយវត្ថុដែលសូមដោយខ្លួនឯងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ និងដោយវត្ថុដែលសូមដោយខ្លួនឯង ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១៣១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ គឺដោយបរិក្ខារដែលគេឲ្យ ដើម្បីចាត់ចែងវត្ថុឯទៀត។ ពាក្យថា ជារបស់គណៈ គឺគេលះចំពោះតែគណៈ មិនមែនចំពោះសង្ឃ មិនមែនចំពោះភិក្ខុនី១រូបទេ។ ពាក្យថា ដោយវត្ថុដែលសូមដោយខ្លួនឯង គឺវត្ថុដែលសូមគេបានមកហើយដោយខ្លួនឯង។ ពាក្យថា ឲ្យគេទិញវត្ថុដទៃ គឺរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុណា ភិក្ខុនីមិនឲ្យគេទិញវត្ថុនោះ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលឲ្យទិញ វត្ថុនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីត្រូវតែលះរបស់នោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះរបស់នោះយ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ វត្ថុដទៃនេះ ខ្ញុំឲ្យគេទិញដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ និងដោយវត្ថុដែលសូមបានមកដោយខ្លួនឯង ជានិស្សគ្គិយ ខ្ញុំសូមលះវត្ថុនេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះ)។

[១៣២] របស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃមែន ហើយឲ្យគេទិញវត្ថុដទៃ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយឲ្យទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់គេ

ឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីបានវត្ថុដែលខ្លួនលះនោះមកវិញហើយ ត្រូវបង្អោនទៅក្នុងវត្ថុដែលទាយកគេឲ្យចំពោះយ៉ាងណា។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ មិនត្រូវអាបត្តិ។

[១៣៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីបង្អោនទៅនូវរបស់ដែលសល់១ ភិក្ខុនីប្រាប់ម្ចាស់របស់ហើយ ទើបបង្អោនទៅ១ ភិក្ខុនីឲ្យគេចាត់ចែងខុសបំណងទាយកក្នុងពេលមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ បត្តវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.ni.10 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[១៣៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។ សម័យនោះឯង ថុល្លនន្ទាភិក្ខុនីជាពហុស្សូត ជាអ្នកឈ្លាសនិយាយក្លៀវក្លា ប្រសប់ធ្វើធម្មីកថា។ មនុស្សទាំងឡាយជាច្រើនតែចូលទៅអង្គុយជិត (សេពគប់)នឹងថុល្លនន្ទាភិក្ខុនី។ សម័យនោះឯង ទីបរិវេណរបស់ថុល្លនន្ទាភិក្ខុនីក៏បាក់បែកទ្រុឌទ្រោម។ មនុស្សទាំងឡាយបានពោលពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ ទីបរិវេណរបស់លោកនេះទ្រុឌទ្រោមទៅដោយហេតុអ្វី។ ថុល្លនន្ទាភិក្ខុនីនិយាយថា នែអ្នកដ៏មានអាយុ ព្រោះគ្មានពួកអ្នកឲ្យ គ្មានពួកអ្នកធ្វើ។ ទើបមនុស្សទាំងឡាយនោះ ប្រមូលបរិក្ខារដែលរៃបានមកដើម្បីប្រយោជន៍ទីបរិវេណនៃថុល្លនន្ទាភិក្ខុនី ហើយបានឲ្យបរិក្ខារនោះដល់ថុល្លនន្ទាភិក្ខុនី។ ថុល្លនន្ទាភិក្ខុនីឲ្យគេទិញភេសជ្ជៈដោយបរិក្ខារនោះផង ដោយរបស់ដែលសូមដោយខ្លួនឯងផង ហើយក៏បរិភោគ។ មនុស្សទាំងឡាយដឹងហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល និងដោយវត្ថុដែលសូមមកដោយខ្លួនឯងសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃចំពោះវត្ថុដទៃ ជារបស់បុគ្គល និងដោយវត្ថុដែលសូមដោយខ្លួនឯង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល នឹងដោយវត្ថុដែលសូមដោយខ្លួនឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល និងដោយវត្ថុដែលសូមដោយខ្លួនឯង ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១៣៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ គឺដោយបរិក្ខារដែលគេឲ្យ ដើម្បីចាត់ចែងវត្ថុឯទៀត។ ពាក្យថា ជារបស់បុគ្គល គឺគេឲ្យចំពោះតែភិក្ខុនីមួយរូប មិនឲ្យដល់សង្ឃ មិនឲ្យដល់គណៈឡើយ។ ពាក្យថា ដោយវត្ថុដែលសូមដោយខ្លួនឯង គឺវត្ថុដែលសូមគេមកដោយខ្លួនឯង។ ពាក្យថា ឲ្យគេទិញវត្ថុដទៃ គឺរបស់ដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុណា ភិក្ខុនីមិនឲ្យគេទិញវត្ថុនោះ ហើយឲ្យគេទិញវត្ថុឯទៀតវិញ ត្រូវទុក្កដក្នុងប្រយោគដែលឲ្យទិញ វត្ថុនោះជានិស្សគ្គិយក្នុងខណៈដែលបានមក ភិក្ខុនីគប្បីលះវត្ថុនោះដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះរបស់នោះយ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ វត្ថុដទៃនេះ ខ្ញុំឲ្យគេទិញដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល និងដោយវត្ថុដែលសូមដោយខ្លួនឯង ជានិស្សគ្គិយ ខ្ញុំសូមលះវត្ថុនេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌនេះ)។

[១៣៦] របស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ហើយឲ្យគេទិញវត្ថុឯទៀត ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ របស់គេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ហើយឲ្យគេទិញវត្ថុដទៃវិញ ត្រូវនិស្សគ្គិយបាចិត្តិយ។ ភិក្ខុនីបានវត្ថុដែលលះនោះមកវិញហើយ គប្បីបង្អោនទៅក្នុងវត្ថុដែលទាយកគេឲ្យចំពោះយ៉ាងណា។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថារបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ភិក្ខុនីសំគាល់ថាមិនមែនរបស់ដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ មិនត្រូវអាបត្តិ។

[១៣៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីបង្អោនទៅនូវរបស់ដែលសល់១ ភិក្ខុនីប្រាប់ម្ចាស់ទានហើយ ទើបបង្អោនទៅ១ ភិក្ខុនីឲ្យគេចាត់ចែងខុសបំណងទាយកព្រោះមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

# (និស្សគ្គិយ) ចីវរវគ្គ (ទី២)

CS vin.vbi.ni.v2 | ភាគ ទី៥

## (និស្សគ្គិយ ចីវរវគ្គ) សិក្ខាបទ ទី១

CS vin.vbi.ni.11 | ភាគ ទី៥

### (១១. ឯកាទសមសិក្ខាបទំ)

[១៣៨] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីឈ្មោះថុល្លនន្ទា ជាពហុស្សូត ជាស្រីមានថ្វីមាត់ ក្លៀវក្លា ប្រសប់ធ្វើធម្មីកថា។ គ្រានោះ ព្រះបាទបសេនទិកោសល ដណ្តប់សំពត់កម្ពលមានដំឡៃច្រើនក្នុងកាលត្រជាក់ ហើយព្រះអង្គចូលទៅកាន់សំណាក់ថុល្លនន្ទាភិក្ខុនី លុះចូលទៅជិតហើយ ក៏ថ្វាយបង្គំថុល្លនន្ទាភិក្ខុនី ហើយគង់នៅក្នុងទីគួរ១។ លុះស្តេចបសេនទិកោសលនៅក្នុងទីគួរ១ហើយ ថុល្លនន្ទាភិក្ខុនីក៏ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា។ កាលនោះ ស្តេចបសេនទិកោសល កាលថុល្លនន្ទាភិក្ខុនីពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា (ដូច្នោះហើយ) ក៏មានបន្ទូលនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការវត្ថុណា គប្បីប្រាប់វត្ថុនោះចុះ។ ថុល្លនន្ទាភិក្ខុនីឆ្លើយថា បពិត្រមហារាជ បើព្រះអង្គមានសេចក្តីប្រាថ្នានឹងប្រគេនដល់អាត្មា ចូរព្រះអង្គប្រគេនសំពត់កម្ពលនេះចុះ។ ទើបស្តេចបសេនទិកោសលប្រគេនសំពត់កម្ពលដល់ថុល្លនន្ទាភិក្ខុនី ហើយក្រោកចាកអាសនៈ ថ្វាយបង្គំថុល្លនន្ទាភិក្ខុនី រួចធ្វើប្រទក្សិណចៀសចេញទៅ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះមានសេចក្តីប្រាថ្នាច្រើន គ្មានសន្តោស មិនសមនឹងសុំសំពត់កម្ពលពីស្តេចសោះ។ ភិក្ខុនីទាំងឡាយ បានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបើនឹងសុំសំពត់កម្ពលពីស្តេចសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថាថុល្លនន្ទាភិក្ខុនី សុំសម្ពត់កម្ពលពីស្តេច ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបើនឹងសុំសម្ពត់កម្ពលពីស្តេចទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនី កាលចាត់ចែងសម្ពត់ដណ្តប់ ដែលមានសាច់ក្រាស ត្រូវចាត់ចែងបានតែសម្ពត់ដែលមានដំឡៃបួនកហាបណៈបួនដងជាយ៉ាងច្រើន បើចាត់ចែងសំពត់ដែលមានដំឡៃហួសពីនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១៣៩] ដែលហៅថា សំពត់ដណ្តប់ដែលមានសាច់ក្រាស គឺសំពត់ដណ្តប់ណាមួយសម្រាប់ដណ្តប់ក្នុងរដូវរងា។ ត្រង់ពាក្យថា កាលចាត់ចែង គឺថា កាលសូម(គេ)។ ពាក្យថា ត្រូវចាត់ចែងបានតែសំពត់មានដំឡៃបួនកហាបណៈបួនដងជាយ៉ាងច្រើន សេចក្តីថា ត្រូវចាត់ចែងបានតែសំពត់មានដំឡៃ១៦កហាបណៈ។ ពាក្យថា បើចាត់ចែងសំពត់ឲ្យលើសពីនោះទៅ សេចក្តីថា ភិក្ខុនីសូមសំពត់ឲ្យលើសលុបពីនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសូម សំពត់នោះជានិស្សគ្គិយក្នុងពេលដែលបានមក ភិក្ខុនីត្រូវលះបង់ដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះបង់យ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ សំពត់ដណ្តប់ដែលមានសាច់ក្រាសនេះ មានដំឡៃលើសពីបួនកហាបណៈបួនដង ជាកំណត់ ខ្ញុំបានសូមមកហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបង់សំពត់នេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌ)។

[១៤០] សំពត់មានដំឡៃលើសពីបួនកហាបណៈ៤ដង ភិក្ខុនីសំគាល់ថាលើសមែន ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ។ សំពត់មានដំឡៃលើសពីបួនកហាបណៈ៤ដង ភិក្ខុនីមានសេចក្តីសង្ស័យ ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ។ សំពត់មានដំឡៃលើសពីបួនកហាបណៈ៤ដង ភិក្ខុនីសំគាល់ថាខ្វះវិញ ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ។ សំពត់មានដំឡៃខ្វះពីបួនកហាបណៈ៤ដង ភិក្ខុនីសំគាល់ថាលើសវិញ ត្រូវអាបត្តិទុក្កដ។ សំពត់មានដំឡៃខ្វះពីបួនកហាបណៈ៤ដង ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ សំពត់មានដំឡៃខ្វះពីបួនកហាបណៈ៤ដង ភិក្ខុនីសំគាល់ថាខ្វះមែន មិនត្រូវអាបត្តិ។

[១៤១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុនីសុំសំពត់ដណ្តប់មានដំឡៃត្រឹមបួនកហាបណៈ៤ដងជាកំណត់១ ភិក្ខុនីសុំសំពត់ដណ្តប់មានដំឡៃខ្វះពីបួនកហាបណៈ៤ដងជាកំណត់១ ភិក្ខុនីសុំសំពត់ដណ្តប់របស់ពួកញាតិ១ ភិក្ខុនីសុំសំពត់ដណ្តប់របស់ពួកជនដែលបវារណា១ ភិក្ខុនីសុំសំពត់ដណ្តប់ដើម្បីបុគ្គលដទៃ១ ភិក្ខុនីបានសំពត់ដណ្តប់មកដោយទ្រព្យរបស់ខ្លួន១ ជនមានសេចក្តីប្រាថ្នាឲ្យភិក្ខុនីសុំសំពត់ដណ្តប់មានដំឡៃច្រើន ភិក្ខុនីត្រឡប់សុំសំពត់ដណ្តប់មានដំឡៃតិច១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (និស្សគ្គិយ ចីវរវគ្គ) សិក្ខាបទ ទី២

CS vin.vbi.ni.12 | ភាគ ទី៥

### (១២. ទ្វាទសមសិក្ខាបទំ)

[១៤២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី ជាពហុស្សូត ជាស្រីមានថ្វីមាត់ ជាស្រីក្លៀវក្លា ប្រសប់ធ្វើធម្មីកថា។ លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ដណ្តប់សំពត់សម្បកឈើមានដំឡៃច្រើនក្នុងកាលក្តៅ ហើយចូលទៅរកថុល្លនន្ទាភិក្ខុនី លុះយាងចូលទៅហើយ ក៏ថ្វាយបង្គំថុល្លនន្ទាភិក្ខុនី ហើយគង់នៅក្នុងទីគួរមួយ។ លុះព្រះបាទបសេនទិកោសលគង់នៅក្នុងទីសមគួរហើយ ថុល្លនន្ទាភិក្ខុនីក៏បានពន្យល់ឲ្យទ្រង់ឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា។ លំដាប់នោះ ព្រះបាទបសេនទិកោសល កាលថុល្លនន្ទាភិក្ខុនីពន្យល់ឲ្យទ្រង់ឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា

ហើយ ក៏មានព្រះបន្ទូលនេះនឹងចុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការវត្ថុណា គប្បីប្រាប់វត្ថុនោះចុះ។ ចុល្លនន្ទាភិក្ខុនីឆ្លើយថា បពិត្រមហារាជ បើព្រះអង្គប្រាថ្នានឹងប្រគេនដល់អាត្មាភាព សូមព្រះអង្គប្រគេនសំពត់សម្បកឈើនេះចុះ។ ទើបព្រះបាទបសេនទិកោសលប្រគេនសំពត់សម្បកឈើដល់ចុល្លនន្ទាភិក្ខុនី រួចទ្រង់ក្រោកចាកអាសនៈ ថ្វាយបង្គំចុល្លនន្ទាភិក្ខុនី ធ្វើប្រទក្សិណាចៀសចេញទៅ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីទាំងនេះមានសេចក្ដីប្រាថ្នាធំ គ្មានសន្ដោស មិនសមបើនឹងសុំសំពត់សម្បកឈើអំពីស្ដេចសោះ។ ពួកភិក្ខុនី ឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុនីណាមានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុល្លនន្ទាជាម្ចាស់ មិនសមបើនឹងសុំសំពត់សម្បកឈើអំពីស្ដេចសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចុល្លនន្ទាភិក្ខុនី សុំសម្ពត់សម្បកឈើពីស្ដេច ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ចុល្លនន្ទាភិក្ខុនី មិនសមបើនឹងសូមសំពត់សម្បកឈើអំពីស្ដេចទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនី កាលចាត់ចែងសម្ពត់ដណ្ដប់ ដែលមានសាច់ស្តើង ត្រូវចាត់ចែងបានតែសម្ពត់ដែលមានដំឡៃត្រឹមបួនកហាបណៈបីដងដោយកន្លះ បើចាត់ចែងឲ្យលើសពីកំណត់នោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ។**

[១៤៣] ដែលហៅថា សំពត់ដណ្ដប់មានសាច់ស្តើង គឺសំពត់ណាមួយសម្រាប់ដណ្ដប់ក្នុងរដូវក្ដៅ។ ត្រង់ពាក្យថា កាលចាត់ចែង គឺកាលសូម។ ពាក្យថា ត្រូវចាត់ចែងបានតែសំពត់ដណ្ដប់មានដំឡៃត្រឹមបួនកហាបណៈបីដងដោយកន្លះ សេចក្ដីថា ត្រូវសូមបានតែសំពត់ដែលមានដំឡៃ១០កហាបណៈ។ ពាក្យថា បើចាត់ចែងឲ្យលើសកំណត់នោះទៅ សេចក្ដីថា ភិក្ខុនីសូមឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសូម សំពត់នោះជានិស្សគ្គិយក្នុងពេលដែលបានមក។ ភិក្ខុនីត្រូវលះបង់ដល់សង្ឃក៏បាន ដល់គណៈក៏បាន ដល់ភិក្ខុនី១រូបក៏បាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវលះបង់យ៉ាងនេះ។បេ។ បពិត្រលោកម្ចាស់ សំពត់ដណ្ដប់ដែលមានសាច់ស្តើងនេះ មានដំឡៃលើសពីបួនកហាបណៈបីដងដោយកន្លះជាកំណត់ ខ្ញុំបានសុំមកហើយ ជានិស្សគ្គិយ ខ្ញុំសូមលះបង់សំពត់នេះដល់សង្ឃ។ (ពាក្យតពីនេះទៅ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី១នៃនិស្សគ្គិយកណ្ឌ)។

[១៤៤] សំពត់ដណ្ដប់មានដំឡៃលើសពីបួនកហាបណៈ៣ដងដោយកន្លះ ភិក្ខុនីសំគាល់ថាលើសមែន ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ។ សំពត់ដណ្ដប់មានដំឡៃលើសពីបួនកហាបណៈ៣ដងដោយកន្លះ តែភិក្ខុនីមានសេចក្ដីសង្ស័យ ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ។ សំពត់ដណ្ដប់មានដំឡៃលើសពីបួនកហាបណៈ៣ដងដោយកន្លះ ភិក្ខុនីសំគាល់ថាខ្វះ ហើយសូម ត្រូវនិស្សគ្គិយបាចិត្តិយ។ សំពត់ដណ្ដប់មានដំឡៃតិចជាងបួនកហាបណៈ៣ដងដោយកន្លះ ភិក្ខុនីសំគាល់ថាលើសទៅវិញ ត្រូវអាបត្តិទុក្កដ។ សំពត់ដណ្ដប់មានដំឡៃខ្វះពីបួនកហាបណៈ៣ដងដោយកន្លះ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ សំពត់ដណ្ដប់មានដំឡៃខ្វះពីបួនកហាបណៈ៣ដងដោយកន្លះ ភិក្ខុនីសំគាល់ថាខ្វះមែន មិនត្រូវអាបត្តិ។

[១៤៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុនីសុំសំពត់ដណ្ដប់មានដំឡៃត្រឹមបួនកហាបណៈ៣ដងដោយកន្លះ១ ភិក្ខុនីសុំសំពត់ដណ្ដប់មានដំឡៃតិចជាងបួនកហាបណៈ៣ដងដោយកន្លះជាកំណត់១ ភិក្ខុនីសុំសំពត់ដណ្ដប់របស់ពួកញាតិ១ ភិក្ខុនីសុំសំពត់ដណ្ដប់របស់ពួកជនដែលបវារណា១ ភិក្ខុនីសុំសំពត់ដណ្ដប់ដើម្បីបុគ្គលដទៃ១ ភិក្ខុនីបានសំពត់ដណ្ដប់មកដោយទ្រព្យរបស់ខ្លួន១ ជនប្រាថ្នាដើម្បីទិញសំពត់ដណ្ដប់មានដំឡៃច្រើន ភិក្ខុនីត្រឡប់ឲ្យទិញសំពត់ដណ្ដប់មានដំឡៃតិច១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

[១៤៦] បពិត្រលោកម្ចាស់ទាំងឡាយ ពួកអាបត្តិឈ្មោះនិស្សគ្គិយបាចិត្តិយ៣០ ខ្ញុំសំដែងឡើងហើយ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសូមសួរជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសូមសួរជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងអាបត្តិទាំងនេះ ព្រោះហេតុដូច្នោះ បានជាលោកទាំងឡាយស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

និស្សគ្គិយ បាចិត្តិយ ចប់។

# បាចិត្តិយកណ្ឌ (ភិក្ខុនីវិភង្គ)

CS vin.vbi.pc | ភាគ ទី៥

**(៤. បាចិត្តិយកណ្ឌំ (ភិក្ខុនីវិភង្គោ))**

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះបាចិត្តិយមែននេះ មានចំនួន១៦៦ តែងមកកាន់ឧទ្ទេស (គឺការសូត្ររាល់ៗកន្លះខែ)

## (បាចិត្តិយ) លសុណវគ្គ (ទី១)

CS vin.vbi.pc.v1 | ភាគ ទី៥

**(១. លសុណវគ្គោ)**

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី១

CS vin.vbi.pc.01 | ភាគ ទី៥

### (១. បឋមសិក្ខាបទំ)

[១៤៧] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានឧបាសកម្នាក់បវារណាភិក្ខុនីសង្ឃដោយខ្ទឹមថា លោកម្ចាស់ទាំងឡាយណា ត្រូវការដោយខ្ទឹម ខ្ញុំព្រះករុណា (នឹងប្រគេនខ្ទឹមដល់លោកម្ចាស់ទាំងឡាយនោះ)។ ឧបាសកនោះក៏បង្គាប់អ្នករក្សាចំការខ្ទឹមថា បើពួកភិក្ខុនីមក អ្នកឯងចូរប្រគេនខ្ទឹមពីរបីមើមដល់ភិក្ខុនី១អង្គៗ។ សម័យនោះឯង ក្រុងសាវត្ថី(មានគេលេង)មហោស្រព។ ខ្ទឹមដែលឧបាសកបានយកមក ក៏អស់រលីងទៅ។ ពួកភិក្ខុនីចូលទៅរកឧបាសកនោះ ហើយបានពោលពាក្យនេះថា ម្នាលអាវុសោ យើងទាំងឡាយត្រូវការដោយខ្ទឹម។ ឧបាសកនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ទឹមគ្មានទេ ខ្ទឹមដែលបានយកមក អស់រលីងទៅហើយ សូមលោកម្ចាស់និមន្តទៅចំការចុះ។ ថុល្លនន្ទាភិក្ខុនីទៅកាន់ចំការហើយ មិនដឹងប្រមាណ ក៏ឲ្យគេនាំយកខ្ទឹមទៅជាច្រើន។ មនុស្សអ្នករក្សាចំការក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនី មិនសមបើនឹងទៅកាន់ចំការហើយ មិនដឹងប្រមាណ ឲ្យគេនាំយកខ្ទឹមទៅច្រើនដល់ម្ល៉េះសោះ។ ភិក្ខុនីទាំងឡាយ បានឮអ្នករក្សាចំការពោលទោស តិះដៀល បន្តុះបង្អាប់(ដូច្នោះ)ហើយ។ ពួកភិក្ខុនីណាមានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបើនឹងមិនដឹងប្រមាណ ឲ្យគេនាំយកខ្ទឹមមកច្រើនដល់ម្ល៉េះសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីមិនដឹងប្រមាណ ឲ្យគេនាំយកខ្ទឹមច្រើន ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបើនឹងមិនដឹងប្រមាណ ឲ្យគេនាំយកខ្ទឹមមកច្រើនដល់ម្ល៉េះសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទៀតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ នាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យខានជ្រះថ្លាទៅផង នាំជនពួកខ្លះដែលជ្រះថ្លាស្រាប់ហើយ ឲ្យទាស់ចិត្តខូចគំនិតទៅវិញផងដោយពិត។

[១៤៨] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលថុល្លនន្ទាភិក្ខុនីជាអនេកបរិយាយ ហើយទ្រង់ធ្វើធម្មីកថាដ៏សមគួរក្នុងពេលនោះ និងល្មមក្នុងពេលនោះដល់ភិក្ខុទាំងឡាយ ទើបទ្រង់ហៅពួកភិក្ខុមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ ថុល្លនន្ទាភិក្ខុនីធ្លាប់បានជាប្រពន្ធព្រាហ្មណ៍១នាក់។ នាងមានកូនស្រី៣នាក់ គឺនាងនន្ទា១ នាងនន្ទវតី១ នាងសុន្ទរីនន្ទា១។ ម្នាលភិក្ខុទាំងឡាយ កាលនោះព្រាហ្មណ៍នោះក៏ធ្វើមរណកាលទៅ កើតក្នុងកំណើតសត្វហង្ស១។ ហង្សនោះមានស្លាបសុទ្ធសឹងជាមាស។ ហង្សនោះឲ្យស្លាបមួយៗដល់ប្រពន្ធ និងកូនស្រីទាំងនោះ ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីគិតថា ហង្សនេះបានឲ្យស្លាបមួយៗដល់យើងទាំងឡាយ គិតដូច្នោះហើយ ក៏ចាប់ស្ដេចហង្សនោះ ហើយក៏ដកយកស្លាបចេញអស់ក្នុងកាលនោះឯង។ ស្លាបទាំងឡាយរបស់ហង្សនោះ កាលដុះឡើងទៀត ក៏សទាំងអស់។ ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនីសាបសូន្យចាកមាសក្នុងកាលនោះ ព្រោះតែសេចក្ដីលោភហួស ឥឡូវនេះមកសាបសូន្យចាកខ្ទឹម។

[១៤៩] ទ្រព្យណាដែលខ្លួនបានហើយ បុគ្គលត្រូវត្រេកអរដោយទ្រព្យនោះ ព្រោះថា សេចក្ដីលោភពេក ជាសភាវៈដ៏លាមក។ ថុល្លនន្ទាភិក្ខុនី លុះចាប់ស្ដេចហង្សបានហើយ ក៏សាបសូន្យចាកមាស។

[១៥០] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលថុល្លនន្ទាភិក្ខុនីដោយអនេកបរិយាយ។បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយទំពាស៊ីខ្ទឹម ត្រូវអាបត្តិបាចិត្តិយ។**

[១៥១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយរួចហើយក្នុងបារាជិកកណ្ឌទី១។បេ។ ដែលហៅថាខ្ទឹម សំដៅយកខ្ទឹមដែលកើតក្នុងដែនមគធ។ ភិក្ខុនីទទួលខ្ទឹមដោយគិតថា អញនឹងទំពាស៊ី ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលលេបចូលទៅ។

[១៥២] ខ្ទឹម ភិក្ខុនីសំគាល់ថាខ្ទឹមមែន ហើយទំពាស៊ី ត្រូវអាបត្តិបាចិត្តិយ។ ខ្ទឹម ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយទំពាស៊ី ត្រូវអាបត្តិបាចិត្តិយ។ ខ្ទឹម ភិក្ខុនីសំគាល់ថាមិនមែនខ្ទឹម ហើយទំពាស៊ី ត្រូវអាបត្តិបាចិត្តិយ។ មិនមែនខ្ទឹម ភិក្ខុនីសំគាល់ថាខ្ទឹម ត្រូវអាបត្តិទុក្កដ។ មិនមែនខ្ទឹម ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនខ្ទឹម ភិក្ខុនីសំគាល់ថាមិនមែនខ្ទឹម មិនត្រូវអាបត្តិ។

[១៥៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១១យ៉ាង) ភិក្ខុនីឆាន់ខ្ទឹមលឿង១ ភិក្ខុនីឆាន់ខ្ទឹមក្រហម១ ភិក្ខុនីឆាន់ខ្ទឹមខៀវ១ ភិក្ខុនីឆាន់ខ្ទឹមតតមើម (ខ្ទឹមដើម)១ ភិក្ខុនីឆាន់ខ្ទឹមដែលគេចំអិនដោយសម្ល១ ភិក្ខុនីឆាន់ខ្ទឹមដែលគេចំអិនដោយសាច់១ ភិក្ខុនីឆាន់ខ្ទឹមដែលគេចំអិនដោយប្រេង១ ភិក្ខុនីឆាន់ខ្ទឹមដែលគេដាក់ក្នុងបបរគ្រឿង១ ភិក្ខុនីឆាន់ខ្ទឹមដែលគេដាក់ក្នុងសម្លការី១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី២

CS vin.vbi.pc.02 | ភាគ ទី៥

### (២. ទុតិយសិក្ខាបទំ)

[១៥៤] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ព្រះអង្គគង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយាភិក្ខុនីឲ្យគេដករោមក្នុងទីចង្អៀត ហើយស្រាតងូតទឹកក្នុងកំពង់១ ជាមួយនឹងពួកស្រីវេស្យាក្នុងស្ទឹងអចិរវតី។ ពួកស្រីវេស្យាក៏ពោល

ទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យគេដករោមក្នុងទីចង្អៀត ដូចជាស្រីគ្រហស្ថបរិភោគកាមគុណសោះ។ ពួកភិក្ខុនីបានឮស្រីវេស្យាទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់(ដូច្នោះ)ហើយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យគេដករោមក្នុងទីចង្អៀតសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាឆព្វគ្គិយាភិក្ខុនីទាំងឡាយឲ្យគេដករោមក្នុងទីចង្អៀត ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យគេដករោមក្នុងទីចង្អៀតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយឲ្យគេដករោមក្នុងទីចង្អៀត ត្រូវអាបត្តិបាចិត្តិយ។**

[១៥៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។បេ។ ដែលហៅថាទីចង្អៀត បានដល់ក្លៀកទាំងពីរ និងកន្លែងបន្ទោបង់នូវទឹកមូត្រ។ ពាក្យថា ឲ្យគេដក សេចក្តីថា ភិក្ខុនីឲ្យគេដករោមសូម្បី១សរសៃក្តី ក៏ត្រូវអាបត្តិបាចិត្តិយ។ ឲ្យគេដករោមច្រើនសរសៃក្តី ក៏ត្រូវអាបត្តិបាចិត្តិយ។

[១៥៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) ភិក្ខុនីឲ្យគេដករោម ព្រោះហេតុមានអាពាធ (កើតបូសកមជាដើម)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.pc.03 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[១៥៧] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីពីររូបមានសេចក្តីអផ្សុកមកបៀតបៀន ក៏ចូលទៅកាន់បន្ទប់ ហើយធ្វើនូវកិរិយាទះនូវផ្ទៃនៃអង្គជាត។ ពួកភិក្ខុនីស្ទុះចូលទៅដោយឮសំឡេងនោះ ហើយពោលនូវពាក្យនេះនឹងភិក្ខុនីទាំងនោះថា បពិត្រលោកម្ចាស់ ហេតុអ្វីបានជាលោកទាំងឡាយប្រទុស្តមួយអន្លើដោយបុរស។ ភិក្ខុនីទាំងនោះឆ្លើយថា បពិត្រលោកម្ចាស់ យើងទាំងឡាយមិនប្រទុស្តមួយអន្លើដោយបុរសទេ។ ពួកភិក្ខុនីប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនី មិនសមបើនឹងធ្វើនូវកិរិយាទះនូវផ្ទៃនៃអង្គជាតសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីធ្វើនូវកិរិយាទះនូវផ្ទៃនៃអង្គជាត ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី មិនសមបើនឹងធ្វើនូវកិរិយាទះនូវផ្ទៃនៃអង្គជាតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**អាបត្តិបាចិត្តិយមានដល់ភិក្ខុនី ព្រោះកិរិយាទះនូវផ្ទៃនៃអង្គជាត។**

[១៥៨] ដែលហៅថា ទះនូវផ្ទៃនៃអង្គជាត គឺភិក្ខុនីត្រេកអរនូវសម្ផស្ស ហើយឲ្យនូវប្រហារវាយក្នុងអវយវជាទីបន្ទោបង់ទឹកមូត្ត ដោយហោចទៅ សូម្បីតែប្រហារដោយស្លឹកឧប្បល ក៏ត្រូវអាបត្តិបាចិត្តិយ។

[១៥៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីវាយអង្គជាត ព្រោះហេតុតែមានអាពាធ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.04 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[១៦០] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានស្រីព្រះស្នំរបស់ស្តេចពីដើម បួសក្នុងសំណាក់ពួកភិក្ខុនីទាំងឡាយ។ ភិក្ខុនីមួយរូបទៀត មានសេចក្តីអផ្សុកមកបៀតបៀន ក៏ចូលទៅរកភិក្ខុនីនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ ស្តេចយូរៗទើបទ្រង់ធ្វើសន្ថវៈនឹងលោកម្តង តើលោកអាចកែកុនបណ្តោះអាសន្នដូចម្តេចទៅ។ ភិក្ខុនីនោះប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំអាចកែកុនដោយដងបង្គួរមានសណ្ឋានរលីង ធ្វើពីអាចម៍ល័ក្ត។ ភិក្ខុនីដែលអផ្សុកសួរថា បពិត្រលោកម្ចាស់ ដងបង្គួរមានសណ្ឋានរលីង ធ្វើពីអាចម៍ល័ក្តនោះ តើដូចម្តេច។ ទើបភិក្ខុនីនោះប្រាប់ដងបង្គួរមានសណ្ឋានរលីង ធ្វើពីអាចម៍ល័ក្តដល់ភិក្ខុនីនោះ។ កាលនោះ ភិក្ខុនីនោះកាន់យកដងបង្គួរមានសណ្ឋានរលីង ធ្វើពីអាចម៍ល័ក្ត ហើយភ្លេចលាងទឹក ក៏ចោលទៅក្នុងទីគួរមួយ។ ពួកភិក្ខុនីឃើញរុយទាំងឡាយរោមដងបង្គួរដូច្នោះ ក៏សួរយ៉ាងនេះថា កម្មនេះជាកម្មរបស់អ្នកណា។ ភិក្ខុនីនោះពោលថា កម្មនេះជាកម្មរបស់ខ្ញុំ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនី មិនសមបើនឹងកាន់យកដង

បង្ហូរមានសណ្ឋានរលីងដែលគេធ្វើពីអាចម៍ល័ក្តសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីកាន់យកដងបង្ហូរមានសណ្ឋានរលីងដែលគេធ្វើពីអាចម៍ល័ក្ត ពិតមែនឬ។ ពួកភិក្ខុឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនសមបើនឹងកាន់យកដងបង្ហូរមានសណ្ឋានរលីងដែលគេធ្វើពីអាចម៍ល័ក្តទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**អាបត្តិបាចិត្តិយមានដល់ភិក្ខុនី ព្រោះដងបង្ហូរមានសណ្ឋានរលីងដែលគេធ្វើពីអាចម៍ល័ក្ត។**

[១៦១] ដែលហៅថា ដងបង្ហូរមានសណ្ឋានរលីងដែលគេធ្វើពីអាចម៍ល័ក្ត បានដល់ដងបង្ហូរដែលគេធ្វើដោយអាចម៍ល័ក្តក្តី ឈើក្តី ម្សៅក្តី ដីស្អិតក្តី។ ភិក្ខុនី កាលត្រេកអរនូវសម្ផស្ស ដោយហោចទៅ គ្រាន់តែញុំាងស្លឹកឧប្បលឲ្យចូលទៅកាន់អវយវៈជាទីបន្ទោបង់នូវទឹកមូត្ត ត្រូវអាបត្តិបាចិត្តិយ។

[១៦២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីញុំាងដងបង្ហូរឲ្យចូលទៅក្នុងអង្គជាតខ្លួន ព្រោះហេតុតែមានអាពាធ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.05 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[១៦៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ព្រះអង្គគង់នៅនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយស្ថិតនៅក្នុងទីក្រោមខ្យល់ (រួចក៏ក្រាបទូលថា) បពិត្រព្រះដ៏មានព្រះភាគ មាតុគ្រាមមានក្លិនអាក្រក់។ ទើបព្រះដ៏មានព្រះភាគទ្រង់មានពុទ្ធដីកាថា ពួកភិក្ខុនីចូរធ្វើនូវការជម្រះដោយទឹកចុះ ហើយទ្រង់ញុំាងព្រះមហាបជាបតិគោតមីឲ្យយល់តាម ឲ្យប្រតិបត្តិតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា។ លំដាប់នោះ ព្រះនាងមហាបជាបតិគោតមី កាលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា រួចហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយក្នុងពេលនោះមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការជម្រះដោយទឹកដល់ពួកភិក្ខុនី។

[១៦៤] សម័យនោះ មានភិក្ខុនី១រូបគិតថា ការជម្រះដោយទឹក ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ (គិតដូច្នោះហើយ) ក៏ធ្វើការជម្រះដោយទឹកឲ្យជ្រៅពេក ហើយក៏ធ្វើឲ្យកើតដម្បៅក្នុងទីជាទីបន្ទោបង់នូវទឹកមូត្ត។ ទើបភិក្ខុនីនោះ ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងធ្វើការជម្រះដោយទឹកឲ្យជ្រៅពេកសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីធ្វើការជម្រះដោយទឹកឲ្យជ្រៅពេក ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងធ្វើការជម្រះដោយទឹកឲ្យជ្រៅពេកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**កាលភិក្ខុនីធ្វើការជម្រះដោយទឹក ត្រូវធ្វើការជម្រះបានត្រឹមពីរថ្នាំងម្រាមដៃជាកំណត់ កាលឲ្យកន្លងហួសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ។**

[១៦៥] ដែលហៅថា ការជម្រះដោយទឹក សំដៅយកការលាងអវយវៈសម្រាប់បន្ទោបង់នូវទឹកមូត្ត។ ត្រង់ពាក្យថា កាលធ្វើ គឺកាលលាង។ ពាក្យថា ត្រូវធ្វើការជម្រះបានត្រឹមពីរថ្នាំងម្រាមដៃជាកំណត់ សេចក្តីថា ភិក្ខុនីត្រូវលាងបានត្រឹមពីរថ្នាំងម្រាមដៃទាំងពីរ។ ពាក្យថា កាលឲ្យកន្លងហួសពីកំណត់នោះទៅ សេចក្តីថា កាលភិក្ខុនីត្រេកអរនូវសម្ផស្សហើយធ្វើឲ្យកន្លងកំណត់នោះទៅ ដោយហោចទៅ សូម្បីតែប៉ុនចុងសក់ ក៏ត្រូវអាបត្តិបាចិត្តិយ។

[១៦៦] ការជម្រះហួសកំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីសំគាល់ថាហួសមែន ហើយលាង ត្រូវអាបត្តិបាចិត្តិយ។ ការជម្រះហួសកំណត់ពីរថ្នាំងម្រាមដៃ តែភិក្ខុនីសង្ស័យ ហើយលាង ត្រូវអាបត្តិបាចិត្តិយ។ ការជម្រះហួសកំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីសំគាល់ថាមិនទាន់ហួសកំណត់ ហើយលាង ត្រូវអាបត្តិបាចិត្តិយ។ ការជម្រះមិនទាន់ដល់កំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីសំគាល់ថាលើសទៅវិញ ត្រូវអាបត្តិទុក្កដ។ ការជម្រះមិនទាន់ដល់កំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ការជម្រះមិនទាន់ដល់កំណត់ពីរថ្នាំងម្រាមដៃ ភិក្ខុនីសំគាល់ថាមិនទាន់ដល់កំណត់មែន មិនត្រូវអាបត្តិ។

[១៦៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីលាងកំណត់ត្រឹមពីរថ្នាំងម្រាមដៃ១ ភិក្ខុនីលាងថយពីកំណត់ពីរថ្នាំងម្រាមដៃ១ ភិក្ខុនីលាងហួសកំណត់ព្រោះហេតុនៃអាពាធ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី៦

### (៦. ឆដ្ឋសិក្ខាបទំ)

[១៦៨] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង មានមហាមាត្យឈ្មោះអារោហន្ត បួសក្នុងសំណាក់ពួកភិក្ខុ។ ស្រីជាប្រពន្ធរបស់មហាមាត្យនោះក៏បួសក្នុងសំណាក់ពួកភិក្ខុនីដែរ។ គ្រានោះឯង ភិក្ខុនោះធ្វើនូវភត្តកិច្ច (ឆាន់ចង្ហាន់) ក្នុងសំណាក់ភិក្ខុនីនោះ។ កាលភិក្ខុនោះកំពុងឆាន់ ភិក្ខុនីនោះបម្រើដោយទឹកផង ដោយផ្លិតផង ហើយនិយាយដឹកនាំដោយពាក្យស្និទ្ធស្នាល។ គ្រានោះ ភិក្ខុនោះ បណ្តេញភិក្ខុនីនោះចេញដោយពាក្យថា ម្នាលប្អូនស្រី នាងកុំធ្វើនូវអំពើមានសភាពយ៉ាងនេះ ការនេះមិនគួរទេ។ ភិក្ខុនីនោះឆ្លើយថា ពីដើមលោកធ្វើនូវអំពើយ៉ាងនេះផងៗនឹងខ្ញុំ ឥឡូវនេះ លោកមិនអាចដើម្បីធ្វើនូវអំពើមានប្រមាណប៉ុណ្ណេះទេ ថាដូច្នោះហើយ ក៏បោះសៀនទឹកទៅលើក្បាលភិក្ខុនោះ ហើយវាយនឹងផ្លិតថែមទៀត។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងវាយភិក្ខុសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីវាយភិក្ខុ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹងវាយភិក្ខុទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ កាលភិក្ខុកំពុងឆាន់ ទៅបម្រើដោយទឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិបាចិត្តិយ។**

[១៦៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកទី១រួចហើយ។ ពាក្យថា ភិក្ខុ សេចក្តីថា បុរសដែលបានឧបសម្បទាហើយ។ ពាក្យថា កាលកំពុងឆាន់ សេចក្តីថា កំពុងឆាន់ភោជនទាំង៥យ៉ាង ភោជនណាមួយ។ ដែលហៅថា ទឹក បានដល់ទឹក គឺបុគ្គលគប្បីផឹកណាមួយ។ ដែលហៅថា ផ្លិត បានដល់វត្ថុសម្រាប់បក់ណាមួយ។ ពាក្យថា បម្រើ សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយ។

[១៧០] ឧបសម្បន្ន ភិក្ខុនីសំគាល់ថាឧបសម្បន្នមែន ហើយបម្រើដោយទឹកផឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុនីមានសេចក្តីសង្ស័យ ហើយបម្រើដោយទឹកផឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុនីសំគាល់ថាអនុបសម្បន្នវិញ ហើយបម្រើដោយទឹកផឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីលះបង់ហត្ថបាស ហើយបំរើ ត្រូវអាបត្តិទុក្កដ។ កាលភិក្ខុកំពុងទំពាស៊ីខាទនីយ ភិក្ខុនីបម្រើ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីបម្រើបុរសជាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាឧបសម្បន្នវិញ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាអនុបសម្បន្នមែន ត្រូវអាបត្តិទុក្កដ។

[១៧១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ(ភិក្ខុនីប្រគេនវត្ថុមានទឹកជាដើម) ដល់ភិក្ខុដោយដៃខ្លួនឯង១ ភិក្ខុនីឲ្យគេប្រគេនដល់ភិក្ខុ១ ភិក្ខុនីបង្គាប់អនុបសម្បន្ន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី៧



### (៧. សត្តមសិក្ខាបទំ)

[១៧២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកភិក្ខុនីនាំគ្នាសូមស្រូវស្រស់ក្នុងរដូវស្រូវ ហើយដឹកនាំទៅកាន់ក្រុង។ មនុស្សទាំងឡាយក៏ដណ្តើមពួកភិក្ខុនីក្នុងទីទៀបទ្វារនគរ ដោយពាក្យថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយចូរឲ្យចំណែក(យើង)ខ្លះ ដូច្នោះ ហើយក៏លែងទៅ។ ទើបពួកភិក្ខុនីទាំងនោះទៅកាន់លំនៅ ហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមនឹងនាំគ្នាសូមស្រូវស្រស់សោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីនាំគ្នាសូមស្រូវស្រស់ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមនឹងនាំគ្នាសូមស្រូវស្រស់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ សូមឯងក្តី ឲ្យគេសូមក្តី កិនឯងក្តី ឲ្យគេកិនក្តី បុកឯងក្តី ឲ្យគេបុកក្តី ចំអិនឯងក្តី ឲ្យគេចំអិនក្តី នូវស្រូវស្រស់ ហើយបរិភោគ ត្រូវអាបត្តិបាចិត្តិយ។**

[១៧៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ស្រូវស្រស់ បានដល់ស្រូវខ្សាយស ស្រូវខ្សាយក្រហម ស្រូវដំណើប ស្រងែ ផ្តៅ ស្គួយ គែលលក។ ពាក្យថា សូមឯង គឺសូមដោយខ្លួនឯង។ ពាក្យថា ឲ្យគេសូម គឺឲ្យអ្នកដទៃសូម។ ពាក្យថា កិនឯង សេចក្តីថា កិនដោយដៃខ្លួនឯង។ ពាក្យថា ឲ្យគេកិន គឺឲ្យអ្នកដទៃកិន។ ពាក្យថា បុកឯង គឺបុកដោយដៃខ្លួនឯង។ ពាក្យថា ឲ្យគេបុក គឺឲ្យអ្នកដទៃបុក។ ពាក្យថា ចំអិនឯង គឺ ចំអិនដោយដៃខ្លួនឯង។ ពាក្យថា ឲ្យគេចំអិន គឺឲ្យអ្នកដទៃចំអិន។ ភិក្ខុនីទទួលដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលលេបចូលទៅ។

[១៧៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីសូម ព្រោះហេតុមានអាពាធ១ ភិក្ខុនីសូមអបរណ្ណជាតិ (មានសណ្តែកល្ង ជាដើម)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី៨

CS vin.vbi.pc.08 | ភាគ ទី៥

### (៨. អដ្ឋមសិក្ខាបទំ)

[១៧៥] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានព្រាហ្មណ៍ម្នាក់ ជារាជអាមាត្យដែលស្តេចដកងារចេញហើយ ក៏គិតថា អញនឹងសូមងារនោះវិញ គិតដូច្នោះហើយ ក៏កក់ក្បាល ហើយទៅអាស្រ័យនៅក្នុងសំណាក់ភិក្ខុនី រួចទើបដើរទៅកាន់ត្រកូលស្តេច។ មានភិក្ខុនី១អង្គ កាលបន្ទោបង់វច្ចៈក្នុងផើង ហើយទម្លាក់ទៅខាងក្រៅជញ្ជាំង ក៏ត្រូវទៅលើក្បាលព្រាហ្មណ៍នោះ។ ទើបព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីត្រងោលទាំងនេះមិនមែនជាសមណី ជាស្រីផ្កាមាស មិនសមនឹងទម្លាក់ផើងគូថមកលើក្បាលអញសោះ ហើយព្រាហ្មណ៍នោះក៏កាន់គប់ភ្លើងដើរចូលទៅកាន់លំនៅរបស់ភិក្ខុនីដោយគិតថា អញនឹងដុតលំនៅពួកភិក្ខុនីទាំងនេះចេញ។ មានឧបាសកម្នាក់កំពុងដើរចេញពីលំនៅរបស់ភិក្ខុនី បានឃើញព្រាហ្មណ៍នោះកាន់គប់ភ្លើងដើរចូលទៅកាន់លំនៅរបស់ភិក្ខុនី លុះបានឃើញហើយ ក៏បាននិយាយពាក្យនេះនឹងព្រាហ្មណ៍នោះថា ម្នាលអ្នកដ៏ចំរើន អ្នកកាន់គប់ភ្លើងដើរចូលទៅកាន់លំនៅរបស់ភិក្ខុនីព្រោះហេតុអ្វី។ ព្រាហ្មណ៍នោះឆ្លើយថា ម្នាលអ្នកដ៏ចំរើន ពួកភិក្ខុនីត្រងោលទាំងនេះ ជាស្រីផ្កាមាស ទម្លាក់ផើងគូថមកលើក្បាលខ្ញុំ ៗនឹងដុតលំនៅពួកភិក្ខុនីទាំងនេះ។ ឧបាសកនោះឆ្លើយថា ម្នាលអ្នកដ៏ចំរើន អ្នកឯងចូរទៅចុះ ហេតុនេះជាមង្គលល្អទេ អ្នកនឹងបាន១ពាន់កហាបណៈផង នឹងបានងារនោះផង។ កាលនោះ ព្រាហ្មណ៍នោះ ក៏កក់លាងក្បាល រួចទៅកាន់រាជត្រកូល ក៏បាន១ពាន់កហាបណៈផង និងងារនោះផង។ គ្រានោះ ឧបាសកនោះចូលទៅកាន់លំនៅរបស់ភិក្ខុនីទាំងឡាយ ហើយប្រាប់សេចក្តីនុ៎ះដល់ពួកភិក្ខុនី រួចក៏ពោលហាមប្រាម។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមនឹងចោលឧច្ចារៈទៅខាងក្រៅជញ្ជាំងសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីចោលឧច្ចារៈទៅខាងក្រៅជញ្ជាំង ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមនឹងចោលឧច្ចារៈទៅខាងក្រៅជញ្ជាំងទេ ម្នាលភិក្ខុទាំងឡាយ ការនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ចោលឯងក្តី ឲ្យគេចោលក្តី នូវឧច្ចារៈក្តី បស្សាវៈក្តី សម្រាមក្តី កាកអាហារក្តី ទៅខាងក្រៅជញ្ជាំងក្តី ខាងក្រៅរបងក្តី ត្រូវអាបត្តិបាចិត្តិយ។**

[១៧៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ឧច្ចារៈ បានដល់លាមក។ ដែលហៅថា បស្សាវៈ បានដល់ទឹកមូត្ត។ ដែលហៅថា សម្រាម បានដល់កំទេចកំទី។ ដែលហៅថា កាកអាហារ គឺសំណល់ទាំងឡាយក្តី ឆ្អឹងទាំងឡាយក្តី ទឹកដ៏សេសសល់ក្តី។ ដែលហៅថា ជញ្ជាំង បានដល់ជញ្ជាំងបីយ៉ាង គឺជញ្ជាំងឥដ្ឋ ជញ្ជាំងថ្ម ជញ្ជាំងឈើ។ ដែលហៅថា របង បានដល់របងបីយ៉ាង គឺរបងឥដ្ឋ របងថ្ម របងឈើ។ ពាក្យថា ខាងក្រៅជញ្ជាំង គឺខាងនាយជញ្ជាំង។ ពាក្យថា ខាងក្រៅរបង គឺខាងនាយរបង។ ពាក្យថា ចោលឯង សេចក្តីថា ភិក្ខុនីចោលដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ឲ្យគេចោល សេចក្តីថា ភិក្ខុនីបង្គាប់ឲ្យអ្នកដទៃចោល ត្រូវអាបត្តិទុក្កដ ភិក្ខុនីប្រើតែម្តង អ្នកទទួលបង្គាប់ចោលសូម្បីច្រើនដង ត្រូវអាបត្តិបាចិត្តិយ។

[១៧៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីពិនិត្យមើលទីដ៏សមគួរ ហើយទើបចោល១ ភិក្ខុនីចោលក្នុងទីដែលគេមិនប្រើប្រាស់១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.pc.09 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[១៧៨] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង មានស្រែស្រូវដំណើបរបស់ព្រាហ្មណ៍ម្នាក់ នៅជិតលំនៅរបស់ភិក្ខុនី។ ពួកភិក្ខុនីចោលឧច្ចារៈខ្លះ បស្សាវៈខ្លះ សម្រាមខ្លះ របស់ជាសំណល់ខ្លះទៅក្នុងស្រែ។ ឯព្រាហ្មណ៍នោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមនឹងប្រទូស្តស្រែស្រូវដំណើបរបស់យើងសោះ។ ពួកភិក្ខុនីឮព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះហើយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមនឹងចោលឧច្ចារៈខ្លះ បស្សាវៈខ្លះ សម្រាមខ្លះ របស់ជាសំណល់ខ្លះ ក្នុងទីមានវត្ថុមានពណ៌ខៀវសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីចោលឧច្ចារៈខ្លះ បស្សាវៈខ្លះ សម្រាមខ្លះ របស់ជាសំណល់ខ្លះ ក្នុងទីមានវត្ថុមានពណ៌ខៀវ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីមិនសមនឹងចោលឧច្ចារៈខ្លះ បស្សាវៈខ្លះ សម្រាមខ្លះ វត្ថុជាសំណល់ខ្លះ ក្នុងទីមានវត្ថុមានពណ៌ខៀវទេ ម្នាលភិក្ខុទាំងឡាយ ការនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ចោលឯង ឬឲ្យគេចោល នូវឧច្ចារៈក្តី បស្សាវៈក្តី សម្រាមក្តី របស់ជាសំណល់ក្តី ក្នុងទីមានវត្ថុមានពណ៌ខៀវ ត្រូវអាបត្តិបាចិត្តិយ។**

[១៧៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ឧច្ចារៈ បានដល់គូថ។ ដែលហៅថា បស្សាវៈ បានដល់ទឹកមូត្ត។ ដែលហៅថា សម្រាម បានដល់កំទេចកំទី។ ដែលហៅថា របស់សំណល់ បានដល់កាកអាមិស ឬពួកឆ្អឹង ឬទឹកដែលសេសសល់។ ដែលហៅថាវត្ថុមានពណ៌ខៀវ គឺវត្ថុណាជាបុព្វណ្ណជាតិ ឬអបរណ្ណជាតិ ជាដំណាំជាគ្រឿងឧបភោគ និងបរិភោគរបស់មនុស្សទាំងឡាយ។ ពាក្យថា ចោលឯង សេចក្តីថា ភិក្ខុនីចោលដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ឲ្យគេចោល សេចក្តីថា ភិក្ខុនីបង្គាប់អ្នកដទៃឲ្យចោល ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីបង្គាប់តែម្តង អ្នកទទួលបង្គាប់ចោលសូម្បីច្រើនដង ត្រូវអាបត្តិបាចិត្តិយ។

[១៨០] ដំណាំ ភិក្ខុនីសំគាល់ថាដំណាំមែន ហើយចោលឯងក្តី ឲ្យគេចោលក្តី ត្រូវអាបត្តិបាចិត្តិយ។ ដំណាំ តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយចោលឯងក្តី ឲ្យគេចោលក្តី ត្រូវអាបត្តិបាចិត្តិយ។ ដំណាំ ភិក្ខុនីសំគាល់ថាមិនមែនដំណាំវិញ ហើយចោលឯងក្តី ឲ្យគេចោលក្តី ត្រូវអាបត្តិបាចិត្តិយ។ មិនមែនដំណាំ ភិក្ខុនីសំគាល់ថាដំណាំទៅវិញ ត្រូវអាបត្តិទុក្កដ។ មិនមែនដំណាំ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនដំណាំ ភិក្ខុនីសំគាល់ថាមិនមែនដំណាំមែន មិនត្រូវអាបត្តិ។

[១៨១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីរមិលមើលទីសមគួរហើយទើបចោល១ ភិក្ខុនីចោលលើភ្លឺស្រែ ឬចំការ១ ភិក្ខុនីសួរពួកម្ចាស់ដោយសព្វគ្រប់ហើយ ប្រាប់ដោយស្រួលបួល ទើបចោល១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ លសុណវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.pc.10 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[១៨២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ គ្រានោះឯង ក្នុងក្រុងរាជគ្រឹះមានមហោស្រពលើកំពូលភ្នំ ភិក្ខុនីទាំងឡាយមានពួក៦ បានទៅមើលមហោស្រពដែលគេលេងលើកំពូលភ្នំ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមនឹងទៅមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តី ដូចជាពួកស្រីគ្រហស្ថបរិភោគកាមគុណសោះ។ ពួកភិក្ខុនីបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់(ដូច្នោះ)ហើយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមានពួក៦មិនសមនឹងទៅមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តីសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយមានពួក៦ ទៅមើលរបាំខ្លះ ចម្រៀងខ្លះ ប្រគំខ្លះ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមានពួក៦ មិនសមនឹងទៅមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តីទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយទៅដើម្បីមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តី ត្រូវអាបត្តិបាចិត្តិយ។**

[១៨៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា របាំ បានដល់ការរាំឯណានីមួយ។ ដែលហៅថា ចម្រៀង បានដល់ចម្រៀងឯណានីមួយ។ ដែលហៅថា ប្រគំ បានដល់ប្រគំឯណានីមួយ។ ភិក្ខុនីទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ភិក្ខុនីឈរមើលក្តី ស្តាប់ក្តី ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយក្នុងទីនោះ។ ភិក្ខុនីលះឧបចារសម្រាប់មើល ហើយមើលឃើញក្តី ស្តាប់ឮក្តី រឿយៗ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីទៅដើម្បីមើលនូវល្បែងមួយៗ ត្រូវអាបត្តិទុក្កដ ភិក្ខុនីឈរមើលក្តី ឈរស្តាប់ក្តី ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយក្នុងទីនោះ។ ភិក្ខុនីលះឧបចារសម្រាប់មើល ហើយមើលឃើញក្តី ស្តាប់ឮក្តី រឿយៗ ត្រូវអាបត្តិបាចិត្តិយ។

[១៨៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុនីឈរមើល ឬស្តាប់ក្នុងអារាម១ ជនទាំងឡាយមកកាន់ទីកន្លែងដែលភិក្ខុនីឈរនៅ ឬអង្គុយ ឬសឹង ហើយរាំក្តី ច្រៀងក្តី ប្រគំក្តី១ ភិក្ខុនីកំពុងដើរទៅជួបតាមផ្លូវហើយឃើញក្តី ស្តាប់ក្តី១ កាលបើភិក្ខុនីមានកិច្ចដើរទៅហើយឃើញក្តី ឮក្តី១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

លសុណវគ្គ ទី ១ ចប់។

# (បាចិត្តិយ) អន្ធការវគ្គ (ទី២)

CS vin.vbi.pc.v2 | ភាគ ទី៥

### (២. អន្ធការវគ្គោ)

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី១

### (១. បឋមសិក្ខាបទំ)

[១៨៥] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានបុរសជាញាតិរបស់ភិក្ខុនីជាកូនសិស្សភទ្ទាកាបិលានីភិក្ខុនី ចេញពីស្រុកក្រៅទៅកាន់ក្រុងសាវត្ថី ដោយមានកិច្ចនីមួយ។ កាលនោះ ភិក្ខុនីនោះ ស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរសនោះ ក្នុងយប់ងងឹតឥតមានប្រទីបឡើយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹងស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីបសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីប ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនសមនឹងស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីបទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយស្ថិតនៅក្តី និយាយក្តី តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីប ត្រូវអាបត្តិបាចិត្តិយ។**

[១៨៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ពាក្យថា ក្នុងយប់ងងឹត សេចក្តីថា ក្នុងវេលាដែលព្រះអាទិត្យលិចចុះទៅហើយ។ ពាក្យថា ឥតមានប្រទីប សេចក្តីថា មិនមានពន្លឺ។ ដែលហៅថាបុរស បានដល់មនុស្សប្រុសជាអ្នកដឹងសេចក្តី អាចដើម្បីស្ថិតនៅផង និយាយផង មិនមែនយក្ស មិនមែនប្រេត មិនមែនតិរច្ឆាន។ ពាក្យថា មួយអន្លើ គឺក្នុងទីជាមួយគ្នា។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺមានតែបុរស១ និងភិក្ខុនី១។ ពាក្យថា ស្ថិតនៅ សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរស ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា និយាយ សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរសហើយចរចា ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីលះបង់ហត្ថបាស ហើយស្ថិតនៅក្តី និយាយក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ថិតនៅក្តី និយាយក្តី មួយអន្លើដោយយក្សក្តី ប្រេតក្តី បណ្ឌកក្តី សត្វតិរច្ឆានដែលមានរាងកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ។

[១៨៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺមានភិក្ខុនីណាមួយដឹងសេចក្តីនៅជាគំរប់ពីរ១ ភិក្ខុនីប្រាថ្នានូវទីមិនស្ងាត់ (ហើយស្ថិតនៅក្តី និយាយក្តី)១ ភិក្ខុនីមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃ ហើយស្ថិតនៅក្តី និយាយក្តី១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី២



### (២. ទុតិយសិក្ខាបទំ)

[១៨៨] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានបុរសជាញាតិរបស់ភិក្ខុនីជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី បានចេញពីស្រុកក្រៅទៅក្រុងសាវត្ថី ដោយកិច្ចនីមួយ។ កាលនោះ ភិក្ខុនីនោះគិតថា ការស្ថិតនៅក្តី និយាយក្តី តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងយប់ងងឹតឥតមានប្រទីប ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (គិតដូច្នោះហើយ) ក៏ស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់មួយអន្លើដោយបុរសនោះឯង ក្នុងទីឱកាសដ៏កំបាំង។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹងស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងទីឱកាសដ៏កំបាំងសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងទីឱកាសដ៏កំបាំង ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនសមនឹងស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងទីដ៏កំបាំងទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយស្ថិតនៅក្តី និយាយក្តី តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងទីដ៏កំបាំង ត្រូវអាបត្តិបាចិត្តិយ។**

[១៨៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ទីកំបាំង បានដល់ទីឱកាសដែលគេបិទបាំងដោយវត្ថុណាមួយ គឺដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយផែងក្តី ដោយវាំងននក្តី ដោយដើមឈើក្តី ដោយសសរក្តី ដោយល្វែងបន្ទប់ក្តី។ ដែលហៅថាបុរស បានដល់មនុស្សប្រុសដែលដឹងក្តី យល់ការ ដើម្បីស្ថិតនៅ ដើម្បីនិយាយ មិនមែនយក្ស មិនមែនប្រេត មិនមែនតិរច្ឆាន។ ពាក្យថា មួយអន្លើ គឺក្នុងទីជាមួយគ្នា។ ពាក្យថា តែម្នាក់នឹងម្នាក់ សេចក្តីថា មានតែបុរស១ និងភិក្ខុនី១។ ពាក្យថា ស្ថិតនៅក្តី សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរស ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា និយាយក្តី សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរសហើយនិយាយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីលះបង់ហត្ថបាស ហើយស្ថិតនៅក្តី និយាយក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ថិតនៅ ឬនិយាយ មួយអន្លើដោយយក្សក្តី ប្រេតក្តី បណ្ឌកក្តី សត្វតិរច្ឆានមានរាងកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ។

[១៩០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺមានភិក្ខុនីណាមួយដឹងសេចក្តីច្បាស់នៅជាគំរប់ពីរ១ ភិក្ខុនីប្រាថ្នានូវទីមិនស្ងាត់ (ហើយស្ថិតនៅក្តី និយាយក្តី)១ ភិក្ខុនីមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃ ហើយស្ថិតនៅក្តី និយាយក្តី១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.pc.13 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[១៩១] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានបុរសជាញាតិរបស់ភិក្ខុនីជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី បានចេញពីស្រុកក្រៅទៅក្រុងសាវត្ថី ដោយកិច្ចនីមួយ។ កាលនោះ ភិក្ខុនីនោះគិតថា ការស្ថិតនៅក្តី និយាយក្តី តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងទីឱកាសដ៏កំបាំង ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (គិតដូច្នោះហើយ) ក៏ស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់មួយអន្លើដោយបុរសនោះឯងក្នុងទីវាល។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹងស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងទីវាលសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងទីវាល ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនសមនឹងស្ថិតនៅខ្លះ និយាយខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងទីវាលទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយស្ថិតនៅក្តី និយាយក្តី តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរសក្នុងទីវាល ត្រូវអាបត្តិបាចិត្តិយ។**

[១៩២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ទីវាល បានដល់ទីដែលគេមិនបិទបាំង គឺទីដែលគេមិនបិទបាំងដោយវត្ថុណាមួយ គឺជញ្ជាំងក្តី សន្ទះទ្វារក្តី ផែងក្តី រាំងននក្តី ដើមឈើក្តី សសរក្តី ល្វែងបន្ទប់ក្តី។ ដែលហៅថា បុរស បានដល់មនុស្សប្រុសដែលដឹងក្តី យល់ការ ស្ថិតនៅបាន និយាយបាន មិនមែនយក្ស មិនមែនប្រេត មិនមែនតិរច្ឆាន។ ពាក្យថា មួយអន្លើ គឺក្នុងទីជាមួយគ្នា។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺមានតែបុរស១ និងភិក្ខុនី១។ ពាក្យថា ស្ថិតនៅក្តី សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរស ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា និយាយក្តី សេចក្តីថា ភិក្ខុនីស្ថិតនៅក្នុងហត្ថបាសនៃបុរស ហើយនិយាយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីលះបង់ហត្ថបាស ហើយស្ថិតនៅក្តី និយាយក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីស្ថិតនៅ ឬនិយាយ មួយអន្លើដោយយក្សក្តី ប្រេតក្តី បណ្ឌកក្តី សត្វតិរច្ឆានមានរាងកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ។

[១៩៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺមានភិក្ខុនីណាមួយដឹងសេចក្តីច្បាស់នៅជាគំរប់ពីរ១ ភិក្ខុនីប្រាថ្នានូវទីមិនស្ងាត់ (ហើយស្ថិតនៅក្តី និយាយក្តី)១ ភិក្ខុនីមានចិត្តបញ្ជូនទៅក្នុងអារម្មណ៍ដទៃ ហើយស្ថិតនៅក្តី និយាយក្តី១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.14 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[១៩៤] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីឈរនៅខ្លះ និយាយខ្លះ ខ្សិបជិតត្រចៀកខ្លះ តែម្នាក់និងម្នាក់ មួយអន្លើដោយបុរស ក្នុងច្រករហូតខ្លះ ក្នុងច្រកទាល់ (កៀនកោះ)ខ្លះ ក្នុងទីប្រជុំផ្លូវមានជ្រុង៤ ឬមានជ្រុង៣ខ្លះ បណ្តេញភិក្ខុនីជាគូកនចេញទៅខ្លះ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមនឹងឈរនៅខ្លះ និយាយខ្លះ ខ្សិបជិតត្រចៀកខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងច្រករហូតខ្លះ ក្នុងច្រកទាល់ខ្លះ ក្នុងទីប្រជុំផ្លូវមានជ្រុង៤ ឬជ្រុង៣ខ្លះ បណ្តេញភិក្ខុនីជាគូកនចេញទៅខ្លះសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីឈរនៅខ្លះ និយាយខ្លះ ខ្សិបជិតត្រចៀកខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងច្រករហូតខ្លះ ក្នុងច្រកទាល់ខ្លះ ក្នុងទីប្រជុំផ្លូវមានជ្រុង៤ ឬជ្រុង៣ខ្លះ បណ្តេញភិក្ខុនីជាគូកនចេញខ្លះ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមនឹងឈរនៅខ្លះ និយាយខ្លះ ខ្សិបជិតត្រចៀកខ្លះ តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរស ក្នុងច្រករហូតខ្លះ ក្នុងច្រកទាល់ខ្លះ ក្នុងទីប្រជុំផ្លូវមានជ្រុង៤ ឬជ្រុង៣ខ្លះ បណ្តេញភិក្ខុនីជាគូកនខ្លះទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយឈរនៅក្តី និយាយក្តី ខ្សិបជិតត្រចៀកក្តី តែម្នាក់នឹងម្នាក់ មួយអន្លើដោយបុរសក្នុងច្រករហូតក្តី ក្នុងច្រកទាល់ក្តី ក្នុងទីប្រជុំផ្លូវមានជ្រុង៤ ឬជ្រុង៣ក្តី បណ្តេញភិក្ខុនីជាគូកនចេញក្តី ត្រូវអាបត្តិបាចិត្តិយ។**

[១៩៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ច្រករហូត បានដល់ផ្លូវដែលរថចេញចូលបាន (ថ្នល់)។ ដែលហៅថា ច្រកទាល់ បានដល់ទីដែលជនទាំងឡាយចូលទៅតាមផ្លូវណា ចេញទៅតាមផ្លូវនោះវិញទើបបាន។ ដែលហៅថា ទីប្រជុំផ្លូវមានជ្រុង៤ ឬជ្រុង៣ បានដល់ស្នាម ឬព្រះលាន។ ដែលហៅថា បុរស បានដល់មនុស្សប្រុសដែលដឹងសេចក្តីច្បាស់ អាចឈរនៅបាន និយាយបាន មិនមែនយក្ស មិនមែនប្រេត មិនមែនសត្វតិរច្ឆាន។ ពាក្យថា មួយអន្លើ គឺក្នុងទីជាមួយគ្នា។ ពាក្យថា ម្នាក់នឹងម្នាក់ គឺមានតែបុរស១ និងភិក្ខុនី១។ ពាក្យថា ឈរនៅក្តី សេចក្តីថា ភិក្ខុនីឈរនៅក្នុងហត្ថបាសនៃបុរស ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា និយាយក្តី សេចក្តីថា ភិក្ខុនីឈរនៅក្នុងហត្ថបាសនៃបុរស ហើយនិយាយ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ខ្សិបជិតត្រចៀកក្តី សេចក្តីថា ភិក្ខុនីប្រាប់សេចក្តីជិតត្រចៀកនៃបុរស ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា បណ្តេញភិក្ខុនីជាគូកនចេញក្តី សេចក្តីថា ភិក្ខុនីមានសេចក្តីប្រាថ្នាដើម្បីប្រព្រឹត្តអនាចារ ហើយបណ្តេញភិក្ខុនីជាគំរប់ពីរ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីជាគូកនកំពុងលះបង់ឧបចារសម្រាប់ឃើញក្តី ឧបចារសម្រាប់ស្តាប់ក្តី ភិក្ខុនីអ្នកបណ្តេញ ត្រូវអាបត្តិទុក្កដ លុះភិក្ខុនីជាគូកនលះបង់ឧបចារផុតទៅហើយ ភិក្ខុនីអ្នកបណ្តេញ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីលះបង់ហត្ថបាស ហើយឈរនៅក្តី និយាយក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីឈរនៅក្តី និយាយក្តី មួយអន្លើដោយយក្សក្តី ប្រេតក្តី បណ្ឌកក្តី សត្វតិរច្ឆានមានរាងកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ។

[១៩៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺមានភិក្ខុនីណាមួយដឹងសេចក្តីច្បាស់នៅជាគំរប់ពីរ១ ភិក្ខុនីប្រាថ្នានូវទីមិនស្ងាត់ (ហើយឈរនៅក្តី និយាយក្តី)១ ភិក្ខុនីមានចិត្តបញ្ជូនទៅក្នុងអារម្មណ៍ឯទៀត ហើយឈរនៅក្តី និយាយក្តី១ ភិក្ខុនីមិនមានសេចក្តីប្រាថ្នាដើម្បីប្រព្រឹត្តអនាចារ ហើយបណ្តេញភិក្ខុនីជាគូកន១ ភិក្ខុនីមានកិច្ច ហើយបណ្តេញភិក្ខុនីជាគូកន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.15 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[១៩៧] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង មានភិក្ខុនី១រូបជាជីតុនប្រកបដោយនិច្ចភត្តរបស់ត្រកូល១។ កាលនោះ ភិក្ខុនីនោះស្លៀកស្បង់អំពីព្រឹក ហើយប្រដាប់បាត្រនិងចីវរ ចូលទៅរកត្រកូលនោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ហើយមិនបានលាពួកជនជាម្ចាស់ផ្ទះ ក៏ចៀសចេញទៅ។ ខ្ញុំស្រីរបស់ត្រកូលនោះ កាលបោសផ្ទះ ក៏ដាក់អាសនៈនោះទៅក្នុងកន្លៀតភាជន៍។ មនុស្សទាំងឡាយមិនឃើញអាសនៈនោះ ក៏និយាយពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រលោកម្ចាស់ អាសនៈនៅឯណា។ ភិក្ខុនីនោះប្រាប់ថា ម្នាលអាវុសោ អាត្មាមិនឃើញអាសនៈនោះទេ។ មនុស្សទាំងឡាយទារយកអាសនៈនោះវិញថា នែលោកម្ចាស់ ចូរឲ្យអាសនៈនេះមក ហើយក៏ផ្តាសាផ្តាច់ទាំងនិច្ចភត្តនោះចេញ។ ទើបពួកមនុស្សនោះនាំគ្នាជម្រះសំអាតផ្ទះ ក៏ឃើញអាសនៈនោះនៅក្នុងកន្លៀតភាជន៍ ហើយសូមឲ្យភិក្ខុនីនោះអត់ទោស រួចក៏ប្រគេននិច្ចភត្តវិញ។ ឯភិក្ខុនីនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមនឹងចូលទៅរកត្រកូលមុនពេលបាយ ហើយអង្គុយលើអាសនៈ រួចមិនលាពួកជនជាម្ចាស់ផ្ទះ ហើយចៀសចេញទៅសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីចូលទៅរកត្រកូលក្នុងពេលមុនបាយ ហើយអង្គុយលើអាសនៈ រួចមិនលាពួកជនជាម្ចាស់ ក៏ចៀសចេញទៅ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី មិនសមនឹងចូលទៅរកត្រកូលទាំងឡាយក្នុងពេលមុនបាយ ហើយអង្គុយលើអាសនៈ រួចមិនបានលាពួកជនជាម្ចាស់ផ្ទះ ហើយចៀសចេញទៅទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយចូលទៅរកត្រកូលទាំងឡាយក្នុងពេលមុនបាយ ហើយអង្គុយលើអាសនៈ រួចមិនបានលាពួកជនជាម្ចាស់ផ្ទះ ចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។**

[១៩៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ក្នុងពេលមុនបាយ គឺរាប់ចាប់តាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់។ ដែលហៅថា ត្រកូល បានដល់ត្រកូលទាំង៤ គឺត្រកូលក្សត្រ១ ត្រកូលព្រាហ្មណ៍១ ត្រកូលអ្នករកស៊ី (ជួញប្រែធ្វើស្រែចំការជាដើម)១ ត្រកូលអ្នករកស៊ីឈ្នួលគេ១។ ពាក្យថា ចូលទៅរក គឺទៅក្នុងត្រកូលនោះ។ ដែលហៅថា អាសនៈ សំដៅយកឱកាសនៃទីអង្គុយ។ ពាក្យថា អង្គុយនៅ គឺអង្គុយលើអាសនៈនោះ។ ពាក្យថា មិនបានលាពួកជនជាម្ចាស់ផ្ទះ ហើយចៀសចេញទៅ សេចក្តីថា មនុស្សណាជាម្ចាស់ផ្ទះក្នុងត្រកូលនោះ ដែលអាចដើម្បីប្រគេន (វត្ថុអ្វីៗបាន) ភិក្ខុនីមិនលាមនុស្សនោះ។ កាលភិក្ខុនីឈានផុតទីដែលភ្លៀងធ្លាក់មិនត្រូវ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីកន្លងឧបចារផ្ទះ ចូលទៅក្នុងទីវាល ត្រូវអាបត្តិបាចិត្តិយ។

[១៩៩] ម្ចាស់ផ្ទះដែលខ្លួនមិនបានលា ភិក្ខុនីសំគាល់ថាមិនបានលាមែន ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ ម្ចាស់ផ្ទះដែលខ្លួនមិនបានលា តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ ម្ចាស់ផ្ទះដែលខ្លួនមិនបានលា ភិក្ខុនីសំគាល់ថាបានលា ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ (ភិក្ខុនីអង្គុយ) ក្នុងទីមិនមែនជាទីឱកាសនៃទីអង្គុយ (មិនលា ហើយចៀសចេញទៅ) ត្រូវអាបត្តិទុក្កដ។ ម្ចាស់ផ្ទះដែលខ្លួនបានលាហើយ ភិក្ខុនីសំគាល់ថាមិនទាន់លា ត្រូវអាបត្តិទុក្កដ។ ម្ចាស់ផ្ទះដែលខ្លួនបានលាហើយ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ម្ចាស់ផ្ទះដែលខ្លួនបានលាហើយ ភិក្ខុនីសំគាល់ថាបានលាមែន មិនត្រូវអាបត្តិ។

[២០០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុនីលាហើយទើបទៅ១ ភិក្ខុនីអង្គុយលើអាសនៈដែលគេនាំយកទៅមិនបាន១ ភិក្ខុនីមានជម្ងឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.pc.16 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[២០១] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីចូលទៅរកត្រកូលទាំងឡាយក្នុងពេលក្រោយបាយ ហើយមិនប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈ។ ពួកមនុស្សកាលខ្លាចថុល្លនន្ទាភិក្ខុនី ក៏មិនហ៊ានអង្គុយ មិនហ៊ានដេកលើអាសនៈ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមនឹងចូលទៅរកត្រកូលទាំងឡាយក្នុងពេលក្រោយបាយ ហើយមិនបានប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈសោះ។ ភិក្ខុនីទាំងលាយឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះហើយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមនឹងចូលទៅរកត្រកូលទាំងឡាយក្នុងពេលក្រោយបាយ ហើយមិនបានប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីចូលទៅរកត្រកូលទាំងឡាយក្នុងពេលក្រោយបាយ ហើយមិនប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះ លើអាសនៈ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមនឹងចូលទៅរកត្រកូលទាំងឡាយក្នុងពេលក្រោយបាយ ហើយមិនបានប្រាប់ពួកជនជាម្ចាស់ផ្ទះ ក៏អង្គុយខ្លះ ដេកខ្លះលើអាសនៈទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយចូលទៅរកត្រកូលទាំងឡាយក្នុងពេលក្រោយបាយ មិនប្រាប់ពួកជនជាម្ចាស់ផ្ទះ ហើយអង្គុយក្តី ដេកក្តី លើអាសនៈ ត្រូវអាបត្តិបាចិត្តិយ។**

[២០២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា ពេលខាងក្រោយបាយ បានដល់ពេលដែលព្រះអាទិត្យជ្រេពីត្រង់រហូតដល់ព្រះអាទិត្យអស្តង្គតទៅ។ ដែលហៅថា ត្រកូល បានដល់ត្រកូលទាំង៤ គឺត្រកូលក្សត្រ១ ត្រកូលព្រាហ្មណ៍១ ត្រកូលអ្នករកស៊ីជួញប្រែធ្វើស្រែចំការ១ ត្រកូលអ្នករកស៊ីឈ្នួល១។ ពាក្យថា ចូលទៅរក គឺទៅក្នុងត្រកូលនោះ។ ពាក្យថា មិនបានប្រាប់ពួកជនជាម្ចាស់ផ្ទះ សេចក្តីថា មនុស្សណា ជាម្ចាស់ឬធំក្នុងត្រកូលនោះ ដែលអាចដើម្បីប្រគេន (វត្ថុអ្វីៗបាន) ភិក្ខុនីមិនប្រាប់មនុស្សនោះ។ ដែលហៅថា អាសនៈ បានដល់ឱកាសល្មមអង្គុយពែនបាន។ ពាក្យថា អង្គុយ សេចក្តីថា ភិក្ខុនីអង្គុយលើអាសនៈនោះ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ដេក សេចក្តីថា ភិក្ខុនីដេកលើអាសនៈនោះ ត្រូវអាបត្តិបាចិត្តិយ។

[២០៣] ម្ចាស់ផ្ទះដែលខ្លួនមិនទាន់បានប្រាប់ ភិក្ខុនីសំគាល់ថាមិនទាន់បានប្រាប់មែន ហើយអង្គុយក្តី ដេកក្តី លើអាសនៈ ត្រូវអាបត្តិបាចិត្តិយ។ ម្ចាស់ផ្ទះដែលខ្លួនមិនបានប្រាប់ តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយអង្គុយក្តី ដេកក្តីលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ។ ម្ចាស់ផ្ទះដែលខ្លួនមិនបានប្រាប់ តែភិក្ខុនីសំគាល់ថាបានប្រាប់ ហើយអង្គុយក្តី ដេកក្តី លើអាសនៈ ត្រូវអាបត្តិបាចិត្តិយ។ (ភិក្ខុនីអង្គុយ ឬដេក) ក្នុងទីមិនមែនជាទីឱកាសនៃទីអង្គុយ ត្រូវអាបត្តិទុក្កដ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ តែភិក្ខុនីសំគាល់ថាមិនទាន់បានប្រាប់ ត្រូវអាបត្តិទុក្កដ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ហើយ តែភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ហើយ ភិក្ខុនីសំគាល់ថាបានប្រាប់ហើយមែន មិនត្រូវអាបត្តិ។

[២០៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុនីបានប្រាប់ហើយអង្គុយក្តី ដេកក្តីលើអាសនៈ១ ភិក្ខុនីអង្គុយ ឬដេកលើអាសនៈដែលគេក្រាលជានិច្ច១ ភិក្ខុនីមានជម្ងឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី៧

CS vin.vbi.pc.17 | ភាគ ទី៥

### (៧. សត្តមសិក្ខាបទំ)

[២០៥] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកភិក្ខុនីច្រើនរូបកាលដែលទៅកាន់ក្រុងសាវត្ថី ក្នុងកោសលជនបទ ក៏ចូលទៅកាន់ស្រុក១ ក្នុងវេលាល្ងាច ហើយចូលទៅរកត្រកូលព្រាហ្មណ៍ម្នាក់ ហើយក៏សូមឱកាស។ កាលនោះ នាងព្រាហ្មណីបានពោលពាក្យនេះនឹងភិក្ខុនីទាំងនោះថា បពិត្រលោកម្ចាស់ សូមលោកទាំងឡាយរង់ចាំសិនទំរាំព្រាហ្មណ៍មក។ ពួកភិក្ខុនីគិតគ្នាថា នឹងបង្អង់ចាំព្រាហ្មណ៍មកសិនដែរ គិតដូច្នោះហើយ ក៏ក្រាលកម្រាលសម្រាប់ដេក រួចខ្លះអង្គុយ ខ្លះដេក។ ឯព្រាហ្មណ៍នោះមកក្នុងរាត្រី ហើយពោលពាក្យនេះនឹងព្រាហ្មណីនោះថា ស្រីទាំងនេះជាអ្វី។ នាងព្រាហ្មណីឆ្លើយថា បពិត្រអ្នកម្ចាស់ (ស្រីទាំងឡាយនេះជា) ភិក្ខុនី។ ព្រាហ្មណ៍ពោលថា អ្នកទាំងឡាយចូរទង់ទាញស្រីផ្កាមាសត្រងោលនេះចេញ ថាដូច្នោះហើយ ក៏ឲ្យគេទង់ទាញចេញពីផ្ទះទៅ។ ឯភិក្ខុនីទាំងនោះនាំគ្នាទៅកាន់ក្រុងសាវត្ថី ហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនី មិនសមនឹងចូលទៅកាន់ត្រកូលក្នុងវេលាវិកាល ហើយមិនបានប្រាប់ពួកជនជាម្ចាស់សិន ក៏ក្រាលឯងខ្លះ ឲ្យគេក្រាលខ្លះនូវកម្រាលសម្រាប់ដេក រួចអង្គុយខ្លះ ដេកខ្លះសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនីចូលទៅរកត្រកូលទាំងឡាយក្នុងវេលាវិកាល ហើយមិនទាន់បានប្រាប់ពួកជនជាម្ចាស់សិន ក៏ក្រាលឯងខ្លះ ឲ្យគេក្រាលខ្លះនូវកម្រាលសម្រាប់ដេក ហើយអង្គុយខ្លះ ដេកខ្លះ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មាន

ព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី មិនសមនឹងចូលទៅរកត្រកូលទាំងឡាយក្នុងវេលាវិកាល មិនទាន់បានប្រាប់ពួកជនជាម្ចាស់សិន ហើយក្រាលឯងខ្លះ ឲ្យគេក្រាលខ្លះនូវកម្រាលសម្រាប់ដេក រួចអង្គុយខ្លះ ដេកខ្លះទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយចូលទៅរកត្រកូលទាំងឡាយក្នុងវេលាវិកាល ហើយមិនទាន់បានប្រាប់ពួកជនជាម្ចាស់សិន ក៏ក្រាលឯងក្តី ឲ្យគេក្រាលក្តីនូវកម្រាលសម្រាប់ដេក ហើយអង្គុយក្តី ដេកក្តី ត្រូវអាបត្តិបាចិត្តិយ។**

[២០៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ដែលហៅថា វេលាវិកាល គឺតាំងពីព្រះអាទិត្យអស្តង្គតទៅដរាបដល់អរុណរះឡើង។ ដែលហៅថា ត្រកូល បានដល់ត្រកូលទាំង៤ គឺត្រកូលក្សត្រ១ ត្រកូលព្រាហ្មណ៍១ ត្រកូលអ្នករកស៊ីជួញប្រែធ្វើស្រែចំការ១ ត្រកូលអ្នកស៊ីឈ្នួលគេ១។ ពាក្យថា ចូលទៅរក គឺទៅក្នុងត្រកូលនោះ។ ពាក្យថា មិនទាន់បានប្រាប់ពួកជនជាម្ចាស់សិន សេចក្តីថា មនុស្សណា ជាម្ចាស់ក្នុងត្រកូលនោះ ដែលអាចដើម្បីប្រគេន (វត្ថុអ្វីៗបាន) ភិក្ខុនីមិនទាន់បានប្រាប់មនុស្សនោះ។ ដែលហៅថា កម្រាលសម្រាប់ដេក ដោយហោចទៅ សូម្បីតែកម្រាលជាវិការនៃស្លឹកឈើ (ក៏ជាកម្រាលដែរ)។ ពាក្យថា ក្រាលឯង គឺក្រាលដោយខ្លួនឯង។ ពាក្យថា ឲ្យគេក្រាល គឺឲ្យអ្នកដទៃក្រាល។ ពាក្យថា អង្គុយ សេចក្តីថា ភិក្ខុនីអង្គុយលើកម្រាលសម្រាប់ដេកនោះ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ដេក គឺភិក្ខុនីដេកលើកម្រាលសម្រាប់ដេកនោះ ត្រូវអាបត្តិបាចិត្តិយ។

[២០៧] ម្ចាស់ផ្ទះដែលខ្លួនមិនទាន់បានប្រាប់ ភិក្ខុនីសំគាល់ថាមិនទាន់បានប្រាប់មែន ហើយក្រាលឯងក្តី ឲ្យគេក្រាលក្តីនូវកម្រាលសម្រាប់ដេក ហើយអង្គុយក្តី ដេកក្តី ត្រូវអាបត្តិបាចិត្តិយ។ ម្ចាស់ផ្ទះដែលខ្លួនមិនទាន់បានប្រាប់ តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយក្រាលឯងក្តី ឲ្យគេក្រាលក្តី នូវកម្រាលសម្រាប់ដេក ហើយអង្គុយក្តី ដេកក្តី ត្រូវអាបត្តិបាចិត្តិយ។ ម្ចាស់ផ្ទះដែលខ្លួនមិនទាន់បានប្រាប់ ភិក្ខុនីសំគាល់ថាបានប្រាប់ទៅវិញ ហើយក្រាលឯងក្តី ឲ្យគេក្រាលក្តី នូវកម្រាលសម្រាប់ដេក ហើយអង្គុយក្តី ដេកក្តី ត្រូវអាបត្តិបាចិត្តិយ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ ភិក្ខុនីសំគាល់ថាមិនទាន់បានប្រាប់ទៅវិញ ត្រូវអាបត្តិទុក្កដ។ ម្ចាស់ផ្ទះដែលខ្លួនបានប្រាប់ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ម្ចាស់ផ្ទះដែលខ្លួនប្រាប់ហើយ ភិក្ខុនីសំគាល់ថាបានប្រាប់ហើយមែន មិនត្រូវអាបត្តិ។

[២០៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីប្រាប់ហើយក្រាលឯងក្តី ឲ្យគេក្រាលនូវកម្រាលសម្រាប់ដេក ហើយអង្គុយក្តី ដេកក្តី១ ភិក្ខុនីមានជម្ងឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី៨

CS vin.vbi.pc.18 | ភាគ ទី៥

### (៨. អដ្ឋមសិក្ខាបទំ)

[២០៩] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី តែងតែបម្រើភទ្ទាកាបិលានីភិក្ខុនីដោយគោរព។ ភទ្ទាកាបិលានីភិក្ខុនីបានពោលពាក្យនេះនឹងពួកភិក្ខុនីថា បពិត្រលោកម្ចាស់ ភិក្ខុនីនេះតែងបម្រើខ្ញុំដោយគោរព ខ្ញុំនឹងឲ្យចីវរដល់ភិក្ខុនីនេះ។ ឯភិក្ខុនីនោះពោលមើលងាយវិញ ដោយការប្រកាន់យកអាក្រក់របស់ខ្លួន ដោយការពិចារណាខុស (របស់ខ្លួន)ថា បពិត្រលោកម្ចាស់ ឮថាខ្ញុំមិនបម្រើលោកម្ចាស់ដោយគោរពទេ ឮថាលោកម្ចាស់មិនឲ្យចីវរមកខ្ញុំទេ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនី មិនសមនឹងមើលងាយគេ ដោយការប្រកាន់អាក្រក់ ដោយការពិចារណាខុសសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីមើលងាយគេដោយការប្រកាន់យកអាក្រក់ ដោយការពិចារណាខុស ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនសមបើនឹងមើលងាយគេដោយការប្រកាន់យកអាក្រក់ ដោយការពិចារណាខុសទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយមើលងាយគេដោយការប្រកាន់យកអាក្រក់ ដោយការពិចារណាខុស ត្រូវអាបត្តិបាចិត្តិយ។**

[២១០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ពាក្យថា ដោយការប្រកាន់យកអាក្រក់ សេចក្តីថា ដោយការប្រកាន់យកដោយប្រការដទៃ (គឺប្រកាន់ខុស)។ ពាក្យថា ដោយការពិចារណាខុស សេចក្តីថា ដោយការពិចារណាដោយប្រការដទៃ (យល់ខុស)។ ពាក្យថា មើលងាយគេ សេចក្តីថា ភិក្ខុនីមើលងាយឧបសម្បន្នាផងគ្នា ត្រូវអាបត្តិបាចិត្តិយ។

[២១១] ឧបសម្បន្នា ភិក្ខុនីសំគាល់ថាឧបសម្បន្នាមែន ហើយមើលងាយ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ហើយមើលងាយ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាអនុបសម្បន្នាទៅវិញ ហើយមើលងាយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមើលងាយអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថា ឧបសម្បន្នាទៅវិញ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នាមែន ត្រូវអាបត្តិទុក្កដ។

[២១២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន២យ៉ាង) គឺ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.pc.19 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[២១៣] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកភិក្ខុនី កាលមិនឃើញភណ្ឌរបស់ខ្លួន បានពោលពាក្យនេះនឹងចណ្ឌកាលីភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ឃើញភណ្ឌរបស់ពួកយើងដែរឬ។ ចណ្ឌកាលីភិក្ខុនីក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ខ្ញុំឯងជាស្រីចោរពិតឬ ខ្ញុំឯងជាស្រីគ្មានសេចក្តីខ្មាសពិតឬ ពួកលោកម្ចាស់ណាមិនឃើញភណ្ឌរបស់ខ្លួន ពួកលោកម្ចាស់នោះពោលនឹងខ្ញុំយ៉ាងនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់ឃើញភណ្ឌរបស់យើងដែរឬទេ បពិត្រលោកម្ចាស់ ប្រសិនបើខ្ញុំយកភណ្ឌរបស់លោកមែន ខ្ញុំមិនមែនជាសមណីទេ ខ្ញុំឃ្លាតចាកព្រហ្មចរិយធម៌ហើយ ខ្ញុំនឹងទៅកើតក្នុងនរក ចំណែកឯភិក្ខុនីណាពោលពាក្យយ៉ាងនេះនឹងខ្ញុំដោយពាក្យមិនពិត ភិក្ខុនីនោះឯង ចូរកុំឲ្យជាសមណី ចូរឃ្លាតចាកព្រហ្មចរិយធម៌ ចូរទៅកើតក្នុងនរកចុះ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចណ្ឌកាលីជាម្ចាស់ មិនសមនឹងផ្តាសាខ្លួនឯងផង អ្នកឯទៀតផង ដោយនរកផង ដោយព្រហ្មចរិយធម៌ផងសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនីផ្តាសាខ្លួនឯងផង អ្នកឯទៀតផង ដោយនរកខ្លះ ដោយព្រហ្មចរិយធម៌ខ្លះ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនី មិនសមនឹងផ្តាសាខ្លួនក្តី អ្នកឯទៀតក្តី ដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តីទេ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយផ្តាសាខ្លួនឯងក្តី អ្នកឯទៀតក្តី ដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ។**

[២១៤] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ពាក្យថា ខ្លួនឯង គឺចំពោះខ្លួនឯង។ ពាក្យថា អ្នកឯទៀត សេចក្តីថា ភិក្ខុនីផ្តាសាឧបសម្បន្នាផងគ្នា ដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ។

[២១៥] ឧបសម្បន្នា ភិក្ខុនីសំគាល់ថាឧបសម្បន្នាមែន ហើយផ្តាសាដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយផ្តាសាដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នាទៅវិញ ហើយផ្តាសាដោយនរកក្តី ដោយព្រហ្មចរិយធម៌ក្តី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីផ្តាសាដោយកំណើតនៃសត្វតិរច្ឆានក្តី ដោយបេតវិស័យក្តី ដោយភាវជាមនុស្សមានត្រកូលថោកទាបក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីផ្តាសាអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នាទៅវិញ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា តែភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នាដដែល ត្រូវអាបត្តិទុក្កដ។

[២១៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីផ្តាសាព្រោះធ្វើអត្ថឲ្យជាប្រធាន១ ភិក្ខុនីផ្តាសាព្រោះធ្វើធម៌ឲ្យជាប្រធាន១ ភិក្ខុនីផ្តាសាព្រោះធ្វើពាក្យប្រៀនប្រដៅឲ្យជាប្រធាន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អន្ធការវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.pc.20 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[២១៧] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនីឈ្លោះនឹងភិក្ខុនីទាំងឡាយ ក៏វាយតប់ទះខ្លួនឯង ហើយយំ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនីនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ចណ្ឌកាលីភិក្ខុនី មិនសមនឹងវាយតប់ទះខ្លួន ហើយយំសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនី វាយតប់ទះខ្លួនឯង ហើយយំ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនី មិនសមនឹងវាយតប់ទះខ្លួនឯង ហើយយំសោះ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយវាយតប់ទះខ្លួនឯង ហើយយំ ត្រូវអាបត្តិបាចិត្តិយ។**

[២១៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ពាក្យថា ខ្លួនឯង គឺចំពោះខ្លួនឯង។ ភិក្ខុនីវាយតប់ទះ ហើយយំ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីគ្រាន់តែវាយតែមិនយំ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីគ្រាន់តែយំ តែមិនបានវាយ ត្រូវអាបត្តិទុក្កដ។

[២១៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីមានសេចក្តីវិនាសញាតិក្តី សេចក្តីវិនាសភោគសម្បត្តិក្តី សេចក្តីវិនាសព្រោះរោគក្តី មកប៉ះពាល់ហើយយំតែមិនវាយ (ខ្លួនឯង)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

អន្តការវគ្គ ទី ២ ចប់។

# (បាចិត្តិយ) នគ្គវគ្គ (ទី៣)

CS vin.vbi.pc.v3 | ភាគ ទី៥

### (៣. នគ្គវគ្គោ)

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី១

CS vin.vbi.pc.21 | ភាគ ទី៥

### (១. បឋមសិក្ខាបទំ)

[២២០] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកភិក្ខុនីច្រើនរូប មានកាយអាក្រាតងូតទឹកឰដ៏កំពង់ទឹកមួយ ជាមួយនឹងពួកស្រីពេស្យាក្នុងស្ទឹងអចិរវតី។ ពួកស្រីពេស្យានាំគ្នាចំអកលេងនឹងភិក្ខុនីទាំងនោះថា នែលោកម្ចាស់ទាំងឡាយ ពួកលោកកំពុងពេញក្រមុំ ខំសន្សំព្រហ្មចរិយធម៌ប្រយោជន៍អ្វី ពួកលោកគួរតែនៅបរិភោគកាមទៅសិន កាលណាលោកទាំងឡាយចាស់ សឹមពួកលោកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងកាលណោះចុះ កាលបើធ្វើយ៉ាងនេះ ប្រយោជន៍ទាំងពីរឈ្មោះថា ពួកលោកបានកាន់យកហើយ។ ភិក្ខុនីទាំងឡាយ កាលដែលពួកស្រីពេស្យានិយាយចំអក(ដូច្នោះ) ក៏មានសេចក្តីអៀនខ្មាស។ គ្រានោះ ភិក្ខុនីទាំងនោះនាំគ្នាទៅកាន់លំនៅ ហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុនីទាំងឡាយ ព្រោះអាស្រ័យនូវប្រយោជន៍ទាំងឡាយ១០ប្រការ គឺដើម្បីសេចក្តី ល្អដល់សង្ឃ១។បេ។ ដើម្បីអនុគ្រោះដល់វិន័យ១ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយអាក្រាតកាយងូតទឹក ត្រូវអាបត្តិបាចិត្តិយ។**

[២២១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានសេចក្តីអធិប្បាយក្នុងបារាជិកកណ្ឌទី១រួចហើយ។ ពាក្យថា អាក្រាតកាយងូតទឹក សេចក្តីថា ភិក្ខុនីមិនស្លៀកសម្ពត់ ឬមិនដណ្តប់សម្ពត់ហើយងូតទឹក ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលងូត វេលាងូតស្រេច ត្រូវអាបត្តិបាចិត្តិយ។

[២២២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីមានចីវរដែលពួកចោរលួចយកទៅ ឬមានចីវរបាត់ទៅ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី២

CS vin.vbi.pc.22 | ភាគ ទី៥

### (២. ទុតិយសិក្ខាបទំ)

[២២៣] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់ក្នុងអារាមជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសម្ពត់ងូតទឹកដល់ពួកភិក្ខុនី។ ឆព្វគ្គិយាភិក្ខុនីទាំងឡាយគិតគ្នាថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសម្ពត់ងូតទឹកហើយ ទើបនាំគ្នាស្លៀកដណ្តប់សម្ពត់ងូតទឹកទាំងឡាយ មិនមានប្រមាណ ក៏ចាប់ទាញពីមុខខ្លះ ពីក្រោយខ្លះ ហើយត្រាច់ដើរទៅ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនី មិនសមបើនឹងទ្រទ្រង់នូវសម្ពត់ងូតទឹកគ្មានប្រមាណសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយាភិក្ខុនី ទ្រទ្រង់នូវសម្ពត់ងូតទឹកមិនមានប្រមាណ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនី មិនសមបើនឹងទ្រទ្រង់នូវសម្ពត់ងូតទឹកមិនមានប្រមាណទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនី កាលឲ្យគេធ្វើសម្ពត់ងូតទឹក គប្បីឲ្យធ្វើឲ្យល្មមប្រមាណ។ ឯប្រមាណក្នុងសំពត់ងូតទឹកនោះ គឺបណ្តោយ៤ចំអាម ទទឹង២ចំអាម ដោយចំអាមព្រះសុគត កាលភិក្ខុនីធ្វើឲ្យកន្លងលើសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ។**[16)]

[២២៤] ភិក្ខុនីងូតទឹកដោយសម្ពត់ស្លៀកណា សម្ពត់ស្លៀកនោះឈ្មោះថាសំពត់ងូតទឹក។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ សេចក្តីថា ភិក្ខុនី កាលធ្វើឯងក្តី ប្រើឲ្យគេធ្វើក្តី គប្បីឲ្យធ្វើឲ្យត្រូវប្រមាណ។ ឯប្រមាណក្នុងសំពត់ងូតទឹកនោះ គឺបណ្តោយ៤ចំអាម ទទឹង២ចំអាម ដោយចំអាមព្រះសុគត។ ភិក្ខុនីធ្វើឯងក្តី ប្រើគេឲ្យធ្វើក្តី ឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុនីត្រូវកាត់ក្នុងខណៈដែលបានមកហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ។

[២២៥] ភិក្ខុនីសម្រេចដោយខ្លួនឯងនូវសម្ពត់ដែលខ្លួនធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីប្រើពួកអ្នកដទៃឲ្យសម្រេច នូវសម្ពត់ដែលខ្លួនធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីសម្រេចដោយខ្លួនឯង នូវសម្ពត់ដែលពួកអ្នកដទៃធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីប្រើពួកអ្នកដទៃឲ្យសម្រេច នូវសម្ពត់ដែលពួកអ្នកដទៃធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីធ្វើឯងក្តី ប្រើគេឲ្យធ្វើក្តី ដើម្បីប្រយោជន៍ដល់អ្នកដទៃ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីបានសំពត់ងូតទឹកដែលអ្នកដទៃធ្វើស្រេចហើយ មកប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[២២៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុនីធ្វើឲ្យត្រូវប្រមាណ១ ភិក្ខុនីធ្វើថយពីប្រមាណចុះមក១ ភិក្ខុនីបានឧទកសាដកដែលអ្នកដទៃធ្វើឲ្យកន្លងហួសប្រមាណ ហើយយកមកកាត់ចេញ ទើបប្រើប្រាស់១ ភិក្ខុនីធ្វើឲ្យជាពិតានក្តី ជាកម្រាលក្រាលផែនដីក្តី ជារនាំងក្តី ជាពូកក្តី ជាខ្នើយក្តី១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.pc.23 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[២២៧] សម័យនោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់នៅក្នុងអារាមជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង សម្ពត់សម្រាប់ធ្វើចីវររបស់ភិក្ខុនី១រូបមានដំឡៃច្រើន ចីវរ(នោះ)ធ្វើក៏មិនល្អ ដេរក៏មិនល្អ។ ថុល្លនន្ទាភិក្ខុនីបានពោលពាក្យនេះនឹងភិក្ខុនីនោះថា នែលោកម្ចាស់ សម្ពត់ចីវររបស់លោកនេះល្អណាស់ តែចីវរនោះធ្វើមិនល្អ ដេរមិនល្អ។ ភិក្ខុនីនោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងរុះចេញ លោកម្ចាស់នឹងដេរឲ្យឬ។ ថុល្លនន្ទាភិក្ខុនីឆ្លើយថា អើលោកម្ចាស់ ខ្ញុំនឹងដេរឲ្យ។ លំដាប់នោះ ភិក្ខុនីនោះក៏រុះចីវរនោះចេញ ហើយប្រគល់ឲ្យថុល្លនន្ទាភិក្ខុនី។ ថុល្លនន្ទាភិក្ខុនីគិតថា អញនឹងដេរៗ តែមិនដេរ មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ។ ភិក្ខុនីនោះក៏ប្រាប់សេចក្តីនុ៎ះដល់ពួកភិក្ខុនីផងគ្នា។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងឲ្យភិក្ខុនីផងគ្នារុះចីវរចេញ ហើយក៏មិនដេរខ្លួនឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរវិញសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ឲ្យភិក្ខុនីផងគ្នារុះចីវរចេញ ហើយមិនដេរខ្លួនឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបីនឹងឲ្យភិក្ខុនីផងគ្នារុះចីវរចេញ ហើយមិនដេរខ្លួនឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ រុះឯងក្តី ឲ្យគេរុះក្តី នូវចីវររបស់ភិក្ខុនីផងគ្នា ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយក្នុងកាលជាខាងក្រោយទេ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ (ដំកល់ទុក) ត្រឹម៤-៥ថ្ងៃ។**

[២២៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងបារាជិកកណ្ឌសិក្ខាបទទី១រួចហើយ។ ពាក្យថា ភិក្ខុនីផងគ្នា គឺភិក្ខុនីឯទៀត។ ដែលហៅថា ចីវរនោះ បានដល់ចីវរ៦យ៉ាង ចីវរណាមួយ។ ពាក្យថា រុះឯង គឺរុះចេញដោយខ្លួនឯង។ ពាក្យថា ឲ្យគេរុះ គឺប្រើអ្នកដទៃឲ្យរុះ។ ពាក្យថា ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយក្នុងពេលជាខាងក្រោយទេ គឺគ្មានសេចក្តីអន្តរាយសោះឡើយ។ ពាក្យថា មិនដេរឯង គឺភិក្ខុនីមិនដេរដោយខ្លួនឯង។ ពាក្យថា មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ គឺភិក្ខុនីមិនបង្គាប់អ្នកដទៃឡើយ។ ពាក្យថា វៀរលែងតែ (ដំកល់ទុក) ត្រឹម៤-៥ថ្ងៃ គឺលើកទុកត្រឹម៤-៥ថ្ងៃប៉ុណ្ណោះ។ បើភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញមិនដេរឯង អញនឹងមិនធ្វើនូវសេចក្តីខ្វល់ខ្វាយដើម្បីឲ្យគេដេរដូច្នេះ ក៏ត្រូវអាបត្តិបាចិត្តិយ។

[២២៩] ឧបសម្បន្នា ភិក្ខុនីសំគាល់ថា ឧបសម្បន្នាមែន ហើយរុះឯងក្តី ប្រើគេឲ្យរុះក្តីនូវចីវរ លុះតមកខាងក្រោយ ភិក្ខុនីនោះក៏មិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ(ទុកដាក់) ត្រឹម៤-៥ថ្ងៃ។ ឧបសម្បន្នា តែភិក្ខុនីមានសេចក្តីសង្ស័យ ហើយរុះឯងក្តី ប្រើគេឲ្យរុះក្តីនូវចីវរ តមកខាងក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ(ទុកដាក់) ត្រឹម៤-៥ថ្ងៃប៉ុណ្ណោះ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថា ជាអនុបសម្បន្នាទៅវិញ រុះឯងក្តី ប្រើគេឲ្យរុះក្តីនូវចីវរ តមកខាងក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែ(ទុកដាក់) ត្រឹម៤-៥ថ្ងៃ។ ភិក្ខុនីរុះឯងក្តី ប្រើគេឲ្យរុះក្តី នូវបរិក្ខារដទៃ តមកខាងក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិទុក្កដ វៀរលែងតែ(ទុកដាក់) ត្រឹម៤-៥ថ្ងៃ។ ភិក្ខុនីរុះឯងក្តី ប្រើគេឲ្យរុះក្តី នូវចីវរក្តី បរិក្ខារដទៃក្តី របស់អនុបសម្បន្នា តមកខាងក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយឡើយ ហើយមិនដេរឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេដេរ ត្រូវអាបត្តិទុក្កដ វៀរលែងតែ(ទុកដាក់) ត្រឹម៤-៥ថ្ងៃ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នាដដែល ត្រូវអាបត្តិទុក្កដ។

[២៣០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុនីមានសេចក្តីអន្តរាយ ហើយស្វែងរកគ្នាមិនបាន១ ភិក្ខុនីកំពុងតែធ្វើស្រាប់តែកន្លងហួស៤-៥ថ្ងៃ ភិក្ខុនីមានជំងឺ១ ភិក្ខុនីមានសេចក្តីអន្តរាយផ្សេងៗកើតឡើង១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.24 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[២៣១] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។ សម័យនោះឯង ពួកភិក្ខុនីផ្ញើចីវរ (សង្ឃាដី) ទុកក្នុងដៃនៃភិក្ខុនីទាំងឡាយ ហើយចៀសចេញទៅកាន់ចារិកជនបទ ដោយមានតែស្បង់ និងចីពរទៅប៉ុណ្ណោះ។ ចីវរទាំងឡាយដែលពួកភិក្ខុនីផ្ញើទុកយូរពេកនោះ ក៏ដុះផ្សិតសៅហ្មងទៅអស់។ ភិក្ខុនីទាំងឡាយយកចីវរនោះទៅសំដិលហាល។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងភិក្ខុនីទាំងនោះថា នែលោកម្ចាស់ទាំងឡាយ ចីវរទាំងនេះរបស់អ្នកណា ក៏ដុះផ្សិតសៅហ្មងអស់។ ទើបភិក្ខុនីទាំងនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនី មិនសមបីនឹងផ្ញើចីវរទុកក្នុងដៃនៃភិក្ខុនីទាំងឡាយ ហើយចៀសចេញទៅកាន់ចារិកជនបទដោយមានតែស្បង់និងចីពរទៅប៉ុណ្ណោះសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយ ផ្ញើចីវរទុកក្នុងដៃនៃភិក្ខុនីទាំងឡាយ ហើយចៀសចេញទៅកាន់ចារិកជនបទដោយមានតែស្បង់និងចីពរប៉ុណ្ណោះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី មិនសមបីនឹងផ្ញើចីវរទុកក្នុងដៃនៃភិក្ខុនីទាំងឡាយ ហើយចៀសចេញទៅកាន់ចារិកជនបទដោយមានតែស្បង់និងចីពរទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ញុំាងវារៈនៃសង្ឃាដិឲ្យកន្លងហួស៥ថ្ងៃទៅ ត្រូវអាបត្តិបាចិត្តិយ។**

[២៣២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្឵រួចហើយ។ ពាក្យថា ញុំាងវារៈនៃសង្ឃាដិឲ្យកន្លងហួស៥ថ្ងៃទៅ សេចក្តីថា ភិក្ខុនីមិនបានស្លៀក មិនបានគ្រង មិនបានសំដិលហាលនូវចីវរទាំង៥អស់ថ្ងៃទី៥ គឺថា ធ្វើឲ្យកន្លងហួសថ្ងៃទី៥ទៅ ត្រូវអាបត្តិបាចិត្តិយ។

[២៣៣] វារៈនៃសង្ឃាដិកន្លងហួស៥ថ្ងៃទៅហើយ ភិក្ខុនីសំគាល់ថា កន្លងហួស៥ថ្ងៃទៅហើយ ត្រូវអាបត្តិបាចិត្តិយ។ វារៈនៃសង្ឃាដិកន្លងហួស៥ថ្ងៃទៅហើយ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិបាចិត្តិយ។ វារៈនៃសង្ឃាដិកន្លងហួស៥ថ្ងៃទៅហើយ ភិក្ខុនីសំគាល់ថា មិនទាន់កន្លងទៅទេ ត្រូវអាបត្តិបាចិត្តិយ។ វារៈនៃសង្ឃាដិមិនទាន់កន្លងហួស៥ថ្ងៃទៅទេ ភិក្ខុនីសំគាល់ថា កន្លងទៅហើយ ត្រូវអាបត្តិទុក្កដ។ វារៈនៃសង្ឃាដិមិនទាន់កន្លងហួស៥ថ្ងៃទៅទេ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ វារៈនៃសង្ឃាដិមិនកន្លងហួស៥ថ្ងៃទៅទេ ភិក្ខុនីសំគាល់ថា មិនទាន់កន្លងទៅទេ មិនត្រូវអាបត្តិឡើយ។

[២៣៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីស្លៀកក្តី គ្រងក្តី សំដិលហាលក្តី នូវចីវរទាំង៥ក្នុងថ្ងៃទីប្រាំ១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.25 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[២៣៥] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនី១រូប ត្រេចទៅបិណ្ឌបាត (ត្រឡប់មកវិញ) ក៏សំដិលចីវរដែលទទឹកដោយញើស ហើយចូលទៅកាន់វិហារ។ មានភិក្ខុនី១រូបយកចីវរនោះគ្រង ហើយចូលទៅកាន់ក្រុងដើម្បីបិណ្ឌបាត។ ភិក្ខុនីនោះចេញ (ពីវិហារ) ទៅហើយ សួរភិក្ខុនីទាំងឡាយថា នែលោកម្ចាស់ទាំងឡាយ លោកទាំងឡាយបានឃើញចីវររបស់ខ្ញុំដែរ។ ភិក្ខុនីទាំងឡាយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីនោះ។ ទើបភិក្ខុនីនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបីនឹងមិនប្រាប់ដល់ខ្ញុំជាមុន ហើយយកចីវរទៅគ្រងសោះ។ ទើបភិក្ខុនីនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនី មិនសមបីនឹងមិនប្រាប់ជាមុនហើយ យកចីវររបស់ភិក្ខុនីផងគ្នាទៅគ្រងសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីមិនបានប្រាប់ជាមុន ហើយយកចីវររបស់ភិក្ខុនីផងគ្នាទៅគ្រង ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនសមបីនឹងមិនប្រាប់ជាមុន ហើយយកចីវររបស់ភិក្ខុនីផងគ្នាទៅគ្រងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ទ្រទ្រង់ (ស្លៀកដណ្តប់) នូវសង្កមនីយចីវរ[17)] គឺចីវរដែលខ្លួនលបយកទៅប្រើប្រាស់មួយសំណើរ ត្រូវអាបត្តិបាចិត្តិយ។**

[២៣៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្឵រួចហើយ។ ចីវរដែលឈ្មោះថា សង្កមនីយនោះ បានដល់ចីវរទាំង៥ ចីវរឯណាមួយ របស់ស្រីដែលជាឧបសម្បន្នា។ ភិក្ខុនីមិនប្រាប់ជាមុន ហើយស្លៀកក្តី គ្រងក្តី នូវចីវរដែលភិក្ខុនីនោះមិនបានឲ្យក្តី នូវសង្កមនីយចីវរនោះក្តី ត្រូវអាបត្តិបាចិត្តិយ។

[២៣៧] ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ហើយទ្រទ្រង់នូវសង្កមនីយចីវរ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ហើយទ្រទ្រង់នូវសង្កមនីយចីវរ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នាទៅវិញ ហើយទ្រទ្រង់នូវសង្កមនីយចីវរ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីទ្រទ្រង់នូវសង្កមនីយចីវររបស់អនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នាទៅវិញ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។

[២៣៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុនីជាម្ចាស់ចីវរនោះបានឲ្យ១ ភិក្ខុនីបានប្រាប់ហើយស្លៀកក្តី ដណ្តប់ក្តីនូវចីវរនោះ១ ភិក្ខុនីមានចីវរចោរដណ្តើមយកទៅ១ ភិក្ខុនីមានចីវរបាត់ទៅ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.pc.26 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[២៣៩] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ ក៏គ្រានោះឯង ត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី បាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងថ្វាយចីវរដល់ភិក្ខុនីសង្ឃ។ ថុល្លនន្ទាភិក្ខុនីនិយាយថា អ្នកទាំងឡាយមានកិច្ចច្រើន មានការដែលត្រូវធ្វើក៏ច្រើន ដូច្នេះហើយក៏ធ្វើចីវរទានឲ្យអន្តរាយទៅ។ ទទួលពេលនោះ ផ្ទះរបស់ត្រកូលនោះភ្លើងឆេះ។ មនុស្សទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងធ្វើទេយ្យធម៌របស់យើងទាំងឡាយឲ្យអន្តរាយសោះ យើងទាំងឡាយវិនាសប្រាសចាកប្រយោជន៍ទាំងពីរយ៉ាង គឺភោគផង បុណ្យផង។ ភិក្ខុនីទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងធ្វើចីវរលាភរបស់គណៈឲ្យអន្តរាយទៅសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ធ្វើចីវរលាភរបស់គណៈឲ្យអន្តរាយទៅ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបីនឹងធ្វើចីវរលាភរបស់គណៈឲ្យអន្តរាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ធ្វើចីវរលាភរបស់គណៈឲ្យអន្តរាយទៅ ត្រូវអាបត្តិបាចិត្តិយ។**

[២៤០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា គណៈ តថាគតសំដៅយកភិក្ខុនីសង្ឃ។ បណ្តាចីវរ៦យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមវិកប្បបាន ហៅថាចីវរ។ ពាក្យថា ធ្វើឲ្យអន្តរាយ សេចក្តីថា ភិក្ខុនីនិយាយថា ជនទាំងឡាយត្រូវឲ្យចីវរនេះធ្វើអ្វី ហើយធ្វើឲ្យអន្តរាយទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីធ្វើបរិក្ខារដទៃឲ្យអន្តរាយ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីធ្វើចីវរក្តី បរិក្ខារដទៃក្តី របស់ភិក្ខុនីច្រើនរូប (ពីររូប ឬបីរូប)ក្តី របស់ភិក្ខុនីមួយរូបក្តី របស់អនុបសម្បន្នាក្តី ឲ្យអន្តរាយ ត្រូវអាបត្តិទុក្កដ។

[២៤១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីសំដែងអានិសង្សហើយហាមឃាត់[18] ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី៧

CS vin.vbi.pc.27 | ភាគ ទី៥

### (៧. សត្តមសិក្ខាបទំ)

[២៤២] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង អកាលចីវរបានកើតឡើងដល់ភិក្ខុនីសង្ឃ។ លំដាប់នោះ ភិក្ខុនីសង្ឃប្រាថ្នាដើម្បីនឹងចែកចីវរនោះ ទើបប្រជុំគ្នា។ វេលានោះឯង ពួកភិក្ខុនីជាអន្តេវាសិនី (កូនសិស្ស) របស់ថុល្លនន្ទាភិក្ខុនី ចៀសចេញទៅ (ពីវត្ត) ថុល្លនន្ទាភិក្ខុនីក៏បាននិយាយពាក្យនេះនឹងភិក្ខុនីទាំងនោះថា នែលោកម្ចាស់ទាំងឡាយ ពួកភិក្ខុនីចៀសចេញទៅអស់ហើយ (សង្ឃ) កុំអាលចែកចីវរ ដូច្នេះហើយ ក៏ហាមឃាត់ការចែកចីវរ។ ភិក្ខុនីទាំងឡាយនាំគ្នាចៀសចេញអស់ទៅដោយគិតថា សង្ឃមិនទាន់ចែកចីវរ។ ថុល្លនន្ទាភិក្ខុនី កាលពួកភិក្ខុនីជាអន្តេវាសិនីមកព្រមគ្នាហើយ ក៏នាំគ្នាចែកចីវរនោះទៅ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌សោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបីនឹងហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ហាមឃាត់ការចែកចីវរដែលប្រកបដោយធម៌ ត្រូវអាបត្តិបាចិត្តិយ។**

[២៤៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ការចែកចីវរ ដែលឈ្មោះថា ប្រកបដោយធម៌នោះ បានដល់ភិក្ខុនីសង្ឃមានសេចក្តីព្រមព្រៀង ប្រជុំគ្នាចែក។ ពាក្យថា ហាមឃាត់ សេចក្តីថា ភិក្ខុនីហាមឃាត់ដោយពាក្យថា ភិក្ខុនីចែកចីវរនេះធ្វើអ្វីដូច្នេះ ត្រូវអាបត្តិបាចិត្តិយ។

[២៤៤] ការចែកចីវរប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា ប្រកបដោយធម៌ ហើយហាមឃាត់ ត្រូវអាបត្តិបាចិត្តិយ។ ការចែកចីវរប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយហាមឃាត់ ត្រូវអាបត្តិទុក្កដ។ ការចែកចីវរប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា មិនប្រកបដោយធម៌វិញ ហើយហាមឃាត់ មិនត្រូវអាបត្តិ។ ការចែកចីវរមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា ប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ ការចែកចីវរមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ការចែកចីវរមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា មិនប្រកបដោយធម៌ មិនត្រូវអាបត្តិ។

[២៤៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីសំដែងអានិសង្សហើយឃាត់[19] ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី៨

CS vin.vbi.pc.28 | ភាគ ទី៥

### (៨. អដ្ឋមសិក្ខាបទំ)

[២៤៦] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី បានឲ្យសមណចីវរដល់ពួកមេរបាំខ្លះ ដល់ពួកកូនរបាំខ្លះ ពួកអ្នកឡើងរាំរែខ្លះ ដល់ពួកអ្នកត្លុកខ្លះ ដល់ពួកអ្នកវាយស្គរខ្លះ ដោយពាក្យថា អ្នកទាំងឡាយចូរពោលសរសើរយើងក្នុងទីប្រជុំបរិសទ្យរបស់យើង។ ពួកមេរបាំក្តី ពួកកូនរបាំក្តី ពួកអ្នកឡើងរាំរែក្តី ពួកអ្នកត្លុកក្តី ពួកអ្នកវាយស្គរក្តី នាំគ្នាពោលសរសើរថុល្លនន្ទាភិក្ខុនីក្នុងទីប្រជុំបរិសទ្យថា ថុល្លនន្ទាជាម្ចាស់ ជាពហុស្សូត ជាអ្នកនិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា អ្នកទាំងឡាយចូរថ្វាយ(ទាន) ដល់លោកម្ចាស់ចុះ អ្នកទាំងឡាយចូរធ្វើ (សក្ការៈ)ដល់លោកម្ចាស់ចុះ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងឲ្យសមណចីវរដល់គ្រហស្ថសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ឲ្យសមណចីវរដល់គ្រហស្ថ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបីនឹងឲ្យសមណចីវរដល់គ្រហស្ថទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យសមណចីវរដល់គ្រហស្ថក្តី ដល់បរិព្វាជកក្តី ដល់បរិព្វាជិកាក្តី ត្រូវអាបត្តិបាចិត្តិយ។**

[២៤៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ជនណាមួយគ្រប់គ្រងផ្ទះ ជននោះឈ្មោះថា គ្រហស្ថ។ បុរសណាមួយបួសជាបរិព្វាជក វៀរលែងតែភិក្ខុនិងសាមណេរចេញ បុរសនោះឈ្មោះថា បរិព្វាជក។ ស្រីណាមួយបួសជាបរិព្វាជិកា វៀរលែងតែភិក្ខុនី សិក្ខមានា និងសាមណេរីចេញ ស្រីនោះឈ្មោះថា បរិព្វាជិកា។ ចីវរដែលធ្វើវិកប្បហើយ ហៅថា សមណចីវរ។ ភិក្ខុនីឲ្យ (សមណចីវរ) ត្រូវអាបត្តិបាចិត្តិយ។

[២៤៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីឲ្យដល់មាតាបិតា១ ភិក្ខុនីឲ្យគេខ្ចី១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.pc.29 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[២៤៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី បាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា បពិត្រលោកម្ចាស់ បើយើងខ្ញុំទាំងឡាយអាច យើងខ្ញុំទាំងឡាយនឹងថ្វាយចីវរដល់ភិក្ខុនីសង្ឃ។ សម័យនោះឯង ភិក្ខុនីទាំងឡាយនៅចាំវស្សារួចហើយ ប្រាថ្នាដើម្បីនឹងចែកចីវរ ទើបប្រជុំគ្នា។ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងភិក្ខុនីទាំងនោះថា នែលោកម្ចាស់ទាំងឡាយ ពួកលោកម្ចាស់ចូរបង្អង់ចាំសិន (ដ្បិត) មានគេនឹងថ្វាយចីវរដល់ភិក្ខុនីសង្ឃ។ ភិក្ខុនីទាំងឡាយបាននិយាយពាក្យនេះនឹងថុល្លនន្ទាភិក្ខុនីថា នែលោកម្ចាស់ លោកចូរទៅ លោកចូរដឹងចីវរនោះចុះ។ ថុល្លនន្ទាភិក្ខុនីចូលទៅរកត្រកូលនោះ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរឲ្យចីវរដល់ភិក្ខុនីសង្ឃចុះ។ មនុស្សទាំងឡាយនោះនិយាយថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយមិនអាចនឹងប្រគេនចីវរដល់ភិក្ខុនីសង្ឃទេ។ ថុល្លនន្ទាភិក្ខុនីប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងញុំាងសម័យនៃចីវរកាលឲ្យកន្លងហួសទៅដោយសេចក្តីប្រាថ្នាចីវរដ៏ទុព្វលសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ញុំាងសម័យនៃចីវរកាលឲ្យកន្លងហួសទៅដោយសេចក្តីប្រាថ្នាចីវរទុព្វល ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបី

នឹងញុំាងសម័យនៃចីវរកាលឲ្យកន្លងហួសទៅដោយសេចក្តីប្រាថ្នាចីវរដ៏ទុព្វលទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ញុំាងសម័យនៃចីវរកាលឲ្យកន្លងហួសទៅដោយសេចក្តីប្រាថ្នាចីវរដ៏ទុព្វល ត្រូវអាបត្តិបាចិត្តិយ។**

[២៥០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា សេចក្តីប្រាថ្នាចីវរដ៏ទុព្វល គឺត្រកូលគេបញ្ចេញវាចីភេទថា បើយើងខ្ញុំទាំងឡាយអាច យើងខ្ញុំទាំងឡាយនឹងប្រគេន នឹងធ្វើ(ចីវរទាន)។ ដែលហៅថា សម័យនៃចីវរកាល គឺភិក្ខុនីមិនទាន់បានក្រាលកឋិន កំណត់ខែមួយជាខាងចុងនៃវស្សានរដូវ (អំពី១រោចខែអស្សុជ ទៅដល់១៥កើតខែកត្តិក) បើភិក្ខុនីបានក្រាលកឋិន កំណត់៥ខែ (អំពី១រោចខែអស្សុជ ទៅដល់ ១៥កើត ខែផល្គុន)។ ពាក្យថា ញុំាងសម័យនៃចីវរកាលឲ្យកន្លងហួសទៅនោះ សេចក្តីថា ភិក្ខុនីមិនបានក្រាលកឋិន ហើយញុំាងថ្ងៃ១ជាខាងចុងនៃវស្សានរដូវឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីបានក្រាលកឋិន ហើយញុំាងថ្ងៃដែលកឋិនដោះឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ។

[២៥១] ចីវរដ៏ទុព្វល ភិក្ខុនីសំគាល់ថាចីវរដ៏ទុព្វលមែន ហើយធ្វើសម័យនៃចីវរកាលឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ។ ចីវរដ៏ទុព្វល ភិក្ខុនីមានសេចក្តីសង្ស័យ ហើយធ្វើសម័យនៃចីវរកាលឲ្យកន្លងហួសទៅ ត្រូវអាបត្តិទុក្កដ។ ចីវរដ៏ទុព្វល ភិក្ខុនីសំគាល់ថាចីវរមិនទុព្វលទេ ហើយធ្វើសម័យនៃចីវរកាលឲ្យកន្លងហួសទៅ មិនត្រូវអាបត្តិអ្វីឡើយ។ ចីវរមិនទុព្វលទេ ភិក្ខុនីសំគាល់ថា ចីវរទុព្វល ត្រូវអាបត្តិទុក្កដ។ ចីវរមិនទុព្វលទេ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ចីវរមិនទុព្វល ភិក្ខុនីសំគាល់ថា ចីវរមិនទុព្វល មិនត្រូវអាបត្តិអ្វីឡើយ។

[២៥២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីសំដែងអានិសង្ស[20)] ហើយហាមឃាត់១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ នគ្គវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.pc.30 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[២៥៣] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង មានឧបាសកម្នាក់ឲ្យគេធ្វើវិហារ (កុដិ) ឧទ្ទិសថ្វាយសង្ឃ។ ក្នុងកាលដែលឆ្លងវិហារនោះ ឧបាសកនោះប្រាថ្នានឹងថ្វាយអកាលចីវរដល់ឧភតោសង្ឃ។ ក៏គ្រានោះឯង ឧភតោសង្ឃបានក្រាលកឋិនហើយ។ ទើបឧបាសកនោះចូលទៅរកសង្ឃ ហើយសូមឲ្យសង្ឃដកកឋិនចេញ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុសង្ឃទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃដកកឋិនចេញបាន ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវដកកឋិនយ៉ាងនេះ។ ភិក្ខុឆ្លាសប្រតិពលគប្បីញុំាងសង្ឃឲ្យដឹងដោយញត្តិទុតិយកម្មវាចាថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើការដកកឋិននេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃត្រូវដកនូវកឋិន។ នេះជាវាចាដែលប្រកាសឲ្យសង្ឃដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ឥឡូវនេះ សង្ឃដកកឋិនចេញ។ ការដកកឋិនគួរដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះពោលឡើង។ កឋិនសង្ឃបានដកហើយ។ ការដកកឋិនសមគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវកម្មនេះដោយអាការស្ងៀមនៅយ៉ាងនេះ។

[២៥៤] លំដាប់នោះ ឧបាសកនោះបានចូលទៅរកភិក្ខុនីសង្ឃ ហើយសូមឲ្យសង្ឃដកកឋិនចេញ។ ថុល្លនន្ទាភិក្ខុនីបានហាមឃាត់នូវការដកកឋិនដោយវាចាថា ចីវរនឹងមានដល់ពួកយើងទាំងឡាយ។ ទើបឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបីនឹងមិនឲ្យការដកកឋិនដល់ពួកយើងសោះ។ ភិក្ខុនីទាំងឡាយបានឮឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងហាមឃាត់នូវការដកកឋិនប្រកបដោយធម៌សោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ហាមឃាត់នូវការដកកឋិនដ៏ប្រកបដោយធម៌ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបីនឹងហាមឃាត់នូវការដកកឋិនដ៏ប្រកបដោយធម៌ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ហាមឃាត់នូវការដកកឋិនប្រកបដោយធម៌ ត្រូវអាបត្តិបាចិត្តិយ។**

[២៥៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា ការដកកឋិនប្រកបដោយធម៌នោះ បានដល់ភិក្ខុនីសង្ឃមានសេចក្តីព្រមព្រៀងប្រជុំគ្នាដក។ ពាក្យថា ហាមឃាត់ សេចក្តីថា ភិក្ខុនីហាមឃាត់ថា ភិក្ខុនីសង្ឃដកកឋិននេះធ្វើអ្វីដូច្នេះ ត្រូវអាបត្តិបាចិត្តិយ។

[២៥៦] ការដកកឋិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាប្រកបដោយធម៌មែន ហើយហាមឃាត់ ត្រូវអាបត្តិបាចិត្តិយ។ ការដកកឋិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយហាមឃាត់ ត្រូវអាបត្តិទុក្កដ។ ការដកកឋិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាមិនប្រកបដោយធម៌

ហើយហាមឃាត់ មិនត្រូវអាបត្តិអ្វីឡើយ។ ការដកកឋិនមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ ការដកកឋិនមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ការដកកឋិនមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថាមិនប្រកបដោយធម៌មែន មិនត្រូវអាបត្តិអ្វីឡើយ។

[២៥៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីសំដែងអានិសង្ស[21] ហើយហាមឃាត់១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ១។

នគ្គវគ្គ ទី ៣ ចប់។

# (បាចិត្តិយ) តុវដ្ដវគ្គ (ទី៤)

CS vin.vbi.pc.v4 | ភាគ ទី៥

### (៤. តុវដ្ដវគ្គោ)

## (បាចិត្តិយ តុវដ្ដវគ្គ) សិក្ខាបទ ទី១

CS vin.vbi.pc.31 | ភាគ ទី៥

### (១. បឋមសិក្ខាបទំ)

[២៥៨] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីពីររូបដេកលើគ្រែមួយ (ជាមួយគ្នា)។ មនុស្សទាំងឡាយដើរទៅកាន់ចារិកនៃវត្ត ឃើញហើយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីពីររូបមិនសមបីនឹងដេកលើគ្រែមួយ (ជាមួយគ្នា) ដូចពួកស្រីគ្រហស្ថអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីពីររូប មិនសមបីនឹងដេកលើគ្រែមួយ (ជាមួយគ្នា)សោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីពីររូបដេកលើគ្រែមួយ (ជាមួយគ្នា) ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីពីររូប មិនសមបីនឹងដេកលើគ្រែមួយ (ជាមួយគ្នា)ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីទាំងឡាយណាពីររូប ដេកលើគ្រែមួយ (ជាមួយគ្នា) ត្រូវអាបត្តិបាចិត្តិយ។**

[២៥៩] ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយណា មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ភិក្ខុនីពីររូបដេកលើគ្រែមួយ(ជាមួយគ្នា) សេចក្ដីថា កាលភិក្ខុនីម្នាក់ដេកនៅហើយ មានភិក្ខុនីដទៃទៅដេកដែរ ត្រូវអាបត្តិបាចិត្តិយ។ ម្យ៉ាងទៀត ភិក្ខុនីពីររូបដេកព្រមគ្នា ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីទាំងពីររូបក្រោកឡើង ហើយដេកទៅវិញញយៗ ត្រូវអាបត្តិបាចិត្តិយ។

[២៦០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីម្នាក់ដេក ភិក្ខុនីដទៃអង្គុយ ឬភិក្ខុនីទាំងពីររូបអង្គុយ១ ភិក្ខុនីទាំងពីររូបនោះឆ្កួត១ ភិក្ខុនីទាំងពីររូបនោះជាដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្ដវគ្គ) សិក្ខាបទ ទី២

CS vin.vbi.pc.32 | ភាគ ទី៥

### (២. ទុតិយសិក្ខាបទំ)

[២៦១] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីពីររូបមានសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់តែមួយ ដេកជាមួយគ្នា។ មនុស្សទាំងឡាយដើរទៅកាន់ចារិកនៃវត្ត ឃើញហើយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីពីររូបមិនសមបីនឹងមានសម្ពត់សម្រាប់ក្រាល សម្រាប់ដណ្ដប់តែមួយ ដេកជាមួយគ្នាដូចយ៉ាងពួកស្រីគ្រហស្ថអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីពីររូប មិនសមបីនឹងមានសម្ពត់សម្រាប់ក្រាល សម្រាប់ដណ្ដប់តែមួយ ដេកជាមួយគ្នាសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីពីររូបមានសម្ពត់សម្រាប់ក្រាល សម្រាប់ដណ្ដប់តែមួយ ដេកជាមួយគ្នា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីពីររូប មិនសមបីនឹងមានសម្ពត់សម្រាប់ក្រាល សម្រាប់ដណ្ដប់តែមួយ ដេកជាមួយគ្នាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីទាំងឡាយឯណាពីររូប មានសម្ពត់សម្រាប់ក្រាល សម្រាប់ដណ្ដប់តែមួយ ដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ។**

[២៦២] ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយណា មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ពីររូបមានសម្ពត់សម្រាប់ក្រាល សម្រាប់ដណ្ដប់តែមួយ ដេកជាមួយគ្នានោះ សេចក្ដីថា ភិក្ខុនីពីររូបក្រាលនូវសម្ពត់នោះឯង ហើយដណ្ដប់នូវសម្ពត់នោះដដែល ត្រូវអាបត្តិបាចិត្តិយ។

[២៦៣] សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់តែមួយ ភិក្ខុនីពីររូបសំគាល់ថាសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់តែមួយដដែល ហើយដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ។ សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់តែមួយ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ។ សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់តែមួយ ភិក្ខុនីសំគាល់ថាសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់ផ្សេងគ្នា ហើយដេកជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីដេកលើកម្រាលជាមួយគ្នា តែដណ្ដប់សំពត់ផ្សេងគ្នា ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីដេកលើកម្រាលផ្សេងគ្នា តែដណ្ដប់ជាមួយគ្នា ត្រូវអាបត្តិទុក្កដ។ សម្ពត់សម្រាប់ក្រាល សម្រាប់ដណ្ដប់ផ្សេងៗគ្នា ភិក្ខុនីសំគាល់ថាសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់ជាមួយគ្នា ត្រូវអាបត្តិទុក្កដ។ សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់ផ្សេងគ្នា ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ សម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់ផ្សេងគ្នា ភិក្ខុនីសំគាល់ថាសម្ពត់សម្រាប់ក្រាលសម្រាប់ដណ្ដប់ផ្សេងគ្នាដដែល មិនត្រូវអាបត្តិអ្វីឡើយ។

[២៦៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺពួកភិក្ខុនីសំដែងនូវទីកំណត់ ហើយដេក១ ពួកភិក្ខុនីឆ្កួត១ ពួកភិក្ខុនីដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្ដវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.pc.33 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[២៦៥] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ស្ដេចគង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី ជាពហុស្សុត ជាអ្នកឆ្លាតនិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា។ សូម្បីភទ្ទាកាបិលានីភិក្ខុនីក៏ជាពហុស្សុត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា ជាអ្នកដែលមហាជនសរសើរក្រៃពេកដែរ។ មនុស្សទាំងឡាយនិយាយថា ភទ្ទាកាបិលានីជាម្ចាស់ ជាពហុស្សុត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា ជាអ្នកដែលមហាជនសរសើរក្រៃពេក ដូច្នេះ ហើយចូលទៅរកភទ្ទាកាបិលានីភិក្ខុនីមុន ទើបចូលទៅរកថុល្លនន្ទាភិក្ខុនីជាក្រោយ។ ថុល្លនន្ទាភិក្ខុនីជាមនុស្សមានសេចក្ដីឫស្យាគ្របសង្កត់ ក៏ពោលថា ពួកភិក្ខុនីណាស្គាល់ច្រើន សូមច្រើន បានឮថា ភិក្ខុនីទាំងឡាយនេះជាអ្នកប្រាថ្នាតិច ជាអ្នកសន្ដោស ជាអ្នកស្ងាត់ ជាអ្នកមិនច្រឡូកច្រឡំ ពោលដូច្នេះហើយ ក៏ដើរខ្លះ ឈរខ្លះ អង្គុយខ្លះ សម្រេចការដេកខ្លះ សំដែងឯងខ្លះ ឲ្យគេសំដែងខ្លះ ធ្វើការស្វាធ្យាយខ្លះ ក្នុងខាងមុខភទ្ទាកាបិលានីភិក្ខុនី។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងមកក្លែង ធ្វើសេចក្ដីមិនសប្បាយដល់ភទ្ទាកាបិលានីជាម្ចាស់សោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនីក្លែងធ្វើសេចក្ដីមិនសប្បាយដល់ភទ្ទាកាបិលានីភិក្ខុនី ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបីនឹងក្លែងធ្វើសេចក្ដីមិនសប្បាយដល់ភទ្ទាកាបិលានីភិក្ខុនីទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយក្លែងធ្វើសេចក្ដីមិនសប្បាយដល់ភិក្ខុនីផងគ្នា ត្រូវអាបត្តិបាចិត្តិយ។**

[២៦៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដល់ភិក្ខុនីផងគ្នា គឺដល់ភិក្ខុនីដទៃ។ ពាក្យថា ក្លែង សេចក្ដីថា ភិក្ខុនី កាលដឹង កាលស្គាល់ ហើយក្លែងប្រព្រឹត្តល្មើស ប្រព្រឹត្តកន្លង។ ពាក្យថា ធ្វើសេចក្ដីមិនសប្បាយ សេចក្ដីថា ភិក្ខុនីគិតថា ដោយហេតុនេះ សេចក្ដីមិនសប្បាយចិត្តនឹងមានដល់ភិក្ខុនីនេះ ដូច្នេះហើយមិនបានប្រាប់ ក៏ដើរខ្លះ ឈរខ្លះ អង្គុយខ្លះ សម្រេចការដេកខ្លះ សំដែងឯងខ្លះ ឲ្យគេសំដែងខ្លះ ធ្វើការស្វាធ្យាយខ្លះ ក្នុងទីខាងមុខ ត្រូវអាបត្តិបាចិត្តិយ។

[២៦៧] ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ហើយក្លែងធ្វើឲ្យមានសេចក្ដីមិនសប្បាយចិត្ត ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយក្លែងធ្វើសេចក្ដីឲ្យមិនសប្បាយចិត្ត ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នា ហើយក្លែងធ្វើឲ្យមានសេចក្ដីមិនសប្បាយចិត្ត ត្រូវអាបត្តិបាចិត្តិយ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។

[២៦៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីមិនប្រាថ្នានឹងធ្វើសេចក្ដីមិនសប្បាយចិត្ត ហើយប្រាប់ ក៏ដើរក្ដី ឈរក្ដី អង្គុយក្ដី សម្រេចការដេកក្ដី សំដែងឯងក្ដី ឲ្យគេសំដែងក្ដី ធ្វើការស្វាធ្យាយក្ដី ក្នុងខាងមុខ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្ដវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.34 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[២៦៩] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី មិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាកូនសិស្ស ដែលដល់នូវសេចក្តីទុក្ខ(មានជម្ងឺ)។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងមិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាកូនសិស្ស ដែលដល់នូវសេចក្តីទុក្ខសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី មិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាកូនសិស្ស ដែលដល់នូវសេចក្តីទុក្ខ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបីនឹងមិនបម្រើឯង មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាកូនសិស្ស ដែលដល់នូវសេចក្តីទុក្ខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើភិក្ខុនីជាកូនសិស្ស ដែលដល់នូវសេចក្តីទុក្ខ ត្រូវអាបត្តិបាចិត្តិយ។**

[២៧០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា ដល់នូវសេចក្តីទុក្ខ សំដៅយកភិក្ខុនីដែលមានជម្ងឺ។ ដែលហៅថា ភិក្ខុនីជាកូនសិស្ស សំដៅយកភិក្ខុនីជាសទ្ធិវិហារិនី (មានធម៌ជាគ្រឿងនៅជាមួយគ្នា)។ ពាក្យថា មិនបម្រើឯង គឺមិនបម្រើដោយខ្លួនឯង។ ពាក្យថា មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើ គឺមិនបង្គាប់អ្នកដទៃ។ កាលភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនបម្រើឯង នឹងមិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនបម្រើឯង មិនធ្វើការខ្វល់ខ្វាយដើម្បីឲ្យគេបម្រើ នូវអន្តេវាសិនីក្តី អនុបសម្បន្នាក្តី ត្រូវអាបត្តិទុក្កដ។

[២៧១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺកាលបើមានសេចក្តីអន្តរាយ ហើយភិក្ខុនីស្វែងរកអ្នកឯទៀតជាអ្នកបម្រើជម្ងឺមិនបាន១ ភិក្ខុនីឈឺខ្លួនឯង១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្តវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.35 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[២៧២] សម័យនោះឯង ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភទ្ទាកាបិលានីភិក្ខុនីនៅចាំវស្សាក្នុងក្រុងសាកេត។ ភទ្ទាកាបិលានីភិក្ខុនីនោះ បានបញ្ជូនទូតទៅក្នុងសំណាក់ថុល្លនន្ទាភិក្ខុនីដោយកិច្ចនីមួយថា បើថុល្លនន្ទាជាម្ចាស់ឲ្យលំនៅដល់ខ្ញុំ ខ្ញុំគួរតែទៅកាន់ក្រុងសាវត្ថី។ ថុល្លនន្ទាភិក្ខុនីនិយាយតបយ៉ាងនេះថា ភទ្ទាកាបិលានីមកចុះ ខ្ញុំនឹងឲ្យ(នៅ)។ លំដាប់នោះ ភទ្ទាកាបិលានីភិក្ខុនីបានចេញអំពីក្រុងសាកេតទៅកាន់ក្រុងសាវត្ថី។ ថុល្លនន្ទាភិក្ខុនីក៏បានឲ្យលំនៅដល់ភទ្ទាកាបិលានីភិក្ខុនី។ ក៏គ្រានោះឯង ថុល្លនន្ទាភិក្ខុនីជាពហុស្សុត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា។ សូម្បីភទ្ទាកាបិលានី ក៏ជាពហុស្សុត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថាដែរ ហើយមហាជនគេសរសើរដោយច្រើនក្រៃពេក។ មនុស្សទាំងឡាយនិយាយថា ភទ្ទាកាបិលានីជាម្ចាស់ ជាពហុស្សុត ជាអ្នកប៉ិននិយាយ ជាអ្នកក្លៀវក្លា ជាអ្នកប្រសប់ធ្វើធម្មីកថា ជាអ្នកដែលគេសរសើរដោយច្រើន និយាយយ៉ាងនេះហើយ បាននាំគ្នាទៅរកភទ្ទាកាបិលានីភិក្ខុនីមុន ហើយទៅរកថុល្លនន្ទាភិក្ខុនីជាខាងក្រោយ។ ថុល្លនន្ទាភិក្ខុនីជាអ្នកមានសេចក្តីឫស្យាគ្របសង្កត់ ទើបនិយាយថា ភិក្ខុនីទាំងឡាយណាជាអ្នកស្គាល់ច្រើន ជាអ្នកសូមច្រើន បានឮថា ភិក្ខុនីទាំងឡាយនេះជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងាត់ ជាអ្នកមិនច្រឡូកច្រឡំ (និយាយយ៉ាងនេះហើយ) ក៏មានសេចក្តីខឹងអាក់អន់ចិត្ត ហើយទង់ទាញភទ្ទាកាបិលានីចេញចាកលំនៅទៅ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបីនឹងឲ្យលំនៅដល់ភទ្ទាកាបិលានីជាម្ចាស់ ហើយត្រឡប់ខឹង អាក់អន់ចិត្ត ទង់ទាញចេញសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាថុល្លនន្ទាភិក្ខុនី ឲ្យលំនៅដល់ភទ្ទាកាបិលានីភិក្ខុនី ហើយត្រឡប់ខឹង អាក់អន់ចិត្ត ទង់ទាញចេញ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបីនឹង ឲ្យលំនៅដល់ភទ្ទាកាបិលានីភិក្ខុនី ហើយត្រឡប់ខឹង អាក់អន់ចិត្ត ទង់ទាញចេញទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យលំនៅដល់ភិក្ខុនីផងគ្នា ហើយខឹង អាក់អន់ចិត្ត ក៏ទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ។**

[២៧៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដល់ភិក្ខុនី គឺដល់ភិក្ខុនីដទៃ។ ទីកុដិដែលមានសន្លឹកទ្វារជាប់នៅ ហៅថាលំនៅ។ ពាក្យថា ឲ្យ គឺឲ្យដោយខ្លួនឯង។ ពាក្យថា ខឹងអាក់អន់ចិត្ត គឺមានចិត្តមិនត្រេកអរ មានចិត្តគឺទោសមកខ្ទាំងខ្ទប់ មានចិត្តរឹងត្អឹង។ ពាក្យថា ទង់ទាញឯង គឺភិក្ខុនីចាប់យកពីក្នុងល្វែងហើយទាញចេញទៅខាងរបៀង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីចាប់ទាញចេញពីរបៀងទៅខាងក្រៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីទាញចេញឲ្យរំលងទ្វារ សូម្បីច្រើន តែដោយប្រយោគ១ (គឺទាញតែម្តង) ត្រូវអាបត្តិបាចិត្តិយ(១)។ ពាក្យថា ឲ្យគេទង់ទាញ សេចក្តីថា ភិក្ខុនីបង្គាប់ឲ្យអ្នកដទៃទង់ទាញ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីបង្គាប់តែម្តង ហើយ(អ្នកទទួលបង្គាប់) ទង់ទាញឲ្យរំលងទ្វារសូម្បីច្រើន ត្រូវអាបត្តិបាចិត្តិយ(១)។

[២៧៤] ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា បានឲ្យលំនៅ ហើយខឹងអាក់អន់ចិត្ត ទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ បានឲ្យលំនៅ ហើយខឹងអាក់អន់ចិត្ត ទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថាជាអនុបសម្បន្នា បានឲ្យលំនៅ ហើយខឹងអាក់អន់ចិត្ត ត្រឡប់ទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តីនូវបរិក្ខារនៃភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តី (នូវភិក្ខុនីផងគ្នា) ចាកលំនៅដែលមិនមានសន្លឹកទ្វារជាប់នៅ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តីនូវបរិក្ខារនៃភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តី នូវអនុបសម្បន្នា ចាកលំនៅដែលមានសន្លឹកទ្វារជាប់នៅក្តី មិនមានសន្លឹកទ្វារជាប់នៅក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទង់ទាញឯងក្តី ឲ្យគេទង់ទាញក្តីនូវបរិក្ខារនៃអនុបសម្បន្នានោះ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាជាឧបសម្បន្នា ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្នា ភិក្ខុនីសំគាល់ថាអនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។

[២៧៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១៤យ៉ាង) គឺភិក្ខុនីទង់ទាញឯង ឬឲ្យគេទង់ទាញនូវភិក្ខុនីជាអលជ្ជិនី១ ទង់ទាញឯង ឬឲ្យគេទង់ទាញនូវបរិក្ខារនៃភិក្ខុនីជាអលជ្ជិនីនោះ១ ទង់ទាញឯង ឬឲ្យគេទង់ទាញភិក្ខុនីឆ្កួត១ ទង់ទាញឯង ឬឲ្យគេទង់ទាញនូវបរិក្ខារនៃភិក្ខុនីឆ្កួតនោះ១ ទង់ទាញឯង ឬឲ្យគេទង់ទាញនូវភិក្ខុនីអ្នកធ្វើការបង្ករហេតុ១ អ្នកធ្វើការឈ្លោះ១ អ្នកធ្វើការទាស់ទែង១ អ្នកធ្វើតិរច្ឆានកថា១ អ្នកធ្វើអធិករណ៍ក្នុងសង្ឃ១ ទង់ទាញឯង ឬឲ្យគេទង់ទាញនូវបរិក្ខារនៃភិក្ខុនីទាំងនោះ១ ទង់ទាញឯង ឬឲ្យគេទង់ទាញនូវភិក្ខុនីជាអន្តេវាសិនី ឬជាសទ្ធិវិហារិនីដែលប្រព្រឹត្តមិនល្អ១ ទង់ទាញឯង ឬឲ្យគេទង់ទាញនូវបរិក្ខារនៃភិក្ខុនីនោះ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្ដវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.pc.36 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[២៧៦] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនីនៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយបុត្ររបស់គហបតីខ្លះ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ចណ្ឌកាលីជាម្ចាស់ មិនសមបីនឹងនៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនរបស់គហបតីខ្លះសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចណ្ឌកាលីភិក្ខុនី នៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនគហបតីខ្លះ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនី មិនសមបីនឹងនៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនគហបតីខ្លះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ នៅច្រឡូកច្រឡំដោយគហបតីក្តី ដោយកូនគហបតីក្តី។ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយពោលយ៉ាងនេះថា នែលោកម្ចាស់ លោកកុំនៅច្រឡូកច្រឡំដោយគហបតី ឬដោយកូនគហបតីឡើយ នែលោកម្ចាស់ លោកចូរស្ងាត់ចុះ សង្ឃរមែងសរសើរសេចក្តីស្ងាត់នៃបងប្អូនស្រី។ ភិក្ខុនីនោះ កាលភិក្ខុនីទាំងឡាយពោលយ៉ាងនេះហើយ ក៏នៅប្រកួតប្រកាន់ធ្វើយ៉ាងនោះដដែល ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្ម ប្រកាសហាមដរាបគំរប់បីដង ដើម្បីឲ្យលះបង់វត្ថុនោះ។ ភិក្ខុនីនោះ បើភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មប្រកាសហាមដរាបគំរប់បីដងហើយ លះវត្ថុនោះបាន ការលះដូច្នេះនេះ ជាការប្រពៃ បើមិនលះទេ ត្រូវអាបត្តិបាចិត្តិយ។**

[២៧៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា ច្រឡូកច្រឡំនោះគឺច្រឡូកច្រឡំដោយកាយកម្ម នឹងវចីកម្ម ដ៏មិនសមគួរ។ ដែលហៅថា គហបតីនោះ បានដល់ជនឯណាមួយនៅគ្រប់គ្រងផ្ទះ។ ដែលហៅថា កូនគហបតីនោះ បានដល់ជនណាមួយជាកូន ឬជាបងប្អូនប្រុស (នៃគហបតីនោះ)។

[២៧៨] ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីណាមួយដែលជាអ្នកច្រឡូកច្រឡំ។ ពាក្យថា ត្រូវភិក្ខុនីទាំងឡាយ គឺត្រូវភិក្ខុនីទាំងឡាយដទៃ។ ភិក្ខុនីទាំងឡាយណាបានឃើញ ភិក្ខុនីទាំងឡាយណាបានឮ ភិក្ខុនីទាំងឡាយនោះគប្បីនិយាយហាមប្រាមថា នែលោកម្ចាស់ លោកកុំនៅច្រឡូកច្រឡំដោយគហបតី ឬដោយកូនរបស់គហបតីឡើយ នែលោកម្ចាស់ លោកចូរស្ងាត់ចុះ សង្ឃរមែងសរសើរសេចក្តីស្ងាត់របស់បងប្អូនស្រី។ ភិក្ខុនីទាំងនោះ គប្បីនិយាយហាមអស់វារៈគំរប់ពីរដងផង គប្បីនិយាយហាមអស់វារៈគំរប់បីដងផង។ បើភិក្ខុនីនោះលះចេញ ការលះដូច្នេះនេះ ជាការប្រពៃ បើមិនលះចេញទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទាំងឡាយណាឮហើយ មិននិយាយ ភិក្ខុនីទាំងឡាយនោះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយទាញមកកាន់កណ្តាលសង្ឃ ហើយគប្បីនិយាយហាមប្រាមថា នែលោកម្ចាស់ លោកកុំនៅច្រឡូកច្រឡំដោយគហបតី ឬដោយកូនរបស់គហបតីឡើយ នែលោកម្ចាស់ លោកចូរស្ងាត់ចុះ សង្ឃរមែងសរសើរសេចក្តីស្ងាត់នៃបងប្អូនស្រី។ ភិក្ខុនីទាំងឡាយនោះ គប្បីនិយាយមហាមប្រាមអស់វារៈគំរប់ពីរដងផង គប្បីនិយាយហាមអស់វារៈគំរប់បីដងផង។ បើភិក្ខុនីនោះ លះបង់បាន ការលះបានដូច្នេះនេះ ជាការប្រពៃ បើមិនលះចេញទេ ត្រូវអាបត្តិទុក្កដ។

[២៧៩] ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្ម។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ គប្បីសូត្រសមនុភាសនកម្មប្រកាសហាមប្រាមយ៉ាងនេះ។ ភិក្ខុនីដែលឆ្លាត ប្រតិពល គប្បីញុំាសង្ឃឲ្យដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះ នៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនរបស់គហបតីខ្លះ។ ភិក្ខុនីនោះមិនលះវត្ថុនោះចេញទេ។ បើកម្មនោះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្មចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះវត្ថុនោះចេញ។ នេះជាញត្តិ (គឺប្រកាសឲ្យសង្ឃដឹង)។ បពិត្រលោក

ម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះ នៅច្រឡូកច្រឡំដោយគហបតីខ្លះ ដោយកូនគហបតីខ្លះ។ ភិក្ខុនីនោះមិនលះចោលវត្តនោះចេញទេ។ ឥឡូវនេះ សង្ឃសូត្រសមនុភាសនកម្មចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្តនោះចេញ។ ការសូត្រសមនុភាសនកម្ម ចំពោះភិក្ខុនីឈ្មោះនេះ ដើម្បីឲ្យលះបង់វត្តនោះចេញ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីស្ងៀមនៅ មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីពោលឡើង។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈជាគំរប់ពីរដងផង។បេ។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈជាគំរប់បីដងផង។បេ។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់វត្តនោះចេញហើយ។ ការសូត្រសមនុភាសនកម្មនេះគួរដល់សង្ឃហើយ ហេតុនោះទើបសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[២៨០] កាលសូត្រចប់ញត្តិ (ភិក្ខុនីនោះមិនលះបង់វត្តនោះ) ត្រូវអាបត្តិទុក្កដ(១) កាលសូត្រកម្មវាចាពីរដង ត្រូវអាបត្តិទុក្កដ(២) កាលចប់កម្មវាចាជាស្រេច ត្រូវអាបត្តិបាចិត្តិយ។

[២៨១] កម្មជាធម៌ ភិក្ខុនីសំគាល់ថា កម្មជាធម៌ ហើយមិនលះបង់វត្តនោះ ត្រូវអាបត្តិបាចិត្តិយ។ កម្មជាធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ។ កម្មជាធម៌ ភិក្ខុនីសំគាល់ថា កម្មមិនជាធម៌ ហើយមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនជាធម៌ ភិក្ខុនីសំគាល់ថា កម្មជាធម៌វិញ ត្រូវអាបត្តិទុក្កដ។ កម្មមិនជាធម៌ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនជាធម៌ ភិក្ខុនីសំគាល់ថា កម្មមិនជាធម៌ ត្រូវអាបត្តិទុក្កដ។

[២៨២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីដែលសង្ឃមិនបានសូត្រសមនុភាសនកម្ម១ ភិក្ខុនីលះបង់វត្តនោះ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្តវគ្គ) សិក្ខាបទ ទីៗ

CS vin.vbi.pc.37 | ភាគ ទី៥

### (ៗ. សត្តមសិក្ខាបទំ)

[២៨៣] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ គ្មានពួកឈ្មួញទៅជាមួយ នាំគ្នាត្រេចទៅកាន់ចារិកខាងក្នុងដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ។ ពួកអ្នកលេងនាំគ្នាប្រទូស្ត(ពួកភិក្ខុនីទាំងឡាយនោះ)។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងនោះពោលទោស តិះដៀលបន្ទុះបង្អាប់ថា ពួកភិក្ខុនី មិនសមបីនឹងគ្មានពួកឈ្មួញទៅជាមួយ ហើយនាំគ្នាត្រេចទៅកាន់ចារិកខាងក្នុងដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុនីទាំងឡាយ គ្មានពួកឈ្មួញទៅជាមួយ ហើយត្រេចទៅកាន់ចារិកខាងក្នុងដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមគួរនឹងគ្មានពួកឈ្មួញទៅជាមួយ ហើយត្រេចទៅកាន់ចារិកខាងក្នុងដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ គ្មានពួកឈ្មួញទៅជាមួយ ហើយត្រេចទៅកាន់ចារិកខាងក្នុងដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិបាចិត្តិយ។**

[២៨៤] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ខាងក្នុងដែន គឺភិក្ខុនីនៅខាងក្នុងដែនរបស់ស្តេចណា ក៏ត្រេចទៅក្នុងដែនរបស់ស្តេចនោះ។ ដែលហៅថា ទីប្រកបដោយសេចក្តីរង្កៀសនោះ បានដល់កន្លែងដែលពួកចោរនៅក៏ប្រាកដ កន្លែងដែលពួកចោរបរិភោគក៏ប្រាកដ កន្លែងដែលពួកចោរឈរក៏ប្រាកដ កន្លែងដែលពួកចោរអង្គុយក៏ប្រាកដ កន្លែងដែលពួកចោរដេកក៏ប្រាកដក្នុងផ្លូវនោះ។ ទីដែលហៅថា ប្រកបដោយភ័យចំពោះមុខនោះ គឺពួកមនុស្សដែលចោរទាំងឡាយសម្លាប់ក៏ប្រាកដ ដែលចោរប្លន់ក៏ប្រាកដ ដែលចោរវាយក៏ប្រាកដក្នុងផ្លូវនោះ។ ដែលហៅថា គ្មានពួកឈ្មួញទៅជាមួយនោះ គឺវៀរចាកពួកឈ្មួញចេញ។ ពាក្យថា ត្រេចទៅកាន់ចារិក សេចក្តីថា ភិក្ខុនីត្រេចទៅក្នុងស្រុកកំណត់មួយរយៈមាន់ហើរ ត្រូវអាបត្តិបាចិត្តិយរាល់ៗចន្លោះស្រុក។ ទីព្រៃមិនមែនជាស្រុក ភិក្ខុនីត្រេចទៅក្នុងទីនោះ ត្រូវអាបត្តិបាចិត្តិយរាល់ៗកន្លះយោជន៍។

[២៨៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីទៅជាមួយពួកឈ្មួញ១ ភិក្ខុនីទៅក្នុងទីក្សេមក្សាន្តមិនមានភ័យ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្តវគ្គ) សិក្ខាបទ ទី៨

CS vin.vbi.pc.38 | ភាគ ទី៥

### (៨. អដ្ឋមសិក្ខាបទំ)

[២៨៦] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ គ្មានពួកឈ្មួញទៅជាមួយ ហើយត្រេចទៅកាន់ចារិកខាងក្រៅដែនដែលគេសន្មតថាជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ។ អ្នកលេងទាំងឡាយនាំគ្នាប្រទូស្ត(ពួកភិក្ខុនីនោះ)។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនី មិនសមគួរនឹងគ្មានពួកឈ្មួញទៅជាមួយ ហើយត្រេចទៅកាន់ចារិកខាងក្រៅដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនី គ្មានពួកឈ្មួញទៅជាមួយ ហើយត្រេចទៅកាន់ចារិកខាងក្រៅដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី មិនសមបីនឹងគ្មានពួកឈ្មួញទៅជាមួយ ហើយត្រេចទៅកាន់ចារិកខាងក្រៅដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ គ្មានពួកឈ្មួញទៅជាមួយ ហើយត្រេចទៅកាន់ចារិកខាងក្រៅដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិបាចិត្តិយ។**

[២៨៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ខាងក្រៅដែន គឺភិក្ខុនីនៅក្នុងដែនរបស់ស្តេចណា ហើយត្រេចទៅកាន់ចារិកក្នុងដែនរបស់ស្តេចឯទៀត ក្រៅពីដែនរបស់ស្តេចនោះ។ ដែលហៅថា ជាទីប្រកបដោយសេចក្តីរង្កៀសនោះ បានដល់កន្លែងដែលពួកចោរនៅក៏ប្រាកដ កន្លែងដែលពួកចោរបរិភោគក៏ប្រាកដ កន្លែងដែលពួកចោរឈរក៏ប្រាកដ កន្លែងដែលពួកចោរអង្គុយក៏ប្រាកដ កន្លែងដែលពួកចោរដេកក៏ប្រាកដក្នុងផ្លូវនោះ។ ទីដែលហៅថា ប្រកបដោយភ័យចំពោះមុខនោះ គឺពួកមនុស្សដែលចោរទាំងឡាយសម្លាប់ក៏ប្រាកដ ដែលពួកចោរប្លន់ក៏ប្រាកដ ដែលពួកចោរវាយក៏ប្រាកដក្នុងផ្លូវនោះ។ ដែលហៅថា គ្មានពួកឈ្មួញ គឺវៀរចាកពួកឈ្មួញ។ ពាក្យថា ត្រេចទៅកាន់ចារិក សេចក្តីថា ភិក្ខុនីត្រេចទៅក្នុងស្រុកកំណត់មួយរយៈមាន់ហើរ ត្រូវអាបត្តិបាចិត្តិយរាល់ៗចន្លោះស្រុក។ ភិក្ខុនីត្រេចទៅក្នុងព្រៃមិនមែនជាស្រុក ត្រូវអាបត្តិបាចិត្តិយរាល់ៗកន្លះយោជន៍។

[២៨៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីទៅជាមួយពួកឈ្មួញ១ ភិក្ខុនីទៅក្នុងទីក្សេមក្សាន្តមិនមានភ័យ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្តវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.pc.39 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[២៨៩] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តវេឡុវនវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ គ្រានោះឯង ពួកភិក្ខុនីត្រេចទៅកាន់ចារិកខាងក្នុងវស្សា។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបីនឹងត្រេចទៅកាន់ចារិកខាងក្នុងវស្សា ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនវត្ថុដែលរស់នៅមានឥន្ទ្រិយតែមួយ ញុំាងសត្វទាំងឡាយតូចៗឲ្យវិនាសទៅជាច្រើនសោះ។ ពួកភិក្ខុនីបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនី មិនសមបីនឹងត្រេចទៅកាន់ចារិកខាងក្នុងវស្សាសោះ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុនី ត្រេចទៅកាន់ចារិកខាងក្នុងវស្សា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី មិនសមបីនឹងត្រេចទៅកាន់ចារិកខាងក្នុងវស្សាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លានៃជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ត្រេចទៅកាន់ចារិកខាងក្នុងវស្សា ត្រូវអាបត្តិបាចិត្តិយ។**

[២៩០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ខាងក្នុងវស្សា សេចក្តីថា ភិក្ខុនីមិនបាននៅចាំវស្សាកំណត់៣ខែខាងដើមក្តី[22] កំណត់៣ខែខាងចុងក្តី[23] ។ ពាក្យថា ត្រេចទៅកាន់ចារិក សេចក្តីថា ភិក្ខុនីត្រេចទៅក្នុងស្រុកកំណត់មួយរយៈមាន់ហើរ ត្រូវអាបត្តិបាចិត្តិយរាល់ៗចន្លោះស្រុក ភិក្ខុនីត្រេចទៅក្នុងព្រៃមិនមែនស្រុក ត្រូវអាបត្តិបាចិត្តិយរាល់ៗកន្លះយោជន៍។

[២៩១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីទៅដោយសត្តាហករណីយកិច្ច១ ភិក្ខុនីទៅព្រោះហេតុនីមួយបៀតបៀន១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ តុវដ្តវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.pc.40 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[២៩២] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តវេឡុវនវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ។ គ្រានោះឯង ភិក្ខុនីទាំងឡាយនៅចាំវស្សាក្នុងវត្តវេឡុវន ជិតក្រុងរាជគ្រឹះនោះឯង (ចេញវស្សាហើយក៏នៅ) ក្នុងទីនោះអស់ហេមន្តរដូវ (នៅ) ក្នុងទីនោះអស់គិម្ហរដូវ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ទិសទាំងឡាយចង្អៀត ងងឹតដល់ភិក្ខុនី ទិសទាំងឡាយមិនប្រាកដច្បាស់ដល់ភិក្ខុនីទាំងនេះ (ឬដូចម្តេច បានជាមិនចេញអំពីទីនេះសោះ)។ ពួកភិក្ខុនីបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបភិក្ខុនីទាំងនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុនីទាំងឡាយ ព្រោះអាស្រ័យអំណាចនៃប្រយោជន៍១០យ៉ាង គឺដើម្បីសេចក្តីប្រពៃដល់សង្ឃ១។បេ។ ដើម្បីសេចក្តីតាំងនៅមាំនៃព្រះសទ្ធម្ម១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ១។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ នៅចាំវស្សា រួចហើយមិនចៀសចេញទៅកាន់ចារិក ដោយហោចទៅសូម្បីតែ៥-៦យោជន៍ ត្រូវអាបត្តិបាចិត្តិយ។**

[២៩៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា នៅចាំវស្សារួចហើយ គឺនៅចាំវស្សាគ្រប់៣ខែខាងដើមក្តី គ្រប់៣ខែខាងចុងក្តី។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនចៀសចេញទៅកាន់ចារិក ដោយហោចទៅសូម្បីតែ៥-៦យោជន៍ ក៏ត្រូវអាបត្តិបាចិត្តិយ។

[២៩៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីកាលមានសេចក្តីអន្តរាយ ហើយស្វែងរកភិក្ខុនីផងគ្នាជាគំរប់ពីរមិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

តុវដ្តវគ្គ ទី ៤ ចប់។

## (បាចិត្តិយ) ចិត្តាគារវគ្គ (ទី៥)

CS vin.vbi.pc.40 | ភាគ ទី៥

### (៥. ចិត្តាគារវគ្គោ)

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី១

CS vin.vbi.pc.41 | ភាគ ទី៥

### (១. បឋមសិក្ខាបទំ)

[២៩៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង នាយជាងបានគូរគំនូរក្នុងព្រះរាជដំណាក់ដ៏វិចិត្រ[24] ក្នុងឧទ្យានស្តេចបសេនទិកោសល។ ពួកមនុស្សជាច្រើនតែងទៅមើលព្រះរាជដំណាក់ដ៏វិចិត្រ(នោះ)។ សូម្បីពួកឆព្វគ្គិយាភិក្ខុនី (ភិក្ខុនីពួក៦រូប) ក៏បានទៅមើលព្រះរាជដំណាក់ដ៏វិចិត្រ (នោះដែរ)។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងទៅមើលព្រះរាជដំណាក់ដ៏វិចិត្រដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮពួកមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់(ដូច្នោះ)។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនី មិនសមបើនឹងទៅមើលព្រះរាជដំណាក់ដ៏វិចិត្រសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយាភិក្ខុនី ទៅមើលរាជដំណាក់ដ៏វិចិត្រ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនគួរបើនឹងទៅមើលរាជដំណាក់ដ៏វិចិត្រទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ ទៅដើម្បីមើលដំណាក់សម្រាប់ក្រសាលរបស់ស្តេចក្តី រោងដ៏វិចិត្រក្តី សួនក្តី ឧទ្យានក្តី ស្រះបោក្ខរណីក្តី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[២៩៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា ដំណាក់ក្រសាលរបស់ស្តេច បានដល់ដំណាក់ដែលគេសាងដើម្បីក្រសាលសប្បាយដល់ស្តេចនៅក្នុងកន្លែងណាមួយ។ ដែលហៅថា រោងដ៏វិចិត្រ បានដល់រោងដែលគេសាងដើម្បីលេងសប្បាយដល់មនុស្សទាំងឡាយនៅក្នុងកន្លែងណាមួយ។ ដែលហៅថា សួន បានដល់សួនដែលគេសាងដើម្បីលេងសប្បាយដល់មនុស្សទាំងឡាយក្នុងកន្លែងណាមួយ។ ដែលហៅថា ឧទ្យាន បានដល់ឧទ្យានដែលគេសាងដើម្បីលេងសប្បាយដល់មនុស្សទាំងឡាយក្នុងទីណាមួយ។ ដែលហៅថា ស្រះបោក្ខរណី បានដល់ស្រះបោក្ខរណីដែលគេសាងដើម្បីលេងសប្បាយដល់មនុស្សទាំងឡាយក្នុងកន្លែងណាមួយ។

ភិក្ខុនីទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ឈរមើលក្នុងទីណា ត្រូវអាបត្តិបាចិត្តិយក្នុងទីនោះ។ ភិក្ខុនីលះបង់ឧបចារមើល ហើយមើលរឿយៗ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីទៅដើម្បីមើលកន្លែងណាតែមួយៗ ត្រូវអាបត្តិទុក្កដ (មួយៗ) ឈរមើលក្នុងទីណា ត្រូវអាបត្តិបាចិត្តិយក្នុងទីនោះ។ លះបង់ឧបចារមើលហើយមើលញយៗ ត្រូវអាបត្តិបាចិត្តិយ។

[២៩៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុនីឈរក្នុងអារាមហើយមើល១ ភិក្ខុនីកំពុងដើរទៅក្តី ដើរមកក្តីឃើញ១ កាលបើមានកិច្ច ភិក្ខុនីទៅហើយឃើញ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី២

CS vin.vbi.pc.42 | ភាគ ទី៥

### (២. ទុតិយសិក្ខាបទំ)

[២៩៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយប្រើប្រាស់អាសន្ទិ[25] ខ្លះ បល្លង្ក [26] ខ្លះ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ ឃើញហើយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងប្រើប្រាស់អាសន្ទិខ្លះ បល្លង្កខ្លះ ដូចជាស្រីគ្រហស្ថជាអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងប្រើប្រាស់អាសន្ទិខ្លះ បល្លង្កខ្លះសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយប្រើប្រាស់អាសន្ទិខ្លះ បល្លង្កខ្លះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនគួរបើនឹងប្រើប្រាស់អាសន្ទិខ្លះ បល្លង្កខ្លះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ប្រើប្រាស់អាសន្ទិក្តី បល្លង្កក្តី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[២៩៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ អាសនៈដែលកន្លងហួសប្រមាណតថាគតឲ្យឈ្មោះថា អាសន្ទិ។ គ្រែដែលគេវិចិត្រដោយសត្វកាចទាំងឡាយលើកទៅមកបាន ឈ្មោះថា បល្លង្ក។ ពាក្យថា ប្រើប្រាស់ គឺភិក្ខុនីអង្គុយ ឬដេកដើអាសនៈនោះ ត្រូវអាបត្តិបាចិត្តិយ។

[៣០០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីកាត់ជើងអាសន្ទិ ហើយទើបប្រើប្រាស់១ ភិក្ខុនីទំលាយរូបសត្វកាចទាំងឡាយនៃបល្លង្ក ហើយទើបប្រើប្រាស់១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.pc.43 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[៣០១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយការសូត្រ (ឬអម្បោះ)។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ ឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងការអម្បោះដូចជាពួកស្រីគ្រហស្ថ ជាអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនី មិនសមបើនឹងការអម្បោះសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ ការអម្បោះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនគួរបើនឹងការអម្បោះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ការអម្បោះ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣០២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ សូត្រទាំងឡាយមាន៦យ៉ាង គឺរបស់ធ្វើដោយសម្បកឈើ១ ធ្វើដោយកប្បាស១ ធ្វើដោយសូត្រ (សម្បកនាង)១ ធ្វើដោយរោមសត្វ១ ធ្វើដោយធ្មៃ១ និងភង្គៈ (របស់ដែលលាយដោយវត្ថុទាំង៥ មានសម្បកឈើជាដើមជាមួយគ្នា)១ ឈ្មោះថាសូត្រ។ ពាក្យថា ការ គឺភិក្ខុនីការដោយខ្លួនឯង ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលការ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលបង្វិលមួយជុំៗ។

[៣០៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីការអម្បោះដែលគេការរួចហើយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.44 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[៣០៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ ធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបីនឹងធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី មិនគួរបើនឹងធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ធ្វើការបម្រើគ្រហស្ថ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣០៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលឈ្មោះថា ការខ្វល់ខ្វាយបម្រើគ្រហស្ថ គឺភិក្ខុនីចំអិនបបរក្តី បាយក្តី ខាទនីយក្តី លាងសាដកក្តី សំពត់ឈ្នួតក្តី ដើម្បីបុគ្គលដែលនៅគ្រប់គ្រងផ្ទះ ត្រូវអាបត្តិបាចិត្តិយ។

[៣០៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីជួយចម្អិនទឹកបបរក្តី សង្ឃភត្តក្តី ដើម្បីសង្ឃ១ ភិក្ខុនីជួយគ្រហស្ថក្នុងការបូជាចេតិយ១ ភិក្ខុនីចម្អិនបបរក្តី បាយក្តី ខាទនីយក្តី លាងសាដកក្តី សំពត់ឈ្នួតក្តី ដើម្បីវេយ្យាវច្ចកររបស់ខ្លួន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.45 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[៣០៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនី១រូប ចូលទៅរកថុល្លនន្ទាភិក្ខុនី ហើយបាននិយាយពាក្យនេះថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះ។ ថុល្លនន្ទាភិក្ខុនីគ្រាន់តែទទួលពាក្យថាសាធុ តែមិនរម្ងាប់មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីរម្ងាប់អធិករណ៍នោះឡើយ។ ទើបភិក្ខុនីនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ កាលដែលភិក្ខុនីនិយាយថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះ ដូច្នេះ បានទទួលពាក្យថា សាធុហើយ មិនសមបីនឹងមិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីរម្ងាប់ (អធិករណ៍នោះ) សោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី កាលដែលភិក្ខុនីនិយាយថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះ ដូច្នេះ បានទទួលពាក្យថា សាធុហើយ តែមិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីរម្ងាប់ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី កាលដែលភិក្ខុនីនិយាយថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះ ដូច្នេះ បានទទួលពាក្យថា សាធុហើយ ហេតុអ្វីក៏មិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីរម្ងាប់ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ កាលដែលភិក្ខុនីនិយាយថា នែនាងម្ចាស់ នាងចូរមក ចូររម្ងាប់អធិករណ៍នេះ ដូច្នេះ បានទទួលពាក្យថា សាធុហើយ ភិក្ខុនីនោះក្នុងកាលជាខាងក្រោយ ឥតមានសេចក្តីអន្តរាយ (អ្វី) ហើយមិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីរម្ងាប់ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣០៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា កាលដែលភិក្ខុនី បានដល់ភិក្ខុនីដទៃ។ អធិករណ៍ទាំងឡាយ៤ គឺវិវាទាធិករណ៍១ អនុវាទាធិករណ៍១ អាបត្តាធិករណ៍១ កិច្ចាធិករណ៍១ ឈ្មោះថា អធិករណ៍។ ពាក្យថា នែនាងម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះ គឺថា នែនាងម្ចាស់ នាងចូរមកវិនិច្ឆ័យអធិករណ៍នេះ។ ពាក្យថា ភិក្ខុនីនោះ ក្នុងកាលជាខាងក្រោយ ឥតមានសេចក្តីអន្តរាយ គឺកាលបើសេចក្តីអន្តរាយមិនមាន។ ពាក្យថា មិនរម្ងាប់ គឺមិនរម្ងាប់ដោយខ្លួនឯង។ ពាក្យថា មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីរម្ងាប់ គឺភិក្ខុនីមិនបង្គាប់ភិក្ខុនីដទៃ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនរម្ងាប់ អញនឹងមិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីរម្ងាប់ដូច្នេះ ត្រូវអាបត្តិបាចិត្តិយ។

[៣០៩] ឧបសម្បន្នា ភិក្ខុនីសំគាល់ថា ឧបសម្បន្នា ហើយមិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីរម្ងាប់នូវអធិករណ៍ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីមានសេចក្តីសង្ស័យ មិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីរម្ងាប់នូវអធិករណ៍ ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្នា ភិក្ខុនីសំគាល់ថា មិនមែនឧបសម្បន្នា ហើយមិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីរម្ងាប់នូវអធិករណ៍ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនរម្ងាប់ មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីរម្ងាប់នូវអធិករណ៍ដល់អនុបសម្បន្នា ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្នា ភិក្ខុនីសំគាល់ថា ឧបសម្បន្នា ត្រូវអាបត្តិ

ទុក្កដ។ មិនមែនឧបសម្បន្នា ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្នា ភិក្ខុនីសំគាល់ថា មិនមែនឧបសម្បន្នា ត្រូវអាបត្តិទុក្កដ។

[៣១០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺកាលបើមានសេចក្ដីអន្តរាយ ហើយភិក្ខុនីស្វែងរកគ្នាមិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.pc.46 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[៣១១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីឲ្យខាទនីយភោជនីយាហារដោយដៃខ្លួនឯង ដល់ពួកមេល្ខោនខ្លះ ដល់ពួកកូនល្ខោនខ្លះ ដល់ពួកអ្នកឡើងរាំវខ្លះ ដល់ពួកអ្នកបំបាត់សេចក្ដីសោក (គឺអ្នកលេងកំប្លែងសើចគឹត្លក) ខ្លះ ដល់ពួកអ្នកវាយស្គរខ្លះ ដោយពាក្យថា អ្នកទាំងឡាយ ចូរពោលសរសើរគុណយើងក្នុងបរិសទ្យចុះ។ ពួកមេល្ខោនខ្លះ កូនល្ខោនខ្លះ អ្នកឡើងរាំវខ្លះ អ្នកលេងត្លកកំប្លែងខ្លះ អ្នកលេងស្គរខ្លះ តែងពោលសរសើរគុណថុល្លនន្ទាភិក្ខុនីក្នុងបរិសទ្យថា នាងម្ចាស់ថុល្លនន្ទា ជាពហុស្សូត ជាអ្នកប្រសប់និយាយ ក្លៀវក្លា ឆ្លាសខាងសំដែងធម្មីកថា អ្នកទាំងឡាយចូរឲ្យទានដល់នាងម្ចាស់ចុះ ចូរធ្វើការបូជាដល់នាងម្ចាស់ចុះ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា នាងម្ចាស់ថុល្លនន្ទា មិនសមបីនឹងឲ្យខាទនីយភោជនីយាហារដល់គ្រហស្ថដោយដៃខ្លួនឯង សោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីឲ្យខាទនីយភោជនីយាហារដល់គ្រហស្ថដោយដៃខ្លួនឯង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងឲ្យខាទនីយភោជនីយាហារដល់គ្រហស្ថដោយដៃខ្លួនឯងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យខាទនីយ ឬភោជនីយ ដល់គ្រហស្ថក្ដី បរិព្វាជកក្ដី បរិព្វាជិកាក្ដី ដោយដៃខ្លួនឯង ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣១២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ បុគ្គលណាមួយនៅគ្រប់គ្រងផ្ទះ បុគ្គលនោះឈ្មោះថាគ្រហស្ថ។ ប្រុសណាមួយដែលបួសជាបរិព្វាជក លើកទុកតែភិក្ខុ និងសាមណេរចេញ អ្នកនោះហៅថា បរិព្វាជក។ ស្រីណាមួយ ដែលបួសជាបរិព្វាជិកា លើកទុកតែភិក្ខុនី សិក្ខមានា និងសាមណេរីចេញ ស្រីនោះហៅថា បរិព្វាជិកា។ ដែលឈ្មោះថា ខាទនីយ គឺលើកទុកតែភោជន៥យ៉ាង និងទឹក និងឈើស្ទន់ចេញ ក្រៅ(អំពីនោះ) ហៅថា ខាទនីយទាំងអស់។ ដែលហៅថា ភោជន បានដល់ភោជន៥យ៉ាង គឺបាយ១ នំកុម្មាស១ សដូវ១ ត្រី១ សាច់១។ ពាក្យថា ឲ្យ គឺភិក្ខុនីឲ្យដោយកាយក្ដី ដោយរបស់ជាប់នឹងកាយក្ដី ដោយបោះឲ្យក្ដី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីឲ្យទឹក និងឈើស្ទន់ ត្រូវអាបត្តិទុក្កដ។

[៣១៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីឲ្យគេឲ្យ មិនបានឲ្យដោយដៃខ្លួនឯង១ ភិក្ខុនីដាក់ (ផុតពីដៃ) ហើយឲ្យ[27] ១ ភិក្ខុនីឲ្យគ្រឿងលាបកាយខាងក្រៅ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី៧

CS vin.vbi.pc.47 | ភាគ ទី៥

### (៧. សត្តមសិក្ខាបទំ)

[៣១៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនីមិនលះបង់អាវសថចីវរ[28] (ឲ្យដល់ភិក្ខុនីដទៃ) ហើយប្រើប្រាស់ (តែម្នាក់ឯង)។ ពួកភិក្ខុនីឯទៀតដែលមានរដូវមិនបានប្រើប្រាស់ផង)។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបើនឹងមិនលះបង់អាវសថចីវរ (ឲ្យដល់ភិក្ខុនីដទៃ) ហើយប្រើប្រាស់ (តែម្នាក់ឯង)សោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនីមិនលះបង់អាវសថចីវរ (ឲ្យដល់ភិក្ខុនីដទៃ) ហើយប្រើប្រាស់ (តែម្នាក់ឯង) ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនគួរបើនឹងមិនលះបង់អាវសថចីវរ (ឲ្យដល់ភិក្ខុនីដទៃ) ហើយប្រើប្រាស់ (តែម្នាក់ឯង)ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មិនប្រគល់អាវសថចីវរ ហើយប្រើប្រាស់ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣១៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា អាវសថចីវរ បានដល់ចីវរដែលទាយកប្រគេនបម្រុងទុកដោយពាក្យថា ភិក្ខុនីទាំងឡាយដែលមានរដូវចូរប្រើប្រាស់ចុះ។ ពាក្យថា មិនប្រគល់ហើយប្រើប្រាស់ គឺភិក្ខុនីប្រើប្រាស់អស់ពីរបីរាត្រីហើយ ក្នុងថ្ងៃទីបួន លាងហើយ មិនប្រគល់ឲ្យដល់ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរីក្តី ហើយប្រើប្រាស់ (ម្នាក់ឯង) ត្រូវអាបត្តិបាចិត្តិយ។

[៣១៦] ចីវរមិនទាន់បានប្រគល់ ភិក្ខុនីសំគាល់ថាមិនទាន់បានប្រគល់ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ចីវរមិនទាន់បានប្រគល់ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ចីវរមិនទាន់បានប្រគល់ ភិក្ខុនីសំគាល់ថាប្រគល់ឲ្យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ។ ចីវរប្រគល់ឲ្យហើយ ភិក្ខុនីសំគាល់ថា មិនទាន់បានប្រគល់ ត្រូវអាបត្តិទុក្កដ។ ចីវរប្រគល់ឲ្យហើយ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ចីវរប្រគល់ឲ្យហើយ ភិក្ខុនីសំគាល់ថា ប្រគល់ឲ្យហើយ មិនត្រូវអាបត្តិ។

[៣១៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុនីប្រគល់ឲ្យ ហើយប្រើប្រាស់១ ភិក្ខុនីប្រើប្រាស់តាមវេនជាថ្មីទៀត១ ពួកភិក្ខុនីឯទៀតដែលមានរដូវក៏មិនមាន (ហើយភិក្ខុនីនោះចេះតែប្រើទៅ មិនបានលះ)១ ភិក្ខុនីដែលចោរដណ្តើមយកចីវរទៅ១ ភិក្ខុនីដែលមានចីវរវិនាស១ ភិក្ខុនីប្រើប្រាស់ក្នុងពេលមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី៨

CS vin.vbi.pc.48 | ភាគ ទី៥

### (៨. អដ្ឋមសិក្ខាបទំ)

[៣១៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ចុល្លនន្ទាភិក្ខុនីមិនប្រគល់លំនៅ(ដល់អ្នកដទៃ) ហើយក៏ចៀសទៅកាន់ចារិក។ ក៏សម័យនោះឯង ភ្លើងឆេះលំនៅរបស់ចុល្លនន្ទាភិក្ខុនី (នោះ)។ ភិក្ខុនីទាំងឡាយបាននិយាយគ្នាយ៉ាងនេះថា នែនាងម្ចាស់ទាំងឡាយ ណ្ហើយចុះ យើងនឹងជញ្ជូនរបស់ចេញ។ ភិក្ខុនីទាំងឡាយពួកខ្លះ បាននិយាយយ៉ាងនេះថា នែនាងម្ចាស់ទាំងឡាយ យើងនឹងមិនជញ្ជូនទេ ក្រែងរបស់ណាមួយបាត់ទៅហើយ គេនឹងចោទប្រកាន់យើង ចំពោះរបស់ទាំងអស់។ ចុល្លនន្ទាភិក្ខុនីត្រឡប់មកកាន់លំនៅនោះវិញទៀត ហើយសួរភិក្ខុនីទាំងឡាយថា នែនាងម្ចាស់ទាំងឡាយ ពួកនាងបានជញ្ជូនរបស់យើងចេញខ្លះដែរឬទេ។ ពួកភិក្ខុនីទាំងនោះតបថា នែនាងម្ចាស់ ពួកយើងមិនបានជញ្ជូនចេញទេ។ ចុល្លនន្ទាភិក្ខុនីក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ កាលបើលំនៅត្រូវភ្លើងឆេះ មិនគួរបើនឹងមិនជញ្ជូនរបស់ចេញផងសោះ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុល្លនន្ទាជាម្ចាស់ មិនសមបើនឹងមិនប្រគល់លំនៅ (ឲ្យគេថែរក្សាសិន) ហើយសិមចៀសចេញទៅកាន់ចារិកដូច្នេះសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ចុល្លនន្ទាភិក្ខុនីមិនប្រគល់លំនៅសិន ហើយចៀសចេញទៅកាន់ចារិក ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចុល្លនន្ទាភិក្ខុនី មិនគួរបើនឹងមិនប្រគល់លំនៅសិន ហើយចៀសចេញទៅកាន់ចារិកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មិនប្រគល់លំនៅ ហើយចៀសចេញទៅកាន់ចារិក ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣១៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា លំនៅ សំដៅយកលំនៅដែលមានសន្ទះទ្វារជាប់។ ពាក្យថា មិនប្រគល់ ហើយចៀសចេញទៅកាន់ចារិក សេចក្តីថា ភិក្ខុនីមិនប្រគល់ដល់ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរីក្តី ហើយឈានកន្លងរបងនៃលំនៅដែលមានរបង ត្រូវអាបត្តិបាចិត្តិយ។ កាលភិក្ខុនីឈានកន្លងឧបចារនៃលំនៅដែលមិនមានរបង ក៏ត្រូវអាបត្តិបាចិត្តិយ។

[៣២០] លំនៅដែលខ្លួនមិនបានប្រគល់ ភិក្ខុនីសំគាល់ថាមិនបានប្រគល់ឲ្យ ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ លំនៅដែលខ្លួនមិនបានប្រគល់ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ លំនៅដែលខ្លួនមិនបានប្រគល់ ភិក្ខុនីសំគាល់ថាប្រគល់ហើយ ក៏ចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនប្រគល់លំនៅដែលគ្មានសន្ទះទ្វារជាប់ ហើយចៀសចេញទៅ ត្រូវអាបត្តិទុក្កដ។ លំនៅដែលខ្លួនប្រគល់ហើយ ភិក្ខុនីសំគាល់ថា មិនទាន់ប្រគល់ ត្រូវអាបត្តិទុក្កដ។ លំនៅដែលខ្លួនប្រគល់ហើយ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ លំនៅដែលខ្លួនប្រគល់ហើយ ភិក្ខុនីសំគាល់ថា ប្រគល់ហើយ មិនត្រូវអាបត្តិ។

[៣២១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺភិក្ខុនីប្រគល់ ហើយទើបចៀសចេញទៅ១ កាលបើមានសេចក្តីអន្តរាយ ភិក្ខុនីក៏ចេញទៅស្វែងរក (គ្មាននឹងប្រគល់ឲ្យតែ) មិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ ហើយក៏ចេញទៅ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.pc.49 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[៣២២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយាភិក្ខុនីរៀនតិរច្ឆានវិជ្ជា។មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងរៀនតិរច្ឆានវិជ្ជា ដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមសោះ។ ពួកភិក្ខុនីបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនី មិនសមបើនឹងរៀនតិរច្ឆានវិជ្ជាសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយាភិក្ខុនីរៀនតិរច្ឆានវិជ្ជា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនី មិនគួរនឹងរៀនតិរច្ឆានវិជ្ជាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ រៀនតិរច្ឆានវិជ្ជា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣២៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ចំណេះណាមួយជាខាងក្រៅ ដែលមិនប្រកបដោយប្រយោជន៍ ចំណេះនោះឈ្មោះថា តិរច្ឆានវិជ្ជា។ ពាក្យថា រៀន សេចក្តីថា ភិក្ខុនីរៀនដោយបទ ត្រូវអាបត្តិបាចិត្តិយរាល់ៗបទ។ (បើ) រៀនដោយអក្សរ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗអក្សរ។

[៣២៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីរៀនសរសេរអក្សរ១ ភិក្ខុនីរៀនធារណសាស្ត្រ[29] ១ ភិក្ខុនីរៀនវិជ្ជាការពារខ្លួនសម្រាប់រក្សា (ខ្លួន)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ចិត្តាគារវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.pc.50 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[៣២៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកឆព្វគ្គិយាភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា។មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងបង្រៀនតិរច្ឆានវិជ្ជា ដូចជាពួកស្រីគ្រហស្ថដែលបរិភោគកាមសោះ។ ភិក្ខុនីបានឮច្បាស់នូវពាក្យមនុស្សទាំងឡាយកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនី មិនសមបើនឹងបង្រៀនតិរច្ឆានវិជ្ជាសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយាភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនី មិនគួរបើនឹងបង្រៀនតិរច្ឆានវិជ្ជាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ បង្រៀនតិរច្ឆានវិជ្ជា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣២៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ចំណេះណាមួយជាខាងក្រៅ ដែលមិនប្រកបដោយប្រយោជន៍ ចំណេះនោះឈ្មោះថា តិរច្ឆានវិជ្ជា។ ពាក្យថា បង្រៀន គឺភិក្ខុនីបង្រៀនដោយបទ ត្រូវអាបត្តិបាចិត្តិយរាល់ៗបទ។ បង្រៀនដោយអក្សរ ត្រូវអាបត្តិបាចិត្តិយរាល់ៗអក្សរ។

[៣២៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីបង្រៀនសរសេរ១ ភិក្ខុនីបង្រៀនធារណសាស្ត្រ១ ភិក្ខុនីបង្រៀនវិជ្ជាការពារខ្លួនដើម្បីរក្សា (ខ្លួន)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

ចិត្តាគារវគ្គ ទី ៥ ចប់។

# (បាចិត្តិយ) អារាមវគ្គ (ទី៦)

CS vin.vbi.pc.v6 | ភាគ ទី៥

### (៦. អារាមវគ្គោ)

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី១

CS vin.vbi.pc.51 | ភាគ ទី៥

### (១. បឋមសិក្ខាបទំ)

[៣២៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូប ទ្រទ្រង់តែចីវរមួយៗម្នាក់ ហើយធ្វើចីវរកម្ម (ដេរ ឬជ្រលក់ចីវរជាដើម) ក្នុងអាវាសដែលតាំងនៅជិតស្រុកតូចមួយ។ ភិក្ខុនីទាំងឡាយមិនបានប្រាប់ ហើយចូលទៅកាន់អារាម រួចចូលទៅរកភិក្ខុទាំងឡាយនោះ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងមិនប្រាប់ (ជាមុន) ហើយចូលមកកាន់អារាមសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ មិនប្រាប់ហើយចូលទៅកាន់អារាម ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងមិនប្រាប់ ហើយចូលទៅកាន់អារាមទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុនីណាមួយ មិនបានប្រាប់ ហើយចូលទៅកាន់អារាម ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុនីទាំងឡាយយ៉ាងនេះរួចហើយ។

[៣២៩] សម័យនោះឯង ភិក្ខុទាំងឡាយនោះចៀសចេញទៅចាកអាវាសនោះហើយ។ ភិក្ខុនីទាំងឡាយមិនបានមកកាន់អារាមដោយគិតថា លោកម្ចាស់ទាំងឡាយចៀសចេញទៅហើយ។ គ្រានោះឯង ភិក្ខុទាំងឡាយនោះត្រឡប់មកអាវាសនោះវិញទៀត។ ភិក្ខុនីទាំងឡាយដឹងថា លោកម្ចាស់ទាំងឡាយមកដល់ហើយ ៗក៏ប្រាប់ រួចចូលទៅកាន់អារាមសំដៅទៅរកភិក្ខុទាំងឡាយនោះ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំភិក្ខុទាំងឡាយនោះ ហើយឈរនៅក្នុងទីគួរមួយ។ លុះភិក្ខុនីទាំងនោះឈរនៅក្នុងទីគួរមួយហើយ ភិក្ខុទាំងឡាយនោះ ក៏និយាយពាក្យនេះថា នែនាងទាំងឡាយ ហេតុអ្វី ក៏នាងទាំងឡាយមិនបោសអារាម មិនដំកល់ទុកនូវទឹកផឹក ទឹកប្រើសោះ។ ភិក្ខុនីទាំងឡាយនិយាយថា បពិត្រលោកម្ចាស់ទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទហើយថា ភិក្ខុនីមិនបានប្រាប់ មិនត្រូវចូលទៅកាន់អារាមដូច្នេះ ហេតុនោះ (បានជា) យើងខ្ញុំទាំងឡាយ មិនបានមក។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់អារាមបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុនីណាមួយ មិនបានប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់អារាម ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តដល់ពួកភិក្ខុនីយ៉ាងនេះរួចហើយ។

[៣៣០] ក៏សម័យនោះឯង ភិក្ខុទាំងឡាយនោះចេញចាកអាវាសនោះ ហើយត្រឡប់មកកាន់អាវាសនោះវិញទៀត។ ភិក្ខុនីទាំងឡាយដឹងថា លោកម្ចាស់ទាំងឡាយចៀសចេញទៅហើយ ក៏មិនបានប្រាប់ ហើយចូលទៅកាន់អារាម។ ភិក្ខុនីទាំងឡាយនោះមានសេចក្តីរង្កៀសថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទហើយថា ភិក្ខុនីមិនទាន់បានប្រាប់ភិក្ខុដែលមាននៅ ហើយមិនត្រូវចូលទៅកាន់អារាមឡើយ ឯយើងទាំងឡាយ មិនបានប្រាប់ភិក្ខុដែលមាននៅហើយ ចូលទៅកាន់អារាម យើងទាំងឡាយត្រូវអាបត្តិបាចិត្តិយដែរឬហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ កាលដឹងហើយ មិនបានប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់អារាម ត្រូវអាបត្តិបាចិត្តិយ។**

[៣៣១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលឈ្មោះថា ភិក្ខុនីកាលដឹង (នោះ) គឺភិក្ខុនីដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ភិក្ខុនីនោះក្តី ពួកភិក្ខុដែលនៅក្នុងអារាមនោះប្រាប់ក្តី។ ភិក្ខុទាំងឡាយនៅក្នុងទីណា សូម្បីក្រោមម្លប់ឈើ ទីនោះ (ក៏)ឈ្មោះថា អារាមមានភិក្ខុ។ ពាក្យថា ភិក្ខុនីមិនបានប្រាប់ ហើយចូលទៅកាន់អារាម សេចក្តីថា ភិក្ខុនីមិនប្រាប់ភិក្ខុក្តី សាមណេរក្តី ញោមវត្តក្តី ហើយឈានកន្លងរបងវត្ត ដែលមានរបង ត្រូវអាបត្តិបាចិត្តិយ។ កាលភិក្ខុនីចូលទៅដល់ឧបចារវត្តដែលគ្មានរបង ក៏ត្រូវអាបត្តិបាចិត្តិយ។

[៣៣២] អារាមដែលមានភិក្ខុ ភិក្ខុនីសំគាល់ថា មានភិក្ខុ មិនបានប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់អារាម ត្រូវអាបត្តិបាចិត្តិយ។ អារាមដែលមានភិក្ខុ ភិក្ខុនីមានសេចក្តីសង្ស័យ មិនប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់អារាម ត្រូវអាបត្តិទុក្កដ។ អារាមដែលមានភិក្ខុ ភិក្ខុនីសំគាល់ថា មិនមានភិក្ខុ មិនបានប្រាប់ភិក្ខុដែលមាននៅ ហើយចូលទៅកាន់អារាម មិនត្រូវអាបត្តិ។ អារាមដែលមិនមានភិក្ខុ ភិក្ខុនីសំគាល់ថា មានភិក្ខុ ត្រូវអាបត្តិទុក្កដ។ អារាមដែលមិនមានភិក្ខុ ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អារាមដែលមិនមានភិក្ខុ ភិក្ខុនីសំគាល់ថា មិនមានភិក្ខុ មិនត្រូវអាបត្តិ។

[៣៣៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុនីប្រាប់ភិក្ខុដែលមាននៅ ហើយទើបចូលទៅ១ ភិក្ខុនីមិនប្រាប់ ព្រោះគ្មានភិក្ខុ ហើយចូលទៅ១ ភិក្ខុនីដែលក្រឡេកឃើញសីស (ភិក្ខុនីដែលចូលទៅមុន) ហើយទើបទៅ១ ពួកភិក្ខុនីប្រជុំនៅក្នុងទីណា ភិក្ខុនីនោះ ក៏ទៅក្នុងទីនោះ១ ភិក្ខុនីដើរតាមផ្លូវដែលមានក្នុងវត្ត១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី២

### (២. ទុតិយសិក្ខាបទំ)

[៣៣៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងកូដាគារសាលា ក្នុងព្រៃមហាវន ទៀបក្រុងវេសាលី។ គ្រានោះឯង ព្រះកប្បិតកដ៏មានអាយុ ជាឧបជ្ឈាយ៍ព្រះឧបាលិដ៏មានអាយុ គង់នៅក្នុងព្រៃស្មសាន។ សម័យនោះឯង ភិក្ខុនីដែលជាធំជាងពួកឆព្វគ្គិយាភិក្ខុនីធ្វើមរណកាល។ ពួកឆព្វគ្គិយាភិក្ខុនីនាំភិក្ខុនីនោះទៅ ហើយដុតភិក្ខុនីនោះក្នុងទីមិនឆ្ងាយពីកុដិព្រះកប្បិតកដ៏មានអាយុ ហើយធ្វើស្តូប (ចេតិយ) ហើយតែងទៅយំជិតស្តូបនោះ។ គ្រានោះឯង ព្រះកប្បិតកដ៏មានអាយុ ធុញទ្រាន់នឹងសំឡេងនោះ ទំលាយស្តូបនោះឲ្យខ្ចាត់ខ្ចាយចេញ។ ពួកឆព្វគ្គិយាភិក្ខុនីប្រឹក្សាគ្នាថា លោកកប្បិតកនេះទំលាយស្តូបភិក្ខុនីជាម្ចាស់របស់យើង បើដូច្នោះ មានតែយើងនឹងសម្លាប់លោកកប្បិតកនោះ។ ភិក្ខុនី១រូបប្រាប់រឿងនុ៎ះដល់ព្រះឧបាលិដ៏មានអាយុ។ ព្រះឧបាលិដ៏មានអាយុប្រាប់រឿងនុ៎ះដល់ព្រះកប្បិតកដ៏មានអាយុ។ លំដាប់នោះឯង ព្រះកប្បិតកដ៏មានអាយុចេញពីកុដិទៅពួន។ ឯពួកឆព្វគ្គិយាភិក្ខុនី ចូលតម្រង់ទៅឯលំនៅព្រះកប្បិតកដ៏មានអាយុ លុះចូលទៅហើយ ក៏ចោលកុដិព្រះកប្បិតកដ៏មានអាយុដោយដុំថ្មផង ដោយដុំដីផង ហើយក៏ចៀសចេញទៅដោយគិតថា លោកកប្បិតកស្លាប់ហើយ។ លំដាប់នោះឯង ព្រះកប្បិតកដ៏មានអាយុ លុះកន្លងរាត្រីនោះ ក៏ស្លៀក ហើយប្រដាប់បាត្រ និងចីវរក្នុងពេលព្រឹកព្រហាម ហើយចូលទៅកាន់ក្រុងវេសាលីដើម្បីបិណ្ឌបាត។ ពួកឆព្វគ្គិយាភិក្ខុនីបានឃើញលោកកប្បិតកដ៏មានអាយុកំពុងត្រេចទៅបិណ្ឌបាត លុះឃើញហើយ បាននិយាយយ៉ាងនេះថា លោកកប្បិតកនេះនៅរស់ (ទេតើ) អ្នកណាហ្ន៎ នាំសេចក្តីប្រឹក្សា (អាថ៌កំបាំង) យើងទៅ (ប្រាប់លោក)។ ពួកឆព្វគ្គិយាភិក្ខុនីបានឮដូច្នេះថា ដំណឹងថា លោកម្ចាស់ឧបាលិនាំសេចក្តីប្រឹក្សាយើងទៅប្រាប់។ ពួកឆព្វគ្គិយាភិក្ខុនីទាំងនោះ ក៏នាំគ្នាជេរព្រះឧបាលិដ៏មានអាយុថា លោកខ្មាន់ព្រះកេសនេះ ជាអ្នកដុសក្អែល (គេ) មានជាតិដ៏ថោកទាប មិនសមបើនឹងនាំយកសេចក្តីប្រឹក្សារបស់យើងទៅប្រាប់សោះ។ ពួកភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយាភិក្ខុនី មិនសមបើនឹងមកនាំគ្នាជេរលោកម្ចាស់ឧបាលិសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយាភិក្ខុនីជេរឧបាលិ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកឆព្វគ្គិយាភិក្ខុនី មិនគួរបើនឹងជេរឧបាលិទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ជេរគំរាមភិក្ខុ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៣៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ភិក្ខុ បានដល់ឧបសម្បន្ន។ ពាក្យថា ជេរ គឺភិក្ខុនីជេរដោយអក្កោសវត្ថុទាំង១០ ឬបណ្តាអក្កោសវត្ថុទាំង១០នោះ ដោយអក្កោសវត្ថុណាមួយ ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា គំរាម គឺភិក្ខុនីសំដែងសេចក្តីខ្លាច ត្រូវអាបត្តិបាចិត្តិយ។

[៣៣៦] ឧបសម្បន្ន ភិក្ខុនីសំគាល់ថា ឧបសម្បន្ន ហើយជេរក្តី គំរាមក្តី ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុនីមានសេចក្តីសង្ស័យ ហើយជេរក្តី គំរាមក្តី ត្រូវអាបត្តិបាចិត្តិយ។ ឧបសម្បន្ន ភិក្ខុនីសំគាល់ថា មិនមែនឧបសម្បន្ន ហើយជេរក្តី គំរាមក្តី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីជេរក្តី គំរាមក្តី នូវអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ។ មិនមែនឧបសម្បន្ន ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ អនុបសម្បន្ន ភិក្ខុនីសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ។

[៣៣៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីធ្វើអត្ថឲ្យជាប្រធាន១ ធ្វើធម៌ឲ្យជាប្រធាន១ ធ្វើពាក្យប្រៀនប្រដៅឲ្យជាប្រធាន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី៣



### (៣. តតិយសិក្ខាបទំ)

[៣៣៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនីជាអ្នកធ្វើសេចក្តីបង្កហេតុ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីទាស់ទែង ធ្វើតិរច្ឆានកថា បង្កើតអធិករណ៍ក្នុងសង្ឃ។ កាលសង្ឃកំពុងធ្វើកម្មដល់ចណ្ឌកាលីភិក្ខុនីនោះ ថុល្លនន្ទាភិក្ខុនីក៏ហាមឃាត់។

[៣៣៩] គ្រានោះឯង ថុល្លនន្ទាភិក្ខុនី បានទៅកាន់ស្រុកតូច (មួយ) ដោយកិច្ចនីមួយ។ ទើបភិក្ខុនីសង្ឃដឹងថា ថុល្លនន្ទាភិក្ខុនីចៀសចេញទៅហើយ ក៏លើកវត្តចំពោះចណ្ឌកាលីភិក្ខុនី ព្រោះសេចក្តីមិនឃើញអាបត្តិ។ ថុល្លនន្ទាភិក្ខុនីសម្រេចកិច្ចនោះក្នុងស្រុកតូចហើយ ក៏ត្រឡប់មកក្រុងសាវត្ថីវិញទៀត។ ចណ្ឌកាលីភិក្ខុនី កាលដែលថុល្លនន្ទាភិក្ខុនីមក ក៏មិនក្រាលអាសនៈ មិនដម្កល់ទឹកលាងជើង តាំងរងជើង ជ្រញ់កល់ជើង មិនក្រោកទទួលបាត្រចីវរ មិនអើពើដោយទឹកផឹក។ ថុល្លនន្ទាភិក្ខុនីបាននិយាយពាក្យនេះនឹងចណ្ឌកាលីភិក្ខុនីថា នែនាងម្ចាស់ កាលបើយើងមកដល់ ហេតុអ្វីក៏នាងមិនក្រាលអាសនៈ មិនដម្កល់ទឹកលាងជើង តាំងសម្រាប់រងជើង ជ្រញ់រងជើង មិនក្រោកទទួលបាត្រចីវរ មិនអើពើដោយទឹកផឹកសោះ។ ចណ្ឌកាលីភិក្ខុនីនិយាយថា នែនាងម្ចាស់ បានជាខ្ញុំមិនធ្វើកិច្ចទាំងអម្បាលនេះ ព្រោះខ្ញុំជាស្រីអនាថា។ ថុល្លនន្ទាភិក្ខុនីសួរថា នែនាងម្ចាស់ នាងជាស្រីអនាថា ព្រោះហេតុអ្វី។ ចណ្ឌកាលីភិក្ខុនីនិយាយថា នែនាងម្ចាស់ ភិក្ខុនីអស់នេះ លើកវត្តចំពោះខ្លួនខ្ញុំ ព្រោះមិនឃើញអាបត្តិ ដោយគិតគ្នាថា ភិក្ខុនីនេះ ជាស្រីអនាថា គ្មានអ្នកណាស្គាល់ គ្មានអ្នកណាមួយគោរពកោតក្រែងដល់ភិក្ខុនីនេះទេ។ ថុល្លនន្ទាភិក្ខុនីនិយាយថា ពួកភិក្ខុនីអស់នុ៎ះល្ងង់ ពួកភិក្ខុនីអម្បាលនុ៎ះមិនឆ្លាស ពួកភិក្ខុនីទាំងនុ៎ះមិនស្គាល់កម្មក្តី ទោសរបស់កម្មក្តី កម្មវិបត្តិក្តី កម្មសម្បត្តិក្តី

ដូច្នេះ ហើយក៏ផ្តាសាគណភិក្ខុនីដោយសេចក្តីកំណាច។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ចុល្លនន្ទា មិនសមបើនឹងផ្តាសាគណភិក្ខុនីដោយសេចក្តីកំណាចសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាចុល្លនន្ទាភិក្ខុនី ផ្តាសាគណភិក្ខុនី ដោយសេចក្តីកំណាច ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចុល្លនន្ទាភិក្ខុនី មិនគួរបើនឹងផ្តាសាគណភិក្ខុនី ដោយសេចក្តីកំណាចទេ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ផ្តាសាគណភិក្ខុនីដោយសេចក្តីកំណាច ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៤០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា កំណាច សំដៅយកសេចក្តីក្រោធ។ ដែលហៅថា គណភិក្ខុនី សំដៅយកភិក្ខុនីសង្ឃ។ ពាក្យថា ផ្តាសា គឺភិក្ខុនីផ្តាសាថា ភិក្ខុនីអស់នុ៎ះល្ងង់ ភិក្ខុនីអម្បាលនុ៎ះមិនឆ្លាស ពួកភិក្ខុនីទាំងនុ៎ះមិនស្គាល់កម្មក្តី ទោសរបស់កម្មក្តី កម្មវិបត្តិក្តី កម្មសម្បត្តិក្តីដូច្នេះ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីផ្តាសាភិក្ខុនីច្រើនរូបក្តី មួយរូបក្តី អនុបសម្បន្នក្តី ត្រូវអាបត្តិទុក្កដ។

[៣៤១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីធ្វើអត្ថជាប្រធាន១ ធ្វើធម៌ជាប្រធាន១ ធ្វើពាក្យប្រៀនប្រដៅជាប្រធាន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.54 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[៣៤២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង មានព្រាហ្មណ៍ម្នាក់ និមន្តពួកភិក្ខុនីឲ្យឆាន់។ ពួកភិក្ខុនីឆាន់ហើយ ហាមភត្តហើយ ក៏ទៅកាន់ត្រកូលជាញាតិទាំងឡាយ ហើយភិក្ខុនីពួកខ្លះឆាន់ (ទៀត) ពួកខ្លះ (គ្រាន់តែ) នាំយកបិណ្ឌបាតទៅ។ គ្រានោះឯង ព្រាហ្មណ៍នោះបាននិយាយពាក្យនេះនឹងពួកមនុស្សដែលស្និទ្ធស្នាលថា នែអ្នកម្ចាស់ទាំងឡាយ ខ្ញុំបានប្រគេនចង្ហាន់ពួកភិក្ខុនីឲ្យឆាន់បរិបូណ៌ហើយ ចូរអ្នកទាំងឡាយមកចុះ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឆ្អែតស្កប់ស្កល់ទៀត។ ពួកមនុស្សទាំងនោះ បាននិយាយពាក្យយ៉ាងនេះថា នែអ្នកម្ចាស់ អ្នកនឹងឲ្យពួកយើងឆ្អែតស្កប់ស្កល់ដូចម្តេច ពួកភិក្ខុនីឯណាដែលអ្នកនិមន្ត ពួកភិក្ខុនីនោះ មកផ្ទះអស់យើងហើយ ពួកខ្លះក៏ឆាន់ ពួកខ្លះក៏នាំយកចង្ហាន់បិណ្ឌបាតទៅហើយ។ ទើបព្រាហ្មណ៍នោះពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនីមិនសមបីនឹងឆាន់ក្នុងផ្ទះយើងរួចហើយ (ទៅ) ឆាន់ក្នុងផ្ទះដទៃ (ទៀត)សោះ ហាក់ដូចជាខ្ញុំមិនអាចឲ្យ (លោកឆាន់) ដរាបដល់ឆ្អែតបាន។ ភិក្ខុនីទាំងឡាយបានឮព្រាហ្មណ៍នោះពោលទោសតិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ ឆាន់ហើយ ហាមភត្តហើយ មិនសមបីនឹង (ទៅ)ឆាន់ក្នុងទីដទៃ(ទៀត)សោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឆាន់ហើយ ហាមភត្តហើយ (ទៅ)ឆាន់ក្នុងទីដទៃ(ទៀត) ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ឆាន់ហើយ ហាមភត្តហើយ មិនគួរបើនឹង ឆាន់ក្នុងទីដទៃ(ទៀត)ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ដែលគេនិមន្តហើយក្តី ហាមភត្តហើយក្តី ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយ ឬភោជនីយ ត្រូវអាបត្តិបាចិត្តិយ។**

[៣៤៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនីដែលឈ្មោះថា គេនិមន្ត គឺភិក្ខុនីដែលគេនិមន្ត បណ្តាភោជន៥យ៉ាង ដោយភោជនណាមួយ។ ភិក្ខុនីដែលឈ្មោះថា ហាមភត្ត គឺកិរិយាឆាន់ក៏ប្រាកដ ភោជនក៏ប្រាកដ ភិក្ខុនីស្ថិតនៅក្នុងហត្ថបាស ទាយកបង្អោនរបស់មកចំពោះមុខ ភិក្ខុនីហាមឃាត់ក៏ប្រាកដ។ វត្ថុដែលឈ្មោះថា ខាទនីយ គឺលើកទុកតែភោជន៥យ៉ាង និងបបរ យាមកាលិក សត្តាហកាលិក យាវជីវិកចេញ ក្រៅពីនោះ ឈ្មោះថា ខាទនីយទាំងអស់។ ដែលហៅថា ភោជនីយ បានដល់ភោជន៥យ៉ាង គឺបាយ នំកុម្មាស សដូវ ត្រី សាច់។ ភិក្ខុនីទទួលដោយគិតថា អញនឹងទំពាស៊ី នឹងបរិភោគ ដូច្នេះ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីត្រូវអាបត្តិបាចិត្តិយគ្រប់ៗវារៈដែលលេបចូលទៅ។

[៣៤៤] ខ្លួនគេនិមន្តហើយ ភិក្ខុនីសំគាល់ថា និមន្តហើយ ៗទំពាស៊ី ឬបរិភោគ នូវខាទនីយក្តី ភោជនីយក្តី ត្រូវអាបត្តិបាចិត្តិយ។ ខ្លួនគេនិមន្តហើយ ភិក្ខុនីសង្ស័យ ហើយទំពាស៊ី ឬបរិភោគ នូវខាទនីយក្តី ភោជនីយក្តី ត្រូវអាបត្តិបាចិត្តិយ។ ខ្លួនគេនិមន្តហើយ ភិក្ខុនីសំគាល់ថា មិនបាននិមន្ត ហើយទំពាស៊ី ឬបរិភោគ នូវខាទនីយក្តី ភោជនីយក្តី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីទទួលយាមកាលិក សត្តាហកាលិក យាវជីវិក ប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីត្រូវអាបត្តិទុក្កដគ្រប់វារៈដែលលេបចូលទៅ។

[៣៤៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុនីដែលគេមិននិមន្ត១ ភិក្ខុនីមិនបានហាមភត្ត១ ភិក្ខុនីផឹកបបរ១ ភិក្ខុនីប្រាប់ម្ចាស់ទាន ហើយទើបបរិភោគ១ កាលបើមានបច្ច័យ (មានហេតុ) ភិក្ខុនីបរិភោគយាមកាលិក សត្តាហកាលិក និងយាវជីវិក១ ភិក្ខុនីឆ្កួត១

ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.55 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[៣៤៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុ១រូបត្រេចទៅបិណ្ឌបាតតាមច្រកតូច១ ក្នុងក្រុងសាវត្ថី ចូលទៅរកត្រកូល១ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ដែលគេក្រាលទុកហើយ។ លំដាប់នោះឯង ពួកមនុស្សទាំងនោះឲ្យភិក្ខុនីនោះឆាន់ ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីទាំងឡាយ សូម្បីដទៃក៏និមន្តមកចុះ។ ទើបភិក្ខុនីនោះគិតថា ធ្វើដូចម្តេច កុំឲ្យភិក្ខុនីទាំងឡាយដទៃមកបានដូច្នេះ ហើយក៏ចូលទៅរកភិក្ខុនីទាំងឡាយ រួចបាននិយាយពាក្យនេះថា នែនាងម្ចាស់ ក្នុងទីឯណោះ មានឆ្កែសាហាវ មានគោកាច មានកន្លែងផុត នាងទាំងឡាយកុំទៅក្នុងទីនោះឡើយ។ ភិក្ខុនី១រូបទៀតត្រេចទៅបិណ្ឌបាតក្នុងច្រកតូចនោះ ចូលទៅរកត្រកូលនោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេតាំងទុកហើយ។ ទើបមនុស្សទាំងឡាយនោះឲ្យភិក្ខុនីនោះឆាន់ ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ ហេតុអ្វីក៏ភិក្ខុនីទាំងឡាយមិនមក។ ទើបភិក្ខុនីនោះប្រាប់ដំណើរនុ៎ះដល់មនុស្សទាំងនោះ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីមិនសមបើនឹងប្រព្រឹត្តកំណាញ់ត្រកូលសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីប្រព្រឹត្តកំណាញ់ត្រកូល ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនគួរបើនឹងប្រព្រឹត្តកំណាញ់ត្រកូលទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មានសេចក្តីកំណាញ់ត្រកូល ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៤៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា ត្រកូល បានដល់ត្រកូល៤យ៉ាង គឺត្រកូលក្សត្រ១ ត្រកូលព្រាហ្មណ៍១ ត្រកូលអ្នកជំនួញ អ្នកធ្វើស្រែ ធ្វើចំការ១ ត្រកូលអ្នកស៊ីឈ្នួល១។ ពាក្យថា មានសេចក្តីកំណាញ់ គឺភិក្ខុនីពោលទោសត្រកូលក្នុងសំណាក់ភិក្ខុនីទាំងឡាយ ដោយគិតថា ធ្វើដូចម្តេចកុំឲ្យភិក្ខុនីទាំងឡាយមកបានដូច្នេះ ត្រូវអាបត្តិបាចិត្តិយ។ ឬភិក្ខុនីពោលទោសភិក្ខុនីទាំងឡាយក្នុងសំណាក់ត្រកូល ក៏ត្រូវអាបត្តិបាចិត្តិយ។

[៣៤៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីមិនប្រព្រឹត្តកំណាញ់១ ភិក្ខុនីប្រាប់ទោសដែលមានពិត១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.pc.56 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[៣៤៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីច្រើនរូបនៅចាំវស្សាក្នុងអាវាសដែលតាំងនៅក្នុងស្រុកក្រៅ ហើយបានទៅកាន់ក្រុងសាវត្ថី។ ភិក្ខុនីទាំងឡាយ (ឯទៀត) បាននិយាយពាក្យនេះនឹងភិក្ខុនីទាំងនោះថា លោកម្ចាស់ទាំងឡាយចាំវស្សាក្នុងទីណា ការទូន្មានបានមាំមួនដែរឬ[30]។ ភិក្ខុនីទាំងឡាយនោះនិយាយថា នែនាងម្ចាស់ ពួកភិក្ខុក្នុងទីនោះគ្មានទេ ការទូន្មាននឹងបានមាំមួនពីណា។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងនៅចាំវស្សាក្នុងអាវាសគ្មានភិក្ខុសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយនៅចាំវស្សាក្នុងអាវាសមិនមានភិក្ខុ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនគួរបើនឹងនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ នៅចាំវស្សាក្នុងអាវាសឥតភិក្ខុ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៥០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ អាវាសដែលភិក្ខុមិនអាចនឹងទៅឲ្យឱវាទក្តី នៅរួមក្តី ឈ្មោះថា អាវាសឥតភិក្ខុ។ ភិក្ខុនីតាំងចិត្តថា អញនឹងនៅចាំវស្សាដូច្នេះ ហើយក្រាលសេនាសនៈ ដម្កល់ទឹកផឹក ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ព្រមគ្នានឹងអរុណរះឡើង។

[៣៥១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុទាំងឡាយនៅចាំវស្សា ហើយចៀសចេញទៅក្តី សឹកទៅក្តី ស្លាប់ក្តី ចូលពួក (គឺទៅចូលសាសនាដទៃ)ក្តី១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី៧

CS vin.vbi.pc.57 | ភាគ ទី៥

### (៧. សត្តមសិក្ខាបទំ)

[៣៥២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីច្រើនរូបនៅចាំវស្សាក្នុងអាវាសដែលតាំងនៅក្នុងស្រុកក្រៅ ហើយបានទៅកាន់ក្រុងសាវត្ថី។ ភិក្ខុនីទាំងឡាយ បាននិយាយពាក្យនេះនឹងភិក្ខុនីទាំងឡាយនោះថា នាងម្ចាស់ទាំងឡាយនៅចាំវស្សាក្នុងទីណា ហើយបវារណានឹងភិក្ខុសង្ឃដែរឬ។ ភិក្ខុនីទាំងឡាយនោះនិយាយថា នែនាងម្ចាស់ ពួកយើងមិនបានបវារណានឹងភិក្ខុសង្ឃទេ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ នៅចាំវស្សាហើយ មិនសមនឹងមិនបវារណានឹងភិក្ខុសង្ឃសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយនៅចាំវស្សាហើយ មិនបវារណានឹងភិក្ខុសង្ឃ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ នៅចាំវស្សាហើយ មិនគួរបើនឹងមិនបវារណានឹងភិក្ខុសង្ឃទេ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ នៅចាំវស្សាហើយ មិនបវារណានឹងឧភតោ ដោយស្ថានបីយ៉ាង គឺដោយឃើញក្ដី ដោយឮក្ដី ដោយរង្កៀសក្ដី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៥៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនីនៅអស់ត្រ័យមាសខាងដើមក្ដី អស់ត្រ័យមាសខាងចុងក្ដី ឈ្មោះថា នៅចាំវស្សាហើយ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនបវារណានឹងឧភតោសង្ឃ ដោយស្ថានបីយ៉ាង គឺដោយឃើញក្ដី ដោយឮក្ដី ដោយរង្កៀសក្ដី ត្រូវអាបត្តិបាចិត្តិយ។

[៣៥៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីមានសេចក្ដីអន្តរាយ ហើយស្វែងរក (ឧភតោសង្ឃ)មិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី៨

CS vin.vbi.pc.58 | ភាគ ទី៥

### (៨. អដ្ឋមសិក្ខាបទំ)

[៣៥៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ ចូលទៅកាន់លំនៅភិក្ខុនី ហើយទូន្មានពួកឆព្វគ្គិយាភិក្ខុនី។ ភិក្ខុនីទាំងឡាយ បាននិយាយពាក្យនេះនឹងពួកឆព្វគ្គិយាភិក្ខុនីថា នែលោកម្ចាស់ទាំងឡាយ ចូរលោកទាំងឡាយមក ពួកយើងនឹងទៅ (ស្តាប់) ឱវាទ។ ពួកឆព្វគ្គិយាភិក្ខុនី និយាយថា នែលោកម្ចាស់ទាំងឡាយ ពួកយើងមិនបាច់ទៅដោយហេតុឱវាទទេ ព្រោះលោកម្ចាស់ឆព្វគ្គិយទាំងឡាយ តែងមកទូន្មានយើងក្នុងទីនេះឯង។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងមិនទៅកាន់ទីស្តាប់ឱវាទសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនី មិនទៅកាន់ទីស្តាប់ឱវាទ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏ទ្រង់ជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងមិនទៅកាន់ទីស្តាប់ឱវាទទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ មិនទៅដើម្បីឱវាទក្ដី ដើម្បីនៅរួបរួមគ្នាក្ដី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៥៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១នៃបារាជិកកណ្ឌរួចហើយ។ គរុធម៌ទាំង៨ ឈ្មោះថាឱវាទ។ កម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សេចក្ដីសិក្សាស្មើគ្នា ឈ្មោះថា នៅរួបរួម។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនទៅដើម្បីឱវាទក្ដី ដើម្បីនៅរួបរួមក្ដី ត្រូវអាបត្តិបាចិត្តិយ។

[៣៥៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីមានសេចក្ដីអន្តរាយ ហើយស្វែងរកភិក្ខុនីជាគំរប់ពីរមិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.pc.59 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[៣៥៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ មិនសួរឧបោសថផង មិនសូមឱវាទផង។ ភិក្ខុទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងមិនសួរឧបោសថផង មិនសូមឱវាទផងសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ មិនសួរឧបោសថផង មិនសូមឱវាទផង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនគួរបើនឹងមិនសួរឧបោសថផង មិនសូមឱវាទផងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរយ៉ាងអំពីភិក្ខុសង្ឃ គឺសួរឧបោសថ១ ចូលទៅទទួលឱវាទ១ រាល់ៗកន្លះខែ កាលភិក្ខុនីឲ្យកន្លងកន្លះខែនោះទៅ ត្រូវអាបត្តិបាចិត្តិយ។**

[៣៥៩] ត្រង់ពាក្យថា រាល់ៗកន្លះខែ គឺគ្រប់ថ្ងៃឧបោសថ។ ឧបោសថពីរយ៉ាង គឺឧបោសថក្នុងតិថីទី១៤មួយ ឧបោសថក្នុងតិថីទី១៥មួយ ឈ្មោះថា ថ្ងៃឧបោសថ។ គរុធម៌ទាំង៨ ឈ្មោះថាឱវាទ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនសួរឧបោសថក្តី មិនសូមឱវាទក្តី ត្រូវអាបត្តិបាចិត្តិយ។

[៣៦០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីមានសេចក្តីអន្តរាយ ហើយស្វែងរកភិក្ខុនីជាគំរប់ពីរមិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ អារាមវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.pc.60 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[៣៦១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនី១រូប តែម្នាក់នឹងម្នាក់ជាមួយនឹងបុរស ឲ្យគេទំលាយពក ឬបូសដែលកើតត្រង់កាយខាងក្រោម។ គ្រានោះឯង បុរសនោះព្យាយាមដើម្បីប្រទូស្តនឹងភិក្ខុនីនោះ។ ភិក្ខុនីនោះបានធ្វើសម្រែកខ្លាំង។ ភិក្ខុនីទាំងឡាយក៏ស្ទុះចូលទៅ ហើយនិយាយពាក្យនេះនឹងភិក្ខុនីនោះថា នែលោកម្ចាស់ ហេតុអ្វីក៏នាងធ្វើសម្រែកខ្លាំងម្ល៉េះ។ ទើបភិក្ខុនីនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីតែម្នាក់នឹងម្នាក់ជាមួយនឹងបុរស មិនសមបើ នឹងឲ្យទំលាយពក ឬបូសដែលកើតត្រង់កាយខាងក្រោមសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីតែម្នាក់នឹងម្នាក់ ជាមួយនឹងបុរសឲ្យទំលាយពក ឬបូសដែលកើតត្រង់កាយខាងក្រោម ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីតែម្នាក់នឹងម្នាក់ ជាមួយនឹងបុរស មិនគួរបើនឹងឲ្យទំលាយពក ឬបូសដែលកើតត្រង់កាយខាងក្រោមទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយមិនបានប្រាប់សង្ឃក្តី គណៈក្តី ហើយតែម្នាក់នឹងម្នាក់ជាមួយនឹងបុរសឲ្យទំលាយក្តី វះក្តី លាងក្តី លាបក្តី ចងក្តី ស្រាយក្តី នូវពកក្តី របួសក្តី ដែលកើតត្រង់កាយខាងក្រោម ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៦២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ សរីរប្រទេសខាងក្រោម ត្រឹមផ្ចិតចុះទៅ ខាងលើ ត្រឹមមណ្ឌលជង្គង់ឡើងមក ហៅថា កាយខាងក្រោម។ ពាក្យថា កើត គឺកើតក្នុងទីក្រោមផ្ចិត ខាងលើមណ្ឌលជង្គង់នោះ។ ដែលហៅថា ពក ឬបូស គឺពក ឬបូសណាមួយ។ ដែលហៅថា របួស គឺដំបៅណាមួយ។ ពាក្យថា មិនប្រាប់ គឺមិនពិតទូល។ ដែលហៅថា សង្ឃ (ក្នុងទីនេះ) សំដៅយកភិក្ខុនីសង្ឃ។ ដែលហៅថា គណៈ សំដៅយកភិក្ខុនីច្រើនរូប (ពីរបីរូប)។ ដែលហៅថា បុរស គឺមនុស្សប្រុសដែលដឹងក្តី អាចប្រទូស្តបាន មិនមែនយក្សប្រុស ប្រេតប្រុស តិរច្ឆានឈ្មោលទេ។ ពាក្យថា ជាមួយ គឺជាមួយគ្នា។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺមានតែប្រុស១ និងភិក្ខុនី១ប៉ុណ្ណោះ។ ភិក្ខុនីបង្គាប់ថា អ្នកចូរទំលាយចុះ ត្រូវអាបត្តិទុក្កដ កាលបើគេទំលាយហើយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីបង្គាប់ថា អ្នកចូរវះចុះ ត្រូវអាបត្តិទុក្កដ កាលបើគេវះហើយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីបង្គាប់ថា អ្នកចូរលាងចុះ ត្រូវអាបត្តិទុក្កដ កាលបើគេលាងហើយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីបង្គាប់ថា អ្នកចូរលាបចុះ ត្រូវអាបត្តិទុក្កដ កាលបើគេលាបហើយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីបង្គាប់ថា អ្នកចូររុំចុះ ត្រូវអាបត្តិទុក្កដ កាលបើគេចងរុំហើយ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីបង្គាប់ថា អ្នកចូរស្រាយចុះ ត្រូវអាបត្តិទុក្កដ កាលបើគេស្រាយហើយ ត្រូវអាបត្តិបាចិត្តិយ។

[៣៦៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីប្រាប់(សង្ឃ ឬគណៈ) ហើយទើបឲ្យគេទំលាយក្តី ឲ្យវះក្តី ឲ្យលាងក្តី ឲ្យលាបក្តី ឲ្យចងរុំក្តី ឲ្យស្រាយក្តី១ មានស្រីណាមួយដែលដឹងក្តីជាគ្នា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

អារាមវគ្គ ទី ៦ ចប់។

# (បាចិត្តិយ) គព្ភិនីវគ្គ (ទី៧)

### (៧. គព្ភិនីវគ្គោ)

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី១

CS vin.vbi.pc.61 | ភាគ ទី៥

### (១. បឋមសិក្ខាបទំ)

[៣៦៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីមានគភ៌។ ភិក្ខុនីមានគភ៌នោះ ត្រេចទៅបិណ្ឌបាត។ មនុស្សទាំងឡាយនិយាយយ៉ាងនេះថា ចូរអ្នកទាំងឡាយប្រគេនភិក្ខាដល់លោកម្ចាស់ (ព្រោះ) លោកម្ចាស់មានគភ៌ធ្ងន់។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីមានគភ៌សោះ។ ភិក្ខុនីទាំងឡាយបានឮច្បាស់នូវពាក្យមនុស្សទាំងឡាយកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីមានគភ៌សោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីមានគភ៌ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យឧបសម្បទាដល់ស្រីមានគភ៌ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយឲ្យឧបសម្បទាដល់ស្រីមានគភ៌ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៦៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា ស្រីមានគភ៌ សំដៅយកស្រីដែលមានសត្វមកដល់ផ្ទៃហើយ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី[31] បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៣៦៦] ស្រីមានគភ៌ ភិក្ខុនីសំគាល់ថា មានគភ៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ ស្រីមានគភ៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ ស្រីមានគភ៌ ភិក្ខុនីសំគាល់ថា មិនមានគភ៌ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ។ ស្រីមិនមានគភ៌ ភិក្ខុនីសំគាល់ថា មានគភ៌ ត្រូវអាបត្តិទុក្កដ។ ស្រីមិនមានគភ៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ស្រីមិនមានគភ៌ ភិក្ខុនីសំគាល់ថា មិនមានគភ៌ មិនត្រូវអាបត្តិ។

[៣៦៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ស្រីមានគភ៌ ភិក្ខុនីសំគាល់ថា មិនមានគភ៌ ហើយឲ្យឧបសម្បទា១ ស្រីមិនមានគភ៌ ភិក្ខុនីសំគាល់ថាមិនមានគភ៌ ហើយឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី២

CS vin.vbi.pc.62 | ភាគ ទី៥

### (២. ទុតិយសិក្ខាបទំ)

[៣៦៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់ស្រីមេដោះ។ ភិក្ខុនីនោះ ត្រេចទៅបិណ្ឌបាត។ មនុស្សទាំងឡាយបាននិយាយយ៉ាងនេះថា ចូរអ្នកទាំងឡាយឲ្យភិក្ខាដល់លោកម្ចាស់ (ព្រោះ) លោកម្ចាស់មានគ្នីគ្នា។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីមេដោះសោះ។ ភិក្ខុនីទាំងឡាយបានឮច្បាស់នូវពាក្យមនុស្សទាំងឡាយកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនី មិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីមេដោះសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីមេដោះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យឧបសម្បទាដល់ស្រីមេដោះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់ស្រីមេដោះ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៦៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា ស្រីមេដោះ គឺមាតាក្តី ស្រីមេដោះមែនៗក្តី។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី

ចីវរក្តី សន្ទតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរលើក ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៣៧០] ស្រីមេដោះ ភិក្ខុនីសំគាល់ថា ស្រីមេដោះ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ ស្រីមេដោះ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ ស្រីមេដោះ ភិក្ខុនីសំគាល់ថា មិនមែនស្រីមេដោះ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ។ មិនមែនស្រីមេដោះ ភិក្ខុនីសំគាល់ថា ស្រីមេដោះ ត្រូវអាបត្តិទុក្កដ។ មិនមែនស្រីមេដោះ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ មិនមែនស្រីមេដោះ ភិក្ខុនីសំគាល់ថា មិនមែនស្រីមេដោះ មិនត្រូវអាបត្តិ។

[៣៧១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ស្រីមេដោះ ភិក្ខុនីសំគាល់ថា មិនមែនស្រីមេដោះ ហើយឲ្យឧបសម្បទា១ មិនមែនស្រីមេដោះ ភិក្ខុនីសំគាល់ថាមិនមែនស្រីមេដោះ ហើយឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.pc.63 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[៣៧២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់សិក្ខមានា[32] ដែលមិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាង[33] អស់ពីរឆ្នាំ។ ភិក្ខុនីទាំងឡាយ(ដែលទើបនឹងបួស) នោះ ជាស្រីល្ងង់ មិនឆ្លាស មិនដឹងការគួរឬការមិនគួរ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏ទ្រង់ជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ទើបត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យភិក្ខុនីសង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់សិក្ខមានា។ ម្នាលភិក្ខុទាំងឡាយ ក៏ឯសិក្ខាសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ។ គឺសិក្ខមានានោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំមានឈ្មោះនេះ ជាសិក្ខមានារបស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំនឹងសង្ឃ។ សិក្ខាសម្មតិនោះ ត្រូវសិក្ខមានានោះសូមអស់វារៈជាគំរប់ពីរដងផង ត្រូវសូមអស់វារៈជាគំរប់បីដងផង។ ភិក្ខុនីដែលឆ្លាស ប្រតិពល ត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ នាងនេះមានឈ្មោះនេះ ជាសិក្ខមានារបស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំនឹងសង្ឃ។ បើសិក្ខាសម្មតិកម្ម មានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់សិក្ខមានាឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ នាងនេះមានឈ្មោះនេះ ជាសិក្ខមានារបស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំនឹងសង្ឃ។ សង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់សិក្ខមានាមានឈ្មោះនេះ។ ការឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់សិក្ខមានាមានឈ្មោះនេះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវនិយាយឡើង។ សង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់សិក្ខមានាមានឈ្មោះនេះហើយ។ ការឲ្យសិក្ខាសម្មតិនេះ គួរដល់សង្ឃ ហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ សិក្ខមានានោះ ត្រូវភិក្ខុនីបង្គាប់ថា នាងចូរថាយ៉ាងនេះ ហើយបញ្ចេញវចីភេទថា ខ្ញុំសូមសមាទាននូវបាណាតិបាតាវេរមណី ជាសមាទានមិនកន្លង(ដាច់) អស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវអទិន្នាទានាវេរមណី ជាសមាទានមិនកន្លង អស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវអព្រហ្មចរិយាវេរមណី ជាសមាទានមិនកន្លង អស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវមុសាវាទាវេរមណី ជាសមាទានមិនកន្លង អស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវសុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណី ជាសមាទានមិនកន្លង អស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវវិកាលភោជនាវេរមណី ជាសមាទានមិនកន្លង អស់ពីរឆ្នាំ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះដោយបរិយាយជាច្រើន។បេ។ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងហ្នឹង ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌ទាំងឡាយ៦អស់ពីរវស្សា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៧៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ។ ដែលហៅថា សិក្ខមានា ដែលមិនបានសិក្សាសិក្ខា គឺសិក្ខមានាដែលភិក្ខុនីមិនបានឲ្យសិក្ខាក្តី សិក្ខមានាដែលភិក្ខុនីបានឲ្យសិក្ខាហើយ តែសិក្ខានោះដាច់ទៅក្តី។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្ទតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៣៧៤] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយឲ្យ(សិក្ខមានា) ឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌

ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៣៧៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីញុំាងសិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំឲ្យបានឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.64 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[៣៧៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់សិក្ខមានាបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំដែលសង្ឃមិនបានសន្មត។ ភិក្ខុនីទាំងឡាយ (រូបឯទៀត) បាននិយាយយ៉ាងនេះថា នែសិក្ខមានាទាំងឡាយ ពួកនាងចូរមក ចូរដឹងកិច្ចនេះ ចូរឲ្យរបស់នេះ ចូរនាំយករបស់នេះមក សេចក្តីត្រូវការដោយរបស់នេះ ពួកនាងចូរធ្វើរបស់នេះឲ្យជាកប្បិយ។ សិក្ខមានាទាំងនោះបាននិយាយពាក្យយ៉ាងនេះថា បពិត្រលោកម្ចាស់ យើងខ្ញុំមិនមែនជាសិក្ខមានាទេ យើងខ្ញុំជាភិក្ខុនី។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដែលសង្ឃមិនបានសន្មតសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់សិក្ខមានាបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដែលសង្ឃមិនបានសន្មត ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំដែលសង្ឃមិនបានសន្មតសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យភិក្ខុនីសង្ឃឲ្យវុដ្ឋានសម្មតិ[34] ដល់សិក្ខមានាដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ម្នាលភិក្ខុទាំងឡាយ ឯវុដ្ឋានសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ។ គឺសិក្ខមានាដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំជាសិក្ខមានារបស់លោកម្ចាស់មានឈ្មោះនេះ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ សិក្ខមានា ត្រូវសូមវុដ្ឋានសម្មតិ អស់វារៈគំរប់ពីរដងផង។ ត្រូវសូមអស់វារៈគំរប់បីដងផង។ ត្រូវភិក្ខុនីដែលឆ្លាស ប្រតិពលឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សិក្ខមានានេះមានឈ្មោះនេះ របស់លោកម្ចាស់មានឈ្មោះនេះ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ បើវុដ្ឋានសម្មតិកម្ម មានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឲ្យវុដ្ឋានសម្មតិ ដល់សិក្ខមានាមានឈ្មោះនេះដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ នេះជាញត្តិ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សិក្ខមានានេះមានឈ្មោះនេះ របស់លោកម្ចាស់មានឈ្មោះនេះ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ សង្ឃឲ្យវុដ្ឋានសម្មតិ ដល់សិក្ខមានាមានឈ្មោះនេះ ដែលបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ។ ការឲ្យវុដ្ឋានសម្មតិ ដល់សិក្ខមានាមានឈ្មោះនេះ ដែលបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវនិយាយឡើង។ សង្ឃឲ្យវុដ្ឋានសម្មតិ ដល់សិក្ខមានាមានឈ្មោះនេះ ដែលបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ការឲ្យវុដ្ឋានសម្មតិ សមគួរដល់សង្ឃ ហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ លំដាប់នោះឯងព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះដោយបរិយាយជាច្រើន។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ញុំាងសិក្ខមានាដែលសិក្សាសិក្ខាហើយក្នុងធម៌៦យ៉ាងអស់ពីរវស្សា ដែលសង្ឃមិនបានសន្មត ឲ្យបានឧបសម្បទា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៧៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ បានអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ។ សិក្ខមានា ដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាង ឈ្មោះថាសិក្សាសិក្ខា។ សិក្ខមានាដែលសង្ឃមិនបានឲ្យវុដ្ឋានសម្មតិ ដោយញត្តិទុតិយកម្ម ឈ្មោះថាសង្ឃមិនបានសន្មត។ ពាក្យថា ឲ្យបានឧបសម្បទា គឺឲ្យបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៣៧៨] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយញុំាងសិក្ខមានាឲ្យបានឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៣៧៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់សិក្ខមានាដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដែលសង្ឃសន្មតហើយ ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.65 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[៣៨០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីគិហិគតា ដែលមានវស្សាមិនគ្រប់១២ឆ្នាំ។ ពួកភិក្ខុនីបួសថ្មីទាំងនោះអត់ទ្រាំមិនបាននឹងត្រជាក់ ក្តៅ ឃ្លាន ស្រេក សម្ផស្សរបោមមូសខ្យល់ កំដៅថ្ងៃ និងសត្វទីឃជាតិ (ពស់តូចពស់ធំ) ទាំងឡាយ មានជាតិជាអ្នកមិនអត់ធន់នឹងគន្លងពាក្យដែលបុគ្គលពោលមិនល្អ មានមកមិនល្អ និងវេទនាដែលប្រជុំក្នុងសរីរកើតឡើងនាំមកនូវសេចក្តីទុក្ខដ៏ក្លៀវក្លា រឹងក្រហាយផ្សារ មិនជាទីត្រេកអរ មិនគាប់ចិត្ត ជាទីនាំបង់នូវជីវិត។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតា ដែលមានវស្សាមិនគ្រប់១២ឆ្នាំសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីគិហិគតា មានវស្សាមិនគ្រប់១២ឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតា មានវស្សាមិនគ្រប់១២ឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ស្រីគិហិគតា ដែលមានវស្សាមិនគ្រប់១២ឆ្នាំ តែងអត់ទ្រាំមិនបាននឹងត្រជាក់ ក្តៅ ឃ្លាន ស្រេក សម្ផស្សរបោមមូស ខ្យល់ កំដៅថ្ងៃ និងសត្វទីឃជាតិ (ពស់តូច ពស់ធំ) ទាំងឡាយ មានជាតិជាអ្នកមិនអត់ធន់នឹងគន្លងពាក្យដែលគេពោលមិនល្អ មានមកមិនល្អ និងវេទនាដែលប្រជុំក្នុងសរីរកើតឡើង នាំមកនូវសេចក្តីទុក្ខដ៏ក្លៀវក្លា រឹងក្រហាយផ្សា មិនជាទីត្រេកអរ មិនគាប់ចិត្ត ជាទីនាំបង់នូវជីវិត ម្នាលភិក្ខុទាំងឡាយ ក៏ឯស្រីគិហិគតា មានវស្សាគ្រប់១២ឆ្នាំហើយ ទើបជាអ្នកអត់ទ្រាំនូវត្រជាក់ ក្តៅ ឃ្លាន ស្រេក សម្ផស្សរបោមមូស ខ្យល់ កំដៅថ្ងៃ និងសត្វទីឃជាតិ (ពស់តូច ពស់ធំ) ទាំងឡាយ មានជាតិជាអ្នកអត់ធន់នឹងគន្លងពាក្យដែលគេពោលមិនគាប់ចិត្ត មានមកមិនល្អ (និង)វេទនាដែលប្រជុំក្នុងសរីរកើតឡើង នាំមកនូវសេចក្តីទុក្ខដ៏ក្លៀវក្លា រឹងក្រហាយផ្សា មិនជាទីត្រេកអរ មិនគាប់ចិត្ត ជាទីនាំបង់នូវជីវិត ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាខ្វះពី១២ឆ្នាំ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៨១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា មានវស្សាខ្វះពី១២ឆ្នាំ គឺស្រីដែលមានឆ្នាំមិនទាន់ដល់១២។ ដែលហៅថា ស្រីគិហិគតា សំដៅយកស្រីដែលល្មមទៅកាន់បុរសដទៃបាន (គឺស្រីល្មមមានប្តីបាន)។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៣៨២] ស្រីគិហិគតាមានវស្សាមិនគ្រប់១២ឆ្នាំ ភិក្ខុនីសំគាល់ថា មានវស្សាមិនគ្រប់១២ឆ្នាំ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ ស្រីគិហិគតាមានវស្សាមិនគ្រប់១២ឆ្នាំ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ ស្រីគិហិគតាមានវស្សាមិនគ្រប់១២ឆ្នាំ ភិក្ខុនីសំគាល់ថា គ្រប់ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ។ ស្រីគិហិគតាមានវស្សា១២បរិបូណ៌ហើយ ភិក្ខុនីសំគាល់ថា មានវស្សាមិនគ្រប់១២ ត្រូវអាបត្តិទុក្កដ។ ស្រីគិហិគតាមានវស្សាពេញ១២ឆ្នាំហើយ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ស្រីគិហិគតាមានវស្សាពេញ១២ឆ្នាំហើយ ភិក្ខុនីក៏សំគាល់ថា បរិបូណ៌ហើយ មិនត្រូវអាបត្តិ។

[៣៨៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ស្រីគិហិគតាមានវស្សាខ្វះពី១២ឆ្នាំ តែភិក្ខុនីសំគាល់ថាគ្រប់១២ឆ្នាំ ហើយឲ្យឧបសម្បទា១ ស្រីគិហិគតាមានវស្សាពេញ១២ឆ្នាំហើយ ភិក្ខុនីសំគាល់ថា ពេញ ហើយឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.pc.66 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[៣៨៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាពេញ១២ឆ្នាំហើយ ដែលមិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ។ ភិក្ខុនីបួសថ្មីទាំងឡាយនោះ ល្ងង់ មិនឆ្លាស មិនដឹងកិច្ចគួរ ឬកិច្ចមិនគួរ។ ភិក្ខុនីទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់១២ឆ្នាំហើយ (តែ) មិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់១២ឆ្នាំហើយ ដែលមិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់១២ឆ្នាំហើយ ដែលមិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុនីសង្ឃ)

ឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់ស្រីគិហិគតាដែលមានឆ្នាំគ្រប់១២ហើយ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯសិក្ខាសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ។ គឺស្រីគិហិគតា ដែលមានឆ្នាំ១២បរិបូណ៌ហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំមានឈ្មោះនេះ ជាគិហិគតារបស់លោកម្ចាស់មានឈ្មោះនេះ មានវស្សា១២បរិបូណ៌ហើយ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ។ សិក្ខាសម្មតិនោះ ត្រូវគិហិគតានោះសូមអស់វារៈគំរប់ពីរដងផង ត្រូវសូមអស់វារៈគំរប់បីដងផង។ ភិក្ខុនីដែលឆ្លាស ប្រតិពល ត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ គិហិគតានេះ មានឈ្មោះនេះ របស់លោកម្ចាស់មានឈ្មោះនេះ មានវស្សា១២បរិបូណ៌ហើយ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ។ បើសិក្ខាសម្មតិកម្ម មានកាលគួរដល់សង្ឃហើយ សង្ឃគួរឲ្យសិក្ខាសម្មតិ ក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់គិហិគតា មានឈ្មោះនេះ ដែលមានវស្សា១២បរិបូណ៌ហើយ។ នេះជាញត្តិ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ គិហិគតានេះ មានឈ្មោះនេះ របស់លោកម្ចាស់មានឈ្មោះនេះ មានវស្សា១២បរិបូណ៌ហើយ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំនឹងសង្ឃ ឥឡូវសង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់ស្រីគិហិគតាឈ្មោះនេះ មានវស្សា១២បរិបូណ៌ហើយ។ ការឲ្យសិក្ខាសម្មតិ ក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់ស្រីគិហិគតា មានឈ្មោះនេះ ដែលមានវស្សាគ្រប់១២ហើយ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវនិយាយឡើង។ សិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ សង្ឃបានឲ្យដល់គិហិគតា មានឈ្មោះនេះ ដែលមានវស្សាគ្រប់១២ហើយ។ ការឲ្យសិក្ខាសម្មតិនោះ គួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ ស្រីគិហិគតានោះ ដែលមានវស្សាគ្រប់១២ហើយ ត្រូវសង្ឃបង្គាប់ថា ចូរនាងពោលយ៉ាងនេះ គឺពោលថា ខ្ញុំសូមសមាទាននូវបាណាតិបាតាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ។បេ។ ខ្ញុំសូមសមាទានូវវិកាលភោជនាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះដោយបរិយាយជាច្រើន។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់១២ហើយ ដែលមិនបានសិក្សាសិក្ខា ក្នុងធម៌៦យ៉ាងអស់ពីរវស្សា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៨៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ស្រីគិហិគតា ដែលមានវស្សាដល់១២ហើយ ឈ្មោះថា មានវស្សាគ្រប់១២ហើយ។ ដែលហៅថា ស្រីគិហិគតា សំដៅយកស្រីដែលលួមទៅតាមប្រុសដទៃបាន។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ។ សិក្ខា ដែលសង្ឃមិនបានឲ្យក្តី (ឬ) សិក្ខាដែលសង្ឃឲ្យហើយ តែកម្រើក (ដាច់)ក្តី នៃស្រីគិហិគតាណា ស្រីគិហិគតានោះឈ្មោះថា មិនបានសិក្សាសិក្ខា។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៣៨៦] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៣៨៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគតា មានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី៧

CS vin.vbi.pc.67 | ភាគ ទី៥

### (៧. សត្តមសិក្ខាបទំ)

[៣៨៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ (តែ) សង្ឃមិនបានសន្មត។ ភិក្ខុនីទាំងឡាយ បាននិយាយយ៉ាងនេះថា នែសិក្ខមានាទាំងឡាយ នាងទាំងឡាយចូរមក ចូរដឹងកិច្ចនេះ ចូរឲ្យរបស់នេះ ចូរនាំយករបស់នេះមក យើងត្រូវការដោយរបស់នេះ ចូរនាងធ្វើរបស់នេះឲ្យជាកប្បិយ។ ភិក្ខុនីបួសថ្មីទាំងឡាយនោះបានឆ្លើយយ៉ាងនេះថា បពិត្រលោកម្ចាស់ យើងខ្ញុំមិនមែនជាសិក្ខមានាទេ យើងខ្ញុំជាភិក្ខុនី។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ (តែ)សង្ឃមិនបានសន្មតឲ្យសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីគិហិគតាដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ (តែ)សង្ឃមិនបានសន្មត ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់ ស្រីគិហិគតាដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ (តែ)សង្ឃមិនបានសន្មតឲ្យទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ៗវុដ្ឋានសម្មតិ ដល់ស្រីគិហិគតាដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯវុដ្ឋានសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ។ ស្រីគិហិគតាដែលមានវស្សាគ្រប់១២ហើយ បាន

សិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលី និយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំមានឈ្មោះនេះ ជាគិហិគតារបស់លោកម្ចាស់ឈ្មោះនេះ មានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ ឯវុដ្ឋានសម្មតិ ស្រីគិហិគតានោះ ត្រូវសូមអស់វារៈពីរដងផង ត្រូវសូមអស់វារៈបីដងផង។ ភិក្ខុនីដែលឆ្លាស ប្រតិពល ត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ស្រីគិហិគតានេះមានឈ្មោះនេះ របស់លោកម្ចាស់ឈ្មោះនេះ មានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ បើវុដ្ឋានសម្មតិកម្ម មានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឲ្យវុដ្ឋានសម្មតិដល់ស្រីគិហិគតា មានឈ្មោះនេះ ដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ នេះជាញត្តិ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ស្រីគិហិគតានេះ មានឈ្មោះនេះ របស់លោកម្ចាស់ឈ្មោះនេះ មានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ ឥឡូវ សង្ឃឲ្យវុដ្ឋានសម្មតិ ដល់ស្រីគិហិគតាមានឈ្មោះនេះ មានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ការឲ្យវុដ្ឋានសម្មតិដល់ស្រីគិហិគតា មានឈ្មោះនេះដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានឲ្យវុដ្ឋានសម្មតិ ដល់ស្រីគិហិគតាមានឈ្មោះនេះ ដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ការឲ្យវុដ្ឋានសម្មតិនោះ សមគួរដល់សង្ឃ ហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះដោយបរិយាយជាច្រើនហើយ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់ស្រីគិហិគតាមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខា ក្នុងធម៌៦យ៉ាងអស់ពីរវស្សាហើយ តែសង្ឃមិនសន្មត(ឲ្យ) ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៨៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ស្រីគិហិគតា មានវស្សាដល់១២ហើយ ឈ្មោះថា មានវស្សាគ្រប់១២ហើយ។ ដែលហៅថា ស្រីគិហិគតា សំដៅយកសិក្ខមានាដែលលួមទៅកាន់បុរសដទៃបាន។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ។ ស្រីគិហិគតា ដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាង ឈ្មោះថា សិក្សាសិក្ខាហើយ។ ស្រីគិហិគតា ដែលសង្ឃមិនបានឲ្យវុដ្ឋានសម្មតិ ដោយកម្មមានញត្តិជាគំរប់ពីរ ឈ្មោះថា សង្ឃមិនបានសន្មត។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៣៩០] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៣៩១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគតា ដែលមានវស្សាគ្រប់១២ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សង្ឃសន្មតហើយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទីឨ

CS vin.vbi.pc.68 | ភាគ ទី៥

### (ឨ. អដ្ឋមសិក្ខាបទំ)

[៣៩២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ថុល្លនន្ទាភិក្ខុនី ឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបានបង្រៀនខ្លួនឯង មិនឲ្យអ្នកដទៃបង្រៀនអស់ពីរឆ្នាំ។ ភិក្ខុនីទាំងឡាយនោះល្ងង់ មិនឆ្លាស មិនស្គាល់កិច្ចគួរ ឬមិនគួរ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនគួរបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបង្រៀនខ្លួនឯង មិនឲ្យគេបង្រៀនអស់ពីរឆ្នាំសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី ឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបង្រៀនខ្លួនឯង មិនឲ្យគេបង្រៀនអស់ពីរឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបង្រៀនខ្លួនឯង មិនឲ្យគេបង្រៀនអស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនី ហើយមិនបង្រៀនដោយខ្លួនឯង មិនឲ្យគេបង្រៀនអស់ពីរវស្សា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៩៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា សិក្ខមានាជាសហជីវិនី សំដៅយកសិក្ខមានាជាសទ្ធិវិហារិនី (កូនសិស្ស)។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ។ ពាក្យថា មិនបង្រៀន (ខ្លួនឯង) គឺមិនបង្រៀនដោយបាលី អដ្ឋកថា សេចក្ដីទូន្មាន ប្រៀនប្រដៅដោយខ្លួនឯង។ ពាក្យថា មិនឲ្យគេបង្រៀន គឺមិនបង្គាប់អ្នកដទៃ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនបង្រៀនខ្លួនឯង មិនឲ្យគេបង្រៀន អស់ពីរឆ្នាំ ត្រូវអាបត្តិបាចិត្តិយ។

[៣៩៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីមានសេចក្ដីអន្តរាយ ហើយស្វែងរកគ្នាមិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានភ័យធំ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.pc.69 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[៣៩៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយ មិនតាមបម្រើភិក្ខុនីជាបវត្តិនី (ឧបជ្ឈាយ៍) ដែលបំបួសខ្លួនអស់ពីរឆ្នាំ។ ពួកភិក្ខុនីទាំងនោះ ល្ងង់ មិនឆ្លាស មិនស្គាល់ការគួរ ឬមិនគួរ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងមិនតាមបម្រើភិក្ខុនីជាបវត្តិនីដែលបំបួសខ្លួនអស់ពីរឆ្នាំសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ មិនតាមបម្រើភិក្ខុនី ជាបវត្តិនី ដែលបំបួសខ្លួនអស់ពីរឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹងមិនបម្រើភិក្ខុនីជាបវត្តិនី ដែលបំបួសខ្លួនអស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មិនតាមបម្រើភិក្ខុនីជាបវត្តិនី ដែលបំបួសខ្លួនអស់ពីរវស្សា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៩៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថាបំបួសខ្លួន គឺឲ្យឧបសម្បទាដល់ខ្លួន។ ដែលហៅថា ភិក្ខុនីជាបវត្តិនី សំដៅយកភិក្ខុនីជាឧបជ្ឈាយ៍។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ។ ពាក្យថា មិនតាមបម្រើ គឺមិនបម្រើដោយខ្លួនឯង។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិនតាមបម្រើអស់ពីរឆ្នាំ ត្រូវអាបត្តិបាចិត្តិយ។

[៣៩៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺឧបជ្ឈាយ៍ល្ងង់១ ឧបជ្ឈាយ៍មិនមានខ្មាស១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ គព្ភិនីវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.pc.70 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[៣៩៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ថុល្លនន្ទាភិក្ខុនី ឲ្យឧបសម្បទាដល់សិក្ខមានា ជាសហជីវិនី (កូនសិស្ស) ហើយមិននាំយកទៅខ្លួនឯង មិនឲ្យគេនាំយកទៅ។ ប្ដីបានចាប់យកទៅ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងឲ្យឧបសម្បទា ដល់សិក្ខមានា ជាសហជីវិនី ហើយមិននាំយកទៅខ្លួនឯង មិនឲ្យគេនាំយកទៅសោះ ប្ដីបានចាប់យកទៅ ប្រសិនបើភិក្ខុនីនេះចៀសចេញទៅហើយ ប្ដីប្រាកដជាមិនបានចាប់យកទៅទេ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី ឲ្យឧបសម្បទា ដល់សិក្ខមានា ជាសហជីវិនី ហើយមិននាំយកទៅខ្លួនឯង មិនឲ្យគេនាំយកទៅ ប្ដីបានចាប់យកទៅ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបើនឹង ឲ្យឧបសម្បទា ដល់សិក្ខមានា ជាសហជីវិនី ហើយមិននាំយកទៅខ្លួនឯង មិនឲ្យគេនាំយកទៅ ប្ដីបានចាប់យកទៅទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទា ដល់សិក្ខមានា ជាសហជីវិនី ហើយមិននាំយកទៅ មិនឲ្យគេនាំយកទៅ ដោយហោចទៅអស់៥-៦យោជន៍ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៣៩៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា សិក្ខមានាជាសហជីវិនី សំដៅយកសិក្ខមានាជាសទ្ធិវិហារិនី (កូនសិស្ស)។ ពាក្យថាឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ពាក្យថា មិននាំយកទៅ គឺមិននាំយកទៅខ្លួនឯង។ ពាក្យថា មិនឲ្យគេនាំយកទៅ គឺមិនបង្គាប់អ្នកដទៃ។ ភិក្ខុនីគ្រាន់តែដាក់ធុរៈថា អញនឹងមិននាំយកទៅ មិនឲ្យអ្នកដទៃនាំយកទៅ ដោយហោចទៅ សូម្បីអស់៥-៦យោជន៍ ត្រូវអាបត្តិបាចិត្តិយ។

[៤០០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុនីមានសេចក្តីអន្តរាយ ហើយស្វែងរកភិក្ខុនីជាគំរប់ពីរមិនបាន១ ភិក្ខុនីមានភ័យធំ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

គព្ភិនីវគ្គ ទី ៧ ចប់។

# (បាចិត្តិយ) កុមារីភូតវគ្គ (ទី៨)

CS vin.vbi.pc.v8 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី១

CS vin.vbi.pc.71 | ភាគ ទី៥

### (១. បឋមសិក្ខាបទំ)

[៤០១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់កុមារីភូតា (សាមណេរី) ដែលមានអាយុមិនគ្រប់២០ឆ្នាំ។ ពួកភិក្ខុនីបួសថ្មីទាំងនោះ ជាអ្នកអត់ទ្រាំមិនបាននឹងត្រជាក់ ក្តៅ ឃ្លាន ស្រេក និងសម្ផស្សរបោមមូសខ្យល់ កំដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ មានជាតិជាអ្នកមិនអត់ធន់នឹងគន្លងពាក្យដែលគេនិយាយមិនគាប់ចិត្ត មានមកមិនល្អ នឹងវេទនាដែលប្រជុំក្នុងសរីរកើតឡើងជាទុក្ខដ៏ក្លៀវក្លា រឹងក្រហល់ក្រហាយ មិនជាទីត្រេកអរ មិនគាប់ចិត្ត ជាទីនាំបង់នូវជីវិត។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់កុមារីភូតា ដែលមានអាយុមិនគ្រប់២០ឆ្នាំសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់កុមារីភូតា ដែលមានអាយុខ្វះពី២០ឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់កុមារីភូតា ដែលមានវស្សាខ្វះពី២០ទេ ម្នាលភិក្ខុទាំងឡាយ ព្រោះជាតិកុមារីភូតា មានវស្សាខ្វះពី២០ ជាអ្នកមិនអត់ទ្រាំនូវត្រជាក់និងក្តៅ។បេ។ មានជាតិជាអ្នកមិនអត់ទ្រាំនូវទុក្ខវេទនា ជាទីនាំបង់នូវជីវិត ម្នាលភិក្ខុទាំងឡាយ ក៏ឯកុមារីភូតា មានឆ្នាំ២០ ទើបអត់ទ្រាំនូវត្រជាក់ ក្តៅ។បេ។ មានជាតិជាអ្នកអត់ទ្រាំនូវទុក្ខវេទនា ជាទីនាំបង់នូវជីវិតបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់កុមារីភូតា មានឆ្នាំខ្វះពី២០ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤០២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ កុមារីភូតា មានឆ្នាំមិនដល់២០ ឈ្មោះថា មានឆ្នាំខ្វះពី២០។ ដែលហៅថា កុមារីភូតា សំដៅយកសាមណេរី។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៤០៣] សាមណេរីមានឆ្នាំខ្វះពី២០ ភិក្ខុនីសំគាល់ថា មានឆ្នាំខ្វះពី២០ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ សាមណេរីមានឆ្នាំខ្វះពី២០ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ សាមណេរីមានឆ្នាំខ្វះពី២០ ភិក្ខុនីសំគាល់ថា គ្រប់ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ។ សាមណេរីមានឆ្នាំគ្រប់២០ហើយ ភិក្ខុនីសំគាល់ថា មានឆ្នាំខ្វះពី២០ ត្រូវអាបត្តិទុក្កដ។ សាមណេរីមានឆ្នាំគ្រប់២០ហើយ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ សាមណេរីមានឆ្នាំគ្រប់២០ហើយ ភិក្ខុនីក៏សំគាល់ថា គ្រប់ហើយ មិនត្រូវអាបត្តិ។

[៤០៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ សាមណេរីមានឆ្នាំខ្វះពី២០ (តែ)ភិក្ខុនីសំគាល់ថាគ្រប់ហើយ ក៏ឲ្យឧបសម្បទា១ សាមណេរីមានឆ្នាំគ្រប់២០ហើយ ភិក្ខុនីក៏សំគាល់ថាគ្រប់២០ ហើយឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី២

CS vin.vbi.pc.72 | ភាគ ទី៥

### (២. ទុតិយសិក្ខាបទំ)

[៤០៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ កុមារីភូតា (សាមណេរី) មានឆ្នាំគ្រប់២០ហើយ (តែ) មិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ។ ភិក្ខុនីបួសថ្មីទាំងនោះ នៅល្ងង់ មិនឆ្លាស មិនស្គាល់ការគួរ ឬមិនគួរ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យឧបសម្បទាដល់កុមារីភូតា ដែលមានវស្សាគ្រប់២០ហើយ (តែ) មិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំសោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់កុមារីភូតា មានវស្សាគ្រប់២០ហើយ តែមិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។

ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់កុមារីភូតា មានឆ្នាំគ្រប់២០ហើយ មិនបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ហើយទើបត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ៗនូវសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់កុមារីភូតា ដែលមានឆ្នាំ១៨។ ម្នាលភិក្ខុទាំងឡាយ ក៏ឯសិក្ខាសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ។ គឺកុមារីភូតា មានឆ្នាំ១៨នោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំមានឈ្មោះនេះ ជាកុមារីភូតា មានឆ្នាំ១៨ របស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ។ កុមារីភូតានោះ ត្រូវសូមសិក្ខាសម្មតិនោះអស់វារៈពីរដងផង ត្រូវសូមអស់វារៈបីដងផង។ ភិក្ខុនីដែលឆ្លាសប្រតិពល ត្រូវឲ្យសង្ឃជ្រាបថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ កុមារីភូតានេះ ឈ្មោះនេះ មានឆ្នាំ១៨ របស់លោកម្ចាស់មានឈ្មោះនេះ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំនឹងសង្ឃ។ បើសិក្ខាសម្មតិកម្ម មានកាលគួរដល់សង្ឃហើយ សូមសង្ឃឲ្យសិក្ខាសម្មតិ ក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់កុមារីភូតា មានឈ្មោះនេះ មានអាយុ១៨ឆ្នាំ។ នេះជាញត្តិ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ កុមារីភូតានេះ មានឈ្មោះនេះ របស់លោកម្ចាស់មានឈ្មោះនេះ មានឆ្នាំ១៨ សូមសិក្ខាសម្មតិក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំនឹងសង្ឃ។ ឥឡូវសង្ឃឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់កុមារីភូតា មានឆ្នាំ១៨ មានឈ្មោះនេះ។ ការឲ្យសិក្ខាសម្មតិ ក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់កុមារីភូតា មានអាយុ១៨ មានឈ្មោះនេះ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានឲ្យសិក្ខាសម្មតិក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ ដល់កុមារីភូតា មានអាយុ១៨ឆ្នាំ មានឈ្មោះនេះហើយ។ ការឲ្យសិក្ខាសម្មតិនោះ គួរដល់សង្ឃ ហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ កុមារីភូតា មានអាយុ១៨នោះ សង្ឃត្រូវបង្គាប់ថា នាងចូរថាយ៉ាងនេះ គឺពោលថា ខ្ញុំសូមសមាទាននូវបាណាតិបាតាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវអទិន្នាទានាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវអព្រហ្មចរិយាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវមុសាវាទាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវសុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ ខ្ញុំសូមសមាទាននូវវិកាលភោជនាវេរមណី ជាសមាទានមិនកន្លងអស់ពីរឆ្នាំ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះ ដោយបរិយាយជាច្រើន។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់កុមារីភូតា មានឆ្នាំពេញ២០ហើយ មិនបានសិក្សាសិក្ខា ក្នុងធម៌៦យ៉ាងអស់ពីរវស្សា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤០៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ សាមណេរីមានឆ្នាំដល់២០ហើយ ឈ្មោះថា មានឆ្នាំពេញ២០។ ដែលហៅថា កុមារីភូតា សំដៅយកសាមណេរី។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ។ សិក្ខា ដែលសង្ឃមិនបានឲ្យក្តី សិក្ខាដែលសង្ឃឲ្យហើយ តែកម្រើកដាច់ក្តី របស់សាមណេរីណា សាមណេរីនោះ ឈ្មោះថា មិនបានសិក្សាសិក្ខា។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ ត្រូវទុក្កដខណៈចប់ញត្តិ។ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៤០៧] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៤០៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់ កុមារីភូតាមានឆ្នាំគ្រប់២០ហើយ សិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.pc.73 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[៤០៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ កុមារីភូតា មានឆ្នាំគ្រប់២០ហើយ សិក្សាសិក្ខាក្នុងធម៌៦យ៉ាងហើយ (តែ) សង្ឃមិនបានសន្មត។ ភិក្ខុនីទាំងឡាយបាននិយាយយ៉ាងនេះថា នែពួកសិក្ខមានា នាងទាំងឡាយចូរមក ចូរដឹងកិច្ចនេះ ចូរឲ្យរបស់នេះ ចូរនាំយករបស់នេះមក យើងត្រូវការដោយរបស់នេះ នាងទាំងឡាយចូរធ្វើរបស់នេះឲ្យជាកប្បិយ។ ភិក្ខុនីបួសថ្មីទាំងឡាយនោះបាននិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ យើងខ្ញុំមិនមែនជាសិក្ខមានាទេ យើងខ្ញុំជាភិក្ខុនីទេតើ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់ កុមារីភូតាមានឆ្នាំពេញ២០ហើយ សិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ (តែ)សង្ឃមិនបានសន្មតសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់កុមារីភូតាមានឆ្នាំពេញ២០ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំ (តែ)សង្ឃមិនបានសន្មត ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទាដល់ កុមារីភូតាមានអាយុពេញ២០ហើយ សិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ (តែ)សង្ឃមិនបានសន្មតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិន

ទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុនីសង្ឃឲ្យវុដ្ឋានសម្មតិ ដល់ កុមារីភូតាមានឆ្នាំពេញ២០ហើយ សិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ម្នាលភិក្ខុទាំងឡាយ ឯវុដ្ឋានសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ។ គឺកុមារីភូតាមានឆ្នាំពេញ២០ហើយ ដែលបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុនីទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំមានឈ្មោះនេះ ជាកុមារីភូតារបស់លោកម្ចាស់ឈ្មោះនេះ មានឆ្នាំពេញ២០ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ វុដ្ឋានសម្មតិនោះ ត្រូវកុមារីភូតានោះ សូមអស់វារៈពីរដងផង ត្រូវសូមអស់វារៈបីដងផង។ ភិក្ខុនីដែលឆ្លាស ប្រតិពល ត្រូវឲ្យសង្ឃដឹងថា បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ កុមារីភូតានេះមានឈ្មោះនេះ របស់លោកម្ចាស់ឈ្មោះនេះ មានឆ្នាំពេញ២០ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ បើវុដ្ឋានសម្មតិកម្ម មានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឲ្យវុដ្ឋានសម្មតិ ដល់កុមារីភូតា មានឈ្មោះនេះ មានឆ្នាំពេញ២០ហើយ ដែលបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ នេះជាញត្តិ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ កុមារីភូតា មានឈ្មោះនេះ របស់លោកម្ចាស់ឈ្មោះនេះ មានឆ្នាំពេញ២០ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ ឥឡូវ សង្ឃឲ្យវុដ្ឋានសម្មតិ ដល់កុមារីភូតា មានឈ្មោះនេះ មានឆ្នាំពេញ២០ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ការឲ្យវុដ្ឋានសម្មតិ ដល់កុមារីភូតា មានឈ្មោះនេះ មានឆ្នាំពេញ២០ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានឲ្យវុដ្ឋានសម្មតិ ដល់កុមារីភូតា មានឈ្មោះនេះ មានឆ្នាំពេញ២០ហើយ បានសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ការឲ្យវុដ្ឋានសម្មតិនោះ គួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះ ដោយបរិយាយជាច្រើន។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់កុមារីភូតា មានឆ្នាំពេញ២០ហើយ សិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ ដែលសង្ឃមិនបានសន្មត(ឲ្យ) ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤១០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ កុមារីភូតា មានឆ្នាំដល់២០ហើយ ឈ្មោះថា មានឆ្នាំពេញ២០ហើយ។ ដែលហៅថា កុមារីភូតា សំដៅយកសាមណេរី។ ពាក្យថា អស់ពីរវស្សា គឺអស់ពីរឆ្នាំ។ ដែលហៅថា បានសិក្សាសិក្ខា គឺបានសិក្សាសិក្ខាក្នុងធម៌៦យ៉ាង។ ដែលហៅថា សង្ឃមិនបានសន្មត គឺសង្ឃមិនបានឲ្យវុដ្ឋានសម្មតិ ដោយញត្តិទុតិយកម្ម។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ។ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៤១១] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៤១២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីឲ្យឧបសម្បទាដល់កុមារីភូតា មានឆ្នាំពេញ២០ហើយ សិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ សង្ឃសន្មតហើយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.74 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[៤១៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុនីទាំងឡាយមានវស្សាមិនគ្រប់១២ ឲ្យឧបសម្បទា(ដល់ស្រីដទៃ)។ ភិក្ខុនីជាឧបជ្ឈាយ៍ទាំងឡាយនោះល្ងង់ មិនឆ្លាស មិនដឹងការគួរ ឬមិនគួរ។ ពួកសទ្ធិវិហារិនី (ក៏) ល្ងង់ មិនឆ្លាស មិនដឹងការគួរ ឬមិនគួរដែរ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមានវស្សាមិនគ្រប់១២ មិនគួរបើនឹងឲ្យឧបសម្បទាដល់ (ស្រីដទៃ)សោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយមានវស្សាមិនគ្រប់១២ ឲ្យឧបសម្បទា(ដល់ស្រីដទៃ) ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមានវស្សាមិនគ្រប់១២ មិនសមបើនឹងឲ្យឧបសម្បទា(ដល់ស្រីដទៃ)ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ចូរភិក្ខុនីទាំងឡាយ សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មានវស្សាមិនគ្រប់១២ ហើយឲ្យឧបសម្បទាដល់ (គេ) ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤១៤] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនីមានវស្សាមិនទាន់ដល់១២ ឈ្មោះថា មានវស្សាមិនគ្រប់១២។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្ដី អាចរិនីក្ដី បាត្រក្ដី ចីវរក្ដី សន្មតសីមាក្ដី ត្រូវអាបត្តិទុក្កដ។ ត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនី ត្រូវអាបត្តិទុក្កដ។

[៤១៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីមានវស្សាពេញ១២ហើយ ឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីធ្វើកន្លងមុនបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.75 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[៤១៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ មានវស្សាពេញ១២បរិបូណ៌ហើយ (តែ) សង្ឃមិនបានសន្មត ក៏ឲ្យឧបសម្បទា (ដល់ពួកកុលធីតា)។ ភិក្ខុនីទាំងឡាយនោះ ល្ងង់ មិនឆ្លាស មិនដឹងការគួរ ឬមិនគួរ។ ពួកភិក្ខុនីជាសទ្ធិវិហារិនី ក៏ល្ងង់ មិនឆ្លាស មិនស្គាល់ការគួរ ឬមិនគួរ (ដូចគ្នាដែរ)។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មានវស្សាពេញ១២ហើយ (តែ) សង្ឃមិនទាន់បានសន្មត មិនសមបើនឹងឲ្យឧបសម្បទាសោះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ មានវស្សាពេញ១២ហើយ សង្ឃមិនបានសន្មត ហើយឲ្យឧបសម្បទា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មានវស្សាពេញ១២ហើយ (តែ) សង្ឃមិនបានសន្មត មិនគួរនឹងឲ្យឧបសម្បទាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីដែលមានវស្សាពេញ១២ហើយ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯវុដ្ឋាបនសម្មតិនោះ សង្ឃត្រូវឲ្យយ៉ាងនេះ។ គឺភិក្ខុនីដែលមានវស្សាពេញ១២ហើយនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុនីដែលចាស់ៗ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃជាម្ចាស់ ខ្ញុំមានឈ្មោះនេះ ជាភិក្ខុនីមានវស្សាពេញ១២ហើយ សូមវុដ្ឋាបនសម្មតិនឹងសង្ឃ។ ភិក្ខុនីនោះ ត្រូវសូមវុដ្ឋាបនសម្មតិនោះ អស់វារៈពីរដងផង ត្រូវសូមអស់វារៈបីដងផង។ ភិក្ខុនីនោះ សង្ឃគប្បីកំណត់ឲ្យដឹងថា ភិក្ខុនីនេះជាអ្នកឆ្លាស មានសេចក្ដីអៀនខ្មាស។ បើភិក្ខុនីនោះល្ងង់ផង មិនមានសេចក្ដីអៀនខ្មាសផង សង្ឃមិនគប្បីឲ្យវុដ្ឋាបនសម្មតិទេ បើភិក្ខុនីនោះល្ងង់ (តែ) មានសេចក្ដីអៀនខ្មាស សង្ឃក៏មិនគប្បីឲ្យ បើភិក្ខុនីឆ្លាស (តែ) មិនមានសេចក្ដីខ្មាស សង្ឃក៏មិនគប្បីឲ្យ(ដែរ) បើភិក្ខុនីនោះឆ្លាសផង មានសេចក្ដីខ្មាសផង សង្ឃគប្បីឲ្យបាន។ ម្នាលភិក្ខុទាំងឡាយ ក៏ឯវុដ្ឋាបនសម្មតិនោះ សង្ឃគប្បីឲ្យយ៉ាងនេះ។ គឺភិក្ខុនីដែលឆ្លាស ប្រតិពល គប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃជាម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុនីនេះមានឈ្មោះនេះ មានវស្សាពេញ១២ហើយ សូមវុដ្ឋាបនសម្មតិនឹងសង្ឃ។ បើវុដ្ឋាបនសម្មតិកម្មនេះ មានកាលដ៏សមគួរដល់សង្ឃហើយ គប្បីសង្ឃឲ្យវុដ្ឋាបនសម្មតិ ដល់ភិក្ខុនី មានឈ្មោះនេះ ដែលមានវស្សាពេញ១២ហើយ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃជាម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុនី មានឈ្មោះនេះ មានវស្សាពេញ១២ហើយ សូមវុដ្ឋានសម្មតិនឹងសង្ឃ។ សង្ឃឲ្យវុដ្ឋាបនសម្មតិ ដល់ភិក្ខុនី ឈ្មោះនេះ មានវស្សាពេញ១២ហើយ។ ការឲ្យវុដ្ឋាបនសម្មតិ ដល់ភិក្ខុនីឈ្មោះនេះ មានវស្សាពេញ១២ហើយ គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីស្ងៀម មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះ គប្បីនិយាយឡើង។ សង្ឃបានឲ្យវុដ្ឋាបនសម្មតិ ដល់ភិក្ខុនី ឈ្មោះនេះ មានវស្សាពេញ១២ហើយ។ ការឲ្យវុដ្ឋាបនសម្មតិនោះ គួរដល់សង្ឃហើយ ហេតុនោះ ទើបសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសភិក្ខុនីទាំងឡាយនោះ ដោយបរិយាយជាច្រើន។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មានវស្សា១២បរិបូណ៌ហើយ សង្ឃមិនបានសន្មត (ហើយឲ្យឧបសម្បទា) ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤១៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនី មានវស្សាដល់១២ហើយ ឈ្មោះថា មានវស្សា១២បរិបូណ៌ហើយ។ ភិក្ខុនីដែលសង្ឃមិនបានឲ្យវុដ្ឋាបនសម្មតិ ដោយញត្តិទុតិយកម្ម ឈ្មោះថា សង្ឃមិនបានសន្មត។ ពាក្យថា ឲ្យឧបសម្បទា គឺញុំាងកុលធីតា ឲ្យដល់នូវគុណពួដ៏ខាងលើ (គឺសម្រេចជាភិក្ខុនីភាព)។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្ដី អាចរិនីក្ដី បាត្រក្ដី ចីវរក្ដី សន្មតសីមាក្ដី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយក្នុងខណៈចប់កម្មវាចាពីរ លុះចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនីត្រូវអាបត្តិទុក្កដ។

[៤១៨] កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ កម្មមិនប្រកបដោយធម៌ ភិក្ខុនីសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ។

[៤១៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីមានវស្សា១២បរិបូណ៌ហើយ សង្ឃបានសន្មតហើយ ឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.pc.76 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[៤២០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ចណ្ឌកាលីភិក្ខុនី ចូលទៅរកភិក្ខុនីសង្ឃ ហើយសូមវុដ្ឋាបនសម្មតិ។ លំដាប់នោះឯង ភិក្ខុនីសង្ឃសង្កេតចណ្ឌកាលីភិក្ខុនី ហើយឃាត់ថា នែលោកម្ចាស់ លោកមិនគួរនឹងឲ្យឧបសម្បទានៅឡើយទេ ហើយក៏មិនបានឲ្យវុដ្ឋាបនសម្មតិ។ ចណ្ឌកាលីភិក្ខុនីទទួលពាក្យថាសាធុ។ ក៏សម័យនោះឯង ភិក្ខុនីសង្ឃឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីទាំងឡាយដទៃ។ ចណ្ឌកាលីភិក្ខុនី ពោលទោស តិះដៀល បន្តុះបង្អាប់ថា ខ្ញុំឯងល្ងង់ទេ ខ្ញុំឯងមិនមានសេចក្តីខ្មាស (បានជា) សង្ឃឲ្យវុដ្ឋាបនសម្មតិដល់ភិក្ខុនីទាំងឡាយដទៃ មិនឲ្យដល់ខ្ញុំ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ចណ្ឌកាលី កាលដែលសង្ឃឃាត់ថា នែនាងម្ចាស់ មិនគួរនាងឲ្យឧបសម្បទានៅឡើយទេ ដូច្នេះ ទទួលពាក្យថា សាធុហើយ មិនគួរនឹងពោលតិះដៀលជាខាងក្រោយសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ចណ្ឌកាលីភិក្ខុនី កាលដែលសង្ឃឃាត់ថា នែលោកម្ចាស់ មិនគួរនាងឲ្យឧបសម្បទានៅឡើយទេ ដូច្នេះ ទទួលពាក្យថា សាធុហើយ គ្រាក្រោយ ត្រឡប់តិះដៀលវិញ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ចណ្ឌកាលីភិក្ខុនី កាលដែលសង្ឃឃាត់ថា នែនាងម្ចាស់ មិនគួរនាងឲ្យឧបសម្បទានៅឡើយទេ ដូច្នេះ ទទួលពាក្យថា សាធុហើយ មិនគួរបើនឹងពោលតិះដៀលជាខាងក្រោយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ កាលដែលសង្ឃនិយាយថា នែលោកម្ចាស់ មិនគួរលោកឲ្យឧបសម្បទានៅឡើយទេ ដូច្នេះ ទទួលពាក្យថា សាធុហើយ គ្រាក្រោយ ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិបាចិត្តិយ។**

[៤២១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា នែលោកម្ចាស់ មិនគួរលោកឲ្យឧបសម្បទានៅឡើយទេ សេចក្តីថា នែលោកម្ចាស់ លោកមិនគួរញុំាងកុលធីតាឲ្យបានឧបសម្បទានៅឡើយទេ។ ភិក្ខុនីទទួលពាក្យថា សាធុហើយ គ្រាក្រោយ ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិបាចិត្តិយ។

[៤២២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺ ភិក្ខុនីតិះដៀលសង្ឃ ដែលធ្វើ ព្រោះសេចក្តីស្រឡាញ់ ព្រោះសំអប់ ព្រោះល្ងង់ ព្រោះខ្លាចដោយប្រក្រតី១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី៧

CS vin.vbi.pc.77 | ភាគ ទី៥

### (៧. សត្តមសិក្ខាបទំ)

[៤២៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង សិក្ខមានា១រូប ចូលទៅរកថុល្លនន្ទាភិក្ខុនី ហើយសូមនូវឧបសម្បទា។ ថុល្លនន្ទាភិក្ខុនី និយាយនឹងសិក្ខមានានោះថា នែនាងម្ចាស់ បើនាងឲ្យចីវរដល់យើង យើងនឹងឲ្យនាងម្ចាស់បានឧបសម្បទា ដោយអាការយ៉ាងនេះ ហើយក៏មិនឲ្យសិក្ខមានានោះបានឧបសម្បទាសោះ ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីឲ្យបានឧបសម្បទា។ ទើបសិក្ខមានានោះ ប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនគួរបើនឹងនិយាយនឹងសិក្ខមានាថា នែនាងម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ដូច្នេះ ហើយមិនឲ្យសិក្ខមានានោះបានឧបសម្បទា នឹងមិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីឲ្យបានឧបសម្បទាសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី និយាយនឹងសិក្ខមានាដូច្នេះថា នែនាងម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ហើយមិនឲ្យសិក្ខមានានោះបានឧបសម្បទា ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីឲ្យបានឧបសម្បទា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបើនឹងនិយាយនឹងសិក្ខមានាដូច្នេះថា នែនាងម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ហើយមិនបានឲ្យឧបសម្បទា និងមិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីឲ្យបានឧបសម្បទាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ និយាយនឹងសិក្ខមានាដូច្នេះថា នែនាងម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ដល់គ្រាក្រោយ ភិក្ខុនីនោះមិនមានសេចក្តីអន្តរាយ ហើយមិនឲ្យ (សិក្ខមានានោះ) បានឧបសម្បទា មិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីឲ្យបានឧបសម្បទា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤២៤] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ស្រីដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាង អស់ពីឆ្នាំហើយ ឈ្មោះថាសិក្ខមានា។ ពាក្យថា នែនាងម្ចាស់ បើនាងនឹងឲ្យចីវរដល់យើង យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ សេចក្ដីថា យើងនឹងបំបួសនាងជាភិក្ខុនី ដោយអាការយ៉ាងនេះ។ ពាក្យថា ដល់គ្រាក្រោយ ភិក្ខុនីនោះមិនមានសេចក្ដីអន្តរាយ គឺកាលបើមិនមានសេចក្ដីអន្តរាយ។ ពាក្យថា មិនឲ្យសិក្ខមានានោះបានឧបសម្បទា គឺមិនបំបួស (សិក្ខមានានោះ) ជាភិក្ខុនីដោយខ្លួនឯង។ ពាក្យថា មិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យបានឧបសម្បទា គឺមិនបង្គាប់ភិក្ខុនីដទៃ។ ភិក្ខុនីនោះគ្រាន់តែដាក់ធុរៈថា អញនឹងមិនឲ្យបានឧបសម្បទា នឹងមិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យគេឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។

[៤២៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ កាលបើមានសេចក្ដីអន្តរាយ ភិក្ខុនីស្វែងរក (ភិក្ខុនីដទៃ) មិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី៨

CS vin.vbi.pc.78 | ភាគ ទី៥

### (៨. អដ្ឋមសិក្ខាបទំ)

[៤២៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង សិក្ខមានា១រូប ចូលទៅរកថុល្លនន្ទាភិក្ខុនី ហើយសូមឧបសម្បទា។ ថុល្លនន្ទាភិក្ខុនី និយាយនឹងសិក្ខមានានោះថា នែនាងម្ចាស់ បើនាងនឹងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ហើយមិនឲ្យឧបសម្បទា មិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យបានឧបសម្បទាសោះ។ ទើបសិក្ខមានានោះ ប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបើនឹងនិយាយនឹងសិក្ខមានាថា នែនាង បើនាងនឹងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ហើយមិនឲ្យឧបសម្បទា មិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យឧបសម្បទាសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី និយាយនឹងសិក្ខមានាថា នែនាង បើនាងនឹងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ហើយមិនឲ្យឧបសម្បទា មិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យឧបសម្បទា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបើនឹងនិយាយនឹងសិក្ខមានាថា នែនាង បើនាងនឹងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ហើយមិនឲ្យឧបសម្បទា និងមិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យឧបសម្បទាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ និយាយនឹងសិក្ខមានាថា នែនាង បើនាងតាមបម្រើយើងអស់ពីរឆ្នាំ យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ ដល់ក្រោយ ភិក្ខុនីនោះមិនមានសេចក្ដីអន្តរាយ ហើយមិនឲ្យឧបសម្បទា មិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យឧបសម្បទា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤២៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ស្រីដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាង អស់ពីឆ្នាំ ឈ្មោះថាសិក្ខមានា។ ពាក្យថា នែនាង បើនាងនឹងតាមបម្រើយើងអស់ពីរឆ្នាំ សេចក្ដីថា នាងនឹងបម្រើអស់ពីរឆ្នាំ។ ពាក្យថា យើងនឹងឲ្យនាងបានឧបសម្បទា ដោយអាការយ៉ាងនេះ សេចក្ដីថា យើងនឹងបំបួសនាងជាភិក្ខុនី ដោយអាការយ៉ាងនេះ។ ពាក្យថា គ្រាក្រោយ ភិក្ខុនីនោះមិនមានសេចក្ដីអន្តរាយ គឺកាលបើមិនមានសេចក្ដីអន្តរាយ។ ពាក្យថា មិនឲ្យឧបសម្បទា គឺមិនឲ្យឧបសម្បទា ដោយខ្លួនឯង។ ពាក្យថា មិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យឧបសម្បទា គឺមិនបង្គាប់ភិក្ខុនីដទៃ។ ភិក្ខុនីនោះគ្រាន់តែដាក់ធុរៈថា អញនឹងមិនឲ្យឧបសម្បទា នឹងមិនធ្វើសេចក្ដីខ្វល់ខ្វាយ ដើម្បីឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ។

[៤២៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺ ភិក្ខុនីមានសេចក្ដីអន្តរាយ ហើយស្វែងរក (ភិក្ខុនីដទៃ) មិនបាន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ (គ្រោះថ្នាក់)១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី៩

CS vin.vbi.pc.79 | ភាគ ទី៥

### (៩. នវមសិក្ខាបទំ)

[៤២៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី ឲ្យសិក្ខមានាឈ្មោះចណ្ឌកាលី ជាស្រីច្រឡូកច្រឡំដោយបុរស ច្រឡូកច្រឡំដោយក្មេងប្រុស ជាស្រីកាច ជាស្រីបណ្ដាលសេចក្ដីសោក (ដល់បុរសដទៃ) ឲ្យបានឧបសម្បទា។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនគួរបើនឹងឲ្យចណ្ឌកាលីសិក្ខមានា ដែលច្រឡូកច្រឡំនឹងប្រុស ច្រឡូកច្រឡំនឹងក្មេងប្រុស ជាស្រីកាច ជាស្រីបណ្ដាលសេចក្ដីសោក ឲ្យបានឧបសម្បទាសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី ឲ្យចណ្ឌកាលីសិក្ខមានា ដែលជាស្រីច្រឡូកច្រឡំដោយប្រុស ច្រឡូកច្រឡំដោយក្មេងប្រុស ជាស្រីកាច ជាស្រីបណ្ដាលសេចក្ដីសោក ឲ្យបានឧបសម្ប ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិន

សមបើនឹងឲ្យចណ្ឌកាលីសិក្ខមានា ដែលជាស្រីច្រឡូកច្រឡំដោយប្រុស ច្រឡូកច្រឡំដោយក្មេងប្រុស ជាស្រីកាច ជាស្រីបណ្តាលសេចក្តីសោក ឲ្យបានឧបសម្បទាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ញុំាំងសិក្ខមានា ដែលច្រឡូកច្រឡំដោយបុរស ដែលច្រឡូកច្រឡំដោយកុមារ ជាស្រីកាច ជាស្រីបណ្តាលសេចក្តីសោក ឲ្យបានឧបសម្បទា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៣០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ជនដែល(មានអាយុ)ដល់២០ឆ្នាំហើយ ឈ្មោះថាបុរស។ ក្មេងប្រុសដែលមិនទាន់ដល់២០ឆ្នាំ ឈ្មោះថាកុមារ។ សិក្ខមានាដែលពាក់ព័ន្ធដោយកិច្ចប្រព្រឹត្តទៅក្នុងកាយ និងកិច្ចប្រព្រឹត្តទៅក្នុងវាចាដ៏មិនសមគួរ ឈ្មោះថា ច្រឡូកច្រឡំ។ សិក្ខមានា ដែលឈ្មោះថា ជាស្រីកាច សំដៅយកស្រីដែលមានសេចក្តីក្រោធ។ ដែលឈ្មោះថា ជាស្រីបណ្តាលសេចក្តីសោក គឺសិក្ខមានាញុំាំងសេចក្តីទុក្ខឲ្យកើតឡើង គឺញុំាំងសេចក្តីសោកឲ្យចូលគ្របសង្កត់ដល់ពួកជនដទៃ។ ស្រីដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាង អស់ពីឆ្នាំហើយ ឈ្មោះថាសិក្ខមានា។ ពាក្យថា ឲ្យឧបសម្បទា គឺឲ្យបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនី ត្រូវអាបត្តិទុក្កដ។

[៤៣១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺ ភិក្ខុនីកាលមិនដឹង ឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី១០

CS vin.vbi.pc.80 | ភាគ ទី៥

### (១០. ទសមសិក្ខាបទំ)

[៤៣២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី ឲ្យសិក្ខមានាដែលមាតាបិតាផង ស្វាមីផង មិនទាន់អនុញ្ញាតឲ្យឧបសម្បទា។ មាតាបិតាផង ស្វាមីផង ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងឲ្យសិក្ខមានាដែលយើងមិនទាន់អនុញ្ញាត បានឧបសម្បទាសោះ។ ភិក្ខុនីទាំងឡាយបានឮមាតាបិតាផង ស្វាមីផង កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ថុល្លនន្ទា មិនសមបើនឹងឲ្យសិក្ខមានា ដែលមាតាបិតាផង ស្វាមីផង មិនបានអនុញ្ញាត បានឧបសម្បទាសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី ឲ្យសិក្ខមានា ដែលមាតាបិតាផង ស្វាមីផង មិនទាន់អនុញ្ញាត បានឧបសម្បទា ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបើនឹងឲ្យសិក្ខមានា ដែលមាតាបិតាផង ស្វាមីផង មិនបានអនុញ្ញាត បានឧបសម្បទាទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ញុំាំងសិក្ខមានា ដែលមាតាបិតាក្តី ស្វាមីក្តី មិនទាន់អនុញ្ញាត ឲ្យឧបសម្បទា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៣៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ជនដែលឈ្មោះថា មាតាបិតា សំដៅយកជនដែលញុំាំងកូនឲ្យកើត។ បុរសណាហួងហែងរក្សានូវស្រី បុរសនោះឈ្មោះថាស្វាមី។ ពាក្យថា មិនអនុញ្ញាត គឺមិនបានយល់ព្រម។ ស្រីដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាង អស់ពីឆ្នាំ ឈ្មោះថាសិក្ខមានា។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនី ត្រូវអាបត្តិទុក្កដ។

[៤៣៤] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុនីមិនដឹង ឲ្យឧបសម្បទា១ ភិក្ខុនីឲ្យលា (មាតាបិតា និងស្វាមី) ហើយទើបឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី១១

CS vin.vbi.pc.81 | ភាគ ទី៥

### (១១. ឯកាទសមសិក្ខាបទំ)

[៤៣៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន[35] ក្បែរក្រុងរាជគ្រឹះ។ គ្រានោះឯង ថុល្លនន្ទាភិក្ខុនី ឲ្យប្រជុំភិក្ខុជាថេរៈទាំងឡាយ ដោយគិតថា អញនឹងឲ្យឧបសម្បទាសិក្ខមានាដូច្នេះ ដល់ឃើញខាទនីយភោជនីយាហារច្រើន (ក៏ត្រឡប់) និយាយថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំនឹងមិនទាន់ឲ្យឧបសម្បទាសិក្ខមានានៅឡើយទេ ហើយបញ្ជូនពួកភិក្ខុជាថេរៈទៅវិញ ទើបឲ្យប្រជុំទេវទត្តភិក្ខុ កោ

កាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ខណ្ឌទេវីបុត្តភិក្ខុ និងសមុទ្ទទត្តភិក្ខុ ហើយក៏ឲ្យឧបសម្បទាសិក្ខមានា។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថុល្លនន្ទាជាម្ចាស់ មិនសមបើនឹងឲ្យឧបសម្បទាដល់សិក្ខមានា ដោយឲ្យឆន្ទៈ ឈ្មោះបារិវាសិក (គឺដែលបរិសទ្យបានឲ្យឆន្ទៈ ឈ្មោះបារិវាសិក[36] )សោះ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ថុល្លនន្ទាភិក្ខុនី ឲ្យឧបសម្បទា ដល់សិក្ខមានា ដោយឲ្យឆន្ទៈឈ្មោះបារិវាសិក ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ថុល្លនន្ទាភិក្ខុនី មិនសមបើនឹង ឲ្យឧបសម្បទា ដល់សិក្ខមានា ដោយឲ្យឆន្ទៈឈ្មោះបារិវាសិកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទា ដល់សិក្ខមានា ដោយឲ្យឆន្ទៈឈ្មោះបារិវាសិក ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៣៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ដោយឲ្យឆន្ទៈឈ្មោះបារិវាសិក គឺបរិសទ្យក្រោកចេញទៅហើយ។ ដែលហៅថា សិក្ខមានា សំដៅយកសាមណេរីដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាង អស់ពីរឆ្នាំហើយ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនី ត្រូវអាបត្តិទុក្កដ។

[៤៣៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺ កាលបើបរិសទ្យមិនទាន់បានក្រោកចេញ ហើយភិក្ខុនីឲ្យឧបសម្បទា១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី១២

CS vin.vbi.pc.82 | ភាគ ទី៥

### (១២. ទ្វាទសមសិក្ខាបទំ)

[៤៣៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទារាល់ឆ្នាំ។ កន្លែងសម្រាប់ភិក្ខុនីនៅ ក៏មិនគ្រប់គ្រាន់។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទារាល់ឆ្នាំសោះ (ព្រោះ) កន្លែងសម្រាប់នៅមិនគ្រប់គ្រាន់។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ (ក៏)ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យឧបសម្បទារាល់ឆ្នាំសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទារាល់ឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹង ឲ្យឧបសម្បទារាល់ឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទារាល់ឆ្នាំ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៣៩] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា រាល់ឆ្នាំ គឺគ្រប់ឆ្នាំ។ ពាក្យថា ឲ្យឧបសម្បទា គឺបំបួសជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីត្រូវទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនី ត្រូវអាបត្តិទុក្កដ។

[៤៤០] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺ ភិក្ខុនីឲ្យឧបសម្បទារំលងមួយឆ្នាំៗ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ កុមារីភូតវគ្គ) សិក្ខាបទ ទី១៣

CS vin.vbi.pc.83 | ភាគ ទី៥

### (១៣. តេរសមសិក្ខាបទំ)

[៤៤១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង១ឆ្នាំ។ កន្លែងជាទីនៅ ក៏មិនល្មមគ្រាន់ដូច្នេះទៀត។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះទៀតថា ភិក្ខុនីទាំងឡាយមិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង១ឆ្នាំសោះ (ព្រោះថា) លំនៅមិនគ្រាន់ដូច្នោះទៀត។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង១ឆ្នាំសោះ។បេ។ ព្រះអង្គ

ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទាដល់ស្រីពីរនាក់ក្នុង១ឆ្នាំ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនី មិនសមបើនឹងឲ្យឧបសម្បទាដល់ស្រីពីររូបក្នុង១ឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់ស្រីពីររូបក្នុង១ឆ្នាំ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៤២] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ក្នុង១ឆ្នាំ គឺក្នុង១ខួប។ ពាក្យថា ឲ្យឧបសម្បទាដល់ស្រីពីររូប គឺបំបួសស្រីពីររូបជាភិក្ខុនី។ ភិក្ខុនីគិតថា អញនឹងឲ្យឧបសម្បទាដល់ស្រីពីររូប ហើយស្វែងរកគណៈក្តី អាចរិនីក្តី បាត្រក្តី ចីវរក្តី សន្មតសីមាក្តី ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីត្រូវអាបត្តិទុក្កដខណៈចប់ញត្តិ ត្រូវទុក្កដទាំងឡាយខណៈចប់កម្មវាចាពីរ ចប់កម្មវាចា ព្រះឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈ និងអាចរិនី ត្រូវអាបត្តិទុក្កដ។

[៤៤៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺ ភិក្ខុនីឲ្យឧបសម្បទាដល់ស្រី១រូប រំលងមួយឆ្នាំៗ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

កុមារីភូតវគ្គ ទី ៨ ចប់។

# (បាចិត្តិយ) ឆត្តុបាហនវគ្គ (ទី៩)

CS vin.vbi.pc.v9 | ភាគ ទី៥

### (៩. ឆត្តុបាហនវគ្គោ)

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី១

CS vin.vbi.pc.84 | ភាគ ទី៥

### (១. បឋមសិក្ខាបទំ)

[៤៤៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយទ្រទ្រង់ឆត្រ និងស្បែកជើង។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងទ្រទ្រង់ឆត្រ និងស្បែកជើង ដូចជាពួកស្រីគ្រហស្ថ ដែលបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនគួរបើនឹងទ្រទ្រង់ឆត្រ និងស្បែកជើងសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ ទ្រទ្រង់ឆត្រ និងស្បែកជើង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងទ្រទ្រង់ឆត្រ និងស្បែកជើងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុនីណាមួយ ទ្រទ្រង់ឆត្រ និងស្បែកជើង ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ។

[៤៤៥] សម័យនោះឯង ភិក្ខុនី១រូបឈឺ ភិក្ខុនីនោះមិនបានទ្រទ្រង់ឆត្រ និងស្បែកជើង ក៏មិនសប្បាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆត្រនិងស្បែកជើងដល់ភិក្ខុនីឈឺ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មិនឈឺ ទ្រទ្រង់ឆត្រ និងស្បែកជើង ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៤៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនីណាវៀរឆត្រនិងស្បែកជើងហើយ នៅតែសប្បាយ ភិក្ខុនីនោះឈ្មោះថាមិនឈឺ។ ភិក្ខុនីណាវៀរឆត្រនិងស្បែកជើងហើយ មិនសប្បាយ ភិក្ខុនីនោះឈ្មោះថាឈឺ។ ដែលហៅថា ឆត្រ គឺឆត្រមានបីយ៉ាង ឆត្រដែលពាសដោយសំពត់ស១ ឆត្រដែលត្បាញដោយបន្ទោះឫស្សី១ ឆត្រដែលពាសដោយស្លឹកឈើ១ (ឆត្រទាំងបីនេះ) ដែលគេចង់ឲ្យមានរៀងមូល ចងឲ្យជាប់មាំដោយឆ្អឹងឆត្រ។ ពាក្យថា ទ្រទ្រង់ គឺភិក្ខុនីប្រើប្រាស់ សូម្បីម្តង (ក៏)ត្រូវអាបត្តិបាចិត្តិយ។

[៤៤៧] ភិក្ខុនីមិនឈឺ សំគាល់ថាមិនឈឺ ហើយទ្រទ្រង់ឆត្រនិងស្បែកជើង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនឈឺ មានសេចក្ដីសង្ស័យ ហើយទ្រទ្រង់ឆត្រនិងស្បែកជើង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនឈឺ សំគាល់ថាឈឺ ហើយទ្រទ្រង់ឆត្រនិងស្បែកជើង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីទ្រទ្រង់ឆត្រ មិនពាក់ស្បែកជើង ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីពាក់ស្បែកជើង មិនបាំងឆត្រ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីឈឺ សំគាល់ថា មិនឈឺ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីឈឺ តែមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីឈឺ សំគាល់ថាឈឺ មិនត្រូវអាបត្តិ។

[៤៤៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៦យ៉ាង) គឺ ភិក្ខុនីឈឺ១ ភិក្ខុនីទ្រទ្រង់ឆត្រនិងស្បែកជើងក្នុងអារាម១ ក្នុងឧបចារនៃអារាម១ ភិក្ខុនីទ្រទ្រង់ក្នុងពេលមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី២

CS vin.vbi.pc.85 | ភាគ ទី៥

### (២. ទុតិយសិក្ខាបទំ)

[៤៤៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយមានដំណើរទៅដោយយាន។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនគួរបើនឹងទៅដោយយាន ដូចជាពួកស្រីគ្រហស្ថ ដែលបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងទៅដោយយានសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយទៅដោយយាន ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងទៅដោយយានទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ទៅដោយយាន ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ។**

[៤៥០] គ្រានោះឯង ភិក្ខុនី១រូបឈឺ មិនអាចនឹងដើរទៅដោយជើងបាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយានដល់ភិក្ខុនីមានជម្ងឺ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយ មិនឈឺ ហើយទៅដោយយាន ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។

[៤៥១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនីដែលអាចទៅដោយជើងបាន ឈ្មោះថាមិនឈឺ។ ភិក្ខុនីណាដែលមិនអាចទៅដោយជើងបាន ភិក្ខុនីនោះឈ្មោះថាឈឺ។ វហ៍ រថ រទេះ រថទ្រង់គ្រឿង គ្រែស្នែង អង្រឹង ឈ្មោះថាយាន។ ពាក្យថាទៅ គឺភិក្ខុនីទៅតែម្ដង ត្រូវអាបត្តិបាចិត្តិយ។

[៤៥២] ភិក្ខុនីមិនឈឺ សំគាល់ថាមិនឈឺ ហើយទៅដោយយាន ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនឈឺ តែសង្ស័យ ហើយទៅដោយយាន ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីមិនឈឺ សំគាល់ថាឈឺ ហើយទៅដោយយាន ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីឈឺ សំគាល់ថា មិនឈឺ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីឈឺ តែសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីឈឺ សំគាល់ថាឈឺ មិនត្រូវអាបត្តិ។

[៤៥៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយធំ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី៣

CS vin.vbi.pc.86 | ភាគ ទី៥

### (៣. តតិយសិក្ខាបទំ)

[៤៥៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនី១រូប ជាជីតុនរបស់ស្រីម្នាក់។ លំដាប់នោះឯង ស្រីនោះបាននិយាយពាក្យនេះនឹងភិក្ខុនីនោះថា បពិត្រនាងម្ចាស់ ណ្ហើយចុះ សូមនាងម្ចាស់ឲ្យខ្សែក្រវាត់ចង្កេះនេះដល់ស្រីឈ្មោះឯណោះទៅ។ ទើបភិក្ខុនីនោះគិតថា បើអញដាក់ក្នុងបាត្រហើយទៅ អញមុខជានឹងភ្លេច គិតដូច្នោះហើយ ក៏ក្រវាត់ដើរទៅ។ កាលបើខ្សែ (សំរាប់ដោត)ដាច់ទៅ កម្រង (ខ្សែក្រវាត់ក៏)ជ្រុះរត់រាយពួដ៏ផ្លូវនោះ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងពាក់ខ្សែក្រវាត់ ដូចជាពួកស្រីគ្រហស្ថ ជាអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនី មិនសមបើនឹងពាក់ខ្សែក្រវាត់សោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីពាក់ខ្សែក្រវាត់ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុ

ទាំងឡាយ ភិក្ខុនី មិនសមបើនឹងពាក់ខ្សែក្រវាត់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ពាក់ខ្សែក្រវាត់ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៥៥] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ របស់ណាមួយសម្រាប់ប្រដាប់ចង្កេះ របស់នោះឈ្មោះថា ខ្សែក្រវាត់។ ពាក្យថា ពាក់ គឺភិក្ខុនីប្រើប្រាស់តែម្តង ក៏ត្រូវអាបត្តិបាចិត្តិយ។

[៤៥៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺ ភិក្ខុនីពាក់ខ្សែចង្កេះ ព្រោះហេតុនៃអាពាធ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី៤

CS vin.vbi.pc.87 | ភាគ ទី៥

### (៤. ចតុត្ថសិក្ខាបទំ)

[៤៥៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយទ្រទ្រង់គ្រឿងប្រដាប់ស្រី (គ្រហស្ថ)។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងប្រើប្រាស់គ្រឿងអលង្ការរបស់ស្រី ដូចជាពួកស្រីគ្រហស្ថ ដែលបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ (ក៏)ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនគួរបើនឹងប្រើប្រាស់គ្រឿងអលង្ការរបស់ស្រីសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយប្រើប្រាស់គ្រឿងអលង្ការរបស់ស្រី ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងប្រើប្រាស់គ្រឿងអលង្ការរបស់ស្រីទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយប្រើប្រាស់គ្រឿងអលង្ការរបស់ស្រី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៥៨] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ គ្រឿងប្រដាប់ក្បាល គ្រឿងប្រដាប់ក គ្រឿងប្រដាប់ដៃ គ្រឿងប្រដាប់ជើង គ្រឿងប្រដាប់ចង្កេះ ឈ្មោះថា គ្រឿងប្រដាប់របស់ស្រី (ក្នុងសិក្ខាបទនេះ)។ ពាក្យថាប្រើប្រាស់ គឺភិក្ខុនីពាក់សូម្បីម្តង ក៏ត្រូវអាបត្តិបាចិត្តិយ។

[៤៥៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីប្រើប្រាស់ព្រោះហេតុនៃអាពាធ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី៥

CS vin.vbi.pc.88 | ភាគ ទី៥

### (៥. បញ្ចមសិក្ខាបទំ)

[៤៦០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាប។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាប ដូចជាពួកស្រីគ្រហស្ថ ជាអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនគួរបើនឹងងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាបសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាប ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនគួរបើនឹងងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាបទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាប ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៦១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា គ្រឿងក្រអូប សំដៅយកវត្ថុណាមួយមានក្លិនក្រអូប។ ដែលហៅថា គ្រឿងលាប សំដៅយករបស់ណាមួយសម្រាប់លាប។ ពាក្យថា ងូតទឹក គឺភិក្ខុនីកំពុងងូត ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលងូត ងូតស្រេច ត្រូវអាបត្តិបាចិត្តិយ។

[៤៦២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីងូតទឹក ព្រោះហេតុនៃអាពាធ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី៦

CS vin.vbi.pc.89 | ភាគ ទី៥

### (៦. ឆដ្ឋសិក្ខាបទំ)

[៤៦៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយងូតទឹកដោយគ្រឿងអប់គ្រឿងលំអិត។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងងូតទឹកដោយគ្រឿងអប់ គ្រឿងលំអិត ដូចជាពួកស្រីគ្រហស្ថ ជាអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងងូតទឹកដោយគ្រឿងអប់ គ្រឿងលំអិតសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីងូតទឹកដោយគ្រឿងអប់ គ្រឿងលំអិត ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងងូតទឹកដោយគ្រឿងអប់ គ្រឿងលំអិតទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ងូតទឹកដោយគ្រឿងអប់ គ្រឿងលំអិត ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៦៤] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា គ្រឿងអប់នោះ គឺគ្រឿងអប់ដែលមានក្លិនក្រអូបណាមួយ។ ដែលហៅថា គ្រឿងលំអិត សំដៅយកម្សៅល្ង។ ពាក្យថា ងូតទឹក សេចក្ដីថា ភិក្ខុនីងូត ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលងូត ងូតស្រេច ត្រូវអាបត្តិបាចិត្តិយ។

[៤៦៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៣យ៉ាង) គឺភិក្ខុនីងូតទឹកដោយគ្រឿងលំអិតជាប្រក្រតី ព្រោះហេតុនៃអាពាធ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី៧

CS vin.vbi.pc.90 | ភាគ ទី៥

### (៧. សត្តមសិក្ខាបទំ)

[៤៦៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយឲ្យភិក្ខុនីគក់រិតខ្លះ ច្របាច់ខ្លះ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ ឃើញហើយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យភិក្ខុនីគក់រិតខ្លះ ច្របាច់ខ្លះ ដូចជាពួកស្រីគ្រហស្ថ ជាអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮពាក្យមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យភិក្ខុនីគក់រិតខ្លះ ច្របាច់ខ្លះសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយឲ្យភិក្ខុនីគក់រិតខ្លះ ច្របាច់ខ្លះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យភិក្ខុនីគក់រិតខ្លះ ច្របាច់ខ្លះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យភិក្ខុនីគក់រិតក្ដី ច្របាច់ក្ដី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៦៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ឲ្យភិក្ខុនី គឺឲ្យភិក្ខុនីដទៃ។ ពាក្យថា គក់រិតក្ដី គឺភិក្ខុនីឲ្យគក់រិត ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ច្របាច់ក្ដី គឺភិក្ខុនីឲ្យគេច្របាច់ ត្រូវអាបត្តិបាចិត្តិយ។

[៤៦៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី៨-៩-១០

CS vin.vbi.pc.91-93 | ភាគ ទី៥

### (៨-៩-១០. អដ្ឋម-នវម-ទសមសិក្ខាបទំ)

[៤៦៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយឲ្យសិក្ខមានាគក់រំអិលខ្លះ ច្របាច់ខ្លះ។បេ។ ឲ្យសាមណេរីគក់រំអិលខ្លះ ច្របាច់ខ្លះ។បេ។ ឲ្យស្រីគ្រហស្ថគក់រំអិលខ្លះ ច្របាច់ខ្លះ។ មនុស្សទាំងឡាយដើរទៅកាន់ចារិកវិហារ ឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនគួរបើនឹងឲ្យស្រីគ្រហស្ថគក់រំអិលខ្លះ ច្របាច់ខ្លះ ដូចជាពួកស្រីគ្រហស្ថ ជាអ្នកបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យស្រីគ្រហស្ថគក់រំអិលខ្លះ ច្របាច់ខ្លះ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយឲ្យស្រីគ្រហស្ថគក់រំអិលខ្លះ ច្របាច់ខ្លះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ មិនសមបើនឹងឲ្យស្រីគ្រហស្ថគក់រំអិលខ្លះ ច្របាច់ខ្លះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ ឲ្យស្រីគ្រហស្ថគក់រំអិលក្ដី ច្របាច់ក្ដី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៧០] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ដែលហៅថា សិក្ខមានា បានដល់សាមណេរីដែលសិក្សាសិក្ខាក្នុងធម៌៦យ៉ាងអស់ពីរឆ្នាំហើយ។ ដែលហៅថា សាមណេរី បានដល់ស្រីអ្នកបួសដែលរក្សាសិក្ខាបទ១០។ ដែលហៅថា ស្រីគ្រហស្ថ សំដៅយកស្រីដែលនៅគ្រប់គ្រងផ្ទះ។ ពាក្យថា ឲ្យគក់រំអិលក្ដី សេចក្ដីថា ភិក្ខុនីឲ្យគេគក់រំអិល ត្រូវអាបត្តិបាចិត្តិយ។ ពាក្យថា ឲ្យច្របាច់ក្ដី សេចក្ដីថា ភិក្ខុនីឲ្យគេច្របាច់ ត្រូវអាបត្តិបាចិត្តិយ។

[៤៧១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីមានហេតុនៃអាពាធ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី១១

CS vin.vbi.pc.94 | ភាគ ទី៥

### (១១. ឯកាទសមសិក្ខាបទំ)

[៤៧២] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយមិនបានប្រាប់ ហើយអង្គុយលើអាសនៈខាងមុខភិក្ខុ។ ភិក្ខុទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើមិនប្រាប់ហើយអង្គុយលើអាសនៈខាងមុខភិក្ខុសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយមិនប្រាប់ ហើយអង្គុយលើអាសនៈខាងមុខភិក្ខុ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនបានប្រាប់ មិនគួរបើនឹងអង្គុយលើអាសនៈខាងមុខភិក្ខុទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ មិនប្រាប់ ហើយអង្គុយលើអាសនៈខាងមុខភិក្ខុ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៧៣] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា ខាងមុខភិក្ខុ គឺខាងមុខនៃឧបសម្បន្ន។ ពាក្យថា មិនបានប្រាប់ គឺមិនបានពិតទូល។ ពាក្យថា អង្គុយលើអាសនៈ គឺភិក្ខុនីអង្គុយដោយហោចទៅសូម្បីលើផែនដី ក៏ត្រូវអាបត្តិបាចិត្តិយ។

[៤៧៤] ភិក្ខុដែលខ្លួនមិនបានប្រាប់ ភិក្ខុនីសំគាល់ថា មិនបានប្រាប់មែន ហើយអង្គុយលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដែលខ្លួនមិនបានប្រាប់ ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយអង្គុយលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដែលខ្លួនមិនបានប្រាប់ ភិក្ខុនីសំគាល់ថា បានប្រាប់ ហើយអង្គុយលើអាសនៈ ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដែលខ្លួនបានប្រាប់ ភិក្ខុនីសំគាល់ថា មិនបានប្រាប់ទេ ត្រូវអាបត្តិទុក្កដ។ ភិក្ខុដែលខ្លួនបានប្រាប់ ភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុដែលខ្លួនបានប្រាប់ ភិក្ខុនីសំគាល់ថា បានប្រាប់ហើយមែន មិនត្រូវអាបត្តិ។

[៤៧៥] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុនីប្រាប់ហើយទើបអង្គុយលើអាសនៈ១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្ដីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី១២

CS vin.vbi.pc.95 | ភាគ ទី៥

### (១២. ទ្វាទសមសិក្ខាបទំ)

[៤៧៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនីទាំងឡាយ សួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាសជាមុន។ ភិក្ខុទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាសសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយមិនសមបើនឹងសួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាសទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ សួរបញ្ហានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៧៧] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា មិនបានសូមឱកាស គឺមិនបានផ្ដៀង។ ពាក្យថា នឹងភិក្ខុ គឺនឹងឧបសម្បន្ន។ ពាក្យថា សួរបញ្ហា គឺភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងព្រះសូត្រ ហើយបែរទៅសួរវិន័យក្ដី អភិធម្មក្ដី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងវិន័យ ហើយបែរទៅសួរព្រះសូត្រក្ដី អភិធម្មក្ដី ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសក្នុងអភិធម្ម ហើយបែរទៅសួរព្រះសូត្រក្ដី វិន័យក្ដី ត្រូវអាបត្តិបាចិត្តិយ។

[៤៧៨] ភិក្ខុដែលខ្លួនមិនបានសូមឱកាស ភិក្ខុនីសំគាល់ថា មិនបានសូមឱកាសមែន ហើយសួរបញ្ហា ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដែលខ្លួនមិនបានសូមឱកាស ភិក្ខុនីមានសេចក្ដីសង្ស័យ ហើយសួរបញ្ហា ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដែលខ្លួនមិនបានសូមឱកាស តែភិក្ខុនីសំគាល់ថា បានសូមឱកាស ហើយសួរបញ្ហា ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុដែលខ្លួនបានសូមឱកាស តែភិក្ខុនីសំគាល់ថា មិនបានសូមឱកាស ត្រូវអាបត្តិទុក្កដ។ ភិក្ខុដែលខ្លួនបានសូមឱកាស តែភិក្ខុនីមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុដែលខ្លួនបានសូមឱកាស ភិក្ខុនីសំគាល់ថា បានសូមឱកាសមែន មិនត្រូវអាបត្តិ។

[៤៧៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៤យ៉ាង) គឺភិក្ខុនីឲ្យភិក្ខុធ្វើឱកាសហើយសួរ១ ភិក្ខុនីឲ្យភិក្ខុធ្វើឱកាសមិនចំពោះ ហើយសួរក្នុងពុទ្ធវចនៈឯណាមួយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាចិត្តិយ ឆត្តុបាហនវគ្គ) សិក្ខាបទ ទី១៣

CS vin.vbi.pc.96 | ភាគ ទី៥

### (១៣. តេរសមសិក្ខាបទំ)

[៤៨០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុនី១រូបគ្មានសម្ពត់ចោមពុង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត។ ខ្យល់ព្យុះទាំងឡាយបក់សើយសង្ឃាដីទាំងឡាយឡើងក្នុងច្រកនោះ។ មនុស្សទាំងឡាយធ្វើសំឡេងហ៊ោឡើងថា ដោះនឹងពោះលោកម្ចាស់ល្អណាស់។ ភិក្ខុនីនោះ កាលដែលមនុស្សទាំងឡាយចំអកឲ្យ (យ៉ាងនោះហើយ) ក៏មានសេចក្ដីអៀនខ្មាស។ ទើបភិក្ខុនីនោះទៅកាន់លំនៅ ហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនី មិនសមបើនឹងគ្មានសម្ពត់ចោមពុង ហើយចូលទៅកាន់ស្រុកសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនី គ្មានសម្ពត់ចោមពុង ហើយចូលទៅកាន់ស្រុក ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនសមបើនឹង គ្មានសម្ពត់ចោមពុង ហើយចូលទៅកាន់ស្រុកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីណាមួយ គ្មានសម្ពត់ចោមពុង ចូលទៅកាន់ស្រុក ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ។**

[៤៨១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ពាក្យថា គ្មានសម្ពត់ចោមពុង គឺលះបង់សម្ពត់ចោមពុង។ សរីរប្រទេសខាងក្រោម តាំងពីដងកាំបិតចុះមក ខាងលើ តាំងពីផ្ចិតឡើងទៅ សម្ពត់ដែលគេធ្វើដើម្បីបិទបាំងសរីរប្រទេសនោះ ហៅថា សម្ពត់ចោមពុង។ ពាក្យថា ចូលទៅកាន់ស្រុក គឺភិក្ខុនីឈានកន្លងរបងស្រុកដែលមានរបង ត្រូវអាបត្តិបាចិត្តិយ។ ភិក្ខុនីឈានចូលដល់ឧបចារស្រុកដែលគ្មានរបង ត្រូវអាបត្តិបាចិត្តិយ។

[៤៨២] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុនីមានចីវរចោរដណ្ដើមយកទៅ១ ភិក្ខុនីមានចីវរវិនាស១ ភិក្ខុនីឈឺ១ ភិក្ខុនីមិនមានសតិ១ ភិក្ខុនីមិនដឹងខ្លួន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

ឆត្តុបាហនវគ្គ ទី ៩ ចប់។

[៤៨៣] បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិបាចិត្តិយទាំងឡាយ១៦៦ ខ្ញុំបានសំដែងឡើងហើយ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិបាចិត្តិយទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះទើបលោកស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

បាចិត្តិយ ចប់។

# បាដិទេសនីយកណ្ឌ (ភិក្ខុនីវិភង្គ)

CS vin.vbi.pd | ភាគ ទី៥

### (៥. បាដិទេសនីយកណ្ឌំ (ភិក្ខុនីវិភង្គោ))

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះ បាដិទេសនីយ៨នេះ មកកាន់ឧទ្ទេស។

## (បាដិទេសនីយ សិក្ខាបទ ទី១)

CS vin.vbi.pd.1 | ភាគ ទី៥

### (១. បឋមបាដិទេសនីយសិក្ខាបទំ)

[៤៨៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយសូមទឹកដោះរាវឆាន់។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងសូមទឹកដោះរាវឆាន់សោះ អ្នកណាមិនគាប់ចិត្តនឹងវត្ថុដែលសម្បូណ៌ អ្នកណាមិនគាប់ចិត្តនឹងវត្ថុដែលឆ្ងាញ់។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយមិនសមបើនឹងសូមទឹកដោះរាវឆាន់សោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុនីទាំងឡាយសូមទឹកដោះរាវឆាន់ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងសូមទឹកដោះរាវឆាន់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុនីណាមួយ សូមទឹកដោះរាវឆាន់ ភិក្ខុនីនោះត្រូវសំដែងចំពោះអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះដ៏មានព្រះភាគតិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសំដែងចំពោះនូវអាបត្តិនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ។

[៤៨៥] សម័យនោះឯង ភិក្ខុនីទាំងឡាយមានជម្ងឺ។ ភិក្ខុនីទាំងឡាយជាអ្នកសួរជម្ងឺ បាននិយាយពាក្យនេះនឹងភិក្ខុនីទាំងឡាយដែលឈឺថា នែលោកម្ចាស់ លោកអាចអត់ទ្រាំសេចក្តីទុក្ខបានឬទេ លោកអាចញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានឬទេ។ ភិក្ខុនីដែលឈឺទាំងឡាយនោះនិយាយថា នែលោកម្ចាស់ ពីដើម យើងទាំងឡាយសូមទឹកដោះរាវឆាន់បាន ហេតុនោះ យើងមានសេចក្តីសប្បាយ តែថាឥឡូវនេះ យើងទាំងឡាយរង្កៀសថា ការសូមនោះ ព្រះដ៏មានព្រះភាគ ទ្រង់ហាមហើយ ដូច្នេះ ទើបមិនហ៊ានសូម ហេតុនោះ ទើបយើងទាំងឡាយមិនមានសេចក្តីសប្បាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីឈឺ សូមទឹកដោះរាវឆាន់បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ មិនឈឺ សូមទឹកដោះរាវឆាន់ ភិក្ខុនីនោះត្រូវសំដែងចំពោះអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះដ៏មានព្រះភាគតិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសំដែងចំពោះនូវអាបត្តិនោះ។**

[៤៨៦] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនីណាលះបង់ទឹកដោះរាវ ហើយបានសេចក្តីសប្បាយ ភិក្ខុនីនោះឈ្មោះថា មិនឈឺ។ ភិក្ខុនីណាលះបង់ទឹកដោះរាវហើយ មិនមានសេចក្តីសប្បាយ ភិក្ខុនីនោះឈ្មោះថាឈឺ។ ដែលហៅថា ទឹកដោះរាវ គឺទឹកដោះរាវរបស់គោក្តី ទឹកដោះរាវរបស់ពពែក្តី ទឹកដោះរាវរបស់ក្របីក្តី សាច់ពួកសត្វណាគួរ ទឹកដោះរាវរបស់សត្វពួកនោះក៏គួរដែរ។ ភិក្ខុនីមិនឈឺ សូមប្រយោជន៍ដើម្បីខ្លួន ត្រូវទុក្កដក្នុងប្រយោគដែលសូម ភិក្ខុនីទទួលដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដក្នុងខណៈដែលបានមក។ ត្រូវបាដិទេសនីយគ្រប់ៗវារៈដែលលេបចូលទៅ។

[៤៨៧] ខ្លួនមិនឈឺ ភិក្ខុនីសំគាល់ថាមិនឈឺ ហើយសូមទឹកដោះរាវឆាន់ ត្រូវអាបត្តិបាដិទេសនីយ។ ខ្លួនមិនឈឺ (តែ)ភិក្ខុនីមានសេចក្តីសង្ស័យ ហើយសូមទឹកដោះរាវឆាន់ ត្រូវអាបត្តិបាដិទេសនីយ។ ខ្លួនមិនឈឺ ភិក្ខុនីសំគាល់ថាឈឺ ហើយសូមទឹកដោះរាវឆាន់ ត្រូវអាបត្តិ

បាដិទេសនីយ។ ខ្លួនឈឺ ភិក្ខុនីសំគាល់ថាមិនឈឺ ត្រូវអាបត្តិទុក្កដ។ ខ្លួនឈឺ (តែ)ភិក្ខុនីមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ខ្លួនឈឺ ភិក្ខុនីសំគាល់ថាឈឺ មិនត្រូវអាបត្តិ។

[៤៨៨] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុនីឈឺ១ ភិក្ខុនីឈឺ សូម(គេបានមក) ហើយត្រឡប់ជាមិនឈឺឆាន់១ ភិក្ខុនីឆាន់របស់សល់អំពីភិក្ខុនីឈឺ១ ភិក្ខុនីបានពីសំណាក់ពួកញាតិ១ អំពីសំណាក់ពួកជនបវារណា១ ភិក្ខុនីសូមដើម្បីប្រយោជន៍អ្នកដទៃ១ ភិក្ខុនីបានមកដោយទ្រព្យរបស់ខ្លួន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

## (បាដិទេសនីយ សិក្ខាបទ ទី២-៨)

CS vin.vbi.pd.2 | ភាគ ទី៥

### (២(-៨). ទុតិយាទិបាដិទេសនីយសិក្ខាបទានិ)

[៤៨៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយសូមប្រេងឆាន់។ សេចក្តីបំប្រួញ។ សូមទឹកឃ្មុំឆាន់។ សូមស្ករអំពៅឆាន់។ សូមត្រីឆាន់។ សូមសាច់ឆាន់។ សូមទឹកដោះស្រស់ឆាន់។ សូមទឹកដោះជូរឆាន់។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងសូមទឹកដោះជូរឆាន់សោះ អ្នកណាដែលមិនគាប់ចិត្តនឹងរបស់សម្បូណ៌ អ្នកណាដែលមិនគាប់ចិត្តនឹងរបស់ឆ្ងាញ់។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងសូមទឹកដោះជូរឆាន់សោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយសូមទឹកដោះជូរឆាន់ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងសូមទឹកដោះជូរឆាន់ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> ភិក្ខុនីណាមួយ សូមទឹកដោះជូរឆាន់ ភិក្ខុនីនោះត្រូវសំដែងចំពោះអាបត្តិថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះដ៏មានព្រះភាគតិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសំដែងចំពោះនូវអាបត្តិនោះ។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយយ៉ាងនេះ។

[៤៩០] សម័យនោះឯង ភិក្ខុនីទាំងឡាយមានជម្ងឺ។ ភិក្ខុនីទាំងឡាយជាអ្នកសួរជម្ងឺ បាននិយាយពាក្យនេះនឹងភិក្ខុនីទាំងឡាយដែលឈឺថា នែលោកម្ចាស់ លោកអាចអត់ធន់ទុក្ខបានទេ អាចញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានឬទេ។ ភិក្ខុនីឈឺទាំងឡាយនោះនិយាយថា នែលោកម្ចាស់ ពីដើម យើងទាំងឡាយសូមទឹកដោះជូរឆាន់បាន ហេតុនោះ យើងទាំងឡាយក៏សប្បាយ តែឥឡូវនេះ យើងទាំងឡាយរង្កៀសថា ព្រះដ៏មានព្រះភាគ ទ្រង់ហាមហើយ (បានជា) មិនសូម ហេតុនោះ ទើបយើងទាំងឡាយមិនសប្បាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីឈឺ សូមទឹកដោះជូរឆាន់បាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

> **ភិក្ខុនីណាមួយ មិនឈឺ សូមទឹកដោះជូរឆាន់ ភិក្ខុនីនោះត្រូវសំដែងចំពោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះដ៏មានព្រះភាគតិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសំដែងចំពោះនូវអាបត្តិនោះ។**

[៤៩១] ត្រង់ពាក្យថា ភិក្ខុនីណាមួយ មានសេចក្តីអធិប្បាយក្នុងសិក្ខាបទទី១ នៃបារាជិកកណ្ឌរួចហើយ។ ភិក្ខុនីណាវៀរទឹកដោះជូរ បានសេចក្តីសប្បាយ ភិក្ខុនីនោះឈ្មោះថា មិនឈឺ។ ភិក្ខុនីណាមួយវៀរទឹកដោះជូរ មិនមានសេចក្តីសប្បាយ ភិក្ខុនីនោះឈ្មោះថាឈឺ។ ដែលហៅថា ប្រេង គឺប្រេងគ្រាប់ល្ង ប្រេងគ្រាប់ស្ពៃ ប្រេងគ្រាប់ស្រគំ ប្រេងគ្រាប់ល្ហុងខ្វែ ប្រេងដែលចំរាញ់ពីខ្លាញ់។ ដែលហៅថា ទឹកឃ្មុំ គឺទឹកផ្អែមដែលឃ្មុំធ្វើ។ ដែលហៅថា ស្ករអំពៅ គឺស្ករកើតពីអំពៅ។ ដែលហៅថា ត្រី គឺសំដៅយកសត្វទឹក។ ដែលហៅថា សាច់ គឺសាច់ពួកសត្វណាគួរ (សង្គ្រោះយក) សាច់ពួកសត្វនោះឯង។ ដែលហៅថា ទឹកដោះស្រស់ គឺទឹកដោះស្រស់របស់គោក្តី ទឹកដោះស្រស់របស់ពពែក្តី ទឹកដោះស្រស់របស់ក្របីក្តី សាច់របស់ពួកសត្វណាគួរ ទឹកដោះស្រស់របស់សត្វអម្បាលនោះក៏គួរដែរ។ ដែលហៅថា ទឹកដោះជូរ គឺទឹកដោះជូររបស់សត្វអម្បាលនោះឯង។ ភិក្ខុនីមិនឈឺ សូមប្រយោជន៍ដើម្បីខ្លួន ត្រូវទុក្កដក្នុងប្រយោគដែលសូម ភិក្ខុនីទទួលដោយគិតថា អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដក្នុងខណៈដែលបានមក ត្រូវអាបត្តិបាដិទេសនីយគ្រប់ៗវារៈដែលលេបចូលទៅ។

[៤៩២] ភិក្ខុនីមិនឈឺ សំគាល់ថាមិនឈឺ ហើយសូមទឹកដោះជូរឆាន់ ត្រូវអាបត្តិបាដិទេសនីយ។ ភិក្ខុនីមិនឈឺ តែមានសេចក្តីសង្ស័យ ហើយសូមទឹកដោះជូរឆាន់ ត្រូវអាបត្តិបាដិទេសនីយ។ ភិក្ខុនីមិនឈឺ សំគាល់ថាឈឺ ហើយសូមទឹកដោះជូរឆាន់ ត្រូវអាបត្តិបាដិទេសនីយ។ ភិក្ខុនីឈឺ សំគាល់ថាមិនឈឺ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីឈឺ តែមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីឈឺ សំគាល់ថាឈឺ មិនត្រូវអាបត្តិ។

[៤៩៣] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុនីឈឺ១ ភិក្ខុនីឈឺ សូម(គេបានមក) ហើយជា ឆាន់១ ភិក្ខុនីឆាន់របស់សល់អំពីភិក្ខុនីឈឺ១ ភិក្ខុនីបានពីសំណាក់ពួកញាតិ១ អំពីសំណាក់ពួកជនបវារណា១ ភិក្ខុនីសូមដើម្បីប្រយោជន៍ជនដទៃ១ ភិក្ខុនីបានមកដោយទ្រព្យរបស់ខ្លួន១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

[៤៩៤] បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះបាដិទេសនីយ៨ ខ្ញុំសំដែងឡើងហើយ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ លោកម្ចាស់ទាំងឡាយបរិសុទ្ធក្នុងអាបត្តិទាំងនេះហើយ ហេតុនោះ បានជាស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

បាដិទេសនីយ ចប់។

# សេខិយកណ្ឌ (ភិក្ខុនីវិភង្គ)

CS vin.vbi.sk | ភាគ ទី៥

**(៦. សេខិយកណ្ឌំ (ភិក្ខុនីវិភង្គោ))**

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះ សេក្ខិយអម្បាលនេះ តែងមកកាន់ឧទ្ទេស។

## (សេខិយកណ្ឌ បរិមណ្ឌលវគ្គ ទី១)

CS vin.vbi.sk.v1 | ភាគ ទី៥

**(១. បរិមណ្ឌលវគ្គោ)**

### (បរិមណ្ឌលវគ្គ សិក្ខាបទ ទី១)

CS vin.vbi.sk.01 | ភាគ ទី៥

(-)

[៤៩៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយស្លៀករយីករយាក (ស្លុយ)មុខខ្លះ (ស្លុយ)ក្រោយខ្លះ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយ មិនសមបើនឹងស្លៀករយីករយាក (ស្លុយ)មុខខ្លះ (ស្លុយ)ក្រោយខ្លះ ដូចជាពួកស្រីគ្រហស្ថបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនគួរបើនឹងស្លៀករយីករយាក (ស្លុយ)មុខខ្លះ (ស្លុយ)ក្រោយខ្លះសោះ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយស្លៀករយីករយាក (ស្លុយ)មុខខ្លះ (ស្លុយ)ក្រោយខ្លះ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនគួរបើនឹងស្លៀកស្លុយមុខខ្លះ ស្លុយក្រោយខ្លះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីគប្បីធ្វើសេចក្តីសិក្សាថា អញនឹងស្លៀកឲ្យជាបរិមណ្ឌល។**

[៤៩៦] ភិក្ខុនីត្រូវស្លៀកឲ្យជាបរិមណ្ឌល គឺបិទបាំងមណ្ឌលផ្ចិត មណ្ឌលជង្គង់។ ភិក្ខុនីណាអាស្រ័យសេចក្តីមិនអើពើ ហើយស្លៀកស្លុយមុខ ឬស្លុយក្រោយ ត្រូវអាបត្តិទុក្កដ។

[៤៩៧] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុនីមិនក្លែង១ ភិក្ខុនីមិនមានសតិ១ ភិក្ខុនីមិនដឹងខ្លួន១ ភិក្ខុនីឈឺ១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។ សេចក្តីសង្ខេប។

## (សេខិយកណ្ឌ បាទុកវគ្គ ទី៧)

CS vin.vbi.sk.v7 | ភាគ ទី៥

**(៧. បាទុកវគ្គោ)**

### (បាទុកវគ្គ សិក្ខាបទ ទី១)

CS vin.vbi.sk.75 | ភាគ ទី៥

(-)

[៤៩៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ឆព្វគ្គិយាភិក្ខុនីទាំងឡាយបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះក្នុងទឹក។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយមិនសមបើនឹងធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះក្នុងទឹក ដូចជាពួកស្រីគ្រហស្ថបរិភោគកាមសោះ។ ភិក្ខុនីទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុនីទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះក្នុងទឹកសោះ។ ទើបភិក្ខុនីទាំងឡាយនោះ ប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ។បេ។ ត្រាស់សួរចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយាភិក្ខុនីទាំងឡាយធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះក្នុងទឹក ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ឆព្វគ្គិយាភិក្ខុនីទាំងឡាយ មិនសមបើនឹងធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះក្នុងទឹកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

ភិក្ខុនីគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនធ្វើឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក។

សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ។

[៤៩៩] សម័យនោះឯង ភិក្ខុនីទាំងឡាយឈឺ ក៏រង្កៀស (មិនហ៊ាន) ធ្វើឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះក្នុងទឹក។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគមានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីឈឺ ធ្វើឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹកបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទាំងឡាយ ចូរសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា

**ភិក្ខុនីគប្បីធ្វើសេចក្តីសិក្សាថា អញមិនឈឺ នឹងមិនធ្វើឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក។**

[៥០០] ភិក្ខុនីមិនឈឺ មិនត្រូវធ្វើឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹកឡើយ ភិក្ខុនីណាមិនឈឺ អាស្រ័យសេចក្តីមិនអើពើ ហើយធ្វើឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក ភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដ។

[៥០១] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន១០យ៉ាង) គឺភិក្ខុនីមិនក្លែង១ ភិក្ខុនីមិនមានសតិ១ ភិក្ខុនីមិនដឹងខ្លួន១ ភិក្ខុនីឈឺ១ ភិក្ខុនីធ្វើឧច្ចារៈ (ជាដើម) លើគោក ហើយហូរហៀរទៅរកទឹក១ ភិក្ខុនីមានសេចក្តីអន្តរាយ១ ភិក្ខុនីឆ្កួត១ ភិក្ខុនីមានចិត្តរវើរវាយ១ ភិក្ខុនីមានវេទនាគ្រប់សង្កត់១ ភិក្ខុនីជាខាងដើមបញ្ញត្តិ១។

[៥០២] បពិត្រលោកម្ចាស់ទាំងឡាយ ធម៌ទាំងឡាយឈ្មោះសេក្ខិយៈ ខ្ញុំសំដែងឡើងហើយ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងធម៌ទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសូមសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសូមសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ លោកម្ចាស់ទាំងឡាយបរិសុទ្ធក្នុងធម៌ទាំងនេះហើយ ហេតុនោះ បានជាស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

សេក្ខិយៈ ចប់។

# អធិករណសមថៈ ទីបំផុត (ភិក្ខុនីវិភង្គ)

CS vin.vbi.ad | ភាគ ទី៥

### (៧. អធិករណសមថា (ភិក្ខុនីវិភង្គោ))

[៥០៣] បពិត្រលោកម្ចាស់ទាំងឡាយ ធម៌សម្រាប់រម្ងាប់នូវអធិករណ៍ទាំងឡាយ៧នេះឯង តែងមកកាន់ឧទ្ទេស។

- សង្ឃត្រូវឲ្យសម្មុខាវិន័យ
- ឲ្យសតិវិន័យ
- ឲ្យអមូឡ្ហវិន័យ
- សង្ឃត្រូវធ្វើបដិញ្ញាតករណៈ
- ត្រូវធ្វើយេភុយ្យសិកា
- ត្រូវធ្វើតស្សបាបិយសិកា
- ត្រូវធ្វើតិណវត្ថារក[37)]

ដើម្បីរម្ងាប់ គឺផ្សះផ្សានូវអធិករណ៍ទាំងឡាយដែលកើតឡើងហើយៗ។

បពិត្រលោកម្ចាស់ទាំងឡាយ ធម៌ទាំងឡាយឈ្មោះអធិករណសមថៈទាំង៧ ខ្ញុំសំដែងឡើងហើយ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយក្នុងធម៌ទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ ខ្ញុំសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ។ លោកម្ចាស់ទាំងឡាយបរិសុទ្ធក្នុងធម៌ទាំងនេះហើយ ហេតុនោះ បានជាស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

អធិករណសមថៈ ចប់។

[៥០៤] បពិត្រលោកម្ចាស់ទាំងឡាយ និទានខ្ញុំសំដែងឡើងហើយ អាបត្តិបារាជិក៨ ខ្ញុំសំដែងឡើងហើយ អាបត្តិសង្ឃាទិសេស១៧ ខ្ញុំសំដែងឡើងហើយ អាបត្តិនិស្សគ្គិយបាចិត្តិយ៣០ ខ្ញុំសំដែងឡើងហើយ អាបត្តិបាចិត្តិយ១៦៦ ខ្ញុំសំដែងឡើងហើយ អាបត្តិបាដិទេសនីយ៨ ខ្ញុំសំដែងឡើងហើយ ធម៌ឈ្មោះសេក្ខិយៈទាំងឡាយ ខ្ញុំសំដែងឡើងហើយ ធម៌ឈ្មោះអធិករណសមថៈ៧ ខ្ញុំសំដែងឡើងហើយ។ ពាក្យរបស់ព្រះដ៏មានព្រះភាគនោះ មានប្រមាណប៉ុណ្ណេះ មកហើយកាន់សុត្ត រាប់បញ្ចូលហើយក្នុងសុត្ត មកកាន់ឧទ្ទេសរាល់កន្លះខែ។ គួរលោកម្ចាស់ទាំងឡាយគ្រប់អង្គ ព្រមព្រៀងគ្នា ស្រុះស្រួលគ្នា កុំទាស់ទែងគ្នា សិក្សាក្នុងពុទ្ធវចនៈនោះចុះ។

ភិក្ខុនីវិភង្គ ចប់។

ចប់ ភាគ៥។

# មាតិកា


| **ភិក្ខុនីវិភង្គ** | លេខ ទំព័រ |
|---|---|
| **បារាជិក** | **១** |
| **បារាជិក ទី ១** | ១ |
| និទានបុរសឈ្មោះសាឡ្ហ ជាចៅមិគារមាតា | ១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៨ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ១១ |
| **បារាជិក ទី ២** | ១៧ |
| និទានសុន្ទរីនន្ទាភិក្ខុនី | ១៧ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៩ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២១ |
| **បារាជិក ទី ៣** | ២៣ |
| និទានថុល្លនន្ទាភិក្ខុនី | ២៣ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៤ |
| ការសូត្រសមនុភាសនកម្ម | ២៧ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២៨ |
| **បារាជិក ទី ៤** | ៣០ |
| និទានឆព្វគ្គិយាភិក្ខុនី | ៣០ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៣១ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៣៤ |
| ឧទ្ទេសាវសាន | ៣៥ |
| **សត្តរសកណ្ឌ** | **៣៦** |
| **សង្ឃាទិសេស ទី ១** | ៣៦ |
| និទានឧបាសកម្នាក់ ប្រគេនឃ្លាំង | ៣៦ |
| សេចក្តីបញ្ញត្តិ | ៣៩ |

| | |
|---|---|
| សិក្ខាបទវិភង្គ និងបទភាជនីយ | ៤០ |
| វារៈដែលមិនត្រូវអាបត្តិ | ៤១ |
| **សង្ឃាទិសេស ទី ២** | ៤១ |
| និទានភរិយាស្តេចលិច្ឆវី | ៤១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៤៤ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៤៥ |
| **សង្ឃាទិសេស ទី ៣** | ៤៧ |
| និទានភិក្ខុនី ជាសិស្សភទ្ទាកាបិលានីភិក្ខុនី | ៤៧ |
| សេចក្តីបញ្ញត្តិជាដម្បូង និងនិទានភិក្ខុនីពីររូប | ៤៨ |
| អនុប្បញ្ញត្តិ ទី១ | ៤៩ |
| និទានភិក្ខុនីច្រើនរូប និងអនុប្បញ្ញត្តិ ទី ២ | ៥០ |
| អនុប្បញ្ញត្តិ ទី៣ និងសិក្ខាបទវិភង្គ | ៥៣ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៥៤ |
| **សង្ឃាទិសេស ទី ៤** | ៥៥ |
| និទានចណ្ឌកាលីភិក្ខុនី | ៥៥ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៥៧ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៥៩ |
| **សង្ឃាទិសេស ទី ៥** | ៦០ |
| និទានសុន្ទរីនន្ទាភិក្ខុនី | ៦០ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៦១ |
| **សង្ឃាទិសេស ទី ៦** | ៦៤ |
| និទានសុន្ទរីនន្ទាភិក្ខុនី | ៦៤ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៦៦ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៦៧ |
| **សង្ឃាទិសេស ទី ៧** | ៦៨ |
| និទានចណ្ឌកាលីភិក្ខុនី | ៦៨ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៧១ |
| ការសូត្រសមនុភាសនកម្ម | ៧៣ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ៧៦ |
| **សង្ឃាទិសេស ទី ៨** | ៧៧ |
| និទានចណ្ឌកាលីភិក្ខុនី | ៧៧ |
| សិក្ខាបទវិភង្គ និងការសូត្រសមនុភាសនកម្ម | ៧៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៨៣ |
| **សង្ឃាទិសេស ទី ៩** | ៨៤ |
| និទានពួកភិក្ខុនី ជាអន្តេវាសិនីរបស់ថុល្លនន្ទាភិក្ខុនី | ៨៤ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៨៥ |
| ការសូត្រសមនុភាសនកម្ម និងបទភាជនីយ | ៨៨ |

| | |
|---|---|
| វារៈដែលមិនត្រូវអាបត្តិ | ៩១ |
| **សង្ឃាទិសេស ទី ១០** | ៩១ |
| និទានថុល្លនន្ទាភិក្ខុនី | ៩១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ៩៣ |
| ការសូត្រសមនុភាសនកម្ម និងបទភាជនីយ | ៩៧ |
| វារៈដែលមិនត្រូវអាបត្តិ និងឧទ្ទេសាវសាន | ១០១ |
| **និស្សគ្គិយកណ្ឌ** | **១០៣** |
| **បត្តវគ្គ សិក្ខាបទ ទី ១** | ១០៣ |
| និទានឆព្វគ្គិយាភិក្ខុនី | ១០៣ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ១០៥ |
| វារៈដែលមិនត្រូវអាបត្តិ និងរឿងឆព្វគ្គិយាភិក្ខុនី | ១០៨ |
| **បត្តវគ្គ សិក្ខាបទ ទី ២** | ១០៩ |
| និទានភិក្ខុនីច្រើនរូប | ១០៩ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ១១១ |
| **បត្តវគ្គ សិក្ខាបទ ទី ៣** | ១១២ |
| និទានថុល្លនន្ទាភិក្ខុនី | ១១២ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១១៤ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ១១៥ |
| **បត្តវគ្គ សិក្ខាបទ ទី ៤** | ១១៦ |
| និទានថុល្លនន្ទាភិក្ខុនី មានជម្ងឺ | ១១៦ |
| សិក្ខាបទវិភង្គ និងបទភាជនីយ | ១១៧ |
| វារៈដែលមិនត្រូវអាបត្តិ | ១២០ |
| **បត្តវគ្គ សិក្ខាបទ ទី ៥** | ១២១ |
| និទានថុល្លនន្ទាភិក្ខុនី មានជម្ងឺ | ១២១ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ១២៣ |
| **បត្តវគ្គ សិក្ខាបទ ទី ៦** | ១២៤ |
| និទានឧបាសកច្រើនរូប | ១២៤ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១២៦ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ១២៧ |
| **បត្តវគ្គ សិក្ខាបទ ទី ៧** | ១២៨ |
| និទានឧបាសកច្រើនរូប | ១២៨ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១២៩ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ១៣១ |
| **បត្តវគ្គ សិក្ខាបទ ទី ៨** | ១៣២ |
| និទានភិក្ខុនីច្រើនរូប | ១៣២ |
| សេចក្តីបញ្ញត្តិ និងបទភាជនីយ | ១៣៤ |

| | |
|---|---|
| វារៈដែលមិនត្រូវអាបត្តិ | ១៣៥ |
| **បត្តវគ្គ សិក្ខាបទ ទី ៩** | ១៣៦ |
| និទានភិក្ខុនីច្រើនរូប | ១៣៦ |
| សេចក្ដីបញ្ញត្តិ និងបទភាជនីយ | ១៣៧ |
| វារៈដែលមិនត្រូវអាបត្តិ | ១៣៩ |
| **បត្តវគ្គ សិក្ខាបទ ទី ១០** | ១៤០ |
| និទានថុល្លនន្ទាភិក្ខុនី | ១៤០ |
| សេចក្ដីបញ្ញត្តិ និងបទភាជនីយ | ១៤១ |
| វារៈដែលមិនត្រូវអាបត្តិ | ១៤៣ |
| **ចីវរវគ្គ សិក្ខាបទ ទី ១** | ១៤៤ |
| និទានថុល្លនន្ទាភិក្ខុនី | ១៤៤ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៤៦ |
| វារៈដែលមិនត្រូវអាបត្តិ | ១៤៧ |
| **ចីវរវគ្គ សិក្ខាបទ ទី ២** | ១៤៨ |
| សេចក្ដីបញ្ញត្តិ និងបទភាជនីយ | ១៤៩ |
| វារៈដែលមិនត្រូវអាបត្តិ និងឧទ្ទេសាវសាន | ១៥១ |
| **លសុណវគ្គ សិក្ខាបទ ទី ១** | ១៥៣ |
| និទានឧបាសកម្នាក់ | ១៥៣ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ១៥៦ |
| **លសុណវគ្គ សិក្ខាបទ ទី ២** | ១៥៧ |
| និទានឆព្វគ្គិយាភិក្ខុនី | ១៥៧ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៥៨ |
| វារៈដែលមិនត្រូវអាបត្តិ | ១៥៩ |
| **លសុណវគ្គ សិក្ខាបទ ទី ៣** | ១៥៩ |
| និទានភិក្ខុនីពីររូប | ១៥៩ |
| សេចក្ដីបញ្ញត្តិ - សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ១៦០ |
| **លសុណវគ្គ សិក្ខាបទ ទី ៤** | ១៦១ |
| និទានស្រីស្នំ | ១៦១ |
| សេចក្ដីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ១៦២ |
| **លសុណវគ្គ សិក្ខាបទ ទី ៥** | ១៦៣ |
| និទានព្រះនាងបជាបតិគោតមី | ១៦៣ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ១៦៥ |
| **លសុណវគ្គ សិក្ខាបទ ទី ៦** | ១៦៦ |
| និទានមហាមាត្យឈ្មោះអារោហន្ត | ១៦៦ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ១៦៧ |
| វារៈដែលមិនត្រូវអាបត្តិ | ១៦៨ |
| **លសុណវគ្គ សិក្ខាបទ ទី ៧** | ១៦៩ |

| | |
|---|---|
| និទានពួកភិក្ខុនី នាំគ្នាសូមស្រូវ | ១៦៩ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ១៧០ |
| **លសុណវគ្គ សិក្ខាបទ ទី ៨** | ១៧១ |
| និទានព្រាហ្មណ៍ម្នាក់ ជារាជអមាត្យ | ១៧១ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ១៧៣ |
| **លសុណវគ្គ សិក្ខាបទ ទី ៩** | ១៧៤ |
| និទានព្រាហ្មណ៍ម្នាក់មានស្រែស្រូវដំណើប | ១៧៤ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ១៧៥ |
| វារៈដែលមិនត្រូវអាបត្តិ | ១៧៦ |
| **លសុណវគ្គ សិក្ខាបទ ទី ១០** | ១៧៦ |
| និទានឆព្វគ្គិយាភិក្ខុនី និងសេចក្ដីបញ្ញាត្តិ | ១៧៧ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ១៧៨ |
| **អន្ធការវគ្គ សិក្ខាបទ ទី ១** | ១៧៩ |
| និទានបុរសជាញាតិរបស់ភិក្ខុនី ជាសិស្សភទ្ទាកាបិលានីភិក្ខុនី | ១៧៩ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ១៨០ |
| វារៈដែលមិនត្រូវអាបត្តិ | ១៨១ |
| **អន្ធការវគ្គ សិក្ខាបទ ទី ២** | ១៨១ |
| និទានបុរសជាញាតិរបស់ភិក្ខុនី ជាសិស្សភទ្ទាកាបិលានីភិក្ខុនី | ១៨១ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ១៨២ |
| វារៈដែលមិនត្រូវអាបត្តិ | ១៨៣ |
| **អន្ធការវគ្គ សិក្ខាបទ ទី ៣** | ១៨៤ |
| និទានបុរសជាញាតិរបស់ភិក្ខុនី ជាសិស្សភទ្ទាកាបិលានីភិក្ខុនី | ១៨៤ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ១៨៥ |
| វារៈដែលមិនត្រូវអាបត្តិ | ១៨៦ |
| **អន្ធការវគ្គ សិក្ខាបទ ទី ៤** | ១៨៦ |
| និទានថុល្លនន្ទាភិក្ខុនី | ១៨៦ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ១៨៧ |
| វារៈដែលមិនត្រូវអាបត្តិ | ១៨៩ |
| **អន្ធការវគ្គ សិក្ខាបទ ទី ៥** | ១៨៩ |
| និទានភិក្ខុនី ១ រូប | ១៨៩ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ១៩១ |
| វារៈដែលមិនត្រូវអាបត្តិ | ១៩៣ |
| **អន្ធការវគ្គ សិក្ខាបទ ទី ៦** | ១៩៣ |
| និទានថុល្លនន្ទាភិក្ខុនី | ១៩៣ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ១៩៤ |
| វារៈដែលមិនត្រូវអាបត្តិ | ១៩៦ |
| **អន្ធការវគ្គ សិក្ខាបទ ទី ៧** | ១៩៦ |

| | |
|---|---|
| និទានភិក្ខុនីច្រើនរូប | ១៩៦ |
| សេចក្តីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ១៩៨ |
| វារៈដែលមិនត្រូវអាបត្តិ | ២០០ |
| **អន្ធការវគ្គ សិក្ខាបទ ទី ៨** | ២០០ |
| និទានភិក្ខុនី ជាសិស្សរបស់ភទ្ទាកាបិលានីភិក្ខុនី | ២០០ |
| សេចក្តីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ២០១ |
| វារៈដែលមិនត្រូវអាបត្តិ | ២០២ |
| **អន្ធការវគ្គ សិក្ខាបទ ទី ៩** | ២០២ |
| និទានពួកភិក្ខុនី - សេចក្តីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ២០២ |
| វារៈដែលមិនត្រូវអាបត្តិ | ២០៥ |
| **អន្ធការវគ្គ សិក្ខាបទ ទី ១០** | ២០៥ |
| និទានចណ្ឌកាលីភិក្ខុនី - សេចក្តីបញ្ញាត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ២០៥ |
| **នគ្គវគ្គ សិក្ខាបទ ទី ១** | ២០៧ |
| និទានភិក្ខុនីច្រើនរូប - សេចក្តីបញ្ញាត្តិ - សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២០៧ |
| **នគ្គវគ្គ សិក្ខាបទ ទី ២** | ២០៨ |
| និទានព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសំពត់ងូតទឹក | ២០៨ |
| សេចក្តីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ២០៩ |
| វារៈដែលមិនត្រូវអាបត្តិ | ២១១ |
| **នគ្គវគ្គ សិក្ខាបទ ទី ៣** | ២១២ |
| និទានភិក្ខុនី ១រូប មានសំពត់សម្រាប់ធ្វើចីវរ | ២១១ |
| សេចក្តីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ២១២ |
| វារៈដែលមិនត្រូវអាបត្តិ | ២១៥ |
| **នគ្គវគ្គ សិក្ខាបទ ទី ៤** | ២១៥ |
| និទានពួកភិក្ខុនីធ្វើចីវរ | ២១៥ |
| សេចក្តីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ២១៦ |
| វារៈដែលមិនត្រូវអាបត្តិ | ២១៧ |
| **នគ្គវគ្គ សិក្ខាបទ ទី ៥** | ២១៧ |
| និទានភិក្ខុនី ១រូប | ២១៧ |
| សេចក្តីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ២១៨ |
| វារៈដែលមិនត្រូវអាបត្តិ | ២២០ |
| **នគ្គវគ្គ សិក្ខាបទ ទី ៦** | ២២០ |
| និទានត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី | ២២០ |
| សេចក្តីបញ្ញាត្តិ | ២២១ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២២២ |
| **នគ្គវគ្គ សិក្ខាបទ ទី ៧** | ២២៣ |
| និទានអកាលចីវរ កើតឡើងដល់ភិក្ខុនីសង្ឃ | ២២៣ |

| | |
|---|---|
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២២៤ |
| វារៈដែលមិនត្រូវអាបត្តិ | ២២៥ |
| **នគ្គវគ្គ សិក្ខាបទ ទី ៨** | ២២៥ |
| និទានថុល្លនន្ទាភិក្ខុនី | ២២៥ |
| សេចក្តីបញ្ញត្តិ | ២២៦ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២២៧ |
| **នគ្គវគ្គ សិក្ខាបទ ទី ៩** | ២២៧ |
| និទានត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី | ២២៧ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២២៩ |
| វារៈដែលមិនត្រូវអាបត្តិ | ២៣០ |
| **នគ្គវគ្គ សិក្ខាបទ ទី ១០** | ២៣១ |
| និទានឧបាសកម្នាក់ឲ្យគេធ្វើវិហារ | ២៣១ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៣៣ |
| វារៈដែលមិនត្រូវអាបត្តិ | ២៣៤ |
| **តុវដ្តវគ្គ សិក្ខាបទ ទី ១** | ២៣៥ |
| និទានភិក្ខុនីពីររូប | ២៣៥ |
| សេចក្តីបញ្ញត្តិ - សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២៣៦ |
| **តុវដ្តវគ្គ សិក្ខាបទ ទី ២** | ២៣៦ |
| និទានភិក្ខុនីពីររូប | ២៣៦ |
| សេចក្តីបញ្ញត្តិ | ២៣៧ |
| សិក្ខាបទវិភង្គ | ២៣៨ |
| វារៈដែលមិនត្រូវអាបត្តិ | ២៣៩ |
| **តុវដ្តវគ្គ សិក្ខាបទ ទី ៣** | ២៣៩ |
| និទានថុល្លនន្ទាភិក្ខុនី | ២៣៩ |
| សេចក្តីបញ្ញត្តិ | ២៤០ |
| សិក្ខាបទវិភង្គ | ២៤១ |
| វារៈដែលមិនត្រូវអាបត្តិ | ២៤២ |
| **តុវដ្តវគ្គ សិក្ខាបទ ទី ៤** | ២៤២ |
| និទានថុល្លនន្ទាភិក្ខុនី | ២៤២ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៤៣ |
| វារៈដែលមិនត្រូវអាបត្តិ | ២៤៤ |
| **តុវដ្តវគ្គ សិក្ខាបទ ទី ៥** | ២៤៤ |
| និទានភទ្ទាកាបិលានីភិក្ខុនី | ២៤៤ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៤៦ |
| សេចក្តីបញ្ញត្តិ ទី ២ | ២៤៧ |
| វារៈដែលមិនត្រូវអាបត្តិ | ២៤៨ |
| **តុវដ្តវគ្គ សិក្ខាបទ ទី ៦** | ២៤៩ |

| | |
|---|---|
| និទានចណ្ឌកាលីភិក្ខុនី | ២៤៩ |
| សិក្ខាបទវិភង្គ | ២៥០ |
| វារៈដែលមិនត្រូវអាបត្តិ | ២៥៣ |
| **តុវដ្ដវគ្គ សិក្ខាបទ ទី ៧** | ២៥៣ |
| និទានភិក្ខុនីទាំងឡាយ | ២៥៣ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ២៥៥ |
| វារៈដែលមិនត្រូវអាបត្តិ | ២៥៦ |
| **តុវដ្ដវគ្គ សិក្ខាបទ ទី ៨** | ២៥៦ |
| និទានភិក្ខុនីទាំងឡាយ | ២៥៦ |
| សេចក្ដីបញ្ញាត្តិ និងសិក្ខាបទវិភង្គ | ២៥៧ |
| វារៈដែលមិនត្រូវអាបត្តិ | ២៥៧ |
| **តុវដ្ដវគ្គ សិក្ខាបទ ទី ៩** | ២៥៨ |
| និទានពួកភិក្ខុនី | ២៥៨ |
| វារៈដែលមិនត្រូវអាបត្តិ | ២៦០ |
| **តុវដ្ដវគ្គ សិក្ខាបទ ទី ១០** | ២៦០ |
| និទានភិក្ខុនីទាំងឡាយ | ២៦០ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ១** | ២៦៣ |
| និទាននាយជាងបានគូរគំនូរ | ២៦៣ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២៦៤ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ២** | ២៦៥ |
| និទានភិក្ខុនីទាំងឡាយ | ២៦៥ |
| វារៈដែលមិនត្រូវអាបត្តិ | ២៦៧ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ៣** | ២៦៧ |
| និទានឆព្វគ្គិយាភិក្ខុនី | ២៦៧ |
| វារៈដែលមិនត្រូវអាបត្តិ | ២៦៩ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ៤** | ២៦៩ |
| និទានភិក្ខុនីទាំងឡាយ | ២៦៩ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២៧០ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ៥** | ២៧០ |
| និទានភិក្ខុនី ១ រូប | ២៧០ |
| សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៧២ |
| វារៈដែលមិនត្រូវអាបត្តិ | ២៧៤ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ៦** | ២៧៤ |
| និទានថុល្លនន្ទាភិក្ខុនី | ២៧៤ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២៧៦ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ៧** | ២៧៦ |
| និទានថុល្លនន្ទាភិក្ខុនី | ២៧៦ |

| | |
|---|---|
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២៧៨ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ៨** | ២៧៩ |
| និទានថុល្លនន្ទាភិក្ខុនី | ២៧៩ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ២៨២ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ៩** | ២៨២ |
| និទានឆព្វគ្គិយាភិក្ខុនី | ២៨២ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ២៨៣ |
| **ចិត្តាគារវគ្គ សិក្ខាបទ ទី ១០** | ២៨៤ |
| និទានឆព្វគ្គិយាភិក្ខុនី | ២៨៤ |
| សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ | ២៨៥ |
| វារៈដែលមិនត្រូវអាបត្តិ | ២៨៥ |
| **អារាមវគ្គ សិក្ខាបទ ទី ១** | ២៨៦ |
| និទានភិក្ខុច្រើនរូប | ២៨៦ |
| វារៈដែលមិនត្រូវអាបត្តិ | ២៩០ |
| **អារាមវគ្គ សិក្ខាបទ ទី ២** | ២៩០ |
| និទានព្រះកប្បិតក | ២៩០ |
| សេចក្តីបញ្ញត្តិ | ២៩២ |
| វារៈដែលមិនត្រូវអាបត្តិ | ២៩៣ |
| **អារាមវគ្គ សិក្ខាបទ ទី ៣** | ២៩៤ |
| និទានចណ្ឌកាលីភិក្ខុនី និងថុល្លនន្ទាភិក្ខុនី | ២៩៤ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ២៩៦ |
| **អារាមវគ្គ សិក្ខាបទ ទី ៤** | ២៩៧ |
| និទានព្រាហ្មណ៍ម្នាក់ និមន្តភិក្ខុនីឆាន់ | ២៩៧ |
| បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ | ២៩៩ |
| **អារាមវគ្គ សិក្ខាបទ ទី ៥** | ៣០០ |
| និទានភិក្ខុនី ១ រូប | ៣០០ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣០១ |
| **អារាមវគ្គ សិក្ខាបទ ទី ៦** | ៣០២ |
| និទានភិក្ខុនីច្រើនរូប | ៣០២ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣០២ |
| **អារាមវគ្គ សិក្ខាបទ ទី ៧** | ៣០៤ |
| និទានភិក្ខុនីច្រើនរូប | ៣០៤ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣០៥ |
| **អារាមវគ្គ សិក្ខាបទ ទី ៨** | ៣០៦ |
| និទានឆព្វគ្គិយភិក្ខុ | ៣០៦ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣០៨ |

| | |
|---|---|
| **អារាមវគ្គ សិក្ខាបទ ទី ៩** | ៣០៨ |
| និទានភិក្ខុនីទាំងឡាយ | ៣០៨ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣០៩ |
| **អារាមវគ្គ សិក្ខាបទ ទី ១០** | ៣១០ |
| និទានភិក្ខុនី ១ រូប | ៣១០ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣១១ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ១** | ៣១៣ |
| និទានភិក្ខុនីទាំងឡាយ | ៣១៣ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣១៤ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ២** | ៣១៥ |
| និទានភិក្ខុនីច្រើនរូប | ៣១៥ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣១៧ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ៣** | ៣១៧ |
| និទានភិក្ខុនីទាំងឡាយឲ្យឧបសម្បទាដល់សិក្ខមានា | ៣១៧ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣២១ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ៤** | ៣២២ |
| និទានភិក្ខុនីឲ្យឧបសម្បទាដល់សិក្ខមានា | ៣២២ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣២៥ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ៥** | ២៣៧ |
| និទានភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគតា មានវស្សាមិនគ្រប់ ១២ ឆ្នាំ | ៣២៧ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣២៩ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ៦** | ៣៣០ |
| និទានភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគតា | ៣៣០ |
| សេចក្តីបញ្ញត្តិ | ៣៣៣ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៣៥ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ៧** | ៣៣៥ |
| និទានភិក្ខុនីឲ្យឧបសម្បទាដល់ស្រីគិហិគតា | ៣៣៥ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៣៩ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ៨** | ៣៤០ |
| និទានថុល្លនន្ទាភិក្ខុនី | ៣៤០ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣៤១ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ៩** | ៣៤២ |
| និទានភិក្ខុនីមិនបំរើឧបជ្ឈាយ៍ | ៣៤២ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣៤៣ |
| **គព្ភិនីវគ្គ សិក្ខាបទ ទី ១០** | ៣៤៤ |
| និទានថុល្លនន្ទាភិក្ខុនី | ៣៤៤ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣៤៥ |

| | |
|---|---|
| **កុមារីភូតវគ្គ សិក្ខាបទ ទី ១** | ៣៣៦ |
| និទានភិក្ខុនីឲ្យឧបសម្បទាដល់កុមារី | ៣៤៦ |
| សេចក្ដីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣៤៧ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ២** | ៣៤៩ |
| និទានភិក្ខុនីឲ្យឧបសម្បទាដល់កុមារី | ៣៤៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៥៣ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ៣** | ៣៥៤ |
| និទានភិក្ខុនីឲ្យឧបសម្បទាដល់កុមារី | ៣៥៤ |
| សេចក្ដីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣៥៧ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ៤** | ៣៥៩ |
| និទានភិក្ខុនីឲ្យឧបសម្បទាដល់កុមារី | ៣៥៩ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៦០ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ៥** | ៣៦០ |
| និទានភិក្ខុនីទាំងឡាយមានវស្សាពេញ ១២ | ៣៦០ |
| វុដ្ឋាបនសម្មតិ | ៣៦១ |
| សេចក្ដីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣៦៣ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ៦** | ៣៦៥ |
| និទានចណ្ឌកាលីភិក្ខុនី | ៣៦៥ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៦៧ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ៧** | ៣៦៧ |
| និទានសិក្ខមានា ១ រូប | ៣៦៧ |
| សេចក្ដីបញ្ញត្តិ - សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៦៩ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ៨** | ៣៧០ |
| និទានសិក្ខមានា ១ រូប | ៣៧០ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៧២ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ៩** | ៣៧៣ |
| និទានថុល្លនន្ទាភិក្ខុនី | ៣៧៣ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៧៤ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ១០** | ៣៧៥ |
| និទានថុល្លនន្ទាភិក្ខុនី | ៣៧៥ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៧៦ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ១១** | ៣៧៧ |
| និទានថុល្លនន្ទាភិក្ខុនី | ៣៧៧ |
| វារៈដែលមិនត្រូវអាបត្តិ | ៣៧៩ |
| **កុមារីភូតវគ្គ សិក្ខាបទ ទី ១២** | ៣៨០ |
| និទានភិក្ខុនីទាំងឡាយ ឲ្យឧបសម្បទារាល់ឆ្នាំ | ៣៨០ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៨១ |

| | |
|---|---|
| **កុមារីភូតវគ្គ សិក្ខាបទ ទី ១៣** | ៣៨១ |
| និទានភិក្ខុនីទាំងឡាយ | ៣៨១ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៨៣ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ១** | ៣៨៤ |
| និទានឆព្វគ្គិយាភិក្ខុនី | ៣៨៤ |
| សេចក្តីបញ្ញត្តិ - សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៨៥ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ២** | ៣៨៦ |
| និទានឆព្វគ្គិយាភិក្ខុនី | ៣៨៦ |
| សេចក្តីបញ្ញត្តិជាដម្បូង | ៣៨៧ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៨៨ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ៣** | ៣៨៩ |
| និទានភិក្ខុនី ១ រូប | ៣៨៩ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៩០ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ៤** | ៣៩១ |
| និទានឆព្វគ្គិយាភិក្ខុនីទ្រទ្រង់គ្រឿងប្រដាប់ស្ត្រី | ៣៩១ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៩២ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ៥** | ៣៩៣ |
| និទានឆព្វគ្គិយាភិក្ខុនី | ៣៩៣ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៩៤ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ៦** | ៣៩៤ |
| និទានឆព្វគ្គិយាភិក្ខុនី | ៣៩៤ |
| សិក្ខាបទវិភង្គ និងវារៈដែលមិនត្រូវអាបត្តិ | ៣៩៦ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ៧** | ៣៩៦ |
| និទានភិក្ខុនីទាំងឡាយ | ៣៩៦ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣៩៧ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ៨ ៩ ១០** | ៣៩៨ |
| និទានភិក្ខុនីទាំងឡាយ | ៣៩៨ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៣៩៩ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ១១** | ៤០០ |
| និទានភិក្ខុនីទាំងឡាយ មិនប្រាប់ ស្រាប់តែអង្គុយលើអាសនៈខាងមុខ | ៤០០ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៤០១ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ១២** | ៤០២ |
| និទានភិក្ខុនីសួរបញ្ហានឹងភិក្ខុ | ៤០២ |
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៤០៣ |
| **ឆត្តុបាហនវគ្គ សិក្ខាបទ ទី ១៣** | ៤០៤ |
| និទានភិក្ខុនីមួយរូប គ្មានសំពត់ចោមពុង | ៤០៤ |
| | |

| | |
|---|---|
| សេចក្តីបញ្ញត្តិ និងវារៈដែលមិនត្រូវអាបត្តិ | ៤០៥ |
| ឧទ្ទេសាវសាន | ៤០៦ |
| **បាដិទេសនីយកណ្ឌ** | **៤០៧** |
| និទានភិក្ខុនី សូមទឹកដោះរាវឆាន់ | ៤០៧ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ និងវារៈដែលមិនត្រូវអាបត្តិ | ៤០៩ |
| ឧទ្ទេសាវសាន | ៤១៥ |
| **សេក្ខិយកណ្ឌ** | **៤១៦** |
| និទានភិក្ខុនី ស្លៀករយីករយាក | ៤១៦ |
| វារៈដែលមិនត្រូវអាបត្តិ | ៤១៧ |
| សេចក្តីបញ្ញត្តិជាបន្ទាប់ | ៤១៩ |
| ឧទ្ទេសាវសាន | ៤២០ |
| **អធិករណសមថៈ ទីបំផុត** | **៤២១** |
| ឧទ្ទេសាវសាន | ៤២២ |


1)
ជាឈ្មោះនាងវិសាខា។ ក្នុងអដ្ឋកថា ធម្មបទថា ឪពុកក្មេកនាងវិសាខាឈ្មោះមិគារសេដ្ឋី ៗកាលដម្បូងឡើយ ជាមិច្ឆាទិដ្ឋិ ដល់មកថ្ងៃក្រោយ បានស្តាប់ធម៌ព្រះដ៏មានព្រះភាគ ក៏មានសេចក្តីជ្រះថ្លា បានសុំនាងវិសាខាធ្វើជាម្តាយ ហេតុនេះ ទើបគេហៅនាងវិសាខានោះថា មិគារមាតា។
2)
សង្ឃទាំងពីរពួក គឺភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ។
3)
តាំងពីបព្វលេខ៣ ដល់លេខ៤ និយាយអំពីជនទាំងពីរ គឺភិក្ខុនី និងបុរសត្រេកអរដូចគ្នា។
4)
បានជាត្រូវអាបត្តិថុល្លច្ច័យ ព្រោះត្រេកអរទាំងពីរខាង គឺទាំងភិក្ខុនី ទាំងបុរស។
5)
តាំងពីបព្វលេខ៥ ដល់បព្វលេខ៦ និយាយអំពីការត្រេកអរតែម្ខាង គឺតែខាងភិក្ខុនី។
6)
បានជាត្រូវអាបត្តិទុក្កដ ព្រោះត្រេកអរតែម្ខាង គឺតែខាងភិក្ខុនី។
7)
អដ្ឋកថា ថា សេចក្តីវិបត្តិចាកបរិវារ ឬដំនៀលក្នុងទីកំបាំងមុខ។
8)
ដឹងថាត្រូវអាបត្តិហើយ ៗមិនសំដែងអាបត្តិនោះ។
9)
សមណស្រី ហៅថា សមណី។
10)
ភិក្ខុនីធ្វើឲ្យកន្លងគ្រប់ទាំង៨ខ ទើបត្រូវបារាជិក បើកន្លងតែខណាមួយ ហើយដាក់ធុរៈថា លែងឲ្យត្រូវទៀតហើយ ក៏សំដែងអាបត្តិចេញ ដល់ថ្ងៃក្រោយ ត្រូវទៀតដល់ទៅ៧ដងក្តី ក៏មិនជាបារាជិកឡើយ។
11)
សមណៈស្រី ហៅថា សមណី ដូចជាភិក្ខុស្រីៗ ហៅថា ភិក្ខុនីដែរ។
12)
ភិក្ខុនីជាសិស្ស
13)
ប្រាម្ពីលសិក្ខាបទទៀតដែលមិនបានសំដែងនោះ លោកថា ព្រោះដូចគ្នានឹងសិក្ខាបទក្នុងភិក្ខុបាដិមោក្ខហើយ
14)
សំដៅយកភិក្ខុនី ស្រីក្រៅពីភិក្ខុនី ហៅថា អនុបសម្បន្នា។
15)

ប្រហែលជាប្រជុំជនទេដឹង។

16)

គឺភិក្ខុនីត្រូវកាត់សំពត់ឲ្យត្រូវប្រមាណ ហើយសិមសំដែងអាបត្តិទើបបាន

17)

ចីវររបស់ភិក្ខុនីឯទៀត ដែលខ្លួនមិនបានប្រាប់ម្ចាស់ចីវរ ហើយកាន់យកទៅ ត្រូវតែប្រគល់ឲ្យម្ចាស់ចីវរវិញ។ (អដ្ឋកថាវិន័យ)។

18)

ភិក្ខុនីពោលយ៉ាងនេះណា អ្នកទាំងឡាយចូរបង្អង់សិនទៅ ព្រោះឥឡូវនេះ សំពត់ថ្លៃណាស់ ប្រហែលជា២-៣ថ្ងៃទៀតកប្បាសនឹងមកដល់ហើយ ថ្លៃសោតក៏ល្មមសមគួរ ដូច្នេះហើយក៏ហាមឃាត់។ (អដ្ឋកថាវិន័យ)។

19)

ភិក្ខុនីនិយាយពន្យល់ថា សំពត់សាដកតែមួយ នឹងចែកគ្នាមិនគ្រាន់ សូមអស់លោកបង្អង់ចាំបន្តិចសិន ប្រហែល ២-៣ថ្ងៃទៀត សំពត់នឹងកើតឡើងថ្មី សិមយើងចែកគ្នាជាខាងក្រោយ ដូច្នេះ ហៅថាសំដែងអានិសង្ស។ (អដ្ឋកថាវិន័យ)។

20)

ភិក្ខុនីនិយាយថា កប្បាសរបស់គេមុខជានឹងមកដល់ បុរសមានសទ្ធាជ្រះថ្លាមុខជាមកប្រគេនមិនខាន ហៅថា សំដែងអានិសង្សក្នុងសិក្ខាបទនេះ។ (អដ្ឋកថាវិន័យ)។

21)

ភិក្ខុនីសំដែងអានិសង្សថា ភិក្ខុនីសង្ឃមានចីវរគ្រាំគ្រាហើយ មហាលាភមានអានិសង្សកឋិនជាមូល។ (អដ្ឋកថាវិន័យ)។

22)

បុរិមិកវស្សា

23)

បច្ឆិមិកវស្សា

24)

អដ្ឋកថា ថា បានដល់សាលាដ៏វិចិត្រសម្រាប់ស្តេចក្រសាល។

25)

ជើងម៉ា៤ជ្រុងដែលអង្គុយបានតែម្នាក់ ក្នុងអដ្ឋកថា ថា បានដល់អាសនៈកន្លងហួសប្រមាណ។

26)

គ្រែវិចិត្រដោយសត្វសាហាវ

27)

អដ្ឋកថា ថា ភិក្ខុនីដាក់ខាទនីយភោជនីយាហារលើផែនដី ហើយឲ្យដោយពាក្យថា យើងឲ្យរបស់នេះដល់អ្នកទាំងឡាយ

28)

ចីវរដែលទាយកប្រគេនទុកនៅទីកន្លែងសម្រាប់ប្រើប្រាស់ ជាសាធារណដល់ភិក្ខុនីដែលមានរដូវទាំងអស់គ្នា។

29)

គឺភិក្ខុនីរៀនគម្ពីរដទៃៗទៀត ដើម្បីឲ្យដឹងស្គាល់នូវលទ្ធិវិជ្ជាក្នុងគម្ពីរនោះៗ។

30)

អដ្ឋកថា ថា ឱវាទដែលប្រកបដោយប្រយោជន៍ទាំងជ្រៅឆ្ងាយទូលាយ មានរសច្រើន ប្រកបដោយសេចក្តីត្រាស់ដឹងនូវលក្ខណៈ

31)

អាចារ្យស្រីសំដៅយកភិក្ខុនីជាគ្រូសូត្រ។

32)

សាមណេរីដែលនៅប្រព្រឹត្តធម៌៦យ៉ាង បំរុងនឹងឧបសម្បទាជាភិក្ខុនី។

33)

តាំងពីបាណាតិបាតាវេរមណី ទៅដល់វិកាលភោជនាវេរមណីសិក្ខាបទ។

34)

ការសន្មតនូវសិក្ខមានាដែលសមាទានសិក្ខាបទ៦ត្រឹមត្រូវ គ្រប់ពីរឆ្នាំហើយនោះ ឲ្យឈប់ លែងសមាទានតទៅទៀត។

35)

មានសេចក្តីអធិប្បាយក្នុងសង្ឃាទិសេសសិក្ខាបទទី៩ នៃមហាវិភង្គរួចហើយ។

36)

សង្ឃឲ្យឆន្ទៈដោយខានធ្វើសង្ឃកម្មក្នុងពេលដែលប្រជុំដម្បូង តែបម្រុងនឹងធ្វើសង្ឃកម្មក្នុងពេលក្រោយទៀត តែអដ្ឋកថា ថា ភិក្ខុទាំងឡាយប្រជុំគ្នាបម្រុងនឹងធ្វើសង្ឃកម្មអ្វីម្យ៉ាង មានភ្លៀងតាំងឡើងក្តី មានអាជ្ញាស្តេចមកបណ្តេញក្តី មានពួកមនុស្សមកគ្របសង្កត់ក្តី ពួកភិក្ខុក៏គិតគ្នាថា ថ្ងៃនេះគ្មានឱកាស យើងនាំគ្នាទៅទីដទៃចុះ ហើយមិនទាន់លះបង់ឆន្ទៈ ក៏ក្រោកចេញទៅ យ៉ាងនេះហៅថា បរិសបរិវាសិយ។ ឯយោជនា ថា បារិសសិយឆន្ទទាន គឺភិក្ខុនីឲ្យឧបសម្បទាដល់សិក្ខមានាដោយបរិសទ្យមិនគាប់ចិត្ត (គឺជំនុំសង្ឃមិនយល់ព្រម)។

37)

មានសេចក្ដីអធិប្បាយពិស្ដារក្នុងមហាវិភង្គចតុត្ថភាគរួចហើយ។

-Namo tassa bhagavato arahato sammā-

ព្រះត្រៃបិដកភាសាខ្មែរ - **Tipiṭaka Khmer language**

ភាគ ០០៦ - Book 006

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថាលោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០៦ - Tipitaka Book 006 [http://forum.sangham.net/index.php/topic,8915.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០០៦

ភាគ ទី ០០៥ | **មាតិកា** | ភាគ ទី ០០៧




គំរូ ឯកសារ ផ្សេងទៀត៖
book_006.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី៦

ទ. ៗ

# វិន័យបិដក

CS vin | ភាគ ទី៦

**ភាគ ទី៦**

# មហាវគ្គ

CS vin.mv | ភាគ ទី៦

**បឋមភាគ**
(ភាគ ទី១)

មហាខន្ធកៈ - ឧបោសថក្ខន្ធកៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

## មហាខន្ធកៈ

CS vin.mv.01 | ភាគ ទី៦

### ១. ពោធិកថា

CS vin.mv.01.01 | ភាគ ទី៦

**(ពោធិកថា (១.))**

[១] សម័យនោះ ព្រះសម្ពុទ្ធដ៏មានជោគ បានត្រាស់ដឹងជាដម្បូង ទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់គង់ដោយព្រះភ្លែនតែមួយអស់៧ថ្ងៃ ក្រោមម្លប់ពោធិព្រឹក្ស ទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ)។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមប្បដិលោម គឺពិចារណាបណ្ដោយចុះ និងច្រាសឡើង
អស់បឋមយាមនៃរាត្រី ដោយន័យថា សង្ខារ[1] ទាំងឡាយកើតមាន ព្រោះមានអវិជ្ជា[2] ជាហេតុ វិញ្ញាណកើតមាន ព្រោះមានសង្ខារជាហេតុ ទ. ២
នាមរូបកើតមាន ព្រោះមានវិញ្ញាណជាហេតុ សឡាយតនៈកើតមាន ព្រោះមាននាមរូបជាហេតុ ផស្សៈកើតមាន ព្រោះមានសឡាយតនៈជាហេតុ វេទនាកើតមាន ព្រោះមានផស្សៈជាហេតុ តណ្ហាកើតមាន ព្រោះមានវេទនាជាហេតុ ឧបាទានកើតមាន ព្រោះមានតណ្ហាជាហេតុ ភពកើតមាន ព្រោះមានឧបាទានជាហេតុ ជាតិកើតមាន ព្រោះមានភពជាហេតុ សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ទាំងឡាយកើតមាន ព្រោះមានជាតិជាហេតុ សេចក្ដីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ម្យ៉ាងទៀតសេចក្ដីរលត់សង្ខារកើតមាន ព្រោះវិនាសនិងរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្ដីរលត់វិញ្ញាណកើតមាន ព្រោះរលត់សង្ខារ សេចក្ដីរលត់នាមរូបកើតមាន ព្រោះរលត់វិញ្ញាណ សេចក្ដីរលត់សឡាយតនៈកើតមាន ព្រោះរលត់នាមរូប សេចក្ដីរលត់ផស្សៈកើតមាន ព្រោះរលត់សឡាយតនៈ
សេចក្ដីរលត់វេទនាកើតមាន ព្រោះរលត់ផស្សៈ សេចក្ដីរលត់តណ្ហាកើតមាន ព្រោះរលត់វេទនា សេចក្ដីរលត់ឧបាទានកើតមាន ព្រោះរលត់ ទ. ៣
តណ្ហា សេចក្ដីរលត់ភពកើតមាន ព្រោះរលត់ឧបាទាន សេចក្ដីរលត់ជាតិកើតមាន ព្រោះរលត់ភព សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងចង្អៀតចង្អល់ចិត្តទាំងឡាយក៏សឹងតែរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្ដីរលត់នៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនេះហើយ ទើបបន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា

ធម៌[3] ទាំងឡាយ រមែងប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្ដៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា សេចក្ដីសង្ស័យទាំងឡាយទាំងពួងរបស់ខីណាសវព្រាហ្មណ៍នោះក៏សឹងតែរម្ងាប់អស់ទៅក្នុងកាលនោះ ព្រោះថា ខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់នូវធម៌ព្រមទាំងហេតុ។

[២] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមប្បដិលោម គឺពិចារណាបណ្ដោយចុះ និងច្រាសឡើង អស់
មជ្ឈិមយាមនៃរាត្រី ដោយន័យថា សង្ខារទាំងឡាយកើតមាន ព្រោះមានអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះមានសង្ខារជាបច្ច័យ នាមរូប ទ. ៤
កើតមាន ព្រោះមានវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះមាននាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះមានសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះមានផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះមានវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះមានតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះមានឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះមានភពជាបច្ច័យ សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតណែនក្នុងចិត្តទាំងឡាយកើតមាន ព្រោះមានជាតិជាបច្ច័យ សេចក្ដីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងកើតមានយ៉ាងនេះឯង ម្យ៉ាងទៀត សេចក្ដីរលត់សង្ខារកើតមាន ព្រោះវិនាសនិងរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្ដីរលត់វិញ្ញាណកើតមាន ព្រោះរលត់សង្ខារ សេចក្ដីរលត់នាមរូបកើតមាន ព្រោះរលត់វិញ្ញាណ សេចក្ដីរលត់សឡាយតនៈកើតមាន ព្រោះរលត់នាមរូប សេចក្ដីរលត់ផស្សៈកើតមាន ព្រោះរលត់សឡាយតនៈ សេចក្ដីរលត់វេទនាកើតមាន ព្រោះរលត់ផស្សៈ សេចក្ដីរលត់តណ្ហាកើតមាន ព្រោះរលត់វេទនា សេចក្ដីរលត់ឧបាទានកើតមាន ព្រោះរលត់តណ្ហា សេចក្ដីរលត់ភពកើតមាន ព្រោះរលត់ឧបាទាន សេចក្ដីរលត់ជាតិកើតមាន ព្រោះរលត់ភព សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ
លំបាកចិត្ត និងចង្អៀតចង្អល់ចិត្តទាំងឡាយក៏សឹងតែរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្ដីរលត់នៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាង ទ. ៥
នេះឯង។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនេះហើយ ទើបបន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា

ធម៌ទាំងឡាយ ប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្ដៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា សេចក្ដីសង្ស័យទាំងឡាយទាំងពួងរបស់ខីណាសវព្រាហ្មណ៍នោះ តែងរម្ងាប់អស់ទៅក្នុងកាលនោះ ព្រោះថា ខីណាសវព្រាហ្មណ៍នោះ បានដឹងច្បាស់នូវព្រះនិព្វានជាទីអស់ទៅនៃបច្ច័យ។

[៣] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមប្បដិលោម គឺពិចារណាបណ្ដោយចុះ និងច្រាសឡើង អស់បច្ឆិមយាមនៃរាត្រី ដោយន័យថា សង្ខារទាំងឡាយកើតមាន ព្រោះមានអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះមានសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះមានវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះមាននាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះមានសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះមានផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះមានវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះមានតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះ
មានឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះមានភពជាបច្ច័យ សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និង ទ. ៦
ចង្អៀតណែនក្នុងចិត្តទាំងឡាយកើតមាន ព្រោះមានជាតិជាបច្ច័យ សេចក្ដីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ម្យ៉ាងទៀត សេចក្ដីរលត់សង្ខារកើតមាន ព្រោះវិនាសនិងរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្ដីរលត់វិញ្ញាណកើតមាន ព្រោះរលត់សង្ខារ សេចក្ដីរលត់នាមរូបកើតមាន ព្រោះរលត់វិញ្ញាណ សេចក្ដីរលត់សឡាយតនៈកើតមាន ព្រោះរលត់នាមរូប សេចក្ដីរលត់ផស្សៈកើតមាន ព្រោះរលត់សឡាយតនៈ សេចក្ដីរលត់វេទនាកើតមាន ព្រោះរលត់ផស្សៈ សេចក្ដីរលត់តណ្ហាកើតមាន ព្រោះរលត់វេទនា សេចក្ដីរលត់ឧបាទានកើតមាន ព្រោះរលត់តណ្ហា សេចក្ដីរលត់ភពកើតមាន ព្រោះរលត់ឧបាទាន សេចក្ដីរលត់ជាតិកើតមាន ព្រោះរលត់ភព សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏សឹងតែរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្ដីរលត់នៃកងទុក្ខទាំងអស់នេះ
រមែងមានយ៉ាងនេះឯង។គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនេះហើយ ក៏បន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា ទ. ៧

ធម៌ទាំងឡាយ ប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា ខីណាសវព្រាហ្មណ៍នោះ រមែងកំចាត់បង់នូវមារ ព្រមទាំងសេនាមារ ហើយឋិតនៅក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើង ធ្វើអាកាសឲ្យរុងរឿងដោយរស្មីរបស់ខ្លួន កំចាត់បង់នូវងងឹត ឋិតនៅ ដូច្នោះឯង។

ចប់ ពោធិកថា ។

## ២. អជបាលកថា

CS vin.mv.01.02 | ភាគ ទី៦

### (អជបាលនិគ្រោធកថា (២.))

[៤] លុះថ្ងៃ៧កន្លងទៅហើយ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកសមាធិនោះ ហើយទ្រង់ចេញពីម្លប់ពោធិព្រឹក្ស យាងចូលទៅកាន់ដើមអជបាលនិគ្រោធ លុះចូលទៅដល់ហើយ ទ្រង់គង់ពែនភ្នែនតែមួយ បង្គុយអស់៧ថ្ងៃ ក្រោមម្លប់អជបាលនិគ្រោធព្រឹក្ស[4] សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ)។

គ្រានោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះហុំហុំកជាតិកៈ (មានជាតិជាអ្នកធ្វើនូវសំឡេងគម្រាមថា ហុំហុំ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយមួយអន្លើដោយព្រះដ៏មានព្រះភាគ លុះធ្វើពាក្យគួរជាទីរីករាយ គួរជាទីរលឹកឲ្យសម្រេចហើយ ក៏ឋិតនៅក្នុងកន្លែងដ៏សមគួរ។ លុះព្រាហ្មណ៍នោះ ឋិតនៅក្នុងកន្លែងដ៏សមគួរហើយ ទើបនិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលដែលបានឈ្មោះថាព្រាហ្មណ៍ ដោយហេតុប៉ុន្មានយ៉ាង ម្យ៉ាងទៀត ធម៌អ្វីខ្លះសម្រាប់ធ្វើបុគ្គលឲ្យជាព្រាហ្មណ៍។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ ក៏បន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា ទ. ៤

ព្រាហ្មណ៍ណាមានបាបធម៌បណ្តែតចោលហើយ មានសំឡេងគម្រាមថា ហុំហុំ លះចោលហើយ មានទឹកម្ចត់គឺរាគាទិក្កិលេសលះចោលហើយ មានចិត្តសង្រួមហើយ ចេះចប់នូវវេទ (គឺមគ្គញាណទាំង៤) មានមគ្គព្រហ្មចរិយៈ នៅរួចហើយ ម្យ៉ាងទៀត ព្រាហ្មណ៍ណា មិនមានគំនរ គឺរាគាទិក្កិលេសក្នុងអារម្មណ៍បន្តិចបន្តួចក្នុងលោកសន្និវាស ព្រាហ្មណ៍នោះ គួរនឹងហៅខ្លួនថា ជាព្រាហ្មណ៍ដោយធម៌បាន។

ចប់ អជបាលនិគ្រោធកថា។

ទ. ៥

## ៣. មុចលិន្ទកថា

CS vin.mv.01.03 | ភាគ ទី៦

### (មុចលិន្ទកថា (៣.))

[៥] លុះថ្ងៃ៧កន្លងទៅហើយ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ក្រោកចាកសមាធិនោះ ហើយទ្រង់ចេញអំពីម្លប់អជបាលនិគ្រោធព្រឹក្ស យាងចូលទៅកាន់ដើមរាំង លុះចូលទៅដល់ហើយ ទ្រង់គង់ដោយព្រះភ្នែនតែមួយ បង្គុយអស់៧ថ្ងៃក្រោមម្លប់រាំង សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ)។

សម័យនោះឯង មហាមេឃពុំជួកាល ក៏បណ្តាលឡើងជាភ្លៀង។ មានភ្លៀងរលឹមអស់៧ថ្ងៃ បណ្តាលឲ្យអាប់ពន្លឺព្រះអាទិត្យ ដោយអំណាចខ្យល់ត្រជាក់។ គ្រានោះ មុចលិន្ទនាគរាជចេញអំពីលំនៅរបស់ខ្លួន ហើយពេនព័ទ្ធព្រះកាយព្រះដ៏មានព្រះភាគ៧ជុំ ដោយភ្នែន (របស់ខ្លួន) ហើយលើកពពារដ៏ធំបាំងពីខាងលើព្រះសីរ្សព្រះដ៏មានព្រះភាគ ហើយឋិតនៅដោយគិតថា រងាកុំបីបៀតបៀនព្រះដ៏មានព្រះភាគ ក្តៅក៏កុំបីបៀតបៀនព្រះដ៏មានព្រះភាគ សម្ផស្ស របោមមូស ខ្យល់ កំដៅថ្ងៃ ពស់តូច ពស់ធំ ក៏កុំបីបៀតបៀនព្រះដ៏មានព្រះភាគឡើយ។ លុះថ្ងៃ៧កន្លងទៅហើយ លំដាប់នោះ មុចលិន្ទនាគរាជដឹងថា ភ្លៀងរាំងហើយ មេឃស្រឡះហើយ ក៏រំសាយភ្នែនចេញចាកព្រះកាយព្រះដ៏មានព្រះភាគ ហើយប្រែភេទរបស់ខ្លួននិម្មិតជាភេទមាណព[5] ឈរប្រណម្យអញ្ជលី នមស្ការព្រះដ៏មានព្រះភាគពីខាងទីចំពោះព្រះភក្ត្រព្រះអង្គ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបសេចក្តីនេះហើយ ក៏បន្លឺនូវឧទានគាថា ក្នុងវេលានោះថា ទ. ១០

សេចក្តីស្ងាត់ចាកកិលេសរបស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គញ្ញាណ) មានធម៌ប្រាកដហើយ បានឃើញធម៌ (ដោយញាណចក្ខុ) ជាគុណឲ្យកើតសេចក្តីសុខ សេចក្តីមិនព្យាបាទ និងសេចក្តីសង្រួម មិនបៀតបៀនសត្វទាំងឡាយ ក៏ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក សេចក្តីណាយចាករាគៈ និងការប្រព្រឹត្តកន្លងកាមទាំងឡាយ ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក កិរិយាកំចាត់បង់នូវអស្មិមានះ កិរិយាកំចាត់បង់នូវអស្មិមានះនុ៎ះ ជាសុខយ៉ាងក្រៃលែង។

ចប់ មុចលិន្ទកថា។

## ៤. រាជាយតនកថា

CS vin.mv.01.04 | ភាគ ទី៦

### (រាជាយតនកថា (៤.))

[៦] លុះថ្ងៃ៧កន្លងទៅហើយ លំដាប់នោះ ព្រះដ៏មានជោគ ទ្រង់ក្រោកចេញចាកសមាធិនោះហើយ យាងចេញពីម្លប់ដើមរាំង ទ. ១៦
ហើយយាងចូលទៅកាន់ដើមរាជាយតនៈ[6] លុះចូលទៅដល់ហើយ ទ្រង់គង់ដោយព្រះភ្នែនតែមួយ បង្អុយអស់៧ថ្ងៃក្រោមម្លប់ដើមរាជាយតនៈ ទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ)។

សម័យនោះឯង មានពាណិជពីរនាក់ (ជាបងប្អូននឹងគ្នាបង្កើត) ឈ្មោះតបុស្សៈ១ ភល្លិកៈ១ ជាអ្នកដើរផ្លូវឆ្ងាយ ចេញអំពីឧក្កលជនបទ សំដៅទៅកាន់ប្រទេសនោះ។ គ្រានោះ មានទេវតាជាញាតិសាលោហិត[7] របស់តបុស្សៈ និងភល្លិកៈពាណិជ បាននិយាយពាក្យនេះនឹងតបុស្សៈ ភល្លិកៈពាណិជថា ម្នាលគ្នាយើង ព្រះដ៏មានព្រះភាគអង្គនេះ ទើបនឹងបានត្រាស់ជាដម្បូង ឥឡូវព្រះអង្គគង់នៅក្រោមម្លប់រាជាយតនៈ (ឯណោះ) អ្នកទាំងឡាយ គួរចូលទៅបូជាព្រះដ៏មានព្រះភាគអង្គនោះដោយសដូវផង់ និងសដូវដុំចុះ ការបូជានោះនឹងបានជាប្រយោជន៍ និងសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលយូរអង្វែង។ គ្រានោះ តបុស្សៈ និងភល្លិកៈពាណិជ ក៏នាំយកនូវសដូវផង់ និងសដូវដុំចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងកន្លែងដ៏សមគួរ។ លុះតបុស្សៈ និងភល្លិកៈពាណិជឋិតនៅក្នុងកន្លែងដ៏សមគួរ
ហើយ ទើបពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទទួលនូវសដូវផង់ និងសដូវដុំរបស់ ទ. ១៧
យើងខ្ញុំ ព្រោះថា ការទទួលនឹងបានជាប្រយោជន៍ និងសេចក្តីសុខដល់យើងខ្ញុំទាំងឡាយអស់កាលយូរអង្វែង។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះថា ធម្មតា ព្រះតថាគតទាំងឡាយមិនដែលទទួល (អាមិសៈ) ផ្ទាល់នឹងដៃឡើយ បើដូច្នោះ តើ តថាគតគួរទទួលនូវសដូវផង់ និងសដូវដុំដោយវត្ថុអ្វីហ្ន៎។ គ្រានោះ មហារាជ[8] ទាំង៤ ទ្រង់ជ្រាបព្រះតម្រិះរបស់ព្រះដ៏មានព្រះភាគ (ដោយចិត្តរបស់ខ្លួន) ទើបនាំនូវបាត្រថ្មកែវទាំងឡាយ៤ អំពីទិសទាំង៤ បង្អោនចូលមកថ្វាយព្រះដ៏មានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទទួលនូវសដូវផង់ និងសដូវដុំដោយបាត្រនេះចុះ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលនូវសដូវផង់ និងសដូវដុំ ដោយបាត្រថ្មកែវទាំងឡាយដ៏មានដំឡៃច្រើន លុះទទួលស្រេចហើយ ក៏ទ្រង់សោយ (ក្នុងពេលនោះ)។ គ្រានោះ តបុស្សៈ និងភល្លិកៈពាណិជបាននិយាយពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន យើងខ្ញុំទាំងឡាយនេះ សូមដល់នូវព្រះដ៏មានព្រះភាគ និងព្រះធម៌ជាទីរឭក សូមព្រះអង្គទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថា
ជាឧបាសកបានដល់នូវទីរឭកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមតរៀងទៅ។ ក៏ឯពាណិជទាំងពីរនាក់នោះបាននាមបញ្ញត្តិថា ទ្វេ ទ. ១៨
វាចិកឧបាសក[9] ជាដម្បូងក្នុងលោក។

ចប់ រាជាយតនកថា។

## ៥. ព្រហ្មយាចនកថា

CS vin.mv.01.05 | ភាគ ទី៦

### (ព្រហ្មយាចនកថា (៥.))

[៧] លុះថ្ងៃ៧កន្លងទៅហើយ លំដាប់នោះ ព្រះមានជោគ ទ្រង់ក្រោកចាកសមាធិនោះ ហើយយាងចេញអំពីក្រោមម្លប់រាជាយតនៈ ហើយយាងចូលទៅកាន់ដើមអជបាលនិគ្រោធវិញ។ បានឮថា ព្រះដ៏មានព្រះភាគ ក៏គង់នៅក្រោមម្លប់អជបាលនិគ្រោធនោះ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ គង់សម្ងំនៅក្នុងទីស្ងាត់តែមួយព្រះអង្គ ទើបទ្រង់ព្រះតម្រិះយ៉ាងនេះថា ក៏ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌គឺសត្វឃើញបានដោយកម្រ ជាធម៌ គឺសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ដ៏ឧត្តម ជាធម៌ដែលសត្វមិនគប្បីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត ជាធម៌ លុះតែអ្នកប្រាជ្ញទើបត្រាស់ដឹងបាន ក៏ឯពពួកសត្វនេះ សុទ្ធតែនៅកំពុងរីករាយក្នុងសេចក្តីអាល័យ កំពុងត្រេកត្រអាលក្នុងសេចក្តីអាល័យ កំពុងស្រើបស្រាលក្នុងសេចក្តីអាល័យ (ចំពោះកាមទាំងឡាយនៅឡើយ) ក៏បដិច្ចសមុប្បាទធម៌
គឺធម៌ជាបច្ច័យនៃគ្នានឹងគ្នាណា បដិច្ចសមុប្បាទធម៌នេះ ជាហេតុនាំឲ្យពពួកសត្វនៅរីករាយក្នុងសេចក្តីអាល័យ នៅត្រេកត្រអាលក្នុង ទ. ១៩
សេចក្តីអាល័យ នៅស្រើបស្រាលក្នុងសេចក្តីអាល័យ ឃើញបានដោយកម្រ ម្យ៉ាងទៀត ធម៌ណាសម្រាប់រម្ងាប់បង់នូវសង្ខារទាំងពួង សម្រាប់លះចោលនូវឧបធិ គឺខន្ធ និងកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីណាយចាករាគៈ ជាទីរលត់នៃទុក្ខគឺនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុដែលពពួកសត្វឃើញបានដោយកម្រក្រៃពេក បើទុកជាតថាគតសំដែងធម៌ទៅ ក៏គង់សត្វទាំងឡាយដទៃមិនអាចនឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ ព្រោះហេតុនោះ សេចក្តីលំបាក សេចក្តីនឿយព្រួយ មុខជានឹងមានដល់តថាគតមិនខាន។ ម្យ៉ាងទៀត ព្រះគាថាទាំងឡាយជាហេតុអស្ចារ្យសមគួរនេះ ព្រះដ៏មានព្រះភាគមិនដែលបានឮក្នុងកាលមុនឡើយ ក៏កើតប្រាកដដល់ព្រះអង្គថា

ឥឡូវនេះ តថាគតគួរសំដែងនូវធម៌ដែលតថាគតបានត្រាស់ដឹងហើយដោយកម្រ (នុ៎ះទៅចុះ)។ ប៉ុន្តែសត្វទាំងឡាយដែលរាគៈទោសៈ គ្របសង្កត់ ក៏មិនអាចនឹងត្រាស់ដឹងនូវធម៌នេះបានដោយងាយទេ។ សត្វទាំងឡាយដែលកំពុងត្រេកអរដោយរាគៈ ដែលគំនរងងឹត (គឺអវិជ្ជា) កំពុងបិទបាំង (យ៉ាងនេះ) មុខជានឹងមិនឃើញនូវធម៌ដែលនាំសត្វឲ្យដល់នូវព្រះនិព្វាន ជាធម៌ល្អិតឆ្មារ ជ្រាលជ្រៅ សត្វឃើញបានដោយកម្រ (នុ៎ះទេ)។

កាលដែលព្រះដ៏មានព្រះភាគពិចារណាឃើញ ដោយន័យដែលត្រិះរិះដូច្នេះហើយ ព្រះហឫទ័យក៏ឱនទៅដើម្បីសេចក្ដីខ្វល់ខ្វាយតិច ទ. ១៥
មិនឱនទៅដើម្បីសំដែងធម៌ឡើយ។

[៨] លំដាប់នោះ សហម្បតិព្រហ្ម ដឹងនូវសេចក្ដីត្រិះរិះក្នុងព្រះហឫទ័យរបស់ព្រះដ៏មានព្រះភាគដោយចិត្តរបស់ខ្លួនហើយ ទើបរំពឹងត្រិះរិះដូច្នេះថា អើហ្ន៎ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ មានព្រះហឫទ័យឱនទៅដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសំដែងធម៌ (យ៉ាងនេះ) ឱ សត្វលោកវិនាសតើហ្ន៎ ឱ សត្វលោកវិនាសតើហ្ន៎។ គ្រានោះ សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ (ដោយឆាប់ភ្លាម) ប្រៀបដូចបុរសអ្នកមានកំឡាំង លាចេញនូវដើមដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដើមដៃដែលខ្លួនលាចេញ។ លំដាប់នោះ សហម្បតិព្រហ្មធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ហើយលុតចុះនូវមណ្ឌលជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលី ថ្វាយបង្គំចំពោះត្រង់ព្រះដ៏មានព្រះភាគ ទើបពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគសំដែងធម៌ សូមព្រះសុគតសំដែងធម៌ (ដ្បិត) សត្វទាំងឡាយដែលមានធូលី គឺរាគាទិក្កិលេសដ៏ស្រាលស្តើងក្នុងភ្នែក គឺបញ្ញា តែខានស្តាប់ធម៌ ក៏មុខជានឹងសាបសូន្យ ទ. ១៦
មិនខាន សត្វទាំងឡាយ អ្នកបម្រុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ។ សហម្បតិព្រហ្មបានពោលពាក្យនេះ (ប៉ុណ្ណោះ) លុះពោលពាក្យនេះរួចហើយ ក៏ពោលពាក្យដទៃតទៅទៀតថា

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយអ្នកប្រកបដោយមន្ទិល តែងគិត ជាធម៌មិនបរិសុទ្ធទេ កើតប្រាកដហើយក្នុងដែនមគធៈ។ សូមព្រះអង្គបើកនូវទ្វារនៃព្រះនិព្វាននុ៎ះ សត្វទាំងឡាយប្រុងចាំស្តាប់ធម៌ដែលព្រះអង្គជាអ្នកប្រាសចាកមន្ទិល ទ្រង់ត្រាស់ដឹងតាម (លំអានព្រះពុទ្ធអំពីបូរាណ)។ ប្រៀបដូចជាបុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំដ៏ហើយដោយថ្មសុទ្ធ ក្រឡេកមើលឃើញប្រជុំជនដោយជុំវិញយ៉ាងណាមិញ បពិត្រព្រះអង្គមានបញ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គជាអ្នកមានសេចក្ដីសោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទដ៏ហើយដោយធម៌ ពិចារណាមើលនូវប្រជុំជនអ្នកច្រឡំដោយសេចក្ដីសោកដែលជាតិ ជរាកំពុងគ្របសង្កត់ មានឧបមាដូច្នោះដែរ។ បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាមហើយ ជានាយកនៃពួកសត្វ អ្នកមិនជាប់ ទ. ១៧
ជំពាក់បំណុល គឺកាម សូមព្រះអង្គក្រោកឡើង សូមទ្រង់ស្តេចទៅក្នុងលោក។ សូមព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម៌ សត្វទាំងឡាយអ្នកបំរុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ។

[៩] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបច្បាស់នូវសេចក្ដីអារាធនារបស់សហម្បតិព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្ដីករុណាចំពោះសត្វទាំងឡាយផង ទើបទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ។ ព្រះដ៏មានព្រះភាគ កាលទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយ មានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែក (ខ្លះ) មានធូលី គឺរាគាទិក្កិលេសច្រើនក្នុងភ្នែក(ខ្លះ) មានឥន្ទ្រិយរឹង(ខ្លះ) មានឥន្ទ្រិយទន់(ខ្លះ) មានអាការល្អ(ខ្លះ) មានអាការអាក្រក់(ខ្លះ) ជាសត្វដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយ(ខ្លះ) ឲ្យត្រាស់ដឹងបានដោយកម្រ(ខ្លះ) ជាអ្នកឃើញបរលោក និងទោសដោយសភាពគួរខ្លាចខ្លះ។ (សេចក្ដីប្រៀបថា) មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី ក្នុងគុម្ពនៃព្រលិតក្ដី ក្នុងគុម្ពនៃឈូកក្រហមក្ដី ក្នុងគុម្ពនៃឈូកសក្ដី តែងកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក លូតលាស់ឡើង ទ. ១៨
តាមទឹក លិចនៅក្នុងទឹកនៅឡើយ មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី តែងកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី តែងកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក ដុះខ្ពស់ឡើងជាងទឹក មិនជាប់ជំពាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ព្រះដ៏មានព្រះភាគ កាលទ្រង់រមិលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយ មានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែក (ខ្លះ) មានធូលី គឺរាគាទិក្កិលេសច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយរឹង(ខ្លះ) មានឥន្ទ្រិយទន់(ខ្លះ) មានអាការល្អ (ខ្លះ) មានអាការមិនល្អ(ខ្លះ) ជាសត្វដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយកម្រ(ខ្លះ) សត្វចំពួកខ្លះ ឃើញបរលោក និងទោសដោយសភាពគួរខ្លាច មានឧបមេយ្យដូច្នោះឯង លុះទ្រង់ឃើញហើយ ទើបទ្រង់សំដែងជាបទគាថានឹងសហម្បតិព្រហ្មថា

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ សត្វទាំងឡាយណាមានសោតប្បសាទ សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធាចុះ។ ទ. ១៩
ម្នាលមហាព្រហ្ម តថាគតមានសេចក្ដីសំគាល់ក្នុងការលំបាក បានជាមិនសំដែងធម៌ដ៏ឧត្តម ដែលស្ទាត់ក្នុងសំណាក់មនុស្សទាំងឡាយ។

គ្រានោះ សហម្បតិព្រហ្មគិតថា ខ្លួនអញជាបុគ្គលគឺព្រះដ៏មានព្រះភាគទ្រង់យល់ព្រមដើម្បីនឹងសំដែងធម៌ហើយ (លុះគិតដូច្នេះហើយ) ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយក៏បាត់អំពីទីនោះមួយរំពេចទៅ។

ចប់ ព្រហ្មយាចនកថា។

## ៦. បញ្ចវគ្គិយកថា

CS vin.mv.01.06 | ភាគ ទី៦

**(៦.)**

[១០] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា តថាគតគួរសំដែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណាអាចត្រាស់ដឹងធម៌នេះឆាប់រហ័សបាន។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះទៀតថា អាឡារតាបសកាលាមគោត្រនេះជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាស វាងវៃ ជា

អ្នកមានបញ្ញា មានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកយូរមកហើយ បើដូច្នោះ គួរតថាគតសំដែងធម៌ដល់អាឡារតាបសកាលាមគោត្រជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន។ គ្រានោះ មានទេវតា (អង្គមួយ) មានរូបមិនប្រាកដ ក្រាបទូលព្រះដ៏មានព្រះភាគដោយ ទ. ២០ ពាក្យថា បពិត្រព្រះអង្គដ៏ចំរើន អាឡារតាបសកាលាមគោត្រធ្វើកាលកិរិយាស្លាប់ទៅ៧ថ្ងៃហើយ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ជ្រាបថា អាឡារតាបសកាលាមគោត្រធ្វើកាលកិរិយាស្លាប់ទៅ៧ថ្ងៃហើយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា អាឡារតាបសកាលាមគោត្រ (នុ៎ះ) មានសេចក្តីសាបសូន្យធំ ប្រសិនបើតាបសនោះបានស្តាប់ធម៌នេះ ក៏គប្បីត្រាស់ដឹងធម៌បានមួយរំពេច។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា តថាគតសំដែងធម៌ដល់អ្នកណាជាមុនអេះ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័យបាន។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ព្រះតម្រិះក្នុងលំដាប់នោះទៀតថា ឧទ្ទកតាបសរាមបុត្រនេះឯង ជាបណ្ឌិត ជាអ្នកឆ្លៀវឆ្លាស វាងវៃ ជាអ្នកមានបញ្ញា មានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកយូរណាស់មកហើយ បើដូច្នោះ គួរតថាគតសំដែងធម៌ដល់ឧទ្ទកតាបសរាមបុត្រជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័យបាន។ គ្រានោះ មានទេវតា (អង្គមួយ) មានរូបមិនប្រាកដ ក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន ឧទ្ទកតាបសរាមបុត្រធ្វើកាលកិរិយាស្លាប់អំពីពេលព្រលប់ទៅហើយ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ជ្រាបថា ឧទ្ទកតាបសរាមបុត្រធ្វើកាលកិរិយាស្លាប់អំពីពេលព្រលប់ហើយដែរ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា ឧទ្ទកតាបសរាមបុត្រ មានសេចក្តីសាបសូន្យធំ ប្រសិនបើតាបសនោះបានស្តាប់ធម៌នេះ គប្បីត្រាស់ដឹងធម៌បានមួយរំពេច។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា តថាគតគួរសំដែងធម៌ដល់ ទ. ២១ អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័យបាន។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះតម្រិះដូច្នេះក្នុងលំដាប់នោះថា បញ្ចវគ្គិយ[10] ភិក្ខុទាំងឡាយ មានឧបការៈច្រើនដល់តថាគត ព្រោះថា បានបម្រើតថាគត កាលដែលកំពុងបញ្ជូនចិត្តទៅក្នុងព្យាយាម[11] បើដូច្នោះ គួរតថាគតសំដែងធម៌ដល់បញ្ចវគ្គិយភិក្ខុទាំងឡាយជាមុនចុះ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះតម្រិះដូច្នេះថា ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងឡាយ នៅឯណា។ លុះព្រះដ៏មានព្រះភាគ ទ្រង់ឃើញបញ្ចវគ្គិយភិក្ខុទាំងឡាយនៅក្នុងឥសិបតនមិគទាយវន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធស្អាត កន្លងលើសចក្ខុរបស់មនុស្ស។ គ្រានោះ ព្រះដ៏មានព្រះភាគ គង់នៅក្នុងឧរុវេលាប្រទេស តាមសមគួរដល់ព្រះអធ្យាស្រ័យ ទើបទ្រង់យាងទៅកាន់ចារិក សំដៅទៅរកក្រុងពារាណសី។

[១១] មានអាជីវកម្នាក់ឈ្មោះឧបកៈ បានឃើញព្រះដ៏មានព្រះភាគ ស្តេចទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃគយាប្រទេសផង ក្នុង ទ. ២២ ចន្លោះពោធិព្រឹក្សផង លុះឃើញហើយ ក៏ពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នកជ្រះថ្លាណាស់ ឆវិវណ្ណ[12] របស់អ្នកក៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្តនឹងធម៌របស់គ្រូណា។ កាលឧបកាជីវកសួរយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់ឆ្លើយតបដោយពាក្យជាគាថាទៅរកឧបកាជីវកថា

> តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់ បានលះចោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯង (ចាំបាច់) ចំពោះបុគ្គលណា។ តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹងតថាគតឡើយ ក្នុងលោកនេះ ព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ។ ព្រោះថា តថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត ជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះខ្លួនឯង តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់ហើយ។
>
> ឥឡូវតថាគតទៅកាន់ក្រុងនៃពួកជនអ្នកកាសី ដើម្បីនឹងសំដែងធម្មចក្ក (ដោយបំណងថា) តថាគតនឹងទូងនូវស្គរ គឺអមតនិព្វានចំពោះសត្វលោក ដែលងងឹត គឺអវិជ្ជាកំពុងគ្របសង្កត់។

ឧបកាជីវកក៏តបថា ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នកថាយ៉ាងណា អ្នក(គួរដើម្បីបាននូវឈ្មោះ)ថា អនន្តជិនៈ (យ៉ាងនោះឯង)។ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះពុទ្ធដីកាទៀតថា។

> ជនទាំងឡាយណាបានដល់នូវធម៌សម្រាប់ធ្វើអាសវៈឲ្យអស់ទៅ ជនទាំងឡាយនោះឈ្មោះថា ជិនៈ (ជាអ្នកឈ្នះកិលេស) ប្រាកដដូចជាតថាគតដែរ។ តថាគតបានឈ្នះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគតបាននូវឈ្មោះថា ជិនៈ (ជាអ្នកឈ្នះបាបធម៌)។

កាលព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ឧបកាជីវកពោលពាក្យថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹង ពិតមែនហើយ (ថាហើយ) ក៏ងក់ក្បាល ហើយកាន់យកផ្លូវខុស (គឺដើរបែកផ្លូវគ្នា) ចៀសចេញទៅ។

[១២] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ហើយក៏យាងចូលទៅក្រុងពារាណសី រួចហើយ ទ្រង់យាងទៅឯឥសិបតនមិគទាយវន សំដៅទៅរកកន្លែងដែលបញ្ចវគ្គិយភិក្ខុនៅ។ បញ្ចវគ្គិយភិក្ខុបានឃើញព្រះដ៏មានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយ ក៏ធ្វើប្តេជ្ញាគ្នាថា ម្នាលអាវុសោ សមណគោតមនេះជាអ្នកប្រតិបត្តិដើម្បីល្មោភ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់ដើម្បីភាវៈល្មោភ ឥឡូវនេះ លោកនិមន្តមក យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលយកបាត្រ ចីវររបស់លោកឡើយ ប៉ុន្តែយើងត្រូវក្រាលអាសនៈបម្រុងទុក បើលោកនឹងចង់គង់ក៏គង់ចុះ។ ព្រះដ៏មានព្រះភាគយាងចូលទៅរកបញ្ចវគ្គិយភិក្ខុដោយប្រការណាៗ បញ្ចវគ្គិយភិក្ខុទាំងនោះ ក៏មិនអាចដើម្បីឋិតនៅក្នុងពាក្យប្តេជ្ញារបស់ខ្លួនដោយប្រការនោះៗបានឡើយ ក៏ស្រាប់តែក្រោកទទួល ព្រះដ៏មានព្រះភាគ ខ្លះទទួលយកបាត្រ ចីវររបស់ព្រះអង្គ ខ្លះក្រាលអាសនៈថ្វាយ ខ្លះដម្កល់ទឹកលាងព្រះបាទ យកតាំងសម្រាប់រងព្រះបាទ និងឈ្នាន់រងព្រះបាទមកថ្វាយ។ ព្រះដ៏មានព្រះភាគ គង់លើអាសនៈដែលបញ្ចវគ្គិយភិក្ខុទាំងឡាយរៀបចំទុកហើយ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ក៏ទ្រង់លាងព្រះបាទទាំងពីរ។ ទើបបញ្ចវគ្គិយភិក្ខុហៅព្រះដ៏មានព្រះភាគចំព្រះនាមផង ដោយពាក្យថា អាវុសោផង។ កាលបញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យហៅយ៉ាងនេះ

ហើយ ព្រះភគវន្តមុនី ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នាកុំហៅតថាគតដោយចំឈ្មោះ និងពាក្យថាអាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ ឥឡូវ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ដែលតថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយដែលចេញចាកផ្ទះហើយបួស ក្នុងភាពនៃបុគ្គលគ្មានការងារជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយកាលបើបានប្រតិបត្តិគួរតាមពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌[13] នោះជាទីបំផុតនៃមគ្គព្រហ្មចរិយៈ និងសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤។ កាលព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ បញ្ចវគ្គិយភិក្ខុ ក៏ពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម្ម ជាធម៌វិសេសដោយញាណនិងទស្សនៈដ៏ឧត្តមអាចកំចាតបង់នូវកិលេស ដោយការប្រព្រឹត្តិនោះផង ដោយការប្រតិបត្តិនោះផង ដោយអំពើដែលអ្នកដទៃធ្វើតាមបានដោយកម្រផង ឥឡូវនេះព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីល្មោភច្រើនហើយ ក៏នឹងបានត្រាស់ដឹងឧត្តរិមនុស្សធម្មដ៏វិសេស ដោយញាណនិងទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេសដូចម្តេចបាន។ លុះបញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យយ៉ាងនេះហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលយ៉ាងនេះនឹងបញ្ចវគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិដើម្បីល្មោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់ដើម្បីល្មោភច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ តថាគតនឹងប្រៀនប្រដៅនូវព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះហើយបួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិគួរដល់ពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ និងសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤។ បញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគជាគំរប់ពីរដងផង។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយជាគំរប់ពីរដងផង។បេ។ បញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគជាគំរប់បីដងផងថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម្ម ជាធម៌វិសេសដោយញាណនិងទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេសដោយការប្រព្រឹត្តិនោះផង ដោយសេចក្តីប្រតិបត្តិនោះផង ដោយអំពើដែលជនដទៃធ្វើតាមបានដោយកម្រផង ឥឡូវនេះ ព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើន ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់ដើម្បីល្មោភច្រើន នឹងបានត្រាស់ដឹងឧត្តរិមនុស្សធម្មដ៏វិសេស ដោយញាណនិងទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេសដូចម្តេចបាន។ កាលបើបញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងបញ្ចវគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរពិចារណាមើលនូវពាក្យរបស់តថាគតឥឡូវនេះ ដូចគ្នានឹងកាលមុនអំពីកាលឥឡូវនេះដែរឬទេ។ បញ្ចវគ្គិយភិក្ខុទាំងឡាយតបថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យហ្នឹង ព្រះអង្គមិនដែលពោលទេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ។ តថាគតនឹងប្រៀនប្រដៅព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះ បួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយប្រតិបត្តិគួរតាមពាក្យប្រដៅរបស់តថាគត ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤។ ព្រះដ៏មានព្រះភាគ បានអាចញ៉ាំងបញ្ចវគ្គិយភិក្ខុទាំងឡាយឲ្យយល់ច្បាស់ (ក្នុងពេលនោះ)។ លុះគ្រាជាខាងក្រោយ បញ្ចវគ្គិយភិក្ខុទាំងឡាយតាំងចិត្តស្តាប់ព្រះដ៏មានព្រះភាគ ផ្ទៀងនូវសោតប្បសាទ ហើយផ្ចង់ចិត្តដើម្បីដឹងច្បាស់។

[១៣] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌អមខាង[14] ទាំងពីរប្រការនេះ គឺបព្វជិតមិនគួរសេពគប់ឡើយ។ (ធម៌អមខាងទាំងពីរប្រការនោះគឺ) ការប្រកបរឿយៗនូវសេចក្តីជាប់ជំពាក់ដោយកាមសុខ ក្នុងកាមទាំងឡាយណា ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គលទេ មិនប្រកបដោយប្រយោជន៍(មួយ) ការប្រកបរឿយៗនូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាកណា តែងនាំមកនៅសេចក្តីទុក្ខ មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ (មួយ) ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទា (គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល) មិនប៉ះពាល់នឹងធម៌អមខាងទាំងពីរនោះ[15] តថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិ ធ្វើអោយកើតបញ្ញាចក្ខុ (គឺធ្វើឲ្យកើតសេចក្តីចេះដឹង) ប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីព្រះនិព្វាន។ ម្នាលភិក្ខុទាំងឡាយ ក៏មជ្ឈិមាបដិបទានោះ ដូចម្តេច ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើអោយកើតបញ្ញាចក្ខុ ប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីនិព្វាន (មជ្ឈិមាបដិបទានោះ) គឺ អរិយមគ្គប្រកបដោយអង្គ៨នេះឯង អរិយមគ្គប្រកបដោយអង្គ៨ប្រការ ដូចម្តេច អរិយមគ្គប្រកបដោយអង្គ៨ប្រការនោះគឺ សេចក្តីឃើញត្រូវ១ សេចក្តីត្រិះរិះត្រូវ១ វាចាត្រូវ១ ការងារត្រូវ១ ការចិញ្ចឹមជីវិតត្រូវ១ សេចក្តីព្យាយាមត្រូវ១ ស្មារតីត្រូវ១ ការតម្កល់ចិត្តត្រូវ១។ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទានេះឯងដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ តែងប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីនិព្វាន។

[១៤] ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីទុក្ខនេះឯងហៅថា អរិយសច្ច គឺ កំណើត (ទាំង៤ មានជលាពុជជាដើម) ជាកងទុក្ខ១ សេចក្តីចាស់គ្រាំគ្រាជាកងទុក្ខ១ ពួកជម្ងឺដំកាត់ជាកងទុក្ខ១ សេចក្តីស្លាប់ជាកងទុក្ខ១ ដំណើរប្រសប់ចូលដោយសត្វ និងសង្ខារមិនជាទីស្រឡាញ់ទាំងឡាយជាកងទុក្ខ១ សេចក្តីព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ទាំងឡាយ ជាកងទុក្ខ១ បុគ្គលប្រាថ្នាវត្ថុណា មិនបានវត្ថុនោះ (ដូចបំណង) ជាកងទុក្ខ១ បើពោលដោយសង្ខេប ឧបាទានខន្ធទាំង៥ (មានរូបខន្ធជាដើម) ជាកងទុក្ខ១។ ម្នាលភិក្ខុទាំងឡាយ ហេតុជាដែនកើតនៃកងទុក្ខនេះឯង ហៅថា អរិយសច្ច គឺតណ្ហា[16] នេះឯង ជាធម្មជាតិនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីរីករាយ និងសេចក្តីត្រេកត្រអាល ជាធម្មជាតិនាំសត្វឲ្យត្រេកត្រអាលនៅក្នុងភពនោះៗ (ឬក្នុងអារម្មណ៍នោះៗ) តណ្ហានោះដូចម្តេច តណ្ហានោះ គឺកាមតណ្ហា (សេចក្តីប្រាថ្នាក្នុងកាមភព)១ ភវតណ្ហា (សេចក្តីប្រាថ្នាក្នុងរូបភព និងអរូបភព)១ វិភវតណ្ហា (សេចក្តីប្រាថ្នាក្នុងភពសូន្យ[17] )១។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់នៃកងទុក្ខនេះឯង ហៅថា អរិយសច្ច បានខាងនិព្វានធម៌ ជាសភាវៈ នឿយណាយ និងរំលត់ដោយមិនមានសេសសល់ ជាសភាវៈលះបង់ គ្រវែងចោល

ជម្រុះចោល មិនអាល័យ ត្រង់តណ្ហានោះឯង។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រតិបត្តិនាំសត្វឲ្យដល់នូវព្រះនិព្វានជាទីរលត់នៃកងទុក្ខនេះឯង ហៅថា អរិយសច្ច បានខាងអរិយមគ្គប្រកបដោយអង្គ៨នេះឯង អរិយមគ្គប្រកបដោយអង្គ៨នោះដូចម្ដេច អរិយមគ្គប្រកបដោយអង្គ៨នោះគឺ សេចក្ដីឃើញត្រូវ១។បេ។ ការដម្កល់ចិត្តត្រូវ១។

[១៥] ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮ ក្នុងកាលពីមុនមកថា កងទុក្ខនេះឈ្មោះថា អរិយសច្ចដូច្នេះឡើយ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយដល់តថាគតថាកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច បុគ្គលគួរកំណត់ដឹង។បេ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮក្នុងកាលពីមុនមកថា កងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលបុគ្គលបានកំណត់ដឹងហើយ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮក្នុងកាលពីមុនមកថា តណ្ហាជាដែនកើតឡើងនៃកងទុក្ខនេះ ឈ្មោះថា អរិយសច្ចដូច្នេះឡើយ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់តថាគតថា តណ្ហាជាដែនកើតឡើងនៃកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ចដែលបុគ្គលគួរលះចោល។បេ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮក្នុងកាលពីមុនមកថា តណ្ហាជាដែនកើតឡើងនៃកងទុក្ខនោះឯង ឈ្មោះថាអរិយសច្ច ដែលបុគ្គលលះចោលហើយ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮក្នុងកាលពីមុនមកថា និព្វានធម៌ជាទីរលត់នៃកងទុក្ខនេះ ឈ្មោះថា អរិយសច្ចដូច្នេះឡើយ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយ ដល់តថាគតថា និព្វានធម៌ជាទីរលត់នៃកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ចដែលបុគ្គលគួរធ្វើអោយជាក់ច្បាស់។បេ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮក្នុងកាលពីមុនមកថា និព្វានធម៌ជាទីរលត់នៃកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលបុគ្គលបានធ្វើឲ្យជាក់ច្បាស់ហើយ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮក្នុងកាលពីមុនមកថា សេចក្ដីប្រតិបត្តិ នាំសត្វឲ្យដល់នូវនិព្វាននេះឈ្មោះថា អរិយសច្ចដូច្នេះឡើយ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺកើតឡើងហើយដល់តថាគតថា សេចក្ដីប្រតិបត្តិនាំសត្វឲ្យដល់និព្វានជាទីរលត់នៃកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលបុគ្គលគួរចំរើន។បេ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮក្នុងកាលពីមុនមកថា សេចក្ដីប្រតិបត្តិនាំសត្វឲ្យដល់នូវនិព្វានជាទីរលត់នៃកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលបុគ្គលចំរើនហើយ។

[១៦] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ញាណទស្សនៈ (ការដឹងការឃើញ) តាមពិត មានបរិវដ្ដៈ៣ មានអាការៈ១២យ៉ាងនេះ ក្នុងអរិយសច្ចទាំងឡាយ៤នេះរបស់តថាគត នៅមិនទាន់បរិសុទ្ធត្រឹមណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្ដេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងចំពោះនូវសម្មាសម្ពោធិញាណដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោកនិងព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតានិងមនុស្ស ត្រឹមនោះ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ញាណទស្សនៈ តាមពិត មានបរិវដ្ដៈ៣ មានអាការៈ១២យ៉ាងនេះ ក្នុងអរិយសច្ចទាំងឡាយ៤នេះ របស់តថាគត បរិសុទ្ធហើយក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្ដេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងចំពោះនូវសម្មាសម្ពោធិញាណដ៏ប្រសើរ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតានិងមនុស្សក្នុងកាលនោះ។ ម្យ៉ាងទៀត ទស្សនកិច្ច គឺការដឹង កើតឡើងដល់តថាគតថា វិមុត្តិ (គឺអរហត្តផល) របស់តថាគតមិនកម្រើកឡើយ ជាតិនេះផុតត្រឹមនេះហើយ តពីនេះទៅ ភពថ្មីមិនមានឡើយ។ ក៏កាលដែលព្រះដ៏មានព្រះភាគកំពុងសំដែងនូវវេយ្យាករណ៍នេះ ធម្មចក្ខុ[18] (ភ្នែកឃើញធម៌) ដ៏ប្រាសចាកធូលី គឺរាគាទិក្កិលេស ប្រាសចាកមន្ទិល (គឺទិដ្ឋិ និងវិចិកិច្ឆា) បានកើតឡើងដល់កោណ្ឌញ្ញភិក្ខុដ៏មានអាយុថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតិទាំងនោះក៏រលត់ទៅវិញជាធម្មតា។

[១៧] ក៏កាលបើព្រះធម្មចក្ក ដែលព្រះដ៏មានព្រះភាគឲ្យប្រព្រឹត្តទៅ (គឺទ្រង់សំដែងដូចគេបង្វិល) (យ៉ាងនេះ) ហើយ ភុម្មទេវតាទាំងឡាយបន្លឺនូវសូរសព្ទថា ព្រះធម្មចក្កហ្នឹង មិនមានចក្កដទៃក្រៃលែងជាង ទោះបីសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី ជនឯណានីមួយក្ដីក្នុងលោក មិនអាចបដិវត្ត (កែប្រែ) បានឡើយ (ឥឡូវ) ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវន ជិតក្រុងពារាណសី។ ទេវតានៅក្នុងស្ថានចាតុម្មហារាជិកៈទាំងឡាយ ឮសម្លេងរបស់ភុម្មទេវតាទាំងឡាយហើយ ក៏បន្លឺនូវសម្លេង (ថាដូចគ្នា)។ ទេវតានៅក្នុងស្ថានតាវត្តិង្សទាំងឡាយ ឮសម្លេងរបស់ចាតុម្មហារាជិកៈទេវតាទាំងឡាយហើយ ក៏បន្លឺនូវសំឡេង (ថាដូចគ្នា)។បេ។ ទេវតានៅក្នុងស្ថានយាមាទាំងឡាយ ទេវតានៅក្នុងស្ថានតុសិតទាំងឡាយ... ទេវតានៅក្នុងស្ថាននិម្មានរតីទាំងឡាយ... ទេវតានៅក្នុងស្ថានបរនិម្មិតវសវត្តីទាំងឡាយ... ទេវតាដែលរាប់ក្នុងពពួកនៃព្រហ្មទាំងឡាយ ក៏បន្លឺនូវសូរសព្ទថា ព្រះធម្មចក្កហ្នឹង មិនមានចក្កដទៃក្រៃលែងជាង ទោះបីសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី ជនឯណានីមួយក្ដីក្នុងលោក មិនអាចនឹងឲ្យប្រព្រឹត្តទៅបានឡើយ (ឥឡូវ) ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវន ជិតក្រុងពារាណសី។ សំឡេង(កងរំពង) ក៏លាន់ឮឡើងទៅដរាបដល់ព្រហ្មលោកក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយប្រការដូច្នេះ។ រីឯលោកធាតុទាំងមួយម៉ឺននេះ ក៏កក្រើករំពើកញាប់ញ័រ។ ទាំងពន្លឺភ្លឺធំទូលាយ ប្រមាណមិនបាន កន្លងលើសអានុភាពរបស់ទេវតាទាំងឡាយ ក៏កើតប្រាកដឡើងក្នុងលោក។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្លឺនូវឧទានវាចាថា អើហ្ន៎ កោណ្ឌញ្ញៈបានត្រាស់ដឹងពិតហើយ អើហ្ន៎ កោណ្ឌញ្ញៈបានត្រាស់ដឹងពិតហើយ។ ព្រោះហេតុនោះ ពាក្យថា អញ្ញាកោណ្ឌញ្ញនេះឯង ក៏បានជាប់ជានាមរបស់ព្រះកោណ្ឌញ្ញៈភិក្ខុដ៏មានអាយុ។

[១៨] គ្រានោះ ព្រះអញ្ញាកោណ្ឌញ្ញៈដ៏មានអាយុបានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានត្រាស់ដឹងអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យហើយ ប្រាសចាកសេចក្ដីងឿងឆ្ងល់ហើយ ដល់នូវសេចក្ដីក្លៀវក្លា មិនបាច់ជឿស្ដាប់បុគ្គលដទៃក្នុងសាសនានៃព្រះសាស្ដា ទើបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គគួរបាននូវ

បព្វជ្ជា គួរបាននូវឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានជោគ ទ្រង់ត្រាស់ហៅថា អ្នកចូរមកជាភិក្ខុចុះ ហើយមានព្រះពុទ្ធដីកាថា សាសនធម៌ តថាគតពោលល្អហើយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីនឹងធ្វើនូវនិព្វាន ជាទីបំផុតនៃកងទុក្ខដោយប្រពៃចុះ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់អញ្ញាកោណ្ឌញ្ញៈដ៏មានអាយុនោះ។

[១៩] លំដាប់តទៅ ព្រះដ៏មានព្រះភាគ ទ្រង់ពោលទូន្មានប្រៀនប្រដៅភិក្ខុដ៏សេស ក្រៅពីអញ្ញាកោណ្ឌញ្ញភិក្ខុនោះដោយធម្មីកថា។ លំដាប់នោះ ព្រះដ៏មានព្រះភាគកំពុងពោលទូន្មានប្រៀនប្រដៅដោយធម្មីកថា ធម្មចក្ខុដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់វប្បភិក្ខុដ៏មានអាយុផង ដល់ភទ្ទិយភិក្ខុដ៏មានអាយុផងថា ធម្មជាតណាមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះក៏រលត់ទៅវិញជាធម្មតា។ ភិក្ខុទាំងឡាយពីរអង្គគឺ វប្បៈ និងភទ្ទិយៈនោះ បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានត្រាស់ដឹងអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យហើយ ប្រាសចាកសេចក្ដីងឿងឆ្ងល់ហើយ ដល់នូវសេចក្ដីក្លៀវក្លា មិនបាច់ជឿស្ដាប់បុគ្គលដទៃក្នុងសាសនានៃព្រះសាស្ដា ទើបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានជោគ ទ្រង់ត្រាស់ហៅថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ ហើយត្រាស់ថា សាសនធម៌ តថាគតពោលល្អហើយ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវនិព្វាន ជាទីបំផុតនៃកងទុក្ខ ដោយប្រពៃចុះ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់វប្បៈ និងភទ្ទិយភិក្ខុដ៏មានអាយុទាំងនោះ។ លំដាប់តទៅ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលភត្តដែលភិក្ខុទាំងឡាយនាំមកអំពីស្រុកមកថ្វាយ ហើយទ្រង់ពោលទូន្មានប្រៀនប្រដៅភិក្ខុទាំងឡាយពីរអង្គ គឺមហានាម និងអស្សជិ ក្រៅពីភិក្ខុបីអង្គគឺ កោណ្ឌញ្ញ វប្បៈ ភទ្ទិយៈនោះដោយធម្មីកថា។ ភិក្ខុទាំងឡាយបីអង្គ ត្រាច់ទៅបិណ្ឌបាត នាំមកនូវវត្ថុណា ឥសីទាំង៦អង្គ (គឺព្រះសម្មាសម្ពុទ្ធ១ បញ្ចវគ្គិយភិក្ខុទាំង៥) ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុនោះ។ លំដាប់នោះ ព្រះដ៏មានព្រះភាគកំពុងពោលទូន្មានប្រៀនប្រដៅដោយធម្មីកថា ធម្មចក្ខុដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល បានកើតឡើងដល់មហានាមដ៏មានអាយុផង ដល់អស្សជិដ៏មានអាយុផងថា ធម្មជាតណាមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងនោះ ក៏រលត់ទៅវិញជាធម្មតា។ ភិក្ខុទាំងឡាយពីរអង្គគឺ មហានាម និងអស្សជិនោះ បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានត្រាស់ដឹងអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យហើយ ប្រាសចាកសេចក្ដីងឿងឆ្ងល់ហើយ ដល់នូវសេចក្ដីក្លៀវក្លា មិនបាច់ជឿស្ដាប់បុគ្គលដទៃក្នុងសាសនានៃព្រះបរមសាស្ដា ទើបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គទាំងឡាយគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានជោគ ទ្រង់ត្រាស់ហៅថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ ហើយត្រាស់ថា សាសនធម៌ តថាគតពោលល្អហើយ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវនិព្វាន ជាទីបំផុតនៃកងទុក្ខ ដោយប្រពៃចុះ។ ព្រះពុទ្ធវាចានោះឯង ជាឧបសម្បទារបស់មហានាម និងអស្សជិដ៏មានអាយុទាំងនោះ។

[២០] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូប គឺរាងកាយជាអនត្តា មិនមែនជារបស់ខ្លួនឡើយ។[19] ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើរូបនេះជារបស់ខ្លួនពិតមែន រូបនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ គឺជម្ងឺដំកាត់ឡើយ ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងរូបថា សូមអោយរូបរបស់អញយ៉ាងនេះទៅ សូមកុំអោយរូបរបស់អញយ៉ាងនេះឡើយ។ ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តាមែនពិត ព្រោះហេតុនោះបានជារូបចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ម្យ៉ាងទៀត បុគ្គលមិនបាន(នូវអំណាច) ក្នុងរូបថា សូមឲ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឲ្យរូបរបស់អញយ៉ាងនេះឡើយ។ វេទនាមិនមែនជារបស់ខ្លួនឡើយ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវេទនានេះជារបស់ខ្លួនពិតមែន វេទនានេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ ម្យ៉ាងទៀត បុគ្គលគប្បីបាន(នូវអំណាច)ក្នុងវេទនាថា សូមឲ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឲ្យវេទនារបស់អញយ៉ាងនេះឡើយ។ ម្នាលភិក្ខុទាំងឡាយ វេទនាជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវេទនាចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ម្យ៉ាងទៀត បុគ្គលមិនបាន(នូវអំណាច) ក្នុងវេទនាថា សូមឲ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឲ្យវេទនារបស់អញយ៉ាងនេះឡើយ។ សញ្ញាមិនមែនជារបស់ខ្លួនឡើយ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើសញ្ញានេះជារបស់ខ្លួនពិតមែន សញ្ញានេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ។ ម្យ៉ាងទៀត បុគ្គលគប្បីបាន(នូវអំណាច) ក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឲ្យសញ្ញារបស់អញយ៉ាងនេះឡើយ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាជាអនត្តាពិតមែន ព្រោះហេតុនោះបានជាសញ្ញាចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ម្យ៉ាងទៀត បុគ្គលមិនបាន(នូវអំណាច) ក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឲ្យសញ្ញារបស់អញយ៉ាងនេះឡើយ។ សង្ខារទាំងឡាយមិនមែនជារបស់ខ្លួនឡើយ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើសង្ខារទាំងឡាយនេះជារបស់ខ្លួនពិតមែន សង្ខារទាំងឡាយនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ។ ម្យ៉ាងទៀត បុគ្គលគប្បីបាន(នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សូមឲ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឲ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយជាអនត្តាពិតមែន ព្រោះហេតុនោះបានជាសង្ខារទាំងឡាយចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ម្យ៉ាងទៀត បុគ្គលមិនបាន(នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សូមឲ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឲ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ។ វិញ្ញាណមិនមែនជារបស់ខ្លួនឡើយ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវិញ្ញាណនេះជារបស់ខ្លួនពិតមែន វិញ្ញាណនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ។ ម្យ៉ាងទៀត បុគ្គលគប្បីបាន(នូវអំណាច) ក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឲ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវិញ្ញាណចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ម្យ៉ាងទៀត បុគ្គលមិនបាន(នូវអំណាច) ក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឲ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ។

[២១] ព្រះបរមសាស្ដាទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្ដីនោះថាដូចម្ដេច។ រូបទៀងឬមិនទៀង។ បញ្ចវគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន រូបមិនទៀងទេ។ ទ្រង់ត្រាស់សួរថា របស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន របស់នោះជាទុក្ខ។ ទ្រង់ត្រាស់សួរថា ក៏របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នុ៎ះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនោះទេ។ ព្រះបរមសាស្ដាទ្រង់ត្រាស់សួរថា វេទនាទៀង ឬមិនទៀង ។[20] បញ្ចវគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន វេទនាមិនទៀងទេ។ ទ្រង់ត្រាស់សួរថា របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន របស់នោះជាទុក្ខ។ ទ្រង់ត្រាស់សួរថា ក៏របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះ

របស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនោះទេ។ ព្រះបរមសាស្តាទ្រង់ត្រាស់សួរថា សញ្ញាទៀង ឬមិនទៀង។ បញ្ចវគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន សញ្ញាមិនទៀងទេ។ ទ្រង់ត្រាស់សួរថា ក៏របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន របស់នោះជាទុក្ខ។ ទ្រង់ត្រាស់សួរថា ក៏របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនោះទេ។ ព្រះបរមសាស្តាទ្រង់ត្រាស់សួរថា សង្ខារទាំងឡាយទៀង ឬមិនទៀង។ បញ្ចវគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន សង្ខារទាំងឡាយមិនទៀងទេ។ ទ្រង់ត្រាស់សួរថា ក៏របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន របស់នោះជាទុក្ខ។ ទ្រង់ត្រាស់សួរថា ក៏របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនោះទេ។ ព្រះបរមសាស្តាទ្រង់ត្រាស់សួរថា វិញ្ញាណទៀង ឬមិនទៀង។ បញ្ចវគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន វិញ្ញាណមិនទៀងទេ។ ទ្រង់ត្រាស់សួរថា ក៏របស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន របស់នោះជាទុក្ខ។ ទ្រង់ត្រាស់សួរថា ក៏របស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ។ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនោះទេ។

[២២] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងលោកនេះ រូបឯណាមួយជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះក៏គ្រាន់តែជារូប (ប៉ុណ្ណោះឯង) អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ។ វេទនាឯណាមួយជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វេទនាណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វេទនាទាំងអស់នោះក៏គ្រាន់តែជាវេទនា (ប៉ុណ្ណោះឯង) អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ។ សញ្ញាឯណាមួយជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សញ្ញាណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី សញ្ញាទាំងអស់នោះក៏គ្រាន់តែជាសញ្ញា (ប៉ុណ្ណោះឯង) អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ។ សង្ខារទាំងឡាយឯណាមួយជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សង្ខារទាំងឡាយណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី សង្ខារទាំងឡាយទាំងអស់នោះក៏គ្រាន់តែជាសង្ខារ (ប៉ុណ្ណោះឯង) អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ។ វិញ្ញាណឯណាមួយជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះក៏គ្រាន់តែជាវិញ្ញាណ (ប៉ុណ្ណោះឯង) អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ។

[២៣] ម្នាលភិក្ខុទាំងឡាយ អរិយសាវកបានស្តាប់ហើយ យល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង កាលបើនឿយណាយ (យ៉ាងនេះហើយ) ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ព្រោះកិរិយាប្រាសចាកតម្រេក កាលដែលចិត្តផុតស្រឡះ (ចាកអាសវៈ) ហើយ ញាណ (របស់អរិយសាវកនោះ) ក៏កើតឡើងប្រាកដថា ចិត្ត(របស់អញ) ផុតស្រឡះ (ចាកអាសវៈ)ហើយ (អរិយសាវកនោះ) ក៏ដឹងច្បាស់ដូច្នេះថា ជាតិ(របស់អញ)អស់ហើយ មគ្គព្រហ្មចរិយធម៌ អញបាននៅរួចហើយ កិច្ចដែលគួរធ្វើ អញក៏បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមាន (ដល់អញ)ឡើយ។

[២៤] ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានសំដែងនូវសូត្រនេះចប់ហើយ។ បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិតនៃព្រះដ៏មានព្រះភាគជាម្ចាស់។ ក៏កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់កំពុងត្រាស់សំដែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង៥រូប បានរួចស្រឡះហើយចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ (ថាអញ ថាយើង)ឡើយ។ ក្នុងសម័យនោះឯង មានព្រះអរហន្ត៦អង្គក្នុងលោកជាដម្បូង (រាប់ទាំងព្រះដ៏មានព្រះភាគផង)។

(ចប់ បញ្ចវគ្គិយកថា)

ចប់ បឋមភាណវារៈ។

## ៧. បព្វជ្ជាកថា

CS vin.mv.01.07 | ភាគ ទី៦

**(បញ្ចវគ្គិយកថា (៧.))**

### បព្វជ្ជារបស់ព្រះយស

[២៥] សម័យនោះឯង ក្នុងក្រុងពារាណសី មានកុលបុត្រ (ម្នាក់) ឈ្មោះយស ជាកូនសេដ្ឋី ជាបុគ្គលចំរើនដោយសេចក្តីសុខ។ យសកុលបុត្រនោះមានប្រាសាទ៣ ប្រាសាទ១ សម្រាប់នៅក្នុងរដូវរងា ប្រាសាទ១សម្រាប់នៅក្នុងរដូវក្តៅ ប្រាសាទ១ សម្រាប់នៅក្នុងរដូវភ្លៀង។ យសកុលបុត្រនោះ មាតាបិតាឲ្យពួកអ្នកភ្លេងតូរ្យតន្ត្រីសុទ្ធសឹងតែស្រីឥតមានបុរសឡើយ ចាំបម្រើអស់កំណត់៤ខែ ក្នុងប្រាសាទសម្រាប់នៅក្នុងរដូវភ្លៀង មិន

ដែលចុះមកកាន់ផ្ទៃប្រាសាទខាងក្រោមទេ។ គ្រានោះ យសកុលបុត្រឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង៥ កាលពួកស្រីកំពុងបម្រើ ក៏ដេកលក់ទៅជាមុន ឯជនជាបរិសទ្យ ក៏ដេកលក់ជាខាងក្រោយ។ រីឯប្រទីបដែលគេអុជទុកដោយប្រេង តែងឆេះបំភ្លឺទាល់ព្រឹក រាល់ៗយប់។ គ្រានោះ យសកុលបុត្រ ភ្ញាក់ពីនិទ្រាមុនគេ បានឃើញជនជាបរិសទ្យរបស់ខ្លួនកំពុងដេកលក់ ស្រីខ្លះមានពិណនៅត្រង់ក្លៀក ស្រីខ្លះមានស្គរសម្ភោរនៅត្រង់ក ស្រីខ្លះមានស្គរធំនៅក្បែរទ្រូង ស្រីខ្លះមានសក់រំសាយ ស្រីខ្លះមានទឹកមាត់ហូរហៀរ ស្រីខ្លះកំពុងមមើ (យសកុលបុត្របានឃើញជនជាបរិសទ្យរបស់ខ្លួន) ហាក់ដូចជាព្រៃស្មសាន មកប្រាកដក្នុងកណ្តាប់ដៃ។ យសកុលបុត្រនោះ លុះបានឃើញហើយ កើតសេចក្តីជិនឆ្អន់ចិត្ត ក៏ឋិតនៅស៊ប់ក្នុងសេចក្តីនឿយណាយ។ ទើបយសកុលបុត្របន្លឺឧទានវាចា (ដោយសេចក្តីសង្វេគ)ថា ឱហ្ន៎ (ទីនេះ) ច្របូកច្របល់ណាស់តើ ឱហ្ន៎ (ទីនេះ) ជំពាក់វាក់វិនណាស់តើ។ គ្រានោះ យសកុលបុត្រពាក់ទ្រនាប់ជើងមាស ដើរសំដៅទៅកាន់មាត់ទ្វារផ្ទះ។ អមនុស្ស[21] ទាំងឡាយ បើកទ្វារទុកដោយបំណងថា អ្នកណាមួយកុំធ្វើអន្តរាយក្នុងការចេញចាកផ្ទះ ហើយបួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះរបស់យសកុលបុត្រឡើយ។ គ្រានោះ យសកុលបុត្រ ក៏ដើរតម្រង់ទៅកាន់ទ្វារព្រះនគរ។ អមនុស្សទាំងឡាយបើកទ្វារទុកដោយបំណងថា អ្នកណាមួយកុំធ្វើអន្តរាយក្នុងការចេញចាកផ្ទះ ហើយបួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះរបស់យសកុលបុត្រឡើយ។ គ្រានោះ យសកុលបុត្រ ក៏ដើរតម្រង់ទៅកាន់ឥសិបតនមិគទាយវន។

[២៦] សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់តើនឡើងក្នុងសម័យព្រឹកព្រាងស្វាងរាត្រី ហើយទ្រង់ចង្ក្រមក្នុងទីវាល។ ព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញយសកុលបុត្រដើរមកអំពីចម្ងាយ លុះទ្រង់ឃើញហើយ ក៏យាងចេញអំពីកន្លែងចង្ក្រម ហើយគង់លើអាសនៈដែលគេក្រាលទុកស្រាប់។ គ្រានោះ យសកុលបុត្របន្លឺឧទានវាចា (ដោយសេចក្តីសង្វេគ) ក្នុងទីជិត ព្រះដ៏មានព្រះភាគថា ឱហ្ន៎ (ទីនុ៎ះ) ច្របូកច្របល់ណាស់តើ ឱហ្ន៎ (ទីនុ៎ះ) ជំពាក់វាក់វិនណាស់តើ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងយសកុលបុត្រថា ម្នាលយស ទីនេះឯង មិនច្របូកច្របល់ ទីនេះមិនជំពាក់វាក់វិនទេ ម្នាលយស មកណេះ មកអង្គុយ (ឯណេះ) តថាគតនឹងសំដែងធម៌ដល់អ្នក។ គ្រានោះ យសកុលបុត្រក៏រីករាយអណ្តែតចិត្តដោយគិតឃើញថា ឮថា ទីនេះមិនច្របូកច្របល់ ទីនេះមិនជំពាក់វាក់វិន (គិតដូច្នេះហើយ) ក៏ដោះទ្រនាប់ជើងមាសចេញ ដើរតម្រង់ទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះយសកុលបុត្រអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា ព្រះអង្គសំដែងអនុបុព្វីកថា ដូចម្តេច គឺទ្រង់ប្រកាស ទានកថា សីលកថា សគ្គកថា និងទោសនៃកាមទាំងឡាយដ៏លាមក ដ៏សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម (បួស)។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវយសកុលបុត្រថាមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ កាលនោះ ព្រះអង្គក៏ទ្រង់សំដែងធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសំដែង ដោយព្រះអង្គឯង គឺទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ច១។ ធម្មតា សំពត់សស្អាត មិនជិតប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គឺធ្យូង ឬល័ក្តខ្មៅជាដើម គួរទទួលទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្តេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់យសកុលបុត្រក្នុងកន្លែងអង្គុយនោះឯងថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ ក៏រលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង។

[២៧] គ្រានោះ មាតារបស់យសកុលបុត្រឡើងទៅកាន់ប្រាសាទ មិនបានឃើញយសកុលបុត្រ ក៏ដើរតម្រង់ទៅរកសេដ្ឋីគហបតិ (ជាស្វាមី) លុះចូលទៅដល់ហើយ ក៏ប្រាប់សេដ្ឋីគហបតិថា បពិត្រគហបតិ យសកុមារ ជាកូនរបស់អ្នក មិនឃើញទេ។ គ្រានោះ សេដ្ឋីគហបតិបញ្ជូនបម្រើទៅដោយសេះក្នុងទិសទាំង៤ ខ្លួនឯងក៏ដើរសំដៅទៅកាន់ឥសិបតនមិគទាយវន។ សេដ្ឋីគហបតិបានឃើញដានទ្រនាប់ជើងមាស (ស្បែកជើងមាស) លុះឃើញហើយ ក៏ដើរទៅតាមដានទ្រនាប់ជើងនោះឯង។ ព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញច្បាស់នូវសេដ្ឋីគហបតិដើរមកអំពីចម្ងាយ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញហើយ ក៏ទ្រង់ពុទ្ធបរិវិតក្កថា តថាគតគួរធ្វើឥទ្ធាភិសង្ខារ[22] មិនឲ្យសេដ្ឋីគហបតិដែលអង្គុយនៅក្នុងទីនេះ ឃើញយសកុលបុត្រ ដែលអង្គុយនៅក្នុងទីនេះឯង។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់តាក់តែងនូវឥទ្ធាភិសង្ខារ មានសភាពដូច្នោះហើយ។ កាលនោះ សេដ្ឋីគហបតិក៏ដើរចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគ ទ្រង់បានឃើញយសកុលបុត្រដែរឬទេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតិ បើដូច្នោះ ចូរអ្នកអង្គុយសិនចុះ បើអ្នកអង្គុយក្នុងទីនេះ មុខជានឹងឃើញយសកុលបុត្រអង្គុយក្នុងទីនេះដែរ។ គ្រានោះ សេដ្ឋីគហបតិនឹកសង្ឃឹមថា ឮថា បើអញអង្គុយនៅក្នុងទីនេះឯង គង់នឹងបានឃើញយសកុលបុត្រអង្គុយនៅក្នុងទីនេះដែរ ហើយក៏ត្រេកអររីករាយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ លុះសេដ្ឋីគហបតិអង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា គឺទ្រង់ប្រកាស ទានកថា១ សីលកថា១ សគ្គកថា១ ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង១ អានិសង្សក្នុងការចេញចាកកាម (បួស)១។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា សេដ្ឋីគហបតិ មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណៈ មានចិត្តខ្ពស់ មានចិត្តជ្រះថ្លា ក្នុងកាលណា ធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើងសំដែង ដោយព្រះអង្គឯង ទ្រង់ក៏ប្រកាសនូវធម្មទេសនានោះគឺ ទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ច១ ក្នុងកាលនោះឯង។ ធម្មតា សំពត់សស្អាត មិនជិតប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គឺធ្យូង ឬល័ក្តខ្មៅជាដើម គួរទទួលទឹកជ្រលក់បានដោយល្អ មានឧបមាដូចម្តេចមិញ ឯធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់សេដ្ឋីគហបតិ ក្នុងទីអង្គុយនោះថា ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង។ គ្រានោះ សេដ្ឋីគហបតិបានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានជឿជាក់នូវអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាវៈ ជាអ្នកក្លាហាន មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន (ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ) ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន (ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ) ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន បុរសដែលផ្ងារឡើងនូវរបស់ដែលគេផ្កាប់ចុះ ឬបើកចេញនូវរបស់ដែលគេបិទបាំងទុក ឬប្រាប់ផ្លូវដល់បុរសអ្នកវង្វេងផ្លូវ ឬទ្រោលបំភ្លឺនូវប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានចក្ខុទាំងឡាយ នឹងឃើញរូបបានដោយងាយ មានឧបមាយ៉ាងណាមិញ ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសហើយដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរលឹក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវទីរលឹកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមទៅ។ ឯសេដ្ឋីគហបតិនោះ (បាននាមបញ្ញត្តិថា) តេវាចិកឧបាសក (គឺឧបាសកដល់តេវាចិកសរណគមន៍) ជាដម្បូងក្នុងលោក។

[២៨] គ្រានោះ យសកុលបុត្រ កាលដែលព្រះដ៏មានព្រះភាគកំពុងសំដែងធម៌ដល់បិតា (របស់ខ្លួន) ក៏ពិចារណានូវភូមិធម៌ដែលខ្លួនឃើញហើយ ដែលខ្លួនត្រាស់ដឹងហើយ ចិត្តក៏រួចផុតស្រឡះចាកអាសវធម៌ទាំងឡាយ ឥតជាប់ចំពាក់ដោយឧបាទានឡើយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា យសកុលបុត្រ កាលដែលតថាគតកំពុងសំដែងធម៌ដល់បិតា (របស់ខ្លួន) ក៏ពិចារណានូវថ្នាក់នៃធម៌ដែលខ្លួនឃើញហើយ ត្រាស់ដឹងហើយ ចិត្តក៏រួចផុតស្រឡះចាកអាសវធម៌ទាំងឡាយ ឥតជាប់ចំពាក់ដោយឧបាទាន ឯយសកុលបុត្រ (នេះ) មិនគួរនឹងវិលត្រឡប់ទៅដើម្បីភាវៈថោកទាប ហើយបរិភោគកាមទាំងឡាយ ដូចកាលនៅយរាវាសក្នុងកាលមុនទេ បើដូច្នោះ គួរតថាគតរម្ងាប់នូវឥទ្ធាភិសង្ខារ[23] (គឺរំសាយឫទ្ធិ ឬស្រាយឫទ្ធិ)នោះចេញ។ គ្រានោះ ព្រះដ៏មានព្រះភាគបានរំសាយឥទ្ធាភិសង្ខារនោះហើយ។ សេដ្ឋីគហបតិ បានឃើញយសកុលបុត្រអង្គុយនៅ (ក្នុងទីនោះ) លុះឃើញហើយ ក៏និយាយពាក្យនេះនឹងយសកុលបុត្រថា នែយស មាតារបស់អ្នកមានសេចក្តីសោកខ្សឹកខ្សួល ចូរអ្នកឲ្យជីវិតដល់មាតារបស់អ្នកផង។ គ្រានោះ យសកុលបុត្រក៏ងើបមើលព្រះដ៏មានព្រះភាគ។ ឯព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងសេដ្ឋីគហបតិថា ម្នាលគហបតិ អ្នកឯងសំគាល់យសកុលបុត្រនោះថាដូចម្តេចទៅ ឯយសកុលបុត្រ(នេះ) ឈ្មោះថាឃើញធម៌ហើយដោយសេក្ខញ្ញាណ និងសេក្ខទស្សនៈ ព្រោះថា យសកុលបុត្រនោះពិចារណានូវភូមិធម៌ ដូចជាធម៌ដែលអ្នកឃើញហើយ អ្នកដឹងហើយ ចិត្ត (របស់យសកុលបុត្រនោះ) ក៏រួចចាកអាសវធម៌ទាំងឡាយហើយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ ម្នាលគហបតិ យស (នេះ) គួរនឹងវិលត្រឡប់ទៅដើម្បីភាវៈថោកទាប ហើយបរិភោគកាមទាំងឡាយដូចនៅជាយរាវាសក្នុងកាលមុនដែរឬទេ។ សេដ្ឋីគហបតិក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ហេតុនេះមិនគួរទេ។ ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលគហបតិ យសកុលបុត្រ(នេះឯង) ឈ្មោះថាឃើញធម៌ហើយដោយសេក្ខញ្ញាណ និងសេក្ខទស្សនៈ ព្រោះយសកុលបុត្រនោះពិចារណានូវភូមិធម៌ ដូចជាធម៌ដែលអ្នកឃើញហើយ អ្នកត្រាស់ដឹងហើយ ចិត្តក៏រួចចាកអាសវធម៌ទាំងឡាយហើយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ ម្នាលគហបតិ យសកុលបុត្រ មិនគួរនឹងវិលត្រឡប់ទៅដើម្បីភាវៈថោកទាប ហើយបរិភោគកាមទាំងឡាយដូចនៅជាយរាវាសក្នុងកាលពីមុនទេ។ សេដ្ឋីគហបតិ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន យសកុលបុត្រមានលាភហើយ បពិត្រព្រះអង្គដ៏ចំរើន (អត្តភាពជាមនុស្ស) យសកុលបុត្របានល្អហើយ ព្រោះចិត្តរបស់យសកុលបុត្ររួចចាកអាសវធម៌ទាំងឡាយហើយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃនេះ ព្រមទាំងយសកុលបុត្រជាបច្ឆា[24] សមណៈផង។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តដោយភាវៈស្ងៀមនៅ។ គ្រានោះ សេដ្ឋីគហបតិដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយដើរចេញទៅ។ កាលបើសេដ្ឋីគហបតិចេញទៅមិនយូរប៉ុន្មាន ក៏យសកុលបុត្រ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគក្នុងពេលនោះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា អ្នកចូរមក[25] ជាភិក្ខុចុះ ហើយទ្រង់ត្រាស់ថា សាសនធម៌ តថាគតំ ពោលល្អហើយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ចុះ។ ឯព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ថា អ្នកចូរមកជាភិក្ខុនោះឯង ជាឧបសម្បទារបស់យសកុលបុត្រដ៏មានអាយុនោះ។ ព្រះអរហន្តទាំងឡាយ៧អង្គ កើតមានក្នុងលោកក្នុងគ្រានោះឯង។

ចប់ បព្វជ្ជារបស់ព្រះយស។

**បព្វជ្ជារបស់គ្រហស្ថជាសំឡាញ់គ្នា៤នាក់**

CS vin.mv.01.07.01 | ភាគ ទី៦

[២៩] លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកស្បង់ ប្រដាប់ដោយបាត្រនិងចីវរក្នុងបុព្វណ្ហសម័យ[26] មានព្រះយសដ៏មានអាយុ ជាបច្ឆាសមណៈ យាងចូលទៅកាន់លំនៅរបស់សេដ្ឋីគហបតិ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលសេដ្ឋីក្រាលបម្រុងទុកហើយ។ គ្រានោះ មាតា និងស្ត្រីជាបុរាណទុតិយិកា[27] របស់ព្រះយសដ៏មានអាយុ នាំគ្នាដើរចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថាដល់ស្រីទាំងនោះ គឺទ្រង់ប្រកាសទានកថា១ សីលកថា១ សគ្គកថា១ ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង១ អានិសង្សក្នុងការចេញចាកកាម (បួស)១។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា ស្រីទាំងឡាយនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះអង្គក៏ទ្រង់សំដែងធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែង ដោយព្រះអង្គឯង គឺទ្រង់ប្រកាសទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ច១ ក្នុងកាលនោះ។ សំពត់សស្អាត មិនប្រឡាក់របស់ខ្មៅ គួរទទួលទឹកជ្រលក់បានដោយប្រពៃ មានឧបមាដូចម្តេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ស្រីទាំងឡាយនោះ ក្នុងទីអង្គុយនោះឯងថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង។ ស្រីទាំងអម្បាលនោះ បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនបាច់ជឿស្តាប់ពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ ពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ ពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន បុរសដែលផ្ងារឡើងនូវរបស់ដែលគេផ្កាប់ចុះ ឬបើកចេញនូវរបស់ដែលគេបិទបាំងទុក ឬប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬទ្រោលបំភ្លឺនូវប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា មនុស្សទាំងឡាយដែលមានចក្ខុ នឹងឃើញរូបបានដោយងាយ មានឧបមាយ៉ាងណាមិញ ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ប្រកាសហើយ ដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីរលឹក សូមព្រះអង្គ ទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថាជាឧបាសិកា ដល់នូវទីរលឹកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមទៅ។ ឯស្រីទាំងអម្បាលនោះ បាននាមបញ្ញត្តិជាឧបាសិកាដល់នូវតេវាចិកាសរណគមន៍ ជាដម្បូងក្នុងលោក។ គ្រានោះ បិតាមាតា និងស្រីជាបុរាណទុតិយិការបស់ព្រះយសដ៏មានអាយុអង្គាសព្រះដ៏មានព្រះភាគ និងព្រះយសដ៏មានអាយុ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ហើយ (សំគាល់) នូវព្រះដ៏មានព្រះភាគដែលឆាន់ហើយ មានព្រះហស្ថលែងលូកចុះក្នុងបាត្រហើយ ទើបអង្គុយចុះក្នុងទីដ៏សមគួរ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់មាតាបិតា និងស្រីបុរាណទុតិយិការបស់ព្រះយសដ៏មានអាយុ ឲ្យយល់ច្បាស់ ឲ្យកាន់យកល្អ ឲ្យឧស្សាហ៍មាំ ឲ្យរីករាយដោយធម្មីកថា ហើយទើបទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ។

[៣០] (លំដាប់នោះ) មានគ្រហស្ថ៤នាក់ ជាសំឡាញ់របស់ព្រះយសដ៏មានអាយុ គឺឈ្មោះវិមលៈ១ សុពាហុ១ បុណ្ណជិ១ គវម្បតិ១ ជាបុត្រពួកត្រកូលសេដ្ឋី និងអនុសេដ្ឋីក្នុងក្រុងពារាណសី បានឮដំណឹងថា យសកុលបុត្រកោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈចេញអំពីផ្ទះ ហើយបួសក្នុងភេទនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ។ លុះសំឡាញ់ទាំងនោះបានឮដំណឹង (យ៉ាងនេះ)ហើយ ទើបត្រិះរិះដូច្នេះថា យសកុលបុត្រកោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈចេញទៅអំពីផ្ទះ ហើយបួសក្នុងភេទនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យណា ធម្មវិន័យនោះ មិនមែនជារបស់ថោកទាបដោយពិត ទាំងបព្វជ្ជានោះសោត ក៏មិនមែនជារបស់ថោកទាបឡើយ។ សំឡាញ់ទាំងនោះនាំគ្នាចូលទៅរកព្រះយសដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះយសដ៏មានអាយុ ហើយឋិតនៅក្នុងទីដ៏សមគួរ។ លំដាប់នោះ ព្រះយសដ៏មានអាយុនាំសំឡាញ់គ្រហស្ថទាំង៤នាក់នោះចូលទៅគាល់ផ្ទះព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ លុះព្រះយសដ៏មានអាយុអង្គុយនៅក្នុងទីដ៏សមគួរហើយ ក្រាបទូលដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សំឡាញ់របស់ខ្ញុំព្រះអង្គជាគ្រហស្ថ៤នាក់នេះ ឈ្មោះវិមលៈ១ សុពាហុ១ បុណ្ណជិ១ គវម្បតិ១ ជាកូនពួកត្រកូលសេដ្ឋី និងអនុសេដ្ឋីក្នុងក្រុងពារាណសី (ជាមួយគ្នា) សូមព្រះដ៏មានព្រះភាគឲ្យឱវាទប្រៀនប្រដៅសំឡាញ់អម្បាលនេះឲ្យទាន។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់សំដែងអនុបុព្វីកថាដល់បុរសទាំងឡាយនោះ គឺទ្រង់សំដែងទានកថា១ សីលកថា១ សគ្គកថា១ ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង១ អានិសង្សក្នុងការចេញចាកកាម (បួស)១។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា បុរសទាំង៤នាក់នោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះអង្គទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសំដែង ដោយព្រះអង្គឯង គឺទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ច១ ក្នុងកាលនោះ។ ធម្មតា សំពត់សស្អាត មិនប្រឡាក់របស់ខ្មៅ គឺធ្យូង ឬល័ក្តខ្មៅជាដើម គួរទទួលទឹកជ្រលក់បានដោយប្រពៃ មានឧបមាដូចម្តេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់បុរសទាំងអម្បាលនោះ ក្នុងទីអង្គុយនោះឯងថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង។ បុរសទាំងអម្បាលនោះបានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានត្រាស់ដឹងអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនបាច់ជឿស្តាប់ពាក្យបុគ្គលដទៃឡើយ ក្នុងសាសនានៃព្រះសាស្តា ទើបក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងអម្បាលនេះ គួរបានបព្វជ្ជា គួរបានឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ ហើយត្រាស់ថា សាសនធម៌ តថាគតពោលល្អហើយ អ្នកទាំងឡាយចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយល្អចុះ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងអម្បាលនោះ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យឱវាទប្រៀនប្រដៅភិក្ខុទាំងអម្បាលនោះដោយធម្មីកថា។ ភិក្ខុទាំងអម្បាលនោះ កាលដែលព្រះដ៏មានព្រះភាគកំពុងឲ្យឱវាទប្រៀនប្រដៅដោយធម្មីកថា ក៏មានចិត្តផុតចាកអាសវធម៌ទាំងឡាយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ។ ព្រះអរហន្តទាំងឡាយ១១អង្គកើតមានក្នុងលោកក្នុងកាលនោះឯង។

ចប់ បព្វជ្ជារបស់គ្រហស្ថជាសំឡាញ់គ្នា៤នាក់។

**បព្វជ្ជារបស់គ្រហស្ថជាសំឡាញ់គ្នា៥០នាក់**

CS vin.mv.01.07.02 | ភាគ ទី៦

[៣១] មានគ្រហស្ថជាសំឡាញ់របស់ព្រះយសដ៏មានអាយុប្រមាណ៥០នាក់(ទៀត) ជាអ្នកនៅក្នុងជនបទ (ស្រុកក្រៅ) ជាកូននៃពួកត្រកូលទាំងឡាយ មានបុព្វបុរសជាលំដាប់នៃបុព្វបុរស[28] បានឮដំណឹងច្បាស់ថា យសកុលបុត្រកោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈ ចេញទៅអំពីផ្ទះ ហើយបួសក្នុងភេទនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ។ លុះជនទាំងនោះបានឮដំណឹង (យ៉ាងនេះ)ហើយ ក៏ត្រិះរិះដូច្នេះថា យសកុលបុត្រកោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកសំពត់កាសាយៈ ចេញអំពីផ្ទះ ហើយបួសក្នុងភេទនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះក្នុងធម្មវិន័យណា ធម្មវិន័យនោះ មិនមែនជារបស់ថោកទាបដោយពិត ទាំងបព្វជ្ជានោះសោត ក៏មិនមែនជារបស់ថោកទាបឡើយ។ បុរសទាំង៥០នាក់នោះ នាំគ្នាចូលទៅរកព្រះយសដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះយសដ៏មានអាយុ ហើយឋិតនៅក្នុងទីដ៏សមគួរ។ គ្រានោះ ព្រះយសដ៏មានអាយុ នាំគ្រហស្ថជាសំឡាញ់ទាំង៥០នាក់នោះចូលទៅគាល់ផ្ទះព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ លុះព្រះយសដ៏មានអាយុអង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចំរើន គ្រហស្ថជាសំឡាញ់របស់ខ្ញុំព្រះអង្គមានប្រមាណ៥០នាក់ទាំងនេះ ជាអ្នកនៅក្នុងជនបទ ជាបុត្រនៃពួកត្រកូលមានបុព្វបុរសជាលំដាប់នៃបុព្វបុរស សូមព្រះដ៏មានព្រះភាគ ទ្រង់ឲ្យឱវាទប្រៀនប្រដៅសំឡាញ់ទាំងអម្បាលនេះឲ្យទាន។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថាដល់បុរសទាំងអម្បាលនោះ គឺទ្រង់សំដែងទានកថា១ សីលកថា១ សគ្គកថា១ ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង១ អានិសង្សក្នុងការចេញចាកកាម (បួស)១។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា បុរសទាំង៥០នាក់នោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះអង្គក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែង ដោយព្រះអង្គឯង គឺទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ច១ ក្នុងកាលនោះ។ ធម្មតាសំពត់សស្អាត មិនប្រឡាក់របស់ខ្មៅ គឺធ្យូង ឬល័ក្តខ្មៅ គួរទទួលទឹកជ្រលក់បានដោយប្រពៃ មានឧបមាដូចម្តេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់បុរសទាំងនោះ ក្នុងទីអង្គុយនោះឯងថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង។ បុរសទាំង៥០នាក់នោះ បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានត្រាស់ដឹងអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាវៈជាអ្នកក្លាហាន មិនបាច់ជឿស្តាប់ពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ក៏ក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយនេះ គួរបានបព្វជ្ជា គួរបានឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ ហើយទ្រង់ត្រាស់ថា សាសនធម៌ តថាគតពោលល្អហើយ អ្នកទាំងឡាយចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខដោយល្អចុះ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងអម្បាលនោះ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទូន្មាន ប្រៀនប្រដៅភិក្ខុទាំងអម្បាលនោះដោយធម្មីកថា។ ភិក្ខុទាំងអម្បាលនោះ កាលដែលព្រះដ៏មានព្រះភាគកំពុងទូន្មាន

ប្រៀនប្រដៅដោយធម្មីកថា ចិត្តក៏រួចចាកអាសវធម៌ទាំងឡាយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ។ ព្រះអរហន្តទាំងឡាយ៦១អង្គកើតឡើងក្នុងលោក ក្នុងកាលនោះឯង។

(ចប់ បព្វជ្ជារបស់គ្រហស្ថជាសំឡាញ់គ្នា៥០នាក់។)

## ៨. មារកថា

CS vin.mv.01.08 | ភាគ ទី៦

**(មារកថា (៨.))**

[៣២] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ហៅភិក្ខុទាំងឡាយមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយ អំពីអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្តី [29] ទោះបីជារបស់មនុស្សក្តី [30] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសោត ក៏បានរួចហើយអំពីអន្ទាក់ទាំងអស់ដែរ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក (គឺស្រុកនិងនិគមនិងរាជធានី ហើយសំដែងធម៌) ដើម្បីជាប្រយោជន៍ និង សេចក្តីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវមួយជាមួយគ្នាឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ឲ្យពីរោះបទដើម បទកណ្តាល និងបទចុង អ្នកទាំងឡាយចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធប្រកបដោយអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយដែលមានធូលី គឺរាគាទិកិលេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះនឹងសាបសូន្យ (ចាកមគ្គផល) ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយអ្នកបំរុង ត្រាស់ដឹងធម៌ គង់នឹងមាន ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត ក៏នឹងចូលទៅកាន់សេនានិគម[31] ក្នុងឧរុវេលាប្រទេស ដើម្បីសម្តែងធម៌ដែរ។

[៣៣] គ្រានោះ ក្រុងមារ ជាអ្នកមានចិត្តអាក្រក់ ចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយគាថា ថា

> បពិត្រសមណៈ ព្រះអង្គជាប់ចំពាក់ហើយដោយអន្ទាក់ទាំងពួង ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី គឺព្រះអង្គជាបុគ្គលជាប់ចំពាក់ដោយចំណងដ៏មាំ ព្រះអង្គមិនរួចអំពីវិស័យរបស់ខ្ញុំឡើយ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា

> នែក្រុងមារ អ្នកជាសត្វដ៏ថោកទាប តថាគតរួចហើយចាកអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី គឺតថាគតជាបុគ្គលរួចស្រឡះហើយចាកចំណងដ៏មាំ អ្នកឯងសោត ក៏តថាគតនាំចេញអំពីពុតកំណាច (គឺតថាគតឲ្យចាលចាញ់ហើយ)។

ក្រុងមារក្រាបបង្គំទូលថា

> បពិត្រព្រះសមណៈ អន្ទាក់ណាដែលត្រាច់ទៅក្នុងអាកាស អន្ទាក់នេះឯង គឺឆន្ទរាគ ដែលត្រាច់ទៅក្នុងចិត្ត (របស់សត្វ ខ្ញុំនឹងទាក់ព្រះអង្គដោយអន្ទាក់ គឺឆន្ទរាគនោះ ព្រះអង្គគង់មិនរួច (អំពីវិស័យ) របស់ខ្ញុំទេ។
>
> ព្រះសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលមារ ជាសត្វដ៏ថោកទាប រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ជាគ្រឿងតម្រេកក្នុងចិត្តនៃសត្វ ចំណង់របស់តថាគតក្នុងអារម្មណ៍ មានរូបជាដើមនេះ ប្រាសចាកអស់ហើយ អ្នកឯងសោត ក៏តថាគតនាំចេញអំពីពុតកំណាច (គឺតថាគតឲ្យចាលចាញ់)ហើយ។

លំដាប់នោះ ក្រុងមារជាអ្នកមានចិត្តអាក្រក់ កើតទុក្ខ តូចចិត្តថា ព្រះដ៏មានព្រះភាគស្គាល់អញ ព្រះសុគតស្គាល់អញ រួចក៏អន្តរធានបាត់ទៅអំពីកន្លែងនោះឯង។

ចប់ មារកថាក់។

## ៩. បព្វជ្ជូបសម្បទាកថា

CS vin.mv.01.09 | ភាគ ទី៦

**(ឧបសម្បទាកថា ដោយត្រ័យសរណគមន៍ (៩.) )**

[៣៤] សម័យនោះឯង ភិក្ខុទាំងឡាយតែងនាំមកនូវពួកបព្វជ្ជាបេក្ខបុគ្គល[32] ផង នូវពួកឧបសម្បទាបេក្ខបុគ្គល[33] ផង អំពីទិសផ្សេងៗ អំពីជនបទផ្សេងៗ ដោយគិតថា ព្រះដ៏មានព្រះភាគនឹងបំបួស នឹងឲ្យឧបសម្បទាដល់កុលបុត្រទាំងនោះ (ចំពោះព្រះអង្គ)។ ឯភិក្ខុទាំងឡាយក្តី បព្វជ្ជាបេក្ខបុគ្គលទាំងឡាយក្តី ឧបសម្បទាបេក្ខបុគ្គលទាំងឡាយក្តី ក៏រមែងលំបាកក្នុងដំណើរនោះ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ងាត់ ទ្រង់សម្ងំនៅក្នុងកម្មដ្ឋាន មានព្រះតម្រិះក្នុងព្រះហឫទ័យកើតឡើងយ៉ាងនេះថា ឥឡូវនេះ ភិក្ខុទាំងឡាយតែងនាំមកនូវពួកបព្វជ្ជាបេក្ខបុគ្គលផង នូវពួកឧបសម្បទាបេក្ខបុគ្គលផង អំពីទិសផ្សេងៗ អំពីជនបទផ្សេងៗ (មកកាន់សំណាក់តថាគត) ដោយគិតថា ព្រះដ៏មានព្រះភាគនឹងបំបួស នឹងឲ្យឧបសម្បទាដល់កុលបុត្រទាំងនោះ ចំណែកភិក្ខុទាំងឡាយក្តី បព្វជ្ជាបេក្ខបុគ្គលទាំងឡាយក្តី ឧបសម្បទាបេក្ខបុគ្គលទាំងឡាយក្តី ក៏រមែងលំបាកក្នុងដំណើរនោះ បើដូច្នោះ គួរតថាគតអនុញ្ញាតដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយត្រូវឲ្យបព្វជ្ជា ឲ្យឧបសម្បទា (ដល់កុលបុត្រ) ក្នុងទិសនោះៗ ក្នុងជនបទនោះៗចុះ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកការសម្ងំនៅក្នុងកម្មដ្ឋាន ក្នុងវេលាថ្ងៃរសៀល ហើយព្រះអង្គឲ្យប្រជុំភិក្ខុសង្ឃ រួចធ្វើធម្មីកថា ត្រាស់ចំពោះភិក្ខុទាំងឡាយក្នុងកាលនោះថា ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅក្នុងទីស្ងាត់ សម្ងំក្នុងកម្មដ្ឋានក្នុងទីនេះ ក៏មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ឥឡូវនេះឯង ភិក្ខុទាំងឡាយតែងនាំមកនូវបព្វជ្ជាបេក្ខបុគ្គលទាំងឡាយផង នូវឧបសម្បទាបេក្ខបុគ្គលទាំងឡាយផង អំពីទិសផ្សេងៗ អំពីជនបទផ្សេងៗ ដោយគិតថា ព្រះដ៏មានព្រះភាគ នឹងឲ្យបព្វជ្ជា និងឧបសម្បទាដល់កុលបុត្រទាំងនោះ ភិក្ខុទាំងឡាយក្តី បព្វជ្ជាបេក្ខបុគ្គលទាំងឡាយក្តី ឧបសម្បទាបេក្ខបុគ្គលទាំងឡាយក្តី ក៏រមែងលំបាកក្នុងដំណើរនោះ បើដូច្នោះ គួរតថាគតអនុញ្ញាតដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយចូរឲ្យបព្វជ្ជា ឲ្យឧបសម្បទា (ដល់កុលបុត្រ) ក្នុងទិសនោះៗ ក្នុងជនបទនោះៗចុះ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថា អ្នកទាំងឡាយ ចូរឲ្យបព្វជ្ជា ឲ្យឧបសម្បទា (ដល់កុលបុត្រ) ក្នុងទិសនោះៗ ក្នុងជនបទនោះៗក្នុងកាលឥឡូវនេះចុះ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវឲ្យបព្វជ្ជា ឲ្យឧបសម្បទាយ៉ាងនេះ។ កុលបុត្រនោះ ភិក្ខុគប្បីកោរសក់ និងពុកមាត់ឲ្យជាដម្បូង ហើយឲ្យស្លៀកសំពត់កាសាយៈទាំងឡាយ រួចឲ្យពាក់ចីពរឆៀងស្មាម្ខាង ឲ្យថ្វាយបង្គំបាទាភិក្ខុទាំងឡាយ ហើយឲ្យអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចប្រាប់ថា អ្នកចូរពោលពាក្យយ៉ាងនេះ[34] ថា ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីរលឹក ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីរលឹក ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីរលឹក ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីរលឹក ជាគំរប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់បីដងផង។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណគមន៍ទាំងឡាយនេះ។

ឧបសម្បទាកថា ដោយត្រ័យសរណគមន៍ ចប់។

## ១០. ទុតិយមារកថា

CS vin.mv.01.10 | ភាគ ទី៦

**(១០.)**

[៣៥] គ្រានោះ ព្រះដ៏មានព្រះភាគនៅចាំវស្សារួចហើយ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អរហត្តផលវិមុត្តិដ៏ប្រសើរ តថាគតបានសម្រេចហើយ អរហត្តផលវិមុត្តិដ៏ប្រសើរ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ដោយបានធ្វើទុកក្នុងចិត្តជាឧបាយ ដោយមានសេចក្តីព្យាយាមដ៏ល្អជាឧបាយ ម្នាលភិក្ខុទាំងឡាយ ចំណែកអ្នកទាំងឡាយក៏បានសម្រេចនូវអរហត្តផលវិមុត្តិដ៏ប្រសើរ ក៏បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលវិមុត្តិដ៏ប្រសើរ ដោយបានធ្វើទុកក្នុងចិត្តជាឧបាយ ដោយមានសេចក្តីព្យាយាមដ៏ល្អជាឧបាយ។

គ្រានោះ ក្រុងមារ ជាអ្នកមានចិត្តអាក្រក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបពោលពាក្យជាគាថានឹងព្រះដ៏មានព្រះភាគថា

> បពិត្រព្រះសមណៈ អន្ទាក់ទាំងឡាយណាៗ ទោះបីជារបស់ទេវតាក្តី ជារបស់មនុស្សក្តី ព្រះអង្គជាប់ហើយដោយអន្ទាក់ទាំងនោះ ដែលជាអន្ទាក់របស់មារ ព្រះអង្គជាប់ចំពាក់ហើយដោយចំណងរបស់មារ ព្រះអង្គមិនរួច(អំពីវិស័យ)ខ្ញុំឡើយ។
>
> ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលមារ ជាសត្វដ៏លាមក អន្ទាក់ទាំងឡាយណាៗ ទោះបីជារបស់ទេវតាក្តី ជារបស់មនុស្សក្តី តថាគតរួចស្រឡះហើយចាកអន្ទាក់ទាំងនោះ ដែលជាអន្ទាក់របស់មារ តថាគតរួចហើយចាកចំណងរបស់មារ អ្នកឯងសោត ក៏តថាគតនាំចេញចាកពុតកំណាច (គឺតថាគតផ្ចាញ់ផ្ចាលហើយ)។

គ្រានោះ ក្រុងមារជាអ្នកមានចិត្តបាប កើតទុក្ខ តូចចិត្តថា ព្រះដ៏មានព្រះភាគទ្រង់ស្គាល់អញ ព្រះសុគតទ្រង់ស្គាល់អញ ហើយក៏អន្តរធានបាត់ទៅអំពីកន្លែងនោះឯង។

(ចប់ ទុតិយ មារកថាក់។)

## ១១. ភទ្ទវគ្គិយវត្ថុ

CS vin.mv.01.11 | ភាគ ទី៦

**(រឿងពួកភទ្ទវគ្គិយភិក្ខុជាសំឡាញ់នឹងគ្នា (១១.))**

[៣៦] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងក្រុងពារាណសី គួរដល់ពុទ្ធអធ្យាស្រ័យ រួចទ្រង់យាងចេញទៅកាន់ចារិកក្នុងឧរុវេលាប្រទេស។ កាលនោះ ព្រះអង្គទ្រង់យាងចុះចាកផ្លូវ សំដៅទៅកាន់ដងព្រៃមួយ លុះយាងទៅដល់ហើយ ទ្រង់ចូលទៅកាន់ដងព្រៃនោះ ហើយគង់នៅទៀបគល់ឈើមួយ។

សម័យនោះឯង ពួកភទ្ទវគ្គិយកុមារ ប្រមាណ៣០នាក់ ជាសំឡាញ់នឹងគ្នា ព្រមទាំងភរិយា កំពុងឲ្យភរិយាបម្រើ (ដោយកាម) ក្នុងដងព្រៃនោះ។ មានកុមារម្នាក់ឥតភរិយានឹងគេ។ ទើបកុមារទាំងនោះទៅនាំយកស្រីពេស្យា (ស្រីផ្កាមាស) ម្នាក់មក ដើម្បីប្រយោជន៍ដល់កុមារដែលឥតភរិយានោះ។ លំដាប់នោះឯង កាលដែលកុមារទាំងនោះ ប្រហែសធ្វេស កំពុងឲ្យភរិយារបស់ខ្លួនបម្រើ ស្រីពេស្យានោះបានលួចយកភណ្ឌៈ[35] រត់បាត់ទៅ។ កាលនោះ កុមារជាសំឡាញ់នឹងគ្នាទាំងនោះ ខ្វល់ខ្វាយដល់កុមារជាសំឡាញ់ ជួយស្វែងរកស្រីពេស្យានោះ ក៏បានដើរទៅកាន់ដងព្រៃនោះ បានឃើញព្រះដ៏មានព្រះភាគ គង់នៅទៀបគល់ឈើមួយ លុះឃើញហើយ ទើបនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគបានឃើញស្រី(ម្នាក់)ដែរឬទេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកុមារទាំងឡាយ ចុះអ្នកត្រូវការអ្វីដោយស្រី(នោះ)។ កុមារទាំងអម្បាលនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងអស់គ្នាប្រមាណ៣០នាក់ ជាពួកដ៏ចំរើន ជាសំឡាញ់នឹងគ្នា នៅក្នុងឧរុវេលាប្រទេសនេះ មានភរិយាគ្រប់ៗគ្នា បានឲ្យភរិយាបម្រើក្នុងដងព្រៃនេះ ឯកុមារជាសំឡាញ់ម្នាក់ មិនមានភរិយានឹងគេឡើយ យើងខ្ញុំបាននាំយកស្រីពេស្យាម្នាក់មក ដើម្បីប្រយោជន៍ដល់កុមារជាសំឡាញ់នោះ បពិត្រព្រះអង្គដ៏ចំរើន កាលដែលយើងខ្ញុំប្រហែសធ្វេស កំពុងឲ្យភរិយារបស់ខ្លួនបម្រើ ស្រីពេស្យានោះក៏លួចយកភណ្ឌៈ រត់បាត់ទៅក្នុងពេលនោះ បពិត្រព្រះអង្គដ៏ចំរើន ហេតុនោះ យើងខ្ញុំជាសំឡាញ់នឹងគ្នាខ្វល់ខ្វាយដល់កុមារជាសំឡាញ់ ជួយស្វែងរកស្រីពេស្យានោះ ក៏បានដើរមកកាន់ដងព្រៃនេះ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលកុមារទាំងឡាយ អ្នកទាំងឡាយសំគាល់រឿងនោះដូចម្តេច អ្នកទាំងឡាយគួរស្វែងរកស្រីប្រសើរជាង ឬគួរស្វែងរកខ្លួនប្រសើរជាង។ កុមារទាំងអម្បាលនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំគួរស្វែងរកខ្លួនប្រសើរជាង។ ទើបព្រះអង្គត្រាស់ថា ម្នាលកុមារទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយអង្គុយមកសិនចុះ តថាគតនឹងសំដែងធម៌ដល់អ្នកទាំងឡាយ។ ភទ្ទវគ្គិយកុមារជាសំឡាញ់នឹងគ្នាទាំងនោះទទួលព្រះពុទ្ធដីកាថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងហ្នឹងហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងនូវអនុបុព្វីកថាដល់ពួកភទ្ទវគ្គិយកុមារជាសំឡាញ់នឹងគ្នាទាំងនោះ គឺទ្រង់ប្រកាសទានកថា១ សីលកថា១ សគ្គកថា១ ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង១ អានិសង្សក្នុងការចេញចាកកាម (បួស)១។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា ភទ្ទវគ្គិយកុមារទាំងនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះអង្គ ក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែង ចំពោះព្រះអង្គ គឺសំដែងទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ច១ ក្នុងកាលនោះ។ ធម្មតា សំពត់សស្អាត ប្រាសចាកពណ៌ខ្មៅ គួរទទួលទឹកជ្រលក់បានដោយប្រពៃ មានឧបមាដូចម្តេចមិញ ឯធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ភទ្ទវគ្គិយកុមារទាំងនោះ ក្នុងទីអង្គុយនោះឯងថា ធម្មជាតិណាមួយ ដែលមានកិរិយាកើតឡើង ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង។ ភទ្ទវគ្គិយកុមារទាំងនោះបានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាវៈ ជាអ្នកក្លាហាន មិនបាច់ជឿស្តាប់ពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំគួរបានបព្វជ្ជា គួរបានឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភទ្ទវគ្គិយកុមារទាំងនោះថា អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ ហើយទ្រង់ត្រាស់ថា សាសនធម៌ តថាគតបានសំដែងល្អហើយ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខដោយល្អចុះ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់ភទ្ទវគ្គិយភិក្ខុដ៏មានអាយុទាំងនោះ។

ចប់ រឿងពួកភទ្ទវគ្គិយភិក្ខុជាសំឡាញ់នឹងគ្នា។

ទុតិយភាណវារៈ ចប់។

## ១២. ឧរុវេលបាដិហារិយកថា

CS vin.mv.01.12 | ភាគ ទី៦

### (ឧរុវេលប្បាដិហារិយភាណវារៈ ជាគំរប់បី (១២.))

**បាដិហារ្យជាបឋម**

[៣៧] គ្រានោះ ព្រះដ៏មានព្រះភាគ ត្រាច់ទៅកាន់ចារិកតាមលំដាប់ ក៏ទ្រង់ពុទ្ធដំណើរសំដៅទៅកាន់ឧរុវេលាប្រទេស។ សម័យនោះឯង ជដិល៣នាក់ (ជាបងប្អូននឹងគ្នា) គឺឧរុវេលកស្សប១ នទីកស្សប១ គយាកស្សប១ អាស្រ័យនៅក្នុងឧរុវេលាប្រទេស(នោះ)។ បណ្តាជដិលទាំងនោះ មានជដិលឈ្មោះឧរុវេលកស្សបជានាយក ជាអ្នកដឹកនាំ ជាកំពូល ជាប្រធាន ជាបុគ្គលដ៏ឧត្តម ប្រសើរជាងជដិល៥០០នាក់។ ជដិលឈ្មោះនទីកស្សប ជានាយក ជាអ្នកដឹកនាំ ជាកំពូល ជាប្រធាន ជាបុគ្គលដ៏ឧត្តម ប្រសើរជាងជដិល៣០០នាក់។ ជដិលឈ្មោះគយាកស្សប ជានាយក ជាអ្នកដឹកនាំ ជាកំពូល ជាប្រធាន ជាបុគ្គលដ៏ឧត្តម ប្រសើរជាងជដិល២០០នាក់។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងចូលទៅកាន់អាស្រមរបស់ជដិលឈ្មោះឧរុវេលកស្សប លុះចូលទៅដល់ហើយ ទ្រង់មានព្រះពុទ្ធដីកានឹងជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប បើអ្នកមិនចង្អៀតចង្អល់ទេ យើងសូមនៅក្នុងរោងភ្លើងបានមួយរាត្រី។ ឧរុវេលកស្សបពោលតបថា បពិត្រមហាសមណៈ ខ្ញុំមិនមានសេចក្តីចង្អៀតចង្អល់អ្វីទេ តែថាក្នុងរោងភ្លើងនេះមាននាគរាជមួយជាសត្វកាច មានឫទ្ធិ មានពិសក្នុងចង្កូម មានពិសដ៏ពន្លឹក កុំឲ្យតែនាគរាជនោះវាបៀតបៀនព្រះអង្គ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងជដិលឈ្មោះ ឧរុវេលកស្សបជាគំរប់ពីរដងទៀតថា នែកស្សប បើអ្នកមិនចង្អៀតចង្អល់ទេ យើងសូមនៅក្នុងរោងភ្លើងបានមួយរាត្រី។ ឧរុវេលកស្សបពោលតបថា បពិត្រមហាសមណៈ ខ្ញុំមិនមានសេចក្តីចង្អៀតចង្អល់អ្វីទេ តែក្នុងរោងភ្លើងនេះ មាននាគរាជមួយជាសត្វកាច មានឫទ្ធិ មានពិសក្នុងចង្កូម មានពិសដ៏ពន្លឹក កុំឲ្យតែនាគរាជនោះវាបៀតបៀនព្រះអង្គ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងជដិល

ឈ្មោះ ឧរុវេលកស្សបជាគំរប់បីដងទៀតថា នែកស្សប បើអ្នកមិនចង្អៀតចង្អល់ទេ យើងសូមនៅក្នុងរោងភ្លើងបានមួយរាត្រី។ ឧរុវេលកស្សបពោលតបថា បពិត្រមហាសមណៈ ខ្ញុំមិនមានសេចក្តីចង្អៀតចង្អល់អ្វីទេ តែក្នុងរោងភ្លើងនេះ មាននាគរាជមួយ ជាសត្វកាច មានឫទ្ធិ មានពិសក្នុងចង្កូម មានពិសដ៏ពន្លឹក កុំឲ្យតែនាគរាជនោះវាបៀតបៀនព្រះអង្គ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែកស្សប នាគរាជនោះបៀតបៀនយើងមិនបានទេ ណ្ហើយចុះ អ្នកចូរព្រមឲ្យរោងភ្លើង (ដល់យើងចុះ)។ ឧរុវេលកស្សបតបថា បពិត្រមហាសមណៈ ព្រះអង្គចូរនៅតាមសប្បាយចុះ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ចូលទៅកាន់រោងភ្លើង ហើយក្រាលនូវកម្រាលស្មៅ គង់ផ្គត់ភ្នែន តាំងកាយដ៏ត្រង់ដម្កល់សតិឆ្ពោះមុខទៅកាន់កម្មដ្ឋាន។

[៣៨] គ្រានោះ នាគនោះបានឃើញព្រះដ៏មានព្រះភាគ យាងចូលទៅ លុះឃើញហើយ កើតទុក្ខ តូចចិត្ត ក៏បណ្តាលផ្សែងឲ្យហុយចេញ។ ឯព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា ការនេះគួរតថាគត កុំបៀតបៀនស្បែកសម្បុរថ្ងៃ ស្បែកបន្ទាប់ សាច់ សរសៃ ឆ្អឹង និងខួរក្នុងឆ្អឹងរបស់នាគរាជនេះឲ្យសោះ ហើយគ្រាន់តែគ្របសង្កត់តេជះ (របស់នាគរាជ) ដោយតេជះរបស់តថាគតចុះ។ លំដាប់នោះ ព្រះដ៏មានព្រះភាគសំដែងឥទ្ធាភិសង្ខារ មានសភាពដូច្នោះហើយ ក៏បណ្តាលផ្សែងឲ្យហុយតបទៅវិញ។ ចំណែកនាគនោះ អត់ទ្រាំសេចក្តីក្រោធមិនបាន ក៏បណ្តាលភ្លើងឲ្យឆេះឡើង។ ឯព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ចូលឈាន មានតេជោធាតុជាអារម្មណ៍ ហើយទ្រង់បណ្តាលភ្លើងឲ្យឆេះឡើងដែរ។ កាលបើអ្នកមានឫទ្ធិទាំងពីរបណ្តាលពន្លឺភ្លើងឲ្យភ្លឺព្រោងព្រាយឡើងហើយ ឯរោងភ្លើងក៏រុងរឿងភ្លឺសន្ធោរសន្ធៅឡើងហាក់ដូចជាភ្លើងឆេះ។ លំដាប់នោះ ជដិលទាំងអម្បាលនោះ នាំគ្នាចោមរោមរោងភ្លើង ហើយពោលយ៉ាងនេះថា ឱសមណៈមានរូបល្អម្ល៉េះ ឥឡូវត្រូវនាគរាជបៀតបៀន។ ឯព្រះដ៏មានព្រះភាគ លុះរាត្រីនោះកន្លងទៅហើយ ទ្រង់មិនបានប៉ះពាល់ស្បែកក្រៅ ស្បែកបន្ទាប់ សាច់ សរសៃ ឆ្អឹង នឹងខួរក្នុងឆ្អឹងរបស់នាគនោះ ទ្រង់គ្របសង្កត់តេជះដោយតេជះ ហើយទ្រង់ចាប់នាគច្រកក្នុងបាត្រ (នាំយកទៅ) បង្ហាញដល់ជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប នេះនាគរបស់អ្នកឯង តថាគតបានគ្របសង្កត់តេជះរបស់វា ដោយតេជះតថាគតហើយ។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សបត្រិះរិះដូច្នេះថា មហាសមណៈ (នេះ) មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះហេតុថា (ព្រះអង្គ) អាចគ្រប់សង្កត់តេជះរបស់នាគជាសត្វកាច មានឫទ្ធិ មានពិសក្នុងចង្កូម មានពិសដ៏ពន្លឹក ដោយតេជះ(របស់ព្រះអង្គបាន) តែបើទុកជាយ៉ាងនោះ ក៏គង់មិនមែនជាព្រះអរហន្តដូចអញទេ។

[៣៩] ព្រះដ៏មានព្រះភាគ (ទ្រង់ប្រថាប់នៅ) ជិតឆ្នេរស្ទឹងនេរញ្ជរា ទ្រង់មានព្រះពុទ្ធដីកានឹងជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប បើអ្នកមិនចង្អៀតចង្អល់ទេ តថាគតសុំនៅក្នុងរោងភ្លើងក្នុងថ្ងៃនេះបាន១ថ្ងៃសិន។ ឧរុវេលកស្សបពោលតបថា អើមហាសមណៈ ខ្ញុំមិនចង្អៀតចង្អល់ទេ ប៉ុន្តែខ្ញុំប្រាថ្នាសេចក្តីសប្បាយ ទើបឃាត់ព្រះអង្គថា ក្នុងរោងភ្លើងនេះមាននាគរាជមួយជាសត្វកាច មានឫទ្ធិ មានពិសក្នុងចង្កូម មានពិសដ៏ពន្លឹក កុំឲ្យនាគរាជនោះវាបៀតបៀនព្រះអង្គឡើយ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែកស្សប ឯនាគនោះមិនអាចបៀតបៀនតថាគតបានទេ ណ្ហើយចុះ អ្នកចូរព្រមឲ្យរោងភ្លើង (ដល់តថាគតចុះ)។

> ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា ឧរុវេលកស្សបព្រមឲ្យហើយ ព្រះអង្គមិនតក់ស្លុត ឥតមានកោតញញើត ទើបយាងចូលទៅ។ ពស់ជាអហិនាគ បានឃើញព្រះអង្គយាងចូលទៅ ក៏តូចចិត្ត ទើបបណ្តាលផ្សែងឲ្យហុយចេញ។ ឯព្រះសម្ពុទ្ធជាមនុស្សនាគ ទ្រង់មានព្រះហឫទ័យរីករាយ ឥតមានសេចក្តីអាក់អន់ ក៏បណ្តាលផ្សែងឲ្យហុយចេញក្នុងទីនោះដែរ។ ចំណែកអហិនាគ អត់ទ្រាំសេចក្តីក្រោធមិនបាន ក៏បណ្តាលភ្លើងឲ្យឆេះឡើង ដូចជាភ្លើងធម្មតា។ ឯមនុស្សនាគ ទ្រង់ឆ្លាសក្នុងឈាន មានតេជោធាតុជាអារម្មណ៍ ក៏បណ្តាលឲ្យឆេះឡើងក្នុងទីនោះដែរ។ កាលបើអ្នកមានឫទ្ធិទាំងពីរបណ្តាលឲ្យភ្លើងភ្លឺព្រោងព្រាយឡើងព្រមគ្នាហើយ ពួជដិលដ៏ចោមរោមរោងភ្លើង។

ជដិលទាំងឡាយនិយាយគ្នាថា ឱ មហាសមណៈមានរូបល្អម្ល៉េះ ឥឡូវត្រូវនាគបៀតបៀន។

> លុះរាត្រីកន្លងទៅហើយ រស្មីរបស់អហិនាគក៏រលត់សូន្យទៅ។ ឯរស្មីមានពណ៌ច្រើនរបស់ព្រះសម្ពុទ្ធដ៏មានឫទ្ធិ ក៏តាំងនៅដដែល។ រស្មីមានពណ៌ច្រើនគឺ ខៀវខ្លះ ក្រហមខ្លះ ហង្សបាទ (ក្រហមទន់)ខ្លះ លឿងខ្លះ ពណ៌ផ្លេកខ្លះ មាននៅក្នុងព្រះកាយរបស់ព្រះសម្ពុទ្ធដែលមានព្រះនាមថា អង្គីរស។ ព្រះសម្ពុទ្ធទ្រង់ចាប់អហិនាគច្រកក្នុងបាត្រហើយ (នាំទៅ) បង្ហាញព្រាហ្មណ៍ថា នែកស្សប នេះនាគរបស់អ្នក តថាគតគ្របសង្កត់តេជះរបស់វា ដោយតេជះរបស់តថាគតហើយ។

គ្រានោះ ជដិលឈ្មោះឧរុវេលកស្សប ជ្រះថ្លាដោយឥទ្ធិប្បាដិហារ្យនេះ របស់ព្រះដ៏មានព្រះភាគ ទើបក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រមហាសមណៈ សូមព្រះអង្គគង់នៅក្នុងទីនេះ ខ្ញុំនឹងអង្គាសដោយនិច្ចភត្តដល់ព្រះអង្គ។

ចប់ បាដិហារ្យជាបឋម។

**បាដិហារ្យជាគំរប់២**

[៤០] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃមួយ ក្នុងទីជិតអាស្រមរបស់ជដិលឈ្មោះឧរុវេលកស្សប។ កាលនោះ ទេវតាទាំង៤ ជាស្តេចធំ មានសម្បុរល្អ (ចុះមក) ក្នុងវេលាពាក់កណ្តាលអធ្រាត្រ បណ្តាលរស្មីឲ្យភ្លឺក្នុងដងព្រៃទាំងអស់ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ទើបឋិតនៅក្នុងទិសទាំង៤ មានគួរនាដូចគំនរភ្លើងដ៏ធំ។ លុះរាត្រីនោះកន្លងហើយ ទើបជដិលឈ្មោះឧរុវេលកស្សបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា

បពិត្រមហាសមណៈ កាល(នេះ) ជាកាលសមគួរហើយ ភត្តាហារសម្រេចហើយ បពិត្រមហាសមណៈ ចុះអ្នកណាដែលមានសម្បុរល្អ (ចុះមក) ក្នុងវេលាពាក់កណ្តាលអធ្រាត្រ បណ្តាលរស្មីឲ្យភ្លឺក្នុងដងព្រៃទាំងអស់ ហើយចូលមកគាល់ព្រះអង្គ លុះចូលមកដល់ហើយ ថ្វាយបង្គំព្រះអង្គ ហើយស្ថិតនៅក្នុងទិសទាំង៤ មានគួរនាដូចគំនរភ្លើងដ៏ធំ។ ទ្រង់ត្រាស់ថា នែកស្សប ឯអ្នកទាំងនោះ គឺស្តេចធំទាំង៤ ចូលមកគាល់តថាគតដើម្បីនឹងស្តាប់ធម៌។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សបត្រិះរិះដូច្នេះថា មហាសមណៈ (នេះ) មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះហេតុថា អម្បាលមហារាជទាំង៤ ក៏គង់ចូលមកគាល់ដើម្បីស្តាប់ធម៌ដែរ តែបើទុកជាយ៉ាងនោះ ក៏គង់មិនមែនជាព្រះអរហន្តដូចអញទេ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់សោយភត្តាហាររបស់ជដិលឈ្មោះឧរុវេលកស្សបស្រេចហើយ ទ្រង់ប្រថាប់នៅក្នុងដងព្រៃនោះឯង។

ចប់ បាដិហារ្យជាគំរប់២។

## បាដិហារ្យជាគំរប់៣

[៤១] គ្រានោះ សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ មានពណ៌ល្អ បណ្តាលរស្មីឲ្យភ្លឺក្នុងដងព្រៃទាំងអស់ ក្នុងវេលាកណ្តាលអធ្រាត្រ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ មានគួរនាដូចគំនរភ្លើងធំដ៏រុងរឿង និងឧត្តមជាងរស្មីនៃពណ៌ដែលមានហើយក្នុងកាលយប់មុន។ លុះរាត្រីនោះកន្លងហើយ ទើបជដិលឈ្មោះឧរុវេលកស្សបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រមហាសមណៈ កាល(នេះ) ជាកាលសមគួរហើយ ភត្តាហារក៏សម្រេចហើយ បពិត្រមហាសមណៈ ចុះអ្នកណាដែលមានពណ៌ល្អ បណ្តាលរស្មីឲ្យភ្លឺក្នុងដងព្រៃទាំងអស់ ក្នុងវេលាកណ្តាលអធ្រាត្រ ហើយចូលមកគាល់ព្រះអង្គ លុះចូលមកដល់ហើយ ថ្វាយបង្គំព្រះអង្គ ទើបឋិតនៅក្នុងទីដ៏សមគួរ មានគួរនាដូចគំនរភ្លើងធំដ៏រុងរឿង និងឧត្តមជាងរស្មីនៃពណ៌ដែលមានហើយក្នុងកាលយប់មុន។ ទ្រង់ត្រាស់ថា នែកស្សប អ្នកនោះហើយ គឺសក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ ចូលមករកតថាគត ដើម្បីនឹងស្តាប់ធម៌។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សបមានសេចក្តីត្រិះរិះយ៉ាងនេះថា មហាសមណៈ (នេះ) មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះថា សក្កទេវរាជ ជាធំជាងពួកទេវតា គង់ចូលមកគាល់ដើម្បីនឹងស្តាប់ធម៌ តែបើទុកជាយ៉ាងនោះ ក៏គង់មិនមែនជាព្រះអរហន្តដូចអញទេ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់សោយភត្តាហាររបស់ជដិលឈ្មោះឧរុវេលកស្សបស្រេចហើយ ទ្រង់ប្រថាប់នៅក្នុងដងព្រៃនោះឯង។

ចប់ បាដិហារ្យជាគំរប់៣។

## បាដិហារ្យជាគំរប់៤

[៤២] លំដាប់នោះ សហម្បតិព្រហ្ម មានសម្បុរល្អ បណ្តាលរស្មីឲ្យភ្លឺក្នុងដងព្រៃទាំងអស់ ក្នុងវេលាកណ្តាលអធ្រាត្រ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ទើបឋិតនៅក្នុងទីដ៏សមគួរមួយ មានគួរនាដូចគំនរភ្លើងធំដ៏រុងរឿង និងឧត្តមជាងរស្មីនៃពណ៌ដែលមានហើយក្នុងយប់មុនៗ។ កាលបើរាត្រីនោះកន្លងទៅហើយ ទើបជដិលឈ្មោះឧរុវេលកស្សបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យនេះថា បពិត្រមហាសមណៈ កាល(នេះ) ជាកាលសមគួរហើយ ភត្តាហារក៏សម្រេចហើយ បពិត្រមហាសមណៈ ចុះអ្នកណាហ្ន៎មានពណ៌ល្អ បណ្តាលរស្មីឲ្យភ្លឺក្នុងដងព្រៃទាំងអស់ ក្នុងវេលាកណ្តាលអធ្រាត្រ ចូលមកគាល់ព្រះអង្គ លុះចូលមកដល់ហើយ ថ្វាយបង្គំព្រះអង្គ ហើយឋិតនៅក្នុងទីដ៏សមគួរ គួរនាដូចគំនរភ្លើងដ៏ធំ រុងរឿង និងឧត្តមជាងរស្មីនៃពណ៌ដែលមានក្នុងយប់មុនៗនោះ។ ព្រះអង្គត្រាស់ថា នែកស្សប ជននោះឯង គឺសហម្បតិព្រហ្ម ចូលមករកតថាគត ដើម្បីនឹងស្តាប់ធម៌។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សបមានសេចក្តីត្រិះរិះដូច្នេះថា មហាសមណៈ (នេះ) មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះថា អម្បាលសហម្បតិព្រហ្ម ក៏គង់ចូលមកគាល់ដើម្បីនឹងស្តាប់ធម៌ដែរ តែបើទុកជាយ៉ាងនោះ ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។ ក្នុងកាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់សោយភត្តាហាររបស់ជដិលឈ្មោះឧរុវេលកស្សបស្រេចហើយ ទ្រង់ប្រថាប់នៅក្នុងដងព្រៃនោះឯង។

ចប់ បាដិហារ្យជាគំរប់៤។

## បាដិហារ្យជាគំរប់៥

[៤៣] សម័យនោះឯង គ្រឿងបូជាធំ នឹងកើតឡើងដល់ជដិលឈ្មោះឧរុវេលកស្សប។ (ព្រោះថា) ជនអ្នកនៅក្នុងដែនអង្គៈ និងមគធៈទាំងអស់គ្នា ប្រាថ្នានឹងនាំយកខាទនីយភោជនីយាហារមានប្រមាណច្រើនចូលមកបូជា។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សប មានសេចក្តីត្រិះរិះដូច្នេះថា កាលឥឡូវនេះឯង គ្រឿងបូជាធំនឹងកើតឡើងដល់អញ ដ្បិតថាជនអ្នកនៅក្នុងដែនអង្គៈ និងមគធៈទាំងអស់គ្នា នឹងនាំយកខាទនីយភោជនីយាហារមានប្រមាណច្រើនចូលមកបូជា បើមហាសមណៈនឹងធ្វើឥទ្ធិប្បាដិហារ្យក្នុងទីប្រជុំមហាជន លាភសក្ការៈនឹងចំរើនដល់មហាសមណៈ លាភសក្ការៈរបស់អញ ក៏នឹងសាបសូន្យទៅ ឱមហាសមណៈ កុំគប្បីមកឆាន់ក្នុងថ្ងៃស្អែកនេះទៅអេះ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបសេចក្តីបរិវិតក្កក្នុងចិត្តរបស់ជដិលឈ្មោះឧរុវេលកស្សប ដោយព្រះហឫទ័យព្រះអង្គ ទើបទ្រង់យាងទៅកាន់ឧត្តរកុរុទ្វីប នាំយកចង្ហាន់បិណ្ឌបាតមកអំពីឧត្តរកុរុទ្វីបនោះ ហើយទ្រង់សោយជិតស្រះអនោតត្ត ហើយទ្រង់សម្រាកឥរិយាបទនៅក្នុងវេលាថ្ងៃក្នុងកន្លែងនោះឯង។កាលបើរាត្រីនោះកន្លងទៅហើយ ទើបជដិលឈ្មោះឧរុវេលកស្សបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យនេះថា បពិត្រមហាសមណៈ កាល(នេះ) ជាកាលសមគួរហើយ ភត្តាហារក៏សម្រេចហើយ បពិត្រមហាសមណៈ ហេតុដូចម្តេច ក៏ព្រះអង្គមិនយាងមកក្នុងថ្ងៃម្សិលមិញ ចំណែកខ្ញុំ ៗតែងរលឹកព្រះអង្គ ទន្ទឹងចាំមើលផ្លូវថា មហាសមណៈមិនមកទេឬអ្វី ហើយបានទាំងដំកល់ចំណែកខាទនីយាហារទុក ដើម្បីព្រះអង្គ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែកស្សប ក្រែងអ្នកត្រិះរិះដូច្នេះថា ក្នុងកាលឥឡូវនេះ គ្រឿងបូជាធំនឹងកើតឡើងដល់អញ ដ្បិតថា ជនអ្នកនៅក្នុងដែនអង្គៈ និងមគធៈទាំងអស់គ្នា នឹងនាំយកខាទនីយភោជនីយាហារមានប្រមាណច្រើនចូលមកបូជា បើមហាសមណៈនឹងធ្វើឥទ្ធិប្បាដិហារ្យក្នុងទីប្រជុំមហាជន ឯលាភសក្ការៈនឹងចំរើនដល់មហាសមណៈ លាភសក្ការៈរបស់អញនឹងសាបសូន្យទៅ ឱមហាសមណៈ កុំគប្បីមកឆាន់ក្នុងថ្ងៃស្អែកទៅអេះ ដូច្នេះ ពិតមែនឬទេ នែកស្សប ចំណែកតថាគតឯង បានដឹងសេចក្តី

បរិវិតក្កក្នុងចិត្តរបស់អ្នកឯង ដោយចិត្តតថាគត ហើយតថាគតក៏ទៅកាន់ឧត្តរកុរុទ្វីប នាំយកចង្ហាន់បិណ្ឌបាតមកអំពីទ្វីបនោះ រួចឆាន់ជិតស្រះអនោតត្ត ហើយសម្រាកឥរិយាបថក្នុងវេលាថ្ងៃក្នុងកន្លែងនោះឯង។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សប ត្រិះរិះដូច្នេះថា មហាសមណៈនេះ មានឫទ្ធិខ្លាំងណាស់តើ មានអានុភាពធំមែន ព្រោះថា ព្រះអង្គស្គាល់ចិត្តដោយចិត្តរបស់ព្រះអង្គបាន តែបើទុកជាយ៉ាងនោះ ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់សោយភត្តាហាររបស់ជដិលឈ្មោះឧរុវេលកស្សបស្រេចហើយ ទ្រង់ប្រថាប់នៅក្នុងដងព្រៃនោះឯង។

ចប់ បាដិហារ្យជាគំរប់៥។

[៤៤] សម័យនោះឯង សំពត់បង្សុកូល[36] កើតឡើងដល់ព្រះដ៏មានព្រះភាគ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់រំពឹងដូច្នេះថា តថាគតគួរនឹងលាងសំពត់បង្សុកូលក្នុងទីណាអេះ។ លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា បានជ្រាបពុទ្ធបរិវិតក្ករបស់ព្រះដ៏មានព្រះភាគ ដោយចិត្តរបស់ខ្លួន ហើយក៏ជីកស្រះ (មួយ) ដោយដៃឯង ហើយក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គលាងសំពត់បង្សុកូលក្នុងស្រះនេះចុះ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា តថាគតគួរបោកគក់សំពត់បង្សុកូលនឹងរបស់អ្វីអេះ។ លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ជ្រាបចេតោបរិវិតក្ក (ព្រះតម្រិះ) របស់ព្រះដ៏មានព្រះភាគ ដោយចិត្តរបស់ខ្លួន ទើបនាំយកថ្ម១ផែនធំមកថ្វាយដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ បោកគក់សំពត់បង្សុកូលលើថ្មនេះចុះ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់រំពឹងថា តថាគតគួរពាក់ព្យួរ ហើយពូតនឹងរបស់អ្វីហ្ន៎។ លំដាប់នោះ មានទេវតាអាស្រ័យនៅលើដើមថ្ងាន់ ជ្រាបចេតោបរិវិតក្ក របស់ព្រះដ៏មានព្រះភាគ ដោយចិត្តរបស់ខ្លួន ទើបបង្អោនមែកថ្ងាន់ឲ្យទាបចុះមក ដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ពាក់ព្យួរ ហើយពូតនឹងមែនថ្ងាន់នេះចុះ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់រំពឹងទៀតថា តថាគតគួរត្រដាងហាលសំពត់បង្សុកូលត្រង់កន្លែងណាហ្ន៎។ ខណៈនោះ សក្កទេវរាជ ជាធំជាងទេវតា ទ្រង់ជ្រាបចេតោបរិវិតក្ករបស់ព្រះដ៏មានព្រះភាគ ដោយចិត្តរបស់ខ្លួន ទើបនាំយកថ្ម១ផែនធំមកថ្វាយ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ត្រដាងហាលសំពត់បង្សុកូលលើថ្មនេះចុះ។ កាលបើរាត្រីនោះកន្លងទៅហើយ ជដិលឈ្មោះឧរុវេលកស្សប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យនេះថា មហាសមណៈ កាលនេះជាកាលសមគួរហើយ ភត្តាហារក៏សម្រេចហើយ បពិត្រមហាសមណៈ ស្រះបោក្ខរណីនេះ ពីមុនមិនមានក្នុងកន្លែងនេះទេ (ឥឡូវនេះ) ស្រះបោក្ខរណីនោះ មានក្នុងកន្លែងនេះ ផែនថ្មនេះគេដម្កល់ទុកពីមុន ក៏មិនមានដែរ ចុះ(ឥឡូវនេះ) ផែនថ្មនេះ អ្នកណាគេដម្កល់ទុក មែកថ្ងាន់នេះកាលពីមុនមិនទាបចុះមកទេ (ក៏ឥឡូវ)នេះ មែកថ្ងាន់នេះឯង ទៅជាទាបចុះមក ព្រោះហេតុអ្វីហ្ន៎។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា នែកស្សប សំពត់បង្សុកូល កើតឡើងដល់តថាគតក្នុងទីនេះ នែកស្សប តថាគតរំពឹងដូច្នេះថា តថាគតគួរលាងសំពត់បង្សុកូលក្នុងទីណាហ្ន៎ នែកស្សប (លុះតថាគតរំពឹងយ៉ាងនេះហើយ) លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ជ្រាបចេតោបរិវិតក្ករបស់តថាគត ដោយចិត្តរបស់គេ ក៏ជីកស្រះបោក្ខរណី ដោយដៃ ហើយពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ លាងសំពត់បង្សុកូលក្នុងស្រះបោក្ខរណីនេះចុះ ស្រះបោក្ខរណីនេះ ហើយដែលអមនុស្ស[37] ជីកដោយដៃ នែកស្សប តថាគតរំពឹងដូច្នេះទៀតថា តថាគតគួរបោកគក់សំពត់បង្សុកូលលើអ្វីហ្ន៎ ម្នាលកស្សប កាលនោះ សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ជ្រាបចេតោបរិវិតក្ក របស់តថាគត ដោយចិត្តរបស់គេ ទើបនាំយកផែនថ្ម១ផ្ទាំងធំ មកថ្វាយដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ បោកគក់សំពត់បង្សុកូលលើថ្មនេះចុះ ថ្មនេះឯងដែលអមនុស្សបានដម្កល់ទុក ម្នាលកស្សប តថាគតរំពឹងដូច្នេះទៀតថា តថាគតគួរពាក់ព្យួរ ហើយពូតនឹងរបស់អ្វីហ្ន៎ កស្សប ក្នុងកាលនោះ ទេវតាអាស្រ័យនៅលើដើមថ្ងាន់ ជ្រាបចេតោបរិវិតក្ក របស់តថាគត ដោយចិត្តរបស់គេ ទើបបង្អោនមែកថ្ងាន់ឲ្យទាបចុះមក ដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ពាក់ព្យួរ ហើយពូតនឹងមែនថ្ងាន់នេះចុះ ឯដើមថ្ងាន់ក៏ទន់ទោរមកតោងដោយដៃបាន កស្សប តថាគតរំពឹងដូច្នេះទៀតថា តថាគតគួរត្រដាងហាលសំពត់បង្សុកូលត្រង់កន្លែងណាហ្ន៎ កស្សប លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ជ្រាបចេតោបរិវិតក្ករបស់តថាគត ដោយចិត្តរបស់គេ ទើបនាំយកផែនថ្ម១ផ្ទាំងធំមកថ្វាយ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ត្រដាងហាលសំពត់បង្សុកូលលើថ្មនេះចុះ ថ្មនេះហើយ ដែលអមនុស្សគេបានដម្កល់ទុក។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សប ត្រិះរិះដូច្នេះថា មហាសមណៈនេះ មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះថា អម្បាលសក្កទេវរាជ ជាធំជាងទេវតា ក៏គង់មកធ្វើការបម្រើ តែបើទុកជាយ៉ាងនោះ ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់សោយភត្តាហាររបស់ជដិលឈ្មោះឧរុវេលកស្សបហើយ ទ្រង់ប្រថាប់នៅក្នុងដងព្រៃនោះឯង។

[៤៥] កាលបើរាត្រីនោះកន្លងទៅហើយ ទើបជដិលឈ្មោះឧរុវេលកស្សប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលនូវកាល (នៃភត្ត) ដល់ព្រះដ៏មានព្រះភាគថា បពិត្រមហាសមណៈ កាលនេះជាកាលគួរហើយ ភត្តាហារក៏សម្រេចហើយ។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាថា ម្នាលកស្សប អ្នកឯងចូរទៅចុះ តថាគតនឹងទៅក្រោយ។ ព្រះដ៏មានព្រះភាគ លុះបញ្ជូនឧរុវេលកស្សបឲ្យទៅមុនហើយ ក៏ទ្រង់យាងទៅកាន់ជម្ពូទ្វីប ដែលលោកសន្មតដោយដើមព្រីង ហើយនាំយកផ្លែអំពីដើមព្រីងនោះ រួចយាងត្រឡប់មកគង់ក្នុងរោងភ្លើង បានមុនជដិលនោះវិញ។ ជដិលឈ្មោះឧរុវេលកស្សប ក៏បានឃើញព្រះដ៏មានព្រះភាគ គង់នៅក្នុងរោងភ្លើងដោយច្បាស់លាស់ លុះឃើញហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រមហាសមណៈ ព្រះអង្គទ្រង់ពុទ្ធដំណើរមកតាមផ្លូវណា (កាលដែលមក) ខ្ញុំចេញមកមុនព្រះអង្គ (លុះមកដល់ទីនេះ) ត្រឡប់ជាព្រះអង្គមកដល់គង់នៅក្នុងរោងភ្លើងមុនខ្ញុំភ្លាម។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កស្សប កាលតថាគតបានបញ្ជូនអ្នកមកក្នុងទីនេះហើយ តថាគតទៅកាន់ជម្ពូទ្វីប ដែលលោកសន្មតដោយដើមព្រីង ហើយតថាគតនាំយកផ្លែអំពីដើមព្រីងនោះ រួចមកអង្គុយនៅក្នុងរោងភ្លើង(នេះ) បានមុនអ្នក កស្សប ផ្លែនេះគឺផ្លែព្រីង មានសម្បុរល្អ មានក្លិនក្រអូប មានរសឆ្ងាញ់ បើអ្នកចង់បរិភោគ ចូរបរិភោគចុះ។ ជដិលឈ្មោះឧរុវេលកស្សបក្រាបទូលថា បពិត្រមហាសមណៈ ណ្ហើយ (ខ្ញុំអរហើយ) ព្រះអង្គបាននាំមកនូវផ្លែព្រីងនេះ សូមព្រះអង្គសោយផ្លែព្រីងនេះព្រះអង្គឯងចុះ។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សប រិះគិតដូច្នេះថា មហាសមណៈនេះ មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះកាលព្រះអង្គបញ្ជូនអញមក (ក្នុងទីនេះ) មុនព្រះអង្គ ហើយទ្រង់ទៅកាន់ជម្ពូទ្វីបដែលលោកសន្មតដោយដើមព្រីង ហើយនាំយកផ្លែអំពីដើមព្រីងនោះ រួចត្រឡប់ជាមកគង់នៅក្នុងរោងភ្លើង(នេះ) បានមុនអញវិញ តែបើទុកជាយ៉ាងនោះឯង ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។ កាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់សោយភត្តាហាររបស់ជដិលឈ្មោះឧរុវេលកស្សបហើយ ទ្រង់ប្រថាប់នៅក្នុងដងព្រៃនោះឯង។ កាលបើរាត្រីនោះកន្លងទៅហើយ ជដិលឈ្មោះឧរុវេលកស្សប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបទូលនូវកាល (នៃភត្ត) ដល់ព្រះដ៏មាន

ព្រះភាគថា បពិត្រមហាសមណៈ កាលនេះជាកាលគួរហើយ ភត្តាហារក៏សម្រេចហើយ។ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ជូនជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប អ្នកទៅ (មុន)ចុះ តថាគតនឹងទៅ(តាមក្រោយ) ហើយព្រះអង្គយាងទៅកាន់ជម្ពូទ្វីប ដែលលោកសន្មតដោយដើមព្រីង ក៏ទ្រង់នាំផ្លែស្វាយនៅជិតដើមព្រីងនោះ។បេ។ ទ្រង់នាំយកផ្លែកន្ទួតនៅជិតដើមព្រីងនោះ។បេ។ ទ្រង់នាំយកផ្លែសម៉ នៅជិតដើមព្រីងនោះ។បេ។ ទ្រង់យាងទៅកាន់ស្ថានតាវត្តឹង្ស ទេវលោក ហើយទ្រង់នាំមកនូវផ្កាបារិច្ឆត្តកព្រឹក្ស រួចទ្រង់មកគង់នៅក្នុងរោងភ្លើងជាមុន។ ជដិលឈ្មោះឧរុវេលកស្សប ក៏បានឃើញព្រះដ៏មានព្រះភាគ គង់នៅក្នុងរោងភ្លើងដោយច្បាស់លាស់ លុះឃើញហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រមហាសមណៈ ព្រះអង្គទ្រង់ពុទ្ធដំណើរមកតាមផ្លូវណា (កាលដែលមក) ខ្ញុំចេញមកមុនព្រះអង្គ (វេលាមកដល់ក្នុងទីនេះ) ត្រឡប់ជាព្រះអង្គមកគង់នៅក្នុងរោងភ្លើងបានមុនខ្ញុំវិញ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែកស្សប កាលតថាគតបញ្ជូនអ្នកមកក្នុងទីនេះ ហើយតថាគតទៅកាន់ស្ថានតាវត្តឹង្ស នាំមកនូវផ្កាបារិច្ឆត្តកព្រឹក្ស រួចមកអង្គុយនៅក្នុងរោងភ្លើង បានមុនអ្នកឯង កស្សប នេះឯងផ្កាបារិច្ឆត្តកព្រឹក្ស មានសម្បុរល្អ មានក្លិនក្រអូបមែន។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សប ត្រិះរិះដូច្នេះថា មហាសមណៈ(នេះ) មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះថា ព្រះអង្គបញ្ជូនអញឲ្យមកមុនព្រះអង្គ រួចព្រះអង្គយាងទៅកាន់ឋានតាវត្តឹង្ស នាំយកផ្កាបារិច្ឆត្តកព្រឹក្ស ហើយមកគង់នៅក្នុងរោងភ្លើងនេះ បានមុនអញ តែបើទុកជាយ៉ាងនោះសោត ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។

[៤៦] សម័យនោះឯង ជដិលទាំងអម្បាលនោះប្រាថ្នានឹងធ្វើសេចក្ដីគោរពភ្លើង ក៏មិនអាចនឹងពុះឧសទាំងឡាយឲ្យបែកចេញបាន។ កាលនោះ ជដិលទាំងអម្បាលនោះមានសេចក្ដីត្រិះរិះដូច្នេះថា យើងមិនអាចនឹងពុះឧសឲ្យបែកបានដោយហេតុណា ហេតុនោះ គឺជាឥទ្ធានុភាពរបស់មហាសមណៈដោយពិតឥតសង្ស័យ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប អ្នកចូរពុះឧសទាំងឡាយឲ្យបែកទៅ។ ឧរុវេលកស្សបទូលថា បពិត្រមហាសមណៈ សូមព្រះអង្គធ្វើឧសទាំងឡាយឲ្យបែកឲ្យទាន។ ចំណែកឧសទាំង៥០០ដុំ ក៏បែកព្រមគ្នាតែម្ដង។ លំដាប់នោះ ជដិលឈ្មោះឧរុវេលកស្សប រពឹងយ៉ាងនេះថា មហាសមណៈនេះ មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះថា ព្រះអង្គអាចនឹងបំបែកឧសទាំងឡាយចេញបាន តែបើទុកជាយ៉ាងនោះ ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។

[៤៧] សម័យនោះឯង ជដិលទាំងអម្បាលនោះប្រាថ្នានឹងធ្វើសេចក្ដីគោរពភ្លើង ក៏មិនអាចនឹងបង្កាត់ភ្លើងឲ្យឆេះឡើងបាន។ កាលនោះ ជដិលទាំងអម្បាលនោះមានសេចក្ដីត្រិះរិះដូច្នេះថា យើងមិនអាចនឹងបង្កាត់ភ្លើងឲ្យឆេះឡើងបានដោយហេតុណា ហេតុនោះ គឺជាឥទ្ធានុភាពរបស់មហាសមណៈដោយពិតឥតសង្ស័យ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប អ្នកចូរបង្កាត់ភ្លើងទៅ។ ជដិលឈ្មោះឧរុវេលកស្សបទូលថា បពិត្រមហាសមណៈ សូមព្រះអង្គបង្កាត់ឲ្យទាន។ ភ្លើងទាំង៥០០គំនរ ក៏ឆេះឡើងព្រមគ្នាតែម្ដង។ លំដាប់នោះ ជដិលឈ្មោះឧរុវេលកស្សប រពឹងយ៉ាងនេះថា មហាសមណៈនេះ មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះថា ព្រះអង្គអាចធ្វើភ្លើងឲ្យឆេះឡើងបាន តែបើទុកជាយ៉ាងនោះ ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។

[៤៨] សម័យនោះឯង ជដិលទាំងអម្បាលនោះធ្វើសេចក្ដីគោរពភ្លើងទាំងឡាយ រួចហើយ មិនអាចនឹងលត់ភ្លើងទាំងឡាយឲ្យរលត់វិញបាន។ កាលនោះ ជដិលទាំងអម្បាលនោះមានសេចក្ដីត្រិះរិះដូច្នេះថា យើងមិនអាចនឹងលត់ភ្លើងទាំងឡាយបាន ដោយហេតុណា ហេតុនោះ គឺជាឥទ្ធានុភាពរបស់មហាសមណៈដោយពិតឥតសង្ស័យ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប អ្នកចូរលត់ភ្លើងទាំងឡាយទៅ។ ជដិលឈ្មោះឧរុវេលកស្សបទូលថា បពិត្រមហាសមណៈ សូមព្រះអង្គលត់ភ្លើងទាំងឡាយឲ្យទាន។ ភ្លើងទាំង៥០០គំនរ ក៏រលត់ព្រមគ្នាតែម្ដង។ លំដាប់នោះ ជដិលឈ្មោះឧរុវេលកស្សប រពឹងយ៉ាងនេះថា មហាសមណៈនេះ មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះហេតុថា ព្រះអង្គអាចនឹងលត់ភ្លើងទាំងឡាយបាន តែបើទុកជាយ៉ាងនោះ ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។

[៤៩] សម័យនោះឯង ជដិលទាំងនោះ នាំគ្នាមុជចុះខ្លះ ងើបឡើងខ្លះ ធ្វើនូវការមុជចុះ និងងើបឡើងខ្លះ ក្នុងស្ទឹងនេរញ្ជរា ក្នុងសម័យមានទឹកសន្សើមធ្លាក់ចុះខ្លាំង ប្រហែលជាផរាត្រី ក្នុងចន្លោះខែទាំងពីរ[38] ជាពេលត្រជាក់ មាននៅក្នុងហេមន្តរដូវ។ ជដិលទាំងអម្បាលនោះ ធ្លាប់នាំគ្នាឡើងមក ហើយអាំងភ្លើងក្នុងកន្លែងណា ព្រះដ៏មានព្រះភាគ ទ្រង់និម្មិតចង្ក្រានប្រមាណ៥០០ទុកក្នុងកន្លែងនោះ។ ឯជដិលអម្បាលនោះ មានសេចក្ដីត្រិះរិះដូច្នេះថា ចង្ក្រានទាំងនេះ គេរៀបចំទុកដោយហេតុណា ហេតុនោះ គឺជាឥទ្ធានុភាពរបស់មហាសមណៈដោយពិតឥតសង្ស័យ។ លំដាប់នោះ ជដិលឈ្មោះឧរុវេលកស្សបមានសេចក្ដីត្រិះរិះយ៉ាងនេះថា មហាសមណៈ(នេះ) មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះថា ព្រះអង្គអាចនិម្មិតចង្ក្រានទុកបានច្រើន តែបើទុកជាយ៉ាងនោះ ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។

[៥០] សម័យនោះឯង មានភ្លៀងធំ ពុំជួនកាល បង្អុរចុះមក មានជំនន់ធំពាសពេញទៅ។ ព្រះដ៏មានព្រះភាគគង់នៅក្នុងប្រទេសណា ប្រទេសនោះ ទឹកលិចអស់។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រិះរិះដូច្នេះថា បើមានហេតុយ៉ាងនេះ គួរតែតថាគតធ្វើទឹកឲ្យញែកចេញដោយជុំវិញ ហើយដើរចង្ក្រមលើផែនដី ដ៏មានធូលីហុយឡើងដេរដាសក្នុងទឹកកណ្ដាលទឹកនោះឯង។ លំដាប់នោះ ព្រះអង្គក៏ធ្វើទឹកឲ្យញែកចេញជុំវិញ រួចទ្រង់ចង្ក្រមលើផែនដី ដ៏មានធូលីហុយឡើងដេរដាស ក្នុងទីកណ្ដាលទឹក (នោះឯង)។ កាលនោះ ជដិលឈ្មោះឧរុវេលកស្សប គិតថា មហាសមណៈសូមកុំឲ្យលង់ទឹកឡើយ។ លុះឧរុវេលកស្សបគិតហើយ ទើបឡើងជិះទូកទៅ មួយអន្លើដោយជដិលទាំងឡាយជាច្រើននាក់ សំដៅទៅកាន់ប្រទេសដែលព្រះអង្គគង់នៅនោះ។ ជដិលឈ្មោះឧរុវេលកស្សប ក៏បានឃើញព្រះដ៏មានព្រះភាគ ធ្វើទឹកឲ្យញែកចេញជុំវិញព្រះអង្គ ហើយយាងចង្ក្រមលើផែនដី ដ៏មានធូលីហុយឡើងដេរដាស ក្នុងទីកណ្ដាលទឹកដោយច្បាស់លាស់ លុះឃើញហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រមហាសមណៈ ព្រះអង្គគង់នៅក្នុងទីនេះឬ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា អើ កស្សប តថាគតនៅក្នុងទីនេះឯង ហើយព្រះអង្គក៏ហោះឡើងទៅឯអាកាស ហើយទ្រង់ចុះទៅគង់ក្នុងទូក (ក្នុងមួយរំពេចនោះឯង)។ លំដាប់នោះ ជដិលឈ្មោះឧរុវេលកស្សប រំពឹងយ៉ាងនេះថា មហាសមណៈនេះ មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះហេតុថា អម្បាលទឹក ក៏គង់នឹងមិនលិចព្រះអង្គ តែបើទុកជាយ៉ាងនោះសោត ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ។

[៥១] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះបរិវិតក្កដូច្នេះថា មោឃបុរសនេះ ត្រិះរិះយ៉ាងនេះយូរណាស់មកហើយថា មហាសមណៈនេះ មានឫទ្ធិខ្លាំង មានអានុភាពធំមែន តែបើទុកជាយ៉ាងនោះ ក៏គង់នៅមិនមែនជាព្រះអរហន្តដូចអញទេ បើដូច្នោះ គួរតថាគតធ្វើជដិលនេះឲ្យកើតសេចក្ដីសង្វេគ (ស្លុតចិត្ត)។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះនឹងជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប អ្នកឯងមិនមែនជា

ព្រះអរហន្តទេ អ្នកមិនទាន់បានដល់អរហត្តមគ្គទេ ម្យ៉ាងទៀត អ្នកឯងនឹងជាអរហន្តឬ ៗថា ជាបុគ្គលដល់ហើយនូវអរហត្តមគ្គ ដោយបដិបទា[39] ណា បដិបទានោះមិនមានដល់អ្នកទេ។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សប ក្រាបសិរសាចុះទៀបព្រះបាទារបស់ព្រះដ៏មានព្រះភាគ ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ គួរបានបព្វជ្ជា គួរបានឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ (ក្នុងកាលឥឡូវនេះ)។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែកស្សប អ្នកឯងជានាយក ជាអ្នកដឹកនាំ ជាកំពូល ជាប្រធាន ជាបុគ្គលដ៏ឧត្តមប្រសើរជាងជដិលទាំងឡាយប្រមាណ៥០០រូប អ្នកត្រូវប្រាប់ជដិលទាំងអម្បាលនោះជាមុនសិន បើជដិលទាំងអម្បាលនោះ គេយល់យ៉ាងណា គេក៏នឹងធ្វើយ៉ាងនោះដែរ។ កាលនោះ ជដិលឧរុវេលកស្សបដើរចូលទៅរកជដិលជាកូនសិស្សទាំងអម្បាលនោះ លុះចូលទៅដល់ហើយ ទើបប្រាប់ជដិលទាំងនោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ខ្ញុំចង់ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមហាសមណៈ (នុ៎ះ) អ្នកទាំងឡាយយល់យ៉ាងណា ចូរធ្វើយ៉ាងនោះចុះ។ ជដិលទាំងអម្បាលនោះតបថា បពិត្រលោកដ៏ចំរើន ខ្ញុំទាំងអស់គ្នា ជាអ្នកជ្រះថ្លាហើយក្នុងសំណាក់ព្រះមហាសមណៈ (នុ៎ះ) យូរណាស់មកហើយ បើលោកម្ចាស់នឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមហាសមណៈ យើងខ្ញុំទាំងអស់គ្នា នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមហាសមណៈ(នុ៎ះ)ដែរ។ កាលនោះ ជដិលទាំងអម្បាលនោះបណ្តែតចោលនូវគ្រឿងបរិក្ខារ ព្រមទាំងសក់ ទាំងជដា[40] ទាំងអម្រែក ទាំងគ្រឿងបូជាភ្លើង ក្នុងទឹក ហើយនាំគ្នាចូលទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅហើយ ក្រាបសិរសាចុះទៀបព្រះបាទាព្រះដ៏មានព្រះភាគ ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយ គួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ ហើយត្រាស់ថា សាសនធម៌ តថាគតពោលល្អហើយ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីនឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយល្អចុះ។ ឯព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងឡាយនោះ។

[៥២] ឯជដិលឈ្មោះនទីកស្សប បានឃើញគ្រឿងបរិក្ខារ ព្រមទាំងសក់ ទាំងជដា ទាំងអម្រែក ទាំងគ្រឿងបូជាភ្លើង អណ្តែតទៅតាមទឹកដោយច្បាស់លាស់ លុះជដិលឈ្មោះនទីកស្សប បានឃើញហើយ គិតដូច្នេះថា សេចក្តីអន្តរាយកុំបីមានដល់តាបសជាបងអញឡើយ។ គិតហើយ ក៏ប្រើជដិលទាំងឡាយឲ្យទៅ ដោយពាក្យថា អ្នកទាំងឡាយចូរទៅស្តាប់ដំណឹងបងខ្ញុំមើល ថាហើយ ទើបខ្លួនឯងក៏ទៅជាមួយនឹងជដិលទាំង៣០០រូប ដើរតម្រង់ទៅកាន់ទីដែលឧរុវេលកស្សបដ៏មានអាយុនៅ លុះចូលទៅដល់ហើយ និយាយពាក្យនេះនឹងឧរុវេលកស្សបដ៏មានអាយុថា បពិត្រកស្សប អំពើនេះប្រសើរហើយឬអ្វីហ្ន៎។ ឧរុវេលកស្សបប្រាប់ថា អើអ្នកដ៏មានអាយុទាំងឡាយ អំពើនេះប្រសើរហើយ។ កាលនោះ ជដិលទាំងអម្បាលនោះក៏បណ្តែតចោលនូវគ្រឿងបរិក្ខារ ព្រមទាំងសក់ ទាំងជដា ទាំងអម្រែក ទាំងគ្រឿងបូជាភ្លើង ទៅក្នុងទឹក ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបសិរសាចុះទៀបព្រះបាទាព្រះដ៏មានព្រះភាគ ហើយក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយ គួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ ហើយត្រាស់ថា សាសនធម៌ តថាគតពោលល្អហើយ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយល្អចុះ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងអម្បាលនោះ។

[៥៣] ឯជដិលឈ្មោះគយាកស្សប បានឃើញគ្រឿងបរិក្ខារ ព្រមទាំងសក់ ទាំងជដា ទាំងអម្រែក ទាំងគ្រឿងបូជាភ្លើង អណ្តែតទៅតាមទឹកដោយច្បាស់លាស់ លុះជដិលឈ្មោះគយាកស្សប បានឃើញហើយ ក៏មានសេចក្តីត្រិះរិះថា សេចក្តីអន្តរាយកុំបីមានដល់តាបសទាំងពីរនាក់ជាបងអញឡើយ។ ទើបប្រើជដិលទាំងឡាយឲ្យទៅ ដោយពាក្យថា អ្នកទាំងឡាយចូរទៅស្តាប់ដំណឹងបងអញទាំងពីរនាក់មើល ថាហើយ ខ្លួនឯងក៏ទៅជាមួយនឹងជដិលទាំង២០០រូប ដើរតម្រង់ទៅកាន់ទីដែលឧរុវេលកស្សបដ៏មានអាយុនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧរុវេលកស្សបដ៏មានអាយុថា បពិត្រកស្សប អំពើនេះប្រសើរឬអ្វីហ្ន៎។ ឧរុវេលកស្សបប្រាប់ថា អើអ្នកដ៏មានអាយុទាំងឡាយ អំពើនេះប្រសើរហើយ។ កាលនោះ ពួកជដិលទាំងនោះ បណ្តែតទៅនូវគ្រឿងបរិក្ខារ ព្រមទាំងសក់ ទាំងជដា ទាំងអម្រែក ទាំងគ្រឿងបូជាភ្លើង ទៅក្នុងទឹក ហើយចូលទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅដល់ហើយ ក្រាបក្បាលទៀបព្រះបាទាព្រះដ៏មានព្រះភាគ ហើយបានពោលនូវពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយ គួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកចុះ ទើបត្រាស់ថា សាសនធម៌ តថាគតពោលហើយដោយប្រពៃ អ្នកទាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងនោះ។

[៥៤] ឧសប្រាំរយកំណាត់មិនបែក ក៏ត្រឡប់ទៅជាបែក ភ្លើងមិនឆេះ ក៏ត្រឡប់ទៅជាឆេះ ភ្លើងមិនរលត់ ក៏ត្រឡប់ទៅជារលត់ ដោយអធិដ្ឋានរបស់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់និម្មិតចង្ក្រានទាំងឡាយចំនួន៥០០។ បាដិហារ្យចំនួនបីពាន់ប្រាំរយ ក៏មានដោយន័យនេះឯង។

[៥៥] គ្រានោះ ព្រះដ៏មានព្រះភាគ គង់នៅក្នុងឧរុវេលាប្រទេស តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅក្នុងគយាសីសប្រទេស មួយអន្លើដោយភិក្ខុសង្ឃដ៏ច្រើនចំនួន១០០០អង្គ គឺពួកភិក្ខុដែលជាជដិលក្នុងកាលមុនទាំងអស់នោះឯង។ មានសេចក្តីដំណាលថា ព្រះដ៏មានព្រះភាគ គង់នៅលើខ្នងថ្មឈ្មោះគយាសីសៈ ទៀបគយាប្រទេសនោះ មួយអន្លើដោយភិក្ខុ១០០០អង្គ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតិទាំងអស់ជារបស់ក្តៅ ម្នាលភិក្ខុទាំងឡាយ ធម្មជាតទាំងអស់ជារបស់ក្តៅ(នោះ) តើគឺអ្វី ម្នាលភិក្ខុទាំងឡាយ ចក្ខុជារបស់ក្តៅ រូបទាំងឡាយជារបស់ក្តៅ ចក្ខុវិញ្ញាណជារបស់ក្តៅ ចក្ខុសម្ផស្ស[41] ជារបស់ក្តៅ ការសោយអារម្មណ៍ណានេះ ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី កើតឡើងអំពីបច្ច័យ គឺចក្ខុសម្ផស្ស ការសោយអារម្មណ៍នោះឯង ក៏ជារបស់ក្តៅ ចុះក្តៅដោយហេតុអ្វី តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ ក្តៅ(ដោយភ្លើង) គឺជាតិ ជរា មរណៈ ក្តៅដោយ(ភ្លើងគឺ) សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត។ ត្រចៀកជារបស់ក្តៅ សំលេង ជារបស់ក្តៅ។បេ។ ច្រមុះជារបស់ក្តៅ ក្លិនទាំងឡាយជារបស់ក្តៅ។បេ។ អណ្តាតជារបស់ក្តៅ រសទាំងឡាយជារបស់ក្តៅ។បេ។ កាយជារបស់ក្តៅ ផោដ្ឋព្វៈ[42] ទាំងឡាយជារបស់ក្តៅ។បេ។ ចិត្តជារបស់ក្តៅ ធម្មារម្មណ៍ទាំងឡាយ ជារបស់ក្តៅ មនោវិញ្ញាណជារបស់ក្តៅ មនោសម្ផស្ស[43] ជារបស់ក្តៅ សេចក្តីសោយអារម្មណ៍ណាជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខជាសុខក្តី តែងកើតឡើងព្រោះបច្ច័យ គឺមនោសម្ផស្ស សេចក្តីសោយអារម្មណ៍នោះ

ឯង ក៏ជារបស់ក្តៅ ចុះក្តៅដោយអ្វី តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ ក្តៅដោយជាតិ ជរា មរណៈ ក្តៅដោយសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកប្រកបដោយសុតៈ (គឺជាអ្នកចេះដឹង) កាលឃើញយ៉ាងនេះ រមែងនឿយណាយក្នុងចក្ខុផង ក្នុងរូបទាំងឡាយផង ក្នុងចក្ខុវិញ្ញាណផង ក្នុងចក្ខុសម្ផស្សផង សេចក្តីសោយអារម្មណ៍ណា ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខ មិនមែនជាសុខក្តី តែងកើតឡើងអំពីបច្ច័យ គឺចក្ខុសម្ផស្ស អរិយសាវករមែងនឿយណាយក្នុងសេចក្តីសោយអារម្មណ៍នោះឯងផង ក្នុងត្រចៀកផង ក្នុងសំឡេងទាំងឡាយផង។បេ។ ក្នុងច្រមុះផង ក្នុងក្លិនទាំងឡាយផង។បេ។ ក្នុងអណ្តាតផង ក្នុងរសទាំងឡាយផង។បេ។ ក្នុងកាយផង ក្នុងផោដ្ឋព្វៈទាំងឡាយផង។បេ។ ក្នុងចិត្តផង ក្នុងធម្មារម្មណ៍ទាំងឡាយផង នឿយណាយក្នុងមនោវិញ្ញាណផង នឿយណាយក្នុងមនោសម្ផស្សផង សេចក្តីសោយអារម្មណ៍ណាដែលជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខ មិនមែនជាសុខក្តី រមែងកើតឡើងអំពីបច្ច័យ គឺមនោសម្ផស្ស អរិយសាវក រមែងនឿយណាយក្នុងសេចក្តីសោយអារម្មណ៍នោះឯងផង កាលបើនឿយណាយហើយ ក៏ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក (នោះឯង) ចិត្តក៏ផុតស្រឡះចាកសេចក្តីប្រកាន់មាំ កាលបើចិត្តរួចស្រឡះហើយ ក៏មានញាណដឹងថា ចិត្តរបស់អញរួចស្រឡះហើយ អរិយសាវកនោះដឹងច្បាស់ថា កំណើតអស់ហើយ ព្រហ្មចរិយធម៌ បាននៅរួចហើយ សោឡសកិច្ច បានធ្វើរួចហើយ កិច្ចដទៃក្រៅអំពីសោឡសកិច្ចនេះ មិនមានឡើយ។ កាលព្រះដ៏មានព្រះភាគ កំពុងសំដែងវេយ្យាករណ៍[44] នេះ ចិត្តរបស់ភិក្ខុចំនួន១០០០រូបនោះ ក៏ផុតចាកអាសវៈធម៌ទាំងឡាយឥតមានជាប់ចំពាក់ដោយឧបាទានឡើយ។

ចប់ អាទិត្តបរិយាយសូត្រ។

ចប់ ឧរុវេលប្បាដិហារិយភាណវារៈ ជាគំរប់បី។

## ១៣. ពិម្ពិសារសមាគមកថា

CS vin.mv.01.13 | ភាគ ទី៦

**(១៣.)**

[៥៦] កាលនោះ ព្រះដ៏មានព្រះភាគ គង់លើខ្នងថ្មឈ្មោះគយាសីសៈ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅក្នុងក្រុងរាជគ្រឹះ មួយអន្លើដោយភិក្ខុសង្ឃដ៏ច្រើន ចំនួន១០០០អង្គ គឺបុរាណជដិលទាំងអស់នោះឯង។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏បានទៅដល់ក្រុងរាជគ្រឹះ។ មានសេចក្តីដំណាលថា ព្រះដ៏មានព្រះភាគ គង់នៅក្នុងសុប្បតិដ្ឋចេតិយ ក្នុងលដ្ឋិវនឧទ្យាន ទៀបក្រុងរាជគ្រឹះនោះ។

[៥៧] ព្រះបាទមាគធសេនិយពិម្ពិសារ បានទ្រង់ព្រះសណ្តាប់ដំណឹងច្បាស់ថា ព្រះសមណគោតមដ៏ចំរើន ជាសក្យបុត្រ ចេញចាកសក្យត្រកូលហើយបួស ឥឡូវយាងមកកាន់ក្រុងរាជគ្រឹះ គង់នៅក្នុងសុប្បតិដ្ឋចេតិយ ក្នុងលដ្ឋិវនឧទ្យាន (សួនច្បារត្នោត) ទៀបក្រុងរាជគ្រឹះ កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងត្រឡប់មកកាន់ភពថ្មីទៀត ដោយប្រការដូច្នេះ ព្រះដ៏មានព្រះភាគនោះ បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះព្រះអង្គឯង ហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វព្រមទាំងសមណៈ និងព្រាហ្មណ៍ ព្រមទាំងទេវតា និងមនុស្សឲ្យបានត្រាស់ដឹងផង ព្រះដ៏មានព្រះភាគនោះ ទ្រង់សំដែងធម៌ដ៏ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈដ៏បរិបូណ៌ពេញលេញ កិរិយាដែលបានឃើញព្រះអរហន្តទាំងឡាយមានសភាពយ៉ាងនោះ ជាការប្រពៃពេក។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ មានទាំងព្រាហ្មណ៍ និងគហបតិ ដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរហ្មឺនជាបរិវារ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចហើយគង់នៅក្នុងទីដ៏សមគួរ។ ឯពួកព្រាហ្មណ៍ និងគហបតិដែលនៅក្នុងដែនមគធៈចំនួនដប់ពីរហ្មឺននោះ ពួកខ្លះថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ពួកខ្លះក៏ពោលពាក្យរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះធ្វើពាក្យគួររីករាយ គួររលឹកឲ្យសម្រេចហើយ ក៏អង្គុយនៅក្នុងទីដ៏សមគួរ ពួកខ្លះ ក៏ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ពួកខ្លះ ក៏ប្រកាសនាម និងគោត្តរបស់ខ្លួនក្នុងសំណាក់ព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ពួកខ្លះក៏ស្ងៀម អង្គុយនៅក្នុងទីដ៏សមគួរ។ ទើបពួកព្រាហ្មណ៍ និងគហបតិដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរហ្មឺននោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា មហាសមណៈប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ឧរុវេលកស្សបឬហ្ន៎ ឬថាឧរុវេលកស្សបប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់មហាសមណៈ។ ឯព្រះដ៏មានព្រះភាគ ក៏ជ្រាបសេចក្តីត្រិះរិះនៃចិត្តរបស់ពួកព្រាហ្មណ៍ និងគហបតិដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរហ្មឺននោះ ដោយព្រះហឫទ័យព្រះអង្គ ហើយទ្រង់ត្រាស់នឹងព្រះឧរុវេលកស្សបដ៏មានអាយុដោយព្រះគាថា ថា

> អ្នកឯងនៅក្នុងឧរុវេលាប្រទេស ជាអ្នកប្រដៅពួកតាបស តើអ្នកឃើញអ្វី បានជាលះបង់ការបូជាភ្លើងចោលចេញ។ ម្នាលកស្សប តថាគតសួរសេចក្តីនេះនឹងអ្នក ការបូជាភ្លើងដែលអ្នកលះបង់ហើយ តើព្រោះហេតុអ្វី។
>
> ឧរុវេលកស្សបក្រាបបង្គំទូលថា ជនទាំងឡាយតែងពោលសរសើរចំពោះនូវកាមទាំងឡាយ គឺរូប សំឡេង ព្រមទាំងរសផង នូវស្រីទាំងឡាយផង ព្រោះការបូជា ខ្ញុំព្រះអង្គដឹងថា កាមគុណមានរូបជាដើមនេះ ជាគ្រឿងសៅហ្មងក្នុងឧបធិ[45] ទាំងឡាយ ព្រោះហេតុដូច្នោះ ខ្ញុំព្រះអង្គមិនត្រេកអរក្នុងការបូជាធំ និងការបូជាតូច (គឺការគោរពភ្លើងរាល់ថ្ងៃ)។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលកស្សប ចិត្តរបស់អ្នកមិនត្រេកអរហើយ ក្នុងកាមគុណទាំងឡាយនោះ គឺរូប សំឡេង ព្រមទាំងរស ម្នាលកស្សប ម្យ៉ាងទៀត ចិត្តរបស់អ្នកត្រេកអរក្នុងមនុស្សលោក និងទេវលោកខ្លះដែរឬ ចូរអ្នកពោលហេតុនេះមកតថាគតមើល។

ព្រះឧរុវេលកស្សបក្រាបទូលថា ខ្ញុំព្រះអង្គឃើញនូវព្រះនិព្វាន ជារបស់ល្អិត ឥតមានឧបធិ ឥតមានសេចក្តីខ្វល់ មិនជាប់ចំពាក់នៅក្នុងកាមភព ជាធម្មជាតពិត មិនប្រែប្រួល ជាធម្មជាត គឺបុគ្គលមិនគប្បីបានដោយហេតុដទៃ (ក្រៅពីមគ្គ) ព្រោះហេតុដូច្នោះ បានជាខ្ញុំព្រះអង្គមិនត្រេកអរក្នុងការបូជាធំ និងការបូជាតូច។

[៥៨] លំដាប់នោះ ព្រះឧរុវេលកស្សបដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គៈ[46] លើស្មាម្ខាង ហើយក្រាបសិរសាទៀបព្រះបាទារបស់ព្រះដ៏មានព្រះភាគ រួចក៏បានបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក។ គ្រានោះ ពួកព្រាហ្មណ៍ និងគហបតីដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរហ្មឺននោះ មានសេចក្តីត្រិះរិះដូច្នេះថា ឧរុវេលកស្សបប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់មហាសមណៈទេតើ។ ពេលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបសេចក្តីត្រិះរិះក្នុងចិត្តនៃពួកព្រាហ្មណ៍ និងគហបតិចំនួនដប់ពីរហ្មឺនដែលនៅក្នុងដែនមគធៈនោះ ដោយព្រះហឫទ័យរបស់ព្រះអង្គ រួចហើយ ក៏ទ្រង់សំដែងអនុបុព្វីកថា គឺទានកថា១ សីលកថា១ សគ្គកថា១ ទោសនៃកាមគុណដ៏លាមក ដ៏សៅហ្មង១ អានិសង្សនៃការចេញចាកកាម (បួស)១។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវពួកព្រាហ្មណ៍ និងគហបតិទាំងនោះថា ជាបុគ្គលមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះធម្មទេសនាណា ដែលព្រះពុទ្ធទាំងឡាយលើកឡើងសំដែងដោយព្រះអង្គឯង ព្រះអង្គក៏ទ្រង់ប្រកាសធម្មទេសនានោះ គឺទុក្ខសច្ចៈ១ សមុទយសច្ចៈ១ និរោធសច្ចៈ១ មគ្គសច្ចៈ១ ក្នុងកាលនោះ។ ធម្មតា សំពត់សស្អាត ដ៏ប្រាសចាកពណ៌ខ្មៅ (គឺផ្សែង ឬល័ក្តខ្មៅជាដើម) គួរទទួលគ្រឿងជ្រលក់បានដោយប្រពៃ មានឧបមាយ៉ាងណាមិញ ឯធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ពួកព្រាហ្មណ៍ និងគហបតិដែលនៅក្នុងដែនមគធៈ ចំនួនដប់មួយហ្មឺន មានព្រះបាទពិម្ពិសារជាប្រធានលើអាសនៈនោះថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ ក៏រលត់ទៅជាធម្មតាដែរ មានឧបមេយ្យដូច្នោះឯង។ ចំណែកព្រាហ្មណ៍ និងគហបតិចំនួនមួយហ្មឺនរូប ក៏ថ្វាយខ្លួនជាឧបាសក។

[៥៩] គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ឃើញអរិយសច្ចធម៌ហើយ ទ្រង់បានដល់អរិយសច្ចធម៌ហើយ ទ្រង់បានត្រាស់ដឹងអរិយសច្ចធម៌ហើយ ទ្រង់ចុះព្រះទ័យស៊ប់ក្នុងអរិយសច្ចធម៌ហើយ ទ្រង់ឆ្លងផុតសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃក្នុងសាសនាព្រះសាស្តា ទ្រង់បានពោលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពីដើម កាលដែលខ្ញុំព្រះអង្គនៅជាកុមារនៅឡើយ ខ្ញុំព្រះអង្គមានបំណង៥យ៉ាង ឥឡូវនេះ បំណងរបស់ខ្ញុំព្រះអង្គនោះ ក៏សម្រេចអស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ពីដើម កាលដែលខ្ញុំព្រះអង្គនៅជាកុមារ មានសេចក្តីត្រិះរិះដូច្នេះថា សូមឲ្យជនទាំងឡាយអភិសេកអញក្នុងរាជសម្បត្តិ បពិត្រព្រះអង្គដ៏ចំរើន នេះជាបំណងទី១របស់ខ្ញុំព្រះអង្គ ឥឡូវនេះ បំណងរបស់ខ្ញុំព្រះអង្គបានសម្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន បំណងទី២របស់ខ្ញុំព្រះអង្គដូច្នេះថា សូមឲ្យព្រះអរហន្តសម្មាសម្ពុទ្ធគប្បីចូលមកកាន់ដែនរបស់អញនោះ ឥឡូវនេះ បំណងរបស់ខ្ញុំព្រះអង្គនោះ ក៏បានសម្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន បំណងទី៣របស់ខ្ញុំព្រះអង្គនេះដូច្នេះថា សូមឲ្យខ្ញុំព្រះអង្គបានចូលទៅសេពគប់នឹងព្រះដ៏មានព្រះភាគនោះ ឥឡូវនេះ បំណងរបស់ខ្ញុំព្រះអង្គនោះ បានសម្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន បំណងទី៤របស់ខ្ញុំព្រះអង្គដូច្នេះថា ព្រះដ៏មានព្រះភាគនោះ គប្បីសំដែងធម៌ដល់អញ ឥឡូវនេះ បំណងរបស់ខ្ញុំព្រះអង្គនោះ សម្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន បំណងទី៥របស់ខ្ញុំព្រះអង្គនេះដូច្នេះថា ចំណែកខាងអញគប្បីដឹងច្បាស់នូវធម៌របស់ព្រះដ៏មានព្រះភាគនោះ ឥឡូវនេះ បំណងរបស់ខ្ញុំព្រះអង្គនោះ បានសម្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន ពីដើម កាលដែលខ្ញុំព្រះអង្គនៅជាកុមារនៅឡើយ ខ្ញុំព្រះអង្គមានបំណង៥យ៉ាងនេះ ឥឡូវនេះ បំណងទាំង៥យ៉ាងរបស់ខ្ញុំព្រះអង្គនោះ ក៏បានសម្រេចបរិបូណ៌ហើយ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះ ឲ្យផ្ងារឡើងពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំងទុក ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬក៏ដូចជាមនុស្សកាន់ប្រទីបប្រេង ទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានចក្ខុ នឹងបានមើលឃើញនូវរូបទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរលឹក សូមព្រះដ៏មានព្រះភាគជាម្ចាស់ ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់តាំងតែអំពីថ្ងៃនេះជាដើមទៅ មិនតែប៉ុណ្ណោះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគជាម្ចាស់ ព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ជ្រាបថា ព្រះដ៏មានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅ។

[៦០] លំដាប់នោះ ព្រះបាទមាគធសេនិយពិម្ពិសារ លុះរាត្រីនោះកន្លងទៅហើយ (ភ្លឺឡើង) ព្រះអង្គក៏ទ្រង់ឲ្យចាត់ចែងខាទនីយភោជនីយាហារដ៏ឧត្តមរួចហើយ ទ្រង់ចាត់ឲ្យមនុស្សទៅក្រាបទូលនូវកាលនៃភត្តដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលនេះ ជាកាលគួរហើយ ភត្តាហារសម្រេចហើយ។ ឯព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកស្បង់ ហើយទ្រង់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ រួចហើយទ្រង់ចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយភិក្ខុសង្ឃដ៏ច្រើនចំនួន១០០០រូប គឺពួកបុរាណជដិលទាំងអស់នោះឯង។

[៦១] សម័យនោះឯង ព្រះឥន្ទ្រជាធំជាងទេវតាទាំងឡាយ ប្លែងភេទជាមាណព ហើយដើរទៅអំពីមុខបង្អស់នៃភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយច្រៀងនូវគាថានេះថា

ព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានហើយ (នូវឥន្ទ្រិយ) មានព្រះហឫទ័យផុតស្រឡះហើយ (ចាកអាសវធម៌) ព្រះអង្គមានពណ៌ល្អដូចដុំមាស ឈ្មោះសិង្គី[47] ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល ដែលជាអ្នកទូន្មានហើយ (នូវឥន្ទ្រិយ)ដែរ ជាអ្នកមានចិត្តផុតស្រឡះហើយ (ចាកអាសវធម៌)។ ព្រះដ៏មានព្រះភាគ មានព្រះហឫទ័យផុតហើយ (ចាកសេចក្តីសៅហ្មង) និងមានព្រះហឫទ័យផុតស្រឡះហើយ (ចាកអាសវធម៌) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិលដែលមានចិត្តផុតហើយ (ចាកសេចក្តីសៅហ្មង) ទាំងមានចិត្តផុតស្រឡះហើយ (ចាកអាសវធម៌)។

ព្រះដ៏មានព្រះភាគ ទ្រង់ឆ្លង (ចាកលោក) ហើយទាំងមានព្រះហឫទ័យផុតស្រឡះហើយ (ចាកអាសវធម៌) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិលដែលឆ្លងហើយ(ចាកលោក) ទាំងមានចិត្តផុតស្រឡះហើយ (ចាកអាសវធម៌)។

ព្រះដ៏មានព្រះភាគ មានព្រះហឫទ័យរម្ងាប់ហើយ (ចាកអកុសលធម៌) ទាំងមានព្រះហឫទ័យផុតស្រឡះហើយ (ចាកអាសវធម៌) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិលដែលមានចិត្តរម្ងាប់ហើយ (ចាកអកុសលធម៌) ទាំងមានចិត្តផុតស្រឡះហើយ (ចាកអាសវធម៌)។

ព្រះដ៏មានព្រះភាគនោះ ទ្រង់មានអរិយវាស១០យ៉ាង[48] ទ្រង់មានកំលាំង១០[49] ព្រះអង្គជ្រាបច្បាស់នូវធម៌ (គឺកម្មបថ)១០ ប្រការ ទ្រង់ប្រកបដោយអង្គជារបស់នៃអសេខបុគ្គល១០យ៉ាង[50] មានភិក្ខុសង្ឃ១ពាន់ជាបរិវារ ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ។

[៦២] ពួកមនុស្សឃើញសក្កទេវរាជ ជាធំជាងទេវតា និងមនុស្សទាំងឡាយហើយ ពោលយ៉ាងនេះថា ឱហ្ន៎ មាណពនេះ មានរូបល្អអីម្ល៉េះ ឱហ្ន៎ មាណពនេះមានរូបគួរពិតពិលរមិលមើល ឱហ្ន៎ មាណពនេះគួរជាទីជ្រះថ្លា មាណពនេះឯងជាកូនចៅអ្នកណាហ្ន៎។ លុះពួកមនុស្សពោលពាក្យយ៉ាងនេះហើយ សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ ក៏បានពោលតបទៅនឹងពួកមនុស្សនោះវិញដោយគាថា ថា

អ្នកប្រាជ្ញណាទូន្មានឥន្ទ្រិយទាំងអស់បានហើយ មានព្រះហឫទ័យស្អាតរកបុគ្គលប្រៀបមិនបាន ឆ្ងាយចាកសត្រូវ ពោលគឺកិលេស មានដំណើរល្អក្នុងលោក ខ្ញុំឯងជាអ្នកបម្រើអ្នកប្រាជ្ញនោះ។

[៦៣] កាលនោះ ព្រះដ៏មានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ទ្រង់យាងចូលទៅកាន់និវេសនស្ថានរបស់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេរៀបចំថ្វាយ។ ទើបព្រះបាទមាគធសេនិយពិម្ពិសារអង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែត ឲ្យស្កប់ស្កល់[51] ដោយខាទនីយភោជនីយាហារដ៏ឧត្តម ដោយព្រះហស្តព្រះអង្គឯង ហើយទ្រង់កំណត់ដឹងនូវព្រះដ៏មានព្រះភាគដែលទ្រង់សោយរួចហើយ ត្រង់ដែលទ្រង់ដាក់ព្រះហស្តចុះចាកបាត្រ រួចក៏ស្តេចគង់នៅក្នុងទីដ៏សមគួរ។ លុះព្រះបាទមាគធសេនិយពិម្ពិសារ គង់នៅក្នុងទីដ៏សមគួរហើយ ក៏ទ្រង់ព្រះតម្រិះដូច្នេះថា ព្រះដ៏មានព្រះភាគគួរគង់នៅក្នុងទីណាហ្ន៎ ទីណាដែលមិនឆ្ងាយ មិនជិតពេក អំពីស្រុក ជាទីល្មមទៅល្មមមកបាន គួរជាទីចូលទៅរកនៃមនុស្សទាំងឡាយដែលត្រូវការ ជាទីមិនបានច្រឡូកច្រឡំក្នុងវេលាថ្ងៃ មានសំឡេងតិច មិនមានសេចក្តីគឹកកងក្នុងវេលាយប់ មានខ្យល់បក់ស្រួល គួរដល់កិរិយាពួននៅនៃមនុស្សទាំងឡាយ និងជាទីគួរដល់ការសម្ងំនៅ។ ព្រះរាជតម្រិះនេះក៏មានដល់ព្រះបាទមាគធសេនិយពិម្ពិសារក្នុងខណៈនោះថា អើ ឧទ្យានវេឡុវនរបស់យើងនេះ មិនឆ្ងាយពេក មិនជិតពេកអំពីស្រុក ជាទីល្មមទៅ ល្មមមកបាន គួរជាទីចូលទៅរកនៃមនុស្សទាំងឡាយដែលត្រូវការ ជាទីមិនបានច្រឡូកច្រឡំក្នុងវេលាថ្ងៃ មានសំឡេងតិច មិនមានសេចក្តីគឹកកងក្នុងវេលាយប់ មានខ្យល់បក់ស្រួល គួរដល់កិរិយាពួននៅនៃមនុស្ស និងជាទីគួរដល់ការសម្ងំ បើដូច្នោះ គួរអញថ្វាយឧទ្យានវេឡុវននេះដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន។ ពេលនោះ ព្រះបាទមាគធសេនិយពិម្ពិសារកាន់យកកុន្ទីទឹក ជាវិការៈនៃមាស ហើយថ្វាយដល់ព្រះដ៏មានព្រះភាគ រួចក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមថ្វាយនូវឧទ្យានវេឡុវននេះដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលអារាម(នោះ)។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ព្រះបាទមាគធសេនិយពិម្ពិសារឲ្យឃើញច្បាស់ ឲ្យកាន់យកល្អ ឲ្យឧស្សាហ៍ឡើង ឲ្យរីករាយស្មើ ដោយពាក្យដ៏ប្រកបដោយធម៌ ហើយក៏ក្រោកចាកអាសនៈចៀសចេញទៅ។ ព្រោះនិទាននេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអារាម (ដល់អ្នកទាំងឡាយ)។

(ចប់ ពិម្ពិសារសមាគមកថា។)

## ១៤. សារិបុត្តមោគ្គល្លានបព្វជ្ជាកថា

CS vin.mv.01.14 | ភាគ ទី៦

### (បព្វជ្ជារបស់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន (១៤.))

[៦៤] សម័យនោះឯង សញ្ជយបរិព្វាជកនៅអាស្រ័យក្នុងក្រុងរាជគ្រឹះ មួយអន្លើដោយបរិព្វាជកបរិសទ្យដ៏ច្រើន គឺបរិព្វាជកចំនួន២៥០រូប។ សម័យនោះឯង ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់បរិព្វាជកឈ្មោះសញ្ជយ។ ព្រះសារីបុត្ត និងព្រះមោគ្គល្លាន នោះបានធ្វើប្តេជ្ញានឹងគ្នាថា អ្នកណាបានដឹងនូវអមតធម៌មុន អ្នកនោះគប្បីប្រាប់ដល់ម្នាក់ទៀត។ កាលនោះ ព្រះអស្សជិដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរអំពីព្រឹក លោកប្រកបដោយឥរិយាបថ គឺដើរទៅ ដើរមក ក្រឡេកមើលទៅ ក្រឡេកមើលផ្សេងៗ បត់ដៃជើង និង

លាតដៃជើង មានភ្នែកសង្រួម គួរជាទីជ្រះថ្លា ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត។ បរិព្វាជកឈ្មោះសារីបុត្ត បានឃើញនូវព្រះអស្សជិដ៏មានអាយុ កំពុងត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ បរិបូណ៌ដោយឥរិយាបថ គឺដើរទៅដើរមក ក្រឡេកមើលទៅ ក្រឡេកមើលផ្សេងៗ បត់ដៃជើង និងលាតដៃជើង មានភ្នែកសង្រួម គួរជាទីជ្រះថ្លា លុះឃើញហើយ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា ឱហ្ន៎ ជនទាំងឡាយណា ជាអរហន្តក្ដី បានដល់ហើយនូវអរហត្តមគ្គក្ដីក្នុងលោក ភិក្ខុនេះក៏ប្រហែលជាពួកនៃជនទាំងនោះដែរ បើដូច្នោះ គួរតែអញចូលទៅរកភិក្ខុនេះហើយសួរថា ម្នាលលោកដ៏មានអាយុ លោកបួសចំពោះអ្នកណា ម្យ៉ាងទៀត អ្នកណាជាគ្រូរបស់លោក ខ្លួនលោកនេះឯងគាប់ចិត្តធម៌របស់អ្នកណា។ លំដាប់នោះ សារីបុត្តបរិព្វាជក មានសេចក្ដីត្រិះរិះដូច្នេះថា កាលនេះជាកាលមិនគួរដើម្បីសួរនូវភិក្ខុនេះឡើយ (ព្រោះ) ភិក្ខុនេះកំពុងចូលទៅកាន់ចន្លោះផ្ទះ ត្រាច់ទៅដើម្បីបិណ្ឌបាត បើដូច្នោះ គួរតែអញទៅតាមភិក្ខុនេះ អំពីក្រោយៗទៅចុះ ក៏ការដែលជាប់តាមភិក្ខុនេះឯង គង់ដឹងនូវមគ្គញ្ញាណដែលជនទាំងឡាយគេត្រូវការដឹង ឬភិក្ខុនេះឯង ជាអ្នកស្វែងរកនូវព្រះនិព្វានដែលជនទាំងឡាយគេត្រូវការដឹង។ ឯព្រះអស្សជិដ៏មានអាយុ ត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទទួលបិណ្ឌបាតហើយ ក៏ត្រឡប់មកវិញ។ បរិព្វាជកឈ្មោះសារីបុត្ត ក៏ចូលទៅកាន់សំណាក់ព្រះអស្សជិដ៏មានអាយុក្នុងកាលនោះ លុះចូលទៅជិតហើយ ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះអស្សជិដ៏មានអាយុ ហើយពោលនូវពាក្យជាទីត្រេកអរ ជាទីរលឹក ល្មមឲ្យកើតសេចក្ដីស្និទ្ធស្នាលបាន លុះសម្រេចកិច្ចនោះហើយ ក៏ឋិតនៅក្នុងទីដ៏សមគួរ។ លុះបរិព្វាជកឈ្មោះសារីបុត្ត ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងព្រះអស្សជិដ៏មានអាយុថា ម្នាលលោកដ៏មានអាយុ ឥន្ទ្រិយទាំងឡាយរបស់លោកក៏ស្រស់បស់ សម្បុរស្បែករបស់លោកក៏ស្អាតផូរផង់ ម្នាលលោកដ៏មានអាយុ លោកបួសចំពោះអ្នកណា ម្យ៉ាងទៀត អ្នកណាជាគ្រូរបស់លោក ខ្លួនលោកនេះឯង ពេញចិត្តធម៌របស់អ្នកណា។ ព្រះអស្សជិឆ្លើយថា ម្នាលអាវុសោ មានមហាសមណៈ(មួយព្រះអង្គ) ជាសក្យបុត្រ ចេញចាកសក្យត្រកូល ហើយទ្រង់ព្រះផ្នួស ខ្ញុំឯងក៏បួសតាមព្រះមហាសមណៈដ៏មានព្រះភាគនោះ ឯព្រះដ៏មានព្រះភាគនោះឯង ជាគ្រូរបស់ខ្ញុំ ចំណែកខ្ញុំក៏គាប់ចិត្តនូវធម៌អាថ៌របស់ព្រះដ៏មានព្រះភាគនោះ។ បរិព្វាជកឈ្មោះសារីបុត្តសួរថា ចុះគ្រូរបស់លោកម្ចាស់ពោលពាក្យដូចម្ដេច សំដែងធម៌ដូចម្ដេច។ ព្រះអស្សជិឆ្លើយថា នែអ្នកដ៏មានអាយុ អាត្មាឯង ជាភិក្ខុថ្មី ទើបនឹងបួស មកកាន់ធម៌វិន័យនេះថ្មីៗ អាត្មាមិនអាចដើម្បីសំដែងធម៌ដោយពិស្ដារបានទេ តែថាអាត្មានឹងពោលនូវសេចក្ដីដល់អ្នកដោយសង្ខេបបាន។

បរិព្វាជកឈ្មោះសារីបុត្តឆ្លើយថា សូមលោកម្ចាស់សំដែងធម៌តិចក្ដី ច្រើនក្ដី សូមសំដែងតែទំនងសេចក្ដីម្យ៉ាងដល់ខ្ញុំ ៗត្រូវការដោយទំនងសេចក្ដី តែម្យ៉ាងទេ លោកម្ចាស់មិនបាច់ពោលព្យញ្ជនៈឲ្យច្រើនឡើយ។

[៦៥] គ្រានោះ ព្រះអស្សជិដ៏មានអាយុ បានពោលនូវធម្មបរិយាយនេះដល់បរិព្វាជកឈ្មោះសារីបុត្ត ថា

ធម៌ទាំងឡាយណា[52] គឺខន្ធ៥ តែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះ ម្យ៉ាងទៀត សេចក្ដីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយណា ព្រះតថាគតពោលនូវសេចក្ដីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយនោះ ព្រះមហាសមណៈ មានប្រក្រតីពោលពាក្យយ៉ាងនេះ។

[៦៦] កាលនោះ បរិព្វាជកឈ្មោះសារីបុត្ត លុះបានស្ដាប់ធម្មបរិយាយនេះហើយ ក៏មានធម្មចក្ខុ គឺសោតាបត្តិមគ្គញ្ញាណ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងថា ធម្មជាតណាមួយ មានសេចក្ដីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះរមែងរលត់ទៅវិញជាធម្មតា។

សារីបុត្តបរិព្វាជកពោលថា និព្វានធម៌នេះមានប្រាកដមែន លោម្ចាស់បានត្រាស់ដឹងនិព្វាន ដែលគ្មានសេចក្ដីសោក ព្រះនិព្វាននោះខ្ញុំមិនដែលបានឃើញ មិនដែលបានជួបប្រទះឡើយ ដោយហ្មឺននៃកប្បទាំងឡាយជាច្រើន។

[៦៧] គ្រានោះ បរិព្វាជកឈ្មោះសារីបុត្ត ចូលទៅរកបរិព្វាជកឈ្មោះមោគ្គល្លាន។ បរិព្វាជកឈ្មោះមោគ្គល្លាន បានឃើញបរិព្វាជកឈ្មោះសារីបុត្តកំពុងដើរមកពីចម្ងាយ លុះឃើញហើយ ក៏បានពោលពាក្យនេះនឹងបរិព្វាជកឈ្មោះសារីបុត្តថា ម្នាលអ្នកដ៏មានអាយុ ឥន្ទ្រិយទាំងឡាយរបស់អ្នកស្រស់បស់អីម្ល៉េះ សម្បុរស្បែករបស់អ្នកក៏ស្អាតផូរផង់ ម្នាលអ្នកដ៏មានអាយុ អ្នកបានដឹងនូវអមតធម៌ហើយឬ។ បរិព្វាជកឈ្មោះសារីបុត្តឆ្លើយថា អើ អ្នកដ៏មានអាយុ ខ្ញុំបានដឹងអមតធម៌ហើយ។ បរិព្វាជកឈ្មោះមោគ្គល្លានសួរថា អ្នកបានដឹងនូវអមតធម៌ដូចម្ដេច។ បរិព្វាជកឈ្មោះសារីបុត្តឆ្លើយថា នែអាវុសោ ខ្ញុំបានឃើញភិក្ខុឈ្មោះអស្សជិកំពុងត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះនេះ ប្រកបដោយឥរិយាបថ គឺដើរទៅដើរមក ក្រឡេកមើលទៅ ក្រឡេកមើលផ្សេងៗ បត់ដៃជើង និងលាតដៃជើង មានភ្នែកសង្រួម គួរជាទីជ្រះថ្លា លុះឃើញហើយ ខ្ញុំក៏មានសេចក្ដីត្រិះរិះថា ឱហ្ន៎ ជនទាំងឡាយណាក្នុងលោកដែលជាអរហន្តក្ដី ជាអ្នកដល់ហើយនូវអរហត្តមគ្គក្ដី ភិក្ខុនេះឯង ប្រហែលជាពួកនៃជនទាំងនោះ បើដូច្នោះ គួរអញចូលទៅរកភិក្ខុនេះហើយសួរថា ម្នាលលោកដ៏មានអាយុ លោកម្ចាស់បួសចំពោះអ្នកណា ម្យ៉ាងទៀត អ្នកណាជាគ្រូរបស់លោក លោកពេញចិត្តនឹងធម៌របស់អ្នកណា នែអ្នកដ៏មានអាយុ ខ្ញុំឯងក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលនេះជាកាលមិនគួរសួរភិក្ខុនេះទេ ភិក្ខុនេះចូលទៅកាន់ចន្លោះផ្ទះ ហើយត្រាច់ទៅដើម្បីបិណ្ឌបាត បើដូច្នោះ គួរអញជាប់តាមភិក្ខុនេះ អំពីក្រោយៗទៅ ក៏ការដែលជាប់តាមភិក្ខុនេះ គង់ដឹងនូវមគ្គញ្ញាណដែលជនទាំងឡាយគេត្រូវការដឹង ឬភិក្ខុនេះឯង ជាអ្នកស្វែងរកនូវព្រះនិព្វានដែលជនទាំងឡាយគេត្រូវការដឹង ម្នាលអ្នកដ៏មានអាយុ ពេលនោះ អស្សជិភិក្ខុ ត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ហើយក៏កាន់យកបិណ្ឌបាតត្រឡប់មកវិញ នែអ្នកដ៏មានអាយុ ខ្ញុំក៏ចូលទៅរកអស្សជិភិក្ខុនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរីករាយជាមួយនឹងអស្សជិភិក្ខុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្ដីស្និទ្ធស្នាលហើយ ក៏ឋិតនៅក្នុងទីដ៏សមគួរ ម្នាលអ្នកដ៏មានអាយុ លុះខ្ញុំឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងអស្សជិភិក្ខុថា ម្នាលលោកដ៏មានអាយុ ឥន្ទ្រិយទាំងឡាយរបស់លោកក៏ស្រស់បស់អីម្ល៉េះ សម្បុរស្បែករបស់លោកក៏បរិសុទ្ធផូរផង់ ម្នាលលោកដ៏មានអាយុ លោកបួសចំពោះអ្នកណា ម្យ៉ាងទៀត អ្នកណាជាគ្រូរបស់លោក លោកពេញចិត្តធម៌របស់អ្នកណា អស្សជិភិក្ខុឆ្លើយថា ម្នាល

អ្នកដ៏មានអាយុ មានមហាសមណៈ ជាសក្យបុត្រ ចេញចាកសក្យត្រកូល ហើយបួស ខ្ញុំបួសតាមនូវព្រះមហាសមណៈដ៏មានព្រះភាគនោះ ឯព្រះដ៏មានព្រះភាគនោះឯង ជាគ្រូរបស់យើង យើងពេញចិត្តនូវធម៌របស់ព្រះដ៏មានព្រះភាគនោះ (ហើយខ្ញុំសួរទៀត)ថា គ្រូរបស់លោកដ៏មានអាយុ មានប្រក្រតីពោលពាក្យដូចម្តេច សំដែងធម៌ដូចម្តេច ទើបអស្សជិភិក្ខុឆ្លើយថា ម្នាលអ្នកដ៏មានអាយុ អាត្មាឯងជាភិក្ខុថ្មី បួសមិនទាន់បានយូរទេ ទើបតែនឹងមកកាន់ធម៌វិន័យនេះថ្មីៗ អាត្មាមិនអាចដើម្បីសំដែងធម៌ដល់អ្នក ឲ្យពិស្តារបានទេ តែថាអាត្មានឹងពោលនូវទំនងសេចក្តីដោយសង្ខេបដល់អ្នកបាន (ខ្ញុំក៏និយាយទៅនឹងអស្សជិភិក្ខុនោះ)ថា

សូមលោកពោលនូវធម៌តិចក្តី ច្រើនក្តីឲ្យទាន សូមលោកពោលនូវទំនងសេចក្តីតែម្យ៉ាងដល់ខ្ញុំ ៗត្រូវការដោយសេចក្តី លោកមិនបាច់សំដែងព្យញ្ជនៈឲ្យច្រើនទេ។

[៦៨] ម្នាលអ្នកដ៏មានអាយុ អស្សជិភិក្ខុ ក៏បានពោលធម្មបរិយាយនេះក្នុងកាលនោះថា

ធម៌ទាំងឡាយណា គឺខន្ធ៥ តែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះ ម្យ៉ាងទៀត សេចក្តីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយណា ព្រះតថាគតពោលនូវសេចក្តីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយនោះ ព្រះមហាសមណៈ មានប្រក្រតីពោលយ៉ាងនេះ។

[៦៩] កាលនោះ បរិព្វាជកឈ្មោះមោគ្គល្លាន លុះបានស្តាប់ធម្មបរិយាយនេះហើយ ក៏មានធម្មចក្ខុ គឺសោតាបត្តិមគ្គញ្ញាណ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងក្នុងចិត្តថា ធម្មជាតណាមួយដែលមានសេចក្តីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានសេចក្តីរលត់ទៅវិញជាធម្មតា។

ទើបបរិព្វាជកឈ្មោះមោគ្គល្លានពោលថា និព្វានធម៌នេះ មានប្រាកដមែន លោកម្ចាស់បានត្រាស់ដឹងព្រះនិព្វានដែលគ្មានសេចក្តីសោក ព្រះនិព្វាននោះ ខ្ញុំមិនដែលបានឃើញ មិនដែលបានជួបប្រទះឡើយ ដោយហ្មឺននៃកប្បទាំងឡាយជាច្រើន។

[៧០] បរិព្វាជកឈ្មោះមោគ្គល្លាន បានពោលពាក្យនេះទៅនឹងបរិព្វាជកឈ្មោះសារីបុត្តក្នុងកាលនោះថា ម្នាលអ្នកដ៏មានអាយុ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ ៗនោះជាគ្រូរបស់យើង។ បរិព្វាជកឈ្មោះសារីបុត្តឆ្លើយថា ម្នាលអ្នកដ៏មានអាយុ បរិព្វាជកចំនួន២៥០រូបនេះឯង អាស្រ័យយើងទាំងឡាយ បានឃើញនូវយើងទាំងឡាយ ទើបនៅក្នុងទីនេះបាន យើងទាំងឡាយត្រូវលាពួកបរិព្វាជកទាំងនោះសិន ពួកបរិព្វាជកទាំងនោះនឹងយល់យ៉ាងណា គេក៏ធ្វើយ៉ាងនោះចុះ។ កាលនោះ សារីបុត្ត និងមោគ្គល្លានក៏ចូលទៅរកពួកបរិព្វាជកទាំងនោះ លុះចូលទៅដល់ហើយ ក៏បានពោលពាក្យនេះទៅនឹងបរិព្វាជកទាំងនោះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ ៗនោះជាគ្រូរបស់យើងទាំងឡាយ។ ពួកបរិព្វាជកទាំងនោះឆ្លើយថា យើងទាំងឡាយអាស្រ័យនូវលោកទាំងឡាយដ៏មានអាយុ បានឃើញនូវលោកទាំងឡាយដ៏មានអាយុ ទើបនៅក្នុងទីនេះបាន បើលោកទាំងឡាយដ៏មានអាយុនឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមហាសមណៈ យើងទាំងឡាយទាំងអស់គ្នា ក៏នឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់មហាសមណៈដែរ។ លំដាប់នោះ សារីបុត្តនិងមោគ្គល្លាន ក៏ចូលទៅរកបរិព្វាជកឈ្មោះសញ្ជយ លុះចូលទៅដល់ហើយ ក៏បានពោលនូវពាក្យនេះនឹងបរិព្វាជកឈ្មោះសញ្ជយថា ម្នាលលោកដ៏មានអាយុ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ ៗនោះជាគ្រូរបស់យើងទាំងឡាយ។ បរិព្វាជកឈ្មោះសញ្ជយឆ្លើយថា ម្នាលអ្នកដ៏មានអាយុ មិនគួរទេ អ្នកទាំងឡាយកុំទៅឡើយ ពួកយើងទាំងបីនាក់នឹងគ្រប់គ្រងរក្សាគណៈនេះ។ សារីបុត្តនិងមោគ្គល្លានបានពោលពាក្យនេះនឹងបរិព្វាជកឈ្មោះសញ្ជយអស់វារៈជាគំរប់ពីរដងផង។បេ។ អស់វារៈគំរប់បីដងផងថា ម្នាលអ្នកដ៏មានអាយុ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ ៗនោះជាគ្រូរបស់យើងទាំងឡាយ។ បរិព្វាជកឈ្មោះសញ្ជយឆ្លើយថា ម្នាលអ្នកដ៏មានអាយុ មិនគួរទេ អ្នកទាំងឡាយកុំទៅឡើយ ពួកយើងទាំង៣នាក់នឹងគ្រប់គ្រងរក្សាគណៈនេះ។ គ្រានោះ សារីបុត្តនិងមោគ្គល្លាន ក៏នាំបរិព្វាជកចំនួន២៥០រូបនោះ ចូលទៅកាន់វត្តវេឡុវន។ ចំណែកខាងបរិព្វាជកឈ្មោះសញ្ជយ ក៏(មានសេចក្តីទោមនស្សផុតឡើង) បណ្តាលឲ្យក្តៅក្រហាយ រហូតដល់ក្អួតឈាមចេញអំពីមាត់ក្នុងទីនោះ។

[៧១] ព្រះដ៏មានព្រះភាគបានទតឃើញសារីបុត្តនិងមោគ្គល្លានកំពុងដើរមកអំពីចម្ងាយ លុះទតឃើញហើយ ក៏ទ្រង់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជនជាសំឡាញ់នឹងគ្នាទាំងពីរនាក់នុ៎ះ ឈ្មោះកោលិតៈ១ ឈ្មោះឧបតិស្សៈ១ នឹងមកដល់ឥឡូវហើយ ហ្នឹងហើយជាគូនៃសាវករបស់តថាគតដែលជាគូដ៏ប្រសើរ ជាគូដ៏ចំរើន។

ពេលនោះ ព្រះសាស្តាទ្រង់ព្យាករនូវជនទាំងពីរនោះដែលមានចិត្តយាងចុះក្នុងធម៌ដ៏ជ្រាលជ្រៅ ក្នុងញាណវិស័យ ក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិដ៏ប្រសើរ (ព្រះនិព្វាន) តាំងតែពីមិនទាន់មកដល់វត្តវេឡុវនថា ជនទាំងពីរនាក់ ជាសំឡាញ់នឹងគ្នានុ៎ះ ឈ្មោះកោលិតៈ១ ឈ្មោះឧបតិស្សៈ១ នឹងមកដល់ឥឡូវហើយ នឹងហើយជាគូនៃសាវករបស់តថាគត ដែលជាគូដ៏ប្រសើរ ជាគូដ៏ចំរើន។

[៧២] គ្រានោះ ព្រះសារីបុត្ត និងព្រះមោគ្គល្លានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបសិរសាទៀបព្រះបាទទាំងគូនៃព្រះដ៏មានព្រះភាគ ហើយបានពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយគប្បីបានបព្វជ្ជា គប្បីបានឧបសម្បទាក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកចុះ ហើយទ្រង់ត្រាស់ថា

ធម៌តថាគតសំដែងហើយដោយប្រពៃ អ្នកទាំងឡាយចូរប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងនោះ។

**(អភិញ្ញាតានំ បព្វជ្ជា)**

CS vin.mv.01.14.01 | ភាគ ទី៦

[៧៣] សម័យនោះឯង កុលបុត្រទាំងឡាយនៅក្នុងដែនមគធៈ ដែលមានកេរ្តិ៍ឈ្មោះ គេដឹងឮគ្រប់គ្នា ក៏តែងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណគោតម ប្រតិបត្តិដើម្បីធ្វើមនុស្សមិនឲ្យមានកូន សមណគោតមប្រតិបត្តិ ដើម្បីធ្វើឲ្យស្រីទៅជាមេម៉ាយ សមណគោតម ប្រតិបត្តិដើម្បីផ្តាច់បង់ត្រកូល ឥឡូវគាត់បំបួសជដិលចំនួនមួយពាន់នាក់ ហើយបំបួសទាំងបរិព្វាជកចំនួន២៥០នាក់ ជាពួកសញ្ជ័យនេះទៀត ទាំងកុលបុត្រទាំងឡាយដែលនៅក្នុងដែនមគធៈដែលមានកេរ្តិ៍ឈ្មោះ គេដឹងឮគ្រប់គ្នានេះទៀត ក៏ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតមដែរ។ ឯមនុស្សទាំងឡាយឃើញពួកភិក្ខុហើយ ក៏នាំគ្នាចោទដោយគាថានេះថា

> មហាសមណៈ យាងមកហើយកាន់ក្រុងគិរិព្វជៈ (ភ្នំមានសណ្ឋានដូចជាក្រោល) របស់ពួកជននៅក្នុងដែនមគធៈ ព្រះអង្គនាំអស់ពួកបរិវាររបស់សញ្ជ័យទៅហើយ ឥឡូវនឹងនាំយកអ្នកណាទៅទៀតអេះ។

[៧៤] ពួកភិក្ខុបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបពួកភិក្ខុនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំឡេងនោះនឹងមិនមាននៅអស់កាលដ៏យូរទេ សំឡេងនោះនឹងមាននៅត្រឹមតែ៧ថ្ងៃ លុះកន្លង៧ថ្ងៃទៅ នឹងអន្តរធានបាត់ទៅឯង ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណា ចោទអ្នកទាំងឡាយដោយគាថានេះថា

> មហាសមណៈយាងមកហើយកាន់ក្រុងគិរិព្វជៈ របស់ពួកជនក្នុងដែនមគធៈ លោកនាំទៅនូវពួកសញ្ជ័យទាំងអស់ហើយ ឥឡូវនេះនឹងនាំអ្នកណាទៅទៀតអេះ។ (បើដូច្នោះ) អ្នកទាំងឡាយ ចូរចោទជនទាំងនោះដោយគាថានេះវិញថា ព្រះតថាគតទាំងឡាយមានសេចក្តីព្យាយាមដ៏មាំ ណែនាំសត្វដោយព្រះសទ្ធម្មដ៏ប្រពៃពិត ហេតុដូចម្តេចក៏មានសេចក្តីច្រណែន នឹងពួកអ្នកប្រាជ្ញ ដែលជាអ្នកណែនាំសត្វដោយធម៌ (នោះឯង)។

[៧៥] សម័យនោះឯង ពួកមនុស្សឃើញភិក្ខុទាំងឡាយហើយ ចោទដោយគាថានេះថា

> មហាសមណៈយាងមកហើយកាន់ក្រុងគិរិព្វជៈ របស់ពួកជនមគធៈ នាំយកពួកបរិវាររបស់សញ្ជ័យទាំងពួងទៅហើយ ឥឡូវនេះនឹងនាំយកអ្នកណាទៅទៀតហ្ន៎។
>
> ភិក្ខុទាំងឡាយ ចោទតបនឹងមនុស្សទាំងនោះដោយគាថានេះថា ព្រះតថាគតទាំងឡាយមានសេចក្តីព្យាយាមដ៏មាំ ណែនាំសត្វដោយព្រះសទ្ធម្មដ៏ប្រពៃពិត ហេតុដូចម្តេចក៏មានសេចក្តីច្រណែនពួកអ្នកប្រាជ្ញ ដែលជាអ្នកណែនាំសត្វដោយធម៌ (នោះឯង)។

[៧៦] ពួកមនុស្សពោលពាក្យយ៉ាងនេះថា បានឮថា សមណៈទាំងឡាយជាសក្យបុត្រ ណែនាំសត្វដោយធម៌ មិនមែនណែនាំដោយសភាវៈមិនមែនធម៌ទេ។ សំឡេងនោះក៏មានត្រឹមតែ៧ថ្ងៃ លុះកន្លង៧ថ្ងៃ ក៏អន្តរធានបាត់ទៅឯង។

ចប់ បព្វជ្ជារបស់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន។

ចប់ ភាណវារៈជាគំរប់៤។

## ១៥. ឧបជ្ឈាយវត្តកថា

CS vin.mv.01.15 | ភាគ ទី៦

**(ឧបជ្ឈាយវត្តកថា (១៥.))**

[៧៧] សម័យនោះឯង ភិក្ខុទាំងឡាយមិនមានឧបជ្ឈាយ៍ គ្មានអ្នកទូន្មាន គ្មានអ្នកប្រៀនប្រដៅ ស្លៀកក៏មិនត្រឹមត្រូវ ដណ្តប់ក៏មិនត្រឹមត្រូវ ទាំងឫកមារយាទក៏មិនបរិបូណ៌ នាំគ្នាត្រាច់ទៅដើម្បីបិណ្ឌបាត កាលពួកមនុស្សកំពុងតែបរិភោគ (ពួកភិក្ខុនោះ) បង្អោនបាត្រសម្រាប់សុំទៅពីខាងលើភោជនខ្លះ បង្អោនបាត្រសម្រាប់សុំ ទៅពីខាងលើខាទនីយៈខ្លះ បង្អោនបាត្រសម្រាប់សុំទៅពីខាងលើវត្ថុដែលបុគ្គលគប្បីលិទ្ធជញ្ជាប់ខ្លះ បង្អោនបាត្រសម្រាប់សុំទៅពីខាងលើទឹកសម្រាប់ផឹកខ្លះ សូមសំឡខ្លះ បាយខ្លះ ដោយខ្លួនឯង ហើយបរិភោគ មានសំឡេងហ៊ោកញ្ជៀវ សំឡេងខ្លាំងនៅក្នុងរោងបាយខ្លះ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រ មិនសមនឹងស្លៀកក៏មិនត្រឹមត្រូវ ដណ្តប់ក៏មិនត្រឹមត្រូវ មានឫកមារយាទមិនសមគួរ ត្រាច់ទៅដើម្បីបិណ្ឌបាត កាលពួកមនុស្សកំពុងតែបរិភោគ (ពួកភិក្ខុនោះ) បង្អោនបាត្រសម្រាប់សុំទៅលើភោជនខ្លះ បង្អោនបាត្រសម្រាប់សុំទៅលើខាទនីយៈខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើវត្ថុសម្រាប់លិទ្ធជញ្ជាប់ខ្លះ បង្អោន

បាត្រសម្រាប់សុំទៅខាងលើទឹកសម្រាប់ផឹកខ្លះ សូមសំឡខ្លះ បាយខ្លះ ដោយខ្លួនឯង ហើយបរិភោគ មានសំឡេងហ៊ោកញ្ជ្រៀវ សំឡេងខ្លាំងនៅក្នុងរោងបាយខ្លះ ដូចជាពួកព្រាហ្មណ៍ ដែលនៅក្នុងកន្លែងជាទីបរិភោគនៃព្រាហ្មណ៍សោះឡើយ។

[៧៨] ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្ដីខ្មាស ជាអ្នករង្កៀស ប្រាថ្នាក្នុងការរៀនសូត្រ ពួកភិក្ខុនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនគួរបើស្លៀកពាក់ក៏មិនត្រឹមត្រូវ មានឫកមារយាទមិនសមគួរ ត្រាច់ទៅដើម្បីបិណ្ឌបាត កាលពួកមនុស្សកំពុងតែបរិភោគ (ភិក្ខុទាំងនោះ) បង្អោនបាត្រសម្រាប់សុំទៅលើភោជនខ្លះ បង្អោនបាត្រសម្រាប់សុំទៅលើខាទនីយៈខ្លះ បង្អោនបាត្រសម្រាប់សុំទៅលើវត្ថុសម្រាប់ភ្លក់ខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើទឹកសម្រាប់ផឹកខ្លះ សូមសំឡខ្លះ បាយខ្លះ ដោយខ្លួនឯង ហើយបរិភោគ មានសំឡេងហ៊ោកញ្ជ្រៀវ សំឡេងខ្លាំង នៅក្នុងរោងបាយខ្លះ (ដូច្នេះ) ឡើយ។ លំដាប់នោះ ភិក្ខុទាំងនោះក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។

[៧៩] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុស្លៀកដណ្ដប់មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ ត្រាច់ទៅដើម្បីបិណ្ឌបាត កាលពួកមនុស្សកំពុងតែបរិភោគ (ភិក្ខុទាំងនោះ) បង្អោនបាត្រសម្រាប់សុំ ទៅលើភោជនខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើខាទនីយៈខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើវត្ថុសម្រាប់ភ្លក់ខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើទឹកសម្រាប់ផឹកខ្លះ សូមសំឡខ្លះ បាយខ្លះ ដោយខ្លួនឯង ហើយបរិភោគ មានសំឡេងហ៊ោកញ្ជ្រៀវ សំឡេងខ្លាំង នៅក្នុងរោងបាយខ្លះ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ (អំពើនោះ) មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគួរ មិនត្រូវធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ចុះហេតុអ្វីបានជាមោឃបុរសទាំងនោះ ស្លៀកដណ្ដប់ក៏មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ ត្រាច់ទៅដើម្បីបិណ្ឌបាត កាលមនុស្សទាំងឡាយកំពុងតែបរិភោគ (ភិក្ខុទាំងនោះ) បង្អោនបាត្រសម្រាប់សុំទៅខាងលើភោជនខ្លះ បង្អោនបាត្រសម្រាប់សុំទៅលើខាទនីយៈខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើវត្ថុសម្រាប់ភ្លក់ខ្លះ បង្អោនបាត្រសម្រាប់សុំទៅខាងលើទឹកសម្រាប់ផឹកខ្លះ សូមសំឡខ្លះ បាយខ្លះ ដោយខ្លួនឯង ហើយបរិភោគ មានសំឡេងហ៊ោកញ្ជ្រៀវ សំឡេងខ្លាំងក្នុងរោងបាយខ្លះ ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាផង មិននាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរិតតែជ្រះថ្លាតទៅទៀតផង ម្នាលភិក្ខុទាំងឡាយ ការនេះនាំឲ្យពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យខានជ្រះថ្លាទៅវិញផង នាំពួកជនខ្លះដែលជ្រះថ្លា ស្រាប់ហើយ ឲ្យប្រែប្រួលផ្តេសផ្តាសទៅវិញផង។

[៨០] លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលភិក្ខុទាំងនោះដោយអនេកបរិយាយ ហើយទ្រង់សំដែងនូវទោសនៃសភាពជាបុគ្គលដែលគេចិញ្ចឹមបានដោយលំបាក គេរក្សាបានដោយលំបាក សេចក្ដីប្រាថ្នាធំ មិនសន្តោស សេចក្ដីច្រឡូកច្រឡំដោយពួកគណៈ សេចក្ដីខ្ជិល ទើបទ្រង់ពោលសរសើរគុណនៃសភាពជាបុគ្គលដែលគេចិញ្ចឹមបានដោយងាយ គេរក្សាបានដោយងាយ សេចក្ដីប្រាថ្នាតិច សេចក្ដីសន្តោស កំចាត់បង់នូវកិលេស ដុសខាត់ចិត្ត សេចក្ដីជ្រះថ្លា មិនសន្សំនូវកិលេសវដ្ដៈ និងសេចក្ដីប្រារព្ធព្យាយាម ដោយព្រះពុទ្ធដីកាជាអនេកបរិយាយ រួចទ្រង់ធ្វើធម្មីកថា ដ៏ល្មមសមគួរដល់ហេតុនោះៗ ចំពោះភិក្ខុទាំងឡាយ ទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបជ្ឈាយ៍ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវយកចិត្តទុកដាក់ក្នុងសទ្ធិវិហារិកឲ្យដូចជាកូន សទ្ធិវិហារិក ត្រូវយកចិត្តទុកដាក់ក្នុងឧបជ្ឈាយ៍ឲ្យដូចជាបិតា ឧបជ្ឈាយ៍ និងសទ្ធិវិហារិកនោះប្រកបដោយសេចក្ដីគោរពកោតក្រែងដល់គ្នានឹងគ្នា មានការចិញ្ចឹមជីវិតស្មើគ្នាយ៉ាងនេះ និងដល់នូវសេចក្ដីចំរើន សេចក្ដីលូតលាស់ សេចក្ដីទូលំទូលាយ ក្នុងធម្មវិន័យនេះ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកគប្បីកាន់យកឧបជ្ឈាយ៍ដោយទំនងយ៉ាងនេះ។ សទ្ធិវិហារិកត្រូវគ្រងចីពរឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងទាំងឡាយ រួចហើយអង្គុយច្រហោង ផ្គងឡើងនូវអញ្ជលីរួចពោលយ៉ាងនេះនឹងឧបជ្ឈាយ៍ថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ជាឧបជ្ឈាយ៍របស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ចូរជាឧបជ្ឈាយ៍របស់ខ្ញុំ បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ចូរជាឧបជ្ឈាយ៍របស់ខ្ញុំ។ ឧបជ្ឈាយ៍ត្រូវពន្យល់សទ្ធិវិហារិកឲ្យដឹងដោយកាយ (ឬ) ឲ្យដឹងដោយវាចា (ឬ) ឲ្យដឹងទាំងកាយទាំងវាចា ដោយពាក្យថា សាហុ (កម្មនេះប្រពៃហើយក្ដី) លហុ (ពាក្យនេះមិនជាការធ្ងន់អ្វីទេក្ដី) ឱបាយិកំ (កម្មនេះជាឧបាយជាទីរើខ្លួនចេញក្ដី) បដិរូបំ (កម្មនេះសមគួរហើយក្ដី) បាសាទិកេន សម្បាទេហិ អ្នកចូរញុំាងកម្មឲ្យបរិបូណ៌ដោយកាយនិងវាចាគួរជាទីនាំមកនូវសេចក្ដីជ្រះថ្លាក្ដី (យ៉ាងនេះ) ឈ្មោះថា សទ្ធិវិហារិកកាន់យកឧបជ្ឈាយ៍ហើយ (បើឧបជ្ឈាយ៍) មិនញុំាងសទ្ធិវិហារិកឲ្យដឹងដោយកាយ ឬដោយវាចា ឬទាំងកាយ ទាំងវាចា (យ៉ាងនេះ) ឈ្មោះថា សទ្ធិវិហារិកមិនកាន់យកឧបជ្ឈាយ៍ឡើយ។

[៨១] ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍។ ឯការប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍នោះ (ដូច្នេះ)។ សទ្ធិវិហារិកត្រូវក្រោកអំពីព្រឹក ហើយដោះស្បែកជើងរួចហើយគ្រងចីពរ ឆៀងស្មាម្ខាង រួចប្រគេនឈើស្ទន់ ប្រគេនទឹកលុបមុខ ក្រាលអាសនៈ (ដល់ឧបជ្ឈាយ៍) ថា បើមានបបរ ត្រូវសទ្ធិវិហារិកលាងភាជន៍ ហើយដាក់បបរទៅប្រគេន បើឧបជ្ឈាយ៍ឆាន់បបររួចហើយ សទ្ធិវិហារិក ត្រូវប្រគេនទឹក ហើយទទួលយកភាជន៍មកវិញ ដោយការឱនលំទោន ហើយកាន់ភាជន៍ឲ្យល្អ កុំឲ្យជល់ទង្គិច លាងហើយរៀបចំទុកដាក់ឲ្យត្រឹមត្រូវ កាលបើឧបជ្ឈាយ៍ក្រោកឡើងហើយ សទ្ធិវិហារិកត្រូវរើអាសនៈចេញ ថាបើទីនោះមានសម្រាម ត្រូវសទ្ធិវិហារិកបោសចេញ។ បើឧបជ្ឈាយ៍មានសេចក្ដីប្រាថ្នាដើម្បីចូលទៅកាន់ស្រុក សទ្ធិវិហារិកត្រូវប្រគេនសម្ពត់សម្រាប់ស្លៀក (ស្បង់) ត្រូវទទួលសម្ពត់ផ្លាស់មកវិញ ត្រូវប្រគេនវត្ថពន្ធចង្កេះ ប្រគេនសង្ឃាដិទាំងឡាយ ដែលបានត្រួតគ្នា[53] ហើយ (បើ)បាត្រមានទឹក ត្រូវសទ្ធិវិហារិក លាងឲ្យជ្រះ ហើយសឹមប្រគេន ថាបើឧបជ្ឈាយ៍ប្រាថ្នានឹងយកខ្លួនទៅជាមួយ ជាបច្ឆាសមណៈផង សទ្ធិវិហារិកនោះត្រូវស្លៀកដណ្ដប់ឲ្យមានបរិមណ្ឌល៣ ស្លៀកស្បង់ឲ្យជាបរិមណ្ឌល ចងវត្ថពន្ធចង្កេះ ហើយឃ្លុំសង្ឃាដិទាំងឡាយដែលបានត្រួតគ្នាហើយ រួចពាក់ឡេវក្ដី លាងបាត្រហើយកាន់ធ្វើជាបច្ឆាសមណៈ (ដើរទៅតាមខាងក្រោយឧបជ្ឈាយ៍) សទ្ធិវិហារិកមិនត្រូវដើរឆ្ងាយពេក មិនត្រូវដើរជិតពេក សទ្ធិវិហារិកគប្បីទទួលយកវត្ថុដែលគេដាក់ចុះក្នុងបាត្រ[54] ឧបជ្ឈាយ៍កំពុងពោល សទ្ធិវិហារិកមិនត្រូវនិយាយស្កាត់ពាក្យនោះឡើយ ឧបជ្ឈាយ៍ កំពុងពោលនូវពាក្យជាទំនងនឹងត្រូវអាបត្តិ សទ្ធិវិហារិកត្រូវឃាត់ សទ្ធិវិហារិកត្រូវត្រឡប់មកមុនឧបជ្ឈាយ៍ ហើយក្រាលអាសនៈចាំ ត្រូវរៀបចំទុកទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើងដែលលាងហើយ ក្បឿងសម្រាប់ជូតជើងដែលមិនបានលាង ហើយក្រោកឡើងទទួលយកបាត្រចីវរ ប្រគេនសម្ពត់ផ្លាស់ ទទួលយកស្បង់។ ថាបើចីវរសើមដោយញើសក្អែល សទ្ធិវិហារិកត្រូវសំដិលក្នុងទីមានកំដៅបន្តិចសិន មិនត្រូវទុកដាក់ចីវរក្នុងទីមានកំដៅយូរទេ ត្រូវតែបត់ចីវរទុកដោយល្អ កាលដែលនឹងបត់ចីវរ ត្រូវបំផ្អើសជាយម្ខាងឲ្យលើសប្រមាណ៤ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យចីវរបាក់ផ្នត់ពាក់កណ្ដាលឡើយ[55] ហើយគប្បីដាក់វត្ថពន្ធចង្កេះក្នុងផ្នត់

ចីវរចុះ។ ថាបើបិណ្ឌបាតមាន ឧបជ្ឈាយ៍ត្រូវការនឹងឆាន់ សទ្ធិវិហារិកត្រូវប្រគេនទឹកហើយ សឹមបង្អោនបិណ្ឌបាតប្រគេន សទ្ធិវិហារិកត្រូវសួរឧបជ្ឈាយ៍អំពីទឹកឆាន់ហើយ ប្រគេនទឹកដល់ឧបជ្ឈាយ៍ដែលឆាន់រួចហើយ រួចទទួលបាត្រយកមកដោយសេចក្តីឱនលំទោន ហើយលាងដោយប្រពៃ កុំឲ្យទង្គិច ហើយធ្វើឲ្យស្ងួតទឹក រួចហើយហាលបាត្រ១ស្របក់ក្នុងទីមានកំដៅ តែមិនត្រូវទុកបាត្រក្នុងទីមានកំដៅយូរពេកទេ ត្រូវដម្កល់ទុកនូវបាត្រនិងចីវរឲ្យល្អ កាលដម្កល់ទុកបាត្រ ត្រូវកាន់យកបាត្រដោយដៃម្ខាង ហើយយកដៃម្ខាងស្ទាបមើលទីជាខាងក្រោមនៃគ្រែក្តី នូវទីជាខាងក្រោមនៃតាំងក្តី ហើយសឹមទុកដាក់បាត្រ (នោះ) ចុះ តែមិនត្រូវដម្កល់ទុកបាត្រលើទីដែលមិនសមគួរ[56] កាលដម្កល់ទុកនូវចីវរសោត ត្រូវកាន់ចីវរដោយដៃម្ខាង ហើយយកដៃម្ខាងជូតស្នៀងចីវរក្តី ខ្សែសម្រាប់ពាក់ចីវរក្តី ហើយធ្វើនូវជាយនៃចីវរខាងនាយឲ្យជាផ្នត់ខាងអាយ គឺបត់ចីពរជាពីរ ហើយដំកល់ចីពរនោះទុក កាលបើឧបជ្ឈាយ៍ក្រោកឡើងហើយ សទ្ធិវិហារិកត្រូវរើអាសនៈចេញ ហើយសឹមរៀបចំទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង និងក្បឿងសម្រាប់ជូតជើង ថាបើទីនោះមានសម្រាម សទ្ធិវិហារិកត្រូវបោសទីនោះចេញ។ បើឧបជ្ឈាយ៍ត្រូវការស្រង់ទឹក គប្បីចាត់ចែងទឹកសម្រាប់ស្រង់ បើឧបជ្ឈាយ៍ត្រូវការដោយទឹកត្រជាក់ សទ្ធិវិហារិកគប្បីចាត់ចែងទឹកត្រជាក់ប្រគេន បើឧបជ្ឈាយ៍ត្រូវការដោយទឹកក្តៅ សទ្ធិវិហារិកគប្បីចាត់ចែងទឹកក្តៅប្រគេន។ បើឧបជ្ឈាយ៍មានសេចក្តីប្រាថ្នាចូលទៅកាន់រោងភ្លើង សទ្ធិវិហារិកត្រូវលាយគ្រឿងលំអិតសម្រាប់ងូត[57] ត្រូវផ្សើមដីស្អិតទុក ត្រូវកាន់យកតាំងសម្រាប់ដំកល់ក្នុងរោងភ្លើង ហើយដើរទៅអំពីខាងក្រោយៗនៃឧបជ្ឈាយ៍ ហើយប្រគេនតាំងសម្រាប់រោងភ្លើង រួចត្រូវទទួលយកចីវរមកដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវប្រគេនគ្រឿងលំអិតសម្រាប់ងូត ត្រូវប្រគេនដីស្អិតផង បើសទ្ធិវិហារិកអាច ត្រូវចូលទៅកាន់រោងភ្លើង កាលចូលទៅកាន់រោងភ្លើង ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំង(កាយ) អំពីខាងមុខផង អំពីខាងក្រោយផង ហើយចូលទៅកាន់រោងភ្លើងចុះ សទ្ធិវិហារិកមិនគប្បីអង្គុយច្រៀតបៀតភិក្ខុទាំងឡាយជាថេរៈ មិនគប្បីហាមឃាត់ភិក្ខុថ្មីទាំងឡាយដោយអាសនៈឡើយ ត្រូវធ្វើបរិកម្ម (គឺកិច្ចទាំងពួងមានឲ្យនូវដីស្អិត និងទឹកក្តៅជាដើម) ដល់ឧបជ្ឈាយ៍ក្នុងរោងភ្លើង កាលចេញអំពីរោងភ្លើង ត្រូវនាំយកតាំងសម្រាប់រោងភ្លើង ហើយបិទបាំង (កាយ) អំពីខាងមុខផង អំពីខាងក្រោយផង ហើយសឹមចេញអំពីរោងភ្លើងចុះ ត្រូវធ្វើបរិកម្មដល់ឧបជ្ឈាយ៍ក្នុងទឹកផង បើសទ្ធិវិហារិកងូតទឹករួចហើយ ត្រូវឡើងមុនឧបជ្ឈាយ៍ ហើយជូតកាយរបស់ខ្លួនឲ្យស្ងួតទឹក រួចសឹមស្លៀក ហើយទើបជូតទឹកអំពីកាយរបស់ឧបជ្ឈាយ៍ ត្រូវប្រគេនសម្ពត់ស្លៀក ប្រគេនសង្ឃាដិ ហើយត្រូវកាន់យកតាំងសម្រាប់រោងភ្លើងមកជាមុន ហើយក្រាលអាសនៈ រៀបចំទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង ក្បឿងសម្រាប់ជូតជើង ត្រូវសួរឧបជ្ឈាយ៍អំពីទឹកឆាន់។ បើសទ្ធិវិហារិកមានសេចក្តីប្រាថ្នាដើម្បីរៀនបាលី គប្បីរៀនបាឡីចុះ បើមានសេចក្តីប្រាថ្នាដើម្បីរៀនអដ្ឋកថា គប្បីរៀនអដ្ឋកថាចុះ។ ឧបជ្ឈាយ៍នៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើសទ្ធិវិហារិកអាចធ្វើបាន វិហារនោះសទ្ធិវិហារិកត្រូវជម្រះសំអាត កាលដែលជម្រះសំអាតវិហារ ត្រូវយកបាត្រនិងចីវរទៅដម្កល់ទុកក្នុងទីដ៏សមគួរជាមុនសិន ត្រូវនាំយកកម្រាលអង្គុយទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូកនិងខ្នើយ ទៅដម្កល់ទុកក្នុងទីដ៏សមគួរ សទ្ធិវិហារិកដែលនឹងនាំគ្រែចេញ ត្រូវធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គុកនឹងផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅដម្កល់ទុកក្នុងទីដ៏សមគួរ សទ្ធិវិហារិកដែលនឹងនាំតាំងចេញ ត្រូវធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គុកនឹងផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅដម្កល់ទុកក្នុងទីដ៏សមគួរ សទ្ធិវិហារិកត្រូវនាំយកទ្រនាប់គ្រែទៅដម្កល់ទុកក្នុងទីដ៏សមគួរ សទ្ធិវិហារិកត្រូវនាំកន្ថោរទៅដម្កល់ទុកក្នុងទីដ៏សមគួរ សទ្ធិវិហារិកត្រូវនាំយកផែនក្តារសម្រាប់ផ្អែកទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវចំណាំឲ្យច្បាស់នូវគ្រឿងកម្រាលផែនដី ដែលគេក្រាលយ៉ាងណា ហើយនាំទៅដម្កល់ទុកក្នុងទីដ៏សមគួរ បើគ្រឿងស្មុកស្មាញ (សម្រាម មានសំបុកកន្លាត និងសរសៃពីងពាងជាដើម) មានក្នុងវិហារ សទ្ធិវិហារិកត្រូវបោសតាំងអំពីពិតានជាមុន កន្លៀតជ្រុងសន្ទះបង្អួច សទ្ធិវិហារិកត្រូវជូតសំអាត បើជញ្ជាំងដែលគេលាបដោយរង់មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់សម្ពត់ ហើយពូតរួចសឹមជូត បើផ្ទៃដែលគេលាបដោយពណ៌ខ្មៅ មានពណ៌សៅហ្មង ត្រូវជ្រលក់សម្ពត់ ហើយពូតរួច សឹមជូត បើផ្ទៃគេមិនបានលាបអ្វីទេ ត្រូវប្រស់ទឹកហើយសឹមជូត សទ្ធិវិហារិកត្រូវប្រមែប្រមូលសម្រាមយកទៅចោលក្នុងទីដ៏សមគួរ ដោយគិតថា វិហារកុំប្រឡាក់ប្រឡូសដោយធូលីឡើយ គ្រឿងកម្រាលផែនដី ដែលសទ្ធិវិហារិកហាលជម្រះគោះហើយ ត្រូវនាំយកមកក្រាលដូចដើមវិញ ទ្រនាប់គ្រែដែលសទ្ធិវិហារិកយកទៅហាលថ្ងៃហើយ ជូតរួចត្រូវយកមកដម្កល់ទុកក្នុងទីដដែល គ្រែដែលសទ្ធិវិហារិកហាលថ្ងៃជម្រះគោះរួច ត្រូវធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គុកផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកមកដាក់រៀបចំ ទុកឲ្យល្អដូចពីដើមវិញ តាំងដែលសទ្ធិវិហារិកហាលថ្ងៃហើយជ្រះគោះហើយ ត្រូវធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គុកផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅដាក់រៀបចំឲ្យល្អដូចពីដើមវិញ ពូកនិងខ្នើយដែលសទ្ធិវិហារិកហាលជម្រះគោះហើយ ត្រូវនាំយកមករៀបចំឲ្យដូចពីដើមវិញ កម្រាលសម្រាប់អង្គុយដែលសទ្ធិវិហារិកហាលជម្រះគោះហើយ ត្រូវនាំយកមកក្រាលឲ្យដូចពីដើមវិញ កន្ថោរដែលសទ្ធិវិហារិកហាលថ្ងៃ ហើយជូតហើយនាំយកមកដម្កល់ទុកដូចដែលវិញ ផែនក្តារសម្រាប់ផ្អែក ដែលសទ្ធិវិហារិកហាលថ្ងៃហើយ និងជូតហើយ ត្រូវនាំមកដម្កល់ទុកដូចដែលវិញ បាត្រនិងចីវរ សទ្ធិវិហារិកត្រូវដម្កល់ទុក កាលយកបាត្រ ទៅទុកដាក់ ត្រូវកាន់បាត្រដោយដៃម្ខាង ហើយយកដៃម្ខាងស្ទាបមើលទីខាងក្រោមនៃគ្រែក្តី ទីខាងក្រោមនៃតាំងក្តី ហើយសឹមទុកបាត្រចុះ មិនត្រូវទុកបាត្រលើទីមិនសមគួរឡើយ កាលយកចីវរទៅទុក ត្រូវកាន់ចីវរដោយដៃម្ខាង យកដៃម្ខាងជូតស្នៀងចីវរក្តី ខ្សែចីវរក្តី ហើយបត់ជាយខាងណោះឲ្យជាផ្នត់ ចូលមកខាងណេះ (គឺបត់ចីវរជាពីរ) ហើយកម្កល់ទុកនូវចីវរចុះ។ បើខ្យល់បក់ទាំងធូលីមកអំពីទិសខាងកើត សទ្ធិវិហារិក ត្រូវបិទបង្អួចទិសខាងកើត បើខ្យល់បក់ទាំងធូលីមកពីទិសខាងលិច សទ្ធិវិហារិក ត្រូវបិទបង្អួចទិសខាងលិច បើខ្យល់បក់ទាំងធូលីមកពីទិសខាងជើង សទ្ធិវិហារិក ត្រូវបិទបង្អួចទិសខាងជើង បើខ្យល់បក់ទាំងធូលីមកពីទិសខាងត្បូង សទ្ធិវិហារិក ត្រូវបិទបង្អួចទិសខាងត្បូង បើកាល គឺរដូវត្រជាក់ សទ្ធិវិហារិក ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ ត្រូវបិទក្នុងវេលាយប់ បើកាល គឺរដូវក្តៅ សទ្ធិវិហារិក ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ ត្រូវបើកក្នុងវេលាយប់។ បើបរិវេណមានសម្រាម សទ្ធិវិហារិកត្រូវបោសបរិវេណ បើបន្ទប់មានសម្រាម សទ្ធិវិហារិកត្រូវបោសបន្ទប់ បើឧបដ្ឋានសាលា[58] មានសម្រាម សទ្ធិវិហារិកត្រូវបោសឧបដ្ឋានសាលា បើរោងភ្លើងមានសម្រាម សទ្ធិវិហារិកត្រូវបោសរោងភ្លើង បើបង្គន់មានសម្រាម សទ្ធិវិហារិកត្រូវបោសបង្គន់ បើទឹកឆាន់មិនមាន សទ្ធិវិហារិកត្រូវដំកល់ទឹកឆាន់ បើទឹកសម្រាប់ប្រើប្រាស់មិនមាន សទ្ធិវិហារិកត្រូវដំកល់ទឹកសម្រាប់ប្រើប្រាស់ បើទឹកមិនមានក្នុងក្អមសម្រាប់ជម្រះអាចមន៍ សទ្ធិវិហារិកត្រូចាក់ទឹកដាក់ក្នុងក្អមសម្រាប់ជម្រះអាចមន៍។ បើសេចក្តីអផ្សុកកើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកត្រូវនាំឧបជ្ឈាយ៍ចៀសចេញទៅកំសាន្តដោយខ្លួនឯង ឬឲ្យភិក្ខុដទៃនាំចៀសចេញទៅកំសាន្ត[59]ម្យ៉ាងទៀត សទ្ធិវិហារិក ត្រូវធ្វើធម្មីកថាដល់ឧបជ្ឈាយ៍នោះ បើឧបជ្ឈាយ៍មានសេចក្តីសង្ស័យកើតឡើង សទ្ធិវិហារិកត្រូវបន្ទោបង់សេចក្តីសង្ស័យនោះដោយខ្លួនឯង ឬឲ្យភិក្ខុដទៃបន្ទោបង់ក៏បាន ឬត្រូវធ្វើធម្មីកថាដល់ឧបជ្ឈាយ៍នោះ បើសេចក្តីយល់ខុស កើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកត្រូវដោះស្រាយសេចក្តីយល់ខុសនោះចេញដោយខ្លួនឯង ឬឲ្យភិក្ខុដទៃដោះស្រាយសេចក្តីយល់ខុសនោះចេញក៏បាន ឬត្រូវធ្វើធម្មីកថាដល់ឧបជ្ឈាយ៍នោះ។ បើឧបជ្ឈាយ៍ត្រូវគរុកាបត្តិ គួរដល់បរិវាស សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃគប្បីឲ្យបរិវាសដល់ ឧបជ្ឈាយ៍(របស់អញ) ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់កិរិយាទាញអន្តរា

បត្តិ[60] មកដាក់ក្នុងមូលាបត្តិ[61] សទ្ធិវិហារិកត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃនឹងអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិចំពោះឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់មានត្ត សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃគប្បីឲ្យមានត្តដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់អព្ភានកម្ម សទ្ធិវិហារិកត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃនឹងឲ្យអព្ភានកម្ម ចំពោះឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎។ បើសង្ឃមានសេចក្តីប្រាថ្នា ដើម្បីធ្វើនូវកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី[62] ដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃកុំគប្បីធ្វើកម្មដល់ឧបជ្ឈាយ៍ ឬសង្ឃគប្បីបង្អោនទៅដើម្បីកម្មស្រាល ដោយឧបាយដូចម្តេចហ្ន៎ ម្យ៉ាងទៀត តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដែលសង្ឃបានធ្វើដល់ឧបជ្ឈាយ៍ហើយ សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យឧបជ្ឈាយ៍របស់អញលោកប្រព្រឹត្តល្អទៅ គប្បីសំឡបរោម (កុំប្រកែប្រកាន់) គប្បីប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្ម សង្ឃគប្បីរម្ងាប់កម្មនោះចេញ (ដោយស្រួល)។ បើចីវររបស់ឧបជ្ឈាយ៍គួរនឹងលាង សទ្ធិវិហារិកត្រូវលាង ឬត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា ធ្វើដូចម្តេច នឹងឲ្យគេលាងចីវររបស់ឧបជ្ឈាយ៍ បើចីវររបស់ឧបជ្ឈាយ៍គួរធ្វើ (មានប៉ះដេរជាដើម) សទ្ធិវិហារិកគប្បីធ្វើប្រគេន ឬត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងឲ្យគេធ្វើចីវរប្រគេនឧបជ្ឈាយ៍ (របស់អញ) បើគ្រឿងជ្រលក់របស់ឧបជ្ឈាយ៍គួរចំអិន សទ្ធិវិហារិកគប្បីចំអិនប្រគេន ឬត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយថា ធ្វើដូចម្តេចហ្ន៎ ជនណាមួយគេនឹងចំអិនទឹកជ្រលក់ប្រគេនឧបជ្ឈាយ៍ បើចីវររបស់ឧបជ្ឈាយ៍គួរជ្រលក់ សទ្ធិវិហារិកគប្បីជ្រលក់ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ធ្វើម្តេចហ្ន៎ ជនណាមួយគប្បីជ្រលក់ចីវររបស់ឧបជ្ឈាយ៍ កាលនឹងជ្រលក់ចីវរ ត្រូវប្រែត្រឡប់ជ្រលក់ឲ្យសព្វល្អ បើដំណក់ទឹកមិនទាន់ដាច់ទេ សទ្ធិវិហារិកមិនត្រូវចៀសចេញទៅឡើយ។ សទ្ធិវិហារិកមិនបានប្រាប់ឧបជ្ឈាយ៍ មិនត្រូវឲ្យបាត្រដល់ភិក្ខុពួកខ្លះ (ភិក្ខុដែលមិនត្រូវនឹងឧបជ្ឈាយ៍) ទេ មិនត្រូវទទួលយកបាត្ររបស់ភិក្ខុពួកខ្លះទេ មិនត្រូវឲ្យចីវរដល់ភិក្ខុពួកខ្លះទេ មិនត្រូវទទួលយកចីវររបស់ភិក្ខុពួកខ្លះទេ មិនត្រូវឲ្យគ្រឿងបរិក្ខារដល់ភិក្ខុពួកខ្លះទេ មិនត្រូវទទួលយកគ្រឿងបរិក្ខាររបស់ភិក្ខុពួកខ្លះទេ មិនត្រូវកោរសក់ដល់ភិក្ខុពួកខ្លះទេ មិនត្រូវឲ្យភិក្ខុពួកខ្លះកោរសក់ឲ្យទេ មិនត្រូវធ្វើបរិកម្មដល់ភិក្ខុពួកខ្លះទេ មិនត្រូវញុំាងភិក្ខុពួកខ្លះឲ្យធ្វើបរិកម្មទេ មិនត្រូវធ្វើសេចក្តីខ្វាល់ខ្វាយបម្រើដល់ភិក្ខុពួកខ្លះទេ មិនត្រូវញុំាងភិក្ខុពួកខ្លះឲ្យធ្វើសេចក្តីខ្វល់ខ្វាយបម្រើខ្លួនទេ មិនត្រូវធ្វើជាបច្ឆាសមណៈនៃភិក្ខុពួកខ្លះទេ មិនត្រូវយកភិក្ខុពួកខ្លះជាបច្ឆាសមណៈទេ មិនត្រូវនាំយកបិណ្ឌបាតឲ្យដល់ភិក្ខុពួកខ្លះទេ មិនត្រូវញុំាងភិក្ខុពួកខ្លះឲ្យនាំយកបិណ្ឌបាតមកឲ្យទេ។ សទ្ធិវិហារិកមិនបានលា ឧបជ្ឈាយ៍ មិនត្រូវចូលទៅកាន់ស្រុកទេ មិនត្រូវទៅកាន់ព្រៃស្មសានទេ មិនត្រូវចៀសចេញទៅកាន់ទិសឡើយ។ បើឧបជ្ឈាយ៍មានជម្ងឺ សទ្ធិវិហារិកត្រូវបម្រើអស់មួយជីវិត ត្រូវរង់ចាំត្រាតែឧបជ្ឈាយ៍ចេញចាកអាពាធ (គឺត្រូវទ្រាំជម្ងឺដរាបទាល់ជា)។

ចប់ ឧបជ្ឈាយវត្តកថា។

## ១៦. សទ្ធិវិហារិកវត្តកថា

CS vin.mv.01.16 | ភាគ ទី៦

### (សទ្ធិវិហារិកវត្តកថា (១៦.))

[៨២] ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវប្រព្រឹត្តឲ្យស្រួលល្អនឹងសទ្ធិវិហារិក។ ឯការដែលប្រព្រឹត្តឲ្យស្រួលល្អនឹងសទ្ធិវិហារិកនោះ (ដូចសេចក្តីតទៅនេះ)។ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវសង្គ្រោះ (ត្រូវទំនុកបំរុង) ត្រូវអនុគ្រោះ (អាណិតអាសូរ) សទ្ធិវិហារិកដោយការបង្រៀនបាលី ដោយអដ្ឋកថា (ពន្យល់នូវសេចក្តីនៃបាលី) ដោយឲ្យដម្បូន្មាន (ដោយសេចក្តីពន្យល់ការខុសត្រូវជាមុន) ដោយពាក្យប្រៀនប្រដៅ (ដោយពាក្យរំលឹកដាស់តឿនរឿយៗ)។ បើឧបជ្ឈាយ៍មានបាត្រ សទ្ធិវិហារិកគ្មានបាត្រ ត្រូវឧបជ្ឈាយ៍ឲ្យបាត្រទៅសទ្ធិវិហារិក (ប្រើប្រាស់ខ្លះផង) ម្យ៉ាងទៀត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ធ្វើម្តេចហ្ន៎ សទ្ធិវិហារិកនឹងបានបាត្រ បើឧបជ្ឈាយ៍មានចីវរ សទ្ធិវិហារិកគ្មានចីវរ ត្រូវឧបជ្ឈាយ៍ឲ្យចីវរទៅសទ្ធិវិហារិក (ប្រើប្រាស់ខ្លះផង) ម្យ៉ាងទៀត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់សទ្ធិវិហារិកគប្បីកើតឡើងដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍មានគ្រឿងបរិក្ខារ សទ្ធិវិហារិកគ្មានគ្រឿងបរិក្ខារ ត្រូវឧបជ្ឈាយ៍ឲ្យគ្រឿងបរិក្ខារទៅសទ្ធិវិហារិក (ប្រើប្រាស់ខ្លះផង) ម្យ៉ាងទៀត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងបរិក្ខាររបស់សទ្ធិវិហារិកគប្បីកើតឡើងដោយឧបាយដូចម្តេចហ្ន៎។ បើសទ្ធិវិហារិកឈឺ ឧបជ្ឈាយ៍ត្រូវក្រោកពីព្រឹក ឲ្យឈើស្ទន់ ឲ្យទឹកលុបមុខ ក្រាលអាសនៈ បើមានបបរ ត្រូវឧបជ្ឈាយ៍លាងភាជន៍ ហើយដាក់បបរឲ្យទៅ កាលសទ្ធិវិហារិកដែលឈឺនោះ ហុតទឹកបបររួចហើយ ឧបជ្ឈាយ៍ត្រូវហុចទឹកឲ្យ រួចទទួលយកភាជន៍មកវិញ ដោយស្រួលបួល កុំឲ្យទង្គិចទង្គកឡើយ រួចលាងរៀបទុកដាក់ឲ្យល្អ កាលបើសទ្ធិវិហារិកក្រោកចេញហើយ ឧបជ្ឈាយ៍ត្រូវរើអាសនៈចេញ បើកន្លែងនោះស្មោគគ្រោក ឧបជ្ឈាយ៍ត្រូវបោសកន្លែងនោះចេញ។ បើសទ្ធិវិហារិកមានប្រាថ្នានឹងចូលទៅកាន់ស្រុក ឧបជ្ឈាយ៍ត្រូវឲ្យស្បង់សម្រាប់ស្លៀកទៅ ទទួលយកស្បង់បន្លាស់នោះមកវិញ ត្រូវឲ្យកាយពន្ធ គឺវត្តពន្ធចង្កេះ ត្រូវដម្រួតសង្ឃាដិជាពីរជាន់ហើយសឹមឲ្យ ត្រូវលាងបាត្រដែលមានទឹកចេញហើយសឹមឲ្យ ឧបជ្ឈាយ៍ត្រូវគិតថា សទ្ធិវិហារិក មុខជានឹងត្រឡប់មកវិញនៅពេលស្មើនេះ ហើយក្រាលអាសនៈបម្រុងទុកឲ្យ ត្រូវដំកល់ទឹកលាងជើង តាំងសម្រាប់រងជើង និងក្បឿងសម្រាប់ជូតជើង[63] ត្រូវក្រោកឡើងទៅទទួលបាត្រ និងចីវរ ត្រូវឲ្យស្បង់សម្រាប់ផ្លាស់ ហើយទទួលយកស្បង់ដែលស្លៀកមកវិញ។ បើចីវរសើមដោយញើស ឧបជ្ឈាយ៍ត្រូវសំដិលចីវរក្នុងកំដៅថ្ងៃ១ស្របក់ ម្យ៉ាងទៀតកុំទុកចីវរក្នុងកំដៅថ្ងៃយូរពេក ត្រូវបត់ចីវរ (យកមកទុក) កាលបើឧបជ្ឈាយ៍បត់ចីវរ ត្រូវបំផ្លើសជាយចីវរឲ្យលើសពីគ្នាប្រមាណ៤ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យបាក់ផ្នត់ចីវរពាក់កណ្តាលឡើយ ហើយដាក់វត្តពន្ធចង្កេះក្នុងផ្នត់ចីវរចុះ។ បើអាហារបិណ្ឌបាតមានហើយ សទ្ធិវិហារិកត្រូវការនឹងឆាន់ ឧបជ្ឈាយ៍ត្រូវឲ្យទឹកហើយ ហុចអាហារបិណ្ឌបាតទៅឲ្យ ឧបជ្ឈាយ៍ត្រូវសួរសទ្ធិវិហារិកអំពីទឹកឆាន់ សទ្ធិវិហារិកឆាន់រួចហើយ ឧបជ្ឈាយ៍ត្រូវហុចទឹកឲ្យ ហើយទទួលយកបាត្រមកវិញដោយស្រួលបួល កុំឲ្យទង្គិចទង្គកឡើយ ហើយលាងឲ្យស្អាត រួចជូតទឹកឲ្យស្ងួត ហើយត្រូវហាលថ្ងៃបាន១ស្របក់ ម្យ៉ាងទៀត មិនត្រូវទុកបាត្រក្នុងកំដៅថ្ងៃយូរពេកទេ រួចត្រូវទុកដាក់បាត្រ និងចីវរ កាលដែលរៀបចំទុកដាក់បាត្រ ដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបមើលក្រោមគ្រែ ឬក្រោមតាំង ហើយសឹមទុកដាក់បាត្រ ម្យ៉ាងទៀត មិនត្រូវទុកដាក់បាត្រលើទីដែលមិនសមគួរឡើយ កាលដែលរៀបចំទុកដាក់ចីវរ ដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នៀងចីវរ ឬខ្សែចីវរ ហើយបត់ជាយខាងណោះឲ្យជាផ្នត់មកខាងណេះ (គឺបត់ចីវរជាពីរ) ហើយសឹមទុកដាក់ចីវរ កាលបើសទ្ធិវិហារិកក្រោកឡើងហើយ ឧបជ្ឈាយ៍ត្រូវរើអាសនៈចេញ រៀបចំទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង ក្បឿងសម្រាប់ជូតជើង ប្រសិនបើកន្លែងនោះស្មោកគ្រោក ដោយសម្រាម ឧបជ្ឈាយ៍

ត្រូវបោសកន្លែងនោះចេញ។ បើសទ្ធិវិហារិកចង់ងូតទឹក ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកសម្រាប់ងូតឲ្យ បើសទ្ធិវិហារិកត្រូវការទឹកត្រជាក់ ឧបជ្ឈាយ៍ត្រូវ
ចាត់ចែងទឹកត្រជាក់ឲ្យ បើសទ្ធិវិហារិកត្រូវការទឹកក្តៅ ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកក្តៅឲ្យ។ បើសទ្ធិវិហារិកចង់ចូលទៅកាន់រោងភ្លើង ឧបជ្ឈាយ៍ត្រូវ
សូន្យលំអិតសម្រាប់ងូតទឹកទុក ត្រូវផ្សើមដីស្អិតទុក រួចនាំយកតាំងសម្រាប់រោងភ្លើង ហើយប្រគល់តាំងសម្រាប់រោងភ្លើងទៅសទ្ធិវិហារិក ស្រេច
ហើយ ទទួលយកចីវរមកទុកដាក់ដោយឡែក ហើយត្រូវឲ្យគ្រឿងលំអិត ត្រូវឲ្យដីស្អិតទៅសទ្ធិវិហារិក បើឧបជ្ឈាយ៍អាចនឹងចូលទៅកាន់រោងភ្លើង
(ផងបាន) គប្បីចូលទៅកាន់រោងភ្លើងចុះ កាលនឹងចូលទៅកាន់រោងភ្លើង ត្រូវយកដីស្អិតលាបមុខ រួចបិទបាំងពីខាងមុខ ខាងក្រោយ ហើយសឹម
ចូលទៅកាន់រោងភ្លើង មិនត្រូវអង្គុយច្រៀតបៀតពួកភិក្ខុចាស់ មិនត្រូវហាមពួកភិក្ខុខ្ចីដោយអាសនៈ ឧបជ្ឈាយ៍ត្រូវធ្វើបរិកម្ម ដល់សទ្ធិវិហារិក
ក្នុងរោងភ្លើង កាលនឹងចេញអំពីរោងភ្លើងទៅ ត្រូវនាំយកតាំងសម្រាប់រោងភ្លើងចេញ ហើយបិទបាំងពីខាងមុខ ខាងក្រោយ រួចសឹមចេញពីរោង
ភ្លើង សូម្បីក្នុងទឹក ក៏ឧបជ្ឈាយ៍ត្រូវតែធ្វើបរិកម្មដល់សទ្ធិវិហារិកដែរ កាលឧបជ្ឈាយ៍ងូតរួច ត្រូវឡើងមកមុន ហើយជូតកាយនៃខ្លួនឲ្យស្ងួតទឹក
ហើយសឹមស្លៀកស្បង់ រួចត្រូវជូតទឹកអំពីកាយរបស់សទ្ធិវិហារិកទៀត ហើយហុចស្បង់សម្រាប់ស្លៀក ហុចសង្ឃាដិទៅឲ្យសទ្ធិវិហារិក រួចហើយ
ត្រូវនាំយកតាំងសម្រាប់រោងភ្លើងចេញមក ហើយក្រាលអាសនៈចាំជាមុន ឧបជ្ឈាយ៍ត្រូវដម្កល់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង និង
ក្បឿងសម្រាប់ជូតជើង ត្រូវសួរសទ្ធិវិហារិកអំពីទឹកឆាន់។ សទ្ធិវិហារិកនៅក្នុងវិហារណា បើវិហារនោះស្មោកគ្រោក បើឧបជ្ឈាយ៍អាចនឹងសំអាត
បាន គប្បីសំអាតវិហារនោះចេញ កាលនឹងសំអាតវិហារ ត្រូវនាំយកបាត្រនិងចីវរចេញជាមុនទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកម្រាលសម្រាប់
អង្គុយទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូកនិងខ្នើយ ទៅទុកក្នុងទីដ៏សមគួរ ត្រូវបន្ទាបគ្រែឲ្យទាប កុំឲ្យត្រដុះនឹងផែនដី កុំឲ្យទង្គិចសន្ទះទ្វារ និង
ក្របទ្វារ ហើយនាំយកចេញឲ្យស្រួយលទៅទុកក្នុងទីដ៏សមគួរ ត្រូវបន្ទាបតាំងឲ្យទាប កុំឲ្យត្រដុះនឹងផែនដី កុំឲ្យទង្គិចទង្គកសន្ទះទ្វារ និងក្របទ្វារ
ហើយនាំយកចេញឲ្យស្រួល ទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកទ្រនាប់គ្រែទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្តោរទៅទុកក្នុងទីដ៏សមគួរ ត្រូវ
នាំយកក្តារសម្រាប់ផ្អែកទៅទុកក្នុងទីដ៏សមគួរ គ្រឿងកម្រាលផែនដី ត្រូវឧបជ្ឈាយ៍កំណត់ឲ្យចាំកន្លែង ដែលគេក្រាលយ៉ាងណា ហើយនាំយកទៅ
ទុកក្នុងទីដ៏សមគួរ បើក្នុងវិហារ មានគ្រឿងស្អកស្មាញ (មានសរសៃពីងពាងជាដើម) ត្រូវបោសអំពីពិតានជាមុន ហើយត្រូវជូតសំអាតកន្លៀត
ជ្រុងសន្លឹកបង្អួច បើជញ្ជាំងគេលាបដោយរង់មានមន្ទិលសៅហ្មង ត្រូវជ្រលក់កំណាត់សម្ពត់ (ក្នុងទឹក) រួចពូតចេញ ហើយសឹមជូត បើទីដែល
គេលាបដោយពណ៌ខ្មៅ មានមន្ទិលសៅហ្មង ត្រូវផ្សើមកំណាត់សម្ពត់ រួចពូតចេញ ហើយសឹមជូត បើទីដែលមិនបានលាបអ្វីទេ ត្រូវយកទឹកទៅ
ប្រស់សិន ហើយសឹមបោសចេញ ត្រូវកំណត់ទុកក្នុងចិត្តថា វិហារមិនត្រូវឲ្យស្មោកគ្រោក ដោយធូលីឡើយ ហើយប្រមូលសម្រាមយកទៅ
ចាក់ចោលដោយឡែក គ្រឿងកម្រាលផែនដី ដែលហាលរួចហើយ ត្រូវគោះ (ឲ្យស្អាត) រួចនាំយកទៅក្រាលដូចដែលវិញ ទ្រនាប់គ្រែដែលហាល
រួច ត្រូវជូត(ឲ្យស្អាត) ហើយនាំយកទៅទុកនៅទីដដែលវិញ គ្រែដែលហាលរួចហើយដុសលាងគោះរួចហើយ ធ្វើឲ្យទាបស្រួល កុំឲ្យត្រដុះនឹង
ផែនដី កុំឲ្យទង្គិចទង្គកសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅរៀបទុកដាក់ដូចដែលវិញ តាំងដែលហាលរួចហើយ ត្រូវគោះហើយ ធ្វើឲ្យទាប
ស្រួល កុំឲ្យត្រដុះនឹងផែនដី កុំឲ្យទង្គិចទង្គកសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកទៅរៀបទុកដាក់ដូចដែលវិញ ពូកនិងខ្នើយដែលហាលរួចហើយ
ត្រូវគោះរួចនាំយកទៅក្រាលដូចដែលវិញ កម្រាលសម្រាប់អង្គុយដែលហាលរួចហើយ ត្រូវគោះរួចនាំយកទៅក្រាលទុកដូចដែលវិញ កន្តោរដែល
ហាលរួចហើយ ត្រូវជូតរួចនាំយកទៅទុកនៅទីដដែលវិញ ក្តារសម្រាប់ផ្អែក ដែលហាលរួចហើយ ត្រូវជូតហើយនាំយកទៅទុកនៅទីដដែលវិញ
ត្រូវទុកបាត្រនិងចីវរ (ឲ្យល្អ) កាលនឹងទុកបាត្រ ដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំងមើល ហើយសឹមទុកបាត្រ មិនត្រូវ
ទុកបាត្រលើទីដែលមិនសមគួរឡើយ កាលនឹងទុកចីវរ ដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នៀងចីវរ ឬខ្សែចីវរ ហើយបត់ជាយខាងណោះមកខាងណេះ
ឲ្យជាផ្នត់សិន រួចសឹមទុកចីវរចុះ។ បើខ្យល់បក់ធូលីមកពីទិសខាងកើត ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីខាងកើត បើខ្យល់បក់ធូលីមកពីទិសខាងលិច
ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីខាងលិច បើខ្យល់បក់ធូលីមកពីទិសខាងជើង ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីខាងជើង បើខ្យល់បក់ធូលីមកពីទិសខាងត្បូង
ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីទិសខាងត្បូង បើរដូវត្រជាក់ ឧបជ្ឈាយ៍ ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ ត្រូវបិទបង្អួចក្នុងវេលាយប់ បើរដូវក្តៅ ឧបជ្ឈាយ៍
ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ ត្រូវបើកបង្អួចក្នុងវេលាយប់វិញ។ បើទីបរិវេណស្មោកគ្រោក មិនស្អាត ឧបជ្ឈាយ៍ត្រូវបោសបរិវេណចេញ បើបន្ទប់
ស្មោកគ្រោក មិនស្អាត ត្រូវបោសបន្ទប់ចេញ បើរោងសម្រាប់ឆាន់មិនស្អាត ត្រូវបោសរោងសម្រាប់ឆាន់ បើរោងភ្លើងស្មោកគ្រោក ត្រូវបោសរោង
ភ្លើងចេញ បើបង្គន់ស្មោកគ្រោក ត្រូវបោសសំអាតបង្គន់ បើគ្មានទឹកសម្រាប់ឆាន់ ត្រូវដំកល់ទឹកសម្រាប់ឆាន់ បើគ្មានទឹកសម្រាប់ប្រើប្រាស់
ត្រូវដំកល់ទឹកសម្រាប់ប្រើប្រាស់ បើទឹកក្នុងក្អមសម្រាប់លាងអាចមន៍គ្មានទេ ត្រូចាក់ទឹកទៅក្នុងក្អមសម្រាប់លាងអាចមន៍។ បើសទ្ធិវិហារិកមាន
សេចក្តីអផ្សុក ឧបជ្ឈាយ៍ត្រូវនាំចៀសចេញទៅកំសាន្តដោយខ្លួនឯង ឬប្រើគេឲ្យនាំចៀសចេញទៅកំសាន្តក៏បាន ឬត្រូវធ្វើធម្មីកថាដល់សទ្ធិវិហារិក
នោះ បើសទ្ធិវិហារិកមានសេចក្តីសង្ស័យកើតឡើង ឧបជ្ឈាយ៍ត្រូវបន្ទោបង់ដោយខ្លួនឯង ឬរកគេឲ្យជួយបន្ទោបង់ក៏បាន ឬត្រូវធ្វើធម្មីកថាដល់
សទ្ធិវិហារិកនោះ បើសេចក្តីយល់ខុស កើតឡើងដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវដោះស្រាយ (ពន្យល់) ដោយខ្លួនឯង ឬប្រើគេឲ្យជួយដោះស្រាយ
(ពន្យល់ឲ្យលះទិដ្ឋិនោះចេញ) ក៏បាន ឬត្រូវធ្វើធម្មីកថាដល់សទ្ធិវិហារិកនោះ។ បើសទ្ធិវិហារិកត្រូវគរុកាបត្តិ គួរនឹងចូលបរិវាស ឧបជ្ឈាយ៍ត្រូវ
ធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគួរឲ្យបរិវាសដល់ សទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់កិរិយាទាញអន្តរាបត្តិ មកដាក់ក្នុង
មូលាបត្តិ ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិចំពោះសទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎
បើសទ្ធិវិហារិកគួរដល់មានត្ត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្តដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិក
គួរដល់អព្ភានកម្ម ឧបជ្ឈាយ៍ត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីធ្វើអព្ភានកម្ម ចំពោះសទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎។ បើសង្ឃចង់ធ្វើ
កម្មគឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយ
ថា សង្ឃកុំគប្បីធ្វើកម្ម ឬគប្បីបង្អោនទៅដើម្បីកម្មស្រាលដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើជាកម្មគឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី
បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី សង្ឃបានធ្វើដល់សទ្ធិវិហារិកនោះរួចទៅហើយ ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ធ្វើ
ដូចម្តេចហ្ន៎ សទ្ធិវិហារិកគប្បីប្រព្រឹត្តដោយប្រពៃ គប្បីសម្របរោម (កុំប្រកែប្រកាន់) គប្បីប្រព្រឹត្តវត្ត គួរក្នុងការរើខ្លួនចេញអំពីអាបត្តិ សង្ឃគប្បី
រម្ងាប់នូវកម្មនោះ។ បើចីវររបស់សទ្ធិវិហារិកគួរនឹងលាង ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកឯងគប្បីលាងយ៉ាងនេះ ឬគប្បីធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់
សទ្ធិវិហារិកគួរនឹងលាងដូចម្តេចហ្ន៎ បើចីវររបស់សទ្ធិវិហារិកគួរនឹងធ្វើ (មានដេរប៉ះជាដើម) ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីធ្វើយ៉ាងនេះ ឬត្រូវធ្វើ
នូវសេចក្តីខ្វល់ខ្វាយថា ចីវររបស់សទ្ធិវិហារិកគួរនឹងធ្វើដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់សទ្ធិវិហារិកគួរនឹងចំអិន ឧបជ្ឈាយ៍ត្រូវ
ប្រាប់ថា អ្នកឯងត្រូវចំអិនគ្រឿងជ្រលក់យ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងជ្រលក់របស់សទ្ធិវិហារិក គួរនឹងចំអិនដោយឧបាយដូចម្តេច
ហ្ន៎ បើចីវររបស់សទ្ធិវិហារិកគួរនឹងជ្រលក់ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកឯងគប្បីជ្រលក់ចីវរបែបនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់សទ្ធិ

វិហារិកគួរនឹងជ្រលក់ដោយឧបាយដូចម្ដេចហ្ន៎ កាលបើជ្រលក់ចីវរ ត្រូវជ្រលក់ដោយប្រែត្រឡប់ឲ្យសព្វស្មើល្អ ប្រសិនបើដំណក់ទឹកស្រក់មិនទាន់អស់ ឧបជ្ឈាយ៍កុំអាលដើរចេញ។ បើសទ្ធិវិហារិក មានជម្ងឺ ឧបជ្ឈាយ៍ត្រូវថែទាំអស់មួយជីវិត ត្រូវរង់ចាំលុះតែជាជម្ងឺ។

ចប់ សទ្ធិវិហារិកវត្តកថា។

## ១៧. បណាមិតកថា

CS vin.mv.01.17 | ភាគ ទី៦

**(១៧.)**

[៨៣] សម័យនោះឯង ពួកសទ្ធិវិហារិក មិនបានប្រព្រឹត្តល្អ (គឺមិនបានយកចិត្តទុកដាក់) នឹងឧបជ្ឈាយ៍ទាំងឡាយឡើយ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសទ្ធិវិហារិក មិនសមបើនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍សោះ។ គ្រានោះ ភិក្ខុទាំងនោះ បានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកសទ្ធិវិហារិកមិនបានប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកសទ្ធិវិហារិក មិនសមបើនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ទេ។ ព្រះដ៏មានបុណ្យ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិក មិនគួរនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ទេ ភិក្ខុណាដែលមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ ត្រូវអាបត្តិទុក្កដ។ ពួកសទ្ធិវិហារិកទាំងនោះ ក៏នៅតែមិនប្រព្រឹត្តល្អក្នុងឧបជ្ឈាយ៍ដដែល ភិក្ខុទាំងឡាយបានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទើបព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឧបជ្ឈាយ៍ បណ្ដេញសទ្ធិវិហារិក ដែលមិនបានប្រព្រឹត្តល្អចេញ។ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវបណ្ដេញសទ្ធិវិហារិកយ៉ាងនេះ គឺឧបជ្ឈាយ៍បញ្ជាក់ឲ្យដឹងដោយកាយ បញ្ជាក់ឲ្យដឹងដោយវាចា ឬទាំងកាយទាំងវាចាថា អញបណ្ដេញអ្នកឯងឥឡូវនេះក្ដី ថាអ្នកឯងកុំចូលមកក្នុងទីនេះក្ដី ថាអ្នកឯងចូរនាំយកបាត្រនិងចីវររបស់អ្នកទៅក្ដី ខ្លួនអញ អ្នកឯងមិនត្រូវមកបម្រើទេក្ដី (យ៉ាងនេះហៅថា) ឧបជ្ឈាយ៍បណ្ដេញសទ្ធិវិហារិក (បើ) ឧបជ្ឈាយ៍មិនបានបញ្ជាក់ឲ្យដឹងដោយកាយ ឬដោយវាចា ឬទាំងកាយ ទាំងវាចា (យ៉ាងនេះហៅថា) ឧបជ្ឈាយ៍មិនបានបណ្ដេញសទ្ធិវិហារិកទេ។ សម័យនោះ ពួកសទ្ធិវិហារិកដែលឧបជ្ឈាយ៍បានបណ្ដេញហើយ ក៏មិនបានឲ្យឧបជ្ឈាយ៍អត់ទោសឲ្យវិញ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកសទ្ធិវិហារិកសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យបាន។ ពួកសទ្ធិវិហារិក នៅតែមិនបានសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យឡើយ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលឧបជ្ឈាយ៍បណ្ដេញចេញទៅហើយ មិនគួរនឹងមិនសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យទេ សទ្ធិវិហារិកណាមួយមិនបានសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យ ត្រូវអាបត្តិទុក្កដ។ គ្រានោះឯង ពួកឧបជ្ឈាយ៍ កាលបើសទ្ធិវិហារិកទៅសូមខមាទោសវិញ ក៏មិនព្រមអត់ទោសឲ្យឡើយ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឧបជ្ឈាយ៍អត់ទោសដល់សទ្ធិវិហារិក។ ឧបជ្ឈាយ៍ទាំងនោះ ក៏មិនព្រមអត់ទោសឲ្យឡើយ។ ឯពួកសទ្ធិវិហារិករត់ចេញទៅខ្លះ សឹកចេញទៅខ្លះ រត់ចូលពួកតិរ្ថិយខ្លះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ កាលបើសទ្ធិវិហារិក មកសូមខមាទោស ឧបជ្ឈាយ៍ត្រូវតែអត់ទោសឲ្យ (បើ) ឧបជ្ឈាយ៍ណាមួយមិនអត់ទោសឲ្យទេ ត្រូវអាបត្តិទុក្កដ។

[៨៤] សម័យនោះឯង ពួកឧបជ្ឈាយ៍បណ្ដេញសទ្ធិវិហារិកដែលប្រព្រឹត្តល្អចេញ មិនបានបណ្ដេញសទ្ធិវិហារិកដែលប្រព្រឹត្តអាក្រក់ចេញឡើយ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលប្រព្រឹត្តល្អហើយ ឧបជ្ឈាយ៍មិនត្រូវបណ្ដេញចេញទេ (បើ) ឧបជ្ឈាយ៍ណាមួយបណ្ដេញចេញ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងសទ្ធិវិហារិកដែលប្រព្រឹត្តអាក្រក់ ឧបជ្ឈាយ៍ត្រូវតែបណ្ដេញចេញបាន (បើ) ឧបជ្ឈាយ៍ណាមួយមិនបណ្ដេញចេញទេ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលប្រកបដោយអង្គ៥ ឧបជ្ឈាយ៍ត្រូវតែបណ្ដេញចេញបាន (ឯអង្គ៥នោះ) គឺសទ្ធិវិហារិកមិនបានស្រឡាញ់ឧបជ្ឈាយ៍ដោយពិត១ មិនមានសេចក្ដីជ្រះថ្លាដោយពិត១ មិនមានសេចក្ដីអៀនខ្មាសដោយពិត១ មិនមានសេចក្ដីគោរពដោយពិត១ មិនមានការចំរើនភាវនាដោយពិត១ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកប្រកបដោយអង្គ៥នេះឯងហើយ ឧបជ្ឈាយ៍ត្រូវតែបណ្ដេញចេញ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលប្រកបដោយអង្គ៥(នោះ) ឧបជ្ឈាយ៍មិនត្រូវបណ្ដេញចេញទេ (ឯអង្គ៥នោះ) គឺសទ្ធិវិហារិកមានសេចក្ដីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត១ មានសេចក្ដីជ្រះថ្លាដោយពិត១ មានសេចក្ដីអៀនខ្មាសដោយពិត១ មានសេចក្ដីគោរពដោយពិត១ មានការចំរើនភាវនាដោយពិត១ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកប្រកបដោយអង្គ៥នេះឯងហើយ ឧបជ្ឈាយ៍មិនត្រូវបណ្ដេញចេញទេ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលប្រកបដោយអង្គ៥ គួរឲ្យឧបជ្ឈាយ៍បណ្ដេញចេញ (ឯអង្គ៥នោះ) គឺសទ្ធិវិហារិកគ្មានសេចក្ដីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត១ គ្មានសេចក្ដីជ្រះថ្លាដោយពិត១ គ្មានសេចក្ដីអៀនខ្មាសដោយពិត១ គ្មានសេចក្ដីគោរពដោយពិត១ គ្មានការចំរើនភាវនាដោយពិត១ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកប្រកបដោយអង្គទាំង៥នេះឯង គួរឲ្យឧបជ្ឈាយ៍បណ្ដេញចេញ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកប្រកបដោយអង្គ៥ ឧបជ្ឈាយ៍មិនគួរបណ្ដេញចេញឡើយ (ឯអង្គ៥នោះ) គឺសទ្ធិវិហារិកមានសេចក្ដីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត១ មានសេចក្ដីជ្រះថ្លាដោយពិត១ មានសេចក្ដីអៀនខ្មាសដោយពិត១ មានសេចក្ដីគោរពដោយពិត១ មានការចំរើនភាវនាដោយពិត១ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកប្រកបដោយអង្គទាំង៥នេះ ឧបជ្ឈាយ៍មិនគួរបណ្ដេញចេញទេ។ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ កាលមិនបណ្ដេញសទ្ធិវិហារិកដែលប្រកបដោយអង្គ៥ (ចំណែកខាងខុស) ចេញទេ នឹងមានទោស (គឺត្រូវអាបត្តិមិនខាន) បើឧបជ្ឈាយ៍បណ្ដេញសទ្ធិវិហារិកដែលប្រកបដោយអង្គ៥នេះចេញ មិនមានទោសទេ (ឯអង្គ៥នោះ) គឺសទ្ធិវិហារិកគ្មានសេចក្ដីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត១ គ្មានសេចក្ដីជ្រះថ្លាដោយពិត១ គ្មានសេចក្ដីអៀនខ្មាសដោយពិត១ គ្មានសេចក្ដីគោរពដោយពិត១ គ្មានការចំរើនភាវនាដោយពិត១ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍មិនបណ្ដេញសទ្ធិវិហារិកដែលប្រកបដោយអង្គ៥នេះឯង នឹងមានទោស (បើ) ឧបជ្ឈាយ៍បានបណ្ដេញសទ្ធិវិហារិកដែលប្រកបដោយអង្គ៥នេះឯង ក៏មិនមានទោសទេ។ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍បណ្ដេញសទ្ធិវិហារិកដែលប្រកបដោយអង្គទាំង៥ (ចំណែកខាងត្រូវ) នឹងមានទោសមិនខាន (បើ) ឧបជ្ឈាយ៍មិនបានបណ្ដេញសទ្ធិវិហារិកដែលប្រកបដោយអង្គ៥នេះចេញទេ មិនមានទោសទេ (អង្គ៥នោះ) គឺសទ្ធិវិហារិកមានសេចក្ដីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត១ មានសេចក្ដីជ្រះថ្លាដោយពិត១ មានសេចក្ដី

អៀនខ្មាសដោយពិត១ មានសេចក្តីគោរពដោយពិត១ មានការចំរើនភាវនាដោយពិត១ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍បណ្តេញសទ្ធិវិហារិកដែលប្រកបដោយអង្គទាំង៥នេះឯង នឹងមានទោសមិនខានទេ (បើ) ឧបជ្ឈាយ៍មិនបានបណ្តេញសទ្ធិវិហារិក ដែលប្រកបដោយអង្គទាំង៥នេះទេ មិនមានទោសទេ។

[៨៥] សម័យនោះឯង មានព្រាហ្មណ៍ម្នាក់បានចូលទៅរកពួកភិក្ខុ ហើយសូមផ្នួស។ ពួកភិក្ខុមិនប្រាថ្នានឹងបំបួសព្រាហ្មណ៍នោះឡើយ។ ព្រាហ្មណ៍នោះ កាលបើមិនបានផ្នួសក្នុងសំណាក់ពួកភិក្ខុហើយ ក៏ទៅជាស្គាំងស្គម មានសម្បុរអាក្រក់ កើតរោគលឿង ស្លេកស្លាំង លេចសរសៃរវាមនៅខ្លួន។ ព្រះដ៏មានព្រះភាគ ទ្រង់បានទតឃើញព្រាហ្មណ៍នោះស្គាំងស្គម មានសម្បុរអាក្រក់ កើតរោគលឿង ស្លេកស្លាំង លេចសរសៃរវាមនៅខ្លួន (ដូច្នេះ) លុះទ្រង់ទតឃើញហើយ ក៏ទ្រង់ត្រាស់ហៅពួកភិក្ខុមកសួរថា ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍នោះ បានជាស្គាំងស្គម មានសម្បុរអាក្រក់ កើតរោគលឿង ស្លេកស្លាំង លេចសរសៃរវាមនៅខ្លួន តើដោយហេតុអ្វី។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រាហ្មណ៍នុ៎ះ បានចូលមករកពួកភិក្ខុ ហើយអង្វរសូមផ្នួស ពួកភិក្ខុមិនប្រាថ្នានឹងបំបួសព្រាហ្មណ៍នោះឡើយ ព្រាហ្មណ៍នោះ កាលបើមិនបានផ្នួសក្នុងសំណាក់ពួកភិក្ខុហើយ ក៏ទៅជា ស្គាំងស្គម មានសម្បុរអាក្រក់ កើតរោគលឿង ស្លេកស្លាំង លេចសរសៃរវាមនៅខ្លួន។ វេលានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាហ្ន៎ អាចរលឹកឃើញអធិការៈ (គុណ) របស់ព្រាហ្មណ៍នោះបាន។ កាលបើព្រះអង្គ ទ្រង់សួរយ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ ក៏បានពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ (អាច) រលឹកនូវអធិការៈ (គុណ) របស់ព្រាហ្មណ៍នោះបាន។ ទ្រង់ត្រាស់សួរទៀតថា ម្នាលសារីបុត្ត អ្នកឯងរលឹកអធិការៈ (គុណ) របស់ព្រាហ្មណ៍នោះបានយ៉ាងដូចម្តេច។ ព្រះសារីបុត្តទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលខ្ញុំព្រះអង្គទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះនេះ ព្រាហ្មណ៍នោះបានប្រើគេឲ្យប្រគេនចង្ហាន់មួយវែក សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គរលឹកបាននូវអធិការៈ (គុណ) របស់ព្រាហ្មណ៍នោះប៉ុណ្ណេះឯង។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែសារីបុត្ត ពាក្យដែលអ្នកពោលមកនេះប្រពៃណាស់ នែសារីបុត្ត ធម្មតាពួកសប្បុរសរមែងជាអ្នកកតញ្ញូកតវេទី[64] ពិត ម្នាលសារីបុត្ត បើដូច្នោះ ចូរអ្នកឲ្យបព្វជ្ជា និងឧបសម្បទាដល់ព្រាហ្មណ៍នោះ។ ព្រះសារីបុត្តក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងត្រូវឲ្យបព្វជ្ជា និងឧបសម្បទាដល់ព្រាហ្មណ៍នោះដូចម្តេចទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបសម្បទាណា ដែលតថាគតបានអនុញ្ញាតដោយត្រៃសរណគមន៍រួចហើយ ចាប់ដើមពីថ្ងៃនេះតទៅ តថាគតឃាត់នូវឧបសម្បទានោះវិញ ម្នាលភិក្ខុទាំងឡាយ ឥឡូវតថាគតអនុញ្ញាតនូវឧបសម្បទាដោយញត្តិចតុត្ថកម្ម គឺកម្មមានញត្តិជាគំរប់៤វិញ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យឧបសម្បទាបែបយ៉ាងនេះ ភិក្ខុអ្នកឆ្លាសប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ[65] របស់លោកដ៏មានអាយុឈ្មោះនេះ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីញុំាងឧបសម្បទាបេក្ខៈឈ្មោះនេះ ឲ្យបានឧបសម្បទា[66] ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ចុះ។ ពាក្យនេះ ជាពាក្យផ្តៀងសង្ឃ(ឲ្យជ្រាប)។ បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត)ឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ។ ឥឡូវសង្ឃញុំាងឈ្មោះនេះឲ្យបានឧបសម្បទា ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឯការញុំាងឈ្មោះនេះឲ្យបានឧបសម្បទា ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ (បើ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង។ បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត)ឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ។ ឥឡូវសង្ឃញុំាងឈ្មោះនេះឲ្យបានឧបសម្បទា ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឯការញុំាងឈ្មោះនេះឲ្យបានឧបសម្បទា ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ (បើ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង។ បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត)ឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ។ ឥឡូវសង្ឃញុំាងឈ្មោះនេះឲ្យបានឧបសម្បទា ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឯការញុំាងឈ្មោះនេះឲ្យបានឧបសម្បទា ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ (បើ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ឈ្មោះនេះ ដែលសង្ឃបានឲ្យឧបសម្បទា ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ហើយ។ (ការដែលឲ្យឧបសម្បទានេះ) គួរដល់ព្រះសង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះឯង។

[៨៦] សម័យនោះឯង មានភិក្ខុ១រូបប្រព្រឹត្តអនាចារ គឺប្រព្រឹត្តល្មើស តាំងអំពីបានឧបសម្បទា។ ពួកភិក្ខុក៏បានពោលដាស់តឿនយ៉ាងនេះថា ម្នាលអាវុសោ អ្នកកុំធ្វើអំពើយ៉ាងនេះឡើយ អំពើនេះ មិនគួរទេ។ ភិក្ខុនោះក៏ពោលយ៉ាងនេះវិញថា ខ្ញុំមិនបានពឹងលោកដ៏មានអាយុទាំងឡាយ ដោយពាក្យថា សូមឲ្យអស់លោកឲ្យឧបសម្បទាដល់ខ្ញុំទេ លោកទាំងឡាយ ខ្ញុំមិនបានអង្វរសោះ ហេតុអ្វីក៏ហ៊ានឲ្យឧបសម្បទាដល់ខ្ញុំ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគេមិនបានសូម មិនត្រូវឲ្យឧបសម្បទា (គេ)ទេ (បើ) ភិក្ខុណាឲ្យឧបសម្បទាគេ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានគេសូម ទើបត្រូវឲ្យឧបសម្បទាគេបាន។ ម្នាលភិក្ខុទាំងឡាយ ឧបសម្បទាបេក្ខៈ ត្រូវសូមនឹងសង្ឃយ៉ាងនេះ គឺឧបសម្បទាបេក្ខៈនោះ ត្រូវចូលទៅកាន់ជំនុំសង្ឃ ហើយគ្រងចីពរឆៀងស្មាម្ខាង រួចថ្វាយបង្គំទៀបបាទានៃភិក្ខុទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី ពោលយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន ខ្ញុំសូមឧបសម្បទានឹងសង្ឃ បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្រោចស្រង់[67] នូវខ្ញុំដោយសេចក្តីអនុគ្រោះ។ ឧបសម្បទាបេក្ខៈ ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។ ភិក្ខុអ្នកឆ្លាសប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបសម្បទាបេក្ខៈនេះ ឈ្មោះនេះ របស់លោកម្ចាស់ដ៏មានអាយុឈ្មោះនេះ។ ឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ បើកម្មមានកាលដ៏សមគួរហើយដល់សង្ឃហើយ សូមសង្ឃឲ្យឧបសម្បទាបុគ្គលឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍។ វាចានេះ ជាវាចាផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបសម្បទាបេក្ខៈនេះ ឈ្មោះនេះ របស់លោកដ៏មានអាយុឈ្មោះនេះ ឥឡូវឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ សង្ឃឲ្យឧបសម្បទាបុគ្គល ឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឧបសម្បទារបស់ឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ (បើ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បី

ពោលឡើង។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះជាគំរប់បីដងផង។បេ។ ឈ្មោះនេះសង្ឃបានឲ្យឧបសម្បទាហើយ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ (ការដែលឲ្យឧបសម្បទានេះ) គួរដល់ព្រះសង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៨៧] សម័យនោះឯង មហាជនក្នុងក្រុងរាជគ្រឹះ នាំគ្នាផ្តើមឡើងចាត់ចែងភត្តាហារដ៏ឧត្តមថ្លៃថ្លា (ជាវេនៗរាល់ថ្ងៃ)។ គ្រានោះ មានព្រាហ្មណ៍ម្នាក់ មានសេចក្តីរិះគិតយ៉ាងនេះថា ពួកសមណៈ ជាសក្យបុត្តទាំងនេះឯង មានសេចក្តីសុខជាប្រក្រតី មានមារយាទស្រួលបួល បរិភោគភោជនដ៏ល្អ សិងលើសំណឹងឥតមានខ្យល់ចូលបាន ណ្ហើយចុះ អាត្មាអញគួរនឹងបួសក្នុងពួកសមណៈជាសក្យបុត្តចុះ។ វេលានោះឯង ព្រាហ្មណ៍នោះបានចូលទៅរកពួកភិក្ខុ ហើយសូមផ្នួសបួស។ ភិក្ខុទាំងឡាយក៏បានឲ្យបព្វជ្ជាឧបសម្បទាដល់ព្រាហ្មណ៍នោះ។ កាលបើព្រាហ្មណ៍នោះបានបួសរួចហើយ ភត្តាហារដែលជាវេន (នោះ) មហាជនក៏ឈប់ធ្វើទៅ។ ភិក្ខុទាំងឡាយបានពោលយ៉ាងនេះថា ម្នាលអាវុសោ លោកចូរមក យើងនឹងត្រាច់ទៅបិណ្ឌបាតឥឡូវ។ ភិក្ខុនោះ ក៏បានពោលពាក្យយ៉ាងនេះវិញថា ម្នាលអាវុសោ ខ្ញុំមិនមែនបួសដោយគិតថា អញនឹងត្រាច់ទៅបិណ្ឌបាតទេ បើអស់លោកអាណិតឲ្យបាយខ្ញុំ ៗក៏នឹងឆាន់ បើអស់លោកមិនឲ្យខ្ញុំទេ ខ្ញុំមុខជានឹងសឹកមិនខានឡើយ។ ភិក្ខុទាំងឡាយពោលថា ម្នាលអាវុសោ លោកបួសមកព្រោះហេតុតែពោះប៉ុណ្ណោះទេឬ។ ភិក្ខុនោះតបថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើនឹងមានភិក្ខុមកបួសព្រោះហេតុតែពោះ ក្នុងធម៌វិន័យដែលព្រះពុទ្ធទ្រង់សំដែងល្អហើយយ៉ាងនេះទេ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងមកបួសព្រោះហេតុតែពោះប៉ុណ្ណោះ ពិតមែនឬ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស ធម៌វិន័យដែលតថាគត បានសំដែងល្អហើយយ៉ាងនេះ អ្នកមិនសមបើបួសមក គ្រាន់តែចំអែតផ្ទៃទេ នែមោឃបុរសអំពើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ ព្រះអង្គបន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាលឲ្យឧបសម្បទា (ដល់កុលបុត្រ) ត្រូវប្រាប់និស្ស័យទាំង៤យ៉ាងផង គឺប្រាប់ថា បព្វជ្ជាត្រូវអាស្រ័យនូវភោជនជាដុំពំនូតដែលអ្នកបួសស្វែងរកបានមកដោយកំលាំងស្មងអ្នកឯងត្រូវធ្វើសេចក្តីឧស្សាហ៍ក្នុងភោជននោះដរាបដល់អស់ជីវិត (តែបើមាន) អតិរេកលាភ គឺសង្ឃភត្ត[68] ឧទ្ទេសភត្ត[69] និមន្តនភត្ត[70] សលាកភត្ត[71] បក្ខិកភត្ត[72] ឧបោសថិកភត្ត[73] និងបាដិបទិកភត្ត[74] (កើតឡើង អ្នកបួសត្រូវទទួលចុះ)១។ បព្វជ្ជា ត្រូវអាស្រ័យនូវសំពត់ចីវរបង្សុកូល អ្នកឯងត្រូវធ្វើសេចក្តីឧស្សាហ៍ក្នុងសំពត់ចីវរបង្សុកូលនោះដរាបដល់អស់ជីវិត (តែបើមាន) អតិរេកលាភ គឺសំពត់ដែលគេធ្វើដោយសម្បកឈើ សំពត់ដែលគេធ្វើដោយកប្បាស សំពត់ដែលគេធ្វើដោយសូត្រ សំពត់ដែលគេធ្វើដោយរោមសត្វ សំពត់ដែលគេធ្វើដោយធ្មៃ និងសំពត់ដែលគេធ្វើលាយដោយវត្ថុ៥យ៉ាងខាងដើមនេះ (កើតឡើង អ្នកបួសត្រូវទទួលចុះ)១។ បព្វជ្ជាត្រូវអាស្រ័យនូវសេនាសនៈទៀបគល់ឈើ ឬក្រោមម្លប់ឈើ អ្នកឯងត្រូវធ្វើសេចក្តីឧស្សាហ៍ក្នុងសេនាសនៈនោះដរាបដល់អស់ជីវិត (តែបើមាន) អតិរេកលាភ គឺវិហារ ប្រាសាទវែង ឬផ្ទះពាក់កណ្តាល (បង្ហារ) ប្រាសាទ៤ជ្រុង ប្រាសាទមានដម្បូលរលីង និងគុហារ (កើតឡើង អ្នកបួសត្រូវទទួលចុះ)១។ បព្វជ្ជាត្រូវអាស្រ័យនូវថ្នាំដែលត្រាំដោយទឹកមូត្រ អ្នកឯងត្រូវធ្វើសេចក្តីឧស្សាហ៍ក្នុងថ្នាំនោះដរាបដល់អស់ជីវិត (តែបើមាន) អតិរេកលាភ គឺទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ និងស្ករអំពៅ (កើតឡើង អ្នកបួសត្រូវទទួលចុះ)១។

ចប់ ឧបជ្ឈាយវត្តភាណវារៈ។

## ១៨. អាចរិយវត្តកថា

CS vin.mv.01.18 | ភាគ ទី៦

### (អាចរិយវត្តកថា (១៨.))

[៨៨] សម័យនោះឯង មានមាណពម្នាក់ ចូលទៅរកពួកភិក្ខុហើយ សូមផ្នួស។ ភិក្ខុទាំងនោះ ក៏បានប្រាប់និស្ស័យដល់មាណពនោះជាមុន។ មាណពនោះបានពោលយ៉ាងនេះវិញថា បពិត្រលោកម្ចាស់ដ៏ចំរើន ប្រសិនបើខ្ញុំបានបួសរួចហើយ សឹមលោកម្ចាស់ទាំងឡាយប្រាប់និស្ស័យដល់ខ្ញុំ (នោះ) ខ្ញុំទទួលត្រេកអរយក បពិត្រលោកម្ចាស់ដ៏ចំរើន ឥឡូវនេះ ខ្ញុំមិនបួសទេ (ព្រោះ) និស្ស័យជាទីបដិកូលគួរខ្ពើមរអើមដល់ខ្ញុំ។ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវប្រាប់និស្ស័យជាមុនទេ ភិក្ខុណាប្រាប់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់និស្ស័យជាបន្ទាប់អំពីឧបសម្បទាកម្មមក។

[៨៩] សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទា (ដល់កុលបុត្រ) ដោយគណៈ គឺភិក្ខុពីររូបខ្លះ បីរូបខ្លះ បួនរូបខ្លះ។ ភិក្ខុទាំងឡាយ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវឲ្យឧបសម្បទា (ដល់កុលបុត្រ) ដោយគណៈតិចជាងពី១០រូបឡើយ ភិក្ខុណាឲ្យឧបសម្បទា (ដូច្នេះ) ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យឧបសម្បទា (ដល់កុលបុត្រ) ដោយគណៈត្រឹម១០រូប ឬច្រើនជាង១០រូបឡើងទៅបាន។

[៩០] សម័យនោះឯង ភិក្ខុទាំងឡាយ ខ្លះបួសបាន១វស្សា ខ្លះបាន២វស្សា ក៏ឲ្យឧបសម្បទាដល់សទ្ធិវិហារិក។ ចំណែកខាងព្រះឧបសេនដ៏មានអាយុ ជាកូនវង្គន្តព្រាហ្មណ៍ បួសបាន១វស្សា ឲ្យឧបសម្បទាសទ្ធិវិហារិកដែរ។ ព្រះឧបសេននោះ លុះនៅចាំវស្សាបាន២វស្សារួចហើយ ក៏នាំយកសទ្ធិវិហារិកដែលបួសបាន១វស្សា ទៅគាល់ព្រះដ៏មានព្រះភាគ ដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគជាម្ចាស់ រួចអង្គុយក្នុងទីដ៏សមគួរ។ ក៏ព្រះសម្ពុទ្ធទាំងឡាយដ៏មានព្រះភាគ ព្រះអង្គតែងសន្សំ តែងធ្វើនូវសេចក្តីរីករាយរាក់ទាក់ មួយអន្លើដោយភិក្ខុជាអាគន្តុកៈទាំងឡាយ នេះជាធម្មតា។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ចំពោះព្រះឧបសេនវង្គន្តបុត្រដ៏មានអាយុថា ម្នាលភិក្ខុទាំងឡាយ អ្នកល្មមអត់ទ្រាំបានឬទេ អ្នកល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានដោយស្រួលឬទេ អ្នកទាំងឡាយមកតាមផ្លូវ ឆ្ងាយ មិនបានលំបាកទេឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំល្មមអត់ទ្រាំបាន សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ម្យ៉ាងទៀត សូមទ្រង់

ព្រះមេត្តាប្រោស យើងខ្ញុំមកតាមផ្លូវឆ្ងាយ មិនបានលំបាកទេ។ (សេចក្តីពន្យល់អំពីពុទ្ធអធ្យាស្រ័យដូចមានតទៅនេះ) ព្រះតថាគតទាំងឡាយ ជ្រាបនូវហេតុហើយសួរក៏មាន ជ្រាបនូវហេតុហើយមិនសួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយសួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយ មិនសួរក៏មាន ព្រះតថាគតទាំងឡាយ ព្រះអង្គតែងសួរនូវអំពើដែលប្រកបដោយប្រយោជន៍ មិនទ្រង់សួរអំពើដែលមិនប្រកបដោយប្រយោជន៍ឡើយ ព្រោះព្រះតថាគតទាំងឡាយ ទ្រង់បានផ្តាច់បង់នូវអំពើមិនប្រកបដោយប្រយោជន៍ទាំងឡាយ ដោយអរិយមគ្គជ្រះស្រឡះហើយ។ ព្រះពុទ្ធដ៏មានជោគទាំងឡាយ ទ្រង់សួរនូវភិក្ខុទាំងឡាយដោយអាការពីរយ៉ាងគឺ ទ្រង់ត្រិះរិះថា តថាគតនឹងសំដែងនូវធម៌១ តថាគតនឹងបញ្ញត្តនូវសិក្ខាបទដល់សាវកទាំងឡាយ១។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ចំពោះនឹងព្រះឧបសេនវង្គន្តបុត្រដ៏មានអាយុថា ម្នាលភិក្ខុ អ្នកឯងបួសបានប៉ុន្មានវស្សាហើយ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបួសបាន២វស្សាហើយ។ ព្រះដ៏មានព្រះភាគ ទ្រង់សួរថា ចុះភិក្ខុនេះ បួសបានប៉ុន្មានវស្សាហើយ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនេះបួសបាន១វស្សាហើយ។ ព្រះដ៏មានព្រះភាគទ្រង់សួរថា ភិក្ខុនេះត្រូវជាអ្វីនឹងអ្នក។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ត្រូវជាសទ្ធិវិហារិករបស់ខ្ញុំព្រះអង្គ។ ព្រះពុទ្ធដ៏មានជោគទ្រង់បន្ទោសថា នែមោឃបុរស អំពើនេះ មិនទំនង មិនសមបែប មិនសមគួរ មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែមោឃបុរស អ្នកគួរតែឲ្យភិក្ខុដទៃទូន្មានប្រៀនប្រដៅ ម្តេចឡើយ ក៏តាំងចិត្តទូន្មានប្រៀនប្រដៅភិក្ខុដទៃវិញ នែមោឃបុរស អ្នកប្រញាប់ពេកណាស់ ព្រោះអ្នកប្រព្រឹត្ត ដើម្បីសេចក្តីល្មោភច្រើន ឯសេចក្តីល្មោភច្រើននេះ បានដល់ការចងជាពួក នែមោឃបុរស អំពើនេះ នឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតរឹតតែជ្រះថ្លាឡើងក៏ទេ។បេ។ ព្រះអង្គទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានវស្សាថយអំពី១០ចុះមក មិនត្រូវឲ្យឧបសម្បទាដល់កុលបុត្រឡើយ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានវស្សា១០ ឬវស្សាច្រើនជាង១០ឡើងទៅ ឲ្យឧបសម្បទាដល់កុលបុត្របាន។

[៩១] សម័យនោះឯង ភិក្ខុទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ មិនឆ្លាស បានឲ្យឧបសម្បទាដល់កុលបុត្រ ដោយគិតអាងថា យើងមានវស្សា១០ហើយ យើងមានវស្សា១០ហើយ។ ពួកឧបជ្ឈាយ៍ជាបុគ្គលពាល ពួកសទ្ធិវិហារិកជាបណ្ឌិត ក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍មិនឆ្លាស ពួកសទ្ធិវិហារិកជាអ្នកឆ្លាស ក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍ចេះដឹងតិច ពួកសទ្ធិវិហារិកជាអ្នកចេះដឹងច្រើន ក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍អាប់ឥតបញ្ញា ពួកសទ្ធិវិហារិកជាអ្នកមានបញ្ញា ក៏ប្រាកដឡើង។ មានភិក្ខុ១រូប កាលពីដើមជាតិរ្ថិយដទៃ កាលបើឧបជ្ឈាយ៍ប្រដៅតាមធម៌ តាមវិន័យ ក៏ពោលទោសដល់ឧបជ្ឈាយ៍ ហើយរត់ទៅកាន់លទ្ធិតិរ្ថិយនោះដូចដែលវិញ។ ពួកភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយជាបុគ្គលពាលមិនឆ្លាស មិនសមបើនឹងហ៊ានឲ្យឧបសម្បទា (ដល់កុលបុត្រ) ដោយគិតថា យើងមានវស្សា១០ហើយ យើងមានវស្សា១០ហើយសោះ ពួកឧបជ្ឈាយ៍ជាបុគ្គលពាល ពួកសទ្ធិវិហារិកជាបណ្ឌិតក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍មិនឆ្លាស ពួកសទ្ធិវិហារិកជាអ្នកឆ្លាស ក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍ជាអ្នកចេះដឹងតិច ពួកសទ្ធិវិហារិកជាអ្នកចេះដឹងច្រើន ក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍អាប់ឥតបញ្ញា ពួកសទ្ធិវិហារិកជាអ្នកមានបញ្ញា ក៏ប្រាកដឡើង។ វេលានោះ ភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុជាបុគ្គលពាលមិនឆ្លៀវឆ្លាស បានឲ្យឧបសម្បទាដល់កុលបុត្រដោយគិតថា យើងមានវស្សា១០ហើយ យើងមានវស្សា១០ហើយ ពួកឧបជ្ឈាយ៍ជាបុគ្គលពាលពួកសទ្ធិវិហារិកជាបណ្ឌិត ក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍មិនឆ្លាស ពួកសទ្ធិវិហារិក ជាអ្នកឆ្លៀវឆ្លាសក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍ជាអ្នកចេះដឹងតិច ពួកសទ្ធិវិហារិក ជាអ្នកចេះដឹងច្រើន ក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍អាប់ឥតបញ្ញា ពួកសទ្ធិវិហារិកមានបញ្ញាក៏ប្រាកដឡើង ពិតមែនឬ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសនោះ ជាបុគ្គលពាលមិនឆ្លាស មិនសមបើនឹងហ៊ានឲ្យឧបសម្បទាដល់កុលបុត្រដោយគិតថា យើងមានវស្សា១០ហើយ យើងមានវស្សា១០ហើយសោះ ពួកឧបជ្ឈាយ៍ជាបុគ្គលពាល ពួកសទ្ធិវិហារិក ជាបណ្ឌិតក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍មិនឆ្លាស ពួកសទ្ធិវិហារិក ជាអ្នកឆ្លាសក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍ចេះដឹងតិច ពួកសទ្ធិវិហារិក ចេះដឹងច្រើន ក៏ប្រាកដឡើង ពួកឧបជ្ឈាយ៍អាប់ឥតបញ្ញា ពួកសទ្ធិវិហារិក មានបញ្ញាក៏ប្រាកដឡើង ម្នាលភិក្ខុទាំងឡាយ អំពើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើងក៏ទេ។បេ។ ព្រះអង្គបន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុពាលមិនឆ្លាសមិនត្រូវឲ្យឧបសម្បទា (ដល់កុលបុត្រ) ឡើយ ភិក្ខុពាលណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆ្លាសប្រតិពលមានវស្សា១០ ឬមានវស្សាច្រើនជាង១០ ឡើងទៅគួរឲ្យឧបសម្បទា (ដល់កុលបុត្រ) បាន។

[៩២] សម័យនោះឯង កាលបើឧបជ្ឈាយ៍ទាំងឡាយដើរចេញ ទៅចាកអាវាសក្តី សឹកទៅក្តី ស្លាប់ទៅក្តី ទៅកាន់ពួកតិរ្ថិយក្តី ឯពួកភិក្ខុក៏ឥតមានអាចារ្យ ឥតមានអ្នកឲ្យដំបូន្មាន ឥតមានអ្នកប្រៀនប្រដៅឡើយ ហើយស្លៀកក៏មិនស្រួល ដណ្តប់ក៏មិនស្រួល មិនបរិបូណ៌ដោយឫកមារយាទ[75] ហើយដើរទៅបិណ្ឌបាត។ កាលបើពួកមនុស្សគេកំពុងបរិភោគបាយ ភិក្ខុទាំងនោះក៏បង្អោនបាត្រសម្រាប់សូមទៅពីលើភោជនក៏មាន បង្អោនបាត្រសម្រាប់សូមទៅពីលើខាទនីយៈក៏មាន បង្អោនបាត្រសម្រាប់សូមទៅពីលើគ្រឿងសម្រាប់លិទ្ធជញ្ជាប់ក៏មាន បង្អោនបាត្រសម្រាប់សូមទៅពីលើទឹកដែលសម្រាប់ផឹកក៏មាន សុំសំឡខ្លះ បាយខ្លះ យកមកឆាន់ខ្លួនឯង មិនតែប៉ុណ្ណោះ ក៏ហ៊ោកព្រៀវនៅក្នុងរោងភត្តទៀតផង។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្ត មិនសមបើនឹងស្លៀកមិនស្រួល ដណ្តប់មិនស្រួល មិនបរិបូណ៌ដោយឫកមារយាទ ហើយដើរទៅបិណ្ឌបាតសោះ កាលពួកមនុស្សកំពុងបរិភោគបាយ ភិក្ខុទាំងនោះ ក៏បង្អោនបាត្រសម្រាប់សូមទៅពីលើភោជនក៏មាន ទៅពីលើខាទនីយៈក៏មាន ទៅពីលើគ្រឿងសម្រាប់លិទ្ធជញ្ជាប់ក៏មាន បង្អោនបាត្រសម្រាប់សូមទៅពីលើទឹកសម្រាប់ផឹកក៏មាន សុំសំឡខ្លះ បាយខ្លះដោយខ្លួនឯងយកមកឆាន់ មិនតែប៉ុណ្ណោះ ក៏ហ៊ោកព្រៀវខ្លាំងក្នុងរោងភត្តទៀត ដូចជាពួកព្រាហ្មណ៍ដែលហ៊ោកព្រៀវក្នុងកន្លែងបរិភោគភោជនរបស់ព្រាហ្មណ៍។ កាលមនុស្សទាំងនោះ កំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់យ៉ាងនេះ ពួកភិក្ខុក៏បានឮច្បាស់។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងស្លៀកមិនល្អ ដណ្តប់មិនល្អ មិនបរិបូណ៌ដោយឫកមារយាទសោះ។ វេលានោះឯង ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុស្លៀកមិនល្អ ដណ្តប់មិនល្អ មិនបរិបូណ៌ដោយឫកមារយាទ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់បន្ទោស។បេ។ លុះទ្រង់បន្ទោសរួចហើយ ក៏ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យមានអាចារ្យ។ ម្នាលភិក្ខុទាំងឡាយ ឯអាចារ្យ ត្រូវតាំងចិត្តនឹងអន្តេវាសិកដូចជាកូន អន្តេវាសិកត្រូវតាំងចិត្តនឹងអាចារ្យដូចជាបិតា ជនទាំងនោះត្រូវមានសេចក្តីគោរពកោតក្រែងដល់គ្នានឹងគ្នា មានការចិញ្ចឹមជីវិត

ស្មើគ្នាយ៉ាងនេះ ទើបនឹងបានសម្រេចសេចក្តីចំរើនលូតលាស់ធំទូលាយក្នុងធម៌វិន័យនេះបាន។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅនៅអាស្រ័យនឹងភិក្ខុដែលមានវស្សា១០ ឯភិក្ខុដែលមានវស្សា១០គួរឲ្យនិស្ស័យគេបាន។ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកត្រូវយកអាចារ្យ (ជាទីអាស្រ័យ) យ៉ាងនេះ។ គឺអន្តេវាសិកត្រូវធ្វើចីពរឆៀងស្មាម្ខាង ហើយសំពះបាទា រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយពោលយ៉ាងនេះនឹងអាចារ្យថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ជាអាចារ្យរបស់ខ្ញុំ ខ្ញុំសូមអាស្រ័យនៅនឹងលោកដ៏មានអាយុ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ជាអាចារ្យរបស់ខ្ញុំ ខ្ញុំសូមអាស្រ័យនៅនឹងលោកដ៏មានអាយុ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ធ្វើជាអាចារ្យរបស់ខ្ញុំ ខ្ញុំសូមអាស្រ័យនៅនឹងលោកដ៏មានអាយុ។ ឯអាចារ្យត្រូវពន្យល់អន្តេវាសិកដោយកាយ ឬដោយវាចា ឬពន្យល់ទាំងកាយទាំងវាចាថា សាហុ[76] ក្តី លហុ[77] ក្តី ឧបាយិកំ[78] ក្តី បដិរូបំ[79] ក្តី បាសាទិកេន សម្បាទេហិ[80] ក្តី (យ៉ាងនេះទើបឈ្មោះថា) អន្តេវាសិកយកអាចារ្យ (ជាទីអាស្រ័យ) (បើ)អាចារ្យមិនបានពន្យល់អន្តេវាសិកដោយកាយ ឬដោយវាចា ឬពន្យល់ទាំងកាយ ទាំងវាចាទេ ឈ្មោះថា អន្តេវាសិកមិនបានយកអាចារ្យ (ជាទីអាស្រ័យ) ឡើយ។

[៩៣] ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកត្រូវប្រព្រឹត្តឲ្យល្អនឹងអាចារ្យ។ ឯការដែលប្រព្រឹត្តឲ្យល្អនឹងអាច្យនោះ (ដូច្នេះ)។ គឺអន្តេវាសិកត្រូវក្រោកអំពីព្រឹក ហើយដោះស្បែកជើង រួចគ្រងចីពរ ឆៀងស្មាម្ខាង ហើយប្រគេនឈើស្ទន់ ប្រគេនទឹកសម្រាប់លុបមុខទៅអាចារ្យ ត្រូវក្រាលអាសនៈ បើមានបបរ អន្តេវាសិកត្រូវលាងភាជន៍ ហើយដាក់បបរប្រគេនទៅអាចារ្យ កាលបើអាចារ្យឆាន់បបររួចហើយ អន្តេវាសិកត្រូវប្រគេនទឹកទៅអាចារ្យ រួចទទួលយកភាជន៍ ធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គុកគ្នា ហើយលាងឲ្យស្អាត រួចរៀបចំទុកដាក់ កាលបើអាចារ្យក្រោកចេញហើយ អន្តេវាសិកត្រូវរើអាសនៈចេញ ថាកន្លែងនោះស្មោកគ្រោក អន្តេវាសិកត្រូវបោសកន្លែងនោះចេញ។ បើអាចារ្យចង់ចូលទៅកាន់ស្រុក អន្តេវាសិកត្រូវប្រគេនស្បង់ទៅអាចារ្យ ហើយទទួលយកស្បង់បន្លាស់មកវិញ ត្រូវប្រគេនវត្ថពន្ធចង្កេះ ត្រូវត្រួតសង្ឃាដិទាំងឡាយជាពីរជាន់ ហើយប្រគេន ត្រូវលាងបាត្រដែលប្រកបដោយទឹក ហើយប្រគេនអាចារ្យ បើអាចារ្យចង់បានអន្តេវាសិកជាបច្ឆាសមណៈ អន្តេវាសិកត្រូវបិទបាំងមណ្ឌលបី ហើយស្លៀកឲ្យជាបរិមណ្ឌល រួចចងវត្ថពន្ធចង្កេះ ហើយត្រួតសង្ឃាដិជាពីរជាន់ ហើយសឹមឃ្លុំ រួចពាក់ឡេវកណ្តុំ ហើយកាន់យកបាត្រដែលលាងហើយ ធ្វើជាសមណៈ ដើរតាមក្រោយអាចារ្យទៅចុះ កុំឲ្យដើរទៅឆ្ងាយពីអាចារ្យពេក កុំឲ្យដើរទៅជិតអាចារ្យពេក ត្រូវចាំទទួលយកវត្ថុដែលគេទុកបាត្រ[81] កាលបើអាចារ្យកំពុងនិយាយ អន្តេវាសិកមិនត្រូវដាក់ពាក្យក្នុងចន្លោះចន្លោះឡើយ បើអាចារ្យកំពុងនិយាយពាក្យជាទំនងនឹងឲ្យត្រូវអាបត្តិ អន្តេវាសិកត្រូវឃាត់ អន្តេវាសិក កាលវិលត្រឡប់មក ត្រូវមកជាមុន ហើយក្រាលអាសនៈ រួចដម្កល់ទុកនូវទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង ក្បឿងសម្រាប់ជូតជើងចាំ រួចត្រូវក្រោកទៅទទួលបាត្រនិងចីវរ ហើយប្រគេនស្បង់បន្លាស់ ទទួលយកស្បង់ស្លៀកមកវិញ។ បើចីវរសើម អន្តេវាសិកត្រូវយកទៅសំដិលក្នុងទីមានកំដៅ១រំពេច តែកុំទុកចីវរហាលថ្ងៃ(ឲ្យយូរពេក) ត្រូវបត់ចីវរ (យកមកទុក) កាលនឹងបត់ចីវរ ត្រូវបំផ្លើសជាយឲ្យហួសពីគ្នាប្រមាណ៤ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យបាក់ផ្នត់ចីវរពាក់កណ្តាលឡើយ ហើយដាក់ទុកវត្ថពន្ធចង្កេះក្នុងផ្នត់ចីវរចុះ។ បើមានចង្ហាន់បិណ្ឌបាត ហើយអាចារ្យចង់ឆាន់ អន្តេវាសិកត្រូវប្រគេនទឹក ហើយប្រគេនចង្ហាន់បិណ្ឌបាត ត្រូវសួរអាចារ្យអំពីទឹក កាលបើអាចារ្យឆាន់រួចហើយ អន្តេវាសិកត្រូវប្រគេនទឹក រួចទទួលយកបាត្រមកវិញ ធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គុកគ្នា ហើយលាងឲ្យស្អាត រួចជូតឲ្យស្ងួតទឹកចេញ ហើយហាលក្នុងទីមានកំដៅ១រំពេច តែកុំដាក់ទុកបាត្រហាលថ្ងៃ (ឲ្យយូរពេក) អន្តេវាសិកត្រូវទុកដាក់បាត្រនិងចីវរ កាលដែលទុកបាត្រ ត្រូវយកដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបមើលក្រោមគ្រែ ឬក្រោមតាំងសិន សឹមទុកបាត្រ ម្យ៉ាងទៀត កុំទុកដាក់បាត្រក្នុងទីដែលមិនសមគួរឡើយ កាលនឹងទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នៀងចីវរ ឬខ្សែចីវរ រួចបត់ជាយចីវរខាងណោះឲ្យជាផ្នត់មកខាងណេះ ហើយសឹមទុកចីវរចុះ កាលបើអាចារ្យក្រោកចេញហើយ អន្តេវាសិកត្រូវរើអាសនៈចេញ រួចត្រូវទុកដាក់នូវទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង ក្បឿងសម្រាប់ជូតជើង ប្រសិនបើកន្លែងនោះស្មោកគ្រោក អន្តេវាសិកត្រូវបោសកន្លែងនោះចេញ។ ថាបើអាចារ្យចង់ស្រង់ទឹក អន្តេវាសិកត្រូវចាត់ចែងទឹកសម្រាប់ស្រង់ប្រគេន បើអាចារ្យត្រូវការទឹកត្រជាក់ អន្តេវាសិកត្រូវចាត់ចែងទឹកត្រជាក់ប្រគេន បើអាចារ្យត្រូវការទឹកក្តៅ អន្តេវាសិកត្រូវចាត់ចែងទឹកក្តៅប្រគេន។ បើអាចារ្យចង់ចូលទៅឯរោងភ្លើង អន្តេវាសិកត្រូវសូន្យគ្រឿងលំអិតសម្រាប់ងូតទុក ត្រូវផ្សើមដីស្អិតទុក ហើយនាំយកតាំងសម្រាប់រោងភ្លើង ដើរតាមពីខាងក្រោយៗនៃអាចារ្យ ហើយប្រគេនតាំងសម្រាប់រោងភ្លើង រួចទទួលចីវរមកទុកដាក់ដោយឡែកវិញ រួចត្រូវប្រគេនគ្រឿងលំអិតសម្រាប់ងូត ត្រូវប្រគេនដីស្អិតទៅអាច្យ បើអន្តេវាសិកអាចនឹងចូលទៅបាន ក៏គប្បីចូលទៅកាន់រោងភ្លើងចុះ កាលនឹងចូលទៅកាន់រោងភ្លើង ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំងពីខាងមុខ អំពីខាងក្រោយ រួចសឹមចូលទៅកាន់រោងភ្លើង ហើយកុំឲ្យអង្គុយច្រៀតបៀតពួកភិក្ខុចាស់ឡើយ មិនត្រូវហាមអាសនៈពួកភិក្ខុថ្មី ត្រូវធ្វើបរិកម្ម មានឲ្យលំអិតសម្រាប់ងូត និងដីស្អិត ជាដើម ដល់អាចារ្យក្នុងរោងភ្លើង កាលអន្តេវាសិកដើរចេញពីរោងភ្លើងទៅ ត្រូវនាំយកតាំងសម្រាប់រោងភ្លើង ហើយបិទបាំងពីខាងមុខ ពីខាងក្រោយ រួចសឹមចេញពីរោងភ្លើង មិនតែប៉ុណ្ណោះ (ទោះបី) ក្នុងទឹក ក៏អន្តេវាសិកត្រូវតែធ្វើបរិកម្មដល់អាចារ្យដែរ កាលអន្តេវាសិកងូតរួចហើយ ត្រូវឡើងមកមុន ហើយជូតកាយរបស់ខ្លួនឲ្យស្ងួតទឹកចេញ ហើយស្លៀកស្បង់ រួចហើយត្រូវជូតទឹកពីកាយរបស់អាចារ្យ រួចត្រូវប្រគេនស្បង់ ប្រគេនសង្ឃាដិ (ទៅអាចារ្យ) ហើយអន្តេវាសិកត្រូវនាំយកតាំងសម្រាប់រោងភ្លើង ដើរចេញមកមុន រៀបចំក្រាលអាសនៈចាំ ត្រូវដំកល់ទុកនូវទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង និងក្បឿងសម្រាប់ជូតជើង ហើយត្រូវសួរអាចារ្យអំពីទឹកសម្រាប់ឆាន់។ បើអន្តេវាសិកចង់រៀនបាលី គប្បីរៀនបាឡីនឹងអាចារ្យចុះ បើអន្តេវាសិកចង់រៀនអដ្ឋកថា គប្បីរៀនអដ្ឋកថានឹងអាចារ្យចុះ។ អាចារ្យនៅក្នុងវិហារណា បើវិហារនោះស្មោកគ្រោក បើអន្តេវាសិកអាចនឹងបោសជម្រះបាន ត្រូវបោសជម្រះចុះ កាលនឹងបោសជម្រះវិហារ ត្រូវនាំយកបាត្រនិងចីវរចេញជាមុន យកទៅដម្កល់ទុកដោយឡែក ត្រូវនាំយកកម្រាលសម្រាប់ទ្រាប់អង្គុយទៅដម្កល់ទុកដោយឡែក ត្រូវនាំយកពូកនិងខ្នើយ ទៅដម្កល់ទុកដោយឡែក ត្រូវនាំគ្រែចេញ ធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គុកនឹងផែនដី កុំឲ្យត្រដុសសន្ទះទ្វារ និងក្របទ្វារ ហើយយកទៅដម្កល់ទុកដោយឡែក ត្រូវនាំយកតាំងចេញ ធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គុកផែនដី កុំឲ្យត្រដុសសន្ទះទ្វារ និងក្របទ្វារ ហើយយកទៅដម្កល់ទុកដោយឡែក ត្រូវនាំយកទ្រនាប់គ្រែទៅដម្កល់ទុកដោយឡែក ត្រូវនាំយកកន្តោរទៅទុកដោយឡែក ត្រូវនាំយកក្តារសម្រាប់ផ្អែកទៅទុកដោយឡែក ត្រូវចំណាំកម្រាលផែនដីដែលគេក្រាលទុកយ៉ាងណា ហើយនាំយកទៅទុកដោយឡែក។ គ្រឿងស្នុកស្មាញ (មានសរសៃពីងពាងជាដើម) មាននៅក្នុងវិហារ អន្តេវាសិកត្រូវបោសចេញអំពីពិតានជាមុន ត្រូវបោសកន្លៀតជ្រុងបង្អួច បើជញ្ជាំងដែលគេលាបដោយរង់ប្រឡាក់ប្រឡូស អន្តេវាសិកត្រូវផ្សើមកំណាត់សំពត់ ពូតរួចសឹមជូត បើផ្ទៃ (ផែនដី)ដែលគេលាបដោយវត្ថុពណ៌ខ្មៅ ប្រឡាក់ប្រឡូស អន្តេវាសិកត្រូវផ្សើមកំណាត់សំពត់ ហើយពូតចេញរួចសឹមជូត បើផ្ទៃគេមិនបានលាបទេ អន្តេវាសិកត្រូវយកទឹកប្រស់រួចសឹមជូត ត្រូវប្រមូលសម្រាម ដោយគិតថា វិហារកុំប្រឡាក់ប្រឡូសដោយធូលីឡើយ ហើយយកទៅចោលដោយឡែក លុះសំដិលហាលកម្រាលផែនដីហើយ បោសគោះដីចេញឲ្យស្អាត រួចហើយសឹមនាំយកទៅក្រាលដូចដែលវិញ លុះហាលទ្រនាប់គ្រែរួចហើយ ជូតឲ្យ

ស្អាត ហើយយកទៅដម្កល់ទុកក្នុងទីដដែលវិញ លុះហាលគ្រែរួចហើយ បោសគោះឲ្យស្អាត រួចនាំចេញទៅ ធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គក ផែនដី កុំឲ្យត្រដុសសន្ទះទ្វារ និងក្របទ្វារ យកទៅតាំងទុកដូចដដែលវិញ លុះសំដិលហាលតាំងរួចហើយ ត្រូវបោសគោះឲ្យស្អាត ហើយនាំចេញទៅដោយស្រួល កុំឲ្យទង្គិចទង្គកផែនដី កុំឲ្យត្រដុសសន្ទះទ្វារ និងក្របទ្វារ យកទៅតាំងទុកដូចដដែលវិញ លុះសំដិលពូកនិងខ្នើយហើយ គោះឲ្យស្អាត រួចនាំយកទៅក្រាលដូចដដែលវិញ លុះសំដិលកម្រាលសម្រាប់ទ្រាប់អង្គុយហើយបោសគោះឲ្យស្អាត រួចយកទៅក្រាលទុកដូចដដែលវិញ លុះហាលកន្តោររួចជូតឲ្យស្អាតហើយ យកទៅដម្កល់ទុកក្នុងទីដដែលវិញ លុះហាលក្តារសម្រាប់ផ្អែក រួចជូតឲ្យស្អាតហើយ យកទៅដម្កល់ទុកក្នុងទីដដែលវិញ អន្តេវាសិក ត្រូវទុកដាក់បាត្រនិងចីវរ កាលនឹងទុកបាត្រ ដៃម្ខាងចាប់យកបាត្រ ដៃម្ខាងស្ទាបមើលក្រោមគ្រែ ឬក្រោមតាំង រួចហើយសឹមទុកបាត្រ ម្យ៉ាងទៀត កុំឲ្យទុកបាត្រលើទីដែលមិនសមគួរ កាលនឹងទុកចីវរ ដៃម្ខាងចាប់យកចីវរ ដៃម្ខាងជូតស្បៀងចីវរក្តី ខ្សែចីវរក្តី ហើយធ្វើជាយខាងណោះឲ្យជាផ្ទត់មកខាងណេះ រួចសឹមទុកចីវរចុះ។ បើមានខ្យល់បក់ទាំងធូលីមកអំពីទិសខាងកើត អន្តេវាសិកត្រូវបិទបង្អួចពីទិសខាងកើត បើមានខ្យល់បក់ទាំងធូលីមកពីទិសខាងលិច អន្តេវាសិកត្រូវបិទបង្អួចពីទិសខាងលិច បើមានខ្យល់បក់ទាំងធូលីមកពីទិសខាងជើង អន្តេវាសិកត្រូវបិទបង្អួចពីទិសខាងជើង បើមានខ្យល់បក់ទាំងធូលីមកពីទិសខាងត្បូង អន្តេវាសិកត្រូវបិទបង្អួចពីទិសខាងត្បូង បើរដូវត្រជាក់ អន្តេវាសិកត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្តៅ អន្តេវាសិកត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកក្នុងវេលាយប់។ បើបរិវេណមានសម្រាម អន្តេវាសិកត្រូវបោសបរិវេណចេញ បើបន្ទប់ស្មោកគ្រោក អន្តេវាសិកត្រូវបោសបន្ទប់ចេញ បើរោងឆាន់ស្មោកគ្រោក អន្តេវាសិកត្រូវបោសរោងឆាន់ចេញ បើរោងភ្លើងមិនស្អាត អន្តេវាសិកត្រូវបោសរោងភ្លើងចេញ បើបង្គន់មិនស្អាត អន្តេវាសិកត្រូវបោសសំអាតចេញ បើគ្មានទឹកសម្រាប់ឆាន់ អន្តេវាសិកត្រូវដំកល់ទឹកសម្រាប់ឆាន់ បើគ្មានទឹកសម្រាប់ប្រើប្រាស់ អន្តេវាសិកត្រូវដំកល់ទឹកសម្រាប់ប្រើប្រាស់ បើគ្មានទឹកក្នុងក្អមសម្រាប់លាងអាចមន៍ទេ អន្តេវាសិកត្រូវដងទឹកដាក់ក្នុងក្អមសម្រាប់លាងអាចមន៍។ បើអាចារ្យមានសេចក្តីអផ្សុកកើតឡើង អន្តេវាសិកត្រូវបំបាត់សេចក្តីអផ្សុកនោះដោយខ្លួនឯង ឬឲ្យគេបំបាត់សេចក្តីអផ្សុកនោះចេញក៏បាន ឬត្រូវធ្វើធម្មីកថាដល់អាចារ្យនោះ បើសេចក្តីសង្ស័យកើតឡើងដល់អាចារ្យ អន្តេវាសិកត្រូវបន្ទោបង់សេចក្តីសង្ស័យនោះដោយខ្លួនឯង ឬឲ្យគេជួយបន្ទោបង់ក៏បាន ឬត្រូវធ្វើធម្មីកថាដល់អាចារ្យនោះ បើទិដ្ឋិ គឺសេចក្តីយល់ខុស កើតឡើងដល់អាចារ្យ អន្តេវាសិកត្រូវជួយពន្យល់ ណែនាំឲ្យយល់ត្រូវឡើងដោយខ្លួនឯង ឬឲ្យអ្នកដទៃពន្យល់ក៏បាន ឬត្រូវធ្វើធម្មីកថាដល់អាចារ្យនោះ។ បើអាចារ្យត្រូវគរុកាបត្តិ គួរនឹងចូលបរិវាស អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យបរិវាសដល់អាចារ្យ(របស់អញ) ដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យគួរនឹងទាញអន្តរាបត្តិ ចូលមកក្នុងមូលាបត្តិ អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញអន្តរាបត្តិចូលមកដាក់ក្នុងមូលាបត្តិចំពោះអាចារ្យ (របស់អញ) ដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យគួរដល់មានត្ត អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្តដល់អាចារ្យ ដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យគួរដល់អព្ភានកម្ម អន្តេវាសិកត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីធ្វើអព្ភានកម្ម (ចំពោះអាចារ្យ) ដោយឧបាយដូចម្តេចហ្ន៎។ បើសង្ឃមានប្រាថ្នាដើម្បីធ្វើនូវកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តីចំពោះអាចារ្យ អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យសង្ឃធ្វើកម្មដល់អាចារ្យ ឬសង្ឃគប្បីបង្អោនទៅដើម្បីកម្មស្រាល ដល់អាចារ្យនោះ ម្យ៉ាងទៀត កម្មគឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដែលសង្ឃបានធ្វើដល់អាចារ្យនោះហើយ អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ធ្វើដូចម្តេចហ្ន៎ ឲ្យលោកអាចារ្យប្រព្រឹត្តល្អទៅ ឲ្យប្រព្រឹត្តសម្របរោម គឺមិនប្រកួតប្រកាន់ ឲ្យប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួនចេញចាកអាបត្តិ សង្ឃគប្បីរម្ងាប់នូវកម្មនោះឲ្យ។ បើចីវររបស់អាចារ្យគួរនឹងលាង អន្តេវាសិកត្រូវលាងឲ្យ ឬធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគួរលាងដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អាចារ្យគួរនឹងធ្វើ (មានដេរប៉ះជាដើម) អន្តេវាសិកត្រូវធ្វើឲ្យ ឬធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគួរនឹងធ្វើដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់អាចារ្យគួរនឹងដាំ ឬស្ងោរ អន្តេវាសិកត្រូវដាំ ឬស្ងោរឲ្យ ឬធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងជ្រលក់របស់អាចារ្យគួរដាំ ឬស្ងោរដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អាចារ្យគួរនឹងជ្រលក់ អន្តេវាសិកត្រូវជ្រលក់ឲ្យ ឬធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគួរជ្រលក់ដោយឧបាយដូចម្តេចហ្ន៎ កាលអន្តេវាសិកជ្រលក់ចីវរ ត្រូវជលក់ដោយប្រែត្រឡប់ឲ្យសព្វល្អ ម្យ៉ាងទៀត កាលបើ (ហាលចីវរ) ដំណក់ទឹកស្រក់មិនទាន់អស់នៅឡើយ អន្តេវាសិកកុំអាលដើរចេញ។ (បើ) អន្តេវាសិកមិនទាន់បានប្រាប់អាចារ្យទេ មិនត្រូវឲ្យបាត្រទៅភិក្ខុពួកខ្លះ[82] ឡើយ មិនត្រូវទទួលយកបាត្ររបស់ភិក្ខុពួកខ្លះទេ មិនត្រូវឲ្យចីវរទៅភិក្ខុពួកខ្លះទេ មិនត្រូវទទួលយកចីវររបស់ភិក្ខុពួកខ្លះទេ មិនត្រូវឲ្យបរិក្ខារទៅភិក្ខុពួកខ្លះទេ មិនត្រូវទទួលយកបរិក្ខាររបស់ភិក្ខុពួកខ្លះទេ មិនត្រូវកោរសក់ឲ្យភិក្ខុពួកខ្លះទេ មិនត្រូវឲ្យភិក្ខុពួកខ្លះកោរសក់ឲ្យទេ មិនត្រូវធ្វើបរិកម្ម (គក់ច្របាច់) ឲ្យភិក្ខុពួកខ្លះទេ មិនត្រូវឲ្យភិក្ខុពួកខ្លះធ្វើបរិកម្មឲ្យខ្លួនទេ មិនត្រូវធ្វើសេចក្តីខ្វល់ខ្វាយដល់ភិក្ខុពួកខ្លះទេ មិនត្រូវឲ្យភិក្ខុពួកខ្លះធ្វើសេចក្តីខ្វល់ខ្វាយបម្រើ(ខ្លួន) មិនត្រូវធ្វើជាបច្ឆាសមណៈនៃភិក្ខុពួកខ្លះឡើយ មិនត្រូវយកភិក្ខុពួកខ្លះធ្វើជាបច្ឆាសមណៈនៃខ្លួន មិនត្រូវនាំយកបិណ្ឌបាតទៅឲ្យភិក្ខុពួកខ្លះ មិនត្រូវឲ្យភិក្ខុពួកខ្លះនាំយកបិណ្ឌបាតមកឲ្យខ្លួន។ (បើ) អន្តេវាសិកមិនទាន់បានប្រាប់អាចារ្យទេ មិនត្រូវចូលទៅកាន់ស្រុក មិនត្រូវចូលទៅកាន់ព្រៃខ្មោច មិនត្រូវដើរចេញទៅកាន់ទិសឡើយ។ បើអាចារ្យមានជម្ងឺឈឺ អន្តេវាសិកត្រូវថែទាំដរាបដល់អស់ជីវិត ត្រូវទៅកំដរចាំត្រាតែអាចារ្យជាស្រឡះ។

ចប់ អាចរិយវត្តកថា។

## ១៩. អន្តេវាសិកវត្តកថា

CS vin.mv.01.19 | ភាគ ទី៦

### (អន្តេវាសិកវត្តកថា (១៩.))

[៩៤] ម្នាលភិក្ខុទាំងឡាយ អាចារ្យត្រូវតែប្រព្រឹត្តឲ្យល្អនឹងអន្តេវាសិក។ ឯការដែលប្រព្រឹត្តឲ្យល្អនឹងអន្តេវាសិកនោះ (ដូចសេចក្តីតទៅនេះ)។ ម្នាលភិក្ខុទាំងឡាយ អាចារ្យត្រូវសង្គ្រោះ ទំនុកបម្រុង ត្រូវអនុគ្រោះ អាណិតអាសូរ អន្តេវាសិកដោយការបង្រៀនបាលី ដោយការ (ពន្យល់នូវសេចក្តីនៃបាលី) អដ្ឋកថា ដោយឲ្យដម្បូន្មាន ដោយប្រៀនប្រដៅ។ បើអាចារ្យមានបាត្រ អន្តេវាសិកគ្មានបាត្រ អាចារ្យត្រូវឲ្យបាត្រដល់អន្តេវាសិក (ប្រើប្រាស់ខ្លះផង) ឬ ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ធ្វើម្តេចហ្ន៎ បាត្រគប្បីកើតឡើងដល់អន្តេវាសិក បើអាចារ្យមានចីវរ អន្តេវាសិកគ្មានចីវរ អាចារ្យត្រូវឲ្យចីវរដល់អន្តេវាសិក ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវរគប្បីកើតឡើងដល់អន្តេវាសិក ដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យមានគ្រឿងបរិក្ខារ អន្តេវាសិកគ្មានគ្រឿងបរិក្ខារ អាចារ្យត្រូវឲ្យគ្រឿងបរិក្ខារដល់អន្តេវាសិក ឬធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងបរិក្ខារគប្បីកើតឡើងដល់អន្តេវាសិក ដោយឧបាយដូចម្តេចហ្ន៎។ បើអន្តេវាសិកមានជម្ងឺ អាចារ្យត្រូវក្រោកពីព្រលឹម ហើយឲ្យឈើស្ទន់ ឲ្យទឹកលុបមុខ ក្រាលនូវអាសនៈ បើមានបបរ

ត្រូវលាងភាជន៍ ដាក់បបរ ហើយយកទៅឲ្យ កាលបើអន្តេវាសិកឆាន់បបរហើយ អាចារ្យត្រូវឲ្យទឹក ហើយទទួលភាជន៍ធ្វើឲ្យទាបស្រួល ហើយត្រូវលាងទុកដាក់ដោយល្អ កុំឲ្យទង្គិចទង្គកនឹងអ្វីឡើយ កាលបើអន្តេវាសិកក្រោកឡើង អាចារ្យត្រូវរើអាសនៈចេញ បើប្រទេសនោះមានសម្រាម អាចារ្យត្រូវបោសច្រាសប្រទេសនោះចេញ។ បើអន្តេវាសិកចង់ចូលទៅកាន់ស្រុក អាចារ្យត្រូវឲ្យស្បង់សម្រាប់ស្លៀក ត្រូវទទួលទុកនូវស្បង់សម្រាប់ផ្លាស់ប្តូរ ត្រូវឲ្យវត្តពន្ធចង្កេះ ត្រូវដម្រួតសង្ឃាដិ និងចីពរជាមួយគ្នា ហើយឲ្យទៅ បាត្រដែលទទឹក ត្រូវលាងជូតហើយឲ្យ ត្រូវកំណត់ទុកក្នុងចិត្តថា អន្តេវាសិក នឹងត្រូវត្រឡប់មកត្រឹមពេលស្មើនេះ ហើយត្រូវតែងតាំងអាសនៈទុកចាំ ត្រូវបម្រុងទឹកលាងជើង តាំងសម្រាប់កល់ជើង តាំងសម្រាប់ជូតជើង ត្រូវក្រោកទៅទទួលយកបាត្រ និងចីវរ ត្រូវឲ្យស្បង់សម្រាប់ផ្លាស់ ត្រូវទទួលយកស្បង់សម្រាប់ស្លៀក។ បើចីវរសើម ត្រូវសំដិលក្នុងទីដែលមានកំដៅ១ស្របក់ ប៉ុន្តែមិនត្រូវទុកចីវរក្នុងទីដែលមានកំដៅយូរទេ ត្រូវបត់ចីវរទុក កាលនឹងបត់ចីវរ ត្រូវបំផ្លើសជាយម្ខាងឲ្យហួសគ្នាប្រមាណ ៤ធ្នាប់ ហើយសឹមបត់ចីវរចុះ ដោយគិតថា កុំឲ្យ(ចីវរ) បាក់ផ្នត់ត្រង់ពាក់កណ្តាលឡើយ ហើយត្រូវដាក់នូវវត្តពន្ធចង្កេះក្នុងផ្នត់ចីវរចុះ។ បើមានអាហារបិណ្ឌបាត អន្តេវាសិកត្រូវការឆាន់ អាចារ្យត្រូវឲ្យទឹក ហើយនាំអាហារបិណ្ឌបាតចូលទៅជិត ត្រូវសួរអន្តេវាសិកអំពីទឹកឆាន់ បើអន្តេវាសិកឆាន់រួចហើយ ត្រូវឲ្យទឹក រួចទទួលយកបាត្រចេញ ធ្វើឲ្យទាបស្រួល កុំឲ្យទង្គិចទង្គក ត្រូវលាងឲ្យស្អាត រួចហើយត្រូវជូតឲ្យស្ងួតទឹក ហើយសំដិលក្នុងទីដែលមានកំដៅមួយស្របក់ តែមិនត្រូវទុកបាត្រក្នុងទីដែលមានកំដៅយូរពេកទេ ត្រូវទុកបាត្រនិងចីវរ កាលនឹងទុកបាត្រ ត្រូវកាន់បាត្រដោយដៃម្ខាង ស្ទាបមើលទីខាងក្រោមគ្រែ ឬតាំងដោយដៃម្ខាង រួចសឹមទុកបាត្រ តែមិនត្រូវទុកបាត្រក្នុងទីមិនសមគួរឡើយ កាលនឹងទុកចីវរ ត្រូវចាប់ចីវរដោយដៃម្ខាង ជូតស្នៀងចីវរ ឬខ្សែចីវរដោយដៃម្ខាង ហើយត្រូវបត់ជាយចីវរខាងណោះឲ្យជាផ្នត់មកខាងណេះ រួចហើយសឹមទុកចីវរចុះ កាលបើអន្តេវាសិកក្រោកឡើង អាចារ្យត្រូវរើអាសនៈ ត្រូវទុកដាក់ទឹកលាងជើង តាំងសម្រាប់កល់ជើង ទ្រនាប់សម្រាប់ជូតជើង បើប្រទេសនោះមានសម្រាម អាចារ្យត្រូវបោសប្រទេសនោះចេញ។ បើអន្តេវាសិកចង់ងូតទឹក អាចារ្យត្រូវចាត់ចែងទឹកសម្រាប់ងូតឲ្យ បើត្រូវការដោយទឹកត្រជាក់ អាចារ្យត្រូវចាត់ចែងទឹកត្រជាក់ឲ្យ បើត្រូវការដោយទឹកក្តៅ អាចារ្យត្រូវចាត់ចែងទឹកក្តៅឲ្យ។ បើអន្តេវាសិកចង់ចូលទៅកាន់រោងភ្លើង អាចារ្យត្រូវសូន្យដុំលំអិតទុក ត្រូវផ្សើមដីស្អិតទុក រួចត្រូវនាំយកតាំងសម្រាប់រោងភ្លើងទៅ ហើយប្រគល់តាំងសម្រាប់រោងភ្លើងទៅអន្តេវាសិកស្រេចហើយ ទទួលយកចីវរមកទុកដោយឡែក រួចត្រូវឲ្យគ្រឿងលំអិត ត្រូវឲ្យដីស្អិតទៅអន្តេវាសិក បើអាចារ្យអាចនឹងចូលទៅកាន់រោងភ្លើងបាន ក៏គប្បីចូលទៅកាន់រោងភ្លើងចុះ កាលនឹងចូលទៅកាន់រោងភ្លើង ត្រូវយកដីស្អិតលាបមុខ រួចបិទបាំងទាំងខាងមុខ ខាងក្រោយ ហើយសឹមចូលទៅកាន់រោងភ្លើង ត្រូវកុំអង្គុយច្រៀតបៀតភិក្ខុចាស់ៗឡើយ ត្រូវកុំហាមអាសនៈភិក្ខុខ្ចីៗ អាចារ្យត្រូវធ្វើបរិកម្ម មានហុចដុំលំអិតជាដើម ដល់អន្តេវាសិកក្នុងរោងភ្លើង កាលនឹងចេញពីរោងភ្លើង ត្រូវនាំយកតាំងសម្រាប់រោងភ្លើងចេញ ហើយបិទបាំងទាំងខាងមុខ ខាងក្រោយ រួចសឹមយកចេញអំពីរោងភ្លើង សូម្បីក្នុងទឹក អាចារ្យក៏ត្រូវតែធ្វើបរិកម្ម មានហុចដុំលំអិតជាដើមដល់អន្តេវាសិកដែរ លុះដល់អាចារ្យងូតរួចហើយ ត្រូវឡើងមកមុន (អន្តេវាសិក) ហើយត្រូវជូតខ្លួនឲ្យស្ងួតទឹក ហើយសឹមស្លៀកស្បង់ រួចត្រូវជូតទឹកអំពីកាយរបស់អន្តេវាសិក រួចហុចស្បង់សម្រាប់ស្លៀក ហុចសង្ឃាដិទៅឲ្យអន្តេវាសិក រួចហើយត្រូវនាំយកតាំងសម្រាប់រោងភ្លើងចេញមកមុន ហើយត្រូវក្រាលអាសនៈ ត្រូវបម្រុងទឹកលាងជើង តាំងសម្រាប់កល់ជើង ទ្រនាប់សម្រាប់ជូតជើង រួចត្រូវសួរអន្តេវាសិកអំពីទឹកឆាន់។ ក្នុងវិហារណាដែលអន្តេវាសិកនៅ បើវិហារនោះស្មោកគ្រោក បើអាចារ្យអាចនឹងបោសច្រាស់បាន ក៏គប្បីបោសច្រាស់ចុះ កាលនឹងបោសច្រាស់វិហារ ត្រូវនាំយកបាត្រនិងចីវរចេញទៅជាមុន ហើយត្រូវទុកដាក់ក្នុងទីគួរមួយ ត្រូវនាំយកគ្រឿងកម្រាលសម្រាប់អង្គុយទៅទុកក្នុងទីសមគួរ ត្រូវនាំយកពូកនិងខ្នើយ ទៅទុកក្នុងទីសមគួរ កាលដែលនាំយកគ្រែទៅ ត្រូវធ្វើឲ្យទាបស្រួល កុំឲ្យត្រដុសនឹងផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ យកទៅទុកឲ្យល្អក្នុងទីសមគួរ កាលនឹងនាំយកតាំងទៅ ត្រូវធ្វើឲ្យទាបស្រួល កុំឲ្យត្រដុសនឹងផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយយកទៅទុកឲ្យល្អក្នុងទីសមគួរ ត្រូវយកទ្រនាប់គ្រែទៅទុកក្នុងទីសមគួរ ត្រូវនាំយកកន្ថោរទៅទុកក្នុងទីសមគួរ ត្រូវនាំយកផែនក្តារសម្រាប់ផ្អែកទៅទុកក្នុងទីសមគួរ កម្រាលផែនដី អាចារ្យត្រូវចំណាំកន្លែង ដែលគេក្រាលយ៉ាងណា ហើយនាំយកទៅទុកក្នុងទីសមគួរ។ បើវិហារមានគ្រឿងស្មុកស្មាញ (មានសម្បុកពីងពាងជាដើម) ត្រូវបោសទម្លាក់អំពីពិតានជាមុន រួចសឹមបោសកន្លៀតជ្រុងនៃសន្ទះបង្អួច បើជញ្ជាំងដែលគេលាបជ័ររង់មានពណ៌សៅហ្មង ត្រូវជ្រលក់កំណាត់សំពត់ រួចពូតចេញ ហើយសឹមជូត បើផ្ទៃដែលគេលាបដោយពណ៌ខ្មៅ មានពណ៌សៅហ្មង ត្រូវជ្រលក់កំណាត់សំពត់ រួចពូតចេញ ហើយសឹមជូត បើផ្ទៃគេមិនបានលាបអ្វីទេ ត្រូវយកទឹកទៅប្រស់ ហើយសឹមបោស ត្រូវកំណត់ទុកក្នុងចិត្តថា វិហារកុំឲ្យស្មោកគ្រោកដោយធូលីឡើយ ហើយប្រមូលសម្រាមយកទៅចាក់ចោលដោយឡែក លុះហាលគ្រឿងកម្រាលផែនដីហើយ ត្រូវគោះរួចសាយកទៅក្រាលទុកកន្លែងដដែលវិញ លុះហាលទ្រនាប់គ្រែរួចហើយ ត្រូវជូត រួចនាំយកទៅទុកដាក់នៅទីដដែលវិញ លុះហាលគ្រែហើយ ត្រូវគោះរួចធ្វើឲ្យទាបស្រួល កុំឲ្យត្រដុសនឹងផែនដី កុំឲ្យប៉ះនឹងសន្ទះទ្វារ និងក្របទ្វារ រួចនាំយកទៅរៀបចំទុកដូចដែលវិញ លុះហាលតាំងរួចហើយ ត្រូវដុសលាង គោះឲ្យស្អាតហើយ ធ្វើឲ្យទាបស្រួល កុំឲ្យត្រដុសនឹងផែនដី កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ រួចសាយកទៅរៀបចំទុកដូចដើមវិញ លុះហាលពូកនិងខ្នើយហើយ ត្រូវដុសលាងគោះចេញ ហើយសាយកទៅរៀបចំទុកដូចដើមវិញ លុះហាលគ្រឿងកម្រាលសម្រាប់អង្គុយហើយ ត្រូវដុសលាងគោះឲ្យស្អាតហើយ សាយកទៅរៀបទុកដូចដើមវិញ លុះហាលកន្ថោរហើយ ត្រូវជូតឲ្យស្អាត រួចយកទៅទុកនៅទីដដែលវិញ លុះហាលក្តារសម្រាប់ផ្អែកហើយ ត្រូវជូតឲ្យស្អាត រួចនាំយកទៅទុកនៅទីដដែលវិញ ត្រូវរៀបទុកបាត្រនិងចីវរ កាលនឹងទុកបាត្រ ដៃម្ខាងត្រូវចាប់បាត្រ ដៃម្ខាងត្រូវស្ទាបមើលក្រោមគ្រែ ឬក្រោមតាំងហើយសឹមទុកបាត្រ តែកុំគប្បីទុកបាត្រលើទីដែលមិនសមគួរឡើយ កាលនឹងទុកចីវរ ដៃម្ខាងត្រូវចាប់ចីវរ ដៃម្ខាងត្រូវជូតស្នៀងចីវរ ឬខ្សែសម្រាប់ហាលចីវរ ត្រូវបត់ជាយខាងណោះឲ្យជាផ្នត់មកខាងណេះ រួចសឹមទុកចីវរចុះ។ បើខ្យល់បក់ទាំងធូលីមកពីទិសខាងកើត អាចារ្យត្រូវបិទបង្អួចខាងកើត បើខ្យល់បក់ទាំងធូលីមកពីទិសខាងលិច ត្រូវបិទបង្អួចទិសខាងលិច បើខ្យល់បក់ទាំងធូលីមកពីទិសខាងជើង ត្រូវបិទបង្អួចទិសខាងជើង បើខ្យល់បក់ទាំងធូលីមកពីទិសខាងត្បូង ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ អាចារ្យត្រូវបើកបង្អួចក្នុងវេលាថ្ងៃ ត្រូវបិទបង្អួចក្នុងវេលាយប់ បើរដូវក្តៅ អាចារ្យត្រូវបិទបង្អួចក្នុងវេលាថ្ងៃ ត្រូវបើកបង្អួចក្នុងវេលាយប់។ បើបរិវេណស្មោកគ្រោកមិនស្អាត អាចារ្យត្រូវបោសទីបរិវេណចេញ បើបន្ទប់ស្មោកគ្រោកមិនស្អាត អាចារ្យត្រូវបោសបន្ទប់ចេញ បើរោងឆាន់មិនស្អាត អាចារ្យត្រូវបោសរោងឆាន់ចេញ បើរោងភ្លើងស្មោកគ្រោក អាចារ្យត្រូវបោសរោងភ្លើងចេញ បើបង្គន់ស្មោកគ្រោក អាចារ្យត្រូវបោសបង្គន់ចេញ បើគ្មានទឹកសម្រាប់ឆាន់ អាចារ្យត្រូវដំកល់ទឹកសម្រាប់ឆាន់ បើគ្មានទឹកសម្រាប់ប្រើប្រាស់ អាចារ្យត្រូវដំកល់ទឹកសម្រាប់ប្រើប្រាស់ បើទឹកក្នុងក្អមសម្រាប់លាងអាចមន៍គ្មានទេ អាចារ្យត្រូចាក់ទឹកទៅក្នុងក្អមសម្រាប់លាងអាចមន៍។ បើសេចក្តីអផ្សុកកើតឡើងដល់អន្តេវាសិក អាចារ្យត្រូវបំបាត់អផ្សុកដោយខ្លួនឯង ឬត្រូវឲ្យគេជួយធ្វើឲ្យបាត់អផ្សុកក៏បាន ឬត្រូវសម្តែងធម្មីកថាដល់អន្តេវាសិក បើសេចក្តីសង្ស័យកើតឡើងដល់អន្តេវាសិក អាចារ្យត្រូវជួយបន្ទោបង់ដោយខ្លួនឯង ឬត្រូវប្រើគេឲ្យជួយបន្ទោបង់ក៏បាន ឬត្រូវសម្តែងធម្មីកថាដល់អន្តេវាសិក បើអន្តេវាសិកមានទិដ្ឋិខុសកើតឡើង អាចារ្យត្រូវដោះស្រាយដោយខ្លួនឯង ឬត្រូវបង្គាប់គេឲ្យជួយដោះស្រាយក៏បាន ឬត្រូវសម្តែងធម្មីកថាដល់អន្តេវាសិក។ បើអន្តេវាសិកត្រូវគរុកាបត្តិ គួរនឹងចូលបរិវាស អាចារ្យត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគួរឲ្យបរិវាសដល់អន្តេវាសិក ដោយ

ឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកគួរទាញអន្តរាបត្តិ ចូលមកក្នុងមូលាបត្តិ អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីទាញអន្តរាបត្តិចូលមកក្នុងមូលាបត្តិចំពោះអន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកគួរដល់មានត្ត អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្តដល់អន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកគួរដល់អព្ភានកម្ម អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីធ្វើអព្ភានកម្ម ចំពោះអន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎។ បើសង្ឃចង់ធ្វើកម្ម គឺតជ្ជនីយកម្មក្ដី និយស្សកម្មក្ដី បព្វាជនីយកម្មក្ដី បដិសារណីយកម្មក្ដី ឧក្ខេបនីយកម្មក្ដីដល់ អន្តេវាសិក អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃមិនគប្បីធ្វើកម្ម ឬគប្បីបង្អោនទៅដើម្បីកម្មស្រាល ដល់អន្តេវាសិកដោយឧបាយដូចម្ដេចហ្ន៎ បើកម្ម គឺតជ្ជនីយកម្មក្ដី និយស្សកម្មក្ដី បព្វាជនីយកម្មក្ដី បដិសារណីយកម្មក្ដី ឧក្ខេបនីយកម្មក្ដី សង្ឃបានធ្វើដល់អន្តេវាសិកនោះរួចហើយ អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ធ្វើដូចម្ដេចហ្ន៎ ឲ្យអន្តេវាសិកគប្បីប្រព្រឹត្តដោយប្រពៃ គប្បីសម្របរោម (គឺលែងប្រកែប្រកាន់) គប្បីប្រព្រឹត្តនូវការរើខ្លួនចេញចាកអាបត្តិ សង្ឃគប្បីរម្ងាប់នូវកម្មនោះ។ បើអន្តេវាសិកត្រូវការលាងចីវរ អាចារ្យត្រូវប្រាប់ថា អ្នកគប្បីលាងយ៉ាងនេះ ពុំនោះសោត ត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ចីវររបស់អន្តេវាសិកគួរលាងដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកត្រូវការធ្វើចីវរ អាចារ្យត្រូវប្រាប់ថា អ្នកគប្បីធ្វើយ៉ាងនេះ ឬក៏ត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ចីវររបស់អន្តេវាសិកគួរធ្វើដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកត្រូវការនឹងដាំទឹកជ្រលក់ អាចារ្យត្រូវប្រាប់ថា អ្នកត្រូវដាំទឹកជ្រលក់យ៉ាងនេះ ពុំនោះសោត ត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា អន្តេវាសិកគួរដាំទឹកជ្រលក់ ដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកត្រូវការនឹងជ្រលក់ចីវរ អាចារ្យត្រូវប្រាប់ថា អ្នកគប្បីជ្រលក់ចីវរបែបនេះ ឬក៏ត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា អន្តេវាសិកគប្បីជ្រលក់ចីវរ ដោយឧបាយដូចម្ដេចហ្ន៎ កាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ប្រែឲ្យសព្វស្មើល្អ បើដំណក់ទឹកស្រក់មិនទាន់អស់ កុំអាលដើរចេញ។ បើអន្តេវាសិកមានជម្ងឺ អាចារ្យត្រូវថែទាំដរាបអស់ជីវិត ត្រូវរង់ចាំលុះតែជាជម្ងឺ។

ចប់ អន្តេវាសិកវត្តកថា។

## ២០. បណាមនា ខមាបនា

CS vin.mv.01.20 | ភាគ ទី៦

### (២០.)

[៩៥] សម័យនោះឯង ពួកអន្តេវាសិកមិនបានប្រព្រឹត្តល្អនឹងពួកអាចារ្យឡើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អន្តេវាសិក ត្រូវប្រព្រឹត្តឲ្យល្អនឹងអាចារ្យ អន្តេវាសិកណាមិនប្រព្រឹត្តឲ្យល្អ នឹងត្រូវអាបត្តិទុក្កដ។ អន្តេវាសិកទាំងនោះ ក៏នៅតែប្រព្រឹត្តមិនល្អដដែល។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យអាចារ្យបណ្ដេញចេញនូវអន្តេវាសិកណាដែលប្រព្រឹត្តមិនល្អនឹងអាចារ្យបាន។ ម្នាលភិក្ខុទាំងឡាយ អាចារ្យត្រូវបណ្ដេញអន្តេវាសិកដូចសេចក្ដីតទៅនេះ។ គឺអាចារ្យបញ្ជាក់អន្តេវាសិកដោយកាយ ឬដោយវាចា ឬបញ្ជាក់ទាំងកាយទាំងវាចាថា ខ្ញុំបណ្ដេញអ្នកឯងដូច្នេះក្ដី ថាអ្នកឯងកុំនៅក្នុងទីនេះដូច្នេះក្ដី ថាអ្នកឯងចូរនាំយកបាត្រនិងចីវររបស់អ្នកឯងចេញទៅដូច្នេះក្ដី ថាអ្នកឯងមិនត្រូវបម្រើខ្ញុំដូច្នេះក្ដី (យ៉ាងនេះ) បានឈ្មោះថា អាចារ្យបណ្ដេញអន្តេវាសិក (បើ) អាចារ្យមិនបានបញ្ជាក់អន្តេវាសិកដោយកាយ ឬដោយវាចា មិនបានបញ្ជាក់ទាំងកាយ ទាំងវាចាទេ មិនហៅថាអាចារ្យបណ្ដេញអន្តេវាសិកឡើយ។ សម័យនោះឯង ពួកអន្តេវាសិកដែលអាចារ្យបានបណ្ដេញចេញហើយ មិនបានសូមអាចារ្យឲ្យអត់ទោសវិញ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យពួកអន្តេវាសិកសូមអាចារ្យឲ្យអត់ទោសឲ្យវិញបាន។ ពួកអន្តេវាសិក ក៏នៅតែមិនសូមអាចារ្យឲ្យអត់ទោសឲ្យដដែល។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ឯអន្តេវាសិក ដែលអាចារ្យបានបណ្ដេញចេញហើយ មិនគួរជាមិនសូមអាចារ្យឲ្យអត់ទោសឲ្យវិញទេ អន្តេវាសិកណា ដែលមិនបានសូមអាចារ្យឲ្យអត់ទោសឲ្យ នឹងត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកអាចារ្យ ដែលអន្តេវាសិកបានសូមឲ្យអត់ទោសឲ្យវិញ ក៏មិនព្រមអត់ទោសឲ្យឡើយ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអាចារ្យអត់ទោសឲ្យ។ ពួកអាចារ្យទាំងនោះ ក៏នៅតែមិនព្រមអត់ទោសឲ្យដដែល។ ពួកអន្តេវាសិកក៏ចៀសចេញទៅខ្លះ សឹកចេញទៅខ្លះ រត់ចូលពួកតិរ្ថិយខ្លះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ អាចារ្យណាដែលអន្តេវាសិកសូមឲ្យអត់ទោសឲ្យ ត្រូវតែអត់ទោសឲ្យវិញ (បើ) អាចារ្យណាមិនអត់ទោសឲ្យទេ នឹងត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកអាចារ្យបណ្ដេញអន្តេវាសិកដែលមានវត្តប្រព្រឹត្តត្រឹមត្រូវចេញ មិនបានបណ្ដេញអន្តេវាសិកដែលប្រព្រឹត្តមិនត្រឹមត្រូវឡើយ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកដែលមានវត្តប្រព្រឹត្តត្រឹមត្រូវហើយ អាចារ្យមិនត្រូវបណ្ដេញចេញទេ អាចារ្យណាបណ្ដេញ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តែបើអន្តេវាសិកដែលមិនប្រព្រឹត្តត្រឹមត្រូវល្អ អាចារ្យគប្បីបណ្ដេញចេញ (បើ) មិនបណ្ដេញចេញ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកប្រកបដោយអង្គ៥ អាចារ្យត្រូវបណ្ដេញចេញ (ឯអង្គ៥នោះ) គឺអន្តេវាសិកគ្មានសេចក្ដីស្រឡាញ់ពេញចិត្តមាំនឹងអាចារ្យ១ គ្មានសេចក្ដីជ្រះថ្លាមាំ១ គ្មានសេចក្ដីអៀនខ្មាសមាំ១ គ្មានសេចក្ដីគោរពកោតក្រែងមាំ១ គ្មានភាវនាមាំ១ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកប្រកបដោយអង្គ៥នេះឯង អាចារ្យត្រូវបណ្ដេញចេញបាន។ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកប្រកបដោយអង្គ៥ អាចារ្យមិនត្រូវបណ្ដេញចេញទេ (ឯអង្គ៥នោះ) គឺអន្តេវាសិកមានសេចក្ដីស្រឡាញ់ពេញចិត្តមាំនឹងអាចារ្យ១ មានសេចក្ដីជ្រះថ្លាមាំ១ មានសេចក្ដីអៀនខ្មាសមាំ១ មានសេចក្ដីគោរពក្រោតក្រែងមាំ១ មានភាវនាមាំមួន១ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកដែលប្រកបដោយអង្គ៥នេះឯង អាចារ្យមិនត្រូវបណ្ដេញចេញទេ។ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកដែលប្រកបដោយអង្គ៥ហើយ អាចារ្យគួរបណ្ដេញចេញ (ឯអង្គ៥នោះ) គឺអន្តេវាសិកគ្មានសេចក្ដីស្រឡាញ់ពេញចិត្តមាំនឹងអាចារ្យ១ គ្មានសេចក្ដីជ្រះថ្លាមាំ១ គ្មានសេចក្ដីអៀនខ្មាសមាំ១ គ្មានសេចក្ដីគោរពក្រោតក្រែងមាំ១ គ្មានភាវនាមាំមួន១ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកដែលប្រកបដោយអង្គ៥នេះឯងហើយ អាចារ្យគួរបណ្ដេញចេញ។ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកដែលប្រកបដោយអង្គ៥ (ចំណែកខាងល្អ) ហើយ អាចារ្យមិនត្រូវបណ្ដេញចេញទេ (ឯអង្គ៥នោះ) គឺអន្តេវាសិកមានសេចក្ដីស្រឡាញ់ពេញចិត្តមាំនឹងអាចារ្យ១ មានសេចក្ដីជ្រះថ្លាមាំ១ មានសេចក្ដីអៀនខ្មាសមាំ១ មានសេចក្ដីគោរពក្រោតក្រែងមាំ១ មានភាវនាមាំមួន១ ម្នាលភិក្ខុទាំងឡាយ អន្តេវាសិកដែលប្រកបដោយអង្គ៥នេះឯងហើយ អាចារ្យមិនគួរបណ្ដេញចេញទេ។ ម្នាលភិក្ខុទាំងឡាយ អាចារ្យ មិនបានបណ្ដេញអន្តេវាសិកដែលប្រកបដោយអង្គ៥ (ចំណែកខាងអាក្រក់ហើយ) នឹងមានទោស (គឺត្រូវអាបត្តិមិនខានឡើយ) (បើ) អាចារ្យបណ្ដេញចេញហើយ ទើបគ្មាន

ទោស (គឺមិនត្រូវអាបត្តិឡើយ) (ឯអង្គ៥ចំណែកខាងអាក្រក់នោះ) គឺអន្តេវាសិកគ្មានសេចក្តីស្រឡាញ់ពេញចិត្តមាំនឹងអាចារ្យ១ គ្មានសេចក្តីជ្រះថ្លាមាំ១ គ្មានសេចក្តីអៀនខ្មាសមាំ១ គ្មានសេចក្តីគោរពកោតក្រែងមាំ១ គ្មានភាវនាមាំមួន១ ម្នាលភិក្ខុទាំងឡាយ អាចារ្យ កាលមិនបណ្តេញអន្តេវាសិកដែលប្រកបដោយអង្គ៥នេះឯងហើយ នឹងមានទោស (បើ) អាចារ្យបណ្តេញចេញ នឹងឥតទោស។ ម្នាលភិក្ខុទាំងឡាយ អាចារ្យ កាលបណ្តេញអន្តេវាសិក ដែលប្រកបដោយអង្គ៥ (ចំណែកខាងល្អ) ហើយ នឹងមានទោស (បើ) មិនបានបណ្តេញចេញទេ នឹងឥតទោស (អង្គ៥នោះ) គឺអន្តេវាសិកមានសេចក្តីស្រឡាញ់ពេញចិត្តមាំនឹងអាចារ្យ១ មានសេចក្តីជ្រះថ្លាដ៏មាំ១ មានសេចក្តីអៀនខ្មាសមាំ១ មានសេចក្តីគោរពកោតក្រែងមាំ១ មានភាវនាដ៏មាំមួន១ ម្នាលភិក្ខុទាំងឡាយ អាចារ្យ កាលបណ្តេញនូវអន្តេវាសិកដែលប្រកបដោយអង្គ៥នេះឯងហើយ នឹងមានទោសមិនខានឡើយ បើមិនបានបណ្តេញចេញទេ ក៏ឥតមានទោសឡើយ។

## ២១. ពាលអព្យត្តវត្ថុ

CS vin.mv.01.21 | ភាគ ទី៦

**(២១.)**

[៩៦] សម័យនោះឯង ភិក្ខុទាំងឡាយជាបុគ្គលពាល មិនឆ្លាសឲ្យនិស្ស័យ (ដល់អន្តេវាសិក) ដោយអាងថា យើងមានវស្សា១០ហើយ យើងមានវស្សា១០ហើយ។ ពួកអាចារ្យជាមនុស្សពាល ពួកអន្តេវាសិកជាបណ្ឌិតក៏ប្រាកដ ពួកអាចារ្យជាមនុស្សមិនឆ្លាស ពួកអន្តេវាសិកជាមនុស្សឆ្លាសក៏ប្រាកដ ពួកអាចារ្យជាមនុស្សចេះដឹងតិច ពួកអន្តេវាសិកជាមនុស្សចេះដឹងច្រើនក៏ប្រាកដ ពួកអាចារ្យជាមនុស្សអាប់ឥតបញ្ញា ពួកអន្តេវាសិកជាមនុស្សមានបញ្ញាក៏ប្រាកដ។ ភិក្ខុទាំងឡាយណាមានសេចក្តី ប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយជាមនុស្សពាល មិនឆ្លាស មិនសមបើនឹងហ៊ានឲ្យនិស្ស័យ (ដល់អន្តេវាសិក) ដោយអាងថា យើងមានវស្សា១០ហើយ យើងមានវស្សា១០ហើយ ពួកអាចារ្យជាមនុស្សពាល ពួកអន្តេវាសិកជាបណ្ឌិតក៏ប្រាកដ ពួកអាចារ្យមិនឆ្លាស ពួកអន្តេវាសិកឆ្លាសក៏ប្រាកដ ពួកអាចារ្យចេះដឹងតិច ពួកអន្តេវាសិកចេះដឹងច្រើនក៏ប្រាកដ ពួកអាចារ្យអាប់ឥតបញ្ញា ពួកអន្តេវាសិកមានបញ្ញាក៏ប្រាកដ។ វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុជាមនុស្សពាល មិនឆ្លាស ឲ្យនិស្ស័យ (ដល់អន្តេវាសិក) ដោយអាងថា យើងមានវស្សា១០ហើយ យើងមានវស្សា១០ហើយ ពួកអាចារ្យជាមនុស្សពាល... ពួកអន្តេវាសិកមានបញ្ញាក៏ប្រាកដ ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ...ក៏ទ្រង់បន្ទោស លុះទ្រង់បន្ទោសរួចហើយ ទើបធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាមនុស្សពាល មិនឆ្លាស មិនត្រូវឲ្យនិស្ស័យទេ ភិក្ខុណាឲ្យ នឹងត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆ្លាសប្រតិពល មានវស្សា១០ ឬមានវស្សាច្រើនជាង១០ ឡើងទៅ ឲ្យនិស្ស័យបាន។

## ២២. និស្សយបដិប្បស្សទ្ធិកថា

CS vin.mv.01.22 | ភាគ ទី៦

**(២២.)**

[៩៧] សម័យនោះឯង កាលបើអាចារ្យ និងឧបជ្ឈាយ៍ទាំងឡាយចៀសចេញទៅក្តី សឹកចេញទៅក្តី ធ្វើមរណកាលទៅក្តី វត់ចូលទៅកាន់ពួកតិរ្ថិយក្តី ពួកភិក្ខុក៏មិនដឹងសេចក្តីរម្ងាប់ចាកនិស្ស័យ គឺដាច់និស្ស័យបានឡើយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការរម្ងាប់និស្ស័យ គឺដាច់និស្ស័យ ព្រោះឧបជ្ឈាយ៍នេះ មាន៥យ៉ាង គឺទី១ ឧបជ្ឈាយ៍ចៀសចេញទៅក្តី ទី២ឧបជ្ឈាយ៍សឹកចេញទៅក្តី ទី៣ឧបជ្ឈាយ៍ធ្វើមរណកាលទៅក្តី ទី៤ឧបជ្ឈាយ៍ទៅកាន់តិរ្ថិយក្តី ទី៥ឧបជ្ឈាយ៍បណ្តេញចេញក្តី ម្នាលភិក្ខុទាំងឡាយ ការដែលរម្ងាប់និស្ស័យ គឺដាច់និស្ស័យ ព្រោះឧបជ្ឈាយ៍មាន៥យ៉ាងនេះឯង។ ម្នាលភិក្ខុទាំងឡាយ ការរម្ងាប់និស្ស័យ គឺដាច់និស្ស័យ ព្រោះអាចារ្យនេះ មាន៦យ៉ាង គឺទី១ អាចារ្យចៀសចេញទៅក្តី ទី២សឹកចេញទៅក្តី ទី៣ធ្វើមរណកាលទៅក្តី ទី៤ទៅកាន់ពួកតិរ្ថិយក្តី ទី៥បណ្តេញចេញក្តី ទី៦ អាចារ្យបានទៅនៅរួបរួមជាមួយនឹងឧបជ្ឈាយ៍ក្តី ម្នាលភិក្ខុទាំងឡាយ ការដែលរម្ងាប់និស្ស័យ គឺដាច់និស្ស័យ ព្រោះអាចារ្យមាន៦យ៉ាងនេះឯង។

## ២៣. ឧបសម្បាទេតព្វបញ្ចកំ

CS vin.mv.01.23 | ភាគ ទី៦

**(ឧបសម្បាទេតព្វបញ្ចកសោឡសវារៈ (២៣.))**

[៩៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនឡើយ គឺភិក្ខុដែលមិនប្រកបដោយសីលក្ខន្ធជាអសេក្ខៈ គឺជារបស់អសេក្ខបុគ្គល១ មិនប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ១ មិនប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯងមិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួន គឺភិក្ខុប្រកបដោយសីលក្ខន្ធជាអសេក្ខៈ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ១ ប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥នេះឯងគួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនឡើយ គឺភិក្ខុមិនប្រកបដោយសីលក្ខន្ធជាអសេក្ខៈដោយខ្លួនឯង មិនបានដឹកនាំកុលបុត្រដទៃឲ្យកាន់យកនូវសីលក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈដោយខ្លួនឯង មិនបានដឹកនាំកុលបុត្រដទៃឲ្យកាន់យកនូវសមាធិក្ខន្ធ

ជាអសេក្ខៈ១ មិនប្រកបដោយបញ្ញាខន្ធជាអសេក្ខៈដោយខ្លួនឯង មិនបានដឹកនាំកុលបុត្រដទៃឲ្យកាន់យកនូវបញ្ញាខន្ធជាអសេក្ខៈ១ មិនប្រកប
ដោយវិមុត្តិក្ខន្ធជាអសេក្ខៈដោយខ្លួនឯង មិនបានដឹកនាំកុលបុត្រដទៃឲ្យកាន់យកនូវវិមុត្តិក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយវិមុត្តិញ្ញាណ
ទស្សនក្ខន្ធជាអសេក្ខៈដោយខ្លួនឯង មិនបានដឹកនាំកុលបុត្រដទៃឲ្យកាន់យកនូវវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ
ប្រកបដោយអង្គ៥នេះ មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ គួរ
ឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុប្រកបដោយសីលក្ខន្ធជាអសេក្ខៈដោយខ្លួនឯង ដឹកនាំកុលបុត្រដទៃឲ្យ
កាន់យកនូវសីលក្ខន្ធជាអសេក្ខៈ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈដោយខ្លួនឯង ដឹកនាំកុលបុត្រដទៃឲ្យកាន់យកនូវសមាធិក្ខន្ធជាអសេក្ខៈ១
ប្រកបដោយបញ្ញាខន្ធជាអសេក្ខៈដោយខ្លួនឯង ដឹកនាំកុលបុត្រដទៃឲ្យកាន់យកនូវបញ្ញាខន្ធជាអសេក្ខៈ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈដោយ
ខ្លួនឯង ដឹកនាំកុលបុត្រដទៃឲ្យកាន់យកនូវវិមុត្តិក្ខន្ធជាអសេក្ខៈ១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈដោយខ្លួនឯង ដឹកនាំកុលបុត្រ
ដទៃឲ្យកាន់យកនូវវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ
គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យ
សាមណេរបម្រើខ្លួនទេ គឺភិក្ខុគ្មានសទ្ធា១ មិនខ្មាសបាប១ មិនខ្លាចបាប១ ខ្ជិល១ ភ្លេចស្មារតី១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥
នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ គួរឲ្យ
ឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុមានសទ្ធា១ ខ្មាសបាប១ ខ្លាចបាប១ ប្រារព្ធព្យាយាមជាប់១ មានសតិខ្ជាប់ខ្ជួន១
ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ
ប្រកបដោយអង្គ៥ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ គឺភិក្ខុវិបត្តិចាកសីល គឺត្រូវអាបត្តិបារាជិក
និងសង្ឃាទិសេសក្នុងអធិសីល (បាដិមោក្ខសំវរសីល)១ វិបត្តិចាកមារយាទ គឺត្រូវអាបត្តិ៥កង មានថុល្លច្ច័យជាដើម ក្នុងអជ្ឈាចារ១ វិបត្តិចាកទិដ្ឋិ
ក្នុងសម្មាទិដ្ឋិ គឺភិក្ខុលះបង់សម្មាទិដ្ឋិ ទៅប្រកបដោយអន្តគាហិកទិដ្ឋិវិញ១ ចេះដឹងតិច១ អាប់ឥតប្រាជ្ញា១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយ
អង្គទាំង៥នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ គួរឲ្យ
ឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើបាន គឺភិក្ខុមិនវិបត្តិចាកសីល ក្នុងអធិសីល១ មិនបានវិបត្តិចាកមារយាទ ក្នុងអជ្ឈាចារ១ មិន
បានវិបត្តិចាកទិដ្ឋិ ក្នុងសម្មាទិដ្ឋិ គឺភិក្ខុមិនលះបង់សម្មាទិដ្ឋិ ទៅប្រកបដោយអន្តគាហិកទិដ្ឋិ១ ចេះដឹងច្រើន១ មានប្រាជ្ញា១ ម្នាលភិក្ខុទាំងឡាយ
ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយ
អង្គ៥ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ គឺភិក្ខុមិនអាចដើម្បីបម្រើនូវអន្តេវាសិក ឬនូវសទ្ធិវិហារិក
ដែលមានជម្ងឺដោយខ្លួនឯង ឬឲ្យគេបម្រើ១ មិនអាចដើម្បីបំបាត់នូវសេចក្តីអផ្សុករបស់អន្តេវាសិក ឬរបស់សទ្ធិវិហារិកដោយខ្លួនឯង ឬឲ្យគេ
បំបាត់ឲ្យ១ មិនអាចដើម្បីបន្ទោបង់នូវសេចក្តីសង្ស័យដែលកើតឡើងដល់អន្តេវាសិក ឬសទ្ធិវិហារិកដោយខ្លួនឯង ឬឲ្យអ្នកដទៃបំបាត់ឲ្យ (ដោយ
និយាយ)ធម៌១ មិនស្គាល់អាបត្តិ១ មិនស្គាល់វិធីចេញចាកអាបត្តិ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង មិនគួរឲ្យឧបសម្បទា
មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរ
បម្រើខ្លួនបាន គឺភិក្ខុអាចដើម្បីបម្រើដោយខ្លួនឯងក្តី ឲ្យគេបម្រើក្តីនូវអន្តេវាសិក ឬនូវសទ្ធិវិហារិកដែលមានជម្ងឺ១ អាចដើម្បីបំបាត់ដោយខ្លួនឯងក្តី
ឲ្យគេបំបាត់ក្តី នូវសេចក្តីអផ្សុករបស់អន្តេវាសិក ឬរបស់សទ្ធិវិហារិក១ អាចដើម្បីបន្ទោបង់ដោយខ្លួនឯងក្តី ឲ្យគេបន្ទោបង់ក្តី នូវសេចក្តីសង្ស័យ
ដែលកើតឡើងដល់អន្តេវាសិក ឬសទ្ធិវិហារិក (ដោយនិយាយ)ធម៌១ ស្គាល់អាបត្តិ១ ស្គាល់វិធីចេញចាកអាបត្តិ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកប
ដោយអង្គទាំង៥នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត
មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ គឺភិក្ខុមិនអាចដើម្បីញុំាងអន្តេវាសិក ឬនូវសទ្ធិវិហារិកឲ្យសិក្សាក្នុង
អភិសមាចារិកសិក្ខា (ខន្ធកវត្ត)១ មិនអាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកដោយអាទិព្រហ្មចរិយសិក្ខា (សេក្ខប្បញ្ញត្តិ)១ មិនអាច
ដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងធម៌ដ៏ក្រៃលែង (ការកំណត់នូវនាមនិងរូប)១ មិនអាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុង
វិន័យដ៏ក្រៃលែង (វិន័យបិដកទាំងមូល)១ មិនអាចដើម្បីដោះស្រាយនូវទិដ្ឋិខុស ដែលកើតឡើងដល់អន្តេវាសិក ឬសទ្ធិវិហារិកដោយធម៌១ ម្នាល
ភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះ មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាលភិក្ខុទាំងឡាយ
ភិក្ខុប្រកបដោយអង្គ៥នេះ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើបាន គឺភិក្ខុអាចដើម្បីបង្រៀនអន្តេវាសិក ឬសទ្ធិវិហារិក ក្នុង
អភិសមាចារិកាសិក្ខា១ អាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអាទិព្រហ្មចរិយកាសិក្ខា១ អាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិក
ក្នុងអភិធម្ម១ អាចដើម្បីទូន្មានអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអភិវិន័យ១ អាចដើម្បីដោះស្រាយនូវទិដ្ឋិខុស ដែលកើតឡើងដល់អន្តេវាសិក ឬសទ្ធិ
វិហារិកដោយធម៌១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។
ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ គឺភិក្ខុមិនស្គាល់
អាបត្តិ១ មិនស្គាល់អនាបត្តិ១ មិនស្គាល់លហុកាបត្តិ១ មិនស្គាល់គរុកាបត្តិ១ មិនបានចេះចាំនូវបាតិមោក្ខទាំងពីរ គឺភិក្ខុបាតិមោក្ខ នឹងភិក្ខុនីបាតិ
មោក្ខ (ដោយពិស្តារ) មិនបានចែកដោយល្អ មិនបានប្រព្រឹត្តទៅដោយល្អ (ចាំស្ទាត់រត់មាត់) មិនបានវិនិច្ឆ័យដោយល្អតាមសុត្ត (ខន្ធកៈ និង
បរិវារៈ) តាមអនុព្យញ្ជនៈ (បរិបូណ៌ដោយបទ និងអក្ខរ)១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យ
និស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥នេះ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើ
ខ្លួនបាន គឺភិក្ខុស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ចេះចាំនូវបាតិមោក្ខទាំងពីរ ដោយពិស្តារ ហើយចែកដោយ
ល្អ ប្រព្រឹត្តទៅដោយល្អ វិនិច្ឆ័យដោយល្អតាមសុត្ត តាមអនុព្យញ្ជនៈ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង គួរឲ្យឧបសម្បទា
គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិន
គួរឲ្យសាមណេរបម្រើទេ គឺភិក្ខុមិនស្គាល់អាបត្តិ១ មិនស្គាល់អនាបត្តិ១ មិនស្គាល់លហុកាបត្តិ១ មិនស្គាល់គរុកាបត្តិ១ មានវស្សាមិនទាន់គ្រប់
ដប់១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាល
ភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១
ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ មានវស្សាដប់ ឬច្រើនជាងដប់ឡើងទៅ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥នេះឯង គួរឲ្យ
ឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើបាន។

ចប់ ឧបសម្បាទេតព្វបញ្ចកសោឡសវារៈ។

## ២៤. ឧបសម្បាទេតព្វឆក្កំ

CS vin.mv.01.24 | ភាគ ទី៦

### (ឧបសម្បាទេតព្វឆក្កសោឡសវារៈ (២៤.))

[៩៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួន គឺភិក្ខុមិនប្រកបដោយសីលក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ១ មិនប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ១ មានវស្សាមិនទាន់គ្រប់ដប់១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦នេះ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើបាន គឺភិក្ខុប្រកបដោយសីលក្ខន្ធជាអសេក្ខៈ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ១ ប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ១ មានវស្សាដប់ ឬមានវស្សាច្រើនជាងដប់ឡើងទៅ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ គឺភិក្ខុមិនប្រកបដោយសីលក្ខន្ធជាអសេក្ខៈដោយខ្លួនឯង មិនបានដឹកនាំអ្នកដទៃឲ្យកាន់យកនូវសីលក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ដោយខ្លួនឯង មិនបានដឹកនាំអ្នកដទៃឲ្យកាន់យកនូវសមាធិក្ខន្ធជាអសេក្ខៈ១ មិនប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ ដោយខ្លួនឯង មិនបានដឹកនាំអ្នកដទៃឲ្យកាន់យកនូវបញ្ញាខន្ធជាអសេក្ខៈ១ មិនប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ដោយខ្លួនឯង មិនបានដឹកនាំអ្នកដទៃឲ្យកាន់យកនូវវិមុត្តិក្ខន្ធជាអសេក្ខៈ១ មិនបានប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ ដោយខ្លួនឯង មិនបានដឹកនាំអ្នកដទៃឲ្យកាន់យកនូវវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ១ មានវស្សាមិនទាន់គ្រប់ដប់១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុប្រកបដោយសីលក្ខន្ធជាអសេក្ខៈដោយខ្លួនឯង បានដឹកនាំអ្នកដទៃឲ្យកាន់យកនូវសីលក្ខន្ធជាអសេក្ខៈ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ដោយខ្លួនឯង បានដឹកនាំអ្នកដទៃឲ្យកាន់យកនូវសមាធិក្ខន្ធជាអសេក្ខៈ១ ប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ ដោយខ្លួនឯង បានដឹកនាំអ្នកដទៃឲ្យកាន់យកនូវបញ្ញាខន្ធជាអសេក្ខៈ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ដោយខ្លួនឯង បានដឹកនាំអ្នកដទៃឲ្យកាន់យកនូវវិមុត្តិក្ខន្ធជាអសេក្ខៈ១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ ដោយខ្លួនឯង បានដឹកនាំអ្នកដទៃឲ្យកាន់យកនូវវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ១ មានវស្សាដប់ ឬមានវស្សាច្រើនជាងដប់ឡើងទៅ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ គឺភិក្ខុគ្មានសទ្ធា១ មិនខ្មាសបាប១ មិនខ្លាចបាប១ ខ្ជិល១ ភ្លេចស្មារតី១ មានវស្សាមិនទាន់គ្រប់ដប់១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុមានសទ្ធា១ មានសេចក្តីខ្មាសបាប១ មានសេចក្តីខ្លាចបាប១ ប្រារព្ធព្យាយាមជាប់១ មានសតិខ្ជាប់ខ្ជួន១ មានវស្សាដប់ ឬមានវស្សាច្រើនជាងដប់ឡើងទៅ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ គឺភិក្ខុវិបត្តិចាកសីល ក្នុងអធិសីល១ វិបត្តិចាកមារយាទ ក្នុងអជ្ឈាចារ១ វិបត្តិចាកទិដ្ឋិ ក្នុងសម្មាទិដ្ឋិ គឺភិក្ខុលះបង់សម្មាទិដ្ឋិ ហើយទៅប្រកបដោយអន្តគាហិកទិដ្ឋិវិញ១ ចេះដឹងតិច១ អាប់ឥតប្រាជ្ញា១ មានវស្សាមិនទាន់គ្រប់ដប់១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើបាន គឺភិក្ខុមិនបានវិបត្តិចាកសីល ក្នុងអធិសីល១ មិនបានវិបត្តិចាកមារយាទ ក្នុងអជ្ឈាចារ១ មិនបានវិបត្តិចាកទិដ្ឋិ ក្នុងសម្មាទិដ្ឋិ១ ចេះដឹងច្រើន១ មានប្រាជ្ញា១ មានវស្សាដប់ ឬមានវស្សាច្រើនជាងដប់ឡើងទៅ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ គឺភិក្ខុមិនអាចដើម្បីបម្រើដោយខ្លួនឯងក្តី ឲ្យគេបម្រើក្តី នូវអន្តេវាសិក ឬនូវសទ្ធិវិហារិកដែលមានជម្ងឺ១ មិនអាចដើម្បីបំបាត់ដោយខ្លួនឯងក្តី ឲ្យគេបំបាត់ក្តី នូវសេចក្តីអផ្សុករបស់អន្តេវាសិក ឬសទ្ធិវិហារិក១ មិនអាចដើម្បីបន្ទោបង់ដោយខ្លួនឯងក្តី ឲ្យគេបន្ទោបង់ក្តី នូវសេចក្តីសង្ស័យដែលកើតឡើងចំពោះអន្តេវាសិក ឬសទ្ធិវិហារិកដោយធម៌១ មិនស្គាល់អាបត្តិ១ មិនស្គាល់វិធីដែលចេញចាកអាបត្តិ១ មានវស្សាមិនទាន់គ្រប់ដប់១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើខ្លួនទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុអាចដើម្បីបម្រើដោយខ្លួនឯងក្តី ឲ្យគេបម្រើក្តីនូវអន្តេវាសិក ឬសទ្ធិវិហារិកដែលមានជម្ងឺ១ អាចដើម្បីបំបាត់ដោយខ្លួនឯងក្តី ឲ្យគេបំបាត់ក្តី នូវសេចក្តីអផ្សុករបស់អន្តេវាសិក ឬរបស់សទ្ធិវិហារិក១ អាចបន្ទោបង់ដោយខ្លួនឯងក្តី ឲ្យគេបន្ទោបង់ក្តី នូវសេចក្តីសង្ស័យដែលកើតឡើងចំពោះអន្តេវាសិក ឬសទ្ធិវិហារិក ដោយធម៌១ ស្គាល់អាបត្តិ១ ស្គាល់វិធីដែលចេញចាកអាបត្តិ១ មានវស្សាដប់ ឬច្រើនជាងដប់ឡើងទៅ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៥៦នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ គឺភិក្ខុមិនអាចដើម្បីញុំាងអន្តេវាសិក ឬសទ្ធីវិហារិកឲ្យសិក្សាក្នុងអភិសមាចារិកាសិក្ខា (ខន្ធកវត្ត)១ មិនអាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអាទិព្រហ្មចរិយកាសិក្ខា (សេក្ខប្បញ្ញត្តិ)១ មិនអាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអភិធម្ម១ មិនអាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអភិវិន័យ១ មិនអាចដើម្បីដោះស្រាយនូវទិដ្ឋិខុស ដែលកើតឡើងចំពោះអន្តេវាសិក ឬសទ្ធិវិហារិកដោយធម៌១ មានវស្សាមិនទាន់គ្រប់ដប់១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុអាចដើម្បីញុំាងអន្តេវាសិក ឬសទ្ធិវិហារិក ក្នុងអភិសមាចារិកាសិក្ខា១ អាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអាទិព្រហ្មចរិយកាសិក្ខា១ អាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិក

ក្នុងអភិធម្ម១ អាចដើម្បីទូន្មាននូវអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអភិវិន័យ១ អាចដើម្បីដោះស្រាយនូវទិដ្ឋិខុស ដែលកើតឡើងចំពោះអន្តេវាសិក ឬសទ្ធិវិហារិកដោយធម៌១ មានវស្សាដប់ ឬមានវស្សាច្រើនជាងដប់ឡើងទៅ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ដទៃទៀត មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ គឺភិក្ខុមិនស្គាល់អាបត្តិ១ មិនស្គាល់អនាបត្តិ១ មិនស្គាល់លហុកាបត្តិ១ មិនស្គាល់គរុកាបត្តិ១ មិនបានចេះចាំស្ទាត់នូវបាតិមោក្ខទាំងពីរដោយពិស្តារ មិនបានចែកដោយល្អ មិនបានប្រព្រឹត្តទៅដោយល្អ មិនបានវិនិច្ឆ័យដោយត្រឹមត្រូវតាមសុត្ត តាមអនុព្យញ្ជនៈ១ មានវស្សាមិនទាន់គ្រប់ដប់១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦នេះឯង មិនគួរឲ្យឧបសម្បទា មិនគួរឲ្យនិស្ស័យ មិនគួរឲ្យសាមណេរបម្រើទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើបាន គឺភិក្ខុស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ចេះចាំស្ទាត់នូវបាតិមោក្ខទាំងពីរដោយពិស្តារ ចែកចេញដោយល្អ ប្រព្រឹត្តទៅដោយល្អ វិនិច្ឆ័យដោយត្រឹមត្រូវតាមសុត្ត តាមអនុព្យញ្ជនៈ១ មានវស្សាដប់ ឬច្រើនជាងដប់ឡើងទៅ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៦នេះ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន។

ចប់ ឧបសម្បាទេតព្វឆក្កសោឡសវារៈ។

## ២៥. អញ្ញតិត្ថិយបុព្វកថា

CS vin.mv.01.25 | ភាគ ទី៦

**(២៥.)**

[១០០] សម័យនោះឯង ភិក្ខុណាដែលធ្លាប់ជាតិរ្ថិយដទៃ កាលបើឧបជ្ឈាយ៍និយាយប្រដៅប្រកបដោយធម៌ហើយ ក៏ពោលតិះដៀលឧបជ្ឈាយ៍ហើយរត់ចូលទៅកាន់លទ្ធិតិរ្ថិយនោះដូចដែលវិញ។ បុគ្គលនោះវិលត្រឡប់មកសូមឧបសម្បទានឹងភិក្ខុទាំងឡាយម្តងទៀត។ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាដែលធ្លាប់ជាតិរ្ថិយដទៃហើយកាលបើឧបជ្ឈាយ៍និយាយប្រដៅប្រកបដោយធម៌ហើយ ក៏ពោលតិះដៀលឧបជ្ឈាយ៍ ហើយរត់ចៀសទៅកាន់លទ្ធិតិរ្ថិយនោះដូចដែលវិញ លុះបុគ្គលនោះត្រឡប់មកវិញ សង្ឃមិនត្រូវឲ្យឧបសម្បទាឡើយ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលណាឯទៀត ធ្លាប់ជាតិរ្ថិយដទៃ ហើយប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម៌វិន័យនេះ សង្ឃត្រូវឲ្យបរិវាសដល់បុគ្គលនោះកំណត់ត្រឹម៤ខែ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសបែបយ៉ាងនេះ។ គឺភិក្ខុត្រូវឲ្យបុគ្គលនោះកោរសក់ និងពុកមាត់ជាមុន រួចហើយឲ្យស្លៀកដណ្តប់សំពត់កាសាយៈ ហើយឲ្យគ្រងចីពរឆៀងស្មាម្ខាង រួចហើយ ឲ្យថ្វាយបង្គំបាទាភិក្ខុទាំងឡាយ រួចឲ្យអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយត្រូវប្រាប់ថា អ្នកឯងចូរពោលយ៉ាងនេះ គឺត្រូវពោលថា ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីរលឹក ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីរលឹក ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីរលឹក ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់បីដងផង ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីរលឹក ជាគំរប់បីដងផង ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់បីដងផង។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃនោះ ត្រូវចូលទៅកាន់ជំនុំសង្ឃ ហើយពាក់ចីពរឆៀងស្មាម្ខាង រួចថ្វាយបង្គំបាទាភិក្ខុទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយគប្បីពោលយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាឈ្មោះនេះ ធ្លាប់ជាតិរ្ថិយដទៃ ប្រាថ្នានូវឧបសម្បទាក្នុងធម៌វិន័យនេះ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះសូមបរិវាសនឹងសង្ឃអស់៤ខែ។ បុគ្គលនោះ គប្បីសូមជាគំរប់ពីរដង គប្បីសូមជាគំរប់បីដង។ ភិក្ខុដែលឆ្លាសប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត) បុគ្គលនេះ ឈ្មោះនេះ ធ្លាប់ជាតិរ្ថិយដទៃ ប្រាថ្នានូវឧបសម្បទាក្នុងធម៌វិន័យនេះ ឥឡូវបុគ្គលនោះសូមបរិវាសនឹងសង្ឃអស់៤ខែ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគួរឲ្យបរិវាសដល់កុលបុត្រឈ្មោះនេះ ដែលធ្លាប់ជាតិរ្ថិយដទៃអស់៤ខែចុះ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បុគ្គលនេះ ឈ្មោះនេះ ធ្លាប់ជាតិរ្ថិយដទៃ ប្រាថ្នានូវឧបសម្បទាក្នុងធម៌វិន័យនេះ។ បុគ្គលនោះសូមបរិវាសនឹងសង្ឃកំណត់៤ខែ។ ឥឡូវសង្ឃឲ្យបរិវាសដល់បុគ្គលនេះ ដែលធ្លាប់ជាតិរ្ថិយដទៃកំណត់៤ខែ។ ការឲ្យបរិវាសដល់បុគ្គលឈ្មោះនេះ ដែលធ្លាប់ជាតិរ្ថិយដទៃកំណត់៤ខែ គួរដល់លោកម្ចាស់ដ៏មានអាយុអង្គណា លោកម្ចាស់ដ៏មានអាយុអង្គនោះ គប្បីស្ងៀមនៅចុះ មិនគួរដល់លោកម្ចាស់ដ៏មានអាយុអង្គណាទេ លោកម្ចាស់ដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃបានឲ្យបរិវាសដល់បុគ្គលឈ្មោះនេះ ដែលធ្លាប់ជាតិរ្ថិយដទៃកំណត់៤ខែហើយ។ ការឲ្យតិត្ថិយបរិវាសនេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃឈ្មោះថា ញុំាងសង្ឃឲ្យត្រេកអរយ៉ាងនេះឯង។ (បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃខ្លះ) មិនបានញុំាងសង្ឃឲ្យត្រេកអរយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ មិនបានញុំាងសង្ឃឲ្យត្រេកអរ តើដូចម្តេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានបុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ចូលទៅកាន់ស្រុកហួសកាល ហួសវេលា ត្រឡប់មកវិញក្នុងវេលាថ្ងៃពេក (ហួសថ្ងៃ)។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃឈ្មោះថាមិនបានញុំាងសង្ឃឲ្យត្រេកអរយ៉ាងនេះក៏មាន។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ គោចរទៅកាន់សំណាក់ស្រីផ្កាមាសក្តី គោចរទៅកាន់សំណាក់ស្រីមេម៉ាយក្តី គោចរទៅកាន់សំណាក់កុមារីធាត់ (ក្រមុំចាស់)ក្តី គោចរទៅកាន់សំណាក់មនុស្សខ្ទើយក្តី គោចរទៅកាន់សំណាក់ភិក្ខុនីក្តី។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា មិនបានញុំាងសង្ឃឲ្យត្រេកអរបែបនេះក៏មាន។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត អស់ទាំងការងារធំតូចទាំងឡាយណារបស់សព្រហ្មចារីបុគ្គលទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ក៏មិនបានវាងវៃក្នុងការងារនោះឡើយ ជាបុគ្គលខ្ជិល មិនប្រកបដោយបញ្ញាពិចារណាជាឧបាយក្នុងការងារធំតូចនោះ មិនអាចដើម្បីធ្វើបាន មិនអាចដើម្បីចាត់ចែងបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា មិនបានញុំាងសង្ឃឲ្យត្រេកអរបែបនេះក៏មាន។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឥតមានសេចក្តីប្រាថ្នាដ៏ក្លៀវក្លាក្នុងបាឡី អដ្ឋកថា អធិសីល (បាតិមោក្ខសំវរសីល) អធិចិត្ត (លោកិយសមាធិភាវនា) និងអធិប្បញ្ញា (លោកុត្តរមគ្គភាវនា) ឡើយ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា មិនបានញុំាងសង្ឃឲ្យត្រេកអរបែបនេះក៏មាន។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃបានចេញចាកលទ្ធិតិរ្ថិយរបស់សាស្តាណាហើយ ដល់វេលាមានគេពោលតិះដៀលចំពោះសាស្តានោះ តាមទិដ្ឋិរបស់សាស្តានោះ តាមសេចក្តីគាប់

ចិត្តរបស់សាស្តានោះ តាមសេចក្តីពេញចិត្តរបស់សាស្តានោះ តាមសេចក្តីប្រកាន់របស់សាស្តានោះ ក៏ស្រាប់តែខឹង តូចចិត្ត ឥតមានត្រេកអរឡើយ កាលបើមានគេពោលតិះដៀល ព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃវិញ ក៏សប្បាយចិត្ត មានកាយនិងចិត្តអណ្តែតឡើង ហើយត្រេកអរពេកណាស់ ម្យ៉ាងទៀត បើចេញចាកពីលទ្ធិតិរ្ថិយរបស់សាស្តាណាហើយ កាលបើមានគេពោលសរសើរចំពោះសាស្តានោះ តាមទិដ្ឋិរបស់សាស្តានោះ តាមសេចក្តីគាប់ចិត្តរបស់សាស្តានោះ តាមសេចក្តីពេញចិត្តរបស់សាស្តានោះ តាមសេចក្តីប្រកាន់របស់សាស្តានោះ ក៏សប្បាយចិត្ត មានកាយនិងចិត្តអណ្តែតឡើង ហើយមានសេចក្តីត្រេកអរពេកណាស់ កាលបើមានគេពោលសរសើរព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃវិញហើយ ក៏ខឹងតូចចិត្ត ឥតត្រេកអរឡើយ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះហើយ ជាហេតុដ៏ឆ្នើម (ជាកំពូល) ក្នុងកិរិយាដែល មិនបានញុំាងសង្ឃឲ្យត្រេកអរ របស់បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា មិនបានញុំាងសង្ឃឲ្យត្រេកអរយ៉ាងនេះឯង។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ មិនបានញុំាងសង្ឃឲ្យត្រេកអរយ៉ាងនេះ បើត្រឡប់មកវិញ សង្ឃមិនត្រូវឲ្យឧបសម្បទាឡើយ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា ញុំាងសង្ឃឲ្យត្រេកអរបាន នោះតើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានបុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ចូលទៅកាន់ស្រុកមិនឲ្យហួសពេល ត្រឡប់ចេញមកវិញ ក៏មិនឲ្យហួសថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថាបានញុំាងសង្ឃឲ្យត្រេកអរបែបនេះក៏មាន។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ មិនបានគោចរទៅកាន់សំណាក់ស្រីផ្កាមាស មិនបានគោចរទៅកាន់សំណាក់ស្រីមេម៉ាយ មិនបានគោចរទៅកាន់សំណាក់កុមារីដ៏ធាត់ (ក្រមុំចាស់) មិនបានគោចរទៅកាន់សំណាក់មនុស្សខ្ទើយ មិនបានគោចរទៅកាន់សំណាក់ភិក្ខុនី។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថាបានញុំាងសង្ឃឲ្យត្រេកអរបែបនេះក៏មាន។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ការងារធំតូចរបស់សព្រហ្មចារីបុគ្គលទាំងឡាយឯណា បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ក៏វាងវៃក្នុងការងារនោះ ជាបុគ្គលមិនខ្ជិល ប្រកបដោយបញ្ញាពិចារណាជាឧបាយក្នុងការងារនោះ អាចដើម្បីធ្វើបាន អាចដើម្បីចាត់ចែងបាន។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា បានញុំាងសង្ឃឲ្យត្រេកអរបែបនេះក៏មាន។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ មានសេចក្តីប្រាថ្នាដ៏ក្លៀវក្លាក្នុងបាឡី អដ្ឋកថា អធិសីល អធិចិត្ត និងអធិប្បញ្ញា។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា បានញុំាងសង្ឃឲ្យត្រេកអរបែបនេះក៏មាន។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ បានចេញចាកលទ្ធិតិរ្ថិយរបស់សាស្តាណាហើយ កាលបើមានគេពោលតិះដៀលចំពោះសាស្តានោះ តាមទិដ្ឋិរបស់សាស្តានោះ តាមសេចក្តីគាប់ចិត្តរបស់សាស្តានោះ តាមសេចក្តីពេញចិត្តរបស់សាស្តានោះ តាមសេចក្តីប្រកាន់របស់សាស្តានោះ ក៏សប្បាយចិត្ត មានកាយនិងចិត្តអណ្តែតឡើងហើយ ត្រេកអរពេកណាស់ កាលបើមានគេពោលតិះដៀល ព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃហើយ ក៏ត្រឡប់ជាខឹងតូចចិត្ត ឥតត្រេកអរឡើយ ម្យ៉ាងទៀត ប្រសិនបើបុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ បានចេញចាកពីលទ្ធិតិរ្ថិយរបស់សាស្តាណាហើយ កាលបើមានគេពោលសរសើរចំពោះសាស្តានោះ តាមទិដ្ឋិរបស់សាស្តានោះ តាមសេចក្តីគាប់ចិត្តរបស់សាស្តានោះ តាមសេចក្តីពេញចិត្តរបស់សាស្តានោះ តាមសេចក្តីប្រកាន់របស់សាស្តានោះហើយ ក៏ខឹង តូចចិត្ត ឥតមានសេចក្តីត្រេកអរឡើយ កាលបើមានគេពោលសរសើរព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃវិញ ក៏សប្បាយចិត្ត មានកាយនិងចិត្តអណ្តែតឡើង ត្រេកអរក្រៃពេក។ ម្នាលភិក្ខុទាំងឡាយ អំពើនេះ ជាហេតុដ៏ឆ្នើម ជាកំពូលក្នុងកិរិយាញុំាងសង្ឃឲ្យត្រេកអរ របស់បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ ឈ្មោះថា ញុំាងសង្ឃឲ្យត្រេកអរយ៉ាងនេះឯង។ ម្នាលភិក្ខុទាំងឡាយ (បើ) បុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ បានញុំាងសង្ឃឲ្យត្រេកអរយ៉ាងនេះហើយ លុះត្រឡប់មកវិញ សង្ឃគួរឲ្យឧបសម្បទាចុះ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ មានកាយអាក្រាតដើរមក សង្ឃត្រូវស្វែងរកចីវរ មានឧបជ្ឈាយ៍ជាមូលឲ្យ (គឺធ្វើឧបជ្ឈាយ៍ឲ្យជាធំ) ប្រសិនបើបុគ្គលនោះ មិនទាន់បានកោរសក់នៅឡើយទេ ហើយដើរមក ភិក្ខុត្រូវផ្ទៀងសង្ឃ ដើម្បីធ្វើភណ្ឌុកម្មឲ្យ (ដើម្បីកោរសក់ឲ្យ[83])ចុះ។ ម្នាលភិក្ខុទាំងឡាយ ពួកជនណាជាតាបស ជាអ្នកបូជាភ្លើង (បើ) ជនទាំងនោះបានមកហើយ សង្ឃគួរឲ្យឧបសម្បទាបាន សង្ឃមិនចាំបាច់ឲ្យបរិវាសដល់ជនទាំងនោះឡើយ។ ការដែលមិនចាំបាច់ឲ្យបរិវាសនោះ ព្រោះហេតុអ្វី។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពួកជនទាំងនោះជាកម្មវាទី (គឺពោលថាកម្មមាន ថាផលកម្មក៏មាន) ជាកិរិយវាទី (គឺពោលថាផលបុណ្យបាបកើតពីកិរិយាធ្វើ)។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាសាកិយដោយជាតិ ធ្លាប់ជាតិរ្ថិយដទៃ មក(សូមឧបសម្បទា) បុគ្គលនោះ លុះមកហើយ សង្ឃគួរឲ្យឧបសម្បទាចុះ សង្ឃកុំចាំបាច់ឲ្យបរិវាសដល់បុគ្គលនោះឡើយ។ ម្នាលភិក្ខុទាំងឡាយ ដ្បិតតថាគតឲ្យការបរិហារ (សេចក្តីរក្សា) នេះ ឲ្យផ្សេងគ្នាដល់ពួកញាតិ។

ចប់ អញ្ញតិត្ថិយបុព្វកថា។

ចប់ ភាណវារៈទី៧។

## ២៦. បញ្ចាពាធវត្ថុ

CS vin.mv.01.26 | ភាគ ទី៦

**(២៦.)**

[១០១] សម័យនោះ អាពាធទាំងឡាយ៥យ៉ាង គឺឃ្លង់ ពក ស្រែង រោគរីងរៃ និងឆ្កួតជ្រូក កើតមានច្រើន ក្នុងដែនមគធៈ។ ពួកមនុស្សដែលកើតរោគទាំង៥យ៉ាង បានចូលទៅរកពេទ្យ ឈ្មោះជីវកកោមារភច្ច ហើយនិយាយយ៉ាងនេះថា បពិត្រលោកអាចារ្យ សូមលោកមេត្តាថែរក្សាជម្ងឺយើងទាំងឡាយផង។ គ្រូពេទ្យនិយាយប្រាប់ថា ម្នាលអ្នកទាំងឡាយ ខ្ញុំមានកិច្ចច្រើន មានការរវល់ច្រើនពេក (សព្វថ្ងៃនេះ) ខ្ញុំត្រូវថែរក្សាព្រះបាទពិម្ពិសារសេនិយជាធំក្នុងដែនមគធៈផង ស្រីស្នំផង ព្រះសង្ឃ មានព្រះពុទ្ធជាប្រធានផង ខ្ញុំមិនអាចនឹងថែរក្សាជម្ងឺ (អ្នកទាំងឡាយ) បានទេ។ មនុស្សទាំងនោះនិយាយអង្វរថា បពិត្រលោកអាចារ្យ សម្បត្តិទាំងអស់ (របស់យើងៗជូន)លោក ឯយើងទាំងអស់គ្នាសោត ក៏នៅជាខ្ញុំលោកទៀត បពិត្រលោកអាចារ្យ សូមលោកមេត្តាថែរក្សាជម្ងឺយើងទាំងឡាយផង។ គ្រូពេទ្យនិយាយប្រាប់ថា ម្នាលអ្នកទាំងឡាយ ខ្ញុំមានកិច្ចច្រើន មានការរវល់ច្រើន (សព្វថ្ងៃនេះ) ខ្ញុំត្រូវថែរក្សាព្រះបាទពិម្ពិសារសេនិយជាធំក្នុងដែនមគធៈផង ស្រីស្នំផង ព្រះសង្ឃ មានព្រះពុទ្ធជាប្រធានផង ខ្ញុំមិនអាចនឹងថែរក្សាជម្ងឺ (អ្នកទាំងឡាយ) បានទេ។ គ្រានោះ ពួកមនុស្សអម្បាលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកសមណៈជាសក្យបុត្រនេះឯង មានសេចក្តីសុខជាប្រក្រតី មានសេចក្តីសុខប្រព្រឹត្តទៅស្មើ ឆាន់តែភោជនល្អ សិងតែលើដំណេកដែលខ្យល់ចូលមិនបាន បើដូច្នោះ គួរតែយើងទាំងអស់បួសក្នុងពួកសមណៈ ជាសក្យបុត្រចុះ ភិក្ខុទាំងឡាយនឹងបានបម្រើផង ពេទ្យឈ្មោះជីវកកោមារភច្ចនឹងបានថែរក្សាជម្ងឺផង ក្នុងទីនោះ

មិនខានឡើយ។ គ្រានោះ ពួកមនុស្សទាំងនោះ ក៏ចូលទៅរកភិក្ខុទាំងឡាយហើយ សូមនូវផ្នួស។ ភិក្ខុទាំងឡាយ ឲ្យបព្វជ្ជា ឧបសម្បទាមនុស្សទាំងនោះ។ (លុះឲ្យបព្វជ្ជា ឧបសម្បទាហើយ) ភិក្ខុទាំងឡាយក៏បម្រើពួកភិក្ខុដែលមានជម្ងឺនោះ ពេទ្យឈ្មោះជីវកកោមារភច្ច ក៏ថែរក្សាជម្ងឺនោះមែន។ សម័យនោះឯង ភិក្ខុទាំងឡាយកាលបម្រើភិក្ខុឈឺជាច្រើនរូប ក៏រមែងសូមគេច្រើនពេក អង្គាសគេច្រើនពេក ដោយពាក្យថា អ្នកទាំងឡាយចូរឲ្យនូវគិលានភត្ត (ភត្តដែលប្រគេនដល់ភិក្ខុឈឺ) នូវគិលានុបដ្ឋាកភត្ត (ភត្តដែលគេប្រគេនដល់ភិក្ខុអ្នកបម្រើភិក្ខុឈឺ) នូវគិលានភេសជ្ជៈ (ថ្នាំសម្រាប់ភិក្ខុមានជម្ងឺ)។ ឯជីវកកោមារភច្ច កាលបើថែទាំរក្សាភិក្ខុឈឺច្រើនរូបហើយ ក៏ចោលរាជកិច្ចខ្លះចេញ។ មានបុរសម្នាក់ទៀត មានអាពាធគ្រប់ទាំង៥ ក៏ចូលទៅរកជីវកកោមារភច្ច ហើយនិយាយពាក្យនេះថា បពិត្រលោកអាចារ្យ សូមលោករក្សាជម្ងឺខ្ញុំផង។ ជីវកកោមារភច្ចនិយាយប្រាប់ថា ម្នាលអ្នក ខ្ញុំមានកិច្ចច្រើន មានការរវល់ច្រើន ខ្ញុំត្រូវថែរក្សាព្រះបាទពិម្ពិសារសេនិយៈជាធំក្នុងដែនមគធៈផង ស្រីស្នំផង ព្រះសង្ឃ មានព្រះពុទ្ធជាប្រធានផង ខ្ញុំមិនអាចនឹងថែរក្សាជម្ងឺ (អ្នកឯង) បានទេ។ បុរសនោះនិយាយអង្វរថា បពិត្រលោកអាចារ្យ សម្បត្តិទាំងអស់(របស់ខ្ញុំៗនឹងជូន)លោក ទាំងខ្លួនខ្ញុំសោត ក៏នឹងនៅជាខ្ញុំលោក បពិត្រលោកអាចារ្យ សូមលោកមេត្តាថែរក្សាជម្ងឺខ្ញុំផង។ ជីវកកោមារភច្ចនិយាយប្រាប់ថា ម្នាលអ្នក ខ្ញុំមានកិច្ចច្រើន មានការរវល់ច្រើន (សព្វថ្ងៃនេះ) ខ្ញុំត្រូវថែរក្សាព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈផង ស្រីស្នំផង ព្រះសង្ឃមានព្រះពុទ្ធជាប្រធានផង ខ្ញុំមិនអាចនឹងថែរក្សាជម្ងឺ (អ្នកឯង) បានទេ។ គ្រានោះ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកសមណៈជាសក្យបុត្រទាំងនេះ មានសេចក្តីសុខជាប្រក្រតី មានសេចក្តីសុខប្រព្រឹត្តទៅស្មើ ឆាន់តែភោជនល្អ សិងតែលើដំណេកដែលខ្យល់ចូលមិនបាន បើដូច្នោះ គួរតែអញបួសក្នុងពួកសមណៈ ជាសក្យបុត្រចុះ ភិក្ខុទាំងឡាយនឹងបម្រើផង ជីវកកោមារភច្ចនឹងថែរក្សាជម្ងឺផង ក្នុងទីនោះមិនខាន លុះខ្លួនអញជារោគកាលណាហើយ នឹងសឹក(មកវិញ)។ លំដាប់នោះ បុរសនោះចូលទៅរកភិក្ខុទាំងឡាយហើយសូមនូវផ្នួស។ ភិក្ខុទាំងនោះ ឲ្យបព្វជ្ជា ឧបសម្បទាបុរសនោះ។ ភិក្ខុទាំងឡាយក៏បម្រើផង ជីវកកោមារភច្ច ក៏ថែរក្សាជម្ងឺបុរសនោះផង។ លុះភិក្ខុនោះបានជារោគហើយ ក៏សឹកទៅវិញ។ ជីវកកោមារភច្ច បានឃើញបុរសដែលសឹកនោះ លុះឃើញហើយ ក៏សួរបុរសនោះថា នែអ្នក អ្នកឯងឬអ្វី ដែលកាលពីដើមឃើញបួសនឹងភិក្ខុទាំងឡាយ។ បុរសនោះឆ្លើយថា ហ្នឹងហើយ លោកអាចារ្យ។ ជីវកកោមារភច្ចសួរថា នែអ្នក ហេតុដូចម្តេចបានជាអ្នកឯងធ្វើដូច្នេះ។ បុរសនោះក៏ប្រាប់រឿងនុ៎ះដល់ជីវកកោមារភច្ច។ ជីវកកោមារភច្ចក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកម្ចាស់ទាំងឡាយមកបំបួសមនុស្សដែលមានអាពាធទាំង៥យ៉ាង (ដូច្នេះ)សោះ។ គ្រានោះ ជីវកកោមារភច្ច ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំ រួចអង្គុយក្នុងទីដ៏សមគួរ លុះអង្គុយក្នុងទីដ៏សមគួរហើយ ជីវកកោមារភច្ចក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមពរថា លោកម្ចាស់ទាំងឡាយកុំបំបួសមនុស្សដែលមានអាពាធទាំង៥យ៉ាងឡើយ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ជីវកកោមារភច្ចឲ្យយល់ច្បាស់ ឲ្យកាន់យកល្អ ឲ្យឧស្សាហ៍មាំ និងឲ្យរីករាយដោយធម្មីកថា។ ឯជីវកកោមារភច្ច ដែលព្រះដ៏មានបុណ្យ ទ្រង់ពន្យល់ឲ្យយល់ច្បាស់ ឲ្យកាន់យកល្អ ឲ្យឧស្សាហ៍មាំ និងឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថាហើយ ទ្រង់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ មនុស្សដែលមានអាពាធទាំង៥យ៉ាងហើយ អ្នកទាំងឡាយមិនគប្បីបំបួសឡើយ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ២៧. រាជភដវត្ថុ

CS vin.mv.01.27 | ភាគ ទី៦

**(២៧.)**

[១០២] សម័យនោះឯង មានកើតបះបោរនៅស្រុកចុងដែនរបស់ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ។ ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ ក៏ទ្រង់ត្រាស់បង្គាប់មហាមាត្យទាំងឡាយដែលជានាយកលើសេនាថា ម្នាលនាយ អ្នកទាំងឡាយចូរទៅត្រួតត្រាមើលស្រុកចុងដែន។ មហាមាត្យទាំងឡាយជានាយកលើសេនាទទួលព្រះរាជឱង្ការរបស់ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈថា ព្រះករុណាវិសេស។ លំដាប់នោះ ពួកយោធាដែលមានកេរ្តិ៍ឈ្មោះល្បីទូទ័រ មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងទាំងឡាយភ្លើតភ្លើនតែក្នុងការច្បាំង កាលបើទៅច្បាំងហើយ ឈ្មោះថាធ្វើអំពើបាបផង ឈ្មោះថាទទួលសោយនូវអំពើបាបដ៏ច្រើនផង យើងទាំងឡាយគួរវៀរចាកបាប និងគួរធ្វើអំពើល្អដោយឧបាយដូចម្តេចហ្ន៎។ ទើបពួកយោធាទាំងនោះមានសេចក្តីរំពឹងយ៉ាងនេះ(ទៀត)ថា មានតែពួកសមណៈជាសក្យបុត្រទាំងនេះ ទើបលោកជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តប្រពៃ ប្រព្រឹត្តប្រសើរ និយាយពាក្យទៀងត្រង់ មានសីល មានកល្យាណធម៌ ប្រសិនណាជាយើងទាំងឡាយទៅបួសនឹងពួកសមណៈជាសក្យបុត្រហើយ យើងទាំងឡាយនឹងបានវៀរចាកបាបផង បានធ្វើបុណ្យផង ដោយទំនងយ៉ាងនេះឯង។ លុះរំពឹងដូច្នេះហើយ ពួកយោធាទាំងនោះក៏ចូលទៅរកភិក្ខុទាំងឡាយហើយសូមនូវផ្នួស។ ភិក្ខុទាំងឡាយក៏ឲ្យបព្វជ្ជា ឧបសម្បទា យោធាទាំងនោះ។ ពួកមហាមាត្យ ជានាយកលើសេនាបានសួររាជអាមាត្យ (ខ្ញុំរាជការ) ទាំងឡាយថា នែនាយ ពួកយោធាឈ្មោះនេះផង ឈ្មោះនេះផង ហេតុដូចម្តេចក៏មិនឃើញ។ រាជអាមាត្យឆ្លើយថា បពិត្រអ្នកម្ចាស់ ពួកយោធាឈ្មោះនេះផង ឈ្មោះនេះផង ទៅបួសនឹងពួកភិក្ខុហើយ។ មហាមាត្យទាំងឡាយដែលជានាយកលើសេនា ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រ មិនសមបើនឹងបំបួសរាជអាមាត្យ (ដូច្នេះ)សោះ។ ពួកមហាមាត្យដែលជានាយកលើសេនាក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ។ លំដាប់នោះ ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ ទ្រង់សួរមហាមាត្យដែលប្រកបដោយវោហារ (ចៅក្រម) ថា នែនាយ នរណាបំបួសរាជអាមាត្យ អ្នកនោះត្រូវទទួលទោសដូចម្តេច។ មហាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ត្រូវកាត់ក្បាលឧបជ្ឈាយ៍ ត្រូវដកអណ្តាតនៃអនុស្សាវកាចារ្យ ត្រូវកាត់ឆ្អឹងជំនីរពាក់កណ្តាលរបស់គណៈសង្ឃ។ គ្រានោះឯង ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ។ លុះចូលទៅដល់ហើយ ទ្រង់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ ទ្រង់គង់ក្នុងទីដ៏សមគួរហើយ ទ្រង់ក្រាបបង្គំទូលយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានបុណ្យដ៏ចំរើន មានពួកស្តេចខ្លះ នៅមិនទាន់មានសទ្ធា មិនទាន់ជ្រះថ្លា ពួកស្តេចទាំងនោះប្រហែលជាគេនឹងបៀតបៀនភិក្ខុទាំងឡាយ ដោយហេតុបន្តិចបន្តួចខ្លះមិនខាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរថា លោកម្ចាស់ទាំងឡាយកុំគប្បីបំបួសរាជអាមាត្យឡើយ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ ឲ្យទ្រង់ជ្រាបច្បាស់ ឲ្យកាន់យកល្អ ឲ្យឧស្សាហ៍ ឲ្យរីករាយ ដោយធម្មីកថា។ ឯព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យជ្រាបច្បាស់ ឲ្យកាន់យកល្អ ឲ្យឧស្សាហ៍មាំ ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើ

ប្រទក្សិណ យាងចៀសចេញទៅ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបំបួសរាជអមាត្យទេ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ២៨. អង្គុលិមាលចោរវត្ថុ

CS vin.mv.01.28 | ភាគ ទី៦

**(២៨.)**

[១០៣] កាលនោះឯង ចោរឈ្មោះអង្គុលិមាល បួសនៅក្នុងសំណាក់ភិក្ខុទាំងឡាយ។ មនុស្សទាំងឡាយបានឃើញហើយ ខ្លះភ្ញាក់ផ្អើល ខ្លះតក់ស្លុត ខ្លះរត់ទៅ ខ្លះដើរទៅទីដទៃ ខ្លះបែរមុខចេញទៅផ្សេង ខ្លះបិទទ្វារ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រ មិនសមបើនឹងបំបួសចោរ ដែលប្រាកដដូចទង់ជ័យ (គឺចោរដែលមានឈ្មោះល្បីល្បាញដូច្នេះ)សោះ។ ភិក្ខុទាំងឡាយបានឮមនុស្សអម្បាលនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបភិក្ខុទាំងឡាយនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីបំបួសចោរ ដែលប្រាកដដូចទង់ជ័យឡើយ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ២៩. ការភេទកចោរវត្ថុ

CS vin.mv.01.29 | ភាគ ទី៦

**(២៩.)**

[១០៤] សម័យនោះឯង ព្រះបាទពិម្ពិសារសេនិយ ជាធំក្នុងដែនមគធៈ បានទ្រង់អនុញ្ញាតថា ជនទាំងឡាយណា ដែលបួសក្នុងសំណាក់សមណៈ ជាសក្យបុត្រ ជនដទៃធ្វើទោសអ្វីមួយ ដល់ជនពួកនោះមិនបានឡើយ (ព្រោះថា) ធម៌ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងល្អហើយ ជនពួកនោះ ចូរខំប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ ក៏សម័យនោះ មានបុរសម្នាក់ធ្វើចោរកម្ម ហើយជាប់ទោសនៅក្នុងគុក។ បុរសនោះទំលាយគុកបានហើយ ក៏រត់ទៅបួសក្នុងសំណាក់ភិក្ខុ។ មនុស្សទាំងឡាយបានឃើញហើយ និយាយពាក្យយ៉ាងនេះថា ភិក្ខុនេះឯង ដែលជាចោរទំលាយគុក ហ៎ពួកយើងចូរនាំចោរនោះទៅ។ ពួកមនុស្សខ្លះនិយាយពាក្យយ៉ាងនេះថា នែនាយទាំងឡាយ អ្នកកុំនិយាយយ៉ាំងហ្នឹង (ដ្បិត) ព្រះបាទពិម្ពិសារសេនិយ ជាធំក្នុងដែនមគធៈ ព្រះអង្គបានអនុញ្ញាតហើយថា ជនទាំងឡាយណា បួសក្នុងសំណាក់សមណៈ ជាសក្យបុត្រ ជនដទៃធ្វើទោសអ្វីមួយ ដល់ជនពួកនោះមិនបានឡើយ (ព្រោះថា) ធម៌ ព្រះដ៏មានបុណ្យ ទ្រង់សំដែងល្អហើយ ជនពួកនោះ ចូរខំប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រទាំងនេះ ជាអ្នកបានព្រះរាជទានអភ័យ ពួកសមណៈទាំងនេះ ជនដទៃធ្វើទោសអ្វីៗមិនបានឡើយ ហេតុដូចម្តេចបានជាមកហ៊ានបំបួសចោរ ដែលទំលាយគុក(ដូច្នេះ)។ ភិក្ខុទាំងឡាយ ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបំបួសចោរ ដែលទំលាយគុកទេ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ៣០. លិខិតកចោរវត្ថុ

CS vin.mv.01.30 | ភាគ ទី៦

**(៣០.)**

[១០៥] សម័យនោះឯង មានបុរសម្នាក់ធ្វើចោរកម្ម ហើយរត់ទៅបួសក្នុងសំណាក់ភិក្ខុ។ បុរសនោះឯង រាជការបានឲ្យកត់ឈ្មោះទុកក្នុងបញ្ជីខាងក្នុងបុរីនៃស្តេចថា ចោរនេះ បើនរណាបានឃើញក្នុងទីណា ត្រូវតែសម្លាប់ក្នុងទីនោះ។ មនុស្សទាំងឡាយបានឃើញហើយ ក៏និយាយពាក្យយ៉ាងនេះថា លោកនេះឯងជាចោរ ដែលមានកត់ឈ្មោះទុកក្នុងបញ្ជីរាជការ ហ៎ពួកយើងនាំគ្នាសម្លាប់វាទៅ។ ពួកមនុស្សខ្លះនិយាយយ៉ាងនេះថា នែនាយទាំងឡាយ អ្នកទាំងឡាយកុំនិយាយយ៉ាងហ្នឹង (ដ្បិត) ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ ព្រះអង្គទ្រង់អនុញ្ញាតហើយថា ជនទាំងឡាយណាមួយ បួសក្នុងពួកសមណៈ ជាសក្យបុត្រ ជនទាំងនោះ អ្នកណាមួយធ្វើទោសអ្វីៗ មិនបានឡើយ (ព្រោះ) ធម៌ ព្រះដ៏មានបុញ្ញសិរីទ្រង់សំដែងដោយល្អហើយ ជនទាំងនោះចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រទាំងនេះ ជាអ្នកបានទទួលព្រះរាជទានអភ័យហើយ ពួកសមណៈទាំងនេះ អ្នកណាមួយធ្វើទោសអ្វីៗ មិនបានឡើយ មិនសមបើនឹងបំបួសចោរ ដែលរាជការកត់ឈ្មោះទុកក្នុងបញ្ជី(ដូច្នេះ)សោះ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីបំបួសចោរ ដែលរាជការកត់ឈ្មោះទុកក្នុងបញ្ជីទេ[84] ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ៣១. កសាហតវត្ថុ

CS vin.mv.01.31 | ភាគ ទី៦

**(៣១.)**

[១០៦] សម័យនោះឯង មានបុរសម្នាក់ ជាមនុស្សមានស្នាម ដែលគេវាយដោយរំពាត់ គេបានធ្វើទណ្ឌកម្មហើយ ទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រ មិនសមបើបំបួសមនុស្សដែលមានស្នាម

រំពាត់ ដែលគេបានធ្វើទណ្ឌកម្មហើយ (ដូច្នេះ)សោះ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបំបួសមនុស្សដែលមានស្នាមរំពាត់ ដែលគេធ្វើទណ្ឌកម្មហើយទេ[85] ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ៣២. លក្ខណាហតវត្ថុ

CS vin.mv.01.32 | ភាគ ទី៦

**(៣២.)**

[១០៧] សម័យនោះឯង មានបុរសម្នាក់ ជាមនុស្សដែលគេបៀតបៀន ឲ្យមានស្លាកស្នាម ដែលគេបានធ្វើទណ្ឌកម្មហើយ ទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រ មិនសមបើនឹងបំបួសមនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម ដែលគេបានធ្វើទណ្ឌកម្មហើយ (ដូច្នេះ)សោះ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបំបួសមនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម[86] ដែលគេបានធ្វើទណ្ឌកម្មហើយ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ៣៣. ឥណាយិកវត្ថុ

CS vin.mv.01.33 | ភាគ ទី៦

**(៣៣.)**

[១០៨] សម័យនោះឯង មានបុរសម្នាក់ ជាមនុស្សចំពាក់បំណុលគេ ហើយរត់ទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ ពួកម្ចាស់ទ្រព្យបានឃើញហើយ ក៏និយាយពាក្យយ៉ាងនេះថា បុរសនេះហើយដែលជំពាក់បំណុលយើងនោះ បើដូច្នោះ ពួកយើងនាំវាទៅ។ មនុស្សមួយពួកក៏និយាយយ៉ាងនេះថា ម្នាលអ្នកម្ចាស់ទាំងឡាយ អ្នកទាំងឡាយកុំនិយាយពាក្យដូច្នេះ ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ បានទ្រង់អនុញ្ញាតហើយថា អ្នកណាបួសក្នុងសំណាក់ពួកសមណៈ សក្យបុត្រ អ្នកណាមួយធ្វើទោសអ្វីៗ ដល់អ្នកនោះមិនបានឡើយ ធម៌ព្រះដ៏មានបុណ្យសំដែងហើយដោយពីរោះ អ្នកទាំងនោះ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខដោយល្អចុះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រទាំងនេះ ជាបុគ្គលបានព្រះរាជអភ័យ ពួកសមណៈទាំងនេះ អ្នកណាមួយធ្វើទោសអ្វីៗ មិនបានឡើយ មិនសមបើនឹងបំបួសមនុស្សដែលជំពាក់បំណុលគេ (ដូច្នេះ)សោះ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីបំបួសមនុស្សដែលជំពាក់បំណុលគេទេ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ៣៤. ទាសវត្ថុ

CS vin.mv.01.34 | ភាគ ទី៦

**(៣៤.)**

[១០៩] សម័យនោះឯង មនុស្សជាខ្ញុំគេម្នាក់រត់ទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ លុះពួកម្ចាស់បំណុលគេបានឃើញហើយ ក៏និយាយយ៉ាងនេះថា បុរសនេះហើយដែលជាខ្ញុំរបស់យើងទាំងឡាយ បើដូច្នោះ យើងនាំវាទៅវិញ។ មនុស្សមួយពួកនិយាយយ៉ាងនេះថា ម្នាលអ្នកជាម្ចាស់ទាំងឡាយ អ្នកទាំងឡាយកុំនិយាយយ៉ាងនេះឡើយ (ព្រោះ) ព្រះបាទពិម្ពិសារសេនិយៈ ជាធំក្នុងដែនមគធៈ បានទ្រង់អនុញ្ញាតហើយថា ពួកជនណាបួសក្នុងសំណាក់ពួកសមណៈ ជាសក្យបុត្រ ពួកជនទាំងនោះ អ្នកណាមួយធ្វើទោសអ្វីៗ មិនបានឡើយ ធម៌ព្រះដ៏មានបុណ្យទ្រង់សំដែងហើយដោយពីរោះ ពួកជនទាំងនោះ ចូរខំប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខដោយប្រពៃចុះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រទាំងនេះ ជាបុគ្គលបានព្រះរាជអភ័យ សមណៈទាំងនេះ អ្នកណាមួយធ្វើទោសអ្វីៗ មិនបានឡើយ មិនសមបើនឹងបំបួសមនុស្សដែលជាខ្ញុំគេ (ដូច្នេះ)សោះ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបំបួសមនុស្សដែលជាខ្ញុំគេទេ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

## ៣៥. កម្មារភណ្ឌុវត្ថុ

CS vin.mv.01.35 | ភាគ ទី៦

**(៣៥.)**

[១១០] សម័យនោះឯង មានទារកម្នាក់ ទុកជុក ជាកូនជាងមាស[87] ឈ្លោះប្រកែកនឹងមាតាបិតាហើយ ទៅកាន់អារាមបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ ឯមាតានិងបិតារបស់ទារកនោះ កាលដែលគន់រកមើលទារកនោះ ក៏បានទៅដល់អារាម ហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយ ពួកលោកបានប្រទះឃើញទារកមានសភាពយ៉ាងនេះដែរឬ។ ពួកភិក្ខុដែលមិនដឹងមែន ក៏ប្រាប់ថា យើងទាំងឡាយមិនដឹងទេ ពួកភិក្ខុដែលមិនឃើញមែន ក៏ប្រាប់ថា យើងទាំងឡាយមិនឃើញទេ។ ឯមាតានិងបិតារបស់ទារកនោះ កាលបើត្រាច់គយគន់មើលទៅ ក៏ឃើញទារកនោះបួសក្នុងសំណាក់ភិក្ខុទាំងឡាយហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រទាំងនេះ ជាបុគ្គលឥតមានខ្មាស ទ្រុស្តសីល និយាយពាក្យកុហក បានដឹងដែរ តែនិយាយថាមិនដឹង បានឃើញដែរ តែនិយាយថាមិនឃើញ ទារកនេះ បួសក្នុងសំណាក់ភិក្ខុទាំងឡាយហើយតើ។ ភិក្ខុទាំងឡាយបានឮសំដីនៃមាតានិងបិតារបស់ទារកនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងនោះ ក៏

ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអបលោក (ប្រាប់) សង្ឃហើយសឹមធ្វើភណ្ឌុកម្ម។[88)]

## ៣៦. ឧបាលិទារកវត្ថុ

CS vin.mv.01.36 | ភាគ ទី៦

**(៣៦.)**

[១១១] សម័យនោះឯង ក្នុងក្រុងរាជគ្រឹះ មានពួកទារកជាសំឡាញ់គ្នា១៧ពួក មានទារកឈ្មោះឧបាលិជាប្រធានរបស់ពួកទារកទាំងនោះ។ឯមាតានិងបិតារបស់ទារកឈ្មោះឧបាលិ បានគិតគ្នាយ៉ាងនេះថា អំណើះពីយើងទាំងឡាយទៅហើយ ឧបាលិគប្បីចិញ្ចឹមជីវិតស្រួលផង មិនលំបាកផង ដោយទំនងដូចម្តេចអេះ។ ទើបមាតានិងបិតារបស់ឧបាលិ ក៏គិតគ្នាយ៉ាងនេះថា បើសិនណាជាឧបាលិរៀនសរសេរអក្សរ អំណើះពីយើងទាំងឡាយទៅ ប្រហែលជាឧបាលិគប្បីចិញ្ចឹមជីវិតស្រួលផង មិនលំបាកផង ដោយទំនងយ៉ាងនេះឯង។ មាតានិងបិតារបស់ឧបាលិ ក៏គិតគ្នាយ៉ាងនេះទៀតថា បើឧបាលិនឹងរៀនសរសេរអក្សរ ម្រាមដៃ(របស់ឧបាលិ) ក៏នឹងលំបាក បើសិនណាជាឧបាលិ គ្រាន់តែរៀនរាប់វិញ ប្រហែលជា អំណើះពីយើងទាំងឡាយទៅ ឧបាលិគប្បីចិញ្ចឹមជីវិតស្រួលផង មិនលំបាកផង ដោយទំនងយ៉ាងនេះឯង។ លំដាប់ពីនោះមក មាតានិងបិតារបស់ឧបាលិ ក៏គិតគ្នាដូច្នេះទៀតថា បើឧបាលិនឹងរៀនរាប់ ទ្រូង (របស់ឧបាលិ) ក៏នឹងលំបាក ប្រសិនណាបើឧបាលិ គ្រាន់តែរៀនមើលរូបនិមិត្តវិញ ដល់អំណើះពីយើងទាំងឡាយទៅ ឧបាលិប្រហែលជានឹងបានចិញ្ចឹមជីវិតស្រួលផង មិនលំបាកផង ដោយអាការដូច្នេះឯង។ គ្រាតមកទៀត មាតានិងបិតារបស់ឧបាលិ ក៏គិតគ្នាដូច្នេះថា បើទុកជាឧបាលិរៀនរូបនិមិត្ត ក៏គង់តែលំបាកភ្នែក ឥឡូវនេះ មានតែពួកសមណៈ ជាសក្យបុត្រទាំងនេះ ទើបរក្សាសីលជាសុខ មានសមាចារស្រួល ឆាន់ភោជនក៏ល្អ សិងលើដំណេកទាំងឡាយដ៏ហប់ រកខ្យល់គ្មាន បើសិនណាជាឧបាលិបានបួសក្នុងសំណាក់ពួកសមណៈ ជាសក្យបុត្រវិញយ៉ាងនេះ ទើបអំណើះពីយើងទាំងឡាយទៅ ឧបាលិនឹងបានចិញ្ចឹមជីវិតងាយផង មិនលំបាកផង។ ឯឧបាលិទារក បានឮពាក្យចរចាររបស់មាតានិងបិតាយ៉ាងនេះហើយ។ លំដាប់តពីនោះមក ឧបាលិទារកក៏ចូលសំដៅទៅរកពួកក្មេងអម្បាលនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងពួកក្មេងទាំងនោះថា នែនាយទាំងឡាយ អ្នកទាំងឡាយចូរមក យើងទាំងឡាយនឹងទៅបួសក្នុងសំណាក់ពួកសមណៈ ជាសក្យបុត្រ។ ពួកក្មេងទាំងនោះនិយាយដូច្នេះថា នែនាយ បើអ្នកបួសមែន យើងទាំងឡាយក៏នឹងបួសដូចអ្នកដែរ។ លំដាប់នោះ ពួកក្មេងអម្បាលនោះ ក៏ចូលទៅរកមាតានិងបិតារៀងខ្លួន ហើយនិយាយពាក្យនេះថា សូមអ្នកម្តាយអ្នកឪពុក អនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបព្វជ្ជាក្នុងសភាពជាបុគ្គលឥតផ្ទះ។ ឯមាតានិងបិតារបស់ក្មេងទាំងនោះ យល់ឃើញថា ពួកក្មេងទាំងអស់គ្នានេះមានសេចក្តីប្រាថ្នាស្មើគ្នា មានបំណងល្អ ក៏អនុញ្ញាតឲ្យ។ ពួកក្មេងទាំងនោះ ចូលទៅរកភិក្ខុទាំងឡាយ ហើយសូមបព្វជ្ជា។ ភិក្ខុទាំងឡាយក៏ឲ្យបព្វជ្ជាឧបសម្បទាក្មេងអម្បាលនោះ។ ពួកភិក្ខុ (ក្មេង) ទាំងនោះ ក្រោកឡើង ហើយយំទារស៊ីក្នុងបច្ចូសសម័យនៃរាត្រីថា សូមលោកឲ្យបបរមក ឲ្យបាយមក ឲ្យវត្ថុជាគ្រឿងទំពាស៊ីមក។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ចូររង់ចាំទម្រាំភ្លឺសិន បើមានបបរ សឹមឆាន់ចុះ បើមានភត្ត សឹមឆាន់ចុះ បើមានវត្ថុជាគ្រឿងទំពាស៊ី សឹមទំពាស៊ីចុះ បើបបរក្តី ភត្តក្តី វត្ថុជាគ្រឿងទំពាស៊ីក្តីមិនមាន ចូរត្រាច់ទៅដើម្បីបិណ្ឌបាត ហើយសឹមឆាន់ចុះ។ ឯពួកភិក្ខុ (ក្មេង) អម្បាលនោះ កាលបើភិក្ខុទាំងឡាយ និយាយយ៉ាងនេះហើយ ក៏រឹងរឹតតែយំរំអុកប្រាប់ភិក្ខុទាំងឡាយថា សូមលោកឲ្យបបរមក ឲ្យបាយមក ឲ្យវត្ថុជាគ្រឿងទំពាស៊ីមក លុះយំទារដូច្នេះហើយ ក៏ជុះដាក់ទីសេនាសនៈខ្លះ នោមស្រោចសេនាសនៈខ្លះ។ ព្រះដ៏មានព្រះភាគ បានទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ទ្រង់បានឮសំឡេងកូនក្មេង លុះទ្រង់បានស្តាប់ហើយ ក៏ហៅព្រះអានន្ទដ៏មានអាយុមកហើយទ្រង់ត្រាស់សួរថា ម្នាលអានន្ទ សំឡេងនោះ តើជាសំឡេងកូនក្មេងឬអ្វី។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរបញ្ជាក់ថែមទៀតថា ម្នាលភិក្ខុទាំងឡាយ តថាគតបានឮថា ភិក្ខុទាំងឡាយដឹងថា បុគ្គលមានអាយុមិនទាន់គ្រប់២០ឆ្នាំ ហើយឲ្យឧបសម្បទា ពិតមែនឬ។ ព្រះអានន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះដឹងថា បុគ្គលមានអាយុមិនទាន់គ្រប់២០ឆ្នាំហើយ មិនសមបើឲ្យឧបសម្បទា(ដូច្នេះ)ទេ ម្នាលភិក្ខុទាំងឡាយ (ធម្មតា) បុគ្គលមានអាយុមិនទាន់គ្រប់២០ឆ្នាំ រមែងមិនចេះអត់ធន់ត្រជាក់ ក្តៅ ឃ្លាន ស្រេក និងរមែងជាបុគ្គល មិនទាន់ចេះទ្រាំនូវសម្ផស្សរបោមមូសខ្យល់កំដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ និងគន្លងពាក្យដែលគេនិយាយមិនពីរោះទ្រគោះខ្ចីខ្ចា និងទុក្ខវេទនាដែលប្រជុំក្នុងសរីរកាយកើតឡើងហើយដ៏ក្លារឹងអាក្រក់ មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត និងនាំឲ្យខូចជីវិត (នោះបានឡើយ) ម្នាលភិក្ខុទាំងឡាយ លុះតែ បុគ្គលមានអាយុគ្រប់២០ឆ្នាំ ទើបជាមនុស្សចេះអត់ធន់ត្រជាក់ ក្តៅ ឃ្លាន ស្រេក និងជាមនុស្សចេះទ្រាំនូវសម្ផស្សរបោមមូសខ្យល់កំដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ និងគន្លងពាក្យដែលគេនិយាយមិនពីរោះទ្រគោះខ្ចីខ្ចា និងទុក្ខវេទនាដែលប្រជុំក្នុងសរីរកាយកើតឡើងហើយដ៏ក្លារឹងអាក្រក់ មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត និងនាំឲ្យខូចជីវិត (នោះបាន) ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាស្រាប់ហើយទេ។បេ។ លុះបន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងថា បុគ្គលមានអាយុមិនទាន់គ្រប់២០ឆ្នាំ មិនគប្បីឲ្យឧបសម្បទាទេ។ ភិក្ខុណាឲ្យឧបសម្បទា វិនយធរត្រូវធ្វើឲ្យសមគួរតាមធម៌ចុះ។[89)]

## ៣៧. អហិវាតករោគវត្ថុ

CS vin.mv.01.37 | ភាគ ទី៦

**((អហិវាតករោគវត្ថុ ៣៧.))**

[១១២] សម័យនោះឯង មានត្រកូល១ ធ្វើមរណកាលស្លាប់ទៅ ដោយអហិវាតករោគ។[90)] ត្រកូលនោះនៅសល់តែបិតា និងបុត្រតូច។ បិតានិងបុត្រតូចទាំងពីរនាក់នោះ បានទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ក៏ត្រាច់ទៅបិណ្ឌបាតតែជាមួយគ្នា។ ឯទារកនោះ កាលបើមានគេឲ្យបាយដល់បិតា ក៏ស្ទុះចូលទៅជិត ហើយនិយាយពាក្យនេះថា នែឪពុក ចូរឲ្យខ្ញុំផង នែឪពុក ចូរឲ្យខ្ញុំផង។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រទាំងនេះ មិនប្រព្រឹត្តធម៌ដ៏ប្រសើរ (សេពមេថុនធម្ម) ទារកនេះ កើតអំពីភិក្ខុនី។ ភិក្ខុទាំងឡាយ បានឮ

មនុស្សអម្បាលនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីបំបួសទារកដែលមានអាយុថយអំពី១៥ឆ្នាំ គឺបួសជាសាមណេរ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

[១១៣] សម័យនោះឯង ត្រកូលឧបដ្ឋាករបស់ព្រះអានន្ទដ៏មានអាយុ ជាត្រកូលមានសទ្ធា និងជ្រះថ្លា ធ្វើមរណកាលដោយអហិវាតករោគ។ នៅសល់តែទារកពីរនាក់។ ទារកទាំងនោះ ឃើញភិក្ខុទាំងឡាយ ដោយសារធ្លាប់ស្គាល់មកពីដើម ក៏ស្ទុះចូលទៅជិត។ ភិក្ខុទាំងឡាយក៏បណ្តេញចេញ។ កាលបើភិក្ខុទាំងឡាយបណ្តេញហើយ ទារកនោះក៏យំ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុបានរិះគិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយថា ទារកដែលមានអាយុថយអំពី១៥ឆ្នាំ ភិក្ខុមិនត្រូវបំបួស ក៏ឥឡូវនេះ ទារកទាំងនេះមានអាយុថយអំពី១៥ឆ្នាំ ដោយទំនងដូចម្តេចហ្ន៎ ទើបបានទារកទាំងនេះមិនគប្បីវិនាស គឺមិនសាបសូន្យចាកផ្នួស។ គ្រានោះ ព្រះអានន្ទដ៏មានអាយុក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលអានន្ទ ចុះទារកទាំងនោះ អាចនឹងចោលបង្អើលក្អែកឲ្យហើរទៅបានដែរឬទេ។ ព្រះអានន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស អាចចោលបង្អើលបាន។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏ទ្រង់បុញ្ញសិរីជាម្ចាស់ ទ្រង់ធ្វើនូវធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបំបួសទារកមានអាយុថយអំពី១៥ឆ្នាំ ដែលអាចចោលបង្អើលក្អែកឲ្យហើរទៅបាន។[91)]

## ៣៨. កណ្តកវត្ថុ

CS vin.mv.01.38 | ភាគ ទី៦

**(៣៨.)**

[១១៤] សម័យនោះឯង ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ មានសាមណេរពីររូប ឈ្មោះកណ្តកៈ១ មហកៈ១។ សាមណេរទាំងនោះចេះតែប្រទូស្ត (សេពមេថុនធម្ម) គ្នានឹងគ្នា។ ភិក្ខុទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសាមណេរ មិនសមបើមកប្រព្រឹត្តអនាចារ មានសភាពដូច្នេះសោះ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុម្នាក់ឯង មិនត្រូវឲ្យសាមណេរពីររូបបម្រើទេ ភិក្ខុណាឲ្យបម្រើ ត្រូវអាបត្តិទុក្កដ។

## ៣៩. អាហុន្ទរិកវត្ថុ

CS vin.mv.01.39 | ភាគ ទី៦

**(៣៩.)**

[១១៥] សម័យនោះឯង ព្រះដ៏មានបុញ្ញសិរី ទ្រង់គង់ចាំវស្សាអស់ហេមន្តរដូវ និងគិម្ហរដូវតែក្នុងក្រុងរាជគ្រឹះនោះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ទិសទាំងឡាយក៏ចង្អៀតចង្អល់ ងងឹតងងល់ដល់ពួកសមណៈ សក្យបុត្រ ទិសទាំងឡាយមិនប្រាកដដល់ពួកសមណៈទាំងនេះ (ឬអ្វី បានជាគាប់ចិត្តនៅតែក្នុងទីនេះ មិនទៅទីឯទៀតសោះ)។ ភិក្ខុទាំងឡាយ បានឮពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ គ្រានោះ ព្រះដ៏មានបុណ្យត្រាស់ហៅព្រះអានន្ទដ៏មានអាយុមក ហើយទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកឯងចូរទៅកាន់យកកូនសោ ហើយចូរប្រាប់ពួកភិក្ខុដែលនៅក្នុងបរិវេណតាមលំដាប់ថា ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគ ព្រះអង្គប្រាថ្នានឹងយាងទៅកាន់ចារិកក្នុងទក្ខិណាគិរិជនបទ (បើ) លោកដ៏មានអាយុអង្គណា ត្រូវការ(ទៅ) លោកដ៏មានអាយុអង្គនោះចូរនិមន្តមកចុះ។ ព្រះអានន្ទដ៏មានអាយុទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ដូច្នេះហើយ ក៏កាន់យកនូវកូនសោ ហើយទៅប្រាប់ភិក្ខុទាំងឡាយដែលនៅតាមបរិវេណថា ម្នាលអាវុសោទាំងឡាយ ព្រះដ៏មានបុណ្យ ព្រះអង្គប្រាថ្នានឹងយាងទៅកាន់ចារិកក្នុងទក្ខិណាគិរិជនបទ (បើ) លោកដ៏មានអាយុអង្គណា ត្រូវការ(ទៅ) លោកដ៏មានអាយុអង្គនោះ ចូរនិមន្តមកចុះ។ ភិក្ខុទាំងឡាយនិយាយដូច្នេះថា ម្នាលអាវុសោអានន្ទ ព្រះដ៏មានបុណ្យ បានទ្រង់បញ្ញត្តដើម្បីឲ្យភិក្ខុនៅជាប់និស្ស័យអស់វស្សាទាំងឡាយ១០ ដើម្បីឲ្យភិក្ខុមានវស្សា១០ ឲ្យនិស្ស័យបាន យើងទាំងឡាយគប្បីទៅក្នុងទីនោះផង គប្បីកាន់យកនិស្ស័យផង ការនៅបានតែបន្តិចបន្តួចផង យើងទាំងឡាយ ក៏ត្រូវត្រឡប់មកវិញផង ត្រូវកាន់យកនិស្ស័យម្តងទៀតផង បើប្រសិនណាជាព្រះឧបជ្ឈាយ៍និងអាចារ្យរបស់យើងទៅផង យើងក៏ទៅដែរ បើព្រះឧបជ្ឈាយ៍ និងអាចារ្យរបស់យើងទាំងឡាយមិនបានទៅទេ យើងក៏មិនបានទៅដែរ ម្នាលអាវុសោអានន្ទ កិរិយាដែលមានចិត្តវិលវល់មុខជានឹងប្រាកដដល់យើងទាំងឡាយ។ គ្រានោះ ព្រះដ៏មានបុណ្យ ទ្រង់យាងទៅកាន់ចារិកក្នុងទក្ខិណាគិរិជនបទ ដោយភិក្ខុសង្ឃមានពួកតិច។ ព្រះដ៏មានបុណ្យ ព្រះអង្គគង់នៅក្នុងទក្ខិណាគិរិជនបទ សមគួរតាមព្រះអធ្យាស្រ័យ ហើយក៏យាងត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ។ ទើបព្រះដ៏មានព្រះភាគ ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកហើយ ទ្រង់ត្រាស់សួរថា ម្នាលអានន្ទ ហេតុដូចម្តេចបានជាកាលដែលតថាគតបានចៀសទៅកាន់ទក្ខិណាគិរិជនបទ មានពួកភិក្ខុសង្ឃតិចម្ល៉េះ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆ្លាសប្រតិពលនៅជាប់និស្ស័យអស់៥វស្សា ភិក្ខុដែលមិនឆ្លាស ត្រូវនៅដរាបដល់អស់ជីវិត។[92)]

## ៤០. និស្សយមុច្ចនកកថា

CS vin.mv.01.40 | ភាគ ទី៦

**(៤០.)**

[១១៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ មិនគប្បីនៅដោយឥតនិស្ស័យ គឺជាភិក្ខុមិនប្រកបដោយកងសីល ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុមិនប្រកបដោយកងសមាធិ ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុមិនប្រកបដោយកងបញ្ញា (វិបស្សនា) ជារបស់អសេក្ខបុគ្គល១

ជាភិក្ខុមិនប្រកបដោយកងវិមុត្តិ (អរហត្តផល) ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុមិនប្រកបដោយកងវិមុត្តិញ្ញាណទស្សនៈ (បច្ចវេក្ខណញ្ញាណ) ជារបស់អសេក្ខបុគ្គល១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង មិនគប្បីនៅដោយឥតនិស្ស័យឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ គប្បីនៅដោយមិនបាច់មាននិស្ស័យបាន គឺជាភិក្ខុប្រកបដោយកងសីល ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុប្រកបដោយកងសមាធិ ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុប្រកបដោយកងបញ្ញា ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុប្រកបដោយកងវិមុត្តិ ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុប្រកបដោយកងវិមុត្តិញ្ញាណទស្សនៈ ជារបស់អសេក្ខបុគ្គល១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ទើបគួរនៅបានដោយមិនបាច់មាននិស្ស័យ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ដទៃទៀត មិនគប្បីនៅដោយឥតមាននិស្ស័យ គឺជាភិក្ខុមិនមានសទ្ធា១ ជាភិក្ខុមិនខ្មាសបាប១ ជាភិក្ខុមិនខ្លាចបាប១ ជាភិក្ខុខ្ជិល១ ជាភិក្ខុវង្វេងស្មារតី១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង មិនគួរនៅដោយឥតនិស្ស័យឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ គួរនៅបានដោយមិនបាច់មាននិស្ស័យ គឺជាភិក្ខុមានសទ្ធា១ ជាភិក្ខុខ្មាសបាប១ ជាភិក្ខុខ្លាចបាប១ ជាភិក្ខុប្រារព្ធព្យាយាម១ ជាភិក្ខុដម្កល់ស្មារតីខ្ជាប់ខ្ជួន១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ទើបគួរនៅបានដោយមិនបាច់មាននិស្ស័យឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ក្រៅពីនេះទៀត មិនគប្បីនៅដោយឥតនិស្ស័យ គឺជាភិក្ខុវិបត្តិសីលក្នុងសីលដ៏ក្រៃលែង១ ជាភិក្ខុវិបត្តិអាចារក្នុងអាចារដ៏ក្រៃលែង១ ជាភិក្ខុវិបត្តិទិដ្ឋិក្នុងទិដ្ឋិដ៏ក្រៃលែង១ ជាភិក្ខុចេះចាំតិច១ ជាភិក្ខុអាប់ឥតប្រាជ្ញា១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង មិនគួរនៅដោយឥតនិស្ស័យឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ គប្បីនៅដោយមិនមាននិស្ស័យបាន គឺជាភិក្ខុមិនវិបត្តិសីលក្នុងសីលដ៏ក្រៃលែង១ ជាភិក្ខុមិនវិបត្តិអាចារក្នុងអាចារដ៏ក្រៃលែង១ ជាភិក្ខុមិនវិបត្តិចាកទិដ្ឋិក្នុងទិដ្ឋិដ៏ក្រៃលែង១ ជាភិក្ខុចេះចាំច្រើន១ ជាភិក្ខុមានប្រាជ្ញា១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ទើបគួរនៅដោយមិនបាច់មាននិស្ស័យបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ក្រៅពីនេះទៀត មិនគប្បីនៅដោយឥតនិស្ស័យ គឺភិក្ខុមិនស្គាល់អាបត្តិ១ មិនស្គាល់អនាបត្តិ១ មិនស្គាល់អាបត្តិស្រាល១ មិនស្គាល់អាបត្តិធ្ងន់១ ទាំងបាតិមោក្ខទាំងឡាយពីរ[93] ភិក្ខុនោះក៏មិនបានចេះដោយពិស្តារ ភិក្ខុនោះមិនបានចែកដោយប្រពៃ មិនបានឲ្យប្រព្រឹត្តដោយប្រពៃ (មិនចាំស្ទាត់រត់មាត់) មិនកាត់សេចក្តីដោយល្អ តាមសុត្ត (សង្គ្រោះយកខន្ធកវិន័យ និងបរិវារៈ) តាមរបៀបនៃព្យញ្ជនៈ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៥នេះឯង មិនគប្បីនៅដោយមិនមាននិស្ស័យឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ គប្បីនៅដោយឥតនិស្ស័យបាន គឺភិក្ខុស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់អាបត្តិស្រាល១ ស្គាល់អាបត្តិធ្ងន់១ ទាំងបាតិមោក្ខទាំងឡាយពីរ ភិក្ខុនោះក៏ចេះដោយត្រឹមត្រូវល្អ យ៉ាងពិស្តារ បានចែកដោយល្អ បានឲ្យប្រព្រឹត្តដោយប្រពៃ បានវិនិច្ឆ័យដោយត្រឹមត្រូវតាមសុត្ត តាមរបៀបនៃព្យញ្ជនៈ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៥នេះឯង ទើបគួរនៅដោយឥតនិស្ស័យបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ក្រៅពីនេះទៀត មិនគប្បីនៅដោយឥតនិស្ស័យ គឺភិក្ខុមិនស្គាល់អាបត្តិ១ មិនស្គាល់អនាបត្តិ១ មិនស្គាល់អាបត្តិស្រាល១ មិនស្គាល់អាបត្តិធ្ងន់១ មានវស្សាថយពីប្រាំចុះមក១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំងឡាយ៥នេះឯង មិនគួរនៅដោយឥតនិស្ស័យឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៥ គប្បីនៅដោយឥតនិស្ស័យបាន គឺភិក្ខុស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់អាបត្តិស្រាល១ ស្គាល់អាបត្តិធ្ងន់១ មានវស្សាប្រាំ ឬមានវស្សាច្រើនជាងប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំងឡាយ៥នេះឯង ទើបគួរនៅដោយឥតនិស្ស័យបាន។

[១១៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៦ មិនគប្បីនៅដោយឥតនិស្ស័យទេ គឺជាភិក្ខុដែលមិនប្រកបដោយកងសីល ជារបស់អសេក្ខបុគ្គល១ ដែលមិនប្រកបដោយកងសមាធិ ជារបស់អសេក្ខបុគ្គល១ ដែលមិនប្រកបដោយកងបញ្ញា ជារបស់អសេក្ខបុគ្គល១ ដែលមិនប្រកបដោយកងវិមុត្តិ ជារបស់អសេក្ខបុគ្គល១ ដែលមិនប្រកបដោយកងវិមុត្តិញ្ញាណទស្សនៈ ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុមានវស្សាមិនទាន់គ្រប់ប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៦នេះឯង មិនគួរនៅដោយឥតនិស្ស័យទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៦ គប្បីនៅដោយឥតនិស្ស័យបាន គឺជាភិក្ខុប្រកបដោយកងសីល ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុប្រកបដោយកងសមាធិ ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុប្រកបដោយកងបញ្ញា ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុប្រកបដោយកងវិមុត្តិ ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុប្រកបដោយកងវិមុត្តិញ្ញាណទស្សនៈ ជារបស់អសេក្ខបុគ្គល១ ជាភិក្ខុមានវស្សាប្រាំ ឬមានវស្សាច្រើនជាងប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៦នេះឯង ទើបគួរនៅដោយឥតនិស្ស័យបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៦ក្រៅពីនេះទៀត មិនគប្បីនៅដោយឥតនិស្ស័យ គឺជាភិក្ខុមិនមានសទ្ធា១ ជាភិក្ខុមិនខ្មាសបាប១ ជាភិក្ខុមិនខ្លាចបាប១ ជាភិក្ខុខ្ជិល១ ជាភិក្ខុវង្វេងស្មារតី១ ជាភិក្ខុមានវស្សាមិនទាន់គ្រប់ប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៦នេះឯង មិនគួរនៅដោយឥតនិស្ស័យឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៦ គប្បីនៅដោយឥតនិស្ស័យបាន គឺជាភិក្ខុមានសទ្ធា១ ជាភិក្ខុខ្មាសបាប១ ជាភិក្ខុខ្លាចបាប១ ជាភិក្ខុមានសេចក្តីប្រារព្ធព្យាយាមហើយ១ ជាភិក្ខុដម្កល់ស្មារតីខ្ជាប់ខ្ជួន១ ជាភិក្ខុមានវស្សាប្រាំ ឬមានវស្សាច្រើនជាងប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៦នេះឯង ទើបគួរនៅដោយឥតនិស្ស័យបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៦ក្រៅពីនេះទៀត មិនគប្បីនៅដោយឥតនិស្ស័យ គឺជាភិក្ខុវិបត្តិសីលក្នុងសីលដ៏ក្រៃលែង១ ជាភិក្ខុវិបត្តិអាចារ (មារយាទ) ក្នុងអាចារដ៏ក្រៃលែង១ ជាភិក្ខុវិបត្តិទិដ្ឋិក្នុងទិដ្ឋិដ៏ក្រៃលែង១ ជាភិក្ខុចេះចាំ(ពុទ្ធវចនៈ)តិច១ ជាភិក្ខុមិនមានប្រាជ្ញា១ ជាភិក្ខុមានវស្សាមិនទាន់គ្រប់ប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំង៦នេះឯង មិនគួរនៅដោយឥតនិស្ស័យឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៦ គប្បីនៅដោយមិនបាច់និស្ស័យ គឺជាភិក្ខុមិនវិបត្តិសីលក្នុងសីលដ៏ក្រៃលែង១ ជាភិក្ខុមិនវិបត្តិអាចារក្នុងអាចារដ៏ក្រៃលែង១ ជាភិក្ខុមិនវិបត្តិទិដ្ឋិក្នុងទិដ្ឋិដ៏ក្រៃលែង១ ជាភិក្ខុចេះចាំ(ពុទ្ធវចនៈ)ច្រើន១ ជាភិក្ខុមានប្រាជ្ញា១ ជាភិក្ខុមានវស្សាប្រាំ ឬមានវស្សាច្រើនជាងប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៦នេះឯង ទើបគួរនៅមិនបាច់មាននិស្ស័យបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៦ក្រៅពីនេះទៀត មិនគប្បីនៅដោយឥតនិស្ស័យ គឺភិក្ខុមិនស្គាល់អាបត្តិ១ មិនស្គាល់អនាបត្តិ១ មិនស្គាល់អាបត្តិស្រាល១ មិនស្គាល់អាបត្តិធ្ងន់១ ទាំងបាតិមោក្ខទាំងឡាយពីរ ភិក្ខុនោះមិនបានចេះចាំដោយពិស្តារ មិនបានចែកដោយល្អ មិនឲ្យប្រព្រឹត្តដោយប្រពៃ មិនវិនិច្ឆ័យដោយត្រឹមត្រូវ តាមសុត្ត តាមលំដាប់ព្យញ្ជនៈ១ ជាភិក្ខុមានវស្សាមិនគ្រប់ប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៦នេះឯង មិនគួរនៅដោយមិនមាននិស្ស័យទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គទាំងឡាយ៦នេះឯង គប្បីនៅដោយមិនបាច់និស្ស័យ គឺភិក្ខុស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់អាបត្តិស្រាល១ ស្គាល់អាបត្តិធ្ងន់១ ទាំងបាតិមោក្ខទាំងឡាយពីរ ភិក្ខុនោះក៏ចេះចាំយ៉ាងពិស្តារ បានចែកដោយល្អ ឲ្យប្រព្រឹត្តទៅដោយប្រពៃ កាត់សេចក្តីដោយត្រឹមត្រូវតាមសុត្ត តាម

លំដាប់ព្យញ្ជនៈ១ ជាភិក្ខុមានវស្សាប្រាំ ឬមានវស្សាច្រើនជាងប្រាំ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គទាំង៦នេះឯង ទើបគួរនៅដោយមិនមាននិស្ស័យបាន។

ចប់ អភយូវរភាណវារៈ។

## ៤១. រាហុលវត្ថុ

CS vin.mv.01.41 | ភាគ ទី៦

**(៤១.)**

[១១៨] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅកាន់ចារិក ឯក្រុងកបិលវត្ថុ ត្រាច់ទៅតាមលំដាប់ៗហើយ ទ្រង់បានយាងទៅដល់ក្រុងកបិលវត្ថុនោះឯង។ តាមដំណាលក្នុងនិទាននោះថា ព្រះដ៏មានបុណ្យទ្រង់គង់ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលវត្ថុ ក្នុងដែនសក្កៈ។ លំដាប់នោះ ព្រះដ៏មានបុណ្យ ព្រះអង្គទ្រង់ស្បង់ ទ្រង់បាត្រចីវរ ហើយយាងចូលទៅកាន់ដំណាក់ព្រះបាទសុទ្ធោទនសក្យរាជ ក្នុងវេលាព្រឹក លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ។ គ្រានោះ ព្រះនាងទេវីជាមាតារាហុល បានពោលពាក្យនេះនឹងរាហុលកុមារថា ម្នាលរាហុល ព្រះសមណៈនេះ ជាបិតារបស់បាហើយ បាឯងចូរទៅសូមទ្រព្យមត៌ករបស់បិតាបាចុះ។ លំដាប់នោះ រាហុលកុមារក៏ចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះសមណៈ ម្លប់ (បុណ្យ) របស់ព្រះអង្គសុខស្រួលណាស់។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ក្រោកចាកពុទ្ធាសនៈ ហើយយាងចេញទៅ។ គ្រានោះ រាហុលកុមារ ក៏តាមព្រះដ៏មានព្រះភាគប្រកិតអំពីខាងក្រោយៗ ហើយក្រាបទូលថា បពិត្រព្រះសមណៈ សូមព្រះអង្គទ្រង់ប្រទានទ្រព្យមត៌កដល់ខ្ញុំ សូមព្រះអង្គ ទ្រង់ប្រទានទ្រព្យមត៌កដល់ខ្ញុំ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ហៅព្រះសារីបុត្រដ៏មានអាយុមក ហើយត្រាស់ថា ម្នាលសារីបុត្រ បើដូច្នោះ អ្នកចូរបំបួសរាហុលកុមារចុះ។ ព្រះសារីបុត្រទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណានឹងបំបួសរាហុលកុមារដោយវិធីដូចម្តេច។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានបុញ្ញសិរី ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាមណេរបព្វជ្ជាដោយត្រៃសរណគមន៍ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីបំបួសកុលបុត្រយ៉ាងនេះគឺ មុនដំបូងភិក្ខុត្រូវកោរសក់ និងពុកមាត់ឲ្យហើយ ឲ្យស្លៀកសំពត់កាសាយៈទាំងឡាយ រួចពាក់សំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ឲ្យសំពះបាទានៃភិក្ខុទាំងឡាយ ឲ្យអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយត្រូវប្រាប់កុលបុត្រនោះថា អ្នកចូរពោលយ៉ាងនេះ គឺត្រូវពោលថា ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីរលឹក ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីរលឹក ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីរលឹក ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីរលឹក ជាគំរប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់បីដងផង ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាមណេរបព្វជ្ជា ដោយត្រៃសរណគមន៍នេះ។ ព្រះសារីបុត្រដ៏មានអាយុ ក៏បំបួសរាហុលកុមារក្នុងខណៈនោះឯង។[94] លំដាប់នោះឯង ព្រះបាទសុទ្ធោទនសក្យរាជ ទ្រង់យាងចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ គង់ក្នុងទីដ៏សមគួរ លុះគង់ក្នុងទីដ៏សមគួរហើយ ព្រះបាទសុទ្ធោទនសក្យរាជ ក៏ទ្រង់មានព្រះរាជឱង្ការយ៉ាងនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាសូមពរម្យ៉ាងអំពីព្រះដ៏មានព្រះភាគ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា បពិត្រព្រះគោតម[95] ព្រះតថាគតទាំងឡាយមានពរកន្លងហើយ។ ព្រះបាទសុទ្ធោទនសក្យរាជ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពរណាដែលគួរ ពរណាដែលមិនមានទោស (ខ្ញុំសូមពរនោះ)។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា បពិត្រព្រះគោតម សូមព្រះអង្គមានព្រះបន្ទូលចំពោះពរនោះចុះ។ ព្រះបាទសុទ្ធោទនសក្យរាជក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលព្រះអង្គមក ទ្រង់ព្រះផ្នួសហើយ ខ្ញុំព្រះករុណាកើតទុក្ខមិនមែនតិចទេ កាលដែលនន្ទនិងរាហុលមកបួស ក៏ខ្ញុំព្រះករុណាកើតទុក្ខខ្លាំងណាស់ដូច្នោះដែរ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីស្រឡាញ់រាហុលកុមារ ដូចជាកូន លើសពន់ប្រមាណ (ហាក់ដូចជា) កាត់នូវសម្បុរស្បែកក្រៅ លុះកាត់សម្បុរស្បែកក្រៅហើយ ក៏កាត់នូវស្បែកក្នុង លុះកាត់ស្បែកក្នុងហើយ ក៏កាត់នូវសាច់ លុះកាត់សាច់ហើយ ក៏កាត់នូវសរសៃ លុះកាត់សរសៃហើយ ក៏កាត់នូវឆ្អឹង លុះកាត់ឆ្អឹងហើយ ក៏ចុចរហូតដល់ខួរក្នុងឆ្អឹង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំសូមអង្វរថា លោកម្ចាស់ទាំងឡាយកុំបំបួសកូនដែលមាតាបិតាមិនបានអនុញ្ញាតឡើយ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ព្រះបាទសុទ្ធោទនសក្យរាជឲ្យឃើញច្បាស់ ឲ្យសមាទាននូវកុសលធម៌ដោយប្រពៃ ឲ្យក្លៀវក្លាឡើងដោយល្អ និងឲ្យមានព្រះហឫទ័យរីករាយដោយធម្មីកថា។ ឯព្រះបាទសុទ្ធោទនសក្យរាជ លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យសមាទាននូវកុសលធម៌ដោយប្រពៃ ឲ្យក្លៀវក្លាឡើងដោយល្អ និងឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ (យាងវិលខាងស្តាំ) ហើយស្តេចចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ បុត្រដែលមាតានិងបិតាមិនបានអនុញ្ញាត ភិក្ខុមិនគប្បីបំបួសឡើយ បើភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។ លំដាប់ពីនោះមក ព្រះដ៏មានបុណ្យ ទ្រង់គង់ក្នុងក្រុងកបិលវត្ថុ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅកាន់ចារិកឯក្រុងសាវត្ថី ទ្រង់ត្រាស់ទៅកាន់ចារិកដោយលំដាប់ៗហើយ ទ្រង់បានដល់ទៅក្រុងសាវត្ថីនោះ។ តាមដំណាលក្នុងនិទាននោះថា ព្រះដ៏មានបុណ្យ ទ្រង់គង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី។

[១១៩] សម័យនោះឯង ត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្រដ៏មានអាយុ បញ្ជូនទារកទៅក្នុងសំណាក់ព្រះសារីបុត្រដ៏មានអាយុ ហើយនិយាយថា សូមព្រះថេរៈបំបួសទារកនេះឲ្យទាន។ គ្រានោះ ព្រះសារីបុត្រដ៏មានអាយុត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តថា ភិក្ខុមួយរូបមិនត្រូវឲ្យសាមណេរពីររូបបម្រើខ្លួន ឥឡូវរាហុលសាមណេរនេះ ជាសាមណេររបស់អញ តើអញនឹងត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ព្រះសារីបុត្រក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមួយរូបដែលឆ្លាសប្រតិពល ឲ្យសាមណេរពីររូបបម្រើបាន ម្យ៉ាងវិញទៀត បើភិក្ខុនោះអាចទូន្មានប្រៀនប្រដៅសាមណេរប៉ុន្មានរូបបាន ឲ្យសាមណេរមានទាំងប៉ុណ្ណោះបម្រើក៏បានដែរ។

## ៤២. សិក្ខាបទកថា

CS vin.mv.01.42 | ភាគ ទី៦

**(៤២.)**

[១២០] គ្រាតពីនោះមក សាមណេរទាំងឡាយបានត្រិះរិះសេចក្ដីនេះនឹងគ្នាថា សិក្ខាបទរបស់យើងទាំងឡាយមានប៉ុន្មានហ្ន៎ ម្យ៉ាងទៀត យើងទាំងឡាយគួរសិក្សាក្នុងវិន័យដូចម្ដេចខ្លះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំងឡាយ១០ ដល់សាមណេរទាំងឡាយ ម្យ៉ាងទៀត អនុញ្ញាតឲ្យសាមណេរទាំងឡាយសិក្សាក្នុងសិក្ខាបទទាំងឡាយ១០នោះគឺ ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង១ ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ១ ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ១ ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក១ ចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ ព្រោះផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ១ ចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស១ ចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌១ ចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ១ ចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ១ ចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាសនិងប្រាក់១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំង១០នេះ ដល់សាមណេរទាំងឡាយ ម្យ៉ាងទៀត អនុញ្ញាតឲ្យពួកសាមណេរសិក្សាក្នុងសិក្ខាបទទាំងឡាយ១០នេះ។

## ៤៣. ទណ្ឌកម្មវត្ថុ

CS vin.mv.01.43 | ភាគ ទី៦

**(រឿងទណ្ឌកម្ម (៤៣.))**

[១២១] សម័យនោះឯង សាមណេរទាំងឡាយមិនគោរព មិនកោតក្រែង មានការចិញ្ចឹមជីវិតមិនស្មើភាគគ្នាក្នុងភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសាមណេរ មិនសមបើមិនគោរព មិនកោតក្រែង មានការចិញ្ចឹមជីវិតមិនស្មើភាគគ្នា ក្នុងភិក្ខុទាំងឡាយ (ដូច្នេះ) សោះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើទណ្ឌកម្មដល់សាមណេរដែលប្រកបដោយអង្គទាំងឡាយ៥ គឺសាមណេរព្យាយាមដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ១ សាមណេរព្យាយាមដើម្បីមិនឲ្យជាប្រយោជន៍[96] ដល់ភិក្ខុទាំងឡាយ១ សាមណេរព្យាយាម ដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបាននូវលំនៅ១ សាមណេរជេរគម្រាមនូវភិក្ខុទាំងឡាយ១ សាមណេរញុំាងភិក្ខុទាំងឡាយឲ្យបែកចាកភិក្ខុទាំងឡាយ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើទណ្ឌកម្ម ដល់សាមណេរ ដែលប្រកបដោយអង្គទាំងឡាយ៥នេះ។ លំដាប់តពីនោះមក ភិក្ខុទាំងឡាយបានត្រិះរិះនូវសេចក្ដីនេះថា យើងទាំងឡាយគប្បីធ្វើទណ្ឌកម្មដូចម្ដេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាម (ថា អ្នកកុំចូលមកក្នុងទីនេះ)។ ក៏សម័យនោះឯង ពួកភិក្ខុធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាមដល់សាមណេរទាំងឡាយអស់ទាំងអារាមរបស់សង្ឃទាំងមូល។ សាមណេរទាំងឡាយ កាលបើចូលទៅកាន់អារាមមិនបាន ក៏ចៀសចេញទៅខ្លះ សឹកចេញទៅខ្លះ ទៅចូលក្នុងពួកតិរ្ថិយខ្លះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អារាមរបស់សង្ឃទាំងមូល ភិក្ខុមិនគប្បីធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាមឡើយ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ សាមណេរធ្លាប់នៅក្នុងទីណា ឬធ្លាប់ចូលទៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាមតែក្នុងទៅនោះ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយធ្វើនូវអាវរណកម្ម គឺកិរិយាហាមប្រាមចំពោះអាហារដែលបរិភោគតាមទ្វារមាត់ ដល់សាមណេរទាំងឡាយ។ មនុស្សទាំងឡាយ កាលធ្វើទឹកបបរខ្លះ សង្ឃភត្តខ្លះ ក៏និយាយពាក្យយ៉ាងនេះនឹងសាមណេរទាំងឡាយថា បពិត្រលោកដ៏ចំរើនលោកទាំងឡាយចូរមកឆាន់បបរចុះ បពិត្រលោកម្ចាស់ដ៏ចំរើន លោកទាំងឡាយចូរមកឆាន់ចង្ហាន់ចុះ។ សាមណេរទាំងឡាយក៏និយាយពាក្យយ៉ាងនេះថា ម្នាលអាវុសោ យើងទាំងឡាយឆាន់មិនបានទេ (ព្រោះ) ភិក្ខុទាំងឡាយ លោកធ្វើអាវរណកម្មហើយ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនសមបើធ្វើអាវរណកម្ម ហាមប្រាមចំពោះអាហារដែលបរិភោគតាមមុខទ្វារ ដល់សាមណេរ (ដូច្នេះ)សោះ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើនូវអាវរណកម្ម ហាមប្រាមចំពោះអាហារដែលបរិភោគតាមមុខទ្វារឡើយ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។

ចប់ រឿងទណ្ឌកម្ម។

## ៤៤. អនាបុច្ឆាវរណវត្ថុ

CS vin.mv.01.44 | ភាគ ទី៦

**(៤៤.)**

[១២២] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនបានប្រាប់ភិក្ខុទាំងឡាយជាឧបជ្ឈាយ៍ ក៏ធ្វើអាវរណកម្មដល់សាមណេរទាំងឡាយ។ ឧបជ្ឈាយ៍ទាំងឡាយស្វែងរក ដោយគិតថា ពួកសាមណេររបស់យើងទាំងឡាយម្ដេចក៏មិនឃើញដូច្នេះ។ ភិក្ខុទាំងឡាយនិយាយប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុធ្វើអាវរណកម្មហើយ។ ឧបជ្ឈាយ៍ទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើមិនប្រាប់យើង ហើយធ្វើអាវរណកម្ម ដល់ពួកសាមណេររបស់យើង (ដូច្នេះ)សោះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានបុណ្យ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) អ្នកទាំងឡាយមិនទាន់ប្រាប់ពួកឧបជ្ឈាយ៍ (ឲ្យដឹងជាមុនទេ) មិនត្រូវធ្វើអាវរណកម្មឡើយ។ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។

## ៤៥. អបលាឡនវត្ថុ

CS vin.mv.01.45 | ភាគ ទី៦

**(៤៥.)**

[១២៣] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រលោមយកពួកសាមណេររបស់ពួកភិក្ខុជាថេរៈ ព្រះថេរៈទាំងឡាយ ក៏បានសេចក្តីលំបាក ដោយកាន់យកឈើស្ទន់ និងទឹកលុបមុខដោយខ្លួនឯង។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីប្រលោមយកបរិសទ្យរបស់ភិក្ខុដទៃឡើយ។ ភិក្ខុណាប្រលោមយក ត្រូវអាបត្តិទុក្កដ[97] ។

## ៤៦. កណ្តកសាមណេរវត្ថុ

CS vin.mv.01.46 | ភាគ ទី៦

**(៤៦.)**

[១២៤] សម័យនោះឯង សាមណេរឈ្មោះកណ្តកៈ (ជាសិស្ស) របស់ព្រះឧបនន្ទសក្យដ៏មានអាយុ ប្រទុស្ត (សេពមេថុនធម្ម) នឹងភិក្ខុនីឈ្មោះកណ្តកី។ ភិក្ខុទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើសាមណេរមកប្រព្រឹត្តអនាចារ មានសភាពដូច្នេះសោះ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុញ៉ាំងសាមណេរដែលប្រកបដោយអង្គទាំងឡាយ១០ ឲ្យវិនាស គឺសាមណេរធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង (គឺសម្លាប់សត្វ)១ សាមណេរកាន់យកវត្ថុដែលគេមិនបានឲ្យ (ដោយកាយឬវាចា)១ សាមណេរប្រព្រឹត្តនូវធម៌មិនប្រសើរ (គឺសេពមេថុនធម្ម)១ សាមណេរពោលពាក្យកុហក១ សាមណេរផឹកទឹកស្រវឹង (គឺសុរានិងមេរ័យ)១ សាមណេរពោលតិះដៀលព្រះពុទ្ធ១ សាមណេរពោលតិះដៀលព្រះធម៌១ សាមណេរពោលតិះដៀលព្រះសង្ឃ១សាមណេរមានទិដ្ឋិខុស១ សាមណេរប្រទូស្តភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុញ៉ាំងសាមណេរ ដែលប្រកបដោយអង្គទាំងឡាយ១០នេះ ឲ្យវិនាស។

## ៤៧. បណ្ឌកវត្ថុ

CS vin.mv.01.47 | ភាគ ទី៦

**(៤៧.)**

[១២៥] សម័យនោះឯង មានមនុស្សខ្ទើយម្នាក់បួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ មនុស្សខ្ទើយនោះ ចូលទៅរកពួកភិក្ខុជាកំឡោះៗ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ ចូរមកប្រទូស្ត (សេពមេថុន) នឹងខ្ញុំចុះ។ ភិក្ខុទាំងឡាយក៏បណ្តេញដោយពាក្យថា នែអ្នកខ្ទើយ អ្នកឯងចូរអន្តរធានទៅ នែអ្នកខ្ទើយ អ្នកឯងចូរវិនាសទៅ យើងមិនត្រូវការនឹងអ្នកឯងទេ។ មនុស្សខ្ទើយនោះ លុះដល់ភិក្ខុទាំងឡាយបណ្តេញចេញហើយ ក៏ចូលទៅរកពួកសាមណេរធំៗ ដែលមានសរីរៈធាត់ៗទៀត ហើយនិយាយយ៉ាងនេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយមកប្រទូស្តនឹងខ្ញុំចុះ។ ពួកសាមណេរក៏បណ្តេញដោយពាក្យថា នែអ្នកខ្ទើយ អ្នកឯងចូរអន្តរធានទៅ នែអ្នកខ្ទើយ អ្នកឯងចូរវិនាសទៅ យើងមិនត្រូវការនឹងអ្នកឯងទេ។ មនុស្សខ្ទើយនោះ លុះសាមណេរទាំងឡាយបណ្តេញហើយ ក៏ចូលទៅរកពួកគង្វាលដំរី និងពួកគង្វាលសេះ ហើយនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អ្នកចូរមកប្រទូស្តនឹងខ្ញុំចុះ។ ពួកគង្វាលដំរី និងពួកគង្វាលសេះ ក៏ប្រទូស្តទៅ។ គង្វាលដំរី និងគង្វាលសេះទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រទាំងនេះជាមនុស្សខ្ទើយ បណ្តាសមណៈទាំងនេះ ប្រហែលជាសមណៈណា ដែលមិនខ្ទើយ មុខជាប្រទូស្តពួកខ្ទើយមិនលែងឡើយ បើដូច្នេះ ពួកសមណៈទាំងនេះ សុទ្ធតែប្រព្រឹត្តអព្រហ្មចរិយធម៌ (មេថុនធម្ម) គ្រប់គ្នាទាំងអស់មិនខាន។ ភិក្ខុទាំងឡាយ កាលបើបានឮពួកគង្វាលដំរី និងពួកគង្វាលសេះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបពួកភិក្ខុនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ខ្ទើយជាអនុបសម្បន្ន សង្ឃមិនគប្បីឲ្យឧបសម្បទឡើយ (បើ) ជាឧបសម្បទហើយ ត្រូវឲ្យវិនាសចេញ។

## ៤៨. ថេយ្យសំវាសកវត្ថុ

CS vin.mv.01.48 | ភាគ ទី៦

**(៤៨.)**

[១២៦] សម័យនោះឯង មានកុលបុត្រចាស់ម្នាក់ ជាបុគ្គលគ្មានញាតិសាលោហិត តែធ្លាប់ជាអ្នកមានសេចក្តីសុខដ៏ល្អិតល្អ។ ឯកុលបុត្រចាស់នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អញឯងជាសុខុមាលជាតិ តែមិនអាចនឹងបានភោគសម្បត្តិដែលខ្លួនមិនទាន់បានផង មិនអាចនឹងធ្វើភោគសម្បត្តិ ដែលខ្លួនបានហើយ ឲ្យរឹតតែចំរើនផង បើដូច្នេះ អញនឹងគប្បីចិញ្ចឹមជីវិតដោយឧបាយយ៉ាងនេះអេះ ទើបបានស្រួល មិនបាច់លំបាកផង។ លំដាប់តពីនោះមក កុលបុត្រចាស់ដែលគ្មានញាតិសាលោហិតនោះបានរំពឹងសេចក្តីនេះតទៅទៀតថា ពួកសមណៈ ជាសក្យបុត្រទាំងនេះ មានសីលជាសុខ មានសមាចារជាសុខ បានឆាន់នូវភោជនដ៏ល្អ ដេកលើដំណេកទាំងឡាយដែលហប់ មិនមានខ្យល់ បើដូច្នោះ មានតែអញត្រូវតាក់តែងបាត្រនិងចីវរ កោរសក់ និងពុកមាត់ ស្លៀកដណ្តប់នូវសំពត់កាសាយៈទាំងឡាយខ្លួនឯង ទៅកាន់អារាម ហើយនៅ

អាស្រ័យជាមួយនឹងភិក្ខុទាំងឡាយចុះ។ ទើបកុលបុត្រចាស់គ្មានញាតិសាលោហិតនោះ ក៏តាក់តែងបាត្រនិងចីវរ កោរសក់និងពុកមាត់ ស្លៀកដណ្តប់នូវសំពត់កាសាយៈទាំងឡាយខ្លួនឯង ទៅកាន់អារាម ហើយថ្វាយបង្គំភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយសួរយ៉ាងនេះថា ម្នាលអាវុសោ លោកបួសបានប៉ុន្មានវស្សាហើយ។ កុលបុត្រនោះត្រឡប់សួរថា ម្នាលអាវុសោ ពាក្យដែលថាបួសបានប៉ុន្មានវស្សានុ៎ះ តើដូចម្តេច។ ភិក្ខុទាំងឡាយសួរតទៅទៀតថា ម្នាលអាវុសោ ចុះលោកណាជាឧបជ្ឈាយ៍របស់លោក។ កុលបុត្រនោះក៏ត្រឡប់សួរបកមកទៀតថា ម្នាលអាវុសោ ពាក្យដែលហៅថាឧបជ្ឈាយ៍នុ៎ះ តើដូចម្តេច។ ភិក្ខុទាំងឡាយនិយាយពាក្យនេះនឹងព្រះឧបាលិដ៏មានអាយុថា ម្នាលអាវុសោឧបាលិ សូមនិមន្តលោកជម្រះសួរបព្វជិតនេះមើល។ ឯកុលបុត្រចាស់ដែលគ្មានញាតិសាលោហិតនោះ កាលបើត្រូវព្រះឧបាលិដ៏មានអាយុជម្រះសួរហើយ ក៏ប្រាប់នូវសេចក្តីនុ៎ះតាមត្រង់។ ព្រះឧបាលិដ៏មានអាយុ ដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាថេយ្យសំវាស (លួចសំវាស) ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាតិត្ថិយបក្កន្តកៈ (ចូលពួកតិរ្ថិយ) ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ។

## ៤៩. តិរច្ឆានគតវត្ថុ

CS vin.mv.01.49 | ភាគ ទី៦

**(៤៩.)**

[១២៧] សម័យនោះឯង នាគមួយរូបនឿយណាយ ខ្ពើមរអើមក្នុងកំណើតរបស់នាគ។ ឯនាគនោះ ក៏រំពឹងគិតដូច្នេះថា ដោយឧបាយដូចម្តេចអេះ ទើបអញនឹងបានរួចស្រឡះអំពីកំណើតនៃនាគផង ត្រឡប់បានជាអត្តភាពជាមនុស្សយ៉ាងឆាប់ផង។ គ្រាតមក នាគនោះរំពឹងគិតដូច្នេះថា មានតែពួកសមណៈ សក្យបុត្រទាំងនេះ ទើបលោកជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តប្រសើរ និយាយពាក្យស្មោះត្រង់ មានសីល មានកល្យាណធម៌ បើសិនជាអញបានបួសនឹងពួកសមណៈសក្យបុត្រ អញមុខជានឹងបានរួចស្រឡះអំពីកំណើតនាគផង មុខជានឹងត្រឡប់បានអត្តភាពជាមនុស្សយ៉ាងឆាប់ផង ដោយទំនងយ៉ាងនេះឯងមិនលែងឡើយ។ លំដាប់នោះ នាគនោះក៏ចូលទៅរកភិក្ខុទាំងឡាយដោយភេទជាមាណព ហើយសូមបព្វជ្ជា។ ភិក្ខុទាំងឡាយក៏ឲ្យបព្វជ្ជាឧបសម្បទានាគនោះ។ សម័យនោះឯង នាគនោះនៅអាស្រ័យក្នុងវិហារ នាទីបំផុត (ដែន) ជាមួយនឹងភិក្ខុមួយរូប។ ឯភិក្ខុនោះក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ទៅដើរចង្រ្កមក្នុងទីវាល។ កាលដែលភិក្ខុនោះចេញទៅហើយ នាគនោះក៏ដេកលក់ស្និទ្ធទៅ។ វិហារ (កុដិ)ទាំងមូល ក៏ពេញដោយពស់។ មានភ្នែនទាំងឡាយ លៀនចេញទៅតាមបង្អួច។ កាលដែលភិក្ខុនោះច្រានសន្ទះទ្វារដោយគិតថា អញនឹងចូលទៅកាន់វិហារ ក៏បានឃើញនូវវិហារទាំងមូល ពេញដោយពស់ និងភ្នែនលៀនចេញតាមបង្អួច លុះឃើញហើយ ក៏ខ្លាច ហើយធ្វើនូវសំឡេងដ៏ប្លែក។ ភិក្ខុទាំងឡាយស្ទុះចូលទៅ ហើយក៏និយាយពាក្យនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ ហេតុអ្វីក៏លោកធ្វើនូវសម្រែកដ៏ប្លែកដូច្នេះ។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ វិហារទាំងមូលនេះ ពេញដោយពស់ មានភ្នែនលៀនចេញទៅតាមបង្អួច។ គ្រានោះ នាគនោះភ្ញាក់ឡើងដោយសំឡេងនោះហើយ ក៏អង្គុយលើអាសនៈជារបស់ខ្លួន។ ភិក្ខុទាំងឡាយសួរថា ម្នាលអាវុសោ អ្នកឯងជាអ្វី។ នាគនោះឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំជានាគ។ ភិក្ខុទាំងនោះសួរទៀតថា ម្នាលអាវុសោ ចុះហេតុដូចម្តេចបានជាអ្នកឯងមកធ្វើយ៉ាងហ្នឹង។ នាគនោះក៏ឆ្លើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានបុណ្យឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់មានព្រះបន្ទូលដូច្នេះនឹងនាគនោះថា អ្នកឯងជាពួកនាគ មិនមានធម៌ដុះដាលឡើងក្នុងធម៌វិន័យនេះទេ ម្នាលនាគ អ្នកឯងចូរទៅវិញទៅ (តែ) អ្នកឯងចូររក្សានូវឧបោសថក្នុងថ្ងៃទី១៤ ថ្ងៃទី១៥ និងថ្ងៃទី៨នៃបក្ខ ក្នុងលំនៅរបស់ខ្លួននោះឯងចុះ កាលបើធ្វើដូច្នេះហើយ អ្នកឯងមុខជានឹងល្មោះចាកកំណើតនាគផង មុខជានឹងត្រឡប់បាននូវអត្តភាពជាមនុស្សយ៉ាងឆាប់រហ័សផង។ នាគនោះក៏គិតថា បានឮថា អញជាសត្វមានធម៌មិនលូតលាស់ឡើងក្នុងធម៌វិន័យនេះទេ រួចក៏មានទុក្ខតូចចិត្ត យំសម្រក់ទឹកភ្នែក ធ្វើនូវសំឡេងដ៏ប្លែក ហើយចៀសចេញទៅ។ ដំណពីនោះមក ព្រះដ៏មានព្រះភាគ ទ្រង់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បច្ច័យដែលនាំឲ្យនាគប្រែត្រឡប់ខ្លួនមកតាមប្រក្រតីវិញនេះ[98] មានពីរយ៉ាង គឺក្នុងកាលដែលនាគសេពមេថុនធម្មដោយនាងនាគមានជាតិស្មើគ្នា១ ក្នុងកាលដែលនាគដេកលក់ស្និទ្ធ១ ម្នាលភិក្ខុទាំងឡាយ បច្ច័យទាំងពីរនេះឯង ជាហេតុដែលនាំឲ្យនាគប្រែត្រឡប់ខ្លួនមកតាមប្រក្រតីវិញ។ ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆានជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ។

## ៥០. មាតុឃាតកវត្ថុ

CS vin.mv.01.50 | ភាគ ទី៦

**(៥០.)**

[១២៨] សម័យនោះឯង មាណពម្នាក់ផ្តាច់ជីវិតមាតា។ មាណពនោះកើតទុក្ខ អៀនអន់ ខ្ពើមរអើមនឹងកម្មដ៏លាមកនោះ។ គ្រាតមក មាណពនោះក៏មានគំនិតយ៉ាងនេះថា អញនឹងជីករំលើងបាបកម្មនេះចោលចេញ ដោយឧបាយដូចម្តេចហ្ន៎។ លំដាប់ពីនោះមកទៀត មាណពនោះ ត្រិះរិះដូច្នេះថា សមណៈ ជាសក្យបុត្រទាំងឡាយនេះ លោកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តប្រសើរ និយាយពាក្យទៀងត្រង់ មានសីល មានកល្យាណធម៌ បើសិនជាអញបានបួសក្នុងសំណាក់ពួកសមណៈសក្យបុត្រ អញមុខជានឹងជីករំលើងកម្មដ៏លាមកនេះបាន ដោយទំនងយ៉ាងនេះឯងមិនលែងឡើយ។ មាណពនោះ ក៏ចូលទៅរកភិក្ខុទាំងឡាយ ហើយសូមបព្វជ្ជាក្នុងគ្រានោះឯង។ ភិក្ខុទាំងឡាយនិយាយពាក្យនេះនឹងព្រះឧបាលិដ៏មានអាយុថា ម្នាលអាវុសោឧបាលិ ក្នុងកាលមុនមាននាគមកបួសក្នុងសំណាក់ពួកភិក្ខុ ដោយភេទជាមាណពម្តងទៅហើយ ម្នាលអាវុសោឧបាលិ យើងសូមរំលឹកលោក សូមឲ្យលោកជម្រះសួរមាណពនេះទៀត។ ឯមាណពនោះ កាលបើត្រូវព្រះឧបាលិដ៏មានអាយុជម្រះសួរទៅហើយ ក៏ប្រាប់រឿងរ៉ាវនុ៎ះតាមត្រង់។ ព្រះឧបាលិដ៏មានអាយុ ដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មនុស្សដែលសម្លាប់មាតា ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ ត្រូវឲ្យវិនាសចេញ។

## ៥១. បិតុឃាតកវត្ថុ

CS vin.mv.01.51 | ភាគ ទី៦

(៥១.)

[១២៩] សម័យនោះឯង មាណពម្នាក់ផ្តាច់បង់ជីវិតបិតា។ មាណពនោះកើតទុក្ខ អៀនអន់ ខ្ពើមរអើមនឹងបាបកម្មនោះ។ លំដាប់ពីនោះមក មាណពនោះមានគំនិតយ៉ាងនេះថា ដោយឧបាយដូចម្តេចអេះ ទើបអញនឹងជីករំលើងកម្មដ៏លាមកនេះចោលចេញបាន។ គ្រាតមកទៀត មាណពនោះ មានសេចក្តីត្រិះរិះដូច្នេះថា ពួកសមណៈ ជាសក្យបុត្រទាំងនេះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តប្រសើរ ពោលពាក្យទៀងត្រង់ មានសីល និងមានកល្យាណធម៌ បើសិនណាជាអញបានបួសក្នុងសំណាក់ពួកសមណៈសក្យបុត្រ អញមុខជានឹងជីករំលើងបាបកម្មនេះ ដោយទំនងយ៉ាងនេះបានមិនខានឡើយ។ មាណពនោះ ក៏ចូលទៅរកភិក្ខុទាំងឡាយ ហើយសូមបព្វជ្ជាក្នុងគ្រានោះឯង។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះនឹងព្រះឧបាលិដ៏មានអាយុថា ម្នាលអាវុសោឧបាលិ កាលពីមុនមាននាគមកបួសនឹងពួកភិក្ខុ ដោយភេទជាមាណពម្តងទៅហើយ ម្នាលអាវុសោឧបាលិ យើងសូមរំលឹកលោក សូមនិមន្តលោកទៅជម្រះសួរមាណពនេះទៀត។ ឯមាណពនោះ កាលបើត្រូវព្រះឧបាលិដ៏មានអាយុលោកជម្រះសួរទៅហើយ ក៏ប្រាប់រឿងនុ៎ះតាមត្រង់។ ព្រះឧបាលិដ៏មានអាយុក៏ដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មនុស្សដែលសម្លាប់បិតា ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ។

## ៥២. អរហន្តឃាតកវត្ថុ

CS vin.mv.01.52 | ភាគ ទី៦

(៥២.)

[១៣០] សម័យនោះឯង មានភិក្ខុទាំងឡាយច្រើនរូបចេញពីក្រុងសាកេត ដើរតាមផ្លូវឆ្ងាយទៅកាន់ក្រុងសាវត្ថី។ ដល់ពាក់កណ្តាលផ្លូវ ពួកចោរចេញមក ខ្លះឆក់ដណ្តើមពួកភិក្ខុ ខ្លះសម្លាប់ពួកភិក្ខុ។ រាជអមាត្យទាំងឡាយចេញពីក្រុងសាវត្ថីបានចាប់នូវចោរពួកខ្លះ។ ពួកចោរខ្លះរត់បាត់ទៅ។ ពួកចោរណាដែលរត់បាត់ទៅនោះ ក៏ទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ ពួកចោរណាដែលរាជអាមាត្យចាប់បានហើយនោះ គេក៏នាំចូលទៅនឹងសម្លាប់។ ពួកចោរដែលបួសហើយទាំងនោះ ក៏បានឃើញពួកចោរដែលគេនាំចូលទៅដើម្បីសម្លាប់នោះ លុះឃើញហើយ និយាយយ៉ាងនេះថា យើងទាំងឡាយលួចរត់រួចបានមកក៏ជាការស្រួល បើសិនណាជាយើងទាំងឡាយត្រូវចាប់ក្នុងថ្ងៃនោះ យើងទាំងឡាយមុខជានឹងត្រូវគេសម្លាប់យ៉ាងនោះឯង មិនលែងឡើយ។ ភិក្ខុទាំងឡាយ សួរយ៉ាងនេះថា ម្នាលអាវុសោ ចុះហេតុដូចម្តេច បានជាអ្នកទាំងឡាយធ្វើដូច្នោះ។ ពួកចោរដែលបួសហើយនោះ ក៏ប្រាប់នូវសេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ (ដែលចោរសម្លាប់ហើយ) នុ៎ះជាអរហន្ត ម្នាលភិក្ខុទាំងឡាយ មនុស្សដែលសម្លាប់អរហន្ត ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ។

## ៥៣. ភិក្ខុនីទូសកវត្ថុ

CS vin.mv.01.53 | ភាគ ទី៦

(៥៣.)

[១៣១] សម័យនោះឯង មានពួកភិក្ខុនីច្រើនរូបចេញពីក្រុងសាកេត ដើរទៅតាមផ្លូវឆ្ងាយទៅកាន់ក្រុងសាវត្ថី។ ដល់ពាក់កណ្តាលផ្លូវ ចោរទាំងឡាយក៏ចេញមក ពួកខ្លះឆក់ដណ្តើមភិក្ខុនីទាំងឡាយ ពួកខ្លះប្រទូស្ត (សេពមេថុនធម្ម) នឹងភិក្ខុនីទាំងឡាយ។ រាជអាមាត្យទាំងឡាយចេញពីក្រុងសាវត្ថីទៅ ចាប់បានពួកចោរខ្លះ។ ពួកចោរខ្លះរត់រួចទៅ។ ពួកចោរណាដែលរត់រួចទៅ ក៏ទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ។ ពួកចោរណាដែលរាជអាមាត្យចាប់បានហើយនោះ គេក៏នាំចូលទៅដើម្បីសម្លាប់។ ពួកចោរទាំងនោះដែលបួសហើយ ក៏បានឃើញពួកចោរដែលគេនាំចូលទៅដើម្បីសម្លាប់នោះ លុះឃើញហើយ ក៏និយាយពាក្យយ៉ាងនេះថា យើងទាំងឡាយបានរត់រួចមក ក៏ជាការស្រួលហើយ បើសិនណាជាយើងទាំងឡាយត្រូវគេចាប់ក្នុងថ្ងៃនោះ យើងត្រូវគេសម្លាប់ដោយទំនងនេះឯង មិនលែងឡើយ។ ភិក្ខុទាំងឡាយ សួរយ៉ាងនេះថា ម្នាលអាវុសោ ចុះហេតុដូចម្តេច បានជាអ្នកទាំងឡាយធ្វើដូច្នោះ។ ពួកចោរដែលបួសហើយនោះ ក៏ប្រាប់រឿងនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មនុស្សដែលទ្រូស្តភិក្ខុនី ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ។ ម្នាលភិក្ខុទាំងឡាយ មនុស្សដែលបំបែកសង្ឃជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ។ ម្នាលភិក្ខុទាំងឡាយ មនុស្សដែលធ្វើលោហិតុប្បាទ (ធ្វើព្រះលោហិតព្រះពុទ្ធឲ្យពូរពងឡើង) ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសហើយ។

## ៥៤. ឧភតោព្យញ្ជនកវត្ថុ

CS vin.mv.01.54 | ភាគ ទី៦

(៥៤.)

[១៣២] សម័យនោះឯង មានមនុស្សឧភតោព្យញ្ជនក (មនុស្សមានភេទពីរ) ម្នាក់ បួសក្នុងសំណាក់ពួកភិក្ខុ។ ឧភតោព្យញ្ជនកនោះធ្វើ (មេថុន) ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើនឹងខ្លួនខ្លះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ ឧភតោព្យញ្ជនក ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឲ្យវិនាសចេញ។

## ៥៥. អនុបជ្ឈាយកាទិវត្ថូនិ

CS vin.mv.01.55 | ភាគ ទី៦

**(៥៥.)**

[១៣៣] សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់សាមណេរដែលគ្មានឧបជ្ឈាយ៍។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សាមណេរដែលគ្មានឧបជ្ឈាយ៍ ភិក្ខុមិនគប្បីឲ្យឧបសម្បទាឡើយ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទា (ដល់សាមណេរ) ដោយមានសង្ឃជាឧបជ្ឈាយ៍។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីឲ្យឧបសម្បទាដោយមានសង្ឃជាឧបជ្ឈាយ៍ឡើយ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានគណៈ ជាឧបជ្ឈាយ៍។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីឲ្យឧបសម្បទាដោយមានគណៈជាឧបជ្ឈាយ៍ឡើយ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ គ្រានោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាមនុស្សខ្ទើយ។បេ។ ឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាមនុស្សលួចសំវាស។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាមនុស្សដែលចូលពួកតិរ្ថិយ។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាសត្វតិរច្ឆាន។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាមាតុឃាតកៈ (អ្នកសម្លាប់ម្តាយ)។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាបិតុឃាតកៈ (អ្នកសម្លាប់បិតា)។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាអរហន្តឃាតកៈ។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាភិក្ខុនីទូសកៈ (ទ្រុស្តភិក្ខុនី)។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាសង្ឃភេទកៈ។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាលោហិតុប្បាទកៈ។ ភិក្ខុទាំងឡាយឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាឧភតោព្យញ្ជនកៈ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាមនុស្សខ្ទើយ មិនគប្បីឲ្យឧបសម្បទា ដោយមានឧបជ្ឈាយ៍ជាថេយ្យសំវាសកៈ (អ្នកលួចសំវាស) មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាអ្នកចូលពួកតិរ្ថិយ មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាសត្វតិរច្ឆាន មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាមាតុឃាតកៈ មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាបិតុឃាតកៈ មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាអរហន្តឃាតកៈ មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាភិក្ខុនីទូសកៈ មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាសង្ឃភេទកៈ មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាលោហិតុប្បាទកៈ មិនគប្បីឲ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាឧភតោព្យញ្ជនកៈ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។

## ៥៦. អបត្តកាទិវត្ថុ

CS vin.mv.01.56 | ភាគ ទី៦

**(៥៦.)**

[១៣៤] សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់កុលបុត្រគ្មានបាត្រ។ ភិក្ខុទាំងនោះ ត្រាច់ទៅបិណ្ឌបាតនឹងដៃទាំងឡាយ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចពួកតិរ្ថិយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីឲ្យឧបសម្បទាដល់កុលបុត្រគ្មានបាត្រទេ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់កុលបុត្រគ្មានចីវរ។ ភិក្ខុទាំងនោះក៏អាក្រាតកាយ ត្រាច់ទៅបិណ្ឌបាត។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចពួកតិរ្ថិយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីឲ្យឧបសម្បទាដល់កុលបុត្រគ្មានចីវរ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់កុលបុត្រគ្មានទាំងបាត្រទាំងចីវរ។ ភិក្ខុទាំងនោះក៏អាក្រាត ត្រាច់ទៅបិណ្ឌបាតនឹងដៃទាំងឡាយ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចពួកតិរ្ថិយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីឲ្យឧបសម្បទាដល់កុលបុត្រគ្មានទាំងបាត្រទាំងចីវរ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់កុលបុត្រដែលមានបាត្រដែលខ្ចីគេ។ ម្ចាស់បាត្រទាំងឡាយនាំយកបាត្រត្រឡប់ទៅវិញ ក្នុងកាលដែលកុលបុត្រនោះបានឧបសម្បទាហើយ។ ពួកភិក្ខុទាំងនោះត្រាច់ទៅបិណ្ឌបាតនឹងដៃទាំងឡាយ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចពួកតិរ្ថិយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុញ្ញសិរី។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីឲ្យឧបសម្បទាដល់កុលបុត្រដែលខ្ចីបាត្រគេ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់កុលបុត្រដែលខ្ចីចីវរគេ។ ម្ចាស់ចីវរទាំងឡាយនាំយកចីវរត្រឡប់ទៅវិញ ក្នុងកាលដែលកុលបុត្រនោះបានឧបសម្បទាហើយ។ ពួភិក្ខុទាំងនោះត្រាច់ទៅបិណ្ឌបាតទាំងអាក្រាតកាយ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ប្រហែលគ្នានឹងពួកតិរ្ថិយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីឲ្យឧបសម្បទាដល់កុលបុត្រដែលខ្ចីចីវរគេឡើយ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់កុលបុត្រដែលខ្ចីទាំងបាត្រ និងចីវរគេ។ ពួកម្ចាស់គេក៏នាំយកបាត្រ និងចីវរត្រឡប់ទៅវិញក្នុងកាលដែលកុលបុត្រនោះបានឧបសម្បទាហើយ។ ពួកភិក្ខុទាំងនោះក៏អាក្រាតកាយ ត្រាច់ទៅបិណ្ឌបាតនឹងដៃទទេ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ប្រហែលគ្នានឹងពួកតិរ្ថិយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីឲ្យឧបសម្បទាដល់កុលបុត្រដែលខ្ចីបាត្រនិងចីវរគេឡើយ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។

ចប់ វារៈសំដែងអំពីបុគ្គល២០ចំពួកដែលសង្ឃមិនគប្បីឲ្យឧបសម្បទា។

៎

## ៥៧. នបព្វាជេតព្វទ្វត្តិំសវារោ

CS vin.mv.01.57 | ភាគ ទី៦

**(៥៧.)**

[១៣៥] ក៏សម័យនោះឯង ភិក្ខុទាំងឡាយបំបួសមនុស្សដាច់ដៃ។បេ។ បំបួសមនុស្សដាច់ជើង។ បំបួសមនុស្សដាច់ទាំងដៃទាំងជើង។ បំបួសមនុស្សដាច់ត្រចៀក។ បំបួសមនុស្សកំបុតច្រមុះ។ បំបួសមនុស្សកំបុតទាំងត្រចៀក ទាំងច្រមុះ។ បំបួសមនុស្សកំបុតម្រាមដៃ។ បំបួសមនុស្សកំបុតមេដៃ ឬមេជើង។ បំបួសមនុស្សដាច់សរសៃធំ។ បំបួសមនុស្សមានម្រាមដៃជាប់គ្នា។ បំបួសមនុស្សគម។ បំបួសមនុស្សតឿ។ បំបួសមនុស្សពកក។ បំបួសមនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម។[99] បំបួសមនុស្សដែលគេវាយដោយរំពាត់។[100] បំបួសមនុស្សដែលរាជការកត់ឈ្មោះទុក (រាជការព្យួរទោសទុក[101] )។ បំបួសមនុស្សមានជើងស្ទក់។ បំបួសមនុស្សមានរោគអាក្រក់។[102] បំបួសមនុស្សមានរូបទ្រុស្តបរិសទ្យ។[103] បំបួសមនុស្សដែលទើបនឹងខ្វាក់។[104] បំបួសមនុស្សក្ញែងដៃ ឬក្ញែងជើង។ បំបួសមនុស្សខ្ចក។ បំបួសមនុស្សស្លាប់កាយម្ខាង។ បំបួសមនុស្សខ្វិន។ បំបួសមនុស្សមានកំឡាំងថយព្រោះជរា។ បំបួសមនុស្សខ្វាក់ពីកំណើត។ បំបួសមនុស្សគ។ បំបួសមនុស្សថ្លង់។ បំបួសមនុស្សទាំងខ្វាក់ទាំងគ។ បំបួសមនុស្សទាំងខ្វាក់ ទាំងថ្លង់។ បំបួសមនុស្សទាំងគ ទាំងថ្លង់។ បំបួសមនុស្សទាំងខ្វាក់ទាំងគទាំងថ្លង់។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ហាមថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវ បំបួសមនុស្សកំបុតដៃ មិនត្រូវបំបួសមនុស្សកំបុតជើង មិនត្រូវបំបួសមនុស្សកំបុតទាំងដៃ ទាំងជើង មិនត្រូវបំបួសមនុស្សកំបុតត្រចៀក មិនត្រូវបំបួសមនុស្សកំបុតច្រមុះ មិនត្រូវបំបួសមនុស្សកំបុតទាំងត្រចៀក ទាំងច្រមុះ មិនត្រូវបំបួសមនុស្សកំបុតម្រាមដៃ មិនត្រូវបំបួសមនុស្សកំបុតមេដៃ ឬមេជើង មិនត្រូវបំបួសមនុស្សដាច់សរសៃធំ មិនត្រូវបំបួសមនុស្សមានម្រាមដៃជាប់គ្នា មិនត្រូវបំបួសមនុស្សគម មិនត្រូវបំបួសមនុស្សតឿ មិនត្រូវបំបួសមនុស្សពកក មិនត្រូវបំបួសមនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម។ មិនត្រូវបំបួសមនុស្សដែលគេវាយដោយរំពាត់ មិនត្រូវបំបួសមនុស្សដែលរាជការកត់ឈ្មោះទុក (ព្យួរទោសទុក) មិនត្រូវបំបួសមនុស្សជើងស្ទក់ មិនត្រូវបំបួសមនុស្សមានរោគអាក្រក់ មិនត្រូវបំបួសមនុស្សទ្រុស្តបរិសទ្យ មិនត្រូវបំបួសមនុស្សទើបនឹងខ្វាក់ មិនត្រូវបំបួសមនុស្សក្ញែងដៃ ឬក្ញែងជើង មិនត្រូវបំបួសមនុស្សខ្ចក មិនត្រូវបំបួសមនុស្សស្លាប់កាយម្ខាង មិនត្រូវបំបួសមនុស្សខ្វិន មិនត្រូវបំបួសមនុស្សមានកម្លាំងថយព្រោះជរា មិនត្រូវបំបួសមនុស្សខ្វាក់ពីកំណើត មិនត្រូវបំបួសមនុស្សគ មិនត្រូវបំបួសមនុស្សថ្លង់ មិនត្រូវបំបួសមនុស្សទាំងខ្វាក់ទាំងគ មិនត្រូវបំបួសមនុស្សទាំងខ្វាក់ ទាំងថ្លង់ មិនត្រូវបំបួសមនុស្សទាំងគ ទាំងថ្លង់ មិនត្រូវបំបួសមនុស្សទាំងខ្វាក់ទាំងគទាំងថ្លង់ ភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ។

ចប់ វារៈនិយាយពីបុគ្គលសាមសិបពីរចំពូកដែលភិក្ខុមិនត្រូវបំបួស។

ចប់ ទាយជ្ជភាណវារៈទី៩។

## ៥៨. អលជ្ជីនិស្សយវត្ថុនិ

CS vin.mv.01.58 | ភាគ ទី៦

**(៥៨.)**

[១៣៦] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យនិស្ស័យដល់អលជ្ជីភិក្ខុទាំងឡាយ (ភិក្ខុដែលឥតខ្មាសបាប)។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនិស្ស័យដល់អលជ្ជីភិក្ខុទាំងឡាយទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ។ សម័យនោះ ភិក្ខុទាំងឡាយនៅអាស្រ័យ (កាន់យកនិស្ស័យ) នឹងអលជ្ជីភិក្ខុទាំងឡាយ។ មិនយូរប៉ុន្មាន ភិក្ខុទាំងឡាយនោះក៏ទៅជាភិក្ខុអលជ្ជី ជាភិក្ខុលាមកដែរ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនៅអាស្រ័យនឹងអលជ្ជីភិក្ខុទាំងឡាយទេ ភិក្ខុណានៅ ត្រូវអាបត្តិទុក្កដ។ លំដាប់នោះឯង ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយថា ភិក្ខុមិនត្រូវឲ្យនិស្ស័យដល់ពួកភិក្ខុអលជ្ជី មិនត្រូវនៅអាស្រ័យនឹងពួកភិក្ខុជាអលជ្ជីដូច្នេះ យើងទាំងឡាយគប្បីស្គាល់ភិក្ខុជាលជ្ជី ឬជាអលជ្ជីដូចម្តេចបាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបង្អង់ចាំ ដោយគិតថា អញនឹងដឹង (ភិក្ខុនេះ) ជាសភាគភិក្ខុ (ភិក្ខុមានធម៌ល្អត្រូវគ្នា) អស់៤ថ្ងៃ ឬ៥ថ្ងៃសិនបាន។

## ៥៩. គមិកាទិនិស្សយវត្ថុនិ

CS vin.mv.01.59 | ភាគ ទី៦

**(៥៩.)**

[១៣៧] ក៏សម័យនោះឯង ភិក្ខុមួយរូបដើរផ្លូវឆ្ងាយក្នុងជនបទ នាដែនកោសល។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគបញ្ញត្តហើយថា ភិក្ខុមិនត្រូវនៅដោយគ្មាននិស្ស័យទេ ឯអាត្មាអញសោត មានកិច្ចដោយនិស្ស័យ (ត្រូវកាន់យកនិស្ស័យ) ហើយជាមនុស្សដើរផ្លូវឆ្ងាយ អញត្រូវប្រតិបត្តិដូចម្តេច។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកដើរផ្លូវឆ្ងាយ ដែលមិនទាន់បាននិស្ស័យ ឲ្យនៅដោយគ្មាននិស្ស័យបាន។

[១៣៨] សម័យនោះឯង ភិក្ខុពីររូបដើរទៅកាន់ផ្លូវឆ្ងាយក្នុងជនបទ នាដែនកោសល។ ភិក្ខុទាំងឡាយនោះដើរចូលទៅកាន់អាវាស១។ បណ្តាភិក្ខុទាំងនោះ ភិក្ខុ១អង្គឈឺ។ ទើបភិក្ខុឈឺនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគបញ្ញត្តហើយថា ភិក្ខុមិនត្រូវនៅដោយគ្មាននិស្ស័យទេ ក៏អាត្មាអញ មានកិច្ចដោយនិស្ស័យ ហើយមានជម្ងឺផង អញត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏

មានព្រះភាគ។ ព្រះអង្គអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺ ដែលមិនទាន់បាននិស្ស័យ ឲ្យនៅដោយគ្មាននិស្ស័យបាន។ ទើបភិក្ខុអ្នកបម្រើជម្ងឺ របស់ភិក្ខុឈឺនោះ មានសេចក្ដីត្រិះរិះថា ព្រះដ៏មានព្រះភាគបញ្ញត្តហើយថា ភិក្ខុមិនត្រូវនៅដោយគ្មាននិស្ស័យទេ ឯអាត្មាអញមានកិច្ចដោយនិស្ស័យ ភិក្ខុនេះសោត ក៏នៅឈឺ អញត្រូវប្រតិបត្តិដូចម្ដេចហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកបម្រើជម្ងឺ ដែលមិនទាន់បាននិស្ស័យ បើភិក្ខុឈឺសុំ (ឲ្យនៅកំដរ ត្រូវនៅដោយគ្មាននិស្ស័យបាន។ សម័យនោះឯង ភិក្ខុ១រូបនៅក្នុងព្រៃ។ ភិក្ខុនោះបានសេចក្ដីសប្បាយក្នុងសេនាសនៈនោះ ទើបភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគបញ្ញត្តហើយថា ភិក្ខុមិនត្រូវនៅដោយគ្មាននិស្ស័យទេ ឯអាត្មាអញសោត មានកិច្ចដោយនិស្ស័យ ឥឡូវនៅក្នុងព្រៃ ម្យ៉ាងទៀត អញក៏បានសេចក្ដីសប្បាយក្នុងសេនាសនៈនេះ អញត្រូវប្រតិបត្តិដូចម្ដេចហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលនៅក្នុងព្រៃ កាលបើកំណត់ដឹងនូវធម៌ជាគ្រឿងនៅសប្បាយ បើមិនទាន់បាននិស្ស័យទេ ត្រូវនៅដោយគ្មាននិស្ស័យបាន ដោយគិតថា ភិក្ខុអ្នកឲ្យនិស្ស័យដ៏សមគួរនឹងមកក្នុងកាលណា អញនឹងនៅអាស្រ័យ (កាន់យកនិស្ស័យ) នឹងភិក្ខុនោះក្នុងកាលនោះ។

## ៦០. គោត្តេន អនុស្សាវនានុជាននា

CS vin.mv.01.60 | ភាគ ទី៦

**(៦០.)**

[១៣៩] ក៏សម័យនោះឯង មានឧបសម្បទាបេក្ខៈ[105] របស់ព្រះមហាកស្សបដ៏មានអាយុ។ ទើបព្រះមហាកស្សបដ៏មានអាយុបញ្ជូនទូតទៅក្នុងសំណាក់ព្រះអានន្ទដ៏មានអាយុថា ចូរអានន្ទមកសូត្រអនុស្សាវនា[106] ចំពោះឧបសម្បទាបេក្ខៈនេះ។ ព្រះអានន្ទដ៏មានអាយុបាននិយាយយ៉ាងនេះថា ខ្ញុំករុណាមិនអាចកាន់យក (ហៅ) ឈ្មោះព្រះថេរៈទេ (ព្រោះ) ព្រះថេរៈជាគ្រូរបស់ខ្ញុំព្រះករុណា។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសូត្រអនុស្សាវនា ដោយគោត្តនាមក៏បាន។

## ៦១. ទ្វេឧបសម្បទាបេក្ខាទិវត្ថុ

CS vin.mv.01.61 | ភាគ ទី៦

**(៦១.)**

[១៤០] ក៏សម័យនោះឯង មានឧបសម្បទាបេក្ខៈពីររូបរបស់ព្រះមហាកស្សបដ៏មានអាយុ។ អ្នកទាំងនោះប្រកែកគ្នាថា ខ្ញុំនឹង (បំពេញ) ឧបសម្បទាមុន ខ្ញុំនឹង (បំពេញ) ឧបសម្បទាមុន។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសូត្រអនុស្សាវនាតែម្ដង ចំពោះឧបសម្បទាបេក្ខៈ ពីរនាក់បាន[107] ។ សម័យនោះឯង មានពួកឧបសម្បទាបេក្ខៈរបស់ព្រះថេរៈច្រើនអង្គ។ ពួកឧបសម្បទាបេក្ខៈទាំងនោះប្រកែកគ្នាថា ខ្ញុំនឹង(បំពេញ)ឧបសម្បទាមុន ខ្ញុំនឹង(បំពេញ)ឧបសម្បទាមុន។ ព្រះថេរៈទាំងឡាយបាននិយាយយ៉ាងនេះថា នែអាវុសោ ណ្ហើយ យើងនឹងសូត្រអ្នកទាំងឡាយក្នុងអនុស្សាវនាជាមួយគ្នា។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនោះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសូត្រអនុស្សាវនាជាមួយគ្នា ចំពោះឧបសម្បទាបេក្ខៈពីរ ឬបីរូបបាន[108] តែការសូត្រអនុស្សាវនានោះ បានតែដោយឧបជ្ឈាយ៍ជាមួយគ្នា ឧបជ្ឈាយ៍ផ្សេងគ្នាមិនបានឡើយ។

## ៦២. គព្ភវីសូបសម្បទានុជាននា

CS vin.mv.01.62 | ភាគ ទី៦

**(៦២.)**

[១៤១] សម័យនោះឯង កុមារកស្សបដ៏មានអាយុមានឆ្នាំ២០ ដោយរាប់យកឆ្នាំតាំងពីនៅក្នុងគភ៌ផងបានឧបសម្បទា។ ទើបកុមារកស្សបដ៏មានអាយុ មានសេចក្ដីត្រិះរិះថា ព្រះដ៏មានព្រះភាគបញ្ញត្តហើយថា ភិក្ខុមិនត្រូវឲ្យឧបសម្បទាដល់បុគ្គលមានអាយុមិនគ្រប់២០ឆ្នាំ ដូច្នេះ ក៏អាត្មាអញមានឆ្នាំ២០ រាប់ទាំងឆ្នាំដែលនៅក្នុងគភ៌ផងបានឧបសម្បទា អាត្មាអញជាឧបសម្បន្ន (ជាភិក្ខុ) ឬមិនបានជាឧបសម្បន្នទេ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចិត្តជាបឋមណា កើតឡើងហើយ វិញ្ញាណជាបឋមណា កើតប្រាកដហើយក្នុងផ្ទៃនៃមាតា កំណើតរបស់សត្វនោះឯង ត្រូវរាប់អំពីបឋមចិត្តនោះ ឬបឋមវិញ្ញាណនោះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យឧបសម្បទា ដល់កុលបុត្រមានឆ្នាំ២០រាប់ទាំងឆ្នាំដែលនៅក្នុងផ្ទៃ។

## ៦៣. ឧបសម្បទាវិធិ

CS vin.mv.01.63 | ភាគ ទី៦

**(៦៣.)**

[១៤២] ក៏សម័យនោះឯង ពួកភិក្ខុដែលបានឧបសម្បទា មានរោគឃ្លង់ខ្លះ រោគពកខ្លះ រោគស្រែងខ្លះ រោគរីងរៃខ្លះ រោគឆ្កួតជ្រូកខ្លះ ក៏កើតប្រាកដឡើង។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាលឲ្យឧបសម្បទា សួរអន្តរាយិកធម៌១៣យ៉ាងសិន។ ម្នាលភិក្ខុទាំងឡាយ ក៏ឧបសម្បទាបេក្ខៈនោះ ភិក្ខុត្រូវសួរយ៉ាងនេះថា អ្នកមានអាពាធ

ទាំងឡាយមានសភាពយ៉ាងនេះឬទេ គឺរោគឃ្លង់ រោគពក រោគស្រែង រោគរីងរៃ រោគឆ្កួតជ្រូក អ្នកឯងជាមនុស្សឬ ជាប្រុសឬ ជាអ្នកជាឬ ជាអ្នកមិនចំពាក់បំណុលគេឬ មិនមែនជារាជអាមាត្យ (អ្នកធ្វើរាជការ)ទេឬ អ្នកឯង មាតាបិតាបានអនុញ្ញាតហើយឬ អ្នកឯងមានឆ្នាំពេញ២០ហើយឬ អ្នកឯងមានបាត្រចីវរគ្រប់គ្រាន់ហើយឬ អ្នកឯងឈ្មោះអ្វី ឧបជ្ឈាយ៍អ្នកឯងឈ្មោះអ្វី។ សម័យនោះ ភិក្ខុទាំងឡាយសួរអន្តរាយិកធម៌ទាំងឡាយនឹងពួកឧបសម្បទាបេក្ខៈ ដែលខ្លួនមិនទាន់បានប្រៀនប្រដៅ។ ឧបសម្បទាបេក្ខៈទាំងឡាយក៏រឹងខ្លួន អៀនអន់មិនអាចឆ្លើយបាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រៀនប្រដៅ (បង្ហាត់) ជាមុនហើយ សឹមសួរអន្តរាយិកធម៌ទាំងឡាយជាខាងក្រោយ។ ភិក្ខុទាំងឡាយប្រៀនប្រដៅក្នុងកណ្ដាលសង្ឃនោះឯង។ ឧបសម្បទាបេក្ខៈទាំងឡាយក៏នៅរឹងខ្លួនអៀនអន់យ៉ាងនោះដដែល មិនអាចនឹងឆ្លើយបាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រៀនប្រដៅក្នុងទីដ៏សមគួរហើយ សឹមសួរអន្តរាយិកធម៌ទាំងឡាយក្នុងកណ្ដាលសង្ឃ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯឧបសម្បទាបេក្ខៈនោះ ភិក្ខុត្រូវប្រៀនប្រដៅយ៉ាងនេះ។ ភិក្ខុត្រូវឲ្យឧបសម្បទាបេក្ខៈនោះកាន់យកឧបជ្ឈាយ៍ជាមុន។ លុះភិក្ខុឲ្យឧបសម្បទាបេក្ខៈ កាន់យកឧបជ្ឈាយ៍ហើយ ត្រូវប្រាប់បាត្រនិងចីវរថា នេះបាត្ររបស់អ្នក នេះសង្ឃាដិ នេះឧត្តរាសង្គៈ នេះអន្តរវាសកៈ អ្នកចូរទៅឈរនៅក្នុងឱកាសឯណោះចុះ។ ភិក្ខុទាំងឡាយល្ងង់ មិនឆ្លាស ហើយប្រៀនប្រដៅឧបសម្បទាបេក្ខៈទាំងឡាយ ដែលភិក្ខុទាំងឡាយប្រៀនប្រដៅមិនល្អ នៅតែរឹងខ្លួនអៀនអន់ មិនអាចនឹងឆ្លើយបាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុល្ងង់ មិនឆ្លាស មិនត្រូវប្រៀនប្រដៅឧបសម្បទាបេក្ខៈទេ ភិក្ខុណាប្រៀនប្រដៅ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យតែភិក្ខុដែលឆ្លាសប្រតិពល ប្រៀនប្រដៅឧបសម្បទាបេក្ខៈបាន។ ភិក្ខុទាំងឡាយដែលសង្ឃមិនបានសន្មតហើយប្រៀនប្រដៅឧបសម្បទាបេក្ខៈ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃមិនបានសន្មត មិនត្រូវប្រៀនប្រដៅឧបសម្បទាបេក្ខៈឡើយ ភិក្ខុណាប្រៀនប្រដៅ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យតែភិក្ខុដែលមានការសន្មតិប្រៀនប្រដៅ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវសន្មតយ៉ាងនេះ។ ត្រូវខ្លួនឯងសន្មតខ្លួនក៏បាន ភិក្ខុដទៃសន្មតភិក្ខុដទៃក៏បាន។ ក៏ឯខ្លួនឯងត្រូវសន្មតខ្លួនដូចម្ដេច។ គឺភិក្ខុដែលឆ្លាសប្រតិពល ត្រូវឲ្យសង្ឃយល់ថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលមានឈ្មោះនេះ[109] ជាឧបសម្បទាបេក្ខៈរបស់លោកដ៏មានអាយុឈ្មោះនេះ។[110] បើកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគួរប្រៀនប្រដៅឧបសម្បទាបេក្ខៈឈ្មោះនេះ។ ត្រូវខ្លួនឯងសន្មតខ្លួនយ៉ាងនេះ។ ភិក្ខុដទៃត្រូវសន្មតភិក្ខុដទៃដូចម្ដេច។ គឺភិក្ខុឆ្លាសប្រតិពលត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ បើកម្មមានកាលគួរដល់សង្ឃហើយ គួរភិក្ខុមានឈ្មោះនេះ ប្រៀនប្រដៅឧបសម្បទាបេក្ខៈឈ្មោះនេះ។ ភិក្ខុដទៃសន្មតភិក្ខុដទៃយ៉ាងនេះ។ ត្រូវភិក្ខុដែលមានការសន្មតិនោះចូលទៅរកឧបសម្បទាបេក្ខៈហើយ និយាយយ៉ាងនេះថា នែអ្នកមានឈ្មោះនេះ អ្នកចាំស្ដាប់ កាលនេះជាកាលពិត កាលមែនរបស់អ្នកហើយ ហេតុឯណាមានកាលបើភិក្ខុសួរហេតុនោះក្នុងកណ្ដាលសង្ឃ (បើ) ហេតុមាន ត្រូវអ្នកនិយាយថាមាន ហេតុគ្មាន ត្រូវអ្នកនិយាយថាគ្មាន អ្នកកុំរឹងខ្លួនឡើយ កុំអៀនខ្មាសឡើយ ភិក្ខុទាំងឡាយនឹងសួរអ្នកយ៉ាងនេះថា អាពាធទាំងឡាយមានសភាពយ៉ាងនេះ គឺឃ្លង់ពក ស្រែង រីងរៃ ឆ្កួតជ្រូក អ្នកឯងមានឬទេ អ្នកឯងជាមនុស្សឬ ជាប្រុសឬ ជាអ្នកជាឬ ជាអ្នកមិនចំពាក់បំណុលគេឬ មិនមែនជារាជអាមាត្យទេឬ អ្នកឯងមាតាបិតាបានអនុញ្ញាតហើយឬ អ្នកឯងមានឆ្នាំពេញ២០ហើយឬ អ្នកឯងមានបាត្រចីវរបរិបូណ៌ហើយឬ អ្នកឯងឈ្មោះអ្វី ឧបជ្ឈាយ៍របស់អ្នកឯងឈ្មោះអ្វី។ មានពាក្យសួរថា ឧបសម្បទាបេក្ខៈ និងអាចារ្យមកជាមួយគ្នា[111] ឬអ្វី។ វិសជ្ជនាថា មិនត្រូវមកជាមួយគ្នាទេ។ ត្រូវអាចារ្យអ្នកប្រៀនប្រដៅមកមុនហើយ ឲ្យសង្ឃជ្រាបថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលមានឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ។ ឧបសម្បទាបេក្ខៈនោះ ខ្ញុំប្រៀនប្រដៅរួចហើយ។ បើកម្មមានកាលគួរដល់សង្ឃហើយ ឧបសម្បទាបេក្ខៈឈ្មោះនេះគួរមក។ ត្រូវអាចារ្យអ្នកប្រៀនប្រដៅហៅឧបសម្បទាបេក្ខៈនោះថា អ្នកចូរមកដូច្នេះ។ ត្រូវអាចារ្យអ្នកប្រៀនប្រដៅឲ្យឧបសម្បទាបេក្ខៈនោះ ធ្វើឧត្តរាសង្គៀងស្មាម្ខាងហើយ ឲ្យថ្វាយបង្គំបាទាភិក្ខុទាំងឡាយហើយ ឲ្យអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយឲ្យសូមឧបសម្បទាថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន ខ្ញុំសូមឧបសម្បទានឹងសង្ឃ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃអាស្រ័យសេចក្ដីអនុគ្រោះហើយស្រោចស្រង់ខ្ញុំផង បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន ខ្ញុំសូមឧបសម្បទានឹងសង្ឃអស់វារៈជាគំរប់ពីរដងផង បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃអាស្រ័យសេចក្ដីអនុគ្រោះហើយ ស្រោចស្រង់ខ្ញុំផង។ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន ខ្ញុំសូមឧបសម្បទានឹងសង្ឃអស់វារៈជាគំរប់បីដងផង បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃអាស្រ័យសេចក្ដីអនុគ្រោះហើយ ស្រោចស្រង់ខ្ញុំផង។ ភិក្ខុដែលឆ្លាសប្រតិពលត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលនេះ ឈ្មោះនេះជាឧបសម្បទាបេក្ខៈរបស់លោកដ៏មានអាយុឈ្មោះនេះ។ បើកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគួរសួរអន្តរាយិកធម៌ទាំងឡាយ នឹងឧបសម្បទាបេក្ខៈឈ្មោះនេះ។ នែអ្នកមានឈ្មោះនេះ អ្នកចាំស្ដាប់ កាលនេះជាកាលពិត កាលមែនរបស់អ្នកហើយ ហេតុឯណាកើតហើយ ខ្ញុំសូមសួរហេតុនោះ ហេតុមាន អ្នកត្រូវនិយាយថាមាន ហេតុមិនមាន អ្នកត្រូវនិយាយថាមិនមាន អាពាធទាំងឡាយមានសភាពយ៉ាងនេះ គឺឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូក អ្នកឯងមានឬទេ អ្នកឯងជាមនុស្សឬ ជាប្រុសឬ ជាអ្នកជាឬ មិនចំពាក់បំណុលគេទេឬ មិនមែនជារាជអាមាត្យទេឬ អ្នកឯងមាតាបិតាបានអនុញ្ញាតហើយឬ អ្នកឯងមានឆ្នាំ២០បរិបូណ៌ហើយឬ អ្នកឯងមានបាត្រចីវរបរិបូណ៌ហើយឬ អ្នកឈ្មោះអ្វី ឧបជ្ឈាយ៍របស់អ្នកឈ្មោះអ្វី។ ភិក្ខុដែលឆ្លាសប្រតិពលត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលនេះ ឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ។ ឧបសម្បទាបេក្ខៈនោះ មានបាត្រនិតចីវរបរិបូណ៌ហើយ។ ឥឡូវឧបសម្បទាបេក្ខៈឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ ដោយមានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍។ បើកម្មមានកាលគួរដល់សង្ឃហើយ សូមសង្ឃឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខៈឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ នេះជាញត្តិ។ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលនេះ ឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ។ ឧបសម្បទាបេក្ខៈមានបាត្រចីវរបរិបូណ៌ហើយ។ ឥឡូវឧបសម្បទាបេក្ខៈ ឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឥឡូវសង្ឃឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខៈ ឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឧបសម្បទារបស់ឧបសម្បទាបេក្ខៈឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំសូត្រសេចក្ដីនេះអស់វារៈជាគំរប់ពីរដងផង។ បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលនេះ ឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ។ ឧបសម្បទាបេក្ខៈនោះ មានបាត្រនិងចីវរបរិបូណ៌ហើយ។ ឥឡូវឧបសម្បទាបេក្ខៈឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឥឡូវសង្ឃឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខៈ ឈ្មោះនេះ

ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឧបសម្បទារបស់ឧបសម្បទាបេក្ខៈឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំសូមសូត្រសេចក្តីនេះអស់វារៈជាគំរប់បីដងផង។ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បុគ្គលនេះ ឈ្មោះនេះ ជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ហើយ។ ឧបសម្បទាបេក្ខៈនោះមានបាត្រនិងចីវរបរិបូណ៌ហើយ។ ឥឡូវឧបសម្បទាបេក្ខៈ ឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឥឡូវសង្ឃឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខៈ ឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍។ ឧបសម្បទារបស់ឧបសម្បទាបេក្ខៈឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះនិយាយឡើង។ សង្ឃបានឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខៈឈ្មោះនេះ ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ហើយ។ ការឲ្យឧបសម្បទានេះគាប់ចិត្តដល់សង្ឃ ហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ ឧបសម្បទាកម្ម។

## ៦៤. ចត្តារោ និស្សយា

CS vin.mv.01.64 | ភាគ ទី៦

### (និស្ស័យ ៤ (៦៤.))

[១៤៣] ក្នុងខណៈឧបសម្បទាហើយភ្លាមៗនោះឯង ភិក្ខុត្រូវវាស់ឆាយា[112] (ស្រមោល) ត្រូវប្រាប់រដូវ[113] ត្រូវប្រាប់ចំណែកថ្ងៃ[114] ត្រូវប្រាប់សង្គីតិ[115] ត្រូវប្រាប់និស្ស័យ៤ថា បព្វជ្ជាអាស្រ័យភោជនជាពំនូត ដែលភិក្ខុត្រូវបានមកដោយកំឡាំងកំភួនជើង អ្នកត្រូវធ្វើសេចក្តីប្រឹងប្រែងក្នុងភោជននោះអស់មួយជីវិត។ អតិរេកលាភ (៧យ៉ាង) គឺភត្តដែលទាយកថ្វាយចំពោះសង្ឃទាំងអស់១ ភត្តដែលទាយកឲ្យដល់ភិក្ខុ២-៣រូប តាមសង្ឃសំដែងឲ្យ១ ភត្តដែលទាយកនិមន្តទៅប្រគេន១ ភត្តដែលទាយកឲ្យដល់ភិក្ខុដោយស្លាក គឺសរសេរឈ្មោះភិក្ខុ ឬទាយកហើយចាប់១ ភត្តដែលទាយកឲ្យតែមួយថ្ងៃក្នុងបក្ខៗ (ខាងខ្នើត ឬរនោច)១ ភត្តដែលទាយកឲ្យក្នុងថ្ងៃឧបោសថ១ ភត្តដែលទាយកឲ្យក្នុងថ្ងៃមួយកើត ឬមួយរោច១ (បព្វជិតត្រេកអរក្នុងអតិរេកលាភនោះបាន)។ បព្វជ្ជាអាស្រ័យនូវចីវរបង្សុកូល[116] អ្នកត្រូវធ្វើការឧស្សាហ៍ក្នុងសំពត់បង្សុកូលនោះអស់មួយជីវិត។ អតិរេកលាភ (៦យ៉ាង) គឺសំពត់ធ្វើពីសំបកឈើ១ សំពត់ធ្វើពីកប្បាស១ សំពត់ធ្វើពីសូត្រ១ សំពត់ធ្វើពីរោមសត្វ១ សំពត់ធ្វើពីធ្មៃ១ សំពត់ភង្គៈ គឺសំពត់ធ្វើពីរបស់ទាំងប្រាំលាយគ្នា១ (បព្វជិតត្រេកអរក្នុងអតិរេកលាភនោះបាន)។ បព្វជ្ជាអាស្រ័យម្លប់ឈើជាសេនាសនៈ អ្នកត្រូវធ្វើការឧស្សាហ៍ក្នុងសេនាសនៈនោះអស់មួយជីវិត។ អតិរេកលាភ (៥យ៉ាង) គឺវិហារ១ អឌ្ឍយោគ (រោងបាំងមួយចំហៀង)១ ប្រាសាទវែង១ ប្រាសាទដំបូលត្រដិល១ គុហា១ (បព្វជិតត្រេកអរក្នុងអតិរេកលាភនោះបាន)។ បព្វជ្ជាអាស្រ័យភេសជ្ជៈដែលត្រាំដោយទឹកមូត្រស្អុយ អ្នកត្រូវធ្វើការឧស្សាហ៍ក្នុងភេសជ្ជៈនោះអស់មួយជីវិត។ អតិរេកលាភ (៥យ៉ាង) គឺទឹកដោះរាវ១ ទឹកដោះខាប់១ ប្រេង១ ទឹកឃ្មុំ១ ស្ករអំពៅ១ (បព្វជិតត្រេកអរក្នុងអតិរេកលាភនោះបាន)។

ចប់ និស្ស័យ ៤។

## ៦៥. ចត្តារិ អករណីយានិ

CS vin.mv.01.65 | ភាគ ទី៦

### (កិច្ចមិនគួរធ្វើ៤យ៉ាង (៦៥.))

[១៤៤] ក៏សម័យនោះឯង ភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់ភិក្ខុមួយរូប ហើយចោលឲ្យនៅម្នាក់ឯង ក៏ចៀសចេញទៅ។ ភិក្ខុនោះមកតែម្នាក់ឯងតាមក្រោយ បានជួបនឹងស្ត្រីដែលធ្លាប់ជាប្រពន្ធអំពីដើមក្នុងចន្លោះផ្លូវ។ ស្ត្រីនោះនិយាយយ៉ាងនេះថា ឥឡូវនេះ អ្នកឯងបួសហើយឬ។ ភិក្ខុនោះឆ្លើយថា អើ អញបួសហើយ។ ស្ត្រីនោះនិយាយថា មេថុនធម្ម ពួកអ្នកបួសបានដោយកម្រណាស់ (ណ្ហើយ) អ្នកចូរមកសេពមេថុនធម្មចុះ។ ភិក្ខុនោះសេពមេថុនធម្មនឹងស្ត្រីនោះហើយ ទៅយឺតយូរក្រោយគេ។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា នែអាវុសោ ហេតុអ្វីបានជាអ្នកឯងធ្វើដំណើរឲ្យយឺតយូរយ៉ាងនេះ។ ទើបភិក្ខុនោះប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះហេតុនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យឧបសម្បទាហើយ ឲ្យភិក្ខុជាគ្នីគ្នាប្រាប់កិច្ចដែលភិក្ខុមិនត្រូវធ្វើ៤យ៉ាងផងថា ភិក្ខុឧបសម្បន្នហើយ មិនត្រូវសេពមេថុនធម្មដោយហោចទៅសូម្បីនឹងសត្វតិរច្ឆានញី។ ភិក្ខុណាសេពមេថុនធម្ម ភិក្ខុនោះមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យៈ។ ធម្មតាបុរសមានក្បាលដាច់ហើយ មិនគួររស់ឡើងបាន ដោយកិរិយាតភ្ជាប់សរីរៈនោះ មានឧបមាយ៉ាងណាមិញ ភិក្ខុសេពមេថុនធម្មហើយ មិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធសក្យៈ ក៏មានឧបមេយ្យយ៉ាងនោះដែរ។ អ្នកមិនត្រូវធ្វើកិច្ចនោះអស់មួយជីវិត។ ភិក្ខុឧបសម្បន្នហើយ មិនត្រូវកាន់យករបស់ដែលគេមិនឲ្យ គឺកាន់យកដោយថេយ្យចិត្ត ដោយហោចទៅ ត្រឹមតែស្មៅមួយទង។ ភិក្ខុណាមួយកាន់យករបស់មានតម្លៃ១បាទក្តី គួរដល់១បាទក្តី លើសជាង១បាទក្តី ដែលគេមិនបានឲ្យ គឺកាន់យកដោយថេយ្យចិត្ត ភិក្ខុនោះមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យៈ។ ធម្មតា ស្លឹកឈើលឿង (ទុំ) ដែលជ្រុះចុះចាកទងហើយ មិនគួរមានពណ៌ខៀវ (ស្រស់ខ្ចី) វិញបាន មានឧបមាយ៉ាងណាមិញ ភិក្ខុកាន់យករបស់មានតម្លៃ១បាទក្តី គួរដល់១បាទក្តី លើសជាង១បាទក្តី ដែលគេមិនបានឲ្យ គឺកាន់យកដោយថេយ្យចិត្ត មិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យៈ ក៏មានឧបមេយ្យយ៉ាងនោះដែរ។ អ្នកមិនត្រូវធ្វើកិច្ចនោះអស់មួយជីវិត។ ភិក្ខុឧបសម្បន្នហើយ មិនត្រូវក្លែងធ្វើសត្វឲ្យធ្លាក់ចុះចាកជីវិតឡើយ ដោយហោចទៅ តាំងពីស្រមោចខ្មៅ និងស្រមោចក្រហម។ ភិក្ខុក្លែងធ្វើរាងកាយមនុស្សឲ្យធ្លាក់ចុះចាកជីវិត រាប់

តាំងពីរំលូតគភ៌ដោយហោចទៅ ភិក្ខុនោះមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យៈ។ ធម្មតា ថ្មក្រាស់ បែកជាពីរហើយ ជាធម្មជាតិជិតវិញមិនបាន មានឧបមាយ៉ាងណាមិញ ភិក្ខុក្លែងធ្វើនូវរាងកាយមនុស្សឲ្យធ្លាក់ចុះចាកជីវិត ក៏មិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យៈ ក៏មានឧបមេយ្យយ៉ាងនោះដែរ។ អ្នកមិនត្រូវធ្វើកិច្ចនោះអស់មួយជីវិត។ ភិក្ខុឧបសម្បន្នហើយ មិនត្រូវនិយាយអួតឧត្តរិមនុស្សធម្មដោយពាក្យថា អាត្មាត្រេកអរចំពោះក្នុងផ្ទះស្ងាត់ដូច្នេះ ដោយហោចទៅ។ ភិក្ខុណាមានសេចក្ដីប្រាថ្នាលាមក ដែលសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ និយាយអួតឧត្តរិមនុស្សធម្ម គឺឈានក្ដី វិមោក្ខក្ដី សមាធិក្ដី សមាបត្តិក្ដី មគ្គក្ដី ផលក្ដី ដែលមិនពិត ភិក្ខុនោះមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យៈ។ ធម្មតា ដើមត្នោតកំបុតចុងហើយ មិនគួរដុះឡើងទៀតបាន មានឧបមាយ៉ាងណាមិញ ភិក្ខុមានសេចក្ដីប្រាថ្នាលាមក ដែលសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ និយាយអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត ក៏មិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធសក្យៈ ក៏មានឧបមេយ្យយ៉ាងនោះដែរ។ អ្នកមិនត្រូវធ្វើកិច្ចនោះអស់មួយជីវិត។

ចប់ កិច្ចមិនគួរធ្វើ៤យ៉ាង។

## ៦៦. អាបត្តិយា អទស្សនេ ឧក្ខិត្តកវត្ថុនិ

CS vin.mv.01.66 | ភាគ ទី៦

**( ៦៦.)**

[១៤៥] ក៏សម័យនោះឯង ភិក្ខុមួយរូបត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ហើយក៏សឹកទៅ។ អ្នកនោះត្រឡប់មកសូមឧបសម្បទានឹងភិក្ខុទាំងឡាយទៀត។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិហើយសឹកទៅ។ អ្នកនោះត្រឡប់មកសូមឧបសម្បទានឹងភិក្ខុទាំងឡាយទៀត។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងអ្នកនោះយ៉ាងនេះថា អ្នកនឹងឃើញអាបត្តិនោះទេ។ បើអ្នកនោះនិយាយថា ខ្ញុំករុណានឹងឃើញអាបត្តិនោះ ត្រូវភិក្ខុទាំងឡាយបំបួសចុះ បើនិយាយថា ខ្ញុំករុណានឹងមិនឃើញអាបត្តិនោះទេ មិនត្រូវបំបួសទេ។ លុះភិក្ខុទាំងឡាយបំបួសហើយ ត្រូវសួរអ្នកនោះថា លោកនឹងឃើញអាបត្តិនោះឬទេ។ បើសាមណេរនោះនិយាយថា ខ្ញុំករុណានឹងឃើញ ត្រូវឲ្យឧបសម្បទាចុះ បើនិយាយថា ខ្ញុំករុណានឹងមិនឃើញទេ មិនត្រូវឲ្យឧបសម្បទាទេ។ លុះភិក្ខុទាំងឡាយឲ្យឧបសម្បទាហើយ ត្រូវសួរភិក្ខុនោះថា លោកនឹងឃើញអាបត្តិនោះទេ។ បើភិក្ខុនោះនិយាយថា ខ្ញុំករុណានឹងឃើញ ភិក្ខុទាំងឡាយត្រូវសូត្រឱសារណកម្មចុះ[117] បើនិយាយថា ខ្ញុំករុណានឹងមិនឃើញទេ មិនត្រូវសូត្រឱសារណកម្មឡើយ។ លុះភិក្ខុទាំងឡាយសូត្រឱសារណកម្មហើយ ត្រូវសួរភិក្ខុនោះថា ឥឡូវលោកឃើញអាបត្តិនោះឬទេ។ បើភិក្ខុនោះឃើញ ការឃើញនេះជាការល្អ បើមិនឃើញទេ កាលបើភិក្ខុទាំងឡាយបានសេចក្ដីព្រមព្រៀងគ្នា ត្រូវលើកវត្តភិក្ខុនោះទៀត កាលបើមិនបានសេចក្ដីព្រមព្រៀងគ្នាទេ មិនមានអាបត្តិព្រោះបរិភោគរួម នៅរួម (ដោយភិក្ខុនោះឡើយ)។ ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ត្រូវសង្ឃលើកវត្ត ព្រោះមិនធ្វើតបអាបត្តិ[118] ហើយសឹកទៅ។ អ្នកនោះត្រឡប់មកសូមឧបសម្បទានឹងភិក្ខុទាំងឡាយទៀត។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងអ្នកនោះយ៉ាងនេះថា អ្នកនឹងធ្វើតបអាបត្តិនោះឬទេ។ បើអ្នកនោះនិយាយថា ខ្ញុំករុណានឹងធ្វើតបវិញ ត្រូវភិក្ខុទាំងឡាយបំបួសចុះ បើនិយាយថា ខ្ញុំករុណានឹងមិនធ្វើតបទេ មិនត្រូវបំបួសទេ។ លុះភិក្ខុទាំងឡាយបំបួសហើយ ត្រូវសួរសាមណេរនោះថា អ្នកនឹងធ្វើតបអាបត្តិនោះឬទេ។ បើសាមណេរនោះនិយាយថា ខ្ញុំករុណានឹងធ្វើតប ត្រូវភិក្ខុទាំងឡាយ ឲ្យឧបសម្បទាចុះ បើនិយាយថា ខ្ញុំករុណានឹងមិនធ្វើតបទេ មិនត្រូវឲ្យឧបសម្បទាឡើយ។ លុះភិក្ខុទាំងឡាយឲ្យឧបសម្បទាហើយ ត្រូវសួរភិក្ខុនោះថា លោកនឹងធ្វើតបអាបត្តិនោះឬទេ។ បើភិក្ខុនោះនិយាយថា ខ្ញុំករុណានឹងធ្វើតបអាបត្តិនោះ ត្រូវសូត្រឱសារណកម្មចុះ បើនិយាយថា ខ្ញុំករុណានឹងមិនធ្វើតបទេ មិនត្រូវឲ្យឱសារណកម្មទេ។ លុះភិក្ខុទាំងឡាយសូត្រឱសារណកម្មហើយ ត្រូវនិយាយនឹងភិក្ខុនោះថា ចូរលោកធ្វើតបអាបត្តិនោះចុះ។ បើភិក្ខុនោះធ្វើតប ការធ្វើតបនេះជាការល្អ បើមិនធ្វើតបទេ កាលបើភិក្ខុទាំងឡាយបានសេចក្ដីព្រមព្រៀងគ្នា ត្រូវលើកវត្តភិក្ខុនោះទៀត កាលបើមិនបានសេចក្ដីព្រមព្រៀងគ្នាទេ មិនត្រូវអាបត្តិព្រោះបរិភោគរួម ព្រោះនៅរួមទេ។ ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ត្រូវភិក្ខុទាំងឡាយលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ហើយសឹកទៅ។ អ្នកនោះត្រឡប់មកសូមឧបសម្បទានឹងភិក្ខុទាំងឡាយទៀត។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងអ្នកនោះយ៉ាងនេះថា អ្នកនឹងលះបង់ទិដ្ឋិអាក្រក់នោះទេ។ បើអ្នកនោះនិយាយថា ខ្ញុំករុណានឹងលះបង់ ត្រូវភិក្ខុទាំងឡាយបំបួសចុះ បើនិយាយថា ខ្ញុំនឹងមិនលះបង់ទេ មិនត្រូវបំបួសទេ។ លុះភិក្ខុទាំងឡាយបំបួសហើយ ត្រូវសួរសាមណេរនោះថា អ្នកនឹងលះបង់ទិដ្ឋិអាក្រក់នោះទេ។ បើសាមណេរនោះនិយាយថា ខ្ញុំករុណានឹងលះបង់ ត្រូវភិក្ខុទាំងឡាយ ឲ្យឧបសម្បទាចុះ បើនិយាយថា ខ្ញុំករុណាមិនលះបង់ទេ មិនត្រូវឲ្យឧបសម្បទាទេ។ លុះភិក្ខុទាំងឡាយឲ្យឧបសម្បទាហើយ ត្រូវសួរថា លោកនឹងលះបង់ទិដ្ឋិអាក្រក់នោះទេ។ បើភិក្ខុនោះនិយាយថា ខ្ញុំករុណានឹងលះបង់ ត្រូវភិក្ខុទាំងឡាយសូត្រឱសារណកម្មចុះ បើនិយាយថា ខ្ញុំករុណានឹងមិនលះបង់ទេ មិនត្រូវសូត្រឱសារណកម្មទេ។ លុះភិក្ខុទាំងឡាយសូត្រឱសារណកម្មហើយ ត្រូវនិយាយនឹងភិក្ខុនោះថា ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះទៅ។ បើភិក្ខុនោះលះបង់ ការលះបង់នេះជាការល្អ បើមិនលះបង់ទេ កាលបើភិក្ខុទាំងឡាយបានសេចក្ដីព្រមព្រៀងគ្នា ត្រូវលើកវត្តភិក្ខុនោះទៀត បើមិនបានសេចក្ដីព្រមព្រៀងគ្នាទេ មិនត្រូវអាបត្តិព្រោះបរិភោគរួម ព្រោះនៅរួមទេ។

ចប់ មហាខន្ធកៈទី១។

## ៦៧. តស្សុទ្ទានំ

CS vin.mv.01.67 | ភាគ ទី៦

**(៦៧.)**

[១៤៦] កាលបើព្រះវិន័យមានប្រយោជន៍ធំ នាំមកនូវសេចក្ដីសុខដល់ភិក្ខុមានសីលជាទីស្រឡាញ់ទាំងឡាយ ជាសភាវទ្រទ្រង់ទុកនូវសាសនាផង ជាទីគោចររបស់ព្រះជិនស្រី ជាសព្វញ្ញូផង មិនមែនជាវិស័យនៃបុគ្គលដទៃ ជាទីក្សេមក្សាន្តដែលព្រះដ៏មាន

ព្រះភាគ ទ្រង់បញ្ញត្តហើយ ដោយប្រពៃ ដើម្បីសង្កត់សង្កិន័នូវពួកភិក្ខុដែលមានសេចក្តីប្រាថ្នាលាមកផង ដើម្បីដម្កល់ដម្កើងនូវពួកភិក្ខុដែលមានសេចក្តីខ្មាសផង ដោយឥតសង្ស័យ អ្នកប្រាជ្ញដែលមានប្រក្រតីធ្វើនូវប្រយោជន៍ដ៏សមគួរ តែងប្រតិបត្តិដោយឧបាយក្នុងខន្ធកវិន័យផង ក្នុងបរិវារៈផង ព្រមទាំងមាតិកា។ បុគ្គលណាមិនស្គាល់គោ បុគ្គលនោះនឹងរក្សាហ្វូងគោដូចម្តេចបាន យ៉ាងណាមិញ ភិក្ខុណាមិនស្គាល់សីល ភិក្ខុនោះនឹងរក្សាសេចក្តីសង្រួមក្នុងសីលដូចម្តេចបាន យ៉ាងនោះដែរ។ បើទុកជាព្រះសូត្រនិងព្រះអភិធម្មសាបសូន្យអស់ទៅហើយ តែបើព្រះវិន័យមិនទាន់វិនាសនៅឡើយទេ ព្រះសាសនាឈ្មោះថា ឋិតថេរតទៅទៀតបាន។ ព្រោះហេតុនៃការសង្គាយនានោះ ខ្ញុំនឹងពោលនូវឧទ្ទានតាមលំដាប់ដោយសមគួរតាមប្រាជ្ញា ចូរលោកទាំងឡាយចាំស្តាប់ខ្ញុំជាអ្នកពោល។ វត្ថុផង និទានផង ន័យនៃអាបត្តិទាំងឡាយផង បេយ្យាលៈផង វត្ថុជាដើមនោះ ខ្ញុំលំបាកនឹងធ្វើឲ្យអស់សព្វគ្រប់ ចូរលោកទាំងឡាយ ជ្រាបច្បាស់នូវវត្ថុជាដើមនោះ តាមន័យ (នៃឧទ្ទានគាថាដែលខ្ញុំពោលដោយសង្ខេបតទៅនេះចុះ)។ រឿងព្រះសម្ពុទ្ធទ្រង់គង់ក្រោមពោធិព្រឹក្ស១ រឿងទ្រង់គង់ក្រោមរាជាយតនព្រឹក្ស១ រឿងទ្រង់ត្រឡប់មកកាន់អជបាលនិគ្រោធវិញ ហើយទ្រង់ពុទ្ធបរិវិតក្ក១ រឿងសហម្បតិព្រហ្ម១ រឿងអាឡារតាបស១ រឿងឧទ្ទកតាបស១ រឿងព្រះសម្ពុទ្ធទ្រង់ត្រិះរិះថា គួរសំដែងធម៌ដល់បញ្ចវគ្គិយភិក្ខុ១ រឿងទ្រង់ជួបនឹងឧបកាជីវក១ រឿងទ្រង់ស្តេចទៅកាន់ព្រៃឥសិបតនមិគទាយវន១ រឿងកោណ្ឌញ្ញភិក្ខុ១ រឿងភទ្ទិយភិក្ខុ១ រឿងវប្បភិក្ខុ១ រឿងមហានាមភិក្ខុ១ រឿងអស្សជិភិក្ខុ១ រឿងយសកុលបុត្រ១ រឿងសំឡាញ់៤នាក់១ រឿងសំឡាញ់៥០នាក់១ រឿងព្រះបរមសាស្តានោះទ្រង់បញ្ជូនពួកព្រះអរហន្តទាំងពួងទៅកាន់ទិស ដើម្បីប្រកាសសាសនា១ រឿងមារ១ រឿងកុមារទាំង៣០នាក់១ រឿងជដិលឈ្មោះឧរុវេលកស្សប១ រឿងជដិលឈ្មោះនទីកស្សប១ រឿងជដិលឈ្មោះគយាកស្សប១ រឿងរោងភ្លើង១ រឿងមហារាជ១ រឿងព្រះឥន្ទ្រ១ រឿងព្រហ្ម១ រឿងអ្នកដែនអង្គៈ មគធៈទាំងអស់១ រឿងសំពត់បង្សុកូល១ រឿងស្រះបោក្ខរណី១ រឿងថ្មបោកសំពត់បង្សុកូល១ រឿងដើមថ្វាន់១ រឿងថ្មហាលសំពត់បង្សុកូល១ រឿងព្រះសម្ពុទ្ធទ្រង់នាំយកផ្លែព្រីង១ រឿងទ្រង់នាំយកផ្លែស្វាយ១ រឿងទ្រង់នាំយកផ្លែកន្ទួតព្រៃ[119] ១ រឿងទ្រង់នាំយកផ្លែសម៉១ រឿងទ្រង់នាំយកផ្កាបារិច្ឆត្តកព្រឹក្ស១ រឿងទ្រង់ធ្វើបាដិហារិយ៍ត្រាស់ថា ម្នាលកស្សប ឧសចូរបែក១ រឿងទ្រង់ត្រាស់ថា ភ្លើងចូរឆេះ១ រឿងទ្រង់ត្រាស់ថា ភ្លើងចូររលត់១ រឿងពួកជដិលមុជទឹក១ រឿងព្រះដ៏មានព្រះភាគនិម្មិតជើងក្រាន១ រឿងភ្លៀង១ រឿងព្រះសម្ពុទ្ធគង់ក្នុងគយាសីសប្រទេស១ រឿងទ្រង់គង់ក្នុងលដ្ឋិវនឧទ្យាន (សួនព្រៃត្នោត)១ រឿងព្រះបាទមាគធរាជ១ រឿងឧបតិស្សមាណព១ រឿងកោលិតមាណព១ រឿងអ្នកដែនមគធៈដឹងច្បាស់ថាពួកកុលបុត្រប្រព្រឹត្តព្រហ្មចារ្យ១ រឿងពួកភិក្ខុស្លៀកដណ្តប់មិនល្អ១ រឿងទ្រង់អនុញ្ញាតឲ្យឧបជ្ឈាយ៍បណ្តេញសទ្ធិវិហារិកដែលប្រព្រឹត្តមិនល្អ១ រឿងព្រាហ្មណ៍ស្គាំងស្គមសៅហ្មង១ រឿងភិក្ខុប្រព្រឹត្តអនាចារ១ រឿងព្រាហ្មណ៍បួសដើម្បីចិញ្ចឹមពោះ១ រឿងមាណពទើបតែនឹងមកសូមផ្នួសភិក្ខុប្រាប់និស្ស័យមុន១ រឿងទ្រង់ហាមមិនឲ្យៗឧបសម្បទាដោយគណសង្ឃតិចជាង១០រូប១ រឿងទ្រង់ហាមភិក្ខុដែលមានវស្សាតិចជាង១០ មិនឲ្យៗឧបសម្បទាគេ១ រឿងទ្រង់ហាមភិក្ខុដែលល្ងង់ៗ មិនឲ្យៗឧបសម្បទាគេ១ រឿងឧបជ្ឈាយ៍ចៀសចេញទៅកាន់ទិស១ រឿងភិក្ខុមានវស្សា១០ឲ្យនិស្ស័យ១ រឿងពួកអន្តេវាសិកប្រព្រឹត្តមិនល្អក្នុងអាចារ្យត្រូវបណ្តេញ១ រឿងទ្រង់ហាមពួកភិក្ខុល្ងង់ៗ មិនឲ្យៗនិស្ស័យគេ១ រឿងរម្ងាប់ចាកនិស្ស័យ១ រឿងភិក្ខុប្រកបដោយអង្គ៥ គួរនិងមិនគួរឲ្យឧបសម្បទាគេជាដើម១ រឿងភិក្ខុប្រកបដោយអង្គ៦ គួរនិងមិនគួរឲ្យឧបសម្បទាគេជាដើម១ រឿងព្រះសម្ពុទ្ធទ្រង់ត្រាស់ថា បុគ្គលណាពីដើមធ្លាប់ជាតិរ្ថិយ៍ដល់មកបួសជាភិក្ខុ មិនស្តាប់ពាក្យឧបជ្ឈាយ៍ ហើយត្រឡប់ទៅជាតិរ្ថិយដូចដើម បើមកវិញមិនត្រូវឲ្យឧបសម្បទាទេ១ រឿងទ្រង់ត្រាស់ថា បើបុគ្គលឯទៀតធ្លាប់ជាតិរ្ថិយ ហើយប្រាថ្នាបព្វជ្ជាឧបសម្បទា ត្រូវឲ្យនៅបរិវាស៤ខែ១ រឿងទ្រង់ត្រាស់ថា បើតិរ្ថិយមកបួសទាំងអាក្រាត ត្រូវឧបជ្ឈាយ៍ស្វែងរកដំឡៃចីវរឲ្យ១ រឿងទ្រង់ត្រាស់ថា បើតិរ្ថិយមិនទាន់កោរសក់ ត្រូវសង្ឃអបលោកធ្វើភណ្ឌុកម្មឲ្យ១ រឿងទ្រង់ត្រាស់ថា បើជដិលជាកម្មវាទី កិរិយវាទី មិនបាច់ឲ្យនៅបរិវាស១ រឿងទ្រង់ត្រាស់ថា បើជាតិសក្យៈធ្លាប់ជាតិរ្ថិយ៍មកបួស មិនបាច់ឲ្យនៅបរិវាស១ រឿងទ្រង់បញ្ញត្តមិនឲ្យបំបួសមនុស្សមានអាពាធ៥យ៉ាងក្នុងដែនមគធៈ១ រឿងទ្រង់បញ្ញត្តមិនឲ្យបំបួសរាជអមាត្យ១ រឿងភិក្ខុបំបួសអង្គុលិមាលចោរ ក្រោយមកទ្រង់បញ្ញត្តមិនឲ្យបំបួសចោរ១ រឿងព្រះបាទមាគធរាជទ្រង់អនុញ្ញាតទោសដល់ពួកអ្នកបួសក្នុងព្រះពុទ្ធសាសនា១ រឿងព្រះសម្ពុទ្ធទ្រង់បញ្ញត្តមិនឲ្យបំបួសចោរទំលាយគុក១ រឿងទ្រង់បញ្ញត្តមិនឲ្យបំបួសចោរដែលរាជការព្យួរទោសទុក១ រឿងទ្រង់បញ្ញត្តមិនឲ្យបំបួសមនុស្សដែលមានស្នាមរំពាត់១ រឿងទ្រង់បញ្ញត្តមិនឲ្យបំបួសមនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម១ រឿងទ្រង់បញ្ញត្តមិនឲ្យបំបួសមនុស្សដែលជំពាក់បំណុលគេ១ រឿងទ្រង់បញ្ញត្តមិនឲ្យបំបួសមនុស្សខ្ញុំគេ១ រឿងភិក្ខុបំបួសទារកកោរទុកជុក១ រឿងភិក្ខុបំបួសទារកឈ្មោះឧបាលិ១ រឿងត្រកូលវិនាសដោយអហិវាតករោគ១ រឿងត្រកូលជាឧបដ្ឋាករបស់ព្រះអានន្ទមានសទ្ធា១ រឿងកណ្តកសាមណេរ១ រឿងមនុស្សពោលទោសភិក្ខុថា ទិសចង្អៀត១ រឿងព្រះដ៏មានព្រះភាគគង់នៅក្នុងនិគ្រោធារាមទៀបក្រុងកបិលវត្ថុ១ រឿងព្រះសារីបុត្តបំបួសទារក១ រឿងទ្រង់អនុញ្ញាតសិក្ខាបទ១០ដល់សាមណេរ១ រឿងសាមណេរនៅដោយមិនគោរពកោតក្រែងភិក្ខុ១ រឿងភិក្ខុត្រិះរិះថាគួរធ្វើទណ្ឌកម្មដូចម្តេចដល់សាមណេរ១ រឿងភិក្ខុធ្វើអាវរណកម្មដល់ពួកសាមណេរទូទៅទាំងអារាមរបស់សង្ឃទាំងមូល១ រឿងភិក្ខុធ្វើអាវរណកម្មដល់ពួកសាមណេរចំពោះអាហារតាមមុខទ្វារ១ រឿងពួកឆព្វគ្គិយភិក្ខុធ្វើអាវរណកម្ម ដល់ពួកសាមណេរមិនប្រាប់ឧបជ្ឈាយ៍១ រឿងពួកឆព្វគ្គិយភិក្ខុប្រលោមយកសាមណេររបស់ភិក្ខុជាថេរៈ១ រឿងកណ្តកសាមណេរប្រទុស្តភិក្ខុនីឈ្មោះកណ្តកី១ រឿងព្រះសម្ពុទ្ធទ្រង់ហាមមិនឲ្យបំបួសបណ្ឌក១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលលួចសំវាស១ រឿងទ្រង់ហាមមិនឲ្យបំបួសភិក្ខុដែលរត់ទៅចូលពួកតិរ្ថិយ១ រឿងទ្រង់ហាមមិនឲ្យបំបួសសត្វតិរច្ឆានដោយហេតុអហិនាគមកបួសក្នុងសំណាក់ភិក្ខុ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលសម្លាប់ម្តាយ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលសម្លាប់ឪពុក១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលសម្លាប់ព្រះអរហន្ត១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលប្រទុស្តភិក្ខុនី១ រឿងទ្រង់ហាមមិនឲ្យបំបួសបុគ្គលដែលបំបែកសង្ឃ១ រឿងទ្រង់ហាមមិនឲ្យបំបួសបុគ្គលដែលធ្វើព្រះលោហិតឲ្យពូរពងឡើង១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលជាឧភតោព្យញ្ជនក១ រឿងទ្រង់ហាមមិនឲ្យៗឧបសម្បទាដល់បុគ្គលគ្មានឧបជ្ឈាយ៍១ រឿងទ្រង់ហាមមិនឲ្យយកសង្ឃជាឧបជ្ឈាយ៍១ រឿងទ្រង់ហាមមិនឲ្យយកគណៈជាឧបជ្ឈាយ៍១ រឿងទ្រង់ហាមមិនឲ្យយកបណ្ឌកជាឧបជ្ឈាយ៍១ រឿងទ្រង់ហាមមិនឲ្យៗឧបសម្បទាដល់កុលបុត្រគ្មានបាត្រ១ រឿងទ្រង់ហាមមិនឲ្យៗឧបសម្បទាដល់កុលបុត្រគ្មានចីវរ១ រឿងទ្រង់ហាមមិនឲ្យៗឧបសម្បទាដល់កុលបុត្រគ្មានបាត្រ គ្មានចីវរទាំងពីរយ៉ាងនោះ១ រឿងទ្រង់ហាមមិនឲ្យៗឧបសម្បទាដល់បុគ្គលដែលខ្ចីបាត្រគេ១ រឿងទ្រង់ហាមមិនឲ្យៗឧបសម្បទាដល់បុគ្គលដែលខ្ចីចីវរគេ១ រឿងទ្រង់ហាមមិនឲ្យៗឧបសម្បទាដល់បុគ្គលដែលខ្ចីទាំងបាត្រ ទាំងចីវរគេ១ រឿង

ទ្រង់ហាមមិនឲ្យបំបួសមនុស្សកំបុតដៃ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សកំបុតជើង១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សកំបុតទាំងដៃទាំងជើង១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សកំបុតត្រចៀក១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សកំបុតច្រមុះ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សកំបុតទាំងត្រចៀក ទាំងច្រមុះ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សកំបុតម្រាមដៃ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សកំបុតមេដៃឬមេជើង១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដាច់សរសៃធំ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សមានម្រាមដៃជាប់គ្នា១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សគម១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សតឿ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សពកក១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលមានស្នាមរំពាត់១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលរាជការព្យួរទោសទុក១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សជើងស្ទក់១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលមានរោគអាក្រក់១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សប្រទុស្តបរិសទ្យ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សទើបនឹងខ្វាក់ ឬខ្វាក់ម្ខាង១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សក្ងែងក្ងង់ដៃជើង១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សខ្ចក១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សដែលស្លាប់មួយចំហៀងខ្លួន១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សខ្វិន១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សចាស់គ្រាំគ្រា១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សខ្វាក់ពីកំណើត ឬខ្វាក់ទាំងពីរខាង១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សគ១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សថ្លង់១ រឿងទ្រង់ហាមមិនឲ្យបំបួសមនុស្សទាំងខ្វាក់ពីកំណើតទាំងគ១ មិនឲ្យបំបួសមនុស្សទាំងខ្វាក់ពីកំណើតទាំងថ្លង់១ មិនឲ្យបំបួសមនុស្សទាំងគទាំងថ្លង់១ មិនឲ្យបំបួសមនុស្សទាំងខ្វាក់ពីកំណើត ទាំងគ ទាំងថ្លង់១ រឿងទ្រង់ហាមមិនឲ្យៗនិស្ស័យដល់ពួកភិក្ខុអលជ្ជី១ រឿងទ្រង់ហាមមិនឲ្យនៅអាស្រ័យនឹងពួកភិក្ខុអលជ្ជី១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុអ្នកដើរផ្លូវឆ្ងាយមិនបាច់មាននិស្ស័យបាន១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុបម្រើជម្ងឺ មិនទាន់បាននិស្ស័យនៅដោយឥតនិស្ស័យបាន ព្រោះភិក្ខុឈឺអង្វរ១ រឿងព្រះមហាកស្សបប្រើបម្រើឲ្យទៅនិមន្តព្រះអានន្ទថា ចូរមកសូត្រឲ្យឧបសម្បទាបេក្ខៈ១ រឿងឧបសម្បទាពីររូប ប្រកែកគ្នាអំពីរឿងដណ្តើមគ្នាឧបសម្បទាមុន១ រឿងទ្រង់អនុញ្ញាតឲ្យសូត្រអនុស្សាវនាជាមួយគ្នាដោយមានឧបជ្ឈាយ៍តែមួយរូប១ រឿងកុមារកស្សបមានអាយុ២០ឆ្នាំ រាប់តាំងពីឆ្នាំដែលនៅក្នុងគភ៌ផង បានឧបសម្បទា១ រឿងពួកឧបសម្បន្នដែលអាពាធទាំងឡាយបៀតបៀនប្រាកដឡើង១ រឿងពួកភិក្ខុសួរអន្តរាយិកធម៌នឹងពួកឧបសម្បទាបេក្ខៈ ដែលមិនទាន់ប្រៀនប្រដៅ ឧបសម្បទាបេក្ខៈអៀនខ្មាស១ រឿងពួកភិក្ខុប្រៀនប្រដៅឧបសម្បទាបេក្ខៈ ក្នុងទីកណ្តាលជំនុំសង្ឃនោះ១ រឿងទ្រង់អនុញ្ញាតឲ្យប្រៀនប្រដៅក្នុងទីសមគួរហើយ សឹមសួរអន្តរាយិកធម៌ក្នុងកណ្តាលសង្ឃ១ រឿងទ្រង់ហាម មិនឲ្យភិក្ខុល្ងង់ៗប្រៀនប្រដៅ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុដែលគ្មានការសន្មតិប្រៀនប្រដៅ១ រឿងទ្រង់ហាមមិនឲ្យអាចារ្យនិងឧបសម្បទាបេក្ខៈ ចូលមកក្នុងជំនុំសង្ឃជាមួយគ្នា១ រឿងឧបសម្បទាបេក្ខៈ សូមឧបសម្បទានឹងសង្ឃដោយពាក្យថា សូមឲ្យសង្ឃស្រោចស្រង់១ រឿងប្រាប់និស្ស័យបួន១ រឿងភិក្ខុដែលបានឧបសម្បទាហើយ ដើរមកតែម្នាក់ឯង ជួបនឹងស្ត្រីជាបុរាណទុតិយិកាត្រង់កណ្តាលផ្លូវ១ រឿងភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ១ រឿងភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនធ្វើតបនូវអាបត្តិ១ រឿងភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនលះបង់នូវទិដ្ឋិអាក្រក់១។

រួមរឿងក្នុងខន្ធកៈនេះ ១៧២រឿងដោយបការដូច្នេះ។

ចប់ ឧទ្ទានក្នុងមហាខន្ធកៈ។

# ឧបោសថក្ខន្ធកៈ

CS vin.mv.02 | ភាគ ទី៦

## ៦៨. សន្និបាតានុជានានា

CS vin.mv.02.01 | ភាគ ទី៦

**(៦៨.)**

[១៤៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ។ ក៏សម័យនោះឯង ពួកបរិព្វាជកមានលទ្ធិដទៃប្រជុំគ្នានិយាយធម៌ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខ។[120] មនុស្សទាំងឡាយតែងចូលទៅរកបរិព្វាជកទាំងនោះ ដើម្បីស្តាប់ធម៌។ មនុស្សទាំងឡាយនោះកើតសេចក្តីស្រឡាញ់ កើតសេចក្តីជ្រះថ្លា ក្នុងពួកបរិព្វាជកមានលទ្ធិដទៃ ពួកបរិព្វាជកមានលទ្ធិដទៃក៏បានបក្ខពួកឡើង។ គ្រានោះឯង ព្រះបាទពិម្ពិសារសេនិយៈ ជាឥស្សរៈក្នុងដែនមគធៈ ទ្រង់សម្ងំនៅក្នុងទីស្ងាត់ កើតព្រះទ័យត្រិះរិះឡើងយ៉ាងនេះថា ឥឡូវនេះឯង ពួកបរិព្វាជកមានលទ្ធិដទៃប្រជុំគ្នា និយាយធម៌ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខ មនុស្សទាំងឡាយតែងចូលទៅរកបរិព្វាជកទាំងនោះដើម្បីស្តាប់ធម៌ មនុស្សទាំងនោះក៏កើតសេចក្តីស្រឡាញ់ កើតសេចក្តីជ្រះថ្លា ក្នុងពួកបរិព្វាជកមានលទ្ធិដទៃ ពួកបរិព្វាជកមានលទ្ធិដទៃក៏បានបក្ខពួកឡើង បើដូច្នោះគួរតែលោកម្ចាស់ទាំងឡាយប្រជុំគ្នាក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខដែរ។ ទើបព្រះបាទពិម្ពិសារសេនិយៈ ជាឥស្សរៈក្នុងដែនមគធៈ ទ្រង់ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីសមគួរ។ ព្រះបាទពិម្ពិសារសេនិយៈ ជាឥស្សរៈក្នុងដែនមគធៈ គង់ក្នុងទីសមគួរហើយ បានទូលព្រះដ៏មានព្រះភាគដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងថ្ងៃនេះ ខ្ញុំព្រះករុណាសម្ងំនៅក្នុងទីស្ងាត់ កើតចិត្តត្រិះរិះឡើងយ៉ាងនេះថា ក៏ឥឡូវនេះ ពួកបរិព្វាជកមានលទ្ធិដទៃ តែងប្រជុំគ្នានិយាយធម៌ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខ មនុស្សទាំងឡាយតែងចូលទៅរកបរិព្វាជកទាំងនោះ ដើម្បីស្តាប់ធម៌ ពួកមនុស្សទាំងនោះ ក៏កើតសេចក្តីស្រឡាញ់ កើតសេចក្តីជ្រះថ្លា ក្នុងពួកបរិព្វាជកមានលទ្ធិដទៃ ពួកបរិព្វាជកមានលទ្ធិដទៃ ក៏បានបក្ខពួកឡើង បើដូច្នោះ គួរតែលោកម្ចាស់ទាំងឡាយប្រជុំគ្នាក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខដែរ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមទ្រង់អនុញ្ញាត បពិត្រព្រះអង្គដ៏ចំរើន លោកម្ចាស់ទាំងឡាយ ត្រូវតែប្រជុំគ្នាក្នុងថ្ងៃទី១៤ ទី១៥ ទី៨នៃបក្ខ។ គ្រានោះឯង ព្រះដ៏មានព្រះភាគញុំាងព្រះបាទពិម្ពិសារសេនិយៈ ជាឥស្សរៈក្នុងដែនមគធៈឲ្យយល់ច្បាស់ ឲ្យប្រតិបត្តិល្អ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា។

លំដាប់នោះ ព្រះបាទពិម្ពិសារសេនិយៈ ជាឥស្សរៈក្នុងដែនមគធៈ ដែលព្រះដ៏មានព្រះភាគឲ្យយល់ច្បាស់ ឲ្យប្រតិបត្តិល្អ ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ (យាងវិលខាងស្តាំ) ហើយចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រជុំគ្នាក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខ។

## ៦៩. បាតិមោក្ខុទ្ទេសានុជាននា

CS vin.mv.02.02 | ភាគ ទី៦

**(៦៩.)**

[១៤៨] សម័យនោះឯង ភិក្ខុទាំងឡាយដឹងថាព្រះដ៏មានព្រះភាគអនុញ្ញាតឲ្យប្រជុំគ្នាក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខហើយ។ ភិក្ខុទាំងនោះក៏ប្រជុំគ្នាក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខ ហើយអង្គុយនៅតែស្ងៀម។ មនុស្សទាំងឡាយក៏ចូលទៅរកភិក្ខុទាំងនោះដើម្បីស្តាប់ធម៌។ មនុស្សទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយ ជាសក្យបុត្រ មិនសមបើនឹងមកប្រជុំគ្នាក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខ ហើយអង្គុយនៅតែស្ងៀម ដូចជាជ្រូកធាត់ (ដូច្នេះ) សោះ គួរតែលោកទាំងឡាយប្រជុំគ្នា ហើយនិយាយធម៌។ ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ទើបភិក្ខុទាំងឡាយនោះក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រជុំគ្នា និយាយធម៌ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខ។

[១៤៩] លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្ងំក្នុងទីស្ងាត់កើតព្រះទ័យត្រិះរិះឡើងយ៉ាងនេះថា បើដូច្នោះមានតែតថាគតអនុញ្ញាតសិក្ខាបទទាំងឡាយនោះដែលតថាគតបញ្ញត្តហើយដល់ភិក្ខុទាំងឡាយ ឲ្យជាបាតិមោក្ខុទ្ទេសដល់ពួកភិក្ខុទាំងនោះ បាតិមោក្ខុទ្ទេសនោះនឹងបានជាឧបោសថកម្មរបស់ភិក្ខុទាំងឡាយនោះ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគចេញចាកទីសម្ងំក្នុងពេលថ្ងៃរសៀល ទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃនេះ តថាគតសម្ងំនៅក្នុងទីស្ងាត់ កើតចិត្តត្រិះរិះឡើងយ៉ាងនេះថា បើដូច្នោះ មានតែតថាគតអនុញ្ញាតសិក្ខាបទទាំងឡាយនោះ ដែលតថាគតបញ្ញត្តដល់ភិក្ខុទាំងឡាយ ឲ្យជាបាតិមោក្ខុទ្ទេសដល់ភិក្ខុទាំងឡាយនោះ បាតិមោក្ខុទ្ទេសនោះនឹងជាឧបោសថកម្មរបស់ភិក្ខុទាំងឡាយនោះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសំដែងនូវបាតិមោក្ខ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុសំដែងយ៉ាងនេះ។ គឺភិក្ខុដែលឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគួរធ្វើឧបោសថ គួរសំដែងនូវបាតិមោក្ខ។ បុព្វកិច្ច[121] របស់សង្ឃដូចម្តេច។ បពិត្រលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយប្រាប់សេចក្តីបរិសុទ្ធិ។ ខ្ញុំនឹងសំដែងនូវបាតិមោក្ខ។ យើងទាំងឡាយដែលមាននៅទាំងអស់គ្នា ចូរប្រុងស្តាប់យកចិត្តទុកដាក់នូវបាលីនោះ។ លោកអង្គណាមានអាបត្តិ ត្រូវលោកអង្គនោះប្រាប់ កាលបើមិនមានអាបត្តិទេ ត្រូវនៅឲ្យស្ងៀម។ ខ្ញុំនឹងសំគាល់លោកដ៏មានអាយុទាំងឡាយថា ជាបុគ្គលបរិសុទ្ធ ដោយភាវៈស្ងៀម។ ដូចជាបុគ្គលដែលត្រូវគេសួរបញ្ហាចំពោះរូបម្នាក់ៗតែងដោះស្រាយ យ៉ាងណាមិញ ពាក្យដែលខ្ញុំប្រកាសឲ្យដឹងអស់វារៈជាគំរប់បីដងយ៉ាងនេះ ក្នុងបរិសទ្យមានសភាពយ៉ាងនេះ ក៏ដូច្នោះដែរ។ ភិក្ខុណាមួយ កាលដែលខ្ញុំប្រកាសឲ្យដឹងអស់វារៈជាគំរប់បីដង ទើបរលឹកឃើញ តែមិនប្រាប់អាបត្តិដែលមាន ភិក្ខុនោះ ត្រូវសម្បជានមុសាវាទ។ បពិត្រលោកដ៏មានអាយុទាំងឡាយ ក៏ឯសម្បជានមុសាវាទ ព្រះដ៏មានព្រះភាគត្រាស់ថាជាធម៌ធ្វើសេចក្តីអន្តរាយមួយដែរ ហេតុនោះ ភិក្ខុដែលត្រូវអាបត្តិហើយ រលឹកឃើញ ប្រាថ្នាសេចក្តីបរិសុទ្ធ ត្រូវប្រាប់អាបត្តិដែលមាន។ ព្រោះថា អាបត្តិដែលភិក្ខុប្រាប់ហើយ ជាការស្រួល។

[១៥០] ត្រង់ពាក្យថា បាតិមោក្ខ សេចក្តីថា ធម្មជាតនេះជាដើម ធម្មជាតនេះជាប្រធាន ធម្មជាតនៃជាមុនដម្បូងនៃកុសលធម៌ទាំងឡាយ ហេតុនោះតថាគតហៅថាបាតិមោក្ខ។ ពាក្យថា លោកដ៏មានអាយុ ឯពាក្យថា លោកដ៏មានអាយុនេះ ជាពាក្យនិយាយដោយសេចក្តីស្រឡាញ់ នេះជាពាក្យនិយាយដោយសេចក្តីគោរព នេះជាឈ្មោះនៃបុគ្គលប្រកបដោយសេចក្តីគោរព និងជាទីកោតក្រែង។ ពាក្យថា ខ្ញុំនឹងសំដែង គឺខ្ញុំនឹងប្រាប់ នឹងបង្ហាញ នឹងឲ្យដឹងច្បាស់ នឹងផ្តួរផ្តង (ផ្តើម) នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់ នឹងប្រកាសឬផ្តៀង។ ពាក្យថា បាលីនោះ តថាគតសំដៅយកបាតិមោក្ខ។ ពាក្យថា យើងទាំងឡាយ ដែលមាននៅទាំងអស់គ្នា គឺភិក្ខុជាថេរៈក្តី ភិក្ខុខ្ចីវស្សាក្តី ភិក្ខុជាកណ្តាលក្តី ទាំងអម្បាលម៉ានក្នុងបរិសទ្យនោះ តថាគតហៅភិក្ខុទាំងឡាយនុ៎ះថា យើងទាំងឡាយដែលមាននៅទាំងអស់គ្នា។ ពាក្យថា ចូរប្រុងស្តាប់ គឺយើងចូរធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចិតផ្ចង់នូវបាតិមោក្ខទាំងអស់ដោយចិត្ត។ ពាក្យថា យកចិត្តទុកដាក់ គឺយើងចូរមានចិត្តមានអារម្មណ៍តែមួយ មានចិត្តមិនរវើរវាយ មានចិត្តមិនរាយមាយ ហើយពិចារណា (បាតិមោក្ខនោះ)។ ពាក្យថា លោកអង្គណាមានអាបត្តិ គឺភិក្ខុជាថេរៈ ឬភិក្ខុខ្ចី ឬភិក្ខុជាកណ្តាល បណ្តាអាបត្តិទាំង៥កង ត្រូវអាបត្តិណាមួយក្តី បណ្តាអាបត្តិទាំង៧កង ត្រូវអាបត្តិណាមួយក្តី។ ពាក្យថា ត្រូវលោកអង្គនោះប្រាប់ គឺភិក្ខុនោះត្រូវសំដែង ភិក្ខុនោះត្រូវបើក ភិក្ខុនោះត្រូវធ្វើឲ្យរាក់ឡើង ភិក្ខុនោះត្រូវប្រកាសក្នុងកណ្តាលសង្ឃក្តី កណ្តាលគណៈក្តី ចំពោះបុគ្គលមួយក្តី។ ដែលឈ្មោះថា មិនមានអាបត្តិ គឺភិក្ខុមិនបានត្រូវអាបត្តិណាក្តី ត្រូវអាបត្តិណាហើយ ចេញចាកអាបត្តិក្តី។ ពាក្យថា ត្រូវនៅស្ងៀម គឺត្រូវអត់ មិនត្រូវនិយាយ។ ពាក្យថា ខ្ញុំនឹងសំគាល់លោកដ៏មានអាយុទាំងឡាយថា ជាបុគ្គលបរិសុទ្ធ គឺខ្ញុំនឹងដឹង នឹងចាំទុក។ ពាក្យថា ដូចជាបុគ្គលដែលត្រូវគេសួរបញ្ហាចំពោះរូបម្នាក់ៗ តែងដោះស្រាយយ៉ាងណាមិញ សេចក្តីថា បុគ្គលម្នាក់ដែលបុគ្គលម្នាក់ទៀតសួរហើយ ត្រូវតែដោះស្រាយ មានឧបមាយ៉ាងណា ភិក្ខុសួរខ្ញុំចំពោះអាបត្តិ ដែលភិក្ខុគួរដឹងក្នុងបរិសទ្យនោះយ៉ាងនោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ។ ដែលហៅថា បរិសទ្យមានសភាពយ៉ាងនេះ គឺតថាគតសំដៅយកភិក្ខុបរិសទ្យ។ ពាក្យថា ពាក្យដែលខ្ញុំប្រកាសឲ្យដឹងអស់វារៈជាគំរប់បីដង គឺពាក្យដែលខ្ញុំប្រកាសឲ្យដឹងអស់វារៈម្តងផង ពាក្យដែលខ្ញុំប្រកាសឲ្យដឹងអស់វារៈជាគំរប់ពីរដងផង ពាក្យដែលខ្ញុំប្រកាសឲ្យដឹងអស់វារៈជាគំរប់បីដងផង។ ពាក្យថា រលឹកឃើញ គឺដឹងបាន ចាំបាន។ ដែលឈ្មោះថា អាបត្តិដែលមាន គឺភិក្ខុត្រូវអាបត្តិណាក្តី ត្រូវហើយមិនចេញចាកអាបត្តិក្តី។ ពាក្យថា មិនប្រាប់ គឺមិនសំដែង មិនបើក មិនធ្វើឲ្យងាយ មិនប្រកាសក្នុងកណ្តាលសង្ឃក្តី កណ្តាលគណៈក្តី ចំពោះបុគ្គលមួយក្តី។ ពាក្យថា ភិក្ខុនោះត្រូវសម្បជានមុសាវាទ គឺសម្បជានមុសាវាទ ជាអាបត្តិអ្វី។ សម្បជានមុសាវាទ ជាអាបត្តិទុក្កដ។ ពាក្យថា ព្រះដ៏មានព្រះភាគត្រាស់ថា ជាធម៌ធ្វើសេចក្តីអន្តរាយ គឺធម៌នោះធ្វើនូវសេចក្តីអន្តរាយដល់អ្វី។ ធម៌នោះធ្វើនូវសេចក្តីអន្តរាយដល់ការបានបឋមជ្ឈាន ធ្វើនូវសេចក្តីអន្តរាយដល់ការបានទុតិយជ្ឈាន ធ្វើនូវសេចក្តីអន្តរាយដល់ការ

បានតតិយជ្ឈាន ធ្វើនូវសេចក្តីអន្តរាយដល់ការបានចតុត្ថជ្ឈាន ធ្វើនូវសេចក្តីអន្តរាយដល់ការបាននូវកុសលធម៌ទាំងឡាយ គឺឈាន វិមោក្ខ សមាធិ សមាបត្តិ នេក្ខម្មៈ ការរលាស់ចេញចាកភព សេចក្តីស្ងប់ស្ងាត់។ ពាក្យថា ហេតុនោះ គឺព្រោះដំណើរនោះ។ ពាក្យថា រលឹកឃើញ គឺដឹងបានចាំបាន។ ពាក្យថា ប្រាថ្នាសេចក្តីបរិសុទ្ធ គឺប្រាថ្នាចេញចាកអាបត្តិ ប្រាថ្នាដើម្បីស្អាត។ ដែលឈ្មោះថា អាបត្តិដែលមាន គឺភិក្ខុត្រូវអាបត្តិណាក្តី ត្រូវហើយមិនចេញចាកអាបត្តិក្តី។ ពាក្យថា ត្រូវប្រាប់ គឺភិក្ខុត្រូវប្រាប់អាបត្តិក្នុងកណ្តាលសង្ឃក្តី កណ្តាលគណៈក្តី ចំពោះបុគ្គលម្នាក់ក្តី។ ពាក្យថា ព្រោះអាបត្តិដែលភិក្ខុប្រាប់ហើយជាការស្រួល គឺជាការស្រួលដើម្បីអ្វី។ ជាការស្រួលដើម្បីបានបឋមជ្ឈាន ជាការស្រួលដើម្បីបានទុតិយជ្ឈាន ជាការស្រួលដើម្បីបានតតិយជ្ឈាន ជាការស្រួលដើម្បីបានចតុត្ថជ្ឈាន ជាការស្រួលដើម្បីបានកុសលធម៌ទាំងឡាយ គឺឈាន វិមោក្ខ សមាធិ សមាបត្តិ នេក្ខម្មៈ ការរលាស់ចេញចាកភព សេចក្តីស្ងប់ស្ងាត់។

[១៥១] ក៏សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យសំដែងនូវបាតិមោក្ខហើយ ក៏សំដែងនូវបាតិមោក្ខរាល់ថ្ងៃ។ ភិក្ខុទាំងឡាយខ្លះក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងនូវបាតិមោក្ខរាល់ថ្ងៃទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសំដែងនូវបាតិមោក្ខតែក្នុងថ្ងៃឧបោសថ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យសំដែងនូវបាតិមោក្ខក្នុងថ្ងៃឧបោសថ ក៏សំដែងនូវបាតិមោក្ខក្នុង១បក្ខ៣ដង គឺក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ខ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងនូវបាតិមោក្ខក្នុង១បក្ខ ៣ដងទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសំដែងនូវបាតិមោក្ខ ១បក្ខម្តង (កន្លះខែម្តង) គឺក្នុងថ្ងៃ១៤ក្តី ទី១៥ក្តី។

[១៥២] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងនូវបាតិមោក្ខ ដោយសមគួរដល់បរិសទ្យ គឺចំពោះបរិសទ្យរបស់ខ្លួនៗ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គមានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងនូវបាតិមោក្ខ ដោយសមគួរដល់បរិសទ្យ គឺចំពោះបរិសទ្យរបស់ខ្លួនៗទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឧបោសថកម្ម ដល់ពួកភិក្ខុដែលព្រមព្រៀងគ្នា។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តឧបោសថកម្ម ដល់ភិក្ខុទាំងឡាយដែលព្រមព្រៀងគ្នា សេចក្តីព្រមព្រៀងមានកំណត់ត្រឹមណាហ្ន៎ មានកំណត់ត្រឹមអាវាសមួយ ឬផែនដីទាំងអស់។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ អាវាសមួយមានកំណត់ត្រឹមណា តថាគតអនុញ្ញាតសេចក្តីព្រមព្រៀងគ្នាមានកំណត់ត្រឹមនុ៎ះឯង។

## ៧០. មហាកប្បិនវត្ថុ

CS vin.mv.02.03 | ភាគ ទី៦

**(៧០.)**

[១៥៣] ក៏សម័យនោះឯង ព្រះមហាកប្បិនដ៏មានអាយុ នៅក្នុងមទ្ទកុច្ឆិមិគទាយវន ក្បែរក្រុងរាជគ្រឹះ។ លំដាប់នោះឯង ព្រះមហាកប្បិនដ៏មានអាយុសម្ងំនៅក្នុងទីស្ងាត់ ក៏កើតសេចក្តីត្រិះរិះឡើងក្នុងចិត្តយ៉ាងនេះថា អាត្មាអញគួរទៅកាន់ឧបោសថឬ ៗមិនគួរទៅទេ អាត្មាអញគួរទៅធ្វើសង្ឃកម្មឬ ៗមិនគួរទៅទេ ព្រោះថា អាត្មាអញបរិសុទ្ធដោយសេចក្តីបរិសុទ្ធយ៉ាងបំផុតហើយ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបការត្រិះរិះក្នុងចិត្តរបស់ព្រះមហាកប្បិនដ៏មានអាយុ ដោយព្រះហឫទ័យ ហើយទ្រង់បាត់អំពីភ្នំគិជ្ឈកូដ មកប្រាកដក្នុងទីចំពោះមុខព្រះមហាកប្បិនដ៏មានអាយុ ក្នុងមទ្ទកុច្ឆិមិគទាយវន (រហ័ស) ឧបមាដូចជាបុរសមានកំឡាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញយ៉ាងនោះឯង។ ព្រះដ៏មានព្រះភាគ គង់លើអាសនៈដែលគេតែងតាំងហើយ។ ព្រះមហាកប្បិនដ៏មានអាយុ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីគួរមួយ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលនេះនឹងព្រះមហាកប្បិនដ៏មានអាយុ ដែលគង់នៅក្នុងទីគួរមួយថា នែកប្បិន អ្នកឯងសម្ងំនៅក្នុងទីស្ងាត់ហើយកើតការត្រិះរិះក្នុងចិត្តយ៉ាងនេះថា អាត្មាអញគួរទៅកាន់ឧបោសថឬ ៗមិនគួរទៅទេ គួរទៅធ្វើសង្ឃកម្មឬ ៗមិនគួរទៅទេ ព្រោះថាអាត្មាអញបរិសុទ្ធដោយសេចក្តីបរិសុទ្ធយ៉ាងបំផុតហើយ ដូច្នេះ មែនឬ។ ព្រះមហាកប្បិនក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងហ្នឹងហើយ។ ព្រះដ៏មានព្រះភាគត្រាស់ថា អ្នកជាពួកព្រាហ្មណ៍ បើនឹងមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាឧបោសថទេ តើបាននរណានឹងធ្វើសក្ការៈ នឹងគោរព នឹងរាប់អាន នឹងបូជាឧបោសថវិញ នែព្រាហ្មណ៍ ចូរអ្នកទៅកាន់ឧបោសថ កុំខានទៅឡើយ ចូរអ្នកទៅ (ធ្វើ)សង្ឃកម្ម កុំខានទៅឡើយ។ ព្រះមហាកប្បិនដ៏មានអាយុទទួលព្រះពុទ្ធដីកាថា សូមទ្រង់ព្រះមេត្តាប្រោស យ៉ាងហ្នឹងហើយ។ លំដាប់នោះ ព្រះដ៏មានព្រះភាគឲ្យព្រះមហាកប្បិនដ៏មានអាយុឃើញត្រូវ កាន់យកត្រូវ អាចហ៊ាន រីករាយដោយធម្មីកថាហើយ ទ្រង់បាត់ទៅអំពីមុខព្រះមហាកប្បិនដ៏មានអាយុក្នុងមទ្ទកុច្ឆិមិគទាយវន ទៅប្រាកដលើភ្នំគិជ្ឈកូដ (រហ័ស) ឧបមាដូចជាបុរសមានកំឡាំង លាដើមដៃដែលបត់ចូល ឬបត់ចូលដើមដៃដែលលាចេញយ៉ាងនោះឯង។

## ៧១. សីមានុជាននា

CS vin.mv.02.04 | ភាគ ទី៦

**(៧១.)**

[១៥៤] គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តថា អាវាសមួយមានកំណត់ត្រឹមណា សេចក្តីព្រមព្រៀងមានកំណត់ត្រឹមនុ៎ះ។ ចុះអាវាសមួយនោះ តើមានកំណត់ដូចម្តេច។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសន្មតសីមា ម្នាលភិក្ខុទាំងឡាយ ក៏ឯសីមានោះ ត្រូវភិក្ខុសន្មតយ៉ាងនេះ។ ដើមដំបូង ត្រូវភិក្ខុកំណត់ (សំដែង) និមិត្រទាំងឡាយ គឺកំណត់ភ្នំជានិមិត្រ[122] ថ្មជានិមិត្រ ព្រៃជានិមិត្រ ដើមឈើជានិមិត្រ ផ្លូវជានិមិត្រ ដម្បូកជានិមិត្រ ស្ទឹងជានិមិត្រ ទឹកជានិមិត្រ លុះភិក្ខុឆ្លាស ប្រតិពលកំណត់និមិត្រទាំងឡាយហើយ ត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃ

ស្តាប់ខ្ញុំ និមិត្រទាំងឡាយដែលសង្ឃកំណត់ហើយ ដោយជុំវិញ មានកំណត់ត្រឹមណា បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃសន្មត សីមាឲ្យជាទីមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដោយនិមិត្រទាំងឡាយនេះ កំណត់ត្រឹមនោះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ និមិត្រទាំងឡាយ ដែលសង្ឃកំណត់ហើយ ដោយជុំវិញ មានកំណត់ត្រឹមណា ឥឡូវសង្ឃសន្មតសីមា ឲ្យជាទីមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដោយនិមិត្រទាំងឡាយនេះ មានកំណត់ត្រឹមនោះ។ សេចក្តីសន្មតិសីមា ឲ្យជាទីមានសំវាសស្មើគ្នា មានឧបោសថ ជាមួយគ្នា ដោយនិមិត្រទាំងឡាយនេះ គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង។ សីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា សង្ឃបានសន្មតដោយនិមិត្រទាំងឡាយនេះហើយ។ ការសន្មតិសីមានោះ គាប់ចិត្តដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[១៥៥] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតការសន្មតិសីមាហើយ ក៏សន្មតសីមាទាំងឡាយធំហួសពេក គឺទំហំ៤យោជន៍ខ្លះ ៥យោជន៍ខ្លះ ៦យោជន៍ខ្លះ។ ភិក្ខុទាំងឡាយដែលមកកាន់ទីឧបោសថ ជួនកាលមកទាន់ភិក្ខុកំពុងសំដែងបាតិមោក្ខ ជួនកាលមកដល់ ក្នុងពេលដែលភិក្ខុសំដែងបាតិមោក្ខរួចហើយ ជួនកាលក៏អាក់ខាននៅត្រឹមពាក់កណ្តាលផ្លូវ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសន្មតសីមាធំហួសពេក គឺមានទំហំ៤យោជន៍ក្តី ៥យោជន៍ក្តី ៦យោជន៍ក្តីទេ ភិក្ខុណាសន្មត ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសន្មតសីមាទំហំ៣យោជន៍យ៉ាងធំ។

[១៥៦] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសន្មតនទីបារសីមា។[123)] កាលភិក្ខុទាំងឡាយមកកាន់ឧបោសថ ក៏រសាត់ទៅតាមទឹកខ្លះ បាត្រទាំងឡាយក៏រសាត់ទៅខ្លះ ចីវរទាំងឡាយក៏រសាត់ទៅខ្លះ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសន្មតនទីបារសីមាទេ ភិក្ខុណាសន្មត ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងស្ទឹងណាមានទូកទៅមកជានិច្ច មានស្ពានតាំងនៅជានិច្ច តថាគតអនុញ្ញាតឲ្យសន្មតស្ទឹងមានសភាពយ៉ាងនោះជានទីបារសីមាបាន។

## ៧២. ឧបោសថាគារកថា

CS vin.mv.02.05 | ភាគ ទី៦

**(៧២.)**

[១៥៧] ក៏សម័យនោះឯង ភិក្ខុទាំងឡាយសំដែងបាតិមោក្ខរាល់ៗបរិវេណ ដោយមិនបានកំណត់ទី។ ពួកភិក្ខុជាអាគន្តុកៈមិនដឹងថា ថ្ងៃនេះសង្ឃនឹងធ្វើឧបោសថក្នុងទីណា។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងនូវបាតិមោក្ខរាល់ៗបរិវេណ ដោយមិនបានកំណត់ទីទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវការទីណា គឺវិហារក្តី អឌ្ឍយោគក្តី ប្រាសាទវែងក្តី ប្រាសាទដម្បូលត្រងិលក្តី គុហាក្តី តថាគតអនុញ្ញាតឲ្យភិក្ខុសន្មតទីនោះ ជារោងឧបោសថ ហើយធ្វើឧបោសថចុះ។ ម្នាលភិក្ខុទាំងឡាយ តែថាភិក្ខុត្រូវសន្មតយ៉ាងនេះ។ គឺភិក្ខុឆ្លាស ប្រតិពលត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃសន្មតលំនៅឈ្មោះនេះ ជារោងឧបោសថ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ឥឡូវសង្ឃសន្មតលំនៅឈ្មោះនេះ ជារោងឧបោសថ។ ការសន្មតិលំនៅឈ្មោះនេះ ជារោងឧបោសថ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគួរស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង។ លំនៅឈ្មោះនេះ សង្ឃបានសន្មតជារោងឧបោសថហើយ។ ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[១៥៨] ក៏សម័យនោះឯង សង្ឃសន្មតរោងឧបោសថពីរ ក្នុងអាវាសមួយ។ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងរោងឧបោសថទាំងពីរ ដោយគិតថា សង្ឃធ្វើឧបោសថក្នុងរោងឧបោសថនេះ សង្ឃធ្វើឧបោសថក្នុងរោងឧបោសថនេះ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសន្មតរោងឧបោសថពីរ ក្នុងអាវាសមួយទេ ភិក្ខុណាសន្មត ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដករោងឧបោសថមួយចេញ ហើយធ្វើឧបោសថក្នុងរោងឧបោសថមួយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវដកយ៉ាងនេះ គឺភិក្ខុដែលឆ្លាស ប្រតិពលត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃដករោងឧបោសថឈ្មោះនេះចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឥឡូវសង្ឃដករោងឧបោសថឈ្មោះនេះ។ ការដករោងឧបោសថឈ្មោះនេះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគួរស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះគួរនិយាយឡើង។ រោងឧបោសថឈ្មោះនេះ សង្ឃបានដកហើយ។ ការដករោងឧបោសថនេះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

## ៧៣. ឧបោសថប្បមុខានុជាននា

CS vin.mv.02.06 | ភាគ ទី៦

**(៧៣.)**

[១៥៩] ក៏សម័យនោះឯង សង្ឃសន្មតរោងឧបោសថតូចពេក ក្នុងអាវាសមួយ។ ឧបោសថក្នុងថ្ងៃនោះ មានភិក្ខុសង្ឃច្រើនប្រជុំគ្នា។ ភិក្ខុទាំងឡាយអង្គុយលើទីដែលសង្ឃមិនបានសន្មត ហើយស្តាប់បាតិមោក្ខ។ ទើបភិក្ខុទាំងឡាយនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយថា ភិក្ខុត្រូវសន្មតរោងឧបោសថ ហើយសឹមធ្វើឧបោសថ ក៏យើងទាំងឡាយអង្គុយលើទីដែលសង្ឃមិនបានសន្មត ហើយស្តាប់បាតិមោក្ខ ឧបោសថ ឈ្មោះថា យើងបានធ្វើ ឬមិនបានធ្វើទេ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអង្គុយលើទីដែលសង្ឃសន្មតហើយក្តី មិនបានសន្មតក្តី ស្តាប់បាតិមោក្ខក្នុងទីណា ភិក្ខុនោះឈ្មោះថា បានធ្វើ

ឧបោសថក្នុងទីនោះហើយ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃត្រូវការរបៀងឧបោសថ[124] ទំហំត្រឹមណា ចូរសន្មតរបៀងឧបោសថទំហំត្រឹមនោះចុះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ។ សង្ឃត្រូវកំណត់និមិត្រទាំងឡាយជាមុន។ ភិក្ខុដែលឆ្លាស ប្រតិពល លុះកំណត់និមិត្រទាំងឡាយហើយ ត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ និមិត្រទាំងឡាយ សង្ឃកំណត់ហើយដោយជុំវិញត្រឹមណា បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃសន្មតរបៀងឧបោសថ ដោយនិមិត្រទាំងឡាយនេះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ និមិត្រទាំងឡាយ ដែលសង្ឃកំណត់ហើយ ដោយជុំវិញត្រឹមណា ឥឡូវសង្ឃសន្មតរបៀងឧបោសថ ដោយនិមិត្រទាំងឡាយនេះ។ ការសន្មតិរបៀងឧបោសថ ដោយនិមិត្រទាំងឡាយនេះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង។ សង្ឃសន្មតរបៀងឧបោសថ ដោយនិមិត្រទាំងឡាយនេះហើយ។ ការសន្មតិរបៀងឧបោសថនោះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[១៦០] ក៏សម័យនោះឯង ក្នុងអាវាសមួយ ពួកភិក្ខុខ្ចីវស្សា ប្រជុំគ្នាមុន ក្នុងថ្ងៃដែលធ្វើឧបោសថនោះ ហើយចៀសចេញទៅ ដោយគិតថា ព្រះថេរៈទាំងឡាយមិនមកទេ។ ឧបោសថក៏នៅជាគ្មានកំណត់កាល។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយជាថេរៈ ប្រជុំគ្នាមុន ក្នុងថ្ងៃដែលធ្វើឧបោសថនោះ។

[១៦១] ក៏សម័យនោះឯង ក្នុងក្រុងរាជគ្រឹះ មានអាវាសជាច្រើន តែមានសីមាស្មើគ្នា (មានសីមាតែមួយ)។ ភិក្ខុទាំងឡាយក្នុងអាវាសទាំងនោះជជែកគ្នាថា ចូរសង្ឃធ្វើឧបោសថក្នុងអាវាសយើងវិញ ចូរសង្ឃធ្វើឧបោសថក្នុងអាវាសយើងវិញ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងទីនេះ មានអាវាសច្រើន មានសីមាស្មើគ្នា ភិក្ខុទាំងឡាយក្នុងអាវាសទាំងនោះជជែកគ្នាថា ចូរសង្ឃធ្វើឧបោសថក្នុងអាវាសយើងវិញ ចូរសង្ឃធ្វើឧបោសថក្នុងអាវាសយើងវិញ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយទាំងអស់នោះប្រជុំធ្វើឧបោសថជាមួយគ្នា តែថាភិក្ខុជាថេរៈនៅក្នុងទីណា ត្រូវសង្ឃប្រជុំគ្នាធ្វើឧបោសថក្នុងទីនោះ មិនត្រូវសង្ឃធ្វើឧបោសថជាពួកឡើយ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។

## ៧៤. អវិប្បវាសសីមានុជានានា

CS vin.mv.02.07 | ភាគ ទី៦

**(៧៤.)**

[១៦២] សម័យនោះឯង ព្រះមហាកស្សបដ៏មានអាយុចេញពីស្រុកឈ្មោះអន្ធកវិន្ទ មកកាន់ឧបោសថក្នុងក្រុងរាជគ្រឹះ ឆ្លងស្ទឹងពាក់កណ្តាលផ្លូវ ត្រូវទឹកកួចទៅបន្តិច ចីវរទាំងឡាយរបស់លោកក៏ទទឹកអស់។ ភិក្ខុទាំងឡាយបាននិយាយពាក្យនេះនឹងព្រះមហាកស្សបដ៏មានអាយុថា នែអាវុសោ ហេតុអ្វីក៏ចីវររបស់អ្នកទទឹកអស់។ ព្រះមហាកស្សបនិយាយថា ម្នាលអាវុសោ ខ្ញុំចេញពីស្រុកឈ្មោះអន្ធកវិន្ទ មកកាន់ឧបោសថក្នុងក្រុងរាជគ្រឹះនេះ ឆ្លងស្ទឹងពាក់កណ្តាលផ្លូវ ត្រូវទឹកកួចទៅបន្តិច ហេតុនោះចីវរទាំងឡាយរបស់ខ្ញុំទទឹកអស់។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ សីមាណាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ដែលសង្ឃសន្មតហើយ ចូរសង្ឃសន្មតសីមានោះឲ្យជាតិចីវរាវិប្បវាសសីមាចុះ។[125] ម្នាលភិក្ខុទាំងឡាយ ក៏ឯសីមា ត្រូវសង្ឃសន្មតយ៉ាងនេះ។ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សីមាណាដែលសង្ឃសន្មតហើយ ឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃសន្មតសីមានោះឲ្យជាតិចីវរាវិប្បសសីមា។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សីមាឯណាដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ឥឡូវសង្ឃសន្មតសីមានោះ ឲ្យជាតិចីវរាវិប្បវាសសីមា។ ការសន្មតិសីមានេះ ឲ្យជាតិចីវរាវិប្បវាសសីមា គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង។ សង្ឃសន្មតសីមានោះ ឲ្យជាតិចីវរាវិប្បវាសសីមាហើយ ការសន្មតិនោះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ការសន្មតិនូវតិចីវរាវិប្បវាសសីមា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ ក៏ទុកចីវរទាំងឡាយក្នុងចន្លោះផ្ទះ។ ចីវរទាំងឡាយនោះវិនាសទៅខ្លះ ត្រូវភ្លើងឆេះខ្លះ ត្រូវកណ្តុរទាំងឡាយកាត់ខ្លះ។ ភិក្ខុទាំងឡាយមានសម្តត់អាក្រក់ មានចីវរសៅហ្មង។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា នែអាវុសោ ហេតុអ្វីក៏អ្នកទាំងឡាយមានសម្តត់អាក្រក់ មានចីវរសៅហ្មង។ ភិក្ខុទាំងឡាយនោះនិយាយថា នែអាវុសោ យើងទាំងឡាយដឹងថា ការសន្មតិនូវតិចីវរាវិប្បវាសសីមា ព្រះដ៏មានព្រះភាគអនុញ្ញាតហើយ ក៏ទុកចីវរទាំងឡាយក្នុងចន្លោះផ្ទះនេះ ចីវរទាំងឡាយនោះបាត់ទៅខ្លះ ត្រូវភ្លើងឆេះខ្លះ ត្រូវកណ្តុរទាំងឡាយកាត់ខ្លះ ហេតុនោះ ទើបយើងមានសម្តត់អាក្រក់ មានចីវរសៅហ្មង។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ សីមាណាដែលសង្ឃសន្មត ឲ្យមានសំវាសស្មើគ្នា ឲ្យមានឧបោសថជាមួយគ្នា ចូរសង្ឃសន្មតសីមានោះឲ្យជាតិចីវរាវិប្បវាសសីមាចុះ លើកទុកតែស្រុក និងឧបចារៈរបស់ស្រុកចេញ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯសីមានោះ ត្រូវសង្ឃសន្មតយ៉ាងនេះ។ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សីមាណាដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃសន្មតសីមានោះឲ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុក និងឧបចារៈរបស់ស្រុកចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ។ សីមាណាដែលសង្ឃសន្មតឲ្យមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ឥឡូវសង្ឃសន្មតសីមានោះ ឲ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុក និងឧបចារៈរបស់ស្រុកចេញ។ ការសន្មតិសីមានេះ ឲ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុក និងឧបចារៈរបស់ស្រុកចេញ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង។ សង្ឃបានសន្មតសីមានោះ ឲ្យជាតិចីវរាវិប្បវាសសីមា លើកទុកតែស្រុក និងឧបចារៈរបស់ស្រុកចេញហើយ។ ការសន្មតិនោះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

## ៧៥. សីមាសមូហនន

**(៧៥.)**

[១៦៣] ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុនឹងសន្មតសីមា ត្រូវសន្មតសមានសំវាសសីមា[126] ជាមុន សឹមសន្មតតិចីវរាវិប្បវាសសីមា[127] ជាខាងក្រោយ។ ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុនឹងដកសីមា ត្រូវដកតិចីវរាវិប្បវាសសីមាជាមុន សឹមដកសមានសំវាសសីមាជាខាងក្រោយ។ ម្នាលភិក្ខុទាំងឡាយ ឯតិចីវរាវិប្បវាសសីមា ត្រូវភិក្ខុដកយ៉ាងនេះ។ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ តិចីវរាវិប្បវាសសីមាណា ដែលសង្ឃសន្មតហើយ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវដកតិចីវរាវិប្បវាសសីមានោះចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ តិចីវរាវិប្បវាសសីមាណា ដែលសង្ឃសន្មតហើយ ឥឡូវសង្ឃដកតិចីវរាវិប្បវាសសីមានោះចេញ។ ការដកនូវតិចីវរាវិប្បវាសសីមានេះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង។ តិចីវរាវិប្បវាសសីមានោះសង្ឃបានដកហើយ។ ការដកនូវតិចីវរាវិប្បវាសសីមានោះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ឯសមានសំវាសសីមា ត្រូវភិក្ខុដកយ៉ាងនេះ។ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សីមាណា ដែលសង្ឃសន្មត ឲ្យជាសមានសំវាសសីមា ឲ្យមានឧបោសថជាមួយគ្នាហើយ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃដកសីមានោះចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សីមាណា ដែលសង្ឃសន្មត ឲ្យជាសមានសំវាសសីមា ឲ្យមានឧបោសថជាមួយគ្នាហើយ ឥឡូវសង្ឃដកសីមានោះចេញ។ ការដកសីមា ដែលមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានេះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា គួរលោកដ៏មានអាយុអង្គនោះនិយាយឡើង។ សង្ឃដកសីមា ដែលមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នានោះហើយ។ ការដក សមានសំវាសសីមានោះ គាប់ចិត្តដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

## ៧៦. គាមសីមាទិ



**(៧៦.)**

[១៦៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលទៅអាស្រ័យស្រុកណាក្តី និគមណាក្តី ហើយនៅក្នុងសីមាដែលសង្ឃមិនបានសន្មត មិនបានតាំងទុកហើយ សីមាណាដែលជាគាមសីមា របស់ស្រុកនោះក្តី សីមាណាដែលជានិគមសីមារបស់និគមនោះក្តី សីមានេះហៅថា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ក្នុងស្រុក ឬក្នុងនិគមនោះ។ ម្នាលភិក្ខុទាំងឡាយ បើក្នុងព្រៃ មិនមែនស្រុក សីមាដែលកំណត់៧អព្ភន្តរៈ[128] ដោយជុំវិញ សីមានេះហៅថា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ក្នុងព្រៃនោះ។ ម្នាលភិក្ខុទាំងឡាយ ស្ទឹង[129] ទាំងអស់មិនមែនជាសីមា សមុទ្ទទាំងអស់មិនមែនជាសីមា ជាតស្រះ[130] ទាំងអស់មិនមែនជាសីមា។ ម្នាលភិក្ខុទាំងឡាយ ទីណាដែលបុគ្គលកំណត់ ដោយសាចទឹករបស់មជ្ឈិមបុរសដោយជុំវិញក្នុងស្ទឹងក្តី ក្នុងសមុទ្ទក្តី ក្នុងជាតស្រះក្តី ទីនេះហៅថា មានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ក្នុងទីមានស្ទឹងជាដើមនោះ។

[១៦៥] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទំលាយ[131] សីមាដោយសីមា។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ សីមាដែលភិក្ខុទាំងឡាយណាសន្មតមុនហើយ កម្មនោះរបស់ភិក្ខុទាំងឡាយនោះ ប្រកបដោយធម៌មិនកម្រើក គួរតាំងនៅបាន ម្នាលភិក្ខុទាំងឡាយ សីមាដែលភិក្ខុទាំងឡាយណាសន្មតជាខាងក្រោយ កម្មនោះរបស់ភិក្ខុទាំងឡាយនោះ មិនប្រកបដោយធម៌ ជាកម្មកម្រើក មិនគួរតាំងនៅបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទំលាយសីមា[132] ដោយសីមាទេ ភិក្ខុណាទំលាយ ត្រូវអាបត្តិទុក្កដ។ ក៏សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយគ្រប់សង្កត់សីមាដោយសីមា។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ សីមាដែលភិក្ខុទាំងឡាយណាសន្មតមុនហើយ កម្មនោះរបស់ភិក្ខុទាំងឡាយនោះ ប្រកបដោយធម៌ ជាកម្មមិនកម្រើក គួរតាំងនៅបាន ម្នាលភិក្ខុទាំងឡាយ សីមាដែលភិក្ខុទាំងឡាយណាសន្មតជាខាងក្រោយ កម្មនោះរបស់ភិក្ខុទាំងឡាយនោះ មិនប្រកបដោយធម៌ ជាកម្មកម្រើក មិនគួរតាំងនៅបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវគ្របសង្កត់សីមា[133] ដោយសីមាទេ ភិក្ខុណាគ្របសង្កត់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសន្មតសីមា ឲ្យដម្កល់ទុកនូវសីមន្តរិក[134] ហើយសឹមសន្មតសីមា។

## ៧៧. ឧបោសថភេទាទិ



**(៧៧.)**

[១៦៦] គ្រានោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ឧបោសថមានប៉ុន្មានយ៉ាងហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ឧបោសថទាំងនេះមានពីរយ៉ាងគឺ ឧបោសថមានក្នុងតិថីទី១៤មួយ ឧបោសថមានក្នុងតិថីទី១៥មួយ ម្នាលភិក្ខុទាំងឡាយ ឧបោសថមានតែពីរយ៉ាងប៉ុណ្ណេះ។ លំដាប់នោះឯង ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ឧបោសថកម្មមានប៉ុន្មានយ៉ាងហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ទ្រង់មានបន្ទូលថា ឧបោសថកម្មទាំងនេះមាន៤គឺ ឧបោសថកម្មជាពួក មិនត្រូវតាមធម៌១ ឧបោសថកម្មព្រមព្រៀងគ្នា តែមិនត្រូវតាមធម៌១ ឧបោសថកម្មជាពួក តែត្រូវតាមធម៌១ ឧបោសថកម្មព្រមព្រៀងត្រូវតាមធម៌១។ ម្នាលភិក្ខុទាំងឡាយ ជំនុំឧបោសថកម្មទាំង៤នេះ ឯឧបោសថកម្មដែលជាពួក មិនត្រូវតាមធម៌ណា ម្នាលភិក្ខុ

ទាំងឡាយ មិនត្រូវអ្នកទាំងឡាយធ្វើឧបោសថកម្មមានសភាពយ៉ាងនេះទេ ម្យ៉ាងទៀត តថាគតមិនអនុញ្ញាតឧបោសថកម្មមានសភាពយ៉ាងនេះទេ។ ម្នាលភិក្ខុទាំងឡាយ ជំនុំឧបោសថកម្មទាំង៤នោះ ឯឧបោសថកម្មដែលព្រមព្រៀងគ្នា តែមិនត្រូវតាមធម៌ណា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអ្នកទាំងឡាយធ្វើឧបោសថកម្មមានសភាពយ៉ាងនេះទេ ម្យ៉ាងទៀត តថាគតមិនអនុញ្ញាតឧបោសថកម្មមានសភាពយ៉ាងនេះទេ។ ម្នាលភិក្ខុទាំងឡាយ ជំនុំឧបោសថកម្មទាំង៤នោះ ឯឧបោសថកម្មដែលជាពួក តែត្រូវតាមធម៌ណា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអ្នកទាំងឡាយធ្វើឧបោសថកម្មមានសភាពយ៉ាងនេះទេ ម្យ៉ាងទៀត តថាគតក៏មិនអនុញ្ញាតឧបោសថកម្មមានសភាពយ៉ាងនេះឡើយ។ ម្នាលភិក្ខុទាំងឡាយ ជំនុំឧបោសថកម្មទាំង៤នោះ ឯឧបោសថកម្មដែលព្រមព្រៀងគ្នា ត្រូវតាមធម៌ណា ម្នាលភិក្ខុទាំងឡាយ ត្រូវអ្នកទាំងឡាយធ្វើឧបោសថកម្មមានសភាពយ៉ាងនេះ តថាគតអនុញ្ញាតឧបោសថកម្មមានសភាពយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ ភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាថា យើងនឹងធ្វើឧបោសថកម្មដែលព្រមព្រៀងគ្នា ត្រូវតាមធម៌ មានសភាពយ៉ាងនេះដូច្នេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវអ្នកទាំងឡាយសិក្សាយ៉ាងនេះឯង។

## ៧៨. សំខិត្តេន បាតិមោក្ខុទ្ទេសាទិ

CS vin.mv.02.11 | ភាគ ទី៦

**(៧៨.)**

[១៦៧] គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា បាតិមោក្ខុទ្ទេសទាំងឡាយ មានប៉ុន្មានយ៉ាងហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ បាតិមោក្ខុទ្ទេសទាំងនេះមាន៥គឺ ភិក្ខុត្រូវសំដែងនូវនិទាន ហើយសូត្រនូវឧទ្ទេសដ៏សេសសល់ដោយសុតបទ[135] នេះជាបាតិមោក្ខុទ្ទេសទី១។ ភិក្ខុត្រូវសំដែងនូវនិទាន ហើយសំដែងនូវបារាជិកទាំង៤ ហើយសូត្រឧទ្ទេសដែលសេសសល់ដោយសុតបទ នេះជាបាតិមោក្ខុទ្ទេសទី២។ ត្រូវភិក្ខុសំដែងនូវនិទាន ហើយសំដែងនូវបារាជិក៤ សំដែងនូវសង្ឃាទិសេស១៣ ហើយសូត្រនូវឧទ្ទេសដែលសេសសល់ដោយសុតបទ នេះជាបាតិមោក្ខុទ្ទេសទី៣។ ភិក្ខុត្រូវសំដែងនូវនិទាន ហើយសំដែងនូវបារាជិកទាំង៤ សំដែងនូវសង្ឃាទិសេស១៣ សំដែងនូវអនិយត២ ហើយសូត្រឧទ្ទេសដ៏សេសសល់ដោយសុតបទ នេះជាបាតិមោក្ខុទ្ទេសទី៤។ ឧទ្ទេសដោយពិស្ដារជាបាតិមោក្ខុទ្ទេសទី៥។ ម្នាលភិក្ខុទាំងឡាយ បាតិមោក្ខុទ្ទេសមាន៥យ៉ាងប៉ុណ្ណេះឯង។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះដ៏មានព្រះភាគអនុញ្ញាតការសំដែងនូវបាតិមោក្ខដោយសង្ខេបហើយ ក៏សំដែងនូវបាតិមោក្ខដោយសង្ខេប សព្វកាល (រាល់ៗថ្ងៃឧបោសថ)។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងនូវបាតិមោក្ខដោយសង្ខេបទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ក៏សម័យនោះឯង ក្នុងអាវាសមួយ ក្នុងកោសលជនបទ មានសព៌រភ័យ[136] ក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងឡាយមិនអាចនឹងសំដែងនូវបាតិមោក្ខដោយពិស្ដារបាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្ដីអន្តរាយ តថាគតអនុញ្ញាតឲ្យសំដែងនូវបាតិមោក្ខដោយសង្ខេបបាន។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ សូម្បីមិនមានសេចក្ដីអន្តរាយ ក៏សំដែងនូវបាតិមោក្ខដោយសង្ខេប។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ កាលបើគ្មានសេចក្ដីអន្តរាយ ភិក្ខុមិនត្រូវសំដែងបាតិមោក្ខដោយសង្ខេបទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសំដែងនូវបាតិមោក្ខដោយសង្ខេបបាន ក្នុងពេលដែលមានសេចក្ដីអន្តរាយ។ ឯអន្តរាយក្នុងពេលដែលសំដែងបាតិមោក្ខនោះ (មាន១០យ៉ាងគឺ) អន្តរាយអំពីស្ដេច (គឺមានស្ដេចយាងចូលមក) អន្តរាយអំពីចោរ (គឺមានចោរចូលមកលុកលុយ) អន្តរាយអំពីភ្លើង (គឺមានភ្លើងព្រៃឆេះរាលមក ឬភ្លើងអន្ទះកើតឡើង) អន្តរាយអំពីទឹក (គឺមានភ្លៀងខ្លាំង ឬជំនន់ហូរមក) អន្តរាយអំពីមនុស្ស (គឺមានមនុស្សច្រើនចូលមក) អន្តរាយអំពីអមនុស្ស (គឺខ្មោចចូលភិក្ខុ) អន្តរាយអំពីសត្វសាហាវ អំពីសត្វទីឃជាតិ (ពួកសត្វលូនវារ) អន្តរាយដល់ជីវិត (គឺមានភិក្ខុកើតជម្ងឺស្លាប់ ឬមានមនុស្សមានពៀរប៉ងសម្លាប់ភិក្ខុ) អន្តរាយដល់ព្រហ្មចារ្យ (គឺមានមនុស្សមកចាប់ភិក្ខុផ្សឹក)។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្ដីអន្តរាយទាំងឡាយបែបយ៉ាងនេះ តថាគតអនុញ្ញាតឲ្យភិក្ខុសំដែងនូវបាតិមោក្ខដោយសង្ខេបបាន កាលបើមិនមានសេចក្ដីអន្តរាយទេ ឲ្យភិក្ខុសំដែងដោយពិស្ដារ។

[១៦៨] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនមានគេអារាធនា ក៏សំដែងធម៌ក្នុងកណ្ដាលសង្ឃ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគេមិនអារាធនា មិនត្រូវសំដែងធម៌ក្នុងកណ្ដាលសង្ឃទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈសំដែងធម៌ខ្លួនឯង ឬអារាធនាភិក្ខុដទៃបាន។

## ៧៩. វិនយបុច្ឆនកថា

CS vin.mv.02.12 | ភាគ ទី៦

**(៧៩.)**

[១៦៩] ក៏សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ មិនទាន់បានការសន្មតិ ក៏សួរវិន័យ ក្នុងកណ្ដាលសង្ឃ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគ្មានកាសន្មតិ មិនត្រូវសួរវិន័យ ក្នុងកណ្ដាលសង្ឃទេ ភិក្ខុណាសួរ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានការសន្មតិ សួរវិន័យ ក្នុងកណ្ដាលសង្ឃបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវសន្មតយ៉ាងនេះ។ ត្រូវសន្មតខ្លួន ដោយខ្លួនឯងក៏បាន ត្រូវភិក្ខុដទៃសន្មតភិក្ខុដទៃក៏បាន។ ក៏ឯសន្មតខ្លួន ដោយខ្លួនឯងនោះដូចម្ដេច។ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំសូមសួរវិន័យនឹងភិក្ខុឈ្មោះនេះ។ ភិក្ខុត្រូវសន្មតខ្លួនដោយខ្លួនឯងយ៉ាងនេះ។ ក៏ឯភិក្ខុដទៃ ត្រូវសន្មតភិក្ខុដទៃដូចម្ដេច។ ត្រូវភិក្ខុដែលឆ្លាសប្រតិពល ឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ភិក្ខុឈ្មោះនេះ គួរសួរវិន័យនឹងភិក្ខុឈ្មោះនេះ។ ត្រូវភិក្ខុដទៃសន្មតភិក្ខុដទៃយ៉ាងនេះ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយ មានសីលជាទីស្រឡាញ់ មានការសន្មតិហើយ ក៏សួរវិន័យក្នុងកណ្ដាលសង្ឃ។ ពួកឆព្វគ្គិយភិក្ខុបានសេចក្ដីគំនុំ បានសេចក្ដីមិនពេញចិត្ត ក៏គម្រាមដោយប្រុងនឹងសម្លាប់។ ភិក្ខុទាំងឡាយក្រាបទូល

ដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលទុកជាមានការសន្មតិហើយមែន ត្រូវតែរមិលមើលបរិសទ្យ ពិចារណាបុគ្គលហើយសិន សិមសួរវិន័យក្នុងកណ្ដាលសង្ឃ។

## ៨០. វិនយវិស្សជ្ជនកថា

CS vin.mv.02.13 | ភាគ ទី៦

**(៨០.)**

ក៏សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ គ្មានការសន្មតិក៏ដោះស្រាយវិន័យក្នុងកណ្ដាលសង្ឃ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគ្មានការសន្មតិ មិនត្រូវដោះស្រាយវិន័យក្នុងកណ្ដាលសង្ឃទេ ភិក្ខុណាដោះស្រាយ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានការសន្មតិហើយ ដោះស្រាយវិន័យក្នុងកណ្ដាលសង្ឃបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវសន្មតយ៉ាងនេះ។ ត្រូវខ្លួនឯងសន្មតខ្លួនក៏បាន ភិក្ខុដទៃសន្មតភិក្ខុដទៃក៏បាន។ ក៏ឯខ្លួនឯងសន្មតខ្លួនឯង តើដូចម្ដេច។ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ភិក្ខុឈ្មោះនេះ សួរវិន័យនឹងខ្ញុំហើយ ខ្ញុំត្រូវតែដោះស្រាយ។ ត្រូវខ្លួនឯងសន្មតខ្លួនឯងយ៉ាងនេះ។ ក៏ឯភិក្ខុដទៃ សន្មតភិក្ខុដទៃ តើដូចម្ដេច។ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ ភិក្ខុឈ្មោះនេះ ត្រូវដោះស្រាយវិន័យដែលភិក្ខុឈ្មោះនេះសួរ។ ត្រូវភិក្ខុដទៃសន្មតភិក្ខុដទៃយ៉ាងនេះ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយ មានសីលជាទីស្រឡាញ់ បានការសន្មតិហើយ ក៏ដោះស្រាយវិន័យក្នុងកណ្ដាលសង្ឃ។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយបានសេចក្ដីគំនុំ បានសេចក្ដីមិនគាប់ចិត្ត ក៏គម្រាមប្រុងនឹងសម្លាប់។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ដែលទុកជាមានការសន្មតិហើយមែន ត្រូវតែរមិលមើលបរិសទ្យ ពិនិត្យបុគ្គលហើយសិន សិមដោះស្រាយវិន័យក្នុងកណ្ដាលសង្ឃ។

## ៨១. ចោទនាកថា

CS vin.mv.02.14 | ភាគ ទី៦

**(៨១.)**

[១៧០] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ចោទអាបត្តិចំពោះភិក្ខុដែលខ្លួនមិនទាន់បានសូមឱកាស (ជាមុន)។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចោទអាបត្តិចំពោះភិក្ខុ ដែលខ្លួនមិនបានសូមឱកាស (ជាមុន)ទេ ភិក្ខុណាចោទ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសូមឱកាសថា សូមលោកដ៏មានអាយុបើកឱកាស(ឲ្យខ្ញុំ) ខ្ញុំចង់និយាយនឹងលោក ដូច្នេះហើយសិន សិមចោទអាបត្តិ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយ មានសីលជាទីស្រឡាញ់ ឲ្យពួកឆព្វគ្គិយភិក្ខុបើកឱកាស ហើយចោទអាបត្តិ។ ពួកឆព្វគ្គិយភិក្ខុបានសេចក្ដីគំនុំ បានសេចក្ដីមិនត្រេកអរ ក៏គម្រាមដោយប្រាថ្នានឹងសម្លាប់។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដទៃបើកឱកាសឲ្យហើយមែន តថាគតអនុញ្ញាតឲ្យពិនិត្យមើលបុគ្គលហើយសិន សិមចោទអាបត្តិ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ គង់តែឲ្យយើងបើកឱកាសជាមុន (មិនខាន) ហើយក៏ឲ្យភិក្ខុទាំងឡាយ ដែលបរិសុទ្ធ មិនមានអាបត្តិ បើកឱកាសជាមុនក្នុងការមិនមែនជារឿង មិនមែនជាហេតុ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យភិក្ខុទាំងឡាយ ដែលបរិសុទ្ធ មិនមានអាបត្តិ បើកឱកាសក្នុងការមិនមែនជារឿង មិនមែនជាហេតុទេ ភិក្ខុណាឲ្យបើក (ឱកាស) ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុពិនិត្យមើលបុគ្គលហើយសិន សិមឲ្យគេបើកឱកាស។

## ៨២. អធម្មកម្មបដិក្កោសនាទិ

CS vin.mv.02.15 | ភាគ ទី៦

**(៨២.)**

[១៧១] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ធ្វើកម្មមិនមែនជាធម៌ ក្នុងកណ្ដាលសង្ឃ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកម្មមិនមែនជាធម៌ ក្នុងកណ្ដាលសង្ឃ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះ នៅតែធ្វើកម្មមិនមែនជាធម៌ដដែល។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុណាមួយធ្វើកម្មមិនប្រកបដោយធម៌ តថាគតអនុញ្ញាតឲ្យភិក្ខុហាមឃាត់បាន។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយ មានសីលជាទីស្រឡាញ់ កាលបើពួកឆព្វគ្គិយភិក្ខុធ្វើកម្មមិនមែនជាធម៌ ក៏ហាមឃាត់។ ពួកឆព្វគ្គិយភិក្ខុ បានសេចក្ដីគំនុំ បានសេចក្ដីមិនសប្បាយចិត្ត ក៏គម្រាមដោយប្រុងសម្លាប់។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រកាសសេចក្ដីយល់ឃើញក៏បាន។ ភិក្ខុទាំងឡាយប្រកាសសេចក្ដីយល់ឃើញក្នុងសំណាក់ឆព្វគ្គិយភិក្ខុទាំងឡាយនោះឯង។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយ បានសេចក្ដីគំនុំ បានសេចក្ដីមិនសប្បាយចិត្ត ក៏គម្រាមដោយប្រុងនឹងសម្លាប់។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ៤ ឬ៥រូប ហាមឃាត់ ឲ្យភិក្ខុ២ ឬ៣រូប ប្រកាសសេចក្ដីយល់ឃើញ ឲ្យភិក្ខុ១រូប អធិដ្ឋាន (តាំងចិត្ត)ថា កម្មនោះមិនគាប់ចិត្តដល់អញទេ។

[១៧២] ក៏សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ កាលសំដែងនូវបាតិមោក្ខ ក្នុងកណ្តាលសង្ឃ ក៏ក្លែង ធ្វើមិនឲ្យឮច្បាស់។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកសំដែងនូវបាតិមោក្ខ មិនត្រូវក្លែង មិនឲ្យឮច្បាស់ទេ ភិក្ខុណាមិនឲ្យឮច្បាស់ ត្រូវអាបត្តិទុក្កដ។ ក៏សម័យនោះឯង ឧទាយិដ៏មានអាយុ ជាអ្នកសំដែងបាតិមោក្ខដល់សង្ឃ មានសំឡេងដូចក្អែក។ ទើបឧទាយិដ៏មានអាយុមានសេចក្តីគិតដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយថា ត្រូវភិក្ខុអ្នកសំដែងនូវបាតិមោក្ខ ធ្វើសំឡេងឲ្យឮច្បាស់ ឯអាត្មាអញមានសំឡេងដូចក្អែក គួរអញប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកសំដែងនូវបាតិមោក្ខ ខំប្រឹងគិតថា អញត្រូវធ្វើសំឡេងឲ្យឮច្បាស់ ដោយបការដូចម្តេច កាលបើភិក្ខុខំប្រឹង (ដូច្នេះ) ទើបមិនត្រូវអាបត្តិ។

[១៧៣] ក៏សម័យនោះឯង ទេវទត្ត សំដែងនូវបាតិមោក្ខ ក្នុងបរិសទ្យ ព្រមជាមួយនឹងគ្រហស្ថ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុសំដែងនូវបាតិមោក្ខ ក្នុងបរិសទ្យ ជាមួយនឹងគ្រហស្ថទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។

[១៧៤] ក៏សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ មិនមានភិក្ខុអារាធនា ក៏សំដែងនូវបាតិមោក្ខ ក្នុងកណ្តាលសង្ឃ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនមានគេអារាធនា មិនត្រូវសំដែងនូវបាតិមោក្ខ ក្នុងកណ្តាលសង្ឃទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបាតិមោក្ខមានព្រះថេរៈជាធំ។

ចប់ អញ្ញតិត្ថិយភាណវារៈទី១១។

## ៨៣. បាតិមោក្ខុទ្ទេសកអជ្ឈេសនាទិ

CS vin.mv.02.16 | ភាគ ទី៦

**(៨៣.)**

[១៧៥] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅកាន់ចោទនាវត្ថុនគរ ទ្រង់ត្រាច់ទៅដោយលំដាប់ ទើបបានទៅដល់ចោទនាវត្ថុនគរនោះ។ សម័យនោះឯង ភិក្ខុច្រើនអង្គនៅក្នុងអាវាសមួយ។ ភិក្ខុជាថេរៈក្នុងអាវាសនោះល្ងង់ មិនឆ្លាស។ ភិក្ខុជាថេរៈនោះមិនដឹងឧបោសថ ឬឧបោសថកម្មបាតិមោក្ខ ឬបាតិមោក្ខុទ្ទេស។ ទើបភិក្ខុទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តថា បាតិមោក្ខមានព្រះថេរៈជាធំ ក៏ព្រះថេរៈរបស់យើងនេះល្ងង់ មិនឆ្លាស មិនដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស ត្រូវយើងប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនោះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវបាតិមោក្ខសម្រេចលើភិក្ខុដែលឆ្លាស ប្រតិពល ក្នុងអាវាសនោះ។

[១៧៦] ក៏សម័យនោះឯង ឧបោសថថ្ងៃនោះ មានភិក្ខុច្រើនរូបនៅក្នុងអាវាសមួយ សុទ្ធតែល្ងង់ មិនឆ្លាស។ ភិក្ខុទាំងនោះមិនដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស។ ភិក្ខុទាំងនោះអារាធនាព្រះថេរៈថា បពិត្រព្រះថេរៈដ៏ចំរើន សូមព្រះថេរៈសំដែងនូវបាតិមោក្ខ។ ព្រះថេរៈនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសំដែងបាតិមោក្ខមិនកើតទេ។ ភិក្ខុទាំងនោះ អារាធនាព្រះថេរៈទី២ថា បពិត្រព្រះថេរៈដ៏ចំរើន សូមព្រះថេរៈសំដែងនូវបាតិមោក្ខ។ ព្រះថេរៈទី២នោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសំដែងមិនកើតទេ។ ភិក្ខុទាំងនោះ អារាធនាព្រះថេរៈទី៣ថា បពិត្រព្រះថេរៈដ៏ចំរើន សូមព្រះថេរៈសំដែងនូវបាតិមោក្ខ។ ព្រះថេរៈទី៣នោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសំដែងមិនកើតទេ។ ភិក្ខុទាំងនោះ អារាធនាដរាបដល់ភិក្ខុថ្មីក្នុងសង្ឃ ដោយឧបាយនេះឯងថា ចូរលោកដ៏មានអាយុសំដែងនូវបាតិមោក្ខ។ ភិក្ខុនោះ ក៏និយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន ខ្ញុំសំដែងមិនកើតទេ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ឧបោសថថ្ងៃនោះមានភិក្ខុច្រើនរូប ជាភិក្ខុល្ងង់ មិនឆ្លាស នៅក្នុងអាវាសមួយ។ ភិក្ខុទាំងឡាយនោះមិនដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស។ ភិក្ខុទាំងនោះអារាធនាព្រះថេរៈថា បពិត្រព្រះថេរៈដ៏ចំរើន សូមព្រះថេរៈសំដែងនូវបាតិមោក្ខ។ ព្រះថេរៈនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសូត្រមិនកើតទេ។ ភិក្ខុទាំងនោះ អារាធនាព្រះថេរៈទី២ថា បពិត្រព្រះថេរៈដ៏ចំរើន សូមព្រះថេរៈសំដែងនូវបាតិមោក្ខ។ ព្រះថេរៈទី២នោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសំដែងមិនកើតទេ។ ភិក្ខុទាំងនោះ អារាធនាព្រះថេរៈទី៣ថា បពិត្រព្រះថេរៈដ៏ចំរើន សូមព្រះថេរៈសំដែងនូវបាតិមោក្ខ។ ព្រះថេរៈទី៣នោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំសូត្រមិនកើតទេ។ ភិក្ខុទាំងនោះ អារាធនាដរាបដល់ភិក្ខុថ្មីក្នុងសង្ឃ ដោយឧបាយនេះឯងថា លោកដ៏មានអាយុ ចូរសំដែងនូវបាតិមោក្ខ។ ភិក្ខុនោះ ក៏និយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន ខ្ញុំសូត្រមិនកើតទេ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបញ្ជូនភិក្ខុ១រូប ទៅកាន់អាវាសដែលមាននៅជិតខាងក្នុងថ្ងៃនោះឯងថា នែអាវុសោ ចូរអ្នកទៅរៀនបាតិមោក្ខដោយសង្ខេប ឬដោយពិស្តារមក។ លំដាប់នោះឯង ភិក្ខុទាំងឡាយមានសេចក្តីគិតដូច្នេះថា យើងត្រូវបញ្ជូនលោកណាទៅហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុថ្មីបាន។ ភិក្ខុថ្មីទាំងឡាយដែលព្រះថេរៈបង្គាប់ហើយ មិនទៅ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្មានជម្ងឺ បើព្រះថេរៈបង្គាប់ហើយ ត្រូវតែទៅ ភិក្ខុណាមិនទៅ ត្រូវអាបត្តិទុក្កដ។

## ៨៤. បក្ខគណនាទិឧគ្គហណានុជាននា

CS vin.mv.02.17 | ភាគ ទី៦

**(៨៤.)**

[១៧៧] លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងចោទនាវត្ថុនគរ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញទៀត។ ក៏សម័យនោះឯង មនុស្សទាំងឡាយសួរពួក ភិក្ខុដែលកំពុងត្រាច់ទៅបិណ្ឌបាតថា បពិត្រលោកដ៏ចំរើន តិថីនៃបក្ខបានប៉ុន្មានហើយ (គឺប៉ុន្មានកើត ប៉ុន្មានរោចហើយ)។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា នែអាវុសោ យើងមិនដឹងទេ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាកូនចៅព្រះពុទ្ធជាសក្យៈទាំងនេះ ត្រឹមតែវិជ្ជារាប់បក្ខ (ប៉ុណ្ណោះ) មិនដឹងទៅហើយ។ ចំណង់បើការល្អណាមួយដទៃទៀត ធ្វើម្តេចពួកសមណៈទាំងនេះនឹងដឹងបាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរៀនរាប់បក្ខ។[137] ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណារៀនរាប់បក្ខហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងអស់គ្នារៀនរាប់បក្ខ។ សម័យនោះឯង ពួកមនុស្សសួរភិក្ខុទាំងឡាយដែលកំពុងត្រាច់ទៅបិណ្ឌបាតថា បពិត្រលោកដ៏ចំរើន ភិក្ខុទាំងឡាយមានប៉ុន្មានអង្គ។ ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា នែអាវុសោ យើងមិនដឹងទេ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាកូនចៅព្រះពុទ្ធជាសក្យៈទាំងនេះ ត្រឹមតែគ្នីគ្នាមានប៉ុន្មាន ក៏មិនដឹង(ទៅហើយ) ធ្វើម្តេចឡើយ ពួកសមណៈទាំងនេះនឹងដឹងការល្អតិចតួចដទៃបាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរាប់ពួកភិក្ខុ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា យើងគួររាប់ភិក្ខុទាំងឡាយក្នុងកាលណាហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរាប់ត្រឹមតែឈ្មោះ ឬឲ្យកាន់យកស្លាកក្នុងឧបោសថថ្ងៃនោះ។

[១៧៨] ក៏សម័យនោះឯង ភិក្ខុទាំងឡាយមិនដឹងថាថ្ងៃនេះ ជាថ្ងៃឧបោសថ ក៏នាំគ្នាដើរទៅកាន់ស្រុកឆ្ងាយ ដើម្បីបិណ្ឌបាត។ ភិក្ខុទាំងឡាយនោះមកដល់ក្នុងពេលដែលភិក្ខុកំពុងសំដែងនូវបាតិមោក្ខ ក៏មាន មកដល់ក្នុងពេលដែលភិក្ខុសំដែងនូវបាតិមោក្ខចប់ហើយក៏មាន។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ថា ថ្ងៃនេះជាថ្ងៃឧបោសថ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ត្រូវភិក្ខុណាប្រាប់ថ្ងៃឧបោសថហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈ ប្រាប់អំពីព្រឹក។ ក៏សម័យនោះឯង ព្រះថេរៈមួយអង្គភ្លេច (មិនបានប្រាប់) អំពីព្រឹក។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ក្នុងពេលឆាន់ក៏បាន។ ភិក្ខុក៏ភ្លេចក្នុងពេលឆាន់ទៀត។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរលឹកឃើញកាលណា ប្រាប់កាលនោះចុះ។

## ៨៥. បុព្វករណានុជាននា

CS vin.mv.02.18 | ភាគ ទី៦

**(៨៥.)**

[១៧៩] ក៏សម័យនោះឯង រោងឧបោសថក្នុងអាវាសមួយស្មោកគ្រោក។ ភិក្ខុជាអាគន្តុកៈទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងមិនបោសរោងឧបោសថសោះ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបោសរោងឧបោសថ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណាបោសរោងឧបោសថហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុខ្ចី។ ពួកភិក្ខុខ្ចី ដែលព្រះថេរៈបង្គាប់ហើយ ក៏នៅតែមិនបោស។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានជម្ងឺ (បើ) ព្រះថេរៈបង្គាប់ហើយ មិនត្រូវមិនបោសទេ (ថាត្រូវតែបោស) ភិក្ខុណាមិនបោស ត្រូវអាបត្តិទុក្កដ។ ក៏សម័យនោះឯង ភិក្ខុមិនបានក្រាលអាសនៈ ក្នុងរោងឧបោសថ។ ភិក្ខុទាំងឡាយអង្គុយផ្ទាល់ដី កាយភិក្ខុក្តី ចីវរទាំងឡាយក្តី ប្រឡាក់ដោយដី។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុក្រាលអាសនៈ ក្នុងរោងឧបោសថ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណាក្រាលអាសនៈក្នុងរោងឧបោសថហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុខ្ចី។ ពួកភិក្ខុខ្ចី ដែលព្រះថេរៈបង្គាប់ហើយ ក៏នៅតែមិនក្រាលអាសនៈ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈឺ (បើ) ភិក្ខុជាថេរៈបង្គាប់ហើយ មិនត្រូវមិនក្រាលអាសនៈទេ ភិក្ខុណាមិនក្រាល ត្រូវអាបត្តិទុក្កដ។ ក៏សម័យនោះឯង ក្នុងរោងឧបោសថគ្មានប្រទីប។ ភិក្ខុទាំងឡាយ ជាន់កាយគ្នាខ្លះ ជាន់ចីវរគ្នាខ្លះ ក្នុងទីងងឹត។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអុជប្រទីបក្នុងរោងឧបោសថ។ ទើបភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ត្រូវអ្នកណាអុជប្រទីបក្នុងរោងឧបោសថហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុខ្ចី។ ពួកភិក្ខុខ្ចី ដែលព្រះថេរៈបង្គាប់ហើយ ក៏នៅតែមិនអុជប្រទីប។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈឺ (បើ) ព្រះថេរៈបង្គាប់ហើយ មិនត្រូវមិនអុជប្រទីបទេ ភិក្ខុណាមិនអុជប្រទីប ត្រូវអាបត្តិទុក្កដ[138] ។

## ៨៦. ទិសំគមិកាទិវត្ថុ

CS vin.mv.02.19 | ភាគ ទី៦

**(៨៦.)**

[១៨០] ក៏សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូបសុទ្ធតែល្ងង់ មិនឆ្លាស មានដំណើរទៅកាន់ទិស មិនបានលាអាចារ្យ និងឧបជ្ឈាយ៍។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាច្រើនក្នុងសាសនានេះ ជាភិក្ខុល្ងង់ មិនឆ្លាស មានដំណើរទៅកាន់ទិស មិនលាអាចារ្យ និងឧបជ្ឈាយ៍។ ម្នាលភិក្ខុទាំងឡាយ ត្រូវអាចារ្យ និងឧបជ្ឈាយ៍សួរភិក្ខុទាំងនោះថា លោកទាំងឡាយនឹងទៅណា នឹងទៅជាមួយនឹងអ្នកណា។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះល្ងង់ មិនឆ្លាស និយាយអាងពួកភិក្ខុដទៃ ដែលល្ងង់ មិនឆ្លាស (ដូចគ្នា) ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាចារ្យ និងឧបជ្ឈាយ៍អនុញ្ញាតឲ្យទេ បើអនុញ្ញាតឲ្យ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុល្ងង់ មិនឆ្លាសទាំងនោះ ដែលអាចារ្យ និងឧបជ្ឈាយ៍មិនអនុញ្ញាត បើនៅតែទៅ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ក្នុងសាសនានេះ ភិក្ខុទាំងឡាយជាច្រើន សុទ្ធតែល្ងង់ មិនឆ្លាសនៅក្នុងអាវាសមួយ។ ភិក្ខុទាំងឡាយនោះ មិនដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស។ ភិក្ខុដទៃជាពហុស្សូត្រ ចេះចាំព្រះត្រៃបិដក ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ចាំមាតិកា ជាបណ្ឌិត ឆ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីខ្មាស មានសេចក្តីរង្កៀស ស្រឡាញ់ការសិក្សា ក៏មកក្នុងអាវាសនោះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះសង្គ្រោះ អនុគ្រោះ និយាយរាក់ទាក់ ទំនុកបម្រុងភិក្ខុជាពហុស្សូត្រនោះ ដោយគ្រឿងលំអិតសម្រាប់ងូត ដោយដីស្អិត ឈើស្ទន់ ទឹកខ្ពុរមាត់ លុបមុខ បើភិក្ខុទាំងឡាយនោះមិនសង្គ្រោះ មិនអនុគ្រោះ មិននិយាយរាក់ទាក់ មិនទំនុកបម្រុង ដោយគ្រឿងលំអិតសម្រាប់ងូត ដោយដីស្អិត ឈើស្ទន់ ទឹកខ្ពុរមាត់ លុបមុខទេ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ឧបោសថថ្ងៃនោះ មានពួកភិក្ខុជាច្រើនរូបសុទ្ធតែល្ងង់ មិនឆ្លាស នៅក្នុងអាវាសមួយ។ ភិក្ខុទាំងឡាយនោះមិនដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយបញ្ជូនភិក្ខុ១រូប ទៅកាន់អាវាសជិតខាង ក្នុងថ្ងៃនោះថា នែអាវុសោ ចូរអ្នកទៅរៀនបាតិមោក្ខដោយសង្ខេប ឬដោយពិស្តារមក។ បើភិក្ខុ (ដែលត្រូវបញ្ជូនទៅនោះ) បានបាតិមោក្ខនុ៎ះ ដោយអាការយ៉ាងនេះ ការបាននុ៎ះជាការល្អ បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងអាវាសណាដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស ត្រូវភិក្ខុទាំងឡាយនោះទៅកាន់អាវាសនោះទាំងអស់គ្នា បើមិនទៅទេ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុជាច្រើនក្នុងសាសនានេះ ល្ងង់ មិនឆ្លាស នៅចាំវស្សាក្នុងអាវាសមួយ។ ភិក្ខុទាំងឡាយនោះមិនដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះបញ្ជូនភិក្ខុ១រូប ទៅកាន់អាវាសជិតខាង ក្នុងថ្ងៃនោះថា នែអាវុសោ ចូរអ្នកទៅរៀនបាតិមោក្ខដោយសង្ខេប ឬដោយពិស្តារហើយមក។ បើភិក្ខុនោះ បានបាតិមោក្ខនុ៎ះ មកយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយបញ្ជូនភិក្ខុ១រូបក្នុងរវាង៧ថ្ងៃថា នែអាវុសោ ចូរអ្នកទៅរៀនបាតិមោក្ខដោយសង្ខេប ឬដោយពិស្តារមក។ បើភិក្ខុនោះ បានបាតិមោក្ខនុ៎ះ យ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុទាំងនោះនៅចាំវស្សាក្នុងអាវាសនោះទេ បើនៅ ត្រូវអាបត្តិទុក្កដ។

## ៨៧. បារិសុទ្ធិទានកថា

CS vin.mv.02.20 | ភាគ ទី៦

**(៨៧.)**

[១៨១] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយប្រជុំគ្នា សង្ឃនឹងធ្វើឧបោសថ។ កាលបើព្រះដ៏មានព្រះភាគទ្រង់មានបន្ទូលយ៉ាងនេះ ភិក្ខុ១រូប បានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន នៅមានភិក្ខុឈឺ ភិក្ខុនោះមិនទាន់មក។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺឲ្យបារិសុទ្ធិបាន។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុឈឺនោះឲ្យបារិសុទ្ធិយ៉ាងនេះ។ ត្រូវភិក្ខុឈឺនោះ ចូលទៅរកភិក្ខុ១រូប ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួចអង្គុយច្រហោង ផ្គងអញ្ជលី ហើយនិយាយយ៉ាងនេះថា ខ្ញុំឲ្យបារិសុទ្ធិ លោកចូរនាំបារិសុទ្ធិរបស់ខ្ញុំទៅ លោកចូរប្រាប់បារិសុទ្ធិរបស់ខ្ញុំ។ ភិក្ខុឈឺនោះបញ្ជាក់ដោយកាយ(ក្តី) បញ្ជាក់ដោយវាចា (ក្តី) បញ្ជាក់ដោយកាយវាចា (ក្តី) ឈ្មោះថា ឲ្យបរិសុទ្ធិហើយ ភិក្ខុនោះមិនបញ្ជាក់ដោយកាយ មិនបញ្ជាក់ដោយវាចា មិនបញ្ជាក់ដោយកាយវាចាទេ មិនឈ្មោះថា ឲ្យបារិសុទ្ធិទេ។ បើភិក្ខុនោះបានបារិសុទ្ធិនុ៎ះយ៉ាងនេះ ការបានបារិសុទ្ធិនុ៎ះ ជាការល្អ បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនាំភិក្ខុឈឺដោយគ្រែ ឬតាំងមកក្នុងកណ្តាលសង្ឃ ហើយធ្វើឧបោសថ។ ម្នាលភិក្ខុទាំងឡាយ បើគំនិតយ៉ាងនេះមានដល់ភិក្ខុអ្នកបម្រើភិក្ខុឈឺថា បើយើងទាំងឡាយឲ្យភិក្ខុឈឺឃ្លាតចាកទី អាពាធនឹងរឹតតែចំរើន ឬនឹងស្លាប់ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យភិក្ខុឈឺឃ្លាតចាកទីទេ ត្រូវសង្ឃទៅធ្វើឧបោសថក្នុងទីនោះ។ មិនត្រូវសង្ឃធ្វើឧបោសថដោយពួកឡើយ បើធ្វើ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុឈឺឲ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិចៀសចេញចាកទីនោះទៅ ត្រូវឲ្យបារិសុទ្ធិដល់ភិក្ខុដទៃ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិទៅ សិកក្នុងទីនោះឯង (ក្តី) ស្លាប់ទៅ (ក្តី) ប្តេជ្ញាខ្លួនជាសាមណេរ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកលាសិក្ខា(ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវអន្តិមវត្ថុ (ក្តី) ប្តេជ្ញាខ្លួនជាមនុស្សឆ្កួត(ក្តី) ប្តេជ្ញាខ្លួនជាអ្នកមានចិត្តរវើរវាយ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកមានវេទនាគ្របសង្កត់(ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ (ក្តី) ប្តេជ្ញាខ្លួនជាមនុស្សខ្ទើយ(ក្តី) ប្តេជ្ញាខ្លួនជាថេយ្យសំវាសកៈ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកទៅចូលពួកតិរ្ថិយ(ក្តី) ប្តេជ្ញាខ្លួនជាតិរច្ឆាន(ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់មាតា(ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់បិតា(ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់ព្រះអរហន្ត (ក្តី) ប្តេជ្ញាខ្លួនជាអ្នកទ្រុស្តភិក្ខុនី(ក្តី) ប្តេជ្ញាខ្លួនជាអ្នកបំបែកសង្ឃ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកញុំាងព្រះលោហិតឲ្យពុរពងឡើង (ក្តី) ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនក (មានភេទពីរក្តី) ត្រូវឲ្យបារិសុទ្ធិទៅភិក្ខុដទៃ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិចៀសចេញទៅក្នុងពាក់កណ្តាលផ្លូវ។ មិនឈ្មោះថា ភិក្ខុនោះបាននាំបារិសុទ្ធិមកដល់ឡើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិសឹក (ក្តី) ស្លាប់(ក្តី)។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនក(ក្តី) ក្នុងពាក់កណ្តាលផ្លូវ បារិសុទ្ធិ ក៏មិនឈ្មោះថា ភិក្ខុនោះបាននាំមកដល់ឡើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិដល់ទៅសង្ឃ ហើយទើបចៀសចេញទៅ បារិសុទ្ធិ ក៏ឈ្មោះថា ភិក្ខុនោះបាននាំមកដល់ហើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិដល់ទៅសង្ឃ ហើយទើបសឹក (ក្តី) ស្លាប់(ក្តី)។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនក(ក្តី) បារិសុទ្ធិ ក៏ឈ្មោះថា ភិក្ខុនោះបាននាំមកដល់ហើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិដល់ទៅសង្ឃ ហើយដេកលក់ មិនបានប្រាប់ ឬភ្លាំងភ្លេច មិនបានប្រាប់ ឬចូលឈាន ហើយមិនបានប្រាប់ បារិសុទ្ធិ ក៏ឈ្មោះថា ភិក្ខុនោះបាននាំមកដល់ហើយ។ អាបត្តិមិនមានដល់ភិក្ខុអ្នកនាំបារិសុទ្ធិទេ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិទៅដល់សង្ឃ ហើយក្លែងមិនប្រាប់ បារិសុទ្ធិ ឈ្មោះថា ភិក្ខុនោះបាននាំមកដល់ហើយ តែភិក្ខុអ្នកនាំបារិសុទ្ធិត្រូវអាបត្តិទុក្កដ។

## ៨៨. ឆន្ទទានកថា

CS vin.mv.02.21 | ភាគ ទី៦

**(៨៨.)**

[១៨២] លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយប្រជុំគ្នា សង្ឃនឹងធ្វើកម្ម។ កាលបើព្រះដ៏មានព្រះភាគមានបន្ទូលយ៉ាងនេះ ភិក្ខុ១រូប បានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចំរើន មានភិក្ខុឈឺ ភិក្ខុនោះមិនទាន់មក។ ព្រះអង្គមានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺឲ្យឆន្ទៈបាន។ ម្នាលភិក្ខុទាំងឡាយ ក៏ឯឆន្ទៈនោះ ត្រូវភិក្ខុឈឺនោះឲ្យយ៉ាងនេះ។ ត្រូវភិក្ខុឈឺនោះ ចូលទៅរកភិក្ខុ១រូប ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះថា ខ្ញុំឲ្យឆន្ទៈ លោកចូរនាំឆន្ទៈរបស់ខ្ញុំទៅចុះ ចូរប្រាប់ឆន្ទៈរបស់ខ្ញុំ(ផង)។ ភិក្ខុឈឺនោះបញ្ជាក់ដោយកាយ(ក៏បាន) បញ្ជាក់ដោយវាចា (ក៏បាន) បញ្ជាក់ដោយកាយវាចា (ក៏បាន) ឆន្ទៈ ឈ្មោះថាភិក្ខុឈឺនោះបានឲ្យហើយ។ ភិក្ខុឈឺមិនបានបញ្ជាក់ដោយកាយ(ក្តី) មិនបានបញ្ជាក់ដោយវាចា(ក្តី) មិនបានបញ្ជាក់ដោយកាយវាចា(ក្តី) មិនឈ្មោះថា ភិក្ខុនោះបានឲ្យឆន្ទៈទេ។ បើបានឆន្ទៈនុ៎ះយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវនាំភិក្ខុឈឺនោះមកក្នុងកណ្តាលសង្ឃ ដោយគ្រែ ឬតាំងមក ហើយត្រូវធ្វើសង្ឃកម្មចុះ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុអ្នកបម្រើជម្ងឺ មានគំនិតយ៉ាងនេះថា បើយើងនឹងឲ្យភិក្ខុឈឺឃ្លាតចាកទី អាពាធនឹងរឹតតែចំរើន ឬនឹងស្លាប់ដូច្នេះ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុឲ្យភិក្ខុឈឺឃ្លាតចាកទីទេ ត្រូវសង្ឃទៅធ្វើកម្មក្នុងទីនោះ មិនត្រូវសង្ឃធ្វើកម្មជាពួកឡើយ បើធ្វើ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈគេចចៀសចេញអំពីទីនោះ ត្រូវឲ្យឆន្ទៈដល់ភិក្ខុដទៃ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈ សឹកក្នុងទីនោះឯង (ក្តី) ស្លាប់ទៅ (ក្តី) ប្តេជ្ញាខ្លួនជាសាមណេរ (ក្តី) ប្តេជ្ញាខ្លួនជាអ្នកពោលលាសិក្ខា(ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវអន្តិមវត្ថុ (បារាជិកក្តី) ប្តេជ្ញាខ្លួនជាមនុស្សឆ្កួត(ក្តី) ប្តេជ្ញាខ្លួនជាអ្នកមានចិត្តរវើរវាយ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកមានវេទនាគ្របសង្កត់(ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ (ក្តី) ប្តេជ្ញាខ្លួនជាមនុស្សខ្ទើយ(ក្តី) ប្តេជ្ញាខ្លួនជាថេយ្យសំវាសកៈ (អ្នកលួចសំវាសក្តី) ប្តេជ្ញាខ្លួនជាអ្នកចូលពួកតិរ្ថិយ(ក្តី) ប្តេជ្ញាខ្លួនជាសត្វតិរច្ឆាន(ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់មាតា(ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់បិតា(ក្តី) ប្តេជ្ញាខ្លួនជាអ្នកសម្លាប់ព្រះអរហន្ត(ក្តី) ប្តេជ្ញាខ្លួនជាអ្នកទ្រុស្តភិក្ខុនី(ក្តី) ប្តេជ្ញាខ្លួនជាអ្នកបំបែកសង្ឃ(ក្តី) ប្តេជ្ញាខ្លួនជាអ្នកធ្វើព្រះលោហិតឲ្យពុរពងឡើង (ក្តី) ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនក (ក្តី) ត្រូវឲ្យឆន្ទៈដល់ភិក្ខុដទៃ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈគេចចៀសទៅក្នុងពាក់កណ្តាលផ្លូវ ភិក្ខុនោះ ឈ្មោះថា មិនបាននាំឆន្ទៈមកដល់ទេ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈសឹកទៅ (ក្តី) ស្លាប់ទៅ(ក្តី)ក្នុងពាក់កណ្តាលផ្លូវ។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនក(ក្តី) ភិក្ខុនោះ ឈ្មោះថា មិនបាននាំឆន្ទៈមកទេ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈទៅដល់សង្ឃ ហើយទើបចៀសចេញទៅ ឆន្ទៈ ឈ្មោះថា នាំមកដល់ហើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈទៅដល់ទៅសង្ឃ ហើយសឹកទៅ (ក្តី) ស្លាប់ទៅ(ក្តី)។បេ។ ប្តេជ្ញាខ្លួនជាឧភតោព្យញ្ជនក(ក្តី) ភិក្ខុនោះ ឈ្មោះថា បាននាំឆន្ទៈមកហើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈដល់ទៅសង្ឃ ហើយដេកលក់ មិនបានប្រាប់(ក្តី) ភ្លេច មិនបានប្រាប់(ក្តី) ចូលសមាបត្តិមិនបានប្រាប់(ក្តី) ភិក្ខុនោះឈ្មោះថា បាននាំឆន្ទៈមកដល់ហើយ។ ភិក្ខុអ្នកនាំឆន្ទៈ មិនត្រូវអាបត្តិ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យឆន្ទៈហើយ បើភិក្ខុអ្នកនាំឆន្ទៈដល់ទៅសង្ឃហើយ ក្លែងមិនប្រាប់ ភិក្ខុនោះឈ្មោះថា នាំឆន្ទៈមកដល់ហើយ។ ភិក្ខុអ្នកនាំឆន្ទៈត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានកិច្ចត្រូវធ្វើ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឲ្យបារិសុទ្ធិក្នុងឧបោសថថ្ងៃនោះឲ្យឆន្ទៈទៀតបាន។

## ៨៩. ញាតកាទិគ្គហណកថា

CS vin.mv.02.22 | ភាគ ទី៦

**(៨៩.)**

[១៨៣] ក៏សម័យនោះឯង ពួកជនជាញាតិចាប់ភិក្ខុ១រូបក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គមានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ពួកជនជាញាតិចាប់ភិក្ខុក្នុងឧបោសថថ្ងៃនោះ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកជនជាញាតិអស់នោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ណ្ហើយចុះ អ្នកទាំងឡាយលែងភិក្ខុនេះមួយរំពេចសិន ទំរាំភិក្ខុនេះធ្វើឧបោសថរួច។ បើភិក្ខុបានការលែងនុ៎ះយ៉ាងនេះ ការបាននុ៎ះជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកជនជាញាតិអស់នោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ណ្ហើយចុះ អ្នកទាំងឡាយនៅចាំក្នុងទីដ៏សមគួរ មួយរំពេចសិន ទំរាំភិក្ខុនេះឲ្យបារិសុទ្ធិរួច។ បើភិក្ខុបានការឈប់បង្អង់នុ៎ះយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកជនជាញាតិអស់នោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ណ្ហើយចុះ អ្នកទាំងឡាយចូរនាំភិក្ខុនេះទៅកាន់ទីក្រៅសីមាមួយរំពេចសិន ទំរាំសង្ឃធ្វើឧបោសថរួច។ បើភិក្ខុបានការនាំទៅនុ៎ះយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ មិនត្រូវសង្ឃធ្វើឧបោសថជាពួកឡើយ បើធ្វើ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ស្តេចទាំងឡាយ ចាប់ភិក្ខុក្នុងឧបោសថថ្ងៃនោះ។បេ។ ពួកចោរចាប់... ពួកអ្នកលេងចាប់... ពួកជនជាសត្រូវនៃភិក្ខុចាប់។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកជនជាសត្រូវនៃភិក្ខុអស់នោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ណ្ហើយចុះ អ្នកទាំងឡាយចូរលែងភិក្ខុនេះមួយរំពេចសិន ទំរាំភិក្ខុនេះធ្វើឧបោសថរួច។ បើភិក្ខុបានការលែងនុ៎ះយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងជនជាសត្រូវនៃភិក្ខុទាំងនោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ណ្ហើយចុះ អ្នកទាំងឡាយចូរឈប់ បង្អង់នៅក្នុងទីដ៏សមគួរ មួយរំពេចសិន ទំរាំភិក្ខុនេះឲ្យបារិសុទ្ធិរួច។ បើភិក្ខុបានការឈប់បង្អង់នុ៎ះយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងជនជាសត្រូវនៃភិក្ខុទាំងនោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ណ្ហើយចុះ អ្នកទាំងឡាយចូរនាំភិក្ខុនេះទៅកាន់ទីក្រៅសីមាមួយរំពេចសិន ទំរាំសង្ឃធ្វើឧបោសថរួច។ បើភិក្ខុបានការនាំទៅនុ៎ះយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ មិនត្រូវសង្ឃធ្វើឧបោសថដោយពួកឡើយ បើធ្វើ ត្រូវអាបត្តិទុក្កដ។

## ៩០. ឧម្មត្តកសម្មុតិ

CS vin.mv.02.23 | ភាគ ទី៦

**(៩០.)**

[១៨៤] លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយប្រជុំគ្នា (ព្រោះ) សង្ឃមានកិច្ចត្រូវធ្វើ។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់មានបន្ទូលយ៉ាងនេះហើយ ភិក្ខុ១រូប បានក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យនេះថា បពិត្រព្រះអង្គដ៏ចំរើន នៅមានភិក្ខុឈ្មោះគគ្គៈឆ្កួត ភិក្ខុនោះមិនទាន់មក។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឆ្កួតទាំងឡាយនេះមានពីរយ៉ាង គឺមានភិក្ខុឆ្កួត១យ៉ាង រលឹកឧបោសថបានខ្លះ រលឹកមិនបានខ្លះ រលឹកសង្ឃកម្មបានខ្លះ រលឹកមិនបានខ្លះ រលឹកមិនបានសោះក៏មាន ភិក្ខុឆ្កួត១យ៉ាង មកកាន់ឧបោសថបានខ្លះ មកមិនបានខ្លះ មកកាន់សង្ឃកម្មបានខ្លះ មកមិនបានខ្លះ មកមិនបានសោះក៏មាន។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុឆ្កួតទាំងពីរយ៉ាងនោះ ភិក្ខុឆ្កួតណារលឹកឧបោសថបានខ្លះ រលឹកមិនបានខ្លះ រលឹកសង្ឃកម្មបានខ្លះ រលឹកមិនបានខ្លះ មកកាន់ឧបោសថបានខ្លះ មកមិនបានខ្លះ មកកាន់សង្ឃកម្មបានខ្លះ មកមិនបានខ្លះ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យឧម្មត្តកសម្មតិ[139] ដល់ភិក្ខុឆ្កួតបែបនេះ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯឧម្មត្តកសម្មតិ សង្ឃត្រូវឲ្យយ៉ាងនេះ។ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះគគ្គៈ ជាមនុស្សឆ្កួត រលឹកឧបោសថបានខ្លះ រលឹកមិនបានខ្លះ រលឹកសង្ឃកម្មបានខ្លះ រលឹកមិនបានខ្លះ មកកាន់ឧបោសថបានខ្លះ មកមិនបានខ្លះ មកកាន់សង្ឃកម្មបានខ្លះ មកមិនបានខ្លះ។ បើសម្មតិកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃឲ្យឧម្មត្តកសម្មតិដល់ភិក្ខុឈ្មោះគគ្គៈជាភិក្ខុឆ្កួត ភិក្ខុឈ្មោះគគ្គៈ គប្បីរលឹកឧបោសថបានក្តី រលឹកមិនបានក្តី រលឹកសង្ឃកម្មបានក្តី រលឹកមិនបានក្តី មកកាន់ឧបោសថបានក្តី មកមិនបានក្តី មកកាន់សង្ឃកម្មបានក្តី មកមិនបានក្តី សង្ឃគប្បីធ្វើឧបោសថ គប្បីធ្វើសង្ឃកម្ម ជាមួយភិក្ខុឈ្មោះគគ្គៈក៏បាន វៀរចាកភិក្ខុឈ្មោះគគ្គៈក៏បាន។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះគគ្គៈ ជាភិក្ខុឆ្កួត រលឹកឧបោសថបានខ្លះ រលឹកមិនបានខ្លះ រលឹកសង្ឃកម្មបានខ្លះ រលឹកមិនបានខ្លះ មកកាន់ឧបោសថបានខ្លះ មកមិនបានខ្លះ មកកាន់សង្ឃកម្មបានខ្លះ មកមិនបានខ្លះ។ ឥឡូវសង្ឃឲ្យឧម្មត្តកសម្មតិដល់ភិក្ខុឈ្មោះគគ្គៈជាភិក្ខុឆ្កួតថា ភិក្ខុឈ្មោះគគ្គៈ គប្បីរលឹកឧបោសថបានក្តី រលឹកមិនបានក្តី រលឹកសង្ឃកម្មបានក្តី រលឹកមិនបានក្តី មកកាន់ឧបោសថបានក្តី មកមិនបានក្តី មកកាន់សង្ឃកម្មបានក្តី មកមិនបានក្តី សង្ឃនឹងធ្វើឧបោសថ នឹងធ្វើសង្ឃកម្ម ជាមួយភិក្ខុឈ្មោះគគ្គៈក៏បាន វៀរចាកភិក្ខុឈ្មោះគគ្គៈក៏បាន។ ការឲ្យឧម្មត្តកសម្មតិដល់ភិក្ខុឈ្មោះគគ្គៈ ជាភិក្ខុឆ្កួត ថាភិក្ខុឈ្មោះគគ្គៈ រលឹកឧបោសថបានក្តី រលឹកមិនបានក្តី រលឹកសង្ឃកម្មបានក្តី រលឹកមិនបានក្តី មកកាន់ឧបោសថបានក្តី មកមិនបានក្តី មកកាន់សង្ឃកម្មបានក្តី មកមិនបានក្តី សង្ឃនឹងធ្វើឧបោសថ នឹងធ្វើសង្ឃកម្ម ជាមួយភិក្ខុឈ្មោះគគ្គៈក៏បាន វៀរចាកភិក្ខុឈ្មោះគគ្គៈក៏បាន ដូច្នេះ គាប់ចិត្តដល់លោកម្ចាស់អង្គណា គួរលោកម្ចាស់អង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា គួរលោកម្ចាស់អង្គនោះនិយាយឡើង។ សង្ឃឲ្យឧម្មត្តកសម្មតិដល់ភិក្ខុឈ្មោះគគ្គៈ ជាភិក្ខុឆ្កួត ហើយថា ភិក្ខុឈ្មោះគគ្គៈ រលឹកឧបោសថបានក្តី រលឹកមិនបានក្តី រលឹកសង្ឃកម្មបានក្តី រលឹកមិនបានក្តី មកកាន់ឧបោសថបានក្តី មកមិនបានក្តី មកកាន់សង្ឃកម្មបានក្តី មកមិនបានក្តី សង្ឃនឹងធ្វើឧបោសថ នឹងធ្វើសង្ឃកម្ម ជាមួយភិក្ខុឈ្មោះគគ្គៈក៏បាន វៀរចាកភិក្ខុឈ្មោះគគ្គៈក៏បាន។ ការឲ្យឧម្មត្តកសម្មតិនោះ គាប់ចិត្តដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀម ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

## ៩១. សង្ឃុបោសថាទិប្បភេទំ

CS vin.mv.02.24 | ភាគ ទី៦

**(៩១.)**

[១៨៥] ក៏សម័យនោះឯង មានភិក្ខុ៤អង្គ គង់ក្នុងអាវាស១ ក្នុងឧបោសថថ្ងៃនោះ។ ទើបភិក្ខុទាំងឡាយនោះ មានគំនិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា ត្រូវភិក្ខុធ្វើឧបោសថ ក៏យើងទាំងឡាយជាជន៤រូប ត្រូវយើងទាំងឡាយធ្វើឧបោសថដូចម្តេចទៅ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ៤រូបសំដែងនូវបាតិមោក្ខបាន។ ក៏សម័យនោះឯង មានភិក្ខុ៣រូប នៅក្នុងអាវាសមួយ ក្នុងឧបោសថថ្ងៃនោះ។ ទើបភិក្ខុទាំងឡាយនោះ មានគំនិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុបួនរូបសំដែងនូវបាតិមោក្ខ ក៏ឯយើងទាំងឡាយជាជនបីរូប ត្រូវយើងធ្វើឧបោសថដូចម្តេចទៅ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ៣រូបធ្វើបារិសុទ្ធិឧបោសថដល់គ្នានឹងគ្នា។ម្នាលភិក្ខុទាំងឡាយ ក៏ឯបារិសុទ្ធិឧបោសថនោះ ត្រូវភិក្ខុធ្វើយ៉ាងនេះ។ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យភិក្ខុទាំងឡាយនោះដឹងថា ចូរលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ ថ្ងៃទី១៥នេះ ជាថ្ងៃឧបោសថ បើកម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយហើយ យើងទាំងឡាយគួរធ្វើបារិសុទ្ធិឧបោសថដល់គ្នានឹងគ្នា។ ត្រូវភិក្ខុជាថេរៈ ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចនិយាយនឹងភិក្ខុទាំងឡាយនោះយ៉ាងនេះថា នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ។ ត្រូវភិក្ខុខ្ចីវស្សា ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចនិយាយនឹងភិក្ខុទាំងឡាយនោះយ៉ាងនេះថា ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកទាំងឡាយចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ។ ក៏សម័យនោះឯង ភិក្ខុ២រូប នៅក្នុងអាវាសមួយ ក្នុងឧបោសថថ្ងៃនោះ។ ទើបភិក្ខុទាំងឡាយនោះ មានគំនិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុបួនរូបសំដែងនូវបាតិមោក្ខ ឲ្យភិក្ខុបីរូបធ្វើបារិសុទ្ធិឧបោសថដល់គ្នានឹងគ្នាបាន ក៏យើងទាំងឡាយជាជនពីររូប ត្រូវយើងទាំងឡាយធ្វើឧបោសថដូចម្តេចទៅ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុពីររូបធ្វើបារិសុទ្ធិឧបោសថបាន។ម្នាលភិក្ខុទាំងឡាយ ក៏ឯបារិសុទ្ធិឧបោសថនោះ ត្រូវភិក្ខុទាំងឡាយធ្វើយ៉ាងនេះ។ ត្រូវភិក្ខុជាថេរៈ ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយពោលនឹងភិក្ខុខ្ចីយ៉ាងនេះថា នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ នែអាវុសោ ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំ ថាជា

បុគ្គលបរិសុទ្ធ។ ត្រូវភិក្ខុខ្ចីវស្សា ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយពោលនឹងភិក្ខុជាថេរៈយ៉ាងនេះថា ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ ទានប្រោស ខ្ញុំជាបុគ្គលបរិសុទ្ធ សូមលោកចាំទុកនូវខ្ញុំ ថាជាបុគ្គលបរិសុទ្ធ។ ក៏សម័យនោះឯង ភិក្ខុតែមួយរូប នៅក្នុងអាវាសមួយ ក្នុងឧបោសថថ្ងៃនោះ។ ទើបភិក្ខុនោះ បានគិតដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុបួនរូបសំដែងនូវបាតិមោក្ខ ឲ្យភិក្ខុបីរូបធ្វើបារិសុទ្ធិឧបោសថដល់គ្នានឹងគ្នា ឲ្យភិក្ខុពីររូបធ្វើបារិសុទ្ធិឧបោសថ ក៏អាត្មាអញនៅតែម្នាក់ឯង ត្រូវអញធ្វើឧបោសថដូចម្តេចទៅ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុតែមួយរូបនៅក្នុងអាវាសមួយក្នុងឧបោសថថ្ងៃនោះ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុតែងត្រឡប់មកនៅក្នុងប្រទេសណាគឺក្នុងឧបដ្ឋានសាលាក្តី មណ្ឌបក្តី គល់ឈើក្តី ត្រូវភិក្ខុនោះបោសប្រទេសនោះហើយ ចូលទៅដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ ក្រាលអាសនៈ អុជប្រទីប ហើយត្រូវអង្គុយចាំ។ បើភិក្ខុទាំងឡាយដទៃមក ត្រូវភិក្ខុនោះធ្វើឧបោសថជាមួយនឹងភិក្ខុទាំងឡាយនោះ បើភិក្ខុទាំងឡាយដទៃមិនមកទេ ត្រូវភិក្ខុនោះអធិដ្ឋានឧបោសថថា ថ្ងៃនេះជាថ្ងៃឧបោសថរបស់អញ បើមិនអធិដ្ឋានទេ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបួនរូបនៅក្នុងអាវាសណា មិនត្រូវភិក្ខុបីរូបនាំបារិសុទ្ធិរបស់ភិក្ខុមួយរូបមក ហើយសំដែងនូវបាតិមោក្ខក្នុងអាវាសនោះទេ បើភិក្ខុទាំងឡាយនោះសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបីរូបនៅក្នុងអាវាសណា មិនត្រូវភិក្ខុពីររូបនាំបារិសុទ្ធិរបស់ភិក្ខុមួយរូបមក ហើយធ្វើបារិសុទ្ធិឧបោសថ ក្នុងអាវាសនោះទេ បើភិក្ខុទាំងនោះធ្វើ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពីររូបនៅក្នុងអាវាសណា មិនត្រូវភិក្ខុមួយរូបនាំបារិសុទ្ធិរបស់ភិក្ខុមួយរូបមក ហើយអធិដ្ឋានឧបោសថក្នុងអាវាសនោះទេ បើអធិដ្ឋាន ត្រូវអាបត្តិទុក្កដ។

## ៩២. អាបត្តិបដិកម្មវិធិ

CS vin.mv.02.25 | ភាគ ទី៦

(៩២.)

[១៨៦] ក៏សម័យនោះឯង ភិក្ខុ១រូបត្រូវអាបត្តិក្នុងឧបោសថថ្ងៃនោះ។ ទើបភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយថា មិនត្រូវភិក្ខុប្រកបដោយអាបត្តិ ធ្វើឧបោសថទេ ក៏អាត្មាអញត្រូវអាបត្តិហើយ ត្រូវអញប្រតិបត្តិដូចម្តេចទៅ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុត្រូវអាបត្តិក្នុងឧបោសថថ្ងៃនោះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះចូលទៅរកភិក្ខុ១រូប ហើយធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលី ហើយនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំត្រូវអាបត្តិមានឈ្មោះនេះ ខ្ញុំសូមសំដែងនូវអាបត្តិនោះ។ ភិក្ខុមិនត្រូវអាបត្តិនោះ គប្បីសួរភិក្ខុត្រូវអាបត្តិនោះថា លោកឃើញអាបត្តិនោះឬ។ ភិក្ខុត្រូវអាបត្តិគប្បីប្រាប់ថា អើ ខ្ញុំឃើញ។ ភិក្ខុមិនត្រូវអាបត្តិ គប្បីប្រាប់ថា លោកគប្បីសង្រួមតទៅ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុមានសេចក្តីសង្ស័យក្នុងអាបត្តិក្នុងឧបោសថថ្ងៃនោះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះចូលទៅរកភិក្ខុ១រូប ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយត្រូវនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំមានសេចក្តីសង្ស័យក្នុងអាបត្តិ មានឈ្មោះនេះ កាលណាខ្ញុំអស់សង្ស័យ ខ្ញុំនឹងសំដែងអាបត្តិនោះក្នុងកាលនោះ លុះនិយាយហើយ ត្រូវធ្វើឧបោសថ ត្រូវស្តាប់បាតិមោក្ខ មិនត្រូវធ្វើសេចក្តីអន្តរាយដល់ឧបោសថ ព្រោះហេតុប៉ុណ្ណោះឡើយ។

[១៨៧] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងអាបត្តិស្មើភាគគ្នា (គឺអាបត្តិដូចគ្នា)។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងអាបត្តិស្មើភាគគ្នាទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទួលអាបត្តិស្មើភាគគ្នា។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុទទួលអាបត្តិស្មើភាគគ្នាទេ ភិក្ខុណាទទួល ត្រូវអាបត្តិទុក្កដ។

## ៩៣. អាបត្តិអាវិករណវិធិ

CS vin.mv.02.26 | ភាគ ទី៦

(៩៣.)

[១៨៨] ក៏សម័យនោះឯង ភិក្ខុ១រូបរលឹកឃើញអាបត្តិក្នុងពេលដែលសង្ឃកំពុងសំដែងបាតិមោក្ខ។ ទើបភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា មិនត្រូវភិក្ខុប្រកបដោយអាបត្តិធ្វើឧបោសថទេ ក៏អាត្មាអញត្រូវអាបត្តិហើយ អញគប្បីប្រតិបត្តិដូចម្តេចទៅ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុរលឹកឃើញនូវអាបត្តិ ក្នុងពេលដែលសង្ឃកំពុងសំដែងបាតិមោក្ខ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីនិយាយនឹងភិក្ខុ (អង្គុយ) ជិតខាងយ៉ាងនេះថា នែអាវុសោ ខ្ញុំត្រូវអាបត្តិឈ្មោះនេះ ខ្ញុំចេញពីទីនេះហើយ នឹងសំដែងអាបត្តិនោះ លុះនិយាយហើយ ត្រូវធ្វើឧបោសថ ត្រូវស្តាប់បាតិមោក្ខ មិនត្រូវធ្វើសេចក្តីអន្តរាយដល់ឧបោសថ ព្រោះហេតុប៉ុណ្ណោះឡើយ។ ម្នាលភិក្ខុទាំងឡាយ មានភិក្ខុក្នុងសាសនានេះ កាលភិក្ខុកំពុងសំដែងនូវបាតិមោក្ខ (ក៏) មានសេចក្តីសង្ស័យក្នុងអាបត្តិ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះនិយាយនឹងភិក្ខុ (អង្គុយ) ជិតខាងយ៉ាងនេះថា នែអាវុសោ ខ្ញុំមានសេចក្តីសង្ស័យក្នុងអាបត្តិឈ្មោះនេះ កាលណាខ្ញុំអស់សង្ស័យ ខ្ញុំនឹងសំដែងអាបត្តិនោះកាលនោះ លុះនិយាយហើយ ត្រូវធ្វើឧបោសថ ត្រូវស្តាប់បាតិមោក្ខ មិនត្រូវធ្វើសេចក្តីអន្តរាយដល់ឧបោសថ ព្រោះហេតុប៉ុណ្ណោះឡើយ។

## ៩៤. សភាគាបត្តិបដិកម្មវិធិ

CS vin.mv.02.27 | ភាគ ទី៦

(៩៤.)

[១៨៩] ក៏សម័យនោះឯង សង្ឃទាំងអស់ក្នុងអាវាសមួយ ត្រូវអាបត្តិស្មើភាគគ្នា ក្នុងឧបោសថថ្ងៃនោះ។ ទើបភិក្ខុទាំងឡាយនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយថា ភិក្ខុមិនត្រូវសំដែងអាបត្តិស្មើភាគគ្នាទេ មិនត្រូវទទួលអាបត្តិស្មើភាគគ្នាទេ ក៏សង្ឃទាំងអស់នេះ ត្រូវអាបត្តិស្មើភាគគ្នា ត្រូវយើងទាំងឡាយប្រតិបត្តិដូចម្តេចទៅ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសង្ឃទាំងអស់ក្នុងអាវាសមួយ ត្រូវអាបត្តិស្មើភាគគ្នា ក្នុងឧបោសថថ្ងៃនោះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយបញ្ជូនភិក្ខុ១រូប ទៅកាន់អាវាសជិតខាង ក្នុងថ្ងៃនោះថា នែអាវុសោ ចូរលោកទៅសំដែងអាបត្តិហើយមក យើងទាំងឡាយនឹងសំដែងអាបត្តិក្នុងសំណាក់លោក។ បើសង្ឃបានការសំដែងអាបត្តិនុ៎ះ ដោយអាការយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើសង្ឃមិនបានទេ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃទាំងអស់នេះត្រូវអាបត្តិស្មើភាគគ្នា កាលណាសង្ឃនឹងឃើញភិក្ខុដទៃបរិសុទ្ធ មិនត្រូវអាបត្តិ សង្ឃនឹងសំដែងអាបត្តិនោះក្នុងសំណាក់ភិក្ខុនោះក្នុងកាលនោះ លុះនិយាយហើយ ត្រូវសង្ឃធ្វើឧបោសថ ត្រូវសំដែងនូវបាតិមោក្ខ មិនត្រូវសង្ឃធ្វើសេចក្តីអន្តរាយដល់ឧបោសថ ព្រោះហេតុតែប៉ុណ្ណោះទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសង្ឃទាំងអស់ក្នុងអាវាសមួយ មានសេចក្តីសង្ស័យក្នុងអាបត្តិស្មើភាគគ្នា ក្នុងឧបោសថថ្ងៃនោះ។ ត្រូវភិក្ខុឆ្លាស ប្រតិពល ឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃទាំងអស់នេះមានសេចក្តីសង្ស័យក្នុងអាបត្តិស្មើភាគគ្នា កាលណាសង្ឃអស់សេចក្តីសង្ស័យ សង្ឃនឹងសំដែងអាបត្តិនោះក្នុងកាលនោះ លុះនិយាយហើយ ត្រូវសង្ឃធ្វើឧបោសថ ត្រូវសំដែងនូវបាតិមោក្ខ មិនត្រូវសង្ឃធ្វើការអន្តរាយដល់ឧបោសថ ព្រោះហេតុតែប៉ុណ្ណោះឡើយ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសង្ឃនៅចាំវស្សាក្នុងអាវាសមួយ ត្រូវអាបត្តិស្មើភាគគ្នា។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបញ្ជូនភិក្ខុ១រូប ទៅកាន់អាវាសជិតខាង ក្នុងថ្ងៃនោះថា នែអាវុសោ ចូរលោកទៅសំដែងអាបត្តិនោះហើយមក យើងទាំងឡាយនឹងសំដែងអាបត្តិនោះក្នុងសំណាក់លោក។ បើសង្ឃបានការសំដែងអាបត្តិនុ៎ះ ដោយអាការយ៉ាងនេះ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវសង្ឃបញ្ជូនភិក្ខុ១រូបទៅក្នុងរវាង៧ថ្ងៃថា នែអាវុសោ ចូរលោកទៅសំដែងអាបត្តិនោះហើយមក យើងទាំងឡាយនឹងសំដែងអាបត្តិនោះក្នុងសំណាក់លោក។

[១៩០] សម័យនោះឯង មានសង្ឃទាំងអស់ក្នុងអាវាសមួយ ត្រូវអាបត្តិស្មើភាគគ្នា។ សង្ឃនោះ មិនដឹងឈ្មោះ មិនដឹងគោត្រ នៃអាបត្តិនោះ។ ភិក្ខុដទៃជាពហុសូត ចេះស្ទាត់នូវព្រះត្រៃបិដក ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ចេះចាំមាតិកា ជាបណ្ឌិតឆ្លាសមានប្រាជ្ញា មានសេចក្តីខ្មាស មានសេចក្តីរអែង ស្រឡាញ់ការសិក្សា មកក្នុងអាវាសនោះ។ ភិក្ខុ១អង្គ ចូលទៅរកភិក្ខុជាបណ្ឌិតនោះ ក្នុងទីដែលភិក្ខុនោះឋិតនៅ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងភិក្ខុនោះថា នែអាវុសោ ភិក្ខុណាធ្វើយ៉ាងនេះផង ៗ ភិក្ខុនោះត្រូវអាបត្តិឈ្មោះអ្វី។ ភិក្ខុជាបណ្ឌិតនោះ និយាយយ៉ាងនេះថា នែអាវុសោ ភិក្ខុណាធ្វើយ៉ាងនេះផង ៗ ភិក្ខុនោះត្រូវអាបត្តិឈ្មោះនេះ នែអាវុសោ លោកត្រូវអាបត្តិឈ្មោះនេះហើយ ចូរលោកសំដែងអាបត្តិនោះចេញ។ ភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោ មិនមែនខ្ញុំតែម្នាក់ឯង ត្រូវអាបត្តិនេះឡើយ សង្ឃទាំងអស់នោះក៏ត្រូវអាបត្តិនេះដែរ។ ភិក្ខុជាបណ្ឌិតនោះ និយាយយ៉ាងនេះថា នែអាវុសោ អ្នកដទៃត្រូវ (អាបត្តិ) ក្តី មិនត្រូវក្តី នឹងធ្វើអ្វីដល់លោកបាន នែអាវុសោ ណ្ហើយ ចូរលោកចេញចាកអាបត្តិរបស់ខ្លួនទៅ។ ទើបភិក្ខុនោះសំដែងអាបត្តិនោះតាមពាក្យភិក្ខុនោះហើយ ក៏ចូលទៅរកភិក្ខុទាំងឡាយនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងភិក្ខុទាំងឡាយនោះថា នែអាវុសោ ឮថា ភិក្ខុណាធ្វើយ៉ាងនេះផងៗ ភិក្ខុនោះត្រូវអាបត្តិឈ្មោះនេះ នែអាវុសោ លោកទាំងឡាយត្រូវអាបត្តិឈ្មោះនេះហើយ ចូរសំដែងអាបត្តិនោះចេញ។ ក៏ឯភិក្ខុទាំងឡាយនោះ មិនប្រាថ្នាដើម្បីសំដែងអាបត្តិនោះ តាមពាក្យភិក្ខុនោះឡើយ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសង្ឃទាំងអស់ក្នុងអាវាសមួយ ត្រូវអាបត្តិស្មើភាគគ្នា។ សង្ឃនោះ មិនដឹងនាម មិនដឹងគោត្រ របស់អាបត្តិនោះទេ។ ភិក្ខុដទៃជាពហុសូត ស្ទាត់ក្នុងព្រះត្រៃបិដក ទ្រទ្រង់ធម៌ ទ្រង់វិន័យ ចេះចាំមាតិកា ជាបណ្ឌិតឆ្លាសមានប្រាជ្ញា មានសេចក្តីខ្មាស សេចក្តីរអែង ស្រឡាញ់ការសិក្សា មកក្នុងអាវាសនោះ។ ភិក្ខុ១អង្គ ចូលទៅរកភិក្ខុជាបណ្ឌិតនោះ ក្នុងទីដែលភិក្ខុនោះឋិតនៅ លុះចូលទៅដល់ហើយ បាននិយាយយ៉ាងនេះ នឹងភិក្ខុនោះថា នែអាវុសោ ភិក្ខុណាធ្វើយ៉ាងនេះផង ៗ ភិក្ខុនោះត្រូវអាបត្តិឈ្មោះអ្វីដែរឬ។ ភិក្ខុជាបណ្ឌិតនោះ និយាយយ៉ាងនេះថា នែអាវុសោ ភិក្ខុណាមួយធ្វើយ៉ាងនេះផង ៗ ភិក្ខុនោះត្រូវអាបត្តិឈ្មោះនេះ នែអាវុសោ លោកត្រូវអាបត្តិឈ្មោះនេះហើយ ចូរលោកសំដែងអាបត្តិនោះចេញ។ ភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោ មិនមែនតែខ្ញុំម្នាក់ឯង ត្រូវអាបត្តិនេះទេ សង្ឃទាំងអស់នេះក៏ត្រូវអាបត្តិនេះដែរ។ ភិក្ខុជាបណ្ឌិតនោះ និយាយយ៉ាងនេះថា នែអាវុសោ អ្នកដទៃត្រូវ (អាបត្តិ)ក្តី មិនត្រូវក្តី នឹងធ្វើអ្វីដល់លោកបាន នែអាវុសោ ណ្ហើយ ចូរលោកចេញចាកអាបត្តិរបស់ខ្លួនទៅ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះសំដែងអាបត្តិនោះតាមពាក្យភិក្ខុនោះហើយ ចូលទៅរកភិក្ខុទាំងឡាយនោះ លុះចូលទៅដល់ហើយ និយាយយ៉ាងនេះនឹងភិក្ខុទាំងឡាយនោះថា នែអាវុសោ ឮថា ភិក្ខុណាធ្វើយ៉ាងនេះផងៗ ភិក្ខុនោះត្រូវអាបត្តិឈ្មោះនេះ នែអាវុសោ លោកទាំងឡាយត្រូវអាបត្តិឈ្មោះនេះហើយ ចូរលោកទាំងឡាយសំដែងអាបត្តិនោះចេញ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះសំដែងអាបត្តិនោះ តាមពាក្យភិក្ខុនោះ ការសំដែងនុ៎ះ ជាការល្អ បើមិនសំដែងទេ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុនោះស្តីថាឲ្យភិក្ខុទាំងនោះឡើយ ព្រោះខ្លួនគ្មានអំណាច (ស្តីថាឲ្យគេទេ)។

ចប់ ចោទនាវត្ថុភាណវារៈ។

## ៩៥. អនាបត្តិបន្នរសកំ

CS vin.mv.02.28 | ភាគ ទី៦

### (វិធីដែលភិក្ខុធ្វើឧបោសថមិនត្រូវអាបត្តិ មាន១៥យ៉ាង (៩៥.))

[១៩១] សម័យនោះឯង ក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុ[140)] ជាច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា ពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ ក៏សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកសំគាល់ថា ព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះកំពុងសំដែងបាតិមោក្ខ (ស្រាប់តែមាន) ពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងវេលានោះ។ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃ មិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជា

វិន័យ ជាពួកសំគាល់ថា ព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះកំពុងសំដែងបាតិមោក្ខ ស្រាប់តែមានពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ត្រូវសំដែងបាតិមោក្ខឡើងម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើក្នុងអាវាស១ មានអាវាសិកភិក្ខុជាច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ ក៏សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកសំគាល់ថា ព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះកំពុងសំដែងបាតិមោក្ខ ស្រាប់តែមានពួកអាវាសិកភិក្ខុដទៃចំនួនស្មើៗគ្នា មកដល់ក្នុងពេលនោះ។ ឧទ្ទេសដែលភិក្ខុសំដែងរួចហើយ ក៏ឈ្មោះថា សំដែងហើយដោយប្រពៃ ត្រូវតែស្តាប់ឧទ្ទេសដ៏សេសសល់អំពីនោះចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើមានពួកអាវាសិកភិក្ខុជាច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងទីអាវាស១ ក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ ក៏សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះកំពុងសំដែងបាតិមោក្ខ ក៏មានពួកអាវាសិកភិក្ខុដទៃតិចជាង មកដល់ក្នុងពេលនោះ។ ឧទ្ទេសដែលភិក្ខុសំដែងរួចហើយ ក៏ឈ្មោះថា សំដែងហើយដោយប្រពៃ ត្រូវតែស្តាប់ឧទ្ទេសសេសសល់អំពីនោះចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុជាច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថា ព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះទើបតែនឹងសំដែងបាតិមោក្ខរួចទៅហើយ ស្រាប់តែមានពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ត្រូវសំដែងបាតិមោក្ខម្តងទៀត។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចទៅហើយ ស្រាប់តែមានពួកអាវាសិកភិក្ខុដទៃចំនួនស្មើៗគ្នា មកដល់ក្នុងពេលនោះ។ បាតិមោក្ខដែល ដែលភិក្ខុបានសំដែងរួចហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ។ ពួកអាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិក្នុងសំណាក់ភិក្ខុទាំងឡាយ ដែលធ្វើឧបោសថហើយនោះចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុជាច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ ស្រាប់តែមានអាវាសិកភិក្ខុដទៃតិចជាង មកដល់ក្នុងពេលនោះ។ បាតិមោក្ខដែលភិក្ខុបានសំដែងរួចហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ អាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិ ក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថា ព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះទើបតែនឹងសំដែងបាតិមោក្ខរួចហើយ ភិក្ខុបរិសទ្យ ក៏មិនទាន់ក្រោកចេញនៅឡើយ ស្រាប់តែមានពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ត្រូវសំដែងបាតិមោក្ខម្តងទៀត។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាស១ មានអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ ភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ ពួកភិក្ខុបរិសទ្យមិនទាន់ក្រោកចេញនៅឡើយ ស្រាប់តែមានពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ បាតិមោក្ខដែលភិក្ខុបានសំដែងរួចទៅហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ អាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិក្នុងសំណាក់ភិក្ខុទាំងនោះចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុជាច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ ភិក្ខុបរិសទ្យខ្លះក៏បានក្រោកចេញទៅហើយ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះត្រូវសំដែងបាតិមោក្ខម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងនោះសំគាល់ថា ជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ ភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ ពួកភិក្ខុបរិសទ្យខ្លះក៏ក្រោកចេញទៅ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ បាតិមោក្ខដែលភិក្ខុបានសំដែងរួចហើយ ក៏ឈ្មោះថា បានសំដែងហើយ អាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិ ក្នុងសំណាក់ភិក្ខុទាំងនោះចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ ភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចទៅហើយ ភិក្ខុបរិសទ្យទាំងអស់ ក៏បានក្រោកចេញទៅ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះត្រូវសំដែងបាតិមោក្ខម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងមិនត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនបានដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ឡើយ។ ភិក្ខុទាំងនោះសំគាល់ថា ជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខ។ ភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ ភិក្ខុបរិសទ្យទាំងអស់ បានក្រោកចេញទៅហើយ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ បាតិមោក្ខដែលភិក្ខុ

បានសំដែងរួចហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ អាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិ ក្នុងសំណាក់ភិក្ខុទាំងនោះចុះ។ ពួកភិក្ខុអ្នកសំដែង មិនត្រូវអាបត្តិឡើយ។

ចប់ វិធីដែលភិក្ខុធ្វើឧបោសថមិនត្រូវអាបត្តិ មាន១៥យ៉ាង។

## ៩៦. វគ្គាវគ្គសញ្ញីបន្នរសកំ

CS vin.mv.02.29 | ភាគ ទី៦

### (រឿងភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មជាបក្ខពួកថាព្រមព្រៀងគ្នាហើយ ធ្វើឧបោសថ មាន១៥យ៉ាង (៩៦.))

[១៩២] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ដែរ។ ភិក្ខុទាំងនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកសំគាល់ថា ព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ កាលភិក្ខុទាំងនោះកំពុងសំដែងបាតិមោក្ខ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងវេលានោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ត្រូវសំដែងបាតិមោក្ខម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ ឧទ្ទេសដែលភិក្ខុបានសំដែងរួចទៅហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ ភិក្ខុទាំងនោះត្រូវស្តាប់ នូវឧទ្ទេសដ៏សេសសល់ចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់ដែរ។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ ភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ ស្រាប់តែមានពួកអាវាសិកភិក្ខុដទៃ ច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ត្រូវសំដែងបាតិមោក្ខម្តងទៀត។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។បេ។ ស្រាប់តែមានពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ បាតិមោក្ខដែល ភិក្ខុបានសំដែងរួចទៅហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ ពួកអាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិក្នុងសំណាក់ភិក្ខុទាំងនោះចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់។ ភិក្ខុទាំងនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួក សំគាល់ថាព្រមព្រៀងគ្នា ក៏ធ្វើឧបោសថ សំដែងបាតិមោក្ខឡើង។ ភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ កាលភិក្ខុបរិសទ្យមិនទាន់ក្រោកចេញនៅឡើយ។បេ។ កាលភិក្ខុបរិសទ្យខ្លះក្រោកចេញទៅហើយ។បេ។ កាលភិក្ខុបរិសទ្យទាំងអស់បានក្រោកចេញទៅហើយ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះត្រូវសំដែងបាតិមោក្ខម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។បេ។ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ បាតិមោក្ខដែល ភិក្ខុបានសំដែងរួចទៅហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ អាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិក្នុងសំណាក់ភិក្ខុនោះចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។

ចប់ រឿងភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មជាបក្ខពួកថាព្រមព្រៀងគ្នាហើយ ធ្វើឧបោសថ មាន១៥យ៉ាង។

## ៩៧. វេមតិកបន្នរសកំ

CS vin.mv.02.30 | ភាគ ទី៦

### (រឿងភិក្ខុមានសេចក្តីសង្ស័យ ហើយធ្វើឧបោសថ មាន១៥យ៉ាង (៩៧.))

[១៩៣] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមកមិនទាន់ដល់។ ភិក្ខុទាំងនោះ ក៏មានសេចក្តីសង្ស័យថា យើងគួរធ្វើឧបោសថ ឬមិនគួរធ្វើទេ ហើយចេះតែធ្វើឧបោសថ សំដែងបាតិមោក្ខទៅ។ កាលដែលភិក្ខុទាំងនោះកំពុងសំដែងបាតិមោក្ខ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងវេលានោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ត្រូវសំដែងបាតិមោក្ខម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។បេ។ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ ឧទ្ទេសដែលភិក្ខុបានសំដែងរួចហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ ភិក្ខុទាំងនោះត្រូវស្តាប់ឧទ្ទេសដ៏សេសសល់ចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់។ ភិក្ខុទាំងនោះ មានសេចក្តីសង្ស័យថា យើងគួរធ្វើឧបោសថ ឬមិនគួរធ្វើទេ ហើយចេះតែធ្វើឧបោសថ សំដែងបាតិមោក្ខ។ កាលដែលភិក្ខុទាំងនោះទើបនឹងសំដែងបាតិមោក្ខរួច។បេ។ កាលភិក្ខុបរិសទ្យមិនទាន់បានក្រោកចេញនៅឡើយ។បេ។ កាលភិក្ខុបរិសទ្យពួកខ្លះបានក្រោកចេញទៅហើយ។បេ។ កាលភិក្ខុបរិសទ្យទាំងអស់បានក្រោកចេញទៅហើយ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះត្រូវសំដែងបាតិមោក្ខម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។បេ។ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ បាតិមោក្ខដែល ភិក្ខុបានសំដែងរួចទៅហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ អាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិក្នុងសំណាក់ភិក្ខុទាំងនោះចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។

ចប់ រឿងភិក្ខុមានសេចក្តីសង្ស័យ ហើយធ្វើឧបោសថ មាន១៥យ៉ាង។

## ៩៨. កុក្កុច្ចបកតបន្នរសកំ

**(រឿងភិក្ខុធ្វើឧបោសថ ដោយមានសេចក្តីរង្កៀស មាន១៥យ៉ាង (៩៨.))**

[១៩៤] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមិនទាន់មកដល់។ ភិក្ខុទាំងនោះ មានសេចក្តីរង្កៀសថា យើងគួរតែធ្វើឧបោសថ មិនមែនថាយើងមិនគួរធ្វើទេ ហើយក៏ធ្វើឧបោសថ សំដែងបាតិមោក្ខទៅ។ កាលភិក្ខុទាំងនោះកំពុងសំដែងបាតិមោក្ខ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ត្រូវសំដែងបាតិមោក្ខម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។បេ។ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ ឧទ្ទេសដែលភិក្ខុបានសំដែងហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ ភិក្ខុទាំងនោះត្រូវស្តាប់ឧទ្ទេសដ៏សេសសល់ចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមកមិនទាន់ដល់។ ភិក្ខុទាំងនោះ មានសេចក្តីរង្កៀសថា យើងគួរតែធ្វើឧបោសថ មិនមែនថាយើងមិនគួរធ្វើទេ ហើយក៏ធ្វើឧបោសថ សំដែងបាតិមោក្ខទៅ។ កាលដែលភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ។បេ។ កាលភិក្ខុបរិសទ្យមិនទាន់ក្រោកចេញនៅឡើយ។បេ។ កាលភិក្ខុបរិសទ្យពួកខ្លះក្រោកចេញទៅហើយ។បេ។ កាលភិក្ខុបរិសទ្យទាំងអស់ក្រោកចេញទៅហើយ ទើបមានពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះត្រូវសំដែងបាតិមោក្ខម្តងទៀតចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។បេ។ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ បាតិមោក្ខដែល ភិក្ខុបានសំដែងរួចទៅហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ អាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិក្នុងសំណាក់ភិក្ខុទាំងនោះចុះ។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិទុក្កដ។

ចប់ រឿងភិក្ខុធ្វើឧបោសថ ដោយមានសេចក្តីរង្កៀស មាន១៥យ៉ាង។

## ៩៩. ភេទបុរេក្ខារបន្នរសកំ



**(រឿងភិក្ខុធ្វើឧបោសថ ដោយមានបំណងនឹងបំបែកសង្ឃ មាន១៥យ៉ាង (៩៩.))**

[១៩៥] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមកមិនទាន់ដល់។ ភិក្ខុទាំងនោះ មានបំណងនឹងបំបែកថា ពួកភិក្ខុនុ៎ះចូរបាត់បង់ទៅ ពួកភិក្ខុនុ៎ះចូរវិនាសទៅ ប្រយោជន៍អ្វីដោយភិក្ខុទាំងនោះ ហើយក៏ធ្វើឧបោសថ សំដែងបាតិមោក្ខទៅ។ កាលដែលភិក្ខុទាំងនោះកំពុងសំដែងបាតិមោក្ខ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ត្រូវសំដែងបាតិមោក្ខម្តងទៀត។ ពួកភិក្ខុអ្នកសំដែងត្រូវអាបត្តិថុល្លច្ច័យ។បេ។ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ ឧទ្ទេសដែលភិក្ខុបានសំដែងរួចហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ ភិក្ខុទាំងនោះ ត្រូវស្តាប់ឧទ្ទេសដ៏សេសសល់ចុះ។ ពួកភិក្ខុអ្នកសំដែង ត្រូវអាបត្តិថុល្លច្ច័យ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ ភិក្ខុទាំងនោះដឹងថា មានពួកអាវាសិកភិក្ខុដទៃមកមិនទាន់ដល់។ ភិក្ខុទាំងនោះ មានបំណងនឹងបំបែកថា ភិក្ខុទាំងនុ៎ះ ចូរបាត់បង់ទៅចុះ ភិក្ខុទាំងនុ៎ះចូរវិនាសទៅចុះ ប្រយោជន៍អ្វីដោយភិក្ខុទាំងនោះ ហើយក៏ធ្វើឧបោសថ សំដែងបាតិមោក្ខទៅ។ កាលដែលភិក្ខុទាំងនោះទើបតែសំដែងបាតិមោក្ខរួចហើយ។បេ។ កាលដែលភិក្ខុបរិសទ្យមិនទាន់បានក្រោកចេញនៅឡើយ។បេ។ កាលដែលភិក្ខុបរិសទ្យពួកខ្លះបានក្រោកចេញទៅហើយ។បេ។ កាលដែលភិក្ខុបរិសទ្យទាំងអស់ បានក្រោកចេញទៅហើយ ស្រាប់តែពួកអាវាសិកភិក្ខុដទៃច្រើនជាង មកដល់ក្នុងពេលនោះឯង។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះត្រូវសំដែងបាតិមោក្ខម្តងទៀត។ តែពួកភិក្ខុអ្នកសំដែង ត្រូវអាបត្តិថុល្លច្ច័យ។បេ។ ស្រាប់តែពួកអាវាសិកភិក្ខុដទៃស្មើៗគ្នា មកដល់ក្នុងពេលនោះ។បេ។ តិចជាង។ បាតិមោក្ខដែលភិក្ខុបានសំដែងរួចទៅហើយ ក៏ឈ្មោះថា បានសំដែងល្អហើយ អាវាសិកភិក្ខុដទៃ ត្រូវប្រាប់បារិសុទ្ធិក្នុងសំណាក់ពួកភិក្ខុទាំងនោះចុះ។ ឯពួកភិក្ខុអ្នកសំដែង ត្រូវអាបត្តិថុល្លច្ច័យ។

ចប់ រឿងភិក្ខុធ្វើឧបោសថ ដោយមានបំណងនឹងបំបែកសង្ឃ មាន១៥យ៉ាង។

ចប់ តិក២៥។

## ១០០. សីមោក្កន្តិកបេយ្យាលំ



**(១០០.)**

[១៩៦] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើក្នុងទីអាវាស១ មានពួកអាវាសិកភិក្ខុច្រើនរូប គឺចំនួន៤រូប ឬច្រើនជាង៤រូបឡើងទៅ ប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ។ ភិក្ខុទាំងនោះមិនដឹងថា មានពួកអាវាសិកភិក្ខុដទៃដើរចូលមកខាងក្នុងសីមាឡើយ។បេ។ ភិក្ខុទាំងនោះ មិនដឹងថា ពួកអាវាសិកភិក្ខុដទៃ បានដើរចូលមកខាងក្នុងសីមាហើយ។បេ។ ភិក្ខុទាំងនោះ មិនឃើញពួកអាវាសិកភិក្ខុដទៃកំពុងដើរចូលមកខាងក្នុងសីមាឡើយ។បេ។ ភិក្ខុទាំងនោះមិនឃើញពួកអាវាសិកភិក្ខុដទៃបានដើរចូលមកខាងក្នុងសីមា។បេ។ ភិក្ខុទាំងនោះ មិនឮថា ពួកអាវាសិកភិក្ខុដទៃដើរចូលមកខាងក្នុងសីមា។បេ។ ភិក្ខុទាំងនោះមិនឮថា ពួកអាវាសិកភិក្ខុដទៃ បានដើរចូលមកខាងក្នុងសីមា។បេ។ អាវាសិកភិក្ខុ និងអាវាសិកភិក្ខុ មានចំនួន១៧៥តិកន័យ អាគន្តុកភិក្ខុ និងអាវាសិកភិក្ខុ ក៏មានចំនួន១៧៥ តិកន័យដែរ អាវាសិកភិក្ខុ និងអាគន្តុកភិក្ខុក៏មានចំនួន១៧៥តិកន័យដែរ អាគន្តុកភិក្ខុ និងអាគន្តុកភិក្ខុផងគ្នា ក៏មានចំនួន១៧៥តិកន័យដែរ បូករួមទាំងអស់ត្រូវជា៧០០តិកន័យ ដោយបេយ្យាលមុខ។

[១៩៧] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើថ្ងៃទី១៤ ជាថ្ងៃរបស់ពួកអាវាសិកភិក្ខុ ថ្ងៃទី១៥ ជាថ្ងៃរបស់ពួកអាគន្តុកភិក្ខុ។ បើពួកអាវាសិកច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុប្រព្រឹត្តតាមពួកអាវាសិកភិក្ខុវិញចុះ[141) ]។ បើទុកជាស្មើៗគ្នា ក៏ត្រូវតែពួកអាគន្តុកភិក្ខុប្រព្រឹត្តតាមពួកអាវាសិកភិក្ខុដែរ។ បើពួកអាគន្តុកច្រើនជាង ត្រូវពួកអាវាសិកភិក្ខុប្រព្រឹត្តតាមពួកអាគន្តុកភិក្ខុវិញចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើថ្ងៃទី១៥ ជាថ្ងៃរបស់ពួកអាវាសិកភិក្ខុ ថ្ងៃទី១៤ ជាថ្ងៃរបស់ពួកអាគន្តុកភិក្ខុ។ បើពួកអាវាសិកភិក្ខុច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុប្រព្រឹត្តតាមពួកអាវាសិកភិក្ខុចុះ។ បើចំនួនស្មើៗគ្នាទេ ត្រូវពួកអាគន្តុកភិក្ខុប្រព្រឹត្តតាមពួកអាវាសិកភិក្ខុវិញ។ បើពួកអាគន្តុកភិក្ខុច្រើនជាង ត្រូវពួកអាវាសិកភិក្ខុប្រព្រឹត្តតាមពួកអាគន្តុកភិក្ខុវិញចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើថ្ងៃទី១កើត ឬ១រោច របស់ពួកអាវាសិកភិក្ខុ ថ្ងៃទី១៥ របស់ពួកអាគន្តុកភិក្ខុ។ បើពួកអាវាសិកភិក្ខុច្រើនជាង ពួកអាវាសិកភិក្ខុមិនប្រាថ្នា (នឹងឲ្យ) មិនត្រូវឲ្យសេចក្តីព្រមព្រៀង ដល់ពួកអាគន្តុកភិក្ខុឡើយ ត្រូវពួកអាគន្តុកភិក្ខុ ចេញទៅក្រៅសីមា ហើយធ្វើឧបោសថ។ បើជាស្មើៗគ្នាវិញ ពួកអាវាសិកភិក្ខុមិនចង់ឲ្យ ក៏មិនត្រូវឲ្យសាមគ្គី ដល់ពួកអាគន្តុកភិក្ខុដែរ ត្រូវតែពួកអាគន្តុកភិក្ខុ ចេញទៅក្រៅសីមា ហើយធ្វើឧបោសថចុះ។ បើពួកអាគន្តុកភិក្ខុច្រើនជាង ត្រូវពួកអាវាសិកភិក្ខុឲ្យសាមគ្គី ដល់ពួកអាគន្តុកភិក្ខុ ឬត្រូវចេញទៅក្រៅសីមា។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើថ្ងៃទី១៥ ជារបស់ពួកអាវាសិកភិក្ខុ ថ្ងៃ១កើត ឬ១រោច ជាថ្ងៃរបស់ពួកអាគន្តុកភិក្ខុ។ បើពួកអាវាសិកភិក្ខុច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុ ឲ្យសាមគ្គី ដល់ពួកអាវាសិកភិក្ខុ ឬត្រូវចេញទៅខាងក្រៅសីមា។ បើជាស្មើៗគ្នាវិញ ត្រូវពួកអាគន្តុកភិក្ខុ ឲ្យសាមគ្គី ដល់ពួកអាវាសិកភិក្ខុ ឬត្រូវចេញទៅខាងក្រៅសីមា។ បើអាគន្តុកភិក្ខុច្រើនជាង អាគន្តុកភិក្ខុមិនប្រាថ្នា (នឹងឲ្យ) ក៏មិនត្រូវឲ្យសាមគ្គីដល់អាវាសិកភិក្ខុឡើយ ត្រូវពួកអាវាសិកភិក្ខុ ចេញទៅធ្វើឧបោសថខាងក្រៅសីមា។

## ១០១. លិង្គាទិទស្សនំ

CS vin.mv.02.34 | ភាគ ទី៦

**(១០១.)**

[១៩៨] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុ ឃើញអាការរបស់អាវាសិកភិក្ខុ ឃើញភេទរបស់អាវាសិកភិក្ខុ ឃើញនិមិត្តរបស់អាវាសិកភិក្ខុ ឃើញឧទ្ទេសរបស់អាវាសិកភិក្ខុ ឃើញគ្រែ តាំង ពូក ខ្នើយ ដែលគេរៀបចំទុកល្អ ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ដែលគេដំកល់ទុកល្អ ឃើញទីបរិវេណរលីងល្អ របស់អាវាសិកភិក្ខុទាំងឡាយ លុះបានឃើញហើយ ក៏មានសេចក្តីសង្ស័យថា មានពួកអាវាសិកភិក្ខុ ឬគ្មានទេ។ អាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ក៏មិនបានគន់មើលឡើយ លុះមិនបានគន់មើលហើយ ក៏ធ្វើឧបោសថទៅ នោះត្រូវអាបត្តិទុក្កដ។ អាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏ខំគន់មើល លុះគន់មើលហើយ ក៏មិនឃើញ លុះមិនឃើញហើយ ក៏ធ្វើឧបោសថទៅ ឥតត្រូវអាបត្តិឡើយ។ អាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏ខំគន់មើល លុះគន់មើលទៅហើយ ក៏បានឃើញ លុះឃើញហើយ ក៏ធ្វើឧបោសថជាមួយគ្នា ឥតត្រូវអាបត្តិឡើយ។ អាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏ខំគន់មើល លុះគន់មើលហើយ ក៏បានឃើញ លុះឃើញហើយ ក៏ធ្វើឧបោសថផ្សេងគ្នា នោះត្រូវអាបត្តិទុក្កដ។ អាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយខំគន់មើល លុះគន់មើលហើយ ក៏ឃើញ លុះឃើញហើយ ក៏មានបំណងនឹងបំបែកថា ភិក្ខុទាំងនុ៎ះ ចូរបាត់បង់ទៅចុះ ភិក្ខុទាំងនុ៎ះ ចូរវិនាសទៅចុះ ប្រយោជន៍អ្វីដោយពួកភិក្ខុទាំងនោះ ហើយក៏ធ្វើឧបោសថទៅ ត្រូវអាបត្តិថុល្លច្ច័យ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុ ឮដំណឹងអាការរបស់អាវាសិកភិក្ខុ ភេទរបស់អាវាសិកភិក្ខុ និមិត្តរបស់អាវាសិកភិក្ខុ ឧទ្ទេសរបស់អាវាសិកភិក្ខុ ឮសូរជើងរបស់អាវាសិកភិក្ខុកំពុងចង្ក្រម ឮសំឡេងស្វាធ្យាយ ឮសំឡេងក្អក ឮសំឡេងកណ្តាសរបស់អាវាសិកភិក្ខុទាំងឡាយ លុះឮហើយ មានសេចក្តីសង្ស័យថា មានពួកអាវាសិកភិក្ខុ ឬមិនមានទេ។ អាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ហើយមិនបានគន់មើល លុះមិនបានគន់មើលហើយ ក៏ធ្វើឧបោសថទៅ ត្រូវអាបត្តិទុក្កដ។ អាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ បានគន់មើល លុះគន់មើលហើយ ក៏មិនឃើញ លុះមិនឃើញហើយ ក៏ធ្វើឧបោសថទៅ ឥតត្រូវអាបត្តិឡើយ។ អាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ បានគន់មើល លុះគន់មើលទៅហើយ ក៏ឃើញ លុះឃើញហើយ ក៏ធ្វើឧបោសថជាមួយគ្នា ឥតត្រូវអាបត្តិឡើយ។ អាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ បានគន់មើល លុះគន់មើលទៅហើយ ក៏ឃើញ លុះឃើញហើយ ក៏ធ្វើឧបោសថផ្សេងគ្នា ត្រូវអាបត្តិទុក្កដ។ អាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ បានគន់មើល លុះគន់មើលទៅហើយ ក៏ឃើញ លុះឃើញហើយ ក៏មានបំណងនឹងបំបែកថា ភិក្ខុទាំងនុ៎ះ ចូរបាត់បង់ទៅចុះ ភិក្ខុទាំងនុ៎ះ ចូរវិនាសទៅចុះ ប្រយោជន៍អ្វីដោយពួកភិក្ខុទាំងនោះ ហើយក៏ធ្វើឧបោសថ ត្រូវអាបត្តិថុល្លច្ច័យ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ ឃើញអាការរបស់អាគន្តុកភិក្ខុ ឃើញភេទរបស់អាគន្តុកភិក្ខុ ឃើញនិមិត្តរបស់អាគន្តុកភិក្ខុ ឃើញឧទ្ទេសរបស់អាគន្តុកភិក្ខុ ឃើញបាត្រ ដែលខ្លួនមិនស្គាល់ ឃើញចីវរដែលខ្លួនមិនស្គាល់ ឃើញសំពត់និសីទនៈដែលខ្លួនមិនស្គាល់ ឃើញទឹកសម្រាប់លាងជើង ទឹកសម្រាប់ស្រោចជើងរបស់អាគន្តុកភិក្ខុទាំងឡាយ លុះឃើញហើយ ក៏មានសេចក្តីសង្ស័យថា មានពួកអាគន្តុកភិក្ខុ ឬគ្មានទេ។ អាវាសិកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ក៏មិនបានគន់មើល លុះមិនបានគន់មើលហើយ ក៏ធ្វើឧបោសថទៅ ត្រូវអាបត្តិទុក្កដ។ អាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏គន់មើល លុះគន់មើលហើយ ក៏មិនបានឃើញ លុះមិនឃើញហើយ ក៏ធ្វើឧបោសថទៅ មិនត្រូវអាបត្តិឡើយ។ អាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏ខំគន់មើល លុះគន់មើលទៅហើយ ក៏ឃើញ លុះបានឃើញហើយ ក៏ធ្វើឧបោសថជាមួយគ្នា មិនត្រូវអាបត្តិ។ អាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏ខំគន់មើល លុះគន់មើលទៅហើយ ក៏ឃើញ លុះឃើញហើយ ក៏ធ្វើឧបោសថផ្សេងគ្នា ត្រូវអាបត្តិទុក្កដ។ អាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏ខំគន់មើល លុះគន់មើលទៅហើយ ក៏ឃើញ លុះឃើញហើយ ក៏មានបំណងនឹងបំបែកថា ពួកភិក្ខុទាំងនុ៎ះ ចូរបាត់បង់ទៅចុះ ពួកភិក្ខុទាំងនុ៎ះ ចូរវិនាសទៅចុះ ត្រូវការអ្វីដោយពួកភិក្ខុទាំងនោះ ហើយក៏ធ្វើឧបោសថទៅ ត្រូវអាបត្តិថុល្លច្ច័យ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ ឮអាការរបស់អាគន្តុកភិក្ខុ ភេទរបស់អាគន្តុកភិក្ខុ និមិត្តរបស់អាគន្តុកភិក្ខុ ឧទ្ទេសរបស់អាគន្តុកភិក្ខុ ឮសូរជើងរបស់អាគន្តុកភិក្ខុកំពុងដើរមក ឮសូរផ្ទាត់ស្បែកជើង ឮសំឡេងក្អក សំឡេងកណ្តាស់របស់អាគន្តុកភិក្ខុទាំងឡាយ លុះឮហើយ ក៏មានសេចក្តីសង្ស័យថា មានពួកអាគន្តុកភិក្ខុ ឬគ្មានទេ។ អាវាសិកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ក៏មិនបានគន់មើល លុះមិនបានគន់មើលហើយ ក៏ធ្វើឧបោសថទៅ ត្រូវអាបត្តិទុក្កដ។ អាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏គន់មើល លុះគន់មើលហើយ ក៏មិនឃើញ លុះមិនឃើញហើយ ក៏ធ្វើឧបោសថទៅ មិនត្រូវអាបត្តិ។ អាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏គន់មើល លុះគន់មើលហើយ ក៏ឃើញ លុះឃើញហើយ ក៏ធ្វើឧបោសថជាមួយគ្នា ឥតត្រូវអាបត្តិឡើយ។ អាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏គន់មើល លុះគន់មើលហើយ ក៏ឃើញ លុះឃើញហើយ ក៏ធ្វើឧបោសថផ្សេងគ្នា នោះត្រូវអាបត្តិ

ទុក្កដ។ អាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ក៏គន់មើល លុះគន់មើលហើយ ក៏ឃើញ លុះឃើញហើយ ក៏មានបំណងនឹងបំបែកថា ភិក្ខុទាំងនុ៎ះ ចូរបាត់បង់ទៅចុះ ភិក្ខុទាំងនុ៎ះ ចូរវិនាសទៅចុះ ត្រូវការអ្វីដោយពួកភិក្ខុទាំងនោះ ហើយក៏ធ្វើឧបោសថទៅ ត្រូវអាបត្តិថុល្លច្ច័យ។

## ១០២. នានាសំវាសកាទីហិ ឧបោសថករណំ

CS vin.mv.02.35 | ភាគ ទី៦

**(១០២.)**

[១៩៩] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុ ឃើញពួកអាវាសិកភិក្ខុមានសំវាសផ្សេងៗគ្នា ពួកអាគន្តុកភិក្ខុទាំងនោះ ក៏ត្រឡប់ជាយល់ឃើញថា ជាអ្នកមានសំវាសស្មើគ្នាទៅវិញ លុះត្រឡប់ជាយល់ឃើញថា ជាអ្នកមានសំវាសស្មើគ្នាហើយ ក៏មិនបានសួរ លុះមិនបានសួរហើយ ក៏ធ្វើឧបោសថជាមួយគ្នា មិនត្រូវអាបត្តិឡើយ។ អាគន្តុកភិក្ខុទាំងនោះ បានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះសួរហើយ ក៏មិនអាចគ្របសង្កត់បាន[142] លុះគ្របសង្កត់មិនបានហើយ ក៏ធ្វើឧបោសថជាមួយគ្នា ត្រូវអាបត្តិទុក្កដ។ អាគន្តុកភិក្ខុទាំងនោះ បានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះសួរហើយ ក៏មិនអាចគ្រប់សង្កត់បាន លុះគ្របសង្កត់មិនបានហើយ ក៏ធ្វើឧបោសថផ្សេងគ្នា ឥតត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុ ឃើញពួកអាវាសិកភិក្ខុមានសំវាសស្មើគ្នា តែពួកអាគន្តុកភិក្ខុទាំងនោះ ត្រឡប់យល់ឃើញថា ជាអ្នកមានសំវាសផ្សេងគ្នាទៅវិញ លុះត្រឡប់យល់ឃើញថា ជាអ្នកមានសំវាសផ្សេងគ្នាទៅវិញហើយ ក៏មិនបានសួរ លទ្ធិរបស់ភិក្ខុទាំងនោះ លុះមិនបានសួរហើយ ក៏ធ្វើឧបោសថជាមួយគ្នា ត្រូវអាបត្តិទុក្កដ។ អាគន្តុកភិក្ខុទាំងនោះ បានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះសួរហើយ ក៏អាចគ្របសង្កត់បាន លុះគ្របសង្កត់បានហើយ ក៏ធ្វើឧបោសថជាផ្សេងគ្នា ត្រូវអាបត្តិទុក្កដ។ អាគន្តុកភិក្ខុទាំងនោះ បានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះសួរហើយ ក៏អាចគ្របសង្កត់បាន លុះគ្របសង្កត់បានហើយ ក៏ធ្វើឧបោសថជាមួយគ្នា ឥតត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ ឃើញពួកអាគន្តុកភិក្ខុមានសំវាសផ្សេងៗគ្នា តែអាវាសិកភិក្ខុទាំងនោះ ត្រឡប់បាននូវសេចក្តីយល់ឃើញថា ជាអ្នកមានសំវាសស្មើគ្នាវិញ លុះត្រឡប់បាននូវសេចក្តីយល់ឃើញថា ជាអ្នកមានសំវាសស្មើគ្នាហើយ ក៏មិនបានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះមិនបានសួរហើយ ក៏ធ្វើឧបោសថជាមួយគ្នា មិនត្រូវអាបត្តិឡើយ។ អាវាសិកភិក្ខុទាំងនោះ បានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះសួរហើយ មិនអាចនឹងគ្របសង្កត់បាន លុះគ្របសង្កត់មិនបានហើយ ក៏ធ្វើឧបោសថជាមួយគ្នា ត្រូវអាបត្តិទុក្កដ។ អាវាសិកភិក្ខុទាំងនោះ បានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះសួរហើយ មិនអាចនឹងគ្របសង្កត់បាន លុះគ្របសង្កត់មិនបានហើយ ក៏ធ្វើឧបោសថផ្សេងគ្នា ឥតត្រូវអាបត្តិឡើយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ ឃើញពួកអាគន្តុកភិក្ខុមានសំវាសស្មើគ្នា តែអាវាសិកភិក្ខុទាំងនោះ ត្រឡប់បាននូវសេចក្តីយល់ឃើញថា ជាអ្នកមានសំវាសផ្សេងគ្នាទៅវិញ លុះត្រឡប់បាននូវសេចក្តីយល់ឃើញថា ជាអ្នកមានសំវាសផ្សេងគ្នាហើយ ក៏មិនបានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះមិនបានសួរហើយ ក៏ធ្វើឧបោសថជាមួយគ្នា ត្រូវអាបត្តិទុក្កដ។ អាវាសិកភិក្ខុទាំងនោះ បានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះសួរហើយ ក៏អាចគ្របសង្កត់បាន លុះគ្របសង្កត់បានហើយ ក៏ធ្វើឧបោសថផ្សេងគ្នា ត្រូវអាបត្តិទុក្កដ។ អាវាសិកភិក្ខុទាំងនោះ បានសួរលទ្ធិរបស់ភិក្ខុទាំងនោះ លុះសួរហើយ ក៏អាចគ្របសង្កត់បាន លុះគ្របសង្កត់បានហើយ ក៏ធ្វើឧបោសថជាមួយគ្នា មិនត្រូវអាបត្តិឡើយ។

## ១០៣. នគន្តព្វវារោ

CS vin.mv.02.36 | ភាគ ទី៦

**(១០៣.)**

[២០០] ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាស ដែលមានភិក្ខុ ហើយទៅកាន់អាវាសដែលគ្មានភិក្ខុឡើយ វៀរលែងតែ (មានភិក្ខុល្មមគ្រប់គណៈសង្ឃ) វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស (ទីដែលមិនមែនជាអាវាស) ដែលគ្មានភិក្ខុឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលគ្មានភិក្ខុឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលគ្មានភិក្ខុ... ទៅកាន់អនាវាសដែលគ្មានភិក្ខុ... ទៅកាន់អាវាស ឬអនាវាសដែលគ្មានភិក្ខុឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលគ្មានភិក្ខុ... ទៅកាន់អនាវាស ដែលគ្មានភិក្ខុ... ទៅកាន់អាវាស ឬអនាវាស ដែលគ្មានភិក្ខុឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ គឺក្នុងអាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នាឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុ គឺក្នុងអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នាឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នាឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ... ទៅកាន់អនាវាសដែលមានភិក្ខុ... ទៅកាន់អាវាស ឬអនាវាសដែលមានភិក្ខុ គឺក្នុងអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នាឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ ... ទៅកាន់អនាវាសដែលមានភិក្ខុ... ទៅកាន់អាវាស ឬអនាវាសដែលមានភិក្ខុ គឺក្នុងអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នាឡើយ វៀរលែងតែសង្ឃ វៀរលែងតែមានសេចក្តីអន្តរាយ។

## ១០៤. គន្តព្វវារោ

**(១០៤.)**

ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុគប្បីចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ (នោះបាន) គឺក្នុងអាវាសណា មានពួកភិក្ខុមានសំវាសស្មើគ្នា ហើយថែមទាំងដឹងថា អាវាសណាដែលខ្លួនអាចទៅទាន់ក្នុងថ្ងៃនេះបានជាប្រាកដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុគប្បីចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុបាន... ទៅកាន់អាវាស ឬអនាវាសដែលមានភិក្ខុ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយទាំងដឹងថា អាវាសណាដែលខ្លួនអាចទៅទាន់ក្នុងថ្ងៃនេះបាន។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុគប្បីចេញពីអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ... ទៅកាន់អនាវាសដែលមានភិក្ខុ... ទៅកាន់អាវាស ឬអនាវាសដែលមានភិក្ខុ គឺក្នុងអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នាបាន ហើយថែមទាំងដឹងថា អាវាសណាដែលខ្លួនអាចទៅទាន់ក្នុងថ្ងៃនេះបានជាប្រាកដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងឧបោសថថ្ងៃនោះ ភិក្ខុគប្បីចេញពីអាវាស ឬអនាវាស ដែលមានភិក្ខុ ហើយទៅកាន់អាវាស ដែលមានភិក្ខុ... ទៅកាន់អនាវាសដែលមានភិក្ខុ... ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺក្នុងអាវាស ឬអនាវាសណាដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយថែមទាំងដឹងថា អាវាសណាដែលខ្លួនអាចទៅទាន់ក្នុងថ្ងៃនេះបានជាប្រាកដ។

## ១០៥. វជ្ជនីយបុគ្គលសន្ទស្សនា



**(១០៥.)**

[២០១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងបាតិមោក្ខដល់ភិក្ខុនីបរិសទ្យ ដែលអង្គុយ (ជាប់ហត្ថបាស)ឡើយ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងបាតិមោក្ខដល់សិក្ខមានា... ដល់សាមណេរ... ដល់សាមណេរី... ដល់ភិក្ខុដែលពោលលាសិក្ខា... ដល់ភិក្ខុដែលត្រូវអន្តិមវត្ថុ (គឺត្រូវអាបត្តិបារាជិកណាមួយ) ដែលជាបរិសទ្យអង្គុយនៅ (ជាប់ហត្ថបាស)ឡើយ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនត្រូវសំដែងបាតិមោក្ខដល់ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ដែលជាបរិសទ្យអង្គុយជាប់ហត្ថបាសឡើយ ភិក្ខុណាសំដែង ភិក្ខុនោះត្រូវវិន័យធរកាត់ទោសឲ្យសមគួរតាមធម៌ចុះ។ ភិក្ខុមិនត្រូវសំដែងបាតិមោក្ខដល់ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនបានសំដែងអាបត្តិ ដែលជាបរិសទ្យអង្គុយជាប់ហត្ថបាសឡើយ... មិនត្រូវសំដែងបាតិមោក្ខដល់ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដែលជាបរិសទ្យអង្គុយជាប់ហត្ថបាសឡើយ ភិក្ខុណាសំដែង ភិក្ខុនោះត្រូវវិន័យធរកាត់ទោសឲ្យសមគួរតាមធម៌ចុះ។ ភិក្ខុមិនត្រូវសំដែងបាតិមោក្ខដល់មនុស្សខ្ទើយ ដែលជាបរិសទ្យអង្គុយជាប់ហត្ថបាសឡើយ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។ ភិក្ខុមិនត្រូវសំដែងបាតិមោក្ខដល់បុគ្គលលួចសំវាស ... ដល់ភិក្ខុដែលរត់ចូលទៅកាន់ពួកតិរ្ថិយ... ដល់សត្វតិរច្ឆាន... ដល់មាតុឃាតកបុគ្គល គឺបុគ្គលដែលសម្លាប់មាតា... ដល់បិតុឃាតកបុគ្គល គឺបុគ្គលដែលសម្លាប់បិតា ដល់អរហន្តឃាតកបុគ្គល គឺបុគ្គលដែលសម្លាប់ព្រះអរហន្ត... ដល់បុគ្គលដែលទ្រុស្តភិក្ខុនី ... ដល់បុគ្គលដែលបំបែកសង្ឃ... ដល់បុគ្គលដែលធ្វើព្រះលោហិតព្រះពុទ្ធជាម្ចាស់ឲ្យពូរពងឡើង ដល់បុគ្គលដែលមានភេទពីរ ដែលជាបរិសទ្យអង្គុយជាប់ហត្ថបាសឡើយ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ។

[២០២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើឧបោសថដោយការឲ្យបារិសុទ្ធិ ហៅថា បារិវាសិកៈ (មានបរិសទ្យក្រោកចេញទៅហើយ) វៀរលែងតែបរិសទ្យមិនទាន់ក្រោកចេញ។

[២០៣] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវធ្វើឧបោសថក្នុងថ្ងៃដែលមិនមែនជាថ្ងៃឧបោសថឡើយ វៀរលែងសង្ឃសាមគ្គីឧបោសថចេញ។

ចប់ ឧបោសថក្ខន្ធកៈ។

ចប់ ភាណវារៈទី៣។

ក្នុងខន្ធកៈនេះ មានរឿង៨៦។

## ១០៦. តស្សុទ្ទានំ



**(ឧទ្ទាននៃឧបោសថក្ខន្ធកៈនោះគឺ (១០៦.))**

[២០៤] រឿងពួកតិរ្ថិយ និងព្រះបាទពិម្ពិសារ១ រឿងភិក្ខុប្រជុំគ្នាអង្គុយស្ងៀម១ រឿងសំដែងធម៌១ រឿងព្រះសម្ពុទ្ធទ្រង់សម្ងំនៅក្នុងទីស្ងាត់ ហើយទ្រង់អនុញ្ញាតឲ្យភិក្ខុសំដែងបាតិមោក្ខ១ រឿងភិក្ខុសំដែងបាតិមោក្ខរាល់ថ្ងៃ ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុសំដែងបាតិមោក្ខក្នុងមួយបក្ខម្តង១ រឿងឆព្វគ្គិយភិក្ខុសំដែងបាតិមោក្ខចំពោះបរិសទ្យរបស់ខ្លួនៗ ទើបព្រះអង្គអនុញ្ញាតឧបោសថកម្មដល់ភិក្ខុដែលព្រមព្រៀងគ្នា១ រឿងព្រះអង្គទ្រង់អនុញ្ញាតដែនសាមគ្គី១ រឿងព្រះមហាកប្បិននៅក្នុងមទ្ទកុច្ឆិមិគទាយវន១ រឿងទ្រង់អនុញ្ញាតឲ្យសម្មតិសីមា១ រឿងឆព្វគ្គិយភិក្ខុសន្មតសីមាធំពេក១ រឿងនទីបារសីមា១ រឿងភិក្ខុសំដែងបាតិមោក្ខរាល់ៗបរិវេណ១ រឿងអាវាសតែមួយ ភិក្ខុសន្មតឲ្យមានរោងឧបោសថពីរ១ រឿងភិក្ខុសន្មតរោងឧបោសថតូចពេក១ រឿងភិក្ខុខ្ចីវស្សា ប្រជុំគ្នាធ្វើ

ឧបោសថមុនភិក្ខុចាស់វស្សា១ រឿងក្រុងរាជគ្រឹះមានអាវាសច្រើន តែមានសីមាជាមួយគ្នា១ រឿងទ្រង់អនុញ្ញាតអវិប្បវាសសីមា និងសម្មតិសមានសំវាសសីមាមុន រួចសម្មតិអវិប្បវាសសីមាក្រោយ១ រឿងសូត្រកម្មវាចាដកសីមា១ រឿងគាមសីមាដែលសង្ឃមិនបានសន្មត១ រឿងនទីសីមា- សមុទ្ទសីមា- ជាតសរសីមា និងឧទកុក្ខេបសីមា១ រឿងឆព្វគ្គិយភិក្ខុទំលាយសីមាដោយសីមា១ រឿងឆព្វគ្គិយភិក្ខុគ្របសីមាគេដោយសីមារបស់ខ្លួន១ រឿងភិក្ខុសង្ស័យថាឧបោសថមានប៉ុន្មាន និងភិក្ខុសង្ស័យថា ឧបោសថកម្មមានប៉ុន្មាន១ រឿងភិក្ខុសង្ស័យថា បាតិមោក្ខុទ្ទេសមានប៉ុន្មាន១ រឿងភិក្ខុមានភ័យអំពីមនុស្សនៅក្នុងដងព្រៃ១ រឿងសំដែងបាតិមោក្ខសង្ខេបដោយឥតមានសេចក្តីអន្តរាយ១ រឿងភិក្ខុសំដែងធម៌ដោយឥតមានគេអារាធនា១ រឿងភិក្ខុសួរវិន័យដោយឥតមានសម្មតិ១ រឿងពួកឆព្វគ្គិយភិក្ខុគម្រាមពួកភិក្ខុមានសីលជាទីស្រឡាញ់១ រឿងពួកឆព្វគ្គិយភិក្ខុគម្រាមបំណងនឹងធ្វើឲ្យវិនាសដល់ពួកភិក្ខុមានសីលជាទីស្រឡាញ់ម្តងទៀត១ រឿងព្រះអង្គអនុញ្ញាតឲ្យភិក្ខុសូមឱកាស ហើយសឹមចោទ១ រឿងព្រះអង្គអនុញ្ញាតឲ្យហាមឃាត់អធម្មកម្ម១ រឿងព្រះអង្គអនុញ្ញាតឲ្យភិក្ខុ៤រូប ឬ៥រូបហាមឃាត់បាន បើ២រូប ៣រូបឲ្យប្រកាសសេចក្តីយល់ឃើញ១ រឿងពួកឆព្វគ្គិយភិក្ខុសំដែងបាតិមោក្ខក្លែងធ្វើសំឡេងមិនឲ្យឮច្បាស់១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុដែលសំដែងបាតិមោក្ខខំប្រឹងប្រែងធ្វើសំឡេងឲ្យឮច្បាស់១ រឿងទេវទត្តសំដែងបាតិមោក្ខដល់បរិសទ្យមានទាំងគ្រហស្ថ១ រឿងពួកឆព្វគ្គិយភិក្ខុឥតមានគេអារាធនាហើយសំដែងបាតិមោក្ខ១ រឿងភិក្ខុនៅក្នុងចោទនាវត្ថុ មិនស្គាល់ថ្ងៃឧបោសថជាដើម១ រឿងភិក្ខុច្រើនរូបមិនស្គាល់ថ្ងៃឧបោសថជាដើម១ រឿងទ្រង់អនុញ្ញាតឲ្យបញ្ជូនភិក្ខុមួយរូបទៅរៀនបាតិមោក្ខក្នុងអាវាសជិតខាងក្នុងថ្ងៃនោះ១ រឿងភិក្ខុខ្ចីទទួលបង្គាប់ភិក្ខុចាស់ ហើយមិនបានទៅ១ រឿងមនុស្សសួរភិក្ខុថាប៉ុន្មាកើត ប៉ុន្មានរោច១ រឿងមនុស្សសួរថា ចំនួនភិក្ខុមានប៉ុន្មានអង្គ១ រឿងភិក្ខុមិនដឹងជាថ្ងៃឧបោសថ ហើយទៅបិណ្ឌបាតក្នុងស្រុកឆ្ងាយ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុប្រាប់ថ្ងៃឧបោសថដល់ភិក្ខុផងគ្នា១ រឿងព្រះថេរៈភ្លេចឧបោសថកាល១ រឿងអាវាសមួយមានរោងឧបោសថស្មោកគ្រោក១ រឿងទ្រង់អនុញ្ញាតឲ្យក្រាលអាសនៈក្នុងរោងឧបោសថ១ រឿងទ្រង់អនុញ្ញាតឲ្យអុជប្រទីបក្នុងរោងឧបោសថ១ រឿងភិក្ខុដើរទៅកាន់ទិស មិនលាអាចារ្យ ឧបជ្ឈាយ៍១ រឿងភិក្ខុដទៃជាពហុស្សូត១ រឿងទ្រង់អនុញ្ញាតឲ្យបញ្ជូនភិក្ខុមួយរូបទៅរៀនបាតិមោក្ខក្នុងអាវាសជិតខាងក្នុងថ្ងៃនោះ១ រឿងភិក្ខុច្រើនរូបមិនឆ្លាសនៅចាំវស្សាក្នុងអាវាសមួយ១ រឿងទ្រង់ឲ្យសង្ឃប្រជុំធ្វើឧបោសថ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឈឺឲ្យបារិសុទ្ធិ១ រឿងទ្រង់ឲ្យសង្ឃប្រជុំធ្វើកម្ម១ រឿងពួកញាតិមកចាប់ភិក្ខុមួយអង្គក្នុងថ្ងៃឧបោសថ១ រឿងគគ្គភិក្ខុ១ រឿងភិក្ខុបួនរូបនៅក្នុងអាវាសមួយ១ រឿងភិក្ខុបីរូបនៅក្នុងអាវាសមួយ១ រឿងភិក្ខុពីររូបនៅក្នុងអាវាសមួយ១ រឿងភិក្ខុមួយរូបនៅក្នុងអាវាសមួយ១ រឿងភិក្ខុត្រូវអាបត្តិ១ រឿងឆព្វគ្គិយភិក្ខុសំដែងសភាគាបត្តិ១ រឿងភិក្ខុរលឹកឃើញនូវអាបត្តិក្នុងពេលដែលសំដែងបាតិមោក្ខ១ រឿងសង្ឃទាំងអស់ត្រូវសភាគាបត្តិហើយមានសេចក្តីសង្ស័យ១ រឿងសង្ឃមិនស្គាល់នាមនិងគោត្ររបស់អាបត្តិ១ រឿងភិក្ខុជាពហុស្សូត១ រឿងអាវាសិកភិក្ខុច្រើនរូប១ រឿងអាវាសិកភិក្ខុដទៃស្មើៗគ្នា១ រឿងអាវាសិកភិក្ខុដទៃតិចជាង១ រឿងបរិសទ្យមិនទាន់ក្រោកចេញ១ រឿងបរិសទ្យខ្លះក្រោកចេញទៅហើយ១ រឿងបរិសទ្យទាំងអស់ក្រោកចេញទៅហើយ១ រឿងអាវាសិកភិក្ខុបានដឹងថាអាវាសិកភិក្ខុដទៃមកមិនទាន់ដល់១ រឿងភិក្ខុមានសេចក្តីសង្ស័យ១ រឿងភិក្ខុមានសេចក្តីរង្កៀសថា យើងគួរធ្វើឧបោសថ ឬមិនគួរធ្វើ១ រឿងភិក្ខុដឹងថា មានអាវាសិកភិក្ខុដទៃមកមិនទាន់ដល់១ រឿងភិក្ខុឃើញអាការជាដើមរបស់អាវាសិកភិក្ខុ១ រឿងភិក្ខុឮអាការជាដើមរបស់អាវាសិកភិក្ខុ១ រឿងអាគន្តុកភិក្ខុនិងអាវាសិកភិក្ខុ១ រឿងអាវាសិកភិក្ខុថាថ្ងៃចាតុទ្ទសី តែអាគន្តុកភិក្ខុថា ថ្ងៃបណ្ណរសី១ រឿងថ្ងៃមួយរោច ឬមួយកើត របស់អាវាសិកភិក្ខុ តែអាគន្តុកភិក្ខុថាជាថ្ងៃបណ្ណរសី១ រឿងអាវាសិកភិក្ខុ និងអាគន្តុកភិក្ខុទាំងពីរពួកមានភេទ និងសំវាសផ្សេងគ្នា ឬស្មើគ្នា១ រឿងទ្រង់ហាមមិនឲ្យភិក្ខុធ្វើឧបោសថ ដោយការឲ្យបារិសុទ្ធិ ឈ្មោះបារិវាសិកៈ១ រឿងទ្រង់ហាមមិនឲ្យធ្វើឧបោសថខុសថ្ងៃឧបោសថ វៀរលែងតែសង្ឃសាមគ្គីឧបោសថចេញ១ ឧទ្ទានទាំងនេះ ជាហេតុធ្វើរឿងឲ្យជឿជាក់ច្បាស់ឡើង យើងបានចំណែកចែកទុកហើយ។

ចប់ ភាគ ៦១

# មាតិកា


| **មហាវគ្គ បឋមភាគ** | លេខ ទំព័រ |
|---|---|
| **មហាខន្ធកៈ** | **១** |
| ព្រះសម្ពុទ្ធជាម្ចាស់បានត្រាស់ដឹងជាដម្បូង ទ្រង់រំពឹងបដិច្ចសមុប្បាទធម៌ | ១ |
| ពោធិកថា ពុទ្ធឧទានគាថា | ៣ |
| អជបាលនិគ្រោធកថា | ៧ |
| មុចលិន្ទកថា | ៩ |
| រាជាយតនកថា រឿងពាណិជឈ្មោះតបុស្ស និងភល្លិក | ១១ |
| ពុទ្ធបរិវិតក្កកថា | ១៣ |
| ព្រហ្មយាចនកថា | ១៥ |
| ព្រហ្មយាចនកថា ពាក្យឧបមាដោយវត្ថុ មានផ្កាឧប្បល ជាដើម | ១៧ |
| ពុទ្ធបរិវិតក្កកថា | ១៩ |

| | |
|---|---|
| រឿងឧបកាជីវក | ២៣ |
| រឿងបញ្ចវគ្គិយភិក្ខុ | ២៥ |
| ធម្មចក្កប្បវត្តនសូត្រ | ២៩ |
| ធម្មចក្កប្បវត្តនសូត្រ ញាណមានបីប្រការ | ៣១ |
| ពុទ្ធឧទាន ធម្មចក្ខុរបស់ពួកព្រះថេរៈ មានកោណ្ឌញ្ញ ជាដើម | ៣៥ |
| អនត្តលក្ខណសូត្រ អនត្តកថា | ៤១ |
| អនត្តលក្ខណសូត្រ អនិច្ចកថា | ៤៣ |
| អនត្តលក្ខណសូត្រ ការដឹង និងការឃើញដោយគួរដល់ពិត | ៤៥ |
| រឿងយសកុលបុត្រ | ៤៧ |
| រឿងមាតាបិតារបស់យសកុលបុត្រ | ៥១ |
| ធម្មចក្ខុ គឺសោតាបត្តិមគ្គរបស់បិតានៃយសកុលបុត្រ | ៥៣ |
| ការសម្រេចនូវព្រះអរហត្តផលនៃព្រះយស | ៥៥ |
| ធម្មចក្ខុ គឺសោតាបត្តិមគ្គរបស់មាតា និងស្រីបុរាណទុតិយិកានៃព្រះយស | ៦៧ |
| និយាយអំពីផ្នួសរបស់គ្រហស្ថ ៤ នាក់ ជាសំឡាញ់នៃព្រះយស | ៦០ |
| រឿងគ្រហស្ថប្រមាណ ៥០នាក់ ជាសំឡាញ់នៃព្រះយស | ៦៣ |
| និយាយអំពីព្រះអរហន្ត ៦១ ព្រះអង្គ | ៦៥ |
| មារកថា | ៦៧ |
| ការទ្រង់អនុញ្ញាតបព្វជ្ជា និងឧបសម្បទា | ៦៩ |
| ពាក្យពោលអំពីការរួចចាកអន្ទាក់មារទាំងឡាយ | ៧១ |
| រឿងភទ្ទវគ្គិយកុមារ ជាសំឡាញ់នឹងគ្នា | ៧៣ |
| ធម្មចក្ខុ គឺសោតាបត្តិមគ្គនៃភទ្ទវគ្គិយកុមារ ជាសំឡាញ់នឹងគ្នា | ៧៥ |
| រឿងជដិលជាបងប្អូននឹងគ្នា បឋមប្បាដិហារ្យ | ៧៧ |
| រឿងជដិលជាបងប្អូននឹងគ្នា បាដិហារ្យ ជាគំរប់ ៣ | ៨៣ |
| រឿងជដិលជាបងប្អូននឹងគ្នា បាដិហារ្យ ជាគំរប់ ៤ | ៨៤ |
| រឿងជដិលជាបងប្អូននឹងគ្នា បាដិហារ្យ ជាគំរប់៥ | ៨៧ |
| រឿងជដិលជាបងប្អូននឹងគ្នា និយាយអំពីចីវរបង្សុកូលរបស់ព្រះដ៏មានព្រះភាគ | ៨៩ |
| រឿងជដិលជាបងប្អូននឹងគ្នា បាដិហារ្យ មានទ្រង់នាំមកនូវផ្លែព្រីង ជាដើម | ៩១ |
| រឿងជដិលជាបងប្អូននឹងគ្នា បាដិហារ្យ មានទ្រង់បំបែកឧស ជាដើម | ៩៥ |
| រឿងជដិលជាបងប្អូននឹងគ្នា បាដិហារ្យ មានទ្រង់និម្មិតចង្ក្រាន | ៩៧ |
| រឿងជដិលជាបងប្អូននឹងគ្នា បព្វជ្ជា និងឧបសម្បទានៃជដិលទាំងឡាយនោះ | ៩៩ |
| បាដិហារ្យចំនួនបីពាន់ប្រាំរយ | ១០៣ |
| អាទិត្តបរិយាយសូត្រ | ១០៥ |
| ពុទ្ធគុណកថា ការជួបជុំរបស់ព្រះបាទពិម្ពិសារ | ១០៧ |
| ការជួបជុំរបស់ព្រះបាទពិម្ពិសារ ពាក្យពោលអំពីការលះបង់នូវគ្រឿងយញ្ញ | ១០៩ |
| ការជួបជុំរបស់ព្រះបាទពិម្ពិសារ អនុបុព្វីកថា | ១១១ |
| ការជួបជុំរបស់ព្រះបាទពិម្ពិសារ ព្រះដ៏មានព្រះភាគទ្រង់យាងចូលក្រុងរាជគ្រឹះ | ១១៣ |
| គាថាជាចម្រៀងរបស់ព្រះឥន្ទ | ១១៥ |

| | |
|---|---|
| រឿងព្រះឥន្ទ | ១១៧ |
| ព្រះតម្រិះរបស់ព្រះបាទពិម្ពិសារ ការទ្រង់ទទួលនូវអារាម | ១១៩ |
| បព្វជ្ជារបស់បរិព្វាជក ឈ្មោះសារីបុត្ត និងមោគ្គល្លាន រឿងអស្សជិត្ថេរ | ១៣១ |
| បព្វជ្ជារបស់បរិព្វាជក ឈ្មោះសារីបុត្ត និងមោគ្គល្លាន ពាក្យបរិព្វាជកឈ្មោះសារីបុត្ត | ១២៥ |
| បព្វជ្ជារបស់បរិព្វាជកឈ្មោះសារីបុត្ត និងមោគ្គល្លាន ធម្មចក្ខុរបស់មោគ្គល្លាន | ១២៧ |
| បព្វជ្ជារបស់បរិព្វាជក ឈ្មោះសារីបុត្ត និងមោគ្គល្លាន រឿងបរិវាររបស់លោកនោះ | ១២៩ |
| បព្វជ្ជារបស់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន | ១៣១ |
| ពាក្យចោទដោយគាថា | ១៣៣ |
| និទាននៃឧបជ្ឈាយវត្ត | ១៣៥ |
| វត្តដែលកូនសិស្សត្រូវធ្វើដល់ឧបជ្ឈាយ៍ | ១៣៩ |
| ឧបជ្ឈាយវត្ត | ១៤១ |
| សទ្ធិវិហារិកវត្ត | ១៥១ |
| បណាមកថា | ១៦១ |
| ការសូមឲ្យឧបជ្ឈាយ៍អត់ទោស | ១៦៣ |
| សទ្ធិវិហារិកប្រកបដោយអង្គ ៥ យ៉ាង គួរឲ្យឧបជ្ឈាយ៍បណ្តេញចេញ | ១៦៥ |
| រឿងព្រាហ្មណ៍ម្នាក់ | ១៦៧ |
| ឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា | ១៦៩ |
| រឿងភិក្ខុ ១ រូប | ១៧០ |
| រឿងព្រាហ្មណ៍ម្នាក់ | ១៧៣ |
| ការប្រាប់និស្ស័យ ៤ ជាដើម | ១៧៥ |
| ឧបជ្ឈាយសទ្ធិវិហារិកកថា | ១៧៧ |
| អាចរិយន្តេវាសិកកថា | ១៨៣ |
| អាចរិយវត្ត | ១៨៥ |
| អន្តេវាសិកវត្ត | ១៩៧ |
| បណាមកថា | ២០៧ |
| អន្តេវាសិកប្រកបដោយអង្គ ៥ យ៉ាង គួរឲ្យអាចារ្យបណ្តេញចេញ | ២០៩ |
| អាចរិយន្តេវាសិកកថា | ២១១ |
| ការរម្ងាប់និស្ស័យចាកឧបជ្ឈាយ៍ និងអាចារ្យ | ២១៣ |
| ឧបសម្បាទេតព្វបញ្ចក ១៦ ដង | ២១៥ |
| ឧបសម្បាទេតព្វឆក្ក ១៦ ដង | ២២៣ |
| តិត្ថិយបរិវាសិកកថា | ២៣១ |
| ពាក្យពោលអំពីបុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃ មិនញុំាំងសង្ឃឲ្យត្រេកអរ | ២៣៥ |
| ពាក្យពោលអំពីបុគ្គលដែលធ្លាប់ជាតិរ្ថិយដទៃញុំាំងសង្ឃឲ្យត្រេកអរ | ២៣៧ |
| អន្តរាយិកធម្មកថា អាពាធ ៥ យ៉ាង | ២៣៩ |
| អន្តរាយិកធម្មកថា បព្វជ្ជានៃរាជអាមាត្យ | ២៤៥ |
| ចោរប្រាកដដូចទង់ជ័យ ចោរទំលាយគុក | ២៤៧ |
| ចោររាជការកត់ឈ្មោះទុកក្នុងបញ្ជី | ២៤៩ |

| | |
|---|---|
| អភយូវរភាណវារ ពួកមនុស្សដែលគេបៀតបៀនឲ្យមានស្លាកស្នាម ជាដើម | ២៥១ |
| អភយូវរភាណវារ ភណ្ឌកម្ម | ២៥៣ |
| អភយូវរភាណវារ រឿងទារកមានពួក ១៧ | ២៥៥ |
| រឿងត្រកូលធ្វើមរណកាលដោយអហិវាតរោគ | ២៥៩ |
| ភិក្ខុ ១ រូប មិនត្រូវឲ្យសាមណេរ ២ រូប បម្រើ | ២៦១ |
| ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរចៀសចេញទៅកាន់ទក្ខិណាគិរិជនបទ | ២៦៣ |
| អភយូវរភាណវារអង្គ (៥) នៃពួកភិក្ខុដែលគួរនៅបានមិនបាច់មាននិស្ស័យ | ២៦៥ |
| រាហុលសាមណេរបព្វជ្ជា | ២៧១ |
| ព្រះបាទសុទ្ធោទនសក្យរាជ និយាយអំពីបុគ្គលដែលមាតាបិតាមិនអនុញ្ញាត | ២៧៣ |
| សិក្ខាបទ ១០ របស់ពួកសាមណេរ | ២៧៧ |
| រឿងទណ្ឌកម្មពួកសាមណេរ | ២៧៩ |
| នាសនង្គ ១០ របស់ពួកសាមណេរ | ២៨១ |
| មនុស្សខ្ទើយ | ២៨៣ |
| មនុស្សលួចសំវាស មនុស្សចូលពួកតិរ្ថិយ | ២៨៥ |
| រឿងនាគ | ២៨៧ |
| មនុស្សដែលសម្លាប់មាតាមិនត្រូវឲ្យឧបសម្បទា | ២៨៩ |
| មនុស្សដែលសម្លាប់ព្រះអរហន្តសង្ឃមិនត្រូវឲ្យឧបសម្បទា | ២៩១ |
| មនុស្សឧភតោព្យញ្ជនក (មនុស្សមានភេទពីរ) សង្ឃមិនត្រូវឲ្យឧបសម្បទា | ២៩៣ |
| ពួកសាមណេរដែលគ្មានឧបជ្ឈាយ៍ ជាដើម សង្ឃមិនត្រូវឲ្យឧបសម្បទា | ២៩៥ |
| មនុស្សគ្មានបាត្រចីវរ សង្ឃមិនត្រូវឲ្យឧបសម្បទា | ២៩៧ |
| ពួកមនុស្ស មានដាច់ដៃ ជាដើម ភិក្ខុមិនត្រូវឲ្យបព្វជ្ជា | ២៩៩ |
| និស្សយវិធី | ៣០១ |
| កុមារកស្សបមានអាយុ ២០ឆ្នាំ ដោយរាប់យកឆ្នាំនៅក្នុងគភ៌ផង បានឧបសម្បទា | ៣០៥ |
| ការសម្មតិនូវភិក្ខុអ្នកប្រៀនប្រដៅឧបសម្បទាបេក្ខ | ៣០៧ |
| ឧបសម្បទាដោយញត្តិចតុត្ថកម្ម | ៣១១ |
| និស្ស័យ (បច្ច័យជាគ្រឿងអាស្រ័យរបស់បព្វជិត) ៤ យ៉ាង | ៣១៥ |
| អករណីយកិច្ច (កិច្ចដែលបព្វជិតមិនត្រូវធ្វើ) ៤ យ៉ាង | ៣១៧ |
| រឿងភិក្ខុត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ជាដើម | ៣១៩ |
| ឧទ្ទានគាថា | ៣២៥ |
| **ឧបោសថក្ខន្ធក** | **៣៣៧** |
| ការស្តាប់ធម៌ | ៣៣៧ |
| ការសំដែងបាតិមោក្ខ | ៣៣៩ |
| និទានុទ្ទេសវិភង្គ | ៣៤១ |
| ការសំដែងបាតិមោក្ខក្នុងថ្ងៃឧបោសថ | ៣៤៥ |
| រឿងមហាកប្បិន | ៣៤៧ |
| ការសន្មតិសីមា | ៣៤៩ |
| | |

| | |
|---|---|
| នទីបារសីមា ការសន្មតិនូវរោងឧបោសថ | ៣៥១ |
| រោងឧបោសថតូចពេក | ៣៥៣ |
| អាវាសច្រើនមានសីមាស្មើគ្នា គឺមានសីមាតែមួយ | ៣៥៥ |
| រឿងព្រះមហាកស្សបត្ថេរ ការសន្មតិនូវអវិប្បវាសសីមា | ៣៥៧ |
| តិចីវរាវិប្បវាសសីមា | ៣៥៩ |
| ការសូត្រដកតិចីវរាវិប្បវាសសីមា | ៣៦១ |
| ការទំលាយសីមាដោយសីមា និងសីមន្តរិក (ទីឧបចារនៃសីមា) | ៣៦៣ |
| ឧបោសថមានពីរ (ចាតុទ្ទសីឧបោសថ១ បណ្ណរសីឧបោសថ១) | ៣៦៥ |
| ការសំដែងបាតិមោក្ខ មាន ៥ យ៉ាង | ៣៦៧ |
| ការសន្មតិខ្លួន ការសន្មតិភិក្ខុដទៃ | ៣៦៩ |
| ការធ្វើនូវកម្មមិនមែនជាធម៌ ជាដើម | ៣៧៣ |
| បាតិមោក្ខមានព្រះថេរៈជាធំ | ៣៧៥ |
| ភិក្ខុច្រើនរូបល្ងង់មិនឆ្លាស | ៣៧៧ |
| ការទ្រង់អនុញ្ញាតឲ្យភិក្ខុរៀនរាប់បក្ខ | ៣៧៩ |
| ត្រូវភិក្ខុបោសរោងឧបោសថ | ៣៨១ |
| ការឧជប្រទីបក្នុងរោងឧបោសថ | ៣៨៣ |
| ពួកភិក្ខុល្ងង់មិនឆ្លាស មានដំណើរទៅកាន់ទិស | ៣៨៥ |
| ការនាំមកនូវបារិសុទ្ធិនៃភិក្ខុឈឺ | ៣៨៧ |
| ការនាំមកនូវឆន្ទៈនៃភិក្ខុឈឺ | ៣៩១ |
| និយាយអំពីពួកជន មានញាតិ ជាដើម ចាប់ភិក្ខុ | ៣៩៥ |
| ភិក្ខុឆ្កួតមានពីរយ៉ាង ការសន្មតិនូវភិក្ខុឆ្កួត | ៣៩៧ |
| ការសំដែងនូវបាតិមោក្ខ បារិសុទ្ធិឧបោសថ | ៣៩៩ |
| អធិដ្ឋានឧបោសថ ការសំដែងអាបត្តិ | ៤០៣ |
| ភិក្ខុអ្នករលឹកឃើញអាបត្តិ ភិក្ខុអ្នកមានសេចក្ដីសង្ស័យក្នុងអាបត្តិ | ៤០៥ |
| សង្ឃត្រូវសភាគាបត្តិ | ៤០៩ |
| ការធ្វើឧបោសថមិនត្រូវអាបត្តិ មាន ១៥ យ៉ាង | ៤១១ |
| ភិក្ខុមានសេចក្ដីសំគាល់ក្នុងកម្មជាបក្ខពួកថា ព្រមព្រៀងគ្នា មាន១៥ យ៉ាង | ៤១៩ |
| ការធ្វើឧបោសថប្រកបដោយសេចក្ដីសង្ស័យ មាន១៥ យ៉ាង | ៤២១ |
| ការធ្វើឧបោសថដោយមានសេចក្ដីរង្កៀស មាន១៥ យ៉ាង | ៤២៣ |
| ការធ្វើឧបោសថដោយមានបំណងនឹងបំបែកសង្ឃ មាន១៥ យ៉ាង | ៤២៥ |
| ការធ្វើឧបោសថផ្សេងគ្នា (ដោយអំណាច) នៃថ្ងៃឧបោសថ | ៤២៧ |
| ការធ្វើឧបោសថដោយបំណងនឹងបំបែកសង្ឃ | ៤២៩ |
| ភិក្ខុមានសំវាសផ្សេងគ្នា និងភិក្ខុមានសំវាសស្មើគ្នា | ៤៣៣ |
| ក្នុងឧបោសថថ្ងៃនោះ ភិក្ខុមិនត្រូវចេញពីអាវាសដែលមានភិក្ខុ | ៤៣៥ |
| ភិក្ខុមិនត្រូវសំដែងបាតិមោក្ខដល់ភិក្ខុនីបរិសទ្យដែលអង្គុយ (ជាប់ហត្ថបាស) | ៤៣៩ |
| ឧទ្ទានគាថា | ៤៤០ |

1)

ក្នុងគម្ពីរវិសុទ្ធិមគ្គថា សង្ខារ៣ គឺបុញ្ញាភិសង្ខារ១ អបុញ្ញាភិសង្ខារ១ អនេញ្ជាភិសង្ខារ១។ បុញ្ញាភិសង្ខារនោះ បានខាងចេតនា១៣ គឺកាមាវចរកុសលចេតនា៨ និងរូបាវចរកុសលចេតនា៥ ប្រព្រឹត្តទៅដោយអំណាចភាវនា ឯអបុញ្ញាភិសង្ខារ បានខាងអកុសលចេតនា១២។ អនេញ្ជាភិសង្ខារ គឺអរូបាវចរកុសលចេតនា៤ ប្រព្រឹត្តទៅដោយអំណាចភាវនា រួមទាំងអស់ជា២៩។

2)

ដែលហៅថា អវិជ្ជានោះ បានខាងសេចក្តីមិនដឹងក្នុងសច្ចៈទាំង៤ មានទុក្ខសច្ចៈជាដើម។ (នេះជាបរិយាយក្នុងសូត្រ ឯបរិយាក្នុងអភិធម្មថា) បានខាងសេចក្តីមិនដឹងនូវវត្ថុ៨ មាន មិនដឹងក្នុងចំណែកខាងអតីតជាដើម ម្យ៉ាងទៀតថា បានខាងមោហចេតសិក មានលក្ខណៈធ្វើចិត្តឲ្យវង្វេងក្នុងអារម្មណ៍។

3)

អដ្ឋកថា ថា បានដល់ពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌។

4)

ដើមជ្រៃដែលជាទីជ្រកអាស្រ័យនៃពួកជនអ្នកឃ្វាលពពែ។

5)

មនុស្សកំឡោះ។

6)

ដើមកែស

7)

ញាតិសាលោហិតនោះ គឺជនដែលធ្លាប់ជាញាតិរបស់ពាណិជទាំងនោះមកកើតជាទេវតា។

8)

លោកបាលទេវបុត្តទាំង៤ ដែលជាស្តេចធំក្នុងស្ថានសួគ៌ឈ្មោះចាតុម្មហារាជិកៈ

9)

ឧបាសកបានបញ្ចេញវាចាប្តេជ្ញាខ្លួនយកព្រះពុទ្ធ និងព្រះធម៌ទាំងពីរជាទីពឹងទីរឭក ព្រោះក្នុងពេលនោះ មិនទាន់មានព្រះសង្ឃនៅឡើយ។

10)

ភិក្ខុមានគ្នា៥រូប។

11)

កំពុងខំប្រឹងបំពេញព្យាយាមឲ្យបានត្រាស់ជាព្រះពុទ្ធ។

12)

សម្បុរស្បែក ឬសម្បុរថ្ងៃ

13)

អនុត្តរធម៌ គឺព្រះអរហត្តផល

14)

ពាក្យនេះប្រែចេញពីបាលីថា អន្តា។ អន្ត ប្រែថា ទីបំផុត តែក្នុងទីនេះ ប្រែថា អមខាង គឺធម៌ជាផ្លូវប្រតិបត្តិលាមក ថោកទាប នៅអមខាងទាំងពីរនៃមជ្ឈិមាបដិបទា ដែលជាផ្លូវប្រតិបត្តិកណ្តាល។

15)

ទីទៃអំពីធម៌អមខាងទាំងពីរនោះ។

16)

តណ្ហា ប្រែថា ចំណង់ សេចក្តីប្រាថ្នា សេចក្តីអន្ទះអន្ទែង សេចក្តីច្រួលច្រាល់ សម្រេក។

17)

តាមន័យក្នុងអដ្ឋកថា និងដីកាថា តម្រេកប្រកបដោយកាមគុណទាំង៥យ៉ាង ហៅថា កាមតណ្ហា តម្រេកក្នុងរូបភព និងអរូបភព តម្រេកប្រកបដោយសេចក្តីអាល័យក្នុងឈាន និងសស្សតទិដ្ឋិ ហៅថា ភវតណ្ហា តម្រេកប្រកបដោយឧច្ឆេទទិដ្ឋិ គឺយល់ថា សត្វស្លាប់ទៅសូន្យ ហៅថា វិភវតណ្ហា។

18)

សារត្ថទីបនីដីកាថា ធម្មចក្ខុនោះ បានខាងមគ្គ៣ខាងក្រោម គឺសោតាបត្តិមគ្គ១ សកទាគាមិមគ្គ១ អនាគាមិមគ្គ១ តែក្នុងអដ្ឋកថា ធម្មចក្កថា ធម្មចក្ខុក្នុងទីនេះ សំដៅយកសោតាបត្តិមគ្គតែម្យ៉ាង។

19)

ក្នុងដីកាថា រូបំ អនត្តា រូបមិនមែនជារបស់ខ្លួននោះ សេចក្តីថា រូបមិនប្រព្រឹត្តទៅក្នុងអំណាចចិត្ត១ មិនមានម្ចាស់១ សោះសូន្យ១ ជាសត្រូវនឹងចិត្ត១។

20)

គម្ពីរខ្លះឃើញមានពាក្យសួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវសេចក្តីនោះថាដូចម្តេច។ គ្រប់ៗបទ តាំងពីវេទនាជាដើម រហូតដល់វិញ្ញាណជាទីបំផុត គម្ពីរខ្លះឃើញមានតែពាក្យថា ម្នាលភិក្ខុទាំងឡាយ វេទនា...ដូច្នេះក៏មាន។

21)

អមនុស្ស សព្ទនេះ ប្រែថា សត្វដែលមិនមែនជាមនុស្ស គឺទេវតា បិសាច។បេ។ តែក្នុងទីនេះ សំដៅសេចក្តីចំពោះទេវតា។
22)

សំដែងឫទ្ធិ មិនឲ្យឃើញ (បំបាំង
23)

គឺព្រះអង្គធ្វើឲ្យសេដ្ឋីគហបតិបានឃើញយសកុលបុត្រ (គឺបង្ហាញ ឬបញ្ចេញខ្លួនយសកុលបុត្រឲ្យបិតាឃើញ)។
24)

អ្នកទៅជាមួយ អ្នកតាមហែ។
25)

អ្នកឯងចូរទៅជាភិក្ខុ ឬចូរក្លាយទៅជាភិក្ខុ។
26)

ក្នុងពេលមុនថ្ងៃរះ ពីព្រហាម ឬពីព្រលឹម។
27)

ប្រពន្ធពីដើម (កាលព្រះយសនៅជាគ្រហស្ថ)។
28)

គឺត្រកូលមានជីដូនជីតាជាលំដាប់តៗគ្នាមកច្រើនជួរ។
29)

កាមគុណទាំង៥ ដ៏ជាទិព្វរបស់ទេវតា។
30)

កាមគុណទំាង៥ ជារបស់មនុស្ស។
31)

ក្នុងតតិយសារត្ថទីបនីដីកាមហាវគ្គពន្យល់ថា សេនានិគមនោះ ជាប្រទេស ជាទីនៅរបស់សេនាទាហានពីបឋមកល្បមក ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ហៅថា សេនានិគម។ សេនានិគមនេះហើយដែលជាស្រុករបស់បិតានាងសុជាតា ដែលថ្វាយមធុបាយាសដល់ព្រះអង្គជាដម្បូង។
32)

អ្នកសំឡឹងយកនូវបព្វជ្ជា គឺអ្នកដែលប្រាថ្នានឹងបួសជាសាមណេរ។
33)

អ្នកសំឡឹងយកនូវឧបសម្បទា គឺអ្នកដែលប្រាថ្នានឹងបួសជាភិក្ខុ។
34)

ក្នុងអដ្ឋកថា មានសេចក្តីបំពេញទៀតថា អាត្មាពោលនូវពាក្យណា អ្នកចូរពោលតាមនូវពាក្យនោះ។
35)

បង្វេច ឬទ្រព្យ
36)

សម្ពត់ដែលជាប់ដោយអាចមន៍ដី មានសម្ពត់ដែលឥតម្ចាស់ជាដើម។
37)

ក្រៅពីជាតិមនុស្ស ក្នុងទីនេះគឺព្រះឥន្ទ្រ។
38)

គឺ៤រាត្រីខាងចុងខែមាឃ ៤រាត្រីខាងដើមខែផល្គុណ រួមជា៨រាត្រី។
39)

សេចក្តីប្រតិបត្តិ
40)

ផ្លុងសក់
41)

វត្ថុដែលពាល់ត្រូវដោយភ្នែក គឺអារម្មណ៍ដែលឃើញដោយភ្នែក មានរូបជាដើម។
42)

វត្ថុដែលមានរូប មានសំពត់អាវ ជាដើម ដែលមកប៉ះពាល់ត្រូវកាយ ហៅថា ផោដ្ឋព្វៈ។
43)

សេចក្តីផ្សព្វផ្សាយក្នុងចិត្ត គឺអារម្មណ៍ដែលមកប៉ះពាល់ដល់គំនិត។
44)

របៀបបាឡីដែលជាពាក្យរាយសុទ្ធ ឥតមានចងជាបទបាទ គឺមិនចងជាពាក្យកាព្យដែលហៅថាគាថាទេ។

45)

វិមតិវិនោទនីដីកា ថា ឧបធិ មាន៤យ៉ាង គឺ កាមូបធិ១ ខន្ធូបធិ១ កិលេសូបធិ១ អភិសង្ខារូបធិ១។ តែក្នុងទីនេះ សំដៅយកខន្ធូបធិតែម្យ៉ាង។ ឯឧបធិសព្ទនេះ ប្រែថា ខ្លួន រាងកាយគោល ហេតុ នៃសេចក្តីវិលកើត កិលេស និងសេចក្តីកង្វល់។

46)

ចីពរ

47)

សព្ទដែលប្រែថា មាស តាមក្នុងអភិធានមាន១៧យ៉ាង គឺសុវណ្ណ កនក ជាតរូប សោណ្ណ កញ្ចន សត្ថុវណ្ណ ហរិ កម្ពុ បារុ ហេម ហាដក តបនីយ ហិរញ្ញ បាមីករ សាតកុម្ភ ជម្ពុនទ សិង្គី។ តែក្នុងវិមតិវិនោទនីដីកាថា បណ្តាមាសទាំង១៧នេះ មាសឈ្មោះសិង្គីប្រសើរជាងមាសឯទៀត។

48)

វិមតិវិនោទនីដីកាថា លះនីវរណធម៌ប្រាំ១ ឆឡង្គុបេក្ខា១ ដំកល់ស្មារតីដោយខ្ជាប់ខ្ជួន១ អបស្សេនធម៌បួន១ លះមិច្ឆាទិដ្ឋិ១ ការមិនស្វែងរកបីយ៉ាងគឺ កាម ភព និងព្រហ្មចារ្យ១ មានសេចក្តីត្រិះរិះមិនល្អក់វិកវរ១ មានកាយសង្ខាររម្ងាប់ហើយ១ មគ្គញ្ញាណ១ ផលញ្ញាណ១។

49)

ប្រកបដោយកំលាំងកាយ១០ និងកំលាំងញាណ១០ ឯកំលាំងកាយ១០ នោះធៀបដោយកំលាំងដំរី១០ត្រកូល គឺដំរីកាឡាវកៈ១ គង្គេយ្យៈ១ បណ្ឌរៈ១ តម្ពៈ១ បិង្គលៈ១ គន្ធៈ១ មង្គល១ ហេមវត១ ឧបោសថ១ ឆទ្ទន្ត១។ កំលាំងដំរីកាឡវក១០ ស្មើនឹងកំលាំងដំរីគង្គេយ្យ១ បណ្តាដំរីទាំង១០ត្រកូលនោះ មានកំលាំងលើសគ្នា១០ៗឡើងទៅ កំលាំងដំរីឆទ្ទន្ត១០ ទើបស្មើនឹងកំលាំងព្រះពុទ្ធ១។ ឯកំលាំងញាណ១០ នោះគឺ កំលាំងសេចក្តីដឹងហេតុគួរ និងមិនគួរតាមពិត១ ដឹងកម្មនិងផលនៃកម្ម១ ដឹងបដិបទាប្រព្រឹត្តទៅក្នុងភពទាំងពួង១ ដឹងលោកដែលមានធាតុច្រើន១ ដឹងថាសត្វទាំងឡាយមានអធ្យាស្រ័យផ្សេងៗគ្នា១ ដឹងឥន្ទ្រិយរបស់សត្វដ៏ឆ្លៀវឆ្លាសនិងទន់ទាប១ ដឹងសេចក្តីសៅហ្មង និងសេចក្តីផូរផង់ និងការចេញចាកឈានវិមោក្ខសមាធិសមាបត្តិ១ ដឹងខន្ធបញ្ចកៈ ដែលអាស្រ័យនៅក្នុងកាលមុន១ ញាណ គឺចក្ខុដូចជាទិព្វ១ ដឹងសេចក្តីអស់ទៅនៃអាសវធម៌១។

50)

គឺអដ្ឋង្គិកមគ្គ និងសម្មាញាណ និងសម្មាវិមុត្តិ។

51)

ក្នុងអដ្ឋកថា ថា មហាក្សត្រិយ៍ ស្តេចទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតបរិបូណ៌ ត្រាតែព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាននោះហាមឃាត់ដោយដៃ ឬដោយមុខ ឬដោយវចីភេទថា ល្មមហើយៗ។

52)

អដ្ឋកថា ធម៌ទាំងឡាយណា ជាផល គឺទុក្ខសច្ច តែងកើតឡើងអំពីហេតុ គឺសមុទយសច្ច ព្រះតថាគតតែងពោលនូវសមុទយសច្ចថា ជាហេតុផ្តើមឡើងឲ្យកើតនូវធម៌ទាំងឡាយ គឺទុក្ខសច្ចនោះ ធម៌ណាជាផល គឺកន្លែងរលត់នៃទុក្ខសច្ច និងសមុទយសច្ចទាំងនោះក្តី ធម៌ណាជាហេតុ ជាឧបាយដើម្បីញុំាងទុក្ខសច្ច និងសមុទយសច្ច មិនឲ្យប្រព្រឹត្តទៅបានក្តី ព្រះតថាគតមានប្រក្រតីពោលនូវធម៌ទាំងនោះ។ អធិប្បាយថា ព្រះតថាគតតែងសំដែងនូវអរិយសច្ចទាំង៤យ៉ាងថា ទុក្ខសច្ចជាផលនៃសេចក្តីទុក្ខទាំងពួង សមុទយសច្ច ជាហេតុនាំឲ្យកើតទុក្ខទាំងពួង និរោធសច្ចជាផលនៃសេចក្តីសុខទាំងពួង មគ្គសច្ច ជាហេតុនាំឲ្យកើតសេចក្តីសុខទាំងពួង។

53)

ត្រង់ពាក្យថា សង្ឃាដិទាំងឡាយដែលត្រួតគ្នានោះ តាមន័យក្នុងអដ្ឋកថា និងវិមតិវិនោទនីដីកាថា ឲ្យសទ្ធិវិហារិកយកចីវរទាំងពីរ គឺចីពរ១ សង្ឃាដិ១ មកដាក់ត្រួតគ្នា ហើយសឹមប្រគេន។

54)

ក្នុងអដ្ឋកថា ថា កាលបើឧបជ្ឈាយ៍បានបាយ ឬបបរ បាត្រនោះក្តៅ ឬធ្ងន់ សទ្ធិវិហារិក ត្រូវប្រគេនបាត្ររបស់ខ្លួនទៅលោក ហើយទទួលយកបាត្ររបស់លោកមកវិញ។

55)

ក្នុងអដ្ឋកថា ថា ដែលទ្រង់ហាមមិនឲ្យចាប់ដោយស្មើគ្នាហើយបត់នោះ ព្រោះផ្នត់ដែលបត់នៅចំកន្លែងដដែលរាល់ៗថ្ងៃ នឹងធ្វើឲ្យបាក់ផ្នត់ខូចចីវរហេតុនេះ ទើបទ្រង់ឲ្យបំផ្លើសដោយចីវរឲ្យហួសពីគ្នាប្រមាណ៤ធ្នាប់រាល់ៗថ្ងៃ គឺថ្ងៃនេះ បត់ត្រង់កន្លែងនេះ ដល់ថ្ងៃស្អែក បត់បំផ្លើសឲ្យហួសពីកន្លែងនោះតទៅទៀត កុំឲ្យបត់ចំត្រង់ផ្នត់ដដែល។

56)

អដ្ឋកថា ថា ភិក្ខុមិនត្រូវទុកលើទីដែលមានអាចម៍ដី និងក្រួសដែលគេមិនក្រាលដោយកន្ទេល និងស្បែកជាដើម។

57)

អដ្ឋកថា ថា យកទឹកទៅលាយនឹងគ្រឿងលំអិត ហើយសឹមសូន្យឲ្យជាដុំៗ។

58)

រោងឆាន់

59)

អដ្ឋកថា ថា សទ្ធិវិហារិកត្រូវនាំឧបជ្ឈាយ៍ទៅទីដទៃក្តី ឲ្យភិក្ខុដទៃនាំទៅក្តី ដើម្បីបន្ទោរបង់សេចក្តីអផ្សុកនៃឧបជ្ឈាយ៍។

60)

អន្តរាបត្តិ សំដៅយកគរុកាបត្តិ ដែលភិក្ខុត្រូវក្នុងវេលាកំពុងប្រព្រឹត្តវត្តបរិវាស។

61)

មូលាបត្តិ សំដៅយកគរុកាបត្តិ ដែលភិក្ខុត្រូវមកពីខាងដើម សេចក្ដីថា ភិក្ខុកំពុងប្រព្រឹត្តបរិវាសមកច្រើនថ្ងៃហើយ ៗត្រូវគរុកាបត្តិណាមួយទៀត ដោយបិទបាំងទុកនោះ សង្ឃត្រូវលុបថ្ងៃដែលបានប្រព្រឹត្តវត្តមកហើយនោះចេញ តាំងឲ្យប្រព្រឹត្តវត្តរាប់ថ្ងៃជាថ្មីទៅទៀត។

62)

កម្មទាំង៥យ៉ាងនេះនឹងមានសំដែងដោយពិស្តារក្នុងកម្មក្ខន្ធកៈ តទៅខាងមុខ។

63)

បានដល់តាំងសម្រាប់រងជើងដែលលាងរួចហើយ គឺតាំងថ្នាក់ខាងលើ ឯក្បឿងសម្រាប់ជូតជើងនោះ បានដល់វត្ថុសម្រាប់ជូតជើង ដែលគេមិនត្រូវការលាង គឺរបស់អ្វីដែលគេសម្រាប់ជូត។

64)

កតញ្ញូជាអ្នកដឹងគុណដែលអ្នកដទៃបានធ្វើដល់ខ្លួន កតវេទី ជាអ្នកប្រកាសនូវឧបការគុណដែលអ្នកដទៃធ្វើហើយប្រាកដ គឺតបគុណគេ។

65)

សាមណេរដែលត្រូវបួសជាភិក្ខុភាវៈ។

66)

ឲ្យដល់នូវគុណពួដ៏ខាងលើ គឺបានសម្រេចជាភិក្ខុភាវៈ។

67)

ក្នុងដីកាថា សូមឲ្យសង្ឃរើខ្ញុំចេញចាកភេទសាមណេរ ហើយឲ្យឧបសម្បទាជាភិក្ខុភាវៈ។

68)

សង្ឃភត្ត គឺភត្តដែលទាយកវេរប្រគេនដល់សង្ឃទាំងអស់។

69)

ឧទ្ទេសភត្ត គឺភត្តដែលទាយកវេរប្រគេនដល់ភិក្ខុដែលខ្លួនឧទ្ទិសអំពីសង្ឃ។

70)

និមន្តនភត្ត គឺភត្តដែលទាយកនិមន្តភិក្ខុ ហើយប្រគេន។

71)

សលាកភត្ត គឺភត្តដែលទាយកប្រគេនដល់ភិក្ខុ ដោយចាប់ស្លាក។

72)

បក្ខិកភត្ត គឺភត្តដែលទាយកប្រគេនភិក្ខុក្នុងមួយបក្ខៗ តែមួយថ្ងៃៗ (គឺកន្លះខែម្ដង)។

73)

ឧបោសថិកភត្ត គឺភត្តដែលទាយកប្រគេនភិក្ខុក្នុងថ្ងៃឧបោសថ។

74)

បាដិបទិកភត្ត គឺភត្តដែលទាយកប្រគេនភិក្ខុក្នុងថ្ងៃ១រោច ឬ១កើត។

75)

ប្រាសចាកសមណសារូប គឺមិនត្រូវតាមសណ្ដាប់ធ្នាប់របស់សមណឡើយ។

76)

១.២.៣.៤.៥បាឡីទាំង៥បទ មានសាហុជាដើម បានប្រែក្នុងឧបជ្ឈាយ៍វត្តរួចហើយ។

77) , 108) , 110) , 132)

២

78)

៣

79)

៤

80)

៥

81)

ពាក្យថា វត្ថុដែលគេទុកបាត្រក្នុងទីនេះ សំដៅយកវត្ថុដែលគេប្រគេនដាក់ក្នុងបាត្រ (តាមពាក្យខ្មែរបូរាណ)។

82)

ភិក្ខុពួកខ្លះ គឺភិក្ខុដែលជាសត្រូវនឹងអាចារ្យរបស់ខ្លួន។

83)

នឹងមានសំដែងទៅខាងមុខ

84)

អដ្ឋកថា ថា មនុស្សណាដែលធ្វើចោរកម្ម ឬកម្មផ្សេងពីនោះ ដែលជាកម្មមានកំហុសយ៉ាងធ្ងន់នឹងរាជការ ហើយលួចរត់ទៅ រាជការបានចាត់សំបុត្រឲ្យរកចាប់ខ្លួនថា បើនរណាឃើញមនុស្សឈ្មោះនោះក្នុងទីណា ត្រូវចាប់សម្លាប់ចោលក្នុងទីនោះក្ដី ត្រូវកាត់អវយវៈទាំងឡាយ មានដៃនិងជើងជាដើមក្ដី ត្រូវឲ្យដាក់អាជ្ញាមានប្រមាណប៉ុណ្ណេះៗក្ដី មនុស្សនោះមិនត្រូវឲ្យបព្វជ្ជា។

85)

អដ្ឋកថា ថា មនុស្សដែលចំពាក់បំណុលគេ ហើយគេវាយនឹងរំពាត់ឲ្យមានដំបៅជាដើម ឈ្មោះថា ជាមនុស្សគេបានធ្វើទណ្ឌកម្មហើយ។ បើដំបៅនោះនៅស្រស់ៗ ដរាបណា មិនគប្បីឲ្យបព្វជ្ជាដរាបនោះ។ តែបើមើលដំបៅឲ្យសះជាដូចប្រក្រតីហើយ ក៏គួរឲ្យបព្វជ្ជាបាន។

86)

អដ្ឋកថា ថា មនុស្សដែលគេធ្វើឲ្យមានស្លាកស្នាមដោយដែកក្ដៅត្រង់ថ្ងាសក្ដី ត្រង់អវយវៈ មានទ្រូងជាដើមក្ដី។ បើមនុស្សនោះជាអ្នកជាទេ តែមុខដំបៅនៅស្រស់ៗ មិនគួរឲ្យបព្វជ្ជាឡើយ។ បើដំបៅនោះដុះសាច់ពេញ មានស្បែកជិតឡើងវិញហើយ តែស្នាមនៅប្រាកដ បើស្លៀកដណ្ដប់ចីវរជាបរិមណ្ឌលបី អាចបិទស្នាមនោះបាន ក៏គួរឲ្យបព្វជ្ជា។

87)

អដ្ឋកថា ថា ទារកនោះជាកូនជាងមាស កោរក្បាលខាងៗជុំវិញ តែទុកជុក ៥អន្លើនៅលើក្បាល។

88)

អដ្ឋកថា ថា វិធីប្រាប់ភណ្ឌកម្មនោះ ត្រូវប្រជុំភិក្ខុដែលមានក្នុងសីមា នាំបព្វជ្ជាបេក្ខៈទៅក្នុងទីនោះ ហើយប្រាប់ថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាសូមប្រាប់ភណ្ឌកម្មរបស់ទារកនេះចំពោះសង្ឃ បីដង ពីរដង ឬម្ដងក៏បាន។ បើទីជាសភាគមានភិក្ខុ១០-២០-៣០រូប ឱកាសជាទីឈរ ឬអង្គុយរបស់ភិក្ខុទាំងនោះត្រឹមណា ត្រូវប្រាប់ត្រឹមណោះ។ បើវត្តនោះធំ មានភិក្ខុច្រើនជាងពាន់ លំបាកនឹងប្រជុំភិក្ខុឲ្យសព្វគ្រប់ ត្រូវនាំទៅកាន់ខណ្ឌ-នទី-ឬសមុទ្ទសីមា ហើយឲ្យបព្វជ្ជាចុះ។ បព្វជ្ជាបេក្ខៈដែលកោរសក់ស្រេចហើយ មិនបានប្រាប់ភណ្ឌកម្មនឹងឲ្យបព្វជ្ជាតែម្ដងក៏គួរ។ បព្វជ្ជាបេក្ខៈដែលសក់វែងជាងពីរអង្គុលី ត្រូវតែប្រាប់សិនទើបឲ្យបព្វជ្ជាបាន។

89)

ក្នុងមហាវិភង្គ ត្រង់ឱនវិសតិវស្សសិក្ខាបទទី៥ នៃសប្បាណកវគ្គទី៧ ក្នុងបាចិត្តិយកណ្ឌថា ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ។

90)

រោគកើតអំពីខ្យល់ មានពិសដូចជាពិសពស់។

91)

អដ្ឋកថា ថា ទារកណា ដែលអង្គុយកាន់ជុំជីដោយដៃឆ្វេង ហើយអាចចោលក្អែកដែលមកដើម្បីស៊ីបាយដែលដាក់ខាងមុខ ឲ្យហើរទៅបាន ទារកនេះគួរឲ្យបព្វជ្ជាបាន។

92)

អដ្ឋកថា ថា ភិក្ខុដែលមិនឆ្លាសនេះ ទោះបីមានវស្សាដល់៦០ ឬ៧០ រាប់អំពីឧបសម្បទាមកក៏ដោយ បើរកភិក្ខុចាស់ជាងខ្លួនធ្វើជាអាចារ្យមិនបាន ត្រូវតែទៅអង្គុយច្រហោង ផ្គងអញ្ជលីក្នុងសំណាក់ភិក្ខុអ្នកឆ្លាស ដែលខ្ចីវស្សាជាងខ្លួន ហើយនិយាយសូមនិស្ស័យថា បពិត្រលោកដ៏មានអាយុ សូមលោកជាអាចារ្យរបស់ខ្ញុំករុណា ៗសូមនៅអាស្រ័យនឹងលោកដ៏មានអាយុផងដូច្នេះ អស់វារៈបីដង។ បើនឹងចូលទៅភូមិ ត្រូវទៅអង្គុយច្រហោង ផ្គងអញ្ជលី ហើយនិយាយលាអាចារ្យថា បពិត្រលោកអាចារ្យ ខ្ញុំករុណាសូមលាទៅភូមិដូច្នេះទើបបាន។

93)

ឱវាទបាតិមោក្ខ និងអាណាបាតិមោក្ខ។ អាណាបាតិមោក្ខចែកជាពីរ គឺភិក្ខុបាតិមោក្ខ១ ភិក្ខុនីបាតិមោក្ខ១ ក្នុងទីនេះ ទ្រង់សំដៅយកភិក្ខុបាតិមោក្ខនិងភិក្ខុនីបាតិមោក្ខ។

94)

ក្នុងអដ្ឋកថា ថា ព្រះមហាមោគ្គល្លានត្ថេរកោរសក់ និងឲ្យសំពត់កាសាយៈដល់រាហុលកុមារ ព្រះសារីបុត្តជាបព្វជ្ជាចារ្យ។ ព្រះមហាកស្សបត្ថេរជាឱវាទាចារ្យ។

95)

ទ្រង់ហៅព្រះពុទ្ធបិតាតាមនាមគោត្រ គឺនាមត្រកូលរបស់ព្រះអង្គដែលហៅថា គោតមគោត្រ។

96)

អដ្ឋកថា សំដៅយកឧបទ្រព គឺបៀតបៀនឲ្យមានភ័យអន្តរាយ ឲ្យចង្អៀតចង្អល់ចិត្ត។

97)

អដ្ឋកថា ថា ភិក្ខុបំបែកសាមណេរ ឬឧបសម្បន្ន ដែលជាបរិសទ្យរបស់ភិក្ខុដទៃ ដោយហោចទៅ ទោះបីបរិសទ្យរបស់ភិក្ខុទ្រុស្តសីលក៏មិនគួរ។ តែបើនិយាយប្រាប់ទោសថា អ្នកឯងនៅអាស្រ័យនឹងភិក្ខុទ្រុស្តសីល ដូចជាបុគ្គលងូតទឹក ហើយមកប្រឡាក់លាមកវិញ (ក៏សាមណេរ ឬឧបសម្បន្ននោះមកឯងៗ) ដូច្នេះ គួរ។

98)

គឺនាគដែលនិម្មិតខ្លួនជាមាណពហើយ អាចត្រឡប់ក្លាយខ្លួនមកជានាគវិញដោយហេតុពីរយ៉ាងនោះ។

99)

មនុស្សដែលគេបោះត្រាដោយដែកក្ដៅ។

100)

មនុស្សដែលចំពាក់បំណុលគេជាដើម ហើយម្ចាស់ទ្រព្យវាយទាល់តែបែកខ្នង។

101)
មនុស្សទោសដែលរាជការចេញប្រកាសឲ្យរកចាប់ធ្វើទោស
102)
មានរោគអាក្រក់មើលមិនជា មានរោគឫសដូងដុះ និងឫសដូងបាទជាដើម។
103)
មានរូបអាក្រក់ពេក ខ្ពស់ពេក ទាបពេកជាដើម។
104)
ក្នុងគម្ពីរមហាបច្ចរិដា ខ្វាក់ម្ខាង
105)
សម្រាប់ហៅសាមណេរដែលចូលទៅសូមឧបសម្បទាជាភិក្ខុ។
106)
សូត្រប្រកាសសេចក្ដីបញ្ជាក់ឲ្យសង្ឃដឹងថា កុលបុត្រដែលសូមឧបសម្បទានោះជាអ្នកបរិសុទ្ធចាកអន្តរាយិកធម៌ជាដើម។
107)
១.២. (អដ្ឋកថា) គ្រូសូត្រ១រូប នឹងសូត្រកម្មវាចាឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខបុគ្គលពីររូបក្ដី បីរូបក្ដី ដំណាលគ្នាតែម្ដងបាន ឥតមានទាស់ទេ ម្យ៉ាងទៀត បើគ្រូសូត្រពីររូបក្ដី បីរូបក្ដី នឹងសូត្រកម្មវាចាឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខបុគ្គលពីររូបក្ដី បីរូបក្ដី ចំពោះកូនសិស្សមួយៗ ជាមួយគ្នាតែម្ដងក៏បាន។
109)
១.២.សម្រាប់ឲ្យបញ្ចូលឈ្មោះមែនទែនត្រង់នោះ បើឈ្មោះនាគក្ដី តិស្សក្ដី ពុទ្ធរក្ខិតក្ដី ក៏ឲ្យច្រកត្រង់កន្លែងនោះ។
111)
ពាក្យនេះ ប្រហែលជាទើបនឹងច្រកថែមមកទេដឹង
112)
ក្នុងខណៈដែលសូត្រញត្តិចតុត្ថកម្មវាចា ឧបសម្បទាហើយ ត្រូវឲ្យមនុស្សទៅឈរនៅទីវាល ហើយវាស់ស្រមោលមនុស្សដែលឈរនោះដោយបាតជើងឲ្យដឹងថា ស្រមោលនោះចោលទៅប៉ុន្មានជាន់ប៉ុន្មានទប់ ឯទប់នោះ គឺស្រមោលដែលនៅសល់មិនពេញមួយជាន់ ហើយគេជាន់ទទឹងផ្ទប់មក វិធីនេះ គេធ្លាប់ធ្វើមកពីដើមតាមបែបក្នុងគម្ពីរ ឥឡូវនេះមាននាឡិកាហើយ តែបួសហើយវេលាណា គេក៏កត់ម៉ោងមីនុតក្នុងពេលនោះឲ្យដឹងថា បួសហើយម៉ោងប៉ុន្មានៗ មីនុត ព្រោះការវាស់ស្រមោល ក៏គឺឲ្យដឹងពេលវេលាដូចគ្នានឹងនាឡិកាដែរ ការកំណត់ពេលតាមនាឡិកានាំឲ្យស្រួលដល់កិច្ចការសព្វវេលា គឺពេលយប់ ឬពេលថ្ងៃស្រទំរកមើលស្រមោលមិនឃើញ។
113)
ឲ្យដឹងថាបួសក្នុងរដូវណា។
114)
ឲ្យដឹងថាពេលព្រឹក ឬរសៀល។
115)
ត្រូវអាចារ្យប្រាប់ការរួបរួមដល់ភិក្ខុដែលទើបនឹងបួសហើយ ឲ្យចាំទុកថា ខ្លួនបួសពីថ្ងៃណា ខែណារដូវណា ពេលម៉ោងប៉ុន្មាន។
116)
សម្ពត់ដែលគេចោលលើគំនរដី ឬសំរាមហើយរើសយកមកធ្វើជាចីវរ។
117)
គឺសង្ឃត្រូវសូត្ររម្ងាប់កម្មនោះ លើកលែងធ្វើទោសតទៅ (មានសេចក្ដីពិស្ដារក្នុងកម្មក្ខន្ធកៈ)។
118)
ត្រូវអាបត្តិហើយ សម្ងំ មិនចូលបរិវាស ឬមិនសំដែង។
119)
បាលីថា អាមណ្ឌោ ធ្លាប់ប្រែថា ល្ហុង តែត្រង់ពាក្យថា អាមណ្ឌោនេះ ឃើញក្នុងច្បាប់ឱរុបថា អាមលកោ ដែលប្រែថាកន្ទួតព្រៃ ហេតុនេះ គួរប្រែថាកន្ទួតព្រៃវិញ ព្រោះរឿងខាងដើមថា ព្រះសម្ពុទ្ធទ្រង់នាំយកផ្លែកន្ទួតព្រៃ។
120)
គឺក្នុងកន្លះខែម្ដងៗ ហៅថាបក្ខមួយៗ។
121)
កិច្ចដែលសង្ឃត្រូវចាត់ចែងឲ្យស្រេចមុនធ្វើឧបោសថ។
122)
អដ្ឋកថា ថា ភ្នំមាន៣យ៉ាង គឺភ្នំថ្មសុទ្ធ១ ភ្នំដីសុទ្ធ១ ភ្នំថ្មលាយដី១ កំណត់ប៉ុនដំរីឡើងទៅ។ និមិត្រថ្មនោះ កំណត់ប៉ុនគោធំ ក្របីធំជាយ៉ាងធំ យ៉ាងតូចកំណត់ប៉ុនដុំស្ករអំពៅ មានទម្ងន់៣២បល (ប្រហែលទម្ងន់គ្រាប់ស្រូវ៥១២០០គ្រាប់)។ និមិត្រព្រៃនោះ គឺរឿរព្រៃឈើមានខ្លឹមខាងក្រៅមានដូង ត្នោត ស្លាជាដើមចេញ ក្រៅអំពីនោះ គួរទាំងអស់។ និមិត្រដើមឈើនោះ បានដល់ដើមឈើមានខ្លឹម មានដើមរាំងភ្នំជាដើម។ និមិត្រផ្លូវនោះ សំដៅយកផ្លូវដើរជើង ផ្លូវរទេះ។ និមិត្រដម្បូកនោះ កំណត់កំពស់៨ធ្នាប់ មានទំហំប៉ុនស្នែងគោឡើងទៅ។ និមិត្រស្ទឹងនោះ គឺសំដៅយកស្ទឹង

ដែលមានខ្សែទឹកមិនដាច់គ្រប់៤ខែ ក្នុងរដូវភ្លៀង កាលភិក្ខុនីស្លៀកដណ្ដប់បិទបាំងបរិមណ្ឌល៣ ចុះឆ្លងទៅ ល្មមទទឹកស្បង់ នេះជាកំណត់យ៉ាងរាក់បំផុត។ និមិត្រទឹកនោះ សំដៅយកទឹកមិនហូរ ដូចជាទឹកដក់នៅក្នុងកន្លែងជ្រុកឈ្មុះក្ដី បឹងសម្រាប់ក្មេងអ្នកស្រុកលេងក្ដី រណ្ដៅដែលគេជីកហើយចាក់ទឹកឲ្យពេញក្ដី រហូតដល់អណ្ដូង ស្រះបោក្ខរណីជាដើម។

123)

សន្មតសីមាត្រើយស្ទឹង គឺសីមាដែលសង្ឃចងគ្របស្ទឹង ទុកឲ្យនៅក្នុងសីមា

124)

រោងឧបោសថដែលសន្មតហើយមុននោះ នៅតូច ហើយត្រូវការតរបៀងថែមឲ្យធំទៀតបាន។

125)

ភិក្ខុនៅក្នុងខេត្តសីមាបែបនេះ ទុកជានៅប្រាសចាកត្រៃចីវរ ក៏មិនត្រូវអាបត្តិ ព្រោះប្រាសចាកត្រៃចីវរ។

126)

សីមាដែលមានសំវាសស្មើគ្នា គឺសីមាដែលសង្ឃត្រូវតែធ្វើសង្ឃកម្ម ដោយព្រមព្រៀងគ្នា បែកគ្នាមិនបាន។

127)

សីមាដែលភិក្ខុនៅប្រាសចាកត្រៃចីវរបាន។

128)

(អដ្ឋកថា) ១អព្ភន្តរៈមានប្រមាណ២៨ហត្ថ។

129)

ស្រះដែលកើតឯង មិនមានអ្នកណាជីក ជាទីខូងស្រាប់ ទឹកហូរមកពេញឯង។

130)

ត្រង់បាឡីថា នទី ប្រែថា ស្ទឹងក៏បាន ទន្លេក៏បាន។

131)

១.២ អដ្ឋកថា ថា ភិក្ខុទំលាយពទ្ធសីមាភិក្ខុដទៃដោយសីមារបស់ខ្លួន គឺប្រៀបដូចជាកន្លែង១មានដើមឈើ២ដើម មានមែកគងពាក់លើគ្នា ដើមស្វាយនៅទិសខាងកើត ដើមព្រីងនៅទិសខាងលិច។ ភិក្ខុ១ពួក ចងសីមា យកដើមព្រីងជានិមិត្តសីមារបស់ខ្លួន នៅទិសខាងលិច។ ភិក្ខុ១ពួកទៀត ចងសីមាយកដើមស្វាយជានិមិត្តរបស់ខ្លួននៅទិសខាងកើត។ ការចងសីមាយ៉ាងនេះ ហៅថា ទំលាយ ឬរំលាយពទ្ធសីមាភិក្ខុដទៃដោយសីមារបស់ខ្លួន។

133)

អដ្ឋកថា ថា ភិក្ខុគ្របសង្កត់ពទ្ធសីមាភិក្ខុដទៃ ដោយសីមារបស់ខ្លួន គឺចងសីមារបស់ខ្លួនយកពទ្ធសីមារបស់ភិក្ខុដទៃទាំងអស់ក្ដី តែមួយកន្លែងក្ដីមកទុកខាងក្នុងសីមារបស់ខ្លួន។

134)

អដ្ឋកថា ថា ទីឧបចារៈរបស់សីមា គឺត្រូវសង្ឃទុកទីទំនេរពីសីមាទៅចំនួន១ហត្ថក្ដី ១ចំអាមក្ដី ៤ធ្នាប់ក្ដី។

135)

អដ្ឋកថា ថា កាលបើសំដែងនិទានចប់ហើយ មិនបានសូត្រសិក្ខាបទដោយពិស្ដារ គឺគ្រាន់តែសូត្រថា សុតា ខោ បនាយស្មន្តោហិ ចត្តារោ បារាជិកា ធម្មា។បេ។ អវិវទមានេហិ សិក្ខិតព្វន្តិ ដូច្នេះជាដើម ប្រែថា បារាជិកធម៌ទាំង៤ លោកដ៏មានអាយុទាំងឡាយបានស្ដាប់ហើយ។បេ។ កុំវិវាទគ្នា គប្បីសិក្សាចុះ។

136)

អដ្ឋកថា ថា ភ័យកើតពីមនុស្សនៅក្នុងព្រៃ។

137)

កន្លះខែមួយៗ ហៅថាបក្ខមួយៗ។

138)

រឿងដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ ប្រាកដក្នុងច្បាប់ឱរុបទាំងឡាយតពីបាលីនេះយ៉ាងនេះថា ក៏សម័យនោះឯង ពួកភិក្ខុអ្នកនៅចាំអាវាស ក្នុងអាវាសកន្លែងមួយ មិនចូលទៅដំកល់ទឹកឆាន់ មិនចូលទៅដំកល់ទឹកប្រើប្រាស់។ ភិក្ខុជាអាគន្តុកៈទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយអ្នកនៅចាំអាវាស មិនសមបើនឹងមិនដំកល់ទឹកឆាន់ មិនដំកល់ទឹកប្រើប្រាស់សោះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដំកល់ទឹកឆាន់ ទឹកប្រើប្រាស់។ ទើបភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា ត្រូវអ្នកណាដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈបង្គាប់ភិក្ខុថ្មី។ ពួកភិក្ខុថ្មី ដែលព្រះថេរៈបង្គាប់ហើយ ក៏នៅតែមិនដំកល់ទុក។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈឺ (បើ) ព្រះថេរៈបង្គាប់ហើយ មិនត្រូវមិនដំកល់ទុក (ត្រូវតែចូលទៅដំកល់ទុក) ភិក្ខុណាមិនដំកល់ទុក ត្រូវអាបត្តិទុក្កដ។

139)

សេចក្ដីសន្មតិថាជាមនុស្សឆ្លួត។

140)

ភិក្ខុដែលនៅជាប់ជានិច្ចក្នុងអាវាសមួយ គឺមិនមែនជាអាគន្តុកភិក្ខុ។

141)

អដ្ឋកថា ថា ពួកភិក្ខុនៅក្នុងអាវាសថា ថ្ងៃចាតុទ្ទសីឧបោសថ ចំណែកខាងពួកភិក្ខុដែលមកពីដែនខាងក្រៅថា ថ្ងៃបណ្ណរសីឧបោសថ បើពួកភិក្ខុនៅក្នុងអាវាស(ច្រើនជាង) បានធ្វើបុព្វកិច្ចថា អជ្ជុបោសថោចាតុទ្ទសោដូច្នេះហើយ ត្រូវតែពួកអាគន្តុកភិក្ខុប្រព្រឹត្តតាម កុំរឹងទទឹងឡើយ។

142)

អាគន្តុកភិក្ខុទាំងនោះ មិនអាចធ្វើភិក្ខុដែលមានសំវាសផ្សេងគ្នា ឲ្យមកជាអ្នកមានសំវាសរួមគ្នាវិញបាន គឺថា ឲ្យគេលះបង់ទិដ្ឋិរបស់គេមិនបាន។

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០០៧ - Book 007

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថាលោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០៧ - Tipitaka Book 007 [http://forum.sangham.net/index.php/topic,8942.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០០៧




គំរូ ឯកសារ ផ្សេងទៀត ៖
book_007.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី៧

ទ.

# វិន័យបិដក

CS vin | ភាគ ទី៧

**ភាគ ទី ៧**

# មហាវគ្គ

CS vin.mv | ភាគ ទី៧

**ទុតិយភាគ**
ភាគ ទី ២

វស្សូបនាយិកក្ខន្ធកៈ - បវារណក្ខន្ធកៈ - ចម្មក្ខន្ធកៈ - ភេសជ្ជក្ខន្ធកៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

## វស្សូបនាយិកក្ខន្ធកៈ

CS vin.mv.03 | ភាគ ទី៧

**(៣. វស្សូបនាយិកក្ខន្ធកោ)**

### ១០៧. វស្សូបនាយិកានុជាននា

CS vin.mv.03.01 | ភាគ ទី៧

(១០៧)

[១] សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ គ្រានោះឯង ការនៅចាំវស្សា ព្រះមានព្រះភាគមិនទាន់បានបញ្ញត្តដល់ភិក្ខុទាំងឡាយនៅឡើយ។ ភិក្ខុទាំងនោះក៏ចេញដើរទៅកាន់ចារិក អស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្តិយ៍ មិនសមបើនឹងដើរទៅកាន់ចារិកអស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀននូវវត្ថុដែលមានជីវិត មានឥន្ទ្រិយតែ១ ញុំាងសត្វតូចៗជាច្រើនឲ្យដល់នូវសេចក្ដីវិនាសសោះ សូម្បីពួកបរិព្វាជក មានលទ្ធិដទៃទាំងនេះ ដែលជាអ្នកពោលធម៌អាក្រក់ ម្ដេចគង់នឹងសម្ងំឈប់សម្រាកនៅចាំវស្សា សូម្បីទាំងពួកសត្វស្លាបនេះទៀតសោត ក៏គង់ធ្វើសំបុកលើចុងឈើទាំងឡាយ ហើយនឹងសម្ងំឈប់សម្រាកនៅចាំវស្សាដែរ ចំឡែកតែពួកសមណៈ ជាសក្យបុត្តិយ៍នេះ នៅតែដើរទៅកាន់ចារិក អស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀននូវវត្ថុដែលមានជីវិត មានឥន្ទ្រិយតែ១ ញុំាងសត្វតូចៗជាច្រើនឲ្យដល់នូវសេចក្ដីវិនាស។ កាលមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ គ្រានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថា ក្នុងវេលានោះឯង រួចហើយទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សា។[1]

[២] គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះយ៉ាងនេះថា យើងគួរចូលវស្សាក្នុងកាលណាហ្ន៎។ ភិក្ខុទាំងនោះក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងវស្សានរដូវ។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះយ៉ាងនេះថា ថ្ងៃចូលវស្សា តើមានប៉ុន្មានហ្ន៎។ ភិក្ខុទាំងនោះ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សានេះមានពីរ គឺថ្ងៃបុរិមិកា[2] វស្សា១ ថ្ងៃបច្ឆិមិកា[3] វស្សា១ ភិក្ខុគួរចូលបុរិមិកាវស្សា ក្នុងថ្ងៃបន្ទាប់នៃថ្ងៃពេញបូណ៌មីខែអាសាឍ (គឺថ្ងៃ១រោចខែអាសាឍ) ភិក្ខុគួរចូលបច្ឆិមិកាវស្សាក្នុងថ្ងៃដែលកន្លងហួស១ខែអំពីថ្ងៃពេញបូណ៌មីខែអាសាឍ (គឺថ្ងៃ១រោច ខែស្រាពណ៍) ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សាមានតែពីរយ៉ាងនេះឯង។

## ១០៨. វស្សានេ ចារិកាបដិក្ខេបាទិ

CS vin.mv.03.02 | ភាគ ទី៧

(១០៨)

[៣] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបានចូលវស្សាហើយ ក៏ចេញដើរទៅកាន់ចារិកក្នុងកណ្ដាលវស្សា។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ដូចក្នុងគ្រាមុននោះទៀតថា ពួកសមណៈ ជាសក្យបុត្តិយ៍ មិនសមបើនឹងដើរទៅកាន់ចារិកអស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនវត្ថុដែលមានជីវិត មានឥន្ទ្រិយតែមួយ ញុំាងពួកសត្វតូចៗជាច្រើនឲ្យដល់នូវសេចក្ដីវិនាសសោះ យ៉ាងដូចជាពួកតិរ្ថិយដទៃនេះ ដែលពោលធម៌អាក្រក់ ម្ដេចគង់នឹងសម្ងំឈប់សម្រាកនៅចាំវស្សា អស់ទាំងពួកសត្វស្លាបនេះទៀតសោត ក៏ធ្វើសំបុកទាំងឡាយទុកនៅលើចុងឈើទាំងឡាយ ហើយនឹងសម្ងំនៅចាំវស្សាដូចគ្នាដែរ ចំឡែកតែពួកសមណៈ ជាសក្យបុត្តិយ៍នេះ ម្ដេចឡើយក៏នៅតែដើរទៅកាន់ចារិក អស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនវត្ថុដែលមានជីវិត មានឥន្ទ្រិយតែមួយ ញុំាងពួកសត្វតូចៗជាច្រើនឲ្យដល់នូវសេចក្ដីវិនាស។ កាលមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុចូលវស្សាហើយ មិនសមបើនឹងចេញដើរទៅកាន់ចារិកក្នុងកណ្ដាលវស្សាសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថារួចហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកបញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលវស្សាហើយ មិននៅចាំបុរិមិកាវស្សាអស់ខែ៣ ឬបច្ឆិមិកាវស្សាអស់ខែ៣ទេ មិនត្រូវចៀសចេញទៅកាន់ចារិកឡើយ ភិក្ខុណាចៀសចេញទៅ ត្រូវអាបត្តិទុក្កដ។

[៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រាថ្នានឹងចូលវស្សា។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំមិនចូលវស្សាឡើយ (គឺត្រូវតែចូលវស្សា) ភិក្ខុណាមិនចូលវស្សា ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមិនប្រាថ្នានឹងចូលវស្សាក្នុងថ្ងៃចូលវស្សានោះ ក៏ក្លែងដើរចេញពីទីអាវាស។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនប្រាថ្នានឹងចូលវស្សា ក៏ក្លែងដើរចេញពីអាវាសទៅក្នុងថ្ងៃចូលវស្សានោះមិនបានទេ ភិក្ខុណាចេញដើរទៅ ត្រូវអាបត្តិទុក្កដ។

[៥] សម័យនោះឯង ព្រះបាទមាគធសេនិយពិម្ពិសារទ្រង់មានសេចក្ដីប្រាថ្នាដើម្បីនឹងលើកខែ[4] ក៏បញ្ជូនរាជបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយគួរតែចូលវស្សាក្នុងខែខាងមុខ (ខែអាសាឍក្រោយ)។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រព្រឹត្តទៅតាមស្ដេចទាំងឡាយចុះ។

## ១០៩. សត្តាហករណីយានុជាននា

CS vin.mv.03.03 | ភាគ ទី៧

(១០៩)

[៦] គ្រានោះឯង ព្រះមានព្រះភាគគង់ក្នុងក្រុងរាជគ្រឹះគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់យាងសំដៅទៅឯក្រុងសាវត្ថី ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ស្រុក ទើបបានដល់ទៅក្រុងសាវត្ថី។ បានឮថា ព្រះមានព្រះភាគគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះឯង។ សម័យនោះឯង ក្នុងកោសលជនបទ មានឧបាសកឈ្មោះឧទេន បានឲ្យគេធ្វើវិហារចំពោះសង្ឃ។ ឧបាសកនោះក៏បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ដ្បិតខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង ស្តាប់ធម៌ផង នឹងបានឃើញភិក្ខុទាំងឡាយផង។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះវិញថា នែអាវុសោ ព្រះមានព្រះភាគបានបញ្ញត្តហើយថា ភិក្ខុទាំងឡាយចូលវស្សាហើយមិនបាននៅចាំបុរិមិកាវស្សាអស់៣ខែ ឬបច្ឆិមិកាវស្សាអស់៣ខែទេ មិនត្រូវចេញដើរទៅកាន់ចារិកឡើយ សូមឲ្យឧទេនឧបាសកបង្អង់ចាំសិន ទំរាំតែភិក្ខុទាំងឡាយនៅចាំវស្សារួច លុះចាំវស្សារួចហើយ មុខជានឹងទៅ បើឧបាសកនោះ មានការត្រូវធ្វើជាប្រញាប់ សូមឲ្យធ្វើវិហារទុកក្នុងសំណាក់ភិក្ខុទាំងឡាយ ដែលនៅក្នុងអាវាសក្នុងទីនោះសិនចុះ។ ឯឧទេនឧបាសក ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ កាលបើអញបានបញ្ជូនពាក្យបណ្តាំទៅហើយ មិនសមបើនឹងមិននិមន្តមកសោះ ដ្បិតអញជាទាយក ជាកប្បិយការកៈ ជាឧបដ្ឋាករបស់សង្ឃ។ កាលឧទេនឧបាសកកំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ វេលានោះ ភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ក្នុងវេលានោះឯង រួចហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ កាលបើជនទាំង៧ពួក គឺភិក្ខុ១ ភិក្ខុនី១ សិក្ខមានា១ សាមណេរ១ សាមណេរី១ ឧបាសក១ ឧបាសិកា១ បានបញ្ជូនបម្រើមកហើយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅដោយសត្តាហករណីយ (កិច្ចដែលគួរធ្វើបាន៧ថ្ងៃ) កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ម្នាលភិក្ខុទាំងឡាយ កាលបើជនទាំង៧ពួកនេះ បានបញ្ជូនបម្រើមកហើយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់ក្នុងរវាង៧ថ្ងៃ។[5] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើវិហារចំពោះសង្ឃហើយ។ បើឧបាសកនោះបញ្ជូនបម្រើមកក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបានបញ្ជូនបម្រើមកហើយ ភិក្ខុត្រូវទៅដោយសត្តាហករណីយបាន កាលបើឥតមានគេបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើរោងអឌ្ឍយោគចំពោះសង្ឃ។បេ។ ឲ្យគេធ្វើប្រាសាទវែង។ ឲ្យគេធ្វើប្រាសាទដម្បូលត្រងិល។ ឲ្យគេធ្វើគុហា។ ឲ្យគេធ្វើបរិវេណ។ ឲ្យគេធ្វើបន្ទប់។ ឲ្យគេធ្វើសាលាសម្រាប់ឆាន់។ ឲ្យគេធ្វើរោងភ្លើង។ ឲ្យគេធ្វើកប្បិយកុដិ។ ឲ្យគេធ្វើវច្ចកុដិ (បង្គន់)។ ឲ្យគេធ្វើទីចង្រ្កម។ ឲ្យគេធ្វើរោងចង្រ្កម។ ឲ្យគេធ្វើអណ្តូងទឹក។ ឲ្យគេធ្វើសាលានៅនាអណ្តូងទឹក។ ឲ្យគេធ្វើផ្ទះជាទីរក្សាកាយ។ ឲ្យគេធ្វើសាលាសម្រាប់ប្រើប្រាស់នៅនាផ្ទះជាទីរក្សាកាយ។ ឲ្យគេធ្វើស្រះ។ ឲ្យគេធ្វើមណ្ឌប។ ឲ្យគេធ្វើអារាម។ ឲ្យគេធ្វើទីអារាម។ បើឧបាសកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុត្រូវទៅដោយសត្តាហករណីយបាន កាលបើឥតមានគេបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកចំពោះភិក្ខុច្រើនរូប។បេ។ បានឲ្យគេធ្វើវិហារចំពោះភិក្ខុ១រូប។ ឲ្យគេធ្វើអឌ្ឍយោគ។ ឲ្យគេធ្វើប្រាសាទវែង។ ឲ្យគេធ្វើប្រាសាទដម្បូលត្រងិល។ ឲ្យគេធ្វើគុហា។ ឲ្យគេធ្វើបរិវេណ។ ឲ្យគេធ្វើបន្ទប់ទឹក។ ឲ្យគេធ្វើរោងសម្រាប់ឆាន់។ ឲ្យគេធ្វើរោងភ្លើង។ ឲ្យគេធ្វើកប្បិយកុដិ។ ឲ្យគេធ្វើវច្ចកុដិ។ ឲ្យគេធ្វើទីចង្រ្កម។ ឲ្យគេធ្វើរោងសម្រាប់ចង្រ្កម។ ឲ្យគេធ្វើអណ្តូងទឹក។ ឲ្យគេធ្វើសាលាសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក។ ឲ្យគេធ្វើផ្ទះជាទីរក្សាកាយ។ ឲ្យគេធ្វើសាលាក្បែរផ្ទះជាទីរក្សាកាយ។ ឲ្យគេធ្វើស្រះ។ ឲ្យគេធ្វើមណ្ឌប។ ឲ្យគេធ្វើអារាម។ ឲ្យគេធ្វើទីដីអារាម។ បើឧបាសកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងឲ្យទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមក ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុគប្បីធ្វើការត្រឡប់វិលមកវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើវិហារចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនីមួយរូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខមានា១រូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរ១រូប ចំពោះសាមណេរីច្រើនរូប ចំពោះសាមណេរី១រូប។ បានឲ្យគេធ្វើអឌ្ឍយោគ។ ឲ្យគេធ្វើប្រាសាទវែង។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល។ ឲ្យគេធ្វើគុហា។ ឲ្យគេធ្វើបរិវេណ។ ឲ្យគេធ្វើបន្ទប់ទឹក។ ឲ្យគេធ្វើរោងសម្រាប់ឆាន់។ ឲ្យគេធ្វើរោងភ្លើង។ ឲ្យគេធ្វើកប្បិយកុដិ។ ឲ្យគេធ្វើវច្ចកុដិ។ ឲ្យគេធ្វើទីចង្រ្កម។ ឲ្យគេធ្វើរោងចង្រ្កម។ ឲ្យគេធ្វើអណ្តូងទឹក។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក។ ឲ្យគេធ្វើស្រះ។ ឲ្យគេធ្វើមណ្ឌប។ ឲ្យគេធ្វើអារាម។ ឲ្យគេធ្វើទីដីអារាម។ បើឧបាសកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមដ៏ចំរើនទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុគប្បីធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសកបានឲ្យគេធ្វើទីនៅចំពោះខ្លួនឯងវិញ។ ឲ្យគេធ្វើផ្ទះសម្រាប់ដេក។ ឲ្យគេធ្វើឃ្លាំង។ ឲ្យគេធ្វើប៉ម (បញ្ចា)។ ឲ្យគេធ្វើប្រាសាទបួនជ្រុង។ ឲ្យគេធ្វើរានផ្សារ។ ឲ្យគេធ្វើរោងរានផ្សារ។ ឲ្យគេធ្វើប្រាសាទវែង។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល។ ឲ្យគេធ្វើគុហា។ ឲ្យគេធ្វើបរិវេណ។ ឲ្យគេធ្វើបន្ទប់ទឹក។ ឲ្យគេធ្វើរោងសម្រាប់បរិភោគ។ ឲ្យគេធ្វើរោងភ្លើង។ ឲ្យគេធ្វើផ្ទះសម្រាប់ចំអិនអាហារ។ ឲ្យគេធ្វើវច្ចកុដិ។ ឲ្យគេធ្វើទីចង្រ្កម។ ឲ្យគេធ្វើរោងចង្រ្កម។ ឲ្យគេធ្វើអណ្តូងទឹក។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក។ ឲ្យគេធ្វើផ្ទះជាទីរក្សាកាយ។ ឲ្យគេធ្វើសាលាក្បែរផ្ទះជាទីរក្សាកាយ។ ឲ្យគេធ្វើស្រះ។ ឲ្យគេធ្វើមណ្ឌប។ ឲ្យគេធ្វើអារាម។ ឲ្យគេធ្វើទីដីអារាម។ មានការដណ្តឹង(កូនស្រី) ដើម្បីកូនប្រុសក្តី មានការដណ្តឹង(កូនប្រុស) ដើម្បីកូនស្រីក្តី គេមានជម្ងឺក្តី គេប្រាប់ព្រះសូត្រដែលគេដឹងប្រាកដក្តី។ បើឧបាសកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកដ៏ចំរើនទាំងឡាយនិមន្តមករៀនយកព្រះសូត្រនេះ កុំឲ្យព្រះសូត្រនេះសាបសូន្យទៅឡើយ។ ម្យ៉ាងទៀត ឧបាសកនោះ មានកិច្ចឯណានីមួយក្តី មានកិច្ចត្រូវធ្វើ (ខានមិនបាន)ក្តី។ បើឧបាសកនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកដ៏ចំរើនទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមក ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសិកាបានឲ្យគេធ្វើវិហារចំពោះសង្ឃ។ បើឧបាសិកានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសិកាបានឲ្យគេធ្វើអឌ្ឍយោគចំពោះ

សង្ឃ។ ឲ្យគេធ្វើប្រាសាទវែង។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល។ ឲ្យគេធ្វើគុហា។ ឲ្យគេធ្វើបរិវេណ។ ឲ្យគេធ្វើបន្ទប់ទឹក។ ឲ្យគេធ្វើរោងសម្រាប់ឆាន់។ ឲ្យគេធ្វើរោងភ្លើង។ ឲ្យគេធ្វើកប្បិយកុដិ។ ឲ្យគេធ្វើវច្ចកុដិ។ ឲ្យគេធ្វើទីចង្ក្រម។ ឲ្យគេធ្វើរោងចង្ក្រម។ ឲ្យគេធ្វើអណ្តូងទឹក។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក។ ឲ្យគេធ្វើផ្ទះជាទីរក្សាកាយ។ ឲ្យគេធ្វើសាលាក្បែរផ្ទះជាទីរក្សាកាយ។ ឲ្យគេធ្វើស្រះ។ ឲ្យគេធ្វើមណ្ឌប។ ឲ្យគេធ្វើអារាម។ ឲ្យគេធ្វើទីដីអារាម។ បើឧបាសិកានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមក ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានឧបាសិកាគេបានធ្វើវិហារចំពោះភិក្ខុច្រើនរូប។បេ។ ចំពោះភិក្ខុ១រូប ចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនី១រូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខមានា១រូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរ១រូប ចំពោះសាមណេរីច្រើនរូប ចំពោះសាមណេរី១រូប។បេ។ បានឲ្យគេធ្វើលំនៅចំពោះខ្លួនឯង។ ឲ្យគេធ្វើផ្ទះសម្រាប់ដេក។ ឲ្យគេធ្វើឃ្លាំង។ ឲ្យគេធ្វើប៉ម (បញ្ហា)។ ឲ្យគេធ្វើប្រាសាទបួនជ្រុង។ ឲ្យគេធ្វើរានផ្សារ។ ឲ្យគេធ្វើរោងរានផ្សារ។ ឲ្យគេធ្វើប្រាសាទវែង។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល។ ឲ្យគេធ្វើគុហា។ ឲ្យគេធ្វើបរិវេណ។ ឲ្យគេធ្វើបន្ទប់ទឹក។ ឲ្យគេធ្វើរោងសម្រាប់បរិភោគអាហារ។ ឲ្យគេធ្វើរោងភ្លើង។ ឲ្យគេធ្វើផ្ទះសម្រាប់ចំអិនអាហារ។ ឲ្យគេធ្វើវច្ចកុដិ។ ឲ្យគេធ្វើទីចង្ក្រម។ ឲ្យគេធ្វើរោងចង្ក្រម។ ឲ្យគេធ្វើអណ្តូងទឹក។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក។ ឲ្យគេធ្វើស្រះ។ ឲ្យគេធ្វើមណ្ឌប។ ឲ្យគេធ្វើអារាម។ ឲ្យគេធ្វើទីដីអារាម។ មានការដណ្តឹង (កូនស្រី) ដើម្បីកូនប្រុសក្តី មានការដណ្តឹង(កូនប្រុស) ដើម្បីកូនស្រីក្តី គេមានជម្ងឺក្តី គេប្រាប់ព្រះសូត្រដែលគេដឹងប្រាកដក្តី។ បើឧបាសិកានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមករៀនយកនូវព្រះសូត្រនេះ កុំឲ្យព្រះសូត្រនេះសាបសូន្យទៅឡើយ។ ម្យ៉ាងទៀត ឧបាសិកានោះ មានកិច្ចឯណានីមួយក្តី មានកិច្ចត្រូវធ្វើ (ខានមិនបាន) ក្តី។ បើឧបាសិកានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុឲ្យគេធ្វើវិហារចំពោះសង្ឃ ភិក្ខុនីឲ្យគេធ្វើវិហារចំពោះសង្ឃ សិក្ខមានាឲ្យគេធ្វើវិហារចំពោះសង្ឃ សាមណេរឲ្យគេធ្វើវិហារចំពោះសង្ឃ សាមណេរីឲ្យគេធ្វើវិហារចំពោះសង្ឃ ចំពោះភិក្ខុច្រើនរូប ចំពោះភិក្ខុ១រូប ចំពោះភិក្ខុនីសង្ឃ ចំពោះភិក្ខុនីច្រើនរូប ចំពោះភិក្ខុនី១រូប ចំពោះសិក្ខមានាច្រើនរូប ចំពោះសិក្ខមានា១រូប ចំពោះសាមណេរច្រើនរូប ចំពោះសាមណេរ១រូប ចំពោះសាមណេរីច្រើនរូប ចំពោះសាមណេរី១រូប។បេ។ បានឲ្យគេធ្វើវិហារចំពោះខ្លួនឯង។ ឲ្យគេធ្វើអឌ្ឍយោគ។ ឲ្យគេធ្វើប្រាសាទវែង។ ឲ្យគេធ្វើប្រាសាទដំបូលត្រងិល។ ឲ្យគេធ្វើគុហា។ ឲ្យគេធ្វើបរិវេណ។ ឲ្យគេធ្វើបន្ទប់ទឹក។ ឲ្យគេធ្វើរោងសម្រាប់បរិភោគអាហារ។ ឲ្យគេធ្វើរោងភ្លើង។ ឲ្យគេធ្វើកប្បិយកុដិ។ ឲ្យគេធ្វើវច្ចកុដិ។ ឲ្យគេធ្វើទីចង្ក្រម។ ឲ្យគេធ្វើរោងចង្ក្រម។ ឲ្យគេធ្វើអណ្តូងទឹក។ ឲ្យគេធ្វើរោងសម្រាប់ប្រើប្រាស់នៅនាអណ្តូងទឹក។ ឲ្យគេធ្វើស្រះ។ ឲ្យគេធ្វើមណ្ឌប។ ឲ្យគេធ្វើអារាម។ ឲ្យគេធ្វើទីដីអារាម។ បើសាមណេរីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នានឹងថ្វាយទានផង នឹងស្តាប់ធម៌ផង នឹងឃើញភិក្ខុទាំងឡាយផង។ ម្នាលភិក្ខុទាំងឡាយ កាលបើមានគេបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើគេមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។

## ១១០. បញ្ចន្នំ អប្បហិតេបិ អនុជាននា

CS vin.mv.03.04 | ភាគ ទី៧

**(១១០)**

[៧] សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺ។ ភិក្ខុនោះ បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានជម្ងឺ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នានឹងឲ្យភិក្ខុទាំងឡាយនិមន្តមក។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ កាលបើសហធម្មិកបុគ្គលទាំង៥ពួក គឺភិក្ខុ១ ភិក្ខុនី១ សិក្ខមានា១ សាមណេរ១ សាមណេរី១ មិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបានបញ្ជូនបម្រើមកហើយនោះ ម្នាលភិក្ខុទាំងឡាយ ពួកសហធម្មិកបុគ្គលទាំង៥ពួកនេះ ទុកជាមិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបានបញ្ជូនបម្រើមកនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុឈឺ។ បើភិក្ខុនោះ បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានជម្ងឺ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នានឹងឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុឈឺនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកភត្តសម្រាប់ភិក្ខុឈឺក្តី នឹងស្វែងរកភត្តសម្រាប់ភិក្ខុបម្រើជម្ងឺក្តី នឹងស្វែងរកថ្នាំសម្រាប់ភិក្ខុឈឺក្តី នឹងសាកសួរជម្ងឺក្តី នឹងបម្រើជម្ងឺក្តី។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីអផ្សុក (ចង់សឹក) កើតឡើងដល់ភិក្ខុ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សេចក្តីអផ្សុកកើតឡើងដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញដោយគិតថា អាត្មាអញនឹងបំបាត់សេចក្តីអផ្សុកដោយខ្លួនឯង ឬនឹងឲ្យអ្នកដទៃបំបាត់ ឬនឹងធ្វើនូវធម្មកថាចំពោះភិក្ខុនោះ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីរង្កៀសកើតឡើងដល់ភិក្ខុហើយ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សេចក្តីរង្កៀសកើតឡើងដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងបន្ទោបង់នូវសេចក្តីរង្កៀសដោយខ្លួនឯង ឬឲ្យអ្នកដទៃបន្ទោបង់ ឬនឹងធ្វើនូវធម្មកថាដល់ភិក្ខុនោះ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ទិដ្ឋិខុសកើតឡើងដល់ភិក្ខុហើយ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ទិដ្ឋិខុសកើតឡើងដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំចង់ឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយ

គិតថា អាត្មាអញនឹងដោះ ឬនឹងឲ្យអ្នកដទៃដោះនូវទិដ្ឋិខុស់ ឬនឹងធ្វើនូវធម្មកថាដល់ភិក្ខុនោះ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុ
ត្រូវគរុធម៌ហើយ គួរដល់បរិវាស។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំត្រូវគរុធម៌ហើយ គួរដល់បរិវាស សូមភិក្ខុ
ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយ
សត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយ
គិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈ (គឺជាអ្នកបំពេញគណៈសង្ឃ) ក្នុងការឲ្យបរិវាស។ ម្នាលភិក្ខុ
ទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុគួរនឹងទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា
ដ្បិតខ្ញុំគួរនឹងទាញអន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជា
ភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុ
ត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬជាគណបូរកៈក្នុងការទាញនូវ
អន្តរាបត្តិមកដាក់ក្នុងមូលាបត្តិ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុគួរដល់មានត្ត។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុ
ទាំងឡាយថា ដ្បិតខ្ញុំគួរដល់មានត្តហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំចង់ឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិន
បានបញ្ជូនបម្រើមកទេ ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើ
ការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈក្នុងការឲ្យមានត្ត។
ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុគួរដល់អព្ភានកម្ម។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ខ្ញុំគួរដល់អព្ភាន
ហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បី
ទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ
ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈក្នុងអព្ភានកម្ម។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ
សង្ឃមានសេចក្តីប្រាថ្នាដើម្បីធ្វើនូវកម្មគឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ចំពោះភិក្ខុហើយ។
បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ឥឡូវសង្ឃមានសេចក្តីប្រាថ្នាដើម្បីធ្វើនូវកម្មដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក
ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹង
និយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា សង្ឃមិនគួរធ្វើនូវកម្ម ឬគួរ
បង្អោនទៅរកដើម្បីកម្មស្រាល ដោយឧបាយដូចម្តេចហ្ន៎។ មួយវិញទៀត កម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយ
កម្មក្តី ឧក្ខេបនីយកម្មក្តី សង្ឃបានធ្វើដល់ភិក្ខុនោះហើយ។ បើភិក្ខុនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ឥឡូវសង្ឃបានធ្វើនូវកម្ម
ដល់ខ្ញុំហើយ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនោះមិនបានបញ្ជូនបម្រើមក ក៏
ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង
៧ថ្ងៃ ដោយគិតថា ភិក្ខុនោះគួរប្រព្រឹត្តវត្តដោយប្រពៃ គួរសម្របរោម គួរប្រព្រឹត្តវត្តសមគួរដល់កិរិយារលាស់ខ្លួនចេញចាកទោស សង្ឃគប្បីរម្ងាប់
នូវកម្មនោះចេញ ដោយឧបាយដូចម្តេចហ្ន៎។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុនីឈឺ។ បើភិក្ខុនីនោះ បញ្ជូនបម្រើទៅក្នុងសំណាក់
ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានជម្ងឺ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជា
ភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ច ដែលភិក្ខុនីបានបញ្ជូនបម្រើមកហើយ
នោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្តក្តី ស្វែងរកគិលានុបដ្ឋាកភត្តក្តី ស្វែងរកគិលាន
ភេសជ្ជៈក្តី នឹងសួរជម្ងឺក្តី នឹងបម្រើជម្ងឺក្តី។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីអផ្សុក កើតឡើងដល់ភិក្ខុនីហើយ។ បើភិក្ខុនីនោះបញ្ជូន
បម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សេចក្តីអផ្សុកកើតឡើងដល់ខ្ញុំហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់
ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅ
ថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងបំបាត់សេចក្តីអផ្សុក
របស់ភិក្ខុនី ឬនឹងឲ្យអ្នកដទៃបំបាត់ ឬនឹងធ្វើនូវធម្មកថាដល់ភិក្ខុនីនោះ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីរង្កៀសកើតឡើងដល់
ភិក្ខុនីហើយ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សេចក្តីរង្កៀសកើតឡើងដល់ខ្ញុំហើយ សូមលោកម្ចាស់ទាំងឡាយ
និមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយ
សត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា
អាត្មាអញនឹងបន្ទោបង់ ឬនឹងឲ្យអ្នកដទៃបន្ទោបង់នូវសេចក្តីរង្កៀស ឬនឹងធ្វើនូវធម្មកថាដល់ភិក្ខុនីនោះ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ
ទិដ្ឋិខុសកើតឡើងដល់ភិក្ខុនីហើយ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ទិដ្ឋិខុសកើតឡើងដល់ខ្ញុំហើយ សូមលោកម្ចាស់
ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ
ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយ
គិតថា អាត្មាអញនឹងដោះ ឬនឹងឲ្យអ្នកដទៃជួយដោះនូវទិដ្ឋិខុស ឬនឹងធ្វើនូវធម្មកថាដល់ភិក្ខុនីនោះ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ
ភិក្ខុនីត្រូវគរុធម៌ គួរដល់មានត្តហើយ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំត្រូវគរុធម៌ គួរដល់មានត្តហើយ សូម
លោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏
ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុង
រវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយក្នុងកាឲ្យនូវមានត្ត។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុនីគួរនឹងទាញ
អន្តរាបត្តិមកចូលក្នុងមូលាបត្តិ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាគួរនឹងទាញអន្តរាបត្តិមកចូលក្នុងមូលា
បត្តិ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូន
បម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិល
វិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយក្នុងការទាញអន្តរាបត្តិមកចូលក្នុងមូលាបត្តិ។ ម្នាលភិក្ខុទាំងឡាយ ក្នុង
សាសនានេះ មានភិក្ខុនីគួរដល់អព្ភានកម្មហើយ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាគួរដល់អព្ភានកម្ម
ហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបាន

បញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយក្នុងអព្ភានកម្ម។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សង្ឃចង់ធ្វើកម្មគឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ភិក្ខុនី។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ឥឡូវសង្ឃចង់ធ្វើកម្មដល់ខ្ញុំករុណាហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា សង្ឃមិនគួរធ្វើកម្ម ឬគួរតែបង្អោនទៅដើម្បីកម្មស្រាល ដោយឧបាយដូចម្តេចហ្ន៎។ មួយទៀត សង្ឃបានធ្វើកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ភិក្ខុនីនោះហើយ។ បើភិក្ខុនីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា សង្ឃបានធ្វើកម្មដល់ខ្ញុំករុណាហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុនីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលភិក្ខុនីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា ភិក្ខុនីនោះគួរប្រព្រឹត្តដោយប្រពៃ គួរសម្រួបរោម គួរប្រព្រឹត្តវត្ត សមគួរដល់កិរិយារលាស់ខ្លួនចេញចាកទោស សង្ឃគប្បីរម្ងាប់កម្មនោះ ដោយឧបាយដូចម្តេចហ្ន៎។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សិក្ខមានាមានជម្ងឺ។ បើសិក្ខមានានោះ បញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានជម្ងឺ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាសិក្ខមានានោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសិក្ខមានាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត ឬនឹងស្វែងរកគិលានុបដ្ឋាកភត្ត ឬនឹងស្វែងរកគិលានភេសជ្ជៈ ឬនឹងសួរជម្ងឺ ឬនឹងបម្រើជម្ងឺ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីអផ្សុកកើតឡើងដល់សិក្ខមានាហើយ។បេ។ សេចក្តីរង្កៀសកើតឡើងហើយ។ ទិដ្ឋិខុសកើតឡើងហើយ។ សិក្ខាកម្រើក (គឺដាច់សិក្ខាសម្មតិ)ហើយ។ បើសិក្ខមានានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ឥឡូវសិក្ខារបស់ខ្ញុំករុណាកម្រើកហើយ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាសិក្ខមានានោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសិក្ខមានាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយក្នុងការសមាទានសិក្ខា។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសិក្ខមានាប្រាថ្នានឹងឧបសម្បទា។ បើសិក្ខមានានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំប្រាថ្នានឹងឧបសម្បទា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាសិក្ខមានានោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសិក្ខមានាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈ ក្នុងឧបសម្បទាកម្ម ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសាមណេរឈឺ។ បើសាមណេរនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាឈឺ សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងជួយស្វែងរកគិលានភត្តក្តី ស្វែងរកគិលានុបដ្ឋាកភត្តក្តី ស្វែងរកគិលានភេសជ្ជៈក្តី សាកសួរជម្ងឺក្តី បម្រើជម្ងឺក្តី។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីអផ្សុកកើតឡើងដល់សាមណេរ។បេ។ សេចក្តីរង្កៀសកើតឡើងដល់សាមណេរ។ ទិដ្ឋិខុសកើតឡើងដល់សាមណេរ។ សាមណេរមានការប្រាថ្នាដើម្បីសួរនូវវស្សា។ បើសាមណេរនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាមានការប្រាថ្នាដើម្បីសួរនូវវស្សា សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងសាកសួរវស្សា ឬនឹងប្រាប់វស្សា។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសាមណេរចង់ឧបសម្បទា។ បើសាមណេរនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាចង់ឧបសម្បទា សូមភិក្ខុទាំងឡាយនិមន្តមក ខ្ញុំករុណាប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើសេចក្តីខ្វល់ខ្វាយ ឬនឹងសូត្រ (កម្មវាចា) ឬនឹងជាគណបូរកៈ ក្នុងឧបសម្បទាកម្ម។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានសាមណេរីឈឺ។ បើសាមណេរីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានជម្ងឺ សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត ឬស្វែងរកគិលានុបដ្ឋាកភត្ត ឬស្វែងរកគិលានភេសជ្ជៈ ឬសួរជម្ងឺ ឬបម្រើជម្ងឺ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ សេចក្តីអផ្សុកកើតឡើងដល់សាមណេរី។ សេចក្តីរង្កៀសកើតឡើងដល់សាមណេរី។ ទិដ្ឋិខុសកើតឡើងដល់សាមណេរី។ សាមណេរីមានសេចក្តីប្រាថ្នាដើម្បីនឹងសួរនូវវស្សា។ មានសេចក្តីប្រាថ្នាដើម្បីសមាទាននូវសិក្ខា។ បើសាមណេរីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំមានសេចក្តីប្រាថ្នាដើម្បីសមាទាននូវសិក្ខា សូមលោកម្ចាស់ទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាសាមណេរីនោះមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលសាមណេរីបានបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងធ្វើនូវសេចក្តីខ្វល់ខ្វាយក្នុងការសមាទាននូវសិក្ខា។

## ១១១. សត្តន្នំ អប្បហិតេបិ អនុជានានា

CS vin.mv.03.05 | ភាគ ទី៧

(១១១)

[៨] សម័យនោះឯង មាតារបស់ភិក្ខុ១រូបមានជម្ងឺ។ មាតានោះក៏បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាកូនថា ដ្បិតខ្ញុំមានជម្ងឺ ខ្ញុំចង់ឲ្យលោកកូននិមន្តមក។ ក្នុងវេលានោះ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយថា កាលបើជនទាំង៧ពួកបានបញ្ជូនបម្រើមកហើយ ភិក្ខុគួរទៅដោយសត្តាហករណីយបាន កាលបើជនទាំង៧ពួកមិនបញ្ជូនបម្រើមកទេ ភិក្ខុមិនគួរទៅទេ ចំណែកឯពួកសហធម្មិកបុគ្គលទាំង៥វិញ មិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគួរទៅដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកហើយនោះ ក៏ឥឡូវ មានតារបស់អញនេះមានជម្ងឺ តែមាតានោះមិនមែនជាឧបាសិកា តើអាត្មាអញត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង៧ គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី មាតា បិតា មិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបានបញ្ជូនបម្រើមកហើយនោះ ម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង៧នេះ មិនបានបញ្ជូនបម្រើមក ក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលគេបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មាតារបស់ភិក្ខុមានជម្ងឺ។ បើមាតានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាកូនថា ដ្បិតខ្ញុំមានជម្ងឺ សូមលោកកូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកកូននិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាមាតាមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលមាតាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត នឹងស្វែងរកគិលានុបដ្ឋាកភត្ត នឹងស្វែងរកគិលានភេសជ្ជៈ ឬនឹងសួរជម្ងឺ ឬនឹងបម្រើជម្ងឺ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បិតារបស់ភិក្ខុមានជម្ងឺ។ បើបិតានោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាកូនថា ដ្បិតខ្ញុំមានជម្ងឺ សូមឲ្យលោកកូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកកូននិមន្តមក។ ម្នាលភិក្ខុទាំងឡាយ ទុកជាបិតាមិនបានបញ្ជូនបម្រើមក ក៏ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន នឹងនិយាយទៅថ្វីដល់កិច្ចដែលបិតាបញ្ជូនបម្រើមកហើយនោះ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ ដោយគិតថា អាត្មាអញនឹងស្វែងរកគិលានភត្ត នឹងស្វែងរកគិលានុបដ្ឋាកភត្ត នឹងស្វែងរកគិលានភេសជ្ជៈ ឬនឹងសួរជម្ងឺ ឬនឹងបម្រើជម្ងឺ។

## ១១២. បហិតេយេវ អនុជានានា

CS vin.mv.03.06 | ភាគ ទី៧

**(១១២)**

ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បងប្អូនប្រុសរបស់ភិក្ខុមានជម្ងឺ។ បើបងប្អូនប្រុសនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុជាបងប្អូនថា ដ្បិតខ្ញុំមានជម្ងឺ សូមឲ្យលោកជាបងប្អូនរបស់ខ្ញុំនិមន្តមក ខ្ញុំចង់ឲ្យលោកជាបងប្អូននិមន្តមក។ ម្នាលភិក្ខុទាំងឡាយ កាលបើបងប្អូនប្រុសបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន បើបងប្អូនប្រុសមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនគួរទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បងប្អូនស្រីរបស់ភិក្ខុមានជម្ងឺ។ បើបងប្អូនស្រីនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុថា ដ្បិតខ្ញុំមានជម្ងឺ សូមឲ្យលោកជាបងប្អូនប្រុសរបស់ខ្ញុំនិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកជាបងប្អូនប្រុសនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ កាលបើបងប្អូនស្រីបានបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន កាលបើបងប្អូនស្រីមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ញាតិរបស់ភិក្ខុមានជម្ងឺ។ បើញាតិនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុថា ដ្បិតខ្ញុំមានជម្ងឺ សូមឲ្យលោកដ៏ចំរើននិមន្តមក ខ្ញុំប្រាថ្នាឲ្យលោកដ៏ចំរើននិមន្តមក។ ម្នាលភិក្ខុទាំងឡាយ កាលបើញាតិបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅដោយសត្តាហករណីយបាន កាលបើញាតិមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ អ្នកធ្វើការឈ្នួលរបស់ភិក្ខុមានជម្ងឺ។ បើអ្នកធ្វើការឈ្នួលនោះបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា ដ្បិតខ្ញុំករុណាមានជម្ងឺ សូមឲ្យភិក្ខុទាំងឡាយនិមន្តមក ខ្ញុំប្រាថ្នាឲ្យភិក្ខុទាំងឡាយនិមន្តមក។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកធ្វើការឈ្នួលបញ្ជូនបម្រើមកហើយ ភិក្ខុគប្បីទៅ ដោយសត្តាហករណីយបាន កាលបើអ្នកធ្វើការឈ្នួលមិនបានបញ្ជូនបម្រើមកទេ ភិក្ខុមិនត្រូវទៅទេ ភិក្ខុត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ។

[៩] សម័យនោះឯង មហាវិហាររបស់សង្ឃបាក់បែកទ្រុតទ្រោមទៅ មានឧបាសកម្នាក់បានឲ្យគេកាប់យកគ្រឿងឈើនៅក្នុងព្រៃ។ ឧបាសកនោះក៏បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា បើលោកដ៏ចំរើនទាំងឡាយអាចឲ្យគេនាំយកគ្រឿងឈើនោះទៅបាន ខ្ញុំករុណានឹងប្រគេនគ្រឿងឈើនោះ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទៅ ដោយសង្ឃករណីយ (កិច្ចដែលសង្ឃគួរធ្វើ)បាន ហើយត្រូវធ្វើការត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃ។

ចប់ ភាណវារៈ សំដែងអំពីភិក្ខុនៅចាំវស្សាជាបឋម។

## ១១៣. អន្តរាយេ អនាបត្តិវស្សច្ឆេទវារោ

CS vin.mv.03.07 | ភាគ ទី៧

**(១១៣)**

[១០] សម័យនោះឯង ភិក្ខុទាំងឡាយបានចាំវស្សាក្នុងអាវាស១ ក្នុងកោសលជនបទ ពួកសត្វសាហាវតែងទៅបៀតបៀន។ ពួកសត្វសាហាវនោះមកចាប់ភិក្ខុទាំងនោះខ្លះ មកចោមព័ទ្ធបង្អើលភិក្ខុទាំងនោះខ្លះ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយបានចូលវស្សាហើយមានពួកសត្វសាហាវមកបៀតបៀន។ ចាប់យកភិក្ខុទាំងនោះក្តី មកចោមព័ទ្ធបង្អើលភិក្ខុទាំងនោះក្តី។ ភិក្ខុទាំងឡាយត្រូវធ្វើទុកក្នុងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយបានចូលវស្សាហើយ ពួកសត្វ

មានពិស[៦] មកបៀតបៀន។ សត្វទីឃជាតិទាំងនោះខាំភិក្ខុខ្លះ មកចោមព័ទ្ធបង្អើលភិក្ខុទាំងនោះខ្លះ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ បើភិក្ខុទាំងឡាយចូលវស្សាហើយ មានពួកចោរមកបៀតបៀន។ ចោរទាំងនោះប្លន់ភិក្ខុទាំងឡាយខ្លះ វាយសំពងភិក្ខុទាំងឡាយខ្លះ។ ភិក្ខុទាំងនោះ ត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ មានពួកបិសាចបៀតបៀន។ បិសាចទាំងនោះចូលទៅ (ក្នុងសរីរៈរបស់ភិក្ខុទាំងឡាយនោះ)ខ្លះ នាំយក (ភិក្ខុទាំងឡាយនោះ)ទៅខ្លះ។ ភិក្ខុទាំងនោះ ត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ ស្រាប់តែភ្លើងឆេះស្រុកជាទីគោចរ។ ភិក្ខុទាំងឡាយក៏លំបាកដោយអាហារបិណ្ឌបាត ភិក្ខុទាំងនោះ ត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ ស្រាប់តែភ្លើងឆេះទីសេនាសនៈ។ ភិក្ខុទាំងឡាយក៏លំបាកដោយទីសេនាសនៈ។ ភិក្ខុទាំងនោះ ត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុទាំងឡាយចូលវស្សាហើយ ស្រាប់តែមានទឹកជន់មកលិចស្រុកជាទីគោចរ។ ភិក្ខុទាំងឡាយក៏លំបាកដោយអាហារបិណ្ឌបាត។ ភិក្ខុទាំងនោះ ត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានទឹកជន់លិចទីសេនាសនៈរបស់ពួកភិក្ខុដែលចូលវស្សាហើយ។ ភិក្ខុទាំងឡាយក៏លំបាកដោយទីសេនាសនៈ។ ភិក្ខុទាំងនោះ ត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។

[១១] សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាហើយក្នុងអាវាស១ ស្រាប់តែមានពួកចោរមកនៅក្នុងស្រុកជាទីគោចរ។ ភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ស្រុកជាទីគោចរ មានក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទៅនៅក្នុងទីនោះចុះ។ ចំណែកអ្នកស្រុកក៏បែកគ្នាទៅជាពីរផ្នែក។ ភិក្ខុទាំងឡាយ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ អ្នកស្រុកទាំងឡាយមានចំនួនច្រើនជាង នៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទៅនៅក្នុងទីនោះបាន។ (ចំណែក) អ្នកស្រុកដែលឥតមានសទ្ធា ឥតមានសេចក្តីជ្រះថ្លា ច្រើនជាង។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកស្រុកដែលមានសទ្ធាជ្រះថ្លា មាននៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយទៅនៅក្នុងទីនោះឯង។

[១២] សម័យនោះឯង ក្នុងកោសលជនបទ មានពួកភិក្ខុចូលវស្សាក្នុងអាវាស១ ក៏មិនដែលបានភោជនសៅហ្មង ឬឧត្តមឲ្យបានឆ្អែតពេញលេញម្តងសោះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុដែលចូលវស្សាហើយ មិនបានភោជនសៅហ្មង ឬឧត្តមល្មមឆ្អែតពេញលេញទេ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុដែលចូលវស្សាហើយ បានភោជនសៅហ្មង ឬឧត្តមល្មមឆ្អែតពេញលេញហើយ តែមិនបានភោជនទាំងឡាយឲ្យជាទីសប្បាយសោះ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុដែលចូលវស្សាហើយ បានភោជនសៅហ្មង ឬឧត្តមល្មមឆ្អែតពេញលេញហើយ បានភោជនទាំងឡាយក៏ជាទីសប្បាយ តែមិនបានភេសជ្ជៈទាំងឡាយជាទីសប្បាយសោះ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកភិក្ខុដែលចូលវស្សាហើយ បានភោជនសៅហ្មង ឬឧត្តមល្មមឆ្អែតពេញលេញបានភោជនទាំងឡាយក៏ជាទីសប្បាយ បានភេសជ្ជៈទាំងឡាយក៏ជាទីសប្បាយ តែមិនបានអ្នកឧបដ្ឋាកឲ្យសមគួរសោះ។ ភិក្ខុទាំងនោះត្រូវតាំងចិត្តថា អាវាសនេះឯង មានសេចក្តីអន្តរាយ ហើយចៀសចេញទៅចុះ។ ភិក្ខុទាំងនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានស្រីមកប្រលោមភិក្ខុដែលចូលវស្សាហើយថា លោកម្ចាស់ចូរនិមន្តមក ខ្ញុំករុណាប្រគេនប្រាក់លោកក្តី ខ្ញុំករុណាប្រគេនមាសលោកក្តី ខ្ញុំករុណាប្រគេនស្រែលោកក្តី ខ្ញុំករុណាប្រគេនចំការលោកក្តី ខ្ញុំករុណាប្រគេនគោឈ្មោលលោកក្តី ខ្ញុំករុណាប្រគេនគោញីលោកក្តី ខ្ញុំករុណាប្រគេនខ្ញុំប្រុសលោកក្តី ខ្ញុំករុណាប្រគេនខ្ញុំស្រីលោកក្តី ខ្ញុំករុណាប្រគេនកូនស្រី ដើម្បីឲ្យជាភរិយាលោកក្តី ខ្ញុំករុណាជាភរិយាលោកក្តី ខ្ញុំករុណានាំយកស្រីដទៃមកឲ្យជាភរិយាលោកក្តី។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ចិត្តជាធម្មជាត តែងប្រែត្រឡប់រហ័សដោយពិត ក្រែងព្រហ្មចរិយធម៌របស់អាត្មាអញនឹងមានសេចក្តីអន្តរាយ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានស្រីផ្កាមាសមកប្រលោមភិក្ខុដែលចូលវស្សាហើយ។បេ។ ចុល្លកុមារី (ស្រីចាស់ក្រមុំ) មកប្រលោម ខ្ទើយមកប្រលោម ពួកញាតិមកប្រលោម ពួកស្តេចមកប្រលោម ពួកចោរមកប្រលោម ពួកអ្នកលេងមកប្រលោមថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និមន្តមក យើងខ្ញុំប្រគេនប្រាក់លោកក្តី យើងខ្ញុំប្រគេនមាសលោកក្តី យើងខ្ញុំប្រគេនស្រែលោកក្តី យើងខ្ញុំប្រគេនចំការលោកក្តី យើងខ្ញុំប្រគេនគោឈ្មោលលោកក្តី យើងខ្ញុំប្រគេនគោញីលោកក្តី យើងខ្ញុំប្រគេនខ្ញុំប្រុសលោកក្តី យើងខ្ញុំប្រគេនខ្ញុំស្រីលោកក្តី យើងខ្ញុំប្រគេនកូនស្រី ដើម្បីឲ្យជាភរិយាលោកក្តី យើងខ្ញុំនាំយកស្រីដទៃមកឲ្យជាភរិយាលោកក្តី។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ចិត្តជាធម្មជាត តែងប្រែត្រឡប់រហ័សដោយពិត ក្រែងមានសេចក្តីអន្តរាយដល់ព្រហ្មចរិយធម៌របស់អាត្មាអញ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ ឃើញកំណប់ទ្រព្យឥតមានម្ចាស់។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ចិត្តជាធម្មជាត តែងប្រែត្រឡប់រហ័សដោយពិត ក្រែងមានសេចក្តីអន្តរាយ ដល់ព្រហ្មចរិយធម៌របស់អញ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។

## ១១៤. សង្ឃភេទេ អនាបត្តិវស្សច្ឆេទវារោ

(១១៤)

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ ឃើញភិក្ខុច្រើនរូបកំពុងព្យាយាមដើម្បីបំបែកសង្ឃ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា សង្ឃភេទ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ សូមកុំឲ្យសង្ឃបែកគ្នាក្នុងទីចំពោះមុខអញឡើយ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ពួកភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ សូមកុំឲ្យសង្ឃបែកគ្នាក្នុងទីចំពោះមុខអញឡើយ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ មានភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះ ជាមិត្តរបស់អាត្មាអញ អាត្មាអញនឹងនិយាយនឹងភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់លោកដ៏មានអាយុ កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះ មុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ មានភិក្ខុច្រើនរូបព្យាយាមដើម្បីបំបែកសង្ឃ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះ មិនមែនជាមិត្តរបស់អាត្មាអញមែន ប៉ុន្តែថា ភិក្ខុទាំងឡាយណាដែលជាមិត្តរបស់ភិក្ខុទាំងឡាយនោះ ភិក្ខុទាំងនោះ ក៏គង់ជាមិត្តរបស់អាត្មាអញដែរ អញនឹងនិយាយប្រាប់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ លុះអាត្មាអញបាននិយាយទៅហើយ មុខជានឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់លោកដ៏មានអាយុ កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះ មុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ សង្ឃមុខជានឹងបែក ព្រោះភិក្ខុច្រើនរូប។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងនោះ ជាមិត្តរបស់អញ ៗនឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ការបំបែកសង្ឃមានទោសធ្ងន់ លោកដ៏មានអាយុទាំងឡាយ កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះ នឹងធ្វើតាម នឹងប្រាថ្នាដើម្បីស្តាប់ពាក្យរបស់អញ នឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ សង្ឃមុខជានឹងបែក ព្រោះភិក្ខុច្រើនរូប។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុទាំងឡាយនោះឯង មិនមែនជាមិត្តរបស់អាត្មាទេ ប៉ុន្តែថា ភិក្ខុទាំងឡាយណាដែលជាមិត្តរបស់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ ក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ លុះអាត្មាអញនិយាយទៅហើយ មុខជានឹងនិយាយប្រាប់ភិក្ខុទាំងនោះថា នែអាវុសោ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់លោកដ៏មានអាយុ កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុទាំងនោះ មុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ មានភិក្ខុនីច្រើនរូប ព្យាយាមដើម្បីបំបែកសង្ឃ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះ ជាមិត្តរបស់អាត្មាអញពិត អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់នាង កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ពួកភិក្ខុនីនោះ មុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ មានភិក្ខុនីច្រើនរូប ព្យាយាមដើម្បីបំបែកសង្ឃ។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះ មិនមែនជាមិត្តរបស់អាត្មាអញមែន ប៉ុន្តែថា ភិក្ខុនីណា ដែលជាមិត្តរបស់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះ ក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះ លុះអាត្មាអញបាននិយាយទៅហើយ មុខជានិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ ពួកនាង កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ពួកភិក្ខុនីនោះ មុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅចុះ។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ សង្ឃមុខជានឹងបែក ព្រោះភិក្ខុនីច្រើនរូប។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះ ជាមិត្តរបស់អាត្មាអញដោយពិត អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ អស់ទាំងនាង កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុនីទាំងនោះ មុខជានឹងធ្វើតាម មុខជានឹងប្រាថ្នាដើម្បីស្តាប់ពាក្យរបស់អាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុចូលវស្សាហើយ បានឮដំណឹងថា ក្នុងអាវាសឯណោះ សង្ឃមុខជានឹងបែក ព្រោះភិក្ខុនីច្រើនរូប។ ក្នុងវេលានោះ បើភិក្ខុមានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុនីទាំងនោះ មិនមែនជាមិត្តរបស់អាត្មាអញពិតមែន ប៉ុន្តែថា ភិក្ខុនីទាំងឡាយណា ដែលជាមិត្តរបស់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងឡាយនោះ ក៏ជាមិត្តរបស់អាត្មាអញដែរ អាត្មាអញនឹងនិយាយប្រាប់ភិក្ខុនីទាំងនោះ ភិក្ខុនីទាំងនោះ លុះអាត្មាអញនិយាយទៅហើយ នឹងនិយាយប្រាប់ភិក្ខុនីទាំងនោះថា នែនាងទាំងឡាយ ការបំបែកសង្ឃ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មានទោសធ្ងន់ ពួកនាង កុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ភិក្ខុនីទាំងនោះ មុខជានឹងធ្វើតាម មុខជាប្រាថ្នាដើម្បីស្តាប់ពាក្យអាត្មាអញ មុខជានឹងផ្ទៀងត្រចៀកស្តាប់ ដូច្នេះហើយ ត្រូវចៀសចេញទៅបាន។ ភិក្ខុនោះដាច់វស្សា តែមិនត្រូវអាបត្តិទេ។

## ១១៥. វជាទីសុ វស្សូបគមនំ

CS vin.mv.03.09 | ភាគ ទី៧

(១១៥)

[១៣] សម័យនោះឯង ភិក្ខុ១រូបមានសេចក្តីប្រាថ្នាដើម្បីចូលវស្សាក្នុងលំនៅរបស់គង្វាលគោ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សា ក្នុងលំនៅរបស់គង្វាលគោបាន។ ឯលំនៅរបស់គង្វាលគោក៏រើចេញទៅ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ លំនៅគង្វាលគោទៅក្នុងទីណា តថាគតអនុញ្ញាតឲ្យភិក្ខុទៅក្នុងទីនោះបាន។ សម័យនោះឯង មានភិក្ខុ១រូប កាលថ្ងៃចូលវស្សាកាន់តែជិតហើយ ក៏ប្រាថ្នាដើម្បីទៅដោយពួកឈ្មួញរទេះ។[7] ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងពួកឈ្មួញរទេះបាន។ សម័យនោះឯង មានភិក្ខុ១រូប កាលថ្ងៃចូលវស្សាកាន់តែជិតហើយ ក៏ប្រាថ្នាដើម្បីទៅដោយទូក។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សាក្នុងទូកបាន។

## ១១៦. វស្សំ អនុបគន្តព្វដ្ឋានានិ

CS vin.mv.03.10 | ភាគ ទី៧

**(១១៦)**

[១៤] សម័យនោះឯង មានភិក្ខុ១រូប ចូលវស្សាក្នុងរោងឈើ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកបិសាច។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ភិក្ខុមិនត្រូវចូលវស្សាក្នុងរូងឈើទេ ភិក្ខុណាចូល ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាលើប្រគាបឈើ។ ពួកមនុស្ស ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកព្រានម្រឹគ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាលើប្រគាបឈើទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ។

[១៥] សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាក្នុងទីវាល។ ដល់វេលាភ្លៀងធ្លាក់មក ភិក្ខុទាំងនោះក៏ស្ទុះចូលទៅរកម្លប់ឈើខ្លះ យុរស្សូវខ្លះ (សំយាប ឬរងស្សូវ)។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងទីវាលទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាឥតមានទីសេនាសនៈឡើយ ក៏លំបាកដោយត្រជាក់ខ្លះ ដោយកំដៅខ្លះ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គបញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាដោយឥតមានទីសេនាសនៈទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាក្នុងខ្ទមខ្មោច។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះ ដូចជាពួកជនដុតខ្មោច។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គបញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងខ្ទមខ្មោចទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាក្នុងឆត្ត។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះដូចជាពួកគង្វាលគោ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គបញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងឆត្តទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ភិក្ខុទាំងឡាយចូលវស្សាក្នុងពាងទឹក។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងនោះ ដូចជាពួកតិរ្ថិយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សាក្នុងពាងទឹកទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ។

## ១១៧. អធម្មិកកតិកា

CS vin.mv.03.11 | ភាគ ទី៧

**(១១៧)**

[១៦] សម័យនោះឯង ក្នុងក្រុងសាវត្ថី សង្ឃបានធ្វើកតិកា (ប្តេជ្ញា)ថា ភិក្ខុមិនត្រូវបំបួសកុលបុត្តក្នុងកណ្តាលវស្សាឡើយ។ ស្រាប់តែចៅរបស់នាងវិសាខា ជាមាតាមិគារសេដ្ឋី បានចូលទៅរកពួកភិក្ខុហើយ សូមនូវផ្នួស។ ភិក្ខុទាំងឡាយក៏បាននិយាយទៅវិញយ៉ាងនេះថា នែអ្នកដ៏មានអាយុ សង្ឃបានធ្វើកតិកាថា មិនត្រូវឲ្យភិក្ខុណាបំបួសកុលបុត្តក្នុងកណ្តាលវស្សាឡើយ នែអ្នកដ៏មានអាយុ អ្នកឯងចូរបង្អង់សិន ទំរាំតែភិក្ខុទាំងឡាយនៅចាំវស្សា លុះចាំវស្សារួចហើយ នឹងបំបួស។ គ្រានោះ ភិក្ខុទាំងនោះ លុះចាំវស្សារួចហើយ ក៏បាននិយាយពាក្យនេះនឹងចៅរបស់នាងវិសាខា ជាមាតាមិគារសេដ្ឋីថា នែអ្នកដ៏មានអាយុ អ្នកឯងចូរមកបួសក្នុងកាលឥឡូវនេះចុះ។ បុរសនោះ ពោលតបយ៉ាងនេះវិញថា បពិត្រលោកដ៏ចំរើន ប្រសិនបើខ្ញុំករុណាបានបួសរួចស្រេចហើយ ខ្ញុំករុណាគួរត្រេកអរពេកណាស់ បពិត្រលោកដ៏ចំរើន ឥឡូវនេះ ខ្ញុំករុណាខានបួសហើយ។ នាងវិសាខា ជាមាតាមិគារសេដ្ឋី ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយមិនសមបើនឹងធ្វើកតិកាបែបយ៉ាងនេះថា ភិក្ខុមិនត្រូវបំបួសកុលបុត្ត ក្នុងកណ្តាលវស្សាសោះ ឯភិក្ខុមិនត្រូវប្រព្រឹត្តធម៌មានកំណត់កាលដូច្នោះទេ។ កាលនាងវិសាខា ជាមាតាមិគារសេដ្ឋី កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ វេលានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកតិកាបែបនេះថា ភិក្ខុមិនត្រូវបំបួសកុលបុត្តក្នុងកណ្តាលវស្សាទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។

## ១១៨. បដិស្សវទុក្កដាបត្តិ

CS vin.mv.03.12 | ភាគ ទី៧

**(១១៨)**

[១៧] សម័យនោះឯង ឧបនន្ទ ជាសក្យបុត្តដ៏មានអាយុ បានទទួលប្តេជ្ញាស្តេចបសេនទិកោសលថា នឹងនៅចាំវស្សាដោយបុរិមិកាវស្សា។ ឧបនន្ទនោះកាលដើរទៅកាន់អាវាសនោះ ក៏បានឃើញអាវាសពីរ ក្នុងពាក់កណ្តាលផ្លូវ ជាអាវាសមានចីវរច្រើន។ ឧបនន្ទនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរអាត្មាអញនៅចាំវស្សាក្នុងអាវាសទាំងពីរនេះចុះ ចីវរមុខជានឹងកើតដល់អាត្មាអញជាច្រើន ដោយអាការយ៉ាងនេះ។ ឧបនន្ទនោះ ក៏បាននៅចាំវស្សាក្នុងអាវាសទាំងពីរនោះ។ ស្តេចបសេនទិកោសល ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧបនន្ទ ជាសក្យបុត្ត បានទទួលប្តេជ្ញាថា អញនៅចាំវស្សាហើយ មិនសមបើនឹងធ្វើឲ្យខុសពាក្យប្តេជ្ញាទៅវិញសោះ ព្រះមានព្រះភាគ ទ្រង់តិះដៀលមុសាវាទ ទ្រង់សរសើរតែការវៀរចាកពាក្យមុសាវាទ ដោយអនេកបរិយាយ។ កាលស្តេចបសេនទិកោសល កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយ ក៏បានឮច្បាស់។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទ ជាសក្យបុត្ត ដ៏មានអាយុ បានទទួលប្តេជ្ញាស្តេចបសេនទិកោសលថា នឹងនៅចាំវស្សាហើយ មិនសមបើនឹងធ្វើឲ្យខុសពាក្យប្តេជ្ញាទៅវិញសោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលចពាក្យមុសាវាទ ទ្រង់សរសើរតែការវៀរចាកពាក្យមុសាវាទ ដោយអនេកបរិយាយ។ វេលានោះ ភិក្ខុទាំងនោះ ក៏ក្រាបទូលនូវសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ក្នុងវេលានោះ ហើយទ្រង់សួរចំពោះឧបនន្ទ ជាសក្យបុត្តដ៏មានអាយុថា ឧបនន្ទ ឮថា អ្នកឯងបានទទួលប្តេជ្ញាស្តេចបសេនទិកោសលថា នឹងនៅចាំវស្សាហើយធ្វើឲ្យខុសពាក្យប្តេជ្ញាទៅវិញ ពិតមែនឬ។ ឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងបានទទួលប្តេជ្ញាស្តេចបសេនទិកោសលថានឹងនៅចាំវស្សាហើយ មិនសមបើនឹងធ្វើឲ្យខុសពាក្យប្តេជ្ញាទៅវិញសោះ ម្នាលមោឃបុរស តថាគតបានតិះដៀលពាក្យមុសាវាទ បានសរសើរតែការវៀរចាកពាក្យមុសាវាទ ដោយអនេកបរិយាយ ម្នាលមោឃបុរស អំពើនេះ នឹងបានដឹកនាំពួកជន ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើងក៏ទេ។បេ។ ទ្រង់បន្ទោសហើយ ធ្វើនូវធម្មីកថា រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះកំពុងតែដើរទៅកាន់អាវាសនោះ ក៏បានឃើញអាវាសពីរក្នុងពាក់កណ្តាលផ្លូវ ជាអាវាសមានចីវរច្រើន។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរអាត្មាអញនឹងនៅចាំវស្សាក្នុងអាវាសទាំងពីរនេះចុះ ចីវរមុខជានឹងកើតដល់អាត្មាអញជាច្រើន ដោយអាការយ៉ាងនេះ។ ភិក្ខុនោះ ក៏នៅចាំវស្សាក្នុងអាវាសទាំងពីរនោះ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះ មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាថានៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះ កាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសដខាងក្រៅ លុះដល់ថ្ងៃ១រោច ទើបចូលទៅវិហារ ក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេន។ ក្នុងថ្ងៃនោះឯង ភិក្ខុនោះឥតមានកិច្ចនឹងត្រូវធ្វើឡើយ ហើយក៏ដើរចេញទៅ។ ម្នាលភិក្ខុទាំងឡាយ ឯបុរិមិកាវស្សា របស់ភិក្ខុនោះ មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង។

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាថា នឹងនៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះ កាលដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ១រោច ទើបចូលទៅវិហារ ក្រាលអាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេន។ ក្នុងថ្ងៃនោះ ភិក្ខុនោះប្រកបដោយកិច្ចត្រូវធ្វើ ហើយក៏ដើរចេញទៅ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះ កាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ១រោច ទើបចូលទៅវិហារ ក្រាលសេនាសនៈ រួចដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេន។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ឥតមានកិច្ចអ្វីនឹងគួរធ្វើឡើយ ហើយក៏ដើរចេញទៅ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះ កាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ ក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេន។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃហើយប្រកបដោយកិច្ចគួរនឹងធ្វើ ក៏ដើរចេញទៅ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះ កាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសដខាងក្រៅ លុះដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេន។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ក៏ដើរចេញទៅដោយសត្តាហករណីយ។ ភិក្ខុនោះនៅខាងក្រៅ(អាវាស)ហួស៧ថ្ងៃនោះ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះ មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាគេថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ក៏ថយចេញទៅ ដោយសត្តាហករណីយ។ ភិក្ខុនោះ វិលត្រឡប់មកវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យប្តេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាគេថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះ កាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ១រោច ចូលទៅឯវិហារ ក្រាលសេនាសនៈ រួចដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ។ ភិក្ខុនោះ កាលបើនៅខ្វះ៧ថ្ងៃទៀត នឹងដល់ថ្ងៃបវារណា ក៏ប្រកបកិច្ចដែលត្រូវធ្វើ ហើយថយចេញទៅ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ បានមកកាន់អាវាសនោះក្តី មិនបានមកកាន់អាវាសនោះក្តី។ ម្នាលភិក្ខុទាំងឡាយ ឯបុរិមិកាវស្សារបស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យប្តេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាគេថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះ ទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថ លុះដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ។ ក្នុងថ្ងៃនោះឯង ភិក្ខុនោះឥតមានកិច្ចរវល់នឹងធ្វើឡើយ ហើយក៏ថយចេញទៅ។ ម្នាលភិក្ខុទាំងឡាយ ឯបុរិមិកាវស្សា របស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្តេជ្ញាគេថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះ ទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថ លុះដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ។ ក្នុងថ្ងៃនោះឯង ភិក្ខុនោះក៏ប្រកបដោយកិច្ចដែលត្រូវធ្វើ ទើបថយចេញទៅ។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ឥតមានកិច្ចអ្វី ក៏ថយចេញទៅ។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ប្រកបដោយកិច្ចការ ក៏ថយចេញទៅ។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ក៏ថយចេញទៅ ដោយសត្តាហករណីយ។ ភិក្ខុនោះ នៅខាងក្រៅ (អាវាស) ឲ្យហួសពី៧ថ្ងៃនោះ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង។បេ។ ភិក្ខុនោះ នៅអស់

ពីរបីថ្ងៃ ក៏ថយចេញទៅដោយសត្តាហករណីយ។ ភិក្ខុនោះ ត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃ។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យប្ដេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាគេថា នៅចាំវស្សា ដោយបុរិមិកាវស្សាហើយ។ ភិក្ខុនោះទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថ លុះដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ និងទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ។ ភិក្ខុនោះ កាលបើនៅខ្វះ៧ថ្ងៃទៀត នឹងដល់ថ្ងៃបវារណា ក៏ប្រកបដោយកិច្ច ហើយថយចេញទៅ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មកកាន់អាវាសនោះក្ដី មិនបានមកក្ដី។ ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យប្ដេជ្ញាផង។

[១៨] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាគេថា នៅចាំវស្សា ដោយបច្ឆិមិកាវស្សាហើយ។ ភិក្ខុនោះ កាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ។ ភិក្ខុនោះឥតមានកិច្ចអ្វី ក៏ចៀសចេញទៅ ក្នុងថ្ងៃនោះឯង។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សា របស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្ដេជ្ញាផង។

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាគេថា នៅចាំវស្សា ដោយបច្ឆិមិកាវស្សាហើយ។ ភិក្ខុនោះ កាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ។ ភិក្ខុនោះមានកិច្ចដែលត្រូវធ្វើ ក៏ចៀសចេញទៅក្នុងថ្ងៃនោះឯង។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ឥតមានកិច្ចអ្វី ក៏ចៀសចេញទៅ។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ មានកិច្ចដែលត្រូវធ្វើ ក៏ចៀសចេញទៅ។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ក៏ចៀសចេញដោយសត្តាហករណីយ។ ភិក្ខុនោះនៅខាងក្រៅហួសកំណត់៧ថ្ងៃនោះទៅ។ បច្ឆិមិកាវស្សារបស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្ដេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាគេថា នៅចាំវស្សា ដោយបច្ឆិមិកាវស្សាហើយ។ ភិក្ខុនោះ កាលនឹងចេញដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅ លុះដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃហើយ ក៏ចៀសចេញទៅដោយសត្តាហករណីយ។ ភិក្ខុនោះ ត្រឡប់វិលវិញ ក្នុងរវាង៧ថ្ងៃនោះ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សា របស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យប្ដេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលពាក្យប្ដេជ្ញាគេថា នៅចាំវស្សា ដោយបច្ឆិមិកាវស្សាហើយ។បេ។ ភិក្ខុនោះ កាលបើនៅខ្វះ៧ថ្ងៃទៀត នឹងដល់ថ្ងៃជាទីរីកឡើងនៃផ្កាកុមុទ គឺថ្ងៃជាគំរប់៤ខែ នៃរដូវភ្លៀង (១៥កើត ខែកត្តិក) មានកិច្ចដែលត្រូវធ្វើ ក៏ចៀសចេញទៅ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ បានមកកាន់អាវាសនោះក្ដី មិនបានមកក្ដី។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សារបស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យប្ដេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាគេថា នៅចាំវស្សា ដោយបច្ឆិមិកាវស្សាហើយ។ ភិក្ខុនោះ ទៅកាន់អាវាសនោះហើយ ក៏ធ្វើឧបោសថ ដល់ថ្ងៃ១រោច ទើបចូលទៅកាន់វិហារ រៀបក្រាលសេនាសនៈ ដំកល់ទឹកឆាន់ និងទឹកប្រើប្រាស់ បោសច្រាសទីបរិវេណ។ ភិក្ខុនោះឥតមានកិច្ចអ្វី ក៏ចៀសចេញទៅក្នុងថ្ងៃនោះឯង។បេ។ ភិក្ខុនោះ មានកិច្ចដែលត្រូវធ្វើ ក៏ចៀសចេញទៅក្នុងថ្ងៃនោះឯង។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ឥតមានកិច្ចអ្វី ក៏ចៀសចេញទៅ។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ មានកិច្ចដែលត្រូវធ្វើ ក៏ចៀសចេញទៅ។បេ។ ភិក្ខុនោះនៅអស់ពីរបីថ្ងៃ ក៏ចៀសចេញទៅ ដោយសត្តាហករណីយ។ ភិក្ខុនោះនៅខាងក្រៅហួសកំណត់៧ថ្ងៃទៅ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សា របស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្ដេជ្ញាផង។បេ។ ភិក្ខុនោះ នៅអស់ពីរបីថ្ងៃ ក៏ចៀសចេញទៅ ដោយសត្តាហករណីយ។ ភិក្ខុនោះត្រឡប់វិលវិញក្នុងរវាង៧ថ្ងៃនោះ។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សា របស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យប្ដេជ្ញាផង។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលប្ដេជ្ញាគេថា នៅចាំវស្សា ដោយបច្ឆិមិកាវស្សាហើយ។បេ។ ភិក្ខុនោះ កាលបើនៅខ្វះ៧ថ្ងៃទៀត នឹងដល់ថ្ងៃជាទីរីកនៃផ្កាកុមុទ គឺថ្ងៃជាគំរប់៤ខែ នៃរដូវភ្លៀង (១៥កើត ខែកត្តិក) មានកិច្ចដែលត្រូវធ្វើ ក៏ចៀសចេញទៅ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មកកាន់អាវាសនោះក្ដី មិនបានមកក្ដី។ ម្នាលភិក្ខុទាំងឡាយ បច្ឆិមិកាវស្សារបស់ភិក្ខុនោះ ក៏ប្រាកដផង ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះទទួលពាក្យប្ដេជ្ញាផង។

ចប់ វស្សូបនាយិកក្ខន្ធកៈទី៣។

ឧទាននៃវស្សូបនាយិកក្ខន្ធកៈនោះ គឺ

## ១១៩. តស្សុទ្ទានំ

CS vin.mv.03.13 | ភាគ ទី៧

**(១១៩)**

[១៩] រឿងព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុចូលវស្សា១ ពួកភិក្ខុគិតថា យើងត្រូវចូលវស្សាក្នុងកាលណាហ្ន៎១ ពួកភិក្ខុគិតថា ថ្ងៃចូលវស្សា តើមានប៉ុន្មានយ៉ាង១ ពួកឆព្វគ្គិយភិក្ខុបានចូលវស្សាហើយ ចេញដើរទៅកាន់ចារិកក្នុងកណ្ដាលវស្សា១ មិនប្រាថ្នានឹងចូលវស្សា១ វេលាជិតចូលវស្សាហើយ ក្លែងដើរចេញទៅកាន់អាវាសដទៃ១ ស្ដេចពិម្ពិសារប្រាថ្នានឹងលើកខែ១ ឧបាសកបានឲ្យគេសាងវិហារចំពោះសង្ឃ១ ភិក្ខុមានជម្ងឺ១ មាតានិងបិតារបស់ភិក្ខុមានជម្ងឺ១ បងប្អូនរបស់ភិក្ខុមានជម្ងឺ១ ញាតិរបស់ភិក្ខុមានជម្ងឺ១ អ្នកធ្វើការឈ្នួលរបស់ភិក្ខុមានជម្ងឺ១ វិហារទ្រុឌទ្រោម១ សត្វសាហាវបៀតបៀនពួកភិក្ខុ១ សត្វមានពិសបៀតបៀនពួកភិក្ខុ១ ពួកចោរបៀតបៀនពួកភិក្ខុ១ ពួកបិសាចបៀតបៀនពួកភិក្ខុ១ ភ្លើងឆេះស្រុក និងឆេះទីសេនាសនៈទាំងពីររឿង១ ទឹកជន់លិចស្រុក១ ចោរមកតាំងនៅក្នុងស្រុក១ ពួកទាយកជាច្រើនឥតមានសទ្ធាជ្រះថ្លា១ ភិក្ខុនៅចាំវស្សាក្នុងអាវាសដទៃ ហើយមិនដែលបានភោជនសៅហ្មង ឬឧត្តមឆាន់ឲ្យឆ្អែតពេញលេញ១ ភិក្ខុនៅចាំវស្សាហើយមិនដែលបានភោជនឆាន់ឲ្យសប្បាយ១ ភិក្ខុបានភេសជ្ជៈជាទីសប្បាយហើយ តែមិនបានឧបដ្ឋាកដ៏សមគួរ១ ស្រីប្រលោមភិក្ខុ១ ស្រីផ្កាមាសប្រលោមភិក្ខុ១ នាងចុល្លកុមារីប្រលោមភិក្ខុ១

មនុស្សខ្មើយប្រលោមភិក្ខុ១ ញាតិប្រលោមភិក្ខុ១ ស្តេចប្រលោមភិក្ខុ១ ពួកចោរប្រលោមភិក្ខុ១ ពួកអ្នកលេងប្រលោមភិក្ខុ១ ភិក្ខុឃើញកំណប់ទ្រព្យ១ ភិក្ខុឃើញភិក្ខុច្រើនរូបព្យាយាមបំបែកសង្ឃ១ ភិក្ខុ៨ពួកបានឮដំណឹងថា ភិក្ខុនិងភិក្ខុនីព្យាយាមបំបែកសង្ឃ១ ភិក្ខុចូលវស្សាក្នុងលំនៅរបស់គង្វាលគោ១ ភិក្ខុចូលវស្សាក្នុងពួកឈ្មួញរទេះ១ ភិក្ខុចូលវស្សាក្នុងទូក១ ភិក្ខុចូលវស្សាក្នុងរូងឈើ១ ភិក្ខុចូលវស្សាលើប្រគាបឈើ១ ភិក្ខុចូលវស្សាក្នុងទីវាល១ ភិក្ខុចាំវស្សាឥតមានទីសេនាសនៈ១ ភិក្ខុចូលវស្សាក្នុងខ្ទមខ្មោច១ ក្រោមឆត្ត១ ក្នុងពាងទឹក១ សង្ឃធ្វើប្តេជ្ញាគ្នាថា កុំឲ្យបំបួសបុលបុត្រក្នុងវស្សា១ ភិក្ខុទទួលប្តេជ្ញាថានៅចាំបុរិមិកាវស្សា ឬបច្ឆិមិកាវស្សា ហើយធ្វើឧបោសថខាងក្រៅ បណ្ឌិតគួរប្រកបតាមសមគួរដល់ន័យ១ ភិក្ខុឥតមានកិច្ចអ្វីហើយចៀសចេញទៅ១ ភិក្ខុមានកិច្ច ហើយចៀសចេញទៅ១ ភិក្ខុនៅអស់ពីរបីថ្ងៃ ក៏ទៅដោយសត្តាហករណីយ ហើយត្រឡប់វិលវិញ១ នៅខ្វះ៧ថ្ងៃទៀត នឹងដល់ថ្ងៃបវារណា ភិក្ខុនោះទៅដោយសត្តាហករណី ហើយត្រឡប់មកកាន់អាវាសនោះក្តី មិនបានត្រឡប់មកកាន់អាវាសនោះក្តី១ បណ្ឌិតគប្បីពិចារណានូវទំនងដែលមានបែបផែនរៀបរយក្នុងឧទ្ទាននៃរឿងទាំងអម្បាលណេះហោង។

ក្នុងខន្ធកៈនេះមានរឿង៥២។

# បវារណក្ខន្ធកៈ

CS vin.mv.04 | ភាគ ទី៧

### (៤. បវារណាក្ខន្ធកោ)

## ១២០. អផាសុកវិហារោ

CS vin.mv.04.01 | ភាគ ទី៧

**(១២០)**

[២០] សម័យនោះឯង ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង មានភិក្ខុច្រើនរូប ជាមិត្រ ទើបនឹងបានជួបប្រទះគ្នាថ្មី ជាមិត្រស្និទ្ធិស្នាលមាំមួន បានចូលវស្សានៅក្នុងអាវាស១ ក្នុងកោសលជនបទ។ គ្រានោះ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ដោយឧបាយដូចម្តេចហ្ន៎ យើងនឹងបានព្រមព្រៀងគ្នា ស្មោះសរ មិនវិវាទគ្នា នៅចាំវស្សាឲ្យបានស្រួលផង មិនលំបាកដោយអាហារបិណ្ឌបាតផង។ លំដាប់នោះឯង ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនោះថា បើយើងមិននិយាយគ្នា មិនចរចារគ្នាទៅវិញទៅមក ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតអំពីស្រុកមុនគេ ភិក្ខុនោះ គប្បីក្រាលអាសនៈ ដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើងដែលលាងរួចហើយ នឹងគ្រឿងសម្រាប់ជូតជើងដែលមិនទាន់លាង គប្បីលាងភាជន៍សម្រាប់ផ្ទេរបាយ ហើយយកទៅដំកល់ទុក គប្បីដំកល់ទឹកឆាន់ និងទឹកប្រើប្រាស់ ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតអំពីស្រុកក្រោយគេ បើមានបិណ្ឌបាតសល់អំពីភិក្ខុនោះឆាន់ បើភិក្ខុនោះប្រាថ្នា គប្បីឆាន់ចុះ បើមិនប្រាថ្នាទេ គួរចាក់ចោលទៅលើទីដែលគ្មានស្មៅស្រស់ ឬជះចោលទៅក្នុងទឹកដែលគ្មានសត្វ(ក៏បាន) ភិក្ខុនោះគប្បីរើអាសនៈ ទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង និងគ្រឿងសម្រាប់ជូតជើង គប្បីលាងភាជន៍សម្រាប់ផ្ទេរបាយ ហើយរៀបចំទុកដាក់ គប្បីទុកដាក់ទឹកឆាន់ ទឹកប្រើប្រាស់ គប្បីបោសច្រាសរោងភត្ត ភិក្ខុណាឃើញក្អមដាក់ទឹកឆាន់ក្តី ក្អមដាក់ទឹកប្រើប្រាស់ក្តី ក្អមលាងវច្ចៈក្តី ដែលរលីងទទេ ភិក្ខុនោះគួរដំកល់ទុក បើភិក្ខុនោះមិនអាច ព្រោះវិការដៃ (ឈឺដៃ) គួរហៅគ្នីគ្នា ដោយអាការបោយដៃ មកឲ្យដំកល់ទុក តែកុំឲ្យបញ្ចេញវាចាព្រោះបច្ច័យនោះឡើយ យ៉ាងនេះឯង ទើបយើងទាំងអស់គ្នាព្រមព្រៀង ស្មោះសរ មិនវិវាទគ្នា នៅចាំវស្សាក៏ស្រួលផង មិនបានលំបាកដោយអាហារបិណ្ឌបាតផង។ គ្រានោះឯង ភិក្ខុទាំងនោះក៏លែងស្តីហៅរកឆ្លើយឆ្លងគ្នានឹងគ្នាទៅវិញទៅមក ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតអំពីស្រុកមុនគេ ភិក្ខុនោះ ក៏ក្រាលអាសនៈ ដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង និងគ្រឿងសម្រាប់ជូតជើង លាងភាជន៍សម្រាប់ផ្ទេរបាយ រួចដំកល់ទុក ដំកល់ទឹកឆាន់ និងទឹកប្រើប្រាស់ ភិក្ខុណាត្រឡប់មកអំពីបិណ្ឌបាតអំពីស្រុកក្រោយគេ បើមានអាហារសេសសល់អំពីភិក្ខុនោះឆាន់ បើភិក្ខុនោះប្រាថ្នា ក៏ឆាន់ទៅ បើមិនប្រាថ្នាទេ ចាក់ចោលទៅលើទីគ្មានស្មៅស្រស់ ឬជះចោលទៅក្នុងទឹកដែលគ្មានសត្វក្តី ភិក្ខុនោះរើអាសនៈចេញ ទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង គ្រឿងសម្រាប់ជូតជើង លាងភាជន៍សម្រាប់ផ្ទេរបាយ ហើយរៀបទុកដាក់ ទុកដាក់ទឹកឆាន់ និងទឹកប្រើប្រាស់ បោសច្រាសរោងភត្ត ភិក្ខុណាឃើញក្អមសម្រាប់ដាក់ទឹកឆាន់ក្តី ក្អមសម្រាប់ដាក់ទឹកប្រើប្រាស់ក្តី ក្អមដាក់ទឹកសម្រាប់វច្ចៈក្តី ដែលរលីងទទេ ភិក្ខុនោះក៏ដំកល់ទុក បើភិក្ខុនោះមិនអាច ព្រោះវិការដៃ ក៏ហៅគ្នីគ្នា ដោយអាការបោយដៃ មកឲ្យដំកល់ទុក តែមិនបានបញ្ចេញវាចាព្រោះបច្ច័យនោះឡើយ។

[២១] ការដែលចូលទៅគាល់ព្រះមានព្រះភាគនុ៎ះ ជាទំនៀមរបស់ភិក្ខុទាំងឡាយ ដែលចាំវស្សារួចហើយ។ វេលានោះឯង ភិក្ខុទាំងនោះ លុះនៅចាំវស្សាកន្លង៣ខែទៅហើយ ក៏រៀបចំទុកដាក់សេនាសនៈ រួចកាន់យកបាត្រ និងចីវរ ចេញដើរសំដៅទៅក្រុងសាវត្ថី លុះដើរទៅដោយលំដាប់ហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ ការរីករាយជាមួយនឹងពួកភិក្ខុជាអាគន្តុកនុ៎ះឯង ជាទំនៀមរបស់ព្រះពុទ្ធមានព្រះភាគទាំងឡាយ (គ្រប់ព្រះអង្គ)។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះនឹងពួកភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយល្មមអត់ធន់សេចក្តីទុក្ខបានឬទេ ល្មមឲ្យឥរិយាបថប្រព្រឹត្តទៅស្រួលបានឬទេ អ្នកទាំងឡាយជាបុគ្គលព្រមព្រៀងគ្នា ស្រុសស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយហើយឬ មួយទៀត អ្នកទាំងឡាយ មិនលំបាកដោយបិណ្ឌបាតទេឬ។ ភិក្ខុទាំងឡាយ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមអត់ទ្រាំសេចក្តីទុក្ខបាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំល្មមឲ្យឥរិយាបថប្រព្រឹត្តទៅស្រួលបាន បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំក៏ព្រមព្រៀងគ្នា ស្រុសស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាតាមសប្បាយ មួយទៀត យើងខ្ញុំមិនលំបាកដោយបិណ្ឌបាតទេ។ ព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបហើយត្រាស់សួរក៏មាន ទ្រង់ជ្រាបហើយ មិនត្រាស់សួរ (ក៏មាន) ទ្រង់ជ្រាបកាលគួរហើយ ត្រាស់សួរ(ក៏មាន) ទ្រង់ជ្រាបកាលគួរហើយ

មិនត្រាស់សួរ (ក៏មាន) ព្រះតថាគតទាំងឡាយ ត្រាស់សួរចំពោះតែហេតុដែលប្រកបដោយប្រយោជន៍ មិនទ្រង់ត្រាស់សួរហេតុដែលឥតប្រយោជន៍ឡើយ (ព្រោះ) ហេតុដែលឥតប្រយោជន៍ ព្រះតថាគតទាំងឡាយទ្រង់ផ្តាច់ផ្តិលដោយអរិយមគ្គហើយ។ ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគត្រាស់សួរចំពោះភិក្ខុទាំងឡាយ ដោយអាការពីរយ៉ាង គឺទ្រង់ត្រាស់សួរ ដោយទ្រង់គិតថា តថាគតនឹងសំដែងធម៌ម្យ៉ាង និងបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយម្យ៉ាង។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះនឹងពួកភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយព្រមព្រៀងគ្នា ស្រុសស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយយ៉ាងណាទៅ មួយទៀត អ្នកទាំងឡាយមិនលំបាកដោយអាហារបិណ្ឌបាតទេឬ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំព្រះភិក្ខុច្រើនរូបជាមិត្រ បានជួបប្រទះគ្នាជាមិត្រ សេពគប់គ្នាមាំមួន ចូលទៅចាំវស្សាក្នុងអាវាសមួយនាកោសលជនបទនេះ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងនោះមានសេចក្តីត្រិះរិះដូច្នេះថា យើងគប្បីជាបុគ្គលព្រមព្រៀងគ្នា ស្រុសស្រួលគ្នា កុំទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយ មួយទៀត យើងមិនគប្បីលំបាកដោយបិណ្ឌបាត ដោយឧបាយដូចម្តេចហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងនោះមានសេចក្តីត្រិះរិះដូច្នេះទៀតថា ប្រសិនបើយើងកុំគប្បីហៅរកគ្នា កុំគប្បីចរចារកគ្នាទៅវិញទៅមក ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតក្នុងស្រុកមុនគេ ភិក្ខុនោះ ត្រូវរៀបចំអាសនៈ ដំកល់ទឹកលាងជើង តាំងរងជើង ទ្រនាប់សម្រាប់ជូតជើង លាងភាជន៍សម្រាប់ផ្ទេរភត្ត រួចហើយដំកល់ទុក ហើយដំកល់ទឹកផឹក ទឹកប្រើប្រាស់ ភិក្ខុណាត្រឡប់មកអំពីបិណ្ឌបាតក្នុងស្រុកក្រោយគេ បើមានអាហារសេសសល់អំពីភិក្ខុឆាន់ បើភិក្ខុនោះចង់ឆាន់ ក៏ឆាន់ចុះ បើមិនចង់ឆាន់ទេ ក៏គប្បីចាក់ចោលលើទីដែលគ្មានស្មៅស្រស់ ឬបាចចោលក្នុងទឹកដែលគ្មានសត្វ ភិក្ខុនោះត្រូវសារអាសនៈ ត្រូវទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង និងទ្រនាប់សម្រាប់ជូតជើង ត្រូវលាងភាជន៍សម្រាប់ផ្ទេរភត្ត ហើយយកទៅទុកដាក់ រួចត្រូវទុកដាក់ទឹកផឹក ទឹកប្រើប្រាស់ ត្រូវបោសរោងភត្ត ភិក្ខុណាឃើញក្អមទឹកផឹកក្តី ក្អមទឹកប្រើប្រាស់ក្តី ក្អមដាក់ទឹកសម្រាប់លាងវច្ចៈក្តី ដែលរលីងទទេ ត្រូវភិក្ខុនោះដំកល់ទុក បើភិក្ខុនោះមិនអាច (នឹងធ្វើការនោះបាន) ព្រោះវិការនៃដៃ (គឺឈឺដៃជាដើម) ត្រូវបោយដៃហៅភិក្ខុទីពីរ ឲ្យដំកល់ទុក មិនត្រូវបញ្ចេញវាចាព្រោះហេតុនោះឡើយ កាលបើធ្វើយ៉ាងនេះហើយ ទើបបានយើងទាំងឡាយជាបុគ្គលព្រមព្រៀងគ្នា ស្រុសស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយ មួយវិញទៀត យើងទាំងឡាយមិនលំបាកដោយបិណ្ឌបាតទេ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះឯង យើងខ្ញុំមិនហៅរកគ្នា មិនចរចារកគ្នាទៅវិញទៅមកទេ ភិក្ខុណាត្រឡប់មកអំពីបិណ្ឌបាតក្នុងស្រុកមុនគេ ភិក្ខុនោះ ក៏ក្រាលអាសនៈ ដំកល់ទុកនូវទឹកលាងជើង តាំងរងជើង និងទ្រនាប់សម្រាប់ជូតជើង លាងភាជន៍សម្រាប់ផ្ទេរភត្ត ហើយដំកល់ទុក រួចដំកល់ទឹកផឹក ទឹកប្រើប្រាស់ ភិក្ខុណាត្រឡប់មកអំពីបិណ្ឌបាតក្នុងស្រុកក្រោយគេ បើមានអាហារសេសសល់អំពីភិក្ខុឆាន់ បើភិក្ខុនោះចង់ឆាន់ ក៏ឆាន់ទៅ បើមិនចង់ឆាន់ទេ ភិក្ខុនោះក៏ចាក់ចោលលើទីដែលគ្មានស្មៅស្រស់ក៏បាន បាចចោលក្នុងទឹកដែលគ្មានសត្វក៏បាន ភិក្ខុនោះសារអាសនៈចេញ ហើយទុកដាក់ទឹកលាងជើង តាំងរងជើង និងទ្រនាប់សម្រាប់ជូតជើង លាងភាជន៍សម្រាប់ផ្ទេរភត្ត ហើយយកទៅទុក រួចដាក់ទឹកផឹក ទឹកប្រើប្រាស់ បោសរោងភត្ត ភិក្ខុណាឃើញក្អមដាក់ទឹកផឹកក្តី ក្អមដាក់ទឹកប្រើប្រាស់ក្តី ក្អមទឹកសម្រាប់លាងវច្ចៈក្តី ដែលរលីងទទេ ភិក្ខុនោះក៏ដងយកមកដំកល់ទុក បើភិក្ខុនោះមិនអាច (នឹងធ្វើការនោះបាន) ព្រោះវិការនៃដៃ (ឈឺដៃជាដើម) ភិក្ខុនោះបក់ដៃហៅភិក្ខុទីពីរ ឲ្យដងយកមកដំកល់ទុក មិនបាច់បញ្ចេញវាចាព្រោះហេតុនោះឡើយ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើធ្វើយ៉ាងនេះហើយ យើងខ្ញុំក៏ព្រមព្រៀងគ្នា ស្រុសស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាជាសប្បាយ មួយវិញទៀត យើងខ្ញុំមិនលំបាក ដោយបិណ្ឌបាតឡើយ។

[២២] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាមោឃបុរសទាំងឡាយនេះ នៅ(ចាំវស្សា) មិនសប្បាយទេ (តែ) ប្តេជ្ញាថាខ្លួនជាអ្នកនៅដោយសប្បាយ ម្នាលភិក្ខុទាំងឡាយ ឮថាមោឃបុរសទាំងឡាយនេះនៅដូចជាការនៅរួមរបស់បសុសត្វ (សត្វចិញ្ចឹម) ហើយប្តេជ្ញាថា ខ្លួនជាអ្នកនៅសប្បាយ ម្នាលភិក្ខុទាំងឡាយ ឮថាមោឃបុរសទាំងឡាយនេះ នៅដូចជាការនៅរួមរបស់សត្វពពែ (តែ) ប្តេជ្ញាថាខ្លួនជាអ្នកនៅសប្បាយ ម្នាលភិក្ខុទាំងឡាយ ឮថាមោឃបុរសទាំងឡាយនេះនៅដូចជាការនៅរបស់បុគ្គលប្រមាទ (តែ) ប្តេជ្ញាថាខ្លួនជាអ្នកនៅដោយសប្បាយ ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងឡាយនេះ មិនសមបើនឹងសមាទានមូគវត្ត (វត្តរបស់មនុស្សគ) ដែលជាតិត្ថិយសមាទាន (សមាទានរបស់តិរ្ថិយ) ទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុសមាទានមូគវត្ត ដែលជាតិត្ថិយសមាទានទេ ភិក្ខុណាសមាទានត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយ ដែលនៅចាំវស្សារួចហើយ បវារណាដោយស្ថាន៣យ៉ាង គឺដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី។ បវារណានោះជាការអនុលោមដើម្បីពោលប្រដៅនូវគ្នានឹងគ្នា ជាការចេញចាកអាបត្តិ ជាការធ្វើវិន័យឲ្យជាប្រធាន នឹងប្រាកដដល់អ្នកទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ ត្រូវអ្នកទាំងឡាយបវារណាយ៉ាងនេះ។ ត្រូវភិក្ខុដែលឆ្លាសប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារណា។ បើបវារណាកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា។ ត្រូវភិក្ខុជាថេរៈធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា នែអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃ ជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម ត្រូវភិក្ខុខ្ចីវស្សាធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមបវារណានឹងសង្ឃជាគំរប់បីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោលចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម។

[២៣] សម័យនោះឯង កាលដែលភិក្ខុទាំងឡាយជាថេរៈកំពុងតែអង្គុយច្រហោង បវារណា ពួកឆព្វគ្គិយភិក្ខុក៏នៅលើអាសនៈទាំងឡាយ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀលបន្តុះបង្អាប់ថា កាលដែលភិក្ខុទាំងឡាយជាថេរៈកំពុងអង្គុយច្រហោង បវារណា មិនសមបើពួកឆព្វគ្គិយភិក្ខុហ៊ាននៅលើអាសនៈទាំងឡាយសោះ។ ទើបភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថាកាលដែលភិក្ខុទាំងឡាយជាថេរៈ កំពុងអង្គុយច្រហោងបវារណា ពួកឆព្វគ្គិយភិក្ខុ

នៅលើអាសនៈ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ការនោះពិតមែន។ ព្រះពុទ្ធមានព្រះភាគ ទ្រង់បន្ទោសថា ម្នាល ភិក្ខុទាំងឡាយ កាលដែលភិក្ខុទាំងឡាយជាថេរៈកំពុងអង្គុយច្រហោង បវារណា មោឃបុរសទាំងឡាយនោះមិនសមបើនឹងហ៊ាននៅលើអាសនៈ ទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុជាថេរៈទាំងឡាយកំពុងអង្គុយច្រហោង បវារណា ភិក្ខុមិនត្រូវនៅលើអាសនៈ ទាំងឡាយទេ ភិក្ខុណានៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងអស់នោះ អង្គុយច្រហោង ហើយបវារណា។ ក៏ សម័យនោះឯង ព្រះថេរៈមួយអង្គ ថយកំឡាំងដោយជរា កាលបើអង្គុយច្រហោង រង់ចាំទំរាំភិក្ខុទាំងឡាយបវារណាគ្រប់គ្នា ក៏ជ្រុលជ្រប់ដួលទៅ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអង្គុយ ច្រហោង ក្នុងពេលដែលខ្លួនកំពុងបវារណា លុះបវារណារួចហើយ ទើបអង្គុយលើអាសនៈបាន។

## ១២១. បវារណាភេទា

CS vin.mv.04.02 | ភាគ ទី៧

**(១២១)**

[២៤] លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា បវារណាមានប៉ុន្មានយ៉ាងហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះ មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បវារណាមានពីរយ៉ាង គឺចាតុទ្ទសិកាបវារណា[8] ១ បណ្ណរសិកាបវារណា[9] ១ ម្នាលភិក្ខុ ទាំងឡាយ បវារណាមានតែពីរយ៉ាងប៉ុណ្ណេះឯង។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា បវារណាកម្មមានប៉ុន្មានយ៉ាងហ្ន៎។ ភិក្ខុ ទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ បវារណាកម្មទាំងនេះមាន៤ គឺបវារណា កម្មជាពួក មិនត្រូវតាមធម៌១ បវារណាកម្មព្រមព្រៀងគ្នា តែមិនត្រូវតាមធម៌១ បវារណាកម្មជាពួក តែត្រូវតាមធម៌១ បវារណាកម្មព្រមព្រៀងគ្នា ត្រូវតាមធម៌១។ ម្នាលភិក្ខុទាំងឡាយ បវារណាកម្មទាំង៤នោះ បវារណាកម្មណាជាពួក តែមិនត្រូវតាមធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិន ត្រូវធ្វើបវារណាកម្មបែបនេះទេ ម្យ៉ាងទៀត តថាគតមិនអនុញ្ញាតបវារណាកម្មបែបនេះទេ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបវារណាកម្មទាំង៤នោះ បវារណាកម្មណាព្រមព្រៀងគ្នា តែមិនត្រូវតាមធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើបវារណាកម្មបែបនេះទេ ម្យ៉ាងទៀត តថាគតមិន អនុញ្ញាតបវារណាកម្មបែបនេះទេ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបវារណាកម្មទាំង៤នោះ បវារណាកម្មណាជាពួកតែត្រូវតាមធម៌ ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយមិនត្រូវធ្វើបវារណាកម្មបែបនេះទេ ម្យ៉ាងទៀត តថាគតមិនអនុញ្ញាតបវារណាកម្មបែបនេះទេ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបវារណាកម្មទាំង៤នោះ បវារណាកម្មណា ព្រមព្រៀងគ្នា ត្រូវតាមធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវធ្វើបវារណាកម្មបែបនេះចុះ តថាគតអនុញ្ញាតបវារណាកម្មបែបនេះ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាដូច្នេះថា បវារណាកម្មណាព្រម ព្រៀងគ្នាត្រូវតាមធម៌ យើងទាំងឡាយនឹងធ្វើបវារណាកម្មបែបនេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវតែសិក្សាយ៉ាងនេះឯង។

## ១២២. បវារណាទានានុជាននា

CS vin.mv.04.03 | ភាគ ទី៧

**(១២២)**

[២៥] គ្រានោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយប្រជុំគ្នាចុះ (ព្រោះ) សង្ឃនឹង បវារណា។ កាលបើព្រះមានព្រះភាគទ្រង់មានបន្ទូលយ៉ាងនេះហើយ ភិក្ខុមួយរូប បានក្រាបទូលព្រះមានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ ចំរើន នៅមានភិក្ខុឈឺ ភិក្ខុនោះមិនបានមក។ ព្រះមានព្រះភាគទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺឲ្យនូវបវារណា បាន។ ម្នាលភិក្ខុទាំងឡាយ ក៏ឯបវារណានោះត្រូវឲ្យយ៉ាងនេះ។ ត្រូវភិក្ខុឈឺនោះចូលទៅរកភិក្ខុមួយរូបធ្វើឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងភិក្ខុនោះថា ខ្ញុំសូមឲ្យបវារណា ចូរលោកនាំបវារណារបស់ខ្ញុំទៅ ចូរលោកបវារណាដើម្បីប្រយោជន៍ ដល់ខ្ញុំផង។ ភិក្ខុនោះបញ្ជាក់ (សេចក្តី) ដោយកាយ (ក្តី) បញ្ជាក់ដោយវាចា(ក្តី) បញ្ជាក់ដោយកាយ និងវាចា(ក្តី) ក៏ឈ្មោះថា ភិក្ខុនោះឲ្យបវារណា ហើយ។ (បើ) ភិក្ខុឈឺមិនបញ្ជាក់ដោយកាយ មិនបញ្ជាក់ដោយវាចា មិនបញ្ជាក់ដោយកាយ និងវាចាទេ មិនឈ្មោះថា ភិក្ខុឈឺនោះ ឲ្យបវារណា ឡើយ។ បើសង្ឃបាននូវការឲ្យបវារណានុ៎ះយ៉ាងនេះហើយ ការបាននុ៎ះ ជាការល្អ បើសង្ឃមិនបានទេ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវនាំភិក្ខុឈឺ នោះដោយគ្រែ ឬតាំងមកក្នុងទីជាកណ្តាលសង្ឃ ហើយសឹមបវារណា។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកភិក្ខុអ្នកបម្រើភិក្ខុឈឺមានសេចក្តីត្រិះរិះ យ៉ាងនេះថា បើយើងទាំងឡាយ ឲ្យភិក្ខុឈឺឃ្លាតចាកទី អាពាធនឹងរឹតតែចំរើន ឬនឹងធ្វើកាលកិរិយា (មិនខាន)។ ម្នាលភិក្ខុទាំងឡាយ សង្ឃមិន ត្រូវឲ្យភិក្ខុឈឺឃ្លាតចាកទីទេ ត្រូវសង្ឃទៅបវារណាក្នុងទីនោះ មិនត្រូវសង្ឃបវារណាជាពួកឡើយ បើបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុ ទាំងឡាយ កាលបើភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាចៀសចេញចាកទីនោះទៅ ត្រូវភិក្ខុនោះ ឲ្យបវារណាដល់ភិក្ខុដទៃ។ ម្នាលភិក្ខុ ទាំងឡាយ កាលបើភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាសឹកក្នុងថ្ងៃនោះឯង។បេ។ ស្លាប់ (ឬ) ប្តេជ្ញាខ្លួនជាសាមណេរ ប្តេជ្ញាខ្លួនជាអ្នក លាសិក្ខា ប្តេជ្ញាខ្លួនជាអ្នកត្រូវអន្តិមវត្ថុ ប្តេជ្ញាខ្លួនជាមនុស្សឆ្កួត ប្តេជ្ញាខ្លួនជាអ្នកមានចិត្តរវើរវាយ ប្តេជ្ញាខ្លួនជាអ្នកមានវេទនាគ្របសង្កត់ ប្តេជ្ញាខ្លួន ជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ប្តេជ្ញាខ្លួនជាអ្នកត្រូវសង្ឃលើកវត្តព្រោះមិនធ្វើតបអាបត្តិ (មិនសំដែងអាបត្តិ) ប្តេជ្ញាខ្លួនជាអ្នកត្រូវ សង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ប្តេជ្ញាខ្លួនជាបណ្ឌក ប្តេជ្ញាខ្លួនជាថេយ្យសំវាសក ប្តេជ្ញាខ្លួនជាអ្នកចូលទៅកាន់ពួកតិរ្ថិយ ប្តេជ្ញាខ្លួន ជាតិរច្ឆាន ប្តេជ្ញាខ្លួនជាអ្នកសំឡាប់មាតា ប្តេជ្ញាខ្លួនជាអ្នកសម្លាប់បិតា ប្តេជ្ញាខ្លួនជាអ្នកសំឡាប់ព្រះអរហន្ត ប្តេជ្ញាខ្លួនជាអ្នកទ្រុស្តភិក្ខុនី ប្តេជ្ញាខ្លួនជា អ្នកបំបែកសង្ឃ ប្តេជ្ញាខ្លួនជាអ្នកធ្វើព្រះលោហិតឲ្យពុរពងឡើង ប្តេជ្ញាខ្លួនជាមនុស្សមានភេទពីរ ត្រូវភិក្ខុនោះឲ្យបវារណាដល់ភិក្ខុដទៃ។ ម្នាលភិក្ខុ ទាំងឡាយ កាលដែលភិក្ខុឈឺ ឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាចៀសចេញទៅ ក្នុងពាក់កណ្តាលផ្លូវ មិនហៅថា បាននាំបវារណាមកដល់ ឡើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺ ឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណា សឹកត្រង់ពាក់កណ្តាលផ្លូវទៅ (ក្តី) ស្លាប់ទៅ(ក្តី)។បេ។ ប្តេជ្ញា ខ្លួនជាមនុស្សមានភេទពីរ (ក្តី) មិនហៅថា បាននាំបវារណាមកដល់ទេ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំ

បវារណា ទៅដល់សង្ឃហើយ ទើបបានចៀសចេញទៅ បវារណាឈ្មោះថា បាននាំមកដល់ហើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយ ទើបបានសឹក (ក្តី) ស្លាប់(ក្តី)។បេ។ ប្តេជ្ញាខ្លួនជាមនុស្សមានភេទពីរ (ក្តី) បវារណាឈ្មោះថា បាននាំមកដល់ហើយ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺ ឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយ ដេកលក់មិនបានប្រាប់ បវារណាឈ្មោះថា បាននាំមកដល់ហើយ ភិក្ខុអ្នកនាំបវារណាមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណា ទៅដល់សង្ឃហើយ ក៏ចូលសមាបត្តិទៅ មិនបានប្រាប់ បវារណាឈ្មោះថា បាននាំមកដល់ហើយ ភិក្ខុអ្នកនាំបវារណា មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយ ភ្លេចមិនបានប្រាប់ បវារណាឈ្មោះថា បាននាំមកដល់ហើយ ភិក្ខុអ្នកនាំបវារណា មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឈឺឲ្យបវារណាហើយ បើភិក្ខុអ្នកនាំបវារណាទៅដល់សង្ឃហើយ ក្លែងមិនប្រាប់ បវារណាឈ្មោះថា បាននាំមកដល់ហើយ (តែ) ភិក្ខុអ្នកនាំបវារណាត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ (បើ) សង្ឃមានកិច្ចត្រូវធ្វើ តថាគតអនុញ្ញាតឲ្យភិក្ខុកាលដែលឲ្យបវារណាហើយ ត្រូវឲ្យឆន្ទៈផង។

## ១២៣. ញាតកាទិគ្គហណកថា

CS vin.mv.04.04 | ភាគ ទី៧

**(១២៣)**

[២៦] ក៏សម័យនោះឯង ពួកញាតិចាប់ភិក្ខុមួយអង្គក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនោះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកជនជាញាតិចាប់ភិក្ខុក្នុងថ្ងៃបវារណានោះ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកជនជាញាតិនោះយ៉ាងនេះថា នែអ្នកដ៏មានអាយុទាំងឡាយ សូមអ្នកទាំងឡាយលែងភិក្ខុនេះមួយរំពេចសិន ទំរាំភិក្ខុនេះបវារណារួច។ បើសង្ឃបានសេចក្តីយល់ព្រមនុ៎ះដូច្នេះហើយ ការដែលបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកជនជាញាតិនោះយ៉ាងនេះថា នែអ្នកដ៏មានអាយុទាំងឡាយ សូមអ្នកទាំងឡាយនៅក្នុងទីដ៏សមគួរមួយរំពេចសិន ទំរាំភិក្ខុនេះឲ្យបវារណារួច។ បើសង្ឃបានសេចក្តីយល់ព្រមនុ៎ះដូច្នេះហើយ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកជនជាញាតិនោះយ៉ាងនេះថា នែអ្នកដ៏មានអាយុទាំងឡាយ សូមអ្នកទាំងឡាយនាំភិក្ខុនេះ ទៅកាន់ទីក្រៅសីមាមួយរំពេចសិន ទំរាំសង្ឃបវារណារួច។ បើសង្ឃបានសេចក្តីយល់ព្រមនុ៎ះដូច្នេះហើយ ការបាននុ៎ះ ជាការល្អ បើមិនបានទេ មិនត្រូវសង្ឃបវារណាដោយពួកឡើយ បើបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើស្តេចទាំងឡាយចាប់ភិក្ខុ(ក្តី) ពួកចោរចាប់ភិក្ខុ(ក្តី) ពួកអ្នកលេងចាប់ភិក្ខុ(ក្តី) ពួកភិក្ខុជាសត្រូវចាប់ភិក្ខុ (ក្តី) ក្នុងថ្ងៃបវារណានោះ។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកភិក្ខុជាសត្រូវទាំងនោះយ៉ាងនេះថា នែលោកដ៏មានអាយុទាំងឡាយ សូមអស់លោកទាំងឡាយលែងភិក្ខុនេះមួយរំពេចសិន ទំរាំភិក្ខុនេះបវារណារួច។ បើសង្ឃបានសេចក្តីយល់ព្រមនុ៎ះដូច្នេះហើយ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុជាសត្រូវទាំងនោះយ៉ាងនេះថា នែលោកដ៏មានអាយុទាំងឡាយ សូមលោកទាំងឡាយនៅក្នុងទីដ៏សមគួរមួយរំពេចសិន ទំរាំភិក្ខុនេះឲ្យបវារណារួច។ បើសង្ឃបានសេចក្តីយល់ព្រមនុ៎ះដូច្នេះហើយ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុទាំងឡាយនិយាយនឹងពួកភិក្ខុជាសត្រូវទាំងនោះយ៉ាងនេះថា នែលោកដ៏មានអាយុទាំងឡាយ សូមអស់លោកនាំភិក្ខុនេះទៅកាន់ទីក្រៅសីមាមួយរំពេចសិន ទំរាំសង្ឃបវារណារួច។ បើសង្ឃបានសេចក្តីយល់ព្រមនុ៎ះដូច្នេះហើយ ការបាននុ៎ះ ជាការល្អ បើមិនបានទេ មិនត្រូវសង្ឃបវារណាដោយពួកឡើយ បើបវារណា ត្រូវអាបត្តិទុក្កដ។

## ១២៤. សង្ឃបវារណាទិប្បភេទា

CS vin.mv.04.05 | ភាគ ទី៧

**(១២៤)**

[២៧] ក្នុងសម័យនោះឯង ភិក្ខុ៥រូបនៅក្នុងអាវាសមួយក្នុងថ្ងៃបវារណានោះ។ គ្រានោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគទ្រង់បញ្ញត្តហើយថា ត្រូវភិក្ខុបវារណាដោយសង្ឃបវារណា ក៏ឥឡូវនេះ យើងទាំងឡាយជាជន៥រូប តើត្រូវយើងទាំងឡាយបវារណាដូចម្តេច។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ៥រូប បវារណា ដោយសង្ឃបវារណា។ សម័យនោះឯង ភិក្ខុ៤រូប នៅក្នុងអាវាសមួយ ក្នុងថ្ងៃបវារណានោះ។ គ្រានោះ ភិក្ខុទាំងឡាយនោះមានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុ៥រូបបវារណា ដោយសង្ឃបវារណា ក៏ឥឡូវនេះ យើងទាំងឡាយជាជន៤រូប តើត្រូវយើងទាំងឡាយបវារណាដូចម្តេច ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ៤រូប បវារណា ដល់គ្នានឹងគ្នាបាន។ ម្នាលភិក្ខុទាំងឡាយ ត្រូវបវារណាយ៉ាងនេះ។ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យភិក្ខុទាំងឡាយនោះ យល់ថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារណា។ បើបវារណាកម្ម មានកាលគួរ ដល់លោកដ៏មានអាយុទាំងឡាយហើយ ត្រូវយើងទាំងឡាយបវារណាដល់គ្នានឹងគ្នា។ ត្រូវភិក្ខុជាថេរៈ ធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ហើយផ្គងអញ្ជលីឡើង រួចនិយាយនឹងភិក្ខុទាំងឡាយនោះយ៉ាងនេះថា នែអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(រំលឹក) ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ (ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ (រំលឹក)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម។ ត្រូវភិក្ខុខ្ចី ធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចនិយាយយ៉ាងនេះ នឹងភិក្ខុទាំងឡាយនោះថា បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ (ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់ពីរដងផង ដោយ

ឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ (ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ (ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម។ ក៏សម័យនោះឯង ភិក្ខុ៣រូប នៅក្នុងអាវាសមួយ ក្នុងថ្ងៃបវារណានោះ។ គ្រានោះ ភិក្ខុទាំងឡាយនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាត ឲ្យភិក្ខុ៥រូបបវារណា ដោយសង្ឃបវារណា ឲ្យភិក្ខុ៤រូប បវារណាដល់គ្នានឹងគ្នា ឥឡូវនេះ យើងទាំងឡាយជាជន៣រូប តើយើងទាំងឡាយត្រូវបវារណាដូចម្តេច។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ៣រូប បវារណាដល់គ្នានឹងគ្នាបាន។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយ បវារណាយ៉ាងនេះ។ ត្រូវភិក្ខុដែលឆ្លាសប្រតិពលឲ្យភិក្ខុទាំងឡាយនោះដឹងថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារណា។ បើបវារណាកម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយហើយ ត្រូវយើងទាំងឡាយបវារណាដល់គ្នានឹងគ្នា។ ត្រូវភិក្ខុជាថេរៈ ធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចនិយាយនឹងភិក្ខុទាំងឡាយនោះយ៉ាងនេះថា នែអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ (ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម។ ត្រូវភិក្ខុខ្ចី ធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចនិយាយយ៉ាងនេះនឹងភិក្ខុទាំងឡាយនោះថា បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយអាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុទាំងឡាយ ជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម។ ក៏សម័យនោះឯង ភិក្ខុពីររូប នៅក្នុងអាវាសមួយ ក្នុងថ្ងៃបវារណានោះ។ គ្រានោះ ភិក្ខុទាំងឡាយនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុ៥រូប បវារណាដោយសង្ឃបវារណា ឲ្យភិក្ខុ៤រូប បវារណាដល់គ្នានឹងគ្នា ឲ្យភិក្ខុ៣រូប បវារណាដល់គ្នានឹងគ្នា ឥឡូវនេះ យើងទាំងឡាយជាជនពីររូប តើយើងត្រូវបវារណាដូចម្តេច។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុពីររូប បវារណាដល់គ្នានឹងគ្នាបាន។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុបវារណាយ៉ាងនេះ។ ត្រូវភិក្ខុជាថេរៈ ធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចនិយាយយ៉ាងនេះ នឹងភិក្ខុខ្ចីថា នែអាវុសោ ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុ ជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ (ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម នែអាវុសោ ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុ ជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម។ ត្រូវភិក្ខុខ្ចី ធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចនិយាយយ៉ាងនេះនឹងភិក្ខុជាថេរៈថា បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណា នឹងលោកដ៏មានអាយុ ជាគំរប់ពីរដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម បពិត្រលោកដ៏ចំរើន ខ្ញុំសូមបវារណានឹងលោកដ៏មានអាយុ ជាគំរប់បីដងផង ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកដ៏មានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ (ដាស់តឿន)ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម។ ក៏សម័យនោះឯង ភិក្ខុមួយរូបនៅក្នុងអាវាសមួយ ក្នុងថ្ងៃបវារណានោះ។ ឯភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុ៥រូបបវារណា ដោយសង្ឃបវារណាឲ្យភិក្ខុ៤រូបបវារណា ដល់គ្នានឹងគ្នា ឲ្យភិក្ខុ៣រូប បវារណាដល់គ្នានឹងគ្នា ឲ្យភិក្ខុពីររូប បវារណាដល់គ្នានឹងគ្នា ឥឡូវនេះ អាត្មាអញតែម្នាក់ឯង គួរអាត្មាអញបវារណាដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ ភិក្ខុមួយរូប នៅក្នុងអាវាសមួយ ក្នុងថ្ងៃបវារណានោះ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុចៀសចេញទៅ អំពីប្រទេសណា គឺឧបដ្ឋានសាលា[10] ក្តី មណ្ឌបក្តី គល់ឈើក្តី ត្រូវភិក្ខុនោះ បោសប្រទេសនោះ ហើយដំកល់ទុកនូវទឹកឆាន់ ទឹកប្រើប្រាស់ ត្រូវក្រាលអាសនៈរួច អុជប្រទីប ហើយត្រូវអង្គុយចាំ។ បើមានភិក្ខុទាំងឡាយដទៃមក ត្រូវភិក្ខុនោះ បវារណាជាមួយនឹងភិក្ខុទាំងឡាយនោះចុះ បើគ្មានភិក្ខុទាំងឡាយមកទេ ត្រូវភិក្ខុនោះអធិដ្ឋានថា ថ្ងៃនេះជាថ្ងៃបវារណារបស់អញ បើមិនអធិដ្ឋានទេ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសណា១ ដែលមានភិក្ខុនៅ៥រូប ភិក្ខុ៤រូប មិនត្រូវនាំបវារណារបស់ភិក្ខុ១រូប ហើយបវារណាដោយសង្ឃបវារណាក្នុងអាវាសនោះទេ បើបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសណា១ ដែលមានភិក្ខុនៅ៤រូប ភិក្ខុ៣រូប មិនត្រូវនាំបវារណារបស់ភិក្ខុ១រូបមក ហើយបវារណាដល់គ្នានឹងគ្នា ក្នុងអាវាសនោះទេ បើបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសណា១ ដែលមានភិក្ខុនៅ៣រូប ភិក្ខុ២រូប មិនត្រូវនាំបវារណារបស់ភិក្ខុ១រូបមក ហើយបវារណាដល់គ្នានឹងគ្នា ក្នុងអាវាសនោះទេ បើបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអាវាសណា១ ដែលមានភិក្ខុនៅ២រូប ភិក្ខុ១រូប មិនត្រូវនាំបវារណារបស់ភិក្ខុ១រូបមក ហើយអធិដ្ឋានក្នុងអាវាសនោះទេ។ បើអធិដ្ឋាន ត្រូវអាបត្តិទុក្កដ។

## ១២៥. អាបត្តិបដិកម្មវិធិ

CS vin.mv.04.06 | ភាគ ទី៧

**(១២៥)**

[២៨] ក៏សម័យនោះឯង ភិក្ខុ១រូបត្រូវអាបត្តិក្នុងថ្ងៃបវារណានោះ។ ក៏ភិក្ខុនោះមានសេចក្ដីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយថា ភិក្ខុដែលមានអាបត្តិ មិនត្រូវបវារណាណាទេ ឥឡូវអាត្មាអញ ត្រូវអាបត្តិហើយ តើអាត្មាអញត្រូវប្រតិបត្តិដូចម្ដេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុ ត្រូវអាបត្តិ ក្នុងថ្ងៃបវារណានោះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះចូលទៅរកភិក្ខុ១រូប ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលី រួចនិយាយយ៉ាងនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិឈ្មោះនេះហើយ ខ្ញុំសូមសំដែងអាបត្តិនោះចេញ។ ត្រូវភិក្ខុអ្នកទទួលអាបត្តិនោះនិយាយថា លោកឃើញឬទេ។ ភិក្ខុអ្នកសំដែងនោះឆ្លើយថា អើខ្ញុំឃើញ។ ភិក្ខុអ្នកទទួលអាបត្តិត្រូវប្រាប់ថា ត្រូវលោកសង្រួមតទៅ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុសង្ស័យ នឹងអាបត្តិ ក្នុងថ្ងៃបវារណានោះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ ចូលទៅរកភិក្ខុ១រូប ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលី រួចនិយាយយ៉ាងនេះ នឹងភិក្ខុនោះថា នែអាវុសោ ខ្ញុំមានសេចក្ដីសង្ស័យនឹងអាបត្តិឈ្មោះនេះ កាលណាខ្ញុំអស់សេចក្ដីសង្ស័យ ខ្ញុំនឹងធ្វើតប (សំដែង) នូវអាបត្តិនោះ ក្នុងកាលនោះ លុះពោលដូច្នេះហើយ ត្រូវបវារណាចុះ។ មិនត្រូវភិក្ខុ ធ្វើនូវសេចក្ដីអន្តរាយដល់បវារណា ព្រោះហេតុប៉ុណ្ណោះទេ។

## ១២៦. អាបត្តិអាវិករណវិធិ

CS vin.mv.04.07 | ភាគ ទី៧

**(១២៦)**

ក៏សម័យនោះឯង ភិក្ខុ១រូប កំពុងតែបវារណា ក៏រលឹកឃើញអាបត្តិ។ ទើបភិក្ខុនោះ មានសេចក្ដីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយថា ភិក្ខុដែលមានអាបត្តិ មិនត្រូវបវារណាទេ ឥឡូវ អាត្មាអញ ត្រូវអាបត្តិហើយ តើអាត្មាអញ ត្រូវប្រតិបត្តិដូចម្ដេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុកំពុងតែបវារណា ក៏រលឹកឃើញអាបត្តិ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ និយាយយ៉ាងនេះ នឹងភិក្ខុជិតខាងថា នែអាវុសោ ខ្ញុំត្រូវអាបត្តិឈ្មោះនេះហើយ ខ្ញុំចេញពីទីនេះហើយ នឹងសំដែងអាបត្តិនោះចេញ លុះពោលដូច្នេះហើយ ត្រូវបវារណាចុះ។ មិនត្រូវភិក្ខុធ្វើនូវសេចក្ដីអន្តរាយដល់បវារណាព្រោះហេតុប៉ុណ្ណោះទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុកំពុងតែបវារណា ហើយមានសេចក្ដីសង្ស័យនឹងអាបត្តិ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ និយាយយ៉ាងនេះ នឹងភិក្ខុជិតខាងថា នែអាវុសោ ខ្ញុំមានសេចក្ដីសង្ស័យ នឹងអាបត្តិឈ្មោះនេះ កាលណា ខ្ញុំអស់សេចក្ដីសង្ស័យ ខ្ញុំនឹងសំដែងអាបត្តិនោះចេញ ក្នុងកាលនោះ លុះពោលដូច្នេះហើយ ត្រូវបវារណាចុះ។ មិនត្រូវភិក្ខុធ្វើសេចក្ដីអន្តរាយដល់បវារណាព្រោះហេតុប៉ុណ្ណោះទេ។

## ១២៧. សភាគាបត្តិបដិកម្មវិធិ

CS vin.mv.04.08 | ភាគ ទី៧

**(១២៧)**

ក៏សម័យនោះឯង សង្ឃទាំងអស់ក្នុងអាវាស១ ត្រូវសភាគាបត្តិ (អាបត្តិដូចគ្នា) ក្នុងថ្ងៃបវារណានោះ។ ក៏ភិក្ខុទាំងឡាយនោះ មានសេចក្ដីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយថា ភិក្ខុមិនត្រូវសំដែងសភាគាបត្តិ មិនត្រូវទទួលសភាគាបត្តិ (នឹងគ្នាទេ) ឥឡូវសង្ឃនេះ សុទ្ធតែត្រូវសភាគាបត្តិហើយ តើយើងទាំងឡាយត្រូវប្រតិបត្តិដូចម្ដេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើសង្ឃទាំងអស់ក្នុងអាវាសមួយ ត្រូវសភាគាបត្តិ ក្នុងថ្ងៃបវារណានោះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បញ្ជូនភិក្ខុ១រូប ទៅកាន់អាវាសជិតខាង ក្នុងថ្ងៃនោះថា នែអាវុសោ ចូរលោកទៅសំដែងអាបត្តិនោះ ហើយមកវិញ យើងទាំងឡាយនឹងសំដែងអាបត្តិនោះ ក្នុងសំណាក់លោក។ បើសង្ឃបានការសំដែងអាបត្តិនុ៎ះដូច្នេះហើយ ការបាននុ៎ះជាការល្អ បើមិនបានទេ ត្រូវភិក្ខុដែលឆ្លាសប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ (ដ្បិត) សង្ឃទាំងអស់នេះត្រូវសភាគាបត្តិហើយ កាលបើសង្ឃឃើញភិក្ខុដទៃបរិសុទ្ធ មិនមានអាបត្តិ សង្ឃនឹងសំដែងអាបត្តិនោះ ក្នុងសំណាក់ភិក្ខុនោះកាលនោះ លុះពោលដូច្នេះហើយ ត្រូវបវារណាចុះ។ មិនត្រូវសង្ឃធ្វើសេចក្ដីអន្តរាយដល់បវារណាព្រោះហេតុប៉ុណ្ណោះទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើសង្ឃទាំងអស់ក្នុងអាវាសមួយ មានសេចក្ដីសង្ស័យនឹងសភាគាបត្តិ ក្នុងថ្ងៃបវារណានោះ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ សង្ឃទាំងអស់នេះ មានសេចក្ដីសង្ស័យ ក្នុងសភាគាបត្តិ កាលណាសង្ឃអស់សេចក្ដីសង្ស័យ សង្ឃនឹងសំដែងអាបត្តិនោះចេញ កាលនោះ លុះពោលដូច្នេះហើយ ត្រូវបវារណាចុះ។ មិនត្រូវសង្ឃធ្វើសេចក្ដីអន្តរាយដល់បវារណា ព្រោះហេតុប៉ុណ្ណោះទេ។

ចប់ បឋមភាណវារៈ។

## ១២៨. អនាបត្តិបន្នរសកំ

CS vin.mv.04.09 | ភាគ ទី៧

**(១២៨)**

[២៩] ក៏សម័យនោះឯង ពួកអាវាសិកភិក្ខុ (អ្នកនៅក្នុងអាវាស) ជាច្រើនប្រមាណ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងអាវាសមួយ ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ មិនដឹងថាមានពួកអាវាសិកភិក្ខុរូបឯទៀតមិនទាន់មកដល់។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថា ព្រមព្រៀងគ្នា ហើយបវារណា។ កាលដែលភិក្ខុទាំងឡាយនោះ កំពុងបវារណា ស្រាប់តែមានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសមួយ មានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ មិនដឹងថា

មានពួកអាវាសិកភិក្ខុដទៃ មិនទាន់មកដល់។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថា ព្រមព្រៀង ហើយ ក៏នាំគ្នាបវារណា។ កាលដែលភិក្ខុទាំងនោះ កំពុងបវារណា ស្រាប់តែមានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បវារណាម្តងទៀត។ ភិក្ខុទាំងឡាយ ដែលបវារណាហើយ មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ មិនដឹងថា មានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ ភិក្ខុទាំងនោះ សំគាល់ថាជាធម៌ ថាជាវិន័យ ជាពួកទេ តែសំគាល់ថា ព្រមព្រៀង ក៏នាំគ្នាបវារណាទៅ។ កាលដែលភិក្ខុទាំងនោះ កំពុងបវារណា ស្រាប់តែមានពួកអាវាសិកភិក្ខុឯទៀត ស្មើៗគ្នាមកដល់។ ភិក្ខុទាំងឡាយ ដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ត្រូវតែភិក្ខុទាំងឡាយ ដែលនៅសល់អំពីនោះ បវារណា ពួកភិក្ខុ ដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើនគឺ ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ មិនដឹងថាមានពួកអាវាសិកភិក្ខុដឯទៀតមិនទាន់មកដល់។ ភិក្ខុទាំងនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងហើយ ក៏បវារណាទៅ។ កាលដែលភិក្ខុទាំងនោះ កំពុងបវារណា ស្រាប់តែមានពួកអាវាសិកភិក្ខុឯទៀត តិចជាងមកដល់។ ភិក្ខុដែលបានបវារណាហើយ ក៏ឈ្មោះថា បវារណាល្អហើយ ត្រូវពួកភិក្ខុ ដែលនៅសល់អំពីនោះ បវារណា ភិក្ខុទាំងឡាយដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ មិនដឹងថាមានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ ភិក្ខុទាំងឡាយនោះ ក៏សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថា ព្រមព្រៀង ហើយបវារណាទៅ។ កាលដែលភិក្ខុទាំងនោះ ទើបតែនឹងបវារណារួច ក៏មានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះ បវារណាម្តងទៀត ភិក្ខុដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។បេ។ ក៏មានពួកអាវាសិកភិក្ខុចំនួនស្មើៗគ្នាមកដល់។ ភិក្ខុទាំងឡាយ ដែលបានបវារណាហើយ ក៏ឈ្មោះថា បវារណាដោយល្អ ត្រូវពួកអាវាសិកភិក្ខុឯទៀត បវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ភិក្ខុដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។បេ។ ក៏មានពួកអាវាសិកភិក្ខុឯទៀតតិចជាងមកដល់។ ពួកភិក្ខុដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ត្រូវ (ពួកភិក្ខុដែលមកក្រោយ) បវារណាក្នុងសំណាក់ភិក្ខុទាំងឡាយ (ដែលបវារណាហើយ) នោះចុះ ភិក្ខុដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ មិនដឹងថា មានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ ភិក្ខុទាំងនោះ ក៏សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថា ព្រមព្រៀង ហើយបវារណាទៅ។ កាលដែលភិក្ខុទាំងឡាយនោះ ទើបតែនឹងបវារណារួច ភិក្ខុបរិសទ្យមិនទាន់ក្រោយចេញនៅឡើយ ក៏ពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បវារណាម្តងទៀត។ ពួកភិក្ខុ ដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។បេ។ ក៏មានពួកអាវាសិកភិក្ខុឯទៀត ចំនួនស្មើៗគ្នាមកដល់។បេ។ តិចជាង។ ភិក្ខុទាំងឡាយ ដែលបានបវារណាហើយ ឈ្មោះថា បវារណាល្អហើយ (ពួកភិក្ខុដែលមិនទាន់បវារណា) ត្រូវបវារណា ក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ពួកភិក្ខុ ដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ មិនដឹងជាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់។ ភិក្ខុទាំងនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថា ព្រមព្រៀងហើយ ក៏បវារណាទៅ។ កាលដែលភិក្ខុទាំងឡាយនោះ ទើបតែនឹងបវារណារួច ភិក្ខុបរិសទ្យពួកខ្លះ ក្រោកចេញទៅហើយ ក៏មានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បវារណាម្តងទៀត ពួកភិក្ខុដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។បេ។ ក៏មានពួកអាវាសិកភិក្ខុឯទៀត ស្មើៗគ្នាមកដល់។បេ។ តិចជាង។ ភិក្ខុដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ភិក្ខុ(ដែលមិនទាន់បវារណា) ត្រូវបវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ភិក្ខុទាំងឡាយ ដែលបានបវារណាហើយ មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ មិនដឹងថា មានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ ភិក្ខុទាំងនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថា ព្រមព្រៀងហើយ ក៏បវារណាទៅ។ កាលដែលភិក្ខុទាំងនោះ ទើបតែនឹងបវារណារួច ភិក្ខុបរិសទ្យទាំងអស់ ក្រោកចេញហើយ ក៏មានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បវារណាម្តងទៀតចុះ ភិក្ខុទាំងឡាយដែលបវារណាហើយ មិនត្រូវអាបត្តិទេ។បេ។ ក៏មានពួកអាវាសិកភិក្ខុឯទៀត ស្មើៗគ្នាមកដល់។បេ។ តិចជាង។ ភិក្ខុដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ភិក្ខុ(ដែលមិនទាន់បវារណា) ត្រូវបវារណា ក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ភិក្ខុដែលបវារណាហើយ មិនត្រូវអាបត្តិទេ។

ចប់ រឿងភិក្ខុបវារណាមិនត្រូវអាបត្តិ មាន១៥យ៉ាង។

## ១២៩. វគ្គាវគ្គសញ្ញីបន្នរសកំ

CS vin.mv.04.10 | ភាគ ទី៧

**(១២៩)**

[៣០] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុ ជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងឡាយនោះ ដឹងថាមានពួកអាវាសិកភិក្ខុឯទៀត មកមិនទាន់ដល់។ ភិក្ខុទាំងឡាយនោះ សំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ ជាពួកទេ តែសំគាល់ថាព្រមព្រៀងគ្នា ហើយក៏បវារណាទៅ។ កាលភិក្ខុទាំងឡាយនោះកំពុងបវារណា ក៏មានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បវារណាម្តងទៀត។ ភិក្ខុដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។បេ។ ក៏មានពួកអាវាសិកភិក្ខុឯទៀត ស្មើៗគ្នាមកដល់។បេ។ តិចជាង។ ភិក្ខុទាំងឡាយដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណា ដោយល្អហើយ ត្រូវភិក្ខុដែលនៅសល់អំពីនោះ បវារណាចុះ ពួកភិក្ខុដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងឡាយនោះដឹងថា មានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ ភិក្ខុទាំងឡាយនោះសំគាល់ថា ជាធម៌ សំគាល់ថា ជាវិន័យ ជាពួកទេ តែសំគាល់ថា ព្រមព្រៀង ហើយក៏បវារណាទៅ។

កាលដែលភិក្ខុទាំងនោះ ទើបតែនឹងបវារណារួច។បេ។ ភិក្ខុបរិសទ្យមិនទាន់ក្រោក ភិក្ខុបរិសទ្យពួកខ្លះក្រោកហើយ ភិក្ខុបរិសទ្យទាំងអស់ ក្រោកចេញហើយ ទើបមានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាង មកដល់។បេ។ ស្មើៗគ្នា។បេ។ តិចជាង។ ពួកភិក្ខុដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ពួកភិក្ខុ(ដែលមិនទាន់បវារណា) ត្រូវបវារណាក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ពួកភិក្ខុ ដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។

ចប់ រឿងពួកភិក្ខុជាពួក តែសំគាល់ថា ព្រមព្រៀងគ្នា មាន១៥យ៉ាង។

## ១៣០. វេមតិកបន្នរសកំ

CS vin.mv.04.11 | ភាគ ទី៧

**(១៣០)**

[៣១] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នាក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងឡាយនោះដឹងថា មានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់។ ពួកភិក្ខុទាំងឡាយនោះមានសេចក្តីសង្ស័យដូច្នេះថា គួរយើងទាំងឡាយបវារណា ឬមិនគួរទេ (ហើយក៏នាំគ្នា) បវារណាទៅ។ កាលដែលភិក្ខុទាំងឡាយនោះ កំពុងតែបវារណា ក៏មានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បវារណាម្តងទៀត ពួកភិក្ខុ ដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។បេ។ ក៏មានពួកអាវាសិកភិក្ខុឯទៀត ស្មើៗគ្នាមកដល់។បេ។ តិចជាង។ ពួកភិក្ខុ ដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ត្រូវពួកភិក្ខុដែលនៅសល់អំពីនោះ បវារណាចុះ ពួកភិក្ខុដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ ដឹងថាមានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ តែពួកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យថា គួរយើងទាំងឡាយបវារណា ឬមិនគួរទេ (ហើយក៏នាំគ្នា) បវារណាទៅ។ កាលដែលពួកភិក្ខុទាំងនោះ ទើបតែនឹងបវារណាហើយ។បេ។ ភិក្ខុបរិសទ្យមិនទាន់ក្រោកចេញ ភិក្ខុបរិសទ្យពួកខ្លះក្រោកចេញហើយ ភិក្ខុបរិសទ្យទាំងអស់ក្រោកចេញហើយ ទើបមានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។បេ។ ស្មើៗគ្នា។បេ។ តិចជាង។ ពួកភិក្ខុ ដែលបវារណាហើយ ឈ្មោះថា បានបវារណាល្អហើយ ពួកភិក្ខុ (ដែលមិនទាន់បវារណា) ត្រូវបវារណា ក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ពួកភិក្ខុ ដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។

ចប់ រឿងពួកភិក្ខុមានសេចក្តីសង្ស័យ មាន១៥យ៉ាង។

## ១៣១. កុក្កុច្ចបកតបន្នរសកំ

CS vin.mv.04.12 | ភាគ ទី៧

**(១៣១)**

[៣២] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ ដឹងថា មានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ ភិក្ខុទាំងនោះ មានសេចក្តីរង្កៀសថា យើងទាំងឡាយគួរតែបវារណា មិនមែនថា យើងមិនគួរបវារណាទេ ដូច្នេះហើយ ក៏បវារណាទៅ។ កាលដែលភិក្ខុទាំងឡាយនោះកំពុងតែបវារណា ទើបមានអាវាសិកភិក្ខុឯទៀតច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុទាំងនោះបវារណាម្តងទៀត ឯពួកភិក្ខុដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។បេ។ ទើបមានពួកអាវាសិកភិក្ខុឯទៀត ស្មើៗគ្នាមកដល់។បេ។ តិចជាង។ ពួកភិក្ខុដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ត្រូវតែពួកភិក្ខុ ដែលនៅសល់អំពីនោះ បវារណាចុះ ពួកភិក្ខុ ដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងនោះ ដឹងថាមានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ ភិក្ខុទាំងនោះ មានសេចក្តីរង្កៀសថា យើងទាំងឡាយ គួរតែបវារណា មិនមែនថាយើងទាំងឡាយ មិនគួរបវារណាទេដូច្នេះ ហើយក៏បវារណាទៅ។ កាលដែលភិក្ខុទាំងឡាយនោះ ទើបតែនឹងបវារណាហើយ។បេ។ ភិក្ខុបរិសទ្យមិនទាន់ក្រោកចេញ ភិក្ខុបរិសទ្យពួកខ្លះក្រោកចេញទៅហើយ ភិក្ខុបរិសទ្យទាំងអស់ ក្រោកចេញទៅហើយ ទើបមានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។បេ។ ស្មើៗគ្នា។បេ។ តិចជាង។ ពួកភិក្ខុ ដែលបវារណាហើយ ក៏ ឈ្មោះថាបានបវារណាល្អហើយ ពួកភិក្ខុ (ដែលមិនទាន់បានបវារណា) ត្រូវបវារណា ក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ភិក្ខុដែលបវារណាហើយ ត្រូវអាបត្តិទុក្កដ។

ចប់ រឿងពួកភិក្ខុមានសេចក្តីរង្កៀស មាន១៥យ៉ាង។

## ១៣២. ភេទបុរេក្ខារបន្នរសកំ

CS vin.mv.04.13 | ភាគ ទី៧

**(១៣២)**

[៣៣] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានអាវាសិកភិក្ខុទាំងឡាយជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងឡាយនោះ ដឹងថាមានពួកអាវាសិកភិក្ខុឯទៀត មិនទាន់មកដល់។ ភិក្ខុទាំងឡាយនោះមានបំណងនឹងបំបែកសង្ឃថា ភិក្ខុទាំងឡាយនុ៎ះ ចូរបាត់ទៅចុះ ភិក្ខុទាំងឡាយនុ៎ះ ចូរវិនាសទៅចុះ ប្រយោជន៍អ្វី ដោយភិក្ខុទាំងឡាយនោះ ដូច្នេះហើយ ក៏បវារណា

ទៅ។ កាលបើភិក្ខុទាំងនោះ កំពុងបវារណា ទើបមានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បវារណាម្តងទៀត ពួកភិក្ខុ ដែលបានបវារណាហើយ ត្រូវអាបត្តិថុល្លច្ច័យ។បេ។ ទើបមានពួកអាវាសិកភិក្ខុឯទៀត ស្មើៗគ្នាមកដល់។បេ។ តិចជាង។ ពួកភិក្ខុ ដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ត្រូវតែពួកភិក្ខុ ដែលនៅសល់អំពីនោះ បវារណាចុះ ពួកភិក្ខុ ដែលបានបវារណាហើយ ត្រូវអាបត្តិថុល្លច្ច័យ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងឡាយនោះ ដឹងថាមានពួកអាវាសិកភិក្ខុឯទៀតមិនទាន់មកដល់។ (តែ) ពួកភិក្ខុទាំងនោះមានបំណងនឹងបំបែកសង្ឃថា ភិក្ខុទាំងឡាយនុ៎ះ ចូរបាត់ទៅចុះ ភិក្ខុទាំងឡាយនុ៎ះ ចូរវិនាសទៅចុះ ត្រូវការអ្វីដោយភិក្ខុទាំងឡាយនោះ ដូច្នេះហើយ ក៏បវារណាទៅ។ កាលបើភិក្ខុទាំងឡាយនោះ ទើបតែនឹងបវារណាហើយ។បេ។ ភិក្ខុបរិសទ្យ មិនទាន់ក្រោកចេញ ភិក្ខុបរិសទ្យពួកខ្លះ ក្រោកចេញហើយ ភិក្ខុបរិសទ្យទាំងអស់ ក្រោកចេញហើយ ទើបមានពួកអាវាសិកភិក្ខុឯទៀត ច្រើនជាងមកដល់។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះ បវារណាម្តងទៀត ពួកភិក្ខុ ដែលបានបវារណាហើយ ត្រូវអាបត្តិថុល្លច្ច័យ។បេ។ ទើបមានពួកអាវាសិកភិក្ខុឯទៀត ស្មើៗគ្នាមកដល់។បេ។ តិចជាង។ ពួកភិក្ខុដែលបវារណាហើយ ក៏ឈ្មោះថា បានបវារណាល្អហើយ ត្រូវភិក្ខុទាំងឡាយនោះ បវារណា ក្នុងសំណាក់ភិក្ខុទាំងឡាយនោះចុះ ពួកភិក្ខុដែលបានបវារណាហើយ ត្រូវអាបត្តិថុល្លច្ច័យ។

ចប់ រឿងពួកភិក្ខុមានបំណងនឹងបំបែកសង្ឃ មាន១៥យ៉ាង។

## ១៣៣. សីមោក្កន្តិកបេយ្យាលំ

CS vin.mv.04.14 | ភាគ ទី៧

**(១៣៣)**

[៣៤] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកអាវាសិកភិក្ខុជាច្រើន គឺ៥រូប ឬជាង៥រូបឡើងទៅ ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងឡាយនោះមិនដឹងជា មានពួកអាវាសិកភិក្ខុឯទៀត កំពុងដើរចូលមកដល់ខាងក្នុងសីមា។បេ។ ភិក្ខុទាំងឡាយនោះមិនដឹងថា មានពួកអាវាសិកភិក្ខុឯទៀត ដើរចូលមកដល់ខាងក្នុងសីមា។បេ។ ភិក្ខុទាំងឡាយនោះ មិនឃើញពួកអាវាសិកភិក្ខុឯទៀត កំពុងដើរចូលមកដល់ខាងក្នុងសីមា។បេ។ ភិក្ខុទាំងឡាយនោះ មិនឃើញពួកអាវាសិកភិក្ខុឯទៀត បានដើរចូលមកដល់ ខាងក្នុងសីមា។បេ។ ពួកភិក្ខុទាំងនោះ មិនឮថា ពួកអាវាសិកភិក្ខុឯទៀត កំពុងដើរចូលមកខាងក្នុងសីមា។បេ។ ពួកភិក្ខុទាំងនោះ មិនឮថា ពួកអាវាសិកភិក្ខុឯទៀត បានដើរចូលមកខាងក្នុងសីមា។ ពួកអាវាសិកភិក្ខុ និងអាវាសិកភិក្ខុមានន័យ១៧៥តិក ពួកអាគន្តុកភិក្ខុ និងអាវាសិកភិក្ខុមានន័យ១៧៥តិក ពួកអាវាសិកភិក្ខុ និងអាគន្តុកភិក្ខុមានន័យ១៧៥តិក ពួកអាគន្តុកភិក្ខុ និងអាគន្តុកភិក្ខុមានន័យ១៧៥តិក ត្រូវជា៧០០តិក តាមរបៀបបេយ្យាលមុខ។

## ១៣៤. ទិវសនានត្តំ

CS vin.mv.04.15 | ភាគ ទី៧

**(១៣៤)**

[៣៥] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកអាវាសិកភិក្ខុ ប្រកាន់ថា ថ្ងៃ១៤ ពួកអាគន្តុកភិក្ខុ ប្រកាន់ថា ថ្ងៃ១៥។ បើពួកអាវាសិកភិក្ខុច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុ ប្រព្រឹត្តតាមអាវាសិកភិក្ខុ។ បើមានចំនួនស្មើៗគ្នាទេ ត្រូវពួកអាគន្តុកភិក្ខុ ប្រព្រឹត្តតាមពួកអាវាសិកភិក្ខុវិញ។ បើពួកអាគន្តុកភិក្ខុ មានចំនួនច្រើនជាង ត្រូវពួកអាវាសិកភិក្ខុប្រព្រឹត្តតាមពួកអាគន្តុកភិក្ខុចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកអាវាសិកភិក្ខុ យល់ថាថ្ងៃ១៥ ពួកអាគន្តុកភិក្ខុយល់ថា ថ្ងៃ១៤។ បើពួកអាវាសិកភិក្ខុ មានចំនួនច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុ ប្រព្រឹត្តតាមពួកអាវាសិកភិក្ខុ។ បើចំនួនស្មើៗគ្នាទេ ត្រូវពួកអាគន្តុកភិក្ខុ ប្រព្រឹត្តតាមពួកអាវាសិកភិក្ខុវិញ។ បើពួកអាគន្តុកភិក្ខុ មានចំនួនច្រើនជាង ត្រូវពួកអាវាសិកភិក្ខុ ប្រព្រឹត្តតាមពួកអាគន្តុកភិក្ខុចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ យល់ថាថ្ងៃ១កើត ឬ១រោច ពួកអាគន្តុកភិក្ខុយល់ថា ថ្ងៃ១៥។ បើពួកអាវាសិកភិក្ខុ មានចំនួនច្រើនជាង មិនត្រូវពួកអាវាសិកភិក្ខុ ឲ្យសាមគ្គីដល់ពួកអាគន្តុកភិក្ខុទេ ត្រូវពួកអាគន្តុកភិក្ខុ ទៅកាន់ទីក្រៅសីមា ហើយបវារណាចុះ។ បើស្មើៗគ្នាទេ មិនត្រូវពួកអាវាសិកភិក្ខុ ឲ្យសាមគ្គី ដល់ពួកអាគន្តុកភិក្ខុឡើយ ត្រូវពួកអាគន្តុកភិក្ខុ ទៅកាន់ទីក្រៅសីមា ហើយបវារណាចុះ។ បើពួកអាគន្តុកភិក្ខុច្រើនជាង ត្រូវពួកអាវាសិកភិក្ខុ ឲ្យសាមគ្គីដល់ពួកអាគន្តុកភិក្ខុ ឬត្រូវទៅកាន់ទីក្រៅសីមា។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ យល់ថាថ្ងៃ១៥ ពួកអាគន្តុកភិក្ខុ យល់ថាថ្ងៃ១កើត ឬ១រោច។ បើពួកអាវាសិកភិក្ខុច្រើនជាង ត្រូវពួកអាគន្តុកភិក្ខុ ឲ្យសាមគ្គី ដល់អាវាសិកភិក្ខុ ឬត្រូវទៅកាន់ទីក្រៅសីមា។ បើពួកភិក្ខុទាំងនោះ ស្មើៗគ្នាទេ ត្រូវពួកអាគន្តុកភិក្ខុ ឲ្យសាមគ្គីដល់ពួកអាវាសិកភិក្ខុ ឬត្រូវទៅកាន់ទីក្រៅសីមា។ បើពួកអាគន្តុកភិក្ខុច្រើនជាង មិនត្រូវពួកអាគន្តុកភិក្ខុ ឲ្យសាមគ្គីដល់ពួកអាវាសិកភិក្ខុឡើយ ត្រូវពួកអាវាសិកភិក្ខុ ទៅកាន់ទីក្រៅសីមា ហើយបវារណាចុះ។

## ១៣៥. លិង្គាទិទស្សនំ

CS vin.mv.04.16 | ភាគ ទី៧

**(១៣៥)**

[៣៦] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុ ឃើញអាការរបស់អាវាសិកភិក្ខុ ភេទរបស់អាវាសិកភិក្ខុ និមិត្តរបស់អាវាសិកភិក្ខុ ឧទ្ទេស របស់អាវាសិកភិក្ខុ គ្រែ និងតាំង ពូក និងខ្នើយ ដែលពួកអាវាសិកភិក្ខុ លាតក្រាលដោយល្អហើយ ទឹកឆាន់ ទឹកប្រើដែលពួកអាវាសិកភិក្ខុ ដម្កល់ល្អហើយ បរិវេណ ដែលពួកអាវាសិកភិក្ខុ បោសស្អាតហើយ។ លុះឃើញហើយ ក៏មានសេចក្តីសង្ស័យថា មានពួកអាវាសិកភិក្ខុ ឬគ្មានទេ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ មិនពិនិត្យ គយគន់មើល លុះមិនពិនិត្យហើយ ក៏បវារណា ត្រូវអាបត្តិទុក្កដ។បេ។

ពួកអាគន្តុកភិក្ខុទាំងនោះសង្ស័យ ហើយក៏ពិនិត្យ លុះពិនិត្យហើយ មិនឃើញ លុះមិនឃើញហើយ ក៏បវារណា មិនត្រូវអាបត្តិទេ។ ពួកអាគន្តុកភិក្ខុទាំងនោះសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យហើយឃើញ លុះឃើញហើយ ក៏បវារណាជាមួយគ្នា មិនត្រូវអាបត្តិទេ។ ពួកអាគន្តុកភិក្ខុទាំងនោះសង្ស័យ ហើយក៏ពិនិត្យ លុះពិនិត្យហើយឃើញ លុះឃើញហើយ ក៏បវារណាផ្សេងៗគ្នា ត្រូវអាបត្តិទុក្កដ។ អាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យមើល ក៏ឃើញ លុះឃើញហើយ ក៏មានបំណងនឹងបំបែកសង្ឃដោយគិតថា ពួកភិក្ខុទាំងនុ៎ះ ចូរបាត់ទៅ ពួកភិក្ខុទាំងនុ៎ះ ចូរវិនាសទៅ ត្រូវការអ្វី ដោយពួកភិក្ខុទាំងនោះ ហើយក៏បវារណា ត្រូវអាបត្តិថុល្លច្ច័យ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាគន្តុកភិក្ខុ ឮអាការរបស់អាវាសិកភិក្ខុ ភេទរបស់អាវាសិកភិក្ខុ និមិត្តរបស់អាវាសិកភិក្ខុ ឧទ្ទេសរបស់អាវាសិកភិក្ខុ សូរជើងរបស់ពួកអាវាសិកភិក្ខុ កំពុងចង្ក្រម សំឡេងស្វាធ្យាយ (សូត្រធម៌) សំឡេងក្អក សំឡេងកណ្តាស់ របស់ពួកអាវាសិកភិក្ខុ។ លុះឮហើយ មានសេចក្តីសង្ស័យថា មានពួកអាវាសិកភិក្ខុ ឬគ្មានទេ។ ពួកអាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយមិនពិនិត្យមើល លុះមិនពិនិត្យហើយ ក៏បវារណាទៅ ត្រូវអាបត្តិទុក្កដ។បេ។ ពួកអាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យហើយមិនឃើញ លុះមិនឃើញហើយ ក៏បវារណាទៅ មិនត្រូវអាបត្តិទេ។ ពួកអាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យមើលហើយ ក៏ឃើញ លុះឃើញហើយ ក៏បវារណាជាមួយគ្នា មិនត្រូវអាបត្តិទេ។ ពួកអាគន្តុកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយក៏ពិនិត្យមើល លុះពិនិត្យមើលហើយ ក៏ឃើញ លុះឃើញហើយ ក៏បវារណាផ្សេងៗគ្នា ត្រូវអាបត្តិទុក្កដ។ ពួកអាគន្តុកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យមើល ហើយឃើញ លុះឃើញហើយ មានបំណងនឹងបំបែកសង្ឃ ដោយគិតថា ពួកលោកទាំងនុ៎ះ បាត់ទៅចុះ ចូរលោកទាំងនុ៎ះ វិនាសទៅចុះ ត្រូវការអ្វី ដោយភិក្ខុទាំងនោះ ដូច្នេះហើយ ក៏បវារណា ត្រូវអាបត្តិថុល្លច្ច័យ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ ឃើញអាការរបស់អាគន្តុកភិក្ខុ ភេទរបស់អាគន្តុកភិក្ខុ និមិត្តរបស់អាគន្តុកភិក្ខុ ឧទ្ទេសរបស់អាគន្តុកភិក្ខុ បាត្រដែលខ្លួនមិនស្គាល់ ចីវរដែលខ្លួនមិនស្គាល់ សំពត់និសីទនៈដែលខ្លួនមិនស្គាល់ ស្នាមដែលស្រោចទឹកលាងជើងរបស់ពួកអាគន្តុកភិក្ខុ។ លុះឃើញហើយ ក៏មានសេចក្តីសង្ស័យថា មានពួកអាគន្តុកភិក្ខុ ឬគ្មានទេ។ ពួកអាវាសិកទាំងនោះ មានសេចក្តីសង្ស័យ ហើយមិនពិនិត្យមើល លុះមិនពិនិត្យមើលហើយ ក៏បវារណា ត្រូវអាបត្តិទុក្កដ។បេ។ ពួកអាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយក៏ពិនិត្យមើល លុះពិនិត្យមើលហើយមិនឃើញ លុះមិនឃើញហើយ ក៏បវារណា មិនត្រូវអាបត្តិទេ។ ពួកអាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយក៏ពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយ បវារណាជាមួយគ្នា មិនត្រូវអាបត្តិទេ។ ពួកអាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ទើបពិនិត្យមើល លុះពិនិត្យហើយឃើញ លុះឃើញហើយ ក៏បវារណាញែកគ្នា ត្រូវអាបត្តិទុក្កដ។ ពួកអាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយក៏ពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយ មានបំណងនឹងបំបែកសង្ឃដោយគិតថា ចូរភិក្ខុទាំងនុ៎ះ បាត់ទៅចុះ ចូរភិក្ខុទាំងនុ៎ះ វិនាសទៅចុះ ត្រូវការអ្វី ដោយពួកភិក្ខុទាំងនោះ ដូច្នេះហើយ ក៏បវារណាទៅ ត្រូវអាបត្តិថុល្លច្ច័យ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ បានឮអាការ របស់អាគន្តុកភិក្ខុ ភេទរបស់អាគន្តុកភិក្ខុ និមិត្តរបស់អាគន្តុកភិក្ខុ ឧទ្ទេសរបស់អាគន្តុកភិក្ខុ សូរជើងរបស់ពួកអាគន្តុកភិក្ខុ កំពុងដើរមក សូរគោះស្បែកជើង សូរក្អក សូរកណ្តាស់ របស់ពួកអាគន្តុកភិក្ខុ។ លុះឮហើយ ក៏មានសេចក្តីសង្ស័យថា មានពួកអាគន្តុកភិក្ខុ ឬគ្មានទេ។ ពួកអាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយមិនពិនិត្យមើល លុះមិនពិនិត្យមើលហើយ ក៏បវារណា ត្រូវអាបត្តិទុក្កដ។បេ។ ពួកអាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យហើយមិនឃើញ លុះមិនឃើញហើយ ក៏បវារណាទៅ មិនត្រូវអាបត្តិទេ។ ពួកអាអាវាសិកទាំងនោះ មានសេចក្តីសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយ ក៏បវារណាជាមួយគ្នា មិនត្រូវអាបត្តិទេ។ ពួកអាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយ ក៏បវារណាញែកគ្នា ត្រូវអាបត្តិទុក្កដ។ ពួកអាវាសិកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ហើយពិនិត្យមើល លុះពិនិត្យមើលហើយឃើញ លុះឃើញហើយ ក៏មានបំណងនឹងបំបែកសង្ឃដោយគិតថា ចូរភិក្ខុទាំងនុ៎ះ បាត់ទៅចុះ ពួកភិក្ខុទាំងនុ៎ះ វិនាសទៅចុះ ត្រូវការអ្វីដោយភិក្ខុទាំងនោះ ដូច្នេះហើយ ក៏បវារណាទៅ ត្រូវអាបត្តិថុល្លច្ច័យ។

## ១៣៦. នានាសំវាសកាទីហិ បវារណា

CS vin.mv.04.17 | ភាគ ទី៧

### (១៣៦)

[៣៧] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើប្រសិនជាពួកអាគន្តុកភិក្ខុ បានឃើញពួកអាវាសិកភិក្ខុ មានសំវាសផ្សេងគ្នា។ ពួកអាគន្តុកភិក្ខុទាំងនោះ ត្រឡប់បានសេចក្តីយល់ថា មានសំវាសស្មើគ្នាទៅវិញ លុះត្រឡប់បានសេចក្តីយល់ថា មានសំវាសស្មើគ្នាហើយ មិនសួរ (លទ្ធិ) លុះមិនសួរហើយ ក៏បវារណាជាមួយគ្នាទៅ មិនត្រូវអាបត្តិទេ។បេ។ ពួកអាគន្តុកភិក្ខុទាំងនោះ សួរ លុះសួរហើយ ក៏មិនអាចគ្របសង្កត់បាន គឺមិនអាចឲ្យភិក្ខុទាំងអស់នោះ លះបង់ទិដ្ឋិខុសបាន លុះគ្របសង្កត់មិនបានហើយ ក៏បវារណាជាមួយគ្នាទៅ ត្រូវអាបត្តិទុក្កដ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយ ក៏មិនអាចគ្របសង្កត់បាន លុះគ្របសង្កត់មិនបានហើយ ក៏បវារណាញែកគ្នា មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើប្រសិនជាពួកអាគន្តុកភិក្ខុ ឃើញពួកអាវាសិកភិក្ខុ មានសំវាសស្មើគ្នា។ ពួកអាគន្តុកភិក្ខុទាំងនោះ ត្រឡប់បានសេចក្តីយល់ថា ពួកអាវាសិកភិក្ខុមានសំវាសផ្សេងគ្នាទៅវិញ លុះត្រឡប់បានសេចក្តីយល់ថា មានសំវាសផ្សេងគ្នាហើយ មិនសួរ (លទ្ធិ) លុះមិនសួរហើយ ក៏បវារណាជាមួយគ្នាទៅ ត្រូវអាបត្តិទុក្កដ។បេ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយ ក៏គ្របសង្កត់បាន គឺឲ្យពួកអាវាសិកភិក្ខុ លះបង់ទិដ្ឋិខុសបាន លុះគ្របសង្កត់បានហើយ ក៏បវារណាញែកគ្នា ត្រូវអាបត្តិទុក្កដ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយ ក៏គ្របសង្កត់បាន លុះគ្របសង្កត់បានហើយ ក៏បវារណាជាមួយគ្នា មិនត្រូវអាបត្តិទេ។ ពួកអាគន្តុកភិក្ខុទាំងនោះសួរ លុះសួរហើយ គ្របសង្កត់មិនបាន លុះគ្របសង្កត់មិនបានហើយ ក៏បវារណាញែកគ្នាទៅ មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុ បានឃើញពួកអាគន្តុកភិក្ខុ មានសំវាសផ្សេងគ្នា។ (តែ) ពួកអាវាសិកភិក្ខុទាំងនោះ ត្រឡប់បានសេចក្តីយល់ថា ពួកអាគន្តុកភិក្ខុ មានសំវាសស្មើគ្នាទៅវិញ លុះត្រឡប់បានសេចក្តីយល់ថា ពួកអាគន្តុកភិក្ខុមានសំវាសស្មើគ្នាហើយ មិនសួរ លុះមិនសួរហើយ ក៏បវារណាជាមួយគ្នាទៅ មិនត្រូវអាបត្តិទេ។បេ។ ពួកអាវាសិកភិក្ខុទាំងនោះសួរ លុះសួរហើយ គ្របសង្កត់មិនបាន លុះគ្របសង្កត់មិនបានហើយ ក៏បវារណាជាមួយគ្នាទៅ ត្រូវអាបត្តិទុក្កដ។ ពួកអាវាសិកភិក្ខុទាំងនោះសួរ លុះសួរហើយ គ្របសង្កត់មិនបាន លុះគ្របសង្កត់មិនបានហើយ ក៏បវារណាញែកគ្នា មិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើពួកអាវាសិកភិក្ខុបានឃើញពួកអាគន្តុកភិក្ខុមានសំវាសស្មើគ្នា។ (តែ) ពួកអាវាសិកភិក្ខុទាំងនោះ ត្រឡប់បានសេចក្តីយល់ថា ពួកអាគន្តុកភិក្ខុមានសំវាសផ្សេងគ្នាទៅវិញ លុះត្រឡប់បានសេចក្តីយល់ថា មានសំវាសផ្សេងគ្នាហើយ មិនសួរ លុះមិនសួរហើយ ក៏បវារណាជាមួយ

គ្នាទៅ ត្រូវអាបត្តិទុក្កដ។បេ។ ពួកអាវាសិកភិក្ខុទាំងនោះសួរ លុះសួរហើយ គ្របសង្កត់បាន លុះគ្របសង្កត់បានហើយ ក៏បវារណាញែកគ្នា ត្រូវអាបត្តិទុក្កដ។ ពួកអាវាសិកភិក្ខុទាំងនោះសួរ លុះសួរហើយ គ្របសង្កត់បាន លុះគ្របសង្កត់បានហើយ ក៏បវារណាជាមួយគ្នាទៅ មិនត្រូវអាបត្តិទេ។

## ១៣៧. ន គន្តព្វវារោ

CS vin.mv.04.18 | ភាគ ទី៧

**(១៣៧)**

[៣៨] ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុទាំងឡាយចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុទាំងឡាយចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អនាវាស (ទីមិនមែនអាវាស) ដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាសដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអនាវាសដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាស ឬពីអនាវាសដែលមានភិក្ខុ ទៅកាន់អាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាស ឬពីអនាវាសដែលមានភិក្ខុ ទៅកាន់អនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាស ឬអនាវាសដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាសដែលគ្មានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អាវាសដែលមានភិក្ខុនោះទេ គឺអាវាសណា ដែលមានពួកភិក្ខុ មានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុនោះទេ គឺអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស។បេ។ ទៅកាន់អាវាស ឬអនាវាសទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ មិនត្រូវភិក្ខុចេញពីអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អនាវាសទេ។បេ។ ទៅកាន់អាវាស ឬអនាវាសទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងគ្នា វៀរលែងតែសង្ឃ វៀរលែងតែភិក្ខុមានការអន្តរាយ។

## ១៣៨. គន្តព្វវារោ

CS vin.mv.04.19 | ភាគ ទី៧

**(១៣៨)**

ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ ភិក្ខុគួរចេញពីអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អនាវាស។បេ។ ទៅកាន់អាវាស ឬអនាវាស គឺអាវាស ឬអនាវាសណាដែលមានពួកភិក្ខុ មានសំវាសស្មើគ្នាបាន ហើយភិក្ខុក៏ដឹងថា អាវាសណា អាត្មាអញ អាចទៅទាន់ក្នុងថ្ងៃនេះជាប្រាកដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ ភិក្ខុគួរចេញពីអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អនាវាស ឬទៅកាន់អាវាស ឬអនាវាស គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសស្មើគ្នា ហើយភិក្ខុក៏ដឹងថា អាវាសណាអាត្មាអញ អាចទៅទាន់ ក្នុងថ្ងៃនេះជាប្រាកដ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបវារណានោះ ភិក្ខុគួរចេញពីអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អនាវាស។បេ។ ទៅកាន់អាវាស ឬអនាវាស គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសស្មើគ្នាបាន ហើយភិក្ខុក៏ដឹងថា អាវាសណា អាត្មាអញ អាចទៅទាន់ ក្នុងថ្ងៃនេះជាប្រាកដ។

## ១៣៩. វជ្ជនីយបុគ្គលសន្ទស្សនា

CS vin.mv.04.20 | ភាគ ទី៧

**(១៣៩)**

[៣៩] ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យដែលមានភិក្ខុនីអង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យ ដែលមាននាងសិក្ខមានា សាមណេរ សាមណេរី បុគ្គលអ្នកលាសិក្ខា បុគ្គលអ្នកត្រូវអន្តិមវត្ថុ អង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យ ដែលមានភិក្ខុត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ អង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវវិនយធរឲ្យភិក្ខុនោះ ធ្វើតាមធម៌ (គឺឲ្យសំដែងអាបត្តិចេញ)។ មិនត្រូវភិក្ខុបវារណា ក្នុងបរិសទ្យ ដែលមានភិក្ខុត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ ភិក្ខុត្រូវសង្ឃលើកវត្ត ព្រោះមិនលះទិដ្ឋិអាក្រក់ អង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវវិនយធរឲ្យភិក្ខុនោះ ធ្វើតាមធម៌។ មិនត្រូវភិក្ខុបវារណាក្នុងបរិសទ្យ ដែលមានបណ្ឌក (ខ្ទើយ) អង្គុយជាមួយផងទេ

ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ។ មិនត្រូវភិក្ខុបវារណា ក្នុងបរិសទ្យដែលមានបុគ្គល ជាថេយ្យសំវាសក[11] បុគ្គលគេចទៅចូលសាសន៍តិរ្ថិយ តិរច្ឆាន បុគ្គលអ្នកសម្លាប់មាតា អ្នកសម្លាប់បិតា អ្នកសម្លាប់ព្រះអរហន្ត អ្នកទ្រុស្តភិក្ខុនី អ្នកបំបែកសង្ឃ អ្នកធ្វើលោហិតុប្បាទ (ធ្វើព្រះលោហិតព្រះពុទ្ធឲ្យពងឡើង) បុគ្គលជាឧភតោព្យញ្ជនកៈ (មនុស្សមានភេទពីរ) អង្គុយជាមួយផងទេ ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណា ដោយឲ្យបវារណា ឈ្មោះថាបរិវាសិក (មានបរិសទ្យក្រោកចេញទៅហើយ) វៀរលែងតែបរិសទ្យមិនទាន់ក្រោកចេញ។ ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុបវារណា ក្នុងថ្ងៃមិនមែនថ្ងៃបវារណាទេ វៀរលែងតែសង្ឃសាមគ្គី បវារណាចេញ។

ចប់ ទុតិយភាណវារៈ។

## ១៤០. ទ្វេវាចិកាទិបវារណា

CS vin.mv.04.21 | ភាគ ទី៧

**(១៤០)**

[៤០] ក៏សម័យនោះឯង មានអាវាសមួយក្នុងកោសលជនបទ កើតសពរភ័យ[12] ក្នុងថ្ងៃបវារណានោះ។ ភិក្ខុទាំងឡាយ មិនអាចនឹងបវារណាជាតេវាចិកាបវារណា (បវារណា ជាគំរប់៣ដង) បាន។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបវារណា ជាទ្វេវាចិកាបវារណា (បវារណា ជាគំរប់ពីរដង) បាន។ (កាលនោះ) សពរភ័យដ៏ក្លាខ្លាំងជាងមុនកើតឡើងទៀត។ ពួកភិក្ខុ មិនអាចនឹងបវារណា ជាទ្វេវាចិកាបវារណាបាន។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុបវារណា ជាឯកវាចិកាបវារណា (បវារណាតែម្តងៗ) បាន។ សពរភ័យដ៏ក្លាខ្លាំងជាងមុនកើតឡើងទៀត។ (កាលនោះ) ពួកភិក្ខុមិនអាចបវារណាជាឯកវាចិកាបវារណាបាន។ ពួកភិក្ខុក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុបវារណាជាសមានវស្សិកាបវារណា (ឲ្យភិក្ខុដែលមានវស្សាស្មើៗគ្នា បវារណាព្រមគ្នា)បាន។ ក៏សម័យនោះឯង ក្នុងអាវាសមួយ មានពួកមនុស្ស(មក) ឲ្យទានក្នុងថ្ងៃបវារណានោះ អស់រាត្រីជាច្រើន (ជិតភ្លឺ)។ ទើបភិក្ខុទាំងឡាយនោះ មានសេចក្តីត្រិះរិះដូច្នេះថា ពួកមនុស្សទាំងនេះ ឲ្យទានអស់រាត្រីជាច្រើន បើសង្ឃនឹងបវារណា ជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនទាន់ ដ្បិតរាត្រីនេះ ជិតភ្លឺហើយ តើយើងទាំងឡាយ ត្រូវប្រតិបត្តិដូចម្តេច។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកមនុស្ស ឲ្យទានក្នុងថ្ងៃបវារណានោះ អស់រាត្រីជាច្រើន។ បើពួកភិក្ខុក្នុងទីនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកមនុស្សដែលឲ្យទាន អស់រាត្រីជាច្រើន បើសង្ឃនឹងបវារណាជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនទាន់ ដ្បិតរាត្រីជិតភ្លឺហើយ។ ត្រូវភិក្ខុដែលឆ្លាសប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិតមាន) ពួកមនុស្សអ្នកឲ្យទាន អស់រាត្រីជាច្រើន។ បើសង្ឃនឹងបវារណាជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនទាន់ទេ ដ្បិតរាត្រីជិតភ្លឺហើយ។ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា ជាទ្វេវាចិកាបវារណា ជាឯកវាចិកាបវារណា ជាសមានវស្សិកាបវារណា។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានពួកភិក្ខុនិយាយធម៌ ពួកភិក្ខុរៀនព្រះសូត្រសង្គាយនា (ផ្ទៀងផ្ទាត់) ព្រះសូត្រ ពួកភិក្ខុជាវិនយធរ វិនិច្ឆ័យវិន័យ ពួកភិក្ខុធម្មកថិកសាកច្ឆាធម៌ ពួកភិក្ខុធ្វើសេចក្តីឈ្លោះគ្នា ក្នុងថ្ងៃបវារណានោះ អស់រាត្រីជាច្រើន។ បើពួកភិក្ខុក្នុងអាវាសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកភិក្ខុធ្វើសេចក្តីឈ្លោះគ្នា អស់រាត្រីជាច្រើន បើសង្ឃនឹងបវារណា ជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនទាន់ ព្រោះរាត្រីទៀបភ្លឺហើយ។ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពួកភិក្ខុធ្វើសេចក្តីឈ្លោះគ្នា អស់រាត្រីជាច្រើន។ បើសង្ឃនឹងបវារណា ជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនទាន់ ព្រោះរាត្រីទៀបភ្លឺហើយ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា ជាទ្វេវាចិកាបវារណា ជាឯកវាចិកាបវារណា ជាសមានវស្សិកាបវារណា។ ក្នុងអាវាសមួយ ក្នុងកោសលជនបទ មានភិក្ខុសង្ឃច្រើន ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ ទីដែលគត់ភ្លៀងក៏តិច មហាមេឃក៏តាំងឡើង (គឺនឹងធ្លាក់ភ្លៀង)។ ទើបភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុសង្ឃនេះ ប្រជុំគ្នាច្រើនម្ល៉េះ ទីដែលគត់ភ្លៀងក៏តិច មហាមេឃ ក៏តាំងឡើងហើយ បើសង្ឃនឹងបវារណា ជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនហើយ ជាប្រាកដ ភ្លៀងនេះនឹងធ្លាក់ចុះមិនខាន គួរពួកយើងប្រតិបត្តិដូចម្តេចហ្ន៎ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានភិក្ខុសង្ឃច្រើន ប្រជុំគ្នា ក្នុងថ្ងៃបវារណានោះ។ ទីគត់ភ្លៀងក៏តិច ភ្លៀងធំក៏តាំងឡើងហើយ។ បើពួកភិក្ខុក្នុងអាវាសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ភិក្ខុសង្ឃនេះ ប្រជុំគ្នាច្រើនដល់ម្ល៉េះ ទីដែលគត់ភ្លៀងក៏តិច ភ្លៀងធំ ក៏តាំងឡើងហើយ បើសង្ឃនឹងបវារណា ជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនហើយ ជាប្រាកដ ភ្លៀងនឹងធ្លាក់ចុះមិនខាន។ ត្រូវភិក្ខុដែលឆ្លាសប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុសង្ឃនេះ ប្រជុំគ្នាច្រើនណាស់។ ទីគត់ភ្លៀងក៏តិច ភ្លៀងធំ ក៏តាំងឡើយហើយ។ បើសង្ឃនឹងបវារណាជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនហើយជាប្រាកដ ភ្លៀងនេះធ្លាក់ចុះមិនខាន។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីបវារណា ជាទ្វេវាចិកាបវារណា ជាឯកវាចិកាបវារណា ជាសមានវស្សិកាបវារណា។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើក្នុងអាវាសណាមួយ មានការអន្តរាយអំពីស្តេច ក្នុងថ្ងៃបវារណានោះ។បេ។ មានការអន្តរាយអំពីចោរ។ មានការអន្តរាយអំពីភ្លើង។ មានការអន្តរាយអំពីទឹក។ មានការអន្តរាយអំពីមនុស្ស។ មានការអន្តរាយអំពីអមនុស្ស (មានខ្មោចបិសាចជាដើម)។ មានការអន្តរាយអំពីសត្វសាហាវ។ មានការអន្តរាយអំពីសត្វលូនវារ (ពស់តូចពស់ធំ)។ មានការអន្តរាយដល់ជីវិត។ មានការអន្តរាយដល់ព្រហ្មចារ្យ។ បើពួកភិក្ខុក្នុងអាវាសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាសេចក្តីអន្តរាយដល់ព្រហ្មចារ្យ បើសង្ឃនឹងបវារណា ជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនហើយជាប្រាកដ នឹងមានការអន្តរាយដល់ព្រហ្មចារ្យនេះមិនខាន។ ត្រូវភិក្ខុឆ្លាស ប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ នេះជាការអន្តរាយដល់ព្រហ្មចារ្យ បើសង្ឃនឹងបវារណា ជាតេវាចិកាបវារណា សង្ឃនឹងបវារណាមិនហើយ ជាប្រាកដ ការអន្តរាយ ដល់ព្រហ្មចារ្យនេះ មុខជានឹងកើតឡើងមិនខាន។ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា ជាទ្វេវាចិកាបវារណា ជាឯកវាចិកាបវារណា ជាសមានវស្សិកាបវារណា។

## ១៤១. បវារណាឋបនំ

CS vin.mv.04.22 | ភាគ ទី៧

### (១៤១)

[៤១] ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមានអាបត្តិ (ថាត្រូវអាបត្តិ) ហើយបវារណា។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានអាបត្តិ មិនត្រូវបវារណាទេ ភិក្ខុណាបវារណា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានអាបត្តិហើយ បវារណា តថាគតអនុញ្ញាត ឲ្យភិក្ខុសុំធ្វើឱកាស ហើយចោទអាបត្តិ ដល់ភិក្ខុនោះ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលដែលភិក្ខុឯទៀតសូមឱកាស មិនប្រាថ្នានឹងបើកឱកាសឲ្យ។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យឃាត់នូវបវារណា ដល់ភិក្ខុដែលមិនធ្វើឱកាស (មិនបើកឲ្យ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវឃាត់បវារណាយ៉ាងនេះ ត្រូវភិក្ខុសូត្រ ក្នុងកណ្តាលសង្ឃ ចំពោះបុគ្គលនោះ ដែលមានក្នុងទីចំពោះមុខ ក្នុងថ្ងៃបវារណានោះ គឺថ្ងៃទី១៤ ឬថ្ងៃទី១៥ ថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បុគ្គលឈ្មោះនេះ ប្រកបដោយអាបត្តិហើយ បវារណា ខ្ញុំសូមឃាត់ នូវបវារណារបស់បុគ្គលនោះ មិនគួរសង្ឃបវារណានឹងបុគ្គលនោះ ដែលមានក្នុងទីចំពោះមុខទេ។ បវារណាឈ្មោះថា ភិក្ខុបានឃាត់ហើយ។ ក៏សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ គិតគ្នាថា ពួកភិក្ខុមានសីលជាទីស្រឡាញ់ មុខជានឹងឃាត់បវារណា របស់ពួកយើងជាមុនហើយ ក៏តាំងរូតរះឃាត់បវារណា ដល់ពួកភិក្ខុដែលបរិសុទ្ធមិនត្រូវអាបត្តិ ដោយឥតមានរឿង ឥតមានហេតុអ្វី ថែមទាំងឃាត់បវារណា ដល់ពួកភិក្ខុដែលបានបវារណាហើយផង។ ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុឃាត់បវារណា ដល់ពួកភិក្ខុដែលបរិសុទ្ធ ដែលមិនត្រូវអាបត្តិ ដោយឥតមានរឿង ឥតមានហេតុអ្វីទេ ភិក្ខុណាឃាត់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឃាត់បវារណា ដល់ពួកភិក្ខុ ដែលបានបវារណាហើយទេ ភិក្ខុណាឃាត់ ត្រូវអាបត្តិទុក្កដ។

[៤២] ម្នាលភិក្ខុទាំងឡាយ បវារណាដែលភិក្ខុបានឃាត់ហើយ ដោយប្រការដូច្នេះឯង។ បវារណា ដែលភិក្ខុឃាត់មិនបាន ដូចមានសេចក្តីតទៅនេះ។ ម្នាលភិក្ខុទាំងឡាយ បវារណា ដែលភិក្ខុឃាត់មិនបាននោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ចំពោះតេវាចិកាបវារណា ដែលសង្ឃបានសូត្រហើយ បានពោលហើយ បានបញ្ចប់ស្រេចហើយ បវារណាឈ្មោះថា ភិក្ខុឃាត់មិនបាន ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ចំពោះទ្វេវាចិកាបវារណា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ចំពោះឯកវាចិកាបវារណា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ចំពោះសមានវស្សិកាបវារណា ដែលសង្ឃបានសូត្រហើយ បានពោលហើយ បានបញ្ចប់ស្រេចហើយ បវារណាឈ្មោះថា ភិក្ខុឃាត់មិនបានឡើយ។ ម្នាលភិក្ខុទាំងឡាយ បវារណា ដែលភិក្ខុមិនត្រូវឃាត់ ដូចបានសំដែងមកនេះឯង។ ម្នាលភិក្ខុទាំងឡាយ បវារណា ដែលឈ្មោះថាភិក្ខុឃាត់បាននោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ចំពោះតេវាចិកាបវារណា ដែលសង្ឃបានសូត្រហើយ បានពោលហើយ តែមិនទាន់ចប់ បវារណាឈ្មោះថា ភិក្ខុបានឃាត់ហើយ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ចំពោះទ្វេវាចិកាបវារណា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ចំពោះឯកវាចិកាបវារណា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឃាត់បវារណា ចំពោះសមានវស្សិកាបវារណាដែលសង្ឃបានសូត្រហើយ បានពោលហើយ តែមិនទាន់ចប់ បវារណាឈ្មោះថា ភិក្ខុបានឃាត់ហើយ។ ម្នាលភិក្ខុទាំងឡាយ បវារណាឈ្មោះថា ភិក្ខុបានឃាត់ហើយ ដូចពោលមកនេះឯង។

[៤៣] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើប្រសិនជាមានភិក្ខុ ឃាត់បវារណាចំពោះភិក្ខុផងគ្នា ក្នុងថ្ងៃបវារណានោះ។ បើពួកភិក្ខុឯទៀតបានស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះឯង មានកាយសមាចារមិនបរិសុទ្ធ[13] មានវចីសមាចារមិនបរិសុទ្ធ[14] មានអាជីវៈមិនបរិសុទ្ធ[15] ល្ងង់ មិនឆ្លាស កាលបើមានគេចោទសួរ ក៏មិនអាចឲ្យគេចោទសួរបាន។ ត្រូវសង្ឃសង្រ្គបសង្រ្គមថា នែភិក្ខុ កុំឡើយ លោកកុំធ្វើការបង្កហេតុ កុំឈ្លោះគ្នា កុំទាស់ទែងគ្នា កុំធ្វើការវិវាទគ្នាឡើយ ដូច្នេះហើយ សឹមបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុឃាត់បវារណា ចំពោះភិក្ខុផងគ្នា ក្នុងថ្ងៃបវារណានោះ។ បើពួកភិក្ខុដទៃបានស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះឯង មានកាយសមាចារបរិសុទ្ធ តែមានវចីសមាចារមិនបរិសុទ្ធ មានអាជីវៈមិនបរិសុទ្ធ ល្ងង់ មិនឆ្លាស កាលបើមានគេចោទសួរ ក៏មិនអាចឲ្យគេចោទសួរបាន។ ត្រូវសង្ឃសង្រ្គបសង្រ្គមថា នែភិក្ខុ កុំឡើយ លោកកុំធ្វើការបង្កហេតុ កុំឈ្លោះគ្នា កុំទាស់ទែងគ្នា កុំវិវាទគ្នាឡើយ ដូច្នេះហើយ សឹមបវារណា។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុឃាត់បវារណាចំពោះភិក្ខុផងគ្នា ក្នុងថ្ងៃបវារណានោះ។ បើពួកភិក្ខុឯទៀតបានស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះឯង មានកាយសមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ តែមានអាជីវៈមិនបរិសុទ្ធ ល្ងង់ មិនឆ្លាស កាលបើមានគេចោទសួរ ក៏មិនអាចឲ្យគេចោទសួរបាន។ ត្រូវសង្ឃសង្រ្គបសង្រ្គមថា នែភិក្ខុ លោកកុំធ្វើការបង្កហេតុ កុំឈ្លោះគ្នា កុំទាស់ទែងគ្នា កុំវិវាទគ្នា ដូច្នេះហើយ សឹមបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុឃាត់បវារណាចំពោះភិក្ខុផងគ្នា ក្នុងថ្ងៃបវារណានោះ។ បើពួកភិក្ខុដទៃស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះឯង មានកាយសមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ មានអាជីវៈបរិសុទ្ធ តែល្ងង់ មិនឆ្លាស កាលគេចោទសួរ ក៏មិនអាចឲ្យគេចោទសួរបាន។ ត្រូវសង្ឃសង្រ្គបសង្រ្គមថា កុំឡើយភិក្ខុ លោកកុំធ្វើការបង្កហេតុ កុំឈ្លោះគ្នា កុំទាស់ទែងគ្នា កុំវិវាទគ្នា ដូច្នេះហើយ សឹមបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុឃាត់បវារណា ចំពោះភិក្ខុផងគ្នា ក្នុងថ្ងៃបវារណានោះ។ បើពួកភិក្ខុដទៃ ស្គាល់ភិក្ខុនោះថា លោកដ៏មានអាយុនេះឯង មានកាយសមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ មានអាជីវៈបរិសុទ្ធ ជាបណ្ឌិត ឆ្លាស មានប្រាជ្ញា កាលមានគេចោទសួរ អាចឲ្យគេចោទសួរបាន។ ត្រូវភិក្ខុទាំងឡាយ និយាយនឹងភិក្ខុនោះថា នែអាវុសោ លោកនេះឯង ឃាត់បវារណា ចំពោះភិក្ខុនេះ លោកឃាត់បវារណានោះ ព្រោះហេតុអ្វី លោកឃាត់ព្រោះសីលវិបត្តិ ឬឃាត់ព្រោះអាចារវិបត្តិ ឬឃាត់ព្រោះទិដ្ឋិវិបត្តិ។ បើភិក្ខុអ្នកឃាត់នោះ និយាយយ៉ាងនេះថា ខ្ញុំឃាត់ព្រោះសីលវិបត្តិ ខ្ញុំឃាត់ព្រោះអាចារវិបត្តិ ខ្ញុំឃាត់ព្រោះទិដ្ឋិវិបត្តិ។ ត្រូវភិក្ខុទាំងឡាយ និយាយនឹងភិក្ខុនោះ យ៉ាងនេះថា លោកដ៏មានអាយុស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរឬ។ បើភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំស្គាល់សីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ ជាប្រាកដ។ ត្រូវភិក្ខុទាំងឡាយ និយាយ នឹងភិក្ខុនោះ យ៉ាងនេះថា នែអាវុសោ ចុះដូចម្តេចហៅថា សីលវិបត្តិ ដូចម្តេចហៅថា អាចារវិបត្តិ ដូចម្តេចហៅថា ទិដ្ឋិវិបត្តិ។ បើភិក្ខុនោះ និយាយយ៉ាងនេះថា បារាជិក៤ សង្ឃាទិសេស១៣ នេះហៅថាសីលវិបត្តិ ថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិត នេះហៅថា អាចារវិបត្តិ មិច្ឆាទិដ្ឋិ និងអន្តគ្គាហិកាទិដ្ឋិ នេះហៅថា ទិដ្ឋិវិបត្តិ។ ត្រូវភិក្ខុទាំងឡាយ និយាយ នឹងភិក្ខុនោះ យ៉ាងនេះថា នែអាវុសោ លោកឃាត់បវារណា ចំពោះភិក្ខុនេះ អ្នកឃាត់ដោយឃើញ ឬឃាត់ដោយឮ ឬឃាត់ដោយរង្កៀស។ បើភិក្ខុនោះ និយាយយ៉ាងនេះថា

ខ្ញុំឃាត់ដោយឃើញក្តី ខ្ញុំឃាត់ដោយឮក្តី ខ្ញុំឃាត់ដោយរង្កៀសក្តី។ ត្រូវភិក្ខុទាំងឡាយ និយាយនឹងភិក្ខុនោះ យ៉ាងនេះថា នែអាវុសោ លោកឃាត់បវារណា ចំពោះភិក្ខុនេះ ដោយឃើញ តើលោកឃើញហេតុដូចម្តេច លោកឃើញអ្វី ក្នុងបវារណានោះ លោកឃើញក្នុងកាលណា លោកឃើញក្នុងទីណា កាលភិក្ខុនោះ ត្រូវអាបត្តិបារាជិក លោកឃើញដែរឬ កាលភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស លោកឃើញដែរឬ កាលភិក្ខុនេះ ត្រូវអាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិត លោកឃើញដែរឬ ចំណែកលោកនៅក្នុងទីណា ឯភិក្ខុនេះនៅក្នុងទីណា លោកកំពុងធ្វើអ្វីខ្លះ ភិក្ខុនេះកំពុងធ្វើអ្វីខ្លះ។ បើភិក្ខុនោះ និយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំមិនមែនឃាត់បវារណា ចំពោះភិក្ខុនេះ ដោយឃើញទេ ខ្ញុំឃាត់បវារណា ដោយឮទេតើ។ ត្រូវភិក្ខុទាំងឡាយ និយាយនឹងភិក្ខុនោះ យ៉ាងនេះថា នែអាវុសោ លោកឃាត់បវារណាណា ចំពោះភិក្ខុនេះដោយឮ លោកឮហេតុដូចម្តេច ក្នុងបវារណានោះ លោកឮអ្វី លោកឮក្នុងកាលណា លោកឮក្នុងទីណា លោកឮថា ភិក្ខុនេះ ត្រូវអាបត្តិបារាជិកហើយឬ លោកឮថា ភិក្ខុនេះ ត្រូវអាបត្តិសង្ឃាទិសេសហើយឬ លោកឮថា ភិក្ខុនេះ ត្រូវអាបត្តិថុល្លច្ច័យ អាបត្តិបាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិតហើយឬ លោកឮពីភិក្ខុឬ លោកឮពីភិក្ខុនីឬ ឮពីនាងសិក្ខមានាឬ ឮពីសាមណេរឬ ឮពីសាមណេរីឬ ឮពីឧបាសកឬ ឮពីឧបាសិកាឬ ឮពីស្តេចទាំងឡាយឬ ឮពីពួកមហាមាត្យស្តេចឬ ឮពីពួកតិរ្ថិយឬ ឮពីពួកសាវកតិរ្ថិយឬ។ បើភិក្ខុនោះ និយាយថា នែអាវុសោ ខ្ញុំមិនបានឃាត់បវារណា ចំពោះភិក្ខុនេះដោយឮទេ ខ្ញុំឃាត់បវារណា ដោយរង្កៀសទេតើ។ ត្រូវភិក្ខុទាំងឡាយ និយាយនឹងភិក្ខុនោះ យ៉ាងនេះថា នែអាវុសោ លោកឃាត់បវារណាណា ចំពោះភិក្ខុនេះដោយរង្កៀស លោករង្កៀសដូចម្តេច ក្នុងបវារណានោះ ហេតុអ្វីក៏លោករង្កៀស លោករង្កៀសក្នុងកាលណា លោករង្កៀសក្នុងទីណា លោករង្កៀសថា ភិក្ខុនេះ ត្រូវអាបត្តិបារាជិកហើយឬ លោករង្កៀសថា ភិក្ខុនេះ ត្រូវអាបត្តិសង្ឃាទិសេសហើយឬ លោករង្កៀសថា ភិក្ខុនេះ ត្រូវអាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិតហើយឬ លោករង្កៀសព្រោះឮពីភិក្ខុឬ លោករង្កៀសព្រោះឮពីភិក្ខុនីឬ លោករង្កៀសព្រោះឮពីសិក្ខមានាឬ លោករង្កៀសព្រោះឮពីសាមណេរឬ លោករង្កៀសព្រោះឮពីសាមណេរីឬ លោករង្កៀសព្រោះឮពីឧបាសកឬ លោករង្កៀសព្រោះឮពីឧបាសិកាឬ លោករង្កៀសព្រោះឮពីពួកស្តេចឬ លោករង្កៀសព្រោះឮពីពួកមហាមាត្យស្តេចឬ លោករង្កៀសព្រោះឮពីពួកតិរ្ថិយឬ លោករង្កៀសព្រោះឮពីពួកសាវកតិរ្ថិយឬ។ បើភិក្ខុនោះ និយាយថា នែអាវុសោ ខ្ញុំមិនមែនឃាត់បវារណាចំពោះភិក្ខុនេះដោយរង្កៀសទេ មួយវិញទៀត ខ្ញុំក៏មិនដឹងថា ខ្ញុំឃាត់បវារណាចំពោះភិក្ខុនោះ ដោយហេតុអ្វីទេ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះ មិនធ្វើចិត្ត របស់ពួកសព្រហ្មចារី ជាវិញ្ញូ ឲ្យត្រេកអរ តាមការសាកសួរទេ គួរនឹងពោលថា ភិក្ខុដែលត្រូវគេចោទ មិនគួរភិក្ខុដទៃតិះដៀលទេ គឺឥតទោសទេ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះ ធ្វើចិត្តរបស់សព្រហ្មចារី ជាវិញ្ញូឲ្យត្រេកអរតាមសេចក្តីសាកសួរ គួរពោលថា ភិក្ខុដែលត្រូវចោទ គួរភិក្ខុដទៃតិះដៀលបាន (មានទោស)។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះ ប្តេជ្ញាចំពោះភិក្ខុ ដែលខ្លួនតាមកំចាត់(ចោទ) ដោយអាបត្តិបារាជិក រកមូលគ្មាន ត្រូវសង្ឃលើកអាបត្តិសង្ឃាទិសេស (ចំពោះភិក្ខុអ្នកចោទនោះ) ហើយសឹមបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះ ប្តេជ្ញាចំពោះភិក្ខុ ដែលខ្លួនតាមកំចាត់ (ចោទ) ដោយអាបត្តិសង្ឃាទិសេស មិនមានមូល ត្រូវសង្ឃឲ្យភិក្ខុនោះ ធ្វើតាមធម៌ (ត្រូវសំដែងអាបត្តិចេញ) ហើយសឹមបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកចោទនោះ ប្តេជ្ញាចំពោះភិក្ខុ ដែលខ្លួនតាមកំចាត់ ដោយអាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិត រកមូលគ្មាន ត្រូវសង្ឃឲ្យភិក្ខុនោះធ្វើតាមធម៌ (សំដែងអាបត្តិចេញ) ហើយសឹមបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុដែលត្រូវចោទ ប្តេជ្ញាខ្លួនថា ត្រូវអាបត្តិបារាជិក ត្រូវសង្ឃធ្វើនាសនកម្ម (ចំពោះភិក្ខុនោះ) ហើយសឹមបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ ដែលត្រូវចោទនោះ ប្តេជ្ញាខ្លួនថា ត្រូវអាបត្តិសង្ឃាទិសេស ត្រូវសង្ឃលើកអាបត្តិសង្ឃាទិសេសហើយ សឹមបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ ដែលត្រូវចោទនោះ ប្តេជ្ញាខ្លួនថា ត្រូវអាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិត ត្រូវសង្ឃឲ្យភិក្ខុនោះ ធ្វើតាមធម៌ (សំដែងអាបត្តិ ហើយសឹមបវារណាចុះ)។

## ១៤២. ថុល្លច្ចយវត្ថុកាទិ

CS vin.mv.04.23 | ភាគ ទី៧

**(១៤២)**

[៤៤] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ក្នុងថ្ងៃបវារណានោះ។ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះ យល់ថា សង្ឃាទិសេស។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ដែលយល់ថា អាបត្តិថុល្លច្ច័យ ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុនោះ នាំភិក្ខុ (ត្រូវអាបត្តិ) នោះ ចេញទៅកាន់ទីគួរមួយ ហើយឲ្យភិក្ខុនោះ ធ្វើតាមធម៌ រួចត្រូវចូលទៅរកសង្ឃ ហើយនិយាយយ៉ាងនេះថា នែអាវុសោ ភិក្ខុនោះត្រូវអាបត្តិណាហើយ ភិក្ខុនោះ បានសំដែងអាបត្តិនោះ តាមធម៌ហើយ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងថ្ងៃបវារណានោះ។ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិបាចិត្តិយ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិបាដិទេសនីយ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិទុក្កដ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះ យល់ថា អាបត្តិទុព្ភាសិត។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ដែលយល់ថា អាបត្តិថុល្លច្ច័យ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុពួកនោះ នាំភិក្ខុនោះចេញ ទៅកាន់ទីគួរមួយ ឲ្យធ្វើតាមធម៌ (សំដែងអាបត្តិ) ហើយសឹមចូលមករកសង្ឃ រួចត្រូវនិយាយ យ៉ាងនេះថា នែអាវុសោ ភិក្ខុនោះត្រូវអាបត្តិណា ភិក្ខុនោះ ក៏បានសំដែងអាបត្តិនោះ តាមធម៌ហើយ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីបវារណា។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុ ត្រូវអាបត្តិបាចិត្តិយ ត្រូវអាបត្តិបាដិទេសនីយ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិទុព្ភាសិត ក្នុងថ្ងៃបវារណានោះ។ មានភិក្ខុពួកខ្លះ យល់ថា ត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះ យល់ថា ត្រូវអាបត្តិសង្ឃាទិសេស។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ដែលយល់ថា ត្រូវអាបត្តិទុព្ភាសិត ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុនោះ នាំភិក្ខុនោះចេញ ទៅកាន់ទីគួរមួយ ឲ្យធ្វើតាមធម៌ ហើយសឹមចូលទៅរកសង្ឃ រួចនិយាយយ៉ាងនេះថា នែអាវុសោ ភិក្ខុនោះត្រូវអាបត្តិណា ភិក្ខុនោះ ក៏បានសំដែងអាបត្តិនោះ តាមធម៌ហើយ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីបវារណាចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុ ត្រូវអាបត្តិទុព្ភាសិត ក្នុងថ្ងៃបវារណានោះ។ មានភិក្ខុពួកខ្លះយល់ថា ត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះ យល់ថា ត្រូវអាបត្តិថុល្លច្ច័យ មានភិក្ខុពួកខ្លះយល់ថា ត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះ យល់ថា ត្រូវអាបត្តិបាចិត្តិយ ភិក្ខុពួកខ្លះយល់ថា ត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះយល់ថា ត្រូវអាបត្តិបាដិទេសនីយ មានភិក្ខុពួកខ្លះយល់ថា ត្រូវអាបត្តិទុព្ភាសិត ភិក្ខុពួកខ្លះយល់ថា ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ដែលយល់ថា ត្រូវអាបត្តិទុព្ភាសិត ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុនោះ នាំភិក្ខុនោះចេញទៅកាន់ទីគួរមួយ ឲ្យធ្វើតាមធម៌ ហើយត្រូវចូលទៅរកសង្ឃ

រួចនិយាយ យ៉ាងនេះថា នែអាវុសោ ភិក្ខុនោះ ត្រូវអាបត្តិណា ភិក្ខុនោះ បានសំដែងអាបត្តិនោះ តាមធម៌ហើយ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីបវារណាចុះ។

## ១៤៣. វត្ថុឋបនាទិ

CS vin.mv.04.24 | ភាគ ទី៧

**(១៤៣)**

[៤៥] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុសូត្រឡើងក្នុងកណ្តាលសង្ឃ ក្នុងថ្ងៃបវារណានោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុនេះប្រាកដ តែបុគ្គលមិនប្រាកដ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឃាត់វត្ថុទុក ហើយសឹមបវារណា។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា នែអាវុសោ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តបវារណា ដើម្បីឲ្យវត្ថុទាំងឡាយស្អាតវិសេស បើវត្ថុប្រាកដ តែបុគ្គលមិនប្រាកដទេ ចូរអ្នកប្រាប់វត្ថុនោះឥឡូវនេះកុំខាន។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុសូត្រឡើងកណ្តាលសង្ឃ ក្នុងថ្ងៃបវារណានោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) បុគ្គលនេះប្រាកដ តែវត្ថុមិនប្រាកដទេ បើកម្មមានកាលគួរដល់សង្ឃហើយ សូមសង្ឃឃាត់នូវបុគ្គល ហើយសឹមបវារណា។ ត្រូវភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះយ៉ាងនេះថា នែអាវុសោ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តបវារណា ដើម្បីឲ្យពួកភិក្ខុព្រមព្រៀងគ្នា បើបុគ្គលប្រាកដ តែវត្ថុមិនប្រាកដទេ ចូរអ្នកប្រាប់បុគ្គលនោះឥឡូវនេះកុំខាន។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុសូត្រឡើងកណ្តាលសង្ឃ ក្នុងថ្ងៃបវារណានោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) វត្ថុនេះក្តី បុគ្គលក្តី ក៏ប្រាកដ បើកម្មមានកាលគួរដល់សង្ឃហើយ ត្រូវសង្ឃឃាត់ទាំងវត្ថុ ទាំងបុគ្គល ហើយសឹមបវារណា។ ត្រូវភិក្ខុទាំងឡាយនិយាយយ៉ាងនេះនឹងភិក្ខុនោះថា នែអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តបវារណា ដើម្បីឲ្យវត្ថុទាំងឡាយបរិសុទ្ធផង ដើម្បីឲ្យភិក្ខុទាំងឡាយព្រមព្រៀងគ្នាផង បើវត្ថុ និងបុគ្គលប្រាកដ ចូរលោកប្រាប់វត្ថុ និងបុគ្គលនោះក្នុងកាលឥឡូវនេះមក។ ម្នាលភិក្ខុទាំងឡាយ បើវត្ថុប្រាកដមុនបវារណា បុគ្គលប្រាកដក្រោយបវារណា គួរនឹងចោទបាន។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលប្រាកដមុនបវារណា វត្ថុប្រាកដក្រោយបវារណា គួរនឹងចោទបាន។ ម្នាលភិក្ខុទាំងឡាយ បើវត្ថុ និងបុគ្គលប្រាកដមុនបវារណា កាលបើសង្ឃបានធ្វើបវារណាហើយ បើភិក្ខុសើរើកម្មនោះឡើង ត្រូវឱក្កោដនកបាចិត្តិយ (ត្រូវបាចិត្តិយព្រោះការសើរើ)។

## ១៤៤. ភណ្ឌនការកវត្ថុ

CS vin.mv.04.25 | ភាគ ទី៧

**(១៤៤)**

[៤៦] ក៏សម័យនោះឯង ពួកភិក្ខុច្រើនរូបដែលជាមិត្រគ្រាន់តែឃើញគ្នា និងជាមិត្របានគប់គ្នា (មិត្រស្និទ្ធស្នាលមាំមួន) ចូលទៅចាំវស្សាក្នុងអាវាសមួយក្នុងកោសលជនបទ។ ពួកភិក្ខុដទៃដែលនៅជិតខាងភិក្ខុទាំងឡាយនោះ ធ្វើសេចក្តីប្រកួតប្រកាន់គ្នា ធ្វើសេចក្តីឈ្លោះគ្នា ធ្វើសេចក្តីទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ជាអ្នកធ្វើអធិករណ៍ក្នុងសង្ឃចូលទៅចាំវស្សាដោយប៉ងថា កាលបើភិក្ខុទាំងនោះនៅចាំវស្សារួចហើយ ពួកយើងនឹងឃាត់បវារណាក្នុងថ្ងៃដែលបវារណា។ ពួកភិក្ខុទាំងនោះបានឮដំណឹងថា ពួកភិក្ខុដទៃដែលនៅជិតខាងយើង ជាអ្នកធ្វើសេចក្តីប្រកួតប្រកាន់គ្នា ធ្វើសេចក្តីឈ្លោះប្រកែក ធ្វើសេចក្តីទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ជាអ្នកធ្វើអធិករណ៍ក្នុងសង្ឃចូលទៅចាំវស្សា ដោយគិតថា កាលបើភិក្ខុទាំងនោះនៅចាំវស្សារួចហើយ ពួកយើងនឹងឃាត់បវារណាក្នុងថ្ងៃដែលបវារណា គួរយើងទាំងឡាយប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុច្រើនរូប ជាមិត្រដែលធ្លាប់ឃើញគ្នា ជាមិត្រស្និទ្ធស្នាលមាំមួន ចូលទៅចាំវស្សាក្នុងអាវាសមួយ។ ពួកភិក្ខុដទៃដែលនៅជិតខាងពួកភិក្ខុទាំងនោះ ជាអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីទាស់ទែង ធ្វើតិរច្ឆានកថា ជាអ្នកធ្វើអធិករណ៍ក្នុងសង្ឃ ចូលទៅចាំវស្សាដោយប៉ងថា កាលបើភិក្ខុទាំងនោះ នៅចាំវស្សារួចហើយ ពួកយើងនឹងឃាត់បវារណា ក្នុងថ្ងៃដែលបវារណា។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកភិក្ខុទាំងនោះ ធ្វើចាតុទ្ទសីឧបោសថពីរបីឧបោសថ[16] ដោយគិតថា ធ្វើដូចម្តេចពួកយើងនឹងគប្បីបវារណាឲ្យបានមុនពួកភិក្ខុទាំងនោះ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុជាអ្នកធ្វើសេចក្តីប្រកួតប្រកាន់គ្នា ធ្វើសេចក្តីឈ្លោះប្រកែកគ្នា ធ្វើសេចក្តីទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះ មកកាន់អាវាស ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុអ្នកនៅក្នុងអាវាសទាំងនោះ ប្រជុំគ្នាបវារណាភ្លាមៗចុះ លុះបវារណាហើយ ត្រូវនិយាយថា នែអាវុសោ យើងទាំងឡាយបានបវារណារួចហើយ លោកដ៏មានអាយុទាំងឡាយសំគាល់យ៉ាងណា ក៏ចូរធ្វើយ៉ាងនោះចុះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុដែលជាអ្នកធ្វើសេចក្តីប្រកួតប្រកាន់គ្នា ធ្វើសេចក្តីឈ្លោះគ្នា វិវាទគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះ មិនបានដឹងរឿងអ្វី ហើយមកកាន់អាវាសនោះ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុអ្នកនៅក្នុងអាវាសទាំងនោះ ក្រាលអាសនៈ ដំកល់ទឹកលាងជើង តាំងរងជើង ទ្រនាប់សម្រាប់ជូតជើង ត្រូវក្រោកឡើងទទួលយកបាត្រ និងចីវរ ត្រូវសួរភិក្ខុទាំងនោះដោយទឹកឆាន់។ ត្រូវបំភាន់ភិក្ខុទាំងនោះ ហើយទៅកាន់ទីក្រៅសីមា ហើយសឹមបវារណាចុះ។ លុះបវារណាហើយ ត្រូវនិយាយថា នែអាវុសោ យើងទាំងឡាយបានបវារណារួចហើយ លោកដ៏មានអាយុទាំងឡាយសំគាល់យ៉ាងណា ចូរធ្វើយ៉ាងនោះចុះ។ បើភិក្ខុបានកិច្ចនោះ ដោយអាការដូច្នោះហើយ ការបាននុ៎ះ ជាការល្អ បើមិនបានទេ ត្រូវភិក្ខុអ្នកនៅក្នុងអាវាសដែលឆ្លាស ប្រតិពល ឲ្យពួកភិក្ខុអ្នកនៅក្នុងអាវាសផងគ្នាដឹងថា សូមលោកដ៏មានអាយុទាំងឡាយដែលនៅក្នុងអាវាសស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយណាហើយ យើងត្រូវធ្វើឧបោសថ ត្រូវសំដែងបាតិមោក្ខ ត្រូវបវារណា ក្នុងកាឡបក្ខ គឺក្នុងរនោច ដែលមកដល់ឥឡូវនេះឯង។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុជាអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីឈ្លោះប្រកែក ធ្វើសេចក្តីទាស់ទែង ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះ និយាយយ៉ាងនេះនឹងអាវាសិកភិក្ខុទាំងនោះថា នែអាវុសោ ខ្ញុំសូមអង្វរ ចូរលោកទាំងឡាយបវារណាចំពោះយើងក្នុងកាលឥឡូវនេះចុះ។ ត្រូវអាវាសិកភិក្ខុនិយាយនឹងភិក្ខុទាំងនោះយ៉ាងនេះថា នែអាវុសោ លោកទាំងឡាយមិនមែនជាធំក្នុងការបវារណារបស់យើងទេ យើងមិនទាន់បវារណានៅឡើយ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុជាអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីឈ្លោះប្រកែក ធ្វើសេចក្តីទាស់ទែង ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះនៅទាល់តែអស់កាឡបក្ខនោះ ត្រូវអាវាសិកភិក្ខុដែលឆ្លាស ប្រតិពល ឲ្យពួកអាវាសិកភិក្ខុផងគ្នាដឹងដោយពាក្យ

ដូច្នេះថា សូមលោកដ៏មានអាយុទាំងឡាយដែលនៅក្នុងអាវាសស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់លោកដ៏មានអាយុទាំងឡាយហើយ យើងទាំងឡាយត្រូវធ្វើឧបោសថ ត្រូវសំដែងបាតិមោក្ខ ត្រូវបវារណា ក្នុងជុណ្ហបក្ខ ដែលមកដល់ក្នុងកាលឥឡូវនេះ គឺក្នុងខ្នើត។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីវិវាទ ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះ និយាយយ៉ាងនេះនឹងភិក្ខុទាំងនោះថា នែអាវុសោ ខ្ញុំសូមអង្វរ ចូរលោកទាំងឡាយបវារណាចំពោះយើងទាំងឡាយ ក្នុងកាលឥឡូវនេះចុះ។ ត្រូវអាវាសិកភិក្ខុទាំងឡាយនិយាយយ៉ាងនេះនឹងភិក្ខុទាំងឡាយនោះថា នែអាវុសោ លោកទាំងឡាយមិនមែនជាធំក្នុងការបវារណារបស់យើងទេ យើងមិនទាន់បវារណានៅឡើយ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុអ្នកធ្វើសេចក្តីប្រកួតប្រកាន់ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីទាស់ទែង ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃទាំងនោះនៅទាល់តែអស់ជុណ្ហបក្ខនោះទៀត ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះនាំគ្នាបវារណា ដោយខានមិនបានក្នុងតិថីជាគំរប់៤ខែនៃវស្សានរដូវ ជាទីរីកនៃផ្កាកុមុទ ក្នុងជុណ្ហបក្ខ ដែលមកដល់ឥឡូវនេះ (ថ្ងៃពេញបូណ៌មី ខែកត្តិក)។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងតែបវារណា ហើយមានភិក្ខុឈឺឃាត់បវារណាដល់ភិក្ខុមិនឈឺ ត្រូវភិក្ខុដទៃនិយាយនឹងភិក្ខុឈឺនោះយ៉ាងនេះថា លោកដ៏មានអាយុជាអ្នកមានជម្ងឺធម្មតា ភិក្ខុឈឺ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ជាបុគ្គលមិនគាប់ចិត្តនឹងការសាកសួរទេ នែអាវុសោ ចូរលោករង់ចាំ ទំរាំលោកជារោគសិន ដល់លោកជារោគហើយ កាលបើត្រូវការនឹងចោទ ក៏ចោទចុះ។ កាលបើភិក្ខុនិយាយយ៉ាងនេះហើយ ភិក្ខុដែលឈឺនោះ នៅតែចោទ ត្រូវអាបត្តិបាចិត្តិយ ព្រោះមិនអើពើ (នឹងពាក្យឃាត់)។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះកំពុងតែបវារណា ហើយមានភិក្ខុមិនឈឺឃាត់បវារណាដល់ភិក្ខុឈឺ ត្រូវភិក្ខុដទៃនិយាយនឹងភិក្ខុមិនឈឺនោះយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះឯងឈឺ ក៏ធម្មតា ភិក្ខុឈឺ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ជាបុគ្គលមិនគួរដល់ការសួរដេញដោលទេ នែអាវុសោ ចូរលោករង់ចាំ ទំរាំភិក្ខុនេះជារោគសិន ដល់លោកនេះជារោគហើយ កាលបើលោកប្រាថ្នានឹងចោទ ក៏ចោទចុះ។ កាលបើភិក្ខុដទៃនិយាយយ៉ាងនេះហើយ ភិក្ខុមិនឈឺនោះនៅតែចោទ ត្រូវអាបត្តិបាចិត្តិយ ព្រោះមិនអើពើ (នឹងពាក្យឃាត់)។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះ កំពុងតែបវារណា ហើយមានភិក្ខុឈឺឃាត់បវារណាដល់ភិក្ខុឈឺ ត្រូវភិក្ខុដទៃនិយាយយ៉ាងនេះនឹងភិក្ខុនោះថា លោកដ៏មានអាយុទាំងឡាយ ជាអ្នកឈឺ ក៏ធម្មតា ភិក្ខុឈឺ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា មិនគួរដល់ការសួរដេញដោលទេ នែអាវុសោ ចូរលោកបង្អង់សិន ទំរាំលោកទាំងឡាយជារោគ ដល់លោកដែលមានហេតុ (នោះ) ជាសះស្បើយហើយ កាលបើលោកត្រូវការនឹងចោទ ក៏ចោទភិក្ខុដែលឥតរោគ (នោះចុះ)។ កាលបើភិក្ខុដទៃនិយាយយ៉ាងនោះហើយ ភិក្ខុឈឺនោះនៅតែចោទ ត្រូវអាបត្តិបាចិត្តិយ ព្រោះមិនអើពើ (នឹងពាក្យឃាត់)។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុទាំងឡាយនោះ កំពុងតែបវារណា ហើយមានភិក្ខុមិនឈឺឃាត់បវារណាដល់ភិក្ខុមិនឈឺ។ ត្រូវសង្ឃដេញដោលភិក្ខុទាំងពីររូបដោយត្រឹមត្រូវ សាកសួរដោយត្រឹមត្រូវ ហើយឲ្យភិក្ខុទាំងនោះធ្វើតាមធម៌ (គឺសំដែងអាបត្តិ) ហើយសឹមបវារណាចុះ។

## ១៤៥. បវារណាសង្គហោ

CS vin.mv.04.26 | ភាគ ទី៧

**(១៤៥)**

[៤៧] ក៏សម័យនោះឯង ពួកភិក្ខុច្រើនរូប ជាមិត្រធ្លាប់ឃើញគ្នា ជាមិត្រស្និទ្ធស្នាលមាំមួន ចូលទៅចាំវស្សាក្នុងអាវាសមួយ ក្នុងកោសលជនបទ។ កាលភិក្ខុទាំងនោះព្រមព្រៀង ស្មោះសររកគ្នា មិនវិវាទគ្នា ហើយក៏បានដល់នូវធម៌ម្យ៉ាង ដែលជាគ្រឿងនៅសប្បាយ។[17)] គ្រានោះឯងភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា កាលយើងទាំងឡាយព្រមព្រៀងគ្នា រីករាយរកគ្នា មិនទាស់ទែងគ្នា ក៏បានដល់នូវធម៌ម្យ៉ាង ដែលជាគ្រឿងនៅសប្បាយហើយ ក្នុងពេលនេះ បើយើងទាំងឡាយនឹងបវារណា គង់នឹងមានពួកភិក្ខុដែលបវារណារួចហើយ ចៀសចេញទៅកាន់ចារិក យើងទាំងឡាយមុខជានឹងឃ្លាតចាកធម៌ ជាគ្រឿងនៅសប្បាយនេះដោយអាការដូច្នេះមិនខាន យើងទាំងឡាយត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុជាច្រើន ជាមិត្រឃើញគ្នា ជាមិត្រស្និទ្ធស្នាលមាំមួន ចូលទៅចាំវស្សាក្នុងអាវាសមួយ។ ភិក្ខុទាំងឡាយនោះ ជាអ្នកព្រមព្រៀង ស្មោះសររកគ្នា មិនទាស់ទែងគ្នា ហើយបានដល់នូវធម៌ម្យ៉ាង ដែលជាគ្រឿងនៅសប្បាយ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនៅក្នុងអាវាសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងទាំងឡាយ ជាអ្នកព្រមព្រៀង រីករាយរកគ្នា មិនវិវាទគ្នា បានដល់នូវធម៌ម្យ៉ាង ដែលជាគ្រឿងនៅសប្បាយ ហើយក្នុងពេលនេះ បើប្រសិនជាយើងនឹងបវារណា គង់មានពួកភិក្ខុដែលបវារណារួចហើយ ចៀសចេញទៅកាន់ចារិក យើងទាំងឡាយមុខជានឹងឃ្លាតចាកធម៌ ជាគ្រឿងនៅសប្បាយនេះ ដោយអាការដូច្នេះមិនខាន។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយនោះ ធ្វើបវារណាសង្គហៈ។ ម្នាលភិក្ខុទាំងឡាយ ក៏ឯបវារណាសង្គហៈនោះ ត្រូវភិក្ខុធ្វើយ៉ាងនេះ។ ត្រូវភិក្ខុទាំងអស់ប្រជុំក្នុងទីជាមួយគ្នា។ លុះប្រជុំគ្នាហើយ ត្រូវភិក្ខុដែលឆ្លាសប្រតិពល ឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ យើងទាំងឡាយ ជាអ្នកព្រមព្រៀងគ្នា ស្មោះសររកគ្នា មិនវិវាទគ្នា បានដល់នូវធម៌ម្យ៉ាង ដែលជាគ្រឿងនៅសប្បាយហើយ។ ក្នុងពេលនេះ បើប្រសិនជាយើងទាំងឡាយនឹងបវារណា គង់មានពួកភិក្ខុដែលបានបវារណារួចហើយ ចេញទៅកាន់ចារិក យើងទាំងឡាយមុខជានឹងឃ្លាតចាកធម៌ ជាគ្រឿងនៅសប្បាយនេះ ដោយអាការដូច្នេះមិនខាន។ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃធ្វើបវារណាសង្គហៈ គួរធ្វើឧបោសថ គួរសំដែងបាតិមោក្ខ គួរបវារណា ក្នុងថ្ងៃជាគំរប់៤ខែ នៃវស្សានរដូវ ជាទីរីកនៃផ្កាកុមុទ ក្នុង(ជុណ្ហបក្ខ) ដែលមកដល់ក្នុងកាលឥឡូវនេះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ យើងទាំងឡាយ ជាអ្នកព្រមព្រៀងគ្នា រីករាយរកគ្នា មិនទាស់ទែងគ្នា បានដល់នូវធម៌ម្យ៉ាង ដែលជាគ្រឿងនៅសប្បាយហើយ។ ក្នុងពេលនេះ បើយើងទាំងឡាយនឹងបវារណាទៅ គង់មានពួកភិក្ខុដែលបានបវារណាហើយ ចៀសចេញទៅកាន់ចារិក យើងទាំងឡាយមុខជានឹងឃ្លាតចាកធម៌ ជាគ្រឿងនៅសប្បាយនេះដោយអាការដូច្នេះមិនខាន។ ឥឡូវសង្ឃធ្វើបវារណាសង្គហៈ ធ្វើឧបោសថ សំដែងបាតិមោក្ខ និងបវារណា ក្នុងថ្ងៃជាគំរប់៤ខែ នៃវស្សានរដូវជាទីរីកនៃផ្កាកុមុទ ក្នុង (ជុណ្ហបក្ខ) ដែលមកដល់ក្នុងកាលឥឡូវនេះ។ ការធ្វើបវារណាសង្គហៈ គឺថាសង្ឃនឹងធ្វើឧបោសថ សំដែងបាតិមោក្ខ និងបវារណា ក្នុងថ្ងៃជាគំរប់៤ខែ នៃវស្សានរដូវ ជាទីរីកនៃផ្កាកុមុទ ក្នុង (ជុណ្ហបក្ខ) ដែលមកដល់ក្នុងកាលឥឡូវនេះ គាប់ចិត្តដល់លោកម្ចាស់អង្គណា គួរលោកម្ចាស់អង្គនោះស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា គួរលោកម្ចាស់អង្គនោះនិយាយឡើង។ បវារណាសង្គហៈ គឺថាសង្ឃនឹងធ្វើឧបោសថ សំដែងបាតិមោក្ខនេះ និងបវារណា ក្នុងថ្ងៃជាគំរប់៤ខែ នៃវស្សានរដូវ ជាទីរីកនៃផ្កាកុមុទ ក្នុង (ជុណ្ហបក្ខ) ដែលមកដល់ក្នុងកាលឥឡូវនេះ សង្ឃបានធ្វើរួចហើយ។ បវារណាសង្គហៈនោះ គាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ

ដោយអាការស្ងៀមនៅយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះ ធ្វើបវារណាសង្គហៈហើយ មានភិក្ខុណាមួយនិយាយយ៉ាងនេះថា នែអាវុសោ ខ្ញុំប្រាថ្នានឹងចេញទៅកាន់ចារិកក្នុងជនបទ ព្រោះខ្ញុំមានកិច្ចត្រូវធ្វើក្នុងជនបទ។ ត្រូវភិក្ខុដទៃនិយាយនឹងភិក្ខុនោះយ៉ាងនេះថា នែអាវុសោ ខ្ញុំសូមអង្វរលោកសិន ចូរលោកបវារណាហើយសឹមទៅចុះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះកំពុងតែបវារណា ឃាត់បវារណាភិក្ខុរូបណាមួយ គួរភិក្ខុដែលត្រូវគេឃាត់នោះនិយាយយ៉ាងនេះនឹងភិក្ខុអ្នកឃាត់នោះថា នែអាវុសោ លោកមិនមែនជាធំ ក្នុងការបវារណារបស់ខ្ញុំទេ ខ្ញុំនឹងមិនទាន់បវារណា។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ កំពុងតែបវារណា បើមានភិក្ខុណាមួយ ឃាត់បវារណាភិក្ខុនោះ ត្រូវសង្ឃដេញដោលសួរភិក្ខុទាំងពីររូប លុះសាកសួរហើយ សឹមឲ្យភិក្ខុទាំងពីរធ្វើតាមធម៌ (គឺសំដែងអាបត្តិ)។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះ បានសម្រេចកិច្ចនោះក្នុងជនបទហើយ ត្រឡប់មកកាន់អាវាសនោះវិញ ខាងក្នុងថ្ងៃគំរប់៤ខែ នៃវស្សានរដូវ ជាទីរីកនៃផ្កាកុមុទ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះ កំពុងតែបវារណា ហើយមានភិក្ខុណាមួយឃាត់បវារណាដល់ភិក្ខុនោះ គួរភិក្ខុដែលត្រូវគេឃាត់នោះ និយាយនឹងភិក្ខុអ្នកឃាត់នោះយ៉ាងនេះថា នែអាវុសោ លោកមិនមែនជាឥស្សរៈ ក្នុងការបវារណារបស់ខ្ញុំទេ ខ្ញុំបានបវារណាហើយ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយនោះ កំពុងតែបវារណា ក៏ភិក្ខុនោះឃាត់បវារណារបស់ភិក្ខុណាមួយ។ ត្រូវសង្ឃដេញដោល សាកសួរភិក្ខុទាំងពីររូប លុះដេញដោល សាកសួរហើយ ឲ្យភិក្ខុទាំងពីររូបធ្វើតាមធម៌ ហើយសឹមបវារណា ដោយសង្ឃបវារណាចុះ។

ចប់ បវារណក្ខន្ធកៈ ទី៤។

រឿងក្នុងខន្ធកៈនេះមាន៤៦រឿង។

ឧទ្ទាននៃបវារណក្ខន្ធកៈនោះគឺ

## ១៤៦. តស្សុទ្ទានំ

CS vin.mv.04.27 | ភាគ ទី៧

**(១៤៦)**

[៤៨] រឿងពួកភិក្ខុនៅចាំវស្សាក្នុងកោសលជនបទ មកគាល់ព្រះសាស្តា១ រឿងភិក្ខុនៅរួមគ្នាដូចបសុសត្វ (គឺសត្វដែលគេចិញ្ចឹម) មិនជាទីសប្បាយ១ រឿងបវារណាជាការអនុលោមដល់គ្នានឹងគ្នា១ រឿងពួកឆព្វគ្គិយភិក្ខុអង្គុយលើអាសនៈ ក្នុងពេលដែលភិក្ខុជាថេរៈ កំពុងបវារណា១ រឿងបវារណាមានពីរយ៉ាង១ រឿងបវារណាកម្មបួនយ៉ាង១ រឿងព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុឈឺឲ្យបវារណា១ រឿងញាតិចាប់ភិក្ខុក្នុងថ្ងៃបវារណា១ រឿងស្តេចចាប់ភិក្ខុក្នុងថ្ងៃបវារណា១ រឿងពួកចោរចាប់ភិក្ខុក្នុងថ្ងៃបវារណា១ រឿងពួកអ្នកលេងចាប់ភិក្ខុក្នុងថ្ងៃបវារណា១ រឿងភិក្ខុជាសត្រូវចាប់ភិក្ខុក្នុងថ្ងៃបវារណា១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុប្រាំរូបធ្វើបវារណាដោយសង្ឃបវារណា១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុបួនរូបបវារណាដល់គ្នានឹងគ្នា១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុបីរូបបវារណាដល់គ្នានឹងគ្នា១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុពីររូបបវារណាដល់គ្នានឹងគ្នា១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុមួយរូបអធិដ្ឋានបវារណា១ រឿងភិក្ខុត្រូវអាបត្តិក្នុងថ្ងៃបវារណា១ រឿងភិក្ខុសង្ស័យអាបត្តិក្នុងថ្ងៃបវារណា១ រឿងភិក្ខុកំពុងតែបវារណា ហើយរលឹកឃើញអាបត្តិ១ រឿងសង្ឃទាំងអស់ត្រូវសភាគាបត្តិក្នុងថ្ងៃបវារណា១ រឿងសង្ឃទាំងអស់សង្ស័យសភាគាបត្តិ១ រឿងភិក្ខុនៅក្នុងអាវាសច្រើនជាង និងស្មើគ្នា និងតិចជាង១ រឿងពួកអាវាសិកភិក្ខុប្រកាន់ថាថ្ងៃដប់បួន តែពួកអាគន្តុកភិក្ខុប្រកាន់ថាថ្ងៃដប់ប្រាំ១ រឿងភេទ និងសំវាសទាំងពីររបស់អាវាសិកភិក្ខុនិងអាគន្តុកភិក្ខុ១ រឿងភិក្ខុគួរទៅកាន់អាវាសដែលមានភិក្ខុក្នុងថ្ងៃបវារណា១ រឿងភិក្ខុមិនត្រូវបវារណាក្នុងបរិសទ្យដែលភិក្ខុនីអង្គុយជាមួយ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុបវារណាក្នុងការឲ្យឆន្ទៈ១ រឿងសញ្ចរភ័យ១ រឿងមនុស្សឲ្យទានក្នុងថ្ងៃបវារណាដរាបដល់ទៀបភ្លឺ១ រឿងមានភ្លៀងក្នុងថ្ងៃបវារណា១ រឿងការអន្តរាយដល់បវារណា១ រឿងព្រះអង្គទ្រង់ហាមមិនឲ្យភិក្ខុមានអាបត្តិធ្វើបវារណា១ រឿងពួកឆព្វគ្គិយភិក្ខុគិតថា ពួកបេសលភិក្ខុឃាត់បវារណាដល់ពួកយើង ហើយប្រញាប់ឃាត់បវារណាជាមុន១ រឿងភិក្ខុឃាត់បវារណាមិនបាន១ រឿងភិក្ខុឃាត់បវារណាដល់ភិក្ខុផងគ្នាក្នុងថ្ងៃបវារណា១ (សេចក្តីសួរថា លោកឃាត់បវារណា) ព្រោះហេតុអ្វី១ រឿងសួរថាវិបត្តិដូចម្តេចខ្លះ១ រឿងឃាត់បវារណាដោយឃើញ ដោយឮ ដោយរង្កៀស១ រឿងភិក្ខុអ្នកចោទ១ រឿងភិក្ខុដែលត្រូវចោទ១ រឿងភិក្ខុត្រូវអាបត្តិថុល្លច្ច័យ១ រឿងវត្ថុនិងបុគ្គល១ រឿងភិក្ខុអ្នកធ្វើការបង្កហេតុ១ រឿងបវារណាសង្គហៈ១ រឿងភិក្ខុមិនជាធំក្នុងការបវារណា១ រឿងសង្ឃគួរសាកសួរភិក្ខុទាំងពីររូប ហើយឲ្យភិក្ខុទាំងពីររូបធ្វើតាមធម៌ ហើយសឹមបវារណា១។

# ចម្មក្ខន្ធកៈ

CS vin.mv.05 | ភាគ ទី៧

**(៥. ចម្មក្ខន្ធកោ)**

## ១៤៧. សោណកោឡិវិសវត្ថុ

CS vin.mv.05.01 | ភាគ ទី៧

**(១៤៧)**

[៤៩] សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ។ គ្រានោះឯង ព្រះបាទមាគធសេនិយពិម្ពិសារ សោយរាជ្យជាឥស្សរាធិបតិលើអ្នកស្រុកទាំង៨ម៉ឺន។ សម័យនោះឯង ក្នុងក្រុងចម្បា មានកូនសេដ្ឋីម្នាក់ឈ្មោះសោណៈ ជាកោឡិវិសគោត្ត ហើយជាសុខុមាលជាតិ។ សេដ្ឋិបុត្តនោះ មានរោមជាច្រើនដុះត្រង់បាតជើងទាំងពីរ។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ប្រជុំពួកអ្នកស្រុកទាំង៨ម៉ឺន ហើយទ្រង់បញ្ជូនរាជបម្រើទៅក្នុងសំណាក់សោណកោឡិវិសដោយមានកិច្ចអ្វីនីមួយថា សោណៈចូរមក ដ្បិតយើងចង់ឲ្យសោណៈមក។ វេលានោះឯង ឯមាតាបិតានៃសោណកោឡិវិសបាននិយាយពាក្យនេះនឹងសោណកោឡិវិសថា នែសោណៈកូន ឥឡូវស្តេចចង់ទតមើលជើងរបស់អ្នក នែសោណៈកូន អ្នកឯងកុំចាំបាច់លាជើងបង្ហាញស្តេចឡើយ អ្នកឯងចូរអង្គុយពែនភ្នែនចំពោះព្រះភក្ត្រស្តេចចុះ កាលបើអ្នកអង្គុយនៅហើយ ស្តេចគង់នឹងទតឃើញជើងអ្នកហើយ។ គ្រានោះឯង ពួកជនក៏បាននាំសោណកោឡិវិសមកដោយគ្រែស្នែង (មកថ្វាយស្តេច)។ ខណៈនោះ សោណកោឡិវិស ក៏បានចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបាទមាគធសេនិយពិម្ពិសារ រួចហើយអង្គុយពែនភ្នែនចំពោះព្រះភក្ត្រស្តេច។ ឯព្រះបាទមាគធសេនិយពិម្ពិសារ ក៏បានទតទៅឃើញរោមទាំងឡាយដែលដុះពេញបាតជើងរបស់សោណកោឡិវិស។ គ្រានោះឯង ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់បានប្រដៅនូវប្រយោជន៍[18] ទាំងឡាយជាបច្ចុប្បន្ន ចំពោះពួកអ្នកស្រុកទាំង៨ម៉ឺននោះស្រេចហើយ ក៏ទ្រង់បញ្ជូនទៅវិញថា នែនាយទាំងឡាយ យើងបានប្រដៅអ្នករាល់គ្នា ក្នុងប្រយោជន៍ជាបច្ចុប្បន្នហើយ អ្នកទាំងឡាយចូរនាំគ្នាទៅវិញចុះ តែអ្នកទាំងឡាយត្រូវនាំគ្នាទៅគាល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគនោះ មុខជានឹងប្រៀនប្រដៅនូវប្រយោជន៍ទាំងឡាយក្នុងបរលោកដល់យើងទាំងឡាយ។ វេលានោះឯង ពួកអ្នកស្រុកទាំង៨ម៉ឺននោះ បានទៅឯភ្នំគិជ្ឈកូដ។ សម័យនោះឯង ព្រះសាគតដ៏មានអាយុ ជាអ្នកបម្រើព្រះដ៏មានព្រះភាគ។ វេលានោះ ពួកអ្នកស្រុកទាំង៨ម៉ឺននោះ បានចូលទៅរកព្រះសាគតដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងព្រះសាគតដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ឥឡូវពួកអ្នកស្រុកទាំង៨ម៉ឺននេះ បានចូលមកក្នុងទីនេះ ដើម្បីឃើញព្រះដ៏មានព្រះភាគ បពិត្រលោកដ៏ចំរើន យើងខ្ញុំគួរបានឃើញព្រះដ៏មានព្រះភាគ ទើបជាការប្រពៃ។ ព្រះសាគតភិក្ខុតបវិញថា នែអ្នកដ៏មានអាយុទាំងឡាយ បើដូច្នោះ អ្នករាល់គ្នាឈប់បង្អង់ចាំអាត្មានៅទីនេះ១ស្របក់ចុះ ចាំអាត្មាក្រាបទូលព្រះដ៏មានព្រះភាគសិន។ គ្រានោះឯង កាលពួកអ្នកស្រុកទាំង៨ម៉ឺននោះកំពុងតែសំឡឹងមើលក្នុងទីចំពោះមុខ ព្រះសាគតដ៏មានអាយុ ក៏ជ្រែកចុះចំផែនថ្ម[19] ហើយទៅផុសក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ រួចក៏បានពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវមានពួកអ្នកស្រុកទាំង៨ម៉ឺននេះ បានចូលមកក្នុងទីនេះដើម្បីឃើញព្រះដ៏មានព្រះភាគ បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគរមែងជ្រាបនូវកាលគួរ ជាប្រយោជន៍ក្នុងកាលឥឡូវនេះ។ ព្រះដ៏មានព្រះភាគតបថា នែសាគត បើដូច្នោះ អ្នកចូរទៅរៀបចំក្រាលអាសនៈ ត្រង់ម្លប់នៃវិហារចុះ។ ព្រះសាគតដ៏មានអាយុ បានទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏នាំយកតាំង ជ្រែកចុះក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ កាលអ្នកស្រុកទាំង៨ម៉ឺននោះ កំពុងសំឡឹងមើលក្នុងទីចំពោះមុខ ក៏ស្រាប់តែទៅផុសចំផែនថ្ម ហើយក្រាលអាសនៈត្រង់ម្លប់នៃវិហារ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់យាងចេញពីវិហារ ទៅគង់នៅលើអាសនៈដែលព្រះសាគតត្ថេរៈបានក្រាលត្រង់ម្លប់នៃវិហារ។ លំដាប់នោះឯង ពួកអ្នកស្រុកទាំង៨ម៉ឺននោះ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ គ្រានោះ ពួកអ្នកស្រុកទាំង៨ម៉ឺននោះ ក៏អបអរ រាក់ទាក់នឹងព្រះសាគតដ៏មានអាយុទៅវិញ មិនបានអបអររាក់ទាក់នឹងព្រះដ៏មានព្រះភាគ ដូច្នោះឡើយ។ វេលានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបសេចក្តីបរិវិតក្ក ក្នុងចិត្តរបស់ពួកអ្នកស្រុកទាំង៨ម៉ឺន ដោយព្រះទ័យនោះហើយ ទើបទ្រង់ត្រាស់ហៅព្រះសាគតដ៏មានអាយុមកថា នែសាគត បើដូច្នោះ អ្នកចូរសំដែងឥទ្ធិប្បាដិហារ្យ ដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ឲ្យក្រៃលែងឡើងទៅទៀត។ ព្រះសាគតដ៏មានអាយុបានទទួលស្តាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ហោះទៅលើវេហាស៍ ចង្រ្កម គឺដើរខ្លះ ឈរខ្លះ គង់ខ្លះ សិងខ្លះ បណ្តាលឲ្យកើតផ្សែងខ្លះ បណ្តាលឲ្យកើតភ្លើងខ្លះ បាត់ខ្លួនទៅខ្លះ ក្នុងប្រទេសទំនេរ គឺអាកាស។ វេលានោះ ព្រះសាគតដ៏មានអាយុ លុះបានសំដែងឥទ្ធិប្បាដិហារ្យ ជាធម៌របស់មនុស្សជាន់ខ្ពស់ មានប្រការច្រើនយ៉ាង នៅលើប្រទេសទំនេរ គឺអាកាសរួចហើយ ក៏មកក្រាបសិរសា ទៀបព្រះបាទា នៃព្រះដ៏មានព្រះភាគ ហើយក៏បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគ ជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក។ ខណៈនោះ អ្នកស្រុកទាំង៨ម៉ឺននោះ ក៏ពោលថា នែគ្នាយើងដ៏ចំរើន គួរអស្ចារ្យពេកណាស់ នែគ្នាយើងដ៏ចំរើន ហេតុដែលមិនធ្លាប់កើត កើតឡើងហើយតើ អម្បាលសាវកមានឫទ្ធិខ្លាំង មានអានុភាពច្រើនម្ល៉ោះទៅហើយ ចំណង់បើគ្រូ គង់មានឫទ្ធានុភាពក្រៃលែង ជាងនេះពិតប្រាកដ ហើយបែរមកអបអរ រាក់ទាក់ នឹងព្រះដ៏មានព្រះភាគវិញ លែងអបអររាក់ទាក់ នឹងព្រះសាគតដ៏មានអាយុដូច្នោះទៀតឡើយ។ វេលានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ជ្រាបសេចក្តីបរិវិតក្ក ក្នុងចិត្តរបស់ពួកអ្នកស្រុក ទាំង៨ម៉ឺននោះ ដោយព្រះទ័យហើយ ទើបទ្រង់សំដែងនូវអនុបុព្វីកថា ឯអនុបុព្វីកថានោះ តើដូចម្តេចខ្លះ គឺព្រះអង្គទ្រង់សំដែងទានកថា សីលកថា សគ្គកថា សំដែងពីទោស របស់កាមគុណ ដែលជារបស់លាមកសៅហ្មង និងអានិសង្សក្នុងកិរិយាចេញបួស។ ព្រះដ៏មានព្រះភាគ ជាម្ចាស់ ទ្រង់បានជ្រាបថា ពួកជនទាំងនោះមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លាក្នុងវេលាណាហើយ ក៏ទ្រង់សំដែងនូវធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើងសំដែងដោយព្រះអង្គឯង គឺសំដែងពីកងទុក្ខ ហេតុដែលនាំឲ្យកើតកងទុក្ខ សេចក្តីរំលត់នូវកងទុក្ខ និងផ្លូវដែលដល់នូវសេចក្តីរំលត់កងទុក្ខ ក្នុងវេលានោះ។ សំពត់សស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួលយកគ្រឿងជ្រលក់ដោយល្អ យ៉ាងណាមិញ ធម្មចក្ខុ (គឺសោតាបត្តិមគ្គ) ឥតមានធូលី ឥតមានមន្ទិល ក៏កើតឡើងដល់ពួកអ្នកស្រុកទាំង៨ម៉ឺននោះ លើអាសនៈនោះថា ធម្មជាតឯណានីមួយ មានសេចក្តីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងមានសេចក្តីរលត់ទៅវិញជាធម្មតា យ៉ាងនោះឯង។ ពួកជនទាំងនោះ ក៏បានយល់នូវអរិយសច្ចធម៌ហើយ បានដល់នូវអរិយសច្ចធម៌ហើយ បានដឹងច្បាស់ នូវអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចេញពីសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនបានជឿបុគ្គលដទៃ ក្នុងសាសនា នៃព្រះសាស្តា ក៏បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ច្បាស់ណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ច្បាស់ណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលផ្ងារឡើង នូវភាជន៍ដែលគេផ្កាប់ចុះ ឬបើកឡើង នូវវត្ថុដែលកំបាំង ឬប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬទ្រោលបំភ្លឺប្រទីបប្រេង ក្នុងទីងងឹត ដោយគិតថា ពួកជនដែលមានចក្ខុ នឹងបានឃើញនូវរូបទាំងឡាយ យ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគ បានសំដែងដោយអនេកបរិយាយ ក៏ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយនេះ សូមដល់នូវព្រះដ៏មានព្រះភាគ ជាម្ចាស់ផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផងថា ជាទីរលឹក សូមព្រះដ៏មានព្រះភាគជាម្ចាស់ ចាំទុកនូវយើងខ្ញុំថា ជាឧបាសក បានដល់នូវព្រះរតនត្រ័យ ថាជាទីរលឹកស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះទៅ។

## សោណស្ស បព្វជ្ជា

## (សោណស្ស បព្វជ្ជា)

[៥០] គ្រានោះ សោណកោឡិវិស មានសេចក្តីត្រិះរិះដូច្នេះថា ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ យ៉ាងណាៗ អាត្មាអញក៏បានដឹងជាក់ បុគ្គលដែលនៅគ្រប់គ្រងរក្សាផ្ទះនេះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យពេញលេញ ឲ្យបរិសុទ្ធដោយចំណែក១ ដូចជាសង្ខ ដែលបុគ្គលដុសខាត់ហើយទេ បើដូច្នោះ មានតែអាត្មាអញនឹងកោរសក់ ពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាយ ចេញចាកផ្ទះ ហើយបួសក្នុងភាព នៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ។ ខណៈនោះ ពួកអ្នកស្រុកទាំង៨ម៉ឺននោះ ក៏បានត្រេកអររីករាយនឹងធម៌ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ក៏ក្រោកចេញចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចធ្វើប្រទក្សិណ ហើយក៏ចៀសចេញទៅ។ វេលានោះឯង សោណកោឡិវិស កាលបើពួកអ្នកស្រុកទាំង៨ម៉ឺន ចៀសចេញទៅមិនយូរប៉ុន្មាន បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ សោណកោឡិវិស លុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គ ទ្រង់សំដែងហើយ យ៉ាងណាៗ ខ្ញុំព្រះអង្គក៏ដឹងបានទាំងអស់ បុគ្គលដែលនៅគ្រប់គ្រងរក្សាផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបានពេញលេញ ឲ្យបានបរិសុទ្ធដោយចំណែក១ ដូចជាសង្ខ ដែលបុគ្គលដុសខាត់ហើយទេ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវ ខ្ញុំព្រះអង្គចង់កោរសក់ និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាយ ចេញចាកផ្ទះ ហើយបួសក្នុងភាពនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ព្រះមេត្តាបំបួសខ្ញុំព្រះអង្គ។ សោណកោឡិវិស បានបព្វជ្ជាឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ។ លុះព្រះសោណដ៏មានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏បានទៅគង់នៅព្រៃសីតវន (ព្រៃត្រជាក់)។ កាលសោណភិក្ខុនោះ ខំព្យាយាមខ្លាំង ដើរចង្រ្កមទៅ បាទារបស់លោកក៏បែក (ចេញឈាម)។ ទីចង្រ្កមក៏ប្រឡាក់ដោយឈាម ដូចជាទីដែលសម្រាប់សម្លាប់គោ។ ខណៈនោះ កាលព្រះសោណៈដ៏មានអាយុ សម្ងំក្នុងទីស្ងាត់ ក៏កើតការត្រិះរិះក្នុងចិត្តយ៉ាងនេះថា ពួកសាវកឯណាមួយ នៃព្រះដ៏មានព្រះភាគ ដែលមានព្យាយាមប្រឹងប្រែង បណ្តាសាវកទាំងនោះ អាត្មាអញ ក៏ជាសាវកមួយដែរ តែបើទុកជាដូច្នោះ ក៏ចិត្តរបស់អាត្មាអញនៅមិនទាន់ផុតចាកអាសវៈ ដោយមិនមានឧបាទានឡើយ ឯត្រកូលរបស់អាត្មាអញ ក៏មានទ្រព្យសម្បត្តិបរិបូណ៌ដែរ អាត្មាអញ អាចនឹងបរិភោគទ្រព្យសម្បត្តិផង អាចនឹងធ្វើបុណ្យផង បើដូច្នោះ គួរអាត្មាអញ វិលត្រឡប់ទៅ ដើម្បីហីនភេទវិញ (គឺសឹក) ហើយនឹងបរិភោគទ្រព្យសម្បត្តិផង ធ្វើបុណ្យផង។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់បានជ្រាបសេចក្តីត្រិះរិះ ក្នុងចិត្តរបស់ព្រះសោណៈដ៏មានអាយុ ដោយព្រះទ័យហើយ ក៏ស្រាប់តែបាត់ព្រះអង្គពីលើភ្នំគិជ្ឈកូដ ទៅប្រាកដព្រះអង្គនៅឯព្រៃសីតវន ប្រៀបដូចបុរសមានកំឡាំង លាចេញនូវដើមដៃ ដែលខ្លួនបត់ចូល ឬបត់ចូលនូវដើមដៃ ដែលខ្លួនលាចេញ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់សេនាសនចារិក ជាមួយនឹងពួកភិក្ខុជាច្រើនរូប បានយាងសំដៅទៅកាន់ទីចង្រ្កមរបស់ព្រះសោណៈដ៏មានអាយុនោះ។ ព្រះមានព្រះភាគ ក៏បានទតទៅឃើញទីចង្រ្កមរបស់ព្រះសោណៈដ៏មានអាយុប្រឡាក់ដោយឈាម លុះទតឃើញហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយមកសួរថា ម្នាលភិក្ខុទាំងឡាយ ទីចង្រ្កមនេះ ជាទីចង្រ្កមរបស់អ្នកណា បានជាប្រឡាក់ដោយឈាម ដូចជាទីសម្រាប់សម្លាប់គោ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលព្រះសោណៈដ៏មានអាយុខំព្យាយាមដើរចង្រ្កមទៅ បាទារបស់លោកក៏បែក នេះជាទីចង្រ្កមរបស់លោកនោះ ដែលប្រឡាក់ដោយឈាម ដូចជាទីដែលសម្រាប់សម្លាប់គោ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់យាងចូលទៅកាន់វិហាររបស់ព្រះសោណៈដ៏មានអាយុ លុះយាងចូលទៅដល់ហើយ ក៏ទ្រង់គង់នៅលើអាសនៈ ដែលគេបានក្រាលទុក។ ចំណែកឯព្រះសោណៈដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយនៅក្នុងទីដ៏សមគួរ។ លុះព្រះសោណៈដ៏មានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលយ៉ាងនេះថា នែសោណៈ កាលអ្នកសម្ងំនៅក្នុងទីស្ងាត់ ក៏កើតការត្រិះរិះក្នុងចិត្តយ៉ាងនេះថា ពួកសាវកណាមួយ របស់ព្រះមានព្រះភាគ ដែលមានព្យាយាមប្រឹងប្រែង បណ្តាសាវកទាំងនោះ អាត្មាអញ ក៏ជាសាវកមួយដែរ តែបើទុកជាដូច្នោះ ក៏ចិត្តរបស់អាត្មាអញនៅមិនទាន់ផុតចាកអាសវៈទាំងឡាយ ដោយមិនមានឧបាទានឡើយ ម្យ៉ាងទៀត ទ្រព្យសម្បត្តិក្នុងត្រកូលរបស់អាត្មាអញ ក៏មានបរិបូណ៌ អាត្មាអញអាចនឹងបរិភោគទ្រព្យសម្បត្តិផង ធ្វើបុណ្យផង បើដូច្នោះ គួរអាត្មាអញ វិលត្រឡប់ទៅ ដើម្បីហីនភេទ ហើយបរិភោគ នូវទ្រព្យសម្បត្តិផង ធ្វើបុណ្យផង។ សោណៈភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន។ ព្រះមានព្រះភាគទ្រង់សួរថា នែសោណៈ អ្នកឯងសំគាល់ហេតុនោះដូចម្តេច កាលពីដើមអ្នកឯងនៅជាគ្រហស្ថនោះ ជាអ្នកឆ្លាសក្នុងសូរសំឡេងខ្សែពិណឬ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន។ ព្រះមានព្រះភាគ ទ្រង់សួរថា នែសោណៈ អ្នកឯងសំគាល់ហេតុនោះដូចម្តេច កាលណាខ្សែពិណ របស់អ្នកតឹងពេកទៅ តើពិណរបស់អ្នកឯង មានសំឡេងពីរោះឬ គួរដល់ការងារ ក្នុងកាលនោះដែរឬ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ការនុ៎ះមិនដូច្នោះទេ។ ព្រះមានព្រះភាគទ្រង់សួរថា នែសោណៈ អ្នកឯងសំគាល់ហេតុនោះដូចម្តេច កាលណាបើខ្សែពិណ របស់អ្នកធូរពេក តើពិណរបស់អ្នកឯង មានសំឡេងពីរោះឬ គួរដល់ការងារ ក្នុងកាលនោះដែរឬ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ការនុ៎ះមិនដូច្នោះទេ។ ព្រះមានព្រះភាគទ្រង់សួរថា នែសោណៈ អ្នកសំគាល់ហេតុនោះដូចម្តេច កាលណាបើខ្សែពិណ របស់អ្នក មិនតឹងពេក មិនធូរពេក តាំងនៅក្នុងគុណដ៏ល្មម តើពិណរបស់អ្នកឯង មានសំឡេងពីរោះឬ គួរដល់ការងារក្នុងកាលនោះដែរឬ។ ព្រះសោណៈនោះក្រាបទូលថា ព្រះករុណាព្រះអង្គ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែសោណៈ សេចក្តីព្យាយាមដែលតឹងពេក នាំឲ្យកើតសេចក្តីរាយមាយ សេចក្តីព្យាយាមដែលធូរពេក នាំឲ្យកើតសេចក្តីខ្ជិលច្រអូស ដូចខ្សែពិណយ៉ាងនោះឯង ព្រោះហេតុនោះ នែសោណៈ ក្នុងវេលានេះ អ្នកចូរតាំងសេចក្តីព្យាយាមឲ្យស្មើ ក្នុងធម្មវិន័យនេះ ត្រូវប្រើឥន្រ្ទិយទាំងឡាយឲ្យស្មើគ្នាផង ត្រូវកាន់យកនូវនិមិត្តក្នុងសមថៈនោះផង។ ព្រះសោណៈដ៏មានអាយុ បានទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ។ វេលានោះឯង ព្រះមានព្រះភាគ ទ្រង់ទូន្មានព្រះសោណៈដ៏មានអាយុ ដោយឱវាទនេះរួចហើយ ទើបទ្រង់បាត់ព្រះអង្គ អំពីទីចំពោះមុខ នៃព្រះសោណៈដ៏មានអាយុ នៅនាព្រៃសីតវន ហើយទ្រង់ប្រាកដនៅលើភ្នំគិជ្ឈកូដវិញ ប្រៀបដូចជាបុរសដែលមានកំឡាំង លាដើមដៃ ដែលខ្លួនបត់ចូល ឬបត់ចូល នូវដើមដៃ ដែលខ្លួនលាចេញ។ លំដាប់នោះ លុះសម័យតមក ព្រះសោណៈដ៏មានអាយុ ក៏បានតាំងសេចក្តីព្យាយាមស្មើ បានប្រើឥន្រ្ទិយទាំង៥ក៏ស្មើគ្នាផង បានកាន់យកនូវនិមិត្តក្នុងសមថៈនោះឯង។ វេលានោះ ព្រះសោណៈដ៏មានអាយុ បានចៀសចេញ ទៅតែម្នាក់ឯង ឥតមានសេចក្តីប្រមាទឡើយ ខំព្យាយាម ដុតបង់នូវកិលេស បញ្ជូនចិត្តឲ្យបែរទៅ (កាន់ព្រះនិព្វាន) ពួកកុលបុត្រ ដែលចេញចាកផ្ទះហើយ ទៅបួសក្នុងភាពជាបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា (ព្រះសោណៈ) ក៏បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ជាទីបំផុត នៃមគ្គព្រហ្មចារ្យ ដោយបញ្ញារបស់ខ្លួន ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤ មិនយូរប៉ុន្មាន ក៏បានដឹង

ច្បាស់ថា ជាតិកំណើតរបស់អាត្មាអញ អស់ហើយ ព្រហ្មចរិយធម៌អញ ក៏បាននៅចប់ហើយ កិច្ចដែលត្រូវធ្វើ អញក៏បានធ្វើហើយ នឹងមានកិច្ចដទៃអំពីកិច្ចនេះតទៅទៀត គ្មានឡើយ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះសោណៈដ៏មានអាយុ ក៏ជាព្រះអរហន្តអង្គមួយដែរ។

[៥១] លំដាប់នោះ កាលព្រះសោណៈដ៏មានអាយុ បានសម្រេចព្រះអរហត្តហើយ ក៏មានសេចក្តីរិះគិតដូច្នេះថា បើដូច្នោះ មានតែអាត្មាអញនឹងសំដែងគុណ គឺអរហត្តផល ក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ វេលានោះ ព្រះសោណៈដ៏មានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ ព្រះសោណៈដ៏មានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា ជាព្រះអរហន្តខីណាស្រព បានសិក្សាព្រហ្មចារ្យចប់ហើយ មានកិច្ចសម្រេចហើយ មានភារៈដាក់ចុះហើយ[20] បានសម្រេចប្រយោជន៍របស់ខ្លួនហើយ មានកិលេស ជាគ្រឿងប្រកបសត្វក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ (ចាកកិលេស) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមានអធ្យាស្រ័យបង្អោនទៅកាន់ហេតុទាំង៦យ៉ាង គឺមានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្ម[21] (គឺអរហត្ត)១ មានអធ្យាស្រ័យបង្អោនទៅក្នុងទីស្ងាត់១ មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ១ មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ ជាគ្រឿងអស់ទៅនៃឧបាទាន១ មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ ជាគ្រឿងអស់ទៅនៃតណ្ហា១ មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេង១ បពិត្រព្រះអង្គដ៏ចំរើន មានហេតុថា ក្នុងលោកនេះ មានលោកដ៏មានអាយុពួកខ្លះ មានសេចក្តីរិះគិតដូច្នេះថា លោកដ៏មានអាយុនេះ ឈ្មោះថាមានអធ្យាស្រ័យ បង្អោនទៅកាន់នេក្ខម្មៈ ព្រោះអាស្រ័យនូវគុណ គ្រាន់តែសេចក្តីជឿប៉ុណ្ណោះឯង បពិត្រព្រះអង្គដ៏ចំរើន បុគ្គលកុំគប្បីយល់ហេតុនេះ ដូច្នេះឡើយ បពិត្រព្រះអង្គដ៏ចំរើន ឯភិក្ខុ ដែលជាព្រះខីណាស្រព បានសិក្សាព្រហ្មចារ្យចប់ហើយ មានកិច្ចសម្រេចហើយ កាលមិនបានពិចារណាខ្លួន ដែលមានកិច្ចត្រូវធ្វើ ឬមិនបានពិចារណា នូវសេចក្តីចំរើននៃកិច្ច ដែលខ្លួនបានធ្វើហើយ បានឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ បពិត្រព្រះអង្គដ៏ចំរើន មានហេតុថា ក្នុងលោកនេះ មានលោកដ៏មានអាយុពួកខ្លះ មានសេចក្តីរិះគិតយ៉ាងនេះថា លោកដ៏មានអាយុនេះ ជាអ្នកប្រាថ្នាលាភសក្ការៈ និងសេចក្តីសរសើរហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅក្នុងទីដ៏ស្ងាត់ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលកុំគប្បីយល់ហេតុនេះ ដូច្នេះឡើយ បពិត្រព្រះអង្គដ៏ចំរើន ឯភិក្ខុជាព្រះខីណាស្រព សិក្សាព្រហ្មចារ្យចប់ហើយ មានកិច្ចសម្រេចហើយ មិនបានពិចារណានូវខ្លួនដែលមានកិច្ចត្រូវធ្វើ ឬមិនបានពិចារណានូវសេចក្តីចំរើននៃកិច្ច ដែលខ្លួនបានធ្វើហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅក្នុងទីដ៏ស្ងាត់ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅក្នុងទីដ៏ស្ងាត់ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅក្នុងទីដ៏ស្ងាត់ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ បពិត្រព្រះអង្គដ៏ចំរើន មានហេតុថា ក្នុងលោកនេះ មានលោកដ៏មានអាយុពួកខ្លះ មានសេចក្តីរិះគិតយ៉ាងនេះថា លោកដ៏មានអាយុនេះ កាលត្រឡប់មកកាន់សេចក្តីប្រកាន់សីល ប្រកាន់វត្តដោយសភាវៈថ្លៃថ្លា ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលកុំគប្បីយល់ហេតុនេះ ដូច្នេះឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាព្រះខីណាស្រព បានសិក្សាព្រហ្មចារ្យចប់ហើយ មានកិច្ចសម្រេចហើយ មិនបានពិចារណានូវខ្លួន ដែលមានកិច្ចត្រូវធ្វើ ឬមិនបានពិចារណា នូវសេចក្តីចំរើន នៃកិច្ចដែលខ្លួនធ្វើហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ ឈ្មោះថាមានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ ជាគ្រឿងអស់ទៅនៃឧបាទាន ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ ជាគ្រឿងអស់ទៅនៃឧបាទាន ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ ជាគ្រឿងអស់ទៅនៃឧបាទាន ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ ជាគ្រឿងអស់ទៅ នៃតណ្ហា ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថា មានអធ្យាស្រ័យ បង្អោនទៅកាន់ធម៌ ជាគ្រឿងអស់ទៅ នៃតណ្ហា ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ ជាគ្រឿងអស់ទៅ នៃតណ្ហា ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេង ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេង ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈហើយ ឈ្មោះថា មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេង ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈហើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុកាលបើមានចិត្តផុតស្រឡះប្រពៃយ៉ាងនេះហើយ បើទុកជារូបទាំងឡាយដែលមានកំឡាំងគួរនឹងដឹងច្បាស់ដោយភ្នែក មកកាន់គន្លងភ្នែក ក៏មិនបានគ្របសង្កត់ចិត្តរបស់ភិក្ខុនោះបានឡើយ ចិត្តរបស់ភិក្ខុនោះ ដែលអារម្មណ៍មិនបានធ្វើឲ្យច្រឡំ ដោយកិលេស ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ឥតមានកម្រើក ដោយតណ្ហាហើយ ពិចារណាឃើញនូវសេចក្តីកើតឡើង និងសេចក្តីរលត់ទៅនៃចិត្តនោះ បើសំឡេងទាំងឡាយដែលមានកំឡាំងគួរនឹងដឹងច្បាស់ដោយត្រចៀកបាន... ក្លិនទាំងឡាយដែលមានកំឡាំងគួរនឹងដឹងច្បាស់ដោយច្រមុះបាន... រសទាំងឡាយ ដែលមានកំឡាំងគួរនឹងដឹងច្បាស់ដោយអណ្តាតបាន... ផោដ្ឋព្វៈ (គឺអារម្មណ៍ដែលមកប៉ះត្រូវកាយ) ទាំងឡាយ ដែលមានកំឡាំងគួរនឹងដឹងច្បាស់ដោយកាយបាន... ធម្មារម្មណ៍ (គឺអារម្មណ៍ដែលកើតក្នុងចិត្ត) ទាំងឡាយ ដែលមានកំឡាំងគួរនឹងដឹងច្បាស់ដោយចិត្តបាន មកកាន់ផ្លូវនៃចិត្ត ក៏គ្របសង្កត់ចិត្តរបស់លោកនោះមិនបានឡើយ ចិត្តរបស់លោកនោះ ដែលអារម្មណ៍មិនបានធ្វើឲ្យច្រឡំដោយកិលេស ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ឥតមានកម្រើកដោយតណ្ហាហើយ លោកបានពិចារណាឃើញ នូវសេចក្តីកើតឡើង និងសេចក្តីរលត់ទៅ នៃចិត្តនោះ បពិត្រព្រះអង្គដ៏ចំរើន ឧបមាដូចជាភ្នំថ្ម ឥតធ្លុះ ឥតប្រហោង ជាភ្នំតាន់សុទ្ធ បើមានសំណុំខ្យល់ ដែលមានកំឡាំងខ្លាំង បក់បោកមកពីទិសខាងកើតក្តី ក៏ញុំាងភ្នំនោះ ឲ្យកម្រើកមិនបាន ឲ្យរំជួយមិនបាន ឲ្យញាប់ញ័រមិនបានឡើយ បើមានសំណុំខ្យល់ ដែលមានកំឡាំងខ្លាំង បក់បោកមកពីទិសខាងលិចក្តី។បេ។ បើមានសំណុំខ្យល់ ដែលមានកំឡាំងខ្លាំង បក់បោកមកពីទិសខាងជើងក្តី។បេ។ បើមានសំណុំខ្យល់ ដែលមានកំឡាំងខ្លាំង បក់បោកមកពីទិសខាងត្បូងក្តី ក៏ញុំាងភ្នំនោះ ឲ្យកម្រើកមិនបាន ឲ្យរំជួយមិនបាន ឲ្យញាប់ញ័រមិនបានឡើយ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុកាលមានចិត្តផុតស្រឡះ ដោយប្រពៃយ៉ាងនេះហើយ បើរូបទាំងឡាយ ដែលមានកំឡាំង គួរនឹងដឹងច្បាស់ដោយភ្នែក មកកាន់គន្លងភ្នែកក្តី ក៏គ្របសង្កត់ចិត្ត របស់លោកនោះមិនបានឡើយ ចិត្តរបស់លោកនោះ ដែលអារម្មណ៍មិនបានធ្វើឲ្យច្រឡំដោយកិលេស ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ឥតមានកម្រើក ដោយតណ្ហា លោកពិចារណានូវសេចក្តីកើតឡើង និងសេចក្តីរលត់ទៅនៃចិត្តនោះ បើសំឡេងទាំងឡាយ ដែលមានកំឡាំងគួរនឹងដឹងច្បាស់ដោយត្រចៀកក្តី... ក្លិនទាំងឡាយ ដែលមានកំឡាំង គួរនឹងដឹងច្បាស់ដោយច្រមុះក្តី... រសទាំងឡាយដែលមានកំឡាំង គួរនឹងដឹងច្បាស់ដោយអណ្តាតក្តី... ផោដ្ឋព្វៈទាំងឡាយដែលមានកំឡាំងគួរនឹងដឹងច្បាស់ដោយកាយក្តី... ធម្មារម្មណ៍ទាំងឡាយ ដែលមានកំឡាំង

គួរនឹងដឹងច្បាស់ដោយចិត្ត មកកាន់ផ្លូវចិត្តក្តី ក៏គ្របសង្កត់នូវចិត្ត របស់លោកនោះមិនបានឡើយ ចិត្តរបស់លោកនោះ ដែលអារម្មណ៍មិនបានធ្វើឲ្យច្រឡំដោយកិលេស ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ឥតមានកម្រើកដោយតណ្ហា លោករមែងពិចារណា នូវសេចក្តីកើតឡើង និងសេចក្តីរលត់នៃចិត្តនោះ ក៏មានឧបមេយ្យដូច្នោះឯង។

[៥២] ភិក្ខុកាលបើមានអធ្យាស្រ័យបង្អោនទៅកាន់នេក្ខម្មៈ (គឺអរហត្ត)ផង មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីស្ងប់ស្ងាត់នៃចិត្តផង មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនព្យាបាទផង មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃឧបាទានផង មានអធ្យាស្រ័យបង្អោនទៅកាន់ធម៌ជាគ្រឿងអស់ទៅនៃតណ្ហាផង មានអធ្យាស្រ័យបង្អោនទៅកាន់សេចក្តីមិនវង្វេងនៃចិត្តផង ចិត្តក៏ផុតស្រឡះដោយប្រពៃ ព្រោះបានឃើញនូវសេចក្តីកើត និងសេចក្តីវិនាសនៃអាយតនៈ កាលភិក្ខុនោះមានចិត្តផុតស្រឡះហើយដោយប្រពៃ មានចិត្តរម្ងាប់ហើយ សេចក្តីចំរើននៃកិច្ចដែលភិក្ខុនោះបានធ្វើហើយក៏គ្មាន កិច្ចដែលគួរនឹងធ្វើក៏គ្មាន។ ថ្មដែលតាន់សុទ្ធ មិនបានរំជួយដោយខ្យល់ យ៉ាងណាមិញ រូប សំឡេង ក្លិន រស ផស្សៈ និងធម្មារម្មណ៍ទាំងអស់ ដែលជាទីគាប់ចិត្តក្តី មិនជាទីគាប់ចិត្តក្តី ក៏ញុំាងចិត្តរបស់ភិក្ខុជាតាទិបុគ្គល[22] ឲ្យញាប់ញ័រមិនបាន យ៉ាងនោះដែរ ចិត្តរបស់ភិក្ខុនោះ ជាចិត្តឋិតនៅខ្ជាប់ខ្ជួន ជាចិត្តផុតស្រឡះចាកកិលេសហើយ លោកពិចារណានូវសេចក្តីកើត និងសេចក្តីរលត់នៃចិត្តនោះ។

## ១៤៨. ទិគុណាទិឧបាហនបដិក្ខេបោ

CS vin.mv.05.02 | ភាគ ទី៧

**(១៤៨)**

[៥៣] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា នែភិក្ខុទាំងឡាយ ពួកកុលបុត្ត តែងប្រកាសគុណ គឺអរហត្តផលយ៉ាងនេះឯង ពួកកុលបុត្តទាំងនោះ បានប្រកាសសេចក្តីនៃបុគ្គលជាអរហន្តផង មិនបានបង្អោនខ្លួនទៅដោយអំនួតថា ខ្លួនជាព្រះអរហន្តផង ម្យ៉ាងទៀត ក្នុងលោកនេះ មានពួកមោឃបុរសខ្លះ ប្រកាសព្រះអរហត្តផល ទំនងធ្វើដូចជាសើចលេង មោឃបុរសទាំងនោះ តែងដល់នូវសេចក្តីចង្អៀតចង្អល់ ក្នុងកាលជាខាងក្រោយ (មិនខានឡើយ)។ វេលានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រះសោណៈដ៏មានអាយុថា នែសោណៈ អ្នកឯងធ្លាប់ចំរើនដោយសេចក្តីសុខ នែសោណៈ ឥឡូវនេះ តថាគតអនុញ្ញាតស្បែកជើង១ជាន់ឲ្យអ្នក។ ព្រះសោណៈនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានលះបង់ប្រាក់ចំនួន៨០រទេះធំ (គឺ១រទេះធំកំណត់ពីររទេះតូច) ផង បានលះបង់នូវពួកសេនាប្រកបដោយដំរី៧ផង ហើយបានចេញពីផ្ទះមកបួសក្នុងភាព នៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ជនទាំងឡាយមុខជានឹងពោល (តិះដៀល) ដល់ខ្ញុំព្រះអង្គថា សោណកោឡិវិស បានលះបង់ប្រាក់ចំនួន៨០រទេះយ៉ាងធំផង បានលះបង់ នូវពួកសេនា ប្រកបដោយដំរី៧ផង ហើយបានចេញចាកផ្ទះ មកបួសក្នុងភាព នៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ឥឡូវនេះ សោណកោឡិវិសនេះ នៅជាប់ចំពាក់នឹងស្បែកជើង១ជាន់ បើព្រះដ៏មានព្រះភាគ នឹងទ្រង់អនុញ្ញាតដល់ភិក្ខុសង្ឃ ទើបខ្ញុំព្រះអង្គហ៊ានប្រើប្រាស់ បើព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាតដល់ភិក្ខុសង្ឃទេ ខ្ញុំព្រះអង្គមិនហ៊ានប្រើប្រាស់ទេ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថា ក្នុងវេលានោះហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវស្បែកជើង១ជាន់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើង២ជាន់ មិនត្រូវពាក់ស្បែកជើង៣ជាន់ មិនត្រូវពាក់ស្បែកជើង៤ជាន់ឡើងទៅទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។

## ១៤៩. សព្វនីលិកាទិបដិក្ខេបោ

CS vin.mv.05.03 | ភាគ ទី៧

**(១៤៩)**

[៥៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើងពណ៌ខៀវសុទ្ធ (ដូចពណ៌ផ្កាត្រកៀត)។បេ។ ពាក់ស្បែកជើងពណ៌លឿងសុទ្ធ (ដូចពណ៌ផ្កាកណ្ណិការ)។ ពាក់ស្បែកជើងពណ៌ក្រហមសុទ្ធ (ដូចពណ៌ផ្កាច្បារ)។ ពាក់ស្បែកជើងពណ៌ហង្សបាទសុទ្ធ (ដូចពណ៌ស្បែង)។ ពាក់ស្បែកជើងពណ៌ខ្មៅសុទ្ធ (ដូចពណ៌ផ្លែផ្គាំ)។ ពាក់ស្បែកជើងពណ៌ក្រហមក្រមៅសុទ្ធ (ដូចពណ៌ខ្នងក្អែប)។ ពាក់ស្បែកជើងពណ៌លឿងទុំសុទ្ធ (ដូចពណ៌ស្លឹកឈើទុំ ឬដូចផ្កាឈូក)។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគនូវកាមគុណ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុះ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងពណ៌ខៀវសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌លឿងសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌ក្រហមសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌ហង្សបាទសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌ខ្មៅសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌ក្រហមក្រមៅសុទ្ធ មិនត្រូវពាក់ស្បែកជើងពណ៌លឿងទុំសុទ្ធឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើងមានខ្សែខៀវ។ ពាក់ស្បែកជើងមានខ្សែលឿង។ ពាក់ស្បែកជើងមានខ្សែក្រហម។ ពាក់ស្បែកជើងមានខ្សែហង្សបាទ។ ពាក់ស្បែកជើងមានខ្សែខ្មៅ។ ពាក់ស្បែកជើងមានខ្សែក្រហមក្រមៅ។ ពាក់ស្បែកជើងមានខ្សែលឿងទុំ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគនូវកាមគុណ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងមានខ្សែខៀវទេ មិនត្រូវពាក់ស្បែកជើងមានខ្សែលឿង មិនត្រូវពាក់ស្បែកជើងមានខ្សែក្រហម មិនត្រូវពាក់ស្បែកជើងមានខ្សែហង្សបាទ មិនត្រូវពាក់ស្បែកជើងមានខ្សែខ្មៅ មិនត្រូវពាក់ស្បែកជើងមានខ្សែក្រហមក្រមៅ មិនត្រូវពាក់ស្បែកជើងមានខ្សែលឿងទុំទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើងបិទកែង។ ពាក់ស្បែកជើងស្រោបជើងទាំងអស់រហូតដល់ស្មងជើង (ដូចជាស្បែកជើងអ្នកស្រុកយោនកៈ)។ ពាក់ស្បែកជើងដែលគេក្រង ជារបៀបបិទខ្នងជើង។ ពាក់ស្បែកជើងដែលញាត់ដោយគរ។ ពាក់ស្បែកជើង មានខ្សែវិចិត្រដូចស្លាបទទា។ ពាក់ស្បែកជើងមានខ្សែមានសណ្ឋានដូចស្នែងកែះ។ ពាក់ស្បែកជើងមានខ្សែមានសណ្ឋានដូចស្នែងពពែ។ ពាក់ស្បែកជើងមានខ្សែ មានសណ្ឋានដូចកន្ទុយសត្វខ្ទួយ។ ពាក់ស្បែកជើងដែលចាក់ស្រែះដោយព្រុយកន្ទុយក្ងោក។ ពាក់ស្បែកជើងដែលវិចិត្រ (ផ្សេងៗ)។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថ ដែលបរិភោគនូវកាមគុណ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុះ

ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងបិទកែង មិនត្រូវពាក់ស្បែកជើងដែលស្រោបជើងទាំងអស់រហូតស្មុងជើង មិនត្រូវពាក់ស្បែកជើងដែលគេក្រងជារបៀបបិទខ្នងជើង មិនត្រូវពាក់ស្បែកជើងដែលញាត់ដោយគរ មិនត្រូវពាក់ស្បែកជើងដែលមានខ្សែវិចិត្រដូចស្លាបទទា មិនត្រូវពាក់ស្បែកជើងមានខ្សែមានសណ្ឋានដូចស្នែងកែះ មិនត្រូវពាក់ស្បែកជើងមានខ្សែមានសណ្ឋានដូចស្នែងពពែមិនត្រូវពាក់ស្បែកជើងមានខ្សែមានសណ្ឋានដូចកន្ទុយសត្វខ្ទួយ មិនត្រូវពាក់ស្បែកជើងដែលគេស្រេះដោយព្រុយកន្ទុយក្ងោក មិនត្រូវពាក់ស្បែកជើងដែលវិចិត្រ(ផ្សេងៗ)ឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើង ដែលចំជាយដោយស្បែកសត្វសីហៈ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លាធំ។ ពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លាដំបង។ ពាក់ស្បែកជើង ដែលចំជាយដោយស្បែកខ្លារខិន។ ពាក់ស្បែកជើង ដែលចំជាយដោយស្បែកភេ។ ពាក់ស្បែកជើង ដែលចំជាយដោយស្បែកឆ្មា។ ពាក់ស្បែកជើង ដែលចំជាយដោយស្បែកសត្វកង្ហែន។ ពាក់ស្បែកជើង ដែលចំជាយដោយស្បែកមៀម។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថ ដែលបរិភោគនូវកាមគុណ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនត្រូវពាក់ស្បែកជើង ដែលចំជាយដោយស្បែកសត្វសីហៈ មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លាធំ មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លាដំបង មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកខ្លារខិន មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកភេ មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកឆ្មា មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកសត្វកង្ហែន មិនត្រូវពាក់ស្បែកជើងដែលចំជាយដោយស្បែកមៀម ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។

## ១៥០. ឱមុក្កគុណង្គុណូបាហនានុជានានា

CS vin.mv.05.04 | ភាគ ទី៧

(១៥០)

[៥៥] គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្លៀកស្បង់ក្នុងវេលាព្រឹកព្រហាម ហើយប្រដាប់បាត្រនិងចីវរ យាងចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត មានភិក្ខុ១រូបជាបច្ឆាសមណៈ (គឺសមណៈតាមក្រោយ)។ ភិក្ខុនោះខ្ចកជើង ដើរតាមក្រោយៗ ព្រះដ៏មានព្រះភាគ ក្នុងវេលានោះ។ មានឧបាសកម្នាក់ ពាក់ស្បែកជើង៤ជាន់ឡើងទៅ បានឃើញព្រះដ៏មានព្រះភាគ ទ្រង់យាងមកពីចម្ងាយ លុះឃើញហើយ ក៏ដោះស្បែកជើងចេញ ហើយចូលសំដៅទៅព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំភិក្ខុនោះហើយ ក៏បាននិយាយពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ហេតុអ្វីបានជាខ្ចក។ ភិក្ខុនោះប្រាប់ថា នែអ្នកដ៏មានអាយុ បាទារបស់អាត្មាបែក។ ឧបាសកនោះនិយាយថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ ទទួលយកស្បែកជើងចុះ។ ភិក្ខុនោះតបថា នែអ្នកដ៏មានអាយុ ណ្ហើយកុំ ព្រោះស្បែកជើង៤ជាន់ឡើងទៅ ព្រះដ៏មានព្រះភាគបានទ្រង់ហាមរួចជាស្រេចហើយ។ ព្រះអង្គមានបន្ទូលថា នែភិក្ខុ ចូរអ្នកទទួលយកស្បែកជើងនេះចុះ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគបានធ្វើនូវធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវស្បែកជើង៤ជាន់ឡើងទៅ ដែលគេពាក់ហើយដោះមកប្រគេន (គឺជាស្បែកជើងចាស់) ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើង៤ជាន់ឡើងទៅ ដែលជាស្បែកជើងថ្មីទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។

## ១៥១. អជ្ឈារាមេ ឧបាហនបដិក្ខេបោ

CS vin.mv.05.05 | ភាគ ទី៧

(១៥១)

[៥៦] សម័យនោះឯង ព្រះដ៏មានព្រះភាគមិនបានទ្រង់ឆ្លងព្រះបាទ (ហើយ) ទ្រង់ចង្ក្រមនៅក្នុងទីវាល។ ឯពួកភិក្ខុចាស់ក៏មិនហ៊ានពាក់ស្បែកជើងដើរចង្ក្រម ដោយគិតឃើញថា ព្រះជាគ្រូមិនទ្រង់ឆ្លងព្រះបាទ ហើយទ្រង់ចង្ក្រម។ កាលបើព្រះបរមសាស្តាមិនទ្រង់ឆ្លងព្រះបាទ ហើយទ្រង់ចង្ក្រម ពួកភិក្ខុចាស់ ក៏មិនពាក់ស្បែកជើង ហើយចង្ក្រម (គឺដើរតាមធម្មតា) ឯពួកឆព្វគ្គិយភិក្ខុ ក៏ពាក់ស្បែកជើង ហើយចង្ក្រម។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា កាលបើព្រះបរមសាស្តា មិនបានទ្រង់ឆ្លងព្រះបាទ កំពុងចង្ក្រមក្តី ពួកភិក្ខុចាស់ មិនបានពាក់ស្បែកជើង កំពុងចង្ក្រមក្តី ពួកឆព្វគ្គិយភិក្ខុ មិនសមបើ នឹងហ៊ានពាក់ស្បែកជើងដើរចង្ក្រមសោះ។ វេលានោះឯង ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា កាលព្រះបរមសាស្តា មិនបានទ្រង់ឆ្លងព្រះបាទ កំពុងចង្ក្រមក្តី ពួកភិក្ខុចាស់ មិនបានពាក់ស្បែកជើង កំពុងចង្ក្រមក្តី ពួកឆព្វគ្គិយភិក្ខុ ក៏ពាក់ស្បែកជើង ហើយដើរចង្ក្រម ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ កាលព្រះសាស្តា មិនបានទ្រង់ឆ្លងព្រះបាទ កំពុងចង្ក្រមក្តី ពួកភិក្ខុចាស់មិនបានពាក់ស្បែកជើង កំពុងចង្ក្រមក្តី មោឃបុរសទាំងនោះ មិនសមបើនឹងហ៊ានពាក់ស្បែកជើង ហើយដើរចង្ក្រមទេ ម្នាលភិក្ខុទាំងឡាយ ពួកគ្រហស្ថដែលស្លៀកស ម្តេចគង់មានសេចក្តីគោរព កោតក្រែងក្នុងអាចារ្យ មានការចិញ្ចឹមជីវិតស្មើគ្នា ព្រោះហេតុនៃសិល្បសាស្ត្រសម្រាប់ចិញ្ចឹមជីវិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ គួរតែប្រព្រឹត្តឲ្យល្អ ព្រោះថា អ្នកទាំងឡាយបានបួសមកក្នុងធម្មវិន័យ ដែលតថាគតបានសំដែង ដោយល្អយ៉ាងនេះហើយ គួរតែគោរពកោតក្រែង មានសេចក្តីចិញ្ចឹមជីវិតស្មើគ្នា ក្នុងអាចារ្យក្តី ក្នុងភិក្ខុល្មមធ្វើជាអាចារ្យក្តី ក្នុងឧបជ្ឈាយ៍ក្តី ក្នុងភិក្ខុល្មមធ្វើជាឧបជ្ឈាយ៍ក្តី ម្នាលភិក្ខុទាំងឡាយ អំពើនេះនឹងបានដឹកនាំពួកជនដែលមិនទាន់បានជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់បន្ទោសរួច ទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ កាលបើអាចារ្យ(ក្តី) ភិក្ខុល្មមធ្វើជាអាចារ្យ(ក្តី) ឧបជ្ឈាយ៍(ក្តី) ភិក្ខុល្មមធ្វើជាឧបជ្ឈាយ៍(ក្តី) មិនបានពាក់ស្បែកជើងដើរចង្ក្រមទេ ភិក្ខុមិនត្រូវពាក់ស្បែកជើង ហើយដើរចង្ក្រមទេ ភិក្ខុណាដើរចង្ក្រម ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងខាងក្នុងវត្តទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។

[៥៧] សម័យនោះឯង មានភិក្ខុ១រូប កើតរោគដំបៅលេចនៅបាតជើង។ ភិក្ខុទាំងឡាយក៏បានគ្រាហ៍យកភិក្ខុនោះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង។ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់សេនាសនចារិក ក៏បានទតទៅឃើញភិក្ខុទាំងនោះ កំពុងគ្រាហ៍យកភិក្ខុនោះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង លុះឃើញហើយ ក៏ទ្រង់យាងចូលទៅរកភិក្ខុនោះ លុះយាងចូលទៅដល់ហើយ ទើបទ្រង់មានបន្ទូលនេះ នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះកើតរោគអ្វី។ ភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន លោកដ៏មានអាយុនេះ កើតរោគដំបៅលេចនៅបាតជើង ពួកខ្ញុំព្រះអង្គក៏គ្រាហ៍យកលោកដ៏មានអាយុនេះមកឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង។

[៥៨] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ (បើ) ភិក្ខុណា មានជើងឈឺក្តី មានជើងបែកក្តី មានរោគដំបៅលេចនៅបាតជើងក្តី តថាគតអនុញ្ញាតឲ្យភិក្ខុនោះពាក់ស្បែកជើងបាន។ សម័យនោះឯង ភិក្ខុទាំងឡាយ មិនបានលាងជើង ហើយស្រាប់តែឡើងទៅកាន់គ្រែខ្លះ តាំងខ្លះ នាំឲ្យប្រឡាក់ចីវរ និងសេនាសនៈ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុពាក់ស្បែកជើងបាន ដោយគិតថា ក្នុងវេលានេះ អាត្មាអញ នឹងឡើងគ្រែ ឬតាំង។ សម័យនោះឯង ក្នុងវេលាយប់ មានពួកភិក្ខុដើរទៅកាន់រោងឧបោសថខ្លះ ទីប្រជុំអង្គុយខ្លះ ក៏ជាន់ទៅលើដង្គត់ឈើខ្លះ លើបន្លាខ្លះ ក្នុងទីងងឹត ជើងរបស់ភិក្ខុទាំងនោះក៏មានទុក្ខវេទនា។ ភិក្ខុទាំងឡាយ ក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុពាក់ស្បែកជើង កាន់គប់ភ្លើង ប្រទីប និងឈើច្រត់ខាងក្នុងអារាមបាន។

## ១៥២. កដ្ឋបាទុកាទិបដិក្ខេបោ

CS vin.mv.05.06 | ភាគ ទី៧

**(១៥២)**

សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី (ជិតភ្លឺ) ក៏ពាក់ទ្រនាប់ជើងឈើ ហើយចង្ក្រមក្នុងទីវាល មានសំឡេងហ៊ោ មានសំឡេងខ្លាំង មានសំឡេងថា ខដខដៈ ហើយនិយាយតិរច្ឆានកថាផ្សេងៗ គឺនិយាយពីស្តេច និយាយពីចោរ និយាយពីមហាមាត្យ និយាយពីសេនា និយាយពីភ័យ និយាយពីចម្បាំង និយាយពីគ្រឿងស៊ី និយាយពីគ្រឿងផឹក និយាយពីសំពត់ និយាយពីការដេក និយាយពីកម្រងផ្កា និយាយពីគ្រឿងក្រអូប និយាយពីញាតិ និយាយពីយាន និយាយពីស្រុក និយាយពីនិគម និយាយពីនគរ និយាយពីជនបទ និយាយពីស្រី និយាយពីប្រុស និយាយពីបុគ្គលដែលក្លៀវក្លា និយាយពីច្រកផ្លូវ និយាយពីកន្លែងក្អមទឹក (គឺកំពង់ទឹក) និយាយពីបុព្វប្រេត (គឺញាតិដែលស្លាប់ទៅហើយ) និយាយពីពាក្យឥតប្រយោជន៍ មានប្រការផ្សេងៗ និយាយពីរឿងកុហកក្នុងលោក (មានរឿងក្អែកស កុកក្រហមជាដើម) និយាយពីរឿងជីកសមុទ្រ និយាយពីសេចក្តីចំរើន និងសេចក្តីសាបសូន្យ ហើយជាន់លើសត្វល្អិតៗឲ្យស្លាប់ខ្លះ ឲ្យភិក្ខុទាំងឡាយឃ្លាតចាកសមាធិខ្លះ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងក្រោកឡើងក្នុងបច្ចូសសម័យ នៃរាត្រី ហើយពាក់ទ្រនាប់ជើងឈើ ដើរក្នុងទីវាល មានសំឡេងហ៊ោ សំឡេងខ្លាំង សំឡេងខដខដៈ ហើយនិយាយពីតិរច្ឆានកថាផ្សេងៗ គឺនិយាយពីស្តេច និយាយពីចោរ។បេ។ និយាយពីសេចក្តីចំរើន និងសេចក្តីសាបសូន្យដូច្នេះៗ ហើយជាន់លើសត្វល្អិតៗឲ្យស្លាប់ខ្លះ ឲ្យភិក្ខុទាំងឡាយ ឃ្លាតចាកសមាធិខ្លះសោះ។ គ្រានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកឆព្វគ្គិយភិក្ខុ ក្រោកឡើងក្នុងបច្ចូសសម័យ នៃរាត្រីហើយ ក៏ពាក់ទ្រនាប់ជើងឈើ ដើរទៅក្នុងទីវាល មានសំឡេងហ៊ោ សំឡេងខ្លាំង សំឡេងខដខដៈ ហើយនិយាយតិរច្ឆានកថាផ្សេងៗ គឺនិយាយពីស្តេច និយាយពីចោរ។បេ។ និយាយពីសេចក្តីចំរើន និងសេចក្តីសាបសូន្យដូច្នេះៗ ហើយដើរជាន់លើសត្វល្អិតៗឲ្យស្លាប់ខ្លះ ឲ្យភិក្ខុទាំងឡាយឃ្លាតចាកសមាធិខ្លះ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។បេ។ លុះព្រះមានព្រះភាគ ទ្រង់បន្ទោសរួច ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងឈើឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។

[៥៩] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្រុងរាជគ្រឹះ ដោយសមគួរដល់ពុទ្ធអធ្យាស្រ័យ រួចហើយទ្រង់យាងសំដៅទៅក្រុងពារាណសី ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសីនោះ។ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវន ទៀបក្រុងពារាណសី។ វេលានោះឯង ពួកឆព្វគ្គិយភិក្ខុគិតថា ទ្រនាប់ជើងឈើ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ក៏ប្រើគេឲ្យកាត់ត្នោតខ្ចីទាំងឡាយ (យកមកធ្វើ) ជាទ្រនាប់ជើងស្លឹកត្នោត ហើយពាក់ ឯត្នោតខ្ចីទាំងនោះ លុះគេកាត់ហើយ ក៏ស្វិតស្រពោន។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្ត មិនសមបើនឹងហ៊ានប្រើគេឲ្យកាត់ត្នោតខ្ចីៗ (យកមកធ្វើ)ជាទ្រនាប់ជើងស្លឹកត្នោត ហើយពាក់សោះ ឯដើមត្នោតខ្ចីទាំងនោះ លុះគេកាត់ហើយ ក៏ស្វិតស្រពោន ពួកសមណៈ ជាសក្យបុត្ត ហ៊ានបៀតបៀនវត្ថុដែលមានជីវិត មានឥន្ទ្រិយតែ១។ កាលមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ វេលានោះឯង ភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយភិក្ខុ ប្រើគេឲ្យកាត់ត្នោតខ្ចីៗ (យកមកធ្វើ)ជាទ្រនាប់ជើងស្លឹកត្នោត ហើយពាក់ ត្នោតខ្ចីទាំងនោះ លុះគេកាត់ហើយ ក៏ស្វិតស្រពោន ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងប្រើគេឲ្យកាត់ត្នោតខ្ចីៗ (យកមកធ្វើ)ជាទ្រនាប់ជើងស្លឹកត្នោត ហើយពាក់ទេ ត្នោតខ្ចីទាំងនោះ លុះគេកាត់ហើយ ក៏ស្វិតស្រពោនអស់ ម្នាលភិក្ខុទាំងឡាយ ដ្បិតពួកមនុស្សតែងសំគាល់ថា ដើមឈើមានជីវិត ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់បន្ទោសរួច ទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងស្លឹកត្នោតឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគិតថា ទ្រនាប់ជើងស្លឹកត្នោត ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ទើបប្រើគេឲ្យកាត់នូវឫស្សីខ្ចីទាំងឡាយវិញ (យកមកធ្វើ) ជាទ្រនាប់ជើងស្លឹកឫស្សី ហើយពាក់ ឯឫស្សីខ្ចីទាំងនោះ លុះគេកាត់ហើយ ក៏ស្វិតស្រពោនអស់។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រ មិនគួរបើនឹងហ៊ានប្រើគេឲ្យកាត់ឫស្សីខ្ចីទាំងឡាយ (យកមកធ្វើ)ជាទ្រនាប់ជើងស្លឹកឫស្សី ហើយពាក់សោះ ឯឫស្សីខ្ចីទាំងនោះ លុះគេកាត់ហើយ ក៏ស្វិតស្រពោនទៅ

ពួកសមណៈ ជាសក្យបុត្រ ហ៊ានបៀតបៀនរបស់ដែលមានជីវិត មានឥន្ទ្រិយតែ១។ កាលមនុស្សទាំងនោះ កំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់។ វេលានោះឯង ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។បេ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងស្លឹកឫស្សីឡើយ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។

[៦០] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងពារាណសី គួរតាមពុទ្ធអធ្យាស្រ័យ រួចទ្រង់យាងទៅកាន់ចារិក នៃក្រុងភទ្ទិយៈ កាលទ្រង់យាងទៅកាន់ចារិក ដោយលំដាប់ ក៏បានដល់ទៅក្រុងភទ្ទិយៈនោះ។ បានឮមកថា ព្រះអង្គគង់នៅក្នុងព្រៃជាតិយាវន ទៀបក្រុងភទ្ទិយៈនោះ។ សម័យនោះឯង ពួកភទ្ទិយៈភិក្ខុ (ភិក្ខុដែលនៅក្នុងក្រុងភទ្ទិយៈ) មានសេចក្តីខ្វល់ខ្វាយក្នុងការប្រដាប់ទ្រនាប់ជើង មានប្រការផ្សេងៗ គឺធ្វើទ្រនាប់ជើងស្មៅខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅយាប្ល័ងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅដំណេកទន្សាយខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្លឹកទន្សែខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅមានពណ៌ដូចផ្កាឈូកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងសំពត់ដែលគេត្បាញដោយរោមសត្វខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ក៏លះបង់ចោលនូវបាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិប្បញ្ញា។ 23) ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភទ្ទិយភិក្ខុ មិនសមបើនឹងខ្វល់ខ្វាយក្នុងការតាក់តែងទ្រនាប់ជើងមានបការផ្សេងៗ គឺ ធ្វើទ្រនាប់ជើងស្មៅខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅយាប្ល័ងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅដំណេកទន្សាយខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្លឹកទន្សែខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅមានពណ៌ដូចផ្កាឈូកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងដែលគេត្បាញដោយរោមសត្វខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ហើយលះបង់នូវបាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិប្បញ្ញាសោះ។ វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភទ្ទិយភិក្ខុខ្វល់ខ្វាយក្នុងការតាក់តែងទ្រនាប់ជើង មានបការផ្សេងៗ គឺធ្វើទ្រនាប់ជើងស្មៅខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅយាប្ល័ងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅដំណេកទន្សាយខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្លឹកទន្សែខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅមានពណ៌ដូចផ្កាឈូកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងសំពត់ដែលគេត្បាញដោយរោមសត្វខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ហើយលះបង់បាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិប្បញ្ញា ពិតមែនឬ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះ មិនសមបើនឹងខ្វល់ខ្វាយក្នុងការតាក់តែងទ្រនាប់ជើង មានបការផ្សេងៗ គឺធ្វើទ្រនាប់ជើងស្មៅខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅយាប្ល័ងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅដំណេកទន្សាយខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្លឹកទន្សែខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងស្មៅមានពណ៌ដូចផ្កាឈូកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើទ្រនាប់ជើងសំពត់ដែលគេត្បាញដោយរោមសត្វខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ លះបង់នូវបាលី អដ្ឋកថា អធិសីល អធិចិត្ត និងអធិប្បញ្ញា ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់បន្ទោសរួច ទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងស្មៅ មិនត្រូវពាក់ទ្រនាប់ជើងស្មៅយាប្ល័ង មិនត្រូវពាក់ទ្រនាប់ជើងស្មៅដំណេកទន្សាយ មិនត្រូវពាក់ទ្រនាប់ជើងស្លឹកទន្សែ មិនត្រូវពាក់ទ្រនាប់ជើងស្មៅមានពណ៌ដូចផ្កាឈូក មិនត្រូវពាក់ទ្រនាប់ជើងសំពត់ដែលគេត្បាញដោយរោមសត្វ មិនត្រូវពាក់ទ្រនាប់ជើងមាស មិនត្រូវពាក់ទ្រនាប់ជើងប្រាក់ មិនត្រូវពាក់ទ្រនាប់ជើងកែវមណី មិនត្រូវពាក់ទ្រនាប់ជើងកែវពិទូរ្យ មិនត្រូវពាក់ទ្រនាប់ជើងកែវផ្លេក មិនត្រូវពាក់ទ្រនាប់ជើងសម្រិត មិនត្រូវពាក់ទ្រនាប់ជើងកែវកញ្ចក់ មិនត្រូវពាក់ទ្រនាប់ជើងសំណប៉ាហាំង (សំណស) មិនត្រូវពាក់ទ្រនាប់ជើងសំណភក់ (សំណខ្មៅ) មិនត្រូវពាក់ទ្រនាប់ជើងទង់ដែងទេ ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់ជើង (គឺជ្រុញជើង) ណាមួយដែលគួរនឹងឲ្យកម្រើកទៅបាន ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើង៣យ៉ាង ដែលគេដំកល់នៅជានិច្ច ដែលគេឲ្យកម្រើកទៅមិនបាន គឺទ្រនាប់ជើងសម្រាប់បន្ទោបង់នូវវច្ចៈ១ ទ្រនាប់ជើងសម្រាប់បន្ទោបង់នូវបស្សាវៈ១ ទ្រនាប់ជើងសម្រាប់លាងជម្រះ(លាមក)១។

[៦១] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងនគរភទ្ទិយៈ គួរដល់ពុទ្ធអធ្យាស្រ័យ រួចទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ។ បានឮមកថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលមេគោទាំងឡាយ កំពុងតែហែលឆ្លងទឹកស្ទឹងអចិរវតី ក៏ចាប់ស្នែងខ្លះ ចាប់ស្លឹកត្រចៀកខ្លះ ចាប់កខ្លះ ចាប់កន្ទុយខ្លះ ឡើងជិះលើខ្នងខ្លះ មានចិត្តតម្រេក ក៏ស្ទាបអង្គជាតខ្លះ ចាប់ជ្រមុជកូនគោទៅក្នុងទឹកឲ្យស្លាប់ខ្លះ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្ត កាលមេគោទាំងឡាយ កំពុងឆ្លងទឹក មិនសមបើនឹងចាប់ស្នែងខ្លះ ចាប់ស្លឹកត្រចៀកខ្លះ ចាប់កខ្លះ ចាប់កន្ទុយខ្លះ ឡើងជិះលើខ្នងខ្លះ មានចិត្តតម្រេក ហើយស្ទាបអង្គជាតខ្លះ ចាប់ជ្រមុជកូនគោទៅក្នុងទឹកឲ្យស្លាប់ខ្លះ ដូចជាពួកគ្រហស្ថអ្នកបរិភោគនូវកាមគុណសោះ។ កាលមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយបានឮច្បាស់។ វេលានោះឯង ភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចាប់ស្នែងមេគោទាំងឡាយ មិនត្រូវចាប់ស្លឹកត្រចៀក មិនត្រូវចាប់ក មិនត្រូវចាប់កន្ទុយ មិនត្រូវឡើងជិះលើខ្នង ភិក្ខុណាឡើងជិះ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវមានចិត្តត្រេកអរ ពាល់អង្គជាត (មេគោ) ឡើយ ភិក្ខុណាពាល់ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុមិនត្រូវធ្វើកូនគោឲ្យស្លាប់ឡើយ ភិក្ខុណាធ្វើឲ្យស្លាប់ ភិក្ខុនោះ វិនយធរត្រូវឲ្យធ្វើតាមធម៌។24)

## ១៥៣. យានាទិបដិក្ខេបោ

CS vin.mv.05.07 | ភាគ ទី៧

**(១៥៣)**

[៦២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទៅដោយយានដែលគេទឹមដោយគោញី មានបុរសជាអ្នកបរក៏មាន ទឹមដោយគោឈ្មោល មានស្រីជាអ្នកបរក៏មាន។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកជនដែលទៅលេងទឹកស្ទឹងគង្គា និងស្ទឹងមហី។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទៅដោយយានឡើយ ភិក្ខុណា

ទៅ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង មានភិក្ខុ១រូបទៅកាន់ក្រុងសាវត្ថី ក្នុងកោសលជនបទ ដើម្បីគាល់ព្រះដ៏មានព្រះភាគ ដល់ពាក់កណ្តាលផ្លូវ ក៏មានជម្ងឺ។ វេលានោះឯង ភិក្ខុនោះក៏គេចចុះចេញអំពីផ្លូវ ទៅអង្គុយនៅក្រោមដើមឈើ១។ មនុស្សទាំងឡាយក្រឡេកឃើញភិក្ខុនោះហើយ ក៏បាននិយាយពាក្យនេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់នឹងនិមន្តទៅទីណា។ ភិក្ខុនោះប្រាប់ថា នែអ្នកដ៏មានអាយុ អាត្មានឹងទៅក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ។ មនុស្សទាំងនោះទូលថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និមន្តមក យើងនឹងទៅជាមួយគ្នា។ ភិក្ខុនោះតបថា នែអ្នកដ៏មានអាយុ អាត្មាទៅមិនរួចទេ ព្រោះអាត្មាមានជម្ងឺ។ មនុស្សទាំងនោះទូលថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និមន្តមកឡើងជិះយាន ទៅ។ ភិក្ខុនោះតបថា នែអ្នកដ៏មានអាយុ មិនគួរទេ ព្រោះយាន ព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់រួចទៅហើយ។ ភិក្ខុនោះរង្កៀសខ្លាចក្រែង ក៏មិនឡើងជិះយានឡើយ។ វេលានោះឯង ភិក្ខុនោះក៏ដើរទៅដល់ក្រុងសាវត្ថី បានដំណាលរឿងនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយានដល់ភិក្ខុដែលមានជម្ងឺ។ វេលានោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា (ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាត) យានដែលទឹមដោយសត្វញី ឬទឹមដោយសត្វឈ្មោលហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយានដែលគេទឹមដោយសត្វឈ្មោល និងយានដែលសម្រាប់អូស ឬរុញដោយដៃ។[25] សម័យនោះឯង មានភិក្ខុ១រូប កើតសេចក្តីមិនសប្បាយខ្លាំង ព្រោះទង្គិច ទង្គកដោយយាន(យានរលាក់)។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគ្រែស្នែង និងអង្រឹងស្នែង។

## ១៥៤. ឧច្ចាសយនមហាសយនបដិក្ខេបោ

CS vin.mv.05.08 | ភាគ ទី៧

**(១៥៤)**

[៦៣] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ឧច្ចាសយនៈ (គ្រែកន្លងហួសប្រមាណ) និងមហាសយនៈ (គ្រឿងកម្រាលមិនគួរ) អាសន្ទិ (អាសនៈដែលខ្ពស់ហួសប្រមាណ)១ បល្លង្កំ (គ្រែដែលមានជើងវិចិត្រដោយរូបសត្វសាហាវ)១ គោណកៈ (ព្រំដែលមានរោមវែងជាង៤ធ្នាប់)១ ចិត្តកៈ (កម្រាលដែលគេធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវ)១ បដិកៈ (កម្រាលពណ៌ស ដែលគេធ្វើដោយរោមសត្វ)១ បដលិកៈ (កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម)១ តូលិកៈ (កម្រាលដែលញាត់ដោយគរ ជាប្រក្រតី)១ វិកតិកៈ (កម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វ មានសីហៈ និងខ្លាធំជាដើម)១ ឧទ្ទលោមិ (កម្រាលដែលធ្វើដោយរោមសត្វ មានរោមច្រាងឡើងតែម្ខាង)១ ឯកន្តលោមិ (កម្រាលដែលធ្វើដោយរោមសត្វ មានរោមច្រាងឡើងទាំងសងខាង)១ កដិស្សៈ (កម្រាលដែលធ្វើដោយឌិនមាស និងសូត្រ ហើយចាក់ស្រេះដោយរតនៈ[26] )១ កោសេយ្យៈ (កម្រាលដែលធ្វើដោយសរសៃសូត្រ ហើយចាក់ស្រេះដោយរតនៈ)១ កុត្តកៈ (កម្រាលដែលធ្វើដោយរោមសត្វល្មមចុះពួកស្រីរបាំ១៦នាក់ ឈររាំបាន)១ ហត្ថត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងដំរី)១ អស្សត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងសេះ)១ រថត្ថរៈ (កម្រាលសម្រាប់ក្រាលលើរថ)១ អជិនប្បវេណិ (កម្រាល ដែលគេធ្វើដោយស្បែកខ្លា)១ កម្រាលដ៏ឧត្តម ដែលគេធ្វើដោយស្បែកសត្វឈ្មុស១ ខ្នើយមានពណ៌ក្រហមទាំងពីរខាង (ខ្នើយក្បាល និងខ្នើយជើង) ព្រមទាំងពិតាន ដែលមានពណ៌ក្រហម១។ មនុស្សទាំងឡាយ កាលដើរទៅកាន់វិហារចារិក បានឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថ ដែលបរិភោគកាមគុណ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឧច្ចាសយនៈ និងមហាសយនៈឡើយ គឺ អាសន្ទិ (អាសនៈដែលខ្ពស់ហួសប្រមាណ)១ បល្លង្ក (គ្រែដែលមានជើងវិចិត្រ ដោយរូបសត្វសាហាវ)១ គោណកៈ (ព្រំដែលមានរោមវែងជាង ៤ធ្នាប់)១ ចិត្តកៈ (កម្រាល ដែលគេធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវ)១ បដិកៈ (កម្រាល ដែលមានពណ៌ស ធ្វើដោយរោមសត្វ)១ បដលិកៈ (កម្រាល ដែលធ្វើដោយរោមសត្វជាផ្កាចង្កោម)១ តូលិកៈ (កម្រាល ដែលញាត់ដោយគរ ជាប្រក្រតី)១ វិកតិកៈ (កម្រាល ដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វ មានសីហៈ និងខ្លាធំជាដើម)១ ឧទ្ទលោមិ (កម្រាល ដែលធ្វើដោយរោមសត្វ មានរោមច្រាងឡើងតែម្ខាង)១ ឯកន្តលោមិ (កម្រាល ដែលធ្វើដោយ រោមសត្វ មានរោមច្រាងឡើងទាំងសងខាង)១ កដិស្ស (កម្រាល ដែលធ្វើដោយឌិនមាស និងសូត្រ ហើយចាក់ស្រេះ ដោយរតនៈ)១ កោសេយ្យ (កម្រាលដែលធ្វើដោយសរសៃសូត្រ ហើយចាក់ស្រេះ ដោយរតនៈ)១ កុត្តកៈ (កម្រាលដែលធ្វើដោយរោមសត្វ ល្មមពួកស្រីរបាំ១៦នាក់ ឈររាំបាន)១ ហត្ថត្ថរៈ (កម្រាល សម្រាប់ក្រាលលើខ្នងដំរី)១ អស្សត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងសេះ)១ រថត្ថរៈ (កម្រាលសម្រាប់ក្រាលលើរថ)១ អជិនប្បវេណិ (កម្រាលដែលគេធ្វើដោយស្បែកខ្លា)១ កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្មុស១ ខ្នើយមានពណ៌ក្រហមទាំងពីរខាង (ខ្នើយក្បាល និងខ្នើយជើង) ព្រមទាំងពិតាន ដែលមានពណ៌ក្រហម១ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

## ១៥៥. សព្វចម្មបដិក្ខេបោ

CS vin.mv.05.09 | ភាគ ទី៧

**(១៥៥)**

[៦៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា ឧច្ចាសយនៈ និងមហាសយនៈ ព្រះមានព្រះភាគ បានទ្រង់ហាមហើយ ក៏នាំគ្នាប្រើប្រាស់ស្បែកសត្វដ៏ធំ គឺស្បែកសត្វសីហៈ ស្បែកខ្លាធំ ស្បែកខ្លាដំបង។ ស្បែកទាំងនោះ ពួកឆព្វគ្គិយភិក្ខុ បានកាត់ឲ្យល្មមនឹងគ្រែខ្លះ កាត់ឲ្យល្មមនឹងតាំងខ្លះ ក្រាលលើគ្រែខាងក្នុងខ្លះ ក្រាលលើគ្រែខាងក្រៅខ្លះ ក្រាលខាងលើតាំងខាងក្នុងខ្លះ ក្រាលលើតាំងខាងក្រៅខ្លះ។ មនុស្សទាំងឡាយ ដើរទៅកាន់វិហារចារិក ឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចពួកគ្រហស្ថ អ្នកបរិភោគនូវកាមគុណ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មិនត្រូវប្រើប្រាស់ នូវស្បែកសត្វដ៏ធំ គឺស្បែកសត្វសីហៈ ស្បែកខ្លាធំ ស្បែកខ្លាដំបងឡើយ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៦៥] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា ស្បែកសត្វដ៏ធំទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ក៏នាំគ្នាប្រើប្រាស់ស្បែកគោទាំងឡាយវិញ។ ស្បែកគោទាំងនោះ ពួកឆព្វគ្គិយភិក្ខុ បានកាត់ឲ្យល្មមនឹងគ្រែខ្លះ កាត់ឲ្យល្មមនឹងតាំងខ្លះ ក្រាលលើគ្រែខាងក្នុងខ្លះ ក្រាលលើគ្រែខាងក្រៅខ្លះ ក្រាលលើតាំងខាងក្នុងខ្លះ ក្រាលលើតាំងខាងក្រៅខ្លះ។ មិនតែប៉ុណ្ណោះ មានភិក្ខុបាបមួយរូប ជាជីតុន របស់ឧបាសកបាបម្នាក់។ វេលានោះ ភិក្ខុបាបនោះ លុះវេលាព្រឹកព្រហាម ក៏ស្លៀកស្បង់ ហើយកាន់យកបាត្រនិងចីវរ ហើយចូលទៅកាន់ផ្ទះ របស់ឧបាសកបាបនោះ លុះចូលទៅដល់ហើយ ក៏អង្គុយនៅលើអាសនៈ ដែលគេក្រាលទុក។ លំដាប់នោះ ឧបាសកបាបនោះ បានចូលទៅរកភិក្ខុបាប លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំភិក្ខុបាបនោះ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ គ្រានោះឯង ឧបាសកបាបនោះ មានកូនគោ១ មានរូបល្អ គួរនឹងរមិលមើល នាំឲ្យកើតសេចក្តីជ្រះថ្លាដ៏វិចិត្រ ប្រហែលនឹងកូនខ្លាដំបង។ វេលានោះ ភិក្ខុបាបនោះ ក៏សំឡឹងមើលទៅកូនគោនោះមិនដាក់ភ្នែកសោះ។ លំដាប់នោះ ឧបាសកបាបនោះ បាននិយាយពាក្យនេះនឹងភិក្ខុបាបនោះថា បពិត្រលោកដ៏ចំរើន ហេតុអ្វី បានជាលោកម្ចាស់ សំឡឹងមើលកូនគោនេះមិនដាក់ភ្នែកសោះ។ ភិក្ខុនោះប្រាប់ថា នែអ្នកដ៏មានអាយុ ដ្បិតអាត្មាត្រូវការស្បែកកូនគោនេះ។ ខណៈនោះ ឧបាសកបាបនោះ ក៏សម្លាប់កូនគោនោះ ហើយពន្លះយកស្បែក ប្រគេនទៅភិក្ខុបាបនោះ។ គ្រានោះ ភិក្ខុបាបនោះ ក៏លាក់ស្បែកនោះ ក្នុងសង្ឃាដិ ហើយក៏ដើរទៅ។ វេលានោះ មេគោនោះ អាល័យកូន ក៏ទៅតាមពីខាងក្រោយៗភិក្ខុបាបនោះ។ ភិក្ខុទាំងឡាយ ក៏បាននិយាយយ៉ាងនេះថា អាវុសោ ហេតុអ្វីបានជាមេគោនេះ មកតាមពីខាងក្រោយៗលោក។ ភិក្ខុនោះប្រាប់ថា អាវុសោ ខ្ញុំមិនដឹងជាមេគោនេះ មកតាមខ្ញុំពីខាងក្រោយៗ ដោយហេតុអ្វីទេ។ វេលានោះឯង សង្ឃាដិរបស់ភិក្ខុបាបនោះ ក៏ប្រឡាក់ទៅដោយឈាម។ ភិក្ខុទាំងឡាយ បាននិយាយយ៉ាងនេះថា អាវុសោ សង្ឃាដិនេះ តើអ្នកធ្វើដូចម្តេច (បានជាប្រឡាក់)។ ខណៈនោះ ភិក្ខុបាបនោះ បានប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយ ក៏បានសួរថា អាវុសោ លោកបានបបួលគេធ្វើបាណាតិបាតទេដឹង។ ភិក្ខុនោះឆ្លើយថា អើអាវុសោ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ភិក្ខុមិនសមបើនឹងបបួលគេឲ្យធ្វើបាណាតិបាតសោះ ក្រែងបាណាតិបាត ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលដោយអនេកបរិយាយ ព្រះអង្គ ទ្រង់សរសើរតែការវៀរចាកអំពើបាណាតិបាតដូច្នោះឬ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[៦៦] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃក្នុងវេលានោះហើយ ទ្រង់សួរចំពោះភិក្ខុបាបនោះថា ម្នាលភិក្ខុ ឮថាអ្នកឯងបានបបួលគេឲ្យធ្វើបាណាតិបាត ពិតមែនឬ។ ភិក្ខុបាបក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានជោគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងមិនសមនឹងបបួលគេឲ្យធ្វើបាណាតិបាតទេ នែមោឃបុរស ក្រែងអំពើបាណាតិបាត តថាគត បានតិះដៀលហើយ ដោយអនេកបរិយាយ តថាគតសរសើរតែការវៀរចាក អំពើបាណាតិបាត ដូច្នោះទេឬ នែមោឃបុរស អំពើនេះ នឹងបានដឹកនាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យបានជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបបួលគេក្នុងបាណាតិបាតទេ ភិក្ខុណាបបួល ត្រូវឲ្យវិនយធរធ្វើតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវប្រើប្រាស់ស្បែកគោទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ស្បែកសត្វណាមួយទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង មានគ្រែ និងតាំង ដែលពួកមនុស្សបានដាសដោយស្បែក បានរួតរឹតដោយស្បែក។ ភិក្ខុទាំងឡាយរង្កៀស មិនហ៊ានអង្គុយលើ។ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអង្គុយលើទីសេនាសនៈ ដែលជាគិហិវិកត (របស់ដែលគ្រហស្ថធ្វើផ្សេងៗ) បាន កុំឲ្យតែដេក។

## ១៥៦. គិហិវិកតានុញ្ញាតាទិ

CS vin.mv.05.10 | ភាគ ទី៧

**(១៥៦)**

វេលានោះឯង មានវិហារ[27] ដែលពួកជនបានរុំចងដោយខ្សែស្បែកទាំងឡាយ។ ភិក្ខុទាំងឡាយរង្កៀស មិនហ៊ានអង្គុយលើ។ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអង្គុយលើវិហារ ដែលគេគ្រាន់តែចងបាន។

[៦៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុពាក់ស្បែកជើង ហើយចូលទៅកាន់ស្រុក។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថ ដែលបរិភោគកាមគុណ។ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើង ចូលទៅកាន់ស្រុកទេ ភិក្ខុណា(ពាក់)ចូលទៅ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺ តែវៀរចាកស្បែកជើង ក៏មិនអាចនឹងដើរចូលទៅកាន់ស្រុកបានឡើយ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជម្ងឺ ពាក់ស្បែកជើង ចូលទៅកាន់ស្រុកបាន។

## ១៥៧. សោណកុដិកណ្ណវត្ថុ

CS vin.mv.05.11 | ភាគ ទី៧

**(១៥៧)**

[៦៨] សម័យនោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ គង់នៅលើភ្នំឈ្មោះបបាត ទៀបក្រុងឈ្មោះកុររឃរៈ ក្នុងអវន្តីជនបទ។ សម័យនោះឯង ឧបាសកឈ្មោះសោណកុដិកណ្ណ [28] ជាឧបដ្ឋាករបស់ព្រះមហាកច្ចានៈដ៏មានអាយុ។ វេលានោះ ឧបាសកឈ្មោះសោណកុដិកណ្ណ បានចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះឧបាសកឈ្មោះសោណកុដិកណ្ណអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បាននិយាយពាក្យនេះនឹងព្រះមហាកច្ចានៈដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ធម៌ដែលលោកម្ចាស់មហាកច្ចានៈបានសំដែងហើយយ៉ាងណាៗ ខ្ញុំករុណាក៏ដឹងច្បាស់ តែបុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌

នេះឲ្យបរិបូណ៌ ពេញលេញ ឲ្យស្អាតរលីង ដូចជាសង្ខដែលបុគ្គលដុសខាត់ហើយ បពិត្រលោកដ៏ចំរើន ឥឡូវខ្ញុំករុណាចង់កោរសក់ និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាយទាំងឡាយ ហើយចេញចាកផ្ទះ ទៅបួសក្នុងភេទរបស់បុគ្គលគ្មានផ្ទះ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់មហាកច្ចានៈបំបួសខ្ញុំផង។ កាលបើឧបាសកនោះនិយាយយ៉ាងនេះហើយ ព្រះមហាកច្ចានៈដ៏មានអាយុ ក៏បាននិយាយពាក្យនេះនឹងសោណកុដិកណ្ណឧបាសកថា នែសោណៈ ការប្រព្រឹត្តនូវការដេកតែម្នាក់ឯង បរិភោគនូវភត្តតែមួយពេល និងប្រព្រឹត្តព្រហ្មចរិយធម៌ ដរាបអស់មួយជីវិត មិនងាយនឹងធ្វើបានឡើយ នែសោណៈ ណ្ហើយចុះ អ្នកឯងគួរតែនៅជាគ្រហស្ថ ប្រកបតាមពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គឺការដេកតែម្នាក់ឯង ការបរិភោគភត្តតែម្តង និងការប្រព្រឹត្តព្រហ្មចរិយធម៌ សមគួរតាមកាល ក្នុងភេទជាគ្រហស្ថនោះចុះ។ ការប្រុងប្រៀបនឹងបួសរបស់សោណកុដិកណ្ណឧបាសកនោះ ក៏បានរម្ងាប់ស្ងប់ស្ងាត់ទៅក្នុងពេលនោះឯង។ សោណកុដិកណ្ណឧបាសក បានចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុជាគំរប់ពីរដងផង។បេ។ សោណកុដិកណ្ណឧបាសក បានចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុជាគំរប់បីដងផង លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះសោណកុដិកណ្ណឧបាសក អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បានិយាយពាក្យនេះ នឹងព្រះមហាកច្ចានៈដ៏មានអាយុថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលលោកម្ចាស់មហាកច្ចានៈ បានសំដែងហើយយ៉ាងណាៗ ខ្ញុំករុណាក៏ដឹងច្បាស់ (តែថា) បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្ត នូវព្រហ្មចរិយធម៌នេះ ឲ្យបានពេញអស់ជើង ឲ្យបានស្អាតអស់ជើង ដូចជាសង្ខ ដែលគេដុសខាត់ហើយទេ បពិត្រលោកដ៏ចំរើន ឥឡូវខ្ញុំករុណាចង់កោរសក់ និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាយ ចេញចាកផ្ទះ ទៅបួសក្នុងភេទរបស់បុគ្គលគ្មានផ្ទះ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំផង។ ព្រះមហាកច្ចានៈដ៏មានអាយុ ក៏បានបំបួសសោណកុដិកណ្ណឧបាសក ក្នុងវេលានោះឯង។ សម័យនោះឯង អវន្តិទក្ខិណាបថជនបទ មានភិក្ខុតិចណាស់។ វេលានោះ ព្រះមហាកច្ចានៈដ៏មានអាយុ ឲ្យប្រជុំភិក្ខុសង្ឃមានពួក១០ ដែលមកពីទិសនោះៗ ហើយឲ្យឧបសម្បទាសោណៈដ៏មានអាយុ ដោយក្រ លំបាកពេកណាស់ លុះតែកន្លង៣ឆ្នាំទៅ (ទើបរកគណៈសង្ឃបានគ្រប់ដប់)។ លំដាប់នោះ កាលសោណៈដ៏មានអាយុ នៅចាំវស្សារួចហើយ នៅក្នុងទីស្ងាត់ លាក់ខ្លួនសម្ងំ ក៏កើតការត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា អាត្មាអញគ្រាន់តែបានឮថា ព្រះមានព្រះភាគនោះ បែបយ៉ាងនេះៗ តែអាត្មាអញ មិនដែលឃើញព្រះមានព្រះភាគ ចំពោះមុខសោះ។ បើឧបជ្ឈាយ៍អនុញ្ញាតឲ្យអាត្មាអញទៅ អាត្មាអញគួរតែទៅ ឲ្យបានឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ។ គ្រានោះ ព្រះសោណៈដ៏មានអាយុ លុះវេលាថ្ងៃរសៀល ក៏ចេញអំពីទីលាក់ខ្លួនពួនសម្ងំហើយ ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ រួចក៏អង្គុយនៅក្នុងទីដ៏សមគួរ។ លុះព្រះសោណៈដ៏មានអាយុ អង្គុយនៅក្នុងទៅដ៏សមគួរហើយ បាននិយាយពាក្យនេះនឹងព្រះមហាកច្ចានៈដ៏មានអាយុថា បពិត្រលោកដ៏ចំរើន កាលខ្ញុំករុណានៅក្នុងទីស្ងាត់ លាក់ខ្លួន ពួនសម្ងំក្នុងទីនេះ ក៏កើតការត្រិះរិះក្នុងចិត្តយ៉ាងនេះថា អាត្មាអញគ្រាន់តែបានឮថា ព្រះមានព្រះភាគនោះ បែបយ៉ាងនេះៗ តែអាត្មាអញ មិនដែលឃើញព្រះមានព្រះភាគ ក្នុងទីចំពោះមុខបានម្តងសោះ បើឧបជ្ឈាយ៍អនុញ្ញាត ឲ្យអាត្មាអញទៅ គួរតែអាត្មាអញទៅ ឲ្យបានឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ បពិត្រលោកដ៏ចំរើន បើឧបជ្ឈាយ៍អនុញ្ញាតឲ្យខ្ញុំករុណាទៅ ខ្ញុំករុណាគួរនឹងទៅ ឲ្យបានឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ។ ព្រះមហាកច្ចានៈក៏និយាយតបវិញថា នែសោណៈ ប្រពៃពេកណាស់ហើយ នែសោណៈ លោកចូរទៅគាល់ព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះចុះ នែសោណៈ លោកមុខជានឹងបានឃើញព្រះមានព្រះភាគនោះ ជាទីនាំឲ្យកើតសេចក្តីជ្រះថ្លា គួរឲ្យជ្រះថ្លា មានឥន្ទ្រិយរម្ងាប់ហើយ មានព្រះទ័យរម្ងាប់ហើយ បានដល់នូវបញ្ញាសម្រាប់ទូន្មាន និងសមាធិសម្រាប់រម្ងាប់ដ៏ឧត្តម បានទូន្មានព្រះអង្គហើយ បានរក្សាព្រះអង្គហើយ បានឈ្នះឥន្ទ្រិយហើយ បានប្រាសចាកកិលេសហើយ នែសោណៈ បើដូច្នោះ លោកចូរថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ដោយសិរសា តាមពាក្យខ្ញុំថា បពិត្រព្រះអង្គដ៏ចំរើន ឧបជ្ឈាយ៍ របស់ខ្ញុំព្រះអង្គ ឈ្មោះមហាកច្ចានៈដ៏មានអាយុ សូមក្រាបថ្វាយបង្គំ ចំពោះព្រះបាទទាំងគូ របស់ព្រះដ៏មានព្រះភាគដោយសិរសា រួចហើយចូរលោកក្រាបទូលយ៉ាងនេះ (ទៀត)ថា បពិត្រព្រះអង្គដ៏ចំរើន ដែនអវន្តិទក្ខិណាបថ មានភិក្ខុតិចណាស់ ខ្ញុំព្រះអង្គប្រជុំភិក្ខុសង្ឃមានពួក១០ អំពីប្រទេសនោះៗ ហើយបានឧបសម្បទា ដោយលំបាកពេកណាស់ លុះតែកន្លង៣ឆ្នាំទៅហើយ (ទើបស្រេច) ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគ គួរទ្រង់អនុញ្ញាត នូវឧបសម្បទា ក្នុងដែនអវន្តិទក្ខិណាបថ ដោយគណៈសង្ឃ ឲ្យតិចល្មមទៅ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ មានផែនដីខ្មៅស្អិត គ្រោតគ្រាត រឹងរដិបរដុប ដោយស្នាមជើងគោ ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគ គួរទ្រង់អនុញ្ញាត ស្បែកជើង៤ជាន់ឡើងទៅ ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ ពួកមនុស្សរាប់អានការងូតទឹកណាស់ ប្រកបដោយសេចក្តីស្អាតព្រោះទឹក ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគ គួរទ្រង់អនុញ្ញាត ការងូតទឹកឲ្យបានជានិច្ច ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ដែនអវន្តិទក្ខិណាបថ មានកម្រាលស្បែកច្រើន គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ បពិត្រព្រះអង្គដ៏ចំរើន ក្នុងមជ្ឈិមជនបទ មានស្មៅ ឈ្មោះឯរគុ[29] ស្មៅឈ្មោះមោរគុ[30] ស្មៅឈ្មោះមជ្ជារុ[31] ស្មៅឈ្មោះជន្តុ[32] យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ ក៏មានកម្រាលស្បែក គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគដូច្នោះដែរ ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគ គួរទ្រង់អនុញ្ញាតកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ មនុស្សទាំងឡាយ ប្រគេនចីវរ ដើម្បីភិក្ខុដែលនៅក្រៅសីមាថា យើងប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ ភិក្ខុទាំងនោះ មកប្រាប់ថា នែអាវុសោ ពួកមនុស្សឈ្មោះនេះ បានប្រគេនចីវរ ដើម្បីលោកហើយ ភិក្ខុទាំងនោះ ក៏រង្កៀស មិនត្រេកអរ ព្រោះយល់ឃើញថា កុំឲ្យត្រូវនិស្សគ្គិយដល់យើងឡើយ ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគ គួរទ្រង់ប្រាប់របៀបប្រតិបត្តិក្នុងចីវរ។ ឯព្រះសោណៈដ៏មានអាយុទទួលស្តាប់ពាក្យព្រះមហាកច្ចានៈដ៏មានអាយុដោយពាក្យថា ករុណាលោកម្ចាស់ រួចហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ ធ្វើប្រទក្សិណ ហើយទុកដាក់គ្រឿងសេនាសនៈ រួចកាន់យកបាត្រនិងចីវរ ចេញដើរដោយលំដាប់ទៅក្រុងសាវត្ថី ក៏ចូលទៅរកព្រះមានព្រះភាគ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា នែអានន្ទ អ្នកចូរទៅក្រាលសេនាសនៈឲ្យអាគន្តុកភិក្ខុនេះ (បន្តិច)។ គ្រានោះ ព្រះអានន្ទដ៏មានអាយុគិតថា ព្រះមានព្រះភាគទ្រង់បង្គាប់អញថា នែអានន្ទ អ្នកឯងចូរក្រាលសេនាសនៈ ឲ្យអាគន្តុកភិក្ខុនេះ (បន្តិច) ចំពោះភិក្ខុណា ព្រះមានព្រះភាគ ទ្រង់ប្រាថ្នា ដើម្បីគង់នៅក្នុងវិហារ១ ជាមួយនឹងភិក្ខុនោះ គឺថាព្រះមានព្រះភាគ ប្រាថ្នាដើម្បីគង់នៅក្នុងវិហារ១ ជាមួយនឹងព្រះសោណៈដ៏មានអាយុ លុះគិតដូច្នោះហើយ ក៏ក្រាលសេនាសនៈ ចំពោះព្រះសោណៈដ៏មានអាយុ ក្នុងវិហារ ដែលព្រះមានព្រះភាគគង់នៅ។

[៦៩] គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីកណ្តាលវាល អស់រាត្រីជាច្រើន ទើបយាងចូលទៅកាន់វិហារ។ ចំណែកខាងព្រះសោណៈដ៏មានអាយុ ក៏នៅក្នុងទីកណ្តាលវាល អស់រាត្រីជាច្រើន ទើបចូលទៅកាន់វិហារដែរ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី បានត្រាស់បង្គាប់ព្រះសោណៈដ៏មានអាយុថា នែភិក្ខុ អ្នកគួរនឹងសំដែងធម៌បន្តិចទៅ។ ព្រះសោណៈដ៏មានអាយុ បានទទួលព្រះពុទ្ធដីកា

ព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏សំដែងនូវសូត្រទាំងឡាយ មាននៅក្នុងអដ្ឋកវគ្គទាំងអស់ ដោយសរភញ្ញ។ លុះចប់សរភញ្ញ របស់ព្រះសោណៈដ៏មានអាយុហើយ ព្រះមានព្រះភាគ ក៏បានអនុមោទនា ក្នុងខណៈនោះថា នែភិក្ខុ ពីរោះហើយៗ នែភិក្ខុ សូត្រទាំងឡាយ ដែលមានក្នុងអដ្ឋកវគ្គ អ្នកបានរៀនមកត្រឹមត្រូវហើយ អ្នកបានធ្វើទុកក្នុងចិត្តល្អហើយ បានពិចារណាល្អហើយ អ្នកប្រកបដោយសំដីដ៏ពីរោះ ក្បោះក្បាយ ប្រាសចាកទោស គួរនឹងញុំាងជនឲ្យបានដឹងច្បាស់នូវសេចក្តី នែភិក្ខុ អ្នកមានវស្សាប៉ុន្មានហើយ។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទើបបានតែ១វស្សាទេ។ ព្រះមានព្រះភាគ ទ្រង់សួរថា នែភិក្ខុ ហេតុអ្វីបានជាអ្នកធ្វើការឲ្យយឺតយូរយ៉ាងនេះ (ក្របួសម្ល៉េះ)។ ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ឯទោសក្នុងកាមទាំងឡាយ ខ្ញុំព្រះអង្គបានឃើញមកជាយូរហើយ តែថាឆម្មតាឃរាវាស មានសេចក្តីចង្អៀតចង្អល់ច្រើន មានកិច្ចច្រើន មានការងារច្រើន។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឡើងនូវឧទាននេះ ក្នុងវេលានោះថា

បុគ្គលបានឃើញទោសក្នុងលោកហើយ

ដឹងនូវធម៌ដែលប្រាសចាកឧបធិក្កិលេស

ជាព្រះអរិយៈ រមែងមិនត្រេកអរក្នុងបាប

ជាបុគ្គលស្អាត រមែងមិនត្រេកអរក្នុងបាប។

## ១៥៨. មហាកច្ចានស្ស បញ្ចវរបរិទស្សនា

CS vin.mv.05.12 | ភាគ ទី៧

**(១៥៨)**

[៧០] គ្រានោះ ព្រះសោណៈដ៏មានអាយុគិតថា ព្រះមានព្រះភាគ ទ្រង់ស្មោះសរនឹងអាត្មាអញដោយពិត ព្រះឧបជ្ឈាយ៍របស់អាត្មាអញ បានធ្វើពាក្យបណ្តាំណា កាលនេះ ជាកាលគួរនឹងក្រាបទូល តាមពាក្យបណ្តាំនោះ ទើបក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គ លើស្មាម្ខាង ហើយក្រាបទៀបព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ដោយសិរសា ហើយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ ឈ្មោះមហាកច្ចានៈដ៏មានអាយុ សូមឱនសិរសា ក្រាបថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះដ៏មានព្រះភាគជាម្ចាស់ ម្យ៉ាងទៀតលោកឲ្យខ្ញុំព្រះអង្គក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ដែនអវន្តិទក្ខិណាបថ មានភិក្ខុតិច (ចាប់ដើមតាំងពីខ្ញុំព្រះអង្គបានបួសជាសាមណេរ) កន្លងទៅ៣ឆ្នាំហើយ ទំរាំប្រជុំភិក្ខុសង្ឃបាន១០រូប ដែលមកពីទិសនោះៗ ហើយទើបបានឧបសម្បទា ដោយលំបាកពន់ពេកណាស់ ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគ គួរទ្រង់អនុញ្ញាត នូវឧបសម្បទា ក្នុងដែនអវន្តិទក្ខិណាបថ ដោយគណៈសង្ឃ តិចជាងមុន បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ មានផែនដីខ្មៅស្អិត គ្រោតគ្រាត រឹងរដិបរដុប ដោយស្នាមជើងគោ ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគ គួរទ្រង់អនុញ្ញាតស្បែកជើង៤ជាន់ឡើងទៅ ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ ពួកមនុស្ស រាប់អានការងូតទឹកណាស់ ប្រកបដោយសេចក្តីស្អាតព្រោះទឹក ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគ គួរទ្រង់អនុញ្ញាត ការងូតទឹក ឲ្យបានជានិច្ច ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ មានកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ បពិត្រព្រះអង្គដ៏ចំរើន ក្នុងមជ្ឈិមជនបទ មានស្មៅឈ្មោះឯរគុ ស្មៅឈ្មោះមោរគុ ស្មៅឈ្មោះមជ្ជារុ ស្មៅឈ្មោះជន្តុ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនអវន្តិទក្ខិណាបថ មានកម្រាលគេធ្វើដោយស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក៏ដូច្នោះដែរ ធ្វើម្តេចហ្ន៎ ព្រះដ៏មានព្រះភាគ គួរទ្រង់អនុញ្ញាតកម្រាលទាំងឡាយ ដែលគេធ្វើដោយស្បែក គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក្នុងដែនអវន្តិទក្ខិណាបថ បពិត្រព្រះអង្គដ៏ចំរើន ក្នុងកាលឥឡូវនេះ មនុស្សទាំងឡាយ គេប្រគេនចីវរ ដើម្បីពួកភិក្ខុ ដែលនៅក្រៅសីមាថា យើងនឹងប្រគេនចីវរនេះ ដើម្បីភិក្ខុឈ្មោះនេះ ភិក្ខុទាំងនោះមកហើយប្រាប់ថា នែអាវុសោ ពួកមនុស្សឈ្មោះនេះ បានប្រគេនចីវរចំពោះលោក ភិក្ខុទាំងនោះក៏រង្កៀស មិនត្រេកអរ ដោយគិតថា កុំឲ្យមាននិស្សគ្គិយដល់យើងឡើយ ធ្វើដូចម្តេចហ្ន៎ ព្រះដ៏មានព្រះភាគ គួរទ្រង់ប្រាប់របៀបប្រតិបត្តិក្នុងចីវរ។

[៧១] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ដែនអវន្តិទក្ខិណាបថ មានភិក្ខុតិច ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទ [33] ទាំងអស់ តថាគតអនុញ្ញាតនូវឧបសម្បទាដោយគណៈសង្ឃ មានវិនយធរ[34] ជាគំរប់ប្រាំបាន។ បណ្តាជនបទទាំងនោះ ជនបទទាំងឡាយនេះ ដែលជាបច្ចន្តិមជនបទ គឺក្នុងទិសខាងកើត មាននិគមឈ្មោះកជង្គល ខាងនាយកជង្គលនិគមនោះ មាននិគមឈ្មោះមហាសាលា ខាងនាយនិគមឈ្មោះមហាសាលានោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី ខាងនាយស្ទឹងសល្លវតីនោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះសេតកណ្ណិក ខាងនាយសេតកណ្ណិកនិគមនោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ។ ក្នុងទិសខាងលិច មានស្រុកព្រាហ្មណ៍ ឈ្មោះថូនគ្រាម ខាងនាយស្រុកថូនគ្រាមនោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជ ខាងនាយភ្នំនោះ ហៅថាបច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ។ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងឡាយបែបនេះ តថាគតអនុញ្ញាតនូវឧបសម្បទាដោយគណៈសង្ឃ មានវិនយធរជាគំរប់៥បាន។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាបថ មានផែនដីខ្មៅស្អិត រឹងគ្រោតគ្រាត រដិបរដុបដោយស្នាមជើងគោ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងអស់ តថាគតអនុញ្ញាតស្បែកជើង៤ជាន់ឡើងទៅ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាបថ ពួកមនុស្សច្រើនរាប់អានការងូតទឹក ប្រកបដោយសេចក្តីស្អាតព្រោះទឹក ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងអស់ តថាគតអនុញ្ញាតនូវការងូតទឹកបានជានិច្ច។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាបថ មានកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម

ស្បែកពពែ ស្បែកម្រឹគ ម្នាលភិក្ខុទាំងឡាយ ក្នុងមជ្ឈិមជនបទទាំងឡាយ មានស្មៅឈ្មោះឯរគុ ស្មៅឈ្មោះមោរគុ ស្មៅឈ្មោះមជ្ជារុ ស្មៅឈ្មោះជន្តុ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាបថ មានកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងអស់ តថាគតអនុញ្ញាតកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកមនុស្សប្រគេនចីវរដើម្បីភិក្ខុទាំងឡាយ ដែលនៅក្រៅសីមាថា យើងប្រគេនចីវរនេះ ចំពោះភិក្ខុឈ្មោះនេះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរបាន ចីវរមិនទាន់មកដល់ដៃដរាបណា ចីវរនោះ ភិក្ខុមិនត្រូវរាប់តាមកំណត់ថ្ងៃ[35) ដរាបនោះ។

ចប់ ចម្មក្ខន្ធកៈ ទី៥។

ក្នុងខន្ធកៈនេះ មាននិទាន៦៣។

ឧទ្ទាននៃចម្មក្ខន្ធកៈនោះ គឺ

## ១៥៩. តស្សុទ្ទានំ

CS vin.mv.05.13 | ភាគ ទី៧

(១៥៩)

[៧២] រឿងព្រះបាទមាគធៈ ជាធំលើអ្នកស្រុក៨ម៉ឺន១ រឿងសោណសេដ្ឋីបុត្រ១ រឿងសាគតភិក្ខុសំដែងឥទ្ធិបាដិហារ្យ ជាឧត្តរិមនុស្សធម៌ច្រើន លើភ្នំគិជ្ឈកូដ១។ រឿងសោណភិក្ខុបួសហើយ ប្រារព្ធព្យាយាមក្រៃពេក បាទាក៏បែក១ រឿងព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានឲ្យសោណភិក្ខុតាំងព្យាយាមតាមខ្សែពិណ១ រឿងព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតស្បែកជើងមួយជាន់១ រឿងព្រះដ៏មានព្រះភាគ ទ្រង់ហាមស្បែកជើងពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ហង្សបាទ ពណ៌ខ្មៅ។ ស្បែកជើងពណ៌ក្រហមក្រមៅ (ដូចខ្នងក្អែប) និងពណ៌លឿងទុំ (ដូចផ្កាឈូក)១ រឿងទ្រង់ហាមខ្សែស្បែកជើង មានពណ៌ខៀវជាដើម១ រឿងទ្រង់ហាមស្បែកជើងបិទកែងជើង១ រឿងទ្រង់ហាមស្បែកជើង ស្រោបជើងទាំងអស់ រហូតស្មងជើង១ រឿងទ្រង់ហាមស្បែកជើង ដែលគេក្រង ជារបៀបបិទខ្នងជើង១ រឿងទ្រង់ហាមស្បែកជើងញាត់ដោយគរ១ រឿងទ្រង់ហាមស្បែកជើងមានពណ៌វិចិត្រ ដូចស្លាបសត្វទទា១ រឿងទ្រង់ហាមស្បែកជើងមានខ្សែមានសណ្ឋានដូចស្នែងកែះ១ រឿងទ្រង់ហាមស្បែកជើង មានខ្សែមានសណ្ឋាន ដូចស្នែងពពែ១។ រឿងទ្រង់ហាមស្បែកជើង មានខ្សែងរ មានសណ្ឋាន ដូចកន្ទុយសត្វខ្ទួយ១ រឿងទ្រង់ហាមស្បែកជើង ដែលចាក់ស្រេះ ដោយព្រុយកន្ទុយសត្វក្ងោក១ រឿងទ្រង់ហាមស្បែកជើងដ៏វិចិត្រផ្សេងៗ១ រឿងទ្រង់ហាមស្បែកជើង ដែលចំជាយដោយស្បែកសត្វសីហៈ សត្វខ្លាធំ សត្វខ្លាដំបង សត្វខ្លារខិន១ ស្បែកភេ ស្បែកឆ្មា ស្បែកកង្ហែន ស្បែកមៀម១។ រឿងទ្រង់អនុញ្ញាតស្បែកជើង៤ជាន់ឡើងទៅដល់ភិក្ខុមានបាតជើងបែក១ រឿងភិក្ខុមានដំបៅលេចនៅបាតជើង១ រឿងភិក្ខុមិនលាងជើង ហើយជាន់លើគ្រែតាំង១ រឿងភិក្ខុជាន់លើដង្កត់ឈើ១ រឿងឆព្វគ្គិយភិក្ខុ ពាក់ទ្រនាប់ជើងឈើ ឮសំឡេងខដខដ១ រឿងឆព្វគ្គិយភិក្ខុប្រើប្រាស់ទ្រនាប់ជើងស្លឹកត្នោត១ រឿងឆព្វគ្គិយភិក្ខុ ប្រើប្រាស់ទ្រនាប់ជើងស្លឹកឫស្សី១ រឿងឆព្វគ្គិយភិក្ខុ ធ្វើទ្រនាប់ជើងស្មៅ១... ស្មៅយាប្លង១... ស្មៅដំណេកទន្សាយ១... ទន្សែ១។ ...ស្មៅមានពណ៌ដូចផ្កាឈូក១ ...សំពត់រោមសត្វ១ មាស១ ប្រាក់១ កែវមណី១ កែវពិទូរ្យ១ កែវផ្លេក១ សំរឹទ្ធ១ កែវកញ្ចក់១ សំណប៉ាហាំង១ សំណភក់១ ទង់ដែងមួយ។ រឿងឆព្វគ្គិយភិក្ខុចាប់អាវយវៈមេគោ មានស្នែងជាដើម១ រឿងឆព្វគ្គិយភិក្ខុជិះយាន១ រឿងភិក្ខុឈឺ១ រឿងព្រះសម្ពុទ្ធទ្រង់អនុញ្ញាតយានទឹមដោយបុរស ឬសត្វឈ្មោល១ រឿងព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាតគ្រែស្នែង១ រឿងឆព្វគ្គិយភិក្ខុ ប្រើប្រាស់ឧច្ចាសយនៈ និងមហាសយនៈ១ រឿងឆព្វគ្គិយភិក្ខុ ប្រើប្រាស់ស្បែកសត្វធំ១ រឿងឆព្វគ្គិយភិក្ខុ ប្រើប្រាស់ស្បែកគោ១ រឿងភិក្ខុលាមក ជាជីតុន របស់ឧបាសកលាមក១។ រឿងព្រះមានព្រះភាគ ទ្រង់អនុញ្ញាត ឲ្យភិក្ខុអង្គុយលើស្បែក ដែលគ្រហស្ថធ្វើប្លែក១ រឿងវិហារដែលគេរុំចង ដោយខ្សែស្បែក១ រឿងឆព្វគ្គិយភិក្ខុ ពាក់ស្បែកជើងចូលទៅកាន់ស្រុក១ រឿងព្រះសម្ពុទ្ធទ្រង់អនុញ្ញាត ឲ្យភិក្ខុឈឺពាក់ស្បែកជើង ចូលទៅកាន់ស្រុកបាន១ រឿងព្រះមហាកច្ចានៈ១ រឿងព្រះសោណត្ថេរ សំដែងសូត្រប្រកបដោយវគ្គ៨ ដោយសរគីសម្លេង១។ រឿងព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាត នូវឧបសម្បទាកម្ម ដោយភិក្ខុ៥រូប១ ស្បែកជើង៤ជាន់ឡើងទៅ១ ការងូតទឹកជានិច្ច១ កម្រាលស្បែក១ ទ្រង់អនុញ្ញាត ឲ្យភិក្ខុត្រេកអរនឹងចីវរ បើមិនទាន់ដល់ដៃទេ មិនត្រូវឲ្យរាប់រាត្រីឡើយ១ ព្រះមានព្រះភាគ ជានាយក ទ្រង់ប្រទានពរទាំង៥នេះដល់ព្រះសោណត្ថេរហើយ។

# ភេសជ្ជក្ខន្ធកៈ

CS vin.mv.06 | ភាគ ទី៧

(៦. ភេសជ្ជក្ខន្ធកោ)

## ១៦០. បញ្ចភេសជ្ជកថា

CS vin.mv.06.01 | ភាគ ទី៧

(១៦០)

[៧៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ គ្រានោះឯង ពួកភិក្ខុកើតអាពាធ (ប្រមាត់) ក្នុងសរទកាល[36] បបរដែលហុតទៅ ក៏ចង្អោរចេញមកវិញ បាយដែលឆាន់ទៅ ក៏ចង្អោរចេញមកវិញ។ ព្រោះហេតុនោះ ពួកភិក្ខុទាំងនោះក៏មានខ្លួនស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ព្រះដ៏មានព្រះភាគបានទតឃើញភិក្ខុទាំងនោះស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ លុះទតឃើញហើយ ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ ក្នុងពេលនេះ ហេតុដូចម្ដេចបានជាពួកភិក្ខុស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ពួកភិក្ខុកើតអាពាធ (ប្រមាត់) ក្នុងសរទកាល បបរដែលហុតទៅ ក៏ចង្អោរចេញមកវិញ បាយដែលឆាន់ទៅ ក៏ចង្អោរចេញមកវិញ ព្រោះអាពាធនោះ បានជាភិក្ខុទាំងនោះស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់សម្ងំនៅក្នុងទីស្ងាត់ ក៏មានព្រះហឫទ័យត្រិះរិះដូច្នេះថា ឥឡូវនេះ ពួកភិក្ខុកើតអាពាធ (ប្រមាត់) ក្នុងសរទកាល បបរដែលហុតទៅ ក៏ចង្អោរចេញមកវិញ បាយដែលឆាន់ទៅ ក៏ចង្អោរចេញមកវិញ ព្រោះអាពាធនោះហើយ បានជាភិក្ខុទាំងនោះ ទៅជាស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ (ឥឡូវ) វត្ថុដែលជាភេសជ្ជៈក៏មាន វត្ថុដែលគេសន្មតថាជាភេសជ្ជៈក៏មាន វត្ថុដែលផ្សាយទៅសម្រាប់ជាអាហាររបស់មនុស្សលោក ក៏មាន វត្ថុដែលជាអាហារមិនបានគ្រោតគ្រាត ក៏មាន តើគួរតថាគតអនុញ្ញាតវត្ថុដូចម្ដេច ទើបសមគួរជាភេសជ្ជៈដល់ភិក្ខុទាំងឡាយហ្ន៎។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះដូច្នេះថា ភេសជ្ជៈទាំង៥នេះគឺ ទឹកដោះរាវ១ ទឹកដោះខាប់១ ប្រេង១ ទឹកឃ្មុំ១ ស្ករអំពៅ១ វត្ថុទាំងនេះ ជាភេសជ្ជៈផង ដែលគេសន្មតថាជាភេសជ្ជៈផង ផ្សាយទៅសម្រាប់ជាអាហាររបស់មនុស្សលោកផង ជាអាហារមិនបានគ្រោតគ្រាតផង បើដូច្នោះ មានតែតថាគតអនុញ្ញាតភេសជ្ជៈទាំង៥នេះដល់ពួកភិក្ខុ ដើម្បីឲ្យភិក្ខុទទួលក្នុងកាលគួរ ឆាន់ក្នុងកាលគួរ[37] បាន។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងទីស្ងាត់ នៅវេលាសាយណ្ហសម័យ ហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងវេលានេះ តថាគតសម្ងំនៅក្នុងទីស្ងាត់ មានចិត្តត្រិះរិះដូច្នេះថា ឥឡូវនេះ ពួកភិក្ខុកើតអាពាធ (ប្រមាត់) ក្នុងសរទកាលហើយ បបរដែលហុតទៅ ក៏ចង្អោរចេញមកវិញ បាយដែលឆាន់ទៅ ក៏ចង្អោរចេញមកវិញ ព្រោះអាពាធនោះ ទើបបានជាភិក្ខុទាំងនោះស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ វត្ថុខ្លះជាភេសជ្ជៈ វត្ថុខ្លះដែលគេសន្មតថាជាភេសជ្ជៈ វត្ថុខ្លះផ្សាយទៅសម្រាប់ជាអាហាររបស់មនុស្សលោក វត្ថុខ្លះជាអាហារមិនបានគ្រោតគ្រាត តើគួរតថាគតអនុញ្ញាតវត្ថុដូចម្ដេច ទើបសមគួរជាភេសជ្ជៈដល់ភិក្ខុទាំងឡាយហ្ន៎ ម្នាលភិក្ខុទាំងឡាយ តថាគតឯង មានសេចក្ដីត្រិះរិះដូច្នេះថា ភេសជ្ជៈទាំង៥នេះគឺ ទឹកដោះរាវ១ ទឹកដោះខាប់១ ប្រេង១ ទឹកឃ្មុំ១ ស្ករអំពៅ១ របស់ទាំងនេះ ជាភេសជ្ជៈផង ដែលគេសន្មតថាជាភេសជ្ជៈផង ផ្សាយទៅសម្រាប់ជាអាហាររបស់មនុស្សលោកផង ជាអាហារមិនបានគ្រោតគ្រាតផង បើដូច្នោះ មានតែតថាគតអនុញ្ញាតភេសជ្ជៈទាំង៥នេះ ដល់ភិក្ខុទាំងឡាយ ដើម្បីឲ្យភិក្ខុទទួលក្នុងកាលគួរ បរិភោគក្នុងកាលគួរ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលភេសជ្ជៈទាំង៥នោះ ក្នុងកាលគួរ បរិភោគក្នុងកាលគួរ។

[៧៤] សម័យនោះឯង ពួកភិក្ខុទទួលភេសជ្ជៈទាំង៥នោះ ក្នុងកាលគួរ ឆាន់ក្នុងកាលគួរ។ សូម្បីភោជនដ៏ស្និទ្ធ ក៏មិនត្រូវមាត់[38] របស់ភិក្ខុទាំងនោះទៅហើយ កុំចាំបាច់និយាយឡើយដល់ភោជនប្រក្រតី ដែលជាវត្ថុសៅហ្មង។ ដោយអាពាធ (ប្រមាត់) កើតឡើងក្នុងសរទកាលនោះផង ដោយភត្តដែលមិនរលួយនេះផង ភិក្ខុទាំងនោះ ក៏រឹងរឹតតែមានខ្លួនស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ព្រោះហេតុទាំងពីរនោះ។ ព្រះមានព្រះភាគ ទ្រង់បានទតឃើញភិក្ខុទាំងនោះ រឹងរឹតតែមានខ្លួនស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ លុះទតឃើញហើយ ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ឥឡូវនេះ ហេតុដូចម្ដេច បានជាពួកភិក្ខុរឹងរឹតតែមានខ្លួនស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ពួកភិក្ខុទទួលភេសជ្ជៈទាំង៥នោះ ក្នុងកាលគួរ ឆាន់ក្នុងកាលគួរ សូម្បីភោជនដ៏ស្និទ្ធ ក៏មិនត្រូវមាត់របស់ភិក្ខុទាំងនោះទៅហើយ កុំចាំបាច់និយាយឡើយដល់ភោជនប្រក្រតី ដែលជាវត្ថុសៅហ្មង ដោយអាពាធ (ប្រមាត់) ដែលកើតឡើងក្នុងសរទកាលនោះផង ដោយភត្តដែលមិនរលួយនេះផង ភិក្ខុទាំងនោះ ក៏រឹងរឹតតែមានខ្លួនស្គាំងស្គម សៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ព្រោះហេតុទាំងពីរនោះ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលភេសជ្ជៈទាំង៥នោះ ឆាន់ក្នុងកាលគួរក៏បាន ក្នុងកាលមិនគួរក៏បាន។[39]

[៧៥] សម័យនោះឯង ពួកភិក្ខុមានជម្ងឺ ត្រូវការដោយខ្លាញ់ជាថ្នាំ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លាញ់ ជាភេសជ្ជៈ គឺខ្លាញ់ខ្លាឃ្មុំ ខ្លាញ់ត្រី ខ្លាញ់ក្រពើ ខ្លាញ់ជ្រូក ខ្លាញ់លា ដែលភិក្ខុទទួលក្នុងកាលគួរ ចំអិនក្នុងកាលគួរ លាយគ្នាក្នុងកាលគួរ សម្រាប់ឲ្យភិក្ខុប្រើប្រាស់ដោយវិធីប្រើប្រាស់ដូចប្រេង (ជាសត្តាហកាលិក)បាន។[40] ម្នាលភិក្ខុទាំងឡាយ បើខ្លាញ់ដែលភិក្ខុបានទទួលក្នុងកាលមិនគួរ ចំអិនក្នុងកាលមិនគួរ លាយគ្នាក្នុងកាលមិនគួរ បើភិក្ខុប្រើប្រាស់ខ្លាញ់នោះ ត្រូវអាបត្តិទុក្កដបី។ ម្នាលភិក្ខុទាំងឡាយ បើខ្លាញ់ដែលភិក្ខុទទួលក្នុងកាលគួរ តែចំអិនក្នុងកាលមិនគួរ លាយគ្នាក្នុងកាលមិនគួរ បើភិក្ខុប្រើប្រាស់ខ្លាញ់នោះ ត្រូវអាបត្តិទុក្កដពីរ។ ម្នាលភិក្ខុទាំងឡាយ បើខ្លាញ់ដែលភិក្ខុទទួលក្នុងកាលគួរ ចំអិនក្នុងកាលគួរ តែលាយគ្នាក្នុងកាលមិនគួរ បើភិក្ខុប្រើប្រាស់ខ្លាញ់នោះ ត្រូវអាបត្តិទុក្កដមួយ។ ម្នាលភិក្ខុទាំងឡាយ បើខ្លាញ់ដែលភិក្ខុទទួលក្នុងកាលគួរ ចំអិនក្នុងកាលគួរ លាយគ្នាក្នុងកាលគួរ បើភិក្ខុប្រើប្រាស់ខ្លាញ់នោះ មិនត្រូវអាបត្តិឡើយ។

## ១៦១. មូលាទិភេសជ្ជកថា

[៧៦] សម័យនោះឯង ពួកភិក្ខុមានជម្ងឺ មានសេចក្តីត្រូវការដោយឫស ឬមើមជាភេសជ្ជៈ។ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឫស ឬមើមជាភេសជ្ជៈ គឺមើមរមៀត មើមខ្ញី មើមលំពាន់ មើមប្រស់ មើមអាច់ឆ្កែស មើមរំដេង មើមស្បូវភ្លាំង មើមស្មៅក្រវាញជ្រូក ម្យ៉ាងទៀត មើមដទៃណា ជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈ ក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ឲ្យភិក្ខុទទួលមើមទាំងឡាយនោះ ហើយរក្សាទុក ដរាបទាល់អស់បាន កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកភិក្ខុមានជម្ងឺ មានសេចក្តីត្រូវការ ដោយម្សៅជាភេសជ្ជៈ ដែលកើតអំពីឫស ឬមើម។ ពួកភិក្ខុ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថ្មកិន និងកូនថ្មកិន។

[៧៧] សម័យនោះឯង ពួកភិក្ខុមានជម្ងឺ មានសេចក្តីត្រូវការដោយទឹកចត់ជាភេសជ្ជៈ។ ភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកចត់ ជាភេសជ្ជៈ គឺទឹកចត់ កើតអំពីដើមស្ដៅ ទឹកចត់កើតអំពីដើមខ្លែងគង់ ទឹកចត់កើតអំពីដើមអម្បែងថ្ងៃ ទឹកចត់កើតអំពីវល្លិ៍បណ្តូលពេជ្រ ទឹកចត់កើតអំពីដើមទន្លា ឬថ្នាន់ ម្យ៉ាងទៀត ទឹកចត់ដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈ ក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ឲ្យភិក្ខុទទួលទឹកចត់ទាំងនោះ ហើយរក្សាទុកដរាបទល់អស់បាន កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ។

[៧៨] សម័យនោះឯង ពួកភិក្ខុមានជម្ងឺ មានសេចក្តីត្រូវការដោយស្លឹកឈើ ជាភេសជ្ជៈ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្លឹកឈើ ជាភេសជ្ជៈ គឺស្លឹកស្ដៅ ស្លឹកខ្លែងគង់ ស្លឹកអម្បែងថ្ងៃ ស្លឹកម្រះព្រៅ ឬជីរលីងលាក់ ស្លឹកកប្បាស ម្យ៉ាងទៀត ស្លឹកដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈ ក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ឲ្យភិក្ខុទទួលស្លឹកទាំងនោះ ហើយទុកដរាបទល់អស់បាន កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ។

[៧៩] សម័យនោះឯង ពួកភិក្ខុមានជម្ងឺ មានសេចក្តីត្រូវការដោយផ្លែឈើ ជាភេសជ្ជៈ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លែឈើជាភេសជ្ជៈ គឺផ្លែពិលង្គ ផ្លែដីប្លី ផ្លែម្រេច ផ្លែសម៉ ផ្លែសម៉ពីភេក ផ្លែកន្ទួតព្រៃ ផ្លែក្រវ៉ាញ ម្យ៉ាងទៀត ផ្លែឈើដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈ ក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ឲ្យភិក្ខុទទួលផ្លែឈើទាំងឡាយនោះ ហើយរក្សាទុកដរាបទល់អស់បាន កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ។

[៨០] សម័យនោះឯង ពួកភិក្ខុមានជម្ងឺ មានសេចក្តីត្រូវការដោយជ័រឈើជាភេសជ្ជៈ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជ័រឈើជាភេសជ្ជៈ គឺជ័រដែលហូរចេញអំពីដើមហិង្គុ១ ជ័រដែលគេយកស្លឹក និងមែកហិង្គុមករំងាស់១ ជ័រដែលគេយកតែស្លឹកហិង្គុតែម្យ៉ាងមករំងាស់១ (ជ័រទាំង៣យ៉ាងនេះ ជាជាតិហិង្គុទាំងអស់) ជ័រដែលហូរចេញអំពីត្រួយឈើ១ ជ័រដែលហូរចេញអំពីស្លឹកឈើ១ ជ័រដែលគេបេះស្លឹកឈើយកមកធ្វើ១ កំញាន១ ម្យ៉ាងទៀត ជ័រឈើដទៃណាដែលជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈ ក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ឲ្យភិក្ខុទទួលជ័រឈើទាំងនោះ ហើយរក្សាទុកដរាបទល់អស់បាន កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ។

[៨១] សម័យនោះឯង ពួកភិក្ខុមានជម្ងឺ មានសេចក្តីត្រូវការដោយអំបិល ជាភេសជ្ជៈ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអំបិលជាភេសជ្ជៈ គឺអំបិលកើតក្បែរឆ្នេរសមុទ្រ មានបែបដូចដីខ្សាច់ អំបិលមានពណ៌ខ្មៅ (អំបិលប្រក្រតី) អំបិលមានពណ៌ស កើតលើភ្នំ អំបិលដែលមានពន្លកដុះអំពីផែនដី (អំបិលដែលកើតអំពីអាចម៍ដីមានរសប្រៃ) អំបិលមានពណ៌ក្រហមដែលគេចំអិនជាមួយនឹងគ្រឿងសម្ភារៈទាំងពួង ម្យ៉ាងទៀត អំបិលដទៃណាដែលជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈ ក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ឲ្យភិក្ខុទទួលអំបិលទាំងនោះ ហើយរក្សាទុកដរាបទល់អស់បាន កាលបើមានហេតុ ទើបភិក្ខុឆាន់បាន កាលបើគ្មានហេតុទេ ហើយភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ។

[៨២] សម័យនោះឯង ព្រះវេលដ្ឋសីសៈដ៏មានអាយុ ជាឧបជ្ឈាយ៍របស់ព្រះអានន្ទដ៏មានអាយុ កើតបូសធំ។ ចីវរដែលប្រឡាក់ដោយទឹករំអិល ក៏ជាប់ស្អិតនៅនឹងកាយរបស់ព្រះវេលដ្ឋសីសៈនោះ។ ពួកភិក្ខុក៏យកទឹកទៅលាបចីវរនោះឲ្យសើមៗ ហើយបកចេញ។ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់សេនាសនចារិក បានទតឃើញភិក្ខុទាំងនោះកំពុងយកទឹកទៅលាបចីវរទាំងនោះឲ្យសើមៗ ហើយបកចេញ លុះទតហើយ ទ្រង់ចូលទៅកាន់សំណាក់ភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ទ្រង់មានពុទ្ធដម្រាស់នេះនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមានអាពាធដូចម្តេច។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះវេលដ្ឋសីសៈដ៏មានអាយុនេះ កើតបូសធំ ចីវរប្រឡាក់ដោយទឹករំអិល ជាប់ស្អិតនៅនឹងកាយ ខ្ញុំព្រះអង្គទាំងឡាយ យកទឹកមកលាបចីវរទាំងនោះឲ្យសើមៗ ហើយបកចេញ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានអាពាធ គឺកម ឬរមាស់ក្តី បូសតូចក្តី អាពាធទឹករងៃក្តី បូសធំក្តី និងកាយមានក្លិនអាក្រក់ តថាគតអនុញ្ញាតគ្រឿងលំអិត ជាភេសជ្ជៈដល់ភិក្ខុនោះ តថាគតអនុញ្ញាតអាចម៍គោ ដីស្អិត និងកាកនៃគ្រឿងជ្រលក់ ដល់ភិក្ខុដែលមានជម្ងឺ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្បាល់ និងអង្រែ។

[៨៣] សម័យនោះឯង ពួកភិក្ខុមានជម្ងឺ មានសេចក្តីត្រូវការដោយគ្រឿងលំអិត ជាភេសជ្ជៈ ដែលគេរែងរួចស្រេចហើយ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកញ្ច្រែង សម្រាប់រែងគ្រឿងលំអិត។ (ពួកភិក្ខុមានជម្ងឺ) មានសេចក្តីត្រូវការដោយគ្រឿងលំអិតដ៏ល្អិតក្រៃលែង។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកញ្ច្រែងសំពត់[41]

[៨៤] សម័យនោះឯង មានភិក្ខុ១រូប មានអាពាធកើតអំពីអមនុស្ស ។[42] អាចារ្យនិងឧបជ្ឈាយ៍ជាអ្នកបម្រើភិក្ខុនោះ ក៏មិនអាចនឹងធ្វើភិក្ខុនោះឲ្យស្បើយរោគបាន។ ភិក្ខុនោះទៅកាន់កន្លែងគេសម្លាប់ជ្រូក ហើយក៏ស៊ីសាច់ឆៅ [43] ផឹកឈាមស្រស់។[44] អាពាធរបស់ភិក្ខុនោះ ដែលកើតអំពីអមនុស្សនោះ ក៏រម្ងាប់ទៅ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាច់ឆៅ ឈាមស្រស់ ដល់ភិក្ខុដែលមានអាពាធកើតអំពីអមនុស្ស។

[៨៥] សម័យនោះឯង ភិក្ខុ១រូប មានអាពាធ ឈឺភ្នែក។ ភិក្ខុទាំងឡាយ នាំគ្នាគ្រាហ៍ភិក្ខុនោះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង។ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់សេនាសនចារិក បានទតឃើញភិក្ខុទាំងនោះកំពុងនាំគ្នាគ្រាហ៍ភិក្ខុនោះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង លុះទតឃើញហើយ ក៏ទ្រង់ចូលទៅកាន់លំនៅភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ទ្រង់មានពុទ្ធតម្រាស់នេះនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមានអាពាធដូចម្តេច។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន លោកដ៏មានអាយុនេះ មានអាពាធឈឺភ្នែក ខ្ញុំព្រះអង្គទាំងឡាយ នាំគ្នាគ្រាហ៍ភិក្ខុនោះទៅឲ្យបន្ទោបង់ឧច្ចារៈផង បស្សាវៈផង។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថ្នាំបន្តក់ភ្នែក គឺថ្នាំបន្តក់ភ្នែកមានពណ៌ខ្មៅ (ដែលគេស្លដោយគ្រឿងសម្ភារៈទាំងពួង) ថ្នាំបន្តក់ភ្នែកធ្វើពីបារទ (ដែលគេធ្វើដោយគ្រឿងសម្ភារៈផ្សេងៗ) ថ្នាំបន្តក់ភ្នែកដែលកើតក្នុងខ្សែទឹក ជ័ររង់ និងធ្យូង (ដែលគេយកអំពីអណ្តាតបទីប)។ ពួកភិក្ខុមានសេចក្តីត្រូវការដោយដោយវត្ថុដែលយកមកកិនលាយជាមួយគ្នានឹងថ្នាំបន្តក់ភ្នែក។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ខ្លឹមក្លាំពាក់ កំញាន និងមើមស្មៅក្រវាញជ្រូក។ សម័យនោះឯង ពួកភិក្ខុទុកថ្នាំបន្តក់ភ្នែកទាំងឡាយ ដែលជាម្សៅក្នុងសៀនទាំងឡាយខ្លះ ក្នុងផ្តិលទាំងឡាយខ្លះ (ថ្នាំបន្តក់ទាំងឡាយនោះ) ច្រឡូកច្រឡំទៅដោយកំទេចស្មៅទាំងឡាយខ្លះ ដោយអាចម៍ដីទាំងឡាយខ្លះ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្លាក់ សម្រាប់ដាក់ថ្នាំបន្តក់ភ្នែក។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់ក្លាក់សម្រាប់ដាក់ថ្នាំបន្តក់ភ្នែកខ្ពស់ និងទាប (គឺមានល្អ មានអាក្រក់) គឺក្លាក់ធ្វើដោយមាស និងក្លាក់ធ្វើដោយប្រាក់។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថ ដែលបរិភោគកាមគុណ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ក្លាក់ សម្រាប់ដាក់ថ្នាំបន្តក់ភ្នែកខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្លាក់ធ្វើដោយឆ្អឹង [45] ធ្វើដោយភ្លុក ធ្វើដោយស្នែង ធ្វើដោយដើមបបុស ធ្វើដោយដើមឫស្សី ធ្វើដោយឈើ ធ្វើដោយជ័រឈើ ធ្វើដោយផ្លែឈើ ធ្វើដោយលោហធាតុ[46] ធ្វើដោយគូថសង្ខ។ សម័យនោះឯង ពួកភិក្ខុមិនបានបិទក្លាក់សម្រាប់ដាក់ថ្នាំបន្តក់ភ្នែក ថ្នាំទាំងនោះ ក៏ច្រឡូកច្រឡំដោយកំទេចស្មៅទាំងឡាយខ្លះ ដោយអាចម៍ដីទាំងឡាយខ្លះ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតគម្រប ឬឆ្នុក។ គម្របចេះតែធ្លាក់។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុរុំ ឬចងក្លាក់ដោយខ្សែ។ ក្លាក់ក៏ចេះតែបែក។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុស្រេះដោយខ្សែ។ សម័យនោះ ពួកភិក្ខុបន្តក់ភ្នែក ដោយម្រាមដៃ ភ្នែកទាំងឡាយ ក៏មិនស្រួល។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចង្កឹះក្លាក់។ សម័យនោះ ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់ចង្កឹះក្លាក់ដ៏ខ្ពស់ និងទាប គឺចង្កឹះធ្វើដោយមាសខ្លះ ធ្វើដោយប្រាក់ខ្លះ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថ អ្នកបរិភោគកាមគុណ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ចង្កឹះក្លាក់ដ៏ខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ចង្កឹះដែលធ្វើដោយឆ្អឹង ធ្វើដោយភ្លុក ធ្វើដោយស្នែង។បេ។ ធ្វើដោយគូថសង្ខ។ សម័យនោះ ចង្កឹះក្លាក់ ក៏ធ្លាក់ទៅលើផែនដី ចង្កឹះក្លាក់នោះក៏អាក្រក់មិនស្អាត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតបំពង់សម្រាប់ដាក់ចង្កឹះ។ សម័យនោះឯង ពួកភិក្ខុរក្សាក្លាក់សម្រាប់ដាក់ថ្នាំបន្តក់ភ្នែកខ្លះ ចង្កឹះក្លាក់ខ្លះនៅតែនឹងដៃ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ថង់សម្រាប់ដាក់ក្លាក់។ ខ្សែយោគរបស់ថង់នោះ ក៏មិនទាន់មាន។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតនូវខ្សែយោគ និងខ្សែសម្រាប់ចង។

[៨៦] សម័យនោះឯង ព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុ កើតជម្ងឺក្តៅក្បាល។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ប្រេងសម្រាប់លាបក្បាល។ ព្រះបិលិន្ទវច្ឆត្ថេរ ក៏នៅតែអត់ទ្រាំរោគនោះមិនបាន។ ពួកភិក្ខុក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនត្ថុកម្ម (គឺការហិត ឬបញ្ច្រក ទៅតាមច្រមុះ)។ ឯថ្នាំសម្រាប់ហិត ឬបញ្ច្រក ទៅតាមច្រមុះ ក៏កំពប់ខ្ចាយទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបំពង់សម្រាប់បញ្ច្រកទៅតាមច្រមុះ (គឺបំពង់នត្ថុ)។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់បំពង់នត្ថុដ៏ខ្ពស់និងទាប គឺបំពង់នត្ថុធ្វើដោយមាសខ្លះ ធ្វើដោយប្រាក់ខ្លះ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថ ដែលបរិភោគកាមគុណ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បំពង់នត្ថុដ៏ខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបំពង់នត្ថុ ដែលធ្វើដោយឆ្អឹង។បេ។ ធ្វើដោយគូថសង្ខ។ ភិក្ខុទាំងឡាយបន្តក់ថ្នាំសម្រាប់នត្ថុទៅមិនស្មើគ្នា ។[47] ពួកភិក្ខុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបំពង់សម្រាប់នត្ថុជាគូ [48] ភិក្ខុទាំងនោះ ក៏នៅតែអត់ទ្រាំមិនបាន។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យជក់យកផ្សែង។ ពួកភិក្ខុក៏យកថ្នាំនោះមកមូរ ធ្វើជាបារី ហើយជក់ទៅ (ក៏ត្រឡប់ទៅជា) ក្តៅក។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវខ្សៀរ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុប្រើប្រាស់ខ្សៀរដ៏ខ្ពស់និងទាប គឺខ្សៀរធ្វើដោយមាសខ្លះ ធ្វើដោយប្រាក់ខ្លះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថដែលបរិភោគកាមគុណ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ខ្សៀរទាំងឡាយដ៏ខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សៀរ ដែលធ្វើដោយឆ្អឹង។បេ។ ដែលធ្វើដោយ

គូថសង្ខ។ សម័យនោះឯង ភិក្ខុទាំងឡាយ មិនបានបិទគ្របខ្សៀរទុក សត្វតូចៗ ក៏ចូលទៅក្នុងខ្សៀរនោះ។ ពួកភិក្ខុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគម្រប។ សម័យនោះឯង ពួកភិក្ខុរក្សាខ្សៀរនៅតែនឹងដៃ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវថង់សម្រាប់ដាក់ខ្សៀរ។ ឯខ្សៀរ និងគម្របក៏ទង្គិចគ្នា។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវថង់ជាគូ។ ខ្សែយោគរបស់ថង់ ក៏មិនទាន់មាននៅឡើយ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវខ្សែយោគ និងខ្សែសម្រាប់ចង។

[៨៧] សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុ មានអាពាធ កើតអំពីខ្យល់។ ពេទ្យទាំងឡាយនិយាយយ៉ាងនេះថា ភិក្ខុត្រូវស្លប្រេង។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុស្លប្រេងបាន។ ភិក្ខុទាំងឡាយក៏លាយទឹកស្រវឹងក្នុងប្រេងដែលស្លនោះ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាយទឹកស្រវឹងក្នុងប្រេងដែលស្លបាន។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លប្រេង លាយទឹកស្រវឹងច្រើនពេក ដល់នាំគ្នាផឹកប្រេងនោះទៅ ក៏ស្រវឹង។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផឹកប្រេងដែលគេលាយទឹកស្រវឹងច្រើនពេកទេ ភិក្ខុណាផឹក ត្រូវវិនយធរឲ្យភិក្ខុនោះធ្វើតាមធម៌ [49] ម្នាលភិក្ខុទាំងឡាយ ប្រេងស្លណាដែលគ្មានពណ៌ គ្មានក្លិន និងគ្មានរសរបស់ទឹកស្រវឹងប្រាកដឡើងទេ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកប្រេង ដែលគេលាយទឹកស្រវឹងមានសភាពយ៉ាងនោះបាន។ សម័យនោះឯង ពួកភិក្ខុស្លប្រេង លាយទឹកស្រវឹងច្រើនពេក។ ក្នុងពេលនោះ ភិក្ខុទាំងឡាយក៏មានសេចក្តីត្រិះរិះដូច្នេះថា ប្រេងដែលគេលាយនឹងទឹកស្រវឹងច្រើនពេក តើយើងត្រូវប្រតិបត្តិដូចម្តេច។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទុកដាក់ប្រេង ដែលគេលាយទឹកស្រវឹងច្រើនពេកនោះ ជាថ្នាំរឹត ឬលាបទៅវិញ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុ មានប្រេងដែលស្លហើយជាច្រើន។ តែគ្មានភាជន៍សម្រាប់ដាក់ប្រេង។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវតុម្ព (គឺកុណ្ឌីទឹក) ទាំង៣យ៉ាង គឺតុម្ពធ្វើដោយទង់ដែង១ តុម្ពធ្វើដោយឈើ១ តុម្ពធ្វើដោយផ្លែឈើ១។ សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុកើតរោគខ្យល់ក្នុងអវយវៈ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេទកម្ម (ការធ្វើឲ្យចេញញើស)។ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ក៏នៅតែអត់ទ្រាំមិនបាន។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆ្អងដោយស្លឹកឈើ និងមែកឈើផ្សេងៗ។ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ក៏នៅតែអត់ទ្រាំមិនបាន។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឆ្អងធំ [50] ព្រះបិលិន្ទវច្ឆដ៏មានអាយុ ក៏នៅតែអត់ទ្រាំមិនបាន។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកដែលគេស្ងោរលាយនឹងស្លឹកឈើ មែកឈើផ្សេងៗ។ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ក៏នៅតែអត់ទ្រាំមិនបាន។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្ទប់ទឹក[51]

[៨៨] សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុ កើតរោគខ្យល់ ចុកសៀតក្នុងសន្លាក់ដៃជើងជាដើម។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើឈាមឲ្យហូរចេញបាន។ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ក៏នៅតែអត់ទ្រាំមិនបាន។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជប់យកឈាម ដោយ(បំពង់)ស្នែងបាន។

[៨៩] សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុ មានបាទាបែក។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថ្នាំសម្រាប់លាបជើង។ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ក៏នៅតែអត់ទ្រាំមិនបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុតាក់តែងទឹកស្រវឹង (សម្រាប់លាបជើងឲ្យស្រួល)។

[៩០] សម័យនោះឯង ភិក្ខុមួយរូប មានអាពាធកើតពក។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសត្ថកម្ម (វះដោយកាំបិត)។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយទឹកចត់។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកចត់។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយម្សៅល្ង។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតម្សៅល្ង។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយដុំសត្លូវ (សម្រាប់បិទមុខដំបៅ)។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដុំសត្លូវ។ ភិក្ខុទាំងឡាយ មានសេចក្តីត្រូវការដោយសំពត់សម្រាប់រុំដម្បៅ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកំណាត់សំពត់សម្រាប់រុំដម្បៅ។ ដម្បៅក៏រមាស់។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាងដោយម្សៅគ្រាប់ស្ពៃ។ ដម្បៅក៏រីកឡើង។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចំហុយដម្បៅនោះ។ (លុះចំហុយទៅហើយ) សាច់ក៏ដុះលានចេញមក។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុយកទឹកលាយនឹងអម្បិលក្រួសមកបង្អាត់ (ដម្បៅនោះចេញ)។ (លុះបង្អាត់ទៅហើយ) ដម្បៅក៏មិនបានដុះសាច់ឡើង។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតប្រេងសម្រាប់លាបដម្បៅ។ ប្រេងក៏ហៀរហូរចេញ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់សម្រាប់បិទប្រេង និងថ្នាំរក្សាដម្បៅទាំងអស់។

[៩១] សម័យនោះឯង មានភិក្ខុ១រូបពស់ចឹក។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យថ្នាំមហាវិកដ៍៤យ៉ាង គឺគូថ (អាចម៍)១ ទឹមូត្រ(ទឹកនោម)១ ផេះ១ ដី១។ ក្នុងពេលនោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា យើងមិនបាច់ទទួលប្រគេនថ្នាំទាំងនេះទេឬ ឬត្រូវតែទទួលប្រគេនទើបបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើមានកប្បិយ[52] ការកៈ តថាគតអនុញ្ញាតឲ្យភិក្ខុប្រើកប្បិយការកៈនោះទទួលជំនួសបាន កាលបើគ្មានកប្បិយការកៈទេ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកខ្លួនឯង ហើយឆាន់ចុះ។ សម័យនោះឯង ភិក្ខុ១រូបផឹកថ្នាំ

ពិស។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកគូថ (អាចម៍ដែលលាយដោយទឹក)។ ក្នុងពេលនោះ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា យើងមិនបាច់ទទួលប្រគេន (នូវគូថនោះ) ទេឬ ឬថាគួរតែទទួលប្រគេនទើបបាន ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដូច្នេះ កាលបើភិក្ខុបន្ទោបង់គូថណាហើយ បានទទួលទុក (អំពីថ្ងៃមុន) លុះដល់ទៅថ្ងៃស្អែក គូថនោះ ឈ្មោះថាភិក្ខុបានទទួលរួចហើយ មិនបាច់ទទួលប្រគេនទៀតទេ។

[៩២] សម័យនោះឯង ភិក្ខុ១រូបមានអាពាធ ព្រោះត្រូវថ្នាំស្នេហ៍។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកទឹកលាយដោយអាច់បំណាស់ ។[53] សម័យនោះឯង ភិក្ខុ១រូបមានអាពាធ ខូចធាតុភ្លើង (កើតរោគមួល)។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកទឹកក្បុង[54] សម័យនោះឯង ភិក្ខុ១រូប កើតរោគស្គមលឿង។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់សម៉ ដែលត្រាំដោយទឹកនោម។[55] សម័យនោះឯង ភិក្ខុ១រូបមានអាពាធគឺខូចសម្បុរ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើការលាបដោយគ្រឿងក្រអូបបាន។ សម័យនោះឯង ភិក្ខុ១រូប មានកាយប្រកបដោយរោគទល់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផឹកថ្នាំបញ្ចុះ។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយទឹកអង្ករថ្លា។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវទឹកអង្ករថ្លា។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយទឹកសណ្តែកបាយស្ងោរ ដែលគេមិនបានធ្វើស្និទ្ធ (គឺគេមិនបានត្រងឲ្យស្អាតបាត)។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកសណ្តែកបាយស្ងោរ ដែលគេមិនបានធ្វើឲ្យស្និទ្ធ។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយទឹកសណ្តែកបាយស្ងោរ ដែលគេធ្វើឲ្យស្និទ្ធ (គេបានត្រងឲ្យស្អាតបាត)។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកសណ្តែកបាយស្ងោរ ដែលគេធ្វើឲ្យស្និទ្ធ។ (ភិក្ខុនោះ) មានសេចក្តីត្រូវការដោយសាច់ដែលមានឱជារស។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាច់ដែលមានឱជារស។

## ១៦២. បិលិន្ទវច្ឆវត្ថុ

CS vin.mv.06.03 | ភាគ ទី៧

**(១៦២)**

[៩៣] សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុ ឲ្យគេជម្រះញកភ្នំក្បែរក្រុងរាជគ្រឹះ ប្រាថ្នានឹងធ្វើទីពួន ឬទីជ្រកកោន។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ យាងចូលទៅកាន់លំនៅព្រះបិលិន្ទវច្ឆដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបិលិន្ទវច្ឆដ៏មានអាយុ រួចគង់នៅក្នុងទីដ៏សមគួរ។ លុះព្រះបាទមាគធសេនិយពិម្ពិសារគង់ក្នុងទីដ៏សមគួរហើយ ក៏ទ្រង់មានព្រះឱង្ការនេះ នឹងព្រះបិលិន្ទវច្ឆដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ព្រះថេរៈប្រើឲ្យគេធ្វើអ្វី។ ព្រះបិលិន្ទវច្ឆឆ្លើយថា បពិត្រមហារាជ អាត្មាភាព ឲ្យគេជម្រះញកភ្នំ ប្រាថ្នានឹងធ្វើទីពួន ឬទីជ្រកកោន។ ស្តេចសួរថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ មានសេចក្តីត្រូវការ ដោយអារាមិកជន[56] ដែរឬ។ ព្រះបិលិន្ទវច្ឆឆ្លើយថា បពិត្រមហារាជ ព្រះដ៏មានបុណ្យមិនទាន់អនុញ្ញាតអារាមិកជននៅឡើយទេ។ ស្តេចទ្រង់មានព្រះឱង្ការថា បពិត្រលោកដ៏ចំរើន បើដូច្នោះ គួរលោកក្រាបទូលសួរព្រះដ៏មានព្រះភាគ ហើយមកប្រាប់ខ្ញុំវិញ។ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ទទួលស្តាប់ព្រះឱង្ការនៃព្រះបាទមាគធសេនិយពិម្ពិសារដោយពាក្យថា សូមថ្វាយព្រះពរមហារាជ។ ព្រះបិលិន្ទវច្ឆដ៏មានអាយុក៏បានពន្យល់ព្រះបាទមាគធសេនិយពិម្ពិសារឲ្យទ្រង់ឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យត្រេកអរ ដោយពាក្យដ៏ប្រកបដោយធម៌។ លំដាប់នោះ ព្រះបាទមាគធសេនិយពិម្ពិសារ កាលដែលព្រះបិលិន្ទវច្ឆដ៏មានអាយុបានពន្យល់ឲ្យទ្រង់ឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យត្រេកអរ ដោយពាក្យប្រកបដោយធម៌ រួចហើយក៏ទ្រង់ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះបិលិន្ទវច្ឆដ៏មានអាយុ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ ក្រោយពីនោះមក ព្រះបិលិន្ទវច្ឆដ៏មានអាយុ បានប្រើបម្រើឲ្យទៅកាន់សំណាក់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់មានសេចក្តីប្រាថ្នានឹងប្រគេននូវអារាមិកជន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេចទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុទទួល) អារាមិកជន។ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ចូលទៅកាន់លំនៅព្រះបិលិន្ទវច្ឆដ៏មានអាយុ ជាគំរប់ពីរដង លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបិលិន្ទវច្ឆដ៏មានអាយុ ហើយគង់នៅក្នុងទីដ៏សមគួរ។ លុះព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់គង់ក្នុងទីដ៏សមគួរហើយ ក៏ទ្រង់មានព្រះឱង្ការដូច្នេះ នឹងព្រះបិលិន្ទវច្ឆដ៏មានអាយុថា បពិត្រលោកដ៏ចំរើន ព្រះដ៏មានបុណ្យទ្រង់បានអនុញ្ញាតអារាមិកជនហើយឬ។ ព្រះបិលិន្ទវច្ឆឆ្លើយថា ថ្វាយព្រះពរ មហារាជ។ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់មានព្រះឱង្ការថា បពិត្រលោកដ៏ចំរើន បើដូច្នោះ ខ្ញុំព្រះករុណានឹងប្រគេនអារាមិកជនដល់លោកម្ចាស់។ គ្រានោះឯង ព្រះបាទមាគធសេនិយពិម្ពិសារ ទទួលថានឹងប្រគេនអារាមិកជនដល់ព្រះបិលិន្ទវច្ឆដ៏មានអាយុ ហើយក៏ទ្រង់ភ្លេចទៅ លុះយូរមក ទើបបានទ្រង់រឭកឃើញ ក៏មានព្រះឱង្ការហៅមហាមាត្យម្នាក់ ជាអ្នកសម្រេចរាជការទាំងពួងថា ម្នាលនាយ អារាមិកជនណា ដែលអញទទួលថានឹងប្រគេនដល់លោកម្ចាស់ អារាមិកជននោះ តើអញបានប្រគេនហើយឬ។ មហាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះអង្គមិនទាន់បានប្រគេនអារាមិកជនដល់លោកម្ចាស់នៅឡើយទេ។ ព្រះបាទពិម្ពិសារទ្រង់សួរថា ម្នាលនាយ តាំងពីថ្ងៃនោះ មកដល់ឥឡូវនេះ តើយូរប៉ុន្មានរាត្រីហើយ។ មហាម្យនោះ បានរាប់រាត្រីទាំងឡាយ (ឃើញ) ហើយក៏ក្រាបបង្គំទូលព្រះបាទមាគធសេនិយពិម្ពិសារក្នុងពេលនោះដូច្នេះថា បពិត្រព្រះសម្មតិទេព (បើគិតតាំងពីថ្ងៃនោះ ដល់មកថ្ងៃនេះ) ចំនួនប្រាំរយរាត្រីហើយ។ ស្តេចទ្រង់មានព្រះឱង្ការថា ម្នាលនាយ បើដូច្នោះ ចូរអ្នកឯងប្រគេនអារាមិកជនប្រាំរយនាក់ ដល់លោកម្ចាស់ចុះ។ មហាមាត្យនោះ ទទួលស្តាប់ព្រះឱង្ការព្រះបាទមាគធសេនិយពិម្ពិសារដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយក៏ប្រគេនអារាមិកជនប្រាំរយនាក់ដល់

ព្រះបិលិន្ទវច្ឆដ៏មានអាយុ។ (ចាប់ដើមពីនោះមក) ស្រុក (នោះ) ក៏តាំងនៅជាស្រុកមួយដោយឡែក។ ពួកជនក៏ហៅស្រុកនោះថា អារាមិកគ្រាមខ្លះ បិលិន្ទវច្ឆគ្រាមខ្លះ។

[៩៤] សម័យនោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុ ជាជីតុន[57] ក្នុងស្រុកនោះ។ គ្រានោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុស្លៀកស្បង់ អំពីព្រឹក ហើយប្រដាប់ដោយបាត្រ និងចីវរ ចូលទៅកាន់បិលិន្ទវច្ឆគ្រាម ដើម្បីបិណ្ឌបាត។ សម័យនោះឯង ក្នុងស្រុកនោះ មានល្បែងមហោស្រព។ ពួកទារក[58] ក៏បានប្រដាប់ខ្លួន ស្អិតស្អាងដោយកម្រងផ្កា ហើយលេងមហោស្រព។ ក្នុងពេលនោះ ព្រះបិលិន្ទវច្ឆដ៏មានអាយុ បានត្រាច់ទៅបិណ្ឌបាត តាមលំដាប់ច្រកក្នុងបិលិន្ទវច្ឆគ្រាម ហើយចូលទៅកាន់ផ្ទះអារាមិកជនម្នាក់ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលប្រគេន។ សម័យនោះឯង ធីតា[59] របស់ប្រពន្ធអារាមិកជននោះឃើញពួកទារកដទៃ ប្រដាប់ខ្លួន ស្អិតស្អាងដោយកម្រងផ្កា ក៏យំទារថា អ្នកម៉ែ ចូរឲ្យកម្រងផ្កាដល់ខ្ញុំ អ្នកម៉ែ ចូរឲ្យគ្រឿងប្រដាប់ដល់ខ្ញុំ។ ក្នុងពេលនោះ ព្រះបិលិន្ទវច្ឆដ៏មានអាយុ បានពោលពាក្យនេះ នឹងប្រពន្ធរបស់អារាមិកជននោះថា ព្រោះហេតុអ្វី បានជាទារិកា[60] នេះយំ។ ប្រពន្ធរបស់អារាមិកជននោះឆ្លើយថា បពិត្រលោកដ៏ចំរើន ទារិកានេះ ឃើញពួកទារកដទៃប្រដាប់ខ្លួន ស្អិតស្អាងដោយកម្រងផ្កា ក៏យំទារថា អ្នកម៉ែ ចូរឲ្យកម្រងផ្កាដល់ខ្ញុំ អ្នកម៉ែ ចូរឲ្យគ្រឿងប្រដាប់ដល់ខ្ញុំ ដូច្នេះ ឯយើងខ្ញុំទាំងឡាយ ជាអ្នកកំសត់ នឹងបានកម្រងផ្កាមកពីណា នឹងបានគ្រឿងប្រដាប់មកពីណា។ គ្រានោះឯង ព្រះបិលិន្ទវច្ឆដ៏មានអាយុ ចាប់យករង្វេលស្មៅមួយ ហើយនិយាយដូច្នេះ នឹងប្រពន្ធអារាមិកជននោះថា បើដូច្នោះ មានតែនាងចូរបំពាក់រង្វេលស្មៅនេះ លើក្បាលទារិកានោះចុះ។ ទើបប្រពន្ធអារាមិកជននោះ ក៏ចាប់យករង្វេលស្មៅនោះ ហើយបំពាក់លើក្បាលទារិកានោះ។ រង្វេលស្មៅនោះ ក៏ក្លាយទៅជាកម្រងផ្កាមាស ល្អល្អះ គួរពិតពិលរមិលមើល ជាទីនាំឲ្យកើតសេចក្តីជ្រះថ្លា។ ទុកជាខាងក្នុងព្រះរាជវាំង ក៏រកកម្រងផ្កាមាសបែបនេះគ្មាន។ ពួកមនុស្សក៏ក្រាបបង្គំទូលព្រះបាទមាគធសេនិយពិម្ពិសារថា បពិត្រព្រះសម្មតិទេព ក្នុងផ្ទះអារាមិកជនឯណោះ មានកម្រងផ្កាមាស ល្អល្អះ គួរពិតពិលរមិលមើល ជាទីនាំឲ្យកើតសេចក្តីជ្រះថ្លា ទុកជាខាងក្នុងវាំងរបស់ព្រះករុណា ក៏រកកម្រងផ្កាមាសបែបនោះគ្មានដែរ អារាមិកជននោះ ជាអ្នកកំសត់ទេ នឹងមានកម្រងផ្កាមាសពីណា ប្រាកដជាវាលួចគេមកមិនខានឡើយ។ ក្នុងវេលានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ប្រើឲ្យមនុស្សទៅចាប់ចងត្រកូលអារាមិកជននោះ។ លុះវេលាព្រឹកព្រហាមឡើង ជាថ្ងៃគំរប់ពីរ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ហើយចូលទៅបិណ្ឌបាតឯបិលិន្ទវច្ឆគ្រាម កាលបើត្រាច់ទៅបិណ្ឌបាត តាមលំដាប់ច្រក ក្នុងបិលិន្ទវច្ឆគ្រាមហើយ ក៏ចូលទៅរកផ្ទះអារាមិកជននោះ លុះចូលទៅដល់ហើយ ក៏សួរពួកមនុស្ស ដែលនៅជិតខាងថា ត្រកូលអារាមិកជននេះ តើទៅឯណា។ ពួកមនុស្ស ដែលនៅជិតខាងឆ្លើយថា បពិត្រលោកដ៏ចំរើន ត្រកូលអារាមិជន ស្តេចឲ្យចាប់ចងអស់ទៅហើយ ព្រោះហេតុតែកម្រងផ្កាមាស (ដែលលោកម្ចាស់ឲ្យទៅ)នុ៎ះ។ ឯព្រះបិលិន្ទវច្ឆដ៏មានអាយុ ក៏ចូលទៅកាន់ព្រះរាជនិវេស៍ របស់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលប្រគេន។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ចូលទៅរកព្រះបិលិន្ទវច្ឆដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ហើយគង់ក្នុងទីសមគួរ។ លុះព្រះបាទមាគធសេនិយពិម្ពិសារ គង់ក្នុងទីសមគួរហើយ ព្រះបិលិន្ទវច្ឆដ៏មានអាយុ បានថ្វាយព្រះពរដូច្នេះថា បពិត្រមហារាជ ហេតុអ្វី បានជាព្រះអង្គឲ្យគេចាប់ចងត្រកូលអារាមិកជនមក។ ព្រះបាទពិម្ពិសារឆ្លើយថា បពិត្រលោកម្ចាស់ ព្រោះក្នុងផ្ទះអារាមិកជននោះ មានកម្រងផ្កាមាស ល្អល្អះ គួរពិតពិលរមិលមើល ជាទីនាំឲ្យកើតសេចក្តីជ្រះថ្លា ទុកជាខាងក្នុងវាំងរបស់ខ្ញុំ ក៏រកកម្រងផ្កាបែបនេះគ្មានដែរ អារាមិកជននោះ ជាមនុស្សកំសត់ទេ នឹងមានកម្រងផ្កាមាសពីណា ប្រាកដជាវាលួចគេមកមិនខានឡើយ។ គ្រានោះ ព្រះបិលិន្ទវច្ឆដ៏មានអាយុ បានអធិដ្ឋានប្រាសាទ របស់ព្រះបាទមាគធសេនិយពិម្ពិសារឲ្យទៅជាមាស (មួយរំពេច)។ ប្រាសាទនោះ ក៏ក្លាយទៅជាមាសសុទ្ធ។ ព្រះបិលិន្ទវច្ឆដ៏មានអាយុ ថ្វាយព្រះពរសួរថា បពិត្រមហារាជ មាសច្រើនម្ល៉េះនេះ តើព្រះអង្គបានមកពីណា។ ព្រះបាទពិម្ពិសារឆ្លើយថា បពិត្រលោកដ៏ចំរើន មាសនេះខ្ញុំដឹងហើយ នេះជាឥទ្ធានុភាពរបស់លោកម្ចាស់ទេតើ មានបន្ទូលដូច្នោះហើយ ក៏ឲ្យគេដោះលែងត្រកូលអារាមិកជននោះទៅ។

[៩៥] ពួកមនុស្សបានឮដំណឹងថា ព្រះបិលិន្ទវច្ឆដ៏មានអាយុ សំដែងឥទ្ធិបាដិហារ្យ ជាឧត្តរិមនុស្សធម្ម ដល់បរិសទ្យ ព្រមទាំងស្តេចហើយ ក៏មានចិត្តត្រេកអរជ្រះថ្លា នាំគ្នាយកភេសជ្ជៈទាំង៥ គឺទឹកដោះរាវ១ ទឹកដោះខាប់១ ប្រេង១ ទឹកឃ្មុំ១ ស្ករអំពៅ១ មកប្រគេនព្រះបិលិន្ទវច្ឆដ៏មានអាយុ។ ឯព្រះបិលិន្ទវច្ឆដ៏មានអាយុ បានលាភមកហើយ ក៏តែងចាត់ចែងបណ្តាភេសជ្ជៈទាំង៥ ភេសជ្ជៈណាមួយ ដែលលោកបានមកៗ (នោះ) ដល់បរិសទ្យជាធម្មតា។ ចំណែកខាងបរិសទ្យរបស់ព្រះបិលិន្ទវច្ឆដ៏មានអាយុនោះ ជាមនុស្សល្មោភច្រើន តែងយកភេសជ្ជៈទាំងអម្បាលម៉ាន ដែលខ្លួនបានមកៗ ទុកដាក់ពេញថ្លាងខ្លះ ពេញក្អមខ្លះ ពេញសម្តត់តម្រងទឹកខ្លះ ពេញថង់ខ្លះ ហើយព្យួរទុករាល់ៗបង្អួច។ ភេសជ្ជៈទាំងនោះហៀរហូរក៏ពប់ខ្ទាយ។ កុដិក៏ដេរដាសដោយពួកកណ្តុរ។ ពួកមនុស្សដើរទៅកាន់វិហារចារិក បានឃើញហើយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្រនេះ មានរបស់ទុកដាក់ក្នុងឃ្លាំង ដូចជាព្រះបាទមាគធសេនិយពិម្ពិសារដែរ។ ពួកភិក្ខុបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុមិនគួរនឹងមកសន្សំ (ភេសជ្ជៈ) ដោយសេចក្តីល្មោភច្រើនបែបដូច្នេះសោះ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុសន្សំ (ភេសជ្ជៈ) ដោយសេចក្តីល្មោភច្រើនបែបដូច្នេះ ពិតមែនឬ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។បេ។ ព្រះសម្ពុទ្ធទ្រង់តិះដៀល ហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ភេសជ្ជៈទាំងឡាយណា ដែលពួកភិក្ខុមានជម្ងឺ គប្បីលិទ្ធភ្លក់ (ឆាន់)បាន គឺទឹកដោះរាវ១ ទឹកដោះខាប់១ ប្រេង១ ទឹកឃ្មុំ១ ស្ករអំពៅ១ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយ ត្រូវទុកដាក់ឆាន់បានកំណត់ត្រឹម៧ថ្ងៃ ជាយ៉ាងយូរបំផុត បើភិក្ខុទុកភេសជ្ជៈទាំងនោះឲ្យកន្លងហួសពីកំណត់នោះទៅ ត្រូវវិនយធរឲ្យភិក្ខុនោះធ្វើតាមធម៌។[61]

ចប់ វារៈសំដែងអំពីភេសជ្ជៈ ដែលព្រះមានព្រះភាគអនុញ្ញាតជាបឋម។

## ១៦៣. គុឡាទិអនុជានានា

CS vin.mv.06.04 | ភាគ ទី៧

[៩៦] គ្រានោះ ព្រះមានព្រះភាគ គង់ទៀបក្រុងសាវត្ថី គួរតាមព្រះអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិកក្រុងរាជគ្រឹះ។ ព្រះកង្ខារេវតដ៏មានអាយុ បានដើរចូលទៅកាន់កន្លែងធ្វើស្ករអំពៅ ក្នុងពាក់កណ្ដាលផ្លូវ ហើយបានឃើញពួកជនកំពុងដាក់ម្សៅខ្លះ ផេះខ្លះ លាយក្នុងស្ករអំពៅ លុះឃើញហើយ ក៏មានសេចក្ដីរង្កៀសថា ស្ករអំពៅលាយដោយអាមិសៈ ជាអកប្បិយៈ ប្រហែលជាស្ករអំពៅ មិនគួរភិក្ខុនឹងឆាន់ក្នុងវេលាវិកាលទេដឹង (កាលរង្កៀសដូច្នេះហើយ) ព្រមទាំងបរិសទ្យ ក៏មិនហ៊ានឆាន់ដុំស្ករអំពៅឡើយ។ ពួកភិក្ខុណាសំគាល់ពាក្យព្រះរេវតនោះ ថាជាពាក្យគួរស្ដាប់បាន ភិក្ខុទាំងនោះ ក៏មិនហ៊ានឆាន់ស្ករអំពៅដែរ។ ភិក្ខុទាំងឡាយ បានក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកជនដាក់ម្សៅខ្លះ ផេះខ្លះ លាយក្នុងស្ករអំពៅដើម្បីប្រយោជន៍អ្វី។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ដើម្បីប្រយោជន៍ឲ្យស្អិត។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើគេដាក់ម្សៅខ្លះ ផេះខ្លះលាយក្នុងស្ករអំពៅ គ្រាន់តែឲ្យស្អិត (ប៉ុណ្ណោះទេ) ស្ករអំពៅនោះ នៅរាប់ថាជាស្ករអំពៅដដែល។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ស្ករអំពៅ(នោះ) បានតាមសប្បាយ។ ព្រះកង្ខារេវតដ៏មានអាយុ បានឃើញសណ្ដែកបាយ ដុះលើដុំលាមក ក្នុងទីពាក់កណ្ដាលផ្លូវ លុះឃើញហើយ ក៏រង្កៀសថា សណ្ដែកបាយ ជាអកប្បិយៈ ទុកជាចំអិនហើយ សណ្ដែកបាយ ក៏គង់តែដុះឡើងខ្លះទៀត កាលរង្កៀសដូច្នេះហើយ ព្រមទាំងបរិសទ្យ ក៏មិនហ៊ានឆាន់សណ្ដែកបាយឡើយ។ ពួកភិក្ខុណា សំគាល់ពាក្យព្រះកង្ខារេវតនោះ ថាជាពាក្យគួរស្ដាប់បាន ភិក្ខុទាំងនោះ ក៏មិនហ៊ានឆាន់សណ្ដែកបាយដែរ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើសណ្ដែកបាយដែលគេចំអិនហើយ នៅតែដុះឡើងខ្លះទៀត ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុឆាន់សណ្ដែកបាយ (នោះ) បានតាមសប្បាយ។ ក៏សម័យនោះឯង ភិក្ខុមួយរូប មានអាពាធកើតអំពីខ្យល់ក្នុងពោះ។ ភិក្ខុនោះបានផឹកថ្នាំ ឈ្មោះលោណសោចិរកៈ [62] ភិក្ខុនោះ ក៏បាត់អាពាធកើតអំពីខ្យល់ក្នុងពោះនោះទៅ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុឈឺ ឆាន់ថ្នាំឈ្មោះលោណសោចិរកៈ (នោះ) បានតាមសប្បាយ ឲ្យភិក្ខុមិនឈឺ ឆាន់ថ្នាំលាយទឹក ដោយវិធីប្រើប្រាស់ដូចទឹក (មានទឹកផ្លែស្វាយជាដើម) បាន។

## ១៦៤. អន្តោវុដ្ឋាទិបដិក្ខេបកថា

CS vin.mv.06.05 | ភាគ ទី៧

**(១៦៤)**

[៩៧] គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ បានដល់ទៅក្រុងរាជគ្រឹះ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវន កលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះនោះ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់អាពាធកើតអំពីខ្យល់ក្នុងព្រះឧទរ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុគិតថា កាលអំពីមុន ព្រះដ៏មានព្រះភាគ ទ្រង់អាពាធកើតអំពីខ្យល់ក្នុងព្រះឧទរ ទ្រង់បានសះស្បើយទៅវិញ ព្រោះ(សោយ) បបរឈ្មោះតេកដុលា[63] (លុះគិតដូច្នោះហើយ) ក៏សូមល្ងខ្លះ អង្ករខ្លះ សណ្ដែកបាយខ្លះ (បានហើយ) ទុកខាងក្នុងអកប្បិយកុដិដោយខ្លួនឯង ចំអិនខាងក្នុងអកប្បិយកុដិដោយខ្លួនឯង ទើបបង្អោនទៅថ្វាយព្រះដ៏មានព្រះភាគ ហើយក្រាបបង្គំទូលថា សូមព្រះដ៏មានព្រះភាគ ទ្រង់សោយនូវបបរឈ្មោះតេកដុលា។ ព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបនូវហេតុហើយសួរក៏មាន ទ្រង់ជ្រាបហើយ មិនសួរក៏មាន ទ្រង់ជ្រាបច្បាស់នូវកាលគួរហើយសួរក៏មាន ទ្រង់ជ្រាបច្បាស់នូវកាលគួរហើយ មិនសួរក៏មាន ឯព្រះតថាគតទាំងឡាយ ព្រះអង្គតែងសួរតែការណាដែលប្រកបដោយប្រយោជន៍ ការដែលមិនប្រកបដោយប្រយោជន៍ ព្រះអង្គមិនសួរឡើយ ព្រោះព្រះតថាគតទាំងឡាយ ទ្រង់បានផ្ដាច់បង់នូវកម្មមិនប្រកបដោយប្រយោជន៍ទាំងឡាយ ដោយអរិយមគ្គជ្រះស្រឡះហើយ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទាំងឡាយ រមែងទ្រង់សួរពួកភិក្ខុដោយអាការពីរយ៉ាង គឺសួរដើម្បីសំដែងធម៌ម្យ៉ាង ដើម្បីនឹងបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយម្យ៉ាង។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ហៅព្រះអានន្ទដ៏មានអាយុមកហើយ ទ្រង់ត្រាស់សួរថា ម្នាលអានន្ទ បបរនេះបានមកពីណា។ ទើបព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលអានន្ទ កម្មដែលអ្នកធ្វើនេះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ ម្នាលអានន្ទ អ្នកឯងមិនសមបើនឹងត្រិះរិះដើម្បីសេចក្ដីប្រាថ្នាច្រើនមានសភាពយ៉ាងនេះទេ ម្នាលអានន្ទ អាមិសៈណា ដែលភិក្ខុទុកខាងក្នុង(អកប្បិយកុដិ) អាមិសៈនោះ ក៏ទៅជាអកប្បិយៈ (មិនគួរ) ដែរ អាមិសៈណាដែលភិក្ខុចំអិនខាងក្នុងអកប្បិយកុដិ អាមិសៈនោះ ក៏ទៅជាអកប្បិយៈដែរ អាមិសៈណា ដែលភិក្ខុចំអិនដោយខ្លួនឯង អាមិសៈនោះ ក៏ទៅជាអកប្បិយៈដែរ ម្នាលអានន្ទ អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីឆាន់អាមិសៈ ដែលជាអន្តោវុត្ថ (ភោជនដែលភិក្ខុទុកខាងក្នុងអកប្បិយកុដិ) អាមិសៈ ដែលជាអន្តោបក្ក (ភោជន ដែលភិក្ខុចំអិនក្នុងអកប្បិយកុដិ) អាមិសៈ ដែលជាសាមបក្ក (ភោជន ដែលភិក្ខុចំអិនដោយខ្លួនឯង)ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជន ខាងក្នុងអកប្បិយកុដិផង ចំអិនខាងក្នុងអកប្បិយកុដិផង ចំអិនដោយខ្លួនឯងផង បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដបី។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជន ខាងក្នុងអកប្បិយកុដិផង ចំអិនខាងក្នុងអកប្បិយកុដិផង តែប្រើពួកអ្នកដទៃចំអិនឲ្យ បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដពីរ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្នុងអកប្បិយកុដិ ចំអិនខាងក្រៅអកប្បិយកុដិ តែភិក្ខុចំអិនខ្លួនឯង បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដពីរ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្រៅអកប្បិយកុដិ ចំអិនខាងក្នុងអកប្បិយកុដិ តែភិក្ខុចំអិនខ្លួនឯង បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដពីរ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជន ខាងក្នុងអកប្បិយកុដិ ចំអិនខាងក្រៅអកប្បិយកុដិ តែប្រើពួកអ្នកដទៃចំអិនឲ្យ បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដមួយ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្រៅអកប្បិយកុដិ ចំអិនខាងក្នុងអកប្បិយកុដិ តែប្រើពួកអ្នកដទៃចំអិនឲ្យ បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដមួយ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជនខាងក្រៅអកប្បិយកុដិ ចំអិនខាងក្រៅអកប្បិយកុដិ តែភិក្ខុចំអិនខ្លួនឯង បើភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិទុក្កដមួយ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទុកភោជន ខាងក្រៅអកប្បិយកុដិ ចំអិនខាងក្រៅអកប្បិយកុដិ តែប្រើពួកអ្នកដទៃចំអិនឲ្យ បើភិក្ខុឆាន់ភោជននោះ មិនត្រូវអាបត្តិទេ។

[៩៨] សម័យនោះឯង ពួកភិក្ខុដឹងថា ការចំអិនខ្លួនឯង ព្រះដ៏មានព្រះភាគ ទ្រង់ហាមហើយ ក៏រង្កៀសក្នុងការចំអិនថែមទៀត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុចំអិនថែមទៀតបាន។

[៩៩] សម័យនោះឯង ក្រុងរាជគ្រឹះកើតទុរភិក្ស (អត់បាយ)។ មនុស្សទាំងឡាយ បាននាំយកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ទៅកាន់អារាម។ ភិក្ខុទាំងឡាយ ទុកវត្ថុទាំងនោះខាងក្រៅ(កុដិ) ពួកសត្វតូចៗ[64] នាំគ្នាស៊ីខ្លះ ពួកចោរលួចយកទៅខ្លះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទុក (វត្ថុទាំងនោះ) ខាងក្នុងអកប្បិយកុដិបាន ភិក្ខុទាំងឡាយ ក៏ទុកវត្ថុទាំងនោះខាងក្នុងអកប្បិយកុដិ ហើយឲ្យគេចំអិនខាងក្រៅ ពួកជនអ្នកស៊ីដែល នាំគ្នាចោមរោមស៊ី។ ភិក្ខុទាំងឡាយ មិនស្និទ្ធចិត្ត (ប្រកបដោយសេចក្តីរង្កៀស) ក៏ចេះតែឆាន់ទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុចំអិនខាងក្នុងអកប្បិយកុដិបាន។ កាលដែលស្រុកអំណត់អត់បាយ ពួកកប្បិយការកជន ក៏នាំយកអាមិសៈអស់ទៅជាច្រើន ប្រគេនតែបន្តិចបន្តួច ដល់ពួកភិក្ខុ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុចំអិនខ្លួនឯងបាន។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុទុកអាមិសៈក្នុងអកប្បិយកុដិបាន ឲ្យចំអិនអាមិសៈ ក្នុងអកប្បិយកុដិបាន ឲ្យចំអិនអាមិសៈខ្លួនឯងបាន។

## ១៦៥. ឧគ្គហិតបដិគ្គហណា

CS vin.mv.06.06 | ភាគ ទី៧

**(១៦៥)**

[១០០] សម័យនោះឯង ពួកភិក្ខុច្រើនរូបនៅចាំវស្សាក្នុងដែនកាសី ហើយក៏នាំគ្នាទៅកាន់ក្រុងរាជគ្រឹះ ដើម្បីគាល់ព្រះមានព្រះភាគ លុះទៅដល់ពាក់កណ្តាលផ្លូវ ក៏រកភោជនសៅហ្មង ឬឧត្តមនឹងឆាន់ឲ្យឆ្អែតបរិបូណ៌មិនបាន (ឃើញ) មានតែផ្លែឈើ ដែលគួរនឹងឆាន់ជាច្រើន តែរកបុគ្គលជាកប្បិយការកគ្មាន។ ភិក្ខុទាំងនោះ មានរូបកាយលំបាក ក៏នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្នុងវត្តវេឡុវន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចក៏អង្គុយនៅក្នុងទៅសមគួរ។ ការដែលរីករាយជាមួយនឹងពួកភិក្ខុអាគន្តុកនេះឯង ជាប្រវេណីរបស់ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ (គ្រប់ព្រះអង្គ)។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះ នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយល្មមអត់ទ្រាំសេចក្តីលំបាកបានដែរឬទេ ល្មមញុំាងឥរិយាបថ ឲ្យប្រព្រឹត្តទៅបានស្រួលដែរឬទេ អ្នក(រាល់គ្នា) ដើរមកតាមផ្លូវឆ្ងាយ មិនលំបាកទេឬ ម្យ៉ាងទៀត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មកអំពីទីណា។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយល្មមធន់ទ្រាំបាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយ ល្មមញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅស្រួលបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយ នៅចាំវស្សាក្នុងដែនកាសី ហើយមកកាន់ក្រុងរាជគ្រឹះ ដើម្បីគាល់ព្រះអង្គ ក្នុងទីនេះ លុះមកដល់ពាក់កណ្តាលផ្លូវ រកភោជនសៅហ្មង ឬឧត្តមនឹងឆាន់ឲ្យបានឆ្អែតបរិបូណ៌គ្មាន (ឃើញ)មានតែផ្លែឈើ ដែលគួរនឹងឆាន់ជាច្រើន តែរកបុគ្គល ជាកប្បិយការកៈគ្មាន ហេតុនោះ បានជាខ្ញុំព្រះអង្គទាំងឡាយ មានរូបកាយលំបាក មកតាមផ្លូវឆ្ងាយ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ (បើភិក្ខុណា) បានឃើញផ្លែឈើ ដែលគួរនឹងឆាន់ក្នុងទីណា តែរកបុគ្គល ជាកប្បិយការកៈគ្មាន តថាគត អនុញ្ញាតឲ្យ (ភិក្ខុនោះ) រើសខ្លួនឯង ហើយនាំយកទៅ លុះឃើញបុគ្គល ជាកប្បិយការកៈហើយ ត្រូវដាក់ចុះលើផែនដី ឲ្យកប្បិយការកៈប្រគេន ហើយឆាន់ចុះ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុទទួលរបស់ឧគ្គហិត គឺវត្ថុដែលភិក្ខុកាន់យកហើយបាន។

[១០១] សម័យនោះឯង ប្រេងល្ងថ្មី និងទឹកឃ្មុំថ្មីកើតឡើងដល់ព្រាហ្មណ៍ម្នាក់។ ឯព្រាហ្មណ៍នោះ ក៏ត្រិះរិះដូច្នេះថា បើដូច្នោះ មានតែគួរអាត្មាអញ ប្រគេនប្រេងល្ងថ្មី និងទឹកឃ្មុំថ្មី ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធាន។ ទើបព្រាហ្មណ៍នោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ បានស្មោះសរ រីករាយ ទៅនឹងព្រះដ៏មានព្រះភាគ លុះធ្វើពាក្យគួរជាទីរីករាយ គួរជាទីរលឹក ឲ្យសម្រេចហើយ ក៏ឈរនៅក្នុងទីសមគួរ។ លុះព្រាហ្មណ៍នោះ ឈរនៅក្នុងទីសមគួរហើយ បាននិមន្តព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលនិមន្ត ដោយភាវៈស្ងៀម។ ចំណែកព្រាហ្មណ៍នោះ ដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ ទើបចៀសចេញទៅ។ លុះកន្លងរាត្រីនោះទៅហើយ ព្រាហ្មណ៍នោះបានតាក់តែង នូវខាទនីយភោជនីយាហារយ៉ាងឧត្តម ស្រេចហើយ ទើបឲ្យក្រាបបង្គំទូលនូវកាលគួរ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ពេលនេះសមគួរហើយ ភត្តសម្រេចហើយ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ហើយ ប្រដាប់ដោយបាត្រ និងចីវរអំពីព្រឹក យាងទៅកាន់ផ្ទះព្រាហ្មណ៍នោះ លុះយាងទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលព្រាហ្មណ៍តាក់តែងទុក ព្រមទាំងភិក្ខុសង្ឃ។ ឯព្រាហ្មណ៍នោះ បានអង្គាសថ្វាយខាទនីយភោជនីយាហារ (បង្អែមចំអាប) ដ៏ឆ្ងាញ់ពីសារ ដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែក លែងទទួលទៀត លុះព្រះដ៏មានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រ (ព្រាហ្មណ៍) ក៏អង្គុយក្នុងទីសមគួរ។ លុះព្រាហ្មណ៍នោះអង្គុយនៅក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈ យាងចៀសចេញទៅ។ កាលព្រះដ៏មានព្រះភាគ យាងចេញទៅ មិនយូរប៉ុន្មាន ព្រាហ្មណ៍នោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញនិមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធានមក ដោយមានបំណងថា នឹងប្រគេនប្រេងល្ងថ្មី និងទឹកឃ្មុំថ្មី ដើម្បីប្រយោជន៍ ដល់ប្រេងល្ង និងទឹកឃ្មុំណា ប្រេងល្ង និងទឹកឃ្មុំនោះ អាត្មាអញភ្លេចប្រគេនទៅហើយ បើដូច្នោះ មានតែអាត្មាអញឲ្យគេនាំយកនូវប្រេងល្ងថ្មី និងទឹកឃ្មុំថ្មី ដោយក្រឡ និងក្អមទៅកាន់អារាម។ ទើបព្រាហ្មណ៍នោះ ឲ្យគេនាំយកប្រេងល្ងថ្មី និងទឹកឃ្មុំថ្មី ដោយក្រឡ និងក្អម ទៅកាន់អារាម ហើយបានចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឈរនៅក្នុងទីសមគួរ។ លុះព្រាហ្មណ៍នោះ ឈរនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយមានបំណងថា នឹងប្រគេនប្រេងល្ងថ្មី និងទឹកឃ្មុំថ្មី ដើម្បីប្រយោជន៍ ដល់ប្រេងល្ង និងទឹកឃ្មុំណា ប្រេងល្ង និងទឹកឃ្មុំនោះ ខ្ញុំព្រះអង្គក៏ភ្លេចប្រគេន សូមព្រះគោតមដ៏ចំរើន ទទួលយកប្រេងល្ងថ្មី និងទឹកឃ្មុំថ្មីរបស់ខ្ញុំព្រះអង្គ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកឯងចូរប្រគេន ដល់ភិក្ខុទាំងឡាយចុះ។ គ្រានោះឯង កាលស្រុកកើតទុរភិក្ស (អត់បាយ) ភិក្ខុទាំងឡាយ ក៏ហាមឃាត់វត្ថុបន្តិចបន្តួចខ្លះ[65] ពិចារណា ហើយហាមឃាត់ខ្លះ[66] ម្យ៉ាងទៀត សង្ឃទាំងអស់ ក៏បានហាមភត្តរួចហើយ។ ពួកភិក្ខុក៏រង្កៀស ហើយមិនហ៊ានទទួល។ ព្រះអង្គ

ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆាន់ហើយ ហាមភត្តរួចហើយ ឆាន់ភោជនមិនមែនជារបស់ដែលអំពីភិក្ខុឈឺ ឬមិនបានធ្វើវិនយកម្ម ដែលគេនាំយកមកអំពីទីដែលគេនិមន្តនោះបាន។

## ១៦៦. បដិគ្គហិតាទិអនុជាននា

CS vin.mv.06.07 | ភាគ ទី៧

**(១៦៦)**

[១០២] សម័យនោះឯង ត្រកូលឧបដ្ឋាករបស់ឧបនន្ទសក្យបុត្រដ៏មានអាយុ បានបញ្ជូនខាទនីយៈទៅ ដើម្បីប្រយោជន៍ដល់សង្ឃ ហើយផ្តាំថា ត្រូវពួកអ្នកឯងបង្ហាញដល់លោកម្ចាស់ឧបនន្ទរួចហើយ សឹមប្រគេនសង្ឃចុះ។ គ្រានោះឯង ឧបនន្ទសក្យបុត្រដ៏មានអាយុចូលទៅស្រុក ដើម្បីបិណ្ឌបាត។ ឯមនុស្សទាំងនោះក៏ទៅកាន់អារាម ហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ឧបនន្ទទៅណាហើយ។ ពួកភិក្ខុប្រាប់ថា ម្នាលអាវុសោទាំងឡាយ ឧបនន្ទសក្យបុត្រដ៏មានអាយុនុ៎ះ ចូលទៅស្រុក ដើម្បីបិណ្ឌបាតហើយ។ មនុស្សទាំងនោះប្រាប់ពួកភិក្ខុថា បពិត្រលោកដ៏ចំរើន ខាទនីយៈនេះ ពួកយើងត្រូវបង្ហាញ ដល់លោកម្ចាស់ឧបនន្ទសិន ហើយសឹមប្រគេនដល់សង្ឃ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរទទួលទុក ទំរាំតែឧបនន្ទវិលមកដល់។ លំដាប់នោះ ឧបនន្ទសក្យបុត្រដ៏មានអាយុ ចូលទៅរកត្រកូលទាំងឡាយ ក្នុងវេលាមុនភត្ត ហើយវិលត្រឡប់មក ក្នុងវេលាថ្ងៃពេក។ សម័យនោះឯង កាលស្រុកកើតទុរភិក្ស (អត់បាយ) ភិក្ខុទាំងឡាយហាមឃាត់វត្ថុបន្តិចបន្តួចខ្លះ ពិចារណា ហើយក៏ហាមឃាត់ខ្លះ ម្យ៉ាងទៀត សង្ឃទាំងអស់ ក៏បានហាមភត្តរួចហើយ។ ពួកភិក្ខុក៏រង្កៀស មិនហ៊ានទទួល។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុដែលបរិភោគហើយ ហាមភត្តរួចហើយ ឆាន់ភោជន មិនមែនជារបស់ដែល អំពីភិក្ខុឈឺ ឬមិនបានធ្វើវិនយកម្ម ដែលភិក្ខុបានទទួល ក្នុងវេលាមុនភត្ត (នោះ)បាន។

[១០៣] គ្រានោះ ព្រះមានព្រះភាគ គង់ក្នុងក្រុងរាជគ្រឹះ តាមសមគួរដល់ព្រះអធ្យាស្រ័យហើយ យាងចេញទៅកាន់ចារិក នៃក្រុងសាវត្ថី ទ្រង់យាងទៅកាន់ចារិក ដោយលំដាប់ ទើបបានទៅដល់ក្រុងសាវត្ថី។ បានឮថា ព្រះមានព្រះភាគ គង់ក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ។ សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ មានអាពាធក្តៅរោលរាលក្នុងកាយ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ និយាយពាក្យនេះនឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោសារីបុត្ត កាលពីមុន លោកមានអាពាធក្តៅ ដុតរោលរាលក្នុងកាយ តើលោកបានជាសះស្បើយ ដោយថ្នាំអ្វី។ ព្រះសារីបុត្តតបថា ម្នាលអាវុសោ ខ្ញុំបានជាសះស្បើយ ដោយមើមឈូក និងក្រអៅឈូក។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បំបាត់ខ្លួន អំពីវត្តជេតវន ហើយទៅប្រាកដទៀបមាត់ស្រះបោក្ខរណី ឈ្មោះមន្ទាកិនី ដោយឆាប់រហ័ស ដូចជាបុរសមានកំលាំង លាចេញនូវដៃដែលខ្លួនបត់ចូល ឬបត់ចូល នូវដៃដែលខ្លួនលាចេញ។ មានដំរី១ បានឃើញព្រះមហាមោគ្គល្លានដ៏មានអាយុមកអំពីចម្ងាយ លុះឃើញហើយ បាននិយាយពាក្យនេះ នឹងព្រះមហាមោគ្គល្លានដ៏មានអាយុថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់មហាមោគ្គល្លានមកចុះ បពិត្រលោកដ៏ចំរើន លោកម្ចាស់មហាមោគ្គល្លានមកល្អហើយ បពិត្រលោកដ៏ចំរើន លោកម្ចាស់ ត្រូវការដោយវត្ថុអ្វី ខ្ញុំបានអ្វីប្រគេនលោកម្ចាស់។ ព្រះមហាមោគ្គល្លានតបថា ម្នាលអាវុសោ យើងត្រូវការដោយមើមឈូក និងក្រអៅឈូក។ ទើបដំរីនោះ បង្គាប់ទៅដំរីដទៃថា ម្នាលនាយ បើដូច្នោះ អ្នកចូរប្រគេនមើមឈូក និងក្រអៅឈូក ដល់លោកម្ចាស់ តាមសព្វព្រះហឫទ័យ។ ឯដំរីនោះ ចុះទៅកាន់ស្រះបោក្ខរណី ឈ្មោះមន្ទាកិនី ហើយដកយក នូវមើមឈូក និងក្រអៅឈូក ដោយប្រមោយ ហើយលាងស្អាត វេចចងជាសំណុំ រួចចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បំបាត់ខ្លួនពីមាត់ស្រះបោក្ខរណី ឈ្មោះមន្ទាកិនី ទៅប្រាកដនៅក្នុងវត្តជេតវនវិញ ដោយឆាប់រហ័យ ដូចជាបុរសមានកំឡាំង លាដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញ។ ឯដំរីនោះ បំបាត់ខ្លួនអំពីមាត់ស្រះបោក្ខរណី ឈ្មោះមន្ទាកិនី ទៅប្រាកដនៅក្នុងវត្តជេតវនដែរ ទើបដំរីនោះ បានឲ្យព្រះមហាមោគ្គល្លានដ៏មានអាយុ ទទួលមើមឈូក និងក្រអៅឈូក ហើយក៏បំបាត់ខ្លួនអំពីវត្តជេតវន ទៅប្រាកដទៀបមាត់ស្រះបោក្ខរណី ឈ្មោះមន្ទាកិនីវិញ។ ចំណែកព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ហុចមើមឈូក និងក្រអៅឈូក ទៅព្រះសារីបុត្តដ៏មានអាយុ។ ឯព្រះសារីបុត្តមានអាយុ កាលបានឆាន់មើមឈូក និងក្រអៅឈូកហើយ ក៏បានសះ ជាអាពាធ ដែលដុតរោលរាលក្នុងកាយ។ មើមឈូក និងក្រអៅឈូក ក៏សល់នៅជាច្រើន។ សម័យនោះឯង កាលស្រុកកើតទុរភិក្ស (អត់បាយ) ភិក្ខុទាំងឡាយ ក៏ហាមឃាត់វត្ថុបន្តិចបន្តួចខ្លះ ពិចារណា ហើយក៏ហាមឃាត់ខ្លះ ម្យ៉ាងទៀត សង្ឃទាំងអស់ក៏បានហាមភត្តរួចហើយ។ ពួកភិក្ខុមានសេចក្តីរង្កៀស ក៏មិនហ៊ានទទួល។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុដែលឆាន់ហើយ ហាមភត្តរួចហើយ ឆាន់ភោជន មិនមែនជារបស់ដែល អំពីភិក្ខុឈឺ ឬមិនបានធ្វើវិនយកម្ម ដែលតាំងនៅក្នុងព្រៃ តាំងនៅក្នុងគុម្ពឈូកបាន។

[១០៤] សម័យនោះឯង ក្នុងក្រុងសាវត្ថី មានវត្ថុសម្រាប់ទំពាស៊ី គឺផ្លែឈើកើតឡើងជាច្រើន តែរកបុគ្គលជាកប្បិយការកៈគ្មាន។ ពួកភិក្ខុមានសេចក្តីរង្កៀស ក៏មិនហ៊ានឆាន់ផ្លែឈើឡើយ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុឆាន់ផ្លែឈើ ដែលគ្មានពូជ (ផ្លែឈើខ្ចី) និងផ្លែឈើ ដែលគួរបន្ទេចយកពូជចេញ (ដូចផ្លែខ្នុរជាដើម) សូម្បីគេមិនបានធ្វើឲ្យជាកប្បិយ ក៏គួរ (ឆាន់បាន)។

## ១៦៧. សត្ថកម្មបដិក្ខេបកថា

CS vin.mv.06.08 | ភាគ ទី៧

**(១៦៧)**

[១០៥] លំដាប់នោះ ព្រះដ៏មានព្រះភាគ គង់ទៀបក្រុងសាវត្ថី សមគួរដល់ព្រះអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិក ក្រុងរាជគ្រឹះ ទ្រង់យាងទៅ ដោយលំដាប់ ទើបបានដល់ទៅក្រុងរាជគ្រឹះ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ

នោះឯង។ សម័យនោះឯង ភិក្ខុ១រូប កើតអាពាធឫសដូងបាត។ ពេទ្យឈ្មោះ អាកាសគោត្រ បានធ្វើសត្ថកម្ម (កាត់ ឬវះឫសដូងបាតនោះ) ដោយកាំបិត។ ទទួលពេលនោះ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ចារិកសេនាសនៈ ក៏បានយាងទៅកាន់លំនៅ របស់ភិក្ខុនោះ។ ពេទ្យឈ្មោះអាកាសគោត្រ បានឃើញព្រះដ៏មានព្រះភាគ យាងមកអំពីចម្ងាយ លុះឃើញច្បាស់ហើយ ក៏បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា សូមព្រះគោតមដ៏ចំរើន ទ្រង់យាងមកទតវច្ចមគ្គរបស់ភិក្ខុនេះ ដូចជាមាត់សត្វទន្សង។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា មោឃបុរសនេះ ចំអកឲ្យតថាគតទេតើ ដូច្នោះហើយ ក៏ទ្រង់យាងត្រឡប់ចាកទីនោះទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងវិហារឯណោះ មានភិក្ខុឈឺដែរឬទេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ មាន។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឈឺដូចម្ដេច។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន លោកដ៏មានអាយុនោះ កើតឫសដូងបាត ពេទ្យឈ្មោះអាកាសគោត្រ ក៏បានធ្វើសត្ថកម្មឲ្យ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើនៃមោឃបុរសនោះ មិនសមគួរ មិនទំនង មិនសមបែប មិនជារបស់សមណៈ មិនគួរគប្បី មិនមែនជាកិច្ចត្រូវធ្វើទេ ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះ មិនគួរនឹងឲ្យគេធ្វើសត្ថកម្ម ក្នុងទីចង្អៀតទេ ម្នាលភិក្ខុទាំងឡាយ ស្បែកក្នុងទីចង្អៀត ជារបស់សុខុមល្អិត មានដំបៅសះបានដោយក្រ កម្របុគ្គលនឹងយកកាំបិតទៅវះ ក្នុងទីចង្អៀតបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរឲ្យគេធ្វើសត្ថកម្ម ក្នុងទីចង្អៀតទេ ភិក្ខុណាឲ្យគេធ្វើ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុគិតគ្នាថា ព្រះដ៏មានព្រះភាគ ទ្រង់ហាមការធ្វើសត្ថកម្មហើយ ទើបឲ្យគេធ្វើវត្ថិកម្មវិញ (ការចងរឹតក្បាលឫសដូងបាតនោះ ដោយខ្សែ)។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើ នឹងឲ្យគេធ្វើវត្ថិកម្មសោះ។ លំដាប់នោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុ ឲ្យគេធ្វើវត្ថិកម្ម ពិតមែនឬ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។បេ។ ព្រះអង្គ ទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេធ្វើ សត្ថកម្ម ឬវត្ថិកម្ម ក្នុងទីជិត ដោយជុំវិញ នៃទីចង្អៀត ប្រមាណពីរធ្នាប់ទេ ភិក្ខុណាឲ្យគេធ្វើ ត្រូវអាបត្តិទុក្កដ។

## ១៦៨. មនុស្សមំសបដិក្ខេបកថា

CS vin.mv.06.09 | ភាគ ទី៧

**(១៦៨)**

[១០៦] គ្រានោះ ព្រះមានព្រះភាគ គង់ក្នុងក្រុងរាជគ្រឹះ សមគួរតាមព្រះអធ្យាស្រ័យហើយ ទ្រង់យាងចេញទៅកាន់ចារិក ក្រុងពារាណសី កាលទ្រង់យាងទៅកាន់ចារិក ដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសីនោះ។ បានឮថា ព្រះដ៏មានព្រះភាគ គង់នៅព្រៃឥសិបតនមិគទាយវន ជិតក្រុងពារាណសីនោះ។ គ្រានោះឯង ក្នុងក្រុងពារាណសី មានជន២នាក់ គឺឧបាសកឈ្មោះសុប្បិយ១ ឧបាសិកា ឈ្មោះសុប្បិយា១ ជាអ្នកមានសេចក្ដីជ្រះថ្លា ជាអ្នកឲ្យទាន ជាអ្នកធ្វើការបម្រើសង្ឃ។ លំដាប់នោះ សុប្បិយាឧបាសិកា បានទៅកាន់វត្ត ហើយដើរចូលទៅគ្រប់វិហារ គ្រប់ទីបរិវេណ ហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ មានលោកម្ចាស់អង្គណាឈឺខ្លះដែរ លោកម្ចាស់អង្គណា ត្រូវការឲ្យខ្ញុំករុណា យករបស់អ្វីមកប្រគេនដែរឬ។ វេលានោះឯង ភិក្ខុ១រូបបានផឹកថ្នាំបញ្ចុះ។ ភិក្ខុនោះក៏និយាយនឹងសុប្បិយាឧបាសិកា ដូច្នេះថា ម្នាលនាង អាត្មាឆាន់ថ្នាំបញ្ចុះ អាត្មាត្រូវការដោយសាច់ ដែលមានឱជារស។ សុប្បិយាឧបាសិកានិយាយថា ល្អហើយ លោកម្ចាស់ នឹងឲ្យគេយកមកប្រគេន (និយាយដូច្នេះហើយ) បានទៅដល់ផ្ទះហើយ ក៏បង្គាប់កូនក្មួយថា ម្នាលនាយ អ្នកចូរទៅ អ្នកចូរដឹង (ចូរទិញ) នូវសាច់សត្វ ដែលស្លាប់ស្រាប់។ បុរសនោះបានទទួលពាក្យសុប្បិយាឧបាសិកាថា បាទអ្នកម្ចាស់ ហើយក៏ដើររកសាច់អស់ទាំងក្រុងពារាណសី មិនបានឃើញសាច់សត្វ ដែលស្លាប់ស្រាប់ឡើយ។ បុរសនោះបានចូលទៅរកសុប្បិយាឧបាសិកា លុះចូលទៅដល់ហើយ បាននិយាយដូច្នេះ នឹងសុប្បិយាឧបាសិកាថា បពិត្រអ្នកម្ចាស់ គ្មានសាច់សត្វ ដែលស្លាប់ស្រាប់ទេ ព្រោះថ្ងៃនេះ គ្មានគេសម្លាប់សត្វសោះ។ លំដាប់នោះ សុប្បិយាឧបាសិកា មានសេចក្ដីត្រិះរិះ យ៉ាងនេះថា កាលបើភិក្ខុឈឺនេះឯង មិនបានសាច់ ដែលមានឱជារសទេ អាពាធ ក៏រឹងរឹតតែចំរើនឡើង ឬមួយ នឹងធ្វើកាលកិរិយាទៅមិនខាន (ឥឡូវ) អាត្មាអញ បានទទួលប្ដេជ្ញាថា នឹងប្រគេនសាច់ ដល់ត្រឡប់ជាមិនឲ្យគេយកទៅប្រគេនវិញ កិច្ចនោះ មិនសមគួរដល់អញសោះ។ សុប្បិយាឧបាសិកា ក៏ចាប់យកកាំបិតសម្រាប់ហាន់សាច់ មកអារសាច់ភ្លៅ (របស់ខ្លួន) ហើយហុចឲ្យទៅទាសីថា ហ៏ ហាងឯងចូរយកសាច់នេះទៅចាត់ចែង ហើយយកទៅប្រគេន ដល់ភិក្ខុឈឺ ក្នុងវិហារឯណោះចុះ ម្យ៉ាងទៀត (បើមាន) ភិក្ខុណាសួររកអញ នាងឯងចូរទូលលោកថា អញឈឺ (និយាយផ្ដាំដូច្នេះហើយ) បានរុំភ្លៅដោយសំពត់សម្រាប់បង្ករ ហើយចូលទៅក្នុងបន្ទប់ ដេកលើគ្រែ។ លំដាប់នោះ សុប្បិយឧបាសក បានទៅកាន់ផ្ទះ ហើយសួរទាសីថា នាងសុប្បិយាទៅណា។ ទាសីនោះប្រាប់ថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់នោះសម្រាន្តក្នុងបន្ទប់។ លំដាប់នោះ សុប្បិយឧបាសកបានចូលទៅរកសុប្បិយាឧបាសិកា លុះចូលទៅដល់ហើយ សួរសុប្បិយាឧបាសិកាយ៉ាងនេះថា ព្រោះហេតុអ្វីបានជានាងដេក។ សុប្បិយាឧបាសិកាឆ្លើយថា ខ្ញុំឈឺ។ សុប្បិយឧបាសកសួរថា នាងឈឺអ្វី។ ទើបសុប្បិយាឧបាសិកា ប្រាប់សេចក្ដីនុ៎ះ ដល់សុប្បិយឧបាសក (ដោយសព្វគ្រប់)។ លំដាប់នោះ សុប្បិយឧបាសកគិតថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចំឡែកពេកណាស់ សុប្បិយាឧបាសិកានេះ ជាស្រីមានសទ្ធាជ្រះថ្លាមែន អម្បាលសាច់របស់ខ្លួន គង់លះបង់បាន ចំណង់បើ វត្ថុតិចតួចឯទៀត ឧបាសិកានេះ នឹងមិនឲ្យដូចម្ដេចបាន គិតដូច្នេះហើយ ក៏មានចិត្តរីករាយខ្ពស់ឡើង បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ។ លុះសុប្បិយឧបាសក អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងព្រះភិក្ខុសង្ឃ និមន្តទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយភាវៈស្ងៀម។ លំដាប់នោះ សុប្បិយឧបាសកបានដឹងថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ លុះកន្លងរាត្រីនោះទៅហើយ សុប្បិយឧបាសក ក៏បានតាក់តែងខាទនីយភោជនីយាហារ ដ៏ឧត្តមហើយ ក៏ឲ្យមនុស្ស ទៅក្រាបបង្គំទូល កាលសមគួរចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពេលសមគួរហើយ ភត្តសម្រេចហើយ។ គ្រានោះ វេលាព្រឹក ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរ យាងទៅកាន់ផ្ទះសុប្បិយឧបាសក លុះយាងទៅដល់ហើយ គង់លើអាសនៈ ដែលគេរៀបចំថ្វាយ មួយអន្លើដោយភិក្ខុសង្ឃ។ វេលានោះ សុប្បិយឧបាសក បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីសមគួរ។ លុះសុប្បិយឧបាសក ឈរនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់មានបន្ទូលដូច្នោះថា នាងសុប្បិយានៅក្នុងទីណា។ សុប្បិយឧបាសក ក្រាប

បង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ នាងសុប្បិយាឈឺ។ ព្រះអង្គទ្រង់មានបន្ទូលថា បើដូច្នោះ (ឲ្យ) នាងសុប្បិយាចូលមក។ សុប្បិយឧបាសក ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ នាងសុប្បិយា មិនអាចនឹងមកបានទេ។ ព្រះអង្គទ្រង់ត្រាស់ថា បើដូច្នោះ អ្នកទាំងឡាយចូរគ្រាហ៍ នាំយកមក។ លំដាប់នោះ សុប្បិយឧបាសក បានគ្រាហ៍សុប្បិយាឧបាសិកា នាំមកថ្វាយ។ និម្មិត្ត តែព្រះមានព្រះភាគ ទ្រង់ទតឃើញ(កាលណា) ដំបៅរបស់នាង ដែលធំដល់ម្ល៉ោះ ក៏ដុះសាច់ សះជា មានសម្បុរល្អ មានរោមដុះពេញឡើងវិញមួយរំពេច។ លំដាប់នោះ សុប្បិយឧបាសក និង សុប្បិយាឧបាសិកាបាននិយាយគ្នាថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចំឡែកពេកណាស់ ព្រះតថាគត មានឫទ្ធិច្រើន មានអានុភាពច្រើន គ្រាន់តែព្រះអង្គ ទ្រង់បានទតឃើញមួយរំពេច ដំបៅ ដែលធំដល់ម្ល៉ោះ ក៏ដុះសាច់សះជា មានសម្បុរល្អ មានរោមដុះពេញឡើងវិញ (អ្នកទាំងនោះ) មានចិត្តរីករាយខ្ពស់ឡើង ក៏អង្គាសខាទនីយភោជនីយាហារ (បង្អែមចំអាប) ដ៏ឆ្ងាញ់ពីសារ ដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែក លែងទទួលទៀត លុះព្រះដ៏មានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្ត ទៅក្នុងបាត្រហើយ ក៏នាំគ្នាអង្គុយក្នុងទីសមគួរ។ លំដាប់នោះ ព្រះមានព្រះភាគ បានញុំាងសុប្បិយឧបាសក និងសុប្បិយាឧបាសិកា ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ទ្រង់ក្រោកចាកអាសនៈ ចៀសចេញទៅ។

[១០៧] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា សូមសាច់អំពីសុប្បិយាឧបាសិកា។ កាលបើព្រះដ៏មានព្រះភាគ ត្រាស់សួរយ៉ាងនេះហើយ ភិក្ខុនោះក្រាបទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានសូមសាច់ អំពីសុប្បិយាឧបាសិកា។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកបានឲ្យគេនាំយកសាច់មកហើយឬនៅ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានឲ្យគេនាំយកសាច់នោះមកហើយ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកបានឆាន់ហើយឬនៅ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានឆាន់ហើយ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ (មុនដែលនឹងឆាន់) អ្នកបានពិចារណាដែរឬទេ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ មិនបានពិចារណាទេ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯង មិនសមបើនឹងមិនពិចារណា ហើយហ៊ានឆាន់សាច់ (ដូច្នេះ) សោះ ម្នាលមោឃបុរស អ្នកឯងឆាន់សាច់មនុស្សពិតហើយ ម្នាលមោឃបុរស អំពើនេះ មិននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ទ្រង់តិះដៀលរួចហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ពួកមនុស្ស ដែលមានសទ្ធា មានសេចក្តីជ្រះថ្លា មនុស្សទាំងនោះ សូម្បីតែសាច់របស់ខ្លួនឯង ក៏គង់លះប្រគេនបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់មនុស្សទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិថុល្លច្ច័យ។ ម្យ៉ាងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបានពិចារណាជាមុនហើយ មិនត្រូវឆាន់សាច់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។

## ១៦៩. ហត្ថិមំសាទិបដិក្ខេបកថា

CS vin.mv.06.10 | ភាគ ទី៧

**(១៦៩)**

[១០៨] សម័យនោះឯង មានដំរីរបស់ស្តេចស្លាប់ជាច្រើន។ ចួនជាវេលាស្រុកអត់បាយ មនុស្សទាំងឡាយ នាំគ្នាស៊ីសាច់ដំរី ក៏បានប្រគេនសាច់ដំរី ដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត។ ភិក្ខុទាំងឡាយ ក៏នាំគ្នាឆាន់សាច់ដំរី។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនសមបើនឹងហ៊ានឆាន់សាច់ដំរីសោះ ដំរីក៏ជាអង្គ (យាន) របស់ស្តេច បើស្តេចទ្រង់ជ្រាប មុខជាខ្ញាល់ នឹងភិក្ខុទាំងនោះមិនខាន។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ដំរីទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង (មាន) សេះរបស់ស្តេចស្លាប់ជាច្រើន។ ចួនជាវេលាស្រុកអត់បាយ មនុស្សទាំងឡាយ នាំគ្នាស៊ីសាច់សេះ ក៏បានប្រគេនសាច់សេះ ដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត។ ភិក្ខុទាំងឡាយ ក៏នាំគ្នាឆាន់សាច់សេះ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនសមបើ នឹងហ៊ានឆាន់សាច់សេះទេ ព្រោះសេះជាអង្គ (យាន) របស់ស្តេចដែរ បើស្តេចទ្រង់ជ្រាប មុខជាខ្ញាល់ នឹងភិក្ខុទាំងនោះមិនខាន។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់សេះទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង វេលាស្រុកអត់បាយ មនុស្សទាំងឡាយ នាំគ្នាស៊ីសាច់ឆ្កែ ក៏បានប្រគេនសាច់ឆ្កែ ដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត។ ភិក្ខុទាំងឡាយ ក៏នាំគ្នាឆាន់សាច់ឆ្កែ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនសមបើ នឹងហ៊ានឆាន់សាច់ឆ្កែសោះ ព្រោះឆ្កែ ជាសត្វគួរខ្ពើមរអើម។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ឆ្កែទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពេលស្រុកអត់បាយ មនុស្សទាំងឡាយ ស៊ីសាច់ពស់ ក៏បានប្រគេនសាច់ពស់ ដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត។ ភិក្ខុទាំងឡាយក៏នាំគ្នាឆាន់សាច់ពស់។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនសមបើ នឹងហ៊ានឆាន់សាច់ពស់សោះ ព្រោះពស់ជាសត្វគួរខ្ពើមរអើម។ ចំណែកខាងស្តេចនាគ ឈ្មោះសុបស្ស បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគហើយ ឋិតនៅក្នុងទីសមគួរ។ លុះសុបស្សនាគរាជ ឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន នាគទាំងឡាយ ជាសត្វគ្មានសទ្ធា គ្មានសេចក្តីជ្រះថ្លាទេ ក្រែងពួកនាគទាំងនោះ បៀតបៀនភិក្ខុទាំងឡាយខ្លះមិនខាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ សូមកុំឲ្យលោកម្ចាស់ទាំងឡាយ ឆាន់សាច់ពស់ឡើយ។ លំដាប់នោះ ព្រះមានព្រះភាគ ញុំាងសុបស្សនាគរាជ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ។ លុះសុបស្សនាគរាជ ដែលព្រះដ៏មានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ពស់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកព្រានសម្លាប់សត្វសីហៈហើយ ស៊ីសាច់សីហៈ ក៏បានប្រគេនសាច់សីហៈ ដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត។ ពួកភិក្ខុឆាន់សាច់សីហៈហើយ ក៏ទៅនៅក្នុងព្រៃ។ ពួកសត្វសីហៈ ធុំក្លិនសាច់សីហៈ ក៏សម្លាប់ភិក្ខុជាច្រើន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់សីហៈទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកព្រានសម្លាប់ខ្លាធំ ហើយស៊ីសាច់ខ្លាធំ ក៏បានប្រគេនសាច់ខ្លាធំ ដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត។ ពួកភិក្ខុឆាន់សាច់ខ្លាធំហើយ ទៅនៅក្នុងព្រៃ។ ពួកខ្លាធំ បានធុំក្លិនសាច់ខ្លាធំ ក៏សម្លាប់ភិក្ខុជាច្រើន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះ

មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាធំទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកព្រានសម្លាប់ខ្លាដំបង ហើយស៊ីសាច់ខ្លាដំបង ក៏បានប្រគេនសាច់ខ្លាដំបង ដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត។ ពួកភិក្ខុឆាន់សាច់ខ្លាដំបងហើយ ក៏ទៅនៅក្នុងព្រៃ។ ពួកខ្លាដំបង បានធុំក្លិនសាច់ខ្លាដំបង ក៏សម្លាប់ភិក្ខុជាច្រើន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាដំបងទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកព្រានសម្លាប់ខ្លាឃ្មុំ ហើយស៊ីសាច់ខ្លាឃ្មុំ ក៏បានប្រគេនសាច់ខ្លាឃ្មុំ ដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត។ ពួកភិក្ខុឆាន់សាច់ខ្លាឃ្មុំហើយ ក៏ទៅនៅក្នុងព្រៃ។ពួកខ្លាឃ្មុំ បានធុំក្លិនសាច់ខ្លាឃ្មុំហើយ ក៏សម្លាប់ភិក្ខុជាច្រើន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាឃ្មុំទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ពួកព្រានសម្លាប់សត្វឆ្កែព្រៃ ហើយស៊ីសាច់ឆ្កែព្រៃ ក៏បានប្រគេនសាច់ឆ្កែព្រៃ ដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត។ ភិក្ខុទាំងឡាយ ឆាន់សាច់ឆ្កែព្រៃហើយ ក៏ទៅនៅក្នុងព្រៃ។ ពួកឆ្កែព្រៃ បានធុំក្លិនសាច់ឆ្កែព្រៃហើយ ក៏សម្លាប់ភិក្ខុជាច្រើន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ឆ្កែព្រៃទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។

ចប់ សុប្បិយភាណវារៈ ទី២។

## ១៧០. យាគុមធុគោឡកានុជាននា

CS vin.mv.06.11 | ភាគ ទី៧

**(១៧០)**

[១០៩] គ្រានោះ ព្រះដ៏មានព្រះភាគ គង់ទៀតក្រុងពារាណសី សមគួរតាមព្រះអធ្យាស្រ័យហើយ ក៏យាងចេញទៅកាន់ចារិកនៃអន្ធកវិន្ទប្រទេស ជាមួយនឹងភិក្ខុសង្ឃជាច្រើន ប្រមាណមួយពាន់ពីររយហាសិបរូប។ សម័យនោះឯង ពួកមនុស្សអ្នកជនបទ បានផ្ទុកអម្បិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ក្នុងរទេះទាំងឡាយ ហើយក៏បរទៅតាមក្រោយៗភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន។ ពួកមនុស្សអ្នកស៊ីដែលប្រមាណប្រាំរយនាក់ ក៏គិតគ្នាថា (បើ) ពួកយើងបានលំដាប់(វេន) នៃភត្តក្នុងកាលណា នឹងធ្វើភត្តក្នុងកាលនោះ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ក៏បានដល់ទៅអន្ធកវិន្ទប្រទេសនោះ។ លំដាប់នោះ កាលព្រាហ្មណ៍ម្នាក់មិនបានលំដាប់(វេន)នៃភត្ត ក៏មានសេចក្តីរិះគិតយ៉ាងនេះថា អាត្មាអញបានដើរតាមភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ជាង២ខែហើយ ដោយប៉ងថា បើអាត្មាអញបានលំដាប់(វេន) នៃភត្តក្នុងកាលណា នឹងធ្វើភត្តក្នុងកាលនោះ ឥឡូវលំដាប់(វេន)នៃភត្ត អាត្មាអញមិនទាន់បាននៅឡើយ ខ្លួនអញទៀតសោតក៏តែម្នាក់ឯង ទាំងប្រយោជន៍ខាងឃរាវាសរបស់អាត្មាអញទៀត ក៏សាបសូន្យទៅជាច្រើន បើដូច្នោះ មានតែគួរអាត្មាអញទៅត្រួតមើលរោងភត្ត វត្ថុណាគ្មានក្នុងរោងភត្ត អាត្មាអញក៏នឹងតាក់តែងនូវវត្ថុនោះ។ វេលាដែលព្រាហ្មណ៍នោះទៅមើលរោងភត្ត ក៏មិនឃើញវត្ថុពីរយ៉ាង គឺបបរនិងនំមានរសផ្អែមឡើយ។[67] ទើបព្រាហ្មណ៍នោះចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ និយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន កាលខ្ញុំករុណាមិនបានលំដាប់(វេន) នៃភត្តក្នុងទីនេះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញដើរតាមភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ជាង២ខែហើយ ដោយប៉ងថា (បើ)អាត្មាអញបានលំដាប់(វេន) នៃភត្តក្នុងពេលណា នឹងធ្វើភត្តក្នុងពេលនោះ ឥឡូវអាត្មាអញមិនទាន់បានលំដាប់(វេន)នៃភត្តនៅឡើយ ខ្លួនអញទៀតសោតក៏តែម្នាក់ឯង ទាំងប្រយោជន៍ខាងឃរាវាសរបស់អាត្មាអញទៀត ក៏សាបសូន្យទៅជាច្រើន បើដូច្នោះ មានតែគួរអាត្មាអញទៅត្រួតមើលរោងភត្ត វត្ថុណាគ្មានក្នុងរោងភត្ត អាត្មាអញនឹងតាក់តែងនូវវត្ថុនោះ (យ៉ាងនេះ) បពិត្រព្រះអានន្ទដ៏ចំរើន កាលខ្ញុំព្រះករុណាទៅមើលរោងភត្ត មិនបានឃើញវត្ថុពីរយ៉ាង គឺបបរនិងនំមានរសផ្អែមឡើយ បពិត្រព្រះអានន្ទដ៏ចំរើន បើខ្ញុំករុណាតាក់តែងបបរនិងនំមានរសផ្អែមមកថ្វាយ ព្រះគោតមដ៏ចំរើន ទ្រង់ទទួលរបស់ខ្ញុំករុណាដែរឬ។ ព្រះអានន្ទប្រាប់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ ចាំអាត្មាទូលសួរព្រះដ៏មានព្រះភាគសិន។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុបានក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ឲ្យព្រាហ្មណ៍នោះតាក់តែងចុះ។ ទើបព្រះអានន្ទទៅប្រាប់ព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរតាក់តែងចុះ។ លុះរាត្រីនោះកន្លងទៅហើយ ឯព្រាហ្មណ៍នោះតាក់តែងបបរ និងនំមានរសផ្អែមជាច្រើន ក៏បានបង្អោនថ្វាយចំពោះព្រះដ៏មានព្រះភាគ ហើយទូលថា សូមព្រះគោតមដ៏ចំរើន ទ្រង់ទទួលបបរ និងនំមានរសផ្អែមរបស់ខ្ញុំព្រះអង្គ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរប្រគេនដល់ភិក្ខុទាំងឡាយចុះ។ ពួកភិក្ខុរង្កៀស មិនហ៊ានទទួល។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលចុះ ចូរឆាន់ចុះ។ ព្រាហ្មណ៍នោះ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធអង្គ ជាប្រធាន ដោយបបរ និងនំមានរសផ្អែមជាច្រើន ដោយដៃរបស់ខ្លួន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែលោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគ ទ្រង់លាងព្រះហស្ថស្រេច លែងលូកទៅក្នុងបាត្រហើយ (ព្រាហ្មណ៍) ក៏អង្គុយក្នុងទីសមគួរ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទៅសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់មានបន្ទូលដូច្នេះថា ម្នាលព្រាហ្មណ៍ អានិសង្សបបរនេះមាន១០យ៉ាង អានិសង្សបបរ១០យ៉ាងនោះ តើដូចម្តេច គឺបុគ្គលអ្នកឲ្យបបរ ឈ្មោះថា ឲ្យអាយុ១ ឲ្យពណ៌សម្បុរ១ ឲ្យសេចក្តីសុខ១ ឲ្យកំលាំងកាយ១ ឲ្យប្រាជ្ញា១ បបរដែលបុគ្គលហុតទៅហើយ រមែងហាមឃាត់សេចក្តីឃ្លាន១ បន្ទោបង់សេចក្តីស្រេក១ ញុំាងខ្យល់ឲ្យដើរទៅស្រួល១ ញុំាងសរសៃឲ្យស្អាត១ ញុំាងអាហារថ្មីដ៏សេសសល់ឲ្យរលួយ១ ម្នាលព្រាហ្មណ៍ អានិសង្សបបរមាន១០យ៉ាងនេះឯង។

[១១០] ជនណាបានឲ្យបបរដោយគោរព ដល់ពួកសមណៈ ដែលជាអ្នកសង្រួម អ្នកបរិភោគភោជនដែលអ្នកដទៃឲ្យ ក្នុងកាលដ៏គួរ (ជននោះ) ឈ្មោះថា ឲ្យនូវហេតុនៃអានិសង្សទាំង១០យ៉ាងគឺ អាយុ១ ពណ៌សម្បុរ១ សេចក្តីសុខ១ កំឡាំងកាយ១ ប្រាជ្ញារបស់បុគ្គលនោះតែងកើតឡើង១ បបរនោះតែងកំចាត់បង់សេចក្តីឃ្លាន១ សេចក្តីស្រេក១ និងញុំាងខ្យល់ (ឲ្យបានដើរស្រួល)១ ញុំាងសរសៃឲ្យស្អាត១ ញុំាងភត្តឲ្យរលួយ១។ នេះជាភេសជ្ជៈ ដែលព្រះសុគតទ្រង់សរសើរហើយ។ ព្រោះហេតុនោះ អ្នកមានសេចក្តីត្រូវការ ចង់បានសេចក្តីសុខជារបស់មនុស្សក្តី ប្រាថ្នាសេចក្តីសុខជារបស់ទិព្វក្តី ចង់បានសេចក្តីល្អរុងរឿងក្នុងមនុស្សក្តី គួរឲ្យបបរជានិច្ចចុះ។

[១១១] លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់អនុមោទនាចំពោះព្រាហ្មណ៍នោះដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈ យ៉ាងចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ តថាគត

អនុញ្ញាត (ឲ្យភិក្ខុឆាន់) បបរ និងនំមានរសផ្អែមបាន។

## ១៧១. តរុណបសន្នមហាមត្តវត្ថុ

CS vin.mv.06.12 | ភាគ ទី៧

**(១៧១)**

[១១២] ពួកមនុស្សបានឮដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតបបរ និងនំមានរសផ្អែមដល់ភិក្ខុទាំងឡាយ (ដូច្នោះ) ហើយ។ មនុស្សទាំងនោះ ក៏នាំគ្នាតាក់តែងបបរភោជ្ជ 68) និងនំមានរសផ្អែម ពីព្រឹកព្រហាម (មកប្រគេនភិក្ខុទាំងឡាយ)។ ពួកភិក្ខុបានឆាន់បបរភោជ្ជ និងនំមានរសផ្អែម ឆ្អែតពីព្រឹកព្រហាមហើយ លុះទៅឆាន់ក្នុងរោងភត្តទៀត ក៏មិនបានឆ្ងាញ់ពីសា។ សម័យនោះឯង មានមហាមាត្យម្នាក់ ជាអ្នកមានសេចក្តីជ្រះថ្លាថ្មី (មិនទាន់មុតមាំ) បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទុក ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ លំដាប់នោះ មហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ មានតែគួរអាត្មាអញតាក់តែងចង្ហាន់សាច់ ចំនួន១២៥០សម្រាប់ (ឲ្យល្មម) ដល់ភិក្ខុ១២៥០រូប ហើយប្រគេនចង្ហាន់សាច់មួយសម្រាប់ៗ ដល់ភិក្ខុមួយរូបៗ។ មហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ លុះកន្លងរាត្រីនោះទៅ ក៏បានតាក់តែងខាទនីយភោជនីយៈ ដ៏ឧត្តម និងចង្ហាន់សាច់១២៥០សម្រាប់ ហើយក៏ប្រើបម្រើឲ្យទៅក្រាបបង្គំទូលពេលឆាន់ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពេលនេះល្មមហើយ ភត្តសម្រេចហើយ។ គ្រានោះ ពេលព្រឹកព្រហាម ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរ យាងទៅកាន់ផ្ទះមហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ លុះយាងទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលគេរៀបចំថ្វាយ មួយអន្លើ ដោយភិក្ខុសង្ឃ។ ឯមហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ បានអង្គាសពួកភិក្ខុក្នុងរោងភត្ត។ ភិក្ខុទាំងឡាយ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរឲ្យ (ភត្ត) តែបន្តិចចុះ ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចបានហើយ។ មហាមាត្យនិយាយថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយ កុំទទួលភត្តបន្តិចបន្តួច ដោយគិតថា មហាមាត្យនេះ មានសេចក្តីជ្រះថ្លាថ្មី ខាទនីយភោជនីយៈ ខ្ញុំបានចាត់ចែងទុកហើយជាច្រើន ទាំងចង្ហាន់សាច់១២៥០សម្រាប់ផង ខ្ញុំនឹងប្រគេនចង្ហាន់សាច់មួយសម្រាប់ៗ ដល់ភិក្ខុមួយរូបៗ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយ ទទួល ដរាបដល់ឆ្អែត។ ពួកភិក្ខុនិយាយតបថា ម្នាលអាវុសោ យើងទាំងឡាយ ទទួលភត្តបន្តិចៗ ព្រោះហេតុប៉ុណ្ណេះក៏ទេ យើងទាំងឡាយ ឆាន់បបរភោជ្ជ និងនំមានរសផ្អែម ឆ្អែតអំពីព្រឹករួចហើយ ព្រោះហេតុនោះ បានជាយើងទទួលភត្តតែបន្តិចៗ។ លំដាប់នោះ មហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ខ្ញុំបាននិមន្តលោកម្ចាស់ទាំងឡាយរួចហើយ មិនសមបើនឹងទៅឆាន់បបរភោជ្ជរបស់ជនឯទៀតសោះ (លោកម្ចាស់ខ្លាចក្រែង) ខ្ញុំមិនអាចនឹងប្រគេនឲ្យឆាន់ឆ្អែតបានឬ។ មហាមាត្យនោះ មានសេចក្តីក្រោធ តូចចិត្ត ប្រាថ្នានឹងចោទ កាលដាក់បាត្រភិក្ខុទាំងឡាយពេញហើយ ក៏ដើរទៅនិយាយថា ពួកលោកណាចង់ឆាន់ក្តី នាំយកទៅក្តី (ក៏តាមចិត្តចុះ)។ លំដាប់នោះ មហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ បានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយៈ ដ៏ឧត្តម ដោយដៃនៃខ្លួន ឲ្យឆ្អែត ស្កប់ស្កល់ ត្រាតែលោកប្រកែក លែងទទួលទៀត លុះព្រះដ៏មានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ (មហាមាត្យ) ក៏អង្គុយក្នុងទីសមគួរ។ លុះមហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ អង្គុយនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ យាងចេញទៅ។ ឯមហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ កាលព្រះដ៏មានព្រះភាគ យាងចេញទៅ មិនយូរប៉ុន្មាន ក៏កើតសេចក្តីរង្កៀស និងសេចក្តីក្តៅក្រហាយថា អាត្មាអញឥតលាភទេតើ លាភរបស់អាត្មាអញ គ្មានសោះទេហ្ន៎ ទាំងអត្តភាពជាមនុស្សសោត ក៏អាត្មាអញបានដោយកម្រ មិនមែនអាត្មាអញបានដោយងាយទេ (ឥឡូវ) អាត្មាអញ ខឹង តូចចិត្ត ប្រាថ្នានឹងចោទ បានដាក់បាត្រភិក្ខុទាំងឡាយឲ្យពេញ ហើយដើរចៀសចេញទៅ និយាយថា លោកទាំងឡាយ ចូរឆាន់ក្តី នាំយកទៅក្តី (ក៏តាមចិត្តចុះ) កម្មដែលអាត្មាអញ សន្សំមកជាច្រើនហើយ (នេះ) នឹងជាបុណ្យ ឬជាបាបហ្ន៎។ ឯមហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ។ លុះមហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលព្រះដ៏មានព្រះភាគ យាងចេញទៅមិនយូរប៉ុន្មាន ក្នុងវេលានេះ ខ្ញុំព្រះអង្គក៏មានសេចក្តីរង្កៀស និងសេចក្តីក្តៅក្រហាយថា អាត្មាអញឥតលាភទេតើ លាភរបស់អាត្មាអញ គ្មានសោះទេហ្ន៎ ទាំងអត្តភាពជាមនុស្សសោត ក៏អាត្មាអញបានដោយកម្រ មិនមែនអាត្មាអញបានដោយងាយទេ (ឥឡូវ) អាត្មាអញ ខឹង អន់ចិត្ត ប្រាថ្នានឹងចោទ បានដាក់បាត្រភិក្ខុទាំងឡាយឲ្យពេញហើយ ដើរចៀសចេញទៅ និយាយថា លោកទាំងឡាយ ចូរឆាន់ក្តី នាំយកទៅក្តី (ក៏តាមចិត្តចុះ) កម្មដែលអាត្មាអញ បានសន្សំមកជាច្រើនហើយ (នេះ) នឹងជាបុណ្យ ឬជាបាបហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន កម្មដែលខ្ញុំព្រះអង្គបានសន្សំមកជាច្រើនហើយ (នេះ) តើនឹងជាបុណ្យ ឬជាបាប។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអាវុសោ ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដែលអ្នកបាននិមន្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក ដោយចំណែកណា ចំណែកដែលអ្នកបានសន្សំហើយនោះ ក៏ជាបុណ្យយ៉ាងច្រើន គ្រាប់បាយមួយគ្រាប់ៗរបស់អ្នក ដែលភិក្ខុមួយរូបៗ ទទួលហើយ ដោយចំណែកណា ចំណែកដែលអ្នកបានសន្សំនោះ ក៏ជាបុណ្យយ៉ាងច្រើនហើយ ឈ្មោះថា អ្នកឯងប្រារព្ធយកឋានសួគ៌ហើយ។ ឯមហាមាត្យ អ្នកមានសេចក្តីជ្រះថ្លាថ្មីនោះ ក៏គិតថា ប្រហែលជាលាភរបស់អាត្មាអញហើយ ប្រហែលជាអាត្មាអញ បានអត្តភាព ជាមនុស្សល្អហើយ ប្រហែលជាអាត្មាអញ បានសន្សំបុណ្យជាច្រើនហើយ ប្រហែលជាឈ្មោះថាអាត្មាអញប្រារព្ធយកឋានសួគ៌ហើយ ក៏មានចិត្តរីករាយ ស្រស់ស្រាយឡើង ក្រោកចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរ ចំពោះពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា គេបាននិមន្តពួកភិក្ខុទៅក្នុងត្រកូលដទៃហើយ ភិក្ខុទាំងនោះ នៅឆាន់បបរភោជ្ជ របស់ត្រកូលឯទៀតវិញ ពិតមែនឬ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ បាននិមន្តក្នុងត្រកូលដទៃហើយ មិនសមបើនឹងទៅឆាន់បបរភោជ្ជ របស់ត្រកូលឯទៀតសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទទួលនិមន្តក្នុងត្រកូលដទៃហើយ មិនត្រូវឆាន់បបរភោជ្ជ របស់ត្រកូលឯទៀតទេ ភិក្ខុណាឆាន់ ត្រូវវិន័យធរឲ្យភិក្ខុនោះធ្វើតាមធម៌ (គឺឲ្យសំដែងអាបត្តិចេញ)។

## ១៧២. ពេលដ្ឋកច្ចានវត្ថុ

**(១៧២)**

[១១៣] គ្រានោះ ព្រះដ៏មានព្រះភាគ គង់នៅក្នុងអន្ធកវិន្ទប្រទេស តាមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទ្រង់យាងចេញទៅកាន់ចារិក ក្រុងរាជគ្រឹះ មួយអន្លើដោយភិក្ខុសង្ឃច្រើន ប្រមាណ១២៥០រូប។ សម័យនោះឯង បុរសឈ្មោះវេលដ្ឋកច្ចាន បានផ្ទុកស្ករទ្ធតែក្អមស្ករអំពៅ ពេញរទេះទាំង៥០០ហើយ ក៏ចេញចាកក្រុងរាជគ្រឹះ ទៅតាមផ្លូវឆ្ងាយ ចំពោះអន្ធកវិន្ទប្រទេស។ ព្រះដ៏មានព្រះភាគ បានទតឃើញវេលដ្ឋកច្ចានដើរមកអំពីចម្ងាយ លុះទតឃើញហើយ ទ្រង់យាងចៀសអំពីផ្លូវ ទៅគង់ក្រោមម្លប់ឈើមួយ។ លំដាប់នោះ វេលដ្ឋកច្ចាន បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចឈរនៅក្នុងទីសមគួរ។ លុះវេលដ្ឋកច្ចាន ឈរនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់ប្រគេនស្ករអំពៅមួយក្អមៗ ដល់ភិក្ខុមួយរូបៗ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ ចូរអ្នកឯងទៅយកស្ករអំពៅតែមួយក្អមមកមើលសិន។ វេលដ្ឋកច្ចាន បានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយយកស្ករអំពៅមួយក្អម ដើរចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានយកក្អមស្ករអំពៅមកហើយ បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គ នឹងត្រូវប្រតិបត្តិដូចម្តេច។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯងចូរប្រគេនស្ករអំពៅ ដល់ភិក្ខុទាំងឡាយចុះ។ វេលដ្ឋកច្ចាន ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយប្រគេនស្ករអំពៅ ដល់ភិក្ខុទាំងឡាយ រួចក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានប្រគេនស្ករអំពៅ ដល់ពួកភិក្ខុរួចហើយ ឥឡូវ ស្ករអំពៅនេះ នៅសល់ជាច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯង ចូរប្រគេនស្ករអំពៅ ដល់ពួកភិក្ខុ ដរាបដល់អស់ចំណង់ចុះ។ វេលដ្ឋកច្ចាន ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយប្រគេនស្ករអំពៅ ដល់ពួកភិក្ខុ ដរាបដល់អស់ចំណង់ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានប្រគេនស្ករអំពៅ ដល់ពួកភិក្ខុ ដរាបដល់អស់ចំណង់ហើយ តែស្ករអំពៅនេះ នៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គ ត្រូវប្រតិបត្តិដូចម្តេច។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯង ចូរឲ្យពួកភិក្ខុឆាន់ឆ្អែត ស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយចុះ។ វេលដ្ឋកច្ចាន ទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយបានញុំាងពួកភិក្ខុឲ្យឆ្អែត ស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយ។ ភិក្ខុពួកខ្លះ ដាក់ពេញបាត្រ ក៏មាន វេចនឹងសម្ពត់តម្រងទឹកក៏មាន ដាក់ពេញថង់យាមក៏មាន។ លុះវេលដ្ឋកច្ចាន បានឲ្យពួកភិក្ខុឆាន់ឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យពួកភិក្ខុឆាន់ឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយហើយ តែថា ស្ករអំពៅនេះ ក៏នៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯង ចូរឲ្យស្ករអំពៅ ដល់ពួកមនុស្ស អ្នកស៊ីដែលផងចុះ។ វេលដ្ឋកច្ចាន បានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយឲ្យស្ករអំពៅ ដល់ពួកមនុស្ស អ្នកស៊ីដែល រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យស្ករអំពៅ ដល់ពួកមនុស្ស អ្នកស៊ីដែលហើយ តែថា ស្ករអំពៅនេះ នៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯង ចូរឲ្យស្ករអំពៅ ដល់ពួកមនុស្ស អ្នកស៊ីដែល ដរាបដល់អស់ចំណង់ចុះ។ វេលដ្ឋកច្ចាន បានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ឲ្យស្ករអំពៅ ដល់ពួកមនុស្ស អ្នកស៊ីដែល ដរាបដល់អស់ចំណង់ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យស្ករអំពៅ ដល់ពួកមនុស្ស អ្នកស៊ីដែល ដរាបដល់អស់ចំណង់ហើយ តែថា ស្ករអំពៅនេះ ក៏នៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេច។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន បើដូច្នោះ អ្នកឯង ចូរឲ្យពួកមនុស្ស អ្នកស៊ីដែលឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយចុះ។ វេលដ្ឋកច្ចាន បានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយឲ្យពួកមនុស្ស អ្នកស៊ីដែល ឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយ។ ពួកមនុស្ស អ្នកស៊ីដែលខ្លះ ដាក់ពេញក្រឡក៏មាន ដាក់ពេញក្អមក៏មាន វេចនឹងសម្ពត់កម្រាលក៏មាន ដាក់ពេញថ្នក់ក៏មាន។ លំដាប់នោះ វេលដ្ឋកច្ចាន បានឲ្យពួកមនុស្ស អ្នកស៊ីដែល ឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយ រួចក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឲ្យពួកមនុស្ស អ្នកស៊ីដែល ឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំងឡាយហើយ តែថា ស្ករអំពៅនេះ នៅសល់ច្រើន បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គនឹងត្រូវប្រតិបត្តិដូចម្តេច។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកច្ចាន ក្នុងលោក ព្រមទាំងទេវតា ព្រមទាំងមារ ព្រមទាំងព្រហ្ម ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងសម្មតិទេព និងមនុស្ស តថាគត មិនដែលឃើញអ្នកណាមួយឆាន់ស្ករអំពៅហើយ ស្ករអំពៅនោះ រលួយទៅដោយស្រួលទេ វៀរលែងតែតថាគត ឬសាវករបស់តថាគតប៉ុណ្ណោះ ម្នាលកច្ចាន បើដូច្នោះ ចូរអ្នកឯង ចោលស្ករអំពៅនោះ ទៅក្នុងទីដែលគ្មានស្មៅស្រស់ ឬចាក់ចោលទៅក្នុងទឹក ដែលគ្មានសត្វក៏បាន។ វេលដ្ឋកច្ចាន បានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចាក់ចោលស្ករអំពៅនោះ ទៅក្នុងទឹកដែលគ្មានសត្វ។ ឯស្ករអំពៅដែលវេលដ្ឋកច្ចានដាក់ចុះទៅក្នុងទឹកនោះ ក៏លាន់ឮសំឡេងថា ចិច្ចិដិ ចិចិដិ ហុយផ្សែងឡើងដេរដាស គួរនាដូចជាផាលនង្គ័ល នៅហាលថ្ងៃអស់មួយថ្ងៃហើយ បុគ្គលដាក់ចុះទៅក្នុងទឹក រមែងឮសំឡេងថា ចិច្ចិដិ ចិចិដិ ហុយផ្សែងឡើងដេរដាស យ៉ាងណាមិញ ស្ករអំពៅនោះ ដែលបុគ្គលដាក់ចុះទៅក្នុងទឹកហើយ រមែងឮសំឡេងថា ចិច្ចិដិ ចិចិដិ ហុយផ្សែងឡើងដេរដាស ដូច្នោះដែរ។ លំដាប់នោះឯង វេលដ្ឋកច្ចាន មានសេចក្តីស្លុតចិត្ត កើតព្រឺព្រួចអស់ទាំងរោម ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីសមគួរ។ លុះវេលដ្ឋកច្ចាន អង្គុយនៅក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា គឺទ្រង់ប្រកាសអំពីទាន១ អំពីសីល១ អំពីស្ថានសួគ៌១ អំពីទោសដ៏លាមកសៅហ្មង របស់កាមទាំងឡាយ១ និងអានិសង្ស ក្នុងការចេញចាកកាម១។ វេលាណា ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា វេលដ្ឋកច្ចាន មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តស្រស់ស្រាយឡើង មានចិត្តជ្រះថ្លា វេលានោះ ក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងប្រកាសចំពោះព្រះអង្គឯង គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច។ គួរនាដូចជាសម្ពត់សស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយល្អ យ៉ាងណាមិញ ឯវេលដ្ឋកច្ចាន ក៏បានកើតធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកគ្រឿងសៅហ្មង លើអាសនៈនោះឯង ដូច្នេះថា ធម្មជាតិណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ ក៏តែងរលត់ទៅវិញ ជាធម្មតា យ៉ាងនោះដែរ។ គ្រាដែលវេលដ្ឋកច្ចាន បានឃើញសច្ចធម៌ហើយ បានដល់សច្ចធម៌ហើយ បានដឹងច្បាស់សច្ចធម៌ហើយ បានយាងចុះកាន់សច្ចធម៌ហើយ បានឆ្លងវិចិកិច្ឆា កំចាត់បង់នូវសេចក្តីងឿងឆ្ងល់ ដល់នូវភាវៈជាអ្នកក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គ

ដ៏ចំរើន គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះ ឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើបង្ហាញរបស់ដែលគេលាក់បាំងទុក ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេង ឬក៏ដូចជាមនុស្សកាន់ប្រទីប ទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា ឲ្យមនុស្សដែលមានភ្នែកភ្លឺ មើលឃើញនូវរូបទាំងឡាយ យ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ថាជាទីពឹង ទីរលឹក សូមព្រះដ៏មានព្រះភាគ ចាំទុកនូវខ្ញុំថាជាឧបាសក អ្នកដល់ (នូវព្រះរតនត្រ័យ) ថាជាទីពឹង ស្មើដោយជីវិត តាំងអំពីថ្ងៃនេះ ជាដើមទៅ។

[១១៤] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិក តាមលំដាប់ បានដល់ទៅក្រុងរាជគ្រឹះនោះ។ បានឮថា ព្រះមានព្រះភាគ គង់ក្នុងវត្តវេឡុវនកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះ។ សម័យនោះឯង ស្ករអំពៅកើតឡើងជាច្រើនក្នុងក្រុងរាជគ្រឹះ។ ពួកភិក្ខុក៏រង្កៀសថា ស្ករអំពៅ ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតចំពោះតែភិក្ខុមានជម្ងឺប៉ុណ្ណោះ មិនបានទ្រង់អនុញ្ញាតដល់ភិក្ខុគ្មានជម្ងឺឡើយ ក៏មិនហ៊ានឆាន់ស្ករអំពៅ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្ករអំពៅដល់ភិក្ខុមានជម្ងឺ (អនុញ្ញាត) ទឹកស្ករអំពៅដល់ភិក្ខុគ្មានជម្ងឺ។

## ១៧៣. បាដលិគាមវត្ថុ

CS vin.mv.06.14 | ភាគ ទី៧

**(១៧៣)**

[១១៥] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមសមគួរដល់ព្រះអធ្យាស្រ័យហើយ ទើបយាងចេញទៅកាន់ចារិកនៃបាដលិគ្រាម មួយអន្លើដោយភិក្ខុសង្ឃច្រើន ប្រមាណ១២៥០រូប។ គ្រាកាលព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅបាដលិគ្រាមនោះ។ ពួកឧបាសកនៅក្នុងបាដលិគ្រាម បានឮដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់យាងមកដល់បាដលិគ្រាមហើយ។ គ្រានោះ ពួកឧបាសកនៅក្នុងបាដលិគ្រាម បាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ លុះពួកឧបាសក អ្នកនៅក្នុងបាដលិគ្រាម អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ លំដាប់នោះ ពួកឧបាសក អ្នកនៅក្នុងដែនបាដលិគ្រាម លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃទទួលយករោងសំណាក់របស់យើងខ្ញុំទាំងឡាយ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយភាវៈស្ងៀម។ លំដាប់នោះ ពួកឧបាសក អ្នកនៅក្នុងបាដលិគ្រាម បានដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏នាំគ្នាក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចូលទៅកាន់រោងសំណាក់ លុះចូលទៅដល់ហើយ ក៏បានក្រាលរោងសំណាក់ដោយគ្រឿងកម្រាលសព្វគ្រប់ហើយ ក៏តែងតាំងអាសនៈទាំងឡាយ និងដម្កល់ក្អមទឹក តែងតាំងប្រទីបប្រេង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ។ ពួកឧបាសក អ្នកនៅក្នុងបាដលិគ្រាម បានឋិតនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឯរោងសំណាក់យើងខ្ញុំ បានក្រាលកម្រាលសព្វគ្រប់ហើយ អាសនៈទាំងឡាយ យើងខ្ញុំបានតែងតាំងស្រេចហើយ ក្អមទឹកយើងខ្ញុំ បានដម្កល់ទុកហើយ ប្រទីបប្រេង យើងខ្ញុំបានតែងតាំងស្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ សំគាល់កាលដ៏គួរ និងនិមន្តទៅក្នុងកាលឥឡូវនេះចុះ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរ យាងទៅកាន់រោងសំណាក់ជាមួយនឹងភិក្ខុសង្ឃ លុះយាងទៅដល់ហើយ ទ្រង់លាងព្រះបាទទាំងគូហើយ ក៏យាងចូលទៅកាន់រោងសំណាក់ ទ្រង់គង់ផ្អែកនឹងសសរកណ្តាល បែរព្រះភក្រ្តទៅទិសខាងកើត។ ពួកភិក្ខុក៏បានលាងជើង ហើយចូលទៅកាន់រោងសំណាក់ដែរ ហើយអង្គុយផ្ទាប់នឹងជញ្ជាំងទិសខាងលិច បែរមុខទៅទិសខាងកើត ឈមមុខត្រង់ទៅរកព្រះដ៏មានព្រះភាគ។ ចំណែកពួកឧបាសក អ្នកនៅក្នុងបាដលិគ្រាម ក៏បានលាងជើង ហើយនាំគ្នាចូលទៅកាន់រោងសំណាក់ ហើយអង្គុយផ្ទាប់នឹងជញ្ជាំងខាងកើត បែរមុខទៅទិសខាងលិច ឈមមុខត្រង់ទៅរកព្រះដ៏មានព្រះភាគដែរ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកឧបាសក អ្នកនៅក្នុងបាដលិគ្រាមមក ហើយទ្រង់ត្រាស់ថា។

[១១៦] ម្នាលគហបតិទាំងឡាយ ទោសទាំង៥ប្រការនេះ ជាទោសនៃបុគ្គលទ្រុស្តសីល [69] ឬវិបត្តិចាកសីល។ ទោសទាំង៥ប្រការនោះ តើដូចម្តេចខ្លះ។ ម្នាលគហបតិទាំងឡាយ បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ក្នុងលោកនេះ តែងបាននូវសេចក្តីវិនាសនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីប្រមាថ។ នេះជាទោសទី១ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល។ ម្នាលគហបតិទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ តែងមានកិត្តិសព្ទអាក្រក់ ឮខ្ចរខ្ចាយទៅ។ នេះជាទោសទី២ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល។ ម្នាលគហបតិទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ទោះបីជាខត្តិយបរិសទ្យក្តី ជាព្រាហ្មណ៍បរិសទ្យក្តី ជាគហបតិបរិសទ្យក្តី ជាសមណបរិសទ្យក្តី ក៏គ្មានក្លៀវក្លា មានតែមុខឱនចុះ ហើយដើរចូលទៅ។ នេះជាទោសទី៣ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល។ ម្នាលគហបតិទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ វេលាទៀបស្លាប់ តែងវង្វេងស្មារតី។ នេះជាទោសទី៤ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល។ ម្នាលគហបតិទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ លុះរំលាងខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់អបាយ[70] (តិរច្ឆាន) ទុគ្គតិ[71] (ប្រេត) វិនិបាត[72] (អសុរកាយ) និរយ (នរក)។ នេះជាទោសទី៥ នៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល។ ម្នាលគហបតិទាំងឡាយ ទោសទាំង៥ប្រការនេះឯង ជាទោសនៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល។

[១១៧] ម្នាលគហបតិទាំងឡាយ អានិសង្សទាំង៥ប្រការនេះ ជាអានិសង្សនៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល។ អានិសង្សទាំង៥ប្រការនោះ តើដូចម្តេចខ្លះ។ ម្នាលគហបតិទាំងឡាយ បុគ្គលមានសីល ឬបរិបូណ៌ដោយសីល ក្នុងលោកនេះ តែងបាននូវគំនរ នៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីមិនប្រមាថ។ នេះជាអានិសង្សទី១ នៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល។ ម្នាលគហបតិទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬបរិបូណ៌ដោយសីលហើយ តែងមានកិត្តិសព្ទដ៏ពីរោះ ឮខ្ចរខ្ចាយទៅ។ នេះជាអានិសង្សទី២ នៃបុគ្គល

មានសីល ឬបរិបូណ៌ដោយសីល។ ម្នាលគហបតិទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬបរិបូណ៌ដោយសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ទោះបីជាខត្តិយបរិសទ្យក្តី ជាព្រាហ្មណ៌បរិសទ្យក្តី ជាគហបតិបរិសទ្យក្តី ជាសមណបរិសទ្យក្តី ក៏ក្លៀវក្លា មិនឱនមុខចុះ គឺថាមិនក្រអឺមក្រអៀម ហើយដើរចូលទៅ។ នេះជាអានិសង្សទី៣ នៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល។ ម្នាលគហបតិទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬបរិបូណ៌ដោយសីលហើយ លុះវេលាទៀបស្លាប់ ក៏មិនវង្វេងស្មារតីឡើយ។ នេះជាអានិសង្សទី៤ នៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល។ ម្នាលគហបតិទាំងឡាយ ពាក្យដទៃមានតទៅទៀត បុគ្គលមានសីល ឬបរិបូណ៌ដោយសីលហើយ លុះរំលាងខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់មនុស្សលោក ឬទេវលោក។ នេះជាអានិសង្សទី៥ នៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល។ ម្នាលគហបតិទាំងឡាយ អានិសង្សទាំង៥ប្រការនេះឯង ជាអានិសង្សនៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល។

[១១៨] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឧបាសកទាំងឡាយ នៅក្នុងបាដលិគ្រាមឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា អស់រាត្រីជាច្រើន ហើយបញ្ជូនទៅដោយព្រះពុទ្ធដីកាថា ម្នាលគហបតិទាំងឡាយ រាត្រី (បឋមយាម) កន្លងទៅហើយ អ្នកទាំងឡាយ ចូរដឹងនូវកាលដ៏គួរ នឹងត្រឡប់ទៅវិញក្នុងកាលឥឡូវនេះចុះ។ ឧបាសកទាំងឡាយនៅក្នុងបាដលិគ្រាម បានទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ។ វេលាដែលឧបាសកទាំងឡាយ នៅក្នុងបាដលិគ្រាម ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះអង្គក៏ទ្រង់យាងចូលទៅកាន់សុញ្ញាគារដ្ឋាន (គឺផ្ទះស្ងាត់)។

## ១៧៤. សុនិធវស្សការវត្ថុ

CS vin.mv.06.15 | ភាគ ទី៧

**(១៧៤)**

[១១៩] សម័យនោះឯង មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ១ វស្សការៈ១ នាំគ្នាកសាងក្រុងក្នុងបាដលិគ្រាម ដើម្បីនឹងការពារពួករាជត្រកូល ដែលនៅក្នុងដែនវជ្ជី។ ព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់ទតដោយទិព្វចក្ខុ ដ៏ស្អាតកន្លងលើសចក្ខុរបស់មនុស្ស បានឃើញពួកទេវតាជាច្រើនកំពុងគយគន់មើលទៅកន្លែងសង់ផ្ទះ ក្នុងបាដលិគ្រាម។ ទេវតាមានសក្តិធំ គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យ ដែលមានសក្តិធំទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិជាកណ្តាល គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យ ដែលមានសក្តិជាកណ្តាលទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិទាប គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យ ដែលមានសក្តិទាបទាំងឡាយ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមក ហើយទ្រង់សួរថា ម្នាលអានន្ទ ជនពួកណាហ្ន៎ គេសាងក្រុងក្នុងបាដលិគ្រាម។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន មហាមាត្យក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ សាងក្រុងក្នុងបាដលិគ្រាម ដើម្បីនឹងការពារនូវពួករាជត្រកូល ដែលនៅក្នុងដែនវជ្ជី។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ បានប្រឹក្សាគ្នានឹងពួកទេវតា ក្នុងស្ថានតាវត្តិង្ស[73] ថាយ៉ាងណាមិញ ម្នាលអានន្ទ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ សាងក្រុងក្នុងបាដលិគ្រាមដើម្បីនឹងការពារនូវពួករាជត្រកូលក្នុងដែនវជ្ជី យ៉ាងនោះដែរ ម្នាលអានន្ទ តថាគតក្រោកឡើងក្នុងបច្ចូសសម័យ នៃរាត្រី ក្នុងសុញ្ញាគារដ្ឋាន (ផ្ទះស្ងាត់) នេះ ហើយមើលដោយទិព្វចក្ខុដ៏ស្អាត កន្លងលើសចក្ខុរបស់មនុស្ស បានឃើញពួកទេវតាជាច្រើន កំពុងគយគន់មើលទៅកន្លែងសង់ផ្ទះក្នុងបាដលិគ្រាម។ ពួកទេវតាមានសក្តិធំ គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យ ដែលមានសក្តិធំ ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិជាកណ្តាល គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យ ដែលមានសក្តិជាកណ្តាល ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ទេវតាមានសក្តិទាប គយគន់មើលទីកន្លែងសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យ ដែលមានសក្តិទាប ក៏បង្អោនទៅដើម្បីនឹងកសាងលំនៅក្នុងប្រទេសនោះដែរ ម្នាលអានន្ទ ទីប្រជុំរបស់អរិយបុគ្គលទាំងឡាយ ដែលមានទាំងអម្បាលមាណ និងផ្លូវជំនួញ ដែលមានទាំងអម្បាលមាណ បាដលិបុត្រនេះ ក៏ជាក្រុងប្រសើរជាងទីប្រជុំព្រះអរិយបុគ្គល និងផ្លូវជំនួញអម្បាលនោះ ម្យ៉ាងទៀត ជាកន្លែងបែកធ្លាយ ឬរបូតបង្វេចទ្រព្យ ម្នាលអានន្ទ ក្រុងបាដលិបុត្រមុខជានឹងមានសេចក្តីអន្តរាយ៣យ៉ាង គឺអន្តរាយអំពីភ្លើង១ អន្តរាយអំពីទឹក១ អន្តរាយអំពីហេតុខាងក្នុង គឺបែកចាកគ្នានឹងគ្នា១។

[១២០] គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ (នាំគ្នា) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរជាទីរីករាយ និងពាក្យគួរជាទីរលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ទើបឋិតនៅក្នុងទីសមគួរ។ លុះមហាមាត្យ ក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ឋិតនៅក្នុងទីសមគួរហើយ ក៏ពោលពាក្យដូច្នេះនឹងព្រះដ៏មានព្រះភាគថា សូមព្រះគោតមដ៏ចំរើនទទួលភត្តរបស់ខ្ញុំព្រះអង្គទាំងឡាយ ដើម្បីឆាន់ក្នុងថ្ងៃស្អែក មួយអន្លើដោយភិក្ខុសង្ឃ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយភាវៈស្ងៀម។ គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ដឹងថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកទីអង្គុយ ហើយដើរចេញទៅ។ គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ តាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម (រួចហើយ) ចាត់បម្រើឲ្យទៅក្រាបបង្គំទូលកាលដ៏គួរ ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើនកាល (នេះជាកាលគួរហើយ) ភត្តក៏សម្រេចហើយ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរ ក្នុងវេលាព្រឹក យាងចូលទៅកាន់លំនៅមហាមាត្យ នៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេរៀបចំថ្វាយ ជាមួយនឹងភិក្ខុសង្ឃ។ គ្រានោះ មហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ក៏អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពីសាដោយដៃនៃខ្លួន ត្រាតែភិក្ខុសង្ឃហាមឃាត់ លុះកំណត់ដឹងថា ព្រះមានព្រះភាគ ទ្រង់សោយរួចហើយ ដាក់ព្រះហស្តចុះចាកបាត្រហើយ ក៏អង្គុយនៅក្នុងទីដ៏សមគួរ។ លុះមហាមាត្យនៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ អង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់អនុមោទនា ដោយព្រះគាថាទាំងឡាយនេះថា

[១២១] មនុស្ស ជាបណ្ឌិតជាតិ រមែងសម្រេចនូវការនៅក្នុងប្រទេសណាហើយ ក៏តែងឲ្យពួកបុគ្គលអ្នកមានសីល ដែលសង្រួមល្អ ប្រព្រឹត្តធម៌ដ៏ប្រសើរ ឲ្យបរិភោគក្នុងលំនៅរបស់ខ្លួន ហើយបានទាំងឧទ្ទិសផលទក្ខិណាទាន (ឲ្យចំណែកបុណ្យ) ដល់ពួកទេវតាដែលនៅក្នុងប្រទេសនោះ (ថែមទៀត)។ ទេវតាទាំងនោះ តែងបូជាចំពោះមនុស្សដែលបានបូជាដល់ខ្លួន តែងរាប់អានចំពោះមនុស្សដែលរាប់អានដល់ខ្លួន តែងអនុគ្រោះមនុស្សនោះ ដូចជាមាតាអនុគ្រោះបុត្រ ដែលខ្លួនបីថ្នម ផ្ទាប់នឹងទ្រូងឲ្យចំរើនឡើង។ មនុស្សដែលទេវតា បានអនុគ្រោះហើយ ក៏តែងឃើញនូវសេចក្តីចំរើនសព្វៗកាល។

[១២២] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់អនុមោទនាដោយព្រះគាថាទាំងឡាយនេះ ចំពោះមហាមាត្យ នៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ (ចប់ហើយ) ក៏ទ្រង់ក្រោកចាកអាសនៈ យាងចេញទៅ។ សម័យនោះឯង មហាមាត្យ នៅក្នុងដែនមគធៈ ឈ្មោះសុនីធៈ និងវស្សការៈ ដើរតាមព្រះមានព្រះភាគ អំពីក្រោយៗ ដោយគិតថា ក្នុងថ្ងៃនេះ ព្រះសមណគោតម នឹងយាងចេញទៅ តាមទ្វារណា ទ្វារនោះ នឹងបានឈ្មោះថា គោតមទ្វារ នឹងឆ្លងស្ទឹងគង្គា តាមកំពង់ណា កំពង់នោះ នឹងបានឈ្មោះថា គោតមតិត្ថ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងចេញ តាមទ្វារណា ទ្វារនោះក៏ឈ្មោះថា គោតមទ្វារ ជាប្រាកដ (ដល់សព្វថ្ងៃនេះ)។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងចូលទៅកាន់ស្ទឹងគង្គា។ ស្ទឹងគង្គាមានទឹកពេញប្រៀប ត្រឹមស្មើនឹងមាត់ច្រាំង ល្មមសត្វក្អែក ឱនផឹកបាន។ មនុស្សពួកខ្លះ រកទូក មនុស្សពួកខ្លះរកផែ មនុស្សពួកខ្លះ ចងក្បូន ប្រាថ្នានឹងឆ្លងអំពីត្រើយខាងអាយ ទៅកាន់ត្រើយខាងនាយ។ ព្រះដ៏មានព្រះភាគ ទ្រង់បានឃើញមនុស្សទាំងនោះ គឺមនុស្សពួកខ្លះ កំពុងរកទូក មនុស្សពួកខ្លះ កំពុងរកផែ មនុស្សពួកខ្លះ កំពុងចងក្បូន ប្រាថ្នានឹងឆ្លងអំពីត្រើយខាងអាយ ទៅត្រើយខាងនាយ លុះព្រះដ៏មានព្រះភាគ ទ្រង់ឃើញហើយ ក៏និម្មិតព្រះអង្គបាត់ (មួយរំពេច) អំពីត្រើយខាងអាយ នៃស្ទឹងគង្គា ទៅប្រាកដនៅត្រើយខាងនាយ ជាមួយនឹងភិក្ខុសង្ឃ គួរនាដូចជាបុរស មានកំឡាំង លាចេញនូវដើមដៃ ដែលបត់ចូល ឬបត់ចូលនូវដើមដៃ ដែលលាចេញ ឆាប់រហ័សដូច្នោះឯង។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់ នូវសេចក្តីនោះហើយ ទើបបន្លឺឡើង នូវឧទានគាថានេះ ក្នុងវេលានោះថា ពួកជនណាឆ្លងស្ទឹង គឺតណ្ហាដ៏ជ្រៅឆ្ងាយទូលាយបាន (ពួកជននោះឯង) តែងធ្វើស្ពាន គឺអរិយមគ្គមិនឲ្យប៉ះពាល់ទីជាទំនាបទាំងឡាយ ហើយឆ្លងបាន សេចក្តីពិតថា ជនធម្មតា (ដែលប្រាថ្នានឹងឆ្លងទឹកបន្តិចបន្តួច) តែងចងក្បូន (ទើបឆ្លងទៅបាន) ឯជនជាអ្នកប្រាជ្ញទាំងឡាយ គឺព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធ លោកបានឆ្លងរួចស្រឡះហើយ។

## ១៧៥. កោដិគាមេ សច្ចកថា

CS vin.mv.06.16 | ភាគ ទី៧

**(១៧៥)**

[១២៣] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងចូលទៅកាន់កោដិគ្រាម[74)]។ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកោដិគ្រាមនោះ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងកោដិគ្រាមនោះមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី អន្ទោលទៅ និងត្រាច់រង្គាត់ទៅកាន់ផ្លូវឆ្ងាយយ៉ាងនេះ ព្រោះមិនបានត្រាស់ដឹង និងមិនបានចាក់ធ្លុះ នូវអរិយសច្ចទាំង៤ អរិយសច្ចទាំង៤ដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគត និងអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅកាន់ផ្លូវឆ្ងាយនេះ ដូច្នេះ ព្រោះមិនបានត្រាស់ដឹង និងមិនបានចាក់ធ្លុះ នូវទុក្ខអរិយសច្ច នូវទុក្ខសមុទយអរិយសច្ច។បេ។ នូវទុក្ខនិរោធអរិយសច្ច។បេ។ តថាគត និងអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅកាន់ផ្លូវឆ្ងាយនេះ ដូច្នេះ ព្រោះមិនបានត្រាស់ដឹង និងមិនបានចាក់ធ្លុះ នូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ម្នាលភិក្ខុទាំងឡាយទុក្ខអរិយសច្ចនោះ តថាគត និងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខសមុទយអរិយសច្ចនោះ តថាគត និងអ្នកទាំងឡាយ បានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធអរិយសច្ចនោះ តថាគត និងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនោះ តថាគត និងអ្នកទាំងឡាយបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា តថាគត និងអ្នកទាំងឡាយ ដកឡើងហើយ ខ្សែ គឺតណ្ហា សម្រាប់ដឹកនាំទៅក្នុងភព ក៏អស់ហើយ ឥឡូវនេះ គ្មានភពថ្មីទៀតទេ។

[១២៤] ការអន្ទោលទៅកាន់ផ្លូវឆ្ងាយក្នុងជាតិទាំងឡាយនោះៗឯង ព្រោះមិនបានឃើញនូវអរិយសច្ចទាំង៤ជាធម៌ពិត។ អរិយសច្ចទាំង៤នេះឯង តថាគត និងអ្នកទាំងឡាយ បានឃើញហើយ តណ្ហាជាអ្នកដឹកនាំទៅកាន់ភព ក៏តថាគត និងអ្នកទាំងឡាយគាស់រំលើងហើយ ឫសនៃសេចក្តីទុក្ខ ក៏តថាគត និងអ្នករាល់គ្នា ផ្តាច់ចោលហើយ ឥឡូវនេះ គ្មានភពថ្មីទៀតទេ។

## ១៧៦. អម្ពបាលីវត្ថុ

CS vin.mv.06.17 | ភាគ ទី៧

**(១៧៦)**

[១២៥] នាងអម្ពបាលី ជាស្រីផ្កាមាស បានឮដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរមកកាន់កោដិគ្រាម។ លំដាប់នោះឯង នាងអម្ពបាលី ជាស្រីផ្កាមាស បានប្រើគេឲ្យទឹមយានដ៏ថ្លៃថ្លាហើយ ក៏ឡើងជិះយានដ៏ថ្លៃថ្លា ចេញទៅអំពីក្រុងវេសាលី ដោយយានដ៏ថ្លៃថ្លាទាំងអម្បាលនោះ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ ហើយដាក់យានទុកក្នុងទីមួយ រួចចុះអំពីយាន ដើរទៅដោយជើងទទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ។ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់នាងអម្ពបាលី ជាស្រីផ្កាមាស ដែលអង្គុយក្នុងទីសមគួរ (នោះ) ឯង ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យរីករាយ ឲ្យត្រេកអរ ដោយធម្មីកថា។ លំដាប់នោះ នាងអម្ពបាលី ជាស្រីផ្កាមាស លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យរីករាយ ឲ្យត្រេកអរ ដោយធម្មីកថាហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក មួយអន្លើ ដោយភិក្ខុសង្ឃ។ ព្រះដ៏មានព្រះភាគ ទ្រង់បានទទួលនិមន្ត ដោយតុណ្ហីភាព។ គ្រានោះ នាងអម្ពបាលី ជាស្រីផ្កាមាស ដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។

## ១៧៧. លិច្ឆវីវត្ថុ

CS vin.mv.06.18 | ភាគ ទី៧

**(១៧៧)**

ពួកស្តេចលិច្ឆវី ក្រុងវេសាលី បានឮដំណឹងថា ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរមកដល់កោដិគ្រាម។ ពួកស្តេចលិច្ឆវី ក្រុងវេសាលី ក៏ឲ្យពួកសារថី ទឹមយានដ៏ថ្លៃថ្លា ហើយឡើងគង់យានដ៏ថ្លៃថ្លា ចេញអំពីក្រុងវេសាលី ទៅដោយយានដ៏ថ្លៃថ្លាទាំងអម្បាលនោះ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ។ ស្តេចលិច្ឆវីពួកខ្លះ លាបពណ៌ខៀវ មានសម្បុរខៀវ[75] ទ្រង់ព្រះពស្ត្រខៀវ[76] មានគ្រឿងតែងខ្លួនក៏ខៀវ[77] ស្តេចលិច្ឆវីពួកខ្លះ លាបពណ៌លឿង មានសម្បុរលឿង ទ្រង់ព្រះពស្ត្រលឿង មានគ្រឿងតែងខ្លួនក៏លឿង ស្តេចលិច្ឆវីពួកខ្លះ លាបពណ៌ក្រហម មានសម្បុរក្រហម ទ្រង់ព្រះពស្ត្រក្រហម មានគ្រឿងតែងខ្លួនក៏ក្រហម ស្តេចលិច្ឆវីពួកខ្លះ លាបពណ៌ស មានសម្បុរស ទ្រង់ព្រះពស្ត្រស មានគ្រឿងតែងខ្លួនក៏ស។ លំដាប់នោះ នាងអម្ពបាលី ជាស្រីផ្កាមាស ប្រជល់ចន្ទោលដោយចន្ទោល បំប៉ះនឹមដោយនឹម បំប៉ះកង់ដោយកង់ បំប៉ះភ្លៅដោយភ្លៅ (នៃយាន) របស់ពួកស្តេចលិច្ឆវីកំឡោះៗ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ និយាយនឹងនាងអម្ពបាលី ជាស្រីផ្កាមាសថា ម្នាលមេ អម្ពបាលី ព្រោះហេតុអ្វី បានជានាងមកប្រជល់ចន្ទោលដោយចន្ទោល បំប៉ះនឹមដោយនឹម បំប៉ះកង់ដោយកង់ បំប៉ះភ្លៅដោយភ្លៅ (នៃយាន) របស់យើងជាស្តេចលិច្ឆវីកំឡោះៗ។ នាងអម្ពបាលីតបថា បពិត្រអយ្យបុត្ត[78] ទាំងឡាយ ព្រោះថា ខ្ញុំបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីនឹងឆាន់ក្នុងថ្ងៃស្អែក។ ស្តេចលិច្ឆវីទាំងអម្បាលនោះ មានព្រះបន្ទូលថា ម្នាលមេអម្ពបាលី ចូរនាងឲ្យភត្តនេះមកយើងចុះ (យើងនឹងឲ្យដំឡៃនាង) ចំនួន១សែនកហាបណៈ។ នាងអម្ពបាលីតបថា បពិត្រអយ្យបុត្ត ទុកជាព្រះអង្គប្រទានក្រុងវេសាលី ព្រមទាំងសួយសារអាករ ដែលមាននៅក្នុងជនបទ មកខ្ញុំ ខ្ញុំក៏មិនព្រមថ្វាយភត្តនោះឡើយ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ទះម្រាមព្រះហស្ត ហើយពោលថា ម្នាលអ្នកទាំងឡាយដ៏ចំរើន យើងចាញ់មាតុគ្រាមហើយ ម្នាលគ្នាយើងដ៏ចំរើន យើងចាញ់មាតុគ្រាមហើយ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះ (ក៏នាំគ្នា) ចូលទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់នៅ។ ព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញស្តេចលិច្ឆវីទាំងនោះ កំពុងយាងមកអំពីចម្ងាយ លុះឃើញហើយ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាដែលមិនធ្លាប់ឃើញទេវតា ក្នុងស្ថានតាវត្តិង្សទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររមិលមើលពួកលិច្ឆវីបរិស័ទ្យចុះ អ្នកទាំងឡាយ ចូររមិលមើលពួកលិច្ឆវីបរិសទ្យរឿយៗចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រៀបធៀបពួកលិច្ឆវីបរិសទ្យ ទៅនឹងពួកទេវតាក្នុងជាន់តាវត្តិង្សមើលចុះ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះ ក៏ដាក់យានទុកក្នុងទីមួយ ហើយចុះអំពីយាន ដើរទៅដោយជើងទទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីសមគួរ។ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ពួកស្តេចលិច្ឆវី ដែលអង្គុយក្នុងទីសមគួរនោះឯង ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យរីករាយ ឲ្យត្រេកអរ ដោយធម្មីកថា។ ឯស្តេចលិច្ឆវីទាំងនោះ ដែលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យរីករាយ ឲ្យត្រេកអរ ដោយធម្មីកថាហើយ ក៏ពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តពួកខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែក។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលលិច្ឆវីទាំងឡាយ តថាគត បានទទួលភត្ត របស់នាងអម្ពបាលី ជាស្រីផ្កាមាស ក្នុងថ្ងៃស្អែករួចទៅហើយ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះ ទះម្រាមព្រះហស្ត ហើយពោលថា ម្នាលគ្នាយើងដ៏ចំរើន យើងចាញ់មាតុគ្រាមហើយ ម្នាលគ្នាយើងដ៏ចំរើន យើងចាញ់មាតុគ្រាមហើយ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះ ត្រេកអររីករាយ តាមភាសិតរបស់ព្រះដ៏មានព្រះភាគហើយ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ គ្រានោះ ព្រះដ៏មានព្រះភាគ គង់ក្នុងកោដិគ្រាម គួរតាមព្រះអធ្យាស្រ័យ ហើយយាងទៅកាន់នាទិកាប្រទេស។ ព្រះអង្គ ទ្រង់គង់នៅក្នុងរោងឥដ្ឋ ក្នុងនាទិកាប្រទេសនោះឯង។ លុះព្រលឹមឡើង នាងអម្ពបាលី ជាស្រីផ្កាមាស ក៏តាក់តែងខាទនីយភោជនីយាហារ (បង្អែម ចំអាប) ក្នុងអារាម (ផ្ទះ) របស់ខ្លួន ហើយចាត់បម្រើឲ្យទៅក្រាបបង្គំទូលកាលគួរ ដល់ព្រះដ៏មានព្រះភាគថា ពេលគួរហើយព្រះអង្គ ភត្តសម្រេចហើយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរអំពីព្រលឹម យាងតម្រង់ទៅកាន់ទីអង្គាស (ចង្ហាន់) របស់នាងអម្ពបាលី ជាស្រីផ្កាមាស លុះយាងទៅដល់ហើយ ទើបគង់លើអាសនៈ ដែលគេក្រាលថ្វាយ ព្រមទាំងភិក្ខុសង្ឃ។ គ្រានោះ នាងអម្ពបាលី ជាស្រីផ្កាមាស អង្គាសថ្វាយខាទនីយភោជនីយាហារ (បង្អែម ចំអាប) ដ៏ឆ្ងាញ់ពីសារ ដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែព្រះដ៏មានព្រះភាគ ទ្រង់ឈប់ទទួល សោយស្រេចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ទើប (នាង) អង្គុយនៅក្នុងទីសមគួរ។ កាលបើនាងអម្ពបាលី ជាស្រីផ្កាមាស អង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ សូមថ្វាយនូវអម្ពបាលិវននេះ ដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលនូវអារាម (នោះ)។ គ្រានោះ ព្រះដ៏មានព្រះភាគ ពន្យល់នាងអម្ពបាលី ជាស្រីផ្កាមាស ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យត្រេកអរ ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ យាងទៅកាន់ព្រៃមហាវន។ បានឮថា ព្រះមានព្រះភាគ គង់នៅក្នុងកូដាគារសាលា នាមមហាវន ជិតក្រុងវេសាលីនោះឯង។

ចប់ វារៈពោលអំពីស្តេចលិច្ឆវី។

## ១៧៨. សីហសេនាបតិវត្ថុ

CS vin.mv.06.19 | ភាគ ទី៧

**(១៧៨)**

[១២៦] សម័យនោះឯង ពួកស្តេចលិច្ឆវី ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នា ក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ[79] ពោលសរសើរគុណព្រះធម៌[80] ពោលសរសើរគុណព្រះសង្ឃ[81] ដោយបរិយាយជាច្រើន។ សម័យនោះ សីហសេនាបតិ ជាសាវកនិគ្រណ្ឋ ក៏អង្គុយនៅក្នុងកណ្តាលបរិសទ្យនោះដែរ។ ទើបសីហសេនាបតិ ត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដ ឥតសង្ស័យឡើយ ព្រោះហេតុនោះ ពួកស្តេចលិច្ឆវីទាំងនោះ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយបរិយាជាច្រើន

បើដូច្នោះ មានតែអាត្មាអញចូលទៅ ដើម្បីឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ (លងមើល)។ លំដាប់នោះ សីហសេនាបតិ ចូលសំដៅទៅត្រង់ទីដែលនិគណ្ឋនាដបុត្តនៅ លុះចូលទៅដល់ហើយ ក៏សំពះនិគណ្ឋនាដបុត្ត ហើយអង្គុយនៅក្នុងទីសមគួរ។ លុះសីហសេនាបតិអង្គុយនៅក្នុងទីសមគួរហើយ ទើបនិយាយទៅនឹងនិគណ្ឋនាដបុត្តថា បពិត្រលោកដ៏ចំរើន ខ្ញុំចង់ចូលទៅឃើញព្រះសមណគោតម (ម្តងមើល)។ និគណ្ឋនាដបុត្តពោលថា នែអ្នកសីហៈ អ្នកឯងជាអ្នកនិយាយចំពោះកិច្ចការថា ត្រូវធ្វើ និងចូលទៅមើលសមណគោត្តម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើដូចម្តេចបាន ម្នាលអ្នកសីហៈ ព្រោះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការ ថាមិនត្រូវធ្វើ សំដែងធម៌ហាមកិច្ចការថា មិនត្រូវធ្វើ និងទូន្មានសាវកទាំងឡាយ ដោយពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើនោះដែរ។ ឯការរៀបចំដំណើររបស់សីហសេនាបតិ ដើម្បីនឹងទៅឃើញព្រះដ៏មានព្រះភាគ (នុ៎ះ) ក៏អាក់ខានទៅ។ ពួកស្តេចលិច្ឆវី ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយបរិយាយជាច្រើន អស់វារៈជាគំរប់ពីរដងផង។បេ។ អស់វារៈជាគំរប់បីដងផង។ ឯសីហសេនាបតិ ក៏មានសេចក្តីត្រិះរិះក្នុងវារៈជាគំរប់បីដងថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដ ឥតសង្ស័យឡើយ ព្រោះហេតុនោះហើយ បានជាពួកស្តេចលិច្ឆវីទាំងនេះ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង អង្គុយប្រជុំគ្នាក្នុងរោងសម្រាប់ទទួលភ្ញៀវ ហើយពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយបរិយាយជាច្រើន និគ្រណ្ឋទាំង (នេះ) ទោះអញលាក្តី មិនលាក្តី នឹងធ្វើអ្វីអញ បើដូច្នោះ អាត្មាអញ មិនបាច់លានិគ្រណ្ឋទាំង (នេះ) ទេ គួរតែចូលទៅឃើញព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះតែម្តង។ លំដាប់នោះ សីហសេនាបតិ ចេញទៅអំពីក្រុងវេសាលី ដោយរថ៥០០ ក្នុងវេលាថ្ងៃ ដើម្បីនឹងឃើញព្រះដ៏មានព្រះភាគ ហើយដាក់យានទុកក្នុងទីសមគួរ ទើបចុះអំពីយាន ដើរទៅដោយជើងទទេ ចូលតម្រង់ទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ទើបអង្គុយក្នុងទីសមគួរ។ លុះសីហសេនាបតិអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮថា ព្រះសមណគោតម ជាអ្នកពោលឃាត់កិច្ចការថា មិនត្រូវធ្វើ សំដែងធម៌ ហាមកិច្ចការថា មិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយ ដោយពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើ ដូច្នោះដែរ បពិត្រព្រះអង្គដ៏ចំរើន គេទាំងឡាយតែងពោលយ៉ាងនេះថា ព្រះសមណគោតម ជាអ្នកពោលឃាត់កិច្ចការថា មិនត្រូវធ្វើ សំដែងធម៌ ហាមកិច្ចការថា មិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយ ដោយពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើដូច្នោះដែរ បពិត្រព្រះអង្គដ៏ចំរើន គេទាំងនោះពោលត្រង់ តាមពាក្យរបស់ព្រះអង្គ មិនមែនពោលបង្កាច់ព្រះអង្គ ដោយពាក្យមិនពិតទេឬ ដ្បិតព្រះអង្គតែងពោលជាក់ច្បាស់ នូវធម៌ សមគួរដល់ធម៌ ប្រសិនបើមានសហធម្មិកណាមួយបាននិយាយត្រូវតាមព្រះពុទ្ធដីកាដែលព្រះអង្គបានពោល (នោះ) ក៏មិនបានដល់នូវហេតុដំណេះដំនៀលឡើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុនោះហើយ បានជាយើងខ្ញុំព្រះអង្គមិនចង់ពោលបង្កាច់ព្រះដ៏មានព្រះភាគ។

[១២៧] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសីហៈ មានហេតុជាទំនងគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើ សំដែងធម៌ ហាមកិច្ចការថា មិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា មិនត្រូវធ្វើនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ មានហេតុជាទំនងគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលថា ត្រូវធ្វើកិច្ចការ សំដែងធម៌ថា ត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវធ្វើនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ មានហេតុជាទំនង គួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិលទេតើ សំដែងធម៌ ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវកាត់ផ្តាច់ផ្តិលនោះដែរ ដែលថានោះ ត្រូវហើយ។ ម្នាលសីហៈ មានហេតុជាទំនង គួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម សំដែងធម៌ ដើម្បីខ្ពើមរអើម ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា គួរខ្ពើមរអើមនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ មានហេតុជាទំនង គួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកបំផ្លាញទេតើ សំដែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវបំផ្លាញនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ មានហេតុជាទំនង គួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកដុតកំដៅទេតើ សំដែងធម៌ ដើម្បីដុតកំដៅ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវដុតកំដៅនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ មានហេតុជាទំនង គួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាមនុស្សឥតកំណើត សំដែងធម៌ ដើម្បីមិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យមិនមានកំណើតនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ មានហេតុជាទំនង គួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកទំនុកបំរុង សំដែងធម៌ ដើម្បីទំនុកបំរុង ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ឲ្យទំនុកបំរុងនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលពាក្យថា មិនត្រូវធ្វើ សំដែងធម៌ ហាមថា មិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា មិនត្រូវធ្វើនោះដែរ ដែលគេថានោះ ត្រូវហើយ តើដូចម្តេច ម្នាលសីហៈ ដ្បិតតថាគតពោលថា មិនត្រូវធ្វើចំពោះតែកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត និងពោលឃាត់កិច្ចការថា មិនត្រូវធ្វើចំពោះតែអកុសលធម៌ដ៏អាក្រក់ច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលឃាត់កិច្ចការថា មិនត្រូវធ្វើ សំដែងធម៌ហាមថា មិនត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា មិនត្រូវធ្វើនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលថា ត្រូវធ្វើ សំដែងធម៌ថា ត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវធ្វើនោះដែរ ដែលគេថានោះ ត្រូវហើយ តើដូចម្តេច។ ម្នាលសីហៈ ដ្បិតតថាគតពោលថា ត្រូវធ្វើចំពោះតែកាយសុចរិត វចីសុចរិត មនោសុចរិត និងពោលថា ត្រូវធ្វើចំពោះតែកុសលធម៌ដែលមានប្រយោជន៍ច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលថា ត្រូវធ្វើ សំដែងធម៌ថា ត្រូវធ្វើ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវធ្វើនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល សំដែងធម៌ ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវកាត់ផ្តាច់ផ្តិល ដែលគេថានោះ ត្រូវហើយ តើដូចម្តេច។ ម្នាលសីហៈ ដ្បិតតថាគតពោលថា ត្រូវកាត់ផ្តាច់ផ្តិលរាគៈ ទោសៈ មោហៈ និងពោលថា ត្រូវកាត់ផ្តាច់ផ្តិលនោះ ចំពោះតែអកុសលធម៌ដ៏អាក្រក់ច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល សំដែងធម៌ ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវកាត់ផ្តាច់ផ្តិល ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម សំដែងធម៌ ដើម្បីការខ្ពើមរអើម ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវខ្ពើមរអើមនោះដែរ ដែលគេថានោះ ត្រូវហើយ តើដូចម្តេច។ ម្នាលសីហៈ ព្រោះតថាគតខ្ពើមចំពោះតែកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត និងខ្ពើមចំពោះសេចក្តីប្រកបចិត្ត ផ្តេកផ្តិតទៅរកអកុសលធម៌ដ៏អាក្រក់ច្រើនប្រការ ម្នាលសីហៈ

ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម សំដែងធម៌ ដើម្បីការខ្ពើមរអើម ទាំងទូន្មានសាវកទាំងឡាយ ដោយការខ្ពើមរអើមនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកបំផ្លាញ សំដែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវបំផ្លាញនោះដែរ ដែលគេថានោះ ត្រូវហើយ តើដូចម្តេច។ ម្នាលសីហៈ ព្រោះតថាគត សំដែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលបំផ្លាញបង់នូវរាគៈ ទោសៈ មោហៈ និងសំដែងធម៌ចំពោះផ្លូវប្រតិបត្តិ បំផ្លាញបង់នូវអកុសលធម៌ដ៏អាក្រក់ច្រើនប្រការ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកបំផ្លាញ សំដែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវបំផ្លាញនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកដុតកំដៅ សំដែងធម៌ ដើម្បីដុតកំដៅ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវដុតកំដៅនោះដែរ ដែលគេថានោះ ត្រូវហើយ តើដូចម្តេច។ ម្នាលសីហៈ ព្រោះតថាគតពោលថា កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ជាអកុសលធម៌ដ៏អាក្រក់ ម្នាលសីហៈ អកុសលធម៌ដ៏អាក្រក់ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ (នោះ) បើអ្នកណាបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោតដែលគេក្រែបែល គាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគត ហៅអ្នកនោះថា អ្នកដុតកំដៅ ម្នាលសីហៈ អកុសលធម៌ដ៏អាក្រក់ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ (នោះ) តថាគតឯង បានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចដើមត្នោត ដែលគេក្រែបែល គាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខហើយ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកដុតកំដៅ សំដែងធម៌ ដើម្បីដុតកំដៅ ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ត្រូវដុតកំដៅនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ ទំនងដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកឥតកំណើត សំដែងធម៌ ដើម្បីមិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា មិនឲ្យមានកំណើតនោះដែរ ដែលគេថានោះ ត្រូវហើយ តើដូចម្តេច។ ម្នាលសីហៈ ព្រោះកិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភព តទៅខាងមុខទៀត បើអ្នកណាបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចដើមត្នោតដែលគេក្រែបែល គាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌ លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគត ហៅអ្នកនោះថា អ្នកឥតកំណើត ម្នាលសីហៈ កិរិយាដេកក្នុងគភ៌ តទៅទៀត ដំណើរកើតក្នុងភព តទៅខាងមុខទៀត តថាគត បានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចដើមត្នោត ដែលគេក្រែបែល គាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌ លែងមានកំណើត តទៅខាងមុខទៀតហើយ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកឥតកំណើត សំដែងធម៌ ដើម្បីមិនឲ្យមានកំណើត ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យមិនឲ្យមានកំណើតនោះដែរ ដែលគេថានោះ ត្រូវហើយ។ ម្នាលសីហៈ ទំនងដែលគួរអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកទំនុកបំរុងពួក សំដែងធម៌ ដើម្បីទំនុកបំរុង ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ឲ្យទំនុកបំរុងនោះដែរ ដែលគេថានោះ ត្រូវហើយ តើដូចម្តេច។ ម្នាលសីហៈ ព្រោះតថាគតជាអ្នកទំនុកបំរុងពួក សំដែងធម៌ ដើម្បីទំនុកបំរុង ដោយសេចក្តីទំនុកបំរុងដ៏ឧត្តម[82] ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ឲ្យទំនុកបំរុងនោះដែរ ម្នាលសីហៈ ទំនងនេះឯងហើយ ដែលគួរឲ្យអ្នកផងថាចំពោះតថាគតថា ព្រះសមណគោតម ជាអ្នកទំនុកបំរុង សំដែងធម៌ ដើម្បីទំនុកបំរុង ទាំងទូន្មានសាវកទាំងឡាយ ដោយពាក្យថា ឲ្យទំនុកបំរុងនោះដែរ ដែលគេថានោះ ត្រូវហើយ។

[១២៨] កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សីហសេនាបតិ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ គួរនាដូចជាមនុស្សចាប់បើករបស់ដែលគេផ្កាប់ចុះ ឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់ បិទបាំង ពុំនោះសោត ដូចជាមនុស្សអ្នកប្រាប់ផ្លូវ ដល់អ្នកវង្វេង ឬក៏ដូចជាមនុស្សកាន់ប្រទីបប្រេង ទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានភ្នែក មើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាទីរឭក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់ហើយនូវព្រះរតនត្រ័យ ថាជាទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសីហៈ អ្នកឯងចូរធ្វើនូវការគិតជញ្ជឹងមើលសិន ឯការគិតជញ្ជឹងមើល (នោះ) ជាកិច្ចប្រពៃ របស់មនុស្សជាអ្នកដឹងទាំងឡាយ ដូចអ្នកឯង (នេះ)។ សីហសេនាបតិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គត្រេកអររីករាយ ជាច្រើនលើសជាងប្រមាណ តាមព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនេះ ដ្បិតព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គថា ម្នាលសីហៈ ចូរអ្នកឯងធ្វើនូវការគិតជញ្ជឹងមើលសិន ឯការគិតជញ្ជឹងមើល (នោះ) ជាកិច្ចប្រពៃរបស់មនុស្សជាអ្នកដឹងទាំងឡាយ ដូចអ្នកឯង (នេះ) បពិត្រព្រះអង្គដ៏ចំរើន តិរ្ថិយដទៃទាំងឡាយ បានខ្ញុំព្រះអង្គជាសាវក មុខជាគេនាំគ្នាលើកទង់ជុំវិញក្រុងវេសាលីទាំងអស់ រួច (គេប្រកាសសេចក្តី) ថា យើងទាំងឡាយ បានសីហសេនាបតិមកជាសាវកហើយ ក៏ក្នុងកាលឥឡូវនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ ចូរអ្នកឯងធ្វើនូវការគិតជញ្ជឹងមើលសិន ឯការគិតជញ្ជឹងមើល (នោះ) ជាកិច្ចប្រពៃ របស់មនុស្សជាអ្នកដឹងទាំងឡាយ ដូចអ្នកឯង (នេះ) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាទីរឭក ជាគំរប់ពីរដង សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់ព្រះរតនត្រ័យ ថាជាទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសីហៈ ត្រកូលរបស់អ្នក ជាអណ្តូងបម្រុងពួកនិគ្រណ្ឋ ជាយូរណាស់មកហើយ អ្នកសំគាល់ថាបានអ្នកណា នឹងឲ្យបិណ្ឌបាតដល់តិរ្ថិយដែលចូលមកនោះ។ សីហសេនាបតី ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គត្រេកអរ រីករាយជាច្រើនលើសប្រមាណ តាមពុទ្ធដីការបស់ព្រះដ៏មានព្រះភាគនេះ ដ្បិតព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ ត្រកូលរបស់អ្នក ជាអណ្តូងបម្រុងពួកនិគ្រណ្ឋ ជាយូរណាស់មកហើយ អ្នកសំគាល់ថាបានអ្នកណា នឹងឲ្យបិណ្ឌបាតដល់និគ្រណ្ឋ ដែលចូលមកនោះវិញ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គស្តាប់បានហើយ ថាព្រះសមណគោតម ទ្រង់ត្រាស់នឹងខ្ញុំយ៉ាងនេះថា អ្នកត្រូវឲ្យទានដល់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកនិគ្រណ្ឋដទៃទេ អ្នកត្រូវឲ្យទានដល់សាវករបស់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកសាវករបស់ពួកនិគ្រណ្ឋដទៃទេ ទានដែលអ្នកឲ្យហើយ ដល់តថាគត ជាទានមានផលច្រើន ទានដែលអ្នកឲ្យហើយ ដល់ពួកនិគ្រណ្ឋដទៃ ជាទានមិនមានផលច្រើនទេ ទានដែលអ្នកឲ្យហើយ ដល់ពួក

សាវករបស់តថាគត ជាទានមានផលច្រើន ទានដែលអ្នកឲ្យហើយ ដល់ពួកសាវករបស់និគ្រណ្ឋដទៃ ជាទានមិនមានផលច្រើនទេ ក៏ក្នុងកាលឥឡូវនេះ ព្រះដ៏មានព្រះភាគ បបួលខ្ញុំព្រះអង្គឲ្យធ្វើទានដល់ពួកនិគ្រណ្ឋ (វិញ) បពិត្រព្រះអង្គដ៏ចំរើន ប៉ុន្តែខ្ញុំព្រះអង្គដឹងកាលដ៏សមគួរ ក្នុងការឲ្យទាននេះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគ ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាទីរឭក ជាគំរប់បីដង សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់ព្រះរតនត្រ័យ ថាជាទីរឭក ដោយជីវិត តាំងអំពីនេះទៅ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា ដល់សីហសេនាបតិ គឺសំដែងនូវទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយ ដ៏លាមកសៅហ្មង និងអានិសង្សក្នុងការចេញបួស។ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា សីហសេនាបតិ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយ មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ក្នុងកាលនោះ ព្រះអង្គក៏សំដែងនូវធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយតែងលើកឡើងសំដែងដោយព្រះអង្គឯង គឺ (សំដែង) ទុក្ខ សមុទយ និរោធ មគ្គ។ ធម្មតា សំពត់ស្អាត មិនជិតប្រឡាក់ ដោយវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយល្អបាន យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់សីហសេនាបតិ ក្នុងទីអង្គុយនោះឯងថា ធម្មជាតណាមួយ មានសេចក្តីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ក៏មានឧបមេយ្យដូច្នោះឯង។ គ្រានោះ សីហសេនាបតិ បានឃើញធម៌ហើយ បានដល់ធម៌ហើយ បានត្រាស់ដឹងធម៌ហើយ ឈមចុះកាន់ធម៌ស៊ប់ហើយ កន្លងផុតសេចក្តីសង្ស័យហើយ កាត់បង់នូវសេចក្តីងឿងឆ្ងល់ ជាអ្នកដល់នូវសេចក្តីក្លាហាន លែងជឿស្តាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែកនេះ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្ត ដោយតុណ្ហីភាព។ គ្រានោះ សីហសេនាបតិ ដឹងថាព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកទីអង្គុយ ថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយដើរចេញទៅ។ ទើបសីហសេនាបតិ បង្គាប់បុរសម្នាក់ថា នែនាយ អ្នកឯងចូរទៅរកសាច់សត្វស្លាប់ស្រាប់មក។ លុះកន្លងរាត្រីយប់នោះហើយ ទើបសីហសេនាបតិ តាក់តែងខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពីសា ហើយចាត់បម្រើឲ្យទៅក្រាបទូលនូវភត្តកាល ដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន (កាលនេះ) ជាកាលសមគួរហើយ ភត្តក៏សម្រេចហើយ។ គ្រានោះ ក្នុងបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ហើយទ្រង់បាត្រចីវរ យាងទៅកាន់ផ្ទះសីហសេនាបតិ លុះចូលទៅដល់ហើយ គង់លើអាសនៈដែលគេក្រាលបម្រុងទុក ព្រមទាំងភិក្ខុសង្ឃ។ សម័យនោះឯង និគ្រណ្ឋទាំងឡាយច្រើន (នាំគ្នានៅ) គ្រប់ច្រក នៅគ្រប់ផ្លូវត្រឡែងកែង ក្នុងក្រុងវេសាលី ហើយផ្គងដៃឡើង កន្ទក់កន្ទេញថា ថ្ងៃនេះ សីហសេនាបតិ សម្លាប់សត្វចិញ្ចឹមដ៏ធាត់ៗ ធ្វើភត្តបម្រុងសមណគោតម សមណគោតមដឹងថា សាច់គេធ្វើចំពោះខ្លួន ក៏នៅតែឆាន់សាច់នោះដែរ។ គ្រានោះ មានបុរសម្នាក់ ចូលទៅរកសីហសេនាបតិ លុះចូលទៅដល់ហើយ និយាយខ្សិបជិតត្រចៀកសីហសេនាបតិថា បពិត្រលោកដ៏ចំរើន សូមលោកជ្រាបចុះ ពួកនិគ្រណ្ឋទាំងអម្បាលនេះជាច្រើន (នាំគ្នានៅ) គ្រប់ច្រក នៅគ្រប់ផ្លូវត្រឡែងកែង ក្នុងក្រុងវេសាលី ហើយផ្គងដៃឡើង កន្ទក់កន្ទេញថា ថ្ងៃនេះ សីហសេនាបតិ សម្លាប់សត្វចិញ្ចឹមដ៏ធាត់ៗ ធ្វើភត្តបម្រុងសមណគោតម សមណគោតមដឹងថា សាច់គេធ្វើចំពោះខ្លួនហើយ ក៏នៅតែឆាន់សាច់នោះដែរ។ សីហសេនាបតិ និយាយថា ម្នាលអ្នក ចូរកុំនិយាយឡើយ លោកដ៏មានអាយុទាំងអម្បាលនោះ ប្រាថ្នានឹងពោលទោសព្រះពុទ្ធ ប្រាថ្នានឹងពោលទោសព្រះធម៌ ប្រាថ្នានឹងពោលទោសព្រះសង្ឃ អស់កាលជាយូរមកហើយ លោកដ៏មានអាយុទាំងអម្បាលនោះ ពោលបង្កាច់ព្រះដ៏មានព្រះភាគនោះដោយរបស់ដែលមិនមាន ដោយការទទេ ដោយពាក្យមុសាវាទ ដោយពាក្យមិនពិត មិនអស់មិនហើយឡើយ ក៏ឯការពិត (នោះ) យើងមិនក្លែងផ្តាច់បង់ជីវិតសត្វ ព្រោះហេតុជីវិត (របស់ខ្លួន) ទេ។ គ្រានោះ សីហសេនាបតិ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយដ៏ផ្ចិតផ្ចង់ ត្រាតែព្រះដ៏មានព្រះភាគ ទ្រង់ឈប់ទទួល សោយជាស្រេច ដាក់ព្រះហស្តអំពីបាត្រ ទើបអង្គុយនៅក្នុងទីដ៏សមគួរ។ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់សីហសេនាបតិ ដែលអង្គុយហើយក្នុងទីសមគួរ ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ យាងចេញទៅ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយទ្រង់ (បញ្ញត្ត) ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលដឹងថា សាច់គេធ្វើចំពោះ (ខ្លួន) កុំគប្បីបរិភោគ ភិក្ខុណាបរិភោគ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្រីនិងសាច់ ដែលបរិសុទ្ធដោយបំផុត៣យ៉ាង គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស។

## ១៧៩. កប្បិយភូមិអនុជាននា

CS vin.mv.06.20 | ភាគ ទី៧

**(១៧៩)**

[១២៩] សម័យនោះឯង ក្រុងវេសាលីមានបាយបរិបូណ៌ មានសន្ទូងល្អ មានបិណ្ឌបាតបានស្រួល ងាយនឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានដោយការស្វែងរក និងការព្យាយាម។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ទីស្ងាត់ សម្ងំនៅក្នុងព្រះកម្មដ្ឋាន ទើបទ្រង់ត្រិះរិះដោយព្រះទ័យយ៉ាងនេះថា ខាទនីយភោជនីយៈទាំងឡាយណា ដែលតថាគតបានអនុញ្ញាតហើយ ដល់ភិក្ខុទាំងឡាយ ក្នុងកាលដែលស្រុកមានអំណត់ មានសន្ទូងមិនល្អ មានបិណ្ឌបាតបានដោយលំបាក គឺខាទនីយភោជនីយៈ ដែលទុកដាក់ខាងក្នុង (អកប្បិយកុដិ) ចំអិនខាងក្នុង (អកប្បិយកុដិ) ភិក្ខុចំអិនដោយខ្លួនឯង ភិក្ខុទទួលរបស់ជាឧគ្គហិត ដែលគេនាំមកអំពីទីនោះ ដែលភិក្ខុទទួលប្រគេនក្នុងវេលាមុនភត្ត វត្ថុនៅក្នុងព្រៃ វត្ថុនៅក្នុងស្រះ ក៏ក្នុងថ្ងៃនេះ ភិក្ខុទាំងឡាយ នៅបរិភោគភត្តទាំងនោះឬ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ចេញអំពីការសម្ងំនៅក្នុងព្រះកម្មដ្ឋាន ក្នុងវេលារសៀលហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមក ទ្រង់ (សួរ) ថា ម្នាលអានន្ទ ខាទនីយភោជនីយៈទាំងឡាយណា ដែលតថាគតបានអនុញ្ញាតហើយ ដល់ភិក្ខុទាំងឡាយ ក្នុងកាលមានអំណត់ មានសន្ទូងមិនល្អ មានបិណ្ឌបាតបានដោយលំបាក គឺខាទនីយភោជនីយៈ ដែលទុកដាក់ខាងក្នុង និងចំអិនខាងក្នុង (អកប្បិយកុដិ) ភិក្ខុចំអិនដោយខ្លួនឯង ភិក្ខុទទួលរបស់ជាឧគ្គហិត ដែលគេនាំមកអំពីទីនោះ ដែលភិក្ខុទទួលប្រគេនក្នុងវេលាមុនភត្ត វត្ថុនៅក្នុងព្រៃ វត្ថុនៅក្នុងស្រះ ក៏ក្នុងថ្ងៃនេះ តើភិក្ខុទាំងឡាយ នៅបរិភោគភត្តទាំងនោះឬអ្វី។ ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ភិក្ខុទាំងឡាយ នៅបរិភោគនៅឡើយ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ខាទនីយភោជនីយៈទាំងឡាយណា ដែលតថាគតបានអនុញ្ញាតហើយ ដល់ភិក្ខុទាំងឡាយ ក្នុងកាលមានអំណត់ មានសន្ទូងមិនល្អ មានបិណ្ឌបាតបានដោយលំបាក គឺខាទនីយភោជនីយៈ ដែលទុកដាក់ខាងក្នុង និងចំអិនខាងក្នុង (អកប្បិយកុដិ) ភិក្ខុចំអិនដោយខ្លួនឯង ភិក្ខុទទួលរបស់ជាឧគ្គហិត ដែលគេនាំមកអំពីទីនោះ ដែលភិក្ខុទទួលប្រគេនក្នុងវេលាមុនភត្ត វត្ថុនៅក្នុងព្រៃ វត្ថុនៅក្នុងស្រះ ឥឡូវនេះ តថាគតហាមខាទនីយភោជនីយៈទាំងនោះ តាំងពីថ្ងៃនេះទៅ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីបរិភោគ

នូវខាទ់នីយ៍ភោជនីយ៍ ជាអន្តោវុត្ថ (ទុកដាក់ខាងក្នុងអកប្បិយកុដិ) អន្តោបក្ក (ចំអិនខាងក្នុងអកប្បិយកុដិ) សាមំបក្ក (ភិក្ខុចំអិនខ្លួនឯង) ឧគ្គហិតបដិគ្គហិត (កាន់ជាមុន ហើយទើបឲ្យគេប្រគេន) បើភិក្ខុណាបរិភោគ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុឆាន់រួច ហើយ ហាមភត្តហើយ កុំគប្បីឆាន់អនតិរិត្តភោជន (ភោជនថ្មោង) គឺខាទនីយភោជនីយ ដែលទាយកនាំមកអំពីទីនោះ ភិក្ខុទទួលក្នុងវេលាមុន ភត្ត វត្ថុដែលតាំងនៅក្នុងព្រៃ វត្ថុដែលតាំងនៅក្នុងស្រះ បើភិក្ខុណាបរិភោគ វិនយធរត្រូវកាត់សេចក្តីតាមអាបត្តិ។

[១៣០] សម័យនោះឯង ពួកមនុស្សអ្នកជនបទផ្ទុកអម្បិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយាហារខ្លះច្រើនមុខ ក្នុងរទេះទាំងឡាយ ហើយបង្វិល រទេះមកឈប់នៅក្បែរក្លោងទ្វារខាងក្រៅអារាម ដោយប៉ងថា យើងទាំងឡាយនឹងបាននូវលំដាប់ (ទីកន្លែង) ក្នុងកាលណា យើងនឹងធ្វើភត្ត (ថ្វាយ សង្ឃ) ក្នុងកាលនោះ។ (ចួនពេលនោះ) មហាមេឃក៏ទូទឹមឡើង។ គ្រានោះ ពួកមនុស្សទាំងអម្បាលនោះ ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះ ចូលទៅដល់ហើយ ទើបទូលព្រះអានន្ទដ៏មានអាយុ ដោយពាក្យដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន មនុស្សអ្នកនៅក្នុងជនបទ ផ្ទុកអម្បិលខ្លះ ប្រេង ខ្លះ អង្ករខ្លះ ខាទនីយាហារខ្លះច្រើនមុខ ក្នុងរទេះទាំងឡាយ ហើយមកឈប់នៅក្បែរក្លោងទ្វារនេះ ចួនពេលនោះ មហាមេឃក៏ទូទឹមឡើង បពិត្រ ព្រះអានន្ទដ៏ចំរើន មនុស្សអ្នកនៅក្នុងជនបទទាំងនោះ គួរប្រតិបត្តិដូចម្តេចទៅ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏ មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ណើ្តយចុះ បើសង្ឃប្រាថ្នានៅទីណា គឺជាវិហារក្តី អឌ្ឍយោគក្តី ប្រាសាទក្តី ប្រាសាទត្រងិលក្តី គូហាក្តី ដែលនៅចុងក្រោយគេ សង្ឃចូរសន្មត (នូវទីនោះ) ឲ្យជាកប្បិយភូមិ ហើយឲ្យអ្នកជនបទទាំងនោះ នៅក្នុងទីនោះចុះ។ ម្នាលភិក្ខុ ទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ គឺភិក្ខុជាអ្នកឆ្លាស ប្រតិពល គប្បីប្តឹងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្ម មានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតវិហារឈ្មោះនេះ ឲ្យជាកប្បិយភូមិ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ ខ្ញុំ សង្ឃសន្មតវិហារឈ្មោះនេះ ឲ្យជាកប្បិយភូមិ។ ការសន្មតវិហារឈ្មោះនេះ ឲ្យជាកប្បិយភូមិ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏ មានអាយុអង្គនោះគប្បីស្ងៀម បើមិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីនិយាយឡើង។ សង្ឃបានសន្មត វិហារឈ្មោះនេះ ឲ្យជាកប្បិយភូមិហើយ។ ការសន្មតនេះ សមគួរដល់សង្ឃ ហេតុនោះ ទើបសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយ អាការស្ងៀមនៅយ៉ាងនេះ។ សម័យនោះឯង មនុស្សទាំងឡាយដាំបបរ ដាំបាយ ស្លសម្ល ចិញ្ច្រាំសាច់ ពុះឧស ធ្វើសំឡេងគឹកកង ក្នុងកប្បិយភូមិ ដែលសង្ឃសន្មតឲ្យនោះឯង។ ព្រះដ៏មានព្រះភាគ ទ្រង់តើនឡើងក្នុងវេលាបច្ចូសសម័យនៃរាត្រី បានឮសំឡេងគឹកកងខ្លាំង ខ្សៀវខ្សារ[83] លុះឮ ហើយ ទើបទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកសួរថា ម្នាលអានន្ទ សំឡេងគឹកកងខ្លាំង ខ្សៀវខ្សារនោះ តើជាសំឡេងអ្វី។ ព្រះអានន្ទក្រាប បង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ មនុស្សទាំងឡាយដាំបបរ ដាំបាយ ស្លសម្ល ចិញ្ច្រាំសាច់ ពុះឧស ក្នុងកប្បិយភូមិ ដែលសង្ឃសន្មត នោះឯង បពិត្រព្រះដ៏មានព្រះភាគ សំឡេងគឹកកងខ្លាំង ខ្សៀវខ្សារនោះ ជាសំឡេងនុ៎ះឯង។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរប្រើប្រាស់នូវកប្បិយភូមិ ដែលសង្ឃសន្មត ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកប្បិយភូមិបីយ៉ាង គឺឧស្សាវនន្តិកា[84] ១ គោនិសាទិកា[85] ១ គហបតិកា[86] ១។ សម័យនោះឯង យសោជភិក្ខុដ៏មានអាយុ មានជម្ងឺ។ មនុស្សទាំងឡាយនាំភេសជ្ជៈ ដើម្បីប្រយោជន៍ដល់លោកនោះ។ ភិក្ខុ ទាំងឡាយ ដាក់ទុកភេសជ្ជៈទាំងនោះក្រៅ (លំនៅ)។ សត្វតូចៗ (មានកណ្តុរ) ជាដើម ទំពាស៊ីខ្លះ ពួកចោរលួចយកទៅខ្លះ។ ភិក្ខុទាំងឡាយ ក្រាប បង្គំទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយប្រើប្រាស់នូវកប្បិយ ភូមិ ដែលសង្ឃសន្មតឲ្យ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកប្បិយភូមិ៤យ៉ាងគឺ ឧស្សាវនន្តិកា១ គោនិសាទិកា១ គហបតិកា១ សម្មតិកា[87] ១។

## ១៨០. មេណ្ឌកគហបតិវត្ថុ

CS vin.mv.06.21 | ភាគ ទី៧

**(១៨០)**

[១៣១] សម័យនោះឯង មេណ្ឌកគហបតិនៅអាស្រ័យក្នុងក្រុងភទ្ទិយៈ។ សេដ្ឋីនោះ មានឥទ្ធានុភាពខាងឯកក់ជំរះនូវសីស (ក្បាល) រួចប្រើគេ ឲ្យបោសជង្រុកស្រូវ ហើយទើបអង្គុយខាងក្រៅទ្វារ។ ធារស្រូវក៏ស្រាប់តែធ្លាក់ចុះមកអំពីអាកាស ពេញទាំងជង្រុក។ ឯភរិយា (របស់សេដ្ឋីនោះ) មានឥទ្ធានុភាពខាងឯចូលទៅអង្គុយជិតថាសមួយ មានចំណុះមួយអាឡ្ហក[88] និងថាសមួយ សម្រាប់ដាក់សម្ល និងម្ហូបក្រៀម ហើយអង្គាសនូវ បុរស ជាទាសកម្មករដោយភត្ត។ បើសេដ្ឋីភរិយាមិនទាន់ក្រោកឡើង ភត្តនោះក៏មិនចេះអស់ទៅ។ កូនប្រុស (របស់សេដ្ឋីនោះ) មានឥទ្ធានុភាព ខាងឯកាន់យកថង់មានចំណុះមួយពាន់ (កហាបណៈ) ហើយឲ្យរង្វាន់ដល់បុរស ជាទាសកម្មករអស់ប្រាំមួយខែ។ បើថង់នៅតែក្នុងដៃរបស់សេដ្ឋី បុត្តនោះដរាបណា រង្វាន់នោះ ក៏មិនចេះអស់ទៅដរាបនោះ។ កូនប្រសាស្រី (របស់សេដ្ឋីនោះ) មានឥទ្ធានុភាព ខាងឯមុខការចូលទៅអង្គុយជិត កញ្ជើមួយ មានចំណុះ៤ទោណ[89] ហើយឲ្យភត្តដល់បុរស ជាទាសកម្មករ អស់ប្រាំមួយខែ។ បើកូនប្រសាស្រីរបស់សេដ្ឋីនោះ មិនទាន់ក្រោក ឡើងដរាបណា ភត្តនោះ ក៏មិនចេះអស់ទៅ ដរាបនោះ។ ខ្ញុំប្រុស (របស់សេដ្ឋីនោះ) មានឥទ្ធានុភាព ខាងឯមុខការភ្ជួរស្រែ ដោយនង្គ័លតែមួយ មានអាចបំណះប្រាំពីរបែកចេញទៅ។ ព្រះបាទមាគធសេនិយពិម្ពិសារ បានឮដំណឹងថា មេណ្ឌកគហបតិនៅក្នុងក្រុងភទ្ទិយៈ ក្នុងដែនរបស់យើង (នេះ) ថាមាន ឥទ្ធានុភាព ខាងឯកក់ជំរះនូវសីសៈ រួចប្រើគេឲ្យបោសជង្រុកស្រូវ ហើយទើបអង្គុយខាងក្រៅទ្វារ ធារស្រូវក៏ធ្លាក់ចុះមកពីអាកាស ពេញទាំងជង្រុកបាន ភរិយារបស់សេដ្ឋីនោះ មានឥទ្ធានុភាព ខាងឯចូលទៅអង្គុយជិតថាសមួយ មានចំណុះមួយអាឡ្ហក និងថាសមួយ សម្រាប់ ដាក់សម្ល និងម្ហូបក្រៀម ហើយអង្គាសនូវបុរស ជាទាសកម្មករដោយភត្ត បើសេដ្ឋីភរិយានោះ មិនទាន់ក្រោកឡើង ដរាបណា ភត្តនោះក៏មិនចេះ អស់ទៅ ដរាបនោះ កូនប្រុសរបស់សេដ្ឋីនោះ មានឥទ្ធានុភាព ខាងឯកាន់យកថង់មានចំណុះមួយពាន់កហាបណៈ ហើយឲ្យរង្វាន់ដល់បុរស ជា ទាសកម្មករអស់ប្រាំមួយខែ បើថង់នៅតែក្នុងដៃរបស់សេដ្ឋីបុត្តនោះដរាបណា រង្វាន់នោះ ក៏មិនចេះអស់ទៅដរាបនោះ កូនប្រសាស្រីរបស់សេដ្ឋី នោះ មានឥទ្ធានុភាព ខាងឯចូលទៅអង្គុយជិតកញ្ជើមួយ មានចំណុះ៤ទោណ ហើយឲ្យភត្តដល់បុរស ជាទាសកម្មករ អស់ប្រាំមួយខែ បើកូន ប្រសាស្រីសេដ្ឋីនោះ មិនទាន់ក្រោកឡើងដរាបណា ភត្តនោះ ក៏មិនចេះអស់ទៅ ដរាបនោះ ខ្ញុំប្រុស របស់សេដ្ឋីនោះ មានឥទ្ធានុភាព ខាងឯការភ្ជួរ ស្រែ ដោយនង្គ័លតែមួយ មានអាចបំណះប្រាំពីរបែកចេញទៅ។ ទើបព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ហៅនូវសព្វត្ថកមហាមាត្យ[90] ម្នាក់មក

ហើយទ្រង់មានព្រះឱង្ការថា នែនាយ ឮថាមេណ្ឌកគហបតិ នៅក្នុងក្រុងភទ្ទិយៈ ក្នុងដែនរបស់យើង (នេះ) មានឥទ្ធានុភាព ខាងឯកក់ជំរះនូវសីសៈ រួចប្រើគេឲ្យបោសជង្រុកស្រូវ ហើយអង្គុយខាងក្រៅទ្វារ ធារស្រូវស្រាប់តែធ្លាក់ចុះមកអំពីអាកាស ពេញទាំងជង្រុក។បេ។ ខ្ញុំប្រុសរបស់សេដ្ឋីនោះ មានឥទ្ធានុភាព ខាងឯការភ្ជួរស្រែ ដោយនង្គ័លតែមួយ មានអាចម៍បំណះប្រាំពីរបែកចេញទៅ នែនាយ អ្នកចូរទៅឲ្យដឹងការ (បើ) អ្នកឃើញហើយ ដូចជាយើងឃើញ ខ្លួនឯងដែរ។ មហាមាត្យនោះទទួលព្រះរាជឱង្ការនៃព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យដូច្នេះថា យ៉ាងហ្នឹងហើយ ព្រះសម្មតិទេព ហើយត្រាច់សំដៅទៅកាន់ក្រុងភទ្ទិយៈ តាមលំដាប់ ជាមួយនឹងសេនាមានអង្គ៤ ចូលទៅរកមេណ្ឌកគហបតិ លុះចូលទៅដល់ហើយ ទើបនិយាយនឹងមេណ្ឌកគហបតិថា នែគហបតិ យើងនេះឯង ព្រះរាជាទ្រង់ត្រាស់បង្គាប់មកថា ម្នាលនាយ ឮថាមេណ្ឌកគហបតិ នៅក្នុងក្រុងភទ្ទិយៈ ក្នុងដែនរបស់យើង (នេះ) មានឥទ្ធានុភាព ខាងឯកក់ជំរះនូវសីសៈ រួចប្រើគេឲ្យបោសជង្រុកស្រូវ ហើយអង្គុយខាងក្រៅទ្វារ ធារស្រូវក៏ស្រាប់តែធ្លាក់ចុះមកអំពីអាកាស ពេញទាំងជង្រុក។បេ។ ខ្ញុំប្រុសរបស់សេដ្ឋីនោះ មានឥទ្ធានុភាព ខាងឯកិច្ចការភ្ជួរស្រែ ដោយនង្គ័លតែមួយ មានអាចម៍បំណះប្រាំពីរបែកចេញទៅ នែនាយ អ្នកចូរទៅឲ្យដឹងការ (បើ) អ្នកឃើញហើយ ដូចជាយើងឃើញ ខ្លួនឯងដែរ ម្នាលគហបតិ ឥឡូវនេះ យើងចង់ឃើញឥទ្ធានុភាពរបស់អ្នក។ គ្រានោះ មេណ្ឌកគហបតិ កក់ជំរះនូវសីសៈ រួចប្រើគេឲ្យបោសជង្រុកស្រូវ ហើយទើបអង្គុយខាងក្រៅទ្វារ ធារស្រូវក៏ស្រាប់តែធ្លាក់ចុះមកអំពីអាកាស ពេញទាំងជង្រុក។ មហាមាត្យនិយាយថា ម្នាលគហបតិ ឥទ្ធានុភាពរបស់អ្នក យើងក៏បានឃើញហើយ តែយើងចង់ឃើញឥទ្ធានុភាពភរិយារបស់អ្នកទៀត។ ទើបមេណ្ឌកគហបតិ បង្គាប់ទៅភរិយាថា នែនាង បើដូច្នោះ ចូរនាងអង្គាសនូវសេនាមានអង្គ៤ ដោយភត្តចុះ។ លំដាប់នោះ ភរិយារបស់មេណ្ឌកគហបតិ ចូលទៅអង្គុយជិតថាស មានចំណុះមួយអាឡ្ហក និងថាសមួយសម្រាប់ដាក់សម្ល និងម្ហូបក្រៀម ហើយអង្គាសនូវសេនាមានអង្គ៤ ដោយភត្ត។ សេដ្ឋីភរិយានោះ មិនទាន់ក្រោកឡើងដរាបណា ភត្តនោះ ក៏មិនចេះអស់ទៅដរាបនោះ។ មហាមាត្យនិយាយថា ម្នាលគហបតិ ឥទ្ធានុភាពភរិយារបស់អ្នក យើងបានឃើញហើយ តែយើងចង់ឃើញឥទ្ធានុភាពកូនប្រុសរបស់អ្នកទៀត។ ទើបមេណ្ឌកគហបតិ បង្គាប់ទៅកូនប្រុសថា នែកូន បើដូច្នោះ អ្នកចូរឲ្យរង្វាន់ ដល់សេនាមានអង្គ៤ អស់ប្រាំមួយខែចុះ។ លំដាប់នោះ កូនរបស់មេណ្ឌកគហបតិ កាន់យកថង់ មានចំណុះមួយពាន់កហាបណៈ ហើយឲ្យរង្វាន់ ដល់សេនាមានអង្គ៤ អស់ប្រាំមួយខែ។ ថង់នៅក្នុងដៃរបស់សេដ្ឋិបុត្តនោះដរាបណា រង្វាន់នោះ ក៏មិនចេះអស់ទៅដរាបនោះ។ មហាមាត្យនិយាយថា ម្នាលគហបតិ ឥទ្ធានុភាពកូនប្រុសរបស់អ្នក យើងបានឃើញហើយ តែយើងចង់ឃើញឥទ្ធានុភាពកូនប្រសាស្រីរបស់អ្នកទៀត។ ទើបមេណ្ឌកគហបតិ បង្គាប់ទៅកូនប្រសាស្រីថា នែនាង បើដូច្នោះ នាងចូរឲ្យនូវភត្ត ដល់សេនាមានអង្គ៤ អស់ប្រាំមួយខែចុះ។ លំដាប់នោះ កូនប្រសាស្រីរបស់មេណ្ឌកគហបតិ ចូលទៅអង្គុយជិតកញ្ជើមួយ មានចំណុះ៤ទោណ ហើយឲ្យនូវភត្ត ដល់សេនាមានអង្គ៤ អស់ប្រាំមួយខែ។ កូនប្រសាស្រីរបស់សេដ្ឋីនោះ មិនទាន់ក្រោកឡើងដរាបណា ភត្តនោះ ក៏មិនចេះអស់ទៅដរាបនោះ។ មហាមាត្យនិយាយថា ម្នាលគហបតិ ឥទ្ធានុភាពកូនប្រសាស្រីរបស់អ្នក យើងបានឃើញហើយ យើងចង់ឃើញឥទ្ធានុភាពខ្ញុំប្រុសរបស់អ្នកទៀត។ មេណ្ឌកគហបតិនិយាយតបថា បពិត្រអ្នកជាម្ចាស់ ឯឥទ្ធានុភាពខ្ញុំប្រុសរបស់ខ្ញុំ អ្នកត្រូវឃើញក្នុងស្រែ (ឯណោះ)។ មហាមាត្យក៏និយាយថា ម្នាលគហបតិ ណ្ហើយចុះ ឯឥទ្ធានុភាពខ្ញុំប្រុសរបស់អ្នក (ទុកដូចជា) យើងបានឃើញហើយដែរ។ លំដាប់នោះ មហាមាត្យនោះ ត្រឡប់មកកាន់ក្រុងរាជគ្រឹះវិញ ព្រមដោយសេនាមានអង្គ៤ ចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ទើបក្រាបទូលដំណើរនុ៎ះ ដល់ព្រះបាទមាគធសេនិយពិម្ពិសារ (ដោយសព្វគ្រប់)។

## ១៨១. បញ្ចគោរសាទិអនុជានានា

CS vin.mv.06.22 | ភាគ ទី៧

**(១៨១)**

[១៣២] គ្រានោះឯង ព្រះដ៏មានព្រះភាគ គង់ក្នុងក្រុងវេសាលី គួរតាមព្រះអធ្យាស្រ័យហើយ ទ្រង់ចៀសចេញទៅកាន់ចារិក ក្នុងក្រុងភទ្ទិយៈ ជាមួយនឹងភិក្ខុសង្ឃជាច្រើន គឺភិក្ខុ១២៥០រូប។ ក្នុងកាលនោះ កាលព្រះមានព្រះភាគ ត្រាច់ទៅកាន់ចារិក ដោយលំដាប់ ក៏យាងតម្រង់ទៅកាន់ក្រុងភទ្ទិយៈនោះ។ បានឮថា ព្រះមានព្រះភាគ គង់ក្នុងព្រៃម្លិះ ទៀបក្រុងភទ្ទិយៈនោះ។ មេណ្ឌកគហបតិ បានឮច្បាស់ (នូវដំណឹងនោះហើយ ទើបប្រកាសសេចក្តីនោះថា) ម្នាលគ្នាយើង បានឮថា ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវស្តេចមកដល់ក្រុងភទ្ទិយៈ ដោយលំដាប់ ហើយគង់ក្នុងព្រៃម្លិះ ទៀបក្រុងភទ្ទិយៈ ក៏កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយសុះសាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ គឺ សេចក្តីចេះដឹង និងកិរិយា ដែលបុគ្គលគប្បីប្រព្រឹត្ត ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អទៅកាន់ព្រះនិព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ថា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ចំពោះព្រះអង្គហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ឲ្យបានត្រាស់ដឹងផង ព្រះអង្គទ្រង់សំដែងធម៌ ពីរោះបទដើម ពីរោះបទកណ្តាល និងពីរោះបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ បរិសុទ្ធអស់ជើង ក៏ដំណើរដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះ ជាការប្រពៃពេក។ លំដាប់នោះ មេណ្ឌកគហបតិ ឲ្យមនុស្សទឹមយានដ៏ល្អៗ ឡើងជិះយានដ៏ល្អៗ មានយានដ៏ល្អៗ បរចេញទៅពីក្រុងភទ្ទិយៈ ដើម្បីគាល់ព្រះមានព្រះភាគ។ ពួកតិរ្ថិយជាច្រើនរូប បានឃើញមេណ្ឌកគហបតិ កំពុងមកពីចម្ងាយ លុះឃើញហើយ បាននិយាយពាក្យនេះនឹងមេណ្ឌកគហបតិថា នែគហបតិ អ្នកទៅណា។ មេណ្ឌកគហបតិនិយាយថា បពិត្រលោកដ៏ចំរើន ខ្ញុំទៅគាល់ព្រះសមណគោតម។ ពួកតិរ្ថិយនិយាយថា នែគហបតិ អ្នកឯងជាកិរិយវាទ (អ្នកពោលពាក្យថា ត្រូវធ្វើកិច្ចការ) នឹងចូលទៅគាល់សមណគោតម ជាអកិរិយវាទ (អ្នកពោលពាក្យឃាត់កិច្ចថា ថាមិនត្រូវធ្វើ) ដូចម្តេចបាន គហបតិ ព្រោះសមណគោតម ជាអកិរិយវាទ សំដែងធម៌តាមបែបអកិរិយវាទ ម្យ៉ាងទៀត សមណគោតមនោះ ទូន្មានពួកសាវក តាមបែបអកិរិយវាទនោះដែរ។ លំដាប់នោះឯង មេណ្ឌកគហបតិ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគនោះ ច្បាស់ជាអរហំសម្មាសម្ពុទ្ធឥតសង្ស័យឡើយ ពួកតិរ្ថិយទាំងនេះ ឈ្នានីសជាប្រាកដ ភូមិប្រទេសនៃយានមានត្រឹមណា ក៏ទៅដោយយានត្រឹមនោះ ហើយចុះចាកយាន ដើរទៅដោយជើងទទេ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏

ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ ព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា ដល់មេណ្ឌកគហបតិ ដែលអង្គុយនៅក្នុងទីសមគួរ អនុបុព្វីកថានោះ ដូចម្តេចខ្លះ (ឯអនុបុព្វីកថានោះ) គឺ ព្រះមានព្រះភាគ ទ្រង់ប្រកាសទានកថា (សំដែងអំពីការធ្វើទាន) សីលកថា (សំដែងអំពីការរក្សាសីល) សគ្គកថា (សំដែងអំពីស្ថានសួគ៌) ទោសរបស់កាមទាំងឡាយ ដ៏ថោកទាប ដ៏សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម។ កាលណាបើព្រះដ៏មានព្រះភាគបានជ្រាបថា មេណ្ឌកគហបតិ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយឡើង មានចិត្តជ្រះថ្លាហើយ ទើបព្រះអង្គ ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង គឺទុក្ខ សមុទយ និរោធ មគ្គ ក្នុងកាលនោះ។ ធម្មតា សំពត់ស្អាត ប្រាសចាកមន្ទិលខ្មៅ គួរទទួលទឹកជ្រលក់ដោយស្រួលបាន យ៉ាងណាមិញ មេណ្ឌកគហបតិ កើតធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល លើអាសនៈនោះឯង (ហើយពិចារណាឃើញ) ដូច្នេះថា របស់ណាមួយ ដែលមានសេចក្តីកើតឡើងជាធម្មតា របស់អស់នោះ ក៏មានសេចក្តីរលត់ទៅជាធម្មតា ក៏មានឧបមេយ្យដូច្នោះដែរ។ វេលាដែលមេណ្ឌកគហបតិ បានឃើញធម៌ សម្រេចធម៌ ដឹងធម៌ជាក់ច្បាស់ យាងចុះមុតមាំក្នុងធម៌ហើយ ឆ្លងផុតចាកសេចក្តីស្នាក់ស្ទើរ ប្រាសចាកសេចក្តីសង្ស័យ ដល់នូវសេចក្តីក្លៀវក្លា មិនជឿអ្នកដទៃ ក្នុងសាសនានៃព្រះសាស្តា បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបន្ទូលរបស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះបន្ទូលរបស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ដូចជាបុគ្គលផ្ងាររបស់ ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬប្រាប់ផ្លូវដល់អ្នកវង្វេង ឬទ្រោលប្រទីបប្រេង ក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានភ្នែក (ភ្លឺ) នឹងបានឃើញរូបទាំងឡាយ មានឧបមាយ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគ ប្រកាសហើយដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ភិក្ខុសង្ឃផងថា ជាទីរលឹក សូមព្រះដ៏មានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់ព្រះរតនត្រ័យ ជាទីរលឹកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើម បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ជាមួយនឹងព្រះភិក្ខុសង្ឃ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព (ការស្ងៀម)។ លំដាប់នោះ មេណ្ឌកគហបតិ ដឹងច្បាស់ថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ លំដាប់នោះ លុះកន្លងរាត្រីនោះទៅ មេណ្ឌកគហបតិ ក៏ឲ្យមនុស្សចាត់ចែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ហើយឲ្យអ្នកបម្រើទៅក្រាបបង្គំទូលកាលគួរ ដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាល (នេះ) ជាកាលគួរហើយ ភត្តសម្រេចហើយ។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ហើយទ្រង់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ យាងចូលទៅកាន់លំនៅរបស់មេណ្ឌកគហបតិ លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលទុកហើយ ជាមួយនឹងភិក្ខុសង្ឃ។ វេលានោះ ប្រពន្ធ កូនប្រុស កូនប្រសាស្រី និងខ្ញុំប្រុសរបស់មេណ្ឌកគហបតិ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ ព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា ដល់ជនទាំងនោះ អនុបុព្វីកថានោះ ដូចម្តេច ឯអនុបុព្វីកថានោះ គឺ ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយ ដ៏ថោកទាប ដ៏សៅហ្មង និងអានិសង្ស ក្នុងការចេញចាកកាម។ កាលណាបើព្រះដ៏មានព្រះភាគ បានជ្រាបថា ជនទាំងអស់នោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយឡើង និងមានចិត្តជ្រះថ្លាហើយ ក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង គឺទុក្ខ ហេតុឲ្យកើតទុក្ខ សេចក្តីរំលត់ទុក្ខ និងបដិបទា ជាផ្លូវទៅកាន់ទីរំលត់ទុក្ខ ក្នុងកាលនោះ។ សំពត់ស្អាត ប្រាសចាកមន្ទិលខ្មៅ គួរទទួលទឹកជ្រលក់ដោយស្រួលបាន យ៉ាងណាមិញ ពួកជនទាំងនោះ កើតធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល លើអាសនៈនោះឯង (ហើយពិចារណាឃើញ) ដូច្នេះថា របស់ណាមួយ ដែលមានកិរិយាកើតឡើងជាធម្មតា របស់អស់នោះ ក៏មានសេចក្តីរលត់ទៅជាធម្មតា ក៏មានឧបមេយ្យដូច្នោះឯង ជនទាំងនោះ បានឃើញធម៌ បានលុះធម៌ បានដឹងធម៌ច្បាស់ ឈមចុះមុតមាំក្នុងធម៌ហើយ ឆ្លងផុតចាកសេចក្តីស្នាក់ស្ទើរ ប្រាសចាកសេចក្តីសង្ស័យ ដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនាព្រះសាស្តា ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបន្ទូលរបស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះបន្ទូលរបស់ព្រះអង្គពីរោះណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន ដូចជាបុគ្គលផ្ងាររបស់ ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវ ឬទ្រោលប្រទីបប្រេងបំភ្លឺ ក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានចក្ខុ នឹងឃើញរូបទាំងឡាយបាន មានឧបមាយ៉ាងណាមិញ ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសហើយ ដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយនេះ សូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផងថា ជាទីរលឹក សូមព្រះដ៏មានព្រះភាគ ចាំទុកនូវយើងខ្ញុំទាំងឡាយថាជាឧបាសក ដល់នូវព្រះរតនត្រ័យ ថាជាទីរលឹកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើម។ វេលានោះ មេណ្ឌកគហបតិ បានអង្គាសខាទនីយភោជនីយាហារ (បង្អែម ចំអាប) ដ៏ឆ្ងាញ់ពីសា ដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ។ លុះមេណ្ឌកគហបតិ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ គង់ក្នុងក្រុងភទ្ទិយៈដរាបណា ខ្ញុំព្រះអង្គនឹងផ្គត់ផ្គង់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តដែលត្រូវថ្វាយជានិច្ចដរាបនោះ។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យមេណ្ឌកគហបតិយល់តាម ឲ្យប្រតិបត្តិតាម ឲ្យអាហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ ចៀសចេញទៅ។

[១៣៣] គ្រានោះ ព្រះមានព្រះភាគ គង់នៅក្រុងភទ្ទិយៈ គួរតាមពុទ្ធអធ្យាស្រ័យ ហើយទ្រង់មិនលាមេណ្ឌកគហបតិ ក៏យាងទៅកាន់ចារិក ក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន១២៥០រូប។ មេណ្ឌកគហបតិ បានឮថា ព្រះដ៏មានព្រះភាគ យាងចេញទៅកាន់ចារិក ក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន១២៥០រូប។ ទើបមេណ្ឌកគហបតិបង្គាប់ពួកខ្ញុំប្រុស និងពួកអ្នកធ្វើការងារថា ម្នាលអ្នកទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយផ្ទុកអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ឲ្យច្រើនក្នុងរទេះទាំងឡាយមក ម្យ៉ាងទៀត នាយគោបាល១២៥០នាក់ ចូរនាំមេគោ១២៥០មក (បើ) យើងជួបនឹងព្រះដ៏មានព្រះភាគក្នុងទីណា យើងនឹងនិមន្តព្រះដ៏មានព្រះភាគ ឲ្យឆាន់ទឹកដោះស្រស់ រូតថ្មីៗ ក្នុងទីនោះ។ មេណ្ឌកគហបតិ ក៏បានផ្គត់ផ្គង់ព្រះដ៏មានព្រះភាគក្នុងទីកន្តារ[91] ពាក់កណ្តាលផ្លូវ។ លំដាប់នោះ មេណ្ឌកគហបតិ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចឈរក្នុងទីសមគួរ។ លុះមេណ្ឌកគហបតិ ឈរក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ជាមួយនឹងភិក្ខុសង្ឃ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព។ ឯមេណ្ឌកគហបតិ ដឹងច្បាស់ថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ លុះកន្លងរាត្រីនោះទៅ ទើប

មេណ្ឌកគហបតិ ឲ្យមនុស្សតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ហើយ ក៏ឲ្យក្រាបបង្គំទូលកាលគួរ ដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាល(នេះ) ជាកាលគួរហើយ ភត្តសម្រេចហើយ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ហើយទ្រង់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ក៏ទ្រង់យាងទៅកាន់ទីអង្គាសរបស់មេណ្ឌកគហបតិ លុះយាងទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ជាមួយនឹងភិក្ខុសង្ឃ។ ទើបមេណ្ឌកគហបតិ បង្គាប់ពួកអ្នកឃ្វាលគោ១២៥០នាក់ថា ម្នាលអ្នកទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយ យកមេគោមួយៗ មកបំរុងទុក ដើម្បីរូតយកទឹកដោះស្រស់ថ្មីៗ ហើយយើងនឹងប្រគេនភិក្ខុមួយអង្គៗឆាន់។ ទើបមេណ្ឌកគហបតិអង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ និងទឹកដោះស្រស់ដែលរូតថ្មីៗ ដោយដៃខ្លួនឯង។ ភិក្ខុទាំងឡាយមានសេចក្តីរង្កៀស មិនហ៊ានទទួលទឹកដោះស្រស់។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទទួលឆាន់ចុះ។ លំដាប់នោះឯងមេណ្ឌកគហបតិ អង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ និងទឹកដោះស្រស់ដែលរូតថ្មីៗ ដោយដៃខ្លួន លុះព្រះដ៏មានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្ថទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ។ លុះមេណ្ឌកគហបតិ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន គង់មានផ្លូវកន្តារទាំងឡាយ ដែលមានទឹកតិច មានភក្សាហារតិច ដែលអ្នកគ្មានស្បៀង មិនអាចនឹងទៅបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះដ៏មានព្រះភាគ អនុញ្ញាតស្បៀង ដល់ភិក្ខុទាំងឡាយ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ឲ្យមេណ្ឌកគហបតិយល់តាម ឲ្យប្រតិបត្តិតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ ចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគោរស៥ គឺទឹកដោះស្រស់១ ទឹកដោះជូរ១ ខ្លាញ់១ ទឹកដោះខាប់១ ទឹកដោះថ្លា១។ ម្នាលភិក្ខុទាំងឡាយ មានផ្លូវកន្តារ ដែលមានទឹកតិច មានភក្សាហារតិច ដែលអ្នកគ្មានស្បៀង មិនអាចនឹងទៅបាន។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុស្វែងរកស្បៀងបាន គឺភិក្ខុត្រូវការអង្ករ ស្វែងរកអង្ករបាន ត្រូវការសណ្តែកបាយ ស្វែងរកសណ្តែកបាយបាន ត្រូវការសណ្តែករាជមាស ស្វែងរកសណ្តែករាជមាសបាន ត្រូវការអំបិល ស្វែងរកអំបិលបាន ត្រូវការស្ករអំពៅ ស្វែងរកស្ករអំពៅបាន ត្រូវការប្រេង ស្វែងរកប្រេងបាន ត្រូវការទឹកដោះថ្លា ស្វែងរកទឹកដោះថ្លាបាន។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយ មានសទ្ធាជ្រះថ្លា មនុស្សទាំងនោះទុកដាក់មាស និងប្រាក់ក្នុងដៃកប្បិយការកៈទាំងឡាយ ដោយពាក្យថា របស់ណាគួរដល់លោកម្ចាស់ ចូរអ្នកទាំងឡាយ ប្រគេនរបស់នោះ ដោយមាស និងប្រាក់នេះចុះ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុត្រេកអរ ចំពោះវត្ថុជាកប្បិយៈ (ដែលកើត) អំពីមាស និងប្រាក់នោះបាន ម្នាលភិក្ខុទាំងឡាយ តែតថាគតមិនពោលថា ត្រូវអ្នកត្រេកអរ ត្រូវអ្នកស្វែងរកមាសនិងប្រាក់ដូច្នេះ ដោយបរិយាយនីមួយឡើយ។

## ១៨២. កេណិយជដិលវត្ថុ

CS vin.mv.06.23 | ភាគ ទី៧

**(១៨២)**

[១៣៤] លំដាប់នោះ កាលព្រះមានព្រះភាគ កាលទ្រង់ត្រាច់ទៅកាន់ចារិកដោយលំដាប់ បានយាងទៅដល់អាបណនិគម។ ជដិលឈ្មោះកេណិយៈ បានឮដំណឹងថា នែគ្នាយើង ឮថា ព្រះសមណគោតម ជាសក្យបុត្រ (ចេញ) ចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវមកដល់អាបណនិគមដោយលំដាប់ ក៏កិត្តិសព្ទពីរោះរបស់ព្រះគោតមដ៏ចំរើននោះឯង ឮខ្ចរខ្ចាយសុះសាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ ដោយប្រពៃ ចំពោះព្រះអង្គ ថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់ព្រះនិព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ថា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ចំពោះព្រះអង្គ ហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ញុំាងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ឲ្យបានត្រាស់ដឹងផង ព្រះអង្គទ្រង់សំដែងធម៌ ពីរោះបទដើម ពីរោះបទកណ្តាល និងពីរោះបទចុង ទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈដ៏ពេញបរិបូណ៌ ដ៏បរិសុទ្ធអស់ជើង ក៏ដំណើរដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះ ជាការប្រពៃពេក។ លំដាប់នោះ កេណិយជដិល មានសេចក្តីត្រិះរិះដូច្នេះថា គួរអញឲ្យគេនាំយករបស់អ្វីហ្ន៎ ទៅថ្វាយព្រះសមណគោតម។ ទើបកេណិយជដិល មានសេចក្តីត្រិះរិះដូច្នេះថា ឫសីទាំងឡាយណា ដែលជាបុព្វបុរសរបស់ព្រាហ្មណ៍ទាំងឡាយ ដែលជាអ្នកកសាងមន្ត ជាអ្នករាយមន្ត បទមន្តបុរាណនេះ ដែលពួកឫសីណា បានច្រៀងមកហើយ បានរាយមកហើយ បានសន្សំមកច្រើនហើយ ឥឡូវនេះ ព្រាហ្មណ៍ទាំងឡាយ តែងស្វាធ្យាយតាមបទមន្តនោះ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំងឡាយនោះពោលហើយ តែងបង្រៀនតាមបទមន្ត ដែលឫសីទាំងឡាយនោះបង្រៀនមកហើយ ដូចជាព្រាហ្មណ៍ ឈ្មោះអដ្ឋកៈ ព្រាហ្មណ៍ឈ្មោះវាមកៈ ព្រាហ្មណ៍ឈ្មោះវាមទេវៈ ព្រាហ្មណ៍ឈ្មោះវេស្សាមិត្តៈ ព្រាហ្មណ៍ឈ្មោះយមតគ្គិ ព្រាហ្មណ៍ឈ្មោះអង្គិរសៈ ព្រាហ្មណ៍ឈ្មោះភារទ្វាជៈ ព្រាហ្មណ៍ឈ្មោះវាសេដ្ឋៈ ព្រាហ្មណ៍ឈ្មោះកស្សបៈ ព្រាហ្មណ៍ឈ្មោះភគុ ពួកព្រាហ្មណ៍ទាំងនោះ ជាអ្នកវៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល (រាប់ពីពេលថ្ងៃត្រង់ទៅដល់អរុណរះ) ត្រេកអរនឹងទឹកបានទាំងឡាយ មានសភាពយ៉ាងនេះ សូម្បីព្រះសមណគោតម ក៏ជាអ្នកវៀរចាកការបរិភោគក្នុងរាត្រី វៀរចាកវិកាលភោជន ព្រះសមណគោតម ក៏គួរត្រេកអរនឹងទឹកបានទាំងឡាយ មានសភាពយ៉ាងនេះដែរហើយ ក៏ឲ្យគេតាក់តែងទឹកបានជាច្រើន ឲ្យរែកទៅដោយម្រែកទាំងឡាយ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះដ៏មានព្រះភាគ ហើយពោលនូវពាក្យរាក់ទាក់ រីករាយ សំណេះសំណាលគួររលឹករួចហើយ ក៏បានឈរនៅក្នុងទីគួរមួយ។ លុះកេណិយជដិល ឈរនៅក្នុងទីគួរមួយហើយ បានទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា សូមព្រះគោតមដ៏ចំរើនទទួលទឹកបានរបស់ខ្ញុំព្រះអង្គ។ ព្រះមានព្រះភាគមានព្រះបន្ទូលថា នែកេណិយៈ បើដូច្នោះ អ្នកឯងចូរប្រគេនដល់ភិក្ខុទាំងឡាយចុះ។ ភិក្ខុទាំងឡាយរង្កៀស មិនហ៊ានទទួល។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយទទួលឆាន់ចុះ។ គ្រានោះ កេណិយជដិល ក៏បានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយទឹកបានទាំងឡាយដ៏ច្រើន ដោយដៃខ្លួនឯង កាលដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់លាងព្រះហស្ថហើយ លែងលូកព្រះហស្ថទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីគួរមួយ។ លុះកេណិយជដិលអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ពន្យល់ឲ្យ

ឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ ឯកេណិយជដិល កាលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគដូច្នេះថា សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ព្រះដ៏មានព្រះភាគ មានព្រះបន្ទូលថា នែកេណិយៈ ភិក្ខុសង្ឃច្រើនណាស់ ចំនួន ១២៥០អង្គ អ្នកសោត ក៏ជ្រះថ្លាខ្លាំងក្នុងព្រាហ្មណ៌ទាំងឡាយហើយ។ កេណិយជដិល បានក្រាបទូលពាក្យនេះ នឹងព្រះមានព្រះភាគ អស់វារៈជាគំរប់ពីរដងផងថា បពិត្រព្រះគោតមដ៏ចំរើន ទុកជាភិក្ខុសង្ឃច្រើន ចំនួន១២៥០អង្គក្តី ទុកជាខ្ញុំព្រះអង្គជ្រះថ្លាខ្លាំងក្នុងព្រាហ្មណ៌ទាំងឡាយក្តី ក៏សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែកេណិយៈ ភិក្ខុសង្ឃច្រើនណាស់ ចំនួន១២៥០អង្គ អ្នកឯងសោត ក៏ជ្រះថ្លាខ្លាំងក្នុងព្រាហ្មណ៌ទាំងឡាយហើយ។ កេណិយជដិល បានទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគ អស់វារៈជាគំរប់បីដងផងថា បពិត្រព្រះគោតមដ៏ចំរើន ទុកជាភិក្ខុសង្ឃច្រើន ចំនួន១២៥០អង្គក្តី ទុកជាខ្ញុំព្រះអង្គជ្រះថ្លាខ្លាំងក្នុងព្រាហ្មណ៌ទាំងឡាយក្តី ក៏សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព។ លំដាប់នោះ កេណិយជដិលដឹងច្បាស់ថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកបានទាំងឡាយ៨យ៉ាង គឺ ទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកឥតគ្រាប់ ទឹកផ្លែស្រគំ ទឹកផ្លែចន្ទន៍ ទឹកក្រអៅឈូក ទឹកផ្លែមាក់ប្រាំង។[92] ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកផ្លែឈើគ្រប់យ៉ាង លើកលែងតែផ្លៃស្រូវ។[93] ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកស្លឹកឈើគ្រប់យ៉ាង លើកលែងតែទឹកបន្លែដែលឆ្អិនហើយ[94] ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកផ្កាឈើគ្រប់យ៉ាង លើកលែងតែទឹកផ្កាស្រគំ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកអំពៅ។ លុះកន្លងរាត្រីនោះទៅ កេណិយជដិល ឲ្យគេតាក់តែងខាទនីយភោជនីយាហារដ៏ថ្លៃថ្លា ក្នុងអាស្រមខ្លួន ហើយឲ្យក្រាបបង្គំទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កាលនេះជាកាលគួរ ភត្តសម្រេចហើយ។ វេលានោះ ក្នុងបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរ យាងចូលទៅកាន់អាស្រមរបស់កេណិយជដិល លុះយាងចូលទៅហើយ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ជាមួយនឹងភិក្ខុសង្ឃ។ លំដាប់នោះឯង កេណិយជដិល បានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ថ្លៃថ្លា ដោយដៃខ្លួនឯង កាលដឹងថាព្រះដ៏មានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ។ លុះកេណិយជដិលអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់អនុមោទនា ដោយគាថាទាំងឡាយនេះថា។

[១៣៥]

> យញ្ញៈទាំងឡាយ មានការបូជាភ្លើង ជាប្រធាន សាវិត្តិឆន្ទ ជាប្រធានរបស់ឆន្ទសាស្ត្រ ស្តេច ជាប្រធានរបស់មនុស្សទាំងឡាយ សាគរ ជាប្រធានរបស់ស្ទឹងទាំងឡាយ ព្រះចន្ទ ជាប្រធាននៃនក្ខត្តឫក្សទាំងឡាយ ព្រះអាទិត្យ ជាប្រធាននៃពន្លឺទាំងឡាយ ព្រះសង្ឃប៉ុណ្ណោះ ជាប្រធានរបស់មនុស្សទាំងឡាយ ដែលប្រាថ្នានូវបុណ្យ ហើយបូជា។

គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់អនុមោទនា ដោយគាថាទាំងឡាយនេះ ចំពោះកេណិយជដិលហើយ ក៏ទ្រង់ក្រោកចាកអាសនៈ ចៀសចេញទៅ។

## ១៨៣. រោជមល្លវត្ថុ

CS vin.mv.06.24 | ភាគ ទី៧

**(១៨៣)**

[១៣៦] គ្រានោះឯង ព្រះដ៏មានព្រះភាគ គង់ក្នុងអាបណនិគម ដោយគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់យាងទៅកាន់ចារិក ក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន១២៥០រូប។ ពួកស្តេចមល្លទាំងឡាយ នៅក្នុងក្រុងកុសិនារា បានឮដំណឹងថា ព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃដ៏ច្រើន ចំនួន១២៥០រូប យាងមកកាន់ក្រុងកុសិនារា។ ពួកមល្លក្សត្រិទាំងនោះ បានធ្វើការប្តេជ្ញាគ្នាថា អ្នកណាមិនធ្វើការក្រោកទទួលព្រះមានព្រះភាគ អ្នកនោះត្រូវពិន័យជាទ្រព្យ៥០០កហាបណៈ (មិនខាន)។ ក៏សម័យនោះឯង មល្លក្សត្រឈ្មោះរោជៈ ជាសំឡាញ់ព្រះអានន្ទដ៏មានអាយុ។ លំដាប់នោះឯង ព្រះមានព្រះភាគ កាលត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏បានយាងទៅដល់ក្រុងកុសិនារានោះ។ ពួកមល្លក្សត្រនៅក្នុងក្រុងកុសិនារា បានធ្វើការក្រោកទទួលព្រះដ៏មានព្រះភាគ។ លំដាប់នោះឯង រោជមល្លក្សត្រ ក៏ធ្វើការក្រោកទទួលព្រះដ៏មានព្រះភាគដែរ ហើយចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយក៏ឈរក្នុងទីសមគួរ។ ព្រះអានន្ទដ៏មានអាយុ បាននិយាយពាក្យនេះ នឹងរោជមល្លក្សត្រ ដែលឈរក្នុងទីសមគួរដូច្នេះថា នែរោជៈដ៏មានអាយុ អ្នកបានធ្វើការក្រោកទទួលណា ចំពោះព្រះមានព្រះភាគ ការក្រោកទទួលនេះ ជាការប្រពៃរបស់អ្នកហើយ។ រោជមល្លក្សត្រនិយាយថា បពិត្រព្រះអានន្ទដ៏ចំរើន ខ្ញុំមិនមែនធ្វើ (សេចក្តីគោរព) ច្រើន ព្រោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃទេ ប៉ុន្តែពួកញាតិ បានធ្វើការប្តេជ្ញាថា អ្នកណាមិនធ្វើការក្រោកទទួលព្រះមានព្រះភាគ អ្នកនោះនឹងត្រូវពិន័យជាទ្រព្យ៥០០កហាបណៈមិនខាន បពិត្រព្រះអានន្ទដ៏ចំរើន ខ្ញុំបានធ្វើការក្រោកទទួលព្រះមានព្រះភាគយ៉ាងនេះ ព្រោះខ្លាចពិន័យរបស់ពួកញាតិទេ។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ មានសេចក្តីអាក់អន់ចិត្តថា រោជមល្លក្សត្រ មិនសមបើនឹងហ៊ាននិយាយយ៉ាងនេះសោះ។ វេលានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន រោជមល្លក្សត្រនេះ ជាអ្នកល្បីល្បាញ ជាមនុស្សមានគេស្គាល់ (ច្រើន) មានឫទ្ធិច្រើន ពួកមនុស្សដែលមានគេស្គាល់ច្រើន មានសភាពយ៉ាងនេះ រមែងមានសេចក្តីជ្រះថ្លាក្នុងធម្មវិន័យនេះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមឱកាស រោជមល្លក្សត្រ គប្បីជ្រះថ្លាក្នុងធម្មវិន័យនេះយ៉ាងណា សូមព្រះមានព្រះភាគ ទ្រង់ធ្វើយ៉ាងនោះ។ ព្រះដ៏មានព្រះភាគ មានព្រះបន្ទូលថា នែអានន្ទ រោជមល្លក្សត្រគប្បីជ្រះថ្លា ក្នុងធម្មវិន័យនេះ ដោយហេតុណា ហេតុនោះ តថាគត

មិនលំបាកឆ្ងៃទេ។ ទើបព្រះដ៏មានព្រះភាគ មានព្រះទ័យប្រកបដោយមេត្តា ផ្សាយទៅកាន់រោជមល្លក្សត្រ ហើយទ្រង់ក្រោកចាកអាសនៈ យាងចូលទៅកាន់វិហារ។ ឯរោជមល្លក្សត្រ កាលបើព្រះដ៏មានព្រះភាគ មានព្រះទ័យមេត្តា ផ្សាយមកប៉ះពាល់ហើយ ក៏ចូលទៅគ្រប់វិហារ គ្រប់បរិវេណ ដូចជាមេគោមានកូនខ្ចីដូច្នោះឯង ហើយក៏សួរពួកភិក្ខុថា លោកដ៏ចំរើន ឥឡូវនេះព្រះដ៏មានព្រះភាគ ជាអរហំ សម្មាសម្ពុទ្ធ ព្រះអង្គគង់ក្នុងទីណា ដ្បិតយើងខ្ញុំចង់ឃើញព្រះដ៏មានព្រះភាគ ជាអរហំ សម្មាសម្ពុទ្ធអង្គនោះ។ ពួកភិក្ខុប្រាប់ថា នែអាវុសោរោជៈ (ព្រះដ៏មានព្រះភាគ ទ្រង់គង់) ក្នុងវិហារដែលគេបិទទ្វារនុ៎ះ ដូច្នោះ ចូរអ្នកមានសំឡេងតិចចូលទៅជិត កុំរួសរាន់ ចូលទៅកាន់របៀង ក្អកគ្រហែម ហើយសឹមគោះសន្ទះទ្វារ ព្រះដ៏មានព្រះភាគនឹងបើទ្វារឲ្យអ្នក។ វេលានោះ រោជមល្លក្សត្រ ចូលទៅកាន់វិហារ ដែលគេបិទនោះ ដោយស្ងប់ស្ងាត់សម្លេងសន្សឹមៗ ដើរចូលទៅកាន់របៀង ក្អកគ្រហែម ហើយគោះសន្ទះទ្វារ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់បើកទ្វារឲ្យ។ គ្រានោះ រោជមល្លក្សត្រ ចូលទៅកាន់វិហារ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ។ លុះរោជមល្លក្សត្រ អង្គុយនៅក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា អនុបុព្វីកថានោះ តើដូចម្តេច (ឯអនុបុព្វីកថានោះ) គឺព្រះមានព្រះភាគ ទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយដ៏លាមកអាក្រក់ និងអានិសង្ស ក្នុងការចេញចាកកាម។ កាលណាបើព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា រោជមល្លក្សត្រ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តរីករាយ មានចិត្តជ្រះថ្លាហើយ ព្រះអង្គ ក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែង ដោយព្រះអង្គឯង គឺទុក្ខ ហេតុឲ្យកើតទុក្ខ ធម៌ជាគ្រឿងរំលត់ទុក្ខ និងសេចក្តីប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ ក្នុងកាលនោះ។ ធម្មតា សំពត់ស្អាត ប្រាសចាកមន្ទិលខ្មៅ គួរទទួលទឹកជ្រលក់ ដោយស្រួលបាន យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់រោជមល្លក្សត្រ លើអាសនៈនោះឯង (ហើយពិចារណាឃើញ) ថា របស់ណាមួយ មានសេចក្តីកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានសេចក្តីរលត់ទៅ ជាធម្មតា ដូច្នោះឯង។ លំដាប់នោះ រោជមល្លក្សត្រ បានឃើញធម៌ បានលុះធម៌ បានដឹងធម៌ច្បាស់ ឈមចុះមុតមាំក្នុងធម៌ហើយ ឆ្លងផុតចាកសេចក្តីស្នាក់ស្ទើរ ប្រាសចាកសេចក្តីសង្ស័យ ដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនា នៃព្រះសាស្តា ហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ សូមឱកាស លោកម្ចាស់ទាំងឡាយ គួរទទួលចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ គឺថ្នាំ ជាបច្ច័យ ដល់មនុស្សមានជម្ងឺ របស់ខ្ញុំព្រះអង្គតែម្យ៉ាង កុំទទួលរបស់ពួកបុគ្គលដទៃ។ ព្រះមានព្រះភាគ មានព្រះបន្ទូលថា នែរោជៈ ពួកជនណាមួយ ឃើញធម៌ ដោយញាណជាសេក្ខៈ ដោយទស្សនៈ ជាសេក្ខៈ ដូចជាធម៌ ដែលអ្នកបានឃើញហើយ ជនទាំងនោះ តែងមានគំនិតយ៉ាងនេះថា ឱហ្ន៎ លោកម្ចាស់ទាំងឡាយ គប្បីទទួលចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ គឺថ្នាំ ជាបច្ច័យ ដល់អ្នកមានជម្ងឺ របស់យើងទាំងឡាយតែម្យ៉ាង កុំទទួលរបស់ជនទាំងឡាយដទៃឡើយ នែរោជៈ បើដូច្នោះ ភិក្ខុទាំងឡាយ នឹងទទួលរបស់អ្នកខ្លះ របស់ពួកជនឯទៀតខ្លះ។ ក៏សម័យនោះឯង ក្នុងក្រុងកុសិនារា ពួកជនបានតាក់តែងលំដាប់ភត្តដ៏ឧត្តម។ គ្រានោះឯង រោជមល្លក្សត្រ កាលមិនបានលំដាប់ភត្ត (ដាក់វេនភត្ត) ក៏មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអញត្រួតមើលរោងភត្ត វត្ថុណាមិនមានក្នុងរោងភត្ត គួរអញតាក់តែងវត្ថុនោះ។ កាលរោជមល្លក្សត្រ ត្រួតមើលរោងភត្ត មិនបានឃើញវត្ថុពីរយ៉ាង គឺអន្លក់១ ខាទនីយៈធ្វើដោយម្សៅ១។ លំដាប់នោះ រោជមល្លក្សត្រ បានចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងព្រះអានន្ទដ៏មានអាយុថា បពិត្រព្រះអានន្ទដ៏ចំរើន កាលខ្ញុំមិនបានលំដាប់ភត្ត ក្នុងក្រុងកុសិនារានេះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអាត្មាអញ ត្រួតមើលរោងភត្ត វត្ថុណាគ្មានក្នុងរោងភត្ត គួរអាត្មាអញ តាក់តែងវត្ថុនោះឡើង បពិត្រព្រះអានន្ទដ៏ចំរើន កាលខ្ញុំនោះ ត្រួតមើលរោងភត្ត មិនបានឃើញវត្ថុពីរមុខ គឺអន្លក់១ ខាទនីយៈធ្វើដោយម្សៅ១ បពិត្រព្រះអានន្ទដ៏ចំរើន បើខ្ញុំនឹងតាក់តែងអន្លក់ផង ខាទនីយៈធ្វើដោយម្សៅផង តើព្រះមានព្រះភាគ នឹងទទួលរបស់ខ្ញុំឬទេ។ ព្រះអានន្ទតបថា នែរោជៈ បើដូច្នោះ ចាំអាត្មានឹងយកសេចក្តី ក្រាបបង្គំទូលព្រះដ៏មានព្រះភាគសិន។ ទើបព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់មានបន្ទូលថា នែអានន្ទ បើដូច្នោះ ចូរឲ្យរោជមល្លក្សត្រតាក់តែងចុះ។ ព្រះអានន្ទដ៏មានអាយុ ប្រាប់ថា នែរោជៈ បើដូច្នោះ ចូរអ្នកតាក់តែងចុះ។ លុះកន្លងរាត្រីនោះទៅ ទើបរោជមល្លក្សត្រ ឲ្យគេតាក់តែងអន្លក់ និងខាទនីយៈធ្វើដោយម្សៅដ៏ច្រើន ហើយបង្អោនថ្វាយ ដល់ព្រះមានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទទួលអន្លក់ និងខាទនីយៈ ធ្វើដោយម្សៅរបស់ខ្ញុំព្រះអង្គ។ ព្រះមានព្រះភាគ ទ្រង់មានបន្ទូលថា នែរោជៈ បើដូច្នោះ ចូរអ្នកប្រគេនដល់ភិក្ខុទាំងឡាយចុះ។ ភិក្ខុទាំងឡាយ មានសេចក្តីរង្កៀស ក៏មិនហ៊ានទទួល (វត្ថុទាំងនោះ)។ ព្រះអង្គទ្រង់មានបន្ទូលថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ ទទួលឆាន់ចុះ។ ទើបរោជមល្លក្សត្រ អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយអន្លក់ និងខាទនីយៈ ធ្វើពីម្សៅ ដោយដៃខ្លួនឯង លុះព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្ត ទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ។ លុះរោជមល្លក្សត្រ អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ ឲ្យប្រតិបត្តិតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ ចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត អន្លក់គ្រប់មុខផង ខាទនីយៈធ្វើពីម្សៅគ្រប់មុខផង។

## ១៨៤. វុឌ្ឍបព្វជិតវត្ថុ

CS vin.mv.06.25 | ភាគ ទី៧

**(១៨៤)**

[១៣៧] គ្រានោះ ព្រះដ៏មានព្រះភាគគង់ក្នុងក្រុងកុសិនារា តាមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិក ក្រុងអាតុមា ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន១២៥០រូប។ ក៏សម័យនោះឯង ភិក្ខុ[95] មួយរូបធ្លាប់ធ្វើជាងកោរកាត់ បួសឯចាស់ នៅអាស្រ័យក្នុងក្រុងអាតុមា។ ទារក[96] ពីរនាក់របស់ភិក្ខុនោះមានសំឡេងពីរោះ ប្រកបដោយសេចក្តីវាងវៃ មិនខ្ជិលច្រអូស សម្រេចសិល្បៈក្នុងវិជ្ជាកោរកាត់ ក្នុងសំណាក់អាចារ្យរបស់ខ្លួន។ ភិក្ខុបួសឯចាស់នោះ បានឮដំណឹងថា ព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃជាច្រើន ចំនួន១២៥០រូប មកកាន់ក្រុងអាតុមា។ គ្រានោះឯង ភិក្ខុបួសឯចាស់នោះ បាននិយាយពាក្យនេះនឹងទារកទាំងឡាយនោះថា នែអ្នកទាំងឡាយ ឮថា ព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃជាច្រើន ចំនួន១២៥០រូប ស្តេចមកកាន់ក្រុងអាតុមា នែអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ទៅយកប្រដាប់កាំបិតកោរ ព្រមទាំងបំពង់ និងថង់ ហើយដើរទៅកាន់ផ្ទះជាលំដាប់ៗ ចូរប្រមូលអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ យើងនឹងធ្វើទឹកបានបបរ ថ្វាយដល់ព្រះដ៏មានព្រះភាគ ដែលទ្រង់ពុទ្ធដំណើរមកដល់។ ទារកទាំងនោះ ទទួលពាក្យភិក្ខុបួសឯចាស់នោះថា ករុណាលោកឪពុក ហើយក៏កាន់យកប្រដាប់កាំបិត

កោរ ដោយបំពង់ និងថង់ ដើរទៅកាន់ផ្ទះជាលំដាប់ៗ ប្រមូលអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ។ មនុស្សទាំងឡាយ ឃើញទារកទាំងនោះ មានសំឡេងពីរោះ ប្រកបដោយសេចក្តីវាងវៃ ទុកជាអ្នកណាមិនចង់ឲ្យធ្វើ (កាត់ ឬកោរ) អ្នកទាំងនោះ ក៏ឲ្យធ្វើ លុះឲ្យធ្វើហើយ ក៏ឲ្យតម្លៃជាច្រើន។ ឯទារកទាំងនោះ ប្រមូលអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ ជាច្រើន។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាច់ទៅកាន់ចារិក ដោយលំដាប់ ក៏បានដល់ទៅក្រុងអាតុមា។ បានឮថា ព្រះដ៏មានព្រះភាគ គង់ក្នុងភូសាគារ[97] ជិតក្រុងអាតុមានោះ។ លុះកន្លងរាត្រីនោះទៅ ទើបភិក្ខុបួសឯចាស់នោះ ឲ្យចាត់ចែងបបរជាច្រើន ហើយបង្អោនថ្វាយចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទទួលបបររបស់ខ្ញុំព្រះអង្គ។ ព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបហើយ សួរក៏មាន ទ្រង់ជ្រាបហើយ មិនសួរក៏មាន ទ្រង់ជ្រាបកាលគួរហើយ សួរក៏មាន ទ្រង់ជ្រាបកាលគួរហើយ មិនសួរក៏មាន ព្រះតថាគតទាំងឡាយ សួរតែហេតុដែលប្រកបដោយប្រយោជន៍ មិនសួរហេតុដែលមិនប្រកបដោយប្រយោជន៍ឡើយ ព្រោះហេតុមិនប្រកបដោយប្រយោជន៍ ព្រះតថាគតទាំងឡាយ សម្លាប់បង់ហើយដោយអរិយមគ្គ។ ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ ទ្រង់សួរពួកភិក្ខុដោយហេតុពីរប្រការ គឺទ្រង់សួរដើម្បីនឹងសំដែងធម៌១ ដើម្បីនឹងបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ១។ គ្រានោះឯងព្រះដ៏មានព្រះភាគ មានព្រះបន្ទូលនេះ នឹងភិក្ខុបួសឯចាស់នោះថា នែភិក្ខុ បបរនេះ អ្នកឯងបានមកពីណា។ ទើបភិក្ខុបួសឯចាស់នោះ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អំពើនេះមិនសមគួរ មិនទំនង មិនត្រូវបែបមិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ នែមោឃបុរស អ្នកឯងជាអ្នកបួស មិនសមបើនឹងបបួល (គេឲ្យធ្វើ) ក្នុងការមិនគួរសោះ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយ (មក ហើយទ្រង់មានព្រះបន្ទូល) ថា ម្នាលភិក្ខុទាំងឡាយ បព្វជិត មិនត្រូវបបួល (គេឲ្យធ្វើ) ក្នុងការមិនគួរទេ បព្វជិតណាបបួល ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុដែលធ្លាប់ធ្វើជាងកោរកាត់ (មកពីដើម) មិនត្រូវរក្សាគ្រឿងប្រដាប់កាំបិតកោរទុកទេ ភិក្ខុណារក្សាទុក ត្រូវអាបត្តិទុក្កដ។

[១៣៨] គ្រានោះឯង ព្រះមានព្រះភាគ គង់ក្នុងក្រុងអាតុមា គួរតាមពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី។ លុះព្រះមានព្រះភាគ ទ្រង់ត្រាច់ទៅកាន់ចារិក ដោយលំដាប់ បានដល់ទៅក្រុងសាវត្ថីនោះ។ បានឮថា ព្រះមានព្រះភាគ គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ។ ក៏សម័យនោះឯង ក្នុងក្រុងសាវត្ថី មានផ្លែឈើជាខាទនីយៈ[98] ច្រើនពោរពាស។ ទើបភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា ផ្លែឈើជាខាទនីយ ដូចម្តេច ដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាត ផ្លែឈើជាខាទនីយៈ ដូចម្តេច ដែលព្រះមានព្រះភាគមិនបានអនុញ្ញាត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្លែឈើជាខាទនីយៈគ្រប់យ៉ាង។

[១៣៩] ក៏សម័យនោះឯង មនុស្សទាំងឡាយដាំពូជឈើទាំងឡាយជារបស់សង្ឃ ក្នុងដីជារបស់បុគ្គល ដាំពូជឈើទាំងឡាយជារបស់បុគ្គល ក្នុងដីជារបស់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ (បើ) ពូជឈើទាំងឡាយជារបស់សង្ឃ ដែលដាំក្នុងដីជារបស់បុគ្គល ត្រូវភិក្ខុឲ្យចំណែក[99] (ដល់ម្ចាស់ដីខ្លះ) ហើយសឹមបរិភោគ (បើ) ពូជឈើទាំងឡាយ ជារបស់បុគ្គល ដែលដាំក្នុងដីជារបស់សង្ឃ ត្រូវភិក្ខុឲ្យចំណែក (ដល់ម្ចាស់ដីខ្លះ) ហើយសឹមបរិភោគ។

## ១៨៥. ចតុមហាបទេសកថា

CS vin.mv.06.26 | ភាគ ទី៧

**(១៨៥)**

[១៤០] ក៏សម័យនោះឯង ភិក្ខុទាំងឡាយកើតសេចក្តីរង្កៀស ក្នុងកន្លែងជាអន្លើៗថា របស់អ្វីហ្ន៎ ដែលព្រះដ៏មានព្រះភាគ អនុញ្ញាត របស់អ្វីដែលព្រះដ៏មានព្រះភាគ មិនបានអនុញ្ញាត។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គមានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះ មិនគួរដល់អ្នកទាំងឡាយឡើយ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះ គួរដល់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះ មិនគួរដល់អ្នកទាំងឡាយឡើយ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះ គួរដល់អ្នកទាំងឡាយ។

[១៤១] គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា វត្ថុជាយាមកាលិក (ដែលច្រឡំ) ដោយវត្ថុជាយាវកាលិក គួរ ឬមិនគួរទេ វត្ថុជាសត្តាហកាលិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក គួរ ឬមិនគួរទេ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក គួរ ឬមិនគួរទេ វត្ថុជាសត្តាហកាលិក (ច្រឡំ) ដោយវត្ថុជាយាមកាលិក គួរ ឬមិនគួរទេ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាយាមកាលិក គួរ ឬមិនគួរទេ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាសត្តាហកាលិក គួរ ឬមិនគួរទេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គមានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាមកាលិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងកាល មិនគួរក្នុងវិកាលទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាសត្តាហកាលិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងកាល មិនគួរក្នុងវិកាលទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងកាល មិនគួរក្នុងវិកាលទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាសត្តាហកាលិក (ច្រឡំ) ដោយវត្ថុជាយាមកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងយាម កន្លងយាមទៅហើយ មិនគួរទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាយាមកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងយាម កន្លងយាមទៅហើយ មិនគួរទេ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក (ច្រឡំ) ដោយវត្ថុជាសត្តាហកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរអស់៧ថ្ងៃ ហួស៧ថ្ងៃទៅហើយ មិនគួរទេ។

ចប់ ភេសជ្ជក្ខន្ធកៈ ទី៦។

ក្នុងខន្ធកៈនេះមាន១០៦រឿង។

ឧទ្ទាននៃភេសជ្ជក្ខន្ធកៈនោះគឺ

## ១៨៦. តស្សុទ្ទានំ

CS vin.mv.06.27 | ភាគ ទី៧

**(១៨៦)**

[១៤២] រឿងភិក្ខុកើតអាពាធក្នុងសរទកាល ព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់ភេសជ្ជបានក្នុងកាលក្តី ខុសកាលក្តី១ រឿងទ្រង់អនុញ្ញាខ្លាញ់រាវ១ រឿងទ្រង់អនុញ្ញាតមើមឈើ១ រឿងភិក្ខុត្រូវការដោយថ្នាំ ដែលកិនជាម្សៅ១ រឿងទ្រង់អនុញ្ញាតថ្នាំទឹកចត់១ រឿងទ្រង់អនុញ្ញាតថ្នាំស្លឹកឈើ១ រឿងទ្រង់អនុញ្ញាតថ្នាំផ្លែឈើ១ រឿងទ្រង់អនុញ្ញាតថ្នាំជ័រឈើ១ រឿងទ្រង់អនុញ្ញាតអម្បិល១ រឿងទ្រង់អនុញ្ញាតអាចម៍គោ និងថ្នាំលំអិត១ រឿងទ្រង់អនុញ្ញាតគ្រឿងរែងថ្នាំលំអិត១ រឿងទ្រង់អនុញ្ញាតសាច់ឆៅ និងឈាមស្រស់១ រឿងទ្រង់អនុញ្ញាតថ្នាំបន្តក់ភ្នែក និងគ្រឿងលំអិតសម្រាប់លាប១ រឿងភិក្ខុប្រើក្លាក់ថ្នាំប្លែកៗ១ រឿងក្លាក់ថ្នាំគ្មានគម្រប១ រឿងទ្រង់អនុញ្ញាតចង្កឹះក្លាក់ថ្នាំ១ រឿងទ្រង់អនុញ្ញាតស្រោមចង្កឹះ១ រឿងទ្រង់អនុញ្ញាតថង់ក្លាក់១ រឿងទ្រង់អនុញ្ញាតខ្សែយោគ និងខ្សែសម្រាប់ចង១ រឿងទ្រង់អនុញ្ញាតប្រេងសម្រាប់លាបក្បាល១ រឿងទ្រង់អនុញ្ញាតការនត្ថុ១ រឿងទ្រង់អនុញ្ញាតបំពង់សម្រាប់នត្ថុ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុជក់ផ្សែង១ រឿងទ្រង់អនុញ្ញាតខ្សៀរ១ រឿងទ្រង់អនុញ្ញាតថង់ខ្សៀរ១ រឿងទ្រង់អនុញ្ញាតការស្លប្រេង១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុដាក់គ្រឿងស្រវឹងទៅក្នុងប្រេងស្ល១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់ប្រេងដែលដាក់គ្រឿងស្រវឹងច្រើនពេក១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុអធិដ្ឋានថ្នាំលាប១ រឿងទ្រង់អនុញ្ញាតតុម្ពសម្រាប់ដាក់ប្រេង១ រឿងទ្រង់អនុញ្ញាតការឆ្អង១ រឿងទ្រង់អនុញ្ញាតការឆ្អងដោយគ្រឿងសម្ភារៈ១ រឿងទ្រង់អនុញ្ញាតការឆ្អងធំ១ រឿងទ្រង់អនុញ្ញាតទឹកដែលស្ងោរដោយស្លឹកឈើ មែកឈើ១ រឿងទ្រង់អនុញ្ញាតបន្ទប់ទឹក១ រឿងទ្រង់អនុញ្ញាតឲ្យជប់យកឈាម និងអនុញ្ញាតស្នែងសម្រាប់ជប់ឈាម១ រឿងទ្រង់អនុញ្ញាតថ្នាំសម្រាប់លាបជើង និងអនុញ្ញាតឲ្យភិក្ខុតាក់តែងទឹកស្រវឹង (សម្រាប់លាបជើងឲ្យស្រួល)១ រឿងទ្រង់អនុញ្ញាតសត្ថកម្ម១ រឿងទ្រង់អនុញ្ញាតទឹកចត់១ រឿងទ្រង់អនុញ្ញាតម្សៅល្ង១ រឿងទ្រង់អនុញ្ញាតដុំសត្តុវ១ រឿងទ្រង់អនុញ្ញាតសំពត់សម្រាប់រុំដម្បៅ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុលាងដម្បៅ ដោយម្សៅគ្រាប់ស្ពៃ១ រឿងទ្រង់អនុញ្ញាតឲ្យធ្វើការចំហុយ១ រឿងទ្រង់អនុញ្ញាតឲ្យបង្កាត់ដម្បៅ ដោយទឹកអម្បិល១ រឿងទ្រង់អនុញ្ញាតប្រេងសម្រាប់លាបដម្បៅ១ រឿងទ្រង់អនុញ្ញាតសម្លត់សម្រាប់រុំប្រេង១ រឿងទ្រង់អនុញ្ញាតថ្នាំមហាវិក័ដ១ រឿងទ្រង់អនុញ្ញាតការទទួលប្រគេន១ រឿងទ្រង់អនុញ្ញាតឲ្យផឹកគូថ១ រឿងទ្រង់អនុញ្ញាតអាចបំណាស់១ រឿងទ្រង់អនុញ្ញាតទឹកក្បុង១ រឿងទ្រង់អនុញ្ញាតសម៉ត្រាំទឹកមូត្រ១ រឿងទ្រង់អនុញ្ញាតការលាបដោយគ្រឿងក្រអូប១ រឿងទ្រង់អនុញ្ញាតថ្នាំបញ្ចុះ១ រឿងទ្រង់អនុញ្ញាតទឹកអង្ករថ្លា១ រឿងទ្រង់អនុញ្ញាតទឹកសណ្តែកបាយស្ងោរ១ រឿងទ្រង់អនុញ្ញាតឱជារសសាច់១ រឿងព្រះបិលិន្ទវច្ឆត្ថេរឲ្យគេជម្រះញកភ្នំ និងអនុញ្ញាតអារាមិកជន១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឈឺ ទុកភេសជ្ជៈឆាន់អស់៧ថ្ងៃ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់ស្ករអំពៅ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់សណ្តែកបាយ១ រឿងទ្រង់អនុញ្ញាតថ្នាំលោណសោចិរកៈ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់វត្ថុជាសាមបក្ក១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុចំអិនថែមទៀត១ រឿងត្រឡប់ ទ្រង់អនុញ្ញាតអន្តោវុត្ថ អន្តោបក្ក និងសាមបក្កវិញ ក្នុងកាលអត់បាយ១ រឿងទ្រង់អនុញ្ញាតផ្លែឈើ ជាខាទនីយៈ និងអនុញ្ញាតល្ង ជាខាទនីយៈ១ រឿងបុរេភត្ត១ រឿងក្តៅក្រហាយក្នុងកាយ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើដែលគ្មានពូជ១ រឿងភិក្ខុមានអាពាធឫសដូងបាទ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុធ្វើវត្ថិកម្ម និងសត្ថកម្ម១ រឿងសុប្បិយាឧបាសិកា១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់មនុស្ស១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់សេះ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ឆ្កែ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ពស់១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់សីហៈ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ខ្លាធំ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ខ្លាដម្បង១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ខ្លាឃ្មុំ១ រឿងទ្រង់ហាមមិនឲ្យភិក្ខុឆាន់សាច់ឆ្កែព្រៃ១ រឿងលំដាប់ភត្ត (វេន)១ រឿងទ្រង់អនុញ្ញាតបបរ១ រឿងមហាមាត្យមានសេចក្តីជ្រះថ្លាថ្មី១ រឿងភិក្ខុដែលគេនិមន្តក្នុងទីដទៃហើយ មិនត្រូវឆាន់បបរអ្នកដទៃ១ រឿងទ្រង់អនុញ្ញាតស្ករអំពៅ ដល់ភិក្ខុមានជម្ងឺ១ រឿងមហាមាត្យឈ្មោះសុនីធ១ រឿងព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងផ្ទះសំណាក់ធ្វើពីឥដ្ឋ១ រឿងស្ទឹងគង្គា១ រឿងព្រះដ៏មានព្រះភាគ គង់នៅក្នុងកោដិគ្រាម ហើយទ្រង់សំដែងចតុរារិយសច្ច១ រឿងស្រីផ្កាមាស ឈ្មោះអម្ពបាលី និងស្តេចលិច្ឆវី១ រឿងសាច់ដែលគេធ្វើចំពោះភិក្ខុ១ រឿងក្រុងវេសាលីសម្បូណ៌បាយ១ រឿងទ្រង់ត្រឡប់ហាម មិនឲ្យឆាន់វត្ថុ ដែលជាអន្តោវុត្ថ អន្តោបក្ក និងសាមបក្ក១ រឿងមហាមេឃ១ រឿងព្រះថេរៈឈ្មោះយសមានជម្ងឺ១ រឿងមេណ្ឌកគហបតិ និងរឿងទ្រង់អនុញ្ញាតគោរសប្រាំ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុស្វែងរកស្បៀងបាន១ រឿងកេណិយជដិល និងរឿងទ្រង់អនុញ្ញាតទឹកបានផ្លែស្វាយ ទឹកបានផ្លែព្រីង ទឹកបានផ្លែចេកមានគ្រាប់ ទឹកបានផ្លែចេកឥតគ្រាប់ ទឹកបានផ្លែស្រគំ ទឹកបានផ្លែចន្ទន៍ ទឹកបានក្រអៅឈូក ទឹកបានផ្លែមាក់ប្រាង១ រឿងទ្រង់អនុញ្ញាតអន្លក់ និងខាទនីយៈ ធ្វើដោយម្សៅ១ រឿងភិក្ខុធ្លាប់ជាជាងកោរកាត់ នៅក្នុងក្រុងអាតុមា១ រឿងទ្រង់អនុញ្ញាតផ្លែឈើជាខាទនីយៈ ក្នុងក្រុងសាវត្ថី១ រឿងពូជឈើជារបស់សង្ឃ គេដាំក្នុងទីដីជារបស់បុគ្គល១ រឿងភិក្ខុមានសេចក្តីសង្ស័យក្នុងទីដោយអន្លើៗ១ រឿងកាលិកលាយគ្នា១។

ចប់ភាគ៧

# មាតិកា


| មហាវគ្គ ភាគ ទី ២ | លេខ ទំព័រ |
|---|---|
| **វស្សូបនាយិកក្ខន្ធកៈ** | **១** |
| ការនៅចាំវស្សាព្រះដ៏មានព្រះភាគមិនទាន់បានបញ្ញត្ត | ១ |
| និទានឆព្វគ្គិយភិក្ខុ | ៣ |
| ការចូលវស្សា | ៤ |
| កិរិយាធ្វើនូវការត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃ | ៧ |
| អន្តរាយទាំងឡាយកើតឡើងដល់ពួកភិក្ខុដែលនៅចាំវស្សា | ៣៧ |
| អន្តរាយទាំងឡាយមានដល់ពួកភិក្ខុដែលចូលវស្សា | ៤១ |
| ការបំបែកសង្ឃកើតឡើងដល់ពួកភិក្ខុដែលចូលវស្សា | ៤៣ |
| និទានភិក្ខុ ១រូប មានសេចក្តីប្រាថ្នាដើម្បីចូលវស្សាក្នុងលំនៅរបស់គង្វាលគោ | ៤៦ |
| ពួកភិក្ខុចូលវស្សាក្នុងទីវាល ជាដើម | ៤៩ |
| សង្ឃប្តេជ្ញាគ្នាថា ភិក្ខុមិនត្រូវបំបួសកុលបុត្រក្នុងកណ្តាលវស្សា | ៥១ |
| និទានឧបនន្ទសក្យបុត្ត | ៥២ |
| ការនៅចាំវស្សាក្នុងអាវាសទាំងឡាយពីរ | ៥៣ |
| ត្រូវអាបត្តិទុក្កដព្រោះទទួលពាក្យប្តេជ្ញា | ៥៥ |
| ឧទ្ទាននៃវស្សូបនាយិកក្ខន្ធក | ៦៣ |
| **បវារណាក្ខន្ធកៈ** | **៦៦** |
| និទានភិក្ខុច្រើនរូបជាមិត្រទើបនឹងបានជួបគ្នាថ្មី | ៦៦ |
| មូគវត្ត (វត្តរបស់មនុស្សគ) ជាតិត្ថិយសមាទាន | ៦៧ |
| តេវាចិកាបវារណា | ៧៥ |
| បវារណាពីរយ៉ាង (ចាតុទ្ទសិកាបវារណា ១ បណ្ណរសិកាបវារណា ១) | ៧៧ |
| ការឲ្យនូវបវារណានៃភិក្ខុឈឺ | ៧៩ |
| អន្តរាយទាំងឡាយកើតឡើងក្នុងពេលនៃបវារណាកម្ម | ៨៣ |
| គណប្បវារណា និងតេវាចិកាបវារណា | ៨៥ |
| ភិក្ខុ ៣ រូប បវារណាដល់គ្នានិងគ្នា | ៨៧ |
| ភិក្ខុ ២ រូប បវារណាដល់គ្នានិងគ្នា | ៨៩ |
| និទានភិក្ខុ ១ រូប ត្រូវអាបត្តិក្នុងថ្ងៃបវារណា | ៩១ |
| ការបវារណានៃភិក្ខុអ្នកមិនមានសភាគាបត្តិ | ៩៣ |
| និទានអាវាសិកភិក្ខុ និយាយពីភិក្ខុអ្នកបវារណាមិនត្រូវអាបត្តិ មាន ១៥ យ៉ាង | ៩៥ |
| ពួកភិក្ខុជាពួកតែសំគាល់ថា ព្រមព្រៀងគ្នា មាន ១៥ យ៉ាង | ១០១ |
| ពួកភិក្ខុមានសេចក្តីរង្កៀស មាន ១៥ យ៉ាង | ១០៣ |
| ពួកភិក្ខុមានបំណងនឹងបំបែកសង្ឃ មាន ១៥ យ៉ាង | ១០៥ |
| ថ្ងៃរបស់អាវាសិកភិក្ខុ និងអាគន្តុកភិក្ខុផ្សេងគ្នា | ១០៧ |
| ការបវារណារបស់ពួកភិក្ខុដែលមានសេចក្តីសង្ស័យ ជាដើម | ១០៩ |
| ការបវារណារបស់ពួកភិក្ខុដែលមានសំវាសស្មើគ្នា ជាដើម | ១១៣ |

| | |
|---|---|
| ភិក្ខុមិនត្រូវទៅក្នុងថ្ងៃបវារណានោះ | ១១៥ |
| កាលភិក្ខុនីបរិសទ្យអង្គុយហើយ ភិក្ខុមិនត្រូវបវារណា | ១១៩ |
| រឿងអាវាស ១ ក្នុងកោសលជនបទកើតសញ្ចរភ័យក្នុងថ្ងៃបវារណានោះ | ១២០ |
| ការបវារណាជាតេវាចិកាបវារណា ជាដើម | ១២១ |
| និទានឆព្វគ្គិយភិក្ខុត្រូវអាបត្តិហើយបវារណា | ១២៥ |
| បវារណាដែលភិក្ខុបានឃាត់ និងបវារណាដែលភិក្ខុមិនបានឃាត់ | ១២៧ |
| ការឃាត់នូវបវារណាចំពោះភិក្ខុផងគ្នា | ១២៩ |
| សេចក្តីយល់ផ្សេងៗគ្នាក្នុងការត្រូវអាបត្តិ | ១៣៥ |
| ពួកភិក្ខុអ្នកធ្វើការប្រកួតប្រកាន់ ជាដើម | ១៣៩ |
| ការធ្វើនូវបវារណាសង្គហនៃភិក្ខុអ្នកព្រមព្រៀងគ្នា ជាដើម | ១៤៥ |
| ការធ្វើនូវបវារណាសង្គហ | ១៤៩ |
| ឧទ្ទាននៃបវារណាក្ខន្ធក | ១៥០ |
| **ចម្មក្ខន្ធកៈ** | **១៥៣** |
| និទានកូនសេដ្ឋីម្នាក់ឈ្មោះសោណជាកោឡិវិសគោត្ត | ១៥៣ |
| និទានព្រះសាគតត្ថេរ | ១៥៥ |
| និទានព្រះសោណត្ថេរ | ១៥៩ |
| ខីណាសវគុណកថា | ១៦៧ |
| ការបញ្ញត្តិស្បែកជើងជាអកប្បិយ | ១៧៥ |
| ស្បែកជើង ៤ ជាន់ ឡើងទៅ ដែលគេពាក់ហើយដោះប្រគេន (ស្បែកជើងចាស់) | ១៧៩ |
| ភិក្ខុមិនត្រូវពាក់ស្បែកជើងខាងក្នុងវត្ត | ១៨១ |
| និទានភិក្ខុមានរោគដំបៅលេចនៅបាទជើង | ១៨២ |
| ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងឈើ | ១៨៥ |
| ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងស្លឹកត្នោត | ១៨៧ |
| (ពួកភិក្ខុក្នុងក្រុងភទ្ទិយ) ពាក់ទ្រនាប់ជើងមានបការផ្សេង ៗ | ១៨៩ |
| សេចក្តីបញ្ញត្តិនូវទ្រនាប់ជើងជាអកប្បិយ | ១៩១ |
| និទានឆព្វគ្គិយភិក្ខុចាប់ស្នែងមេគោ ជាដើម | ១៩២ |
| ភិក្ខុមិនត្រូវចាប់មេគោ | ១៩៣ |
| និទានឆព្វគ្គិយភិក្ខុទៅដោយយានដែលទឹមដោយគោញី | ១៩៤ |
| ការទ្រង់អនុញ្ញាតនូវគ្រែស្នែង | ១៩៥ |
| ឧច្ចាសយនមហាសយនកថា | ១៩៧ |
| ភិក្ខុមិនត្រូវប្រើប្រាស់ស្បែកសត្វដ៏ធំ | ១៩៩ |
| និទានភិក្ខុបាប | ២០០ |
| ភិក្ខុមិនត្រូវពាក់ស្បែកជើងចូលទៅកាន់ស្រុក | ២០៣ |
| និទានព្រះសោណត្ថេរ | ២០៤ |
| ព្រះដ៏មានព្រះភាគទ្រង់ប្រទានពរ ៥ យ៉ាង ដល់ព្រះសោណត្ថេរ | ២១៤ |
| ទ្រង់ទ្រាយនៃមជ្ឈិមបទេស | ២១៥ |
| ឧទ្ទាននៃចម្មក្ខន្ធក | ២១៦ |

| | |
|---|---|
| **ភេសជ្ជក្ខន្ធកៈ** | **២២១** |
| និទានភិក្ខុកើតអាពាធ (ប្រមាត់) | ២២១ |
| ពោលអំពីភេសជ្ជទាំង៥ | ២២៣ |
| ពោលអំពីភេសជ្ជ មានខ្លាញ់ ជាដើម | ២២៥ |
| ពោលអំពីភេសជ្ជ មានទឹកចត់ ជាដើម | ២២៧ |
| ពោលអំពីភេសជ្ជ មានជ័រ ជាដើម | ២២៩ |
| ពោលអំពីភេសជ្ជ មានគ្រឿងលំអិត ជាដើម | ២៣១ |
| ពោលអំពីការទ្រង់អនុញ្ញាតភេសជ្ជ មានថ្នាំបន្តក់ភ្នែក ជាដើម | ២៣៣ |
| ពោលអំពីការទ្រង់អនុញ្ញាតនូវចង្កឹះភ្លាក់ | ២៣៥ |
| និទានបិលិន្ទវច្ឆត្ថេរដ៏មានអាយុកើតជម្ងឺក្តៅក្បាល | ២៣៦ |
| ពោលអំពីការទ្រង់អនុញ្ញាតភេសជ្ជ មានប្រេងលាបក្បាល ជាដើម | ២៣៧ |
| និទានបិលិន្ទវច្ឆត្ថេរ | ២៣៩ |
| និទានភិក្ខុ ១ រូប មានអាពាធកើតពក | ២៤២ |
| ថ្នាំមហាវិកដ ៤ យ៉ាង | ២៤៣ |
| ពោលអំពីភិក្ខុមានអាពាធផ្សេងៗ | ២៤៥ |
| និទានព្រះបិលិន្ទវច្ឆត្ថេរ និយាយអំពីការទ្រង់អនុញ្ញាតនូវអារាមិកជន | ២៤៧ |
| និទានព្រះបិលិន្ទវច្ឆត្ថេរ និយាយអំពីកម្រងផ្កាជាវិការនៃមាស | ២៤៩ |
| និទានព្រះបិលិន្ទវច្ឆត្ថេរ និយាយអំពីភេសជ្ជ ៥ យ៉ាង | ២៥៣ |
| និទានព្រះកង្ខារេវតត្ថេរ ពោលអំពីស្ករអំពៅ | ២៥៥ |
| ព្រះដ៏មានព្រះភាគទ្រង់អាពាធកើតអំពីខ្យល់ក្នុងព្រះឧទរ | ២៥៧ |
| ភោជនដែលភិក្ខុទុក និងចំអិនខាងក្នុងអកប្បិយកុដិ និងចំអិនដោយខ្លួនឯង | ២៥៩ |
| និទានព្រាហ្មណ៍ ១ រូប | ២៦៣ |
| និទានឧបនន្ទសក្យបុត្ត | ២៦៧ |
| ព្រះសារីបុត្តមានអាពាធក្តៅរោលរាលក្នុងកាយ | ២៦៨ |
| ការទ្រង់អនុញ្ញាតផ្លែឈើដែលគ្មានពូជ ជាដើម | ២៧១ |
| សត្ថកម្ម (ការកាត់ ឬវះ) វត្ថិកម្ម (ការចងរឹត) | ២៧៣ |
| (ភិក្ខុត្រូវការដោយ) សាច់ដែលមានឱជារស | ២៧៥ |
| និទានសុប្បិយាឧបាសិកា | ២៧៧ |
| ពោលអំពីសាច់ដែលមិនគួរ | ២៧៩ |
| និទានព្រាហ្មណ៍ ១ រូប | ២៨៥ |
| ពោលអំពីអានិសង្សបបរ មាន ១០ យ៉ាង | ២៨៧ |
| និទានមហាមាត្យ (ម្នាក់) ជាអ្នកមានសេចក្តីជ្រះថ្លាថ្មី (មិនទាន់មុតមាំ) | ២៨៩ |
| សេចក្តីរង្កៀសរបស់មហាមាត្យអ្នកមានសេចក្តីជ្រះថ្លាថ្មី | ២៩១ |
| និទានបុរសឈ្មោះវេលដ្ឋកច្ចាន និយាយអំពីការប្រគេនស្ករអំពៅ | ២៩៤ |
| ធម្មចក្ខុ គឺសោតាបត្តិមគ្គរបស់បុរសឈ្មោះវេលដ្ឋកច្ចាន | ២៩៩ |
| និទានពួកភិក្ខុរង្កៀសមិនហ៊ានឆាន់ស្ករអំពៅ | ៣០០ |
| ពោលអំពីការទ្រង់ទទួលនូវរោងសំណាក់ | ៣០១ |

| | |
|---|---|
| ទោស ៥ ប្រការ នៃបុគ្គលទ្រុស្តសីល ឬ វិបត្តិចាកសីល | ៣០៣ |
| អានិសង្ស ៥ ប្រការ នៃបុគ្គលមានសីល ឬបរិបូណ៌ដោយសីល | ៣០៥ |
| និទានមហាមាត្យឈ្មោះសុនធនឯវស្សការ | ៣០៧ |
| អនុមោទនាគាថា | ៣១១ |
| ចតុរារយសច្ចទេសនាកថា | ៣១៣ |
| និទាននាងអម្ពបាលីជាស្រីផ្កាមាស | ៣១៥ |
| និទានស្តេចលិច្ឆវីក្នុងក្រុងវេសាលី | ៣១៧ |
| និទានសីហសេនាបតិ ពោលអំពីអកិរិយវាទ | ៣២១ |
| និទានសីហសេនាបតិ ពោលអំពីវាទ មានអកិរិយវាទ ជាដើម | ៣២៥ |
| និទានសីហសេនាបតិ ការសំដែងនូវភាវនៃខ្លួនជាឧបាសក | ៣៣១ |
| និទានសីហសេនាបតិ ពោលអំពីសាច់ដែលគេធ្វើចំពោះ (ខ្លួន) | ៣៣៥ |
| ភិក្ខុកាលដឹងថាសាច់ដែលគេធ្វើចំពោះ (ខ្លួន) មិនត្រូវបរិភោគ | ៣៣៧ |
| និទានពួកមនុស្សអ្នកជនបទ និយាយអំពីការសន្និតិកប្បិយភូមិ | ៣៣៩ |
| កប្បិយភូមិ ៤ យ៉ាង និទានមេណ្ឌកគហបតី | ៣៤៣ |
| និទានមេណ្ឌកគហបតី អានុភាពនៃជន មានមេណ្ឌកគហបតី ជាដើម | ៣៤៥ |
| និទានមេណ្ឌកគហបតី ពុទ្ធគុណកថា | ៣៤៩ |
| និទានមេណ្ឌកគហបតី អនុបុព្វីកថា | ៣៥១ |
| និទានមេណ្ឌកគហបតី ការសំដែងនូវភាវនៃខ្លួនជាឧបាសក | ៣៥៣ |
| ធម្មចក្ខុ គឺសោតាបត្តិមគ្គនៃមេណ្ឌកគហបតី | ៣៥៥ |
| និទានមេណ្ឌកគហបតី ការអង្គាសនៃមេណ្ឌកគហបតី (នោះ) | ៣៥៦ |
| ការទ្រង់អនុញ្ញាតនូវការស្វែងរកស្បៀង | ៣៥៩ |
| និទានកេណិយជដិល | ៣៦១ |
| និទានមល្លក្សត្រទាំងឡាយនៅក្នុងក្រុងកុសិនារា | ៣៦៦ |
| និទានមល្លក្សត្រឈ្មោះរោជ ការធ្វើនូវការក្រោកទទួលព្រះដ៏មានព្រះភាគ | ៣៦៧ |
| និទានមល្លក្សត្រឈ្មោះរោជ អនុបុព្វីកថា | ៣៦៩ |
| និទានរោជមល្លក្សត្រ | ៣៧១ |
| និទានភិក្ខុបួសឯចាស់ | ៣៧៣ |
| ពោលអំពីមនុស្សដាំពូជឈើរបស់សង្ឃ (ក្នុងដី) របស់បុគ្គល | ៣៧៧ |
| ពោលអំពីកាលិក មានយាមកាលិក ជាដើម | ៣៧៩ |
| ឧទ្ទាននៃភេសជ្ជក្ខន្ធក | ៣៨០ |


1)

អដ្ឋកថា អធិប្បាយថា ក្នុងវស្សានរដូវ ភិក្ខុត្រូវចូលវស្សាឲ្យគ្រប់បីខែ។

2)

ថ្ងៃចូលវស្សាមុន។

3)

ថ្ងៃចូលវស្សាក្រោយ។

4)

អដ្ឋកថា ថា ទ្រង់មានសេចក្តីប្រាថ្នានឹងលើកខែជាដម្បូងនៃវស្សានរដូវ គឺប្រាថ្នានឹងធ្វើខែស្រាពណ៍ ឲ្យទៅជាខែអាសាធវិញ (ខែអាសាធខាងដើម ហៅបឋមាសាធ ខែដែលលើកខាងក្រោយ ហៅទុតិយាសាធ)។
5)
សេចក្តីថា ភិក្ខុលើកសត្តាហៈចេញទៅអំពីវត្តហើយ ត្រូវត្រឡប់មកវត្តខាងក្នុងអរុណថ្ងៃទី៧វិញ កុំទៅនៅក្រៅវត្តឲ្យហួសអរុណថ្ងៃទី៧ឡើយ។
6)
សិរីសប សំដៅយកសត្វលូនវារ ដែលមានពិស មានពស់ ក្អែបជាដើម។
7)
ក្នុងដីកាថា ប្រជុំជន។
8)
បវារណាក្នុងថ្ងៃទី១៤
9)
បវារណាក្នុងថ្ងៃទី១៥
10)
សាលាឆាន់
11)
លួចសំវាស
12)
ភ័យដែលកើតអំពីមនុស្សនៅក្នុងព្រៃ។
13)
សេចក្តីប្រព្រឹត្តិដោយកាយមិនបរិសុទ្ធ។
14)
សេចក្តីប្រព្រឹត្តិដោយវាចាមិនបរិសុទ្ធ។
15)
សេចក្តីចិញ្ចឹមជីវិតមិនបរិសុទ្ធ។
16)
ក្នុងវស្សា៣ខែ បើមានហេតុទាស់ ទ្រង់អនុញ្ញាតឲ្យធ្វើចាតុទ្ទសីឧបោសថពីរបីឧបោសថបាន គឺឧបោសថទី៣-៤-៥។ ឯទី៣ គឺរនោចខែស្រាពណ៍ ទី៤-៥ ខែភទ្របទ។ ឯធ្វើបែបនេះខុសពីធម្មតាតែខែភទ្របទមួយទេ។
17)
អដ្ឋកថា សំដៅយកសមថៈ ឬវិបស្សនា ដែលទើបនឹងបាន នៅទន់ ឬខ្ចីនៅឡើយ។
18)
(អដ្ឋកថា) សំដៅយកអំពើទាំងឡាយ មានការភ្ជួរស្រែ និងលក់ដូរជាដើម ដែលប្រកបដោយធម៌ និងចិញ្ចឹមមាតាបិតាដែលប្រកបដោយធម៌។
19)
អដ្ឋកថា ថា ផែនថ្មមានសណ្ឋានដូចព្រះចន្ទពាក់កណ្តាលវង់ នៅខាងក្រោមជណ្តើរ។
20)
កិលេស១០យ៉ាង និងខន្ធ៥ ជាដើម ឈ្មោះថា ភារៈ គឺគ្រឿងធ្ងន់ ដែលហៅថាមានភារៈដាក់ចុះហើយ គឺអស់រវល់ដោយកិលេស និងខន្ធជាដើម នោះតទៅទៀត។
21)
អដ្ឋកថា ថា បានចាក់ធ្លុះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត។
22)
(អដ្ឋកថា) បុគ្គលដែលមិនញាប់ញ័រដោយសេចក្តីត្រេកអរ និងសេចក្តីអន់ចិត្ត ក្នុងអារម្មណ៍ជាទីគាប់ចិត្ត និងអារម្មណ៍មិនជាទីគាប់ចិត្ត។
23)
អដ្ឋកថា កែមហាខន្ធកៈ ពន្យល់សេចក្តីថា អធិសីល បានខាងបាតិមោក្ខសីល។ អធិចិត្ត បានខាង សមាធិភាវនាជាលោកិយ។ អធិប្បញ្ញា បាន ខាងមគ្គភាវនាជាលោកុត្តរ។
24)
ត្រូវសម្រេចអាបត្តិតាមសញ្ចិច្ចបាណសិក្ខាបទ សប្បាណវគ្គបាចិត្តិយកណ្ឌ។ ក្នុងខន្ធកៈទាំងអស់ មានបំណងប្រាប់តែអាបត្តិដែលមានក្រៅបាតិមោក្ខ បើកន្លែងណាមាននិយាយជាប់ទាក់ទងដោយអាបត្តិក្នុងបាតិមោក្ខផងនោះ គ្រាន់តែមានប្រាប់ថា ត្រូវធ្វើតាមធម៌ៗ យ៉ាងនេះ ព្រោះបាននិយាយរួចមកហើយ។
25)
អដ្ឋកថា ថា យានដែលសម្រាប់អូស ឬរុញដោយដៃ ទុកជាប្រុសក្តី ស្រីក្តី អូស ឬរុញទៅ ក៏គួរ។
26)

រតនៈ សំដៅយកកែវមុក្តា កែវមណី សង្ខ ថ្ម មាស និងប្រាក់ជាដើម។
27)
សំដៅយកទីនៅ ដូចកុដិ និងសាលាជាដើម។
28)
ឧបាសកឈ្មោះសោណៈ តែងពាក់គ្រឿងប្រដាប់ត្រចៀក មានដម្លៃមួយកោដិ បានជាគេហៅថា កុដិកណ្ណ ជាប់ផង (អដ្ឋកថា)
29)
១.២.៣.៤ តាមអដ្ឋកថា ថា ស្មៅទាំង៤យ៉ាងនេះ គេតែងយកមកធ្វើជាកន្ទេលរឹងខ្លះ កន្ទេលទន់ខ្លះ ឯស្មៅឈ្មោះឯរគុមានសម្ផស្សរឹង គ្រោតគ្រាត ស្មៅឈ្មោះមោរគុនោះ មានចុងក្រហម មានសាច់ល្អិតទន់ មានសម្ផស្សស្រួល គេតែងយកមកធ្វើជាកន្ទេលទន់សម្រាប់ដេក កាលបើដេកសង្កត់ទៅហើយ លុះក្រោកចេញ ក៏ប៉ោងឡើងវិញ ឯស្មៅឈ្មោះមជ្ជារុនោះ គេយកមកធ្វើជាសំពត់សាដកក៏បាន ស្មៅឈ្មោះជន្ទុនោះ មានពណ៌ដូចកែវមណី។
30) , 76)
២
31) , 77)
៣
32) , 44)
៤
33)
សំដៅយកប្រទេស ជាខាងក្រៅពីមជ្ឈិមប្រទេស។
34)
សំដៅយកគ្រូសូត្រ
35)
តាមធម្មតា ក្នុងមជ្ឈិមបទេស ភិក្ខុបានទទួលចីវរក្តី បានដឹងដំណឹងចីវរដែលគេមិនប្រគេនក្តី ភិក្ខុត្រូវរាប់ថ្ងៃតាំងតែបានទទួល ឬបានដឹងដំណឹងនោះ បើភិក្ខុមិនបានវិកប្ប ឬមិនបានអធិដ្ឋានឲ្យហួសកំណត់១០ថ្ងៃទៅ ចីវរនោះជានិស្សគ្គិយ ឯបច្ចន្តិមជនបទ តាមពុទ្ធានុញ្ញាតនេះ បើចីវរមិនទាន់ដល់ដៃ ភិក្ខុមិនបាច់រាប់ថ្ងៃឡើយ។
36)
កាលដែលជាទីស្រៀវស្រាញ សង្កើរសង្កាញ់ គឺខែជាខាងចុងនៃវស្សានរដូវ និងខាងដើមនៃហេមន្តរដូវ។
37)
សំដៅយកតាំងពីពេលព្រឹក ទៅទល់ថ្ងៃត្រង់។ តទៅខាងមុខ នឹងមានទ្រង់អនុញ្ញាតរើរុះទៀត។
38)
សារត្ថទីបនី និងវិមតិវិនោទនីដីកាថា ភោជនទាំងនោះ ក៏ត្រឡប់ទៅជាសៅហ្មង មិនមានឱជារសឆ្ងាញ់ពីសាវិញ។
39)
កាលគួរ គឺតាំងពីអរុណរះ ទៅទល់ថ្ងៃត្រង់ ឯកាលមិនគួរនោះ តាំងពីថ្ងៃជ្រេពីត្រង់ ទៅទល់នឹងអរុណរះ
40)
ប្រើប្រាស់បានកំណត់ត្រឹម៧ថ្ងៃ ជាយ៉ាងយូរ។
41)
វត្ថុសម្រាប់វែងគ្រឿងលំអិត មានម្សៅជាដើម ដែលហៅថា កាតៅ។
42)
ជម្ងឺដែលឈឺព្រោះខ្មោចចូល
43)
៣.៤ អដ្ឋកថា ថា ភិក្ខុនោះមិនស៊ីសាច់ឆៅ ផឹកឈាមស្រស់នោះខ្លួនឯងទេ គឺខ្មោចដែលវាចូលភិក្ខុនោះវាស៊ី វាផឹក លុះស៊ីផឹកហើយ វាចេញទៅ។
45)
វៀរលែងតែឆ្អឹងមនុស្សចេញ ក្រៅពីនោះ ទោះឆ្អឹងអ្វីៗក៏គួរទាំងអស់។
46)
គឺក្លាក់ដែលធ្វើពីជាតិស្ពាន់ ទង់ដែង ដែក សំណភក់ សំណប៉ាហាំង។
47)
គឺប្រេងដែលចូលទៅតាមច្រមុះនោះ មិនស្មើគ្នា ចួនកាលច្រើន ចួនកាលតិច។
48)
ដើម្បីឲ្យនត្ថុចូលទៅព្រមគ្នា។
49)
ត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិបាចិត្តិយចេញ។

50)

អដ្ឋកថា ថា ត្រូវដាក់រងើកភ្លើងឲ្យពេញក្នុងរណ្ដៅ ឲ្យបានប្រមាណមួយជំហរបុរស រួចបិទរណ្ដៅនោះដោយអាចម៍ដី និងដីខ្សាច់ជាដើមហើយក្រាលស្លឹកឈើផ្សេងៗលើរណ្ដៅនោះ ហើយយកប្រេងលាបខ្លួន រួចដេកប្រែចុះ ប្រែឡើងលើរណ្ដៅនោះ ឲ្យចេញញើសពីសរីរៈ។

51)

អដ្ឋកថា ថា ត្រូវដាក់ទឹកក្ដៅឲ្យពេញក្នុងភាជន៍ ឬស្នូក ហើយចូលទៅធ្វើការឆ្អុងក្នុងបន្ទប់ទឹកនោះ។

52)

សំដៅយកបុគ្គលដែលប្រសប់ធ្វើវត្ថុមិនគួរ ឲ្យជាវត្ថុគួរ

53)

ព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុយកអាច់បំណាស់ដែលជាប់នឹងផាលនង្គ័ល មកលាយនឹងទឹកហើយផឹក។

54)

អដ្ឋកថា ថា ឲ្យយកបាយមកដុតនឹងភ្លើងឲ្យឆេះជាផេះ ហើយច្រោះត្រងយកទឹកមកផឹក។

55)

អដ្ឋកថា ថា សំដៅយកតែទឹកនោមគោម្យ៉ាង មិនបាននិយាយដល់ទឹកនោមមនុស្សទេ។

56)

មនុស្សដែលស្ដេចបានវេរផ្ដាច់ ឲ្យជាអ្នកថែរក្សាវត្ត (រាជពីដើមហៅថាពលព្រះ)។

57)

ជាអ្នកធ្លាប់ចូលទៅមកក្នុងត្រកូល។

58)

ក្មេងប្រុស។

59)

កូនស្រី

60)

ក្មេងស្រី

61)

ត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិបាចិត្តិយចេញ។

62)

អដ្ឋកថា កែតតិយបារាជិកថា ថ្នាំឈ្មោះលោណសោចិរកនោះ គេធ្វើដាក់ផ្លែសម៉ កន្ទួតព្រៃ សម៉ពិភេគ គ្រឿងចត់ និងស្រូវទាំងពួង មានស្រូវសាលីជាដើម និងអបរណ្ណជាតិ មានសណ្ដែកល្ងជាដើម និងបាយនៃស្រូវ៧ប្រការ មានស្រូវសាលីជាដើម និងផ្លែឈើទាំងពួង មានផ្លែចេកជាដើម និងលម្ពង់ឈើទាំងពួង មានលម្ពង់ផ្ដៅ និងកាកោះជាដើម និងត្រីសាច់ និងភេសជ្ជៈជាច្រើន មានទឹកឃ្មុំ ទឹកអំពៅ អម្បិលសិន្ធវជាដើម ហើយត្រាំក្នុងភាជន៍ បិទមាត់ភាជន៍ឲ្យជិត ទុកឲ្យយូរកំណត់១ឆ្នាំ ២ឆ្នាំ ឬ៣ឆ្នាំក៏បាន។ ថ្នាំនោះក៏ឆ្អិនល្អ មានពណ៌ដូចទឹកផ្លែព្រីង សម្រាប់ឆាន់កែរោគខ្យល់ក្អក ឃ្លង់ ស្គមលឿង និងឫសដូងបាទជាដើម ម្យ៉ាងទៀត ជាថ្នាំសម្រាប់ឆាន់ក្រោយបាយ។

63)

បបរលាយដោយរបស់បីយ៉ាងគឺ ល្ង អង្ករ និងសណ្ដែក។

64)

ក្នុងអដ្ឋកថា ថា សត្វឆ្មា កណ្ដុរ ទន្សង និងស្កាវ។

65)

ក្នុងវិមតិវិនោទនីដីកា ថា កាលបើមានទាយកប្រគេនវត្ថុបន្តិចបន្តួចរួចហើយ ភិក្ខុទាំងឡាយក៏ហាមឃាត់ មិនទទួលទៀត។

66)

ភិក្ខុកំណត់ដឹងថា យើងអាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុមានប្រមាណប៉ុណ្ណោះ វត្ថុដ៏សល់អំពីនេះ ចូរបានដល់ភិក្ខុឯទៀតចុះ ហើយក៏ហាមឃាត់មិនទទួល។

67)

ក្នុងដីកាថា នំដែលគេលាយដោយវត្ថុ មានស្ករជាដើម

68)

បបរដែលគេធ្វើអំពីភោជនទាំង៥ គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១ ដែលនាំឲ្យកើតបវារណា តាមសិក្ខាបទទី៥ នៃភោជនវគ្គ។

69)

ក្នុងតតិយសារត្ថទីបនីដីកាតតិយសមន្ត អធិប្បាយពីរយ៉ាង គឺបុគ្គលមិនបានសមាទានសីល ឬសមាទានសីលហើយធ្វើសីលឲ្យដាច់ទៅវិញ។

70)

ប្រទេសប្រាសចាកសេចក្ដីសុខ។

71)

ទី គឺបណ្ឌិតគប្បីខ្ពើម។

72)

ចូរមើលវិនយបិដក មហាវិភង្គភាគទី១ ទំព័រ១៤៦ណោះ។

73)

អដ្ឋកថា និងដីកាថា ពួកមហាមាត្យ ដែលសាងក្រុងក្នុងបាដលិគ្រាម ក៏ហាក់ដូចជាបានទៅប្រឹក្សាគ្នានឹងទេវតាក្នុងស្ថានតាវត្តិង្ស។

74)

ក្នុងតតិយសារត្ថទីបនីដីកាតតិយសមន្ត ពន្យល់សេចក្តីថា កោដិគ្រាមនោះ នៅត្រង់កន្លែងកំពូលប្រាសាទនៃស្តេចមហាបនាទ ដែលលិចចុះទៅក្នុងផែនដី (មើលមង្គលត្ថទីបនី ក្នុងតតិយគាថា សិប្បកថា)។

75)

១.២.៣ ក្នុងតតិយសារត្ថទីបនីដីកា តតិយសមន្តថា សូម្បីរាជរថ ទង់ សេះ ដងជន្លួញ ក៏សឹងប្រដាប់ដោយមាស និងកែវ មានសម្បុរខៀវទាំងអស់ ទាំងលឿង ក្រហម ស ក៏ដូចគ្នា។

78)

អយ្យបុត្ត គឺព្រះអង្គម្ចាស់

79)

ក្នុងដីកា ពន្យល់សេចក្តីថា ពោលសរសើរពុទ្ធគុណ ដោយចរិយា៣ គឺ ញាតត្ថចរិយា១ លោកត្ថចរិយា១ ពុទ្ធត្ថចរិយា១។

80)

ពោលសរសើរធម្មគុណ ដោយចំណែកនិកាយ៥ បិដក៣ នវង្គសត្ថុសាសន៩ ធម្មក្ខន្ធ៨៤.០០០។

81)

ពោលសរសើរសង្ឃគុណ ដោយអំណាចបព្វជ្ជាថា ភទ្ទិយរាជ មហាកប្បិនរាជ បុក្កុស យសកុលបុត្ត សោណសេដ្ឋិបុត្ត រដ្ឋបាលកុលបុត្ត (លោកទាំងអម្បាលនេះជាដើម) ស្តាប់ធម៌ហើយ បាននូវសទ្ធា លះស្វេត្រឆត្ររាជសម្បត្តិ លះទីសេនាបតិ ទីជាសេដ្ឋី ទីជានាយឃ្លាំង ចេញបួសក្នុងសាសនារបស់ព្រះសាស្តា។

82)

ក្នុងដីកាថា ទំនុកបំរុងដើម្បីឲ្យបានសម្រេចមគ្គ៤ និងផល៤។

83)

សំឡេងដូចក្អែកកញ្ជ្រៀវ។

84)

អដ្ឋកថា កប្បិយកុដិ ដែលសង្ឃសូត្រព្រមគ្នាថា កប្បិយកុដី ករោម យើងទាំងឡាយ ធ្វើកប្បិយកុដិដូច្នេះ បីដង ហើយកសាងឡើង ឈ្មោះថា ឧស្សាវនន្តិកា។

85)

ខ្ទមតូច ឬរោងតូច ដែលចាស់ គ្រាំគ្រា ដូចរោងគោ គួរជាកប្បិយកុដិបាន ឈ្មោះថា គោនិសាទិកា ៗមានពីរយ៉ាងគឺ សេនាសនៈ ដែលគ្មានរបង ឬជញ្ជាំង ឈ្មោះថា អារាមគោនិសាទិកា១ សេនាសនៈទាំងអស់ ដែលមានរបង ឬជញ្ជាំងខ្លះក្តី មិនមានខ្លះក្តី ឈ្មោះថា វិហារគោនិសាទិកា១។

86)

មនុស្សទាំងឡាយ កសាងអាវាសហើយ គេនិយាយថា សូមលោកម្ចាស់ទាំងឡាយ ប្រើប្រាស់នូវ (កប្បិយកុដិ) នេះចុះ កប្បិយកុដិនេះ ឈ្មោះថា គហបតិកា។

87)

កុដិ ដែលសង្ឃប្រកាសដោយញត្តិទុតិយកម្ម សន្មតឲ្យជាកប្បិយកុដិ ហៅថា សម្មតិកា។

88)

បួននាឡិ ជាមួយអាឡ្ហក។

89)

បួនអាឡ្ហក ជាមួយទោណ គឺ១៦នាឡិ

90)

អមាត្យ អ្នកសម្រេចរាជការទាំងអស់។

91)

ផ្លូវជាទីញុំាងទឹកឲ្យឆ្លង បានដល់ផ្លូវ ដែលគេទៅមកបានដោយលំបាក។

92)

អដ្ឋកថា ថា ទឹកអដ្ឋបានទាំងនេះ ជារបស់ត្រជាក់ក្តី ឆ្អិនដោយកំដៅថ្ងៃក្តី ក៏គួរ បើចំអិនដោយភ្លើង មិនគួរ។

93)

បានដល់ស្រូវ៧ប្រការ។

94)

រសពួកស្លឹកឈើ ដែលជាយាវកាលិក ជារបស់គួរក្នុងបុរេភត្តប៉ុណ្ណោះ រសស្លឹកឈើ ដែលជាយាវជីវិក ភិក្ខុចំអិនលាយនឹងសប្បិជាដើម គួរអស់កាល៧ថ្ងៃ បើចំអិនដោយទឹកសុទ្ធ គួរដរាបដល់អស់ បើចំអិនដោយទឹកដោះជាដើម មិនគួរ សូម្បីស្លឹកឈើដែលគេចំអិនដោយវត្ថុឯទៀតៗ ក៏

ហៅថា រសបន្លែដែរ។
95)
តាមសារត្ថទីបនីដីកាថា ភិក្ខុនោះឈ្មោះសុភទ្ទ។
96)
ក្មេងពីរនាក់នេះ ជាកូនរបស់លោក បានបួសជាសាមណេរ។
97)
តាមសារត្ថទីបនីដីកាថា មានគំនរចំបើងធំនៅទីនោះ គេបានកាយចំបើងចេញពីខាងក្នុង ហើយធ្វើឲ្យសមគួរ ជាលំនៅរបស់បព្វជិតទាំងឡាយ ដូចជាសាលា។
98)
ផ្លែឈើដែលត្រូវទំពាឆាន់។
99)
អដ្ឋកថា ថា ត្រូវបែងជា១០ភាគ ហើយត្រូវយក១ភាគ ដែលជាភាគទី១០ ឲ្យដល់ម្ចាស់ដី សល់ក្រៅពីនោះ ៩ភាគ ត្រូវបានម្ចាស់ពូជ។ រឿងចែកយ៉ាងនេះ ជាបោរាណកចារិត្តក្នុងជម្ពូទ្វីប។

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០០៨ - Book 008

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថាលោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០៨ - Tipitaka Book 008 [http://forum.sangham.net/index.php/topic,8970.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០០៨

ភាគ ទី ០០៧ | **មាតិកា** | ភាគ ទី ០០៩




គំរូ ឯកសារ ផ្សេងទៀត ៖
book_008.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី៨

ទ.

# វិន័យបិដក

CS vin | ភាគ ទី៨

**ភាគ ទី៨**

# មហាវគ្គ

CS vin.mv | ភាគ ទី៨

**តតិយភាគ**
ភាគ ទី ៣

កឋិនក្ខន្ធកៈ - ចីវរក្ខន្ធកៈ - ចម្បេយ្យក្ខន្ធកៈ - កោសម្ពិក្ខន្ធកៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

## កឋិនក្ខន្ធកៈ

CS vin.mv.07 | ភាគ ទី៨

### ៧. កថិនក្ខន្ធកោ

### ១៨៧. កថិនានុជាននា

CS vin.mv.07.01 | ភាគ ទី៨

[១] សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកភិក្ខុនៅក្នុងដែនបាឋា[1] ប្រមាណ៣០រូប សុទ្ធតែជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្តប្រើសំពត់បង្សុកូល ជាអ្នកប្រព្រឹត្តប្រើតែចីវរ៣ គ្រប់រូបទាំងអស់ នាំគ្នាទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ កាលបើតិថី ដែលចូលវស្សាជិតណាស់មកហើយ ក៏មិនអាចនឹងទៅឲ្យទាន់ចូលវស្សា ក្នុងក្រុងសាវត្ថីបានឡើយ ហើយនាំគ្នាចូលទៅចាំវស្សាក្នុងក្រុងសាកេត នាពាក់កណ្ដាលផ្លូវ។ ភិក្ខុទាំងនោះនៅចាំវស្សាទាំងមានសេចក្ដីអផ្សុក ព្រោះគិតថា ព្រះមានព្រះភាគ ព្រះអង្គគង់នៅក្នុងទីជិតយើងទាំងឡាយ ចម្ងាយ៦យោជន៍អំពីទីនេះទៅ យើងទាំងឡាយមិនសមបើមិនបានទៅគាល់ព្រះអង្គសោះ។ គ្រានោះ ពួកភិក្ខុទាំងនោះ នៅចាំវស្សាអស់ត្រៃមាស[2] រួចហើយក៏នាំគ្នាធ្វើបវារណា (រដូវនោះ) នៅមានទឹកភ្លៀងធ្លាក់ជោកជាំ មានទឹកភក់រអិលនៅឡើយ (ភិក្ខុទាំងនោះ) ក៏មានចីវរទាំងឡាយទទឹកជោក បានសេចក្ដីលំបាកកាយ នាំគ្នាដើរសំដៅទៅកាន់ក្រុងសាវត្ថី ហើយចូលទៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ ការស្រុសស្រួលទទួលជាមួយនឹងពួកភិក្ខុអាគន្តុកៈនេះ ជាទំនៀមរបស់ព្រះពុទ្ធដ៏មានព្រះភាគគ្រប់ព្រះអង្គ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលនេះ នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាល្មមអត់ទ្រាំបានទេឬ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅ បានស្រួលទេឬ អ្នកទាំងឡាយ មានសេចក្ដីសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួល មិនលំបាក ដោយអាហារបិណ្ឌបាតទេឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នា ល្មមអត់ទ្រាំបាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងអស់គ្នា សាមគ្គីស្មោះសរ ឥតវិវាទទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួលបួល មិនលំបាក ដោយអាហារបិណ្ឌបាតទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយ នៅក្នុងដែនបាឋា ប្រមាណ៣០រូប មកកាន់ក្រុងសាវត្ថីនេះ ដើម្បីគាល់ព្រះអង្គ កាលបើតិថីចូលវស្សាជិតណាស់ហើយ ក៏មិនអាចនឹងមកទាន់ពេលចូលវស្សា ក្នុងក្រុងសាវត្ថីបានឡើយ ក៏នៅចាំវស្សា ក្នុងក្រុងសាកេត នាពាក់កណ្ដាលផ្លូវ (នោះទៅ) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងនោះ នៅចាំវស្សាទាំងមានសេចក្ដីអផ្សុក ព្រោះគិតថា ព្រះដ៏មានព្រះភាគ ព្រះអង្គគង់នៅក្នុងទីជិតយើងទាំងឡាយ ចម្ងាយ៦យោជន៍ អំពីទីនេះទៅ យើងទាំងឡាយ មិនសមបើមិនបានទៅគាល់ព្រះអង្គសោះ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គទាំងអស់គ្នា នៅចាំវស្សាអស់ត្រៃមាសហើយ ក៏នាំគ្នាធ្វើបវារណា (ព្រោះរដូវនេះ) នៅមានទឹកភ្លៀងធ្លាក់ជោកជាំ មានទឹកភក់រអិលនៅឡើយ ទើបខ្ញុំព្រះអង្គទាំងអស់គ្នា មានចីវរទាំងឡាយទទឹកជោក បានសេចក្ដីលំបាកកាយ មកតាមផ្លូវឆ្ងាយ។

[២] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យពួកភិក្ខុ ដែលនៅចាំវស្សារួចហើយ ក្រាលកឋិនបាន។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ បានក្រាលកឋិនហើយ នឹងសម្រេចអានិសង្ស៥យ៉ាង គឺត្រាច់ទៅ (ណា) មិនបាច់លា (ភិក្ខុផងគ្នា)១ ត្រាច់ទៅ (ណា) មិនបាច់យកត្រៃចីវរ (គ្រប់ប្រដាប់)១ (ឆាន់) គណភោជនបាន១ (ទុកដាក់) អតិរេកចីវរបានតាមត្រូវការ១ ចីវរណា ដែលកើតឡើង ក្នុងអាវាសនោះ ចីវរនោះ នឹងមានដល់ភិក្ខុទាំងនោះ១។ ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំង៥នេះ នឹងសម្រេចដល់អ្នកទាំងឡាយដែលបានក្រាលកឋិន។ ម្នាលភិក្ខុទាំងឡាយ ក៏ឯកឋិន (នោះ) ត្រូវអ្នកទាំងឡាយ ក្រាលយ៉ាងនេះ។ គឺត្រូវឲ្យភិក្ខុអ្នកឆ្លាស ប្រតិពល ប្តឹងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ (ដ្បិត) សំពត់កឋិននេះ កើតឡើងដល់សង្ឃហើយ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ គួរសង្ឃឲ្យសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ខ្ញុំ (ដ្បិត) សំពត់កឋិននេះ កើតឡើងដល់សង្ឃហើយ។ (ឥឡូវ) សង្ឃឲ្យសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន។ ការឲ្យសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន (បើ) គួរ ដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះស្ងៀម (បើ) មិនគួរ ដល់លោកដ៏មានអាយុអង្គណាទេ ត្រូវលោកដ៏មានអាយុអង្គនោះនិយាយឡើង។ សំពត់កឋិននេះ សង្ឃឲ្យដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិនហើយ។ ការឲ្យសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ទំនងជាគួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវការនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ឯកឋិន ដែលភិក្ខុក្រាលឡើងបែបនេះ ក្រាលមិនឡើងបែបនេះ។

[៣] ម្នាលភិក្ខុទាំងឡាយ ចំណែកកឋិនដែលភិក្ខុក្រាលមិនឡើង តើដូចម្ដេច។ (ឯកឋិនដែលភិក្ខុក្រាលមិនឡើងនោះគឺ) សំពត់ដែលគ្រាន់តែវាស់គូសក្រិតចំណាំ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែបោកគក់លាង ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែចាត់ចែងលៃលកជាចីវរ (ជាខ័ណ្ឌមានបញ្ចខ័ណ្ឌជាដើម) ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែកាត់ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែដានភ្ជាប់គ្នា ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែដេរ (មានដេរបណ្ដោយជាដើម) ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែភ្ជាប់កណ្ដុំ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែថែមសំពត់ឲ្យមាំ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែប្រក់អនុវាត ខាងខ្នង ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែប្រក់អនុវាតខាងពោះ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែដេរគួបគ្នា ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលគ្រាន់តែជ្រលក់ម្ដង មានពណ៌ដូចភ្លុកដំរី ឬដូចស្លឹកឈើទុំ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលបានមក ព្រោះធ្វើនិមិត្ត ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលបានមក ព្រោះនិយាយបញ្ចុះបញ្ចូលគេ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលខ្ចីគេមកក្រាល មិនឡើងជាកឋិន។ សំពត់ដែលមិនបានធ្វើឲ្យស្រេចក្នុងថ្ងៃនោះ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលធ្វើឲ្យកន្លងរាត្រី គឺឲ្យអរុណរះឡើងទាន់ ហើយក្រាល មិនឡើងជាកឋិន។ សំពត់ដែលមិនបានធ្វើពិន្ទុកប្ប ហើយក្រាល មិនឡើងជាកឋិន។ វៀរចាកសង្ឃាដី ហើយក្រាល មិនឡើងជាកឋិន។ វៀរចាកឧត្តរាសង្គ ហើយក្រាល មិនឡើងជាកឋិន។ វៀរចាកអន្តរវាសក ហើយក្រាល មិនឡើងជាកឋិន។ វៀរចាកចីវរមានមណ្ឌលគ្រប់គ្រាន់ ដែលកាត់ដាច់ជាបញ្ចខ័ណ្ឌក្ដី លើសពីបញ្ចខ័ណ្ឌក្ដី ក្នុងថ្ងៃនោះឯង ហើយក្រាល ក៏មិនឡើងជាកឋិន។ មិនឲ្យបុគ្គលក្រាល (ទៅឲ្យសង្ឃ ឬគណៈក្រាលវិញ) មិនឡើងជាកឋិន។ ការក្រាលមិនត្រឹមត្រូវ ក៏មិនឡើងជាកឋិន។ បើភិក្ខុនៅក្រៅសីមា ហើយអនុមោទនាកឋិននោះ ការក្រាលបែបនេះ មិនឡើងជាកឋិនឡើយ។ ម្នាលភិក្ខុទាំងឡាយ ការក្រាលកឋិនដូចន័យ ដែលតថាគតពោលមកនេះឯង មិនឡើងជាកឋិនទេ។

[៤] ម្នាលភិក្ខុទាំងឡាយ ចំណែកកឋិនដែលភិក្ខុក្រាលឡើង(នោះ) តើដូចម្តេច។ (ឯកឋិនដែលភិក្ខុក្រាលឡើងនោះគឺ) សំពត់ថ្មី ក្រាលឡើងជាកឋិន។ សំពត់ជំនំ ក្រាលឡើងជាកឋិន។ សំពត់ចាស់ ក្រាលឡើងជាកឋិន។ សំពត់បង្សុកូល ក្រាលឡើងជាកឋិន។ សំពត់ដែលធ្លាក់ទៀបរានផ្សារ ក្រាលឡើងជាកឋិន។ សំពត់ដែលបានមកដោយមិនបានធ្វើនិមិត្ត ក្រាលឡើងជាកឋិន។ សំពត់ដែលបានមក ដោយមិនបាននិយាយបញ្ចុះបញ្ចូល ក្រាលឡើងជាកឋិន។ សំពត់ដែលមិនខ្ចីគេ ក្រាលឡើងជាកឋិន។ សំពត់ដែលបានធ្វើឲ្យស្រេចក្នុងថ្ងៃនោះ ក្រាលឡើងជាកឋិន។ សំពត់ដែលមិនធ្វើឲ្យកន្លងរាត្រី គឺមិនឲ្យអរុណរះឡើងទាន់ ក្រាលឡើងជាកឋិន។ សំពត់ដែលបានធ្វើពិន្ទុកប្បហើយ ក្រាលឡើងជាកឋិន។ សង្ឃាដិ ក្រាលឡើងជាកឋិន។ ឧត្តរាសង្គ ក្រាលឡើងជាកឋិន។ អន្តរវាសក ក្រាលឡើងជាកឋិន។ សំពត់ដែលមានមណ្ឌលគ្រប់គ្រាន់ កាត់ដាច់ត្រឹមត្រូវជាបញ្ចខ័ណ្ឌក្តី លើសពីបញ្ចខ័ណ្ឌក្តី ក្នុងថ្ងៃនោះឯង ហើយក្រាល ឡើងជាកឋិន។ ឲ្យបុគ្គលក្រាល ទើបឡើងជាកឋិន។ ការក្រាលដោយត្រឹមត្រូវ ទើបបានឡើងជាកឋិន។ បើភិក្ខុនៅក្នុងសីមា ហើយអនុមោទនាកឋិននោះ ការក្រាលបែបនេះ ទើបឡើងជាកឋិន។ ម្នាលភិក្ខុទាំងឡាយ ការក្រាលកឋិនដូចន័យដែលតថាគតពោលមកនេះឯង ទើបឡើងជាកឋិនបាន។

[៥] ម្នាលភិក្ខុទាំងឡាយ ឯកឋិននឹងដោះ (នោះ) តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ មាតិកាទាំង៨ប្រការនេះ នាំឲ្យកឋិនដោះ គឺ មានការចៀសចេញទៅជាកំណត់១ មានការធ្វើចីវរសម្រេច ជាកំណត់១ មានសេចក្តីសន្និដ្ឋាន ជាកំណត់១ មានចីវរវិនាសទៅ ជាកំណត់១ មានការឮដំណឹង ជាកំណត់១ អស់សេចក្តីសង្ឃឹម១ មានការកន្លងខេត្តកឋិន ជាកំណត់១ សង្ឃព្រមព្រៀងគ្នាដោះកឋិន១។

## ១៨៨. អាទាយសត្តកំ

CS vin.mv.07.02 | ភាគ ទី៨

### អាទាយសត្តកៈ ជាបឋម

[៦] ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលខ្លួនធ្វើស្រេចចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ការដែលចៀសចេញទៅ ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យស្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ធ្វើចីវរឲ្យស្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះធ្វើចីវរស្រេចហើយ ឮដំណឹងថា សង្ឃបានដកកឋិនក្នុងអាវាសនោះហើយ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់បានឮដំណឹង ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះធ្វើចីវរស្រេចហើយ ក៏នៅតែគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់នៅឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ) ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយ គិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ។

ចប់ អាទាយសត្តកៈ ជាបឋម។

## ១៨៩. សមាទាយសត្តកំ

CS vin.mv.07.03 | ភាគ ទី៨

### សមាទាយសត្តកៈ ទី ២

[៧] ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើហើយចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ការដែលចៀសចេញទៅ ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យស្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ធ្វើចីវរឲ្យស្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះបានធ្វើចីវររួច ក៏បានឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃបានព្រមគ្នាដកហើយ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់បានឮដំណឹង ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះបានធ្វើចីវរស្រេចហើយ ក៏នៅតែគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បាន

ត្រឡប់នៅឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ) ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយ គិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ។

ចប់ សមាទាយសត្តកៈទី២។

## ១៩០. អាទាយឆក្កំ

CS vin.mv.07.04 | ភាគ ទី៨

### អាទាយឆក្កៈ ទី ៣

[៨] ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ធ្វើចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះ កំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយ ក៏ស្រាប់តែឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់បានឮដំណឹង ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយ គិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់នៅឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ) ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ដោយគិតថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះបានធ្វើចីវររួចហើយ ក៏គិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ។

ចប់ អាទាយឆក្កៈ ទី ៣។

## ១៩១. សមាទាយឆក្កំ

CS vin.mv.07.05 | ភាគ ទី៨

### សមាទាយឆក្កៈ ទី ៤

[៩] ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានសេចក្តីតាំងចិត្តយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ធ្វើចីវរឲ្យសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានសេចក្តីតាំងចិត្តយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវររបស់ភិក្ខុនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះបានធ្វើចីវរហើយ ឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃបានព្រមគ្នាដកហើយ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ឮដំណឹង ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ដោយតាំងចិត្តថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះធ្វើចីវរហើយ ក៏នៅគិតថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់នៅឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ) ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេចចៀសចេញទៅ ដោយតាំងចិត្តថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ ភិក្ខុនោះធ្វើចីវរហើយ តាំងចិត្តថា អាត្មាអញនឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ។

ចប់ សមាទាយឆក្កៈ ទី ៤។

## ១៩២. អាទាយបន្នរសកំ

CS vin.mv.07.06 | ភាគ ទី៨

[១០] ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ធ្វើចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

[១១] ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយតាំងចិត្តថា អាត្មាអញនឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ធ្វើចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយតាំងចិត្តថា អាត្មាអញនឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះឡើយ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយតាំងចិត្តថា អាត្មាអញនឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

[១២] ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញ ក៏គ្មានដែរ។[3] កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញនឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញនឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

[១៣] ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ធ្វើចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ ភិក្ខុនោះធ្វើចីវររួចហើយ ឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ឮដំណឹង ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះធ្វើចីវរស្រេចហើយ គិតថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់នៅឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ) ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ លុះភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ ភិក្ខុនោះធ្វើចីវរនោះស្រេចហើយ គិតថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញ នឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ។

## ១៩៣. សមាទាយបន្នរសកាទិ

CS vin.mv.07.07 | ភាគ ទី៨

(១៩៣)

[១៤] ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរចៀសចេញទៅ។ (ពាក្យយ៉ាងនេះ ប្រហែលនឹងអាទាយវារៈ បណ្ឌិតគប្បីសំដែងឲ្យពិស្តារចុះ)។ ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ (ពាក្យយ៉ាងនេះ ប្រហែលនឹងសមាទាយវារៈ បណ្ឌិតគប្បីសំដែងឲ្យពិស្តារចុះ)។

## ១៩៤. វិប្បកតសមាទាយបន្នរសកំ

CS vin.mv.07.08 | ភាគ ទី៨

**(១៩៤)**

[១៥] ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្ដីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ។ កាលភិក្ខុនោះទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

[១៦] ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្ដីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

[១៧] ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញនឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្ដីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

[១៨] ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេច ចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្ដីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញនឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះ ធ្វើចីវរសម្រេចហើយ ក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់បានឮដំណឹង ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេចចៀសចេញទៅ ដោយបំណងថា អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ ភិក្ខុនោះធ្វើចីវរស្រេចហើយ គិតថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញនឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់នៅឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ) ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ប្រមូលយកចីវរដែលធ្វើមិនទាន់សម្រេច ចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះ។ លុះភិក្ខុនោះ ធ្វើចីវរនោះសម្រេចហើយ គិតថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញ នឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ។

ចប់ សមាទាយភាណវារៈ។

## ១៩៥. អនាសាទោឡសកំ

CS vin.mv.07.09 | ភាគ ទី៨

### (ការបានចីវរ) ខុសបំណង១២ប្រការ។

[១៩] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ។ លុះភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះ ក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ។ ឯសេចក្តីចង់បានចីវររបស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្តីសង្ឃឹម។

[២០] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ហើយចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះ ក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ។ ឯសេចក្តីចង់បានចីវររបស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្តីសង្ឃឹម។

[២១] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះ ក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះគ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ។ ឯសេចក្តីចង់បានចីវររបស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្តីសង្ឃឹម។

ចប់ (ការបានចីវរ) ខុសបំណង១២ប្រការ។

## ១៩៦. អាសាទោឡសកំ

CS vin.mv.07.10 | ភាគ ទី៨

### (ការបានចីវរ) ត្រូវតាមបំណង១២ប្រការ។

[២២] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរ

សម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមាហើយ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមាហើយ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះ ក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ហើយមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ។ ឯសេចក្តីចង់បានចីវររបស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្តីសង្ឃឹម។

[២៣] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា កឋិនក្នុងអាវាសនោះ កាលណាបើសង្ឃព្រមគ្នាដកហើយ អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា កឋិនក្នុងអាវាសនោះ កាលណាបើសង្ឃព្រមគ្នាដកហើយ អាត្មាអញ នឹងចូលទៅកាន់ទី ដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា កឋិនក្នុងអាវាសនោះ កាលណាបើសង្ឃព្រមគ្នាដកហើយ អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា កឋិនក្នុងអាវាសនោះ កាលណាបើសង្ឃព្រមគ្នាដកហើយ អាត្មាអញនឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ។ ឯសេចក្តីចង់បានចីវរនោះរបស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្តីសង្ឃឹម។

[២៤] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។លុះភិក្ខុនោះ ធ្វើចីវររួចហើយ ក៏ឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ឮដំណឹង ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ។ ឯសេចក្តីចង់បានចីវររបស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្តីសង្ឃឹម។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ ភិក្ខុនោះធ្វើចីវររួចហើយ ក៏គិតថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញ នឹងត្រឡប់វិញដែរ (តែមិនទាន់បានត្រឡប់នៅឡើយ) កឋិនក៏ដោះខាងក្រៅ (នោះ)ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ព្រោះចង់បានចីវរ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ត្រូវតាមបំណង គឺមិនបានខុសបំណង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ ភិក្ខុនោះធ្វើចីវររួចហើយ គិតថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញ នឹងត្រឡប់វិញ ហើយក៏មកទាន់ពេលដោះកឋិនមែន។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ។

ចប់ (ការបានចីវរ) ត្រូវតាមបំណង១២ប្រការ។

## ១៩៧. ករណីយទោឡសកំ

CS vin.mv.07.11 | ភាគ ទី៨

### ករណីយកិច្ច១២ប្រការ។

[២៥] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្តីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា

អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្ដីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ។ ភិក្ខុនោះ ទៅដល់ក្រៅសីមាហើយ សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះ កំពុងធ្វើ ចីវរនោះ ក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងចូលទៅកាន់ទី ដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ចូលទៅកាន់ទី ដែលខ្លួនអញចង់បានចីវរនោះ។ ឯសេចក្ដីចង់បានចីវរនោះ របស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្ដីសង្ឃឹម។

[២៦] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ ចូលទៅកាន់ទី ដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ)ខុស បំណង គឺមិនបានត្រូវតាមបំណង។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្ដីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលទៅកាន់ទី ដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង។ ភិក្ខុនោះ ចូលទៅកាន់ទី ដែលខ្លួនចង់បានចីវរនោះ។ ឯសេចក្ដីចង់បានចីវរ របស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្ដីសង្ឃឹម។

[២៧] ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះ គ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះ គ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានត្រូវតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្ដីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះ គ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ កាលភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ ក៏បាន (ចីវរ) ខុសបំណង គឺមិនបានតាមបំណង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ធ្វើចីវរនោះ។ កាលភិក្ខុកំពុងធ្វើចីវរក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅ ដោយមានកិច្ចឯណានីមួយ ដោយមិនបានតាំងចិត្ត គឺភិក្ខុនោះ គ្មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ទាំងគំនិតរបស់ភិក្ខុនោះថា អាត្មាអញ នឹងមិនត្រឡប់វិញ ក៏គ្មានដែរ។ កាលភិក្ខុនោះ ទៅដល់ក្រៅសីមា សេចក្ដីចង់បានចីវរ ក៏កើតឡើង។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងចូលទៅកាន់ទីដែលអាត្មាអញចង់បានចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ចូលទៅកាន់ទីដែលខ្លួនចង់បានចីវរនោះ។ ឯសេចក្ដីចង់បានចីវររបស់ភិក្ខុនោះ ក៏ដាច់ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់អស់សេចក្ដីសង្ឃឹម។

ចប់ ករណីយកិច្ច១២ប្រការ។

## ១៩៨. អបវិលាយននវកំ

CS vin.mv.07.12 | ភាគ ទី៨

### សេចក្ដីមិនខ្វល់ខ្វាយ (ក្នុងចីវរ) ៩ប្រការ។

[២៨] ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ ឥតមានសេចក្ដីខ្វល់ខ្វាយនឹងចំណែកនៃចីវរ (របស់ខ្លួន) ភិក្ខុទាំងឡាយ សួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកនៅចាំវស្សាក្នុងអាវាសណា ម្យ៉ាងទៀត ចំណែកចីវររបស់លោក

(មាននៅ) ក្នុងអាវាសណា។ ភិក្ខុនោះ ពោលតបយ៉ាងនេះថា ខ្ញុំនៅចាំវស្សាក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (ក៏មាននៅ) ក្នុងអាវាសនោះដែរ។ ទើបភិក្ខុទាំងនោះ ពោលយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចូរលោកទៅយកចីវរនោះមក យើងទាំងឡាយ នឹងធ្វើចីវរឲ្យលោកក្នុងទីនេះ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយ ក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុទាំងឡាយ ចំណែកចីវររបស់ខ្ញុំ ទុកក្នុងទីណា។ ភិក្ខុទាំងនោះ ពោលតបយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះ ជាចំណែករបស់លោកហើយ តើលោកនឹងទៅក្នុងទីណា។ ភិក្ខុនោះឆ្លើយយ៉ាងនេះថា ខ្ញុំនឹងទៅកាន់អាវាសឯណោះ ដ្បិតពួកភិក្ខុក្នុងអាវាសនោះ បំរុងនឹងធ្វើចីវរឲ្យខ្ញុំ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ណ្ហើយលោកដ៏មានអាយុ លោកកុំទៅឡើយ យើងទាំងឡាយនឹងធ្វើចីវរឲ្យលោកក្នុងទីនេះ។ ឯភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ។បេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ។បេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

[២៩] ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ គ្មានសេចក្តីខ្វល់ខ្វាយនឹងចំណែកចីវរ (របស់ខ្លួន)។ ភិក្ខុទាំងឡាយ សួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកនៅចាំវស្សាក្នុងអាវាសណា មួយទៀត ចំណែកចីវររបស់លោក (មាននៅ) ក្នុងអាវាសណា។ ភិក្ខុនោះ ឆ្លើយតបយ៉ាងនេះថា ខ្ញុំនៅចាំវស្សាក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (មាននៅ) ក្នុងអាវាសនោះដែរ។ ភិក្ខុទាំងនោះ និយាយថា ម្នាលលោកដ៏មានអាយុ ចូរលោកទៅយកចីវរនោះមក យើងទាំងឡាយ នឹងធ្វើចីវរឲ្យលោកក្នុងទីនេះ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយ ក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុទាំងឡាយ ចំណែកចីវររបស់ខ្ញុំ (ទុក)ក្នុងទីណា។ ភិក្ខុទាំងនោះ ឆ្លើយតបយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះ ជាចំណែករបស់លោក។ ភិក្ខុនោះ ក៏នាំយកចីវរនោះ ហើយដើរទៅកាន់អាវាសនោះ។ ដល់ពាក់កណ្តាលផ្លូវ ភិក្ខុទាំងឡាយ ក៏សួរភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកទៅឯណា។ ភិក្ខុនោះប្រាប់យ៉ាងនេះថា ខ្ញុំនឹងទៅអាវាសឯណោះ (ដ្បិត) ពួកភិក្ខុក្នុងអាវាសនោះ បំរុងនឹងធ្វើចីវរឲ្យខ្ញុំ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ណ្ហើយលោកដ៏មានអាយុ លោកកុំទៅឡើយ យើងទាំងឡាយ នឹងធ្វើចីវរឲ្យលោក ក្នុងទីនេះ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់មកវិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ គ្មានសេចក្តីខ្វល់ខ្វាយនឹងចំណែកចីវរ (របស់ខ្លួនទេ)។ ភិក្ខុទាំងឡាយ សួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកនៅចាំវស្សាក្នុងអាវាសណា មួយទៀត ចំណែកចីវររបស់លោក (មាននៅ) ក្នុងអាវាសណា។ ភិក្ខុនោះ ឆ្លើយតបយ៉ាងនេះថា ខ្ញុំនៅចាំវស្សាក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (មាននៅ) ក្នុងអាវាសនោះដែរ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ លោកចូរទៅយកចីវរនោះមក យើងទាំងឡាយ នឹងធ្វើចីវរឲ្យលោកក្នុងទីនេះ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយ ក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុទាំងឡាយ ចំណែកចីវររបស់ខ្ញុំ (ទុក)ក្នុងឯទីណា។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះ ជាចំណែករបស់លោក។ ភិក្ខុនោះ ក៏នាំយកចីវរនោះ ហើយដើរទៅកាន់អាវាសនោះ។ ដល់ពាក់កណ្តាលផ្លូវ ភិក្ខុទាំងឡាយ ក៏សួរភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកទៅឯណា។ ភិក្ខុនោះឆ្លើយប្រាប់យ៉ាងនេះថា ខ្ញុំទៅកាន់អាវាសឯណោះ (ដ្បិត) ពួកភិក្ខុក្នុងអាវាសនោះ បំរុងនឹងធ្វើចីវរឲ្យខ្ញុំ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ណ្ហើយលោកដ៏មានអាយុ លោកកុំទៅឡើយ យើងទាំងឡាយ នឹងធ្វើចីវរឲ្យលោកក្នុងទីនេះ។ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ គ្មានសេចក្តីខ្វល់ខ្វាយនឹងចំណែកចីវរ (របស់ខ្លួន)។ ភិក្ខុទាំងឡាយ សួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកនៅចាំវស្សាក្នុងអាវាសណា មួយទៀត ចំណែកចីវររបស់លោក (មាននៅ) ក្នុងអាវាសណា។ ភិក្ខុនោះ ប្រាប់យ៉ាងនេះថា ខ្ញុំនៅចាំវស្សាក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (មាននៅ) ក្នុងអាវាសនោះដែរ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចូរលោកទៅយកចីវរនោះមក យើងទាំងឡាយ នឹងធ្វើចីវរឲ្យលោកក្នុងទីនេះ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយ ក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុទាំងឡាយ ចំណែកចីវររបស់ខ្ញុំ (ទុក)ក្នុងទីណា។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះ ជាចំណែករបស់លោក។ ភិក្ខុនោះ ក៏នាំយកចីវរនោះ ហើយទៅកាន់អាវាសនោះ។ ដល់ពាក់កណ្តាលផ្លូវ ភិក្ខុទាំងឡាយ សួរភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកទៅឯណា។ ភិក្ខុនោះតបយ៉ាងនេះថា ខ្ញុំនឹងទៅកាន់អាវាសឯណោះ (ដ្បិត) ភិក្ខុទាំងឡាយ ក្នុងអាវាសនោះ បំរុងនឹងធ្វើចីវរឲ្យខ្ញុំ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ណ្ហើយលោកដ៏មានអាយុ លោកកុំទៅឡើយ យើងទាំងឡាយ នឹងធ្វើចីវរឲ្យលោក ក្នុងទីនេះ។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏ធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

[៣០] ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ គ្មានសេចក្តីខ្វល់ខ្វាយនឹងចំណែកចីវរ (របស់ខ្លួន)។ ភិក្ខុទាំងឡាយ សួរភិក្ខុដែលទៅកាន់ទិសនោះថា ម្នាលលោកដ៏មានអាយុ លោកនៅចាំវស្សាក្នុងអាវាសណា មួយទៀត ចំណែកចីវររបស់លោក (មាននៅ) ក្នុងអាវាសណា។ ភិក្ខុនោះ ប្រាប់យ៉ាងនេះថា ខ្ញុំនៅចាំវស្សាក្នុងអាវាសឯណោះ ឯចំណែកចីវររបស់ខ្ញុំ (មាននៅ) ក្នុងអាវាសនោះដែរ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចូរលោកទៅយកចីវរនោះមក យើងទាំងឡាយ នឹងធ្វើចីវរឲ្យលោកក្នុងទីនេះ។ លុះភិក្ខុនោះទៅកាន់អាវាសនោះហើយ ក៏សួរភិក្ខុទាំងឡាយថា នែលោកដ៏មានអាយុទាំងឡាយ ចំណែកចីវររបស់ខ្ញុំ (ទុក)ក្នុងទីណា។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ចីវរនេះ ជាចំណែករបស់លោក។ ភិក្ខុនោះ ក៏នាំយកចីវរនោះ ហើយទៅកាន់អាវាសនោះ។ លុះភិក្ខុនោះទៅដល់អាវាសនោះហើយ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ។បេ។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចហើយ មានដំណើរទៅកាន់ទិស ក៏ចៀសចេញទៅ។បេ។ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះ។ កាលភិក្ខុនោះកំពុងធ្វើ ចីវរនោះក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។

ចប់ សេចក្តីមិនខ្វល់ខ្វាយ (ក្នុងចីវរ) ៩ប្រការ។

## ១៩៩. ផាសុវិហារបញ្ចកំ

CS vin.mv.07.13 | ភាគ ទី៨

### កិរិយានៅជាសុខសប្បាយ ៥ប្រការ។

[៣១] ភិក្ខុបានក្រាលកឋិនរួចនៅជាសុខសប្បាយ ហើយនាំយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងទៅកាន់អាវាសឯណោះ បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើគ្មានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើគ្មានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញ នឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើគ្មានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចនៅជាសុខសប្បាយ ហើយនាំយកចីវរចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងទៅកាន់អាវាសឯណោះ បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើគ្មានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយ ដល់អាត្មាអញទេ អាត្មាអញ នឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយ ដល់អាត្មាអញ ៗនឹងនៅ បើឥតសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងមិនធ្វើចីវរនេះទេ អាត្មាអញ នឹងមិនត្រឡប់វិញទេ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចនៅជាសុខសប្បាយ ហើយនាំយកចីវរ ដែលមិនទាន់ធ្វើ ចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងទៅកាន់អាវាសឯណោះ បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញ នឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយ ដល់អាត្មាអញទេ អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏មានគំនិតយ៉ាងនេះថា អាត្មាអញ នឹងធ្វើចីវរនេះ ក្នុងទីនេះឯង អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ភិក្ខុនោះ ក៏បានធ្វើចីវរនោះឲ្យសម្រេច។ កាលភិក្ខុកំពុងធ្វើ ចីវរនោះ ក៏វិនាសទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចនៅជាសុខសប្បាយ ហើយនាំយកចីវរ ដែលមិនទាន់ធ្វើ ចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងទៅកាន់អាវាសឯណោះ បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញ នឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយ ដល់អាត្មាអញទេ អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏ធ្វើចីវរនោះ។ ភិក្ខុនោះ ធ្វើចីវររួចហើយ គិតថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញ នឹងត្រឡប់វិញដែរ (តែមិនទាន់មកនៅឡើយ) កឋិន ក៏ដោះខាងក្រៅ (នោះ) ទៅ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់។ ភិក្ខុបានក្រាលកឋិនរួចនៅជាសុខសប្បាយ ហើយនាំយកចីវរ ដែលមិនទាន់ធ្វើហើយ ចៀសចេញទៅ ដោយគិតថា អាត្មាអញ នឹងទៅកាន់អាវាសឯណោះ បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញនឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយដល់អាត្មាអញទេ អាត្មាអញ នឹងទៅកាន់អាវាសឯណោះ (ទៀត) បើក្នុងអាវាសនោះ មានសេចក្តីសប្បាយដល់អាត្មាអញ ៗនឹងនៅ បើឥតមានសេចក្តីសប្បាយ ដល់អាត្មាអញទេ អាត្មាអញ នឹងត្រឡប់វិញ។ ភិក្ខុនោះ ទៅដល់ក្រៅសីមា ក៏បានធ្វើចីវរនោះឲ្យសម្រេច។ ភិក្ខុនោះ ធ្វើចីវររួចហើយ គិតថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញ នឹងត្រឡប់វិញ ហើយក៏មកទាន់ពេលដោះកឋិននោះមែន។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ។

ចប់ កិរិយានៅជាសុខសប្បាយ ៥ប្រការ។

## ២០០. បលិពោធាបលិពោធកថា

CS vin.mv.07.14 | ភាគ ទី៨

### (២០០)

[៣២] ម្នាលភិក្ខុទាំងឡាយ បលិពោធ (កង្វល់) របស់កឋិននេះ មាន២យ៉ាង អបលិពោធ (គ្មានកង្វល់) របស់កឋិននេះ មាន២យ៉ាង។ ម្នាលភិក្ខុទាំងឡាយ បលិពោធរបស់កឋិនទាំង២យ៉ាង (នោះ) ដូចម្តេច។ (ឯបលិពោធរបស់កឋិនទាំង២យ៉ាងនោះ) គឺ អាវាសបលិពោធ (កង្វល់ក្នុងអាវាស)១ ចីវរបលិពោធ (កង្វល់ក្នុងចីវរ)១។ ម្នាលភិក្ខុទាំងឡាយ ឯអាវាសបលិពោធ (នោះ) ដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងអាវាសនោះក្តី មានសេចក្តីអាល័យចំពោះអាវាសនោះ ហើយចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញក្តី។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា អាវាសបលិពោធ។ ម្នាលភិក្ខុទាំងឡាយ ឯចីវរបលិពោធ (នោះ) តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ចីវរដែលភិក្ខុក្នុងសាសនានេះ មិនទាន់បានធ្វើឬ ឬថាបានធ្វើហើយ តែមិនទាន់ស្រេច ទាំងសេចក្តីប្រាថ្នាចីវរ ក៏មិនទាន់ដាច់នៅឡើយ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហើយ ដែលហៅថា ចីវរបលិពោធ។ ម្នាលភិក្ខុទាំងឡាយ បលិពោធរបស់កឋិន មាន២យ៉ាងដូច្នេះឯង។ ម្នាលភិក្ខុទាំងឡាយ ចំណែកអបលិពោធ របស់កឋិន មាន២យ៉ាង (នោះ) ដូចម្តេចខ្លះ។ (ឯអបលិពោធទាំង២យ៉ាងនោះ) គឺ អាវាសាបលិពោធ (គ្មានកង្វល់ក្នុងអាវាស)១ ចីវរាបលិពោធ (គ្មានកង្វល់ក្នុងចីវរ)១។ ម្នាលភិក្ខុទាំងឡាយ អាវាសាបលិពោធ (នោះ) តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

ដើរចៀសចេញ ទៅចាកអាវាសនោះ ដោយលះបង់ចោលស្រឡះ ដាច់អាល័យថា អាត្មាអញ នឹងមិនត្រឡប់វិញទេ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា អាវាសាបលិពោធ។ ម្នាលភិក្ខុទាំងឡាយ ឯចីវរាបលិពោធ (នោះ) តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ចីវរដែលភិក្ខុក្នុងសាសនានេះ បានធ្វើហើយក្តី បាត់ទៅក្តី វិនាសទៅក្តី ភ្លើងឆេះទៅក្តី សេចក្តីប្រាថ្នាចីវរដាច់ទៅក្តី។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា ចីវរាបលិពោធ។ ម្នាលភិក្ខុទាំងឡាយ អបលិពោធ របស់កឋិន មាន២យ៉ាងដូច្នេះឯង។

ចប់ កឋិនក្ខន្ធកៈ ទី៧។

ក្នុងកឋិនក្ខន្ធកៈនេះ មានរឿង១១៨ មានបេយ្យាល១២ ជាប្រធាន។

## ២០១. តស្សុទ្ទានំ

CS vin.mv.07.15 | ភាគ ទី៨

### ឧទ្ទាននៃកឋិនក្ខន្ធកៈនោះគឺ

[៣៣] រឿងបាថេយ្យកភិក្ខុ៣០រូប មានសេចក្តីអផ្សុក នៅក្នុងស្រុកសាកេត លុះនៅចាំវស្សារួចហើយ ក៏មានចីវរទទឹកជោកមកគាល់ព្រះជិនស្រី នេះជារឿង (ខាងដើម) នៃកឋិន១ រឿងអានិសង្សទាំង៥ សម្រេចដល់ភិក្ខុដែលបានក្រាលកឋិនហើយ គឺ ភិក្ខុចេញទៅណា មិនបាច់លាភិក្ខុផងគ្នា ត្រាច់ទៅណា មិនបាច់យកត្រៃចីវរគ្រប់ប្រដាប់បាន ឆាន់គណភោជនបាន ទុកដាក់អតិរេកចីវរបានតាមត្រូវការ និងចីវរដែលកើតឡើងដល់សង្ឃ គួរបានដល់ពួកភិក្ខុដែលបានក្រាលកឋិនហើយ១។ រឿងសូត្រញត្តិ១ រឿងក្រាលកឋិនឡើងបែបយ៉ាងនេះ និងក្រាលកឋិនមិនឡើងបែបយ៉ាងនេះ (ឯការក្រាលកឋិនមិនឡើងនោះ) គឺ (ក្រាលដោយសំពត់គ្រាន់តែ) គូសក្រិតចំណាំ១ គ្រាន់តែបោកគក់លាង១ គ្រាន់តែចាត់ចែងលៃលក១ គ្រាន់តែកាត់១ គ្រាន់តែដានភ្ជាប់គ្នា១ គ្រាន់តែដេរ១ គ្រាន់តែភ្ជាប់កណ្តៅ១ គ្រាន់តែថែមសំពត់ឲ្យមាំ១ គ្រាន់តែប្រក់អនុវាត (ខាងខ្នង)១ គ្រាន់តែប្រក់អនុវាត (ខាងពោះ)១ គ្រាន់តែដេរគួបគ្នាជាពីរ១ គ្រាន់តែជ្រលក់ឲ្យមានពណ៌ដូចភ្លុកដំរី ឬដូចស្លឹកឈើទុំ១ សំពត់ដែលបានមក ព្រោះធ្វើនិមិត្រ១ សំពត់ដែលបានមក ព្រោះនិយាយបញ្ចុះបញ្ចូលគេ១ សំពត់ដែលខ្ចីគេ១ សំពត់ដែលមិនបានធ្វើឲ្យសម្រេចថ្ងៃនោះ១ សំពត់ដែលធ្វើឲ្យកន្លងរាត្រី គឺឲ្យអរុណរះឡើងទាន់១ សំពត់ដែលមិនបានធ្វើពិន្ទុកប្ប១ វៀរចាកចីវរទាំងបី១ វៀរចាកចីវរមានមណ្ឌលគ្រប់គ្រាន់ ដែលកាត់ដាច់ជាបញ្ចខ័ណ្ឌក្តី លើសពីបញ្ចខ័ណ្ឌក្តី១ មិនឲ្យបុគ្គលក្រាល (ទៅឲ្យសង្ឃ ឬគណៈក្រាលវិញ)១ ការក្រាលមិនត្រឹមត្រូវ ឬភិក្ខុនៅក្រៅសីមាអនុមោទនា១ កឋិនដែលក្រាលមិនឡើង ព្រះពុទ្ធជាម្ចាស់ ទ្រង់សំដែងហើយ យ៉ាងនេះឯង (ឯការក្រាលកឋិនឡើងនោះគឺ) ក្រាលដោយសំពត់ថ្មី១ សំពត់ជំនំ១ សំពត់ចាស់១ សំពត់បង្សុកូល១ សំពត់ធ្លាក់ចុះទៀបរានផ្សារ១ សំពត់ដែលបានមកដោយមិនបានធ្វើនិមិត្ត១ សំពត់ដែលបានមកដោយមិនបាននិយាយបញ្ចុះបញ្ចូល១ សំពត់ដែលមិនខ្ចីគេ១ សំពត់ដែលបានធ្វើសម្រេចក្នុងថ្ងៃនោះ១ សំពត់ដែលមិនធ្វើឲ្យកន្លងរាត្រី គឺមិនឲ្យអរុណរះឡើងទាន់១ សំពត់ដែលបានធ្វើពិន្ទុកប្ប១ ក្រាលដោយចីវរទាំង៣ (ចីវរណាមួយក៏បាន)១ សំពត់ដែលធ្វើឲ្យមានមណ្ឌលគ្រប់គ្រាន់ កាត់ដាច់ត្រឹមត្រូវជាបញ្ចខ័ណ្ឌក្តី លើសពីបញ្ចខ័ណ្ឌក្តី១ ឲ្យបុគ្គលក្រាល១ ការក្រាលដោយត្រឹមត្រូវ ឬភិក្ខុក្នុងសីមាអនុមោទនា១ ការក្រាលឡើងជាកឋិន ដោយអាការយ៉ាងនេះឯង មាតិកានាំឲ្យកឋិនដោះ មាន៨យ៉ាង គឺ មានការចៀសចេញទៅ ជាកំណត់១ មានការធ្វើចីវរសម្រេច ជាកំណត់១ មានសេចក្តីសន្និដ្ឋាន ជាកំណត់១ មានចីវរវិនាស ជាកំណត់១ មានការឮដំណឹង ជាកំណត់១ អស់សេចក្តីសង្ឃឹម១ មានការកន្លងខេត្តកឋិន ជាកំណត់១ សង្ឃព្រមព្រៀងគ្នាដោះកឋិនមួយទៀត ជាគំរប់ប្រាំបី១ (អធិប្បាយថា) ភិក្ខុនាំយកចីវរ ដែលធ្វើហើយ ចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញទេ កឋិននោះ របស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចៀសចេញទៅ ជាកំណត់ ភិក្ខុនាំយកចីវរ ចៀសចេញទៅ លុះទៅដល់ក្រៅសីមា ក៏មានគំនិតថា អាត្មាអញ នឹងធ្វើចីវរក្នុងទីនេះ អាត្មាអញ នឹងមិនត្រឡប់វិញទេ កឋិន (របស់ភិក្ខុនោះ) ឈ្មោះថាដោះ ត្រង់ចីវរសម្រេច ជាកំណត់។ ភិក្ខុនាំយកចីវរ ចៀសចេញទៅ លុះទៅដល់ក្រៅសីមា ក៏មានគំនិតថា អាត្មាអញ នឹងមិនធ្វើ (ចីវរនេះ) អាត្មាអញ នឹងមិនត្រឡប់វិញទេ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់ ភិក្ខុនាំយកចីវរ ចៀសចេញទៅ លុះទៅដល់ក្រៅសីមា ក៏មានគំនិតថា អាត្មាអញ នឹងធ្វើចីវរក្នុងទីនេះ អាត្មាអញនឹងមិនត្រឡប់វិញទេ កាលភិក្ខុនោះកំពុងធ្វើ ចីវរក៏វិនាសទៅ កឋិននោះ របស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ចីវរវិនាស ជាកំណត់ ភិក្ខុនាំយកចីវរ ចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ ក៏ធ្វើចីវរ (នោះ) ខាងក្រៅសីមា លុះធ្វើចីវរស្រេច ស្រាប់តែឮដំណឹងថា កឋិនក្នុងអាវាសនោះ សង្ឃព្រមគ្នាដកហើយ កឋិននោះរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់ឮដំណឹង ជាកំណត់ ភិក្ខុនាំយកចីវរ ចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ ក៏ធ្វើចីវរ (នោះ) ខាងក្រៅសីមា លុះធ្វើចីវរហើយ ក៏បង្អង់ឲ្យការដោះកឋិន (នោះ) កន្លងហួសទៅខាងក្រៅសីមា កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ត្រង់កន្លងខេត្តកឋិន ជាកំណត់ ភិក្ខុនាំយកចីវរ ចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ ក៏ធ្វើចីវរ (នោះ) ខាងក្រៅសីមា លុះធ្វើចីវរស្រេចហើយ ក៏មានគំនិតថា អាត្មាអញ នឹងត្រឡប់វិញ ហើយក៏បានមកទាន់ពេលដោះកឋិនមែន កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះ ជាមួយនឹងភិក្ខុទាំងឡាយ ក្នុងរឿងអាទាយ និងសមាទាយ (ទាំង២នេះ) មានប្រការប្រាំពីរៗ ដំណើរក្នុងរឿង ដែលភិក្ខុធ្វើចីវរមិនទាន់ស្រេច ៦ប្រការ គ្មានការដោះកឋិន ត្រង់ចៀសចេញទៅ ជាកំណត់ទេ ការដោះកឋិន ត្រង់ធ្វើចីវរសម្រេច១ ត្រង់សេចក្តីសន្និដ្ឋាន ជាកំណត់១ ត្រង់ចីវរវិនាស ជាកំណត់១ ទាំង៣នេះ កើតដោយភិក្ខុនាំយក (ចីវរចៀសចេញទៅ) ខាងក្រៅសីមា ហើយមានគំនិតថា អាត្មាអញ នឹងធ្វើ (ចីវរ) ក្នុងទីនេះ និដ្ឋានន្តិកាក្តី សន្និដ្ឋានន្តិកាក្តី នាសនន្តិកាក្តី ទាំង៣នេះថា ភិក្ខុនាំយក (ចីវរចៀសចេញទៅ) ដោយបំណងថា អាត្មាអញ នឹងមិនត្រឡប់វិញ អាត្មាអញ នឹងទៅធ្វើខាងក្រៅសីមា រឿងន័យវិធីទាំង៣ ដែលមានតទៅខាងក្រោយថា (ភិក្ខុនាំយកចីវរចៀសចេញទៅ) ដោយមិនបានតាំងចិត្ត គឺភិក្ខុគ្មានគំនិតថា (អាត្មាអញ នឹងត្រឡប់វិញ ឬមិនត្រឡប់វិញទេ) ការដោះកឋិនត្រង់ធ្វើចីវរសម្រេច ជាកំណត់១ ត្រង់សេចក្តីសន្និដ្ឋាន ជា

កំណត់១ ត្រង់ចីវរវិនាស ជាកំណត់១ ត្រង់ឮដំណឹង ជាកំណត់១ ត្រង់កន្លងខេត្តកឋិន ជាកំណត់១ ដោះជាមួយនឹងភិក្ខុទាំងឡាយ១ (ទាំង៦នេះ) ថា ភិក្ខុកាន់យក (ចីវរ) ចៀសចេញទៅ ដោយបំណងថា អាត្មាអញ នឹងត្រឡប់វិញ អាត្មាអញ នឹងទៅធ្វើខាងក្រៅសីមា (លុះកំពុងធ្វើ) ក៏គិតថា អាត្មាអញ នឹងមិនត្រឡប់វិញ ហើយក៏ធ្វើចីវរឲ្យសម្រេច យ៉ាងនេះ ជាគតិមាន១៥ប្រការ រឿងភិក្ខុប្រមូលយកចីវរ ដែលធ្វើមិនទាន់ស្រេច និងប្រមូលយកចីវរ ដែលធ្វើស្រេចដូចគ្នា វារៈទាំង៤នេះ រួមទាំងអស់ត្រូវជា១៥ប្រការ រឿងទាំង៣នោះ គឺបានចីវរខុសបំណង១ បានចីវរត្រូវបំណង១ កិច្ចដែលត្រូវធ្វើ១ បណ្ឌិតគប្បីដឹងរឿងនោះ ដោយន័យថា មានដប់ពីរ៣ដង រឿងសេចក្តីមិនខ្វល់ខ្វាយ (ក្នុងចីវរ) មាន៩ប្រការ រឿងភិក្ខុនៅជាសុខសប្បាយ មាន៥ប្រការ រឿងបលិពោធ និងអបលិពោធ ក្នុងអាវាស និងចីវរនោះ១ ឯឧទ្ទាន (នៃកឋិនក្ខន្ធកៈនេះ) យើងបានធ្វើហើយ ដោយន័យ (ដូចពោលមកយ៉ាងនេះឯង)។

# ចីវរក្ខន្ធកៈ

CS vin.mv.08 | ភាគ ទី៨

### ៨. ចីវរក្ខន្ធកោ

## ២០២. ជីវកវត្ថុ

CS vin.mv.08.01 | ភាគ ទី៨

**(២០២)**

[៣៤] សម័យនោះ ព្រះពុទ្ធមានជោគ គង់នៅវត្តវេឡុវន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង ក្រុងវេសាលី ក៏ស្តុកស្តម្ភទូលាយមានជនច្រើន មានមនុស្សមីរដេរដាស មានអាហារ ផ្ទះកំពូល ចំណីក៏សម្បូរណ៌ មានប្រាសាទ៧ពាន់៧រយ៧ប្រាសាទ មានផ្ទះកំពូល ៧ពាន់ ៧រយ ៧ផ្ទះ មានសួនច្បារ ៧ពាន់ ៧រយ ៧សួនច្បារ មានស្រះបោក្ខរណី ៧ពាន់ ៧រយ ៧ស្រះ ទាំងមានស្រីផ្កាមាស(ម្នាក់) ឈ្មោះនាងអម្ពបាលី រូបល្អគួរជាទីពិតពិលរមិលមើល ជាទីនាំឲ្យកើតសេចក្តីជ្រះថ្លា ប្រកបដោយសម្បុរល្អ និងជាទីគាប់ចិត្តរបស់ជនពន់ពេក ហើយជាស្រីប្រសប់ ក្នុងការល្បែងរាំច្រៀង និងការដេញដំប្រគំ ជាស្រីដែលពួកមនុស្សត្រូវការទាំងប៉ុន្មាន តែងចូលទៅរកច្រើន ឯនាង (នោះ) ទៅក្នុងមួយយប់ៗ (តែងយកថ្លៃ) ៥០កហាបណៈ។ ឯក្រុងវេសាលីសោត សឹងថ្កុំថ្កើងលើសលុបប្រមាណ ព្រោះនាងអម្ពបាលីនោះ។ គ្រានោះ មានពួកកុដុម្ពីរនៅក្រុងរាជគ្រឹះ បានទៅក្រុងវេសាលីដោយមានកិច្ចណាមួយ។ ពួកកុដុម្ពីរនៅក្រុងរាជគ្រឹះក៏បានឃើញក្រុងវេសាលីស្តុកស្តម្ភទូលាយ មានជនច្រើន មានមនុស្សមីរដេរដាស មានអាហារចំណី ក៏សម្បូរណ៌ មានប្រាសាទ៧ពាន់៧រយ៧ប្រាសាទ មានផ្ទះកំពូល៧ពាន់ ៧រយ ៧ផ្ទះ មានសួនច្បារ ៧ពាន់ ៧រយ ៧សួនច្បារ មានស្រះបោក្ខរណី ៧ពាន់ ៧រយ ៧ស្រះ ទាំងមានស្រីផ្កាមាស(ម្នាក់) ឈ្មោះអម្ពបាលី រូបល្អ គួរជាទីពិតពិល រមិលមើល នាំឲ្យកើតសេចក្តីជ្រះថ្លា ប្រកបដោយសម្បុរល្អ និងជាទីគាប់ចិត្ត របស់ជនពន់ពេក ហើយប្រសប់ ក្នុងការល្បែង រាំច្រៀង ដេញដំប្រគំ ជាស្រីដែលពួកមនុស្សទាំងប៉ុន្មាន តែងទៅរកច្រើន ឯនាង (នោះ) ទៅក្នុងមួយយប់ៗ (យកថ្លៃ) ៥០កហាបណៈ ឯក្រុងវេសាលី ក៏ថ្កុំថ្កើងលើសប្រមាណ ព្រោះនាងអម្ពបាលី។ វេលានោះ ពួកកុដុម្ពីរ នៅក្រុងរាជគ្រឹះ បានពិចារណា នូវកិច្ចដែលគួរធ្វើនោះ ក្នុងក្រុងវេសាលីរួចហើយ ក៏ត្រឡប់មក ក្រុងរាជគ្រឹះវិញ បានចូលទៅគាល់ ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូល ព្រះបាទមាគធសេនិយពិម្ពិសារ ដូច្នេះថា បពិត្រព្រះសម្មតិទេព ក្រុងវេសាលី ក៏ស្តុកស្តម្ភទូលាយ មានជនច្រើន មានពួកមនុស្សមីរដេរដាស មានអាហារចំណី ក៏សម្បូរណ៌ មានប្រាសាទ៧ពាន់ ៧រយ ៧ប្រាសាទ មានផ្ទះកំពូល៧ពាន់ ៧រយ ៧ផ្ទះ មានសួនច្បារ ៧ពាន់ ៧រយ ៧សួនច្បារ មានស្រះបោក្ខរណី ៧ពាន់ ៧រយ ៧ស្រះ ទាំងមានស្រីផ្កាមាស (ម្នាក់) ឈ្មោះនាងអម្ពបាលី រូបល្អ គួរជាទីពិតពិល រមិលមើល នាំឲ្យកើតសេចក្តីជ្រះថ្លា ហើយប្រកបដោយសម្បុរល្អ និងជាទីគាប់ចិត្ត របស់ជនពន់ពេក ហើយជាស្រីប្រសប់ ក្នុងការល្បែងរាំច្រៀង និងដេញដំប្រគំ ជាស្រីដែលពួកមនុស្សត្រូវការទាំងប៉ុន្មាន តែងចូលទៅរកច្រើន ឯនាង (នោះ) ទៅក្នុងមួយយប់ៗ យកថ្លៃ៥០កហាបណៈ ឯក្រុងវេសាលី ល្អដោយក្រៃលែងជាងប្រមាណ ព្រោះនាងអម្ពបាលីនោះ បពិត្រព្រះសម្មតិទេព គួរតែយើងខ្ញុំ តាំងស្រីផ្កាមាសឡើងខ្លះ ទើបជាការល្អ។ ស្តេចនោះ ទ្រង់ត្រាស់តបថា នែនាយ បើដូច្នោះ អ្នកទាំងឡាយ ចូរជ្រើសរើសនាងកុមារីណា ដែលមានរូបល្អ ប្រហែលនាងនោះ តាំងឲ្យជាស្រីផ្កាមាសឡើង។ សម័យនោះឯង ក្នុងក្រុងរាជគ្រឹះ មាននាងកុមារីម្នាក់ ឈ្មោះសាលវតី រូបល្អ គួរជាទីពិតពិលរមិលមើល នាំឲ្យកើតសេចក្តីជ្រះថ្លា ហើយប្រកបដោយសម្បុរល្អ និងជាទីគាប់ចិត្ត របស់ជនពន់ពេក។ វេលានោះ ពួកកុដុម្ពីរនៅក្រុងរាជគ្រឹះ ក៏បានតាំងនាង សាលវតីកុមារី ឲ្យធ្វើជាស្រីផ្កាមាស។ គ្រានោះ មិនយូរប៉ុន្មាន នាងសាលវតីស្រីផ្កាមាស ក៏ជាស្រីប្រសប់ ក្នុងការល្បែងរាំច្រៀង និងដេញដំប្រគំ ជាស្រីដែលពួកមនុស្ស ត្រូវការទាំងប៉ុន្មាន តែងចូលទៅរកច្រើន ឯនាងនោះ ទៅក្នុង១យប់ (យកថ្លៃ) ១០០កហាបណៈ។ លំដាប់នោះ នាងសាលវតី ស្រីផ្កាមាស មិនយូរប៉ុន្មាន ក៏មានគភ៌ឡើង។ វេលានោះ នាងសាលវតី ស្រីផ្កាមាស មានសេចក្តីត្រិះរិះ ដូច្នេះថា (ធម្មតា) ស្រី តែមានគភ៌ហើយ រមែងមិនជាទីគាប់ចិត្ត របស់ពួកបុរសឡើយ ប្រសិនបើបុរសណាមួយ នឹងដឹងអាត្មាអញថា នាងសាលវតី ស្រីផ្កាមាស មានគភ៌ហើយ គ្រឿងសក្ការៈទាំងអស់ របស់អញ មុខជានឹងសាបសូន្យ (មិនខាន) បើដូច្នោះ គួរតែអញប្រាប់គេថា មានជម្ងឺ។ គ្រានោះ នាងសាលវតី ស្រីផ្កាមាស ក៏បានបង្គាប់នាយទ្វារថា នែនាយទ្វារ កុំឲ្យបុរសណាមួយ ចូលមកឡើយ ទុកជានរណាមក សួររកខ្ញុំ អ្នកឯងត្រូវប្រាប់ថា នាងសាលវតី មានជម្ងឺ។ នាយទ្វារនោះ ក៏បានទទួលពាក្យ នាងសាលវតីស្រីផ្កាមាស ដោយពាក្យថា អឺនាង។ លំដាប់នោះ នាងសាលវតីស្រីផ្កាមាស លុះដល់គភ៌នោះចាស់ហើយ ក៏សម្រាលកូនប្រុស១មក។ វេលានោះ នាងសាលវតីស្រីផ្កាមាស បានបង្គាប់ខ្ញុំស្រីថា នែនាង ហ៏ នាងឯងចូរដាក់ទារកនេះ ក្នុងចង្អេរចាស់ ហើយនាំយកទៅចោល លើគំនរសម្រាមចុះ។ ឯខ្ញុំស្រីនោះ បានទទួលស្តាប់ពាក្យ នាងសាលវតីស្រីផ្កាមាស ដោយពាក្យថា ចាសអ្នកម្ចាស់ ហើយក៏ដាក់ទារកនោះ ក្នុងចង្អេរចាស់ ហើយនាំយកទៅចោល លើគំនរសម្រាម។ សម័យនោះឯង ព្រះរាជកុមារ ឈ្មោះអភយៈ ចេញទៅគាល់បម្រើស្តេច ក្នុងវេលាព្រឹក ក៏បានឃើញទារកនោះ មានពួកសត្វក្អែកចោមរោម លុះឃើញហើយ ក៏សួរទៅមនុស្សទាំងឡាយថា នែនាយ អ្វីនេះ ដែលពួកក្អែកចោមរោម។ មនុស្សទាំងនោះក្រាបបង្គំទូលថា សូមទ្រង់មេត្តាប្រោស ទារក។ រាជកុមារត្រាស់សួរថា នែនាយ ទារកនេះ វានៅរស់ទេឬ។ មនុស្សទាំងនោះក្រាបទូលថា សូមទ្រង់

មេត្តាប្រោស នៅរស់ទេ។ រាជកុមារក៏ត្រាស់ថា នែនាយ បើដូច្នោះ អ្នកទាំងឡាយ ចូរនាំយកទារកនោះ ទៅក្នុងព្រះរាជវាំងយើង ហើយប្រគល់ឲ្យពួកស្រីដោះចិញ្ចឹម។ មនុស្សទាំងនោះ បានទទួលពាក្យអភយរាជកុមារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ករុណាវិសេស ក៏នាំយកទារកនោះទៅក្នុងព្រះរាជវាំង របស់អភយរាជកុមារ ហើយប្រគល់ឲ្យទៅពួកមេដោះថា នាងទាំងឡាយចូរចិញ្ចឹមចុះ។ ជនទាំងឡាយ បានឲ្យឈ្មោះទារកនោះថា ជីវកៈ ដោយហេតុថា ទារកនោះនៅរស់ ឲ្យឈ្មោះទារកនោះ (ខាងក្រោយទៀត) ថា កោមារភច្ច ព្រោះថាទារកនោះ អភយរាជកុមារ បានឲ្យគេរើសយកមកចិញ្ចឹម។ គ្រានោះ ជីវកកោមារភច្ច មិនយូរប៉ុន្មាន ក៏បានជាអ្នកដឹងក្តីឡើង។ វេលានោះ ជីវកកោមារភច្ច បានចូលទៅគាល់អភយរាជកុមារ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូល អភយរាជកុមារ ដូច្នេះថា បពិត្រព្រះសម្មតិទេព អ្នកណាជាមាតារបស់ខ្ញុំ អ្នកណាជាបិតារបស់ខ្ញុំ។ អភយរាជកុមារតបថា ហៃបាជីវកៈ ទុកជាអញ ក៏មិនបានស្គាល់មាតារបស់អ្នកដែរ ប៉ុន្តែខ្លួនអញ ទុកដូចជាបិតារបស់អ្នក (ព្រោះ) អ្នកឯង យើងបានឲ្យគេយកមកចិញ្ចឹម។ លំដាប់នោះ ជីវកកោមារភច្ច មានសេចក្តីត្រិះរិះ ដូច្នេះថា ពួករាជត្រកូលនេះ តែបុគ្គលគ្មានសិល្បសាស្រ្តហើយ មិនងាយនឹងចិញ្ចឹមជីវិតបានទេ បើដូច្នោះ មានតែអាត្មាអញ រករៀនសិល្បសាស្រ្ត។

[៣៥] សម័យនោះឯង មានពេទ្យម្នាក់ ជាទិសាបាមោក្ខ នៅអាស្រ័យក្នុងក្រុងតក្កសិលា។ វេលានោះ ជីវកកោមារភច្ច មិនបានលាអភយរាជកុមារឡើយ ហើយចេញដើរសំដៅទៅក្រុងតក្កសិលា ក៏បានចូលទៅរកពេទ្យនោះ ឯក្រុងតក្កសិលាដោយលំដាប់ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងពេទ្យនោះថា បពិត្រលោកអាចារ្យ ខ្ញុំប្រាថ្នានឹងសិក្សាសិល្បសាស្រ្ត។ ឯអាចារ្យទិសាបាមោក្ខនោះ ក៏តបវិញថា នែនាយជីវកៈ បើដូច្នោះ អ្នកឯងចូររៀនចុះ។ វេលានោះ ជីវកកោមារភច្ច ក៏រៀនសិល្បសាស្រ្តបានច្រើនផង រៀបបានឆាប់ផង ចាំទុកបានល្អផង សិល្បសាស្រ្ត ដែលជីវកកោមារភច្ចនោះ បានរៀនហើយ ក៏មិនភ្លេចទៅផង។ លុះកន្លង៧ឆ្នាំទៅហើយ ទើបជីវកកោមារភច្ច មានសេចក្តីរិះគិតដូច្នេះថា អាត្មាអញ រៀនសិល្បសាស្រ្តបានច្រើនផង រៀនបានឆាប់ផង ចាំទុកបានល្អផង សិល្បសាស្រ្ត ដែលអញបានរៀនហើយ ក៏មិនភ្លេចទៅផង ម្យ៉ាងទៀត កាលអាត្មាអញ រៀនអស់៧ឆ្នាំហើយ ក៏រកទីបំផុតសិល្បសាស្រ្តនេះមិនប្រាកដឡើយ ទីបំផុតសិល្បសាស្រ្តនេះ តើនឹងបានប្រាកដ ក្នុងវេលាណា។ លំដាប់នោះ ជីវកកោមារភច្ច ក៏បានចូលទៅរកពេទ្យនោះ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងពេទ្យនោះថា បពិត្រលោកអាចារ្យ ខ្ញុំរៀនសិល្បសាស្រ្តបានច្រើនផង រៀនបានឆាប់ផង ចាំទុកបានល្អផង សិល្បសាស្រ្ត ដែលខ្ញុំបានរៀនហើយ មិនភ្លេចទៅវិញផង ម្យ៉ាងទៀត ខ្ញុំរៀនអស់៧ឆ្នាំហើយ ក៏រកទីបំផុតសិល្បសាស្រ្តនេះ មិនប្រាកដសោះ ទីបំផុតសិល្បសាស្រ្តនេះ តើនឹងបានប្រាកដក្នុងវេលាណា។ ឯអាចារ្យនោះ ក៏ប្រាប់ថា នែនាយជីវកៈ បើដូច្នោះ អ្នកឯងត្រូវកាន់យកចបជីក ដើរទៅចំនួន១យោជន៍ជុំវិញក្រុងតក្កសិលា ហើយគន់មើលវត្ថុឯណានីមួយ ដែលមិនមែនជាថ្នាំ ចូរអ្នកនាំវត្ថុនោះមក។ ឯជីវកកោមារភច្ច ទទួលស្តាប់ពាក្យពេទ្យនោះ ដោយពាក្យថា បាទលោកអាចារ្យ ហើយក៏កាន់ចបជីក ដើរទៅចំនួន១យោជន៍ជុំវិញក្រុងតក្កសិលា ក៏មិនឃើញមានវត្ថុអ្វីមួយ ដែលមិនមែនជាថ្នាំឡើយ។ គ្រានោះ ជីវកកោមារភច្ច ក៏បានចូលទៅរកពេទ្យនោះវិញ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងពេទ្យនោះថា បពិត្រលោកអាចារ្យ ខ្ញុំបានដើរទៅចំនួន១យោជន៍ជុំវិញក្រុងតក្កសិលា ក៏មិនឃើញមានវត្ថុអ្វីមួយ ដែលមិនមែនជាថ្នាំសោះ។ ឯអាចារ្យនោះក៏និយាយថា នែនាយជីវកៈ អ្នកឯង យើងបានបង្រៀនរួចហើយ សិល្បសាស្រ្តប៉ុណ្ណេះ ល្មមចិញ្ចឹមជីវិតរបស់អ្នកឯងបានហើយ ៗក៏ប្រគល់ស្បៀងបន្តិចបន្តួចឲ្យជីវកកោមារភច្ច។ លំដាប់នោះ ជីវកកោមារភច្ច ក៏បាននាំយកស្បៀងបន្តិចបន្តួចនោះចេញដើរ សំដៅទៅក្រុងរាជគ្រឹះវិញ។ វេលានោះ ស្បៀងបន្តិចបន្តួច របស់ជីវកកោមារភច្ចនោះ ក៏អស់រលីងទៅ ទៀបក្រុងសាកេត នៅពាក់កណ្តាលផ្លូវ។ គ្រានោះ ជីវកកោមារភច្ច ក៏មានសេចក្តីរិះគិតដូច្នេះថា ផ្លូវអស់ទាំងនេះ ជាផ្លូវដាច់ស្រយាល មានទឹកតិច មានចំណីអាហារតិច នរណា ដែលមិនមានស្បៀងអាហារហើយ មិនងាយនឹងទៅបានឡើយ បើដូច្នោះ គួរអាត្មាអញ ដើរស្វែងរកស្បៀងសិន (រួចសឹមទៅ)។

## ២០៣. សេដ្ឋិភរិយាវត្ថុ

CS vin.mv.08.02 | ភាគ ទី៨

**(២០៣)**

[៣៦] សម័យនោះឯង ក្នុងក្រុងសាកេត មានភរិយាសេដ្ឋីម្នាក់ កើតជម្ងឺឈឺក្បាល៧ឆ្នាំហើយ។ ពួកពេទ្យដែលជាទិសាបាមោក្ខយ៉ាងធំៗច្រើននាក់ នាំគ្នាមកព្យាបាល ក៏មិនអាចធ្វើឲ្យជារោគបាន ហើយនាំយកតែប្រាក់ទៅជាច្រើន។ គ្រានោះ ជីវកកោមារភច្ច បានចូលទៅក្រុងសាកេត ហើយសួរមនុស្សទាំងឡាយថា នែនាយ នរណាមានជម្ងឺ (ខ្លះ) នរណាឲ្យខ្ញុំព្យាបាល (ខ្លះ)។ មនុស្សទាំងនោះប្រាប់ថា បពិត្រលោកអាចារ្យ មានតែភរិយាសេដ្ឋីនេះ មានជម្ងឺឈឺក្នុងក្បាល៧ឆ្នាំហើយ បពិត្រលោកអាចារ្យ អ្នកអញ្ជើញទៅព្យាបាលភរិយាសេដ្ឋីចុះ។ វេលានោះ ជីវកកោមារភច្ច ក៏បានចូលទៅកាន់លំនៅ របស់សេដ្ឋីគហបតី លុះចូលទៅដល់ ហើយ ក៏បង្គាប់នាយទ្វារថា នែនាយទ្វារ ចូរអ្នកឯង ទៅជំរាបភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ ឥឡូវមានគ្រូពេទ្យអញ្ជើញមក គាត់ចង់ឃើញអ្នកម្ចាស់។ នាយទ្វារនោះ បានទទួលស្តាប់ពាក្យជីវកកោមារភច្ច ដោយពាក្យថា បាទលោកអាចារ្យ ហើយក៏ចូលទៅរកភរិយាសេដ្ឋី។ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះ នឹងភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ ឥឡូវមានគ្រូពេទ្យអញ្ជើញមក គាត់ចង់ឃើញអ្នកម្ចាស់។ ឯភរិយាសេដ្ឋីក៏សួរថា នែនាយទ្វារ គ្រូពេទ្យនោះ តើបែបយ៉ាងណា។ នាយទ្វារជំរាបថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យនោះនៅក្មេងទេ។ ឯភរិយាសេដ្ឋីក៏តបថា កុំឡើយនាយទ្វារ គ្រូពេទ្យនៅក្មេងម្ល៉េះ នឹងធ្វើរោគអញឲ្យជាម្តេចបាន គ្រូពេទ្យដែលជាទិសាបាមោក្ខយ៉ាងធំៗ ច្រើននាក់ ក៏បានមកព្យាបាលហើយ ក៏គង់មិនអាចនឹងធ្វើរោគឲ្យសះជាបាន នាំយកប្រាក់ជាច្រើនទៅហើយ។ ខណៈនោះ នាយទ្វារក៏បានចូលទៅរកជីវកកោមារភច្ចវិញ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះនឹងជីវកកោមារភច្ចថា បពិត្រលោកអាចារ្យ ភរិយាសេដ្ឋីបាននិយាយយ៉ាងនេះថា កុំឡើយនាយទ្វារ គ្រូពេទ្យនៅក្មេងម្ល៉េះ នឹងព្យាបាលរោគអញឲ្យសះជាម្តេចបាន គ្រូពេទ្យដែលជាទិសាបាមោក្ខធំៗ ច្រើននាក់ បានមកព្យាបាល ក៏គង់មិនអាចនឹងធ្វើរោគឲ្យសះជាបាន នាំយកប្រាក់ជាច្រើនទៅហើយ។ ឯជីវកកោមារភច្ច ក៏និយាយវិញថា នែនាយទ្វារ ចូរអ្នកឯងទៅជំរាបភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យបាននិយាយពាក្យ យ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់កុំអាលឲ្យវត្ថុអ្វីៗមុនឡើយ ចាំអ្នកម្ចាស់ជារោគពេលណា អ្នកម្ចាស់ចង់ឲ្យវត្ថុណា ក៏គប្បីឲ្យវត្ថុនោះ ក្នុងពេលនោះចុះ។ នាយទ្វារនោះ ទទួលស្តាប់ពាក្យជីវកកោមារភច្ច ដោយពាក្យថា បាទលោកអាចារ្យ ហើយក៏ចូលទៅរកភរិយាសេដ្ឋីវិញ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះ នឹងភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យបាននិយាយពាក្យយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកម្ចាស់កុំអាលឲ្យវត្ថុអ្វីៗមុនឡើយ ចាំអ្នកម្ចាស់ជារោគវេលាណា អ្នកម្ចាស់ចង់ឲ្យវត្ថុណា ក៏គប្បីឲ្យវត្ថុនោះ ក្នុងវេលានោះចុះ។ ឯភរិយាសេដ្ឋីក៏ប្រាប់ថា នែនាយទ្វារ បើ

ដូច្នោះ សូមឲ្យគ្រូពេទ្យអញ្ជើញចូលមកចុះ។ នាយទ្វារនោះ បានទទួលស្តាប់ពាក្យភរិយាសេដ្ឋី ដោយពាក្យថា បាទអ្នកម្ចាស់ ហើយក៏ចូលទៅរកជីវកកោមារភច្ចវិញ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះ នឹងជីវកកោមារភច្ចថា បពិត្រលោកអាចារ្យ ភរិយាសេដ្ឋីឲ្យអញ្ជើញលោក។ វេលានោះ ជីវកកោមារភច្ច ក៏បានចូលទៅរកភរិយាសេដ្ឋី លុះចូលទៅដល់ហើយ ក៏សង្កេតស្គាល់កាយវិការរបស់ភរិយាសេដ្ឋី ហើយបាននិយាយពាក្យនេះនឹងភរិយាសេដ្ឋីថា បពិត្រអ្នកម្ចាស់ ខ្ញុំបាទត្រូវការសប្បិ១ទូកដៃ។ លំដាប់នោះ ភរិយាសេដ្ឋី ក៏បានបង្គាប់ឲ្យគេឲ្យសប្បិ១ទូកដៃទៅជីវកកោមារភច្ច។ វេលានោះ ជីវកកោមារភច្ច ក៏បានស្លសប្បិនោះជាមួយនឹងថ្នាំទាំងឡាយផ្សេងៗ រួចហើយឲ្យភរិយាសេដ្ឋីដេកផ្ងារលើគ្រែ ហើយបញ្ច្រុកថ្នាំនោះ។ ខណៈនោះ សប្បិដែលជីវកកោមារភច្ច បានច្រកទៅហើយនោះ ក៏ខ្ពុរចេញពីមាត់។ គ្រានោះ ភរិយាសេដ្ឋី ក៏ខ្ជាក់សប្បិនោះទៅក្នុងកន្ថោរ ហើយបង្គាប់ទាសីថា ចូរនាងយកសំឡីមកផ្តិតសប្បិនេះចេញ។ វេលានោះ ជីវកកោមារភច្ច មានសេចក្តីរិះគិតដូច្នេះថា អើអស្ចារ្យអ្វីម្ល៉េះ ស្រីមេផ្ទះនេះ ជាស្រីអន់ណាស់តើ ព្រោះនាងឲ្យទាសីយកសំឡីមកផ្តិតសប្បិនេះ ដែលជារបស់គួរតែចោល ម្យ៉ាងទៀតថ្នាំដែលមានដំឡៃច្រើនៗ អញបានប្រើប្រាស់អស់ច្រើនទៅហើយ ស្រីជាម្ចាស់ផ្ទះនេះ នឹងឲ្យទេយ្យធម៌ (រង្វាន់) តិចតួចដល់អញដូចម្តេចបាន។ លំដាប់នោះ ភរិយាសេដ្ឋីសង្កេតស្គាល់វិការជីវកកោមារភច្ច ហើយក៏បាននិយាយពាក្យនេះ នឹងជីវកកោមារភច្ចថា នែលោកអាចារ្យ ហេតុអ្វីបានជាអ្នកមានចិត្តប្លែកម្ល៉េះ។ ឯជីវកកោមារភច្ច តបវិញថា ខ្ញុំបាទមានសេចក្តីរិះគិត ក្នុងទីនេះយ៉ាងនេះថា អស្ចារ្យអ្វីម្ល៉េះ ស្រីមេផ្ទះនេះ ជាស្រីអន់ណាស់តើ ព្រោះនាងឲ្យទាសីយកសំឡីមកផ្តិតសប្បិនេះ ដែលជារបស់គួរតែចោល ម្យ៉ាងទៀត ថ្នាំដែលមានដំឡៃច្រើនៗ អញបានប្រើប្រាស់អស់ច្រើនទៅហើយ ស្រីជាម្ចាស់ផ្ទះនេះ នឹងឲ្យទេយ្យធម៌តិចតួច ដល់អាត្មាអញដូចម្តេចបាន។ ឯភរិយាសេដ្ឋី តបវិញថា នែលោកអាចារ្យ យើងជាស្រីគ្រប់គ្រងផ្ទះ គួរចេះសំចៃសប្បិនេះ សប្បិនេះ នឹងធ្វើជាថ្នាំលាបជើងពួកទាសៈ ពួកកម្មករ ឬនឹងស្រោចទៅក្នុងកិច្ច ដែលធ្វើប្រទីប ក៏គង់តែប្រសើរ នែលោកអាចារ្យ លោកកុំតូចចិត្តឡើយ ទេយ្យធម៌របស់លោក មុខជាមិនសាបសូន្យទេ។ ខណៈនោះ ជីវកកោមារភច្ច ក៏បានផ្សះជម្ងឺឈឺក្បាល ៧ឆ្នាំ របស់ភរិយាសេដ្ឋី ដោយការច្រក តែម្តងប៉ុណ្ណោះ។ វេលានោះ ភរិយាសេដ្ឋី ក៏បានសះ ជារោគនោះទៅ ហើយបានឲ្យ (រង្វាន់) ចំនួន៤ពាន់កហាបណៈ ទៅជីវកកោមារភច្ច។ ឯកូនប្រុសគិតថា មាតារបស់អាត្មាអញ បានសះ ជាជម្ងឺហើយ ក៏បានឲ្យ (រង្វាន់) ចំនួន៤ពាន់កហាបណៈទៀត។ ឯស្រីជាកូនប្រសា គិតថា ម្តាយក្មេករបស់អាត្មាអញ បានសះ ជាជម្ងឺហើយ ក៏បានឲ្យ (រង្វាន់) ចំនួន៤ពាន់កហាបណៈទៀត។ ឯសេដ្ឋីគហបតី គិតថា ភរិយារបស់អាត្មាអញ បានសះ ជាជម្ងឺហើយ ក៏ឲ្យ (រង្វាន់) ចំនួន៤ពាន់កហាបណៈ ហើយឲ្យទាសា ទាសី និងរថទឹមសេះ (ថែមទៀត)។ គ្រានោះ ជីវកកោមារភច្ច បាននាំយក (រង្វាន់) ទាំង១៦ពាន់កហាបណៈនោះ និងទាសាទាសី ទាំងរថទឹមសេះ ហើយចេញទៅក្រុងរាជគ្រឹះ ក៏បានចូលទៅរក អភយរាជកុមារ ឰដក្រុងរាជគ្រឹះដោយលំដាប់ លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះ នឹងអភយរាជកុមារថា សូមទ្រង់មេត្តាប្រោស រង្វាន់ទាំង១៦ពាន់ក្តី ទាសាក្តី ទាសីក្តី សេះ និងរថក្តី នេះជាស្នាដៃដំបូងរបស់ទូលបង្គំជាខ្ញុំ សូមព្រះសម្មតិទេព ទ្រង់ទទួលយកគ្រឿងសម្រាប់ចិញ្ចឹមរបស់ទូលបង្គំជាខ្ញុំចុះ។ ឯអភយរាជកុមារក៏តបថា នែនាយជីវកៈ ណ្ហើយ (របស់ទាំងនេះ) ស្រេចនឹងអ្នកឯងចុះ ប៉ុន្តែត្រូវអ្នកឯងសាងលំនៅ ក្នុងបូរីរបស់យើង។ ឯជីវកកោមារភច្ច បានទទួលស្តាប់ព្រះបន្ទូលអភយរាជកុមារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយក៏បានសាងលំនៅ ក្នុងវាំងរបស់អភយរាជកុមារ។

## ២០៤. ពិម្ពិសាររាជវត្ថុ

CS vin.mv.08.03 | ភាគ ទី៨

**(២០៤)**

[៣៧] សម័យនោះឯង ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់កើតរោគឫសដូងបាត។ សំពត់សាដកទាំងឡាយ ក៏សឹងតែប្រឡាក់ទៅដោយឈាម។ ពួកព្រះនាងទេវី ឃើញហើយ ក៏ចំអកថា ឥឡូវនេះ ព្រះសម្មតិទេព ទ្រង់មានរដូវហើយ ផ្កាគឺឈាម បានកើតឡើងដល់ព្រះសម្មតិទេពហើយ មិនយូរប៉ុន្មានទេ ព្រះសម្មតិទេព មុខជានឹងប្រសូតិ (បុត្រ) មិនខាន។ ព្រះមហាក្សត្រ ក៏ទ្រង់អៀនអន់ដោយហេតុនោះ។ វេលានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់មានព្រះរាជឱង្ការសួរទៅអភយរាជកុមារថា នែនាយអភ័យ យើងមានជម្ងឺប្រាកដដូច្នោះហើយ អស់ទាំងសំពត់សាដក ប្រឡាក់ទៅដោយឈាម ឯពួកនាងទេវី ឃើញហើយ ក៏ចំអកថា ឥឡូវនេះ ព្រះសម្មតិទេព ទ្រង់មានរដូវហើយ ផ្កាគឺឈាម បានកើតឡើង ដល់ព្រះសម្មតិទេពហើយ មិនយូរប៉ុន្មានទេ ព្រះសម្មតិទេព មុខជានឹងប្រសូតិ (បុត្រ) មិនខាន នែនាយអភ័យ យើងសូមអង្វរអ្នក ចូរអ្នកស្វែងរកពេទ្យណា ដែលអាចព្យាបាលយើងបាន។ អភយរាជកុមារ តបវិញថា បពិត្រព្រះសម្មតិទេព ពេទ្យរបស់ខ្ញុំព្រះអង្គ ឈ្មោះជីវកៈ នៅក្មេង ជាមនុស្សកំពុងចំរើន ពេទ្យនោះ នឹងព្យាបាលព្រះសម្មតិទេពបាន។ ព្រះបាទពិម្ពិសារត្រាស់ថា នែនាយអភ័យ បើដូច្នោះ ចូរអ្នកបង្គាប់ពេទ្យជីវកៈ ឲ្យគេមកព្យាបាលអញចុះ។ លំដាប់នោះ អភយរាជកុមារ ក៏បានបង្គាប់ជីវកកោមារភច្ចថា នែនាយជីវកៈ ចូរអ្នកឯង ទៅព្យាបាលរោគ ថ្វាយព្រះមហាក្សត្រ។ ជីវកកោមារភច្ច បានទទួលបង្គាប់អភយរាជកុមារ ដោយពាក្យថា ករុណាវិសេស ហើយក៏នាំយកថ្នាំចំនួនមួយក្រចក ចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះបាទមាគធសេនិយពិម្ពិសារ ដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមមើលជម្ងឺព្រះអង្គ។ វេលានោះ ជីវកកោមារភច្ច ក៏បានផ្សះរោគឫសដូងបាត របស់ព្រះបាទមាគធសេនិយពិម្ពិសារ ដោយលាបថ្នាំតែម្តង។ គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់បានសះ ជារោគហើយ ទើបទ្រង់ឲ្យពួកស្រីទាំងប្រាំរយ ស្អិតស្អាងគ្រឿងអលង្ការទាំងពួង ហើយឲ្យដោះចេញ ទ្រង់ឲ្យគរជាគំនរ រួចទ្រង់ត្រាស់ទៅ នឹងជីវកកោមារភច្ច ដូច្នេះថា នែនាយជីវកៈ គ្រឿងអលង្ការទាំងពួង របស់ស្រីទាំងប្រាំរយនេះ ត្រូវបានអ្នកឯងហើយ។ ជីវកកោមារភច្ច ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កុំព្រួយព្រះរាជហឫទ័យឡើយ សូមព្រះសម្មតិទេព ទ្រង់គ្រាន់តែរំលឹកឧបការរបស់ខ្ញុំព្រះអង្គចុះ។ ព្រះបាទពិម្ពិសារត្រាស់ថា នែនាយជីវកៈ បើដូច្នោះ ចូរអ្នកឯងបម្រើយើងផង ស្រីស្នំផង ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានផង។ ជីវកកោមារភច្ច បានទទួលស្តាប់ព្រះរាជឱង្ការព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស។

## ២០៥. រាជគហសេដ្ឋិវត្ថុ

CS vin.mv.08.04 | ភាគ ទី៨

**(២០៥)**

[៣៨] សម័យនោះឯង សេដ្ឋីនៅក្រុងរាជគ្រឹះ កើតរោគឈឺក្បាល៧ឆ្នាំហើយ។ ពួកពេទ្យដែលជាទិសាបាមោក្ខធំៗច្រើននាក់ មកព្យាបាល ក៏មិនអាចនឹងកែរោគឲ្យសះជាបាន នាំយកតែប្រាក់ជាច្រើនទៅ។ ម្យ៉ាងទៀត សេដ្ឋីនោះ ពួកពេទ្យ ក៏បោះបង់ចោលហើយ។ មានពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតិ មុខជានឹងធ្វើមរណកាល ក្នុងថ្ងៃទី៥។ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតិ មុខជានឹងធ្វើមរណកាល ក្នុងថ្ងៃទី៧។ លំដាប់នោះ ពួកកុដុម្ពិកៈ នៅក្នុងក្រុងរាជគ្រឹះ មានសេចក្តីរិះគិត ដូច្នេះថា សេដ្ឋីគហបតិនេះឯង មានឧបការៈច្រើនដល់ស្តេចផង ដល់ពួកកុដុម្ពិកៈផង ម្យ៉ាងទៀត សេដ្ឋីនោះ ពួកពេទ្យ បោះបង់ចោលហើយ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតិ មុខជានឹងធ្វើមរណកាល ក្នុងថ្ងៃទី៥។ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតិ មុខជានឹងធ្វើមរណកាល ក្នុងថ្ងៃទី៧ ម្យ៉ាងទៀត ពេទ្យជីវកៈ របស់ព្រះមហាក្សត្រនេះ នៅក្មេង ជាមនុស្សកំពុងចំរើន បើដូច្នោះ គួរតែយើងទូលសូមពេទ្យជីវកៈ អំពីព្រះមហាក្សត្រ ដើម្បីព្យាបាលរោគ សេដ្ឋីគហបតិ។ គ្រានោះ ពួកកុដុម្ពិកៈ នៅក្នុងក្រុងរាជគ្រឹះ បានចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏បានក្រាបទូលព្រះបាទមាគធសេនិយពិម្ពិសារថា សូមទ្រង់ព្រះមេត្តាប្រោស សេដ្ឋីគហបតិនេះ មានឧបការៈច្រើន ដល់ព្រះសម្មតិទេពផង ដល់ពួកកុដុម្ពិកៈផង ម្យ៉ាងទៀត ពួកពេទ្យ ក៏បោះបង់ហើយ ពួកពេទ្យខ្លះ និយាយយ៉ាងនេះថា សេដ្ឋីគហបតិ មុខជានឹងធ្វើមរណកាល ក្នុងថ្ងៃទី៥ ពួកពេទ្យខ្លះនិយាយយ៉ាងនេះថា សេដ្ឋីគហបតិ មុខជានឹងធ្វើមរណកាល ក្នុងថ្ងៃទី៧ យើងខ្ញុំសូមអង្វរ សូមព្រះសម្មតិទេព ទ្រង់បង្គាប់ពេទ្យជីវកៈ ឲ្យព្យាបាលរោគសេដ្ឋីគហបតិ។ ខណៈនោះ ព្រះបាទមាគធសេនិយពិម្ពិសារ ក៏ទ្រង់បានបង្គាប់ ជីវកកោមារភច្ចថា នែនាយជីវកៈ អ្នកឯងចូរទៅព្យាបាលសេដ្ឋីគហបតិចុះ។ ជីវកកោមារភច្ច ទទួលស្តាប់ព្រះរាជឱង្ការ ព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស រួចចូលទៅរកសេដ្ឋីគហបតិ លុះចូលទៅដល់ហើយ ក៏សង្កេតដឹងវិការៈ របស់សេដ្ឋីគហបតិ រួចហើយនិយាយនឹងសេដ្ឋីគហបតិដូច្នេះថា នែគហបតិ ប្រសិនបើខ្ញុំកែរោគលោក សះជាហើយ តើខ្ញុំនឹងត្រូវបានរង្វាន់ដូចម្តេច។ សេដ្ឋីគហបតិតបថា លោកអាចារ្យ សម្បត្តិរបស់ខ្ញុំទាំងអស់ក្តី ក៏ត្រូវបានលោក ខ្លួនខ្ញុំក្តី ក៏ធ្វើជាខ្ញុំរបស់លោក។ ជីវកកោមារភច្ចសួរថា នែគហបតិ លោកអាចនឹងសម្រាន្តផ្អៀងតែម្ខាងអស់៧ខែបានឬទេ។ សេដ្ឋីគហបតិតបថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្អៀងតែម្ខាង អស់៧ខែបាន។ ជីវកកោមារភច្ចសួរថា នែគហបតិ លោកអាចនឹងសម្រាន្តផ្អៀងមកម្ខាងទៀត អស់៧ខែបានឬទេ។ សេដ្ឋីគហបតិតបថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្អៀងមកម្ខាងទៀត អស់៧ខែបាន។ ជីវកកោមារភច្ចសួរថា នែគហបតិ លោកអាចនឹងសម្រាន្តផ្ងារ អស់៧ខែបានឬទេ។ សេដ្ឋីគហបតិប្រាប់ថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ងារ អស់៧ខែបាន។ ខណៈនោះ ជីវកកោមារភច្ច ក៏ឲ្យសេដ្ឋីគហបតិដេកលើគ្រែ រួចចងសេដ្ឋីភ្ជាប់លើគ្រែ ហើយវះស្បែកក្បាល វែកថ្មេរ (រលាក្បាល) ចេញ ក៏នាំយកបាណកជាតិ[4] បានពីរ ហើយបង្ហាញដល់ជនថា ចូរអ្នកទាំងឡាយ មើលបាណកជាតិទាំងពីរនេះចុះ បាណកជាតិ១តូច បាណកជាតិ១ធំ ពួកអាចារ្យណានិយាយយ៉ាងនេះថា សេដ្ឋីគហបតិនឹងធ្វើមរណកាលក្នុងថ្ងៃទី៥ (ព្រោះ) ពួកអាចារ្យទាំងនោះ បានឃើញបាណកជាតិធំនេះ ដល់ថ្ងៃទី៥ វានឹងជញ្ជក់យកខួរក្នុងរលាក្បាលរបស់សេដ្ឋីគហបតិ ៗនឹងធ្វើមរណកាល ព្រោះវាជញ្ជក់យកខួរក្នុងរលាក្បាល អាចារ្យទាំងនោះគេឃើញត្រូវ (របស់គេ មិនខុសទេ) ចំណែកខាងពួកអាចារ្យណា និយាយយ៉ាងនេះថា សេដ្ឋីគហបតិនឹងធ្វើមរណកាលក្នុងថ្ងៃទី៧ (ព្រោះ) អាចារ្យទាំងនោះ បានឃើញបាណកជាតិតូចនេះ ដល់ថ្ងៃទី៧ វានឹងជញ្ជក់ខួរក្នុងរលាក្បាលសេដ្ឋីគហបតិ ៗនឹងធ្វើមរណកាល ព្រោះវាជញ្ជក់ខួរក្នុងរលាក្បាល អាចារ្យទាំងនោះ គេឃើញត្រូវ (របស់គេ មិនខុសទេ) រួចហើយទើបបិទថ្មេរ (រលាក្បាល) ហើយដេរស្បែកក្បាល រួចលាបថ្នាំឲ្យ។ វេលានោះ លុះកន្លង៧ថ្ងៃទៅ សេដ្ឋីគហបតិ ក៏និយាយទៅនឹងជីវកកោមារភច្ចយ៉ាងនេះថា នែលោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្អៀងខាងម្ខាងអស់៧ខែបានទេ។ ជីវកកោមារភច្ចតបថា នែគហបតិ ក្រែងលោកបានទទួលប្តេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្អៀងតែម្ខាងឲ្យអស់៧ខែបាន មិនដូច្នោះឬ។ សេដ្ឋីតបថា លោកអាចារ្យ ខ្ញុំបានទទួលប្តេជ្ញាពិតមែនហើយ ប៉ុន្តែថា ខ្ញុំមុខជានឹងស្លាប់ (មិនខាន ព្រោះ) ខ្ញុំមិនអាចនឹងដេកផ្អៀងតែម្ខាង ឲ្យអស់៧ខែបាន។ ជីវកកោមារភច្ចនិយាយថា នែគហបតិ បើដូច្នោះ ចូរលោកដេកផ្អៀងទៅម្ខាងទៀត អស់៧ខែចុះ។ វេលានោះ លុះកន្លង៧ថ្ងៃទៅ សេដ្ឋីគហបតិ បាននិយាយនឹងជីវកកោមារភច្ចយ៉ាងនេះថា លោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្អៀងម្ខាងទៀត អស់៧ខែបានឡើយ។ ជីវកកោមារភច្ចតបថា នែគហបតិ ក្រែងលោកបានទទួលប្តេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្អៀងទៅម្ខាងទៀត អស់៧ខែបាន មិនដូច្នោះឬ។ សេដ្ឋីនិយាយថា លោកអាចារ្យ ខ្ញុំបានទទួលប្តេជ្ញាពិតមែនហើយ ប៉ុន្តែថា ខ្ញុំមុខជានឹងស្លាប់ (មិនខាន ព្រោះ) ខ្ញុំមិនអាចនឹងដេកផ្អៀងទៅម្ខាងទៀត អស់៧ខែបានទេ។ ជីវកកោមារភច្ចតបថា នែគហបតិ បើដូច្នោះ ចូរលោកដេកផ្ងារ ឲ្យអស់៧ខែវិញចុះ។ លំដាប់នោះ លុះកន្លង៧ថ្ងៃទៅ សេដ្ឋីគហបតិ បាននិយាយទៅនឹងជីវកកោមារភច្ច យ៉ាងនេះថា លោកអាចារ្យ ខ្ញុំមិនអាចនឹងដេកផ្ងារ អស់៧ខែបានទេ។ ជីវកកោមារភច្ចតបថា នែគហបតិ ក្រែងលោកបានទទួលប្តេជ្ញានឹងខ្ញុំថា លោកអាចារ្យ ខ្ញុំអាចនឹងដេកផ្ងារ អស់៧ខែបាន មិនដូច្នោះឬ។ សេដ្ឋីនិយាយថា លោកអាចារ្យ ខ្ញុំបានទទួលប្តេជ្ញាពិតមែនហើយ ប៉ុន្តែថា ខ្ញុំមុខជានឹងស្លាប់ (មិនខាន ព្រោះ) ខ្ញុំមិនអាចនឹងដេកផ្ងារ អស់៧ខែបានទេ។ ជីវកកោមារភច្ចតបវិញថា នែគហបតិ បើខ្ញុំមិនបាននិយាយនឹងលោក (យ៉ាងនេះទេ) អ្នកមុខជាមិនដេក អស់កាលមានប្រមាណប៉ុណ្ណេះឡើយ ម្យ៉ាងទៀត យើងបានដឹងពីមុនហើយថា ដល់គ្រប់៧ថ្ងៃ៣ដង សេដ្ឋីគហបតិ មុខជានឹងសះស្បើយរោគជាប្រាកដ (មិនខាន) នែគហបតិ ចូរអ្នកក្រោកឡើង ឥឡូវ លោកបានសះ ជារោគហើយ ចូរលោកដឹង លោកត្រូវឲ្យរង្វាន់ខ្ញុំដូចម្តេចខ្លះ។ សេដ្ឋីគហបតិ និយាយថា លោកអាចារ្យ សម្បត្តិខ្ញុំទាំងអស់ក្តី ក៏ត្រូវបានលោក ខ្លួនខ្ញុំក្តី ក៏សូមធ្វើជាខ្ញុំលោក។ ជីវកកោមារភច្ច តបថា នែគហបតិ ឈ្មើយចុះ លោកកុំឲ្យសម្បត្តិទាំងអស់មកខ្ញុំឡើយ ម្យ៉ាងទៀត លោកកុំធ្វើជាបាវរបស់ខ្ញុំ លោកចូរថ្វាយទ្រព្យ ១សែនកហាបណៈ ទៅស្តេច ឲ្យទ្រព្យ ១សែនកហាបណៈមកខ្ញុំចុះ។ គ្រានោះ សេដ្ឋីគហបតិ បានសះជារោគហើយ ក៏បានថ្វាយទ្រព្យ ១សែនកហាបណៈ ទៅស្តេច ជូនទ្រព្យ ១សែនកហាបណៈ ទៅជីវកកោមារភច្ច។

## ២០៦. សេដ្ឋិបុត្តវត្ថុ

CS vin.mv.08.05 | ភាគ ទី៨

**(២០៦)**

[៣៩] សម័យនោះឯង មានសេដ្ឋីបុត្ត នៅក្នុងក្រុងពារាណសី លេងល្បែងដាំដូង ក៏កើតរោគជុំ ក្នុងពោះវៀនធំ។ បបរដែលសេដ្ឋីបុត្ត បានហុតក្តី ក៏មិនបានរលួយស្រួល បាយដែលសេដ្ឋីបុត្តបានបរិភោគក្តី ក៏មិនបានរលួយស្រួល ឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនបានស្រួលសោះ។ ព្រោះរោគនោះ សេដ្ឋីបុត្តនោះ ក៏ទៅជាស្គម សៅហ្មង មានសម្បុរអាក្រក់ កើតរោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ។ វេលានោះ សេដ្ឋីនៅក្នុងក្រុងពារាណសី មានសេចក្តីរិះគិតដូច្នេះថា ជម្ងឺកូនអញ ប្រាកដដូច្នោះ ទឹកបបរ (ដែលកូនអញ)ហុតទៅក្តី ក៏មិនបានរលួយស្រួល បាយដែល

បរិភោគក្តី ក៏មិនបានរលួយស្រួល ឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនបានស្រួលសោះ ព្រោះរោគនោះ បានជាកូនអញ ទៅជាស្គម សៅហ្មង មានសម្បុរអាក្រក់ កើតរោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ បើដូច្នោះ គួរអាត្មាអញ ទៅកាន់ក្រុងរាជគ្រឹះ ហើយសូមយកពេទ្យជីវកៈ ពីស្តេចមក ដើម្បីឲ្យមកព្យាបាលកូនអញ។ លំដាប់នោះ សេដ្ឋីនៅក្នុងក្រុងពារាណសី បានទៅឯក្រុងរាជគ្រឹះ ហើយចូលទៅគាល់ ព្រះបាទមាគធសេនិយពិម្ពិសារ លុះចូលទៅដល់ហើយ ក៏ក្រាបទូល ព្រះបាទមាគធសេនិយពិម្ពិសារ ដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ជម្ងឺកូនខ្ញុំព្រះអង្គប្រាកដដូច្នោះ ទឹកបបរ ដែលកូនខ្ញុំព្រះអង្គ ហុតទៅក្តី ក៏មិនបានរលួយស្រួល បាយដែលបរិភោគទៅហើយក្តី ក៏មិនបានរលួយស្រួល ឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនដែលបានស្រួលសោះ ព្រោះរោគនោះ កូនខ្ញុំព្រះអង្គ ទៅជាស្គម សៅហ្មង មានសម្បុរអាក្រក់ កើតរោគលឿង ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះសម្មតិទេព ទ្រង់បង្គាប់ពេទ្យជីវកៈ ឲ្យព្យាបាលរោគកូនខ្ញុំព្រះអង្គ។ ខណៈនោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់បង្គាប់ជីវកកោមារភច្ចថា នែនាយជីវកៈ ចូរអ្នកឯង ទៅក្រុងពារាណសី ហើយព្យាបាលរោគ កូនសេដ្ឋី នៅក្រុងពារាណសីផង។ ជីវកកោមារភច្ច ទទួលព្រះរាជឱង្ការ ព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ករុណាវិសេស ហើយទៅកាន់ ក្រុងពារាណសី ចូលទៅរកកូនសេដ្ឋី នៅក្រុងពារាណសី លុះចូលទៅដល់ហើយ ក៏សង្កេតដឹងវិការកូនសេដ្ឋី នៅក្រុងពារាណសី រួចបណ្តេញជនឲ្យដើរចេញ ហើយបិទបាំងរាំងននពីខាងក្រៅ ហើយចងកូនសេដ្ឋីភ្ជាប់នឹងសសរ រួចឲ្យភរិយា (នៃសេដ្ឋីបុត្ត) ឈរនៅពីខាងមុខ រួចវះស្បែកពោះ នាំយកដុំក្នុងពោះវៀនធំ បង្ហាញដល់ភរិយា (សេដ្ឋីបុត្តនោះ) ថា នាងចូរមើលរោគរបស់ស្វាមីនាង បបរដែលហុតទៅហើយក្តី ក៏មិនបានរលួយស្រួល បាយដែលបរិភោគទៅហើយក្តី ក៏មិនបានរលួយស្រួល ឧច្ចារៈក្តី បស្សាវៈក្តី ក៏មិនដែលបានស្រួល ព្រោះតែរោគនេះហើយ បានជាស្វាមីរបស់នាងនេះ ទៅជាស្គម សៅហ្មង មានសម្បុរអាក្រក់ កើតរោគលឿង ស្លេកស្លាំង មានខ្លួនរវាម ដោយសរសៃ (ថាហើយក៏) ស្រាវយកដុំពីក្នុងពោះវៀនធំ ហើយបញ្ចូលពោះវៀនទៅវិញ រួចដេរស្បែកពោះហើយ លាបថ្នាំឲ្យ។ វេលានោះ មិនយូរប៉ុន្មាន កូនសេដ្ឋី នៅក្នុងក្រុងពារាណសី ក៏បានសះ ជារោគនោះទៅ។ គ្រានោះ សេដ្ឋីនៅក្នុងក្រុងពារាណសីគិតថា កូនរបស់អាត្មាអញបានសះជារោគហើយ ក៏បានប្រគល់ឲ្យ នូវទ្រព្យ១៦ពាន់កហាបណៈ ដល់ជីវកកោមារភច្ច។ គ្រានោះ ជីវកកោមារភច្ច បានទទួលទ្រព្យទាំង ១៦ពាន់កហាបណៈនោះ ហើយក៏ត្រឡប់មកក្រុងរាជគ្រឹះវិញ។

## ២០៧. បជ្ជោតរាជវត្ថុ

CS vin.mv.08.06 | ភាគ ទី៨

### (២០៧)

[៤០] សម័យនោះឯង ព្រះបាទបជ្ជោត ក្នុងក្រុងឧជ្ជេនី ទ្រង់អាពាធ ដោយរោគលឿង។ ពួកពេទ្យ ដែលជាទិសាបាមោក្ខធំៗច្រើននាក់ មកព្យាបាល ក៏មិនអាចនឹងកែរោគនោះ ឲ្យសះជាបាន នាំយកតែប្រាក់ទៅជាច្រើន។ គ្រានោះ ព្រះបាទបជ្ជោត ក៏បានបញ្ជូនព្រះរាជបម្រើ ឲ្យទៅកាន់សំណាក់ ស្តេចមាគធសេនិយពិម្ពិសារ ដោយព្រះបណ្តាំថា សូមទ្រង់ព្រះមេត្តាប្រោស ជម្ងឺខ្ញុំប្រាកដដូច្នោះ ខ្ញុំសូមអង្វរ សូមព្រះសម្មតិទេព ទ្រង់ត្រាស់បង្គាប់ឲ្យជីវកពេទ្យ ឲ្យគាត់ទៅព្យាបាលរោគខ្ញុំ។ ខណៈនោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់បង្គាប់ទៅ ជីវកកោមារភច្ចថា នែនាយជីវកៈ ចូរអ្នកទៅក្រុងឧជ្ជេនី ហើយព្យាបាល ព្រះបាទបជ្ជោតផង។ ជីវកកោមារភច្ច ទទួលស្តាប់ព្រះរាជឱង្ការ ព្រះបាទមាគធសេនិយពិម្ពិសារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយទៅកាន់ក្រុងឧជ្ជេនី ក៏ចូលទៅគាល់ព្រះបាទបជ្ជោត លុះចូលទៅគាល់ហើយ ក៏សង្កេតស្គាល់វិការៈ របស់ព្រះបាទបជ្ជោត ហើយក៏ក្រាបបង្គំទូល ព្រះបាទបជ្ជោតយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងស្លសប្បិថ្វាយ ព្រះសម្មតិទេព នឹងសោយសប្បិនោះបានដែរឬ។ ព្រះមហាក្សត្រត្រាស់ថា នែនាយជីវកៈ មិនបានទេ អ្នកឯងអាចនឹងរក្សារោគឲ្យបានសះជា ដោយថ្នាំណាមួយវិញ វៀរលែងតែសប្បិចេញ ចូរអ្នកផ្សំថ្នាំនោះចុះ ដ្បិតសប្បិជាទីខ្ពើមរអើមរបស់ខ្ញុំ។ លំដាប់នោះ ជីវកកោមារភច្ច មានសេចក្តីរិះគិតដូច្នេះថា អាពាធរបស់ស្តេចនេះ ប្រាកដដូច្នោះ តែវៀរលែងសប្បិចេញហើយ អាត្មាអញមិនអាចនឹងធ្វើឲ្យសះជាបានឡើយ។ បើដូច្នោះ គួរអាត្មាអញនឹងស្លសប្បិ (នោះ) ឲ្យមានពណ៌ដូចទឹកចត់ ឲ្យមានក្លិនដូចក្លិនទឹកចត់ ឲ្យមានរសដូចរសទឹកចត់វិញ។ លំដាប់នោះ ជីវកកោមារភច្ច ស្លសប្បិឲ្យមានពណ៌ដូចជាពណ៌ទឹកចត់ មានក្លិនដូចជាក្លិនទឹកចត់ មានរសដូចជារសទឹកចត់ ជាមួយនឹងថ្នាំទាំងឡាយផ្សេងៗ។ លំដាប់នោះ ជីវកកោមារភច្ច មានសេចក្តីរិះគិត ដូច្នេះថា សប្បិដែលស្តេចនេះសោយហើយ ដល់ជ្រួតជ្រាបទៅ មុខជានឹងចង្អោរចេញ ហើយស្តេចកំណាចនេះ នឹងបង្គាប់មនុស្ស ឲ្យសម្លាប់អាត្មាអញ មិនខានឡើយ បើដូច្នោះ គួរអាត្មាអញ សូមលាជាមុនហើយ។ វេលានោះ ជីវកកោមារភច្ច បានចូលទៅគាល់ ព្រះបាទបជ្ជោត លុះចូលទៅជិតហើយ ក៏បានក្រាបបង្គំទូលសេចក្តីនេះ នឹងព្រះបាទបជ្ជោតថា បពិត្រព្រះសម្មតិទេព ធម្មតា ពួកខ្ញុំជាពេទ្យ តែងគាស់យកឫសឈើ មកផ្សំថ្នាំ ដោយការរហ័សយ៉ាងនោះ សូមអង្វរ សូមព្រះសម្មតិទេព ទ្រង់ត្រាស់បង្គាប់ពួកអ្នកដែលនៅចាំរោង សម្រាប់ដាក់វាហនៈ ហើយនឹងពួកអ្នករក្សាទ្វារថា (បើ) ជីវកៈប្រាថ្នាទៅ ដោយវាហនៈណា ចូរឲ្យទៅដោយវាហនៈនោះ ជីវកៈប្រាថ្នាទៅតាមទ្វារណា ចូរឲ្យទៅតាមទ្វារនោះ ជីវកៈប្រាថ្នាចង់ទៅក្នុងកាលណា ត្រូវឲ្យទៅក្នុងកាលនោះ ជីវកៈប្រាថ្នាចង់ចូលមក ក្នុងក្រុងកាលណា ត្រូវឲ្យចូលមក ក្នុងកាលនោះចុះ។ ខណៈនោះ ព្រះបាទបជ្ជោត ក៏បានត្រាស់បង្គាប់ទៅពួកអ្នកនៅចាំរោង សម្រាប់ដាក់វាហនៈ និងពួកអ្នករក្សាទ្វារថា (បើ) ជីវកៈប្រាថ្នាទៅ ដោយវាហនៈណា ចូរឲ្យទៅដោយវាហនៈនោះ ជីវកៈប្រាថ្នាទៅតាមទ្វារណា ចូរឲ្យទៅតាមទ្វារនោះ ជីវកៈប្រាថ្នាចង់ទៅ ក្នុងកាលណា ចូរឲ្យទៅ ក្នុងកាលនោះ ជីវកៈប្រាថ្នាចូលមកក្នុងក្រុងកាលណា ចូរឲ្យចូលមក ក្នុងកាលនោះចុះ។ សម័យនោះ ព្រះបាទបជ្ជោត មានមេដំរី១ ឈ្មោះភទ្ទវតិកា អាចដើរទៅបាន ៥០យោជន៍ (ក្នុង១ថ្ងៃ)។ វេលានោះ ជីវកកោមារភច្ច ក៏បានបង្អោនថ្វាយ សប្បិនោះទៅព្រះបាទបជ្ជោតថា សូមព្រះសម្មតិទេព ទ្រង់សោយទឹកចត់ (នេះ)។ លំដាប់នោះ ជីវកកោមារភច្ច បានឲ្យព្រះបាទបជ្ជោត សោយសប្បិរួចហើយ ក៏ទៅកាន់រោងដំរី (ឡើងជិះ) លើមេដំរី ឈ្មោះភទ្ទវតិកា ហើយក៏បរចេញពីក្រុងទៅ។ ខណៈនោះ សប្បិ ដែលព្រះបាទបជ្ជោត បានសោយហើយ ជ្រួតជ្រាបទៅ ក៏បង្អោរចេញមក។ វេលានោះ ព្រះបាទបជ្ជោត ទ្រង់មានបន្ទូល ទៅនឹងមនុស្សទាំងឡាយ ដូច្នេះថា នែនាយ (ឥឡូវនេះ) ជីវកៈកំណាច បានឲ្យអញផឹកសប្បិទៅហើយ នែនាយ បើដូច្នោះ ចូរអ្នកទាំងឡាយទៅគន់រកមើលពេទ្យជីវកៈ។ មនុស្សទាំងនោះ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស (ឯពេទ្យជីវកៈនោះ) គាត់ជិះដំរី ឈ្មោះភទ្ទវតិកា បរចេញអំពីក្រុង បាត់ទៅហើយ។ សម័យនោះឯង មានខ្ញុំម្នាក់របស់ព្រះបាទបជ្ជោត ឈ្មោះកាកៈ អាចដើរទៅបានចំនួន ៦០យោជន៍ (ក្នុង១ថ្ងៃ) ព្រោះអាស្រ័យដោយអមនុស្ស។ គ្រានោះ ព្រះបាទបជ្ជោត ទ្រង់បង្គាប់ទៅខ្ញុំ ឈ្មោះកាកៈថា នែនាយកាកៈ ចូរឯងទៅ ឲ្យពេទ្យជីវកៈត្រឡប់មកវិញថា លោកអាចារ្យ ព្រះមហាក្សត្រ ឲ្យលោកត្រឡប់ទៅវិញ (កុំឲ្យខាន) នែនាយកាកៈ ធម្មតា ពួកពេទ្យនេះ តែងមានមាយាច្រើន ម្យ៉ាងទៀត ឯងកុំទទួលយករបស់បន្តិចបន្តួចរបស់ពេទ្យនោះឡើយ។ លំដាប់

នោះ ខ្ញុំឈ្មោះកាកៈ ក៏បានតាមទៅទាន់ជីវកកោមារភច្ច កំពុងបរិភោគបាយព្រឹក ក្នុងរវាងពាក់កណ្តាលផ្លូវ ជិតក្រុងកោសម្ពី។ វេលានោះ ខ្ញុំឈ្មោះកាកៈ បាននិយាយ ទៅនឹងជីវកកោមារភច្ច ដូច្នេះថា លោកអាចារ្យ ព្រះមហាក្សត្រឲ្យលោកត្រឡប់ទៅវិញ។ ឯជីវកកោមារភច្ច តបថា នែនាយកាកៈ ចូរអ្នកឯងបង្អង់ ចាំយើងបរិភោគរួចសិន នែនាយកាកៈ បើដូច្នោះ ចូរអ្នកឯងបរិភោគបាយសិន។ កាកៈតបថា លោកអាចារ្យ កុំព្រួយដ្បិតខ្ញុំ ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ថា នែនាយកាកៈ ធម្មតា ពួកពេទ្យទាំងនេះ តែងមានមាយាច្រើន ម្យ៉ាងទៀត អ្នកឯងកុំទទួលរបស់បន្តិចបន្តួចរបស់ពេទ្យនោះឡើយ។ សម័យនោះឯង ជីវកកោមារភច្ច បានបង់ថ្នាំដោយក្រចក ហើយទំពាស៊ីផ្លែកន្ទួតព្រៃផង ផឹកទឹកផង។ វេលានោះ ជីវកកោមារភច្ច ក៏បាននិយាយទៅនឹងខ្ញុំឈ្មោះកាកៈដូច្នេះថា នែនាយកាកៈ បើដូច្នោះ អ្នកចូរទំពារស៊ីផ្លែកន្ទួតព្រៃផង ផឹកទឹកផងចុះ។ លំដាប់នោះ ខ្ញុំឈ្មោះកាកៈគិតថា ពេទ្យនេះឯង ហ៊ានទំពាស៊ីផ្លែកន្ទួតព្រៃផង ផឹកទឹកផង ពេទ្យនេះ មិនគួរនឹងមានអំពើអាក្រក់តិចតួចឡើយ ហើយក៏ទំពាស៊ីផ្លែកន្ទួតព្រៃមួយចំហៀងផង ផឹកទឹកផង។ ផ្លែកន្ទួតព្រៃមួយចំហៀង ដែលខ្ញុំឈ្មោះកាកៈ ទំពាស៊ីហើយនោះ ក៏ចុះរាក ក្នុងទីនោះឯង។ ខណៈនោះ ខ្ញុំឈ្មោះកាកៈ បាននិយាយទៅនឹងជីវកកោមារភច្ច ដូច្នេះថា លោកអាចារ្យ ខ្ញុំនៅមានជីវិត (តទៅទៀតឬទេ)។ ជីវកកោមារភច្ចប្រាប់ថា នែនាយកាកៈ អ្នកឯងកុំភ័យឡើយ ខ្លួនអ្នកឯងក្តី ស្តេចកំណាចក្តី នឹងបានសះ ជារោគហើយ ស្តេចនោះ នឹងឲ្យគេសម្លាប់ខ្ញុំមិនខាន ព្រោះហេតុនោះ បានជាខ្ញុំមិនត្រឡប់ទៅវិញ ថាដូច្នោះហើយ ក៏ប្រគល់មេដំរីឈ្មោះភទ្ទវតិកាទៅខ្ញុំឈ្មោះកាកៈវិញ ហើយចៀសចេញទៅកាន់ក្រុងរាជគ្រឹះ ចូលទៅគាល់ព្រះបាទមាគធសេនិយពិម្ពិសារ ឯក្រុងរាជគ្រឹះដោយលំដាប់ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះបាទមាគធសេនិយពិម្ពិសារ។ ស្តេចទ្រង់ត្រាស់តបថា នែនាយជីវកៈ អ្នកឯងមិនបានវិលត្រឡប់ទៅវិញ ដោយហេតុណា ឈ្មោះថា បានធ្វើនូវហេតុនោះ ដោយល្អហើយ ស្តេចកំណាចនោះ មុខជានឹងឲ្យគេសម្លាប់អ្នកឯងមិនខាន។ គ្រានោះ ព្រះបាទបជ្ជោត បានសះ ជារោគហើយ ក៏បញ្ជូនរាជបម្រើ ទៅក្នុងសំណាក់ជីវកកោមារភច្ចថា សូមឲ្យជីវកៈមក (កុំខាន) យើងនឹងឲ្យពរ។ ឯជីវកកោមារភច្ចតបថា សូមទ្រង់ព្រះមេត្តាប្រោស កុំព្រួយព្រះទ័យ សូមព្រះសម្មតិទេព គ្រាន់តែទ្រង់រលឹក នូវឧបការៈ របស់ខ្ញុំព្រះអង្គចុះ។

## ២០៨. សិវេយ្យកទុស្សយុគកថា

CS vin.mv.08.07 | ភាគ ទី៨

**(២០៨)**

សម័យនោះ សំពត់សិវេយ្យកៈ១គូ ក៏កើតឡើងដល់ព្រះបាទបជ្ជោត ជាសំពត់ដ៏លើសលុប ប្រសើរ ជាប្រធានខ្ពង់ខ្ពស់ ក្រៃលែង ជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន។ វេលានោះ ព្រះបាទបជ្ជោត បានបញ្ជូនសំពត់ សិវេយ្យកៈ ១គូនោះ ទៅជីវកកោមារភច្ច។ លំដាប់នោះ ជីវកកោមារភច្ច មានសេចក្តីរិះគិត ដូច្នេះថា ជាសំពត់ សិវេយ្យកៈ ១គូ ដែលព្រះបាទបជ្ជោតបានបញ្ជូនមកឲ្យអាត្មាអញនេះ ជាសំពត់ដ៏លើសលុបប្រសើរ ជាប្រធានខ្ពង់ខ្ពស់ក្រៃលែង ជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន អ្នកដទៃណាមួយ មិនគួរនឹងប្រើប្រាស់សំពត់សិវេយ្យកៈនេះឡើយ វៀរលែងតែព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះចេញ ឬវៀរលែងតែព្រះបាទមាគធសេនិយពិម្ពិសារចេញ។

## ២០៩. សមត្តិំសវិរេចនកថា

CS vin.mv.08.08 | ភាគ ទី៨

**(២០៩)**

[៤១] សម័យនោះឯង ព្រះកាយរបស់ព្រះមានព្រះភាគ ក្រាស់ដោយទោស (រោគទល់)។ វេលានោះ ព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា នែអានន្ទ កាយរបស់តថាគត ក្រាស់ដោយទោសហើយ តថាគតប្រាថ្នានឹងឆាន់ថ្នាំបញ្ចុះ។ ខណៈនោះ ព្រះអានន្ទដ៏មានអាយុ ក៏ចូលទៅរកជីវកកោមារភច្ច លុះចូលទៅដល់ហើយ ក៏និយាយនឹងជីវកកោមារភច្ចដូច្នេះថា នែជីវកៈដ៏មានអាយុ កាយរបស់ព្រះតថាគតក្រាស់ដោយទោសហើយ ព្រះតថាគតត្រូវការឆាន់ថ្នាំបញ្ចុះ។ ជីវកកោមារភច្ចតបថា បពិត្រព្រះអានន្ទដ៏ចំរើន បើដូច្នោះ សូមឲ្យលោកសម្រួលព្រះកាយរបស់ព្រះដ៏មានព្រះភាគ បាន២ ៣ថ្ងៃសិន។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានសម្រួលព្រះកាយរបស់ព្រះដ៏មានព្រះភាគ២ ៣ថ្ងៃ រួចហើយ ក៏ចូលទៅរកជីវកកោមារភច្ច លុះចូលទៅដល់ហើយ ក៏និយាយនឹងជីវកកោមារភច្ចដូច្នេះថា នែអាវុសោជីវកៈ ព្រះកាយរបស់ព្រះតថាគត បានស្រួលបួលហើយ អ្នកសំគាល់នូវកាលគួរក្នុងគ្រានេះចុះ។ គ្រានោះ ជីវកកោមារភច្ច មានសេចក្តីរិះគិតដូច្នេះថា អាត្មាអញ ថ្វាយថ្នាំបញ្ចុះដ៏គ្រោតគ្រាតដល់ព្រះដ៏មានព្រះភាគ អំពើនេះ មិនសមគួរដល់អាត្មាអញឡើយ ណើ្តយចុះ គួរអាត្មាអញ នឹងអប់ផ្កាឧប្បលទាំងឡាយបាន៣ក្តាប់ ជាមួយនឹងថ្នាំទាំងឡាយផ្សេងៗ ហើយសឹមបង្អោនថ្វាយដល់ព្រះតថាគត។ គ្រានោះ ជីវកកោមារភច្ច បានអប់ផ្កាឧប្បល៣ក្តាប់ ជាមួយនឹងថ្នាំទាំងឡាយផ្សេងៗ រួចហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏បង្អោនថ្វាយផ្កាឧប្បល១ក្តាប់ដល់ព្រះដ៏មានព្រះភាគ ដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ទ្រង់ហិតផ្កាឧប្បល១ក្តាប់ដំបូងនេះ ផ្កាឧប្បលនេះ នឹងបញ្ចុះព្រះដ៏មានព្រះភាគ បាន១០ដង រួចបង្អោនថ្វាយផ្កាឧប្បលក្តាប់ទី២ ដល់ព្រះដ៏មានព្រះភាគ ដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ទ្រង់ហិតផ្កាឧប្បលក្តាប់ទី២នេះ ផ្កាឧប្បលនេះ នឹងបញ្ចុះព្រះដ៏មានព្រះភាគបាន១០ដង រួចបង្អោនថ្វាយផ្កាឧប្បលក្តាប់ទី៣ ដល់ព្រះដ៏មានព្រះភាគ ដោយពាក្យថា សូមទ្រង់មេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ទ្រង់ហិតផ្កាឧប្បលក្តាប់ទី៣នេះ ផ្កាឧប្បលនេះ នឹងបញ្ចុះព្រះដ៏មានព្រះភាគបាន១០ដង រួមកិច្ចដែលបញ្ចុះថ្នាំព្រះដ៏មានព្រះភាគ ត្រូវជា៣០ដងគត់ ដោយអាការយ៉ាងនេះ។ លំដាប់នោះ ជីវកកោមារភច្ច បានថ្វាយថ្នាំបញ្ចុះ៣០ដងគត់ ចំពោះព្រះដ៏មានព្រះភាគ រួចថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយថយចេញទៅ។ លំដាប់នោះ ជីវកកោមារភច្ច កាលចេញទៅដល់ក្រៅខ្លោងទ្វារហើយ ក៏មានសេចក្តីរិះគិតដូច្នេះថា ថ្នាំបញ្ចុះទាំង៣០ដងគត់ អាត្មាអញ បានថ្វាយដល់ព្រះដ៏មានព្រះភាគហើយ ព្រះកាយរបស់ព្រះតថាគត ដែលក្រាស់ដោយទោស ថ្នាំនោះ នឹងបញ្ចុះព្រះដ៏មានព្រះភាគគ្រប់៣០ដងគត់ក៏ទេ មុខជានឹងបញ្ចុះព្រះដ៏មានព្រះភាគ ត្រឹមតែ២៩ដង ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគបានបញ្ចុះថ្នាំហើយ មុខជានឹងស្រង់ទឹក ថ្នាំនោះ នឹងបញ្ចុះព្រះដ៏មានព្រះភាគ ដែលបានស្រង់ទឹកហើយម្តងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ៣០ដងគត់ ដោយអាការយ៉ាងនេះ។ ព្រះដ៏មានព្រះភាគ បានជ្រាបសេចក្តីរិះ

គិតនៃចិត្តរបស់ជីវកកោមារភច្ច ដោយព្រះទ័យ ហើយទើបទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកក្នុងពេលនោះថា នែអានន្ទ កាលជីវកកោមារភច្ច ចេញទៅដល់ក្រៅខ្លោងទ្វារហើយ ក៏មានសេចក្ដីរិះគិតដូច្នេះថា ថ្នាំបញ្ចុះទាំង៣០ដងគត់ អាត្មាអញ បានថ្វាយដល់ព្រះដ៏មានព្រះភាគរួចហើយ កាយរបស់ព្រះតថាគតក្រាស់ដោយទោស ថ្នាំនោះ នឹងបញ្ចុះព្រះមានព្រះភាគគ្រប់៣០ដងគត់ក៏ទេ មុខជានឹងបញ្ចុះព្រះដ៏មានព្រះភាគបាន ត្រឹមតែ២៩ដង ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគបានបញ្ចុះហើយ មុខជានឹងស្រង់ទឹក ថ្នាំនោះ នឹងបញ្ចុះព្រះដ៏មានព្រះភាគ ដែលបានស្រង់ទឹកហើយម្ដងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ៣០ដងគត់ ដោយអាការយ៉ាងនេះ នែអានន្ទ បើដូច្នោះ អ្នកចូរចាត់ចែងទឹកក្ដៅឡើង។ ព្រះអានន្ទដ៏មានអាយុ បានទទួលស្ដាប់ព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគ ដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះករុណាម្ចាស់ ហើយក៏បានចាត់ចែងទឹកក្ដៅ។ វេលានោះ ជីវកកោមារភច្ច បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ជីវកកោមារភច្ច អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ចុះថ្នាំហើយឬនៅ។ ព្រះដ៏មានព្រះភាគ ទ្រង់តបថា នែជីវកៈ តថាគតបានបញ្ចុះថ្នាំហើយ។ ជីវកកោមារភច្ច ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលខ្ញុំព្រះអង្គ ចេញទៅដល់ក្រៅខ្លោងទ្វារហើយ ក៏មានសេចក្ដីរិះគិតដូច្នេះថា ថ្នាំបញ្ចុះចំនួន ៣០ដងគត់ អាត្មាអញ បានថ្វាយដល់ព្រះមានព្រះភាគរួចហើយ កាយរបស់ព្រះតថាគត ក្រាស់ដោយទោស ថ្នាំនោះ នឹងបញ្ចុះព្រះមានព្រះភាគ ៣០ដងគត់ក៏ទេ មុខជានឹងបញ្ចុះព្រះមានព្រះភាគ បានត្រឹមតែ២៩ដង ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ទ្រង់បញ្ចុះថ្នាំរួចហើយ មុខជានឹងស្រង់ទឹក ថ្នាំនោះ នឹងបញ្ចុះព្រះដ៏មានព្រះភាគ ដែលស្រង់ទឹករួចហើយ ម្ដងទៀត រួមជាការបញ្ចុះថ្នាំ របស់ព្រះដ៏មានព្រះភាគ ៣០ដងគត់ ដោយអាការយ៉ាងនេះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ទ្រង់ស្រង់ទឹកចុះ សូមព្រះសុគត ទ្រង់ស្រង់ទឹកចុះ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្រង់ទឹកក្ដៅហើយ ថ្នាំនោះ ក៏បានបញ្ចុះព្រះដ៏មានព្រះភាគ ដែលបានស្រង់ទឹកហើយម្ដងទៀត រួមជាការបញ្ចុះថ្នាំរបស់ព្រះដ៏មានព្រះភាគ ៣០ដងគត់យ៉ាងនេះ។ វេលានោះ ជីវកកោមារភច្ច បានក្រាបទូល ព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស កាយរបស់ព្រះដ៏មានព្រះភាគ តាំងនៅជាប្រក្រតីដរាបណាហើយ នឹងបានចំរើនដោយដុំព្រះមំសៈដរាបនោះ។

## ២១០. វរយាចនាកថា

CS vin.mv.08.09 | ភាគ ទី៨

**(២១០)**

វេលានោះ មិនយូរប៉ុន្មាន កាយរបស់ព្រះមានព្រះភាគ ក៏បានជាប្រក្រតីវិញ។ ខណៈនោះ ជីវកកោមារភច្ច បាននាំយកសំពត់ សិវេយ្យកៈ[5] ១គូនោះចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ។ ជីវកកោមារភច្ច អង្គុយនៅក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគ ដោយពាក្យថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមពរ១ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា នែជីវកៈ ព្រះតថាគតទាំងឡាយ មានពរកន្លងហើយ។ ជីវកកោមារភច្ច ទូលថា សូមទ្រង់ព្រះមេត្តាប្រោស អំពើណាគួរផង មិនមានទោសផង (ខ្ញុំព្រះអង្គសូមចំពោះអំពើនោះ)។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែជីវកៈ អ្នកចូរនិយាយមកចុះ។ ជីវកកោមារភច្ចទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះមានព្រះភាគក្ដី ភិក្ខុសង្ឃក្ដី តែងតែទ្រទ្រង់សំពត់បង្សុកូល សូមទ្រង់ព្រះមេត្តាប្រោស សំពត់សិវេយ្យកៈ១គូនេះហើយ ដែលព្រះបាទបជ្ជោតបញ្ជូនមកឲ្យខ្ញុំព្រះអង្គ ជាសំពត់លើសលុបប្រសើរ ជាប្រធានខ្ពង់ខ្ពស់ក្រៃលែងជាងសំពត់ដ៏ច្រើន ជាងគូនៃសំពត់ដ៏ច្រើន ជាងរយនៃគូសំពត់ដ៏ច្រើន ជាងពាន់នៃគូសំពត់ដ៏ច្រើន ជាងសែននៃគូសំពត់ដ៏ច្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគ ទ្រង់ទទួលយកសំពត់សិវេយ្យកៈ១គូ របស់ខ្ញុំព្រះអង្គ សូមទ្រង់អនុញ្ញាត គហបតិចីវរ ដល់ភិក្ខុសង្ឃផង។ ព្រះមានព្រះភាគ ព្រមទទួលយកសំពត់សិវេយ្យកៈ ១គូ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ជីវកកោមារភច្ច ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ លំដាប់នោះ ជីវកកោមារភច្ច កាលដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយថយចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវគហបតិចីវរ ភិក្ខុណាប្រាថ្នា (បង្សុកូល) ភិក្ខុនោះ ចូរទ្រទ្រង់សំពត់បង្សុកូលចុះ ភិក្ខុណាប្រាថ្នា (គហបតិចីវរ) ភិក្ខុនោះ ចូរត្រេកអរ នឹងគហបតិចីវរចុះ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគត ពោលសរសើរសេចក្ដីសន្ដោសដោយបច្ច័យណាមួយ (តាមមានតាមបាន)។

[៤២] ពួកមនុស្សក្រុងក្រុងរាជគ្រឹះ បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតគហបតិចីវរ ដល់ភិក្ខុទាំងឡាយហើយ។ មនុស្សទាំងនោះ ក៏មានចិត្តរីករាយ ស្រស់ស្រាយឡើងថា យើងមុខជានឹងបានឲ្យទាន មុខជានឹងបានធ្វើបុណ្យ ក្នុងកាលនោះឯង ចាប់ដើមតាំងពីព្រះដ៏មានព្រះភាគ ទ្រង់បានអនុញ្ញាត គហបតិចីវរ ដល់ភិក្ខុទាំងឡាយ។ ក្នុងក្រុងរាជគ្រឹះ មានចីវរច្រើនពាន់កើតឡើងតែក្នុង១ថ្ងៃប៉ុណ្ណោះ។ ពួកមនុស្សដែលនៅក្នុងជនបទ បានឮដំណឹងថា គហបតិចីវរ ព្រះមានព្រះភាគ ទ្រង់បានអនុញ្ញាត ដល់ភិក្ខុទាំងឡាយហើយ។ មនុស្សទាំងនោះ ក៏មានចិត្តរីករាយ ស្រស់ស្រាយឡើងថា យើងមុខជានឹងបានឲ្យទាន មុខជានឹងបានធ្វើបុណ្យ ក្នុងកាលនោះឯង ចាប់ដើមតាំងពីព្រះដ៏មានព្រះភាគ ទ្រង់បានអនុញ្ញាត គហបតិចីវរ ដល់ភិក្ខុទាំងឡាយ។ សូម្បីតែក្នុងជនបទ ក៏មានចីវរច្រើនពាន់កើតឡើងតែក្នុង១ថ្ងៃប៉ុណ្ណោះ។

[៤៣] សម័យនោះឯង សំពត់បាវារ[6] កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត សំពត់បាវារ។ សំពត់បាវារ ធ្វើពីសូត្របានកើតឡើង។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត សំពត់បាវារ ដែលគេធ្វើពីសូត្រ។ សំពត់កោជវៈ[7] បានកើតឡើង។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់កោជវៈ។

ចប់ ភាណវារៈ ជាដម្បូង។

## ២១១. កម្ពលានុជាននាទិកថា

**(២១១)**

[៤៤] សម័យនោះឯង ស្តេចក្នុងដែនកាសី បានបញ្ជូនសំពត់កម្ពល មានដំឡៃកន្លះពាន់ (៥០០កហាបណៈ) គឺប្រហែលនឹងវត្ថុទាំងឡាយ ដែលមានដំឡៃកន្លះពាន់ដែរ ទៅឲ្យជីវកកោមារភច្ច។ វេលានោះ ជីវកកោមារភច្ច ក៏បាននាំយកសំពត់កម្ពលមានដំឡៃកន្លះពាន់នោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ជីវកកោមារភច្ច លុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា សូមទ្រង់មេត្តាប្រោស សំពត់កម្ពលមានដំឡៃកន្លះពាន់ របស់ខ្ញុំព្រះអង្គនេះ ប្រហែលនឹងវត្ថុទាំងឡាយ ដែលមានដំឡៃកន្លះពាន់ដែរ ស្តេចកាសី បានបញ្ជូនមកប្រទាន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលយកសំពត់កម្ពល របស់ខ្ញុំព្រះអង្គ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះអង្គ អស់កាលជាអង្វែង (តទៅ)។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលយកសំពត់កម្ពល។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ជីវកកោមារភច្ច ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ។ លំដាប់នោះ ជីវកកោមារភច្ច កាលដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយថយចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ក៏ទ្រង់ធ្វើធម្មីកថា ក្នុងពេលនោះ ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវសំពត់កម្ពល។

[៤៥] សម័យនោះឯង មានចីវរល្អ និងមិនល្អ កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ មានសេចក្តីរិះគិតដូច្នេះថា ចីវរដូចម្តេច ដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាត ចីវរដូចម្តេច ដែលព្រះមានព្រះភាគ មិនអនុញ្ញាត។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ចីវរ៦យ៉ាង គឺចីវរដែលធ្វើដោយសម្បកឈើ១ ចីវរដែលធ្វើដោយកប្បាស១ ចីវរដែលធ្វើដោយសូត្រ១ ចីវរដែលធ្វើដោយរោមសត្វ (វៀរលែងតែសក់ ឬរោមមនុស្សចេញ)១ សំពត់ដែលធ្វើដោយសម្បកធ្មៃ១ សំពត់ដែលធ្វើលាយដោយវត្ថុ៥យ៉ាងខាងដើម១។ សម័យនោះឯង ពួកភិក្ខុណា ត្រេកអរនឹងគហបតិចីវរ ភិក្ខុទាំងនោះ ក៏រង្កៀស មិនត្រេកអរ នឹងសំពត់បង្សុកូលឡើយ ព្រោះគិតថា ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតតែចីវរ១ មិនបានអនុញ្ញាត ចីវរពីរទេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលត្រេកអរនឹងគហបតិចីវរហើយ ត្រេកអរនឹងសំពត់បង្សុកូលផង ក៏បាន ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគត សរសើរសេចក្តីសន្តោស ដោយចីវរទាំងពីរយ៉ាងនោះ។

## ២១២. បំសុកូលបរិយេសនកថា



**(២១២)**

[៤៦] សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ។ ភិក្ខុពួកខ្លះ ដើរទៅកាន់ព្រៃស្មសាន ដើម្បីនឹងបង្សុកូល ភិក្ខុពួកខ្លះមិនបានរង់ចាំឡើយ។ ពួកភិក្ខុណា ដើរទៅកាន់ព្រៃស្មសាន ដើម្បីនឹងបង្សុកូល ភិក្ខុទាំងនោះ ក៏បានសំពត់បង្សុកូលទាំងឡាយ។ ពួកភិក្ខុណា ដែលមិនបានរង់ចាំ ភិក្ខុទាំងនោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ ចូរលោកទាំងឡាយ ឲ្យចំណែកមកយើងខ្លះ។ ភិក្ខុទាំងនោះ ក៏និយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឲ្យចំណែក ដល់លោកទាំងឡាយទេ (បើលោកទាំងឡាយ ចង់បានសំពត់បង្សុកូល) ហេតុដូចម្តេច បានជាលោកទាំងឡាយ មិនរង់ចាំយើង។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមិនប្រាថ្នានឹងឲ្យ ក៏កុំឲ្យនូវចំណែក ដល់ភិក្ខុទាំងឡាយ ដែលមិនរង់ចាំបាន។ សម័យនោះឯង មានភិក្ខុច្រើនរូប ដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ។ ភិក្ខុពួកខ្លះ ដើរទៅកាន់ព្រៃស្មសាន ដើម្បីនឹងបង្សុកូល ភិក្ខុពួកខ្លះបានរង់ចាំ។ ពួកភិក្ខុណា ចូលទៅកាន់ព្រៃស្មសាន ដើម្បីនឹងបង្សុកូល ភិក្ខុទាំងនោះ ក៏បានសំពត់បង្សុកូល។ ពួកភិក្ខុណា ដែលរង់ចាំ ភិក្ខុទាំងនោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ ចូរលោកទាំងឡាយ ឲ្យចំណែកមកយើងខ្លះ។ ភិក្ខុទាំងនោះ ពោលតបវិញយ៉ាងនេះថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុម្តេច បានជាលោកទាំងឡាយ មិនចូលទៅ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុដែលទុកជាមិនចង់ឲ្យ ក៏ត្រូវឲ្យចំណែក ដល់ភិក្ខុទាំងឡាយ ដែលរង់ចាំ។ សម័យនោះឯង មានពួកភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ។ ភិក្ខុពួកខ្លះ ដើរចូលទៅកាន់ ព្រៃស្មសានជាមុន ដើម្បីបង្សុកូល ភិក្ខុពួកខ្លះ ចូលទៅជាខាងក្រោយ។ ពួកភិក្ខុណា ដែលដើរចូលទៅព្រៃស្មសានមុន ដើម្បីបង្សុកូល ភិក្ខុទាំងនោះ ក៏បានសំពត់បង្សុកូល។ ពួកភិក្ខុណា ចូលទៅក្រោយ ភិក្ខុទាំងនោះ ក៏ឥតបានឡើយ។ ភិក្ខុទាំងនោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ លោកទាំងឡាយ ចូរឲ្យចំណែក ដល់យើងខ្លះ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនបានឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វី បានជាលោកទាំងឡាយ ដើរចូលទៅក្រោយគេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុដែលមិនចង់ឲ្យ ក៏កុំបាច់ឲ្យនូវចំណែក ដល់ភិក្ខុទាំងឡាយដែលដើរចូលទៅក្រោយគេ។ សម័យនោះឯង មានពួកភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ។ ភិក្ខុទាំងនោះ បានដើរចូលទៅកាន់ព្រៃស្មសាន ដើម្បីបង្សុកូលព្រមគ្នា។ ភិក្ខុពួកខ្លះ បានសំពត់បង្សុកូល ភិក្ខុពួកខ្លះមិនបាន។ ពួកភិក្ខុណា ដែលមិនបាន ភិក្ខុទាំងនោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ លោកទាំងឡាយ ចូរឲ្យចំណែកមកយើងខ្លះ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វីបានជាលោកមិនបាននឹងគេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុដែលទុកមិនចង់ឲ្យ ក៏ត្រូវឲ្យចំណែកដល់ភិក្ខុទាំងឡាយ ដែលចូលទៅកាន់ព្រៃស្មសានព្រមគ្នា។ សម័យនោះឯង មានភិក្ខុច្រើនរូបដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងកោសលជនបទ។ ភិក្ខុទាំងនោះ បានធ្វើកតិកា (ប្តេជ្ញា) នឹងគ្នារួចហើយ ក៏ចូលទៅកាន់ព្រៃស្មសាន ដើម្បីបង្សុកូល។ ភិក្ខុពួកខ្លះបានសំពត់បង្សុកូល ភិក្ខុពួកខ្លះមិនបាន។ ពួកភិក្ខុណា ដែលមិនបាន ភិក្ខុទាំងនោះ ក៏និយាយយ៉ាងនេះថា នែអាវុសោ លោកទាំងឡាយ ចូរឲ្យចំណែកមកយើងខ្លះ។ ភិក្ខុ

ទាំងនោះ និយាយយ៉ាងនេះវិញថា នែអាវុសោ យើងមិនឲ្យចំណែកដល់លោកទាំងឡាយទេ ហេតុអ្វីបានជាលោកមិនបាននឹងគេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុដែលទុកជាមិនចង់ឲ្យ ក៏ត្រូវឲ្យចំណែកដល់ភិក្ខុទាំងឡាយ ដែលធ្វើកតិកា (ប្តេជ្ញា) គ្នា ហើយចូលទៅកាន់ព្រៃស្មសាន។

## ២១៣. ចីវរបដិគ្គាហកសម្មុតិកថា

CS vin.mv.08.12 | ភាគ ទី៨

**(២១៣)**

[៤៧] សម័យនោះឯង ពួកមនុស្សបាននាំចីវរមកកាន់អារាម។ មនុស្សទាំងនោះ កាលមិនបានភិក្ខុណាមួយទទួលចីវរ ក៏ត្រឡប់នាំយកចីវរទៅវិញ។ ឯចីវរ ក៏កើតតិចៗទៅ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុ ដែលប្រកបដោយអង្គ៥ ឲ្យជាអ្នកទទួលចីវរ គឺ ភិក្ខុមិនបានលុះឆន្ទាគតិ១ មិនបានលុះទោសាគតិ១ មិនបានលុះមោហាគតិ១ មិនបានលុះភយាគតិ១ ដឹងនូវចីវរ ដែលខ្លួនបានទទួល និងមិនបានទទួល១។ ម្នាលភិក្ខុទាំងឡាយ ត្រូវសង្ឃសន្មតយ៉ាងនេះ។ សង្ឃត្រូវអង្វរករភិក្ខុជាមុន លុះអង្វរកររួចហើយ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរចុះ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទទួលចីវរ គួរដល់លោកដ៏មានអាយុអង្គណាហើយ លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកទទួលចីវរហើយ។ ការសន្មតនេះ សមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៤៨] សម័យនោះឯង ពួកភិក្ខុអ្នកទទួលចីវរ បានទទួលចីវរ ទុកចោលក្នុងទីនោះឯង ហើយចៀសចេញទៅ។ ចីវរក៏វិនាសទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុ ដែលប្រកបដោយអង្គ៥ ឲ្យជាអ្នកទុកដាក់ចីវរ គឺ ភិក្ខុដែលមិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ដឹងនូវចីវរដែលខ្លួនបានទុកដាក់ហើយ និងមិនបានទុកដាក់ហើយ១។ ម្នាលភិក្ខុទាំងឡាយ ត្រូវសង្ឃសន្មតយ៉ាងនេះ ត្រូវសង្ឃអង្វរករភិក្ខុជាមុន លុះអង្វរកររួចហើយ ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ គួរសង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកដាក់ចីវរ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកដាក់ចីវរ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកទុកដាក់ចីវរ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម (បើ) មិនសមគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកទុកដាក់ចីវរហើយ។ ការសន្មតនេះ សមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

## ២១៤. ភណ្ឌាគារសម្មុតិអាទិកថា

CS vin.mv.08.13 | ភាគ ទី៨

**(២១៤)**

[៤៩] សម័យនោះឯង ពួកភិក្ខុអ្នកទុកដាក់ចីវរ ទុកចីវរក្នុងមណ្ឌប (បារាំ) ខ្លះ ក្រោមម្លប់ឈើខ្លះ ទៀបយុរស្សវខ្លះ ក្នុងទីកណ្តាលវាលខ្លះ។ ពួកសត្វកណ្តុរខ្លះ ពួកសត្វកណ្តៀរខ្លះ ក៏កាត់ចីវរទាំងនោះ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ (បើ) សង្ឃប្រាថ្នានូវទីណា គឺវិហារក្តី ប្រាសាទមានសណ្ឋានដូចស្លាបគ្រុឌក្តី ប្រាសាទវែងក្តី ប្រាសាទមានដំបូលត្រងិលក្តី គូហាក្តី ក៏តថាគតអនុញ្ញាតឲ្យសង្ឃសន្មតនូវទីនោះឲ្យជាឃ្លាំងបាន។ ម្នាលភិក្ខុទាំងឡាយ គួរសង្ឃសន្មតយ៉ាងនេះ។ ត្រូវភិក្ខុអ្នកឆ្លាស ប្រតិពល ញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគួរសន្មតវិហារឈ្មោះនេះ ឲ្យជាឃ្លាំងបាន។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតវិហារឈ្មោះនេះ ឲ្យជាឃ្លាំងហើយ។ ការសន្មតិវិហារឈ្មោះនេះ ឲ្យជាឃ្លាំង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ វិហារឈ្មោះនេះ សង្ឃបានសន្មត ឲ្យជាឃ្លាំងហើយ។ ការសន្មតិគួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៥០] សម័យនោះឯង ចីវរក្នុងឃ្លាំងរបស់សង្ឃ ឥតមានលោកណាគ្រប់គ្រងរក្សាឡើយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសន្មតភិក្ខុ ដែលប្រកបដោយអង្គ៥ ឲ្យជាអ្នករក្សាឃ្លាំង គឺភិក្ខុដែលមិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ដឹងនូវរបស់ ដែលខ្លួនបានគ្រប់គ្រងរក្សាហើយ និងមិនទាន់បានគ្រប់គ្រងរក្សា១។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ។ សង្ឃត្រូវអង្វរករភិក្ខុជាមុន លុះអង្វរករហើយ ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលសមគួរ ដល់សង្ឃហើយ សង្ឃគួរសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង។ ការសន្មតិភិក្ខុឈ្មោះនេះ ឲ្យជាអ្នករក្សាឃ្លាំង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នករក្សាឃ្លាំងហើយ។ ការសន្មតិនេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។

[៥១] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបណ្តេញភិក្ខុអ្នករក្សាឃ្លាំងឲ្យចៀសចេញ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្តេញ[8] ភិក្ខុអ្នករក្សាឃ្លាំងចេញទេ ភិក្ខុណាបណ្តេញ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

[៥២] សម័យនោះឯង ចីវរក្នុងឃ្លាំងរបស់សង្ឃក៏សម្បូណ៌ឡើង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃដែលនៅជួបជុំគ្នា[9] ចែកចីវរបាន។ គ្រានោះឯង សង្ឃទាំងពួង កាលចែកចីវរ ក៏បានធ្វើនូវសេចក្តីកោលាហលឡើង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសង្ឃសន្មតភិក្ខុដែលប្រកបដោយអង្គ៥ ឲ្យជាអ្នកចែកចីវរបាន គឺ ភិក្ខុដែលមិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ដឹងនូវរបស់ដែលខ្លួនបានចែកហើយ និងមិនទាន់បានចែក១។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ។ សង្ឃត្រូវអង្វរករភិក្ខុជាមុន លុះអង្វរកររួចហើយ ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគួរសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចែកចីវរ។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចែកចីវរ។ ការសន្មតិភិក្ខុឈ្មោះនេះ ឲ្យជាអ្នកចែកចីវរ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកចែកចីវរហើយ។ ការសន្មតិនេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ។ វេលានោះ ពួកភិក្ខុអ្នកចែកចីវរ មានសេចក្តីរិះគិតដូច្នេះថា យើងគួរចែកចីវរដូចម្តេចហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុជ្រើសរើស (ចីវរ) ជាមុន ហើយស្ទង់មើល (ដម្លៃ) ហើយលៃលកចីវរដែលមានសណ្ឋានតូចធំ ថ្លៃច្រើនតិច (ឲ្យមានចំណែកស្មើគ្នា) ហើយរាប់ភិក្ខុ ហើយចងចីវរឲ្យជាពួកៗ រួចសឹមដំកល់ទុក នូវចំណែកនៃចីវរ។ វេលានោះ ពួកភិក្ខុអ្នកចែកចីវរ មានសេចក្តីរិះគិតដូច្នេះថា យើងត្រូវឲ្យចំណែកចីវរដល់ពួកសមណេរដូចម្តេចហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយ ឲ្យចំណែកពាក់កណ្តាល ដល់ពួកសាមណេរ។ សម័យនោះឯង ភិក្ខុ១រូប មានសេចក្តីប្រាថ្នានឹងឆ្លងស្ទឹង ឬឆ្លងផ្លូវឆ្ងាយ ហើយចង់បានចំណែករបស់ខ្លួន (ជាប់ទៅផង)។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ឲ្យចំណែករបស់ខ្លួន (គឺរបស់ភិក្ខុអ្នកឆ្លងស្ទឹង) ដល់ភិក្ខុអ្នកឆ្លង (ស្ទឹង ឬផ្លូវឆ្ងាយ) ចុះ។ សម័យនោះឯង ភិក្ខុ១រូប មានសេចក្តីប្រាថ្នានឹងឆ្លងស្ទឹង ឬឆ្លងផ្លូវឆ្ងាយ ចង់បានចំណែកថ្លៃច្រើនជាងគេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើកប្បិយភណ្ឌ គេបានឲ្យហើយ តថាគតអនុញ្ញាតឲ្យភិក្ខុ ឲ្យចំណែកដ៏ច្រើនចុះ។ គ្រានោះ ពួកភិក្ខុអ្នកចែកចីវរ មានសេចក្តីរិះគិតដូច្នេះថា យើងត្រូវឲ្យចំណែកចីវរដូចម្តេចហ្ន៎ យើងត្រូវឲ្យចំណែកចីវរដោយលំដាប់ភិក្ខុដែលមកឬ ៗនឹងត្រូវឲ្យចំណែកចីវរ តាមលំដាប់ភិក្ខុចាស់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើចីវរខ្វះហើយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយ ញ៉ាំងភិក្ខុឲ្យគ្រេកអរសិន ហើយសឹមធ្វើការបោះស្លាក។

## ២១៥. ចីវររជនកថា

CS vin.mv.08.14 | ភាគ ទី៨

**(២១៥)**

[៥៣] សម័យនោះឯង ភិក្ខុទាំងឡាយជ្រលក់ចីវរ ដោយអាចម៍គោខ្លះ ដោយដីស្អិត មានពណ៌លឿងខ្លះ។ ចីវរនោះ ក៏មានពណ៌មិនល្អ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកជ្រលក់៦យ៉ាង គឺទឹកជ្រលក់កើតពីមើម១ ទឹកជ្រលក់កើតពីដើម១ ទឹកជ្រលក់កើតពីសម្បក១ ទឹកជ្រលក់កើតពីស្លឹក១ ទឹកជ្រលក់កើតពីផ្កា១ ទឹកជ្រលក់កើតពីផ្លែ១។ សម័យនោះឯង ភិក្ខុទាំងឡាយ ជ្រលក់ចីវរ ដោយទឹកត្រជាក់។ ចីវរនោះ ក៏មានក្លិនមិនល្អ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវឆ្នាំងជ្រលក់តូច ដើម្បីដាំទឹកជ្រលក់។ ទឹកជ្រលក់ក៏ផុលឡើង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចងប្រទាស។[10] សម័យនោះឯង ភិក្ខុទាំងឡាយ មិនដឹងទឹកជ្រលក់ឆ្អិនហើយ ឬនៅមិនទាន់ឆ្អិន។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យបន្តក់[11] ដំណក់ទឹក លើទឹកក៏បាន លើខ្នងក្រចកក៏បាន។ សម័យនោះឯង ភិក្ខុទាំងឡាយ កាលដាក់ទឹកជ្រលក់ ក៏ទង្គិចនឹងឆ្នាំង ៗក៏បែកទៅ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវបោយសម្រាប់ដងទឹកជ្រលក់ ដែលមានដង។ សម័យនោះឯង ភាជន៍សម្រាប់ដាក់ទឹកជ្រលក់ របស់ភិក្ខុទាំងឡាយមិនទាន់មាន។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវឆ្នាំងសម្រាប់ដាក់ទឹកជ្រលក់ និងក្អមសម្រាប់ដាក់ទឹកជ្រលក់។ សម័យនោះឯង ភិក្ខុទាំងឡាយ គក់ចីវរក្នុងថាសខ្លះ ក្នុងបាត្រខ្លះ។ ចីវរក៏ដាច់ដាចអស់។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវស្នូកសម្រាប់ជ្រលក់។ សម័យនោះឯង ភិក្ខុទាំងឡាយ ត្រដាងហាលចីវរ លើផែនដី ចីវរក៏ប្រឡាក់ដោយអាចម៍ដី។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវកម្រាលស្មៅ។ កម្រាលស្មៅ ពួកសត្វកណ្តៀរកោរអស់ទៅ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវឈើស្នួរ សម្រាប់ហាលចីវរ និងខ្សែស្បៀង។ ភិក្ខុទាំងឡាយ ពាក់ចីវរចំទីពាក់កណ្តាល ទឹកជ្រលក់ ក៏ហៀរចុះទៅតាមជាយទាំងពីរ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យចងត្រង់ជាយចីវរ។ ជាយចីវរក៏ទក់។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវខ្សែសម្រាប់ចងជាយចីវរ។ ទឹកជ្រលក់ ក៏ហៀរទៅតាមជាយម្ខាង។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យជ្រលក់ចីវរប្រែត្រឡប់ឲ្យសព្វគ្រប់ ម្យ៉ាងទៀត កាលបើដំណក់ទឹក មិនទាន់ដាច់អស់ទេ ភិក្ខុកុំអាលដើរចេញឡើយ។ សម័យនោះឯង ចីវរជិតខ្លាំងពេក។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យត្រាំចីវរទៅក្នុងទឹក (ទទេ)។ សម័យនោះឯង ចីវរក៏មានសាច់រឹង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យគក់ចីវរដោយដៃ។

[៥៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ចីវរមិនបានកាត់ ទ្រទ្រង់ចីវរជ្រលក់ ដោយទឹកចត់ មានពណ៌ដូចភ្លុក។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មិនត្រូវប្រើប្រាស់ចីវរ ដែលមិនបានកាត់ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

## ២១៦. ឆិន្នកចីវរានុជាននា

CS vin.mv.08.15 | ភាគ ទី៨

**(២១៦)**

[៥៥] គ្រានោះ ព្រះមានព្រះភាគគង់នៅក្នុងក្រុងរាជគ្រឹះ ដោយសមគួរ ដល់ពុទ្ធអធ្យាស្រ័យ ហើយក៏ទ្រង់យាងចេញទៅ កាន់ចារិក ក្នុងទក្ខិណាគិរីជនបទ។ ព្រះមានព្រះភាគ ទ្រង់ឃើញស្រែអ្នកដែនមគធៈ មានសណ្ឋានជាស្រែ មានជ្រុងបួន មានសណ្ឋានជាស្រែ មានភ្លឺវែង ដោយបណ្តោយផង ដោយទទឹងផង មានសណ្ឋានជាស្រែ មានភ្លឺខ្លីក្នុងចន្លោះៗ មានសណ្ឋាន ជាបួនជ្រុង ដោយមានភ្លឺខ្លីបាញ់រត់គ្នា លុះទ្រង់ទតឃើញហើយ ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា នែអានន្ទ អ្នកឃើញស្រែអ្នកដែនមគធៈ មានសណ្ឋានជាស្រែ មានជ្រុងបួន មានសណ្ឋានជាស្រែ មានភ្លឺវែង ដោយបណ្តោយផង ដោយទទឹងផង មានសណ្ឋានជាស្រែ មានភ្លឺខ្លីក្នុងចន្លោះៗ មានសណ្ឋានជាបួនជ្រុង ដោយមានភ្លឺខ្លីបាញ់រត់គ្នាឬទេ។ ព្រះអានន្ទ ក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា នែអានន្ទ អ្នកអាចចាត់ចែងចីវរបែបនេះ ដល់ភិក្ខុទាំងឡាយបានឬទេ។ ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គអាចធ្វើបាន។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងទក្ខិណាគិរីជនបទ គួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់យាងត្រឡប់មកក្រុងរាជគ្រឹះវិញ។ ខណៈនោះ ព្រះអានន្ទដ៏មានអាយុ ក៏បានចាត់ចែងចីវរ ដល់ភិក្ខុទាំងឡាយជាច្រើនរូប រួចហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទតចីវរ ដែលខ្ញុំព្រះអង្គចាត់ចែងហើយចុះ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ក៏ធ្វើនូវធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ អានន្ទ មានប្រាជ្ញាច្រើន ព្រោះថា ពាក្យដែលតថាគត ពោលហើយ ដោយសង្ខេប អានន្ទ អាចដឹងសេចក្តីដោយពិស្តារបាន ហើយចេះធ្វើសំពត់ ឈ្មោះកុសិផង ធ្វើសំពត់ ឈ្មោះអឌ្ឍកុសិផង ធ្វើសំពត់ ឈ្មោះមណ្ឌលៈផង ធ្វើសំពត់ ឈ្មោះអឌ្ឍមណ្ឌលៈផង ធ្វើសំពត់ ឈ្មោះវិវដ្តៈផង ធ្វើសំពត់ ឈ្មោះអនុវិវដ្តៈផង ធ្វើសំពត់ ឈ្មោះគីវេយ្យកៈផង ធ្វើសំពត់ ឈ្មោះជង្ឃេយ្យកៈផង ធ្វើសំពត់ ឈ្មោះពាហន្តៈផង ហើយសំពត់នោះ អានន្ទ ក៏បានកាត់ដាច់ ឲ្យសៅហ្មង ដោយមុខកាំបិត ឲ្យសមគួរដល់សមណៈ ឲ្យជារបស់មិនគួរប្រាថ្នា ដល់ពួកចោរជាសត្រូវ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសង្ឃាដិកាត់ ឧត្តរាសង្គៈកាត់ អន្តរវាសកៈកាត់។

## ២១៧. តិចីវរានុជាននា

CS vin.mv.08.16 | ភាគ ទី៨

**(២១៧)**

[៥៦] គ្រានោះ ព្រះមានព្រះភាគគង់ក្នុងក្រុងរាជគ្រឹះ គួរដល់ពុទ្ធអធ្យាស្រ័យ ហើយក៏ទ្រង់ចៀស ទៅកាន់ចារិកក្រុងវេសាលី។ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ផ្លូវឆ្ងាយ ជាចន្លោះក្រុងរាជគ្រឹះ និងចន្លោះក្រុងវេសាលី ក៏បានទតឃើញភិក្ខុទាំងឡាយច្រើនរូប មានចីវរវេចជាសំពាយ បានដាក់ផ្ទត់ចីវរលើក្បាលខ្លះ ដាក់ផ្ទត់ចីវរលើ ក ខ្លះ ដាក់ផ្ទត់ចីវរលើចង្កេះខ្លះ ដើរមក លុះទតឃើញហើយ ព្រះដ៏មានព្រះភាគ ទ្រង់រិះគិតយ៉ាងនេះថា ពួកមោឃបុរសទាំងនេះ វិលមករកសេចក្តីលោភ ក្នុងចីវរឆាប់រហ័សណាស់ បើដូច្នោះ គួរតថាគត ចងសីមាតាំងទុកនូវខេត្តដែនក្នុងចីវរ ដល់ភិក្ខុទាំងឡាយ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ចារិក ដោយលំដាប់ ទើបបានដល់ទៅក្រុងវេសាលី។ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងគោតមចេតិយ ទៀបក្រុងវេសាលីនោះ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ចីវរតែមួយ គង់នៅក្នុងទីកណ្តាលវាល ក្នុងវេលាយប់ ក្នុងសម័យមានទឹកសន្សើមធ្លាក់ចុះ ក្នុងរាត្រីទាំងឡាយ ដែលត្រជាក់ នៅក្នុងហេមន្តរដូវ ឋិតនៅជាចន្លោះ នៃខែមាឃ និងខែផល្គុណ[12)] ព្រះអង្គក៏មិនរងាឡើយ លុះបឋមយាមកន្លងទៅហើយ ទើបព្រះអង្គរងា ហើយព្រះអង្គ ទ្រង់ចីវរជាគំរប់ពីរ ព្រះអង្គក៏បាត់រងាទៅ លុះមជ្ឈិមយាមកន្លងទៅហើយ ទើបព្រះអង្គរងា ហើយព្រះអង្គទ្រង់ដណ្តប់ចីវរជាគំរប់បី ព្រះអង្គក៏បាត់រងាទៀត លុះបច្ឆិមយាមកន្លងទៅហើយ កាលអរុណរះឡើង រាត្រីក៏ភ្លឺព្រាងៗ ទើបព្រះអង្គរងា ព្រះអង្គទ្រង់ដណ្តប់ចីវរជាគំរប់បួន ព្រះអង្គក៏បាត់រងាទៅ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់រិះគិតដូច្នេះថា ក្នុងធម៌វិន័យនេះ កុលបុត្តទាំងឡាយណា ដែលជាអ្នករងាជាប្រក្រតី ជាអ្នកខ្លាចរងា កុលបុត្តទាំងនោះ ក៏អាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយចីវរ៣បាន បើដូច្នេះ គួរតថាគត ចងសីមា ហើយតាំងទុកនូវខេត្តដែនក្នុងចីវរ ហើយអនុញ្ញាតចីវរ៣ ដល់ភិក្ខុទាំងឡាយ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនេះ តថាគត បានដើរទៅកាន់ផ្លូវឆ្ងាយ ជាចន្លោះក្រុងរាជគ្រឹះ និងចន្លោះក្រុងវេសាលី ហើយឃើញភិក្ខុច្រើនរូប មានចីវរវេចជាសំពាយ ដាក់ផ្ទត់ចីវរលើក្បាលខ្លះ ដាក់ផ្ទត់ចីវរលើ ក ខ្លះ ដាក់ផ្ទត់ចីវរលើចង្កេះខ្លះ ដើរមក លុះឃើញហើយ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា ពួកមោឃបុរសទាំងនេះ វិលមករកសេចក្តីលោភ ក្នុងចីវរឆាប់ពេកណាស់ បើដូច្នោះ គួរតថាគត ចងសីមា តាំងទុកនូវខេត្តដែន ក្នុងចីវរ

ដល់ភិក្ខុទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនេះ តថាគត ទ្រង់ចីវរតែមួយ អង្គុយនៅក្នុងទីកណ្តាលវាល ក្នុងវេលាយប់ ក្នុងសម័យមានទឹកសន្សើមធ្លាក់ចុះ ក្នុងរាត្រីទាំងឡាយ ដែលត្រជាក់ នៅក្នុងហេមន្តរដូវ ឋិតនៅជាចន្លោះ នៃខែមាឃ និងខែផល្គុណ តថាគត ក៏មិនរងាឡើយ លុះបឋមយាមកន្លងទៅហើយ ទើបតថាគតរងា តថាគត បានដណ្តប់ចីវរជាគំរប់ពីរ តថាគតក៏បាត់រងាទៅ លុះមជ្ឈិមយាមកន្លងទៅហើយ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគំរប់បី ទើបតថាគតបាត់រងាទៅ លុះបច្ឆិមយាមកន្លងទៅហើយ អរុណរះឡើង រាត្រីក៏ភ្លឺព្រាងៗ ទើបតថាគតរងា តថាគតបានដណ្តប់ចីវរជាគំរប់បួន តថាគតក៏បាត់រងាទៅ ម្នាលភិក្ខុទាំងឡាយ តថាគត ក៏មានសេចក្តីរិះគិតដូច្នេះថា ក្នុងធម៌វិន័យនេះ កុលបុត្តទាំងឡាយណា ដែលជាអ្នករងាជាប្រក្រតី ជាអ្នកខ្លាចរងា កុលបុត្តទាំងនោះ អាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយចីវរ៣បាន បើដូច្នេះ គួរតថាគត ចងសីមា តាំងទុកនូវខេត្តដែនក្នុងចីវរ គួរអនុញ្ញាតចីវរ៣ ដល់ភិក្ខុទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតចីវរ៣ គឺសង្ឃាដិពីរជាន់ ឧត្តរាសង្គៈ (ចីពរ)១ជាន់ ស្បង់១ជាន់។

## ២១៨. អតិរេកចីវរកថា

CS vin.mv.08.17 | ភាគ ទី៨

**(២១៨)**

[៥៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា ចីវរ៣ ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតរួចហើយ ៗក៏នាំគ្នាចូលទៅកាន់ស្រុក ដោយចីវរ៣ដទៃទៀត នៅក្នុងវត្ត ដោយចីវរ៣ដទៃទៀត ចុះទៅកាន់កំពង់ ជាទីស្រង់ទឹក ដោយចីវរ៣ដទៃទៀត។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងទ្រទ្រង់អតិរេកចីវរសោះ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ក្នុងពេលនោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរទេ ភិក្ខុណាទ្រទ្រង់ ភិក្ខុនោះត្រូវវិន័យធរ ឲ្យធ្វើតាមធម៌។ សម័យនោះ អតិរេកចីវរ បានកើតឡើង ដល់ព្រះអានន្ទដ៏មានអាយុ។ ឯព្រះអានន្ទដ៏មានអាយុ ប្រាថ្នាប្រគេនចីវរនោះ ទៅព្រះសារីបុត្តដ៏មានអាយុ។ ព្រះសារីបុត្តដ៏មានអាយុ ក៏គង់នៅឯក្រុងសាកេត។ វេលានោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីរិះគិតដូច្នេះថា ព្រះមានព្រះភាគ បានបញ្ញត្តថា ភិក្ខុមិនត្រូវទ្រទ្រង់អតិរេកចីវរទេ ក៏ឯអតិរេកចីវរនេះ កើតឡើងដល់អាត្មាអញហើយ តែថា អាត្មាអញ ចង់ប្រគេនចីវរនេះ ទៅព្រះសារីបុត្តដ៏មានអាយុ ឥឡូវ ព្រះសារីបុត្តដ៏មានអាយុ គង់នៅឯក្រុងសាកេត តើអាត្មាអញ ត្រូវប្រតិបត្តិដូចម្តេច។ ខណៈនោះ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា នែអានន្ទ ចុះសារីបុត្ត នៅយូរប៉ុន្មានថ្ងៃទៀត ទើបបានមកដល់។ ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ព្រះសារីបុត្ត មុខជានឹងមកក្នុងថ្ងៃទី៩ ឬក្នុងថ្ងៃទី១០។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុទាំងឡាយ ទ្រទ្រង់អតិរេកចីវរ កំណត់ត្រឹម១០ថ្ងៃ។ សម័នោះ អតិរេកចីវរ កើតឡើងដល់ភិក្ខុទាំងឡាយ។ វេលានោះ ភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា យើងគួរប្រតិបត្តិក្នុងអតិរេកចីវរដូចម្តេចហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យវិកប្បអតិរេកចីវរទុកបាន។

[៥៨] គ្រានោះ ព្រះដ៏មានព្រះភាគគង់ក្នុងក្រុងវេសាលី គួរដល់ពុទ្ធអធ្យាស្រ័យ ហើយក៏ទ្រង់យាងទៅកាន់ចារិកក្រុងពារាណសី កាលទ្រង់យាងទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសី។ បានឮមកថា ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងឥសិបតនមិគទាយវន ទៀបក្រុងពារាណសីនោះ។ សម័យនោះ ភិក្ខុ១រូប មានស្បង់ធ្លុះ។ វេលានោះ ភិក្ខុនោះ មានសេចក្តីត្រិះរិះដូច្នេះថា ចីវរ៣ គឺសង្ឃាដិ២ជាន់ ឧត្តរាសង្គៈ១ជាន់ ស្បង់១ជាន់ ព្រះដ៏មានព្រះភាគ បានអនុញ្ញាតរួចហើយ ឯស្បង់របស់អាត្មាអញធ្លុះ បើដូច្នោះ គួរអាត្មាអញប៉ះនូវបម្នះ កាលបើដូច្នោះ ស្បង់នោះ នឹងទៅជា២ជាន់ដោយជុំវិញ កណ្តាល១ជាន់។ វេលានោះ ភិក្ខុនោះ ក៏បានប៉ះនូវបម្នះ។ ព្រះដ៏មានព្រះភាគ បានយាងទៅកាន់សេនាសនចារិក ក៏បានទតឃើញភិក្ខុនោះ កំពុងប៉ះនូវបម្នះ លុះទតឃើញហើយ ក៏ទ្រង់យាងចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងភិក្ខុនោះដូច្នេះថា នែភិក្ខុ អ្នកធ្វើអ្វី។ ភិក្ខុនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គប៉ះនូវបម្នះ។ ព្រះដ៏មានព្រះភាគ ទ្រង់តបថា ប្រពៃហើយ ៗភិក្ខុ ប្រពៃហើយភិក្ខុ អ្នកបានប៉ះនូវបម្នះ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ធ្វើនូវធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នៅថ្មោង ឬសំពត់ដែលគេបោកលាងម្តងហើយ តថាគតអនុញ្ញាត (ឲ្យអ្នកទាំងឡាយធ្វើ) សង្ឃាដិ២ជាន់ ឧត្តរាសង្គៈ១ជាន់ ស្បង់១ជាន់ (បើ) សំពត់ដែលគេរើឡើងពីរដូវ (គឺសំពត់ចាស់) តថាគតអនុញ្ញាត ឲ្យអ្នកទាំងឡាយ ធ្វើសង្ឃាដិ៤ជាន់ ឧត្តរាសង្គៈ២ជាន់ ស្បង់២ជាន់ អ្នកទាំងឡាយ គួរធ្វើនូវសេចក្តីប្រឹងប្រែង ស្វែងរកសំពត់បង្សុកូល សំពត់ធ្លាក់ចុះក្នុងរានផ្សារ តាមត្រូវការ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវបម្នះ[13] នូវការជុល នូវក្រវិលកណ្តុំ នូវកណ្តុំ នូវការធ្វើឲ្យមាំ។ [14]

## ២១៩. វិសាខាវត្ថុ

CS vin.mv.08.18 | ភាគ ទី៨

**(២១៩)**

[៥៩] គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្រុងពារាណសី គួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់យាងទៅកាន់ចារិកក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិក ដោយលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ។ បានឮមកថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ។ វេលានោះ នាងវិសាខាមិគារមាតា បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ កាលនាងវិសាខាមិគារមាតាអង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់នាងវិសាខាមិគារមាតា ដែលអង្គុយនៅក្នុងទីសមគួរហើយ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយ

ធម្មីកថា។ លំដាប់នោះ នាងវិសាខាមិគារមាតា លុះព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ជាមួយនឹងភិក្ខុសង្ឃ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្ត ដោយតុណ្ហីភាព។ លំដាប់នោះ នាងវិសាខាមិគារមាតា បានដឹងច្បាស់ថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ សម័យនោះឯង លុះរាត្រីនោះកន្លងទៅហើយ មានភ្លៀងធំធ្លាក់ចុះសព្វទ្វីបទាំង៤។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ភ្លៀងធ្លាក់ចុះ ក្នុងវត្តជេតពនយ៉ាងណា ភ្លៀងធ្លាក់ចុះក្នុងទ្វីបទាំង៤ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរងូតជំរះកាយគ្រប់ៗគ្នាទៅចុះ (ព្រោះ) ភ្លៀងធំ ដែលធ្លាក់សព្វទ្វីបទាំង៤នេះ ជាបំផុតត្រឹមនេះហើយ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន ព្រះករុណាព្រះអង្គ ហើយក៏នាំគ្នាដាក់ចីវរចេញ ងូតទឹកភ្លៀង ជំរះកាយ[15] គ្រានោះ នាងវិសាខាមិគារមាតា បានឲ្យជនតាក់តែងខាទនីយភោជនីយាហារ ដ៏ឧត្តម ហើយបង្គាប់ទាសីថា នែហង ហងចូរទៅកាន់អារាម ហើយក្រាបបង្គំទូលភត្តកាល[16] ថា បពិត្រព្រះអង្គដ៏ចំរើន កាលនេះ ជាកាលគួរហើយ ភត្តក៏សម្រេចហើយ។ ទាសីនោះ ទទួលស្តាប់ពាក្យរបស់នាងវិសាខាមិគារមាតា ដោយពាក្យថា ចាំសអ្នកជាម្ចាស់ ហើយទៅកាន់អារាម ក៏បានឃើញពួកភិក្ខុ ដែលដាក់ចីវរចេញ កំពុងងូតទឹកភ្លៀងជំរះកាយ លុះឃើញហើយ ក៏គិតថា ក្នុងអារាមនេះ គ្មានពួកភិក្ខុទេ មានតែពួកអាជីវក កំពុងងូតទឹកភ្លៀងជំរះកាយ រួចហើយក៏ត្រឡប់ចូលទៅកាន់សំណាក់នាងវិសាខាមិគារមាតាវិញ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងនាងវិសាខាមិគារមាតាថា បពិត្រអ្នកម្ចាស់ ក្នុងអារាមនេះ គ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវក កំពុងងូតទឹកភ្លៀងជំរះកាយ។ លំដាប់នោះ នាងវិសាខាមិគារមាតា ជាបណ្ឌិត ជាស្រីឆ្លាស ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ជាលោកម្ចាស់ទាំងឡាយ ដាក់ចីវរចេញ ហើយនាំគ្នាងូតទឹកភ្លៀងជំរះកាយ តែទាសីនេះ ជាស្រីល្ងង់ សំគាល់ថា ក្នុងអារាម គ្មានភិក្ខុទេ មានសុទ្ធតែពួកអាជីវក កំពុងនាំគ្នាងូតទឹកភ្លៀង ជំរះកាយ។ នាងវិសាខាមិគារមាតា បង្គាប់ទាសីថា នែហង ហងចូរទៅកាន់អារាម ហើយក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចំរើន កាលនេះ ជាកាលគួរហើយ ភត្តក៏សម្រេចហើយ។ កាលនោះ ភិក្ខុទាំងនោះ ងូតទឹកឲ្យត្រជាក់ខ្លួន មានកាយដ៏ស្រួលហើយ ក៏នាំគ្នាយកចីវរទាំងឡាយ ចូលទៅកាន់លំនៅ ដូចដែលវិញ។ ឯទាសីនោះ ទៅកាន់អារាម មិនឃើញពួកភិក្ខុ ក៏គិតថា ក្នុងអារាមគ្មានភិក្ខុសោះ មានតែអារាមទទេ ហើយក៏ត្រឡប់ចូលទៅកាន់សំណាក់នាងវិសាខាមិគារមាតាវិញ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងនាងវិសាខាមិគារមាតាថា បពិត្រអ្នកម្ចាស់ ក្នុងអារាម គ្មានភិក្ខុសោះ មានតែអារាមទទេ។ លំដាប់នោះ នាងវិសាខាមិគារមាតា ជាបណ្ឌិត ជាស្រីឆ្លាស ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ជាលោកម្ចាស់ទាំងឡាយ ងូតទឹកឲ្យត្រជាក់ខ្លួន មានកាយដ៏ស្រួល ហើយនាំយកចីវរទាំងឡាយ ចូលទៅកាន់លំនៅដូចដែល ទាសីនេះ ជាស្រីល្ងង់ សំគាល់ថា ក្នុងអារាម គ្មានពួកភិក្ខុសោះ មានតែអារាមទទេ។ នាងវិសាខា ក៏បង្គាប់ទាសីទៀតថា នែហង ហងចូរទៅកាន់អារាម ហើយក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចំរើន កាលនេះ ជាកាលគួរហើយ ភត្តក៏សម្រេចហើយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នករាល់គ្នា រៀបចំបាត្រ និងចីវរចុះ (ព្រោះ) ដល់ពេលចង្ហាន់ហើយ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះបន្ទូលរបស់ព្រះដ៏មានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ។ លុះវេលាព្រឹកឡើង ព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ហើយទ្រង់បំបាត់ព្រះអង្គ អំពីវត្តជេតពន ទៅប្រាកដទៀបក្លោងទ្វារ របស់នាងវិសាខាមិគារមាតា (ដោយឆាប់រហ័ស) ប្រៀបដូចបុរសមានកំឡាំង លាដៃដែលខ្លួនបត់ចូល ឬបត់ដៃដែលខ្លួនលាចេញ។ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើអាសនៈ ដែលគេតាក់តែងថ្វាយ ជាមួយនឹងព្រះភិក្ខុសង្ឃ។ គ្រានោះ នាងវិសាខាមិគារមាតាគិតថា អើហ្ន៎ (ហេតុនេះ) អស្ចារ្យពេកណាស់ អើហ្ន៎ (ហេតុនេះ) ចំឡែកពេកណាស់ ព្រះតថាគត មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថាជំនន់ប្រមាណត្រឹមជង្គង់ខ្លះ ត្រឹមចង្កេះខ្លះ កំពុងហូរទៅៗ សូម្បីតែជើង ឬចីវររបស់ភិក្ខុ១អង្គ ក៏គ្មានទទឹកឡើយ ហើយក៏មានចិត្តរីករាយខ្ពស់ឡើង រួចអង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយៈ និងភោជនីយាហារដ៏ឧត្តម ដោយដៃរបស់ខ្លួន ត្រាតែព្រះភិក្ខុសង្ឃហាមឃាត់ លុះកំណត់ដឹងថា ព្រះមានព្រះភាគ ឆាន់ហើយ ដាក់ព្រះហស្តចុះចាកបាត្រហើយ នាងក៏អង្គុយនៅក្នុងទីសមគួរ។ នាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ សូមពរ៨ប្រការអំពីព្រះអង្គ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ធម្មតា ព្រះតថាគតទាំងឡាយគ្មានពរទេ។ នាងវិសាខា ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ សូមតែពរណា ដែលគួរ និងពរណា ដែលឥតទោស។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ចូរនាងនិយាយមកចុះ។ នាងវិសាខា ក៏ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចង់ប្រគេនវស្សិកសាដក (សំពត់សម្រាប់ងូតទឹកភ្លៀង) ចង់ប្រគេនអាគន្តុកភត្ត (ភត្តដែលប្រគេនដល់ភិក្ខុទើបមកដល់ថ្មី) ចង់ប្រគេនគមិកភត្ត (ភត្តដែលប្រគេនដល់ភិក្ខុអ្នកមានដំណើរទៅ) ចង់ប្រគេនគិលានភត្ត (ភត្តដែលប្រគេនដល់ភិក្ខុមានជម្ងឺ) ចង់ប្រគេនគិលានុបដ្ឋាកភត្ត (ភត្តដែលប្រគេនដល់ភិក្ខុអ្នកបម្រើជម្ងឺ) ចង់ប្រគេនគិលានភេសជ្ជៈ (ថ្នាំដែលប្រគេន ដល់ភិក្ខុមានជម្ងឺ) ចង់ប្រគេនធុវយាគូ (បបរ ដែលត្រូវប្រគេនជានិច្ច) ដល់ព្រះសង្ឃ និងចង់ប្រគេនឧទកសាដិក (សំពត់សម្រាប់ងូតទឹក) ដល់ភិក្ខុនីសង្ឃ ដរាបដល់អស់ជីវិត។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនាងវិសាខា នាងឃើញអំណាចប្រយោជន៍ដូចម្តេច បានជាសូមពរ៨ប្រការ អំពីតថាគត។ នាងវិសាខា ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងវេលាព្រឹកមិញនេះ ខ្ញុំព្រះអង្គបង្គាប់ទាសីថា នែហង ហងចូរទៅកាន់អារាម ហើយក្រាបបង្គំទូលភត្តកាលថា បពិត្រព្រះអង្គដ៏ចំរើន កាលនេះ ជាកាលគួរហើយ ភត្តក៏សម្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន ទាសីនោះ ក៏ទៅកាន់អារាម ហើយបានឃើញពួកភិក្ខុ ដាក់ចីវរចេញហើយ កំពុងនាំគ្នាងូតទឹកភ្លៀងជំរះកាយ លុះឃើញហើយ ក៏សំគាល់ថា ក្នុងអារាម គ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវក កំពុងងូតទឹកភ្លៀង ជំរះកាយ រួចក៏ត្រឡប់ចូលមកកាន់សំណាក់ខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ បាននិយាយពាក្យនេះ នឹងខ្ញុំព្រះអង្គថា បពិត្រអ្នកម្ចាស់ ក្នុងអារាម គ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវក ងូតទឹកភ្លៀង ជំរះកាយ បពិត្រព្រះអង្គដ៏ចំរើន កិរិយាអាក្រាត ជាការមិនស្អាត គួរខ្ពើមរអើម បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនវស្សិកសាដិក ដល់សង្ឃអស់មួយជីវិត។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃ មានតទៅទៀត ភិក្ខុជាអាគន្តុកៈ (ទើបមកដល់ថ្មី) មិនទាន់ឆ្លាសក្នុងផ្លូវ មិនទាន់ឆ្លាស ក្នុងទីគោចរ លំបាកនឹងត្រាច់ទៅបិណ្ឌបាត ភិក្ខុជាអាគន្តុកៈនោះ នឹងឆាន់អាគន្តុកភត្ត របស់ខ្ញុំព្រះអង្គហើយ មុខជានឹងឆ្លាសក្នុងផ្លូវ ឆ្លាសក្នុងទីគោចរ មិនលំបាកនឹងត្រាច់ទៅបិណ្ឌបាត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនអាគន្តុកភត្ត ដល់សង្ឃអស់មួយជីវិត។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃ មានតទៅទៀត ភិក្ខុអ្នកដំណើរ បើរវល់តែស្វែងរកភត្តសម្រាប់ខ្លួន មុខជានឹងបែកខ្នែក ចាកគ្នីគ្នា ឬបើចង់ទៅកាន់លំនៅ ក្នុងប្រទេសណា នឹងចូលទៅដល់ប្រទេសនោះខុសកាលវេលា នាំឲ្យលំបាកនឹងទៅកាន់ផ្លូវឆ្ងាយ កាលបើភិក្ខុអ្នកដំណើរនោះ បានឆាន់គមិកភត្តរបស់ខ្ញុំព្រះអង្គហើយ មុខជាមិនបែកខ្នែក ចាកគ្នីគ្នាទេ ឬបើចង់ទៅកាន់លំនៅក្នុងប្រទេសណា ក៏បានចូលទៅដល់ប្រទេសនោះ មិនខុសកាលវេលា ឃើញថា មិនលំបាកនឹងទៅកាន់ផ្លូវឆ្ងាយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ឃើញអំណាច

ប្រយោជន៍នេះហើយ បានជាចង់ប្រគេនគមិកភត្ត ដល់សង្ឃអស់មួយជីវិត។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃ មានតទៅទៀត ភិក្ខុមានជម្ងឺ កាលបើមិនបានភោជន ជាទីសប្បាយទេ អាពាធក៏រឹងរឹតតែចំរើនឡើង ឬនឹងធ្វើមរណភាពទៅក៏សឹងមាន កាលបើភិក្ខុមានជម្ងឺនោះ បានឆាន់គិលានភត្ត របស់ខ្ញុំព្រះអង្គហើយ អាពាធ ក៏មិនចំរើនឡើង មរណភាពក៏គ្មាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនគិលានភត្ត ដល់ព្រះសង្ឃអស់មួយជីវិត។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃ មានតទៅទៀត ភិក្ខុអ្នកបម្រើភិក្ខុឈឺ កាលបើរវល់តែនឹងស្វែងរកភត្តសម្រាប់ខ្លួនហើយ មុខជានឹងនាំយកភត្តមកឲ្យភិក្ខុឈឺក្នុងវេលាថ្ងៃពេក ហើយក៏នឹងធ្វើភិក្ខុឈឺ ឲ្យដាច់ចង្ហាន់ បើភិក្ខុអ្នកបម្រើភិក្ខុឈឺនោះ បានឆាន់គិលានុបដ្ឋាកភត្ត របស់ខ្ញុំព្រះអង្គហើយ នឹងបាននាំយកភត្ត មកឲ្យភិក្ខុឈឺ ក្នុងកាលគួរ ហើយនឹងមិនធ្វើភិក្ខុឈឺ ឲ្យដាច់ចង្ហាន់ឡើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនគិលានុបដ្ឋាកភត្ត ដល់សង្ឃអស់មួយជីវិត។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃ មានតទៅទៀត ភិក្ខុមានជម្ងឺ កាលបើមិនបានភេសជ្ជៈ ជាទីសប្បាយទេ អាពាធក៏រឹងរឹតតែចំរើនឡើង ឬនឹងធ្វើមរណភាពទៅក៏សឹងមាន កាលបើភិក្ខុមានជម្ងឺនោះ បានឆាន់គិលានភេសជ្ជៈ របស់ខ្ញុំព្រះអង្គហើយ អាពាធក៏មិនចំរើនឡើង មិនធ្វើមរណភាពទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនគិលានភេសជ្ជៈ ដល់សង្ឃអស់មួយជីវិត។ បពិត្រព្រះអង្គដ៏ចំរើន ពរដទៃ មានតទៅទៀត ព្រះដ៏មានព្រះភាគ ទ្រង់យល់ឃើញអានិសង្សទាំង១០យ៉ាងហើយ បានជាទ្រង់អនុញ្ញាតបបរ ក្នុងអន្ធកវិន្ទប្រទេស បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ បានឃើញអានិសង្សទាំងនោះដែរ បានជាចង់ប្រគេនធុវយាគូ ដល់សង្ឃអស់មួយជីវិត។ បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុនី ក្នុងសាសនានេះ មានកាយអាក្រាត ងូតទឹកក្នុងកំពង់មួយ ជាមួយនឹងពួកស្រីពេស្យា (ផ្កាមាស) នាស្ទឹងអចិរវតី បពិត្រព្រះអង្គដ៏ចំរើន ពួកស្រីពេស្យាទាំងនោះ នាំគ្នាចំអក ចំអន់ពួកភិក្ខុនីថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយ នៅក្មេងនៅឡើយ ប្រញាប់អ្វីប្រព្រឹត្តព្រហ្មចរិយធម៌ គួរតែលោកម្ចាស់ទាំងឡាយ នៅបរិភោគកាមគុណសិន បើលោកម្ចាស់ទាំងឡាយ ចាស់ជរាវេលាណា សឹមនាំគ្នាប្រព្រឹត្តព្រហ្មចរិយធម៌វេលានោះចុះ យ៉ាងនេះ ទើបឈ្មោះថា លោកម្ចាស់ទាំងឡាយ បានរក្សាប្រយោជន៍ទាំងពីរទុក បពិត្រព្រះអង្គដ៏ចំរើន កាលបើពួកស្រីពេស្យា និយាយចំអក ចំអន់ (ឲ្យដូច្នេះ) ហើយ ភិក្ខុនីទាំងនោះ ក៏មានសេចក្តីអៀនខ្មាស បពិត្រព្រះអង្គដ៏ចំរើន មាតុគ្រាម មានកាយអាក្រាត ជាការមិនស្អាតទេ គួរខ្ពើមរអើមពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ឃើញអំណាចប្រយោជន៍នេះហើយ បានជាចង់ប្រគេនឧទកសាដិកៈ[17] ដល់ភិក្ខុនីសង្ឃអស់មួយជីវិត។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ចុះនាងយល់ឃើញអានិសង្សដូចម្តេច បានជានាងសូមពរ៨ប្រការ អំពីតថាគត។ នាងវិសាខា ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុក្នុងសាសនានេះ នៅចាំវស្សាក្នុងទិសទាំងឡាយ រួចហើយនឹងមកកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះអង្គ ភិក្ខុទាំងនោះនឹងចូលមកគាល់ព្រះអង្គ ហើយសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឈ្មោះនេះ ធ្វើមរណកាលហើយ ភិក្ខុនោះ មានគតិដូចម្តេច មានបរលោកដូចម្តេច ព្រះដ៏មានព្រះភាគ មុខជានឹងទ្រង់ព្យាករណ៍បញ្ហានេះ ក្នុងសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តផលក្តី ខ្ញុំព្រះអង្គ នឹងចូលទៅរកភិក្ខុទាំងនោះ ហើយនឹងសួរថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន លោកម្ចាស់នោះ ធ្លាប់និមន្តមកក្រុងសាវត្ថីដែរឬ បើប្រសិនជាពួកភិក្ខុនិយាយប្រាប់ខ្ញុំព្រះអង្គថា ភិក្ខុនោះ ធ្លាប់និមន្តមកក្រុងសាវត្ថីដែរ ខ្ញុំព្រះអង្គ នឹងដល់នូវសេចក្តីចូលចិត្តក្នុងហេតុនេះថា ច្បាស់ជាលោកម្ចាស់នោះ ធ្លាប់បានបរិភោគវស្សិកសាដិកក្តី អាគន្តុកភត្តក្តី គមិកភត្តក្តី គិលានភត្តក្តី គិលានុបដ្ឋាកភត្តក្តី គិលានភេសជ្ជៈក្តី ធុវយាគូក្តី (មិនខាន) កាលខ្ញុំព្រះអង្គនោះ រលឹកទាននោះរឿយៗហើយ សេចក្តីត្រេកអរទន់ នឹងកើតឡើង កាលបើសេចក្តីត្រេកអរទន់ កើតឡើងហើយ ចិត្តប្រកបដោយបីតិ នឹងកើតឡើង កាលបើចិត្តប្រកបដោយបីតិ កើតឡើងហើយ កាយក៏នឹងស្ងប់រម្ងាប់ លុះខ្ញុំព្រះអង្គ មានកាយស្ងប់រម្ងាប់ហើយ នឹងទទួលសេចក្តីសុខ កាលបើខ្ញុំព្រះអង្គ បានទទួលសេចក្តីសុខហើយ ចិត្តក៏នឹងដំកល់មាំ ឥន្ទ្រិយភាវនា ពលភាវនា ពោជ្ឈង្គភាវនានោះ នឹងមានដល់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ បានយល់ឃើញអានិសង្សនេះហើយ បានជាសូមពរ៨ប្រការ អំពីព្រះតថាគត។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ល្អហើយ ល្អហើយ ម្នាលនាងវិសាខា នាងបានយល់ឃើញអានិសង្សនេះ ហើយបានសូមពរ៨ប្រការ អំពីតថាគត ជាការប្រពៃពិត ម្នាលនាងវិសាខា (បើដូច្នោះ) តថាគតអនុញ្ញាតពរ៨ប្រការដល់នាង។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់អនុមោទនា ចំពោះនាងវិសាខា ដោយគាថាទាំងឡាយនេះថា

[៦០] ស្រីណាជាអ្នកឲ្យបាយ និងទឹក មានចិត្តរីករាយ មានសីលបរិបូណ៌ ជាសាវិការបស់ព្រះសុគត គ្របសង្កត់នូវសេចក្តីកំណាញ់បាន ហើយឲ្យនូវទាន ស្រីនោះឯង តែងបាននូវផល គឺអារម្មណ៍ដ៏ប្រសើរដោយប្រពៃ មានរូបជាដើម បានបន្ទោបង់នូវសេចក្តីសោក នាំមកនូវសេចក្តីសុខ មានកំឡាំង និងអាយុទិព្វ ស្រីនោះ ជាស្រីមានសេចក្តីប្រាថ្នានូវបុណ្យ មានសេចក្តីសុខ ឥតមានទុក្ខ តែងរីករាយក្នុងស្ថានសួគ៌ អស់កាលជាអង្វែង ព្រោះអាស្រ័យនូវមគ្គចិត្ត ដ៏ប្រាសចាកធូលី មិនមានកិលេស (នោះឯង)។

[៦១] កាលនោះ ព្រះដ៏មានព្រះភាគទ្រង់អនុមោទនាចំពោះនាងវិសាខាមិគារមាតា ដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈ យាងចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវស្សិកសាដិកៈ អាគន្តុកភត្ត គមិកភត្ត គិលានភត្ត គិលានុបដ្ឋាកភត្ត គិលានភេសជ្ជៈ ធុវយាគូ និងឧទកសាដិកៈ ជារបស់ភិក្ខុនីសង្ឃ។

ចប់ វារៈពោលអំពីនាងវិសាខា។

## ២២០. និសីទនាទិអនុជានានា

CS vin.mv.08.19 | ភាគ ទី៨

**(២២០)**

[៦២] សម័យនោះឯង ពួកភិក្ខុបានឆាន់ភោជនទាំងឡាយដ៏ឧត្តម ក៏ភ្លេចស្មារតី មិនដឹងខ្លួន សិងលក់ទៅ។ កាលបើភិក្ខុទាំងនោះ ភ្លេចស្មារតី មិនដឹងខ្លួន កំពុងសិងលក់ អសុចិ ក៏ឃ្លាតចេញ ដោយយល់សប្តិ សេនាសនៈ ក៏ប្រឡាក់ដោយអសុចិ។ កាលនោះ ព្រះមានព្រះភាគ មានព្រះអានន្ទដ៏មានអាយុ ជាបច្ឆាសមណៈ[18] ទ្រង់ពុទ្ធដំណើរទៅកាន់សេនាសនចារិក ហើយទតឃើញសេនាសនៈប្រឡាក់ដោយអសុចិ លុះទតឃើញច្បាស់ ក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ សេនាសនៈនេះ ប្រឡាក់ដោយវត្ថុអ្វី។ អានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន

ក្នុងពេលនេះ ពួកភិក្ខុបានឆាន់ភោជនទាំងឡាយដ៏ឧត្តម ក៏ភ្លេចស្មារតី មិនដឹងខ្លួន ហើយសិងលក់ទៅ កាលបើភិក្ខុទាំងនោះ ភ្លេចស្មារតី មិនដឹងខ្លួន កំពុងតែសិងលក់ អសុចិ ក៏ឃ្លាតចេញ ដោយយល់សប្តិ បពិត្រព្រះមានព្រះភាគ សេនាសនៈនោះ ប្រឡាក់ដោយអសុចិ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ យ៉ាងហ្នឹងហើយ ម្នាលអានន្ទ យ៉ាងហ្នឹងហើយ ម្នាលអានន្ទ ព្រោះតែភិក្ខុទាំងនោះភ្លេចស្មារតី មិនដឹងខ្លួន បានជាដេកលក់ទៅ អសុចិឃ្លាតចេញ ដោយយល់សប្តិ ម្នាលអានន្ទ ពួកភិក្ខុណាដំកល់ស្មារតីខ្ជាប់ ដឹងខ្លួន ហើយដេកលក់ទៅ អសុចិរបស់ភិក្ខុទាំងនោះ មិនឃ្លាតចេញទេ ម្នាលអានន្ទ ម្យ៉ាងទៀត ពួកភិក្ខុណា ជាបុថុជ្ជនមែន តែគ្មានតម្រេក ក្នុងកាមទាំងឡាយ អសុចិរបស់ពួកភិក្ខុនោះ ក៏មិនឃ្លាតចេញដែរ ម្នាលអានន្ទ ឯពាក្យថា អសុចិរបស់ព្រះអរហន្ត ឃ្លាតចេញនេះ មិនសមហេតុ មិនសមផលទេ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមក ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគត មានអានន្ទជាបច្ឆាសមណៈ ដើរទៅកាន់សេនាសនចារិក ក្នុងទីនេះ បានឃើញសេនាសនៈប្រឡាក់ដោយអសុចិ លុះឃើញហើយ ក៏ហៅអានន្ទមកសួរថា ម្នាលអានន្ទ សេនាសនៈនេះ ប្រឡាក់ដោយវត្ថុអ្វី អានន្ទឆ្លើយថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងពេលនេះ ពួកភិក្ខុបានឆាន់ភោជនទាំងឡាយ ដ៏ឧត្តម ហើយភ្លេចស្មារតី មិនដឹងខ្លួន ដេកលក់ទៅ កាលបើភិក្ខុទាំងនោះ ភ្លេចស្មារតី មិនដឹងខ្លួន កំពុងដេកលក់ អសុចិ ក៏ឃ្លាតចេញ ដោយយល់សប្តិ បពិត្រព្រះមានព្រះភាគ សេនាសនៈនោះ ប្រឡាក់ដោយអសុចិ តថាគត ក៏ពោលថា ម្នាលអានន្ទ យ៉ាងហ្នឹងហើយ ម្នាលអានន្ទ យ៉ាងហ្នឹងហើយ ម្នាលអានន្ទ ព្រោះតែភិក្ខុទាំងនោះ ភ្លេចស្មារតី មិនដឹងខ្លួន បានជាដេកលក់ទៅ អសុចិឃ្លាតចេញ ដោយយល់សប្តិ ម្នាលអានន្ទ ភិក្ខុទាំងឡាយណា ដំកល់ស្មារតីខ្ជាប់ ដឹងខ្លួន ហើយដេកលក់ទៅ អសុចិរបស់ភិក្ខុទាំងនោះ មិនឃ្លាតចេញទេ ម្នាលអានន្ទ ម្យ៉ាងទៀត ពួកភិក្ខុណា ជាបុថុជ្ជនមែន តែគ្មានតម្រេក ក្នុងកាមទាំងឡាយ អសុចិរបស់ពួកភិក្ខុនោះ ក៏មិនឃ្លាតចេញដែរ ម្នាលអានន្ទ ឯពាក្យថា អសុចិ របស់ព្រះអរហន្តឃ្លាតចេញនេះ មិនសមហេតុ មិនសមផលទេ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់ភិក្ខុភ្លេចស្មារតី មិនដឹងខ្លួន ដេកលក់ទៅនេះ មាន៥យ៉ាង គឺ ភិក្ខុនោះលក់លំបាក១ ភ្ញាក់លំបាក១ ឃើញសុបិនអាក្រក់១ ទេវតាមិនរក្សា១ អសុចិឃ្លាតចេញ១ ម្នាលភិក្ខុទាំងឡាយ ទោសរបស់ភិក្ខុភ្លេចស្មារតី មិនដឹងខ្លួន ហើយដេកលក់ទៅ មាន៥យ៉ាងនេះឯង។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់ភិក្ខុ ដែលបានដំកល់ស្មារតីខ្ជាប់ ដឹងខ្លួនហើយ ដេកលក់ទៅនេះ មាន៥យ៉ាង គឺ ភិក្ខុនោះដេកលក់ស្រួល១ ភ្ញាក់ស្រួល១ មិនឃើញសុបិនអាក្រក់១ ទេវតារក្សា១ អសុចិមិនឃ្លាតចេញ១ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់ភិក្ខុបានដំកល់ស្មារតីខ្ជាប់ ដឹងខ្លួន ហើយដេកលក់ទៅ មាន៥យ៉ាងនេះឯង។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនិសីទនៈ (សំពត់ទ្រាប់អង្គុយ) ដើម្បីរក្សាកាយ ដើម្បីរក្សាចីវរ ដើម្បីរក្សាសេនាសនៈ។ សម័យនោះឯង និសីទនៈតូចពេក រក្សាសេនាសនៈទាំងអស់មិនបាន។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុចង់បានកម្រាលទំហំប៉ុន្មាន តថាគតអនុញ្ញាតឲ្យធ្វើទំហំប៉ុណ្ណោះ។

[៦៣] សម័យនោះឯង ព្រះវេលដ្ឋសីសៈដ៏មានអាយុ ជាឧបជ្ឈាយ៍របស់ព្រះអានន្ទដ៏មានអាយុ កើតបូសធំ។ ចីវរទាំងឡាយ របស់ព្រះវេលដ្ឋសីសៈនោះ ជាប់ស្អិតនឹងកាយ ដោយទឹករំអិល។ ពួកភិក្ខុ យកទឹកផ្សើមចីវរទាំងនោះឲ្យជោក ហើយទើបបកចេញបាន។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរ ទៅកាន់សេនាសនចារិក ទ្រង់ទតឃើញភិក្ខុទាំងនោះ កំពុងយកទឹកទៅផ្សើមចីវរទាំងនោះ ឲ្យជោក ហើយបកចេញ ក៏ទ្រង់ពុទ្ធដំណើរចូលទៅកាន់សំណាក់ភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ទ្រង់មានព្រះពុទ្ធដីកានេះ នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ មានអាពាធដូចម្តេច។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន លោកដ៏មានអាយុនេះ កើតបូសធំ ចីវរទាំងឡាយ ជាប់ស្អិតនឹងកាយ ដោយទឹករំអិល យើងខ្ញុំទាំងឡាយ យកទឹកមកផ្សើមចីវរទាំងនោះ ឲ្យជោក ហើយបកចេញ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមក ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មានអាពាធ គឺកម ឬរមាស់ក្តី បូសតូចក្តី ទឹករងៃក្តី បូសធំក្តី តថាគតអនុញ្ញាត សំពត់សម្រាប់គ្របកម (ជាដើម) ដល់ភិក្ខុនោះ។

[៦៤] គ្រានោះ នាងវិសាខាមិគារមាតា នាំយកសំពត់សម្រាប់ជូតមុខ ចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូល ព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់ទទួលសំពត់សម្រាប់ជូតមុខ របស់ខ្ញុំព្រះអង្គ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង។ ព្រះដ៏មានព្រះភាគ ក៏បានទទួលសំពត់សម្រាប់ជូតមុខ (នោះ)។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់នាងវិសាខាមិគារមាតា ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ ឯនាងវិសាខាមិគារមាតា កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ[19] ហើយចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមក ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត សំពត់សម្រាប់ជូតមុខ។

[៦៥] សម័យនោះឯង មល្លក្សត្រឈ្មោះរោជៈ ជាសំឡាញ់របស់ព្រះអានន្ទដ៏មានអាយុ។ មល្លក្សត្រ ឈ្មោះរោជៈ (នោះ) បានទុកដាក់សំពត់សម្បកឈើ លើកដៃនៃព្រះអានន្ទដ៏មានអាយុ។ ឯព្រះអានន្ទដ៏មានអាយុ ក៏ត្រូវការនឹងសំពត់សម្បកឈើ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុកាន់យក ដោយសេចក្តីស្និទ្ធស្នាលរបស់មិត្រ ប្រកបដោយអង្គ៥គឺ មិត្រដែលគ្រាន់តែបានឃើញគ្នាម្តងមួយគ្រា១ មិត្រដែលស្និទ្ធស្នាលនឹងគ្នាមាំមួន១ មិត្រដែលបាននិយាយបើកឱកាសគ្នាតាមត្រូវការ១ មិត្រនោះមានជីវិតរស់នៅ១ ភិក្ខុដឹងថា បើអាត្មាអញ កាន់យកវត្ថុណាមួយហើយ មិត្រនោះ មានសេចក្តីត្រេកអរ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុកាន់យក ដោយសេចក្តីស្និទ្ធស្នាល របស់មិត្រ ប្រកបដោយអង្គ ទាំង៥នេះបាន។

## ២២១. បច្ឆិមវិកប្បនុបគចីវរាទិកថា

CS vin.mv.08.20 | ភាគ ទី៨

[៦៦] សម័យនោះឯង ពួកភិក្ខុមានត្រៃចីវរបរិបូណ៌ហើយ តែត្រូវការដោយសំពត់តម្រងទឹកផង ដោយថង់បាត្រផង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតសំពត់បរិក្ខារ។ ក្នុងពេលនោះ ពួកភិក្ខុ មានសេចក្តីត្រិះរិះ ដូច្នេះថា សំពត់ទាំងឡាយណា គឺត្រៃចីវរក្តី សំពត់សម្រាប់ងូតទឹកភ្លៀងក្តី សំពត់សម្រាប់ទ្រាប់អង្គុយក្តី សំពត់កម្រាលក្តី សំពត់សម្រាប់គ្របកមក្តី សំពត់សម្រាប់ជូតមុខក្តី សំពត់បរិក្ខារក្តី ដែលព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតហើយ សំពត់ទាំងអស់នោះ តើយើងគួរអធិដ្ឋាន ឬគួរវិកប្បទុក។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុអធិដ្ឋានត្រៃចីវរ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់សម្រាប់ងូតទឹកភ្លៀងអស់៤ខែ នៃរដូវភ្លៀង តអំពីកាល៤ខែនោះទៅ ត្រូវវិកប្បទុក ឲ្យអធិដ្ឋានសំពត់សម្រាប់ទ្រាប់អង្គុយ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់កម្រាល មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់សម្រាប់គ្របកម កំណត់ត្រឹមមានអាពាធ ហួសអំពីអាពាធនោះទៅ ត្រូវវិកប្បទុក ឲ្យអធិដ្ឋានសំពត់សម្រាប់ជូតមុខ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់បរិក្ខារ មិនឲ្យវិកប្បទេ។ ក្នុងពេលនោះ ពួកភិក្ខុ មានសេចក្តីត្រិះរិះ ដូច្នេះថា ឱហ្ន៎ ចីវរយ៉ាងតូចបំផុត ត្រឹមប៉ុនណា ទើបត្រូវវិកប្បបាន។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុវិកប្បចីវរ យ៉ាងតូចបំផុត បណ្តោយត្រឹម៨ធ្នាប់ ទទឹងត្រឹម៤ធ្នាប់ ដោយធ្នាប់ព្រះសុគត។ សម័យនោះឯង ព្រះកស្សបដ៏មានអាយុ ជាអ្នកធ្វើសេចក្តីគោរព ក្នុងសំពត់បង្សុកូល។[20] ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុធ្វើចីវរឲ្យសៅហ្មង ដោយចេស (គឺដេរប៉ះដោយចេស)។ ចីវរមានជាយមិនស្មើគ្នា។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុរុះរើចីវរ ដែលមានជាយមិនស្មើគ្នា (គឺកាត់ជាយដែលវែងជាងគេចេញ)។ សរសៃអំបោះទាំងឡាយ ក៏ចេះតែរសាត់ចេញ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលើកឡើង (គឺប៉ះ) អនុវាតខាងខ្នង នឹងអនុវាតខាងពោះ។ សម័យនោះឯង ជាន់ទាំងឡាយនៃសង្ឃាដិ ដាច់ចេញពីគ្នា។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុធ្វើថ្នេរ ឲ្យមានសណ្ឋានដូចជាក្រឡាចត្រង្គ។

[៦៧] សម័យនោះឯង ពួកភិក្ខុកំពុងធ្វើចីវរ (ឲ្យ) ភិក្ខុ១រូប លុះភិក្ខុកាត់ចីវរទាំងអស់ទៅហើយ ក៏មិនគ្រប់គ្រាន់។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យកាត់តែចីវរពីរ ចីវរមួយ មិនបាច់កាត់ក៏បាន។ ដល់កាត់ចីវរពីរ ចីវរមួយមិនកាត់ ក៏នៅតែមិនគ្រប់គ្រាន់។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ចីវរពីរមិនបាច់កាត់ ឲ្យកាត់តែចីវរមួយបាន។ ភិក្ខុមិនកាត់ចីវរពីរ កាត់តែចីវរមួយ ក៏នៅតែមិនគ្រប់គ្រាន់ទៀត។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលើកឡើង (គឺប៉ះ) សំពត់អាគន្តុកៈ (សំពត់ថ្មី) ទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់ចីវរ ដែលមិនកាត់ទាំងអស់នោះទេ ភិក្ខុណាទ្រទ្រង់ (ស្លៀកដណ្តប់) ត្រូវអាបត្តិទុក្កដ។

[៦៨] សម័យនោះឯង ចីវរកើតឡើងជាច្រើនដល់ភិក្ខុមួយរូប។ ឯភិក្ខុនោះ ចង់ឲ្យចីវរនោះ ដល់មាតា និងបិតា។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឲ្យចីវរ ដោយគិតថា មាតា និងបិតា ដូច្នេះ តថាគតនឹងថាដូចម្តេចបាន ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យចីវរដល់មាតា និងបិតាបាន ម្នាលភិក្ខុទាំងឡាយ តែថា ភិក្ខុមិនត្រូវធ្វើទាន ដែលគេឲ្យដោយសទ្ធា ឲ្យធ្លាក់ចុះឡើយ ភិក្ខុណាឲ្យធ្លាក់ចុះ ត្រូវអាបត្តិទុក្កដ។

[៦៩] សម័យនោះឯង ភិក្ខុមួយរូបទុកចីវរក្នុងអន្ធវន (ព្រៃងងឹត) ហើយមានតែស្បង់ និងឧត្តរាសង្គៈ (ចីពរ) ចូលទៅស្រុកដើម្បីបិណ្ឌបាត។ ពួកចោរ ក៏លួចយកចីវរនោះទៅ។ ភិក្ខុនោះ មានសំពត់អាក្រក់ មានចីវរសៅហ្មង។ ពួកភិក្ខុនិយាយយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វី ក៏អ្នកមានសំពត់អាក្រក់ មានចីវរសៅហ្មង។ ភិក្ខុនោះ និយាយនឹងភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំទុកចីវរក្នុងអន្ធវននេះ ហើយមានតែស្បង់ និងឧត្តរាសង្គៈ ចូលទៅស្រុក ដើម្បីបិណ្ឌបាត ពួកចោរ លួចយកចីវរនោះទៅ ព្រោះហេតុនោះ បានជាខ្ញុំ មានសំពត់អាក្រក់ មានចីវរសៅហ្មង។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មានតែស្បង់ និងឧត្តរាសង្គៈ មិនត្រូវចូលទៅស្រុកទេ ភិក្ខុណាចូលទៅ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ព្រះអានន្ទដ៏មានអាយុ មានតែស្បង់ និងឧត្តរាសង្គៈ ចូលទៅស្រុក ដើម្បីបិណ្ឌបាត ដោយភ្លេចស្មារតី។ ពួកភិក្ខុបាននិយាយដូច្នេះ នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តថា ភិក្ខុមានតែស្បង់ និងឧត្តរាសង្គៈ មិនត្រូវចូលទៅស្រុក មិនមែនទេឬ ម្នាលអាវុសោ ចុះហេតុអ្វី បានជាអ្នក មានតែស្បង់ និងឧត្តរាសង្គៈ ចូលទៅស្រុក។ ព្រះអានន្ទឆ្លើយថា ម្នាលអាវុសោ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុមានតែស្បង់ និងឧត្តរាសង្គៈ មិនត្រូវចូលទៅស្រុកទេ ក៏ពិតមែនហើយ ម្នាលអាវុសោ តែថា ខ្ញុំចូលទៅហើយ ដោយភ្លេចស្មារតី។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ឯហេតុគួរទុកដាក់សង្ឃាដិមាន៥យ៉ាង គឺភិក្ខុមានជម្ងឺ១ មានកំណត់ដោយរដូវភ្លៀង៤ខែ១ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ១ វិហារមានការរក្សាទ្វារមាំមួន១ ភិក្ខុបានក្រាលកឋិនហើយ១ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង៥យ៉ាងនេះឯង ជាហេតុគួរទុកដាក់សង្ឃាដិបាន។ ម្នាលភិក្ខុទាំងឡាយ ឯហេតុគួរទុកដាក់នូវសំពត់ឧត្តរាសង្គៈ មាន៥យ៉ាង គឺ ភិក្ខុមានជម្ងឺ១ មានកំណត់ដោយរដូវភ្លៀង៤ខែ១ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ១ វិហារមានការរក្សាទ្វារមាំមួន១ ភិក្ខុបានក្រាលកឋិនហើយ១ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង៥យ៉ាងនេះឯង ជាហេតុគួរទុកដាក់សំពត់ឧត្តរាសង្គៈបាន។ ម្នាលភិក្ខុទាំងឡាយ ឯហេតុគួរទុកដាក់ស្បង់មាន៥យ៉ាង គឺភិក្ខុមានជម្ងឺ១ មានកំណត់ដោយរដូវភ្លៀង៤ខែ១ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ១ វិហារមានការរក្សាទ្វារមាំមួន១ ភិក្ខុបានក្រាលកឋិនហើយ១ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង៥យ៉ាងនេះឯង ជាហេតុគួរទុកដាក់ស្បង់បាន។ ម្នាលភិក្ខុទាំងឡាយ ឯហេតុគួរទុកដាក់សំពត់សម្រាប់ងូតទឹកភ្លៀង មាន៥យ៉ាងគឺ ភិក្ខុមានជម្ងឺ១ ភិក្ខុទៅកាន់ទីឥតមានសីមា១ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ១ វិហារមានការរក្សាទ្វារមាំមួន១ សំពត់សម្រាប់ងូតទឹកភ្លៀង ភិក្ខុមិនទាន់បានធ្វើ ឬធ្វើមិនទាន់ស្រេច១ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង៥យ៉ាងនេះឯង ជាហេតុគួរទុកដាក់ សំពត់សម្រាប់ងូតទឹកភ្លៀងបាន។

## ២២២. សង្ឃិកចីវរុប្បាទកថា

CS vin.mv.08.21 | ភាគ ទី៨

**(២២២)**

[៧០] សម័យនោះឯង ភិក្ខុមួយរូបនៅចាំវស្សាតែម្នាក់ឯង។ មនុស្សទាំងឡាយ នាំគ្នាប្រគេនចីវរក្នុងទីនោះ ដោយពាក្យថា យើងទាំងឡាយ ប្រគេនចំពោះសង្ឃ។ ភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ បានបញ្ញត្តថា ដែលហៅថាសង្ឃ បើយ៉ាងតិចបំផុត ត្រឹមភិក្ខុ៤រូប ឥឡូវ អាត្មាអញ តែម្នាក់ឯង ក៏មនុស្សទាំងនេះ ប្រគេនចីវរទាំងឡាយ ដោយពាក្យថា យើងទាំងឡាយ ប្រគេនចំពោះសង្ឃ បើដូច្នោះ មានតែអាត្មាអញ នាំយកចីវររបស់សង្ឃទាំងនេះ ទៅកាន់ក្រុងសាវត្ថី។ ភិក្ខុនោះ ក៏នាំយកចីវរទាំងនោះ ទៅកាន់ក្រុងសាវត្ថី ហើយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ ចីវរទាំងនោះ ជាចីវររបស់អ្នក កំណត់តែត្រឹមកឋិនដោះ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុក្នុងសាសនានេះ នៅចាំវស្សាតែម្នាក់ឯង។ ក្នុងទីនោះ ពួកមនុស្ស ប្រគេនចីវរទាំងឡាយ ដោយពាក្យថា យើងទាំងឡាយ ប្រគេនចីវរ ចំពោះសង្ឃ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរទាំងនោះ ដល់ភិក្ខុនោះឯង កំណត់ត្រឹមកឋិនដោះ។ សម័យនោះឯង ភិក្ខុមួយរូប នៅតែម្នាក់ឯង អស់កាលនៃរដូវ។[21] ក្នុងទីនោះ ពួកមនុស្សបានប្រគេនចីវរទាំងឡាយ ដោយពាក្យថា យើងទាំងឡាយ ប្រគេនចីវរចំពោះសង្ឃ។ ភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ បានបញ្ញត្តថា ដែលហៅថាសង្ឃ បើយ៉ាងតិចបំផុត ត្រឹមភិក្ខុ៤រូប ក៏ឥឡូវ អាត្មាអញ តែម្នាក់ឯង ចំណែកខាងពួកមនុស្សនេះ បានប្រគេនចីវរទាំងឡាយ ដោយពាក្យថា យើងទាំងឡាយប្រគេនចីវរចំពោះសង្ឃ បើដូច្នោះ គួរអាត្មាអញ នាំយកចីវរ របស់សង្ឃទាំងនេះ ទៅកាន់ក្រុងសាវត្ថី។ ភិក្ខុនោះ ក៏នាំយកចីវរទាំងនោះ ទៅកាន់ក្រុងសាវត្ថី ហើយបានប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យសង្ឃ ដែលមានក្នុងទីចំពោះមុខ[22] ចែកគ្នាបាន។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅតែម្នាក់ឯង អស់កាលនៃរដូវ។ ក្នុងទីនោះ ពួកមនុស្សប្រគេនចីវរទាំងឡាយ ដោយពាក្យថា យើងទាំងឡាយ ប្រគេនចីវរ ចំពោះសង្ឃ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនោះ អធិដ្ឋានចីវរទាំងនោះ ដូច្នេះថា ចីវរទាំងនេះ ជារបស់អាត្មាអញ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះ មិនទាន់អធិដ្ឋានចីវរនោះទេ ទទួលមានភិក្ខុឯទៀតមកដល់ ត្រូវភិក្ខុនោះ ចែកចំណែកស្មើ (ដល់ភិក្ខុដែលទើបមកដល់នោះ) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ កំពុងចែកចីវរនោះ ហើយស្លាក មិនទាន់ធ្លាក់អស់ ទទួលមានភិក្ខុឯទៀតមកដល់ ត្រូវភិក្ខុនោះ ចែកចំណែកស្មើ (ដល់ភិក្ខុដែលទើបមកដល់នោះ) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុទាំងនោះ ចែកចីវរនោះ ស្លាកធ្លាក់អស់ទៅហើយ ទើបមានភិក្ខុឯទៀតមកដល់ មិនបាច់ចែកឲ្យទេ។ សម័យនោះឯង មានព្រះថេរៈពីររូប ជាបងប្អូននឹងគ្នា គឺព្រះថេរៈឈ្មោះឥសិទាសៈដ៏មានអាយុ១ ព្រះថេរៈឈ្មោះឥសិភត្តដ៏មានអាយុ១ នៅចាំវស្សាក្នុងក្រុងសាវត្ថី លុះចេញវស្សាហើយ ក៏នាំគ្នាទៅកាន់អាវាស ក្បែរស្រុកតូចមួយ។ ពួកមនុស្សនិយាយគ្នាថា ព្រះថេរៈទាំងឡាយបាត់យូរណាស់ហើយ ទើបឃើញនិមន្តមក ថាដូច្នោះហើយ ក៏នាំគ្នាប្រគេនចង្ហាន់ ព្រមទាំងចីវរ។ ពួកភិក្ខុ អ្នកនៅក្នុងអាវាស សួរព្រះថេរៈទាំងឡាយថា បពិត្រព្រះថេរៈដ៏ចំរើន ចីវររបស់សង្ឃទាំងនេះ កើតឡើង ក៏ព្រោះតែព្រះថេរៈទាំងឡាយ តើព្រះថេរៈទាំងឡាយ នឹងត្រេកអរនឹងចំណែកដែរឬទេ។ ព្រះថេរៈទាំងឡាយ ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ ធម៌[23] ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយយ៉ាងណា យើងទាំងឡាយ ក៏បានដឹងច្បាស់ហើយថា ចីវរទាំងនោះ ជាចីវររបស់លោកទាំងឡាយ កំណត់តែត្រឹមកឋិនដោះ។ សម័យនោះឯង ភិក្ខុ៣រូប នៅចាំវស្សា ក្នុងក្រុងរាជគ្រឹះ។ ពួកមនុស្ស ក្នុងទីនោះ ប្រគេនចីវរទាំងឡាយ ដោយពាក្យថា យើងទាំងឡាយ ប្រគេនចីវរចំពោះសង្ឃ។ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តថា ដែលហៅថា សង្ឃ បើយ៉ាងតិចបំផុត ត្រឹមភិក្ខុ៤រូប ឥឡូវ យើងទាំងឡាយ ជាជន៣រូប ក៏មនុស្សទាំងនេះ ប្រគេនចីវរទាំងឡាយ ដោយពាក្យថា យើងទាំងឡាយ ប្រគេនចីវរចំពោះសង្ឃ តើយើងទាំងឡាយ ត្រូវប្រតិបត្តិដូចម្តេច។ សម័យនោះឯង ព្រះថេរៈច្រើនអង្គ គឺព្រះថេរៈ ឈ្មោះនិលវាសីដ៏មានអាយុ១ ព្រះថេរៈ ឈ្មោះសាណវាសីដ៏មានអាយុ១ ព្រះថេរៈ ឈ្មោះគោបកៈដ៏មានអាយុ១ ព្រះថេរៈ ឈ្មោះភគុដ៏មានអាយុ១ ព្រះថេរៈ ឈ្មោះផលិកសន្ទានៈដ៏មានអាយុ១ នៅក្នុងកុក្កុដារាម ទៀបក្រុងបាតលិបុត្ត។ កាលនោះ ភិក្ខុទាំងនោះ នាំគ្នាទៅកាន់ក្រុងបាតលិបុត្ត ហើយសួរព្រះថេរៈទាំងឡាយ។ ព្រះថេរៈទាំងឡាយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយយ៉ាងណា យើងទាំងឡាយ ក៏បានដឹងច្បាស់ថា ចីវរទាំងឡាយនោះ ជាចីវររបស់អ្នកទាំងឡាយ កំណត់តែត្រឹមកឋិនដោះ។

## ២២៣. ឧបនន្ទសក្យបុត្តវត្ថុ

CS vin.mv.08.22 | ភាគ ទី៨

**(២២៣)**

[៧១] សម័យនោះឯង ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ នៅចាំវស្សាក្នុងក្រុងសាវត្ថី លុះចេញវស្សាហើយ ក៏បានទៅកាន់អាវាស ក្បែរស្រុកតូចមួយ។ ពួកភិក្ខុ មានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះ។ ភិក្ខុទាំងនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ។ ព្រះឧបនន្ទសក្យបុត្រឆ្លើយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ថាដូច្នោះហើយ ក៏ទទួលយកចំណែកចីវរ អំពីអាវាសនោះ ទៅកាន់អាវាសឯទៀត។ ឯពួកភិក្ខុ មានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះទៀត។ ភិក្ខុទាំងនោះ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ។ ព្រះឧបនន្ទសក្យបុត្រឆ្លើយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ថាដូច្នោះហើយ ក៏ទទួលយកចំណែកចីវរ អំពីអាវាសនោះ ទៅកាន់អាវាសឯទៀត។ ពួកភិក្ខុ មានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះទៀត។ ភិក្ខុទាំងនោះ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ។ ព្រះឧបនន្ទសក្យបុត្រឆ្លើយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ថាដូច្នោះហើយ ក៏ទទួលយកចំណែកចីវរ អំពីអាវាសនោះ ហើយក៏ស្ពាយសំពាយចីវរធំ រួចត្រឡប់មកកាន់ក្រុងសាវត្ថីវិញដដែល។ ពួកភិក្ខុ និយាយយ៉ាងនេះថា ម្នាលអាវុសោឧបនន្ទ លោកជាអ្នកមានបុណ្យធំ បានជាលោកបានចីវរច្រើន។ ព្រះឧបនន្ទសក្យបុត្តឆ្លើយថា ម្នាលអាវុសោ ខ្ញុំមានបុណ្យមកពីណា ដោយសារតែខ្ញុំនៅចាំវស្សា ក្នុងក្រុងសាវត្ថីនេះ លុះចេញវស្សាហើយ ខ្ញុំបានទៅកាន់អាវាសក្បែរស្រុកតូចមួយ ពួកភិក្ខុ មានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នាក្នុងអាវាសនោះ ភិក្ខុទាំងនោះ បាននិយាយយ៉ាងនេះនឹងខ្ញុំថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹង

ចំណែកដែរឬ ខ្ញុំឆ្លើយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ថាដូច្នោះហើយ ខ្ញុំក៏ទទួលយកចំណែកចីវរ អំពីអាវាសនោះ រួចបានទៅកាន់អាវាសឯទៀត ពួកភិក្ខុ មានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នា ក្នុងអាវាសនោះទៀត ភិក្ខុទាំងនោះ បាននិយាយយ៉ាងនេះនឹងខ្ញុំថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ ខ្ញុំបាននិយាយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ថាដូច្នោះហើយ ខ្ញុំក៏ទទួលយកចំណែកចីវរ អំពីអាវាសនោះ ទៅកាន់អាវាសឯទៀត ពួកភិក្ខុ មានសេចក្តីប្រាថ្នានឹងចែកចីវរ ក៏ប្រជុំគ្នា ក្នុងអាវាសនោះទៀត ភិក្ខុទាំងនោះ បាននិយាយយ៉ាងនេះនឹងខ្ញុំថា ម្នាលអាវុសោ ចីវររបស់សង្ឃទាំងនេះ យើងនឹងចែកគ្នា តើលោកត្រេកអរនឹងចំណែកដែរឬ ខ្ញុំនិយាយថា អើអាវុសោ ខ្ញុំត្រេកអរដែរ ថាដូច្នោះហើយ ខ្ញុំក៏ទទួលយកចំណែកចីវរ អំពីអាវាសនោះមក យ៉ាងនេះ បានជាខ្ញុំបានចីវរច្រើន។ ពួកភិក្ខុសួរថា ម្នាលអាវុសោឧបនន្ទ លោកនៅចាំវស្សាក្នុងអាវាសដទៃ ហើយលោកត្រេកអរនឹងចំណែកចីវរ ក្នុងអាវាសដទៃ មែនឬ។ ព្រះឧបនន្ទសក្យបុត្តឆ្លើយថា ម្នាលអាវុសោ មែនហើយ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ មិនគួរបើនឹងនៅចាំវស្សា ក្នុងអាវាសដទៃ ហើយត្រេកអរនឹងចំណែកចីវរ ក្នុងអាវាសដទៃសោះ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបនន្ទ ឮថា អ្នកឯង នៅចាំវស្សា ក្នុងអាវាសដទៃ ហើយត្រេកអរ នឹងចំណែកចីវរ ក្នុងអាវាសដទៃ ពិតមែនឬ។ ព្រះឧបនន្ទសក្យបុត្តឆ្លើយថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯង មិនគួរបើនឹងនៅចាំវស្សា ក្នុងអាវាសដទៃ ហើយត្រេកអរនឹងចំណែកចីវរ ក្នុងអាវាសដទៃសោះ នែមោឃបុរស អំពើនេះ មិនមែននាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនៅចាំវស្សា ក្នុងអាវាសឯទៀត មិនត្រូវត្រេកអរនឹងចំណែកចីវរ ក្នុងអាវាសឯទៀតទេ ភិក្ខុណាត្រេកអរ ត្រូវអាបត្តិទុក្កដ។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ នៅចាំវស្សាក្នុងអាវាសពីរតែម្នាក់ឯង ដោយគិតថា ចីវរមុខជានឹងកើតឡើងដល់អញជាច្រើនដូច្នេះ។ ក្នុងពេលនោះ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយ ត្រូវឲ្យចំណែកចីវរ ដល់ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុដែរឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរឲ្យចីវរតែមួយចំណែក ដល់មោឃបុរសចុះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុក្នុងសាសនានេះ នៅចាំវស្សា ក្នុងអាវាសពីរតែម្នាក់ឯង ដោយគិតថា ចីវរមុខជានឹងកើតឡើងដល់អញ ជាច្រើនដូច្នេះ។ បើភិក្ខុនោះ នៅចាំវស្សា ក្នុងអាវាសឯណោះ បានពាក់កណ្តាល ចាំវស្សា ក្នុងអាវាសឯណោះ បានពាក់កណ្តាល ភិក្ខុទាំងឡាយ ត្រូវឲ្យចំណែកចីវរ ក្នុងអាវាសឯណោះ ពាក់កណ្តាល ក្នុងអាវាសឯណោះ ពាក់កណ្តាល ទៅភិក្ខុនោះចុះ ប្រសិនបើ ភិក្ខុនៅចាំវស្សា ក្នុងអាវាសណាច្រើនជាង ភិក្ខុទាំងឡាយ ត្រូវឲ្យចំណែកចីវរទៅភិក្ខុនោះ តាមកំណត់ថ្ងៃដែលច្រើននោះចុះ។

## ២២៤. គិលានវត្ថុកថា

CS vin.mv.08.23 | ភាគ ទី៨

**(២២៤)**

[៧២] សម័យនោះឯង ភិក្ខុ១រូបមានរោគឈឺពោះ។ ភិក្ខុនោះដេកត្រាំនៅលើមូត្រ និងករីសរបស់ខ្លួន។ គ្រានោះ ព្រះដ៏មានព្រះភាគ មានព្រះអានន្ទដ៏មានអាយុ ជាបច្ឆាសមណៈ ទ្រង់ពុទ្ធដំណើរ ទៅកាន់សេនាសនចារិក ហើយចូលទៅកាន់លំនៅ នៃភិក្ខុនោះ។ ព្រះដ៏មានព្រះភាគ បានទតឃើញភិក្ខុនោះ ដេកត្រាំនៅលើមូត្រ និងករីសរបស់ខ្លួន លុះទតច្បាស់ហើយ ក៏ទ្រង់ចូលទៅកាន់សំណាក់ភិក្ខុនោះ លុះចូលទៅដល់ហើយ ទ្រង់មានព្រះតម្រាស់យ៉ាងនេះ នឹងភិក្ខុនោះថា ម្នាលភិក្ខុ អ្នកមានរោគអ្វី។ ភិក្ខុនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គឈឺពោះ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯង មានភិក្ខុជាអ្នកបម្រើដែរឬទេ។ ភិក្ខុនោះ ក្រាបបង្គំទូលថា សូមទ្រង់មេត្តាប្រោស គ្មានទេ។ ព្រះអង្គទ្រង់ត្រាស់ថា ចុះពួកភិក្ខុ ហេតុអ្វីក៏មិនបម្រើអ្នក។ ភិក្ខុនោះ ក្រាបបង្គំទូលថា សូមទ្រង់មេត្តាប្រោស (ដ្បិត) ខ្ញុំព្រះអង្គ មិនដែលធ្វើ (ឧបការៈ) ដល់ពួកភិក្ខុសោះ ព្រោះហេតុនោះ បានជាពួកភិក្ខុ មិនបម្រើខ្ញុំព្រះអង្គ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅនាំយកទឹកមក យើងនឹងឲ្យភិក្ខុនេះងូត។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏នាំយកទឹកមក។ ព្រះដ៏មានព្រះភាគ ទ្រង់ស្រោចទឹក ព្រះអានន្ទដ៏មានអាយុដុសលាង ព្រះដ៏មានព្រះភាគ ចាប់ខាងក្បាល ព្រះអានន្ទដ៏មានអាយុ ចាប់ខាងជើង សែងឡើង យកទៅដាក់ឲ្យដេកលើគ្រែតូច។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ភិក្ខុទាំងឡាយ ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ក្នុងវិហារឯណោះ មានភិក្ខុឈឺដែរឬ។ ពួកភិក្ខុ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស មាន។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មានរោគអ្វី។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស លោកដ៏មានអាយុនោះ មានរោគពោះ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកបម្រើភិក្ខុនោះ មានដែរឬ។ ពួកភិក្ខុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស គ្មានទេ។ ព្រះអង្គទ្រង់ត្រាស់ថា ចុះហេតុអ្វី បានជាពួកភិក្ខុមិនបម្រើភិក្ខុនោះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ដ្បិតភិក្ខុនោះ មិនដែលធ្វើ (ឧបការៈ) ដល់ភិក្ខុទាំងឡាយ ព្រោះហេតុនោះ បានជាភិក្ខុទាំងឡាយ មិនបម្រើភិក្ខុនោះ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គ្មានមាតាបិតាទេ បានអ្នកណាបម្រើអ្នករាល់គ្នា ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនបម្រើគ្នានឹងគ្នាហើយ តើបានអ្នកណា នឹងបម្រើវិញ ម្នាលភិក្ខុទាំងឡាយ អ្នកណាបម្រើតថាគត អ្នកនោះ ឈ្មោះថាបម្រើភិក្ខុឈឺ។ បើមានឧបជ្ឈាយ៍ ឧបជ្ឈាយ៍ត្រូវបម្រើភិក្ខុនោះអស់១ជីវិត ឧបជ្ឈាយ៍ត្រូវរង់ចាំ ទំរាំភិក្ខុនោះសះជា។ បើមានអាចារ្យ អាចារ្យត្រូវបម្រើភិក្ខុនោះ អស់១ជីវិត អាចារ្យ ត្រូវរង់ចាំ ទំរាំភិក្ខុនោះសះជា។ បើមានសទ្ធិវិហារិក សទ្ធិវិហារិក ត្រូវបម្រើភិក្ខុនោះ អស់១ជីវិត សទ្ធិវិហារិក ត្រូវរង់ចាំ ទំរាំភិក្ខុនោះសះជា។ បើមានអន្តេវាសិក (កូនសិស្ស) អន្តេវាសិក ត្រូវបម្រើភិក្ខុនោះ អស់១ជីវិត អន្តេវាសិក ត្រូវរង់ចាំ ទំរាំភិក្ខុនោះសះជា។ បើមានភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នា ត្រូវភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នាបម្រើភិក្ខុនោះ អស់១ជីវិត ភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នា ត្រូវរង់ចាំ ទំរាំភិក្ខុនោះសះជា។ បើមានភិក្ខុមានអាចារ្យស្មើគ្នា ភិក្ខុមានអាចារ្យស្មើគ្នា ត្រូវបម្រើភិក្ខុនោះអស់១ជីវិត ភិក្ខុមានអាចារ្យស្មើគ្នា ត្រូវរង់ចាំ ទំរាំភិក្ខុនោះសះជា។ បើឧបជ្ឈាយ៍ក្តី អាចារ្យក្តី សទ្ធិវិហារិកក្តី អន្តេវាសិកក្តី ភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នាក្តី ភិក្ខុមានអាចារ្យស្មើគ្នាក្តី មិនមានទេ សង្ឃត្រូវបម្រើភិក្ខុមានជម្ងឺនោះ។ បើសង្ឃមិនបម្រើទេ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានជម្ងឺ ប្រកបដោយអង្គ៥ ជាបុគ្គលលំបាកគេបម្រើ គឺបុគ្គលមិនចេះធ្វើខ្លួនឲ្យសប្បាយ១ មិនដឹងប្រមាណ ក្នុងការសប្បាយ៍១ មិនខ្ជាស់ខ្នែងប្រើថ្នាំ១ មិនប្រាប់អាពាធ ដែលចំរើន ថាចំរើនក្តី មិនប្រាប់អាពាធ ដែលធូរថយ ថាធូរថយក្តី មិនប្រាប់អាពាធ ដែលនៅនឹងដដែល ថានៅនឹងដដែលក្តី ឲ្យច្បាស់តាមពិត ដល់បុគ្គលអ្នកបម្រើជម្ងឺ ដែលជាអ្នកចង់ឲ្យសះជា១ មិនអត់សង្កត់ នូវទុក្ខវេទនា ដ៏រឹងក្លាផ្សាក្តៅ ដែលកើតឡើងក្នុងប្រជុំ នៃសរីរៈ មិនឆ្ងាញ់ពីសា មិនគាប់ចិត្ត ជាទីនាំ

ឲ្យខូចជីវិត១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានជម្ងឺ ប្រកបដោយអង្គ ទាំង៥នេះឯង តែងលំបាកគេបម្រើ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានជម្ងឺ ប្រកបដោយ អង្គ៥ ងាយគេបម្រើ គឺបុគ្គលចេះធ្វើខ្លួនឲ្យសប្បាយ១ ដឹងប្រមាណ ក្នុងការសប្បាយ១ ខ្វាស់ខ្វែងប្រើថ្នាំ១ ប្រាប់អាពាធ ដែលចំរើនឡើង ថាចំរើនឡើងក្តី ប្រាប់អាពាធ ដែលធូរថយ ថាធូរថយក្តី ប្រាប់អាពាធ ដែលនៅនឹងដដែល ថានៅនឹងដដែល ឲ្យច្បាស់តាមពិត ដល់បុគ្គលអ្នកបម្រើជម្ងឺ ដែលជាអ្នកចង់ឲ្យសះជា១ ជាអ្នកអត់សង្កត់ នូវទុក្ខវេទនា ដ៏រឹងក្លាផ្សាក្តៅ ដែលកើតឡើង ក្នុងប្រជុំ នៃសរីរៈ មិនឆ្ងាញ់ពីសា មិនគាប់ចិត្ត ជាទីនាំឲ្យខូចជីវិត១ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានជម្ងឺ ប្រកបដោយ អង្គទាំង៥ នេះឯង តែងងាយគេបម្រើ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជម្ងឺ ប្រកបដោយអង្គ៥ មិនគួរនឹងបម្រើជម្ងឺទេ គឺបុគ្គលមិនប្រសប់ចាត់ចែងថ្នាំ១ មិនស្គាល់ហេតុសប្បាយ និងមិនសប្បាយ១ នាំរបស់ដែលមិនសប្បាយចូលទៅ នាំរបស់ដែលសប្បាយចេញមក១ បម្រើអ្នកជម្ងឺ ចង់បានតែអាមិសៈ ឥតមានចិត្តមេត្តា មានតែខ្ពើមរអើមនឹងការនាំចេញនូវឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី កំអួតក្តី១ មិនអាចនឹងពន្យល់អ្នកមានជម្ងឺ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា សព្វៗកាល១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជម្ងឺ ប្រកបដោយ អង្គ៥នេះឯង មិនគួរបម្រើជម្ងឺទេ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជម្ងឺ បើប្រកបដោយ អង្គ៥ ទើបគួរបម្រើជម្ងឺបាន គឺបុគ្គលប្រសប់ចាត់ចែងថ្នាំ១ ស្គាល់ហេតុសប្បាយ និងមិនសប្បាយ១ នាំរបស់ដែលមិនសប្បាយចេញទៅ នាំរបស់ដែលសប្បាយចូលមក១ មានចិត្តមេត្តា មិនប្រាថ្នាអាមិសៈ ហើយបម្រើជម្ងឺ មិនខ្ពើមរអើម ក្នុងការនាំចេញនូវឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី កំអួតក្តី១ អាចនឹងពន្យល់អ្នកមានជម្ងឺ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា សព្វៗកាល១ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបម្រើជម្ងឺ លុះតែប្រកបព្រមដោយអង្គ ទាំង៥នេះឯង ទើបគួរបម្រើជម្ងឺបាន។

## ២២៥. មតសន្តកកថា

CS vin.mv.08.24 | ភាគ ទី៨

**(២២៥)**

[៧៣] សម័យនោះឯង មានភិក្ខុពីររូបដើរទៅតាមផ្លូវឆ្ងាយ ក្នុងកោសលជនបទ។ ភិក្ខុទាំងពីររូបនោះ ចូលទៅកាន់អាវាស១។ ក្នុងអាវាសនោះ មានភិក្ខុមួយរូបឈឺ។ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគ ទ្រង់សរសើរការបម្រើជម្ងឺពេកណាស់ អាវុសោ បើដូច្នោះ មានតែយើងទាំងឡាយ នឹងបម្រើភិក្ខុនេះ។ ភិក្ខុទាំងនោះ ក៏នាំគ្នាបម្រើភិក្ខុឈឺនោះ។ កាលដែលភិក្ខុទាំងនោះ កំពុងបម្រើភិក្ខុឈឺ ក៏ធ្វើមរណកាលទៅ។ គ្រានោះ ភិក្ខុទាំងនោះ ក៏នាំយកបាត្រ និងចីវររបស់ភិក្ខុឈឺនោះ ទៅឯក្រុងសាវត្ថី ហើយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុ(ណាមួយ) ធ្វើមរណភាពទៅហើយ ត្រូវសង្ឃជាម្ចាស់លើបាត្រ និងចីវរ (របស់ភិក្ខុនោះ) តែថា ពួកភិក្ខុអ្នកបម្រើជម្ងឺ មានឧបការៈច្រើនជាងគេ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសង្ឃ ឲ្យត្រៃចីវរ និងបាត្រ ដល់ភិក្ខុអ្នកបម្រើជម្ងឺចុះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ភិក្ខុអ្នកបម្រើជម្ងឺនោះ ត្រូវចូលទៅរកសង្ឃ ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ភិក្ខុឈ្មោះនេះ ធ្វើមរណភាពទៅហើយ ត្រៃចីវរ និងបាត្រនេះ ជារបស់ភិក្ខុនោះ។ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុឈ្មោះនេះ ធ្វើមរណភាពទៅហើយ ត្រៃចីវរ និងបាត្រនេះ ជារបស់ភិក្ខុនោះ។ បើការឲ្យត្រៃចីវរ និងបាត្រ មានកាលសមគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យត្រៃចីវរ និងបាត្រនេះ ដល់ពួកភិក្ខុអ្នកបម្រើជម្ងឺចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុឈ្មោះនេះ ធ្វើមរណភាពទៅហើយ ត្រៃចីវរនេះ និងបាត្រនេះ ជារបស់ភិក្ខុនោះ។ ឥឡូវ សង្ឃបានឲ្យត្រៃចីវរ និងបាត្រនេះ ដល់ពួកភិក្ខុអ្នកបម្រើជម្ងឺហើយ។ ការឲ្យត្រៃចីវរ និងបាត្រដល់ពួកភិក្ខុអ្នកបម្រើជម្ងឺនេះ (បើ) គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម (បើ) មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ ត្រូវលោកដ៏មានអាយុអង្គនោះ និយាយឡើង។ សង្ឃបានឲ្យត្រៃចីវរ និងបាត្រនេះ ដល់ពួកភិក្ខុ អ្នកបម្រើជម្ងឺហើយ។ ការឲ្យត្រៃចីវរ និងបាត្រ ដល់ពួកភិក្ខុអ្នកបម្រើជម្ងឺ ប្រហែលជាគាប់ចិត្ត ដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ សម័យនោះឯង មានសាមណេរមួយរូប ធ្វើមរណភាព។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើសាមណេរ (ណាមួយ) ធ្វើមរណភាពទៅហើយ ត្រូវសង្ឃជាម្ចាស់លើបាត្រ និងចីវរ (របស់សាមណេរនោះ) តែថា ភិក្ខុអ្នកបម្រើជម្ងឺ មានឧបការៈច្រើនជាង។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃ ឲ្យចីវរ និងបាត្រដល់ពួកភិក្ខុអ្នកបម្រើជម្ងឺ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ភិក្ខុអ្នកបម្រើជម្ងឺនោះ ត្រូវចូលទៅរកសង្ឃ ហើយនិយាយយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សាមណេរឈ្មោះនេះ ធ្វើមរណភាពទៅហើយ ចីវរ និងបាត្រនេះ ជារបស់សាមណេរនោះ។ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសាមណេរឈ្មោះនេះ ធ្វើមរណភាពទៅហើយ ចីវរ និងបាត្រនេះ ជារបស់សាមណេរនោះ។ បើការឲ្យចីវរ និងបាត្រ មានកាលសមគួរដល់សង្ឃហើយ សង្ឃត្រូវឲ្យចីវរ និងបាត្រនេះ ដល់ពួកភិក្ខុអ្នកបម្រើជម្ងឺចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសាមណេរឈ្មោះនេះ ធ្វើមរណភាពទៅហើយ ចីវរ និងបាត្រនេះ ជារបស់សាមណេរនោះ។ ឥឡូវ សង្ឃឲ្យចីវរ និងបាត្រនេះ ដល់ពួកភិក្ខុអ្នកបម្រើជម្ងឺហើយ។ ការឲ្យចីវរ និងបាត្រដល់ពួកភិក្ខុអ្នកបម្រើជម្ងឺនេះ (បើ) គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម (បើ) មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ ត្រូវលោកដ៏មានអាយុអង្គនោះ និយាយឡើង។ ចីវរ និងបាត្រនេះ សង្ឃបានឲ្យ ដល់ពួកភិក្ខុអ្នកបម្រើជម្ងឺហើយ។ ការឲ្យចីវរ និងបាត្រ ដល់ពួកភិក្ខុអ្នកបម្រើជម្ងឺ ប្រហែលជាគាប់ចិត្ត ដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុករឿងនេះ ដោយអាការស្ងៀមនៅ យ៉ាងនេះ។ សម័យនោះឯង មានភិក្ខុមួយរូប និងសាមណេរមួយរូប បម្រើភិក្ខុឈឺ។ កាលបើភិក្ខុ និងសាមណេរទាំងនោះ កំពុងបម្រើ ភិក្ខុឈឺនោះ ក៏ធ្វើមរណភាពទៅ។ ឯភិក្ខុអ្នកបម្រើជម្ងឺនោះ ក៏មានសេចក្តីត្រិះរិះថា អាត្មាអញ ត្រូវឲ្យចំណែកចីវរទៅសាមណេរ ដែលជាអ្នកបម្រើជម្ងឺដែរឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ឲ្យចំណែកស្មើគ្នា ទៅសាមណេរ ដែលជាអ្នកបម្រើជម្ងឺចុះ។ សម័យនោះឯង មានភិក្ខុ១រូប មានទ្រព្យច្រើន មានបរិក្ខារច្រើន ធ្វើមរណភាពទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុ (ណាមួយ) ធ្វើមរណភាពទៅហើយ ត្រូវសង្ឃជាម្ចាស់លើបាត្រ និងចីវរ (របស់ភិក្ខុនោះ) តែថា ពួកភិក្ខុអ្នកបម្រើជម្ងឺ មានឧបការៈច្រើនជាងគេ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃ ឲ្យត្រៃចីវរ និងបាត្រ ដល់ពួកភិក្ខុអ្នកបម្រើជម្ងឺចុះ បើមានវត្ថុណាមួយ ជាគ្រឿងលហុភណ្ឌ[24] ឬជាគ្រឿងលហុបរិក្ខារ[25] នៅក្នុងទីនោះ តថាគតអនុញ្ញាតឲ្យសង្ឃ ដែលមាន

ក្នុងទីចំពោះមុខ (ព្រមព្រៀងគ្នា) ចែកគ្រឿងលហុភណ្ឌ និងគ្រឿងលហុបរិក្ខារនោះបាន បើមានគ្រឿងគរុភណ្ឌ ឬគ្រឿងគរុបរិក្ខារណា នៅក្នុងទីនោះ គ្រឿងគរុភណ្ឌ និងគ្រឿងគរុបរិក្ខារនោះ ត្រូវទុកសម្រាប់សង្ឃដែលមក ឬមិនទាន់បានមកពីទិសទាំង៤ ភិក្ខុមិនត្រូវលះ មិនត្រូវចែកគ្នាទេ។

## ២២៦. នគ្គិយបដិក្ខេបកថា

CS vin.mv.08.25 | ភាគ ទី៨

**(២២៦)**

[៧៤] សម័យនោះឯង មានភិក្ខុ១រូបមានកាយអាក្រាត ហើយចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គតែងទ្រង់សរសើរគុណរបស់បុគ្គលអ្នកប្រាថ្នាតិច មានចិត្តសន្តោស មានចិត្តផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្ត ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន ការអាក្រាតនេះ នាំឲ្យមានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស សេចក្តីផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្ត និងនាំឲ្យមានសេចក្តីប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់អនុញ្ញាតការអាក្រាត ដល់ពួកភិក្ខុ ជាការស្រួលពេកណាស់។ ព្រះពុទ្ធមានព្រះភាគ បន្ទោសថា នែមោឃបុរស អំពើនេះមិនទំនងទេ។បេ។ ម្នាលមោឃបុរស អ្នកមិនសមបើ នឹងសមាទាននូវការអាក្រាត ជាតិត្ថិយសមាទាន[26] (ដូច្នេះ) សោះ ម្នាលមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ការអាក្រាត ជាតិត្ថិយសមាទាន ភិក្ខុមិនត្រូវសមាទានទេ ភិក្ខុណាសមាទាន ត្រូវអាបត្តិថុល្លច្ច័យ។

## ២២៧. កុសចីរាទិបដិក្ខេបកថា

CS vin.mv.08.26 | ភាគ ទី៨

**(២២៧)**

សម័យនោះឯង មានភិក្ខុ១រូប ស្លៀកសំពត់ដែលគេធ្វើពីស្បូវភ្លាំង។បេ។ ស្លៀកសំពត់ដែលគេធ្វើពីសម្បកឈើ។បេ។ ស្លៀកសំពត់ដែលគេធ្វើពីផែនក្តារ។បេ។ ស្លៀកសំពត់កម្ពល ដែលគេធ្វើពីសក់។បេ។ ស្លៀកសំពត់កម្ពលដែលគេធ្វើពីរោមកន្ទុយសត្វ។បេ។ ស្លៀកសំពត់ដែលគេធ្វើពីស្លាបមៀម។បេ។ ស្លៀកសំពត់ដែលគេធ្វើពីស្បែកខ្លា ហើយចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គ តែងទ្រង់សរសើរគុណ របស់បុគ្គលអ្នកប្រាថ្នាតិច មានចិត្តសន្តោស មានចិត្តផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្ត ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន ស្បែកខ្លានេះ នាំឲ្យមានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស សេចក្តីផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្តៈ និងនាំឲ្យមានសេចក្តីប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ទ្រង់អនុញ្ញាតឲ្យពួកភិក្ខុស្លៀកដណ្តប់សំពត់ស្បែកខ្លា ជាការស្រួលពេកណាស់។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អំពើនេះមិនទំនងទេ។បេ។ នែមោឃបុរស អ្នកមិនសមបើនឹងទ្រទ្រង់សំពត់ស្បែកខ្លា ជាទង់ជ័យ នៃតិរ្ថិយសោះ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ ទ្រង់បន្ទោសរួច ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់ស្បែកខ្លា ជាទង់ជ័យរបស់តិរ្ថិយទេ ភិក្ខុណាទ្រទ្រង់ ត្រូវអាបត្តិថុល្លច្ច័យ។ សម័យនោះឯង មានភិក្ខុ១រូប ស្លៀកសំពត់ដែលគេធ្វើពីដើមរាក់។បេ។ ស្លៀកសំពត់ដែលគេធ្វើពីសម្បកក្រចៅ ហើយចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គ តែងទ្រង់សរសើរគុណ របស់បុគ្គលអ្នកប្រាថ្នាតិច មានចិត្តសន្តោស មានចិត្តផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្តៈ ប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សំពត់សម្បកក្រចៅនេះ នាំឲ្យមានសេចក្តីប្រាថ្នាតិច សេចក្តីសន្តោស សេចក្តីផូរផង់ កំចាត់បង់កិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំកិលេសវដ្តៈ និងនាំឲ្យមានសេចក្តីប្រារព្ធព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ទ្រង់អនុញ្ញាតឲ្យពួកភិក្ខុ (ទ្រទ្រង់) សំពត់សម្បកក្រចៅ ជាការស្រួលពេកណាស់។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អំពើនេះមិនទំនងទេ។បេ។ ម្នាលមោឃបុរស អ្នកមិនសមបើ នឹងស្លៀកសំពត់សម្បកក្រចៅសោះ ម្នាលមោឃបុរស អំពើនេះ មិនមែននាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ។បេ។ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្លៀកសំពត់សម្បកក្រចៅទេ ភិក្ខុណាស្លៀក ត្រូវអាបត្តិទុក្កដ។

## ២២៨. សព្វនីលកាទិបដិក្ខេបកថា

CS vin.mv.08.27 | ភាគ ទី៨

**(២២៨)**

[៧៥] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទ្រទ្រង់[27] ចីវរខៀវសុទ្ធ ទ្រទ្រង់ចីវរលឿងសុទ្ធ ទ្រទ្រង់ចីវរក្រហមសុទ្ធ ទ្រទ្រង់ចីវរពណ៌ហង្សបាទសុទ្ធ ទ្រទ្រង់ចីវរខ្មៅសុទ្ធ ទ្រទ្រង់ចីវរក្រហមក្រម៉ៅសុទ្ធ (ពណ៌ខ្ចងក្អែប) ទ្រទ្រង់ចីវរលឿងទុំសុទ្ធ (ពណ៌ដូចផ្កាឈូក) ទ្រទ្រង់ចីវរមានជាយមិនបានកាត់ចេញ ទ្រទ្រង់ចីវរមានជាយវែង ទ្រទ្រង់ចីវរមានជាយជាផ្កាឈើ ទ្រទ្រង់ចីវរមានជាយជាផ្លែឈើ ទ្រទ្រង់អាវ ទ្រទ្រង់មួក ទ្រទ្រង់សំពត់ឈ្នួត។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ដូចជាពួកគ្រហស្ថ អ្នកបរិភោគកាម។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់ចីវរខៀវសុទ្ធ មិនត្រូវទ្រទ្រង់ចីវរលឿងសុទ្ធ មិនត្រូវទ្រទ្រង់ចីវរ

ក្រហមសុទ្ធ មិនត្រូវទ្រទ្រង់ចីវរពណ៌ហង្សបាទសុទ្ធ មិនត្រូវទ្រទ្រង់ចីវរខ្មៅសុទ្ធ មិនត្រូវទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ មិនត្រូវទ្រទ្រង់ចីវរលឿងទុំសុទ្ធ មិនត្រូវទ្រទ្រង់ចីវរ មានជាយ មិនបានកាត់ចេញ មិនត្រូវទ្រទ្រង់ចីវរមានជាយវែង មិនត្រូវទ្រទ្រង់ចីវរមានជាយជាផ្កាឈើ មិនត្រូវទ្រទ្រង់ចីវរមានជាយជាផ្លែឈើ មិនត្រូវទ្រទ្រង់អាវ មិនត្រូវទ្រទ្រង់មួក មិនត្រូវទ្រទ្រង់សំពត់ឈ្នួត ភិក្ខុណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ។

## ២២៩. វស្សំវុដ្ឋានំ អនុប្បន្នចីវរកថា

CS vin.mv.08.28 | ភាគ ទី៨

**(២២៩)**

[៧៦] សម័យនោះឯង ភិក្ខុទាំងឡាយនៅចាំវស្សារួចហើយ តែចីវរមិនទាន់កើតឡើង[28] ក៏នាំគ្នាចៀសចេញទៅខ្លះ សឹកចេញទៅខ្លះ ស្លាប់ទៅខ្លះ ប្ដេជ្ញាខ្លួនជាសាមណេរខ្លះ ប្ដេជ្ញាខ្លួនជាបុគ្គលពោលលាសិក្ខាខ្លះ ប្ដេជ្ញាខ្លួនជាបុគ្គលត្រូវអន្តិមវត្ថុខ្លះ ប្ដេជ្ញាខ្លួនជាបុគ្គលឆ្កួតខ្លះ ប្ដេជ្ញាខ្លួនជាបុគ្គលមានចិត្តអណ្ដែតអណ្ដូងខ្លះ ប្ដេជ្ញាខ្លួនជាបុគ្គល គឺវេទនាគ្របសង្កត់ខ្លះ ប្ដេជ្ញាខ្លួនជាបុគ្គល គឺសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិខ្លះ ប្ដេជ្ញាខ្លួនជាបុគ្គល គឺសង្ឃលើកវត្ត ព្រោះមិនបានសំដែងអាបត្តិខ្លះ ប្ដេជ្ញាខ្លួនជាបុគ្គល គឺសង្ឃលើកវត្ត ព្រោះមិនបានលះបង់ទិដ្ឋិអាក្រក់ខ្លះ ប្ដេជ្ញាខ្លួនជាខ្ទើយខ្លះ ប្ដេជ្ញាខ្លួនជាអ្នកលួចសំវាសខ្លះ ប្ដេជ្ញាខ្លួនជាអ្នកចូលពួកតិរ្ថិយខ្លះ ប្ដេជ្ញាខ្លួនជាសត្វតិរច្ឆានខ្លះ ប្ដេជ្ញាខ្លួនជាអ្នកសម្លាប់មាតាខ្លះ ប្ដេជ្ញាខ្លួនជាអ្នកសម្លាប់បិតាខ្លះ ប្ដេជ្ញាខ្លួនជាអ្នកសម្លាប់ព្រះអរហន្តខ្លះ ប្ដេជ្ញាខ្លួនជាអ្នកទ្រុស្តភិក្ខុនីខ្លះ ប្ដេជ្ញាខ្លួនជាអ្នកបំបែកសង្ឃខ្លះ ប្ដេជ្ញាខ្លួនជាអ្នកធ្វើលោហិត (ព្រះបរមគ្រូ) ឲ្យពុរពង់ឡើងខ្លះ ប្ដេជ្ញាខ្លួនជាឧភតោព្យញ្ជនក (មនុស្សមានភេទពីរ)ខ្លះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរ មិនទាន់កើតឡើង ក៏ចៀសចេញទៅ។ កាលបើមានភិក្ខុអ្នកទទួលយកចីវរដ៏សមគួរ សង្ឃត្រូវឲ្យចីវរ (នោះទៅ)ចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង ក៏សឹកទៅក្ដី ស្លាប់ទៅក្ដី ប្ដេជ្ញាខ្លួនជាសាមណេរក្ដី ប្ដេជ្ញាខ្លួនជាអ្នកពោលលាសិក្ខាក្ដី ប្ដេជ្ញាខ្លួនជាអ្នកត្រូវអន្តិមវត្ថុក្ដី។ សង្ឃត្រូវជាម្ចាស់ (ចីវរនោះឯង)។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរ មិនទាន់កើតឡើង ក៏ប្ដេជ្ញាខ្លួនជាមនុស្សឆ្កួតក្ដី ប្ដេជ្ញាខ្លួនជាមនុស្សមានចិត្តអណ្ដែតអណ្ដូងក្ដី ប្ដេជ្ញាខ្លួនជាមនុស្សមានវេទនាគ្របសង្កត់ក្ដី ប្ដេជ្ញាខ្លួនជាភិក្ខុ គឺសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្ដី ប្ដេជ្ញាខ្លួនជាភិក្ខុ គឺសង្ឃលើកវត្ត ព្រោះមិនបានសំដែងអាបត្តិក្ដី ប្ដេជ្ញាខ្លួនជាភិក្ខុ គឺសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្ដី។ កាលបើមានភិក្ខុជាអ្នកទទួលយកចីវរដ៏សមគួរ ត្រូវសង្ឃឲ្យចីវរ (នោះទៅ)ចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុ នៅចាំវស្សារួចហើយ កាលបើចីវរ មិនទាន់កើតឡើង ក៏ប្ដេជ្ញាខ្លួនជាមនុស្សខ្ទើយក្ដី។បេ។ ប្ដេជ្ញាខ្លួនជាឧភតោព្យញ្ជនកក្ដី។ សង្ឃត្រូវជាម្ចាស់ (ចីវរនោះឯង)។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុ នៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឃមិនទាន់បានចែក ខ្លួនក៏ចៀសចេញទៅ។ កាលបើមានភិក្ខុ ជាអ្នកទទួលចីវរដ៏សមគួរ ត្រូវសង្ឃឲ្យចីវរ (នោះទៅ)ចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឃមិនទាន់បានចែក ខ្លួនក៏សឹកទៅក្ដី ស្លាប់ទៅក្ដី ប្ដេជ្ញាខ្លួនជាសាមណេរក្ដី ប្ដេជ្ញាខ្លួនជាអ្នកពោលលាសិក្ខាក្ដី ប្ដេជ្ញាខ្លួនជាបុគ្គលត្រូវអន្តិមវត្ថុក្ដី។ សង្ឃត្រូវជាម្ចាស់(ចីវរនោះ)។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើង តែសង្ឃមិនទាន់បានចែក ក៏ប្ដេជ្ញាខ្លួនជាមនុស្សឆ្កួតក្ដី ប្ដេជ្ញាខ្លួនជាបុគ្គលមានចិត្តអណ្ដែតអណ្ដូងក្ដី ប្ដេជ្ញាខ្លួនជាបុគ្គលមានវេទនាគ្របសង្កត់ក្ដី ប្ដេជ្ញាខ្លួនជាភិក្ខុ គឺសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្ដី ប្ដេជ្ញាខ្លួនជាភិក្ខុ គឺសង្ឃលើកវត្ត ព្រោះមិនបានសំដែងអាបត្តិក្ដី ប្ដេជ្ញាខ្លួនជាភិក្ខុ គឺសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្ដី។ កាលបើមានភិក្ខុជាអ្នកទទួលចីវរដ៏សមគួរ ត្រូវសង្ឃឲ្យចីវរ (នោះទៅ)ចុះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឃមិនទាន់បានចែក ក៏ប្ដេជ្ញាខ្លួនជាមនុស្សខ្ទើយក្ដី។បេ។ ប្ដេជ្ញាខ្លួនជាឧភតោព្យញ្ជនកក្ដី។ សង្ឃត្រូវជាម្ចាស់ (ចីវរនោះឯង)។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឃក៏បែកគ្នាទៅ[29] មនុស្សទាំងឡាយក្នុងទីនោះ ក៏នាំគ្នាប្រគេនទឹក ចំពោះភិក្ខុមួយពួក ប្រគេនចីវរចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយប្រគេនចំពោះសង្ឃ។ ទឹកនិងចីវរនេះ ក៏នៅជារបស់សង្ឃដដែល។

## ២៣០. សង្ឃេ ភិន្នេ ចីវរុប្បាទកថា

CS vin.mv.08.29 | ភាគ ទី៨

**(២៣០)**

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឃក៏បែកគ្នាទៅ។ មនុស្សទាំងឡាយក្នុងទីនោះ ក៏នាំគ្នាប្រគេនទឹក ចំពោះភិក្ខុមួយពួក ប្រគេនចីវរ ចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយ ប្រគេនចំពោះសង្ឃ។ ទឹកនិងចីវរនេះ ក៏នៅជារបស់សង្ឃដដែល។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឃក៏បែកគ្នាទៅ។ មនុស្សទាំងឡាយក្នុងទីនោះ ក៏នាំគ្នាប្រគេនទឹក ចំពោះភិក្ខុមួយពួក ប្រគេនចីវរ ចំពោះភិក្ខុមួយពួក ដោយពាក្យថា យើងទាំងឡាយ ប្រគេនចំពោះពួក។ ទឹកនិងចីវរនេះ ក៏នៅជារបស់ពួកដដែល។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរមិនទាន់កើតឡើង សង្ឃក៏បែកគ្នាទៅ។ មនុស្សទាំងឡាយក្នុងទីនោះ ក៏នាំគ្នាប្រគេនទឹក ចំពោះភិក្ខុមួយពួក ប្រគេនចីវរ ចំពោះភិក្ខុមួយពួកនោះឯង ដោយពាក្យថា យើងទាំងឡាយ ប្រគេនចំពោះពួក។ ទឹកនិងចីវរនេះ ក៏នៅជារបស់ពួកដដែល។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកភិក្ខុនៅចាំវស្សារួចហើយ កាលបើចីវរកើតឡើងហើយ តែសង្ឃមិនទាន់ចែក សង្ឃក៏បែកគ្នាទៅ។ ចីវរនោះ សង្ឃត្រូវចែកដល់ពួកភិក្ខុទាំងអស់ឲ្យស្មើគ្នា។

## ២៣១. ទុគ្គហិតសុគ្គហិតាទិកថា

CS vin.mv.08.30 | ភាគ ទី៨

(២៣១)

[៧៧] សម័យនោះឯង ព្រះរេវតដ៏មានអាយុ បានផ្ញើចីវរទៅប្រគេនព្រះសារីបុត្តដ៏មានអាយុនឹងដៃភិក្ខុ១រូប ដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ព្រះថេរៈផងចុះ។ គ្រានោះឯង លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុនោះក៏យកចីវរនោះ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងព្រះរេវតដ៏មានអាយុ។ គ្រាក្រោយ ព្រះរេវតដ៏មានអាយុ បានមកជួបនឹងព្រះសារីបុត្តដ៏មានអាយុ ហើយសួរថា បពិត្រព្រះថេរៈដ៏ចំរើន ខ្ញុំករុណាបានផ្ញើចីវរ មកប្រគេនព្រះថេរៈ តើចីវរនោះ បានដល់មកហើយឬ។ ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ខ្ញុំមិនឃើញចីវរនោះទេ។ ទើបព្រះរេវតដ៏មានអាយុ បាននិយាយ ទៅនឹងភិក្ខុនោះថា ម្នាលអាវុសោ ខ្ញុំបានផ្ញើចីវរ មកប្រគេនព្រះថេរៈ នឹងដៃលោកដ៏មានអាយុ តើចីវរនោះ នៅឯណា។ ភិក្ខុនោះឆ្លើយថា បពិត្រព្រះថេរៈដ៏ចំរើន ខ្ញុំបានយកចីវរនោះ (មកប្រើប្រាស់ ដោយខ្លួនឯងទៅហើយ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងលោកដ៏មានអាយុ។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅ នឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ភិក្ខុ ឈ្មោះនេះ ផងចុះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះ ក៏យកចីវរ (មកប្រើប្រាស់ ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ភិក្ខុ ឈ្មោះនេះផងចុះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះ ក៏យកចីវរ (មកប្រើប្រាស់ ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ។ បើភិក្ខុអ្នកទទួលបញ្ញើ យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅ នឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ភិក្ខុ ឈ្មោះនេះផងចុះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះ ឮដំណឹងថា ភិក្ខុដែលផ្ញើចីវរមកនោះ ស្លាប់ទៅហើយ ៗក៏អធិដ្ឋានមតកចីវរ[30] របស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ។ បើភិក្ខុអ្នកទទួលបញ្ញើ យកចីវរ (មកប្រើប្រាស់ ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងភិក្ខុអ្នកចាំទទួលចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះផងចុះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះ ឮដំណឹងថា ភិក្ខុដែលចាំទទួលចីវរនោះ ស្លាប់ទៅហើយ ៗក៏អធិដ្ឋានមតកចីវរ របស់ភិក្ខុនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អ (អធិដ្ឋានមិនឡើង)។ បើភិក្ខុអ្នកទទួលបញ្ញើ យកចីវរ (មកប្រើប្រាស់ ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅ នឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ចូរលោកប្រគេនចីវរនេះ ដល់ភិក្ខុ ឈ្មោះនេះផងចុះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះ ឮដំណឹងថា ភិក្ខុទាំងពីររូប[31] ស្លាប់ទៅហើយ ៗក៏អធិដ្ឋានមតកចីវរ របស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ។ បើភិក្ខុអ្នកទទួលបញ្ញើ អធិដ្ឋានមតកចីវរ របស់ភិក្ខុដែលចាំទទួលចីវរវិញ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំករុណាប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើ ក៏យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ។ បើភិក្ខុអ្នកទទួលបញ្ញើ យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរវិញ (យ៉ាងនេះ) ហៅថា កាន់យកល្អ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំករុណា ប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះ ក៏យកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាល នឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរទៅនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំករុណា ប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើ ក៏ឮដំណឹងថា ភិក្ខុដែលផ្ញើចីវរមកនោះ ស្លាប់ទៅហើយ ហើយក៏អធិដ្ឋានមតកចីវរ របស់ភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អទេ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា កាន់យកល្អ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំករុណា ប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះ ឮដំណឹងថា ភិក្ខុអ្នកចាំទទួលយកចីវរនោះ ស្លាប់ទៅហើយ ៗក៏អធិដ្ឋានមតកចីវរ របស់ភិក្ខុអ្នកចាំទទួលយកចីវរនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ។ បើភិក្ខុអ្នកទទួលបញ្ញើយកចីវរ (មកប្រើប្រាស់ដោយខ្លួនឯងវិញ) ដោយអាងសេចក្តីស្និទ្ធស្នាលនឹងភិក្ខុអ្នកផ្ញើនោះ (យ៉ាងនេះ) ហៅថា កាន់យកមិនល្អទេ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានភិក្ខុផ្ញើចីវរនឹងដៃភិក្ខុផងគ្នា ដោយពាក្យថា ខ្ញុំករុណា ប្រគេនចីវរនេះ ដល់ភិក្ខុឈ្មោះនេះ។ លុះដល់ពាក់កណ្តាលផ្លូវ ភិក្ខុអ្នកទទួលបញ្ញើនោះ ឮដំណឹងថា ភិក្ខុទាំងពីររូបស្លាប់ទៅហើយ ៗក៏អធិដ្ឋានមតកចីវរ របស់ភិក្ខុអ្នកផ្ញើទៅនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានមិនល្អ។ បើភិក្ខុអ្នកទទួលបញ្ញើ អធិដ្ឋានមតកចីវរ របស់ភិក្ខុអ្នកចាំទទួលចីវរនោះ (យ៉ាងនេះ) ហៅថា អធិដ្ឋានល្អ។

## ២៣២. អដ្ឋចីវរមាតិកា

CS vin.mv.08.31 | ភាគ ទី៨

(២៣២)

[៧៨] ម្នាលភិក្ខុទាំងឡាយ មាតិកា (ហេតុ) ដែលនាំឲ្យកើតចីវរឡើង មាន៨យ៉ាង គឺ គេឲ្យចីវរក្នុងសីមា១ គេឲ្យចីវរ ដោយសេចក្តីប្តេជ្ញា១ គេឲ្យចីវរ ដោយសេចក្តីបញ្ញត្តិ នៃភិក្ខា (ទីបរិច្ចាគទាន របស់ខ្លួន)១ គេឲ្យចីវរចំពោះសង្ឃ១ គេឲ្យចីវរចំពោះឧភតោសង្ឃ១ គេឲ្យចីវរចំពោះសង្ឃដែលនៅចាំវស្សា១ គេចំពោះវត្ថុ ឬកំណត់វត្ថុហើយ ទើបឲ្យចីវរ១ គេឲ្យចីវរ ចំពោះបុគ្គល១។ ដែលហៅថា គេឲ្យចីវរក្នុងសីមា គឺ (សំដៅយក) ភិក្ខុមានចំនួនប៉ុន្មានរូប ដែលនៅខាងក្នុងសីមា ត្រូវភិក្ខុទាំងនោះ ចែកចីវរគ្នាចុះ។ ដែលហៅថា គេឲ្យចីវរដោយសេចក្តីប្តេជ្ញាគឺ (សំដៅយក) អាវាសច្រើន ជាអាវាស មានលាភស្មើគ្នា កាលបើគេឲ្យចីវរក្នុងអាវាសតែ១ ទុកដូចជា បានឲ្យចីវរ ក្នុងអាវាសទាំងអស់។ ដែលហៅថា គេឲ្យចីវរដោយ

សេចក្ដីបញ្ញត្តិនៃភិក្ខា គឺ (សំដៅយក) ការបូជាជានិច្ច ដែលគេធ្វើ ចំពោះសង្ឃ ក្នុងទីណា គេក៏ឲ្យចីវរក្នុងទីនោះ។ ដែលហៅថា គេឲ្យចីវរចំពោះសង្ឃ គឺ (សំដៅយក) សង្ឃដែលមកជួបជុំមុខគ្នា ហើយត្រូវចែកចីវរចុះ។ ដែលហៅថា គេឲ្យចីវរ ចំពោះឧភតោសង្ឃ (សំដៅយក) ភិក្ខុសូម្បីច្រើនរូប ភិក្ខុនីតែ១រូប សង្ឃក៏ត្រូវឲ្យចីវរពាក់កណ្ដាល (ស្មើគ្នា)។ ភិក្ខុនី សូម្បីច្រើនរូប ភិក្ខុតែ១រូប សង្ឃក៏ត្រូវឲ្យចីវរពាក់កណ្ដាល (ស្មើគ្នា)។ ដែលហៅថា គេឲ្យចីវរចំពោះសង្ឃដែលនៅចាំវស្សា (សំដៅយក) ភិក្ខុមានកំណត់ប៉ុន្មានរូប នៅចាំវស្សាក្នុងអាវាសនោះ ភិក្ខុទាំងនោះ ត្រូវចែកចីវរគ្នាចុះ។ ដែលហៅថា ចំពោះវត្ថុ ឬកំណត់វត្ថុហើយ ទើបគេឲ្យចីវរគឺ (សំដៅយកត្រង់ហេតុ) ដែលគេឲ្យបបរហើយ គេឲ្យចីវរផង ជូនកាល គេឲ្យភត្តហើយ គេឲ្យចីវរផង ជូនកាល គេឲ្យខាទនីយៈហើយ គេឲ្យចីវរផង ជូនកាល គេឲ្យចីវរតែម្ដង ជូនកាលគេឲ្យសេនាសនៈហើយ គេឲ្យទាំងចីវរផង ពុំនោះសោត គេឲ្យភេសជ្ជៈ ព្រមទាំងចីវរផង។ ដែលហៅថា គេឲ្យចីវរ ចំពោះបុគ្គលគឺ (សំដៅយកត្រង់ហេតុ) ដែលគេឲ្យ ដោយពាក្យថា ខ្ញុំឲ្យចីវរនេះ ចំពោះភិក្ខុឈ្មោះនេះ។

ចប់ ចីវរក្ខន្ធកៈទី៨។

ក្នុងខន្ធកៈនេះ មាន៩៦រឿង។

## ២៣៣. តស្សុទ្ទានំ

CS vin.mv.08.32 | ភាគ ទី៨

### ឧទ្ទានរបស់ចីវរក្ខន្ធកៈនោះគឺ

[៧៩] រឿងពួកកុដុម្ពិកៈនៅក្នុងក្រុងរាជគ្រឹះ ឃើញពួកស្រីផ្កាមាសក្នុងក្រុងវេសាលី ហើយទៅក្រុងរាជគ្រឹះវិញ ក៏បានក្រាបទូលសេចក្ដីនុ៎ះដល់ស្ដេច១។ រឿងកូនប្រុសនៃស្រីផ្កាមាស ឈ្មោះសាលវតី ត្រឡប់បានមកជា កូនអភយរាជកុមារវិញ ព្រះរាជកុមារ បានចិញ្ចឹមទុក ឲ្យឈ្មោះថា ជីវកៈ ព្រោះហេតុតែពាក្យសួរថា កូននោះ មានជីវិតរស់នៅ ឬស្លាប់១។ រឿងជីវកកោមារភត្យ ទៅក្រុងតក្កសិលា រៀនធ្វើពេទ្យ បានជាមហាពេទ្យ ហើយមើលជម្ងឺក្នុងក្បាលភរិយា របស់សេដ្ឋី ដែលឈឺ៧ឆ្នាំ ឲ្យសះជា ដោយនត្ថុកម្ម គឺការបញ្ច្រកថ្នាំ ទៅតាមច្រមុះ១។ រឿងជីវកកោមារភត្យ ទាញចេញ (មើលជា) អាពាធឫសដូងបាត នៃព្រះបាទពិម្ពិសារ ដោយថ្នាំលាប។ ព្រះរាជា ទ្រង់មានបន្ទូល នឹងកោមារភត្យថា អ្នកឯងចូរបម្រើអញផង ពួកស្រីក្នុងវាំងផង ព្រះពុទ្ធ និងព្រះសង្ឃផង១។ រឿងសេដ្ឋី នៅក្នុងក្រុងរាជគ្រឹះ១ រឿងជីវកកោមារភត្យមើលអាពាធពក ក្នុងពោះវៀន១ រឿងជីវកកោមារភត្យ ញុំាងមហារោគ នៃព្រះបាទបជ្ជោត ឲ្យសះជាទៅ ព្រោះសោយទឹកដោះរាវ។ ជីវកកោមារភត្យ ក្រាបទូលថា សូមឲ្យព្រះបាទបជ្ជោត រំឮកអធិការរបស់ខ្លួន រួចទ្រង់បានផ្ញើសំពត់ សិវេយ្យកៈ មួយគូ មកជីវកកោមារភត្យ១ រឿងជីវកកោមារភត្យ ញុំាងកាយព្រះមានព្រះភាគ ដែលមានរោគទល់ ឲ្យស្រួល ហើយបានថ្វាយថ្នាំបញ្ចុះ៣០ដង ដោយផ្កាឧប្បល៣ក្ដាប់ ព្រះមានព្រះភាគ ក៏មានព្រះកាយ ជាប្រក្រតី ទើបទ្រង់ទទួលសំពត់ សិវេយ្យកៈ ដែលជីវកកោមារភត្យសុំពរ ហើយថ្វាយព្រះអង្គ១ រឿងព្រះតថាគតអនុញ្ញាត គហបតិចីវរ១។ រឿងចីវរកើតឡើងជាច្រើន ក្នុងក្រុងរាជគ្រឹះ១ ក្នុងជនបទ១ រឿងព្រះមានព្រះភាគ អនុញ្ញាត សំពត់ឈ្មោះបាវារៈ ធ្វើដោយសូត្រ១ សំពត់កោជវៈ ធ្វើដោយរោម១ រឿងស្ដេចក្នុងដែនកាសី បញ្ជូនសំពត់កម្ពល មានដំឡៃកន្លះពាន់ មកជីវកកោមារភត្យ១ រឿងចីវរខ្ពស់ និងទាប កើតឡើងដល់សង្ឃហើយ ព្រះអង្គ ទ្រង់សរសើរសេចក្ដីសន្តោស១ រឿងព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាត កុំឲ្យភិក្ខុឲ្យចំណែកចីវរដល់ភិក្ខុ ដែលមិនបានឈប់ចាំគ្នា១ រឿងព្រះដ៏មានព្រះភាគអនុញ្ញាតឲ្យភិក្ខុឲ្យចំណែកចីវរ ដល់ភិក្ខុដែលឈប់ចាំគ្នា១ រឿងភិក្ខុចូលទៅកាន់ព្រៃស្មសានមុន និងចូលទៅកាន់ព្រៃស្មសានក្រោយ១ រឿងភិក្ខុចូលទៅក្នុងព្រៃស្មសានដំណាលគ្នា១ រឿងភិក្ខុធ្វើសេចក្ដីប្ដេជ្ញានឹងគ្នា ហើយចូលទៅក្នុងព្រៃស្មសាន ដើម្បីបង្សុកូល១ រឿងពួកមនុស្ស នាំយកចីវរ មកកាន់អារាម លុះរកភិក្ខុអ្នកទទួលមិនបាន ក៏នាំត្រឡប់ទៅវិញ១ រឿងព្រះសាស្ដា អនុញ្ញាត ឲ្យភិក្ខុសន្មតឃ្លាំង ដាក់ចីវរ១ រឿងចីវរក្នុងឃ្លាំង ឥតមានអ្នកណាថែរក្សា១ រឿងឆព្វគ្គិយភិក្ខុបណ្ដេញអ្នករក្សាឃ្លាំង១ រឿងចីវរកើតឡើងក្រាស់ក្រៃល១ រឿងសង្ឃចែកចីវរ ធ្វើឲ្យកោលាហល១ រឿងភិក្ខុអ្នកចែកចីវររិះគិតថា យើងត្រូវចែកចីវរដូចម្ដេច១ រឿងភិក្ខុអ្នកចែកចីវររិះគិតថា យើងត្រូវឲ្យចំណែកចីវរដល់សាមណេរដូចម្ដេច១ រឿងភិក្ខុមានសេចក្ដីប្រាថ្នានឹងឆ្លងបឹង ឬផ្លូវលំបាក យកទាំងចំណែកចីវរ របស់ខ្លួនទៅផង១ រឿងភិក្ខុមានសេចក្ដីប្រាថ្នានឹងឆ្លងស្ទឹង ឬផ្លូវលំបាក យកទាំងចំណែកចីវរ ដែលមានដំឡៃច្រើនជាងគេ១ រឿងភិក្ខុអ្នកចែកចីវររិះគិតថា យើងត្រូវឲ្យចំណែកចីវរដូចម្ដេច១ រឿងភិក្ខុជ្រលក់ចីវរ ដោយអាច់គោ១ រឿងភិក្ខុជ្រលក់ចីវរ ដោយទឹកត្រជាក់ និងទឹកក្ដៅ១ រឿងទឹកជ្រលក់ពុះផុលកំពប់១ រឿងភិក្ខុមិនដឹងថា ទឹកជ្រលក់ឆ្អិន ឬមិនឆ្អិន១ រឿងភិក្ខុសិតទឹកជ្រលក់ ឆ្នាំងក៏បែកទៅ១ រឿងភិក្ខុគ្មានភាជនសម្រាប់ដាក់ទឹកជ្រលក់១ រឿងភិក្ខុជ្រលក់ចីវរក្នុងផើង១ រឿងភិក្ខុហាលចីវរលើផែនដី១ រឿងសត្វកណ្ដៀរកាត់កម្រាលស្មៅ១ រឿងភិក្ខុហាលចីវរបត់ចំទីពាក់កណ្ដាល១ រឿងចីវររេចរឹ១ រឿងទឹកជ្រលក់ហូរទៅតែម្ខាង១ រឿងភិក្ខុជ្រលក់ចីវរជិតពេក១ រឿងចីវរអាក្រក់១ រឿងឆព្វគ្គិយភិក្ខុទ្រទ្រង់ចីវរមិនកាត់១ រឿងស្រែអ្នកមគធៈ មានសណ្ឋានជាបួនជ្រុង១ រឿព្រះមានព្រះភាគ បានទតឃើញភិក្ខុទាំងឡាយ វេចចីវរធ្វើជាបង្វេច១ រឿងព្រះសក្យមុនី ទ្រង់ល្បងមើលរដូវត្រជាក់ ក្នុងវេលាយប់ ហើយទ្រង់អនុញ្ញាតត្រៃចីវរ១ រឿងឆព្វគ្គិយភិក្ខុទ្រទ្រង់អតិរេកចីវរដទៃៗ១ រឿងព្រះអានន្ទបានអតិរេកចីវរ១ រឿងភិក្ខុស្បង់ធ្លុះ១ រឿងភ្លៀងធ្លាក់សព្វទ្វីបទាំងបួន១ រឿងនាងវិសាខាសុំពរ ដើម្បីប្រគេនវស្សិកសាដិកៈ អាគន្តុកភត្ត គមិកភត្ត គិលានភត្ត ឧបដ្ឋាកភត្ត ភេសជ្ជៈ ធុវយាគុ និងឧទកសាដិកៈ១ រឿងភិក្ខុឆាន់បណីតភោជន១ រឿងសំពត់និសីទនតូចពេក១ រឿងព្រះវេលដ្ឋសីស កើតបូសធំ១ រឿងព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតសំពត់ជូតមុខ១ រឿងរោជមល្លក្សត្រផ្ញើសំពត់សម្បកឈើ ទុកនឹងព្រះអានន្ទ១ រឿងត្រៃចីវរបរិបូណ៌ កើតឡើងដល់ភិក្ខុ១ រឿងព្រះអង្គទ្រង់អនុញ្ញាត ឲ្យភិក្ខុអធិដ្ឋានត្រៃចីវរជាដើម១ រឿងព្រះអង្គទ្រង់អនុញ្ញាត ឲ្យវិកប្បចីវរ យ៉ាងតូចបំផុត១ រឿងព្រះកស្សប ធ្វើសេចក្ដីគោរព ក្នុងការដេរប៉ះសំពត់បង្សុកូល១ រឿងចីវរមានជាយមិនស្មើគ្នា១ រឿងចេសរសាត់ចេញ១ រឿងស្រទាប់សង្ឃាដិដាច់ចេញពីគ្នា១ រឿងភិក្ខុកាត់ចីវរសំពត់មិនគ្រាន់ ព្រះអង្គទ្រង់អនុញ្ញាត ឲ្យលើកឡើង នូវអាគន្តុកបដៈ១ រឿងចីវរ

ច្រើន កើតឡើងដល់ភិក្ខុ១ រឿងភិក្ខុទុកចីវរ ក្នុងអន្ធវ័ន (ព្រៃងងឹត)១ រឿងព្រះអានន្ទ មានតែស្បង់ និងឧត្តរាសង្គៈ ចូលទៅបិណ្ឌបាតក្នុងស្រុក ដោយភ្លេចស្មារតី១ រឿងភិក្ខុចាំវស្សាតែម្នាក់ឯង១ រឿងភិក្ខុនៅតែម្នាក់ឯង អស់មួយរដូវ១ រឿងព្រះថេរៈពីររូបជាបងប្អូននឹងគ្នា នៅចាំវស្សា ក្នុងក្រុងសាវត្ថី១ រឿងភិក្ខុបីរូបនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ១ រឿងព្រះឧបនន្ទ នៅចាំវស្សា ក្នុងក្រុងសាវត្ថី១ រឿងព្រះឧបនន្ទនៅចាំវស្សាតែម្នាក់ឯង ក្នុងអាវាសទាំងពីរ១ រឿងភិក្ខុមានអាពាធវិការក្នុងពោះ១ រឿងភិក្ខុមួយរូបមានជម្ងឺ១ រឿងជនទាំងពីរ គឺភិក្ខុមួយរូប សាមណេរមួយរូប បម្រើភិក្ខុមានជម្ងឺ១ រឿងភិក្ខុអាក្រាត១ រឿងភិក្ខុស្លៀកសំពត់ស្បូវភ្លាំង១ រឿងភិក្ខុស្លៀកសំពត់ ធ្វើពីសម្បកឈើ១ រឿងភិក្ខុស្លៀកសំពត់ ធ្វើពីផែនក្តារ១ រឿងភិក្ខុស្លៀកសំពត់កម្ពល ធ្វើពីសក់១ រឿងភិក្ខុស្លៀកសំពត់ ធ្វើពីរោមកន្ទុយសត្វ១ រឿងភិក្ខុស្លៀកសំពត់ ធ្វើពីស្លាបមៀម១ រឿងភិក្ខុស្លៀកសំពត់ធ្វើពីស្បែកខ្លា១ រឿងភិក្ខុស្លៀកសំពត់ធ្វើពីដើមរាក់១ រឿងភិក្ខុស្លៀកសំពត់ ធ្វើពីសម្បកក្រចៅ១ រឿងឆព្វគ្គិយភិក្ខុ ប្រើចីវរមានពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ហង្សបាទ ពណ៌ខ្មៅ ពណ៌ក្រហមក្រមៅដូចខ្នងក្អែប ពណ៌លឿងទុំដូចផ្កាឈូក មានជាយមិនកាត់ មានជាយវែង មានជាយមានផ្កាជាផ្កាឈើ មានជាយមានផ្កាជាផ្លែឈើ អាវ មួក និងសំពត់ឈ្នួត១ រឿងចីវរមិនទាន់កើតឡើង ភិក្ខុចៀសចេញទៅ១ រឿងសង្ឃបែកគ្នា១ រឿងពួកជនប្រគេនទឹកមួយចំណែក និងចីវរមួយចំណែក ចំពោះសង្ឃ១ រឿងព្រះរេវតដ៏មានអាយុផ្ញើចីវរ១ រឿងភិក្ខុកាន់យកចីវរដោយសេចក្តីស្និទ្ធស្នាល១ រឿងភិក្ខុអធិដ្ឋានមតកចីវរ១ រឿងមាតិកានាំឲ្យកើតចីវរមានប្រាំបីយ៉ាង១។

# ចម្មេយ្យក្ខន្ធកៈ

CS vin.mv.09 | ភាគ ទី៨

### ៩. ចម្មេយ្យក្ខន្ធកោ

## ២៣៤. កស្សបគោត្តភិក្ខុវត្ថុ

CS vin.mv.09.01 | ភាគ ទី៨

**(២៣៤)**

[៨០] សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នាឆ្នេរស្រះបោក្ខរណី ឈ្មោះគគ្គរា ទៀបក្រុងចម្បា។ សម័យនោះឯង ក្នុងកាសីជនបទ មានស្រុក១ ឈ្មោះវាសភៈ។ ភិក្ខុឈ្មោះកស្សបគោត្ត ជាម្ចាស់អាវាស ក្នុងស្រុកឈ្មោះវាសភៈនោះ មានចិត្តជាប់ចំពាក់ដោយការរៀបចំ ក្នុងអាវាសនោះ ដល់នូវសេចក្តីខ្វល់ខ្វាយដូច្នេះថា ធ្វើដូចម្តេច ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ ដែលមិនទាន់មកដល់ ក៏គប្បីឲ្យមកផង ភិក្ខុមានសីលជាទីស្រឡាញ់ ដែលមកដល់ហើយ ក៏គប្បីនៅជាសុខផង ម្យ៉ាងទៀត អាវាសនេះ គប្បីដល់នូវសេចក្តីចំរើន សេចក្តីលូតលាស់ និងការទូលំទូលាយ។ សម័យនោះឯង ពួកភិក្ខុជាច្រើនរូប ត្រាច់ទៅកាន់ចារិក ក្នុងកាសីជនបទ ក៏បានទៅដល់ស្រុក ឈ្មោះវាសភៈ ភិក្ខុឈ្មោះកស្សបគោត្ត បានឃើញពួកភិក្ខុនោះ កំពុងដើរមក អំពីចម្ងាយ លុះឃើញហើយ ក៏ក្រាលអាសនៈ ដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់កល់ជើង និងវត្ថុសម្រាប់ជូតជើង ហើយក្រោកទទួលបាត្រ និងចីវរ អើពើដោយទឹកឆាន់ ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងការងូត ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយ និងភត្តទៀត។ ពួកភិក្ខុ ជាអាគន្តុកទាំងនោះ បានប្រឹក្សាគ្នាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាម្ចាស់អាវាសនេះ ល្អណាស់ ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងការងូត ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើងនឹងសម្រេចការនៅក្នុងវាសភគ្រាមនេះចុះ។ គ្រានោះ ពួកអាគន្តុកភិក្ខុនោះ ក៏សម្រេចការនៅ ក្នុងវាសភគ្រាមនោះឯង។ ភិក្ខុឈ្មោះកស្សបគោត្ត មានសេចក្តីត្រិះរិះ ក្នុងពេលនោះ ដូច្នេះថា សេចក្តីលំបាក ដោយកិច្ចជាអាគន្តុក របស់អាគន្តុកភិក្ខុទាំងនេះ ក៏ស្ងប់រម្ងាប់ទៅហើយ ឥឡូវ ភិក្ខុទាំងឡាយនោះ ដែលមិនស្គាល់ទីគោចរជាប្រក្រតី ក៏ត្រឡប់ស្គាល់ហើយ ឯការធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងត្រកូល នៃបុគ្គលដទៃ អស់មួយជីវិត ជាការកម្រពេកណាស់ ម្យ៉ាងទៀត ការសូម មិនជាទីគាប់ចិត្ត ដល់មនុស្សទាំងឡាយ បើដូច្នោះ គួរតែអញ កុំធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត។ ភិក្ខុឈ្មោះកស្សបគោត្តនោះ លែងធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្ត។ សេចក្តីប្រឹក្សាដូច្នេះ កើតមាន ដល់ភិក្ខុអាគន្តុកនោះថា ម្នាលអាវុសោទាំងឡាយ ពីដើម ភិក្ខុជាម្ចាស់អាវាសនេះ ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងការងូត ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត ឥឡូវ ភិក្ខុជាម្ចាស់អាវាសនោះ លែងធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តហើយ ម្នាលអាវុសោទាំងឡាយ ឥឡូវនេះ ភិក្ខុជាម្ចាស់អាវាសនេះ ត្រឡប់ទៅជាកាចវិញហើយ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ គួរយើងទាំងឡាយ លើកវត្តភិក្ខុជាម្ចាស់អាវាសនេះ។ គ្រានោះឯង ពួកភិក្ខុ ជាអាគន្តុកនោះ ប្រជុំគ្នាហើយ បាននិយាយពាក្យនេះ នឹងភិក្ខុឈ្មោះកស្សបគោត្តថា ម្នាលអាវុសោ ពីដើម លោកធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងការងូត ធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្ត ឥឡូវនេះ លោកលែងធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្ត ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះឬទេ។ ភិក្ខុជាម្ចាស់អាវាសនោះ ឆ្លើយថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំគប្បីឃើញនោះ ខ្ញុំគ្មានទេ។ លំដាប់នោះ ពួកភិក្ខុជាអាគន្តុកនោះ លើកវត្តភិក្ខុ ឈ្មោះកស្សបគោត្ត ព្រោះមិនឃើញអាបត្តិ។ ភិក្ខុឈ្មោះកស្សបគោត្ត មានសេចក្តីត្រិះរិះ ក្នុងពេលនោះថា អាត្មាអញ មិនដឹងនូវហេតុនេះថា នេះជាអាបត្តិ ឬមិនមែនជាអាបត្តិ ម្យ៉ាងទៀត អញត្រូវអាបត្តិហើយ ឬមិនទាន់ត្រូវទេ សង្ឃ (គួរ) លើកវត្តអញ ឬមិន (គួរ) លើកវត្តទេ ដោយកម្មប្រកបដោយធម៌ ឬមិនប្រកបដោយធម៌ទេ ដោយកម្មដ៏កម្រើក ឬមិនកម្រើកទេ ដោយកម្មគួរដល់ហេតុ ឬមិនគួរដល់ហេតុទេ បើដូច្នោះ មានតែអញ គប្បីទៅកាន់ក្រុងចម្បា ហើយក្រាបបង្គំទូលសួរសេចក្តីនេះ នឹងព្រះដ៏មានព្រះភាគ។ គ្រានោះឯង ភិក្ខុឈ្មោះកស្សបគោត្ត រៀបចំទុកដាក់សេនាសនៈ ហើយកាន់យកបាត្រ និងចីវរ ចៀសចេញ ទៅកាន់ក្រុងចម្បា ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ ឯក្រុងចម្បា ដោយលំដាប់ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ការរាក់ទាក់មួយអន្លើ ដោយភិក្ខុទាំងឡាយ ជាអាគន្តុកនេះ ជាបវេណី របស់ព្រះពុទ្ធទាំងឡាយ ដ៏មានព្រះភាគ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលនេះ នឹងភិក្ខុ ឈ្មោះកស្សបគោត្តថា ម្នាលភិក្ខុ អ្នកឯងអាចអត់ទ្រាំសេចក្តីទុក្ខបានឬទេ អាចញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ អ្នកឯងមកកាន់ផ្លូវឆ្ងាយ មិនលំបាកទេឬ ម្នាលភិក្ខុ ម្យ៉ាងទៀត អ្នកមកពីណា។ ភិក្ខុឈ្មោះកស្សបគោត្ត ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ អាចអត់ធន់សេចក្តីទុក្ខបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ អាចញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅបាន បពិត្រ

ព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ម់កកាន់ផ្លូវឆ្ងាយ ដោយមិនមានសេចក្ដីលំបាកទេ បពិត្រព្រះអង្គ៏ដ៏ចំរើន ស្រុកឈ្មោះវាសភៈ មានក្នុងកាសីជនបទ ខ្ញុំព្រះអង្គជាម្ចាស់អាវាស ក្នុងស្រុកឈ្មោះវាសភៈនោះ ជាប់ចំពាក់ដោយការរៀបចំក្នុងអាវាសនោះ ដល់នូវសេចក្ដីខ្វល់ខ្វាយថា ធ្វើដូចម្ដេច ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ដែលមិនទាន់មក គប្បីឲ្យមកផង ភិក្ខុដែលមានសីលជាទីស្រឡាញ់មកដល់ហើយ គប្បីនៅសប្បាយផង ម្យ៉ាងទៀត អាវាសនេះ គប្បីដល់នូវសេចក្ដីចំរើន លូតលាស់ ទូលំទូលាយ បពិត្រព្រះអង្គដ៏ចំរើន ពេលនោះ មានពួកភិក្ខុជាច្រើនរូប ត្រេចទៅកាន់ចារិក ក្នុងកាសីជនបទ ក៏បានទៅដល់វាសភគ្រាម បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ បានឃើញពួកភិក្ខុនោះមកពីចម្ងាយ លុះឃើញហើយ ក៏ក្រាលអាសនៈ ដំកល់ទឹកលាងជើង តាំងសម្រាប់ទ្រជើង និងវត្ថុសម្រាប់ជូតជើង ហើយក្រោកទទួលនូវបាត្រ និងចីវរ អើពើដោយទឹកឆាន់ បានធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងការងូត បានធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត បពិត្រព្រះអង្គដ៏ចំរើន សេចក្ដីប្រឹក្សាដូច្នេះ មានដល់ភិក្ខុទាំងឡាយ ជាអាគន្តុកនោះ ក្នុងពេលនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាម្ចាស់អាវាសនេះ ល្អណាស់ ធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងការងូត ធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត ម្នាលអាវុសោទាំងឡាយ បើដូច្នោះ មានតែយើងទាំងឡាយ នឹងសម្រេចការនៅក្នុងវាសភគ្រាមនេះឯង បពិត្រព្រះអង្គដ៏ចំរើន គ្រានោះឯង ពួកភិក្ខុជាអាគន្តុកនោះ សម្រេចការនៅ ក្នុងវាសភគ្រាមនោះ បពិត្រព្រះអង្គដ៏ចំរើន សេចក្ដីត្រិះរិះនេះ មានដល់ខ្ញុំព្រះអង្គថា ការលំបាក ដោយអាគន្តុកកិច្ច របស់អាគន្តុកភិក្ខុទាំងនេះ ក៏ស្ងប់រម្ងាប់ទៅហើយ ឥឡូវ ភិក្ខុទាំងឡាយ ដែលមិនស្គាល់ទីគោចរជាប្រក្រតីនោះ ក៏បានស្គាល់ហើយ ការធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងត្រកូល នៃបុគ្គលដទៃ អស់មួយជីវិត ជាការកម្រពេកណាស់ ម្យ៉ាងទៀត ការសូម ក៏មិនជាទីគាប់ចិត្ត ដល់មនុស្សទាំងឡាយឡើយ បើដូច្នោះ គួរតែអាត្មាអញ លែងធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ លែងធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត បពិត្រព្រះអង្គដ៏ចំរើន ក្នុងពេលនោះ ភិក្ខុជាអាគន្តុកទាំងនោះ បានប្រឹក្សាគ្នាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ពីដើម ភិក្ខុជាម្ចាស់អាវាសនេះ ធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងការងូត ធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តទៀត ឥឡូវ ភិក្ខុនោះ លែងធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តហើយ ម្នាលអាវុសោទាំងឡាយ ឥឡូវ ភិក្ខុជាម្ចាស់អាវាសនេះ កាចណាស់ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ មានតែយើងទាំងឡាយ នឹងលើកវត្តភិក្ខុជាម្ចាស់អាវាសនេះ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ពួកភិក្ខុជាអាគន្តុកនោះ ប្រជុំគ្នាហើយ និយាយពាក្យនេះ នឹងខ្ញុំព្រះអង្គថា ម្នាលអាវុសោ ពីដើម អ្នកធ្វើសេចក្ដីខ្វល់ខ្វាយក្នុងការងូត ធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្ត ឥឡូវ អ្នកលែងធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងបបរ និងខាទនីយៈ និងភត្តហើយ ម្នាលអាវុសោ អ្នកត្រូវអាបត្តិហើយ អ្នកឃើញអាបត្តិឬទេ ខ្ញុំព្រះអង្គឆ្លើយថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំគប្បីឃើញនោះ មិនមានទេ បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុជាអាគន្តុកនោះ លើកវត្តខ្ញុំព្រះអង្គ ព្រោះមិនឃើញអាបត្តិ ក្នុងកាលនោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញមិនដឹងហេតុនេះថា នេះជាអាបត្តិ ឬមិនមែនជាអាបត្តិ ម្យ៉ាងទៀត អញត្រូវអាបត្តិហើយ ឬមិនទាន់ត្រូវទេ ម្យ៉ាងទៀតសង្ឃ (គួរ) លើកវត្តអញ ឬមិន (គួរ) លើកវត្តទេ ដោយកម្មប្រកបដោយធម៌ ឬមិនប្រកបដោយធម៌ទេ ដោយកម្មដ៏កម្រើក ឬមិនកម្រើកទេ ដោយកម្មគួរដល់ហេតុ ឬមិនគួរដល់ហេតុទេ បើដូច្នោះ មានតែអញ គប្បីទៅកាន់ក្រុងចម្បា ហើយក្រាបបង្គំទូលសួរសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ បពិត្រព្រះដ៏មានព្រះភាគ ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គមក។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ អ្នកជាភិក្ខុ ដែលមិនត្រូវអាបត្តិ អ្នកជាភិក្ខុមិនត្រូវអាបត្តិ (អ្វីទេ) អ្នកជាភិក្ខុ ដែលសង្ឃមិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ អ្នកសង្ឃបានលើកវត្តហើយ ដោយកម្មមិនប្រកបដោយធម៌ ដោយកម្មដ៏កម្រើក ដោយកម្មមិនគួរតាមហេតុទេ ម្នាលភិក្ខុ អ្នកចូរទៅសម្រេចការ នៅក្នុងវាសភគ្រាមនោះវិញចុះ។ ភិក្ខុឈ្មោះកស្សបគោត្ត ទទួលស្ដាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចៀសចេញទៅកាន់វាសភគ្រាមនោះ។ ក្នុងលំដាប់នោះ ពួកភិក្ខុជាអាគន្តុកនោះ កើតសេចក្ដីរង្កៀសក្ដៅក្រហាយថា មិនមែនជាលាភរបស់យើងហើយ យើងឈ្មោះថា ឥតលាភហើយ អត្តភាពជាមនុស្ស យើងបានដោយក្រ មិនមែនយើងបានដោយងាយទេ (ព្រោះ) យើងលើកវត្តភិក្ខុបរិសុទ្ធមិនមានអាបត្តិ ដោយឥតរឿង ឥតហេតុ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ មានតែយើងទាំងឡាយ នឹងទៅក្រុងចម្បា ហើយសំដែងនូវទោសតាមទោស ក្នុងសំណាក់ព្រះដ៏មានព្រះភាគ។ គ្រានោះឯង ពួកភិក្ខុជាអាគន្តុកនោះ ក៏រៀបចំទុកដាក់សេនាសនៈ ហើយកាន់យកបាត្រ និងចីវរចៀសចេញទៅកាន់ក្រុងចម្បា ចូលទៅគាល់ព្រះដ៏មានព្រះភាគ ឯក្រុងចម្បា ដោយលំដាប់ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ សេចក្ដីរីករាយនឹងភិក្ខុអាគន្តុកនេះ ជាប្រពៃណី របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលនេះនឹងពួកភិក្ខុនោះថា ម្នាលភិក្ខុទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ អាចអត់ទ្រាំសេចក្ដីទុក្ខបានឬទេ អាចញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅបានឬទេ អ្នកទាំងឡាយ មកកាន់ផ្លូវឆ្ងាយ ដោយការមិនលំបាកទេឬ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អ្នកទាំងឡាយមកអំពីទីណា។ ពួកភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ អាចអត់ទ្រាំបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ អាចញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចំរើន ម្យ៉ាងទៀត យើងខ្ញុំទាំងឡាយ មកកាន់ផ្លូវឆ្ងាយ ដោយការមិនលំបាកទេ បពិត្រព្រះអង្គដ៏ចំរើន មានស្រុកមួយឈ្មោះវាសភៈ នៅក្នុងកាសីជនបទ បពិត្រព្រះមានព្រះភាគ យើងខ្ញុំទាំងឡាយ មកអំពីស្រុក ឈ្មោះវាសភៈនោះ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ លើកវត្តភិក្ខុ ជាចៅអាវាស មែនឬ។ ពួកភិក្ខុ ក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ លើកវត្ត ព្រោះវត្ថុដូចម្ដេច ព្រោះហេតុដូចម្ដេច។ ពួកភិក្ខុ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយ លើកវត្ត ដោយគ្មានវត្ថុ គ្មានហេតុទេ។ ព្រះពុទ្ធមានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ការនេះមិនសមគួរ មិនទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនត្រូវធ្វើទេ ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរ នឹងលើកវត្តភិក្ខុដ៏ស្អាត គ្មានអាបត្តិ ដោយគ្មានវត្ថុ គ្មានហេតុទេ ម្នាលមោឃបុរសទាំងឡាយ ការនេះ នាំមិនឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លា។បេ។ ទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលើកវត្តភិក្ខុដ៏បរិសុទ្ធ គ្មានអាបត្តិ ដោយគ្មានវត្ថុ គ្មានហេតុទេ ភិក្ខុណាលើកវត្ត ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។ គ្រានោះ ពួកភិក្ខុនោះ ក្រោកចាកអាសនៈ ហើយធ្វើសំពត់ឧត្តរាសង្គៈ លើស្មាម្ខាង ហើយក្រាបចុះទៀបព្រះបាទទាំងឡាយ នៃព្រះដ៏មានព្រះភាគ ដោយសិរសា ហើយទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំទាំងឡាយ ត្រូវទោស ព្រោះជាបុគ្គលពាលយ៉ាងណា ជាបុគ្គលវង្វេងយ៉ាងណា ជាបុគ្គលមិនឆ្លាសយ៉ាងណា (ដោយហេតុ) យើងខ្ញុំទាំងឡាយ លើកវត្តភិក្ខុដ៏ស្អាត មិនមានអាបត្តិ ដោយគ្មានវត្ថុ គ្មានហេតុ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទទួលអត់ទោស តាមទោស នៃយើងខ្ញុំទាំងឡាយ ដើម្បីសង្រួមតទៅ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវទោស ព្រោះជាបុគ្គលពាល ជាបុគ្គលវង្វេង ជាបុគ្គលមិនឆ្លាស យ៉ាងណា (ដោយហេតុ) អ្នកទាំងឡាយ បានលើកវត្តភិក្ខុដ៏ស្អាត មិនមានអាបត្តិ ដោយគ្មានវត្ថុ គ្មានហេតុ ម្នាលភិក្ខុទាំងឡាយ កាលណាបើអ្នកទាំងឡាយ ឃើញទោសតាមទោសហើយ ចូរធ្វើតប (សំដែង) នូវទោសតាមធម៌ចុះ តថាគត ទទួលអត់ទោសនោះ របស់អ្នក

ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ សេចក្ដីពិតថា ភិក្ខុណាឃើញទោស តាមទោសហើយ ធ្វើតបទោសនោះ តាមធម៌ ដល់នូវសេចក្ដីសង្រួមតទៅ នេះជាសេចក្ដីចំរើន របស់ភិក្ខុនោះ ក្នុងអរិយវិន័យ។

## ២៣៥. អធម្មេន វគ្គាទិកម្មកថា

CS vin.mv.09.02 | ភាគ ទី៨

**(២៣៥)**

[៨១] សម័យនោះឯង ភិក្ខុទាំងឡាយនៅក្នុងក្រុងចម្បា ធ្វើកម្មទាំងឡាយ មានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួក ព្រមទាំងមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មព្រមព្រៀង តែមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួក តែប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួក ព្រមទាំងប្រកប ដោយធម៌ប្លមខ្លះ ធ្វើកម្មព្រមព្រៀង តែប្រកបដោយធម៌ប្លមខ្លះ ភិក្ខុមួយរូប លើកវត្តភិក្ខុមួយរូប ក៏មាន ភិក្ខុមួយរូប លើកវត្តភិក្ខុពីររូបក៏មាន ភិក្ខុមួយរូប លើកវត្តភិក្ខុច្រើនរូប ក៏មាន ភិក្ខុមួយរូប លើកវត្តសង្ឃ ក៏មាន ភិក្ខុពីររូប លើកវត្តភិក្ខុមួយរូប ក៏មាន ភិក្ខុពីររូប លើកវត្តភិក្ខុពីររូប ក៏មាន ភិក្ខុពីររូប លើកវត្តភិក្ខុច្រើនរូប ក៏មាន ភិក្ខុពីររូប លើកវត្តសង្ឃ ក៏មាន ភិក្ខុច្រើនរូប លើកវត្តភិក្ខុមួយរូប ក៏មាន ភិក្ខុច្រើនរូប លើកវត្តភិក្ខុពីររូប ក៏មាន ភិក្ខុច្រើនរូប លើកវត្តភិក្ខុច្រើនរូប ក៏មាន ភិក្ខុច្រើនរូប លើកវត្តសង្ឃ ក៏មាន សង្ឃលើកវត្តសង្ឃ ក៏មាន។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុក្នុងក្រុងចម្បា មិនគួរនឹងធ្វើកម្មទាំងឡាយ មានសភាពយ៉ាងនេះ នឹងធ្វើកម្មជាពួក ព្រមទាំងមិនប្រកបដោយធម៌។បេ។ សង្ឃលើកវត្តសង្ឃក៏មាន។ គ្រានោះ ពួកភិក្ខុនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកភិក្ខុក្នុងក្រុងចម្បា ធ្វើកម្មទាំងឡាយ មានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួក ព្រមទាំងមិនប្រកបដោយធម៌។បេ។ សង្ឃលើកវត្តសង្ឃក៏មាន ពិតមែនឬ។ ពួកភិក្ខុ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្ដាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោស។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា។

[៨២] ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួក ទាំងមិនប្រកបដោយធម៌ ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀង តែមិនប្រកបដោយធម៌ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួក តែប្រកបដោយធម៌ ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួក ទាំងប្រកបដោយធម៌ប្លម ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុមួយរូបលើកវត្តភិក្ខុមួយរូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ ភិក្ខុមួយរូប លើកវត្តភិក្ខុពីររូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុមួយរូប លើកវត្តភិក្ខុច្រើនរូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុមួយរូប លើកវត្តសង្ឃក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុពីររូប លើកវត្តភិក្ខុមួយរូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុពីររូប លើកវត្តភិក្ខុពីររូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុពីររូប លើកវត្តភិក្ខុច្រើនរូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុពីររូប លើកវត្តសង្ឃក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុច្រើនរូប លើកវត្ត ចំពោះភិក្ខុមួយរូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុច្រើនរូប លើកវត្តភិក្ខុពីររូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុច្រើនរូប លើកវត្តភិក្ខុច្រើនរូបក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ ភិក្ខុច្រើនរូប លើកវត្តសង្ឃក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។ សង្ឃលើកវត្តសង្ឃក្ដី ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ។

[៨៣] ម្នាលភិក្ខុទាំងឡាយ ឯកម្មនេះមាន៤យ៉ាងគឺ កម្មជាពួកទាំងមិនប្រកបដោយធម៌១ កម្មព្រមព្រៀង តែមិនប្រកបដោយធម៌១ កម្មជាពួក តែប្រកបដោយធម៌១ កម្មព្រមព្រៀង ទាំងប្រកបដោយធម៌១។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំង៤យ៉ាងនេះ កម្មណាជាពួក ទាំងមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឯង ជាកម្មកំរើក (ខូច) មិនគួរដល់ហេតុ ព្រោះជាកម្មមិនប្រកបដោយធម៌ផង ជាពួកផង ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះ តថាគតមិនបានអនុញ្ញាតទេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំងឡាយនោះ កម្មណាព្រមព្រៀង តែមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះ ជាកម្មកំរើក មិនគួរដល់ហេតុ ព្រោះថាកម្មនោះ មិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះ តថាគតមិនបានអនុញ្ញាតទេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំងឡាយនោះ កម្មណាជាពួក តែប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឯង ជាកម្មកំរើក មិនគួរដល់ហេតុ ព្រោះថាកម្មនោះ ជាពួក ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុមិនត្រូវធ្វើទេ កម្មមានសភាពយ៉ាងនេះ តថាគតមិនបានអនុញ្ញាតទេ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំងឡាយនោះ កម្មណាព្រមព្រៀង ទាំងប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ កម្មនេះឯង ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ ព្រោះថាកម្មនោះ ប្រកបដោយធម៌ផង ព្រមព្រៀងផង ម្នាលភិក្ខុទាំងឡាយ កម្មមានសភាពយ៉ាងនេះ ភិក្ខុត្រូវធ្វើចុះ កម្មមានសភាពយ៉ាងនេះ តថាគតក៏អនុញ្ញាត។ ព្រោះហេតុដូច្នោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាក្នុងសាសនានេះថា យើងទាំងឡាយ នឹងធ្វើកម្មមានសភាពយ៉ាងនេះ គឺកម្មព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាដោយប្រការដូច្នេះឯង។

## ២៣៦. ញត្តិវិបន្នកម្មាទិកថា

CS vin.mv.09.03 | ភាគ ទី៨

**(២៣៦)**

[៨៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើកម្មទាំងឡាយមានសភាពយ៉ាងនេះគឺ ធ្វើកម្មជាពួក ទាំងមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មព្រមព្រៀង តែមិនប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួក តែប្រកបដោយធម៌ខ្លះ ធ្វើកម្មជាពួក ទាំងប្រកបដោយធម៌ប្លមខ្លះ ធ្វើកម្មព្រមព្រៀង តែប្រកបដោយធម៌ប្លមខ្លះ ធ្វើកម្មវិបត្តិដោយញត្តិ តែបរិបូណ៌ដោយអនុស្សាវនាខ្លះ ធ្វើកម្មវិបត្តិ ដោយអនុស្សាវនា តែបរិបូណ៌ដោយញត្តិខ្លះ ធ្វើកម្មវិបត្តិដោយញត្តិ និងវិបត្តិដោយអនុស្សាវនាខ្លះ ធ្វើកម្មខុសចាកធម៌ខ្លះ ធ្វើកម្មខុសចាកវិន័យខ្លះ ធ្វើកម្មខុសចាកសត្ថុសាសនខ្លះ ធ្វើកម្មដែលព្រះពុទ្ធតិះដៀលហើយ ជាកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក មិនគួរដល់ហេតុខ្លះ។ ពួកភិក្ខុណា មានសេចក្ដីប្រាថ្នាតិច។បេ។ ពួកភិក្ខុទាំងនោះ ពោលទោស

តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងធ្វើកម្មទាំងឡាយ មានសភាពយ៉ាងនេះសោះ គឺធ្វើកម្មជាពួក ទាំងមិនប្រកបដោយធម៌ខ្លះ។បេ។ ធ្វើកម្មដែលព្រះពុទ្ធ ទ្រង់តិះដៀលហើយ ជាកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុខ្លះ។ គ្រានោះ ពួកភិក្ខុនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុ ធ្វើកម្មទាំងឡាយ មានសភាពយ៉ាងនេះ គឺធ្វើកម្មជាពួក ទាំងមិនប្រកបដោយធម៌ខ្លះ។បេ។ ធ្វើកម្ម ដែលព្រះពុទ្ធ ទ្រង់តិះដៀល ជាកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុខ្លះ ពិតមែនឬ។ ពួកភិក្ខុ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀល។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា។

[៨៥] ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួក ទាំងមិនប្រកបដោយធម៌ ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀង តែមិនប្រកបដោយធម៌ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួក តែប្រកបដោយធម៌ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួក ទាំងប្រកបដោយធម៌ប្លម ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មព្រមព្រៀង តែប្រកបដោយធម៌ប្លម ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិដោយញត្តិ តែបរិបូណ៌ដោយអនុស្សាវនា ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិ ដោយអនុស្សាវនា តែបរិបូណ៌ដោយញត្តិ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មវិបត្តិដោយញត្តិផង វិបត្តិដោយអនុស្សាវនាផង ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកធម៌ក្តី ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកវិន័យ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ កម្មខុសចាកសត្ថុសាសនៈ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។ ម្នាលភិក្ខុទាំងឡាយ បើកម្មដែលព្រះពុទ្ធ ទ្រង់តិះដៀល ជាកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ ក៏ឈ្មោះថា មិនមែនជាកម្ម មិនត្រូវធ្វើទេ។

[៨៦] ម្នាលភិក្ខុទាំងឡាយ កម្មនេះមាន៦យ៉ាង គឺកម្មមិនប្រកបដោយធម៌១ កម្មជាពួក១ កម្មព្រមព្រៀង១ កម្មជាពួក ទាំងប្រកបដោយធម៌ប្លម១ កម្មព្រមព្រៀង តែប្រកបដោយធម៌ប្លម១ កម្មព្រមព្រៀង ទាំងប្រកបដោយធម៌១។

[៨៧] ម្នាលភិក្ខុទាំងឡាយ កម្មមិនប្រកបដោយធម៌ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (សង្ឃ) ធ្វើកម្មដោយញត្តិម្តង តែមិនសូត្រកម្មវាចា ហៅថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (សង្ឃ) ធ្វើកម្មដោយញត្តិពីរដង តែមិនសូត្រកម្មវាចា ហៅថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (សង្ឃ) ធ្វើកម្ម ដោយកម្មវាចា១ តែមិនតាំងញត្តិ ហៅថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ បើកម្ម មានញត្តិជាគំរប់ពីរ (សង្ឃ) ធ្វើកម្ម ដោយកម្មវាចាពីរ តែមិនតាំងញត្តិ ហៅថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ (សង្ឃ) ធ្វើកម្ម ដោយញត្តិ១ តែមិនសូត្រកម្មវាចា ហៅថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ (សង្ឃ) ធ្វើកម្ម ដោយញត្តិពីរក្តី ដោយញត្តិបីក្តី ដោយញត្តិបួនក្តី តែមិនសូត្រកម្មវាចា ហៅថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ (សង្ឃ) ធ្វើកម្ម ដោយកម្មវាចា១ តែមិនតាំងញត្តិ ហៅថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ (សង្ឃ) ធ្វើកម្ម ដោយកម្មវាចាពីរក្តី ដោយកម្មវាចាបីក្តី ដោយកម្មវាចាបួនក្តី តែមិនបានតាំងញត្តិ ហៅថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ កម្មនេះ តថាគតហៅថា កម្មមិនប្រកបដោយធម៌។

[៨៨] ម្នាលភិក្ខុទាំងឡាយ កម្មជាពួក(នោះ) តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុប៉ុន្មានរូបគួរដល់កម្ម ភិក្ខុទាំងឡាយនោះ មិនទាន់មកជួបជុំគ្នាក្តី ឆន្ទរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទ ភិក្ខុក៏មិនបាននាំមកក្តី ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងឡាយនោះ មកជួបជុំគ្នាហើយ តែឆន្ទរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទ ភិក្ខុក៏មិនបាននាំមកក្តី ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់ក្តី ហៅថា កម្មជាពួក។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះ ក៏មកជួបជុំគ្នាហើយក្តី ឆន្ទរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទ ភិក្ខុក៏បាននាំមកក្តី តែភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្ម ហៅថា កម្មជាពួក។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះ ក៏មិនបានមកជួបជុំគ្នាក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកក្តី ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះ ក៏បានមកជួបជុំគ្នាហើយ តែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមក ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ក៏ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុដែលគួរដល់កម្មទាំងប៉ុន្មាន ភិក្ខុទាំងនោះ ក៏បានមកជួបជុំគ្នាហើយ ឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយ តែភិក្ខុដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្ម ហៅថា កម្មជាពួក។ ម្នាលភិក្ខុទាំងឡាយ កម្មនេះ តថាគត ហៅថា កម្មជាពួក។

[៨៩] ម្នាលភិក្ខុទាំងឡាយ កម្មព្រមព្រៀង (នោះ) តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុទាំងឡាយមានប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងឡាយនោះ បានមកជួបជុំគ្នាហើយផង ឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយផង ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ មិនហាមឃាត់កម្មផង ហៅថា កម្មព្រមព្រៀង។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុទាំងឡាយមានប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងឡាយនោះ បានមកជួបជុំគ្នាហើយផង ឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយផង ភិក្ខុទាំងឡាយ មានក្នុងទីចំពោះមុខ មិនហាមឃាត់កម្មផង ហៅថា កម្មព្រមព្រៀង។ ម្នាលភិក្ខុទាំងឡាយ កម្មនេះ តថាគត ហៅថា កម្មព្រមព្រៀង។

[៩០] ម្នាលភិក្ខុទាំងឡាយ កម្មជាពួក ព្រមទាំងប្រកបដោយធម៌ប្លម តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ (ភិក្ខុ) សូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ មិនបានមកជួបជុំគ្នាក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកហើយក្តី ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក ព្រមទាំងប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុ

ទាំងឡាយមានប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ បានមកជួបជុំគ្នាហើយ តែឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាន នាំមកក្តី ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក ព្រមទាំងប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ បានមកជួបជុំគ្នាហើយក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយក្តី តែភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្ម ហៅថា កម្មជាពួក ព្រមទាំងប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ មិនទាន់មកជួបជុំគ្នាក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកក្តី ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក ព្រមទាំងប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ មកជួបជុំគ្នាហើយ តែឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុមិនបាននាំមកហើយក្តី ភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្មក្តី ហៅថា កម្មជាពួក ព្រមទាំងប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុសូត្រកម្មវាចាជាមុន ទើបតាំងញត្តិជាខាងក្រោយវិញ ភិក្ខុទាំងឡាយមានប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ បានមកជួបជុំគ្នាហើយក្តី ឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ភិក្ខុបាននាំមកហើយក្តី តែភិក្ខុទាំងឡាយ ដែលមានក្នុងទីចំពោះមុខ ហាមឃាត់កម្ម ហៅថា កម្មជាពួក ព្រមទាំងប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ កម្មនេះ តថាគតហៅថា កម្មជាពួក ព្រមទាំងប្រកបដោយធម៌ប្លម។

[៩១] ម្នាលភិក្ខុទាំងឡាយ ឯកម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម (នោះ) ដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុសូត្រកម្មវាចាជាមុន ហើយទើបតាំងសូត្រញត្តិជាខាងក្រោយ ភិក្ខុទាំងឡាយ ដែលគួរដល់កម្មមានប៉ុន្មានរូប ភិក្ខុទាំងនោះ ក៏បានមកហើយ ទាំងបាននាំឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយ មកជួបជុំគ្នាហើយ ក៏មិនឃាត់ហាម កម្មនោះឈ្មោះថា កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នាដែរ តែប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុសូត្រកម្មវាចាជាមុន ហើយទើបតាំងញត្តិជាខាងក្រោយ ភិក្ខុទាំងឡាយ ដែលគួរដល់កម្មមានប៉ុន្មានរូប ភិក្ខុទាំងនោះ ក៏បានមកហើយ ទាំងបាននាំឆន្ទៈ របស់ភិក្ខុដែលគួរដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយ មកជួបជុំគ្នាហើយ ក៏មិនឃាត់ហាម កម្មនោះឈ្មោះថា កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នាដែរ តែប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ កម្មនេះ តថាគតហៅថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។

[៩២] ម្នាលភិក្ខុទាំងឡាយ ឯកម្មរបស់ភិក្ខុព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ (នោះ) ដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់ពីរ ភិក្ខុតាំងញត្តិមុនហើយ ទើបធ្វើកម្ម (នោះ) ដោយកម្មវាចាតែម្តងជាខាងក្រោយ ភិក្ខុទាំងឡាយ ដែលគួរដល់កម្ម មានប៉ុន្មានរូប ភិក្ខុទាំងនោះ ក៏បានមកហើយ ទាំងបាននាំឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយ មកជួបជុំគ្នា ក៏មិនឃាត់ហាម កម្មនោះឈ្មោះថា កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ បើកម្មមានញត្តិជាគំរប់៤ ភិក្ខុតាំងញត្តិមុនហើយ ទើបធ្វើកម្ម (នោះ) ដោយកម្មវាចាបីដងជាខាងក្រោយ ភិក្ខុទាំងឡាយ ដែលគួរដល់កម្ម មានប៉ុន្មានរូប ភិក្ខុទាំងនោះ ក៏បានមកហើយ ទាំងបាននាំឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈមកហើយ ភិក្ខុទាំងឡាយ មកជួបជុំគ្នា ក៏មិនឃាត់ហាម កម្មនោះឈ្មោះថា កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ កម្មនេះ តថាគត ហៅថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌។

## ២៣៧. ចតុវគ្គករណាទិកថា

CS vin.mv.09.04 | ភាគ ទី៨

**(២៣៧)**

[៩៣] ជំនុំសង្ឃមាន៥ពួក គឺភិក្ខុសង្ឃចតុវគ្គ (សង្ឃមានភិក្ខុ៤រូប)១ ភិក្ខុសង្ឃបញ្ចវគ្គ (សង្ឃមានភិក្ខុ៥រូប)១ ភិក្ខុសង្ឃទសវគ្គ (សង្ឃមានភិក្ខុ១០រូប)១ ភិក្ខុសង្ឃវីសតិវគ្គ (សង្ឃមានភិក្ខុ២០រូប)១ ភិក្ខុសង្ឃអតិរេកវីសតិវគ្គ (សង្ឃមានភិក្ខុលើសពី២០រូប)១។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសង្ឃទាំង៥ពួកនោះ ឯភិក្ខុសង្ឃចតុវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្ម ក្នុងកម្មទាំងពួង វៀរលែងតែកម្ម៣យ៉ាងគឺ ឧបសម្បទាកម្ម១ បវារណាកម្ម១ អព្ភានកម្ម១។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសង្ឃទាំង៥ពួកនោះ ឯភិក្ខុសង្ឃបញ្ចវគ្គនេះ បើព្រមព្រៀងគ្នា ដោយធម៌ហើយ ឈ្មោះថា គួរដល់កម្ម ក្នុងកម្មទាំងពួង វៀរលែងតែកម្ម២យ៉ាងគឺ ឧបសម្បទាកម្ម១ ក្នុងមជ្ឈិមជនបទ១ អព្ភានកម្ម១។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសង្ឃទាំង៥ពួកនោះ ឯភិក្ខុសង្ឃទសវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្ម ក្នុងកម្មទាំងពួង វៀរលែងតែកម្ម១ គឺ អព្ភានកម្ម១។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសង្ឃទាំង៥ពួកនោះ ឯភិក្ខុសង្ឃវីសតិវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្ម ក្នុងកម្មទាំងពួង។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសង្ឃទាំង៥ពួកនោះ ឯភិក្ខុសង្ឃអតិរេកវីសតិវគ្គនេះ បើព្រមព្រៀងគ្នាដោយធម៌ហើយ ឈ្មោះថា គួរដល់កម្ម ក្នុងកម្មទាំងពួង។

[៩៤] ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ សង្ឃមានភិក្ខុនីជាគំរប់៤ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ សង្ឃមានសិក្ខមានាជាគំរប់៤។បេ។ មានសាមណេរ ជាគំរប់៤ មានសាមណេរី ជាគំរប់៤ មានភិក្ខុដែលពោលលាសិក្ខា ជាគំរប់៤ មានភិក្ខុដែលត្រូវអន្តិមវត្ថុ ជាគំរប់៤ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ជាគំរប់៤ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ ជាគំរប់៤ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាគំរប់៤ មានមនុស្សខ្ទើយ ជាគំរប់៤ មានបុគ្គល ដែលលួចសំវាស ជាគំរប់៤ មានភិក្ខុដែលចូលទៅកាន់ពួកតិរិ្ថយ ជាគំរប់៤ មានសត្វតិរច្ឆាន ជាគំរប់៤ មានបុគ្គល ដែលសម្លាប់មាតា ជាគំរប់៤ មានបុគ្គល ដែលសម្លាប់បិតា ជាគំរប់៤ មានបុគ្គលដែលសម្លាប់ព្រះអរហន្ត ជាគំរប់៤ មានបុគ្គល ដែលទ្រុស្តភិក្ខុនី ជាគំរប់៤ មានភិក្ខុ ដែលបំបែកសង្ឃ ជាគំរប់៤ មានបុគ្គល ដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុរពងឡើង ជាគំរប់៤ មានឧភតោព្យញ្ជនក ជាគំរប់៤ មានភិក្ខុ ដែលមានសំវាសផ្សេងៗគ្នា ជាគំរប់៤ មានភិក្ខុ ដែលឋិតនៅក្នុងសីមាផ្សេងៗគ្នា ជាគំរប់៤ មានភិក្ខុ ដែល

ឋិតនៅលើអាកាស ដោយឫទ្ធិ ជាគំរប់៤ សង្ឃធ្វើកម្ម ដល់បុគ្គលណា សង្ឃមានបុគ្គលនោះ ជាគំរប់៤ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។

ចប់ កម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ។

[៩៥] ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃបញ្ចវគ្គ សង្ឃមានភិក្ខុនីជាគំរប់៥ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃមិនត្រូវធ្វើផង។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃបញ្ចវគ្គ សង្ឃមានសិក្ខមានាជាគំរប់៥។បេ។ មានសាមណេរ ជាគំរប់៥ មានសាមណេរី ជាគំរប់៥ មានភិក្ខុដែលពោលលាសិក្ខា ជាគំរប់៥ មានភិក្ខុត្រូវអន្តិមវត្ថុជាគំរប់៥ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ជាគំរប់៥ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ ជាគំរប់៥ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ជាគំរប់៥ មានមនុស្សខ្ទើយ ជាគំរប់៥ មានបុគ្គល ដែលលួចសំវាស ជាគំរប់៥ មានភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយ ជាគំរប់៥ មានសត្វតិរច្ឆាន ជាគំរប់៥ មានបុគ្គល ដែលសម្លាប់មាតា ជាគំរប់៥ មានបុគ្គលដែលសម្លាប់បិតា ជាគំរប់៥ មានបុគ្គលដែលសម្លាប់ព្រះអរហន្ត ជាគំរប់៥ មានបុគ្គលដែលទ្រុស្តភិក្ខុនី ជាគំរប់៥ មានភិក្ខុដែលបំបែកសង្ឃ ជាគំរប់៥ មានបុគ្គលដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុរពងឡើង ជាគំរប់៥ មានឧភតោព្យញ្ជនក ជាគំរប់៥ មានភិក្ខុដែលមានសំវាសផ្សេងៗគ្នា ជាគំរប់៥ មានភិក្ខុដែលស្ថិតនៅក្នុងសីមាផ្សេងៗគ្នា ជាគំរប់៥ មានភិក្ខុដែលស្ថិតនៅលើអាកាស ដោយឫទ្ធិ ជាគំរប់៥ សង្ឃធ្វើកម្ម ដល់បុគ្គលណា សង្ឃមានបុគ្គលនោះ ជាគំរប់៥ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។

ចប់កម្មសម្រាប់ធ្វើដោយសង្ឃបញ្ចវគ្គ។

[៩៦] ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃទសវគ្គ សង្ឃមានភិក្ខុនី ជាគំរប់១០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃទសវគ្គ សង្ឃមានសិក្ខមានាជាគំរប់១០។បេ។ មានសាមណេរ ជាគំរប់១០ មានសាមណេរី ជាគំរប់១០ មានភិក្ខុដែលពោលលាសិក្ខា ជាគំរប់១០ មានភិក្ខុដែលត្រូវអន្តិមវត្ថុជាគំរប់១០ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ជាគំរប់១០ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ ជាគំរប់១០ មានភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាគំរប់១០ មានមនុស្សខ្ទើយ ជាគំរប់១០ មានបុគ្គល ដែលលួចសំវាស ជាគំរប់១០ មានភិក្ខុ ដែលចូលទៅកាន់ពួកតិរ្ថិយ ជាគំរប់១០ មានសត្វតិរច្ឆាន ជាគំរប់១០ មានបុគ្គល ដែលសម្លាប់មាតា ជាគំរប់១០ មានបុគ្គល ដែលសម្លាប់បិតា ជាគំរប់១០ មានបុគ្គល ដែលសម្លាប់ព្រះអរហន្ត ជាគំរប់១០ មានបុគ្គល ដែលទ្រុស្តភិក្ខុនី ជាគំរប់១០ មានភិក្ខុ ដែលបំបែកសង្ឃ ជាគំរប់១០ មានបុគ្គល ដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុរពងឡើង ជាគំរប់១០ មានឧភតោព្យញ្ជនក ជាគំរប់១០ មានភិក្ខុ ដែលមានសំវាសផ្សេងៗគ្នា ជាគំរប់១០ មានភិក្ខុ ដែលស្ថិតនៅក្នុងសីមាផ្សេងៗគ្នា ជាគំរប់១០ មានភិក្ខុ ដែលស្ថិតនៅលើអាកាស ដោយឫទ្ធិ ជាគំរប់១០ សង្ឃធ្វើកម្ម ដល់បុគ្គលណា សង្ឃមានបុគ្គលនោះ ជាគំរប់១០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។

ចប់កម្មសម្រាប់ធ្វើដោយសង្ឃទសវគ្គ។

[៩៧] ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ សង្ឃមានភិក្ខុនី ជាគំរប់២០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។ ម្នាលភិក្ខុទាំងឡាយ បើកម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ សង្ឃមានសិក្ខមានាជាគំរប់២០។បេ។ មានសាមណេរ ជាគំរប់២០ មានសាមណេរី ជាគំរប់២០ មានភិក្ខុ ដែលពោលលាសិក្ខា ជាគំរប់២០ មានភិក្ខុ ដែលត្រូវអន្តិមវត្ថុ ជាគំរប់២០ មានភិក្ខុ ដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ជាគំរប់២០ មានភិក្ខុ ដែលសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ ជាគំរប់២០ មានភិក្ខុ ដែលសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាគំរប់២០ មានមនុស្សខ្ទើយ ជាគំរប់២០ មានបុគ្គល ដែលលួចសំវាស ជាគំរប់២០ មានភិក្ខុ ដែលចូលទៅកាន់ពួកតិរ្ថិយ ជាគំរប់២០ មានសត្វតិរច្ឆាន ជាគំរប់៤ មានបុគ្គល ដែលសម្លាប់មាតា ជាគំរប់២០ មានបុគ្គល ដែលសម្លាប់បិតា ជាគំរប់២០ មានបុគ្គល ដែលសម្លាប់ព្រះអរហន្ត ជាគំរប់២០ មានបុគ្គល ដែលទ្រុស្តភិក្ខុនី ជាគំរប់២០ មានភិក្ខុ ដែលបំបែកសង្ឃ ជាគំរប់២០ មានភិក្ខុ ដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុរពងឡើង ជាគំរប់២០ មានឧភតោព្យញ្ជនក ជាគំរប់២០ មានភិក្ខុ ដែលមានសំវាសផ្សេងគ្នា ជាគំរប់២០ មានភិក្ខុ ដែលឋិតនៅក្នុងសីមាផ្សេងៗគ្នា ជាគំរប់២០ មានភិក្ខុដែលឋិតនៅលើអាកាស ដោយឫទ្ធិ ជាគំរប់២០(អត់មានក្នុងបិដក មានតែក្នុងឆដ្ឋសង្គាយនា) សង្ឃធ្វើកម្មដល់បុគ្គលណា សង្ឃមានបុគ្គលនោះ ជាគំរប់២០ ហើយធ្វើកម្ម (កម្មនោះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។

ចប់ កម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ។

## ២៣៨. បារិវាសិកាទិកថា

CS vin.mv.09.05 | ភាគ ទី៨

**(២៣៨)**

[៩៨] ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុអ្នកនៅបរិវាស ជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិ មកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឃមានភិក្ខុអ្នកនៅបរិវាសនោះ ជាគំរប់២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុ ដែលគួរដល់ការទាញអន្តរាបត្តិ មកដាក់ក្នុងមូលាបត្តិ ជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិ មកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឃមានភិក្ខុនោះជាគំរប់២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថា កម្មផង សង្ឃក៏មិនត្រូវធ្វើផង។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុ ដែលគួរដល់មានត្ត ជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិ មកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត (បើ) សង្ឃមានភិក្ខុ ដែលគួរដល់មានត្តនោះ ជាគំរប់២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថាកម្មផង សង្ឃមិនត្រូវធ្វើផង។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុ អ្នកប្រព្រឹត្តមានត្ត ជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិ មកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត បើសង្ឃមានភិក្ខុ អ្នកប្រព្រឹត្តមានត្តនោះ ជាគំរប់២០

ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។ ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានភិក្ខុ ដែលគួរដល់អព្ភាន ជាគំរប់៤ ហើយឲ្យបរិវាស ទាញអន្តរាបត្តិ មកដាក់ក្នុងមូលាបត្តិ ហើយឲ្យមានត្ត បើសង្ឃមានភិក្ខុ ដែលគួរដល់អព្ភាននោះ ជាគំរប់២០ ហើយឲ្យអព្ភាន (យ៉ាងនេះ) មិនហៅថាកម្មផង សង្ឃក៏មិនត្រូវធ្វើផង។

[៩៩] ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ក្នុងកណ្តាលជំនុំសង្ឃ របស់បុគ្គលខ្លះឡើង របស់បុគ្គលខ្លះ មិនឡើង។ ម្នាលភិក្ខុទាំងឡាយ ឯការហាមឃាត់ ក្នុងកណ្តាលជំនុំសង្ឃ របស់នរណា ដែលមិនឡើង។ ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ ក្នុងកណ្តាលជំនុំសង្ឃ របស់ភិក្ខុនី មិនឡើងទេ។ ម្នាលភិក្ខុទាំងឡាយ របស់សិក្ខមានា។បេ។ ម្នាលភិក្ខុទាំងឡាយ របស់សាមណេរ ម្នាលភិក្ខុទាំងឡាយ របស់សាមណេរី ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុអ្នកពោលលាសិក្ខា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុ អ្នកត្រូវអន្តិមវត្ថុ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលឆ្កួត ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុ ដែលមានចិត្តរវើរវាយ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលមានវេទនាគ្របសង្កត់ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុ ដែលសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុ ដែលសង្ឃលើកវត្ត ព្រោះមិនលះបង់ នូវទិដ្ឋិអាក្រក់ ម្នាលភិក្ខុទាំងឡាយ របស់បណ្ឌកៈ ម្នាលភិក្ខុទាំងឡាយ របស់បុគ្គល ដែលលួចសំវាស ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយ ម្នាលភិក្ខុទាំងឡាយ របស់សត្វតិរច្ឆាន ម្នាលភិក្ខុទាំងឡាយ របស់បុគ្គល ដែលសម្លាប់មាតា ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលសម្លាប់បិតា ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលសម្លាប់ព្រះអរហន្ត ម្នាលភិក្ខុទាំងឡាយ របស់បុគ្គលដែលទ្រុស្តភិក្ខុនី ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុ ដែលបំបែកសង្ឃ ម្នាលភិក្ខុទាំងឡាយ របស់បុគ្គល ដែលធ្វើព្រះលោហិត (ព្រះសាស្តា) ឲ្យពុរពងឡើង ម្នាលភិក្ខុទាំងឡាយ របស់ឧភតោព្យញ្ជនកៈ ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុដែលមានសំវាសផ្សេងៗគ្នា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុ ដែលស្ថិតនៅក្នុងសីមាផ្សេងៗគ្នា ម្នាលភិក្ខុទាំងឡាយ របស់ភិក្ខុ ដែលស្ថិតនៅលើអាកាសដោយឫទ្ធិ ជំនុំសង្ឃ ធ្វើកម្មដល់បុគ្គលណា ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ ក្នុងកណ្តាលជំនុំសង្ឃ របស់បុគ្គលនោះ មិនឡើងទេ។ ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ ក្នុងកណ្តាលជំនុំសង្ឃ របស់បុគ្គលទាំងអម្បាលនេះឯង មិនឡើងទេ។ ម្នាលភិក្ខុទាំងឡាយ ឯការហាមឃាត់ ក្នុងកណ្តាលជំនុំសង្ឃ របស់នរណាទើបឡើង។ ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់ ក្នុងកណ្តាលជំនុំសង្ឃ របស់ភិក្ខុជាបកតត្ត មានសំវាសស្មើគ្នា ស្ថិតនៅក្នុងសីមាជាមួយគ្នា ដោយហោចទៅ សូម្បីភិក្ខុដែលអង្គុយនៅ ជាលំដាប់ ដែលញុំាងសង្ឃ ឲ្យដឹង ក៏ឡើងដែរ។ ម្នាលភិក្ខុទាំងឡាយ ការហាមឃាត់កណ្តាលជំនុំសង្ឃ របស់ភិក្ខុនេះឯង ទើបឡើង។

## ២៣៩. ទ្វេនិស្សារណាទិកថា

CS vin.mv.09.06 | ភាគ ទី៨

**(២៣៩)**

[១០០] ម្នាលភិក្ខុទាំងឡាយ និស្សារណាកម្ម (ការបណ្តេញចេញ) នេះមាន២យ៉ាង ម្នាលភិក្ខុទាំងឡាយ មានបុគ្គល គឺភិក្ខុដែលមិនទាន់ដល់នូវនិស្សារណាកម្មនៅឡើយ បើសង្ឃបណ្តេញបុគ្គលនោះចេញ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃបណ្តេញចេញដោយល្អ (ត្រូវ) បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃបណ្តេញចេញ ដោយអាក្រក់ (ខុស)។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលមិនទាន់ដល់ នូវនិស្សារណាកម្មនៅឡើយ បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញ ដោយអាក្រក់។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្អាត បរិសុទ្ធ គ្មានអាបត្តិ បើសង្ឃបណ្តេញភិក្ខុនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយអាក្រក់។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ តថាគតហៅថា បុគ្គលដែលមិនទាន់ដល់នូវនិស្សារណាកម្ម បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយអាក្រក់។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលមិនទាន់ដល់នូវនិស្សារណាកម្ម បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយល្អ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ បើសង្ឃបណ្តេញភិក្ខុនោះចេញ ឈ្មោះថា សង្ឃបណ្តេញចេញដោយល្អ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ តថាគតហៅថា បុគ្គលដែលមិនទាន់ដល់នូវនិស្សារណាកម្ម បើសង្ឃបណ្តេញបុគ្គលនោះចេញ ឈ្មោះថា បណ្តេញចេញដោយល្អ។

[១០១] ម្នាលភិក្ខុទាំងឡាយ ឱសារណាកម្ម[32)] មាន២យ៉ាង ម្នាលភិក្ខុទាំងឡាយ មានបុគ្គលដែលមិនទាន់ដល់ នូវឱសារណាកម្មនៅឡើយ បើសង្ឃហៅបុគ្គលនោះបញ្ចូល បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃហៅបញ្ចូលដោយល្អ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃហៅបញ្ចូលដោយអាក្រក់។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលមិនទាន់ដល់ នូវឱសារណាកម្ម បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូលដោយអាក្រក់។ ម្នាលភិក្ខុទាំងឡាយ បណ្ឌកៈ មិនដល់នូវឱសារណាកម្មទេ បើសង្ឃហៅបណ្ឌកៈនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូល ដោយអាក្រក់។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ដែលលួចសំវាស។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលចូលទៅកាន់ពួកតិរ្ថិយ ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្លាប់មាតា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្លាប់បិតា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលសម្លាប់ព្រះអរហន្ត ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលទ្រុស្តភិក្ខុនី ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបំបែកសង្ឃ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលធ្វើលោហិតុប្បាទ ម្នាលភិក្ខុទាំងឡាយ ឧភតោព្យញ្ជនកៈ មិនដល់នូវឱសារណាកម្មទេ បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូល ដោយអាក្រក់។ ម្នាលភិក្ខុទាំងឡាយ តថាគត ហៅបុគ្គលនេះឯងថា មិនដល់នូវឱសារណាកម្ម បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូល ដោយអាក្រក់។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដូចម្តេច ដែលមិនដល់ នូវឱសារណាកម្ម បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូលដោយល្អ។ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតដៃ មិនដល់នូវឱសារណាកម្មទេ បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូលដោយល្អ។ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតជើង។បេ។ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតទាំងដៃ ទាំងជើង ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតត្រចៀក ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតច្រមុះ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតទាំងត្រចៀក ទាំងច្រមុះ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតម្រាមដៃ ម្នាលភិក្ខុទាំងឡាយ មនុស្សកំបុតមេដៃ មេជើង ម្នាលភិក្ខុទាំងឡាយ មនុស្សដាច់សរសៃធំ (សរសៃពួរជើង) ម្នាលភិក្ខុទាំងឡាយ មនុស្សមានដៃព្រែក (មានម្រាមដៃជាប់គ្នា ដូចស្លាបប្រចៀវ) ម្នាលភិក្ខុទាំងឡាយ មនុស្សគម ម្នាលភិក្ខុទាំងឡាយ មនុស្សតឿ ម្នាលភិក្ខុទាំងឡាយ មនុស្សពកក ឬពកត្រង់អវយវៈឯណានីមួយ ម្នាលភិក្ខុទាំងឡាយ មនុស្សដែលគេបៀតបៀន ឲ្យមានស្លាកស្នាម ម្នាលភិក្ខុទាំងឡាយ មនុស្សដែលគេវាយ ឲ្យ

មានស្លាកស្នាម ដោយរំពាត់ ម្នាលភិក្ខុទាំងឡាយ មនុស្សដែលគេកត់ឈ្មោះទុក (ព្យួរទោសទុក) ម្នាលភិក្ខុទាំងឡាយ មនុស្ស ដែលមានជើងហើមស្អក់ ម្នាលភិក្ខុទាំងឡាយ មនុស្ស ដែលមានរោគអាក្រក់ (មានឫសដូងបាត ជាដើម) ម្នាលភិក្ខុទាំងឡាយ មនុស្ស ដែលមានរូបទ្រុស្តបរិសទ្យ (គឺមានរូបអាក្រក់ខុសគេ មានខ្ពស់ពេក ទាបពេក ជាដើម) ម្នាលភិក្ខុទាំងឡាយ មនុស្ស ដែលទើបតែនឹងខ្វាក់ ឬខ្វាក់ម្ខាង ម្នាលភិក្ខុទាំងឡាយ មនុស្សក្ងែងក្ងង់ដៃជើង ជាដើម ម្នាលភិក្ខុទាំងឡាយ មនុស្សខ្ចកជើង ម្នាលភិក្ខុទាំងឡាយ មនុស្សដែលស្លាប់ ១ចំហៀងខ្លួន ម្នាលភិក្ខុទាំងឡាយ មនុស្សខ្វិន ម្នាលភិក្ខុទាំងឡាយ មនុស្សចាស់គ្រាំគ្រា ម្នាលភិក្ខុទាំងឡាយ មនុស្ស ដែលខ្វាក់ពីកំណើត ម្នាលភិក្ខុទាំងឡាយ មនុស្សគ ម្នាលភិក្ខុទាំងឡាយ មនុស្សថ្លង់ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងខ្វាក់ ទាំងគ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងខ្វាក់ ទាំងថ្លង់ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងគ ទាំងថ្លង់ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងខ្វាក់ ទាំងគ ទាំងថ្លង់ មិនដល់នូវឱសារណាកម្មទេ បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូលដោយល្អ។ ម្នាលភិក្ខុទាំងឡាយ តថាគត ហៅបុគ្គលនេះឯងថា មិនដល់នូវឱសារណាកម្មទេ បើសង្ឃហៅបុគ្គលនោះបញ្ចូល ឈ្មោះថា សង្ឃហៅបញ្ចូលដោយល្អ។

ចប់វាសភគាមភាណវារៈ ទី១។

# ២៤០. អធម្មកម្មាទិកថា

CS vin.mv.09.07 | ភាគ ទី៨

**(២៤០)**

[១០២] ម្នាលភិក្ខុទាំងឡាយ បើអាបត្តិដែលភិក្ខុត្រូវឃើញ មិនមានដល់ភិក្ខុក្នុងសាសនានេះទេ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល (គឺភិក្ខុ) ១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ។ ភិក្ខុនោះ ពោលតបវិញយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិ ដែលខ្ញុំគួរឃើញនោះ មិនមានដល់ខ្ញុំទេ។ សង្ឃក៏លើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិ ដែលភិក្ខុត្រូវសំដែង មិនមានដល់ភិក្ខុក្នុងសាសនានេះទេ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ។ ភិក្ខុនោះ ពោលតបវិញ យ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែងនោះ មិនមានដល់ខ្ញុំទេ។ សង្ឃក៏លើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិចេញ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ទិដ្ឋិអាក្រក់ ដែលត្រូវលះបង់ មិនមានដល់ភិក្ខុក្នុងសាសនានេះទេ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ។ ភិក្ខុនោះ ពោលតបវិញ យ៉ាងនេះថា ម្នាលអាវុសោ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ មិនមានដល់ខ្ញុំទេ។ សង្ឃក៏លើកវត្តភិក្ខុនោះ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវឃើញ ក៏មិនមាន អាបត្តិ ដែលត្រូវសំដែង ក៏មិនមាន ដល់ភិក្ខុក្នុងសាសនានេះទេ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ។ ភិក្ខុនោះ ពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញ មិនមានដល់ខ្ញុំទេ ម្នាលអាវុសោ អាបត្តិ ដែលខ្ញុំត្រូវសំដែង ក៏មិនមានដល់ខ្ញុំដែរ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញ (អាបត្តិ)ក្តី ព្រោះមិនសំដែងក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលត្រូវឃើញ ក៏មិនមាន ទិដ្ឋិអាក្រក់ ដែលត្រូវលះបង់ ក៏មិនមាន ដល់ភិក្ខុក្នុងសាសនានេះទេ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ។ ភិក្ខុនោះ ពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិ ដែលខ្ញុំត្រូវឃើញ មិនមានដល់ខ្ញុំទេ ទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ ក៏មិនមានដល់ខ្ញុំដែរ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញ (អាបត្តិ)ក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិ ដែលត្រូវសំដែង ក៏មិនមាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ ក៏មិនមាន ដល់ភិក្ខុក្នុងសាសនានេះទេ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ។ ភិក្ខុនោះ ពោលតបវិញ យ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែង មិនមានដល់ខ្ញុំទេ ម្នាលអាវុសោ ទិដ្ឋិអាក្រក់ ដែលខ្ញុំត្រូវលះបង់ ក៏មិនមានដល់ខ្ញុំដែរ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវឃើញ ក៏មិនមាន អាបត្តិដែលត្រូវសំដែង ក៏មិនមាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ ក៏មិនមាន ដល់ភិក្ខុក្នុងសាសនានេះទេ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ។ ភិក្ខុនោះ ពោលតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញ មិនមានដល់ខ្ញុំទេ ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវសំដែង ក៏មិនមានដល់ខ្ញុំដែរ ម្នាលអាវុសោ ទាំងទិដ្ឋិអាក្រក់ដែលខ្ញុំត្រូវលះបង់ ក៏មិនមានដល់ខ្ញុំដែរ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។

[១០៣] ម្នាលភិក្ខុទាំងឡាយ មួយទៀត អាបត្តិដែលត្រូវឃើញ មានដល់ភិក្ខុ ក្នុងសាសនា នេះ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា អើអាវុសោ ខ្ញុំឃើញដែរ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត អាបត្តិដែលត្រូវសំដែង មានដល់ភិក្ខុ ក្នុងសាសនានេះ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនោះចេញ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា អើអាវុសោ ចាំខ្ញុំសំដែង។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ទិដ្ឋិអាក្រក់ ដែលត្រូវលះបង់ មានដល់ភិក្ខុ ក្នុងសាសនានេះ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា អើអាវុសោ ចាំខ្ញុំលះបង់។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនលះបង់ ទិដ្ឋិអាក្រក់ចេញ (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយ

ធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវឃើញ ក៏មាន អាបត្តិ ដែលត្រូវសំដែង ក៏មានដល់ភិក្ខុ ក្នុងសាសនានេះ។ អាបត្តិដែលត្រូវឃើញក៏មាន ទិដ្ឋិអាក្រក់ ដែលត្រូវលះបង់ក៏មាន។ អាបត្តិដែលត្រូវសំដែងក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន។ អាបត្តិដែលត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន (ទាំង) ទិដ្ឋិអាក្រក់ ដែលត្រូវលះបង់ក៏មាន។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះទិដ្ឋិអាក្រក់នោះចេញ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា អើអាវុសោ ខ្ញុំឃើញដែរ អើចាំខ្ញុំសំដែងចេញ អើចាំខ្ញុំលះបង់ចេញ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ឈ្មោះថា កម្មមិនប្រកបដោយធម៌។

[១០៤] ម្នាលភិក្ខុទាំងឡាយ អាបត្តិដែលត្រូវឃើញ មានដល់ភិក្ខុ ក្នុងសាសនានេះ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញ មិនមានដល់ខ្ញុំទេ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ (យ៉ាងនេះ) ហៅថា កម្មប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវសំដែង មានដល់ភិក្ខុ ក្នុងសាសនានេះ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ ចូរលោកសំដែងអាបត្តិនុ៎ះចេញ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិ ដែលខ្ញុំត្រូវសំដែង មិនមានដល់ខ្ញុំទេ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ (យ៉ាងនេះ) ហៅថា កម្មប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ទិដ្ឋិអាក្រក់ ដែលត្រូវលះបង់មានដល់ភិក្ខុ ក្នុងសាសនានេះ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា ម្នាលអាវុសោ ទិដ្ឋិអាក្រក់ ដែលខ្ញុំត្រូវលះបង់ មិនមានដល់ខ្ញុំទេ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនលះបង់ ទិដ្ឋិអាក្រក់ចេញ (យ៉ាងនេះ) ហៅថា កម្មប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អាបត្តិដែលត្រូវឃើញ ក៏មាន អាបត្តិដែលត្រូវសំដែង ក៏មានដល់ភិក្ខុ ក្នុងសាសនានេះ។ អាបត្តិដែលត្រូវឃើញក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន។ អាបត្តិដែលត្រូវសំដែងក៏មាន ទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន។ អាបត្តិដែលត្រូវឃើញក៏មាន អាបត្តិដែលត្រូវសំដែងក៏មាន ទាំងទិដ្ឋិអាក្រក់ដែលត្រូវលះបង់ក៏មាន។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា ម្នាលអាវុសោ លោកត្រូវអាបត្តិហើយ លោកឃើញអាបត្តិនុ៎ះទេ ចូរលោកសំដែងអាបត្តិនោះចេញ ម្នាលអាវុសោ លោកមានទិដ្ឋិអាក្រក់ហើយ ចូរលោកលះបង់ទិដ្ឋិអាក្រក់នោះចេញ។ ភិក្ខុនោះ និយាយតបយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញ មិនមានដល់ខ្ញុំទេ អាបត្តិដែលខ្ញុំត្រូវសំដែង ក៏មិនមានដល់ខ្ញុំ ទាំងទិដ្ឋិអាក្រក់ ដែលខ្ញុំត្រូវលះបង់ ក៏មិនមានដល់ខ្ញុំដែរ។ សង្ឃលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី (យ៉ាងនេះ) ហៅថា កម្មប្រកបដោយធម៌។

## ២៤១. ឧបាលិបុច្ឆាកថា

CS vin.mv.09.08 | ភាគ ទី៨

**(២៤១)**

[១០៥] គ្រានោះឯង ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរពាក្យនេះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កម្មដែលត្រូវធ្វើក្នុងទីចំពោះមុខ សង្ឃណាមួយ ព្រមព្រៀងគ្នា ធ្វើក្នុងទីកំបាំងមុខទៅវិញ បពិត្រព្រះអង្គដ៏ចំរើន កម្មនោះជាកម្មត្រូវតាមធម៌ ជាកម្មត្រូវតាមវិន័យដែរឬ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះ ជាកម្មមិនត្រូវតាមធម៌ ជាកម្មមិនត្រូវតាមវិន័យទេ។ ព្រះឧបាលិដ៏មានអាយុ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឃណាមួយព្រមព្រៀងគ្នាធ្វើ ដោយការមិនសាកសួរវិញ កម្មដែលត្រូវធ្វើដោយការប្តេជ្ញា សង្ឃធ្វើ ដោយមិនបានប្តេជ្ញាវិញ ឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលគួរដល់សតិវិន័យវិញ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យវិញ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្មវិញ ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្មវិញ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្មវិញ ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្មវិញ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្មវិញ ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្មវិញ ឲ្យមូលាយបដិកស្សន ដល់ភិក្ខុដែលគួរដល់បរិវាសវិញ ឲ្យមានត្តដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈវិញ ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់មានត្តវិញ ឲ្យឧបសម្បទា ដល់ភិក្ខុដែលគួរដល់អព្ភានវិញ បពិត្រព្រះអង្គដ៏ចំរើន កម្មនោះ ជាកម្មត្រូវតាមធម៌ ជាកម្មត្រូវតាមវិន័យដែរឬ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះមិនមែនជាកម្មត្រូវតាមធម៌ មិនមែនជាកម្មត្រូវតាមវិន័យទេ ម្នាលឧបាលិ សង្ឃណាមួយព្រមព្រៀងគ្នា ធ្វើកម្មដែលត្រូវធ្វើ ក្នុងទីចំពោះមុខ (ត្រឡប់ជាធ្វើ) ក្នុងទីកំបាំងមុខវិញ ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា អធម្មកម្ម (កម្មមិនត្រូវតាមធម៌) ឈ្មោះថា អវិន័យកម្ម (កម្មមិនត្រូវតាមវិន័យ) ឯសង្ឃសោត ក៏ជាសង្ឃប្រកបដោយទោស ដោយប្រការដូច្នេះ ម្នាលឧបាលិ កម្មដែលត្រូវធ្វើដោយការសាកសួរ សង្ឃណាមួយព្រមព្រៀងគ្នាធ្វើ ដោយមិនបានសាកសួរ កម្មដែលត្រូវធ្វើ ដោយសេចក្តីប្តេជ្ញា សង្ឃធ្វើដោយមិនបានប្តេជ្ញាវិញ ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុ ដែលគួរដល់ សតិវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ដែលគួរដល់ អមូឡ្ហវិន័យ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុ ដែលគួរដល់ តស្សបាបិយសិកាកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុ ដែលគួរដល់ តជ្ជនីយកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុ ដែលគួរដល់ និយស្សកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុ ដែលគួរដល់ បព្វាជនីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុ ដែលគួរដល់ បដិសារណីយកម្ម ឲ្យបរិវាស ដល់ភិក្ខុ ដែលគួរដល់ ឧក្ខេបនីយកម្ម ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុ ដែលគួរដល់ បរិវាស ឲ្យមានត្ត ដល់ភិក្ខុ ដែលគួរដល់ មូលាយបដិកស្សនៈ ឲ្យអព្ភាន ដល់ភិក្ខុ ដែលគួរដល់មានត្ត ឲ្យឧបសម្បទា ដល់ភិក្ខុដែលគួរដល់ អព្ភាន ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឃសោត ក៏ជាសង្ឃ ប្រកបដោយទោស ដោយប្រការយ៉ាងនេះ។

[១០៦] ព្រះឧបាលិត្ថេរ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កម្មដែលត្រូវធ្វើ ក្នុងទីចំពោះមុខ សង្ឃណាមួយ ព្រមព្រៀងគ្នា ធ្វើក្នុងទីចំពោះមុខ បពិត្រព្រះអង្គដ៏ចំរើន កម្មរបស់សង្ឃនោះ តើហៅថាធម្មកម្ម (កម្មត្រូវតាមធម៌) ថាវិនយកម្ម (កម្មត្រូវតាមវិន័យ) ដែរឬ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះ ហៅថា ជាធម្មកម្ម ជាវិនយកម្ម។ ព្រះឧបាលិត្ថេរ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កម្មដែលត្រូវធ្វើ

ដោយការសាកសួរ សង្ឃណាមួយ ព្រមព្រៀងគ្នា ធ្វើដោយការសាកសួរ កម្មដែលត្រូវធ្វើ ដោយសេចក្តីប្តេជ្ញា សង្ឃធ្វើដោយសេចក្តីប្តេជ្ញា ឲ្យសតិ
វិន័យ ដល់ភិក្ខុដែលគួរដល់ សតិវិន័យ ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ដែលគួរដល់
តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុ ដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុ ដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម
ដល់ភិក្ខុដែលគួរដល់ បព្វាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់ បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់
ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់ មូលាយបដិកស្សនៈ ឲ្យមានត្ត ដល់ភិក្ខុ
ដែលគួរដល់មានត្ត ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់ អព្ភាន ឲ្យឧបសម្បទា ដល់កុលបុត្ត ដែលគួរដល់ ឧបសម្បទា បពិត្រព្រះអង្គដ៏ចំរើន កម្ម
របស់សង្ឃនោះ ជាធម្មកម្ម ជាវិនយកម្មដែរឬ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះ ជាធម្មកម្ម ជាវិនយកម្ម ម្នាលឧបាលិ កម្មដែលត្រូវ
ធ្វើ ក្នុងទីចំពោះមុខ សង្ឃណាមួយ ព្រមព្រៀងគ្នាធ្វើ ក្នុងទីចំពោះមុខ ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាធម្មកម្ម ជាវិនយកម្ម ឯ
សង្ឃសោត ក៏ឈ្មោះថា ជាសង្ឃ មិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ ម្នាលឧបាលិ កម្មដែលត្រូវធ្វើ ដោយការសាកសួរ សង្ឃណាមួយ
ព្រមព្រៀងគ្នាធ្វើ ដោយការសាកសួរ កម្មដែលត្រូវធ្វើដោយសេចក្តីប្តេជ្ញា សង្ឃធ្វើដោយសេចក្តីប្តេជ្ញា ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់សតិ
វិន័យ ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់ អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម
ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុ ដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើ
បដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរ
ដល់បរិវាស ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុ ដែលគួរដល់ មូលាយបដិកស្សនៈ ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភាន ដល់ភិក្ខុ ដែល
គួរដល់អព្ភាន ឲ្យឧបសម្បទា ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាធម្មកម្ម ជាវិនយកម្ម។ ឯ
សង្ឃសោត ក៏ហៅថា ជាសង្ឃ មិនប្រកបដោយទោស ដោយប្រការយ៉ាងនេះ។

[១០៧] ព្រះឧបាលិត្ថេរ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃណាមួយ ព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់សតិ
វិន័យ ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ បពិត្រព្រះអង្គដ៏ចំរើន កម្មនោះ ជាធម្មកម្ម ជាវិនយកម្មដែរឬ។ ព្រះអង្គទ្រង់ត្រាស់ថា
ម្នាលឧបាលិ កម្មនោះ ជាអធម្មកម្ម ជាអវិនយកម្ម។ ព្រះឧបាលិត្ថេរ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃណាមួយ ព្រមព្រៀងគ្នា
ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុ
ដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម
ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់
បព្វាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម
ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរ
ដល់ឧក្ខេបនីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យបរិវាស ដល់ភិក្ខុដែល
គួរដល់មូលាយបដិកស្សនៈ ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភាន
ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទា ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់
ឧបសម្បទា បពិត្រព្រះអង្គដ៏ចំរើន កម្មនោះ ជាធម្មកម្ម ជាវិនយកម្មដែរឬ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ កម្មនោះ មិនមែនជាធម្មកម្ម ជា
វិនយកម្មទេ។ ម្នាលឧបាលិ សង្ឃណាមួយ ព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់
អមូឡ្ហវិន័យ ម្នាលឧបាលិ កម្មយ៉ាងនោះឯង ឈ្មោះថា ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឃសោត ក៏ជាសង្ឃប្រកបដោយទោស ដោយប្រការ
ដូច្នេះ។ ម្នាលឧបាលិ សង្ឃណាមួយ ព្រមព្រៀងគ្នា ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរ
ដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយ
កម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរ
ដល់និយស្សកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើ
បព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុ
ដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យ
មូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់
មូលាយបដិកស្សនៈ ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់
អព្ភាន ឲ្យឧបសម្បទា ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់ឧបសម្បទា ម្នាលឧបាលិ កម្មយ៉ាងនោះឯង ជាអធម្មកម្ម ជា
អវិនយកម្ម។ ឯសង្ឃសោត ក៏ជាសង្ឃប្រកបដោយទោស ដោយប្រការដូច្នេះ។

[១០៨] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃណាមួយ ព្រមព្រៀងគ្នា ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់សតិវិន័យ
ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ បពិត្រព្រះអង្គដ៏ចំរើន កម្មនោះ ជាធម្មកម្ម ជាវិនយកម្មដែរឬ។ ព្រះអង្គទ្រង់ត្រាស់ថា
ម្នាលឧបាលិ កម្មនោះ ជាធម្មកម្ម ជាវិនយកម្មហើយ។ ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃណាមួយ ព្រមព្រៀងគ្នា
ឲ្យអមូឡ្ហវិន័យ ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែល
គួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយ
កម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យ
មូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យ
ឧបសម្បទា ដល់កុលបុត្តដែលគួរដល់ឧបសម្បទា បពិត្រព្រះអង្គដ៏ចំរើន កម្មនោះ ជាធម្មកម្ម ជាវិនយកម្មដែរឬ។ ព្រះអង្គទ្រង់ត្រាស់ថា
ម្នាលឧបាលិ កម្មនោះ ជាធម្មកម្ម ជាវិនយកម្មហើយ។ ម្នាលឧបាលិ សង្ឃណាមួយ ព្រមព្រៀងគ្នា ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់សតិវិន័យ
ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាធម្មកម្ម ជាវិនយកម្ម។ ឯសង្ឃសោត ក៏ជាសង្ឃមិន
ប្រកបដោយទោស ដោយប្រការយ៉ាងនេះ។ ម្នាលឧបាលិ សង្ឃណាមួយ ព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ
ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុ

ដែលគួរដល់និយស្សកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់បរិវាស ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មូលាយបដិកស្សនៈ ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់មានត្ត ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់អព្ភាន ឲ្យឧបសម្បទា ដល់កុលបុត្តដែលគួរដល់ឧបសម្បទា ម្នាលឧបាលិ កម្មយ៉ាងនេះឯង ឈ្មោះថា ជាធម្មកម្ម ជាវិនយកម្ម។ ឯសង្ឃសោត ក៏ជាសង្ឃមិនប្រកបដោយទោស ដោយប្រការដូច្នេះ។

[១០៩] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយ ព្រមព្រៀងគ្នា ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់សតិវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឃសោត ក៏ជាសង្ឃប្រកបដោយទោស ដោយប្រការយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយ ព្រមព្រៀងគ្នា ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យអព្ភាន ដល់ភិក្ខុដែលគួរដល់សតិវិន័យ ឲ្យឧបសម្បទា ដល់ភិក្ខុដែលគួរដល់សតិវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម ជាអវិនយកម្ម ឯសង្ឃសោត ក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃឯណាមួយ ព្រមព្រៀងគ្នា ធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឃសោត ក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយ ព្រមព្រៀងគ្នាធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យមូលាយបដិកស្សនៈ ដល់ភិក្ខុ ដែលគួរដល់អមូឡ្ហវិន័យ ឲ្យមានត្ត ដល់ភិក្ខុដែលគួរដល់អមូឡ្ហវិន័យ ឲ្យអព្ភាន ដល់ភិក្ខុ ដែលគួរដល់អមូឡ្ហវិន័យ ឲ្យឧបសម្បទា ដល់ភិក្ខុ ដែលគួរដល់អមូឡ្ហវិន័យ ឲ្យសតិវិន័យ ដល់ភិក្ខុ ដែលគួរដល់ អមូឡ្ហវិន័យម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឃសោត ក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃណាមួយ ព្រមព្រៀងគ្នាធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលគួរដល់ តស្សបាបិយសិកាកម្ម ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុ ដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើបដិសារណីយកម្ម ដល់ភិក្ខុ ដែលគួរដល់តស្សបាបិយសិកាកម្ម ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ឲ្យបរិវាស ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម។ បេ។ ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុដែលគួរដល់តស្សបាបិយសិកាកម្ម ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឃសោត ក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃឯណានីមួយ ព្រមព្រៀងគ្នា ឲ្យសតិវិន័យ ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម។បេ។ ដល់ភិក្ខុដែលគួរដល់និយស្សកម្ម ដល់ភិក្ខុដែលគួរដល់បព្វាជនីយកម្ម ដល់ភិក្ខុដែលគួរដល់បដិសារណីយកម្ម ដល់ភិក្ខុដែលគួរដល់ឧក្ខេបនីយកម្ម ដល់ភិក្ខុដែលគួរដល់បរិវាស ដល់ភិក្ខុដែលគួរដល់ មូលាយបដិកស្សនៈ ដល់ភិក្ខុដែលគួរដល់មានត្ត ដល់ភិក្ខុដែលគួរដល់អព្ភាន ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ឲ្យអមូឡ្ហវិន័យ ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ធ្វើតស្សបាបិយសិកាកម្ម ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ធ្វើតជ្ជនីយកម្ម ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ធ្វើនិយស្សកម្ម ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ធ្វើបព្វាជនីយកម្ម ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ធ្វើបដិសារណីយកម្ម ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ធ្វើឧក្ខេបនីយកម្ម ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ឲ្យបរិវាស ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ឲ្យមូលាយបដិកស្សនៈ ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ឲ្យមានត្ត ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ឲ្យអព្ភាន ដល់កុលបុត្ត ដែលគួរដល់ឧបសម្បទា ម្នាលភិក្ខុទាំងឡាយ កម្មយ៉ាងនេះឯង ជាអធម្មកម្ម អវិនយកម្ម ឯសង្ឃសោត ក៏ប្រកបដោយទោស ដោយប្រការយ៉ាងនេះ។

ចប់ ឧបាលិបុច្ឆាភាណវារៈ ទី២។

## ២៤២. តជ្ជនីយកម្មកថា

CS vin.mv.09.09 | ភាគ ទី៨

**(២៤២)**

[១១០] ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ (ទាស់ទែងគ្នា) ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះ មានតែយើងរាល់គ្នា ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងឡាយនោះ ជាពួកមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ឯភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃទៀត។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ ក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួកមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងឡាយនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ក៏ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ (ទៀត)។ ភិក្ខុនោះ ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃទៀត។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ ក៏គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងរាល់គ្នា ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងឡាយនោះ ជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ(ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួក តែប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងឡាយនោះ ជាពួក ទាំងប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃទៀត។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោ

ទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយជាពួក ទាំងប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងរាល់គ្នា ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងឡាយនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ក៏ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។

[១១១] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ(ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ ក៏គិតគ្នា យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងឡាយនោះ ជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ(ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ ក៏គិតគ្នា យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួក តែប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ (ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួក ទាំងប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ(ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។

[១១២] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ(ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួក តែប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួក ទាំងប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នា យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ(ទៀត)។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។

[១១៣] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងវិញទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវ អធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវ ការបង្កហេតុ ជាអ្នកធ្វើ នូវជំលោះ ជាអ្នកធ្វើ នូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវ អធិករណ៍ ក្នុងសង្ឃ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងឡាយនោះ ជាពួក ទាំងប្រកបដោយប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នា យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្ម ដោយភិក្ខុទាំងឡាយ ជាពួក ទាំងប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ(ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ (ទៀត)។ ភិក្ខុទាំងឡាយនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ (ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ (ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ (ទៀត)។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។

[១១៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើ នូវវិវាទ ជាអ្នកធ្វើ នូវតិរច្ឆានកថា ជាអ្នកធ្វើនូវ អធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវ ការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវ តិរច្ឆានកថា ជាអ្នកធ្វើនូវ អធិករណ៍ក្នុងសង្ឃ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ (ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ (ទៀត)។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ជាពួក តែប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ(ទៀត)។

## ២៤៣. និយស្សកម្មកថា

CS vin.mv.09.10 | ភាគ ទី៨

**(២៤៣)**

[១១៥] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើនិយស្សកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងអម្បាលនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើនិយស្សកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នា យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើនិយស្សកម្មហើយ ដោយភិក្ខុទាំងឡាយ ជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើនិយស្សកម្ម ដល់ភិក្ខុនេះ (ទៀត)។ ភិក្ខុទាំងអម្បាលនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើនិយស្សកម្ម ដល់ភិក្ខុនោះ។បេ។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្ក[33] ឲ្យដូចសេចក្តី ដែលបានពោលមកហើយពួដ៏ខាងក្រោយ។

## ២៤៤. បព្វាជនីយកម្មកថា

CS vin.mv.09.11 | ភាគ ទី៨

**(២៤៤)**

[១១៦] ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុជាអ្នកទ្រុស្តត្រកូល មានមារយាទអាក្រក់។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកទ្រុស្តត្រកូល មានមារយាទអាក្រក់ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ដែលជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុនោះ (ទៀត)។បេ។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្ក (បំពេញសេចក្តី ដូចខាងដើម)។

## ២៤៥. បដិសារណីយកម្មកថា

CS vin.mv.09.12 | ភាគ ទី៨

**(២៤៥)**

[១១៧] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ក្នុងសាសនានេះ ភិក្ខុជេរប្រទេចពួកគ្រហស្ថ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជេរប្រទេចពួកគ្រហស្ថ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើបដិសារណីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើបដិសារណីយកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្ក (បំពេញសេចក្តី ដូចខាងដើម)។

## ២៤៦. អទស្សនេ ឧក្ខេបនីយកម្មកថា

CS vin.mv.09.13 | ភាគ ទី៨

**(២៤៦)**

[១១៨] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិសោះ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុនេះ ព្រោះមិនឃើញអាបត្តិ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៤៧. អប្បដិកម្មេ ឧក្ខេបនីយកម្មកថា

CS vin.mv.09.14 | ភាគ ទី៨

**(២៤៧)**

ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុនោះ ព្រោះមិនសំដែងអាបត្តិ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៤៨. អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មកថា

CS vin.mv.09.15 | ភាគ ទី៨

**(២៤៨)**

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញសោះ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុនោះ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់។ ភិក្ខុទាំងអម្បាលនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុនោះ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៤៩. តជ្ជនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.16 | ភាគ ទី៨

**(២៤៩)**

[១១៩] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់តជ្ជនីយកម្ម (នឹងសង្ឃ)។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវនេះ មកសូមការរម្ងាប់តជ្ជនីយកម្មនោះ បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងអម្បាលនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ឯភិក្ខុទាំងឡាយ ក្នុងអាវាសនោះ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានរម្ងាប់ តជ្ជនីយកម្មហើយ ដោយភិក្ខុទាំងឡាយ ជាពួក ទាំងមិនប្រកបដោយធម៌ បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ (ទៀត)។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។បេ។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្តគួរដល់កិរិយា រលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់តជ្ជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នា យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវនេះ មកសូមការរម្ងាប់ តជ្ជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។បេ។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ ជាពួក ទាំងមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្មហើយ សូមការរម្ងាប់តជ្ជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវនេះ មកសូមការរម្ងាប់ តជ្ជនីយកម្ម

បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក តែប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។ បេ។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ ជាពួក ទាំងមិនប្រកបដោយធម៌។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្មហើយ មកសូមការ រម្ងាប់តជ្ជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នា យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវនេះ មកសូមការរម្ងាប់ តជ្ជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងប្រកបដោយធម៌ប្លម រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ ជាពួក ទាំងមិនប្រកបដោយធម៌។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ហើយមកសូមការ រម្ងាប់តជ្ជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវនេះ មកសូមការរម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។បេ។ ជាពួក ទាំងមិនប្រកបដោយធម៌។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។

## ២៥០. និយស្សកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.17 | ភាគ ទី៨

**(២៥០)**

[១២០] ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើនិយស្សកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្ម ហើយមកសូមការរម្ងាប់និយស្សកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានធ្វើនិយស្សកម្មហើយ ក៏បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់និយស្សកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់និយស្សកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់និយស្សកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៥១. បព្វាជនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.18 | ភាគ ទី៨

**(២៥១)**

[១២១] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់បព្វាជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់បព្វាជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៥២. បដិសារណីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.19 | ភាគ ទី៨

**(២៥២)**

[១២២] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់បដិសារណីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់បដិសារណីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៥៣. អទស្សនេ ឧក្ខេបនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.20 | ភាគ ទី៨

(២៥៣)

[១២៣] ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុនេះចុះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៥៤. អប្បដិកម្មេ ឧក្ខេបនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.21 | ភាគ ទី៨

(២៥៤)

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ដល់ភិក្ខុនេះចុះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៥៥. អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.22 | ភាគ ទី៨

(២៥៥)

ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ បណ្ឌិតគប្បីធ្វើចក្កចុះ។

## ២៥៦. តជ្ជនីយកម្មវិវាទកថា

CS vin.mv.09.23 | ភាគ ទី៨

(២៥៦)

[១២៤] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលស្ថិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុដែលព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុ ជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុ ដែលព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើមិនល្អហើយ កម្មសង្ឃត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ ពុំនោះសោត ភិក្ខុណានិយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើមិនល្អហើយ កម្ម ភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី (អ្នកពោលត្រូវធម៌) ក្នុងកម្មនោះ។

[១២៥] ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះ មានតែយើង

ទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលស្ថិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុ ជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

[១២៦] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះ គួរតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុ ដែលព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ឯភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

[១២៧] ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

[១២៨] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកធ្វើនូវការបង្កហេតុ ជាអ្នកធ្វើនូវជំលោះ ជាអ្នកធ្វើនូវវិវាទ ជាអ្នកធ្វើនូវតិរច្ឆានកថា ជាអ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃ។ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

## ២៥៧. និយស្សកម្មវិវាទកថា

CS vin.mv.09.24 | ភាគ ទី៨

**(២៥៧)**

[១២៩] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើនិយស្សកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើនិយស្សកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៥៨. បព្វាជនីយកម្មវិវាទកថា

CS vin.mv.09.25 | ភាគ ទី៨

**(២៥៨)**

[១៣០] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើបព្វាជនីយកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ បើភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៥៩. បដិសារណីយកម្មវិវាទកថា

CS vin.mv.09.26 | ភាគ ទី៨

**(២៥៩)**

[១៣១] ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ ជេរប្រទេចពួកគ្រហស្ថ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ជេរប្រទេចពួកគ្រហស្ថ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើបដិសារណីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើបដិសារណីយកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦០. អទស្សនេ ឧក្ខេបនីយកម្មវិវាទកថា

CS vin.mv.09.27 | ភាគ ទី៨

**(២៦០)**

[១៣២] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញនូវអាបត្តិ (នោះ)។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញនូវអាបត្តិ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញនូវអាបត្តិ ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញនូវអាបត្តិ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ឯភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦១. អប្បដិកម្មេ ឧក្ខេបនីយកម្មវិវាទកថា

CS vin.mv.09.28 | ភាគ ទី៨

**(២៦១)**

ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិចេញ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែង

អាបត្តិ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦២. អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មវិវាទកថា

CS vin.mv.09.29 | ភាគ ទី៨

### (២៦២)

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញសោះ បើដូច្នោះ មានតែយើងទាំងឡាយ ធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ ធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦៣. តជ្ជនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.30 | ភាគ ទី៨

### (២៦៣)

[១៣៣] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់តជ្ជនីយកម្ម (នឹងសង្ឃ)។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការ រម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះចុះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

[១៣៤] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់តជ្ជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងអម្បាលនោះ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ បើភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

[១៣៥] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់ តជ្ជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់ តជ្ជនីយកម្ម បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក តែ

ប្រកបដោយធម៌ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុ ជាពួក ទាំងមិនប្រកបដោយធម៌ ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

[១៣៦] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់តជ្ជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់ តជ្ជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងប្រកបដោយធម៌ប្លម រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុ ជាពួក ទាំងប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

[១៣៧] ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់តជ្ជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់តជ្ជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម រម្ងាប់តជ្ជនីយកម្ម ដល់ភិក្ខុនោះ។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។

## ២៦៤. និយស្សកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.31 | ភាគ ទី៨

**(២៦៤)**

[១៣៨] ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើនិយស្សកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់ និយស្សកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើនិយស្សកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់និយស្សកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់និយស្សកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងអម្បាលនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់និយស្សកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦៥. បព្វាជនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.32 | ភាគ ទី៨

**(២៦៥)**

[១៣៩] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់ បព្វាជនីយកម្ម។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើ បព្វាជនីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់ បព្វាជនីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុ

ទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦៦. បដិសារណីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.33 | ភាគ ទី៨

**(២៦៦)**

[១៤០] ម្នាលភិក្ខុទាំងឡាយ ន័យមួយទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់បដិសារណីយកម្ម។ ក្នុងរឿងនោះ ភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់ បដិសារណីយកម្ម (នោះ) បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុនេះ។ ភិក្ខុទាំងនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦៧. អទស្សនេ ឧក្ខេបនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.34 | ភាគ ទី៨

**(២៦៧)**

[១៤១] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ ក៏បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុនេះ។ ភិក្ខុទាំងអម្បាលនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ បើភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦៨. អប្បដិកម្មេ ឧក្ខេបនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.35 | ភាគ ទី៨

**(២៦៨)**

ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃ បានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុនេះ។ ភិក្ខុទាំងអម្បាលនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា

កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

## ២៦៩. អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មបដិប្បស្សទ្ធិកថា

CS vin.mv.09.36 | ភាគ ទី៨

**(២៦៩)**

[១៤២] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ សង្ឃបានធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្មហើយ មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ។ ក្នុងរឿងនោះ បើភិក្ខុទាំងឡាយ គិតគ្នាយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ដែលសង្ឃធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ក៏បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្ម ឥឡូវ មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ បើដូច្នោះ មានតែយើងទាំងឡាយ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុនេះ។ ភិក្ខុទាំងអម្បាលនោះ ជាពួក ទាំងមិនប្រកបដោយធម៌ រម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុនោះ។បេ។ ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌។ ជាពួក តែប្រកបដោយធម៌។ ជាពួក ទាំងប្រកបដោយធម៌ប្លម។ ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម។ សង្ឃដែលឋិតនៅក្នុងទីនោះ ជជែកគ្នាថា កម្មរបស់ភិក្ខុជាពួក ទាំងមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក តែប្រកបដោយធម៌ កម្មរបស់ភិក្ខុជាពួក ទាំងប្រកបដោយធម៌ប្លម កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងនោះ បើភិក្ខុទាំងឡាយឯណា និយាយយ៉ាងនេះថា កម្មរបស់ភិក្ខុព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយយ៉ាងនេះថា កម្មឈ្មោះថា ភិក្ខុមិនបានធ្វើហើយ កម្មឈ្មោះថា ភិក្ខុធ្វើអាក្រក់ហើយ កម្មភិក្ខុត្រូវធ្វើទៀត។ ភិក្ខុទាំងអម្បាលនេះ ឈ្មោះថា ជាធម្មវាទី ក្នុងកម្មនោះ។ វារៈទាំងប្រាំនេះ ជាសេចក្តីសង្ខេប។

ចប់ ចម្បេយ្យក្ខន្ធកៈ ទី៩។

ក្នុងខន្ធកៈនេះ មានរឿង៣៦។

## ២៧០. តស្សុទ្ទានំ

CS vin.mv.09.37 | ភាគ ទី៨

**ឧទ្ទាននៃចម្បេយ្យក្ខន្ធកៈនោះ គឺ**

[១៤៣] កាលព្រះមានព្រះភាគ គង់នៅក្នុងនគរចម្បា (មានភិក្ខុឈ្មោះកស្សបគោត្ត ជាចៅអាវាស) នៅក្នុងស្រុកឈ្មោះវាសភៈ បានធ្វើសេចក្តីខ្វល់ខ្វាយ ដល់ពួកភិក្ខុជាអាគន្តុកៈ លុះដឹងថា ពួកភិក្ខុជាអាគន្តុកៈ ស្គាល់ច្បាស់ក្នុងគោចរ ដែលភិក្ខុគប្បីប្រាថ្នាហើយ ក៏លែងធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងកាលនោះ ភិក្ខុឈ្មោះកស្សបគោត្តនោះ ពួកភិក្ខុជាអាគន្តុកៈ លើកវត្តថាមិនធ្វើ (សេចក្តីខ្វល់ខ្វាយដល់យើង) ហើយបានទៅកាន់សំណាក់ព្រះជិនស្រី។ (ពួកភិក្ខុក្នុងនគរចម្បា) ធ្វើកម្មជាពួក ទាំងមិនប្រកបដោយធម៌ផង ធ្វើកម្មព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ផង ធ្វើកម្មជាពួក តែប្រកបដោយធម៌ផង ធ្វើកម្មជាពួក ទាំងប្រកបដោយធម៌ប្លមផង ធ្វើកម្មព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លមផង ភិក្ខុមួយរូបលើកវត្តភិក្ខុមួយរូបផង ភិក្ខុមួយរូប លើកវត្តភិក្ខុពីររូបផង លើកវត្តភិក្ខុច្រើនរូបផង លើកវត្តសង្ឃផង ភិក្ខុពីររូប ភិក្ខុច្រើនរូប សង្ឃ លើកវត្តសង្ឃផង។ ព្រះសព្វញ្ញុពុទ្ធ ដ៏ប្រសើរ ទ្រង់ជ្រាប (រឿងនោះ) ហើយ ទ្រង់ហាមថា ជាកម្មមិនប្រកបដោយធម៌។ (ឆព្វគ្គិយភិក្ខុ) ធ្វើកម្មវិបត្តិចាកញត្តិ តែដល់ព្រម ដោយអនុស្សាវនាផង ធ្វើកម្មវិបត្តិ ចាកអនុស្សាវនា តែដល់ព្រម ដោយញត្តិផង ធ្វើកម្មវិបត្តិចាកញត្តិ និងអនុស្សាវនាទាំងពីរផង ធ្វើកម្មវៀរចាកធម៌ផង ធ្វើកម្មវៀរចាកវិន័យផង ធ្វើកម្មវៀរចាកសាសនៈ នៃព្រះសាស្តាផង ធ្វើកម្ម ដែលព្រះដ៏មានព្រះភាគ តិះដៀលថា ជាកម្មកំរើក មានរូបមិនគួរដល់ហេតុផង កម្មមិនប្រកបដោយធម៌ផង កម្មជាពួកផង កម្មព្រមព្រៀងគ្នាផង កម្មពីរទៀតគឺ (កម្មជាពួក) ទាំងប្រកបដោយធម៌ប្លមផង (កម្មព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លមផង) ម្យ៉ាងទៀត ព្រះតថាគត ទ្រង់អនុញ្ញាតកម្ម ដែលព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌ ប៉ុណ្ណោះ។ សង្ឃមាន៥ពួកគឺ សង្ឃចតុវគ្គ១ បញ្ចវគ្គ១ ទសវគ្គ១ វីសតិវគ្គ១ អតិរេកវីសតិវគ្គ១។ សង្ឃចតុវគ្គ គួរដល់កម្ម (ទាំងពួង) វៀរលែងតែ (កម្ម៣យ៉ាង) គឺ ឧបសម្បទាកម្ម១ បវារណាកម្ម១ អព្ភានកម្ម១។ សង្ឃបញ្ចវគ្គ គួរដល់កម្មក្នុងកម្មទាំងពួង វៀរលែងតែកម្មពីរយ៉ាង គឺឧបសម្បទាកម្ម ក្នុងមជ្ឈិមប្រទេស១ អព្ភានកម្ម១។ ភិក្ខុសង្ឃទសវគ្គ (ធ្វើកម្មទាំងអស់បាន) វៀរលែងតែ អព្ភានកម្ម មួយចេញ។ សង្ឃវីសតិវគ្គ គួរដល់កម្ម ក្នុងកម្មទាំងពួង ឈ្មោះថាធ្វើកម្ម បានគ្រប់កម្ម។ ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី ភិក្ខុដែលពោលលាសិក្ខាក្តី ភិក្ខុដែលត្រូវ អន្តិមវត្ថុ ក្តី ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ទិដ្ឋិចេញក្តី មនុស្សខ្ទើយក្តី មនុស្សដែលលួចសំវាសក្តី ភិក្ខុដែលចូលទៅកាន់លទ្ធិតិរ្ថិយក្តី សត្វតិរច្ឆានក្តី បុគ្គល ដែលធ្វើមាតុឃាតក្តី បិតុឃាតក្តី អរហន្តឃាតក្តី បុគ្គល ដែលទ្រុស្តភិក្ខុនីក្តី បុគ្គល ដែលធ្វើសង្ឃភេទក្តី បុគ្គល ដែលធ្វើលោហិតុប្បាទក្តី ឧភតោព្យញ្ជនកក្តី ភិក្ខុមានសំវាសផ្សេងៗគ្នាក្តី ភិក្ខុនៅក្នុងសីមាផ្សេងៗគ្នាក្តី (ភិក្ខុ

ឋិតនៅលើអាកាស) ដោយឫទ្ធិក្តី (បណ្តាបុគ្គលទាំងនេះ) បើជំនុំសង្ឃធ្វើកម្ម ដល់បុគ្គលឯណានីមួយ ឯបុគ្គលទាំង២៤ពួកនោះ ព្រះសម្ពុទ្ធ ទ្រង់ហាមថា បុគ្គលទាំងអម្បាលនេះ ជាគណបូរកៈ មិនបានឡើយ ម្យ៉ាងទៀត សង្ឃមានបារិវាសិកភិក្ខុ ជាគំរប់៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនៈ ឲ្យមានត្ត ឲ្យអព្ភាន (កម្មរបស់សង្ឃនោះ) មិនឈ្មោះថា កម្មផង សង្ឃមិនត្រូវធ្វើផង ម្យ៉ាងទៀត សង្ឃមានភិក្ខុ ដែលគួរដល់ មូលាយបដិកស្សនៈ ជាគំរប់៤ក្តី មានភិក្ខុ ដែលគួរដល់មានត្ត ជាគំរប់៤ក្តី មានភិក្ខុ ដែលប្រព្រឹត្តមានត្ត ជាគំរប់៤ក្តី មានភិក្ខុ ដែលគួរដល់អព្ភាន ជាគំរប់៤ក្តី ភិក្ខុទាំង៥ពួកនេះ ព្រះសម្ពុទ្ធ ទ្រង់ប្រកាសថា មិនមែនជាអ្នកធ្វើកម្មឡើយ។ ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី ភិក្ខុដែលពោលលាសិក្ខាក្តី ភិក្ខុដែលត្រូវ អន្តិមវត្ថុក្តី ភិក្ខុឆ្កួតក្តី ភិក្ខុមានចិត្តរវើរវាយក្តី ភិក្ខុមានវេទនាគ្របសង្កត់ក្តី ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី ខ្ទើយក្តី បុគ្គល ដែលលួចសំវាសក្តី ភិក្ខុដែលចូលទៅកាន់លទ្ធិតិរ្ថិយក្តី សត្វតិរច្ឆានក្តី បុគ្គល ជាមាតុឃាតកក្តី បិតុឃាតកក្តី អរហន្តឃាតកក្តី បុគ្គលដែលទ្រុស្តភិក្ខុនីក្តី ដែលធ្វើសង្ឃភេទក្តី ធ្វើលោហិតុប្បាទក្តី ឧភតោព្យញ្ជនកក្តី ភិក្ខុដែលមានសំវាសផ្សេងៗគ្នាក្តី ភិក្ខុដែលឋិតនៅក្នុងសីមាផ្សេងៗគ្នាក្តី ភិក្ខុដែលឋិតនៅលើអាកាសក្តី (សង្ឃធ្វើ) កម្ម ដល់បុគ្គលណា បុគ្គលនោះក្តី ឯការហាមឃាត់ (ក្នុងកណ្តាលជំនុំសង្ឃ) របស់បុគ្គល ទាំង២៧ពួកនេះ មិនឡើងឡើយ។ (ការហាមឃាត់ ក្នុងកណ្តាលជំនុំសង្ឃ) របស់ភិក្ខុជា បកតត្ត ទើបឡើង ភិក្ខុបរិសុទ្ធ (បើសង្ឃបណ្តេញចេញ) ឈ្មោះថា បណ្តេញចេញ ដោយអាក្រក់ ឯភិក្ខុល្ងង់ (បើសង្ឃបណ្តេញចេញ) ឈ្មោះថា បណ្តេញចេញ ដោយល្អ មនុស្សខ្ទើយក្តី បុគ្គលលួចសំវាសក្តី ភិក្ខុចូលទៅកាន់លទ្ធិតិរ្ថិយក្តី តិរច្ឆានក្តី បុគ្គលជាមាតុឃាតកៈក្តី បិតុឃាតកៈក្តី អរហន្តឃាតកៈក្តី ភិក្ខុនីទូសកៈក្តី សង្ឃភេទកៈក្តី លោហិតុប្បាទកៈក្តី ឧភតោព្យញ្ជនកៈក្តី ឯបុគ្គល ទាំង១១ពួកនេះ មិនគួរដល់ ឱសារណាកម្ម ឡើយ។ មនុស្សកំបុតដៃក្តី កំបុតជើងក្តី កំបុតដៃ និងជើងទាំងពីរក្តី កំបុតត្រចៀកក្តី កំបុតច្រមុះក្តី កំបុតត្រចៀក និងច្រមុះទាំងពីរក្តី កំបុតម្រាមដៃក្តី កំបុតមេដៃ មេជើងក្តី មនុស្សដាច់សរសៃធំក្តី មនុស្សមានម្រាមដៃព្រែកក្តី មនុស្សគមក្តី មនុស្សតឿក្តី មនុស្សពកក ឬពកត្រង់អវយវៈណាមួយក្តី មនុស្សដែលគេបៀតបៀន ឲ្យមានស្លាកស្នាមក្តី មនុស្សមានស្នាម ដែលគេវាយ ដោយរំពាត់ក្តី មនុស្ស ដែលគេកត់ឈ្មោះព្យួរទោសទុកក្តី មនុស្សដែលមានជើងហើមស្ទក់ក្តី មនុស្សដែលមានរោគអាក្រក់ក្តី មនុស្សទ្រុស្តបរិសទ្យ គឺមនុស្សមានរូបអាក្រក់ខុសគេក្តី មនុស្សដែលទើបតែនឹងខ្វាក់ក្តី មនុស្សក្វែងក្ងង់ត្រង់អវយវៈណាមួយក្តី មនុស្សខ្ជកក្តី មនុស្ស ដែលស្លាប់មួយចំហៀងខ្លួនក្តី មនុស្សខ្វិនក្តី មនុស្សចាស់គ្រាំគ្រាក្តី មនុស្សដែលខ្វាក់ពីកំណើតក្តី មនុស្សគក្តី ថ្លង់ក្តី មនុស្សខ្វាក់ផង គផងក្តី មនុស្សខ្វាក់ផង ថ្លង់ផងក្តី មនុស្សគផង ថ្លង់ផងក្តី មនុស្សទាំងខ្វាក់ ទាំងគ ទាំងថ្លង់ក្តី មនុស្សទាំង៣២ពួកគត់នេះ ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រកាសថា មនុស្សទាំងនោះ គួរដល់ ឱសារណាកម្ម។ អាបត្តិដែលត្រូវឃើញ អាបត្តិដែលត្រូវសំដែង និងទិដ្ឋិអាក្រក់ ដែលត្រូវលះបង់ មិនមានដល់ (ភិក្ខុណា) ការលើកវត្តដល់ភិក្ខុនោះ ចាត់ជាកម្ម មិនប្រកបដោយធម៌ មាន៧យ៉ាង ភិក្ខុទាំងឡាយ ចោទភិក្ខុដែលត្រូវអាបត្តិ សូម្បីកម្មរបស់ភិក្ខុទាំងនោះ ក៏ចាត់ជាកម្មមិនប្រកបដោយធម៌ មាន៧យ៉ាង ភិក្ខុទាំងឡាយចោទភិក្ខុដែលត្រូវអាបត្តិ (សូម្បី) កម្មរបស់ភិក្ខុទាំងនោះ ក៏ចាត់ជាកម្មប្រកបដោយធម៌ល្អ មាន៧យ៉ាង ការកសង្ឃ ធ្វើកម្មដែលត្រូវធ្វើ ក្នុងទីចំពោះមុខក្តី ធ្វើដោយការសាកសួរក្តី ធ្វើដោយសេចក្តីប្តេជ្ញាក្តី ឲ្យសតិវិន័យក្តី អមូឡ្ហវិន័យក្តី ធ្វើតស្សបាបិយសិកាកម្មក្តី តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ឲ្យបរិវាសក្តី ឲ្យមូលាយបដិកស្សនៈក្តី មានត្តក្តី អព្ភានក្តី ឧបសម្បទាក្តី ហើយសង្ឃត្រឡប់ធ្វើកម្មដទៃ ដល់បុគ្គលដទៃវិញ កម្មទាំង១៦នេះ ឈ្មោះថា មិនប្រកបដោយធម៌ សង្ឃធ្វើកម្មនោះៗ ដល់ភិក្ខុដែលគួរដល់កម្មនោះៗ កម្មទាំង១៦នេះ ឈ្មោះថា ប្រកបដោយធម៌ល្អ សង្ឃលើកឡើង នូវកម្មដទៃចំពោះភិក្ខុ ដែលគួរដល់កម្មដទៃវិញ កម្មទាំង១៦នេះឈ្មោះថា មិនប្រកបដោយធម៌ កម្មមានមូលពីរៗ ដែលសង្ឃបានធ្វើ ដល់ភិក្ខុនោះ កម្មទាំង១៦នោះ ក៏ឈ្មោះថា កម្មប្រកបដោយធម៌ដែរ។ សូម្បីចក្កដែលមានមូលមួយៗ ព្រះជិនស្រី ទ្រង់ត្រាស់ថា មិនប្រកបដោយធម៌ សង្ឃ (គិតគ្នាថា) ភិក្ខុនេះ ជាអ្នកធ្វើការបង្កហេតុ ហើយបានធ្វើ តជ្ជនីយកម្ម (ដល់ភិក្ខុនោះ) តែធ្វើកម្ម ជាពួក ទាំងមិនប្រកបដោយធម៌ ភិក្ខុនោះក៏ចេញទៅកាន់អាវាសដទៃ ឯភិក្ខុទាំងឡាយ ដែលនៅក្នុងអាវាសនោះ ក៏ព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះទៀត (ភិក្ខុនោះ) ក៏ចេញទៅកាន់អាវាសដទៃ ភិក្ខុទាំងឡាយ ដែលនៅក្នុងអាវាសដទៃ (នោះ) ជាពួក តែប្រកបដោយធម៌ ធ្វើតជ្ជនីយកម្ម ដល់ភិក្ខុនោះទៀត ឯភិក្ខុទាំងឡាយនោះ ជាពួក ទាំងប្រកបដោយធម៌ប្លម ក៏មាន ព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លម ក៏មាន បានធ្វើតជ្ជនីយកម្ម (ដល់ភិក្ខុនោះ) ដូចគ្នា បទទាំងឡាយនេះគឺ កម្មព្រមព្រៀងគ្នា តែមិនប្រកបដោយធម៌ក្តី កម្មជាពួក តែប្រកបដោយធម៌ក្តី កម្មជាពួក ទាំងប្រកបដោយធម៌ប្លមក្តី កម្មព្រមព្រៀងគ្នា តែប្រកបដោយធម៌ប្លមក្តី (បទទាំងអម្បាលនេះ) អ្នកមានប្រាជ្ញា គប្បីធ្វើឲ្យមានមូលមួយៗ ហើយចងឲ្យជាចក្ក។ សង្ឃធ្វើនិយស្សកម្ម ដល់ភិក្ខុល្ងង់ក្តី មិនឆ្លាសក្តី សង្ឃធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលទ្រុស្តត្រកូលក្តី សង្ឃធ្វើ បដិសារណីយកម្ម ដល់ភិក្ខុ ដែលជេរគ្រហស្ថក្តី ភិក្ខុណា មិនឃើញអាបត្តិក្តី មិនសំដែងអាបត្តិក្តី មិនលះបង់ទិដ្ឋិអាក្រក់ចេញក្តី ព្រមបរមគ្រូ ជាសត្ថវាហៈ ទ្រង់សំដែងនូវ ឧក្ខេបនីយកម្ម ដល់ភិក្ខុទាំងនោះ អ្នកមានប្រាជ្ញា គប្បីនាំទៅ គឺថា គប្បីធ្វើ តជ្ជនីយកម្ម ដល់ភិក្ខុទាំងឡាយ ដែលគួរ ដល់វិនយកម្ម ភិក្ខុដែលសង្ឃបានធ្វើកម្មហើយ ក៏ប្រព្រឹត្តដោយប្រពៃ ចំពោះវត្ត ដ៏សមគួរដល់កម្មទាំងអម្បាលនោះ ហើយមកសូមការរម្ងាប់កម្មទាំងនោះ (នឹងសង្ឃ) តាមន័យនៃកម្មពួដ៏ខាងក្រោយ សង្ឃដែលឋិតនៅ ក្នុងទីនោះ ជជែកគ្នា ក្នុងកម្មនោះៗក្តី ពុំនោះសោត ភិក្ខុទាំងឡាយណា និយាយថា កម្មឈ្មោះថា សង្ឃមិនបានធ្វើហើយ កម្មឈ្មោះថា សង្ឃធ្វើអាក្រក់ហើយ កម្មសង្ឃត្រូវធ្វើទៀតក្តី ភិក្ខុទាំងនោះ ឈ្មោះថា ធម្មវាទី ក្នុងការរម្ងាប់នូវកម្ម (នោះ) ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ ដ៏ប្រសើរ ទ្រង់ឃើញភិក្ខុទាំងឡាយ ដែលមានវិបត្តិបៀតបៀនហើយ ជាភិក្ខុគួរដល់កម្ម ទើបទ្រង់សំដែង នូវវិធីរម្ងាប់កម្ម ដូចជាពេទ្យមើលរបួស ប្រាប់នូវឱសថដូច្នេះឯង។

# កោសម្ពិក្ខន្ធកៈ

CS vin.mv.10 | ភាគ ទី៨

## ១០. កោសម្ពកក្ខន្ធកោ

# ២៧១. កោសម្ពកវិវាទកថា

CS vin.mv.10.01 | ភាគ ទី៨

## (២៧១)

[១៤៤] សម័យនោះឯង ព្រះពុទ្ធជាម្ចាស់មានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី។ វេលានោះឯង មានភិក្ខុមួយរូប ត្រូវអាបត្តិ។ ភិក្ខុនោះ យល់ឃើញអាបត្តិនោះថា ជាអាបត្តិមែន ពួកភិក្ខុដទៃយល់ឃើញអាបត្តិនោះថា មិនមែនជាអាបត្តិទៅវិញ។ លុះកាលជាខាងក្រោយមក ភិក្ខុនោះ ត្រឡប់យល់ឃើញអាបត្តិនោះថា មិនមែនជាអាបត្តិទៅវិញ ពួកភិក្ខុដទៃ ត្រឡប់យល់ឃើញអាបត្តិនោះថា ជាអាបត្តិទៅវិញ។ គ្រានោះ ភិក្ខុទាំងនោះ បាននិយាយពាក្យនេះ នឹងភិក្ខុនោះថា នែអាវុសោ លោកត្រូវអាបត្តិហើយ តើលោកបានឃើញអាបត្តិនុ៎ះឬទេ។ ភិក្ខុនោះតបទៅវិញថា នែអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញនោះ គ្មានទេ។ វេលានោះ ភិក្ខុទាំងនោះ បានសេចក្តីព្រមព្រៀងគ្នាហើយ ក៏លើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ។ ឯភិក្ខុនោះសោត ក៏ជាពហុស្សុត (ជាអ្នកចេះដឹងច្រើន) ស្ទាត់ក្នុងបិដក ជាអ្នកទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឆ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរអែង និងមានសេចក្តីស្រឡាញ់ក្នុងសិក្ខា។ លំដាប់នោះ ភិក្ខុនោះ ក៏បានចូលទៅរកពួកភិក្ខុ ដែលជាមិត្តគ្រាន់តែឃើញគ្នា និងជាមិត្តដ៏មាំមួន ហើយនិយាយពាក្យនេះថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ខ្ញុំជាភិក្ខុ ដែលមិនត្រូវអាបត្តិ ជាភិក្ខុឥតត្រូវអាបត្តិ (អ្វីទេ) ខ្ញុំជាភិក្ខុ ដែលសង្ឃ មិនគួរលើកវត្ត ជាភិក្ខុ ដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តខ្ញុំ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមលោកទាំងឡាយ មកជាបក្ខពួករបស់ខ្ញុំតាមធម៌ តាមវិន័យ។ ភិក្ខុនោះ ក៏បានភិក្ខុ ដែលជាមិត្តគ្រាន់តែឃើញគ្នា និងមិត្តដ៏មាំមួន មកជាបក្ខពួកឡើង។ មិនតែប៉ុណ្ណោះ ភិក្ខុនោះ ក៏បញ្ជូនបម្រើ ទៅក្នុងសំណាក់ពួកភិក្ខុ ដែលជាមិត្តគ្រាន់តែបានឃើញគ្នា និងមិត្តដ៏មាំមួន ដែលនៅក្នុងជនបទថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ខ្ញុំជាភិក្ខុដែលមិនត្រូវអាបត្តិ ជាភិក្ខុឥតត្រូវអាបត្តិ (អ្វីទេ) ខ្ញុំជាភិក្ខុដែលសង្ឃ មិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តខ្ញុំ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុឡើយ សូមអស់លោកដ៏មានអាយុទាំងឡាយ មកជាបក្ខពួកនឹងខ្ញុំតាមធម៌ តាមវិន័យ។ ភិក្ខុនោះ ក៏បានភិក្ខុដែលជាមិត្តគ្រាន់តែបានឃើញគ្នា និងមិត្តដ៏មាំមួន ដែលនៅក្នុងជនបទ មកជាបក្ខពួកឡើង។ គ្រានោះ ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្តនោះ បានចូលទៅរកពួកភិក្ខុអ្នកលើកវត្ត លុះចូលទៅដល់ហើយ ក៏បាននិយាយពាក្យនេះ នឹងពួកភិក្ខុលើកវត្តថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ភិក្ខុនេះ មិនត្រូវអាបត្តិ ភិក្ខុនេះ ឥតត្រូវអាបត្តិ (អ្វីទេ) ភិក្ខុនេះ សង្ឃមិនគួរលើកវត្ត ភិក្ខុនេះ សង្ឃលើកវត្តមិនបានទេ សង្ឃលើកវត្តភិក្ខុនេះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុឡើយ។ កាលបើភិក្ខុទាំងនោះ និយាយយ៉ាងនេះហើយ ពួកភិក្ខុអ្នកលើកវត្ត បាននិយាយពាក្យនេះ នឹងពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តវិញថា នែអាវុសោ នេះមិនមែនជាអនាបត្តិទេ ភិក្ខុនេះ ត្រូវអាបត្តិហើយ ភិក្ខុនេះ មិនមែនជាមិនត្រូវអាបត្តិទេ ភិក្ខុនេះ សង្ឃគួរលើកវត្តបានហើយ ភិក្ខុនេះ មិនមែនជាភិក្ខុ ដែលសង្ឃលើកវត្តមិនបានទេ ភិក្ខុនេះ សង្ឃលើកវត្ត ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុហើយ បពិត្រលោកដ៏មានអាយុទាំងឡាយ អស់លោកកុំប្រព្រឹត្តតាម កុំតាមចោមរោមភិក្ខុ ដែលសង្ឃបានលើកវត្តនេះឡើយ។ ឯពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្តនោះ កាលបើពួកភិក្ខុអ្នកលើកវត្តនិយាយ យ៉ាងនេះហើយ ក៏នៅតែប្រព្រឹត្តតាម នៅតែតាមចោមរោមភិក្ខុ ដែលសង្ឃបានលើកវត្តហើយនោះដដែល។

[១៤៥] គ្រានោះ មានភិក្ខុ១រូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ភិក្ខុនោះ លុះអង្គុយនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះ មានភិក្ខុ១រូប ត្រូវអាបត្តិហើយ ភិក្ខុនោះ បានយល់ឃើញអាបត្តិនោះ ថាជាអាបត្តិមែន តែពួកភិក្ខុដទៃ យល់ឃើញអាបត្តិនោះថា មិនមែនជាអាបត្តិ លុះកាលជាខាងក្រោយ ភិក្ខុនោះ ត្រឡប់យល់ឃើញអាបត្តិនោះថា មិនមែនជាអាបត្តិទៅវិញ ពួកភិក្ខុដទៃ ត្រឡប់យល់ឃើញអាបត្តិនោះថា ជាអាបត្តិទៅវិញ សូមទ្រង់ព្រះមេត្តាប្រោស ក្នុងវេលានោះឯង ភិក្ខុទាំងឡាយនោះ និយាយពាក្យនេះ នឹងភិក្ខុនោះថា នែអាវុសោ លោកត្រូវអាបត្តិហើយ តើលោកឃើញអាបត្តិនុ៎ះឬទេ ភិក្ខុនោះឆ្លើយថា នែអាវុសោ អាបត្តិដែលខ្ញុំត្រូវឃើញនោះ គ្មានទេ សូមទ្រង់ព្រះមេត្តាប្រោស គ្រានោះ ភិក្ខុទាំងនោះ បានសេចក្តីសាមគ្គីគ្នាហើយ ក៏លើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ សូមទ្រង់ព្រះមេត្តាប្រោស ឯភិក្ខុនោះសោត ក៏ជាពហុស្សុត ស្ទាត់ក្នុងបិដក ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ហើយជាបណ្ឌិត ឆ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរអែង មានសេចក្តីស្រឡាញ់ក្នុងសិក្ខា សូមទ្រង់ព្រះមេត្តាប្រោស គ្រានោះ ភិក្ខុនោះ ចូលទៅរកពួកភិក្ខុ ដែលជាមិត្តគ្រាន់តែឃើញគ្នា និងមិត្តដ៏មាំមួន ហើយនិយាយពាក្យនេះថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ខ្ញុំជាភិក្ខុដែលមិនត្រូវអាបត្តិ ជាភិក្ខុឥតត្រូវអាបត្តិ (អ្វីទេ) ខ្ញុំជាភិក្ខុដែលសង្ឃ មិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តខ្ញុំ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមអស់លោក មកជាបក្ខពួកនឹងខ្ញុំតាមធម៌ តាមវិន័យ សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនោះ ក៏បានភិក្ខុដែលជាមិត្តគ្រាន់តែឃើញគ្នា និងជាមិត្តដ៏មាំមួន មកជាបក្ខពួកឡើង មិនតែប៉ុណ្ណោះ ភិក្ខុនោះ បានបញ្ជូនបម្រើ ទៅក្នុងសំណាក់ពួកភិក្ខុ ដែលជាមិត្តគ្រាន់តែឃើញគ្នា និងជាមិត្តដ៏មាំមួន ដែលនៅក្នុងជនបទថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ខ្ញុំជាភិក្ខុដែលមិនត្រូវអាបត្តិ ជាភិក្ខុឥតត្រូវអាបត្តិ (អ្វីទេ) ខ្ញុំជាភិក្ខុ ដែលសង្ឃ មិនគួរលើកវត្ត ជាភិក្ខុដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តខ្ញុំ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ សូមអស់លោកដ៏មានអាយុ មកជាបក្ខពួកនឹងខ្ញុំតាមធម៌ តាមវិន័យ សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនោះ ក៏បានភិក្ខុ ដែលជាមិត្តគ្រាន់តែឃើញគ្នា និងជាមិត្តដ៏មាំមួន ដែលនៅក្នុងជនបទ មកជាបក្ខពួកឡើង សូមទ្រង់ព្រះមេត្តាប្រោស វេលានោះ ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្តនោះ បានចូលទៅរកពួកភិក្ខុអ្នកលើកវត្ត លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងពួកភិក្ខុអ្នកលើកវត្តថា នែអាវុសោ នេះជាអនាបត្តិ នេះមិនមែនជាអាបត្តិទេ ភិក្ខុនេះ មិនត្រូវអាបត្តិ ភិក្ខុនេះ ឥតត្រូវអាបត្តិ (អ្វីទេ) ភិក្ខុនេះ សង្ឃមិនគួរលើកវត្ត ភិក្ខុនេះ សង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តភិក្ខុនេះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកំរើក ជាកម្មមិនគួរដល់ហេតុ សូមទ្រង់ព្រះមេត្តាប្រោស កាលបើភិក្ខុទាំងនោះ និយាយយ៉ាងនេះហើយ ឯពួកភិក្ខុអ្នកលើកវត្ត ក៏និយាយពាក្យនេះ នឹងពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្ត យ៉ាងនេះថា នែអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ភិក្ខុនេះ ត្រូវអាបត្តិហើយ ភិក្ខុនេះ មិនមែនជាមិនត្រូវអាបត្តិទេ ភិក្ខុនេះ សង្ឃគួរលើកវត្តហើយ ភិក្ខុនេះ មិនមែនជាភិក្ខុ ដែលសង្ឃលើកវត្តមិនបានទេ សង្ឃបានលើកវត្តភិក្ខុនេះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុហើយ បពិត្រលោកដ៏មានអាយុទាំងឡាយ អស់លោកកុំប្រព្រឹត្តតាម កុំតាមចោមរោមភិក្ខុ ដែល

សង្ឃបានលើកវត្តនេះឡើយ សូមទ្រង់ព្រះមេត្តាប្រោស ក៏ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្តនោះ កាលបើពួកភិក្ខុ អ្នកលើកវត្ត និយាយយ៉ាងនេះហើយ ក៏នៅតែប្រព្រឹត្តតាម នៅតែតាមចោមរោមភិក្ខុ ដែលសង្ឃបានលើកវត្តនោះដដែល។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា ភិក្ខុសង្ឃបែកគ្នាហើយ ភិក្ខុសង្ឃបែកគ្នាហើយ ទើបទ្រង់ក្រោកចាកអាសនៈ ហើយយាងចូលទៅរកពួកភិក្ខុអ្នកលើកវត្ត លុះយាងចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈ ដែលគេរៀបចំក្រាលថ្វាយ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់រួចហើយ ក៏មានព្រះពុទ្ធដីកា នឹងពួកភិក្ខុអ្នកលើកវត្ត យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំសំគាល់ភិក្ខុ ដែលសង្ឃគប្បីលើកវត្ត ព្រោះហេតុណាមួយថា ការនេះប្រាកដដល់យើងហើយ ការនេះប្រាកដដល់យើងហើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ។ ភិក្ខុនោះ យល់ឃើញអាបត្តិនោះថា ជាអនាបត្តិ ឯពួកភិក្ខុដទៃ យល់ឃើញអាបត្តិនោះថា ជាអាបត្តិមែន។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ ស្គាល់ភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះ ជាពហុស្សូត។បេ។ មានសេចក្តីស្រឡាញ់ក្នុងសិក្ខា បើយើងនឹងលើកវត្តភិក្ខុនេះ ព្រោះមិនឃើញអាបត្តិ យើងនឹងមិនធ្វើឧបោសថជាមួយនឹងភិក្ខុនេះ យើងវៀរលែងភិក្ខុនេះចេញ ទើបធ្វើឧបោសថ (នោះ) ការបង្កហេតុ ការឈ្លោះ ការប្រកាន់ផ្សេងៗ សេចក្តីវិវាទ សេចក្តីបែកធ្លាយនៃសង្ឃ សេចក្តីប្រេះឆានៃសង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ មុខជានឹងមានដល់សង្ឃ ព្រោះការលើកវត្តភិក្ខុនោះជាហេតុមិនខាន។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលមានចិត្តធ្ងន់ ក្នុងការបំបែកសង្ឃ មិនគួរនឹងលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសាសនានេះ មានភិក្ខុត្រូវអាបត្តិហើយ។ ភិក្ខុនោះ យល់ឃើញអាបត្តិនោះថា ជាអនាបត្តិ ឯពួកភិក្ខុដទៃ យល់ឃើញអាបត្តិនោះថា ជាអាបត្តិ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ ស្គាល់ភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុនេះ ជាពហុស្សូត។បេ។ មានសេចក្តីស្រឡាញ់ក្នុងសិក្ខា បើយើងនឹងលើកវត្តភិក្ខុនេះ ព្រោះមិនឃើញនូវអាបត្តិហើយ យើងមុខជាមិនបវារណា ជាមួយនឹងភិក្ខុនេះ តែយើងវៀរលែងភិក្ខុនេះចេញ ហើយបវារណា យើងមុខជានឹងមិនធ្វើសង្ឃកម្ម ជាមួយនឹងភិក្ខុនេះដែរ តែយើងវៀរលែងភិក្ខុនេះចេញ ហើយធ្វើសង្ឃកម្ម យើងមុខជានឹងមិនអង្គុយលើអាសនៈ ជាមួយនឹងភិក្ខុនេះដែរ តែយើងវៀរលែងភិក្ខុនេះចេញ ហើយអង្គុយលើអាសនៈ យើងមុខជានឹងមិនអង្គុយនៅក្នុងទីឆាន់បបរ ជាមួយនឹងភិក្ខុនេះដែរ តែយើងវៀរលែងភិក្ខុនេះចេញ ហើយអង្គុយនៅក្នុងទីឆាន់បបរ យើងមុខជានឹងមិនអង្គុយក្នុងរោងភត្ត ជាមួយនឹងភិក្ខុនេះដែរ តែយើងវៀរលែងភិក្ខុនេះចេញ ហើយអង្គុយក្នុងរោងភត្ត យើងមុខជានឹងមិននៅក្នុងទីដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុនេះដែរ តែយើងវៀរលែងភិក្ខុនេះចេញ ហើយនៅក្នុងទីដែលមានដម្បូលមួយ យើងមុខជានឹងមិនធ្វើអភិវាទនកម្ម[34] បច្ចុដ្ឋានកម្ម[35] អញ្ជលិកម្ម[36] និងសាមីចិកម្ម[37] តាមលំដាប់ចាស់ ជាមួយនឹងភិក្ខុនេះដែរ តែយើងវៀរលែងភិក្ខុនេះចេញ ហើយធ្វើអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម និងសាមីចិកម្ម តាមលំដាប់ចាស់ខ្ចី (នោះ) ការបង្កហេតុ ការឈ្លោះ ការប្រកាន់ផ្សេងៗ សេចក្តីវិវាទ សេចក្តីបែកធ្លាយនៃសង្ឃ សេចក្តីប្រេះឆានៃសង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ មុខជានឹងមានដល់សង្ឃ ព្រោះការលើកវត្តភិក្ខុនោះជាហេតុមិនខាន។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលមានចិត្តធ្ងន់ ក្នុងការបំបែកសង្ឃ មិនគួរនឹងលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិទេ។ គ្រានោះ ព្រះដ៏មានព្រះភាគ បានសំដែងសេចក្តីនុ៎ះ ដល់ពួកឧក្ខេបកភិក្ខុរួចហើយ ក៏ទ្រង់ក្រោកចាកអាសនៈ ហើយយាងចូលទៅរកពួក ឧក្ខិត្តានុវត្តកភិក្ខុ លុះយាងចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលគេរៀបចំថ្វាយ។ លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ ក៏មានព្រះពុទ្ធដីកាទៅនឹងពួក ឧក្ខិត្តានុវត្តកភិក្ខុ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវអាបត្តិហើយ កុំសំគាល់អាបត្តិថា ខ្លួនមិនត្រូវសំដែង ដោយគិតថា យើងមិនត្រូវអាបត្តិទេ យើងមិនត្រូវអាបត្តិទេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ។ ភិក្ខុនោះ យល់ឃើញអាបត្តិនោះ ថាជាអនាបត្តិ តែពួកភិក្ខុដទៃ យល់ឃើញអាបត្តិនោះថា ជាអាបត្តិមែន។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះ ស្គាល់ភិក្ខុទាំងនោះ យ៉ាងនេះថា អស់លោកដ៏មានអាយុនេះ ជាពហុស្សូត។បេ។ មានការប្រាថ្នាក្នុងសិក្ខា មិនគួរនឹងលុះអគតិ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីវង្វេង សេចក្តីខ្លាច ព្រោះហេតុអាត្មាអញ ឬព្រោះហេតុពួកបុគ្គលដទៃឡើយ បើភិក្ខុទាំងនេះ នឹងលើកវត្តអាត្មាអញ ព្រោះមិនឃើញអាបត្តិហើយ មុខជានឹងមិនធ្វើឧបោសថជាមួយនឹងអាត្មាអញទេ តែភិក្ខុទាំងនោះ វៀរលែងអាត្មាអញ ហើយធ្វើឧបោសថ (នោះ) ការបង្កហេតុ ការឈ្លោះ ការប្រកាន់ផ្សេងៗ សេចក្តីវិវាទ សេចក្តីបែកធ្លាយនៃសង្ឃ សេចក្តីប្រេះឆានៃសង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ មុខជានឹងមានដល់សង្ឃ ព្រោះការលើកវត្តអាត្មាអញនោះ ជាហេតុមិនខាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានចិត្តធ្ងន់ ក្នុងការបំបែកសង្ឃ គួរតែសំដែងអាបត្តិនោះចេញ តាមសេចក្តីជឿពាក្យ របស់ភិក្ខុដទៃ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ។ ភិក្ខុនោះ យល់ឃើញអាបត្តិនោះថា ជាអនាបត្តិ តែពួកភិក្ខុដទៃ យល់ឃើញអាបត្តិនោះថា ជាអាបត្តិមែន។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះ ស្គាល់ភិក្ខុទាំងនោះ យ៉ាងនេះថា លោកដ៏មានអាយុទាំងនេះ ជាពហុស្សូត។បេ។ មានការប្រាថ្នាក្នុងសិក្ខា មិនគួរនឹងលុះអគតិ ព្រោះសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីវង្វេង សេចក្តីខ្លាច ព្រោះហេតុអាត្មាអញ ឬព្រោះហេតុពួកភិក្ខុដទៃឡើយ បើភិក្ខុទាំងនេះ នឹងលើកវត្តអាត្មាអញ ព្រោះមិនឃើញអាបត្តិហើយ មុខជានឹងមិនបវារណា ជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញ ហើយបវារណា មុខជានឹងមិនធ្វើសង្ឃកម្ម ជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញ ហើយធ្វើសង្ឃកម្ម មុខជានឹងមិនអង្គុយលើអាសនៈ ជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញ ហើយអង្គុយលើអាសនៈ មុខជានឹងមិនអង្គុយក្នុងទីឆាន់បបរ ជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញ ហើយអង្គុយក្នុងទីឆាន់បបរ មុខជានឹងមិនអង្គុយក្នុងរោងភត្ត ជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញ ហើយអង្គុយក្នុងរោងភត្ត មុខជានឹងមិននៅក្នុងទីមានដម្បូលមួយ ជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញ ហើយនៅក្នុងទីមានដម្បូលមួយ មុខជានឹងមិនធ្វើអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម និងសាមីចិកម្ម តាមលំដាប់ចាស់ខ្ចី ជាមួយនឹងអាត្មាអញដែរ តែវៀរចាកអាត្មាអញ ហើយធ្វើអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម និងសាមីចិកម្ម តាមលំដាប់ចាស់ខ្ចី (នោះ) សេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីប្រកាន់ផ្សេងៗ សេចក្តីវិវាទ សេចក្តីបែកធ្លាយនៃសង្ឃ សេចក្តីប្រេះឆានៃសង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ព្រោះហេតុតែអាត្មាអញនោះ មុខជានឹងមានដល់សង្ឃមិនខាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាអ្នកមានចិត្តធ្ងន់ ក្នុងការបំបែកសង្ឃហើយ ត្រូវតែសំដែងអាបត្តិនោះចេញ តាមសេចក្តីជឿពាក្យ របស់ភិក្ខុដទៃ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងសេចក្តីនុ៎ះ ដល់ពួកភិក្ខុ អ្នកប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្តហើយ ក៏ទ្រង់ក្រោកចាកអាសនៈ យាងចេញទៅ។

[១៤៦] សម័យនោះឯង ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្ត ក៏នៅតែធ្វើឧបោសថ ធ្វើសង្ឃកម្ម ខាងក្នុងសីមានោះដដែល។ ចំណែកខាងពួកភិក្ខុអ្នកលើកវត្ត ក៏ទៅធ្វើឧបោសថ ធ្វើសង្ឃកម្ម ក្រៅសីមាវិញ។ វេលានោះ មានភិក្ខុអ្នកលើកវត្ត១រូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ លុះភិក្ខុនោះ អង្គុយនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្តនោះ ធ្វើឧបោសថ ធ្វើសង្ឃកម្ម ខាងក្នុងសីមានោះដដែល សូមទ្រង់ព្រះមេត្តាប្រោស ចំណែកខាងយើងខ្ញុំព្រះអង្គ ដែលជា ឧក្ខេបកភិក្ខុ ក៏ទៅធ្វើឧបោសថ

ធ្វើសង្ឃកម្ម ក្រៅសីមាវិញហើយ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុ ដែលសង្ឃលើកវត្តទាំងនោះ នឹងធ្វើឧបោសថ ធ្វើសង្ឃកម្ម ខាងក្នុងសីមានោះដដែល ត្រូវដូចជាញត្តិ និងអនុស្សាវនា ដែលតថាគតបានបញ្ញត្តហើយ កម្មរបស់ភិក្ខុទាំងនោះ ក៏ឈ្មោះថា ប្រកបដោយធម៌ ឥតមានកំរើក ហើយជាកម្មសមគួរដល់ហេតុ។ ម្នាលភិក្ខុ បើអស់អ្នកជាឧក្ខេបកភិក្ខុ (ភិក្ខុអ្នកលើកវត្ត) នឹងធ្វើឧបោសថ ធ្វើសង្ឃកម្ម ខាងក្នុងសីមានោះដដែល ត្រូវដូចជាញត្តិ និងអនុស្សាវនា ដែលតថាគត បានបញ្ញត្តហើយ កម្មរបស់អ្នកទាំងឡាយនោះសោត ក៏ឈ្មោះថា ប្រកបដោយធម៌ ឥតមានកំរើក ហើយជាកម្មសមគួរដល់ហេតុ។ ហេតុអ្វី បានជាតថាគត ពោលយ៉ាងនេះ។ ម្នាលភិក្ខុ ព្រោះភិក្ខុទាំងនោះ មានសំវាសផ្សេងៗ អំពីអ្នកទាំងឡាយ ចំណែកខាងអ្នកទាំងឡាយ ក៏មានសំវាសផ្សេងគ្នា អំពីភិក្ខុទាំងនោះដែរ។ ម្នាលភិក្ខុ ឯភូមិរបស់ភិក្ខុ មានសំវាសផ្សេងគ្នានេះ មាន២យ៉ាង គឺ ភិក្ខុធ្វើខ្លួនឲ្យមានសំវាសផ្សេងគ្នាដោយខ្លួនឯង១ សង្ឃព្រមព្រៀងគ្នា លើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិ ឬមិនបានសំដែងអាបត្តិ ឬមិនបានលះបង់ទិដ្ឋិអាក្រក់ចេញ១ ម្នាលភិក្ខុ ភូមិរបស់ភិក្ខុដែលមានសំវាសផ្សេងគ្នា មាន២យ៉ាងនេះឯង។ ម្នាលភិក្ខុ ភូមិរបស់ភិក្ខុដែលមានសំវាសស្មើគ្នានេះ មាន២យ៉ាងគឺ ភិក្ខុធ្វើខ្លួនឲ្យមានសំវាសស្មើគ្នា ដោយខ្លួនឯង១ សង្ឃព្រមព្រៀងគ្នា ធ្វើឱសារណាកម្ម (លើកលែងទោស) ភិក្ខុដែលសង្ឃបានលើកវត្តហើយ ព្រោះមិនឃើញអាបត្តិ ឬមិនសំដែងអាបត្តិ ឬមិនបានលះបង់ទិដ្ឋិអាក្រក់ចេញនោះ១ ម្នាលភិក្ខុ ភូមិរបស់ភិក្ខុ ដែលមានសំវាសស្មើគ្នា មាន២យ៉ាងនេះឯង។

[១៤៧] សម័យនោះឯង ភិក្ខុទាំងឡាយកើតសេចក្តីបង្កហេតុ ឈ្លោះទាស់ទែងគ្នា សំដែងកាយកម្ម និងវចីកម្ម ធ្វើអាការប៉ះពាល់ដោយដៃ មិនសមគួរដល់គ្នានឹងគ្នា ក្នុងរោងភត្ត ក្នុងចន្លោះផ្ទះ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្ត មិនសមបើនឹងកើតសេចក្តីបង្កហេតុ ឈ្លោះទាស់ទែងគ្នា សំដែងកាយកម្ម និងវចីកម្ម ធ្វើអាការប៉ះពាល់ដោយដៃ មិនសមគួរដល់គ្នានឹងគ្នា ក្នុងរោងភត្ត ក្នុងចន្លោះផ្ទះសោះ។ ភិក្ខុទាំងឡាយ ក៏បានឮសំដីមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយ មិនសមបើនឹងកើតសេចក្តីបង្កហេតុ។បេ។ ធ្វើអាការប៉ះពាល់ដោយដៃ ក្នុងរោងភត្ត ក្នុងចន្លោះផ្ទះសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា មានពួកភិក្ខុ កើតសេចក្តីបង្កហេតុ។បេ។ ធ្វើអាការប៉ះពាល់ដោយដៃ ក្នុងរោងភត្ត ក្នុងចន្លោះផ្ទះ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា ការនោះពិតមែនព្រះអង្គ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោស។បេ។ លុះបន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ កំពុងធ្វើកិច្ចមិនប្រកបដោយធម៌ កំពុងតែពោលវាចាមិនជាទីរីករាយរកគ្នា អ្នកទាំងឡាយ មិនគប្បីអង្គុយលើអាសនៈ ដោយគិតថា យើងសំដែងនូវកាយកម្ម និងវចីកម្ម ធ្វើអាការប៉ះពាល់ ដោយដៃមិនសមគួរដល់គ្នានឹងគ្នា ដោយហេតុមានប្រមាណប៉ុណ្ណេះទេ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ កំពុងធ្វើកិច្ចប្រកបដោយធម៌ កំពុងតែពោលវាចា ជាទីរីករាយរកគ្នា អ្នកទាំងឡាយ គួរអង្គុយលើអាសនៈឃ្លាតពីគ្នា។

[១៤៨] សម័យនោះឯង ភិក្ខុទាំងឡាយកើតសេចក្តីបង្កហេតុ ឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានឹងគ្នា ដោយលំពែងមាត់ ក្នុងកណ្តាលជំនុំសង្ឃ។ ភិក្ខុទាំងនោះ មិនអាចនឹងរម្ងាប់អធិករណ៍នេះបានឡើយ។ គ្រានោះ មានភិក្ខុ១រូប បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ។ លុះភិក្ខុនោះ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសេចក្តីព្រះមានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះ មានពួកភិក្ខុ កើតសេចក្តីបង្កហេតុ ឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានឹងគ្នា ដោយលំពែងមាត់ ក្នុងកណ្តាលជំនុំសង្ឃ ភិក្ខុទាំងនោះ មិនអាចនឹងរម្ងាប់អធិករណ៍នោះបានឡើយ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគយាងទៅជួបនឹងភិក្ខុទាំងនោះ ដោយសេចក្តីអនុគ្រោះ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលនិមន្ត ដោយភាវៈស្ងៀមនៅ។ វេលានោះ ព្រះមានព្រះភាគ ក៏យាងទៅជួបនឹងភិក្ខុទាំងនោះ លុះយាងចូលទៅដល់ហើយ គង់លើអាសនៈ ដែលគេរៀបចំថ្វាយ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ហើយ ក៏ត្រាស់ទៅនឹងភិក្ខុទាំងនោះ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយ កុំធ្វើសេចក្តីបង្កហេតុ កុំធ្វើសេចក្តីឈ្លោះគ្នា កុំធ្វើសេចក្តីប្រកាន់ផ្សេងៗគ្នា កុំធ្វើសេចក្តីវិវាទគ្នា។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ក៏ស្រាប់តែមានភិក្ខុ១រូប ជាអធម្មវាទី ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ជាម្ចាស់ធម៌ ទ្រង់ឈប់នៅចុះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបតែនឹងធម៌ ដែលជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នរឿយៗចុះ ឯយើងខ្ញុំមុខជានឹងប្រាកដ ដោយសេចក្តីបង្កហេតុ ដោយសេចក្តីឈ្លោះគ្នា ដោយសេចក្តីប្រកាន់ផ្សេងៗគ្នា ដោយសេចក្តីវិវាទគ្នានេះមិនខាន។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះបន្ទូលនេះ នឹងភិក្ខុទាំងនោះ ជាគំរប់ពីរដងទៀតថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយ កុំធ្វើសេចក្តីបង្កហេតុ កុំធ្វើសេចក្តីឈ្លោះគ្នា កុំធ្វើសេចក្តីប្រកាន់ផ្សេងៗគ្នា កុំធ្វើសេចក្តីវិវាទគ្នា។ ភិក្ខុជាអធម្មវាទីនោះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ជាគំរប់ពីរដងទៀតយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ ជាម្ចាស់ធម៌ ទ្រង់ឈប់នៅចុះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបតែនឹងធម៌ ដែលជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នរឿយៗចុះ ឯយើងខ្ញុំ មុខជានឹងប្រាកដ ដោយសេចក្តីបង្កហេតុ ដោយសេចក្តីឈ្លោះគ្នា ដោយសេចក្តីប្រកាន់ផ្សេងៗគ្នា ដោយសេចក្តីវិវាទគ្នានេះមិនខានទេ។

## ២៧២. ទីឃាវុវត្ថុ

CS vin.mv.10.02 | ភាគ ទី៨

### រឿងទីឃាវុកុមារ

[១៤៩] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ កាលពីដើម មានស្តេចក្នុងដែនកាសី ក្រុងពារាណសី ទ្រង់ព្រះនាមព្រហ្មទត្ត ជាស្តេចស្តុកស្តម្ភមាំមួន មានទ្រព្យច្រើន មានសម្បត្តិច្រើន មានពលច្រើន មានពាហនៈច្រើន មានដែនច្រើន មានឃ្លាំង និងជង្រុកដ៏បរិបូណ៌។ មានស្តេចក្នុងដែនកោសល ឈ្មោះទីឃីតិ ជាស្តេចកំសត់ មានទ្រព្យតិច មានសម្បត្តិតិច មានពលតិច មានពាហនៈតិច មានដែនតិច មានឃ្លាំង និងជង្រុកមិនបានបរិបូណ៌។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត បានរៀបចំពួកសេនាប្រកបដោយអង្គ៤ លើកចេញទៅច្បាំង នឹងស្តេចទីឃីតិកោសល។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ បានឮដំណឹងថា ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត រៀបចំពួកសេនា ប្រកបដោយអង្គ៤ លើកចេញមកច្បាំងនឹងអាត្មាអញហើយ។ ម្នាលភិក្ខុ

ទាំងឡាយ គ្រានោះ ស្តេចដែនកោសល ព្រះនាមទីឃីតិ ទ្រង់ព្រះតម្រិះយ៉ាងនេះថា ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ជាស្តេចស្តុកស្តម្ភមាំមួន មានទ្រព្យច្រើន មានសម្បត្តិច្រើន មានពលច្រើន មានពាហនៈច្រើន មានដែនច្រើន មានឃ្លាំង និងជង្រុកដ៏បរិបូណ៌ ឯអាត្មាអញសោត ក៏ជាស្តេចកំសត់ មានទ្រព្យតិច មានសម្បត្តិតិច មានពលតិច មានពាហនៈតិច មានដែនតិច មានឃ្លាំង និងជង្រុកមិនបរិបូណ៌ អាត្មាអញ នឹងអាចដើម្បីតទល់ នឹងស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត សូម្បីតែម្តង ក៏មិនបាន បើដូច្នោះ គួរតែអាត្មាអញ លបរត់ចេញ ទៅពីក្រុងជាមុន ឲ្យហើយ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ក៏នាំមហេសី លបរត់ចេញទៅ ពីក្រុងជាមុន។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដណ្តើមយកពួកពល ពាហនៈ ជនបទ ឃ្លាំង ជង្រុក របស់ស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ហើយក៏គ្រប់គ្រងរក្សា។ ម្នាលភិក្ខុទាំងឡាយ ឯស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី យាងចេញទៅឯក្រុង ពារាណសី ក៏បានទៅដល់ក្រុងពារាណសី ដោយលំដាប់។ ម្នាលភិក្ខុទាំងឡាយ បានឮមកថា ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី ក្លែងភេទរបស់ខ្លួន មិនឲ្យបុគ្គលដទៃស្គាល់បាន ទ្រង់ស្លៀកដណ្តប់ជា បរិព្វាជក ហើយក៏នៅអាស្រ័យក្នុងផ្ទះស្មូនឆ្នាំង ក្នុងឱកាសមួយ ជាទីបំផុត ក្រុងពារាណសីនោះឯង។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសី របស់ស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ មិនយូរប៉ុន្មាន ក៏ទ្រង់គភ៌។ ឯព្រះមហេសីនោះ ក៏កើតមានចំណង់ មានសភាពយ៉ាងនេះ គឺព្រះនាង ចង់ឃើញពួកសេនា ប្រកបដោយអង្គ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរនៅក្នុងទី មានផែនដីរាបស្អាត ក្នុងវេលា ដែលព្រះអាទិត្យរះឡើង១ ចង់សោយទឹក ដែលគេលាងព្រះខាន់១។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មហេសី របស់ស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ក៏បានក្រាបទូលស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ យ៉ាងនេះថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មានគភ៌ហើយ ឯខ្ញុំម្ចាស់ កើតមានចំណង់ មានសភាពយ៉ាងនេះ គឺខ្ញុំម្ចាស់ ចង់ឃើញសេនា ប្រកបដោយអង្គ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរនៅ ក្នុងទីមានផែនដីរាបស្អាត ក្នុងវេលា ដែលព្រះអាទិត្យរះឡើង១ ចង់ផឹកទឹក ដែលគេលាងព្រះខាន់១។ ស្តេចនោះ ទ្រង់ត្រាស់តបទៅវិញថា នែនាងទេវី បើយើងជាអ្នកកំសត់ម្ល៉េះ តើនឹងទៅរកសេនា ប្រកបដោយអង្គ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរ នៅក្នុងទីមានផែនដីរាបស្អាត និងទឹក ដែលគេលាងព្រះខាន់បានមកពីណា។ ព្រះនាងទេវីទូលតបថា បពិត្រព្រះសម្មតិទេព បើខ្ញុំម្ចាស់មិនបានគ្រឿងទាំងនោះទេ ខ្ញុំម្ចាស់មុខជានឹងស្លាប់មិនខាន។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង មានព្រាហ្មណ៍ ជាបុរោហិត របស់ស្តេចក្នុង ដែនកាសី ព្រះនាមព្រហ្មទត្ត ជាសំឡាញ់នឹងស្តេច ក្នុងដែនកោស ឈ្មោះទីឃីតិ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកោស ព្រះនាមទីឃីតិ យាងចូលទៅរកព្រាហ្មណ៍ ជាបុរោហិតរបស់ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត លុះចូលទៅដល់ហើយ ទ្រង់ត្រាស់ទៅនឹងព្រាហ្មណ៍ ជាបុរោហិត របស់ស្តេច ក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត យ៉ាងនេះថា នែសំឡាញ់ ឥឡូវ ស្រីជាសំឡាញ់របស់អ្នក មានគភ៌ហើយ ឯចំណង់របស់នាងនោះ កើតឡើងបែបនេះ គឺនាងនោះ ចង់តែឃើញពួកសេនា ប្រកបដោយអង្គ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរនៅក្នុងទី មានផែនដីរាបស្អាត ក្នុងវេលាព្រះអាទិត្យរះឡើង និងចង់ផឹកទឹក ដែលគេលាងព្រះខាន់។ ឯព្រាហ្មណ៍បុរោហិត ទូលតបវិញថា សូមទ្រង់ព្រះមេត្តាប្រោស បើដូច្នោះ យើងខ្ញុំ ចង់ឃើញព្រះនាងទេវីផង។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសី របស់ស្តេចក្នុងដែនកោស ព្រះនាមទីឃីតិ ក៏បានចូលទៅរកព្រាហ្មណ៍ ជាបុរោហិតរបស់ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត។ ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍ ជាបុរោហិតរបស់ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត បានឃើញមហេសី របស់ស្តេចក្នុងដែនកោស ព្រះនាមទីឃីតិ យាងមកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រោកចាកអាសនៈ ហើយធ្វើសំពត់សម្រាប់បង្ក លើស្មាម្ខាង រួចប្រណម្យអញ្ជលីឡើង ចំពោះមហេសី របស់ស្តេចក្នុងដែនកោស ព្រះនាមទីឃីតិ ហើយបន្លឺឡើងនូវឧទាន ៣ដងថា អើហ្ន៎ ស្តេចក្នុងដែន កោសល បានមកឋិតនៅ ក្នុងផ្ទៃហើយ អើហ្ន៎ ស្តេចក្នុងដែនកោសល បានមកឋិតនៅក្នុងផ្ទៃហើយ បពិត្រព្រះនាងទេវី ព្រះនាងកុំព្រួយព្រះទ័យឡើយ លុះវេលាព្រះអាទិ្យរះឡើងហើយ ព្រះនាងមុខជានឹងបានឃើញពួកសេនា ប្រកបដោយអង្គ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរនៅក្នុងទី មានផែនដីរាបស្អាតផង បានសោយទឹក ដែលគេលាងព្រះខាន់ផង មិនខានឡើយ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ព្រាហ្មណ៍ជាបុរោហិត របស់ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត បានចូលទៅគាល់ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត លុះចូលទៅដល់ហើយ ក៏ក្រាបទូលស្តេច ក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស និមិត្តទាំងឡាយ ក៏ប្រាកដដូច្នេះ កាលបើព្រះអាទិត្យរះឡើង ក្នុងវេលាថ្ងៃស្អែកហើយ សូមឲ្យពួកសេនាប្រកបដោយអង្គ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរ នៅលើទីមានផែនដីរាបល្អផង សូមឲ្យជនទាំងឡាយ លាងនូវព្រះខាន់ផង។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ក៏បានត្រាស់បង្គាប់ ទៅពួកមនុស្សថា នែនាយទាំងឡាយ ព្រាហ្មណ៍ជាបុរោហិត បានបង្គាប់យ៉ាងណា ក៏អស់អ្នករាល់គ្នា ចូរធ្វើយ៉ាងនោះកុំខាន។ ម្នាលភិក្ខុទាំងឡាយ កាលបើព្រះអាទិត្យរះឡើងហើយ ឯមហេសី របស់ស្តេចក្នុងដែនកោស ព្រះនាមទីឃីតិ ក៏បានឃើញពួកសេនា ប្រកបដោយអង្គ៤ ស្អិតស្អាងគ្រឿងប្រដាប់ ពាក់អាវក្រោះ ហើយឈរនៅលើទីមានផែនដីរាបល្អផង បានសោយទឹក ដែលគេលាងព្រះខាន់ផង។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មហេសី របស់ស្តេចក្នុងដែនកោស ព្រះនាមទីឃីតិ លុះមានគភ៌ចាស់ហើយ ក៏ទ្រង់ប្រសូតព្រះរាជបុត្រមក។ ព្រះមាតាបិតា ទ្រង់ប្រទាននាម កុមារនោះថា ទីឃាវុ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារ មិនយូរប៉ុន្មាន ក៏បានដល់នូវការដឹងក្តី។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកោស ព្រះនាមទីឃីតិ ទ្រង់រិះគិតយ៉ាងនេះថា ស្តេចក្នុងដែនកាសី ឈ្មោះព្រហ្មទត្តនេះ បានធ្វើសេចក្តីវិនាស ដល់យើងជាច្រើន ទាំងពួកពលផង ពាហនៈផង ជនបទផង ឃ្លាំងផង ជង្រុកផង របស់យើង ស្តេចនេះ ក៏រឹបជាន់យកអស់ ប្រសិនបើស្តេចនេះ ជ្រាបដំណឹងយើងហើយ មុខជានឹងឲ្យមនុស្សសម្លាប់យើងទាំងបីនាក់ មិនខានឡើយ បើដូច្នោះហើយ គួរអាត្មាអញ ឲ្យទីឃាវុកុមារ ចេញទៅនៅក្រៅក្រុងវិញ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ស្តេចក្នុងដែនកោស ព្រះនាមទីឃីតិ ក៏បានឲ្យទីឃាវុកុមារ ចេញទៅនៅខាងក្រៅក្រុង។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារ កាលនៅខាងក្រៅក្រុង មិនយូរប៉ុន្មាន ក៏បានសិក្សា ចេះដឹងនូវសិល្បសាស្ត្រសព្វគ្រប់។

[១៥០] ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង នាយខ្មាន់ព្រះកេស របស់ស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ នៅអាស្រ័យ ក្នុងសំណាក់ស្តេច ក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត។ ម្នាលភិក្ខុទាំងឡាយ នាយខ្មាន់ព្រះកេស របស់ស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ បានឃើញស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី ធ្វើភេទរបស់ខ្លួន មិនឲ្យបុគ្គលដទៃស្គាល់បាន ទ្រង់ស្លៀកដណ្តប់ ជាបរិព្វាជក ហើយនៅអាស្រ័យ ក្នុងផ្ទះស្មូនឆ្នាំង ក្នុងទីឱកាសមួយ ជាទីបំផុត ក្រុងពារាណសី លុះបានឃើញហើយ ក៏បានចូលទៅគាល់ស្តេច ក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត លុះចូលទៅដល់ហើយ ក៏ក្រាបទូលស្តេច ក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី ធ្វើភេទរបស់ខ្លួន មិនឲ្យបុគ្គលដទៃស្គាល់បាន ទ្រង់ស្លៀកដណ្តប់ ជាបរិព្វាជក ហើយនៅអាស្រ័យ ក្នុងផ្ទះស្មូនឆ្នាំង ក្នុងទីឱកាស មួយជាទីបំផុត ក្រុងពារាណសី ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ក៏ទ្រង់បង្គាប់ ពួក

មនុស្សទាំងឡាយថា នែនាយទាំងឡាយ បើដូច្នោះ អ្នករាល់គ្នា ចូរទៅនាំយកស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសីមក។ ម្នាលភិក្ខុទាំងឡាយ ឯមនុស្សទាំងនោះ បានទទួលព្រះឱង្ការ របស់ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដោយពាក្យថា ព្រះករុណាវិសេស ព្រះអង្គ ហើយក៏ទៅនាំយកស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសីមក។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់បង្គាប់ ទៅពួកមនុស្សទាំងឡាយថា នែនាយទាំងឡាយ បើដូច្នោះ អ្នករាល់គ្នា ចូរនាំគ្នាចាប់ស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី ចងឲ្យមានដើមដៃ ទៅខាងក្រោយ[38] ឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងចេញ រួច (ត្រូវទូង) ស្គរ ដែលមានសំឡេងឮខ្លាំង ហើយនាំបណ្តើរជុំវិញសព្វច្រក សព្វផ្លូវត្រឡែងកែង រួចនាំចេញតាមទ្វារខាងត្បូង ហើយកាប់ជា៤កំណាត់ កប់ទៅក្នុងរណ្តៅគ្រប់ទិសទាំង៤ ជាខាងត្បូងនៃក្រុង។ ម្នាលភិក្ខុទាំងឡាយ ឯមនុស្សទាំងនោះ បានទទួលព្រះឱង្ការស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដោយពាក្យថា ព្រះករុណាវិសេស ហើយក៏នាំគ្នាចាប់ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី ឲ្យមានដើមដៃទៅខាងក្រោយ ឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងចេញហើយ (ទូង) ស្គរ ដែលមានសំឡេងឮខ្លាំង រួចនាំបណ្តើរជុំវិញសព្វច្រកសព្វផ្លូវត្រឡែងកែង។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារ មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញ ខានឃើញមាតាបិតាយូរណាស់ហើយ បើដូច្នោះ គួរតែអាត្មាអញ ទៅមើលមាតាបិតាបានម្តងសិន។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារ ចូលទៅក្រុងពារាណសីហើយ ក៏បានឃើញមាតាបិតា ដែលគេកំពុងតែចងស្លាបសេក ជាប់ដោយខ្សែដ៏មាំ កោរក្បាលឲ្យរលីងចេញ (ទូង)ស្គរ ដែលមានសំឡេងឮខ្លាំង ហើយនាំបណ្តើរជុំវិញសព្វច្រកសព្វផ្លូវត្រឡែងកែង លុះឃើញហើយ ក៏ចូលទៅរកមាតាបិតា។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ ទ្រង់ទតទៅឃើញទីឃាវុកុមារ មកអំពីចម្ងាយ លុះឃើញហើយ ក៏មានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតា ពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ។ ម្នាលភិក្ខុទាំងឡាយ កាលបើស្តេចនោះ មានព្រះឱង្ការ យ៉ាងនេះហើយ ពួកមនុស្សទាំងនោះ ក៏ពោលពាក្យនេះ នឹងស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិថា ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិនេះឆ្កួត និយាយផ្តេសផ្តាសទេតើ នរណាឈ្មោះ ទីឃាវុ (ជាកូន) របស់ស្តេចនេះ ស្តេចនេះនិយាយទៅនឹងនរណា យ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតា ពៀរមិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ។ ស្តេចទីឃីតិនោះតបទៅវិញថា នែនាយ យើងមិនមែនឆ្កួត និយាយផ្តេសផ្តាសទេ បើនរណា ជាអ្នកប្រាជ្ញ អ្នកនោះទើបថ្លែងសេចក្តីបាន។ ម្នាលភិក្ខុទាំងឡាយ ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ មានព្រះឱង្ការទៅនឹងទីឃាវុកុមារ ជាគំរប់ពីរដងផង។បេ។ ម្នាលភិក្ខុទាំងឡាយ ស្តេចក្នុងដែនកោសល ព្រះនាមទីឃីតិ មានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ ជាគំរប់បីដងផង យ៉ាងនេះថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតា ពៀរ មិនដែលរម្ងាប់ ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរ តែងរម្ងាប់ ដោយការមិនចងពៀរ។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងនោះ ក៏បាននិយាយពាក្យនេះ នឹងស្តេចក្នុងដែនកោសល ព្រះនាម ទីឃីតិ ជាគំរប់បីដងទៀតថា ស្តេចក្នុងដែនកោសល ព្រះនាម ទីឃីតិនេះឆ្កួត និយាយផ្តេសផ្តាសទេតើ នរណាឈ្មោះទីឃាវុ (ជាកូន) របស់ស្តេចនេះ ស្តេចនេះនិយាយទៅនឹងនរណា យ៉ាងនេះថា នែទីឃាវុកូន អ្នកកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតា ពៀរ មិនដែលរម្ងាប់ ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរតែងរម្ងាប់ដោយការមិនចងពៀរ។ ស្តេចនោះ ទ្រង់តបទៅវិញថា នែនាយ យើងមិនមែនជាមនុស្សឆ្កួត និយាយផ្តេសផ្តាសទេ ប៉ុន្តែបើនរណា ជាអ្នកប្រាជ្ញ អ្នកនោះទើបថ្លែងសេចក្តីបាន។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មនុស្សទាំងនោះ ក៏នាំបណ្តើរស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រមទាំងមហេសី ទៅសព្វច្រក សព្វផ្លូវត្រឡែងកែង ហើយចេញទៅតាមទ្វារខាងត្បូង ហើយកាត់ខ្លួន ជា៤កំណាត់ រួចកប់ក្នុងរណ្តៅគ្រប់ទិសទាំង៤ ជាខាងត្បូង នៃព្រះនគរ ហើយទុកពួកពល (ឲ្យនៅថែទាំ) រួចថយចេញទៅ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារ ចូលទៅកាន់ក្រុងពារាណសី ហើយក៏នាំយកសុរាមកបំផឹកពួកពល (ទាំងនោះ)។ ពួកពលទាំងនោះស្រវឹងដួលដេកទៅកាលណា ទីឃាវុកុមារ ក៏ប្រមូលកំណាត់ឈើ ហើយលើកសរីរៈមាតាបិតា ដាក់លើជើងថ្ករ រួចបូជាភ្លើង ហើយផ្គងអញ្ជលី ធ្វើប្រទក្សិណជើងថ្ករ៣ជុំ។ ម្នាលភិក្ខុទាំងឡាយ ចួនជាពេលនោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់គង់នៅលើប្រាសាទដ៏ប្រសើរឰដ៏ខាងលើ។ ម្នាលភិក្ខុទាំងឡាយ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត បានទតឃើញទីឃាវុកុមារ កំពុងតែផ្គងអញ្ជលី ធ្វើប្រទក្សិណជើងថ្ករ៣ជុំ លុះឃើញហើយ ក៏ទ្រង់ត្រិះរិះយ៉ាងនេះថា មនុស្សនោះ ច្បាស់ជាញាតិ ឬជាសាលោហិត របស់ស្តេច ក្នុងដែនកោសល ព្រះនាមទីឃីតិហើយ ឱហ្ន៎ សេចក្តីវិនាស (ព្រោះបុរសនេះ គង់នឹងមាន) ដល់អាត្មាអញ មិនសមបើ គ្មាននរណាមួយ ប្រាប់អាត្មាអញសោះ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទីឃាវុកុមារ ទៅឯព្រៃ ហើយខ្សឹកខ្សួល ទួញយំអស់ចិត្ត រួចជូតទឹកភ្នែកហើយ ត្រឡប់ចូលទៅក្នុង ក្រុងពារាណសីវិញ ក៏ទៅឯរោងដំរី ទៀបព្រះរាជវាំង ហើយនិយាយពាក្យនេះ នឹងហ្មដំរីថា នែអ្នកហ្មដំរី ខ្ញុំចង់រៀនសិល្បៈ (អំពីអ្នក តើបានឬទេ)។ ឯហ្មដំរីនោះ និយាយតបថា នែនាយមាណព បើដូច្នោះ ចូរអ្នករៀនចុះ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារ ក្រោកឡើង ក្នុងបច្ចូសសម័យ នៃរាត្រី ក៏ស្រែកច្រៀង ដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត បានទ្រង់ព្រះសណ្តាប់ចម្រៀង និងពិណ ដែលទីឃាវុកុមារ ក្រោកឡើងក្នុងបច្ចូសសម័យ នៃរាត្រី ហើយច្រៀង ប្រកបដោយសំឡេងយ៉ាងពីរោះ ក្នុងរោងដំរី លុះទ្រង់ព្រះសណ្តាប់រួចហើយ ក៏ទ្រង់ត្រាស់សួរមនុស្សទាំងឡាយថា នែនាយ នរណាក្រោកឡើង ក្នុងបច្ចូសសម័យ នៃរាត្រី ក៏ច្រៀង ដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី។ មនុស្សទាំងនោះ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មាណព ជាកូនសិស្ស របស់ហ្មដំរីឯណោះ ក្រោកឡើង ក្នុងបច្ចូសសម័យ នៃរាត្រី ក៏ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី។ ស្តេចនោះ ទ្រង់ត្រាស់ថា នែនាយ បើដូច្នោះ អ្នកទាំងឡាយ ចូរនាំមាណពនោះមក។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងនោះ ទទួលស្តាប់ព្រះឱង្ការ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្តដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ទៅនាំ ទីឃាវុកុមារមក។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់មានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែនាយមាណព អ្នកឯងក្រោកឡើង ក្នុងបច្ចូសសម័យ នៃរាត្រី ក៏ច្រៀងដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង ក្នុងរោងដំរី មែនឬ។ ទីឃាវុកុមារ ក្រាបទូលថា ព្រះករុណាវិសេស។ ស្តេចនោះ ទ្រង់ត្រាស់ថា នែនាយមាណព បើដូច្នោះ ចូរអ្នកឯងច្រៀង ហើយដេញពិណ ឲ្យយើងស្តាប់មើល។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារ ទទួលស្តាប់ព្រះឱង្ការស្តេច ក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដោយពាក្យថា ព្រះករុណាវិសេស ហើយចង់ឲ្យស្តេចប្រោសប្រាណ ទើបស្រែកច្រៀង ដោយសំឡេងដ៏ពីរោះ ហើយដេញពិណផង។ ម្នាលភិក្ខុទាំងឡាយ ខណនោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត មានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែនាយមាណព ចូរអ្នកឯងនៅបម្រើយើងចុះ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារ ក៏ទទួលស្តាប់ព្រះឱង្ការស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដោយពាក្យថា ព្រះករុណាវិសេស។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារ ក៏បានក្រោកមុន ដេកក្រោយ និងទទួលស្តាប់បង្គាប់ការអ្វីៗ ប្រព្រឹត្ត គួរជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ ដល់ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត មិន

យូរប៉ុន្មាន ក៏បានតាំង ទីឃាវុកុមារ ក្នុងទីជាអ្នកស្និទ្ធស្នាលខាងក្នុង។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់មានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែនាយមាណព បើដូច្នោះ ចូរអ្នកទឹមរាជរថមក យើងនឹងទៅកាន់ទីប្រពាធម្រឹគ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារ ទទួលស្ដាប់ព្រះឱង្ការ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដោយពាក្យថា ព្រះករុណាវិសេស ហើយក៏រៀបទឹមរាជរថ រួចក្រាបទូលស្ដេច ក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឯរាជរថរបស់ព្រះអង្គ ខ្ញុំព្រះអង្គទឹមរួចស្រេចហើយ សូមព្រះអង្គ ទ្រង់ជ្រាបកាលគួរ ឥឡូវនេះចុះ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់ឡើងគង់លើរាជរថ ទីឃាវុកុមារ ក៏បររាជរថទៅ។ ពួកសេនាដើរទៅតាមផ្លូវឯទៀត ទីឃាវុកុមារ ជាអ្នកបររាជរថ ក៏បរទៅតាមផ្លូវឯទៀត បែកផ្សេងពីគ្នា។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត យាងទៅដល់ទីឆ្ងាយ ហើយទ្រង់មានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែនាយមាណព បើដូច្នោះ ចូរអ្នកឯងដាក់រាជរថសិន ដ្បិតយើងនឿយព្រួយលំបាក យើងនឹងដេកសម្រាកបន្តិចសិន។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារ បានទទួលស្ដាប់ព្រះឱង្ការស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ដាក់រាជរថចេញ អង្គុយពែនភ្នែនលើផែនដី។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ក៏ទ្រង់ផ្ទំកើយព្រះសិរសៈ លើភ្លៅទីឃាវុកុមារ។ ស្ដេចនោះ នឿយព្រួយលំបាក ទ្រង់ផ្ទំលក់មួយរំពេច។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ទីឃាវុកុមារ ក៏មានសេចក្ដីត្រិះរិះ យ៉ាងនេះថា ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្តនេះ បានធ្វើសេចក្ដីវិនាសជាច្រើន ដល់អាត្មាអញ ទាំងពល ពាហនៈ ជនបទ ឃ្លាំង និងជង្រុក របស់អាត្មាអញ ស្ដេចនេះ រឹបជាន់យកអស់ មិនតែប៉ុណ្ណោះ ទាំងមាតាបិតា របស់អាត្មាអញ ស្ដេចនេះ ក៏សម្លាប់ចោលអស់ វេលានេះ គួរអាត្មាអញ សងពៀរ ដល់ស្ដេចនេះវិញ ហើយក៏ហូតព្រះខាន់ចេញពីស្រោម។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ទីឃាវុកុមារ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា បិតាបានផ្ដាំអាត្មាអញ ក្នុងពេលដែលទៀបធ្វើមរណភាពថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតា ពៀរ មិនដែលរម្ងាប់ ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរ តែងរម្ងាប់ដោយការមិនចងពៀរ បើអាត្មាអញ កន្លងពាក្យបិតាហើយ អំពើនេះ ឈ្មោះថា មិនសមគួរដល់អាត្មាអញឡើយ ហើយក៏សៀតព្រះខាន់ ទៅក្នុងស្រោមវិញ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារ មានសេចក្ដីត្រិះរិះ ជាគំរប់ពីរដងទៀត។បេ។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារ មានសេចក្ដីត្រិះរិះ ជាគំរប់បីដងទៀត យ៉ាងនេះថា ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្តនេះ បានធ្វើសេចក្ដីវិនាសជាច្រើន ដល់អាត្មាអញ ទាំងពល ពាហនៈ ជនបទ ឃ្លាំង និងជង្រុក របស់អាត្មាអញ ស្ដេចនេះរឹបជាន់យកអស់ មិនតែប៉ុណ្ណោះ ទាំងមាតាបិតា របស់អាត្មាអញ ស្ដេចនេះ ក៏សម្លាប់ចោលអស់ វេលានេះ គួរអាត្មាអញ សងពៀរ ដល់ស្ដេចនេះវិញ ហើយក៏ហូតព្រះខាន់ ចេញពីស្រោម (ម្ដងទៀត)។ ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារ មានសេចក្ដីត្រិះរិះ ជាគំរប់បីដងទៀត យ៉ាងនេះថា បិតាបានផ្ដាំអាត្មាអញ ក្នុងពេលដែលទៀបធ្វើមរណភាពថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតា ពៀរ មិនដែលរម្ងាប់ ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរ តែងរម្ងាប់ដោយការមិនចងពៀរ បើអាត្មាអញ កន្លងពាក្យបិតាហើយ អំពើនេះ ឈ្មោះថា មិនសមគួរដល់អាត្មាអញឡើយ ហើយក៏សៀតព្រះខាន់ ទៅក្នុងស្រោមវិញ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់ភិតភ័យ ភ្ញាក់ផ្អើល ស្ញើតស្លក់ តក់ស្លុត ហើយក៏តើនឡើងភ្លាម។ ម្នាលភិក្ខុទាំងឡាយ ខណៈនោះ ទីឃាវុកុមារទូលសួរស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ហេតុអ្វី បានជាព្រះអង្គទ្រង់ភិតភ័យ ភ្ញាក់ផ្អើល ស្ញើតស្លក់ តក់ស្លុត ហើយតើនឡើងភ្លាម។ ស្ដេចនោះតបវិញថា នែនាយមាណព ព្រោះយើងយល់សប្តិ (ថាដូចជា) ទីឃាវុកុមារ ជាកូនស្ដេច ក្នុងដែនកោសល ឈ្មោះទីឃីតិ លើកព្រះខាន់ឡើង គម្រាមយើងក្នុងទីនេះ ព្រោះហេតុនោះ បានជាយើងភិតភ័យ ភ្ញាក់ផ្អើល ស្ញើតស្លក់ តក់ស្លុត ហើយក្រោកឡើងភ្លាម។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ទីឃាវុកុមារ យកដៃខាងឆ្វេង ចាប់សង្កត់ព្រះសិរសៈ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ហើយយកដៃខាងស្ដាំ ហូតព្រះខាន់ រួចនិយាយពាក្យនេះ នឹងស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្តថា នែព្រះអង្គ ខ្លួនខ្ញុំឯងហើយ ដែលឈ្មោះ ទីឃាវុកុមារ ជាកូនស្ដេច ក្នុងដែនកោសល ព្រះនាមទីឃីតិ ព្រះអង្គបានធ្វើសេចក្ដីវិនាស ជាច្រើនដល់ខ្ញុំ ទាំងពល ពាហនៈ ជនបទ ឃ្លាំង និងជង្រុករបស់ខ្ញុំ ព្រះអង្គ ក៏រឹបជាន់យកអស់ ម្យ៉ាងទៀត ទាំងមាតាបិតា របស់ខ្ញុំ ព្រះអង្គក៏សម្លាប់ចោលអស់ វេលានេះ គួរខ្ញុំសងពៀរដល់ព្រះអង្គវិញ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ក៏ឱនព្រះសិរ្ស ក្រាបទៀបជើង ទីឃាវុកុមារ ហើយមានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែទីឃាវុកូន សូមអ្នកអាណិត ឲ្យជីវិតដល់យើងផង នែទីឃាវុកូន សូមអ្នកអាណិត ឲ្យជីវិតដល់យើងផង។ ទីឃាវុកុមារ តបវិញថា ខ្ញុំនឹងអាចថ្វាយជីវិតព្រះអង្គ ដូចម្ដេចបាន គួរតែព្រះអង្គប្រទានជីវិត មកខ្ញុំវិញ។ ស្ដេចនោះ ទ្រង់ត្រាស់ថា នែទីឃាវុកូន បើដូច្នោះ អ្នកឯងចូរឲ្យជីវិតដល់យើងចុះ យើងក៏ឲ្យជីវិត ដល់អ្នកឯងវិញ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត និងទីឃាវុកុមារ បានឲ្យជីវិតគ្នា ទៅវិញទៅមក ហើយបានទាំងចាប់ដៃគ្នាផង ធ្វើសម្បថផង ដើម្បីមិនឲ្យមានរឿងប្រទូស្តគ្នា តទៅទៀត។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់មានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែទីឃាវុកូន បើដូច្នោះ ចូរអ្នកទឹមរាជរថចុះ យើងនឹងត្រឡប់ទៅវិញ។ ម្នាលភិក្ខុទាំងឡាយ ឯទីឃាវុកុមារ បានទទួលស្ដាប់ព្រះឱង្ការ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ដោយពាក្យថា ព្រះករុណាវិសេស ហើយក៏ទឹមរាជរថ រួចក្រាបទូលស្ដេច ក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឯរាជរថ របស់ព្រះអង្គ ខ្ញុំព្រះអង្គ ទឹមរួចស្រេចហើយ សូមព្រះអង្គទ្រង់ជ្រាបកាលគួរ ឥឡូវនេះចុះ។ ម្នាលភិក្ខុទាំងឡាយ ខណៈនោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់យាងឡើងគង់លើរាជរថ ឯទីឃាវុកុមារ ក៏បររាជរថទៅ។ មិនយូរប៉ុន្មាន ទីឃាវុកុមារ ក៏បររាជរថទៅជួបនឹងពួកសេនា ដែលទៅតាមផ្លូវផ្សេងពីគ្នានោះ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់យាងចូលទៅ ក្រុងពារាណសី ហើយទ្រង់ប្រជុំពួកអមាត្យ ជាបរិសទ្យរួចហើយ ទ្រង់មានព្រះឱង្ការ យ៉ាងនេះថា នែនាយ ប្រសិនបើអ្នកទាំងឡាយ បានឃើញទីឃាវុកុមារ ជាកូនស្ដេច ក្នុងដែនកោសល ឈ្មោះទីឃីតិហើយ តើគួរធ្វើ ទីឃាវុកុមារ នោះដូចម្ដេច។ អមាត្យទាំងឡាយ ក៏ក្រាបទូលដោយពួកៗ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំ គួរតែកាត់ដៃចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំ គួរតែកាត់ជើងចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំ គួរតែកាត់ទាំងដៃ ទាំងជើងចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំ គួរតែកាត់ត្រចៀកចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំ គួរតែកាត់ច្រមុះចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំគួរតែកាត់ទាំងត្រចៀក ទាំងច្រមុះចេញ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំ គួរតែកាត់ក្បាលចេញ។ ស្ដេចនោះ ទ្រង់ប្រាប់ថា នែនាយទាំងឡាយ បុរសនេះឯងហើយ ដែលឈ្មោះទីឃាវុកុមារ ជាកូនស្ដេចក្នុងដែនកោសល ឈ្មោះទីឃីតិនោះ អ្នកទាំងឡាយ មិនត្រូវធ្វើទោសកុមារនេះតិចតួចទេ ព្រោះកុមារនេះ បានឲ្យជីវិតយើង យើងក៏បានឲ្យជីវិតដល់កុមារនេះដែរ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្ដេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់មានព្រះឱង្ការ ទៅនឹងទីឃាវុកុមារ យ៉ាងនេះថា នែទីឃាវុកូន កាលដែលបិតារបស់អ្នកជិតនឹងមរណភាព បានផ្ដាំបណ្ដាំណា ចំពោះអ្នកឯងថា នែទីឃាវុកូន អ្នកឯងកុំឃើញកាលវែង កុំឃើញកាលខ្លី នែទីឃាវុកូន ធម្មតា ពៀរ មិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរ តែងរម្ងាប់ដោយការមិនចងពៀរ តើបិតារបស់អ្នក សំដៅយកហេតុត្រង់ណា បានជាផ្ដាំ (ដូច្នេះ)។ ទីឃាវុកុមារ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតា

របស់ខ្ញុំព្រះអង្គ ជិតនឹងធ្វើមរណភាព បានផ្តាំបណ្តាំណា ចំពោះខ្ញុំព្រះអង្គថា អ្នកកុំឃើញកាលវែង គឺថា អ្នកឯង កុំធ្វើពៀរ ឲ្យយូរអង្វែងឡើយ សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គ ជិតនឹងធ្វើមរណភាព បានផ្តាំបណ្តាំនេះឯង (នេះហៅថា) កុំឃើញកាលវែង សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គ ទៀបនឹងធ្វើមរណភាព បានផ្តាំបណ្តាំណា ចំពោះខ្ញុំព្រះអង្គថា អ្នកឯងកុំឃើញកាលខ្លី គឺថា អ្នកឯងកុំប្រញាប់បែកចាកពួកមិត្តសំឡាញ់ឡើយ សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គ ជិតនឹងធ្វើមរណភាព បានផ្តាំបណ្តាំនេះឯង (នេះហៅថា) កុំឃើញកាលខ្លី សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតារបស់ខ្ញុំព្រះអង្គ ជិតនឹងធ្វើមរណភាព បានផ្តាំបណ្តាំណា ចំពោះខ្ញុំព្រះអង្គថា នែទីឃាវុកូន ធម្មតា ពៀរ មិនដែលរម្ងាប់ ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរ តែងរម្ងាប់ ដោយការមិនចងពៀរ (នោះសំដៅត្រង់) មាតាបិតារបស់ខ្ញុំព្រះអង្គ ដែលព្រះអង្គ សម្លាប់ចោលអស់ ព្រោះហេតុនោះ បើខ្ញុំព្រះអង្គ នឹងបំផ្លាញព្រះអង្គ ឲ្យចាកជីវិតហើយ គង់មានពួកជន ដែលប្រាថ្នាប្រយោជន៍ ចំពោះព្រះអង្គ នឹងបំផ្លាញខ្ញុំព្រះអង្គ ឲ្យដាច់ចាកជីវិតវិញ ពួកជនដែលប្រាថ្នាប្រយោជន៍ ដល់ខ្ញុំព្រះអង្គ មុខជានឹងបំផ្លាញជនទាំងនោះ ឲ្យដាច់ចាកជីវិតមិនខានឡើយ ពៀរនោះ មិនបានរម្ងាប់ ដោយការចងពៀរ យ៉ាងនេះឯង ឥឡូវ ព្រះអង្គ ទ្រង់ប្រទានជីវិតដល់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គ ក៏ថ្វាយជីវិត ដល់ព្រះអង្គវិញ ពៀរនោះ នឹងរម្ងាប់ ដោយការមិនចងពៀរ យ៉ាងនេះឯង សូមទ្រង់ព្រះមេត្តាប្រោស កាលដែលបិតា របស់ខ្ញុំព្រះអង្គ ជិតនឹងធ្វើមរណភាព បានផ្តាំបណ្តាំនេះឯងថា នែទីឃាវុកូន ធម្មតា ពៀរ មិនដែលរម្ងាប់ដោយការចងពៀរទេ នែទីឃាវុកូន ឯពៀរ តែងរម្ងាប់ដោយការមិនចងពៀរ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្តេចក្នុងដែនកាសី ព្រះនាមព្រហ្មទត្ត ទ្រង់ស្ងើចថា អើហ្ន៎ (ហេតុនេះ) ហៅពេញជា អស្ចារ្យណាស់ អើហ្ន៎ (ហេតុនេះ) ហៅពេញជាចំឡែកណាស់ ទីឃាវុកុមារនេះ ពេញជាអ្នកប្រាជ្ញមែន ព្រោះដឹងសេចក្តីដែលបិតា ពោលដោយសង្ខេប ដោយពិស្តារបាន ហើយក៏ទ្រង់ត្រឡប់ប្រគល់ពល ពាហនៈ ជនបទ ឃ្លាំង និងជង្រុក ជាដំណែលបិតា ទៅទីឃាវុកុមារវិញ បានទាំងប្រទានធីតា១ថែមទៀត។ ម្នាលភិក្ខុទាំងឡាយ គួរកោតដែរ យ៉ាងពួកក្សត្រទាំងនោះ (ធ្លាប់តែ) កាន់ដំបង (ធ្លាប់តែ) កាន់គ្រឿងសស្ត្រាហើយ ចេះមានអំណត់ នឹងសេចក្តីប្រព្រឹត្តល្អ បែបនេះបាន។ ព្រោះហេតុដូច្នោះ ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា បានមកបួស ក្នុងធម្មវិន័យនេះ ដែលតថាគត បានសំដែង ដោយល្អយ៉ាងនេះហើយ គួរតែខំអត់ធន់ គួរតែខំប្រព្រឹត្តល្អ ឲ្យល្អឡើង។

[១៥១] ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកា ទៅនឹងភិក្ខុទាំងនោះ ជាគំរប់បីដង យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយ កុំធ្វើសេចក្តីបង្កហេតុ កុំធ្វើសេចក្តីឈ្លោះគ្នា កុំធ្វើសេចក្តីប្រកាន់ផ្សេងៗគ្នា កុំធ្វើសេចក្តីវិវាទគ្នាឡើយ។ ឯអធម្មវាទីភិក្ខុនោះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ជាគំរប់បីដង យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគ ជាធម្មស្សាមី ទ្រង់ឈប់បង្អង់ចុះ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគ មានសេចក្តីខ្វល់ខ្វាយតិច សូមទ្រង់ប្រកបតែធម៌ ដែលជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នរឿយៗចុះ ឯយើងខ្ញុំទាំងឡាយ មុខជានឹងប្រាកដ ដោយសេចក្តីបង្កហេតុ ដោយសេចក្តីឈ្លោះគ្នា ដោយសេចក្តីប្រកាន់ផ្សេងៗគ្នា ដោយសេចក្តីវិវាទគ្នាមិនខាន។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់រិះគិតថា ពួកមោឃបុរសទាំងនេះ មានសភាព គឺកិលេសគ្របសង្កត់ហើយ តថាគត មិនងាយនឹងពន្យល់មោឃបុរសទាំងនេះបានឡើយ ហើយក៏ទ្រង់ក្រោកចាកអាសនៈ ចៀសចេញទៅ។

ចប់ វារៈពោលអំពីទីឃាវុកុមារ ទី១។

[១៥២] លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ ហើយទ្រង់បាត្រ និងចីវរ យាងចូលទៅក្រុងកោសម្ពី ដើម្បីបិណ្ឌបាត ក្នុងពេលព្រឹកព្រហាម លុះយាងទៅបិណ្ឌបាត ក្នុងក្រុងកោសម្ពីហើយ ទ្រង់ត្រឡប់មកពីបិណ្ឌបាតវិញ ក៏ទ្រង់រៀបទុកដាក់គ្រឿងសេនាសនៈ ហើយកាន់យកបាត្រ និងចីវរ ទ្រង់ឋិតកណ្តាលជំនុំសង្ឃ ក្នុងវេលាក្រោយភត្ត ហើយទ្រង់ពោលព្រះគាថាទាំងនេះថា

[១៥៣] ជននេះមានសំឡេងខ្លាំងផង ជាជនប្រហែលគ្នាផង សូម្បីជនណាមួយ ដឹងខ្លួនថាជាបុគ្គលពាល ក៏គ្មាន កាលបើសង្ឃកំពុងតែបែកគ្នា ជនទាំងឡាយ ក៏មិនបានដឹងហេតុដទៃ ឲ្យក្រៃលែង។ ពួកជនដែលភ្លេចស្មារតី ហើយធ្វើឫក្សពាខ្លួនដូចជាអ្នកប្រាជ្ញ មានសំដីជាអារម្មណ៍ ចង់ហារមាត់និយាយប៉ុន្មាន ក៏និយាយប៉ុណ្ណោះទៅ ទុកជាមានគេនាំទៅប្រជល់ឲ្យឈ្លោះគ្នា ក៏មិនដឹងសេចក្តីនោះថា ជាសេចក្តីឈ្លោះឡើយ។ ពួកជនណា ចងសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះ បានជេរអាត្មាអញ ជនឯណោះ បានវាយអាត្មាអញ ជនឯណោះ បានផ្ចាញ់ផ្ចាលអាត្មាអញ ជនឯណោះ បានលួចទ្រព្យអាត្មាអញ ពៀររបស់ជនទាំងនោះ មិនបានរម្ងាប់ទេ។ ម្យ៉ាងទៀត ពួកជនណា មិនបានចងសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះ បានជេរអាត្មាអញ ជនឯណោះ បានវាយអាត្មាអញ ជនឯណោះ បានផ្ចាញ់ផ្ចាលអាត្មាអញ ជនឯណោះ បានលួចទ្រព្យអាត្មាអញ ពៀររបស់ជនទាំងនោះ ទើបរម្ងាប់ទៅបាន។ ក្នុងលោកនេះ ធម្មតា ពៀរ មិនដែលរម្ងាប់ ដោយការចងពៀរបានម្តងឡើយ រម្ងាប់បានតែ ដោយការមិនចងពៀរ នេះជាធម្មតា តែងមានពីដើមរៀងមក។ ពួកជនដទៃ មិនដែលដឹងច្បាស់ថា យើងដល់នូវសេចក្តីវិនាស ក្នុងកណ្តាលជំនុំសង្ឃនេះទេ បណ្តាជនទាំងនោះ បើពួកជនណាមួយដឹងច្បាស់ សេចក្តីឈ្លោះ ទើបរម្ងាប់អំពីសំណាក់ជនទាំងនោះបាន។ អម្បាលឆ្អឹងមាតាបិតា របស់ទីឃាវុកុមារ គេកាត់ចោល ទាំងជីវិត គេក៏សម្លាប់ចោល ទាំងគោ សេះ និងធនធាន គេក៏នាំយកទៅ ទាំងដែន គេក៏រឹបជាន់ ដណ្តើមយកអស់ ម្តេចស្តេចទាំងនោះ គង់នៅមានសេចក្តីព្រមព្រៀងគ្នាបាន។ ចុះអ្នកទាំងឡាយ ហេតុអ្វី ក៏គ្មានសេចក្តីព្រមព្រៀងគ្នា។

បើបុគ្គលបានសំឡាញ់មានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន[39] ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នា បុគ្គលនោះ អាចគ្របសង្កត់ នូវសេចក្តីអន្តរាយទាំងពួងបាន ហើយជាអ្នកមានសេចក្តីត្រេកអរ មានស្មារតី គប្បីត្រាច់ទៅជាមួយនឹងសំឡាញ់នោះចុះ។ បើបុគ្គលមិនបានសំឡាញ់ ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះ គួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាស្តេច លះបង់ដែន ដែលខ្លួនឈ្នះហើយ ត្រាច់ទៅម្នាក់ឯង (ពុំនោះសោត) ប្រៀបដូចជា ដំរីដ៏ប្រសើរ ត្រាច់ទៅម្នាក់ឯងក្នុងព្រៃ។ ការដែលបុគ្គល ត្រាច់ទៅតែម្នាក់ឯង ហៅពេញជាប្រសើរ ព្រោះបុគ្គលពាល គ្មានសហាយតាគុណ[40] ទេ។ ម្យ៉ាងទៀត បុគ្គល គួរត្រាច់ទៅតែម្នាក់ឯង មិនគួរធ្វើអំពើលាមកឡើយ ប្រៀបដូចជាដំរី ដ៏ប្រសើរ មានសេចក្តីខ្វល់ខ្វាយតិច ត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ។

## ២៧៣. ពាលកលោណកគមនកថា

**(២៧៣)**

[១៥៤] កាលបើព្រះមានព្រះភាគ ទ្រង់ឋិតកណ្ដាលជំនុំសង្ឃ ពោលព្រះគាថាអម្បាលនេះហើយ ក៏ទ្រង់យាងទៅឯពាលកលោណការក គ្រាម។ សម័យនោះឯង ក៏ចួនជាព្រះភគុដ៏មានអាយុ គង់នៅក្នុងពាលកលោណការកគ្រាមដែរ។ ឯព្រះភគុដ៏មានអាយុ បានឃើញព្រះមានព្រះភាគ ទ្រង់យាងមកអំពីចម្ងាយ លុះឃើញហើយ ក៏រៀបក្រាលអាសនៈ រួចដំកល់ទឹកសម្រាប់លាងព្រះបាទ តាំងសម្រាប់ទ្រព្រះបាទ ដែលលាងរួចហើយ និងគ្រឿងសម្រាប់ទ្រព្រះបាទ ដែលមិនទាន់លាង ស្រេចហើយ ទើបក្រោកឡើង ទៅទទួលបាត្រ និងចីវរ។ ព្រះមានព្រះភាគ ក៏ទ្រង់គង់លើអាសនៈ ដែលភិក្ខុក្រាលថ្វាយ លុះគង់ហើយ ទើបលាងព្រះបាទា។ ចំណែកឯព្រះភគុដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំ ព្រះមានព្រះភាគ រួចអង្គុយនៅក្នុងទីសមគួរ។ លុះព្រះភគុដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុ អ្នកល្មមអត់ធន់បានទេឬ អ្នកល្មមប្រព្រឹត្តទៅបានស្រួលទេឬ អ្នកមិនលំបាកដោយបិណ្ឌបាតទេឬ។ ព្រះភគុដ៏មានអាយុ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ល្មមអត់ធន់បាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត ខ្ញុំព្រះអង្គ មិនលំបាកដោយបិណ្ឌបាតទេ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ព្រះភគុដ៏មានអាយុ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ យាងទៅឯប្រទេស នៃព្រៃឈ្មោះបាចីនវង្ស។

## ២៧៤. បាចីនវំសទាយគមនកថា

CS vin.mv.10.04 | ភាគ ទី៨

**(២៧៤)**

សម័យនោះឯង ចួនជាព្រះអនុរុទ្ធដ៏មានអាយុ១ ព្រះនន្ទិយៈដ៏មានអាយុ១ ព្រះកិម្ពិលៈដ៏មានអាយុ១ គង់នៅក្នុងប្រទេស នៃព្រៃឈ្មោះបាចីនវង្សដែរ។ មានបុរសម្នាក់ ជាអ្នករក្សាព្រៃ បានឃើញព្រះមានព្រះភាគ ទ្រង់យាងមកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រសមណៈ ព្រះអង្គ កុំយាងចូលទៅក្នុងព្រៃនេះឡើយ ដ្បិតមានពួកកុលបុត្ត៣រូប មានសភាពជាអ្នកស្រឡាញ់ខ្លួន នៅក្នុងព្រៃនេះ ព្រះអង្គ កុំធ្វើសេចក្ដីអផ្សុក ដល់កុលបុត្តទាំងនោះឡើយ។ ព្រះអនុរុទ្ធដ៏មានអាយុ ក៏បានឮពាក្យបុរស ជាអ្នករក្សាព្រៃ កំពុងប្រឹក្សាជាមួយនឹងព្រះមានព្រះភាគដែរ លុះឮហើយ ក៏និយាយទៅនឹងបុរសជាអ្នករក្សាព្រៃ យ៉ាងនេះថា ម្នាលអ្នករក្សាព្រៃដ៏មានអាយុ អ្នកឯង កុំឃាត់ព្រះមានព្រះភាគឡើយ ដ្បិតព្រះមានព្រះភាគ ជាគ្រូរបស់យើង ព្រះអង្គ ទ្រង់យាងមកដល់ហើយ។ ខណៈនោះ ព្រះអនុរុទ្ធដ៏មានអាយុ ចូលទៅរកព្រះនន្ទិយៈដ៏មានអាយុ និងព្រះកិម្ពិលៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះនន្ទិយៈដ៏មានអាយុ និងព្រះកិម្ពិលៈដ៏មានអាយុយ៉ាងនេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយ និមន្តទៅទទួល ម្នាលលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយ និមន្តទៅទទួល ដ្បិតព្រះមានព្រះភាគ ជាគ្រូរបស់យើង ព្រះអង្គទ្រង់យាងមកដល់ហើយ។ វេលានោះ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះនន្ទិយៈដ៏មានអាយុ និងព្រះកិម្ពិលៈដ៏មានអាយុ ក៏ក្រោកទៅទទួលព្រះមានព្រះភាគ មួយអង្គទទួលបាត្រ និងចីវរព្រះមានព្រះភាគ មួយអង្គរៀបចំក្រាលអាសនៈ មួយអង្គដំកល់ទឹកសម្រាប់លាងព្រះបាទ តាំងសម្រាប់ដំកល់ព្រះបាទ ដែលលាងហើយ និងគ្រឿងសម្រាប់ដំកល់ព្រះបាទ ដែលមិនទាន់បានលាង។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈ ដែលភិក្ខុនោះក្រាលហើយ លុះគង់ហើយ ទ្រង់លាងព្រះបាទា។ ចំណែកលោកដ៏មានអាយុទាំងនោះ ក៏នាំគ្នាក្រាបថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់រួចហើយ អង្គុយនៅក្នុងទីសមគួរ។ លុះព្រះអនុរុទ្ធដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះអង្គទ្រង់ត្រាស់សួរ យ៉ាងនេះថា ម្នាលអនុរុទ្ធទាំងឡាយ[41] អ្នកទាំងឡាយ ល្មមអត់ធន់បានឬទេ អ្នកទាំងឡាយ ល្មមប្រព្រឹត្តទៅបានស្រួលឬទេ អ្នកទាំងឡាយ មិនលំបាកដោយបិណ្ឌបាតឬទេ។ ព្រះថេរៈទាំង៣អង្គ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំ ល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ យើងខ្ញុំ ល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត យើងខ្ញុំ មិនលំបាកដោយបិណ្ឌបាតទេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរទៀតថា ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ បានព្រមព្រៀង ស្មោះសរ មិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ដែរឬ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា ព្រះករុណា យើងខ្ញុំទាំងនោះ ព្រមព្រៀង ស្មោះសរនឹងគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់បាន។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរទៀតថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយ បានជាព្រមព្រៀង ស្មោះសរនឹងគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ដូចម្ដេចទៅ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះ ខ្ញុំព្រះអង្គ មានសេចក្ដីត្រិះរិះថា អាត្មាអញ បាននៅជាមួយនឹងពួកបុគ្គល ដែលប្រព្រឹត្តធម៌ ដ៏ប្រសើរស្មើគ្នាបែបនេះ ហៅពេញជាលាភ របស់អាត្មាអញ អាត្មាអញ ហៅពេញជាបានស្រួលពេកហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ តែងដំកល់កាយកម្ម ប្រកបដោយមេត្តា ចំពោះលោកដ៏មានអាយុទាំងអម្បាលនេះ ទាំងទីចំពោះមុខ និងទីកំបាំង ខ្ញុំព្រះអង្គ តែងដំកល់វចីកម្ម និងមនោកម្ម ប្រកបដោយមេត្តា ទាំងទីចំពោះមុខ និងទីកំបាំង សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ អាត្មាអញ គួរដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញ សូមទ្រង់ព្រះមេត្តាប្រោស (លុះគិតដូច្នេះហើយ) ខ្ញុំព្រះអង្គ ក៏បានដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះទៅ សូមទ្រង់ព្រះមេត្តាប្រោស ឯកាយរបស់យើងខ្ញុំផ្សេងគ្នាក៏ពិតមែន ប៉ុន្តែ ចិត្តដូចគ្នាតែម្យ៉ាង។ ឯព្រះនន្ទិយៈដ៏មានអាយុ និងព្រះកិម្ពិលៈដ៏មានអាយុ ក៏បានក្រាបបង្គំ ទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ទៀតថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា អាត្មាអញ នៅជាមួយនឹងពួកបុគ្គល ដែលប្រព្រឹត្តធម៌ ដ៏ប្រសើរស្មើគ្នាបែបនេះ ហៅពេញជាលាភ របស់អាត្មាអញ អាត្មាអញ ហៅពេញជាបានស្រួលពេកហើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ តែងដំកល់កាយកម្ម ប្រកបដោយមេត្តា ចំពោះលោកដ៏មានអាយុទាំងអម្បាលនេះ ទាំងទីចំពោះមុខ និងទីកំបាំងមុខ ខ្ញុំព្រះអង្គ តែងដំកល់វចីកម្ម និងមនោកម្ម ប្រកបដោយមេត្តា ទាំងទីចំពោះមុខ និងទីកំបាំង សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ អាត្មាអញ គួរដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញចុះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនោះ បានដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្តលោកដ៏មានអាយុទាំងនេះវិញ សូមទ្រង់ព្រះមេត្តាប្រោស ឯកាយរបស់យើងខ្ញុំផ្សេងគ្នា ក៏ពិតមែន ប៉ុន្តែ ចិត្តដូចគ្នាតែម្យ៉ាង សូមទ្រង់ព្រះមេត្តាប្រោស ដោយហេតុយ៉ាងនេះហើយ បានជាយើងខ្ញុំព្រមព្រៀង ស្មោះសរ មិនវិវាទគ្នា ដូចជាទឹកដោះលាយទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់បាន។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយ មិនបានប្រហែសធ្វេស មាន

ព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅត្រង់ខ្លះដែរឬ។ ព្រះអនុរុទ្ធក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំមិនបានប្រហែសធ្វេសទេ ហើយមានព្យាយាមដុតកិលេស នឹងមានចិត្តបញ្ជូនទៅត្រង់។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយ ដែលឥតមានប្រហែសធ្វេស មានតែព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅត្រង់ តើយ៉ាងដូចម្ដេច។ ព្រះថេរៈទាំង៣អង្គ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស បណ្ដាយើងខ្ញុំ ដែលនៅក្នុងទីនេះ បើលោកណាត្រឡប់មកពីបិណ្ឌបាត អំពីស្រុកមុនគេ លោកនោះ រៀបចំក្រាលអាសនៈ ដំកល់ទឹកសម្រាប់លាងជើង ដំកល់តាំងសម្រាប់ទ្រជើង ដែលលាងរួច និងដំកល់គ្រឿងសម្រាប់ទ្រជើង ដែលមិនទាន់លាង ហើយលាងភាជន៍ សម្រាប់ផ្ទេរបាយ ដំកល់ទុកឲ្យស្រួល រួចដំកល់ទឹកឆាន់ និងទឹកប្រើប្រាស់ លោកណាមកពីបិណ្ឌបាត អំពីស្រុកក្រោយគេ បើមានរបស់ដែលសល់ពីឆាន់ បើភិក្ខុនោះចង់ឆាន់ ក៏ឆាន់ទៅ បើមិនចង់ឆាន់ទេ ចាក់ចោលទៅក្នុងទីគ្មានស្មៅស្រស់ក៏បាន បាចសាចទៅក្នុងទឹក ដែលគ្មានសត្វតូចក៏បាន រួចលោកនោះ រើអាសនៈចេញ ហើយរៀបចំទុកដាក់ទឹក សម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ដែលលាងរួចហើយ និងគ្រឿងសម្រាប់ទ្រជើង ដែលមិនទាន់លាង ហើយលាងភាជន៍សម្រាប់ផ្ទេរបាយ រៀបចំទុកដាក់ រួចរៀបទុកដាក់ទឹកឆាន់ និងទឹកប្រើប្រាស់ ហើយបោសរោងភត្ត បើលោកណា ឃើញក្អមសម្រាប់ដាក់ទឹកឆាន់ក្តី ក្អមសម្រាប់ដាក់ទឹកប្រើប្រាស់ក្តី ក្អមសម្រាប់ដាក់ទឹកលាងវច្ចៈក្តី រលីងសោះទទេ លោកនោះ ក៏ដំកល់ទុកឲ្យមានឡើង បើលោកនោះ មិនអាចលើកដោយកំឡាំងដៃបានទេ ក៏យើងខ្ញុំហៅភិក្ខុ (ឯទៀត) មកជាពីររូប ជួយលើក ឬសែងដោយដៃ យកទៅដំកល់ទុក សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំមិនបាច់បញ្ចេញវាចា ព្រោះហេតុប៉ុណ្ណោះឡើយ សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត តែគ្រប់៥ថ្ងៃហើយ យើងខ្ញុំតែងអង្គុយប្រជុំគ្នា ដោយធម្មីកថា អស់រាត្រីទាំងមូល[42] សូមទ្រង់ព្រះមេត្តាប្រោស ដោយហេតុយ៉ាងនេះហើយ បានជាយើងខ្ញុំព្រះអង្គ ឥតមានសេចក្តីប្រហែសធ្វេស ខំព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅត្រង់ ឥតមាននឹកនា (ដល់កាយ និងជីវិតឡើយ)។

## ២៧៥. បាលិលេយ្យកគមនកថា

CS vin.mv.10.05 | ភាគ ទី៨

**(២៧៥)**

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ព្រះអនុរុទ្ធដ៏មានអាយុផង ព្រះនន្ទិយៈដ៏មានអាយុផង ព្រះកិម្ពិលៈដ៏មានអាយុផង ឲ្យយល់ប្រយោជន៍ ក្នុងបច្ចុប្បន្ន និងបរលោក ឲ្យប្រតិបត្តិតាម ឲ្យខ្មីឃ្មាតក្នុងការកុសល ឲ្យរីករាយ ដោយធម្មីកថា រួចទ្រង់ក្រោកចាកអាសនៈហើយ យាងទៅកាន់ចារិក ប្រទេសបារិលេយ្យកៈ កាលទ្រង់យាងទៅកាន់ចារិក ដោយលំដាប់ ក៏បានដល់ទៅប្រទេសបារិលេយ្យកៈ។ ឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្រោមម្លប់ភទ្ទសាលព្រឹក្ស ក្នុងដងព្រៃឈ្មោះរក្ខិត នាប្រទេសបារិលេយ្យកៈនោះ។

[១៥៥] វេលានោះ កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ងាត់ សម្ងំនៅក្នុងព្រះកម្មដ្ឋាន ទ្រង់កើតមានព្រះហឫទ័យ ត្រិះរិះឡើងយ៉ាងនេះថា ក្នុងពេលមុន តថាគត នៅច្រឡូកច្រឡំ ដោយពួកភិក្ខុទាំងនោះ ដែលនៅក្នុងក្រុងកោសម្ពី ជាអ្នកធ្វើសេចក្តីបង្កហេតុ ធ្វើសេចក្តីឈ្លោះ ធ្វើសេចក្តីវិវាទ ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ មិនបានសេចក្តីសប្បាយ ក្នុងពេលនេះ តថាគត តែម្នាក់ឯង គ្មាននរណាជាគំរប់ពីរ ហើយបាននៅជាសប្បាយ ព្រោះវៀរផុតអំពីពួកភិក្ខុទាំងនោះ ដែលនៅក្នុងក្រុងកោសម្ពី ជាអ្នកធ្វើសេចក្តីបង្កហេតុ ធ្វើសេចក្តីឈ្លោះគ្នា ធ្វើសេចក្តីវិវាទគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ។ មានដំរីដ៏ប្រសើរ១ នៅច្រឡូកច្រឡំនឹងពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ និងពួកកូនដំរីតូចៗ ហើយស៊ីស្មៅដែលពួកដំរី (មានដំរីឈ្មោលជាដើមនោះ) បោចផ្ដាច់ចុងចេញ ចំណែកខាងពួកដំរីទាំងនោះ ក៏ស៊ីមែកឈើបាក់ៗ ដែលដំរីដ៏ប្រសើរនោះកាច់បំបាក់ខ្ទេចខ្ទីវិញ ឯដំរីដ៏ប្រសើរ ក៏ផឹកតែទឹកល្អក់ កាលបើដំរីដ៏ប្រសើរ ដើរចុះឡើងកំពង់ទឹក អស់ពួកមេដំរី ក៏ដើរត្រដុសកាយ។ ឯដំរីដ៏ប្រសើរនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញ នៅច្រឡូកច្រឡំដោយពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ និងពួកកូនដំរីតូចៗ ហើយស៊ីស្មៅដែលដំរីទាំងនោះ បោចផ្ដាច់ចុងចេញ ចំណែកពួកដំរីទាំងនោះ ក៏ស៊ីមែកឈើបាក់ៗ ដែលអាត្មាអញកាច់បំបាក់ខ្ទេចខ្ទីវិញ អាត្មាអញ ផឹកទឹកក៏ល្អក់ កាលបើអាត្មាអញ ដើរចុះឡើងកំពង់ទឹក អស់ពួកមេដំរី ក៏ដើរត្រដុសកាយ បើដូច្នោះ គួរអាត្មាអញ ថយចេញពីហ្វូង ទៅនៅម្នាក់ឯងវិញចុះ។ គ្រានោះ ដំរីដ៏ប្រសើរនោះ ដើរបែកចេញពីហ្វូង ចូលទៅកាន់សំណាក់ព្រះដ៏មានព្រះភាគ ដែលទ្រង់គង់ក្រោមម្លប់ភទ្ទសាលព្រឹក្ស ក្នុងដងព្រៃឈ្មោះរក្ខិត នាបារិលេយ្យកប្រទេស លុះចូលទៅដល់ហើយ ក៏ដំកល់ទឹកឆាន់ និងទឹកប្រើប្រាស់ ដោយប្រមោយ ចំពោះព្រះដ៏មានព្រះភាគ ហើយធ្វើទីកន្លែងនោះ មិនឲ្យមានស្មៅស្រស់ផង។ លំដាប់ពីនោះមក ដំរីដ៏ប្រសើរនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា កាលពីដើម អាត្មាអញ នៅច្រឡូកច្រឡំនឹងពួកដំរីឈ្មោល ពួកមេដំរី ពួកដំរីស្ទាវ និងពួកកូនដំរីតូចៗ ហើយអាត្មាអញ បានស៊ីស្មៅដែលពួកដំរីទាំងនោះ បោចផ្ដាច់ចុងចេញ ចំណែកខាងពួកដំរីទាំងនោះ ក៏បានស៊ីមែកឈើបាក់ៗ ដែលអាត្មាអញ កាច់បំបាក់ខ្ទេចខ្ទីវិញ មិនតែប៉ុណ្ណោះសោត អាត្មាអញ បានទាំងផឹកទឹកល្អក់ កាលបើអាត្មាអញ ដើរចុះឡើងកំពង់ទឹក ពួកមេដំរី វាក៏ដើរត្រដុសកាយ ក្នុងពេលនេះ អាត្មាអញ តែម្នាក់ឯង ឥតមាននរណាជាគំរប់ពីរ ហើយបាននៅជាសុខស្រួលបួល ព្រោះបានវៀរចាកពួកដំរីឈ្មោល ពួកដំរីញី ពួកដំរីស្ទាវ និងពួកកូនដំរីតូចៗ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបសេចក្តីវិវេក របស់ព្រះអង្គផង ហើយទ្រង់ជ្រាបសេចក្តីត្រិះរិះ នៃចិត្តរបស់ដំរីដ៏ប្រសើរនោះ ដោយព្រះហឫទ័យ របស់ព្រះអង្គផង ហើយក៏ទ្រង់បន្លឺព្រះឧទាននេះ ក្នុងពេលនោះថា

> ហត្ថិនាគ (ដំរីប្រសើរ) រមែងត្រេកអរក្នុងព្រៃ តែម្នាក់ឯង ហេតុណា ហេតុនុ៎ះ ចិត្តរបស់ហត្ថិនាគ មានភ្លុកងរទន្ទាំនេះ ស្មើគ្នានឹងចិត្តរបស់ព្រះពុទ្ធនាគដែរ។[43]

[១៥៦] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងបារិលេយ្យកប្រទេស គួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងទៅកាន់ចារិក នៃក្រុងសាវត្ថី កាលទ្រង់យាងទៅកាន់ចារិក ដោយលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ។ បានឮមកថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថីនោះ។

[១៥៧] វេលានោះ ពួកឧបាសកដែលនៅក្នុងក្រុងកោសម្ពី មានសេចក្ដីត្រិះរិះ យ៉ាងនេះថា ពួកលោកជាម្ចាស់ទាំងនេះ ជាភិក្ខុនៅក្នុងក្រុងកោសម្ពី បានធ្វើអំពើឥតប្រយោជន៍ជាច្រើន ដល់យើង ព្រះដ៏មានព្រះភាគសោត ក៏ពួកភិក្ខុទាំងនេះបៀតបៀន ទាល់តែទ្រង់យាងចេញបាត់ទៅ បើដូច្នោះ យើងមិនគួរសំពះ មិនគួរក្រោកទទួល មិនគួរធ្វើអញ្ជលីកម្ម មិនគួរធ្វើសាមីចិកម្ម មិនគួរធ្វើសក្ការៈ មិនគួរធ្វើសេចក្ដីគោរព មិនគួររាប់អាន មិនគួរបូជា ពួកលោកម្ចាស់ ជាភិក្ខុនៅក្នុងក្រុងកោសម្ពីទេ ទុកជាភិក្ខុទាំងនោះ ចូលមកជិត យើងក៏មិនគួរឲ្យបិណ្ឌបាតឡើយ ភិក្ខុទាំងនេះ តែពួកយើងលែងធ្វើសក្ការៈ លែងធ្វើសេចក្ដីគោរព លែងរាប់អាន លែងបូជា យ៉ាងនេះហើយ ក៏ទៅជាអ្នកគ្មានគ្រឿងសក្ការៈហើយ មុខជានឹងរត់ចេញទៅខ្លះ សឹកចេញទៅខ្លះ ញុំាងព្រះមានព្រះភាគ ឲ្យប្រោសប្រាណខ្លះមិនខាន។ គ្រានោះ ពួកឧបាសកក្រុងកោសម្ពី លែងសំពះ លែងក្រោកទទួល លែងធ្វើអញ្ជលិកម្ម និងសាមីចិកម្ម លែងធ្វើសក្ការៈ គោរព រាប់អាន បូជា ពួកភិក្ខុក្រុងកោសម្ពី ទុកជាភិក្ខុទាំងនោះ ចូលទៅបិណ្ឌបាត ក៏លែងឲ្យបិណ្ឌបាត។ វេលានោះ ពួកភិក្ខុក្រុងកោសម្ពី កាលបើពួកឧបាសកក្រុងកោសម្ពី លែងធ្វើសក្ការៈ គោរព រាប់អាន បូជា ក៏ទៅជាអ្នកគ្មានគ្រឿងសក្ការៈ ហើយក៏និយាយនឹងគ្នាយ៉ាងនេះថា នែអាវុសោ បើដូច្នោះ មានតែយើងទៅក្រុងសាវត្ថី រម្ងាប់អធិករណ៍នេះ ក្នុងសំណាក់ព្រះមានព្រះភាគចេញ។

## ២៧៦. អដ្ឋារសវត្ថុកថា

CS vin.mv.10.06 | ភាគ ទី៨

### អដ្ឋារសវត្ថុអធម្មវាទិ អធម្មវាទីបុគ្គល

លំដាប់នោះ ពួកភិក្ខុក្រុងកោសម្ពី ក៏រៀបចំទុកដាក់គ្រឿងសេនាសនៈ រួចនាំយកបាត្រ និងចីវរ ចូលទៅក្រុងសាវត្ថី។

[១៥៨] ព្រះសារីបុត្រដ៏មានអាយុបានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើការបង្កហេតុ ឈ្លោះទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិរកណ៍ ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថី។ ទើបព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីសមគួរ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថាពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា និងធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថី សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គ នឹងប្រតិបត្តិ ក្នុងពួកភិក្ខុទាំងនោះ ដូចម្ដេចខ្លះ។ ព្រះដ៏មានព្រះភាគ ទ្រង់តបថា នែសារីបុត្ត បើដូច្នោះ អ្នកចូរតាំងនៅ ឲ្យសមគួរតាមធម៌ចុះ។ ព្រះសារីបុត្តក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ធ្វើដូចម្ដេច ខ្ញុំព្រះអង្គអាចស្គាល់ថាជាធម៌ ឬមិនមែនជាធម៌បាន។ ព្រះដ៏មានព្រះភាគ តបថា នែសារីបុត្ត អ្នកត្រូវស្គាល់អធម្មវាទីបុគ្គល (បុគ្គលពោលខុសធម៌) ដោយវត្ថុ១៨យ៉ាង នែសារីបុត្ត ក្នុងសាសនានេះ មានភិក្ខុសំដែងសភាវៈ ដែលមិនមែនធម៌ ថាជាធម៌វិញ សំដែងធម៌ ថាមិនមែនជាធម៌វិញ សំដែងសភាវៈមិនមែនវិន័យ ថាជាវិន័យវិញ សំដែងវិន័យ ថាមិនមែនវិន័យវិញ សំដែងពាក្យ ដែលតថាគតមិនបានពោល មិនបានចរចា ថាតថាគត បានពោល បានចរចាវិញ សំដែងពាក្យ ដែលតថាគត បានពោល បានចរចា ថាតថាគតមិនបានពោល មិនបានចរចាវិញ សំដែងកិច្ចដែលតថាគតមិនបានសន្សំ ថាតថាគតបានសន្សំវិញ សំដែងកិច្ចដែលតថាគតបានសន្សំ ថាតថាគតមិនបានសន្សំវិញ សំដែងសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្ត ថាតថាគតបានបញ្ញត្តវិញ សំដែងសិក្ខាបទ ដែលតថាគត បានបញ្ញត្ត ថាតថាគត មិនបានបញ្ញត្តវិញ សំដែងអនាបត្តិ ថាជាអាបត្តិវិញ សំដែងអាបត្តិ ថាជាអនាបត្តិវិញ សំដែងអាបត្តិស្រាល ថាជាអាបត្តិធ្ងន់វិញ សំដែងអាបត្តិធ្ងន់ ថាជាអាបត្តិស្រាលវិញ សំដែងអាបត្តិដែលជាសាវសេស[44] ថាអាបត្តិជាអនវសេស[45] វិញ សំដែងអាបត្តិដែលជាអនវសេស ថាអាបត្តិជាសាវសេសវិញ សំដែងទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិវិញ សំដែងអទុដ្ឋុល្លាបត្តិ ថាទុដ្ឋុល្លាបត្តិវិញ នែសារីបុត្ត អ្នកត្រូវស្គាល់អធម្មវាទីបុគ្គល ដោយវត្ថុ ១៨យ៉ាងនេះឯងចុះ នែសារីបុត្ត ចំណែកខាងធម្មវាទីបុគ្គល អ្នកត្រូវស្គាល់ដោយវត្ថុ១៨យ៉ាងដែរ នែសារីបុត្ត ក្នុងសាសនានេះ មានភិក្ខុសំដែងសភាវៈ មិនមែនធម៌ ថាមិនមែនធម៌ សំដែងធម៌ ថាធម៌ សំដែងសភាវៈមិនមែនជាវិន័យ ថាមិនមែនវិន័យ សំដែងវិន័យ ថាវិន័យ សំដែងពាក្យ ដែលតថាគតមិនបានពោល មិនបានចរចា ថាតថាគត មិនបានពោល មិនបានចរចា សំដែងពាក្យ ដែលតថាគត បានពោល បានចរចា ថាតថាគតបានពោល បានចរចា សំដែងកិច្ចដែលតថាគតមិនបានសន្សំ ថាតថាគតមិនបានសន្សំ សំដែងកិច្ចដែលតថាគតបានសន្សំ ថាតថាគតបានសន្សំ សំដែងសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្ត ថាតថាគតមិនបានបញ្ញត្ត សំដែងសិក្ខាបទ ដែលតថាគត បានបញ្ញត្ត ថាតថាគត បានបញ្ញត្ត សំដែងអនាបត្តិ ថាអនាបត្តិ សំដែងអាបត្តិ ថាអាបត្តិ សំដែងអាបត្តិស្រាល ថាអាបត្តិស្រាល សំដែងអាបត្តិធ្ងន់ ថាអាបត្តិធ្ងន់ សំដែងអាបត្តិ ដែលជាសាវសេស ថាអាបត្តិជាសាវសេសៈ សំដែងអាបត្តិដែលជាអនវសេសៈ ថាអាបត្តិជាអនវសេសៈ សំដែងទុដ្ឋុល្លាបត្តិ ថាទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថាអទុដ្ឋុល្លាបត្តិដដែល នែសារីបុត្ត អ្នកត្រូវស្គាល់ធម្មវាទីបុគ្គល ដោយវត្ថុ ១៨យ៉ាងនេះឯង។

[១៥៩] ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឮ។បេ។ ព្រះមហាកស្សបដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហាកោដ្ឋិតដ៏មានអាយុ ព្រះមហាកប្បិនដ៏មានអាយុ ព្រះមហាចុន្ទដ៏មានអាយុ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះរេវតដ៏មានអាយុ ព្រះឧបាលិដ៏មានអាយុ ព្រះអានន្ទដ៏មានអាយុ ព្រះរាហុលដ៏មានអាយុ បានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ។ គ្រានោះ ព្រះរាហុលដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះព្រះរាហុលដ៏មានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថាពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្ដីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថី សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គ នឹងប្រតិបត្តិ ក្នុងពួកភិក្ខុទាំងនោះ ដូចម្ដេច។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់តបថា នែរាហុល បើដូច្នោះ អ្នកចូរតាំងនៅ ឲ្យសមគួរតាមធម៌ចុះ។ ព្រះរាហុលដ៏មានអាយុ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ធ្វើដូចម្ដេច ខ្ញុំព្រះអង្គ អាចស្គាល់ថាធម៌ ឬថាមិនមែនជាធម៌បាន។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែរាហុល អ្នកត្រូវស្គាល់អធម្មវាទីបុគ្គល ដោយវត្ថុ១៨យ៉ាង។បេ។ នែរាហុល អ្នកត្រូវស្គាល់អធម្មវាទីបុគ្គល ដោយវត្ថុ១៨យ៉ាងនេះឯង នែរាហុល ចំណែកខាងធម្មវាទីបុគ្គល អ្នកក៏ត្រូវស្គាល់ ដោយវត្ថុ១៨យ៉ាងដែរ។បេ។ នែរាហុល អ្នកត្រូវស្គាល់ធម្មវាទីបុគ្គល ដោយវត្ថុ ១៨យ៉ាងនេះឯង។

[១៦០] ព្រះនាងមហាបជាបតីគោតមី បានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ។ គ្រានោះ ព្រះនាងមហាបជាបតីគោតមី បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ។ លុះព្រះនាងមហាបជាបតីគោតមី បានឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឮថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គ នឹងប្រតិបត្តិ ក្នុងពួកភិក្ខុទាំងនោះ ដូចម្តេច។ ព្រះមានព្រះភាគ ទ្រង់តបថា នែគោតមី បើដូច្នោះ ព្រះនាងចូរស្តាប់ធម៌ ក្នុងសំណាក់សង្ឃទាំងពីរពួកចុះ បើនាងស្តាប់ធម៌ ក្នុងសំណាក់សង្ឃទាំងពីរពួកហើយ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណា ដែលជាធម្មវាទី ចូរព្រះនាងកាន់យកតាមទិដ្ឋិ សេចក្តីគាប់ចិត្ត សេចក្តីពេញចិត្ត និងលទ្ធិរបស់ពួកភិក្ខុនោះ ម្យ៉ាងទៀត របស់ឯណានីមួយ ដែលភិក្ខុនីសង្ឃ គប្បីប្រាថ្នាអំពីសំណាក់ភិក្ខុសង្ឃ របស់ទាំងអស់នោះ ភិក្ខុនី ត្រូវប្រាថ្នាអំពីធម្មវាទីបុគ្គលចុះ។

[១៦១] អនាថបិណ្ឌិកគហបតិ បានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថី។ វេលានោះ អនាថបិណ្ឌិកគហបតិ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះអនាថបិណ្ឌិកគហបតិ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គ នឹងប្រតិបត្តិ ក្នុងពួកភិក្ខុទាំងនោះ ដូចម្តេច។ ព្រះដ៏មានព្រះភាគ ទ្រង់តបថា នែគហបតិ បើដូច្នោះ អ្នកត្រូវឲ្យទាន ក្នុងសង្ឃទាំងពីរពួកចុះ លុះអ្នកឲ្យទាន ក្នុងសង្ឃទាំងពីរពួករួចហើយ អ្នកចូរស្តាប់ធម៌ ក្នុងសំណាក់សង្ឃទាំងពីរពួកទៀត លុះអ្នកស្តាប់ធម៌ ក្នុងសំណាក់សង្ឃទាំងពីរពួករួចហើយ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណា ដែលជាធម្មវាទី ចូរអ្នកកាន់យកតាមទិដ្ឋិ សេចក្តីគាប់ចិត្ត សេចក្តីពេញចិត្ត នឹងលទ្ធិរបស់ពួកភិក្ខុនោះចុះ។

[១៦២] នាងវិសាខា ជាមិគារមាតា បានឮដំណឹងថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ។ លំដាប់នោះ នាងវិសាខា ជាមិគារមាតា បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះនាងវិសាខា ជាមិគារមាតា អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឮថាពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ បពិត្រព្រះអង្គដ៏ចំរើន តើខ្ញុំព្រះអង្គ នឹងប្រតិបត្តិ ក្នុងពួកភិក្ខុទាំងនោះ ដូចម្តេច។ ព្រះដ៏មានព្រះភាគ ទ្រង់តបថា នែនាងវិសាខា បើដូច្នោះ ចូរនាងឲ្យទាន ក្នុងសង្ឃទាំងពីរពួកចុះ លុះនាងឲ្យទាន ដល់សង្ឃទាំងពីរពួករួចហើយ ចូរនាងស្តាប់ធម៌ ក្នុងសំណាក់សង្ឃទាំងពីរពួកទៀត លុះនាងស្តាប់ធម៌ ក្នុងសំណាក់សង្ឃទាំងពីរពួកហើយ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណា ដែលជាធម្មវាទី ចូរនាងកាន់យកតាមទិដ្ឋិ សេចក្តីគាប់ចិត្ត សេចក្តីពេញចិត្ត នឹងលទ្ធិរបស់ពួកភិក្ខុនោះចុះ។

[១៦៣] គ្រានោះ ពួកភិក្ខុក្រុងកោសម្ពីបានដល់ទៅក្រុងសាវត្ថី ដោយលំដាប់។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឮថា ពួកភិក្ខុក្រុងកោសម្ពីនោះ ជាអ្នកធ្វើសេចក្តីបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ បានមកដល់ក្រុងសាវត្ថីហើយ សូមទ្រង់ព្រះមេត្តាប្រោស តើខ្ញុំព្រះអង្គ នឹងប្រតិបត្តិ ក្នុងពួកភិក្ខុទាំងនោះ ដោយសេនាសនៈដូចម្តេច។ ព្រះមានព្រះភាគ ទ្រង់តបថា នែសារីបុត្ត បើដូច្នោះ អ្នកចូរឲ្យទីសេនាសនៈដ៏ស្ងាត់ទៅ ភិក្ខុទាំងនោះចុះ។ ព្រះសារីបុត្ត ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស បើគ្មានទីសេនាសនៈស្ងាត់ទេ តើខ្ញុំព្រះអង្គ ត្រូវប្រតិបត្តិដូចម្តេច។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែសារីបុត្ត បើដូច្នោះ អ្នកត្រូវធ្វើទីសេនាសនៈដ៏ស្ងាត់ ឲ្យតែខាងបាន ហើយប្រគល់ឲ្យភិក្ខុទាំងនោះទៅ នែសារីបុត្ត តថាគតមិនបានពោលថា ភិក្ខុត្រូវហាមទីសេនាសនៈ ដល់ភិក្ខុដែលចាស់ជាង ដោយបរិយាយនីមួយទេ ភិក្ខុណាហាម ត្រូវអាបត្តិទុក្កដ។ ព្រះសារីបុត្ត ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ចំណែកខាងគ្រឿងអាមិសៈវិញ តើខ្ញុំព្រះអង្គ ត្រូវប្រតិបត្តិដូចម្តេច។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែសារីបុត្ត ចំណែកខាងគ្រឿងអាមិសៈនោះ អ្នកត្រូវចែកទៅភិក្ខុទាំងអស់ឲ្យស្មើគ្នា។

## ២៧៧. ឱសារណានុជាននា

CS vin.mv.10.07 | ភាគ ទី៨

**(២៧៧)**

[១៦៤] គ្រានោះ ឧក្ខិត្តកភិក្ខុនោះ កាលពិចារណាធម៌ និងវិន័យហើយ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ អាត្មាអញ ជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ អាត្មាអញ ជាភិក្ខុដែលសង្ឃ (គួរ) លើកវត្តហើយ មិនមែនជាភិក្ខុ ដែលសង្ឃលើកវត្តមិនបានទេ អាត្មាអញ ជាភិក្ខុដែលសង្ឃលើកវត្តហើយ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ។ វេលានោះ ឧក្ខិត្តកភិក្ខុនោះ បានចូលទៅរកពួកឧក្ខិត្តានុវត្តកភិក្ខុ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះ នឹងពួកឧក្ខិត្តានុវត្តកភិក្ខុថា នែអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ខ្ញុំជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ ខ្ញុំជាភិក្ខុដែលសង្ឃ (គួរ) លើកវត្តហើយ មិនមែនជាភិក្ខុ ដែលសង្ឃលើកវត្តមិនបានទេ ខ្ញុំជាភិក្ខុដែលសង្ឃលើកវត្តហើយ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមអស់លោក មកធ្វើឱសារណាកម្ម ចំពោះខ្ញុំចុះ។ លំដាប់នោះ ឧក្ខិត្តានុវត្តកភិក្ខុទាំងនោះ បាននាំឧក្ខិត្តកភិក្ខុនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះភិក្ខុទាំងនោះ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ឧក្ខិត្តកភិក្ខុនេះ បាននិយាយយ៉ាងនេះថា នែអាវុសោ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ខ្ញុំជាភិក្ខុត្រូវអាបត្តិហើយ មិនមែនជាភិក្ខុមិនត្រូវអាបត្តិទេ ខ្ញុំជាភិក្ខុដែលសង្ឃ (គួរ)

លើកវត្តហើយ មិនមែនជាភិក្ខុ ដែលសង្ឃលើកវត្តមិនបានទេ ខ្ញុំជាភិក្ខុដែលសង្ឃលើកវត្តហើយ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ បពិត្រលោកដ៏មានអាយុទាំងឡាយ សូមអស់លោក មកធ្វើឱសារណាកម្ម ចំពោះខ្ញុំចុះ សូមទ្រង់ព្រះមេត្តាប្រោស តើយើងខ្ញុំព្រះអង្គ គួរប្រតិបត្តិដូចម្តេចទៅ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះជាអាបត្តិ នេះមិនមែនជាអនាបត្តិទេ ភិក្ខុនេះ ជាអ្នកត្រូវអាបត្តិហើយ ភិក្ខុនេះ មិនមែនជាមិនត្រូវអាបត្តិទេ ភិក្ខុនេះ ជាភិក្ខុដែលសង្ឃ (គួរ) លើកវត្តហើយ ភិក្ខុនេះ មិនមែនជាភិក្ខុ ដែលសង្ឃលើកវត្តមិនបានទេ ភិក្ខុនេះ សង្ឃបានលើកវត្តហើយ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកំរើក ជាកម្មគួរដល់ហេតុ ម្នាលភិក្ខុទាំងឡាយ វេលាណា បើភិក្ខុនោះត្រូវអាបត្តិផង សង្ឃលើកវត្តហើយផង ឃើញអាបត្តិផង ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នករាល់គ្នា ចូរធ្វើឱសារណកម្មភិក្ខុនោះវេលានោះចុះ។

## ២៧៨. សង្ឃសាមគ្គីកថា

CS vin.mv.10.08 | ភាគ ទី៨

**(២៧៨)**

វេលានោះ ឧក្ខិត្តានុវត្តកភិក្ខុទាំងនោះ ក៏បានធ្វើឱសារណកម្ម ចំពោះឧក្ខិត្តកភិក្ខុនោះរួចហើយ ក៏ចូលទៅរកពួកឧក្ខេបកភិក្ខុវិញ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះ នឹងពួកឧក្ខេបកភិក្ខុថា នែអាវុសោ សេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីកាន់យកផ្សេងៗ ការវិវាទ ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃ ព្រោះរឿងរ៉ាវណា ភិក្ខុនោះឯង ត្រូវអាបត្តិផង សង្ឃបានលើកវត្តផង ឃើញអាបត្តិផង សង្ឃបានធ្វើឱសារណកម្មស្រេចហើយ នែអាវុសោ ណ្ហើយចុះ យើងធ្វើសង្ឃសាមគ្គី ដើម្បីនឹងរម្ងាប់រឿងរ៉ាវនោះចេញ។ វេលានោះ ឧក្ខេបកភិក្ខុទាំងនោះ ក៏បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះពួកឧក្ខេបកភិក្ខុនោះ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ពួកឧក្ខិត្តានុវត្តកភិក្ខុនោះ បាននិយាយ យ៉ាងនេះថា នែអាវុសោ សេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីកាន់យកផ្សេងៗ ការវិវាទ ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃ ព្រោះរឿងរ៉ាវណា ភិក្ខុនោះឯង ដែលត្រូវអាបត្តិផង សង្ឃបានលើកវត្តផង បានឃើញអាបត្តិផង សង្ឃបានធ្វើឱសារណកម្មស្រេចហើយផង នែអាវុសោ ណ្ហើយចុះ យើងធ្វើសង្ឃសាមគ្គី ដើម្បីរម្ងាប់រឿងរ៉ាវនោះចេញ សូមទ្រង់ព្រះមេត្តាប្រោស តើពួកខ្ញុំព្រះអង្គ ត្រូវប្រតិបត្តិដូចម្តេចទៅ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វេលាណា បើភិក្ខុនោះ ត្រូវអាបត្តិផង សង្ឃបានលើកវត្តផង ឃើញអាបត្តិផង សង្ឃបានធ្វើឱសារណកម្មផងម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើសង្ឃសាមគ្គី ដើម្បីរម្ងាប់រឿងរ៉ាវនោះចេញ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវធ្វើបែបយ៉ាងនេះ។ ភិក្ខុទាំងអស់ ត្រូវប្រជុំគ្នាក្នុងទីតែមួយ ពួកភិក្ខុឯណានីមួយ ទោះឈឺក្តី មិនឈឺក្តី មិនបាច់ឲ្យឆន្ទៈទេ។ លុះប្រជុំគ្នារួចហើយ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ដ្បិតសេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដមានដល់សង្ឃហើយ ព្រោះរឿងណា ភិក្ខុនោះហើយ ដែលត្រូវអាបត្តិផង សង្ឃបានលើកវត្តផង ឃើញអាបត្តិផង សង្ឃបានធ្វើឱសារណកម្មស្រេចហើយផង។ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើសង្ឃសាមគ្គី ដើម្បីរម្ងាប់រឿងនោះចេញ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ដ្បិតសេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា ភិក្ខុនោះហើយ ដែលត្រូវអាបត្តិផង សង្ឃបានលើកវត្តផង ឃើញអាបត្តិផង សង្ឃបានធ្វើឱសារណកម្មផង។ ឥឡូវ សង្ឃបានធ្វើសង្ឃសាមគ្គី ដើម្បីរម្ងាប់រឿងនោះហើយ។ ការធ្វើសង្ឃសាមគ្គី ដើម្បីរម្ងាប់រឿងនោះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ឯសង្ឃសាមគ្គី សង្ឃបានធ្វើហើយ ការបំបែកសង្ឃ សង្ឃក៏បានផ្សះផ្សាហើយ សេចក្តីកំណត់របស់សង្ឃ សង្ឃក៏បានផ្សះផ្សាហើយ ទាំងអំពើផ្សេងៗរបស់សង្ឃ សង្ឃក៏បានផ្សះផ្សាហើយ ដើម្បីរម្ងាប់នូវរឿងនោះ។ ការធ្វើសង្ឃសាមគ្គី ប្រហែលជាគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីព្រមព្រៀងនេះ ដោយការស្ងៀមនៅយ៉ាងនេះ។ សង្ឃត្រូវធ្វើឧបោសថ ត្រូវសំដែងបាតិមោក្ខ ក្នុងខណៈនោះឯង។

## ២៧៩. ឧបាលិសង្ឃសាមគ្គីបុច្ឆា

CS vin.mv.10.09 | ភាគ ទី៨

**(២៧៩)**

[១៦៥] គ្រានោះ ព្រះឧបាលិដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃមិនទាន់បានជំរះរឿងនោះ មិនទាន់ដឹងដើមហេតុ តាមហេតុនៃរឿងនោះ ហើយស្រាប់តែធ្វើសង្ឃសាមគ្គីតែម្តង សូមទ្រង់ព្រះមេត្តាប្រោស សង្ឃសាមគ្គីនោះ ប្រកបដោយធម៌ដែរឬ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែឧបាលិ សេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ ការប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃមិនទាន់បានជំរះរឿងនោះ មិនទាន់ដឹងដើមហេតុ តាមហេតុនៃរឿងនោះ ហើយស្រាប់តែធ្វើសង្ឃសាមគ្គីតែម្តង នែឧបាលិ សង្ឃសាមគ្គីនោះ មិនប្រកបដោយធម៌ទេ។ ព្រះឧបាលិ ក្រាបបង្គំទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ម្យ៉ាងទៀត ចុះបើសេចក្តីបង្កហេតុ សេចក្តីឈ្លោះ សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃបានជំរះរឿងនោះ បានដឹងដើម

ហេតុ តាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឃសាមគ្គីទៅ សូមទ្រង់ព្រះមេត្តាប្រោស សង្ឃសាមគ្គីនោះ ប្រកបដោយធម៌ដែរឬ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា នែឧបាលិ សេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃក៏បានជំរះរឿងនោះចេញ បានដឹងដើមហេតុ តាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឃសាមគ្គីទៅ នែឧបាលិ សង្ឃសាមគ្គីនោះ ហៅថា ប្រកបដោយធម៌។ ព្រះឧបាលិ ក្រាបបង្គំទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស សង្ឃសាមគ្គី តើមានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា នែឧបាលិ សង្ឃសាមគ្គី មានពីរយ៉ាង នែឧបាលិ សង្ឃសាមគ្គី ប្រាសចាកអត្ថ តែប្រកបដោយព្យញ្ជនៈ១ នែឧបាលិ សង្ឃសាមគ្គីប្រកបទាំងអត្ថ ទាំងព្យញ្ជនៈ១។ នែឧបាលិ ឯសង្ឃសាមគ្គី ដែលប្រាសចាកអត្ថ តែប្រកបដោយព្យញ្ជនៈ តើដូចម្តេច។ នែឧបាលិ សេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទ ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃមិនទាន់បានជំរះរឿងនោះ មិនទាន់ដឹងដើមហេតុ តាមហេតុនៃរឿងនោះ ហើយស្រាប់តែធ្វើសង្ឃសាមគ្គីទៅ នែឧបាលិ សង្ឃសាមគ្គីនេះ តថាគត ហៅថា ប្រាសចាកអត្ថ តែប្រកបដោយព្យញ្ជនៈ។ នែឧបាលិ ចំណែកខាងសង្ឃសាមគ្គី ដែលប្រកបទាំងអត្ថ ទាំងព្យញ្ជនៈ តើដូចម្តេច។ នែឧបាលិ សេចក្តីបង្កហេតុ សេចក្តីឈ្លោះគ្នា សេចក្តីប្រកាន់ផ្សេងៗគ្នា ការវិវាទគ្នា ការបំបែកសង្ឃ សេចក្តីប្រេះឆារ របស់សង្ឃ សេចក្តីកំណត់របស់សង្ឃ និងអំពើផ្សេងៗ របស់សង្ឃ ប្រាកដដល់សង្ឃហើយ ព្រោះរឿងណា សង្ឃក៏បានជំរះរឿងនោះ បានដឹងដើមហេតុ តាមហេតុនៃរឿងនោះ ហើយក៏ធ្វើសង្ឃសាមគ្គីទៅ នែឧបាលិ សង្ឃសាមគ្គីនេះ តថាគត ហៅថា ប្រកបទាំងអត្ថ ទាំងព្យញ្ជនៈ។ នែឧបាលិ សង្ឃសាមគ្គី មានពីរយ៉ាងនេះឯង។ វេលានោះ ព្រះឧបាលិដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈ (ចីពរ) ឆៀងស្មាម្ខាង រួចប្រណម្យអញ្ជលី ចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគ ដោយព្រះគាថា ថា

[១៦៦] កាលបើកិច្ចក្តី ការប្រឹក្សាវិន័យក្តី សេចក្តីអធិប្បាយវិន័យក្តី សេចក្តីវិនិច្ឆ័យវិន័យក្តី កើតចំពោះសង្ឃហើយ តើជន គឺភិក្ខុមានប្រការដូចម្តេច ទើបហៅថា មានឧបការៈច្រើន ក្នុងសាសនានេះ និងដូចម្តេច ដែលគួរលើកដម្កើង ក្នុងសាសនានេះ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ភិក្ខុនោះ ដែលគេមិនគួរតិះដៀល ដោយសីលជាបឋម បានពិចារណាមើលមារយាទខ្លួន បានសង្រួមឥន្ទ្រិយ ដោយល្អហើយ ពួកសត្រូវ ក៏មិនបានតិះដៀល ដោយធម៌ឡើយ អ្នកដទៃ គួរនិយាយ (បន្ទោស) ភិក្ខុដោយហេតុណា ហេតុនោះ មិនមានដល់ភិក្ខុនោះឡើយ។ ភិក្ខុបែបនោះឯង តាំងនៅក្នុងសីលវិសុទ្ធិ ក្លៀវក្លា អង់អាច និយាយគ្របសង្កត់គេបាន ទៅក្នុងកណ្តាលបរិសទ្យ ក៏គ្មានតក់ស្លុត គ្មានរន្ធត់ឡើយ ភិក្ខុនោះ មិនបាននិយាយពាក្យមិនគួរ ដែលញុំាងប្រយោជន៍ឲ្យសាបសូន្យឡើយ (បើមាន) គេសួរប្រស្នា ក្នុងពួកបរិសទ្យយ៉ាងនោះ ក៏ឥតជ្រប់ស្រពោន ឥតអៀនអន់ឡើយ។ ភិក្ខុនោះ មានប្រាជ្ញា ញុំាងបរិសទ្យ ជាអ្នកប្រាជ្ញឲ្យត្រេកអរ និងពាក្យដែលមានមកក្នុងកាលគួរ និងគួរជាទីដោះស្រាយប្រស្នាបាន ទាំងមានសេចក្តីគោរពពួកភិក្ខុចាស់ជាង និងក្លៀវក្លាក្នុងពាក្យអាចារ្យរបស់ខ្លួន ហើយអាចពិចារណា នូវហេតុនោះៗ និងស្ទាត់ក្នុងពាក្យដែលគួរនិយាយ ឆ្លាសក្នុងហេតុដែលភ្លាត់ខុសរបស់ពួកសត្រូវ ពួកសត្រូវសង្កត់សង្កិនក្តី មហាជនតែងពន្យល់ក្តី ដោយពាក្យណា ភិក្ខុនេះ មិនលះបង់ នូវពាក្យអាចារ្យរបស់ខ្លួន ដោយពាក្យនោះឡើយ កាលនឹងដោះស្រាយប្រស្នា ជាប្រស្នាមិនបានបៀតបៀនឡើយ ហើយអាចក្នុងទូតេយ្យកម្មផង ទទួលរងខាងកិច្ចការ របស់សង្ឃផង ដូចជាជនអ្នកទទួលយកនូវគ្រឿងបូជា ភិក្ខុនោះ កាលពួកភិក្ខុបញ្ជូនទៅ (ដើម្បី) ធ្វើនូវពាក្យជាកិច្ចការរបស់សង្ឃ ក៏មិនបានមើលងាយ ដោយអំពើនោះថា អាត្មាអញធ្វើឡើយ បើត្រូវអាបត្តិ ក្នុងវត្ថុមានប្រមាណណា ក៏ចេញចាកអាបត្តិ ដោយសមគួរតាម (វត្ថុមានប្រមាណប៉ុណ្ណោះ) ភិក្ខុនោះ ចេះចាំស្ទាត់ នូវវិភង្គទាំងពីរនេះ ហើយវាងវៃ ក្នុងហេតុដែលចេញចាកអាបត្តិ ប្រសិនបើភិក្ខុដទៃ ប្រព្រឹត្តនូវអំពើទាំងឡាយណា មានសេចក្តីបង្កហេតុជាដើម ហើយគួរនឹងធ្វើនិស្សារណាកម្ម (កម្មដែលរលាស់ខ្លួនចេញ) ភិក្ខុនោះ បានជួយធ្វើនិស្សារណាកម្ម ដោយសមគួរតាមរឿង (នៃអំពើនោះ) ឱសារណាកម្ម (កម្មដែលសង្ឃឲ្យចូលពួកវិញ) ណា ដែលសង្ឃត្រូវធ្វើចំពោះជន គឺភិក្ខុដែលប្រព្រឹត្តតាមវត្តនោះ ភិក្ខុនោះ ក៏ឆ្លាសក្នុងវិភង្គ អាចស្គាល់ឱសារណាកម្មនុ៎ះឯង ភិក្ខុនោះ ប្រកបដោយសេចក្តីគោរព ក្នុងពួកភិក្ខុដែលចាស់ជាងខ្លួន ម្យ៉ាងទៀត ប្រកបដោយសេចក្តីគោរពក្នុងភិក្ខុខ្ចីផង ភិក្ខុចាស់ផង ភិក្ខុជាកណ្តាលផង ជាបណ្ឌិតប្រព្រឹត្តនូវប្រយោជន៍ដល់មហាជន ក្នុងលោកនេះ ភិក្ខុបែបនោះឯង គួរគេនឹងដម្កល់ដម្កើងក្នុងសាសនានេះ។

ចប់ កោសម្ពិក្ខន្ធកៈ ទី១០។

## ២៨០. តស្សុទ្ទានំ

CS vin.mv.10.10 | ភាគ ទី៨

### ឧទ្ទាននៃកោសម្ពិក្ខន្ធកៈនោះគឺ

[១៦៧] រឿងព្រះជិនស្រីដ៏ប្រសើរ គង់ក្នុងក្រុងកោសម្ពី១ រឿងវិវាទព្រោះឃើញអាបត្តិ១ រឿងភិក្ខុលើកវត្ត ព្រោះមិនឃើញអាបត្តិនោះ១ រឿងព្រះអង្គទ្រង់ត្រាស់ថា អាបត្តិណា មានដល់ភិក្ខុនោះ ភិក្ខុនោះ ត្រូវសំដែងអាបត្តិនោះចេញ១ រឿងឧក្ខិត្តានុវត្តកភិក្ខុ ធ្វើឧបោសថ សង្ឃកម្មខាងក្នុងសីមា១ រឿងព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ពាលកលោណការកគ្រាម១ រឿងព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ព្រៃបាចីនវង្ស១ រឿងព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ប្រទេស ឈ្មោះបារិលេយ្យកៈ១ រឿងព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ក្រុងសាវត្ថី១ រឿងព្រះសារីបុត្ត ព្រះកោលិតៈ (មោគ្គលាន) ព្រះមហាកស្សប ព្រះមហាកច្ចានៈ ព្រះកោដ្ឋិតៈ ព្រះកប្បិន ព្រះមហាចុន្ទ ព្រះអនុរុទ្ធ ព្រះរេវតៈ ព្រះឧបាលិ ព្រះអានន្ទ និងព្រះរាហុល១ រឿងព្រះនាងគោតមី១ រឿងអនាថបិណ្ឌិកសេដ្ឋី១ រឿងនាងវិសាខា ជាមិគារមាតា១ រឿងព្រះសារីបុត្ត ក្រាបបង្គំទូលព្រះអង្គថា យើងខ្ញុំត្រូវប្រតិបត្តិ ភិក្ខុទាំងនោះ ដោយសេនាសនៈដូចម្តេច១ រឿងសេនាសនៈស្ងាត់១ រឿងចែកគ្រឿងអាមិសៈស្មើគ្នា១ រឿងភិក្ខុណាមួយមិនត្រូវឲ្យឆន្ទៈ១ រឿងព្រះឧបាលិ ក្រាបបង្គំទូលសួរ១ រឿងបុគ្គល ដែលគេមិនគួរតិះដៀល ដោយសីល១ រឿងសង្ឃសាមគ្គីក្នុងសាសនាព្រះជិនស្រី១។

ចប់ មហាវគ្គ។

ចប់ ភាគ៨។

# មាតិកា


| **មហាវគ្គ តតិយភាគ** | លេខ ទំព័រ |
| --- | --- |
| **កឋិនក្ខន្ធកៈ** | **១** |
| រឿងភិក្ខុ ៣០ រូប នៅក្នុងដែនបាឋេយ្យ | ១ |
| ពោលអំពីអានិសង្ស កឋិន មាន ៥ យ៉ាង | ៣ |
| ពោលអំពីកឋិនដែលភិក្ខុក្រាលមិនឡើង | ៥ |
| ពោលអំពីកឋិនដែលភិក្ខុក្រាលឡើង | ៧ |
| ពោលអំពីកឋិនដែលនឹងដោះ និយាយអំពីមាតិកា ៨ យ៉ាង | ៩ |
| និយាយពីកឋិនដោះ អាទាយសត្តកវារ | ១១ |
| និយាយពីកឋិនដោះ អាទាយឆក្កវារ | ១៣ |
| និយាយពីកឋិនដោះ សមាទាយឆក្កវារ | ១៥ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរវិនាសជាកំណត់ ជាដើម | ១៧ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់សេចក្ដីសន្និដ្ឋានជាកំណត់ ជាដើម | ២១ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរសម្រេចជាកំណត់ ជាដើម | ២៣ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់បានឮដំណឹងជាកំណត់ ជាដើម | ២៥ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរវិនាសជាកំណត់ ជាដើម | ២៧ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរសម្រេចជាកំណត់ ជាដើម | ២៩ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់សេចក្ដីសន្និដ្ឋានជាកំណត់ ជាដើម | ៣៣ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់អស់សេចក្ដីសង្ឃឹមជាកំណត់ ជាដើម | ៣៥ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរវិនាសជាកំណត់ ជាដើម | ៣៧ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់អស់សេចក្ដីសង្ឃឹមជាកំណត់ ជាដើម | ៣៩ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរវិនាសជាកំណត់ ជាដើម | ៤១ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់សេចក្ដីសន្និដ្ឋានជាកំណត់ ជាដើម | ៤៥ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់ចីវរសម្រេចជាកំណត់ ជាដើម | ៤៧ |
| និយាយពីកឋិនដោះ ការដោះកឋិនត្រង់សេចក្ដីសន្និដ្ឋានជាកំណត់ ជាដើម | ៤៩ |
| និយាយពីបលិពោធ និងអបលិពោធ | ៥១ |
| ឧទ្ទានគាថា | ៥៣ |
| **ចីវរក្ខន្ធកៈ** | **៦១** |
| រឿងពួកកុដុម្ពិកនៅក្រុងរាជគ្រឹះ | ៦៣ |
| រឿងជីវកកោមារភច្ច | ៦៥ |
| រឿងជីវកកោមារភច្ច និងរឿងភិរិយាសេដ្ឋី | ៦៩ |
| និយាយពីរឿងព្រះបាទពិម្ពិសារកើតរោគឫសដូងបាទ | ៧៥ |
| និយាយពីសេដ្ឋីក្រុងរាជគ្រឹះកើតរោគឈឺក្បាល | ៧៧ |
| និយាយពីរឿងកូនសេដ្ឋីកើតរោគដុំពោះវៀន | ៨៣ |
| និយាយពីរឿងព្រះបាទចណ្ឌបជ្ជោតកើតរោគស្លេមលឿង | ៨៥ |

| | |
|---|---|
| រឿងព្រះបាទចណ្ឌបជ្ជោត និយាយពីការថ្វាយសប្បិ | ៨៧ |
| រឿងព្រះបាទចណ្ឌបជ្ជោត និយាយពីការឲ្យផ្លែកន្ទួតព្រៃដល់ខ្ញុំឈ្មោះកាក | ៨៩ |
| និយាយពីព្រះដ៏មានព្រះភាគ ទ្រង់ហិត ថ្នាំបញ្ចុះ | ៩១ |
| ការទ្រង់អនុញ្ញាតគហបតីចីវរ | ៩៧ |
| សំពត់កម្ពលមានដំឡៃកន្លះពាន់របស់ស្តេចកាសី | ៩៩ |
| និយាយពី ការទ្រង់អនុញ្ញាត ចីវរ ៦ យ៉ាង និងគហបតិចីវរ | ១០១ |
| និយាយពីភិក្ខុចូលទៅកាន់ព្រៃស្មសាន | ១០៣ |
| ការសន្មតិភិក្ខុឲ្យជាអ្នកទទួលចីវរ | ១០៥ |
| ការសន្មតិឃ្លាំង | ១០៧ |
| ការសន្មតិភិក្ខុឲ្យជាអ្នករក្សាឃ្លាំង | ១០៩ |
| ការសន្មតិភិក្ខុឲ្យជាអ្នកចែកចីវរ | ១១១ |
| ការទ្រង់អនុញ្ញាតទឹកជ្រលក់ ៦ យ៉ាង | ១១៣ |
| ការទ្រង់អនុញ្ញាតខ្សែសម្រាប់ចងជាយចីវរ ជាដើម | ១១៥ |
| រឿងព្រះអានន្ទត្ថេរ | ១១៧ |
| និយាយពីរាត្រីជាចន្លោះនៃខែមាឃ និងខែផល្គុណ | ១១៩ |
| សេចក្តីបញ្ញត្តិអតិរេកចីវរ | ១២១ |
| រឿងភិក្ខុ ១ រូប មានស្បង់ធ្លុះ | ១២៣ |
| រឿងនាងវិសាខាមិគារមាតា | ១២៥ |
| រឿងនាងវិសាខាមិគារមាតា និយាយអំពីពរ ៨ប្រការ | ១២៦ |
| និយាយពីភិក្ខុភ្លេចស្មារតីសិងលក់ | ១៣៧ |
| ការទ្រង់អនុញ្ញាតនិសីទន សំពត់ទ្រាប់អង្គុយ | ១៣៩ |
| ការទ្រង់អនុញ្ញាតសំពត់សម្រាប់ជូតមុខ | ១៤០ |
| ការទ្រង់អនុញ្ញាតនូវការអធិដ្ឋានត្រៃចីវរ ជាដើម | ១៤៣ |
| ភិក្ខុមិនត្រូវទ្រទ្រង់ចីវរដែលមិនកាត់ទាំងអស់ | ១៤៥ |
| ហេតុដែលគួរទុកដាក់ត្រៃចីវរ | ១៤៧ |
| និយាយពីចីវរជារបស់សង្ឃ | ១៤៩ |
| រឿងឧបនន្ទ និយាយអំពីចំណែកចីវរ | ១៥៣ |
| រឿងភិក្ខុមានរោគឈឺពោះ | ១៥៧ |
| និយាយអំពីភិក្ខុអ្នកបម្រើជម្ងឺ | ១៥៩ |
| និយាយអំពីការឲ្យបាត្រ និងចីវររបស់ភិក្ខុស្លាប់ ដល់អ្នកបម្រើជម្ងឺ | ១៦១ |
| និយាយអំពីតិត្ថិយសមាទាន មានការអាក្រាត ជាដើម | ១៦៥ |
| រឿងឆព្វគ្គិយភិក្ខុ និយាយអំពីការទ្រទ្រង់ចីវរមានពណ៌ខៀវសុទ្ធ ជាដើម | ១៦៩ |
| និយាយអំពីចីវរដែលមិនទាន់កើតឡើងដល់ភិក្ខុដែល នៅចាំវស្សារួចហើយ | ១៧១ |
| រឿងព្រះរេវតត្ថេរ និយាយអំពីការកាន់យកចីវរដោយសេចក្តីស្និទ្ធស្នាល | ១៧៥ |
| មាតិកា ៨ យ៉ាង ដែលជាហេតុឲ្យកើតចីវរ | ១៧៩ |
| ឧទ្ទានគាថា | ១៨១ |
| | |

| | |
|---|---|
| **ចម្លេយ្យភត្ថន្ទកៈ** | **១៨៨** |
| រឿងកស្សបគោត្តភិក្ខុ | ១៨៩ |
| រឿងអាគន្តុកភិក្ខុ | ១៩៥ |
| ឧក្ខេបនីយកម្ម និយាយអំពីកម្ម និងមិនមែនកម្ម | ១៩៩ |
| និយាយអំពីកម្ម ៤ យ៉ាង | ២០១ |
| រឿងឆព្វគ្គិយភិក្ខុ និយាយអំពីធម្មជាតមិនមែនជាកម្ម | ២០៣ |
| និយាយអំពីកម្ម ៦ យ៉ាង | ២០៥ |
| និយាយអំពីជំនុំសង្ឃ មាន ៥ ពួក និងកម្មសម្រាប់ធ្វើដោយសង្ឃចតុវគ្គ | ២១៣ |
| និយាយអំពីជំនុំសង្ឃ មាន ៥ ពួក និងកម្មសម្រាប់ធ្វើដោយសង្ឃទសវគ្គ | ២១៥ |
| និយាយអំពីជំនុំសង្ឃ មាន ៥ ពួក និងកម្មសម្រាប់ធ្វើដោយសង្ឃវីសតិវគ្គ | ២១៧ |
| ការហាមឃាត់ កណ្តាលជំនុំសង្ឃ របស់បុគ្គល ខ្លះឡើង ខ្លះមិនឡើង | ២១៩ |
| និស្សារណាកម្ម ការបណ្តេញចេញ មានពីរយ៉ាង | ២២១ |
| ឱសារណាកម្ម ការហៅបញ្ចូលពួក មានពីរយ៉ាង | ២២៣ |
| ឧក្ខេបនីយកម្មដែលជាកម្មមិនប្រកបដោយធម៌ | ២២៥ |
| ឧក្ខេបនីយកម្មដែលជាកម្មប្រកបដោយធម៌ | ២៣១ |
| ពាក្យសួររបស់ឧបាលិត្ថេរអំពីបព្វាជនីយកម្ម ជាដើម | ២៣៣ |
| ពាក្យសួររបស់ឧបាលិត្ថេរអំពីកម្មដែលមិនមែនជាធម្មវិន័យ | ២៣៧ |
| ពាក្យសួររបស់ឧបាលិត្ថេរអំពីកម្មដែលជាធម៌ជាវិន័យ | ២៤១ |
| កម្មដែលមិនមែនជាធម៌ជាវិន័យ | ២៤៣ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ តជ្ជនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៤៥ |
| ពួកភិក្ខុព្រមព្រៀងគ្នា ធ្វើ តជ្ជនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៤៧ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ តជ្ជនីយកម្មប្រកបដោយធម៌ ជាដើម | ២៤៩ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ តជ្ជនីយកម្មប្រកបដោយធម៌ប្លម ជាដើម | ២៥១ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ តជ្ជនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៥៣ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ បព្វាជនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៥៥ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៥៧ |
| ពួកភិក្ខុព្រមព្រៀងគ្នា រំងាប់ តជ្ជនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៥៩ |
| ភិក្ខុទាំងឡាយជាពួក រំងាប់ តជ្ជនីយកម្មដោយការប្លមធម៌ ជាដើម | ២៦១ |
| ភិក្ខុទាំងឡាយជាពួក រំងាប់ បដិសារណីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៦៣ |
| ភិក្ខុទាំងឡាយជាពួក រំងាប់ ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៦៥ |
| ពួកភិក្ខុព្រមព្រៀងគ្នា ធ្វើ តជ្ជនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៦៧ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ តជ្ជនីយកម្មដោយការប្លមធម៌ ជាដើម | ២៦៩ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ និយស្សកម្មមិនប្រកបដោយធម៌ ជាដើម | ២៧១ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ បព្វាជនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៧៣ |
| ភិក្ខុទាំងឡាយជាពួក ធ្វើ ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៧៥ |
| ពួកភិក្ខុព្រមព្រៀងគ្នា ធ្វើ ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៧៧ |
| ភិក្ខុទាំងឡាយជាពួក រំងាប់ តជ្ជនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៧៩ |

| | |
|---|---|
| ភិក្ខុទាំងឡាយជាពួក រំងាប់ តជ្ជនីយកម្មប្រកបដោយធម៌ ជាដើម | ២៨១ |
| ពួកភិក្ខុព្រមព្រៀងគ្នា រំងាប់ តជ្ជនីយកម្មដោយការប្លមធម៌ ជាដើម | ២៨៣ |
| ភិក្ខុទាំងឡាយជាពួក រំងាប់ និយស្សកម្មមិនប្រកបដោយធម៌ ជាដើម | ២៨៥ |
| ភិក្ខុទាំងឡាយជាពួក រំងាប់ បដិសារណីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៨៧ |
| ភិក្ខុទាំងឡាយជាពួក រំងាប់ ឧក្ខេបនីយកម្មមិនប្រកបដោយធម៌ ជាដើម | ២៨៩ |
| ឧទ្ទានគាថា | ២៩៣ |
| **កោសម្ពិក្ខន្ធកៈ** | **៣០៤** |
| និទានភិក្ខុ ១ រូប ត្រូវអាបត្តិ | ៣០៤ |
| ការយល់ឃើញអាបត្តិ ថាជាអាបត្តិមែន | ៣០៥ |
| ពួកភិក្ខុអ្នកប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត | ៣០៩ |
| ការយល់ឃើញអាបត្តិ ថាជាអនាបត្តិ | ៣១១ |
| ការធ្វើឧបោសថកម្មជាដើម ក្នុងទីច្ចដ៏ខាងក្នុងនៃសីមា ជាដើម | ៣១៥ |
| និយាយអំពីការបង្កហេតុ និងជំលោះ ជាដើម | ៣១៧ |
| រឿងទីឃាវុកុមារ | ៣២៩ |
| អំណត់នឹងការប្រព្រឹត្តិល្អ និងគាថាសំដែងអំពីការរំងាប់នូវពៀរ | ៣៤៣ |
| គាថាសំដែងអំពីការរំងាប់នូវពៀរ | ៣៤៥ |
| ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ពាលកលោណការកគ្រាម | ៣៤៧ |
| សាមគ្គីធម្មកថា | ៣៤៩ |
| រឿងដំរីដ៏ប្រសើរឈ្មោះបារិលេយ្យក | ៣៥៥ |
| ពួកឧបាសកក្នុងក្រុងកោសម្ពីមិនធ្វើកម្ម មានអភិវាទនកម្ម ជាដើម | ៣៥៧ |
| បុគ្គលពោលខុសធម៌ដោយវត្ថុ ១៨ យ៉ាង | ៣៥៩ |
| បុគ្គលពោលត្រូវធម៌ដោយវត្ថុ ១៨ យ៉ាង | ៣៦១ |
| ពាក្យសួររបស់មហាបជាបតីគោតមី | ៣៦៣ |
| ពាក្យសួររបស់វិសាខាមិគារមាតា | ៣៦៥ |
| ការធ្វើ ឱសារណាកម្មចំពោះឧក្ខិត្តកភិក្ខុ | ៣៦៧ |
| ការធ្វើសង្ឃសាមគ្គី | ៣៦៩ |
| សង្ឃសាមគ្គី មានពីរយ៉ាង | ៣៧៣ |
| ឧបាលិគាថា | ៣៧៥ |
| ឧទ្ទានគាថា | ៣៧៨ |



1)

យោជនាថា នៅក្នុងដែនបាវាដូច្នេះក៏មាន។

2)

បីខែ

3)

ភិក្ខុនោះមានគំនិតជាកណ្ដាល នឹងគិតថាត្រឡប់វិញ ឬមិនត្រឡប់វិញជាដាច់ខាត ក៏ទេ។

4)

ជាតិសត្វតូចៗ (មេរោគ)។

5)

អដ្ឋកថា ថា បានដល់សំពត់ដែលគេចោលនៅព្រៃខ្មោច ក្នុងឧត្តរកុរុទ្វីប។ បានឮមកថា ពួកមនុស្សក្នុងឧត្តរកុរុទ្វីប តែងរុំសាកសពដោយសំពត់នោះឯង ហើយយកទៅចោល។ មានសត្វបក្សី មានប្រមាណដូចដំរី វាសំគាល់នូវសំពត់នោះ ថាជាដុំសាច់ ហើយឆាបនាំយកទៅដំកល់ទុកលើកំពូលភ្នំហិមពាន្ត បកសំពត់នោះចោលចេញ វាស៊ីសាច់សពនោះ។ វេលានោះ ពួកអ្នកដើរព្រៃ បានឃើញសំពត់នោះហើយ ក៏នាំយកមកថ្វាយស្តេច។ សំពត់នេះហើយ ដែលព្រះបាទបជ្ជោត បានមកដោយហេតុយ៉ាងនេះឯង។

6)

សំពត់បែបយ៉ាងល្អ ដែលគេធ្វើមានលាយដោយរោមសត្វដ៏ទន់។

7)

(អដ្ឋកថា) សំពត់នេះ ប្រហែលគ្នានឹងសំពត់បាវារៈ សំពត់នេះ គេធ្វើពីរោមសត្វ។

8)

បុគ្គលដែលមិនត្រូវបណ្តេញចេញ ចាកទីកន្លែង មាន៤ពួក គឺភិក្ខុចាស់ជាង១ ភិក្ខុជាអ្នករក្សាឃ្លាំង១ ភិក្ខុមានជម្ងឺ១ ភិក្ខុដែលបានសេនាសនៈអំពីសង្ឃ១។ ភិក្ខុក្មេងមិនត្រូវបណ្តេញភិក្ខុចាស់ចេញ ព្រោះលោកចាស់ជាងខ្លួន។ ភិក្ខុជាអ្នករក្សាឃ្លាំង ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះសង្ឃបានសន្មតឲ្យជាអ្នករក្សាឃ្លាំង។ ភិក្ខុមានជម្ងឺ ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះលោកឈឺ។ ភិក្ខុដែលបានសេនាសនៈ អំពីសង្ឃ ភិក្ខុមិនត្រូវបណ្តេញចេញ ព្រោះសង្ឃបានឲ្យទីកន្លែង ជាទីសប្បាយ ដល់លោក ដែលជាពហូសូត្រ មានឧបការៈដល់សង្ឃដោយកិច្ច មានបង្រៀនបាឡី និងអដ្ឋកថាជាដើម (អដ្ឋកថា)។

9)

បានដល់សង្ឃ ដែលនៅខាងក្នុងឧបចារសីមាជាមួយគ្នា (អដ្ឋកថា)។

10)

គឺដាក់ឈើតារាងនៅមាត់ឆ្នាំង ដើម្បីកុំឲ្យគ្រឿងជ្រលក់ មានចំណាំងឈើជាដើម ផុលឡើងបាន។

11)

បើទឹកដែលដាំពុះហើយ យកទៅបន្តក់លើភាជនៈទឹក (ដទៃ) ក៏មិនសាយចេញរហ័ស ឬបន្តក់លើខ្នងក្រចក ក៏ដូច្នោះដែរ (អដ្ឋកថា)។

12)

វិមតិវិនោទនីដីកាថា រាត្រី៨ គឺខាងចុងខែមាឃ ៤រាត្រី ខាងដើមខែផល្គុណ៤រាត្រី ហៅថា រាត្រីនៅជាចន្លោះនៃខែមាឃ និងខែផល្គុណ។

13)

បានដល់សំពត់ ដែលភិក្ខុប៉ះត្រង់កន្លែងធ្លុះ ឬត្រង់កន្លែងដែលខ្លួនកាត់ចេញ។

14)

បានដល់សំពត់ ដែលភិក្ខុប៉ះត្រង់កន្លែង ដែលមិនបានកាត់ចេញ។

15)

ភិក្ខុទាំងនោះ ងូតទឹកភ្លៀងគ្មានសំពត់ងូត (អាក្រាត)។

16)

ពេលគួរឆាន់ចង្ហាន់

17)

សំពត់សម្រាប់ងូតទឹក ឬដែលហៅជាពាក្យកាត់ខ្លីថា សំពត់ងូត។

18)

ជាសមណៈ ដើរតាមក្រោយព្រះអង្គ។

19)

ដើរវិលខាងស្តាំ

20)

អដ្ឋកថា ថា ព្រះមហាកស្សប លោកជាអ្នកគោរព ក្នុងការប៉ះចីវរបង្សុកូល ក្នុងកន្លែងដែលគ្រាំគ្រា។

21)

សំដៅយកកាលដទៃ អំពីរដូវភ្លៀង។

22)

អដ្ឋកថា ថា ត្រូវសង្ឃដែលឋិតនៅក្នុងឧបចារសីមា វាយរគាំង ប្រាប់វេលា ហើយសឹមចែកគ្នា។

23)

ច្បាប់ដែលព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្ត

24)

១.២ គឺរបស់រាយរង ក្រៅអំពីគរុភណ្ឌទាំង២៥

25)

២

26)

ទ្រង់ឃាត់ មិនឲ្យភិក្ខុប្រព្រឹត្តវត្ត បែបពួកតិរ្ថិយ ព្រោះតិរ្ថិយខ្លះអាក្រាត តមមិនស្លៀកសំពត់ មិនដណ្តប់សំពត់។

27)

នេះជាពាក្យសាធារណៈ នឹងហៅថាស្បៀក ឬហៅថាដណ្តប់ ឬហៅថា ពាក់ និងជួតជាដើមក៏បាន ហៅតាមសមគួរ ដល់របស់ដែលប្រើប្រាស់។

28)

បានសេចក្តីថា ភិក្ខុទាំងនោះ នៅចាំវស្សារួចហើយ មិនទាន់បានចីវរពីណាទេនៅឡើយ។

29)

សង្ឃបែកគ្នាជាពីរពួក ដូចពួកភិក្ខុនៅក្រុងកោសម្ពី (អដ្ឋកថា)។

30)

ចីវររបស់ភិក្ខុដែលស្លាប់

31)

សំដៅយកភិក្ខុអ្នកធ្វើចីវរ១រូប ភិក្ខុអ្នកចាំទទួលយកចីវរ១រូប។

32)

ការហៅបញ្ចូលពួក ដោយអំណាចនៃកម្ម មានឧបសម្បទា ឲ្យបានជាភិក្ខុភាវៈ ជាដើម ហៅថា ឱសារណាកម្ម។

33)

រឿងដែលត្រូវសំដែងវិលទៅរកសេចក្តីដើមវិញ ហៅថា ចក្ក គឺត្រូវបន្ថែមសេចក្តីខាងដើម និងខាងចុង ដូចរឿងរ៉ាវដែលនិយាយមកហើយ។

34)

ការថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន។

35)

ការគោរព ដោយកិរិយាក្រោកទទួល

36)

ការគោរព ដោយការប្រណម្យដៃ។

37)

ការកោតក្រែង

38)

គឺចងស្លាបសេក បណ្តើរអាក្រោស។

39)

ក្នុងអដ្ឋកថា មេត្តសូត្តថា បុគ្គលមានប្រាជ្ញា ចេះរក្សាសីល ឲ្យបរិសុទ្ធ និងពិចារណាបច្ច័យ មានចីវរជាដើម និងកំណត់ដឹងនូវសេចក្តីសប្បាយ៧យ៉ាង មានសប្បាយដោយអាវាសជាដើម ហៅថា មានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន។

40)

អដ្ឋកថាធម្មបទថា ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ១០ ធុតង្គគុណ១៣ វិបស្សនាញាណ មគ្គ៤ ផល៤ វិជ្ជា៣ អភិញ្ញា៦ អមតមហានិព្វាន ហៅថា សហាយតាគុណ។

41)

ព្រះអង្គទ្រង់ត្រាស់ហៅ មិនសំដៅយកព្រះអនុរុទ្ធតែមួយអង្គទេ ទ្រង់ត្រាស់ហៅ ចំពោះព្រះនាមព្រះថេរៈទាំងបីព្រះអង្គ។

42)

គ្រប់៥ថ្ងៃ តែងប្រជុំគ្នា និយាយធម៌អាថ៌ អស់មួយយប់។

43)

ពាក្យថា ពុទ្ធនាគ គឺព្រះពុទ្ធជាម្ចាស់។

44)

លើកតែអាបត្តិបារាជិកចេញ អាបត្តិទាំងអស់ ហៅថា សាវសេស។

45)

គឺអាបត្តិបារាជិក

sangham.net
Virtual AccessToInsight

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០០៩ - Book 009

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្ដីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថា លោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០០៩ - Tipitaka Book 009 [http://forum.sangham.net/index.php/topic,9187.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០០៩




គំរូ ឯកសារ ផ្សេងទៀត ៖
book_009.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី៩

ទ. ៖

# វិន័យបិដក

CS vin | ភាគ ទី៩

**ភាគ ទី៩**

# ចុល្លវគ្គ

CS vin.cv | ភាគ ទី៩

**(ចូឡវគ្គោ)**

**បឋមភាគ**
ភាគ ទី១

**កម្មក្ខន្ធកៈ** | **បារិវាសិកក្ខន្ធកៈ** | **សមុច្ចយក្ខន្ធកៈ**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

# កម្មក្ខន្ធកៈ (ទី១)

CS vin.cv.01 | ភាគ ទី៩

**(១. កម្មក្ខន្ធកំ)**

# (តជ្ជនីយកម្មជាបឋម ទី១)

CS vin.cv.01.01 | ភាគ ទី៩

### (១. តជ្ជនីយកម្មំ)

[១] សម័យនោះ ព្រះសព្វញ្ញុពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ[1] ទាំងឡាយ ជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ ដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃទៀត ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយពាក្យយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនោះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោករាល់គ្នាប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នា ក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្តីអៀនខ្មាស សេចក្តីអែង ជាអ្នកប្រាថ្នាក្នុងសិក្ខា ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ហេតុអ្វីបានជាបណ្ឌុកភិក្ខុ និងលោហិតកភិក្ខុទាំងឡាយ ជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ ដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃទៀត ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយពាក្យយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោករាល់គ្នា ប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក៏យកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះមានព្រះភាគ។

[២] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បានឮថា បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុទាំងឡាយ ជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ ដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃ ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោករាល់គ្នា ប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោក ចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះពួកយើងរាល់គ្នា ក៏ជាបក្ខពួករបស់លោកទាំងឡាយ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយ ដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះសព្វញ្ញុពុទ្ធមានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងអម្បាលនោះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុអ្វី បានជាមោឃបុរសទាំងអម្បាលនោះ បង្កហេតុ។បេ។ បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្កហេតុ។បេ។ ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោករាល់គ្នាប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬដឹកនាំពួកជន ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មានតែដឹកនាំសេចក្តីមិនជ្រះថ្លា ឲ្យកើតដល់ពួកជន ដែលមិនទាន់ជ្រះថ្លានៅឡើយ និងដឹកនាំជនទាំងឡាយខ្លះ ដែលជ្រះថ្លាស្រាប់ហើយ ឲ្យទាស់ចិត្តទៅវិញទេតើ។

[៣] គ្រានោះ ព្រះមានព្រះភាគ ទ្រង់តិះដៀលបណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ ដោយអនេកបរិយាយ ហើយទ្រង់សំដែងនូវទោស នៃសភាពជាបុគ្គល ដែលគេចិញ្ចឹមបានដោយកម្រ និងថែទាំបានដោយកម្រ មានសេចក្តីប្រាថ្នាច្រើន មិនមានសេចក្តីសន្តោស នៅច្រឡូកច្រឡំដោយពួក មានសេចក្តីខ្ជិលច្រអូស ទើបទ្រង់សំដែងគុណ នៃសភាព ជាបុគ្គល ដែលគេចិញ្ចឹមបានដោយងាយ និងថែទាំបានដោយងាយ មានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស មានចិត្តផូរផង់ កំចាត់បង់ នូវកិលេស នាំឲ្យកើតសេចក្តីជ្រះថ្លា មិនសន្សំនូវកិលេសវដ្ត ប្រារព្ធសេចក្តីព្យាយាម ហើយទ្រង់សំដែង នូវធម្មីកថា ដ៏ល្មមសមគួរដល់កម្មនោះៗ ដល់ភិក្ខុទាំងឡាយ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទើបមានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើ តជ្ជនីយកម្ម[2] ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុចុះ។ ម្នាលភិក្ខុទាំងឡាយ ឯតជ្ជនីយកម្មនោះ សង្ឃគប្បីធ្វើយ៉ាងនេះ។ សង្ឃត្រូវចោទបណ្ឌុក និងលោហិតកភិក្ខុជាមុន លុះចោទហើយ គប្បីរំលឹក លុះរំលឹកហើយ គប្បីលើកអាបត្តិឡើង លុះលើកអាបត្តិហើយ ភិក្ខុអ្នកឆ្លាសប្រតិពល គប្បីប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុនេះ ជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុដទៃទៀត ដែលជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោករាល់គ្នា ប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ទាំងជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នា ក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីធ្វើតជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុនេះ ជាអ្នកបង្កហេតុ។បេ។ បង្កអធិករណ៍ ក្នុងសង្ឃដោយ

ខ្លួនឯង ហើយចូលទៅរកភិក្ខុឯទៀត ដែលជាអ្នកបង្កហេតុ។បេ។ បង្កអធិករណ៍ ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោករាល់គ្នា ប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ទាំងជាអ្នកអង់អាចជាងភិក្ខុនោះផង ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នា ក៏ជាពួករបស់លោកទាំងឡាយដែរ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត។ សង្ឃធ្វើ តជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ។ ការធ្វើតជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុនេះ ជាអ្នកបង្កហេតុ។បេ។ បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្កហេតុ។បេ។ បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោករាល់គ្នា ប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នា ក៏ជាពួករបស់លោកទាំងឡាយដែរ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើត ក៏កើតឡើង ការបង្កហេតុទាំងឡាយ ដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត។ សង្ឃធ្វើ តជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ។ ការធ្វើតជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុនេះ ជាអ្នកបង្កហេតុ។បេ។ បង្កអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកបង្កហេតុ។បេ។ បង្កអធិករណ៍ក្នុងសង្ឃដូចគ្នាដែរ ហើយនិយាយយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុ៎ះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោករាល់គ្នា ប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ហើយជាអ្នកអង់អាចជាងភិក្ខុនោះ ម្យ៉ាងទៀត ពួកលោកចូរកុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នា ក៏ជាពួករបស់លោកទាំងឡាយដែរ។ ព្រោះហេតុនោះ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើត ក៏កើតឡើង ការបង្កហេតុទាំងឡាយដែលកើតឡើងហើយ ក៏រឹងរឹតតែកើតធំទូលាយឡើងទៀត។ សង្ឃធ្វើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ។ ការធ្វើ តជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានធ្វើតជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុហើយ ការធ្វើតជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុនោះ សមគួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

## (តជ្ជនីយកម្មមានចំនួន១២ក្នុងអធម្មកម្ម)

CS vin.cv.01.01.01 | ភាគ ទី៩

### (អធម្មកម្មទ្វាទសកំ)

[៤] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្ម ដែលសង្ឃរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ គឺកម្មដែលសង្ឃធ្វើកំបាំងមុខ១ កម្មដែលសង្ឃធ្វើ ដោយការមិនសាកសួរ១ កម្មដែលសង្ឃធ្វើ ដោយមិនតាមពាក្យប្តេជ្ញា របស់ភិក្ខុ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្ម (កម្មមិនប្រកបដោយធម៌) ផង ជាអវិន័យកម្ម (កម្មមិនប្រកបដោយវិន័យ) ផង ជាកម្ម ដែលសង្ឃរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៥] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយមិនមានអាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិមិនមែនជា ទេសនាគាមិនី[3] ១ កម្មដែលធ្វើដោយទេសិតាបត្តិ (អាបត្តិ ដែលភិក្ខុសំដែងហើយ)១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៦] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលមិនទាន់ចោទសិន ហើយស្រាប់តែធ្វើ១ កម្មដែលមិនទាន់រំលឹកសិន ហើយស្រាប់តែធ្វើ១ កម្មដែលមិនទាន់លើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៧] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៨] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយការមិនសាកសួរ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៩] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយមិនតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១០] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយមិនមានអាបត្តិ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១១] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១២] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយទេសិតាបត្តិ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៣] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលមិនបានចោទសិន ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៤] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលមិនបានរំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៥] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលមិនលើកអាបត្តិឡើងសិន ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

ចប់ តជ្ជនីយកម្មមានចំនួន១២ក្នុងអធម្មកម្ម។

## (តជ្ជនីយកម្មមានចំនួន១២ក្នុងធម្មកម្ម)

CS vin.cv.01.01.02 | ភាគ ទី៩

### (ធម្មកម្មទ្វាទសកំ)

[១៦] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិនយផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ១ កម្មដែលធ្វើដោយការសាកសួរ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[១៧] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើតាមអាបត្តិ១ កម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី១ កម្មដែលធ្វើដោយអទេសិតាបត្តិ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[១៨] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលចោទហើយទើបធ្វើ១ កម្មដែលរំលឹកហើយទើបធ្វើ១ កម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[១៩] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើចំពោះមុខ១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២០] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលសាកសួរហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២១] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

## (តជ្ជនីយកម្ម ដែលសង្ឃប្រាថ្នានឹងធ្វើ មានចំនួន៦)

CS vin.cv.01.01.03 | ភាគ ទី៩

## (អាកង្ខមានឆក្កំ)

[២២] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើតាមអាបត្តិ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៣] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិជាទេសនាគាមិនី១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៤] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយអទេសិតាបត្តិ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៥] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលចោទហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៦] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលរំលឹកហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៧] ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលលើកអាបត្តិឡើងហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តជ្ជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

ចប់ តជ្ជនីយកម្មមានចំនួន១២ក្នុងធម្មកម្ម។

[២៨] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺភិក្ខុអ្នកបង្កហេតុ បង្កជម្លោះ បង្កទាស់ទែង បង្កតិរច្ឆានកថា បង្កអធិករណក្នុងសង្ឃ ភិក្ខុពាល មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះចុះ។

[២៩] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុមានសីលវិបត្តិ[4] ក្នុងអធិសីល១ ភិក្ខុមានអាចារវិបត្តិក្នុងអជ្ឈាចារ១ ភិក្ខុមានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[៣០] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ភិក្ខុពោលតិះដៀលព្រះធម៌១ ភិក្ខុពោលតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[៣១] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ៣ពួកគឺភិក្ខុមួយពួកជាអ្នកបង្កហេតុ។បេ។ បង្កអធិករណក្នុងសង្ឃ១ ភិក្ខុមួយពួកល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ១ ភិក្ខុមួយពួកនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ៣ពួកនេះឯង។

[៣២] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុមួយពួក មានសីលវិបត្តិក្នុងអធិសីល១ ភិក្ខុមួយពួកមានអាចារវិបត្តិ ក្នុងអជ្ឈាចារ១ ភិក្ខុមួយពួក មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ៣ពួកនេះឯង។

[៣៣] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុពួកមួយ ពោលតិះដៀលព្រះពុទ្ធ ភិក្ខុពួកមួយ ពោលតិះដៀលព្រះធម៌ ភិក្ខុពួកមួយ ពោលតិះដៀលព្រះសង្ឃ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្មដល់ភិក្ខុ៣ពួកនេះឯង។

ចប់ (តជ្ជនីយកម្ម) ដែលសង្ឃប្រាថ្នានឹងធ្វើ មានចំនួន៦។

## (វត្ត១៨ក្នុងតជ្ជនីយកម្ម)

### (អដ្ឋារសវត្តំ)

[៣៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើតជ្ជនីយកម្មហើយ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ។ ឯការប្រព្រឹត្តវត្តដោយប្រពៃក្នុងតជ្ជនីយកម្មនោះ ដូច្នេះ គឺភិក្ខុដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយនោះ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃបានសន្មតហើយ ក៏គង់មិនត្រូវប្រដៅភិក្ខុនីដែរ សង្ឃបានធ្វើតជ្ជនីយកម្មព្រោះអាបត្តិណា កុំគប្បីឲ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃប្រហែលគ្នាក្តី អាបត្តិធ្ងន់ជាងអាបត្តិមុននោះក្តី ភិក្ខុមិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ) មិនត្រូវទទួលនាទីជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស[5] មិនត្រូវចោទគេ (ដោយវត្ថុ ឬដោយអាបត្តិ) មិនត្រូវរំលឹក (ទោសអ្នកដទៃ) មិនត្រូវប្រកបពួកភិក្ខុ(ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា។

ចប់ វត្ត១៨ក្នុងតជ្ជនីយកម្ម។

## (តជ្ជនីយកម្មដែលសង្ឃមិនត្រូវរម្ងាប់ មានចំនួន១៨)

CS vin.cv.01.01.05 | ភាគ ទី៩

### (នប្បដិប្បស្សម្ភេតព្វអដ្ឋារសកំ)

[៣៥] លំដាប់នោះ សង្ឃបានធ្វើតជ្ជនីយកម្មដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ។ ភិក្ខុទាំងឡាយនោះ ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម[6] ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម រួចក៏ចូលទៅរកភិក្ខុទាំងឡាយ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ យើងខ្ញុំ ដែលសង្ឃបានធ្វើ តជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញ ចាកកម្មហើយ យើងខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត។ ភិក្ខុទាំងឡាយ យកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់តជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុចុះ។

[៣៦] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុឲ្យឧបសម្បទា១ ភិក្ខុឲ្យនិស្ស័យ១ ភិក្ខុឲ្យសាមណេរបម្រើខ្លួន១ ភិក្ខុទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី១ ភិក្ខុដែលសង្ឃសន្មត ហើយប្រៀនប្រដៅភិក្ខុនីទាំងឡាយ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ តជ្ជនីយកម្ម របស់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។

[៣៧] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើតជ្ជនីយកម្ម ព្រោះអាបត្តិណា ហើយត្រឡប់ត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលគ្នានឹងអាបត្តិមុននោះ១ ឬអាបត្តិធ្ងន់ជាងអាបត្តិមុននោះ១ ភិក្ខុតិះដៀលតជ្ជនីយកម្ម១ ភិក្ខុតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[៣៨] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុហាមឧបោសថរបស់ភិក្ខុជាបកតត្ត១ ហាមបវារណារបស់ភិក្ខុជាបកតត្ត១ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណណានោះ)១ ទទួលនាទីជាធំក្នុងវត្ត១ ភិក្ខុដែលឲ្យធ្វើឱកាស (ដើម្បីចោទ)១ ភិក្ខុចោទគេ១ ភិក្ខុរំលឹកគេ១ ភិក្ខុប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៨នេះទេ។

ចប់ តជ្ជនីយកម្មដែលសង្ឃមិនត្រូវរម្ងាប់ មានចំនួន១៨។

## (តជ្ជនីយកម្មដែលសង្ឃត្រូវរម្ងាប់ មានចំនួន១៨)

CS vin.cv.01.01.06 | ភាគ ទី៩

### (បដិប្បស្សម្ភេតព្វអដ្ឋារសកំ)

[៣៩] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុ ដែលប្រកបដោយអង្គ៥ គឺភិក្ខុមិនឲ្យឧបសម្បទា១ មិនឲ្យនិស្ស័យ១ មិនឲ្យសាមណេរបម្រើខ្លួន១ មិនទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី១ បើទុកជាសង្ឃសន្មតឲ្យហើយ ក៏គង់មិនទៅប្រដៅភិក្ខុនីទាំងឡាយ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[៤០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើតជ្ជនីយកម្ម ព្រោះអាបត្តិណាហើយ មិនត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលគ្នានឹងអាបត្តិមុននោះ១ ឬអាបត្តិធ្ងន់ជាងអាបត្តិមុននោះ១ មិនតិះដៀលតជ្ជនីយកម្ម១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[៤១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុ ដែលប្រកបដោយអង្គ៨ គឺភិក្ខុមិនហាមឧបោសថ របស់ភិក្ខុជាបកតត្ត១ មិនហាមបវារណា របស់ភិក្ខុជាបកតត្ត១ មិនធ្វើជាអ្នកមានមាត់ពាក្យ១ មិនទទួលនាទីជាធំក្នុងវត្ត១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនចោទគេ១ មិនរំលឹកគេ១ មិនប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់តជ្ជនីយកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៨នេះឯង។

ចប់ តជ្ជនីយកម្មដែលសង្ឃត្រូវរម្ងាប់ មានចំនួន១៨។

[៤២] ម្នាលភិក្ខុទាំងឡាយ ឯតជ្ជនីយកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុទាំងនោះ គប្បីចូលទៅរកជំនុំសង្ឃ ហើយធ្វើសំពត់ឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយសំពះបាទារបស់ភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ ដែលសង្ឃធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ខ្ញុំព្រះករុណាទាំងឡាយ មកសូមការរម្ងាប់តជ្ជនីយកម្ម។ គប្បីសូមជាគំរប់ពីរដងផង។ គប្បីសូមជាគំរប់បីដងផង។ ភិក្ខុអ្នកឆ្លាស ប្រតិពល គប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុនេះ ដែលសង្ឃធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ និងសម្លបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម មកសូមការរម្ងាប់តជ្ជនីយកម្ម។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុនេះ ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់តជ្ជនីយកម្ម។ សង្ឃក៏រម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ។ ការរម្ងាប់តជ្ជនីយកម្ម របស់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ។បេ។ ក៏ការរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុនេះ ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់តជ្ជនីយកម្ម។ សង្ឃក៏រម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ។ ការរម្ងាប់តជ្ជនីយកម្ម របស់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុហើយ ការរម្ងាប់តជ្ជនីយកម្មរបស់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ គួរដល់សង្ឃ ព្រោះហេតុដូច្នោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ តជ្ជនីយកម្មជាបឋម។

# (និយស្សកម្មជាគំរប់ពីរ ទី២)

CS vin.cv.01.02 | ភាគ ទី៩

## (២. និយស្សកម្មំ)

[៤៣] សម័យនោះឯង សេយ្យសកភិក្ខុដ៏មានអាយុ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយ ជាបកតត្តសោត ក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន។ ភិក្ខុទាំងឡាយឯណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វី បានជា សេយ្យសកភិក្ខុដ៏មានអាយុ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយ ជាបកតត្តសោត ក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[៤៤] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរភិក្ខុទាំងឡាយ ក្នុងកាលនោះថា ម្នាលភិក្ខុទាំងឡាយ ឮថា សេយ្យសកភិក្ខុ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយ ជាបកតត្តសោត ក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះសព្វញ្ញុពុទ្ធ ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសនោះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុអ្វីបានជាមោឃបុរសនោះ ជាបុគ្គលល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយ ជាបកតត្តសោត ក៏ឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ មិនមែនដឹងនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់បន្ទោសរួច ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើនិយស្សកម្ម[7] ដល់សេយ្យសកភិក្ខុ ដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ។[8] ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីធ្វើ និយស្សកម្មយ៉ាងនេះ។ សង្ឃត្រូវចោទសេយ្យសកភិក្ខុជាមុន លុះចោទហើយ ត្រូវរំលឹក លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិហើយ ត្រូវភិក្ខុអ្នកឆ្លាស ប្រតិពលញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយ ជាបកតត្តសោត ក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីធ្វើ និយស្សកម្ម ដល់សេយ្យសកភិក្ខុ ដោយពាក្យថា អ្នកត្រូវនៅ ដោយមាននិស្ស័យ (ទៀត)។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយ ជាបកតត្ត ក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន។ ឥឡូវនេះ សង្ឃធ្វើនិយស្សកម្ម ដល់សេយ្យសកភិក្ខុ ដោយពាក្យថា អ្នកត្រូវនៅ ដោយមាននិស្ស័យ (ទៀត)។ ការធ្វើនិយស្សកម្ម ដល់សេយ្យសកភិក្ខុ ដោយពាក្យថា អ្នកត្រូវនៅដោយមាននិស្ស័យ (ទៀត) គួរដល់លោកដ៏មានអាយុ

អង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សេយ្យសកភិក្ខុនេះ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ ឯភិក្ខុទាំងឡាយ ជាបកតត្តសោត ក៏តែងឲ្យបរិវាស ឲ្យមូលាយបដិកស្សន ឲ្យមានត្ត ឲ្យអព្ភាន។ ឥឡូវនេះ សង្ឃធ្វើនិយស្សកម្ម ដល់សេយ្យសកភិក្ខុ ដោយពាក្យថា អ្នកត្រូវនៅ ដោយមាននិស្ស័យ (ទៀត)។ ការធ្វើនិយស្សកម្ម ដល់សេយ្យសកភិក្ខុ ដោយពាក្យថា អ្នកត្រូវនៅ ដោយមាននិស្ស័យ (ទៀត) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ។បេ។ លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានធ្វើនិយស្សកម្ម ដល់សេយ្យសកភិក្ខុ ដោយពាក្យថា អ្នកត្រូវនៅ ដោយមាននិស្ស័យ (ទៀត) ដូច្នេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

## (និយស្សកម្ម មានចំនួន១២ក្នុងអធម្មកម្ម)

CS vin.cv.01.02.01 | ភាគ ទី៩

### (អធម្មកម្មទ្វាទសកំ)

[៤៥] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលសង្ឃរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ គឺកម្មដែលសង្ឃធ្វើកំបាំងមុខ១ កម្មដែលមិនសាកសួរ ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើ ដោយមិនតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[៤៦] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយអនាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិមិនមែនជា ទេសនាគាមិនី១ កម្មដែលធ្វើ ដោយទេសិតាបត្តិ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[៤៧] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលមិនទាន់ចោទ ហើយស្រាប់តែធ្វើ១ កម្មដែលមិនទាន់រំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលមិនទាន់លើកអាបត្តិឡើង ហើយធ្វើ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៤៨] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើកំបាំងមុខ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[៤៩] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលមិនទាន់សាកសួរ ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើ ដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៥០] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយមិនតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៥១] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយអនាបត្តិ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើ ដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលសង្ឃរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៥២] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយអាបត្តិមិនមែនជាទេសនាគាមិនី១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើ ដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៥៣] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយទេសិតាបត្តិ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[៥៤] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្ម ដែលមិនទាន់ចោទ ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើ ដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[៥៥] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលមិនទាន់រំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្ម

កម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[៥៦] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលមិនទាន់លើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើ ដោយពួក១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

ចប់ និយស្សកម្មមានចំនួន១២ក្នុងអធម្មកម្ម។

## (និយស្សកម្ម មានចំនួន១២ក្នុងធម្មកម្ម)

CS vin.cv.01.02.02 | ភាគ ទី៩

### (ធម្មកម្មទ្វាទសកំ)

[៥៧] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើចំពោះមុខ១ កម្មដែលសាកសួរហើយទើបធ្វើ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[៥៨] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើតាមអាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិជាទេសនាគាមិនី១ កម្មដែលធ្វើ ដោយអទេសិតាបត្តិ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣នេះឯង។

[៥៩] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលចោទហើយ ទើបធ្វើ១ កម្មដែលរំលឹកហើយ ទើបធ្វើ១ កម្មដែលលើកអាបត្តិឡើងហើយ ទើបធ្វើ១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣នេះឯង។

[៦០] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ចំពោះមុខ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[៦១] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលសាកសួរហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣នេះឯង។

[៦២] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣នេះឯង។

[៦៣] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើតាមអាបត្តិ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[៦៤] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិ ជាទេសនាគាមិនី១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[៦៥] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយអទេសិតាបត្តិ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣នេះឯង។

[៦៦] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្ម ដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលចោទហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣នេះឯង។

[៦៧] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្ម ដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលរំលឹកហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣នេះឯង។

[៦៨] ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្មដែលលើកអាបត្តិឡើង ហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ និយស្សកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

ចប់ និយស្សកម្មមានចំនួន១២ក្នុងធម្មកម្ម។

## (និយស្សកម្ម ដែលសង្ឃប្រាថ្នានឹងធ្វើ មានចំនួន៦)

CS vin.cv.01.02.03 | ភាគ ទី៩

### (អាកង្ខមានឆក្កំ)

[៦៩] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺភិក្ខុជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ១ ជាភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ១ ជាភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[៧០] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីល១ ភិក្ខុមានអាចារវិបត្តិក្នុងអជ្ឈាចារ១ ភិក្ខុមានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុដែលប្រកបដោយ អង្គ៣នេះឯង។

[៧១] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[៧២] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុ៣ពួកគឺភិក្ខុអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃពួក១ ភិក្ខុល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិពួក១ ភិក្ខុនៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុ៣ពួកនេះឯង។

[៧៣] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីលពួក១ ភិក្ខុមានអាចារវិបត្តិ ក្នុងអជ្ឈាចារពួក១ ភិក្ខុមានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុ៣ពួកនេះឯង។

[៧៤] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុទាំងឡាយ៣ពួកដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធពួក១ ពោលតិះដៀលព្រះធម៌ពួក១ ពោលតិះដៀលព្រះសង្ឃពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុទាំង៣ពួកនេះឯង។

ចប់ និយស្សកម្ម ដែលសង្ឃប្រាថ្នានឹងធ្វើ មានចំនួន៦។

## (វត្ត១៨ក្នុងនិយស្សកម្ម)

CS vin.cv.01.02.04 | ភាគ ទី៩

### (អដ្ឋារសវត្តំ)

[៧៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើនិយស្សកម្មហើយ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ។ ឯការប្រព្រឹត្តវត្ត ដោយប្រពៃ ក្នុងនិយស្សកម្មនោះ ដូច្នេះ គឺភិក្ខុមិនត្រូវឲ្យឧបសម្បទា១ មិនត្រូវឲ្យនិស្ស័យ១ មិនត្រូវឲ្យសាមណេរបម្រើខ្លួន១ មិនត្រូវទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ បើទុកជាសង្ឃ បានសន្មតឲ្យហើយ ក៏មិនត្រូវទៅប្រដៅពួកភិក្ខុនីឡើយ១ និយស្សកម្ម ដែលសង្ឃធ្វើព្រោះអាបត្តិណា ភិក្ខុកុំឲ្យត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃប្រហែលគ្នា នឹងអាបត្តិមុននោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ១ មិនត្រូវតិះដៀលនិយស្សកម្ម១ មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ មិនត្រូវហាមឧបោសថ របស់ភិក្ខុជាបកតត្ត១ មិនត្រូវហាមបវារណា (របស់ភិក្ខុជាបកតត្ត)១ មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ មិនត្រូវទទួលនាទីជាធំក្នុងវត្ត១ មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនត្រូវចោទគេ១ មិនត្រូវរំលឹកគេ១ មិនត្រូវប្រកបពួកភិក្ខុ(ឲ្យឈ្លោះ) នឹងពួកភិក្ខុ១។

ចប់ វត្ត១៨ក្នុងនិយស្សកម្ម។

[៧៦] លំដាប់នោះ សង្ឃបានធ្វើនិយស្សកម្មដល់សេយ្យសកភិក្ខុ ដោយពាក្យថា លោកត្រូវនៅដោយមាននិស្ស័យ (ទៀត)។ សេយ្យសកភិក្ខុដែលសង្ឃបានធ្វើនិយស្សកម្មហើយនោះ ក៏សេពគប់ ចូលទៅអង្គុយជិតពួកភិក្ខុ ជាកល្យាណមិត្ត សូមរៀនបាលី និងអដ្ឋកថា ក៏បានជាពហុស្សូត ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក អ្នកទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត វាងវៃ មានបញ្ញា មានសេចក្តីខ្មាស មានសេចក្តីរអែង ប្រាថ្នាក្នុងសិក្ខា សេយ្យសកភិក្ខុនោះ ក៏ប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួនចេញចាកកម្ម ហើយក៏

ចូលទៅរកភិក្ខុទាំងឡាយ និយាយយ៉ាងនេះថា ម្នាលលោកទាំងឡាយដ៏មានអាយុ ខ្ញុំ ដែលសង្ឃធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួនចេញ ចាកកម្មហើយ ខ្ញុំត្រូវប្រតិបត្តិដូចម្ដេចទៀត។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។

## (និយស្សកម្ម មានចំនួន១៨ ដែលសង្ឃមិនត្រូវរម្ងាប់)

CS vin.cv.01.02.05 | ភាគ ទី៩

### (នប្បដិប្បស្សម្ភេតព្ពអដ្ឋារសកំ)

[៧៧] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់និយស្សកម្ម របស់សេយ្យសកភិក្ខុចុះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្មរ បស់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុឲ្យឧបសម្បទា១ ភិក្ខុឲ្យនិស្ស័យ១ ភិក្ខុឲ្យសាមណេរបម្រើខ្លួន១ ភិក្ខុទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី១ ភិក្ខុដែលសង្ឃសន្មតឲ្យហើយ ក៏នៅតែទៅប្រដៅភិក្ខុនីទាំងឡាយ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្ម របស់ភិក្ខុដែលប្រកបដោយ អង្គ៥ឡើយ។

[៧៨] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើនិយស្សកម្ម ព្រោះអាបត្តិណា ហើយត្រឡប់ត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលនឹងអាបត្តិមុននោះ១ ឬអាបត្តិធ្ងន់ជាងអាបត្តិនោះ១ តិះដៀលនិយស្សកម្ម១ តិះដៀលពួកភិក្ខុអ្នកធ្វើនិយស្សកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ និយស្សកម្ម របស់ភិក្ខុ ដែលប្រកបដោយ អង្គ៥នេះទេ។

[៧៩] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុហាមឧបោសថ របស់ភិក្ខុជាបកតត្ត១ ហាមបវារណា របស់ភិក្ខុជាបកតត្ត១ ធ្វើជាអ្នកមានមាត់ពាក្យ១ ទទួលនាទីជាធំក្នុងវត្ត១ ឲ្យធ្វើឱកាស (ដើម្បីចោទ)១ ចោទគេ១ រំលឹកគេ១ ប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុដែលប្រកបដោយអង្គ៨នេះទេ។

ចប់ និយស្សកម្ម មានចំនួន១៨ ដែលសង្ឃមិនត្រូវរម្ងាប់។

## (និយស្សកម្ម មានចំនួន១៨ ដែលសង្ឃត្រូវរម្ងាប់)

CS vin.cv.01.02.06 | ភាគ ទី៩

### (បដិប្បស្សម្ភេតព្ពអដ្ឋារសកំ)

[៨០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុ ដែលប្រកបដោយអង្គ៥ គឺភិក្ខុមិនឲ្យឧបសម្បទា១។បេ។

[៨១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើនិយស្សកម្ម ព្រោះអាបត្តិណាហើយ មិនត្រឡប់ត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលគ្នានឹងអាបត្តិមុននោះ១ ឬអាបត្តិធ្ងន់ជាងអាបត្តិមុននោះ១ មិនតិះដៀលនិយស្សកម្ម១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើនិយស្សកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្ម របស់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[៨២] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុ ដែលប្រកបដោយអង្គ៨ គឺភិក្ខុមិនហាមឧបោសថ របស់ភិក្ខុជាបកតត្ត១ មិនហាមបវារណា របស់ភិក្ខុជាបកតត្ត១ មិនធ្វើឲ្យជាអ្នកមានមាត់ពាក្យ១ មិនទទួលនាទីជាធំក្នុងវត្ត១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនចោទគេ១ មិនរំលឹកគេ១ មិនប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់និយស្សកម្មរបស់ភិក្ខុ ដែលប្រកបដោយអង្គ៨នេះឯង។

ចប់ និយស្សកម្ម មានចំនួន១៨ ដែលសង្ឃត្រូវរម្ងាប់។

[៨៣] ម្នាលភិក្ខុទាំងឡាយ ឯនិយស្សកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ សេយ្យសកភិក្ខុនោះ គប្បីចូលទៅរកជំនុំសង្ឃ ហើយធ្វើសំពត់ឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយសំពះបាទារបស់ភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយពាក្យយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណា ដែលសង្ឃបានធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្ម ខ្ញុំសូមការរម្ងាប់ និយស្សកម្ម។ គប្បីសូមជាគំរប់ពីរដងផង។ គប្បីសូមជាគំរប់បីដងផង។ ភិក្ខុអ្នកឆ្លាសប្រតិពល គប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ សេយ្យសកភិក្ខុនេះ ដែលសង្ឃធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួនចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់និយស្សកម្ម។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់ និយស្សកម្មរបស់សេយ្យសកភិក្ខុនោះចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតសេយ្យសកភិក្ខុនេះ ដែលសង្ឃបានធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួនចេញចាកកម្ម ឥឡូវមកសូមការរម្ងាប់និយស្សកម្ម។ សង្ឃរម្ងាប់ និយស្សកម្ម របស់សេយ្យសកភិក្ខុ។ ការរម្ងាប់និយស្សកម្ម របស់សេយ្យសកភិក្ខុ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្ដីនេះជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ សេយ្យសកភិក្ខុនេះ ដែលសង្ឃធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់និយស្សកម្ម។ សង្ឃរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុ។ ការរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុ

អង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្ដីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ សេយ្យសកភិក្ខុនេះ ដែលសង្ឃបានធ្វើនិយស្សកម្មហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់និយស្សកម្ម។ សង្ឃរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុ។ ការរម្ងាប់និយស្សកម្ម របស់សេយ្យសកភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង។ សង្ឃបានរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុហើយ ការរម្ងាប់និយស្សកម្មរបស់សេយ្យសកភិក្ខុ គួរដល់សង្ឃហើយ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្ដីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ និយស្សកម្មជាគំរប់ពីរ។

# (បព្វាជនីយកម្ម ទី៣)

CS vin.cv.01.03 | ភាគ ទី៩

## (៣. បព្ពាជនីយកម្មំ)

[៨៤] សម័យនោះឯង ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក ជាចៅអាវាស ទៀបកិដាគិរិជនបទ ជាភិក្ខុលាមកឥតខ្មាស។ ភិក្ខុទាំងនោះ ប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កា ដោយខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ឲ្យគេស្រោចខ្លះ បេះខ្លួនឯងខ្លះ ឲ្យគេបេះខ្លះ ក្រងខ្លួនឯងខ្លះ ឲ្យគេក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុនោះ នាំយកផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ យកផ្កាកម្រងដែលមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាឈើចាក់រំលេចទងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាឈើសម្រាប់ស៊កក្នុងបំពង់ទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ ដើម្បីស្រីនៃត្រកូល ដើម្បីធីតានៃត្រកូល ដើម្បីកុមារីនៃត្រកូល ដើម្បីស្រីជាកូនប្រសានៃត្រកូល ដើម្បីទាសីនៃត្រកូលទាំងឡាយ អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុទាំងនោះឆាន់ភោជនក្នុងភាជន៍មួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល និងទាសីនៃត្រកូលទាំងឡាយខ្លះ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ ដេកលើកម្រាល និងដណ្តប់ជាមួយគ្នាខ្លះ ឆាន់ភោជនក្នុងវេលាវិកាលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូប និងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡា៨[9)] ខ្លះ លេងបាស្កាមានក្រឡា១០[10)] ខ្លះ លេងបាស្កាក្នុងអាកាស[11)] ខ្លះ លេងវាងផ្លូវដែលខ្លួនគួរវាង[12)] ខ្លះ លេងផ្ទាត់គ្រាប់ (មានគ្រួសជាដើម) ខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងផ្លុំស្លឹកខ្លះ លេងកូននង្គ័លខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ (បាយឡុកបាយឡ) ខ្លះ លេងរថតូចៗខ្លះ លេងធ្នូតូចៗខ្លះ លេងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត (ស្តេចចង់)ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់ដង (មានដងដាវជាដើម)ខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលកំពុងរាំយ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះ មើលដូច្នេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួន និងថ្ងាសស្រីរបាំខ្លះ ប្រព្រឹត្តអនាចារផ្សេងៗខ្លះ (ក្រៅអំពីនេះទៅទៀត)។

[៨៥] សម័យនោះឯង មានភិក្ខុមួយរូបចាំវស្សា ក្នុងដែនកាសី រួចហើយទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ក៏ដើរសំដៅទៅកិដាគិរិជនបទ។ លុះវេលាព្រឹកឡើង ភិក្ខុនោះក៏ស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរដើរចូលទៅកាន់កិដាគិរិជនបទ ដើម្បីបិណ្ឌបាត មានភ្នែកសង្រួម មានឥរិយាបទរំទំ ឈានដើរទៅមុខ ឬថយក្រោយ ក្រឡេកមើលទៅមុខ ឬមើលចំហៀង បត់ដៃចូល ឬលាចេញ គួរឲ្យកើតសេចក្តីជ្រះថ្លា។ មនុស្សទាំងឡាយ ឃើញភិក្ខុនោះហើយ និយាយយ៉ាងនេះថា លោកអ្វីនេះ ដូចជាសង្រួមហួស ដូចជាទន់ល្វន់ពេក ដូចជាមុខស្រពោនពេក អ្នកណានឹងឲ្យដុំបាយដល់លោកនេះ ដែលចូលទៅរក(គេនោះ) ចំណែកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុជាម្ចាស់យើង ពោលពាក្យផ្អែម ពោលពាក្យពីរោះ ពោលពាក្យជាសុខ មានញញឹមញញែមជាមុន តែងនិយាយថា អ្នកចូរមក អ្នកមកល្អហើយ មានមុខមិនស្រពោន មានមុខងើប តែងនិយាយមុន យើងគួរប្រគេនដុំបាយដល់លោកម្ចាស់អស់នោះ។ ឧបាសកម្នាក់បានឃើញភិក្ខុនោះត្រេចទៅបិណ្ឌបាតក្នុងកិដាគិរិជនបទ លុះឃើញហើយ ក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា សូមមេត្តាប្រោស លោកម្ចាស់បានចង្ហាន់ខ្លះដែរឬ។ ភិក្ខុនោះប្រាប់ថា អាវុសោ ចង្ហាន់ អាត្មាមិនទាន់បានទេ។ ឧបាសកនោះនិយាយថា សូមមេត្តាប្រោស សូមលោកម្ចាស់និមន្តមក យើងនឹងនាំគ្នាទៅផ្ទះ។ ទើបឧបាសកនោះ នាំភិក្ខុនោះទៅផ្ទះ ឲ្យឆាន់ស្រេចហើយ ក៏បានសួរដូច្នេះថា សូមមេត្តាប្រោស លោកម្ចាស់នឹងនិមន្តទៅក្នុងទីណាទៀត។ ភិក្ខុនោះប្រាប់ថា អាវុសោ អាត្មានឹងទៅក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ។ ឧបាសកនោះផ្តាំថា សូមមេត្តាប្រោស បើដូច្នោះ សូមលោកម្ចាស់ថ្វាយបង្គំ ព្រះបាទាព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យរបស់ខ្ញុំផង ម្យ៉ាងទៀត សូមលោកម្ចាស់ក្រាបបង្គំទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស អាវាសក្នុងកិដាគិរិជនបទខូចហើយ ដ្បិតភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក ជាចៅអាវាសក្នុងកិដាគិរិជនបទ ជាភិក្ខុលាមកឥតខ្មាស ភិក្ខុទាំងពីររូបនោះប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ឲ្យគេស្រោចខ្លះ បេះខ្លួនឯងខ្លះ ឲ្យគេបេះខ្លះ ក្រងខ្លួនឯងខ្លះ ឲ្យគេក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ

ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើដែលដោតជាចង្កោមខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុនោះ នាំយកផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំយកផ្កាកម្រងមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំយកទៅខ្លះ នាំផ្កាឈើចាក់រំលេចទងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាឈើសម្រាប់ស៊កក្នុងបំពង់ទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ ដើម្បីស្រីនៃត្រកូល ដើម្បីធីតានៃត្រកូល ដើម្បីកុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ ភិក្ខុទាំងនោះឆាន់ភោជនក្នុងភាជន៍មួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយខ្លះ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ ដេកលើកម្រាល និងដណ្តប់ជាមួយគ្នាខ្លះ ឆាន់ភោជនក្នុងវេលាវិកាលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូប និងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡា៨ខ្លះ លេងបាស្កាមានក្រឡា១០ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងវាងផ្លូវដែលខ្លួនគួរវាងខ្លះ លេងផ្ទាត់គ្រាប់ (មានគ្រួសជាដើម) ខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងផ្លុំស្លឹកខ្លះ លេងកូននង្គ័លខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ខ្លះ លេងរថតូចៗខ្លះ លេងធ្នូតូចៗខ្លះ លេងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត (ស្តេចចង់)ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់ដង (មានដងដាវជាដើម)ខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលកំពុងរាំយ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះមើល ដូច្នេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួន និងថ្ងាសស្រីរបាំខ្លះ ប្រព្រឹត្តអនាចារផ្សេងៗ (ក្រៅអំពីនេះទៅទៀត)ខ្លះ បពិត្រព្រះអង្គដ៏ចំរើន ក៏មនុស្សទាំងឡាយឯណា ដែលធ្លាប់មានសទ្ធាជ្រះថ្លាមកពីមុន ឥឡូវនេះមនុស្សទាំងនោះ ត្រឡប់ជាគ្មានសទ្ធា គ្មានសេចក្តីជ្រះថ្លាទៅវិញ លំអានទានទាំងឡាយឯណា (ដែលគេធ្លាប់ធ្វើ) ដល់សង្ឃមកពីមុន ឥឡូវនេះលំអានទានទាំងនោះ គេក៏ផ្តាច់អស់ហើយ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ក៏នាំគ្នារត់ចេញ នៅតែពួកភិក្ខុដែលលាមក សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះដ៏មានព្រះភាគ ទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅកិដាគិរិជនបទ ដើម្បីឲ្យអាវាសក្នុងកិដាគិរិជនបទនេះបានស្ថិតស្ថេរ (តទៅ)។ ភិក្ខុនោះទទួលពាក្យបណ្តាំឧបាសកនោះថា អើអាវុសោ ហើយក្រោកចាកអាសន ចៀសចេញទៅកាន់ក្រុងសាវត្ថី ហើយបានចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ឯក្រុងសាវត្ថីដោយលំដាប់ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ។

[៨៦] ក៏ការទទួលរាក់ទាក់ជាមួយនឹងពួកភិក្ខុជាអាគន្តុកនេះ ជាទំនៀមរបស់ព្រះពុទ្ធ ជាម្ចាស់ដ៏មានព្រះភាគទាំងឡាយ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ អ្នកល្មមអត់ទ្រាំបានទេឬ អ្នកល្មមប្រព្រឹត្តទៅបានទេឬ អ្នកមកតាមផ្លូវឆ្ងាយ មិនសូវលំបាកទេឬ ម្នាលភិក្ខុ ចុះអ្នកមកអំពីទីណា។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គល្មមអត់ទ្រាំទៅបាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គល្មមប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត ខ្ញុំព្រះអង្គមកតាមផ្លូវឆ្ងាយ មិនសូវលំបាកទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនៅចាំវស្សាក្នុងដែនកាសីរួចហើយ មកក្រុងសាវត្ថីដើម្បីគាល់ព្រះអង្គក្នុងទីនេះ បានដើរសំដៅមកកិដាគិរិជនបទ បពិត្រព្រះអង្គដ៏ចំរើន លុះវេលាព្រឹកឡើង ខ្ញុំព្រះអង្គស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រចីវរ ចូលទៅកាន់កិដាគិរិជនបទ ដើម្បីបិណ្ឌបាត្រ បពិត្រព្រះអង្គដ៏ចំរើន មានឧបាសកម្នាក់ បានឃើញខ្ញុំព្រះអង្គកំពុងត្រេចទៅបិណ្ឌបាត្រក្នុងកិដាគិរិជនបទ លុះឃើញហើយ ក៏ចូលមករកខ្ញុំព្រះអង្គ លុះចូលមកហើយ ថ្វាយបង្គំខ្ញុំព្រះអង្គ ហើយបានសួរដូច្នេះថា សូមមេត្តាប្រោស លោកម្ចាស់ បានចង្ហាន់ខ្លះដែរឬ ខ្ញុំព្រះអង្គប្រាប់ថា ម្នាលអាវុសោ ចង្ហាន់ អាត្មាមិនទាន់បានទេ ឧបាសកនោះនិយាយថា សូមមេត្តាប្រោស សូមលោកម្ចាស់និមន្តមក យើងនឹងនាំគ្នាទៅផ្ទះ។ បពិត្រព្រះអង្គដ៏ចំរើន លុះឧបាសកនោះ នាំខ្ញុំព្រះអង្គទៅផ្ទះ ឲ្យឆាន់ស្រេចហើយ បានសួរដូច្នេះថា សូមមេត្តាប្រោស លោកម្ចាស់នឹងនិមន្តទៅក្នុងទីណា ខ្ញុំព្រះអង្គប្រាប់ថា អាវុសោ អាត្មានឹងទៅក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ឧបាសកនោះក៏ផ្តាំថា សូមមេត្តាប្រោស បើដូច្នោះ សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទាព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យរបស់ខ្ញុំ ម្យ៉ាងទៀត សូមលោកម្ចាស់ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អាវាសក្នុងកិដាគិរិជនបទខូចហើយ ព្រោះភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក ជាចៅអាវាសក្នុងកិដាគិរិជនបទ ជាភិក្ខុលាមកមិនមានសេចក្តីអៀនខ្មាស ភិក្ខុទាំងនោះប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ។បេ។ ប្រព្រឹត្តអនាចារផ្សេងៗ (ក្រៅអំពីនេះទៅទៀត)ខ្លះ បពិត្រព្រះអង្គដ៏ចំរើន ពួកមនុស្សឯណា ដែលធ្លាប់មានសទ្ធាជ្រះថ្លាមកពីមុន ឥឡូវនេះមនុស្សទាំងនោះ ក៏ត្រឡប់ជាគ្មានសទ្ធាជ្រះថ្លាទៅវិញ លំអានទានទាំងឡាយឯណា (ដែលគេធ្លាប់ធ្វើ) ដល់សង្ឃមកពីមុន ឥឡូវនេះលំអានទានទាំងនោះ គេក៏ផ្តាច់អស់ហើយ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ក៏ខ្ចាត់ភ្លាត់ចេញអស់ នៅតែពួកភិក្ខុដែលលាមក បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះដ៏មានព្រះភាគជាម្ចាស់ បញ្ជូនពួកភិក្ខុទៅកាន់កិដាគិរិជនបទ ដើម្បីឲ្យអាវាសក្នុងកិដាគិរិជនបទនេះ បានតាំងនៅខ្ជាប់ខ្ជួនដូចដែលវិញ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទើបនឹងមកអំពីទីនោះ។

[៨៧] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា អស្សជិភិក្ខុ និបុនព្វសុកភិក្ខុ ជាចៅអាវាសក្នុងកិដាគិរិជនបទ ជាភិក្ខុអលជ្ជីលាមក ភិក្ខុទាំងនោះ ប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ។បេ។ ប្រព្រឹត្តអនាចារមានប្រការផ្សេងៗ (ក្រៅអំពីនេះទៅទៀត) ខ្លះ ពួកមនុស្សណាធ្លាប់មានសទ្ធាជ្រះថ្លាមកពីមុន ឥឡូវនេះ មនុស្សទាំងនោះក៏បាត់សទ្ធាជ្រះថ្លាទៅវិញ លំអានទានទាំងឡាយឯណា (ដែលគេធ្លាប់ធ្វើ) ដល់សង្ឃក្នុងកាលមុន ឥឡូវនេះ លំអានទានទាំងនោះ គេក៏ផ្តាច់អស់ហើយ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ក៏ខ្ចាត់ភ្លាត់ចេញអស់ នៅតែពួកភិក្ខុដែលលាមក (សេចក្តីនេះ) ជាពិតមែនឬ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុ

ទាំងឡាយ អំពើនៃមោឃបុរសទាំងនោះ មិនសមគួរទេ។បេ។ ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះមិនសមបើនឹងប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះ គឺដាំកូនឈើខ្លួនឯងខ្លះ ឲ្យគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ឲ្យគេស្រោចខ្លះ បេះខ្លួនឯងខ្លះ ឲ្យគេបេះខ្លះ ក្រងខ្លួនឯងខ្លះ ឲ្យគេក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ឲ្យគេធ្វើខ្លះ អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុនោះ នាំផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងដែលមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាឈើចាក់រំលេចទងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាឈើសម្រាប់ស៊កក្នុងបំពង់ទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ឲ្យគេនាំទៅខ្លះ ដើម្បីស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ ភិក្ខុទាំងនោះឆាន់ភោជនក្នុងភាជន៍មួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល និងទាសីនៃត្រកូលទាំងឡាយខ្លះ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់សំពត់ជាមួយគ្នាខ្លះ ដេកលើកម្រាល ដណ្តប់សំពត់ជាមួយគ្នាខ្លះ ឆាន់ភោជនក្នុងវេលាវិកាលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រង គឿងក្រអូប នឹងគឿងលាបខ្លះ រាំខ្លះ ចៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡា៨ខ្លះ លេងបាស្កាមានក្រឡា១០ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងផ្លូវដែលខ្លួនគូរវាងខ្លះ លេងផ្ទាត់គ្រាប់ (មានគ្រួសជាដើម) ខ្លះ លេងបាស្កា ក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងផ្លុំស្លឹកខ្លះ លេងកូននង្គ័លតូចខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ខ្លះ លេងរថតូចៗខ្លះ លេងធ្នូតូចៗខ្លះ លេងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត (ស្តេចចង់)ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់ដង (មានដងដាវជាដើម)ខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលកំពុងរាំយ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទៅនេះមើល ដូច្នេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួននឹងថ្ងាសស្រីរបាំខ្លះ ប្រព្រឹត្តអនាចារផ្សេងៗ (ក្រៅអំពីនេះទៅទៀត)ខ្លះ ក៏ពួកមនុស្សណាធ្លាប់មានសទ្ធាជ្រះថ្លាមកអំពីមុន ឥឡូវនេះ មនុស្សទាំងនោះត្រឡប់ជាគ្មានសទ្ធាជ្រះថ្លាទៅវិញ លំអានទានទាំងឡាយឯណា (ដែលគេធ្លាប់ធ្វើ) ដល់សង្ឃក្នុងកាលមុន ឥឡូវនេះ លំអានទានទាំងនោះគេក៏ផ្តាច់អស់ទៅហើយ ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ក៏ខ្វាត់ភ្លាត់ចេញអស់ នៅតែពួកភិក្ខុលាមក ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅព្រះសារីបុត្ត និងព្រះមោគ្គល្លានមកថា ម្នាលសារីបុត្ត និងមោគ្គល្លាន ចូរអ្នកទាំងឡាយ ទៅកិដាគិរិជនបទ ហើយធ្វើបព្វាជនីយកម្ម[13] ដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរិជនបទ ចេញ(ដ្បិត) ភិក្ខុទាំងនុ៎ះ ជាសទ្ធិវិហារិករបស់អ្នកទាំងឡាយស្រាប់ហើយ។ ព្រះសារីបុត្ត និងព្រះមោគ្គល្លានក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំនឹងធ្វើបព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក(ឲ្យចេញ) ចាកកិដាគិរិជនបទ ដូចម្តេចបាន ព្រោះភិក្ខុទាំងនោះ សុទ្ធតែជាមនុស្សកាច រឹងរូសណាស់។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត មោគ្គល្លាន បើដូច្នោះ ចូរអ្នកទាំងឡាយទៅជាមួយនឹងពួកភិក្ខុច្រើនរូបចុះ។ ព្រះសារីបុត្ត និងព្រះមោគ្គល្លានទទួលព្រះបន្ទូលព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ។

[៨៨] ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឯបព្វាជនីយកម្មនេះ សង្ឃត្រូវធ្វើយ៉ាងនេះ។ ត្រូវចោទភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុកជាមុន លុះចោទហើយ ត្រូវរំលឹក លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឆ្លាសប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុកនេះ ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ មារយាទអាក្រក់របស់ភិក្ខុទាំងនេះ គេក៏បានឃើញ បានឮ ទាំងពួកត្រកូលដែលភិក្ខុទាំងនេះទ្រុស្តហើយ គេក៏បានឃើញ បានឮដែរ។ បើបព្វាជនីយកម្ម មានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើបព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរិជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុកនេះ ជាអ្នកទ្រុស្តត្រកូល មានមារយាទអាក្រក់ មារយាទអាក្រក់របស់ភិក្ខុទាំងនេះ គេក៏បានឃើញ បានឮ ទាំងពួកត្រកូលដែលភិក្ខុទាំងនោះទ្រុស្តហើយ គេក៏បានឃើញ បានឮដែរ។ (ឥឡូវ) សង្ឃធ្វើបព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរិជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ។ ការធ្វើបព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរិជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុកនេះ ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ មារយាទអាក្រក់របស់ភិក្ខុទាំងនេះ គេក៏បានឃើញ បានឮ ទាំងពួកត្រកូលដែលភិក្ខុទាំងនេះទ្រុស្តហើយ គេក៏បានឃើញ បានឮដែរ។ សង្ឃធ្វើបព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ចាកកិដាគិរិជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ។ ការធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរិជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ ដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំប្រកាសសេចក្តីនេះជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុកនេះ ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់ មារយាទអាក្រក់របស់ភិក្ខុទាំងនេះ គេក៏បានឃើញ បានឮ ទាំងពួកត្រកូលដែលភិក្ខុទាំងនេះទ្រុស្តហើយ គេក៏បានឃើញ បានឮដែរ។ សង្ឃធ្វើបព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុ

ឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរីជនបទទេ។ ការធ្វើបព្វាជនីយកម្មដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរីជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរីជនបទ ដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃបានធ្វើបព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក (ឲ្យចេញ) ពីកិដាគិរិជនបទថា ភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរីជនបទ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

## (បព្វាជនីយកម្ម មានចំនួន១២ក្នុងអធម្មកម្ម)

CS vin.cv.01.03.01 | ភាគ ទី៩

### (អធម្មកម្មទ្វាទសកំ)

[៨៩] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ គឺកម្មដែលសង្ឃធ្វើក្នុងទីកំបាំងមុខ១ កម្មដែលធ្វើដោយមិនសាកសួរ១ កម្មដែលធ្វើមិនតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គទាំង៣នេះឯង។

[៩០] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយមិនមានអាបត្តិ១ កម្មដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី១ កម្មដែលធ្វើដោយអាបត្តិដែលភិក្ខុសំដែងហើយ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គទាំង៣នេះឯង។

[៩១] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលមិនទាន់ចោទហើយស្រាប់តែធ្វើ១ កម្មដែលមិនទាន់បានរំលឹកហើយស្រាប់តែធ្វើ១ កម្មដែលមិនទាន់បានរលឹកអាបត្តិឡើងហើយស្រាប់តែធ្វើ១ ម្នាលភិក្ខុទាំងឡាយ។បេ។

[៩២] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើកំបាំងមុខ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង។បេ។ កម្មដែលធ្វើដោយមិនបានសាកសួរ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១។បេ។ កម្មដែលធ្វើមិនតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១។បេ។ កម្មដែលធ្វើដោយមិនមានអាបត្តិ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១។បេ។ កម្មដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១។បេ។ កម្មដែលធ្វើដោយអាបត្តិដែលភិក្ខុសំដែងហើយ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១។បេ។ កម្មដែលមិនទាន់បានចោទហើយ ស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១។បេ។ កម្មដែលមិនទាន់រំលឹកហើយ ស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១។បេ។ កម្មដែលមិនទាន់លើកអាបត្តិឡើងហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្មដែលរម្ងាប់អាក្រក់ផង ប្រកបដោយអង្គទាំង៣នេះឯង។

ចប់ បព្វាជនីយកម្មមានចំនួន១២ក្នុងអធម្មកម្ម។

## (បព្វាជនីយកម្ម មានចំនួន១២ក្នុងធម្មកម្ម)

CS vin.cv.01.03.02 | ភាគ ទី៩

### (ធម្មកម្មទ្វាទសកំ)

[៩៣] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្មជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ១ កម្មដែលធ្វើ ដោយការសាកសួរ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា១។បេ។

[៩៤] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយអាបត្តិ១ កម្មដែលធ្វើដោយអាបត្តិជា ទេសនាគាមិនី១ កម្មដែលធ្វើ ដោយអាបត្តិ ដែលភិក្ខុមិនបានសំដែង១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយអង្គទាំង៣នេះឯង។

[៩៥] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលចោទហើយ ទើបធ្វើ១ កម្មដែលរំលឹកហើយ ទើបធ្វើ១ កម្មដែលលើកអាបត្តិឡើងហើយ ទើបធ្វើ១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង។បេ។

[៩៦] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើចំពោះមុខ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង ជាធម្មកម្មផង។បេ។

[៩៧] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយការសាកសួរ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង។បេ។

[៩៨] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើតាមពាក្យប្ដេជ្ញា១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង ជាធម្មកម្មផង។បេ។

[៩៩] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើតាមអាបត្តិ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង។បេ។

[១០០] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើតាមអាបត្តិជាទេសនាគាមិនី១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង។បេ។

[១០១] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ដែលភិក្ខុមិនបានសំដែង១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង។បេ។

[១០២] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលចោទហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង។បេ។

[១០៣] ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលរំលឹកហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ប្រកបដោយអង្គទាំង៣នេះឯង។បេ។

[១០៤] អង្គទាំងឡាយ៣ដទៃទៀត។បេ។ គឺកម្មដែលលើកអាបត្តិឡើង ហើយទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើដោយការព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បព្វាជនីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គទាំង៣នេះឯង។

ចប់ បព្វាជនីយកម្មមានចំនួន១២ក្នុងធម្មកម្ម។

## (បព្វាជនីយកម្ម មាន១៤ ដែលសង្ឃប្រាថ្នា)

CS vin.cv.01.03.03 | ភាគ ទី៩

### (អាកង្ខមានចុទ្ទសកំ)

[១០៥] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺភិក្ខុជាអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ១ ភិក្ខុល្ងង់ មិនឆ្លាស ត្រូវអាបត្តិច្រើន ឥតមានការកំណត់អាបត្តិ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៣នេះឯង។

[១០៦] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គទាំងឡាយ៣ដទៃទៀត គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីល១ មានអាចារវិបត្តិក្នុងអជ្ឈាចារ១ មានទិដ្ឋិវិបត្តិក្នុងអតិទិដ្ឋិ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[១០៧] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុពោលពាក្យតិះដៀលព្រះពុទ្ធ១ ពោលពាក្យតិះដៀលព្រះធម៌១ ពោលពាក្យតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[១០៨] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុប្រកបដោយការល្បែងតាមកាយទ្វារ ប្រកបដោយការល្បែងតាមវចីទ្វារ១ ប្រកបដោយការល្បែងតាមកាយទ្វារ និងវចីទ្វារ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[១០៩] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុប្រកបដោយអនាចារផ្លូវកាយ[14]១ ប្រកបដោយអនាចារផ្លូវវាចា១ ប្រកបដោយអនាចារផ្លូវកាយវាចា១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[១១០] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុប្រកបដោយការបៀតបៀនសិក្ខាបទ[15] ដោយផ្លូវកាយ១ ភិក្ខុប្រកបដោយការបៀតបៀន (សិក្ខាបទ) ដោយផ្លូវវាចា១ ភិក្ខុប្រកបដោយការបៀតបៀន (សិក្ខាបទ) ទាំងផ្លូវកាយ ទាំងផ្លូវវាចា១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[១១១] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុប្រកបដោយមិច្ឆាជីវផ្លូវកាយ[16] ១ ប្រកបដោយមិច្ឆាជីវផ្លូវវាចា[17] ១ ប្រកបដោយមិច្ឆាជីវទាំងផ្លូវកាយ ទាំងផ្លូវវាចា១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[១១២] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុ៣ពួក គឺភិក្ខុអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណក្នុងសង្ឃពួក១ ភិក្ខុល្ងង់ មិនឆ្លាស ត្រូវអាបត្តិច្រើន ឥតមានការកំណត់អាបត្តិពួក១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុ៣ពួកនេះឯង។

[១១៣] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុមានសីលវិបត្តិក្នុងអធិសីលពួក១ មានអាចារវិបត្តិ ក្នុងអជ្ឈាចារពួក១ មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ៣ពួកនេះឯង។

[១១៤] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុពោលពាក្យតិះដៀលព្រះពុទ្ធពួក១ ពោលពាក្យតិះដៀលព្រះធម៌ពួក១ ពោលពាក្យតិះដៀលព្រះសង្ឃពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំង៣ពួកនេះឯង។

[១១៥] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុប្រកបដោយការល្បែងតាមកាយទ្វារពួក១ ប្រកបដោយការល្បែងតាមវចីទ្វារពួក១ ប្រកបដោយការល្បែងតាមកាយទ្វារ និងវចីទ្វារពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំង៣ពួកនេះឯង។

[១១៦] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុប្រកបដោយអនាចារផ្លូវកាយពួក១ ប្រកបដោយអនាចារផ្លូវវាចាពួក១ ប្រកបដោយអនាចារទាំងផ្លូវកាយ ទាំងផ្លូវវាចាពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ៣ពួកនេះឯង។

[១១៧] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុប្រកបដោយការបៀតបៀន (សិក្ខាបទ) តាមផ្លូវកាយពួក១ ប្រកបដោយការបៀតបៀន (សិក្ខាបទ) តាមផ្លូវវាចាពួក១ ប្រកបដោយការបៀតបៀន (សិក្ខាបទ) ទាំងផ្លូវកាយ ទាំងផ្លូវវាចាពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំង៣ពួកនេះឯង។

[១១៨] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុប្រកបដោយមិច្ឆាជីវផ្លូវកាយពួក១ ប្រកបដោយមិច្ឆាជីវផ្លូវវាចាពួក១ ប្រកបដោយមិច្ឆាជីវទាំងផ្លូវកាយ ទាំងផ្លូវវាចាពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំង៣ពួកនេះឯង។

ចប់ បព្វាជនីយកម្ម មាន១៤ ដែលសង្ឃប្រាថ្នា(នឹងធ្វើ ក៏ធ្វើបាន)។

## (វត្ត១៨ ក្នុងបព្វាជនីយកម្ម)

CS vin.cv.01.03.04 | ភាគ ទី៩

### (អដ្ឋារសវត្តំ)

[១១៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើបព្វាជនីយកម្មហើយ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ។ ឯការប្រព្រឹត្តវត្តដោយប្រពៃក្នុងបព្វាជនីយកម្មនោះដូច្នេះ គឺភិក្ខុដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយនោះ មិនត្រូវឲ្យឧបសម្បទា១ មិនត្រូវឲ្យនិស្ស័យ១ មិនត្រូវឲ្យសាមណេរបម្រើខ្លួន១ មិនត្រូវទទួលការសន្មតិខ្លួនប្រដៅភិក្ខុនី១ ទុកជាសង្ឃសន្មតឲ្យហើយ ក៏មិនត្រូវប្រដៅពួកភិក្ខុនី១ សង្ឃបានធ្វើបព្វាជនីយកម្ម ព្រោះអាបត្តិណាហើយ មិនឲ្យត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃទៀត ដែលប្រហែលនឹងអាបត្តិនោះ១ ឬអាបត្តិធ្ងន់ជាងអាបត្តិនោះ១ មិនត្រូវតិះដៀលកម្ម១ មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ មិនត្រូវហាមឧបោសថរបស់ភិក្ខុជាបកតត្ត១ មិនត្រូវហាមបវារណារបស់ភិក្ខុជាបកតត្ត១ មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ មិនត្រូវទទួលនាទីជាធំក្នុងវត្ត១ មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនត្រូវចោទ(ភិក្ខុដទៃ)១ មិនត្រូវរំលឹក (ភិក្ខុដទៃ)១ មិនត្រូវប្រកបពួកភិក្ខុ(ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១។

ចប់ វត្ត១៨ក្នុងបព្វាជនីយកម្ម។

[១២០] គ្រានោះ ភិក្ខុសង្ឃ មានព្រះសារីបុត្ត និងព្រះមោគ្គល្លាន ជាប្រធាន បានទៅកាន់កិដាគិរិជនបទ ហើយធ្វើបព្វាជនីយកម្ម (បណ្តេញ) ពួកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ (ឲ្យចេញ) អំពីកិដាគិរិជនបទ ដោយពាក្យថា ពួកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ មិនត្រូវនៅក្នុងកិដាគិរិជនបទទេ។ ភិក្ខុអម្បាលនោះ កាលបើសង្ឃបានធ្វើបព្វាជនីយកម្មហើយ ក៏មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្លបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ចេញចាកកម្ម មិនបានឲ្យភិក្ខុទាំងឡាយអត់ទោស ហើយត្រឡប់ជា ជេរប្រទេច បន្ទោសការកសង្ឃវិញថា សង្ឃលំអៀងដោយសេចក្តីស្រឡាញ់ លំអៀង ដោយសេចក្តីស្អប់ លំអៀងដោយសេចក្តីល្ងង់ លំអៀងដោយសេចក្តីខ្លាច ភិក្ខុទាំងនោះក៏ចេញទៅខ្លះ សឹកទៅខ្លះ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា ពួកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ ដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ មិនសមបើនឹងមិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្លបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម និងមិនបានឲ្យភិក្ខុ

ទាំងឡាយអត់ទោស ត្រឡប់ជាជេរប្រទេចបន្ទោសការកសង្ឃថា សង្ឃលំអៀងដោយសេចក្តីស្រឡាញ់ លំអៀងដោយសេចក្តីស្អប់ លំអៀងដោយសេចក្តីល្ងង់ លំអៀងដោយសេចក្តីខ្លាច ហើយភិក្ខុទាំងនោះក៏ចេញទៅខ្លះ សឹកទៅខ្លះ។ ទើបភិក្ខុទាំងនោះ យកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។

[១២១] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ ដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ មិនព្រមប្រព្រឹត្តវត្តដោយប្រពៃ មិនសម្លបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម និងមិនបានឲ្យភិក្ខុទាំងឡាយអត់ទោស ត្រឡប់ជាជេរប្រទេចបន្ទោសការកសង្ឃវិញថា សង្ឃលំអៀង ដោយសេចក្តីស្រឡាញ់ លំអៀង ដោយសេចក្តីស្អប់ លំអៀង ដោយសេចក្តីល្ងង់ លំអៀង ដោយសេចក្តីខ្លាច ហើយភិក្ខុទាំងនោះក៏ចេញទៅខ្លះ សឹកទៅខ្លះ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះ មិនសមគួរទេ។បេ។ ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ ដែលសង្ឃបានធ្វើបព្វាជនីយកម្មហើយ មិនសមបើនឹងមិនព្រមប្រព្រឹត្តវត្តដោយប្រពៃ មិនសម្លបរោម មិនប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួនចេញ ចាកកម្ម និងមិនបានឲ្យភិក្ខុទាំងឡាយអត់ទោស ត្រឡប់ជា ជេរប្រទេច បន្ទោសការកសង្ឃថា សង្ឃលំអៀង ដោយសេចក្តីស្រឡាញ់ លំអៀង ដោយសេចក្តីស្អប់ លំអៀង ដោយសេចក្តីល្ងង់ លំអៀង ដោយសេចក្តីខ្លាច ហើយភិក្ខុទាំងនោះ ចេញទៅខ្លះ សឹកទៅខ្លះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនជាទីជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់បព្វាជនីយកម្មចេញ។

## (វត្ត១៨ ដែលសង្ឃមិនត្រូវរម្ងាប់ ក្នុងបព្វាជនីយកម្ម)

CS vin.cv.01.03.05 | ភាគ ទី៩

### (នប្បដិប្បស្សម្ភេតព្វអដ្ឋារសកំ)

[១២២] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ គឺភិក្ខុឲ្យឧបសម្បទា១ ឲ្យនិស្ស័យ១ ឲ្យសាមណេរបម្រើខ្លួន១ ទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី១ សង្ឃសន្មតឲ្យហើយ ទៅប្រដៅពួកភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយ អង្គ៥នេះទេ។

[១២៣] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុ ដែលសង្ឃបានធ្វើបព្វាជនីយកម្ម ព្រោះអាបត្តិណាហើយ ត្រឡប់ត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ដែលប្រហែលគ្នា នឹងអាបត្តិមុននោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ១ តិះដៀលកម្ម១ តិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះទេ។

[១២៤] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ ភិក្ខុហាមបវារណា ដល់ភិក្ខុជាបកតត្ត១ ភិក្ខុធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ)១ ភិក្ខុទទួលនាទីជាធំក្នុងវត្ត១ ភិក្ខុឲ្យធ្វើឱកាស (ដើម្បីចោទ)១ ភិក្ខុចោទគេ១ ភិក្ខុរំលឹកគេ១ ភិក្ខុប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយ អង្គ៨នេះទេ។

ចប់ វត្ត១៨ ដែលសង្ឃមិនត្រូវរម្ងាប់ ក្នុងបព្វាជនីយកម្ម។

## (វត្ត១៨ ដែលសង្ឃត្រូវរម្ងាប់ក្នុង បព្វាជនីយកម្ម)

CS vin.cv.01.03.06 | ភាគ ទី៩

### (បដិប្បស្សម្ភេតព្វអដ្ឋារសកំ)

[១២៥] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ គឺភិក្ខុមិនបានឲ្យឧបសម្បទា១ មិនបានឲ្យនិស្ស័យ១ មិនបានឲ្យសាមណេរបម្រើខ្លួន១ មិនទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ ទុកជាសង្ឃសន្មតហើយ ក៏មិនបានទៅប្រដៅភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុប្រកបដោយអង្គ៥នេះឯង។

[១២៦] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើ បព្វាជនីយកម្ម ព្រោះអាបត្តិណាហើយ មិនបានត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ដែលប្រហែលគ្នា នឹងអាបត្តិមុននោះ១ ឬអាបត្តិធ្ងន់ជាងអាបត្តិមុននោះ១ មិនបានតិះដៀលកម្ម១ មិនបានតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ បព្វាជនីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។

[១២៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុមិនបានហាម ឧបោសថ ដល់ភិក្ខុជាបកតត្ត១ មិនបានហាម បវារណា ដល់ភិក្ខុជាបកតត្ត១ មិនបានធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ)១ មិនបានទទួលនាទីជាធំក្នុងវត្ត១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនបានចោទគេ១ មិនបានរំលឹកគេ១ មិនបានប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ ទាំង៨នេះឯង។

ចប់ វត្ត១៨ដែលសង្ឃត្រូវរម្ងាប់ក្នុង បព្វាជនីយកម្ម។

[១២៨] ម្នាលភិក្ខុទាំងឡាយ ឯបព្វាជនីយកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើ បព្វាជនីយកម្មហើយនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើសំពត់ឧត្តរាសង្គ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្លួនខ្ញុំ សង្ឃបានធ្វើ បព្វាជនីយកម្មហើយ ព្រមប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម និងប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញ ចាកកម្ម មកសូមការរម្ងាប់ បព្វាជនីយកម្ម។ ភិក្ខុនោះ ត្រូវសូមអស់វារៈពីរដងផង។ ភិក្ខុនោះ ត្រូវសូមអស់វារៈបីដងផង។ ភិក្ខុដែលឆ្លាស ប្រតិពល គប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុឈ្មោះនេះ សង្ឃបានធ្វើ បព្វាជនីយកម្មហើយ ព្រមប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម និងប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្ម មកសូមការរម្ងាប់ បព្វាជនីយកម្ម។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់ បព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះនេះចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ សង្ឃបានធ្វើ បព្វាជនីយកម្មហើយ ព្រមប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម បានប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្មហើយ មកសូមការរម្ងាប់ បព្វាជនីយកម្ម។ សង្ឃរម្ងាប់បព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះនេះ។ ការរម្ងាប់ បព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ សង្ឃបានធ្វើ បព្វាជនីយកម្មហើយ ព្រមប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម និងប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្ម ឥឡូវ មកសូមការរម្ងាប់ បព្វាជនីយកម្ម។ សង្ឃរម្ងាប់ បព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះនេះ។ ការរម្ងាប់ បព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃបានរម្ងាប់ បព្វាជនីយកម្ម ដល់ភិក្ខុឈ្មោះនេះ ការរម្ងាប់ បព្វាជនីយកម្មនេះ គួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ បព្វាជនីយកម្មទី៣។

# (បដិសារណីយកម្ម ទី៤)

CS vin.cv.01.04 | ភាគ ទី៩

### (៤. បដិសារណីយកម្មំ)

[១២៩] សម័យនោះឯង សុធម្មភិក្ខុដ៏មានអាយុ ជាចៅអាវាស របស់ចិត្តគហបតិ ជិតនគរមច្ឆិកាសណ្ឌ ជាអ្នកប្រកបការកសាង ជាអ្នកមានធុរភត្ត (ជាអ្នកដែលគហបតិទំនុកបម្រុងដោយនិច្ចភត្ត)។ កាលណាចិត្តគហបតិ ត្រូវការនឹងនិមន្តសង្ឃក្តី គណក្តី បុគ្គលក្តី តែមិនទាន់បានប្រាប់ សុធម្មភិក្ខុ (ជាមុន)ហើយ មិនហ៊ាននិមន្តសង្ឃ ឬគណ ឬបុគ្គលឡើយ។ គ្រានោះ ពួកភិក្ខុ ដែលជាថេរច្រើនរូប គឺព្រះសារីបុត្តដ៏មានអាយុ១ ព្រះមហាមោគ្គល្លានដ៏មានអាយុ១ ព្រះមហាកច្ចានដ៏មានអាយុ១ ព្រះមហាកោដ្ឋិតដ៏មានអាយុ១ ព្រះមហាកប្បិនដ៏មានអាយុ១ ព្រះមហាចុន្ទដ៏មានអាយុ១ ព្រះអនុរុទ្ធដ៏មានអាយុ១ ព្រះរេវតដ៏មានអាយុ១ ព្រះឧបាលិដ៏មានអាយុ១ ព្រះអានន្ទដ៏មានអាយុ១ ព្រះរាហុលដ៏មានអាយុ១ នាំគ្នាទៅកាន់ចារិក ក្នុងដែនកាសី ក៏បានទៅដល់នគរ មច្ឆិកាសណ្ឌ។

[១៣០] ចិត្តគហបតិ បានឮដំណឹងថា ភិក្ខុជាថេរទាំងឡាយ បានមកដល់នគរមច្ឆិកាសណ្ឌហើយ។ លំដាប់នោះ ចិត្តគហបតិ ក៏បានចូលទៅរកភិក្ខុជាថេរទាំងឡាយ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំភិក្ខុជាថេរទាំងឡាយ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ លុះចិត្តគហបតិ អង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះសារីបុត្តដ៏មានអាយុ ក៏បានពន្យល់ឲ្យយល់ ឲ្យសមាទាន ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ លំដាប់នោះ ចិត្តគហបតិ កាលបើព្រះសារីបុត្តដ៏មានអាយុ បានពន្យល់ ឲ្យយល់ ឲ្យសមាទាន ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បាននិយាយ នឹងភិក្ខុជាថេរទាំងឡាយ ដោយពាក្យដូច្នេះថា បពិត្រព្រះថេរទាំងឡាយដ៏ចំរើន សូមព្រះថេរទាំងឡាយ ទទួលអាគន្តុកភត្ត របស់ខ្ញុំព្រះករុណា ក្នុងថ្ងៃស្អែក។ ភិក្ខុជាថេរទាំងនោះ ក៏បានទទួលនិមន្ត ដោយសភាពស្ងៀម។

[១៣១] លំដាប់នោះ ចិត្តគហបតិដឹងថា ភិក្ខុជាថេរទាំងឡាយនិមន្តហើយ ក៏ក្រោកឡើងចាកអាសនៈ ថ្វាយបង្គំភិក្ខុ ជាថេរទាំងឡាយ ធ្វើប្រទក្សិណ ហើយក៏ដើរចូលទៅរកសុធម្មភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានថ្វាយបង្គំសុធម្មភិក្ខុដ៏មានអាយុ ហើយឈរក្នុងទីដ៏សមគួរ។ លុះចិត្តគហបតិ បានឈរក្នុងទីដ៏សមគួរហើយ ក៏បាននិយាយនឹងសុធម្មភិក្ខុដ៏មានអាយុដូច្នេះថា បពិត្រលោកដ៏ចំរើន សូមលោកសុធម្មភិក្ខុជាម្ចាស់ ទទួលភត្ត របស់ខ្ញុំ ក្នុងថ្ងៃស្អែក ជាមួយនឹងព្រះថេរទាំងឡាយ។ លំដាប់នោះ សុធម្មភិក្ខុដ៏មានអាយុគិតថា គ្រាមុនៗ ចិត្តគហបតិនេះ កាលណាត្រូវការនិមន្តសង្ឃក្តី គណក្តី បុគ្គលក្តី តែមិនទាន់បានប្រាប់អាត្មាអញ(ជាមុន)ហើយ មិនហ៊ាននិមន្តសង្ឃ ឬគណ ឬបុគ្គលទេ ឥឡូវនេះគាត់ មិនប្រាប់អាត្មាអញ(ជាមុន) ហើយមកនិមន្តភិក្ខុ ជាថេរទាំងឡាយ ឥឡូវនេះ ចិត្តគហបតិនេះ ខឹងមិនអាឡោះអាល័យ នឿយណាយចាកអាត្មាអញហើយ (គិតដូច្នេះហើយ) ទើបតបទៅ ចិត្តគហបតិ ដោយពាក្យដូច្នេះថា នែគហបតិ កុំឡើយ អាត្មា មិនទទួលនិមន្តទេ។ ចិត្តគហបតិ បានអង្វរ សុធម្មភិក្ខុ ដ៏មានអាយុ ជាគំរប់ពីរដង ដោយពាក្យដូច្នេះ បពិត្រលោកដ៏ចំរើន សូមលោកសុធម្មភិក្ខុជាម្ចាស់ ទទួលភត្ត របស់ខ្ញុំ ក្នុងថ្ងៃព្រឹកស្អែក ជាមួយនឹងព្រះថេរទាំងឡាយ។ សុធម្មភិក្ខុតបថា នែគហបតិ កុំឡើយ អាត្មាមិនទទួលនិមន្តទេ។ ចិត្តគហបតិ បានអង្វរសុធម្មភិក្ខុដ៏មានអាយុ ជាគំរប់បីដង ដោយពាក្យដូច្នេះថា បពិត្រលោកដ៏ចំរើន សូមលោកសុធម្មភិក្ខុជាម្ចាស់ ទទួលភត្ត របស់ខ្ញុំ ក្នុងថ្ងៃព្រឹកស្អែក ជាមួយនឹងព្រះថេរទាំងឡាយ។ សុធម្មភិក្ខុតបថា នែគហបតិ កុំឡើយ អាត្មា មិនទទួលនិមន្តទេ។ លំដាប់នោះ ចិត្តគហបតិគិតថា លោកសុធម្មភិក្ខុជាម្ចាស់ ទោះទទួលនិមន្តក្តី មិនទទួលនិមន្តក្តី នឹងមានប្រយោជន៍អ្វី ដល់អាត្មាអញ ហើយក៏ថ្វាយបង្គំ សុធម្មភិក្ខុ ដ៏មានអាយុ ធ្វើប្រទក្សិណ ហើយដើរចេញទៅ។

[១៣២] លុះកន្លងរាត្រីនោះទៅ ចិត្តគហបតិ ក៏តាក់តែងខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ ដើម្បីភិក្ខុ ជាថេរទាំងឡាយ។ លំដាប់នោះ សុធម្មភិក្ខុដ៏មានអាយុគិតថា គួរតែអាត្មាអញទៅមើលគ្រឿងសក្ការ ដែលចិត្តគហបតិ តាក់តែងដល់ភិក្ខុជាថេរទាំងឡាយ ហើយក៏ស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរអំពីព្រហាម ចូលទៅកាន់លំនៅ របស់ចិត្តគហបតិ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ដែលគេតែងតាំងទុក។ ឯចិត្តគហបតិ ក៏បានចូលទៅរក សុធម្មភិក្ខុដ៏មានអាយុ លុះចូលទៅដល់ ក៏ថ្វាយបង្គំសុធម្មភិក្ខុដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះចិត្តគហបតិ អង្គុយក្នុងទីសមគួរហើយ សុធម្មភិក្ខុ ដ៏មានអាយុ ក៏បាននិយាយពាក្យនេះថា ម្នាលគហបតិ ខាទនីយភោជនីយាហារ ដែលអ្នកតាក់តែងនេះ បរិបូណ៌ណាស់ហើយ ទាស់តែក្នុងទីនេះ គ្មាននំទ្រាបលូ មួយមុខប៉ុណ្ណោះ។ ចិត្តគហបតិតបថា សូមមេត្តាប្រោស បើព្រះពុទ្ធវចនមានច្រើនម្ល៉េះតើ (ថ្វីក៏) លោកម្ចាស់សុធម្ម ពោលពាក្យតែបន្តិចបន្តួចថា នំទ្រាបលូវិញ សូមមេត្តាប្រោស ធ្លាប់មានរឿងមកហើយថា មានពួកពាណិជ នៅស្រុកទក្ខិណាបថ បានទៅកាន់ បុរត្ថិមជនបទ ពាណិជទាំងនោះ នាំយកមេមាន់ពី បុរត្ថិមជនបទនោះមក សូមមេត្តាប្រោស ឯមេមាន់នោះ បានរួមសង្វាស ជាមួយនឹងក្អែក មេមាន់នោះ ក៏កើតកូន សូមមេត្តាប្រោស កាលណាកូនមាន់នោះ ចង់រងាវ ជាសំឡេងក្អែក វាក៏រងាវថា កាកាកុក្កុដី (ក្អែកមាន់) កាលណាបើចង់រងាវ ជាសំឡេងមាន់ វាក៏រងាវថា កុក្កុដីកាកា (មាន់ក្អែក) យ៉ាងណាមិញ សូមមេត្តាប្រោស បើពុទ្ធវចនមានច្រើនដល់ម្ល៉េះ (ថ្វីក៏) លោកម្ចាស់សុធម្ម ពោលពាក្យបន្តិចបន្តួចថា នំទ្រាបលូវិញ ក៏យ៉ាងនេះឯង។ សុធម្មភិក្ខុឆ្លើយថា ម្នាលគហបតិ អ្នកឯងជេរអាត្មា អ្នកឯងផ្ដាសាអាត្មា ម្នាលគហបតិ នុ៎ះអាវាស របស់អ្នកឯង អាត្មា មុខជាដើរចេញ ពីអាវាសនោះហើយ។ ចិត្តគហបតិនិយាយតបថា សូមមេត្តាប្រោស ខ្ញុំមិនបានជេរ មិនបានផ្ដាសា លោកម្ចាស់សុធម្មទេ សូមមេត្តាប្រោស សូមលោកម្ចាស់ សុធម្ម គង់ក្នុងវត្តអម្ពាដករវ័ន ជារម្មណីយស្ថាន ជិតនគរមច្ឆិកាសណ្ឌចុះ ខ្ញុំនឹងធ្វើសេចក្ដីខ្វល់ខ្វាយ ដល់លោកម្ចាស់សុធម្ម ដោយចីវរបិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យ ដល់មនុស្សឈឺ។ សុធម្មភិក្ខុដ៏មានអាយុ បាននិយាយពាក្យនេះ នឹងចិត្តគហបតិ ជាគំរប់ពីរដងទៀតថា ម្នាលគហបតិ អ្នកឯងជេរអាត្មា ម្នាលគហបតិ អ្នកឯងផ្ដាសាអាត្មា ម្នាលគហបតិ នុ៎ះអាវាសរបស់អ្នក អាត្មាមុខជាដើរចេញ ពីអាវាសនោះហើយ។ ចិត្តគហបតិក៏តបថា សូមមេត្តាប្រោស ខ្ញុំមិនបានជេរ មិនបានផ្ដាសា លោកម្ចាស់សុធម្មទេ សូមមេត្តាប្រោស សូមលោកម្ចាស់សុធម្មគង់ក្នុងវត្តអម្ពាដករវ័ន ជារម្មណីយស្ថាន ជិតនគរមច្ឆិកាសណ្ឌចុះ ខ្ញុំនឹងធ្វើសេចក្ដីខ្វល់ខ្វាយ ដល់លោកម្ចាស់សុធម្ម ដោយចីវរបិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យ ដល់មនុស្សឈឺ។ សុធម្មភិក្ខុដ៏មានអាយុ បាននិយាយពាក្យនេះ នឹងចិត្តគហបតិ ជាគំរប់បីដងទៀតថា ម្នាលគហបតិ អ្នកឯងជេរអាត្មា ម្នាលគហបតិ អ្នកឯងផ្ដាសាអាត្មា ម្នាលគហបតិ នុ៎ះអាវាស របស់អ្នក អាត្មាមុខជាដើរចេញ ពីអាវាសនោះហើយ។ ចិត្តគហបតិសួរថា សូមមេត្តាប្រោស ចុះលោកម្ចាស់សុធម្ម នឹងនិមន្តទៅ ក្នុងទីឯណា។ សុធម្មភិក្ខុប្រាប់ថា ម្នាលគហបតិ អាត្មានឹងទៅកាន់ ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ។ ចិត្តគហបតិផ្ដាំថា សូមមេត្តាប្រោស បើដូច្នោះ ពាក្យណា ដែលលោកម្ចាស់ បានពោលក្ដី ពាក្យណា ដែលខ្ញុំ បានពោលក្ដី សូមលោកម្ចាស់ (នាំយក) ពាក្យនោះ ទៅក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ឲ្យសព្វគ្រប់ផងចុះ សូមមេត្តាប្រោស បើលោកម្ចាស់ សុធម្ម ត្រឡប់មកកាន់នគរមច្ឆិកាសណ្ឌវិញ ដោយហេតុឯណា ហេតុនោះមិនជាអស្ចារ្យទេ។

[១៣៣] គ្រានោះ សុធម្មភិក្ខុដ៏មានអាយុ ក៏បានរៀបចំទុកដាក់ សេនាសនៈ ស្រេចហើយ នាំយកបាត្រ និងចីវរ ចេញទៅកាន់ក្រុងសាវត្ថី ហើយចូលទៅគាល់ ព្រះដ៏មានព្រះភាគ ឯវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ដោយលំដាប់ លុះចូលទៅដល់ហើយ បានថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះសុធម្មភិក្ខុអង្គុយក្នុងទីដ៏សមគួរហើយ ក៏(នាំយក) ពាក្យដែលខ្លួនពោល និងពាក្យដែល ចិត្តគហបតិ ពោលនោះ ក្រាបបង្គំទូល ព្រះដ៏មានព្រះភាគសព្វគ្រប់។

[១៣៤] ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អំពើនេះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ ម្នាលមោឃបុរស អ្នកឯងមិនសមបើ នឹងជេរ ចិត្តគហបតិ ដែលមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការក ជាឧបដ្ឋាកសង្ឃ ដោយពាក្យថោកទាប និងដៀលត្មះ ដោយពាក្យថោកទាបសោះ ម្នាលមោឃបុរស អំពើនេះ មិននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់តិះដៀលហើយ។បេ។ ក៏ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើបដិសារណីយកម្ម ដល់សុធម្មភិក្ខុ ដោយពាក្យថា លោកត្រូវសូមទោស នឹងគហបតិ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម នោះ សង្ឃត្រូវធ្វើយ៉ាងនេះ។ សង្ឃត្រូវចោទសុធម្មភិក្ខុ ជាមុន លុះចោទហើយ ត្រូវរំលឹក លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវញុំាងសង្ឃ ឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតសុធម្មភិក្ខុនេះ ជេរចិត្តគហបតិ ដែលជាអ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការក ជាឧបដ្ឋាកសង្ឃ ដោយពាក្យថោកទាប និងដៀលត្មះ ដោយពាក្យថោកទាប។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវធ្វើ បដិសារណីយកម្ម ដល់សុធម្មភិក្ខុ ដោយពាក្យថា លោកត្រូវសូមទោស នឹងចិត្តគហបតិ។ នេះជាវាចាប្រកាសឲ្យសង្ឃដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតសុធម្មភិក្ខុនេះ ជេរចិត្តគហបតិ ដែលជាអ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការក ជាឧបដ្ឋាកសង្ឃ ដោយពាក្យថោកទាប និងដៀលត្មះ ដោយពាក្យថោកទាប។ សង្ឃធ្វើបដិសារណីយកម្ម ដល់សុធម្មភិក្ខុ ដោយពាក្យថា លោកត្រូវសូមទោស នឹងចិត្តគហបតិ។ ការធ្វើ បដិសារណីយកម្ម ដល់សុធម្មភិក្ខុ ដោយពាក្យថា លោកត្រូវសូមទោស នឹងចិត្តគហបតិ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំប្រកាសសេចក្ដីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្ដីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតសុធម្មភិក្ខុនេះ ជេរចិត្តគហបតិ ដែលជាអ្នកមានសទ្ធាជ្រះថ្លា ជាទាយក ជាកប្បិយការក ជាឧបដ្ឋាកសង្ឃ ដោយពាក្យថោកទាប និងដៀលត្មះ ដោយពាក្យថោកទាប។ ឥឡូវ សង្ឃធ្វើ បដិសារណីយកម្ម ដល់សុធម្មភិក្ខុ ដោយពាក្យថា លោកត្រូវសូមទោស នឹងចិត្តគហបតិ។ ការធ្វើបដិសារណីយកម្ម ដល់សុធម្មភិក្ខុ ដោយពាក្យថា លោកត្រូវសូមទោស នឹងចិត្តគហបតិ ដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ បដិសារណីយកម្ម សង្ឃបានធ្វើដល់សុធម្មភិក្ខុ ដោយពាក្យថា លោកត្រូវសូមទោស នឹងចិត្តគហបតិ ដូច្នេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកសេចក្ដីនោះ ដោយអាការស្ងៀមយ៉ាងនេះ។

## (អធម្មកម្មមានចំនួន១២ ក្នុងបដិសារណីយកម្ម)

**(អធម្មកម្មទ្វាទសកំ)**

[១៣៥] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលសង្ឃរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើ ក្នុងទីកំបាំងមុខ១ កម្មដែលធ្វើ ដោយមិនបានសាកសួរ១ កម្មដែលធ្វើមិនបានតាមប្ដេជ្ញា១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[១៣៦] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយមិនមានអាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិ ជាអទេសនាគាមិនី១ កម្មដែលធ្វើ ដោយអាបត្តិ ដែលភិក្ខុបានសំដែងហើយ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៣៧] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្ម ដែលមិនបានចោទហើយ ស្រាប់តែធ្វើ១ កម្មដែលមិនរំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលមិនលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៣៨] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ក្នុងទីកំបាំងមុខ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើ ដោយពួក១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ប្រកបដោយ អង្គ៣នេះឯង។បេ។

[១៣៩] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើ ដោយមិនបានសាកសួរ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[១៤០] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្ម ដែលធ្វើមិនតាមប្ដេជ្ញា (របស់ភិក្ខុ)១ កម្មដែលធ្វើ មិនត្រូវតាមធម៌១ កម្មដែល ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៤១] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្ម ដែលធ្វើដោយមិនមានអាបត្តិ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៤២] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្ម ដែលធ្វើដោយអាបត្តិជាអទេសនាគាមិនី១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១។បេ។

[១៤៣] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ដែលភិក្ខុសំដែងហើយ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្ម។បេ។ ប្រកបដោយអង្គ៣នេះឯង។

[១៤៤] ម្នាលភិក្ខុទាំងឡាយ អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនចោទ ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៤៥] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលមិនរំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលមិនត្រូវធ្វើតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[១៤៦] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង។បេ។ ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលសង្ឃមិនលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាអធម្មកម្មផង ជាអវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

ចប់ អធម្មកម្មមានចំនួន១២ ក្នុងបដិសារណីយកម្ម។

## (ធម្មកម្មមាន១២ ក្នុងបដិសារណីយកម្ម)

CS vin.cv.01.04.02 | ភាគ ទី៩

**(ធម្មកម្មទ្វាទសកំ)**

[១៤៧] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្ម ដែលធ្វើចំពោះមុខ១ កម្មដែលធ្វើ ដោយការសាកសួរ១ កម្មដែលធ្វើតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[១៤៨] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្ម ដែលធ្វើដោយអាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិជា ទេសនាគាមិនី១ កម្មដែលធ្វើតាមអាបត្តិ ដែលភិក្ខុមិនបានសំដែង១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្ម ដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[១៤៩] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្ម ដែលចោទហើយ ទើបធ្វើ១ កម្មដែលរំលឹកហើយ ទើបធ្វើ១ កម្មដែលលើកអាបត្តិហើយ ទើបធ្វើ១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម។បេ។ ប្រកបដោយអង្គ៣នេះឯង។

[១៥០] ម្នាលភិក្ខុទាំងឡាយ អង្គ៣ដទៃទៀត។បេ។ គឺកម្ម ដែលធ្វើចំពោះមុខ១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម។បេ។ ប្រកបដោយអង្គ៣នេះឯង។

[១៥១] ម្នាលភិក្ខុទាំងឡាយ អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយការសាកសួរ១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម។បេ។ ប្រកបដោយអង្គ៣នេះឯង។

[១៥២] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ តាមពាក្យប្តេជ្ញា១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម។បេ។ ប្រកបដោយអង្គ៣នេះឯង។

[១៥៣] ម្នាលភិក្ខុទាំងឡាយ អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយអាបត្តិ១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម។បេ។ ប្រកបដោយអង្គ៣នេះឯង។

[១៥៤] ម្នាលភិក្ខុទាំងឡាយ អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយអាបត្តិ ជា ទេសនាគាមិនី១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀង១។បេ។

[១៥៥] ម្នាលភិក្ខុទាំងឡាយ អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយអាបត្តិ ដែលភិក្ខុមិនបានសំដែង១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ។បេ។

[១៥៦] ម្នាលភិក្ខុទាំងឡាយ អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលចោទហើយ ទើបធ្វើ១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ។បេ។

[១៥៧] ម្នាលភិក្ខុទាំងឡាយ អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលរំលឹកហើយ ទើបធ្វើ១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[១៥៨] ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្មដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣ដទៃទៀត គឺកម្ម ដែលលើកអាបត្តិឡើង ហើយទើបធ្វើ១ កម្មដែលធ្វើតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ បដិសារណីយកម្ម ជាធម្មកម្មផង ជាវិនយកម្មផង ជាកម្ម ដែលរម្ងាប់ ដោយល្អផង ប្រកបដោយ អង្គ៣នេះឯង។

ចប់ ធម្មកម្មមាន១២ ក្នុងបដិសារណីយកម្ម។

## (បដិសារណីយកម្ម មានប្រាំៗ បួនលើក ដែលសង្ឃប្រាថ្នា)

CS vin.cv.01.04.03 | ភាគ ទី៩

### (អាកង្ខមានចតុក្កំ)

[១៥៩] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើ បដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយ អង្គ៥ គឺភិក្ខុព្យាយាម មិនឲ្យពួកគ្រហស្ថបានលាភ១ ព្យាយាម មិនឲ្យពួកគ្រហស្ថបានប្រយោជន៍១ ព្យាយាម មិនឲ្យពួកគ្រហស្ថ បានលំនៅ១ ជេរប្រទេចពួកគ្រហស្ថ១ បំបែកពួកគ្រហស្ថ ឲ្យបែកចាកពួកគ្រហស្ថ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយ អង្គ៥នេះឯង។[18)]

[១៦០] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយ អង្គ៥ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ ចំពោះ (មុខ) ពួកគ្រហស្ថ១ ពោលតិះដៀលព្រះធម៌ ចំពោះ (មុខ) ពួកគ្រហស្ថ១ ពោលតិះដៀលព្រះសង្ឃ ចំពោះ (មុខ) ពួកគ្រហស្ថ១ ជេរពួកគ្រហស្ថ ដោយពាក្យថោកទាប១ ដៀលត្មះពួកគ្រហស្ថ ដោយពាក្យថោកទាប១ ទទួលពាក្យប្តេជ្ញា ប្រកបដោយធម៌ អំពីពួកគ្រហស្ថហើយ ត្រឡប់ជាមិនធ្វើឲ្យពិត តាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។ (ឃើញថាមានអង្គ៦ មិនមែន៥ទេ)

[១៦១] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុ ៥ពួក គឺភិក្ខុមួយពួក ព្យាយាមមិនឲ្យគ្រហស្ថបានលាភ១ មួយពួកព្យាយាម មិនឲ្យពួកគ្រហស្ថបានប្រយោជន៍១ មួយពួកព្យាយាម មិនឲ្យពួកគ្រហស្ថបានលំនៅ១ មួយពួកជេរប្រទេចពួកគ្រហស្ថ១ មួយពួកបំបែកពួកគ្រហស្ថ (ឲ្យបែក)ចាកពួកគ្រហស្ថ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុ៥ពួកនេះឯង

[១៦២] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុ៥ពួកដទៃទៀត គឺភិក្ខុមួយពួកពោលតិះដៀលព្រះពុទ្ធ ចំពោះ (មុខ) ពួកគ្រហស្ថ១ មួយពួកពោលតិះដៀលព្រះធម៌ ចំពោះ (មុខ) ពួកគ្រហស្ថ១ មួយពួកពោលតិះដៀលព្រះសង្ឃ ចំពោះ (មុខ) ពួកគ្រហស្ថ១ មួយពួកជេរពួកគ្រហស្ថ ដោយពាក្យថោកទាប១ មួយពួកដៀលត្មះពួកគ្រហស្ថ ដោយពាក្យថោកទាប១ មួយពួកទទួលពាក្យប្តេជ្ញាប្រកបដោយធម៌ អំពីពួកគ្រហស្ថហើយ ហើយត្រឡប់ជាមិនធ្វើឲ្យពិត តាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុ៥ពួកនេះឯង។ (ឃើញថាមាន៦ពួក មិនមែន៥ពួកទេ)

ចប់ បដិសារណីយកម្ម មានប្រាំៗ បួនលើក (ម្តៗ) ដែលសង្ឃប្រាថ្នា (នឹងធ្វើ ក៏ធ្វើបាន)។

## (វត្ត១៨ ក្នុងបដិសារណីយកម្ម)

CS vin.cv.01.04.04 | ភាគ ទី៩

### (អដ្ឋារសវត្តំ)

[១៦៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើបដិសារណីយកម្មហើយ គួរប្រព្រឹត្តវត្ត ដោយត្រឹមត្រូវ។ ឯការប្រព្រឹត្តវត្ត ដោយត្រឹមត្រូវក្នុងបដិសារណីយកម្មនោះ ដូច្នេះ គឺភិក្ខុនោះ មិនត្រូវឲ្យឧបសម្បទា១ មិនត្រូវឲ្យនិស្ស័យ១ មិនត្រូវឲ្យសាមណេរបម្រើខ្លួន១ មិនត្រូវទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ ទុកជាសង្ឃបានសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនីទាំងឡាយ១ សង្ឃបានធ្វើបដិសារណីយកម្ម ព្រោះអាបត្តិណា ភិក្ខុមិនគប្បីត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលគ្នានឹងអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ១ ភិក្ខុនោះ មិនត្រូវតិះដៀលកម្ម១ មិនត្រូវតិះដៀលភិក្ខុដែលធ្វើកម្ម១ មិនត្រូវហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត១ មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ មិនត្រូវទទួលនាទី ជាធំក្នុងវត្ត១ មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនត្រូវចោទគេ១ មិនត្រូវរំលឹកគេ១ មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១។

ចប់ វត្ត១៨ ក្នុងបដិសារណីយកម្ម។

[១៦៤] គ្រានោះ សង្ឃបានធ្វើបដិសារណីយកម្ម ដល់សុធម្មភិក្ខុថា លោកត្រូវសូមទោស នឹងចិត្តគហបតិ។ សុធម្មភិក្ខុនោះ កាលបើសង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ទៅកាន់នគរមច្ឆិកាសណ្ឌ បែរជាអៀនអន់ មិនអាចនឹងសូមទោសចិត្តគហបតិឡើយ។ លោកក៏ត្រឡប់ មកក្រុងសាវត្ថីវិញ។ ភិក្ខុទាំងឡាយ និយាយយ៉ាងនេះថា នែអាវុសោសុធម្ម លោកបានសូមទោស នឹងចិត្តគហបតិហើយឬ។ សុធម្មភិក្ខុឆ្លើយថា នែអាវុសោទាំងឡាយ ខ្ញុំបានចេញអំពីទីនេះ ទៅដល់នគរមច្ឆិកាសណ្ឌហើយ ក៏មានសេចក្តីអៀនអន់ មិនអាចសូមទោស នឹងចិត្តគហបតិឡើយ។ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃឲ្យអនុទូត[19] ដល់សុធម្មភិក្ខុ ដើម្បីសូមទោស នឹងចិត្តគហបតិ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុជាអនុទូតនោះ) សង្ឃត្រូវប្រគល់យ៉ាងនេះ។ សង្ឃត្រូវសូមភិក្ខុជាមុន លុះសូមហើយ ត្រូវភិក្ខុដែលឆ្លាស ប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើបដិសារណីយកម្ម មានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវប្រគល់ភិក្ខុឈ្មោះនេះ ឲ្យជាអនុទូត របស់សុធម្មភិក្ខុ ដើម្បីសូមទោស នឹងចិត្តគហបតិចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃប្រគល់ភិក្ខុឈ្មោះនេះ ឲ្យជាអនុទូត របស់សុធម្មភិក្ខុ ដើម្បីសូមទោស នឹងចិត្តគហបតិ។ ការប្រគល់ភិក្ខុឈ្មោះនេះ ឲ្យជាអនុទូត របស់សុធម្មភិក្ខុ ដើម្បីសូមទោស នឹងចិត្តគហបតិ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានប្រគល់ ភិក្ខុឈ្មោះនេះ ឲ្យជាអនុទូត របស់សុធម្មភិក្ខុ ដើម្បីនឹងសូមទោស នឹងចិត្តគហបតិហើយ ការប្រគល់អនុទូតនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[១៦៥] ម្នាលភិក្ខុទាំងឡាយ សុធម្មភិក្ខុនោះ ត្រូវទៅនគរមច្ឆិកាសណ្ឌ ជាមួយនឹងភិក្ខុជាអនុទូត ហើយសូមទោស នឹងចិត្តគហបតិថា ម្នាលគហបតិ អ្នកចូរអត់ទោស ម្នាលគហបតិ អាត្មាឲ្យអ្នកជ្រះថ្លា (វិញ) បើសុធម្មភិក្ខុនោះ និយាយយ៉ាងនេះ ចិត្តគហបតិ ក៏បានព្រមអត់ទោសឲ្យ ការអត់ទោសឲ្យ យ៉ាងនេះ ជាការល្អ។ បើចិត្តគហបតិ មិនព្រមអត់ទោសឲ្យទេ ត្រូវភិក្ខុជាអនុទូត ជួយនិយាយថា ម្នាលចិត្តគហបតិ អ្នកចូរអត់ទោស ដល់ភិក្ខុនេះចុះ ភិក្ខុនេះ នឹងឲ្យអ្នកជ្រះថ្លាវិញ បើភិក្ខុជាអនុទូត និយាយយ៉ាងនេះហើយ ចិត្តគហបតិ ក៏អត់ទោសឲ្យ ការព្រមអត់ទោសឲ្យ យ៉ាងនេះ ជាការល្អ។ បើចិត្តគហបតិ មិនព្រមអត់ទោសឲ្យទេ ត្រូវភិក្ខុជាអនុទូត និយាយថា ម្នាលចិត្តគហបតិ អ្នកចូរអត់ទោស ដល់ភិក្ខុនេះចុះ អាត្មានឹងឲ្យអ្នកជ្រះថ្លាវិញ បើភិក្ខុជាអនុទូត និយាយយ៉ាងនេះហើយ ចិត្តគហបតិ ក៏ព្រមអត់ទោសឲ្យ ការព្រមអត់ទោសឲ្យ យ៉ាងនេះ ជាការល្អ។ បើចិត្តគហបតិនោះ មិនព្រមអត់ទោសឲ្យទេ ត្រូវភិក្ខុជាអនុទូត និយាយទៀតថា ម្នាលចិត្តគហបតិ អ្នកចូរអត់ទោស ដល់ភិក្ខុនេះ តាមពាក្យរបស់សង្ឃចុះ បើភិក្ខុជាអនុទូត និយាយយ៉ាងនេះហើយ ចិត្តគហបតិ ក៏ព្រមអត់ទោសឲ្យ ការព្រមអត់ទោសឲ្យ យ៉ាងនេះ ជាការល្អ។ បើចិត្តគហបតិ មិនព្រមអត់ទោសឲ្យទេ ត្រូវភិក្ខុជាអនុទូត កុំឲ្យសុធម្មភិក្ខុលះទីឧបចារ ដែលមើលឃើញ កុំឲ្យលះទីឧបចារ ដែលស្តាប់ឮ របស់ចិត្តគហបតិឡើយ ហើយឲ្យធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង រួចឲ្យអង្គុយច្រហោង ផ្គងអញ្ជលី ហើយឲ្យសំដែងអាបត្តិនោះចេញ។

[១៦៦] វេលានោះ ឯសុធម្មភិក្ខុដ៏មានអាយុ ក៏បានទៅកាន់នគរមច្ឆិកាសណ្ឌ ជាមួយនឹងភិក្ខុជាអនុទូត ហើយសូមទោសចិត្តគហបតិ។ សុធម្មភិក្ខុនោះ ព្រមប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ចេញចាកកម្ម រួចចូលទៅរកភិក្ខុទាំងឡាយ ហើយនិយាយ

យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាអ្នកដែលសង្ឃបានធ្វើបដិសារណីយកម្មហើយ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួនចេញចាកកម្មហើយ ខ្ញុំត្រូវប្រតិបត្តិដូចម្តេច(ទៀត)។ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់បដិសារណីយកម្មរបស់សុធម្មភិក្ខុចុះ។

## (អង្គមានចំនួន១៨ ដែលសង្ឃមិនត្រូវរម្ងាប់ ក្នុងបដិសារណីយកម្ម)

CS vin.cv.01.04.05 | ភាគ ទី៩

### (នប្បដិប្បស្សម្ភេតព្ពអដ្ឋារសកំ)

[១៦៧] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ គឺភិក្ខុឲ្យឧបសម្បទា១ ឲ្យនិស្ស័យ១ ឲ្យសាមណេរបម្រើខ្លួន១ ទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ ដែលសង្ឃបានសន្មតហើយ ក៏ទៅប្រដៅភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្ម របស់ភិក្ខុ ដែលប្រកបដោយ អង្គ៥នេះទេ។

[១៦៨] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយ អង្គ៥ដទៃទៀត គឺភិក្ខុ ដែលសង្ឃបានធ្វើបដិសារណីយកម្ម ព្រោះអាបត្តិណា នៅតែត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ដែលប្រហែលគ្នា នឹងអាបត្តិនោះ១ ឬអាបត្តិ ដែលធ្ងន់ជាងអាបត្តិនោះ១ តិះដៀលកម្ម១ តិះដៀលពួកភិក្ខុដែលធ្វើកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយ អង្គ៥នេះទេ។

[១៦៩] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៨ គឺភិក្ខុហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ ហាមបវារណា ដល់ភិក្ខុជាបកតត្ត១ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ ទទួលនាទី ជាធំក្នុងវត្ត១ ឲ្យធ្វើឱកាស (ដើម្បីចោទ)១ ចោទ១ រំលឹក១ ប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៨នេះទេ។

ចប់ អង្គមានចំនួន១៨ ដែលសង្ឃមិនត្រូវរម្ងាប់ ក្នុងបដិសារណីយកម្ម។

## (អង្គមានចំនួន១៨ ដែលសង្ឃត្រូវរម្ងាប់ ក្នុងបដិសារណីយកម្ម)

CS vin.cv.01.04.06 | ភាគ ទី៩

### (បដិប្បស្សម្ភេតព្ពអដ្ឋារសកំ)

[១៧០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ គឺភិក្ខុមិនបានឲ្យឧបសម្បទា១ មិនបានឲ្យនិស្ស័យ១ មិនបានឲ្យសាមណេរបម្រើខ្លួន១ មិនបានទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ ដែលសង្ឃបានសន្មតហើយ ក៏មិនប្រដៅភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយ អង្គ៥នេះឯង។

[១៧១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើបដិសារណីយកម្ម ព្រោះអាបត្តិណា ហើយមិនបានត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលគ្នា នឹងអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ១ មិនបានតិះដៀលកម្ម១ មិនបានតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយ អង្គ៥នេះឯង។

[១៧២] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ បដិសារណីយកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៨ គឺភិក្ខុមិនបានហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ មិនបានហាមបវារណា ដល់ភិក្ខុជាបកតត្ត១ មិនបានធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ មិនបានទទួលនាទីជាធំក្នុងវត្ត១ មិនបានឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនបានចោទគេ១ មិនបានរំលឹក១ មិនបានប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់បដិសារណីយកម្ម ដល់ភិក្ខុដែលប្រកបដោយ អង្គ៨នេះឯង។

ចប់ អង្គមានចំនួន១៨ ដែលសង្ឃត្រូវរម្ងាប់ ក្នុងបដិសារណីយកម្ម។

[១៧៣] ម្នាលភិក្ខុទាំងឡាយ ឯបដិសារណីយកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សុធម្មភិក្ខុ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង រួចថ្វាយបង្គំបាទា របស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី និយាយយ៉ាងនេះនឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកដែលសង្ឃ បានធ្វើបដិសារណីយកម្មរួចហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ចេញចាកកម្ម មកសូមការរម្ងាប់ បដិសារណីយកម្ម។ ភិក្ខុនោះ ត្រូវសូម ជាគំរប់ពីរដងផង។ ត្រូវសូម ជាគំរប់បីដងផង។ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សុធម្មភិក្ខុនេះ សង្ឃបានធ្វើ បដិសារណីយកម្មហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ បដិសារណីយកម្ម។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវរម្ងាប់ បដិសារណីយកម្ម ដល់សុធម្មភិក្ខុចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សុធម្មភិក្ខុនេះ សង្ឃបានធ្វើ បដិសារណីយកម្មហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ បដិសារណីយកម្ម។ សង្ឃរម្ងាប់បដិសារណីយកម្ម ដល់សុធម្មភិក្ខុ។ ការរម្ងាប់បដិសារណីយកម្ម ដល់សុធម្មភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវ

និយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សុធម្មភិក្ខុនេះ សង្ឃបានធ្វើ បដិសារណីយកម្មហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួនចេញចាកកម្ម មកសូមការរម្ងាប់ បដិសារណីយកម្ម។ សង្ឃរម្ងាប់បដិសារណីយកម្ម ដល់សុធម្មភិក្ខុ។ ការរម្ងាប់បដិសារណីយកម្ម ដល់សុធម្មភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សុធម្មភិក្ខុនេះ សង្ឃបានធ្វើ បដិសារណីយកម្មហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួនចេញ ចាកកម្ម មកសូមការរម្ងាប់ បដិសារណីយកម្ម។ សង្ឃរម្ងាប់ បដិសារណីយកម្ម ដល់សុធម្មភិក្ខុ។ ការរម្ងាប់ បដិសារណីយកម្ម ដល់ សុធម្មភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានរម្ងាប់បដិសារណីយកម្ម ដល់សុធម្មភិក្ខុហើយ ការរម្ងាប់បដិសារណីយកម្ម ដល់សុធម្មភិក្ខុនេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ បដិសារណីយកម្ម ទី៤។

# (ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ជាគំរប់៥)

CS vin.cv.01.05 | ភាគ ទី៩

### (៥. អាបត្តិយា អទស្សនេ ឧក្ខេបនីយកម្មំ)

[១៧៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី។ វេលានោះឯង ឆន្នភិក្ខុដ៏មានអាយុ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញ នូវអាបត្តិឡើយ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ ឆន្នដ៏មានអាយុ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិសោះ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[១៧៥] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ក្នុងវេលានោះ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បានឮថា ឆន្នភិក្ខុត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ការនេះ មិនសមគួរទេ។បេ។ ម្នាលភិក្ខុទាំងឡាយ មិនសមបើ មោឃបុរសនោះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ នឹងបានដឹកនាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងក៏ទេ។បេ។ លុះទ្រង់បន្ទោសរួច។បេ។ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុចុះ។ ម្នាលភិក្ខុទាំងឡាយ ឯឧក្ខេបនីយកម្មនោះ សង្ឃត្រូវធ្វើយ៉ាងនេះ។ សង្ឃត្រូវចោទឆន្នភិក្ខុជាមុន លុះចោទហើយ ត្រូវរំលឹក លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិឡើយ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើឧក្ខេបនីយកម្ម គឺកុំឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិទេ។ សង្ឃក៏ធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ។ ការធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងឃើញអាបត្តិទេ។ សង្ឃក៏ធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ។ ការធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុហើយ ការធ្វើឧក្ខេបនីយកម្ម ដល់ឆន្នភិក្ខុនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រាប់គ្នា ក្នុងអាវាសតៗទៅថា ឆន្នភិក្ខុ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួមជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិហើយ។

## (អធម្មកម្ម មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ)

CS vin.cv.01.05.01 | ភាគ ទី៩

### (អធម្មកម្មទ្វាទសកំ)

[១៧៦] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣ គឺកម្ម ដែលធ្វើ ក្នុងទីកំបាំងមុខ១ កម្មដែលធ្វើ ដោយមិនបានសាកសួរ១ កម្មដែលធ្វើ ដោយមិនតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[១៧៧] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយគ្មានអាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិមិនមែនជាទេសនាគាមិនី១ កម្មដែលធ្វើ ដោយអាបត្តិ ដែលភិក្ខុសំដែងហើយ១។បេ។

[១៧៨] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនបានចោទ ហើយស្រាប់តែធ្វើ១ កម្មដែលមិនបានរំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលមិនបានលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១។បេ។

[១៧៩] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១។បេ។

[១៨០] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយមិនបានសាកសួរ១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ។បេ។

[១៨១] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយមិនតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១។បេ។

[១៨២] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយគ្មានអាបត្តិ១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១។បេ។

[១៨៣] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយអាបត្តិដែលមិនមែនជា ទេសនាគាមិនី១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១។បេ។

[១៨៤] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ដែលភិក្ខុសំដែងហើយ១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១។បេ។

[១៨៥] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនបានចោទ ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១។បេ។

[១៨៦] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនបានរំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១។បេ។

[១៨៧] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនបានលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនប្រកបដោយធម៌១ កម្មដែលធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

ចប់ អធម្មកម្ម មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។

## (ធម្មកម្ម មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ)

CS vin.cv.01.05.02 | ភាគ ទី៩

### (ធម្មកម្មទ្វាទសកំ)

[១៨៨] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ១ កម្មដែលធ្វើ ដោយការសាកសួរ១ កម្មដែលធ្វើ តាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[១៨៩] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើតាមអាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិ ជាទេសនាគាមិនី១ កម្មដែលធ្វើ ដោយអាបត្តិ ដែលភិក្ខុមិនបានសំដែងចេញ១។បេ។

[១៩០] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលចោទហើយ ទើបធ្វើ១ កម្មដែលរំលឹកហើយ ទើបធ្វើ១ កម្មដែលលើកអាបត្តិហើយ ទើបធ្វើ១។បេ។

[១៩១] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[១៩២] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយការសាកសួរ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[១៩៣] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[១៩៤] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើតាមអាបត្តិ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[១៩៥] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ជាទេសនាគាមិនី១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[១៩៦] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ដែលភិក្ខុមិនបានសំដែងចេញ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[១៩៧] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលចោទហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[១៩៨] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលរំលឹកហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[១៩៩] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលលើកអាបត្តិឡើងហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដែលជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

ចប់ ធម្មកម្ម មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។

## (ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ មានចំនួន៦ ដែលសង្ឃប្រាថ្នា)

CS vin.cv.01.05.03 | ភាគ ទី៩

### (អាកង្ខមានឆក្កំ)

[២០០] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺភិក្ខុបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណក្នុងសង្ឃ១ ភិក្ខុល្ងង់ មិនឆ្លាស ត្រូវអាបត្តិច្រើន មិនមានការកំណត់អាបត្តិ១ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[២០១] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីល១ មានអាចារវិបត្តិ ក្នុងអជ្ឈាចារ១ មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[២០២] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[២០៣] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុ៣ពួក គឺភិក្ខុអ្នកបង្កហេតុ។បេ។ បង្កអធិករណក្នុងសង្ឃពួក១ ជាអ្នកល្ងង់ មិនឆ្លាស ត្រូវអាបត្តិច្រើន មិនមានការកំណត់អាបត្តិពួក១ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុ៣ពួកនេះឯង។

[២០៤] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីលពួក១ មានអាចារវិបត្តិ ក្នុងអជ្ឈាចារពួក១ មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុ៣ពួកនេះឯង។

[២០៥] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធពួក១ ពោលតិះដៀលព្រះធម៌ពួក១ ពោលតិះដៀលព្រះសង្ឃពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុ៣ពួកនេះឯង។

ចប់ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ មានចំនួន៦ ដែលសង្ឃប្រាថ្នា (នឹងធ្វើក៏ធ្វើបាន)។

## (វត្ត៤៣ ក្នុងឧក្ខេបនីយកម្ម ព្រោះការមិនឃើញអាបត្តិ)

CS vin.cv.01.05.04 | ភាគ ទី៩

### (តេចត្តាលីសវត្តំ)

[២០៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃ បានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ ត្រូវប្រព្រឹត្តវត្ត ដោយប្រពៃ។ ការប្រព្រឹត្តវត្តដោយប្រពៃ ក្នុងឧក្ខេបនីយកម្មនោះ ដូច្នេះ គឺភិក្ខុនោះ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី ទុកជាសង្ឃបានសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនីឡើយ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិចំពោះអាបត្តិណា មិនឲ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃ ប្រហែលអាបត្តិនោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវ

តិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវត្រេកអរនឹងការថ្វាយបង្គំ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេក ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រចីវរ និងការបរិកម្ម (ដុស) ខ្នង ក្នុងវេលាស្រង់ទឹក របស់ភិក្ខុជាបកតត្ត មិនត្រូវចោទភិក្ខុជាបកតត្ត ដោយសីលវិបត្តិ មិនត្រូវចោទភិក្ខុជាបកតត្ត ដោយអាចារវិបត្តិ មិនត្រូវចោទភិក្ខុជាបកតត្ត ដោយទិដ្ឋិវិបត្តិ មិនត្រូវចោទភិក្ខុជាបកតត្ត ដោយអាជីវវិបត្តិ មិនត្រូវបំបែកភិក្ខុទាំងឡាយ ឲ្យបែកចាកពួកភិក្ខុ មិនត្រូវទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ[20] មិនត្រូវទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ[21] មិនត្រូវសេពគប់នឹងពួកតិរ្ថិយ ត្រូវសេពគប់នឹងពួកភិក្ខុ ត្រូវសិក្សាសិក្ខារបស់ភិក្ខុ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងទីមិនមែនអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬទីមិនមែនអាវាស ដែលមានដម្បូលមួយជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្តហើយ ត្រូវក្រោកឡើងពីអាសនៈ មិនត្រូវរុករានភិក្ខុជាបកតត្ត ខាងក្នុង ឬខាងក្រៅ (វិហារ) មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ ក្នុងអធិករណនោះ មិនត្រូវទទួលនាទី ជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា។

ចប់ វត្ថុ៤៣ ក្នុងឧក្ខេបនីយកម្ម ព្រោះការមិនឃើញអាបត្តិ។

[២០៧] គ្រានោះ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគជាមួយនឹងសង្ឃ ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ។ ឆន្នភិក្ខុនោះ ជាអ្នកដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិរួចហើយ ក៏បានចេញពីអាវាសនោះ ទៅកាន់អាវាសដទៃ ឯភិក្ខុទាំងឡាយក្នុងអាវាសនោះ មិនបានសំពះ មិនបានក្រោកទទួល មិនបានធ្វើអញ្ជលីកម្ម មិនបានធ្វើសាមីចិកម្ម មិនបានធ្វើសក្ការ មិនបានធ្វើសេចក្តីគោរព មិនបានរាប់អាន មិនបានបូជា។ ឆន្នភិក្ខុនោះ កាលបើពួកភិក្ខុទាំងឡាយ មិនបានធ្វើសក្ការ មិនបានធ្វើសេចក្តីគោរព មិនបានរាប់អាន មិនបានបូជា ឥតមានគេធ្វើសក្ការហើយ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃទៀត ឯពួកភិក្ខុទាំងឡាយក្នុងអាវាសនោះសោត ក៏មិនបានសំពះ មិនបានក្រោកទទួល មិនបានធ្វើអញ្ជលីកម្ម មិនបានធ្វើសាមីចិកម្ម មិនបានធ្វើសក្ការ មិនបានធ្វើសេចក្តីគោរព មិនបានរាប់អាន មិនបានបូជាឡើយ។ ឆន្នភិក្ខុនោះ កាលបើពួកភិក្ខុលែងធ្វើសក្ការ លែងគោរព លែងរាប់អាន លែងបូជា ឥតមានគេធ្វើសក្ការហើយ ក៏ចេញពីអាវាសនោះ ទៅកាន់អាវាសដទៃទៀត ឯពួកភិក្ខុក្នុងអាវាសនោះសោត ក៏មិនបានសំពះ មិនបានក្រោកទទួល មិនបានធ្វើអញ្ជលីកម្ម មិនបានធ្វើសាមីចិកម្ម មិនបានធ្វើសក្ការ មិនបានធ្វើសេចក្តីគោរព មិនបានរាប់អាន មិនបានបូជាឡើយ។ ឆន្នភិក្ខុនោះ កាលបើពួកភិក្ខុ មិនបានធ្វើសក្ការ មិនបានធ្វើសេចក្តីគោរព មិនបានរាប់អាន មិនបានបូជា ឥតមានគេធ្វើសក្ការហើយ ក៏ត្រឡប់វិលមកក្រុងកោសម្ពីវិញ ឆន្នភិក្ខុនោះ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម រួចចូលទៅរកភិក្ខុទាំងឡាយ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្លួនខ្ញុំសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនបានឃើញអាបត្តិ ខ្ញុំបានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម ខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត។ ឯភិក្ខុទាំងនោះ ក៏បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុចុះ។

## (វត្ថុ៤៣ ដែលសង្ឃមិនត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ)

CS vin.cv.01.05.05 | ភាគ ទី៩

### (នប្បដិប្បស្សម្ភេតព្វតេចត្តាលីសកំ)

[២០៨] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុឲ្យឧបសម្បទា១ ឲ្យនិស្ស័យ១ ឲ្យសាមណេរបម្រើខ្លួន១ ទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ សង្ឃបានសន្មតហើយ ក៏នៅតែប្រដៅភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២០៩] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ចំពោះអាបត្តិណា ហើយនៅតែត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ១ តិះដៀលកម្ម១ តិះដៀលពួកភិក្ខុដែលធ្វើកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២១០] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុត្រេកអរនឹងការសំពះ១ ការក្រោកឡើងទទួល១ អញ្ជលិកម្ម១ សាមីចិកម្ម១ ការនាំអាសនមក១ របស់ភិក្ខុជាបកតត្ត ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២១១] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុត្រេកអរនឹងការនាំទីដេកមក១ ទឹកលាងជើង១ តាំងសម្រាប់រងជើង និងវត្ថុសម្រាប់ជូតជើង១ ការទទួលយកបាត្រ និងចីវរ១ និងបរិកម្ម (ដុស) ខ្នង ក្នុងការងូតទឹក១ របស់ភិក្ខុជាបកតត្ត ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២១២] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុចោទភិក្ខុជាបកតត្ត ដោយសីលវិបត្តិ១ ចោទដោយអាចារវិបត្តិ១ ចោទដោយទិដ្ឋិវិបត្តិ១ ចោទដោយអាជីវវិបត្តិ១ បំបែកពួកភិក្ខុ ឲ្យបែកចាកភិក្ខុទាំងឡាយ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២១៣] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ១ ទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ១ សេពគប់នឹងពួកតិរ្ថិយ១ មិនសេពគប់នឹងពួកភិក្ខុ១ មិនសិក្សាសិក្ខារបស់ភិក្ខុ១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២១៤] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុនៅក្នុងអាវាស ដែលមានដម្បូលមួយ១ នៅក្នុងទីមិនមែនអាវាស ដែលមានដម្បូលមួយ១ នៅក្នុងអាវាស ឬទីមិនមែនអាវាស ដែលមានដម្បូលមួយ១ ជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្តហើយ មិនបានក្រោកចាកអាសន១ រុករានភិក្ខុជាបកតត្ត ខាងក្នុង ឬខាងក្រៅ (វិហារ)១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២១៥] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ ហាមបវារណា ដល់ភិក្ខុជាបកតត្ត១ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ ទទួលនាទីជាធំក្នុងវត្ត១ ឲ្យធ្វើឱកាស (ដើម្បីចោទ)១ ចោទ១ រំលឹក១ ប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៨នេះទេ។

ចប់ វត្ត៤៣ ដែលសង្ឃមិនត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។

## (វត្តមានចំនួន៤៣ ដែលសង្ឃត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ)

CS vin.cv.01.05.06 | ភាគ ទី៩

### (បដិប្បស្សម្ភេតព្វតេចត្តាលីសកំ)

[២១៦] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុមិនឲ្យឧបសម្បទា១ មិនឲ្យនិស្ស័យ១ មិនឲ្យសាមណេរបម្រើខ្លួន១ មិនទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ ទុកជាសង្ឃបានសន្មតហើយ ក៏មិនប្រដៅភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២១៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ចំពោះអាបត្តិណា មិនឲ្យត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ១ មិនតិះដៀលកម្ម១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២១៨] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុមិនត្រេកអរនឹងការសំពះ១ ការក្រោកទទួល១ អញ្ជលិកម្ម១ សាមីចិកម្ម១ ការនាំអាសនមកឲ្យ១ របស់ភិក្ខុជាបកតត្ត ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២១៩] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុមិនត្រេកអរនឹងការនាំទីដៃកមកឲ្យ១ ទឹកសម្រាប់លាងជើង១ តាំងសម្រាប់ទ្រជើង និងវត្ថុសម្រាប់ជូតជើង១ ការទទួលបាត្រ ចីវរ១ និងបរិកម្ម (ដុស) ខ្នង ក្នុងការងូតទឹក១ របស់ភិក្ខុជាបកតត្ត ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២២០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុមិនចោទភិក្ខុជាបកតត្ត ដោយសីលវិបត្តិ១ មិនចោទដោយអាចារវិបត្តិ១ មិនចោទដោយទិដ្ឋិវិបត្តិ១ មិនចោទដោយអាជីវវិបត្តិ១ មិនបំបែកពួកភិក្ខុ (ឲ្យបែក)ចាកភិក្ខុទាំងឡាយ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២២១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុមិនទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ១ មិនទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ១ មិនសេពគប់នឹងពួកតិរ្ថិយ១ សេពគប់នឹងពួកភិក្ខុ១ សិក្សាសិក្ខារបស់ភិក្ខុ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២២២] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុមិននៅក្នុងអាវាសមានដម្បូលមួយ១ មិននៅក្នុងទីមិនមែនជាអាវាស ដែលមានដម្បូលមួយ១ មិននៅក្នុងទីអាវាស ឬទីមិនមែនអាវាស ដែលមានដម្បូលមួយ១ ជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្តហើយ ក្រោកចេញពីអាសន១ មិនរុករានភិក្ខុជាបកតត្ត ខាងក្នុង ឬខាងក្រៅ (វិហារ)១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២២៣] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុមិនហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ មិនហាមបវារណា ដល់ភិក្ខុជាបកតត្ត១ មិនធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ)១ មិនទទួលនាទីជាធំក្នុងវត្ត១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនចោទ១ មិនរំលឹក១ មិនប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៨នេះឯង។

ចប់ វត្តមានចំនួន៤៣ ដែលសង្ឃត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។

[២២៤] ម្នាលភិក្ខុទាំងឡាយ ឯឧក្ខេបនីយកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឆន្នភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទា ភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលី និយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។ ត្រូវសូមជាគំរប់ពីរដងផង។ ត្រូវសូមជាគំរប់បីដងផង។ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។ បើកម្ម មានកាលគួរ ដល់សង្ឃហើយ សង្ឃគួររម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុនេះចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ដល់ឆន្នភិក្ខុហើយ ការរម្ងាប់ឧក្ខេបនីយកម្មនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ជាគំរប់៥។

# (ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាគំរប់៦)

CS vin.cv.01.06 | ភាគ ទី៩

### (៦. អាបត្តិយា អប្បដិកម្មេ ឧក្ខេបនីយកម្មំ)

[២២៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់ក្នុងឃោសិតារាម ជិតក្រុងកោសម្ពី។ សម័យនោះឯង ឆន្នភិក្ខុដ៏មានអាយុ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិចេញ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ មិនសមបើ នឹងត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិចេញសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ក្នុងវេលានោះ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆន្នភិក្ខុត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិចេញ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា អំពើនេះ មិនសមគួរ។បេ។ មិនគប្បីធ្វើទេ ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះ ត្រូវអាបត្តិហើយ មិនសមបើ នឹងមិនប្រាថ្នាសំដែងអាបត្តិចេញទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ នឹងបានដឹកនាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងក៏ទេ។បេ។ លុះទ្រង់បន្ទោសហើយ។បេ។ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ។

[២២៦] ម្នាលភិក្ខុទាំងឡាយ ឯឧក្ខេបនីយកម្មនោះ សង្ឃត្រូវធ្វើយ៉ាងនេះ។ សង្ឃត្រូវចោទឆន្នភិក្ខុជាមុន លុះចោទហើយ ត្រូវរំលឹក លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិចេញ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិចេញ។ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ។ ការធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ ត្រូវអាបត្តិហើយ មិនប្រាថ្នានឹងសំដែងអាបត្តិចេញ។ សង្ឃធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ។ ការធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុហើយ ការធ្វើឧក្ខេបនីយកម្មនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អ្នកទាំងឡាយ ចូរប្រាប់គ្នា ក្នុងអាវាសតៗទៅថា ឆន្នភិក្ខុ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញហើយ។

### (អធម្មកម្ម មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ)

### (អធម្មកម្មទ្វាទសកំ)

[២២៧] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មមិនប្រកបដោយធម៌ផង ជាកម្ម មិនប្រកប ដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ គឺកម្ម ដែលធ្វើក្នុងទីកំបាំងមុខ១ កម្មដែលធ្វើ ដោយការមិនបានសាកសួរ១ កម្មដែលមិនធ្វើតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

[២២៨] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយគ្មានអាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិមិនមែនជាទេសនាគាមិនី១ កម្មដែលធ្វើ ដោយអាបត្តិ ដែលភិក្ខុសំដែងហើយ១។បេ។

[២២៩] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនបានចោទ ហើយស្រាប់តែធ្វើ១ កម្មដែលមិនបានរំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលមិនបានលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១។បេ។

[២៣០] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៣១] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយមិនបានសាកសួរ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៣២] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយមិនតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៣៣] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយគ្មានអាបត្តិ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយ អង្គ៣នេះឯង។បេ។

[២៣៤] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយអាបត្តិមិនមែនជា ទេសនាគាមិនី១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១។បេ។

[២៣៥] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ដែលសំដែងហើយ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១។បេ។

[២៣៦] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនបានចោទ ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៣៧] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនបានរំលឹក ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៣៨] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនបានលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ កម្មដែលធ្វើមិនត្រូវតាមធម៌១ កម្មដែលធ្វើជាពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ជាកម្មមិនប្រកបដោយធម៌ផង ជាកម្មមិនប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

ចប់ អធម្មកម្ម មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ។

## (ធម្មកម្ម មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ)



### (ធម្មកម្មទ្វាទសកំ)

[២៣៩] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ១ កម្មដែលធ្វើ ដោយការសាកសួរ១ កម្មដែលធ្វើ តាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលសង្ឃរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៤០] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយអាបត្តិ១ កម្មដែលធ្វើ ដោយអាបត្តិ ជាទេសនាគាមិនី១ កម្មដែលធ្វើ

ដោយអាបត្តិ ដែលមិនបានសំដែង១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៤១] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលបានចោទហើយ ទើបធ្វើ១ កម្មដែលបានរំលឹកហើយ ទើបធ្វើ១ កម្មដែលបានលើកអាបត្តិឡើងហើយ ទើបធ្វើ១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៤២] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។បេ។

[២៤៣] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយការសាកសួរ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[២៤៤] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើតាមពាក្យប្តេជ្ញា១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៤៥] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៤៦] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ជាទេសនាគាមិនី១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[២៤៧] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ដែលមិនបានសំដែងចេញ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១។បេ។

[២៤៨] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលចោទហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៤៩] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលរំលឹកហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៥០] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលលើកអាបត្តិឡើងហើយ ទើបធ្វើ១ កម្មដែលធ្វើត្រូវតាមធម៌១ កម្មដែលធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

ចប់ ធម្មកម្ម មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ។

## (វត្ថុមានចំនួន៦ ដែលសង្ឃប្រាថ្នា ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ)

CS vin.cv.01.06.03 | ភាគ ទី៩

### (អាកង្ខមានឆក្កំ)

[២៥១] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺភិក្ខុបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណក្នុងសង្ឃ១ ល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ១ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[២៥២] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីល១ ភិក្ខុមានអាចារវិបត្តិ ក្នុងអជ្ឈាចារ១ ភិក្ខុមានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[២៥៣] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[២៥៤] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុ៣ពួក គឺភិក្ខុអ្នកបង្កហេតុ បង្កជម្លោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណក្នុងសង្ឃពួក១ ល្ងង់ មិនឆ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិពួក១ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុ៣ពួកនេះឯង។

[២៥៥] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុវិបត្តិចាកសីល ក្នុងអធិសីលពួក១ វិបត្តិចាកអាចារ ក្នុងអជ្ឈាចារពួក១ វិបត្តិចាកទិដ្ឋិ ក្នុងអតិទិដ្ឋិពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុ៣ពួកនេះឯង។

[២៥៦] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធពួក១ ពោលតិះដៀលព្រះធម៌ពួក១ ពោលតិះដៀលព្រះសង្ឃពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុ៣ពួកនេះឯង។

ចប់ វត្តមានចំនួន៦ ដែលសង្ឃប្រាថ្នា (នឹងធ្វើ ក៏ធ្វើបាន) ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។

## (វត្ត៤៣ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ)

CS vin.cv.01.06.04 | ភាគ ទី៩

### (តេចត្តាលីសវត្តំ)

[២៥៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃ បានធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនសំដែងអាបត្តិចេញ ត្រូវប្រព្រឹត្តវត្ត ដោយប្រពៃ។ ការប្រព្រឹត្តវត្តដោយប្រពៃ ក្នុងឧក្ខេបនីយកម្មនោះ ដូច្នេះ គឺភិក្ខុនោះ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី ទុកជាសង្ឃបានសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនីដែរ ភិក្ខុនោះ ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ចំពោះអាបត្តិណា កុំឲ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិឯទៀត ប្រហែលនឹងអាបត្តិនោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុដែលធ្វើកម្ម មិនត្រូវត្រេកអរនឹងការសំពះ ការក្រោកទទួល ការធ្វើអញ្ជលីកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកលាងជើង តាំងទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រនិងចីវរ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្ត មិនត្រូវចោទភិក្ខុ ជាបកតត្ត ដោយសីលវិបត្តិ មិនត្រូវចោទ ដោយអាចារវិបត្តិ មិនត្រូវចោទ ដោយទិដ្ឋិវិបត្តិ មិនត្រូវចោទ ដោយអាជីវវិបត្តិ មិនត្រូវបំបែកពួកភិក្ខុ (ឲ្យបែក) ចាកភិក្ខុផងគ្នា មិនត្រូវទ្រទ្រង់ទង់ជ័យ របស់គ្រហស្ថ មិនត្រូវទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ មិនត្រូវសេពគប់នឹងតិរ្ថិយ ត្រូវតែគប់រកពួកភិក្ខុ ត្រូវតែសិក្សាសិក្ខា របស់ភិក្ខុ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងទីមិនមែនជាអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬទីមិនមែនជាអាវាស ដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត បើឃើញភិក្ខុជាបកតត្តមកហើយ ត្រូវតែក្រោកឡើងចាកអាសនៈ មិនត្រូវរុករានភិក្ខុ ជាបកតត្ត ខាងក្នុង ឬខាងក្រៅ (វិហារ) មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា ដល់ភិក្ខុ ជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ) មិនត្រូវទទួលនាទី ជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទគេ មិនត្រូវរំលឹកគេ មិនត្រូវញុះញង់ពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា។

ចប់ វត្ត៤៣ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។

[២៥៨] គ្រានោះ សង្ឃបានធ្វើឧក្ខេបនីយកម្ម គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ។ ឆន្នភិក្ខុនោះ លុះត្រូវសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏ចេញអំពីអាវាសនោះ ទៅកាន់អាវាសឯទៀត។ ពួកភិក្ខុ ក្នុងអាវាសនោះ ក៏មិនថ្វាយបង្គំ មិនក្រោកទទួល មិនធ្វើអញ្ជលីកម្ម មិនធ្វើសាមីចិកម្ម មិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជាឡើយ។ ឆន្នភិក្ខុនោះ កាលដែលពួកភិក្ខុ មិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជា គ្មាននរណាធ្វើសក្ការហើយ ក៏ចេញអំពីអាវាសនោះ ទៅកាន់អាវាសដទៃ។ ពួកភិក្ខុក្នុងអាវាសនោះ ក៏មិនថ្វាយបង្គំ មិនក្រោកទទួល មិនធ្វើអញ្ជលិកម្ម មិនធ្វើសាមីចិកម្ម មិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជាទៀតដែរ។ ឆន្នភិក្ខុនោះ កាលបើពួកភិក្ខុមិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជា គ្មាននរណាធ្វើសក្ការហើយ ក៏ចេញអំពីអាវាសនោះ ទៅកាន់អាវាសដទៃទៀត។ ពួកភិក្ខុក្នុងអាវាសនោះ ក៏មិនថ្វាយបង្គំ មិនក្រោកទទួល មិនធ្វើអញ្ជលិកម្ម មិនធ្វើសាមីចិកម្ម មិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជាដែរ។ ឆន្នភិក្ខុនោះ កាលដែលពួកភិក្ខុ មិនធ្វើសក្ការ មិនគោរព មិនរាប់អាន មិនបូជា គ្មាននរណាធ្វើសក្ការហើយ ក៏ត្រឡប់មកក្រុងកោសម្ពីវិញ។ ឆន្នភិក្ខុ ក៏ប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម ហើយចូលទៅរកភិក្ខុទាំងឡាយ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ ក៏បានប្រព្រឹត្តវត្តដោយប្រពៃ និងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម តើខ្ញុំគប្បីប្រតិបត្តិ ដូចម្ដេចទៀត។ ពួកភិក្ខុនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូររម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុចុះ។

## (វត្ត៤៣ ដែលសង្ឃមិនត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ)

CS vin.cv.01.06.05 | ភាគ ទី៩

### (នប្បដិប្បស្សម្ភេតព្ពតេចត្តាលីសកំ)

[២៥៩] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនគប្បីរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុឲ្យឧបសម្បទា១ ឲ្យនិស្ស័យ១ ឲ្យសាមណេរបម្រើខ្លួន១ ទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ ទុកជាសង្ឃសន្មតហើយ នៅតែប្រដៅពួកភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២៦០] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ចំពោះអាបត្តិណា ហើយនៅតែត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ១ តិះដៀលកម្ម១ តិះដៀលពួកភិក្ខុដែលធ្វើកម្ម១។បេ។

[២៦១] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុត្រេកអរនឹងការសំពះ១ ការក្រោកទទួល១ អញ្ជលិកម្ម១ សាមីចិកម្ម១ ការនាំអាសនមកឲ្យ១ របស់ភិក្ខុជាបកតត្ត។បេ។

[២៦២] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុត្រេកអរនឹងការនាំទីដេកមកឲ្យ១ ទឹកសម្រាប់លាងជើង១ តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង១ ការទទួលបាត្រ និងចីវរ១ ការដុសខ្នង ក្នុងវេលាងូតទឹក១ របស់ភិក្ខុជាបកតត្ត។បេ។

[២៦៣] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុចោទភិក្ខុជាបកតត្ត ដោយសីលវិបត្តិ១ ចោទដោយអាចារវិបត្តិ១ ចោទដោយទិដ្ឋិវិបត្តិ១ ចោទដោយអាជីវវិបត្តិ១ បំបែកពួកភិក្ខុ (ឲ្យបែកចាក)ពួកភិក្ខុផងគ្នា១។បេ។

[២៦៤] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ១ ទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ១ សេពគប់នឹងពួកតិរ្ថិយ១ មិនសេពគប់ពួកភិក្ខុ១ មិនសិក្សាសិក្ខារបស់ភិក្ខុ១។បេ។

[២៦៥] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុនៅក្នុងអាវាស ដែលមានដំបូលមួយ១ នៅក្នុងទីមិនមែនអាវាស ដែលមានដំបូលមួយ១ នៅក្នុងអាវាស ឬទីមិនមែនអាវាស ដែលមានដំបូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត១ ឃើញភិក្ខុជាបកតត្តហើយ មិនក្រោកចាកអាសន១ រុករានភិក្ខុជាបកតត្តខាងក្នុង ឬខាងក្រៅ (វិហារ)១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះទេ។

[២៦៦] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុឃាត់ឧបោសថ ដល់ភិក្ខុជាបកតត្ត១ ឃាត់បវារណា១ ជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ)១ ទទួលនាទីជាធំក្នុងវត្ត១ ឲ្យធ្វើឱកាស (ដើម្បីចោទ)១ ចោទគេ១ រំលឹកគេ១ ប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៨នេះទេ។

ចប់ វត្ត៤៣ ដែលសង្ឃមិនត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។

## (វត្ត៤៣ ដែលសង្ឃត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ)

CS vin.cv.01.06.06 | ភាគ ទី៩

### (បដិប្បស្សម្ភេតព្វតេចត្តាលីសកំ)

[២៦៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុមិនឲ្យឧបសម្បទា១ មិនឲ្យនិស្ស័យ១ មិនឲ្យសាមណេរបម្រើខ្លួន១ មិនទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ បើទុកជាសង្ឃសន្មតហើយ ក៏មិនប្រដៅភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២៦៨] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ចំពោះអាបត្តិណា មិនត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ដែលប្រហែលនឹងអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ១ មិនតិះដៀលកម្ម១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១។បេ។

[២៦៩] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុមិនត្រេកអរនឹងអភិវាទនកម្ម១ បច្ចុដ្ឋានកម្ម១ អញ្ជលិកម្ម១ សាមីចិកម្ម១ ការនាំអាសនមកឲ្យ១ របស់ភិក្ខុជាបកតត្ត។បេ។

[២៧០] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុមិនត្រេកអរនឹងការនាំទីដេកមកឲ្យ១ ទឹកសម្រាប់លាងជើង១ តាំងទ្រជើង និងវត្ថុសម្រាប់ជូតជើង១ ការទទួលបាត្រ និងចីវរ១ ការដុសខ្នង ក្នុងវេលាស្រង់ទឹក១ របស់ភិក្ខុជាបកតត្ត។បេ។

[២៧១] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុមិនចោទភិក្ខុជាបកតត្ត ដោយសីលវិបត្តិ១ មិនចោទដោយអាចារវិបត្តិ១ មិនចោទដោយទិដ្ឋិវិបត្តិ១ មិនចោទដោយអាជីវវិបត្តិ១ មិនបំបែកពួកភិក្ខុ (ឲ្យបែក)ចាកពួកភិក្ខុផងគ្នា១។បេ។

[២៧២] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុមិនទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ១ មិនទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ១ មិនសេពគប់ពួកតិរ្ថិយ១ សេពគប់តែពួកភិក្ខុ១ សិក្សាសិក្ខារបស់ភិក្ខុ១។បេ។

[២៧៣] អង្គ៥ដទៃទៀត។បេ។ គឺភិក្ខុមិននៅក្នុងអាវាសដែលមានដម្បូលមួយ១ មិននៅក្នុងទីមិនមែនជាអាវាស ដែលមានដម្បូលមួយ១ មិននៅក្នុងទីជាអាវាស ឬមិនមែនជាអាវាស ដែលមានដម្បូលមួយ១ ជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្តហើយ ក្រោកចាកអាសន១ មិនរុករានភិក្ខុជាបកតត្ត ខាងក្នុង ឬខាងក្រៅ (វិហារ)១។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[២៧៤] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុមិនឃាត់ឧបោសថ ដល់ភិក្ខុជាបកតត្ត១ មិនឃាត់បវារណា ដល់ភិក្ខុជាបកតត្ត១ មិនធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ)១ មិនទទួលនាទីជាធំក្នុងវត្ត១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនចោទ១ មិនរំលឹក១ មិនប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ដល់ភិក្ខុដែលប្រកបដោយអង្គ៨នេះឯង។

ចប់ វត្ត៤៣ ដែលសង្ឃត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ។

[២៧៥] ម្នាលភិក្ខុទាំងឡាយ ឯឧក្ខេបនីយកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ឆន្នភិក្ខុនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទា ភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។ ឆន្នភិក្ខុ គប្បីសូម ជាគំរប់ពីរដងផង។ គប្បីសូម ជាគំរប់បីដងផង។ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយា រលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។ បើកម្ម មានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ សង្ឃបានធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឆន្នភិក្ខុនេះ សង្ឃបានធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ។ ការរម្ងាប់ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ដល់ឆន្នភិក្ខុ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីនិយាយឡើង។ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ សង្ឃបានរម្ងាប់ដល់ឆន្នភិក្ខុហើយ ការរម្ងាប់ ឧក្ខេបនីយកម្មនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ ជាគំរប់៦។

# (ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ជាគំរប់៧)

CS vin.cv.01.07 | ភាគ ទី៩

### (៧. បាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខេបនីយកម្មំ)

[២៧៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ភិក្ខុឈ្មោះអរិដ្ឋ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះ កើតឡើងថា យើងដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា តែងធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គល អ្នកសេពទេ។ ភិក្ខុទាំងឡាយ ជាច្រើនរូប បានឮដំណឹងថា ភិក្ខុឈ្មោះអរិដ្ឋ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះ កើតឡើងដូច្នេះថា យើងដឹងច្បាស់ នូវធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា តែងធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គល អ្នកសេពទេ។ គ្រានោះ ភិក្ខុទាំងនោះ ចូលទៅរកអរិដ្ឋភិក្ខុ ដែលជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងអរិដ្ឋភិក្ខុ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាតថា ម្នាលអាវុសោអរិដ្ឋ ឮថា អ្នកឯង មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះ កើតឡើងដូច្នេះថា យើងដឹងច្បាស់ នូវធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា តែងធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គល អ្នកសេពទេ ពិតមែនឬ។ អរិដ្ឋភិក្ខុឆ្លើយថា ម្នាលអាវុសោ យើងដឹងច្បាស់ នូវធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ដូច្នោះមែន។ ភិក្ខុទាំងឡាយនោះ និយាយថា ម្នាលអាវុសោអរិដ្ឋ លោកកុំពោលយ៉ាងនេះ លោកកុំពោបង្កាច់ ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ ព្រោះថា ព្រះដ៏មានព្រះភាគ មិនមែនទ្រង់ត្រាស់ដូច្នេះទេ ម្នាលអាវុសោ អរិដ្ឋ ធម៌ទាំងឡាយ ដែលធ្វើសេចក្តីអន្តរាយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអនេកបរិយាយ ឯធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពមែន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានសេចក្តីរីករាយតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានច្រើន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយ

រាងឆ្អឹង មានសេចក្តីទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយដុំសាច់។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយគប់ភ្លើងស្មៅ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយរណ្តៅរងើកភ្លើង។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយយល់សប្តិ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយរបស់ខ្ចីគេ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយផ្លែឈើ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយកាំបិត និងជ្រញ់។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយលំពែង និងដែកស្រួច។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា កាមទាំងឡាយ មានឧបមា ដោយក្បាលពស់។បេ។ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានច្រើន។ អរិដ្ឋភិក្ខុ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត កាលដែលពួកភិក្ខុទាំងនោះ និយាយដាស់តឿន យ៉ាងនេះហើយ ក៏នៅតែប្រកាន់ទិដ្ឋិលាមកនោះ ដោយមាំ ហើយនិយាយយ៉ាងនេះដដែលថា ម្នាលអាវុសោ យើងដឹងច្បាស់ នូវធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពបានទេ ដូច្នោះមែន។ ពួកភិក្ខុនោះ មិនអាចនឹងដោះ អរិដ្ឋភិក្ខុ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត ឲ្យរួចចាកទិដ្ឋិដ៏លាមកនោះបាន។ លំដាប់នោះ ពួកភិក្ខុទាំងនោះ ចូលទៅក្រាបបង្គំគាល់ ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូល សេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[២៧៧] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ អរិដ្ឋភិក្ខុ ជាកូននៃត្រកូល អ្នកសម្លាប់ត្មាត ក្នុងកាលនោះថា ម្នាលអរិដ្ឋ ឮថា ទិដ្ឋិលាមក មានសភាពដូច្នេះ កើតឡើងដល់អ្នកឯងថា យើងដឹងច្បាស់ នូវធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពបានទេ ពិតមែនឬ។ អរិដ្ឋភិក្ខុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំដឹងច្បាស់ នូវធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពបានទេ ដូច្នោះមែន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលមោឃបុរស អ្នកឯងដឹងច្បាស់នូវធម៌ ដែលតថាគតសំដែងហើយយ៉ាងនេះ អំពីអ្នកណា ម្នាលមោឃបុរស ធម៌ទាំងឡាយ ដែលធ្វើសេចក្តីអន្តរាយ តថាគត សំដែងហើយ ដោយអនេកបរិយាយ មិនមែនទេឬ ឯធម៌ទាំងនោះ អាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេព ពិតមែន តថាគតសំដែងថា កាមទាំងឡាយ មានសេចក្តីរីករាយតិច មានសេចក្តីទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានច្រើន តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយរាងឆ្អឹង។បេ។ មានសេចក្តីទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានច្រើន តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយដុំសាច់។បេ។ តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយគប់ភ្លើងស្មៅ។បេ។ តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយរណ្តៅរងើកភ្លើង។បេ។ តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយយល់សប្តិ។បេ។ តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយរបស់ខ្ចីគេ។បេ។ តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយផ្លែឈើ។បេ។ តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយកាំបិត និងជ្រញ់។បេ។ តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយលំពែង និងដែកស្រួច។បេ។ តថាគតសំដែងថា កាមទាំងឡាយ មានឧបមា ដោយក្បាលពស់។បេ។ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើន ម្នាលមោឃបុរស បើដូច្នោះ អ្នកឯងឈ្មោះថា ពោលបង្កាច់តថាគតផង គាស់រំលើងខ្លួនឯងផង សោយបាបជាច្រើនផង ដោយទិដ្ឋិ ដែលខ្លួនប្រកាន់ខុស ម្នាលមោឃបុរស ទិដ្ឋិ ដែលអ្នកប្រកាន់ខុសនោះ នឹងប្រព្រឹត្តទៅ ដើម្បីទុក្ខ មិនមែនជាប្រយោជន៍ ដល់អ្នកឯង អស់កាលដ៏វែង ម្នាលមោឃបុរស អំពើនោះ មិនមែននាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លា ឬនាំពួកជន ដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹតរឹងតែជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់តិះដៀលហើយ។បេ។ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុ ជាកូននៃត្រកូល អ្នកសម្លាប់ត្មាត។

[២៧៨] ម្នាលភិក្ខុទាំងឡាយ ឯឧក្ខេបនីយកម្មនោះ សង្ឃត្រូវធ្វើយ៉ាងនេះ សង្ឃត្រូវចោទអរិដ្ឋភិក្ខុ ដែលជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត ជាមុនសិន លុះចោទហើយ ត្រូវរំលឹក លុះរំលឹកហើយ ត្រូវលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឆ្លាស ប្រតិពល ត្រូវញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ទិដ្ឋិដ៏លាមក មានសភាពយ៉ាងនេះ កើតឡើងដល់អរិដ្ឋភិក្ខុ ជាកូននៃត្រកូល អ្នកសម្លាប់ត្មាត ដូច្នេះថា យើងដឹងច្បាស់ នូវធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គល អ្នកសេពទេ។ អរិដ្ឋភិក្ខុនោះ មិនលះបង់ទិដ្ឋិនោះសោះ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុ ដែលជាកូន នៃត្រកូលអ្នកសម្លាប់ត្មាត។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះ កើតឡើងដល់អរិដ្ឋភិក្ខុ ដែលជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត ដូច្នេះថា យើងដឹងច្បាស់ នូវធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ។ អរិដ្ឋភិក្ខុនោះ ក៏មិនលះបង់ទិដ្ឋិនោះសោះ។ សង្ឃធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុ ជាកូននៃត្រកូល ជាអ្នកសម្លាប់ត្មាត។ ការធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ទិដ្ឋិដ៏លាមក មានសភាពយ៉ាងនេះ កើតឡើងដល់អរិដ្ឋភិក្ខុ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត ដូច្នេះថា យើងដឹងច្បាស់ នូវធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា ធម៌ទាំងឡាយឯណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ធ្វើសេចក្តីអន្តរាយ បានយ៉ាងណា ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គល អ្នកសេពទេ។ អរិដ្ឋភិក្ខុនោះ មិនលះបង់ទិដ្ឋិនោះចេញទេ។ សង្ឃធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុ ជាកូននៃត្រកូល ជាអ្នកសម្លាប់ត្មាត។ ការធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិលាមក គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ៗបានធ្វើ ដល់អរិដ្ឋ

ភិក្ខុ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាតហើយ ការធ្វើ ឧក្ខេបនីយកម្មនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អ្នកទាំងឡាយ ចូរប្រាប់គ្នា ក្នុងអាវាសតៗទៅថា អរិដ្ឋភិក្ខុ ជាកូន នៃត្រកូល អ្នកសម្លាប់ត្មាត សង្ឃបានធ្វើ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិដ៏លាមក គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃហើយ។

## (អធម្មកម្ម ១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់)

CS vin.cv.01.07.01 | ភាគ ទី៩

### (អធម្មកម្មទ្វាទសកំ)

[២៧៩] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មដែលរម្ងាប់ ដោយអាក្រក់ផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើ ក្នុងទីកំបាំងមុខ១ ធ្វើដោយមិនបានសាកសួរ១ ធ្វើដោយមិនតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្ម មិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្ម ដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយ អង្គ៣នេះឯង។

[២៨០] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយគ្មានអាបត្តិ១ ធ្វើដោយអាបត្តិមិនមែនជាទេសនាគាមិនី១ ធ្វើដោយអាបត្តិ ដែលសំដែងហើយ១។បេ។

[២៨១] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនចោទ ហើយស្រាប់តែធ្វើ១ មិនរំលឹក ហើយស្រាប់តែធ្វើ១ មិនលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១។បេ។

[២៨២] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើក្នុងទីកំបាំងមុខ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៨៣] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយមិនបានសាកសួរ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយ អង្គ៣នេះឯង។បេ។

[២៨៤] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយមិនតាមពាក្យប្តេជ្ញា១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៨៥] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយគ្មានអាបត្តិ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៨៦] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើ ដោយអាបត្តិមិនមែនជា ទេសនាគាមិនី១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១។បេ។

[២៨៧] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ដែលសំដែងរួចហើយ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៨៨] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនចោទ ហើយស្រាប់តែធ្វើ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៨៩] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនរំលឹក ហើយស្រាប់តែធ្វើ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៩០] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលមិនលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មដែលរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣នេះឯង។

ចប់ អធម្មកម្ម ១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់។

## (កម្មប្រកបដោយធម៌ មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់)

CS vin.cv.01.07.02 | ភាគ ទី៩

### (ធម្មកម្មទ្វាទសកំ)

[២៩១] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្មដែលធ្វើ ក្នុងទីចំពោះមុខ១ សួរហើយទើបធ្វើ១ ធ្វើតាមពាក្យប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

[២៩២] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មប្រកបដោយធម៌ផង ប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលធ្វើដោយមានអាបត្តិ១ ធ្វើដោយអាបត្តិ ជាទេសនាគាមិនី១ ធ្វើដោយអាបត្តិ ដែលមិនទាន់សំដែង១។បេ។

[២៩៣] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលចោទហើយ ទើបធ្វើ១ រំលឹកហើយ ទើបធ្វើ១ លើកអាបត្តិឡើងហើយ ទើបធ្វើ១។បេ។

[២៩៤] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើក្នុងទីចំពោះមុខ១ ធ្វើដោយធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៩៥] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលបញ្ជាក់ហើយ ទើបធ្វើ១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៩៦] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើតាមពាក្យប្តេជ្ញា១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៩៧] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយមានអាបត្តិ១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[២៩៨] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ជាទេសនាគាមិនី១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១។បេ។

[២៩៩] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលធ្វើដោយអាបត្តិ ដែលមិនទាន់សំដែង១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១។បេ។

[៣០០] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលចោទហើយ ទើបធ្វើ១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[៣០១] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលរំលឹកហើយ ទើបធ្វើ១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ប្រកបដោយអង្គ៣នេះឯង។បេ។

[៣០២] អង្គ៣ដទៃទៀត។បេ។ គឺកម្មដែលលើកអាបត្តិឡើងហើយ ទើបធ្វើ១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀង១ ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មដែលរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣នេះឯង។

ចប់ កម្មប្រកបដោយធម៌ មានចំនួន១២ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់។

## (កម្មមានចំនួន៦លើក ដែលសង្ឃប្រាថ្នា ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ)

CS vin.cv.01.07.03 | ភាគ ទី៩

### (អាកង្ខមានឆក្កំ)

[៣០៣] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺភិក្ខុអ្នកធ្វើការបង្កហេតុ អ្នកធ្វើការបង្កជម្លោះ អ្នកធ្វើការទាស់ទែង អ្នកធ្វើតិរច្ឆានកថា អ្នកធ្វើអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឆ្លាស ច្រើនទៅដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[៣០៤] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុវិបត្តិចាកសីល ក្នុងអធិសីល១ វិបត្តិចាកអាចារ ក្នុងអជ្ឈាចារ១ វិបត្តិចាកទិដ្ឋិ ក្នុងអតិទិដ្ឋិ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[៣០៥] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣នេះឯង។

[៣០៦] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុ៣ពួក គឺភិក្ខុជាអ្នកធ្វើការបង្កហេតុ ជាអ្នកធ្វើការជម្លោះ ជាអ្នកធ្វើសេចក្តីទាស់ទែង ជាអ្នកធ្វើតិរច្ឆានកថា ជាអ្នកធ្វើអធិករណ៍ក្នុងសង្ឃពួក១ ល្ងង់ មិនឆ្លាស ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិពួក១ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុ៣ពួកនេះឯង។

[៣០៧] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុវិបត្តិចាកសីល ក្នុងអធិសីលពួក១ វិបត្តិចាកអាចារ ក្នុងអជ្ឈាចារពួក១ វិបត្តិចាកទិដ្ឋិ ក្នុងអតិទិដ្ឋិពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុទាំង៣ពួកនេះឯង។

[៣០៨] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុ៣ពួកដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធពួក១ ពោលតិះដៀលព្រះធម៌ពួក១ ពោលតិះដៀលព្រះសង្ឃពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុទាំង៣ពួកនេះឯង។

ចប់ កម្មមានចំនួន៦លើក ដែលសង្ឃប្រាថ្នា (នឹងធ្វើ ក៏ធ្វើបាន) ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ។

## (វត្ត១៨ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់)

CS vin.cv.01.07.04 | ភាគ ទី៩

### (តេចត្តាលីសវត្តំ)

[៣០៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃ បានធ្វើឧក្ខេបនីយកម្មហើយ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញហើយ ត្រូវប្រព្រឹត្តវត្ត ដោយប្រពៃ។ ការប្រព្រឹត្តវត្តដោយប្រពៃ ក្នុងឧក្ខេបនីយកម្មនោះ ដូច្នេះ គឺមិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវឲ្យទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី ទុកជាសង្ឃសន្មតរួចហើយ ក៏មិនត្រូវប្រដៅភិក្ខុនី សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ចំពោះអាបត្តិណា កុំឲ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃ ដែលប្រហែលនឹងអាបត្តិនោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុដែលធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ ក្នុងអធិករណនោះ មិនត្រូវទទួលនាទី ជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា។

ចប់ វត្ត១៨ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់។

[៣១០] គ្រានោះ សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ គឺមិនឲ្យបរិភោគរួម ជាមួយនឹងសង្ឃ ដល់អរិដ្ឋភិក្ខុ ដែលជាកូននៃត្រកូលអ្នកសម្លាប់ត្មាត។ អរិដ្ឋភិក្ខុនោះ លុះសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ហើយ ក៏សឹកចេញទៅ។ ពួកភិក្ខុទាំងឡាយឯណា ដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា អរិដ្ឋភិក្ខុ ជាកូននៃត្រកូលអ្នកសម្លាប់ត្មាត សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ មិនគួរនឹងសឹកសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[៣១១] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ពួកភិក្ខុ ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ឮថា អរិដ្ឋភិក្ខុ ជាកូននៃត្រកូលអ្នកសម្លាប់ត្មាត សង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ហើយក៏សឹកចេញទៅ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសនោះ ដែលសង្ឃបានធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ មិនសមគួរនឹងសឹកទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិដ៏អាក្រក់។

## (អង្គមានចំនួន១៨ ដែលសង្ឃមិនត្រូវរម្ងាប់ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ)

CS vin.cv.01.07.05 | ភាគ ទី៩

### (នប្បដិប្បស្សម្ភេតព្ពតេចត្តាលីសកំ)

[៣១២] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនគប្បីរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុឲ្យឧបសម្បទា១ ឲ្យនិស្ស័យ១ ឲ្យសាមណេរបម្រើខ្លួន១ ទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ បើទុកជាសង្ឃសន្មតរួចហើយ ក៏នៅតែប្រដៅពួកភិក្ខុនី១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គទាំង៥នេះទេ។

[៣១៣] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ចំពោះអាបត្តិណា នៅតែត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ដែលប្រហែលគ្នា នឹងអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងនោះ១ តិះដៀលកម្ម១ តិះដៀលពួកភិក្ខុដែលធ្វើកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គទាំង៥នេះទេ។

[៣១៤] ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុដែលហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ ហាមបវារណា១ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ)១ ទទួលនាទីជាធំក្នុងវត្ត១ ឲ្យធ្វើឱកាស (ដើម្បីចោទ)១ ចោទ១ រំលឹក១ ប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃមិនត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៨នេះទេ។

ចប់ អង្គមានចំនួន១៨ ដែលសង្ឃមិនត្រូវរម្ងាប់ ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ។

## (អង្គមានចំនួន១៨ ដែលសង្ឃត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ)

CS vin.cv.01.07.06 | ភាគ ទី៩

### (បដិប្បស្សម្ភេតព្វតេចត្តាលីសកំ)

[៣១៥] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ គឺភិក្ខុមិនឲ្យឧបសម្បទា១ មិនឲ្យនិស្ស័យ១ មិនឲ្យសាមណេរបម្រើខ្លួន១ មិនទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ ទុកជាសង្ឃសន្មតហើយ ក៏មិនប្រដៅភិក្ខុនីទាំងឡាយ១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[៣១៦] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត គឺភិក្ខុដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ចំពោះអាបត្តិណា ហើយមិនត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលគ្នា នឹងអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ១ មិនតិះដៀលកម្ម១ មិនតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង។

[៣១៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៨ គឺភិក្ខុមិនហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ មិនហាមបវារណា១ មិនធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ)១ មិនទទួលនាទីជាធំក្នុងវត្ត១ មិនឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនចោទ១ មិនរំលឹក១ មិនប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ ដល់ភិក្ខុដែលប្រកបដោយអង្គ៨នេះឯង។

ចប់ អង្គមានចំនួន១៨ ដែលសង្ឃត្រូវរម្ងាប់ក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ។

[៣១៨] ម្នាលភិក្ខុទាំងឡាយ ឧក្ខេបនីយកម្មនោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង សំពះបាទា របស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់រួចហើយ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ។ គប្បីសូមជាគំរប់ពីរដងផង។ គប្បីសូមជាគំរប់បីដងផង។ ភិក្ខុអ្នកឆ្លាស ប្រតិពល គប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ ដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ។ បើកម្ម មានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ ដែលសង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញហើយ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុឈ្មោះនេះ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈជាគំរប់ពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ សង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ហើយបានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម មកសូមការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ។ សង្ឃរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុឈ្មោះនេះ។ ការរម្ងាប់ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ សង្ឃបានរម្ងាប់ដល់ភិក្ខុឈ្មោះនេះហើយ ការរម្ងាប់ឧក្ខេបនីយកម្មនោះ គួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ ឧក្ខេបនីយកម្ម ព្រោះមិនលះទិដ្ឋិអាក្រក់ចេញ ជាគំរប់៧។

ចប់កម្មក្ខន្ធក ជាបឋម។

ក្នុងខន្ធកនេះ មាន៧រឿង។

ឧទ្ទាននៃកម្មក្ខន្ធកនោះគឺ

[៣១៩]

រឿងបណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ ជាអ្នកធ្វើការបង្កហេតុដោយខ្លួនឯង ហើយចូលទៅរកពួកភិក្ខុជាអ្នកធ្វើការបង្កហេតុដូចគ្នាដែរ ហើយក៏នាំគ្នាប្រឹងប្រែងក្នុងការបង្កហេតុ ការបង្កហេតុទាំងឡាយ ដែលមិនទាន់កើត ក៏កើតឡើង ដែលកើតឡើងហើយ ក៏ចំរើនឡើង ពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ មានសេចក្តីប្រាថ្នាតិច ក៏ពោលទោស ក្នុងកណ្តាលបរិសទ្យ ព្រះពុទ្ធជិនស្រី ជា

ព្រះសយម្ភូ ជាអគ្គបុគ្គល ទ្រង់ប្រាថ្នាការស្ថិតស្ថេរ នៃព្រះសទ្ធម្ម ទើបទ្រង់បង្គាប់ឲ្យធ្វើតជ្ជនីយកម្ម ជិតក្រុងសាវត្ថី។ តជ្ជនីយកម្មឯណា ដែលសង្ឃធ្វើ ក្នុងទីកំបាំងមុខ ធ្វើដោយការមិនសាកសួរ ធ្វើដោយមិនតាមពាក្យប្ដេជ្ញា១ តជ្ជនីយកម្មឯណា ដែលសង្ឃធ្វើ ដោយគ្មានអាបត្តិ ដោយអាបត្តិមិនមែនជាទេសនាគាមិនី ដោយអាបត្តិដែលសំដែងរួចហើយ១ តជ្ជនីយកម្មឯណា ដែលសង្ឃមិនចោទ ហើយស្រាប់តែធ្វើ មិនរំលឹក ហើយស្រាប់តែធ្វើ មិនលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ តជ្ជនីយកម្មឯណា ដែលសង្ឃធ្វើក្នុងទីកំបាំងមុខ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក១ តជ្ជនីយកម្មឯណា ដែលសង្ឃធ្វើដោយមិនបានសាកសួរ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក១ តជ្ជនីយកម្មឯណា ដែលសង្ឃធ្វើដោយមិនតាមពាក្យប្ដេជ្ញា ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក១ តជ្ជនីយកម្មឯណា ដែលសង្ឃធ្វើដោយគ្មានអាបត្តិ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ធ្វើដោយអាបត្តិមិនមែនជាទេសនាគាមិនី ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក១ (តជ្ជនីយកម្មទាំងនោះ ចាត់ជាអធម្មកម្ម ជាអវិនយកម្ម) តជ្ជនីយកម្ម ដែលសង្ឃធ្វើ ដោយអាបត្តិដែលសំដែងហើយ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ក៏ចាត់ជាអធម្មកម្ម ជាអវិនយកម្មដូចគ្នាដែរ តជ្ជនីយកម្ម ដែលសង្ឃមិនបានចោទ ហើយស្រាប់តែធ្វើ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ក៏ដូចគ្នាដែរ កម្មដែលសង្ឃមិនបានរំលឹក ហើយស្រាប់តែធ្វើ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ក៏ដូចគ្នាដែរ កម្ម ដែលសង្ឃមិនបានលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ ធ្វើមិនត្រូវតាមធម៌ ធ្វើដោយពួក ក៏ដូចគ្នាដែរ បណ្ឌិតគប្បីដឹងសុក្កវារ (វារនៃកម្មស គឺចំណែកខាងកម្មត្រូវ) តាមទំនងនៃកណ្ហវារ (វារនៃកម្មខ្មៅ គឺចំណែកខាងកម្មខុស) នោះចុះ។ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលជាអ្នកបង្កហេតុ លូង់ នៅច្រឡូកច្រឡំ ដោយគ្រហស្ថ សង្ឃគប្បីធ្វើតជ្ជនីយកម្ម ដល់ភិក្ខុមានសីលវិបត្តិ ក្នុងអធិសីល មានអាចារវិបត្តិ ក្នុងអជ្ឈាចារ មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិ និងភិក្ខុ ដែលពោលតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សង្ឃគប្បីធ្វើតជ្ជនីយកម្ម ដល់ភិក្ខុ៣ពួកទៀត គឺភិក្ខុអ្នកធ្វើនូវការបង្កហេតុពួក១ លូង់ពួក១ នៅច្រឡូកច្រឡំដោយគ្រហស្ថពួក១។ ភិក្ខុមានសីលវិបត្តិ ក្នុងអធិសីលពួក១ មានអាចារវិបត្តិ ក្នុងអជ្ឈាចារពួក១ មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិពួក១ (សង្ឃគប្បីធ្វើតជ្ជនីយកម្ម) ដូចគ្នាដែរ នឹងភិក្ខុ ដែលពោលតិះដៀលព្រះពុទ្ធពួក១ ព្រះធម៌ពួក១ ព្រះសង្ឃពួក១។ ភិក្ខុដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ត្រូវប្រព្រឹត្តវត្ត ដោយប្រពៃយ៉ាងនេះ គឺភិក្ខុដែលសង្ឃធ្វើតជ្ជនីយកម្មហើយ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនីឡើយ មិនឲ្យត្រូវអាបត្តិនោះទៀត ឬអាបត្តិដែលប្រហែលនឹងអាបត្តិមុននោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ មិនត្រូវទទួលនាទីជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុឲ្យឈ្លោះគ្នា។ តជ្ជនីយកម្ម (មិន) រម្ងាប់ដោយអង្គទាំងឡាយ៥ គឺភិក្ខុឲ្យឧបសម្បទា ឲ្យនិស្ស័យ ឲ្យសាមណេរបម្រើខ្លួន ទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃសន្មតហើយ ក៏ទៅប្រដៅភិក្ខុនី។ តជ្ជនីយកម្ម មិនរម្ងាប់ (ដោយអង្គ៥ដទៃទៀត) គឺភិក្ខុនៅតែត្រូវអាបត្តិនោះ ឬអាបត្តិដែលប្រហែលនឹងអាបត្តិមុននោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ តិះដៀលកម្ម តិះដៀលពួកភិក្ខុអ្នកធ្វើកម្ម។ ភិក្ខុឯណា ប្រកបដោយអង្គ៨នេះ គឺហាមឧបោសថ ហាមបវារណា ធ្វើជាអ្នកមានមាត់ពាក្យ ទទួលនាទីជាធំក្នុងវត្ត ឲ្យធ្វើឱកាស (ដើម្បីចោទ) ចោទ រំលឹក ប្រកបដោយពួកភិក្ខុឲ្យឈ្លោះគ្នា តជ្ជនីយកម្ម របស់ភិក្ខុនោះ មិនរម្ងាប់ឡើយ។ បណ្ឌិតគប្បីដឹងសុក្កវារតាមទំនងនៃកណ្ហវារចុះ។ រឿងសេយ្យសកភិក្ខុ ជាភិក្ខុលូង់ មានអាបត្តិច្រើន នៅច្រឡូកច្រឡំ ដោយគ្រហស្ថ ទើបព្រះសម្ពុទ្ធមហាមុនិ ទ្រង់បង្គាប់ឲ្យធ្វើនិយស្សកម្ម។ រឿងភិក្ខុពីររូបឈ្មោះអស្សជិ និងបុនព្វសុក នៅក្នុងកិដាគិរិជនបទ ជាអ្នកមិនសង្រួម ប្រព្រឹត្តអនាចារផ្សេងៗ ទើបព្រះសម្ពុទ្ធជិនស្រី (ទ្រង់បង្គាប់ឲ្យធ្វើ) បព្វាជនីយកម្ម ជិតក្រុងសាវត្ថី។ រឿងសុធម្មភិក្ខុ នៅក្នុងអាវាសរបស់ចិត្តគហបតិ ក្នុងនគរមច្ឆិកាសណ្ឌ សុធម្មភិក្ខុនោះ ជេរចិត្តគហបតិ ជាឧបាសក ដោយពាក្យតិះដៀលដល់ជាតិ ទើបព្រះតថាគត ទ្រង់បង្គាប់ឲ្យធ្វើបដិសារណីយកម្ម។ រឿងឆន្នភិក្ខុក្នុងក្រុងកោសម្ពី (ត្រូវអាបត្តិហើយ) ក៏មិនប្រាថ្នានឹងឃើញអាបត្តិ។ ទើបព្រះជិនស្រីដ៏ឧត្តម ទ្រង់បង្គាប់ឲ្យធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ។ ឆន្នភិក្ខុ ក៏មិនប្រាថ្នានឹងសំដែងអាបត្តិនោះឡើយ ព្រះសម្ពុទ្ធ ជានាយកដ៏វិសេស ទ្រង់បង្គាប់ឲ្យធ្វើឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិចេញ។ រឿងអរិដ្ឋភិក្ខុ មានទិដ្ឋិដ៏លាមក ព្រោះអាស្រ័យសេចក្ដីមិនដឹង ព្រះជិនស្រីទ្រង់ត្រាស់ឲ្យធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ។ ទ្រង់បង្គាប់ឲ្យធ្វើនិយស្សកម្ម បព្វាជនីយកម្ម និងបដិសារណីយកម្ម ព្រោះហេតុដូចគ្នាដែរ។ (ឧក្ខេបនីយកម្ម) ព្រោះមិនឃើញអាបត្តិ១ មិនសំដែងអាបត្តិ១ មិនលះទិដ្ឋិអាក្រក់១ ល្បែង១ មារយាទមិនសមគួរ១ ការបៀតបៀន១ មិច្ឆាអាជីវ១ ទាំងនេះ ជាអតិរេកបទ ក្នុងបព្វាជនីយកម្ម។ អង្គ៥ គឺភិក្ខុព្យាយាមមិនឲ្យគ្រហស្ថបានលាភ និងពោលទោសព្រះរតនត្រ័យ (ជាដើម) មាន២លើក មានឈ្មោះថា ទ្វេបញ្ចក ទាំងនេះ ជាអតិរេកបទ ក្នុងបដិសារណីយកម្ម។ មួយវិញទៀត កម្មទាំងឡាយពីរ គឺតជ្ជនីយកម្ម១ និយស្សកម្ម១ មានលក្ខណដូចគ្នា។ មួយវិញទៀត កម្មទាំងឡាយពីរ គឺបព្វាជនីយកម្ម១ បដិសារណីយកម្ម១ មានអង្គ៨ខ្លះ ថយពី៨ខ្លះ មិនលើសពី៨ឡើយ ឧក្ខេបនីយកម្ម៣នោះ ប្រហែលៗគ្នា ដោយការចែកកម្មដ៏សេស អ្នកប្រាជ្ញ គប្បីដឹងតាមទំនង នៃតជ្ជនីយកម្ម (នោះចុះ)។

# បារិវាសិកក្ខន្ធកៈ (ទី២)

CS vin.cv.02 | ភាគ ទី៩

**(២. បារិវាសិកក្ខន្ធកំ)**

## (បារិវាសិកវត្ត ទី១)

CS vin.cv.02.01 | ភាគ ទី៩

## (១. បារិវាសិកវត្តំ)

[៣២០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ពួកភិក្ខុអ្នកនៅបរិវាស[22] តែងទទួលត្រេកអរ ចំពោះអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែល ក្នុងវេលាស្រង់ទឹក របស់ភិក្ខុជាបកតត្តទាំងឡាយ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុអ្នកនៅបរិវាស មិនសមបើនឹងត្រេកអរ ចំពោះអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែល ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយសោះ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[៣២១] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុអ្នកនៅបរិវាស ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែល ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកនៅបរិវាស មិនសមបើ នឹងត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែល ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយទេ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ។បេ។ លុះទ្រង់បន្ទោសរួចហើយ ទើបទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅបរិវាស មិនត្រូវត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែល ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទេ ភិក្ខុឯណាត្រេកអរ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាត ឲ្យភិក្ខុអ្នកនៅបរិវាស (ត្រេកអរ) នឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែល ក្នុងវេលាងូតទឹក នៃគ្នានឹងគ្នា គឺភិក្ខុដែលនៅបរិវាសដូចគ្នា តាមលំដាប់ភិក្ខុចាស់ (ខ្ចី)បាន។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឧបោសថ១ បវារណា១ ការទទួលវស្សិកសាដក១ ការលះបង់ភត្ត[23] ១ ការទទួលភត្ត[24] ១ ទាំង៥យ៉ាង ដល់ភិក្ខុអ្នកនៅបរិវាសទាំងឡាយ តាមលំដាប់ភិក្ខុចាស់ (ខ្ចី)។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគត នឹងបញ្ញត្តវត្ត ដល់ពួកភិក្ខុអ្នកនៅបរិវាស តាមទំនងដែលភិក្ខុអ្នកនៅបរិវាស ត្រូវប្រព្រឹត្ត។

[៣២២] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ (ភិក្ខុអ្នកនៅបរិវាស) ត្រូវប្រព្រឹត្តវត្ត ដោយប្រពៃ។ ការប្រព្រឹត្តវត្តដោយប្រពៃ ក្នុងការនៅបរិវាសនោះ ដូច្នេះ គឺភិក្ខុដែលនៅបរិវាសនោះ មិនត្រូវឲ្យឧបសម្បទា[25] ១ មិនត្រូវឲ្យនិស្ស័យ[26] ១ មិនត្រូវឲ្យសាមណេរបម្រើខ្លួន[27] ១ មិនត្រូវទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី១ បើទុកជាសង្ឃសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនី១ សង្ឃឲ្យបរិវាស ចំពោះអាបត្តិណា មិនឲ្យត្រូវអាបត្តិនោះទៀត១ ឬអាបត្តិដទៃ ប្រហែលគ្នា នឹងអាបត្តិនោះ១ ឬត្រូវអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ១ មិនត្រូវតិះដៀលកម្ម១ មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១ មិនត្រូវហាមឧបោសថ ដល់ភិក្ខុជាបកតត្ត១ មិនត្រូវហាមបវារណា១ មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ)១ មិនត្រូវទទួលនាទីជាធំ ក្នុងវត្ត១ មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ)១ មិនត្រូវចោទគេ១ មិនត្រូវរំលឹកគេ១ មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា១។

[៣២៣] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវដើរមុខ មិនត្រូវអង្គុយមុខភិក្ខុ ជាបកតត្ត ទីឱកាសឯណា ដែលជាទីបំផុត នៃទីអង្គុយ ជាទីបំផុតនៃទីដេក (គ្រែ ឬតាំងដែលអាក្រក់ជាងគេ) ជាទីបំផុតនៃលំនៅ (លំនៅដែលអាក្រក់ជាងគេ) របស់សង្ឃ ៗត្រូវប្រគល់ឲ្យឱកាសនោះដល់បារិវាសិកភិក្ខុនោះ បារិវាសិកភិក្ខុនោះ ត្រូវត្រេកអរ ចំពោះឱកាសនោះ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ (មិនត្រូវធ្វើ) ភិក្ខុជាបកតត្ត ឲ្យជាបុរេសមណ (សមណដើរមុខ) ឬបច្ឆាសមណ (សមណដើរក្រោយ) ចូលទៅកាន់ត្រកូលទាំងឡាយទេ មិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាត្រមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះ ដោយគិតថា ជនទាំងឡាយកុំដឹង (រឿង) អញឡើយ។[28]

[៣២៤] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ជាអាគន្តុក ត្រូវប្រាប់ដល់អាគន្តុកភិក្ខុផងគ្នា ត្រូវប្រាប់ក្នុងថ្ងៃឧបោសថ ត្រូវប្រាប់ក្នុងថ្ងៃបវារណា បើមានជម្ងឺ (មិនអាចនឹងទៅបាន) ប្រើបម្រើទៅប្រាប់ក៏បាន។

[៣២៥] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស[29] ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស[30] ដែលគ្មានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុ

ទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ។

[៣២៦] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ គឺអាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុទេ គឺអនាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ គឺអាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុទេ គឺអនាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ គឺអាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុទេ គឺអនាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ។

[៣២៧] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន គឺអាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុបាន គឺអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុបាន គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន គឺអាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុបាន គឺអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុបាន គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន គឺអាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុបាន គឺអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ ត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុបាន គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុមានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅ (ឲ្យទាន់) ក្នុងថ្ងៃនេះបាន។

[៣២៨] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្តទេ ឃើញភិក្ខុជាបកតត្តហើយ ត្រូវក្រោកចាកអាសនៈ ត្រូវនិមន្តភិក្ខុ ជាបកតត្ត ដោយអាសនៈ (របស់ខ្លួន) មិនត្រូវអង្គុយលើអាសនៈមួយ ជាមួយនឹងភិក្ខុជាបកតត្ត កាលបើភិក្ខុជាបកតត្ត អង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈ មិនត្រូវចង្រ្កម ក្នុងទីចង្រ្កមមួយ (ជាមួយនឹងភិក្ខុជាបកតត្ត) កាលបើភិក្ខុជាបកតត្តចង្រ្កម ក្នុងទីចង្រ្កមទាប មិនត្រូវចង្រ្កម ក្នុងទីចង្រ្កមខ្ពស់ កាលបើភិក្ខុជាបកតត្ត ចង្រ្កមលើផែនដី មិនត្រូវចង្រ្កមក្នុងទីចង្រ្កមឡើយ។

[៣២៩] ម្នាលភិក្ខុទាំងឡាយ បារិវាសិកភិក្ខុ មិនត្រូវនៅ។បេ។ ជាមួយនឹងបារិវាសិកភិក្ខុ ដែលចាស់ជាងខ្លួន ជាមួយនឹងភិក្ខុ ដែលគួរដល់កិរិយាទាញចូលក្នុងមូលាបត្តិ។បេ។ ជាមួយនឹងភិក្ខុ ដែលគួរដល់មានត្ត។បេ។ ជាមួយនឹងភិក្ខុ ដែលប្រព្រឹត្តមានត្ត។បេ។ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុ ដែលគួរដល់អព្ភាន មិនត្រូវអង្គុយលើអាសនៈមួយ ជាមួយនឹងអព្ភានារហភិក្ខុ (ភិក្ខុដែលគួរដល់អព្ភាន) កាលអព្ភានារហភិក្ខុ អង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ កាលអព្ភានារហភិក្ខុ អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈ មិនត្រូវចង្រ្កម លើទីចង្រ្កមជាមួយគ្នា កាលអព្ភានារហភិក្ខុ ចង្រ្កម លើទីចង្រ្កមទាប មិនត្រូវចង្រ្កម លើទីចង្រ្កមខ្ពស់ កាលអព្ភានារហភិក្ខុ ចង្រ្កមលើផែនដី មិនត្រូវចង្រ្កមលើទីចង្រ្កមឡើយ។

[៣៣០] ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃ មានបារិវាសិកភិក្ខុ ជាគំរប់៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា (ទាញចូលមកកាន់មូលាបត្តិ) ឲ្យមានត្ត គណសង្ឃ មានបារិវាសិកភិក្ខុ ជាគំរប់២០ ឲ្យអព្ភានកម្មនោះ មិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង។

ចប់ បារិវាសិកវត្ត ៩៤។

[៣៣១] គ្រានោះ ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ព្រះឧបាលិដ៏មានអាយុអង្គុយ ក្នុងទីដ៏សមគួរហើយ ទើបក្រាបថ្វាយបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ការដាច់រាត្រីរបស់បារិវាសិកភិក្ខុ មានប៉ុន្មាន។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ការដាច់រាត្រី របស់បារិវាសិកភិក្ខុ មាន៣យ៉ាង គឺការនៅរួមគ្នា[31] ១ ការមិននៅរួមគ្នា[32] ១ ការមិនប្រាប់[33] ១ ម្នាលឧបាលិ ការដាច់រាត្រី របស់បារិវាសិកភិក្ខុ មាន៣យ៉ាងដូច្នេះឯង។

[៣៣២] សម័យនោះឯង ភិក្ខុសង្ឃប្រជុំគ្នាច្រើន ក្នុងក្រុងសាវត្ថី។ ពួកបារិវាសិកភិក្ខុ មិនអាចនឹងជម្រះបរិវាស។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យដាក់បរិវាស។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសនោះ ភិក្ខុត្រូវដាក់យ៉ាងនេះ។ បារិវាសិកភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុមួយរូប ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ចលីឡើង ហើយនិយាយយ៉ាងនេះថា ខ្ញុំសូមដាក់បរិវាស។ បរិវាសឈ្មោះថា ភិក្ខុដាក់ហើយ។ ថាខ្ញុំសូមដាក់វត្ត។ បរិវាសបានឈ្មោះថា ភិក្ខុដាក់ហើយដែរ។

[៣៣៣] សម័យនោះឯង ភិក្ខុទាំងឡាយ ចេញពីក្រុងសាវត្ថី ហើយចៀសចេញ ទៅក្នុងទីនោះៗ។ ពួកបារិវាសិកភិក្ខុ អាចនឹងជម្រះបរិវាសបាន។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសមាទានបរិវាស។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសនោះ ភិក្ខុត្រូវសមាទានយ៉ាងនេះ។ បារិវាសិកភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុមួយរូប ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ចលីឡើង ហើយនិយាយយ៉ាងនេះថា ខ្ញុំសូមសមាទានបរិវាស។ បរិវាស បានឈ្មោះថា ភិក្ខុសមាទានហើយ។ ថាខ្ញុំសូមសមាទាននូវវត្ត។ បរិវាស បានឈ្មោះថា ភិក្ខុសមាទានហើយដែរ។

ចប់បារិវាសិកវត្ត។

# (មូលាយបដិកស្សនារហវត្ត ទី២)

CS vin.cv.02.02 | ភាគ ទី៩

### (២. មូលាយបដិកស្សនារហវត្តំ)

[៣៣៤] សម័យនោះឯង ពួកភិក្ខុដែលគួរដល់មូលាយបដិកស្សនា ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនៈមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់ភិក្ខុជាបកតត្តទាំងឡាយ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ពួកភិក្ខុ ដែលគួរដល់មូលាយបដិកស្សនា ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនៈមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់ភិក្ខុទាំងឡាយ ជាបកតត្តសោះ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[៣៣៥] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកមូលាយបដិកស្សនារហភិក្ខុ (ភិក្ខុដែលគួរដល់កិរិយាទាញត្រឡប់មករកអាបត្តិដើម) ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់ពួកភិក្ខុជាបកតត្តទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមូលាយបដិកស្សនារហភិក្ខុ មិនសមបើនឹងត្រេកអរ នូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់ពួកភិក្ខុជាបកតត្តទេ។ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់សំដែងធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់ពួកភិក្ខុ ជាបកតត្តទេ ភិក្ខុណាត្រេកអរ ភិក្ខុនោះត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក ដល់ពួកមូលាយបដិកស្សនារហភិក្ខុ តាមលំដាប់ចាស់ (ខ្ចី)បាន។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបោសថ១ បវារណា១ ការទទួលវស្សិកសាដក១ ការលះបង់ភត្ត១ ការទទួលភត្ត១ ទាំង៥យ៉ាង ដល់ពួកមូលាយបដិកស្សនារហភិក្ខុ តាមលំដាប់ចាស់ (ខ្ចី)បាន។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគត នឹងបញ្ញត្តវត្ត ដល់ពួកមូលាយបដិកស្សនារហភិក្ខុ តាមទំនងដែលពួកមូលាយបដិកស្សនារហភិក្ខុ ត្រូវប្រព្រឹត្តតាម។

[៣៣៦] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ។ ឯការប្រព្រឹត្តវត្ត ដោយប្រពៃ ក្នុងមូលាយបដិកស្សនានោះ ដូច្នេះ គឺមូលាយបដិកស្សនារហភិក្ខុ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើ (ខ្លួន) មិនត្រូវទទួលការសន្មតិខ្លួនជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃបានសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនី ភិក្ខុ ដែលគួរដល់កិរិយាទាញមករកអាបត្តិដើម ចំពោះអាបត្តិណា មិនគួរត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃ ដែលប្រហែលនឹងអាបត្តិនោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ) មិនត្រូវទទួលនាទី ជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា។

[៣៣៧] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវដើរមុន មិនត្រូវអង្គុយមុខភិក្ខុជាបកតត្តឡើយ ឱកាសឯណា ជាទីបំផុត នៃទីអង្គុយ ជាទីបំផុតនៃទីដេក ជាទីបំផុត នៃវិហារជារបស់សង្ឃ សង្ឃត្រូវប្រគល់ឲ្យទីឱកាសនោះ ដល់មូលាយបដិកស្សនារហភិក្ខុនោះ មួយវិញ

ទៀត ភិក្ខុនោះ ត្រូវត្រេកអរនឹងទីឱកាសនោះ។ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ (មិនត្រូវធ្វើ) បកតត្តភិក្ខុ ឲ្យជាបុរេសមណ ឬ បច្ឆាសមណ ចូលទៅកាន់ត្រកូលទាំងឡាយឡើយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទាន បិណ្ឌបាតិកធុតង្គ មិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះ ដោយគិតថា ជនទាំងឡាយ កុំដឹង (រឿង) អញឡើយ។

[៣៣៨] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ។

[៣៣៩] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ គឺអាវាសណា ដែលមានពួកភិក្ខុ មានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមានភិក្ខុទេ។បេ។ មិនត្រូវទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ មិនត្រូវទៅកាន់អនាវាស ដែលមានភិក្ខុទេ។បេ។ មិនត្រូវទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ មិនត្រូវទៅកាន់អនាវាស ដែលមានភិក្ខុទេ។បេ។ មិនត្រូវទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ។

[៣៤០] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ គួរចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុបាន គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ គួរចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ គួរចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន។

[៣៤១] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្ត (ដើរមក) ត្រូវក្រោកឡើងចាកអាសនៈ ត្រូវនិមន្តភិក្ខុ ជាបកតត្ត ដោយអាសនៈ មិនត្រូវអង្គុយលើអាសនៈមួយ ជាមួយនឹងភិក្ខុជាបកតត្ត កាលបើភិក្ខុជាបកតត្តអង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ទេ កាលបើភិក្ខុជាបកតត្តអង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈទេ មិនត្រូវចង្ក្រមលើទីចង្ក្រមជាមួយគ្នា កាលបើភិក្ខុជាបកតត្តចង្ក្រម លើទីចង្ក្រមទាប មិនត្រូវចង្ក្រម លើទីចង្ក្រមខ្ពស់ កាលបើភិក្ខុជាបកតត្ត ចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមទេ។

[៣៤២] ម្នាលភិក្ខុទាំងឡាយ មូលាយបដិកស្សនារហភិក្ខុ មិនត្រូវនៅជាមួយនឹងបារិវាសិកភិក្ខុទេ។បេ។ មិនត្រូវនៅជាមួយនឹងមូលាយបដិកស្សនារហភិក្ខុ ដែលចាស់ជាងខ្លួនទេ។បេ។ មិនត្រូវនៅជាមួយនឹងមានត្តារហភិក្ខុ (ភិក្ខុគួរដល់មានត្ត)ទេ។បេ។ មិនត្រូវនៅជាមួយនឹងមានត្តចារិកភិក្ខុ (ភិក្ខុដែលប្រព្រឹត្តមានត្ត) ទេ។បេ។ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយគ្នានឹងអព្ភានារហភិក្ខុ (ភិក្ខុដែលគួរដល់អព្ភាន) មិនត្រូវអង្គុយលើអាសនៈជាមួយគ្នា កាលបើភិក្ខុជាបកតត្ត អង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ទេ កាលបើភិក្ខុជាបកតត្ត អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈទេ មិនត្រូវចង្ក្រម លើទីចង្ក្រមជាមួយគ្នា កាលបើភិក្ខុជាបកតត្ត ចង្ក្រមលើទីចង្ក្រមទាប មិនត្រូវចង្ក្រម លើទីចង្ក្រមខ្ពស់ទេ កាលបើភិក្ខុជាបកតត្ត ចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមទេ។

[៣៤៣] ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃ មានមូលាយបដិកស្សនារហភិក្ខុ ជាគំរប់៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា ឲ្យមានត្ត គណសង្ឃ មានមូលាយបដិកស្សនារហភិក្ខុនោះ ជាគំរប់២០ ឲ្យអព្ភានកម្ម នោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង។

ចប់ វត្តរបស់មូលាយបដិកស្សនារហភិក្ខុ។

# (មានត្តារហវត្ត ទី៣)

CS vin.cv.02.03 | ភាគ ទី៩

### (៣. មានត្តារហវត្តំ)

[៣៤៤] សម័យនោះឯង ពួកមានត្តារហភិក្ខុ ទទួលត្រេកអរនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់បកតត្តភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកមានត្តារហភិក្ខុ មិនសមបើ នឹងទទួលត្រេកអរ នូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក នៃបកតត្តភិក្ខុទាំងឡាយសោះ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកមានត្តារហភិក្ខុ ទទួលត្រេកអរ នូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់បកតត្តភិក្ខុទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុទាំងឡាយ មិនសមបើនឹងទទួលត្រេកអរ នូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់បកតត្តភិក្ខុទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវត្រេកអរ នូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់បកតត្តភិក្ខុទាំងឡាយទេ ភិក្ខុណាត្រេកអរ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក ដល់មានត្តារហភិក្ខុទាំងឡាយ តាមលំដាប់ចាស់ (ខ្ចី)បាន។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវឧបោសថ១ បវារណា១ ការទទួលវស្សិកសាដិក១ ការលះបង់ភត្ត១ ការទទួលភត្ត១ ទាំង៥យ៉ាង ដល់មានត្តារហភិក្ខុទាំងឡាយ តាមលំដាប់ចាស់ (ខ្ចី)។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគត នឹងបញ្ញត្តវត្ត ដល់ពួកមានត្តារហភិក្ខុ តាមទំនងដែលមានត្តារហភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តតាម។

[៣៤៥] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ ត្រូវប្រព្រឹត្តវត្តដោយប្រព្រៃ ឯការប្រព្រឹត្តវត្ត ដោយប្រពៃ ក្នុងមានត្តនោះ ដូច្នេះ គឺមានត្តារហភិក្ខុ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី បើសង្ឃបានសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនីទាំងឡាយ ភិក្ខុដែលគួរដល់មានត្ត ព្រោះអាបត្តិណា មិនគប្បីត្រូវអាបត្តិនោះ ឬអាបត្តិដទៃ ប្រហែលនឹងអាបត្តិមុននោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិមុននោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា (ដល់បកតត្តភិក្ខុ) មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ) មិនត្រូវទទួលនាទី ជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុឡើយ។

[៣៤៦] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវដើរមុន មិនត្រូវអង្គុយខាងមុខបកតត្តភិក្ខុឡើយ ឱកាសឯណា ជាទីបំផុតនៃទីអង្គុយ ទីដេក និងវិហាររបស់សង្ឃ សង្ឃត្រូវប្រគល់ឲ្យទីឱកាសនោះ ដល់មានត្តារហភិក្ខុនោះ មួយទៀត មានត្តារហភិក្ខុនោះ ត្រូវត្រេកអរទីឱកាសដែលសង្ឃប្រគល់ឲ្យនោះ។ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវធ្វើបកតត្តភិក្ខុ ឲ្យជាបុរេសមណ ឬបច្ឆាសមណ ចូលទៅកាន់ត្រកូលទាំងឡាយឡើយ មានត្តារហភិក្ខុ មិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មួយទៀត មិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះ ដោយគិតថា ជនទាំងឡាយ កុំដឹងអាត្មាអញឡើយ។

[៣៤៧] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ ជាអាគន្តុក ត្រូវប្រាប់ (ដល់ភិក្ខុទាំងឡាយក្នុងវត្ត) ត្រូវប្រាប់ដល់អាគន្តុកភិក្ខុ (ដែលមកដល់កន្លែងខ្លួន) ត្រូវប្រាប់ក្នុងថ្ងៃឧបោសថ ត្រូវប្រាប់ក្នុងថ្ងៃបវារណា ត្រូវប្រាប់រាល់ថ្ងៃ បើមានជម្ងឺ (មិនអាចនឹងទៅបាន) ត្រូវឲ្យទូតប្រាប់ (ជំនួសខ្លួនក៏បាន)។

[៣៤៨] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ។

[៣៤៩] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ។

[៣៥០] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ គួរចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ គួរចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ គួរចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺអាវាស ឬអនាវាសណា ដែលមានភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន។

[៣៥១] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្តទេ ឃើញភិក្ខុជាបកតត្តហើយ ត្រូវក្រោកចាកអាសនៈ ត្រូវនិមន្តភិក្ខុ ជាបកតត្ត ដោយអាសនៈ មិនត្រូវអង្គុយលើអាសនៈមួយ ជាមួយនឹងភិក្ខុ ជាបកតត្ត កាលបើភិក្ខុជាបកតត្ត អង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ កាលបើភិក្ខុជាបកតត្ត អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈ មិនត្រូវចង្រ្កម លើទីចង្រ្កមជាមួយគ្នា កាលបើភិក្ខុជាបកតត្តចង្រ្កម លើទីចង្រ្កមទាប មិនត្រូវចង្រ្កម លើទីចង្រ្កមខ្ពស់ កាលបើភិក្ខុជាបកតត្ត ចង្រ្កមលើផែនដី មិនត្រូវចង្រ្កមលើទីចង្រ្កម។

[៣៥២] ម្នាលភិក្ខុទាំងឡាយ មានត្តារហភិក្ខុ មិនត្រូវនៅជាមួយនឹងបារិវាសិកភិក្ខុ។បេ។ ជាមួយនឹងមូលាយបដិកស្សនារហភិក្ខុ។បេ។ ជាមួយនឹងមានត្តារហភិក្ខុ ដែលចាស់ជាងខ្លួន។បេ។ ជាមួយនឹងមានត្តចារិកភិក្ខុ។បេ។ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងអព្ភានារហភិក្ខុ មិនត្រូវអង្គុយលើអាសនៈជាមួយគ្នា កាលបើអព្ភានារហភិក្ខុ អង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ កាលបើអព្ភានារហភិក្ខុ អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈ មិនត្រូវចង្រ្កម លើទីចង្រ្កមជាមួយគ្នា កាលបើអព្ភានារហភិក្ខុ ចង្រ្កម លើទីចង្រ្កមទាប មិនត្រូវចង្រ្កម លើទីចង្រ្កមខ្ពស់ កាលបើអព្ភានារហភិក្ខុ ចង្រ្កមលើផែនដី មិនត្រូវចង្រ្កមលើទីចង្រ្កម។

[៣៥៣] ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃ មានមានត្តារហភិក្ខុ ជាគំរប់៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា ឲ្យមានត្ត គណសង្ឃ មានមានត្តារហភិក្ខុនោះ ជាគំរប់២០ ឲ្យអព្ភានកម្ម កម្មនោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង។

ចប់វត្តរបស់មានត្តារហភិក្ខុ។

# (មានត្តចារិកវត្ត ទី៤)

CS vin.cv.02.04 | ភាគ ទី៩

### (៤. មានត្តចារិកវត្តំ)

[៣៥៤] សម័យនោះឯង ពួកមានត្តចារិកភិក្ខុ ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក នៃបកតត្តភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ពួកមានត្តចារិកភិក្ខុ ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយដូច្នោះ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[៣៥៥] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកមានត្តចារិកភិក្ខុ ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមានត្តចារិកភិក្ខុ មិនសមបើនឹងត្រេកអរអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវត្រេកអរអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក របស់ពួកភិក្ខុជាបកតត្តឡើយ ភិក្ខុណាត្រេកអរ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត អភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាស្រង់ទឹក ដល់មានត្តចារិកភិក្ខុទាំងឡាយ តាមលំដាប់ចាស់ (ខ្ចី)។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបោសថ១ បវារណា១ ការទទួលសំពត់វស្សិកសាដិក១ ការលះបង់ភត្ត១ ការទទួលភត្ត១ ទាំង៥យ៉ាង ដល់មានត្តចារិកភិក្ខុ តាមលំដាប់ចាស់ (ខ្ចី)។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគត នឹងបញ្ញត្តវត្ត ដល់ពួកមានត្តចារិកភិក្ខុ តាមទំនងដែលមានត្តចារិកភិក្ខុ ត្រូវប្រព្រឹត្ត។

[៣៥៦] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ ត្រូវប្រព្រឹត្តវត្តដោយប្រព្រៃ។ ឯការប្រព្រឹត្តវត្ត ដោយប្រពៃ ក្នុងមានត្តនោះ ដូច្នេះ គឺមានត្តចារិកភិក្ខុ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន មិនត្រូវទទួលការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី បើទុកជាសង្ឃសន្មតហើយ ក៏មិនត្រូវប្រដៅភិក្ខុនី សង្ឃឲ្យមានត្ត ចំពោះអាបត្តិណា មិនគប្បីត្រូវអាបត្តិនោះទៀត ឬអាបត្តិដទៃ ដែលប្រហែលនឹងអាបត្តិនោះ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះ មិនត្រូវតិះដៀលកម្ម មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើកម្ម មិនត្រូវហាមឧបោសថ មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណនោះ) មិនត្រូវទទួលនាទី ជាធំក្នុងវត្ត មិនត្រូវឲ្យធ្វើឱកាស (ដើម្បីចោទ) មិនត្រូវចោទ មិនត្រូវរំលឹក មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា។

[៣៥៧] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវដើរមុន មិនត្រូវអង្គុយមុខភិក្ខុជាបកតត្តឡើយ ឱកាសឯណា ជាទីបំផុតនៃអាសនៈ ជាទីបំផុតនៃទីដេក ជាទីបំផុត នៃវិហាររបស់សង្ឃ សង្ឃត្រូវប្រគល់ឱកាសនោះ ដល់ភិក្ខុនោះ ឯភិក្ខុនោះ ត្រូវត្រេកអរចំពោះទីឱកាសនោះ។ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវធ្វើភិក្ខុជាបកតត្ត ឲ្យជាបុរេសមណ ឬបច្ឆាសមណ ចូលទៅកាន់ត្រកូលទាំងឡាយឡើយ មិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មួយទៀត មិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះ ដោយគិតថា ជនទាំងឡាយ កុំដឹងអាត្មាអញឡើយ។

[៣៥៨] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ ជាអាគន្តុក ត្រូវប្រាប់ (ដល់ភិក្ខុក្នុងអាវាស ដែលខ្លួនទៅដល់) ត្រូវប្រាប់ដល់អាគន្តុកភិក្ខុ (ដែលមកដល់ទីកន្លែងខ្លួន) ត្រូវប្រាប់ ក្នុងថ្ងៃឧបោសថ ត្រូវប្រាប់ក្នុងថ្ងៃបវារណា ត្រូវប្រាប់រាល់ថ្ងៃ បើមានជម្ងឺ ត្រូវប្រើបម្រើ ទៅប្រាប់ ក៏បាន។

[៣៥៩] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ។

[៣៦០] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុទេ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុទេ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុមានសំវាសផ្សេងៗគ្នា វៀរលែងតែសង្ឃ វៀរលែងតែមានការអន្តរាយ។

[៣៦១] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ គួរចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញអាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ គួរចេញចាកអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុបាន គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញ អាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ គួរចេញចាកអាវាស ឬអនាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន។បេ។ ទៅកាន់អនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុបាន គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញ អាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន។

[៣៦២] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត បើឃើញភិក្ខុជាបកតត្តហើយ ត្រូវក្រោកចាកអាសនៈ ត្រូវនិមន្តភិក្ខុ ជាបកតត្ត ដោយអាសនៈ មិនត្រូវអង្គុយលើអាសនៈមួយ ជាមួយនឹងភិក្ខុ ជាបកតត្ត កាលបើភិក្ខុជាបកតត្ត អង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ កាលបើភិក្ខុជាបកតត្ត អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈទេ មិនត្រូវចង្ក្រម លើទីចង្ក្រមជាមួយគ្នា កាលបើភិក្ខុជាបកតត្តចង្ក្រម លើទីចង្ក្រមទាប មិនត្រូវចង្ក្រម លើទីចង្ក្រមខ្ពស់ឡើយ កាលបើភិក្ខុជាបកតត្ត ចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមឡើយ។

[៣៦៣] ម្នាលភិក្ខុទាំងឡាយ មានត្តចារិកភិក្ខុ មិនត្រូវនៅជាមួយនឹងបារិវាសិកភិក្ខុ។បេ។ ជាមួយនឹងមូលាយបដិកស្សនារហភិក្ខុ។បេ។ ជាមួយនឹងមានត្តារហភិក្ខុ។បេ។ ជាមួយនឹងមានត្តចារិកភិក្ខុ ដែលចាស់ជាងខ្លួន។បេ។ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងអព្ភានារហភិក្ខុ មិនត្រូវអង្គុយលើអាសនៈជាមួយគ្នា កាលបើអព្ភានារហភិក្ខុ អង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ កាលបើអព្ភានារហភិក្ខុ អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈ មិនត្រូវចង្ក្រម លើទីចង្ក្រមជាមួយគ្នា កាលបើអព្ភានារហភិក្ខុ ចង្ក្រម លើទីចង្ក្រមទាប មិនត្រូវចង្ក្រម លើទីចង្ក្រមខ្ពស់ កាលបើអព្ភានារហភិក្ខុ ចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមឡើយ។

[៣៦៤] ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃ មានមានត្តចារិកភិក្ខុ ជាគំរប់៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា ឲ្យមានត្ត គណសង្ឃ មានមានត្តចារិកភិក្ខុនោះ ជាគំរប់២០ ឲ្យអព្ភាន កម្មនោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង។

[៣៦៥] គ្រានោះ ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ ព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ការដាច់រាត្រី របស់មានត្តចារិកភិក្ខុ មានប៉ុន្មាន។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ការដាច់រាត្រី របស់មានត្តចារិកភិក្ខុ

មាន៤យ៉ាងគឺ ការនៅរួមគ្នា[34] ១ ការមិននៅរួមគ្នា[35] ១ ការមិនប្រាប់[36] ១ ភិក្ខុនោះប្រព្រឹត្តមានត្ត ក្នុងពួកបកតត្តភិក្ខុមិនគ្រប់ចំនួន[37] ១ ម្នាលឧបាលិ ការដាច់រាត្រី របស់មានត្តចារិកភិក្ខុ មាន៤យ៉ាងនេះឯង។

[៣៦៦] សម័យនោះ ភិក្ខុសង្ឃប្រជុំគ្នាច្រើន ក្នុងក្រុងសាវត្ថី។ ពួកមានត្តចារិកភិក្ខុ មិនអាចជំរះមានត្តបាន។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យដាក់មានត្តបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវដាក់មានត្ត យ៉ាងនេះ។ មានត្តចារិកភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុ១រូប ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា ខ្ញុំសូមដាក់នូវមានត្ត។ មានត្ត ឈ្មោះថា ភិក្ខុបានដាក់ហើយ។ ថាខ្ញុំសូមដាក់វត្ត។ មានត្ត ក៏ឈ្មោះថា ភិក្ខុបានដាក់ហើយដែរ។

[៣៦៧] សម័យនោះ ភិក្ខុទាំងឡាយចេញអំពីក្រុងសាវត្ថី ទៅក្នុងទីនោះៗ។ មានត្តចារិកភិក្ខុទាំងឡាយ ក៏អាចជំរះនូវមានត្តបាន។ ភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាត ឲ្យសមាទានមានត្ត។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវសមាទាន យ៉ាងនេះ។ មានត្តចារិកភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុ១រូប ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា ខ្ញុំសូមសមាទានមានត្ត។ មានត្ត ឈ្មោះថា ភិក្ខុបានសមាទានហើយ។ ថាខ្ញុំសូមសមាទានវត្ត មានត្ត ឈ្មោះថា ភិក្ខុបានសមាទានហើយដែរ។

ចប់ វត្តរបស់មានត្តចារិកភិក្ខុ។

# (អញ្ញាតនារហវត្ត ទី៥)

CS vin.cv.02.05 | ភាគ ទី៩

### (៥. អញ្ញាតនារហវត្តំ)

[៣៦៨] សម័យនោះ ពួកអញ្ញាតនារហភិក្ខុ ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម។ បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយ។ ភិក្ខុទាំងឡាយឯណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកអញ្ញាតនារហភិក្ខុ មិនសមបើ ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយសោះ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។

[៣៦៩] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា អញ្ញាតនារហភិក្ខុទាំងឡាយ ត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ អញ្ញាតនារហភិក្ខុទាំងឡាយ មិនសមបើ នឹងត្រេកអរអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទើបទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អញ្ញាតនារហភិក្ខុ មិនត្រូវត្រេកអរ នឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក របស់ភិក្ខុជាបកតត្តទាំងឡាយឡើយ ភិក្ខុឯណាត្រេកអរ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត អភិវាទនកម្ម បច្ចុដ្ឋានកម្ម។បេ។ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹក ដល់អញ្ញាតនារហភិក្ខុទាំងឡាយ តាមលំដាប់ចាស់ (ខ្ចី)។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឧបោសថ១ បវារណា១ ការទទួលសំពត់វស្សិកសាដិក១ ការលះបង់ភត្ត១ ការទទួលភត្ត១ ទាំង៥យ៉ាង ដល់អញ្ញាតនារហភិក្ខុទាំងឡាយ តាមលំដាប់ចាស់ (ខ្ចី)។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគត នឹងបញ្ញត្តវត្ត ដល់ពួកអញ្ញាតនារហភិក្ខុ តាមទំនងដែលអញ្ញាតនារហភិក្ខុទាំងឡាយត្រូវប្រព្រឹត្ត។

[៣៧០] ម្នាលភិក្ខុទាំងឡាយ អញ្ញាតនារហភិក្ខុ ត្រូវប្រព្រឹត្តវត្តដោយប្រពៃ ឯការប្រព្រឹត្តវត្ត ដោយប្រពៃ ក្នុងអញ្ញាននោះ ដូច្នេះ គឺអញ្ញាតនារហភិក្ខុ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន។បេ។ វត្តរបស់មូលាយបដិកស្សនារហភិក្ខុ ដូចម្តេចមិញ វត្តរបស់មានត្តារហភិក្ខុក្តី មានត្តចារិកភិក្ខុក្តី អញ្ញាតនារហភិក្ខុក្តី ទាំង៣ពួក ក៏មានសេចក្តីដូចគ្នា យ៉ាងនោះដែរ បណ្ឌិត គប្បីឲ្យពិស្តារចុះ។បេ។ មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា។

[៣៧១] ម្នាលភិក្ខុទាំងឡាយ អញ្ញាតនារហភិក្ខុ មិនត្រូវដើរមុន មិនត្រូវអង្គុយមុខភិក្ខុជាបកតត្តឡើយ ទីឱកាសឯណា ដែលជាទីបំផុតនៃអាសនៈ ជាទីបំផុតនៃទីដេក ជាទីបំផុត នៃវិហាររបស់សង្ឃ សង្ឃត្រូវប្រគល់ឲ្យទីឱកាសនោះ ដល់ភិក្ខុនោះ ភិក្ខុនោះសោះ ក៏ត្រូវត្រេកអរ នឹងទីឱកាសនោះដែរ។ ម្នាលភិក្ខុទាំងឡាយ អញ្ញាតនារហភិក្ខុ (មិនត្រូវធ្វើ) ភិក្ខុជាបកតត្ត ឲ្យជាបុរេសមណ ឬបច្ឆាសមណ ចូលទៅកាន់ត្រកូលទាំងឡាយឡើយ អញ្ញាតនារហភិក្ខុ មិនត្រូវសមាទានអារញ្ញិកធុតង្គ មិនត្រូវសមាទានបិណ្ឌបាតិកធុតង្គ មួយវិញទៀត មិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាតមក (ដើម្បីខ្លួន) ព្រោះបច្ច័យនោះ ដោយគិតថា ជនទាំងឡាយ កុំដឹង (រឿង) អាត្មាអញឡើយ។

[៣៧២] ម្នាលភិក្ខុទាំងឡាយ អញ្ញាតនារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ ម្នាលភិក្ខុទាំងឡាយ អញ្ញាតនារហភិក្ខុ មិនត្រូវចេញចាកអាវាស ដែលមានភិក្ខុ ទៅកាន់អនាវាស ដែលមិនមានភិក្ខុទេ វៀរលែងតែមានភិក្ខុជាបកតត្ត វៀរលែងតែមានការអន្តរាយ បណ្ឌិត គប្បីឲ្យពិស្តារ តាមន័យ ដែលមានហើយខាងក្រោមចុះ។បេ។ ម្នាលភិក្ខុទាំងឡាយ អញ្ញាតនារហភិក្ខុ គួរចេញចាកអាវាស ដែលមានភិក្ខុ។បេ។ ចាកអនាវាស។បេ។ ចាកអាវាស ឬអនាវាស ទៅកាន់អាវាស ដែល

មានភិក្ខុ។បេ។ ចាកអនាវាស ដែលមានភិក្ខុ។បេ។ ទៅកាន់អាវាស ឬអនាវាស ដែលមានភិក្ខុ គឺអាវាស ឬអនាវាសណា ដែលមានពួកភិក្ខុ មានសំវាសស្មើគ្នា ហើយដឹងថា អាវាស ឬអនាវាសណា អាត្មាអញ អាចនឹងទៅឲ្យទាន់ ក្នុងថ្ងៃនេះបាន។

[៣៧៣] ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត ឃើញភិក្ខុជាបកតត្តហើយ ត្រូវក្រោកចាកអាសនៈ ត្រូវនិមន្តភិក្ខុ ជាបកតត្ត ដោយអាសនៈ មិនត្រូវអង្គុយលើអាសនៈមួយ ជាមួយនឹងភិក្ខុ ជាបកតត្ត កាលបើភិក្ខុជាបកតត្ត អង្គុយលើអាសនៈទាប មិនត្រូវអង្គុយលើអាសនៈខ្ពស់ឡើយ កាលបើភិក្ខុជាបកតត្ត អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈ មិនត្រូវចង្ក្រម លើទីចង្ក្រមជាមួយគ្នា កាលបើភិក្ខុជាបកតត្តចង្ក្រម លើទីចង្ក្រមទាប មិនត្រូវចង្ក្រម លើទីចង្ក្រមខ្ពស់ កាលបើភិក្ខុជាបកតត្ត ចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមឡើយ។

[៣៧៤] ម្នាលភិក្ខុទាំងឡាយ អព្ភានារហភិក្ខុ មិនត្រូវនៅជាមួយនឹងបារិវាសិកភិក្ខុ។បេ។ ជាមួយនឹងមូលាយបដិកស្សនារហភិក្ខុ។បេ។ ជាមួយនឹងមានត្តារហភិក្ខុ។បេ។ ជាមួយនឹងមានត្តចារិកភិក្ខុ។បេ។ មិនត្រូវនៅក្នុងអាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអនាវាស ដែលមានដម្បូលមួយ មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ ជាមួយនឹងអព្ភានារហភិក្ខុ ដែលចាស់ជាងខ្លួន មិនត្រូវអង្គុយលើអាសនៈជាមួយគ្នា (កាលបើអព្ភានារហភិក្ខុ ដែលចាស់ជាងខ្លួន) អង្គុយលើអាសនៈទាប (អព្ភានារហភិក្ខុ ដែលខ្ចីជាង) មិនត្រូវអង្គុយលើអាសនៈខ្ពស់ កាលបើអព្ភានារហភិក្ខុ អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសនៈ មិនត្រូវចង្ក្រម លើទីចង្ក្រមជាមួយគ្នា កាលបើអព្ភានារហភិក្ខុ ចង្ក្រមលើទីចង្ក្រមទាប មិនត្រូវចង្ក្រម លើទីចង្ក្រមខ្ពស់ កាលបើអព្ភានារហភិក្ខុ ចង្ក្រមលើផែនដី មិនត្រូវចង្ក្រមលើទីចង្ក្រមឡើយ។

[៣៧៥] ម្នាលភិក្ខុទាំងឡាយ បើគណសង្ឃ មានអព្ភានារហភិក្ខុ ជាគំរប់៤ ឲ្យបរិវាស ឲ្យមូលាយបដិកស្សនា ឲ្យមានត្ត គណសង្ឃ មានអព្ភានារហភិក្ខុនោះ ជាគំរប់២០ ឲ្យអព្ភាន កម្មនោះមិនឡើងជាកម្មផង សង្ឃមិនត្រូវធ្វើផង។

ចប់វត្តរបស់អព្ភានារហភិក្ខុ។ ចប់បារិវាសិកក្ខន្ធក ជាគំរប់២។ ក្នុងខន្ធកនេះ មាន៥រឿង។ ឧទ្ទាននៃបារិវាសិកក្ខន្ធកនោះគឺ

[៣៧៦]

> បារិវាសិកភិក្ខុទាំងឡាយ តែងត្រេកអរនឹងអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលិកម្ម សាមីចិកម្ម ការនាំអាសនមកឲ្យ ការនាំទីដេកមកឲ្យ ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង វត្ថុសម្រាប់ជូតជើង ការទទួលបាត្រ និងចីវរ ការដុសក្អែលខ្នង ក្នុងវេលាងូតទឹករបស់ភិក្ខុជាបកតត្តទាំងឡាយ ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ក៏ពោលទោស។ អាបត្តិទុក្កដ មានដល់បារិវាសិកភិក្ខុ ដែលត្រេកអរ (នូវអភិវាទនកម្ម ជាដើមនោះ) ទ្រង់អនុញ្ញាតឧបោសថ១ បវារណា១ ការទទួលសំពត់វស្សិកសាដិក១ ការលះបង់ភត្ត១ ការទទួលភត្ត១ ទាំង៥យ៉ាង ដល់គ្នានឹងគ្នា តាមលំដាប់ចាស់ខ្ចី ការប្រព្រឹត្តវត្ត ដោយប្រពៃ (របស់ពួកបារិវាសិកភិក្ខុ) បារិវាសិកភិក្ខុ ទៅជាមួយនឹងបកតត្តភិក្ខុបាន ឱកាសឯណា ដែលជាទីបំផុត (នៃសេនាសន បារិវាសិកភិក្ខុ គួរត្រេកអរ នឹងឱកាសជាទីបំផុត នៃសេនាសននោះ)បាន បារិវាសិកភិក្ខុ មិនត្រូវធ្វើបកតត្តភិក្ខុ ឲ្យជាបុរេសមណ ឬបច្ឆាសមណ មិនត្រូវសមាទានអារញ្ញិកធុតង្គ និងបិណ្ឌបាតិកធុតង្គ និងឲ្យនាំបិណ្ឌបាតមក ត្រូវប្រាប់វត្ត ដល់អាគន្តុកភិក្ខុ ត្រូវប្រាប់វត្ត ក្នុងថ្ងៃឧបោសថ ក្នុងថ្ងៃបវារណា (បើមានជម្ងឺ) នឹងប្រើបម្រើទៅប្រាប់ក៏បាន មួយទៀត បារិវាសិកភិក្ខុ ទៅកាន់អាវាស ដែលមានភិក្ខុបាន មិនត្រូវនៅក្នុងអាវាស ឬអនាវាស ដែលមានដម្បូលមួយ កាលបើភិក្ខុជាបកតត្ត អង្គុយលើផែនដី មិនត្រូវអង្គុយលើអាសន កាលបើភិក្ខុជាបកតត្ត ចង្ក្រមលើទីចង្ក្រមទាប (មិនត្រូវចង្ក្រម លើទីចង្ក្រមខ្ពស់) កាលបើភិក្ខុ ជាបកតត្ត ចង្ក្រមលើផែនដី (មិនត្រូវចង្ក្រម) លើទីចង្ក្រមឡើយ មិនត្រូវនៅរួមនឹងបារិវាសិកភិក្ខុ ដែលចាស់ជាងខ្លួន កម្មដែលមានបារិវាសិកភិក្ខុ ជាគំរប់៤ មិនឡើងជាកម្ម ទ្រង់សំដែងការដាច់រាត្រី និងការជម្រះបរិវាស ទ្រង់អនុញ្ញាតការដាក់វត្ត និងការសមាទានវត្តទាំងនេះ បារិវាសិកភិក្ខុ ត្រូវដឹងរាល់គ្នា សូម្បីមូលាយបដិកស្សនារហភិក្ខុ មានត្តារហភិក្ខុ មានត្តចារិកភិក្ខុ អព្ភានារហភិក្ខុ ក៏គប្បីដឹង តាមន័យដែលផ្សេងៗគ្នា យ៉ាងនេះចុះ។ ការដាច់រាត្រីទាំងឡាយ របស់បារិវាសិកភិក្ខុ មាន៣ របស់មានត្តចារិកភិក្ខុ មាន៤ មិនស្មើគ្នា មួយទៀត ភិក្ខុប្រព្រឹត្តមានត្ត ត្រូវប្រាប់វត្តសព្វថ្ងៃៗ។ កម្មទាំងពីរ ជាកម្មប្រហែលៗគ្នា កម្មទាំង៣ ដែលសេសសល់ ក៏ស្មើគ្នាៗ។

# សមុច្ចយក្ខន្ធកៈ (ទី៣)

CS vin.cv.03 | ភាគ ទី៩

### (៣. សមុច្ចយក្ខន្ធកំ)

## (សុក្កវិស្សដ្ឋិ ទី១)

CS vin.cv.03.01 | ភាគ ទី៩

### (១. សុក្កវិស្សដ្ឋិ)

[៣៧៧] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ វេលានោះឯង ឧទាយិដ៏មានអាយុ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ[38] តែមិនបានបិទបាំងទេ។ ឧទាយិភិក្ខុនោះ ប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវ

អាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទេ តើខ្ញុំ ត្រូវប្រតិបត្តិដូចម្ដេចហ្ន៎។ ភិក្ខុទាំងនោះ នាំយកសេចក្ដីនុ៎ះ ទៅក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យមានត្ត៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។

## (អប្បដិច្ឆន្នមានត្តៈ)

CS vin.cv.03.01.01 | ភាគ ទី៩

### (អប្បដិច្ឆន្នមានត្តំ)

[៣៧៨] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយប្រហោង ផ្គងអញ្ជលីឡើង ហើយពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ជាគំរប់ពីរដងទៀត ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។

[៣៧៩] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឧទាយិភិក្ខុនោះ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ នេះជាពាក្យផ្ទៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឧទាយិភិក្ខុនោះ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃ ក៏ឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ កិរិយាឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឧទាយិភិក្ខុនោះ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃ ក៏ឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ កិរិយាឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឧទាយិភិក្ខុនោះ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃ ក៏ឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ កិរិយាឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ មានត្ត ៦រាត្រី ដែលសង្ឃបានឲ្យដល់ ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្ដីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (អប្បដិច្ឆន្នអព្ភានៈ)

CS vin.cv.03.01.02 | ភាគ ទី៩

### (អប្បដិច្ឆន្នអព្ភានំ)

[៣៨០] ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ក៏ប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកហើយ ខ្ញុំនោះ បានសន្សំមានត្តរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្ដេចទៅ។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្ដីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើអព្ភានកម្ម[39] ដល់ឧទាយិភិក្ខុចុះ។

[៣៨១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវធ្វើអព្ភានកម្ម យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ឧទាយិភិក្ខុនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ បានសន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្ម នឹងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវ

អាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ សូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ បានសន្សំមានត្តរួចហើយ មកសូមអព្ភានកម្ម នឹងសង្ឃ ជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ បានសន្សំមានត្តរួចហើយ មកសូមអព្ភានកម្ម នឹងសង្ឃ ជាគំរប់បីដងផង។

[៣៨២] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានមកសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ មកសូមអព្ភានកម្មនឹងសង្ឃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរធ្វើអព្ភានកម្ម ចំពោះឧទាយិភិក្ខុចុះ។ នេះជាពាក្យផ្ទៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានមកសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុករួចហើយ។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ មកសូមអព្ភានកម្មនឹងសង្ឃ។ សង្ឃក៏ធ្វើអព្ភានកម្ម ចំពោះឧទាយិភិក្ខុ។ អព្ភានកម្ម របស់ឧទាយិភិក្ខុ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ ត្រូវពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ មកសូមអព្ភានកម្មនឹងសង្ឃ។ សង្ឃក៏ធ្វើអព្ភានកម្ម ចំពោះឧទាយិភិក្ខុ។ អព្ភានកម្ម របស់ឧទាយិភិក្ខុ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុករួចហើយ។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ មកសូមអព្ភានកម្មនឹងសង្ឃ។ សង្ឃក៏ធ្វើអព្ភានកម្ម ចំពោះឧទាយិភិក្ខុ។ អព្ភានកម្ម របស់ឧទាយិភិក្ខុ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃបានធ្វើអព្ភានកម្ម ចំពោះឧទាយិភិក្ខុ អព្ភានកម្ម គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (ឯកាហប្បដិច្ឆន្នបរិវាស)

CS vin.cv.03.01.03 | ភាគ ទី៩

### (ឯកាហប្បដិច្ឆន្នបរិវាសំ)

[៣៨៣] សម័យនោះឯង ឧទាយិដ៏មានអាយុ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ។ ឧទាយិភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៅ។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យឯកាហបរិវាស (បរិវាស១ថ្ងៃ) ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបានបិទបាំងទុក១ថ្ងៃចុះ។

[៣៨៤] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន ឥឡូវ ខ្ញុំនោះ មកសូមឯកាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៣៨៥] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ មកសូមឯកាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃចុះ។ នេះជាពាក្យផ្ទៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ មកសូមឯកាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏ឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ការឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ មកសូមឯកាហបរិវាសនឹងសង្ឃ ចំពោះ

អាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ សង្ឃក៏ឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ការឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ឯកាហបរិវាស សង្ឃបានឲ្យ ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃរួចហើយ ការឲ្យឯកាហបរិវាសនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំចាំនូវសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (ឯកាហប្បដិច្ឆន្នមានត្តៈ)

CS vin.cv.03.01.04 | ភាគ ទី៩

### (ឯកាហប្បដិច្ឆន្នមានត្តំ)

[៣៨៦] ឧទាយិភិក្ខុនោះ បាននៅបរិវាសហើយ ក៏ប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ខ្ញុំនោះ បានមកសូមឯកាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ខ្ញុំ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃហើយ ខ្ញុំនោះ បាននៅបរិវាសរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។

[៣៨៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ខ្ញុំនោះ បានមកសូមឯកាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃហើយ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ បាននៅបរិវាសរួចហើយ មកសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៣៨៨] ភិក្ខុអ្នកឆ្លាស ប្រតិពលត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ បានមកសូមឯកាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ឥឡូវ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ បើកម្មមានកាលដ៏សមគួរ ដល់សង្ឃហើយ សង្ឃគួរឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ នេះជាពាក្យផ្ទៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ បានមកសូមឯកាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ឥឡូវ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏ឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ការឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ បានមកសូមឯកាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ឥឡូវ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏ឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ការឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ មានត្ត៦រាត្រី សង្ឃបានឲ្យដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ ការឲ្យមានត្តនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (ឯកាហប្បដិច្ឆន្នអព្ភានៈ)

CS vin.cv.03.01.05 | ភាគ ទី៩

### (ឯកាហប្បដិច្ឆន្នអព្ភានំ)

[៣៨៩] ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ក៏ប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ខ្ញុំនោះ បានសូមឯកាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ ខ្ញុំនោះ បាននៅបរិវាសរួចហើយ បានមកសូម

មានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ ខ្ញុំនោះ បានសន្សំមានត្តរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្ដេចតទៅទៀត។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្ដីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើអព្ភានកម្ម ចំពោះឧទាយិភិក្ខុចុះ។

[៣៩០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវធ្វើអព្ភានកម្ម យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ចលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ខ្ញុំនោះ បានសូមឯកាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃបានឲ្យឯកាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ខ្ញុំនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ បានសន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្ម នឹងសង្ឃ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមអព្ភានកម្មនឹងសង្ឃ ជាគំរប់ពីរដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ខ្ញុំនោះ បានសូមឯកាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ខ្ញុំនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ បានសន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្ម នឹងសង្ឃ ជាគំរប់បីដងផង។

[៣៩១] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្សៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ បានមកសូមឯកាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃហើយ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្មនឹងសង្ឃ។ បើកម្មមានកាលដ៏សមគួរ ដល់សង្ឃហើយ សង្ឃគួរឲ្យអព្ភានកម្ម ចំពោះឧទាយិភិក្ខុចុះ។ នេះជាពាក្យផ្សៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមឯកាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ បានមកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃហើយ។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្មនឹងសង្ឃ។ សង្ឃក៏ធ្វើអព្ភានកម្ម ចំពោះឧទាយិភិក្ខុ។ អព្ភានកម្ម របស់ឧទាយិភិក្ខុ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមឯកាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យឯកាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃហើយ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ បានមកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃ។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១ថ្ងៃហើយ។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្មនឹងសង្ឃ។ សង្ឃក៏ធ្វើអព្ភានកម្ម ចំពោះឧទាយិភិក្ខុ។ អព្ភានកម្ម របស់ឧទាយិភិក្ខុ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃបានធ្វើអព្ភានកម្ម ដល់ឧទាយិភិក្ខុហើយ ការធ្វើអព្ភានកម្ម គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំសូមចាំសេចក្ដីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (បញ្ចាហប្បដិច្ឆន្នបរិវាស)

CS vin.cv.03.01.06 | ភាគ ទី៩

### (បញ្ចាហប្បដិច្ឆន្នបរិវាសោ)

[៣៩២] សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក២ថ្ងៃ បិទបាំងទុក៣ថ្ងៃ បិទបាំងទុក៤ថ្ងៃ បិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ ក៏ប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក២ថ្ងៃ បិទបាំងទុក៣ថ្ងៃ បិទបាំងទុក៤ថ្ងៃ បិទបាំងទុក៥ថ្ងៃហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្ដេចទៅ។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្ដីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យបញ្ចាហបរិវាស (បរិវាស៥ថ្ងៃ) ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបានបិទបាំងទុក៥ថ្ងៃចុះ។

[៣៩៣] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ចលីឡើង ហើយពោលយ៉ាងនេះ (នឹងសង្ឃ)ថា បពិត្រព្រះសង្ឃដ៏ចំរើន

ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ មកសូមបញ្ញាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៣៩៤] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានមកសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានមកសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏ឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ការឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានមកសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃក៏ឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ការឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ បញ្ញាហបរិវាស សង្ឃបានឲ្យ ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃហើយ ការឲ្យបញ្ញាហបរិវាសនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (បារិវាសិកមូលាយបដិកស្សនា)

CS vin.cv.03.01.07 | ភាគ ទី៩

### (បារិវាសិកមូលាយបដិកស្សនា)

[៣៩៥] ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ។ ឧទាយិភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ (អាបត្តិដើម) ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកចុះ។

[៣៩៦] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិហើយ តែមិនបានបិទបាំងទុកទេ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៣៩៧] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបិទបាំងទុកទេ ទើបឧទាយិភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ នេះជាពាក្យផ្តៀងសង្ឃឲ្យដឹង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឧទាយិភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឥឡូវ សង្ឃទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ការទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុ

អង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ចាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ចាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបានបិទបាំងទុកទេ ឧទាយិភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ ឥឡូវ សង្ឃទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ ការទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ឧទាយិភិក្ខុ សង្ឃបានទាញមកដាក់ ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុកហើយ ការទាញនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (មានត្តារហមូលាយបដិកស្សនា)

CS vin.cv.03.01.08 | ភាគ ទី៩

### (មានត្តារហមូលាយបដិកស្សនា)

[៣៩៨] ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបានបិទបាំងទុកទេ។ ឧទាយិភិក្ខុនោះ ក៏បានប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមបញ្ចាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃក៏បានឲ្យបញ្ចាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបានបិទបាំងទុក ខ្ញុំនោះ សូមការទាញមកដាក់ ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក ខ្ញុំនោះបាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបានបិទបាំងទុក តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៅទៀត។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុកចុះ។

[៣៩៩] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយសំពះបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមបញ្ចាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ចាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ សូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ ខ្ញុំនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបានបិទបាំងទុកទេ បពិត្រព្រះសង្ឃដ៏ចំរើន ឥឡូវ ខ្ញុំនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤០០] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ចាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ចាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបិទបាំងទុកទេ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបានបិទបាំងទុក ឥឡូវ ឧទាយិភិក្ខុនោះ មកសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ចាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ចាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញ ឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរ

ដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឥឡូវ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឥឡូវ សង្ឃក៏ទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ការទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានទាញ ឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកហើយ ការទាញនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (តិកាបត្តិមានត្តៈ)

CS vin.cv.03.01.09 | ភាគ ទី៩

### (តិកាបត្តិមានត្តំ)

[៤០១] ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ក៏ប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមបញ្ញាហបរិវាស នឹងសង្ឃ ចំពោះត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ខ្ញុំ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក សង្ឃក៏ទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ខ្ញុំនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ខ្ញុំនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ខ្ញុំនោះ បាននៅបរិវាសរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចតទៅទៀត។ ភិក្ខុទាំងនោះ បាននាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ចុះ។

[៤០២] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឲ្យឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។ ខ្ញុំនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឥឡូវ ខ្ញុំនោះបានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ខ្ញុំនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះបាននៅបរិវាសរួចហើយ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិទាំង៣។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤០៣] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឥឡូវ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឥឡូវ ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ឥឡូវ សូមមានត្ត៦រាត្រី នឹងសង្ឃចំពោះអាបត្តិទាំង៣។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរឲ្យមានត្ត៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឥឡូវ ឧទាយិភិក្ខុនោះ ក៏បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញ ឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិ

ភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ឥឡូវ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃបានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ឥឡូវ មកសូមមានត្ត៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិទាំង៣ សង្ឃក៏ឲ្យមានត្ត៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣។ ការឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។ បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ហើយ ការឲ្យនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំរឿងនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (មានត្តចារិកមូលាយបដិកស្សនា)

CS vin.cv.03.01.10 | ភាគ ទី៩

### (មានត្តចារិកមូលាយបដិកស្សនា)

[៤០៤] ឧទាយិភិក្ខុនោះ កំពុងតែប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ។ ឧទាយិភិក្ខុនោះ ក៏ប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមបញ្ញាហបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក សង្ឃក៏ទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ខ្ញុំនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ហើយខ្ញុំនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិទាំង៣ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិទាំង៣ ខ្ញុំនោះ កំពុងតែប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចតទៅទៀត។ ភិក្ខុទាំងនោះ បាននាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរទាញ ឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ហើយសឹមឲ្យមានត្ត ៦រាត្រីទៅចុះ។

[៤០៥] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញឧទាយិភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ ក៏បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះបានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ខ្ញុំនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ខ្ញុំនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិទាំង៣។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិទាំង៣។ ខ្ញុំនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ បពិត្រព្រះសង្ឃដ៏ចំរើន ឥឡូវ ខ្ញុំនោះ សូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤០៦] ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកឡើយ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកឡើយ ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិទាំង៣។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣។ ឧទាយិភិក្ខុនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកឡើយ ឥឡូវ ឧទាយិ

ភិក្ខុនោះ សូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកឡើយ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញ ឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួច ហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកឡើយ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួច ហើយ សូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិទាំង៣។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ ឧទាយិភិក្ខុនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកឡើយ ឧទាយិភិក្ខុនោះ ក៏សូមការទាញមក ដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឥឡូវ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ការទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ការទាញនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

[៤០៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យមានត្ត៦រាត្រីយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។បេ។ ខ្ញុំនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិទាំង៣ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិទាំង៣។ ខ្ញុំនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បពិត្រព្រះសង្ឃដ៏ចំរើន ឥឡូវ ខ្ញុំនោះ សូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤០៨] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។បេ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិទាំង៣។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣។ ឧទាយិភិក្ខុនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកឡើយ ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឥឡូវ ឧទាយិភិក្ខុនោះ សូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។បេ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រី ចំពោះអាបត្តិទាំង៣។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣។ ឧទាយិភិក្ខុនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកឡើយ ឧទាយិភិក្ខុនោះ ក៏បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឥឡូវ ឧទាយិភិក្ខុនោះ សូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏ឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ការឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គួរពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ មានត្ត ៦រាត្រី សង្ឃបានឲ្យដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកហើយ ការឲ្យមានត្តនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

**(អព្ភានារហមូលាយបដិកស្សនា)**

### (អព្ភានារហមូលាយបដិកស្សនា)

[៤០៩] ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ។ ឧទាយិភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។បេ។ ខ្ញុំនោះ សន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងនោះ បាននាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ហើយសិមឲ្យមានត្ត ៦រាត្រីចុះ។

[៤១០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តយ៉ាងនេះ។បេ។

[៤១១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យមានត្ត ៦រាត្រី យ៉ាងនេះ។បេ។ ឲ្យ។បេ។ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុកហើយ ការឲ្យមានត្តនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (មូលាយបដិកស្សិតអព្ភានៈ)

CS vin.cv.03.01.12 | ភាគ ទី៩

### (មូលាយបដិកស្សិតអព្ភានំ)

[៤១២] ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ក៏ប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។បេ។ ខ្ញុំនោះ សន្សំមានត្តរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច តទៅទៀត។ ភិក្ខុទាំងនោះ បាននាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើអព្ភានកម្ម ដល់ឧទាយិភិក្ខុចុះ។

[៤១៣] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវធ្វើអព្ភានកម្មយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង រួចសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ សូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃបានឲ្យបញ្ញាហបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃបានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ខ្ញុំនោះ នៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះបានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃបានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ខ្ញុំនោះ នៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិទាំង៣។ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិទាំង៣។ ខ្ញុំនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃបានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ខ្ញុំនោះ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក ខ្ញុំនោះ សន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុកទេ ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃបានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ខ្ញុំនោះ បានសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ សន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្មនឹងសង្ឃ។ (ឧទាយិភិក្ខុនោះ) ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤១៤] ត្រូវភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមបញ្ញាហបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យបញ្ញាហបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ

បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិទាំង៣។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣។ ឧទាយិភិក្ខុនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រីដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ តែមិនបានបិទបាំងទុក ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បានសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រីដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលមិនបានបិទបាំងទុក។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្មនឹងសង្ឃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីធ្វើអព្ភានកម្ម ដល់ឧទាយិភិក្ខុចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។បេ។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ឥឡូវមកសូមអព្ភានកម្មនឹងសង្ឃ។ សង្ឃក៏ធ្វើអព្ភានកម្ម ដល់ឧទាយិភិក្ខុ។ អព្ភានកម្មរបស់ឧទាយិភិក្ខុ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ ឧទាយិភិក្ខុ សង្ឃបានធ្វើអព្ភានកម្មរួចហើយ អព្ភានកម្មនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំរឿងនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (បក្ខប្បដិច្ឆន្នបរិវាស)

CS vin.cv.03.01.13 | ភាគ ទី៩

### (បក្ខប្បដិច្ឆន្នបរិវាសោ)

[៤១៥] សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ (កន្លះខែ)។ ឧទាយិភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច។ ពួកភិក្ខុនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃឲ្យបក្ខបរិវាស (បរិវាសកន្លះខែ) ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។

[៤១៦] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ សូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ ត្រូវឧទាយិភិក្ខុនោះ សូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤១៧] ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ឧទាយិភិក្ខុនោះ មកសូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ឧទាយិភិក្ខុនោះ មកសូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ សង្ឃក៏ឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ ការឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខហើយ ការឲ្យបក្ខបរិវាសនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (បក្ខបារិវាសិកមូលាយបដិកស្សនា)

CS vin.cv.03.01.14 | ភាគ ទី៩

### (បក្ខបារិវាសិកមូលាយបដិកស្សនា)

[៤១៨] ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានប្រាប់ដល់ពួកភិក្ខុថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ខ្ញុំនោះ សូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ សង្ឃឲ្យបក្ខបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរ

សង្ឃទាញ ឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ហើយសឹមឲ្យសមោធានបរិវាស (បរិវាសដែលប្រជុំអាបត្តិ) ចំពោះអាបត្តិខាងដើមចុះ។

[៤១៩] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ខ្ញុំនោះ សូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ សង្ឃឲ្យបក្ខបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ សូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ត្រូវឧទាយិភិក្ខុសូមជាគំរប់ពីរដងផង សូមជាគំរប់បីដងផង។

[៤២០] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្សៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ឧទាយិភិក្ខុនោះ បានសូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ សង្ឃក៏បានឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ សូមការទាញមកដាក់មូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ នេះជាពាក្យផ្សៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ឧទាយិភិក្ខុនោះ បានសូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ សង្ឃក៏បានឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឥឡូវ ឧទាយិភិក្ខុនោះ សូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ការទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃហើយ ការទាញនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (សមោធានបរិវាស)

CS vin.cv.03.01.15 | ភាគ ទី៩

### (សមោធានបរិវាសោ)

[៤២១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសមោធានបរិវាស ចំពោះអាបត្តិមុន យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ខ្ញុំនោះ សូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ សង្ឃឲ្យបក្ខបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ សូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃទាញខ្ញុំនោះមកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ មកសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ ឧទាយិភិក្ខុគប្បីសូមជាគំរប់ពីរដងផង គប្បីសូមជាគំរប់បីដងផង។

[៤២២] ភិក្ខុអ្នកឆ្លាស ប្រតិពល គប្បីផ្សៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ឧទាយិភិក្ខុនោះ បានសូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ សង្ឃក៏បានឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ សូមការទាញមកដាក់មូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានទាញឧទាយិភិក្ខុមកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ មកសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ នេះជាពាក្យផ្សៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ឧទាយិភិក្ខុនោះ បានសូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ សង្ឃក៏បានឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។

ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ មកសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ ការឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម ការឲ្យនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (មានត្តារហមូលាយបដិកស្សនាទិ)

CS vin.cv.03.01.16 | ភាគ ទី៩

### (មានត្តារហមូលាយបដិកស្សនាទិ)

[៤២៣] ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។បេ។ ខ្ញុំនោះ នៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ហើយសឹមឲ្យសមោធានបរិវាស ចំពោះអាបត្តិខាងដើមចុះ។

[៤២៤] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញមកដាក់ក្នុងមូលាបត្តិ យ៉ាងនេះ។បេ។

[៤២៥] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសមោធានបរិវាស ចំពោះអាបត្តិខាងដើម យ៉ាងនេះ។បេ។ សង្ឃឲ្យ។បេ។ សង្ឃបានឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម ការឲ្យសមោធានបរិវាសនោះ គាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (តិកាបត្តិមានត្តៈ)

CS vin.cv.03.01.17 | ភាគ ទី៩

### (តិកាបត្តិមានត្តំ)

[៤២៦] ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ក៏ប្រាប់ដល់ពួកភិក្ខុថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។បេ។ ខ្ញុំបាននៅបរិវាសរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ចុះ។

[៤២៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ បាននៅបរិវាសរួចហើយ ឥឡូវ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិទាំង៣។ ឧទាយិភិក្ខុនោះ ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤២៨] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។បេ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ឥឡូវ មកសូមមានត្ត ៦រាត្រី នឹងសង្ឃ ចំពោះអាបត្តិទាំង៣។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។បេ។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ មកសូមមានត្ត ៦រាត្រីនឹងសង្ឃ ចំពោះអាបត្តិទាំង៣។ សង្ឃក៏ឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣។ ការឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣ហើយ ការឲ្យមានត្តនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (មានត្តចារិកមូលាយបដិកស្សនាទិ)

### (មានត្តចារិកមូលាយបដិកស្សនាទិ)

[៤២៩] ឧទាយិភិក្ខុនោះកំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។បេ។ ខ្ញុំនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ហើយឲ្យសមោធានបរិវាស ចំពោះអាបត្តិខាងដើម ហើយសឹមឲ្យមានត្ត ៦រាត្រីចុះ។

[៤៣០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញមកដាក់ក្នុងមូលាបត្តិយ៉ាងនេះ។បេ។

[៤៣១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសមោធានបរិវាស ចំពោះអាបត្តិខាងដើម យ៉ាងនេះ។បេ។

[៤៣២] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យមានត្ត ៦រាត្រី យ៉ាងនេះ។បេ។ សង្ឃឲ្យ។បេ។ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ការឲ្យមានត្តនោះ គាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំរឿងនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (អព្ភានារហមូលាយបដិកស្សនាទិ)



### (អព្ភានារហមូលាយបដិកស្សនាទិ)

[៤៣៣] ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។បេ។ ខ្ញុំនោះ សន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ហើយឲ្យសមោធានបរិវាស ចំពោះអាបត្តិខាងដើម ហើយសឹមឲ្យមានត្ត ៦រាត្រីចុះ។

[៤៣៤] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវទាញមកដាក់ក្នុងមូលាបត្តិយ៉ាងនេះ។បេ។

[៤៣៥] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសមោធានបរិវាស ចំពោះអាបត្តិខាងដើម យ៉ាងនេះ។បេ។

[៤៣៦] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យមានត្ត ៦រាត្រី យ៉ាងនេះ។បេ។ ឲ្យ។បេ។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ការឲ្យមានត្តនោះ គាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

[៤៣៧] ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ ក៏ប្រាប់ដល់ពួកភិក្ខុថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។បេ។ ខ្ញុំនោះ សន្សំមានត្តរួចហើយ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៀត។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរសង្ឃធ្វើអព្ភានកម្ម ដល់ឧទាយិភិក្ខុចុះ។

## (បក្ខប្បដិច្ឆន្នអព្ភានៈ)



### (បក្ខប្បដិច្ឆន្នអព្ភានំ)

[៤៣៨] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យអព្ភានកម្មយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឧទាយិភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ខ្ញុំនោះ សូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ សង្ឃក៏បានឲ្យបក្ខបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ ខ្ញុំនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃក៏បានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម ខ្ញុំនោះបាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុង

ចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃបានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះបានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិ១ខាងដើម សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម ខ្ញុំនោះបាននៅបរិវាសរួចហើយ ក៏សូមមានត្ត ៦រាត្រី នឹងសង្ឃទៀត ចំពោះអាបត្តិទាំង៣ ខ្ញុំនោះកំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃបានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ខ្ញុំចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម ខ្ញុំនោះនៅបរិវាសរួចហើយ បានសូមមានត្ត៦រាត្រីនឹងសង្ឃទៀត ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំបានសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃបានទាញខ្ញុំនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ ខ្ញុំនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម សង្ឃបានឲ្យសមោធានបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម ខ្ញុំនោះ បាននៅបរិវាសរួចហើយ បានសូមមានត្ត ៦រាត្រី នឹងសង្ឃទៀត ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ សង្ឃបានឲ្យមានត្ត ៦រាត្រី ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះបានសន្សំមានត្តរួចហើយ ឥឡូវ មកសូមអព្ភានកម្មនឹងសង្ឃ។ ឧទាយិភិក្ខុ ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤៣៩] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ ឧទាយិភិក្ខុនោះ បានសូមបក្ខបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ សង្ឃក៏បានឲ្យបក្ខបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក១បក្ខ។ ឧទាយិភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ គួរដល់មានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមការទាញមកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏ទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ក៏សូមមានត្ត ៦រាត្រី នឹងសង្ឃទៀត ចំពោះអាបត្តិទាំង៣។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិទាំង៣។ ឧទាយិភិក្ខុនោះ កំពុងប្រព្រឹត្តមានត្ត ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានទាញឧទាយិភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ក៏បានសូមមានត្ត ៦រាត្រី នឹងសង្ឃទៀត ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានសន្សំមានត្តរួចហើយ គួរដល់អព្ភានកម្ម ក៏ត្រូវអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក៥ថ្ងៃ ឧទាយិភិក្ខុនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានទាញឧទាយិភិក្ខុ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ សង្ឃក៏បានឲ្យសមោធានបរិវាស ដល់ឧទាយិភិក្ខុនោះ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ និងចំពោះអាបត្តិខាងដើម។ ឧទាយិភិក្ខុនោះ បាននៅបរិវាសរួចហើយ ក៏បានសូមមានត្ត ៦រាត្រី នឹងសង្ឃទៀត ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ សង្ឃក៏បានឲ្យមានត្ត ៦រាត្រី ដល់ឧទាយិភិក្ខុ ចំពោះអាបត្តិ១ ក្នុងចន្លោះ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក៥ថ្ងៃ។ ឧទាយិភិក្ខុនោះ បានប្រព្រឹត្តមានត្តរួចហើយ មកសូមអព្ភានកម្មនឹងសង្ឃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវឲ្យអព្ភានកម្ម ដល់ឧទាយិភិក្ខុ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧទាយិភិក្ខុនេះ ត្រូវអាបត្តិ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ហើយបិទបាំងទុក១បក្ខ។បេ។ ឧទាយិភិក្ខុនោះ បានប្រព្រឹត្តមានត្តរួចហើយ មកសូមអព្ភានកម្មនឹងសង្ឃ។ សង្ឃក៏បានឲ្យអព្ភានកម្ម ដល់ឧទាយិ

ភិក្ខុ។ អញ្ញត្តិកម្ម របស់ឧទាយិភិក្ខុ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានឲ្យអញ្ញត្តិកម្ម ដល់ឧទាយិភិក្ខុ អញ្ញត្តិកម្មនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្ដីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ អំពើដែលធ្វើទឹកសុក្កឲ្យឃ្លាតចេញ។

# (បរិវាស ទី២)

CS vin.cv.03.02 | ភាគ ទី៩

### (២. បរិវាសោ)

## (អគ្ឃសមោធានបរិវាស)

CS vin.cv.03.02.01 | ភាគ ទី៩

### (អគ្ឃសមោធានបរិវាសោ)

[៤៤០] សម័យនោះឯង ភិក្ខុ១រូប ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ អាបត្តិ១ បិទបាំងទុក២ថ្ងៃ អាបត្តិ១ បិទបាំងទុក៣ថ្ងៃ អាបត្តិ១ បិទបាំងទុក៤ថ្ងៃ អាបត្តិ១ បិទបាំងទុក៥ថ្ងៃ អាបត្តិ១ បិទបាំងទុក៦ថ្ងៃ អាបត្តិ១ បិទបាំងទុក៧ថ្ងៃ អាបត្តិ១ បិទបាំងទុក៨ថ្ងៃ អាបត្តិ១ បិទបាំងទុក៩ថ្ងៃ អាបត្តិ១ បិទបាំងទុក១០ថ្ងៃ។ ភិក្ខុនោះ បានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ។បេ។ អាបត្តិ១ បិទបាំងទុក១០ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្ដេច។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្ដីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលភិក្ខុនោះបិទបាំងទុក១០ថ្ងៃ សង្ឃចូរឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ តាមដម្លៃ[40] អាបត្តិនោះ។

[៤៤១] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទាពួកភិក្ខុចាស់ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបានត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ។បេ។ អាបត្តិ១ បិទបាំងទុក១០ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលបិទបាំងទុក១០ថ្ងៃ ខ្ញុំសូមសមោធានបរិវាស នឹងសង្ឃ តាមដម្លៃអាបត្តិនោះ។ ភិក្ខុនោះ ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤៤២] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ។បេ។ អាបត្តិ១ បិទបាំងទុក១០ថ្ងៃ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលបិទបាំងទុក១០ថ្ងៃ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ តាមដម្លៃអាបត្តិនោះ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលបិទបាំងទុក១០ថ្ងៃ សង្ឃត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ តាមដម្លៃអាបត្តិនោះចុះ។ នេះជាពាក្យផ្ទៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ។បេ។ អាបត្តិ១ បិទបាំងទុក១០ថ្ងៃ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលបិទបាំងទុក១០ថ្ងៃ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ តាមដម្លៃអាបត្តិនោះ។ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលបិទបាំងទុក១០ថ្ងៃ សង្ឃឲ្យសមោធានបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ តាមដម្លៃអាបត្តិនោះ។ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលបិទបាំងទុក១០ថ្ងៃ ការឲ្យសមោធានបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ តាមដម្លៃអាបត្តិនោះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់បីដងផង។បេ។ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលបិទបាំងទុក១០ថ្ងៃ សង្ឃបានឲ្យសមោធានបរិវាស ដល់ភិក្ខុ ឈ្មោះដូច្នេះ តាមដម្លៃអាបត្តិនោះហើយ ការឲ្យសមោធានបរិវាសនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្ដីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (សព្វចិរប្បដិច្ឆន្នអគ្ឃសមោធានៈ)

CS vin.cv.03.02.02 | ភាគ ទី៩

### (សព្ពចិរប្បដិច្ឆន្នអគ្ឃសមោធានំ)

[៤៤៣] សម័យនោះឯង ភិក្ខុ១រូប ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ អាបត្តិ២ បិទបាំងទុក២ថ្ងៃ អាបត្តិ៣ បិទបាំងទុក៣ថ្ងៃ អាបត្តិ៤ បិទបាំងទុក៤ថ្ងៃ អាបត្តិ៥ បិទបាំងទុក៥ថ្ងៃ អាបត្តិ៦ បិទបាំងទុក៦ថ្ងៃ អាបត្តិ៧ បិទបាំងទុក៧ថ្ងៃ អាបត្តិ៨ បិទបាំងទុក៨ថ្ងៃ អាបត្តិ៩ បិទបាំងទុក៩ថ្ងៃ អាបត្តិ១០ បិទបាំងទុក១០ថ្ងៃ។ ភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ។បេ។ អាបត្តិ១០ បិទបាំងទុក១០ថ្ងៃ តើខ្ញុំត្រូវប្រតិបត្តិដូចម្ដេច។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្ដីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលបិទបាំងទុកយូរជាងអាបត្តិទាំងអស់ សង្ឃចូរឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ តាមដម្លៃអាបត្តិទាំងនោះចុះ។

[៤៤៤] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង។បេ។ រួចពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ។បេ។ អាបត្តិ១០ បិទបាំងទុក១០ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលខ្ញុំបិទបាំងទុកយូរជាងអាបត្តិទាំងអស់ ខ្ញុំសូមសមោធានបរិវាស នឹងសង្ឃ តាមដម្លៃអាបត្តិទាំងនោះ។ ភិក្ខុនោះ ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤៤៥] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ។បេ។ អាបត្តិ១០ បិទបាំងទុក១០ថ្ងៃ បណ្ដាអាបត្តិទាំងនោះ អាបត្តិទាំងឡាយឯណា ដែលបិទបាំងទុកយូរជាងអាបត្តិទាំងអស់ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ តាមដម្លៃអាបត្តិទាំងនោះ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ បណ្ដាអាបត្តិទាំងនោះ អាបត្តិណា ដែលភិក្ខុនោះបិទបាំងទុកយូរជាងអាបត្តិទាំងអស់ សង្ឃត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ តាមដម្លៃអាបត្តិទាំងនោះចុះ។ នេះជាពាក្យផ្ទៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិ១ បិទបាំងទុក១ថ្ងៃ។បេ។ អាបត្តិ១០ បិទបាំងទុក១០ថ្ងៃ បណ្ដាអាបត្តិទាំងនោះ ពួកអាបត្តិណា ដែលភិក្ខុនោះបិទបាំងទុកយូរជាងអាបត្តិទាំងអស់ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ តាមដម្លៃអាបត្តិទាំងនោះ។ បណ្ដាអាបត្តិទាំងនោះ ពួកអាបត្តិណា ដែលភិក្ខុនោះបិទបាំងទុកយូរជាងអាបត្តិទាំងអស់ សង្ឃឲ្យសមោធានបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ តាមដម្លៃអាបត្តិទាំងនោះ។ បណ្ដាអាបត្តិទាំងនោះ ពួកអាបត្តិណា ដែលភិក្ខុនោះបិទបាំងទុកយូរជាងអាបត្តិទាំងអស់ ការឲ្យសមោធានបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ តាមដម្លៃអាបត្តិទាំងនោះ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់បីដងផង។បេ។ បណ្ដាអាបត្តិទាំងនោះ ពួកអាបត្តិណា ដែលភិក្ខុនោះ បិទបាំងទុកយូរជាងអាបត្តិទាំងអស់ សង្ឃបានឲ្យសមោធានបរិវាស ដល់ភិក្ខុ ឈ្មោះដូច្នេះ តាមដម្លៃអាបត្តិទាំងនោះ ការឲ្យសមោធានបរិវាសនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្ដីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

## (ទ្វេមាសបរិវាស)

CS vin.cv.03.02.03 | ភាគ ទី៩

### (ទ្វេមាសបរិវាសោ)

[៤៤៦] សម័យនោះឯង ភិក្ខុ១រូបត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ ដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស (បរិវាស២ខែ) នឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ុប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ ហើយអាត្មាអញ ក៏បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់អាត្មាអញ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែហើយ កាលបើអាត្មាអញ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ ខ្ញុំនោះ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែហើយ ខ្ញុំនោះ ក៏បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ កាលដែលខ្ញុំនោះ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ុប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ ខ្ញុំនោះ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ កាលខ្ញុំនោះ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ តើខ្ញុំត្រូវប្រតិបត្តិដូចម្ដេច។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្ដីនុ៎ះ ក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែចុះ។

[៤៤៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង។បេ។ រួចពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ ខ្ញុំនោះ ក៏មានសេចក្ដីត្រិះរិះ ដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ ខ្ញុំនោះ ក៏បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ កាលដែលខ្ញុំនោះ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ុប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ ខ្ញុំនោះ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ ខ្ញុំក៏បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ខ្ញុំ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ កាលដែលខ្ញុំកំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំង

ទុក២ខែ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤៤៨] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ ដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ កាលដែលភិក្ខុនោះ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ អាត្មាអញ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់អាត្មាអញ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ កាលដែលអាត្មាអញ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវឲ្យទ្វេមាសបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ នេះជាពាក្យផ្ទៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃា២ ហើយបិទបាំងទុក២ខែ។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះ ដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ ឥឡូវ ភិក្ខុនោះ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ កាលដែលភិក្ខុនោះ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ អាត្មាអញ ក៏បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់អាត្មាអញ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ កាលដែលអាត្មាអញ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ឥឡូវ ភិក្ខុនោះ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ការឲ្យទ្វេមាសបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ គាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្ដីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែហើយ ការឲ្យនោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្ដីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ព្រោះអាស្រ័យអាបត្តិនោះ។

## (ទ្វេ មាសា បរិវសិតព្វវិធិ)

CS vin.cv.03.02.04 | ភាគ ទី៩

## (ទ្វេ មាសា បរិវសិតព្វវិធិ)

[៤៤៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ។ កាលដែលភិក្ខុនោះ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញនោះ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ អាត្មាអញនោះ ក៏បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិ១ ដែលបិទបាំងទុក២ខែ កាលដែលអាត្មាអញនោះ កំពុងនៅបរិវាស ក៏មានសេចក្ដីខ្មាសបាបចុះស៊ប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ព្រោះអាស្រ័យអាបត្តិនោះ។

[៤៥០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ (ភិក្ខុនោះ) ដឹងអាបត្តិ១ មិនដឹងអាបត្តិ១។ ភិក្ខុនោះដឹងអាបត្តិណា ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែដឹងអាបត្តិ១ទៀត។ ភិក្ខុនោះ មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែបានដឹងអាបត្តិ១ មិនបានដឹងអាបត្តិ១ អាត្មាអញនោះ ដឹងអាបត្តិណា ក៏បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែហើយ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ស្រាប់តែដឹងអាបត្តិ១ទៀត បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ សង្ឃ

ក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ព្រោះអាស្រ័យអាបត្តិនោះ។

[៤៥១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ (ភិក្ខុនោះ) រលឹកបានតែអាបត្តិ១ អាបត្តិ១ទៀត រលឹកមិនបាន។ ភិក្ខុនោះ រលឹកបានអាបត្តិណា ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែរលឹកឃើញអាបត្តិ១ទៀត។ ភិក្ខុនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញ រលឹកបានតែអាបត្តិ១ អាបត្តិ១ទៀត រលឹកមិនបាន អាត្មាអញនោះ រលឹកបានអាបត្តិណា ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិនោះ បិទបាំងទុក២ខែ។ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ស្រាប់តែរលឹកឃើញអាបត្តិ១ទៀត បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ព្រោះអាស្រ័យអាបត្តិនោះ។

[៤៥២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាបត្តិ១ឥតមានសង្ស័យទេ សង្ស័យតែក្នុងអាបត្តិ១។ ភិក្ខុនោះ ឥតមានសង្ស័យក្នុងអាបត្តិណា ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែអស់សេចក្តីសង្ស័យក្នុងអាបត្តិ១ទៀត។ ភិក្ខុនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាបត្តិ១ ឥតមានសង្ស័យទេ សង្ស័យតែក្នុងអាបត្តិ១ អាត្មាអញ ឥតមានសេចក្តីសង្ស័យ ក្នុងអាបត្តិណា ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ស្រាប់តែអស់សេចក្តីសង្ស័យ ក្នុងអាបត្តិ១ទៀត បើដូច្នោះ មានតែអាត្មាអញ សូមទ្វេមាសបរិវាស នឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ១ទៀត ដែលបិទបាំងទុក២ខែ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ព្រោះអាស្រ័យអាបត្តិនោះ។

[៤៥៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាបត្តិ១ ភិក្ខុដឹងហើយ បិទបាំងទុក អាបត្តិ១ ភិក្ខុមិនដឹង ហើយបិទបាំងទុក។ ភិក្ខុនោះ ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែមានភិក្ខុដទៃ ជាពហុស្សុត ចេះចាំគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត វាងវៃ មានប្រាជ្ញា មានសេចក្តីខ្មាសបាប ជាអ្នកមានសេចក្តីរអែង និងមានសេចក្តីប្រាថ្នានូវសិក្ខា បានមកដល់។ ភិក្ខុនោះ ក៏សួរយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិអ្វី នៅបរិវាស ចំពោះអាបត្តិអ្វី។ ពួកភិក្ខុនោះ ពោលយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែអាបត្តិ១ ភិក្ខុនោះដឹង ហើយបិទបាំងទុក អាបត្តិ១ ភិក្ខុនោះ មិនដឹង ហើយបិទបាំងទុក ភិក្ខុនោះ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ ដែលបិទបាំងទុក២ខែ ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិទាំងនោះ ឥឡូវ ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ ពោលយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិណា ដែលភិក្ខុនោះដឹង ហើយបិទបាំងទុក ការឲ្យបរិវាស ចំពោះអាបត្តិនោះ ឈ្មោះថាប្រកបដោយធម៌ ដុះឡើងតាមសភាវធម៌ ម្នាលអាវុសោ ម្យ៉ាងទៀត អាបត្តិណា ដែលភិក្ខុមិនដឹង ហើយបិទបាំងទុក ការឲ្យបរិវាស ចំពោះអាបត្តិនោះ ឈ្មោះថា មិនប្រកបដោយធម៌ មិនបានដុះឡើង ព្រោះមិនត្រូវតាមសភាវធម៌ ម្នាលអាវុសោ ភិក្ខុគួរដល់មានត្ត ចំពោះអាបត្តិនេះឯង។

[៤៥៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាបត្តិ១ ភិក្ខុរលឹកបាន ហើយបិទបាំងទុក អាបត្តិ១ ភិក្ខុរលឹកមិនបាន ហើយបិទបាំងទុក។ ភិក្ខុនោះ ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិនោះ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែមានភិក្ខុដទៃ ជាពហុស្សុត ចេះចាំគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត វាងវៃ មានប្រាជ្ញា ជាអ្នកមានសេចក្តីខ្មាសបាប ជាអ្នកមានសេចក្តីរអែង និងមានសេចក្តីប្រាថ្នានូវសិក្ខា បានមកដល់។ ភិក្ខុនោះ សួរយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិអ្វី ភិក្ខុនោះ នៅបរិវាស ចំពោះអាបត្តិអ្វី។ ពួកភិក្ខុនោះ ពោលយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាបត្តិ១ ភិក្ខុនោះរលឹកបាន ហើយបិទបាំងទុក អាបត្តិ១ ភិក្ខុនោះ រលឹកមិនបាន ហើយបិទបាំងទុក ភិក្ខុនោះ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ ដែលបិទបាំងទុក២ខែ ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិទាំងនោះ ឥឡូវ ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ ពោលយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិណា ដែលភិក្ខុរលឹកបាន ហើយបិទបាំងទុក ការឲ្យបរិវាស ចំពោះអាបត្តិនោះ ឈ្មោះថា ប្រកបដោយធម៌ ដុះឡើងតាមសភាវធម៌ ម្នាលអាវុសោ ម្យ៉ាងទៀត អាបត្តិណា ដែលភិក្ខុរលឹកមិនបាន ហើយបិទបាំងទុក ការឲ្យបរិវាស ចំពោះអាបត្តិនោះ ឈ្មោះថា មិនប្រកបដោយធម៌ មិនដុះឡើង ព្រោះមិនត្រូវតាមសភាវធម៌ ម្នាលអាវុសោ ភិក្ខុគួរដល់មានត្ត ចំពោះអាបត្តិនេះឯង។

[៤៥៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាបត្តិ១ ភិក្ខុឥតមានសេចក្តីសង្ស័យ បិទបាំងទុក អាបត្តិ១ ភិក្ខុមានសេចក្តីសង្ស័យ ហើយបិទបាំងទុក។ ឥឡូវ ភិក្ខុនោះ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែមានភិក្ខុដទៃ ជាពហុស្សុត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត វាងវៃ មានប្រាជ្ញា ជាអ្នកមានសេចក្តីខ្មាសបាប ជាអ្នកមានសេចក្តីរអែង នឹងមានសេចក្តីប្រាថ្នានូវសិក្ខា បានមកដល់។ ភិក្ខុនោះ សួរយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិអ្វី ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិអ្វី។ ពួកភិក្ខុនោះ ពោលយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំង

ទុក២ខែ អាបត្តិ១ ភិក្ខុនោះ ឥតមានសេចក្តីសង្ស័យ ហើយបិទបាំងទុក អាបត្តិ១ ភិក្ខុនោះ មានសេចក្តីសង្ស័យ ហើយបិទបាំងទុក ភិក្ខុនោះ សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ ដែលបិទបាំងទុក២ខែ ម្នាលអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិទាំងនោះ ឥឡូវ ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ ពោលយ៉ាងនេះថា ម្នាលអាវុសោ អាបត្តិណា ដែលភិក្ខុគ្មានសេចក្តីសង្ស័យ ហើយបិទបាំងទុក ការឲ្យបរិវាស ចំពោះអាបត្តិនោះ ឈ្មោះថា ប្រកបដោយធម៌ ដុះឡើងតាមសភាវធម៌ ម្នាលអាវុសោ ម្យ៉ាងទៀត អាបត្តិណា ដែលភិក្ខុមានសេចក្តីសង្ស័យ ហើយបិទបាំងទុក ការឲ្យបរិវាស ចំពោះអាបត្តិនោះ ឈ្មោះថា មិនប្រកបដោយធម៌ មិនបានដុះឡើង ព្រោះមិនត្រូវតាមសភាវធម៌ ម្នាលអាវុសោ ភិក្ខុគួរដល់មានត្ត ចំពោះអាបត្តិនេះឯង។

[៤៥៦] សម័យនោះ ភិក្ខុ១រូបត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាស (បរិវាស១ខែ) នឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត)ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ កាលអាត្មាអញនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមមាសបរិវាស១ទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ ខ្ញុំនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ ខ្ញុំនោះ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ ខ្ញុំនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត)ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ ខ្ញុំនោះ បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ កាលខ្ញុំនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមមាសបរិវាស១ទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ តើខ្ញុំត្រូវប្រតិបត្តិដូចម្តេចទៅ។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យមាសបរិវាស១ទៀត ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែចុះ។

[៤៥៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវឲ្យភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ ខ្ញុំនោះ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ ខ្ញុំនោះ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ កាលខ្ញុំនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ ខ្ញុំនោះ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់ខ្ញុំនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ កាលខ្ញុំនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមមាសបរិវាស១ទៀត នឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ បពិត្រព្រះសង្ឃដ៏ចំរើន ឥឡូវខ្ញុំនោះ សូមមាសបរិវាស១ទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤៥៨] ភិក្ខុអ្នកឆ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញនោះ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់អាត្មាអញ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ កាលអាត្មាអញនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមមាសបរិវាស១ទៀត នឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ឥឡូវ ភិក្ខុនោះ មកសូមមាសបរិវាស១ទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យមាសបរិវាស១ទៀត ដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែចុះ។ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃា២ ហើយបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។

សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត) ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ មានតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញនោះ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់អាត្មាអញ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ កាលអាត្មាអញ កំពុងនៅបរិវាស ក៏មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ មានតែអាត្មាអញ សូមមាសបរិវាស១ទៀត នឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ឥឡូវ ភិក្ខុនោះ មកសូមមាសបរិវាស១ទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ឥឡូវ សង្ឃឲ្យមាសបរិវាស១ទៀត ដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ កិរិយាឲ្យមាសបរិវាស១ទៀត ដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គួរស្ងៀម មិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សង្ឃបានឲ្យមាសបរិវាស១ទៀត ដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែហើយ (ការឲ្យមាសបរិវាសនោះ) គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ដោយរាប់យកខែខាងដើមផង។

[៤៥៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ បានត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ គួរតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យឯកមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស មានសេចក្តីខ្មាសបាប ចុះស៊ុប (ក្នុងចិត្ត)ថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ អាត្មាអញនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ បើដូច្នោះ គួរតែអាត្មាអញ សូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញនោះ ក៏បានសូមឯកមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យឯកមាសបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ កាលអាត្មាអញនោះ កំពុងនៅបរិវាស សេចក្តីខ្មាសបាប ក៏ចុះស៊ុប (ក្នុងចិត្ត)ថា បើដូច្នោះ គួរតែអាត្មាអញ សូមមាសបរិវាស១ទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏សូមមាសបរិវាស១ទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យមាសបរិវាស១ទៀត ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ដោយរាប់យកខែខាងដើមផង។

[៤៦០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែភិក្ខុនោះ ដឹង១ខែ មិនដឹង១ខែ។ ភិក្ខុនោះដឹងខែណា ក៏សូមបរិវាសខែនោះ នឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះដឹងខែណា សង្ឃក៏ឲ្យបរិវាសខែនោះ ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែដឹង១ខែទៀត។ ភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែថា បានដឹង១ខែ មិនបានដឹង១ខែ អាត្មាអញនោះ បានដឹងខែណា ក៏សូមបរិវាស១ខែនោះនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញ បានដឹងខែណា សង្ឃបានឲ្យបរិវាស១ខែនោះ ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ស្រាប់តែដឹងខែ១ទៀត បើដូច្នោះ គួរតែអាត្មាអញ សូមមាសបរិវាស១ខែទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏សូមមាសបរិវាស១ទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យមាសបរិវាស១ទៀត ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ដោយរាប់យកខែខាងដើមផង។

[៤៦១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែរលឹកឃើញ១ខែ រលឹកមិនឃើញ១ខែ។ ភិក្ខុនោះរលឹកឃើញខែណា ក៏សូមបរិវាស១ខែនោះ នឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុរលឹកឃើញខែណា សង្ឃក៏ឲ្យបរិវាស១ខែនោះ ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែរលឹកឃើញ១ខែទៀត។ ភិក្ខុនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែបានរលឹកឃើញ១ខែ រលឹកមិនឃើញ១ខែ អាត្មាអញនោះ រលឹកឃើញខែណា ក៏សូមបរិវាស១ខែនោះនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញ រលឹកឃើញខែណា សង្ឃក៏បានឲ្យបរិវាស១ខែនោះ ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ស្រាប់តែរលឹកឃើញខែ១ទៀត បើដូច្នោះ គួរតែអាត្មាអញ សូមបរិវាស១ខែទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏សូមបរិវាស១ខែទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏បានឲ្យបរិវាស១ខែទៀត ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ដោយរាប់យកខែខាងដើមផង។

[៤៦២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែឥតមានសេចក្តីសង្ស័យ១ខែ មានសេចក្តីសង្ស័យ១ខែ។ ភិក្ខុនោះ ឥតមានសេចក្តីសង្ស័យខែណា ក៏សូមបរិវាស១ខែនោះ នឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ឥតមានសេចក្តីសង្ស័យខែណា សង្ឃក៏ឲ្យបរិវាស១ខែនោះ ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែអស់សេចក្តីសង្ស័យក្នុងខែ១ទៀត។ ភិក្ខុនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំង ទុក២ខែ តែឥតមានសេចក្តីសង្ស័យ១ខែ មានសេចក្តីសង្ស័យ១ខែ អាត្មាអញនោះ ឥតមានសេចក្តីសង្ស័យខែណា ក៏សូមបរិវាស១ខែនោះនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញ ឥតមានសេចក្តីសង្ស័យខែណា សង្ឃក៏ឲ្យបរិវាស១ខែនោះ ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ស្រាប់តែអស់សេចក្តីសង្ស័យក្នុងខែ១ទៀត បើដូច្នោះ គួរតែអាត្មាអញ សូមបរិវាស១ខែទៀតនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ភិក្ខុនោះ ក៏សូមបរិវាស១ខែទៀតនឹងសង្ឃ ចំពោះអាបត្តិ

ទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យបរិវាស១ខែទៀត ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ នៅបរិវាស២ខែ ដោយរាប់យកខែខាងដើមផង។

[៤៦៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែខែ១ ភិក្ខុដឹងហើយ បិទបាំងទុកខែ១ទៀត ភិក្ខុមិនដឹង ហើយបិទបាំងទុក។ ភិក្ខុនោះ ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែមានភិក្ខុដទៃ ជាពហុស្សុត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឆ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីខ្មាសបាប មានសេចក្តីរអែង មានការប្រាថ្នានូវសិក្ខា បានមកដល់។ ភិក្ខុនោះសួរយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិអ្វី ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិអ្វី។ ភិក្ខុទាំងនោះ ឆ្លើយយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែខែ១ ភិក្ខុនោះដឹងហើយបិទបាំងទុក ខែ១ទៀត ភិក្ខុនោះ មិនដឹង ហើយបិទបាំងទុក ភិក្ខុនោះ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិទាំងនោះ ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិទាំងនោះ។ ភិក្ខុជាបណ្ឌិតនោះ ក៏ពោលយ៉ាងនេះថា នែអាវុសោ ខែណា ដែលភិក្ខុដឹង ហើយបិទបាំងទុក ការឲ្យបរិវាស១ខែនោះ ឈ្មោះថា ប្រកបដោយធម៌ ក៏ដុះឡើងតាមសភាវធម៌ នែអាវុសោ ម្យ៉ាងទៀត ខែណា ដែលភិក្ខុមិនដឹង ហើយបិទបាំងទុក ការឲ្យបរិវាស១ខែនោះ ឈ្មោះថា មិនប្រកបដោយធម៌ មិនដុះឡើង ព្រោះមិនត្រូវតាមសភាវធម៌ នែអាវុសោ ភិក្ខុគួរដល់មានត្ត តែ១ខែនេះឯង។

[៤៦៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែខែ១ ភិក្ខុនោះរលឹកឃើញ ហើយបិទបាំងទុក ខែ១ទៀត ភិក្ខុនោះ រលឹកមិនឃើញ ហើយបិទបាំងទុក។ ភិក្ខុនោះ ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែមានភិក្ខុដទៃ ជាពហុស្សុត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឆ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីខ្មាសបាប មានសេចក្តីរអែង មានការប្រាថ្នានូវសិក្ខា បានមកដល់។ ភិក្ខុជាបណ្ឌិតនោះ ក៏សួរយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិអ្វី ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិអ្វី។ ភិក្ខុទាំងនោះ ឆ្លើយយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែខែ១ ភិក្ខុនោះរលឹកឃើញ ហើយបិទបាំងទុក ខែ១ទៀត ភិក្ខុនោះ រលឹកមិនឃើញ ហើយបិទបាំងទុក ភិក្ខុនោះ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិទាំងនោះ ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិទាំងនោះ។ ភិក្ខុជាបណ្ឌិតនោះ ក៏ពោលយ៉ាងនេះថា នែអាវុសោ ខែណា ដែលភិក្ខុរលឹកឃើញ ហើយបិទបាំងទុក ការឲ្យបរិវាស១ខែនោះ ឈ្មោះថាប្រកបដោយធម៌ ក៏ដុះឡើងតាមសភាវធម៌ នែអាវុសោ ម្យ៉ាងទៀត ខែណា ដែលភិក្ខុនោះ រលឹកមិនឃើញ ហើយបិទបាំងទុក ការឲ្យបរិវាស១ខែនោះ ឈ្មោះថា មិនប្រកបដោយធម៌ មិនបានដុះឡើង ព្រោះមិនត្រូវតាមសភាវធម៌ នែអាវុសោ ភិក្ខុគួរដល់មានត្ត តែ១ខែនេះឯង។

[៤៦៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែខែ១ ភិក្ខុនោះ ឥតមានសេចក្តីសង្ស័យ ហើយបិទបាំងទុក ខែ១ទៀត ភិក្ខុនោះ មានសេចក្តីសង្ស័យ ហើយបិទបាំងទុក។ ភិក្ខុនោះ ក៏សូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ សង្ឃក៏ឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ។ កាលភិក្ខុនោះ កំពុងនៅបរិវាស ក៏ស្រាប់តែមានភិក្ខុដទៃ ជាពហុស្សុត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឆ្លៀវឆ្លាស មានប្រាជ្ញា មានសេចក្តីខ្មាសបាប មានសេចក្តីរអែង និងមានការប្រាថ្នានូវសិក្ខា បានមកដល់។ ភិក្ខុជាបណ្ឌិតនោះ ក៏សួរយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិអ្វី ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិអ្វី។ ភិក្ខុទាំងនោះ ក៏ឆ្លើយយ៉ាងនេះថា នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិសង្ឃាទិសេស២ ហើយបិទបាំងទុក២ខែ តែខែ១ ភិក្ខុនោះ ឥតមានសេចក្តីសង្ស័យ ហើយបិទបាំងទុក ខែ១ទៀត ភិក្ខុនោះ មានសេចក្តីសង្ស័យ ហើយបិទបាំងទុក ភិក្ខុនោះ បានសូមទ្វេមាសបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ សង្ឃក៏បានឲ្យទ្វេមាសបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំង២ ដែលបិទបាំងទុក២ខែ នែអាវុសោ ភិក្ខុនេះ ត្រូវអាបត្តិទាំងនោះ ភិក្ខុនេះ នៅបរិវាស ចំពោះអាបត្តិទាំងនោះ។ ភិក្ខុជាបណ្ឌិតនោះ ក៏ពោលយ៉ាងនេះថា នែអាវុសោ ខែណា ដែលភិក្ខុនោះ ឥតមានសេចក្តីសង្ស័យ ហើយបិទបាំងទុក ការឲ្យបរិវាស១ខែនោះ ឈ្មោះថា ប្រកបដោយធម៌ ក៏ដុះឡើងតាមសភាវធម៌ នែអាវុសោ ម្យ៉ាងទៀត ខែណា ដែលភិក្ខុនោះ មានសេចក្តីសង្ស័យ ហើយបិទបាំងទុក ការឲ្យបរិវាស១ខែនោះ ឈ្មោះថា មិនប្រកបដោយធម៌ ក៏មិនបានដុះឡើង ព្រោះមិនត្រូវតាមសភាវធម៌ នែអាវុសោ ភិក្ខុគួរដល់មានត្ត តែ១ខែនេះឯង។

## (សុទ្ធន្តបរិវាស)

CS vin.cv.03.02.05 | ភាគ ទី៩

### (សុទ្ធន្តបរិវាសោ)

[៤៦៦] សម័យនោះឯង មានភិក្ខុ១រូប ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន។[41] ភិក្ខុនោះ មិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យ ក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យ ក្នុងទីកំណត់រាត្រី។ ភិក្ខុនោះ បានប្រាប់ដល់ភិក្ខុទាំងឡាយថា នែអាវុសោ ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យ ក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យ ក្នុងទីកំណត់រាត្រី តើខ្ញុំត្រូវប្រតិបត្តិដូចម្តេច។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូល ព្រះដ៏មានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យសុទ្ធន្តបរិវាស[42] (បរិវាស មានសេចក្តីស្អាត ជាទីបំផុត) ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះចុះ។

[៤៦៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនោះ ចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង សំពះបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យ ក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យ ក្នុងទីកំណត់រាត្រី បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំនោះ សូមសុទ្ធន្តបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ ត្រូវសូមជាគំរប់ពីរដងផង ត្រូវសូមជាគំរប់បីដងផង។

[៤៦៨] ត្រូវភិក្ខុអ្នកឆ្លាស ប្រតិពល ផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យ ក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យ ក្នុងទីកំណត់រាត្រី ភិក្ខុនោះ ក៏សូមសុទ្ធន្តបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរឲ្យសុទ្ធន្តបរិវាស ដល់ភិក្ខុមានឈ្មោះដូច្នេះ ចំពោះអាបត្តិទាំងនោះ នេះជាពាក្យផ្តៀងសង្ឃ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតភិក្ខុនេះ មានឈ្មោះដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី មានសេចក្តីសង្ស័យ ក្នុងទីកំណត់អាបត្តិ ទាំងមានសេចក្តីសង្ស័យ ក្នុងទីកំណត់រាត្រី ភិក្ខុនោះ ក៏សូមសុទ្ធន្តបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃឲ្យសុទ្ធន្តបរិវាស ដល់ភិក្ខុមានឈ្មោះដូច្នេះ ចំពោះអាបត្តិទាំងនោះ។ ការឲ្យសុទ្ធន្តបរិវាស ដល់ភិក្ខុមានឈ្មោះដូច្នេះ ចំពោះអាបត្តិទាំងនោះ គាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម បើមិនគាប់ចិត្ត ដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់ពីរដងផង។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគំរប់បីដងផង។បេ។ សុទ្ធន្តបរិវាស សង្ឃបានឲ្យដល់ភិក្ខុ មានឈ្មោះដូច្នេះ ចំពោះអាបត្តិទាំងនោះហើយ ការឲ្យសុទ្ធន្តបរិវាសនោះ គាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

[៤៦៩] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសុទ្ធន្តបរិវាសយ៉ាងនេះ។ សង្ឃត្រូវឲ្យបរិវាសយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសុទ្ធន្តបរិវាស ដូចម្តេចខ្លះ។ (បើ) ភិក្ខុមិនដឹងទីកំណត់អាបត្តិ ទាំងមិនដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ ទាំងរលឹកមិនឃើញទីកំណត់រាត្រី សង្ស័យ ក្នុងទីកំណត់អាបត្តិ ទាំងសង្ស័យ ក្នុងទីកំណត់រាត្រី ហើយសង្ឃត្រូវឲ្យសុទ្ធន្តបរិវាសចុះ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិ តែមិនដឹងទីកំណត់រាត្រី រលឹកឃើញទីកំណត់អាបត្តិ តែរលឹកមិនឃើញទីកំណត់រាត្រី មិនសង្ស័យក្នុងទីកំណត់អាបត្តិ តែសង្ស័យក្នុងទីកំណត់រាត្រី សង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសដែរ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិខ្លះ មិនដឹងខ្លះ ទាំងមិនដឹងទីកំណត់រាត្រី រលឹកឃើញទីកំណត់អាបត្តិខ្លះ រលឹកមិនឃើញខ្លះ ទាំងរលឹកមិនឃើញទីកំណត់រាត្រី សង្ស័យក្នុងទីកំណត់អាបត្តិខ្លះ មិនសង្ស័យខ្លះ សង្ស័យ តែត្រង់ទីកំណត់រាត្រី ហើយសង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសដែរ។ (បើ) ភិក្ខុមិនដឹងទីកំណត់អាបត្តិ តែដឹងទីកំណត់រាត្រីខ្លះ មិនដឹងខ្លះ រលឹកមិនឃើញទីកំណត់អាបត្តិ តែរលឹកឃើញទីកំណត់រាត្រីខ្លះ រលឹកមិនឃើញខ្លះ សង្ស័យក្នុងទីកំណត់អាបត្តិ ទាំងសង្ស័យក្នុងទីកំណត់រាត្រីខ្លះ មិនសង្ស័យខ្លះ សង្ឃក៏ឲ្យសុទ្ធន្តបរិវាសដែរ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិ ទាំងដឹងទីកំណត់រាត្រីខ្លះ មិនដឹងខ្លះ រលឹកឃើញទីកំណត់អាបត្តិខ្លះ ទាំងរលឹកឃើញទីកំណត់រាត្រីខ្លះ រលឹកមិនឃើញខ្លះ មិនសង្ស័យក្នុងទីកំណត់អាបត្តិ តែសង្ស័យក្នុងទីកំណត់រាត្រីខ្លះ មិនសង្ស័យខ្លះ សង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសដែរ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិខ្លះ មិនដឹងខ្លះ ដឹងទីកំណត់រាត្រីខ្លះ មិនដឹងខ្លះ រលឹកឃើញទីកំណត់អាបត្តិខ្លះ រលឹកមិនឃើញខ្លះ រលឹកឃើញទីកំណត់រាត្រីខ្លះ រលឹកមិនឃើញខ្លះ សង្ស័យក្នុងទីកំណត់អាបត្តិខ្លះ មិនសង្ស័យខ្លះ សង្ស័យក្នុងទីកំណត់រាត្រីខ្លះ មិនសង្ស័យខ្លះ សង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសដែរ។ ម្នាលភិក្ខុទាំងឡាយ សង្ឃក៏ត្រូវឲ្យសុទ្ធន្តបរិវាសយ៉ាងនេះឯង។

[៤៧០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសដូចម្តេច។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិ ទាំងដឹងទីកំណត់រាត្រី រលឹកឃើញទីកំណត់អាបត្តិ ទាំងរលឹកឃើញទីកំណត់រាត្រី មិនសង្ស័យក្នុងទីកំណត់អាបត្តិ ទាំងមិនសង្ស័យក្នុងទីកំណត់រាត្រី សង្ឃត្រូវឲ្យបរិវាសចុះ។ (បើ) ភិក្ខុមិនដឹងទីកំណត់អាបត្តិ តែដឹងទីកំណត់រាត្រី រលឹកមិនឃើញទីកំណត់អាបត្តិ តែរលឹកឃើញទីកំណត់រាត្រី សង្ស័យក្នុងទីកំណត់អាបត្តិ តែមិនសង្ស័យក្នុងទីកំណត់រាត្រី សង្ឃក៏ត្រូវឲ្យបរិវាសដែរ។ (បើ) ភិក្ខុដឹងទីកំណត់អាបត្តិខ្លះ មិនដឹងខ្លះ ដឹងតែទីកំណត់រាត្រី រលឹកឃើញទីកំណត់អាបត្តិខ្លះ រលឹកមិនឃើញខ្លះ រលឹកឃើញតែទីកំណត់រាត្រី សង្ស័យក្នុងទីកំណត់អាបត្តិខ្លះ មិនសង្ស័យខ្លះ មិនសង្ស័យតែត្រង់ទីកំណត់រាត្រី សង្ឃក៏ត្រូវឲ្យបរិវាសដែរ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាសយ៉ាងនេះឯង។

ចប់បរិវាស។

# (ចត្តាលីសកៈ ទី៣)

CS vin.cv.03.03 | ភាគ ទី៩

### (៣. ចត្តាលីសកំ)

[៤៧១] សម័យនោះឯង មានភិក្ខុ១រូបកំពុងនៅបរិវាស ក៏ស្រាប់តែសឹកចេញទៅ។ បុរសនោះ បានត្រឡប់មកសូមឧបសម្បទានឹងភិក្ខុទាំងឡាយវិញ។ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ក្រាបបង្គំទូល ព្រះដ៏មានព្រះភាគ។

[៣៧២] ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយសឹកចេញទៅ។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុ ដែលសឹកចេញទៅហើយ មិនបានលូតលាស់ឡើងទេ។ បើបុគ្គលនោះ ត្រឡប់មកបួសវិញទៀត ការដែលឲ្យបរិវាសអំពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ ឯបរិវាសដែលសល់ ភិក្ខុនោះ ត្រូវនៅទៀតចុះ។

[៤៧៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយក៏ប្តេជ្ញាខ្លួន ជាសាមណេរវិញ។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសរបស់សាមណេរនោះ ក៏មិនបានលូតលាស់ឡើងទេ។ បើសាមណេរនោះ មកបួសជាភិក្ខុវិញ ការដែលឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ ឯបរិវាសដែលសល់ ភិក្ខុនោះ ត្រូវនៅទៀតចុះ។

[៤៧៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយក៏ទៅជាមនុស្សឆ្កួត។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសរបស់ភិក្ខុដែលឆ្កួត មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ បាត់ឆ្កួតទៅវិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ ឯបរិវាសដែលសល់ ភិក្ខុនោះ ត្រូវនៅទៀតចុះ។

[៤៧៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយក៏មានចិត្តរវើរវាយ។ ម្នាលភិក្ខុទាំងឡាយ ឯបរិវាសរបស់ភិក្ខុ ដែលមានចិត្តរវើរវាយ មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ បាត់រវើរវាយចិត្តទៅវិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុនោះ បាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ ឯបរិវាសដែលសល់ ភិក្ខុនោះ ត្រូវនៅទៀតចុះ។

[៤៧៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយក៏មានទុក្ខវេទនាគ្របសង្កត់។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុ ដែលមានទុក្ខវេទនាគ្របសង្កត់ មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ ត្រឡប់ជាឥតមានទុក្ខវេទនាគ្របសង្កត់វិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុ បាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ បរិវាសដែលសល់ ភិក្ខុនោះ ត្រូវនៅទៀតចុះ។

[៤៧៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុ ដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្ម (បានឲ្យលាទោសចេញ) វិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ បរិវាសដែលសល់ ភិក្ខុនោះ ត្រូវនៅទៀតចុះ។

[៤៧៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិចេញ។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុ ដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ បរិវាសដែលសល់ ភិក្ខុនោះ ត្រូវនៅទៀតចុះ។

[៤៧៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ស្រាប់តែសង្ឃលើកវត្ត ព្រោះមិនបានលះបង់ទិដ្ឋិលាមកចេញ។ ម្នាលភិក្ខុទាំងឡាយ បរិវាសរបស់ភិក្ខុ ដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ សង្ឃបានឲ្យឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ ឯបរិវាសដែលសល់ ភិក្ខុនោះ ត្រូវនៅទៀតចុះ។

[៤៨០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរនឹងទាញមកដាក់ក្នុងមូលាបត្តិហើយ ក៏ស្រាប់តែសឹកចេញទៅ។ ការទាញភិក្ខុដែលសឹកចេញទៅ មកដាក់ក្នុងមូលាបត្តិ មិនបានលូតលាស់ឡើងទេ។ បើបុគ្គលនោះ ត្រឡប់មកបួសវិញទៀត ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ ភិក្ខុនោះ សង្ឃត្រូវទាញមកដាក់ ក្នុងមូលាបត្តិ។

[៤៨១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរនឹងទាញមកដាក់ក្នុងមូលាបត្តិហើយ ក៏ប្តេជ្ញាខ្លួនជាសាមណេរវិញ។បេ។ ក៏ត្រឡប់ទៅជាឆ្កួត។បេ។ ត្រឡប់ទៅជាមានចិត្តរវើរវាយ។បេ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់។បេ។ សង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ។បេ។ សង្ឃលើកវត្ត ព្រោះមិនបានសំដែងអាបត្តិ។បេ។ សង្ឃលើកវត្ត ព្រោះមិនបានលះបង់ទិដ្ឋិលាមកចេញ។ ម្នាលភិក្ខុទាំងឡាយ ការទាញភិក្ខុ ដែលសង្ឃលើកវត្ត មកដាក់ក្នុងមូលាបត្តិ មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ ឯភិក្ខុនោះ សង្ឃត្រូវទាញមកដាក់ ក្នុងមូលាបត្តិចុះ។

[៤៨២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់មានត្តហើយ ក៏ត្រឡប់សឹកទៅវិញ។ ម្នាលភិក្ខុទាំងឡាយ ការឲ្យមានត្ត ដល់បុគ្គលដែលសឹកចេញ មិនបានលូតលាស់ឡើងទេ។ បើបុគ្គលនោះ ត្រឡប់មកបួសវិញ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ សង្ឃត្រូវឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៤៨៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់មានត្តហើយ ក៏ប្តេជ្ញាខ្លួនជាសាមណេរវិញ។បេ។ ត្រឡប់ទៅជាឆ្កួត។បេ។ ត្រឡប់ទៅជាមានចិត្តរវើរវាយ។បេ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់។បេ។ សង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ។បេ។ សង្ឃលើកវត្ត ព្រោះមិនបានសំដែងអាបត្តិ។បេ។ សង្ឃលើកវត្ត ព្រោះមិនបានលះបង់ទិដ្ឋិលាមកចេញ។ ម្នាលភិក្ខុទាំងឡាយ ការឲ្យមានត្ត ដល់ភិក្ខុ ដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា

ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ សង្ឃត្រូវឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៤៨៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងប្រព្រឹត្តមានត្តហើយ ក៏ស្រាប់តែសឹកចេញទៅ។ ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តិមានត្ត របស់ភិក្ខុដែលសឹកចេញទៅ មិនបានលូតលាស់ឡើងទេ។ បើបុគ្គលនោះ ត្រឡប់មកបួសវិញទៀត ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ មានត្តឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ មានត្តឯណា ដែលភិក្ខុបានសន្សំរួចហើយ ក៏ឈ្មោះថា សន្សំល្អហើយ។ មានត្តដែលសល់ ភិក្ខុនោះ ត្រូវប្រព្រឹត្តតទៅទៀតចុះ។

[៤៨៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងប្រព្រឹត្តមានត្តហើយ ក៏ប្តេជ្ញាខ្លួន ទៅជាសាមណេរ។បេ។ ត្រឡប់ទៅជាឆ្កួត។បេ។ ត្រឡប់ទៅជាមានចិត្តរវើរវាយ។បេ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់។បេ។ សង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ។បេ។ សង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ។បេ។ សង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិលាមកចេញ។ ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តិមានត្ត របស់ភិក្ខុដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុនៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ មានត្តឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ មានត្តឯណា ដែលភិក្ខុបានសន្សំរួចហើយ ក៏ឈ្មោះថា សន្សំល្អហើយ។ មានត្តដែលសល់នៅ ភិក្ខុនោះ ត្រូវប្រព្រឹត្តតទៅទៀតចុះ។

[៤៨៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្មហើយ ក៏ស្រាប់តែសឹកចេញទៅ។ ម្នាលភិក្ខុទាំងឡាយ អព្ភានកម្ម របស់ភិក្ខុដែលសឹកចេញ មិនបានលូតលាស់ឡើងទេ។ បើបុគ្គលនោះ ត្រឡប់មកបួសវិញ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ មានត្តឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ មានត្តឯណា ដែលភិក្ខុបានសន្សំរួចហើយ ក៏ឈ្មោះថា សន្សំល្អហើយ។ ភិក្ខុនោះ សង្ឃត្រូវឲ្យអព្ភានកម្មចុះ។

[៤៨៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្មហើយ ក៏ប្តេជ្ញាខ្លួន ទៅជាសាមណេរ។បេ។ ត្រឡប់ទៅជាឆ្កួត។បេ។ ត្រឡប់ទៅជាមានចិត្តរវើរវាយ។បេ។ ត្រឡប់ទៅជាមានទុក្ខវេទនាគ្របសង្កត់។បេ។ សង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ។បេ។ សង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ។បេ។ សង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិលាមកចេញ។ ម្នាលភិក្ខុទាំងឡាយ អព្ភានកម្ម របស់ភិក្ខុដែលសង្ឃលើកវត្ត មិនបានលូតលាស់ឡើងទេ។ បើភិក្ខុនោះ សង្ឃបានធ្វើឱសារណកម្មវិញហើយ ការឲ្យបរិវាសពីមុន ដល់ភិក្ខុនោះ ក៏នៅនឹងដដែល។ បរិវាសឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ បរិវាសឯណា ដែលភិក្ខុបាននៅរួចហើយ ក៏ឈ្មោះថា នៅល្អហើយ។ មានត្តឯណា ដែលសង្ឃបានឲ្យហើយ ក៏ឈ្មោះថា ឲ្យល្អហើយ។ មានត្តឯណា ដែលភិក្ខុបានសន្សំរួចហើយ ក៏ឈ្មោះថា សន្សំល្អហើយ។ ភិក្ខុនោះ សង្ឃត្រូវឲ្យអព្ភានកម្មចុះ។

ចប់វារចំនួន៤០។

# (ឆត្តិំសកៈ ទី៤)

CS vin.cv.03.04 | ភាគ ទី៩

### (៤. ឆត្តិំសកំ)

[៤៨៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែមិនបានបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិវិញ។

[៤៨៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន ហើយបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៤៩០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៤៩១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់មិនបាន តែមិនបានបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ។

[៤៩២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់មិនបាន ហើយបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៤៩៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់មិនបាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៤៩៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ តែមិនបានបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ។

[៤៩៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៤៩៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ បិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៤៩៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់មានត្ត។បេ។

[៤៩៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងប្រព្រឹត្តមានត្ត។បេ។

[៤៩៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែមិនបានបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ។

[៥០០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន ហើយបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥០១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់បាន តែបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥០២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់មិនបាន តែមិនបានបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ។

[៥០៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់មិនបាន ហើយបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥០៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់មិនបាន តែបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥០៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ តែមិនបានបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ។

[៥០៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥០៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ តែបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ រួចហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលខ្លួនបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

ចប់វារចំនួន១៦។

## (មានត្តសតកៈ ទី៥)

## (៥. មានត្តសតកំ)

[៥០៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែមិនបានបិទបាំងទុក ក៏សឹកចេញទៅ។ បុគ្គលនោះត្រឡប់មកបួសវិញ ហើយក៏មិនបានបិទបាំងអាបត្តិទាំងនោះឡើយ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យមានត្ត ដល់ភិក្ខុនោះតែម្តងចុះ។

[៥០៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែមិនបានបិទបាំងទុក ក៏សឹកចេញទៅ។ បុគ្គលនោះត្រឡប់មកបួសវិញ ហើយក៏បិទបាំងអាបត្តិទាំងនោះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលភិក្ខុបិទបាំងទុកខាងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះ។

[៥១០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយបិទបាំងទុក ក៏សឹកចេញទៅ។ លុះបុគ្គលនោះត្រឡប់មកបួសវិញ ហើយក៏មិនបានបិទបាំងទុកអាបត្តិទាំងនោះឡើយ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលភិក្ខុបិទបាំងទុកពីមុនប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះ។

[៥១១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយបិទបាំងទុក ក៏សឹកចេញទៅ។ លុះបុគ្គលនោះត្រឡប់មកបួសវិញ ក៏បិទបាំងអាបត្តិទាំងនោះទុកទៀត។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលភិក្ខុបិទបាំងទុកទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥១២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន។ តែអាបត្តិទាំងនោះ ភិក្ខុនោះបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះសឹកចេញទៅ ហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសខាងក្រោយ ក៏ត្រឡប់ជាមិនបិទបាំងពួកអាបត្តិនោះវិញ ពួកអាបត្តិណា ដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសខាងក្រោយ ក៏នៅតែមិនបិទបាំងទុកពួកអាបត្តិនោះដដែល។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលភិក្ខុបិទបាំងទុកពីមុនប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥១៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន។ តែអាបត្តិទាំងនោះ ភិក្ខុនោះបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ ភិក្ខុនោះ សឹកចេញទៅ ហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជា មិនបិទបាំងពួកអាបត្តិនោះទុកវិញ ពួកអាបត្តិណា ដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាបិទបាំងពួកអាបត្តិនោះទុកវិញ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលភិក្ខុបិទបាំងទុក ទាំងមុន ទាំងក្រោយ ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥១៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន។ តែអាបត្តិទាំងនោះ ភិក្ខុបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ ភិក្ខុនោះ សឹកចេញទៅ ហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏បិទបាំងពួកអាបត្តិនោះទុកទៀត ពួកអាបត្តិណា ដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកទៀត។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលភិក្ខុបិទបាំងទុក ទាំងមុន ទាំងក្រោយ ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥១៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន។ តែអាបត្តិទាំងនោះ ភិក្ខុនោះបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ ភិក្ខុនោះ សឹកចេញទៅ ហើយក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ឈ្មោះថាបិទបាំងពួកអាបត្តិនោះទុកទៀត ពួកអាបត្តិណា ដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាបិទបាំងពួកអាបត្តិនោះទុកវិញ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយ ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥១៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់អាបត្តិណា ក៏បិទបាំងអាបត្តិនោះទុក មិនស្គាល់អាបត្តិណា ក៏មិនបានបិទបាំងអាបត្តិនោះទុក។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនស្គាល់ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនបិទបាំងពួកអាបត្តិ ដែលខ្លួនស្គាល់នោះទុក ពួកអាបត្តិណា ដែលខ្លួនមិនស្គាល់ ហើយបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាស្គាល់ ហើយមិនបានបិទបាំងពួកអាបត្តិនោះទុក។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលភិក្ខុបិទបាំងទុកពីមុនប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥១៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់ពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក មិនស្គាល់ពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកទេ។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ស្គាល់ពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាមិនបិទបាំងអាបត្តិ ដែលស្គាល់នោះទុក មិនស្គាល់ពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាស្គាល់ ពួកអាបត្តិនោះ ហើយបិទបាំងទុក។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥១៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់ពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក មិនស្គាល់ពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏

ត្រឡប់មកបួសវិញ ស្គាល់ពួកអាបត្តិណា ដែលបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏បិទបាំងពួកអាបត្តិ ដែលស្គាល់នោះទុកទៀត មិនស្គាល់ពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាស្គាល់ ពួកអាបត្តិនោះ តែមិនបានបិទបាំងទុកទេ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះ។

[៥១៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់ពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក មិនស្គាល់ពួកអាបត្តិណា ក៏មិនបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ស្គាល់ពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏បិទបាំងពួកអាបត្តិ ដែលស្គាល់នោះទុកទៀត មិនស្គាល់ពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាស្គាល់ ពួកអាបត្តិនោះ ហើយបិទបាំងទុក។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះ។

[៥២០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែរលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ រលឹកឃើញពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក រលឹកមិនឃើញពួកអាបត្តិណា ក៏មិនបិទបាំងអាបត្តិទាំងនោះទុកឡើយ។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ រលឹកឃើញពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏រលឹកឃើញអាបត្តិទាំងនោះទៀត ហើយមិនបានបិទបាំងទុកទេ រលឹកមិនឃើញពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏រលឹកឃើញអាបត្តិទាំងនោះ ហើយមិនបានបិទបាំងទុក។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុកពីមុន ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥២១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែរលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ រលឹកឃើញពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក រលឹកមិនឃើញពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ រលឹកឃើញពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏រលឹកឃើញអាបត្តិទាំងនោះទៀត ហើយមិនបានបិទបាំងទុកទេ រលឹកមិនឃើញពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏រលឹកឃើញអាបត្តិទាំងនោះ តែបិទបាំងទុកទៅវិញ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥២២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ហើយរលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ រលឹកឃើញពួកអាបត្តិណា ក៏បិទបាំងអាបត្តិទាំងនោះទុក រលឹកមិនឃើញពួកអាបត្តិណា ក៏មិនបានបិទបាំងអាបត្តិទាំងនោះទុកឡើយ។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ រលឹកឃើញពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏រលឹកឃើញអាបត្តិទាំងនោះ ហើយបិទបាំងទុកទៀត រលឹកមិនឃើញពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏រលឹកឃើញអាបត្តិទាំងនោះ ហើយមិនបានបិទបាំងទុកទៀត។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥២៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែរលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ រលឹកឃើញពួកអាបត្តិណា ក៏បិទបាំងអាបត្តិទាំងនោះទុក រលឹកមិនឃើញពួកអាបត្តិណា ក៏មិនបានបិទបាំងអាបត្តិទាំងនោះទុកឡើយ។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ រលឹកឃើញពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏រលឹកឃើញអាបត្តិទាំងនោះ ហើយបិទបាំងទុកទៀត រលឹកមិនឃើញពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជារលឹកឃើញអាបត្តិទាំងនោះ ហើយបិទបាំងទុក។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥២៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែឥតមានសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ ឥតសង្ស័យក្នុងពួកអាបត្តិណាហើយ ក៏បិទបាំងអាបត្តិទាំងនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងអាបត្តិទាំងនោះទុក។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ឥតសង្ស័យនឹងពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏ឥតមានសង្ស័យនឹងអាបត្តិទាំងនោះ ហើយមិនបានបិទបាំងទុក សង្ស័យនឹងពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុក។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុកពីមុនប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥២៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែឥតមានសង្ស័យ ក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ ឥតមានសង្ស័យក្នុងពួកអាបត្តិណាហើយ ក៏បិទបាំងអាបត្តិទាំងនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងអាបត្តិទាំងនោះទុក។ ភិក្ខុនោះ សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ឥតមានសង្ស័យនឹងពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏ឥតមានសង្ស័យនឹងពួកអាបត្តិទាំងនោះ តែមិនបានបិទបាំងទុក សង្ស័យនឹងពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ តែបិទបាំងទុកទៅវិញ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥២៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែមិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងអាបត្តិទាំងនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងអាបត្តិទាំងនោះទុក។ ភិក្ខុនោះ

សឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ មិនសង្ស័យនឹងពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះទៀត សង្ស័យនឹងពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុក។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥២៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែមិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងអាបត្តិទាំងនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុក។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ មិនសង្ស័យនឹងពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងពួកអាបត្តិនោះទុកទៀត សង្ស័យនឹងពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យ តែត្រឡប់ជាបិទបាំងទុកពួកអាបត្តិនោះវិញ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

[៥២៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន តែមិនបានបិទបាំងទុកទេ ក៏ប្តេជ្ញាខ្លួនទៅជាសាមណេរ។បេ។ ត្រឡប់ទៅជាមនុស្សឆ្កួត។បេ។ ត្រឡប់ទៅជាមានចិត្តរវើរវាយ។បេ។ (សេចក្តី) ខាងក្រោយយ៉ាងណា បណ្ឌិតគួរសំដែងសេចក្តីនេះ ឲ្យពិស្តារយ៉ាងនោះចុះ។បេ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់។បេ។ អាបត្តិទាំងឡាយនោះ ភិក្ខុបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។បេ។ ស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ។បេ។រលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ។បេ។ មិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះ មានទុក្ខវេទនាគ្របសង្កត់ លុះភិក្ខុនោះ អស់ទុក្ខវេទនាគ្របសង្កត់ហើយ មិនសង្ស័យនឹងពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យនឹងពួកអាបត្តិនោះទៀត តែត្រឡប់ជាមិនបិទបាំងទុកទៅវិញ សង្ស័យនឹងពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុកទៀត។បេ។ មិនសង្ស័យនឹងពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យនឹងពួកអាបត្តិនោះទៀត តែមិនបានបិទបាំងទុកទៅវិញ សង្ស័យនឹងពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ តែបិទបាំងទុកទៅវិញ។បេ។ មិនសង្ស័យនឹងពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះទៀត សង្ស័យនឹងពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុកទៀត។បេ។ មិនសង្ស័យនឹងពួកអាបត្តិណា ដែលបិទបាំងទុកពីមុនហើយ ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះទៀត សង្ស័យនឹងពួកអាបត្តិណា ដែលមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ តែបិទបាំងទុកទៅវិញ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យបរិវាស ចំពោះកងអាបត្តិ ដែលបិទបាំងទុក ទាំងមុន ទាំងក្រោយប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុនោះចុះ។

ចប់មានត្ត១០០។

# (សមូលាយសមោធានបរិវាសចតុស្សតៈ ទី៦)

CS vin.cv.03.06 | ភាគ ទី៩

### (៦. សមូលាយសមោធានបរិវាសចតុស្សតំ)

[៥២៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនបានបិទបាំងទុក ហើយក៏សឹកចេញទៅ។ លុះបុគ្គលនោះ ត្រឡប់មកបួសវិញហើយ ក៏មិនបានបិទបាំងអាបត្តិទាំងនោះទុកទៀត។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ។

[៥៣០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនបានបិទបាំងទុក ហើយក៏សឹកចេញទៅ។ លុះបុគ្គលនោះ ត្រឡប់មកបួសវិញហើយ ក៏បិទបាំងអាបត្តិទាំងនោះទុកទៀត។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិដែលបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ បិទបាំងទុក ហើយក៏សឹកចេញទៅ។ លុះបុគ្គលនោះ ត្រឡប់មកបួសវិញហើយ ក៏មិនបានបិទបាំងអាបត្តិទាំងនោះទុកឡើយ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិដែលបិទបាំងទុកប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ បិទបាំងទុក ហើយក៏សឹកចេញទៅ។ លុះបុគ្គលនោះ ត្រឡប់មកបួសវិញ ក៏បិទបាំងអាបត្តិទាំងនោះទុកទៀត។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ។ អាបត្តិទាំងនោះ ភិក្ខុនោះបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនបានបិទបាំងអាបត្តិទាំងនោះឡើយ ពួកអាបត្តិណា ដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាង

ក្រោយ ក៏មិនបានបិទបាំងអាបត្តិទាំងនោះទៀត។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ។ អាបត្តិទាំងនោះ ភិក្ខុនោះបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជា មិនបិទបាំងទុកអាបត្តិទាំងនោះវិញ ពួកអាបត្តិណា ដែលខ្លួនមិនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាបិទបាំងអាបត្តិទាំងនោះវិញ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ។ អាបត្តិទាំងនោះ ភិក្ខុនោះបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏បិទបាំងអាបត្តិទាំងនោះទៀត ពួកអាបត្តិណា ដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនបានបិទបាំងអាបត្តិទាំងនោះទៀត។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ។ អាបត្តិទាំងនោះ ភិក្ខុនោះបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏បិទបាំងអាបត្តិទាំងនោះទៀត ពួកអាបត្តិណា ដែលខ្លួនមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាបិទបាំងអាបត្តិទាំងនោះវិញ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់អាបត្តិពួកណា ក៏បិទបាំងពួកអាបត្តិនោះទុក មិនស្គាល់អាបត្តិពួកណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនស្គាល់ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏នៅតែស្គាល់ពួកអាបត្តិនោះដដែល តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនមិនស្គាល់ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាស្គាល់ពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុកទៀត។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់ពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក មិនស្គាល់ពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនស្គាល់ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏នៅតែស្គាល់ពួកអាបត្តិនោះដដែល តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនមិនស្គាល់ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាស្គាល់ ហើយបិទបាំងទុកពួកអាបត្តិនោះវិញ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៣៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់ពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក មិនស្គាល់ពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនស្គាល់ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏នៅតែស្គាល់ ហើយបិទបាំងពួកអាបត្តិនោះទៀត ពួកអាបត្តិណា ដែលខ្លួនមិនស្គាល់ ហើយមិនបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាស្គាល់ពួកអាបត្តិនោះ តែមិនបិទបាំងទុកទេ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ ស្គាល់ពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក មិនស្គាល់ពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនស្គាល់ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏នៅតែស្គាល់ហើយបិទបាំងទុកពួកអាបត្តិនោះទៀត ពួកអាបត្តិណា ដែលខ្លួនមិនស្គាល់ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជាស្គាល់ពួកអាបត្តិនោះ តែបិទបាំងទុកទៅវិញ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែរលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ រលឹកឃើញពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក រលឹកមិនឃើញពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនរលឹកឃើញ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏រលឹកឃើញពួកអាបត្តិនោះទៀត តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនរលឹកមិនឃើញ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជារលឹកឃើញពួកអាបត្តិនោះវិញ តែមិនបានបិទបាំងទុកទេ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែរលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ រលឹកឃើញពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក រលឹកមិនឃើញពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិទាំងនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនរលឹកឃើញ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏នៅតែរលឹកឃើញពួកអាបត្តិនោះទៀត តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនរលឹកមិនឃើញ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជារលឹកឃើញ ហើយបិទបាំងទុកពួកអាបត្តិនោះវិញ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែរលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ រលឹកឃើញពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក រលឹកមិនឃើញពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនរលឹកឃើញ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏នៅតែរលឹកឃើញ ហើយបិទបាំងពួកអាបត្តិនោះដដែល ពួកអាបត្តិណា ដែលខ្លួនរលឹកមិនឃើញ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជារលឹកឃើញពួកអាបត្តិនោះវិញ តែមិនបិទបាំងទុកទេ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែរលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ រលឹកឃើញពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក រលឹកមិនឃើញពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុក។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនរលឹកឃើញ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏នៅតែរលឹកឃើញ ហើយបិទបាំងទុកពួកអាបត្តិនោះដដែល ពួកអាបត្តិណា ដែលខ្លួនរលឹកមិនឃើញ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏ត្រឡប់ជារលឹកឃើញ ហើយបិទបាំងទុកពួកអាបត្តិនោះវិញ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យនឹងពួកអាបត្តិនោះដដែល តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុកទៀត។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិទាំងនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យនឹងពួកអាបត្តិនោះទៀត តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះវិញ។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះទៀត ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុកទៀត។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះសឹកចេញទៅហើយ ក៏ត្រឡប់មកបួសវិញ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះទៀត ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៤៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងនៅបរិវាស ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនបានបិទបាំងទុក ហើយប្តេជ្ញាខ្លួនជាសាមណេរ។បេ។ ត្រឡប់ទៅជាមនុស្សឆ្កួត។បេ។ ត្រឡប់ជាមានចិត្តរវើរវាយ។បេ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់។បេ។ អាបត្តិទាំងឡាយ ភិក្ខុនោះបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ រឿងបរិវាស ដែលពិស្តារមកហើយយ៉ាងណា បណ្ឌិតត្រូវឲ្យពិស្តារយ៉ាងនោះចុះ។បេ។ ភិក្ខុនោះ ស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ។បេ។ រលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ។បេ។ មិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះ មានទុក្ខវេទនាគ្របសង្កត់។ លុះភិក្ខុនោះ អស់ទុក្ខវេទនាគ្របសង្កត់ហើយ ពួកអាបត្តិណា

ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យនឹងពួកអាបត្តិនោះទៀត តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុកដដែល។បេ។ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យនឹងពួកអាបត្តិនោះទៀត តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សង្ស័យ តែបិទបាំងទុកទៅវិញ។បេ។ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងពួកអាបត្តិនោះទៀត ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុកទៀត។បេ។ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះទៀត ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

[៥៥០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់មានត្ត។បេ។

[៥៥១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កំពុងប្រព្រឹត្តមានត្ត។បេ។

[៥៥២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភានកម្ម ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនបានបិទបាំងទុក ហើយសឹកចេញទៅ។បេ។ យើងបានសំដែង អំពីភិក្ខុដែលនៅបរិវាស ឲ្យពិស្តារហើយយ៉ាងណា ចំណែកភិក្ខុដែលគួរដល់មានត្ត ប្រព្រឹត្តមានត្ត និងគួរដល់អព្ភាន បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះចុះ។

[៥៥៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរដល់អព្ភាន ហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ តែមិនបានបិទបាំងទុក ហើយប្តេជ្ញាខ្លួនជាសាមណេរ។បេ។ ត្រឡប់ទៅជាឆ្កួត។បេ។ ត្រឡប់ជាមានចិត្តរវើរវាយ។បេ។ ត្រឡប់ជាមានទុក្ខវេទនាគ្របសង្កត់។បេ។ អាបត្តិទាំងនោះ ភិក្ខុនោះ បិទបាំងខ្លះ មិនបានបិទបាំងខ្លះ។បេ។ ស្គាល់អាបត្តិពួកខ្លះ មិនស្គាល់អាបត្តិពួកខ្លះ។បេ។ រលឹកឃើញអាបត្តិពួកខ្លះ រលឹកមិនឃើញអាបត្តិពួកខ្លះ។បេ។ មិនសង្ស័យក្នុងអាបត្តិពួកខ្លះ សង្ស័យក្នុងអាបត្តិពួកខ្លះ មិនសង្ស័យក្នុងពួកអាបត្តិណា ក៏បិទបាំងពួកអាបត្តិនោះទុក សង្ស័យក្នុងពួកអាបត្តិណា ក៏មិនបានបិទបាំងពួកអាបត្តិនោះទុកឡើយ។ ភិក្ខុនោះ មានទុក្ខវេទនាគ្របសង្កត់។ ភិក្ខុនោះ អស់ទុក្ខវេទនាគ្របសង្កត់វិញហើយ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យនឹងពួកអាបត្តិនោះទៀត តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ តែមិនបានបិទបាំងទុកទេ។បេ។ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យនឹងពួកអាបត្តិនោះទៀត តែមិនបានបិទបាំងទុក ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ តែបិទបាំងទុកទៅវិញ។បេ។ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះទៀត ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ ហើយមិនបានបិទបាំងទុកទេ។បេ។ ពួកអាបត្តិណា ដែលខ្លួនមិនសង្ស័យ ហើយបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏មិនសង្ស័យ ហើយបិទបាំងទុកពួកអាបត្តិនោះទៀត ពួកអាបត្តិណា ដែលខ្លួនសង្ស័យ ហើយមិនបានបិទបាំងទុកពីមុន ដល់មកបួសជាខាងក្រោយ ក៏អស់សេចក្តីសង្ស័យនឹងពួកអាបត្តិនោះ តែបិទបាំងទុក។ សង្ឃត្រូវទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ហើយត្រូវឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ និងចំពោះអាបត្តិខាងដើម។

# (បរិមាណាទិវារអដ្ឋកៈ ទី៧)

CS vin.cv.03.07 | ភាគ ទី៩

### (៧. បរិមាណាទិវារអដ្ឋកំ)

[៥៥៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួនគួរនឹងរាប់បាន ហើយមិនបានបិទបាំងទុក ក៏សឹកចេញទៅ។បេ។ មានចំនួនគួររាប់មិនបាន ហើយមិនបានបិទបាំងទុក ក៏សឹកចេញទៅ។បេ។ ជាអាបត្តិមានឈ្មោះតែមួយ ហើយមិនបានបិទបាំងទុក ក៏សឹកចេញទៅ។បេ។ ជាអាបត្តិមានឈ្មោះផ្សេងគ្នា ហើយមិនបានបិទបាំងទុក ក៏សឹកចេញទៅ។បេ។ ជាអាបត្តិ មានចំណែកស្មើគ្នា ហើយមិនបានបិទបាំងទុក ក៏សឹកចេញទៅ។បេ។ ជាអាបត្តិ មានចំណែកខុសគ្នា ហើយមិនបានបិទបាំងទុក ក៏សឹកចេញទៅ។បេ។ ជាអាបត្តិដែលកំណត់បាន (មិនច្រឡូកច្រឡំ) ហើយមិនបានបិទបាំងទុក ក៏សឹកចេញទៅ។បេ។ ជាអាបត្តិ ដែលច្រឡូកច្រឡំគ្នា ហើយមិនបានបិទបាំងទុក ក៏សឹកចេញទៅ។បេ។

# (ទ្វេភិក្ខុវារឯកាទសកៈ ទី៨)

CS vin.cv.03.08 | ភាគ ទី៩

### (៨. ទ្វេភិក្ខុវារឯកាទសកំ)

[៥៥៥] មានភិក្ខុពីររូប ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទាំងនោះយល់ឃើញអាបត្តិសង្ឃាទិសេស ថាជាអាបត្តិសង្ឃាទិសេសមែន តែភិក្ខុមួយរូបបិទបាំងទុក ភិក្ខុមួយរូប មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក ត្រូវវិនយធរ ឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិដែលបិទបាំងទុក ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូបចុះ។

[៥៥៦] មានភិក្ខុពីររូប ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទាំងនោះ មានសេចក្ដីសង្ស័យក្នុងអាបត្តិសង្ឃាទិសេស តែភិក្ខុ១រូបបិទបាំងទុក ភិក្ខុ១រូប មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក ត្រូវវិនយធរ ឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូបចុះ។

[៥៥៧] មានភិក្ខុពីររូប ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទាំងនោះ មានសេចក្ដីយល់ឃើញក្នុងអាបត្តិសង្ឃាទិសេស ថាជាអាបត្តិច្រឡូកច្រឡំ[43] គ្នា តែភិក្ខុ១រូបបិទបាំងទុក ភិក្ខុ១រូប មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក ត្រូវវិនយធរ ឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូបចុះ។

[៥៥៨] មានភិក្ខុពីររូប ត្រូវអាបត្តិច្រឡូកច្រឡំគ្នា ភិក្ខុទាំងនោះមានសេចក្ដីយល់ឃើញក្នុងអាបត្តិច្រឡូកច្រឡំគ្នា ថាជាអាបត្តិសង្ឃាទិសេស តែភិក្ខុ១រូប បិទបាំងទុក ភិក្ខុ១រូប មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក ត្រូវវិនយធរ ឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូបចុះ។

[៥៥៩] មានភិក្ខុពីររូប ត្រូវអាបត្តិច្រឡូកច្រឡំគ្នា ភិក្ខុទាំងនោះ ក៏មានសេចក្ដីយល់ឃើញក្នុងអាបត្តិច្រឡូកច្រឡំគ្នា ថាជាអាបត្តិច្រឡូកច្រឡំគ្នាមែន តែភិក្ខុ១រូបបិទបាំងទុក ភិក្ខុ១រូប មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក ត្រូវវិនយធរ ឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិ ដែលបិទបាំងទុក ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូបចុះ។

[៥៦០] មានភិក្ខុពីររូប ត្រូវសុទ្ធកាបត្តិ[44] ភិក្ខុទាំងនោះ មានសេចក្ដីយល់ឃើញ ក្នុងសុទ្ធកាបត្តិ ថាជា អាបត្តិ សង្ឃាទិសេសទៅវិញ។ តែភិក្ខុ១រូប បិទបាំងទុក ភិក្ខុ១រូប មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក ត្រូវវិនយធរ ឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត វិនយធរ ត្រូវឲ្យភិក្ខុទាំងពីររូបធ្វើតាមធម៌ (សំដែងអាបត្តិនោះៗចេញ)។

[៥៦១] មានភិក្ខុពីររូប ត្រូវសុទ្ធកាបត្តិ ភិក្ខុទាំងនោះ មានសេចក្ដីយល់ឃើញ ក្នុងសុទ្ធកាបត្តិ ថាជា សុទ្ធកាបត្តិមែន តែភិក្ខុ១រូប បិទបាំងទុក ភិក្ខុ១រូបទៀត មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក វិនយធរត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត វិនយធរ ត្រូវឲ្យភិក្ខុទាំងពីររូបធ្វើតាមធម៌។

[៥៦២] មានភិក្ខុពីររូប ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទាំងនោះ មានសេចក្ដីយល់ឃើញក្នុងអាបត្តិសង្ឃាទិសេស ថាជាអាបត្តិសង្ឃាទិសេសមែន តែភិក្ខុ១រូប គិតថានឹងប្រាប់គេ។ ភិក្ខុ១រូបទៀត គិតថា នឹងមិនប្រាប់គេ។ ភិក្ខុនោះ បិទបាំងទុកអស់យាមជាបឋមផង បិទបាំងទុកអស់យាម ជាគំរប់ពីរផង បិទបាំងទុកអស់យាម ជាគំរប់បីផង លុះអរុណរះឡើងហើយ ភិក្ខុនោះឈ្មោះថា បិទបាំងអាបត្តិទុក។ ភិក្ខុណាបិទបាំងទុក វិនយធរ ត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិដែលបិទបាំងទុក ប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូប។

[៥៦៣] មានភិក្ខុពីររូប ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទាំងនោះ មានសេចក្ដីយល់ឃើញក្នុងអាបត្តិសង្ឃាទិសេស ថាជាអាបត្តិសង្ឃាទិសេសមែន ភិក្ខុទាំងនោះ ដើរទៅ ក៏គិតគ្នាថា នឹងប្រាប់គេ។ លុះដល់ពាក់កណ្ដាលផ្លូវ ភិក្ខុ១រូប ក៏មានសភាវបិទបាំងកើតឡើងថា នឹងមិនប្រាប់គេទៅវិញ។ ភិក្ខុនោះ បិទបាំងអស់យាមជាបឋមផង បិទបាំងអស់យាម ជាគំរប់ពីរផង បិទបាំងអស់យាម ជាគំរប់បីផង លុះអរុណរះឡើងហើយ ក៏ឈ្មោះថា បិទបាំងអាបត្តិទុក។ ភិក្ខុណាបិទបាំងទុក វិនយធរ ត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិ ដែលបិទបាំងទុកប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូបចុះ។

[៥៦៤] មានភិក្ខុពីររូប ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទាំងនោះ មានសេចក្ដីយល់ឃើញ ក្នុងអាបត្តិសង្ឃាទិសេស ថាជាអាបត្តិសង្ឃាទិសេសមែន។ ភិក្ខុទាំងនោះ ក៏ត្រឡប់ទៅជាមនុស្សឆ្កួត។ លុះកាលខាងក្រោយ ភិក្ខុទាំងនោះ ជាពីឆ្កួតវិញ តែភិក្ខុ១រូប បិទបាំងទុក ភិក្ខុ១រូបទៀត មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក វិនយធរ ត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិ ដែលបិទបាំងទុកប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូបចុះ។

[៥៦៥] មានភិក្ខុពីររូប ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទាំងនោះ កាលបើសង្ឃកំពុងសំដែងបាតិមោក្ខ ក៏ពោលយ៉ាងនេះថា ឥឡូវនេះ យើងដឹងប្រាកដថា ធម៌នេះឯង មកហើយក្នុងសុត្ត (មាតិកា) រាប់បញ្ចូលក្នុងសុត្ត តែងមកកាន់ឧទ្ទេស រាល់ៗកន្លះខែ។ ភិក្ខុទាំងនោះ មានសេចក្ដីយល់ឃើញ ក្នុងអាបត្តិសង្ឃាទិសេស ថាជាអាបត្តិសង្ឃាទិសេសមែន។ តែភិក្ខុ១រូប បិទបាំងទុក ភិក្ខុ១រូបទៀត មិនបានបិទបាំងទុក។ ភិក្ខុណាបិទបាំងទុក វិនយធរ ត្រូវឲ្យភិក្ខុនោះសំដែងអាបត្តិទុក្កដចេញ។ ម្យ៉ាងទៀត សង្ឃត្រូវឲ្យបរិវាស ដល់ភិក្ខុនោះ ចំពោះកងអាបត្តិ ដែលបិទបាំងទុកប៉ុន្មានថ្ងៃ ហើយសឹមឲ្យមានត្ត ដល់ភិក្ខុទាំងពីររូបចុះ។

## (មូលាយអវិសុទ្ធិនវកៈ ទី៩)

CS vin.cv.03.09 | ភាគ ទី៩

**(៩. មូលាយអវិសុទ្ធិនវកំ)**

[៥៦៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួរនឹងរាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ (មិនច្រឡូកច្រឡំ) ច្រឡូកច្រឡំខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បាន តែមិនបានបិទបាំងទុក។ ភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ដោយត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ធ្វើអព្ភាន ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបានបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

[៥៦៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន ហើយបិទបាំងទុក។ ភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ហើយធ្វើអព្ភាន ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបានបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

[៥៦៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់បាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ដោយត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ធ្វើអព្ភានកម្ម ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបានបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

[៥៦៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើនក្នុងចន្លោះ មានចំនួនគួររាប់មិនបាន តែមិនបានបិទបាំងទុក។ ភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ធ្វើអព្ភាន ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបានបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

[៥៧០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់មិនបាន ហើយបិទបាំងទុក។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ធ្វើអព្ភាន ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបានបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

[៥៧១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់មិនបាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ធ្វើអព្ភាន ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបានបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

[៥៧២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ តែមិនបានបិទបាំងទុក។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ធ្វើអព្ភាន ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបានបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

[៥៧៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន រាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ធ្វើអព្ភាន ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

[៥៧៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ តែឲ្យមានត្តមិនត្រូវតាមធម៌ ធ្វើអព្ភាន ក៏មិនត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មិនបរិសុទ្ធ ចាកអាបត្តិទាំងនោះឡើយ។

ចប់ វារៈ៩ នៃការមិនបរិសុទ្ធិ ដោយមូលាបត្តិ។

# (ទុតិយនវកំ ទី១០)

CS vin.cv.03.10 | ភាគ ទី៩

### (១០. ទុតិយនវកំ)

[៥៧៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់បាន តែមិនបានបិទបាំងទុក។បេ។ មានចំនួនគួររាប់បាន ហើយបិទបាំងទុក។បេ។ មានចំនួនគួររាប់បាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ធ្វើអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

[៥៧៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់មិនបាន តែមិនបានបិទបាំងទុក។បេ។ មានចំនួនរាប់មិនបាន ហើយបិទបាំងទុក។បេ។ មានចំនួនរាប់មិនបាន តែបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ធ្វើអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

[៥៧៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ តែមិនបានបិទបាំងទុក។បេ។ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក។បេ។ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុកខ្លះ មិនបិទបាំងទុកខ្លះ។ ភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ធ្វើអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

ចប់វារៈ៩ នៃការបរិសុទ្ធិ ដោយមូលាបត្តិ។

# (តតិយនវកៈ ទី១១)

CS vin.cv.03.11 | ភាគ ទី៩

### (១១. តតិយនវកំ)

[៥៧៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែមិនបានបិទបាំងទុក។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស មិនត្រូវតាមធម៌។ ភិក្ខុនោះ សំគាល់ថា ខ្លួននៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែមិនបានបិទបាំងទុក។ ភិក្ខុនោះ កំពុងឈរលើផែនដីក្នុងទីនោះ ក៏រលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុន និងរលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ អាត្មាអញនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ សង្ឃក៏បានឲ្យសមោធានបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំងនោះ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែមិនបានបិទបាំងទុក អាត្មាអញនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ សង្ឃក៏ទាញអាត្មាអញនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ហើយថែមទាំងឲ្យសមោធានបរិវាស មិនត្រូវតាមធម៌។ អាត្មាអញនោះ សំគាល់ថា ខ្លួននៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែមិនបានបិទបាំងទុក អាត្មាអញនោះ កំពុងឈរលើផែនដីក្នុងទីនោះ ហើយក៏រលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុន និងរលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយ បើដូច្នោះ មានតែអាត្មាអញ សូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយសូមសមោធានបរិវាស ឲ្យត្រូវតាមធម៌ សូមមានត្ត ដោយត្រូវតាមធម៌ សូមអព្ភាន ដោយត្រូវតាមធម៌។ ភិក្ខុនោះ សូមការទាញមកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយសូមសមោធានបរិវាស ដោយត្រូវតាមធម៌ សូមមានត្ត ដោយត្រូវតាមធម៌ សូមអព្ភាន ដោយត្រូវតាមធម៌។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ដោយត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ធ្វើអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

[៥៧៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន ហើយបិទបាំងទុក។បេ។ មានចំនួនគួររាប់បាន ហើយបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស មិនត្រូវតាមធម៌។ ភិក្ខុនោះ សំគាល់ថា ខ្លួននៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះ កំពុងឈរលើផែនដីក្នុងទីនោះ ក៏រលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិមុន និងរលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ អាត្មាអញនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ សង្ឃក៏ឲ្យសមោធានបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំងនោះ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ អាត្មាអញនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ សង្ឃក៏ទាញអាត្មាអញនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ថែមទាំងឲ្យសមោធានបរិវាស មិនត្រូវតាមធម៌ អាត្មាអញនោះ ក៏សំគាល់ថា ខ្លួននៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ ជាអាបត្តិរាប់បាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ អាត្មាអញនោះ កំពុងឈរលើផែនដីក្នុងទីនោះ ហើយក៏រលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុន និងរលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយ បើដូច្នោះ មានតែអាត្មាអញ សូមការទាញ មកដាក់ក្នុង មូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយសូមសមោធានបរិវាស ឲ្យត្រូវតាមធម៌ សូមមានត្ត ក៏ត្រូវតាមធម៌ សូមអព្ភាន ក៏ត្រូវតាមធម៌។ ភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយសូមសមោធានបរិវាស ត្រូវតាមធម៌ សូមមានត្ត ក៏ត្រូវតាមធម៌ សូមអព្ភាន ក៏ត្រូវតាមធម៌។ សង្ឃបានទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ធ្វើអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

[៥៨០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនរាប់មិនបាន តែមិនបានបិទបាំងទុក។បេ។ មានចំនួនរាប់មិនបាន ហើយបិទបាំងទុក។បេ។ មានចំនួនរាប់មិនបាន តែបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ថែមទាំងឲ្យសមោធានបរិវាស ក៏មិនត្រូវតាមធម៌។ ភិក្ខុនោះ សំគាល់ថា ខ្លួននៅបរិវាសហើយ។បេ។ សង្ឃក៏ឲ្យសមោធានបរិវាស ត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ធ្វើអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

[៥៨១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ តែមិនបានបិទបាំងទុក។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ថែមទាំងឲ្យសមោធានបរិវាស មិនត្រូវតាមធម៌។ ភិក្ខុនោះ សំគាល់ថា ខ្លួននៅបរិវាសហើយ។បេ។ សង្ឃក៏ឲ្យសមោធានបរិវាស ត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ធ្វើអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

[៥៨២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ ក៏សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ថែមទាំងឲ្យសមោធានបរិវាស មិនត្រូវតាមធម៌។ ភិក្ខុនោះ សំគាល់ថា ខ្លួននៅបរិវាសហើយត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក។ ភិក្ខុនោះ កំពុងឈរលើផែនដី ក្នុងទីនោះ ក៏រលឹកឃើញអាបត្តិ ក្នុងចន្លោះ នៃអាបត្តិពីមុន និងរលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ អាត្មាអញនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ សង្ឃក៏បានឲ្យសមោធានបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំងនោះ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក អាត្មាអញនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ សង្ឃក៏ទាញអាត្មាអញនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស មិនត្រូវតាមធម៌ អាត្មាអញ ក៏សំគាល់ថា ខ្លួននៅបរិវាសហើយ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុក អាត្មាអញនោះ កំពុងឈរលើផែនដីក្នុងទីនោះ ក៏រលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុន និងរលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយ បើដូច្នោះ មានតែអាត្មាអញ សូមការទាញ មកដាក់ក្នុង មូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយសូមសមោធានបរិវាស ត្រូវតាមធម៌ សូមមានត្ត ក៏ត្រូវតាមធម៌ សូមអព្ភាន ក៏ត្រូវតាមធម៌។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយសូមសមោធានបរិវាស ត្រូវតាមធម៌ សូមមានត្ត ក៏ត្រូវតាមធម៌ សូមអព្ភាន ក៏ត្រូវតាមធម៌។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ធ្វើអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

[៥៨៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ។បេ។ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ។ ភិក្ខុនោះ សូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ។ សង្ឃក៏ឲ្យសមោធានបរិវាស ដល់ភិក្ខុនោះ ចំពោះអាបត្តិទាំងនោះ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះ សូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស មិនត្រូវតាមធម៌។ ភិក្ខុនោះ សំគាល់ថា ខ្លួននៅបរិវាសហើយ ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ។ ភិក្ខុនោះ កំពុងឈរលើផែនដី ក្នុងទីនោះ ក៏រលឹកឃើញអាបត្តិ ក្នុងចន្លោះ នៃអាបត្តិពីមុន និងរលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយ។ ភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានចំនួន គួររាប់បានខ្លះ រាប់មិនបានខ្លះ មានឈ្មោះដូចគ្នាខ្លះ មានឈ្មោះផ្សេងគ្នាខ្លះ មានចំណែកស្មើគ្នាខ្លះ មានចំណែកខុសគ្នាខ្លះ កំណត់បានខ្លះ ច្រឡូកច្រឡំគ្នាខ្លះ អាត្មាអញនោះ បានសូមសមោធានបរិវាសនឹងសង្ឃ ចំពោះអាបត្តិទាំងនោះ សង្ឃក៏ឲ្យសមោធានបរិវាស ដល់អាត្មាអញនោះ ចំពោះអាបត្តិទាំងនោះ អាត្មាអញនោះ កំពុងនៅបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ អាត្មាអញនោះ បានសូមការទាញ មកដាក់ក្នុងមូលាបត្តិនឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ សង្ឃក៏ទាញអាត្មាអញនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ ដោយកម្មមិនប្រកបដោយធម៌ ជាកម្មកម្រើក ជាកម្មមិនគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ក៏មិនត្រូវតាមធម៌ អាត្មាអញនោះ ក៏សំគាល់ថា ខ្លួននៅបរិវាសហើយ ក៏ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ក្នុងចន្លោះ មានចំនួនគួររាប់បានខ្លះ រាប់មិនបានខ្លះ ហើយបិទបាំងទុកខ្លះ មិនបានបិទបាំងទុកខ្លះ អាត្មាអញនោះ កំពុងឈរលើផែនដីក្នុងទីនោះ រលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុន និងរលឹកឃើញអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយ បើដូច្នោះ មានតែអាត្មាអញ សូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយសូមសមោធានបរិវាស ក៏ត្រូវតាមធម៌ សូមមានត្ត ក៏ត្រូវតាមធម៌ សូមអព្ភាន ក៏ត្រូវតាមធម៌។ ភិក្ខុនោះ ក៏សូមការទាញ មកដាក់ក្នុងមូលាបត្តិ នឹងសង្ឃ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយសូមសមោធានបរិវាស ក៏ត្រូវតាមធម៌ សូមមានត្ត ក៏ត្រូវតាមធម៌ សូមអព្ភាន ក៏ត្រូវតាមធម៌។ សង្ឃក៏ទាញភិក្ខុនោះ មកដាក់ក្នុងមូលាបត្តិ ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិពីមុនផង ចំពោះអាបត្តិក្នុងចន្លោះ នៃអាបត្តិខាងក្រោយផង ដោយកម្មប្រកបដោយធម៌ ជាកម្មមិនកម្រើក ជាកម្មគួរដល់ហេតុ ហើយឲ្យសមោធានបរិវាស ក៏ត្រូវតាមធម៌ ឲ្យមានត្ត ក៏ត្រូវតាមធម៌ ឲ្យអព្ភាន ក៏ត្រូវតាមធម៌។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ទើបបរិសុទ្ធ ចាកអាបត្តិទាំងនោះបាន។

ចប់សមុច្ចយក្ខន្ធក ជាគំរប់បី។ ឧទ្ទាននៃសមុច្ចយក្ខន្ធកនោះគឺ

[៥៨៤]

រឿងអប្បដិច្ឆន្នមានត្ត១ រឿងឯកាហបរិវាស១ រឿងទ្វីហ- តីហ-ចតូហ- បញ្ចាហបរិវាស១ រឿងបក្ខបរិវាស១ រឿងភិក្ខុបិទបាំងអាបត្តិមានបិទបាំងអាបត្តិទុក ដរាបដល់១០ថ្ងៃ ជាទីបំផុត១ រឿងមាសបរិវាស១ រឿងមហាបរិសុទ្ធន្តបរិវាស១ រឿងភិក្ខុកំពុងនៅបរិវាសហើយសឹកចេញទៅ១ រឿងភិក្ខុត្រូវអាបត្តិសង្ឃាទិសេសទាំងឡាយច្រើន ហើយរាប់បាន១ រឿងភិក្ខុពីររូបសំគាល់ ក្នុងអាបត្តិសង្ឃាទិសេសនោះ១ រឿងភិក្ខុពីររូប សង្ស័យក្នុងអាបត្តិសង្ឃាទិសេស១ រឿងភិក្ខុពីររូប មានសេចក្តីយល់ឃើញថា អាបត្តិច្រឡូកច្រឡំគ្នា១ រឿងភិក្ខុពីររូបមានសេចក្តីយល់ឃើញ ក្នុងអាបត្តិច្រឡូកច្រឡំគ្នា ថាអាបត្តិច្រឡូកច្រឡំគ្នាមែន១ រឿងភិក្ខុពីររូបមានសេចក្តីយល់ឃើញក្នុងអសុទ្ធកាបត្តិ១ រឿងភិក្ខុពីររូប មានសេចក្តីយល់ឃើញក្នុងសុទ្ធកាបត្តិនោះថា ជាសុទ្ធកាបត្តិមែន ហើយភិក្ខុមួយរូបបិទបាំងទុក ភិក្ខុមួយរូបទៀត មិនបានបិទបាំងទុក១ រឿងភិក្ខុពីររូប ត្រូវអាបត្តិសង្ឃាទិសេស ហើយចៀសចេញទៅ១ រឿងភិក្ខុពីររូបត្រូវអាបត្តិសង្ឃាទិសេស ហើយត្រឡប់ទៅជាឆ្កួត១ រឿងភិក្ខុពីររូប និយាយទៅនឹងសង្ឃ ដែលកំពុងសំដែងបាតិមោក្ខ១ រឿងសង្ឃទាញភិក្ខុ មកដាក់ក្នុងមូលាបត្តិ១៨វារ (៩ជាអវិសុទ្ធិ ៩ជាវិសុទ្ធិ)១ ព្រះអាចារ្យទាំងឡាយ មានប្រក្រតីនៅក្នុងមហាវិហារដែលមាននៅក្នុងតម្ពបណ្ណិទ្វីប (កោះលង្កា) ជាទីជ្រះថ្លា ថាអ្នកចែកនូវបទព្រះវិន័យ បានសំដែង (សមុច្ចយក្ខន្ធកនេះ) ទុកដើម្បីញុំាងព្រះសទ្ធម្ម គឺព្រះពុទ្ធសាសនា ឲ្យតាំងនៅមាំមួន ជាអង្វែងទៅហោង។

ចប់ភាគ៩

# មាតិកា

Index incomplete!


| ចុល្លវគ្គ | លេខ ទំព័រ |
|---|---|
| **ភាគ ទី១** | **១** |
| **កម្មក្ខន្ធកៈ** | ១ |
| និទានឆព្វគ្គិយភិក្ខុ | ? |
| រឿងបណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ | ១ |
| ការទ្រង់បន្ទោសបណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ | ៣ |
| ការទ្រង់បន្ទោស និងទ្រង់ធ្វើតជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ | ៥ |
| (សង្ឃធ្វើ ) តជ្ជនីយកម្ម ដល់បណ្ឌុកភិក្ខុ និងលោហិតកភិក្ខុ | ៧ |
| តជ្ជនីយកម្មជាកម្មដែលមិនត្រូវតាមធម៌ | ១១ |
| តជ្ជនីយកម្មជាកម្មដែលត្រូវតាមធម៌ | ១៥ |
| ការធ្វើតជ្ជនីយកម្មដល់ភិក្ខុ ៣ ពួក | ១៩ |
| តជ្ជនីយកម្មដែលសង្ឃមិនត្រូវរម្ងាប់ | ២៣ |
| ការរម្ងាប់តជ្ជនីយកម្ម | ២៥ |
| និយស្សកម្ម រឿងសេយ្យសកភិក្ខុ | ២៩ |
| និយស្សកម្ម ជាកម្មដែលមិនត្រូវតាមធម៌ | ៣៣ |
| និយស្សកម្ម ជាកម្មដែលត្រូវតាមធម៌ | ៣៧ |
| ការធ្វើនិយស្សកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ | ៤១ |
| ការធ្វើនិយស្សកម្មដល់ភិក្ខុ ៣ ពួក | ៤៣ |
| និយស្សកម្មដែលសង្ឃមិនត្រូវរម្ងាប់ | ៤៥ |
| និយស្សកម្មដែលសង្ឃត្រូវរម្ងាប់ | ៤៧ |
| | |

| | |
|---|---|
| ការរម្ងាប់និយស្សកម្ម | ៤៩ |
| បព្វាជនីយកម្ម រឿងអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ | ៥១ |
| ការធ្វើបព្វាជនីយកម្ម | ៦៥ |
| បព្វាជនីយកម្មជាកម្មដែលមិនត្រូវតាមធម៌ | ៦៩ |
| បព្វាជនីយកម្មជាកម្មដែលត្រូវតាមធម៌ | ៧១ |
| ការធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៣ | ? |
| ការធ្វើបព្វាជនីយកម្ម ដល់ភិក្ខុ ៣ ពួក | ? |
| ការធ្វើបព្វាជនីយកម្ម ដល់អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ | ? |
| ការធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ ៥ | ? |
| ការរម្ងាប់បព្វាជនីយកម្ម | ? |
| បដិសារណីយកម្ម រឿងសុធម្មភិក្ខុ | ? |
| បដិសារណីយកម្មជាកម្មដែលមិនត្រូវតាមធម៌ | ? |
| បដិសារណីយកម្មជាកម្មដែលត្រូវតាមធម៌ | ? |
| វត្ត ១៨ ក្នុងបដិសារណីយកម្ម | ? |
| វិធីញុំាងសុធម្មភិក្ខុដ៏មានអាយុឲ្យសូមខមាទោស | ? |
| បដិសារណីយកម្មដែលសង្ឃមិនត្រូវរម្ងាប់ | ? |
| ការរម្ងាប់បដិសារណីយកម្ម | ? |
| ឧក្ខេបនីយកម្មព្រោះការមិនឃើញអាបត្តិ | ? |
| ការធ្វើឧក្ខេបនីយកម្មដល់ឆន្នភិក្ខុ | ? |
| ឧក្ខេបនីយកម្មជាកម្មដែលមិនត្រូវតាមធម៌ | ? |
| ឧក្ខេបនីយកម្មជាកម្មដែលត្រូវតាមធម៌ | ? |
| ការធ្វើឧក្ខេបនីយកម្មដល់ភិក្ខុ ៣ ពួក | ? |
| ការប្រព្រឹត្តិដោយប្រពៃក្នុងឧក្ខេបនីយកម្ម | ? |
| ឆន្នភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនីយកម្មហើយ | ? |
| ឧក្ខេបនីយកម្មដែលសង្ឃមិនត្រូវរម្ងាប់ | ? |
| ឧក្ខេបនីយកម្មដែលសង្ឃត្រូវរម្ងាប់ | ? |
| ការរម្ងាប់ឧក្ខេបនីយកម្ម | ? |
| ឧក្ខេបនីយកម្មព្រោះមិនសំដែងអាបត្តិ | ? |
| ឧក្ខេបនីយកម្មជាកម្មដែលមិនត្រូវតាមធម៌ | ? |
| ឧក្ខេបនីយកម្មជាកម្មដែលត្រូវតាមធម៌ | ? |
| ការធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ | ? |
| ការប្រព្រឹត្តដោយប្រពៃក្នុងឧក្ខេបនីយកម្ម | ? |
| ឆន្នភិក្ខុគឺសង្ឃបានធ្វើឧក្ខេបនីយកម្មហើយ | ? |
| ឧក្ខេបនីយកម្មដែលសង្ឃមិនត្រូវរម្ងាប់ | ? |
| ឧក្ខេបនីយកម្មដែលសង្ឃត្រូវរម្ងាប់ | ? |
| ការរម្ងាប់ឧក្ខេបនីយកម្ម | ? |
| រឿងអរិដ្ឋភិក្ខុ និយាយអំពីទិដ្ឋិអាក្រក់ | ? |

| | |
|---|---|
| រឿងអរិដ្ឋភិក្ខុ និយាយអំពីទោសរបស់កាម | ? |
| ឧក្ខេបនីយកម្មព្រោះការមិនលះបង់ទិដ្ឋិអាក្រក់ | ? |
| ឧក្ខេបនីយកម្មជាកម្មដែលមិនត្រូវតាមធម៌ | ? |
| ឧក្ខេបនីយកម្មជាកម្មដែលត្រូវតាមធម៌ | ? |
| ការធ្វើឧក្ខេបនីយកម្មដល់ភិក្ខុដែលប្រកបដោយអង្គ ៣ | ? |
| ការធ្វើឧក្ខេបនីយកម្មដល់ភិក្ខុ ៣ ពួក | ? |
| រឿងអរិដ្ឋភិក្ខុដែលសង្ឃបានធ្វើឧក្ខេបនីយកម្មព្រោះមិនលះបង់ទិដ្ឋិអាក្រក់ | ? |
| ឧក្ខេបនីយកម្មដែលសង្ឃមិនត្រូវរម្ងាប់ | ? |
| ឧក្ខេបនីយកម្មដែលសង្ឃត្រូវរម្ងាប់ | ? |
| ការរម្ងាប់ឧក្ខេបនីយកម្ម | ? |
| ឧទ្ទាននៃកម្មក្ខន្ធក | ? |
| បារិវាសិកក្ខន្ធកៈ | ? |
| រឿងពួកភិក្ខុអ្នកនៅបរិវាស | ? |
| ការទ្រង់បន្ទោសពួកភិក្ខុអ្នកនៅបរិវាស | ? |
| ការប្រព្រឹត្តិដោយប្រពៃនៃភិក្ខុអ្នកនៅបរិវាស | ? |
| វត្តរបស់ភិក្ខុអ្នកនៅបរិវាស | ? |
| វត្តរបស់ភិក្ខុអ្នកនៅបរិវាស | ២១១ |
| រឿងព្រះឧបាលិក្រាបបង្គំទូលសួរពីការដាច់រាត្រីរបស់បារិវាសិកភិក្ខុ | ២១២ |
| វត្តរបស់ភិក្ខុអ្នកនៅបរិវាស | ២១៣ |
| រឿងមូលាយបដិកស្សនារហភិក្ខុ | ២១៤ |
| វត្តរបស់មូលាយបដិកស្សនារហភិក្ខុ | ២១៦ |
| វត្តរបស់មានត្តារហភិក្ខុ | ២២២ |
| វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តមានត្ត | ២៣០ |
| វត្តរបស់អព្ភានារហភិក្ខុ | ២៤០ |
| ឧទ្ទាននៃបារិវាសិកក្ខន្ធក | ២៤៥ |
| សមុច្ចយក្ខន្ធកៈ | ២៤៨ |
| រឿងឧទាយី ត្រូវអាបត្តិឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ | ២៤៨ |
| ការឲ្យមានត្ត | ២៤៩ |
| ការសូមអព្ភាន | ២៥៣ |
| អព្ភានកម្ម | ២៥៤ |
| ការឲ្យឯកាហបរិវាស | ២៤៧ |
| ការឲ្យមានត្ត | ២៦០ |
| ការសូមអព្ភានកម្ម | ២៦៥ |
| អព្ភានកម្ម | ២៦៧ |
| ការសូមបញ្ចាហបរិវាស | ២៧១ |
| ការសូមមូលាយបដិកស្សនា | ២៧៣ |
| មូលាយបដិកស្សនា | ២៧៥ |

| | |
|---|---|
| ការសូមមូលាយបដិកស្សនា | ២៧៩ |
| មូលាយបដិកស្សនា | ២៨១ |
| ការសូមមានត្ត | ២៨៥ |
| ការឲ្យមានត្ត | ២៨៧ |
| ការសូមមូលាយបដិកស្សនា | ២៩១ |
| មូលាយបដិកស្សនា | ២៩៣ |
| ការសូមមានត្ត | ២៩៧ |
| ការឲ្យមានត្ត | ២៩៩ |
| ការសូមអព្ភានកម្ម | ៣០៣ |
| អព្ភានកម្ម | ៣០៦ |
| ការសូមបក្ខបរិវាស | ៣០៩ |
| ការឲ្យបក្ខបរិវាស | ៣១០ |
| ការសូមមូលាយបដិកស្សនា | ៣១៣ |
| មូលាយបដិកស្សនា | ៣១៤ |
| ការឲ្យសមោធានបរិវាស | ៣១៧ |
| ការឲ្យមានត្ត | ៣២២ |
| មូលាយបដិកស្សនា | ៣២៥ |
| ការសូមអព្ភានកម្ម | ៣២៦ |
| អព្ភានកម្ម | ៣៣១ |
| ការឲ្យសមោធានបរិវាសតាមតម្លៃអាបត្តិ | ៣៣៦ |
| ការសូមទ្វេមាសបរិវាស | ៣៤២ |
| ការឲ្យទ្វេមាសបរិវាស | ៣៤៥ |
| ត្រូវ (ភិក្ខុនោះ) នៅបរិវាសពីរខែ | ៣៤៩ |
| ភិក្ខុត្រូវនៅបរិវាសពីរខែ | ៣៥១ |
| ភិក្ខុគួរដល់មានត្ត | ៣៥៥ |
| សង្ឃត្រូវឲ្យមាសបរិវាសដល់ភិក្ខុ | ៣៥៩ |
| មាសបរិវាសសង្ឃត្រូវឲ្យដល់ភិក្ខុ | ៣៦១ |
| ការឲ្យមាសបរិវាស | ៣៦៣ |
| ភិក្ខុត្រូវនៅបរិវាសពីរខែ | ៣៦៧ |
| ត្រូវភិក្ខុនោះនៅបរិវាសពីរខែ | ៣៧១ |
| ភិក្ខុគួរដល់មានត្ត | ៣៧៣ |
| ការឲ្យសុទ្ធន្តបរិវាស | ៣៧៧ |
| សុទ្ធន្តបរិវាស | ៣៧៩ |
| បរិវាសរបស់ភិក្ខុឆ្អតជាដើមមិនលូតលាស់ឡើង | ៣៨៣ |
| បរិវាសរបស់ភិក្ខុដែលសង្ឃលើកវត្តជាដើមមិនលូតលាស់ឡើង | ៣៨៥ |
| ការប្រព្រឹត្តមានត្តរបស់បុគ្គលដែលសឹកចេញជាដើមមិនលូតលាស់ឡើង | ៣៨៧ |

| | |
|---|---|
| អព្ភានកម្មរបស់ភិក្ខុដែលសឹកចេញមិនលូតលាស់ឡើង | ៣៨៩ |
| (សង្ឃត្រូវឲ្យ) សមោធានបរិវាសចំពោះអាបត្តិខាងដើម | ៣៩១ |
| សង្ឃត្រូវឲ្យបរិវាសទៀតហើយសឹមឲ្យមានត្ត | ៣៩៦ |
| (សង្ឃត្រូវឲ្យ) សមោធានបរិវាសចំពោះអាបត្តិខាងដើម | ៤១០ |
| ភិក្ខុគួរដល់មានត្ត ប្រព្រឹត្តមានត្ត និងគួរដល់អព្ភានកម្ម | ៤២៥ |
| (សង្ឃត្រូវឲ្យ) សមោធានបរិវាសចំពោះអាបត្តិខាងដើម | ៤២៧ |
| សង្ឃត្រូវឲ្យមានត្តដល់ភិក្ខុទាំងពីររូប | ៤១៨ |
| ភិក្ខុទាំងនោះមិនបានបរិសុទ្ធចាកអាបត្តិទាំងនោះ | ៤៣២ |
| ភិក្ខុនោះបរិសុទ្ធចាកអាបត្តិទាំងនោះ | ៤៤០ |
| ឧទ្ទាននៃសមុច្ចយក្ខន្ធក | ៤៥៣ |


ភាគ ទី៨ | **មាតិកា** | ភាគ ទី១០

1)
ភិក្ខុពីររូបនេះនៅក្នុងពួកឆព្វគ្គិយភិក្ខុ ក្នុងអដ្ឋកថា ថា សូម្បីតែសិស្សគណៈរបស់ភិក្ខុពីររូបនោះ ក៏គេហៅថា បណ្ឌុក និងលោហិតកដែរ។
2)
កម្មដែលសង្ឃត្រូវធ្វើដល់ភិក្ខុដែលគួរគម្រាម។
3)
អាបត្តិដែលសំដែងមិនដាច់ អដ្ឋកថាថា បានដល់អាបត្តិពីរកង គឺបារាជិក១ សង្ឃាទិសេស១ តែសារត្ថទីបនីដីកាថា អាបត្តិដែលមិនមែនជាទេសនាគាមិនីក្នុងទីនេះ សំដៅយកអាបត្តិបារាជិកតែម្យ៉ាង ព្រោះតជ្ជនីយកម្ម សង្ឃធ្វើដល់ភិក្ខុ ដែលត្រូវអាបត្តិសង្ឃាទិសេសប៉ុណ្ណោះ មិនមែនធ្វើដល់ភិក្ខុ ដែលត្រូវអាបត្តិបារាជិកទេ។
4)
ក្នុងទីឯទៀត លោកសំដៅយកអាបត្តិបារាជិក និងសង្ឃាទិសេស ប៉ុន្តែក្នុងទីនេះ សំដៅយកអាបត្តិសង្ឃាទិសេសតែម្យ៉ាង ហេតុនេះ សង្ឃមិនត្រូវធ្វើតជ្ជនីយកម្មព្រោះត្រូវអាបត្តិបារាជិកទេ សង្ឃត្រូវធ្វើតជ្ជនីយកម្មបាន ចំពោះតែត្រូវអាបត្តិសង្ឃាទិសេសតែម្យ៉ាងប៉ុណ្ណោះ (សារត្ថទីបនីដីកា)។
5)
ភិក្ខុដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ មិនត្រូវសូមឱកាស ភិក្ខុណាមួយដែលមានទោសដើម្បីចោទភិក្ខុនោះ។
6)
ស្លូត សុភាពរាបទាប
7)
កម្មដែលសង្ឃត្រូវធ្វើឲ្យថយ យស។
8)
ភិក្ខុដែលល្ងង់ មិនឆ្លាសនោះ ត្រូវសូមនិស្ស័យ ហើយនៅអាស្រ័យនឹងគ្រូអាចារ្យរបស់ខ្លួន មិនត្រូវនៅ ដោយនិស្សយមុត្តកទេ។
9)
ចត្រង្គមានក្រឡា៨
10)
ចត្រង្គមានក្រឡា១០។ ន័យខ្លះប្រែថា បាយខុំ
11)
ចត្រង្គគ្មានក្ដារ លេងតែមាត់ទទេ។
12)
ប្រហែលជាលេងបិទមុខ បិទពួន។
13)
កម្មដែលសង្ឃត្រូវបណ្ដេញ ឬបំបរបង់ភិក្ខុដែលមានទោសឲ្យចេញពីទីអាវាស។
14)
ការល្មើសនឹងសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្ត ក្នុងកាយទ្វារ ហៅថា អនាចារផ្លូវកាយ (អដ្ឋកថា)។
15)
ការបៀតបៀន បានខាងឯការបំផ្លាញ ពង្រេច ដោយមិនប្រឹងសិក្សាសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្តក្នុងកាយទ្វារ។

16)

មិច្ឆាជីវៈផ្លូវកាយ បានដល់ការចិញ្ចឹមជីវិត មានស្លប្រេង ស្លថ្នាំអវិជ្ជជាដើម ដោយអំណាចអនេសនា មានវេជ្ជកម្មដែលទ្រង់ហាមជាដើម។
17)

មិច្ឆាជីវៈផ្លូវវាចា បានដល់ទទួល និងប្រាប់ដំណឹងរបស់ពួកគ្រហស្ថជាដើម (ទូត)។
18)

អដ្ឋកថា ថា សូម្បីប្រកបដោយអង្គ១ ក៏គប្បីធ្វើបដិសារណីយកម្មដែរ។
19)

ភិក្ខុជាអ្នកទទួលបម្រើរបស់សង្ឃ ដែលត្រូវចាត់ឲ្យទៅ តាមពិនិត្យមើលការ ឬជួយសូមទោស គឺជាអ្នកដំណាងសង្ឃ។
20)

ក្នុងអដ្ឋកថា ថា មិនត្រូវទ្រទ្រង់សំពត់ពណ៌ស មិនបានកាត់ជាយផង មានជាយជាផ្កាផង។
21)

មិនត្រូវទ្រទ្រង់សំពត់ទាំងឡាយ មានសំពត់ដែលគេក្រងដោយស្បូវជាដើម។
22)

បរិវាស មាន៤យ៉ាង គឺអប្បដិច្ឆន្នបរិវាស១ បដិច្ឆន្នបរិវាស១ សុទ្ធន្តបរិវាស១ សមោធានបរិវាស១។ ឯអប្បដិច្ឆន្នបរិវាសនោះ បានសំដែងរួចហើយ ក្នុងមហាខន្ធក នៃមហាវគ្គ ចំណែកបរិវាស៣ទៀតនោះ មានសេចក្តីពិស្តារក្នុងសមុច្ចយក្ខន្ធក។
23)

លំដាប់ភត្ត មានឧទ្ទេសភត្តជាដើម ដែលសង្ឃត្រូវចែកឲ្យដល់ខ្លួនក្នុងថ្ងៃនេះ ហើយខ្លួនក៏លះបង់ភត្តនោះ គឺប្រាប់ឲ្យចែកដល់ភិក្ខុដទៃសិន ចំណែកខ្លួន នឹងសូមទទួល ក្នុងថ្ងៃតទៅ។
24)

ទទួលចែកភត្ត ដែលខ្លួនត្រូវបានតាមលំដាប់វស្សាបាន
25)

អដ្ឋកថាថា មិនត្រូវធ្វើជាឧបជ្ឈាយ៍ ឲ្យឧបសម្បទា ដល់កុលបុត្ត ប៉ុន្តែ បើបានដាក់វត្តហើយ នឹងឲ្យឧបសម្បទា ក៏គួរ។ មិនត្រូវធ្វើជាអាចារ្យ សូត្រកម្មវាចា កាលបើគ្មានភិក្ខុដទៃ ភិក្ខុនោះបានដាក់វត្តហើយ សូត្រកម្មវាចាក៏គួរ។
26)

មិនត្រូវឲ្យនិស្ស័យ ដល់ភិក្ខុជាអាគន្តុក ភិក្ខុឯណាបានកាន់និស្ស័យទៅហើយ ត្រូវប្រាប់ភិក្ខុអស់នោះថា ខ្ញុំធ្វើវិនយកម្ម ត្រូវលោកកាន់យកនិស្ស័យ ក្នុងសំណាក់ព្រះថេរៈឯណោះចុះ កុំមកធ្វើវត្តដល់ខ្ញុំឡើយ វេលាចូលស្រុក កុំមកលាខ្ញុំឡើយ។ បើបានហាមយ៉ាងនេះហើយ គេនៅតែធ្វើ នោះ បារិវាសិកភិក្ខុ មិនត្រូវអាបត្តិទេ។
27)

មិនត្រូវទទួលសាមណេរឯទៀត ទុកជាសាមណេរដែលខ្លួនបំបួសហើយ ក៏ត្រូវហាមថា ខ្ញុំធ្វើវិនយកម្ម កុំមកធ្វើវត្តដល់ខ្ញុំឡើយ។ បើបានហាមយ៉ាងនេះហើយ សាមណេរអស់នោះ នៅតែធ្វើ បារិវាសិកភិក្ខុនោះ មិនត្រូវអាបត្តិឡើយ។
28)

បារិវាសិកភិក្ខុគិតថា អញនឹងអង្គុយឆាន់ក្នុងវត្តនេះ ហើយនឹងរាប់រាត្រីទាំងឡាយ កាលបើអញចេញទៅបិណ្ឌបាត្រ នឹងប្រទះភិក្ខុក្នុងស្រុក កាលបើអញមិនប្រាប់ នឹងដាច់រាត្រី បារិវាសិកភិក្ខុនោះ មិនត្រូវឲ្យគេនាំចង្ហាន់បិណ្ឌបាត មកដើម្បីខ្លួន ដោយហេតុនេះឯង។ ទុកជាប្រើឲ្យសាមណេរចំអិន ហើយឆាន់ ក្នុងវត្ត ដោយអធ្យាស្រ័យថា កុំឲ្យអ្នកណាមួយ ដឹងសោះឡើយ ដូច្នេះ ក៏មិនបាន បារិវាសិកភិក្ខុនោះ ត្រូវតែចូលទៅបិណ្ឌបាតក្នុងស្រុក។
29)

អាវាស បានដល់ទីសេនាសន ដែលគេធ្វើសម្រាប់នៅ។
30)

អនាវាស បានដល់រាន សម្រាប់ទុកអម្បោស រានសម្រាប់ទុកឧស រោងទឹក បង្គន់ និងក្លោងទ្វារ ជាដើម។
31)

គឺនៅជាមួយនឹងភិក្ខុ ជាបកតត្ត ក្នុងលំនៅដែលមានដម្បូលមួយរួមគ្នា។
32)

គឺនៅតែឯង មិនបាននៅក្នុងអាវាស ដែលមានភិក្ខុជាបកតត្ត។
33)

គឺមិនប្រាប់ ការដែលខ្លួនប្រព្រឹត្ត ដល់ភិក្ខុផងគ្នា មានអាគន្តុកភិក្ខុជាដើម។
34)

អដ្ឋកថា ថា គឺនៅក្នុងទីមានដម្បូលមួយ ជាមួយនឹងភិក្ខុជាបកតត្ត។
35)

នៅតែម្នាក់ឯង គឺនៅក្នុងទី ដែលគ្មានសង្ឃជាគ្នា។
36)

គឺមិនប្រាប់ ថាខ្លួនជាមានត្តចារិកភិក្ខុ ដល់អាគន្តុកភិក្ខុ ជាដើម។
37)
គឺមិនគ្រប់ចំនួនសង្ឃ តាំងពី៤រូបឡើងទៅ។
38)
អាបត្តិប្រកបដោយចិត្តក្លែង ហៅថា សញ្ចេតនិក ការញ៉ាំងទឹកសុក្ក ឲ្យឃ្លាតចេញ ហៅថា សុក្កវិសដ្ឋិ
39)
ពាក្យថា អព្ភានកម្ម បានខាង កម្មដែលសង្ឃហៅរកបារិវាសិកភិក្ខុ មកជាបកតត្តភិក្ខុវិញ។
40)
គឺតាមចំនួនថ្ងៃ ដែលបិទក្រោយបង្អស់។
41)
ទីនេះ សំដៅយកតែត្រឹមអាបត្តិសង្ឃាទិសេស៣។
42)
បរិវាស មានបរិសុទ្ធិជាទីបំផុតនោះ ប្រៀបដូចជាភិក្ខុមួយរូប បួសបាន៧ខែ តែ៣ខែខាងដើម ភិក្ខុនោះ នឹកឃើញថា ខ្លួនបរិសុទ្ធ ឥតមានត្រូវអាបត្តិសង្ឃាទិសេស ៤ខែខាងចុង ភិក្ខុនោះដឹងខ្លះ សង្ស័យខ្លះ ថាខ្លួនមិនបរិសុទ្ធ តែមិនដឹងកំណត់អាបត្តិ និងកំណត់រាត្រីជាដើម ត្រូវធ្វើបរិវាស៤ខែ គឺរាប់ថ្ងៃឲ្យទល់នឹងថ្ងៃដែលបរិសុទ្ធ ហៅថា សុទ្ធន្តបរិវាស។
43)
អាបត្តិសង្ឃាទិសេស ដែលច្រឡូកច្រឡំ ដោយលហុកាបត្តិ មានថុល្លច្ច័យជាដើម (អដ្ឋកថា)។
44)
ពួកលហុកាបត្តិ មានថុល្លច្ច័យជាដើម ហៅថា សុទ្ធកាបត្តិ (អដ្ឋកថា)។

sangham.net
Virtual AccessToInsight

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ១០ - Book 010

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថា លោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០១០ - Tipitaka Book 010 [http://forum.sangham.net/index.php/topic,9190.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០១០




គំរូ ឯកសារ ផ្សេងទៀត ៖
book_010.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី ១០

ទ.

# វិន័យបិដក

CS vin | ភាគ ទី១០

**ភាគ ទី១៤**

# ចុល្លវគ្គ

CS vin.cv | ភាគ ទី១០

**(ចូឡវគ្គោ)**

**ទុតិយភាគ**
ភាគ ទី២

សមថក្ខន្ធកៈ | ខុទ្ទកវត្ថុក្ខន្ធកៈ | និងសេនាសនក្ខន្ធកៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

# សមថក្ខន្ធកៈ (ទី៤)

CS vin.cv.04 | ភាគ ទី១០

**(៤. សមថក្ខន្ធកំ)**

# (សម្មុខាវិនយ ទី១)

CS vin.cv.04.01 | ភាគ ទី១០

## (១. សម្មុខាវិនយោ)

[១] សម័យនោះ ព្រះសម្មាសម្ពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ តែងធ្វើកម្មទាំងឡាយ គឺតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយ ដែលមិនមានក្នុងទីចំពោះមុខ។ ភិក្ខុទាំងឡាយណា ជាអ្នកប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងធ្វើកម្មទាំងឡាយ គឺតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយ ដែលមិនមាន ក្នុងទីចំពោះមុខសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុ តែងធ្វើកម្មទាំងឡាយ គឺតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយ ដែលមិនមានក្នុងទីចំពោះមុខ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះពុទ្ធមានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើ នឹងធ្វើកម្មទាំងឡាយ គឺតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយ ដែលមិនមានក្នុងទីចំពោះមុខទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លា។ បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយ ដែលមិនមានក្នុងទីចំពោះមុខទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។

[២] (បទមាតិកាទាំង៦) គឺ បុគ្គល ជាអធម្មវាទី (អ្នកពោលមិនត្រូវធម៌)១ ភិក្ខុទាំងឡាយច្រើន[1] ជាអធម្មវាទី១ សង្ឃជាអធម្មវាទី១ បុគ្គលជាធម្មវាទី (អ្នកពោលត្រូវធម៌)១ ភិក្ខុទាំងឡាយច្រើន ជាធម្មវាទី១ សង្ឃជាធម្មវាទី១។

# (កណ្ហបក្ខនវក)

CS vin.cv.04.01.01 | ភាគ ទី១០

## (កណ្ហបក្ខនវកំ)

[៣] បុគ្គលជាអធម្មវាទី ញុំាងបុគ្គលជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរគាប់ចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ ជាសម្មុខាវិន័យប្លម គឺគ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។ បុគ្គលជាអធម្មវាទី ញុំាងភិក្ខុទាំងឡាយច្រើន ជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកទាំងឡាយ ចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។ បុគ្គលជាអធម្មវាទី ញុំាងសង្ឃ ជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គឺគ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។ ភិក្ខុទាំងឡាយច្រើន ជាអធម្មវាទី ញុំាងបុគ្គលជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។ ភិក្ខុទាំងឡាយច្រើន ជាអធម្មវាទី ញុំាងភិក្ខុទាំងឡាយច្រើន ជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកទាំងឡាយ ចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។ ភិក្ខុទាំងឡាយច្រើន ជាអធម្មវាទី ញុំាងសង្ឃ ជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។ សង្ឃ ជាអធម្មវាទី ញុំាងបុគ្គលជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។ សង្ឃ ជាអធម្មវាទី ញុំាងភិក្ខុច្រើន ជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកទាំងឡាយ ចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។ សង្ឃ ជាអធម្មវាទី ញុំាងសង្ឃជាធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្តា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយមិនត្រូវតាមធម៌ គ្រាន់តែប្រហែលគ្នា នឹងសម្មុខាវិន័យ។

ចប់ កណ្ហបក្ខ មានចំនួន៩។

## (សុក្កបក្ខនវក)

CS vin.cv.04.01.02 | ភាគ ទី១០

### (សុក្កបក្ខនវកំ)

[៤] បុគ្គលជាធម្មវាទី ញុំាងបុគ្គលជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ។ បុគ្គលជាធម្មវាទី ញុំាងភិក្ខុទាំងឡាយច្រើន ជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ។ បុគ្គលជាធម្មវាទី ញុំាងសង្ឃជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ។ ភិក្ខុទាំងឡាយច្រើន ជាធម្មវាទី ញុំាងបុគ្គលជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ។ ភិក្ខុទាំងឡាយច្រើន ជាធម្មវាទី ញុំាងភិក្ខុច្រើន ជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ។ ភិក្ខុទាំងឡាយច្រើន ជាធម្មវាទី ញុំាងសង្ឃ ជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ។ សង្ឃ ជាធម្មវាទី ញុំាងបុគ្គលជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ។ សង្ឃ ជាធម្មវាទី ញុំាងភិក្ខុទាំងឡាយច្រើន ជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យ។ សង្ឃ ជាធម្មវាទី ញុំាងសង្ឃ ជាអធម្មវាទី ឲ្យកត់សំគាល់ ឲ្យពិចារណា ឲ្យពិនិត្យ ឲ្យពិនិត្យរឿយៗ ឲ្យឃើញ ឲ្យឃើញរឿយៗថា នេះធម៌ នេះវិន័យ នេះពាក្យប្រដៅ របស់ព្រះសាស្ដា អ្នកចូរកាន់យកពាក្យនេះចុះ ចូរពេញចិត្តនឹងពាក្យនេះចុះ ដូច្នេះ បើអធិករណ៍នោះ រម្ងាប់យ៉ាងនេះ ឈ្មោះថា រម្ងាប់ដោយធម៌ ដោយសម្មុខាវិន័យដូច្នេះ។

ចប់ សុក្កបក្ខ មានចំនួន៩។

# (សតិវិនយ ទី២)

CS vin.cv.04.02 | ភាគ ទី១០

### (២. សតិវិនយោ)

[៥] សម័យនោះ ព្រះសម្មាសម្ពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង ព្រះទព្វមល្លបុត្តដ៏មានអាយុ បានធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល តាំងអំពីកើតមកបាន៧ឆ្នាំ ថែមទាំងគុណជាតណាមួយ ដែល សាវ័កត្រូវដល់ គុណជាតនោះ លោកក៏បានដល់ ដោយលំដាប់សព្វគ្រប់ហើយ កិច្ចអ្វីមួយ ដែលលោកគប្បីធ្វើតទៅទៀត ឬការសន្សំនូវកិច្ចដែលធ្វើរួចហើយ ក៏មិនមានដល់លោក។

[៦] លំដាប់នោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ ទៅកាន់ទីស្ងាត់ សម្ងំនៅស្ងប់ស្ងៀមតែម្នាក់ឯង ហើយមានចិត្តត្រិះរិះកើតឡើង យ៉ាងនេះថា អាត្មាអញ បានធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល តាំងពីកើតមកបាន៧ឆ្នាំ គុណជាតណានីមួយ ដែលសាវ័កត្រូវដល់ អាត្មាអញ ក៏បានដល់ នូវគុណជាតនោះ ដោយលំដាប់សព្វគ្រប់ហើយ មួយទៀត កិច្ចអ្វីមួយ ដែលអាត្មាអញ ត្រូវធ្វើតទៅទៀត ឬការសន្សំនូវកិច្ចដែលធ្វើរួចហើយ ក៏មិនមានដល់អាត្មាអញ (បើដូច្នោះ) គួរអាត្មាអញ ធ្វើការខ្វល់ខ្វាយបម្រើដល់សង្ឃដូចម្តេចហ្ន៎។ គ្រានោះ ព្រះទព្វមល្លបុត្តមានអាយុ បានត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញ ត្រូវរៀបចំសេនាសនៈផង ត្រូវចាត់ចែងចង្ហាន់ដល់សង្ឃផងចុះ។

[៧] គ្រានោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ លុះសាយណ្ហសម័យ ក៏ចេញពីទីពួនសម្ងំនៅ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយក្នុងទីដ៏សមគួរ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គទៅកាន់ទីស្ងាត់ ពួនសម្ងំនៅតែម្នាក់ឯង ក៏មានចិត្តត្រិះរិះ កើតឡើងយ៉ាងនេះថា អាត្មាអញ បានធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល តាំងអំពីកើតមកបាន៧ឆ្នាំ ហើយគុណជាតណានីមួយ ដែលសាវ័កត្រូវដល់ អាត្មាអញ ក៏បានដល់ នូវគុណជាតនោះ ដោយលំដាប់សព្វគ្រប់ហើយ មួយទៀត កិច្ចអ្វីមួយ ដែលអាត្មាអញ គប្បីធ្វើតទៅទៀត ឬការសន្សំនូវកិច្ច ដែលបានធ្វើរួចហើយ មិនមានដល់អាត្មាអញទេ គួរអាត្មាអញ ធ្វើការខ្វល់ខ្វាយបម្រើ ដល់សង្ឃដូចម្តេចហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា បើដូច្នោះ មានតែអាត្មាអញ ត្រូវរៀបចំសេនាសនៈផង ត្រូវចាត់ចែងចង្ហាន់ ដល់សង្ឃផងចុះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចង់រៀបចំសេនាសនៈផង ចង់ចាត់ចែងចង្ហាន់ ដល់សង្ឃផង។ ព្រះបរមគ្រូ ទ្រង់ត្រាស់ថា ម្នាលទព្វៈ ប្រពៃហើយៗ ម្នាលទព្វៈ

បើដូច្នោះ អ្នកចូររៀបចំសេនាសនៈ ហើយចាត់ចែងចង្ហាន់ ដល់សង្ឃចុះ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណា ព្រះអង្គ។

[៨] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរសន្មតទព្វមល្លបុត្ត ឲ្យជាសេនាសនប្បញ្ញាបកៈ (អ្នកចាត់ចែងសេនាសនៈ)ផង ឲ្យជាភត្តុទ្ទេសកៈ (អ្នកចាត់ចែងចង្ហាន់)ផង។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ។ មុនដំបូង ត្រូវសង្ឃសូមទព្វភិក្ខុ លុះសូមរួចហើយ ត្រូវភិក្ខុដែលឈ្លាសវៃ ប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើការសន្មតិ មានកាលគួរ ដល់សង្ឃហើយ សូមសង្ឃសន្មតទព្វមល្លបុត្តមានអាយុ ឲ្យជាសេនាសនប្បញ្ញាបកៈផង ឲ្យជាភត្តុទ្ទេសកៈផង។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតទព្វមល្លបុត្តមានអាយុ ឲ្យជាសេនាសនប្បញ្ញាបកៈផង ឲ្យជាភត្តុទ្ទេសកៈផង។ ការសន្មតិព្រះទព្វមល្លបុត្តមានអាយុ ឲ្យជាសេនាសនប្បញ្ញាបកៈផង ឲ្យជាភត្តុទ្ទេសកៈផង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានសន្មតព្រះទព្វមល្លបុត្តមានអាយុ ឲ្យជាសេនាសនប្បញ្ញាបកៈផង ឲ្យជាភត្តុទ្ទេសកៈផងហើយ ការសន្មតិនេះ គួរដល់សង្ឃ ហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[៩] ព្រះទព្វមល្លបុត្តដ៏មានអាយុ ដែលសង្ឃបានសន្មតរួចហើយ ក៏រៀបចំសេនាសនៈ ដើម្បីភិក្ខុទាំងឡាយ ដែលសុទ្ធតែជាសភាគៈនឹងគ្នា ក្នុងទីជាមួយគ្នា ពួកភិក្ខុណាជាអ្នករៀនព្រះសូត្រ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏រៀបចំសេនាសនៈ ដើម្បីពួកភិក្ខុនោះ ក្នុងទីជាមួយគ្នា ដោយគិតថា ភិក្ខុទាំងនោះ នឹងនាំគ្នាហាត់សមព្រះសូត្រ ពួកភិក្ខុណា ជាអ្នកទ្រទ្រង់វិន័យ ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនៈ ដើម្បីពួកភិក្ខុទាំងនោះ ក្នុងទីជាមួយគ្នា ដោយគិតថា ភិក្ខុទាំងនោះ នឹងនាំគ្នាវិនិច្ឆ័យវិន័យ ពួកភិក្ខុណា ជាធម្មកថិក ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនៈ ដើម្បីភិក្ខុទាំងនោះ ក្នុងទីជាមួយគ្នា ដោយគិតថា ភិក្ខុទាំងនោះ នឹងនាំគ្នាធ្វើសាកច្ឆាធម៌ ពួកភិក្ខុណា ជាអ្នកចំរើនឈាន ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនៈ ដើម្បីភិក្ខុទាំងនោះ ក្នុងទីជាមួយគ្នា ដោយគិតថា ភិក្ខុទាំងនោះ នឹងមិនបៀតបៀនគ្នាទៅវិញទៅមក ពួកភិក្ខុណា ជាអ្នកពោលនូវតិរច្ឆានកថា ច្រើនតែមានរាងកាយមាំមួន ព្រះទព្វមល្លបុត្ត ក៏រៀបចំសេនាសនៈ ដើម្បីពួកភិក្ខុនោះ ក្នុងទីជាមួយគ្នា ដោយគិតថា លោកមានអាយុទាំងឡាយនេះ នឹងនៅទាល់ភ្លឺ ដោយពោលនូវតិរច្ឆានកថានេះ ភិក្ខុទាំងឡាយណា មកដល់ក្នុងវេលាវិកាល[2] ព្រះទព្វមល្លបុត្ត ក៏ចូលកាន់តេជោធាតុ ហើយរៀបចំសេនាសនៈ ដើម្បីភិក្ខុទាំងនោះ ដោយពន្លឺនៃតេជោធាតុនោះឯង។ ចួនកាល មានភិក្ខុទាំងឡាយក្លែងមក ក្នុងវេលាវិកាល ដោយគិតថា យើងទាំងឡាយ នឹងបានឃើញឥទ្ធិប្បាដិហារ្យ របស់ព្រះទព្វមល្លបុត្តដ៏មានអាយុ។ ភិក្ខុទាំងឡាយនោះ ក៏ចូលទៅរកព្រះទព្វមល្លបុត្តដ៏មានអាយុ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោទព្វៈ ចូរលោករៀបចំសេនាសនៈ ដើម្បីយើងទាំងឡាយ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ និយាយយ៉ាងនេះ នឹងភិក្ខុទាំងនោះថា លោកទាំងឡាយដ៏មានអាយុ ចង់នៅក្នុងទីណា ឲ្យខ្ញុំរៀបចំក្នុងទីណា។ ភិក្ខុទាំងឡាយនោះ ក្លែងចង្អុលទៅរកទីឆ្ងាយ ដោយពាក្យថា ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈលើភ្នំគិជ្ឈកូដ ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ជិតជ្រោះសម្រាប់ទម្លាក់ចោរ ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ លើកាឡសិលាខាងភ្នំឥសិគិលិ ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ក្នុងសត្តបណ្ណគុហា ខាងភ្នំវេភារៈ ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ទៀបញកភ្នំ ឈ្មោះ សប្បសោណ្ឌិកៈ ក្នុងសីតវ័ន (ព្រៃត្រជាក់) ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ទៀបជ្រោះភ្នំ ឈ្មោះ គោមដៈ ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ទៀបជ្រោះភ្នំ ឈ្មោះ តិណ្ឌុកៈ ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ទៀបជ្រោះភ្នំ ឈ្មោះកបោតៈ ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ក្នុងវត្តតបោទា ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ក្នុងជីវកម្ពវ័ន ដើម្បីយើងទាំងឡាយចុះ។ ម្នាលអាវុសោទព្វៈ លោកចូររៀបចំសេនាសនៈ ក្នុងមិគទាយវ័ន ទៀបភ្នំមទ្ទកុច្ឆិ ដើម្បីយើងទាំងឡាយចុះ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ចូលកាន់តេជោធាតុ ហើយមានម្រាមភ្លឺរុងរឿង ដើរទៅអំពីខាងមុខៗ នៃភិក្ខុទាំងឡាយនោះ។ ភិក្ខុទាំងឡាយនោះ ក៏ដើរទៅអំពីខាងក្រោយៗ នៃព្រះទព្វមល្លបុត្តមានអាយុ ដោយពន្លឺនោះឯង។ ព្រះទព្វមល្លបុត្តមានអាយុ រៀបចំសេនាសនៈ ដល់ភិក្ខុទាំងឡាយនោះ យ៉ាងនេះថា នេះគ្រែ នេះតាំង នេះពូក នេះខ្នើយ នេះទីសម្រាប់បន្ទោបង់ឧច្ចារៈ នេះទីសម្រាប់បន្ទោបង់បស្សាវៈ នេះទឹកសម្រាប់ឆាន់ នេះទឹកសម្រាប់ប្រើប្រាស់ នេះឈើច្រត់ នេះទីកតិកាសញ្ញារបស់សង្ឃ ពេលនេះ ត្រូវលោកទាំងឡាយចូល ពេលនេះ ត្រូវលោកទាំងឡាយចេញ។ ព្រះទព្វមល្លបុត្តមានអាយុ រៀបចំសេនាសនៈ យ៉ាងនេះ ដល់ភិក្ខុទាំងឡាយនោះ ហើយនិមន្តត្រឡប់មកវត្តវេឡុវ័នវិញ។

[១០] សម័យនោះឯង មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយ ជាភិក្ខុថ្មីផង មានបុណ្យតិចផង។ លោកទាំងនោះ តែងបានសេនាសនៈទាំងឡាយ របស់សង្ឃ ដែលជារបស់ថោកទាប និងភត្តដ៏ថោកទាប។ សម័យនោះឯង មនុស្សទាំងឡាយ ក្នុងក្រុងរាជគ្រឹះ ចង់ប្រគេនសប្បិខ្លះ ប្រេងខ្លះ សម្លឧត្តរិភង្គខ្លះ[3] ដែលគេតាក់តែងឡើង ដោយផ្ចិតផ្ចង់ ដល់ភិក្ខុទាំងឡាយជាថេរៈ ចំណែកខាងមេត្តិយភិក្ខុ និងភុម្មជកភិក្ខុវិញ គេប្រគេនតែត្រឹមបាយចុងអង្ករ មានទឹកជ្រក់ ជាគំរប់ពីរ ជាភោជនប្រក្រតី ដែលគេប្រារព្ធហើយយ៉ាងណា។[4] ពួកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងនោះ ត្រឡប់ពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយក៏សួរភិក្ខុទាំងឡាយ ជាថេរៈថា ម្នាលអាវុសោទាំងឡាយ ក្នុងរោងភត្តរបស់លោក មានអ្វីខ្លះ មិនមានអ្វីខ្លះ។ ព្រះថេរៈទាំងឡាយពួកខ្លះ ប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ក្នុងរោងឆាន់របស់យើង មានសប្បិ មានប្រេង មានសម្លឧត្តរិភង្គ។ ឯមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ និយាយប្រាប់យ៉ាងនេះថា ម្នាលអាវុសោ យើងគ្មានវត្ថុអ្វីទេ មានតែបាយចុងអង្ករ និងទឹកជ្រក់ ជាគំរប់ពីរ ជាភោជនប្រក្រតី ដែលគេប្រារព្ធហើយយ៉ាងណាប៉ុណ្ណោះ។

[១១] សម័យនោះឯង គហបតិ ឈ្មោះកល្យាណភត្តិកៈ តែងប្រគេនចតុក្កភត្ត[5] ជានិច្ចភត្ត ដល់សង្ឃ។ គហបតិនោះ ព្រមទាំងកូនប្រពន្ធ តែងចូលទៅបម្រើ អង្គាស (ព្រះសង្ឃ) ក្នុងរោងភត្ត។ ភិក្ខុទាំងឡាយដទៃៗ ក៏សួររកបាយ សួររកសម្ល រកប្រេង រកសម្លឧត្តរិភង្គ។

[១២] សម័យនោះឯង ភត្តុទ្ទេសកភិក្ខុ ចាត់ពួកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ (ឲ្យទៅទទួល) ចង្ហាន់របស់កល្យាណភត្តិកគហបតិ ក្នុងថ្ងៃព្រឹកស្អែក។ គ្រានោះ កល្យាណភត្តិកគហបតិ បានទៅកាន់អារាម ដោយមានកិច្ចអ្វីមួយ ហើយក៏ចូលទៅរកព្រះទព្វមល្លបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះទព្វមល្លបុត្តដ៏មានអាយុ រួចអង្គុយក្នុងទីដ៏សមគួរ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ បាននិយាយពន្យល់ កល្យាណ

ភត្តិកគហបតិ ដែលអង្គុយនៅក្នុងទីដ៏សមគួរ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ លំដាប់នោះ កល្យាណភត្តិកគហបតិ កាលព្រះទព្វមល្លបុត្តដ៏មានអាយុ និយាយពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ និយាយពាក្យនេះ នឹងព្រះទព្វមល្លបុត្តដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ស្អែកនេះ លោកម្ចាស់ចាត់ភិក្ខុអង្គណា (ឲ្យទៅទទួល) ភត្តក្នុងផ្ទះរបស់ខ្ញុំ។ ព្រះទព្វមល្លបុត្តឆ្លើយថា ម្នាលគហបតី ស្អែកនេះ អាត្មានឹងចាត់មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយ (ឲ្យទៅទទួល) ភត្តក្នុងផ្ទះអ្នកក្នុងថ្ងៃស្អែក។ លំដាប់នោះ កល្យាណភត្តិកគហបតិ មានសេចក្តីអាក់អន់ចិត្ត ដោយគិតថា ចុះហេតុអ្វី បានជាភិក្ខុលាមកទាំងឡាយ ទៅឆាន់ក្នុងផ្ទះរបស់អាត្មាអញ (លុះគិតដូច្នេះហើយ) ក៏ទៅផ្ទះ បង្គាប់ទាសីថា នែហង ស្អែកត្រូវពួកលោកណាមកទទួលចង្ហាន់ ហងឯងចូរក្រាលអាសនៈក្នុងជង្រុក ហើយអង្គាសលោកទាំងនោះ ដោយបាយចុងអង្ករ មានទឹកជ្រក់ ជាគំរប់ពីរចុះ។ ទាសីនោះ ទទួលស្តាប់ពាក្យ កល្យាណភត្តិកគហបតិ ដោយពាក្យថា ចា៎ះ អ្នកម្ចាស់។ លំដាប់នោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយគិតគ្នាថា ម្នាលអាវុសោ អំពីថ្ងៃម្សិលមិញ ភត្តុទ្ទេសកភិក្ខុ បានចាត់ឲ្យយើងទៅទទួលភត្ត របស់កល្យាណភត្តិកគហបតិ កល្យាណភត្តិកគហបតិ ព្រមទាំងកូនប្រពន្ធ នឹងចូលមកបម្រើ អង្គាសពួកយើងក្នុងថ្ងៃស្អែក ភិក្ខុទាំងឡាយដទៃៗ មុខជានឹងសួររកបាយ រកសម្ល រកប្រេង រកសម្លឧត្តរិភង្គ។ ដោយសេចក្តីសោមនស្សនោះឯង មេត្តិយភិក្ខុ និងភុម្មជកភិក្ខុនោះ ក៏ដេកមិនលក់ តាមសេចក្តីគាប់ចិត្ត ក្នុងរាត្រី(នោះ)។ គ្រានោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ក៏ស្លៀកស្បង់ ប្រដាប់បាត្រ ចីវរ ចូលទៅកាន់លំនៅ របស់កល្យាណភត្តិកគហបតិ អំពីព្រឹកព្រហាម។ ទាសីនោះ បានឃើញមេត្តិយភិក្ខុនិងភុម្មជកភិក្ខុកំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រាលអាសនៈ ក្នុងជង្រុក ហើយបាននិយាយពាក្យនេះ នឹងមេត្តិយភុម្មជកភិក្ខុថា បពិត្រលោកទាំងឡាយដ៏ចំរើន សូមលោកទាំងឡាយគង់ចុះ។ លំដាប់នោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ត្រិះរិះដូច្នេះថា កុំសង្ស័យឡើយ ចង្ហាន់មិនទាន់ស្រេចទេ បានជាគេឲ្យយើងអង្គុយក្នុងជង្រុកសិន។ គ្រានោះ ទាសីនោះ ក៏ផ្គត់ផ្គង់ ដោយបាយចុងអង្ករ មានទឹកជ្រក់ ជាគំរប់ពីរ ហើយនិមន្តថា បពិត្រលោកដ៏ចំរើន សូមលោកទាំងឡាយឆាន់ចុះ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ឆ្លើយថា ម្នាលប្អូនស្រី យើងទាំងឡាយ សុទ្ធតែជាអ្នក ទទួលនិច្ចភត្ត។ ទាសីនោះ ឆ្លើយថា ខ្ញុំព្រះករុណាដឹងថា លោកម្ចាស់ទាំងឡាយ ជាអ្នកទទួលនិច្ចភត្តហើយ តែម្សិលមិញ គហបតិ បង្គាប់ខ្ញុំព្រះករុណាថា នែហង លោកទាំងឡាយណា ត្រូវការដោយចង្ហាន់ និមន្តមក ក្នុងថ្ងៃស្អែក ហងឯង ចូរក្រាលអាសនៈ ក្នុងជង្រុកចុះ ហើយអង្គាសលោកទាំងនោះ ដោយបាយចុងអង្ករ មានទឹកជ្រក់ ជាគំរប់ពីរចុះ បពិត្រលោកទាំងឡាយដ៏ចំរើន សូមលោកទាំងឡាយឆាន់ចុះ។ លំដាប់នោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ និយាយគ្នាថា ម្នាលអាវុសោ កាលថ្ងៃម្សិលមិញ កល្យាណភត្តិកគហបតិ បានទៅកាន់អារាមនៅ នាសំណាក់ទព្វមល្លបុត្ត ពួកយើង ប្រាកដជាទព្វមល្លបុត្ត ញុះញង់ក្នុងសំណាក់នៃគហបតីពិតហើយ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងនោះ ក៏មិនបានឆាន់ដូចចិត្ត ដែលប៉ុនប៉ង ព្រោះតែសេចក្តីទោមនស្សនោះឯង។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ត្រឡប់ពីបិណ្ឌបាត ក្នុងវេលាក្រោយភត្តហើយ ទៅកាន់អារាមក្នុងពេលនោះ ក៏រៀបទុកដាក់បាត្រ និងចីវរហើយអង្គុយ ត្របោមក្បាលជង្គង់ ទាំងសង្ឃាដិខាងក្រៅក្លោងទ្វារវត្តនៅស្ងៀម មានសេចក្តីអៀនអន់ ឱនកចុះ មានមុខជ្រប់ ស្រពាប់ស្រពោន ឥតមាននិយាយអ្វីសោះ។ គ្រានោះ ភិក្ខុនីឈ្មោះ មេត្តិយា ចូលទៅរកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះ នឹងមេត្តិយភិក្ខុ និងភុម្មជកភិក្ខុថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណា សូមថ្វាយបង្គំ។ កាលបើមេត្តិយាភិក្ខុនី និយាយយ៉ាងនេះហើយ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិននិយាយតបតសោះឡើយ។ មេត្តិយាភិក្ខុនី បាននិយាយពាក្យនេះ ចំពោះមេត្តិយភុម្មជកភិក្ខុ ជាគំរប់ពីរដងផង។ បេ។ ជាគំរប់បីដងផងថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណា សូមថ្វាយបង្គំ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិននិយាយតប ជាគំរប់បីដងផង។ ទើបមេត្តិយាភិក្ខុនីសួរថា ខ្ញុំព្រះករុណា បានប្រទូស្តនឹងលោកម្ចាស់រាល់អង្គ ដូចម្តេចខ្លះ ហេតុអ្វី បានជាលោកម្ចាស់រាល់អង្គ មិននិយាយនឹងខ្ញុំព្រះករុណា។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ពិតដូច្នោះហើយ ទព្វមល្លបុត្ត កំពុងបៀតបៀនយើង នាងឯងក៏ធ្វើព្រងើយកន្តើយ។ មេត្តិយាភិក្ខុនីសួរថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណា នឹងធ្វើដូចម្តេច។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី បើនាងប្រាថ្នានឹង (ធ្វើ) ត្រូវក្រាបបង្គំទូល ព្រះមានព្រះភាគ ឲ្យញុំាងទព្វមល្លបុត្តមានអាយុ ឲ្យវិនាសចេញ ក្នុងថ្ងៃនេះឲ្យបាន។ មេត្តិយាភិក្ខុនីសួរថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំនឹងធ្វើដូចម្តេច ចុះអំពើអ្វី ដែលខ្ញុំនឹងអាចធ្វើបាន។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី នាងចូរមក នាងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរក្រាបបង្គំទូលព្រះមានព្រះភាគថាយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ការនេះ មិនមែនជាការកំបាំងទេ មិនមែនជាការសមគួរ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះ ត្រឡប់ជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពទៅវិញ ទីណា ដែលមិនធ្លាប់មានខ្យល់ ទីនោះត្រឡប់ជាមានខ្យល់វិញ ដូចជាទឹកធ្លាប់ត្រជាក់ ប្រែខ្ទេជាក្តៅ ឥឡូវព្រះទព្វមល្លបុត្តជាម្ចាស់ បានប្រទូស្ត នឹងខ្ញុំព្រះអង្គហើយ។ មេត្តិយាភិក្ខុនីទទួលស្តាប់ពាក្យមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ដោយពាក្យថា យ៉ាងហ្នឹងហើយ លោកម្ចាស់ រួចហើយចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតនៅ ក្នុងទីដ៏សមគួរ។ មេត្តិយាភិក្ខុនីនោះ លុះឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ការនេះមិនមែនជាការកំបាំងទេ មិនមែនជាការសមគួរទេ បពិត្រព្រះអង្គដ៏ចំរើន ទិសណាដែលមិនធ្លាប់មានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះត្រឡប់ទៅជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពទៅវិញ ទីណាដែលមិនធ្លាប់មានខ្យល់ ទីនោះ ត្រឡប់ទៅជាមានខ្យល់វិញ ដូចជាទឹកធ្លាប់ត្រជាក់ ប្រែខ្ទេជាក្តៅវិញ ឥឡូវព្រះទព្វមល្លបុត្តជាម្ចាស់ បានប្រទូស្តនឹងខ្ញុំព្រះអង្គហើយ។

[១៣] ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ នូវព្រះទព្វមល្លបុត្តដ៏មានអាយុ ក្នុងវេលានោះថា ម្នាលទព្វៈ អ្នករលឹកឃើញថា អ្នកបានធ្វើអំពើ ដូចភិក្ខុនីនេះ បានពោលឬទេ។ ព្រះទព្វមល្លបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ដូចជាព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គស្រាប់ហើយ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរ ព្រះទព្វមល្លបុត្ត ជាគំរប់ពីរដងផង។ បេ។ ជាគំរប់បីដងផងថា ម្នាលទព្វៈ អ្នករលឹកឃើញថា អ្នកបានធ្វើអំពើ ដូចជាភិក្ខុនីនេះ បានពោលឬទេ។ ព្រះទព្វមល្លបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ដូចជាព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គស្រាប់ហើយ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយ មិននិយាយបណ្តោះបណ្តៃយ៉ាងនេះទេ បើអំពើដែលអ្នកបានធ្វើហើយ អ្នកចូរនិយាយថា ខ្ញុំបានធ្វើហើយ បើអំពើដែលអ្នកមិនបានធ្វើទេ អ្នកចូរនិយាយថា ខ្ញុំមិនបានធ្វើទេ។ ព្រះទព្វមល្លបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន តាំងពីខ្ញុំព្រះអង្គកើតមក សូម្បីតែយល់សប្តិសេពមេថុនធម្មក៏មិនដែលស្គាល់សោះឡើយ នឹងបាច់និយាយទៅថ្វី ដល់ការភ្ញាក់រលឹកឡើង។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរឲ្យមេត្តិយាភិក្ខុនីសឹកចេញ មួយទៀត អ្នកទាំងឡាយ ចូរសាកសួរពួកភិក្ខុទាំងនេះមើល។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ក្រោកចាកអាសនៈ ចូលទៅកាន់វិហារវិញ។ ភិក្ខុទាំងឡាយនោះ ក៏ឲ្យមេត្តិយា

ភិក្ខុនីសឹកចេញ ក្នុងពេលនោះ។ ទើបមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ និយាយពាក្យនេះ នឹងភិក្ខុទាំងឡាយនោះថា ម្នាលអាវុសោ ចូរលោកទាំងឡាយកុំផ្សឹកមេត្តិយាភិក្ខុនីឡើយ នាងនោះ ឥតមានកំហុសអ្វីទេ (ហេតុដើមមកពី) យើងខឹង អាក់អន់ចិត្ត ចង់ឲ្យទព្វមល្លបុត្ត ឃ្លាតចាកសមណភេទ ទើបឲ្យមេត្តិយាភិក្ខុនីនោះ ខ្មាស់ខ្មែងឡើង។ ភិក្ខុទាំងឡាយសួរថា ម្នាលអាវុសោ អ្នកហ៊ានចោទ ព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយសីលវិបត្តិ មិនមានមូលដែរឬ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ចោទព្រះទព្វមល្លបុត្តមានអាយុ ដោយសីលវិបត្តិ មិនមានមូលសោះ។ ឯភិក្ខុទាំងនោះ ក៏បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ចោទទព្វមល្លបុត្ត ដោយសីលវិបត្តិ មិនមានមូល ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន។ បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យសតិវិន័យ ដល់ទព្វមល្លបុត្ត ជាអ្នកបរិបូណ៌ដោយសតិចុះ។ ម្នាលភិក្ខុទាំងឡាយ សតិវិន័យនោះ សង្ឃត្រូវឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ទព្វមល្លបុត្តនោះ ត្រូវចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គ ឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយនេះ ចោទខ្ញុំដោយសីលវិបត្តិ មិនមានមូល បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ។ ទព្វមល្លបុត្ត គប្បីសូមជាគំរប់ពីរដងផង។ បេ។ គប្បីសូម ជាគំរប់បីដងផងថា បពិត្រព្រះសង្ឃដ៏ចំរើន មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយនេះ ចោទខ្ញុំដោយសីលវិបត្តិ មិនមានមូល បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ ជាគំរប់បីដងផង។

[១៤] ភិក្ខុដែលឈ្លាស ប្រតិពល គប្បីប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយនេះ ចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយសីលវិបត្តិ មិនមានមូល។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ។ បើការសូមសតិវិន័យ មានកាលគួរ ដល់សង្ឃហើយ សូមសង្ឃឲ្យសតិវិន័យ ដល់ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយនេះ ចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយសីលវិបត្តិ មិនមានមូល។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ។ សង្ឃបានឲ្យសតិវិន័យ ដល់ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ។ ការឲ្យសតិវិន័យ ដល់ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនសមគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។ បេ។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយនេះ ចោទព្រះទព្វមល្លបុត្តដ៏មានអាយុ ដោយសីលវិបត្តិ មិនមានមូល។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ មកសូមសតិវិន័យនឹងសង្ឃ។ សង្ឃបានឲ្យសតិវិន័យ ដល់ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ។ ការឲ្យសតិវិន័យ ដល់ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនសមគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានឲ្យសតិវិន័យ ដល់ព្រះទព្វមល្លបុត្តដ៏មានអាយុ ជាអ្នកបរិបូណ៌ដោយសតិហើយ (ការឲ្យសតិវិន័យនេះ) សមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[១៥] ម្នាលភិក្ខុទាំងឡាយ ការឲ្យសតិវិន័យ[6] ដែលប្រកបដោយធម៌នេះ មាន៥យ៉ាង គឺឲ្យដល់ភិក្ខុបរិសុទ្ធ មិនមានអាបត្តិ១ ភិក្ខុឯទៀតចោទភិក្ខុនោះ១ ភិក្ខុនោះសូម១ សង្ឃឲ្យសតិវិន័យ ដល់ភិក្ខុនោះ១ សង្ឃព្រមព្រៀងឲ្យ ដោយធម៌១ ម្នាលភិក្ខុទាំងឡាយ ការឲ្យសតិវិន័យប្រកបដោយធម៌ ៥យ៉ាងនេះឯង។

# (អមូឡ្ហវិនយ ទី៣)

CS vin.cv.04.03 | ភាគ ទី១០

### (៣. អមូឡ្ហវិនយោ)

[១៦] សម័យនោះឯង គគ្គភិក្ខុ ជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល។ ភិក្ខុឆ្កួត ដែលមានចិត្តវិបល្លាស ប្រែប្រួលហើយនោះ រមែងតែប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន។ ភិក្ខុទាំងឡាយ ចោទគគ្គភិក្ខុ ដោយអាបត្តិ ព្រោះតែលោកជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ គគ្គភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាមនុស្សឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលខ្ញុំឆ្កួត មានចិត្តវិបល្លាសប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញ នូវអំពើនោះថា អំពើនេះ អាត្មាអញ បានធ្វើដោយសេចក្តីវង្វេង។ ភិក្ខុទាំងឡាយ ក៏នៅតែពោលចោទគគ្គភិក្ខុនោះ យ៉ាងនេះទៀតថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយ មិនសមបើនឹងចោទគគ្គភិក្ខុ ដោយអាបត្តិ ព្រោះតែលោក ជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ គគ្គភិក្ខុនោះ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញ នូវអំពើនោះថា អំពើនេះ អាត្មាអញ បានធ្វើដោយសេចក្តីវង្វេង ភិក្ខុទាំងឡាយ ក៏នៅតែពោលចោទគគ្គភិក្ខុនោះ យ៉ាងនេះទៀតថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ លំដាប់នោះ ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំណើរនោះ ពិតមែនឬ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឲ្យអមូឡ្ហវិន័យ ដល់គគ្គភិក្ខុ ដែលបាត់វង្វេងចុះ។

ម្នាលភិក្ខុទាំងឡាយ អមូឡ្ហវិន័យនោះ សង្ឃគប្បីឲ្យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ គគ្គភិក្ខុនោះ គប្បីចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ហើយថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល កាលខ្ញុំឆ្កួត មានចិត្តវិបល្លាសប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តកន្លង បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ឯភិក្ខុទាំងឡាយ ក៏ចោទខ្ញុំដោយអាបត្តិ ព្រោះតែខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ខ្ញុំបាននិយាយ នឹងភិក្ខុទាំងឡាយនោះ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញ នូវអំពើនោះថា អំពើនេះ អាត្មាអញ បានធ្វើហើយ ដោយសេចក្ដីវង្វេង ភិក្ខុទាំងឡាយ ក៏ពោលចោទខ្ញុំ យ៉ាងនេះទៀតថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ។ គគ្គភិក្ខុ ត្រូវសូមជាគំរប់ពីរដងផង។ បេ។ សូមជាគំរប់បីដងផងថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ឯភិក្ខុទាំងឡាយ ក៏ចោទខ្ញុំ ដោយអាបត្តិ ព្រោះតែខ្ញុំឆ្កួត មានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ខ្ញុំក៏បាននិយាយនឹងភិក្ខុទាំងឡាយនោះវិញ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញ នូវអំពើនោះថា អំពើនេះ អាត្មាអញ បានធ្វើហើយ ដោយសេចក្ដីវង្វេង ឯភិក្ខុទាំងឡាយ ពោលចោទខ្ញុំ យ៉ាងនេះទៀតថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ ជាគំរប់បីដងផង។

[១៧] ភិក្ខុដែលឈ្លាស ប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ គគ្គភិក្ខុនោះ ជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលលោកកំពុងឆ្កួត មានចិត្តវិបល្លាសប្រែប្រួលនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន។ ឯភិក្ខុទាំងឡាយ ចោទគគ្គភិក្ខុ ដោយអាបត្តិ ព្រោះតែលោកឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល បានប្រព្រឹត្តអនាចារថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ គគ្គភិក្ខុនោះ ឆ្លើយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលនោះ បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញ នូវអំពើនោះថា អំពើនេះ អាត្មាអញ បានធ្វើហើយ ដោយសេចក្ដីវង្វេង។ ឯភិក្ខុទាំងឡាយ ក៏នៅតែពោលចោទគគ្គភិក្ខុនោះ យ៉ាងនេះទៀតថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ ឥឡូវ គគ្គភិក្ខុនោះ បាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ។ បើការសូមអមូឡ្ហវិន័យ មានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យអមូឡ្ហវិន័យ ដល់គគ្គភិក្ខុ ជាអ្នកបាត់វង្វេងហើយចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ គគ្គភិក្ខុនេះ ជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលលោកកំពុងឆ្កួត មានចិត្តវិបល្លាសប្រែប្រួល បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន។ ឯភិក្ខុទាំងឡាយ ក៏ចោទគគ្គភិក្ខុ ដោយអាបត្តិ ព្រោះតែលោកជាភិក្ខុឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល បានប្រព្រឹត្តអនាចារថា ចូរលោកដ៏មានអាយុ រលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ គគ្គភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំកំពុងឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលនោះ បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរលឹកមិនឃើញ នូវអំពើនោះថា អំពើនេះ អាត្មាអញ បានធ្វើហើយ ដោយសេចក្ដីវង្វេង។ ភិក្ខុទាំងឡាយ ក៏នៅតែពោលចោទគគ្គភិក្ខុនោះ យ៉ាងនេះទៀតថា លោកមានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ គគ្គភិក្ខុនោះ បាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ។ សង្ឃឲ្យអមូឡ្ហវិន័យ ដល់គគ្គភិក្ខុ ជាអ្នកបាត់វង្វេងហើយ។ ការឲ្យអមូឡ្ហវិន័យ ដល់គគ្គភិក្ខុ ជាអ្នកបាត់វង្វេង គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។ បេ។ ខ្ញុំប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បេ។ សង្ឃបានឲ្យអមូឡ្ហវិន័យ ដល់គគ្គភិក្ខុ ជាអ្នកបាត់វង្វេងហើយ ការឲ្យអមូឡ្ហវិន័យនេះ គួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[១៨] ម្នាលភិក្ខុទាំងឡាយ ការឲ្យអមូឡ្ហវិន័យនេះ ដែលមិនប្រកបដោយធម៌ មាន៣យ៉ាង ដែលប្រកបដោយធម៌ មាន៣យ៉ាង។ ការឲ្យអមូឡ្ហវិន័យ មិនប្រកបដោយធម៌ មាន៣យ៉ាង (នោះ) តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គលមួយរូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ ភិក្ខុនោះ កាលរលឹកឃើញ ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះ ខ្ញុំរលឹកមិនឃើញទេ។ សង្ឃឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុនោះ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។

[១៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ កាលភិក្ខុនោះ រលឹកឃើញ ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំរលឹកឃើញដែរ តែដូចជាយល់សប្តិ។ សង្ឃឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុនោះ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។

[២០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវអាបត្តិហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ ភិក្ខុនោះ មិនមែនជាឆ្កួត តែក្លែងធ្វើជាឆ្កួត និយាយថា ខ្ញុំរមែងធ្វើយ៉ាងនេះ សូម្បីលោកទាំងឡាយ ក៏ធ្វើយ៉ាងនេះដែរ អំពើនេះ សមគួរដល់ខ្ញុំផង អំពើនេះ សមគួរដល់លោកទាំងឡាយផង។ សង្ឃក៏ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុនោះ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ការឲ្យអមូឡ្ហវិន័យ ដែលមិនប្រកបដោយធម៌ មាន៣យ៉ាង ប៉ុណ្ណេះឯង។

[២១] ការឲ្យអមូឡ្ហវិន័យ ដែលប្រកបដោយធម៌ មាន៣យ៉ាង (នោះ) តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល។ ភិក្ខុឆ្កួតនោះ មានចិត្តវិបល្លាស ប្រែប្រួល ហើយក៏ប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ ភិក្ខុឆ្កួតនោះ រលឹកមិនឃើញសោះ ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះ ខ្ញុំរលឹកមិនឃើញទេ។ សង្ឃឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុនោះ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថា ប្រកបដោយធម៌។

[២២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល។ ភិក្ខុឆ្កួតនោះ មានចិត្តវិបល្លាស ប្រែប្រួល បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ ភិក្ខុនោះ រលឹកមិនឃើញសោះ តែនិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំរលឹកឃើញដែរ តែថា ដូចជាយល់សប្តិ។ សង្ឃក៏ឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុនោះ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថា ប្រកបដោយធម៌។

[២៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាភិក្ខុឆ្កួត មានចិត្តវិបល្លាសប្រែប្រួល។ ភិក្ខុឆ្កួតនោះ មានចិត្តវិបល្លាស ប្រែប្រួលហើយ បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ។ ភិក្ខុនោះឆ្កួតមែន ក៏ធ្វើអាការជាឆ្កួត ហើយនិយាយថា ខ្ញុំរមែងធ្វើយ៉ាងនេះ សូម្បីលោកទាំងឡាយ ក៏ធ្វើយ៉ាងនេះដែរ អំពើនេះ សមគួរដល់ខ្ញុំផង អំពើនេះ សមគួរ ដល់លោកទាំងឡាយផង។ សង្ឃឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុនោះ។ ការឲ្យអមូឡ្ហវិន័យ (យ៉ាងនេះ) ឈ្មោះថា ប្រកបដោយធម៌។ ការឲ្យអមូឡ្ហវិន័យ ដែលប្រកបដោយធម៌ មាន៣យ៉ាងប៉ុណ្ណេះឯង។

# (បដិញ្ញាតករណៈ ទី៤)

CS vin.cv.04.04 | ភាគ ទី១០

### (៤. បដិញ្ញាតករណំ)

[២៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើកម្មទាំងឡាយ គឺតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយ ដោយមិនតាមពាក្យប្តេជ្ញា។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងធ្វើកម្មទាំងឡាយ គឺតជ្ជនីយកម្មខ្លះ និយស្សកម្មខ្លះ បព្វាជនីយកម្មខ្លះ បដិសារណីយកម្មខ្លះ ឧក្ខេបនីយកម្មខ្លះ ដល់ភិក្ខុទាំងឡាយ ដោយមិនតាមពាក្យប្តេជ្ញាសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ដំណើរនោះ ពិតមែនឬ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ភិក្ខុទាំងឡាយ ដោយមិនតាមពាក្យប្តេជ្ញាទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។

[២៥] ម្នាលភិក្ខុទាំងឡាយ ការធ្វើតាមពាក្យប្តេជ្ញា មិនប្រកបដោយធម៌ យ៉ាងនេះ ការធ្វើតាមពាក្យប្តេជ្ញា ប្រកបដោយធម៌ យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯការធ្វើតាមពាក្យប្តេជ្ញា ដែលមិនប្រកបដោយធម៌នោះ ដូចម្តេច។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកមានអាយុ ត្រូវអាបត្តិបារាជិកហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិសង្ឃាទិសេសទេតើ។ សង្ឃក៏ឲ្យភិក្ខុនោះធ្វើ (វុដ្ឋានវិធី) ដោយអាបត្តិសង្ឃាទិសេស។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ភិក្ខុត្រូវអាបត្តិបារាជិក។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិបារាជិកហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិថុល្លច្ច័យទេតើ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិថុល្លច្ច័យ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិបារាជិកហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិបាចិត្តិយៈទេតើ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិបាចិត្តិយៈ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិបារាជិកហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិបាដិទេសនីយៈទេតើ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិបាដិទេសនីយៈ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិបារាជិកហើយ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិទុក្កដទេតើ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិទុក្កដ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិបារាជិកហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រូវអាបត្តិបារាជិកទេ ត្រូវអាបត្តិទុព្ភាសិតទេតើ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិទុព្ភាសិត។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ។ បេ។ ថុល្លច្ច័យ។ បេ។ បាចិត្តិយៈ។ បេ។ បាដិទេសនីយៈ។ បេ។ ទុក្កដ។ បេ។ ត្រូវអាបត្តិទុព្ភាសិតហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិទុព្ភាសិតហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនត្រូវអាបត្តិទុព្ភាសិតទេ ត្រូវអាបត្តិបារាជិកទេតើ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ការប្តេជ្ញាខ្លួនជាគ្រហស្ថ) ដោយអាបត្តិបារាជិក។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ភិក្ខុត្រូវអាបត្តិទុព្ភាសិតហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មាន

អាយុ ត្រូវអាបត្តិទុព្ភាសិតហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ ខ្ញុំមិនត្រូវអាបត្តិទុព្ភាសិតទេ ត្រូវអាបត្តិសង្ឃាទិសេសទេតើ។ បេ។ ថុល្លច្ច័យ។ បេ។ បាចិត្តិយៈ។ បេ។ បាដិទេសនីយៈ។ បេ។ ត្រូវអាបត្តិទុក្កដ។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិទុក្កដ។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា មិនប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ការធ្វើតាមពាក្យប្តេជ្ញា ដែលមិនប្រកបដោយធម៌ យ៉ាងនេះឯង។

[២៦] ម្នាលភិក្ខុទាំងឡាយ ចំណែកឯការធ្វើតាមពាក្យប្តេជ្ញា ដែលប្រកបដោយធម៌ (នោះ) ដូចម្តេច។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិបារាជិកហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អើខ្ញុំត្រូវអាបត្តិបារាជិកមែន។ សង្ឃឲ្យភិក្ខុនោះធ្វើ (ការប្តេជ្ញាខ្លួនជាគ្រហស្ថ) ដោយអាបត្តិបារាជិក។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា ប្រកបដោយធម៌។ ភិក្ខុត្រូវអាបត្តិ សង្ឃាទិសេស។ បេ។ ថុល្លច្ច័យ។ បេ។ បាចិត្តិយៈ។ បេ។ បាដិទេសនីយៈ។ បេ។ ទុក្កដ។ បេ។ ទុព្ភាសិត។ សង្ឃក្តី ភិក្ខុច្រើនរូបក្តី បុគ្គល១រូបក្តី ចោទភិក្ខុនោះថា លោកដ៏មានអាយុ ត្រូវអាបត្តិទុព្ភាសិតហើយ។ ភិក្ខុនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ អើខ្ញុំត្រូវអាបត្តិទុព្ភាសិតមែន។ សង្ឃឲ្យភិក្ខុនោះធ្វើ (ទេសនាវិធី) ដោយអាបត្តិទុព្ភាសិត។ ការធ្វើតាមពាក្យប្តេជ្ញា (យ៉ាងនេះ) ឈ្មោះថា ប្រកបដោយធម៌។ ម្នាលភិក្ខុទាំងឡាយ ការធ្វើតាមពាក្យប្តេជ្ញា ដែលប្រកបដោយធម៌ យ៉ាងនេះឯង។

# (យេភុយ្យសិកា ទី៥)

CS vin.cv.04.05 | ភាគ ទី១០

### (៥. យេភុយ្យសិកា)

[២៧] សម័យនោះឯង ភិក្ខុទាំងឡាយ បង្កហេតុ ឈ្លោះទាស់ទែងគ្នា ក្នុងកណ្តាលជំនុំសង្ឃ ពោលពាក្យចាក់ដោតគ្នាទៅវិញទៅមក ដោយលំពែង គឺមាត់ ភិក្ខុទាំងឡាយ មិនអាចញុំាងអធិករណ៍នោះ ឲ្យរម្ងាប់បាន។ ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរម្ងាប់អធិករណ៍ មានសភាពយ៉ាងនេះ ដោយយេភុយ្យសិកា។[7] សង្ឃគប្បីសន្មតភិក្ខុ ដែលប្រកបដោយអង្គ៥ គឺភិក្ខុដែលមិនលុះនូវឆន្ទាគតិ១ មិនលុះនូវទោសាគតិ១ មិនលុះនូវមោហាគតិ១ មិនលុះនូវភយាគតិ១ ដឹងនូវស្លាកដែលបានចាប់ហើយ និងមិនទាន់បានចាប់១ឲ្យ (ធ្វើ) ជាសលាកគ្គាហាបកៈ (អ្នកចាត់ចែងឲ្យគេចាប់ស្លាក) ម្នាលភិក្ខុទាំងឡាយ ឯសលាកគ្គាហាបកៈនោះ សង្ឃត្រូវសន្មតយ៉ាងនេះ។ មុនដម្បូងត្រូវសង្ឃសូមភិក្ខុ (នោះ) លុះសូមរួចហើយ ត្រូវភិក្ខុដែលឈ្លាស ប្រតិពល ផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើការសន្មតិ មានកាលគួរ ដល់សង្ឃហើយ សូមសង្ឃសន្មតិភិក្ខុ ឈ្មោះនេះ ឲ្យជាសលាកគ្គាហាបកៈចុះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាសលាកគ្គាហាបកៈ។ ការសន្មតិភិក្ខុ ឈ្មោះនេះ ឲ្យជាសលាកគ្គាហាបកៈ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាសលាកគ្គាហាបកៈហើយ ការសន្មតិនេះ គួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៨] ម្នាលភិក្ខុទាំងឡាយ ការឲ្យចាប់ស្លាកនេះ ដែលមិនប្រកបដោយធម៌ មាន១០យ៉ាង ដែលប្រកបដោយធម៌ មាន១០យ៉ាង។ ការឲ្យចាប់ស្លាក ដែលមិនប្រកបដោយធម៌ ១០យ៉ាង (នោះ) តើដូចម្តេច។ គឺមានអធិករណ៍បន្តិចបន្តួច[8] ១ អធិករណ៍មិនទៅតាមគតិ១ អធិករណ៍ ដែលភិក្ខុមិនទាន់បានរលឹកឃើញខ្លួនឯង និងរំលឹកអ្នកដទៃ១ ភិក្ខុដឹងថា ពួកអធម្មវាទី មានចំនួនច្រើនជាង១ ភិក្ខុគិតថា ធ្វើម្តេចហ្ន៎ ទើបពួកអធម្មវាទី មានចំនួនច្រើនជាង១ ភិក្ខុដឹងថា សង្ឃនឹងបែកគ្នា១ ភិក្ខុគិតថា ធ្វើម្តេចហ្ន៎ ទើបសង្ឃបែកគ្នា១ ភិក្ខុទាំងឡាយ ចាប់ស្លាកដោយមិនតាមធម៌[9] ១ ភិក្ខុទាំងឡាយ ចាប់ស្លាកជាពួកៗ១ ភិក្ខុទាំងឡាយ មិនចាប់ស្លាកតាមសមគួរ ដល់ទិដ្ឋិ[10] ១ ការឲ្យចាប់ស្លាក ដែលមិនប្រកបដោយធម៌ មាន១០យ៉ាង ប៉ុណ្ណេះឯង។

[២៩] ការឲ្យចាប់ស្លាក ដែលប្រកបដោយធម៌ មាន១០យ៉ាង (នោះ) តើដូចម្តេច។ គឺមិនមានអធិករណ៍បន្តិចបន្តួច១ អធិករណ៍ប្រព្រឹត្តទៅតាមគតិ១ អធិករណ៍ ដែលភិក្ខុបានរលឹកឃើញខ្លួនឯង ឬបានរំលឹកអ្នកដទៃ១ ភិក្ខុដឹងថា ពួកធម្មវាទី មានចំនួនច្រើនជាង១ ភិក្ខុគិតថា ធ្វើម្តេចហ្ន៎ ទើបពួកធម្មវាទី មានចំនួនច្រើនជាង១ ភិក្ខុដឹងថា សង្ឃនឹងមិនបែកគ្នា១ ភិក្ខុគិតថា ធ្វើម្តេចហ្ន៎ ទើបសង្ឃមិនបែកគ្នា១ ភិក្ខុទាំងឡាយ ចាប់ស្លាកប្រកបដោយធម៌១ ព្រមព្រៀងគ្នាចាប់ស្លាក១ ចាប់ស្លាកដោយសមគួរ ដល់ទិដ្ឋិ១ ការឲ្យចាប់ស្លាក ដែលប្រកបដោយធម៌ មាន១០យ៉ាង ប៉ុណ្ណេះឯង។

# (តស្សបាបិយសិកា ទី៦)

CS vin.cv.04.06 | ភាគ ទី១០

### (៦. តស្សបាបិយសិកា)

[៣០] សម័យនោះឯង ឧបវាឡភិក្ខុ កាលត្រូវគេសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ក៏គេចកែសំដី ហើយទទួលដឹង ទទួលដឹងហើយ បែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃវិញ ពោលសម្បជានមុសាវាទ គឺពោលពាក្យកុហកដោយដឹងខ្លួន។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបវាឡភិក្ខុ កាលត្រូវគេសាកសួរ ដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ មិនសមបើនឹងគេចកែសំដី ហើយបែរជាទទួលដឹង ទទួលដឹងហើយ បែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃពោលសម្បជានមុសាវាទសោះ។ គ្រានោះ ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា

ម្នាលភិក្ខុទាំងឡាយ ដំណើរនោះ ពិតមែនឬ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរធ្វើតស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុចុះ។ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្មនោះ សង្ឃគប្បីធ្វើយ៉ាងនេះ។ មុនដំបូង សង្ឃគប្បីចោទ ឧបវាឡភិក្ខុ លុះចោទហើយ គប្បីរំលឹក លុះរំលឹកហើយ គប្បីលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឈ្លាស ប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបវាឡភិក្ខុនេះ កាលត្រូវគេសាកសួរ ដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ក៏គេចកែសំដី ហើយបែរជាទទួលដឹង ទទួលដឹងហើយ បែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលសម្បជានមុសាវាទ។ បើការធ្វើ តស្សបាបិយសិកាកម្ម មានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីធ្វើ តស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបវាឡភិក្ខុនេះ កាលត្រូវគេសាកសួរ ដោយអាបត្តិ ក្នុងកណ្តាលជំនុំសង្ឃ ក៏គេចកែសំដី ហើយបែរជាទទួលដឹង ទទួលដឹងហើយ បែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលសម្បជានមុសាវាទ។ សង្ឃធ្វើ តស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុ។ ការធ្វើ តស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនសមគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ ខ្ញុំសូមប្រកាសសេចក្តីនេះ ជាគំរប់ពីរដងផង។ បេ។ ខ្ញុំសូមប្រកាសសេចក្តីនេះ ជាគំរប់បីដងផង។ បេ។ សង្ឃបានធ្វើ តស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុហើយ (ការធ្វើតស្សបាបិយសិកាកម្មនេះ) សមគួរ ដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[៣១] ម្នាលភិក្ខុទាំងឡាយ ការធ្វើតស្សបាបិយសិកាកម្មនេះ ប្រកបដោយធម៌ មាន៥យ៉ាង គឺភិក្ខុនោះ (មានកាយវាចា) មិនស្អាត១ ជាអ្នកមិនមានសេចក្តីអៀនខ្មាស១ ជាអ្នកប្រកបដោយពាក្យគេតិះដៀល១ សង្ឃធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុនោះ១ សង្ឃធ្វើដោយសេចក្តីព្រមព្រៀងគ្នា ត្រូវតាមធម៌១ ម្នាលភិក្ខុទាំងឡាយ ការធ្វើតស្សបាបិយសិកាកម្ម ដែលប្រកបដោយធម៌ មាន៥យ៉ាង ប៉ុណ្ណេះឯង។

## (អធម្មកម្មទ្វាទសកៈ)

CS vin.cv.04.06.01 | ភាគ ទី១០

### (អធម្មកម្មទ្វាទសកំ)

[៣២] ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ គឺកម្មដែលសង្ឃធ្វើកំបាំងមុខ១ ធ្វើដោយមិនបានសាកសួរជាមុន១ ធ្វើដោយមិនតាមប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គទាំង៣ នេះឯង។ បេ។ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលសង្ឃមិនលើកអាបត្តិឡើង ហើយស្រាប់តែធ្វើ១ ធ្វើមិនត្រូវតាមធម៌១ ធ្វើដោយពួក១ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មមិនត្រូវតាមធម៌ផង ជាកម្មមិនត្រូវតាមវិន័យផង ជាកម្មរម្ងាប់ដោយអាក្រក់ផង ប្រកបដោយអង្គទាំង៣ នេះឯង។

## (ធម្មកម្មទ្វាទសកៈ)

CS vin.cv.04.06.02 | ភាគ ទី១០

### (ធម្មកម្មទ្វាទសកំ)

[៣៣] ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ គឺកម្មដែលសង្ឃធ្វើក្នុងទីចំពោះមុខ១ ធ្វើដោយបានសាកសួរជាមុន១ ធ្វើតាមប្តេជ្ញា១ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មរម្ងាប់ដោយល្អផង ប្រកបដោយអង្គទាំង៣ នេះឯង។ បេ។ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មរម្ងាប់ដោយល្អផង ប្រកបដោយអង្គ៣ដទៃទៀត គឺកម្មដែលសង្ឃលើកអាបត្តិឡើង ហើយទើបធ្វើ១ ធ្វើត្រូវតាមធម៌១ ធ្វើដោយសេចក្តីព្រមព្រៀងគ្នា១ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម ជាកម្មប្រកបដោយធម៌ផង ជាកម្មប្រកបដោយវិន័យផង ជាកម្មរម្ងាប់ដោយល្អផង ប្រកបដោយអង្គទាំង៣ នេះឯង។

## (អាកង្ខមានឆក្កៈ)

CS vin.cv.04.06.03 | ភាគ ទី១០

### (អាកង្ខមានឆក្កំ)

[៣៤] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា (នឹងធ្វើ) ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៣បាន គឺភិក្ខុអ្នកធ្វើនូវសេចក្តីបង្កហេតុ ធ្វើជម្លោះ ធ្វើសេចក្តីទាស់ទែង បង្កតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ១ ភិក្ខុល្ងង់ មិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិ១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំ មិនសមគួរ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គទាំង៣ នេះឯង។

[៣៥] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀត គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីល១ មានអាចារវិបត្តិ ក្នុងអជ្ឈាចារ១ មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិ១។ បេ។

[៣៦] ម្នាលភិក្ខុទាំងឡាយ។ បេ។ អង្គ៣ដទៃទៀត គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គទាំង៣នេះឯង។

[៣៧] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ៣ពួក គឺ ភិក្ខុអ្នកធ្វើការបង្កហេតុ ធ្វើជម្លោះ ធ្វើសេចក្តីទាស់ទែង បង្កតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃពួក១ ភិក្ខុល្ងង់ មិនឈ្លាស មានអាបត្តិច្រើន មិនមានការកំណត់អាបត្តិពួក១ ភិក្ខុនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុទាំង៣ពួកនេះឯង។

[៣៨] ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ៣ពួកដទៃទៀត គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីលពួក១ ភិក្ខុមានអាចារវិបត្តិ ក្នុងអជ្ឈាចារពួក១ ភិក្ខុមានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិពួក១។ បេ។

[៣៩] ម្នាលភិក្ខុទាំងឡាយ។ បេ។ ភិក្ខុ ៣ពួកដទៃទៀត គឺ ភិក្ខុពោលតិះដៀលព្រះពុទ្ធពួក១ ពោលតិះដៀលព្រះធម៌ពួក១ ពោលតិះដៀលព្រះសង្ឃពួក១ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃប្រាថ្នា ក៏គប្បីធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុទាំង៣ពួកនេះឯង។

### (អដ្ឋារសវត្ត)

CS vin.cv.04.06.04 | ភាគ ទី១០

#### (អដ្ឋារសវត្តំ)

[៤០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃបានធ្វើតស្សបាបិយសិកាកម្មហើយនោះ ត្រូវប្រព្រឹត្តវត្ត ដោយប្រពៃ។ ឯការប្រព្រឹត្តវត្ត ដោយប្រពៃ ក្នុងតស្សបាបិយសិកាកម្មនោះ ដូច្នេះ គឺភិក្ខុនោះ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើ មិនត្រូវត្រេកអរ ក្នុងការសន្មតិខ្លួន ជាអ្នកប្រដៅភិក្ខុនី ទុកជាបានទទួលការសន្មតិហើយ ក៏មិនត្រូវប្រដៅភិក្ខុនី។ បេ។ មិនត្រូវប្រកបពួកភិក្ខុ (ឲ្យឈ្លោះ) នឹងពួកភិក្ខុផងគ្នា។ គ្រានោះ សង្ឃបានធ្វើតស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុ។

## (តិណវត្ថារក ទី៧)

CS vin.cv.04.07 | ភាគ ទី១០

#### (៧. តិណវត្ថារកំ)

[៤១] សម័យនោះឯង ពួកភិក្ខុនាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ គ្រានោះ ភិក្ខុទាំងនោះ មានសេចក្តីបរិវិតក្ក យ៉ាងនេះថា ពួកយើង នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន ប្រសិនបើពួកយើង នឹងញុំាងគ្នានិងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ) តើពួកយើងគប្បីប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។

[៤២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុក្នុងទីនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ពួកយើង នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន ប្រសិនបើពួកយើង ញុំាងគ្នានិងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ)។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យសង្ឃរម្ងាប់អធិករណ៍ មានសភាពយ៉ាងនេះ ដោយតិណវត្ថារកសមថៈ។[11]

[៤៣] ម្នាលភិក្ខុទាំងឡាយ អធិករណ៍នោះ សង្ឃត្រូវរម្ងាប់យ៉ាងនេះ។ ភិក្ខុទាំងអស់ គប្បីប្រជុំក្នុងទីជាមួយគ្នា លុះប្រជុំគ្នាហើយ ភិក្ខុដែលឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ យើងខ្ញុំទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើយើងខ្ញុំទាំងឡាយ នឹងញុំាងគ្នានិងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះ ក៏បានដែរ តែអធិករណ៍នោះ នឹងគប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ)។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់អធិករណ៍នេះ ដោយតិណវត្ថារកសមថៈ វៀរលែងតែអាបត្តិមានទោសធ្ងន់[12] វៀរលែងតែអាបត្តិដែលជាគិហិប្បដិសំយុត្ត។[13] បណ្តាភិក្ខុទាំងឡាយ ដែលជាបក្ខពួកជាមួយគ្នា ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងបក្ខពួករបស់ខ្លួនថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ ពួកយើង នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន ប្រសិនបើយើងទាំងឡាយ នឹងនាំគ្នាធ្វើ ដោយអាបត្តិទាំងនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ)។ បើកម្មមានកាលគួរ ដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំសូមសំដែងអាបត្តិ របស់លោកមានអាយុទាំងឡាយផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ ដល់លោកដ៏មានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ និងវៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត។

[៤៤] បណ្តាភិក្ខុទាំងឡាយ ដែលជាពួក ជាមួយគ្នាដទៃទៀត ភិក្ខុដែលឈ្លាស ប្រតិពល ត្រូវផ្តៀងពួករបស់ខ្លួន ក្នុងវេលានោះថា សូមលោកដ៏មានអាយុទាំងឡាយស្តាប់ខ្ញុំ ពួកយើងទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស

នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើពួកយើង នឹងញ៉ាំងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ)។ បើកម្មមានកាលដ៏សមគួរ ដល់លោកដ៏មានអាយុទាំងឡាយហើយ ខ្ញុំសូមសំដែងអាបត្តិ របស់លោកដ៏មានអាយុទាំងឡាយផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ ដល់លោកដ៏មានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ មានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត។

[៤៥] បណ្តាភិក្ខុទាំងឡាយ ដែលជាបក្ខពួកជាមួយគ្នា ភិក្ខុដែលឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ យើងខ្ញុំទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើពួកយើង នឹងញ៉ាំងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ)។ បើកម្មមានកាលដ៏សមគួរ ដល់សង្ឃហើយ ខ្ញុំសូមសំដែងអាបត្តិ របស់លោកដ៏មានអាយុទាំងនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ ដល់លោកដ៏មានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពួកយើង នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើយើងទាំងឡាយ នឹងនាំគ្នាធ្វើ ដោយអាបត្តិទាំងនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ)។ ខ្ញុំសូមសំដែងអាបត្តិ របស់លោកមានអាយុទាំងនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ ដល់លោកដ៏មានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត។ ការសំដែងអាបត្តិទាំងឡាយនេះ របស់ពួកយើង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរ ដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវនិយាយឡើង។ អាបត្តិទាំងឡាយនេះ យើងទាំងឡាយបានសំដែងហើយ ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត ការសំដែងនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀម យ៉ាងនេះ។

[៤៦] បណ្តាភិក្ខុ ដែលជាពួកជាមួយគ្នាដទៃទៀត ភិក្ខុដែលឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃ ក្នុងវេលានោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ យើងទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ប្រសិនបើយើងទាំងឡាយ ញ៉ាំងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះ អធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ)។ បើកម្មមានកាលគួរ ដល់សង្ឃហើយ ខ្ញុំគប្បីសំដែងអាបត្តិ របស់លោកដ៏មានអាយុទាំងនេះផង អាបត្តិរបស់ខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ ដល់លោកដ៏មានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ យើងខ្ញុំទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន។ ប្រសិនបើយើងទាំងឡាយ ញ៉ាំងគ្នានឹងគ្នាឲ្យធ្វើ ដោយអាបត្តិទាំងនេះ អធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីទំលាយ (សង្ឃ)។ ខ្ញុំសូមសំដែងអាបត្តិ របស់លោកដ៏មានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ ដើម្បីប្រយោជន៍ ដល់លោកដ៏មានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត។ ការសំដែងអាបត្តិទាំងឡាយនេះ របស់យើងទាំងឡាយ ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរ ដល់លោកមានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ អាបត្តិទាំងនេះ យើងទាំងឡាយ បានសំដែងហើយ ក្នុងកណ្តាលជំនុំសង្ឃ ដោយតិណវត្ថារកសមថៈ វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត ការសំដែងអាបត្តិនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀម យ៉ាងនេះ។

[៤៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថាបានចេញចាកអាបត្តិទាំងឡាយនោះ ដោយអាការយ៉ាងនេះហើយ វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្ត វៀរលែងតែការធ្វើឲ្យច្បាស់នូវទិដ្ឋិ វៀរលែងតែភិក្ខុទាំងឡាយណា ដែលមិនមាននៅ[14] ក្នុងទីនោះ។

# (អធិករណៈ ទី៨)

CS vin.cv.04.08 | ភាគ ទី១០

### (៨. អធិករណំ)

[៤៨] សម័យនោះឯង ភិក្ខុទាំងឡាយ ទាស់ទែងនឹងពួកភិក្ខុនី។ ពួកភិក្ខុនី ក៏ទាស់គ្នា នឹងពួកភិក្ខុ។ ចំណែកខាងឆន្នភិក្ខុ ក៏ចូលជ្រៀតជ្រកទៅរកពួកភិក្ខុនី ហើយទាស់ទែងនឹងពួកភិក្ខុ ប្រកាន់ គឺចូលដៃខាងពួកភិក្ខុនី។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុ មិនសមបើនឹងចូលជ្រៀតជ្រក ទៅរកពួកភិក្ខុនី ហើយមកទាស់ទែងនឹងពួកភិក្ខុ ប្រកាន់ខាងពួកភិក្ខុនីសោះ។ លំដាប់នោះ ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំណើរនោះ ពិតមែនឬ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ដំណើរនោះ ពិតមែន។ បេ។ លុះទ្រង់

តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អធិករណ៍ទាំងឡាយ៤នេះ គឺវិវាទាធិករណ៍១ អនុវាទាធិករណ៍១ អាបត្តាធិករណ៍១ កិច្ចាធិករណ៍១។

[៤៩] បណ្តាអធិករណ៍៤យ៉ាងនោះ វិវាទាធិករណ៍ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ ទាស់ទែងគ្នាថា នេះជាធម៌ ឬថា នេះមិនមែនជាធម៌ នេះជាវិន័យ ឬថា នេះមិនមែនជាវិន័យ នេះជាពាក្យ ដែលព្រះតថាគត ទ្រង់ត្រាស់សំដែងទុកមកហើយ ឬថា នេះជាពាក្យ ដែលព្រះតថាគត មិនបានទ្រង់ត្រាស់សំដែងទុកមកទេ នេះជាកិច្ច ដែលព្រះតថាគត ទ្រង់ប្រព្រឹត្តសន្សំមកហើយ ឬថា នេះជាកិច្ច ដែលព្រះតថាគត មិនបានទ្រង់ប្រព្រឹត្តសន្សំមកទេ នេះជាពាក្យ ដែលព្រះតថាគត ទ្រង់បញ្ញត្តទុកមកហើយ ឬថា នេះជាពាក្យ ដែលព្រះតថាគត មិនបានទ្រង់បញ្ញត្តទុកមកទេ នេះជាអាបត្តិ ឬថា នេះមិនមែនជាអាបត្តិ នេះជាអាបត្តិស្រាល ឬថា នេះជាអាបត្តិធ្ងន់ នេះជាអាបត្តិមានចំណែកសេសសល់ ឬថា នេះជាអាបត្តិ មិនមានចំណែកសេសសល់ នេះជាអាបត្តិអាក្រក់ ឬថា នេះមិនមែនជាអាបត្តិអាក្រក់ បណ្តាអធិករណ៍ទាំងឡាយនោះ ការបង្កហេតុ ការឈ្លោះ ការប្រកាន់ផ្សេងគ្នា ការទាស់ទែងគ្នា ការពោលផ្សេងៗគ្នា ការពោលដោយឡែកពីគ្នា ការពោល ដើម្បីសេចក្តីទុក្ខដល់ចិត្ត ការប្រកួតប្រកាន់ណា ការបង្កហេតុ ជាដើមនេះ តថាគតហៅថា វិវាទាធិករណ៍។

[៥០] បណ្តាអធិករណ៍ទាំង៤នោះ អនុវាទាធិករណ៍ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី បណ្តាអធិករណ៍ទាំង៤នោះ ការចោទ ការតិះដៀល ការពោលរឿយៗ ការនិយាយរឿយៗ ការបង្អោនទៅ (កាន់អធិករណ៍) ការប្រឹងប្រែងឡើង ការបន្ថែមកំលាំងណា ការចោទ ជាដើមនោះ តថាគតហៅថា អនុវាទាធិករណ៍។

[៥១] បណ្តាអធិករណ៍ទាំង៤នោះ អាបត្តាធិករណ៍ តើដូចម្តេច។ អាបត្តិទាំង៥កង ជាអាបត្តាធិករណ៍ក៏មាន អាបត្តិទាំង៧កង ជាអាបត្តាធិករណ៍ក៏មាន នេះតថាគតហៅថា អាបត្តាធិករណ៍។

[៥២] បណ្តាអធិករណ៍ទាំង៤នោះ កិច្ចាធិករណ៍ តើដូចម្តេច។ កិច្ចរបស់សង្ឃ (ឬ) កម្មដែលសង្ឃត្រូវធ្វើបាន (ដូចយ៉ាង) អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម និងញត្តិចតុត្ថកម្ម នេះ តថាគតហៅថា កិច្ចាធិករណ៍។

[៥៣] អ្វីជាមូលនៃ វិវាទាធិករណ៍។ ធម៌៦យ៉ាង ជាមូលនៃសេចក្តីវិវាទ ចាត់ជា មូលនៃវិវាទាធិករណ៍ គឺ អកុសលមូល ៣យ៉ាង ជាមូលនៃវិវាទាធិករណ៍ និងកុសលមូល ៣យ៉ាង ជាមូលនៃវិវាទាធិករណ៍ដែរ។ ធម៌៦យ៉ាង ជាមូលនៃវិវាទ ដែលចាត់ជា មូលនៃវិវាទាធិករណ៍ នោះ ដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីក្រោធច្រើន ជាអ្នកចងគំនុំទុក ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មានសេចក្តីក្រោធច្រើន ជាអ្នកចងគំនុំទុក ភិក្ខុនោះ ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង ឈ្មោះថា មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ភិក្ខុនោះ ឈ្មោះថា ញុំាងសេចក្តីវិវាទ ដែលកំពុងកើត ឲ្យកើតឡើងក្នុងសង្ឃ ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនបានសេចក្តីសុខ ដល់ជនច្រើន ដើម្បីសេចក្តីមិនចម្រើន ដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ពិចារណាឃើញ នូវមូលនៃសេចក្តីវិវាទខាងក្នុងក្តី ខាងក្រៅក្តី មានសភាពយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីព្យាយាម ដើម្បីលះបង់ នូវមូលនៃសេចក្តីវិវាទ ដ៏លាមកនោះឯង ក្នុងអធិករណ៍នោះចេញ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនបានពិចារណាឃើញ នូវមូលនៃសេចក្តីវិវាទខាងក្នុង និង ខាងក្រៅ មានសភាពយ៉ាងនេះទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរប្រតិបត្តិ កុំឲ្យមូលនៃសេចក្តីវិវាទ ដ៏លាមកនោះ ចំរើនតទៅខាងមុខ ក្នុងអធិករណ៍នោះទៀតឡើយ។ យ៉ាងនេះឯង ឈ្មោះថា ការលះបង់ នូវមូលនៃសេចក្តីវិវាទដ៏លាមកនុ៎ះ។ យ៉ាងនេះឯង ឈ្មោះថា មិនឲ្យមូល នៃសេចក្តីវិវាទ ដ៏លាមកនោះ ចំរើនតទៅខាងមុខទៀតបាន។

[៥៤] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រណាំងវាសនា។ បេ។ ជាអ្នកមានសេចក្តីឫស្យា ជាអ្នកមានសេចក្តីកំណាញ់។ បេ។ ជាអ្នកអួតអាង ជាអ្នកមានមាយា។ បេ។ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ជាអ្នកមានសេចក្តីឃើញខុស។ បេ។ ជាអ្នកបបោសអង្អែលទិដ្ឋិរបស់ខ្លួន ប្រកាន់ខ្ជាប់មាំ លះបង់បានដោយកម្រ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកបបោសអង្អែលទិដ្ឋិរបស់ខ្លួន ប្រកាន់ខ្ជាប់មាំ លះបង់បានដោយកម្រ ភិក្ខុនោះ ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង។ បេ។ ក្នុងព្រះសង្ឃផង។ បេ។ មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ភិក្ខុនោះ ឈ្មោះថា ញុំាងវិវាទ ដែលកំពុងកើត ឲ្យកើតឡើងក្នុងសង្ឃ ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនបានសេចក្តីសុខ ដល់ជនច្រើន ដើម្បីមិនមានសេចក្តីចម្រើន ដល់ជនច្រើន ដើម្បីមិនមានប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ពិចារណាឃើញ នូវមូលនៃសេចក្តីវិវាទខាងក្នុងក្តី ខាងក្រៅក្តី មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវព្យាយាម ដើម្បីលះបង់ នូវមូលនៃសេចក្តីវិវាទ ដ៏លាមកនោះឯង ក្នុងអធិករណ៍នោះចេញ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនពិចារណាឃើញមូល នៃវិវាទខាងក្នុងក្តី ខាងក្រៅក្តី ដែលមានសភាពយ៉ាងនេះទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរប្រតិបត្តិ កុំឲ្យមូលនៃវិវាទដ៏លាមកនោះ ចំរើនតទៅខាងមុខ ក្នុងអធិករណ៍នោះទៀតឡើយ។ យ៉ាងនេះឯង ឈ្មោះថា ការលះបង់ នូវមូលនៃសេចក្តីវិវាទ ដ៏លាមកនុ៎ះ។ យ៉ាងនេះឯង ឈ្មោះថា មិនឲ្យមូល នៃវិវាទ ដ៏លាមកនោះ ចំរើនតទៅខាងមុខទៀតបាន មូលនៃវិវាទ៦យ៉ាងនេះ ចាត់ជា មូលនៃវិវាទាធិករណ៍។

[៥៥] អកុសលមូល៣ ដែលចាត់ជា មូលនៃវិវាទាធិករណ៍ នោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តលោភទាស់ទែងគ្នា មានចិត្តប្រទូស្តទាស់ទែងគ្នា មានចិត្តវង្វេងទាស់ទែងគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី នេះជាវិន័យក្តី នេះមិនមែនជាវិន័យក្តី

នេះជាពាក្យ ដែលព្រះតថាគត ទ្រង់ត្រាស់សំដែងទុកមកហើយក្តី នេះមិនមែនជាពាក្យ ដែលព្រះតថាគត ទ្រង់ត្រាស់សំដែងទុកមកទេក្តី នេះជាកិច្ច ដែលព្រះតថាគត ទ្រង់ប្រព្រឹត្តសន្សំមកហើយក្តី នេះមិនមែនជាកិច្ច ដែលព្រះតថាគត ទ្រង់ប្រព្រឹត្តសន្សំមកក្តី នេះជាពាក្យ ដែលព្រះតថាគត ទ្រង់បញ្ញត្តក្តី នេះមិនមានជាពាក្យ ដែលព្រះតថាគត ទ្រង់បញ្ញត្តក្តី នេះជាអាបត្តិក្តី នេះមិនមែនជាអាបត្តិក្តី នេះជាអាបត្តិស្រាលក្តី នេះជាអាបត្តិធ្ងន់ក្តី នេះជាអាបត្តិ មានចំណែកសេសសល់ក្តី នេះជាអាបត្តិ មិនមានចំណែកសេសសល់ក្តី នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី អកុសលមូល ទាំង៣នេះឯង ចាត់ជា មូលនៃវិវាទាធិករណ៍។

[៥៦] កុសលមូល ៣យ៉ាង ដែលចាត់ជា មូលនៃវិវាទាធិករណ៍ នោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តមិនលោភទាស់ទែងគ្នា មានចិត្តមិនប្រទូស្តទាស់ទែងគ្នា មានចិត្តមិនវង្វេងទាស់ទែងគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី។ បេ។ នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី កុសលមូល ទាំង៣យ៉ាងនេះឯង ចាត់ជា មូលនៃវិវាទាធិករណ៍។

[៥៧] មូលនៃអនុវាទាធិករណ៍ នោះ តើដូចម្តេច។ មូលនៃការចោទគ្នា មាន៦យ៉ាង ចាត់ជាមូលនៃអនុវាទាធិករណ៍ គឺអកុសលមូល ៣យ៉ាង ក៏ចាត់ជាមូលនៃអនុវាទាធិករណ៍ កុសលមូល ៣យ៉ាង ក៏ចាត់ជាមូលនៃអនុវាទាធិករណ៍ដែរ កាយ ក៏ចាត់ជាមូលនៃអនុវាទាធិករណ៍ ទាំងវាចា ក៏ចាត់ជាមូលនៃអនុវាទាធិករណ៍ដែរ។

[៥៨] មូលនៃការចោទគ្នា មាន៦យ៉ាង ចាត់ជា មូលនៃអនុវាទាធិករណ៍ នោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីក្រោធ ជាអ្នកចងគំនុំទុក ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកមានសេចក្តីក្រោធ ជាអ្នកចងគំនុំទុក ភិក្ខុនោះ ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ភិក្ខុនោះ ឈ្មោះថា ញ៉ាំងអនុវាទ គឺការចោទ ដែលកំពុងកើត ឲ្យកើតក្នុងសង្ឃ ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនមានសេចក្តីសុខ ដល់ជនច្រើន ដើម្បីមិនមានសេចក្តីចំរើន ដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ពិចារណាឃើញ មូលនៃអនុវាទ ទាំងខាងក្នុង និងខាងក្រៅ មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីព្យាយាម ដើម្បីលះបង់ នូវមូលនៃអនុវាទ ដ៏លាមកនោះ ក្នុងអធិករណ៍នោះចេញ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនពិចារណាឃើញ មូលនៃអនុវាទ ទាំងខាងក្នុង និងខាងក្រៅ មានសភាពយ៉ាងនេះទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីប្រតិបត្តិ ដើម្បីកុំឲ្យមូលនៃអនុវិវាទ ដ៏លាមកនោះ ចំរើនតទៅខាងមុខ ក្នុងអធិករណ៍នោះទៀតឡើយ។ យ៉ាងនេះឯង ឈ្មោះថា ការលះបង់ នូវមូលនៃអនុវាទដ៏លាមកនុ៎ះ។ យ៉ាងនេះឯង ឈ្មោះថា មិនឲ្យមូល នៃអនុវាទ ដ៏លាមកនុ៎ះ ចំរើនតទៅទៀតបាន។

[៥៩] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រណាំងវាសនា។ បេ។ ជាអ្នកមានសេចក្តីឫស្យា ជាអ្នកមានសេចក្តីកំណាញ់។ បេ។ ជាអ្នកមានអំនួត ជាអ្នកមានមាយា។ បេ។ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ជាអ្នកមានសេចក្តីឃើញខុស។ បេ។ ជាអ្នកបបោសអង្អែលទិដ្ឋិរបស់ខ្លួន ប្រកាន់មាំ លះបង់បានដោយកម្រ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកបបោសអង្អែលទិដ្ឋិរបស់ខ្លួន ប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុនោះ ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង។ បេ។ ឈ្មោះថា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង ឈ្មោះថា មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ឥតមានសេចក្តីគោរព ឥតមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង។ បេ។ ក្នុងព្រះសង្ឃផង។ បេ។ មិនធ្វើឲ្យពេញលេញ ក្នុងសិក្ខាផង ភិក្ខុនោះ ឈ្មោះថា ញ៉ាំងអនុវាទ ដែលកំពុងកើត ឲ្យកើតឡើងក្នុងសង្ឃ ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនមានសេចក្តីសុខ ដល់ជនច្រើន ដើម្បីសេចក្តីមិនចំរើន ដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ពិចារណាឃើញ មូលនៃអនុវាទ ទាំងខាងក្នុង និងខាងក្រៅ មានសភាពយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីព្យាយាម ដើម្បីលះបង់ មូលនៃអនុវាទ ដ៏លាមកនោះ ក្នុងអធិករណ៍នោះចេញ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនពិចារណាឃើញ មូលនៃអនុវាទ ទាំងខាងក្នុង និងខាងក្រៅ មានសភាពយ៉ាងនេះទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីប្រតិបត្តិ ដើម្បីកុំឲ្យមូលនៃអនុវាទដ៏លាមកនោះ ចំរើនតទៅខាងមុខ ក្នុងអធិករណ៍នោះទៀតបានឡើយ។ យ៉ាងនេះឯង ឈ្មោះថា លះបង់នូវ មូលនៃអនុវាទ ដ៏លាមកនុ៎ះ។ យ៉ាងនេះឯង ឈ្មោះថា មិនបានឲ្យមូល នៃអនុវាទ ដ៏លាមកនុ៎ះ ចំរើនតទៅទៀតបាន មូលនៃអនុវាទ ទាំង៦យ៉ាងនេះ ចាត់ជា មូលនៃអនុវាទាធិករណ៍។

[៦០] អកុសលមូល ៣យ៉ាង ដែលចាត់ជា មូលនៃអនុវាទាធិករណ៍ នោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តលោភ ពោលចោទ មានចិត្តប្រទូស្តពោលចោទ មានចិត្តវង្វេងពោលចោទ នូវភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី អកុលមូល ទាំង៣យ៉ាងនេះ ជាមូលនៃអនុវាទាធិករណ៍។

[៦១] កុសលមូល ៣យ៉ាង ដែលចាត់ជា មូលនៃអនុវាទាធិករណ៍ នោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តមិនលោភពោលចោទ មានចិត្តមិនប្រទូស្តពោលចោទ មានចិត្តមិនវង្វេងពោលចោទ នូវភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី កុសលមូល ទាំង៣យ៉ាងនេះ ជា មូលនៃអនុវាទាធិករណ៍។

[៦២] ឯកាយ ចាត់ជា មូលនៃអនុវាទាធិករណ៍ នោះ តើដូចម្តេច។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ មានសម្បុរអាក្រក់ មានរូបអាក្រក់ ជាមនុស្សតឿ មានអាពាធច្រើន ខ្វាក់ ក្ញែង ខ្ចក ឬស្លាប់ខ្លួន១ចំហៀង[15] ភិក្ខុទាំងឡាយចោទភិក្ខុនោះ ដោយកាយណា កាយនោះ ជាមូលនៃអនុវាទាធិករណ៍។

[៦៣] ចុះវាចា ដូចម្តេច ដែលជា មូលនៃអនុវាទាធិករណ៍។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកមានវាចាអាក្រក់ ជាអ្នកនិយាយជាប់ ជាអ្នកមានវាចាប៉ប៉ាច់ ប៉ប៉ោច ភិក្ខុទាំងឡាយ ចោទភិក្ខុនោះ ដោយវាចាណា វាចានោះ ឈ្មោះថាជា មូលនៃអនុវាទាធិករណ៍។

[៦៤] អ្វីដែលជា មូលនៃអាបត្តាធិករណ៍។ សមុដ្ឋាន នៃអាបត្តិ៦យ៉ាង ជាមូលនៃអាបត្តាធិករណ៍ (សមុដ្ឋាន នៃអាបត្តិ៦នោះ គឺ) អាបត្តិ កើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា អំពីចិត្ត១ អាបត្តិ កើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ អំពីចិត្ត១ អាបត្តិ កើតឡើងអំពីកាយ អំពីវាចា មិនកើតឡើងអំពីចិត្ត១ អាបត្តិ កើតឡើងអំពីកាយ អំពីចិត្ត មិនកើតឡើងអំពីវាចា១ អាបត្តិ កើតឡើងអំពីវាចា អំពីចិត្ត មិនកើតឡើងអំពីកាយ១ អាបត្តិ កើតឡើងអំពីកាយ អំពីវាចា អំពីចិត្ត១ សមុដ្ឋាន នៃអាបត្តិ៦យ៉ាងនេះ ជាមូលនៃអាបត្តាធិករណ៍។

[៦៥] អ្វីជា មូលនៃកិច្ចាធិករណ៍។ មានតែសង្ឃមួយ ជាមូលនៃកិច្ចាធិករណ៍។[16)]

[៦៦] (សំដែងអំពី) វិវាទាធិករណ៍ ជាកុសល ជាអកុសល ជាអព្យាកតៈ។ វិវាទាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈ ក៏មាន។

[៦៧] បណ្តាវិវាទាធិករណ៍ទាំង៣នោះ វិវាទាធិករណ៍ ជាអកុសល តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង មានចិត្តជាអកុសល ជជែកគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី។ បេ។ នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី ការបង្កហេតុ ជម្លោះ សេចក្តីប្រកាន់ខុស ទាស់ទែង ការពោលផ្សេងៗ ការពោលដោយឡែកពីគ្នា ការនិយាយដើម្បីឲ្យព្រួយចិត្ត សេចក្តីប្រកួតប្រកាន់ណា ក្នុងអធិករណ៍នោះ ការបង្កហេតុជាដើមនេះ តថាគត ហៅថា វិវាទាធិករណ៍ ជាអកុសល។

[៦៨] បណ្តាវិវាទាធិករណ៍ទាំង៣នោះ វិវាទាធិករណ៍ ជាកុសល តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង មានចិត្តជាកុសល ជជែកគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី។ បេ។ នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី ការបង្កហេតុ ជម្លោះ សេចក្តីប្រកាន់ខុស ការទាស់ទែង ការពោលផ្សេងៗ ការពោលដោយឡែកពីគ្នា ការនិយាយដើម្បីឲ្យព្រួយចិត្ត ការប្រកួតប្រកាន់ណា ក្នុងអធិករណ៍នោះ ការបង្កហេតុជាដើមនេះ តថាគត ហៅថា វិវាទាធិករណ៍ ជាកុសល។

[៦៩] បណ្តាវិវាទាធិករណ៍ទាំង៣នោះ វិវាទាធិករណ៍ ជាអព្យាកតៈ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង មានចិត្តជាអព្យាកតៈ ជជែកនឹងភិក្ខុផងគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី។ បេ។ នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី ការបង្កហេតុ ជម្លោះ សេចក្តីប្រកាន់ខុស ការទាស់ទែងគ្នា ការពោលផ្សេងៗ ការពោលដោយឡែកពីគ្នា ការនិយាយដើម្បីឲ្យព្រួយចិត្ត ការប្រកួតប្រកាន់ណា ក្នុងវិវាទាធិករណ៍នោះ ការបង្កហេតុជាដើមនេះ តថាគត ហៅថា វិវាទាធិករណ៍ ជាអព្យាកតៈ។

[៧០] (សំដែងអំពី) អនុវាទាធិករណ៍ ជាកុសល ជាអកុសល ជាអព្យាកតៈ។ អនុវាទាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។

[៧១] បណ្តាអនុវាទាធិករណ៍ទាំង៣នោះ អនុវាទាធិករណ៍ ជាអកុសល តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង មានចិត្តជាអកុសល ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី ការចោទ ការតិះដៀល ការចរចារឿយៗ ការនិយាយរឿយៗ ការពោលបង្កាច់ ការប្រឹងប្រែង ការបន្ថែមកម្លាំងឲ្យណា ក្នុងអធិករណ៍នោះ ការចោទ ជាដើមនេះ តថាគត ហៅថា អនុវាទាធិករណ៍ ជាអកុសល។

[៧២] បណ្តាអនុវាទាធិករណ៍ទាំង៣នោះ អនុវាទាធិករណ៍ ជាកុសល តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង មានចិត្តជាកុសល ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី ការចោទ ការតិះដៀល ការចរចារឿយៗ ការនិយាយរឿយៗ ការពោលបង្កាច់ ការប្រឹងប្រែង ការបន្ថែមកម្លាំងឲ្យណា ក្នុងអធិករណ៍នោះ ការចោទ ជាដើមនេះ តថាគត ហៅថា អនុវាទាធិករណ៍ ជាកុសល។

[៧៣] បណ្តាអនុវាទាធិករណ៍ទាំង៣នោះ អនុវាទាធិករណ៍ ជាអព្យាកតៈ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មានចិត្តជាអព្យាកតៈ ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី ការចោទ ការតិះដៀល ការចរចារឿយៗ ការនិយាយរឿយៗ ការពោលបង្កាច់ ការប្រឹងប្រែង ការបន្ថែមកម្លាំងឲ្យណា ក្នុងអធិករណ៍នោះ ការចោទ ជាដើមនេះ តថាគត ហៅថា អនុវាទាធិករណ៍ ជាអព្យាកតៈ។

[៧៤] (សំដែងអំពី) អាបត្តាធិករណ៍ ជាអកុសល ជាអព្យាកតៈ។ អាបត្តាធិករណ៍ ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន អាបត្តាធិករណ៍ ជាកុសល គ្មានទេ។

[៧៥] បណ្តាអាបត្តាធិករណ៍ ទាំង២នោះ អាបត្តាធិករណ៍ ជាអកុសល តើដូចម្តេច។ ភិក្ខុ កាលបើដឹង ស្គាល់ហើយ ក្លែងព្យាយាមកន្លង នូវអាបត្តិណា អាបត្តិនេះ តថាគត ហៅថា អាបត្តាធិករណ៍ ជាអកុសល។ បណ្តាអាបត្តាធិករណ៍ ទាំង២នោះ អាបត្តាធិករណ៍ ជាអព្យាកតៈ តើដូចម្តេច។ ភិក្ខុ កាលមិនដឹង មិនស្គាល់ហើយ មិនក្លែង មិនព្យាយាមកន្លង នូវអាបត្តិណា អាបត្តិនេះ តថាគត ហៅថា អាបត្តាធិករណ៍ ជាអព្យាកតៈ។[17)]

[៧៦] ] (សំដែងអំពី) កិច្ចាធិករណ៍ ជាកុសល ជាអកុសល ជាអព្យាកតៈ។ កិច្ចាធិករណ៍ ជាកុសល ក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។

[៧៧] បណ្តាកិច្ចាធិករណ៍ ទាំង៣នេះ កិច្ចាធិករណ៍ ជាអកុសល តើដូចម្តេច។ សង្ឃមានចិត្ត ជាអកុសល ធ្វើកម្មណា គឺអបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម កម្មនេះ តថាគត ហៅថា កិច្ចាធិករណ៍ ជាអកុសល។

[៧៨] បណ្តាកិច្ចាធិករណ៍ ទាំង៣នេះ កិច្ចាធិករណ៍ ជាកុសល តើដូចម្តេច។ សង្ឃមានចិត្ត ជាកុសល ធ្វើកម្មណា គឺអបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម កម្មនេះ តថាគត ហៅថា កិច្ចាធិករណ៍ ជាកុសល។

[៧៩] បណ្តាកិច្ចាធិករណ៍ ទាំង៣នេះ កិច្ចាធិករណ៍ ជាអព្យាកតៈ តើដូចម្តេច។ សង្ឃមានចិត្ត ជាអព្យាកតៈ ធ្វើកម្មណា គឺអបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម កម្មនេះ តថាគត ហៅថា កិច្ចាធិករណ៍ ជាអព្យាកតៈ។

[៨០] (សំដែងអំពី) ការទាស់ទែងគ្នា ចាត់ជាវិវាទាធិករណ៍ ការទាស់ទែងគ្នា មិនចាត់ជាអធិករណ៍ អធិករណ៍ មិនចាត់ជាការទាស់ទែងគ្នា ចាត់ជាអធិករណ៍ផង ជាការទាស់ទែងគ្នាផង។ ការទាស់ទែងគ្នា ចាត់ជាវិវាទាធិករណ៍ក៏មាន ការទាស់ទែងគ្នា មិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍ មិនចាត់ជាការទាស់ទែងគ្នាក៏មាន ចាត់ជាអធិករណ៍ផង ជាការទាស់ទែងគ្នាផងក៏មាន។

[៨១] បណ្តាអធិករណ៍ទាំងនោះ ការទាស់ទែងគ្នា ដែលចាត់ជាវិវាទាធិករណ៍ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ ជជែកគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី។ បេ។ នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី ការបង្កហេតុ ជម្លោះ ការប្រកាន់ខុស ការទាស់ទែង ការនិយាយផ្សេងៗ ការនិយាយផ្តេសផ្តាស ការនិយាយដើម្បីឲ្យព្រួយចិត្ត ការប្រកួតប្រកាន់ណា ក្នុងអធិករណ៍នោះ ការបង្កហេតុជាដើមនេះ ចាត់ជាការទាស់ទែងគ្នា ហៅថា វិវាទាធិករណ៍។ បណ្តាអធិករណ៍ទាំងនោះ ការទាស់ទែងគ្នា ដែលមិនមែនជាអធិករណ៍ តើដូចម្តេច។ មាតាទាស់នឹងបុត្រក្តី បុត្រទាស់នឹងមាតាក្តី បិតាទាស់នឹងបុត្រក្តី បុត្រទាស់នឹងបិតាក្តី បងប្អូនប្រុសទាស់នឹងបងប្អូនប្រុសក្តី បងប្អូនប្រុស ទាស់នឹងបងប្អូនស្រីក្តី បងប្អូនស្រី ទាស់នឹងបងប្អូនប្រុសក្តី សម្លាញ់ ទាស់នឹងសម្លាញ់ក្តី នេះហៅថា ការទាស់ទែងគ្នា មិនមែនជាអធិករណ៍។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ ដែលមិនចាត់ជាការទាស់ទែងគ្នា តើដូចម្តេច។ អនុវាទាធិករណ៍១ អាបត្តាធិករណ៍១ កិច្ចាធិករណ៍១ នេះហៅថា អធិករណ៍ ដែលមិនចាត់ជាការទាស់ទែងគ្នា។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ ដែលចាត់ពេញថា ជាអធិករណ៍ផង ជាការទាស់ទែងគ្នាផង តើដូចម្តេច។ វិវាទាធិករណ៍ ចាត់ជាអធិករណ៍ផង ជាការទាស់ទែងគ្នាផង។

[៨២] (សំដែងអំពី) ការចោទ ចាត់ជាអនុវាទាធិករណ៍ ការចោទ មិនចាត់ជាអធិករណ៍ អធិករណ៍ មិនចាត់ជាការចោទ ទាំងជាអធិករណ៍ផង ចាត់ជាការចោទផង។ ការចោទ ចាត់ជាអនុវាទាធិករណ៍ក៏មាន ការចោទ មិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍ មិនចាត់ជាការចោទក៏មាន ទាំងជាអធិករណ៍ផង ចាត់ជាការចោទផងក៏មាន។

[៨៣] បណ្តាអធិករណ៍ទាំងនោះ ការចោទ ចាត់ជាអនុវាទាធិករណ៍ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះឯង ចោទប្រកាន់ភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី ការចោទ ការតិះដៀល ការចរចារឿយៗ ការនិយាយរឿយៗ ការពោលបង្កាច់ ការប្រឹងប្រែង ការបន្ថែមកម្លាំងឲ្យណា ក្នុងអធិករណ៍នោះ ការចោទជាដើមនេះ ហៅថា អនុវាទាធិករណ៍។ បណ្តាអធិករណ៍ទាំងនោះ ការចោទ ដែលមិនចាត់ជាអធិករណ៍ តើដូចម្តេច។ មាតាចោទបុត្រក្តី បុត្រចោទមាតាក្តី បិតាចោទបុត្រក្តី បុត្រចោទបិតាក្តី បងប្អូនប្រុសចោទបងប្អូនប្រុសក្តី បងប្អូនប្រុស ចោទបងប្អូនស្រីក្តី បងប្អូនស្រី ចោទបងប្អូនប្រុសក្តី សម្លាញ់ ចោទសម្លាញ់ក្តី នេះឯងហៅថា ការចោទ ដែលមិនមែនជាអធិករណ៍។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ តែមិនចាត់ជាការចោទ តើដូចម្តេច។ អាបត្តាធិករណ៍១ កិច្ចាធិករណ៍១ វិវាទាធិករណ៍១ នេះហៅថា អធិករណ៍ តែមិនចាត់ជាការចោទទេ។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ ដែលចាត់ពេញថា ជាអធិករណ៍ផង ចាត់ជាការចោទផង តើដូចម្តេច។ អនុវាទាធិករណ៍ ចាត់ជាអធិករណ៍ផង ចាត់ជាការចោទផង។

[៨៤] (សំដែងអំពី) អាបត្តិ ចាត់ជាអាបត្តាធិករណ៍ អាបត្តិ មិនមែនជាអធិករណ៍ អធិករណ៍ មិនមែនជាអាបត្តិ ទាំងអធិករណ៍ ទាំងអាបត្តិ។ អាបត្តិ ចាត់ជាអាបត្តាធិករណ៍ក៏មាន អាបត្តិ មិនមែនជាអធិករណ៍ក៏មាន អធិករណ៍ មិនមែនជាអាបត្តិក៏មាន អធិករណ៍ផង អាបត្តិផងក៏មាន។

[៨៥] បណ្តាអធិករណ៍ទាំងនោះ អាបត្តិ ដែលចាត់ជាអាបត្តាធិករណ៍ តើដូចម្តេច។ អាបត្តិទាំង៥កង ក៏ចាត់ជាអាបត្តាធិករណ៍ អាបត្តិទាំង៧កង ក៏ចាត់ជាអាបត្តាធិករណ៍ នេះហៅថា អាបត្តិ ដែលចាត់ជាអាបត្តាធិករណ៍។ បណ្តាអធិករណ៍ទាំងនោះ អាបត្តិដែលមិនចាត់ជាអធិករណ៍ តើដូចម្តេច។ សោតាបត្តិ និងសមាបត្តិ នេះហៅថា អាបត្តិ តែមិនចាត់ជាអធិករណ៍។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ ដែលមិនចាត់ជាអាបត្តិ តើដូចម្តេច។ កិច្ចាធិករណ៍១ វិវាទាធិករណ៍១ អនុវាទាធិករណ៍១ នេះហៅថា អធិករណ៍ មិនមែនជាអាបត្តិ។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ ដែលចាត់ជាអធិករណ៍ផង ជាអាបត្តិផង តើដូចម្តេច។ អាបត្តាធិករណ៍ ចាត់ជាអធិករណ៍ផង ជាអាបត្តិផង។

[៨៦] (សំដែងអំពី) កិច្ចចាត់ជាកិច្ចាធិករណ៍ កិច្ចមិនមែនជាអធិករណ៍ អធិករណ៍ មិនមែនជាកិច្ច ជាអធិករណ៍ផង កិច្ចផង។ កិច្ច ចាត់ជាកិច្ចាធិករណ៍ក៏មាន កិច្ច មិនមែនជាអធិករណ៍ក៏មាន អធិករណ៍ មិនមែនជាកិច្ចក៏មាន ជាអធិករណ៍ផង កិច្ចផងក៏មាន។

[៨៧] បណ្តាអធិករណ៍ទាំងនោះ កិច្ច ដែលចាត់ជាកិច្ចាធិករណ៍ តើដូចម្តេច។ កិច្ច ឬកម្មណា ដែលសង្ឃគប្បីធ្វើ គឺ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម ទាំងនេះ ហៅថា កិច្ចដែលចាត់ជាកិច្ចាធិករណ៍។ បណ្តាអធិករណ៍ទាំងនោះ កិច្ច ដែលមិនមែនជាអធិករណ៍ តើដូចម្តេច។ អាចរិយកិច្ច ឧបជ្ឈាយកិច្ច សមានុបជ្ឈាយកិច្ច សមានាចរិយកិច្ច ទាំងនេះហៅថា កិច្ច មិនមែនជាអធិករណ៍។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ ដែលមិនមែនជាកិច្ច តើដូចម្តេច។ វិវាទាធិករណ៍ អនុវាទាធិករណ៍ អាបត្តាធិករណ៍ នេះហៅថា អធិករណ៍ មិនមែនជាកិច្ច។ បណ្តាអធិករណ៍ទាំងនោះ អធិករណ៍ ដែលចាត់ជា អធិករណ៍ផង ជាកិច្ចផង តើដូចម្តេច។ កិច្ចាធិករណ៍ ចាត់ជាអធិករណ៍ផង ជាកិច្ចផង។

## (អធិករណវូបសមនសមថៈ ទី៩)

## (៩. អធិករណរូបសមនសមថោ)

## (សម្មុខាវិនយ)



### (សម្មុខាវិនយោ)

[៨៨] វិវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ វិវាទាធិករណ៍ រម្ងាប់ដោយសមថៈពីរយ៉ាងគឺ សម្មុខាវិន័យ១ យេភុយ្យសិកា១។ វិវាទាធិករណ៍ មិនអាស្រ័យសមថៈ១ គឺ យេភុយ្យសិកា គ្រាន់តែរម្ងាប់ដោយសមថៈតែ១ គឺសម្មុខាវិន័យក៏មាន។ ពាក្យដែលបណ្ឌិត គប្បីពោលថា ក៏មានដូច្នេះ។ ពាក្យនោះ តើដូចសំដែងត្រង់បទណា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ ក្នុងសាសនានេះ ជជែកគ្នាថា នេះជាធម៌ក្តី នេះមិនមែនជាធម៌ក្តី នេះជាវិន័យក្តី នេះមិនមែនជាវិន័យក្តី នេះជាពាក្យ ដែលព្រះតថាគត បានទ្រង់ត្រាស់សំដែងទុកក្តី នេះមិនមែនជាពាក្យ ដែលព្រះតថាគត ទ្រង់ត្រាស់សំដែងទុកមកទេក្តី នេះជាកិច្ច ដែលព្រះតថាគត ទ្រង់ប្រព្រឹត្តសន្សំទុកក្តី នេះមិនមែនជាកិច្ច ដែលព្រះតថាគត ទ្រង់ប្រព្រឹត្តសន្សំមកទេក្តី នេះជាពាក្យ ដែលព្រះតថាគត ទ្រង់បញ្ញត្តក្តី នេះមិនមែនជាពាក្យ ដែលព្រះតថាគត ទ្រង់បញ្ញត្តទេក្តី នេះជាអាបត្តិក្តី នេះមិនមែនជាអាបត្តិក្តី នេះជាអាបត្តិស្រាលក្តី នេះជាអាបត្តិធ្ងន់ក្តី នេះជាអាបត្តិ មានចំណែកសេសសល់ក្តី នេះជាអាបត្តិ មិនមានចំណែកសេសសល់ក្តី នេះជាអាបត្តិអាក្រក់ក្តី នេះមិនមែនជាអាបត្តិអាក្រក់ក្តី ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ អាចរម្ងាប់អធិករណ៍នោះបាន ម្នាលភិក្ខុទាំងឡាយ នេះហើយ ដែលតថាគតហៅថា អធិករណ៍រម្ងាប់។ អធិករណ៍នោះ រម្ងាប់ដោយអ្វី។ អធិករណ៍នោះ រម្ងាប់ដោយសម្មុខាវិន័យ។ ក្នុងសម្មុខាវិន័យនោះ មានអង្គប៉ុន្មាន។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ ពួកភិក្ខុ មានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ ក៏បានមក ទាំងឆន្ទៈរបស់ភិក្ខុ ដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយ ភិក្ខុទាំងឡាយមកប្រជុំចំពោះមុខ មិនឃាត់ហាម នេះហៅថា ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ អធិករណ៍នោះ រម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា នេះហៅថា ចំពោះមុខធម៌ ចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ ឯការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ បុគ្គលណា ទាស់ទែងគ្នា ទៅវិញទៅមក បុគ្គលទាំងពីរនេះ ជាសត្រូវនឹងគ្នា មាននៅក្នុងទីចំពោះមុខ នេះហៅថា ចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ មានភិក្ខុអ្នកធ្វើត្រឡប់ សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ (ត្រូវអាបត្តិបាចិត្តិយៈ ព្រោះរើរុស)។ ភិក្ខុអ្នកឲ្យឆន្ទៈហើយ ត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ (ត្រូវអាបត្តិបាចិត្តិយៈ ព្រោះតិះដៀល)។

[៨៩] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ មិនអាចរម្ងាប់អធិករណ៍នោះ ក្នុងអាវាសនោះបានទេ ម្នាលភិក្ខុទាំងឡាយ (បើ) អាវាសណា មានភិក្ខុច្រើនក្រាសក្រៃល ត្រូវភិក្ខុទាំងនោះ ទៅរកអាវានោះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ កំពុងទៅរកអាវាសនោះ អាចរម្ងាប់អធិករណ៍នោះ ក្នុងកណ្តាលផ្លូវបាន ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគត ហៅថា អធិករណ៍រម្ងាប់។ អធិករណ៍នោះ រម្ងាប់ដោយធម៌ដូចម្តេច។ រម្ងាប់ដោយសម្មុខាវិន័យ។ ចុះក្នុងសម្មុខាវិន័យនោះ មានអង្គប៉ុន្មាន។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ ក៏ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ ពួកភិក្ខុ មានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ ក៏បានមក ទាំងឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ក៏បាននាំមក ភិក្ខុទាំងឡាយមានក្នុងទីចំពោះមុខ ក៏មិនបានហាមឃាត់ នេះហៅថា ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ។ ឯការចំពោះមុខធម៌ ការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ អធិករណ៍នោះ រម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា នេះហៅថា ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ។ ឯការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ បុគ្គលណា ទាស់ទែងគ្នា ទៅវិញទៅមក បុគ្គលទាំងពីររូប ជាសត្រូវនឹងគ្នា មានក្នុងទីចំពោះមុខ នេះហៅថា ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ មានភិក្ខុអ្នកធ្វើត្រឡប់ សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ ភិក្ខុអ្នកធ្វើ ឲ្យឆន្ទៈហើយ ត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ។

[៩០] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ កំពុងទៅកាន់អាវាសនោះ មិនអាចរម្ងាប់អធិករណ៍ ក្នុងកណ្តាលផ្លូវបានទេ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះ ទៅកាន់អាវាសនោះហើយ ពោលយ៉ាងនេះ នឹងភិក្ខុទាំងឡាយ ជាម្ចាស់អាវាសថា ម្នាលលោកទាំងឡាយមានអាយុ អធិករណ៍នេះ កើតប្រាកដយ៉ាងនេះហើយ សូមលោកមានអាយុទាំងឡាយ រម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ដោយប្រពៃ តាមទំនង ដែលអធិរកណ៍នេះ គប្បីរម្ងាប់ទៅដោយប្រពៃចុះ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុ ជាម្ចាស់អាវាស ចាស់ជាង ពួកភិក្ខុជាអាគន្តុកៈ ខ្ចីជាង ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុជាម្ចាស់អាវាសទាំងនោះ និយាយទៅនឹងពួកភិក្ខុ ជាអាគន្តុកៈ យ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ បើដូច្នោះ ចូរលោកទាំងឡាយនៅរង់ចាំ ក្នុងទីសមគួរ មួយរំពេចសិន ទំរាំយើងទាំងឡាយ ប្រឹក្សាគ្នា។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកភិក្ខុជាម្ចាស់អាវាស ខ្ចីជាង ពួកភិក្ខុជាអាគន្តុកៈ ចាស់ជាង ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុជាម្ចាស់អាវាសទាំងនោះ និយាយទៅនឹងពួកភិក្ខុជាអាគន្តុកៈ យ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ បើដូច្នោះ ចូរលោកទាំងឡាយ នៅរង់ចាំ ក្នុងទីនេះ មួយរំពេចសិន ទំរាំយើងទាំងឡាយ ប្រឹក្សាគ្នា។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ពួកភិក្ខុជាម្ចាស់អាវាស កំពុងប្រឹក្សាគ្នា មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងទាំងឡាយ មិនអាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាបានទេ អធិករណ៍នោះ ភិក្ខុជាម្ចាស់អាវាសទាំងឡាយ មិនត្រូវទទួលទេ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកភិក្ខុជាម្ចាស់អាវាស កំពុងប្រឹក្សាគ្នា មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងទាំងឡាយ អាចនឹងរម្ងាប់អធិករណ៍នេះតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាបាន ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុជាម្ចាស់អាវាសនោះ ត្រូវនិយាយ នឹងពួកភិក្ខុជាអាគន្តុកៈ យ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ ប្រសិនបើលោកទាំងឡាយ ប្រាប់អធិករណ៍នេះ តាមរឿង ដែលកើតប្រាកដហើយ ដល់យើងទាំងឡាយ យើងទាំងឡាយ នឹងរម្ងាប់អធិករណ៍នេះ ឲ្យសមគួរតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាបាន អធិករណ៍ មុខជានឹងរម្ងាប់បាន ដោយស្រួល បើយ៉ាងនេះ ទើបយើងទាំងឡាយ នឹងទទួលអធិករណ៍នេះ។ ម្នាលលោកមានអាយុ

ប្រសិនបើលោកទាំងឡាយ មិនប្រាប់អធិករណ៍នេះ តាមរឿង ដែលកើតប្រាកដ ដល់យើងទាំងឡាយទេ ចំណែកខាងយើងទាំងឡាយ នឹងរម្ងាប់អធិករណ៍នេះ ឲ្យសមគួរតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា អធិករណ៍នោះ មុខជាមិនបានរម្ងាប់ ដោយល្អឡើយ យើងទាំងឡាយ មិនព្រមទទួលអធិករណ៍នេះទេ។ ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុជាម្ចាស់អាវាស ធ្វើសេចក្តីកំណត់ ឲ្យស្រួលបួលយ៉ាងនេះ រួចហើយ ត្រូវទទួលអធិករណ៍នោះចុះ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុជាអាគន្តុកៈនោះ ត្រូវនិយាយទៅនឹងពួកភិក្ខុជាម្ចាស់អាវាសយ៉ាងនេះថា យើងទាំងឡាយ នឹងប្រាប់អធិករណ៍នេះ តាមរឿង ដែលកើតប្រាកដ ដល់លោកមានអាយុទាំងឡាយ ប្រសិនបើលោកមានអាយុទាំងឡាយ អាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ដោយហេតុមានប្រមាណប៉ុណ្ណេះក្តី ៗ អធិករណ៍នោះ មុខជានឹងរម្ងាប់បាន ដោយល្អ បើយ៉ាងនេះ ទើបយើងទាំងឡាយ នឹងប្រគល់អធិករណ៍នេះ ឲ្យលោកមានអាយុទាំងឡាយ បើលោកមានអាយុទាំងឡាយ មិនអាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ដោយហេតុមានប្រមាណប៉ុណ្ណេះក្តី ៗ អធិករណ៍នោះ ក៏មុខជានឹងមិនរម្ងាប់ ដោយប្រពៃឡើយ យើងទាំងឡាយ នឹងមិនប្រគល់អធិករណ៍នេះ ឲ្យលោកមានអាយុទាំងឡាយទេ យើងទាំងឡាយ នឹងជាម្ចាស់អធិករណ៍នេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវពួកភិក្ខុ ជាអាគន្តុកៈ ធ្វើសេចក្តីកំណត់ ឲ្យស្រួលបួលយ៉ាងនេះ រួចហើយ សឹមប្រគល់អធិករណ៍នោះ ដល់ពួកភិក្ខុជាម្ចាស់វត្តចុះ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនោះ អាចនឹងរម្ងាប់អធិករណ៍នោះបាន ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគត ហៅថា អធិករណ៍ រម្ងាប់បានដោយស្រួលល្អ។ អធិករណ៍នោះ រម្ងាប់បានដោយអ្វី។ រម្ងាប់បានដោយសម្មុខាវិន័យ។ ក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេចខ្លះ។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គ ក្នុងសម្មុខាវិន័យនោះ)។ បេ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយ ត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ។

[៩១] ម្នាលភិក្ខុទាំងឡាយ កាលបើអធិករណ៍នោះ ភិក្ខុទាំងឡាយនោះ កំពុងវិនិច្ឆ័យ ក៏មានពាក្យទ្រហឹង អឺងកង មិនមានទីបំផុត គឺមិនចេះអស់ មិនចេះហើយ កើតឡើងផង ទាំងសេចក្តីអធិប្បាយ នៃភាសិតនុ៎ះ ក៏មិនមាននរណាដឹងច្បាស់ផង ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យរម្ងាប់អធិករណ៍បែបនេះ ដោយឧព្វាហិ[18] កាកម្មវាចា។ សង្ឃគប្បីសន្មតភិក្ខុ ដែលប្រកបដោយអង្គ១០ប្រការ ដោយឧព្វាហិកាកម្មវាចា (ឯអង្គ ១០ប្រការនោះ) គឺ ភិក្ខុជាអ្នកមានសីល១ សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ១ ឃើញភ័យ ក្នុងទោសបន្តិចបន្តួច ហើយសមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ១ ជាពហុស្សុត ទ្រង់ទ្រង់ពុទ្ធវចនៈ ជាអ្នកសន្សំនូវពុទ្ធវចនៈ១ ធម៌ណា ដែលមានពីរោះបទខាងដើម ពីរោះបទកណ្តាល ពីរោះបទចុង ពោលសរសើរព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ឲ្យបរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពយ៉ាងនេះ ភិក្ខុនោះ ក៏បានស្តាប់ច្រើន បានចាំទុក បានសន្សំទុកដោយវាចា (ស្ទាត់ជំនាញ) ជាក់ច្បាស់ក្នុងចិត្ត ត្រាស់ដឹងល្អ ដោយទិដ្ឋិ១ មិនតែប៉ុណ្ណោះឡើយ បាតិមោក្ខ ទាំងពីរយ៉ាង ក៏ភិក្ខុនោះចាំបាន ដោយពិស្តារ ចេះចែក រលែកស្រួល ចេះស្ទាត់រត់មាត់ វិនិច្ឆ័យបានដោយល្អ តាមសុត្តៈ តាមអនុព្យញ្ជនៈ១ ជាអ្នកខ្ជាប់ខ្ជួន ឥតទើសទាល់ ក្នុងផ្លូវវិន័យ១ ជាអ្នកអង់អាច ដើម្បីធ្វើបុគ្គលទាំងពីរ ដែលជាសត្រូវនឹងគ្នា ឲ្យដឹងច្បាស់ ឲ្យពិនិត្យ ឲ្យពិចារណា ឲ្យឃើញ ឲ្យជ្រះថ្លាបាន១ ជាអ្នកឈ្លាស ដើម្បីរម្ងាប់អធិករណ៍ ដែលកើតឡើងហើយ១ ស្គាល់អធិករណ៍ ស្គាល់ហេតុ ដែលឲ្យកើតអធិករណ៍ ស្គាល់ធម៌សម្រាប់រំលត់អធិករណ៍ ទាំងស្គាល់ផ្លូវ ទៅកាន់ធម៌ សម្រាប់រំលត់អធិករណ៍១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យសន្មតភិក្ខុ ដែលប្រកបដោយអង្គទាំង១០ប្រការនេះ ដោយឧព្វាហិកាកម្ម។

## (ឧព្វាហិកាយវូបសមន)

CS vin.cv.04.09.02 | ភាគ ទី១០

### (ឧព្វាហិកាយវូបសមនំ)

[៩២] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតភិក្ខុនោះយ៉ាងនេះ។ សង្ឃត្រូវសូមភិក្ខុជាមុន លុះសូមរួចហើយ ភិក្ខុជាអ្នកឈ្លាស ប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ អធិករណ៍នេះ យើងទាំងឡាយ កំពុងវិនិច្ឆ័យ ក៏មានពាក្យទ្រហឹង អឺងកង មិនមានទីបំផុតកើតឡើង សេចក្តីអធិប្បាយ នៃភាសិតនុ៎ះ ក៏មិនមាននរណាដឹងច្បាស់។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវសន្មតភិក្ខុឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចា។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ អធិករណ៍នេះ យើងទាំងឡាយ កំពុងវិនិច្ឆ័យ ក៏មានពាក្យទ្រហឹង អឺងកង មិនមានទីបំផុតកើតឡើង សេចក្តីអធិប្បាយ នៃភាសិតនុ៎ះ ក៏មិនមាននរណាដឹងច្បាស់។ សង្ឃសន្មតភិក្ខុឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យរម្ងាប់នូវអធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចា។ ការសន្មតិ នូវភិក្ខុឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីរម្ងាប់នូវអធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចា គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវពោលឡើង។ ភិក្ខុឈ្មោះនេះផង ឈ្មោះនេះផង សង្ឃបានសន្មត ដើម្បីឲ្យរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចាហើយ ការសន្មតិភិក្ខុ ដើម្បីឲ្យរម្ងាប់នូវអធិករណ៍នេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[៩៣] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ អាចដើម្បីរម្ងាប់អធិករណ៍នោះ ដោយឧព្វាហិកាកម្មវាចាបាន ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគត ហៅថា អធិករណ៍រម្ងាប់ហើយ។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ។ ក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់ សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។

[៩៤] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ កំពុងតែវិនិច្ឆ័យអធិករណ៍នោះ មានភិក្ខុជាធម្មកថិក នៅក្នុងបរិសទ្យនោះ មិនចាំសុត្តៈ (មាតិកា) មិនចាំសុត្តវិភង្គ (វិន័យ) ភិក្ខុនោះ មិនបានកំណត់សេចក្តី ប្រកាន់យកតែព្យញ្ជនៈជាប្រមាណ ហើយត្រឡប់បដិសេធសេចក្តីចោលចេញ ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវនិយាយបញ្ជាក់ភិក្ខុទាំងនោះថា លោកមានអាយុទាំងឡាយ ចូរប្រុងស្តាប់ខ្ញុំ ភិក្ខុជាធម្មកថិកឈ្មោះនេះ ៗ មិនចាំសុត្តៈ មិនស្ទាត់សុត្តវិភង្គទេ ភិក្ខុជាធម្មកថិកនោះ កំណត់សេចក្តីមិនបានទេ ប្រកាន់យកតែព្យញ្ជនៈជាប្រមាណ ហើយត្រឡប់បដិសេធសេចក្តីចោលចេញ។

បើកម្មមានកាលគួរ ដល់លោកមានអាយុទាំងឡាយហើយ យើងទាំងឡាយដ៏សេស គប្បីឲ្យភិក្ខុឈ្មោះនេះ ក្រោកឡើង ហើយសឹមរម្ងាប់នូវអធិករណ៍នេះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ ឲ្យភិក្ខុនោះក្រោកឡើងហើយ អាចដើម្បីរម្ងាប់អធិករណ៍នោះបាន ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគតហៅថា អធិករណ៍រម្ងាប់។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ។ ចុះក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើត្រឡប់ សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។

[៩៥] ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍នោះ ភិក្ខុទាំងឡាយនោះ កំពុងតែវិនិច្ឆ័យ មានភិក្ខុជាធម្មកថិក ក្នុងបរិសទ្យនោះ ជាអ្នកចាំសុត្តៈ តែមិនចាំសុត្តវិភង្គ ភិក្ខុនោះ កំណត់សេចក្តីមិនបាន ប្រកាន់យកតែព្យញ្ជនៈជាប្រមាណ ហើយត្រឡប់បដិសេធសេចក្តីចោលចេញ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវនិយាយបញ្ជាក់ភិក្ខុទាំងនោះថា សូមលោកមានអាយុទាំងឡាយ ស្តាប់ខ្ញុំ (ដ្បិត) ភិក្ខុជាធម្មកថិកឈ្មោះនេះ ៗ លោកជាអ្នកចាំសុត្តៈ តែមិនចាំសុត្តវិភង្គទេ លោកកំណត់សេចក្តីមិនបាន ប្រកាន់យកតែព្យញ្ជនៈជាប្រមាណ ហើយត្រឡប់បដិសេធសេចក្តីចោលចេញ។ បើកម្មមានកាលគួរ ដល់លោកដ៏មានអាយុទាំងឡាយហើយ យើងទាំងឡាយដ៏សេស គប្បីញុំាងភិក្ខុឈ្មោះនេះ ឲ្យក្រោកចេញ ហើយសឹមរម្ងាប់អធិករណ៍នេះ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ បានឲ្យភិក្ខុនោះក្រោកចេញហើយ អាចដើម្បីនឹងរម្ងាប់អធិករណ៍នោះបាន ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគតហៅថា អធិករណ៍រម្ងាប់។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ។ ក៏ក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើ ត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។

## (យេភុយ្យសិកាវិនយ)

CS vin.cv.04.09.03 | ភាគ ទី១០

### (យេភុយ្យសិកាវិនយោ)

[៩៦] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងនោះ មិនអាចដើម្បីនឹងរម្ងាប់អធិករណ៍នោះ ដោយឧព្វាហិកាកម្មវាចាទេ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងនោះ ប្រគល់អធិករណ៍នោះ ដល់សង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន យើងទាំងឡាយ មិនអាចដើម្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកាកម្មវាចាទេ សូមសង្ឃ រម្ងាប់អធិករណ៍នេះចុះ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីរម្ងាប់អធិករណ៍បែបនេះ ដោយយេភុយ្យសិកាវិញ។ សង្ឃគប្បីសន្មតភិក្ខុប្រកបដោយអង្គ៥ប្រការ ឲ្យជាសលាកគ្គាហាបកៈ (អ្នកចែកស្លាក) គឺភិក្ខុណា មិនលំអៀងទៅខាងឆន្ទាគតិ១ មិនលំអៀងទៅខាងទោសាគតិ១ មិនលំអៀងទៅខាងមោហាគតិ១ មិនលំអៀងទៅខាងភយាគតិ១ ដឹងស្លាកដែលគេបានចាប់ និងមិនបានចាប់១។ បេ។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មត ឲ្យជាសលាកគ្គាហាបកៈ ការសន្មតិ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ សលាកគ្គាហាបកភិក្ខុនោះ គប្បីឲ្យភិក្ខុទាំងឡាយចាប់ស្លាកចុះ។ (បើ) ភិក្ខុទាំងឡាយ ជាធម្មវាទី មានចំនួនច្រើនជាង ពោលឡើងយ៉ាងណា សង្ឃត្រូវរម្ងាប់អធិករណ៍នោះ យ៉ាងនោះចុះ ម្នាលភិក្ខុទាំងឡាយ នេះទើបតថាគតហៅថា អធិករណ៍រម្ងាប់។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ និងយេភុយ្យសិកា។ ចុះក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ) ក៏ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ ពួកភិក្ខុ មានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ ក៏បានមក ទាំងឆន្ទៈរបស់ភិក្ខុទាំងឡាយ ដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយ ភិក្ខុទាំងឡាយ ដែលមាននៅក្នុងទីចំពោះមុខ ក៏មិនបានហាមឃាត់ នេះហៅថា ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ។ ឯការចំពោះមុខធម៌ និងការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ អធិករណ៍នោះ រម្ងាប់តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា នេះហៅថា ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ។ ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ ភិក្ខុណា ទាស់ទែងគ្នា ទៅវិញទៅមក ភិក្ខុទាំងពីររូបនោះ ជាសត្រូវនឹងគ្នា ព្រោះការទាស់ទែងគ្នា ក៏មាននៅក្នុងទីចំពោះមុខ នេះហៅថា ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ។ ក្នុងយេភុយ្យសិកាកម្មនោះ មានវិធីធ្វើដូចម្តេច។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅអែបនែប ការទទួល និងការមិនហាមឃាត់ នូវយេភុយ្យសិកាកម្មណា នេះហៅថា វិធីធ្វើ ក្នុងយេភុយ្យសិកាកម្មនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើ ត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយ ត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ។

## (តិវិធសលាកគ្គាហៈ)

CS vin.cv.04.09.04 | ភាគ ទី១០

### (តិវិធសលាកគ្គាហោ)

[៩៧] សម័យនោះឯង ក្នុងក្រុងសាវត្ថី មានអធិករណ៍កើតប្រាកដយ៉ាងនេះឡើង។ គ្រានោះឯង ភិក្ខុទាំងនោះ ជាអ្នកមិនត្រេកអរ ដោយវិធីរម្ងាប់អធិករណ៍ របស់សង្ឃ ក្នុងក្រុងសាវត្ថីឡើយ ហើយបានឮដំណឹងថា មានព្រះថេរៈច្រើនអង្គ គង់នៅក្នុងអាវាសឯណោះ ជាពហុស្សុត ចេះចាំនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាអ្នកប្រាជ្ញ វាងវៃ មានប្រាជ្ញា មានអៀនខ្មាស ជាអ្នកមានរង្កៀស ជាអ្នកប្រាថ្នាការសិក្សា បើព្រះថេរៈទាំងនោះ រម្ងាប់អធិករណ៍នេះតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា យ៉ាងនេះ ទើបអធិករណ៍នេះ រម្ងាប់បានដោយស្រួល។ គ្រានោះឯង ភិក្ខុទាំងឡាយនោះ នាំគ្នាទៅកាន់អាវាសនោះ ហើយនិយាយពាក្យនុ៎ះ នឹងព្រះថេរៈទាំងនោះថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន អធិករណ៍នេះ កើតប្រាកដយ៉ាងនេះហើយ បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន យើងខ្ញុំសូមអង្វរ សូមព្រះថេរៈទាំងឡាយ រម្ងាប់នូវអធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ដោយទំនងដែលអធិករណ៍នេះ គប្បីរម្ងាប់បានដោយស្រួល។ គ្រានោះឯង ព្រះថេរៈទាំងនោះ បានរម្ងាប់អធិករណ៍ទាំងនោះ តាមទំនង ដែលអធិករណ៍បានរម្ងាប់ដោយស្រួល ដូចជាអធិករណ៍ ដែលសង្ឃបានរម្ងាប់ហើយ ក្នុងក្រុងសាវត្ថី។ គ្រានោះឯង ភិក្ខុទាំងឡាយនោះ ក៏នៅតែមិនត្រេកអរ ដោយការរម្ងាប់អធិករណ៍ របស់សង្ឃ ក្នុងក្រុងសាវត្ថី ទាំង

មិនត្រេកអរដោយការរម្ងាប់អធិករណ៍ របស់ព្រះថេរៈទាំងឡាយច្រើនអង្គ បានឮដំណឹងថា ព្រះថេរៈទាំងឡាយបីអង្គ គង់នៅក្នុងអាវាសឯណោះ។ បេ។ ព្រះថេរៈទាំងឡាយពីរអង្គគង់នៅ។ បេ។ ព្រះថេរៈមួយអង្គ គង់នៅ (ក្នុងអាវាសឯណោះ) ជាពហុស្សូត ចេះចាំនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ មានប្រាជ្ញា មានអៀនខ្មាស់ មានសេចក្ដីរង្កៀសប្រាថ្នាការសិក្សា ប្រសិនបើព្រះថេរៈអង្គនោះ គប្បីរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្ដា យ៉ាងនេះ ទើបអធិករណ៍នេះ រម្ងាប់បានដោយស្រួល។ គ្រានោះឯង ភិក្ខុទាំងឡាយនោះ បានទៅកាន់អាវាសនោះ ហើយនិយាយពាក្យនុ៎ះ នឹងព្រះថេរៈនោះថា បពិត្រលោកម្ចាស់ដ៏ចំរើន អធិករណ៍នេះ កើតប្រាកដយ៉ាងនេះ បពិត្រលោកម្ចាស់ដ៏ចំរើន យើងខ្ញុំសូមអង្វរ សូមព្រះថេរៈរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្ដា ដោយទំនងដែលអធិករណ៍នេះ គប្បីរម្ងាប់បានដោយស្រួល។ គ្រានោះឯង ព្រះថេរៈនោះ ក៏បានរម្ងាប់អធិករណ៍នោះ តាមទំនង ដែលអធិករណ៍រម្ងាប់ទៅដោយស្រួល ដូចជាអធិករណ៍ ដែលសង្ឃបានរម្ងាប់ហើយ ក្នុងក្រុងសាវត្ថី ដូចជាអធិករណ៍ ដែលព្រះថេរៈច្រើនអង្គ បានរម្ងាប់ហើយ ដូចជាអធិករណ៍ ដែលព្រះថេរៈទាំងឡាយបីអង្គ បានរម្ងាប់ហើយ ដូចជាអធិករណ៍ ដែលព្រះថេរៈទាំងឡាយពីរអង្គ បានរម្ងាប់ហើយ។ គ្រានោះឯង ភិក្ខុទាំងឡាយនោះ ក៏នៅតែមិនត្រេកអរ ដោយការរម្ងាប់អធិករណ៍ របស់សង្ឃ ក្នុងក្រុងសាវត្ថី មិនត្រេកអរ ដោយការរម្ងាប់អធិករណ៍ របស់ព្រះថេរៈទាំងឡាយច្រើនអង្គ មិនត្រេកអរ ដោយការរម្ងាប់អធិករណ៍ របស់ព្រះថេរៈទាំងឡាយបីអង្គ មិនត្រេកអរ ដោយការរម្ងាប់អធិករណ៍ របស់ព្រះថេរៈទាំងឡាយពីរអង្គ មិនត្រេកអរ ដោយការរម្ងាប់អធិករណ៍ របស់ព្រះថេរៈមួយអង្គ ហើយក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅជិតហើយ ក៏ក្រាបបង្គំទូល ដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អធិករណ៍នុ៎ះ សង្ឃបានកំចាត់បង់ឲ្យស្ងប់រម្ងាប់ហើយ ឈ្មោះថារម្ងាប់ដោយប្រពៃហើយ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ការចាប់ស្លាកបីយ៉ាង គឺគូឡ្ហកៈ (បិទមុខ)១ សកណ្ណជប្បកៈ (ខ្សឹបប្រាប់)១ វិវដកៈ[19] (បើកចំហ)១ ដើម្បីបញ្ញាក់ដល់ភិក្ខុទាំងនោះ។ ម្នាលភិក្ខុទាំងឡាយ ចុះការចាប់ស្លាក ឈ្មោះគូឡ្ហកៈនោះដូចម្ដេច។ ត្រូវសលាកគ្គាហាបកភិក្ខុនោះ ធ្វើស្លាកឲ្យមានពណ៌ផ្សេងគ្នា ហើយចូលទៅរកភិក្ខុ១រូបម្ដងៗ ហើយនិយាយយ៉ាងនេះថា នេះស្លាករបស់ភិក្ខុមានវាទៈយ៉ាងនេះ នេះស្លាករបស់ភិក្ខុមានវាទៈយ៉ាងនេះ លោកចង់ចាប់ស្លាកណា ចូរលោកចាប់ស្លាកនោះចុះ។ លុះភិក្ខុអ្នកចាប់នោះ ចាប់យកទៅហើយ សលាកគ្គាហាបកភិក្ខុ ត្រូវប្រាប់ថា លោកកុំបង្ហាញអ្នកណាឲ្យសោះ។ បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាអធម្មវាទី មានចំនួនច្រើនជាង ត្រូវប្រាប់ថា ការចាប់នេះមិនល្អទេ ហើយសើរើជាថ្មីទៀត។[20] បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាធម្មវាទី មានចំនួនច្រើនជាង ត្រូវប្រកាសថា ការចាប់នេះ ល្អហើយ។ ម្នាលភិក្ខុទាំងឡាយ ការចាប់ស្លាកយ៉ាងនេះហើយ ដែលហៅថា គូឡ្ហកៈ។ ម្នាលភិក្ខុទាំងឡាយ ការចាប់ស្លាក ឈ្មោះសកណ្ណជប្បកៈនោះ តើដូចម្ដេច។ សលាកគ្គាហាបកភិក្ខុនោះ ត្រូវខ្សឹបជិតត្រចៀកភិក្ខុមួយរូបៗថា នេះស្លាករបស់ភិក្ខុមានវាទៈយ៉ាងនេះ នេះស្លាករបស់ភិក្ខុមានវាទៈយ៉ាងនេះ លោកចង់ចាប់ស្លាកណា ចូរយកស្លាកនោះចុះ។ លុះភិក្ខុចាប់ស្លាកទៅហើយ ត្រូវសលាកគ្គាហាបកភិក្ខុ និយាយថា លោកកុំប្រាប់អ្នកណាឲ្យសោះ។ បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាអធម្មវាទី មានចំនួនច្រើនជាង ត្រូវប្រាប់ថា ការចាប់នេះមិនល្អទេ ហើយសើរើជាថ្មីទៀត។ បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាធម្មវាទី មានចំនួនច្រើនជាង ត្រូវប្រកាសថា ការចាប់នេះ ល្អហើយ។ ម្នាលភិក្ខុទាំងឡាយ ការចាប់ យ៉ាងនេះ ដែលហៅថា សកណ្ណជប្បកៈ។ ម្នាលភិក្ខុទាំងឡាយ ការចាប់ស្លាក ឈ្មោះវិវដកៈនោះដូចម្ដេច។ បើសលាកគ្គាហាបកភិក្ខុដឹងថា ភិក្ខុជាធម្មវាទី មានចំនួនច្រើនជាង ត្រូវបណ្ដោយឲ្យចាប់ដោយវិធីចាប់ស្លាក ឈ្មោះវិវកដៈចុះ ម្នាលភិក្ខុទាំងឡាយ ការចាប់ស្លាកយ៉ាងនេះហើយ ដែលហៅថា វិវដកៈ ម្នាលភិក្ខុទាំងឡាយ វិធីចាប់ស្លាកមាន៣យ៉ាង ប៉ុណ្ណេះឯង។

## (សតិវិនយ)

CS vin.cv.04.09.05 | ភាគ ទី១០

### (សតិវិនយោ)

[៩៨] អនុវាទាធិករណ៍ រម្ងាប់ដោយសមថៈ ប៉ុន្មានយ៉ាង។ អនុវាទាធិករណ៍ រម្ងាប់ដោយសមថៈ៤យ៉ាង គឺសម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ១ តស្សបាបិយសិកា១។

[៩៩] អនុវាទាធិករណ៍ មិនបាច់អាស្រ័យសមថៈពីរយ៉ាង គឺអមូឡ្ហវិន័យ និងតស្សបាបិយសិកាទេ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាង គឺសម្មុខាវិន័យ និងសតិវិន័យ (ប៉ុណ្ណោះ) ក៏មាន។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មាន ដូច្នេះ។ ពាក្យនោះ តើដូចសំដែងត្រង់បទណា។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិ ឥតមានមូល។ ម្នាលភិក្ខុទាំងឡាយ សតិវិន័យ សង្ឃត្រូវឲ្យដល់ភិក្ខុដែលមានសតិបរិបូណ៌នោះឯង។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យសតិវិន័យយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវចូលទៅរកសង្ឃ ធ្វើចីវរឆៀងស្មាម្ខាង។ បេ។ ហើយនិយាយនឹងសង្ឃ យ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ភិក្ខុទាំងឡាយ ចោទខ្ញុំដោយសីលវិបត្តិ ឥតមានមូល បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាអ្នកមានសតិពេញបរិបូណ៌ហើយ មកសូមសតិវិន័យនឹងសង្ឃ។ ភិក្ខុនោះ ត្រូវសូមសតិវិន័យ ជាគំរប់ពីរដងផង។ ភិក្ខុនោះ ត្រូវសូមសតិវិន័យ ជាគំរប់បីដងផង។

[១០០] ភិក្ខុអ្នកឈ្លាស វាងវៃ ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុទាំងឡាយ ចោទភិក្ខុឈ្មោះនេះ ដោយសីលវិបត្តិ ឥតមានមូល។ ភិក្ខុនោះ ជាអ្នកមានសតិពេញបរិបូណ៌ ហើយមកសូមសតិវិន័យនឹងសង្ឃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវឲ្យសតិវិន័យ ដល់ភិក្ខុឈ្មោះនេះ ជាអ្នកមានសតិពេញបរិបូណ៌ហើយ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុទាំងឡាយ ចោទភិក្ខុឈ្មោះនេះ ដោយសីលវិបត្តិ ឥតមានមូល។ ភិក្ខុនោះ ជាអ្នកមានសតិពេញបរិបូណ៌ ហើយមកសូមសតិវិន័យនឹងសង្ឃ។ សង្ឃបានឲ្យនូវសតិវិន័យ ដល់ភិក្ខុឈ្មោះនេះ ដែលជាអ្នកមានសតិពេញបរិបូណ៌ហើយ។ ការឲ្យនូវសតិវិន័យ ដល់ភិក្ខុឈ្មោះនេះ ដែលជាអ្នកមានសតិពេញបរិបូណ៌ហើយ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំប្រកាសសេចក្ដីនេះ ជាគំរប់ពីរដងផង។ បេ។ ខ្ញុំប្រកាសសេចក្ដីនេះ ជាគំរប់បីដងផង។ បេ។ សតិវិន័យ សង្ឃបានឲ្យដល់ភិក្ខុឈ្មោះនេះ ដែលជាអ្នកមានសតិពេញបរិបូណ៌ហើយ ការឲ្យសតិវិន័យនេះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្ដីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា អធិករណ៍ រម្ងាប់ហើយ។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ និងសតិវិន័យ។ ចុះក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្ដេច។ ការចំពោះមុខសង្ឃ ការចំពោះ

មុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ចុះការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ បុគ្គលណា ចោទគ្នាទៅវិញទៅមក បុគ្គលទាំងពីរនាក់នោះ ក៏មាននៅក្នុងទីចំពោះមុខ នេះហៅថា ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ។ ចុះក្នុងសតិវិន័យនោះ មានកិច្ចដូចម្តេច។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅឯបនែប ការទទួល និងកិរិយាមិនឃាត់ហាមនូវសតិវិន័យកម្មណា នេះជាកិច្ច ក្នុងសតិវិន័យនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើ ត្រឡប់ សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយ ត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ។

## (អមូឡ្ហវិនយ)

CS vin.cv.04.09.06 | ភាគ ទី១០

## (អមូឡ្ហវិនយោ)

[១០១] អនុវាទាធិករណ៍ មិនបាច់អាស្រ័យសមថៈពីរយ៉ាង គឺសតិវិន័យ១ តស្សបាបិយសិកា១ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាង គឺសម្មុខាវិន័យ១ អមូឡ្ហវិន័យ១ ក៏មាន។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មាន ដូច្នេះ។ ពាក្យនោះ តើដូចសំដែងត្រង់បទណា។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាមនុស្សឆ្កួត មានចិត្តវិបល្លាសប្រែប្រួល ភិក្ខុឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន។ ព្រោះហេតុតែភិក្ខុឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល ហើយបានប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយ ក៏នាំគ្នាចោទភិក្ខុនោះ ដោយអាបត្តិថា លោកមានអាយុ ត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល។ ភិក្ខុឆ្កួតនោះ ឆ្លើយយ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ខ្ញុំឯង ជាមនុស្សឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល ខ្ញុំឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំនឹកអំពើនោះ មិនឃើញទេ អំពើនុ៎ះ ខ្ញុំបានធ្វើហើយ ដោយសេចក្តីវង្វេង។ ភិក្ខុទាំងឡាយ ក៏នៅតែពោលចោទភិក្ខុឆ្កួតនោះ យ៉ាងនេះទៀតថា លោកមានអាយុ ត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឆ្កួតនោះបាត់វង្វេងហើយ សង្ឃគប្បីឲ្យអមូឡ្ហវិន័យចុះ។ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីឲ្យអមូឡ្ហវិន័យ យ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីចូលទៅរកសង្ឃ ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង។ បេ។ ហើយពោលនឹងសង្ឃ យ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំជាមនុស្សឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល កាលខ្ញុំឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន ព្រោះតែខ្ញុំជាមនុស្សឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល បានប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយ ក៏នាំគ្នាចោទខ្ញុំ ដោយអាបត្តិថា លោកមានអាយុ ត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល ខ្ញុំក៏បានឆ្លើយតបនឹងភិក្ខុទាំងឡាយនោះវិញ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំជាមនុស្សឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលមែន ខ្ញុំឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំនឹកអំពើនោះ មិនឃើញទេ អំពើនុ៎ះ ខ្ញុំបានធ្វើហើយ ដោយសេចក្តីវង្វេង។ ភិក្ខុទាំងឡាយ ក៏នៅតែពោលចោទខ្ញុំ យ៉ាងនេះទៀតថា លោកមានអាយុ ត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំបាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ។ ភិក្ខុនោះ ត្រូវសូមអមូឡ្ហវិន័យ អស់វារៈពីរដងផង។ ត្រូវសូមអមូឡ្ហវិន័យ អស់វារៈបីដងផង។

[១០២] ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ ជាមនុស្សឆ្កួត ជាអ្នកមានចិត្តវិបល្លាស ប្រែប្រួល ភិក្ខុឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន។ ព្រោះតែភិក្ខុឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល ប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយ នាំគ្នាចោទភិក្ខុនោះ ដោយអាបត្តិថា លោកមានអាយុ ត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល។ ភិក្ខុនោះ ក៏ឆ្លើយយ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ខ្ញុំជាមនុស្សឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលមែន ខ្ញុំឆ្កួត មានចិត្តវិបល្លាសប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំនឹករកអំពើនោះ មិនឃើញទេ អំពើនុ៎ះ ខ្ញុំបានធ្វើហើយ ដោយសេចក្តីវង្វេង។ ភិក្ខុទាំងឡាយ ក៏នៅតែចោទភិក្ខុនោះ យ៉ាងនេះទៀតថា លោកមានអាយុ ត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល។ ភិក្ខុនោះ បាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវអមូឡ្ហវិន័យ ដល់ភិក្ខុឈ្មោះនេះ ជាអ្នកបាត់វង្វេង។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ ជាមនុស្សឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល ភិក្ខុឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន។ ព្រោះតែភិក្ខុឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល ប្រព្រឹត្តអនាចារ ភិក្ខុទាំងឡាយ ក៏នាំគ្នាចោទភិក្ខុនោះ ដោយអាបត្តិថា លោកមានអាយុ ត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល។ ភិក្ខុនោះ ក៏ឆ្លើយតបយ៉ាងនេះវិញថា ម្នាលលោកមានអាយុទាំងឡាយ ខ្ញុំជាមនុស្សឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលមែន កាលខ្ញុំឆ្កួត មានចិត្តវិបល្លាស ប្រែប្រួលហើយនោះ ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំនឹករកអំពើនោះ មិនឃើញទេ អំពើនុ៎ះ ខ្ញុំបានធ្វើហើយ ដោយសេចក្តីវង្វេង។ ភិក្ខុទាំងឡាយ ក៏នៅតែពោលចោទភិក្ខុនោះ យ៉ាងនេះទៀតថា លោកមានអាយុ ត្រូវអាបត្តិ មានសភាពយ៉ាងនេះហើយ ចូរនឹកមើល។ ភិក្ខុនោះ បាត់វង្វេងហើយ មកសូមអមូឡ្ហវិន័យនឹងសង្ឃ។ សង្ឃបានឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុឈ្មោះនេះ ដែលបាត់វង្វេងហើយ។ ការឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុឈ្មោះនេះ ជាអ្នកបាត់វង្វេងហើយ សមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីស្ងៀម មិនសមគួរ ដល់លោកមានអាយុអង្គណាទេ លោកមានអាយុអង្គនោះ គប្បីពោលឡើង។ ខ្ញុំពោលសេចក្តីនេះ អស់វារៈពីរដងផង។ បេ។ ខ្ញុំពោលសេចក្តីនេះ អស់វារៈបីដងផង។ បេ។ អមូឡ្ហវិន័យ សង្ឃបានឲ្យដល់ភិក្ខុឈ្មោះនេះ ដែលបាត់វង្វេងហើយ ការឲ្យអមូឡ្ហវិន័យនេះ គួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា អធិករណ៍ រម្ងាប់ហើយ។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ និងអមូឡ្ហវិន័យ។ ចុះក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ក្នុងអមូឡ្ហវិន័យនោះ មានកិច្ចដូចម្តេច។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅអែបនែប ការទទួល និងការមិនហាមឃាត់ នូវអមូឡ្ហវិន័យកម្មណា នេះជាកិច្ច ក្នុងអមូឡ្ហវិន័យនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើ ត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ ភិក្ខុអ្នកឲ្យឆន្ទៈ ត្រឡប់តិះដៀល ត្រូវខីយនកបាចិត្តិយៈ។

## (តស្សបាបិយសិកាវិនយ)

CS vin.cv.04.09.07 | ភាគ ទី១០

### (តស្សបាបិយសិកាវិនយោ)

[១០៣] អនុវាទាធិករណ៍ មិនបាច់អាស្រ័យសមថៈពីរយ៉ាង គឺសតិវិន័យ១ អមូឡ្ហវិន័យ១ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាង គឺសម្មុខាវិន័យ១ តស្សបាបិយសិកា១ ក៏មាន។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មាន ដូច្នេះ។ ពាក្យនោះ តើដូចសំដែងត្រង់បទណា។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចោទភិក្ខុផងគ្នា ដោយគរុកាបត្តិ ក្នុងកណ្ដាលជំនុំសង្ឃថា លោកមានអាយុ ត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិក ឬអាបត្តិរងបារាជិក[21] ហើយ ចូរនឹកមើលទៅ។ ភិក្ខុនោះ ក៏ឆ្លើយតបយ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ខ្ញុំនឹកមិនឃើញថា ខ្ញុំត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិក ឬអាបត្តិរងបារាជិកទេ។ ភិក្ខុនោះ ក៏នៅតែចោទប្រកាន់ភិក្ខុ ដែលប្រកែកនោះ ដោយពាក្យថា លោកមានអាយុ ខ្ញុំសូមដាស់តឿន លោកចូរដឹងដោយស្រួលបួលចុះ បើលោកមានអាយុ ត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិក ឬអាបត្តិរងបារាជិកហើយ នឹករកឃើញ។ ភិក្ខុនោះ ក៏ឆ្លើយតបវិញថា ម្នាលលោកមានអាយុ ខ្ញុំនឹកមិនឃើញថា ខ្ញុំត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះគឺ អាបត្តិបារាជិក ឬអាបត្តិរងបារាជិកទេ ម្នាលលោកមានអាយុ ខ្ញុំនឹកឃើញត្រឹមតែថា ខ្ញុំត្រូវអាបត្តិបន្តិចបន្តួច មានសភាពយ៉ាងនេះ ប៉ុណ្ណោះ។ ភិក្ខុនោះ ក៏នៅតែចោទប្រកាន់ភិក្ខុ ដែលប្រកែកនោះ ដោយពាក្យថា លោកមានអាយុ ខ្ញុំសូមដាស់តឿន លោកចូរដឹងដោយស្រួលបួលចុះ បើលោកមានអាយុ ត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិក ឬអាបត្តិរងបារាជិកហើយ នឹករកឃើញ។ ភិក្ខុនោះ ក៏ឆ្លើយតបយ៉ាងនេះវិញថា ម្នាលលោកមានអាយុ ខ្ញុំត្រូវអាបត្តិឈ្មោះនេះបន្តិចបន្តួច ទោះបីឥតគេសួរនោះ ក៏គង់តែខ្ញុំប្ដេជ្ញា ចំណង់បើខ្ញុំត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះគឺ អាបត្តិបារាជិក ឬអាបត្តិរងបារាជិក គេសួរហើយ ខ្ញុំនឹងមិនប្ដេជ្ញា ដូចម្ដេចបាន។ ភិក្ខុនោះ ក៏ឆ្លើយតបវិញថា ម្នាលលោកមានអាយុ លោកត្រូវអាបត្តិ ឈ្មោះនេះបន្តិចបន្តួច ទោះបីឥតគេសួរនោះ ក៏គង់តែលោកមិនប្ដេជ្ញា ចំណង់បើលោកត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះគឺ អាបត្តិបារាជិក ឬអាបត្តិរងបារាជិក គេមិនសួរហើយ លោកនឹងប្ដេជ្ញា ដូចម្ដេចបាន លោកមានអាយុ ខ្ញុំសូមដាស់តឿន លោកចូរដឹង ដោយស្រួលបួលចុះ បើលោកត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិក ឬអាបត្តិរងបារាជិកហើយ នឹករកឃើញ។ ភិក្ខុនោះ ក៏ឆ្លើយតបវិញយ៉ាងនេះថា ម្នាលលោកមានអាយុ ខ្ញុំនឹកឃើញត្រឹមតែថា ខ្ញុំត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះ គឺ អាបត្តិបារាជិក ឬអាបត្តិរងបារាជិក ពាក្យនេះ ខ្ញុំនិយាយលេងទេ ពាក្យនេះ ខ្ញុំនិយាយភ្លាត់ទេ ខ្ញុំនឹកមិនឃើញថា ខ្ញុំត្រូវគរុកាបត្តិ មានសភាពយ៉ាងនេះគឺ អាបត្តិបារាជិក ឬអាបត្តិរងបារាជិកទេ។ ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្មនេះ សង្ឃត្រូវតែធ្វើដល់ភិក្ខុនោះកុំខានឡើយ។

[១០៤] ម្នាលភិក្ខុទាំងឡាយ តស្សបាបិយសិកាកម្ម សង្ឃត្រូវធ្វើយ៉ាងនេះ។ ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុឈ្មោះនេះ កាលសង្ឃសាកសួរ ដោយគរុកាបត្តិ ក្នុងកណ្ដាលជំនុំសង្ឃ គេចកែសំដីហើយ បែរជាប្ដេជ្ញា ប្ដេជ្ញាហើយ បែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលសម្បជានមុសាវាទ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ភិក្ខុឈ្មោះនេះ កាលសង្ឃសាកសួរ ដោយគរុកាបត្តិ ក្នុងកណ្ដាលជំនុំសង្ឃ ក៏គេចកែសំដីហើយ បែរជាប្ដេជ្ញា ប្ដេជ្ញាហើយ បែរជាគេចកែសំដីវិញ បិទបាំងហេតុដទៃ ដោយហេតុដទៃ ពោលសម្បជានមុសាវាទ។ សង្ឃធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុឈ្មោះនេះ។ ការធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុឈ្មោះនេះ សមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីស្ងៀម មិនសមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង ខ្ញុំពោលសេចក្ដីនេះ អស់វារៈពីរដងផង។ បេ។ ខ្ញុំពោលសេចក្ដីនេះ អស់វារៈបីដងផង។ បេ។ តស្សបាបិយសិកាកម្ម សង្ឃបានធ្វើហើយ ដល់ភិក្ខុឈ្មោះនេះ ការធ្វើនូវតស្សបាបិយសិកាកម្មនេះ សមគួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្ដីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា អធិករណ៍រម្ងាប់ហើយ។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ និងតស្សបាបិយសិកា។ ចុះក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្ដេច។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ក្នុងតស្សបាបិយសិកាកម្មនោះ មានកិរិយាធ្វើដូចម្ដេច។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅអែបនែប ការទទួល និងការមិនឃាត់ហាម នូវតស្សបាបិយសិកាកម្មណា នេះជាកិរិយាធ្វើ ក្នុងតស្សបាបិយសិកាកម្មនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកធ្វើ ត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយ ត្រឡប់តិះដៀលវិញ ត្រូវខីយនកបាចិត្តិយៈ។

## (បដិញ្ញាតករណៈ)

CS vin.cv.04.09.08 | ភាគ ទី១០

### (បដិញ្ញាតករណំ)

[១០៥] អាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ ប៉ុន្មានយ៉ាង។ អាបត្តាធិករណ៍ រម្ងាប់ដោយសមថៈបីយ៉ាងគឺ សម្មុខាវិន័យ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។

[១០៦] អាបត្តាធិករណ៍មិនបាច់អាស្រ័យសមថៈ១ គឺតិណវត្ថារកៈ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាង គឺសម្មុខាវិន័យ និងបដិញ្ញាតករណៈ១ ក៏មាន។ ពាក្យដែលបណ្ឌិតគប្បីពោលថា ក៏មាន ដូច្នេះ។ ពាក្យនោះ តើដូចសំដែងត្រង់បទណា។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវលហុកាបត្តិ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីចូលទៅរកភិក្ខុ១រូប ហើយធ្វើចីវរឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីឡើងហើយ ពោលយ៉ាងនេះ នឹងភិក្ខុនោះថា ម្នាលលោកមានអាយុ ខ្ញុំត្រូវអាបត្តិ ឈ្មោះនេះហើយ សូមសំដែងអាបត្តិនោះចេញ។ ភិក្ខុអ្នកទទួលអាបត្តិនោះ ត្រូវពោលថា លោកឃើញឬទេ។ ភិក្ខុអ្នកសំដែង ឆ្លើយថា ករុណា ខ្ញុំឃើញហើយ។ ភិក្ខុអ្នកទទួល ត្រូវប្រាប់ថា លោកត្រូវសង្រួមតទៅទៀត។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អធិករណ៍រម្ងាប់ហើយ។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ។

ចុះក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ឯការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ បុគ្គលទាំងពីររូប ដែលសំដែងអាបត្តិដល់គ្នានឹងគ្នា ក៏មាននៅក្នុងទីចំពោះមុខ នេះហៅថា ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ។ ចុះក្នុងបដិញ្ញាតករណៈនោះ មានកិច្ចដូចម្តេច។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅអែបនែប ការទទួល និងការមិនឃាត់ហាម នូវបដិញ្ញាតករណកម្មណា នេះជាកិច្ច ក្នុងបដិញ្ញាតករណកម្មនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកទទួល ត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ បើភិក្ខុនោះបានភិក្ខុអ្នកទទួលយ៉ាងនេះហើយ ការបានយ៉ាងនេះ នេះជាការស្រួល បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវចូលទៅរកភិក្ខុច្រើនរូប ហើយធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ក្រាបសំពះបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី គប្បីពោលយ៉ាងនេះ នឹងភិក្ខុទាំងនោះថា បពិត្រលោកទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណា ត្រូវអាបត្តិឈ្មោះនេះហើយ សូមសំដែងអាបត្តិនោះចេញ។ ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងភិក្ខុទាំងនោះថា លោកមានអាយុទាំងឡាយ ចូរស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ នេះនឹកឃើញអាបត្តិ បង្ហើបអាបត្តិ ធ្វើអាបត្តិឲ្យងាយ សំដែងអាបត្តិ។ បើកម្មមានកាលដ៏សមគួរ ដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីទទួលអាបត្តិ របស់ភិក្ខុឈ្មោះនេះ។ ភិក្ខុអ្នកទទួលនោះ ត្រូវពោលថា លោកឃើញឬទេ។ ភិក្ខុនោះពោលថា ករុណា ខ្ញុំឃើញហើយ។ ភិក្ខុអ្នកទទួល ត្រូវប្រាប់ថា លោកត្រូវសង្រួមតទៅទៀត។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា អធិករណ៍រម្ងាប់ហើយ។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ។ ក្នុងសម្មុខាវិន័យនោះ មានអង្គ ដូចម្តេច។ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ចុះការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ បុគ្គលទាំងពីររូប ដែលសំដែងអាបត្តិដល់គ្នានឹងគ្នា ក៏មាននៅក្នុងទីចំពោះមុខ នេះហៅថា ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ។ ក្នុងបដិញ្ញាតករណៈ មានកិច្ចដូចម្តេច។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅអែបនែប ការទទួល និងការមិនហាមឃាត់ នូវបដិញ្ញាតករណកម្មណា នេះជាកិច្ច ក្នុងបដិញ្ញាតករណកម្មនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកទទួល ត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ បើភិក្ខុ បានភិក្ខុអ្នកទទួលនុ៎ះ យ៉ាងនេះហើយ ការបានយ៉ាងនេះ ជាការស្រួល បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ហើយក្រាបសំពះបាទាភិក្ខុចាស់ទាំងឡាយ អង្គុយច្រហោង ផ្គងអញ្ជលី ពោលនឹងសង្ឃ យ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំត្រូវអាបត្តិ ឈ្មោះនេះហើយ សូមសំដែង នូវអាបត្តិនោះចេញ។ ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ នឹកឃើញនូវអាបត្តិ បង្ហើបអាបត្តិ ធ្វើអាបត្តិឲ្យងាយ សំដែងអាបត្តិ។ បើកម្មមានកាលដ៏គួរ ដល់សង្ឃហើយ ខ្ញុំត្រូវទទួលនូវអាបត្តិ របស់ភិក្ខុឈ្មោះនេះ។ ភិក្ខុអ្នកទទួលនោះ ត្រូវពោលថា លោកឃើញឬទេ។ ភិក្ខុអ្នកសំដែង ឆ្លើយថា ករុណា ខ្ញុំឃើញហើយ។ ភិក្ខុអ្នកទទួល ត្រូវប្រាប់ថា លោកត្រូវសង្រួមតទៅទៀតចុះ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា អធិករណ៍រម្ងាប់ហើយ។ អធិករណ៍ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ។ ក្នុងសម្មុខាវិន័យនោះ មានអង្គដូចម្តេច។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ បេ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកទទួល ត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ ភិក្ខុអ្នកឲ្យឆន្ទៈ ហើយត្រឡប់តិះដៀលវិញ ត្រូវខីយនកបាចិត្តិយៈ។

## (តិណវត្ថារកៈ)

CS vin.cv.04.09.09 | ភាគ ទី១០

### (តិណវត្ថារកំ)

[១០៧] អាបត្តាធិករណ៍ មិនបាច់អាស្រ័យសមថៈ១ គឺបដិញ្ញាតករណៈ គ្រាន់តែរម្ងាប់ដោយសមថៈពីរយ៉ាងគឺ សម្មុខាវិន័យ១ តិណវត្ថារកៈ១ ក៏មាន។ ពាក្យដែលបណ្ឌិត គប្បីពោលថា ក៏មាន ដូច្នេះ។ ពាក្យនោះ ដូចសំដែងត្រង់បទណា។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ បង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុទាំងឡាយ ក្នុងទីនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា កាលបើយើងទាំងឡាយ នាំបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន បើយើងទាំងឡាយ នឹងញុំាងគ្នានឹងគ្នា ឲ្យធ្វើដោយអាបត្តិទាំងឡាយនោះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក(សង្ឃ)។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាត ដើម្បីឲ្យរម្ងាប់អធិករណ៍ មានសភាពយ៉ាងនេះ ដោយតិណវត្ថារកៈ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវរម្ងាប់អធិករណ៍យ៉ាងនេះ។ ភិក្ខុទាំងឡាយរាល់គ្នា ត្រូវប្រជុំក្នុងទីជាមួយគ្នា លុះប្រជុំគ្នាហើយ ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលបើយើងទាំងឡាយ បង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ បើយើងទាំងឡាយ នឹងញុំាងគ្នានឹងគ្នា ឲ្យធ្វើដោយអាបត្តិទាំងឡាយនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក(សង្ឃ)។ បើកម្មមានកាលដ៏សមគួរ ដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់នូវអធិករណ៍នេះ ដោយតិណវត្ថារកៈ វៀរលែងតែ អាបត្តិ ដែលមានទោសធំ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្តចេញ។ បណ្តាភិក្ខុទាំងឡាយ ដែលជាបក្ខពួកជាមួយគ្នា ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងពួករបស់ខ្លួនថា លោកមានអាយុទាំងឡាយ ចូរស្តាប់ខ្ញុំ កាលយើងទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ ប្រសិនបើយើងទាំងឡាយ នឹងញុំាងគ្នានឹងគ្នា ឲ្យធ្វើដោយអាបត្តិទាំងឡាយនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក(សង្ឃ)។ បើកម្មមានកាលដ៏សមគួរ ដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីសំដែងអាបត្តិ របស់លោកទាំងឡាយផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ ដើម្បីប្រយោជន៍ ដល់លោកមានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធំ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្តចេញ។

[១០៨] បណ្តាភិក្ខុទាំងឡាយ ដែលជាបក្ខពួក ជាមួយគ្នាម្ខាងទៀត ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងពួករបស់ខ្លួនថា លោកមានអាយុទាំងឡាយ ចូរស្តាប់ខ្ញុំ កាលដែលយើងទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ ប្រសិនបើយើងទាំងឡាយ នឹងញុំាងគ្នានឹងគ្នា ឲ្យធ្វើដោយអាបត្តិទាំងឡាយនេះ ក៏បានដែរ តែ

អធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក (សង្ឃ)។ បើកម្មមានកាលដ៏សមគួរ ដល់លោកមានអាយុទាំងឡាយហើយ ខ្ញុំគប្បីសំដែងអាបត្តិ របស់លោកទាំងឡាយផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ ដើម្បីប្រយោជន៍ ដល់លោកមានអាយុទាំងឡាយផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធំ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្តចេញ។

[១០៩] បណ្តាភិក្ខុទាំងឡាយ ដែលជាបក្ខពួកជាមួយគ្នា ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលដែលយើងទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ក៏បានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ ប្រសិនបើយើងទាំងឡាយ នឹងញុំាងគ្នានឹងគ្នា ឲ្យធ្វើដោយអាបត្តិទាំងឡាយនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក (សង្ឃ)។ បើកម្មមានកាលដ៏សមគួរ ដល់សង្ឃហើយ ខ្ញុំគប្បីសំដែងអាបត្តិ របស់លោកមានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ ដើម្បីប្រយោជន៍ ដល់លោកមានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធំ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្តចេញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលដែលយើងទាំងឡាយ នាំគ្នាបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល និងព្យាយាមធ្វើល្មើស នូវកិច្ច មិនមែនជារបស់សមណៈជាច្រើន។ ប្រសិនបើយើងទាំងឡាយ នឹងញុំាងគ្នានឹងគ្នា ឲ្យធ្វើ ដោយអាបត្តិទាំងឡាយនេះ ក៏បានដែរ តែអធិករណ៍នោះ គប្បីប្រព្រឹត្តទៅ ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច ដើម្បីបំបែក (សង្ឃ)។ ខ្ញុំសូមសំដែងអាបត្តិ របស់លោកមានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ ដើម្បីប្រយោជន៍ ដល់លោកមានអាយុទាំងឡាយនេះផង ដើម្បីប្រយោជន៍ ដល់ខ្លួនខ្ញុំផង វៀរលែងតែអាបត្តិ ដែលមានទោសធំ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្តចេញ។ ការសំដែងអាបត្តិទាំងឡាយនេះ របស់យើងទាំងឡាយ ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ វៀរលែងតែអាបត្តិ ដែលមានទោសធំ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្តចេញ។ ការសំដែងអាបត្តិនេះ សមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនសមគួរ ដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង។ អាបត្តិទាំងឡាយនេះ យើងទាំងឡាយ បានសំដែងហើយ ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ វៀរលែងតែអាបត្តិ ដែលមានទោសធ្ងន់ វៀរលែងតែអាបត្តិ ដែលជាគិហិប្បដិសំយុត្តចេញ ការសំដែងនេះ សមគួរដល់សង្ឃ ព្រោះហេតុនោះ ទើបសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ លំដាប់នោះ ភិក្ខុទាំងឡាយ១ពួកទៀត។ បេ។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិករណ៍រម្ងាប់ហើយ។ អធិករណ៍នោះ រម្ងាប់ដោយធម៌អ្វី។ រម្ងាប់ដោយសម្មុខាវិន័យ និងតិណវត្ថារកៈ។ ក្នុងសម្មុខាវិន័យនោះ តើមានអង្គដូចម្តេច។ ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ ការចំពោះមុខវិន័យ ការចំពោះមុខបុគ្គល (ជាអង្គក្នុងសម្មុខាវិន័យនោះ)។ ចុះការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ ភិក្ខុទាំងឡាយ ដែលគួរដល់កម្ម មានចំនួនប៉ុន្មានរូប ភិក្ខុទាំងនោះ ក៏បានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុ ដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយ ភិក្ខុទាំងឡាយ មាននៅក្នុងទីចំពោះមុខ ក៏មិនបានហាមឃាត់ នេះហៅថា ការចំពោះមុខសង្ឃ ក្នុងសម្មុខាវិន័យនោះ។ ចុះការចំពោះមុខធម៌ និងការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ អធិករណ៍នោះ រម្ងាប់តាមធម៌ណា តាមវិន័យណា តាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា នេះហៅថា ការចំពោះមុខធម៌ និងការចំពោះមុខវិន័យ ក្នុងសម្មុខាវិន័យនោះ។ ចុះការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ តើដូចម្តេច។ បុគ្គលទាំងពីររូប ដែលសំដែងអាបត្តិ ដល់គ្នានឹងគ្នា ក៏មាននៅក្នុងទីចំពោះមុខ នេះហៅថា ការចំពោះមុខបុគ្គល ក្នុងសម្មុខាវិន័យនោះ។ ក្នុងតិណវត្ថារកៈ មានកិច្ចដូចម្តេច។ ការធ្វើ កិរិយាធ្វើ ការចូលទៅជិត ការចូលទៅអែបនែប ការទទួល និងការមិនហាមឃាត់ នូវតិណវត្ថារកកម្មណា នេះជាកិច្ច ក្នុងតិណវត្ថារកកម្មនោះ។ ម្នាលភិក្ខុទាំងឡាយ បើអធិករណ៍រម្ងាប់យ៉ាងនេះហើយ ភិក្ខុអ្នកទទួល ត្រឡប់សើរើឡើងវិញ ត្រូវឧក្កោដនកបាចិត្តិយៈ។ ភិក្ខុអ្នកឲ្យឆន្ទៈហើយ ត្រឡប់តិះដៀលវិញ ត្រូវខីយនកបាចិត្តិយៈ។

[១១០] កិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ កិច្ចាធិករណ៍ រម្ងាប់ដោយសមថៈតែមួយ គឺសម្មុខាវិន័យ។

ចប់ សមថក្ខន្ធកៈ ទី៤។

# ខុទ្ទកវត្ថុក្ខន្ធកៈ (ទី៥)

CS vin.cv.05 | ភាគ ទី១០

### (៥. ខុទ្ទកវត្ថុក្ខន្ធកំ)

## (ខុទ្ទកវត្ថូនិ)

CS vin.cv.05.01 | ភាគ ទី១០

### (ខុទ្ទកវត្ថូនិ)

[១១១] សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នាំគ្នាងូតទឹក ហើយត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងដើមឈើ។ មនុស្សទាំងឡាយ បានឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្តិយ៍ មិនសមបើនឹងមកងូតទឹក ត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងដើមឈើ ដូចអ្នកប្រដាល់ ឬដូចពួកមនុស្ស អ្នកនៅក្នុងក្រុង ដែលជាអ្នកខ្វល់ខ្វាយ នឹងការប្រដាប់កាយ ដូច្នេះសោះ។ ពួកភិក្ខុ បានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ បេ។ គ្រានោះ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ពួកភិក្ខុ ក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយ

ភិក្ខុ នាំគ្នាងូតទឹក ត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងដើមឈើ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះពុទ្ធមានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះ ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងមកនាំគ្នាងូតទឹក ត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងដើមឈើទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។ បេ។ លុះទ្រង់បន្ទោសហើយ ក៏ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹក មិនត្រូវត្រដុសកាយ នឹងដើមឈើទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ។

[១១២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នាំគ្នាងូតទឹក ត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងសសរ។[22] មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្តិយ៍ មិនសមបើនឹងងូតទឹក ត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងសសរ ដូចអ្នកប្រដាល់ ឬដូចពួកមនុស្ស អ្នកនៅក្នុងក្រុង ដែលជាអ្នកខ្វល់ខ្វាយ នឹងការប្រដាប់កាយសោះ។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ បេ។ វេលានោះ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពិតមែនឬ។ បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះមានព្រះភាគ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹក មិនត្រូវត្រដុសកាយ នឹងសសរទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ។

[១១៣] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នាំគ្នាងូតទឹក ត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងជញ្ជាំង។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្តិយ៍ មិនសមបើនឹង មកងូតទឹក ត្រដុសកាយ ត្រង់ភ្លៅខ្លះ ដើមដៃខ្លះ ទ្រូងខ្លះ ខ្នងខ្លះ នឹងជញ្ជាំង ដូចអ្នកប្រដាល់ ឬដូចពួកមនុស្ស អ្នកនៅក្នុងក្រុង ដែលជាអ្នកខ្វល់ខ្វាយ នឹងការប្រដាប់កាយសោះ។ បេ។ ព្រះមានបុណ្យ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុងូតទឹក មិនត្រូវត្រដុសកាយ នឹងជញ្ជាំងទេ ភិក្ខុណាត្រដុស ត្រូវអាបត្តិទុក្កដ។

[១១៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលងូតទឹក ក៏នាំគ្នាទៅងូត ក្នុងទីមិនគួរ។[23] មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចជាពួកគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ បេ។ គ្រានោះ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពិតមែនឬ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលងូតទឹក មិនត្រូវងូតក្នុងទីមិនគួរទេ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ។

[១១៥] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹក ដោយឈើ ដែលគេធ្វើជាដៃគន្ធព្វ។[24] មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ បេ។ គ្រានោះ ភិក្ខុទាំងនោះ ក៏បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវងូតទឹក ដោយឈើដែលគេធ្វើជាដៃគន្ធព្វទេ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ។

[១១៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នាំគ្នាងូតទឹកដោយដុំលំអិតថ្ម ឈ្មោះកុរុវិន្ទកៈ។[25] មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវងូតទឹក ដោយដុំលំអិតថ្ម ឈ្មោះកុរុវិន្ទកៈឡើយ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ។

[១១៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ញុំាងគ្នានឹងគ្នាឲ្យធ្វើបរិកម្ម[26] មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវញុំាងគ្នានឹងគ្នា ឲ្យធ្វើបរិកម្ម ទៅវិញទៅមកទេ ភិក្ខុណាឲ្យធ្វើ ត្រូវអាបត្តិទុក្កដ។

[១១៨] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ងូតទឹកដោយឈើ មានសណ្ឋានដូចជើងកន្លោរ[27] មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងនោះ ក៏បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវងូតទឹក ដោយឈើ មានសណ្ឋានដូចជើងកន្លោរទេ ភិក្ខុណាងូត ត្រូវអាបត្តិទុក្កដ។

[១១៩] សម័យនោះឯង មានភិក្ខុ១រូប កើតអាពាធកមរមាស់។ ភិក្ខុនោះ វៀរចាកឈើ មានសណ្ឋានដូចជើងកន្លោរ ក៏មិនបានសេចក្តីសប្បាយ។ បេ។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើ មានសណ្ឋានដូចជើងកន្លោរ ដែលគេមិនបានឆ្លាក់ជាក្បាច់ធ្មេញមករ ដល់ភិក្ខុមានជម្ងឺ។

[១២០] សម័យនោះឯង មានភិក្ខុ១រូប ចាស់ជរាកំឡាំងថយ កាលបើងូតទឹក មិនអាចនឹងដុសកាយខ្លួនឯងបាន។ បេ។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សាញ់សំពត់[28] (សម្រាប់ភិក្ខុចាស់ជរាងូតទឹកដុសខ្លួនបាន)។

[១២១] សម័យនោះឯង មានភិក្ខុ១រូប រង្កៀសនឹងការបរិកម្មខ្នង (ដុសខ្នង)។ បេ។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការដុសខ្នង ដោយដៃបាន។

[១២២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ទ្រទ្រង់គ្រឿងប្រដាប់ត្រចៀក[29)]។ បេ។ ទ្រទ្រង់សង្វារ។ ទ្រទ្រង់គ្រឿងប្រដាប់ក។ ទ្រទ្រង់គ្រឿងប្រដាប់ចង្កេះ។ ពាក់កង។ ទ្រទ្រង់គ្រឿងប្រដាប់ដើមដៃ[30)] ទ្រទ្រង់គ្រឿងប្រដាប់ដៃ។ ពាក់ចិញ្ចៀន។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ បេ។ លំដាប់នោះ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុ ទ្រទ្រង់គ្រឿងប្រដាប់ត្រចៀក។ ទ្រទ្រង់សង្វារ។ ទ្រទ្រង់គ្រឿងប្រដាប់ក។ ទ្រទ្រង់គ្រឿងប្រដាប់ចង្កេះ។ ពាក់កង។ ទ្រទ្រង់គ្រឿងប្រដាប់ដើមដៃ។ ទ្រទ្រង់គ្រឿងប្រដាប់ដៃ។ ពាក់ចិញ្ចៀន ពិតមែនឬ។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ត្រចៀក មិនត្រូវទ្រទ្រង់សង្វារ មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ក មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ចង្កេះ មិនត្រូវពាក់កង មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ដើមដៃ មិនត្រូវទ្រទ្រង់គ្រឿងប្រដាប់ដៃ មិនត្រូវពាក់ចិញ្ចៀន ភិក្ខុណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ។

[១២៣] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទុកសក់វែង។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកសក់វែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យទុកសក់ កំណត់កាលត្រឹមពីរខែ ឬកំណត់ត្រឹមពីរធ្នាប់។[31)]

[១២៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ សិតសក់ដោយស្និត។ សិតសក់ដោយក្រាស។ ជ្រងសក់ដោយក្រាស គឺដៃធ្វើជាក្រាស។ សិតសក់ដោយក្រមួន និងប្រេង។ សិតសក់ដោយប្រេង ដែលលាយដោយទឹក។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសិតសក់ដោយស្និត មិនត្រូវសិតសក់ដោយក្រាស មិនត្រូវជ្រងសក់ដោយដៃ ធ្វើជាក្រាស មិនត្រូវសិតសក់ ដោយក្រមួន និងប្រេង មិនត្រូវសិតសក់ដោយប្រេង ដែលលាយដោយទឹកទេ ភិក្ខុណាសិត ត្រូវអាបត្តិទុក្កដ។

[១២៥] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ មើលមុខនិមិត្ត គឺស្រមោលមុខ ក្នុងកញ្ចក់ខ្លះ ក្នុងភាជនៈទឹកខ្លះ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវមើលមុខនិមិត្ត ក្នុងកញ្ចក់ ឬក្នុងភាជនៈទឹកទេ ភិក្ខុណាមើល ត្រូវអាបត្តិទុក្កដ។

[១២៦] សម័យនោះឯង មានភិក្ខុ១រូប កើតដម្បៅត្រង់មុខ។ ភិក្ខុនោះ សួរភិក្ខុទាំងឡាយថា ម្នាលលោកមានអាយុ ដម្បៅខ្ញុំ ដូចម្តេចទៅ។ ភិក្ខុទាំងឡាយ ប្រាប់យ៉ាងនេះថា ម្នាលលោកមានអាយុ ដម្បៅលោកដូច្នេះ។ ភិក្ខុនោះមិនជឿ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានអាពាធ ជាហេតុ តថាគតអនុញ្ញាត ឲ្យភិក្ខុមើលនិមិត្ត ក្នុងកញ្ចក់ ឬក្នុងភាជនៈទឹកបាន។

[១២៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នាំគ្នាផាត់មុខ។ ដុសខាត់មុខ។ ប្រស់មុខ។ ចុចមុខដោយថ្មនោសិលា។ ធ្វើការលាបខ្លួន។ ធ្វើការលាបមុខ។ ធ្វើការលាបទាំងខ្លួន ទាំងមុខ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផាត់មុខ មិនត្រូវដុសខាត់មុខ មិនត្រូវប្រស់មុខ មិនត្រូវចុចមុខ ដោយថ្មនោសិលា មិនត្រូវធ្វើការលាបខ្លួន មិនត្រូវធ្វើការលាបមុខ មិនត្រូវធ្វើការលាបទាំងខ្លួន ទាំងមុខទេ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។

[១២៨] សម័យនោះឯង មានភិក្ខុ១រូប កើតអាពាធឈឺភ្នែក។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានអាពាធ ជាហេតុ តថាគតអនុញ្ញាតឲ្យភិក្ខុផាត់មុខបាន។

[១២៩] សម័យនោះឯង មានល្បែងមហោស្រព លើកំពូលភ្នំ ទៀបក្រុងរាជគ្រឹះ។ ពួកឆព្វគ្គិយភិក្ខុ នាំគ្នាទៅមើលល្បែងមហោស្រពលើកំពូលភ្នំ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈសក្យបុត្តិយ៍ មិនសមបើនឹង ទៅមើលរាំ ឬស្តាប់ច្រៀង និងស្តាប់ភ្លេងប្រគំ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម ដូច្នេះសោះ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទៅមើលរាំ ស្តាប់ច្រៀង ឬភ្លេងប្រគំទេ ភិក្ខុណាទៅ ត្រូវអាបត្តិទុក្កដ។

[១៣០] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ច្រៀងធម៌ ដោយសំលេងច្រៀងដ៏វែងៗ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា យើងច្រៀងយ៉ាងណាមិញ ពួកសមណៈ សក្យបុត្តិយ៍ទាំងនេះ ក៏ច្រៀងធម៌ ដោយសម្លេងច្រៀងដ៏វែងៗ យ៉ាងនោះដែរ។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹង ច្រៀងធម៌ ដោយសម្លេងច្រៀងដ៏វែងៗ ដូច្នេះសោះ។ លំដាប់នោះ ភិក្ខុទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពិតមែនឬ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ បេ។ ព្រះអង្គ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ទោសទាំង៥នេះ នឹងមានដល់ភិក្ខុអ្នកច្រៀងធម៌ ដោយសម្លេងច្រៀងវែងៗ គឺភិក្ខុនោះ ត្រេកអរក្នុងសម្លេងរបស់ខ្លួននោះ១ ជនទាំងឡាយដទៃ រមែងត្រេកអរ ក្នុងសម្លេងនោះ១ គហបតិទាំងឡាយ តែងពោលទោស១ បុគ្គល ដែលពេញចិត្តនឹងការសូត្ររលាក់រលែកសម្លេង រមែងខូចសមាធិ១ ពួកជនខាងក្រោយ នឹងដល់នូវទិដ្ឋានុគតិ (យកតម្រាប់តាម)១ ម្នាលភិក្ខុទាំងឡាយ ទោសទាំង៥នេះឯង នឹងមានដល់ភិក្ខុអ្នកច្រៀងធម៌ ដោយសម្លេងច្រៀងដ៏វែងៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវច្រៀងធម៌ ដោយសម្លេងច្រៀងដ៏វែងៗទេ ភិក្ខុណាច្រៀង ត្រូវអាបត្តិទុក្កដ។

[១៣១] សម័យនោះឯង ភិក្ខុទាំងឡាយរង្កៀសក្នុងសរភ័ញ្ញ គឺការសូត្រដោយប្រែសំឡេង។[32] លំដាប់នោះ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសូត្រសរភ័ញ្ញបាន។

[១៣២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់សំពត់ ដែលគេធ្វើដោយរោមសត្វ មានរោមចេញមកខាងក្រៅ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់សំពត់ ដែលគេធ្វើដោយរោមសត្វ មានរោមចេញមកខាងក្រៅទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[១៣៣] សម័យនោះឯង ក្នុងសួនរបស់ព្រះរាជា ទ្រង់ព្រះនាមមាគធសេនិយពិម្ពិសារ មានស្វាយផ្លែជាច្រើន។ ព្រះរាជា ទ្រង់ព្រះនាមមាគធសេនិយពិម្ពិសារ ទ្រង់បវារណាថា សូមលោកម្ចាស់ទាំងឡាយ និមន្តឆាន់ផ្លែស្វាយ តាមសប្បាយចុះ។ ពួកឆព្វគ្គិយភិក្ខុ នាំគ្នាបេះផ្លែស្វាយខ្ចីៗឆាន់។ ក៏ជួនជា ព្រះរាជាមាគធសេនិយពិម្ពិសារ ទ្រង់មានសេចក្តីត្រូវការ ដោយផ្លែស្វាយដែរ។ លំដាប់នោះ ព្រះរាជាមាគធសេនិយពិម្ពិសារ ទ្រង់បង្គាប់មនុស្សទាំងឡាយថា ម្នាលនាយ អ្នកទាំងឡាយ ចូរទៅសួន ហើយបេះផ្លែស្វាយមក។ មនុស្សទាំងនោះ ទទួលព្រះរាជឱង្ការព្រះរាជាមាគធសេនិយពិម្ពិសារ ដោយពាក្យថា ព្រះករុណាពិសេស ហើយក៏ទៅកាន់សួន និយាយនឹងនាយអារាមបាល (អ្នករក្សាសួន) យ៉ាងនេះថា នែនាយ ព្រះសម្មតិទេព ទ្រង់ត្រូវការដោយផ្លែស្វាយ ចូរអ្នកទាំងឡាយ ថ្វាយផ្លែស្វាយកុំខាន។ នាយអារាមបាល ក៏ឆ្លើយថា បពិត្រលោកទាំងឡាយ ផ្លែស្វាយគ្មានទេ ព្រោះពួកភិក្ខុ បេះផ្លែស្វាយខ្ចីៗ យកទៅឆាន់អស់ហើយ។ លំដាប់នោះ មនុស្សទាំងនោះ ក៏នាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលព្រះរាជាមាគធសេនិយពិម្ពិសារ។ ព្រះមហាក្សត្រ មានព្រះបន្ទូលថា ម្នាលនាយ លោកម្ចាស់ទាំងឡាយ បានឆាន់ផ្លែស្វាយ ក៏ជាការប្រពៃហើយ តែថា ព្រះមានព្រះភាគ ទ្រង់សរសើរការដឹងប្រមាណ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ សក្យបុត្តិយ៍ មិនសមបើ នឹងឆាន់ផ្លែស្វាយ របស់ព្រះរាជា មិនដឹងប្រមាណសោះ។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ បេ។ លំដាប់នោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ផ្លែស្វាយ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។

[១៣៤] សម័យនោះ មានសង្ឃភត្តរបស់ប្រជុំជន១ពួក។ ប្រជុំជននោះ បានដាក់ចំណិតផ្លែស្វាយក្នុងសម្ល។ ភិក្ខុទាំងឡាយ មានសេចក្តីរង្កៀស មិនហ៊ានទទួល។ បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទទួលឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចំណិតផ្លែស្វាយ។

[១៣៥] សម័យនោះឯង មានសង្ឃភត្តរបស់ប្រជុំជន១ពួក។ មនុស្សទាំងនោះ មិនអាចនឹងធ្វើចំណិតផ្លែស្វាយបាន។ ជនទាំងនោះ ក៏នាំយកផ្លែស្វាយទាំងមូល ទៅក្នុងរោងភត្ត។ ភិក្ខុទាំងឡាយ មានសេចក្តីរង្កៀស មិនហ៊ានទទួល។ បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទទួលឆាន់ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើ ដោយសមណកប្ប[33] ៥យ៉ាង គឺផ្លែឈើដែលគេអុជ ឬដុតកំដៅដោយភ្លើង១ ដែលគេចោះ ពុះ ចិត ដោយសស្ត្រា១ ដែលគេចុចដោយក្រចក១ ដែលគ្មានពូជដុះតទៅ១ មានពូជដែរ តែគួរបន្លេចគ្រាប់ចេញបាន១ ជាគំរប់ប្រាំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើ ដោយសមណកប្បទាំង៥នេះឯង។

[១៣៦] សម័យនោះឯង ភិក្ខុ១រូបពស់ចឹកហើយក៏ស្លាប់ទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានជាដូច្នោះ ព្រោះភិក្ខុនោះ មិនផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង៤។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុនោះ បានផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង៤ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ បើទុកជាពស់ចឹក ក៏មិនបានស្លាប់ទេ។ ត្រកូលស្តេចពស់ទាំង៤ ដូចម្តេចខ្លះ។ ត្រកូលស្តេចពស់ទាំង៤នោះ គឺ ត្រកូលស្តេចពស់ ឈ្មោះវិរូបក្ខៈ ត្រកូលស្តេចពស់ ឈ្មោះឯរាបថៈ ត្រកូលស្តេចពស់ ឈ្មោះឆព្យាបុត្តៈ ត្រកូលស្តេចពស់ ឈ្មោះកណ្ហាគោតមក ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបានជាដូច្នោះ ព្រោះភិក្ខុនោះ មិនផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង៤នេះឯង។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុនោះ បានផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង៤នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ បើទុកជាពស់ចឹក ក៏មិនបានស្លាប់ទេ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង៤នេះ ដើម្បីគ្រប់គ្រងខ្លួន ដើម្បីរក្សាខ្លួន ដើម្បីការពារខ្លួន។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវធ្វើមេត្តាចិត្តយ៉ាងនេះឯង។

[១៣៧] មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកត្រកូលស្តេចពស់ ឈ្មោះវិរូបក្ខៈផង[34] មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកត្រកូលស្តេចពស់ ឈ្មោះឯរាបថៈផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកត្រកូលស្តេចពស់ ឈ្មោះឆព្យាបុត្តៈផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកត្រកូលស្តេចពស់ ឈ្មោះកណ្ហាគោតមកៈផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកសត្វមិនមានជើងផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកសត្វមានជើងពីរផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកសត្វមានជើងបួនផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកសត្វមានជើងច្រើនផង សត្វគ្មានជើង កុំបៀតបៀនយើង សត្វមានជើងពីរ កុំបៀតបៀនយើងឡើយ។ សត្វមានជើងបួន កុំបៀតបៀនយើង សត្វមានជើងច្រើន កុំបៀតបៀនយើងឡើយ។ ពួកសត្វ[35] ទាំងអស់ផង ពួកបាណៈ[36] ទាំងអស់ផង ពួកភូត[37] ទាំងអស់ផង គ្រប់យ៉ាង សត្វទាំងអស់ (នោះ) ចូរឃើញ នូវអារម្មណ៍ ដ៏ចំរើន អំពើដ៏អាក្រក់តិចតួច កុំបីមកឡើយ។ ព្រះពុទ្ធ មានគុណប្រមាណមិនបាន ព្រះធម៌ មានគុណប្រមាណមិនបាន ព្រះសង្ឃ មានគុណប្រមាណមិនបាន ពួកសត្វទីឃជាតិ គឺពស់ ខ្ទួយ ក្អែប ពីងពាង តុកកែ និងកណ្តុរ ជាសត្វប្រកបដោយគុណសម្បត្តិ (តិច) ការរក្សា យើងបានធ្វើហើយ សេចក្តីការពារ យើងបានធ្វើហើយ សត្វទាំងឡាយ ចូរចៀសចេញទៅ យើងធ្វើកិរិយានមស្ការ ចំពោះព្រះមានព្រះភាគ ធ្វើកិរិយានមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធទាំង៧ព្រះអង្គ (មានព្រះពុទ្ធ ទ្រង់ព្រះនាមវិបស្សីជាដើម)។

[១៣៨] សម័យនោះឯង ភិក្ខុ១រូប មានសេចក្តីអផ្សុកបៀតបៀន ហើយក៏កាត់នូវអង្គជាតរបស់ខ្លួន។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុដទៃ[38] ដែលខ្លួនគួរកាត់ ក៏មាន តែមោឃបុរសនោះ ទៅកាត់ឯវត្ថុដទៃ (អង្គជាត)វិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវកាត់អង្គជាតរបស់ខ្លួនទេ ភិក្ខុណាកាត់ ត្រូវអាបត្តិថុល្លច្ច័យ។

[១៣៩] សម័យនោះឯង រាជគហសេដ្ឋី (ជាសេដ្ឋីនៅក្នុងក្រុងរាជគ្រឹះ) បានពកចន្ទន៍ នៃខ្លឹមចន្ទន៍ មានតម្លៃច្រើន។ លំដាប់នោះ រាជគហសេដ្ឋី មានសេចក្តីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ឲ្យជាងក្រឡឹងបាត្រ ដោយពកចន្ទន៍នេះ លំអិតដែលបានពីការក្រឡឹង ក៏ជាគ្រឿងប្រើប្រាស់របស់អាត្មាអញផង ហើយអាត្មាអញ នឹងបានឲ្យបាត្រ ទៅជាទានផង។ គ្រានោះ រាជគហសេដ្ឋី ក៏ឲ្យជាងក្រឡឹងបាត្រ ដោយពកចន្ទន៍នោះ ហើយច្រកក្នុងសង្រែក ព្យួរលើចុងឫស្សី ហើយលើកឫស្សីតៗគ្នា (ឲ្យខ្ពស់)ឡើង រួចនិយាយយ៉ាងនេះថា លោកណា ទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី ដែលជាព្រះអរហន្ត មានឫទ្ធិ លោកនោះ ចូរដាក់យកបាត្រ ដែលយើងឲ្យហើយទៅចុះ។

[១៤០] គ្រានោះ គ្រូឈ្មោះ បូរណកស្សបៈ ចូលទៅរករាជគហសេដ្ឋី លុះចូលទៅដល់ហើយ ក៏និយាយយ៉ាងនេះ នឹងរាជគហសេដ្ឋីថា នែគហបតិ អាត្មាជាព្រះអរហន្ត ទាំងមានឫទ្ធិផង សូមអ្នកឲ្យបាត្រមកអាត្មាចុះ។ សេដ្ឋីនិយាយថា បពិត្រលោកដ៏ចំរើន បើលោកមានអាយុ ជាព្រះអរហន្ត ទាំងមានឫទ្ធិផងមែន ចូរលោកដាក់យកបាត្រ ដែលយើងឲ្យហើយទៅចុះ។ លំដាប់នោះ គ្រូឈ្មោះ មក្ខលិគោសាល គ្រូឈ្មោះ អជិតកេសកម្ពល គ្រូឈ្មោះបកុធកច្ចាយនៈ គ្រូឈ្មោះ សញ្ជយវេឡដ្ឋបុត្ត គ្រូឈ្មោះ និគណ្ឋនាដបុត្ត បានចូលទៅរករាជគហសេដ្ឋី លុះចូលទៅដល់ហើយ ក៏និយាយយ៉ាងនេះ នឹងរាជគហសេដ្ឋីថា នែគហបតិ អាត្មាជាព្រះអរហន្ត ទាំងមានឫទ្ធិផង សូមអ្នកឲ្យបាត្រមកអាត្មាចុះ។ សេដ្ឋីនិយាយថា បពិត្រលោកដ៏ចំរើន បើលោកមានអាយុ ជាព្រះអរហន្ត ទាំងមានឫទ្ធិមែន ចូរលោកដាក់យកបាត្រ ដែលយើងឲ្យហើយទៅចុះ។

## រឿងព្រះបិណ្ឌោលភារទ្វាជត្ថេរ

[១៤១] សម័យនោះឯង ព្រះមហាមោគ្គល្លានមានអាយុ និងព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ស្លៀកដណ្តប់ក្នុងបុព្វណ្ហសម័យ ហើយទ្រង់បាត្រ និងចីវរ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត។ ចំណែកខាងព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ជាព្រះអរហន្ត ទាំងមានឫទ្ធិផង។ ព្រះមហាមោគ្គល្លានមានអាយុ ជាព្រះអរហន្ត ទាំងមានឫទ្ធិផងដែរ។ គ្រានោះ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ និយាយនឹងព្រះមហាមោគ្គល្លានមានអាយុ យ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន ចូរលោកនិមន្តទៅដាក់យកបាត្រនុ៎ះមក បាត្រនុ៎ះ ជាបាត្ររបស់លោកហើយ។ ឯព្រះមហាមោគ្គល្លានមានអាយុ ក៏និយាយទៅនឹងព្រះបិណ្ឌោលភារទ្វាជៈមានអាយុ យ៉ាងនេះវិញថា ម្នាលអាវុសោភារទ្វាជៈ ចូរលោកនិមន្តទៅដាក់យកបាត្រនុ៎ះមក បាត្រនុ៎ះ ជាបាត្ររបស់លោកហើយ។ លំដាប់នោះ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ក៏ហោះទៅឯអាកាស កាន់យកបាត្រនោះ ហើយហោះក្រឡឹងក្រុងរាជគ្រឹះបីជុំ។

[១៤២] សម័យនោះឯង រាជគហសេដ្ឋី ព្រមទាំងកូន និងប្រពន្ធ ឈរនៅទីផ្ទះរបស់ខ្លួន ផ្គងអញ្ជលីនមស្ការនិយាយថា បពិត្រលោកដ៏ចំរើន សូមព្រះភារទ្វាជៈជាម្ចាស់ មកប្រតិស្ឋាន ក្នុងផ្ទះរបស់យើងឯនេះ។ លំដាប់នោះ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ក៏មកប្រតិស្ឋាន ក្នុងទីផ្ទះរបស់រាជគហសេដ្ឋី។ លំដាប់នោះ រាជគហសេដ្ឋី ទទួលបាត្រ អំពីព្រះហស្តព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ហើយដាក់ខាទនីយៈ ដែលមានថ្លៃច្រើនឲ្យពេញ រួចប្រគេនដល់ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ។ ឯព្រះបិណ្ឌោលភារទ្វាជៈមានអាយុ ក៏ទទួលយកបាត្រនោះ ហើយដើរទៅកាន់អារាម។ មនុស្សទាំងឡាយ បានឮច្បាស់ថា ឥឡូវ បាត្ររបស់រាជគហសេដ្ឋី ព្រះបិណ្ឌោលភារទ្វាជៈជាម្ចាស់ បានដាក់យកទៅហើយ។ មនុស្សទាំងនោះ ក៏ហ៊ោ កញ្ជ្រៀវ ដើរទៅតាមក្រោយៗព្រះបិណ្ឌោលភារទ្វាជៈមានអាយុ។ ព្រះមានព្រះភាគ ទ្រង់បានឮសំឡេងហ៊ោកញ្ជ្រៀវ លុះឮហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកសួរថា ម្នាលអានន្ទ សំឡេងហ៊ោកញ្ជ្រៀវនោះ ជាសំឡេងអ្វី។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវ បាត្ររបស់រាជគហសេដ្ឋី ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ បានដាក់យកទៅហើយ បពិត្រព្រះអង្គដ៏ចំរើន មនុស្សទាំងឡាយ បានឮដំណឹងថា បាត្ររបស់រាជគហសេដ្ឋី លោកម្ចាស់បិណ្ឌោលភារទ្វាជៈ បានដាក់យកទៅហើយ បពិត្រព្រះអង្គដ៏ចំរើន មនុស្សទាំងនោះ ក៏ហ៊ោកញ្ជ្រៀវឡើង ដើរទៅតាមក្រោយៗ ព្រះបិណ្ឌោលភារទ្វាជៈមានអាយុ បពិត្រព្រះមានព្រះភាគ សំឡេងហ៊ោកញ្ជ្រៀវនោះ គឺជាសំឡេងនុ៎ះឯង។

[១៤៣] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរព្រះបិណ្ឌោលភារទ្វាជៈមានអាយុថា ម្នាលភារទ្វាជៈ ឮថា អ្នកបានដាក់យកបាត្រ របស់រាជគហសេដ្ឋី ពិតមែនឬ។ ព្រះបិណ្ឌោលភារទ្វាជៈ ក្រាបបង្គំទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន។ ព្រះពុទ្ធមានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភារទ្វាជៈ (អំពើនេះ) មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនត្រូវធ្វើ ម្នាលភារទ្វាជៈ អ្នកមិនសមបើនឹងសំដែងឥទ្ធិប្បាដិហារ្យ ដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ដល់ពួកគ្រហស្ថ ព្រោះតែបាត្រឈើ ជារបស់ថោកទាបទេ ម្នាលភារទ្វាជៈ មាតុគ្រាមបង្ហាញកេរ្តិ៍ខ្មាស ព្រោះតែរូបមាសក[39] ដូចជាសាកសព ជារបស់ថោកទាប យ៉ាងណាមិញ ម្នាលភារទ្វាជៈ អ្នកឯងសំដែងឥទ្ធិប្បាដិហារ្យ ដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ដល់ពួកគ្រហស្ថ ព្រោះតែបាត្រឈើ ជារបស់ថោកទាប ក៏យ៉ាងនោះដែរ ម្នាលភារទ្វាជៈ អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ជន ដែលមិនទាន់ជ្រះថ្លាទេ។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសំដែងឥទ្ធិប្បាដិហារ្យ ដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ដល់ពួកគ្រហស្ថទេ ភិក្ខុណាសំដែង ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបំបែកបាត្រឈើនុ៎ះចេញ ហើយធ្វើឲ្យជាចំណែកៗ ហើយឲ្យដល់ភិក្ខុទាំងឡាយ សម្រាប់កិន ធ្វើជាថ្នាំលាបភ្នែក ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បាត្រឈើទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[១៤៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់បាត្រខ្ពស់ និងទាប គឺល្អអាក្រក់ គឺបាត្រធ្វើអំពីមាសខ្លះ ធ្វើអំពីប្រាក់ខ្លះ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បាត្រធ្វើដោយមាស មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយប្រាក់ មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយកែវមណី មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយកែវពិទូរ្យ មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយកែវផលិក មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយសំរឹទ្ធិ មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយកែវកញ្ចក់ មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយសំណប៉ាហាំង មិនត្រូវប្រើប្រាស់

បាត្រ ធ្វើដោយសំណរភក់ មិនត្រូវប្រើប្រាស់បាត្រ ធ្វើដោយស្ពាន់ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបាត្រពីរយ៉ាង គឺ បាត្រដែកម្យ៉ាង បាត្រដីម្យ៉ាង។

[១៤៥] សម័យនោះឯង ផ្ទៃបាត្រខាងក្រោម ក៏សឹករិលរេចទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ជើងបាត្រ។

[១៤៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់ជើងបាត្រខ្ពស់ និងទាប គឺល្អអាក្រក់ គឺ ធ្វើដោយមាសខ្លះ ធ្វើដោយប្រាក់ខ្លះ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ជើងបាត្រខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជើងបាត្រពីរយ៉ាង គឺ ធ្វើដោយសំណប៉ាហាំងម្យ៉ាង ធ្វើដោយសំណភក់ម្យ៉ាង។ ជើងបាត្រក្រាសពេក ភិក្ខុចាប់កាន់មិនស្និទ្ធិ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រឡឹងបាន[40] ល្អសក៏កើតមាន (ដល់ពួកភិក្ខុក្នុងសម័យនោះ)។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាត់លួសនោះ ធ្វើជាក្បាច់ធ្មេញមករ។

[១៤៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់ជើងបាត្រទាំងឡាយ ដ៏វិចិត្រ ឆ្លាក់ ដេរដាស ដោយរូបស្រី និងប្រុសជាដើម ហើយលាបឲ្យមានពណ៌ផ្សេងៗ ក៏ដើរបង្ហាញជើងបាត្រទាំងនោះ (ដល់មនុស្សទាំងពួង) តាមផ្លូវថ្នល់។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ជើងបាត្រ ដ៏វិចិត្រ ឆ្លាក់ ដេរដាស ដោយរូបស្រី និងប្រុសជាដើម និងលាបឲ្យមានពណ៌ផ្សេងៗទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជើងបាត្រជាប្រក្រតី។[41]

[១៤៨] សម័យនោះឯង ភិក្ខុទាំងឡាយ ទុកដាក់បាត្រទាំងទទឹក។ បាត្រក៏វិនាសខូចទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកដាក់បាត្រទាំងទទឹកទេ ភិក្ខុណាទុកដាក់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុហាលបាត្រសិន ហើយសឹមទុកដាក់។

[១៤៩] សម័យនោះឯង ភិក្ខុទាំងឡាយ ហាលបាត្រទាំងទទឹក។ បាត្រក៏មានក្លិនអាក្រក់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវហាលបាត្រទាំងទទឹកទេ ភិក្ខុណាហាល ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជូតបាត្រឲ្យស្ងួតទឹកសិន ហើយសឹមហាលទុកដាក់ចុះ។

[១៥០] សម័យនោះឯង ភិក្ខុទាំងឡាយ ទុកបាត្រក្នុងទីក្តៅ។ បាត្រក៏ខូចពណ៌។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកបាត្រក្នុងទីក្តៅទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យហាលបាត្រក្នុងទីក្តៅមួយរំពេច ហើយសឹមទុកដាក់ចុះ។

[១៥១] សម័យនោះឯង មានបាត្រជាច្រើន តែមិនទាន់មានគ្រឿងរងដំកល់ ភិក្ខុទុកដាក់ក្នុងទីវាលស្រឡះ។ បាត្រទាំងនោះ ក៏រមៀលបែកខូចទៅ ដោយខ្យល់កំបុតត្បូង។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងរង ដំកល់បាត្រ។[42]

[១៥២] សម័យនោះឯង ពួកភិក្ខុដាក់បាត្រលើទីបំផុតផែនក្តារតាំង។[43] បាត្រក៏រមៀល ទង្គិចបែក។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រលើទីបំផុត នៃផែនក្តារតាំងទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ។

[១៥៣] សម័យនោះឯង ពួកភិក្ខុដាក់បាត្រក្នុងទីបំផុតនៃថ្នាក់។[44] បាត្រក៏រមៀល ធ្លាក់បែក។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រក្នុងទីបំផុត នៃថ្នាក់ទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ។

[១៥៤] សម័យនោះឯង ភិក្ខុទាំងឡាយ ផ្កាប់បាត្រលើផែនដី។ រឹមមាត់បាត្រ ក៏សឹករិលរេចទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកម្រាលស្មៅ។ ពួកកណ្តៀរ ក៏កាត់កម្រាលស្មៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកំណាត់សំពត់។ ពួកកណ្តៀរ ក៏កាត់កំណាត់សំពត់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរោងសម្រាប់ទុកបាត្រ។ បាត្រក៏រមៀល ធ្លាក់អំពីរោងសម្រាប់ទុកបាត្របែកទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភាជន៍ដី មានមាត់ធំ (ថ្លាង) សម្រាប់ទុកបាត្រ។ បាត្រក៏សឹកដោយភាជនៈដី មានមាត់ធំ សម្រាប់ទុកបាត្រ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់បាត្រ។ យោគបាត្រមិនទាន់មាននៅឡើយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយោគបាត្រ និងខ្សែសម្រាប់ចង។

[១៥៥] សម័យនោះឯង ភិក្ខុទាំងឡាយព្យួរបាត្រនឹងមេដញ្ជាំងខ្លះ នឹងដៃកែវខ្លះ។ បាត្រ ក៏រមៀល ធ្លាក់បែកទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវព្យួរបាត្រទេ ភិក្ខុណាព្យួរ ត្រូវអាបត្តិទុក្កដ។

[១៥៦] សម័យនោះឯង ភិក្ខុទាំងឡាយទុកបាត្រលើគ្រែ។ ភិក្ខុទាំងឡាយ ភ្លេចស្មារតី ក៏អង្គុយសង្កត់បាត្របែកទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកបាត្រលើគ្រែទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ។

[១៥៧] សម័យនោះឯង ភិក្ខុទាំងឡាយទុកបាត្រលើតាំង។ ភិក្ខុទាំងឡាយ ភ្លេចស្មារតី អង្គុយសង្កត់បាត្របែកទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកបាត្រលើតាំងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ។

[១៥៨] សម័យនោះឯង ភិក្ខុទាំងឡាយដាក់បាត្រលើភ្លៅទាំងភ្នែន។ ក្រោកឡើងដោយភ្លេចស្មារតី។ បាត្រ ក៏រមៀលធ្លាក់បែកទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រលើភ្លៅទាំងភ្នែនទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ។

[១៥៩] សម័យនោះឯង ភិក្ខុទាំងឡាយដាក់បាត្រក្នុងឆត្រ។ ខ្យល់កំបុតត្បូង ក៏បក់ផើយ ប៉ើងឆត្រឡើង។ បាត្រក៏ធ្លាក់បែកទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដាក់បាត្រក្នុងឆត្រទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ។

[១៦០] សម័យនោះឯង ភិក្ខុទាំងឡាយមានបាត្រនៅដៃ ច្រានសន្ទះទ្វារ។ បាត្រ ក៏ទង្គិច នឹងសន្ទះទ្វារ បែកទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានបាត្រនៅដៃ មិនត្រូវច្រានសន្ទះទ្វារទេ ភិក្ខុណាច្រាន ត្រូវអាបត្តិទុក្កដ។

[១៦១] សម័យនោះឯង ភិក្ខុទាំងឡាយ ដើរទៅបិណ្ឌបាត ដោយសំបកឃ្លោក (កាន់សំបកឃ្លោក)។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកតិរ្ថិយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរទៅបិណ្ឌបាត ដោយសំបកឃ្លោកទេ ភិក្ខុណាដើរទៅ ត្រូវអាបត្តិទុក្កដ។

[១៦២] សម័យនោះឯង ពួកភិក្ខុដើរទៅបិណ្ឌបាត ដោយអម្បែងឆ្នាំង។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកតិរ្ថិយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរទៅបិណ្ឌបាត ដោយអម្បែងឆ្នាំងទេ ភិក្ខុណាដើរទៅ ត្រូវអាបត្តិទុក្កដ។

[១៦៣] សម័យនោះឯង ភិក្ខុ១រូប ជាអ្នកប្រព្រឹត្តយកវត្ថុបំសុកូលគ្រប់មុខ។[45] ភិក្ខុនោះ ប្រើប្រាស់បាត្រក្បាលខ្មោច។ មានស្រីម្នាក់ ឃើញហើយខ្លាច ស្រែកភ្លាត់សំឡេងថា ឱនេះជាបិសាច ធ្វើសេចក្តីវិនាសដល់អញតើ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ ពួកសមណៈ សក្យបុត្តិយ៍ ប្រើប្រាស់បាត្រក្បាលខ្មោច ដូចពួកបិសាចសោះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បាត្រក្បាលខ្មោចទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវជាអ្នកប្រព្រឹត្តយកវត្ថុបំសុកូលគ្រប់មុខទេ ភិក្ខុណាប្រព្រឹត្តយក ត្រូវអាបត្តិទុក្កដ។

[១៦៤] សម័យនោះឯង ភិក្ខុទាំងឡាយ យកបាត្រដាក់កាកអាមិសៈ ដែលគេចោលខ្លះ ឆ្អឹងខ្លះ ទឹកជាដែលខ្លះ ហើយនាំយកទៅចោល។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ សក្យបុត្តិយ៍ទាំងនេះ ឆាន់ក្នុងបាត្រណា បាត្រនោះឯង ជាកន្ថោររបស់លោក។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវយកបាត្រ ដាក់កាកអាមិសៈ ដែលគេចោលក្តី ឆ្អឹងក្តី ទឹកជាដែលក្តី នាំយកទៅចោលទេ ភិក្ខុណានាំយកទៅចោល ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកន្ថោរ។

[១៦៥] សម័យនោះឯង ភិក្ខុទាំងឡាយ ហែកចីវរដោយដៃ ហើយដេរចីវរ។ ចីវរក៏មិនស្មើគ្នា។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាំបិត និងកំណាត់សំពត់ សម្រាប់រុំកាំបិត។

[១៦៦] សម័យនោះឯង កាំបិតមានដង កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាំបិតមានដង។

[១៦៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ដងកាំបិត ដ៏ខ្ពស់ និងទាប[46] គឺធ្វើដោយមាស និងធ្វើដោយប្រាក់។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចជាពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ដងកាំបិតខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដងកាំបិត ធ្វើដោយឆ្អឹង ធ្វើដោយភ្លុក ធ្វើដោយស្នែង ធ្វើដោយបបុស ធ្វើដោយឫស្សី ធ្វើដោយឈើ ធ្វើដោយជ័រ ធ្វើដោយផ្លែ ធ្វើដោយលោហធាតុ[47] ធ្វើដោយគូថស័ង្ខ។

[១៦៨] សម័យនោះឯង ភិក្ខុទាំងឡាយដេរចីវរដោយស្លាបមាន់ខ្លះ ដោយចំរៀកឫស្សីខ្លះ។ ចីវរមានថ្នេរមិនល្អ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតម្ជុល។ ម្ជុលទាំងឡាយ ក៏មានច្រែះចាប់។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត បំពង់ម្ជុល។ ច្រែះក៏ចាប់ក្នុងបំពង់ម្ជុលទៀត។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យដាក់លំអិតបំពេញ (ក្នុងបំពង់ម្ជុល)។ ច្រែះ ក៏កើតឡើងក្នុងលំអិតទៀត។ បេ។ ព្រះអង្គ ទ្រង់

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យបំពេញបំពង់ម្ជុល ដោយលំអិតម្សៅ ដ៏លាយដោយរមៀត។ ច្រែះក៏កើតឡើងក្នុងលំអិតម្សៅដ៏លាយដោយរមៀតទៀត។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត លំអិតថ្ម។ ច្រែះក៏កើតឡើង ក្នុងលំអិតថ្មទៀត។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យលាបដោយក្រមួនឃ្មុំ។ ក្រមួនឃ្មុំដែលភិក្ខុលាបហើយ ក៏បែករាត់រាយទៅ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត កំណាត់សំពត់សម្រាប់រុំក្រមួនឃ្មុំ។

[១៦៩] សម័យនោះឯង ភិក្ខុទាំងឡាយ ជីកដាំបង្គោលក្នុងទីនោះៗ ហើយចងដេរចីវរ។ ចីវរក៏ស្មោក មិនស្មើល្អ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចងឈើស្ទឹង[48] និងខ្សែស្ទឹង[49] ដើម្បីឲ្យភិក្ខុចងចីវរ ហើយដេរក្នុងទីនោះៗ។ ភិក្ខុទាំងឡាយ លាតឈើស្ទឹងក្នុងទីមិនស្មើ។ ឈើស្ទឹងក៏បែកបាក់ទៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលាតឈើស្ទឹង ក្នុងទីមិនស្មើទេ ភិក្ខុណាលាត ត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងឡាយ លាតឈើស្ទឹង លើផែនដី។ ឈើស្ទឹង ក៏ប្រឡាក់ដោយធូលី។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត កម្រាលស្មៅ។ ជាយចីវរ ដែលចងនឹងឈើស្ទឹង ក៏ទក់ទីអស់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលើក (ថែម) អនុវាតបណ្តោយ និអនុវាតទទឹងរបស់ចីវរ។ ឈើស្ទឹងមិនល្មមគ្នានឹងចីវរ[50]។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដងឈើស្ទឹង[51] នឹងការបត់ទ្រនាប់ឈើស្ទឹង ឲ្យជាពីរជាន់[52] ស្លាកសម្រាប់បញ្ចូលក្នុងចន្លោះនៃចីវរមានជាន់ពីរ ខ្សែសម្រាប់រឹតឈើស្ទឹងតូច ជាមួយនឹងឈើស្ទឹងធំ និងខ្សែសម្រាប់រឹតចីវរភ្ជាប់នឹងឈើស្ទឹងតូច ដើម្បីចងចីវរដេរ។ ចន្លោះថ្នេរចីវរមិនស្មើគ្នា។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ខ្នាតសម្រាប់វាស់។ ថ្នេរចីវរក៏វៀច មិនត្រង់ល្អ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែបន្ទាត់។

[១៧០] សម័យនោះឯង ភិក្ខុទាំងឡាយ មានជើងមិនស្អាត ហើយដើរជាន់ឈើស្ទឹង។ ឈើស្ទឹងក៏ប្រឡាក់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានជើងមិនស្អាត មិនត្រូវដើរជាន់ឈើស្ទឹងទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ។

[១៧១] សម័យនោះឯង ភិក្ខុទាំងឡាយ មានជើងទទឹក ដើរជាន់លើឈើស្ទឹង។ ឈើស្ទឹងក៏ប្រឡាក់។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានជើងទទឹក មិនត្រូវជាន់ឈើស្ទឹងទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ។

[១៧២] សម័យនោះឯង ភិក្ខុទាំងឡាយ ពាក់ស្បែកជើង ដើរជាន់ឈើស្ទឹង។ ឈើស្ទឹងក៏សៅហ្មង។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើង ជាន់ឈើស្ទឹងទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ។

[១៧៣] សម័យនោះឯង ភិក្ខុទាំងឡាយ ដេរចីវរ កាន់ដោយម្រាមដៃ។ ម្រាមដៃក៏ឈឺ។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្នាប់ម្រាមដៃ។[53]

[១៧៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ស្នាប់ម្រាមដៃ ដ៏ខ្ពស់និងទាប គឺធ្វើដោយមាស និងធ្វើដោយប្រាក់។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចជាពួកគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ស្នាប់ម្រាមដៃខ្ពស់និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្នាប់ម្រាមដៃ ធ្វើដោយឆ្អឹង។ បេ។ ធ្វើដោយគូថស័ង្ខ។

[១៧៥] សម័យនោះឯង ម្ជុល កាំបិត នឹងស្នាប់ម្រាមដៃបាត់ទៅ។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវត្ថុសម្រាប់ដាក់។[54] (លុះដាក់) ក្នុងវត្ថុសម្រាប់ដាក់ក៏នៅតែរាត់រាយ។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់សម្រាប់ដាក់ស្នាប់ម្រាមដៃ។ ខ្សែយោគ មិនទាន់មាននៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ខ្សែយោគ និងខ្សែសម្រាប់ចង។

[១៧៦] សម័យនោះឯង ភិក្ខុទាំងឡាយ ដេរចីវរក្នុងទីវាល លំបាកដោយត្រជាក់ និងក្តៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរោងសម្រាប់ដាក់ឈើស្ទឹង បារាំងសម្រាប់ដាក់ឈើស្ទឹង។ រោងសម្រាប់ដាក់ឈើស្ទឹងមានទីដ៏ទាប។ ទឹកក៏លិច។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង។ ខឿនក៏របេះ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូនខឿន៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ភិក្ខុទាំងឡាយ ក៏លំបាកនឹងឡើង។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ៣យ៉ាង គឺ ជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ កាលភិក្ខុទាំងឡាយឡើងទៅ ក៏ធ្លាក់មកវិញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ។

[១៧៧] សម័យនោះឯង កំទេចស្មៅ ជ្រុះក្នុងរោងឈើស្ទឹង។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ហើយបូកទាំងខាងក្នុងខាងក្រៅ ធ្វើឲ្យមានពណ៌ស ពណ៌ខ្មៅ និងបរិកម្មដោយរង់ ក្បាច់ភ្ញីផ្កា ភ្ញីវល្លិ៍ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥យ៉ាង ស្នួរចីវរ និងខ្សែស្បៀងចីវរ។

[១៧៨] សម័យនោះឯង ភិក្ខុទាំងឡាយដេរចីវររួចហើយ ទុកឈើស្ទឹងចោល ក្នុងទីនោះ ហើយចៀសចេញទៅ។ ពួកកណ្តុរខ្លះ កណ្ដៀរខ្លះ កាត់កោរ (ឈើស្ទឹង)។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសាឈើស្ទឹងទុក។ ឈើស្ទឹងក៏បាក់បែក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យមូរឈើស្ទឹងដោយឈើស្ទូល។ ឈើស្ទឹងក៏រលាចេញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែសម្រាប់ចង។

[១៧៩] សម័យនោះឯង ភិក្ខុទាំងឡាយផ្អែកឈើស្ទឹងទុកនឹងជញ្ជាំងខ្លះ នឹងសសរខ្លះ ហើយចៀសចេញទៅ។ ឈើស្ទឹង ក៏រលំបាក់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពាក់ (ឈើស្ទឹង) នឹងមេជញ្ជាំង ឬដៃកែរ។

[១៨០] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះ តាមសមគួរ ដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់យាងទៅកាន់ចារិក ក្រុងវេសាលី។ សម័យនោះឯង ភិក្ខុទាំងឡាយ យកម្ទូលខ្លះ កាំបិតខ្លះ ភេសជ្ជៈខ្លះ ដាក់ក្នុងបាត្រ ដើរទៅ។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់សម្រាប់ដាក់ភេសជ្ជៈ។ ខ្សែយោគ មិនទាន់មាននៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែយោគ និងខ្សែសម្រាប់ចង។

[១៨១] សម័យនោះឯង ភិក្ខុ១រូប ចងស្បែកជើងនឹងវត្តពន្ធចង្កេះ ហើយចូលទៅបិណ្ឌបាតក្នុងស្រុក។ មានឧបាសកម្នាក់ ថ្វាយបង្គំភិក្ខុនោះ ក៏ទង្គិចក្បាលនឹងស្បែកជើង។ ភិក្ខុនោះ មានសេចក្តីអៀនខ្មាស។ ចំណែកខាងភិក្ខុនោះ ទៅកាន់អារាម ហើយក៏បានប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុ បានយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថង់សម្រាប់ដាក់ស្បែកជើង។ ខ្សែយោគ មិនទាន់មាននៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែយោគ និងខ្សែសម្រាប់ចង។

[១៨២] សម័យនោះឯង មានទឹកជាអកប្បិយៈ ក្នុងចន្លោះផ្លូវ។ សំពត់តម្រងទឹក មិនទាន់មាននៅឡើយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់តម្រងទឹក។ កំណាត់សំពត់ មិនគ្រាន់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតម្រងទឹក ដែលគេរឹតភ្ជាប់នឹងឈើបីកំណាត់។ កំណាត់សំពត់មិនគ្រាន់។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតធម្មក្រក។

[១៨៣] សម័យនោះឯង ក្នុងកោសលជនបទ មានភិក្ខុពីររូប នាំគ្នាដើរទៅកាន់ផ្លូវឆ្ងាយ។ ភិក្ខុមួយរូបប្រព្រឹត្តអនាចារ។ ភិក្ខុទីពីរ បាននិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ អ្នកកុំធ្វើអំពើយ៉ាងនេះឡើយ អំពើនេះ មិនគួរទេ។ ភិក្ខុដែលប្រព្រឹត្តអនាចារនោះ ក៏ចងគំនុំ នឹងភិក្ខុនោះ។ ចំណែកខាងភិក្ខុ អ្នកប្រព្រឹត្តអនាចារនោះ ស្រេកទឹក ក៏និយាយទៅនឹងភិក្ខុ ដែលខ្លួនចងគំនុំយ៉ាងនេះថា ម្នាលអាវុសោ ចូរលោកឲ្យតម្រងទឹកមកខ្ញុំ ៗនឹងឆាន់ទឹក។ ភិក្ខុ ដែលគេចងគំនុំមិនព្រមឲ្យ។ ភិក្ខុ ដែលប្រព្រឹត្តអនាចារនោះ ស្រេកទឹកខ្លាំង ក៏ធ្វើមរណកាលទៅ។ កាលភិក្ខុ ដែលគេចងគំនុំនោះទៅអារាម ក៏បានប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងនោះ ក៏និយាយថា ម្នាលអាវុសោ កាលគេសុំសំពត់តម្រងទឹក លោកមិនឲ្យគេមែនឬ។ ភិក្ខុនោះឆ្លើយថា មែនហើយ អាវុសោ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា កាលបើគេខ្ចីសំពត់តម្រងទឹក ភិក្ខុមិនសមបើ មិនឲ្យគេទេ។ លំដាប់នោះ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។

[១៨៤] ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ក្នុងវេលានោះ ហើយត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា គេខ្ចីសំពត់តម្រងទឹក អ្នកមិនឲ្យគេ ពិតមែនឬ។ ភិក្ខុនោះ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះមានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អំពើរបស់អ្នក ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនត្រូវធ្វើ ម្នាលមោឃបុរស កាលបើគេខ្ចីសំពត់តម្រងទឹក អ្នកមិនសមបើនឹងមិនឲ្យគេទេ ម្នាលមោឃបុរស អំពើនេះ មិនមែននាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដើរទៅតាមផ្លូវឆ្ងាយ កាលបើគេខ្ចីតម្រងទឹក កុំគប្បីមិនឲ្យ ភិក្ខុណាមិនឲ្យ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុគ្មានសំពត់តម្រងទឹក មិនត្រូវដើរផ្លូវឆ្ងាយទេ ភិក្ខុណាដើរ ត្រូវអាបត្តិទុក្កដ បើមិនមានសំពត់តម្រងទឹកក្តី ធម្មក្រកក្តី ទុកជាជាយសង្ឃាដិ ក៏ត្រូវអធិដ្ឋានបានថា អាត្មាអញនឹងត្រងទឹក ដោយជាយសង្ឃាដិនេះឆាន់។

[១៨៥] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរ ទៅកាន់ចារិក ដោយលំដាប់ ទ្រង់សំដៅទៅកាន់ក្រុងវេសាលី។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា ព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះ។

[១៨៦] សម័យនោះឯង ភិក្ខុទាំងឡាយធ្វើនវកម្ម (ការងារថ្មី)ៗ ភិក្ខុទាំងនោះ មិនបានសន្ទុតសំពត់តម្រងទឹកនៅឡើយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់តម្រងទឹកមានដង។ ភិក្ខុមិនទាន់សន្ទុតសំពត់តម្រងទឹកមានដងនៅឡើយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់តម្រងត្រាំ។[55)]

[១៨៧] សម័យនោះឯង មូសបៀតបៀនភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតមុង។

[១៨៨] សម័យនោះឯង ក្រុងវេសាលី ពួកជនបានចាត់ចែងភត្តដ៏ឧត្តម (ប្រគេនពួកភិក្ខុ)។ ពួកភិក្ខុ បានឆាន់ភោជនទាំងឡាយដ៏ឧត្តម មានកាយច្រើនទៅដោយទោស (រោគទល់) មានអាពាធច្រើន។ គ្រានោះឯង ជីវកកោមារភត្យ បានទៅក្រុងវេសាលី ដោយកិច្ចនីមួយ។ ជីវកកោមារភត្យ បានឃើញភិក្ខុទាំងឡាយ មានកាយច្រើនទៅដោយរោគ មានអាពាធច្រើន លុះបានឃើញហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះជីវកកោមារភត្យ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ភិក្ខុទាំងឡាយ មានកាយច្រើនទៅដោយទោស មានអាពាធច្រើន បពិត្រព្រះមានព្រះភាគដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះអង្គ អនុញ្ញាតទីចង្រ្កម និងរោងភ្លើង ដល់ភិក្ខុទាំងឡាយ ជាការប្រពៃ កាលបើយ៉ាងនេះ ភិក្ខុទាំងឡាយ នឹងមិនសូវមានអាពាធ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ជីវកកោមារភត្យ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ វេលានោះ ជីវកកោមារភត្យ កាលដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថារួចហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ។

[១៨៩] ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ក្នុងវេលានោះ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទីចង្រ្កម និងរោងភ្លើង។

[១៩០] សម័យនោះឯង ភិក្ខុទាំងឡាយចង្រ្កមក្នុងទីចង្រ្កមមិនរាបស្មើ។ ជើងទាំងឡាយក៏ឈឺ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីចង្រ្កម ឲ្យរាបស្មើ។

[១៩១] សម័យនោះឯង ទីចង្រ្កមជាទីទាប។ ទឹកក៏លិច ក្នុងទីចង្រ្កមនោះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីចង្រ្កមឲ្យខ្ពស់ឡើង។ ខឿនក៏របេះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូនខឿន៣យ៉ាង ខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ភិក្ខុទាំងឡាយនាំគ្នាឡើងទៅ ក៏លំបាក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ៣យ៉ាង គឺជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ ភិក្ខុទាំងឡាយនាំគ្នាឡើងទៅ ក៏ធ្លាក់ចុះមកវិញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ។

[១៩២] សម័យនោះឯង ពួកភិក្ខុកំពុងចង្រ្កម លើទីចង្រ្កម ក៏ធ្លាក់ចុះមក។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ[56] ក្នុងទីចង្រ្កម។

[១៩៣] សម័យនោះឯង ភិក្ខុទាំងឡាយកំពុងចង្រ្កមក្នុងទីវាល ក៏លំបាកដោយត្រជាក់ខ្លះ ក្តៅខ្លះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរោងចង្រ្កម។ កំទេចស្មៅក៏ជ្រុះមក ក្នុងរោងចង្រ្កម។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ហើយបូកទាំងខាងក្នុង ខាងក្រៅ ធ្វើឲ្យមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ក្បាច់ភ្ញីផ្កា ភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥ ស្នួរចីវរ និងខ្សែស្បៀង។

[១៩៤] សម័យនោះឯង រោងភ្លើងមានទីដីទាប។ ទឹក (ជោរជន់មក) ក៏លិច រោងភ្លើងនោះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីដីឲ្យខ្ពស់ឡើង។ ខឿនក៏របេះធ្លាក់ចុះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូនខឿន៣យ៉ាង ខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ពួកភិក្ខុនាំគ្នាឡើងទៅ ក៏លំបាក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ៣យ៉ាង គឺជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ ពួកភិក្ខុនាំគ្នាឡើងទៅ ក៏ធ្លាក់ចុះមកវិញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ។ រោងភ្លើង មិនទាន់មានទ្វារ បង្អួចនៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ត្បាល់ ឬដំណាប់ក្រោម ឈើអន្ទាក់លើ (ដំណាប់លើ) សសររបស់សន្ទះទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញ និងខ្សែសម្រាប់ទាញ (បិទបើក)។ ជើងជញ្ជាំងរោងភ្លើងក៏ពុក។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីដីឲ្យទាបជុំវិញ[57] ប្រហោងសម្រាប់បង្ហុយផ្សែង របស់រោងភ្លើង មិនទាន់មាននៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតប្រហោង សម្រាប់បង្ហុយផ្សែង។

[១៩៥] សម័យនោះឯង ពួកភិក្ខុធ្វើចង្ក្រានកណ្តាលរោងភ្លើងតូច។ ទីឱកាសសម្រាប់ចេញចូលមិនមាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើរោងភ្លើងតូច តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើចង្ក្រាន ក្នុងទីដ៏សមគួរមួយ កាលបើរោងភ្លើងធំ ឲ្យធ្វើចង្ក្រាន ក្នុងទីពាក់កណ្តាលចុះ។ ភ្លើងក្នុងរោងភ្លើង ក៏ជះចំហាយក្តៅមកត្រូវមុខ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកដីមកលាបមុខ។ ពួកភិក្ខុ ធ្វើដីឲ្យទទឹកដោយដៃ (របស់ខ្លួន)។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ស្នូកសម្រាប់ដាក់ដីស្អិត។ ដីស្អិតក៏ធុំក្លិនស្អុយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអប់ដោយគ្រឿងក្រអូប។

[១៩៦] សម័យនោះឯង ភ្លើងក្នុងរោងភ្លើងក៏ជះចំហាយក្តៅមកត្រូវកាយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យដងទឹកទុក។ ពួកភិក្ខុ ដងទឹកដោយចានខ្លះ ដោយបាត្រខ្លះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស៊ៀន និងផ្តិល។ រោងភ្លើង ដែលប្រក់ដោយស្មៅ ក៏គ្មានចំហាយញើស។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ហើយបូកលាបដីស្អិតទាំងខាងក្នុង ខាងក្រៅ។ រោងភ្លើង ក៏មានភក់ជ្រាំ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាល៣យ៉ាង គឺកម្រាលឥដ្ឋ១ កម្រាលថ្ម១ កម្រាលឈើ១។ រោងភ្លើង ក៏នៅតែមានភក់ជ្រាំដដែល។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាងចេញ។ ទឹកក៏ដក់នៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយទឹក។

[១៩៧] សម័យនោះឯង ពួកភិក្ខុអង្គុយផ្ទាល់លើផែនដី ក្នុងរោងភ្លើង យកដៃអេះខ្លួន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងសម្រាប់រោងភ្លើង។

[១៩៨] សម័យនោះឯង រោងភ្លើង មិនមានវត្ថុអ្វីបិទបាំងនៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបិទបាំងកំពែង៣យ៉ាង គឺកំពែងឥដ្ឋ១ កំពែងថ្ម១ កំពែងឈើ១។ បន្ទប់មិនទាន់មាននៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបន្ទប់។ បន្ទប់មានទីដីទាប។ ទឹកក៏ជោរជន់លិចមក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង។ ខឿនក៏របេះធ្លាក់ចេញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូនខឿន៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ភិក្ខុទាំងឡាយ ក៏នាំគ្នាឡើងទៅ បានដោយលំបាក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្ដើរ៣យ៉ាង គឺជណ្ដើរឥដ្ឋ១ ជណ្ដើរថ្ម១ ជណ្ដើរឈើ១។ ពួកភិក្ខុឡើងទៅ ក៏ធ្លាក់ចុះមក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ។ បន្ទប់មិនទាន់មានទ្វារ បង្អួចនៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ត្បាល់ ឬដំណាប់ក្រោមឈើ អន្ទាក់លើ (ដំណាប់លើ) សសរ របស់សន្ទះទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញ និងខ្សែសម្រាប់ទាញ (បិទបើក)។

[១៩៩] សម័យនោះឯង កំទេចស្មៅ ក៏ធ្លាក់ចុះមកក្នុងបន្ទប់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ហើយបូកលាប ទាំងខាងក្នុង ខាងក្រៅ ធ្វើឲ្យមានពណ៌ស ពណ៌ខ្មៅ និងលាបដោយរង់ ធ្វើភ្ញីផ្កា ភ្ញីវល្លិ ក្បាច់ធ្មេញមករ និងក្បាច់មានស្រទាប់៥។ ទីបរិវេណក៏មានភក់ជ្រាំ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកខ្សាច់ចាក់រោយរាយចុះ។ ដីខ្សាច់មិនរាបស្មើ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាលថ្ម។ ទឹកក៏ដក់នៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយសម្រាប់បង្ហូរទឹក។

[២០០] សម័យនោះឯង ពួកភិក្ខុអាក្រាត សំពះភិក្ខុអាក្រាត។ ពួកភិក្ខុអាក្រាត សំពះភិក្ខុមិនអាក្រាត។ ពួកភិក្ខុអាក្រាត ឲ្យគេសំពះភិក្ខុអាក្រាត។ ពួកភិក្ខុអាក្រាត ឲ្យគេសំពះភិក្ខុមិនអាក្រាត។ ពួកភិក្ខុអាក្រាត ធ្វើបរិកម្ម ដល់ភិក្ខុអាក្រាត។ ពួកភិក្ខុអាក្រាត ឲ្យគេធ្វើបរិកម្ម ដល់ភិក្ខុអាក្រាត។ ពួកភិក្ខុអាក្រាតឲ្យ (របស់) ដល់ភិក្ខុអាក្រាត។ ពួកភិក្ខុអាក្រាតទទួល (របស់)។ ពួកភិក្ខុអាក្រាតទំពាស៊ី។ ពួកភិក្ខុអាក្រាតបរិភោគ។ ពួកភិក្ខុអាក្រាតលិតភ្លក្ស។ ពួកភិក្ខុអាក្រាតផឹក។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រាត មិនត្រូវសំពះភិក្ខុអាក្រាត ភិក្ខុអាក្រាត មិនត្រូវសំពះ (គេ) ភិក្ខុអាក្រាត មិនត្រូវឲ្យគេសំពះភិក្ខុអាក្រាត ភិក្ខុអាក្រាត មិនត្រូវឲ្យគេសំពះខ្លួន ភិក្ខុអាក្រាត មិនត្រូវធ្វើបរិកម្ម ដល់ភិក្ខុអាក្រាត ភិក្ខុអាក្រាត មិនត្រូវឲ្យគេធ្វើបរិកម្មដល់ខ្លួន ភិក្ខុអាក្រាត មិនត្រូវឲ្យរបស់ ដល់ភិក្ខុអាក្រាត ភិក្ខុអាក្រាត មិនត្រូវទទួលរបស់ ភិក្ខុអាក្រាតមិនត្រូវទំពាស៊ី ភិក្ខុអាក្រាតមិនត្រូវបរិភោគ ភិក្ខុអាក្រាត មិនត្រូវលិតភ្លក្ស ភិក្ខុអាក្រាត មិនត្រូវផឹកទេ ភិក្ខុណាផឹក ត្រូវអាបត្តិទុក្កដ។

[២០១] សម័យនោះឯង ពួកភិក្ខុដាក់ចីវរលើផែនដី ក្នុងរោងភ្លើង។ ចីវរក៏ប្រឡាក់ទៅដោយអាចម៍ដី។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែស្នួរចីវរ និងខ្សែស្នៀងចីវរ ក្នុងរោងភ្លើង។ កាលដែលភ្លៀងបង្អោរចុះមក ចីវរក៏ទទឹក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាលាជិតរោងភ្លើង។ សាលាជិតរោងភ្លើង មានទីទាប។ ទឹកក៏ជោរជន់មកលិចចុះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង។ ខឿនក៏របេះធ្លាក់ចេញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកពូន។ បេ។ ពួកភិក្ខុ នាំគ្នាឡើងទៅ ក៏លំបាក។ បេ។ ពួកភិក្ខុឡើងទៅ ក៏ធ្លាក់ចុះមក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) បង្កាន់ដៃ។

[២០២] សម័យនោះឯង កំទេចស្មៅ ក៏ធ្លាក់ចុះមកក្នុងរោងភ្លើង។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ហើយបូកលាប ដោយដី ទាំងខាងក្នុង ខាងក្រៅ។ បេ។ (តថាគតអនុញ្ញាតឲ្យធ្វើ) ស្នៀងស្នួរចីវរ និងខ្សែស្នៀងចីវរ។

[២០៣] សម័យនោះឯង ពួកភិក្ខុមានសេចក្ដីរង្កៀស នឹងធ្វើបរិកម្មខ្នង (ដុសខ្នង) ក្នុងរោងភ្លើងខ្លះ ក្នុងទឹកខ្លះ។ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទីបិទបាំង៣យ៉ាង គឺទីបិទបាំងដោយរោងភ្លើង១ ទីបិទបាំងដោយទឹក១ ទីបិទបាំងដោយសំពត់១។

[២០៤] សម័យនោះឯង រោងភ្លើងមិនទាន់មានទឹកនៅឡើយ។ ភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើអណ្ដូងទឹក។ ច្រាំងអណ្ដូង ក៏បាក់ចុះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យក) ខឿន៣យ៉ាងគឺ ខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ អណ្ដូងទឹកមានទីទាប។ ទឹកក៏ជោរជន់លិច។ ពួកភិក្ខុក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីដី ឲ្យខ្ពស់ឡើង។ ខឿនក៏របេះធ្លាក់ចេញ។ បេ។ ពួកភិក្ខុនាំគ្នាឡើង ក៏លំបាក។ បេ។ ពួកភិក្ខុនាំគ្នាឡើងទៅ ក៏ធ្លាក់ចុះមក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) បង្កាន់ដៃ។

[២០៥] សម័យនោះឯង ពួកភិក្ខុយោងទឹកឡើងដោយវល្លិខ្លះ ដោយវត្ថពន្ធចង្កេះខ្លះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ខ្សែសម្រាប់យោងទឹកអណ្ដូង។ ដៃក៏ឈឺ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ឈើថ្លឹងយន្ត សម្រាប់យោង (ទឹក) ព្រ័ត្រវែង និងរ៉ត (សម្រាប់យោង)។ ភាជន៍ ក៏បែកបាក់ជាច្រើន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបំពង់៣យ៉ាង គឺបំពង់លោហជាតិ១ បំពង់ឈើ១ បំពង់ស្បែក១។

[២០៦] សម័យនោះឯង ពួកភិក្ខុយោងទឹកក្នុងទីវាល ក៏លំបាក ដោយរងាខ្លះ ដោយក្ដៅខ្លះ ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើរោងអណ្ដូងទឹក។ កំទេចស្មៅ ក៏ធ្លាក់ចុះ

ក្នុងរោងអណ្តូងទឹក។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យគាបដម្បូល ហើយបូកលាបដីស្អិត ទាំងខាងក្នុង ខាងក្រៅ ឲ្យមានពណ៌ស ឲ្យមានពណ៌ខ្មៅ លាបដោយរង់ ធ្វើភ្ញីផ្កា ភ្ញីវល្លិ ក្បាច់ធ្មេញមករ ធ្វើក្បាច់មានស្រទាប់៥ ស្បៀងស្នួរចីវរ ខ្សែស្បៀងចីវរ។

[២០៧] សម័យនោះឯង អណ្តូងទឹក មិនទាន់មានគំរបនៅឡើយ។ កំទេចស្មៅខ្លះ អាចម៍ដីខ្លះ ក៏រោយរាយចុះ (ក្នុងអណ្តូងនោះ)។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើគំរប។

[២០៨] សម័យនោះឯង ភាជន៍សម្រាប់ដងទឹកមិនទាន់មាននៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ស្នូកសម្រាប់ដាក់ទឹក និងផើងសម្រាប់ដាក់ទឹក។

[២០៩] សម័យនោះឯង ពួកភិក្ខុងូតទឹក ក្នុងទីពីសពាស ក្នុងអារាម។ អារាម ក៏មានភក់ជ្រាំ។ ភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអណ្តូងសម្រាប់ដាក់ទឹកជ្រាំ។ អណ្តូងសម្រាប់ដាក់ទឹកជ្រាំ តាំងនៅក្នុងទីវាល មិនទាន់បានបិទបាំងនៅឡើយ។ ពួកភិក្ខុក៏អៀនខ្មាស មិនហ៊ានងូតទឹក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបិទបាំង ដោយកំពែង៣យ៉ាង គឺកំពែងឥដ្ឋ១ កំពែងថ្ម១ កំពែងឈើ១។ អណ្តូងសម្រាប់ដាក់ទឹកជ្រាំក៏មានភក់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាល ៣យ៉ាងគឺ កម្រាលឥដ្ឋ១ កម្រាលថ្ម១ កម្រាលឈើ១។ ទឹកក៏ដក់នៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយទឹក។

[២១០] សម័យនោះឯង ពួកភិក្ខុមានខ្លួនត្រជាក់ (ដោយដំណក់ទឹក)។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើវត្ថុសម្រាប់ជូតទឹក (មានភួកជាដើម) ឬនឹងជូតដោយកំណាត់សំពត់ ក៏បាន។

[២១១] សម័យនោះឯង មានឧបាសកម្នាក់ មានចំណង់នឹងធ្វើស្រះ ជាប្រយោជន៍ដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើស្រះបាន។ (វេលានោះ) ភ្លឺស្រះ ក៏របេះចេញ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើខឿន៣យ៉ាងគឺ ខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ពួកភិក្ខុនាំគ្នាឡើង ក៏លំបាក។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ៣យ៉ាង គឺជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ ភិក្ខុទាំងនោះ នាំគ្នាឡើងទៅ ក៏ធ្លាក់ចុះមកវិញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃ។ (វេលានោះ) ក្នុងស្រះ មានទឹកចាស់ដក់នៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយទឹក និងទបង្ហូរទឹក។

[២១២] សម័យនោះឯង មានឧបាសកម្នាក់ មានចំណង់នឹងធ្វើរោងភ្លើង ជាទីរក្សាកាយ (ប្រកបដោយ) ជហ្វាដងក្តារ ដើម្បីជាប្រយោជន៍ដល់ភិក្ខុសង្ឃ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើរោងភ្លើង ជាទីរក្សាកាយ មានជហ្វាដងក្តារ។

[២១៣] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នៅប្រាសចាកនិសីទនៈ អស់៤ខែ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនៅប្រាសចាកនិសីទនៈ អស់៤ខែទេ ភិក្ខុណានៅប្រាស ត្រូវអាបត្តិទុក្កដ។

[២១៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ដេកលើដំណេក ដែលគេរោយរាយ ដោយផ្កា។ មនុស្សទាំងឡាយ ដើរមកកាន់វិហារចារិក ឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដេកលើដំណេក ដែលគេរោយរាយដោយផ្កាទេ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ។

[២១៥] សម័យនោះឯង មនុស្សទាំងឡាយ នាំយកគ្រឿងក្រអូបខ្លះ ផ្កាកម្រងខ្លះ មកកាន់អារាម។ ពួកភិក្ខុ មានសេចក្តីរង្កៀស មិនហ៊ានទទួល។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យទទួលគ្រឿងក្រអូប ហើយឲ្យប្រស់ព្រំដោយម្រាមដៃ ៥ ត្រង់ទ្វារ និងបង្អួច ព្រមទាំងទទួលយកផ្កា ទៅទុកក្នុងទីដ៏សមគួរ ក្នុងវិហារបាន។

[២១៦] សម័យនោះឯង កម្រាលស្មាច់ ដែលគេធ្វើដោយរោមចៀម កើតឡើងដល់សង្ឃ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកម្រាលស្មាច់ ដែលគេធ្វើដោយរោមចៀម។ ភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះថា កម្រាលស្មាច់ ដែលគេធ្វើដោយរោមចៀមនេះ យើងគួរអធិដ្ឋាន ឬគួរវិកប្ប។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបាច់អធិដ្ឋាន មិនបាច់វិកប្ប នូវកម្រាលស្មាច់ ដែលគេធ្វើដោយរោមចៀមទេ។

[២១៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ឆាន់ភោជនក្នុងភាជន៍ពិសេស[58] សម្រាប់រងចង្ហាន់។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ភោជន ក្នុងភាជន៍ពិសេស សម្រាប់រងចង្ហាន់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។

[២១៨] សម័យនោះឯង ភិក្ខុ១រូប មានជម្ងឺ។ កាលដែលភិក្ខុនោះឆាន់ មិនអាចនឹងទប់បាត្រដោយដៃបាន។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភាជន៍ សម្រាប់រង ដែលធ្វើដោយឈើ។

[២១៩] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់ (ភោជន) ក្នុងភាជន៍ជាមួយគ្នាខ្លះ។ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ។ ដេកលើគ្រែ ជាមួយគ្នាខ្លះ។ ដេកលើកម្រាលជាមួយគ្នាខ្លះ។ ដេកដណ្តប់ជាមួយគ្នាខ្លះ។ ដេកលើកម្រាល និងដណ្តប់ជាមួយគ្នាខ្លះ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ

ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ (ភោជន) រួមភាជន៍ជាមួយគ្នា មិនត្រូវផឹកទឹករួមផ្តិលជាមួយគ្នា មិនត្រូវដេកលើគ្រែជាមួយគ្នា មិនត្រូវដេកលើកម្រាលជាមួយគ្នា មិនត្រូវដេកដណ្តប់ជាមួយគ្នា មិនត្រូវដេកលើកម្រាល និងដណ្តប់ជាមួយគ្នាទេ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ។

[២២០] សម័យនោះឯង វឌ្ឍលិច្ឆវិ ជាសំឡាញ់ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ។ លំដាប់នោះ វឌ្ឍលិច្ឆវិ ចូលទៅរកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ លុះចូលទៅដល់ហើយ ក៏និយាយទៅនឹងមេត្តិយភិក្ខុ និងភុម្មជកភិក្ខុថា លោកម្ចាស់ ខ្ញុំព្រះករុណាថ្វាយបង្គំ។ កាលវឌ្ឍលិច្ឆវិ និយាយយ៉ាងនេះហើយ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ មិនបាននិយាយរាក់ទាក់មកវិញឡើយ។ វឌ្ឍលិច្ឆវិ ក៏និយាយទៅរកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ជាគំរប់ពីរដងទៀតថា លោកម្ចាស់ ខ្ញុំព្រះករុណាថ្វាយបង្គំ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ក៏មិនបាននិយាយរាក់ទាក់ ជាគំរប់ពីរដងទៀត។ វឌ្ឍលិច្ឆវិ និយាយទៅរកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ជាគំរប់បីដងទៀតថា លោកម្ចាស់ ខ្ញុំព្រះករុណា ថ្វាយបង្គំ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ក៏មិនបាននិយាយរាក់ទាក់ ជាគំរប់បីដងទៀត។ វឌ្ឍលិច្ឆវិ និយាយថា ខ្ញុំធ្វើខុសនឹងលោកម្ចាស់ដូចម្តេច ហេតុអ្វី ក៏បានជាលោកម្ចាស់ មិននិយាយរាក់ទាក់នឹងខ្ញុំ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុនិយាយថា នែអាវុសោវឌ្ឍៈ បានជាយើងមិននិយាយរាក់ទាក់ទៅរកអ្នក ព្រោះព្រះទព្វមល្លបុត្រ បៀតបៀនយើង អ្នកមិនអើពើសោះ។ វឌ្ឍលិច្ឆវិនិយាយថា លោកម្ចាស់ ខ្ញុំនឹងធ្វើដូចម្តេច។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុនិយាយថា នែអាវុសោវឌ្ឍៈ ប្រសិនបើអ្នកចង់ដែរ (ចូលដៃផង) ព្រះមានព្រះភាគ គប្បីឲ្យព្រះទព្វមល្លបុត្តមានអាយុវិនាស ក្នុងថ្ងៃនេះឯង។ វឌ្ឍលិច្ឆវិនិយាយថា លោកម្ចាស់ ខ្ញុំនឹងធ្វើដូចម្តេច ខ្ញុំនឹងអាចដើម្បីធ្វើដូចម្តេច។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ និយាយបង្គាប់ថា នែអាវុសោវឌ្ឍៈ អ្នកឯងចូរមក អ្នកចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ត្រូវក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទីនេះមិនកំបាំង មិនសមគួរ បពិត្រព្រះអង្គដ៏ចំរើន ទិសណា ដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះ ក៏ត្រឡប់ទៅជាមានភ័យ មានចង្រៃ មានឧបទ្រពវិញ ខ្យល់ចេញអំពីទិសណា ទិសនោះ ត្រឡប់ទៅជាមានខ្យល់ចូលវិញ ទឹក (ត្រជាក់) ត្រឡប់ទៅជាក្តៅវិញ ឥឡូវនេះ លោកម្ចាស់ទព្វមល្លបុត្ត បានប្រទូស្តនឹងប្រពន្ធខ្ញុំ។ វឌ្ឍលិច្ឆវិ ទទួលស្តាប់ពាក្យរបស់មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងនោះថា ករុណា លោកម្ចាស់ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះវឌ្ឍលិច្ឆវិ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទីនេះមិនកំបាំង មិនសមគួរ បពិត្រព្រះអង្គដ៏ចំរើន ទិសណា ដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះ ក៏ត្រឡប់ទៅជាមានភ័យ មានចង្រៃ មានឧបទ្រព ខ្យល់ចេញអំពីទិសណា ទិសនោះ ត្រឡប់ទៅជាមានខ្យល់ចូលវិញ ទឹក (ត្រជាក់) ត្រឡប់ទៅជាក្តៅវិញ ឥឡូវនេះ លោកម្ចាស់ទព្វមល្លបុត្ត ប្រទូស្តនឹងភរិយារបស់ខ្ញុំ។

[២២១] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរព្រះទព្វមល្លបុត្តមានអាយុថា ម្នាលទព្វៈ អ្នករលឹកមើល អ្នកបានធ្វើអំពើយ៉ាងនេះ ដូចជាវឌ្ឍៈនេះពោលមែនឬ។ ព្រះទព្វមល្លបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបខ្ញុំព្រះអង្គស្រាប់ហើយ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ទៅនឹងព្រះទព្វមល្លបុត្ត ដ៏មានអាយុ ជាគំរប់ពីរដងផង។ បេ។ ជាគំរប់បីដងផងថា ម្នាលទព្វៈ អ្នករលឹកមើល អ្នកបានធ្វើអំពើយ៉ាងនេះ ដូចជាវឌ្ឍៈនេះពោលមែនឬ។ ព្រះទព្វមល្លបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបខ្ញុំព្រះអង្គស្រាប់ហើយ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយ មិនពោលបណ្តោះបណ្តែយ៉ាងនេះទេ បើអំពើអ្វី ដែលអ្នកបានធ្វើហើយ អ្នកចូរឆ្លើយថា ធ្វើហើយ បើអំពើ ដែលអ្នកមិនបានធ្វើទេ អ្នកចូរឆ្លើយថា មិនបានធ្វើទេ។ ព្រះទព្វមល្លបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ តាំងអំពីកើតមក វេលាណា មិនដែលស្គាល់សេពមេថុនធម្មទេ សូម្បីតែយល់សប្តិ ក៏មិនដែលឃើញឡើយ បាច់និយាយទៅថ្វី ដល់ការភ្ញាក់រលឹក។

[២២២] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃត្រូវផ្កាប់បាត្រដល់វឌ្ឍលិច្ឆវិ គឺធ្វើមិនឲ្យសង្ឃសេពគប់រក។

[២២៣] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្កាប់បាត្រ ដល់ឧបាសកប្រកបដោយអង្គ៨ប្រការ គឺឧបាសកព្យាយាម ដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបានលាភ១ ព្យាយាម ដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបានប្រយោជន៍១ ព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានទីលំនៅ១ ជេរប្រទេចពួកភិក្ខុ១ បំបែកពួកភិក្ខុឲ្យបែកចាកពួកភិក្ខុ១ ពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផ្កាប់បាត្រ ដល់ឧបាសក ដែលប្រកបដោយអង្គ៨ប្រការនេះឯង។

[២២៤] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្កាប់បាត្រយ៉ាងនេះ។ ភិក្ខុដែលឈ្លាស ប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) វឌ្ឍលិច្ឆវិ (ឧបាសក) ចោទព្រះទព្វមល្លបុត្រមានអាយុ ដោយសីលវិបត្តិ មិនមានមូល បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃត្រូវផ្កាប់បាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើវឌ្ឍលិច្ឆវិ មិនឲ្យសង្ឃរាប់អាន។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វឌ្ឍលិច្ឆវិ ចោទព្រះទព្វមល្លបុត្រដ៏មានអាយុ ដោយសីលវិបត្តិ មិនមានមូល។ សង្ឃផ្កាប់បាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើវឌ្ឍលិច្ឆវិ មិនឲ្យសង្ឃរាប់អាន។ ការផ្កាប់បាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើវឌ្ឍលិច្ឆវិ មិនឲ្យសង្ឃរាប់អាន គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណាទេ លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានផ្កាប់បាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើវឌ្ឍលិច្ឆវិ មិនឲ្យសង្ឃរាប់អានហើយ ការផ្កាប់បាត្រនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២២៥] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ កាន់យកបាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ផ្ទះវឌ្ឍលិច្ឆវិ លុះចូលទៅដល់ហើយ ក៏ពោលនឹងវឌ្ឍលិច្ឆវិយ៉ាងនេះថា ម្នាលអាវុសោវឌ្ឍៈ សង្ឃបានផ្កាប់បាត្រ ដល់អ្នកហើយ ខ្លួនអ្នក សង្ឃលែងរាប់អានហើយ។ ឯវឌ្ឍលិច្ឆវិ ឮដំណឹងថា សង្ឃផ្កាប់បាត្រ ដល់អាត្មាអញហើយ អាត្មាអញ សង្ឃលែងរាប់អានហើយ ក៏ជ្រប់ដួល នៅក្នុងទីនោះឯង។ គ្រានោះ ពួកមិត្តអមាត្យ ញាតិសាលោហិត របស់វឌ្ឍលិច្ឆវិ ក៏បាននិយាយទៅនឹងវឌ្ឍលិច្ឆវិ យ៉ាងនេះថា ណ្ហើយ អាវុសោ វឌ្ឍៈ អ្នកកុំសោយសោក កុំខ្សឹកខ្សួលឡើយ យើងនឹងធ្វើព្រះមានព្រះភាគ និងព្រះសង្ឃ ឲ្យជ្រះថ្លាឡើងវិញ។ លំដាប់នោះ វឌ្ឍលិច្ឆវិ ព្រមទាំងបុត្រ ភរិយា មិត្តអមាត្យ និងញាតិសាលោហិត មានសំពត់ទទឹក មានសក់ទទឹក នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ឱនសិរ្សៈ ទៀបព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ហើយពោលនឹងព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សេចក្តីឆ្គាំឆ្គង មានដល់ខ្ញុំព្រះអង្គហើយ តាមដោយខ្ញុំព្រះអង្គ ជា

មនុស្សល្ងង់ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ព្រោះថាខ្ញុំព្រះអង្គ បានចោទលោកម្ចាស់ទព្វមល្លបុត្រ ដោយសីលវិបត្តិ មិនមានមូលហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ អត់សេចក្តីឆ្គាំឆ្គង តាមដោយសេចក្តីឆ្គាំឆ្គងរបស់ខ្ញុំព្រះអង្គ ដើម្បីនឹងសម្រួមតទៅ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអាវុសោវឌ្ឍៈ អើ សេចក្តីឆ្គាំឆ្គង មានដល់អ្នកហើយ តាមដោយអ្នក ជាមនុស្សល្ងង់ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ព្រោះថាអ្នកបានចោទទព្វមល្លបុត្រ ដោយសីលវិបត្តិ មិនមានមូលហើយ ម្នាលអាវុសោវឌ្ឍៈ (ឥឡូវនេះ) អ្នកឃើញសេចក្តីឆ្គាំឆ្គង តាមដោយសេចក្តីឆ្គាំឆ្គង ហើយសំដែងទោស សមគួរតាមដំណើរទោស យើងក៏អត់ទោសនោះដល់អ្នក ម្នាលអាវុសោ វឌ្ឍៈ អ្នកណា បានឃើញសេចក្តីឆ្គាំឆ្គង តាមដោយសេចក្តីឆ្គាំឆ្គង ហើយសំដែងទោស សមគួរតាមដំណើរទោស ដល់នូវសេចក្តីសង្រួមតទៅ នេះជាសេចក្តីចំរើន របស់អ្នកនោះ ក្នុងអរិយវិន័យ។

[២២៦] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរផ្ងារបាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើវឌ្ឍលិច្ឆវិ ឲ្យសង្ឃរាប់អានវិញ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្ងារបាត្រ ដល់ឧបាសក ដែលប្រកបដោយអង្គ៨ប្រការ គឺឧបាសកមិនព្យាយាមដើម្បីនឹងឲ្យសាបសូន្យលាភ របស់ភិក្ខុទាំងឡាយ១ មិនព្យាយាម ដើម្បីឲ្យខូចប្រយោជន៍ របស់ភិក្ខុទាំងឡាយ១ មិនព្យាយាម ដើម្បីឲ្យភិក្ខុទាំងឡាយខានបានទីលំនៅ១ មិនជេរប្រទេចភិក្ខុទាំងឡាយ១ មិនញុះញង់ភិក្ខុទាំងឡាយ ឲ្យបែកចាកភិក្ខុទាំងឡាយ១ មិនពោលតិះដៀលព្រះពុទ្ធ១ មិនពោលតិះដៀលព្រះធម៌១ មិនពោលតិះដៀលព្រះសង្ឃ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្ងារបាត្រ ដល់ឧបាសកដែលប្រកបដោយអង្គទាំង៨នេះ។

[២២៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវផ្ងារបាត្រយ៉ាងនេះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវវឌ្ឍលិច្ឆវិនោះ ចូលទៅរកសង្ឃ ធ្វើសំពត់បង់ក ឆៀងស្មាម្ខាង សំពះបាទាភិក្ខុទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង និយាយយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន សង្ឃបានផ្កាប់បាត្រ ដល់ខ្ញុំហើយ សង្ឃលែងរាប់អានខ្ញុំហើយ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំបានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកទោស ខ្ញុំមកសូមឲ្យព្រះសង្ឃ ផ្ងារបាត្រឡើងវិញ។ វឌ្ឍលិច្ឆវិនោះ ត្រូវសូមជាគំរប់ពីរដងផង ជាគំរប់បីដងផង។

[២២៨] ភិក្ខុដែលឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃបានផ្កាប់បាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើមិនឲ្យសង្ឃរាប់អាន។ វឌ្ឍលិច្ឆវិនោះ បានប្រព្រឹត្តវត្ត ដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួនចេញចាកទោស មកសូមឲ្យសង្ឃផ្ងារបាត្រឡើងវិញ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីផ្ងារបាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើឲ្យសង្ឃរាប់រកឡើងវិញ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃបានផ្កាប់បាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើមិនឲ្យសង្ឃរាប់រក។ (ឥឡូវនេះ) វឌ្ឍលិច្ឆវិនោះ បានប្រព្រឹត្តវត្តដោយប្រពៃ ទាំងសម្លបរោម ប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួនចេញចាកទោស មកសូមឲ្យសង្ឃផ្ងារបាត្រឡើងវិញ។ សង្ឃក៏ផ្ងារបាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើឲ្យសង្ឃរាប់អានឡើងវិញ។ ការផ្ងារបាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើឲ្យសង្ឃរាប់អានឡើងវិញ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវនិយាយឡើង។ សង្ឃបានផ្ងារបាត្រ ដល់វឌ្ឍលិច្ឆវិ គឺធ្វើឲ្យសង្ឃរាប់រកវិញហើយ ការផ្ងារបាត្រនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២២៩] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងវេសាលី គួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងភគ្គជនបទ យាងទៅតាមលំដាប់ ក៏បានទៅដល់ភគ្គជនបទនោះ។ ឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវ័ន[59] ជាទីឲ្យអភ័យ ដល់សត្វម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទនោះ។

[២៣០] សម័យនោះឯង ពោធិរាជកុមារ ចាត់ការកសាងប្រាសាទ ឈ្មោះកោកនុទ[60] ទើបតែនឹងហើយថ្មីៗ ដែលសមណៈ និងព្រាហ្មណ៍ ឬបុគ្គលណានីមួយ ជាតិជាមនុស្ស មិនដែលធ្លាប់បាននៅអាស្រ័យ។ លំដាប់នោះ ពោធិរាជកុមារ ទ្រង់ហៅសញ្ជិកាបុត្តមាណពមកប្រាប់ថា នែសញ្ជិកាបុត្តសំឡាញ់ អ្នកចូរមក អ្នកចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំបាទាព្រះមានព្រះភាគដោយត្បូង ទូលសួរអាពាធតិចតួច សេចក្តីលំបាកតិចតួច សេចក្តីព្យាយាមស្រួល កម្លាំងកាយ និងធម៌ជាគ្រឿងនៅសប្បាយ តាមពាក្យអញថា បពិត្រព្រះអង្គដ៏ចំរើន ពោធិរាជកុមារ សូមថ្វាយបង្គំព្រះបាទាព្រះអង្គ ដោយត្បូង ទូលសួរអាពាធតិចតួច សេចក្តីលំបាកតិចតួច សេចក្តីព្យាយាមស្រួល កម្លាំងកាយ និងធម៌ ជាគ្រឿងនៅសប្បាយ ហើយទូលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ សញ្ជិកាបុត្តមាណព ទទួលព្រះបន្ទូលពោធិរាជកុមារថា ព្រះករុណាវិសេស ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលរាក់ទាក់ សំណេះសំណាល ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួរជាទីរីករាយ និងពាក្យដែលគួររឭកហើយ អង្គុយក្នុងទីដ៏សមគួរ។ លុះសញ្ជិកាបុត្តមាណព អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យយ៉ាងនេះថា ពោធិរាជកុមារ សូមថ្វាយបង្គំព្រះបាទាព្រះគោតមជាម្ចាស់ ដោយត្បូង ទូលសួរអាពាធតិចតួច សេចក្តីលំបាកតិចតួច សេចក្តីព្យាយាមស្រួល កម្លាំងកាយ និងធម៌ ជាគ្រឿងនៅសប្បាយ មួយទៀត ពោធិរាជកុមារ ឲ្យក្រាបទូលព្រះអង្គ យ៉ាងនេះថា សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព។ គ្រានោះ សញ្ជិកាបុត្តមាណព ដឹងថា ព្រះមានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ចូលទៅរកពោធិរាជកុមារ លុះចូលទៅដល់ហើយ ក៏ក្រាបទូលពោធិរាជកុមារយ៉ាងនេះថា ខ្ញុំព្រះអង្គ បានក្រាបបង្គំទូលព្រះគោតមមានព្រះភាគ តាមបន្ទូលរបស់ទ្រង់ហើយថា ពោធិរាជកុមារ សូមថ្វាយបង្គំព្រះបាទាព្រះគោតមដ៏ចំរើន ដោយត្បូង ទូលសួរអាពាធតិចតួច សេចក្តីលំបាកតិចតួច សេចក្តីព្យាយាមស្រួល កម្លាំងកាយ និងធម៌ ជាគ្រឿងនៅសប្បាយ មួយទៀត ពោធិរាជកុមារ ឲ្យក្រាបទូលព្រះអង្គយ៉ាងនេះថា សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្ត របស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ព្រះសមណគោតមជាម្ចាស់ បានទទួលនិមន្តហើយ។

[២៣១] លុះព្រឹកឡើង ពោធិរាជកុមារ ក៏ចាត់ចែងខាទនីយភោជនីយាហារដ៏ឧត្តម ហើយឲ្យក្រាលកោកនុទប្រាសាទ ដោយសំពត់សទាំងឡាយ ដរាបដល់កាំជណ្តើរជាន់ខាងក្រោមបំផុត ហើយត្រាស់ហៅសញ្ជិកាបុត្តមាណពមកថា ម្នាលសញ្ជិកាបុត្ត សំឡាញ់ អ្នកចូរមក អ្នកចូរទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ

ភត្តក៏សម្រេចហើយ។ សញ្ជិកាបុត្តមាណព ទទួលព្រះបន្ទូល របស់ពោធិរាជកុមារថា ព្រះករុណាវិសេស ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តក៏សម្រេចហើយ។

[២៣២] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្លៀកស្បង់ ទ្រង់បាត្រ ចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរទៅកាន់និវេសនស្ថាន របស់ពោធិរាជកុមារ។ សម័យនោះឯង ពោធិរាជកុមារ ឈរនៅខាងក្រៅខ្លោងទ្វារ រង់ចាំព្រះមានព្រះភាគ។ ពោធិរាជកុមារ បានឃើញព្រះមានព្រះភាគ ទ្រង់ស្តេចយាងមកអំពីចំងាយលិមៗ លុះឃើញហើយ ក៏ក្រោកទៅទទួលក្នុងទីនោះ ហើយក្រាបថ្វាយបង្គំព្រះមានព្រះភាគ និមន្តព្រះអង្គ ឲ្យស្តេចយាងទៅខាងមុខ ហើយចូលទៅកាន់កោកនុទប្រាសាទ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ឈប់អាស្រ័យនៅកាំជណ្តើរជាន់ខាងក្រោមបំផុត។ លំដាប់នោះ ពោធិរាជកុមារ ក្រាបថ្វាយបង្គំ ទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់ជាន់សំពត់ទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះសុគត ទ្រង់ជាន់សំពត់ទាំងឡាយ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង។ កាលពោធិរាជកុមារ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះអង្គទ្រង់នៅស្ងៀម។ ពោធិរាជកុមារ ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគំរប់ពីរដងផង។ បេ។ ជាគំរប់បីដងផងថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់ជាន់សំពត់ទាំងឡាយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះសុគត ទ្រង់ស្តេចយាងជាន់សំពត់ទាំងឡាយ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់បែរព្រះភក្ត្រ ទៅរកព្រះអានន្ទមានអាយុ។ ព្រះអានន្ទមានអាយុ ក៏មានថេរវាចាទៅនឹងពោធិរាជកុមារ យ៉ាងនេះថា បពិត្ររាជកុមារ សូមទ្រង់សារសំពត់ចេញ ព្រះមានព្រះភាគ ព្រះអង្គ មិនទ្រង់ជាន់កម្រាលសំពត់ទេ ព្រះតថាគត ទ្រង់អនុគ្រោះដល់ប្រជុំជនជាខាងក្រោយ។ គ្រានោះ ពោធិរាជកុមារ ទ្រង់ឲ្យសារសំពត់ទាំងឡាយចេញ ហើយទ្រង់ឲ្យក្រាលអាសនៈខាងលើកោកនុទប្រាសាទវិញ។ ព្រះមានព្រះភាគ ស្តេចយាងឡើងកាន់កោកនុទប្រាសាទ ហើយគង់លើអាសនៈ ដែលគេក្រាលស្រេចហើយ ព្រមទាំងភិក្ខុសង្ឃ។ លំដាប់នោះ ពោធិរាជកុមារ បានអង្គាសខាទនីយភោជនីយាហារ (បង្អែមចំអាប) ដ៏ឆ្ងាញ់ពីសារ ថ្វាយដោយព្រះហស្តព្រះអង្គឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់ទ្រង់ហាមឃាត់ លុះកំណត់ជ្រាបថា ព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្ត ទៅក្នុងបាត្រហើយ ក៏គង់ក្នុងទីសមគួរ។ លុះពោធិរាជកុមារ គង់ក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ ស្តេចចេញទៅ។

[២៣៣] ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវជាន់កម្រាលសំពត់ទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ។

[២៣៤] សម័យនោះឯង មានស្រីម្នាក់ សម្រាលកូនរួចហើយ និមន្តភិក្ខុទាំងឡាយ ហើយក្រាលសំពត់ និយាយយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចំរើន សូមលោកទាំងឡាយ ជាន់សំពត់ចុះ។ ភិក្ខុទាំងឡាយ មានសេចក្តីរង្កៀស មិនហ៊ានជាន់។ ស្រីនោះនិយាយថា បពិត្រលោកទាំងឡាយដ៏ចំរើន សូមលោកទាំងឡាយ ជាន់សំពត់ ដើម្បីប្រយោជន៍ជាមង្គល។ ភិក្ខុទាំងឡាយ ក៏នៅតែរង្កៀស មិនហ៊ានជាន់សំពត់ (ទៀត)។ លំដាប់នោះ ស្រីនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ កាលបើគេអង្វរ ដើម្បីប្រយោជន៍ជាមង្គល មិនសមបើនឹងមិនហ៊ានជាន់កម្រាលសំពត់សោះ។ ភិក្ខុទាំងឡាយ បានឮស្រីនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ ភិក្ខុអម្បាលនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) គ្រហស្ថត្រូវការមង្គល ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ដែលគ្រហស្ថអង្វរ ដើម្បីប្រយោជន៍ជាមង្គល ជាន់កម្រាលសំពត់បាន។

[២៣៥] សម័យនោះឯង ភិក្ខុទាំងឡាយរង្កៀសនឹងជាន់កម្រាលសម្រាប់ភិក្ខុ ដែលមានជើងស្អាតបាត។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាន់លើកម្រាល សម្រាប់ភិក្ខុ ដែលមានជើងស្អាតបាត។

ចប់ ភាណវារៈ ជាគំរប់ពីរ។

[២៣៦] គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភគ្គជនបទ គួរដល់ពុទ្ធអធ្យាស្រ័យ ហើយយាងទៅកាន់ចារិក ក្នុងក្រុងសាវត្ថី ទ្រង់ពុទ្ធដំណើរ ទៅកាន់ចារិក ដោយលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ។ ឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ។ លំដាប់នោះ នាងវិសាខាមិគារមាតា នាំយកក្អម និងទ្រនាប់សម្រាប់ជូតជើង មានរចនាដូចពកផ្លែឈូក[61] និងអម្បោស ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទទួលក្អមទ្រនាប់ជូតជើង និងអម្បោស ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំម្ចាស់ អស់កាលជាអង្វែងទៅ។ ព្រះមានព្រះភាគ ទ្រង់ទទួលតែក្អម និងអម្បោស។ ព្រះអង្គ មិនទ្រង់ទទួលទ្រនាប់ជូតជើងឡើយ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់នាងវិសាខាមិគារមាតា ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ លំដាប់នោះ នាងវិសាខាមិគារមាតា កាលដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។

[២៣៧] ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្អម និងអម្បោស ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់សម្រាប់ជូតជើង មានរចនាដូចពកផ្លែឈូក[62] ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់សម្រាប់ជូតជើង៣យ៉ាង គឺគ្រួស ឬដុំថ្ម១ អង្ក្លែងក្បឿង ឬឥដ្ឋ១ ផ្សិត ដែលកើតពីពពុះទឹកសមុទ្រ១។

[២៣៨] គ្រាខាងក្រោយ នាងវិសាខាមិគារមាតា នាំយកផ្តិត៤ជ្រុង និងផ្តិតមូល[63] ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទទួលផ្តិត៤ជ្រុង និងផ្តិតមូល (ស្លឹកត្នោត) ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំម្ចាស់ អស់កាលជាអង្វែង។ ព្រះមានព្រះភាគ ទ្រង់ទទួលយកផ្តិត៤ជ្រុង ផ្តិតមូល (ស្លឹកត្នោត) រួចហើយ។ ទើបព្រះមានព្រះភាគ ទ្រង់ពន្យល់នាងវិសាខាមិគារមាតា ឲ្យយល់ (ប្រយោជន៍) ដោយធម្មីកថា។ បេ។ ធ្វើប្រទក្សិណ រួចចៀសចេញទៅ។

[២៣៩] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្តិត៤ជ្រុង និងផ្តិតមូល (ស្លឹកត្នោត)។

[២៤០] សម័យនោះឯង ផ្តិតសម្រាប់បក់មូស កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្តិតសម្រាប់បក់មូស។ (សម័យខាងក្រោយមក) ផ្តិតដែលគេធ្វើដោយរោមចាមរី កើតឡើង (ដល់សង្ឃ)។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ផ្តិត ដែលគេធ្វើដោយរោមចាមរីទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្តិត៣យ៉ាង គឺ ផ្តិតដែលគេធ្វើដោយសម្បកឈើ១ ផ្តិតដែលគេក្រងដោយស្បូវភ្លាំង១ ផ្តិតដែលគេធ្វើដោយរោមកន្ទុយក្ងោក១។

[២៤១] សម័យនោះឯង មានឆត្រកើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆត្រ។

[២៤២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបាំងឆត្រដើរទៅ។ សម័យនោះឯង មានឧបាសកម្នាក់ដើរទៅកាន់ឱទ្យាន ជាមួយនឹងពួកសាវ័ករបស់អាជីវកជាច្រើននាក់។ សាវ័ករបស់អាជីវកទាំងឡាយនោះ បានឃើញពួកឆព្វគ្គិយភិក្ខុបាំងឆត្រ ដើរមកអំពីចម្ងាយលឹមៗ លុះឃើញហើយ ក៏និយាយនឹងឧបាសកនោះយ៉ាងនេះថា លោកទាំងអម្បាលនេះ ជាជីតុនរបស់អ្នក លោកបាំងឆត្រដើរមក ដូចជាពួកមហាមាត្យត្រួតពល។ ឧបាសកនោះក៏តបថា លោកទាំងអម្បាលនេះ មិនមែនជាភិក្ខុទេ គឺជាបរិព្វាជក។ ពួកសាវ័កអាជីវក និងឧបាសក ក៏ភ្នាល់គ្នាដោយពាក្យថា ភិក្ខុ (ឬ) មិនមែនជាភិក្ខុ។ ទើបឧបាសកនោះ ដើរចូលទៅជិត មើលស្គាល់ច្បាស់ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីក៏លោកម្ចាស់ដ៏ចំរើនបាំងឆត្រដើរ។ ភិក្ខុទាំងឡាយ បានឮឧបាសកនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (អំពើនោះ) ពិតមែនឬ។ បេ។ ភិក្ខុទាំងអម្បាលនោះ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ បេ។ ព្រះអង្គ ទ្រង់បន្ទោស រួចហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឆត្រទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[២៤៣] សម័យនោះឯង ភិក្ខុ១រូបទៀតមានជម្ងឺ។ ភិក្ខុនោះ បើខានបាំងឆត្រ មិនបានសេចក្តីសប្បាយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆត្រ ដល់ភិក្ខុមានជម្ងឺ។

[២៤៤] សម័យនោះឯង ភិក្ខុទាំងឡាយដឹងថា ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឆត្រ ដល់ភិក្ខុមានជម្ងឺតែម្យ៉ាង មិនបានទ្រង់អនុញ្ញាត ដល់ភិក្ខុគ្មានជម្ងឺទេ ហើយរង្កៀសនឹងការបាំងឆត្រក្នុងអារាម និងឧបចាររបស់អារាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមិនមានជម្ងឺបាំងឆត្រក្នុងអារាម និងឧបចារនៃអារាមបាន។

[២៤៥] សម័យនោះឯង ភិក្ខុ១រូបច្រកបាត្រក្នុងសង្រែក ហើយពាក់លើឈើច្រត់ ដើរទៅតាមទ្វារស្រុកមួយ ក្នុងវេលាវិកាល។ មនុស្សទាំងឡាយនាំគ្នានិយាយថា បពិត្រអ្នកម្ចាស់ទាំងឡាយ បុរសនេះជាចោរដើរទៅ ដាវរបស់វា (មានមុខ) ភ្លឺស្វាច ហើយក៏ដេញតាមចាប់ លុះចាប់បានហើយ ស្គាល់ថា (ជាភិក្ខុ) ក៏លែងទៅវិញ។ ទើបភិក្ខុនោះទៅកាន់អារាម ប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុផងគ្នា។ ភិក្ខុទាំងអម្បាលនោះ សួរថា ម្នាលអាវុសោ អ្នកទ្រទ្រង់ឈើច្រត់ទាំងសង្រែក ឬអ្វី។ ភិក្ខុនោះប្រាប់ថា អើអាវុសោ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមបើនឹងទ្រទ្រង់ឈើច្រត់ ទាំងសង្រែកសោះ។ ទើបភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់បន្ទោស ហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឈើច្រត់ទាំងសង្រែកទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[២៤៦] សម័យនោះឯង ភិក្ខុ១រូបមានជម្ងឺ តែវៀរលែងឈើច្រត់ចេញហើយ មិនអាចនឹងដើរទៅមកបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃ ឲ្យទណ្ឌសម្មតិ ដល់ភិក្ខុមានជម្ងឺ។

[២៤៧] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ភិក្ខុមានជម្ងឺនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទារបស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី ពោលពាក្យយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំមានជម្ងឺ បើវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមកបាន បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំសូមទណ្ឌសម្មតិនឹងសង្ឃ។ ភិក្ខុនោះគប្បីសូមជាគំរប់ពីរដងផង គប្បីសូមជាគំរប់បីដងផង។

[២៤៨] ភិក្ខុដែលឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ នេះមានជម្ងឺ តែវៀរលែងឈើច្រត់ចេញហើយ ក៏មិនអាចនឹងដើរទៅមកបាន ភិក្ខុនោះមកសូមទណ្ឌសម្មតិនឹងសង្ឃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យទណ្ឌសម្មតិ ដល់ភិក្ខុឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះ មានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមកបាន ភិក្ខុនោះ មកសូមទណ្ឌសម្មតិនឹងសង្ឃ។ សង្ឃឲ្យទណ្ឌសម្មតិ ដល់ភិក្ខុឈ្មោះនេះ។ ការឲ្យទណ្ឌសម្មតិ ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ

ត្រូវពោលឡើង។ សង្ឃបានឲ្យទណ្ឌសម្មតិ ដល់ភិក្ខុឈ្មោះនេះហើយ ការឲ្យនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៤៩] សម័យនោះឯង ភិក្ខុ១រូប មានជម្ងឺ តែវៀរលែងសង្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រទៅបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសង្ឃឲ្យសិក្កាសម្មតិ ដល់ភិក្ខុមានជម្ងឺ។

[២៥០] ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ភិក្ខុដែលមានជម្ងឺ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទារបស់ភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី ពោលពាក្យយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំមានជម្ងឺ បើវៀរលែងសង្រែកចេញ ក៏មិនអាចនាំយកបាត្រទៅបាន បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវនេះ) ខ្ញុំមកសូមសិក្កាសម្មតិនឹងសង្ឃ។ ភិក្ខុនោះ គប្បីសូមជាគំរប់ពីរដងផង គប្បីសូមជាគំរប់បីដងផង។

[២៥១] ភិក្ខុដែលឈ្លាស ប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះ មានជម្ងឺ តែវៀរលែងសង្រែកចេញហើយ ក៏មិនអាចនាំយកបាត្រទៅបាន (ឥឡូវនេះ) ភិក្ខុនោះមកសូមសិក្កាសម្មតិនឹងសង្ឃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះ មានជម្ងឺ តែវៀរលែងសង្រែកចេញ ក៏មិនអាចនាំយកបាត្រទៅបាន (ឥឡូវនេះ) ភិក្ខុនោះ មកសូមសិក្កាសម្មតិនឹងសង្ឃ។ សង្ឃក៏ឲ្យសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះ។ ការឲ្យសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវពោលឡើង។ សង្ឃឲ្យសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះហើយ ការឲ្យនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៥២] សម័យនោះឯង ភិក្ខុ១រូប មានជម្ងឺ តែវៀរលែងឈើច្រត់ ចេញ ក៏មិនអាចនឹងដើរទៅមក បើវៀរលែងសង្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រទៅបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសង្ឃឲ្យទណ្ឌសិក្កាសម្មតិ ដល់ភិក្ខុមានជម្ងឺ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ ភិក្ខុដែលមានជម្ងឺនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលី ពោលពាក្យយ៉ាងនេះថា បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំមានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមក តែវៀរលែងសង្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រទៅបាន បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំមកសូមទណ្ឌសិក្កាសម្មតិនឹងសង្ឃ។ ភិក្ខុនោះ គប្បីសូម ជាគំរប់ពីរដងផង គប្បីសូម ជាគំរប់បីដងផង។

[២៥៣] ភិក្ខុដែលឈ្លាស ប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះ មានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមក វៀរលែងតែសង្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រទៅបាន (ឥឡូវនេះ) ភិក្ខុនោះ សូមទណ្ឌសិក្កាសម្មតិនឹងសង្ឃ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យទណ្ឌសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះនេះ មានជម្ងឺ តែវៀរលែងឈើច្រត់ចេញ ក៏មិនអាចនឹងដើរទៅមក វៀរលែងសង្រែកចេញ ក៏មិនអាចនឹងនាំយកបាត្រទៅបាន (ឥឡូវនេះ) ភិក្ខុនោះ មកសូមទណ្ឌសិក្កាសម្មតិនឹងសង្ឃ។ សង្ឃឲ្យទណ្ឌសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះ។ ការឲ្យទណ្ឌសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវពោលឡើង។ សង្ឃបានឲ្យទណ្ឌសិក្កាសម្មតិ ដល់ភិក្ខុឈ្មោះនេះហើយ ការឲ្យនោះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៥៤] សម័យនោះឯង ភិក្ខុ១រូបទំពាអៀងជាប្រក្រតី។ ភិក្ខុនោះទំពាអៀងៗ ហើយលេបចូលទៅ។ ភិក្ខុទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនេះឆាន់ភោជន ក្នុងវេលាវិកាល។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះទើបតែច្យុតមកអំពីកំណើតនៃគោ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទំពាអៀង ដល់ភិក្ខុអ្នកទំពាអៀង ជាប្រក្រតី ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំខ្ជាក់អាហារចេញមកខាងក្រៅទ្វារមាត់ ហើយលេបចូលទៅវិញ បើភិក្ខុណា លេបចូលទៅវិញ វិនយធរគប្បីឲ្យភិក្ខុនោះធ្វើតាមធម៌ (សំដែងអាបត្តិចេញ)។

[២៥៥] សម័យនោះឯង មានសង្ឃភត្តរបស់ប្រជុំជន១ពួក។ គ្រាប់បាយដ៏ច្រើន ក៏ជ្រុសរោយរាយ ក្នុងរោងភត្ត។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្តិយ៍ កាលបើគេកំពុងប្រគេនបាយ មិនសមបើ មិនទទួលដោយសេចក្តីគោរពសោះ ធម្មតាគ្រាប់បាយមួយគ្រាប់ៗ រមែងញុំាងការងារច្រើន ឲ្យសម្រេចបាន។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ)។ ទើបភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រាប់បាយណា ដែលគេកំពុងឲ្យ ហើយធ្លាក់ចុះ តថាគតអនុញ្ញាតឲ្យភិក្ខុរើសគ្រាប់បាយនោះខ្លួនឯង ហើយឆាន់ចុះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា គ្រាប់បាយនោះ ទាយកគេលះ គឺប្រគេនរួចស្រេចហើយ។

[២៥៦] សម័យនោះឯង ភិក្ខុ១រូបមានក្រចកវែង ដើរទៅបិណ្ឌបាត។ ស្រីម្នាក់ឃើញហើយ និយាយនឹងភិក្ខុនោះដូច្នេះថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់និមន្តមកសេពមេថុនធម្ម (នឹងខ្ញុំចុះ)។ ភិក្ខុនោះឃាត់ថា នែប្អូនស្រី កុំឡើយ ការនុ៎ះ មិនគួរទេ។ ស្រីនោះ និយាយទៀតថា បពិត្រលោកដ៏ចំរើន បើលោកម្ចាស់មិនសេពទេ ខ្ញុំនឹងខ្វារក្រចៅខ្លួន ដោយក្រចករបស់ខ្លួន ហើយនឹងស្រែកឥឡូវនេះថា ភិក្ខុនេះ ធ្វើវិប្បការនឹងខ្ញុំ។ ភិក្ខុនោះ ក៏បណ្តោយថា ប្អូនស្រី នាងឯងចូរដឹងចុះ។ ទើបស្រីនោះ ខ្វារក្រចៅរាងកាយ ដោយក្រចករបស់ខ្លួន ហើយស្រែកថា ភិក្ខុនេះធ្វើវិប្បការនឹងខ្ញុំ។ មនុស្សទាំងឡាយ ក៏ស្ទុះទៅចាប់ភិក្ខុនោះ។ មនុស្សទាំងអម្បាលនោះ បានឃើញស្បែក និងឈាមក្នុងក្រចកស្រីនោះ លុះឃើញហើយ ក៏ជឿជាក់ថា ភិក្ខុនេះ មិនបានធ្វើកម្មនេះ ដល់ស្រីនេះទេ ហើយក៏លែងភិក្ខុនោះទៅ។ ទើបភិក្ខុនោះ ទៅកាន់អារាមប្រាប់ដំណើរនុ៎ះ ដល់ភិក្ខុផងគ្នា។

ភិក្ខុទាំងឡាយសួរថា ម្នាលលោកមានអាយុ ចុះលោកទុកក្រចកវែងឬ។ ភិក្ខុនោះប្រាប់ថា អើអាវុសោ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។ បេ។ ពួកភិក្ខុនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមបើនឹងទុកក្រចកវែងសោះ។ លំដាប់នោះ ភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកក្រចកវែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ។

[២៥៧] សម័យនោះឯង ភិក្ខុទាំងឡាយ កាត់ក្រចកដោយក្រចកខ្លះ។ កាត់ក្រចកដោយមាត់ខ្លះ។ ត្រដុសក្រចកនឹងជញ្ជាំងខ្លះ។ ម្រាមដៃទាំងឡាយ ក៏ឈឺចាប់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកាំបិតកាត់ក្រចក។ ភិក្ខុទាំងនោះ កាត់ក្រចកត្រាតែដល់ឈាម។ ម្រាមដៃទាំងឡាយ ក៏ឈឺចាប់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុកាត់ក្រចកត្រឹមនឹងសាច់។

[២៥៨] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ឲ្យគេខាត់ក្រចកទាំង២០។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេខាត់ក្រចកទាំង២០ទេ ភិក្ខុណាឲ្យគេខាត់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុគ្រាន់តែជម្រះក្អែលប៉ុណ្ណោះ។

[២៥៩] សម័យនោះឯង ភិក្ខុទាំងឡាយមានសក់វែង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ អាចនឹងកោរសក់គ្នាទៅវិញទៅមកបានឬទេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ អាចនឹងកោរបាន។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ឲ្យប្រជុំភិក្ខុសង្ឃ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាំបិតកោរ ថ្មសំលៀងកាំបិតកោរ ស្រោមកាំបិតកោរ គ្រឿងស្ទាច់ដែលគេធ្វើដោយរោមចៀម និងគ្រឿងប្រដាប់កាំបិតកោរទាំងពួង។

[២៦០] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ឲ្យគេកាត់ពុកមាត់ (ដោយកន្ត្រៃខ្លះ)។ ទុកពុកមាត់ (ឲ្យវែង)ខ្លះ។ ឲ្យគេធ្វើពុកចង្កាឲ្យវែង ដូចជាពុកចង្កាពពែខ្លះ។ ឲ្យគេធ្វើពុកមាត់ជា៤ជ្រុងខ្លះ។ ប្រមូលជួររោមត្រង់ទ្រូងខ្លះ។ ទុកជួររោមត្រង់ពោះខ្លះ។ ទុកពុកមាត់ឲ្យដូចជាចង្កូមខ្លះ។ ឲ្យគេដករោមក្នុងទីចង្កៀតខ្លះ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេកាត់ពុកមាត់ (ដោយកន្ត្រៃ) មិនត្រូវទុកពុកមាត់ ឲ្យវែង មិនត្រូវឲ្យគេធ្វើពុកចង្កាឲ្យវែង (ដូចជាពុកចង្កាពពែ) មិនត្រូវឲ្យគេធ្វើពុកមាត់៤ជ្រុង មិនត្រូវប្រមូលជួររោមត្រង់ទ្រូង មិនត្រូវទុកជួររោមត្រង់ពោះ មិនត្រូវទុកពុកមាត់ឲ្យដូចជាចង្កូម មិនត្រូវឲ្យគេដករោមក្នុងទីចង្កៀត ភិក្ខុណាឲ្យគេដក ត្រូវអាបត្តិទុក្កដ។

[២៦១] សម័យនោះឯង ភិក្ខុមួយរូបកើតដំបៅក្នុងទីចង្កៀត។ លាបថ្នាំមិនជាប់។ បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មានអាពាធជាហេតុ តថាគតអនុញ្ញាតឲ្យភិក្ខុ ឲ្យគេដករោមក្នុងទីចង្កៀតបាន។

[២៦២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើគេឲ្យកាត់សក់ ដោយកន្ត្រៃ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេកាត់សក់ ដោយកន្ត្រៃទេ។ ភិក្ខុណាឲ្យគេកាត់ ត្រូវអាបត្តិទុក្កដ។

[២៦៣] សម័យនោះឯង ភិក្ខុ១រូប កើតដំបៅត្រង់ក្បាល។ ភិក្ខុនោះ មិនអាចនឹងកោរសក់ ដោយកាំបិតកោរបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) មានអាពាធជាហេតុ តថាគតអនុញ្ញាតឲ្យភិក្ខុ ឲ្យគេកាត់សក់ដោយកន្ត្រៃបាន។

[២៦៤] សម័យនោះឯង ភិក្ខុទាំងឡាយ ទុករោមច្រមុះវែង។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចបិសាច។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុករោមច្រមុះឲ្យវែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ។

[២៦៥] សម័យនោះឯង ភិក្ខុទាំងឡាយ ឲ្យគេដករោមច្រមុះ ដោយដុំក្រួសខ្លះ ដោយក្រមួនឃ្មុំខ្លះ។ ច្រមុះក៏ឈឺចាប់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសណ្តាស។

[២៦៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេដកសក់ស្កូវ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេដកសក់ស្កូវទេ ភិក្ខុណាឲ្យគេដក ត្រូវអាបត្តិទុក្កដ។

[២៦៧] សម័យនោះឯង ភិក្ខុមួយរូបមានត្រចៀកថ្លង់ ដោយអាចម៍ត្រចៀក។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចង្កៀលអាចម៍ត្រចៀក។

[២៦៨] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់ចង្កៀលអាចម៍ត្រចៀកខ្ពស់និងទាប (មិនរាបសា) គឺធ្វើដោយមាសខ្លះ ដោយប្រាក់ខ្លះ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ចង្កៀលអាចម៍ត្រចៀកខ្ពស់ និងទាប (មិន

រាបសា)ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចង្កៀលអាចម៍ត្រចៀក ដែលធ្វើដោយឆ្អឹង ភ្លុក ស្នែង បបុស ឫស្សី ឈើ ជ័រឈើ ផ្លែឈើ លោហជាតិ គូថស័ង្ខ។

[២៦៩] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសន្សំទុកដាក់គ្រឿងលោហជាតិ និងសំរិទ្ធជាច្រើន។ មនុស្សទាំងឡាយ ដើរទៅកាន់វិហារចារិក ឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកសមណសក្យបុត្តិយ៍ សន្សំទុកដាក់គ្រឿងលោហជាតិ និងគ្រឿងសំរិទ្ធ ដូចពួកអ្នកជួញសំរិទ្ធសោះ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសន្សំទុកដាក់គ្រឿងលោហជាតិ និងសំរិទ្ធទេ ភិក្ខុណាសន្សំទុកដាក់ ត្រូវអាបត្តិទុក្កដ។

[២៧០] សម័យនោះឯង ពួកភិក្ខុរង្កៀសនឹងកិច្ចសព្វបើគ្រាន់តែចងបំពង់ថ្នាំភ្នែកខ្លះ (គឺចងចង្កុំ) ចង្កឹះបំពង់ថ្នាំភ្នែកខ្លះ ចង្កៀលអាចម៍ត្រចៀកខ្លះ។ ភិក្ខុទាំងឡាយ ក៏ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្រឹមតែការចងបំពង់ថ្នាំភ្នែក ចង្កឹះបំពង់ថ្នាំភ្នែក ចង្កៀលអាចម៍ត្រចៀកបាន។

[២៧១] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុអង្គុយត្របោមក្បាលជង្គង់ទាំងសង្ឃាដិ។ ផ្នត់សង្ឃាដិក៏ទក់ខូចអស់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវអង្គុយត្របោមក្បាលជង្គង់ទាំងសង្ឃាដិទេ ភិក្ខុណាអង្គុយ ត្រូវអាបត្តិទុក្កដ។

[២៧២] សម័យនោះឯង ភិក្ខុ១រូបមានជម្ងឺ។ ភិក្ខុនោះ តែវៀរលែងសំពត់អាយោគចេញ ក៏មិនបានសេចក្តីសប្បាយកាយ។ បេ។ ទើបពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសំពត់អាយោគ។ ទើបភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា សំពត់អាយោគ យើងរាល់គ្នា គប្បីដឹងដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្តារមូរ ធ្មេញឈើ ខ្សែសម្រាប់រឹត ចន្ទាស់ និងប្រដាប់តម្បាញទាំងអស់។

[២៧៣] សម័យនោះឯង ភិក្ខុ១រូប មិនមានកាយពន្ធ គឺវត្ថពន្ធចង្កេះ ចូលទៅបិណ្ឌបាត ក្នុងស្រុក។ ស្បង់របស់ភិក្ខុនោះ របូតចុះក្នុងច្រកផ្លូវ។ មនុស្សទាំងឡាយ ឃើញហើយ ក៏ស្រែកហ៊ោឡើង។ ភិក្ខុនោះមានសេចក្តីអៀនខ្មាស។ ទើបភិក្ខុនោះ ទៅកាន់អារាម ប្រាប់ដំណើរនុ៎ះ ដល់ពួកភិក្ខុផងគ្នា។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានកាយពន្ធ[64] មិនត្រូវចូលទៅកាន់ស្រុកទេ ភិក្ខុណាចូលទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាយពន្ធ។

[២៧៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រើប្រាស់កាយពន្ធខ្ពស់ និងទាប (មិនរាបសា) គឺកាយពន្ធមានខ្សែច្រើន កាយពន្ធមានសណ្ឋានដូចក្បាលពស់ទឹក កាយពន្ធមានសណ្ឋានដូចខ្សែរឹតសំភោរ និងកាយពន្ធ មានសណ្ឋានដូចសង្វារ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់កាយពន្ធខ្ពស់ និងទាប (មិនរាបសា) គឺកាយពន្ធមានខ្សែច្រើន កាយពន្ធមានសណ្ឋានដូចក្បាលពស់ទឹក កាយពន្ធដូចខ្សែរឹតសំភោរ និងកាយពន្ធ មានសណ្ឋានដូចសង្វារទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកាយពន្ធពីរយ៉ាង គឺកាយពន្ធធ្វើជាផ្ទាំង១ កាយពន្ធមានសណ្ឋានដូចពោះវៀនជ្រូក១។ បេ។ លុះដល់កាយពន្ធ មានជាយរេច។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជាយកាយពន្ធ មានសណ្ឋានដូចខ្សែរឹតសំភោរ និងជាយកាយពន្ធ មានសណ្ឋានដូចសង្វារ។ (ក្រោយមកទៀត) រិមកាយពន្ធក៏រេច។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដេរ លិន និដេរឲ្យមានអាការដូចក្តួផ្លែស្គួយ។ (យូរមកទៀត) ចុងអន្ទាក់កាយពន្ធក៏រេច។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រវិលកាយពន្ធ។

[២៧៥] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ក្រវិលកាយពន្ធខ្ពស់ និងទាប (មិនរាបសា) គឺធ្វើដោយមាសខ្លះ ប្រាក់ខ្លះ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ក្រវិលកាយពន្ធខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រវិលកាយពន្ធ ដែលធ្វើដោយឆ្អឹង ដោយភ្លុក ដោយស្នែង ដោយបបុះ ដោយឫស្សី។ បេ។ ធ្វើដោយគូថស័ង្ខ ធ្វើដោយសូត្រ ឬអំបោះ។

[២៧៦] សម័យនោះឯង ព្រះអានន្ទមានអាយុ ឃ្លុំសង្ឃាដិ និងឧត្តរាសង្គៈដែលស្រាល ហើយចូលទៅបិណ្ឌបាតក្នុងស្រុក។ ខ្យល់កំបុតត្បូងក៏ប៉ើងសង្ឃាដិ និងឧត្តរាសង្គៈ របស់ព្រះអានន្ទនោះ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ទៅកាន់អារាម ហើយប្រាប់រឿងនុ៎ះ ដល់ពួកភិក្ខុផងគ្នា។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឡេវ និងអន្ទាក់ឡេវ។

[២៧៧] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ឡេវខ្ពស់ និងទាប គឺធ្វើដោយមាសខ្លះ ប្រាក់ខ្លះ។ ពួកមនុស្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ឡេវខ្ពស់ និងទាបទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឡេវ ដែលធ្វើដោយឆ្អឹង ដោយភ្លុក ដោយស្នែង ដោយបបុះ ដោយឫស្សី ដោយឈើ ដោយជ័រឈើ ដោយផ្លែឈើ ដោយលោហជាតិ ដោយគូថស័ង្ខ ដោយសូត្រ ឬអំបោះ។

[២៧៨] សម័យនោះឯង ពួកភិក្ខុដេរភ្ជាប់ឡេវ និងអន្ទាក់ក្នុងផ្ទៃចីវរ។ ចីវរក៏គ្រាំគ្រា។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ឡេវ និងទ្រនាប់អន្ទាក់ឡេវ។ ពួកភិក្ខុទាំងនោះ ដេរភ្ជាប់ទ្រនាប់ឡេវ និងទ្រនាប់អន្ទាក់ឡេវក្នុងទីបំផុត (ចីវរ)។ មុំចីវរក៏របើក។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដេរភ្ជាប់ទ្រនាប់ឡេវក្នុងទីបំផុតចីវរ ដេរទ្រនាប់អន្ទាក់ បន្ថយចូលមកខាងក្នុង ត្រឹម៧ធ្នាប់ ឬ៨ធ្នាប់។

[២៧៩] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកស្បង់ ដូចសំលៀករបស់គ្រហស្ថ គឺស្លៀកឲ្យស្លុយមុខ ដូចប្រមោយដំរី (ដូចសំលៀកមនុស្សស្រីក្នុងចោឡកប្រទេស) ស្លៀកមានសណ្ឋានដូចកន្ទុយត្រី[65] ស្លៀកឲ្យមានជ្រុង៤ (ស្លៀកបន្លេចជ្រុងស្បង់ទាំង៤ឲ្យប្រាកដ) ស្លៀកដោយអាការដូចផ្កាងត្នោត (ស្លៀកសំឡយសាដកឲ្យស្លុយចុះ) ស្លៀកអង្កាញ់ ឲ្យមានផ្នត់ច្រើន។ ពួកមនុស្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្លៀកស្បង់ ដូចសំលៀកគ្រហស្ថ គឺស្លៀកឲ្យស្លុយមុខ ដូចប្រមោយដំរី មានសណ្ឋានដូចកន្ទុយត្រី ស្លៀកឲ្យមានជ្រុង៤ ស្លៀកមានអាការដូចផ្កាងត្នោត ស្លៀកអង្កាញ់ ឲ្យមានផ្នត់ច្រើនទេ ភិក្ខុណាស្លៀក ត្រូវអាបត្តិទុក្កដ។

[២៨០] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ដណ្តប់ដូចគ្រហស្ថ។ ពួកមនុស្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដណ្តប់ដូចពួកគ្រហស្ថទេ ភិក្ខុណាដណ្តប់ ត្រូវអាបត្តិទុក្កដ។

[២៨១] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកចងក្បិន។ ពួកមនុស្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកមនុស្ស អ្នកនាំគ្រឿងបរិក្ខារ របស់ព្រះរាជា ដែលយាងទៅកាន់ទីណាមួយ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្លៀកចងក្បិនទេ ភិក្ខុណាស្លៀក ត្រូវអាបត្តិទុក្កដ។

[២៨២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ នាំយកអម្រែកទាំងសងខាង គឺរែក។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកមនុស្ស នាំគ្រឿងបរិក្ខារ របស់ព្រះរាជា ដែលយាងទៅកាន់ទីណាមួយ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនាំអម្រែកទេ ភិក្ខុណានាំទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុពុន សែង ទូល លី កណ្តៀត នឹងយួរបាន។

[២៨៣] សម័យនោះឯង ពួកភិក្ខុមិនទំពាឈើស្ទន់។ មាត់ក៏មានក្លិនស្អុយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិនទំពាឈើស្ទន់នេះ មាន៥ប្រការ គឺនាំឲ្យថយកំលាំងភ្នែក១ មាត់មានក្លិនស្អុយ១ សរសៃសម្រាប់នាំរសមិនបរិសុទ្ធ១ ប្រមាត់ និងស្លេស្មរួបរឹតបាយ១ ភិក្ខុនោះឆាន់ចង្ហាន់មិនឆ្ងាញ់១ ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិនទំពាឈើស្ទន់ មាន៥ប្រការនេះឯង។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ក្នុងការទំពាឈើស្ទន់នេះ មាន៥ប្រការ គឺនាំឲ្យមានកំលាំងភ្នែក១ មាត់មិនមានក្លិនស្អុយ១ សរសៃសម្រាប់នាំរសបរិសុទ្ធ១ ប្រមាត់ និងស្លេស្ម មិនរួបរឹតបាយ១ ភិក្ខុនោះឆ្ងាញ់បាយ១ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទន់ មាន៥ប្រការនេះឯង។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើស្ទន់។

[២៨៤] សម័យនោះ ពួកឆព្វគ្គិយភិក្ខុទំពាឈើស្ទន់វែង ហើយគោះ វាយសាមណេរ ដោយឈើស្ទន់នោះឯង។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទំពាឈើស្ទន់វែងទេ ភិក្ខុណាទំពា ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើស្ទន់យ៉ាងវែង ត្រឹម៨[66] ធ្នាប់ តែថា កុំគោះវាយសាមណេរ ដោយឈើស្ទន់នោះឡើយ ភិក្ខុណាគោះ ត្រូវអាបត្តិទុក្កដ។

[២៨៥] សម័យនោះឯង ភិក្ខុមួយរូប មានឈើស្ទន់ខ្លីពេក ឈើស្ទន់ ក៏របូតចូលទៅក្នុងបំពង់ក។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទំពាឈើស្ទន់ខ្លីពេកទេ ភិក្ខុណាទំពា ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឈើស្ទន់យ៉ាងខ្លីបំផុតត្រឹម៤ធ្នាប់។

[២៨៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដុតព្រៃ។ ពួកមនុស្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចអ្នកដុតព្រៃ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដុតព្រៃទេ ភិក្ខុណាដុតព្រៃ ត្រូវអាបត្តិទុក្កដ។

[២៨៧] សម័យនោះឯង វិហារទាំងឡាយ ក៏ស្មុកស្មាញដោយស្មៅ។ កាលដែលភ្លើងឆេះព្រៃ (រាលមក) ក៏ឆេះទាំងវិហារផង។ ភិក្ខុទាំងឡាយ រង្កៀសនឹងការដុតភ្លើងតទល់គ្នា ដើម្បីនឹងធ្វើសេចក្តីការពារ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភ្លើងព្រៃឆេះមក តថាគតអនុញ្ញាត ឲ្យដុតភ្លើងតទល់ ដើម្បីនឹងធ្វើសេចក្តីការពារបាន។

[២៨៨] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឡើងដើមឈើ ឆ្លងពីដើមឈើមួយ ទៅដើមឈើមួយ។ ពួកមនុស្ស ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកស្វា។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឡើងដើមឈើទេ ភិក្ខុណាឡើង ត្រូវអាបត្តិទុក្កដ។

[២៨៩] សម័យនោះឯង ភិក្ខុមួយរូប ដើរសំដៅទៅក្រុងសាវត្ថី ក្នុងកោសលជនបទ ក៏មានដំរីដេញព្រេច ពាក់កណ្តាលផ្លូវ។ ទើបភិក្ខុនោះស្ទុះចូលទៅរកដើមឈើ ក៏មានសេចក្តីរង្កៀស មិនហ៊ានឡើងដើមឈើ។ ដំរីនោះ ក៏ហួសទៅទីដទៃ។ គ្រានោះឯង ភិក្ខុនោះទៅដល់ក្រុងសាវត្ថី ប្រាប់

ដំណើរនុ៎ះ ដល់ពួកភិក្ខុផងគ្នា។ ពួកភិក្ខុ ក៏ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើមានកិច្ចគួរធ្វើ តថាគតអនុញ្ញាតឲ្យឡើងដើមឈើបានត្រឹមមួយជួរបុរស បើមានអន្តរាយ[67] ឲ្យឡើងកំណត់ត្រឹមណាក៏បាន។

[២៩០] សម័យនោះឯង មានភិក្ខុពីររូប ជាបងប្អូននឹងគ្នា ឈ្មោះមេដ្ឋកៈ១ ឱកុដ្ឋៈ១ ជាជាតិព្រាហ្មណ៍ មានសំដីពីរោះ មានសំឡេងក៏ពីរោះ។ ភិក្ខុទាំងពីររូបនោះ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សព្វថ្ងៃនេះ ពួកភិក្ខុមានឈ្មោះផ្សេងគ្នា មានគោត្រផ្សេងគ្នា មានជាតិផ្សេងគ្នា ចេញអំពីត្រកូលទីទៃៗ មកបួស ភិក្ខុទាំងនោះ ធ្វើពុទ្ធវចនៈឲ្យខូច ដោយភាសារបស់ខ្លួន បពិត្រព្រះមានព្រះភាគ បើដូច្នោះ ខ្ញុំព្រះអង្គទាំងអម្បាលនេះ សូមលើកពុទ្ធវចនៈតាមឆន្ទ។[68] ព្រះពុទ្ធ ទ្រង់ព្រះភាគជាម្ចាស់ ព្រះអង្គ ទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ មិនសមបើអ្នករាល់គ្នាពោលថា បពិត្រព្រះអង្គដ៏ចំរើន បើដូច្នោះ ខ្ញុំព្រះអង្គរាល់គ្នា សូមលើកពុទ្ធវចនៈ តាមឆន្ទ ដូច្នេះទេ នែមោឃបុរស អំពើដែលអ្នករាល់គ្នាធ្វើនេះ មិននាំឲ្យកើតសេចក្ដីជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ។ បេ។ លុះទ្រង់បន្ទោសហើយ ក៏ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលើកពុទ្ធវចនៈតាមឆន្ទទេ ភិក្ខុណាលើក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរៀនពុទ្ធវចនៈ តាមសកភាសា[69] គឺមគធភាសា។

[២៩១] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុរៀនគម្ពីរលោកាយតៈ។[70] មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ ពួកភិក្ខុ បានឮមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់។ បេ។ ទើបភិក្ខុទាំងអម្បាលនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុធ្លាប់ឃើញថា មានខ្លឹមក្នុងគម្ពីរលោកាយតៈហើយ គួរដល់នូវសេចក្ដីចំរើនលូតលាស់ ធំទូលាយក្នុងធម្មវិន័យនេះដែរឬ។ ពួកភិក្ខុ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ សេចក្ដីនេះ មិនមែនទេ។ ទ្រង់ត្រាស់សួរទៀតថា ចុះភិក្ខុដែលឃើញថា មានខ្លឹមក្នុងធម្មវិន័យនេះហើយ គួររៀនគម្ពីរលោកាយតៈដែរឬ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ សេចក្ដីនេះ មិនមែនទេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវរៀនគម្ពីរលោកាយតៈទេ ភិក្ខុណារៀន ត្រូវអាបត្តិទុក្កដ។

[២៩២] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ បង្រៀនគម្ពីរលោកាយតៈ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបង្រៀនគម្ពីរលោកាយតៈទេ ភិក្ខុណាបង្រៀន ត្រូវអាបត្តិទុក្កដ។

[២៩៣] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុរៀនតិរច្ឆានវិជ្ជា។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវរៀនតិរច្ឆានវិជ្ជាទេ ភិក្ខុណារៀន ត្រូវអាបត្តិទុក្កដ។

[២៩៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុបង្រៀនតិរច្ឆានវិជ្ជា។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបង្រៀនតិរច្ឆានវិជ្ជាទេ ភិក្ខុណាបង្រៀន ត្រូវអាបត្តិទុក្កដ។

[២៩៥] សម័យនោះឯង ព្រះពុទ្ធទ្រង់ព្រះភាគ មានបរិសទ្យជាច្រើនចោមរោម ទ្រង់សំដែងធម៌ ហើយទ្រង់កណ្ដាស។ ពួកភិក្ខុក៏ធ្វើសំឡេងគឹកកងយ៉ាងខ្លាំងថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគចំរើនព្រះជន្មាយុរស់នៅ សូមព្រះសុគតចំរើនព្រះជន្មាយុរស់នៅ។[71] ធម្មកថា ក៏ដាច់ពាក់កណ្ដាល ដោយសំឡេងនោះ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកសួរថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេនិយាយថា អ្នកចូររស់នៅដូច្នេះ ក្នុងវេលាដែលកណ្ដាស បុគ្គលនោះ គួររស់នៅ ឬគួរស្លាប់ ព្រោះហេតុប៉ុណ្ណោះដែរឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ហេតុនុ៎ះមិនមែនទេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកដទៃ ភិក្ខុមិនត្រូវពោលថា អ្នកចូររស់នៅក្នុងវេលាកណ្ដាស (ប៉ុណ្ណោះ)ទេ ភិក្ខុណាពោល ត្រូវអាបត្តិទុក្កដ។

[២៩៦] សម័យនោះឯង មនុស្សទាំងឡាយ ទៅនិយាយនឹងពួកភិក្ខុ ក្នុងវេលាដែលកណ្ដាសថា បពិត្រលោកទាំងឡាយដ៏ចំរើន ចូរលោករស់នៅ។ ពួកភិក្ខុមានសេចក្ដីរង្កៀស មិនហ៊ានពោលតបវិញ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ សមណសក្យបុត្តិយ៍ទាំងនេះ កាលបើពួកយើងនិយាយថា បពិត្រលោកទាំងឡាយដ៏ចំរើន ចូរលោករស់នៅដូច្នេះ ហើយលោកមិនពោលតបនឹងយើងសោះ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតា គ្រហស្ថទាំងឡាយ តែងត្រូវការដោយមង្គល ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ដែលគ្រហស្ថទាំងឡាយនិយាយថា បពិត្រលោកដ៏ចំរើន លោកចូររស់នៅ ដូច្នេះ ឲ្យនិយាយតបទៅវិញថា អ្នកចូររស់នៅអស់កាលយូរ ដូច្នេះបាន។

[២៩៧] សម័យនោះឯង ព្រះមានព្រះភាគ មានបរិសទ្យច្រើនចោមរោម ទ្រង់គង់សំដែងធម៌។ ភិក្ខុមួយរូបឆាន់ខ្ទឹម។ ភិក្ខុនោះ អង្គុយក្នុងទីបំផុតដោយគិតថា ពួកភិក្ខុកុំធុំក្លិនឡើយ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញភិក្ខុនោះ អង្គុយក្នុងទីបំផុត លុះឃើញហើយ ទើបត្រាស់ហៅពួកភិក្ខុមកសួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលអង្គុយក្នុងទីបំផុតនោះ ដោយហេតុអ្វី។ ពួកភិក្ខុ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគដ៏ចំរើន (ព្រោះ) ភិក្ខុនោះឆាន់ខ្ទឹម បានជាភិក្ខុនោះ អង្គុយក្នុងទីបំផុត ដោយគិតថា ពួកភិក្ខុកុំធុំក្លិនឡើយ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលនៅឆ្ងាយពីធម្មកថា មានសភាពយ៉ាងនេះ ព្រោះតែឆាន់ខ្ទឹមណា ខ្ទឹមនោះ ភិក្ខុគួរឆាន់ដែរឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះ មិនគួរទេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់ខ្ទឹមទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ។

[២៩៨] សម័យនោះឯង ព្រះសារីបុត្តមានអាយុ មានអាពាធ កើតអំពីខ្យល់ក្នុងផ្ទៃ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ មានថេរវាចាសួរព្រះសារីបុត្តមានអាយុដូច្នេះថា នែអាវុសោសារីបុត្ត អាពាធ ដែលកើតអំពីខ្យល់

ក្នុងផ្ទៃរបស់លោកពីមុន តែងជាសះស្បើយ ដោយថ្នាំអ្វី។ ព្រះសារីបុត្តតបថា ម្នាលអាវុសោ ខ្ញុំតែងជាសះស្បើយដោយខ្ទឹម។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាត ឲ្យឆាន់ខ្ទឹមបាន។

[២៩៩] សម័យនោះឯង ពួកភិក្ខុ បន្ទោបង់បស្សាវៈ ក្នុងទីពីសពាស។ អារាមមិនស្អាត។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបន្ទោបង់បស្សាវៈ តែក្នុងកន្លែងមួយ។ អារាមមានក្លិនអាក្រក់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆ្នាំងសម្រាប់រងបស្សាវៈ។ ពួកភិក្ខុលំបាកនឹងអង្គុយបន្ទោបង់បស្សាវៈ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ។ ទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ នៅទីវាល មិនបិទបាំង។ ពួកភិក្ខុអៀននឹងបន្ទោបង់បស្សាវៈ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបិទបាំងដោយកំពែង ៣យ៉ាង គឺកំពែងឥដ្ឋ១ កំពែងថ្ម១ កំពែងឈើ១។ ឆ្នាំងសម្រាប់រងបស្សាវៈ មិនទាន់មានគ្រប ក៏ធុំក្លិនស្អុយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគម្រប។

[៣០០] សម័យនោះឯង ពួកភិក្ខុបន្ទោបង់វច្ចៈ ក្នុងទីពីសពាស ក្នុងអារាម។ អារាមក៏មិនស្អាត។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបន្ទោបង់វច្ចៈ តែក្នុងកន្លែងមួយ។ អារាមក៏ធុំក្លិនស្អុយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរណ្តៅវច្ចៈ។ មាត់រណ្តៅវច្ចៈ ក៏បាក់រលុះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុកខឿន ៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ រណ្តៅវច្ចៈ មានទីដីទាប។ ទឹកក៏លិចកន្លែងនោះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើទីដីឲ្យខ្ពស់ឡើង។ ខឿនក៏បាក់រលុះហូរចេញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកខឿន ៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ពួកភិក្ខុឡើង ក៏លំបាក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ ៣យ៉ាង គឺជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ ពួកភិក្ខុឡើងទៅ ក៏ដួល។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ។ ពួកភិក្ខុអង្គុយក្នុងទីបំផុត កំពុងបន្ទោបង់វច្ចៈ ក៏ធ្លាក់ចុះមក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុក្រាលក្តារ ហើយចោះប្រហោងកណ្តាល ហើយបន្ទោបង់វច្ចៈ។ ពួកភិក្ខុក៏លំបាកនឹងអង្គុយបន្ទោបង់វច្ចៈ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើង សម្រាប់បន្ទោបង់វច្ចៈ។ ពួកភិក្ខុបន្ទោបង់បស្សាវៈខាងក្រៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ សម្រាប់រងបស្សាវៈ។ ឈើខ្ញៀសមិនទាន់មាននៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឈើខ្ញៀស។ ត្រកសម្រាប់ដាក់ឈើខ្ញៀស មិនទាន់មាននៅឡើយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្រកសម្រាប់ដាក់ឈើខ្ញៀស។ រណ្តៅវច្ចៈ មិនទាន់មានគ្រប ក៏ធុំក្លិនស្អុយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគម្រប។

[៣០១] សម័យនោះឯង ពួកភិក្ខុបន្ទោបង់វច្ចៈក្នុងទីកណ្តាលវាល ក៏លំបាកដោយត្រជាក់ខ្លះ ក្តៅខ្លះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវច្ចកុដិ។ សន្ទះទ្វារវច្ចកុដិ មិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ក្បាល (ដំណាប់ក្រោម) អន្ទាក់លើ (ដំណាប់លើ) សសររបស់សន្ទះទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញ និងខ្សែសម្រាប់ទាញ។ កំទេចស្មៅធ្លាក់ចុះក្នុងវច្ចកុដិ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុគាបដំបូល ហើយបូកលាបទាំងខាងក្នុង ខាងក្រៅ[72] និងថ្នាំមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥ ស្នួរសំរាប់ពាក់ចីវរ និងខ្សែសំរាប់ពាក់ចីវរ។

[៣០២] សម័យនោះឯង ភិក្ខុមួយរូប ជរាទុព្វល កាលនឹងបន្ទោបង់វច្ចៈ ហើយក្រោកឡើង ក៏ដួលទៅវិញ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរបស់សម្រាប់តោង។

[៣០៣] សម័យនោះឯង វច្ចកុដិ មិនទាន់មានរបង ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបិទបាំងដោយកំពែង៣យ៉ាង គឺកំពែងឥដ្ឋ១ កំពែងថ្ម១ កំពែងឈើ១។

[៣០៤] បន្ទប់មិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្ទប់។ បន្ទប់មានទីដីដ៏ទាប។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើទីដីឲ្យខ្ពស់ឡើង។ ខឿនក៏បាក់រលុះរលាយ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកខឿន៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ពួកភិក្ខុលំបាកនឹងឡើង។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ៣យ៉ាង គឺជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ កាលពួកភិក្ខុ នាំគ្នាឡើង ក៏ធ្លាក់មកវិញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបង្កាន់ដៃ។ សន្ទះទ្វាររបស់បន្ទប់មិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ក្បាល (ដំណាប់ក្រោម) អន្ទាក់លើ (ដំណាប់លើ) សសរ របស់សន្ទះទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញ ខ្សែសម្រាប់ទាញ។ កំទេចស្មៅ ក៏ធ្លាក់ចុះក្នុងបន្ទប់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុគាបដំបូល ហើយបូកលាបទាំងខាងក្នុង ទាំងខាងក្រៅ និងថ្នាំមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ និងក្បាច់មានស្រទាប់៥។ ទីលានក៏ភក់ជ្រាំ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរោយរាយដោយក្រួសរវាន។ ទីលានមិនរាបស្មើ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាលថ្ម។ បេ។ ទឹកក៏ដក់នៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ-ទឹក។ ឆ្នាំងទឹកសម្រាប់ជម្រះមិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឆ្នាំងទឹកសម្រាប់ជ្រះ។ ផ្តិលសម្រាប់ជម្រះមិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្តិលសម្រាប់ជម្រះ។ ពួកភិក្ខុលំបាកនឹងអង្គុយជម្រះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើងសម្រាប់ជម្រះ។ ទ្រនាប់ជើងសម្រាប់ជម្រះ នៅកណ្តាលវាល។ ពួកភិក្ខុអៀនខ្មាសនឹងជម្រះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបិទបាំងដោយកំពែង៣យ៉ាង គឺកំពែងឥដ្ឋ១ កំពែងថ្ម១ កំពែងឈើ១។ ឆ្នាំងទឹកសម្រាប់ជម្រះមិន

ទាន់មានគម្រប។ ផ្ទាំងទឹកសម្រាប់ជម្រះ ស្មោកគ្រោកដោយកំទេចស្មៅខ្លះ អាចម៍ដីខ្លះ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគម្រប។

[៣០៥] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះ គឺដាំកូនផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើកម្រងផ្កា ឲ្យមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើ ចាក់រំលេចទងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើ ដោត[73] ជាចង្កោម ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រង សម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រង សម្រាប់ប្រដាប់ត្រចៀក ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រង សម្រាប់ប្រដាប់ទ្រូង ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ពួកភិក្ខុទាំងអម្បាលនោះ នាំផ្កាកម្រង មានទងតែម្ខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាកម្រង មានទងទាំងពីរខាង ទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើចាក់រំលេចទង ទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាឈើដែលដោតជាចង្កោម ទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាកម្រង សម្រាប់ប្រដាប់ក្បាល ទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាកម្រង សម្រាប់ប្រដាប់ត្រចៀក ទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ នាំផ្កាកម្រង សម្រាប់ប្រដាប់ទ្រូង ទៅខ្លួនឯងខ្លះ ប្រើគេនាំទៅឲ្យខ្លះ ដើម្បីពួកស្រីក្រមុំនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូល។ ពួកភិក្ខុទាំងអម្បាលនោះ ឆាន់ (ភោជន) ក្នុងភាជន៍មួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយខ្លះ ផឹកទឹកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់សំពត់ជាមួយគ្នាខ្លះ ដេកលើកម្រាលទាំងដណ្តប់សំពត់ជាមួយគ្នាខ្លះ ស៊ីខុសពេលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីដែលរាំខ្លះ ច្រៀងជាមួយនឹងស្រីដែលរាំខ្លះ ប្រគំជាមួយនឹងស្រីដែលរាំខ្លះ កែក្រាយជាមួយនឹងស្រីដែលរាំខ្លះ។ បេ។ រាំជាមួយនឹងស្រីដែលកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីដែលកែក្រាយខ្លះ ប្រគំជាមួយនឹងស្រី ដែលកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រី ដែលកែក្រាយខ្លះ លេងបាស្កាមានក្រឡាប្រាំបីខ្លះ លេងបាស្កាមានក្រឡាដប់ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងវាងផ្លូវដែលគូរវាង (លេងពួន)ខ្លះ លេងផ្ទាត់គ្រាប់ មានគ្រាប់ក្រួសជាដើមខ្លះ លេងបាស្កា ក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកល័ក្ត ឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងនង្គ័លតូចខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ (បាយឡុកបាយឡ) ខ្លះ លេងរថតូចខ្លះ លេងធ្នូតូចខ្លះ លេងសរសេរខ្យល់ ឲ្យទាយខ្លះ លេងទាយចិត្ត (ស្តេចចង់) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់វិជ្ជាដង មានដងដាវជាដើមខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិ ក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលរាំ យ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំ ក្នុងទីនេះខ្លះ ដាក់ម្រាមដៃ លើថ្ងាសខ្លួន និងលើថ្ងាសស្រី ដែលរាំខ្លះ ប្រព្រឹត្តអនាចារផ្សេងៗខ្លះ (ក្រៅអំពីនេះទៅទៀត)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រព្រឹត្តអនាចារផ្សេងៗទេ ភិក្ខុណាប្រព្រឹត្ត វិន័យធរ គប្បីឲ្យភិក្ខុនោះ ធ្វើតាមធម៌។

[៣០៦] សម័យនោះឯង កាលព្រះឧរុវេឡកស្សបមានអាយុ ចូលមកបួសហើយ ក៏មានគ្រឿងលោហៈ គ្រឿងឈើ គ្រឿងដី ជាច្រើន កើតឡើងដល់សង្ឃ។ ពួកភិក្ខុគិតយ៉ាងនេះថា គ្រឿងលោហៈ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ឬមិនទាន់អនុញ្ញាតទេ គ្រឿងឈើ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ឬមិនទាន់អនុញ្ញាតទេ គ្រឿងដី ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ឬមិនទាន់អនុញ្ញាតទេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងលោហៈទាំងពួង វៀរលែងតែ លោហៈ ដែលជាគ្រឿងសម្រាប់ប្រហារ អនុញ្ញាតគ្រែទាំងពួង វៀរលែងតែ អាសនៈកន្លងហួសប្រមាណ ដែលហៅថាអាសន្ទិ អនុញ្ញាតគ្រឿងឈើទាំងពួង វៀរលែងតែបាត្រឈើ និងទ្រនាប់ជើងឈើ អនុញ្ញាតគ្រឿងដីទាំងពួង វៀរលែងតែ គ្រឿងជូតជើង ដែលគេធ្វើជាពក ឲ្យស្រួចៗឡើង មានអាការដូចពកគ្រាប់ផ្លែឈូក និងកុដិធ្វើដោយដីសុទ្ធ (ដូចកុដិធនិយភិក្ខុ)។

ចប់ខុទ្ទកវត្ថុក្ខន្ធកៈ ជាគំរប់៥។

ឧទ្ទាន គឺបញ្ជីរឿងនៃ ខុទ្ទកវត្ថុក្ខន្ធកៈ នោះដូច្នេះ

[៣០៧]

រឿងភិក្ខុងូតទឹក ត្រដុសកាយនឹងដើមឈើ នឹងសសរ នឹងជញ្ជាំង ទាំងងូតទឹក ក្នុងទីមិនសមគួរ ងូតទឹកដុសខ្លួន ដោយឈើដែលគេធ្វើជាដៃគន្ធព្វ ងូតទឹក ដុសដោយលំអិតថ្ម ឈ្មោះករុវិន្ទកសុត្តិ ងូតទឹកត្រដុសគ្នាទៅវិញទៅមក ងូតទឹកដោយឈើ មានសណ្ឋានដូចជើងកន្លោរ១ រឿងភិក្ខុកើតកមរមាស់ និងភិក្ខុជរា ទ្រង់អនុញ្ញាតឲ្យដុសខ្នងដោយបាតដៃបាន១ រឿងទ្រង់ហាមមិនឲ្យភិក្ខុទ្រទ្រង់ប្រដាប់ត្រចៀក សង្វារប្រដាប់ក ប្រដាប់ចង្កេះ កងប្រដាប់ដើមដៃ ប្រដាប់ដៃ និងចិញ្ចៀន១ រឿងភិក្ខុទុកសក់វែង សិតសក់ដោយស្និត សិតសក់ដោយក្រាស សិតសក់ដោយដៃ សិតសក់ដោយក្រមួន លាបសក់ដោយប្រេង លាយដោយទឹក១ រឿងភិក្ខុឆ្លុះមុខក្នុងកញ្ចក់ ក្នុងភាជន៍ទឹក១ រឿងភិក្ខុកើតដំបៅមុខ លាបមុខ ផាត់មុខ ប្រស់មុខ ចុចមុខ លាបអវយវៈ លាបមុខ និងលាបទាំងអវយវៈទាំងមុខ១ រឿងភិក្ខុកើតរោគភ្នែក១ រឿងមហោស្រពលើកំពូលភ្នំ១ រឿងភិក្ខុច្រៀងធម៌ ដោយសំឡេងវែង១ រឿងភិក្ខុមានសេចក្តីវង្វេងសនឹងសូត្រជាប់ទំនុកច្រៀង១ រឿងភិក្ខុទ្រទ្រង់សំពត់ដែលធ្វើដោយរោមសត្វ មានរោមចេញមកខាងក្រៅ១ រឿងអនុញ្ញាតចំណិតស្វាយ១ រឿងពួកជន នាំយកផ្លែស្វាយទាំងមូលទៅក្នុងរោងភត្ត១ រឿងភិក្ខុពស់ចឹក១ រឿងភិក្ខុកាត់អង្គជាតរបស់ខ្លួន១ រឿងបាត្រខ្លឹមចន្ទន៍១ រឿងភិក្ខុប្រើបាត្រខ្ពស់ និងទាប១ រឿងផ្ទៃបាត្រសឹករិល ព្រោះគ្មានជើង១ រឿងបញ្ញត្តជើងបាត្រ ធ្វើដោយមាស និងប្រាក់១ រឿងជើងបាត្រក្រាស់ពេក១ រឿងលួសកើតឡើងដល់ភិក្ខុ១ រឿងភិក្ខុប្រើជើងបាត្រ វិចិត្រផ្សេងៗ១ រឿងភិក្ខុទុកបាត្រទាំងទទឹក បាត្រក៏ខូចទៅ១ រឿងបាត្រធុំក្លិនអាក្រក់១ រឿងភិក្ខុទុកបាត្រក្នុងទីក្តៅ បាត្ររមៀលធ្លាក់បែក១ រឿងភិក្ខុទុក

បាត្រក្នុងទីបំផុតនៃក្តារតាំង ទុកបាត្រក្នុងទីបំផុតនៃថ្នាក់១ រឿងអនុញ្ញាតកម្រាលស្មៅ អនុញ្ញាតកំណាត់សំពត់ អនុញ្ញាតរោងទុកបាត្រ អនុញ្ញាតថ្លាងសម្រាប់ទុកបាត្រ អនុញ្ញាតស្លោកបាត្រ យោគបាត្រ និងខ្សែសម្រាប់ចងបាត្រ១ រឿងភិក្ខុព្យួរបាត្រនឹងចំរឹងជញ្ជាំង ទុកបាត្រលើគ្រែ និងតាំង ដាក់បាត្រលើភ្លៅ ទុកបាត្រក្នុងឆត្រ និងមានបាត្រក្នុងដៃ ច្រានសន្ទះទ្វារ១ រឿងភិក្ខុត្រាច់ទៅបិណ្ឌបាត ដោយសំបកឃ្លោក ដោយអំបែងឆ្នាំង១ រឿងភិក្ខុប្រើបាត្រក្បាលខ្មោច១ រឿងភិក្ខុយកបាត្រទៅដាក់កាកអាមិសៈ ហើយយកទៅចាក់ចោល ទ្រង់អនុញ្ញាតកន្តោរ១ រឿងភិក្ខុហែកចីវរដោយដៃ១ រឿងកាំបិតមានដង កើតឡើងដល់សង្ឃ ភិក្ខុប្រើដងកាំបិត ធ្វើដោយមាស (ជាដើម)១ រឿងភិក្ខុដេរចីវរ ដោយស្លាបមាន់ និងចំរៀកឫស្សី ទ្រង់អនុញ្ញាតបំពង់ម្ជុល អនុញ្ញាតឲ្យយកលំអិតពូជសុរា (ដំបែ) ច្រកក្នុងបំពង់ម្ជុល អនុញ្ញាតឲ្យយកលំអិតម្សៅលាយដោយរមៀត ឲ្យយកលំអិតថ្ម ច្រកក្នុងបំពង់ម្ជុល ក្រមួនឃ្មុំ និងស្រោមលំអិតថ្ម១ រឿងដេរចីវរមានមុំមិនស្មើគ្នា ទ្រង់អនុញ្ញាតឈើស្ដឹង និងខ្សែស្ដឹងឲ្យភិក្ខុចងដេរចីវរ១ រឿងភិក្ខុលាឈើស្ដឹង ក្នុងទីមិនរាបទាប ភិក្ខុក្រាល ឬលាឈើស្ដឹងលើផែនដី ឈើស្ដឹងរេចរិលត្រង់ដោយជាយជុំវិញ១ រឿងអនុញ្ញាតខ្នាតសម្រាប់វាស់ចីវរ និងខ្សែបន្ទាត់១ រឿងភិក្ខុមិនលាងជើង ហើយជាន់លើឈើស្ដឹង ភិក្ខុពាក់ស្បែកជើង ជាន់លើឈើស្ដឹង១ រឿងភិក្ខុឈឺម្រាមដៃ ព្រោះដេរចីវរ ទ្រង់អនុញ្ញាតស្នាប់ម្រាមដៃដេរ ប្រអប់សម្រាប់ដាក់ម្ជុលកាំបិត ស្នាប់ម្រាមដៃដេរ ថង់សម្រាប់ដាក់ស្នាប់ម្រាមដៃដេរ ខ្សែយោគ និងខ្សែចង១ រឿងភិក្ខុដេរចីវរក្នុងទីវាល រោងសម្រាប់ដាក់ឈើស្ដឹង មានទីដីទាប១ រឿងខឿនបាក់រលុះរលើងទៅ ភិក្ខុលំបាកឡើងខឿន ដែលគ្មានជណ្ដើរ ភិក្ខុដួលធ្លាក់ដោយឡើងជណ្ដើរ កំទេចស្មៅធ្លាក់ចុះ ក្នុងរោងឈើស្ដឹង ទ្រង់អនុញ្ញាតឲ្យបូក លាបដំបូលទាំងក្នុង ទាំងក្រៅ ធ្វើឲ្យមានពណ៌ស ពណ៌ខ្មៅ និងបរិកម្មដោយរង់ ទ្រង់អនុញ្ញាតឲ្យធ្វើក្បាច់ភ្ញីផ្កា ភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ប្រាំ ទាំងអនុញ្ញាតស្នួរចីវរ និងខ្សែស្បៀង១។ រឿងភិក្ខុចោលឈើស្ដឹង ហើយចៀសចេញទៅ ឈើស្ដឹងវិនាសខូចទៅ ភិក្ខុមូរឈើស្ដឹង ៗ ចេះតែរលាចេញ ភិក្ខុផ្អែកឈើស្ដឹងនឹងជញ្ជាំង ភិក្ខុយកបាត្រដាក់ម្ជុល កាំបិត និងថ្នាំហើយដើរទៅ អនុញ្ញាតថង់សម្រាប់ដាក់ថ្នាំ និងខ្សែចង១ រឿងភិក្ខុចងស្បែកជើងនឹងវត្ថពន្ធចង្កេះ អនុញ្ញាតថង់សម្រាប់ដាក់ស្បែកជើង ខ្សែយោគ និងខ្សែចង១ រឿងទឹកជាអកប្បិយៈ មានកណ្ដាលផ្លូវ អនុញ្ញាតសំពត់តម្រងទឹក និងធម្មក្រក១ រឿងភិក្ខុពីររូបដើរផ្លូវឆ្ងាយ១ រឿងព្រះមហាមុនី យាងទៅកាន់ក្រុងវេសាលី អនុញ្ញាតសំពត់តម្រងទឹក ដែលមានដង និងសំពត់តម្រងត្រាំ ក្នុងក្រុងវេសាលីនោះ១។ រឿងភិក្ខុមានមូសខាំ ភិក្ខុមានអាពាធច្រើន ព្រោះឆាន់បណីតភោជន១ រឿងជីវកកោមារភត្យ១ រឿងអនុញ្ញាតទីចង្ក្រម និងរោងភ្លើង១ រឿងភិក្ខុចង្ក្រម ក្នុងទីចង្ក្រមមិនស្មើ ទីចង្ក្រមមានទីដីទាប ទ្រង់អនុញ្ញាតខឿន៣យ៉ាង ពួកភិក្ខុលំបាកនឹងឡើង ព្រោះគ្មានជណ្ដើរ ទ្រង់អនុញ្ញាតជណ្ដើរ និងបង្កាន់ដៃ និងដៃវបៃនៃទីចង្ក្រម១ រឿងភិក្ខុចង្ក្រមក្នុងទីវាល កំទេចស្មៅធ្លាក់ចុះក្នុងរោងចង្ក្រម ទ្រង់អនុញ្ញាតឲ្យបូក លាបទាំងក្នុង ទាំងក្រៅ ទ្រង់អនុញ្ញាតថ្នាំមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ធ្វើក្បាច់ភ្ញីផ្កា ភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ប្រាំ ស្នួរចីវរ និងខ្សែស្បៀង១។ រឿងអនុញ្ញាតឲ្យធ្វើទីដីរោងភ្លើងឲ្យខ្ពស់ឡើង ខឿន ជណ្ដើរ និងបង្កាន់ដៃជណ្ដើរ សន្ទះទ្វាររោងភ្លើង ក្របទ្វារ ក្បាល (ដំណាប់ក្រោម) អន្ទាក់ខាងលើ (ដំណាប់លើ ឬច្បោះ) សសរនៃសន្ទះទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់បិទបើក ខ្សែទាញបិទបើក និងអនុញ្ញាតឲ្យធ្វើមណ្ឌលគឺដីឲ្យទាបជុំវិញរោងភ្លើង បំពង់ផ្សែង (បំពង់ភ្លើង)១ រឿងភិក្ខុធ្វើចង្ក្រាន ពាក់កណ្ដាលរោងភ្លើងតូច អនុញ្ញាតដីលាបមុខ ទាំងអនុញ្ញាតស្នូកសម្រាប់លាយដីស្អិត ដីធុំក្លិនអាក្រក់១ រឿងភ្លើងរលាកភិក្ខុ១ រឿងអនុញ្ញាតអាងទឹក និងផ្តិលទឹក១ រឿងដំបូលស្មៅមិនមានចំហាយញើស១ រឿងរោងភ្លើងមានភក់ជ្រាំ១ រឿងអនុញ្ញាតឲ្យលាងកម្រាលរោងភ្លើង និងធ្វើឲ្យទទឹក១ រឿងអនុញ្ញាតតាំងសម្រាប់រោងភ្លើង១ រឿងអនុញ្ញាតបន្ទប់ទឹក និងកិច្ចការក្នុងរោងភ្លើង១ រឿងអនុញ្ញាតឲ្យរោយក្រួសរវាន អនុញ្ញាតកម្រាលថ្ម និងទទឹក១ រឿងភិក្ខុអាក្រាត សំពះគ្នា១ រឿងភិក្ខុដាក់ចីវរលើផែនដី ភ្លៀងទទឹកចីវរ១ រឿងអនុញ្ញាតគ្រឿងបិទបាំងកាយបីយ៉ាង១ រឿងទឹកមិនមានក្នុងរោងភ្លើងនោះ អនុញ្ញាតអណ្ដូងទឹក មាត់អណ្ដូងទឹក បាក់រលុះរលាយ ភិក្ខុយោងទឹកដោយវល្លិខ្លះ ដោយវត្ថពន្ធចង្កេះខ្លះ អនុញ្ញាតថ្លឹងសម្រាប់យោងទឹក យន្តសម្រាប់ទាញទឹក និងរហាត់ទឹក១ រឿងភាជន៍បែកជាច្រើន បំពង់លោហៈ បំពង់ឈើ និងចម្មខណ្ឌ១ រឿងអនុញ្ញាតសាលាជិតអណ្ដូងទឹក កំទេចស្មៅធ្លាក់ចុះក្នុងសាលា អនុញ្ញាតគ្របអណ្ដូងទឹក ស្នូកទឹក អណ្ដូងជ្រាំ និងកំពែង ៣យ៉ាង១ រឿងអណ្ដូងជ្រាំ មានភក់ អនុញ្ញាតទ បង្ហូរទឹក១ រឿងភិក្ខុមានកាយរងារ១ រឿងឧបាសកជីកស្រះបោក្ខរណីទឹកដក់នៅយូរក្នុងស្រះបោក្ខរណី១ រឿងឧបាសក សង់រោងភ្លើង មានជហ្វាដងក្តារ១ រឿងភិក្ខុនៅប្រាសចាកសំពត់និសីទនៈ៤ខែ១ រឿងភិក្ខុដេកនៅលើទីដំណេក ដែលរោយរាយដោយផ្កា ពួកមនុស្សនាំយកគ្រឿងក្រអូប និងផ្កាកម្រងមកកាន់អារាម១ រឿងទ្រង់ហាមមិនឲ្យអធិដ្ឋានសំពត់ស្នាច់ ដោយរោមចៀម១ រឿងភិក្ខុឆាន់លើតុ ឬថាស អនុញ្ញាតភាជន៍ឈើសម្រាប់ដម្កល់បាត្រ១ រឿងភិក្ខុឆាន់ក្នុងភាជន៍ជាមួយគ្នា ដេកលើគ្រែជាមួយគ្នា លើកម្រាលជាមួយគ្នា១ រឿងវឌ្ឍលិច្ឆវិ១ រឿងពោធិរាជកុមារ១ រឿងមិនទ្រង់ជាន់លើកម្រាលសំពត់១ រឿងនាងវិសាខានាំយកក្អម និងទ្រនាប់សម្រាប់ជូតជើង ដែលមានពក និងអំបោស ទ្រង់អនុញ្ញាតទ្រនាប់សម្រាប់ជូតជើង ៣យ៉ាងគឺ ទ្រនាប់ថ្ម ក្បឿង ឬអំបែង និងទ្រនាប់ផ្សិតសមុទ្រ រឿងនាងវិសាខា នាំយកផ្លិតបួនជ្រុង និងផ្លិតមូល ទៅថ្វាយព្រះមានព្រះភាគ១ រឿងផ្លិតបក់មូស កើតឡើងដល់សង្ឃ ទ្រង់ហាមមិនឲ្យភិក្ខុប្រើប្រាស់ផ្លិតចាមរី១ រឿងភិក្ខុឈឺតែខានបាំងឆត្រ មិនសប្បាយ និងភិក្ខុរង្កៀសនឹងបាំងឆត្រ ក្នុងអារាម១ រឿងអនុញ្ញាតសិក្កាសម្មតិ ដល់ភិក្ខុ៣រូប រឿងភិក្ខុទំពាអៀង១ រឿងគ្រាប់បាយធ្លាក់រាត់រាយ ក្នុងរោងភត្ត រឿងភិក្ខុមានក្រចកវែង ភិក្ខុកាត់ក្រចកដោយក្រចក ភិក្ខុត្រដុសក្រចកនឹងជញ្ជាំង ម្រាមដៃឈឺចាប់ ភិក្ខុកាត់ក្រចក ត្រាតែចេញឈាម ទ្រង់អនុញ្ញាតឲ្យកាត់ក្រចកស្មើនឹងសាច់១ រឿងភិក្ខុដុសខាត់ក្រចកទាំងម្ភៃ១ រឿងភិក្ខុទុកសក់វែង អនុញ្ញាតកាំបិតកោរ ថ្មសំលៀងកាំបិតកោរ ស្រោមកាំបិតកោរ គ្រឿងស្នាច់ ធ្វើដោយរោមចៀម និងគ្រឿងប្រដាប់កាំបិតកោរទាំងអស់១ រឿងភិក្ខុកោរពុកមាត់ ទុកពុកមាត់ ទុកពុកចង្កាឲ្យវែង ដូចជាពុកចង្កាពពែ ទុកពុកមាត់ឲ្យមានជ្រុង៤ ប្រមូលជួររោមត្រង់ដើមទ្រូង ទុកជួររោមត្រង់ពោះ ទុកពុកមាត់ដូចចង្កូម១ រឿងទ្រង់អនុញ្ញាតឲ្យដករោមក្នុងទីចង្អៀត ដោយមានអាពាធជាហេតុ១ រឿងភិក្ខុកាត់សក់ដោយកន្ត្រៃ រឿងភិក្ខុកើតដំបៅក្បាល១ រឿងភិក្ខុទុករោមច្រមុះវែង ភិក្ខុឲ្យគេដករោមច្រមុះដោយក្រួស ភិក្ខុឲ្យគេដកសក់ស្កូវ១ រឿងភិក្ខុថ្លង់ ឆព្វគ្គិយភិក្ខុប្រើចង្កៀលត្រចៀកខ្ពស់ និងទាប ភិក្ខុសន្សំទុកគ្រឿងលោហៈជាច្រើន១ រឿងភិក្ខុរង្កៀសនឹងចងចង្កឹះក្លាក់ដាក់ថ្នាំ សម្រាប់លាបភ្នែក១ រឿងភិក្ខុអង្គុយត្របោមក្បាលជង្គង់ទាំងសង្ឃាដិ១ រឿងភិក្ខុសង្ស័យនឹងសំពត់អាយោគ ទ្រង់អនុញ្ញាតក្ដារមូរសម្រាប់ធ្វើសំពត់អាយោគ១ ទ្រង់អនុញ្ញាតកាយពន្ធ ភិក្ខុប្រើកាយពន្ធ មានខ្សែច្រើន មានសណ្ឋានដូចក្បាលពស់ទឹក មានសណ្ឋានដូចខ្សែសម្ពោរ និងមានសណ្ឋានដូចសង្វារ ទ្រង់អនុញ្ញាតកាយពន្ធពីរយ៉ាង គឺ

សំពត់ផ្ទាំងមួយ សំពត់ដូចពោះរៀនជ្រូកមួយ រឿងជាយកាយពន្ធរេច ទ្រង់អនុញ្ញាតកាយពន្ធ មានសណ្ឋានដូចខ្សែរិតសម្ភោរ និងមានសណ្ឋានដូចសង្វារ រឿងរឹមកាយពន្ធរេច ទ្រង់អនុញ្ញាតឲ្យដេរលិន និងដេរឲ្យមានអាការដូចក្ដផ្លែស្គច រឿងអន្ទាក់កាយពន្ធរេច និងរឿងភិក្ខុប្រើឡេវក្តំខ្ពស់ និងទាប១ រឿងភិក្ខុដេរទ្រនាប់ឡេវ ទ្រនាប់អន្ទាក់ ក្នុងទីបំផុតនៃចីវរ ទ្រង់អនុញ្ញាតឲ្យដាក់ទ្រនាប់អន្ទាក់លូកចូលទៅខាងក្នុង១ រឿងភិក្ខុស្លៀកស្បង់ដូចគ្រហស្ថ ស្លៀកស្បង់ស្លយមុខ ដូចប្រមោយដំរី ស្លៀកមានសណ្ឋានដូចកន្ទុយត្រី ស្លៀកបន្តិចជ្រុងស្បង់ទាំង៤ ឲ្យប្រាកដ ស្លៀកដោយអាការដូចកំពូលត្នោត ស្លៀកអង្កាញ់ឲ្យមានផ្នត់ច្រើន ដណ្តប់ដូចគ្រហស្ថ និងស្លៀកចងក្បិន១ រឿងភិក្ខុរែក១ រឿងភិក្ខុមិនទំពាឈើស្ទន់ ភិក្ខុគោះសាមណេរដោយឈើស្ទន់ ភិក្ខុទំពាឈើស្ទន់ខ្លីពេក ឈើស្ទន់ក៏របូតចូលក្នុងបំពង់ក១ រឿងភិក្ខុដុតព្រៃ ភិក្ខុរង្កៀសនឹងការដុតភ្លើងតទល់ ភិក្ខុរត់ឡើងដើមឈើ ព្រោះដំរីដេញ១ រឿងភិក្ខុទូលសូមសូត្រពុទ្ធវចនៈ ជាភាសាសំស្រ្កឹត ភិក្ខុរៀនទាំងបង្រៀនគម្ពីរលោកាយតៈ និងភិក្ខុរៀនតិរច្ឆានវិជ្ជា១ រឿងព្រះអង្គកណ្តាស់ រឿងអនុញ្ញាតឲ្យភិក្ខុឆ្លើយតបដើម្បីមង្គល រឿងភិក្ខុឆាន់ខ្ទឹម១ រឿងព្រះសារីបុត្រអាពាធដោយខ្យល់១ រឿងភិក្ខុបន្ទោបង់បស្សាវៈ ក្នុងអារាមៗ ក៏មិនស្អាត អារាមមានក្លិនអាក្រក់ ភិក្ខុលំបាកនឹងអង្គុយបន្ទោបង់បស្សាវៈ ទ្រង់អនុញ្ញាតទ្រនាប់ជើង សម្រាប់បន្ទោបង់បស្សាវៈ ភិក្ខុអៀនខ្មាសនឹងបន្ទោបង់បស្សាវៈ ឆ្នាំងបស្សាវៈមិនមានគ្រប មានក្លិនអាក្រក់ ភិក្ខុបន្ទោបង់វច្ចៈ ក្នុងទីពីសពាសអារាមមានក្លិនអាក្រក់ អនុញ្ញាតឲ្យធ្វើរណ្តៅវច្ចៈ១ រឿងមាត់រណ្តៅបាក់រលុះ ទ្រង់អនុញ្ញាតឲ្យធ្វើទីដីឲ្យខ្ពស់ឡើង មួយអន្លើដោយខឿន៣យ៉ាង និងជណ្តើរ បង្កាន់ដៃជណ្តើរ ពួកភិក្ខុអង្គុយបន្ទោបង់វច្ចៈ ក្នុងទីបំផុត ក៏ធ្លាក់ចុះ ភិក្ខុលំបាកនឹងអង្គុយបន្ទោបង់វច្ចៈ ទ្រង់អនុញ្ញាតទ្រនាប់ជើង សម្រាប់បន្ទោបង់វច្ចៈ ពួកភិក្ខុបន្ទោបង់បស្សាវៈខាងក្រៅ ទ្រង់អនុញ្ញាតស្នូកបស្សាវៈ ទ្រង់អនុញ្ញាតឈើខ្នៀស និងត្រកសម្រាប់ដាក់ឈើខ្នៀស រណ្តៅវច្ចៈមិនមានគ្រប១ រឿងអនុញ្ញាតវច្ចកុដិ និងសន្ទះទ្វារ ក្របទ្វារ ក្បាល (ដំណាប់ក្រោម) អន្ទាក់លើ (ដំណាប់លើ) សសរទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឹះទ្វារ មេសោ ប្រហោងសម្រាប់ទាញ និងខ្សែសម្រាប់ទាញ ទ្រង់អនុញ្ញាតឲ្យបូក លាបវច្ចកុដិ ទាំងខាងក្នុង ទាំងខាងក្រៅ និងថ្នាំមានពណ៌ស ពណ៌ខ្មៅ ក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់ប្រាំ ស្នួរចីវរ ខ្សែស្ទៀង១ រឿងភិក្ខុមានកំលាំងថយដោយជរា អនុញ្ញាតកំពែង៣យ៉ាង អនុញ្ញាតបន្ទប់ទឹក និងកំពែងដូច្នោះ អនុញ្ញាតឲ្យរោយក្រួសរវាន អនុញ្ញាតឲ្យក្រាលកម្រាលថ្ម១ រឿងទឹកដក់នៅក្នុងបន្ទប់នោះ ទ្រង់អនុញ្ញាតទទឹក អនុញ្ញាតឆ្នាំងសម្រាប់ដាក់ទឹកជម្រះ អនុញ្ញាតផ្តិលសម្រាប់ជម្រះ ភិក្ខុលំបាកនឹងអង្គុយជម្រះ ភិក្ខុអៀនខ្មាសនឹងជម្រះ ទ្រង់អនុញ្ញាតគ្រប១ រឿងភិក្ខុប្រព្រឹត្តអនាចារ១។ រឿងអនុញ្ញាតលោហភណ្ឌ លើកលែងតែលោហភណ្ឌ ដែលជាគ្រឿងប្រហារទាំងពួង១។ រឿងព្រះមហាមុនី ទ្រង់អនុញ្ញាតគ្រែ វៀរលែងតែអាសន្ទិ ព្រះមហាមុនី ទ្រង់អនុញ្ញាតគ្រឿងឈើទាំងអស់ វៀរលែងតែបាត្រឈើ និងទ្រនាប់ជើងឈើ១។ រឿងព្រះតថាគត មានសេចក្តីអនុគ្រោះ ទ្រង់អនុញ្ញាតគ្រឿងដីទាំងពួង វៀរលែងតែទ្រនាប់សម្រាប់ជូតជើង ដែលគេធ្វើមានពកឡើង និងកុដិធ្វើដោយដីសុទ្ធ១។ កិរិយាសំដែងចេញនូវវត្ថុណា វត្ថុនោះដូចគ្នានឹងវត្ថុមុនដដែល យើងបានពោលទុកដោយសង្ខេបក្នុងឧទ្ទាន អ្នកប្រាជ្ញគប្បីដឹងនូវវត្ថុនោះ តាមន័យ (សមគួរចុះ)។ អ្នកប្រាជ្ញ ជាវិន័យធរ មានចិត្តប្រកបដោយប្រយោជន៍ មានសីលជាទីស្រឡាញ់ដោយប្រពៃ អ្នកធ្វើនូវប្រទីប គឺព្រះសទ្ធម្ម គួរដល់ការបូជា ជាពហុស្សូត ជាអ្នកញុំាងព្រះសទ្ធម្ម ឲ្យតាំងនៅមាំផង ជាអ្នកអនុគ្រោះ ដល់ភិក្ខុមានសីលជាទីស្រឡាញ់ទាំងឡាយផង បានសិក្សាហើយដោយប្រពៃ នូវវត្ថុមានចំនួន១១០ ក្នុងខុទ្ទកវត្ថុក្ខន្ធកៈ ក្នុងព្រះវិន័យ ដោយប្រការដូច្នេះហោង។

# សេនាសនក្ខន្ធកៈ (ទី៦)

CS vin.cv.06 | ភាគ ទី១០

### (៦. សេនាសនក្ខន្ធកំ)

## (បឋមភាណវារៈ ទី១)

CS vin.cv.06.01 | ភាគ ទី១០

### (១. បឋមភាណវារោ)

### (វិហារានុជាននៈ)

CS vin.cv.06.01.01 | ភាគ ទី១០

### (វិហារានុជាននំ)

[៣០៨] សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ។ សម័យនោះឯង ព្រះមានព្រះភាគ មិនទាន់បានបញ្ញត្តសេនាសនៈ ដល់ពួកភិក្ខុនៅឡើយ។ ភិក្ខុទាំងនោះ ក៏នៅក្នុងទីនោះៗ គឺព្រៃ គល់ឈើ ភ្នំ ច្រក គូហាទៀបភ្នំ ព្រៃស្មសាន ព្រៃធំ ទីកណ្តាលវាល និងគំនរចម្បើង។ លុះព្រលឹមឡើង ភិក្ខុទាំងនោះ ដើរចេញអំពីទីនោះៗ គឺព្រៃ គល់ឈើ ភ្នំ ច្រក គូហាទៀបភ្នំ ព្រៃស្មសាន ព្រៃធំ ទីកណ្តាលវាល និងគំនរចម្បើង សឹងមានចក្ខុសំឡឹងចុះ បរិបូណ៌ដោយឥរិយាបថ គឺឈានទៅមុខ ថយក្រោយ ក្រឡេកស្តាំ ក្រឡេកឆ្វេង បត់ចូល លាចេញ គួរឲ្យកើតសេចក្តីជ្រះថ្លា។

[៣០៩] គ្រានោះឯង រាជគហសេដ្ឋី បានទៅឱទ្យានអំពីព្រលឹម។ រាជគហសេដ្ឋី ក៏បានឃើញភិក្ខុទាំងនោះ កំពុងនិមន្តចេញពីទីនោះៗ គឺព្រៃ គល់ឈើ ភ្នំ ច្រក គូហាទៀបភ្នំ ព្រៃស្មសាន ព្រៃធំ ទីកណ្តាលវាល និងគំនរចម្បើងអំពីព្រលឹមដែរ សឹងមានចក្ខុសំឡឹងចុះ បរិបូណ៌ដោយ

ឥរិយាបថ គឺឈានទៅមុខ ថយក្រោយ ក្រឡេកស្តាំ ក្រឡេកឆ្វេង បត់ចូល លាចេញ គួរឲ្យកើតសេចក្តីជ្រះថ្លា។ លុះរាជគហសេដ្ឋីនោះឃើញហើយ ក៏មានចិត្តជ្រះថ្លា។ លំដាប់នោះ រាជគហសេដ្ឋី ក៏ដើរចូលទៅរកពួកភិក្ខុនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងភិក្ខុទាំងនោះថា បពិត្រលោកទាំងឡាយដ៏ចំរើន ប្រសិនបើខ្ញុំព្រះករុណាឲ្យគេធ្វើវិហារ[74] (ប្រគេន) តើលោកម្ចាស់ទាំងឡាយ នឹងនៅក្នុងវិហាររបស់ខ្ញុំព្រះករុណាឬទេ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលគហបតិ ព្រះមានព្រះភាគមិនទាន់បានអនុញ្ញាតវិហារទេ។ រាជគហសេដ្ឋីឆ្លើយថា បពិត្រលោកទាំងឡាយដ៏ចំរើន បើដូច្នោះ សូមលោកម្ចាស់ ក្រាបបង្គំទូលសួរ ចំពោះព្រះមានព្រះភាគ (អំពីរឿងវិហារនោះ) ហើយមេត្តាប្រាប់ដល់ខ្ញុំព្រះករុណាផង។ ភិក្ខុទាំងនោះ ទទួលស្តាប់ពាក្យរាជគហសេដ្ឋី ដោយពាក្យថា យ៉ាងហ្នឹងហើយ គហបតិ រួចក៏ចូលទៅកាន់ទី ដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ។ ភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន រាជគហសេដ្ឋី មានសេចក្តីប្រាថ្នានឹងឲ្យគេធ្វើវិហារ បពិត្រព្រះអង្គដ៏ចំរើន តើយើងខ្ញុំគប្បីប្រតិបត្តិដូចម្តេច។

[៣១០] ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេនាសនៈ៥យ៉ាង គឺវិហារ[75] ១ អឌ្ឍយោគ[76] ១ ប្រាសាទ[77] ១ ហម្មិយៈ[78] ១ គុហា[79] ១។

[៣១១] គ្រានោះ ពួកភិក្ខុនោះ ចូលទៅរករាជគហសេដ្ឋី លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងរាជគហសេដ្ឋីថា ម្នាលគហបតិ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតវិហារហើយ ឥឡូវនេះ អ្នកយល់ថាកាលណាគួរ (ក៏គប្បីធ្វើចុះ)។ គ្រានោះ រាជគហសេដ្ឋី ឲ្យគេសាងវិហារចំនួន៦០ តែមួយថ្ងៃគត់ ក៏ហើយជាស្រេច។ រាជគហសេដ្ឋី ឲ្យគេសាងវិហារ៦០ រួចស្រេចហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ។ រាជគហសេដ្ឋី លុះអង្គុយក្នុងទីសមគួរហើយ បានក្រាបទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីធ្វើភត្តកិច្ច ក្នុងថ្ងៃស្អែក។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្ត ដោយតុណ្ហីភាព។ គ្រានោះ រាជគហសេដ្ឋី ដឹងច្បាស់ថា ព្រះមានព្រះភាគ ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចចៀសចេញទៅ។ គ្រាកាលកន្លងរាត្រីនោះទៅ រាជគហសេដ្ឋី ក៏ឲ្យតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ហើយឲ្យទៅក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន វេលាគួរហើយ ភត្តសម្រេចហើយ។

[៣១២] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ និងបាត្រចីវរ ក្នុងវេលាបុព្វណ្ហសម័យ ហើយទ្រង់យាងទៅកាន់លំនៅនៃរាជគហសេដ្ឋី លុះយាងទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាល (បម្រុងទុក) មួយអន្លើ ដោយភិក្ខុសង្ឃ។ ឯរាជគហសេដ្ឋី បានអង្គាសខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពីសារដោយដៃខ្លួនឯង ថ្វាយចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ លុះព្រះមានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ (សេដ្ឋីនោះ) ក៏អង្គុយក្នុងទីសមគួរ។ រាជគហសេដ្ឋី លុះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយបុណ្យ និងឋានសួគ៌ បានសាងវិហារទាំង៦០នុ៎ះស្រេចហើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ នឹងប្រតិបត្តិក្នុងវិហារទាំងនោះដូចម្តេច។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលគហបតិ បើដូច្នោះ អ្នកចូរប្រតិស្ឋានវិហារទាំង៦០នោះ សម្រាប់សង្ឃ ដែលមកហើយ និងមិនទាន់មក អំពីទិសទាំង៤ចុះ។ រាជគហសេដ្ឋី ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ប្រតិស្ឋានវិហារទាំង៦០នោះ ដើម្បីសង្ឃ ដែលមកហើយ ទាំងមិនទាន់មក អំពីទិសទាំង៤។ ទើបព្រះមានព្រះភាគ ទ្រង់អនុមោទនា ចំពោះរាជគហសេដ្ឋី ដោយគាថាទាំងឡាយនេះថា

[៣១៣] (វិហារ គឺទីអាវាស ឬសេនាសនៈ ជាទីនៅនៃសង្ឃទាំងឡាយ) រមែងការពាររងាផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូច និងពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់ និងកំដៅថ្ងៃដ៏ក្លាខ្លាំង ដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះៗ។ វិហារទាន គឺការឲ្យលំនៅ (ដែលបុគ្គលបានឲ្យហើយ) ដល់សង្ឃ ដើម្បីជាទីជ្រកកោនផង ដើម្បីនៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចំរើនវិបស្សនាផង ព្រះពុទ្ធទាំងឡាយ តែងសរសើរ ថាជាទានដ៏ប្រសើរ។ ព្រោះហេតុនោះឯង បុរស (ស្ត្រី) ជាបណ្ឌិត កាលបើបានឃើញច្បាស់ នូវប្រយោជន៍របស់ខ្លួន ក៏គួរកសាងព្រះវិហារ គឺអាវាស ឬសេនាសនៈទាំងឡាយ ដ៏ជាទីគួររីករាយ ហើយគួរនិមន្តលោក ដែលជាពហុស្សូត[80] គឺលោកអ្នកចេះដឹងច្រើនទាំងឡាយ ឲ្យនៅក្នុងទីនោះ។ គួរមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយ ដែលមានចិត្តត្រង់ ហើយប្រគេនបាយ ទឹក សំពត់ និងសេនាសនៈទាំងឡាយ ដល់លោកទាំងនោះចុះ។ លោកទាំងនោះ រមែងសំដែងធម៌ ជាគ្រឿងបន្ទោបង់ ឲ្យឃ្លាតចាកទុក្ខគ្រប់ប្រការ ដល់អ្នកនោះ លុះអ្នកនោះបានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន។ កាលដែលព្រះមានព្រះភាគ ទ្រង់អនុមោទនា ចំពោះរាជគហសេដ្ឋី ដោយគាថាទាំងឡាយនេះហើយ ទើបទ្រង់ក្រោកចាកអាសនៈ យាងចៀសចេញទៅ។

[៣១៤] មនុស្សទាំងឡាយបានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតវិហារហើយ។ មនុស្សទាំងនោះ ក៏យកចិត្តទុកដាក់ នាំគ្នាកសាងវិហារ។ វិហារទាំងនោះ មិនទាន់មានសន្ទះទ្វារនៅឡើយ។ ពស់ និងខ្ទួយខ្លះ ក្អែបខ្លះ ក៏តែងចូលទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យមានសន្ទះទ្វារ។ ពួកភិក្ខុធ្វើប្រហោងជញ្ជាំង ហើយចងសន្ទះទ្វារដោយវល្លិខ្លះ ដោយខ្សែខ្លះ។ កណ្តុរខ្លះ កណ្តៀរខ្លះ ក៏ចេះតែកោរកាត់។ ចំណងដែលសត្វកាត់ហើយ សន្ទះទ្វារ ក៏ធ្លាក់ចុះមក។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ក្របទ្វារ ដំណាប់ក្រោម និងដំណាប់លើ។ សន្ទះទ្វារទាំងឡាយ មិនជិតស្និទ្ធល្អ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ប្រហោងសម្រាប់ដាក់ខ្សែទាញ និងខ្សែសម្រាប់ទាញ។ ភិក្ខុបិទសន្ទះទ្វារ មិនកើត។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) មេទ្វារ ត្រដោកទ្វារ រនុកទ្វារ និងគន្លឹះទ្វារខាងលើ។

[៣១៥] សម័យនោះ ពួកភិក្ខុបិទសន្ទះទ្វារមិនកើត។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ប្រហោងសោ និងសោ៣យ៉ាង គឺ សោធ្វើដោយលោហជាតិ១ សោធ្វើដោយឈើ១ សោធ្វើដោយស្នែង១។ ភិក្ខុទាំងឡាយណាបើកទ្វារចូលទៅ។ (ភិក្ខុទាំងនោះ) មិនបានបិទវិហារទៅវិញ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) គ្រឿងយន្ត និងគន្លឹះ។

[៣១៦] សម័យនោះឯង វិហារប្រក់ស្មៅ រដូវរងាក៏រងាណាស់ រដូវក្ដៅ ក៏ក្ដៅណាស់។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអប ឬឲ្យគាបដម្បូល ហើយបូកលាបខាងក្នុង និងខាងក្រៅ។

[៣១៧] សម័យនោះឯង វិហារមិនទាន់មានបង្អួចនៅឡើយ ទៅជាងងឹត មើលអ្វីមិនឃើញ ទាំងធំក្លិនស្អុយ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត បង្អួច៣យ៉ាង គឺបង្អួចមានវេទិ[81] (ដូចវេទីចេតិយ)១ បង្អួចដែលគេចង ឲ្យមានសណ្ឋានដូចក្រឡាសំណាញ់១ បង្អួចមានឈើចំរឹង១។ សត្វកង្ហែនខ្លះ ប្រចៀវខ្លះ ចូលទៅតាមចន្លោះបង្អួចបាន។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរនាំងបង្អួច។ សត្វកង្ហែនខ្លះ ប្រចៀវខ្លះ ក៏ចូលទៅតាមចន្លោះរនាំង (នោះទៀត)។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះបង្អួច ឬរនាំងពួកបង្អួច។

[៣១៨] សម័យនោះឯង ពួកភិក្ខុដេកផ្ទាល់នឹងផែនដី។ ខ្លួន និងចីវររបស់ភិក្ខុប្រឡាក់ដោយអាចម៍ដី។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកម្រាលធ្វើដោយស្មៅ។ សត្វកណ្ដុរ និងកណ្ដៀរ តែងកាត់កម្រាលស្មៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្ទះក្ដារសម្រាប់ដេក។ ពួកភិក្ខុឈឺខ្លួន ព្រោះដេកលើបន្ទះក្ដារ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែផ្ដៅ។

## (មញ្ចបីឋាទិអនុជាននៈ)

CS vin.cv.06.01.02 | ភាគ ទី១០

### (មញ្ចបីឋាទិអនុជាននំ)

[៣១៩] សម័យនោះឯង គ្រែដែលមានមេ គេបញ្ចូលទៅក្នុងដំណាប់ជើង ដែលគេចោលក្នុងព្រៃស្មសាន កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែ ដែលមានមេ គេបញ្ចូលទៅក្នុងដំណាប់ជើង។ (តមកទៀត) មានតាំងដែលមានមេ គេបញ្ចូលទៅក្នុងដំណាប់ជើង កើតឡើង(ដល់សង្ឃ)។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង ដែលមានមេ គេបញ្ចូលទៅក្នុងដំណាប់ជើង។

[៣២០] សម័យនោះឯង គ្រែដែលគេបង្ខាំជើង ដោយមេគ្រែ ចោលក្នុងព្រៃស្មសាន កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែ ដែលគេបង្ខាំជើងដោយមេគ្រែ។ (តមកទៀត) តាំងដែលគេបង្ខាំជើង ដោយមេតាំង កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង ដែលគេបង្ខាំជើងជាប់នឹងមេតាំង។

[៣២១] សម័យនោះឯង គ្រែមានជើងដូចជើងក្ដាម[82] ដែលគេចោលក្នុងព្រៃស្មសាន កើតឡើងដល់សង្ឃ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត គ្រែមានជើងដូចជើងក្ដាម។ (តមកទៀត) តាំងមានជើងដូចជើងក្ដាម[83] កើតឡើង(ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត តាំងមានជើងដូចជើងក្ដាម។

[៣២២] សម័យនោះឯង គ្រែមានជើងទល់នឹងមេ ឬគ្រែដែលគេបញ្ចូលជើង ទៅក្នុងដំណាប់មេ ដែលគេចោលក្នុងព្រៃស្មសាន កើតឡើងដល់សង្ឃ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមានជើងទល់នឹងមេ ឬគ្រែដែលគេបញ្ចូលជើង ទៅក្នុងដំណាប់មេ។ (តមកទៀត) តាំងមានជើងទល់នឹងមេ ឬតាំងដែលគេបញ្ចូលជើង ទៅក្នុងដំណាប់មេ កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង មានជើងទល់នឹងមេ ឬតាំងដែលគេបញ្ចូលជើង ទៅក្នុងដំណាប់មេ។

[៣២៣] សម័យនោះឯង តាំង៤ជ្រុងកើតឡើងដល់សង្ឃ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង៤ជ្រុង។ (តមកទៀត) តាំង៤ជ្រុង មានជើងខ្ពស់ កើតឡើង(ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង៤ជ្រុង សូម្បីមានជើងខ្ពស់[84]។ (តមកទៀត) គ្រែមានអង្គ៧ កើតឡើង(ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែ មានអង្គ៧។[85] (តមកទៀត) គ្រែមានអង្គ៧ មានជើងខ្ពស់កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមានអង្គ៧ សូម្បីមានជើងខ្ពស់ក៏បាន។ (តមកទៀត) មានតាំងចាក់ផ្ដៅ[86] កើតឡើង(ដល់សង្ឃ)។ បេ។ ព្រះអង្គ ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងចាក់ផ្ដៅ។ (តមកទៀត) មានតាំងសំពត់ កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

តថាគតអនុញ្ញាតតាំងសំពត់។ (តមកទៀត) តាំងមានជើងដូចជើងពពែ កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំងមានជើងដូចជើងពពែ។ (តមកទៀត) ក៏មានតាំង (មានជើងច្រើន ដែលគេប្រកបដោយ) អាការដូចជាផ្លែកន្ទួតព្រៃ កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង (មានជើងច្រើន ដែលគេប្រកបដោយ) អាការដូចជាផ្លែកន្ទួតព្រៃ។ (តមកទៀត) ផែនក្ដារ ក៏កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផែនក្ដារ។ (តមកទៀត) កៅអី ក៏កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតកៅអី។ (តមកទៀត) តាំង ដែលធ្វើពីចំបើង ក៏កើតឡើង។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង ដែលធ្វើពីចំបើង។

[៣២៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដេកលើគ្រែខ្ពស់។ មនុស្សទាំងឡាយ ដើរមកកាន់វិហារចារិកបានឃើញ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំដេកលើគ្រែខ្ពស់ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ។

[៣២៥] សម័យនោះឯង ភិក្ខុ១រូបដេកលើគ្រែទាប ពស់ក៏ចឹក (ភិក្ខុនោះ)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់គ្រែ។

[៣២៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ទ្រនាប់គ្រែខ្ពស់។ ភិក្ខុធ្វើគ្រែឲ្យរញ្ជួយទាំងទ្រនាប់គ្រែ។ មនុស្សទាំងឡាយដើរមកកាន់វិហារចារិក បានឃើញ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់គ្រែខ្ពស់ទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់គ្រែយ៉ាងខ្ពស់ត្រឹម៨ធ្នាប់។

[៣២៧] សម័យនោះឯង អម្បោះកើតឡើងដល់សង្ឃ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកអម្បោះចងប្រទាក់គ្រែ។ ភិក្ខុចងប្រទាក់រាងគ្រែ (ទាំងនោះ) ក៏អស់អម្បោះប្រើ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចោះត្រង់រាងគ្រែ ហើយចងឆ្វាក់ ជាក្រឡាចត្រង្គ។ (តមកទៀត) កំណាត់សំពត់ ក៏កើតឡើង (ដល់សង្ឃ)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទ្រនាប់។ (តមកទៀត) គ្រឿងសេនាសនៈ ដែលញាត់ដោយប៉ុយ ក៏កើតឡើង (ដល់សង្ឃ)។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជជុះចេញ ហើយធ្វើជាខ្នើយបាន ឯប៉ុយមាន៣យ៉ាង គឺប៉ុយដើមឈើ១ ប៉ុយវល្លិ១ ប៉ុយស្មៅ១។

[៣២៨] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រើប្រាស់ខ្នើយពាក់កណ្ដាលកាយ។ មនុស្សទាំងឡាយ ដើរទៅកាន់វិហារចារិកឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់ខ្នើយពាក់កណ្ដាលកាយទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើខ្នើយ ឲ្យល្មមប៉ុនក្បាល។

[៣២៩] សម័យនោះឯង មានមហោស្រពលេងលើកំពូលភ្នំ ជិតក្រុងរាជគ្រឹះ។ មនុស្សទាំងឡាយ នាំគ្នាតាក់តែងពូកជាច្រើន គឺពូកញាត់រោមកែះ ញាត់សំពត់ ញាត់សម្បកឈើ ញាត់ស្មៅ ញាត់ស្លឹកឈើ ដើម្បីប្រយោជន៍ដល់ពួកមហាមាត្យ។ លុះមហោស្រពស្ងប់ស្ងាត់ ឈប់លេងហើយ មនុស្សទាំងនោះ ក៏បកតែស្រោមពូក យកទៅ។ ពួកភិក្ខុ ក៏បានឃើញពូកទាំងឡាយ ញាត់រោមកែះខ្លះ ញាត់សំពត់ខ្លះ ញាត់សម្បកឈើខ្លះ ញាត់ស្មៅខ្លះ ញាត់ស្លឹកឈើខ្លះ ជាច្រើន ដែលគេចោលនៅទីមហោស្រព។ លុះឃើញហើយ ក៏ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតពូក៥យ៉ាង គឺពូកញាត់រោមកែះ១ ពូកញាត់សំពត់១ ពូកញាត់សម្បកឈើ១ ពូកញាត់ស្មៅ១ ពូកញាត់ស្លឹកឈើ១។

[៣៣០] សម័យនោះឯង មានសំពត់ជារបស់គួរប្រើប្រាស់ ក្នុងសេនាសនៈ កើតឡើងដល់សង្ឃ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុញាត់ពូកដោយសំពត់។

[៣៣១] សម័យនោះឯង ពួកភិក្ខុយកពូកសម្រាប់គ្រែ ទៅក្រាលលើតាំង យកពូកសម្រាប់តាំង ទៅក្រាលគ្រែវិញ។ ពូកទាំងឡាយ ក៏រហែកអស់។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែដែលញាត់ភ្ជាប់ និងតាំងដែលញាត់ភ្ជាប់ (ដោយគ្រឿងញាត់)។ ពួកភិក្ខុ មិនបានទ្រាប់ទ្រនាប់ពីក្រោម ហើយក៏ក្រាល។ គ្រឿងញាត់ទាំងនោះ ក៏លៀនចេញទៅខាងក្រៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទ្រាប់ នូវទ្រនាប់ រួចក្រាល ហើយសឹមញាត់ពូក។ ពួកចោរ ក៏បកតែស្រោមពូកយកទៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រស់ព្រំ។[87] ពួកចោរក៏នៅតែលួចទៀត។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុគូសដោយគំនូសផ្សេងៗ។ ពួកចោរក៏នៅតែលួចយកទៀត។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្តិតនឹងម្រាមដៃ។

## (សេតវណ្ណាទិអនុជាននៈ)

CS vin.cv.06.01.03 | ភាគ ទី១០

## (សេតវណ្ណាទិអនុជាននំ)

[៣៣២] សម័យនោះឯង ទីដេករបស់ពួកតិរ្ថិយ មានពណ៌ស។ ផ្ទៃលាបពណ៌ខ្មៅ។ ជញ្ជាំងលាបដោយរង់។ មនុស្សទាំងឡាយជាច្រើន (ដែលទៅដល់ទីនោះ) មៀងមើលទីដេកហើយ ទើបដើរទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបូកលាបវិហារ ឲ្យមានពណ៌ស ពណ៌ខ្មៅ និងលាបដោយរង់។

[៣៣៣] សម័យនោះឯង ពណ៌ស ជិតមិនស្មើ ព្រោះផ្ទៃជញ្ជាំងមិនស្អាត។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយអង្កាម ហើយកៀសដោយខ្នៀស ឲ្យពណ៌សជិតស្មើ។ ពណ៌ស ក៏នៅតែមិនស្អិតជាប់គ្នា។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយដីស្អិតដ៏មដ្ឋ ហើយកៀសដោយខ្នៀស ឲ្យពណ៌សជិតស្មើ។ ពណ៌ស ក៏នៅតែមិនស្អិតជាប់គ្នា។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជ័រឈើ ឬបាយម៉ានក៏បាន។

[៣៣៤] សម័យនោះឯង ផ្ទៃជញ្ជាំងអាក្រក់ ជ័ររង់ជិតមិនស្មើ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយអង្កាម ហើយកៀសដោយខ្នៀស ឲ្យជ័ររង់ជិតស្មើ។ ជ័ររង់ ក៏នៅតែជិតមិនស្មើ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកដីដែលលាយដោយកុណ្ឌក ហើយកៀសដោយខ្នៀស ឲ្យជ័ររង់ជិតស្មើ។ ជ័ររង់ ក៏នៅតែជិតមិនស្មើ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យយកម្សៅគ្រាប់ស្ពៃ ឬប្រេងលាយក្រមួន។ ដំណក់ថ្នាំលាប ក៏ជោរឡើង (ហូរចៀរចេញ)។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យជូតដោយកំណាត់សំពត់ចេញ។

[៣៣៥] សម័យនោះឯង ផ្ទៃជញ្ជាំងអាក្រក់ ពណ៌ខ្មៅជិតមិនសព្វ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយអង្កាម ហើយកៀសដោយខ្នៀស ឲ្យពណ៌ខ្មៅជិតស្មើ។ ពណ៌ខ្មៅ ក៏នៅតែមិនស្អិតជាប់គ្នា។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលាយដីអាចម៍ជន្លេន ហើយកៀសដោយខ្នៀស ឲ្យពណ៌ខ្មៅជិតស្មើ។ ពណ៌ខ្មៅ ក៏នៅតែមិនស្អិតជាប់គ្នា។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជ័រឈើ និងទឹកចត់។[88)]

## (បដិភានចិត្តបដិក្ខេប)

CS vin.cv.06.01.04 | ភាគ ទី១០

### (បដិភានចិត្តបដិក្ខេបំ)

[៣៣៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេគូរគំនូរជារូបស្រី និងរូបបុរស ក្នុងវិហារ។ មនុស្សទាំងឡាយ ដើរមកកាន់វិហារចារិក ឃើញហើយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។ បេ។ ដូចពួកគ្រហស្ថ អ្នកបរិភោគកាម។ បេ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេគូរគំនូរ ជារូបស្រី និងរូបបុរសទេ ភិក្ខុណាឲ្យគេគូរ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគំនូរភ្ញីផ្កា និងគំនូរភ្ញីវល្លិ និងក្បាច់ធ្មេញមករ និងក្បាច់មានស្រទាប់៥។

## (ឥដ្ឋកាចយាទិអនុជាននៈ)

CS vin.cv.06.01.05 | ភាគ ទី១០

### (ឥដ្ឋកាចយាទិអនុជាននំ)

[៣៣៧] សម័យនោះឯង វិហារមានទីទាប។ ទឹកក៏លិច។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង។ ខឿនវិហារក៏រលំ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកខឿន៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ពួកភិក្ខុនាំគ្នាឡើងទៅ ក៏លំបាក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជណ្តើរ៣យ៉ាង គឺ ជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ ពួកភិក្ខុនាំគ្នាឡើងទៅ ក៏ធ្លាក់ចុះមកវិញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃ។

[៣៣៨] សម័យនោះឯង វិហារមានមនុស្សកុះករច្រើនពេក។ ពួកភិក្ខុក៏អៀនខ្មាស (មិនអាច) នឹងសិងបាន។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) រនាំង។ ពួកមនុស្ស ក៏នៅតែបើករនាំងមើល។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជញ្ជាំងតឿ។ ពួកមនុស្ស ក៏នៅតែអើតមើលពីខាងលើជញ្ជាំងតឿទៀត។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបន្ទប់៣យ៉ាង គឺបន្ទប់មានជ្រុងបួន១ បន្ទប់មានបណ្តោយវែង១ បន្ទប់មានដម្បូលខ្ពស់១។

[៣៣៩] សម័យនោះឯង ពួកភិក្ខុធ្វើបន្ទប់ត្រង់កណ្តាលវិហារតូច។ ទីឧបចារៈមិនមាន។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបន្ទប់ក្នុងទីសមគួរ ក្នុងវិហារតូច ឲ្យធ្វើបន្ទប់ត្រង់កណ្តាលវិហារធំបាន។

[៣៤០] សម័យនោះឯង ជើងជញ្ជាំងវិហារ ក៏ពុកផុយទៅ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទ្រនាប់ជើងជញ្ជាំង។ ភ្លៀងក៏សាចមកត្រូវជញ្ជាំងវិហារ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រដឹសសម្រាប់ការពារភ្លៀង ហើយលាបដីស្អិត។[89)]

[៣៤១] សម័យនោះឯង មានពស់ធ្លាក់ពីដម្បូលស្មៅ មកលើ-ក-ភិក្ខុ១រូប។ ភិក្ខុនោះខ្លាច ក៏ស្រែកភ្លាត់សំឡេង។ ភិក្ខុទាំងឡាយ ក៏ស្ទុះទៅសួរភិក្ខុនោះដូច្នេះថា ម្នាលអាវុសោ ព្រោះហេតុអ្វី បានជាលោកស្រែកភ្លាត់សំឡេងដល់ម្ល៉េះ។ ទើបភិក្ខុនោះ បានប្រាប់សេចក្តីនុ៎ះ ដល់ពួកភិក្ខុ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ពិតានឡើង។

[៣៤២] សម័យនោះឯង ពួកភិក្ខុព្យួរថង់នឹងជើងគ្រែខ្លះ នឹងជើងតាំងខ្លះ។ អស់ទាំងសត្វកណ្តុរ និងកណ្តៀរ កាត់ដាច់ដាចអស់។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យធ្វើ) ចំរឹងជញ្ជាំង និងដៃកែវ។

[៣៤៣] សម័យនោះឯង ពួកភិក្ខុទុកចីវរលើគ្រែខ្លះ លើតាំងខ្លះ។ ចីវរក៏ធ្លុះធ្លាយអស់។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្នួរចីវរ និងខ្សែស្នៀងទុកក្នុងវិហារ។

[៣៤៤] សម័យនោះឯង វិហារនៅមិនទាន់មានរបៀង ឥតមានទីញកជ្រកកោនបាន។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយ័មុខ ជើងជញ្ជាំង ឬធរណីបាំងសាចជុំវិញ និងហោណាំង។ យ័មុខ ក៏នៅវាល (ឥតមានវត្ថុអ្វីបិទបាំង)។ ពួកភិក្ខុ អ្នកមានអៀនខ្មាស (មិនអាច) នឹងសិងបាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតរនាំងព្រួល សម្រាប់រូតចុះឡើង នឹងឡប់ឡែ។

## (ឧបដ្ឋានសាលាអនុជាននៈ)

CS vin.cv.06.01.06 | ភាគ ទី១០

### (ឧបដ្ឋានសាលាអនុជាននំ)

[៣៤៥] សម័យនោះឯង ពួកភិក្ខុធ្វើនូវការឆាន់អាហារ ក្នុងទីវាល លំបាកដោយត្រជាក់ខ្លះ ក្តៅខ្លះ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបដ្ឋានសាលា[90)] ឧបដ្ឋានសាលា ក៏មានទីទាប។ ទឹកក៏លិច។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង។ ខឿនសាលានោះ ក៏រលំ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកខឿន៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ពួកភិក្ខុ ឡើងទៅតាមខឿននោះក៏លំបាក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជណ្តើរ៣យ៉ាង គឺជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ ពួកភិក្ខុឡើងតាមជណ្តើរនោះ ក៏ធ្លាក់មកវិញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃឡើង។ កំទេចស្មៅ ក៏ធ្លាក់រោយរាយចុះមក ក្នុងឧបដ្ឋានសាលា។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូលហើយលាប ទាំងខាងក្នុង ខាងក្រៅ ហើយបរិកម្មឲ្យមានពណ៌ស ពណ៌ខ្មៅ ពណ៌រង់ គួរគំនូរភ្ញីផ្កា គំនូរភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥ ស្នួរចីវរ និងខ្សែស្នៀង។

[៣៤៦] សម័យនោះឯង ពួកភិក្ខុហាលចីវរលើដីក្នុងទីវាល។ ចីវរក៏ប្រឡាក់អាចម៍ដី។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើស្នួរចីវរ និងខ្សែស្នៀងក្នុងទីវាល។ បេ។ ទឹកសម្រាប់ឆាន់ក៏ក្តៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើរោងសម្រាប់ដាក់ទឹកឆាន់ និងបាំរាំងសម្រាប់ដាក់ទឹកឆាន់។ រោងសម្រាប់ដាក់ទឹកឆាន់នោះ ក៏មានទីទាប។ ទឹកក៏លិច។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង។ ខឿនរោងនោះ ក៏រលំ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកខឿន៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ពួកភិក្ខុ ឡើងទៅតាមខឿននោះ ក៏លំបាក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជណ្តើរ៣យ៉ាង គឺជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ ពួកភិក្ខុឡើងតាមជណ្តើរនោះ ក៏ធ្លាក់មកវិញ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃឡើង។ កំទេចស្មៅ ក៏ធ្លាក់រោយរាយចុះមក ក្នុងរោងសម្រាប់ដាក់ទឹកឆាន់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ហើយឲ្យលាប ទាំងខាងក្នុង ខាងក្រៅ បរិកម្មឲ្យមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ គួរគំនូរភ្ញីផ្កា គំនូរភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥ ស្នួរចីវរ និងខ្សែស្នៀង។ (គ្រានោះ) ភាជន៍សម្រាប់ដាក់ទឹកឆាន់មិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស័ង្ខសម្រាប់ដាក់ទឹកឆាន់ និងផ្តិលទឹក។

## (បាការាទិអនុជាននៈ អារាមបរិក្ខេបអនុជាននៈ)

CS vin.cv.06.01.07-08 | ភាគ ទី១០

### (បាការាទិអនុជាននំ អារាមបរិក្ខេបអនុជាននំ)

[៣៤៧] សម័យនោះឯង វិហារមិនមានគ្រឿងបិទបាំង។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបិទបាំង ដោយកំពែង៣យ៉ាង គឺ កំពែងឥដ្ឋ១ កំពែងថ្ម១ កំពែងឈើ១។ បន្ទប់ទឹកមិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្ទប់ទឹក។ បន្ទប់ទឹកមានទីទាប។ ទឹកក៏លិច។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង។ សន្ទះទ្វារបន្ទប់ ក៏មិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ដំណាប់ក្រោម ដំណាប់លើ មេទ្វារ ត្រដោកទ្វារ រនុកទ្វារ គន្លឺះទ្វារខាងលើ ប្រហោងសោ ប្រហោងសម្រាប់ទាញ និងខ្សែសម្រាប់ទាញ។ កំទេចស្មៅ ក៏ធ្លាក់

រោយរាយចុះមក ក្នុងបន្ទប់។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ហើយធ្វើប្រដីស ហើយលាបទាំងខាងក្នុង ខាងក្រៅ លាបឲ្យមានពណ៌ស ពណ៌ខ្មៅ បរិកម្មដោយរង់ ធ្វើជាក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥។

[៣៤៨] សម័យនោះឯង ទីបរិវេណ មានភក់ជ្រាំ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យចាក់ក្រាលក្រួសរវាន (នៅទីនោះ)។ ក្រួសរវាន ក៏មិនបានរាបស្មើ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលថ្ម។ ទឹកក៏ដក់នៅ (លើថ្មនោះ)។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតប្រឡាយទឹក។

[៣៤៩] សម័យនោះឯង ភិក្ខុនាំគ្នាធ្វើចង្ក្រានត្រង់ទីនោះៗ ក្នុងបរិវេណ។ ទីបរិវេណ ក៏ខ្មាំដោយសម្រាម។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើរោងភ្លើង ក្នុងទីដ៏សមគួរ។ រោងភ្លើងមានទីទាប។ ទឹកក៏លិច។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើទីឲ្យខ្ពស់ឡើង។ ខឿន (រោងភ្លើងនោះ) រលំ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យកខឿន៣យ៉ាង គឺខឿនឥដ្ឋ១ ខឿនថ្ម១ ខឿនឈើ១។ ពួកភិក្ខុ ឡើង (តាមខឿននោះទៅ) ក៏លំបាក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជណ្តើរ ៣យ៉ាង គឺជណ្តើរឥដ្ឋ១ ជណ្តើរថ្ម១ ជណ្តើរឈើ១។ ពួកភិក្ខុឡើងទៅ (តាមជណ្តើរ) ក៏ធ្លាក់ចុះមក។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើបង្កាន់ដៃឡើង។ សន្ទះទ្វារនៃរោងភ្លើង នៅមិនទាន់មាន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ដំណាប់ក្រោម ដំណាប់លើ មេទ្វារ ត្រដោកទ្វារ គន្លឹះទ្វារខាងលើ ប្រហោងសោ ប្រហោងសម្រាប់ដាក់ខ្សែទាញ និងខ្សែទាញ។ កំទេចស្មៅ ក៏ធ្លាក់រោយរាយចុះមក ក្នុងរោងភ្លើង។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ហើយធ្វើប្រដីស លាបទាំងខាងក្នុង ខាងក្រៅ ធ្វើឲ្យមានពណ៌ស ពណ៌ខ្មៅ លាបដោយរង្គ ធ្វើជាក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ ក្បាច់មានស្រទាប់៥ ស្នួរចីវរ និងខ្សែស្បៀង។ អារាម នៅមិនទាន់មានរបង។ ពួកសត្វពពែ និងសត្វចិញ្ចឹម (ឯទៀតៗ) តែងចូលទៅបៀតបៀនដំណាំ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបិទបាំងរបង៣យ៉ាង គឺរបងឫស្សី១ របងបន្លា១ និងស្នាមភ្លោះ១។ ខ្លោងទ្វារនៅមិនទាន់មាន។ ពួកសត្វពពែ និងសត្វចិញ្ចឹម (ឯទៀតៗ) នៅតែចូលទៅបៀតបៀនដំណាំបានដដែល។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្លោងទ្វារ ទ្វារគាបបន្លា[91)] សន្ទះទ្វារទាំងគូ របងសសរ និងទ្វារជើងគុល។ កំទេចស្មៅ ក៏ធ្លាក់រោយរាយចុះមក ក្នុងខ្លោងទ្វារ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យគាបដម្បូល ធ្វើប្រដីស ហើយលាប ទាំងខាងក្នុង ខាងក្រៅ លាបឲ្យមានពណ៌ស ពណ៌ខ្មៅ លាបដោយរង្គ ធ្វើក្បាច់ភ្ញីផ្កា ក្បាច់ភ្ញីវល្លិ ក្បាច់ធ្មេញមករ និងក្បាច់មានស្រទាប់៥។ អារាម ក៏មានភក់ជ្រាំ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលក្រួសរវាន។ ក្រួសនោះ ក៏មិនបានរាបស្មើ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាលថ្ម។ ទឹកក៏ដក់នៅ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើប្រឡាយទឹក។

[៣៥០] សម័យនោះឯង ព្រះបាទពិម្ពិសារមាគធសេនិយរាជ ទ្រង់មានបំណងឲ្យគេសាងប្រាសាទ លាបដោយបាយអ ដើម្បីប្រយោជន៍ដល់សង្ឃ។ វេលានោះ ពួកភិក្ខុ មានសេចក្តីត្រិះរិះថា គ្រឿងសម្រាប់ប្រក់ ព្រះមានព្រះភាគ បានអនុញ្ញាតហើយឬ។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រឿងប្រក់៥យ៉ាង គឺប្រក់ដោយឥដ្ឋ១ ប្រក់ដោយថ្ម១ ប្រក់ដោយបាយអ១ ប្រក់ដោយស្មៅ១ ប្រក់ដោយស្លឹកឈើ១។

ចប់ភាណវារៈ ជាបឋម។

# (ទុតិយភាណវារៈ ទី២)

CS vin.cv.06.02 | ភាគ ទី១០

### (២. ទុតិយភាណវារោ)

រឿងអនាថបិណ្ឌិកសេដ្ឋី និងរឿងរាជគហសេដ្ឋី

## (អនាថបិណ្ឌិកវត្ថុ)

CS vin.cv.06.02.01 | ភាគ ទី១០

### (អនាថបិណ្ឌិកវត្ថុ)

[៣៥១] សម័យនោះឯង អនាថបិណ្ឌិកគហបតិ ជាប្តីប្អូនស្រីរបស់រាជគហសេដ្ឋី គឺជាប្អូនថ្លៃរាជគហសេដ្ឋី។ គ្រានោះ អនាថបិណ្ឌិកគហបតិ បានទៅកាន់ក្រុងរាជគ្រឹះ ដោយកិច្ចការនីមួយ។

[៣៥២] សម័យនោះឯង រាជគហសេដ្ឋី និមន្តព្រះសង្ឃ មានព្រះពុទ្ធអង្គ ជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក។ ឯរាជគហសេដ្ឋី ក៏បានបង្គាប់ខ្ញុំប្រុសស្រីខ្លះ និងពួកអ្នកធ្វើការឈ្នួលខ្លះថា នែនាយរាល់គ្នា បើដូច្នោះ ចូរអ្នករាល់គ្នាក្រោមពីព្រលឹម ហើយចំអិនបបរ ចំអិនបាយ ចាត់ចែងសម្លនិងតាក់តែងសម្លឧត្តរិភង្គៈ (ឲ្យល្អ)។

[៣៥៣] លំដាប់នោះ អនាថបិណ្ឌិកគហបតិ មានសេចក្តីត្រិះរិះថា កាលពីដើម បើអញបានមកដល់ហើយ គហបតិនេះ ក៏រមែងតែបញ្ឈប់កិច្ចការទាំងពួង ហើយនិយាយរាក់ទាក់មកនឹងអញ ក៏ឥឡូវគហបតិនេះ ជាអ្នកតោះតើយ (បែរទៅ) បង្គាប់ខ្ញុំប្រុសស្រីខ្លះ ពួកអ្នកធ្វើការឈ្នួលខ្លះថា នែនាយរាល់គ្នា បើដូច្នោះ ចូរអ្នករាល់គ្នាក្រោមពីព្រលឹម ហើយចំអិនបបរ ចំអិនបាយ ចាត់ចែងសម្ល និងតាក់តែងសម្លឧត្តរិភង្គៈ (ឲ្យល្អ) ប្រហែលជាគហបតិនេះ មានអាវាហមង្គល ឬវិវាហមង្គល ឬក៏មហាយញ្ញពិធី ឬពុំនោះ គាត់អញ្ជើញព្រះបាទពិម្ពិសារមាគធសេនិយរាជ ព្រមទាំងពួកពល ឲ្យមកទទួលក្រយាហារ ក្នុងថ្ងៃស្អែកទេដឹង។

[៣៥៤] គ្រានោះ រាជគហសេដ្ឋី បង្គាប់ខ្ញុំប្រុសស្រីខ្លះ ពួកអ្នកធ្វើការឈ្នួលខ្លះរួចហើយ ទើបចូលទៅរកអនាថបិណ្ឌិកគហបតិ លុះចូលទៅដល់ហើយ ក៏និយាយរាក់ទាក់ ជាមួយនឹង អនាថបិណ្ឌិកគហបតិ ហើយក៏អង្គុយក្នុងទីដ៏សមគួរ។ អនាថបិណ្ឌិកគហបតិ និយាយនឹងរាជគហសេដ្ឋី ដែលអង្គុយក្នុងទីដ៏សមគួរ ដោយពាក្យដូច្នេះថា នែគហបតិ កាលពីដើម បើខ្ញុំបានមកដល់ហើយ អ្នករមែងតែបញ្ឈប់កិច្ចការទាំងពួង ហើយនិយាយរាក់ទាក់មកជាមួយនឹងខ្ញុំ ក៏ឥឡូវនេះ អ្នកធ្វើតោះតើយ បែរជាបង្គាប់ខ្ញុំប្រុសស្រីខ្លះ ពួកអ្នកធ្វើការឈ្នួលខ្លះថា នែនាយរាល់គ្នា បើដូច្នេះ ចូរអ្នករាល់គ្នាក្រោមពីព្រលឹម ហើយចំអិនបបរ ចំអិនបាយ ចាត់ចែងសម្ល និងតាក់តែងសម្លឧត្តរិភង្គៈ (ឲ្យល្អ) នែគហបតិ អាវាហមង្គល និងវិវាហមង្គល ឬមហាយញ្ញពិធី នឹងកើតមានឡើងប្រាកដដល់អ្នកឬអ្វី ឬមួយអ្នកបានអញ្ជើញព្រះបាទពិម្ពិសាមាគធសេនិយរាជ ព្រមទាំងពួកពល ឲ្យមកទទួលក្រយាហារ ក្នុងថ្ងៃស្អែក។ រាជគហសេដ្ឋី និយាយថា នែគហបតិ អាវាហមង្គល និងវិវាហមង្គលរបស់ខ្ញុំ មិនមានទេ ឬមួយខ្ញុំអញ្ជើញព្រះបាទពិម្ពិសាមាគធសេនិយរាជ ព្រមទាំងពួកពល ឲ្យមកទទួលក្រយាហារ ក្នុងថ្ងៃស្អែកនេះក៏ទេដែរ ខ្ញុំមានតែមហាយញ្ញពិធីមែន គឺនិមន្តព្រះសង្ឃ មានព្រះពុទ្ធអង្គ ជាប្រធាន មកទទួលភត្តក្នុងថ្ងៃស្អែកនេះ។ អនាថបិណ្ឌិកគហបតិសួរថា នែគហបតិ អ្នកពោលថា ពុទ្ធោ ដូច្នេះឬ។ រាជគហសេដ្ឋីតបថា អើគហបតិ ខ្ញុំពោលថា ពុទ្ធោ ដូច្នេះមែន។ អនាថបិណ្ឌិកគហបតិ សួរទៀតថា នែគហបតិ អ្នកពោលថា ពុទ្ធោ ដូច្នេះឬ។ រាជគហសេដ្ឋីតបថា អើគហបតិ ខ្ញុំពោលថា ពុទ្ធោ ដូច្នេះមែន។ អនាថបិណ្ឌិកគហបតិ សួរទៀតថា នែគហបតិ អ្នកពោលថា ពុទ្ធោ ដូច្នេះឬ។ រាជគហសេដ្ឋីតបថា អើគហបតិ ខ្ញុំពោលថា ពុទ្ធោ ដូច្នេះមែន។ អនាថបិណ្ឌិកគហបតិ ពោលទៀតថា អើគហបតិ សម្លេងគឺកកងថា ពុទ្ធោ ដូច្នេះនេះ ជាសម្លេងដែលគេរកបានដោយកម្រក្នុងលោក ម្នាលគហបតិ តើខ្ញុំនឹងអាចចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ទាន់ក្នុងពេលនេះបានដែរឬ។ រាជគហសេដ្ឋីតបថា ម្នាលគហបតិ កាលនេះ ជាកាលមិនគួរ ដើម្បីនឹងចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះទាន់ក្នុងពេលនេះទេ ចាំដល់វេលាថ្ងៃស្អែក សឹមអ្នកចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ទើបគួរ។

[៣៥៥] គ្រានោះ អនាថបិណ្ឌិកគហបតិគិតថា ឥឡូវនេះ វេលាថ្ងៃ ស្អែកនេះ អញនឹងចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ទើបគួរ គិតហើយ ក៏ដំកល់ស្មារតី ចំពោះទៅរកព្រះពុទ្ធជាអារម្មណ៍ ហើយក៏ដេកទៅ ក៏ក្នុងវេលាយប់ (នោះ) អនាថបិណ្ឌិកគហបតិ ស្មានថាភ្លឺហើយ ក៏ក្រោកឡើង៣ដង។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ ចូលទៅកាន់ទ្វារសីតវន (ព្រៃត្រជាក់)។ ពួកអមនុស្ស[92] ក៏នាំគ្នាបើកទ្វារឲ្យ។ កាលអនាថបិណ្ឌិកគហបតិ ចេញផុតអំពីនគរហើយ ពន្លឺក៏បាត់ទៅវិញ។ ស្រាប់តែមានងងឹតកើតឡើង។ ភ័យ សេចក្តីតក់ស្លុត និងព្រឺរោមក៏កើតឡើង។ អនាថបិណ្ឌិកគហបតិ ចង់ត្រឡប់អំពីទីនោះមកវិញ។

[៣៥៦] គ្រានោះ សីវកយក្ស ដែលបាត់ទៅ ក៏បញ្ចេញសម្លេងឡើងថា ដំរី១សែន សេះ១សែន រថទឹមដោយមេសេះអស្សតរ១សែន ស្រីជំទង់ដែលប្រដាប់ដោយកុណ្ឌល ជាវិការៈ នៃកែវមណី១សែន ក៏មិនដល់មួយចំណិត នៃការឈានទៅ១ជំហាន ដែលបណ្ឌិតចែកឲ្យជាចំណែក១៦ អស់វារៈ១៦ដងទេ។ ម្នាលគហបតិ អ្នកចូរឈានដើរទៅ ម្នាលគហបតិ អ្នកចូរឈានដើរទៅ ការឈានដើរទៅរបស់អ្នក ប្រសើរណាស់ ការត្រឡប់ទៅវិញ មិនប្រសើរទេ។

[៣៥៧] លំដាប់នោះ អនាថបិណ្ឌិកគហបតិ ក៏បាត់ងងឹតទៅវិញ។ ពន្លឺភ្លឺ ក៏កើតប្រាកដឡើង។ ភ័យ សេចក្តីតក់ស្លុត ព្រឺរោមនោះឯង ក៏រម្ងាប់បាត់ទៅ។ អនាថបិណ្ឌិកគហបតិ ក៏បាត់ពន្លឺអស់វារៈពីដងផង។ បេ។ អស់វារៈបីដងផង។ ងងឹតក៏កើតប្រាកដឡើង។ ភ័យ សេចក្តីតក់ស្លុត ព្រឺរោមក៏កើតឡើង។ អនាថបិណ្ឌិកគហបតិ ចង់ត្រឡប់អំពីទីនោះមកវិញ សីវកយក្ស ដែលបាត់ទៅហើយនោះ ស្រាប់តែបញ្ចេញសម្លេងអស់វារៈជាគំរប់បីដងថា ដំរី១សែន សេះ១សែន រថដែលទឹមដោយមេសេះអស្សតរ១សែន ស្រីជំទង់ ដែលពាក់ដោយកុណ្ឌល ជាវិការៈនៃកែវមណី១សែន មិនដល់ចំណិត នៃការឈានទៅ១ជំហាន ដែលបណ្ឌិតចែក ឲ្យជាចំណែក១៦ អស់វារៈ១៦ដងទេ។ ម្នាលគហបតិ អ្នកចូរឈានដើរទៅ ម្នាលគហបតិ អ្នកចូរឈានដើរទៅ ការឈានដើរទៅរបស់អ្នក ប្រសើរណាស់ ដំណើរត្រឡប់ថយក្រោយវិញ មិនប្រសើរទេ។ អនាថបិណ្ឌិកគហបតិ ក៏បាត់ងងឹតទៅវិញ អស់វារៈបីដង។ ពន្លឺក៏កើតប្រាកដឡើង។ ភ័យសេចក្តីតក់ស្លុត ព្រឺរោមនោះឯង ក៏រម្ងាប់ទៅ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ ចូលទៅកាន់សីតវន។

[៣៥៨] សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់ចង្រ្កមក្នុងទីវាល។ ព្រះមានព្រះភាគ ទ្រង់ទតឃើញអនាថបិណ្ឌិកគហបតិ ដើរមកពីចម្ងាយលឹមៗ លុះទ្រង់ទតឃើញហើយ ក៏ថយចុះអំពីទីចង្រ្កម ទ្រង់គង់លើអាសនៈ ដែលគេតាក់តែងថ្វាយស្រាប់។ ព្រះមានព្រះភាគ ទ្រង់គង់ហើយ ទើបមានព្រះបន្ទូលនេះ ទៅនឹងអនាថបិណ្ឌិកគហបតិថា ម្នាលសុទត្ត អ្នកចូរមកនេះ។ ឯអនាថបិណ្ឌិកគហបតិ មានចិត្តត្រេកអរ រីករាយ ដោយគិតថា ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលត្រាស់ហៅអាត្មាអញចំឈ្មោះ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទៀបព្រះបាទទាំងគូ នៃព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ផ្ទុំស្កុលស្រួលទេឬ។

[៣៥៩]

ព្រះអង្គ ទ្រង់ត្រាស់ថា បុគ្គលណាមានសេចក្តីត្រជាក់ មិនមានកិលេសគ្រឿងសៅហ្មងមិនជាប់នៅក្នុងកាមទាំងឡាយ បុគ្គលនោះ ឈ្មោះថាព្រាហ្មណ៍ អ្នកមានទុក្ខរំលត់ហើយ រមែងដេកនៅជាសុខគ្រប់កាលទាំងពួង។ (មនុស្សណា) កាត់បង់នូវសេចក្តីប្រាថ្នា

ក្នុងភពទាំងពួង ហើយនាំបង់នូវសេចក្តីក្រវល់ក្រវាយ ក្នុងហឫទ័យចេញ (មនុស្សនោះ) ឈ្មោះថា ជាអ្នកស្ងប់រម្ងាប់ ដល់ហើយនូវសេចក្តីរម្ងាប់នៃចិត្ត រមែងដេកនៅជាសុខ។

[៣៦០] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា ដល់អនាថបិណ្ឌិកគហបតិ។ អនុបុព្វីកថា នោះគឺអ្វីខ្លះ។ អនុបុព្វីកថានោះគឺ ទ្រង់ប្រកាសនូវទានកថា១ សីលកថា១ សគ្គកថា១ កាមាទីនវៈ ដ៏លាមកសៅហ្មង១ និងអានិសង្ស ក្នុងការចេញសាងផ្នួស១។ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា អនាថបិណ្ឌិកគហបតិ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លាក្នុងពេលណា ក៏ធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង ព្រះអង្គ ទ្រង់ប្រកាសនូវធម្មទេសនានោះ គឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ក្នុងពេលនោះ។ សំពត់ដ៏ស្អាត ដែលមិនមានពណ៌ខ្មៅ តែងទទួលយកនូវទឹកជ្រលក់ដោយប្រពៃយ៉ាងណាមិញ ក៏ដូចជាធម្មចក្ខុ គឺសោតាបត្តិផល មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ ក៏បានកើតឡើងដល់អនាថបិណ្ឌិកគហបតិ លើអាសនៈនោះដូច្នេះថា ធម្មជាតឯណានីមួយ មានសភាពកើតឡើងហើយជាធម្មតា ធម្មជាតទាំងអស់នោះ មានសភាពរលត់ទៅវិញជាធម្មតា។

[៣៦១] គ្រានោះ អនាថបិណ្ឌិកគហបតិ បានឃើញធម៌ហើយ បានលុះធម៌ហើយ បានជ្រាបច្បាស់ធម៌ហើយ មានចិត្តចុះកាន់ធម៌ស៊ប់ហើយ ឆ្លងចាកសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា លែងជឿនូវពាក្យបុគ្គលដទៃក្នុងសាសនា របស់ព្រះសាស្តា ហើយបានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គ ទ្រង់សម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) គួរនាដូចជាមនុស្ស បើករបស់ដែលគេផ្កាប់ ឲ្យផ្ងាឡើង ឬដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំងទុក ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវ ដល់អ្នកវង្វេង ឬដូចមនុស្សកាន់ប្រទីប ទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក នឹងមើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ថាជាទីពឹងទីរលឹក សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់ហើយនូវព្រះត្រៃសរណគមន៍ ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះ ជាដើមរៀងទៅ បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត សូមព្រះមានព្រះភាគ មួយអន្លើដោយព្រះភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព។ គ្រានោះ អនាថបិណ្ឌិកគហបតិ ដឹងច្បាស់ថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចចៀសចេញទៅ។

[៣៦២] រាជគហសេដ្ឋីបានឮថា អនាថបិណ្ឌិកគហបតិនិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែកដូច្នេះហើយ។ ចំណែកខាងរាជគហសេដ្ឋី បាននិយាយពាក្យនេះ នឹងអនាថបិណ្ឌិកគហបតិថា ម្នាលគហបតិ បានឮថា អ្នកនិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈ នឹងធ្វើភត្តដើម្បីព្រះសង្ឃ មានព្រះពុទ្ធជាប្រធានដោយវត្ថុសម្រាប់ចាយវាយ (ស្បៀង) ឯណា ម្នាលគហបតិ ខ្ញុំនឹងឲ្យវត្ថុសម្រាប់ចាយវាយនោះដល់អ្នក។ អនាថបិណ្ឌិកគហបតិឆ្លើយថា ម្នាលគហបតិ កុំចុះ ខ្ញុំមានវត្ថុសម្រាប់ចាយវាយ ធ្វើភត្ត ដើម្បីសង្ឃ មានព្រះពុទ្ធជាប្រធានហើយ។

[៣៦៣] អ្នកនិគមក្រុងរាជគ្រឹះ បានឮដំណឹងច្បាស់ថា អនាថបិណ្ឌិកគហបតិ បាននិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក។ វេលានោះ អ្នកនិគមក្រុងរាជគ្រឹះ និយាយពាក្យនេះ ទៅនឹងអនាថបិណ្ឌិកគហបតិថា បពិត្រគហបតិ ឮថា អ្នកបាននិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈ នឹងធ្វើភត្តដើម្បីព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយវត្ថុសម្រាប់ចាយវាយឯណា ម្នាលគហបតិ ខ្ញុំឲ្យវត្ថុសម្រាប់ចាយវាយនោះដល់អ្នក។ អនាថបិណ្ឌិកឆ្លើយថា នែអ្នក កុំចុះ ខ្ញុំមានវត្ថុសម្រាប់ចាយវាយ ធ្វើភត្ត ដើម្បីសង្ឃ មានព្រះពុទ្ធជាប្រធានហើយ។

[៣៦៤] ព្រះបាទពិម្ពិសាររាជមាគធសេនិយរាជ ជ្រាបច្បាស់ថា ឮថា អនាថបិណ្ឌិកគហបតិ បាននិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក។ ឯព្រះបាទពិម្ពិសាររាជមាគធសេនិយរាជ ទ្រង់មានបន្ទូលនេះ ទៅនឹងអនាថបិណ្ឌិកគហបតិថា ម្នាលគហបតិ ឮថា អ្នកបាននិមន្តព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក តែអ្នកជាអាគន្តុកៈ នឹងធ្វើភត្តដើម្បីព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយវត្ថុសម្រាប់ចាយវាយឯណា យើងនឹងឲ្យនូវវត្ថុសម្រាប់ចាយវាយនោះដល់អ្នក។ អនាថបិណ្ឌិកគហបតិក្រាបទូលតបថា បពិត្រព្រះសម្មតិទេព ពុំបាច់ទេ ខ្ញុំព្រះអង្គ មានវត្ថុសម្រាប់ចាយវាយ ធ្វើភត្ត ដើម្បីព្រះសង្ឃ មានព្រះពុទ្ធជាប្រធានហើយ។

[៣៦៥] គ្រានោះ អនាថបិណ្ឌិកគហបតិ លុះកន្លងរាត្រីនោះទៅ ក៏ឲ្យជនតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ក្នុងលំនៅរបស់រាជគហសេដ្ឋី ហើយឲ្យជន ក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានបុណ្យថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តក៏សម្រេចហើយ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ និងបាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរ ទៅកាន់លំនៅរបស់រាជគហសេដ្ឋី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលបុគ្គលក្រាលថ្វាយ ជាមួយនឹងភិក្ខុសង្ឃ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ បានអង្គាសថ្វាយខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពីសា ដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែក លែងទទួលទៀត លុះព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏អង្គុយក្នុងទីដ៏សមគួរ។ អនាថបិណ្ឌិកគហបតិ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលនិមន្តគង់ចាំវស្សា ក្នុងក្រុងសាវត្ថីរបស់ខ្ញុំព្រះអង្គ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលគហបតិ ព្រះតថាគតទាំងឡាយ រមែងត្រេកអរចំពោះក្នុងលំនៅដ៏ស្ងាត់តែម្យ៉ាង។ អនាថបិណ្ឌិកគហបតិក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គដឹងច្បាស់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងច្បាស់ហើយ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់អនាថបិណ្ឌិកគហបតិ ឲ្យឃើញព្រម ឲ្យកាន់យកព្រម ឲ្យឧស្សាហ៍ព្រម ឲ្យរីករាយព្រម ដោយធម្មីកថា ហើយព្រះអង្គ ក្រោកចាកអាសនៈ ទ្រង់ពុទ្ធដំណើរចៀសចេញទៅ។

[៣៦៦] សម័យនោះឯង អនាថបិណ្ឌិកគហបតិ ជាបុគ្គលមានមិត្តច្រើន មានសម្លាញ់ច្រើន មានវាចាគួរឲ្យអ្នកផងកាន់យក។ ទើបអនាថបិណ្ឌិកគហបតិពិចារណា នូវកិច្ចដែលគួរធ្វើនោះ ក្នុងក្រុងរាជគ្រឹះ រួចហើយក៏ត្រឡប់មកក្រុងសាវត្ថីវិញ។ លុះដល់ពាក់កណ្តាលផ្លូវ អនាថបិណ្ឌិកគហបតិ បង្គាប់មនុស្សទាំងឡាយថា ម្នាលអ្នកទាំងឡាយ ចូរអ្នករាល់គ្នាធ្វើអារាម សាងវិហារ ផ្តើមធ្វើនូវទាន ឥឡូវនេះ ព្រះពុទ្ធត្រាស់ហើយក្នុងលោក ឯព្រះអង្គនោះសោត ខ្ញុំក៏បាននិមន្តហើយ ព្រះអង្គនឹងទ្រង់ពុទ្ធដំណើរមកតាមផ្លូវនេះ។ គ្រានោះ ពួកមនុស្សដែលអនាថបិណ្ឌិកគហបតិបញ្ជូនទៅនោះ ក៏បានធ្វើអារាម សាងវិហារ និងផ្តើមធ្វើនូវទាន។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ ទៅដល់ក្រុងសាវត្ថីហើយ ក៏គយគន់មើល (កន្លែង) ក្នុងក្រុងសាវត្ថីគ្រប់អន្លើ ដោយគិតថា ព្រះមានព្រះភាគ សមនឹងគង់នៅក្នុងទីណាហ្ន៎ ទីណាមិនជិតពេក មិនឆ្ងាយពេកអំពីស្រុក ល្មមទៅ ល្មមមកបាន ល្មមពួកមនុស្សដែលត្រូវការដោយប្រយោជន៍ ងាយនឹងទៅមក ជាទីមិនច្រឡូកច្រឡំក្នុងវេលាថ្ងៃ មានសម្លេងតិច ឥតមានសម្លេងគឹកកង ជាទីប្រាសចាកខ្យល់បក់មកអំពីសរីរៈ នៃជនគួរជាទីធ្វើការសម្ងាត់នៃមនុស្ស និងជាទីគួរដល់វិវេកក្នុងវេលាយប់។ អនាថបិណ្ឌិកគហបតិ បានឃើញឱទ្យានរបស់រាជកុមារឈ្មោះជេត ជាទីមិនឆ្ងាយពេក មិនជិតពេក អំពីស្រុក ល្មមទៅមកបាន ល្មមពួកមនុស្សដែលត្រូវការដោយប្រយោជន៍ ងាយទៅមក មិនច្រឡូកច្រឡំក្នុងវេលាថ្ងៃ មានសម្លេងតិច ឥតមានសម្លេងគឹកកង ជាទីប្រាសចាកខ្យល់បក់មកអំពីសរីរៈ នៃមនុស្សគួរជាទីធ្វើការសម្ងាត់នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ លុះឃើញហើយ ក៏ចូលទៅរកព្រះរាជកុមារឈ្មោះជេត លុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងព្រះរាជកុមារឈ្មោះជេតថា បពិត្រព្រះអយ្យបុត្រ សូមព្រះអង្គប្រទានឱទ្យានមកខ្ញុំព្រះអង្គ ដើម្បីនឹងធ្វើអារាម។ ជេតរាជកុមារឆ្លើយថា ម្នាលគហបតិ អារាមខ្ញុំឲ្យ (អ្នកទទេ) មិនបានទេ លុះតែ (អ្នកឲ្យថ្លៃ) គឺក្រាលដោយកោដិនៃកហាបណៈ (ទើបឲ្យបាន)។ អនាថបិណ្ឌិកគហបតិឆ្លើយថា បពិត្រព្រះអយ្យបុត្រ អារាម ខ្ញុំព្រះអង្គមុខជានឹងយកហើយ។ ជេតរាជកុមារឆ្លើយថា ម្នាលគហបតិ អ្នកកុំអាលយកអារាម (ចាំយើងសួរពួកមហាមាត្រ អ្នកវិនិច្ឆ័យសេចក្តីសិន)។ ជេតរាជកុមារ និងអនាថបិណ្ឌិកគហបតិ ក៏សួរពួកមហាមាត្រ អ្នកវិនិច្ឆ័យសេចក្តីថា អារាម គួរឲ្យអនាថបិណ្ឌិកគហបតិយក ឬមិនឲ្យយកទេ។ ពួកមហាមាត្រពោលយ៉ាងនេះថា បពិត្រព្រះអយ្យបុត្រ ព្រះអង្គបានកាត់ថ្លៃអារាមចំនួនប៉ុន្មាន ក៏ឲ្យអនាថបិណ្ឌិកគហបតិទទួលយក ដោយថ្លៃប៉ុណ្ណោះចុះ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ បានឲ្យគេផ្ទុកប្រាក់ដោយរទេះទាំងឡាយ ហើយឲ្យក្រាលតំរៀប ដោយកោដិនៃកហាបណៈ ក្នុងព្រៃរបស់ជេតរាជកុមារ។ ប្រាក់ដែលជញ្ជូនយកមកតែម្តងប៉ុណ្ណោះ មិនគ្រាន់ត្រង់ទីឱកាសបន្តិចជុំវិញខ្លោងទ្វារ។ ឯអនាថបិណ្ឌិកគហបតិ ក៏បានបង្គាប់ពួកមនុស្សថា នែនាយរាល់គ្នា ចូរអ្នកទៅនាំយកប្រាក់មកទៀត យើងនឹងក្រាលត្រង់ទីឱកាសនេះ។ គ្រានោះ ជេតរាជកុមារ មានសេចក្តីត្រិះរិះដូច្នេះថា គហបតិនេះ ចំណាយប្រាក់ច្រើនដល់ម្ល៉ោះ ចំពោះកិច្ចណា កិច្ចនោះ មិនមែនជារបស់ថោកទាបទេ។ វេលានោះ ជេតរាជកុមារ ពោលនូវពាក្យនេះ នឹងអនាថបិណ្ឌិកគហបតិថា ណ្ហើយគហបតិ អ្នកកុំឲ្យក្រាលទីឱកាសនោះឡើយ អ្នកចូរឲ្យទីឱកាសនោះដល់ខ្ញុំ ទាននុ៎ះនឹងមានដល់ខ្ញុំ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ បានថ្វាយទីឱកាសនោះ ដល់ជេតរាជកុមារ ដោយគិតថា ជេតរាជកុមារនេះ ជាមនុស្សល្បីល្បាញ មានមនុស្សស្គាល់(ច្រើន) មានឫទ្ធិច្រើន ឯសេចក្តីជ្រះថ្លាក្នុងធម្មវិន័យនេះ (នឹងមាន) ដល់ពួកមនុស្សដែលគេស្គាល់ មានសភាពយ៉ាងនេះ។ គ្រានោះ ជេតរាជកុមារ បានកសាងខ្លោងទ្វារ ក្នុងទីឱកាសនោះ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ ឲ្យគេធ្វើវិហារ ឲ្យគេធ្វើបរិវេណ ឲ្យធ្វើបន្ទប់ ឲ្យធ្វើឧបដ្ឋានសាលា ឲ្យធ្វើរោងភ្លើង ឲ្យធ្វើកប្បិយកុដិ ឲ្យធ្វើវច្ចកុដិ ឲ្យធ្វើទីចង្រ្កម ឲ្យធ្វើសាលាសម្រាប់ចង្រ្កម ឲ្យធ្វើអណ្តូងទឹក ឲ្យធ្វើសាលាទៀបអណ្តូងទឹក ឲ្យធ្វើរោងភ្លើង ឲ្យធ្វើសាលាទៀបរោងភ្លើង ឲ្យធ្វើស្រះបោក្ខរណី ឲ្យធ្វើមណ្ឌបក្នុងជេតវន។

## (នវកម្មទានៈ)

CS vin.cv.06.02.02 | ភាគ ទី១០

## (នវកម្មទានំ)

[៣៦៧] គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះ គួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្រុងវេសាលី ព្រះអង្គទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ដោយលំដាប់ឆ្ពោះត្រង់ទៅក្រុងវេសាលី។ មានសេចក្តីដំណាលថា ព្រះមានព្រះភាគ គង់នៅក្នុងកូដាគារសាលា ក្នុងព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះ។

[៣៦៨] សម័យនោះឯង មនុស្សទាំងឡាយ កំពុងយកចិត្តទុកដាក់ធ្វើនវកម្ម គឺការងារថ្មី ក៏បានផ្គត់ផ្គង់ពួកភិក្ខុ ដែលជាអ្នករវ៉ាប់រវងនូវនវកម្ម ដោយចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ថ្នាំជាបច្ច័យសម្រាប់អ្នកជម្ងឺដោយគោរព។

[៣៦៩] លំដាប់នោះ មានជាងជុល ឬដេរម្នាក់ ជាអ្នកកំសត់ មានសេចក្តីត្រិះរិះដូច្នេះថា ពួកមនុស្សទាំងនេះ កំពុងយកចិត្តទុកដាក់ធ្វើនវកម្ម ព្រោះអំពើណា អំពើនេះ មិនមែនជារបស់ថោកទាបទេ បើដូច្នោះ គួរតែអញធ្វើនវកម្មដែរ។ ឯជាងជុល ឬដេរជាអ្នកកំសត់នោះ ជាន់ដី បោះឥដ្ឋ ហើយធ្វើជញ្ជាំងដោយខ្លួនឯង។ ជាងជុលនោះ មិនឈ្លាសវៀប ជញ្ជាំងវៀច ជញ្ជាំងក៏រលំទៅ។ ជាងជុលកំសត់នោះ ជាន់ដីឥដ្ឋ ធ្វើជញ្ជាំងដោយខ្លួនឯង។ អស់វារៈ ជាគំរប់ពីរដងផង។ បេ។ អស់វារៈ ជាគំរប់បីដងផង។ ជាងជុល មិនឈ្លាសនោះ ធ្វើជញ្ជាំងវៀច ជញ្ជាំងក៏រលំទៅ។ លំដាប់នោះ ជាងជុលកំសត់នោះ ពោលទោសតិះដៀល បន្តុះបង្អាប់ថា ជនទាំងឡាយណា ឲ្យចីវរ បិណ្ឌបាតសេនាសនៈ និងភេសជ្ជបរិក្ខារថ្នាំ ជាបច្ច័យសម្រាប់អ្នកជម្ងឺ ដល់ពួកសមណៈ ជាសក្យបុត្តិយ៍នេះ ពួកសមណសក្យបុត្តិយ៍នេះ ទូន្មានប្រៀនប្រដៅនូវជនទាំងឡាយផង រវ៉ាប់រវងនូវនវកម្មរបស់ជនទាំងនោះផង ចំណែកខាងអញ ជាមនុស្សកំសត់ គ្មានអ្នកណាមួយជួយទូន្មាន ប្រៀនប្រដៅ ឬរវ៉ាប់រវង នូវនវកម្មរបស់អញសោះឡើយ។ ពួកភិក្ខុ ក៏បានឮជាងជុលកំសត់នោះ ពោលទោស តិះដៀល បន្តុះបង្អាប់។ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុ) ឲ្យនវកម្ម[93] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយនវកម្ម នឹងដល់នូវសេចក្តីខ្វល់ខ្វាយថា គិតដូចម្តេច នឹងឲ្យវិហារហើយឆាប់ នឹងជួសជុលនូវទីដែលបាក់បែកឡើងវិញបាន។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យយ៉ាងនេះ។ មុនដម្បូង ត្រូវសង្ឃសូមភិក្ខុ។ លុះសូមហើយ ត្រូវភិក្ខុដែលឈ្លាស ប្រតិពល ផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវនវកម្ម ដល់ភិក្ខុមានឈ្មោះនេះ ចំពោះវិហាររបស់គហបតិឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃឲ្យនូវនវកម្ម ដល់ភិក្ខុឈ្មោះនេះ ចំពោះវិហាររបស់គហបតិឈ្មោះនេះ ការឲ្យនវកម្ម ដល់ភិក្ខុឈ្មោះនេះ ចំពោះវិហាររបស់គហបតិឈ្មោះនេះ គួរដល់លោកមានអាយុ

អង្គណា លោកមានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃឲ្យនវកម្ម ដល់ភិក្ខុឈ្មោះនេះ ចំពោះវិហាររបស់គហបតិឈ្មោះនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយការស្ងៀមយ៉ាងនេះ។

## (អគ្គាសនាទិអនុជាននៈ)

CS vin.cv.06.02.03 | ភាគ ទី១០

### (អគ្គាសនាទិអនុជាននំ)

[៣៧០] គ្រានោះ ព្រះមានព្រះភាគ គង់នៅក្នុងក្រុងវេសាលី គួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់ក្រុងសាវត្ថី។ សម័យនោះឯង ពួកភិក្ខុជាអន្តេវាសិក របស់ពួកឆព្វគ្គិយភិក្ខុ នាំគ្នាដើរជែងទៅខាងមុខៗសង្ឃ មានព្រះពុទ្ធជាប្រធាន ក៏ហួងហែងវិហារ ហួងហែងទីដេកថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់ពួកយើង ទីនេះសម្រាប់អាចារ្យរបស់ពួកយើង ទីនេះសម្រាប់ពួកយើង។ កាលនោះ ព្រះសារីបុត្តមានអាយុ ទៅអំពីខាងក្រោយៗសង្ឃ មានព្រះពុទ្ធជាប្រធាន កាលបើពួកអន្តេវាសិករបស់ពួកឆព្វគ្គិយភិក្ខុហួងហែងវិហារ ហួងហែងទីដេកហើយ លោកក៏រកទីសំណឹងមិនបាន ទើបទៅគង់ទៀបគល់ឈើ១។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់តើនឡើង ក្នុងពេលបច្ចូសសម័យនៃរាត្រី ហើយទ្រង់ក្អកគ្រហែម។ ព្រះសារីបុត្តមានអាយុ ក៏ក្អកគ្រហែមដែរ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា នរណានៅក្នុងទីនុ៎ះ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះសារីបុត្ត។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ហេតុអ្វីក៏អ្នកមកអង្គុយក្នុងទីនេះ។ ឯព្រះសារីបុត្តមានអាយុ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។

[៣៧១] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុជាអន្តេវាសិក របស់ពួកឆព្វគ្គិយភិក្ខុ ដើរជែងទៅខាងមុខៗសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយហួងហែងវិហារ ហួងហែងទីដំណេកថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់ពួកយើង ទីនេះសម្រាប់អាចារ្យរបស់ពួកយើង ទីនេះសម្រាប់ពួកយើង ពិតមែនឬ។ ពួកភិក្ខុ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធមានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសនោះ មិនសមបើនឹង ដើរជែងទៅខាងមុខៗសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយហួងហែងវិហារ ហួងហែងទីដំណេកថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់ពួកយើង ទីនេះសម្រាប់អាចារ្យរបស់ពួកយើង ទីនេះសម្រាប់ពួកយើង ដូច្នេះទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែនដឹកនាំពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើងទេ។ បេ។ លុះទ្រង់បន្ទោសហើយ ក៏ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដូចម្តេច គួរនឹងទទួលអាសនៈប្រសើរ[94] ទឹកប្រសើរ[95] និងដុំបាយប្រសើរ[96] បាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាចេញអំពីខត្តិយត្រកូលមកបួស ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាចេញអំពីព្រាហ្មណត្រកូលមកបួស ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាចេញអំពីគហបតិត្រកូលមកបួស ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណា រៀនគម្ពីរព្រះសូត្រ ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណា ទ្រទ្រង់វិន័យ។ បេ។ បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាធម្មកថិក ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណា បានបឋមជ្ឈាន ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានទុតិយជ្ឈាន ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានតតិយជ្ឈាន។ បេ។ បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានចតុត្ថជ្ឈាន ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាសោតាបន្ន ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាសកទាគាមី។ បេ។ បពិត្រព្រះមានព្រះភាគ ភិក្ខុណា ជាអនាគាមី។ បេ។ បពិត្រព្រះមានព្រះភាគ ភិក្ខុណាជាអរហន្ត ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានវិជ្ជា៣ ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។ ពួកភិក្ខុខ្លះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុណាបានអភិញ្ញា៦ ភិក្ខុនោះ ទើបគួរទទួលអាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរបាន។

#### រឿងសត្វជាសម្លាញ់គ្នា៣តួ

[៣៧២] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ហេតុ (នេះ) ធ្លាប់មានមកហើយ នៅខាងហិមវន្តប្បទេស មានដើមជ្រៃធំ១ដើម។ សត្វ៣តួ គឺ ទទា១ ស្វា១ ដំរី១ ជាសំឡាញ់គ្នា តែងនៅអាស្រ័យនឹងដើមជ្រៃធំនោះ។ សត្វទាំងនោះ មិនគោរព មិនកោតក្រែង មិនប្រព្រឹត្តស្មោះស្មើទៅវិញទៅមករកគ្នាឡើយ។ ម្នាលភិក្ខុទាំងឡាយ សត្វជាសម្លាញ់នឹងគ្នាទាំងនោះ មានសេចក្តីត្រិះរិះថា ឱពួកយើង ធ្វើម្តេចនឹងដឹងពិតថា នរណាជាធំពីកំណើតជាងយើង ៗត្រូវធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជាអ្នកនោះ ម្យ៉ាងទៀត យើងត្រូវឋិតនៅក្នុងឱវាទរបស់អ្នកនោះ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទទា និងស្វាសួរដំរីថា ម្នាលសម្លាញ់ អ្នកបានរលឹកឃើញហេតុពីមុនដូចម្តេច។ ដំរីឆ្លើយថា ម្នាលសម្លាញ់ទាំងឡាយ កាលដែលខ្ញុំនៅតូច ខ្ញុំធ្វើដើមជ្រៃនេះ ក្នុងចន្លោះភ្លៅទាំងពីរហើយដើរទៅ ចុងត្រួយ (ជ្រៃនេះ) ទល់នឹងពោះខ្ញុំ ម្នាលសម្លាញ់ទាំងឡាយ ខ្ញុំរលឹកឃើញនូវហេតុពីមុនដូច្នេះ។ ម្នាលភិក្ខុទាំងឡាយ កាលនោះ ទទា និងដំរីសួរស្វាថា ម្នាលសម្លាញ់ អ្នករលឹកឃើញហេតុពីមុនដូចម្តេចខ្លះ។ ស្វាឆ្លើយថា ម្នាលសម្លាញ់ទាំងឡាយ កាលដែលខ្ញុំនៅតូច ខ្ញុំអង្គុយលើផែនដី ហើយទំពាស៊ីត្រួយជ្រៃនេះ ម្នាលសម្លាញ់ទាំងឡាយ ខ្ញុំរលឹកឃើញហេតុពីមុនដូច្នេះ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ស្វា និងដំរីសួរទៅទទាថា ម្នាលសម្លាញ់ អ្នករលឹកឃើញហេតុពីមុនដូចម្តេចខ្លះ។ ទទាឆ្លើយថា ម្នាលសម្លាញ់ទាំងឡាយ ក្នុងទីឯណោះ មានដើមជ្រៃធំ១ដើម ខ្ញុំស៊ីផ្លែរួចហើយ ហើរមកអំពីនោះ មកបន្ទោបង់

វច្ចៈក្នុងឱកាសនេះ ជ្រៃនេះក៏កើតអំពីវច្ចៈរបស់ខ្ញុំ ម្នាលសម្លាញ់ទាំងឡាយ ខ្ញុំជាសត្វធំពីកំណើត តាំងអំពីកាលនោះមក។ ម្នាលភិក្ខុទាំងឡាយ ស្វា និងដំរីបានពោលពាក្យនេះ នឹងទទាថា ម្នាលសម្លាញ់ អ្នកជាធំពីកំណើតជាងយើង យើងនឹងធ្វើសក្ការៈ គោរព រាប់អាន បូជាអ្នក មួយទៀត យើងនឹងតាំងនៅក្នុងឱវាទរបស់អ្នក។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទទាឲ្យស្វា និងដំរីកាន់សីលទាំង៥ ហើយសមាទាន ប្រព្រឹត្តសីលទាំង៥ ដោយខ្លួនឯង។ សត្វទាំងឡាយនោះ គោរពកោតក្រែង ប្រព្រឹត្តស្មោះស្មើ ទៅវិញទៅមករកគ្នា លុះទំលាយខន្ធ ទៅកាន់លោកខាងមុខ ក៏បានទៅកើតក្នុងសុគតិ គឺឋានសួគ៌។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នុ៎ះឯង ឈ្មោះតិត្តិរិយព្រហ្មចរិយៈ។

[៣៧៣] ព្រះអង្គ ទ្រង់ត្រាស់ថា ពួកជនដែលឈ្លាសក្នុងធម៌ កោតក្រែងចាស់ព្រឹទ្ធាចារ្យ រមែងបានសេចក្តីសរសើរក្នុងបច្ចុប្បន្នផង បានសុគតិក្នុងបរលោកផង។ ម្នាលភិក្ខុទាំងឡាយ អម្បាលពួកសត្វតិរច្ឆានទាំងនោះ ម្តេចក៏ចេះគោរព កោតក្រែង ប្រព្រឹត្តស្មោះស្មើ ដល់គ្នានឹងគ្នាទៅបាន ចំណង់បើអ្នកទាំងឡាយបួសក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយដោយប្រពៃយ៉ាងនេះ គួរណាស់តែគោរព កោតក្រែង ប្រព្រឹត្តស្មោះស្មើដល់គ្នានឹងគ្នា ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរធ្វើហេតុនុ៎ះឲ្យល្អ ក្នុងសាសនានេះចុះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម អាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរ (ដល់ភិក្ខុ) តាមលំដាប់ចាស់ខ្ចី ម្នាលភិក្ខុទាំងឡាយ តែថា វត្ថុជារបស់សង្ឃ ភិក្ខុមិនត្រូវឃាត់ខាំងតាមលំដាប់ចាស់ខ្ចីទេ ភិក្ខុណាឃាត់ខាំង ត្រូវអាបត្តិទុក្កដ៍។

## (អវន្ទិយាទិបុគ្គលា)

CS vin.cv.06.02.04 | ភាគ ទី១០

### (អវន្ទិយាទិបុគ្គលា)

អវន្ទិយបុគ្គល វន្ទិយបុគ្គល

[៣៧៤] ម្នាលភិក្ខុទាំងឡាយ អវន្ទិយបុគ្គល (បុគ្គលដែលភិក្ខុមិនត្រូវសំពះ) នេះ មាន១០ពួក គឺ ភិក្ខុដែលបានឧបសម្បទាមុន មិនត្រូវសំពះភិក្ខុ ដែលបានឧបសម្បទាក្រោយ១ មិនត្រូវសំពះអនុបសម្បន្ន១ មិនត្រូវសំពះភិក្ខុចាស់ ដែលមានសំវាសផ្សេងគ្នា ជាអធម្មវាទី១ មិនត្រូវសំពះមាតុគ្រាម១ មិនត្រូវសំពះមនុស្សខ្ទើយ១ មិនត្រូវសំពះភិក្ខុ ដែលកំពុងនៅបរិវាស១ មិនត្រូវសំពះភិក្ខុ ដែលគួរទាញមកកាន់មូលាបត្តិ១ មិនត្រូវសំពះភិក្ខុ ដែលគួរដល់មានត្ត១ មិនត្រូវសំពះភិក្ខុ ដែលកំពុងប្រព្រឹត្តមានត្ត១ មិនត្រូវសំពះភិក្ខុ ដែលគួរដល់អព្ភានកម្ម១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលភិក្ខុមិនត្រូវសំពះ មាន១០ចំពូក ដូច្នេះឯង។ ម្នាលភិក្ខុទាំងឡាយ វន្ទិយបុគ្គល (បុគ្គលដែលភិក្ខុត្រូវសំពះ) នេះ មាន៣ពួក គឺភិក្ខុដែលបានឧបសម្បទាក្រោយ ត្រូវសំពះភិក្ខុដែលបានឧបសម្បទាមុន១ ត្រូវសំពះភិក្ខុចាស់ជាង ដែលមានសំវាសផ្សេងគ្នា ជាធម្មវាទី១ ម្នាលភិក្ខុទាំងឡាយ ត្រូវថ្វាយបង្គំព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស១ ម្នាលភិក្ខុទាំងឡាយ បុគ្គល ដែលភិក្ខុត្រូវសំពះ មាន៣ចំពូក ដូច្នេះឯង។

## (អាសនប្បដិពាហនបដិក្ខេប)

CS vin.cv.06.02.05 | ភាគ ទី១០

### (អាសនប្បដិពាហនបដិក្ខេបំ)

[៣៧៥] សម័យនោះឯង មនុស្សទាំងឡាយ តាក់តែងមណ្ឌប តាក់តែងកម្រាល តាក់តែងទីឱកាសចំពោះសង្ឃ។ ភិក្ខុទាំងឡាយជាសិស្សរបស់ពួកឆព្វគ្គិយភិក្ខុគិតគ្នាថា វត្ថុជារបស់សង្ឃ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាត ទៅតាមលំដាប់ចាស់ខ្ចីពិតមែនហើយ តែវត្ថុដែលគេធ្វើឧទ្ទិស (ដល់សង្ឃ) ព្រះមានព្រះភាគ មិនទាន់ទ្រង់អនុញ្ញាតនៅឡើយ (លុះគិតដូច្នោះហើយ) ក៏នាំគ្នាដើរជែងទៅពីខាងមុខៗសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយហួងហែងមណ្ឌប ហួងហែងកម្រាល ហួងហែងទីឱកាសថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់ពួកយើង ទីនេះសម្រាប់អាចារ្យរបស់ពួកយើង ទីនេះសម្រាប់ពួកយើង។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ និមន្តទៅពីខាងក្រោយៗសង្ឃ មានព្រះពុទ្ធជាប្រធាន កាលបើពួកអន្តេវាសិករបស់ពួកឆព្វគ្គិយភិក្ខុ ហួងហែងមណ្ឌប ហួងហែងកម្រាល ហួងហែងទីឱកាស (ដូច្នោះ) លោកមិនបានទីឱកាស ក៏ទៅគង់ទៀបគល់ឈើ១។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់តើនឡើង ក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់ក្អកគ្រហែម។ ព្រះសារីបុត្តមានអាយុ ក៏ក្អកគ្រហែមដែរ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា នរណានៅក្នុងទីនុ៎ះ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះសារីបុត្ត។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលសារីបុត្ត ហេតុអ្វីបានជាអ្នកមកអង្គុយក្នុងទីនេះ។ ព្រះសារីបុត្តមានអាយុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។

[៣៧៦] ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា ភិក្ខុទាំងឡាយជាសិស្ស របស់ពួកឆព្វគ្គិយភិក្ខុ គិតគ្នាថា វត្ថុជារបស់សង្ឃ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតតាមលំដាប់ចាស់ខ្ចី ពិតមែនហើយ តែវត្ថុដែលគេឧទ្ទិស (ដល់សង្ឃ) ព្រះមានព្រះភាគ មិនទាន់ទ្រង់អនុញ្ញាតនៅឡើយ (លុះគិតដូច្នោះហើយ) ក៏នាំគ្នាដើរជែងទៅពីខាងមុខៗសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក៏នាំគ្នាហួងហែងមណ្ឌប ហួងហែងកម្រាល ហួងហែងទីឱកាសថា ទីនេះសម្រាប់ឧបជ្ឈាយ៍របស់យើង ទីនេះសម្រាប់អាចារ្យរបស់យើង ទីនេះសម្រាប់យើង ពិតមែនឬ។ ពួកភិក្ខុ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ទោះបីវត្ថុដែលគេធ្វើឧទ្ទិស (ដល់សង្ឃ) ពួកភិក្ខុមិនត្រូវឃាត់ខាំងទៅតាមលំដាប់ចាស់ខ្ចីទេ ភិក្ខុណាឃាត់ខាំង ត្រូវអាបត្តិទុក្កដ។

## (គិហិវិកតអនុជាននៈ)

CS vin.cv.06.02.06 | ភាគ ទី១០

### (គិហិវិកតអនុជាននំ)

[៣៧៧] សម័យនោះឯង មនុស្សទាំងឡាយនាំគ្នាក្រាលអាសនៈខ្ពស់ អាសនៈប្រសើរ ក្នុងរោងភត្ត និងចន្លោះផ្ទះ (ប្រគេនពួកភិក្ខុ) អាសនៈខ្ពស់ អាសនៈប្រសើរដូចម្ដេចខ្លះ អាសនៈខ្ពស់ អាសនៈប្រសើរនោះគឺ អាសន្ទិ (អាសនៈខ្ពស់ហួសប្រមាណ) បល្លង្កៈ (គ្រែដែលមានជើងខ្ពស់វិចិត្រដោយរូបសត្វសាហាវ) គោណកៈ (ព្រំដែលមានរោមវែងជាង៤ធ្នាប់) ចិត្តកៈ (កម្រាលដែលធ្វើពីរោមសត្វ វិចិត្រដោយរូបសត្វសាហាវ) បដិកៈ (កម្រាលមានពណ៌ស ដែលធ្វើដោយរោមសត្វ) បដលិកៈ (កម្រាលដែលធ្វើដោយរោមសត្វ ជាផ្កាចង្កោម) តូលិកៈ (កម្រាលដែលញាត់ដោយសំឡីគ) វិកតិកៈ (កម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វ មានសីហៈ និងខ្លាធំជាដើម) ឧទ្ទលោមិ (កម្រាលដែលធ្វើដោយរោមសត្វមានរោមច្រាងតែម្ខាង) ឯកន្តលោមិ (កម្រាលដែលធ្វើដោយរោមសត្វ មានរោមច្រាងទាំងពីរខាង) កដិស្សៈ (កម្រាលដែលធ្វើដោយឱនមាស និងសូត្រ ហើយចាក់ស្រែះដោយរតនវត្ថុ) កោសេយ្យៈ (កម្រាលដែលធ្វើដោយសរសៃសូត្រ ហើយចាក់ស្រែះដោយរតនវត្ថុ) កម្ពលៈ (កម្រាលដែលធ្វើដោយរោមសត្វ) កុត្តកៈ (កម្រាលដែលធ្វើដោយរោមសត្វ ល្មមពួកស្រីរបាំ១៦នាក់ឈររាំបាន) ហត្ថត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងដំរី) អស្សត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងសេះ) រថត្ថរៈ (កម្រាលសម្រាប់ក្រាលលើរថ) អជិនប្បវេណិ (កម្រាលដែលធ្វើដោយស្បែកខ្លា) កទលិមិគបវរប្បច្ចត្ថរណៈ (កម្រាលដ៏ឧត្តម ដែលធ្វើដោយស្បែកសត្វឈ្លូស) សឧត្តរច្ឆទៈ (ទីដេកដែលមានពិតានក្រហមពីខាងលើ) ឧភតោលោហិតកុបធានៈ (កម្រាលដែលមានខ្នើយ មានពណ៌ក្រហមទាំងពីរខាង គឺខ្នើយក្បាល និងខ្នើយជើង)។ ពួកភិក្ខុរង្កៀស មិនហ៊ានអង្គុយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអង្គុយលើអាសនៈដ៏សេស ជាគិហិវិកដ គឺអាសនៈដែលប្លែកសម្រាប់គ្រហស្ថបាន តែដេកមិនបាន វៀរលែងតែសេនាសនៈ៣យ៉ាង គឺអាសន្ទិ១ បល្លង្កៈ១ តូលិកៈ១។

[៣៧៨] សម័យនោះឯង ពួកមនុស្សតាក់តែងគ្រែផង តាំងផង ដែលញាត់សំឡីគ ក្នុងរោងភត្ត និងចន្លោះផ្ទះ ពួកភិក្ខុរង្កៀស មិនហ៊ានអង្គុយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអង្គុយលើអាសនៈជាគិហិវិកដ ដែលប្លែកសម្រាប់គ្រហស្ថបាន តែដេកមិនបាន។

## (ជេតវនវិហារានុមោទនា)

CS vin.cv.06.02.07 | ភាគ ទី១០

### (ជេតវនវិហារានុមោទនា)

[៣៧៩] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកតាមលំដាប់ សំដៅត្រង់ទៅកាន់ក្រុងសាវត្ថី។ មានរឿងដំណាលថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះ។ លំដាប់នោះ អនាថបិណ្ឌិកគហបតិ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ។ លុះអនាថបិណ្ឌិកគហបតិ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់ទទួលភត្ត របស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ជាមួយនឹងភិក្ខុសង្ឃ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព។ លុះអនាថបិណ្ឌិកគហបតិ ដឹងច្បាស់ថា ព្រះមានព្រះភាគ ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។

[៣៨០] លំដាប់នោះ អនាថបិណ្ឌិកគហបតិ ឲ្យតាក់តែងខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពីសា ក្នុងពេលដែលកន្លងរាត្រីនោះទៅហើយ ឲ្យទៅក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តសម្រេចហើយ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ និងបាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់អនាថបិណ្ឌិកគហបតិ លុះយាងទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេតាក់តែងថ្វាយ ជាមួយនឹងភិក្ខុសង្ឃ។ អនាថបិណ្ឌិកគហបតិ ក៏បានអង្គាសខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពីសា ថ្វាយដោយដៃឯង ចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែទ្រង់ប្រកែក លែងទទួលទៀត (លុះដឹងថា) ព្រះមានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្ដទៅក្នុងបាត្រហើយ ទើបអង្គុយក្នុងទីសមគួរ។ អនាថបិណ្ឌិកគហបតិ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ត្រូវប្រតិបត្តិក្នុងវត្តជេតវនដូចម្ដេច។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលគហបតិ បើដូច្នោះ អ្នកចូរប្រតិស្ឋានវត្តជេតវន សម្រាប់សង្ឃ ដែលបានមកហើយ និងមិនទាន់បានមក អំពីទិសទាំង៤។ អនាថបិណ្ឌិកគហបតិ ទទួលស្ដាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងហ្នឹងហើយ ហើយក៏ប្រតិស្ឋានវត្តជេតវន សម្រាប់សង្ឃ ដែលបានមកហើយ និងមិនទាន់បានមកអំពីទិសទាំង៤។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់អនុមោទនា ចំពោះអនាថបិណ្ឌិកគហបតិ ដោយគាថាទាំងនេះថា

[៣៨១]

(វិហារ គឺទីអាវាស ឬសេនាសនៈ ជាទីនៅនៃសង្ឃទាំងឡាយ) រមែងការពាររងាផង ក្ដៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូចពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់ និងកំដៅថ្ងៃ ដ៏ក្លាខ្លាំង ដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះៗ។ វិហារទាន គឺ ការឲ្យលំនៅ (ដែលបុគ្គលបានឲ្យហើយ) ដល់សង្ឃ សម្រាប់ជ្រកកោនផង សម្រាប់នៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចំរើនវិបស្សនាផង ព្រះពុទ្ធជាម្ចាស់ទាំងឡាយ តែងត្រាស់សរសើរថា ជាអគ្គទាន (ទានដ៏ប្រសើរ)។ ព្រោះហេតុនោះឯង បុរស (ស្ត្រី) ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីកសាងវិហារ គឺអាវាស ឬសេនាសនៈទាំងឡាយ ដ៏ជាទីគួររីករាយ ហើយគប្បីនិមន្តលោក ដែលជាពហុស្សុត គឺលោកអ្នកចេះដឹងច្រើនទាំងឡាយ ឲ្យនៅក្នុងទីនោះ។ គប្បីមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយ ដែលមានកាយ និងចិត្តត្រង់ ហើយឲ្យម្ហូបចំណីផង ទឹកផង សំពត់ និងសេនាសនៈទាំងឡាយផង ដល់លោកទាំងនោះចុះ។ លោកទាំងនោះ រមែងសំដែងធម៌

ជាគ្រឿងបន្ទោបង់សេចក្តីទុក្ខគ្រប់ប្រការ ដល់អ្នកនោះ លុះអ្នកនោះបានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន។

លុះព្រះមានព្រះភាគ ទ្រង់អនុមោទនា ចំពោះអនាថបិណ្ឌិកគហបតិ ដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈ ទ្រង់ពុទ្ធដំណើរចៀសចេញទៅ។

## (អាសនប្បដិពាហនាទិ)

CS vin.cv.06.02.08 | ភាគ ទី១០

### (អាសនប្បដិពាហនាទិ)

[៣៨២] សម័យនោះ មានមហាមាត្រម្នាក់ ជាសាវ័ករបស់អាជីវក ធ្វើសង្ឃភត្ត។ ឧបនន្ទសក្យបុត្រមានអាយុមកដល់ក្រោយគេ ក៏បណ្តេញភិក្ខុដែលមានវស្សាជាលំដាប់ខ្លួន កំពុងឆាន់មិនទាន់លែង ឲ្យក្រោកចេញ។ រោងភត្តក៏កើតមានសេចក្តីជ្រួលជ្រើម។ មហាមាត្រនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈ ជាសក្យបុត្តិយ៍ មកដល់ក្រោយគេ មិនគួរនឹងបណ្តេញភិក្ខុ ដែលមានវស្សាជាលំដាប់ខ្លួន កំពុងឆាន់មិនទាន់លែង ឲ្យក្រោកចេញសោះ (នាំឲ្យ) រោងភត្តកើតមានសេចក្តីជ្រួលជ្រើម បើយ៉ាងហ្នឹង ភិក្ខុឯទៀត អាចឆាន់ឆ្អែត ស្រួលបួលដែរ វៀរលែងតែភិក្ខុដែលអង្គុយស៊ប់ហើយ។ ពួកភិក្ខុបានឮមហាមាត្រនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទសក្យបុត្តិយ៍មានអាយុ មកក្រោយគេ មិនគួរនឹងបណ្តេញភិក្ខុ ដែលមានវស្សាជាលំដាប់ខ្លួន កំពុងឆាន់ មិនទាន់លែង ឲ្យក្រោកចេញសោះ (នាំឲ្យ) រោងភត្តកើតមានសេចក្តីជ្រួលជ្រើម។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកមកដល់ក្រោយគេ ហើយបណ្តេញភិក្ខុ ដែលមានវស្សាជាលំដាប់ខ្លួន កំពុងឆាន់មិនទាន់លែង ឲ្យក្រោកចេញ (នាំឲ្យ) រោងភត្តកើតមានសេចក្តីជ្រួលជ្រើម ពិតមែនឬ។ ឧបនន្ទ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះពុទ្ធមានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស មិនគួរបើអ្នកមកក្រោយគេ ហើយបណ្តេញភិក្ខុ ដែលមានវស្សាជាលំដាប់ កំពុងឆាន់មិនទាន់លែង ឲ្យក្រោកចេញសោះ (នាំឲ្យ) រោងភត្តកើតមានសេចក្តីជ្រួលជ្រើម នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។ បេ។ លុះទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្តេញភិក្ខុ ដែលអង្គុយខាងក្រោយគេបង្អស់ ដែលកំពុងនៅឆាន់ មិនទាន់លែង ឲ្យក្រោកចេញទេ ភិក្ខុណាបណ្តេញ ត្រូវអាបត្តិទុក្កដ តែបើ (ភិក្ខុចាស់) បណ្តេញ (ភិក្ខុខ្ចីដែលកំពុងឆាន់) ឲ្យក្រោកចេញ ត្រូវភិក្ខុខ្ចីឃាត់ ហើយនិយាយថា ចូរលោកទៅយកទឹកមក បើបានទឹកនោះមក ដោយអាការដូច្នេះ ការនេះជាការឥតទោស បើមិនបានទឹកមកទេ ត្រូវភិក្ខុខ្ចី លេបគ្រាប់បាយឲ្យស្រួល ហើយឲ្យអាសនៈ ដល់ភិក្ខុចាស់ជាង (នោះ) ចុះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលពោលថា ឲ្យភិក្ខុទាំងឡាយឃាត់អាសនៈ ចំពោះភិក្ខុចាស់ជាង ដោយបរិយាយឯណានីមួយទេ ភិក្ខុណាឃាត់ ត្រូវអាបត្តិទុក្កដ។

[៣៨៣] សម័យនោះ ពួកឆព្វគ្គិយភិក្ខុ នាំគ្នាបណ្តេញពួកភិក្ខុឈឺ ឲ្យក្រោកចេញ។ ភិក្ខុឈឺទាំងឡាយ ពោលយ៉ាងនេះថា ម្នាលអាវុសោ ពួកខ្ញុំករុណាសុទ្ធតែជាអ្នកឈឺ មិនអាចនឹងក្រោកចេញបានទេ។ ពួកឆព្វគ្គិយភិក្ខុ គិតគ្នាថា យើងនឹងបណ្តេញលោកមានអាយុទាំងឡាយឲ្យក្រោកចេញ ហើយក៏នាំគ្នាចាប់ភិក្ខុទាំងនោះ ឲ្យក្រោកឈរឡើង ហើយលែងចេញ។ ពួកភិក្ខុឈឺ ក៏ជ្រប់ដួលទៅ។ បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបណ្តេញភិក្ខុឈឺទេ ភិក្ខុណាបណ្តេញ ត្រូវអាបត្តិទុក្កដ។

[៣៨៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ គិតគ្នាថា យើងទាំងឡាយជាអ្នកឈឺ ទុកជាអ្នកណា ក៏មិនគប្បីបណ្តេញ ឲ្យក្រោកចេញបាន ហើយក៏ដេកជាប់នៅនឹងដំណេកដ៏ប្រសើរ។ បេ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យៗទីដំណេកដ៏សមគួរ ដល់ភិក្ខុឈឺបាន។

[៣៨៥] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ឃាត់អាសនៈដោយកលមាយាអាក្រក់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវហាមឃាត់អាសនៈ ដោយកលមាយាអាក្រក់ទេ[97] ភិក្ខុណាហាមឃាត់ ត្រូវអាបត្តិទុក្កដ។

[៣៨៦] សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុ ជួសជុលវិហារធំមួយ ដែលមាននៅក្នុងទីបំផុតដែន ដោយគិតគ្នាថា ពួកយើងនឹងនៅចាំវស្សាក្នុងវិហារធំនេះ។ ពួកឆព្វគ្គិយភិក្ខុ បានឃើញពួកសត្តរសវគ្គិយភិក្ខុ កំពុងតែជួសជុលវិហារ លុះឃើញហើយ ក៏បានពោលពាក្យយ៉ាងនេះថា ម្នាលអាវុសោ ពួកសត្តរសវគ្គិយភិក្ខុទាំងនេះ កំពុងតែជួសជុលវិហារ បើដូច្នោះ ពួកយើងនឹងនាំគ្នាបណ្តេញភិក្ខុទាំងនោះ ឲ្យដើរចេញ ភិក្ខុពួកខ្លះពោលយ៉ាងនេះថា លោកទាំងឡាយ ចូរបង្អង់សិន ដ្បិតសត្តរសវគ្គិយភិក្ខុ កំពុងតែជួសជុល ចាំដល់លោកទាំងនោះ ជួសជុលរួចស្រេច សឹមយើងនាំគ្នាបណ្តេញឲ្យដើរចេញ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ ពោលពាក្យនេះ នឹងពួកសត្តរសវគ្គិយភិក្ខុថា ម្នាលអាវុសោ លោកចូរក្រោកចេញ វិហារ (នេះ) ត្រូវបានមកពួកយើងទេ។ សត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ លោកទាំងឡាយ គួរប្រាប់មក ឲ្យប្រាកដជាមុន ពួកយើងនឹងនាំគ្នាជួសជុលវិហារឯទៀត។ ឆព្វគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ វិហារ (នេះ) ជារបស់សង្ឃ មិនមែនឬ។ សត្តរសវគ្គិយភិក្ខុនិយាយតបថា ម្នាលលោកដ៏មានអាយុ អើ វិហារ (នេះ) ជារបស់សង្ឃមែន។ ឆព្វគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ លោកត្រូវក្រោកចេញទៅ វិហារ (នេះ) ត្រូវបានមកពួកយើងទេ។ សត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ វិហារធំដែរ លោកទាំងឡាយនៅក៏បាន យើងនៅក៏បាន។ ឆព្វគ្គិយភិក្ខុ ខឹងអាក់អន់ចិត្ត ហើយច្បាមត្រង់ក ទាញចេញដោយពាក្យថា ម្នាលអាវុសោ លោកទាំងឡាយ ចូរក្រោកដើរចេញ វិហារ ត្រូវបានមកពួកយើងទេ។ សត្តរសវគ្គិយភិក្ខុនោះ កាលបើឆព្វគ្គិយភិក្ខុទាញចេញ ក៏នាំគ្នាស្រែកយំ។ ភិក្ខុទាំងឡាយសួរយ៉ាងនេះថា ម្នាលអាវុសោ ព្រោះហេតុអ្វី បានជា

លោកយំ។ សត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ឆព្វគ្គិយភិក្ខុទាំងនេះ ខឹងអាក់អន់ចិត្ត ហើយចាប់ទាញពួកយើង ឲ្យចេញចាកវិហាររបស់សង្ឃ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុ មិនសមបើនឹងខឹង អាក់អន់ចិត្ត ហើយចាប់ទាញភិក្ខុទាំងឡាយ ឲ្យចេញចាកវិហារ ជារបស់សង្ឃសោះ។ លំដាប់នោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ឆព្វគ្គិយភិក្ខុ ខឹងអាក់អន់ចិត្ត ហើយចាប់កន្ត្រាក់ភិក្ខុទាំងឡាយ ឲ្យចេញចាកវិហារជារបស់សង្ឃ ពិតមែនឬ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ បេ។ ព្រះមានព្រះភាគ ទ្រង់បន្ទោស ហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវខឹង អាក់អន់ចិត្ត ហើយចាប់កន្ត្រាក់ភិក្ខុទាំងឡាយ ឲ្យចេញចាកវិហារជារបស់សង្ឃទេ ភិក្ខុណាចាប់កន្ត្រាក់ទាញចេញ វិនយធរ គប្បីកាត់សម្រេចឲ្យសមគួរ តាមអាបត្តិ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យមានភិក្ខុប្រគល់សេនាសនៈ (ដល់ភិក្ខុណាមួយ)។

## (សេនាសនគ្គាហាបកសម្មុតិ)

CS vin.cv.06.02.09 | ភាគ ទី១០

### (សេនាសនគ្គាហាបកសម្មុតិ)

[៣៨៧] គ្រានោះ ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា ភិក្ខុដូចម្ដេចហ្ន៎ ដែលគួរប្រគល់សេនាសនៈឲ្យបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុ ដែលប្រកបដោយអង្គ៥ ឲ្យជាសេនាសនគ្គាហាបកៈ (អ្នកប្រគល់សេនាសនៈ) គឺភិក្ខុមិនលុះក្នុងឆន្ទាគតិ១ មិនលុះក្នុងទោសាគតិ១ មិនលុះក្នុងមោហាគតិ១ មិនលុះក្នុងភយាគតិ១ ដឹងច្បាស់នូវសេនាសនៈ ដែលខ្លួនបានប្រគល់ និងមិនទាន់បានប្រគល់១។

[៣៨៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវសន្មតយ៉ាងនេះ។ សង្ឃត្រូវសូមភិក្ខុជាមុនសិន។ លុះសូមហើយ ត្រូវភិក្ខុដែលឈ្លាស ប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាសេនាសនគ្គាហាបកៈ (អ្នកប្រគល់សេនាសនៈ)។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតសង្ឃនឹងសន្មតភិក្ខុឈ្មោះនេះ ឲ្យជាសេនាសនគ្គាហាបកៈ។ ការសន្មតិភិក្ខុឈ្មោះនេះ ឲ្យជាសេនាសនគ្គាហាបកៈ សមគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវឆ្លើយមក។ ភិក្ខុឈ្មោះនេះ សង្ឃបានសន្មត ឲ្យជាសេនាសនគ្គាហាបកៈ គួរដល់សង្ឃ ព្រោះហេតុដូច្នោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្ដីនុ៎ះទុក ដោយអាការស្ងៀមយ៉ាងនេះ។

[៣៨៩] គ្រានោះឯង ពួកភិក្ខុជាសេនាសនគ្គាហាបកៈ មានសេចក្ដីត្រិះរិះដូច្នេះថា យើងគប្បីប្រគល់សេនាសនៈដូចម្ដេចហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរាប់ភិក្ខុមុន លុះរាប់ភិក្ខុរួចហើយ ឲ្យរាប់ដំណេក លុះរាប់ដំណេករួចហើយ សឹមប្រគល់ឲ្យតាមកំណត់នៃដំណេក។ ភិក្ខុទាំងឡាយ ក៏ប្រគល់ឲ្យតាមកំណត់នៃដំណេក ដំណេក ក៏សល់នៅច្រើន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រគល់តាមកំណត់នៃវិហារ។ ភិក្ខុទាំងឡាយ ក៏ប្រគល់ឲ្យតាមកំណត់នៃវិហារ វិហារក៏សល់នៅច្រើន។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យប្រគល់តាមកំណត់នៃបរិវេណ។ ពួកភិក្ខុ ក៏ប្រគល់ឲ្យតាមកំណត់នៃបរិវេណ បរិវេណ ក៏សល់នៅច្រើន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យៗ នូវបរិវេណ តាមចំណែកជាលំដាប់ទៅចុះ កាលបើចំណែកនៃបរិវេណតាមលំដាប់ ពួកភិក្ខុបានទទួលយកហើយ ទើបមានភិក្ខុឯទៀតមកដល់ (តែបើភិក្ខុនោះ) មិនត្រូវការ មិនត្រូវឲ្យទេ។

[៣៩០] សម័យនោះឯង ភិក្ខុទាំងឡាយប្រគល់សេនាសនៈ ដល់ភិក្ខុដែលឋិតនៅក្នុងទីក្រៅសីមា។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រគល់សេនាសនៈ ដល់ភិក្ខុដែលឋិតនៅក្នុងទីក្រៅសីមាទេ ភិក្ខុណាប្រគល់ឲ្យ ត្រូវអាបត្តិទុក្កដ។

[៣៩១] សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកសេនាសនៈ[98)] ហើយឃាត់ខាំងទុកគ្រប់កាល។[99)] ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលយកសេនាសនៈ ហើយឃាត់ខាំងទុកគ្រប់កាលទេ ភិក្ខុណាឃាត់ខាំងទុក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឃាត់ខាំងបានតែត្រឹម៣ខែ ក្នុងវស្សានរដូវ (ប៉ុណ្ណោះ) មិនឲ្យឃាត់ខាំងគ្រប់រដូវទេ។

[៣៩២] គ្រានោះឯង ភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា ការប្រគល់សេនាសនៈ មានប៉ុន្មានហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការប្រគល់សេនាសនៈនេះ មាន៣យ៉ាង គឺបុរិមកៈ១ បច្ឆិមកៈ១ អន្តរាមុត្តកៈ១ ដែលឈ្មោះថា បុរិមកៈ ត្រូវភិក្ខុប្រគល់ឲ្យតាំងអំពីថ្ងៃ១រោច ខែអាសាធទៅ ដែលឈ្មោះថា បច្ឆិមកៈ ត្រូវភិក្ខុប្រគល់ឲ្យ តាំងអំពីថ្ងៃ១រោច ខែស្រាពណ៍ទៅ ដែលឈ្មោះថា អន្តរាមុត្តកៈ ត្រូវភិក្ខុប្រគល់ឲ្យ តាំងអំពីថ្ងៃបវារណា ក្នុងខែអស្សុជទៅ ដើម្បីនៅចាំវស្សាតទៅ ម្នាលភិក្ខុទាំងឡាយ ការប្រគល់សេនាសនៈ មាន៣យ៉ាងដូច្នេះឯង។

ចប់ ភាណវារៈ ជាគំរប់ពីរ។

# (តតិយភាណវារៈ ទី៣)

CS vin.cv.06.03 | ភាគ ទី១០

## (៣. តតិយភាណវារោ)

[៣៩៣] សម័យនោះឯង ឧបនន្ទភិក្ខុមានអាយុ ជាសក្យបុត្ត ទទួលយកសេនាសនៈ ទៀបក្រុងសាវត្ថី ហើយដើរទៅកាន់អាវាស ក្នុងស្រុកតូចមួយ ក៏ទទួលយកសេនាសនៈ ក្នុងទីនោះទៀត។ លំដាប់នោះ ភិក្ខុទាំងនោះ (ដែលនៅក្នុងទីអាវាសនោះ) គិតគ្នាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ឧបនន្ទភិក្ខុមានអាយុ ជាសក្យបុត្តនេះ ជាអ្នកធ្វើនូវសេចក្តីប្រកួតប្រកាន់ ធ្វើនូវជំលោះ ធ្វើនូវការទាស់ទែង ធ្វើនូវតិរច្ឆានកថា ធ្វើនៅអធិករណ៍ក្នុងសង្ឃ ប្រសិនបើ ឧបនន្ទភិក្ខុនេះ នៅចាំវស្សាក្នុងទីនេះ យើងទាំងអស់គ្នា នឹងនៅពុំបានសប្បាយឡើយ បើដូច្នោះ មានតែយើងសួរលោកមើល។ ភិក្ខុទាំងនោះ ក៏សួរឧបនន្ទភិក្ខុមានអាយុ ជាសក្យបុត្តដូច្នេះថា ម្នាលអាវុសោឧបនន្ទ លោកបានទទួលយកសេនាសនៈ ទៀបក្រុងសាវត្ថី មែនឬ។ ឧបនន្ទភិក្ខុឆ្លើយថា ម្នាលអាវុសោទាំងឡាយ ខ្ញុំបានទទួលយកមែន។ ភិក្ខុទាំងនោះសួរថា ម្នាលអាវុសោឧបនន្ទ ចុះលោកតែម្នាក់ឯងទេ ម្តេចក៏ហួងហែងសេនាសនៈ ដល់ទៅពីរកន្លែង។ ឧបនន្ទភិក្ខុឆ្លើយថា ម្នាលអាវុសោទាំងឡាយ ឥឡូវនេះ ខ្ញុំលែងយកក្នុងទីនេះហើយ ខ្ញុំនឹងទៅទទួលយកក្នុងទីនោះវិញ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧបនន្ទភិក្ខុមានអាយុ ជាសក្យបុត្ត តែមួយរូប មិនសមបើនឹងហួងហែងសេនាសនៈ ដល់ទៅពីរកន្លែងសោះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបនន្ទ ឮថា អ្នកតែម្នាក់ឯង ហួងហែងសេនាសនៈ ដល់ទៅពីរកន្លែង មែនឬ។ ឧបនន្ទ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់មានព្រះភាគ ទ្រង់បន្ទោសថា នែមោឃបុរស អ្នកតែម្នាក់ឯង មិនសមបើនឹងហួងហែងសេនាសនៈ ដល់ទៅពីរកន្លែងទេ ម្នាលមោឃបុរស (បើ) អ្នកទទួលយកសេនាសនៈ ក្នុងទីនោះហើយ មានតែលែងទទួលយកក្នុងទីនេះ (បើ) អ្នកទទួលយកក្នុងទីនេះហើយ មានតែលែងទទួលយកក្នុងទីនោះ នែមោឃបុរស បើយ៉ាងហ្នឹង អ្នកចាត់ថា ជាមនុស្សខាងក្រៅ គឺថា មិនត្រូវបានសេនាសនៈក្នុងទីទាំងពីរខាងទេ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុម្នាក់ឯង មិនត្រូវហួងហែងសេនាសនៈពីរកន្លែងទេ ភិក្ខុណាហួងហែងទុក ត្រូវអាបត្តិទុក្កដ។

[៣៩៤] សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់សំដែងវិនយកថា សំដែងគុណរបស់វិន័យ សំដែងគុណរបស់ការសិក្សាវិន័យ សំដែងគុណរបស់ព្រះថេរៈឈ្មោះឧបាលិដ៏មានអាយុរឿយៗ ដល់ភិក្ខុទាំងឡាយ ដោយបរិយាយជាច្រើន។ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដែងវិនយកថា សំដែងគុណរបស់វិន័យ សំដែងគុណរបស់ការសិក្សាវិន័យ សំដែងគុណរបស់ព្រះថេរៈ ឈ្មោះឧបាលិដ៏មានអាយុរឿយៗ ដល់ភិក្ខុទាំងឡាយ ដោយបរិយាយជាច្រើន ម្នាលអាវុសោ បើដូច្នោះ យើងនឹងរៀនវិន័យ ក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុចុះ។ ភិក្ខុច្រើនអង្គទាំងនោះ ទោះជាថេរៈក្តី ខ្ចីក្តី កណ្តាលក្តី តែងនាំគ្នាមករៀនវិន័យ ក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ។ ព្រះថេរៈ ឈ្មោះឧបាលិដ៏មានអាយុ ក៏ចេះតែឈរ សំដែង (វិន័យ) ដោយសេចក្តីគោរព ចំពោះពួកភិក្ខុជាថេរៈ។ ឯពួកភិក្ខុជាថេរៈ ក៏ឈរឲ្យលោកសំដែង (វិន័យ) ដោយសេចក្តីគោរពក្នុងធម៌ដែរ។ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុជាថេរៈក្តី ព្រះឧបាលិដ៏មានអាយុក្តី ក៏លំបាក (ពេកណាស់)។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុខ្ចីដែលសំដែង (វិន័យ) អង្គុយលើអាសនៈស្មើគ្នាក៏បាន ខ្ពស់ជាងក៏បាន ដោយសេចក្តីគោរពក្នុងធម៌ និងអនុញ្ញាតឲ្យភិក្ខុជាថេរៈ ដែលនិមន្តភិក្ខុខ្ចីឲ្យសំដែងវិន័យ អង្គុយលើអាសនៈស្មើគ្នាក៏បាន ទាបជាងណាស់ទៅក៏បាន ដោយសេចក្តីគោរពក្នុងធម៌។

[៣៩៥] សម័យនោះឯង ភិក្ខុច្រើនរូប នាំគ្នាឈររៀនបាលី ក្នុងសំណាក់នៃព្រះឧបាលិដ៏មានអាយុ ក៏លំបាក។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកភិក្ខុដែលមានអាសនៈស្មើគ្នា អង្គុយជាមួយគ្នាបាន។

[៣៩៦] គ្រានោះឯង ពួកភិក្ខុមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុដែលហៅថា មានអាសនៈស្មើគ្នា ដោយវស្សាប៉ុន្មានហ្ន៎។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានវស្សារវាង៣ អង្គុយជាមួយគ្នាបាន។[100)]

[៣៩៧] សម័យនោះឯង ភិក្ខុច្រើនរូបមានអាសនៈស្មើគ្នា នាំគ្នាទៅអង្គុយលើគ្រែមួយ ទាល់តែបាក់គ្រែ។ ទៅអង្គុយលើតាំងមួយ ក៏បាក់តាំងទៅទៀត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមួយ ដល់ភិក្ខុ៣រូប តាំងមួយ ដល់ភិក្ខុ៣រូប។ ភិក្ខុ៣រូបអង្គុយលើគ្រែមួយ ក៏បាក់គ្រែទៅ។ អង្គុយលើតាំងមួយ ក៏បាក់តាំងទៀត។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមួយ ដល់ភិក្ខុពីររូប តាំងមួយ ដល់ភិក្ខុពីររូប។[101)]

[៣៩៨] សម័យនោះឯង ពួកភិក្ខុមានសេចក្តីសង្ស័យនឹងការអង្គុយលើអាសនៈវែងជាមួយនឹងភិក្ខុដែលមានអាសនៈមិនស្មើគ្នា។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យអង្គុយលើអាសនៈវែង ជាមួយនឹងភិក្ខុ ដែលមានអាសនៈមិនស្មើគ្នាបាន វៀរលែងតែមនុស្សខ្ទើយ មាតុគ្រាម និងមនុស្សមានភេទពីរ។

[៣៩៩] គ្រានោះ ភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា អាសនៈវែង តើមានទីបំផុតត្រឹមណា។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអាសនៈវែង ដែលមានទីបំផុតល្មមភិក្ខុ៣រូប (អង្គុយបាន)។

[៤០០] សម័យនោះឯង នាងវិសាខា ជាមិគារមាតា ចង់ឲ្យជាងធ្វើប្រាសាទ ប្រកបដោយរបៀងឈ្មោះ ហត្ថិនខកៈ[102)] បំរុងប្រគេនព្រះសង្ឃ។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគ បានទ្រង់អនុញ្ញាតការប្រើប្រាស់ប្រាសាទហើយឬ ៗមិនទាន់បានទ្រង់អនុញ្ញាតទេហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការប្រើប្រាស់ប្រាសាទគ្រប់យ៉ាងបាន។

[៤០១] សម័យនោះ ព្រះអយ្យិការបស់ព្រះបាទបសេនទិកោសលសុគត។ កាលដែលព្រះអយ្យិកានោះសុគតទៅ សង្ឃក៏បានអកប្បិយភណ្ឌជាច្រើន ឯអកប្បិយភណ្ឌនោះគឺ អាសនៈ ដែលកន្លងហួសប្រមាណ គ្រែមានជើងវិចិត្រដោយរូបសត្វសាហាវ ព្រំមានរោមវែងជាង៤ធ្នាប់ កម្រាលដែលធ្វើពីរោមសត្វ វិចិត្រដោយរូបសត្វសាហាវ កម្រាលមានពណ៌ស ដែលធ្វើពីរោមសត្វ កម្រាលដែលធ្វើពីរោមសត្វជាផ្កាចង្កោម កម្រាលដែលញាត់គ កម្រាលដែលធ្វើពីរោមសត្វ វិចិត្រដោយរូបសីហៈ និងខ្លាធំជាដើម កម្រាលដែលធ្វើពីរោមសត្វ មានរោមច្រាងតែម្ខាង កម្រាលដែលធ្វើពីរោមសត្វ មានរោមច្រាងទាំងពីរខាង កម្រាលដែលធ្វើពីឱនមាស ឬខ្សែសយ ចាក់ស្រែះដោយរតនវត្ថុ កម្រាលដែលដែលធ្វើពីសរសៃសូត្រ ចាក់ស្រែះដោយរតនវត្ថុ កម្រាលដែលធ្វើពីរោមសត្វល្មមស្រីរបាំ១៦នាក់ឈររាំបាន កម្រាលសម្រាប់ក្រាលលើខ្នងដំរី កម្រាលសម្រាប់ក្រាលលើខ្នងសេះ កម្រាលសម្រាប់ក្រាលលើរថ កម្រាលដែលធ្វើដោយស្បែកខ្លា កម្រាលដ៏ឧត្តម ដែលធ្វើពីស្បែកឈ្លូស ខ្នើយពណ៌ក្រហមទាំងពីរខាង (គឺខ្នើយក្បាល និងខ្នើយជើង) ព្រមទាំងពិតាន ដែលមានពណ៌ក្រហម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យកាត់ជើងអាសនៈ ដែលកន្លងហួសប្រមាណ ហើយសឹមប្រើប្រាស់ ឲ្យទំលាយរូបសត្វសាហាវនៃគ្រែមានជើងវិចិត្រដោយរូបសត្វសាហាវ ហើយសឹមប្រើប្រាស់ ឲ្យកកាយកម្រាលដែលញាត់គ យកមកធ្វើជាខ្នើយ អាសនៈក្រៅអំពីនោះ យកមកធ្វើជាកម្រាលសម្រាប់ក្រាលលើផែនដីបាន។

## (អវិស្សជ្ជិយវត្ថុ)

CS vin.cv.06.03.01 | ភាគ ទី១០

### (អវិស្សជ្ជិយវត្ថុ)

[៤០២] សម័យនោះឯង ពួកអាវាសិកភិក្ខុ នៅក្នុងអាវាសជិតស្រុកតូច១ មិនឆ្ងាយពីក្រុងសាវត្ថី មានសេចក្តីលំបាកនឹងរៀបចំក្រាលសេនាសនៈបម្រុងពួកភិក្ខុមកថ្មី និងពួកភិក្ខុរៀបដំណើរទៅ។ ភិក្ខុទាំងនោះ ក៏គិតគ្នាថា ម្នាលអាវុសោទាំងឡាយ ឥឡូវនេះ ពួកយើងលំបាកនឹងក្រាលសេនាសនៈបម្រុងពួកភិក្ខុមកថ្មី និងពួកភិក្ខុរៀបដំណើរទៅ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើងនឹងប្រគល់សេនាសនៈទាំងអស់ ជារបស់សង្ឃ ទៅភិក្ខុមួយរូប ឯយើងរាល់គ្នា ចាំប្រើប្រាស់ទ្រព្យរបស់ ដោយសារភិក្ខុនោះវិញ។ ភិក្ខុទាំងនោះ ក៏បានប្រគល់សេនាសនៈទាំងអស់ ជារបស់សង្ឃ ទៅភិក្ខុមួយរូប។ ពួកអាគន្តុកភិក្ខុនិយាយពាក្យនេះ នឹងអាវាសិកភិក្ខុនោះថា ម្នាលអាវុសោ ចូរលោករៀបចំសេនាសនៈបម្រុងយើង។ អាវាសិកភិក្ខុឆ្លើយថា ម្នាលអាវុសោ សេនាសនៈរបស់សង្ឃ មិនមានទេ (ព្រោះ) យើងបានប្រគល់ឲ្យភិក្ខុមួយរូបអស់ទៅហើយ។ អាគន្តុកភិក្ខុសួរថា ម្នាលអាវុសោ ពួកលោកហ៊ានលះសេនាសនៈរបស់សង្ឃឬ។ អាវាសិកភិក្ខុឆ្លើយថា យ៉ាងហ្នឹងហើយ អាវុសោ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុ មិនសមបើហ៊ានលះសេនាសនៈ ជារបស់សង្ឃសោះ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុ លះសេនាសនៈរបស់សង្ឃ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះសម្ពុទ្ធមានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនសមបើនឹងលះសេនាសនៈរបស់សង្ឃសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ របស់ដែលមិនគួរលះចេញ៥យ៉ាងនេះ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ។ របស់ទាំង៥នោះ ដូចម្តេច។ គឺអារាម គឺសួនច្បារ[103] ១ អារាមវត្ថុ គឺទីដីដាំសួនច្បារ១ នេះជារបស់មិនគួរលះចេញ ជាដំបូង ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ វិហារ គឺលំនៅ១ វិហារវត្ថុ គឺទីដីសម្រាប់សង់លំនៅ១ នេះជារបស់មិនគួរលះចេញ ជាគំរប់ពីរ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ មញ្ចៈ គឺគ្រែ១ បីឋៈ គឺតាំង ឬកៅអី១ ភិសី គឺពូក១ ពិម្ពោហនៈ គឺខ្នើយ១ នេះជារបស់មិនគួរលះចេញ ជាគំរប់បី ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ លោហកុម្ភី គឺឆ្នាំងដែលធ្វើពីលោហជាតិ១ លោហភាណកៈ គឺខ្ទះលោហៈ១ លោហវារកៈ គឺក្អមលោហៈ១ លោហកដាហៈ គឺផើងលោហៈ១ វាសី គឺកាំបិត១ ផរសុ គឺពូថៅ១ កុឋារី គឺដឹងចាំង១ កុទ្ទាលៈ គឺចប១ និខាទនៈ គឺពន្លាក១ នេះជារបស់មិនគួរលះចេញ ជាគំរប់៤ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ វល្លិ គឺវល្លិ១ វេឡុ គឺឫស្សី១ មុញ្ជៈ គឺស្មៅដំណេកទន្សាយ១ បព្វជៈ គឺស្មៅយ៉ាផ្លង១ តិណៈ គឺស្មៅធម្មតា១ មត្តិកា គឺដីស្អិត១ ទារុភណ្ឌៈ គឺគ្រឿងឈើ១ មត្តិកាភណ្ឌៈ គឺគ្រឿងធ្វើពីដី១ នេះជារបស់មិនគួរលះចេញ ជាគំរប់៥ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ ម្នាលភិក្ខុទាំងឡាយ របស់ទាំង៥ពួកនេះឯង ជារបស់មិនគួរលះចេញ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ។

## (អវេភង្គិយវត្ថុ)

CS vin.cv.06.03.02 | ភាគ ទី១០

### (អវេភង្គិយវត្ថុ)

[៤០៣] គ្រានោះឯង ព្រះមានព្រះភាគទ្រង់គង់នៅក្នុងក្រុងសាវត្ថី សំរាន្តពុទ្ធឥរិយាបថ ហើយយាងទៅកាន់ចារិក ក្នុងកិដាគិរិជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើន ប្រមាណ៥០០រូប ព្រមទាំងព្រះសារីបុត្ត និងព្រះមោគ្គល្លានផង។ ពួកអស្សជិ និងបុនព្វសុកភិក្ខុ បានឮដំណឹងថា ព្រះមានព្រះភាគ យាងមកដល់កិដាគិរិជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើន ប្រមាណ៥០០រូប ព្រមទាំងព្រះសារីបុត្ត និងព្រះមោគ្គល្លានផង ក៏និយាយថា ម្នាលអាវុសោ បើដូច្នោះ មានតែយើងនាំគ្នាចែកសេនាសនៈ ជារបស់សង្ឃទាំងអស់ (ដ្បិត) សារីបុត្ត និងមោគ្គល្លាន ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចសេចក្តីប្រាថ្នាលាមក យើងរាល់គ្នា កុំរៀបចំក្រាលសេនាសនៈប្រគេនលោកឡើយ។ ភិក្ខុទាំងនោះ ក៏នាំគ្នាចែកសេនាសនៈ ដែលជារបស់សង្ឃទាំងអស់។ គ្រានោះ ព្រះមានព្រះភាគ កំពុងស្តេចមកកាន់ចារិក តាមលំដាប់ ទ្រង់តម្រង់ទៅកាន់កិដាគិរិ

ជនបទនោះ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុច្រើនរូបមកថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា ចូរដើរទៅរកពួកអស្សជិ និងបុនព្វសុកភិក្ខុ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគ កំពុងតែស្តេចមក ជាមួយនឹងភិក្ខុសង្ឃច្រើន ប្រមាណ៥០០រូប ព្រមទាំងព្រះសារីបុត្ត និងព្រះមោគ្គល្លានផង ម្នាលអាវុសោ លោករាល់គ្នា ចូររៀបចំក្រាលសេនាសនៈទុក បម្រុងព្រះមានព្រះភាគផង បម្រុងព្រះភិក្ខុសង្ឃផង បម្រុងព្រះសារីបុត្ត និងព្រះមោគ្គល្លានផង។ ភិក្ខុទាំងនោះ ទទួលស្តាប់ (ព្រះពុទ្ធដីកា) នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏នាំគ្នាចូលទៅរកពួកអស្សជិ និងបុនព្វសុកភិក្ខុ លុះចូលទៅដល់ហើយ ទើបថ្លែងបណ្តាំនេះ ប្រាប់ពួកអស្សជិ និងបុនព្វសុកភិក្ខុថា ម្នាលអាវុសោ ដ្បិតព្រះមានព្រះភាគ ស្តេចមក ជាមួយនឹងភិក្ខុសង្ឃច្រើន ប្រមាណ៥០០រូប ព្រមទាំងព្រះសារីបុត្ត និងព្រះមោគ្គល្លានផង ម្នាលអាវុសោ លោកទាំងឡាយ ចូរនាំគ្នារៀបចំក្រាលសេនាសនៈទុក បម្រុងព្រះមានព្រះភាគផង បម្រុងព្រះភិក្ខុសង្ឃផង បម្រុងព្រះសារីបុត្ត និងព្រះមោគ្គល្លានផង។ ពួកអស្សជិ និងបុនព្វសុកភិក្ខុឆ្លើយថា ម្នាលអាវុសោ សេនាសនៈ ដែលជារបស់សង្ឃ មិនមានទេ (ព្រោះ) សេនាសនៈទាំងអស់ យើងចែកគ្នាអស់ហើយ ម្នាលអាវុសោ ព្រះមានព្រះភាគ ស្តេចមកល្អហើយ ព្រះអង្គសព្វព្រះហឫទ័យគង់ក្នុងវិហារណា ក៏នឹងគង់ក្នុងវិហារនោះទៅ ឯសារីបុត្ត និងមោគ្គល្លាន ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះអំណាចនៃសេចក្តីប្រាថ្នាលាមក យើងរាល់គ្នា មិនបានរៀបចំក្រាលសេនាសនៈឲ្យលោកទាំងនោះទេ។ ភិក្ខុទាំងនោះសួរថា ម្នាលអាវុសោ លោកទាំងឡាយ នាំគ្នាចែកសេនាសនៈរបស់សង្ឃ មែនឬ។ ពួកអស្សជិ និងបុនព្វសុកភិក្ខុឆ្លើយថា ម្នាលអាវុសោ យើងចែកមែន។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកអស្សជិ និងបុនព្វសុកភិក្ខុ មិនសមបើមកនាំគ្នាចែកសេនាសនៈរបស់សង្ឃសោះ។ លំដាប់នោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអស្សជិ និងបុនព្វសុកភិក្ខុ នាំគ្នាចែកសេនាសនៈរបស់សង្ឃ មែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនគួរនឹងហ៊ាននាំគ្នាចែកសេនាសនៈរបស់សង្ឃទេ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លាទេ។ បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ របស់ដែលមិនគួរចែក៥ពួកនេះ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ។ របស់៥ពួក ដូចម្តេច។ (របស់៥ពួកនោះ គឺ) អារាម គឺសួនច្បារ១ អារាមវត្ថុ គឺទីដីដាំសួនច្បារ១ នេះជារបស់មិនគួរចែក ជាដំបូង ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ វិហារ គឺលំនៅ១ វិហារវត្ថុ គឺទីដីសម្រាប់សង់លំនៅ១ នេះជារបស់មិនគួរចែក ជាគំរប់ពីរ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ មញ្ចៈ គឺគ្រែ១ បីឋៈ គឺតាំង ឬកៅអី១ ភិសី គឺពូក១ ពិម្ពោហនៈ គឺខ្នើយ១ នេះជាវត្ថុមិនគួរចែក ជាគំរប់បី ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ លោហកុម្ភី គឺឆ្នាំងដែលធ្វើពីលោហជាតិ១ លោហភាណកៈ គឺខ្ទះលោហៈ១ លោហវារកៈ គឺក្អមលោហៈ១ លោហកដាហៈ គឺផើងលោហៈ១ វាសី គឺកាំបិត១ ផរសុ គឺពូថៅ១ កុឋារី គឺដឹងចាំង១ កុទ្ទាលៈ គឺចប១ និខាទនៈ គឺពន្លាក១ នេះជាវត្ថុមិនគួរចែក ជាគំរប់៤ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ វល្លិ៍ គឺវល្លិ១ វេឡុ គឺឫស្សី១ មុញ្ជៈ គឺស្មៅដំណេកទន្សាយ១ បព្វជៈ គឺស្មៅយ៉ាផ្លុង១ តិណៈ គឺស្មៅធម្មតា១ មត្តិកា គឺដីស្អិត១ ទារុភណ្ឌៈ គឺគ្រឿងឈើ១ មត្តិកាភណ្ឌៈ គឺគ្រឿងធ្វើពីដី១ នេះជាវត្ថុមិនគួរចែក ជាគំរប់៥ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថាចែក ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ម្នាលភិក្ខុទាំងឡាយ របស់ទាំង៥ពួកនេះឯង ជាវត្ថុមិនគួរចែក ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថាចែកឡើយ ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ។

## (នវកម្មទានកថា)

CS vin.cv.06.03.03 | ភាគ ទី១០

### (នវកម្មទានកថា)

[៤០៤] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកិដាគិរិជនបទ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយយាងទៅកាន់ចារិកក្នុងដែនអាឡវី ទ្រង់ត្រាច់ទៅកាន់ចារិក តាមលំដាប់ សំដៅទៅកាន់ដែនអាឡវីនោះ។ ឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុង អគ្គាឡវចេតិយ ទៀបដែនអាឡវីនោះ។

[៤០៥] សម័យនោះឯង ពួកភិក្ខុនៅក្នុងដែនឡាឡវី ឲ្យនវកម្មមានសភាពយ៉ាងនេះ គឺឲ្យនវកម្មដោយគ្រាន់តែទុកដាក់ដុំដី ឬដុំបាយអខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបជញ្ជាំងខ្លះ ឲ្យនវកម្ម ដោយគ្រាន់តែដំកល់ទ្វារខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើសសរមេទ្វារខ្លះ ឲ្យនវកម្ម ដោយគ្រាន់តែធ្វើបង្អួចខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបពណ៌សខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបពណ៌ខ្មៅខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើបរិកម្មដោយជ័ររង្គខ្លះ[104] ឲ្យនវកម្មដោយគ្រាន់តែប្រក់ព្រំខ្លះ ឲ្យនវកម្មដោយគ្រាន់តែចងខ្លះ ឲ្យនវកម្មដោយគ្រាន់តែបិទបាំងទីអាស្រ័យនៅ នៃសត្វព្រាបខ្លះ ឲ្យនវកម្មដោយគ្រាន់តែជួសជុល ត្រង់កន្លែងដែលដាច់ និងធ្លុះខ្លះ ឲ្យនវកម្មដោយគ្រាន់តែប្រោះព្រំខ្លះ ឲ្យនវកម្មអស់២០ឆ្នាំខ្លះ ឲ្យនវកម្មអស់៣០ឆ្នាំខ្លះ ឲ្យនវកម្មអស់១ជីវិតខ្លះ ឲ្យនវកម្ម ចំពោះវិហារដែលធ្វើស្រេចហើយ ដែលខ្លួនបានអបលោកឲ្យ ក្នុងកាលមានផ្សែងខ្លះ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។ បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុនៅដែនអាឡវី មិនសមនឹងឲ្យនវកម្មមានសភាពយ៉ាងនេះទេ គឺឲ្យនវកម្មដោយគ្រាន់តែទុកដាក់ដុំដី ឬដុំបាយអខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបជញ្ជាំងខ្លះ ឲ្យនវកម្មដោយគ្រាន់តែដំកល់ទ្វារខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើសសរមេទ្វារខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើបង្អួចខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបពណ៌សខ្លះ ឲ្យនវកម្មដោយគ្រាន់តែលាបពណ៌ខ្មៅខ្លះ ឲ្យនវកម្មដោយគ្រាន់តែធ្វើបរិកម្មដោយជ័ររង្គខ្លះ ឲ្យនវកម្មដោយគ្រាន់តែប្រក់ព្រំខ្លះ ឲ្យនវកម្មដោយគ្រាន់តែចងខ្លះ ឲ្យនវកម្មដោយគ្រាន់តែបិទបាំងទីអាស្រ័យនៅ នៃសត្វព្រាបខ្លះ ឲ្យនវកម្មដោយគ្រាន់តែជួសជុល ត្រង់កន្លែងដែលដាច់ និងធ្លុះខ្លះ ឲ្យនវកម្មដោយគ្រាន់តែប្រោះព្រំខ្លះ ឲ្យនវកម្មអស់២០ឆ្នាំខ្លះ ឲ្យនវកម្មអស់៣០ឆ្នាំខ្លះ ឲ្យនវកម្មអស់១ជីវិតខ្លះ ឲ្យនវកម្ម ចំពោះវិហារដែលធ្វើស្រេចហើយ ដែលខ្លួនបានអបលោកឲ្យ ក្នុងកាលមានផ្សែងខ្លះ។ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការនោះពិតមែនឬ។ បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។ បេ។ លុះទ្រង់

បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនវកម្មដោយគ្រាន់តែទុកដាក់ដុំដី ឬដុំបាយអ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែលាបជញ្ជាំង មិនត្រូវឲ្យនវកម្ម ដោយគ្រាន់តែដំកល់ទ្វារ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែធ្វើសសរមេទ្វារ មិនត្រូវឲ្យនវកម្ម ដោយគ្រាន់តែធ្វើបង្អួច មិនត្រូវឲ្យនវកម្មដោយគ្រាន់តែលាបឲ្យមានពណ៌ស មិនត្រូវឲ្យនវកម្មដោយគ្រាន់តែលាបឲ្យមានពណ៌ខ្មៅ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែធ្វើបរិកម្មដោយជ័ររង្គ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែប្រក់ព្រំ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែចងទុក មិនត្រូវឲ្យនវកម្មដោយគ្រាន់តែបិទបាំងទីអាស្រ័យនៅ នៃសត្វព្រាប មិនត្រូវឲ្យនវកម្មដោយគ្រាន់តែជួសជុល ត្រង់កន្លែងដែលដាច់ និងធ្លុះ មិនត្រូវឲ្យនវកម្មដោយគ្រាន់តែប្រោះព្រំ មិនត្រូវឲ្យនវកម្មអស់២០ឆ្នាំ មិនត្រូវឲ្យនវកម្មអស់៣០ឆ្នាំ មិនត្រូវឲ្យនវកម្មអស់១ជីវិត មិនត្រូវឲ្យនវកម្មអស់ ចំពោះវិហារដែលធ្វើស្រេចហើយ ដែលខ្លួនបានអបលោកឲ្យ ក្នុងកាលមានផ្សែង ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឲ្យនវកម្ម ចំពោះតែវិហារ ដែលមិនទាន់ធ្វើ ឬធ្វើមិនទាន់ហើយ (បើ) វិហារតូច ឲ្យត្រួតមើលការងារហើយ សឹមឲ្យនវកម្មអស់ត្រឹម៦ឆ្នាំ ឬ៥ឆ្នាំ ឲ្យរួច (បើ) អឌ្ឍយោគ ឲ្យត្រួតមើលការងារ ហើយសឹមឲ្យនូវនវកម្ម អស់ត្រឹម៧ឆ្នាំ ឬ៨ឆ្នាំឲ្យរួច (បើ) វិហារធំ ឬប្រាសាទ ឲ្យត្រួតមើលការងារហើយសឹមឲ្យនវកម្មអស់ត្រឹម១០ឆ្នាំ ឬ១២ឆ្នាំឲ្យរួច។

[៤០៦] សម័យនោះឯង ភិក្ខុទាំងឡាយឲ្យនវកម្មចំពោះវិហារទាំងអស់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនវកម្ម ចំពោះវិហារទាំងអស់ទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ។

[៤០៧] សម័យនោះឯង ភិក្ខុទាំងឡាយឲ្យនវកម្មពីរកន្លែង ដល់ភិក្ខុ១រូប។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនកម្មពីរកន្លែង ដល់ភិក្ខុ១រូបទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ។

[៤០៨] សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកនវកម្ម (ក្នុងវិហាររបស់សង្ឃ) ហើយឲ្យភិក្ខុដទៃនៅវិញ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលយកវនកម្ម (ក្នុងវិហាររបស់សង្ឃ) ហើយឲ្យភិក្ខុដទៃនៅទេ ភិក្ខុណាឲ្យភិក្ខុដទៃនៅ ត្រូវអាបត្តិទុក្កដ។

[៤០៩] សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកនវកម្ម (ក្នុងវិហាររបស់សង្ឃ) ហើយហាមឃាត់សេនាសនៈរបស់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលយកវនកម្ម ហើយហាមឃាត់សេនាសនៈរបស់សង្ឃទេ ភិក្ខុណាហាមឃាត់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យភិក្ខុដែលធ្វើការនោះ) ទទួលយកទីដេកដ៏ប្រសើរ១ (បន្ទប់បាន)។

[៤១០] សម័យនោះឯង ភិក្ខុទាំងឡាយឲ្យនវកម្ម ដល់ភិក្ខុនៅក្នុងទីឥតសីមា។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យនវកម្ម ដល់ភិក្ខុនៅក្នុងទីឥតសីមាទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ។

[៤១១] សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកនវកម្ម ហើយហាមឃាត់គ្រប់កាល។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលយកនវកម្ម ហើយហាមឃាត់គ្រប់កាលទេ ភិក្ខុណាហាមឃាត់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យហាមឃាត់ត្រឹម៣ខែ នៃវស្សានរដូវ (ប៉ុណ្ណោះ) មិនមែនហាមឃាត់គ្រប់កាលនៃរដូវទេ។

[៤១២] សម័យនោះឯង ភិក្ខុទាំងឡាយទទួលយកនវកម្មហើយ ដើរចេញទៅខ្លះ សឹកខ្លះ ធ្វើមរណភាពខ្លះ ប្តេជ្ញាខ្លួនទៅជាសាមណេរខ្លះ ប្តេជ្ញាជាអ្នកលាសិក្ខាខ្លះ ប្តេជ្ញាជាអ្នកត្រូវអន្តិមវត្ថុខ្លះ ប្តេជ្ញាជាមនុស្សឆ្កួតខ្លះ ប្តេជ្ញាជាអ្នកមានចិត្តរវើរវាយខ្លះ ប្តេជ្ញាជាអ្នកមានទុក្ខវេទនាគ្របសង្កត់ខ្លះ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិខ្លះ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិខ្លះ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញខ្លះ ប្តេជ្ញាជាមនុស្សខ្ទើយខ្លះ ប្តេជ្ញាជាមនុស្សលួចសំវាសខ្លះ ប្តេជ្ញាជាមនុស្សស្ទុះទៅកាន់លទ្ធិតិរ្ថិយខ្លះ ប្តេជ្ញាជាសត្វតិរច្ឆានខ្លះ ប្តេជ្ញាជាអ្នកសម្លាប់មាតាខ្លះ ប្តេជ្ញាជាអ្នកសម្លាប់បិតាខ្លះ ប្តេជ្ញាជាអ្នកសម្លាប់ព្រះអរហន្តខ្លះ ប្តេជ្ញាជាអ្នកប្រទូស្តភិក្ខុនីខ្លះ ប្តេជ្ញាជាអ្នកបំបែកសង្ឃខ្លះ ប្តេជ្ញាជាអ្នកធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពងខ្លះ ប្តេជ្ញាជាអ្នកមានភេទពីរខ្លះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។

[៤១៣] ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយ ចៀរចេញទៅ។ ត្រូវភិក្ខុនោះឲ្យ (នវកម្មនោះ) ដល់ភិក្ខុដទៃ ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាសឡើយ។ ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្ម ហើយសឹកចេញ ធ្វើមរណភាព ប្តេជ្ញាទៅជាសាមណេរ ប្តេជ្ញាជាអ្នកលាសិក្ខា ប្តេជ្ញាជាអ្នកត្រូវអន្តិមវត្ថុ ប្តេជ្ញាជាមនុស្សឆ្កួត ប្តេជ្ញាជាអ្នកមានចិត្តរវើរវាយ ប្តេជ្ញាជាអ្នកមានទុក្ខវេទនាគ្របសង្កត់ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ប្តេជ្ញាជាមនុស្សខ្ទើយ ប្តេជ្ញាជាមនុស្សលួចសំវាស ប្តេជ្ញាជាមនុស្សស្ទុះទៅកាន់លទ្ធិតិរ្ថិយ ប្តេជ្ញាជាសត្វតិរច្ឆាន ប្តេជ្ញាជាអ្នកសម្លាប់មាតា ប្តេជ្ញាជាអ្នកសម្លាប់បិតា ប្តេជ្ញាជាអ្នកសម្លាប់ព្រះអរហន្ត ប្តេជ្ញាជាអ្នកប្រទូស្តភិក្ខុនី ប្តេជ្ញាជាអ្នកបំបែកសង្ឃ ប្តេជ្ញាជាអ្នកធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពង ប្តេជ្ញាជាអ្នកមានភេទពីរ។ ត្រូវភិក្ខុនោះឲ្យ (នវកម្មនោះ) ដល់ភិក្ខុដទៃ ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាសឡើយ។

[៤១៤] ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយ ចៀសចេញទៅក្នុងវេលាដែលធ្វើ (នវកម្ម) មិនទាន់ស្រេច។ ត្រូវភិក្ខុនោះឲ្យ (នវកម្មនោះ) ដល់ភិក្ខុឯទៀត ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាសឡើយ។ ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយ សឹកចេញ ក្នុងវេលាដែលធ្វើនវកម្ម មិនទាន់ស្រេច។ ធ្វើមរណភាព។ បេ។ ប្តេជ្ញាជាអ្នកមានភេទពីរ។ ត្រូវភិក្ខុនោះឲ្យ (នវកម្មនោះ) ដល់ភិក្ខុដទៃ ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាសឡើយ។

[៤១៥] ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយ ចៀសចេញទៅ ក្នុងវេលាដែលធ្វើ (នវកម្ម) ហើយស្រេច (លុះត្រឡប់មកនៅវិញ) នវកម្មនុ៎ះ ជារបស់ភិក្ខុនោះឯង។

[៤១៦] ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយ សឹកចេញ ធ្វើមរណភាព ប្តេជ្ញាជាសាមណេរ ប្តេជ្ញាជាអ្នកលាសិក្ខា ប្តេជ្ញាជាអ្នកត្រូវអន្តិមវត្ថុ ក្នុងវេលាដែលធ្វើនវកម្មហើយស្រេច។ ត្រូវសង្ឃជាម្ចាស់។

[៤១៧] ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយ ប្តេជ្ញាជាមនុស្សឆ្កួត ប្តេជ្ញាជាអ្នកមានចិត្តរវើរវាយ ប្តេជ្ញាជាអ្នកត្រូវទុក្ខវេទនាគ្របសង្កត់ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនសំដែងអាបត្តិចេញ ប្តេជ្ញាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ក្នុងវេលាដែលធ្វើនវកម្មហើយស្រេច នវកម្មនុ៎ះ ជារបស់ភិក្ខុនោះឯង។

[៤១៨] ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុក្នុងសាសនានេះ ទទួលយកនវកម្មហើយ ប្តេជ្ញាជាមនុស្សខ្ទើយ ប្តេជ្ញាជាអ្នកលួចសំវាស ប្តេជ្ញាជាអ្នកស្ទុះទៅកាន់លទ្ធិតិរ្ថិយ ប្តេជ្ញាជាសត្វតិរច្ឆាន ប្តេជ្ញាជាអ្នកសម្លាប់មាតា ប្តេជ្ញាជាអ្នកសម្លាប់បិតា ប្តេជ្ញាជាអ្នកសម្លាប់ព្រះអរហន្ត ប្តេជ្ញាជាអ្នកប្រទូស្តភិក្ខុនី ប្តេជ្ញាជាអ្នកបំបែកសង្ឃ ប្តេជ្ញាជាអ្នកធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពង ប្តេជ្ញាជាអ្នកមានភេទពីរ ក្នុងវេលាដែលធ្វើ(នវកម្ម)ហើយស្រេច។ ត្រូវសង្ឃជាម្ចាស់។

## (អញ្ញត្របរិភោគបដិក្ខេបាទិ)

CS vin.cv.06.03.04 | ភាគ ទី១០

### (អញ្ញត្របរិភោគបដិក្ខេបាទិ)

[៤១៩] សម័យនោះឯង ភិក្ខុទាំងឡាយយកសេនាសនៈរបស់ឧបាសកម្នាក់ (ដែលគេឧទ្ទិស) ជាគ្រឿងសម្រាប់ប្រើប្រាស់ ក្នុងវិហារ ទៅប្រើប្រាស់ក្នុងទីឯទៀត។ គ្រានោះ ឧបាសកនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកដ៏ចំរើនទាំងឡាយ មិនសមបើនឹងយកគ្រឿងប្រើប្រាស់អំពីទីឯទៀត ទៅប្រើប្រាស់ក្នុងទីឯទៀតសោះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវយកគ្រឿងប្រើប្រាស់ ក្នុងទីឯទៀត ទៅប្រើប្រាស់ក្នុងទីឯទៀតទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ។

[៤២០] សម័យនោះឯង ពួកភិក្ខុមានសេចក្តីសង្ស័យ (មិនហ៊ាន) នាំយក (គ្រឿងប្រើប្រាស់) ទៅកាន់រោងឧបោសថ កាន់រោងជាទីប្រជុំ ហើយក៏នាំគ្នាអង្គុយផ្ទាល់លើផែនដី។ ទាំងខ្លួន ទាំងចីវរ (របស់ភិក្ខុនោះ) ក៏ប្រឡាក់ប្រឡូស ដោយអាចម៍ដី។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យនាំយក (គ្រឿងប្រើប្រាស់នោះ) ឲ្យជារបស់ខ្ចីបាន។

[៤២១] សម័យនោះឯង វិហារធំរបស់សង្ឃទ្រុឌទ្រោម។ ពួកភិក្ខុសង្ស័យ មិនហ៊ាននាំយកសេនាសនៈចេញ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យនាំយក (សេនាសនៈ) ទៅទុកថែរក្សាបាន។

[៤២២] សម័យនោះឯង សំពត់កម្ពលមានតម្លៃច្រើន ជាសេនាសនបរិក្ខារ កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផ្លាស់ប្តូរ ដើម្បីប្រយោជន៍ ជាផាតិកម្ម គឺការចំរើនបាន។

[៤២៣] សម័យនោះឯង សំពត់មានតម្លៃច្រើន ជាបរិក្ខារក្នុងសេនាសនៈ កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យផ្លាស់ប្តូរ ដើម្បីប្រយោជន៍ ជាផាតិកម្មបាន។

[៤២៤] សម័យនោះឯង ស្បែកខ្លាឃ្មុំ កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជាទ្រនាប់សម្រាប់ជូតជើងបាន។

[៤២៥] សម័យនោះឯង វត្ថុមានសណ្ឋានដូចជាកង់ (ដែលគេវេញ ដោយសំពត់កម្ពលជាដើម) កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជារង្វេល ម្រាប់ជូតជើងបាន។

[៤២៦] សម័យនោះឯង មានកំណាត់សំពត់ កើតឡើងដល់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើជាសំពត់ សម្រាប់ជូតជើងបាន។

[៤២៧] សម័យនោះឯង ពួកភិក្ខុមិនទាន់លាងជើង[105] ហើយដើរជាន់សេនាសនៈ។ សេនាសនៈក៏ប្រឡាក់អស់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឥតលាងជើង មិនត្រូវដើរជាន់សេនាសនៈទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ។

[៤២៨] សម័យនោះឯង ពួកភិក្ខុដើរជាន់សេនាសនៈទាំងជើងទទឹក។ សេនាសនៈក៏សើមអស់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរជាន់សេនាសនៈទាំងជើងទទឹកទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ។

[៤២៩] សម័យនោះឯង ពួកភិក្ខុពាក់ស្បែកជើង ដើរជាន់សេនាសនៈ។ សេនាសនៈក៏ប្រឡាក់អស់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុពាក់ស្បែកជើង មិនត្រូវដើរជាន់សេនាសនៈទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ។

[៤៣០] សម័យនោះឯង ពួកភិក្ខុស្តោះទឹកមាត់ លើទីដែលគេតាក់តែងឲ្យស្អាត។ (ទីនោះ) ក៏អាប់អន់ពណ៌សម្បុរទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវស្តោះទឹកមាត់ លើទីដែលគេតាក់តែងទេ ភិក្ខុណាស្តោះ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យប្រើ) កន្ថោរទឹកមាត់។

[៤៣១] សម័យនោះឯង ជើងគ្រែខ្លះ ជើងតាំងខ្លះ ក៏កោសដាច់ទីកន្លែង ដែលគេតាក់តែងឲ្យល្អ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរុំ (ជើងគ្រែ ជើងតាំងនោះ) ដោយកំណាត់សំពត់។

[៤៣២] សម័យនោះឯង ពួកភិក្ខុផ្អែកនឹងជញ្ជាំងដែលគេលាប (ថ្នាំផ្សេងៗ)។ ពណ៌សម្បុរ (ជញ្ជាំង) ក៏អាប់អន់ទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផ្អែកនឹងជញ្ជាំង ដែលគេលាប (ថ្នាំផ្សេងៗ) ទេ ភិក្ខុណាផ្អែក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផែនក្តារសម្រាប់ផ្អែក។ ឯផែនក្តារសម្រាប់ផ្អែក ក៏កោសផ្ទៃទីខាងក្រោមនឹងជញ្ជាំងខាងលើ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរុំសំពត់ទាំងខាងលើ ទាំងខាងក្រោម។

[៤៣៣] សម័យនោះឯង ភិក្ខុមានជើងលាងស្រេចហើយ តែនៅមានសង្ស័យ (មិនហ៊ាន) ដេក។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យក្រាលកម្រាលរួចសឹមដេក។

## (សង្ឃភត្តាទិអនុជាននៈ)

CS vin.cv.06.03.05 | ភាគ ទី១០

### (សង្ឃភត្តាទិអនុជាននំ)

[៤៣៤] គ្រានោះ ព្រះមានព្រះភាគគង់នៅក្នុងដែន អាឡវី គួរតាមព្រះអធ្យាស្រ័យ រួចហើយ ទ្រង់ស្តេចទៅកាន់ចារិក ក្រុងរាជគ្រឹះ ស្តេចទៅកាន់ចារិកតាមលំដាប់ សំដៅទៅកាន់ក្រុងរាជគ្រឹះនោះ។ បានឮថា ព្រះមានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។

[៤៣៥] សម័យនោះឯង ក្រុងរាជគ្រឹះក៏កើតទុរ្ភិក្ស (អត់បាយ) មនុស្សទាំងឡាយ មិនអាចនឹងធ្វើសង្ឃភត្តបាន ហើយក៏ប្រាថ្នានឹងធ្វើឧទ្ទេសភត្ត និមន្តភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត និងបាដិបទិកភត្ត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសង្ឃភត្ត ឧទ្ទេសភត្ត និមន្តភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត និងបាដិបទិកភត្ត។

## (ភត្តុទ្ទេសកសម្មុតិ)

CS vin.cv.06.03.06 | ភាគ ទី១០

### (ភត្តុទ្ទេសកសម្មុតិ)

[៤៣៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទួលយកភត្តប្រសើរ ចំពោះខ្លួនឯង ហើយឲ្យភត្តមិនថ្លៃថ្លា ដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ៥ ឲ្យជាភត្តុទ្ទេសកៈ គឺអ្នកសំដែងភត្ត (អង្គ៥នោះគឺ) មិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ស្គាល់ភត្តដែលខ្លួនបានសំដែង និងមិនទាន់បានសំដែង១។

[៤៣៧] ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ។ សង្ឃត្រូវសូមភិក្ខុជាមុនសិន។ លុះសូមរួចហើយ ត្រូវឲ្យភិក្ខុជាអ្នកឈ្លាសប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាភត្តុទ្ទេសកៈ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាភត្តុទ្ទេសកៈ។ ការសន្មតិភិក្ខុឈ្មោះនេះ ឲ្យជាភត្តុទ្ទេសកៈ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីឆ្លើយមក។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាភត្តុទ្ទេសកៈហើយ ការសន្មតិនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[៤៣៨] លំដាប់នោះ ពួកភិក្ខុជាភត្តុទ្ទេសកៈ មានសេចក្តីត្រិះរិះដូច្នេះថា យើងគួរសំដែងភត្តដូចម្តេចហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចារិក ដោយសលាក ឬដំបា (មានបន្ទះឫស្សី និងស្លឹកត្នោតជាដើម) លា ឬបើកហើយ សឹមសំដែងភត្ត។

## (សេនាសនបញ្ញាបកាទិសម្មុតិ)

### (សេនាសនបញ្ញាបកាទិសម្មុតិ)

[៤៣៩] សម័យនោះឯង មិនទាន់មានភិក្ខុជាសេនាសនប្បញ្ញាបកៈ (អ្នកក្រាលសេនាសនៈ) បម្រុងសង្ឃ។ បេ។ មិនទាន់មានភិក្ខុជាភណ្ឌាគារិកៈ (អ្នករក្សាឃ្លាំង)។ បេ។ មិនទាន់មានភិក្ខុជាចីវរប្បដិគ្គាហកៈ (អ្នកទទួលចីវរទុក)។ បេ។ មិនទាន់មានភិក្ខុជាចីវរភាជកៈ (អ្នកចែកចីវរ)។ បេ។ មិនទាន់មានភិក្ខុជាយាគុភាជកៈ (អ្នកចែកបបរ)។ បេ។ មិនទាន់មានភិក្ខុជាផលភាជកៈ (អ្នកចែកផ្លែឈើ)។ បេ។ មិនទាន់មានភិក្ខុជាខជ្ជកភាជកៈ (អ្នកចែកបង្អែម)នៅឡើយ។ បេ។ បង្អែមដែលមិនបានចែក ក៏ខូចអស់ទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ៥ ឲ្យជាខជ្ជកភាជកៈ (អង្គ៥នោះគឺ) មិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ស្គាល់វត្ថុដែលខ្លួនបានចែក និងមិនទាន់បានចែក១។

[៤៤០] ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ។ សង្ឃគប្បីសូមភិក្ខុជាមុនសិន។ លុះសូមរួចហើយ ត្រូវឲ្យភិក្ខុជាអ្នកឈ្លាសប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាខជ្ជកភាជកៈ (អ្នកចែកបង្អែម)។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឥឡូវ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាខជ្ជកភាជកៈ។ ការសន្មតភិក្ខុឈ្មោះនេះ ឲ្យជាខជ្ជកភាជកៈ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវឆ្លើយមក។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាខជ្ជកភាជកៈហើយ ការសន្មតិនេះ សមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

## (អប្បមត្តកវិស្សជ្ជកសម្មុតិ)



### (អប្បមត្តកវិស្សជ្ជកសម្មុតិ)

[៤៤១] សម័យនោះឯង បរិក្ខារតិចតួច មានក្រាស់ក្រែលឡើង ក្នុងឃ្លាំងរបស់សង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ៥ ឲ្យជាអប្បមត្តកវិស្សជ្ជកៈ (អ្នកចែកចាយនូវបរិក្ខារតិចតួច) (អង្គ៥នោះគឺ) មិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ស្គាល់បរិក្ខារដែលខ្លួនបានចែកចាយហើយ និងមិនទាន់បានចែកចាយហើយ១។

[៤៤២] ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ។ សង្ឃត្រូវសូមភិក្ខុជាមុនសិន។ លុះសូមរួចហើយ ត្រូវភិក្ខុដែលឈ្លាស ប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអប្បមត្តកវិស្សជ្ជកៈ (អ្នកចែកចាយបរិក្ខារតិចតួច)។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអប្បមត្តកវិស្សជ្ជកៈ។ ការសន្មតិភិក្ខុឈ្មោះនេះ ឲ្យជាអប្បមត្តកវិស្សជ្ជកៈ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវឆ្លើយមក។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាអប្បមត្តកវិស្សជ្ជកៈហើយ ការសន្មតិនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[៤៤៣] ភិក្ខុជាអប្បមត្តកវិស្សជ្ជកៈនោះ (បើមានភិក្ខុមកសូមម្ជុល) ត្រូវឲ្យម្ជុលមួយ (ម្តង)។ ត្រូវឲ្យកាំបិត។ ត្រូវឲ្យស្បែកជើង។ ត្រូវឲ្យវត្ថពន្ធចង្កេះ។ ត្រូវឲ្យយោគបាត្រ។ ត្រូវឲ្យសំពត់តម្រង់ទឹក។ ត្រូវឲ្យធម្មក្រក។ ត្រូវឲ្យសំពត់កុសិ (ខ្នង់វែង)។ ត្រូវឲ្យសំពត់អឌ្ឍកុសិ (ខ្នង់ខ្លី)។ ត្រូវឲ្យសំពត់មណ្ឌល (ផ្ទាំងធំ)។ ត្រូវឲ្យសំពត់អឌ្ឍមណ្ឌល (ផ្ទាំងតូច)។ ត្រូវឲ្យសំពត់អនុវាត។ ត្រូវឲ្យសំពត់សម្រាប់ថែម ឬសំពត់សម្រាប់ប៉ះ។ បើមានសប្បិក្តី ប្រេងក្តី ទឹកឃ្មុំក្តី ស្ករអំពៅក្តី (ភិក្ខុអ្នកចែកចាយបរិក្ខារនោះ) ត្រូវឲ្យដល់សង្ឃឆាន់ ក្នុងគ្រាម្តងៗ។ បើសង្ឃត្រូវការទៀត ត្រូវឲ្យទៀត។ បើសង្ឃត្រូវការម្តងទៀត ត្រូវឲ្យម្តងទៀត។

## (សាដិយគ្គាហាបកាទិសម្មុតិ)



### (សាដិយគ្គាហាបកាទិសម្មុតិ)

[៤៤៤] សម័យនោះឯង មិនទាន់មានភិក្ខុជាសាដិយគ្គាហាបកៈ (អ្នកប្រគល់សំពត់ដល់សង្ឃ)។ បេ។ មិនទាន់មានភិក្ខុជាបត្តគ្គាហាបកៈ (អ្នកប្រគល់បាត្រ)។ បេ។ មិនទាន់មានភិក្ខុជាអារាមិកបេសកៈ (អ្នកប្រើញោមវត្ត)។ បេ។ មិនទាន់មានសាមណេរបេសកៈ (អ្នកប្រើសាមណេរ)។ បេ។ សាមណេរទាំងឡាយ កាលបើភិក្ខុមិនប្រើ ក៏មិនធ្វើការងារ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ៥ ឲ្យជាសាមណេរបេសកៈ (អ្នកប្រើសាមណេរ) (អង្គ៥នោះគឺ) មិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ស្គាល់សាមណេរ ដែលខ្លួនបានប្រើ និងមិនទាន់បានប្រើ១។

[៤៤៥] ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ។ សង្ឃគប្បីសូមភិក្ខុជាមុនសិន។ លុះសូមរួចហើយ ត្រូវភិក្ខុដែលឈ្លាស ប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគួរសន្មតភិក្ខុឈ្មោះនេះ ឲ្យជា

សាមណេរបេសកៈ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះ ឲ្យជាសាមណេរបេសកៈ។ ការសន្មតិភិក្ខុឈ្មោះនេះ ឲ្យជាសាមណេរបេសកៈ គួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវឆ្លើយមក។ សង្ឃបានសន្មតភិក្ខុឈ្មោះនេះ ឲ្យជាសាមណេរបេសកៈហើយ ការសន្មតិនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។

ចប់ ភាណវារៈ ទី៣ ចប់ សេនាសនក្ខន្ធកៈ ទី៦។ ឧទ្ទាននៃសេនាសនក្ខន្ធកៈនោះ (ដូចតទៅនេះ)

[៤៤៦]

រឿងព្រះសម្មាសម្ពុទ្ធប្រសើរ មិនទាន់បានបញ្ញត្តវិហារក្នុងគ្រានោះ១ រឿងសាវ័កព្រះជិនស្រី ដើរចេញទៅ នៅក្នុងទីនោះៗ១ រឿងសេដ្ឋីគហបតិ បានឃើញព្រះសាវ័កទាំងនោះ ហើយដឹណាលរឿងនេះ ប្រាប់ភិក្ខុទាំងឡាយថា ខ្ញុំព្រះករុណា បម្រុងនឹងឲ្យជាងធ្វើវិហារ សូមលោកម្ចាស់ទាំងឡាយ គង់នៅក្នុងវិហាររបស់យើង១ រឿងពួកភិក្ខុក្រាបបង្គំទូល (ដំណើរនុ៎ះ) ចំពោះព្រះសម្មាសម្ពុទ្ធ ជានាយក១។ រឿងទ្រង់អនុញ្ញាតទីជ្រកកោន៥យ៉ាង គឺវិហារ១ អឌ្ឍយោគ១ ប្រាសាទ១ ប្រាសាទដំបូលត្រងិល១ គុហា១ រឿងសេដ្ឋីឲ្យជាងធ្វើវិហារ១។ រឿងមហាជនឲ្យជាងធ្វើវិហារ ឥតមានសន្ទះទ្វារ១ រឿងទ្រង់អនុញ្ញាតសន្ទះទ្វារ ក្របទ្វារ ត្រណាប់ក្រោម និងត្រណាប់លើជាដើម១។ រឿងទ្រង់អនុញ្ញាតប្រហោងដាក់ខ្សែសម្រាប់ទាញ និងខ្សែសម្រាប់ទាញគន្លឹះ មេទ្វារ ត្រដោកទ្វារ រនុកគន្លឹះ និងសោ៣យ៉ាង គឺ សោធ្វើពីលោហៈ សោធ្វើពីឈើ សោធ្វើពីស្នែង១។ រឿងទ្រង់អនុញ្ញាតសោយន្ត និងគន្លឹះ រឿងទ្រង់អនុញ្ញាតដម្បូល និងឲ្យបូកលាបខាងក្នុង ខាងក្រៅ១ រឿងទ្រង់អនុញ្ញាតបង្អួច៣យ៉ាង គឺបង្អួចមានវេទី បង្អួចមានក្រឡាសំណាញ់ បង្អួចមានសសរចម្រឹង១ រឿងទ្រង់អនុញ្ញាតឲ្យយកវត្ថុសម្រាប់ជូតជើង ដែលគេវេញ មានសណ្ឋានដូចជាកំផ្ចងបង្អួច១ រឿងទ្រង់អនុញ្ញាតកម្រាលស្មៅ១ រឿងទ្រង់អនុញ្ញាតបន្ទះក្តារ សម្រាប់អង្គុយ ឬដេក១ រឿងទ្រង់អនុញ្ញាតគ្រែផ្តៅ១ រឿងទ្រង់អនុញ្ញាតគ្រែដែលគេដាប់ជើង ហើយបញ្ចូលមេទៅក្នុងដំណាប់ ដែលគេចោលក្នុងព្រៃស្មសាន១ រឿងទ្រង់អនុញ្ញាតគ្រែ ដែលគេបង្ខាំងជើងគ្រែដោយមេគ្រែ១ រឿងទ្រង់អនុញ្ញាតគ្រែ ដែលគេធ្វើជើងប្រហែលនឹងជើងសេះ ឬជើងពពែជាដើម១ រឿងទ្រង់អនុញ្ញាតគ្រែ ដែលគេបញ្ចុះពន្លួញទៅក្នុងមេ១ រឿងទ្រង់អនុញ្ញាតគ្រែបួនជ្រុង មានជើងខ្ពស់១ រឿងទ្រង់អនុញ្ញាតគ្រែ មានអង្គប្រាំពីរ១ រឿងទ្រង់អនុញ្ញាតតាំងផ្តៅ១ រឿងទ្រង់អនុញ្ញាតគ្រែ និងតាំងមានជើងដូចជើងពពែ១ រឿងទ្រង់អនុញ្ញាតតាំង មានជើងច្រើន ដែលគេប្រកបដោយអាការដូចជាផ្លែកន្ទួតព្រៃ១ រឿងទ្រង់អនុញ្ញាតផែនក្តារ១ រឿងទ្រង់អនុញ្ញាតកៅអីមានទ្រនាប់១ រឿងទ្រង់អនុញ្ញាតតាំងញាត់ចម្បើង១ រឿងទ្រង់ហាមគ្រែខ្ពស់ហួសប្រមាណ១ រឿងពស់ចឹកភិក្ខុ ទើបទ្រង់អនុញ្ញាតទ្រនាប់គ្រែ១ រឿងទ្រង់អនុញ្ញាតទ្រនាប់ជើងគ្រែ មានកំពស់៨ធ្នាប់១ រឿងទ្រង់អនុញ្ញាតអំបោះសម្រាប់រ៉ុគ្រែ១ រឿងទ្រង់អនុញ្ញាតឲ្យចាក់ស្រែះគ្រែ ជាក្រឡាចត្រង្គ១ រឿងទ្រង់អនុញ្ញាតសំពត់សម្រាប់ទ្រាប់គ្រែ១ រឿងទ្រង់អនុញ្ញាតឲ្យកកាយវត្ថុដែលញាត់ដោយសំឡី យកមកធ្វើជាខ្នើយបាន១ រឿងទ្រង់អនុញ្ញាតខ្នើយកន្លះកាយ១ រឿងមហោស្រពលើកំពូលភ្នំ១ រឿងទ្រង់អនុញ្ញាតពូក១ រឿងសំពត់សម្រាប់ប្រើប្រាស់ ក្នុងសេនាសនៈ១ រឿងទ្រង់អនុញ្ញាតគ្រែតាំង ដែលញាត់ភ្ជាប់គ្រឿងញាត់ ក៏លៀនចេញធ្លាក់មកខាងក្រោម១ រឿងពួកចោរបកយកស្រោមពូកទៅ១ រឿងទ្រង់អនុញ្ញាតឲ្យគូស ដោយគំនូសផ្សេងៗ១ រឿងទ្រង់អនុញ្ញាតឲ្យផ្តិតនឹងម្រាមដៃ១ រឿងដំណោកពួកតិរ្ថិយ១ រឿងទ្រង់អនុញ្ញាតឲ្យលាបវិហារ ដោយជ័រមានពណ៌ស ឬខ្មៅ១ រឿងទ្រង់អនុញ្ញាតឲ្យលាយអង្កាម និងដីដែលមដ្ឋ១ រឿងទ្រង់អនុញ្ញាតជ័រឈើ១ រឿងទ្រង់អនុញ្ញាតដីលាយនឹងកុណ្ឌក ហើយកៀសដោយខ្នៀស១ រឿងទ្រង់អនុញ្ញាតម្សៅគ្រាប់ស្ពៃ ឬប្រេងលាយនឹងក្រមួន១ រឿងទ្រង់អនុញ្ញាត ឲ្យយកកំណាត់សំពត់ជូតប្រេង ដែលជោរឡើង១ រឿងផ្ទៃជញ្ជាំងអាក្រក់១ រឿងទ្រង់អនុញ្ញាតឲ្យលាយដីអាចម៍ជន្លេន១ រឿងទ្រង់អនុញ្ញាតជ័រឈើ និងទឹកចត់១ រឿងទ្រង់បញ្ញត្តមិនឲ្យភិក្ខុគូររូបស្រីប្រុស១ រឿងទីវិហារទាប ទ្រង់អនុញ្ញាតឲ្យធ្វើខឿន (៣យ៉ាង)១ រឿងទ្រង់អនុញ្ញាតជណ្តើរ (៣យ៉ាង)១ រឿងភិក្ខុធ្លាក់ពីលើជណ្តើរ១ រឿងវិហារមានមនុស្សកុះករច្រើន ភិក្ខុមានខ្មាស មិនហ៊ានដេក ទើបទ្រង់អនុញ្ញាតឲ្យធ្វើជញ្ជាំងតឿ១ រឿងទ្រង់អនុញ្ញាតបន្ទប់៣យ៉ាងទៀត១ រឿងទ្រង់អនុញ្ញាតឲ្យធ្វើបន្ទប់ក្នុងវិហារតូច១ រឿងជើងជញ្ជាំងវិហារពុកផុយ១ រឿងភ្លៀងសាចមកត្រូវជញ្ជាំង១ រឿងភិក្ខុស្រែកខ្លាំង (ព្រោះខ្លាចពស់)១ រឿងទ្រង់អនុញ្ញាតចម្រឹងជញ្ជាំង និងដៃកែវ១ រឿងទ្រង់អនុញ្ញាតស្នូរចីវរ និងខ្សែស្នៀង១ រឿងទ្រង់អនុញ្ញាតឲ្យធ្វើរបៀងវិហារ១ រឿងទ្រង់អនុញ្ញាតសំពត់រនាំងព្រួល សម្រាប់រូតចុះរូតឡើងបាន១ រឿងទ្រង់អនុញ្ញាតបង្កាន់ដៃ១ រឿងកំទេចស្មៅ (ជ្រុះក្នុងឧបដ្ឋានសាលា)១ រឿងទ្រង់អនុញ្ញាតឲ្យពូនដីក្នុងទីទាប១ រឿងភិក្ខុដាក់ទឹកឆាន់ក្នុងទីវាល (ទឹកក៏ក្តៅ ឆាន់មិនកើត) ទើបទ្រង់អនុញ្ញាតឲ្យធ្វើរោងដាក់ទឹក១ រឿងភាជន៍សម្រាប់ដាក់ទឹកមិនទាន់មាន១ រឿងវិហារមិនទាន់មានគ្រឿងបិទបាំង១ រឿងទ្រង់អនុញ្ញាតបន្ទប់១ រឿងទ្រង់អនុញ្ញាតបរិវេណ១ រឿងទ្រង់អនុញ្ញាតរោងភ្លើង១ រឿងទ្រង់អនុញ្ញាតឲ្យពូនដី ត្រង់ទីទាបក្នុងអារាម១ រឿងទ្រង់អនុញ្ញាតក្លោងទ្វារជាដើម១ (រឿងតទៅ) បណ្ឌិតគប្បីធ្វើន័យដូចពោលរួចហើយខាងក្រោយ រឿងអនាថបិណ្ឌិកសេដ្ឋី មានសទ្ធាយល់ធម៌ច្បាស់លាស់ (ថ្ងៃមួយ) បានដើរទៅកាន់ព្រៃជាំ (ព្រៃត្រជាក់) ហើយនិមន្តព្រះសម្មាសម្ពុទ្ធជានាយក ព្រមទាំងភិក្ខុសង្ឃ (ដើម្បីឆាន់ក្នុងថ្ងៃស្អែក) បានបង្គាប់ទាសកម្មករ ឲ្យចាត់ចែងភត្តក្នុងពាក់កណ្តាលផ្លូវ (លុះខាងក្រោយមក) បានឲ្យពួកជាងសាងវត្ត (បម្រុងព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន)១ រឿង (មនុស្សទាំងឡាយធ្វើ) នវកម្ម ក្នុងនគរវេសាលី១ រឿង (កូនសិស្សឆព្វគ្គិយភិក្ខុ) ដើរជែងទៅមុនភិក្ខុសង្ឃ ហើយហួងហែងសេនាសនៈ១ រឿង (ព្រះអង្គត្រាស់សួរថា) នរណាគួរទទួលភត្តដ៏ប្រសើរជាដើម១ រឿង (ស្វា និងដំរី) និយាយនឹងសត្វទទា១ រឿង (អវន្ទិយបុគ្គល)១ រឿង (ពួកសិស្សឆព្វគ្គិយភិក្ខុ) ហួងហែងសេនាសនៈរបស់សង្ឃ១ រឿង (មនុស្សទាំងឡាយតាក់តែង) គ្រែតាំង ដែលញាត់ដោយសំឡី ហើយទុកនៅក្នុងចន្លោះផ្ទះ១ រឿងព្រះមានព្រះភាគ ស្តេចយាងសំដៅទៅក្រុងសាវត្ថី១ រឿងអនាថបិណ្ឌិកគហបតិវេរអារាម (ចំពោះព្រះសង្ឃ ដែលមកអំពីទិសទាំងបួន)១ រឿងកើតកោលាហលក្នុងរោងភត្ត១ រឿង (ឆព្វគ្គិយភិក្ខុ) បណ្តេញភិក្ខុឈឺ១ រឿង (ឆព្វគ្គិយភិក្ខុ) ដេកជាប់នឹងដំណេកដ៏ប្រសើរ១ រឿងទ្រង់បញ្ញត្តមិនឲ្យហាមឃាត់សេនាសនៈ ដោយអាងលេស១ រឿងសត្តរសវគ្គិយភិក្ខុ (ជួសជុលវិហារ) ក្នុងទីនោះៗ១ រឿងភិក្ខុគិតគ្នាថា ភិក្ខុណាហ្ន៎ គួរប្រគល់សេនាសនៈ១ រឿងសេនាសនគ្គាហាបកៈភិក្ខុ គិតគ្នាថា យើងគួរប្រគល់សេនាសនៈដូចម្តេចហ្ន៎១ រឿងភិក្ខុប្រគល់

សេនាសនៈ តាមកំណត់វិហារ១ រឿងទ្រង់អនុញ្ញាតឲ្យឲ្យបរិវេណ តាមចំណែកជាលំដាប់ បើមានភិក្ខុឯទៀតមកដល់ (បើលោក) មិនត្រូវការ ក៏មិនត្រូវឲ្យចំណែក១ រឿងទ្រង់បញ្ញត្តមិនឲ្យភិក្ខុប្រគល់សេនាសនៈ ដល់ភិក្ខុឋិតនៅក្នុងទីឥតសីមា១ រឿង (ទ្រង់បញ្ញត្ត មិនឲ្យភិក្ខុហាមឃាត់) សេនាសនៈ អស់កាលទាំងពួង១ រឿងភិក្ខុអ្នកប្រគល់សេនាសនៈ៣ពួក១ រឿងឧបនន្ទភិក្ខុ (ហួងហែង សេនាសនៈច្រើនកន្លែង)១ រឿងព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងគុណនៃវិន័យ១ រឿងព្រះថេរៈឈររៀនវិន័យ ទើបទ្រង់អនុញ្ញាតឲ្យ អង្គុយលើអាសនៈស្មើគ្នា១ រឿងភិក្ខុមានអាសនៈស្មើគ្នា អង្គុយលើគ្រែជាមួយគ្នា ទាល់តែបាក់ ទើបទ្រង់អនុញ្ញាតឲ្យភិក្ខុ៣រូបខ្លះ ២រូបខ្លះ អង្គុយលើសេនាសនៈ ជាមួយគ្នាបាន១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុមានអាសនៈមិនស្មើគ្នា អង្គុយលើអាសនៈវែងជាមួយគ្នា បាន១ រឿងទ្រង់អនុញ្ញាតឲ្យប្រើប្រាស់ប្រាសាទមានរបៀង១ រឿងព្រះអយ្យិកា (នៃព្រះបាទបសេនទិកោសលសុគត)១ (រឿង អាវាសិកភិក្ខុ នៅក្នុងអាវាសជិតស្រុកតូចមួយ) ក្នុងទីមិនឆ្ងាយ (ពីក្រុងសាវត្ថី)១ រឿងភិក្ខុចែកសេនាសនៈរបស់សង្ឃ១ រឿងព្រះ មានព្រះភាគ ស្តេចយាងទៅកាន់កិដាគិរីជនបទ១ រឿងព្រះមានព្រះភាគ ស្តេចយាងទៅកាន់ដែនអាឡវី១ រឿងភិក្ខុឲ្យនវកម្ម ដោយ គ្រាន់តែទុកដាក់ដុំដី ឬបាយអលាបជញ្ជាំង ដំកល់សន្ទះទ្វារ សសរមេទ្វារ ធ្វើបង្អួច ធ្វើឲ្យមានពណ៌ស ឲ្យមានពណ៌ខ្មៅ ធ្វើឲ្យជិត ស្និទ្ធ ដោយបិទជំរង្គ ដោយបិទបាំង ដោយគ្រាន់តែបិទបាំងទីអាស្រ័យនៅ នៃសត្វព្រាប ជួសជុលត្រង់កន្លែងដែលដាច់ ឲ្យនវកម្ម អស់២០ឆ្នាំខ្លះ ៣០ឆ្នាំខ្លះ ឲ្យនវកម្មចំពោះវិហារ ដែលខ្លួនអបលោកឲ្យ ក្នុងកាលមានផ្សែងខ្លះ១ រឿងទ្រង់អនុញ្ញាតឲ្យឲ្យនវកម្ម ចំពោះវិហារ ដែលមិនទាន់ធ្វើ ឬធ្វើមិនទាន់ហើយ បើវិហារតូច ទ្រង់អនុញ្ញាតឲ្យត្រួតមើលការងារ ហើយសឹមឲ្យនវកម្មត្រឹម៦ឆ្នាំ ឬ៥ឆ្នាំបាន បើអឌ្ឍយោគ ទ្រង់អនុញ្ញាតឲ្យឲ្យនវកម្មត្រឹម៧ឆ្នាំ ឬ៨ឆ្នាំបាន បើវិហារធំ ទ្រង់អនុញ្ញាតឲ្យឲ្យនវកម្ម ត្រឹម១០ឆ្នាំ ឬ១២ឆ្នាំបាន១ រឿងភិក្ខុឲ្យនវកម្ម ចំពោះវិហារទាំងអស់១ រឿងភិក្ខុឲ្យនវកម្ម ពីរកន្លែង ដល់ភិក្ខុមួយរូប១ រឿងភិក្ខុទទួលនវកម្ម ក្នុង វិហាររបស់សង្ឃ ហើយប្រើឲ្យភិក្ខុឯទៀតនៅ១ រឿងភិក្ខុហាមឃាត់សេនាសនៈរបស់សង្ឃ១ រឿងទ្រង់បញ្ញត្តមិនឲ្យឲ្យនវកម្មដល់ភិក្ខុ ដែលនៅក្នុងទីឥតសីមា១ រឿងទ្រង់បញ្ញត្តមិនឲ្យហាមឃាត់ (សេនាសនៈ) អស់កាលទាំងពួង១ រឿងភិក្ខុទទួលយកនវកម្ម ហើយចៀសចេញទៅខ្លះ សឹកខ្លះ ស្លាប់ខ្លះ ប្តេជ្ញាជាសាមណេរខ្លះ ជាអ្នកលាសិក្ខាខ្លះ ជាអ្នកត្រូវអន្តិមវត្ថុខ្លះ ជាមនុស្សឆ្កួតខ្លះ ជា អ្នកមានចិត្តរាយមាយខ្លះ ជាអ្នកត្រូវទុក្ខវេទនាគ្របសង្កត់ខ្លះ ជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិខ្លះ ព្រោះមិនសំដែង អាបត្តិខ្លះ ព្រោះមិនលះបង់ទិដ្ឋិខ្លះ ជាមនុស្សខ្ទើយខ្លះ ជាមនុស្សលួចសំវាសខ្លះ ជាមនុស្សចូលលទ្ធិតិរ្ថិយខ្លះ ជាតិរច្ឆានខ្លះ ជា មនុស្សសម្លាប់មាតាខ្លះ ជាមនុស្សសម្លាប់បិតាខ្លះ ជាមនុស្សសម្លាប់ព្រះអរហន្តខ្លះ ជាមនុស្សទ្រុស្តភិក្ខុនីខ្លះ ជាមនុស្សបំបែកសង្ឃ ខ្លះ ជាមនុស្សធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពងខ្លះ ជាមនុស្សមានភេទពីរខ្លះ១ រឿងភិក្ខុឲ្យនវកម្ម ដល់ភិក្ខុដទៃ ដោយគិតថា សូមកុំឲ្យនវកម្មរបស់សង្ឃវិនាស១ រឿងភិក្ខុធ្វើនវកម្មមិនទាន់ហើយ ៗប្រគល់ឲ្យដល់ភិក្ខុដទៃ១ រឿងភិក្ខុនោះធ្វើនវ កម្មហើយ ចៀសចេញទៅខ្លះ សឹកចេញទៅខ្លះ ស្លាប់ទៅខ្លះ ប្តេជ្ញាជាសាមណេរខ្លះ ជាអ្នកលាសិក្ខាខ្លះ ជាអ្នកត្រូវអន្តិមវត្ថុខ្លះ សង្ឃ ត្រូវជាម្ចាស់ (នវកម្មនោះ)១ ភិក្ខុធ្វើនវកម្មរួចស្រេចហើយ ប្តេជ្ញាជាមនុស្សឆ្កួតខ្លះ ជាមនុស្សមានចិត្តរាយមាយខ្លះ ជាអ្នកត្រូវទុក្ខ វេទនាគ្របសង្កត់ខ្លះ ថាជាអ្នកត្រូវសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិខ្លះ ព្រោះមិនសំដែងអាបត្តិខ្លះ ព្រោះមិនលះបង់ទិដ្ឋិខ្លះ នវ កម្មនោះ ជារបស់ភិក្ខុនោះឯង១ ភិក្ខុធ្វើនវកម្មរួចស្រេចហើយ ថាបើភិក្ខុនោះប្តេជ្ញាខ្លួនជាមនុស្សខ្ទើយខ្លះ ជាអ្នកលួចសំវាសខ្លះ ជា មនុស្សចូលកាន់លទ្ធិតិរ្ថិយខ្លះ ប្តេជ្ញាជាសត្វតិរច្ឆានខ្លះ ជាអ្នកសម្លាប់មាតាខ្លះ ជាអ្នកសម្លាប់បិតាខ្លះ ជាអ្នកសម្លាប់ព្រះអរហន្តខ្លះ ជាអ្នកប្រទុស្តភិក្ខុនីខ្លះ ជាអ្នកបំបែកសង្ឃខ្លះ ជាអ្នកធ្វើព្រះលោហិត (របស់ព្រះសម្មាសម្ពុទ្ធ) ឲ្យពុរពងខ្លះ ជាអ្នកមានភេទពីរខ្លះ សង្ឃត្រូវជាម្ចាស់ (នវកម្មនោះ)១ រឿងភិក្ខុនាំយកសេនាសនៈ (របស់គ្រហស្ថ ដែលគេឧទ្ទិស ជាគ្រឿងសម្រាប់ប្រើប្រាស់ក្នុងវិហារ) ទៅប្រើប្រាស់ក្នុងទីដទៃ១ រឿងភិក្ខុមានសេចក្តីសង្ស័យ១ រឿងវិហារទ្រុឌទ្រោម១ រឿងសំពត់កម្ពលកើតឡើងដល់សង្ឃ១ រឿង សំពត់មានថ្លៃច្រើន កើតឡើងដល់សង្ឃ១ រឿងស្បែកខ្លាឃ្មុំកើតឡើងដល់សង្ឃ១ រឿងខ្សែដែលគេវេញ ឲ្យមានសណ្ឋានដូចជាកង់ កើតឡើងដល់សង្ឃ១ រឿងកំណាត់សំពត់កើតឡើងដល់សង្ឃ១ រឿងភិក្ខុមិនលាងជើង ដើរជាន់ (សេនាសនៈ)១ រឿងភិក្ខុជើងទទឹក ដើរជាន់សេនាសនៈ១ រឿងភិក្ខុពាក់ស្បែកជើង (ដើរជាន់សេនាសនៈ)១ រឿងភិក្ខុស្តោះទឹកមាត់ដាក់ (លើទីវិចិត្រល្អ)១ រឿងជើង គ្រែកោសដាច់ទីផ្ទៃ១ រឿងភិក្ខុផ្អែក (នឹងជញ្ជាំង)១ រឿងទ្រង់អនុញ្ញាតផែនក្តារសម្រាប់ផ្អែក១ រឿងផែនក្តារសម្រាប់ផ្អែក កោស ដាច់ទីផ្ទៃ១ រឿងភិក្ខុមានជើងលាងរួចហើយ (តែមិនហ៊ានដេក) ទ្រង់អនុញ្ញាតឲ្យក្រាលកម្រាលសិន (សឹមដេក)១ រឿងក្រុងរាជគ្រឹះ (កើតទុរ្ភិក្ស) មនុស្សទាំងឡាយ (ចង់ធ្វើសង្ឃភត្ត) តែមិនអាចនឹងធ្វើបាន១ រឿងឆព្វគ្គិយភិក្ខុទទួលភត្តថ្លៃថ្លា បម្រុងខ្លួនឯង ហើយ ឲ្យភត្តមិនថ្លៃថ្លា ដល់ភិក្ខុដទៃ១ រឿងទ្រង់អនុញ្ញាតឲ្យសន្មតភត្តុទ្ទេសកភិក្ខុ១ រឿងភត្តុទ្ទេសកភិក្ខុ មានសេចក្តីសង្ស័យថា ធ្វើដូច ម្តេចហ្ន៎១ រឿងមិនទាន់មានភិក្ខុអ្នកចាត់ចែងសេនាសនៈបម្រុងសង្ឃ១ រឿងសន្មតភិក្ខុឲ្យជាអ្នករក្សាឃ្លាំង១ រឿងសន្មតភិក្ខុឲ្យជាអ្នក ទទួល (ចីវរ)ទុក១ រឿងទ្រង់អនុញ្ញាតឲ្យជាអ្នកចែកបបរ១ ឲ្យជាអ្នកចែកផ្លែឈើ១ ឲ្យជាអ្នកចែកបង្អែម១ ឲ្យជាអ្នកចាត់ចែងបរិក្ខារ តិចតួច១ ឲ្យជាអ្នកប្រគល់សំពត់១ ឲ្យជាអ្នកប្រគល់បាត្រ១ រឿងសន្មតភិក្ខុឲ្យជាអ្នកប្រើញោមវត្ត និងសាមណេរ១ រឿងព្រះ សម្មាសម្ពុទ្ធ ជាវិនាយក ព្រះអង្គមានព្រះហឫទ័យប្រាថ្នានូវប្រយោជន៍ (ដល់សត្វ) ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់គ្រប សង្កត់ជនទាំងពួង (ទ្រង់អនុញ្ញាតសេនាសនៈដូចបានថ្លែងមកនេះ) ដើម្បីជ្រកកោនផង ដើម្បីនៅជាសុខសប្បាយផង ដើម្បីដុតបង់[106] (នូវអកុសលធម៌)ផង ដើម្បីពិចារណា នូវសង្ខារ[107] ផង។

ចប់ ភាគ១០

# មាតិកា


| **ចុល្លវគ្គ** | លេខ ទំព័រ |
|---|---|
| **ភាគ ទី២ ទុតិយភាគ** | ១ |

| | |
|---|---|
| **សមថក្ខន្ធកៈ** | **១** |
| រឿងពួកឆព្វគ្គិយភិក្ខុធ្វើកម្ម មានតជ្ជនីយកម្មជាដើម មិនមានក្នុងទីចំពោះមុខ | ១ |
| បុគ្គលជាអធម្មវាទី និងបុគ្គលជាធម្មវាទី | ៣ |
| សង្ឃជាអធម្មវាទី និងសង្ឃជាធម្មវាទី | ៥ |
| ភិក្ខុទាំងឡាយច្រើនជាធម្មវាទី និងសង្ឃជាអធម្មវាទី | ៧ |
| និទានព្រះទព្វមល្លបុត្ត | ៩ |
| សេចក្តីសន្មតិនូវការចាត់ចែងសេនាសនៈជាដើម | ១១ |
| និទានព្រះទព្វមល្លបុត្ត | ១២ |
| និទានមេត្តិយភុម្មជកភិក្ខុ | ១៥ |
| ការសូមសតិវិន័យ | ២៤ |
| និទានភគ្គភិក្ខុ | ២៧ |
| ការសូមអមូឡ្ហវិន័យ | ២៨ |
| ការឲ្យអមូឡ្ហវិន័យ | ៣០ |
| ការឲ្យអមូឡ្ហវិន័យមិនប្រកបដោយធម៌ មាន ៣យ៉ាង | ៣៣ |
| ការឲ្យអមូឡ្ហវិន័យប្រកបដោយធម៌ មាន ៣យ៉ាង | ៣៤ |
| រឿងពួកឆព្វគ្គិយភិក្ខុធ្វើកម្មទាំងឡាយ ដល់ពួកភិក្ខុមិនតាមពាក្យប្តេជ្ញា | ៣៦ |
| ការធ្វើតាមពាក្យប្តេជ្ញាមិនប្រកបដោយធម៌ | ៣៧ |
| ភិក្ខុប្រកបដោយអង្គ ៥ ជាអ្នកចាត់ចែងឲ្យគេចាប់ស្លាក | ៤០ |
| ការឲ្យចាប់ស្លាកដែលប្រកបដោយធម៌ មាន ១០យ៉ាង | ៤៣ |
| ការធ្វើតស្សបាបិយសិកាកម្ម ដល់ឧបវាឡភិក្ខុ | ៤៥ |
| តស្សបាបិយសិកាកម្ម ដែលជាកម្មមិនប្រកបដោយធម៌វិន័យ | ៤៦ |
| តស្សបាបិយសិកាកម្ម ដែលជាកម្មប្រកបដោយធម៌វិន័យ | ៤៧ |
| ការធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុ ៣ពួក | ៤៩ |
| ការរម្ងាប់ (អធិករណ៍) ដោយតិណវត្ថារកសមថៈ | ៥១ |
| ការសំដែង (អាបត្តិ) ដោយតិណវត្ថារកសមថៈ | ៥២ |
| អធិករណ៍ ៤យ៉ាង | ៥៩ |
| មូលនៃវិវាទាធិករណ៍ | ៦១ |
| មូលនៃអនុវាទាធិករណ៍ | ៦៥ |
| វិវាទាធិករណ៍ជាកុសលក៏មាន ជាអកុសលក៏មាន | ៧១ |
| អនុវាទាធិករណ៍ជាកុសល ជាអកុសល ជាអព្យាកតៈ | ៧២ |
| កិច្ចាធិករណ៍ជាកុសល ជាអកុសល ជាអព្យាកតៈ | ៧៥ |
| ការចោទចាត់ជាអនុវាទាធិករណ៍ | ៧៦ |
| អាបត្តិចាត់ជាអាបត្តាធិករណ៍ | ៧៨ |
| កិច្ចចាត់ជាកិច្ចាធិករណ៍ | ៧៨ |
| វិវាទាធិករណ៍រម្ងាប់ដោយសមថៈ ២យ៉ាង | ៨០ |
| ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ | ៨១ |
| អធិករណ៍រម្ងាប់ | ៨៥ |

| | |
|---|---|
| ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ | ៨៧ |
| ការសន្មតិភិក្ខុដែលប្រកបដោយអង្គ ១០ ដោយឧព្វាហិកាកម្ម | ៨៩ |
| ធម្មកថិកមិនចាំសុត្តៈ មិនចាំសុត្តវិភង្គ | ៩១ |
| ការប្រគល់អធិករណ៍ដល់សង្ឃ | ៩៣ |
| អធិករណ៍កើតឡើងក្នុងក្រុងសាវត្ថី | ៩៥ |
| ពួកភិក្ខុមិនត្រេកអរដោយរម្ងាប់អធិករណ៍ | ៩៧ |
| ការចាប់ស្លាកឈ្មោះសកណ្ហជក្ខកៈ | ៩៩ |
| អនុវាទាធិករណ៍រម្ងាប់ដោយសមថៈ ៤យ៉ាង | ១០០ |
| ការឲ្យសតិវិន័យដល់ភិក្ខុ ជាអ្នកមានសតិពេញបរិបូណ៌ | ១០១ |
| ភិក្ខុឆ្កួតមានចិត្តវិបល្លាសប្រែប្រួល | ១០៣ |
| ការឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុបាត់វង្វេងហើយ | ១០៤ |
| អនុវាទាធិករណ៍មិនបាច់អាស្រ័យសមថៈ ២យ៉ាង | ១០៧ |
| ការធ្វើតស្សបាបិយសិកាកម្ម | ១០៩ |
| អាបត្តាធិករណ៍រម្ងាប់ដោយសមថៈ ៣យ៉ាង | ១១០ |
| កិច្ចនៃបដិញ្ញាតករណកម្ម | ១១៣ |
| ការសំដែងអាបត្តិ | ១១៥ |
| អាបត្តាធិករណ៍មិនបាច់អាស្រ័យសមថៈ ១ | ១១៦ |
| ការរម្ងាប់អធិករណ៍ ដោយតិណវត្ថារកៈកណ្តាលជំនុំសង្ឃ | ១១៦ |
| ការសំដែងដោយតិណវត្ថារកៈកណ្តាលជំនុំសង្ឃ | ១១៨ |
| ការចំពោះមុខសង្ឃ ការចំពោះមុខធម៌ | ១២១ |
| **ខុទ្ទកវត្ថុក្ខន្ធកៈ** | **១២៣** |
| រឿងពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹក | ១២៣ |
| រឿងឆព្វគ្គិយភិក្ខុ នហានវត្ត | ១២៥ |
| រឿងភិក្ខុចាស់ជរាកំឡាំងថយ នហានវត្ត | ១២៩ |
| រឿងឆព្វគ្គិយភិក្ខុ ការសិតសក់ដោយស្និតជាដើម | ១៣១ |
| រឿងឆព្វគ្គិយភិក្ខុ ការផាត់មុខជាដើម | ១៣៣ |
| ទោស ៥ប្រការ នៃការច្រៀងធម៌ ដោយសម្លេងច្រៀងដ៏វែង | ១៣៥ |
| ព្រះបាទពិម្ពិសារទ្រង់មានសេចក្តីត្រូវការ ដោយផ្លែស្វាយ | ១៣៦ |
| រឿងអញ្ញតរភិក្ខុ ត្រកូលស្តេចពស់ ៤ត្រកូល | ១៣៩ |
| រឿងអញ្ញតរភិក្ខុ កិរិយាកាត់អង្គជាត | ១៤១ |
| រឿងគ្រូ ៦នាក់ បាត្រពកចន្ទន៍ | ១៤៣ |
| រឿងព្រះបិណ្ឌោលភារទ្វាជត្ថេរ | ១៤៥ |
| និយាយអំពីបាត្រ រឿងឆព្វគ្គិយភិក្ខុ | ១៤៧ |
| រឿងភិក្ខុច្រើនរូប និយាយអំពីបាត្រ | ១៥១ |
| ការហែកចីវរដោយដៃ និយាយអំពីចីវរ | ១៥៧ |
| ការជីកដាំបង្គោល និយាយអំពីចីវរ | ១៥៩ |

| | |
|---|---|
| ពួកភិក្ខុពាក់ស្បែកជើង ដើរជាន់ឈើស្តឹង និយាយអំពីស្នាប់ម្រាមដៃ | ១៦១ |
| ការទ្រង់អនុញ្ញាតរោងសម្រាប់ដាក់ឈើស្តឹង និងបាវាំសម្រាប់ដាក់ឈើស្តឹងជាដើម | ១៦៣ |
| ការទ្រង់អនុញ្ញាតខ្សែយោគ និងខ្សែសម្រាប់ចង | ១៦៥ |
| រឿងអនុញ្ញាតសំពត់តម្រងទឹក | ១៦៦ |
| ភិក្ខុ ២រូប នាំគ្នាដើរទៅកាន់ផ្លូវឆ្ងាយ | ១៦៧ |
| ការទ្រង់អនុញ្ញាតមុង | ១៦៩ |
| ការទ្រង់អនុញ្ញាតជណ្តើរ ៣យ៉ាង | ១៧១ |
| ការទ្រង់អនុញ្ញាតប្រហោង សម្រាប់បង្ហុយផ្សែងជាដើម | ១៧៣ |
| ការទ្រង់អនុញ្ញាតខឿន ៣យ៉ាងជាដើម | ១៧៤ |
| ការទ្រង់អនុញ្ញាតខ្សែស្នួរចីវរ និងខ្សែស្បៀងចីវរជាដើម | ១៧៧ |
| ការទ្រង់អនុញ្ញាត (ឲ្យធ្វើ) បង្កាន់ដៃជាដើម | ១៧៩ |
| ការទ្រង់អនុញ្ញាតវត្ថុមានសំពត់សម្រាប់ងូតទឹកជាដើម | ១៨១ |
| ទីមានដំណេកដែលគេរោយរាយដោយផ្កាជាដើម | ១៨៣ |
| កិច្ចមានបរិភោគក្នុងភាជនៈជាមួយគ្នាជាដើម និងរឿងវឌ្ឍលិច្ឆវី | ១៨៥ |
| រឿងវឌ្ឍលិច្ឆវី និងរឿងមេត្តិយភុម្មជកភិក្ខុ | ១៨៦ |
| ការផ្កាប់បាត្រដល់វឌ្ឍលិច្ឆវី | ១៨៩ |
| មិត្តអមាត្យ និងញាតិសាលោហិតរបស់វឌ្ឍលិច្ឆវី | ១៩១ |
| ការផ្ងារបាត្រឡើងវិញ | ១៩៣ |
| រឿងព្រះពោធិរាជកុមារ | ១៩៤ |
| ព្រះមានព្រះភាគយាងទៅកាន់ព្រះរាជនិវេសន៍ របស់ព្រះពោធិរាជកុមារ | ១៩៧ |
| កម្រាលសំពត់ និងរឿងស្រីម្នាក់ | ១៩៩ |
| ក្អម អម្បោស និងរឿងនាងវិសាខាមិគារមាតា | ២០១ |
| ការទ្រង់អនុញ្ញាតផ្ចិត ៤ជ្រុង និងផ្ចិតមូល (ផ្ចិតស្លឹកត្នោត) ជាដើម | ២០៣ |
| រឿងភិក្ខុ ១រូប និងការទ្រង់អនុញ្ញាតឆត្រ | ២០៥ |
| រឿងភិក្ខុ ១រូប ច្រកបាត្រក្នុងសង្រែក និងភិក្ខុ ១រូប មានជម្ងឺ | ២០៦ |
| ការសូម និងការឲ្យទណ្ឌសម្មតិ | ២០៧ |
| ការឲ្យសិក្កាសម្មតិ | ២០៩ |
| ការឲ្យទណ្ឌសិក្កាសម្មតិ និងរឿងភិក្ខុទំពាអៀង | ២១០ |
| រឿងភិក្ខុ ១រូប និងរឿងស្រីម្នាក់ | ២១៣ |
| ការទ្រង់អនុញ្ញាតឲ្យភិក្ខុកាត់ក្រចកត្រឹមនឹងសាច់ | ២១៤ |
| ការទ្រង់អនុញ្ញាតគ្រឿងប្រដាប់សម្រាប់កោរ មានកាំបិតកោរជាដើម | ២១៥ |
| ការឲ្យកាត់សក់ដោយកន្ត្រៃ និងការទ្រង់អនុញ្ញាតសណ្តាស | ២១៧ |
| គ្រឿងលោហៈ គ្រឿងសម្រិទ្ធិ និងការទ្រង់អនុញ្ញាតបំពង់ថ្នាំភ្នែកជាដើម | ២១៩ |
| ការទ្រង់អនុញ្ញាតកាយពន្ធ (វត្ថពន្ធចង្កេះ) | ២២០ |
| ការទ្រង់អនុញ្ញាតក្រវិលឡេវ អន្ទាក់ឡេវ | ២២២ |
| ភិក្ខុស្លៀកស្បង់ដូចសម្លៀកគ្រហស្ថ ដណ្តប់ដូចគ្រហស្ថ | ២២៤ |
| អានិសង្ស ៤ប្រការ ក្នុងការទំពាឈើស្ទន់ និងរឿងឆព្វគ្គិយភិក្ខុ | ២២៦ |

| | |
|---|---|
| ការឡើងដើមឈើ | ២២៩ |
| រឿងភិក្ខុ ២រូប ជាបងប្អូននឹងគ្នា នាំគ្នាទៅគាល់ព្រះមានព្រះភាគ | ២៣០ |
| ការរៀនគម្ពីរលោកាយតៈ | ២៣១ |
| រឿងព្រះមានព្រះភាគទ្រង់កណ្តាស់ | ២៣៣ |
| ការទ្រង់អនុញ្ញាតខ្ទឹម និងការបន្ទោបង់បស្សាវៈ | ២៣៥ |
| ការទ្រង់អនុញ្ញាតឲ្យភិក្ខុធ្វើទីដីឲ្យខ្ពស់ឡើងជាដើម | ២៣៦ |
| ការទ្រង់អនុញ្ញាតវត្ថុសម្រាប់តោងជាដើម | ២៣៩ |
| រឿងឆព្វគ្គិយភិក្ខុ និងអនាចារមានប្រការផ្សេង ៗ | ២៤១ |
| ឧទ្ទានគាថា នៃខុទ្ទកវត្ថុក្ខន្ធកៈ | ២៤៥ |
| **សេនាសនក្ខន្ធកៈ** | **២៥៩** |
| រឿងរាជគហសេដ្ឋី | ២៥៩ |
| ការទ្រង់អនុញ្ញាតសេនាសនៈ ៥យ៉ាង និងរឿងរាជគហសេដ្ឋី | ២៦១ |
| គាថាសម្រាប់អនុមោទនាសេនាសនៈ | ២៦៣ |
| ការទ្រង់អនុញ្ញាតសន្ទះទ្វារជាដើម | ២៦៥ |
| ការទ្រង់អនុញ្ញាតបង្អួច ៣យ៉ាងជាដើម | ២៦៧ |
| ការទ្រង់អនុញ្ញាតតាំង ដែលគេបង្ខាំជើងជាប់នឹងមេតាំងជាដើម | ២៦៩ |
| ការទ្រង់អនុញ្ញាតតាំងចាក់ផ្តៅជាដើម | ២៧១ |
| ការទ្រង់អនុញ្ញាតទ្រនាប់ត្រៃជាដើម | ២៧៣ |
| ការទ្រង់អនុញ្ញាតពូកទាំងឡាយ មានពូកញាត់រោមកែះជាដើម | ២៧៥ |
| ការទ្រង់អនុញ្ញាតជ័រឈើ និងបាយម៉ានជាដើម | ២៧៧ |
| ការទ្រង់អនុញ្ញាតគំនូរភ្ញីផ្កាជាដើម | ២៧៩ |
| ការទ្រង់អនុញ្ញាតពីដានជាដើម | ២៨១ |
| ការទ្រង់អនុញ្ញាតជណ្តើរឥដ្ឋជាដើម | ២៨៣ |
| ការទ្រង់អនុញ្ញាតសន្ទះទ្វារជាដើម | ២៨៥ |
| ការទ្រង់អនុញ្ញាតថ្នាំពណ៌សជាដើម | ២៨៧ |
| រឿងអនាថបិណ្ឌិកសេដ្ឋី និងរឿងរាជគហសេដ្ឋី | ២៨៩ |
| សីលវកគាថា | ២៩៣ |
| អនុបុព្វីកថា | ២៩៥ |
| ធម្មចក្ខុ | ២៩៧ |
| ការថ្វាយភត្ត | ២៩៩ |
| រឿងអនាថបិណ្ឌិកគហបតិ និងវត្តព្រះជេតពន | ៣០១ |
| ការធ្វើនវកម្ម និងរឿងជាងជុល ឬដេរ | ៣០៥ |
| ការឲ្យនវកម្មនឹងពួកអន្តេវាសិករបស់ឆព្វគ្គិយភិក្ខុ | ៣០៧ |
| អាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរ | ៣០៩ |
| រឿងសត្វជាសម្លាញ់នឹងគ្នា ៣តួ | ៣១១ |
| គារវកថា | ៣១៣ |
| អវន្ទិយបុគ្គល មាន ១០ពួក | ៣១៤ |

| | |
|---|---|
| វន្ទិយបុគ្គល មាន ៣ពួក | ៣១៥ |
| វត្ថុដែលគេធ្វើឧទ្ទិសដល់សង្ឃ | ៣១៥ |
| អាសនៈខ្ពស់ និងអាសនៈប្រសើរ | ៣១៧ |
| ការថ្វាយវត្តព្រះជេតពន | ៣១៩ |
| គាថានៃវិហារទាន | ៣២១ |
| ការបណ្តេញភិក្ខុដែលកំពុងឆាន់មិនទាន់លែង ឲ្យក្រោកចេញ | ៣២៣ |
| រឿងឆព្វគ្គិយភិក្ខុ | ៣២៥ |
| រឿងសត្តរសវគ្គិយភិក្ខុ | ៣២៦ |
| ការសន្មតិសេនាសនគ្គាហាបកភិក្ខុ | ៣២៨ |
| ការប្រគល់សេនាសនៈ មាន ៣យ៉ាង និងរឿងឧបនន្ទភិក្ខុ | ៣៣១ |
| ការហួងហែងសេនាសនៈ មាន ២យ៉ាង និងការសំដែងវិន័យ | ៣៣៣ |
| ការទ្រង់អនុញ្ញាតឲ្យភិក្ខុអង្គុយ ជាមួយនឹងភិក្ខុមានវស្សារវាង ៣ ជាដើម | ៣៣៥ |
| រឿងព្រះអយ្យិការបស់ព្រះបាទបសេនទិកោសល | ៣៣៧ |
| របស់ដែលភិក្ខុលះមិនដាច់ មាន ៥យ៉ាង | ៣៣៩ |
| របស់មិនត្រូវលះ មាន ៥យ៉ាង | ៣៤១ |
| រឿងអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ | ៣៤១ |
| ការចែកសេនាសនៈជារបស់សង្ឃ | ៣៤៣ |
| របស់ដែលមិនត្រូវចែក មាន ៥យ៉ាង | ៣៤៤ |
| រឿងភិក្ខុនៅក្នុងដែនអាឡវី | ៣៤៦ |
| ការឲ្យនវកម្ម | ៣៤៧ |
| ការឲ្យនវកម្មចំពោះវិហារទាំងអស់ជាដើម | ៣៤៩ |
| ការដែលភិក្ខុទទួលនវកម្ម ហើយដើរចៀសចេញទៅជាដើម | ៣៥១ |
| ការដែលភិក្ខុទទួលនវកម្ម ហើយចៀសចេញទៅ ក្នុងវេលាដែលធ្វើរួចជាដើម | ៣៥៣ |
| ការនាំយកគ្រឿងប្រើប្រាស់ឲ្យជារបស់ខ្ចីជាដើម | ៣៥៥ |
| ការជាន់សេនាសនៈដោយជើងមិនទាន់លាងជាដើម | ៣៥៧ |
| ការទ្រង់អនុញ្ញាតឲ្យក្រាលកម្រាល ហើយសឹមដេកជាដើម | ៣៥៩ |
| ភត្តុទ្ទេសកភិក្ខុ និងសេនាសនប្បញ្ញាបកភិក្ខុ | ៣៦០ |
| ការសម្មតិអប្បមត្តកវិស្សជ្ជកភិក្ខុ | ៣៦៣ |
| ភិក្ខុជាសាដិយគ្គាហាបកៈជាដើម | ៣៦៥ |
| ឧទ្ទានគាថានៃសេនាសនក្ខន្ធកៈ | ៣៦៦ |


ភាគ ទី៩ | **មាតិកា** | ភាគ ទី១១

1)
សំដៅយកភិក្ខុ២.៣រូប បើនឹងហៅថា គណៈវិញ ក៏បាន ចំណែកភិក្ខុតែមួយរូប បាលីហៅថា បុគ្គល តាំងពី៤រូបឡើងទៅ ហៅថាសង្ឃ។

2)
វេលាវិកាល កន្លែងខ្លះ សំដៅយក ពេលតាំងអំពីថ្ងៃជ្រេពីត្រង់ ទៅទល់អរុណរះ កន្លែងខ្លះ សំដៅយកពេលតាំងពីព្រលប់ឡើងទៅ ដូចក្នុងទីនេះ សំដៅយកពេលព្រលប់ឡើងទៅ។

3)

ជាឈ្មោះសម្លម្យ៉ាង ប្រែថា សម្លកាច់បង់នូវរសដ៏ក្រៃលែង គឺជាសម្លមានឱជារសឆ្ងាញ់ជាងភោជនឯទៀតៗ ដែលគេនិយមក្នុងជាន់នោះ។

4)

គេប្រគេន ត្រឹមតែបាយចុងអង្ករ គំរប់ពីនឹងទឹកជ្រក់ ជាភោជនធម្មតា ដែលគេធ្វើខ្ចីខ្ចាឲ្យតែបាន

5)

ភត្តសម្រាប់ភិក្ខុ៤រូប។

6)

អដ្ឋកថា ថា សតិវិន័យនេះ សង្ឃត្រូវឲ្យតែព្រះខីណាស្រពប៉ុណ្ណោះ មិនត្រូវឲ្យដល់ភិក្ខុឯទៀតទេ ដោយហោចទៅ សូម្បីតែភិក្ខុជាអនាគាមី ក៏មិនត្រូវឲ្យដែរ។ សតិវិន័យនោះ ត្រូវឲ្យដល់ភិក្ខុដែលភិក្ខុដទៃចោទ បើគេមិនចោទ ក៏មិនត្រូវឲ្យដែរ។ កាលបើសង្ឃឲ្យសតិវិន័យហើយ អ្នកចោទ ក៏ចោទមិនឡើងឡើយ។

7)

គឺកំណត់យកពួកខាងធម្មវាទី មានចំនួនច្រើនជាង។

8)

អដ្ឋកថា ថា អធិករណ៍នោះ មិនទាន់រាលដាលដល់អាវាសទី៣ ឬមិនទាន់បានវិនិច្ឆ័យពីរបីលើកនៅឡើយ

9)

ពួកអធម្មវាទីពោលថា ពួកយើងមានចំនួនច្រើនជាង ហើយចាប់ស្លាកពីរៗម្នាក់។

10)

ពួកធម្មវាទីពោលថា ពួកយើងជាបក្ខពួក មានកំឡាំង ហើយទៅចាប់ស្លាករបស់អធម្មវាទីវិញ។

11)

ប្រែថា ធម៌ជាគ្រឿងរម្ងាប់ ដូចគ្របទុកដោយស្មៅ បានដល់កិរិយា ដែលឲ្យមានសេចក្ដីស្រុះស្រួលគ្នា ទាំងពីរខាង គឺមិនជម្រះរកសេចក្ដីដើម (ផ្សះផ្សា)។

12)

អដ្ឋកថា ថា បានដល់អាបត្តិបារាជិក១ សង្ឃាទិសេស១។

13)

បានដល់អាបត្តិដែលភិក្ខុត្រូវ ដោយជេរប្រទេច នូវពួកគ្រហស្ថ ដោយពាក្យថោកទាប និងការទទួលពាក្យប្ដេជ្ញា ប្រកបដោយធម៌។

14)

គឺមិនបានមកក្នុងទីនោះ ឬមកហើយ ឲ្យឆន្ទះហើយ តែទៅអង្គុយក្នុងទីដទៃ មានបរិវេណជាដើម

15)

ក្នុងដីកា ថា ខ្ញុំន

16)

អធិករណ៍ឯទៀត មានមូលច្រើន ចំណែកកិច្ចាធិករណ៍នេះ មានមូលតែ១។

17)

អដ្ឋកថា ថា អាបត្តាធិករណ៍ ជាអព្យាកតៈនោះ គឺភិក្ខុមិនបានក្លែង មិនបានដឹងអ្វីសោះ តែត្រូវអាបត្តិ (ជាអចិត្តកៈ) មានបឋមសហសេយ្យសិក្ខាបទ ជាដើម។ ក្នុងដីកាថា ដូចជាភិក្ខុ មានចិត្តចុះស៊ប់ កាន់កម្មដ្ឋាន ហើយសិងលក់ទៅ បើមានមាតុគ្រាម មកដេកជាមួយ ត្រូវអាបត្តិ ដោយការដេកក្នុងខណៈនោះ តែមិនមានចិត្តជាអកុសល បានជាលោកហៅថា អាបត្តាធិករណ៍ ជាអព្យាកតៈ។

18)

អដ្ឋកថា ថា ត្រូវសង្ឃអបលោក ហើយសន្មត ឬសន្មតដោយញត្តិទុតិយកម្មវាចា ឯភិក្ខុ ដែលសង្ឃសន្មតយ៉ាងនេះហើយ ត្រូវទៅអង្គុយផ្សេងគ្នា ភិក្ខុឯទៀត ប្រកាសដល់បរិសទ្យនោះថា អ្នកទាំងឡាយ កុំនិយាយអ្វីឡើយ ហើយសឹមវិនិច្ឆ័យអធិករណ៍នោះ។

19)

អដ្ឋកថា ថា កាលបើភិក្ខុបរិសទ្យ ជាអលជ្ជីច្រើនជាង ត្រូវធ្វើស្លាកបិទមុខ។ បើភិក្ខុបរិសទ្យ ជាលជ្ជីច្រើនជាង ត្រូវធ្វើស្លាកបើកមុខ។ បើភិក្ខុបរិសទ្យជាមនុស្សល្ងង់ច្រើនជាង ត្រូវខ្សឹបប្រាប់ជិតត្រចៀក។

20)

អដ្ឋកថា ថា ត្រូវឲ្យចាប់ជាថ្មីទៀត ដរាបតែគ្រប់បីដង។

21)

អដ្ឋកថា ថា អាបត្តិទុក្កដ ឈ្មោះថា អាបត្តិរងបារាជិក ក្នុងមេថុនធម្មសិក្ខាបទ។ អាបត្តិថុល្លច្ច័យ ឈ្មោះថា អាបត្តិរងបារាជិក ក្នុងសិក្ខាបទឯទៀត មានអទិន្នានសិក្ខាបទ ជាដើម។

22)

សសរ ដែលគេបោះទុក ក្បែរកំពង់ សម្រាប់ងូតទឹក

23)

ឈើដែលគេយកទៅចាំង ធ្វើជាផែនក្តារ ហើយឆូត ឲ្យមានស្នាមគំនូស ដូចជាក្រឡាចត្រង្គ ហើយជីកដាំទុកក្បែរកំពង់សម្រាប់ងូតទឹក ហៅថា ទីមិនគួរ មនុស្សយកគ្រឿងលំអ ទៅដាក់ក្នុងផែនក្តារនោះហើយ ត្រដុសកាយ។
24)
ឈើដែលគេធ្វើ ដូចជាដៃនៃមនុស្ស ហើយគេតម្កល់ទុកក្បែរកំពង់សម្រាប់ងូតទឹក មនុស្សទាំងឡាយយកគ្រឿងលំអិតទៅដាក់គរនឹងឈើនោះ ហើយត្រដុសកាយដោយឈើនោះ (អដ្ឋកថា)។
25)
គេយកលំអិតថ្ម ឈ្មោះកុរុវិន្ទកៈ មកលាយច្របល់នឹងល័ក្ត ហើយសូនធ្វើជាដុំ ហើយស្រែះ ដោយអម្បោះ ហើយកាន់របស់នោះខាងចុងខាងដើម ហើយដុះកាយក្នុងវេលាងូតទឹក (អដ្ឋកថា)។
26)
ដុសខ្លួននឹងខ្លួន ទៅវិញទៅមក។
27)
ឈើដែលគេឆ្លាក់ជាក្បាច់ធ្មេញមករ ហើយធ្វើឲ្យមានទ្រង់ទ្រាយដូចជើងកន្តោរ (អដ្ឋកថា)។
28)
ខ្មាញ់ ឬឆ្អឹងសំពត់ដែលគេត្របាញ់។
29)
គ្រឿងប្រដាប់ត្រចៀក ដែលគេព្យួរសំយុងចុះ ឲ្យផុតអំពីត្រចៀកជាដើម (បើតាមដីកាថា គ្រឿងប្រដាប់ត្រចៀក មានកណ្តួលជាដើម)។ អដ្ឋកថា។
30)
ព្រះសុវណ្ណពាហុរតន៍ (កន្រ្ទុំ)។
31)
ពីរធ្នាប់ទទឹងម្រាមដៃ
32)
អដ្ឋកថា ថា វត្ថុសម្រាប់សូត្រសរភ័ញ្ញ មាន៣២យ៉ាង មានគរង្គវត្ត ទោហកវត្ត និងគលិតវត្តជាដើម។ ភិក្ខុពេញចិត្ត ចង់សូត្រដោយវត្តបែបណាក៏បាន ប៉ុន្តែត្រូវប្រយ័ត្ន កុំធ្វើបទនឹងព្យញ្ជនៈឲ្យខូច ត្រូវសូត្រដោយន័យ ជាចតុរស្ស សមគួរតាមសណ្តាប់ធ្នាប់របស់សមណៈ។
33)
ផ្លែឈើ ដែលគេធ្វើឲ្យសមគួរ ដល់សមណៈ ហៅថា សមណកប្ប
34)
យើងមានមេត្តាចិត្ត គឺចិត្តដែលឥតមានព្យាបាទ ដល់ពួកត្រកូលពស់ ឈ្មោះវិរូបក្ខៈ។
35)
១.២.៣ ពាក្យទាំងបីនេះ ជាពាក្យសម្រាប់ផ្លាស់ប្តូរគ្នា និងពាក្យថាបុគ្គល (សារត្ថទីបនីដីកា)។
36) , 83)
២
37)
៣
38)
ក្នុងដីកាថា រាគានុសយៈ ហៅថាវត្ថុដទៃ
39)
វត្ថុសម្រាប់ចាយ មានប្រាក់ជាដើម
40)
អដ្ឋកថា ថា ធ្វើឲ្យស្តើង
41)
គ្រឿងប្រដាប់សម្រាប់ថ្កល់បាត្រជាធម្មតា។
42)
តាមអដ្ឋកថា ថា គ្រឿងរងដំកល់បាត្រ ដែលគេធ្វើដោយភ្លុក និងវល្លិ និងផ្តៅជាដើម។ វិមតិវិនោទនីដីកា ថា គ្រឿងរងដំកល់បាត្រ មានសណ្ឋានដូចជាកង ដែលគេធ្វើ ដោយវត្ថុមានភ្លុកជាដើម (ឬនឹងហៅថា រង្វេល ថាទ្រនាប់ ដូច្នេះវិញក៏បាន)
43)
អដ្ឋកថា ថា ក្នុងទីបំផុត នៃផែនក្តារតាំង ដែលគេដំកល់ទុកក្នុងរបៀងជាដើម។
44)
សារត្ថទីបនីដីកា ថា ផែនក្តារតាំង ដែលស្តើង គេធ្វើឲ្យមាំដល់ជើងជញ្ជាំងខាងក្រៅនៃផ្ទះ ហៅថា ថ្នាក់ (ក្តារបែន)។
45)
យកវត្ថុបង្សុកូល តាមតែប្រទេះ គឺវត្ថុដទៃ ក្រៅអំពីត្រៃចីវរ និងគ្រែ តាំង

46)

ល្អ និងអន់
47)

លោហជាតិផ្សេងៗ មានទង់ដែងជាដើម
48)

គេយកឈើ៤កំណាត់ មកផ្គុំគ្នាជា៤ជ្រុង រាងទ្រវែង ឲ្យល្មមដាក់ចីវរដេរបាន មានទាំងទ្រនាប់សម្រាប់ឈើស្ទឹងនោះផង។
49)

ខ្សែសម្រាប់ចងចីវរ នឹងឈើស្ទឹង ចំពោះភិក្ខុដែលដេរចីវរពីរជាន់។
50)

ឈើស្ទឹងដែលគេធ្វើតម្រូវនឹងភិក្ខុខ្ពស់ លុះដេរចីវរភិក្ខុទាប ក៏មិនល្មម
51)

ទ្រង់អនុញ្ញាតឲ្យចងឈើស្ទឹងតូច ត្រង់កណ្ដាលឈើស្ទឹងធំ។
52)

ទ្រង់អនុញ្ញាតឲ្យបត់ជាយទ្រនាប់ជាពីរជាន់ជុំវិញ ឲ្យល្មមនឹងឈើស្ទឹងតូចនោះ
53)

ស្នាប់ដៃ ដែលគេពាក់សម្រាប់ដេរ ដើម្បីកុំឲ្យម្ជុលមុតដៃ។
54)

វត្ថុណានីមួយ មានភាជនៈ និងប្រអប់ជាដើម (អដ្ឋកថា)
55)

សំពត់ដែលគេចងជាយទាំង៤ភ្ជាប់នឹងបង្គោលទាំង៤ ដែលគេបោះក្នុងទឹក ហើយសង្កត់ត្រង់កណ្ដាលសំពត់នោះ ឲ្យទឹកជ្រាបចូលមក ហើយយកភាជន៍ទៅដងទឹកនោះ។
56)

វត្ថុដែលបោះរាំងទីចង្ក្រម បង្ការកុំឲ្យធ្លាក់ ហៅថាបង្កាន់ដៃ ស្រុកខ្លះហៅថា ដៃរបៃក៏មាន
57)

ធ្វើទីដីឲ្យទាប ព័ទ្ធជុំវិញជញ្ជាំង ដើម្បីនឹងទប់ជើងជញ្ជាំង។
58)

អដ្ឋកថា តុ ឬថាស ដែលធ្វើដោយស្ពាន់ ឬទង់ដែង និងប្រាក់។
59)

ព្រៃឈើហិង្គុ ឬព្រៃនៃយក្ខិនី ឈ្មោះភេសកឡា នៅរក្សាគ្រប់គ្រង។
60)

បានជាឈ្មោះថា កោកនុទ ព្រោះប្រាសាទនោះ មានការរចនា មានលំអដូចផ្កាឈូកក្រហម។
61)

ទ្រនាប់សម្រាប់ជូតជើង ដែលគេធ្វើឲ្យមានពក កន្ទួលខ្ពស់ៗឡើង មានអាការដូចគ្រាប់ឈូក ដែលកន្ទួលផុលៗ ឡើងចេញពីផ្លែ។
62)

ក្នុងអដ្ឋកថា ពន្យល់ថា បានជាទ្រង់ហាម ព្រោះទ្រនាប់សម្រាប់ជូតជើងនោះ ប្រកបការច្រើន អស់បច្ច័យក៏ច្រើន។
63)

សារត្ថទីបនីដីកាពន្យល់ថា ផ្លិតមូល គេធ្វើដោយស្លឹកត្នោតជាដើម។
64)

ក្នុងអដ្ឋកថា ពន្យល់ថា បើភ្លេច មិនបានក្រវាត់កាយពន្ធដើរចេញ (ពីវត្ត) ទៅ លុះនឹកឃើញត្រឹមណា ត្រូវក្រវាត់ត្រឹមណោះ (ទើបរួចទោស)។
65)

ស្លៀកលយជាយ
66)

អដ្ឋកថា ពន្យល់ថា ឈើស្ទន់ប្រវែង៨ធ្នាប់មនុស្សប្រក្រតី ដីកាថា ៨ធ្នាប់ជាងឈើ។ ឈើស្ទន់ប្រវែង៤ធ្នាប់ មានន័យដូចគ្នា។
67)

អដ្ឋកថា ពន្យល់ថា ភិក្ខុឃើញម្រឹគសាហាវជាដើមក្ដី វង្វេងផ្លូវ ហើយប្រាថ្នានឹងរមិលមើលទិសក្ដី ឃើញភ្លើងឆេះក្ដី ឃើញទឹកជន់ កំពុងហូរមកក្ដី ហើយឡើងដើមឈើខ្ពស់ហួសប្រមាណ ព្រោះអន្តរាយ ដូច្នេះបាន។
68)

ពាក្យថា ឆន្ទ នេះ ក្នុងទីដទៃសំដៅកាព្យឃ្លោង ឯក្នុងទីនេះ សំដៅយកសកដភាសា គឺភាសាសំស្ក្រឹត។
69)

ក្នុងអដ្ឋកថា ពន្យល់ថា វោហារ (ពាក្យពោល) របស់អ្នកស្រុកមគធ ដែលព្រះសម្មាសម្ពុទ្ធ តែងពោល ឈ្មោះថា សកភាសា។
70)

គម្ពីរតិត្ថិយ ដែលប្រកបដោយហេតុឥតប្រយោជន៍ មានពាក្យថា វត្ថុទាំងពួងជារបស់ដែល (គេលះចោល) វត្ថុទាំងពួង មិនមែនជារបស់ដែល គឺរបស់ថ្មោង ក្អែកស បានជាស ព្រោះហេតុនេះ កុកបានជាខ្មៅ ព្រោះហេតុនេះ ជាដើម ឈ្មោះថា លោកាយតៈ។
71)

ត្រង់ពាក្យថា ព្រះមានព្រះភាគចូររស់នៅ និងពាក្យថា ព្រះសុគតចូររស់នៅ ពាក្យទាំងពីរនេះ ជាពាក្យថ្វាយព្រះពរ តែព្រះពុទ្ធជាម្ចាស់ទ្រង់ហាម
72)

អដ្ឋកថា ថា ទ្រង់អនុញ្ញាតឲ្យប្រក់ដំបូល ហើយច្រុះឈើតាន់ ហើយបូកទាំងខាងក្នុង ខាងក្រៅដោយដីស្អិត។
73)

អដ្ឋកថា ពន្យល់ថា កម្រងផ្កាដែលគេដោតដោយម្ជុល ឬកន្លះ
74)

សំដៅយកទីនៅរបស់សង្ឃ។
75)

លំនៅដែលក្រៅពីសេនាសនៈ មានអឌ្ឍយោគជាដើម។
76)

ផ្ទះមានសណ្ឋានដូចស្លាបគ្រុឌ ឬផ្ទះដែលមានដំបូលតែម្ខាង គឺបង្ហារ។
77)

ប្រាសាទវែង
78)

ផ្ទះ ឬប្រាសាទមានកំពូល
79)

គុហាដែលធ្វើដោយឥដ្ឋ ដោយថ្ម ដោយឈើ ដោយអាចម៍ដី ឬដែលកើតឯង ក្នុងភ្នំ (អដ្ឋកថា)។
80)

ពាក្យថា ពហុស្សូត សំដៅយកពហុស្សូតពីរយ៉ាង គឺ បរិយត្តិពហុស្សូត និងបដិវេធពហុស្សូត (អដ្ឋកថា)។
81)

ជាពាក្យហៅរបស់សម្រាប់រង សម្រាប់កល់ របស់សម្រាប់អង្គុយ ជើងម៉ាសម្រាប់អង្គុយ និងក្របរងស្បូវ ដូចទីបំផុតរងស្បូវជាន់លើ និងរងស្បូវជាន់ក្រោម ឬក្បាច់ខ្សែចេតិយ ដែលធ្វើជាត្របកឈូកផ្កា និងត្របកឈូកផ្កាប់ គឺត្រង់កចេតិយ និងតួចេតិយ បង្កាន់ដៃស្ពានទាំងនេះ ហៅថា វេទិ។
82)

១.២.គ្រែដែលមានជើងដូចជើងសេះ ជើងពពែ ជើងក្តាមជាដើម ឯតាំង ក៏មានជើងដូចជើងគ្រែដែរ។
84)

អដ្ឋកថា ថា តាំង៤ជ្រុង សូម្បីមានជើងខ្ពស់ហួសប្រមាណក៏គួរ បើតាំងដែលវែង លុះតែធ្វើឲ្យមានជើងកំពស់ត្រឹម៨ធ្នាប់ ទើបគួរ។
85)

គ្រែដែលមានបង្អែក១ ភ្នាក់ដៃ២ និងជើង៤ ទុកជាកន្លងហួសប្រមាណ ក៏គួរ
86)

អដ្ឋកថា ពន្យល់ថា ធ្វើអំពីផ្តៅសុទ្ធ គឺទាំងតួ ទាំងជើង ទាំងបង្អែក សុទ្ធតែផ្តៅទាំងអស់ ឥតមានអ្វីលាយសោះឡើយ។
87)

អដ្ឋកថា ពន្យល់ថា ត្រូវឲ្យភិក្ខុយកទឹកជ្រលក់ ឬរមៀតមកប្រស់ព្រំ។
88)

អដ្ឋកថា ថា ទឹកចត់សំដៅយកទឹកផ្លែសម៉ ឬផ្លែកន្ទួតព្រៃ។
89)

អដ្ឋកថា ថា ឲ្យយកដីស្អិតលាយជាមួយនឹងអាចម៍គោ និងផេះ ហើយលាបប្រដឹសនោះ។
90)

សាលាសម្រាប់សម្រេចសាធារណកិច្ចគ្រប់យ៉ាង។
91)

អដ្ឋកថា ពន្យល់ថា ទ្វារញាត់បន្ទា ដែលគេបញ្ចូលឈើសម្រួច ក្នុងមេឈើវែង ហើយចងរឹតបន្ទាឲ្យណែន ហើយទើបធ្វើ។
92)

អមនុស្ស គឺខ្មោច ឬទេវតា
93)

បើមានឧបាសក មានសទ្ធាធ្វើការងារថ្មី គឺសាងវិហារ កុដិជាដើម ប្រគេនសង្ឃ សង្ឃត្រូវចាត់ភិក្ខុដែលប៉ិនប្រសប់ណាមួយ ឲ្យជាអ្នកជួយរ៉ាប់រងត្រួតត្រាការងារនោះ ដូចកាលនាងវិសាខាសាងបុព្វារាម ព្រះសម្មាសម្ពុទ្ធ ទ្រង់ចាត់ព្រះមោគ្គល្លាន ឲ្យជាអ្នកជួយត្រួតត្រាដូច្នោះ។

94)

អដ្ឋកថា ថា សំដៅយកអាសនៈសម្រាប់ព្រះថេរៈ។

95)

សំដៅយកទឹកទក្ខិណោទកៈ។

96)

សំដៅយកដុំបាយសម្រាប់សង្ឃត្ថេរ។

97)

ដោយកលមាយា អាងហេតុ ឬដោយពុតមាយា ដូចអាងដល់ជម្ងឺឈឺក្បាលជាដើម។

98)

(អដ្ឋកថា) ទទួលយកសេនាសនៈក្នុងថ្ងៃជិតចូលវស្សា។

99)

អស់វស្សានរដូវ៤ខែ

100)

អដ្ឋកថា ថា សំដៅយកភិក្ខុដែលចាស់ជាងគ្នាពីរវស្សា ឬក្មេងជាងគ្នាពីរវស្សា

101)

អដ្ឋកថា ថា បើគ្រែ ឬតាំងចំណុះភិក្ខុ៣រូប ទ្រង់អនុញ្ញាតឲ្យអង្គុយតែពីររូប

102)

ប្រែថា ប្រាសាទ តាំងនៅលើពោងដំរី

103)

អដ្ឋកថា ថា សួនផ្កា សួនផ្លែ

104)

មិនចំពោះតែជ័ររង្គប៉ុណ្ណោះទេ សូម្បីជ័រឈើដទៃ ដូចយ៉ាងជ័រចុងជ័រទឹក ក៏រាប់បញ្ចូលក្នុងជ័រសម្រាប់ផ្និតដែរ។

105)

បញ្ញត្តិនេះ ចំពោះយកជើងមិនស្អាតជាប្រមាណ សូម្បីជើងដែលបានលាងហើយ តែនៅមិនទាន់ស្អាត ក៏មិនគួរជាន់សេនាសនៈឡើយ។

106)

ចំរើនសមថកម្មដ្ឋាន៤០ប្រភេទ

107)

ចំរើនវិបស្សនា១០យ៉ាង

-Namo tassa bhagavato arahato sammā-

ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language

ភាគ១១ - Book 011

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថា លោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០១១ - Tipitaka Book 011 [http://forum.sangham.net/index.php/topic,9191.0.html], for change log on ati.eu see here: រាយការណ៍ ភាគ ០១១




គំរូ ឯកសារ ផ្សេងទៀត ៖
book_011.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី១១

ទ. ១

# វិន័យបិដក

CS vin | ភាគ ទី១១

**ភាគ ទី១១**

# ចុល្លវគ្គ

CS vin.cv | ភាគ ទី១១

**(ចូឡវគ្គោ)**

**តតិយភាគ**
ភាគ ទី៣

សង្ឃភេទក្ខន្ធកៈ | វត្តក្ខន្ធកៈ | បាតិមោក្ខដ្ឋបនក្ខន្ធកៈ | ភិក្ខុនីខន្ធកៈ | បញ្ចសតិកក្ខន្ធកៈ | សត្តសតិកក្ខន្ធកៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

# សង្ឃភេទក្ខន្ធកៈ (ទី៧)

CS vin.cv.07 | ភាគ ទី១១

**(៧. សង្ឃភេទកក្ខន្ធកំ)**

# (បឋមភាណវារៈ ទី១)

CS vin.cv.07.01 | ភាគ ទី១១

### (១. បឋមភាណវារោ)

## (ឆសក្យបព្ពជ្ជាកថា)

CS vin.cv.07.01.01 | ភាគ ទី១១

### (ឆសក្យបព្ពជ្ជាកថា)

[១] សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅក្នុងនិគម ឈ្មោះអនុបិយា ជានិគមរបស់មល្លក្សត្រ ទៀបព្រៃអនុបិយា។ ក៏សម័យនោះឯង ពួកសក្យកុមារ សុទ្ធតែជាអ្នកមាននាមល្បីល្បាញ ចេញបួសតាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ។

[២] សម័យនោះ មានសក្យៈជាបងប្អូន២អង្គ ឈ្មោះមហានាមសក្កៈ១ ឈ្មោះអនុរុទ្ធសក្កៈ១។ ឯអនុរុទ្ធសក្កៈ ជាស្ដេចសុខុមាលជាតិ។[1] អនុរុទ្ធសក្កៈនោះ មានប្រាសាទ៣ខ្នង ប្រាសាទមួយ សម្រាប់រដូវរងា ប្រាសាទមួយសម្រាប់រដូវក្ដៅ ប្រាសាទមួយសម្រាប់រដូវភ្លៀង។ អនុរុទ្ធសក្កៈនោះ (គង់នៅ) លើប្រាសាទសម្រាប់រដូវភ្លៀងអស់បួនខែ មានតន្ត្រី នៅចាំគាល់បម្រើ មិនមានមនុស្សប្រុស (នៅលាយ) មិនដែលយាងចុះអំពីប្រាសាទ មកខាងក្រោមឡើយ។ គ្រានោះឯង មហានាមសក្កៈ មានសេចក្ដីត្រិះរិះដូច្នេះថា ឥឡូវនេះ ពួកសក្យកុមារ សុទ្ធតែជាអ្នកមាននាមល្បីល្បាញ បានចេញបួសតាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ចំណែកខាងត្រកូលរបស់យើង គ្មាននរណាមួយ ចេញចាកផ្ទះ ទៅបួសក្នុងសាសនាសោះ បើដូច្នោះ គួរតែអាត្មាអញ ឬអនុរុទ្ធ បួសកុំខានចុះ។ ទើបមហានាមសក្កៈ ចូលទៅរកអនុរុទ្ធសក្កៈ លុះចូលទៅដល់ហើយ បាននិយាយរឿងនុ៎ះ ចំពោះអនុរុទ្ធសក្កៈថា ម្នាលអនុរុទ្ធ ជាអនុជ ឥឡូវនេះ ពួកសក្យកុមារ សុទ្ធតែជាអ្នកមាននាមល្បីល្បាញ បានចេញបួស តាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ចំណែកខាងត្រកូលរបស់យើង គ្មាននរណាមួយ ចេញចាកផ្ទះ ទៅបួសក្នុងសាសនាសោះ បើដូច្នោះ ចូរឯងបួស ឬអញនឹងបួសក៏បាន។ អនុរុទ្ធឆ្លើយថា ខ្ញុំជាមនុស្សសុខុមាលជាតិ ខ្ញុំមិនអាចនឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនាបានទេ សូមទ្រង់ស្ដេចបួសចុះ។ មហានាមសក្កៈ និយាយថា ម្នាលអនុរុទ្ធ ជាអនុជ ចូរប្អូនមកអាយ បងនឹងពន្យល់ប្រយោជន៍របស់ឃរាវាសដល់ប្អូនថា ការធ្វើស្រែនោះ មុនដំបូងត្រូវភ្ជួរ ភ្ជួររួចហើយ ត្រូវព្រោះ ព្រោះរួចហើយ ត្រូវបញ្ចូលទឹក បញ្ចូលទឹករួចហើយ ត្រូវបញ្ចេញទឹក បញ្ចេញទឹករួចហើយ ត្រូវជំរះស្មៅ ជំរះស្មៅរួចហើយ ត្រូវច្រូតស្រូវ ច្រូតស្រូវហើយ ត្រូវចងកណ្ដាប់ ចងជាកណ្ដាប់ហើយ ត្រូវធ្វើឲ្យជាគំនរ ធ្វើឲ្យជាគំនរហើយ ត្រូវបោក ឬបញ្ជាន់ បញ្ជាន់ហើយ ត្រូវជជុះយកចំបើង ជជុះយកចំបើងហើយ ត្រូវជជុះយកកំទេចចេញ ជជុះយកកំទេចចេញហើយ ត្រូវរោយ រោយហើយ ត្រូវជញ្ជូនយកមកទុក ជញ្ជូនយកមកទុកហើយ ត្រូវចាប់ធ្វើតែយ៉ាងនេះតទៅទៀត រាល់ៗឆ្នាំ ត្រូវចាប់ធ្វើ (សាពីដើម) តាមទំនងនេះទៀត តែរាល់ៗឆ្នាំ។ អនុរុទ្ធសក្កៈ និយាយថា ការងារមិនចេះអស់ទេ ទីបំផុតនៃការងារមិនប្រាកដទេ កាលណានឹងអស់ការងារ កាលណានឹងប្រាកដថា ផុតការងារបាន កាលណាយើងនឹងថយខ្វល់ខ្វាយឆ្អែតឆ្អន់ នឹងស្កប់ស្កល់បម្រើដោយកាមគុណ៥។ ម្នាលអនុរុទ្ធ ជាអនុជ ការងារមិនចេះអស់ទេ ទីបំផុតការងារក៏មិនប្រាកដ មាតាបិតាក្ដី ជីតាក្ដី ធ្វើមរណភាព (ទៅអស់) ឯការងារ មិនចេះអស់ទេ។ បើដូច្នោះ អនុជឯង ចូរជ្រាបអំពីប្រយោជន៍របស់ឃរាវាសចុះ បងមុខជានឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា (មិនខាន)។

[៣] ក្នុងគ្រានោះ អនុរុទ្ធសក្កៈ ចូលទៅរកព្រះមាតា លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះមាតាយ៉ាងនេះថា បពិត្រព្រះមាតា ខ្ញុំចង់ចេញចាកផ្ទះ ទៅបួសក្នុងសាសនា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះ ទៅបួសក្នុងសាសនា។ កាលបើអនុរុទ្ធសក្កៈ និយាយយ៉ាងនេះហើយ ព្រះមាតានៃអនុរុទ្ធសក្កៈ និយាយយ៉ាងនេះថា ម្នាលអនុរុទ្ធកូន អ្នកជាបុត្រប្រុសទាំងពីររបស់យើង រមែងជាទីស្រឡាញ់ពេញចិត្ត ឥតមានស្អប់ខ្ពើមទេ សូម្បីដល់មរណភាព យើងក៏ពុំចង់ព្រាត់ប្រាស និរាសចាកអ្នកឡើយ កាលបើអ្នករស់នៅៗឡើយ យើងធ្វើម្ដេចនឹងយល់ព្រមឲ្យអ្នកចេញចាកផ្ទះ ទៅបួសក្នុងសាសនាបាន។ អនុរុទ្ធសក្កៈនិយាយនឹងព្រះមាតា យ៉ាងនេះ អស់វារៈពីរដងផង។បេ។ អស់វារៈបីដងផងថា បពិត្រព្រះមាតា ខ្ញុំចង់ចេញចាកផ្ទះ ទៅបួសក្នុងសាសនា បពិត្រព្រះមាតា សូមព្រះមាតា អនុញ្ញាត ឲ្យខ្ញុំចេញចាកផ្ទះ ទៅបួសក្នុងសាសនា។

[៤] សម័យនោះឯង ភទ្ទិយសក្យរាជ សោយរាជ្យជាស្ដេចរបស់សក្យៈទាំងឡាយ។ ឯភទ្ទិយសក្យរាជនោះ ត្រូវជាសំឡាញ់នឹងអនុរុទ្ធសក្កៈ។ គ្រានោះឯង ព្រះមាតារបស់អនុរុទ្ធសក្កៈ ទ្រង់ព្រះចិន្ដាថា ព្រះភទ្ទិយសក្យរាជនេះ ទ្រង់សោយរាជ្យ ជាស្ដេចរបស់ពួកសក្យៈ ស្ដេចនោះ ជាសំឡាញ់នឹងអនុរុទ្ធសក្កៈ គង់មិនអាចចេញចាកអគារដ្ឋាន ទៅបួសក្នុងសាសនាទេ (លុះទ្រង់ព្រះចិន្ដាដូច្នេះហើយ) ទើបមានព្រះសវនីយទៅនឹងអនុរុទ្ធសក្កៈទៀតថា ម្នាលអនុរុទ្ធកូន ប្រសិនបើ ភទ្ទិយសក្យរាជ ចេញចាកផ្ទះ ទៅបួសក្នុងសាសនា កាលបើដូច្នេះ សឹមកូនឯងទៅបួសចុះ។ លំដាប់នោះ អនុរុទ្ធសក្កៈ ចូលទៅរកព្រះភទ្ទិយសក្យរាជ លុះចូលទៅដល់ហើយ ទើបថ្លែងសេចក្ដីនុ៎ះ ទៅនឹងភទ្ទិយសក្យរាជថា ម្នាលសំឡាញ់ ការបួសរបស់ខ្ញុំជាប់ទាក់ទងគ្នានឹងអ្នក។ ភទ្ទិយសក្យរាជ ក៏ឆ្លើយតបថា ម្នាលសំឡាញ់ បើបព្វជ្ជារបស់អ្នក ជាប់ទាក់ទងគ្នានឹងខ្ញុំក្ដី មិនជាប់ក្ដី បព្វជ្ជានោះ ចូលលើកទុកចុះ យើងគង់តែនឹងបួសជាមួយអ្នកតាមសប្បាយដែរ។ អនុរុទ្ធសក្កៈ បបួលទៀតថា ម្នាលសំឡាញ់ អ្នកចូរមក យើងទាំងពីរនាក់នឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា។ ព្រះភទ្ទិយសក្យរាជតបថា ម្នាលសំឡាញ់ ខ្ញុំមិនអាចចេញចាកផ្ទះ ទៅបួសក្នុងសាសនាបានទេ កិច្ចឯទៀតដែលខ្ញុំល្មមធ្វើជំនួសអ្នកបាន ខ្ញុំនឹងធ្វើជំនួសអ្នក អ្នកចូរបួសចុះ។ អនុរុទ្ធសក្កៈ និយាយថា ម្នាលសំឡាញ់ ព្រះមាតានិយាយនឹងខ្ញុំយ៉ាងនេះថា ម្នាលអនុរុទ្ធ បើភទ្ទិយសក្យរាជ ចេញចាកផ្ទះ ទៅបួសក្នុងសាសនា កាលបើដូច្នោះ អ្នកឯងចូរបួសចុះ។ ភទ្ទិយសក្យរាជឆ្លើយថា ម្នាលសំឡាញ់ ខ្ញុំបាននិយាយវាចានុ៎ះ ចំពោះអ្នកមែនថា ម្នាលសំឡាញ់ បើបព្វជ្ជារបស់អ្នកជាប់ទាក់ទងនឹងខ្ញុំក្ដី មិនជាប់ក្ដី បព្វជ្ជានោះ លើកទុកទៅចុះ ខ្ញុំគង់តែនឹងបួសជាមួយនឹងអ្នកតាមសប្បាយដែរ។ អនុរុទ្ធបបួលថា ម្នាលសំឡាញ់ អ្នកចូរមក យើងទាំងពីរនាក់ នឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា។ ក្នុងសម័យនោះ ពួកមនុស្ស ច្រើននិយាយពាក្យសច្ចៈ ប្ដេជ្ញាគ្នាដោយពាក្យសច្ចៈ។ លំដាប់នោះ ព្រះភទ្ទិយសក្យរាជ តបនឹងអនុរុទ្ធសក្កៈយ៉ាងនេះថា ម្នាលសំឡាញ់ អ្នកចូរបង្អង់៧ឆ្នាំសិន លុះអំណើះ៧ឆ្នាំទៅ យើងទាំងពីរនាក់ នឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា។ អនុរុទ្ធសក្កៈ ឆ្លើយតបថា ម្នាលសំឡាញ់ ៧ឆ្នាំនោះយូរណាស់ ខ្ញុំមិនអាចនឹងបង្អង់ចាំដល់៧ឆ្នាំទេ។ ព្រះភទ្ទិយសក្យរាជ ឆ្លើយថា ម្នាលសំឡាញ់ អ្នកចូររង់

ចាំ៦ឆ្នាំចុះ។បេ។ ៥ឆ្នាំ ៤ឆ្នាំ ៣ឆ្នាំ ២ឆ្នាំ ១ឆ្នាំចុះ លុះអំណឹះ១ឆ្នាំទៅ យើងទាំងពីរនាក់ នឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា។ អនុរុទ្ធសក្កៈបបួលទៀតថា ម្នាលសំឡាញ់ ១ឆ្នាំនោះយូរពេកណាស់ ខ្ញុំមិនអាចនឹងរង់ចាំទៅដល់១ឆ្នាំបានទេ។ ព្រះភទ្ទិយសក្យរាជ អង្វរទៀតថា ម្នាលសំឡាញ់ អ្នកចូរបង្អង់៧ខែចុះ លុះអំណឹះ៧ខែទៅ យើងទាំងពីរនាក់ នឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា។ អនុរុទ្ធសក្កៈតបថា ម្នាលសំឡាញ់ ៧ខែនោះយូរណាស់ ខ្ញុំមិនអាចនឹងរង់ចាំដល់ទៅ៧ខែបានទេ។ ព្រះភទ្ទិយសក្យរាជ អង្វរថា ម្នាលសំឡាញ់ អ្នកចូរបង្អង់ដល់៦ខែ។បេ។ ៥ខែ ៤ខែ ៣ខែ ២ខែ ១ខែ កន្លះខែចុះ លុះអំណឹះកន្លះខែទៅ សឹមយើងទាំងពីរនាក់ ចេញចាកផ្ទះ ទៅបួសក្នុងសាសនា។ អនុរុទ្ធសក្កៈតបថា ម្នាលសំឡាញ់ កន្លះខែយូរពេកណាស់ ខ្ញុំមិនអាចនឹងរង់ចាំដល់កន្លះខែបានទេ។ ព្រះភទ្ទិយសក្យរាជ អង្វរចុះមកទៀតថា ម្នាលសំឡាញ់ អ្នកចូរបង្អង់៧ថ្ងៃសិន ទម្រាំតែខ្ញុំនឹងប្រគល់រាជ្យសម្បត្តិឲ្យកូន ឬបងប្អូន។ អនុរុទ្ធសក្កៈទទួលព្រមថា ម្នាលសំឡាញ់ ៧ថ្ងៃនោះ មិនជាយូរប៉ុន្មានទេ ខ្ញុំនឹងរង់ចាំបាន។

[៥] គ្រានោះឯង (ពួកសក្យៈទាំង៦អង្គ) គឺភទ្ទិយសក្យរាជ១ អនុរុទ្ធ១ អានន្ទ១ ភគ្គុ១ កិមិល១ ទេវទត្ត១ ជាគំរប់៧នាក់នឹងខ្មាន់ព្រះកេស ឈ្មោះឧបាលិ ចេញទៅកាន់ឧទ្យាន មួយអន្លើដោយសេនាមានអង្គ៤ ក្នុងកាលពីដើមយ៉ាងណា សក្យរាជទាំងនោះ យាងចេញទៅ (ដើម្បីបព្វជ្ជា មួយអន្លើ) ដោយសេនាមានអង្គ៤ ក៏យ៉ាងនោះដែរ។ សក្យៈទាំងនោះ លុះយាងទៅដល់ទីឆ្ងាយ ទើបឲ្យសេនាវិលមកវិញ លុះចូលទៅដល់ដែនដទៃហើយ ទើបដោះគ្រឿងប្រដាប់ វេចជាបង្វេចដោយព្រះពស្ត្រសម្រាប់ពានា រួចហើយទើបមានព្រះបន្ទូលទៅនឹងខ្មាន់ព្រះកេស ឈ្មោះឧបាលិថា នែនាយឧបាលិ ណ្ហើយនាយឧបាលិ ចូរអ្នកឯងវិលទៅវិញចុះ ទ្រព្យប៉ុណ្ណេះ ក៏ល្មមនឹងចិញ្ចឹមជីវិតរបស់អ្នកបានហើយ។

[៦] គ្រានោះឯង កាលឧបាលិកប្បកៈ កំពុងតែដើរវិលមកវិញ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួសក្យៈសុទ្ធតែជាអ្នកាចៗ នឹងសម្លាប់អញក៏បាន ព្រោះគិតថា ឧបាលិកប្បកៈនេះហើយ សម្លាប់ព្រះរាជកុមារ អម្បាលសក្យកុមារទាំងឡាយ ម្ដេចគង់ចេញចាកអគារដ្ឋាន ទៅបួសក្នុងសាសនាបាន ចំណង់បើអញ នឹងបាច់និយាយទៅថ្វី។ ឧបាលិកប្បកៈនោះ ក៏ស្រាយបង្វេចចេញ ហើយព្យួររបស់នោះ លើដើមឈើ ទើបនិយាយថា បើអ្នកណាឃើញ ចូររើសយករបស់ដែលអញឲ្យហើយចុះ ហើយដើរចូលទៅរកពួកសក្យកុមារវិញ។ ពួកសក្យកុមារទាំងនោះ បានឃើញឧបាលិកប្បកៈ កំពុងដើរមកអំពីចម្ងាយហើយ ទើបនិយាយទៅនឹងឧបាលិកប្បកៈយ៉ាងនេះថា នែនាយឧបាលិ ហេតុដូចម្ដេច បានជាអ្នកវិលមកវិញ។ ឧបាលិកប្បកៈ ក៏ក្រាបទូលថា បពិត្រព្រះអយ្យបុត្ត កាលដែលខ្ញុំព្រះអង្គវិលអំពីទីនេះទៅ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា ពួសក្យរាជសុទ្ធតែកាចៗ នឹងសម្លាប់ខ្ញុំព្រះអង្គចោលក៏បាន ព្រោះគិតថា ខ្ញុំព្រះអង្គនេះហើយ ដែលសម្លាប់ព្រះរាជកុមារ អម្បាលពួកសក្យកុមារនេះ (ម្ដេចក៏) ចេញចាកអគារដ្ឋាន ទៅបួសក្នុងសាសនា ចុះនឹងចាំស្ដីទៅថ្វី ដល់ខ្លួនខ្ញុំព្រះអង្គ បពិត្រព្រះអយ្យបុត្ត ខ្ញុំព្រះអង្គ ស្រាយបង្វេចចេញ ហើយព្យួររបស់នោះ លើដើមឈើ ហើយនិយាយថា បើអ្នកណាឃើញ ចូររើសយករបស់ដែលអញឲ្យហើយចុះ ខ្ញុំព្រះអង្គ ក៏វិលអំពីទីនោះមកវិញ។ ពួកសក្យកុមារនិយាយថា នែនាយឧបាលិ ដែលអ្នកត្រឡប់មកវិញនោះ ឈ្មោះថាបានធ្វើប្រពៃហើយ ដ្បិតពួកសក្យៈកាចៗណាស់ នឹងសម្លាប់អ្នកចោល ក៏បាន ព្រោះគិតថា អ្នកនេះហើយ ជាអ្នកសម្លាប់ព្រះរាជកុមារទាំងឡាយ។

[៧] គ្រានោះ ពួកសក្យកុមារទាំងនោះ នាំឧបាលិកប្បកៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ។ ពួកសក្យកុមារទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសេចក្ដីនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំជាសក្យរាជ តែងមានមានះ បពិត្រព្រះអង្គដ៏ចំរើន ឧបាលិកប្បកៈនេះ ជាអ្នកធ្លាប់បម្រើយើងខ្ញុំ អស់កាលជាអង្វែងមកហើយ សូមព្រះមានព្រះភាគ បំបួសឧបាលិកប្បកៈនេះមុន យើងខ្ញុំនឹងធ្វើនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលីកម្ម និងសាមីចិកម្ម ចំពោះឧបាលិកប្បកៈនេះ កាលបើយើងខ្ញុំបានធ្វើយ៉ាងនេះហើយ សេចក្ដីប្រកាន់ថា ខ្លួនយើងខ្ញុំ ជាសក្យៈនោះ នឹងថយចុះទៅ។ លំដាប់នោះឯង ព្រះមានព្រះភាគ បានបំបួសឧបាលិកប្បកៈមុន ហើយទើបបំបួសពួកសក្យកុមារទាំងនោះក្រោយ។

[៨] គ្រានោះ ព្រះភទ្ទិយៈដ៏មានអាយុ បានសម្រេចនូវវិជ្ជា៣យ៉ាង ខាងក្នុងនៃវស្សានោះឯង។ ព្រះអនុរុទ្ធដ៏មានអាយុ បានសម្រេចទិព្វចក្ខុ។ ព្រះអានន្ទដ៏មានអាយុ បានសម្រេចសោតាបត្តិផល។ ឯទេវទត្ត បានសម្រេចនូវឫទ្ធិ ជារបស់បុថុជ្ជន។

[៩] សម័យនោះឯង ព្រះភទ្ទិយដ៏មានអាយុ ទៅក្នុងព្រៃក្ដី នៅក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី បន្លឺនូវឧទានជារឿយៗថា ឱសុខអ្វីម៉្លេះ ឱសុខអ្វីម៉្លេះ។ លំដាប់នោះ ពួកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ។ ពួកភិក្ខុទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះភទ្ទិយៈដ៏មានអាយុ ទៅក្នុងព្រៃក្ដី នៅក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី តែងបន្លឺនូវឧទានជារឿយៗថា ឱសុខអ្វីម៉្លេះ ឱសុខអ្វីម៉្លេះ បពិត្រព្រះអង្គដ៏ចំរើន ព្រះភទ្ទិយៈដ៏មានអាយុ ប្រាកដជាអផ្សុកនឹងប្រព្រឹត្តព្រហ្មចរិយធម៌ដោយពិត ពុំនោះសោត លោករលឹកនូវសេចក្ដីសុខ ក្នុងរាជសម្បត្តិពីមុននោះឯង បានជាទៅក្នុងព្រៃក្ដី នៅក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី តែងបន្លឺនូវឧទានជារឿយៗថា ឱសុខអ្វីម៉្លេះ ឱសុខអ្វីម៉្លេះ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ១រូបមក ហើយបង្គាប់ថា ម្នាលភិក្ខុ អ្នកចូរមក ចូរអ្នកទៅហៅភទ្ទិយភិក្ខុ តាមពាក្យតថាគតថា ម្នាលអាវុសោភទ្ទិយៈ ព្រះសាស្ដាទ្រង់ឲ្យហៅអ្នក។ ភិក្ខុនោះ ទទួលស្ដាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងនេះហើយ ក៏ចូលទៅរកភទ្ទិយភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះ នឹងភទ្ទិយភិក្ខុដ៏មានអាយុថា ម្នាលអាវុសោភទ្ទិយៈ ព្រះសាស្ដាត្រាស់ហៅអ្នក។

[១០] ព្រះភទ្ទិយៈដ៏មានអាយុ ទទួលស្ដាប់ពាក្យរបស់ភិក្ខុនោះថា ម្នាលអាវុសោ ដូច្នេះហើយ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះ នឹងព្រះភទ្ទិយៈដ៏មានអាយុ ដែលអង្គុយក្នុងទីដ៏សមគួរថា ម្នាលភទ្ទិយៈ បានឮថា អ្នកទៅក្នុងព្រៃក្ដី នៅក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី តែងបន្លឺឧទានជារឿយៗថា ឱសុខអ្វីម៉្លេះ ឱសុខអ្វីម៉្លេះ ពិតមែនឬ។ ភទ្ទិយភិក្ខុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភទ្ទិយៈ ចុះអ្នកពិចារណាឃើញអំណាចប្រយោជន៍យ៉ាងណា បានជាអ្នកទៅក្នុងព្រៃក្ដី នៅក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី តែងបន្លឺឧទានជារឿយៗថា ឱសុខអ្វីម៉្លេះ ឱសុខអ្វីម៉្លេះ ដូច្នេះ។ ភទ្ទិយភិក្ខុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលពីដើម ខ្ញុំព្រះអង្គនៅជាស្ដេច ការរក្សាខាងក្នុងព្រះរាជវាំង គេបានចាត់ចែងល្អ ការរក្សាខាងក្រៅព្រះរាជវាំង គេបានចាត់ចែងល្អ ការរក្សាខាងក្នុងនគរ គេបានចាត់ចែងល្អ ការរក្សាខាងក្រៅនគរ គេបានចាត់ចែងល្អ ការរក្សាខាងក្នុងជនបទ គេបានចាត់ចែងល្អ ការរក្សាខាងក្រៅជនបទ គេក៏បានចាត់ចែងល្អ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះឯង ជាមនុស្ស

ដែលគេរក្សាមកយ៉ាងនេះផង គ្រប់គ្រងយ៉ាងនេះផង គង់នៅមានខ្លាច ញាប់ញ័រ រន្ធត់ តក់ស្លុត បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គតែម្នាក់ឯង ទៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ក៏ឥតខ្លាច ឥតញាប់ញ័រ ឥតរន្ធត់តក់ស្លុតឡើយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ជាមនុស្សសម្ញូបរោម ចិញ្ចឹមជីវិតដោយចតុប្បច្ច័យ ដែលបុគ្គលដទៃឲ្យ មានចិត្តដូចជាពួកសត្វម្រឹគ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ពិចារណាឃើញនូវអំណាចប្រយោជន៍យ៉ាងនេះហើយ ទើបបានទៅក្នុងព្រៃក្តី។បេ។ តែងបន្លឺឧទានជារឿយៗថា ឱសុខអ្វីម្ល៉េះ ឱសុខអ្វីម្ល៉េះ ដូច្នេះ។ លំដាប់នោះ ព្រះមានព្រះភាគជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

[១១]

> សេចក្តីក្រោធ មិនមានក្នុងចិត្តរបស់អ្នកណា អ្នកនោះឈ្មោះថា កន្លងផុតនូវសេចក្តីចំរើន និងសេចក្តីវិនាសច្រើនប្រការ ទេវតាទាំងឡាយ ក៏កម្រនឹងបានឃើញនូវអ្នក ដែលមានភ័យកន្លងផុតហើយ បានប្រកបដោយសេចក្តីសុខ ឥតមានសេចក្តីសោកនោះឡើយ។

## (ទេវទត្តវត្ថុ)

CS vin.cv.07.01.02 | ភាគ ទី១១

### (ទេវទត្តវត្ថុ)

[១២] គ្រានោះឯង ព្រះមានព្រះភាគ ព្រះអង្គគង់នៅក្នុងព្រៃអនុបិយា គួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់យាងសំដៅ ទៅកាន់ចារិកនគរកោសម្ពី ត្រាច់ទៅកាន់ចារិកតាមលំដាប់ ឆ្ពោះទៅនគរកោសម្ពី។ បានឮថា ព្រះមានព្រះភាគ ទ្រង់សម្រេចឥរិយាបថ ក្នុងឃោសិតារាម ទៀបនគរកោសម្ពីនោះ។

[១៣] គ្រានោះ ទេវទត្តទៅក្នុងទីស្ងាត់ សម្ងំនៅក្នុងទីស្ងាត់ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា អញនឹងឲ្យអ្នកណាជ្រះថ្លាហ្ន៎ កាលបើអ្នកណាកើតចិត្តជ្រះថ្លាចំពោះអញ លាភសក្ការៈច្រើន មុខជានឹងកើតដល់អញពុំខាន។ គ្រានោះ ទេវទត្តមានសេចក្តីត្រិះរិះដូច្នេះថា អជាតសត្តុកុមារនេះ នៅក្មេងផង មានសេចក្តីចម្រើនតទៅទៀតផង បើដូច្នោះ គួរអញឲ្យអជាតសត្តុកុមារជ្រះថ្លា កាលបើអជាតសត្តុកុមារនោះ មានចិត្តជ្រះថ្លាចំពោះអញហើយ លាភសក្ការៈច្រើន មុខជានឹងកើតឡើងដល់អញ។ លំដាប់នោះ ទេវទត្ត រៀបចំអាសនៈ ប្រដាប់បាត្រ និងចីវរ សំដៅទៅនគររាជគ្រឹះតាមលំដាប់លំដោយ ឆ្ពោះទៅនគររាជគ្រឹះនោះ។ គ្រានោះ ទេវទត្តដំណែងភេទខ្លួន និម្មិតធ្វើជាក្មេងតូច ពាក់សង្វារពស់ ស្រាប់តែទៅអង្គុយលើភ្លៅអជាតសត្តុកុមារភ្លាម។ គ្រានោះ អជាតសត្តុកុមារ ក៏ខ្លាច ញាប់ញ័រ រន្ធត់តក់ស្លុត។ លំដាប់នោះ ទេវទត្ត បាននិយាយពាក្យនេះនឹងអជាតសត្តុកុមារថា បពិត្រកុមារ ព្រះអង្គខ្លាចអាត្មាឬ។ អជាតសត្តុកុមារឆ្លើយថា អើខ្ញុំខ្លាច ចុះអ្នកជាអ្វី។ ទេវទត្តថា អាត្មានេះ ជាភិក្ខុ ឈ្មោះទេវទត្ត។ អជាតសត្តុកុមារថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ឈ្មោះទេវទត្តមែន សូមផ្លាស់មកជាភេទរបស់ខ្លួនវិញមើល។ គ្រានោះ ទេវទត្តផ្លាស់ភេទក្មេងតូចចេញហើយ ត្រឡប់មកជាភិក្ខុ ទ្រទ្រង់សង្ឃាដិ បាត្រ និងចីវរ ឈរពីខាងមុខអជាតសត្តុកុមារ។ លំដាប់នោះ អជាតសត្តុកុមារមានចិត្តជ្រះថ្លាពេក ដោយឥទ្ធិប្បាដិហារ្យនេះ របស់ទេវទត្ត ហើយតែងទៅដោយរថប្រាំរយ បម្រើទាំងល្ងាច ទាំងព្រឹក ទាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់ប្រាំរយថាសទៅផង។ គ្រានោះ ទេវទត្ត ដែលលាភសក្ការៈ និងសេចក្តីសរសើរគ្របសង្កត់ហើយ ក៏មានចិត្តប្រែប្រួល កើតមានសេចក្តីប្រាថ្នា មានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រងនូវភិក្ខុសង្ឃ ដូច្នេះ ទេវទត្ត ក៏សាបសូន្យចាកឫទ្ធិនោះ ក្នុងពេលជាមួយនឹងអកុសលចិត្តកើតឡើង។

[១៤] សម័យនោះឯង មានកូនអ្នកស្រុក កោឡិយៈ ម្នាក់ ឈ្មោះកក្កុធៈ ជាឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានដ៏មានអាយុ ទើបនឹងស្លាប់ភ្លាម ហើយបានទៅកើតជាទេវកាយ ដែលសម្រេចដោយចិត្តមួយអង្គ។ ទេវបុត្តនោះ បាននូវអត្តភាព មានសភាពយ៉ាងនេះ ដូចជាបានគាមក្ខេត្តរបស់អ្នកស្រុកមគធៈពីរឬបី។ លោកមិនដែលបៀតបៀនខ្លួនឯង និងអ្នកដទៃ ដោយអាងបានអត្តភាពនោះទេ។ គ្រានោះ កក្កុធទេវបុត្ត ចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយទើបឈរក្នុងទីសមគួរ។ លុះកក្កុធទេវបុត្តឈរក្នុងទីសមគួរហើយ បានថ្លែងពាក្យនេះ នឹងព្រះមហាមោគ្គល្លានដ៏មានអាយុថា បពិត្រលោកម្ចាស់ (ឥឡូវ) ទេវទត្ត ត្រូវលាភសក្ការៈ និងសេចក្តីសរសើរគ្របសង្កត់ហើយ មានចិត្តប្រែប្រួល កើតមានសេចក្តីប្រាថ្នា មានសភាពយ៉ាងនេះថា អញនឹងរក្សានូវភិក្ខុសង្ឃ បពិត្រលោកម្ចាស់ ទេវទត្តសាបសូន្យចាកឫទ្ធិនោះ ក្នុងវេលាជាមួយនឹងអកុសលចិត្តកើតឡើង។ កក្កុធទេវបុត្ត បានថ្លែងពាក្យនេះ លុះថ្លែងពាក្យនេះហើយ ក៏ក្រាបថ្វាយបង្គំលាព្រះមហាមោគ្គល្លានដ៏មានអាយុ ធ្វើប្រទក្សិណ ហើយស្រាប់តែបាត់ពីទីនោះទៅ។

[១៥] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កូនអ្នកស្រុកកោឡិយៈម្នាក់ ឈ្មោះកក្កុធៈ ជាឧបដ្ឋាករបស់ខ្ញុំព្រះអង្គ ទើបនឹងស្លាប់អំបាញ់មិញ បានទៅកើតជាទេវកាយ ដែលសម្រេចដោយចិត្តមួយអង្គ ទេវបុត្តនោះ បានអត្តភាពយ៉ាងនេះ ដូចជាបានគាមក្ខេត្តរបស់អ្នកស្រុកមគធៈពីរឬបី ទេវបុត្តនោះ មិនដែលបៀតបៀនខ្លួនឯង និងអ្នកដទៃ ដោយអាងបានអត្តភាពនោះទេ បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ កក្កុធទេវបុត្ត ចូលមករកខ្ញុំព្រះអង្គ លុះមកដល់ហើយ ថ្វាយបង្គំចំពោះខ្ញុំព្រះអង្គរួចស្រេច ក៏ឈរក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន កក្កុធទេវបុត្ត លុះឈរក្នុងទីដ៏សមគួរហើយ បានថ្លែងពាក្យនេះ នឹងខ្ញុំព្រះអង្គថា បពិត្រលោកម្ចាស់ (ឥឡូវនេះ) ទេវទត្ត ត្រូវលាភសក្ការៈ និងសេចក្តីសរសើរគ្របសង្កត់ហើយ មានចិត្តប្រែប្រួល កើតមានសេចក្តីប្រាថ្នា មានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រងនូវភិក្ខុសង្ឃ បពិត្រលោកម្ចាស់ ទេវទត្តសាបសូន្យចាកឫទ្ធិនោះ ក្នុងវេលាជាមួយនឹងអកុសលចិត្តកើតឡើង បពិត្រព្រះអង្គដ៏ចំរើន កក្កុធទេវបុត្ត បានថ្លែងពាក្យនេះ លុះថ្លែងពាក្យនេះហើយ ទើបក្រាបថ្វាយបង្គំលាខ្ញុំ

ព្រះអង្គ ធ្វើប្រទក្សិណ ហើយក៏បាត់ពីទីនោះទៅ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលមោគ្គល្លាន កក្កុធទេវបុត្ត អ្នកបានកំណត់ដឹងចិត្ត ដោយចិត្តច្បាស់ហើយឬ កក្កុធទេវបុត្ត និយាយពាក្យណាមួយ ពាក្យនោះជាពាក្យពិត ឬជាពាក្យក្លែងទេ។ ព្រះមហាមោគ្គល្លាន ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ កំណត់ដឹងចិត្ត ដោយចិត្តច្បាស់ថា កក្កុធទេវបុត្ត និយាយពាក្យណាមួយ ពាក្យទាំងនោះ ជាពាក្យពិតហើយ មិនមែនជាពាក្យក្លែងទេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ចូរអ្នករក្សាទុកនូវសំដីនេះចុះ ម្នាលមោគ្គល្លាន ចូរអ្នករក្សាទុកនូវសំដីនេះចុះ ដ្បិតឥឡូវនេះ មោឃបុរសនោះ ធ្វើខ្លួនឲ្យល្បីដោយខ្លួនឯង។

## (បញ្ចសត្ថុកថា)

CS vin.cv.07.01.03 | ភាគ ទី១១

### (បញ្ចសត្ថុកថា)

[១៦] ម្នាលមោគ្គល្លាន គ្រូក្នុងលោកនេះ មាន៥ពួក។ គ្រូទាំង៥ពួកនោះ គឺគ្រូណាខ្លះ។ ម្នាលមោគ្គល្លាន គ្រូពួកមួយក្នុងលោកនេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីលរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ។ សាវ័កទាំងឡាយ តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីលរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ តែថា បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងរាប់អាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា លោកគង់នឹងប្រាកដ ដោយកម្មនោះមិនខាន។ ម្នាលមោគ្គល្លានសាវ័កទាំងឡាយ តែងរក្សាគ្រូបែបនេះដោយសីល។ ឯគ្រូមានសភាពយ៉ាងនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយសីល។

[១៧] ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធខ្លះ ថាអាជីវៈរបស់អញ បរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ។ ពួកសាវ័ក ដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធខ្លះ ថាអាជីវៈរបស់អញ បរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ តែថា បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងរាប់អាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដ ដោយកម្មនោះមិនខាន។ ម្នាលមោគ្គល្លាន សាវ័កទាំងឡាយ តែងរក្សាគ្រូបែបនេះដោយអាជីវៈ។ ឯគ្រូមានសភាពយ៉ាងនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយអាជីវៈ។

[១៨] ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធខ្លះ ថាធម្មទេសនារបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ។ ពួកសាវ័ក តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធខ្លះ ថាធម្មទេសនារបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ តែថា បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្ត ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងរាប់អាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដ ដោយកម្មនោះមិនខាន។ ម្នាលមោគ្គល្លាន ពួកសាវ័ក តែងរក្សាគ្រូបែបនេះ ដោយធម្មទេសនា។ ឯគ្រូបែបនេះសោត តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយធម្មទេសនា។

[១៩] ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានវេយ្យាករណ៍មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធខ្លះ ថាវេយ្យាករណ៍ របស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ។ ពួកសាវ័ក តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានវេយ្យាករណ៍មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធខ្លះ ថាវេយ្យាករណ៍របស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងរាប់អាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដឡើង ព្រោះកម្មនោះមិនខាន។ ម្នាលមោគ្គល្លាន ពួកសាវ័ក តែងរក្សាគ្រូបែបនេះ ដោយវេយ្យាករណ៍។ ចំណែកខាងគ្រូនោះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយវេយ្យាករណ៍។

[២០] ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញ បរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ។ សាវ័ក តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញ បរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងរាប់អាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដឡើង ព្រោះកម្មនោះមិនខាន។ ម្នាលមោគ្គល្លាន ពួកសាវ័ក តែងរក្សាគ្រូបែបនេះ ដោយញាណទស្សនៈ។ ក៏ឯគ្រូមានសភាពយ៉ាងនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយញាណទស្សនៈ។ ម្នាលមោគ្គល្លាន គ្រូ៥ពួកនេះឯង តែងមានក្នុងលោក។

[២១] ម្នាលមោគ្គល្លាន ចំណែកខាងតថាគត ជាបុគ្គលមានសីលបរិសុទ្ធ ប្តេជ្ញាថា តថាគតមានសីលបរិសុទ្ធខ្លះ ថាសីលរបស់តថាគតបរិសុទ្ធផូរផង់ ឥតមាសៅហ្មងខ្លះ ពួកសាវ័ក មិនបានរក្សាតថាគតដោយសីលឡើយ តថាគតសោត ក៏មិននឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយសីលទេ។ (តថាគត) មានអាជីវៈបរិសុទ្ធ។បេ។ មានធម្មទេសនាបរិសុទ្ធ។បេ។ មានវេយ្យាករណ៍បរិសុទ្ធ។បេ។ មានញាណទស្សនៈបរិសុទ្ធ ប្តេជ្ញាថា តថាគតមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់តថាគត បរិសុទ្ធផូរផង់ ឥតមាសៅហ្មងខ្លះ សាវ័ក មិនបានរក្សាតថាគតដោយញាណទស្សនៈទេ តថាគតសោត មិននឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័ក ដោយញាណទស្សនៈឡើយ។

[២២] គ្រានោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនគរកោសម្ពី គួរតាមពុទ្ធអធ្យាស្រ័យហើយ ស្តេចទៅកាន់ចារិកនគររាជគ្រឹះ ត្រាច់ទៅកាន់ចារិកតាមលំដាប់ ឆ្ពោះទៅនគររាជគ្រឹះ។ បានឮថា ព្រះមានព្រះភាគ គង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបនគររាជគ្រឹះ។

[២៣] លំដាប់នោះ ភិក្ខុច្រើនរូបនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចទើបអង្គុយក្នុងទីដ៏សមគួរ។ ភិក្ខុទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អជាតសត្តុកុមារ តែងទៅដោយរថ៥រយ បម្រើទេវទត្ត ទាំងល្ងាច ទាំងព្រឹក ទាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់៥រយថាស ទៅប្រគេន (ទេវទត្តផង)។ ព្រះអង្គ ទ្រង់ត្រាស់តបថា ម្នាលភិក្ខុទាំងឡាយ អ្នកកុំស្ញើចលាភសក្ការៈ និងសេចក្តីសរសើររបស់ទេវទត្តឡើយ ម្នាលភិក្ខុទាំងឡាយ អជាតសត្តុកុមារ ដែលទៅដោយរថ៥រយ ទៅបម្រើទេវទត្ត ទាំងល្ងាច ទាំងព្រឹក ទាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់៥រយថាស ទៅប្រគេន (ទេវទត្ត) ដរាបណា ម្នាលភិក្ខុទាំងឡាយ សេចក្តីសាបសូន្យ មុខជានឹងកើតមានដល់ទេវទត្ត (ដរាបនោះ) មិនខាន ឯការចំរើនក្នុងកុសលធម៌ មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចគេច្របាច់ទឹកប្រម៉ាត់ (ត្រី ឬខ្លាឃ្មុំ) ដាក់ក្នុងច្រមុះឆ្កែកាច ឆ្កែនោះ រឹតតែកាចឡើងជាងដើម យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក៏ដូចជាអជាតសត្តុកុមារ ទៅដោយរថ៥រយ បម្រើទេវទត្ត ទាំងល្ងាច ទាំងព្រឹក ទាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់៥រយថាស ទៅប្រគេន (ទេវទត្ត) ដរាបណា សេចក្តីសាបសូន្យ មុខជានឹងកើតមានដល់ទេវទត្ត (ដរាបនោះ) ពុំខាន ការចំរើនក្នុងកុសលធម៌ មិនមានឡើយ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ម្នាលភិក្ខុទាំងឡាយ ដើមចេកចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីវិនាស យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏ដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ ឫស្សីចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីសេចក្តីវិនាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីបំផ្លាញខ្លួន ក៏ដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ ដូចដើមបបុស ចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីសេចក្តីវិនាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីបំផ្លាញខ្លួន ក៏ដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ ដូចមេសេះអស្សតរ មានផ្ទៃដើម្បីសម្លាប់ខ្លួន មានផ្ទៃ ដើម្បីវិនាសខ្លួន យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈ និងសេចក្តីសរសើរកើតឡើងហើយ ដល់ទេវទត្ត ដើម្បីបំផ្លាញខ្លួន ក៏ដូច្នោះដែរ។

[២៤] ផ្លែចេក តែងសម្លាប់ដើមចេក ផ្លែឫស្សី តែងសម្លាប់ដើមឫស្សី ផ្លែបបុស តែងសម្លាប់ដើមបបុស សក្ការៈ តែងសម្លាប់បុរសអាក្រក់ ដូចជាគភ៌ តែងសម្លាប់មេសេះអស្សតរ។

ចប់ ភាណវារៈ ទី១។

# (ទុតិយភាណវារៈ ទី២)

CS vin.cv.07.02 | ភាគ ទី១១

### (២. ទុតិយភាណវារោ)

## (បកាសនីយកម្ម)

CS vin.cv.07.02.01 | ភាគ ទី១១

### (បកាសនីយកម្មំ)

[២៥] សម័យនោះឯង ព្រះមានព្រះភាគមានបរិសទ្យច្រើន ព្រមទាំងស្តេចចោមរោមជុំវិញ ព្រះអង្គកំពុងគង់សំដែងធម៌។ គ្រានោះ ទេវទត្តក្រោកចាកទីអង្គុយ ធ្វើចីពរឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ហើយក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ព្រះជរា មានព្រះជន្មចម្រើនហើយ ចាស់ព្រះអង្គហើយ ទ្រង់ព្រះជន្មយូរឆ្នាំមកហើយ មានជ្រះជន្មជ្រុល ចូលមកក្នុងបច្ឆិមវ័យហើយ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះមានព្រះភាគកុំខ្វល់ខ្វាយពេក សូមសម្រាកព្រះអង្គឲ្យបានសុខស្រួល ក្នុងបច្ចុប្បន្ននេះចុះ សូមព្រះអង្គ ប្រគល់ភិក្ខុសង្ឃឲ្យមកខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងទទួលគ្រប់គ្រងភិក្ខុសង្ឃ។ ព្រះអង្គ ទ្រង់ត្រាស់តបថា ម្នាលទេវទត្ត ណ្ហើយ អ្នកកុំពេញចិត្តនឹងការគ្រប់គ្រងភិក្ខុសង្ឃឡើយ។ ទេវទត្ត បានក្រាបទូលពាក្យនេះ នឹងព្រះមានព្រះភាគ អស់វារៈពីរដងផង។ បេ។ អស់វារៈបីដងផងថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់ព្រះជរា មានព្រះជន្មចម្រើនហើយ ចាស់ព្រះអង្គហើយ ទ្រង់ព្រះជន្មយូរឆ្នាំមកហើយ មានជ្រះជន្មចូលមកក្នុងបច្ឆិមវ័យហើយ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះមានព្រះភាគកុំខ្វល់ខ្វាយពេក សូមសម្រាកព្រះអង្គឲ្យបានសុខស្រួល ក្នុងបច្ចុប្បន្ននេះចុះ សូមព្រះអង្គ ប្រគល់ភិក្ខុសង្ឃឲ្យមកខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងគ្រប់គ្រងភិក្ខុសង្ឃ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលទេវទត្ត អម្បាលយ៉ាងសារីបុត្ត និងមោគ្គល្លាន ម្តេច តថាគតមិនប្រគល់ភិក្ខុសង្ឃឲ្យ ចំណង់បើអ្នក ជាមនុស្សជួជាតិអាក្រក់ ជាមនុស្សបរិភោគចតុប្បច្ច័យ ដែលកើតអំពីអនេសនៈ ដូចជាដុំទឹកមាត់ តថាគត នឹងប្រគល់ឲ្យដូចម្តេចបាន។ លំដាប់នោះ ទេវទត្តមានសេចក្តីក្រោធ អាក់អន់ចិត្តថា ព្រះមានព្រះភាគ ធ្វើអញឲ្យអាប់មុខ ក្នុងកណ្តាលបរិសទ្យ ព្រមទាំងស្តេច ដោយពាក្យថា (ទេវទត្តនេះ) បរិភោគចតុប្បច្ច័យ ដែលកើតអំពីអនេសនៈ ដូចជាដុំទឹកមាត់ ហើយបែរទៅលើកតំកើងសារីបុត្ត និងមោគ្គល្លានវិញ ហើយក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ចៀសចេញទៅ។ នេះជាគំនុំដម្បូង របស់ទេវទត្ត ចំពោះព្រះមានព្រះភាគ។

[២៦] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ត្រូវសង្ឃធ្វើបកាសនីយកម្ម ដល់ទេវទត្ត ក្នុងនគររាជគ្រឹះ (ដ្បិត) កាលពីដើម ទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង។ ម្នាលភិក្ខុទាំងឡាយ បកាសនីយកម្ម សង្ឃគប្បីធ្វើយ៉ាងនេះ។ គប្បីឲ្យភិក្ខុដែលឈ្លាស ប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីធ្វើបកាសនីយកម្ម ដល់ទេវទត្ត ក្នុងនគររាជគ្រឹះ (ដ្បិត) ពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយកម្មនោះតែម្យ៉ាង។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃធ្វើបកាសនីយកម្ម ដល់ទេវទត្ត ក្នុងនគររាជគ្រឹះ (ដ្បិត) ពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយកម្មនោះតែម្យ៉ាង។ ការធ្វើបកាសនីយកម្ម ដល់ទេវទត្ត ក្នុងនគររាជគ្រឹះថា កាលពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយកម្មនោះតែម្យ៉ាង ដូច្នេះ គួរដល់លោកមានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីឆ្លើយឡើង។ សង្ឃបានធ្វើបកាសនីយកម្ម ដល់ទេវទត្ត ក្នុងនគររាជគ្រឹះថា ពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយកម្មនោះតែម្យ៉ាង ការធ្វើបកាសនីយកម្មនោះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៧] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះសារីបុត្តដ៏មានអាយុមកថា ម្នាលសារីបុត្ត បើដូច្នោះ ចូរអ្នកប្រកាស (ទោស) ទេវទត្ត ក្នុងនគររាជគ្រឹះ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលពីមុន ខ្ញុំព្រះអង្គបានប្រកាសគុណទេវទត្ត ក្នុងនគររាជគ្រឹះថា ទេវទត្ត ជាគោធិបុត្ត មានឫទ្ធិច្រើន ជាគោធិបុត្ត មានអានុភាពច្រើន បពិត្រព្រះអង្គដ៏ចំរើន (ឥឡូវនេះ) ខ្ញុំព្រះអង្គ នឹងប្រកាស (ទោស) ទេវទត្តដូចម្តេចបាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត អ្នកបានប្រកាសគុណពិតរបស់ទេវទត្ត ក្នុងនគររាជគ្រឹះថា ទេវទត្ត ជាគោធិបុត្ត មានឫទ្ធិច្រើន ជាគោធិបុត្ត មានអានុភាពច្រើន ដូច្នោះហើយឬ។ ព្រះសារីបុត្តក្រាបបង្គំទូលថា ករុណាព្រះអង្គ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកប្រកាស (ទោស) ទេវទត្តឲ្យពិតយ៉ាងនោះចុះ។ ព្រះសារីបុត្តដ៏មានអាយុ ក្រាបបង្គំទូលថា ករុណាព្រះអង្គ។

[២៨] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរសន្មតសារីបុត្ត ដើម្បីឲ្យប្រកាស (ទោស) ទេវទត្ត ក្នុងនគររាជគ្រឹះថា ពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយអំពើនោះតែម្យ៉ាង។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ។ សង្ឃត្រូវសូមសារីបុត្តជាដំបូងសិន។ លុះសូមរួចហើយ ត្រូវឲ្យភិក្ខុជាអ្នកឈ្លាស ប្រតិពល ប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតព្រះសារីបុត្តដ៏មានអាយុ ដើម្បីឲ្យប្រកាស (ទោស) ទេវទត្ត ក្នុងនគររាជគ្រឹះថា (ដ្បិត) ពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណា ដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយអំពើនោះតែម្យ៉ាង។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតព្រះសារីបុត្តដ៏មានអាយុ ឲ្យជាអ្នកប្រកាស (ទោស) ទេវទត្ត ក្នុងនគររាជគ្រឹះថា កាលពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយអំពើនោះតែម្យ៉ាង។ ការសន្មតិព្រះសារីបុត្តដ៏មានអាយុ ឲ្យជាអ្នកប្រកាស (ទោស) ទេវទត្ត ក្នុងនគររាជគ្រឹះថា កាលពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយអំពើនោះតែម្យ៉ាង ដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីនិយាយឡើង។ សង្ឃបានសន្មតព្រះសារីបុត្តដ៏មានអាយុ ឲ្យជាអ្នកប្រកាស (ទោស) ទេវទត្ត ក្នុងនគររាជគ្រឹះថា ពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយអំពើនោះតែម្យ៉ាង ការសន្មតិនោះ គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៩] ព្រះសារីបុត្តដ៏មានអាយុដែលសង្ឃបានសន្មតរួចហើយ ក៏ចូលទៅនគររាជគ្រឹះ ជាមួយនឹងភិក្ខុច្រើនរូប បានប្រកាស (ទោស) ទេវទត្ត ក្នុងនគររាជគ្រឹះថា កាលពីដើម ទេវទត្ត មានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយកម្មនោះតែម្យ៉ាង។ ក្នុងនគររាជគ្រឹះនោះ មនុស្សពួកណា ដែលមិនមានសទ្ធា មិនជ្រះថ្លា ជាអ្នកឥតប្រាជ្ញា មនុស្សពួកនោះ និយាយគ្នាយ៉ាងនេះថា សមណសក្យបុត្តិយ៍ទាំងនេះ ជាអ្នកច្រណែន ឈ្នានីសលាភសក្ការៈរបស់ទេវទត្ត។ ចំណែកមនុស្សពួកណា ដែលមានសទ្ធាជ្រះថ្លា មានប្រាជ្ញាវាងវៃ មនុស្សពួកនោះ និយាយគ្នាថា ព្រះមានព្រះភាគឲ្យភិក្ខុសង្ឃប្រកាស (ទោស) ទេវទត្ត ក្នុងនគររាជគ្រឹះ ដោយកិច្ចណា កិច្ចនេះ មិនមែនជាការថោកទាបទេ។

## (អជាតសត្តុកុមារវត្ថុ)

CS vin.cv.07.02.02 | ភាគ ទី១១

### (អជាតសត្តុកុមារវត្ថុ)

[៣០] លំដាប់នោះ ទេវទត្តចូលទៅរកអជាតសត្តុកុមារ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងអជាតសត្តុកុមារថា ម្នាលកុមារ កាលពីដើម មនុស្សមានអាយុវែងមែន ឥឡូវនេះ មានអាយុខ្លីណាស់ ព្រះអង្គនៅក្មេងក៏ពិត តែគង់ធ្វើមរណកាលដោយហេតុណា ហេតុនុ៎ះ

តែងតែមានជាប្រាកដ ម្នាលកុមារ បើដូច្នោះ ចូរព្រះអង្គសម្លាប់បិតា ហើយព្រះអង្គ នឹងបានជាស្តេចទ្រង់រាជ ឯអាត្មាក៏សម្លាប់ព្រះមានព្រះភាគ ហើយនឹងបានជាព្រះពុទ្ធដែរ។ គ្រានោះ អជាតសត្តុកុមារគិតថា លោកម្ចាស់ទេវទត្តមានឫទ្ធិច្រើនផង មានអានុភាពច្រើនផង លោកម្ចាស់ទេវទត្ត ដឹង (ការនេះ) លុះគិតដូច្នោះហើយ ក៏សៀតកាំបិតស្នៀតបណ្តោយភ្លៅ មានសេចក្តីខ្លាច ញាប់ញ័ររន្ធត់ តក់ស្លុត ចូលទៅកាន់ព្រះរាជវាំង ដោយរួសរាន់ទាំងថ្ងៃត្រង់។ ពួកមហាមាត្រ ជាអ្នករក្សាព្រះរាជវាំង បានឃើញអជាតសត្តុកុមារ មានសេចក្តីខ្លាច ញាប់ញ័រ រន្ធត់ តក់ស្លុត ចូលទៅព្រះរាជវាំង ដោយរួសរាន់ទាំងថ្ងៃត្រង់ ក៏នាំគ្នាចាប់។ ពួកមហាមាត្រទាំងនោះ ពិនិត្យមើលទៅ ឃើញមានសៀតកាំបិតស្នៀត បណ្តោយភ្លៅ ក៏ក្រាបទូលសួររឿងនុ៎ះ នឹងអជាតសត្តុកុមារថា បពិត្រព្រះរាជកុមារ ព្រះអង្គចង់ធ្វើការអ្វី។ អជាតសត្តុកុមារឆ្លើយថា យើងត្រូវការសម្លាប់បិតា។ មហាមាត្រ ក្រាបទូលសួរថា អ្នកណាបញ្ឆេះព្រះអង្គ។ អជាតសត្តុកុមារឆ្លើយថា លោកម្ចាស់ទេវទត្ត (ពន្យល់យើង)។ មហាមាត្រពួកខ្លះ វិនិច្ឆ័យយ៉ាងនេះថា ព្រះរាជកុមារ យើងត្រូវសម្លាប់ ទាំងទេវទត្ត និងភិក្ខុទាំងពួង ក៏យើងត្រូវសម្លាប់។ មហាមាត្រពួកខ្លះ វិនិច្ឆ័យយ៉ាងនេះថា យើងមិនត្រូវសម្លាប់ពួកភិក្ខុឡើយ ដ្បិតភិក្ខុទាំងនោះ មិនបានប្រទូស្តអ្វីទេ យើងត្រូវសម្លាប់តែព្រះរាជកុមារ និងទេវទត្ត។ មហាមាត្រពួកខ្លះ វិនិច្ឆ័យថា កុមារក្តី ទេវទត្តក្តី ភិក្ខុទាំងឡាយក្តី យើងមិនត្រូវសម្លាប់ទេ (រឿងនេះ) គួរយើងក្រាបទូលដល់ព្រះរាជាសិន បើព្រះរាជាមានព្រះរាជឱង្ការយ៉ាងណា សឹមយើងធ្វើយ៉ាងនោះ។

[៣១] លំដាប់នោះ ពួកមហាមាត្រទាំងនោះ នាំអជាតសត្តុកុមារចូលទៅគាល់ព្រះបាទពិម្ពិសារមាគធសេនិយរាជ លុះចូលទៅដល់ហើយ ក៏ក្រាបទូលរឿងនុ៎ះ ចំពោះព្រះបាទពិម្ពិសារមាគធសេនិយរាជ។ ព្រះរាជា ទ្រង់ត្រាស់សួរថា ម្នាលនាយ ពួកមហាមាត្រវិនិច្ឆ័យដូចម្តេចខ្លះ។ ពួកមហាមាត្រក្រាបទូលថា បពិត្រព្រះសម្មតិទេព មហាមាត្រពួកខ្លះ វិនិច្ឆ័យយ៉ាងនេះថា យើងត្រូវសម្លាប់ព្រះរាជកុមារផង ត្រូវសម្លាប់ទេវទត្ត និងភិក្ខុទាំងអស់ផង មហាមាត្រពួកខ្លះ វិនិច្ឆ័យយ៉ាងនេះថា យើងមិនត្រូវសម្លាប់ពួកភិក្ខុឡើយ ព្រោះភិក្ខុទាំងនោះ មិនបានប្រទូស្តអ្វីទេ យើងត្រូវសម្លាប់តែព្រះរាជកុមារ និងទេវទត្ត មហាមាត្រពួកខ្លះ វិនិច្ឆ័យយ៉ាងនេះថា កុមារក្តី ទេវទត្តក្តី ពួកភិក្ខុក្តី យើងមិនត្រូវសម្លាប់ទេ (រឿងនេះ) គួរយើងក្រាបទូល ដល់ព្រះរាជាសិន បើព្រះរាជាមានព្រះរាជឱង្ការយ៉ាងណា សឹមយើងធ្វើយ៉ាងនោះ។ ព្រះរាជាទ្រង់មានព្រះឱង្ការថា ម្នាលនាយ ព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី នឹងធ្វើអ្វី ព្រះមានព្រះភាគ ទ្រង់ចាត់ឲ្យភិក្ខុសង្ឃប្រកាសទោសទេវទត្ត ក្នុងនគររាជគ្រឹះថា កាលពីដើម ទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្ត ធ្វើអំពើណាដោយកាយ វាចា អំពើនោះ នាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញ ដោយកម្មនោះតែម្យ៉ាង ជាមុនរួចហើយ មិនដូច្នោះឬ។ បណ្តាពួកមហាមាត្រទាំងនោះ មហាមាត្រពួកណា វិនិច្ឆ័យសេចក្តីថា យើងត្រូវសម្លាប់ទាំងកុមារ ទាំងទេវទត្ត ទាំងពួកភិក្ខុ (ព្រះរាជា) ទ្រង់ហូតងារមហាមាត្រទាំងនោះ។ មហាមាត្រពួកណាវិនិច្ឆ័យថា យើងមិនត្រូវសម្លាប់ពួកភិក្ខុ ព្រោះពួកភិក្ខុមិនបានប្រទូស្តអ្វីទេ យើងត្រូវសម្លាប់តែព្រះរាជកុមារ និងទេវទត្ត (ព្រះរាជា) ក៏បន្ថយឋានន្តរមហាមាត្រទាំងនោះ ក្នុងថ្នាក់ទាបវិញ។ មហាមាត្រពួកណាវិនិច្ឆ័យថា កុមារក្តី ទេវទត្តក្តី ភិក្ខុទាំងឡាយក្តី យើងមិនត្រូវសម្លាប់ គួរយើងក្រាបទូលដល់ព្រះរាជាសិន បើព្រះរាជាមានព្រះរាជឱង្ការយ៉ាងណា សឹមយើងធ្វើយ៉ាងនោះ (ព្រះរាជា) ក៏តាំងមហាមាត្រទាំងនោះ ឲ្យឡើងឋានន្តរខ្ពស់។ លំដាប់នោះ ព្រះបាទពិម្ពិសារមាគធសេនិយរាជ បានត្រាស់ព្រះតម្រាស់នេះ នឹងអជាតសត្តុកុមារថា ម្នាលកុមារ អ្នកចង់សម្លាប់យើងដើម្បីអ្វី។ អជាតសត្តុកុមារក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គត្រូវការដោយរាជសម្បត្តិ។ ព្រះរាជាប្រគល់រាជសម្បត្តិ ដល់អជាតសត្តុកុមារថា ម្នាលកុមារ បើអ្នកត្រូវការដោយរាជសម្បត្តិ រាជសម្បត្តិនេះ ជារបស់អ្នកឯងហើយ។

## (អភិមារបេសនៈ)

CS vin.cv.07.02.03 | ភាគ ទី១១

### (អភិមារបេសនំ)

[៣២] គ្រានោះ ទេវទត្ត ចូលទៅរកអជាតសត្តុកុមារ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងអជាតសត្តុកុមារថា បពិត្រមហារាជ សូមព្រះអង្គប្រើបុរសឲ្យទៅសម្លាប់ព្រះសមណគោតម។ អជាតសត្តុកុមារបង្គាប់មនុស្សទាំងឡាយថា ម្នាលនាយ លោកម្ចាស់ទេវទត្ត មានថេរវាចាយ៉ាងណា ចូរអ្នកទាំងអស់គ្នា ធ្វើយ៉ាងនោះចុះ។ គ្រានោះ ទេវទត្តបង្គាប់បុរសម្នាក់ថា ម្នាលនាយ ចូរអ្នកទៅសម្លាប់ព្រះសមណគោតម ដែលគង់នៅក្នុងឱកាសឯណោះ ហើយសឹមមកតាមផ្លូវនេះ បង្គាប់បុរសពីរនាក់ ឲ្យឈរចាំទៀបផ្លូវនោះថា បុរសណាដែលមកតែម្នាក់ឯង តាមផ្លូវនេះ ចូរអ្នកទាំងពីរនាក់សម្លាប់បុរសនោះ ហើយសឹមដើរមកតាមផ្លូវនេះ បង្គាប់បុរស៤នាក់ ឲ្យឈរចាំទៀបផ្លូវនោះថា (បើ) បុរសពីរនាក់ណា មកតាមផ្លូវនេះ ចូរអ្នកសម្លាប់បុរសទាំងពីរនាក់នោះ ហើយសឹមដើរមកតាមផ្លូវនេះ បង្គាប់បុរស៨នាក់ ឲ្យឈរចាំទៀបផ្លូវនោះថា (បើ) បុរស៤នាក់ណា ដើរមកតាមផ្លូវនេះ ចូរអ្នកសម្លាប់បុរសទាំង៤នាក់នោះ ហើយសឹមដើរមកតាមផ្លូវនេះ បង្គាប់បុរស១៦នាក់ ឲ្យឈរចាំទៀបផ្លូវនោះថា (បើ) បុរស៨នាក់ណា ដើរមកតាមផ្លូវនេះ ចូរអ្នកសម្លាប់បុរសទាំង៨នាក់នោះ ហើយសឹមដើរមក (តាមផ្លូវនេះ)។

[៣៣] គ្រានោះ បុរសម្នាក់នោះ កាន់ដាវ និងខែល ស្ពាយធ្នូ និងបំពង់ព្រួញ ដើរសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ភ័យញាប់ញ័រ រន្ធត់ តក់ស្លុត ឈររឹងខ្លួន ជិតព្រះមានព្រះភាគ។ ព្រះមានព្រះភាគទតឃើញបុរសនោះ កំពុងភ័យ ញាប់ញ័រ រន្ធត់ តក់ស្លុត ឈរគាំងខ្លួនដូច្នោះ លុះទតឃើញហើយ ទើបត្រាស់ទៅនឹងបុរសនោះថា ម្នាលអ្នកដ៏មានអាយុ អ្នកឯងចូលមកចុះ កុំខ្លាចឡើយ។ លំដាប់នោះ បុរសនោះទុកដាវ និងខែល ក្នុងទីដ៏សមគួរ ហើយដាក់ធ្នូ និងបំពង់ព្រួញ ទើបដើរចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបចុះទៀបព្រះបាទារបស់ព្រះមានព្រះភាគដោយត្បូង ហើយក្រាបបង្គំទូលរឿងនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កំហុសគ្របសង្កត់ហើយនូវខ្ញុំព្រះអង្គ តាមដោយខ្ញុំព្រះអង្គ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ខ្ញុំព្រះអង្គដែលមានចិត្តប្រទូស្ត មានចិត្តចង់សម្លាប់ ហើយដើរចូលមកដល់ទីនេះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ អត់នូវកំហុស តាមទោសរបស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅទៀត។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលអ្នកដ៏មានអាយុ ណ្ហើយចុះ អ្នកមានកំហុសគ្របសង្កត់ហើយ ព្រោះអ្នកឯងជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស អ្នកមានចិត្តប្រទូស្ត មានចិត្តចង់សម្លាប់ (តថាគត) ហើយដើរចូលមកដល់ទីនេះ ម្នាលអ្នកដ៏មានអាយុ បើអ្នកបានឃើញកំហុស តាមទោសខុសណាហើយ ចូរធ្វើឲ្យសមគួរតាមធម៌ តថាគតនឹងទទួលអត់ទោសរបស់អ្នកនោះ ម្នាលអ្នកដ៏មានអាយុ (បើ) អ្នកណាមួយ បានឃើញកំហុស តាមទោសខុសពិត ហើយសំដែង (ទោសនោះ) តាមធម៌ ដល់នូវសេចក្តីសង្រួមតទៅ នេះជាសេចក្តីចំរើនរបស់អ្នក

នោះ ក្នុងអរិយវិន័យ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់សំដែងនូវអនុបុព្វីកថា ដល់បុរសនោះ អនុបុព្វីកថានោះ ដូចម្ដេច ព្រះអង្គទ្រង់សំដែង ទានកថា សីលកថា សគ្គកថា និងទោសនៃកាម ដែលថោកទាបសៅហ្មង អានិសង្សក្នុងការចេញបួស។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុរសនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណធម៌ មានចិត្តរីករាយ មានចិត្តជ្រះថ្លាក្នុងកាលណាហើយ ធម្មទេសនាណា ជារបស់ព្រះពុទ្ធទាំងឡាយ ដែលទ្រង់លើកឡើងសំដែង ដោយព្រះអង្គឯង ព្រះអង្គ ក៏ប្រកាសនូវធម្មទេសនានោះ គឺទុក្ខ១ សមុទយ១ និរោធ១ មគ្គ១ ក្នុងកាលនោះ។ សំពត់ស្អាត ឥតមានពណ៌ខ្មៅ គួរទទួលនូវគ្រឿងជ្រលក់ដោយល្អ យ៉ាងណាមិញ បុរសនោះ អង្គុយលើអាសនៈនោះ កើតធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិលថា ធម្មជាតណាមួយ តែងកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា ដូច្នោះដែរ។ លំដាប់នោះ បុរសនោះ ឃើញធម៌ច្បាស់ហើយ បានលុះធម៌ហើយ ដឹងធម៌ច្បាស់ហើយ មានចិត្តចុះកាន់ធម៌ស៊ប់ហើយ ឆ្លងផុតសេចក្ដីសង្ស័យហើយ ប្រាសចាកសេចក្ដីងឿងឆ្ងល់ហើយ ដល់នូវសេចក្ដីក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្ដា ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គបានសំដែងហើយ ដោយអនេកបរិយាយ (យ៉ាងនេះ) គួរនាដូចជាគេបើករបស់ដែលផ្កាប់ ឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់ដែលគេបិទបាំងទុក ពុំនោះសោត ដូចគេប្រាប់ផ្លូវ ដល់អ្នកវង្វេងផ្លូវ ឬក៏ដូចគេទ្រោលប្រទីប ក្នុងទីងងឹត ឲ្យមនុស្សដែលមានភ្នែក មើលឃើញរូបបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ទីរលឹក សូមព្រះមានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក អ្នកដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹង ទីរលឹកស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះ នឹងបុរសនោះថា ម្នាលអ្នកដ៏មានអាយុ អ្នកកុំទៅតាមផ្លូវនេះ ចូលទៅតាមផ្លូវនេះវិញ ហើយក៏បញ្ជូនបុរសនោះ ទៅតាមផ្លូវដទៃទៅ។

[៣៤] គ្រានោះ បុរសទាំងពីរនាក់នោះ គិតគ្នាថា បុរសម្នាក់នោះ ដូចម្ដេចក៏ក្រមកម្ល៉េះ ហើយក៏នាំគ្នាទៅកាន់ផ្លូវជួបគ្នា ស្រាប់តែបានឃើញព្រះមានព្រះភាគ គង់ទៀបគល់ឈើមួយ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ លុះទៅដល់ហើយ ក៏ក្រាបអភិវាទចំពោះព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ ព្រះមានព្រះភាគ ទ្រង់សំដែងនូវអនុបុព្វីកថា ដល់បុរសទាំងពីរនាក់នោះ។បេ។ បុរសទាំងពីនាក់នោះ ក៏មិនជឿបុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្ដា ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់។បេ។ សូមព្រះមានព្រះភាគ ចាំទុកនូវយើងខ្ញុំទាំងឡាយថា ជាឧបាសកអ្នកដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹង ទីរលឹកស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះទៅ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះ នឹងបុរសនោះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ចូរអ្នកកុំដើរទៅតាមផ្លូវនេះ ចូរអ្នកដើរទៅតាមផ្លូវនេះវិញ ហើយក៏បញ្ជូនទៅតាមផ្លូវដទៃទៅ។

[៣៥] គ្រានោះ បុរស៤នាក់។បេ។ គ្រានោះ បុរស៨នាក់។បេ។ គ្រានោះ បុរស១៦នាក់ គិតគ្នាថា បុរស៨នាក់ ដូចម្ដេចក៏ក្រមកម្ល៉េះ ហើយទៅកាន់ផ្លូវជួបគ្នា ស្រាប់តែបានឃើញព្រះមានព្រះភាគ គង់នៅទៀបគល់ឈើមួយ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ ក្រាបអភិវាទចំពោះព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ ព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថា ដល់បុរសទាំង១៦នាក់នោះ អនុបុព្វីកថានោះដូចម្ដេច គឺទានកថា សីលកថា។បេ។ បុរសទាំង១៦នាក់នោះ មិនជឿបុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្ដា ហើយបានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់។បេ។ សូមព្រះមានព្រះភាគ ចាំទុកនូវយើងខ្ញុំថា ជាឧបាសក អ្នកដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹង ស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះទៅ។ លំដាប់នោះឯង មានបុរសម្នាក់ ចូលទៅរកទេវទត្ត លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងទេវទត្តថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណា មិនអាចនឹងសម្លាប់ព្រះមានព្រះភាគនោះទេ ដ្បិតព្រះមានព្រះភាគនោះ មានឫទ្ធិច្រើន មានអានុភាពច្រើនណាស់។ ទេវទត្តនិយាយថា ណ្ហើយ អ្នកដ៏មានអាយុ បើអ្នកមិនអាចនឹងសម្លាប់ព្រះសមណគោតមបានទេ ទុកឲ្យយើងឯង នឹងសម្លាប់ព្រះសមណគោតមវិញ។

## (លោហិតុប្បាទកកម្ម)

CS vin.cv.07.02.04 | ភាគ ទី១១

### (លោហិតុប្បាទកកម្មំ)

[៣៦] សម័យនោះឯង ព្រះមានព្រះភាគទ្រង់ចង្ក្រម ក្នុងម្លប់ភ្នំគិជ្ឈកូដ។ លំដាប់នោះ ទេវទត្តឡើងទៅលើ (កំពូល)ភ្នំគិជ្ឈកូដ ហើយប្រមៀលដុំថ្មធំ ដោយបំណងថា អញនឹងសម្លាប់ព្រះសមណគោតម ដោយដុំថ្មនេះ។ ឯកំពូលភ្នំទាំងពីរ ក៏មកប្រជុំគ្នា រងដុំថ្មនោះ។ គ្រានោះ បំណែកថ្ម ក៏ខ្ទាតឡើង ទង្គិចធ្វើព្រះលោហិត ក្នុងព្រះបាទព្រះមានព្រះភាគ ឲ្យពុរពងឡើង។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ទតព្រះនេត្រទៅខាងលើ ហើយមានព្រះពុទ្ធដីកាទៅរកទេវទត្តថា នែមោឃបុរស អ្នកឯងមានចិត្តប្រទូស្ដ មានចិត្តចង់សម្លាប់ ហើយធ្វើលោហិតរបស់តថាគតឲ្យពុរពងឡើង ដោយអំពើណា អំពើនោះ អ្នកនឹងរងអកុសលកម្មច្រើន។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមានចិត្តប្រទូស្ដ មានចិត្តចង់សម្លាប់ បានធ្វើលោហិតរបស់តថាគតឲ្យពុរពងឡើង ដោយអំពើណា អំពើនេះ ឈ្មោះថា អនន្តរិយកម្ម ដែលទេវទត្តសន្សំមកជាដម្បូង។ ភិក្ខុទាំងឡាយបានឮដំណឹងថា ទេវទត្តព្យាយាមសម្លាប់ព្រះមានព្រះភាគហើយ។ ពួកភិក្ខុទាំងនោះ ចង្ក្រមព័ទ្ធជុំវិញវិហារ របស់ព្រះមានព្រះភាគ នាំគ្នាស្រែកធ្វើសំឡេងគឹកកងខ្លាំង ធ្វើស្វាធ្យាយ ដើម្បីរក្សាការពារគ្រប់គ្រងព្រះមានព្រះភាគ។ ព្រះមានព្រះភាគ បានឮសំឡេងគឹកកង សំឡេងខ្លាំង សំឡេងស្វាធ្យាយ លុះទ្រង់ព្រះហើយ ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ សំឡេងគឹកកង សំឡេងខ្លាំង សំឡេងស្វាធ្យាយនោះ តើជាសំឡេងអ្វី។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុទាំងឡាយបានឮដំណឹងថា ទេវទត្តព្យាយាមសម្លាប់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុទាំងនោះ ក៏ចង្ក្រមព័ទ្ធជុំវិញវិហារ របស់ព្រះមានព្រះភាគ នាំគ្នាស្រែកធ្វើសំឡេងគឹកកង សំឡេងខ្លាំង ធ្វើស្វាធ្យាយ ដើម្បីរក្សាការពារគ្រប់គ្រងព្រះមានព្រះភាគ បពិត្រព្រះមានព្រះភាគ សំឡេងគឹកកង សំឡេងខ្លាំង សំឡេងស្វាធ្យាយនោះ គឺជាសំឡេងនោះឯង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកហៅភិក្ខុទាំងនោះមកតាមពាក្យតថាគតថា ព្រះសាស្ដាឲ្យហៅលោកដ៏មានអាយុទាំងឡាយ។ ព្រះអានន្ទដ៏មានអាយុ ទទួលពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ រួច

ហើយ ក៏ចូលសំដៅទៅរកភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងភិក្ខុទាំងនោះថា ព្រះសាស្តាត្រាស់ឲ្យហៅលោកដ៏មានអាយុទាំងឡាយ។ ភិក្ខុទាំងឡាយនោះ ទទួលស្តាប់ពាក្យអានន្ទដ៏មានអាយុថា យ៉ាងនេះហើយអាវុសោ រួចហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបបង្គំ ចំពោះព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ បានត្រាស់តម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស (គួរធ្វើបានឡើយ) ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតទាំងឡាយ មិនដែលបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់អ្នកដទៃទេ។ ម្នាលភិក្ខុទាំងឡាយ គ្រូក្នុងលោកនេះ មាន៥ពួក គ្រូទាំង៥ពួកនោះ គឺគ្រូណាខ្លះ ម្នាលភិក្ខុទាំងឡាយ គ្រូ១ពួកក្នុងលោកនេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីលរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ។ ពួកសាវ័ក តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីលរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងរាប់អាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដឡើង ព្រោះកម្មនោះមិនខាន។ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័ក តែងរក្សាគ្រូបែបនេះដោយសីល។ ឯគ្រូបែបនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយសីល។

[៣៧] ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃនៅមានទៀត គ្រូ១ពួកក្នុងលោកនេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាខ្លួនថា អញមានអាជីវៈបរិសុទ្ធខ្លះ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័ក តែងរក្សាគ្រូបែបនេះដោយអាជីវៈ។ ឯគ្រូបែបនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយអាជីវៈ។

[៣៨] ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃនៅមានទៀត គ្រូ១ពួកក្នុងលោកនេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធខ្លះ។បេ។ ម្នាលភិក្ខុទាំងឡាយ សាវ័ក តែងរក្សាគ្រូបែបនេះ ដោយធម្មទេសនា។ ឯគ្រូបែបនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយធម្មទេសនា។

[៣៩] ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃនៅមានទៀត គ្រូ១ពួកក្នុងលោកនេះ មានវេយ្យាករណ៍មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធខ្លះ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័ក តែងរក្សាគ្រូបែបនេះ ដោយវេយ្យាករណ៍។ ឯគ្រូបែបនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយវេយ្យាករណ៍។

[៤០] ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូ១ពួកក្នុងលោកនេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញ បរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ។ សាវ័កទាំងឡាយ តែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញ បរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងរាប់អានយើង ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដឡើង ព្រោះកម្មនោះមិនខាន។ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័ក រមែងរក្សាគ្រូបែបនេះ ដោយញាណទស្សនៈ។ ក៏គ្រូបែបនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយញាណទស្សនៈ។ ម្នាលភិក្ខុទាំងឡាយ គ្រូទាំង៥ពួកនេះឯង តែងមានក្នុងលោកនេះ។ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត ជាអ្នកមានសីលបរិសុទ្ធ ទើបប្តេជ្ញាថា តថាគតមានសីលបរិសុទ្ធខ្លះ ថាសីលរបស់តថាគត បរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ។ ឯសាវ័កទាំងឡាយ មិនបានរក្សាតថាគតដោយសីលទេ។ ចំណែកតថាគត ក៏មិននឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កទាំងឡាយ ដោយសីលឡើយ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគត ជាអ្នកមានអាជីវៈបរិសុទ្ធ។បេ។ មានធម្មទេសនាបរិសុទ្ធ។បេ។ មានវេយ្យាករណ៍បរិសុទ្ធ។បេ។ មានញាណទស្សនៈបរិសុទ្ធ ទើបប្តេជ្ញាថា តថាគតមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់តថាគត បរិសុទ្ធផូរផង់ ឥតមាសៅហ្មងខ្លះ។ ឯសាវ័កទាំងឡាយ មិនបានរក្សាតថាគត ដោយញាណទស្សនៈឡើយ។ ចំណែកតថាគត ក៏មិននឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយញាណទស្សនៈដែរ។ ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស (គួរឲ្យធ្វើបានឡើយ) ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់បុគ្គលដទៃទេ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទៅកាន់វិហាររាល់ខ្លួនចុះ ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនបាច់មានបុគ្គលរក្សាទេ។

## (នាឡាគិរិបេសនៈ)

CS vin.cv.07.02.05 | ភាគ ទី១១

### (នាឡាគិរិបេសនំ)

[៤១] ក៏សម័យនោះឯង ក្នុងនគររាជគ្រឹះ មានដំរី១ ឈ្មោះ នាឡាគិរី ជាសត្វកាចសាហាវ តែងសម្លាប់មនុស្ស។ លំដាប់នោះ ទេវទត្តចូលទៅកាន់នគររាជគ្រឹះ ហួសទៅដល់រោងដំរី ហើយបាននិយាយពាក្យនេះនឹងពួកអ្នករក្សាដំរីថា នែនាយ យើងនេះ ជាព្រះញាតិនឹងស្តេច អាចតាំងអ្នកដែលនៅក្នុងតំណែងទាប ឲ្យនៅក្នុងតំណែងខ្ពស់ក៏បាន អាចបង្កើនភត្ត និងបៀវត្សក៏បាន ម្នាលនាយ បើដូច្នោះ ព្រះសមណគោតម ដើរមកកាន់ច្រកនេះពេលណា អ្នកចូរលែងដំរីនាឡាគិរីនេះ ឲ្យដើរទៅកាន់ច្រកនេះ ក្នុងពេលនោះ។ ពួកអ្នករក្សាដំរីទាំងនោះ ទទួលស្តាប់ពាក្យទេវទត្តថា កុរុណាលោកម្ចាស់។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់នគររាជគ្រឹះ ជាមួយនឹងភិក្ខុទាំងឡាយជាច្រើនរូប។ លំដាប់នោះ ព្រះមានព្រះភាគ ស្តេចទៅកាន់ច្រកនោះ។ ឯពួកអ្នករក្សាដំរីទាំងនោះ បានឃើញព្រះមានព្រះភាគ ស្តេចទៅកាន់ច្រកនោះ លុះឃើញហើយ ក៏លែងដំរីនាឡាគិរី ឲ្យដើរទៅកាន់ច្រកនោះ។ ដំរីនាឡាគិរី បានឃើញព្រះមានព្រះភាគ ស្តេចមកអំពីចម្ងាយលឹមៗ លុះឃើញហើយ ក៏លើកប្រមោយ សម្រឹងត្រចៀក និងកន្ទុយ ស្ទុះទៅរកព្រះមានព្រះភាគ។ ពួកភិក្ខុទាំងនោះ បានឃើញដំរីនាឡាគិរីមកអំពីចម្ងាយលឹមៗ លុះឃើញហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ដំរីនាឡាគិរីនេះកាចអាក្រក់ ជាសត្វ

សម្លាប់មនុស្ស (ឥឡូវ) ដើរមកកាន់ច្រកនេះហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគថយចេញ សូមព្រះសុគតស្តេចថយចេញ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកមកចុះ កុំខ្លាចឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស (គួរធ្វើបានឡើយ) ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់អ្នកដទៃទេ។ ពួកភិក្ខុទាំងនោះ បានក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈពីរដងផង។បេ។ ពួកភិក្ខុទាំងនោះ បានក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈបីដងផងថា បពិត្រព្រះអង្គដ៏ចំរើន ដំរីនាឡាគិរីនេះកាចអាក្រក់ ជាសត្វសម្លាប់មនុស្ស (ឥឡូវ) ដើរមកកាន់ច្រកនេះហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគថយចេញ សូមព្រះសុគតស្តេចថយចេញ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកមកចុះ កុំខ្លាចឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់អ្នកដទៃទេ។

[៤២] សម័យនោះឯង មនុស្សទាំងឡាយ នាំគ្នាឡើងទៅនៅលើប្រាសាទខ្លះ លើប្រាសាទដំបូលត្រងិលខ្លះ លើដំបូលផ្ទះខ្លះ។ បណ្តាពួកមនុស្សទាំងនោះ មនុស្សពួកណាមិនទាន់មានសទ្ធា មិនទាន់ជ្រះថ្លា ឥតប្រាជ្ញា មនុស្សពួកនោះ និយាយគ្នាយ៉ាងនេះថា ម្នាលគ្នាយើង មហាសមណៈ ឈ្មោះគោតម មានរូបល្អណាស់ ប៉ុន្តែមុខជាត្រូវដំរីបៀតបៀន។ ចំណែកខាងមនុស្សពួកណា មានសទ្ធាជ្រះថ្លា ជាបណ្ឌិត មានប្រាជ្ញា មនុស្សពួកនោះ និយាយគ្នាយ៉ាងនេះថា ម្នាលគ្នាយើង មិនយូរប៉ុន្មានឡើយ មុខជាព្រះពុទ្ធនាគ នឹងធ្វើសង្គ្រាមជាមួយនឹងហត្ថិនាគ (នេះ)។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ផ្សាយមេត្តាចិត្តទៅកាន់ដំរីនាឡាគិរី។ គ្រានោះ ដំរីនាឡាគិរី ដែលមេត្តាចិត្តរបស់ព្រះមានព្រះភាគពាល់ត្រូវហើយ ក៏ដាក់ប្រមោយចុះ ចូលទៅជិតព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានឈរនៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ។ ព្រះមានព្រះភាគ យកព្រះហស្តខាងស្តាំ ស្ទាបពោងដំរីនាឡាគិរី ហើយសំដែងគាថា ចំពោះដំរីនាឡាគិរីនោះថា

[៤៣] ម្នាលកុញ្ជរ អ្នកកុំចូលមកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគឡើយ ម្នាលកុញ្ជរ ព្រោះថា ការចូលមកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគ ជាហេតុឲ្យកើតទុក្ខ។ ម្នាលកុញ្ជរ កាលបើអ្នកសម្លាប់ព្រះពុទ្ធនាគហើយ ទៅអំពីជាតិនេះ ទៅកាន់លោកខាងមុខ (អ្នក) មិនបានទៅកើតក្នុងសុគតិទេ។ ចូរអ្នកលែងស្រវឹង លែងប្រមាទទៅ ព្រោះថា សត្វទាំងឡាយ ដែលប្រមាទហើយ តែងមិនបានទៅកាន់សុគតិភូមិឡើយ។ អ្នកនឹងទៅកាន់សុគតិ ដោយប្រការដែលអ្នកធ្វើខ្លួនឯង។

[៤៤] លំដាប់នោះ ដំរីនាឡាគិរីចាប់លួងធូលី ដែលជាប់នឹងព្រះបាទព្រះមានព្រះភាគ ដោយប្រមោយ យកមករោយរាយលើក្បាល ហើយបែរមុខចំព្រះមានព្រះភាគ អង្គុញជើងមុខ ថយក្រោយ ដរាបទាល់តែលែងឃើញព្រះមានព្រះភាគ។ លំដាប់នោះ ដំរីនាឡាគិរី ដើរទៅកាន់រោងដំរី ក៏បានឈរនៅក្នុងកន្លែងរបស់ខ្លួនដដែល។ ព្រះមានព្រះភាគ បានទូន្មានដំរីនាឡាគិរី ដោយប្រការដូច្នេះឯង។

[៤៥] សម័យនោះឯង មនុស្សទាំងឡាយនាំគ្នាច្រៀងគាថានេះថា

> ជនពួក១តែងទូន្មាន (ដំរី) ដោយដំបងខ្លះ ដោយកង្វេរខ្លះ ដោយរំពាត់ខ្លះ (ចំណែក) ព្រះពុទ្ធ ដែលព្រះអង្គស្វែងរកនូវគុណធំ ឥតមានដំបង ឥតមានគ្រឿងសស្ត្រាអ្វីទេ តែអាចទូន្មានហត្ថិនាគបាន។

មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តនេះ ជាមនុស្សអាក្រក់ ជាអ្នកឥតបុណ្យសោះ មិនសមបើនឹងព្យាយាមសម្លាប់ព្រះសមណគោតម ដែលមានឫទ្ធិច្រើន មានអានុភាពច្រើនយ៉ាងនេះឡើយ។ ទេវទត្តក៏សាបសូន្យលាភសក្ការៈទៅ។ ឯលាភសក្ការៈ ក៏រឹតតែចំរើនឡើង ដល់ព្រះមានព្រះភាគ។

## (បញ្ចវត្ថុយាចនកថា)

CS vin.cv.07.02.06 | ភាគ ទី១១

### (បញ្ចវត្ថុយាចនកថា)

[៤៦] សម័យនោះឯង ទេវទត្ត ព្រមទាំងបរិសទ្យសាបសូន្យលាភសក្ការៈ ហើយក៏នាំគ្នារែអង្គាសគ្រប់ត្រកូល មកបរិភោគ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើសមណៈទាំងឡាយ ជាសក្យបុត្តិយ៍ នាំគ្នារែអង្គាសគ្រប់ត្រកូល យកមកឆាន់សោះ អ្នកណា មិនពេញចិត្តនឹងរបស់សម្បូណ៌ អ្នកណា មិនគាប់ចិត្តនឹងរបស់ឆ្ងាញ់។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ភិក្ខុណាដែល មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តព្រមទាំងបរិសទ្យ មិនសមបើនឹងរែអង្គាសគ្រប់ត្រកូល យកមកឆាន់សោះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលទេវទត្ត បានឮថា អ្នកព្រមទាំងបរិសទ្យ រែអង្គាសគ្រប់ត្រកូល យកមកបរិភោគ ពិតមែនឬ។ ទេវទត្តក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។បេ។ ព្រះពុទ្ធមានព្រះភាគ ទ្រង់បន្ទោសហើយ ធ្វើនូវធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងអនុញ្ញាតតិកភោជន[2)] គ្រប់ត្រកូល ដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍៣យ៉ាង (គឺ) ដើម្បីនឹងផ្ចាញ់ផ្ចាលនូវបុគ្គលទាំងឡាយ ដែលមិនមានអៀនខ្មាស១ ដើម្បីកិរិយានៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ថាកុំឲ្យពួកភិក្ខុ មានសេចក្តីប្រាថ្នាដ៏លាមក អាស្រ័យបក្ខពួក ហើយនាំគ្នាបំបែកសង្ឃ១ ដើម្បីសេចក្តីអាណិតដល់ត្រកូល១ (វិនយធរ) ត្រូវកាត់សេចក្តីតាមអាបត្តិក្នុងគណភោជនសិក្ខាបទចុះ។

[៤៧] គ្រានោះ ទេវទត្តដើរចូលទៅរកកោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ខណ្ឌទេវិយាបុត្តភិក្ខុ និងសមុទ្ទទត្តភិក្ខុ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ ទៅនឹងកោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ខណ្ឌទេវិយាបុត្តភិក្ខុ និងសមុទ្ទទត្តភិក្ខុថា ម្នាលអាវុសោទាំងឡាយ អ្នកចូរមក

ពួកយើងនឹងធ្វើការបំបែកសង្ឃ និងទំលាយចក្ររបស់ព្រះសមណគោតម។ កាលបើទេវទត្តនិយាយយ៉ាងនេះហើយ កោកាលិកភិក្ខុ ក៏បាននិយាយពាក្យនេះ ទៅនឹងទេវទត្តថា ម្នាលអាវុសោ ព្រះសមណគោតម មានឫទ្ធិច្រើន មានអានុភាពច្រើនណាស់ ពួកយើងនឹងធ្វើការបំបែកសង្ឃ នឹងទំលាយចក្រ របស់ព្រះសមណគោតម ដូចម្តេចបាន។ ទេវទត្តឆ្លើយថា ម្នាលអាវុសោ ចូរអ្នកទាំងឡាយមក ពួកយើងនឹងនាំគ្នាចូលទៅគាល់ព្រះសមណគោតម ហើយទូលសុំវត្ថុ៥ប្រការថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ តែងសរសើរគុណ នៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច អ្នកសន្តោស ដុសខាត់ចិត្ត ទ្រទ្រង់ធុតង្គវត្ត គួរជាទីជ្រះថ្លា មិនសន្សំកិលេសវដ្តៈ ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន វត្ថុ៥ប្រការទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសន្តោស ដើម្បីដុសខាត់ចិត្ត ដើម្បីធុតង្គវត្ត ដើម្បីសេចក្តីជ្រះថ្លា ដើម្បីមិនសន្សំកិលេសវដ្តៈ ដើម្បីប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយ នៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ កាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្តន៍ ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ ប្រើប្រាស់តែសំពត់បង្សុកូលអស់មួយជីវិត ភិក្ខុណាត្រេកអរចំពោះគហបតិចីវរ ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ នៅទៀបគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណាចូលទៅនៅក្នុងទីប្រក់ទីបាំង ភិក្ខុនោះនឹងត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រី និងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រី និងសាច់ ភិក្ខុនោះនឹងត្រូវទោស ព្រះសមណគោតម មុខជាមិនអនុញ្ញាតវត្ថុ៥ប្រការនេះឲ្យទេ ហើយពួកយើងឯង នឹងពន្យល់ជន (ឲ្យត្រេកអរនឹងយើង) ដោយវត្ថុ៥ប្រការនេះ។ កោកាលិកភិក្ខុនិយាយថា ម្នាលអាវុសោ ពួកយើងអាចនឹងធ្វើការទំលាយសង្ឃ ទំលាយចក្ររបស់ព្រះសមណគោតម ដោយវត្ថុ៥ប្រការនេះបាន ម្នាលអាវុសោទាំងឡាយ ដ្បិតមនុស្សទាំងឡាយ ដែលជ្រះថ្លាដោយវត្ថុសៅហ្មង (មានច្រើន)។

[៤៨] គ្រានោះ ទេវទត្តព្រមទាំងបរិសទ្យ ចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ។ លុះទេវទត្តអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះទ្រង់យស តែងសរសើរគុណ នៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ដុសខាត់ចិត្ត ទ្រទ្រង់ធុតង្គវត្ត គួរជាទីជ្រះថ្លា មិនសន្សំកិលេសវដ្តៈ ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន វត្ថុ៥ប្រការទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសន្តោស ដើម្បីដុសខាត់ចិត្ត ដើម្បីធុតង្គវត្ត ដើម្បីសេចក្តីជ្រះថ្លា ដើម្បីមិនសន្សំកិលេសវដ្តៈ ដើម្បីប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយ នៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ កាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្តន៍ ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ ទ្រទ្រង់សំពត់បង្សុកូលអស់មួយជីវិត ភិក្ខុណាត្រេកអរចំពោះគហបតិចីវរ ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ នៅទៀបគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណាចូលទៅនៅក្នុងទីប្រក់ទីបាំង ភិក្ខុនោះនឹងត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រី និងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រី និងសាច់ ភិក្ខុនោះនឹងត្រូវទោស។ ព្រះអង្គ ទ្រង់ត្រាស់ថា កុំទេវទត្ត ភិក្ខុណាចង់នៅក្នុងព្រៃ ចូរឲ្យភិក្ខុនោះនៅចុះ ភិក្ខុណាចង់នៅក្នុងស្រុក ចូរឲ្យភិក្ខុនោះនៅចុះ ភិក្ខុណាចង់ប្រព្រឹត្តបិណ្ឌបាតជាវត្ត ចូរឲ្យភិក្ខុនោះប្រព្រឹត្តចុះ ភិក្ខុណាចង់ត្រេកអរដោយការនិមន្តន៍ ចូរឲ្យភិក្ខុនោះត្រេកអរចុះ ភិក្ខុណាចង់ត្រេកអរនឹងគហបតិចីវរ ចូរឲ្យភិក្ខុនោះត្រេកអរចុះ ម្នាលទេវទត្ត ដ្បិតតថាគតអនុញ្ញាតសេនាសនៈទៀបគល់ឈើអស់កាល៨ខែហើយ ទាំងបានអនុញ្ញាតត្រីសាច់ ដែលបរិសុទ្ធ ដោយទីបំផុត៣ប្រការ គឺមិនបានឃើញ១ មិនបានឮ១ មិនបានរង្កៀស១ (ឲ្យភិក្ខុទាំងឡាយឆាន់បាន)។ លំដាប់នោះ ទេវទត្តត្រេកអររីករាយថា ព្រះមានព្រះភាគ មិនព្រមអនុញ្ញាតវត្ថុ៥ប្រការនេះទេ បានក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ព្រមទាំងបរិសទ្យ ក្រោកចាកអាសនៈ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។

[៤៩] គ្រានោះ ទេវទត្តព្រមទាំងបរិសទ្យ ចូលទៅកាន់ក្រុងរាជគ្រឹះ ពន្យល់អ្នកផងឲ្យយល់ ដោយវត្ថុ៥ប្រការ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ ពួកយើងបានចូលទៅគាល់ព្រះសមណគោតម ហើយទូលសុំវត្ថុ៥ប្រការថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ តែងសរសើរគុណ របស់បុគ្គលជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន វត្ថុ៥ប្រការទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច។បេ។ ដើម្បីប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយ នៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះនឹងត្រូវទោស។បេ។ សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រី និងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រី និងសាច់ ភិក្ខុនោះនឹងត្រូវទោស (ឥឡូវ) វត្ថុ៥ប្រការទាំងនេះ ព្រះសមណគោតមមិនព្រមអនុញ្ញាតឲ្យទេ ពួកយើងទាំងអស់គ្នានោះ នឹងសមាទានប្រព្រឹត្តវត្ថុទាំង៥ប្រការនេះ។

[៥០] បណ្តាមនុស្សទាំងនោះ មនុស្សពួកណាដែលឥតសទ្ធា មិនជ្រះថ្លា ឥតប្រាជ្ញា មនុស្សពួកនោះ និយាយគ្នាយ៉ាងនេះថា ពួកសមណៈ ជាសក្យបុត្តទាំងនោះ ជាអ្នកកំចាត់បង់នូវកិលេស ជាអ្នកប្រព្រឹត្តដុសខាត់ចិត្ត ចំណែកព្រះសមណគោតម ជាអ្នកល្មោភ (ដោយបច្ច័យ មានចីវរជាដើម) តែងត្រិះរិះដើម្បីសេចក្តីល្មោភ (ចីវរជាដើម)។ ចំណែកពួកមនុស្សណា ដែលមានសទ្ធាជ្រះថ្លា ជាបណ្ឌិត មានប្រាជ្ញា មនុស្សពួកនោះ នាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្ត មិនសមបើនឹងខំប្រឹងទំលាយសង្ឃ និងទំលាយចក្រសោះ។ ភិក្ខុទាំងឡាយ បានឮដំណឹងមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ។ ពួកភិក្ខុណា ដែលមានសេចក្តីប្រាថ្នាតិច។បេ។ ពួកភិក្ខុនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើទេវទត្ត ខំប្រឹងទំលាយសង្ឃ និងទំលាយចក្រសោះ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលទេវទត្ត ឮថា អ្នកខំប្រឹងបំបែកសង្ឃ និងបំបែកចក្រ មែនឬ។ ទេវទត្តឆ្លើយថា បពិត្រព្រះមានព្រះភាគ ពិតមែន។ ព្រះអង្គ ទ្រង់ត្រាស់ថា កុំទេវទត្ត អ្នកកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ម្នាលទេវទត្ត ដ្បិតការបំបែកសង្ឃ មានទោសជាទម្ងន់ណាស់ ម្នាលទេវទត្ត ប្រសិនបើអ្នកណាមួយបំបែកសង្ឃ ដែលកំពុងព្រមព្រៀងគ្នា (អ្នកនោះ) រមែងទទួលទោសលាមកអាក្រក់ តាំងនៅអស់១កប្ប ឆេះនៅក្នុងនរកអស់១កប្ប ម្នាលទេវទត្ត បើអ្នកណាមួយធ្វើសង្ឃ ដែលបែកគ្នាហើយ ឲ្យព្រមព្រៀងគ្នាទៅវិញ (អ្នកនោះ) តែងទទួលនូវបុណ្យដ៏ប្រសើរ ហើយនឹងរីករាយក្នុងឋានសួគ៌អស់១កប្ប ណ្ហើយទេវទត្ត អ្នកកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ម្នាលទេវទត្ត ដ្បិតការបំបែកសង្ឃ មានទោសធ្ងន់ណាស់។

[៥១] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ។ ទេវទត្តបានឃើញព្រះអានន្ទដ៏មានអាយុ កំពុងត្រាច់ទៅបិណ្ឌបាត ក្នុងនគររាជគ្រឹះ លុះឃើញហើយ ក៏ចូលទៅជិតព្រះអានន្ទដ៏មានអាយុ លុះចូល

ទៅដល់ហើយ បាននិយាយពាក្យនេះ នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទដ៏មានអាយុ ឥឡូវនេះ ខ្ញុំនឹងធ្វើឧបោសថកម្ម និងធ្វើសង្ឃកម្ម បែកចេញចាកព្រះមានព្រះភាគ បែកចេញចាកភិក្ខុសង្ឃ ចាប់ដើមពីថ្ងៃនេះរៀងទៅ។ ព្រះអានន្ទដ៏មានអាយុ ត្រាច់ទៅបិណ្ឌបាត ក្នុងនគររាជគ្រឹះ បានត្រឡប់មកពីបិណ្ឌបាត ក្នុងខាងក្រោយភត្តហើយ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះអង្គុយក្នុងទីដ៏សមគួរហើយ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងបុព្វណ្ហសម័យថ្ងៃនេះ ខ្ញុំព្រះអង្គ ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ ទេវទត្តបានឃើញខ្ញុំព្រះអង្គ កំពុងត្រាច់បិណ្ឌបាត ក្នុងនគររាជគ្រឹះ លុះឃើញហើយ ចូលមករកខ្ញុំព្រះអង្គ លុះមកដល់ហើយ បាននិយាយពាក្យនេះ នឹងខ្ញុំព្រះអង្គថា នែអាវុសោអានន្ទ ឥឡូវនេះ ខ្ញុំនឹងធ្វើឧបោសថកម្ម និងធ្វើសង្ឃកម្ម បែកចេញចាកព្រះមានព្រះភាគ បែកចេញចាកភិក្ខុសង្ឃ ចាប់ដើមពីថ្ងៃនេះរៀងទៅហើយ បពិត្រព្រះអង្គដ៏ចំរើន ថ្ងៃនេះទំនងជាទេវទត្តបំបែកសង្ឃហើយ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវដំណើរនេះហើយ ទើបទ្រង់បន្លឺនូវឧទានវាចានេះ ក្នុងវេលានោះថា

[៥២]

> អំពើល្អ មនុស្សសប្បុរសធ្វើបានដោយងាយ អំពើល្អ មនុស្សបាប ធ្វើបានដោយក្រ។ អំពើបាប មនុស្សបាប ធ្វើបានដោយងាយ អំពើបាប ព្រះអរិយៈទាំងឡាយ ធ្វើបានដោយក្រ។

ចប់ ភាណវារៈ ទី២។

# (តតិយភាណវារៈ ទី៣)

CS vin.cv.07.03 | ភាគ ទី១១

### (៣. តតិយភាណវារោ)

## (សង្ឃភេទកថា)

CS vin.cv.07.03.01 | ភាគ ទី១១

### (សង្ឃភេទកថា)

[៥៣] គ្រានោះ ទេវទត្តក្រោកចាកអាសនៈក្នុងថ្ងៃឧបោសថនោះ ហើយបង្គាប់ភិក្ខុឲ្យចាប់ស្លាក ដោយពាក្យថា ម្នាលអាវុសោ ពួកយើងបាននាំគ្នាចូលទៅគាល់ព្រះសមណគោតម ទូលសុំវត្ថុ៥ប្រការថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគទ្រង់សរសើរគុណ របស់បុគ្គលអ្នកប្រាថ្នាតិច។ បេ។ ប្រារព្ធសេចក្ដីព្យាយាម ដោយបរិយាយច្រើន បពិត្រព្រះអង្គដ៏ចំរើន វត្ថុ៥ប្រការទាំងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រាថ្នាតិច។បេ។ ដើម្បីប្រារព្ធសេចក្ដីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយ នៅតែក្នុងព្រៃជាវត្តអស់១ជីវិត ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះនឹងត្រូវទោស។បេ។ សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រី និងសាច់អស់១ជីវិត ភិក្ខុណាឆានត្រីនិងសាច់ ភិក្ខុនោះនឹងត្រូវទោស ព្រះសមណគោតម មិនទ្រង់អនុញ្ញាតវត្ថុ៥ប្រការនេះទេ តែពួកយើងទាំងនោះ នឹងនាំគ្នាសមាទាន ប្រព្រឹត្តវត្ថុ៥ប្រការនេះវិញ វត្ថុ៥ប្រការនេះ គួរដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុអង្គនោះចាប់ស្លាកចុះ។

[៥៤] សម័យនោះឯង វជ្ជីបុត្តកភិក្ខុ នៅក្នុងនគរវេសាលី ប្រមាណ៥០០រូប ជាអ្នកទើបនឹងបួសថ្មីផង ជាអ្នកមិនដឹងប្រក្រតី (មិនចេះវិន័យ)ផង។ ភិក្ខុទាំងនោះ គិតគ្នាថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដា ហើយក៏នាំគ្នាចាប់ស្លាក។ លំដាប់នោះ ទេវទត្តបំបែកសង្ឃ ហើយនាំភិក្ខុទាំង៥០០រូប (នោះ) ឆ្ពោះទៅកាន់គយាសីសប្រទេស។

[៥៥] គ្រានោះ ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបអភិវាទ ចំពោះព្រះមានព្រះភាគរួចអង្គុយក្នុងទីដ៏សមគួរ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទេវទត្តបំបែកសង្ឃ ហើយនាំភិក្ខុប្រមាណ៥០០រូប ឆ្ពោះទៅកាន់គយាសីសប្រទេសទៅហើយ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត និងមោគ្គល្លាន អ្នកទាំងឡាយ ទំនងជាមានសេចក្ដីអាណិតភិក្ខុ ដែលទើបនឹងបួសថ្មីទាំងនោះទេដឹង ម្នាលសារីបុត្ត និងមោគ្គល្លាន ចូរអ្នកទាំងឡាយនាំគ្នាទៅចុះ ភិក្ខុទាំងនោះ គង់ដល់នូវសេចក្ដីវិនាស ក្នុងកាលជាអនាគត។ ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ហើយក្រោកចាកអាសនៈ ក្រាបបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយដើរសំដៅទៅគយាសីសប្រទេស។

[៥៦] សម័យនោះ មានភិក្ខុមួយរូបឈរយំ នៅជិតព្រះមានព្រះភាគ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់តម្រាស់នេះ នឹងភិក្ខុនោះថា ម្នាលភិក្ខុ ហេតុអ្វីក៏អ្នកយំ។ ភិក្ខុនោះ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន អគ្គសាវ័ករបស់ព្រះមានព្រះភាគ គឺព្រះសារីបុត្ត និងព្រះមោគ្គល្លានទាំងនោះ ពេញចិត្តនឹងធម៌ទេវទត្តហើយ បានជាទៅកាន់សំណាក់ទេវទត្ត។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ សារីបុត្ត និងមោគ្គល្លាន ពេញចិត្តនឹងធម៌ទេវទត្ត ដោយឧបាយណា ឧបាយនោះ មិនមែនជាហេតុ មិនមែនជាឱកាសឡើយ ឯសារីបុត្ត និងមោគ្គល្លានទៅនោះ ដើម្បីពន្យល់ភិក្ខុផងគ្នាទេតើ។

[៥៧] ចួនសម័យនោះឯង ទេវទត្តមានបរិសទ្យជាច្រើនចោមរោមត្រៀបត្រា កំពុងអង្គុយសំដែងធម៌។ ទេវទត្តបានឃើញព្រះសារីបុត្ត និងព្រះមោគ្គល្លាន ដើរមកអំពីចម្ងាយលឹមៗ លុះឃើញហើយ ក៏ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកមើលចុះ ធម៌យើងសំដែងហើយ

ដោយល្អទាល់តែអគ្គសាវ័ករបស់ព្រះសមណគោតម គឺសារីបុត្ត និងមោគ្គល្លាន (ពេញចិត្តនឹងធម៌យើងហើយ បានជា) មកកាន់សំណាក់យើង។ កាលបើទេវទត្តនិយាយយ៉ាងនេះហើយ កោកាលិកភិក្ខុ ក៏បាននិយាយពាក្យនេះនឹងទេវទត្តថា នែអាវុសោទេវទត្ត អ្នកកុំទុកចិត្តសារីបុត្ត និងមោគ្គល្លានឡើយ (ដ្បិត) សារីបុត្ត និងមោគ្គល្លាន(នេះ) ជាអ្នកប្រាថ្នាលាមក លុះក្នុងអំណាចសេចក្តីប្រាថ្នាអាក្រក់។ ទេវទត្តឆ្លើយថា មិនអ្វីទេ អាវុសោ សារីបុត្ត និងមោគ្គល្លាននោះ មកដោយស្រួលទេ ព្រោះហេតុតែពេញចិត្តនឹងធម៌របស់យើងហើយ។ ទេវទត្តនិមន្តព្រះសារីបុត្តដ៏មានអាយុដោយអាសនៈពាក់កណ្តាលថា នែអាវុសោសារីបុត្ត សូមលោកនិមន្តមកគង់លើអាសនៈនេះចុះ។ ព្រះសារីបុត្តដ៏មានអាយុនិយាយថា ណ្ហើយ អាវុសោ ដូច្នេះ រួចកាន់យកអាសនៈមួយ ហើយអង្គុយក្នុងទីដ៏សមគួរ។ ឯព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏កាន់យកអាសនៈមួយ ហើយអង្គុយក្នុងទីសមគួរ។ គ្រានោះ ទេវទត្តបានពន្យល់ភិក្ខុទាំងឡាយច្រើន ឲ្យយល់ព្រម ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យត្រេកអររីករាយ ដោយធម្មីកថាទាល់តែយប់ជ្រៅ ទើបនិមន្តព្រះសារីបុត្តដ៏មានអាយុថា នែអាវុសោសារីបុត្ត ភិក្ខុសង្ឃប្រាសចាកថីនមិទ្ធហើយ ម្នាលអាវុសោសារីបុត្ត ចូរអ្នកជួយបំភ្លឺធម្មីកថា ដល់ភិក្ខុទាំងឡាយផងចុះ ដ្បិតខ្ញុំឈឺខ្នងណាស់ ខ្ញុំនឹងសម្រាកបន្តិច។ ព្រះសារីបុត្តដ៏មានអាយុ ទទួលពាក្យទេវទត្តថា អើអាវុសោ។ ទេវទត្តក៏ក្រាលសង្ឃាដិ៤ជាន់ សម្រេចនូវសេយ្យា (សិង) ផ្អៀងទៅខាងស្តាំ។ ទេវទត្តនោះ ក៏ចួនជាអស់កំឡាំង ភ្លេចភ្លាំងស្មារតី មិនដឹងខ្លួនប្រាណ ក៏ដេកលក់មួយរំពេចទៅ។

[៥៨] គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ បានទូន្មានប្រៀនប្រដៅភិក្ខុទាំងឡាយ ដោយធម្មីកថា ជាអាទេសនាបាដិហារ្យ[3] និងអនុសាសនីបាដិហារ្យ[4] ចំណែកខាងព្រះមោគ្គល្លានដ៏មានអាយុ ក៏ទូន្មានប្រៀនប្រដៅភិក្ខុទាំងឡាយ ដោយធម្មីកថា ជាឥទ្ធិប្បាដិហារ្យ[5] និងអនុសាសនីបាដិហារ្យ។ លំដាប់នោះ ពួកភិក្ខុទាំងនោះ ដែលព្រះសារីបុត្តដ៏មានអាយុ ទូន្មានប្រៀនប្រដៅ (ដោយធម្មីកថា) ជាអាទេសនាបាដិហារ្យ និងអនុសាសនីបាដិហារ្យ ដែលព្រះមោគ្គល្លានដ៏មានអាយុ ទូន្មានប្រៀនប្រដៅ (ដោយធម្មីកថា) ជាឥទ្ធិប្បាដិហារ្យ និងអនុសាសនីបាដិហារ្យ ក៏កើតធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល (ដោយបញ្ញាថា) ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា។ ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោ ពួកយើងនាំគ្នាទៅកាន់សំណាក់ព្រះមានព្រះភាគ លោកអង្គណា ចូលចិត្តនឹងធម៌របស់ព្រះមានព្រះភាគនោះ ចូរលោកអង្គនោះនិមន្តមក។ ទើបព្រះសារីបុត្ត និងព្រះមោគ្គល្លាននាំភិក្ខុទាំង៥០០រូបនោះ ចូលសំដៅទៅវត្តវេឡុវន។ លំដាប់នោះ កោកាលិកភិក្ខុ ដាស់ទេវទត្តឲ្យក្រោកឡើងថា នែអាវុសោទេវទត្ត ចូរអ្នកក្រោកឡើង ដ្បិតសារីបុត្ត និងមោគ្គល្លាន នាំភិក្ខុទាំងនោះទៅហើយ ម្នាលអាវុសោទេវទត្ត យើងបាននិយាយប្រាប់អ្នកថា នែទេវទត្តដ៏មានអាយុ អ្នកកុំទុកចិត្តសារីបុត្ត និងមោគ្គល្លានឡើយ ដ្បិតសារីបុត្ត និងមោគ្គល្លាន (នោះ) ជាមនុស្សប្រាថ្នាលាមក លុះក្នុងអំណាចសេចក្តីប្រាថ្នាអាក្រក់ ឥឡូវឃើញទេហ៍។ លំដាប់នោះ ទេវទត្តក៏ស្រាប់តែក្អួតឈាមក្តៅ ចេញមកពីមាត់ក្នុងទីនោះ។

[៥៩] គ្រានោះ ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះសារីបុត្តដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយ ដែលជាអ្នកប្រព្រឹត្តតាមភិក្ខុ ដែលបំបែកសង្ឃ ឧបសម្បទាជាថ្មីទៀត។ ព្រះអង្គ ទ្រង់ត្រាស់ថា ណ្ហើយសារីបុត្ត អ្នកកុំចូលចិត្តនឹងការឲ្យពួកភិក្ខុជាអ្នកប្រព្រឹត្តតាមភិក្ខុ ដែលបំបែកសង្ឃ ទទួលឧបសម្បទាជាថ្មីទៀតឡើយ ម្នាលសារីបុត្ត បើដូច្នោះ ចូរអ្នកឲ្យភិក្ខុដែលប្រព្រឹត្តតាមភិក្ខុ ដែលបំបែកសង្ឃ (នោះ) សំដែងអាបត្តិថុល្លច្ច័យចេញចុះ ម្នាលសារីបុត្ត ចុះទេវទត្តប្រតិបត្តិចំពោះអ្នកដូចម្តេច។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ បានពន្យល់ភិក្ខុទាំងឡាយ ឲ្យយល់ប្រយោជន៍ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យត្រេកអរ ឲ្យរីករាយដោយធម្មីកថា ទាល់តែយប់ជ្រៅ ទើបបានអារាធនាខ្ញុំព្រះអង្គថា ម្នាលសារីបុត្ត ភិក្ខុសង្ឃប្រាសចាកសេចក្តីងុយងោកអស់ហើយ ម្នាលសារីបុត្ត ចូរអ្នកបំភ្លឺធម្មីកថា ចំពោះភិក្ខុទាំងឡាយនោះផងចុះ ដ្បិតតថាគតឈឺខ្នង តថាគតនឹងឈប់សម្រាកបន្តិច រឿងនេះយ៉ាងណា បពិត្រព្រះអង្គដ៏ចំរើន ទេវទត្ត ក៏ប្រតិបត្តិយ៉ាងនោះដែរ។

[៦០] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ មានដំរីច្រើន នៅអាស្រ័យនឹងស្រះធំ១ ជិតព្រៃរំលោង។ ដំរីទាំងនោះ ចុះកាន់ស្រះនោះ ដកយកក្រអៅឈូកដោយប្រមោយ លាងសម្អាត ហើយទំពាលេបរបស់ដែលគ្មានភក់នោះទៅ។ ក្រអៅឈូកនោះ ក៏នាំឲ្យមានពណ៌សម្បុរ និងកំឡាំងដល់ដំរីទាំងនោះ។ ដំរីទាំងនោះ ក៏មិនបានដល់នូវសេចក្តីស្លាប់ផង នូវសេចក្តីទុក្ខ ជិតនឹងស្លាប់ផង ព្រោះការទំពាស៊ីក្រអៅឈូកនោះទេ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងពួកដំរីក្មេង គឺដំរីស្ទាវ និងកូនដំរី តែងយកតម្រាប់ដំរីធំទាំងនោះ ក៏នាំគ្នាចុះកាន់ស្រះនោះ ហើយដកយកក្រអៅឈូកដោយប្រមោយ តែមិនបានលាងទឹកឲ្យស្អាត ហើយក៏ទំពាលេបទាំងភក់ទៅ។ ក្រអៅឈូកនោះ ក៏មិននាំឲ្យកើតសម្បុរ និងកំឡាំងដល់ដំរីទាំងនោះឡើយ។ (ដំរីស្ទាវ និងកូនដំរីទាំងឡាយ) តែងដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះការទំពាស៊ីរបស់មិនស្អាតនោះជាហេតុ (យ៉ាងណាមិញ) ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ដែលធ្វើតាមតថាគត នឹងដល់សេចក្តីលំបាក ស្លាប់អសារឥតការ យ៉ាងនោះដែរ។

[៦១]

កាលដំរីធំរក្សាហ្វូង គាស់រំលើងផែនដី ទំពាស៊ីក្រអៅឈូក្នុងស្រះ កូនដំរីធ្វើតាមដំរីធំនោះ ក៏ទំពាស៊ីក្រអៅឈូកទាំងភក់ ដល់នូវសេចក្តីស្លាប់ យ៉ាងណាមិញ ទេវទត្ត ដែលធ្វើតាមតថាគត ក៏ដល់សេចក្តីលំបាក ហើយនិងស្លាប់ យ៉ាងនោះដែរ។

[៦២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គ៨ប្រការ ទើបគួរដល់នូវទូតកម្មបាន។ អង្គ៨ប្រការនោះ គឺអ្វីខ្លះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្តាប់បានដោយខ្លួនឯង១ ញុំាងបុគ្គលដទៃឲ្យស្តាប់បាន១ បានរៀនយក១ ចេះចាំទុកស្ទាត់១ ដឹងសេចក្តីដោយខ្លួនឯង១ ញុំាងបុគ្គលដទៃឲ្យដឹងសេចក្តីនោះ១ ឈ្លាសវៃក្នុងហេតុដែលគួរ និងមិនគួរ១ ជាអ្នកមិនធ្វើនូវជំលោះ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ៨ប្រការនេះឯង ទើបគួរដល់នូវ ទូតកម្ម បាន។

[៦៣] ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយអង្គ៨ប្រការ ទើបគួរដល់នូវទូតកម្មបាន។ អង្គ៨ប្រការនោះគឺអ្វីខ្លះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សារីបុត្ត ជាអ្នកស្តាប់បានដោយខ្លួនឯង១ ញុំាងបុគ្គលដទៃឲ្យស្តាប់បាន១ បានរៀនយក១ ចេះចាំទុកស្ទាត់១ ដឹងសេចក្តីដោយខ្លួនឯង១ ញុំាងបុគ្គលដទៃឲ្យដឹងសេចក្តី១ ឈ្លាសវាងវៃក្នុងហេតុដែលគួរ និងមិនគួរ១ ជាអ្នកមិនធ្វើនូវជំលោះ១ ម្នាលភិក្ខុទាំងឡាយ សារីបុត្ត ប្រកបដោយអង្គ៨ប្រការនេះឯង ទើបគួរដល់នូវ ទូតកម្មបាន។

[៦៤]

ភិក្ខុណា ទៅដល់បរិសទ្យដែលពោលពាក្យបង្គ្រប ហើយមិនញាប់ញ័រ១ មិនបំភ្លេចពាក្យ១ មិនលាក់ពាក្យបណ្តាំគេ១ ប្រាប់មិនឲ្យច្រឡំពាក្យ១ គេសួរមកហើយ មិនខឹង១ ភិក្ខុប្រាកដដូច្នោះ នោះឯង ទើបគួរដល់ទូតកម្មបាន។

[៦៥] ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវអសទ្ធម្ម (លោកធម៌) ទាំង៨ប្រការ គ្របសង្កត់ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អសទ្ធម្ម៨ប្រការតើដូចម្តេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវលាភគ្របសង្កត់ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ម្នាលភិក្ខុទាំងឡាយ ព្រោះមិនមានលាភ។បេ។ ម្នាលភិក្ខុទាំងឡាយ ព្រោះយស។បេ។ ម្នាលភិក្ខុទាំងឡាយ ព្រោះមិនមានយស។បេ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសក្ការៈ។បេ។ ម្នាលភិក្ខុទាំងឡាយ ព្រោះមិនមានសក្ការៈ។បេ។ ម្នាលភិក្ខុទាំងឡាយ ព្រោះខ្លួនមានសេចក្តីប្រាថ្នាអាក្រក់។បេ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវភាវៈជាបាបមិត្តគ្របសង្កត់ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវអសទ្ធម្មទាំង៨ប្រការនេះ គ្របសង្កត់ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសង្កត់សង្កិនញាំញី នូវលាភដែលកើតឡើងហើយ នូវអលាភដែលកើតឡើងហើយ។បេ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាអាក្រក់ដែលកើតឡើងហើយ។បេ។ គ្របសង្កត់នូវភាវៈជាបាបមិត្តដែលកើតឡើងហើយ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសង្កត់សង្កិន នូវលាភដែលកើតឡើងហើយ នូវអលាភដែលកើតឡើងហើយ។បេ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាអាក្រក់ដែលកើតឡើងហើយ។បេ។ គ្របសង្កត់នូវភាវៈជាបាបមិត្តដែលកើតឡើងហើយ ព្រោះអាស្រ័យប្រយោជន៍ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា បើភិក្ខុមិនបានសង្កត់សង្កិននូវលាភណា ដែលកើតឡើងហើយ អាសវក្កិលេសទាំងឡាយ គឺសេចក្តីចង្អៀតចង្អល់ និងសេចក្តីក្តៅក្រហាយ គប្បីកើតឡើង (ដល់ភិក្ខុនោះ) កាលបើភិក្ខុបានសង្កត់សង្កិនញាំញីនូវលាភដែលកើតឡើងហើយយ៉ាងនេះ អាសវក្កិលេសទាំងនោះ គឺសេចក្តីចង្អៀតចង្អល់ និងសេចក្តីក្តៅក្រហាយ រមែងមិនមាន (ដល់ភិក្ខុនោះ) ម្នាលភិក្ខុទាំងឡាយ ព្រោះថា បើភិក្ខុនោះ មិនសង្កត់សង្កិន នូវអលាភណា ដែលកើតឡើងហើយ។បេ។ នូវយស ដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ សេចក្តីប្រាថ្នាអាក្រក់ ដែលកើតឡើងហើយ។បេ។ កាលភិក្ខុមិនសង្កត់សង្កិននូវភាវៈជាបាបមិត្ត ដែលកើតឡើងហើយទេ អាសវក្កិលេសទាំងឡាយ គឺសេចក្តីចង្អៀតចង្អល់ និងសេចក្តីក្តៅក្រហាយ គប្បីកើតឡើង ដល់ភិក្ខុនោះ កាលបើភិក្ខុបានសង្កត់សង្កិនញាំញី នូវអលាភដែលកើតឡើងហើយ នូវភាវៈជាបាបមិត្តដែលកើតឡើងហើយ អាសវក្កិលេសទាំងនោះ គឺសេចក្តីចង្អៀតចង្អល់ និងសេចក្តីក្តៅក្រហាយ រមែងមិនមាន (ដល់ភិក្ខុនោះ) យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសង្កត់សង្កិន នូវលាភដែលកើតឡើងហើយ នូវអលាភដែលកើតឡើងហើយ។បេ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាអាក្រក់ដែលកើតឡើងហើយ។បេ។ គ្របសង្កត់នូវភាវៈជាបាបមិត្តដែលកើតឡើងហើយ ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូច្នេះ ក្នុងសាសនានេះ គួរយើងទាំងឡាយ សង្កត់សង្កិន ញាំញី នូវលាភដែលកើតឡើងហើយ។ គួរយើងទាំងឡាយ សង្កត់សង្កិន ញាំញី នូវអលាភដែលកើតឡើងហើយ។បេ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាអាក្រក់ដែលកើតឡើងហើយ។បេ។ គ្របសង្កត់នូវភាវៈជាបាបមិត្ត ដែលកើតឡើងហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ។

[៦៦] ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវអសទ្ធម្ម៣ប្រការ គ្របសង្កត់ មានចិត្តប្រែប្រួល ជាបុគ្គលទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប កែខ្លួនលែងបាន។ អសទ្ធម្ម៣ប្រការតើដូចម្តេចខ្លះ។ (អសទ្ធម្ម៣ប្រការនោះគឺ) សេចក្តីប្រាថ្នាអាក្រក់១ ភាវៈជាបាបមិត្ត១ ដល់នូវសេចក្តីវាយមាឃ ក្នុងពាក់កណ្តាល ដោយកិរិយាបាននូវគុណវិសេស គឺត្រឹមតែឈានដ៏ថោកទាប១ ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវអសទ្ធម្មទាំង៣ប្រការនេះ គ្របសង្កត់ហើយ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប។

[៦៧]

បុគ្គលណាមួយ ជាអ្នកប្រាថ្នាលាមក សូមកុំកើតក្នុងលោកឡើយ ដំណើរនៃបុគ្គលមានសេចក្តីប្រាថ្នាលាមកទាំងឡាយ យ៉ាងណា អ្នកទាំងឡាយ ចូរដឹងដំណើរនោះ ដោយហេតុនេះចុះ។ តថាគតបានឮថា ទេវទត្ត អ្នកផងឲ្យឈ្មោះថា ជាបណ្ឌិត អ្នកផងសន្មតថា ជាអ្នកមានចិត្តអប់រំហើយ ទេវទត្តហាក់ដូចជាកាលរុងរឿង ដោយយសឋិតនៅ។ ទេវទត្តនោះឯង តែងសន្សំសេចក្តីប្រមាទរឿយៗ ហើយបៀតបៀនតថាគតនោះ ក៏ធ្លាក់ទៅរងទុក្ខក្នុងនរកអវិចី មានទ្វារ៤ ដែលគួរខ្លាច។ សេចក្តីពិតថា នរណាប្រទូស្តចំពោះបុគ្គលដែលមិនបានប្រទូស្ត មិនបានធ្វើអំពើអាក្រក់ បាប តែងពាល់ត្រូវនូវបុគ្គល ដែលមានចិត្តប្រទូស្តអ្នកមិនអើពើនោះវិញ។ អ្នកណាប៉ងប្រទូស្តនូវសមុទ្រ ដោយថ្នាំពិស១ក្អម អ្នកនោះឯង មិនអាចនឹងប្រទូស្តដោយថ្នាំពិស១ក្អមនោះបានឡើយ ព្រោះថា សមុទ្រធំទូលាយ គួរឲ្យស្ញប់ស្ញែង (សេចក្តីនេះ) មានឧបមាយ៉ាងណា មានឧបមេយ្យ ដូចជានរណាប្រទូស្តនឹងតថាគត ដែលមាន

ចិត្តស្មើ មានចិត្តស្ងប់ ដោយពាក្យពោលទោស ពាក្យជាទោសនោះ មិនបានលូតលាស់ ចំរើនឡើងក្នុងតថាគតនោះឡើយ។ ភិក្ខុដើរទៅតាមតម្រាយនៃមិត្តណា គប្បីដល់នូវកិរិយាក្ស័យទៅនៃទុក្ខបាន ភិក្ខុជាបណ្ឌិត គប្បីធ្វើនូវសេចក្ដីស្និទ្ធស្នាលនឹងមិត្តដូច្នោះផង គប្បីសេពគប់នឹងមិត្តនោះផង។

## (ឧបាលិបញ្ហា)

CS vin.cv.07.03.02 | ភាគ ទី១១

### (ឧបាលិបញ្ហា)

[៦៨] គ្រានោះ ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សេចក្ដីប្រេះឆានៃសង្ឃ ដែលហៅថា សង្ឃរាជី បពិត្រព្រះអង្គដ៏ចំរើន សេចក្ដីប្រេះឆានៃសង្ឃ ដែលមិនមែនជាសង្ឃភេទ ដោយហេតុប៉ុន្មានយ៉ាង សេចក្ដីប្រេះឆានៃសង្ឃផង សង្ឃភេទផង ដោយហេតុប៉ុន្មានយ៉ាង។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង[6] មួយរូប ភិក្ខុប៉ែកម្ខាង[7] ពីររូប ឯភិក្ខុគំរប់៤[8]) សូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្ដីប្រេះឆានៃសង្ឃ មិនមែនជាសង្ឃភេទទេ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាងពីររូប ភិក្ខុប៉ែកម្ខាងពីររូប ឯភិក្ខុជាគំរប់៥ សូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្ដីប្រេះឆានៃសង្ឃ មិនមែនជាសង្ឃភេទ។បេ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាងពីររូប ភិក្ខុប៉ែកម្ខាងបីរូប ឯភិក្ខុជាគំរប់៦ សូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្ដីប្រេះឆានៃសង្ឃ មិនមែនជាសង្ឃភេទទេ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង៣រូប ភិក្ខុប៉ែកម្ខាង៣រូប ឯភិក្ខុជាគំរប់៧ សូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្ដីប្រេះឆានៃសង្ឃ មិនមែនជាសង្ឃភេទទេ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង៣រូប ភិក្ខុប៉ែកម្ខាង៤រូប ឯភិក្ខុជាគំរប់៨ សូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្ដីប្រេះឆានៃសង្ឃ មិនមែនជាសង្ឃភេទទេ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង៤រូប ភិក្ខុប៉ែកម្ខាង៤រូប ឯភិក្ខុជាគំរប់៩ សូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្ដីប្រេះឆានៃសង្ឃផង ហៅថា សង្ឃភេទផង។ ម្នាលឧបាលិ សេចក្ដីប្រេះឆានៃសង្ឃ និងសង្ឃភេទ រមែងមានដល់ភិក្ខុ៩រូបក៏មាន ដល់ភិក្ខុច្រើនជាង៩រូបទៅក៏មាន។ ម្នាលឧបាលិ ភិក្ខុនី មិនឈ្មោះថាបំបែកសង្ឃទេ តែបានឈ្មោះថា ព្យាយាមដើម្បីបំបែក(សង្ឃ) សិក្ខមានា ក៏មិនឈ្មោះថា បំបែកសង្ឃ សាមណេរ ក៏មិនឈ្មោះថា បំបែកសង្ឃ សាមណេរី ក៏មិនឈ្មោះថា បំបែកសង្ឃ ឧបាសក ក៏មិនឈ្មោះថា បំបែកសង្ឃ ឧបាសិកា ក៏មិនឈ្មោះថា បំបែកសង្ឃ តែបានឈ្មោះថា ព្យាយាមដើម្បីបំបែកសង្ឃ។ ម្នាលឧបាលិ លុះតែភិក្ខុ ដែលមានខ្លួនជាប្រក្រតី[9] មានសំវាសស្មើគ្នា ឋិតនៅក្នុងសីមាជាមួយគ្នា ទើបឈ្មោះថា បំបែកសង្ឃ។

[៦៩] ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការបំបែកសង្ឃ ព្រះអង្គត្រាស់ថា សង្ឃភេទ បពិត្រព្រះអង្គដ៏ចំរើន ចុះសង្ឃដែលបែកធ្លាយ ដោយហេតុប៉ុន្មានយ៉ាង។ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុទាំងឡាយក្នុងសាសនានេះ សំដែងសភាពមិនមែនធម៌ ថាជាធម៌ សំដែងធម៌ ថាមិនមែនជាធម៌ សំដែងសភាពមិនមែនវិន័យ ថាជាវិន័យ សំដែងវិន័យ ថាមិនមែនជាវិន័យ សំដែងធម៌វិន័យ ដែលតថាគតមិនបានសំដែង មិនបានពោល ថាតថាគតបានសំដែង បានពោល សំដែងធម៌វិន័យ ដែលតថាគតបានសំដែង បានពោល ថាតថាគតមិនបានសំដែង មិនបានពោលវិញ សំដែងវត្ត ដែលតថាគតមិនបានសន្សំមកហើយ ថាជាវត្ត ដែលតថាគតសន្សំមកហើយ សំដែងវត្ត ដែលតថាគតបានសន្សំមកហើយ ថាជាវត្ត ដែលតថាគតមិនបានសន្សំមកទេ សំដែងសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្ត ថាតថាគតបានបញ្ញត្ត សំដែងសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ថាតថាគតមិនបានបញ្ញត្តទេ សំដែងអនាបត្តិ ថាជាអាបត្តិ សំដែងអាបត្តិ ថាជាអនាបត្តិ សំដែងលហុកាបត្តិ ថាជាគរុកាបត្តិ សំដែងគរុកាបត្តិ ថាជាលហុកាបត្តិ សំដែងសាវសេសាបត្តិ[10] ថាជាអនវសេសាបត្តិ[11] សំដែងអនវសេសាបត្តិ ថាជាសាវសេសាបត្តិ សំដែងទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុទាំងនោះ ក៏ទង់ទាញ កៀរគរ (បរិសទ្យ) ហើយធ្វើឧបោសថផ្សេងពីគ្នា ធ្វើបវារណាផ្សេងពីគ្នា ធ្វើសង្ឃកម្មផ្សេងពីគ្នា ដោយវត្ថុ១៨ប្រការនេះឯង ម្នាលឧបាលិ សង្ឃដែលបែកធ្លាយ ដោយហេតុប៉ុណ្ណេះឯង។

[៧០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សេចក្ដីព្រមព្រៀងនៃសង្ឃ ព្រះអង្គត្រាស់ថា សង្ឃសាមគ្គី បពិត្រព្រះអង្គដ៏ចំរើន សង្ឃដែលព្រមព្រៀងគ្នា ដោយហេតុប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុទាំងឡាយក្នុងសាសនានេះ សំដែងសភាពមិនមែនធម៌ ថាមិនមែនធម៌ សំដែងធម៌ ថាជាធម៌ សំដែងសភាពមិនមែនវិន័យ ថាមិនមែនជាវិន័យ សំដែងវិន័យ ថាជាវិន័យ សំដែងធម៌វិន័យ ដែលតថាគតមិនបានសំដែង មិនបានពោល ថាតថាគតមិនបានសំដែង មិនបានពោលទេ សំដែងធម៌វិន័យ ដែលតថាគតបានសំដែង បានពោល ថាតថាគតបានសំដែង បានពោល សំដែងវត្ត ដែលតថាគតមិនធ្លាប់សន្សំមក ថាជាវត្ត ដែលតថាគតមិនធ្លាប់សន្សំមកទេ សំដែងវត្ត ដែលតថាគតធ្លាប់សន្សំមក ថាជាវត្ត ដែលតថាគតធ្លាប់សន្សំមក សំដែងសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្ត ថាតថាគតមិនបានបញ្ញត្តទេ សំដែងសិក្ខាបទ ដែលតថាគតបានបញ្ញត្ត ថាតថាគតបានបញ្ញត្ត សំដែងអនាបត្តិ ថាជាអនាបត្តិ សំដែងអាបត្តិ ថាជាអាបត្តិ សំដែងលហុកាបត្តិ ថាជាលហុកាបត្តិ សំដែងគរុកាបត្តិ ថាជាគរុកាបត្តិ សំដែងសាវសេសាបត្តិ ថាជាសាវសេសាបត្តិ សំដែងអនវសេសាបត្តិ ថាជាអនវសេសាបត្តិ សំដែងទុដ្ឋុល្លាបត្តិ (អាបត្តិបារាជិក ឬសង្ឃាទិសេស) ថាជាទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ (អាបត្តិ៥កង) ថាជាអទុដ្ឋុល្លាបត្តិ ភិក្ខុទាំងនោះ មិន

ទង់ទាញ មិនកៀរគរយក (បរិសទ្យ) ហើយមិនធ្វើឧបោសថផ្សេងគ្នា មិនធ្វើបវារណាផ្សេងគ្នា មិនធ្វើសង្ឃកម្មផ្សេងគ្នា ដោយវត្ថុ១៨នេះ ម្នាលឧបាលិ សង្ឃឈ្មោះថា ព្រមព្រៀងគ្នា ដោយហេតុប៉ុណ្ណេះឯង។

[៧១] ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុបំបែកសង្ឃ ដែលកំពុងព្រមព្រៀងគ្នា ភិក្ខុនោះ រមែងបាននូវផលដូចម្តេចខ្លះ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុបំបែកសង្ឃ ដែលកំពុងព្រមព្រៀងគ្នា រមែងបាននូវផលដ៏ខ្លោចផ្សា តាំងនៅអស់១កប្ប ឆេះនៅក្នុងនរកអស់១កប្ប។

[៧២]

ភិក្ខុបំបែកសង្ឃ ត្រេកអរក្នុងពួក មិនដំកល់ខ្លួននៅក្នុងធម៌ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់១កប្ប រមែងឃ្លាតចាកធម៌ ជាគ្រឿងក្សេមចាកយោគៈ។ ភិក្ខុបំបែកសង្ឃ ដែលកំពុងព្រមព្រៀងគ្នា រមែងឆេះនៅក្នុងនរកអស់១កប្ប។

[៧៣] ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុ ជាអ្នកសង្គ្រួបសង្គ្រួមសង្ឃ ដែលបែកគ្នាហើយ ឲ្យបានព្រមព្រៀងគ្នាទៅវិញ រមែងបាននូវផលដូចម្តេចខ្លះ។ ព្រះអង្គ ទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុអ្នកសង្គ្រួបសង្គ្រួមសង្ឃ ដែលបែកគ្នាហើយ ឲ្យបានព្រមព្រៀងគ្នាទៅវិញ រមែងបាននូវបុណ្យដ៏ប្រសើរ រីករាយក្នុងឋានសួគ៌អស់១កប្ប។

[៧៤]

សេចក្តីព្រមព្រៀងនៃពួក តែងនាំសេចក្តីសុខមកឲ្យ ភិក្ខុអ្នកអនុគ្រោះ ដល់បុគ្គលមានសេចក្តីព្រមព្រៀងគ្នាទាំងឡាយក្តី ជាអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀងក្តី បានដំកល់ខ្លួនក្នុងធម៌ក្តី (ភិក្ខុនោះ) មិនឃ្លាតចាកធម៌ ជាគ្រឿងក្សេមចាកយោគៈឡើយ។ ភិក្ខុអ្នកសង្គ្រួបសង្គ្រួមសង្ឃ ឲ្យបានព្រមព្រៀងគ្នា តែងរីករាយក្នុងឋានសួគ៌ អស់១កប្ប។

[៧៥] ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកបំបែកសង្ឃ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប កែខ្លួនលែងបាន មានឬទេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប កែខ្លួនលែងបាននោះ មាន។ ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុអ្នកបំបែកសង្ឃ មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់១កប្ប នៅកែខ្លួនបាន មានដែរឬ។ ព្រះអង្គ ទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃ មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់១កប្ប នៅកែខ្លួនបាន ក៏មានដែរ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុអ្នកបំបែកសង្ឃ ទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប លែងកែខ្លួនបាន ដូចម្តេចខ្លះ។ ព្រះអង្គ ទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងសភាពមិនមែនជាធម៌ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនជាធម៌ បិទបាំងទិដ្ឋិ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង តែងកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ពាក្យដទៃនៅមានទៀត ភិក្ខុសំដែងសភាពមិនមែនធម៌ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែកសង្ឃ ថាជាធម៌ បិទបាំងទិដ្ឋិ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ពាក្យដទៃនៅមានទៀត ភិក្ខុសំដែងសភាពមិនមែនធម៌ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនជាធម៌ មានសេចក្តីសង្ស័យក្នុងការបំបែក ហើយបិទបាំងទិដ្ឋិ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ពាក្យដទៃនៅមានទៀត ភិក្ខុសំដែងសភាពមិនមែនធម៌ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនជាធម៌។បេ។ មានសេចក្តីយល់ឃើញក្នុងធម៌នោះ មានសេចក្តីសង្ស័យក្នុងការបំបែក។បេ។ មានសេចក្តីសង្ស័យក្នុងធម៌នោះ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនជាធម៌ មានសេចក្តីសង្ស័យក្នុងធម៌នោះ មានសេចក្តីយល់ឃើញក្នុងការបំបែកថាជាធម៌ មានសេចក្តីសង្ស័យក្នុងធម៌នោះ មានសេចក្តីសង្ស័យក្នុងការបំបែក ហើយបិទបាំងទិដ្ឋិ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ពាក្យដទៃនៅមានទៀត ភិក្ខុសំដែងធម៌ ថាមិនមែនធម៌។បេ។ សំដែងសភាវៈមិនមែនវិន័យ ថាជាវិន័យ សំដែងវិន័យ ថាមិនមែនវិន័យ សំដែងធម៌វិន័យ ដែលតថាគតមិនបានសំដែង មិនបានពោល ថាតថាគតបានសំដែង បានពោល សំដែងធម៌វិន័យ ដែលតថាគតបានសំដែង បានពោល ថាតថាគតមិនបានសំដែង មិនបានពោលទេ សំដែងវត្ត ដែលតថាគតមិនបានសន្សំមក ថាជាវត្តដែលតថាគតបានសន្សំមក សំដែងវត្តដែលតថាគតបានសន្សំមក ថាជាវត្ត ដែលតថាគតមិនបានសន្សំមកទេ សំដែងសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្ត ថាតថាគតបានបញ្ញត្ត សំដែងសិក្ខាបទ ដែលតថាគតបានបញ្ញត្ត ថាតថាគតមិនបានបញ្ញត្តទេ សំដែងអនាបត្តិ ថាជាអាបត្តិ សំដែងអាបត្តិ ថាជាអនាបត្តិ សំដែងលហុកាបត្តិ ថាជាគរុកាបត្តិ សំដែងគរុកាបត្តិ ថាជាលហុកាបត្តិ សំដែងសាវសេសាបត្តិ ថាជាអនវសេសាបត្តិ សំដែងអនវសេសាបត្តិ ថា

ជាសាវសេសាបត្តិ សំដែងទុដ្ឋុល្លាបត្តិ ថាមិនមែនជាទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ មានសេចក្តីយល់ឃើញធម៌នោះ ថាមិនមែនធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនធម៌ មានសេចក្តីសង្ស័យក្នុងការបំបែក មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាជាធម៌ មានសេចក្តីសង្ស័យ ក្នុងការបំបែក មានសេចក្តីសង្ស័យក្នុងធម៌នោះ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនធម៌ មានសេចក្តីសង្ស័យក្នុងធម៌នោះ មានសេចក្តីយល់ឃើញក្នុងការបំបែកថាជាធម៌ មានសេចក្តីសង្ស័យក្នុងធម៌នោះ មានសេចក្តីសង្ស័យក្នុងការបំបែក ហើយបិទបាំងទិដ្ឋិ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប កែខ្លួនលែងបាន។

[៧៦] ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុអ្នកបំបែកសង្ឃ មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់១កប្ប នៅកែខ្លួនបាននោះ ដូចម្តេចខ្លះ។ ព្រះអង្គ ទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងសភាពមិនមែនធម៌ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាជាធម៌ ហើយមិនបិទបាំងទិដ្ឋិ មិនបិទបាំងសេចក្តីគាប់ចិត្ត មិនបិទបាំងសេចក្តីពេញចិត្ត មិនបិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់១កប្ប គួរដល់កិរិយារក្សាបាន។ ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុសំដែងធម៌ ថាមិនមែនធម៌។បេ។ សំដែងទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ មានសេចក្តីយល់ឃើញក្នុងអធម៌នោះ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាជាធម៌ ហើយមិនបិទបាំងទិដ្ឋិ មិនបិទបាំងសេចក្តីគាប់ចិត្ត មិនបិទបាំងសេចក្តីពេញចិត្ត មិនបិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់១កប្ប ជាបុគ្គលនៅកែខ្លួនបាន។

ចប់ ភាណវារៈ ទី៣។

ចប់ សង្ឃភេទក្ខន្ធកៈ ទី៧ តែប៉ុណ្ណេះ។

**ឧទ្ទាន**

(បញ្ជីរឿងនៃសង្ឃភេទក្ខន្ធកៈ គឺ)

[៧៧]

រឿងព្រះសម្មាសម្ពុទ្ធ គង់ក្នុងអនុបិយនិគម១ រឿងពួកសក្យកុមារមានឈ្មោះល្បីល្បាញ១ រឿងអនុរុទ្ធសក្យៈ ជាសុខុមាលជាតិ មិនចង់ចេញសាងផ្នួស១ រឿងមហានាមពន្យល់អនុរុទ្ធថា ការធ្វើស្រែ មុនដម្បូងត្រូវភ្ជួររាស់ ៗរួចសាបព្រោះ ៗរួចបញ្ចូលទឹក ៗរួចជំរះស្មៅ ៗរួចច្រូត ៗរួចចងជាកណ្តាប់ ៗរួច គរកណ្តាប់ជាគំនរ ៗរួចបញ្ជាន់ ឬបែនបោក ៗរួចជជុះចំបើង ៗរួចជជុះកំទេច ៗរួចរោយស្រូវ ៗរួចជញ្ជូនមកទុក ទាំងពន្យល់ថា ស្រែត្រូវតែធ្វើយ៉ាងនេះរាល់ឆ្នាំតទៅ ថាមាតាបិតា និងជីដូនជីតា ទោះបីអនិច្ចកម្មទៅអស់ឯការងារក៏នៅតែមិនចេះអស់១ រឿងភទ្ទិយៈ អនុរុទ្ធ អានន្ទ ភគុ និងកិមិលៈ ចេញបួស១ រឿងពួកសក្យរាជកុមារបន្ថយនូវមានះ១ រឿងព្រះអង្គគង់នៅ (ក្នុងឃោសិតារាម) ទៀបក្រុងកោសម្ពី១ រឿងទេវទត្តសាបសូន្យ (លាភសក្ការៈ)១ រឿងកក្កុធទេវបុត្ត១ រឿងព្រះសារីបុត្តត្ថេរប្រកាសនូវ (ទោសទេវទត្ត)១ រឿងទេវទត្តដឹកនាំអជាតសត្តុកុមារឲ្យសម្លាប់បិតា១ បញ្ជូនបុរសទាំងឡាយ ឲ្យទៅសម្លាប់ព្រះពុទ្ធអង្គ១ ប្រមៀលថ្ម១ លែងដំរីនាឡាគិរី១ រឿងព្រះពុទ្ធអង្គអនុញ្ញាត តិកភោជន១ រឿងទេវទត្តសូមវត្ថុ៥ប្រការ១ រឿងព្រះពុទ្ធអង្គសំដែងថា បុគ្គលដែលបំបែកសង្ឃ មានទោសជាទម្ងន់១ រឿងទេវទត្តបំបែកសង្ឃ១ រឿងព្រះពុទ្ធអង្គ ទ្រង់បង្គាប់ឲ្យ ភេទានុវត្តកភិក្ខុ សំដែងថុល្លច្ចយាបត្តិចេញ១ រឿងព្រះពុទ្ធអង្គ ទ្រង់សំដែងពីភិក្ខុដែលគួរធ្វើទូតបាន លុះតែប្រកបដោយអង្គ៨ប្រការបីលើក១ រឿងព្រះពុទ្ធអង្គ ទ្រង់សំដែងអសទ្ធម្ម៣ប្រការ១ រឿងព្រះឧបាលិត្ថេរ ទូលសួរព្រះពុទ្ធអង្គ ពីសេចក្តីប្រេះឆានៃសង្ឃ និងការបែកធ្លាយនៃសង្ឃ១ ពីភិក្ខុអ្នកបំបែកសង្ឃ ដែលទៅកើតក្នុងអបាយមានឬទេ១។

# វត្តក្ខន្ធកៈ (ទី៨)

CS vin.cv.08 | ភាគ ទី១១

**(៨. វត្តក្ខន្ធកំ)**

## (អាគន្តុកវត្តកថា ទី១)

CS vin.cv.08.01 | ភាគ ទី១១

## (១. អាគន្តុកវត្តកថា)

[៧៨] សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកគហបតិ ទៀបក្រុងសាវត្ថី។ សម័យនោះឯង អាគន្តុកភិក្ខុទាំងឡាយ ពាក់ស្បែកជើងដើរចូលទៅកាន់អារាមខ្លះ បាំងឆត្រដើរចូលទៅកាន់អារាមខ្លះ ទទូរក្បាលដើរចូលទៅកាន់អារាមខ្លះ ទូលចីវរលើក្បាលដើរចូលទៅកាន់អារាមខ្លះ លាងជើងដោយទឹកសម្រាប់ផឹកខ្លះ មិនថ្វាយបង្គំអាវាសិកភិក្ខុ[12] ទាំងឡាយ ដែលចាស់ជាងខ្លួនខ្លះ មិនសួររកសេនាសនៈខ្លះ។ មានអាគន្តុកភិក្ខុមួយរូបទៀត បើកគន្លឹះ ច្រានសន្ទះទ្វារ ហើយចូលទៅកាន់វិហារ ដែលមិនមានអ្នកណានៅ ដោយប្រញាប់ប្រញាល់។ មានពស់ធ្លាក់ពីខាងលើក្របទ្វារ មកត្រូវត្រង់កភិក្ខុនោះ។ ភិក្ខុនោះខ្លាច ក៏ស្រែកភ្លាត់សម្លេង។ ភិក្ខុទាំងឡាយ ស្ទុះចូលទៅសួរភិក្ខុនោះថា ម្នាលអាវុសោ ហេតុអ្វីបានជាលោកស្រែកភ្លាត់សម្លេងម្ល៉េះ។ លំដាប់នោះ ភិក្ខុនោះ បានប្រាប់ដំណើរនោះ ដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនគួរបើអាគន្តុកភិក្ខុទាំងឡាយ ពាក់ស្បែកជើងដើរចូលទៅកាន់អារាមខ្លះ បាំងឆត្រដើរចូលទៅកាន់អារាមខ្លះ ទទូរក្បាលដើរចូលទៅកាន់អារាមខ្លះ ទូលចីវរលើក្បាលដើរចូលទៅកាន់អារាមខ្លះ លាងជើងដោយទឹកសម្រាប់ផឹកខ្លះ មិនថ្វាយបង្គំអាវាសិកភិក្ខុទាំងឡាយ ដែលចាស់ជាងខ្លួនខ្លះ មិនសួររកសេនាសនៈខ្លះសោះ។ គ្រានោះឯង ភិក្ខុទាំងនោះ បានក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា អាគន្តុកភិក្ខុទាំងឡាយ ពាក់ស្បែកជើងដើរចូលទៅកាន់អារាមខ្លះ បាំងឆត្រដើរចូលទៅកាន់អារាមខ្លះ ទទូរក្បាលដើរចូលទៅកាន់អារាមខ្លះ ទូលចីវរលើក្បាលដើរចូលទៅកាន់អារាមខ្លះ លាងជើងដោយទឹកសម្រាប់ផឹកខ្លះ មិនថ្វាយបង្គំអាវាសិកភិក្ខុទាំងឡាយ ដែលចាស់ជាងខ្លួនខ្លះ មិនសួររកសេនាសនៈខ្លះ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។ ព្រះពុទ្ធមានព្រះភាគ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មិនសមបើអាគន្តុកភិក្ខុទាំងឡាយ ហ៊ានពាក់ស្បែកជើងដើរចូលទៅកាន់អារាមខ្លះ បាំងឆត្រដើរចូលទៅកាន់អារាមខ្លះ ទទូរក្បាលដើរចូលទៅកាន់អារាមខ្លះ ទូលចីវរលើក្បាលដើរចូលទៅកាន់អារាមខ្លះ លាងជើងដោយទឹកសម្រាប់ផឹកខ្លះ មិនថ្វាយបង្គំអាវាសិកភិក្ខុទាំងឡាយ ដែលចាស់ជាងខ្លួនខ្លះ មិនសួររកសេនាសនៈខ្លះ (ដូច្នោះ)សោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់បន្ទោសហើយ ទើបទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្ត ដល់អាគន្តុកភិក្ខុទាំងឡាយ តាមទំនងដែលអាគន្តុកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ។

[៧៩] ម្នាលភិក្ខុទាំងឡាយ អាគន្តុកភិក្ខុគិតថា អាត្មាអញនឹងចូលទៅកាន់អារាមក្នុងកាលឥឡូវនេះ ហើយត្រូវដោះស្បែកជើង ធ្វើឲ្យទាបហើយគោះចេញ កាន់យកទៅ ហើយដម្លោះឆត្រ បើកក្បាល ដាក់ចីវរពីលើក្បាល មកលើ-កវិញ ហើយត្រូវដើរសន្សឹមៗ ចូលទៅកាន់អារាមដោយស្រួល កាលនឹងដើរចូលទៅកាន់អារាម ត្រូវកំណត់ទុកក្នុងចិត្តថា អាវាសិកភិក្ខុទាំងឡាយ ប្រជុំគ្នាក្នុងទីណា (បើ) អាវាសិកភិក្ខុទាំងឡាយ ប្រជុំគ្នាក្នុងទីណា ត្រូវទៅក្នុងទីនោះ គឺក្នុងឧបដ្ឋានសាលាក្ដី ក្នុងមណ្ឌបក្ដី ទៀបគល់ឈើក្ដី ហើយទុកដាក់បាត្រ ក្នុងទីដ៏សមគួរ ទុកដាក់ចីវរក្នុងទីដ៏សមគួរ កាន់យកអាសនៈដ៏សមគួរ ហើយអង្គុយ គប្បីសួររកទឹកសម្រាប់ឆាន់ គប្បីសួររកទឹកសម្រាប់ប្រើប្រាស់ថា ណាទឹកសម្រាប់ឆាន់ ណាទឹកសម្រាប់ប្រើប្រាស់ បើមានសេចក្ដីត្រូវការដោយទឹកសម្រាប់ឆាន់ ត្រូវយកទឹកសម្រាប់ឆាន់ ហើយឆាន់ចុះ បើមានសេចក្ដីត្រូវការដោយទឹកសម្រាប់ប្រើប្រាស់ ត្រូវយកទឹកសម្រាប់ប្រើប្រាស់លាងជើងចុះ កាលនឹងលាងជើង ត្រូវស្រោចទឹកដោយដៃម្ខាង លាងជើងដោយដៃម្ខាង បើស្រោចទឹកដោយដៃណា មិនត្រូវលាងជើងដោយដៃនោះទេ ត្រូវសួររកកំណាត់សម្ពត់សម្រាប់ជូតស្បែកជើង រួចជូតស្បែកទាំងឡាយចុះ កាលដែលនឹងជូតស្បែកជើង (នោះ) មុនដម្បូង ជូតដោយកំណាត់ស្ងួត ខាងក្រោយមក ត្រូវជូតដោយកំណាត់សម្ពត់ទទឹក ត្រូវលាងកំណាត់សម្ពត់សម្រាប់ជូតស្បែកជើង ហើយពូតហាលទុកក្នុងទីដ៏សមគួរ បើអាវាសិកភិក្ខុចាស់វស្សាជាង អាគន្តុកភិក្ខុត្រូវថ្វាយបង្គំ បើខ្ចីវស្សា អាគន្តុកភិក្ខុត្រូវឲ្យថ្វាយបង្គំខ្លួនវិញ អាគន្តុកភិក្ខុ ត្រូវសួររកសេនាសនៈថា សេនាសនៈដូចម្ដេច សម្រាប់ខ្ញុំព្រះករុណា ត្រូវសួរអំពីសេនាសនៈ ដែលគេនៅហើយឬៗគ្មានគេនៅទេ ត្រូវសួររកគោចរគ្រាម[13] ត្រូវសួររកអគោចរគ្រាម[14] ត្រូវសួររកសេក្ខសម្មតិត្រកូល ត្រូវសួររកទីសម្រាប់បន្ទោបង់វច្ចៈ ត្រូវសួររកទីសម្រាប់បន្ទោបង់បស្សាវៈ ត្រូវសួររកទឹកសម្រាប់ឆាន់ ត្រូវសួររកឈើច្រត់ ត្រូវសួររករបៀបនៃកតិកា គឺសេចក្ដីប្ដេជ្ញារបស់សង្ឃថា គួរចូលទៅក្នុងពេលណា គួរចេញមកវិញក្នុងពេលណា បើវិហារគ្មានភិក្ខុណានៅទេ អាគន្តុកភិក្ខុ ត្រូវគោះសន្ទះទ្វារ ហើយរង់ចាំមួយស្របក់ ដកគន្លឹះ ហើយច្រានសន្ទះទ្វារ ហើយឈរខាងក្រៅ ពិនិត្យឲ្យគ្រប់សព្វ បើវិហារមានសម្រាមក្ដី គេតម្រួតគ្រែលើគ្រែក្ដី គេតម្រួតតាំងលើតាំងក្ដី គេបានតម្រួតសេនាសនៈគរទុកលើគ្នាក្ដី បើអាគន្តុកភិក្ខុអាច (ដើម្បីសំអាតបាន) ត្រូវសំអាតចេញ កាលសំអាតវិហារ មុនដម្បូង ត្រូវជញ្ជូនកម្រាលផ្ទាល់ផែនដីទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវយកទ្រនាប់គ្រែទាំងឡាយទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវជញ្ជូនយកពូក និងខ្នើយទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវជញ្ជូនយកកម្រាលសម្រាប់អង្គុយទៅទុកដាក់ក្នុងទីដ៏សមគួរ អាគន្តុកភិក្ខុ ត្រូវលើកគ្រែបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះនឹងសន្ទះទ្វារ នឹងក្របទ្វារ ហើយជញ្ជូនឲ្យស្រួល យកទៅទុកក្នុងទីដ៏សមគួរ ត្រូវលើកតាំងបន្ទាប កុំឲ្យទង្គិច កុំឲ្យប៉ះនឹងសន្ទះទ្វារ នឹងក្របទ្វារ ហើយជញ្ជូនឲ្យស្រួលយកទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្ថោរសម្រាប់ស្ដោះទឹកមាត់ទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកផែនក្ដារសម្រាប់ផ្អែក ទៅទុកក្នុងទីដ៏សមគួរ បើគ្រឿងស្មុកស្មាញ (មានសំបុកកណ្ដុប និងសរសៃពីងពាងជាដើម) មាននៅក្នុងវិហារ អាគន្តុកភិក្ខុ ត្រូវបោសតាំងពីពិតានមកជាមុន ចំណែកជ្រុងសន្ទះបង្អួច ត្រូវជូតសំអាត បើជញ្ជាំងដែលគេលាបដោយរង់ មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់កំណាត់សម្ពត់ពូតហើយសឹមជូត បើផ្ទៃគេធ្វើដោយវត្ថុមានពណ៌ខ្មៅ មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់កំណាត់សម្ពត់ពូតហើយសឹមជូត បើទីផ្ទៃគេមិនបានធ្វើទេ ត្រូវប្រស់ដោយទឹក រួចហើយសឹមជូត ដោយគិតថា កុំឲ្យវិហាររាយខ្ចាំ ដោយធូលីឡើយ គប្បីប្រមូលសម្រាមយកទៅចោល ក្នុងទីដ៏សមគួរ លុះហាលកម្រាលផ្ទាល់ផែនដីហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អ រួចនាំយកមកក្រាលដូចដើមវិញ លុះហាលទ្រនាប់គ្រែហើយ ត្រូវបោសឲ្យស្អាត នាំយកមកទុកដូចដើមវិញ លុះហាលគ្រែហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អ លើកបន្ទាប កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ នឹងក្របទ្វារ ហើយនាំឲ្យស្រួល យកទៅទុកដូចដែលវិញ លុះហាលតាំងហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អ លើកបន្ទាប កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ នឹងក្របទ្វារ ហើយនាំឲ្យស្រួល យកទៅទុកដូចដែលវិញ លុះហាលពូកខ្នើយហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អ រួចយកទៅរៀបចំទុកដូចដែលវិញ លុះហាលកម្រាលសម្រាប់អង្គុយហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អ យកទៅក្រាលទុកដូចដើមវិញ លុះហាលកន្ថោរសម្រាប់ស្ដោះទឹកមាត់ហើយ ត្រូវជូតឲ្យស្អាត រួចយកទៅទុកដូចដែលវិញ លុះហាលផែនក្ដារ សម្រាប់ផ្អែកហើយ ត្រូវជូតឲ្យស្អាត រួចយកទៅទុកដូចដែលវិញ ត្រូវរៀបចំទុកដាក់បាត្រ និងចីវរ កាលនឹងទុកដាក់បាត្រ ត្រូវកាន់បាត្រដៃម្ខាង ស្ទាបក្រោមគ្រែ ឬក្រោមតាំងដៃម្ខាង ហើយទុកដាក់បាត្រចុះ តែមិនត្រូវទុកដាក់បាត្រ លើផ្ទៃដែលមិនស្អាតទេ កាលនឹងទុកចីវរ ត្រូវចាប់ចីវរដៃម្ខាង ជូតស្នួរចីវរ ឬខ្សែស្បៀងដៃម្ខាង ធ្វើជាយខាងនាយ ឲ្យជាផ្នត់មកខាងអាយ ហើយទុកចីវរចុះ បើខ្យល់

ប្រកបដោយធូលី បក់មកអំពីទិសខាងកើត អាគន្តុកភិក្ខុ ត្រូវបិទបង្អួចទិសខាងកើត បើខ្យល់ប្រកបដោយធូលី បក់មកអំពីទិសខាងលិច ត្រូវបិទបង្អួចទិសខាងលិច បើខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងជើង ត្រូវបិទបង្អួចទិសខាងជើង បើខ្យល់ប្រកបដោយធូលី បក់មកអំពីទិសខាងត្បូង ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ ត្រូវបិទបង្អួចក្នុងវេលាយប់ បើរដូវក្តៅ ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ ត្រូវបើកក្នុងវេលាយប់ បើបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់ទឹកមានសម្រាម ត្រូវបោសបន្ទប់ទឹកចេញ បើឧបដ្ឋានសាលា (រោងឆាន់) មានសម្រាម ត្រូវបោសឧបដ្ឋានសាលាចេញ បើរោងភ្លើងមានសម្រាម ត្រូវបោសរោងភ្លើងចេញ បើបង្គន់មានសម្រាម ត្រូវបោសបង្គន់ចេញ បើទឹកឆាន់មិនមាន ត្រូវដម្កល់ទឹកឆាន់ទុក បើទឹកសម្រាប់ប្រើប្រាស់មិនមាន ត្រូវដម្កល់ទុកនូវទឹកសម្រាប់ប្រើប្រាស់ បើទឹកក្នុងឆ្នាំងសម្រាប់ជម្រះមិនមាន ត្រូវចាក់ទឹកដាក់ទៅក្នុងឆ្នាំងសម្រាប់ជម្រះ ម្នាលភិក្ខុទាំងឡាយ នេះជាវត្តរបស់អាគន្តុកភិក្ខុទាំងឡាយ ដែលអាគន្តុកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ។

# (អាវាសិកវត្តកថា ទី២)

CS vin.cv.08.02 | ភាគ ទី១១

### (២. អាវាសិកវត្តកថា)

[៨០] សម័យនោះឯង ពួកអាវាសិកភិក្ខុ ឃើញអាគន្តុកភិក្ខុទាំងឡាយហើយ មិននាំគ្នាក្រាលអាសនៈ មិនបានដម្កល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រាប់ជើង ដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់លាង មិនក្រោកទៅទទួលបាត្រ និងចីវរ មិនសួរទឹកសម្រាប់ផឹក មិនសួរទឹកសម្រាប់ប្រើប្រាស់ មិនថ្វាយបង្គំពួកអាគន្តុកភិក្ខុដែលចាស់ជាងខ្លួន មិនរៀបចំសេនាសនៈ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនគួរបើពួកអាវាសិកភិក្ខុ ឃើញអាគន្តុកភិក្ខុទាំងឡាយហើយ មិននាំគ្នាក្រាលអាសនៈ ទទួល មិនដម្កល់ទឹកលាងជើង តាំងសម្រាប់ទ្រាប់ជើង ដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង មិនក្រោកទៅទទួលបាត្រ និងចីវរ មិនសួរទឹកសម្រាប់ផឹក មិនសួរទឹកសម្រាប់ប្រើប្រាស់ មិនថ្វាយបង្គំពួកអាគន្តុកភិក្ខុ ដែលចាស់ជាងខ្លួន មិនរៀបចំសេនាសនៈសោះ។ លំដាប់នោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ដំណើរនោះ ពិតមែនឬ។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្ត ដល់អាវាសិកភិក្ខុទាំងឡាយ តាមទំនងដែលអាវាសិកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ។

[៨១] ម្នាលភិក្ខុទាំងឡាយ អាវាសិកភិក្ខុ ឃើញអាគន្តុកភិក្ខុ ដែលចាស់ជាងខ្លួនហើយ ត្រូវក្រាលអាសនៈ ត្រូវដម្កល់ទុកនូវទឹកលាងជើង តាំងសម្រាប់ទ្រាប់ជើង ដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវក្រោកទទួលយកបាត្រ និងចីវរ ត្រូវសួរទឹកសម្រាប់ផឹក ត្រូវសួរទឹកសម្រាប់ប្រើប្រាស់ បើអាវាសិកភិក្ខុមានសេចក្តីឧស្សាហ៍ ត្រូវជូតស្បែកជើង កាលនឹងជូតស្បែកជើង មុនដម្បូង ត្រូវជូតដោយសំពត់ស្ងួត បន្ទាប់មក ត្រូវជូតដោយសម្ពត់ទទឹក ត្រូវលាងកំណាត់សម្ពត់សម្រាប់ជូតស្បែកជើង ហើយពូតហាលទុកក្នុងទីដ៏សមគួរ (បើ) អាគន្តុកភិក្ខុចាស់វស្សាជាង អាវាសិកភិក្ខុត្រូវថ្វាយបង្គំ ត្រូវរៀបសេនាសនៈ ដោយពាក្យថា សេនាសនៈនេះសម្រាប់លោកម្ចាស់ ត្រូវប្រាប់សេនាសនៈ ដែលមានគេនៅក្តី ឥតមានគេនៅក្តី ត្រូវប្រាប់គោចរគ្រាម ត្រូវប្រាប់អគោចរគ្រាម ត្រូវប្រាប់ត្រកូលទាំងឡាយ ដែលសង្ឃសន្មតថាជាសេក្ខៈ ត្រូវប្រាប់ទីសម្រាប់បន្ទោបង់វច្ចៈ ត្រូវប្រាប់ទីសម្រាប់បន្ទោបង់បស្សាវៈ ត្រូវប្រាប់ទឹកសម្រាប់ឆាន់ ត្រូវប្រាប់ទឹកសម្រាប់ប្រើប្រាស់ ត្រូវប្រាប់ឈើច្រត់ ត្រូវប្រាប់របៀបកតិការបស់សង្ឃថា លោកម្ចាស់ត្រូវចូលមកក្នុងពេលនេះ ត្រូវចេញទៅក្នុងពេលនេះ បើអាគន្តុកភិក្ខុខ្ចីវស្សាជាង អាវាសិកភិក្ខុ ត្រូវអង្គុយប្រាប់វិញថា ចូរលោកទុកបាត្រត្រង់ទីនេះ ចូរទុកចីវរត្រង់នេះចុះ ចូរអង្គុយលើអាសនៈនេះចុះ អាវាសិកភិក្ខុ ត្រូវប្រាប់ទឹកសម្រាប់ឆាន់ ត្រូវប្រាប់ទឹកសម្រាប់ប្រើប្រាស់ ត្រូវប្រាប់សម្ពត់សម្រាប់ជូតស្បែកជើង បើអាគន្តុកភិក្ខុខ្ចីវស្សាជាង អាវាសិកភិក្ខុ ត្រូវបង្គាប់ឲ្យថ្វាយបង្គំខ្លួន ត្រូវប្រាប់សេនាសនៈថា សេនាសនៈនុ៎ះសម្រាប់លោក ត្រូវប្រាប់សេនាសនៈដែលមានគេនៅក្តី ឥតមានគេនៅក្តី ត្រូវប្រាប់គោចរគ្រាម ត្រូវប្រាប់អគោចរគ្រាម ត្រូវប្រាប់ត្រកូលទាំងឡាយ ដែលសង្ឃសន្មតជាសេក្ខៈ ត្រូវប្រាប់ទីសម្រាប់បន្ទោបង់វច្ចៈ ត្រូវប្រាប់ទីសម្រាប់បន្ទោបង់បស្សាវៈ ត្រូវប្រាប់ទឹកសម្រាប់ឆាន់ ត្រូវប្រាប់ទឹកសម្រាប់ប្រើប្រាស់ ត្រូវប្រាប់ឈើច្រត់ ត្រូវប្រាប់របៀបកតិការបស់សង្ឃថា លោកត្រូវចូលមកក្នុងពេលនេះ ត្រូវចេញទៅវិញក្នុងពេលនេះ ម្នាលភិក្ខុទាំងឡាយ នេះហើយ ជាវត្តរបស់អាវាសិកភិក្ខុទាំងឡាយ តាមបែបបទ ដែលអាវាសិកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ។

# (គមិកវត្តកថា ទី៣)

CS vin.cv.08.03 | ភាគ ទី១១

### (៣. គមិកវត្តកថា)

[៨២] សម័យនោះឯង ពួកគមិកភិក្ខុ (ភិក្ខុអ្នកដំណើរ) មិនរៀបចំទុកដាក់គ្រឿងឈើ[15] និងគ្រឿងដី[16] បើកទ្វារ និងបង្អួចចោល មិនអើពើនឹងសេនាសនៈ ហើយចៀសចេញទៅ។ គ្រឿងឈើ គ្រឿងដី ក៏វិនាសអស់ទៅ។ ឯសេនាសនៈ ក៏រកអ្នកណាគ្រប់គ្រងគ្មាន។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនគួរបើពួកគមិកភិក្ខុ មិនរៀបចំទុកដាក់គ្រឿងឈើ គ្រឿងដី បើកទ្វារ និងបង្អួចចោល មិនអើពើនឹងសេនាសនៈ ហើយចៀសចេញទៅសោះ ឯគ្រឿងឈើ គ្រឿងដី ក៏វិនាសអស់ទៅ សេនាសនៈ ក៏រកអ្នកណាគ្រប់គ្រងគ្មាន។ លំដាប់នោះ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា រឿងនោះពិតមែនឬ។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់

ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្ត ដល់ពួកគមិកភិក្ខុ តាមបែបបទ ដែលពួកគមិកភិក្ខុត្រូវប្រព្រឹត្តដោយប្រពៃ។

[៨៣] ម្នាលភិក្ខុទាំងឡាយ គមិកភិក្ខុត្រូវរៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី ហើយបិទទ្វារ និងបង្អួច អើពើនឹងសេនាសនៈ[17)] បើមិនមានភិក្ខុទេ ត្រូវលាសាមណេរ បើមិនមានសាមណេរ ត្រូវលាអារាមិកជន បើមិនមានអារាមិកជន ត្រូវលាឧបាសក បើភិក្ខុក្តី សាមណេរក្តី អារាមិកជនក្តី ឧបាសកក្តី មិនមានទេ ត្រូវរៀបចំគ្រែលើថ្មតូច៤ដុំ ហើយតម្រួតគ្រែលើគ្រែ តម្រួតតាំងលើតាំង ធ្វើសេនាសនៈឲ្យគរលើគ្នា ហើយរៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី ហើយបិទទ្វារ និងបង្អួច រួចដើរចេញទៅចុះ ប្រសិនបើវិហារលេច បើគមិកភិក្ខុអាច (ប្រក់បាន) ក៏គប្បីប្រក់ម្យ៉ាងទៀត គប្បីធ្វើសេចក្តីខ្វល់ខ្វាយថា អាត្មាអញប្រក់វិហារដោយឧបាយដូចម្តេចហ្ន៎ បើគមិកភិក្ខុបានធ្វើសេចក្តីខ្វល់ខ្វាយយ៉ាងនេះ ការបានដូច្នេះនេះ ក៏ជាការគាប់ប្រពៃ បើមិនបានទេ ទីណាជាទីមិនលេច គមិកភិក្ខុ ត្រូវរៀបចំគ្រែលើថ្មតូច៤ដុំ ក្នុងប្រទេសនោះ ហើយតម្រួតគ្រែលើគ្រែ តម្រួតតាំងលើតាំង ហើយធ្វើសេនាសនៈឲ្យគរលើគ្នា រៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី បិទទ្វារ និងបង្អួច រួចដើរចេញទៅចុះ ប្រសិនបើវិហារលេចគ្មានសល់ បើគមិកភិក្ខុអាច (នាំយកទៅបាន) ត្រូវនាំសេនាសនៈទៅកាន់ស្រុក ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា អាត្មាអញ នឹងនាំយកសេនាសនៈទៅកាន់ស្រុក ដោយឧបាយដូចម្តេចហ្ន៎ បើគមិកភិក្ខុបានធ្វើសេចក្តីខ្វល់ខ្វាយយ៉ាងនេះ ការបានដូច្នេះ នេះជាការល្អ បើមិនបានទេ គមិកភិក្ខុត្រូវរៀបចំគ្រែលើថ្មតូច៤ដុំ ក្នុងទីវាល ហើយតម្រួតគ្រែលើគ្រែ តម្រួតតាំងលើតាំង ធ្វើសេនាសនៈឲ្យគរលើគ្នា ហើយរៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី បិទបាំងដោយស្មៅ ឬដោយស្លឹកឈើ រួចសឹមដើរចេញទៅ ដោយធ្វើទុកក្នុងចិត្តថា ធ្វើដូចម្តេច នឹងឲ្យអវយវៈ (របស់គ្រែ និងតាំង) ទាំងឡាយសល់នៅបាន ម្នាលភិក្ខុទាំងឡាយ នេះហើយជាវត្តរបស់ពួកគមិកភិក្ខុ តាមបែបបទ ដែលពួកគមិកភិក្ខុត្រូវប្រព្រឹត្តដោយប្រពៃ។

# (អនុមោទនវត្តកថា ទី៤)

CS vin.cv.08.04 | ភាគ ទី១១

### (៤. អនុមោទនវត្តកថា)

[៨៤] សម័យនោះឯង ភិក្ខុទាំងឡាយមិនអនុមោទនាក្នុងរោងភត្ត។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយ៍ មិនគួរបើមិនអនុមោទនា ក្នុងរោងភត្តសោះ។ កាលដែលមនុស្សទាំងឡាយ កំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ពួកភិក្ខុក៏បានឮ។ លំដាប់នោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើអនុមោទនាក្នុងរោងភត្ត។

[៨៥] លំដាប់នោះ ពួកភិក្ខុមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុដូចម្តេចហ្ន៎ ដែលគួរអនុមោទនាក្នុងរោងភត្តបាន។ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈ អនុមោទនាក្នុងរោងភត្ត។

[៨៦] សម័យនោះឯង មានសង្ឃភត្តរបស់គណៈជនមួយពួក។ ព្រះសារីបុត្តដ៏មានអាយុជាសង្ឃត្ថេរ។ ភិក្ខុទាំងឡាយគិតគ្នាថា ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យភិក្ខុជាថេរៈអនុមោទនាក្នុងរោងភត្ត ហើយក៏ដើរចៀសចេញទៅ ចោលព្រះសារីបុត្តដ៏មានអាយុ ឲ្យគង់នៅតែមួយអង្គ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ (និយាយ) សំណេះសំណាលនឹងមនុស្សទាំងនោះហើយ ក៏បាននិមន្តទៅតែមួយអង្គ ក្នុងកាលជាខាងក្រោយ។ ព្រះមានព្រះភាគ ទ្រង់បានទតទៅឃើញព្រះសារីបុត្តដ៏មានអាយុ កំពុងតែដើរមកតែមួយអង្គ អំពីចម្ងាយ លុះទ្រង់ទតឃើញហើយ ក៏ត្រាស់សួរសេចក្តីនុ៎ះ នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ចុះភត្តមានបរិបូណ៌ទេឬ។ ព្រះសារីបុត្តដ៏មានអាយុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ភត្តមានបរិបូណ៌ទេ ប៉ុន្តែភិក្ខុទាំងឡាយ ដើរចោលខ្ញុំព្រះអង្គ ឲ្យនៅតែម្នាក់ឯង។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភិក្ខុទាំងឡាយជាថេរៈ និងអនុត្ថេរបួនប្រាំរូប រង់ចាំក្នុងរោងភត្ត។

[៨៧] សម័យនោះ មានព្រះថេរៈមួយរូប ឈឺបន្ទោបង់ឧច្ចារៈ ហើយរង់ចាំក្នុងរោងភត្ត កាលបើព្រះថេរៈនោះ ខំអត់ទ្រាំឧច្ចារៈ លោកក៏ជ្រប់ដួលទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើមានកិច្ចគួរធ្វើ តថាគតអនុញ្ញាតឲ្យលាភិក្ខុ ដែលអង្គុយនៅលើអាសនៈ ជាលំដាប់ ហើយទៅបាន។

# (ភត្តគ្គវត្តកថា ទី៥)

CS vin.cv.08.05 | ភាគ ទី១១

### (៥. ភត្តគ្គវត្តកថា)

[៨៨] សម័យនោះ ពួកឆព្វគ្គិយភិក្ខុ ស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ដើរទៅកាន់រោងភត្ត ជែងទៅខាងមុខៗ នៃពួកភិក្ខុជាថេរៈខ្លះ ចូលទៅអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈខ្លះ ឃាត់ពួកភិក្ខុខ្ចីដោយអាសនៈខ្លះ អង្គុយសង្កត់សង្ឃាដិ ក្នុងចន្លោះផ្ទះខ្លះ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរបើស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ដើរទៅកាន់រោងភត្តសោះ ឆព្វគ្គិយភិក្ខុទាំងនោះ ដើរជែងទៅខាងមុខៗ នៃពួកភិក្ខុជាថេរៈខ្លះ ចូលទៅអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈខ្លះ ឃាត់ពួកភិក្ខុខ្ចីដោយអាសនៈខ្លះ អង្គុយសង្កត់សង្ឃាដិ ក្នុងចន្លោះផ្ទះខ្លះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាប

បង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកឆព្វគ្គិយភិក្ខុ ស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ដើរទៅកាន់រោងភត្ត ដើរជែងទៅខាងមុខៗ នៃពួកភិក្ខុជាថេរៈខ្លះ អង្គុយជ្រៀតបៀតភិក្ខុជាថេរៈខ្លះ ឃាត់ពួកភិក្ខុខ្ចីដោយអាសនៈខ្លះ អង្គុយសង្កត់សង្ឃាដិ ក្នុងចន្លោះផ្ទះ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះអង្គ ពិតមែន។បេ។ ព្រះមានព្រះភាគ ទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្ត ក្នុងរោងភត្ត ដល់ភិក្ខុទាំងឡាយ តាមទំនង ដែលភិក្ខុទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃក្នុងរោងភត្ត។

[៨៩] បើគេប្រាប់ភត្តកាលក្នុងអារាមហើយ ភិក្ខុត្រូវបិទបាំងមណ្ឌល៣ គឺស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់សម្ពត់កាយពន្ធន៍ (វត្ថពន្ធចង្កេះ) តម្រួតឧត្តរាសង្គ និងសង្ឃាដិ ហើយឃ្លុំពាក់ក្ដំ ហើយជូតបាត្រឲ្យស្អាត ហើយកាន់យកទៅ ដើរតាមសម្រួល មិនរលះរលាំង ចូលទៅកាន់ស្រុក មិនត្រូវដើរជែងទៅខាងមុខៗ នៃពួកភិក្ខុជាថេរៈទេ ត្រូវបិទបាំងកាយដោយល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសម្លឹងចុះក្រោម គឺក្រឡេកមើលប្រមាណមួយជួរនឹម ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរ ដើរចូលទៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិច ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវដើរគ្រលែងកាយទៅក្នុងចន្លោះផ្ទះ មិនត្រូវបង់បោយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវងេកងោកក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ ត្រូវបិទបាំងកាយឲ្យល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នដោយល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសម្លឹងចុះក្រោម គឺក្រឡេកមើលប្រមាណមួយជួរនឹម អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរអង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិចអង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវគ្រលែងកាយអង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវឆ្ការដៃ អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវងេកងោកក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះអង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវត្របោមក្បាលជង្គង់អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវអង្គុយច្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវបៀតបៀនភិក្ខុខ្ចីទាំងឡាយ ដោយអាសនៈ មិនត្រូវអង្គុយសង្កត់សង្ឃាដិ ក្នុងចន្លោះផ្ទះ កាលបើទាយកប្រគេនទឹក ត្រូវកាន់បាត្រដោយដៃទាំងពីរ ហើយទទួលយកទឹក ត្រូវបន្ទាបបាត្រឲ្យស្រួល កុំឲ្យទង្គិច (អ្វីៗ) ឡើយ ហើយលាងឲ្យស្អាត បើមានកន្ថោរដាក់ទឹក ត្រូវធ្វើឲ្យទាប ហើយចាក់ទឹកទៅក្នុងកន្ថោរដាក់ទឹក ដោយតាំងចិត្តថា កុំឲ្យកន្ថោរដាក់ទឹកខ្ចាត់ខ្ចាយទឹកឡើយ កុំឲ្យភិក្ខុទាំងឡាយជិតខាងទទឹកដោយទឹកឡើយ កុំឲ្យសង្ឃាដិទទឹកដោយទឹកឡើយ បើគ្មានកន្ថោរដាក់ទឹកទេ ភិក្ខុត្រូវធ្វើទឹក (នោះ) ឲ្យទាប ហើយស្រោចលើផែនដី ដោយតាំងចិត្តថា កុំឲ្យភិក្ខុជិតខាងទាំងឡាយ ទទឹកដោយទឹកឡើយ កុំឲ្យសង្ឃាដិ ទទឹកដោយទឹកឡើយ បើមានទាយកប្រគេនបាយ ត្រូវកាន់បាត្រដោយដៃទាំងពីរ ហើយទទួលយកបាយ តែត្រូវធ្វើទីឱកាសឲ្យដាក់សម្លបានផង បើមានទឹកដោះថ្លាក្ដី ប្រេងក្ដី សម្លឧត្តរិភង្គក្ដី ភិក្ខុជាថេរៈត្រូវពោលថា ចូរអ្នកចាត់ចែងដល់ភិក្ខុគ្រប់រូបឲ្យបានស្មើៗគ្នា ត្រូវទទួលបិណ្ឌបាតដោយគោរព ត្រូវមានសេចក្ដីសំគាល់តែក្នុងបាត្រ ទទួលបិណ្ឌបាត ត្រូវទទួលបិណ្ឌបាតឲ្យមានសម្លស្មើគ្នា ត្រូវទទួលបិណ្ឌបាតឲ្យស្មើតែត្រឹមកណ្ដាប់មាត់បាត្រ ភិក្ខុគ្រប់រូបមិនទាន់បានបាយទុកគ្រប់គ្រាន់ត្រឹមណា ភិក្ខុជាថេរៈ មិនគប្បីឆាន់ត្រឹមនោះ ត្រូវឆាន់ចង្ហាន់បិណ្ឌបាតដោយគោរព ត្រូវឆាន់ចង្ហាន់បិណ្ឌបាតសំគាល់តែក្នុងបាត្រ ត្រូវឆាន់ចង្ហាន់បិណ្ឌបាតវាចឲ្យស្មើ ត្រូវឆាន់ចង្ហាន់បិណ្ឌបាតមានសម្លស្មើគ្នា មិនត្រូវច្រមចុះអំពីកំពូលបាយឆាន់ចង្ហាន់បិណ្ឌបាតមិនត្រូវកកាយបាយលុបសម្ល ឬម្ហូបក្រៀម ដើម្បីឲ្យបានច្រើនជាងគេ បើគ្មានជម្ងឺ មិនត្រូវសូមសម្ល ឬបាយដើម្បីជាប្រយោជន៍ដល់ខ្លួន ហើយឆាន់ទេ មិនត្រូវសំឡឹងរំពៃមើលបាត្រភិក្ខុទាំងឡាយដទៃ ដោយគិតនឹងលើកទោសទេ មិនត្រូវធ្វើពំនូតបាយ ឲ្យធំហួសប្រមាណ ត្រូវធ្វើពំនូតបាយឲ្យជាបរិមណ្ឌល គឺធ្វើឲ្យមូល កាលបើពំនូតបាយ មិនទាន់ដល់មាត់ មិនត្រូវហារមាត់ចាំឡើយ កាលនឹងឆាន់ មិនត្រូវញាត់ម្រាមដៃទាំងអស់ ទៅក្នុងមាត់ មិនត្រូវនិយាយទាំងពំនូតបាយនៅក្នុងមាត់ មិនត្រូវបោះដុំបាយ (ទៅក្នុងមាត់) ហើយឆាន់ទេ មិនត្រូវឆាន់ខាំកាត់ពំនូតបាយ (មួយកំណាត់ម្ដង) មិនត្រូវឆាន់បៀមពំនូតបាយ ឲ្យទុលថ្ពាល់ឡើង (ដូចជាស្វា) មិនត្រូវឆាន់រលាស់ដៃបណ្ដើរ មិនត្រូវឆាន់បាយឲ្យរោយរាយគ្រាប់បាយ មិនត្រូវឆាន់លៀនអណ្ដាតចេញមកក្រៅ (ទទួលអាហារ) មិនត្រូវឆាន់ឲ្យឮផ្ចប់ៗ មិនត្រូវឆាន់ឲ្យឮគ្រូកៗ មិនត្រូវឆាន់លិទ្ធដៃ មិនត្រូវឆាន់លិទ្ធបាត្រ មិនត្រូវឆាន់លិទ្ធបបូរមាត់ មិនត្រូវទទួលភាជន៍ទឹកទាំងដៃប្រឡាក់អាមិសៈ ភិក្ខុទាំងពួង មិនទាន់ឆាន់ហើយត្រឹមណា ភិក្ខុជាថេរៈ មិនគប្បីទទួលយកទឹកត្រឹមនោះ កាលបើទាយកប្រគេនទឹក ត្រូវកាន់បាត្រដោយដៃទាំងពីរ ហើយទទួលយកទឹក ត្រូវធ្វើបាត្រឲ្យទាប កុំឲ្យទង្គិច (អ្វីៗ) ហើយលាងឲ្យស្អាត បើមានកន្ថោរទឹក ត្រូវធ្វើឲ្យទាប ហើយចាក់ទឹកទៅក្នុងកន្ថោរដាក់ទឹក ដោយតាំងចិត្តថា កុំឲ្យកន្ថោរដាក់ទឹកខ្ចាត់ខ្ចាយទឹកឡើយ កុំឲ្យពួកភិក្ខុជិតខាងទទឹកដោយទឹកឡើយ កុំឲ្យសង្ឃាដិទទឹកដោយទឹកឡើយ បើមិនមានកន្ថោរទឹកទេ ត្រូវធ្វើទឹកឲ្យទាប ហើយចាក់លើផែនដី ដោយតាំងចិត្តថា កុំឲ្យពួកភិក្ខុជិតខាង ទទឹកដោយទឹកឡើយ កុំឲ្យសង្ឃាដិ ទទឹកដោយទឹកឡើយ មិនត្រូវចាក់ទឹកលាងបាត្រមានទាំងគ្រាប់បាយក្នុងចន្លោះផ្ទះ កាលបើត្រឡប់វិញ ត្រូវត្រឡប់ឲ្យបានមុនពួកភិក្ខុខ្ចី ត្រូវបិទបាំងកាយឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ក្រោយភិក្ខុជាថេរៈទាំងឡាយ ត្រូវសង្រួមប្រយ័ត្នឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសម្លឹងចុះក្រោម គឺក្រឡេកមើលប្រមាណមួយជួរនឹម ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិចៗ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវដើរគ្រលែងកាយទៅក្នុងចន្លោះផ្ទះ មិនត្រូវបង់បោយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវងេកងោកក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវដើរចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ ម្នាលភិក្ខុទាំងឡាយ នេះហើយជាវត្តរបស់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃក្នុងរោងភត្ត។

ភាណវារៈ ទី១ ចប់។

# (បិណ្ឌចារិកវត្តកថា ទី៦)

CS vin.cv.08.06 | ភាគ ទី១១

### (៦. បិណ្ឌចារិកវត្តកថា)

[៩០] សម័យនោះឯង ពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត ស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ត្រាច់ទៅបិណ្ឌបាត មិនបានសង្កេត ហើយចូលទៅកាន់លំនៅ (ផ្ទះគេ) ខ្លះ មិនបានសង្កេត ហើយចេញមកខ្លះ ចូលទៅដោយរហ័សពេកខ្លះ ចេញមកដោយរហ័សពេកខ្លះ ឈរក្នុងទីឆ្ងាយពេកខ្លះ ឈរក្នុងទីជិតពេកខ្លះ ឈរយូរពេកខ្លះ ត្រឡប់មកវិញដោយរហ័សពេកខ្លះ។ មានភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតមួយរូប

មិនបានសង្កេត ហើយដើរចូលទៅកាន់លំនៅ (គេ)។ ភិក្ខុនោះ កាលសំគាល់នូវទ្វារ ដើរចូលទៅកាន់បន្ទប់តូចមួយ។ ក្នុងបន្ទប់តូចនោះសោត មានស្រីអាក្រាតដេកផ្ងារ។ ភិក្ខុនោះ ក៏បានឃើញស្រីអាក្រាតដេកផ្ងារនោះ លុះឃើញហើយ គិតថា នេះមិនមែនជាទ្វារទេ នេះជាបន្ទប់តូចទេតើ ហើយក៏ចេញចាកបន្ទប់តូចនោះមក។ ស្វាមីរបស់ស្រីនោះ ក៏បានឃើញស្រីជាប្រពន្ធនោះអាក្រាតដេកផ្ងារ លុះឃើញហើយ ក៏គិតថា ភិក្ខុនេះប្រទូស្តនឹងប្រពន្ធរបស់អញហើយតើ ហើយចាប់ទះតប់ភិក្ខុនោះ។ លំដាប់នោះ ស្រីនោះ ក៏ភ្ញាក់ឡើង ដោយសារឮសូរសន្ធឹកនោះ ហើយបានសួរបុរសនោះថា នែអ្នក ហេតុអ្វីបានជាអ្នកទះតប់ភិក្ខុនេះ។ ស្វាមីឆ្លើយថា ភិក្ខុនេះប្រទូស្តហងឯងហើយ។ ប្រពន្ធប្រាប់ថា នែអ្នក ភិក្ខុនេះ មិនបានប្រទូស្តខ្ញុំទេ ភិក្ខុនោះ ឥតបានធ្វើ (អំពើដូច្នោះទេ) ថាហើយ ក៏ឲ្យប្តីលែងភិក្ខុនោះទៅ។ ខណៈនោះ ភិក្ខុនោះបានទៅកាន់អារាម ហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយណា ដែលមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត មិនសមបើនឹងស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ត្រាច់ទៅបិណ្ឌបាត មិនបានសង្កេត ហើយចូលទៅកាន់លំនៅ (គេ) ខ្លះ មិនបានសង្កេត ហើយចេញមកខ្លះ ចូលទៅដោយរហ័សពេកខ្លះ ចេញមកដោយរហ័សពេកខ្លះ ឈរក្នុងទីឆ្ងាយពេកខ្លះ ឈរក្នុងទីជិតពេកខ្លះ ឈរយូរពេកខ្លះ ត្រឡប់មកដោយរហ័សពេកខ្លះ (ដូច្នេះ)សោះ។ គ្រានោះ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថារឿងនោះពិតមែនឬ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្ត ដល់ពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត តាមទំនង ដែលពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត គប្បីប្រព្រឹត្តដោយប្រពៃបាន។

[៩១] ម្នាលភិក្ខុទាំងឡាយ បិណ្ឌចារិកភិក្ខុ (ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត) គិតថា អាត្មាអញនឹងចូលទៅកាន់ស្រុក ក្នុងកាលឥឡូវនេះ ហើយគប្បីបិទបាំងមណ្ឌលបី គឺស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់សម្ពត់កាយពន្ធន៍ (វត្តពន្ធចង្កេះ) ហើយតម្រួតឧត្តរាសង្គ និងសង្ឃាដិ ពាក់ក្ដុំហើយឃ្លុំ ជូតបាត្រឲ្យស្អាត កាន់ដើរចូលទៅកាន់ស្រុកដោយស្រួល មិនរលះរលាំង ត្រូវបិទបាំងកាយឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសម្លឹងចុះក្រោម ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិចៗ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវគ្រលែងកាយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវបង់បោយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវងេកងោកក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ កាលដែលនឹងចូលទៅកាន់លំនៅគេ ត្រូវកំណត់ថា អាត្មាអញនឹងចូលទៅតាមផ្លូវនេះ នឹងចេញមកវិញតាមផ្លូវនេះ មិនត្រូវដើរចូលទៅដោយរហ័សពេក មិនត្រូវចេញមកដោយរហ័សពេក មិនត្រូវឈរក្នុងទីឆ្ងាយពេក មិនត្រូវឈរក្នុងទីជិតពេក មិនត្រូវឈរយូរពេក មិនត្រូវត្រឡប់រហ័សពេក ត្រូវឈរសង្កេតថា គេមានបំណងនឹងឲ្យចង្ហាន់ ឬឥតមានបំណងនឹងឲ្យទេ បើប្រសិនជាគេបញ្ឈប់ការងារ ឬគេក្រោកចាកអាសនៈ ឬចាប់វែក ឬចាប់ភាជន៍ ឬគេមានបំណងនឹងឲ្យ ហើយនិមន្តឲ្យរង់ចាំក្តី ដឹងដូច្នេះហើយ ត្រូវឈររង់ចាំ កាលបើគេប្រគេនចង្ហាន់ បិណ្ឌចារិកភិក្ខុត្រូវវែកសង្ឃាដិដោយដៃឆ្វេង បង្អោនបាត្រដោយដៃស្តាំ ហើយទ្របាត្រដោយដៃទាំងពីរ ទទួលយកចង្ហាន់ តែកុំសំឡឹងមើលមុខស្រីដែលប្រគេន[18] ចង្ហាន់នោះឡើយ ត្រូវសង្កេតថា គេមានបំណងនឹងឲ្យសម្ល ឬមិនមានបំណងនឹងឲ្យទេ បើប្រសិនជាគេចាប់វែកក្តី ចាប់ភាជន៍ក្តី ឬគេមានបំណងនឹងឲ្យ ហើយនិមន្តឲ្យរង់ចាំក្តី បិណ្ឌចារិកភិក្ខុដឹងដូច្នេះហើយ ត្រូវឈររង់ចាំ កាលបើគេបានប្រគេនចង្ហាន់ហើយ ត្រូវបិទបាំងបាត្រដោយសង្ឃាដិ ដើរត្រឡប់មកដោយស្រួល មិនរលះរលាំង ត្រូវបិទបាំងកាយឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នដោយល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសម្លឹងចុះក្រោម ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិចៗ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវគ្រលែងកាយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវបង់បោយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវងេកងោកក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតក្នុងស្រុកមុនគេ ភិក្ខុនោះត្រូវក្រាលអាសនៈ (ទុកចាំ) ត្រូវដម្កល់ទុកនូវទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រាប់ជើង ដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់លាង ត្រូវលាងភាជន៍សម្រាប់ផ្ទេរភោជន ហើយដម្កល់ទុក ត្រូវដម្កល់ទុកនូវទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតក្នុងស្រុកក្រោយគេ បើមានអាហារ ដែលសល់អំពីបរិភោគ បើចង់ឆាន់ គប្បីឆាន់ចុះ បើមិនចង់ឆាន់ទេ ត្រូវយកទៅចោលក្នុងទីដែលគ្មានវត្ថុខៀវ (មានស្មៅជាដើម) ឬយកទៅចាក់ក្នុងទឹកដែលគ្មានសត្វ ភិក្ខុនោះគប្បីសារអាសនៈទុក ត្រូវទុកដាក់នូវទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រាប់ជើងដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់លាង ត្រូវលាងភាជន៍សម្រាប់ផ្ទេរភោជន ហើយរៀបចំទុកដាក់ ត្រូវទុកដាក់ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ត្រូវបោសរោងភត្ត ភិក្ខុណាឃើញក្អមសម្រាប់ដាក់ទឹកឆាន់ក្តី ក្អមសម្រាប់ដាក់ទឹកប្រើប្រាស់ក្តី ក្អមសម្រាប់ដាក់ទឹកលាងវច្ចៈក្តី ដែលទទេគ្មានទឹក ភិក្ខុនោះត្រូវរកទឹកមកដម្កល់ទុក បើភិក្ខុនោះ មិនអាចនឹងលើក(ដោយដៃខ្លួន) រួចទេ ត្រូវហៅរកគេ ជាគំរប់ពីរនាក់ ដោយហត្ថវិការ (បោយដៃ) ហើយឲ្យគេជួយលើកដម្កល់ទុក តែកុំបញ្ចេញវាចា ព្រោះហេតុតែកិច្ចប៉ុណ្ណោះឡើយ ម្នាលភិក្ខុទាំងឡាយ ទាំងនេះ ជាវត្តរបស់បិណ្ឌចារិកភិក្ខុទាំងឡាយ តាមទំនងដែលបិណ្ឌចារិកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ។

# (អារញ្ញិកវត្តកថា ទី៧)

CS vin.cv.08.07 | ភាគ ទី១១

### (៧. អារញ្ញិកវត្តកថា)

[៩២] សម័យនោះឯង មានភិក្ខុច្រើនរូបនៅក្នុងព្រៃ។ ភិក្ខុទាំងនោះ មិនដងទឹកសម្រាប់ឆាន់ទុក មិនដងទឹកសម្រាប់ប្រើប្រាស់ទុក មិនបានដម្កល់ទុកនូវភ្លើង មិនបានដម្កល់ទុកនូវពំនួតភ្លើង មិនដឹងផ្កាយនក្ខត្តឫក្ស មិនដឹងចំណែកនៃទិស។ មានពួកចោរទៅក្នុងទីនោះ បានសួរភិក្ខុទាំងនោះថា មានទឹកផឹកឬទេ លោកម្ចាស់។ ភិក្ខុទាំងឡាយប្រាប់ថា គ្មានទេ អាវុសោ។ ចោរសួរថា ចុះទឹកសម្រាប់ប្រើប្រាស់ មានឬទេ លោកម្ចាស់។ ភិក្ខុទាំងឡាយប្រាប់ថា គ្មានទេ អាវុសោ។ ពួកចោរសួរថា ចុះភ្លើងមានឬទេ លោកម្ចាស់។ ភិក្ខុទាំងឡាយប្រាប់ថា គ្មានទេអាវុសោ។ ពួកចោរសួរថា ចុះឈើពំនួតភ្លើង មានឬទេ លោកម្ចាស់។ ភិក្ខុទាំងឡាយប្រាប់ថា គ្មានទេ អាវុសោ។ ពួកចោរសួរថា ចុះក្នុងថ្ងៃនេះ ប្រកបដោយផ្កាយនក្ខត្តឫក្សអ្វី។ ភិក្ខុទាំងឡាយប្រាប់ថា ម្នាលអាវុសោ យើងទាំងឡាយមិនដឹងទេ។ ពួកចោរសួរថា នេះហៅថាទិសអ្វី លោកម្ចាស់។ ភិក្ខុ

ទាំងឡាយប្រាប់ថា យើងទាំងឡាយមិនដឹងទេ អាវុសោ។ លំដាប់នោះ ចោរទាំងនោះនិយាយថា ទឹកសម្រាប់ផឹករបស់ភិក្ខុទាំងនេះក៏គ្មាន ទឹកសម្រាប់ប្រើប្រាស់ក៏គ្មាន ភ្លើងក៏គ្មាន ឈើពំនួតភ្លើងក៏គ្មាន ផ្កាយនក្ខត្តឫក្សក៏មិនដឹង ចំណែកនៃទិសក៏មិនស្គាល់ ពួកនេះ ជាចោរទេតើ ពួកនេះមិនមែនជាភិក្ខុឡើយ ថាហើយ ក៏នាំគ្នាវាយ ហើយដើរចេញទៅ។ លំដាប់នោះ ភិក្ខុទាំងនោះ បានប្រាប់ដំណើរនុ៎ះ ដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយ បានយកសេចក្តីនុ៎ះ ក្រាបបង្គំទូល ចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្ត ដល់អារញ្ញកភិក្ខុទាំងឡាយ (ភិក្ខុអ្នកនៅក្នុងព្រៃ) តាមទំនងដែលអារញ្ញកភិក្ខុទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃបាន។

[៩៣] ម្នាលភិក្ខុទាំងឡាយ (អារញ្ញកភិក្ខុ) ត្រូវក្រោកឡើងអំពីព្រឹកព្រហាម ហើយច្រកបាត្រក្នុងស្លោក រួចស្ពាយលើស្មា ធ្វើចីពរឲ្យនៅលើ-ក ពាក់ស្បែកជើង ហើយរៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី បិទទ្វារ និងបង្អួច រួចហើយចុះពីទីសេនាសនៈ ដោយគិតថា អាត្មាអញ នឹងចូលទៅកាន់ស្រុកក្នុងកាលឥឡូវនេះ ត្រូវដោះស្បែកជើង ហើយបន្ទាបគោះ ច្រកដាក់ក្នុងស្លោកបាត្រ ហើយស្ពាយលើស្មា បិទបាំងកាយឲ្យមានមណ្ឌលបី ស្លៀកស្បង់ឲ្យជាបរិមណ្ឌល ក្រវាត់សម្ពត់កាយពន្ធន៍ តម្រួតឧត្តរាសង្គៈ និងសង្ឃាដិ ហើយឃ្លុំពាក់ក្ដី ហើយជូតបាត្រ កាន់ដើរចូលទៅក្នុងស្រុកដោយស្រួល មិនរលះរលាំង អារញ្ញកភិក្ខុ ត្រូវបិទបាំងកាយឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នដោយល្អ ដើរទៅក្នុងចន្លោះផ្ទះ។បេ។ មិនត្រូវចំអើតជើង ដើរទៅក្នុងចន្លោះផ្ទះ កាលបើនឹងចូលទៅកាន់លំនៅគេ ត្រូវកំណត់ទុកក្នុងចិត្តថា អាត្មាអញនឹងចូលទៅ តាមផ្លូវនេះ នឹងចេញមកវិញតាមផ្លូវនេះ មិនត្រូវចូលទៅដោយរហ័សពេក មិនត្រូវចេញមកវិញដោយរហ័សពេក មិនត្រូវឈរក្នុងទីឆ្ងាយពេក មិនត្រូវឈរក្នុងទីជិតពេក មិនត្រូវឈរយូរពេក មិនត្រូវត្រឡប់មករហ័សពេក ត្រូវឈរសង្កេតមើលថា គេចង់ឲ្យចង្ហាន់ ឬមិនចង់ឲ្យទេ បើគេបញ្ឈប់ការងារក្តី ក្រោកអំពីអាសនៈក្តី ចាប់កាន់វែកក្តី ចាប់កាន់ភាជន៍ក្តី គេចង់ប្រគេនចង្ហាន់ ហើយនិមន្តឲ្យរង់ចាំក្តី ភិក្ខុដឹងដូច្នេះហើយ ត្រូវរង់ចាំ កាលបើគេប្រគេនចង្ហាន់ ត្រូវយកដៃឆ្វេងវែកសង្ឃាដិ យកដៃស្តាំបង្អោនបាត្រ ហើយទ្របាត្រដោយដៃទាំងពីរ ទទួលយកចង្ហាន់ តែកុំសំឡឹងមើលមុខស្ត្រីដែលប្រគេនចង្ហាន់ឡើយ ត្រូវសង្កេតពិនិត្យមើលថា គេចង់ប្រគេនសម្ល ឬមិនចង់ប្រគេនទេ បើគេចាប់កាន់វែកក្តី ចាប់កាន់ភាជន៍ក្តី គេចង់ប្រគេន ហើយនិមន្តឲ្យរង់ចាំក្តី ភិក្ខុដឹងដូច្នេះហើយ ត្រូវរង់ចាំ កាលបើគេប្រគេនចង្ហាន់ហើយ ត្រូវយកសង្ឃាដិបិទបាំងបាត្រ ដើរត្រឡប់ចេញមកដោយស្រួល មិនរលះរលាំង ត្រូវបិទបាំងកាយឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ។បេ។ មិនត្រូវចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ កាលបើត្រឡប់ចេញមកពីស្រុកវិញហើយ ត្រូវច្រកបាត្រក្នុងស្លោក ហើយស្ពាយលើស្មា ហើយប្រមូលចីពរទូល លើក្បាល ហើយពាក់ស្បែកជើងដើរទៅ ម្នាលភិក្ខុទាំងឡាយ អារញ្ញកភិក្ខុត្រូវដងទឹកសម្រាប់ឆាន់ទុក ត្រូវដងទឹកសម្រាប់ប្រើប្រាស់ទុក ត្រូវកម្តល់ទុកនូវភ្លើង ត្រូវដម្កល់ទុកនូវឈើពំនួតភ្លើង ត្រូវដម្កល់ទុកនូវឈើច្រត់ ត្រូវរៀននូវផ្កាយនក្ខត្តឫក្សទាំងអស់ ឬដោយឯកទេស គួរជាអ្នកឈ្លាសវៃក្នុងទិស ម្នាលភិក្ខុទាំងឡាយ ទាំងនេះ ជាវត្តរបស់អារញ្ញកភិក្ខុទាំងឡាយ តាមទំនងដែលអារញ្ញកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ។

# (សេនាសនវត្តកថា ទី៨)

CS vin.cv.08.08 | ភាគ ទី១១

### (៨. សេនាសនវត្តកថា)

[៩៤] សម័យនោះឯង មានភិក្ខុច្រើនរូបធ្វើចីវរកម្មក្នុងទីវាល។ ពួកឆព្វគ្គិយភិក្ខុ គោះគ្រឿងសេនាសនៈ ក្នុងទីធ្លាដែលជាទីច្រាសខ្យល់។ ភិក្ខុទាំងឡាយប្រឡាក់ដោយធូលី។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងគោះគ្រឿងសេនាសនៈ ក្នុងទីធ្លាដែលជាទីច្រាសខ្យល់ ឲ្យភិក្ខុទាំងឡាយប្រឡាក់ដោយធូលីសោះឡើយ។ ភិក្ខុទាំងឡាយនោះ បានយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកឆព្វគ្គិយភិក្ខុ គោះគ្រឿងសេនាសនៈ ក្នុងទីធ្លាដែលជាទីច្រាសខ្យល់ ឲ្យភិក្ខុទាំងឡាយប្រឡាក់ដោយធូលី ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសេនាសនវត្ត ដល់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃ។

[៩៥] ភិក្ខុនៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើអាច (សំអាតបាន) ក៏ត្រូវសំអាត កាលដែលនឹងសំអាតវិហារ ត្រូវយកបាត្រ និងចីវរទៅទុកក្នុងទីដ៏សមគួរជាមុន ហើយត្រូវយកនិសីទនៈ និងកម្រាល ទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូក និងខ្នើយទៅទុកក្នុងទីដ៏សមគួរ ត្រូវលើកបន្ទាបគ្រែឲ្យស្រួល កុំឲ្យទង្គិចទង្គក កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកទៅទុកក្នុងទីដ៏សមគួរ ត្រូវលើកបន្ទាបតាំងឲ្យស្រួល កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកទ្រនាប់ជើងគ្រែទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្តោរសម្រាប់ស្តោះទឹកមាត់ទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកក្តារសម្រាប់ផ្អែក ទៅទុកក្នុងទីដ៏សមគួរ ត្រូវកំណត់ទីដែលគេក្រាលកម្រាលផែនដីយ៉ាងណា ហើយនាំយកទៅទុកក្នុងទីដ៏សមគួរ បើក្នុងវិហារស្មុកស្មាញ (មិនស្អាតដោយសំរសៃពីងពាងជាដើម) ភិក្ខុត្រូវបោសតាំងពីពិតានជាមុន ចំណែកជ្រុងសន្ទះបង្អួច ត្រូវជូតសំអាត បើជញ្ជាំងដែលគេលាបដោយថ្នាំ មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់កំណាត់សម្ពត់ពូត ហើយសឹមជូត បើទីផ្ទៃដែលគេធ្វើដោយវត្ថុមានពណ៌ខ្មៅ មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់កំណាត់សម្ពត់ពូត រួចសឹមជូត បើទីផ្ទៃគេមិនធ្វើទេ ភិក្ខុត្រូវប្រស់ដោយទឹក ហើយសឹមជូត ដោយគិតថា កុំឲ្យវិហារប្រឡាក់ដោយធូលីឡើយ ត្រូវប្រមូលសម្រាមទៅចោល ក្នុងទីដ៏សមគួរ មិនត្រូវគោះគ្រឿងសេនាសនៈជិតភិក្ខុផងគ្នា មិនត្រូវគោះគ្រឿងសេនាសនៈជិតវិហារ មិនត្រូវគោះគ្រឿងសេនាសនៈជិតទឹកសម្រាប់ឆាន់ មិនត្រូវគោះគ្រឿងសេនាសនៈជិតទឹកសម្រាប់ប្រើប្រាស់ មិនត្រូវគោះគ្រឿងសេនាសនៈ ក្នុងធ្លាដែលជាទីច្រាសខ្យល់ ត្រូវគោះគ្រឿងសេនាសនៈ ក្នុងទីក្រោមខ្យល់ ត្រូវហាលកម្រាលផែនដីហើយ ជម្រះគោះក្នុងទីដ៏សមគួរ រួចសារយកមកក្រាលដូចដើមវិញ ត្រូវហាលទ្រនាប់ជើងគ្រែហើយជូតសំអាតក្នុងទីដ៏សមគួរ រួចនាំយកមកដម្កល់ទុកដូចដែលវិញ ត្រូវហាលគ្រែ ហើយជម្រះគោះក្នុងទីដ៏សមគួរ ហើយលើកបន្ទាបឲ្យស្រួល កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ រួចនាំយកទៅទុកដូចដើមវិញ ត្រូវហាលតាំង ហើយជម្រះគោះក្នុងទីដ៏សមគួរ ហើយលើកបន្ទាបឲ្យស្រួល កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ រួចនាំយកមកទុកដូចដើមវិញ ត្រូវហាលពូកខ្នើយ ហើយជម្រះគោះ ក្នុងទីដ៏សមគួរ រួចនាំយកមករៀបចំទុកដូចដើមវិញ ត្រូវហាលកម្រាលសម្រាប់អង្គុយ ហើយជម្រះគោះ ក្នុងទីដ៏សមគួរ រួចសារយកមកក្រាលទុកដូចដើមវិញ ត្រូវហាលកន្តោរសម្រាប់ស្តោះទឹកមាត់ក្នុងទីដ៏

សមគួរ ហើយជូត រួចនាំយកមកទុកដូចដែលវិញ ត្រូវហាលផែនក្តារសម្រាប់ផ្អែក ក្នុងទីដ៏សមគួរ ហើយជូត រួចនាំយកមកទុកដូចដែលវិញ ត្រូវទុកដាក់បាត្រ និងចីវរ កាលដែលទុកដាក់បាត្រ ត្រូវកាន់បាត្រដោយដៃម្ខាង ហើយស្ទាបខាងក្រោមគ្រែ ឬខាងក្រោមតាំង ដោយដៃម្ខាងសិន សឹមទុកដាក់បាត្រចុះ តែថាមិនត្រូវទុកដាក់បាត្រ ក្នុងទីដែលមិនស្អាតឡើយ កាលដែលនឹងទុកចីវរ ត្រូវកាន់ចីវរដោយដៃម្ខាង ហើយជូតស្នួរចីវរ ឬខ្សែស្បៀងដោយដៃម្ខាង ហើយធ្វើជាយខាងនាយ ឲ្យជាផ្នត់មកខាងអាយសិន សឹមទុកចីវរចុះ បើមានខ្យល់ប្រកបដោយធូលី បក់មកអំពីទិសខាងកើត ភិក្ខុត្រូវបិទបង្អួចទិសខាងកើត បើមានខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងលិច ត្រូវបិទបង្អួចទិសខាងលិច បើមានខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងជើង ត្រូវបិទបង្អួចទិសខាងជើង បើមានខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងត្បូង ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ ភិក្ខុត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្តៅ ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកបង្អួចក្នុងវេលាយប់ បើបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់ទឹកមានសម្រាម ត្រូវបោសបន្ទប់ទឹកចេញ បើឧបដ្ឋានសាលាមានសម្រាម ត្រូវបោសឧបដ្ឋានសាលាចេញ បើរោងភ្លើងមានសម្រាម ត្រូវបោសរោងភ្លើងចេញ បើបង្គន់មានសម្រាម ត្រូវបោសបង្គន់ចេញ បើមិនមានទឹកសម្រាប់ឆាន់ ត្រូវដងទឹកសម្រាប់ឆាន់ទុក បើមិនមានទឹកសម្រាប់ប្រើប្រាស់ ភិក្ខុត្រូវដងទឹកសម្រាប់ប្រើប្រាស់ទុក បើមិនមានទឹកក្នុងឆ្នាំងសម្រាប់ជម្រះ ត្រូវចាក់ទឹកក្នុងឆ្នាំងសម្រាប់ជម្រះទុក បើភិក្ខុខ្ចីនៅក្នុងវិហារមួយ ជាមួយនឹងភិក្ខុចាស់ មិនទាន់បានអនុញ្ញាតពីភិក្ខុចាស់ទេ មិនត្រូវបង្រៀនបាលី មិនត្រូវបង្រៀនអដ្ឋកថា មិនត្រូវធ្វើស្វាធ្យាយ មិនត្រូវសំដែងធម៌ មិនត្រូវអុជចង្កៀង មិនត្រូវលត់ចង្កៀង មិនត្រូវបើកបង្អួច មិនត្រូវបិទបង្អួចឡើយ បើភិក្ខុខ្ចីដើរចង្ក្រម ក្នុងទីចង្ក្រមមួយជាមួយនឹងភិក្ខុចាស់ ភិក្ខុចាស់ ចង្ក្រមតាមផ្លូវណា ភិក្ខុខ្ចីត្រូវដើរចៀសពីផ្លូវនោះ តែកុំឲ្យជាយសង្ឃាដីប៉ះភិក្ខុចាស់ឡើយ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាសេនាសនវត្តរបស់ភិក្ខុទាំងឡាយ តាមទំនង ដែលភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងសេនាសនៈ។

# (ជន្តាឃរវត្តកថា ទី៩)

CS vin.cv.08.09 | ភាគ ទី១១

### (៩. ជន្តាឃរវត្តកថា)

[៩៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលដែលភិក្ខុទាំងឡាយជាថេរៈ ហាមប្រាមក្នុងផ្ទះជាទីរក្សាកាយ ក៏នៅតែមិនអើពើ នាំគ្នាគរឧសច្រើនបង្កាត់ភ្លើង ហើយបិទទ្វារ អង្គុយនៅត្រង់ទ្វារ។ ជួនជាភិក្ខុទាំងឡាយជាថេរៈ ត្រូវកំដៅបៀតបៀនខ្លាំងណាស់ ហើយរកទ្វារចេញមកមិនបាន ក៏ជ្រប់ដួលទៅ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ ពួកឆព្វគ្គិយភិក្ខុ កាលដែលភិក្ខុទាំងឡាយជាថេរៈ ហាមឃាត់ក្នុងផ្ទះជាទីរក្សាកាយ ក៏នៅតែមិនអើពើ នាំគ្នាគរឧសជាច្រើន បង្កាត់ភ្លើង ហើយបិទទ្វារ អង្គុយនៅត្រង់ទ្វារសោះ ជួនជាភិក្ខុទាំងឡាយជាថេរៈ ត្រូវកំដៅបៀតបៀនខ្លាំងណាស់ ហើយរកទ្វារចេញមកមិនបាន ក៏ជ្រប់ដួលទៅ។ គ្រានោះ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកឆព្វគ្គិយភិក្ខុ កាលដែលភិក្ខុទាំងឡាយជាថេរៈ ហាមឃាត់ក្នុងផ្ទះជាទីរក្សាកាយ ក៏នៅតែមិនអើពើ នាំគ្នាមកគរឧសជាច្រើនបង្កាត់ភ្លើង ហើយបិទទ្វារ អង្គុយនៅត្រង់ទ្វារ ភិក្ខុទាំងឡាយជាថេរៈ ត្រូវកំដៅបៀតបៀនខ្លាំងណាស់ រកទ្វារចេញមកមិនបាន ក៏ជ្រប់ដួលទៅ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន។បេ។ លុះទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ (បើ) ភិក្ខុជាថេរៈហាមឃាត់ក្នុងផ្ទះ ជាទីរក្សាកាយហើយ មិនត្រូវនាំគ្នាគរឧសជាច្រើន បង្កាត់ភ្លើង ព្រោះអាស្រ័យសេចក្តីមិនអើពើទេ ភិក្ខុណាបង្កាត់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវបិទទ្វារ ហើយអង្គុយនៅត្រង់ទ្វារឡើយ ភិក្ខុណាអង្គុយ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តជន្តាឃរវត្ត ដល់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃ ក្នុងផ្ទះជាទីរក្សាកាយ។

[៩៧] ភិក្ខុណាទៅកាន់ផ្ទះ ជាទីរក្សាកាយមុនគេ បើមានផេះនៅកកកុញ ភិក្ខុនោះ ត្រូវកើបផេះចោលចេញ បើផ្ទះជាទីរក្សាកាយមានសម្រាម ត្រូវបោសផ្ទះជាទីរក្សាកាយចេញ បើលានខាងក្រៅ (ផ្ទះជាទីរក្សាកាយ) មានសម្រាម ត្រូវបោសលានខាងក្រៅចេញ បើបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់មានសម្រាម ត្រូវបោសបន្ទប់ចេញ បើរោងនៃផ្ទះជាទីរក្សាកាយមានសម្រាម ត្រូវបោសរោងនៃផ្ទះជាទីរក្សាកាយចេញ ត្រូវសូន្យគ្រឿងលំអិតទុក ត្រូវលាយដីស្អិតទុក ត្រូវចាក់ទឹកទុកក្នុងស្នូកទឹក កាលនឹងចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំងទាំងខាងមុខ ទាំងខាងក្រោយ ហើយសឹមចូលទៅកាន់ផ្ទះជាទីរក្សាកាយ មិនត្រូវអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ពួកភិក្ខុថ្មីដោយអាសនៈ បើអាច (ធ្វើបរិកម្មបាន) ត្រូវធ្វើបរិកម្មដល់ភិក្ខុទាំងឡាយជាថេរៈ ក្នុងផ្ទះជាទីរក្សាកាយ កាលភិក្ខុនឹងចេញពីផ្ទះជាទីរក្សាកាយទៅ ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ហើយបិទបាំងទាំងខាងមុខ ទាំងខាងក្រោយ ហើយសឹមចេញពីផ្ទះជាទីរក្សាកាយ បើភិក្ខុអាច (ធ្វើបរិកម្មបាន) សូម្បីក្នុងទឹក ក៏ត្រូវធ្វើបរិកម្ម ដល់ភិក្ខុទាំងឡាយជាថេរៈបានដែរ មិនត្រូវងូតទឹកពីខាងមុខពួកភិក្ខុជាថេរៈ មិនត្រូវងូតទឹកពីខាងលើខ្សែទឹក កាលភិក្ខុងូតរួចហើយ ឡើងមកវិញ ត្រូវបើកផ្លូវឲ្យដល់ភិក្ខុទាំងឡាយដែលកំពុងចុះទៅ ភិក្ខុណា ចេញពីផ្ទះជាទីរក្សាកាយខាងក្រោយគេ បើផ្ទះជាទីរក្សាកាយមានភក់ ភិក្ខុនោះត្រូវលាងចេញ ត្រូវលាងស្នូកសម្រាប់ដាក់ដីស្អិត ហើយរៀបចំទុកដាក់តាំងសម្រាប់ផ្ទះជាទីរក្សាកាយ រួចលត់ភ្លើង ហើយបិទទ្វារសឹមចេញមក ម្នាលភិក្ខុទាំងឡាយ ទាំងនេះ ជាជន្តាឃរវត្តរបស់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងផ្ទះជាទីរក្សាកាយ។

# (វច្ចកុដិវត្តកថា ទី១០)

CS vin.cv.08.10 | ភាគ ទី១១

### (១០. វច្ចកុដិវត្តកថា)

[៩៨] សម័យនោះឯង ភិក្ខុ១រូប ជាតិជាព្រាហ្មណ៍ បន្ទោបង់វច្ចៈហើយ មិនប្រាថ្នាដើម្បីនឹងជម្រះចេញ ដោយគិតថា នរណានឹងហ៊ានប៉ះពាល់នូវរបស់អាក្រក់ មានក្លិនស្អុយនេះ។ ដង្កូវក៏តាំងនៅក្នុងវច្ចមគ្គ របស់ភិក្ខុនោះ។ ភិក្ខុនោះ ក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ។ ភិក្ខុទាំងឡាយសួរថា ម្នាលលោកដ៏មានអាយុ លោកបន្ទោបង់វច្ចៈ ហើយមិនជម្រះចេញទេដឹង។ ភិក្ខុនោះប្រាប់ថា ម្នាលលោកមានអាយុ យ៉ាងហ្នឹងហើយ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុបន្ទោបង់វច្ចៈ ហើយមិនជម្រះចេញសោះ។ ភិក្ខុទាំងឡាយនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកបន្ទោបង់វច្ចៈហើយ មិនជម្រះចេញ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ។បេ។ ព្រះមានព្រះភាគ ទ្រង់តិះដៀល ហើយធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុបន្ទោបង់វច្ចៈហើយ បើទឹកមាន[19] ភិក្ខុកុំគប្បីមិនជម្រះចេញ ភិក្ខុណាមិនជម្រះចេញ ត្រូវអាបត្តិទុក្កដ៍។

[៩៩] សម័យនោះ ភិក្ខុទាំងឡាយបន្ទោបង់វច្ចៈក្នុងវច្ចកុដិ តាមលំដាប់ចាស់ខ្ចី។ ភិក្ខុថ្មីទាំងឡាយ ដែលឈឺវច្ចៈមកដល់មុនហើយរង់ចាំ។ ភិក្ខុទាំងនោះខំអត់ទ្រាំវច្ចៈ ក៏ជ្រប់ដួលទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ភិក្ខុទាំងឡាយបន្ទោបង់វច្ចៈក្នុងវច្ចកុដិ តាមលំដាប់ចាស់ខ្ចី ភិក្ខុខ្ចីទាំងឡាយ ដែលឈឺវច្ចៈមកដល់មុនហើយរង់ចាំ ភិក្ខុទាំងនោះខំអត់ទ្រាំវច្ចៈ ក៏ជ្រប់ដួលទៅ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបន្ទោបង់វច្ចៈ ក្នុងវច្ចកុដិ តាមលំដាប់ចាស់ខ្ចីទេ ភិក្ខុណាបន្ទោបង់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបន្ទោបង់វច្ចៈ តាមលំដាប់ដែលមកដល់[20]

[១០០] សម័យនោះ ពួកឆព្វគ្គិយភិក្ខុ ចូលទៅកាន់វច្ចកុដិដោយរហ័សពេកខ្លះ សើយស្បង់ចូលទៅខ្លះ បន្ទោបង់វច្ចៈប្រឹងរមាត់ខ្លះ បន្ទោបង់វច្ចៈទាំងទំពាឈើស្ទន់ខ្លះ បន្ទោបង់វច្ចៈខាងក្រៅទវច្ចៈខ្លះ បន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈខ្លះ ស្តោះទឹកមាត់ក្នុងទបស្សាវៈខ្លះ កិតដោយឈើដ៏គ្រោតគ្រាតខ្លះ ចោលឈើសម្រាប់កិតក្នុងរណ្តៅវច្ចខ្លះ ចេញមកដោយរហ័សពេកខ្លះ សើយស្បង់ចេញមកខ្លះ ជម្រះធ្វើសំឡេងឮចបុចបុខ្លះ ទុកទឹកឲ្យសល់នៅក្នុងភាជន៍សម្រាប់ជម្រះខ្លះ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកឆព្វគ្គិយភិក្ខុ នឹងចូលទៅកាន់វច្ចកុដិដោយរហ័សពេកខ្លះ សើយស្បង់ចូលទៅកាន់ខ្លះ ខំប្រឹងរមាត់បន្ទោបង់វច្ចៈខ្លះ បន្ទោបង់វច្ចៈទាំងទំពាឈើស្ទន់ខ្លះ បន្ទោបង់វច្ចៈខាងក្រៅទវច្ចៈខ្លះ បន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈខ្លះ ស្តោះទឹកមាត់ក្នុងទបស្សាវៈខ្លះ កិតដោយឈើដ៏គ្រោតគ្រាតខ្លះ ចោលឈើសម្រាប់កិតក្នុងរណ្តៅវច្ចៈខ្លះ ចេញមកដោយរហ័សពេកខ្លះ សើយស្បង់ចេញមកខ្លះ ជម្រះធ្វើឲ្យឮសំឡេងចបុចបុខ្លះ ទុកទឹកឲ្យសល់នៅក្នុងភាជន៍សម្រាប់ជម្រះខ្លះ ដូច្នេះសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងនុ៎ះពិតមែនឬ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ។បេ។ ព្រះមានព្រះភាគ ទ្រង់តិះដៀលហើយ ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តនូវវច្ចកុដិវត្តដល់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃ ក្នុងវច្ចកុដិចុះ។

[១០១] ភិក្ខុណាទៅកាន់វច្ចកុដិ ភិក្ខុនោះត្រូវឈរខាងក្រៅ ហើយគ្រហែម ទោះបីភិក្ខុដែលអង្គុយនៅខាងក្នុង ក៏ត្រូវគ្រហែមតប ភិក្ខុនោះត្រូវពាក់ចីវរលើស្នួរចីវរ ឬខ្សែស្បៀង រួចកុំប្រញាប់ប្រញាល់ ចូលទៅកាន់វច្ចកុដិដោយស្រួល កុំចូលទៅដោយប្រញាប់ពេក មិនត្រូវសើយស្បង់ចូលទៅ ត្រូវឈរលើទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈ ហើយសឹមសើយស្បង់ មិនត្រូវខំប្រឹងរមាត់បន្ទោបង់វច្ចៈ មិនត្រូវបន្ទោបង់វច្ចៈទាំងទំពាឈើស្ទន់ មិនត្រូវបន្ទោបង់វច្ចៈខាងក្រៅទវច្ចៈ មិនត្រូវបន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈ មិនត្រូវស្តោះទឹកមាត់ក្នុងទបស្សាវៈ មិនត្រូវកិតដោយឈើគ្រោតគ្រាត មិនត្រូវចោលឈើសម្រាប់កិតក្នុងរណ្តៅវច្ចៈ ត្រូវឈរលើទ្រនាប់សម្រាប់បន្ទោបង់វច្ចៈ ហើយសឹមបិទបាំង (ស្បង់) មិនត្រូវចេញមកដោយរួសរាន់ពេក មិនត្រូវចេញមកទាំងសើយស្បង់ ត្រូវឈរលើទ្រនាប់សម្រាប់ជម្រះ ហើយសឹមសើយស្បង់ មិនត្រូវជម្រះធ្វើសំឡេងឲ្យឮចបុចបុ មិនត្រូវទុកទឹកឲ្យសល់នៅក្នុងភាជន៍សម្រាប់ជម្រះ ត្រូវឈរលើទ្រនាប់សម្រាប់ជម្រះ ហើយសឹមបិទបាំង បើវច្ចកុដិប្រឡាក់ ត្រូវលាងចេញ បើកញ្ជើសម្រាប់ដាក់ឈើសម្រាប់កិតពេញ ត្រូវចាក់ឈើសម្រាប់កិតចោលចេញ បើវច្ចកុដិមានសម្រាម ត្រូវបោសវច្ចកុដិចេញ បើលានវច្ចកុដិមានសម្រាម ត្រូវបោសលានវច្ចកុដិចេញ បើបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់មានសម្រាម ត្រូវបោសបន្ទប់ចេញ បើទឹកក្នុងក្អមសម្រាប់ជម្រះគ្មានទេ ត្រូវចាក់ទឹកដាក់ក្នុងក្អមសម្រាប់ជម្រះ ម្នាលភិក្ខុទាំងឡាយ ទាំងនេះ ជា វច្ចកុដិវត្ត របស់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្ត ដោយប្រពៃក្នុងវច្ចកុដិចុះ។

# (ឧបជ្ឈាយវត្តកថា ទី១១)

CS vin.cv.08.11 | ភាគ ទី១១

### (១១. ឧបជ្ឈាយវត្តកថា)

[១០២] សម័យនោះឯង ពួកសទ្ធិវិហារិក មិនប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកសទ្ធិវិហារិក មិនប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកសទ្ធិវិហារិក មិនប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ។ ព្រះពុទ្ធជាម្ចាស់ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មិនសមបើសទ្ធិវិហារិក មិនប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ។បេ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តនូវ ឧបជ្ឈាយវត្ត ដល់សទ្ធិវិហារិកទាំងឡាយ តាមទំនងដែលសទ្ធិវិហារិកទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយ។

[១០៣] ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍។ ឯសេចក្ដីប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍នោះ ដូច្នេះ សទ្ធិវិហារិក ត្រូវក្រោកអំពីព្រឹក ហើយដោះស្បែកជើង រួចធ្វើសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាង ហើយប្រគេនឈើស្ទន់ ប្រគេនទឹកសម្រាប់លុបមុខ ក្រាលអាសនៈ បើមានបបរ សទ្ធិវិហារិក ត្រូវលាងភាជន៍ ហើយបង្អោនបបរចូលទៅប្រគេន កាលបើឧបជ្ឈាយ៍ហុតបបររួចហើយ សទ្ធិវិហារិក ត្រូវប្រគេនទឹក ហើយទទួលយកភាជន៍ លើកបន្ទាបឲ្យស្រួល កុំឲ្យទង្គិច (អ្វីៗ) ហើយលាងឲ្យស្អាត រួចរៀបចំទុកដាក់ កាលបើឧបជ្ឈាយ៍ក្រោកចេញហើយ សទ្ធិវិហារិកត្រូវសាររអាសនៈចេញ បើប្រទេសនោះមានសម្រាម សទ្ធិវិហារិកត្រូវបោសប្រទេសនោះចេញ បើឧបជ្ឈាយ៍ចង់ចូលទៅកាន់ស្រុក សទ្ធិវិហារិកត្រូវប្រគេនស្បង់ ហើយទទួលស្បង់បន្លាស់មកវិញ ត្រូវប្រគេនវត្ថពន្ធចង្កេះ ត្រូវតម្រួតឧត្តរាសង្គៈ និងសង្ឃាដិ ហើយប្រគេន ត្រូវជូតបាត្រដែលទទឹក រួចហើយសឹមប្រគេន បើឧបជ្ឈាយ៍ចង់បានសទ្ធិវិហារិកជាបច្ឆាសមណៈ (តាមក្រោយឧបជ្ឈាយ៍) សទ្ធិវិហារិក ត្រូវបិទបាំងមណ្ឌល៣ គឺស្លៀកស្បង់ឲ្យជាបរិមណ្ឌល ក្រវាត់វត្ថពន្ធចង្កេះ ហើយតម្រួតឧត្តរាសង្គៈ និងសង្ឃាដិ ហើយឃ្លុំពាក់ក្ដុំ ហើយជូតបាត្រ ហើយកាន់យកទៅ ធ្វើជាបច្ឆាសមណៈ មិនត្រូវដើរឆ្ងាយពេក មិនត្រូវដើរជិតពេក ត្រូវចាំទទួលយកវត្ថុ ដែលគេដាក់ក្នុងបាត្រ កាលបើឧបជ្ឈាយ៍កំពុងនិយាយ សទ្ធិវិហារិកមិនត្រូវនិយាយស្កាត់ក្នុងចន្លោះៗឡើយ បើឧបជ្ឈាយ៍ កំពុងនិយាយពាក្យដែលជិតនឹងត្រូវអាបត្តិ សទ្ធិវិហារិកត្រូវឃាត់ កាលវិលត្រឡប់មកវិញ សទ្ធិវិហារិកត្រូវមកឲ្យបានមុន ហើយក្រាលអាសនៈចាំ រួចដម្កល់ទុកនូវទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង ហើយត្រូវក្រោកទៅទទួលបាត្រ និងចីវរ ត្រូវប្រគេនស្បង់បន្លាស់ ទទួលយកស្បង់ដែលស្លៀកមកវិញ បើចីវរទទឹក សទ្ធិវិហារិក ត្រូវសំដិលក្នុងកំដៅថ្ងៃមួយស្របក់ តែមិនត្រូវទុកចីវរក្នុងកំដៅថ្ងៃ (ឲ្យយូរពេក) ត្រូវបត់ចីវរទុក កាលនឹងបត់ចីវរ ត្រូវលើកជាយឲ្យហួសពីគ្នាមានប្រមាណ៤ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យបាក់ផ្នត់ចីវរពាក់កណ្ដាលឡើយ ត្រូវដាក់វត្ថពន្ធចង្កេះក្នុងផ្នត់ចីវរ បើមានអាហារបិណ្ឌបាត ហើយឧបជ្ឈាយ៍ចង់ឆាន់ សទ្ធិវិហារិកត្រូវប្រគេនទឹក ហើយបង្អោនអាហារបិណ្ឌបាតចូលទៅប្រគេន ត្រូវសួរឧបជ្ឈាយ៍ដោយទឹកសម្រាប់ឆាន់ កាលបើឧបជ្ឈាយ៍ឆាន់រួចហើយ សទ្ធិវិហារិក ត្រូវប្រគេនទឹក រួចទទួលយកបាត្រមកវិញ កាន់បន្ទាប កុំឲ្យទង្គិច (អ្វីៗ) លាងឲ្យស្អាត ជូតឲ្យស្ងួតទឹកចេញ ហើយហាលក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកបាត្រក្នុងកំដៅថ្ងៃ (យូរពេក) សទ្ធិវិហារិក ត្រូវទុកបាត្រ និងចីវរ កាលដែលទុកបាត្រ ត្រូវយកដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំងសិន ហើយសឹមទុកបាត្រ តែមិនត្រូវទុកក្នុងទីដែលមិនស្អាតឡើយ កាលនឹងទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នួរចីវរ ឬខ្សែស្មៀង រួចធ្វើជាយចីវរខាងនាយ ឲ្យជាផ្នត់មកខាងអាយ ហើយសឹមទុកចីវរចុះ កាលបើឧបជ្ឈាយ៍ក្រោកចេញហើយ សទ្ធិវិហារិកត្រូវសាររអាសនៈចេញ ត្រូវទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើងដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង បើប្រទេសនោះមានសម្រាម សទ្ធិវិហារិកត្រូវបោសប្រទេសនោះចេញ បើឧបជ្ឈាយ៍ចង់ស្រង់ទឹក សទ្ធិវិហារិកត្រូវចាត់ចែងទឹកសម្រាប់ស្រង់ប្រគេន បើឧបជ្ឈាយ៍ត្រូវការទឹកត្រជាក់ សទ្ធិវិហារិកត្រូវចាត់ចែងទឹកត្រជាក់ប្រគេន បើឧបជ្ឈាយ៍ត្រូវការទឹកក្ដៅ សទ្ធិវិហារិកត្រូវចាត់ចែងទឹកក្ដៅប្រគេន បើឧបជ្ឈាយ៍ចង់ចូលទៅកាន់ផ្ទះជាទីរក្សាកាយ សទ្ធិវិហារិក ត្រូវសូន្យគ្រឿងលំអិតត្រូវលាយដីស្អិត ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ហើយដើរតាមពីខាងក្រោយៗឧបជ្ឈាយ៍ ហើយប្រគេនតាំងសម្រាប់ផ្ទះជាទីរក្សាកាយ រួចទទួលចីវរមកទុកដាក់ ក្នុងទីដ៏សមគួរ ត្រូវប្រគេនគ្រឿងលំអិត ត្រូវប្រគេនដីស្អិត បើសទ្ធិវិហារិកអាចចូលទៅបាន ក៏គប្បីចូលទៅកាន់ផ្ទះជាទីរក្សាកាយ កាលនឹងចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំង(កាយ) ពីខាងមុខ ខាងក្រោយ រួចសឹមចូលទៅកាន់ផ្ទះជាទីរក្សាកាយចុះ មិនត្រូវអង្គុយច្រៀតបៀតភិក្ខុជាថេរៈទាំងឡាយ មិនត្រូវហាមឃាត់ភិក្ខុខ្ចី ដោយអាសនៈ ត្រូវធ្វើបរិកម្ម ដល់ឧបជ្ឈាយ៍ក្នុងផ្ទះជាទីរក្សាកាយ កាលឧបជ្ឈាយ៍ដើរចេញពីផ្ទះជាទីរក្សាកាយទៅ សទ្ធិវិហារិក ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ហើយបិទបាំង (កាយ) ពីខាងមុខ ខាងក្រោយ រួចសឹមថយចេញពីផ្ទះជាទីរក្សាកាយ សូម្បីក្នុងទឹក សទ្ធិវិហារិក ក៏ត្រូវធ្វើបរិកម្មដល់ឧបជ្ឈាយ៍ លុះស្រង់ទឹករួចហើយ ត្រូវឡើងមកមុន ហើយជូតកាយរបស់ខ្លួនឲ្យស្ងួតទឹកចេញ រួចស្លៀកស្បង់ ហើយត្រូវជូតទឹកពីកាយរបស់ឧបជ្ឈាយ៍ ត្រូវប្រគេនស្បង់ ប្រគេនសង្ឃាដិ (ទៅឧបជ្ឈាយ៍) សទ្ធិវិហារិក ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ដើរចេញមកមុន ហើយរៀបចំអាសនៈចាំ ត្រូវដំកល់ទុកនូវទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើងដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង ត្រូវសួរឧបជ្ឈាយ៍ដោយទឹកសម្រាប់ឆាន់ បើសទ្ធិវិហារិកចង់រៀនបាលី គប្បីឲ្យឧបជ្ឈាយ៍បង្រៀនចុះ បើសទ្ធិវិហារិកចង់រៀនអដ្ឋកថា គប្បីរៀនអដ្ឋកថា (នឹងឧបជ្ឈាយ៍)ចុះ ឧបជ្ឈាយ៍នៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើសទ្ធិវិហារិកអាច (នឹងបោសសំអាតបាន) ត្រូវបោសសំអាតចេញ កាលនឹងបោសសំអាតវិហារ ត្រូវនាំយកបាត្រ និងចីវរចេញមកមុន ទៅកម្កល់ទុកក្នុងទីដ៏សមគួរត្រូវនាំយកកម្រាលសម្រាប់អង្គុយ ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូកនិងខ្នើយ ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវលើកគ្រែបន្ទាប កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកដោយស្រួល ទៅទុកក្នុងទីដ៏សមគួរ ត្រូវលើកតាំងបន្ទាប កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ ហើយនាំយកឲ្យស្រួល ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកទ្រនាប់ជើងគ្រែ ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្ថោរសម្រាប់ស្ដោះទឹកមាត់ ទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវនាំយកក្ដារសម្រាប់ផ្អែក ទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវចំណាំទុកនូវកម្រាលផែនដី ដែលគេក្រាលទុកនៅកន្លែងណា ហើយនាំយកទៅទុកក្នុងទីដ៏សមគួរ បើគ្រឿងស្ទកស្ទាញ (មានសរសៃពីងពាងជាដើម) មាននៅក្នុងវិហារ សទ្ធិវិហារិកត្រូវបោសចេញពីពិតានជាមុន ត្រូវបោសចំណែកជ្រុងសន្លឹកបង្អួច បើជញ្ជាំងគេលាបដោយថ្នាំរួចហើយ ត្រឡប់ជាមានប្រឡាក់ដោយធូលីជាដើម សទ្ធិវិហារិក ត្រូវជ្រលក់កំណាត់សំពត់ពូត ហើយសឹមជូត បើផ្ទៃ (ផែនដី) ដែលគេបរិកម្មដោយវត្ថុមានពណ៌ខ្មៅរួចហើយ ត្រឡប់ជាមានប្រឡាក់ សទ្ធិវិហារិក ត្រូវជ្រលក់កំណាត់សំពត់ពូត ហើយសឹមជូត បើផ្ទៃ (ផែនដី) គេមិនបានធ្វើបរិកម្មទេ សទ្ធិវិហារិក ត្រូវប្រស់ទឹករួច សឹមជូត ដោយគិតថា វិហារកុំប្រឡាក់ដោយធូលីឡើយ ត្រូវប្រមូលសម្រាមយកទៅចាក់ចោល ក្នុងទីដ៏សមគួរ ត្រូវហាលកម្រាលផែនដី រួចហើយបោកជម្រះ គោះ (ដីចេញឲ្យស្អាត) រួចហើយ សឹមនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវហាលទ្រនាប់ជើងគ្រែ ហើយជូត (ឲ្យស្អាត) ហើយនាំយកទៅដម្កល់ទុកក្នុងទីដូចដែលវិញ ត្រូវហាលគ្រែ រួចហើយបោសជម្រះ គោះ (ឲ្យស្អាត) រួចលើកបន្ទាប កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកចេញដោយស្រួល ហើយតាំងទុកដូចដែលវិញ ត្រូវសំដិលហាលតាំង ហើយបោសជម្រះ គោះ (ឲ្យស្អាត) ហើយលើកបន្ទាប កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកដោយស្រួល ហើយរៀបចំទុកដាក់ដូចដែលវិញ ត្រូវសំដិលពូកនិងខ្នើយ រួចហើយបោសគោះហើ (ឲ្យស្អាត) រួចនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវសំដិលកម្រាលសម្រាប់ទ្រាប់អង្គុយ ហើយបោសជម្រះគោះ (ឲ្យស្អាត) រួចនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវហាលកន្ថោរសម្រាប់ស្ដោះទឹកមាត់ រួចជូត (ឲ្យស្អាត) ហើយនាំយកទៅដម្កល់ទុកក្នុងទីដូចដែលវិញ ត្រូវហាលក្ដារសម្រាប់ផ្អែក រួចជូត ហើយនាំយកទៅទុក ក្នុងទីដូចដែលវិញ ត្រូវទុកបាត្រ និងចីវរ (ឲ្យល្អ) កាលដែលនឹងទុកបាត្រ ត្រូវយកដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំង ហើយសឹមទុកបាត្រ តែមិនត្រូវទុកបាត្រលើទីដែលមិនស្អាតឡើយ កាលដែលនឹងទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នួរចីវរ ឬខ្សែស្មៀង ហើយបត់ជាយខាងនាយ ឲ្យជាផ្នត់មកខាងអាយ រួចសឹមទុកចីវរចុះ បើខ្យល់មានទាំងធូលី បក់មកអំពីទិសខាងកើត សទ្ធិវិហារិក

ត្រូវបិទបង្អួចទិសខាងកើត បើខ្យល់មានទាំងធូលីបក់មកពីទិសខាងលិច សទ្ធិវិហារិក ត្រូវបិទបង្អួចទិសខាងលិច បើខ្យល់មានទាំងធូលីបក់មកពីទិសខាងជើង សទ្ធិវិហារិក ត្រូវបិទបង្អួចទិសខាងជើង បើខ្យល់មានទាំងធូលីបក់មកពីទិសខាងត្បូង សទ្ធិវិហារិក ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ សទ្ធិវិហារិក ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទបង្អួចក្នុងវេលាយប់ បើរដូវក្តៅ សទ្ធិវិហារិក ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកបង្អួចក្នុងវេលាយប់ បើទីបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់មានសម្រាម ត្រូវបោសបន្ទប់ចេញ បើរោងឆាន់មានសម្រាម ត្រូវបោសរោងឆាន់ចេញ បើរោងភ្លើងមានសម្រាម ត្រូវបោសរោងភ្លើង បើបង្គន់មានសម្រាម ត្រូវបោសបង្គន់ចេញ បើគ្មានទឹកសម្រាប់ឆាន់ទេ ត្រូវដងទឹកសម្រាប់ឆាន់ទុក បើគ្មានទឹកសម្រាប់ប្រើប្រាស់ទេ ត្រូវដងទឹកសម្រាប់ប្រើប្រាស់ទុក បើទឹកក្នុងក្អមសម្រាប់ជម្រះមិនមាន សទ្ធិវិហារិក ត្រូវចាក់ទឹកទៅក្នុងក្អមសម្រាប់ជម្រះ បើសេចក្តីអផ្សុកកើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិក ត្រូវរម្ងាប់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយរម្ងាប់ ឬនិយាយធម្មកថាដល់ឧបជ្ឈាយ៍នោះ បើសេចក្តីសង្ស័យកើតឡើង ដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកត្រូវបន្ទោបង់ដោយខ្លួនឯង ឬត្រូវរកគេឲ្យជួយបន្ទោបង់ ឬនិយាយធម្មកថា ដល់ឧបជ្ឈាយ៍នោះ បើទិដ្ឋិអាក្រក់ កើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិក ត្រូវជួយដោះស្រាយដោយខ្លួនឯង ឬត្រូវឲ្យគេជួយដោះស្រាយ ឬនិយាយធម្មកថា ដល់ឧបជ្ឈាយ៍នោះ បើឧបជ្ឈាយ៍ត្រូវគរុកាបត្តិ គួរនឹងចូលបរិវាស សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគួរឲ្យបរិវាសដល់ ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់មូលាយបដិកស្សនៈ គឺទាញមកដាក់ក្នុងមូលាបត្តិ សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញឧបជ្ឈាយ៍ មកដាក់ក្នុងមូលាបត្តិ ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់មានត្ត សទ្ធិវិហារិក ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្ត ដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់អព្ភានកម្ម សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យអព្ភានកម្ម ដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើសង្ឃប្រាថ្នានឹងធ្វើកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ឧបជ្ឈាយ៍ សទ្ធិវិហារិក ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃមិនគប្បីធ្វើកម្ម ឬគប្បីបន្ទោនទៅដើម្បីកម្មស្រាល ដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ ប្រសិនបើសង្ឃបានធ្វើកម្ម គឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ឧបជ្ឈាយ៍នោះរួចហើយ សទ្ធិវិហារិក ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ឧបជ្ឈាយ៍ គប្បីប្រព្រឹត្តដោយប្រពៃ គប្បីសម្លបរោម គប្បីប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម សង្ឃគប្បីរម្ងាប់កម្មនោះ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់ឧបជ្ឈាយ៍គួរនឹងលាង សទ្ធិវិហារិកត្រូវលាង ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គួរនឹងលាងចីវររបស់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់ឧបជ្ឈាយ៍ ជាសំពត់គួរធ្វើ សទ្ធិវិហារិកត្រូវធ្វើ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គួរនឹងធ្វើចីវរដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់ឧបជ្ឈាយ៍គួរស្ងោរ សទ្ធិវិហារិក ត្រូវស្ងោរ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា នឹងគប្បីស្ងោរគ្រឿងជ្រលក់ របស់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់ឧបជ្ឈាយ៍គួរជ្រលក់ សទ្ធិវិហារិក ត្រូវជ្រលក់ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា នឹងគប្បីជ្រលក់ចីវររបស់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ កាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ ប្រែត្រឡប់ឲ្យសព្វល្អ បើដំណក់ទឹកមិនទាន់ដាច់ទេ សទ្ធិវិហារិក មិនត្រូវចៀសចេញទៅឡើយ សទ្ធិវិហារិកមិនទាន់ប្រាប់ឧបជ្ឈាយ៍ មិនត្រូវឲ្យបាត្រដល់ភិក្ខុណាមួយ មិនត្រូវទទួលយកបាត្ររបស់ភិក្ខុណាមួយ មិនត្រូវឲ្យចីវរ ដល់ភិក្ខុណាមួយ មិនត្រូវទទួលចីវររបស់ភិក្ខុណាមួយ មិនត្រូវឲ្យគ្រឿងបរិក្ខារ ដល់ភិក្ខុណាមួយ មិនត្រូវទទួលបរិក្ខាររបស់ភិក្ខុណាមួយ មិនត្រូវកោរសក់ ដល់ភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយកោរសក់ឲ្យ មិនត្រូវធ្វើបរិកម្ម ដល់ភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយ ធ្វើបរិកម្ម (ដល់ខ្លួន) មិនត្រូវធ្វើសេចក្តីខ្វាល់ខ្វាយ ដល់ភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយ ធ្វើសេចក្តីខ្វល់ខ្វាយ (ដល់ខ្លួន) មិនត្រូវធ្វើជាបច្ឆាសមណៈរបស់ភិក្ខុណាមួយ មិនត្រូវយកភិក្ខុណាមួយ ជាបច្ឆាសមណៈ (របស់ខ្លួន) មិនត្រូវនាំចង្ហាន់បិណ្ឌបាត ទៅឲ្យភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយ នាំបិណ្ឌបាតមកឲ្យ (ខ្លួន) សទ្ធិវិហារិកមិនបានលាឧបជ្ឈាយ៍ មិនត្រូវចូលទៅកាន់ស្រុក មិនត្រូវទៅកាន់ព្រៃស្មសាន មិនត្រូវចៀសចេញទៅកាន់ទិស បើឧបជ្ឈាយ៍មានជម្ងឺ សទ្ធិវិហារិក ត្រូវនៅបម្រើអស់កាល ដែលលោកមានជីវិតរស់នៅ ត្រូវរង់ចាំលោកទាល់តែសះជារោគ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជា ឧបជ្ឈាយវត្ត របស់សទ្ធិវិហារិកទាំងឡាយ តាមទំនងដែលសទ្ធិវិហារិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយ។

# (សទ្ធិវិហារិកវត្តកថា ទី១២)

CS vin.cv.08.12 | ភាគ ទី១១

### (១២. សទ្ធិវិហារិកវត្តកថា)

[១០៤] សម័យនោះឯង ឧបជ្ឈាយ៍ទាំងឡាយ ពុំបានប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិកទាំងឡាយឡើយ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើឧបជ្ឈាយ៍ទាំងឡាយ មិនប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិកទាំងឡាយសោះ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ឧបជ្ឈាយ៍ទាំងឡាយ មិនប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិកទាំងឡាយ ពិតមែនឬ។ ពួកភិក្ខុក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្ត សទ្ធិវិហារិកវត្ត ដល់ឧបជ្ឈាយ៍ទាំងឡាយ តាមទំនងដែលឧបជ្ឈាយ៍ទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងពួកភិក្ខុជាសទ្ធិវិហារិក។

[១០៥] ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិក។ ឯការដែលប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិកនោះ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវសង្គ្រោះ និងអនុគ្រោះសទ្ធិវិហារិក ដោយបាលី ដោយអដ្ឋកថា ដោយធម្មទាន ដោយការប្រៀនប្រដៅ បើឧបជ្ឈាយ៍មានបាត្រ សទ្ធិវិហារិកគ្មានបាត្រ ឧបជ្ឈាយ៍ត្រូវឲ្យបាត្រទៅសទ្ធិវិហារិក ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា បាត្រគប្បីកើតដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍មានចីវរ សទ្ធិវិហារិកគ្មានចីវរ ឧបជ្ឈាយ៍ត្រូវឲ្យចីវរទៅសទ្ធិវិហារិក ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវរគប្បីកើតដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍មានគ្រឿងបរិក្ខារ សទ្ធិវិហារិកគ្មានគ្រឿងបរិក្ខារ ឧបជ្ឈាយ៍ត្រូវឲ្យគ្រឿងបរិក្ខារទៅសទ្ធិវិហារិក ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងបរិក្ខារ គប្បីកើតឡើងដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកមានជម្ងឺ ឧបជ្ឈាយ៍ត្រូវក្រោកឡើងពីព្រឹក ហើយឲ្យឈើស្ទន់ ឲ្យទឹកលុបមុខ ក្រាលអាសនៈ បើមានបបរ ត្រូវឧបជ្ឈាយ៍លាងភាជន៍ ហើយបង្អោនបបរទៅឲ្យ កាលសទ្ធិវិហារិកហុតបបររួចហើយ ឧបជ្ឈាយ៍ត្រូវឲ្យទឹក រួចទទួលភាជន៍យកមកវិញ កាន់បន្ទាប កុំឲ្យទង្គិច (នឹងអ្វីៗ) លាងរួចហើយ ទុកដាក់ឲ្យល្អ កាលបើសទ្ធិវិហារិកក្រោកចេញហើយ ឧបជ្ឈាយ៍ត្រូវសារអាសនៈទុក បើប្រទេសនោះមានសម្រាម ឧបជ្ឈាយ៍ត្រូវបោសប្រទេសនោះចេញ បើសទ្ធិ

វិហារិក មានប្រាថ្នានឹងចូលទៅកាន់ស្រុក ឧបជ្ឈាយ៍ត្រូវឲ្យស្បង់សម្រាប់ស្លៀក ត្រូវទទួលយកស្បង់បន្លាស់មកវិញ ត្រូវឲ្យវត្ថពន្ធចង្កេះ ត្រូវដម្រួតឧត្តរាសង្គៈ និងសង្ឃាដិហើយឲ្យ ត្រូវជូតបាត្រដែលទទឹក ហើយសឹមឲ្យ ឧបជ្ឈាយ៍ត្រូវក្រាលអាសនៈទុក ដោយគិតថា ពេលថ្មើនេះ សទ្ធិវិហារិកមុខជានឹងត្រឡប់មកវិញ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវក្រោកឡើង ទៅទទួលបាត្រ និងចីវរ ត្រូវឲ្យស្បង់បន្លាស់ ហើយទទួលយកស្បង់ ដែលស្លៀកមកវិញ បើចីវរសើម ឬជាំដាម (ដោយញើសក្អែល) ត្រូវសំដិលចីវរក្នុងកំដៅថ្ងៃ១ស្របក់ តែកុំទុកចីវរក្នុងកំដៅថ្ងៃ (ឲ្យយូរពេក) ត្រូវបត់ចីវរ (យកមកទុក) កាលនឹងបត់ចីវរ ត្រូវលើកជាយចីវរឲ្យហួសពីគ្នាប្រមាណ៤ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យបាក់ផ្នត់ពាក់កណ្តាលឡើយ ត្រូវធ្វើវត្ថពន្ធចង្កេះក្នុងផ្នត់ចីវរ បើមានអាហារបិណ្ឌបាត សទ្ធិវិហារិកត្រូវការនឹងឆាន់ ឧបជ្ឈាយ៍ត្រូវឲ្យទឹក ហើយបង្អោនអាហារបិណ្ឌបាតចូលទៅឲ្យ ត្រូវសួរសទ្ធិវិហារិកដោយទឹកឆាន់ លុះសទ្ធិវិហារិកឆាន់រួចហើយ ឧបជ្ឈាយ៍ត្រូវឲ្យទឹក ហើយទទួលយកបាត្រមកវិញ កាន់បន្ទាប កុំឲ្យទង្គិច (នឹងអ្វីៗ) លាងឲ្យស្អាត ហើយជូតទឹកឲ្យស្ងួត ហើយហាលថ្ងៃ១ស្របក់ តែមិនត្រូវទុកបាត្រក្នុងកំដៅថ្ងៃ (ឲ្យយូរពេកឡើយ) ត្រូវទុកដាក់បាត្រ និងចីវរ កាលនឹងរៀបទុកដាក់បាត្រ ដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំង ហើយសឹមទុកដាក់បាត្រ តែមិនត្រូវទុកដាក់បាត្រលើទីដែលមិនស្អាតឡើយ កាលនឹងរៀបចំទុកដាក់ចីវរ ដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នួរចីវរ ឬខ្សែស្ទៀង ហើយធ្វើជាយខាងនាយ ឲ្យជាផ្នត់មកខាងអាយ រួចសឹមទុកដាក់ចីវរ កាលសទ្ធិវិហារិកក្រោកឡើង ឧបជ្ឈាយ៍ត្រូវសាររអាសនៈ រៀបចំទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង បើប្រទេសនោះមានសម្រាម ឧបជ្ឈាយ៍ត្រូវបោសប្រទេសនោះចេញ បើសទ្ធិវិហារិកចង់ងូតទឹក ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកសម្រាប់ងូតឲ្យ បើសទ្ធិវិហារិកត្រូវការទឹកត្រជាក់ ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកត្រជាក់ឲ្យ បើសទ្ធិវិហារិកត្រូវការទឹកក្តៅ ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកក្តៅឲ្យ បើសទ្ធិវិហារិកចង់ចូលទៅកាន់ផ្ទះជាទីរក្សាកាយ ឧបជ្ឈាយ៍ត្រូវសូន្យគ្រឿងលំអិត ត្រូវលាយដីស្អិត ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយទៅ ហើយប្រគល់តាំងសម្រាប់ផ្ទះជាទីរក្សាកាយ ដល់(សទ្ធិវិហារិក) ហើយទទួលយកចីវរមកទុកដាក់ក្នុងទីដ៏សមគួរ ឧបជ្ឈាយ៍ត្រូវឲ្យគ្រឿងលំអិត ត្រូវឲ្យដីស្អិតដល់ (សទ្ធិវិហារិក) បើឧបជ្ឈាយ៍អាចនឹងចូលទៅកាន់ (ផ្ទះជាទីរក្សាកាយបាន) ត្រូវចូលទៅកាន់ផ្ទះជាទីរក្សាកាយចុះ កាលនឹងចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវយកដីស្អិតលាបមុខ រួចបិទបាំង (កាយ) ទាំងខាងមុខ ទាំងខាងក្រោយ ហើយសឹមចូលទៅកាន់ផ្ទះជាទីរក្សាកាយ មិនត្រូវអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវហាមពួកភិក្ខុខ្ចីដោយអាសនៈ ត្រូវធ្វើបរិកម្ម ដល់សទ្ធិវិហារិកក្នុងផ្ទះជាទីរក្សាកាយ កាលនឹងចេញពីផ្ទះជាទីរក្សាកាយ ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយចេញ ហើយបិទបាំង (កាយ) ទាំងខាងមុខ ខាងក្រោយ រួចសឹមចេញពីផ្ទះជាទីរក្សាកាយ សូម្បីក្នុងទឹក ឧបជ្ឈាយ៍ ក៏ត្រូវតែធ្វើបរិកម្ម ដល់សទ្ធិវិហារិកដែរ ងូតរួចហើយ ឧបជ្ឈាយ៍ ត្រូវឡើងមកមុន ជូតកាយរបស់ខ្លួនឲ្យស្ងួតទឹក ហើយស្លៀកស្បង់ រួចត្រូវជូតទឹកអំពីកាយរបស់សទ្ធិវិហារិក ហុចស្បង់សម្រាប់ស្លៀក ហុចសង្ឃាដិទៅឲ្យ (សទ្ធិវិហារិក) ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយចេញមកមុន ហើយក្រាលអាសនៈចាំ ត្រូវដម្កល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវសួរសទ្ធិវិហារិកដោយទឹកសម្រាប់ឆាន់ សទ្ធិវិហារិកនៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើឧបជ្ឈាយ៍អាចនឹង (បោសសំអាតបាន) ត្រូវសំអាតចេញ កាលនឹងសំអាតវិហារ ត្រូវនាំយកបាត្រ និងចីវរចេញជាមុន ទៅទុកក្នុងទីដ៏សមគួរ។បេ។ បើទឹកក្នុងក្អមសម្រាប់ជម្រះគ្មាន ឧបជ្ឈាយ៍ ត្រូវចាក់ទឹកទៅក្នុងក្អមសម្រាប់ជម្រះ បើសេចក្តីអផ្សុកកើតឡើងដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវរម្ងាប់ ដោយខ្លួនឯង ឬត្រូវឲ្យគេជួយរម្ងាប់ ឬធ្វើធម្មកថា ដល់សទ្ធិវិហារិកនោះ បើសេចក្តីសង្ស័យកើតឡើង ដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវបន្ទោបង់ដោយខ្លួនឯង ឬឲ្យគេជួយបន្ទោបង់ ឬធ្វើធម្មកថា ដល់សទ្ធិវិហារិកនោះ បើទិដ្ឋិ (អាក្រក់) កើតឡើងដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវដោះស្រាយ ដោយខ្លួនឯង ឬឲ្យគេជួយដោះស្រាយ ឬធ្វើធម្មកថា ដល់សទ្ធិវិហារិកនោះ បើសទ្ធិវិហារិកត្រូវគរុកាបត្តិ គួរនឹងចូលបរិវាស ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគួរឲ្យបរិវាស ដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់មូលាយបដិកស្សនៈ គឺទាញមកដាក់ក្នុងមូលាបត្តិ ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញសទ្ធិវិហារិក មកដាក់ក្នុងមូលាបត្តិ ដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់មានត្ត ឧបជ្ឈាយ៍ ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្ត ដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិក គួរដល់អព្ភានកម្ម ឧបជ្ឈាយ៍ត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យអព្ភានកម្ម ដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើសង្ឃចង់ធ្វើកម្ម គឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សូមកុំឲ្យសង្ឃធ្វើកម្ម ឬបង្អោនទៅ ដើម្បីកម្មស្រាល ដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ ម្យ៉ាងទៀត តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី សង្ឃបានធ្វើ ដល់សទ្ធិវិហារិកនោះរួចហើយ ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សទ្ធិវិហារិក គប្បីប្រព្រឹត្តដោយប្រពៃ គប្បីសម្លួបរោម គប្បីប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម សង្ឃគប្បីរម្ងាប់នូវកម្មនោះ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់សទ្ធិវិហារិកគួរនឹងលាង ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីលាងយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់សទ្ធិវិហារិកគួរនឹងលាង ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់សទ្ធិវិហារិកគួរនឹងធ្វើ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីធ្វើចីវរយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់សទ្ធិវិហារិកគួរនឹងធ្វើដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់សទ្ធិវិហារិក គួរនឹងស្ងោរ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកត្រូវស្ងោរយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងជ្រលក់របស់សទ្ធិវិហារិក គួរនឹងស្ងោរដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់សទ្ធិវិហារិកគួរនឹងជ្រលក់ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកត្រូវជ្រលក់ចីវរយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់សទ្ធិវិហារិក គួរនឹងជ្រលក់ដោយឧបាយដូចម្តេចហ្ន៎ កាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ប្រែត្រឡប់ឲ្យសព្វស្មើល្អ បើដំណក់ទឹកស្រក់មិនទាន់អស់ ឧបជ្ឈាយ៍កុំអាលដើរចេញ បើសទ្ធិវិហារិក មានជម្ងឺ ឧបជ្ឈាយ៍ត្រូវថែទាំដរាបអស់កាលដែលមានជីវិតរស់នៅ ត្រូវរង់ចាំដរាបសទ្ធិវិហារិកសះជាជម្ងឺ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជា សទ្ធិវិហារិកវត្ត របស់ឧបជ្ឈាយ៍ តាមទំនងដែលឧបជ្ឈាយ៍ទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិកទាំងឡាយ។

ចប់ ភាណវារៈជាគំរប់ពីរ។

# (អាចរិយវត្តកថា ទី១៣)

CS vin.cv.08.13 | ភាគ ទី១១

**(១៣. អាចរិយវត្តកថា)**

[១០៦] សម័យនោះឯង ពួកអន្តេវាសិក មិនបានប្រព្រឹត្តដោយប្រពៃក្នុងអាចារ្យទាំងឡាយ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ ពួកអន្តេវាសិក មិនប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យទាំងឡាយសោះ។ គ្រានោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអន្តេវាសិក មិនបានប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ។បេ។ ទ្រង់បន្ទោស ហើយធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្ត អាចរិយវត្ត ដល់ពួកភិក្ខុជាអន្តេវាសិក តាមទំនងដែលពួកភិក្ខុជាអន្តេវាសិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យទាំងឡាយ។

[១០៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអន្តេវាសិក ត្រូវប្រព្រឹត្តដោយប្រពៃក្នុងអាចារ្យ។ ឯការប្រព្រឹត្តដោយប្រពៃ ក្នុងអាច្យនោះ ដូច្នេះ គឺអន្តេវាសិកត្រូវក្រោកអំពីព្រឹក ហើយដោះស្បែកជើង ធ្វើសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាង ហើយប្រគេនឈើស្ទន់ ប្រគេនទឹកសម្រាប់លាងមុខ ក្រាលអាសនៈទុក បើបបរមាន អន្តេវាសិកត្រូវលាងភាជន៍ ហើយបង្អោនបបរទៅប្រគេន កាលបើអាចារ្យហុតបបររួចហើយ អន្តេវាសិកត្រូវប្រគេនទឹក ហើយទទួលភាជន៍មកវិញ កាន់បន្ទាប កុំឲ្យទង្គិចនឹង (អ្វីៗ) ហើយលាងឲ្យស្អាត រួចរៀបចំទុកដាក់ កាលបើអាចារ្យក្រោកចេញហើយ អន្តេវាសិកត្រូវសារអាសនៈចេញ បើប្រទេសនោះមានសម្រាម អន្តេវាសិក ត្រូវបោសប្រទេសនោះចេញ បើអាចារ្យចង់ចូលទៅកាន់ស្រុក អន្តេវាសិក ត្រូវប្រគេនស្បង់សម្រាប់ស្លៀក ហើយទទួលយកស្បង់បន្លាស់មកវិញ ត្រូវប្រគេនវត្តពន្ធចង្កេះ តម្រួតឧត្តរាសង្គៈ និងសង្ឃាដិហើយប្រគេន ត្រូវជូតបាត្រដែលទទឹក ហើយសឹមប្រគេន បើអាចារ្យចង់បានភិក្ខុជាបច្ឆាសមណៈ អន្តេវាសិកត្រូវបិទបាំងមណ្ឌលបី គឺស្លៀកស្បង់ឲ្យជាបរិមណ្ឌល ក្រវាត់វត្តពន្ធចង្កេះ ហើយតម្រួតឧត្តរាសង្គៈ និងសង្ឃាដិ ហើយឃ្លុំ ពាក់ឡេវក្ដុំ លាងបាត្រ ហើយកាន់យកទៅធ្វើជាបច្ឆាសមណៈ នៃអាចារ្យ កុំដើរឆ្ងាយពេក កុំដើរជិតពេក ត្រូវចាំទទួលយកវត្ថុ ដែលគេដាក់ចុះក្នុងបាត្រ កាលបើអាចារ្យកំពុងនិយាយ អន្តេវាសិក មិនត្រូវនិយាយស្កាត់ពាក្យក្នុងចន្លោះៗឡើយ កាលបើអាចារ្យនិយាយពាក្យ ដែលជិតនឹងត្រូវអាបត្តិ អន្តេវាសិកត្រូវឃាត់ កាលនឹងត្រឡប់មក អន្តេវាសិក ត្រូវស្រូតមកមុន ហើយក្រាលអាសនៈចាំ ត្រូវដម្កល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង រួចក្រោកទៅទទួលបាត្រ និងចីវរ ប្រគេនស្បង់បន្លាស់ ទទួលយកស្បង់ដែលស្លៀកមកវិញ បើចីវរសើម ឬជាំដាម (ដោយញើស) អន្តេវាសិក ត្រូវសំដិលក្នុងទីមានកំដៅថ្ងៃមួយស្របក់ តែកុំទុកចីវរក្នុងទីមានកំដៅថ្ងៃ (ឲ្យយូរពេក) ត្រូវបត់ចីវរទុក កាលនឹងបត់ចីវរ ត្រូវលើកជាយ ឲ្យហួសពីគ្នាប្រមាណ៤ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យចីវរបាក់ផ្នត់ត្រង់ពាក់កណ្ដាលឡើយ ត្រូវធ្វើវត្តពន្ធចង្កេះក្នុងផ្នត់ចីវរ បើមានចង្ហាន់បិណ្ឌបាត ហើយអាចារ្យចង់ឆាន់ អន្តេវាសិក ត្រូវប្រគេនទឹក ហើយបង្អោនបិណ្ឌបាតទៅប្រគេន ត្រូវសួរអាចារ្យដោយទឹកឆាន់ លុះអាចារ្យឆាន់រួចហើយ អន្តេវាសិកត្រូវប្រគេនទឹក ហើយទទួលយកបាត្រមកវិញ កាន់បន្ទាប កុំឲ្យទង្គិចទង្គក (នឹងអ្វីៗ) ហើយលាងឲ្យស្អាត ជូតឲ្យស្ងួតទឹក រួចហាលក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកបាត្រចោលក្នុងកំដៅថ្ងៃ (ឲ្យយូរពេក) អន្តេវាសិក ត្រូវទុកបាត្រ និងចីវរ កាលនឹងទុកបាត្រ ដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំង ហើយសឹមទុកបាត្រ តែមិនត្រូវទុកបាត្រ ក្នុងទីដែលមិនស្អាតឡើយ កាលនឹងទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នួរចីវរ ឬខ្សែស្ទៀង ធ្វើជាយខាងនាយ ឲ្យជាផ្នត់មកខាងអាយ ហើយសឹមទុកចីវរចុះ កាលបើអាចារ្យក្រោកចេញ អន្តេវាសិក ត្រូវសារអាសនៈចេញ ត្រូវទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង បើប្រទេសនោះមានសម្រាម អន្តេវាសិកត្រូវបោសប្រទេសនោះចេញ បើអាចារ្យចង់ស្រង់ទឹក អន្តេវាសិក ត្រូវចាត់ចែងទឹកសម្រាប់ស្រង់ប្រគេន បើអាចារ្យត្រូវការទឹកត្រជាក់ អន្តេវាសិកត្រូវចាត់ចែងទឹកត្រជាក់ប្រគេន បើអាចារ្យត្រូវការទឹកក្ដៅ អន្តេវាសិកត្រូវចាត់ចែងទឹកក្ដៅប្រគេន បើអាចារ្យចង់ចូលទៅកាន់ផ្ទះជាទីរក្សាកាយ អន្តេវាសិកត្រូវសូន្យគ្រឿងលំអិត ត្រូវលាយដីស្អិត ហើយកាន់យកតាំង សម្រាប់ផ្ទះជាទីរក្សាកាយ ដើរតាមក្រោយអាចារ្យ ហើយប្រគេនតាំងសម្រាប់ផ្ទះជាទីរក្សាកាយ រួចទទួលយកចីវរមកទុកដាក់ក្នុងទីដ៏សមគួរ ត្រូវប្រគេនគ្រឿងលំអិត ត្រូវប្រគេនដីស្អិត បើអន្តេវាសិកអាច (នឹងចូលទៅបាន) គប្បីចូលទៅកាន់ផ្ទះជាទីរក្សាកាយ កាលនឹងចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំង (កាយ) ទាំងខាងមុខ ទាំងខាងក្រោយ រួចសឹមចូលទៅកាន់ផ្ទះជាទីរក្សាកាយ មិនត្រូវអង្គុយច្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ពួកភិក្ខុខ្ចី ដោយអាសនៈ ត្រូវធ្វើបរិកម្ម ដល់អាចារ្យក្នុងផ្ទះជាទីរក្សាកាយ កាលនឹងចេញពីផ្ទះជាទីរក្សាកាយ អន្តេវាសិកត្រូវកាន់យកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ហើយបិទបាំង (កាយ) ទាំងខាងមុខ ទាំងខាងក្រោយ រួចសឹមចេញពីផ្ទះជាទីរក្សាកាយ សូម្បីក្នុងទឹក អន្តេវាសិក ក៏ត្រូវតែធ្វើបរិកម្ម ដល់អាចារ្យដែរ កាលអន្តេវាសិកងូតរួចហើយ ត្រូវឡើងមកមុន ហើយជូតកាយរបស់ខ្លួនឲ្យស្ងួតទឹក ស្លៀកស្បង់ រួចត្រូវជូតទឹកពីកាយរបស់អាចារ្យ ត្រូវប្រគេនស្បង់ ប្រគេនសង្ឃាដិ ត្រូវកាន់យកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ដើរចេញមកមុន ហើយក្រាលអាសនៈចាំ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវសួរអាចារ្យដោយទឹកសម្រាប់ឆាន់ បើអន្តេវាសិក ចង់ឲ្យអាចារ្យបង្រៀនបាលី ត្រូវឲ្យលោកបង្រៀនចុះ បើអន្តេវាសិក ចង់រៀនអដ្ឋកថា គប្បីរៀនអដ្ឋកថា(នឹងអាចារ្យចុះ) អាចារ្យនៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើអន្តេវាសិកអាច (នឹងបោសសំអាតបាន) ត្រូវបោសសំអាតចេញ កាលនឹងបោសសំអាតវិហារ ត្រូវនាំយកបាត្រ និងចីវរចេញមកមុន ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកម្រាលសម្រាប់អង្គុយ ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូក និងខ្នើយ ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវលើកគ្រែបន្ទាប កុំឲ្យទង្គិចទង្គក កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកឲ្យស្រួល ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវលើកបន្ទាបតាំង កុំឲ្យទង្គិចទង្គក កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកឲ្យស្រួល ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកទ្រនាប់ជើងគ្រែ ទៅដម្កល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្ថោរ សម្រាប់ស្ដោះទឹកមាត់ ទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកក្ដារសម្រាប់ផ្អែកទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវកំណត់ចាំទុកនូវកម្រាលផែនដី ដែលគេក្រាលទុកនៅកន្លែងណា ហើយនាំយកទៅទុកក្នុងទីដ៏សមគួរ បើក្នុងវិហារមានគ្រឿងស្មុកស្មាញ (មានសរសៃពីងពាងជាដើម) អន្តេវាសិក ត្រូវបោសពីពិតានចុះមកជាមុន ត្រូវជូតចំណែកជ្រុងសន្លឹកបង្អួច បើជញ្ជាំង ដែលគេបរិកម្មដោយថ្នាំរួចហើយ ត្រឡប់ជាមានប្រឡាក់ អន្តេវាសិកត្រូវជ្រលក់កំណាត់សំពត់ ពូតហើយសឹមជូត បើផ្ទៃផែនដី ដែលគេបរិកម្មដោយវត្ថុមានពណ៌ខ្មៅរួចហើយ ត្រឡប់ជាមានប្រឡាក់ អន្តេវាសិក ត្រូវជ្រលក់កំណាត់សំពត់ ពូតចេញ រួចហើយសឹមជូត បើផ្ទៃគេមិនបានបរិកម្មទេ អន្តេវាសិក ត្រូវប្រស់ដោយទឹក រួចសឹមជូត ដោយគិតថា វិហារកុំប្រឡាក់ដោយធូលីឡើយ ត្រូវប្រមូលសម្រាមយកទៅចាក់ចោលក្នុងទីដ៏សមគួរ លុះអន្តេវាសិក ហាលកម្រាលផែនដី ហើយ ជម្រះគោះ (ដីចេញឲ្យស្អាត) រួចហើយសឹមនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវហាលទ្រនាប់ជើងគ្រែ រួចហើយជូត (ឲ្យស្អាត) ហើយនាំយកទៅដម្កល់ទុកក្នុងទីដូចដែលវិញ ត្រូវហាលគ្រែ រួចហើយជម្រះគោះ (ឲ្យស្អាត) រួចលើកបន្ទាប កុំឲ្យទង្គិចទង្គក កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកទៅដោយស្រួល ហើយតាំងទុកដូចដែលវិញ ត្រូវហាលតាំង រួចហើយត្រូវជម្រះគោះ (ឲ្យស្អាត) ហើយលើកបន្ទាប កុំឲ្យទង្គិចទង្គក កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកទៅដោយស្រួល តាំងទុកដូចដែលវិញ

ត្រូវហាលពូក និងខ្នើយ ហើយជម្រះគោះ (ឲ្យស្អាត) ហើយនាំយកទៅរៀបចំទុកដាក់ដូចដែលវិញ ត្រូវសំដិលកម្រាលសម្រាប់ទ្រាប់អង្គុយ ហើយជម្រះគោះ (ឲ្យស្អាត) រួចនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវហាលកន្តោរសម្រាប់ស្តោះទឹកមាត់ រួចហើយជូត (ឲ្យស្អាត) ហើយនាំយកទៅដម្កល់ទុកក្នុងទីដូចដែលវិញ ត្រូវហាលផែនក្តារសម្រាប់ផ្អែក រួចជូត (ឲ្យស្អាត) ហើយនាំយកទៅដម្កល់ទុកក្នុងទីដូចដែលវិញ អន្តេវាសិក ត្រូវទុកដាក់បាត្រ និងចីវរ កាលនឹងទុកបាត្រ ត្រូវយកដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំង រួចហើយសឹមទុកដាក់បាត្រ តែមិនត្រូវទុកបាត្រលើទីដែលមិនស្អាតឡើយ អន្តេវាសិក កាលនឹងទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នួរចីវរ ឬខ្សែស្បៀង ហើយធ្វើជាយខាងនាយ ឲ្យជាផ្នត់មកខាងអាយ ហើយសឹមទុកចីវរ បើមានខ្យល់ទាំងធូលីបក់មកពីទិសខាងកើត អន្តេវាសិក ត្រូវបិទបង្អួចទិសខាងកើត បើខ្យល់មានទាំងធូលីបក់មកពីទិសខាងលិច អន្តេវាសិក ត្រូវបិទបង្អួចទិសខាងលិច បើខ្យល់មានទាំងធូលីបក់មកពីទិសខាងជើង អន្តេវាសិក ត្រូវបិទបង្អួចទិសខាងជើង បើខ្យល់មានទាំងធូលីបក់មកពីទិសខាងត្បូង អន្តេវាសិក ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ អន្តេវាសិកត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្តៅ អន្តេវាសិកត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកក្នុងវេលាយប់ បើទីបរិវេណមានសម្រាម អន្តេវាសិកត្រូវបោសបរិវេណចេញ បើបន្ទប់មានសម្រាម អន្តេវាសិកត្រូវបោសបន្ទប់ចេញ បើរោងឆាន់មានសម្រាម អន្តេវាសិកត្រូវបោសរោងឆាន់ចេញ បើរោងភ្លើងមានសម្រាម អន្តេវាសិកត្រូវបោសរោងភ្លើងចេញ បើវច្ចកុដិមានសម្រាម អន្តេវាសិកត្រូវបោសវច្ចកុដិចេញ បើគ្មានទឹកសម្រាប់ឆាន់ អន្តេវាសិកត្រូវដំកល់ទឹកសម្រាប់ឆាន់ទុក បើគ្មានទឹកសម្រាប់ប្រើប្រាស់ អន្តេវាសិកត្រូវដំកល់ទឹកសម្រាប់ប្រើប្រាស់ បើទឹកក្នុងក្អមសម្រាប់ជម្រះគ្មាន អន្តេវាសិក ត្រូវចាក់ទឹកក្នុងក្អមសម្រាប់ជម្រះ បើសេចក្តីអផ្សុកកើតឡើងដល់អាចារ្យ អន្តេវាសិក ត្រូវបំបាត់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយបំបាត់ ឬធ្វើធម្មកថា ដល់អាចារ្យនោះ បើសេចក្តីសង្ស័យកើតឡើងដល់អាចារ្យ អន្តេវាសិកត្រូវបន្ទោបង់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយបន្ទោបង់ ឬធ្វើធម្មកថាដល់អាចារ្យនោះ បើទិដ្ឋិ (សេចក្តីយល់ខុស) កើតឡើងដល់អាចារ្យ អន្តេវាសិក ត្រូវដោះស្រាយដោយខ្លួនឯង ឬត្រូវឲ្យគេជួយដោះស្រាយ ឬធ្វើធម្មកថាដល់អាចារ្យនោះ បើអាចារ្យត្រូវគរុកាបត្តិ គួរដល់បរិវាសកម្ម អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យបរិវាសកម្មដល់អាចារ្យដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យគួរដល់មូលាយបដិកស្សនៈ (ទាញមកដាក់ក្នុងមូលាបត្តិ) អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញអាចារ្យ មកដាក់ក្នុងមូលាបត្តិ ដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យគួរដល់មានត្ត អន្តេវាសិក ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្តដល់អាចារ្យ ដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យគួរដល់អព្ភានកម្ម អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីធ្វើអព្ភានកម្ម ដល់អាចារ្យ ដោយឧបាយដូចម្តេចហ្ន៎ បើសង្ឃមានប្រាថ្នាដើម្បីធ្វើកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់អាចារ្យហើយ អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីធ្វើកម្មដល់អាចារ្យ ឬសង្ឃបង្អោនទៅ ដើម្បីកម្មដ៏ស្រាលដល់អាចារ្យ ដោយឧបាយដូចម្តេចហ្ន៎ មួយវិញទៀត បើកម្ម គឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដែលសង្ឃបានធ្វើដល់អាចារ្យរួចហើយ អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា អាចារ្យគប្បីប្រព្រឹត្តដោយប្រពៃ គប្បីសម្លបរោម គប្បីប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម សង្ឃគប្បីរម្ងាប់នូវកម្មនោះ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អាចារ្យគួរនឹងលាង អន្តេវាសិកត្រូវលាងប្រគេន ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគួរនឹងលាងដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អាចារ្យគួរនឹងធ្វើ អន្តេវាសិកត្រូវធ្វើប្រគេន ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគួរនឹងធ្វើ ដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់អាចារ្យគួរនឹងស្ងោរ អន្តេវាសិកត្រូវស្ងោរប្រគេន ឬធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងជ្រលក់របស់អាចារ្យគួរនឹងស្ងោរ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អាចារ្យគួរនឹងជ្រលក់ អន្តេវាសិកត្រូវជ្រលក់ប្រគេន ឬធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគួរនឹងជ្រលក់ ដោយឧបាយដូចម្តេចហ្ន៎ អន្តេវាសិកកាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ប្រែត្រឡប់ឲ្យសព្វល្អ មួយទៀត កាលបើដំណក់ទឹកស្រក់ពុំទាន់អស់ អន្តេវាសិក កុំអាលចៀសចេញទៅឡើយ អន្តេវាសិកមិនទាន់ប្រាប់អាចារ្យ មិនត្រូវឲ្យបាត្រដល់ភិក្ខុណាមួយ មិនត្រូវទទួលបាត្ររបស់ភិក្ខុណាមួយ មិនត្រូវឲ្យចីវរដល់ភិក្ខុណាមួយ មិនត្រូវទទួលយកចីវររបស់ភិក្ខុណាមួយ មិនត្រូវឲ្យបរិក្ខារដល់ភិក្ខុណាមួយ មិនត្រូវទទួលបរិក្ខាររបស់ភិក្ខុណាមួយ មិនត្រូវកោរសក់ឲ្យភិក្ខុណាមួយ មិនត្រូវឲ្យអ្នកណាមួយមកកោរសក់ឲ្យខ្លួនឡើយ មិនត្រូវធ្វើបរិកម្ម (គក់ច្របាច់) ដល់ភិក្ខុណាមួយ មិនត្រូវឲ្យអ្នកណាមួយ ធ្វើបរិកម្មដល់ខ្លួន មិនត្រូវធ្វើវេយ្យាវច្ចៈ ដល់ភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយ ធ្វើវេយ្យាវច្ចៈ ដល់ខ្លួន មិនត្រូវធ្វើជាបច្ឆាសមណៈរបស់ភិក្ខុណាមួយ មិនត្រូវកាន់យកភិក្ខុណាមួយ (ធ្វើជា) បច្ឆាសមណៈរបស់ខ្លួន មិនត្រូវនាំបិណ្ឌបាតទៅឲ្យភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយ នាំបិណ្ឌបាតមកឲ្យខ្លួន អន្តេវាសិកមិនទាន់លាអាចារ្យ មិនត្រូវចូលទៅកាន់ស្រុក មិនត្រូវទៅកាន់ព្រៃស្មសាន មិនត្រូវចៀសទៅកាន់ទិស បើអាចារ្យមានជម្ងឺ អន្តេវាសិកត្រូវថែទាំអស់កាលដែលលោករស់នៅ អន្តេវាសិក ត្រូវរង់ចាំត្រាតែអាចារ្យសះជាជម្ងឺ ម្នាលភិក្ខុទាំងឡាយ ទាំងនេះ ជា អាចារិយវត្ត របស់អន្តេវាសិកទាំងឡាយ តាមទំនងដែលអន្តេវាសិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យទាំងឡាយ។

# (អន្តេវាសិកវត្តកថា ទី៤)

CS vin.cv.08.14 | ភាគ ទី១១

### (១៤. អន្តេវាសិកវត្តកថា)

[១០៨] សម័យនោះឯង ពួកអាចារ្យពុំបានប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកអាចារ្យមិនប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយសោះ។ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះភិក្ខុទាំងឡាយ ក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអាចារ្យពុំបានប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយ ពិតមែនឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា ពិតមែនព្រះអង្គ។បេ។ ព្រះសព្វញ្ញូជាម្ចាស់ ទ្រង់បន្ទោស ហើយធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្ត អន្តេវាសិកវត្ត ដល់អាចារ្យទាំងឡាយ តាមទំនងដែលអាចារ្យទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយ។

[១០៩] ម្នាលភិក្ខុទាំងឡាយ អាចារ្យត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិក។ ការដែលប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិកនោះ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ អាចារ្យត្រូវសង្គ្រោះ ត្រូវអនុគ្រោះអន្តេវាសិកដោយបាលី ដោយអដ្ឋកថា ដោយដម្បូន្មាន ដោយការប្រៀនប្រដៅ បើអាចារ្យមាន

បាត្រ អន្តេវាសិកគ្មានបាត្រ ត្រូវអាចារ្យឲ្យបាត្រទៅអន្តេវាសិក ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា បាត្រគប្បីកើតឡើងដល់អន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ បើអាចារ្យមានចីវរ អន្តេវាសិកគ្មានចីវរ ត្រូវអាចារ្យឲ្យចីវរទៅអន្តេវាសិក ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ចីវរគប្បីកើតឡើងដល់អន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ បើអាចារ្យមានគ្រឿងបរិក្ខារ អន្តេវាសិកគ្មានគ្រឿងបរិក្ខារ ត្រូវអាចារ្យឲ្យគ្រឿងបរិក្ខារទៅអន្តេវាសិក ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា គ្រឿងបរិក្ខារ គប្បីកើតឡើងដល់អន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកមានជម្ងឺ អាចារ្យត្រូវក្រោកពីព្រឹក ហើយឲ្យឈើស្ទន់ ឲ្យទឹកសម្រាប់លាងមុខ ក្រាលអាសនៈ បើមានបបរ អាចារ្យ ត្រូវលាងភាជន៍ ហើយបង្អោនបបរឲ្យទៅ កាលអន្តេវាសិកហុតបបររួចហើយ អាចារ្យត្រូវឲ្យទឹក រួចទទួលយកភាជន៍មកវិញ កាន់បន្ទាប កុំឲ្យទង្គិចទង្គក (អ្វី) ហើយរៀបចំទុកដាក់ឲ្យល្អ កាលបើអន្តេវាសិកក្រោកចេញឡើង អាចារ្យត្រូវសាររអាសនៈចេញ បើប្រទេសនោះមានសម្រាម អាចារ្យត្រូវបោសប្រទេសនោះចេញ បើអន្តេវាសិកមានប្រាថ្នាដើម្បីនឹងចូលទៅកាន់ស្រុក អាចារ្យត្រូវឲ្យស្បង់សម្រាប់ស្លៀក ហើយទទួលយកស្បង់បន្លាស់មកវិញ ត្រូវឲ្យវត្ថពន្ធចង្កេះ ត្រូវតម្រួតឧត្តរាសង្គៈ និងសង្ឃាដិហើយឲ្យ ត្រូវជូតបាត្រដែលទទឹក ហើយសឹមឲ្យ អាចារ្យត្រូវក្រាលអាសនៈទុក ដោយគិតថា អន្តេវាសិកមុខជានឹងត្រឡប់មកវិញ ក្នុងវេលានេះ ត្រូវដំកល់ទឹកលាងជើង តាំងសម្រាប់រងជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវក្រោកទៅទទួលបាត្រ និងចីវរ ត្រូវឲ្យស្បង់បន្លាស់ ហើយទទួលយកស្បង់ដែលស្លៀកមកវិញ បើចីវរសើម ឬជាំដាម (ដោយញើសក្អែល) ត្រូវសំដិលចីវរក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកចីវរក្នុងកំដៅថ្ងៃ (ឲ្យយូរពេក) អាចារ្យត្រូវបត់ចីវរ កាលនឹងបត់ចីវរ ត្រូវលើកជាយចីវរឲ្យហួសពីគ្នាប្រមាណ៤ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យបាក់ផ្នត់ពាក់កណ្ដាលឡើយ ត្រូវធ្វើវត្ថពន្ធចង្កេះក្នុងផ្នត់ចីវរ បើអាហារបិណ្ឌបាតមាន ហើយអន្តេវាសិកត្រូវការចង់ឆាន់ អាចារ្យត្រូវឲ្យទឹក ហើយបង្អោនអាហារបិណ្ឌបាតចូលទៅ អាចារ្យត្រូវសួរអន្តេវាសិកដោយទឹកឆាន់ លុះអន្តេវាសិកឆាន់រួចហើយ អាចារ្យត្រូវឲ្យទឹក ហើយទទួលយកបាត្រមកវិញ កាន់បន្ទាបកុំឲ្យទង្គិចទង្គក ហើយលាងឲ្យស្អាត ជូតឲ្យស្ងួតទឹកចេញ ហើយហាលថ្ងៃមួយស្របក់ តែមិនត្រូវទុកបាត្រក្នុងកំដៅថ្ងៃ (ឲ្យយូរពេក) អាចារ្យត្រូវទុកបាត្រ និងចីវរ កាលដែលរៀបចំទុកដាក់បាត្រ។បេ។ កាលដែលរៀបចំទុកចីវរ។បេ។ ត្រូវបត់ជាយចីវរខាងនាយ ឲ្យជាផ្នត់មកខាងអាយ ហើយសឹមទុកចីវរចុះ កាលអន្តេវាសិកក្រោកចេញហើយ អាចារ្យត្រូវសាររអាសនៈចេញ ត្រូវរៀបចំទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង បើប្រទេសនោះមានសម្រាម អាចារ្យត្រូវបោសប្រទេសនោះចេញ បើអន្តេវាសិកចង់ងូតទឹក អាចារ្យត្រូវចាត់ចែងទឹកសម្រាប់ងូតឲ្យ បើអន្តេវាសិកត្រូវការដោយទឹកត្រជាក់ អាចារ្យត្រូវចាត់ចែងទឹកត្រជាក់ឲ្យ បើអន្តេវាសិកត្រូវការដោយទឹកក្ដៅ អាចារ្យត្រូវចាត់ចែងទឹកក្ដៅឲ្យ បើអន្តេវាសិកចង់ចូលទៅកាន់ផ្ទះជាទីរក្សាកាយ អាចារ្យត្រូវសូន្យគ្រឿងលំអិត ត្រូវលាយដីស្អិត ត្រូវកាន់យកតាំងសម្រាប់ផ្ទះជាទីរក្សាកាយហើយទៅ ឲ្យតាំងសម្រាប់ផ្ទះជាទីរក្សាកាយ រួចហើយទទួលយកចីវរមកទុកដាក់ក្នុងទីដ៏សមគួរ ត្រូវឲ្យគ្រឿងលំអិត ត្រូវឲ្យដីស្អិត បើអាចារ្យអាច (នឹងចូលទៅបាន) ត្រូវចូលទៅកាន់ផ្ទះជាទីរក្សាកាយចុះ កាលនឹងចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវយកដីស្អិតលាបមុខ ហើយបិទបាំងទាំងខាងមុខ ទាំងខាងក្រោយ ហើយសឹមចូលទៅកាន់ផ្ទះជាទីរក្សាកាយ មិនត្រូវអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ពួកភិក្ខុខ្ចីដោយអាសនៈ អាចារ្យត្រូវធ្វើបរិកម្ម ដល់អន្តេវាសិកក្នុងផ្ទះជាទីរក្សាកាយ កាលនឹងចេញពីផ្ទះជាទីរក្សាកាយ ត្រូវយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ហើយបិទបាំងទាំងខាងមុខ ទាំងខាងក្រោយ ហើយសឹមចេញពីផ្ទះជាទីរក្សាកាយ សូម្បីក្នុងទឹក អាចារ្យក៏ត្រូវតែធ្វើបរិកម្ម ដល់អន្តេវាសិកដែរ លុះអាចារ្យងូតទឹករួចហើយ ត្រូវឡើងមកមុន ហើយជូតខ្លួនឲ្យស្ងួតទឹក រួចសឹមស្លៀកស្បង់ ហើយជូតទឹកអំពីខ្លួនរបស់អន្តេវាសិក ត្រូវឲ្យស្បង់សម្រាប់ស្លៀក ត្រូវឲ្យសង្ឃាដិ ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីរក្សាកាយមកមុន ហើយក្រាលអាសនៈចាំ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវសួរអន្តេវាសិក ដោយទឹកសម្រាប់ឆាន់ អន្តេវាសិកនៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើអាចារ្យអាច (នឹងសំអាតបាន) ត្រូវសំអាត កាលនឹងសំអាតវិហារ ត្រូវនាំយកបាត្រ និងចីវរចេញមុន ទៅទុកដាក់ក្នុងទីដ៏សមគួរ។បេ។ បើគ្មានទឹកក្នុងក្អមសម្រាប់ជម្រះ អាចារ្យត្រូវចាក់ទឹកទៅក្នុងក្អមសម្រាប់ជម្រះ បើសេចក្ដីអផ្សុក កើតឡើងដល់អន្តេវាសិក អាចារ្យត្រូវរម្ងាប់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយរម្ងាប់ ឬធ្វើធម្មកថាដល់អន្តេវាសិកនោះ បើសេចក្ដីសង្ស័យ កើតឡើងដល់អន្តេវាសិក អាចារ្យត្រូវបន្ទោបង់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយបន្ទោបង់ ឬធ្វើធម្មកថាដល់អន្តេវាសិកនោះ បើទិដ្ឋិ (អាក្រក់) កើតឡើង ដល់អន្តេវាសិក អាចារ្យត្រូវដោះស្រាយដោយខ្លួនឯង ឬត្រូវឲ្យគេជួយដោះស្រាយ ឬធ្វើធម្មកថាដល់អន្តេវាសិកនោះ បើអន្តេវាសិកត្រូវគរុកាបត្តិ គួរដល់បរិវាសកម្ម អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យបរិវាសដល់អន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកគួរដល់មូលាយបដិកស្សនៈ (ទាញមកដាក់ក្នុងមូលាបត្តិ) អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីទាញអន្តេវាសិក មកដាក់ក្នុងមូលាបត្តិ ដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកគួរដល់មានត្ត អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្តដល់អន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ បើអន្តេវាសិកគួរដល់អព្ភានកម្ម អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យអព្ភានកម្ម ដល់អន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ បើសង្ឃប្រាថ្នានឹងធ្វើកម្ម គឺ តជ្ជនីយកម្មក្ដី និយស្សកម្មក្ដី បព្វាជនីយកម្មក្ដី បដិសារណីយកម្មក្ដី ឧក្ខេបនីយកម្មក្ដី ដល់អន្តេវាសិក អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃកុំគប្បីធ្វើកម្ម ឬគប្បីបង្អោនទៅ ដើម្បីកម្មស្រាល ដល់អន្តេវាសិក ដោយឧបាយដូចម្ដេចហ្ន៎ ម្យ៉ាងទៀត បើកម្ម គឺ តជ្ជនីយកម្មក្ដី និយស្សកម្មក្ដី បព្វាជនីយកម្មក្ដី បដិសារណីយកម្មក្ដី ឧក្ខេបនីយកម្មក្ដី សង្ឃបានធ្វើដល់អន្តេវាសិកនោះរួចហើយ អាចារ្យត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា អន្តេវាសិក គប្បីប្រព្រឹត្តដោយប្រពៃ គប្បីសម្លបរោម គប្បីប្រព្រឹត្តវត្ត គួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម សង្ឃគប្បីរម្ងាប់កម្មនោះ ដោយឧបាយដូចម្ដេចហ្ន៎ បើចីវររបស់អន្តេវាសិក គួរនឹងលាង អាចារ្យត្រូវប្រាប់ថា អ្នកត្រូវលាងយ៉ាងនេះ ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ចីវររបស់អន្តេវាសិកគួរនឹងលាងដោយឧបាយដូចម្ដេចហ្ន៎ បើចីវររបស់អន្តេវាសិក គួរនឹងធ្វើ អាចារ្យត្រូវប្រាប់ថា អ្នកត្រូវធ្វើយ៉ាងនេះ ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ចីវររបស់អន្តេវាសិក គួរនឹងធ្វើដោយឧបាយដូចម្ដេចហ្ន៎ បើគ្រឿងជ្រលក់របស់អន្តេវាសិក គួរនឹងស្ងោរ អាចារ្យត្រូវប្រាប់ថា អ្នកត្រូវស្ងោរយ៉ាងនេះ ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា គ្រឿងជ្រលក់របស់អន្តេវាសិកគួរនឹងស្ងោរ ដោយឧបាយដូចម្ដេចហ្ន៎ បើចីវររបស់អន្តេវាសិក គួរនឹងជ្រលក់ អាចារ្យត្រូវប្រាប់ថា អ្នកត្រូវជ្រលក់ចីវរយ៉ាងនេះ ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា បើចីវររបស់អន្តេវាសិកគួរនឹងជ្រលក់ ដោយឧបាយដូចម្ដេចហ្ន៎ កាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ប្រែត្រឡប់ឲ្យសព្វល្អ បើដំណក់ទឹកស្រក់ពុំទាន់អស់ អាចារ្យកុំអាលចៀសចេញទៅ បើអន្តេវាសិកមានជម្ងឺ អាចារ្យត្រូវថែទាំ ដល់កាលដែលអន្តេវាសិកមានជីវិតរស់នៅ ត្រូវរង់ចាំត្រាតែសះជាជម្ងឺ ម្នាលភិក្ខុទាំងឡាយ ទាំងនេះ ជាអន្តេវាសិកវត្ត របស់អាចារ្យតាមទំនងដែលពួកអាចារ្យត្រូវប្រព្រឹត្ត ដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយ។

ចប់ វត្តក្ខន្ធកៈ ជាគំរប់៨។

ក្នុងខន្ធកៈនេះ មានរឿង១៩ មានវត្ត១៤។

[១១០]

រឿងអាគន្តុកភិក្ខុពាក់ស្បែកជើង បាំងឆត្រ ទទូរក្បាល ដាក់ចីវរលើក្បាល លាងជើងដោយទឹកឆាន់ មិនសំពះអាវាសិកភិក្ខុ ដែលចាស់ជាងខ្លួន និងមិនសួររកទីសេនាសនៈ រឿងពស់ធ្លាក់លើភិក្ខុ ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ ក៏ពោលទោស (ក្នុងរឿងអម្បាលនេះ)។ រឿងព្រះអង្គទ្រង់អនុញ្ញាតថា អាគន្តុកភិក្ខុត្រូវដោះស្បែកជើង ដំឡោះឆត្រ ដាក់ចីវរឮដ៏ស្មា ហើយសន្សឹមៗចូលទៅកាន់អារាម អាគន្តុកភិក្ខុត្រូវចូលទៅកាន់ទីដែលអាវាសិកភិក្ខុប្រជុំគ្នា ត្រូវទុកបាត្រ និងចីវរក្នុងទីសមគួរ ត្រូវកាន់យកអាសនៈដ៏សមគួរមកអង្គុយ ត្រូវសួររកទឹកឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ត្រូវចាក់ទឹកដោយដៃម្ខាង លាងជើងដោយដៃម្ខាង ត្រូវជូតស្បែកជើង ដោយសំពត់ស្ងួតមុន រួចសឹមជូតដោយសំពត់ទទឹកជាខាងក្រោយ អាវាសិកភិក្ខុចាស់ជាង អាគន្តុកភិក្ខុត្រូវសំពះ បើក្មេងជាង អាគន្តុកភិក្ខុត្រូវឲ្យអាវាសិកភិក្ខុសំពះវិញ អាគន្តុកភិក្ខុត្រូវសួររកសេនាសនៈ ត្រូវសួររកសេនាសនៈ ដែលមានគេនៅ ឬឥតគេនៅ ត្រូវសួររកគោចរគ្រាម និងអគោចរគ្រាម ត្រូវសួររកសេក្ខត្រកូល ដែលសង្ឃសន្មត ត្រូវសួររកទីសម្រាប់បន្ទោបង់វច្ចៈ និងបស្សាវៈ ត្រូវសួររកទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ ត្រូវសួររកឈើច្រត់ ត្រូវសួរអំពីរបៀបនៃកតិការបស់សង្ឃ បើវិហារគ្មានគេនៅ ត្រូវគោះសន្ទះទ្វារ រួចឈររង់ចាំមួយស្របក់សិន បើវិហារមានសម្រាម ត្រូវបោសជម្រះចេញ ត្រូវជញ្ជូនយកកម្រាលផែនដីទ្រនាប់ជើងគ្រែ ពូក ខ្នើយ គ្រែ តាំង កន្ទេល និងផែនក្តារសម្រាប់ផ្អែក ទៅទុកក្នុងទីដ៏សមគួរ បើវិហារមានគ្រឿងស្មុកស្មាញ ភិក្ខុត្រូវបោសអំពីពិតានចុះមកជាមុន ត្រូវជូតចំណែកជ្រុងបង្អួច បើជញ្ជាំងគេបរិកម្មដោយថ្នាំ មានសម្បុរសៅហ្មង បើផ្ទៃផែនដីដែលគេបរិកម្មដោយពណ៌ខ្មៅ ភិក្ខុត្រូវជ្រលក់សំពត់ រួចពូតចេញហើយសឹមជូត បើផ្ទៃដែលគេមិនបានធ្វើបរិកម្ម ភិក្ខុត្រូវប្រស់ហើយសឹមជូត ត្រូវជញ្ជូនសម្រាមទៅចាក់ចោល ក្នុងទីដ៏សមគួរ ត្រូវជញ្ជូនយកកម្រាលផែនដី ទ្រនាប់ជើងគ្រែ គ្រែ តាំង ពូក ខ្នើយ កម្រាលសម្រាប់អង្គុយ កន្ទេល និងក្តារសម្រាប់ផ្អែក ទៅទុកក្នុងទីដដែលវិញ ត្រូវទុកដាក់បាត្រ និងចីវរ មិនត្រូវទុកបាត្រ ក្នុងទីដែលមិនស្អាត ត្រូវបត់ចីវរធ្វើជាយខាងនាយ ឲ្យមានផ្នត់មកខាងអាយ បើខ្យល់ប្រកបដោយធូលីបក់មកពីទិសខាងកើត ត្រូវបិទបង្អួចទិសខាងកើត បក់មកពីទិសខាងលិច ត្រូវបិទបង្អួចទិសខាងលិច បក់មកពីទិសខាងជើង ត្រូវបិទបង្អួចទិសខាងជើង បក់មកពីទិសខាងត្បូង ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ ត្រូវបើកបង្អួចវេលាថ្ងៃ បិទវេលាយប់ បើរដូវក្តៅ ត្រូវបិទបង្អួចវេលាថ្ងៃ បើកវេលាយប់ បរិវេណ បន្ទប់ រោងឆាន់ រោងភ្លើង វច្ចកុដិ (បើមានសម្រាម ភិក្ខុត្រូវបោសចេញ) ត្រូវដម្កល់ទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ ត្រូវចាក់ទឹកក្នុងក្អមសម្រាប់ជម្រះ ព្រះតថាគតមិនមានបុគ្គលប្រៀបផ្ទឹម បានទ្រង់បញ្ញត្តវត្ត ដែលអាគន្តុកភិក្ខុទាំងឡាយ (ត្រូវប្រព្រឹត្ត)។ រឿងភិក្ខុម្ចាស់អាវាសមិនក្រាលអាសនៈទទួលអាគន្តុកៈ មិនដំកល់ទឹកទុក មិនក្រោកទទួលបាត្រ និងចីវរ មិនសួរដោយទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ មិនថ្វាយបង្គំអាគន្តុកភិក្ខុ ដែលមានវស្សាចាស់ជាង មិនរៀបចំសេនាសនៈឲ្យអាគន្តុកភិក្ខុ ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ ក៏ពោលទោសឡើង (ក្នុងរឿងនោះ)។ (ព្រះអង្គទ្រង់បញ្ញត្តថា) អាវាសិកភិក្ខុត្រូវក្រាលអាសនៈដល់អាគន្តុកភិក្ខុដែលចាស់ជាង ត្រូវដំកល់ទឹកសម្រាប់លាងជើង ត្រូវក្រោកទៅទទួល (បាត្រនិងចីវរ) ត្រូវសួររកទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ត្រូវជូតស្បែកជើង ដោយសំពត់ស្ងួតមុន រួចជូតដោយសំពត់ទទឹកជាខាងក្រោយ ត្រូវលាងកំណាត់សំពត់សម្រាប់ជូតស្បែកជើង ពូតហើយហាលទុកក្នុងទីដ៏សមគួរ ត្រូវថ្វាយបង្គំភិក្ខុអាគន្តុកៈ ដែលចាស់ជាង ត្រូវចាត់ចែងសេនាសនៈ ឲ្យភិក្ខុអាគន្តុកៈ ត្រូវប្រាប់សេនាសនៈដែលមានភិក្ខុនៅហើយ ឬមិនមានភិក្ខុនៅ ត្រូវប្រាប់គោចរគ្រាម និងអគោចរគ្រាម ត្រូវប្រាប់សេក្ខត្រកូល ដែលសង្ឃសន្មត ត្រូវប្រាប់ទីសម្រាប់បន្ទោបង់ឧច្ចារៈ និងបស្សាវៈ ត្រូវប្រាប់ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ត្រូវប្រាប់ឈើច្រត់ ត្រូវប្រាប់កតិការបស់សង្ឃថា កាលនេះត្រូវចូល កាលនេះត្រូវចេញ បើភិក្ខុជាអាគន្តុកៈខ្ចីវស្សាជាង អាវាសិកភិក្ខុគ្រាន់តែអង្គុយប្រាប់ក៏បាន ត្រូវឲ្យថ្វាយបង្គំ ត្រូវប្រាប់សេនាសនៈ (តអំពីនេះទៅ) បណ្ឌិតគប្បីដឹងតាមន័យដែលបានពោលរួចមកហើយចុះ។ ព្រះតថាគតជានាយកនៃពពួកសត្វ បានសំដែងវត្ត ដែលអាវាសិកភិក្ខុទាំងឡាយ (ត្រូវប្រព្រឹត្តដោយប្រពៃ)។ រឿងភិក្ខុជាអ្នកដំណើរមិនរៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី បើកទ្វារ និងបង្អួចចំហចោល មិនអើពើនឹងសេនាសនៈ ហើយចៀសចេញទៅ ឯគ្រឿងឈើ គ្រឿងដី ក៏ខូចខាតអស់ទៅ សេនាសនៈ ក៏គ្មានអ្នករក្សា ទើបភិក្ខុមានសីលជាទីស្រឡាញ់ ក៏ពោលទោសឡើង។ រឿងភិក្ខុអ្នកដំណើរ ត្រូវរៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី ហើយបិទទ្វារ បង្អួច អើពើនឹងសេនាសនៈ រួចហើយសឹមចៀសចេញទៅ។ បើគ្មានភិក្ខុ ឬសាមណេរ ឬអ្នករក្សាវត្ត ឬឧបាសកទេ ភិក្ខុអ្នកដំណើរ ត្រូវរៀបចំគ្រែ លើថ្ម៤ដុំ ហើយធ្វើសេនាសនៈឲ្យគរលើគ្នា រួចសឹមទុកដាក់គ្រឿងឈើ និងគ្រឿងដី បិទទ្វារបង្អួចរួចហើយ សឹមចៀសចេញទៅ បើវិហារលេច អាគន្តុកភិក្ខុអាចនឹងប្រក់បាន ត្រូវប្រក់ ឬធ្វើសេចក្តីខ្វល់ខ្វាយ ទីណាភ្លៀងមិនលេច អាគន្តុកភិក្ខុរៀបចំគ្រែលើថ្ម៤ដុំ ដូចន័យមុន បើវិហារភ្លៀងលេចគ្មានសល់ ត្រូវនាំយកគ្រឿងសេនាសនៈទៅផ្ញើនឹងមនុស្សអ្នកស្រុក បើមិនដូច្នោះ ត្រូវរៀបចំគ្រែលើថ្ម៤ដុំក្នុងទីវាល ហើយត្រូវប្រតិបត្តិដូចន័យមុន ហើយចៀសចេញទៅ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ ចំណែកផ្សេងៗនៃគ្រឿងឈើ និងគ្រឿងដីគប្បីសល់នៅខ្លះ នេះជាវត្តដែលភិក្ខុអ្នកដំណើរ (ត្រូវប្រព្រឹត្ត)។ រឿងភិក្ខុមិនអនុមោទនា ក្នុងរោងភត្ត ព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុជាថេរៈ ធ្វើអនុមោទនា រឿងភិក្ខុទាំងឡាយលះបង់ព្រះសារីបុត្ត ទ្រង់អនុញ្ញាតឲ្យភិក្ខុជាថេរៈបួនប្រាំរូបរង់ចាំក្នុងរោងភត្ត រឿងព្រះថេរៈមួយរូបឈឺបន្ទោបង់វច្ចៈ ខំអត់ទ្រាំទាល់តែជ្រប់ដួលទៅ នេះជាវត្តដែលព្រះតថាគត បានអនុញ្ញាតទុកក្នុងអនុមោទនាវិធី។ រឿងពួកឆព្វគ្គិយភិក្ខុស្លៀកមិនល្អ ដណ្តប់មិនល្អ មានមារយាទមិនសមគួរ ហើយដើរទៅខាងមុខភិក្ខុជាថេរៈ អង្គុយជ្រៀតបៀតភិក្ខុជាថេរៈ ហាមឃាត់ភិក្ខុថ្មី ដោយអាសនៈ អង្គុយសង្កត់សង្ឃាដិក្នុងចន្លោះផ្ទះ ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ ក៏ពោលទោសឡើង។ (រឿងព្រះអង្គទ្រង់បញ្ញត្តវត្តក្នុងរោងភត្តថា) ភិក្ខុត្រូវបិទបាំងមណ្ឌលបី គឺស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់វត្ថពន្ធចង្កេះ ហើយតម្រួតឧត្តរាសង្គៈ និងសង្ឃាដិ ហើយឃ្លុំ ពាក់ក្ដុំហើយសឹមដើរចូលទៅកាន់ស្រុក មិនត្រូវដើរទៅអំពីខាងមុខភិក្ខុជាថេរៈ ត្រូវបិទបាំងកាយដោយល្អ ត្រូវសង្រួមដោយប្រពៃ ត្រូវមានភ្នែកសំឡឹងចុះក្រោម មិនត្រូវសើយចីវរ មិនត្រូវសើចឮខ្លាំង ត្រូវមានសំឡេងតិចៗ ការកំរើក៣យ៉ាង គឺ (ឃ្លោងកាយ បង់បោយ ងេកងោកក្បាល) មិនត្រូវស្ទឹមចង្កេះ មិនត្រូវទទូរក្បាល មិនត្រូវចំអើតជើង ភិក្ខុត្រូវបិទបាំងកាយដោយល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមដោយល្អ ត្រូវមានភ្នែកសម្លឹងចុះក្រោម មិន

ត្រូវសើយចីវរ មិនត្រូវសើចខ្លាំង ត្រូវមានសំឡេងតិចៗ ការកំរើក៣យ៉ាង (ឃ្លោងកាយ បង់បោយ ងេកងោកក្បាល) មិនត្រូវស្ទឹមចង្កេះ មិនត្រូវទទូរក្បាល មិនត្រូវត្របោមក្បាលជង្គង់ មិនត្រូវអង្គុយជ្រៀតបៀតភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ភិក្ខុថ្មីដោយអាសនៈ មិនត្រូវអង្គុយសង្កត់សង្ឃាដិ បើទាយកប្រគេនទឹក ត្រូវទ្របាត្រដោយដៃទាំងពីរ ហើយទទួលទឹក ត្រូវធ្វើឲ្យទាប ហើយលាងបាត្រឲ្យស្អាត ត្រូវចាក់ទៅក្នុងកន្ថោរទឹក ដោយគិតថា អ្នកជិតខាង កុំទទឹកដោយទឹកឡើយ សង្ឃាដិ កុំទទឹកដោយទឹកឡើយ។ បើទាយកប្រគេនបាយ ភិក្ខុត្រូវទ្របាត្រដោយដៃទាំងពីរ ហើយទទួលយកបាយ ត្រូវទុកឱកាសដល់សម្ល បើមានសម្លឧត្តរិភង្គជាដើម ព្រះថេរៈត្រូវប្រាប់ទាយកថា អ្នកចូរចាត់ចែងដល់ភិក្ខុគ្រប់រូបឲ្យស្មើៗគ្នា ត្រូវទទួលបិណ្ឌបាតដោយគោរព ត្រូវធ្វើសេចក្តីសំគាល់តែក្នុងបាត្រ ត្រូវទទួលបិណ្ឌបាត ឲ្យមានសម្លសមគួរដល់បាយ ត្រូវទទួលបិណ្ឌបាតស្មើត្រឹមកណ្តាប់មាត់បាត្រ បើបាយមិនទាន់គ្រប់គ្រាន់ទេ ព្រះថេរៈកុំអាលឆាន់មុន ត្រូវឆាន់បិណ្ឌបាតដោយគោរព ត្រូវមានសេចក្តីសំគាល់តែក្នុងបាត្រ ត្រូវឆាន់បិណ្ឌបាតវាចឲ្យស្មើ ត្រូវឆាន់បិណ្ឌបាតឲ្យមានសម្ល និងម្ហូបស្មើគ្នា មិនត្រូវឆាន់បិណ្ឌបាតច្រមចុះពីកំពូលបាយ មិនត្រូវកកាយបាយលុបសម្ល ឬម្ហូបដើម្បីឲ្យបានច្រើនជាងគេ ភិក្ខុមិនឈឺ មិនត្រូវសូមសម្ល ឬម្ហូប ឬបាយដើម្បីខ្លួន មិនត្រូវសំគាល់ក្នុងបាត្រភិក្ខុដទៃ ដើម្បីលើកទោស មិនត្រូវធ្វើពំនូតបាយឲ្យធំហួសប្រមាណ ត្រូវធ្វើពំនូតបាយឲ្យជាបរិមណ្ឌល កាលពំនូតបាយនៅមិនទាន់ដល់មាត់ កុំហាមាត់ចាំ កុំឆាន់ញាត់ម្រាមដៃទាំងអស់ទៅក្នុងមាត់ មិនត្រូវនិយាយទាំងបាយនៅក្នុងមាត់ មិនត្រូវឆាន់បោះដុំបាយទៅក្នុងមាត់ មិនត្រូវឆាន់ខាំកាត់ពំនូតបាយមួយកំណាត់ម្តង មិនត្រូវឆាន់បៀមពំនូតបាយទុលថ្ពាល់ឡើង មិនត្រូវឆាន់រលាស់ដៃបណ្តើរ មិនត្រូវឆាន់ឲ្យជ្រុះគ្រាប់បាយ មិនត្រូវឆាន់លៀនអណ្តាត មិនត្រូវឆាន់ឲ្យឮផ្លប់ៗ មិនត្រូវឆាន់ឲ្យឮគ្រូកៗ មិនត្រូវឆាន់លិទ្ធដៃ លិទ្ធបាត្រ លិទ្ធបបូរមាត់ មិនត្រូវយកដៃប្រឡាក់អាមិសៈ ទទួលចាប់កាន់ភាជន៍ទឹក ភិក្ខុទាំងពួងឆាន់មិនទាន់រួច ព្រះថេរៈកុំអាលទទួលទឹក បើគេប្រគេនទឹក ត្រូវទទួលទឹកធ្វើឲ្យទាប កុំឲ្យទង្គិចទង្គុកអ្វី ហើយលាងបាត្រឲ្យស្អាត ត្រូវចាក់ទឹកទៅក្នុងកន្ថោរទឹក ដោយគិតថា ភិក្ខុជិតខាងកុំទទឹកដោយទឹកឡើយ សង្ឃាដិកុំទទឹកដោយទឹកឡើយ បើកន្ថោរទឹកមិនមាន ត្រូវបន្ទាប់ភាជន៍ទឹកឲ្យទាប ហើយសឹមចាក់ទៅលើផែនដី មិនត្រូវចាក់ទឹកលាងបាត្រទាំងគ្រាប់បាយក្នុងចន្លោះផ្ទះ ភិក្ខុថ្មីត្រូវត្រឡប់ស្រូតមកមុន ដើរក្នុងចន្លោះផ្ទះ ត្រូវបិទបាំងកាយដោយល្អ មិនត្រូវចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ ភត្តគ្គវត្តនេះ ព្រះតថាគតជាធម្មរាជ បានបញ្ញត្តទុកហើយ។ រឿងបិណ្ឌចារិកភិក្ខុស្លៀកមិនល្អ មានកិរិយាមិនសមគួរ ត្រាច់ទៅបិណ្ឌបាត មិនបានពិនិត្យ ហើយចូលទៅកាន់ទីលំនៅគេខ្លះ ចេញមកខ្លះ ចូលដោយរហ័សពេកខ្លះ ចេញមកដោយរហ័សពេកខ្លះ ឈរឆ្ងាយពេកខ្លះ ឈរជិតពេកខ្លះ ឈរយូរពេកខ្លះ ត្រឡប់មករហ័សពេកខ្លះ រឿងបិណ្ឌចារិកភិក្ខុ១រូបទៀត បានប្រព្រឹត្តដូច្នោះដែរ (ព្រះអង្គទ្រង់បញ្ញត្តថា) បិណ្ឌចារិកភិក្ខុ ត្រូវបិទបាំងកាយដោយល្អ ហើយសឹមដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមដោយល្អ ត្រូវមានភ្នែកសម្លឹងចុះក្រោម មិនត្រូវសើយចីវរ មិនត្រូវសើចខ្លាំង ត្រូវមានសំឡេងតិចៗ ការកម្រើក៣យ៉ាង (គឺគ្រលែងកាយ បង់បោយ ងេកងោកក្បាល) មិនត្រូវស្ទឹមចង្កេះ មិនត្រូវទទូរក្បាល មិនត្រូវដើរចំអើតជើង ត្រូវកំណត់ផ្លូវចេញផ្លូវចូល មិនត្រូវចូលទៅដោយរហ័សពេក មិនត្រូវចេញមកដោយរហ័សពេក មិនត្រូវឈរឆ្ងាយពេក ជិតពេក យូរពេក ឆាប់ពេក មិនត្រូវត្រឡប់រហ័សពេក ត្រូវកំណត់អាការរបស់ទាយក ដែលគេប្រគេនបាយ បើគេបញ្ឈប់ការងារក្តី ក្រោកចាកអាសនៈក្តី ចាប់វែកក្តី ចាប់ភាជន៍ក្តី និមន្តឲ្យរង់ចាំក្តី កាលគេប្រគេនបាយ ត្រូវវែកសង្ឃាដិដោយដៃឆ្វេង បង្អោនបាត្រដោយដៃស្តាំ ហើយទទួលយកបាយ មិនត្រូវមើលមុខទាយក ទុកជាសម្ល ឬម្ហូបក្រៀម ក៏ត្រូវកំណត់អាការរបស់ទាយកដូចគ្នាដែរ ភិក្ខុត្រូវបិទបាំងបាត្រដោយសង្ឃាដិ ត្រូវបិទបាំងកាយដោយល្អ ហើយសឹមដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមដោយល្អ ត្រូវមានភ្នែកសំឡឹងចុះក្រោម មិនត្រូវសើយចីវរ មិនត្រូវសើចខ្លាំង ត្រូវមានសំឡេងតិចៗ ការកម្រើក៣យ៉ាង (គឺគ្រលែងកាយ បង់បោយ ងេកងោកក្បាល) មិនត្រូវស្ទឹមចង្កេះ មិនត្រូវទទូរក្បាល មិនត្រូវចំអើតជើង ភិក្ខុណាដែលត្រឡប់មកពីបិណ្ឌបាតមុនគេ ភិក្ខុនោះត្រូវក្រាលអាសនៈ ត្រូវលាងបាត្រសម្រាប់ផ្ទេរភោជន ហើយដំកល់ទុក ត្រូវដំកល់ទឹកសម្រាប់ឆាន់ សម្រាប់ប្រើប្រាស់ ភិក្ខុដែលត្រឡប់ពីបិណ្ឌបាតក្រោយគេ បើមានភោជនសល់នៅ ត្រូវការនឹងឆាន់ ក៏គប្បីឆាន់ចុះ បើមិនត្រូវការឆាន់ទេ ត្រូវយកទៅចាក់ចោលក្នុងទីដែលគ្មានវត្ថុខៀវស្រស់ ឬក្នុងទីដែលគ្មានសត្វ ត្រូវសារអាសនៈចេញ ត្រូវរៀបចំទុកដាក់ទឹកសម្រាប់លាងជើងជាដើម ត្រូវបោសច្រាសរោងភត្ត បើឃើញក្អមទឹកសម្រាប់ឆាន់ក្តី ក្អមទឹកសម្រាប់ប្រើប្រាស់ក្តី ក្អមវច្ចៈក្តី គ្មានទឹកទេ ត្រូវដងដំកល់ទុក ត្រូវបោយដៃហៅគ្នា ឲ្យមកជួយលើកទឹកទៅដំកល់ទុក តែមិនត្រូវបញ្ចេញវាចា នេះជា បិណ្ឌបាតិកវត្ត ។ រឿងភិក្ខុនៅព្រៃ មិនដំកល់ទុកនូវទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ ភ្លើង ពំនួតភ្លើង មិនស្គាល់ផ្កាយនក្ខត្តឫក្ស មិនស្គាល់ទិស ចោរទាំងឡាយ ក៏ទះតប់នូវភិក្ខុទាំងឡាយ ដែលនៅព្រៃ ព្រោះឆ្លើយថា មិនមានរបស់ទាំងអម្បាលនេះ (ព្រះអង្គទ្រង់បញ្ញត្តថា) ភិក្ខុនៅព្រៃ ត្រូវក្រោកពីព្រឹកច្រកបាត្រក្នុងស្លោក រួចស្ពាយ ពាក់ចីវរលើស្មា ពាក់ស្បែកជើង ទុកដាក់គ្រឿងឈើ គ្រឿងដី បិទទ្វារបង្អួច ហើយចុះពីសេនាសនៈទៅ ដោយគិតថា អាត្មាអញនឹងចូលទៅកាន់ស្រុកក្នុងកាលឥឡូវនេះ ត្រូវដោះស្បែកជើង ហើយច្រកក្នុងថង់ ស្ពាយ ហើយបិទបាំងមណ្ឌលបី ស្លៀកដណ្តប់ឲ្យជាបរិមណ្ឌល ក្នុងអារញ្ញិកវត្តនេះ បណ្ឌិតគប្បីដឹងសេចក្តី ដូចជាបិណ្ឌចារិកវត្ត ដូច្នោះ ភិក្ខុអ្នកនៅក្នុងព្រៃ លុះចេញពីស្រុកហើយ ត្រូវច្រកបាត្រក្នុងស្លោក ហើយស្ពាយ បត់ចីវរដាក់លើក្បាល ពាក់ស្បែកជើង ហើយទើបដើរចេញទៅ ភិក្ខុអ្នកនៅព្រៃត្រូវដំកល់ទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ ភ្លើង ឈើពំនួតភ្លើង ឈើច្រត់ ត្រូវរៀនផ្កាយនក្ខត្តឫក្សទាំងអស់ ឬដោយឯកទេស ត្រូវឈ្លាសក្នុងទិស។ អារញ្ញិកវត្ត ព្រះតថាគត ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វ បានបញ្ញត្តទុកហើយ រឿងភិក្ខុច្រើនរូបធ្វើចីវរក្នុងទីវាល ពួកឆព្វគ្គិយភិក្ខុ គោះសេនាសនៈក្នុងទីធ្លា ជាទីច្រាសខ្យល់ ភិក្ខុទាំងឡាយ ក៏ប្រឡាក់ដោយធូលី ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ ក៏ពោលទោសឡើង។ (ព្រះអង្គទ្រង់បញ្ញត្តថា) បើវិហារមានសម្រាម ភិក្ខុត្រូវបោសជម្រះចេញ កាលនឹងបោសសំអាតវិហារ ត្រូវជញ្ជូនយកបាត្រ និងចីវរចេញជាមុន ទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវនាំយកពូក ខ្នើយ គ្រែ តាំង កន្ថោរសម្រាប់ស្តោះទឹកមាត់ ក្តារបង្អែក (ទៅដំកល់ទុកក្នុងទីដ៏សមគួរ) ត្រូវបោសអីពីពិតានជាមុន ហើយសឹមបោសជ្រុងបង្អួច បើជញ្ជាំងដែលគេបរិកម្មដោយថ្នាំ មានពណ៌សម្បុរសៅហ្មង បើផ្ទៃដែលគេធ្វើដោយវត្ថុមានពណ៌ខ្មៅសៅហ្មង ត្រូវជ្រលក់កំណាត់សំពត់ហើយសឹមជូត បើផ្ទៃគេមិនបានធ្វើទេ ត្រូវប្រស់ ហើយសឹមជូត ត្រូវប្រមូលសម្រាមទៅចាក់ចោល មិនត្រូវគោះសេនាសនៈជិតភិក្ខុ ជិតវិហារ ជិតទឹកសម្រាប់ឆាន់ ជិតទឹកសម្រាប់ប្រើប្រាស់ ក្នុងទីធ្លាជាទីច្រាសខ្យល់ ត្រូវគោះសេនាសនៈក្នុងទីក្រោមខ្យល់ កម្រាលផែនដី ទ្រនាប់ជើងគ្រែ គ្រែ តាំង ពូក ខ្នើយ កម្រាលសម្រាប់អង្គុយ កន្ថោរសម្រាប់ស្តោះទឹកមាត់ និងក្តារបង្អែក (បើហាលរួចហើយត្រូវជញ្ជូនយកទៅទុកក្នុងទីដដែលវិញ) ត្រូវទុកដាក់បាត្រចីវរ តែមិនត្រូវទុកដាក់បាត្រក្នុងទីដែលមិនស្អាត ត្រូវបត់ចីវរ ធ្វើជាយ

ខាងនាយ ឲ្យជាផ្ទត់មកខាងអាយ បើខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងកើត ពីទិសខាងលិច ពីទិសខាងជើង ពីទិសខាងត្បូង ត្រូវបិទបង្អួចការពារខ្យល់ បើរដូវត្រជាក់ ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្ដៅ ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកក្នុងវេលាយប់ បើបរិវេណ បន្ទប់ រោងឆាន់ រោងភ្លើង បង្គន់ (មានសម្រាម ត្រូវបោសចេញ) ត្រូវដំកល់ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ត្រូវចាក់ទឹកក្នុងក្អមសម្រាប់ជម្រះ បើនៅជាមួយនឹងភិក្ខុចាស់ជាង មិនទាន់ប្រាប់លោកជាមុន កុំបង្រៀនបាលី កុំបង្រៀនអដ្ឋកថា កុំស្វាធ្យាយធម៌ កុំសំដែងធម៌ កុំអុជប្រទីប កុំលត់ប្រទីប កុំបើកបង្អួច កុំបិទបង្អួច បើចង្ក្រមជាមួយនឹងភិក្ខុចាស់ ភិក្ខុចាស់ ចង្ក្រមក្នុងទីណា ភិក្ខុត្រូវផ្លាស់ទីចង្ក្រម កុំឲ្យប៉ះជាយសង្ឃាដិភិក្ខុចាស់ឡើយ ព្រះសម្មាសម្ពុទ្ធមានព្យាយាមធំ បានបញ្ញត្តវត្តនោះ ក្នុងសេនាសនៈទាំងឡាយ (យ៉ាងនេះ)។ រឿងឆព្វគ្គិយភិក្ខុទាំងឡាយ គរឧសជាច្រើន ក្នុងផ្ទះជាទីរក្សាកាយ ដុត ហើយអង្គុយរាំងមាត់ទ្វារ ព្រះថេរៈទាំងឡាយត្រូវកំដៅខ្លាំងណាស់ មិនបានទ្វារចេញមក ក៏ជ្រប់ដួលទៅ ភិក្ខុទាំងឡាយ មានសីលជាទីស្រឡាញ់ ក៏ពោលទោសឡើង។ (ព្រះអង្គទ្រង់បញ្ញត្តថា) បើផេះកកកុញច្រើន ក្នុងផ្ទះជាទីរក្សាកាយ ភិក្ខុត្រូវចាក់ផេះចោល បើផ្ទះជាទីរក្សាកាយ ទីលានខាងក្រៅបរិវេណ បន្ទប់ និងរោងនៃផ្ទះជាទីរក្សាកាយ (មានសម្រាម ត្រូវបោសចេញ) ត្រូវសូន្យគ្រឿងលំអិត ត្រូវលាយដីស្អិត ត្រូវចាក់ទឹកក្នុងស្នូក ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំងពីមុខពីក្រោយ ហើយសឹមចូលទៅកាន់ផ្ទះជាទីរក្សាកាយ មិនត្រូវអង្គុយជ្រៀតបៀតព្រះថេរៈ មិនត្រូវហាមឃាត់ភិក្ខុខ្ចីដោយអាសនៈ បើអាចធ្វើបរិកម្មបាន ត្រូវធ្វើបរិកម្មដល់ព្រះថេរៈ មិនត្រូវងូតទឹកពីខាងមុខព្រះថេរៈ មិនត្រូវងូតទឹកពីលើខ្សែទឹក ត្រូវបើកផ្លូវឲ្យភិក្ខុដែលចុះទៅងូតទឹក ត្រូវលាងផ្ទះជាទីរក្សាកាយ ដែលប្រឡាក់ដោយភក់ ត្រូវលាងស្នូកសម្រាប់ដាក់ដីស្អិត ហើយទុកដាក់តាំងសម្រាប់ផ្ទះជាទីរក្សាកាយ លត់ភ្លើង បិទទ្វារ ហើយសឹមដើរចៀសចេញទៅ នេះជាវត្តដែលព្រះតថាគតបានបញ្ញត្តទុកហើយ ក្នុងផ្ទះជាទីរក្សាកាយទាំងឡាយ។ រឿងភិក្ខុបន្ទោបង់ឧច្ចារៈ ហើយមិនជម្រះចេញ រឿងភិក្ខុបន្ទោបង់ឧច្ចារៈតាមលំដាប់ចាស់ខ្ចី ទើបព្រះអង្គទ្រង់អនុញ្ញាតឲ្យបន្ទោបង់ឧច្ចារៈតាមលំដាប់ដែលមកដល់ រឿងឆព្វគ្គិយភិក្ខុ ចូលទៅកាន់វច្ចកុដិដោយរហ័សពេកខ្លះ សើយស្បង់ចូលទៅខ្លះ បន្ទោបង់ឧច្ចារៈរមាត់ខ្លះ ទំពាឈើស្ទន់បន្ទោបង់ឧច្ចារៈខ្លះ បន្ទោបង់ឧច្ចារៈខាងក្រៅទឧច្ចារៈខ្លះ បន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈខ្លះ ស្តោះទឹកមាត់ក្នុងទបស្សាវៈខ្លះ កិតដោយឈើគគ្រាតខ្លះ ចោលឈើសម្រាប់កិត ក្នុងរណ្ដៅឧច្ចារៈខ្លះ ចេញពីវច្ចកុដិដោយរហ័សពេកខ្លះ សើយស្បង់ចេញមកខ្លះ ជម្រះឲ្យឮចបុចបុខ្លះ ឲ្យសល់ទឹកនៅក្នុងបំពង់សម្រាប់ជម្រះខ្លះ (ទើបព្រះអង្គទ្រង់បញ្ញត្តថា) ភិក្ខុណាទៅកាន់វច្ចកុដិ ភិក្ខុនោះ ត្រូវឈរគ្រហែមពីខាងក្រៅ ឯភិក្ខុដែលអង្គុយនៅខាងក្នុង ត្រូវគ្រហែមតប រឿងពាក់ចីវរលើស្នួរចីវរ ឬខ្សែស្បៀងចីវរ ហើយសឹមចូលទៅដោយសន្សឹមៗ មិនត្រូវចូលទៅដោយរហ័សពេក មិនត្រូវសើយស្បង់ចូលទៅ ត្រូវឈរលើទ្រនាប់សម្រាប់បន្ទោបង់ឧច្ចារៈ ហើយសឹមសើយស្បង់ មិនត្រូវប្រឹងរមាត់បន្ទោបង់ឧច្ចារៈ មិនត្រូវទំពាឈើស្ទន់បន្ទោបង់ឧច្ចារៈ មិនត្រូវបន្ទោបង់ឧច្ចារៈខាងក្រៅទ មិនត្រូវបន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈ មិនត្រូវស្តោះទឹកមាត់ក្នុងទបស្សាវៈ មិនត្រូវកិតដោយឈើគគ្រាត មិនត្រូវចោលឈើសម្រាប់កិត ក្នុងរណ្ដៅឧច្ចារៈ ត្រូវឈរលើទ្រនាប់សម្រាប់បន្ទោបង់ឧច្ចារៈ រួចសឹមបិទបាំងស្បង់ មិនត្រូវចេញមកដោយរហ័សពេក មិនត្រូវសើយស្បង់ចេញមក ត្រូវឈរលើទ្រនាប់សម្រាប់ជម្រះ ហើយសឹមសើយស្បង់ មិនត្រូវជម្រះឲ្យឮចបុចបុ មិនត្រូវទុកទឹកឲ្យសល់នៅក្នុងបំពង់សម្រាប់ជម្រះ ត្រូវឈរលើទ្រនាប់សម្រាប់ជម្រះ ហើយសឹមបិទបាំង ត្រូវលាងវច្ចកុដិដែលប្រឡាក់ បើកញ្ជើសម្រាប់ដាក់ឈើសម្រាប់កិតពេញហើយ ត្រូវនាំយកទៅចាក់ចោល បើវច្ចកុដិ លានវច្ចកុដិ បរិវេណ និងបន្ទប់មានសម្រាម ត្រូវបោសសំអាតចេញ ត្រូវចាក់ទឹកក្នុងក្អមសម្រាប់ជម្រះ (នេះ) ជាវត្តដែលព្រះតថាគត បានបញ្ញត្តទុកក្នុងវច្ចកុដិទាំងឡាយ។ (រឿងព្រះអង្គទ្រង់បញ្ញត្តឧបជ្ឈាយវត្តថា) សទ្ធិវិហារិក ត្រូវក្រោកអំពីព្រឹក ហើយដោះស្បែកជើង ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយប្រគេនឈើស្ទន់ ប្រគេនទឹកលាងមុខ ក្រាលអាសនៈ ប្រគេនបបរ ប្រគេនទឹក ហើយទទួលយកភាជន៍ ហើយលាងទុកដាក់ ត្រូវសារអាសនៈចេញ បើទីនោះមានសម្រាម ត្រូវបោសចេញ បើឧបជ្ឈាយ៍ចង់ចូលទៅកាន់ស្រុក សទ្ធិវិហារិកត្រូវប្រគេនស្បង់ទៅលោក ត្រូវប្រគេនវត្ថពន្ធចង្កេះ តម្រួតឧត្តរាសង្គៈ និងសង្ឃាដិប្រគេន ត្រូវជូតបាត្រដែលទទឹក រួចហើយសឹមប្រគេន បើឧបជ្ឈាយ៍ចង់បានជាបច្ឆាសមណៈ ត្រូវបិទបាំងមណ្ឌលបី គឺស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់វត្ថពន្ធចង្កេះ ឃ្លុំតម្រួតឧត្តរាសង្គៈ និងសង្ឃាដិ ពាក់ក្ដី លាងបាត្រ ហើយកាន់យកទៅ ធ្វើជាបច្ឆាសមណៈចុះ មិនត្រូវដើរឆ្ងាយពេក មិនត្រូវដើរជិតពេក ត្រូវចាំទទួលរបស់ដែលគេដាក់ក្នុងបាត្ររបស់ឧបជ្ឈាយ៍ បើឧបជ្ឈាយ៍កំពុងនិយាយ មិនត្រូវនិយាយស្កាត់ បើឧបជ្ឈាយ៍និយាយពាក្យដែលជិតនឹងត្រូវអាបត្តិ ត្រូវហាម ត្រូវត្រឡប់ស្រូតមកមុន ហើយក្រាលអាសនៈចាំ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងរងជើងដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវក្រោកទទួលបាត្រ និងចីវរ ត្រូវប្រគេនស្បង់បន្លាស់ ហើយទទួលយកស្បង់ដែលស្លៀកមកវិញ ត្រូវសំដិលចីវរក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកចីវរយូរពេក ត្រូវបត់ចីវរកុំឲ្យបាក់ពាក់កណ្ដាល ធ្វើវត្ថពន្ធក្នុងផ្នត់ចីវរ បើឧបជ្ឈាយ៍ចង់ឆាន់ ត្រូវបង្អោនបិណ្ឌបាតចូលទៅប្រគេន ត្រូវសួរទឹកឆាន់ ត្រូវប្រគេនទឹក ហើយទទួលបាត្រ កាន់ឲ្យទាបស្រួល លាង ហើយហាលក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកយូរពេក ត្រូវទុកដាក់បាត្រ និងចីវរ មិនត្រូវទុកបាត្រក្នុងទីមិនស្អាត ត្រូវធ្វើជាយចីវរខាងនាយ ឲ្យជាផ្ទត់មកខាងអាយ ហើយសឹមទុកដាក់ កាលឧបជ្ឈាយ៍ក្រោកឡើងហើយ ត្រូវសារអាសនៈចេញ ហើយរៀបទុកដាក់ទឹកត្រជាក់ ទឹកក្ដៅ បើឧបជ្ឈាយ៍ចង់ស្រង់ទឹក ត្រូវចាត់ចែងទឹកស្រង់ បើឧបជ្ឈាយ៍ចង់ចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវសូន្យគ្រឿងលំអិតទុក ត្រូវលាយដីស្អិត ត្រូវកាន់យកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ដើរទៅពីខាងក្រោយឧបជ្ឈាយ៍ ប្រគេនតាំងហើយ ទទួលយកចីវរមកដាក់ក្នុងទីសមគួរ ត្រូវប្រគេនគ្រឿងលំអិត ត្រូវប្រគេនដីស្អិត បើសទ្ធិវិហារិកអាចនឹងចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំងពីមុខ ពីក្រោយ ហើយសឹមចូលទៅ មិនត្រូវអង្គុយជ្រៀតបៀតភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ភិក្ខុខ្ចីដោយអាសនៈ ត្រូវធ្វើបរិកម្ម ដល់ឧបជ្ឈាយ៍ ក្នុងផ្ទះជាទីរក្សាកាយ កាលនឹងចេញមកវិញ ត្រូវបិទបាំងពីមុខ ពីក្រោយ រួចសឹមចេញមកពីផ្ទះជាទីរក្សាកាយ សូម្បីក្នុងទឹក ក៏ត្រូវធ្វើបរិកម្ម ដល់ឧបជ្ឈាយ៍ កាលសទ្ធិវិហារិកងូតរួចហើយ ត្រូវឡើងមកមុន ជូតខ្លួនឲ្យស្ងួតទឹក ហើយស្លៀកស្បង់ រួចសឹមជូតទឹកអំពីខ្លួនរបស់ឧបជ្ឈាយ៍ ត្រូវប្រគេនស្បង់សម្រាប់ស្លៀក ត្រូវប្រគេនសង្ឃាដិ ត្រូវនាំយកតាំងមកមុន ហើយក្រាលអាសនៈ ត្រូវដំកល់ទឹកលាងជើង តាំងរងជើង ដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង សទ្ធិវិហារិកត្រូវសួរឧបជ្ឈាយ៍ ដោយទឹកឆាន់ ត្រូវឲ្យឧបជ្ឈាយ៍បង្រៀនបាលី ត្រូវឲ្យឧបជ្ឈាយ៍បង្រៀនអដ្ឋកថា បើវិហារមានសម្រាម ត្រូវបោសសម្រាមចេញ កាលនឹងសំអាតវិហារ ត្រូវនាំយកបាត្រ និងចីវរចេញជាមុន ទៅទុកក្នុងទីដ៏សមគួរ កម្រាលសម្រាប់អង្គុយ ពូកនិងខ្នើយ គ្រែ តាំង

ទ្រនាប់ជើងគ្រែ កន្តោរសម្រាប់ស្តោះទឹកមាត់ ក្តារសម្រាប់ផ្អែក កម្រាលផែនដី សទ្ធិវិហារិក ត្រូវនាំយកទៅទុកក្នុងទីដ៏សមគួរ បើវិហារមានគ្រឿងស្មុកស្មាញ មានសរសៃពីងពាងជាដើម ត្រូវបោសអំពីពិតានមកមុន ត្រូវជូតជ្រុងបង្អួច បើជញ្ជាំងដែលគេបរិកម្មដោយថ្នាំរួចហើយ ត្រឡប់ជាមានសៅហ្មង ត្រូវជ្រលក់កំណាត់សំពត់ពូត ហើយសឹមជូត ត្រូវជូតផ្ទៃដែលគេធ្វើដោយវត្ថុមានពណ៌ខ្មៅ បើផ្ទៃដែលគេមិនបានធ្វើ ត្រូវប្រស់ទឹក ហើយសឹមជូត កម្រាលផែនដី ទ្រនាប់ជើងគ្រែ គ្រែ តាំង ពូក ខ្នើយ កម្រាលសម្រាប់អង្គុយ កន្តោរសម្រាប់ស្តោះទឹកមាត់ និងក្តារសម្រាប់ផ្អែក លុះសទ្ធិវិហារិកហាលរួចហើយ ត្រូវនាំយកទៅទុក ក្នុងទីដដែលវិញ ត្រូវទុកដាក់បាត្រ និងចីវរ បើខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងកើត ពីទិសខាងលិច ពីទិសខាងជើង ពីទិសខាងត្បូង (ត្រូវបិទបង្អួចការពារខ្យល់) បើរដូវត្រជាក់ ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្តៅ ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកក្នុងវេលាយប់ បរិវេណ បន្ទប់ រោងឆាន់ រោងភ្លើង និងវច្ចកុដិ បើមានសម្រាម សទ្ធិវិហារិក ត្រូវបោសសម្រាមចេញ ត្រូវដំកល់ទឹកសម្រាប់ឆាន់ ដំកល់ទឹកសម្រាប់ប្រើប្រាស់ ត្រូវចាក់ទឹកក្នុងក្អមសម្រាប់ជម្រះ បើឧបជ្ឈាយ៍ កើតសេចក្តីអផ្សុក ត្រូវជួយរម្ងាប់សេចក្តីអផ្សុករបស់ឧបជ្ឈាយ៍ ត្រូវជួយបន្ទោបង់សេចក្តីសង្ស័យរបស់ឧបជ្ឈាយ៍ ត្រូវជួយដោះទិដ្ឋិរបស់ឧបជ្ឈាយ៍ ត្រូវធ្វើសេចក្តីខ្វល់ខ្វាយដល់ឧបជ្ឈាយ៍ ដែលត្រូវគរុកាបត្តិ ដែលគួរដល់មូលាយបដិកស្សនៈ ដែលគួរដល់មានត្ត ដែលគួរដល់អព្ភាន បើសង្ឃធ្វើតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី សទ្ធិវិហារិក ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ត្រូវលាងចីវររបស់ឧបជ្ឈាយ៍ ត្រូវធ្វើចីវររបស់ឧបជ្ឈាយ៍ ត្រូវស្ងោរគ្រឿងជ្រលក់ ត្រូវជ្រលក់ចីវរ ប្រែត្រឡប់ឲ្យសព្វល្អ មិនត្រូវទទួលបាត្រ ចីវរ បរិក្ខារ កោរសក់ ធ្វើបរិកម្ម ធ្វើវេយ្យាវច្ចៈ ធ្វើជាបច្ឆាសមណៈរបស់ភិក្ខុឯទៀត មិនត្រូវឲ្យបិណ្ឌបាត ដល់ភិក្ខុណានីមួយឡើយ មិនទាន់លាឧបជ្ឈាយ៍ មិនត្រូវចូលទៅកាន់ស្រុក មិនត្រូវចូលទៅកាន់ព្រៃស្មសាន មិនត្រូវចៀសចេញទៅកាន់ទិស បើឧបជ្ឈាយ៍អាពាធ ត្រូវបម្រើត្រាតែអស់ជីវិត នេះជា ឧបជ្ឈាយវត្ត ដែលព្រះតថាគតបានបញ្ញត្តទុក ចំពោះសទ្ធិវិហារិកទាំងឡាយ។ (រឿងព្រះអង្គទ្រង់បញ្ញត្តសទ្ធិវិហារិកវត្តថា) ឧបជ្ឈាយ៍ត្រូវសង្គ្រោះ អនុគ្រោះសទ្ធិវិហារិក ដោយដមូ្ទាន ដោយពាក្យប្រដៅ ដោយបាលី ដោយអដ្ឋកថា ត្រូវឲ្យបាត្រ ឲ្យចីវរ ឲ្យបរិក្ខារ បើសទ្ធិវិហារិកមានជម្ងឺ ឧបជ្ឈាយ៍ត្រូវថែទាំ ឧបជ្ឈាយ៍មិនត្រូវធ្វើជាបច្ឆាសមណៈរបស់សទ្ធិវិហារិក ក្នុងឧបជ្ឈាយ៍វត្ត សទ្ធិវិហារិក ត្រូវប្រព្រឹត្តយ៉ាងណា សូម្បីក្នុងអាចរិយវត្ត អន្តេវាសិក ក៏ត្រូវប្រព្រឹត្តយ៉ាងនោះដែរ សទ្ធិវិហារិកវត្ត ឧបជ្ឈាយ៍ត្រូវប្រព្រឹត្តយ៉ាងណា អន្តេវាសិកវត្ត អាចារ្យត្រូវប្រព្រឹត្តយ៉ាងនោះដែរ។ ក្នុងខន្ធកៈនេះ មានរឿង១៩ មានវត្ត១៤ គឺ អាគន្តុកវត្ត១ អាវាសិកវត្ត១ គមិកវត្ត១ អនុមោទនាវត្ត១ ភត្តគ្គវត្ត១ បិណ្ឌបាតិកវត្ត១ អារញ្ញកវត្ត១ សេនាសនវត្ត១ ជន្តាឃរវត្ត១ វច្ចកុដិវត្ត១ ឧបជ្ឈាយវត្ត១ សទ្ធិវិហារិកវត្ត១ អាចរិយវត្ត១ អន្តេវាសិកវត្ត១ ភិក្ខុណាមិនបានញុំាងវត្តឲ្យពេញបរិបូណ៌ទេ សីលរបស់ភិក្ខុនោះក៏មិនពេញបរិបូណ៌ដែរ ភិក្ខុណាមានសីលមិនបរិសុទ្ធ ខ្សត់ប្រាជ្ញា ភិក្ខុនោះក៏មិនបាននូវឯកគ្គតាចិត្តឡើយ ភិក្ខុណាមានចិត្តរវើរវាយ មានអារម្មណ៍រាយមាយ ភិក្ខុនោះ នឹងមិនបានឃើញព្រះសទ្ធម្មដោយប្រពៃ កាលបើភិក្ខុណា មិនបានឃើញព្រះសទ្ធម្មហើយ ភិក្ខុនោះនឹងមិនបានរួចផុតចាកទុក្ខ។ ភិក្ខុណា បានញុំាងវត្តណានីមួយ ឲ្យពេញបរិបូណ៌ហើយ សីលរបស់ភិក្ខុនោះក៏ពេញបរិបូណ៌ ភិក្ខុណាមានសីលបរិសុទ្ធ ប្រកបដោយប្រាជ្ញា ភិក្ខុនោះរមែងបានឯកគ្គតាចិត្ត ភិក្ខុណាមានចិត្តមិនរវើរវាយ មានអារម្មណ៍តែមួយ ភិក្ខុនោះ នឹងបានឃើញច្បាស់នូវធម៌ដោយប្រពៃ កាលបើឃើញច្បាស់នូវព្រះសទ្ធម្ម (ដោយប្រពៃហើយ) ភិក្ខុនោះនឹងបានផុតចាកសេចក្តីទុក្ខ។ ព្រោះហេតុនោះ ភិក្ខុដែលជាបុត្តនៃព្រះជិនស្រី ជាអ្នកមានប្រាជ្ញា ពិចារណាឃើញច្បាស់នូវឱវាទ នៃព្រះពុទ្ធដ៏ប្រសើរ គប្បីបំពេញវត្តឲ្យពេញលេញ នឹងបានសម្រេចនូវព្រះនិព្វាន ក្នុងលំដាប់នោះឯង។

# បាតិមោក្ខដ្ឋបនក្ខន្ធកៈ (ទី៩)

CS vin.cv.09 | ភាគ ទី១១

### (៩. បាតិមោក្ខដ្ឋបនក្ខន្ធកំ)

## (បាតិមោក្ខុទ្ទេសយាចនា ទី១)

CS vin.cv.09.01 | ភាគ ទី១១

### (១. បាតិមោក្ខុទ្ទេសយាចនា)

[១១១] សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់ក្នុងប្រាសាទមិគារមាតា ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី។ សម័យនោះឯង នាថ្ងៃបណ្ណរសីឧបោសថនោះ ព្រះមានព្រះភាគ ទ្រង់គង់ (ក្នុងរោងឧបោសថ) មានភិក្ខុសង្ឃចោមរោម។ លុះវេលារាត្រីបឋមយាមកន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន វេលារាត្រីបឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សំដែង បាតិមោក្ខ ដល់ភិក្ខុទាំងឡាយ។ កាលដែលព្រះអានន្ទដ៏មានអាយុក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគក៏គង់ស្ងៀម។ កាលបើវេលារាត្រីមជ្ឈិមយាមកន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យ ចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ អស់វារៈ ជាគំរប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន វេលារាត្រីមជ្ឈិមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សំដែង បាតិមោក្ខ ដល់ភិក្ខុទាំងឡាយ។ ព្រះមានព្រះភាគ ទ្រង់គង់ស្ងៀម អស់វារៈ ជាគំរប់ពីរដង។ លុះវេលារាត្រីបច្ឆិមយាមកន្លងទៅហើយ រាត្រីក៏ប្រាកដដូចជាមានមុខស្រស់ (បំព្រង) ក្នុងពេលដែលអរុណរះឡើង ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ហើយធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ជាគំរប់បីដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន

ឥឡូវនេះ រាត្រីបច្ឆិមយាមកន្លងទៅហើយ អរុណក៏រះហើយ រាត្រីក៏ប្រាកដដូចជាមានមុខស្រស់ហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សំដែង បាតិមោក្ខ ដល់ភិក្ខុទាំងឡាយ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិសទ្យមិនបរិសុទ្ធទេ។

[១១២] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សំដៅយកបុគ្គលណាហ្ន៎ បានជាទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិសទ្យមិនបរិសុទ្ធទេយ៉ាងនេះ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ស្ទង់មើលចិត្ត (របស់សង្ឃ) ដោយចិត្ត (របស់លោក) ហើយធ្វើទុកក្នុងចិត្តចំពោះភិក្ខុសង្ឃទាំងអស់នោះ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញបុគ្គលទ្រុស្តសីលនោះ មានធម៌លាមក មានមារយាទមិនល្អ គួរឲ្យគេរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនជាសមណៈ តែប្តេជ្ញាថាខ្លួនជាសមណៈ មិនប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ កខ្វក់ដូចសម្រាម អង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃ លុះឃើញហើយ ក៏ចូលទៅរកបុគ្គលនោះ លុះចូលទៅជិតហើយ ក៏ពោលពាក្យនេះ ចំពោះបុគ្គលនោះថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគ ទ្រង់បានឃើញអ្នកឯងច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ។ កាលដែលព្រះមហាមោគ្គល្លាន ពោលយ៉ាងនេះ បុគ្គលនោះក៏នៅស្ងៀម។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយពាក្យនេះ នឹងបុគ្គលនោះ ជាគំរប់ពីរដងទៀតថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគ ទ្រង់បានឃើញអ្នកច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ។ បុគ្គលនោះ ក៏នៅស្ងៀម អស់វារៈពីរដងទៀត។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយពាក្យនេះ នឹងបុគ្គលនោះ ជាគំរប់បីដងទៀតថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគ ទ្រង់បានឃើញអ្នកឯងច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ។ ឯបុគ្គលនោះ ក៏នៅស្ងៀម អស់វារៈជាគំរប់បីដងទៀត។ តពីនោះមក ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ចាប់ដៃបុគ្គលនោះ ទាញចេញទៅខាងក្រៅស៊ុំទ្វារ ហើយស៊កខ្នាស់គន្លឹះ និងរនុកទ្វារ រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គល (ទ្រុស្តសីល) នោះ ខ្ញុំព្រះអង្គ បានបណ្តេញឲ្យដើរចេញទៅហើយ ឥឡូវនេះ បរិសទ្យបរិសុទ្ធហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ ទ្រង់សំដែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន (ហេតុនេះ) អស្ចារ្យណាស់ មិនធ្លាប់កើតមានទេ ម្នាលមោគ្គល្លាន មោឃបុរសនោះ មិនសមបើនឹងមក ដរាបតែគេចាប់ទាញដៃ (បណ្តេញចេញដូច្នេះ) សោះ។

# (មហាសមុទ្ទេអដ្ឋច្ឆរិយៈ ទី២)

CS vin.cv.09.02 | ភាគ ទី១១

### (២. មហាសមុទ្ទេអដ្ឋច្ឆរិយំ)

[១១៣] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ មានធម្មតា មិនដែលកើតគួរអស្ចារ្យ៨យ៉ាងនេះ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។ ធម្មតាគួរអស្ចារ្យ៨យ៉ាង ដូចម្តេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តង ដូចជាអណ្តូងទេ ម្នាលភិក្ខុទាំងឡាយ ឯមហាសមុទ្រ ដែលមានទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តង ដូចអណ្តូងទេ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យទី១ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត មហាសមុទ្រ មានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបានទេ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ តែងមានទឹកតាំងនៅនឹង ជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងបានឡើយ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើតមាន គួរអស្ចារ្យទី២ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។

[១១៥] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត មហាសមុទ្រ មិនដែលមានសាកសពស្លាប់នៅរួមបានទេ បើសាកសពស្លាប់ណា មាននៅក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះ ទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ម្នាលភិក្ខុទាំងឡាយ ឯមហាសមុទ្រ មិនដែលមានសាកសពស្លាប់នៅរួមបាន បើសាកសពណា មានក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះ ទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យទី៣ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។

[១១៦] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ទន្លេធំៗទាំងឡាយណានីមួយ ដូចជាទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់មហាសមុទ្រហើយ តែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ម្នាលភិក្ខុទាំងឡាយ ទន្លេធំទាំងឡាយណានីមួយ ដូចជាទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់មហាសមុទ្រហើយ តែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យទី៤ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។

[១១៧] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ទឹកទន្លេទាំងឡាយណានីមួយក្នុងលោក ដែលហូរស្រោចទៅរកមហាសមុទ្រក្តី ទ-ទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកពីអាកាសក្តី មហាសមុទ្រ ក៏មិនប្រាកដជាស្រក ឬពេញដោយទឹកទន្លេ និងទ ទឹកភ្លៀងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ទឹកទន្លេទាំងឡាយណានីមួយក្នុងលោក ដែលហូរទៅរកមហាសមុទ្រក្តី ទ-ទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកពីអាកាសក្តី មហាសមុទ្រ ក៏មិនប្រាកដជាស្រក ឬពេញដោយទឹកទន្លេ និងទ-ទឹកភ្លៀងទាំងនោះ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យទី៥ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។

[១១៨] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត មហាសមុទ្រមានរសតែមួយ គឺរសប្រៃ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រតែងមានរសតែមួយ គឺរសប្រៃ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យទី៦ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។

[១១៩] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត មហាសមុទ្រ មានរតនៈ (ទ្រព្យជាគ្រឿងពេញចិត្ត) ច្រើនយ៉ាង មិនមែនមានតែរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះ ដែលមានក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (ត្បូងទទឹម) និងកែវមរកត ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានរតនៈច្រើនយ៉ាង មិនមែនមានតែរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះ ដែលមាននៅក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម និងកែវមរកត ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យទី៧ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។

[១២០] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗជាច្រើន ពួកសត្វធំៗទាំងនេះ (តែងនៅ) ក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល ឈ្មោះតិមិតិមិង្គល ឈ្មោះមហាតិមិង្គល និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព១រយយោជន៍ខ្លះ មានអត្តភាព២រយយោជន៍ខ្លះ មានអត្តភាព៣រយយោជន៍ខ្លះ មានអត្តភាព៤រយយោជន៍ខ្លះ មានអត្តភាព៥រយយោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗជាច្រើន ពួកសត្វធំៗទាំងនេះ ក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល ឈ្មោះតិមិតិមិង្គល ឈ្មោះមហាតិមិង្គល និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព១រយយោជន៍ខ្លះ។បេ។ មានអត្តភាព៥រយយោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យទី៨ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ។

# (ឥមស្មិំធម្មវិនយេអដ្ឋច្ឆរិយៈ ទី៣)

CS vin.cv.09.03 | ភាគ ទី១១

### (៣. ឥមស្មិំធម្មវិនយេអដ្ឋច្ឆរិយំ)

[១២១] ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌វិន័យនេះ មានសភាពមិនដែលកើត គួរអស្ចារ្យ៨ប្រការ ដែលភិក្ខុទាំងឡាយឃើញហើយ តែងត្រេកអរក្នុងធម៌វិន័យនេះ ដូចមហាសមុទ្រដែរ។ សភាពគួរអស្ចារ្យ៨ប្រការនោះ ដូចម្តេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌វិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងព្រះអរហត្តផលតែម្តងទេ ដូចមហាសមុទ្រដែលមានទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីទេរដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តង ដូចអណ្តូងទេ ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌វិន័យនេះ តែងមានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងព្រះអរហត្តផលតែម្តង ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យទី១ ក្នុងធម៌វិន័យនេះ ដែលភិក្ខុទាំងឡាយឃើញហើយ តែងត្រេកអរក្នុងធម៌វិន័យនេះ។

[១២២] ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគតបានបញ្ញត្តដល់សាវ័កទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះឡើយ ដូចមហាសមុទ្រ ដែលមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅបាន ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគតបានបញ្ញត្តដល់សាវ័កទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះ ដោយសភាពណា នេះជាសភាពមិនដែលកើត គួរអស្ចារ្យទី២ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម៌វិន័យនេះ។

[១២៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនល្អ គួរឲ្យគេរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថា ជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ កខ្វក់ដូចសម្រាម សង្ឃនៅរួមជាមួយនឹងបុគ្គលនោះមិនបាន សង្ឃប្រជុំគ្នា នាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះ បើទុកជាអង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃពិតមែន បុគ្គលនោះ ក៏ឈ្មោះថានៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃ ក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះ ដូចមហាសមុទ្រ មិនដែលមានសាកសពស្លាប់នៅរួមបាន បើសាកសពស្លាប់ណានីមួយ ដែលមានក្នុងមហាសមុទ្រ មហាសមុទ្រតែងបន្សាត់សាកសពនោះទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនល្អ គួរឲ្យគេរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថា ជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ កខ្វក់ដូចសម្រាម សង្ឃនៅរួមជាមួយនឹងបុគ្គលនោះមិនបាន សង្ឃតែងប្រជុំគ្នា នាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះ បើទុកជាអង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃដោយពិត បុគ្គលនោះ ក៏ឈ្មោះថានៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃ ក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះ ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យទី៣ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម៌វិន័យនេះ។

[១២៤] ម្នាលភិក្ខុទាំងឡាយ វណ្ណៈ៤ពួកនេះ គឺខត្តិយៈ១ ព្រាហ្មណ៍១ វេស្សៈ១ សុទ្ទៈ១ វណ្ណៈទាំងនោះ ចេញចាកផ្ទះមកបួសក្នុងធម៌វិន័យ ដែលតថាគតសំដែងហើយ រមែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់បញ្ចូល ថាជាសមណសក្យបុត្តិយ៍តែម្យ៉ាង ដូចទន្លេធំៗទាំងឡាយ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់មហាសមុទ្រហើយ តែលះបង់នាម និងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់ថា ជាមហាសមុទ្រតែម្យ៉ាង ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ វណ្ណៈ៤ពួកនេះ គឺខត្តិយៈ១ ព្រាហ្មណ៍១ វេស្សៈ១ សុទ្ទៈ១ វណ្ណៈទាំងនោះ ចេញចាកផ្ទះ មកបួសក្នុងធម៌វិន័យ ដែលតថាគតសំដែងហើយ ក៏រមែងលះបង់នាម និងគោត្រដើម (របស់ខ្លួន) ហើយ

ដល់នូវកិរិយារាប់បញ្ចូល ថាជាសមណសក្យបុត្តិយ៍តែម្យ៉ាង ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យទី៤ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ រមែងត្រេកអរក្នុងធម៌វិន័យនេះ។

[១២៥] ម្នាលភិក្ខុទាំងឡាយ ទោះបីពួកភិក្ខុច្រើនរូប បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុ ក៏មិនប្រាកដថា ខ្វះ ឬពេញដោយភិក្ខុទាំងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ដូចទឹកទន្លេទាំងឡាយណានីមួយក្នុងលោក ដែលហូរស្រោច ចុះទៅកាន់មហាសមុទ្រក្តី ទ-ទឹកភ្លៀងទាំងឡាយណា ដែលហូរចុះមកពីអាកាសក្តី មហាសមុទ្រ ក៏មិនប្រាកដថាស្រក ឬពេញដោយទឹកនោះ ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយទុកជាពួកភិក្ខុច្រើនរូប បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុ ក៏មិនប្រាកដថា ខ្វះ ឬពេញ ដោយភិក្ខុទាំងនោះ ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យទី៥ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម៌វិន័យនេះ។

[១២៦] ម្នាលភិក្ខុទាំងឡាយ ធម៌វិន័យនេះ មានរសតែមួយ គឺ វិមុត្តិរស ដូចមហាសមុទ្រ ដែលមានរសតែមួយ គឺរសប្រៃ ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ។បេ។ គឺវិមុត្តិរស ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យទី៦ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម៌វិន័យនេះ។

[១២៧] ម្នាលភិក្ខុទាំងឡាយ ធម៌វិន័យនេះ មានរតនៈ (ធម៌ជាទីរីករាយ) ច្រើនយ៉ាង មិនមែនមានត្រឹមតែមួយប៉ុណ្ណោះទេ រតនៈនេះ ក្នុងធម៌វិន័យនោះ គឺ សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គ៧ និងមគ្គប្រកបដោយអង្គ៨ ដែលជាផ្លូវដ៏ប្រសើរ ដូចមហាសមុទ្រ មានរតនៈ (ទ្រព្យជាគ្រឿងរីករាយ) ច្រើនយ៉ាង មិនមែនមានតែមួយទេ រតនៈទាំងនេះ ក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (ត្បូងទទឹម) និងកែវមរកត ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម៌វិន័យនេះ មានរតនៈច្រើនយ៉ាង មិនមែនមានត្រឹមតែមួយប៉ុណ្ណោះទេ រតនៈទាំងនេះ ក្នុងធម៌វិន័យនោះ គឺ សតិប្បដ្ឋាន៤។បេ។ និងមគ្គប្រកបដោយអង្គ៨ ដែលជាផ្លូវដ៏ប្រសើរ ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យទី៧ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម៌វិន័យនេះ។

[១២៨] ម្នាលភិក្ខុទាំងឡាយ ធម៌វិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗជាច្រើន បុគ្គលទាំងនេះ ក្នុងធម៌វិន័យនោះ គឺ សោតាបន្នបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សកទាគាមិបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល អនាគាមិបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល អរហន្ត និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បី (ធ្វើឲ្យជាក់ច្បាស់) នូវអរហត្តផល ដូចមហាសមុទ្រ ដែលជាទីនៅអាស្រ័យនៃពួកសត្វធំៗជាច្រើន ឯពួកសត្វទាំងនេះ ក្នុងមហាសមុទ្រនោះ គឺ ត្រីឈ្មោះតិមិ។បេ។ និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព១រយយោជន៍ខ្លះ មានអត្តភាព២រយយោជន៍ខ្លះ មានអត្តភាព៣រយយោជន៍ខ្លះ មានអត្តភាព៤រយយោជន៍ខ្លះ មានអត្តភាព៥រយយោជន៍ខ្លះ ដែលមាននៅក្នុងមហាសមុទ្រដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម៌វិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗជាច្រើន ពួកបុគ្គលទាំងនេះ ក្នុងធម៌វិន័យនោះ គឺ សោតាបន្នបុគ្គល។បេ។ និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បី (ធ្វើឲ្យជាក់ច្បាស់) នូវអរហត្តផល ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យទី៨ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម៌វិន័យនេះ ម្នាលភិក្ខុទាំងឡាយ នេះឯងហើយ ដែលហៅថា សភាពមិនដែលកើត គួរអស្ចារ្យ៨ប្រការ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម៌វិន័យនេះ។

[១២៩] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទ្រង់បន្លឺនូវឧទានវាចានេះ ក្នុងវេលានោះថា

> ភិក្ខុត្រូវអាបត្តិហើយ បិទបាំងអាបត្តិទុក រមែងត្រូវអាបត្តិថ្មីដទៃទៀត ភិក្ខុត្រូវអាបត្តិហើយ បើកអាបត្តិ មិនត្រូវអាបត្តិដទៃទៀតទេ ព្រោះហេតុនោះ កាលបើភិក្ខុ (ណាមួយ) ត្រូវអាបត្តិហើយ បិទបាំងអាបត្តិទុក ភិក្ខុ (នោះ) ត្រូវបើកអាបត្តិចេញ ធ្វើយ៉ាងនេះ ទើបមិនត្រូវអាបត្តិនោះទៀតឡើយ។

# (បាតិមោក្ខសវនារហៈ ទី៤)

CS vin.cv.09.04 | ភាគ ទី១១

### (៤. បាតិមោក្ខសវនារហោ)

[១៣០] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ តាំងអំពីថ្ងៃនេះតទៅមុខ តថាគតនឹងមិនធ្វើឧបោសថ មិនសំដែងបាតិមោក្ខទេ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ចាប់ដើមអំពីថ្ងៃនេះតទៅមុខ ចូរអ្នកទាំងឡាយ នាំគ្នាធ្វើឧបោសថ សំដែងបាតិមោក្ខចុះ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងធ្វើឧបោសថ សំដែងបាតិមោក្ខជាមួយនឹងបរិសទ្យមិនបរិសុទ្ធដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាស (ល្មមនឹងធ្វើបានទេ) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុដែលមានអាបត្តិ មិនត្រូវស្តាប់បាតិមោក្ខទេ ភិក្ខុណាស្តាប់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបញ្ឈប់បាតិមោក្ខ ដល់ភិក្ខុដែលមានអាបត្តិហើយមកស្តាប់បាតិមោក្ខ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវបញ្ឈប់ (បាតិមោក្ខ) យ៉ាងនេះឯង។ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះ កាលបើមានបុគ្គល គឺភិក្ខុនោះមក ក្នុងទីចំពោះមុខ ភិក្ខុគប្បីប្រកាសកណ្តាលជំនុំសង្ឃថា បពិត្រព្រះអង្គដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតបុគ្គលឈ្មោះនេះ ជាអ្នកមានអាបត្តិ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ដល់បុគ្គលនោះ កាលបើបុគ្គលនោះ នៅក្នុងទីចំពោះមុខ សង្ឃមិនគួរសំដែងបាតិមោក្ខទេ។ សង្ឃឈ្មោះថា បញ្ឈប់បាតិមោក្ខហើយ។

[១៣១] ក្នុងសម័យនោះ ពួកឆព្វគ្គិយភិក្ខុ សុទ្ធតែជាអ្នកមានអាបត្តិ នាំគ្នាមកស្តាប់បាតិមោក្ខ ដោយគិតថា មិនមាននរណាស្គាល់ពួកយើងទេ។ ពួកភិក្ខុជាថេរៈ ដែលជ្រាបច្បាស់នូវវារៈចិត្តនៃបុគ្គលដទៃ ក៏ប្រាប់ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ឆព្វគ្គិយភិក្ខុឈ្មោះនេះមួយ ឈ្មោះនេះមួយ សុទ្ធតែជាអ្នកមានអាបត្តិ ហើយនាំគ្នាមកស្តាប់បាតិមោក្ខ ដោយគិតថា មិនមាននរណាស្គាល់ពួកយើងទេ។ ពួកឆព្វគ្គិយភិក្ខុបានឮដំណឹងថា ពួកភិក្ខុជាថេរៈ ដែលលោកជ្រាបច្បាស់នូវវារៈចិត្ត នៃបុគ្គលដទៃប្រាប់ (រឿង) យើងដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ពួកឆព្វគ្គិយភិក្ខុឈ្មោះនេះមួយ ឈ្មោះនេះមួយ សុទ្ធតែជាអ្នកមានអាបត្តិ ហើយនាំគ្នាមកស្តាប់បាតិមោក្ខ ដោយគិតថា មិនមាននរណាស្គាល់ពួកយើងទេ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះគិតគ្នាថា កាលពីមុន ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ បញ្ឈប់បាតិមោក្ខចំពោះពួកយើង ហើយប្រញាប់បញ្ឈប់បាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ដែលបរិសុទ្ធ មិនមានអាបត្តិ ដោយឥតមានរឿង ឥតមានហេតុ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងបញ្ឈប់បាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ដែលបរិសុទ្ធមិនមានអាបត្តិ ដោយឥតមានរឿង ឥតមានហេតុសោះឡើយ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកឆព្វគ្គិយបញ្ឈប់បាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ដែលបរិសុទ្ធ មិនមានអាបត្តិ ដោយឥតមានរឿង ឥតមានហេតុ ពិតមែនឬ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន។បេ។ ព្រះមានព្រះភាគទ្រង់បន្ទោស ហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបញ្ឈប់បាតិមោក្ខ ដល់ពួកភិក្ខុ ដែលបរិសុទ្ធ មិនមានអាបត្តិ ដោយឥតមានរឿង ឥតមានហេតុទេ ភិក្ខុណាបញ្ឈប់ ត្រូវអាបត្តិទុក្កដ។

# (ធម្មិកាធម្មិកបាតិមោក្ខដ្ឋបនៈ ទី៥)

CS vin.cv.09.05 | ភាគ ទី១១

### (៥. ធម្មិកាធម្មិកបាតិមោក្ខដ្ឋបនំ)

[១៣២] ម្នាលភិក្ខុទាំងឡាយ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌១ ប្រកបដោយធម៌១ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌២យ៉ាង ប្រកបដោយធម៌២យ៉ាង។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៣យ៉ាង ប្រកបដោយធម៌៣យ៉ាង។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៤យ៉ាង ប្រកបដោយធម៌៤យ៉ាង។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៥យ៉ាង ប្រកបដោយធម៌៥យ៉ាង។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៦យ៉ាង ប្រកបដោយធម៌៦យ៉ាង។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៧យ៉ាង ប្រកបដោយធម៌៧យ៉ាង។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៨យ៉ាង ប្រកបដោយធម៌៨យ៉ាង។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៩យ៉ាង ប្រកបដោយធម៌៩យ៉ាង។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌១០យ៉ាង ប្រកបដោយធម៌១០យ៉ាង។

[១៣៣] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌១យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌១យ៉ាង។

[១៣៤] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌១យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌១យ៉ាង។

[១៣៥] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌២យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌២យ៉ាង។

[១៣៦] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌២យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌២យ៉ាង។

[១៣៧] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៣យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៣យ៉ាង។

[១៣៨] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៣យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៣យ៉ាង។

[១៣៩] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៤យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមិនមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៤យ៉ាង។

[១៤០] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៤យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៤យ៉ាង។

[១៤១] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៥យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះបារាជិកាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះសង្ឃាទិសេសាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះបាចិត្តិយាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះ

បាដិទេសនីយាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទុក្កដាបត្តិមិនមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៥យ៉ាង។

[១៤២] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៥យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះបារាជិកាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះសង្ឃាទិសេសាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះបាចិត្តិយាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះបាដិទេសនីយាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទុក្កដាបត្តិមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៥យ៉ាង។

[១៤៣] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៦យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៦យ៉ាង។

[១៤៤] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៦យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៦យ៉ាង។

[១៤៥] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៧យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះបារាជិកាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះសង្ឃាទិសេសាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះថុល្លច្ចយាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះបាចិត្តិយាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះបាដិទេសនីយាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទុក្កដាបត្តិមិនមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទុព្ភាសិតាបត្តិមិនមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៧យ៉ាង។

[១៤៦] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៧យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះបារាជិកាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះសង្ឃាទិសេសាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះថុល្លច្ចយាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះបាចិត្តិយាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះបាដិទេសនីយាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទុក្កដាបត្តិមានមូល១ បញ្ឈប់បាតិមោក្ខ ព្រោះទុព្ភាសិតាបត្តិមានមូល១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៧យ៉ាង។

[១៤៧] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៨យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៨យ៉ាង។

[១៤៨] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៨យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៨យ៉ាង។

[១៤៩] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៩យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ និងមិនធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ និងមិនធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ និងមិនធ្វើហើយ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌៩យ៉ាង។

[១៥០] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៩យ៉ាង។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ និងមិនធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ និងមិនធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ និងមិនធ្វើហើយ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌៩យ៉ាង។

[១៥១] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌១០យ៉ាង។ មិនមានភិក្ខុត្រូវបារាជិក អង្គុយក្នុងបរិសទ្យនោះ១ មិនមានពាក្យពណ៌នា អំពីភិក្ខុត្រូវបារាជិក ដែលសង្ឃធ្វើមិនទាន់ស្រេច១ មិនមានភិក្ខុអ្នកពោលលាសិក្ខា អង្គុយក្នុងបរិសទ្យនោះ១ មិនមានពាក្យពណ៌នា អំពីភិក្ខុអ្នកពោលលាសិក្ខា ដែលសង្ឃធ្វើមិនទាន់ស្រេច១ ភិក្ខុចូលមកព្រមព្រៀងគ្នា ប្រកបដោយធម៌១ ភិក្ខុមិនត្រឡប់សើរើសេចក្តីព្រម

ព្រៀង ដែលប្រកបដោយធម៌១ មានពាក្យពណ៌នា អំពីការត្រឡប់សើរើសេចក្តីព្រមព្រៀងប្រកបដោយធម៌ ដែលសង្ឃធ្វើស្រេចហើយ១ មិនមានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយសីលវិបត្តិ១ មិនមានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយអាចារវិបត្តិ១ មិនមានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយទិដ្ឋិវិបត្តិ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌១០យ៉ាង។

[១៥២] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌១០យ៉ាង។ មានភិក្ខុត្រូវបារាជិក អង្គុយក្នុងបរិសទ្យនោះ១ មានពាក្យពណ៌នា អំពីភិក្ខុត្រូវបារាជិក ដែលសង្ឃធ្វើមិនទាន់ស្រេច១ មានភិក្ខុអ្នកពោលលាសិក្ខា អង្គុយក្នុងបរិសទ្យ១ មានពាក្យពណ៌នា អំពីភិក្ខុអ្នកពោលលាសិក្ខា ដែលសង្ឃធ្វើមិនទាន់ស្រេច១ ភិក្ខុមិនចូលមកព្រមព្រៀងគ្នាប្រកបដោយធម៌១ ភិក្ខុត្រឡប់សើរើសេចក្តីព្រមព្រៀង ដែលប្រកបដោយធម៌១ មានពាក្យពណ៌នា អំពីការត្រឡប់សើរើសេចក្តីព្រមព្រៀងប្រកបដោយធម៌ ដែលសង្ឃបានធ្វើស្រេចហើយ១ មានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយសីលវិបត្តិ១ មានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយអាចារវិបត្តិ១ មានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយទិដ្ឋិវិបត្តិ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌១០យ៉ាង។

## (ធម្មិកបាតិមោក្ខដ្ឋបនៈ ទី៦)

CS vin.cv.09.06 | ភាគ ទី១១

### (៦. ធម្មិកបាតិមោក្ខដ្ឋបនំ)

[១៥៣] ដូចម្តេចហៅថា ភិក្ខុត្រូវបារាជិក អង្គុយក្នុងបរិសទ្យនោះ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ រមែងមានការត្រូវអាបត្តិបារាជិក ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ឯភិក្ខុរមែងឃើញភិក្ខុដែលត្រូវអាបត្តិបារាជិក ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនបានឃើញភិក្ខុដែលត្រូវអាបត្តិបារាជិក (នោះ) ទេ ក៏គង់មានភិក្ខុឯទៀត ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ ប្រសិនបើភិក្ខុមិនឃើញភិក្ខុដែលត្រូវអាបត្តិបារាជិកនោះទេ ទាំងភិក្ខុឯទៀត ក៏មិនបានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ ដូច្នេះទេ ក៏ភិក្ខុនោះឯង ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិបារាជិកហើយ ដូច្នេះ (មិនខាន) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមានប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្តាលសង្ឃ ចំពោះបុគ្គល គឺភិក្ខុត្រូវអាបត្តិបារាជិក ដែលនៅក្នុងទីចំពោះមុខនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតបុគ្គលឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ ឥឡូវនេះ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គលនោះមកនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ។ ការបញ្ឈប់បាតិមោក្ខនេះ ឈ្មោះថា ប្រកបដោយធម៌។

[១៥៤] កាលបើសង្ឃបញ្ឈប់បាតិមោក្ខដល់ភិក្ខុហើយ បរិសទ្យក្រោកឡើង ព្រោះបណ្តាអន្តរាយទាំង១០យ៉ាង អន្តរាយណាមួយ ទោះបីអន្តរាយអំពីព្រះរាជាក្តី អន្តរាយអំពីចោរក្តី អន្តរាយអំពីភ្លើងក្តី អន្តរាយអំពីទឹកក្តី អន្តរាយអំពីមនុស្សក្តី អន្តរាយអំពីអមនុស្សក្តី អន្តរាយអំពីសត្វសាហាវក្តី អន្តរាយអំពីសត្វពស់តូច និងពស់ធំក្តី អន្តរាយអំពីជីវិតក្តី អន្តរាយព្រហ្មចរិយធម៌ក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខនោះ ក្នុងអាវាសនោះ ឬក្នុងអាវាសណាមួយបានថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីបារាជិក របស់បុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចនៅឡើយទេ (ព្រោះ) រឿងនោះ សង្ឃមិនទាន់វិនិច្ឆ័យដាច់ស្រេច បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីវិនិច្ឆ័យរឿងនោះចុះ។ បើសង្ឃបានវិនិច្ឆ័យរឿងនោះដាច់ស្រេច នេះជាការល្អ បើបែរជាវិនិច្ឆ័យមិនបានវិញ ភិក្ខុត្រូវសូត្រក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីបារាជិក របស់បុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចនៅឡើយ (ព្រោះ) រឿងនោះ សង្ឃមិនទាន់វិនិច្ឆ័យដាច់ស្រេច ឥឡូវ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ដល់បុគ្គលនោះ កាលបើបុគ្គលនោះ នៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌។

[១៥៥] ភិក្ខុអ្នកពោលលាសិក្ខា អង្គុយនៅក្នុងបរិសទ្យនោះ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពោលលាសិក្ខា ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុឃើញភិក្ខុកំពុងពោលលាសិក្ខា ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនបានឃើញភិក្ខុកំពុងពោលលាសិក្ខា (នោះ) ទេ គង់មានភិក្ខុឯទៀត ប្រាប់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ ពោលលាសិក្ខាហើយ បើភិក្ខុមិនឃើញភិក្ខុកំពុងពោលលាសិក្ខា ទាំងភិក្ខុឯទៀត ក៏មិនប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ ពោលលាសិក្ខាហើយ ដូច្នេះទេ ក៏គង់ភិក្ខុនោះឯង ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំពោលលាសិក្ខាហើយ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បុគ្គលឈ្មោះនេះ ពោលលាសិក្ខាហើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌។

[១៥៦] កាលបើសង្ឃបញ្ឈប់បាតិមោក្ខដល់ភិក្ខុហើយ បរិសទ្យក្រោកឡើង ព្រោះអន្តរាយទាំង១០យ៉ាង អន្តរាយណាមួយ ទោះបីអន្តរាយអំពីព្រះរាជាក្តី។បេ។ អន្តរាយព្រហ្មចរិយធម៌ក្តី ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខនោះ ក្នុងអាវាសនោះ ឬក្នុងអាវាសណាមួយថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីភិក្ខុអ្នកពោលលាសិក្ខា នៃបុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចទេ (ព្រោះ) រឿងនោះ សង្ឃកាត់សេចក្តីមិនទាន់ដាច់ស្រេចនៅឡើយ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីវិនិច្ឆ័យរឿងនោះចុះ។ បើសង្ឃបានវិនិច្ឆ័យរឿងនោះដាច់ស្រេច នេះជាការល្អ បើបែរជាវិនិច្ឆ័យមិនបានវិញ ភិក្ខុត្រូវសូត្រក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីភិក្ខុអ្នកពោលលាសិក្ខា នៃបុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចទេ (ព្រោះ) រឿងនោះ សង្ឃកាត់សេចក្តីមិនទាន់

ដាច់ស្រេចនៅឡើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ដល់បុគ្គលនោះ កាលបើបុគ្គលនោះ នៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌។

[១៥៧] ភិក្ខុមិនបានចូលមកព្រមព្រៀងគ្នា ប្រកបដោយធម៌ (នោះ) តើដូចម្ដេច។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកិរិយាមិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុឃើញភិក្ខុដែលមិនដល់សេចក្ដីព្រមព្រៀងគ្នា ប្រកបដោយធម៌ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនឃើញភិក្ខុដែលមិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ (នោះ) ទេ គង់មានភិក្ខុឯទៀត ប្រាប់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ទេ ប្រសិនបើភិក្ខុ ក៏មិនបានឃើញភិក្ខុដែលមិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ ទាំងភិក្ខុឯទៀត ក៏មិនបានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ ដូច្នេះទេ ក៏គង់ភិក្ខុនោះឯង ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំមិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ទេ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្ដាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ (ដ្បិត) បុគ្គល គឺភិក្ខុឈ្មោះនេះ មិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ទេ ឥឡូវ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ដល់បុគ្គលនោះ កាលបើបុគ្គលនោះ នៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌។

[១៥៨] ភិក្ខុត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ (នោះ) តើដូចម្ដេច។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ រមែងមានការត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុឃើញភិក្ខុដែលត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនឃើញភិក្ខុដែលត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ទេ គង់មានភិក្ខុឯទៀត ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ ត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ហើយ ប្រសិនបើភិក្ខុ ក៏មិនឃើញភិក្ខុដែលត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ ទាំងភិក្ខុឯទៀត ក៏មិនបានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ ត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ហើយ ដូច្នេះទេ ក៏គង់ភិក្ខុនោះ ប្រាប់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ហើយ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រាថ្នា គប្បីសូត្រក្នុងកណ្ដាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលឈ្មោះនេះ ត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ហើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ដល់បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌។

[១៥៩] កាលបើសង្ឃបានបញ្ឈប់បាតិមោក្ខដល់ភិក្ខុនោះហើយ បរិសទ្យក៏ក្រោកចេញ ព្រោះបណ្ដាអន្តរាយទាំង១០យ៉ាង អន្តរាយណាមួយ ទោះបីអន្តរាយអំពីព្រះរាជាក្ដី។បេ។ អន្តរាយព្រហ្មចរិយធម៌ក្ដី ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្ដាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខនោះ ក្នុងអាវាសនោះ ឬក្នុងអាវាសណាមួយថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ពាក្យពណ៌នាអំពីការត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ នៃបុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចនៅឡើយ (ព្រោះ) រឿងនោះ សង្ឃវិនិច្ឆ័យមិនទាន់ដាច់ស្រេច បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីវិនិច្ឆ័យរឿងនោះចុះ។ បើសង្ឃបានវិនិច្ឆ័យរឿងនោះដាច់ស្រេច នេះក៏ជាការប្រពៃ បើបែរជាវិនិច្ឆ័យមិនបានវិញ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះ ភិក្ខុត្រូវសូត្រក្នុងកណ្ដាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ ពាក្យពណ៌នាអំពីការត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ នៃបុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចនៅឡើយទេ (ព្រោះ) រឿងនោះ សង្ឃវិនិច្ឆ័យមិនទាន់ដាច់ស្រេច ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ដល់បុគ្គលនោះ កាលបើបុគ្គលនោះ នៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌។

[១៦០] ភិក្ខុដែលគេបានឃើញ ឮ រង្កៀសដោយសីលវិបត្តិ តើដូចម្ដេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដែលគេបានឃើញ ឮ រង្កៀស ដោយសីលវិបត្តិ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុក៏ឃើញភិក្ខុដែលគេបានឃើញ ឮ រង្កៀស ដោយសីលវិបត្តិ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនឃើញភិក្ខុដែលគេឃើញ ឮ រង្កៀស ដោយសីលវិបត្តិនោះទេ គង់មានភិក្ខុឯទៀត ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ រង្កៀសដោយសីលវិបត្តិ (ប្រសិនបើ) ភិក្ខុមិនឃើញភិក្ខុដែលមានគេឃើញ ឮ រង្កៀស ដោយសីលវិបត្តិ ទាំងភិក្ខុឯទៀត ក៏មិនប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ រង្កៀស ដោយសីលវិបត្តិ ដូច្នេះទេ ក៏គង់ភិក្ខុនោះឯង ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្លួនខ្ញុំមានគេឃើញ ឮ ឬរង្កៀស ដោយសីលវិបត្តិដូច្នេះ (មិនលែង) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុមានប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្ដាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ (ដ្បិត) បុគ្គលឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀស ដោយសីលវិបត្តិ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ចំពោះបុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខសង្ឃ សង្ឃមិនត្រូវសំដែងបាតិមោក្ខឡើយ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌។

[១៦១] ភិក្ខុដែលគេឃើញ ឮ រង្កៀសដោយអាចារវិបត្តិ តើដូចម្ដេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងមានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុក៏ឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀសហើយ ដោយអាចារវិបត្តិ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះដែរ បើភិក្ខុមិនបានឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិនោះទេ គង់មានភិក្ខុឯទៀត ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិដូច្នេះដែរ (ប្រសិនបើ) ភិក្ខុក៏មិនបានឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិទេ ទាំងភិក្ខុឯទៀត ក៏មិនបានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិ ដូច្នេះទេ ក៏គង់ភិក្ខុនោះឯង ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្លួនខ្ញុំមានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្ដាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ (ដ្បិត) បុគ្គលឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិហើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ចំពោះ

បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខឡើយ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌។

[១៦២] ភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀសដោយទិដ្ឋិវិបត្តិ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុផងគ្នាក៏ឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះដែរ បើភិក្ខុផងគ្នាមិនឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិទេ គង់មានភិក្ខុឯទៀត ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀសដោយទិដ្ឋិវិបត្តិដូច្នេះដែរ (ប្រសិនបើ) ភិក្ខុក៏មិនឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយសីលវិបត្តិទេ ទាំងភិក្ខុឯទៀត ក៏មិនប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀសហើយ ដោយទិដ្ឋិវិបត្តិ ដូច្នេះទេ ក៏គង់ភិក្ខុនោះឯង ប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្លួនខ្ញុំមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើប្រាថ្នា ក៏គប្បីសូត្រក្នុងទីកណ្តាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) បុគ្គលឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិហើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ចំពោះបុគ្គលនោះ កាលបើបុគ្គលនោះ នៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ។ (នេះ) ឈ្មោះថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌។ ទាំង១០នេះ ឈ្មោះថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌។

ភាណវារៈ ជាបឋម។

# (អត្តាទានអង្គៈ ទី៧)

CS vin.cv.09.07 | ភាគ ទី១១

### (៧. អត្តាទានអង្គំ)

[១៦៣] គ្រានោះឯង ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយក្នុងទីដ៏សមគួរ។ ព្រះឧបាលិដ៏មានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសេចក្តីនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលមានប្រាថ្នានឹងកាន់យកនូវអត្តាទាន[21] (ការទទួលរាំងរងអធិករណ៍ដោយខ្លួនឯង) តើត្រូវកាន់យកនូវអត្តាទានប្រកបដោយអង្គប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ (បើ) ភិក្ខុមានសេចក្តីប៉ុនប៉ងនឹងកាន់យកនូវអត្តាទាន ត្រូវកាន់យកនូវអត្តាទានដែលប្រកបដោយអង្គ៥ ម្នាលឧបាលិ ឯភិក្ខុដែលមានសេចក្តីប៉ុនប៉ងនឹងកាន់យកនូវអត្តាទាន (នោះ) ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញមានបំណងនឹងកាន់យកនូវអត្តាទាននេះ ចុះកាលនេះ ជាកាលគួរនឹងកាន់យកនូវអត្តាទាននេះ ឬមិនគួរទេ។ ម្នាលឧបាលិ ប្រសិនបើភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា កាលនេះជាកាលមិនគួរ ជាកាលមិនទំនងនឹងកាន់យកនូវអត្តាទាននេះទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា កាលនេះជាកាលគួរ មិនមែនជាកាលមិនគួរនឹងកាន់យកនូវអត្តាទាននេះទេ ម្នាលឧបាលិ ភិក្ខុនោះ ត្រូវពិចារណាតទៅទៀតថា អាត្មាអញ មានបំណងនឹងកាន់យកនូវអត្តាទាននេះ តើអត្តាទាននេះពិតឬទេ។ ម្នាលឧបាលិ បើភិក្ខុពិចារណាទៅដឹងយ៉ាងនេះថា អត្តាទាននេះ មិនពិត មិនប្រាកដទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា អត្តាទាននេះ ពិតប្រាកដហើយ មិនមែនមិនពិតទេ ម្នាលឧបាលិ ភិក្ខុនោះ ត្រូវពិចារណាតទៅទៀតថា អាត្មាអញ មានបំណងនឹងកាន់យកនូវអត្តាទាននេះ អត្តាទាននេះ តើប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ទេ។ ម្នាលឧបាលិ ប្រសិនបើភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា អត្តាទាននេះ មិនប្រកបដោយប្រយោជន៍ ជាអំពើឥតប្រយោជន៍ទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា អត្តាទាននេះ ប្រកបដោយប្រយោជន៍ មិនមែនជាអំពើឥតប្រយោជន៍ទេ ម្នាលឧបាលិ ភិក្ខុនោះ ត្រូវពិចារណាតទៅទៀតថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះទៅ តើនឹងបានពួកភិក្ខុជាមិត្តសម្លាញ់គ្រាន់តែជួបគ្នា ឬជាមិត្តសម្លាញ់ តែងនៅរួមជាមួយគ្នា ជាពួកខាងធម៌ ខាងវិន័យ ឬមិនបានទេ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះទៅហើយ នឹងមិនបានពួកភិក្ខុជាមិត្តសម្លាញ់គ្រាន់តែជួបគ្នា ឬជាមិត្តសម្លាញ់តែងនៅរួមជាមួយគ្នា ជាពួកខាងធម៌ ខាងវិន័យ (ទាំងនោះទេ) ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះទៅ នឹងបានពួកភិក្ខុ ជាមិត្តសម្លាញ់គ្រាន់តែជួបគ្នា ឬជាមិត្តសម្លាញ់តែងនៅរួមជាមួយគ្នា ដែលជាពួកខាងធម៌ ខាងវិន័យ ម្នាលឧបាលិ ភិក្ខុនោះ ត្រូវពិចារណាតទៅទៀតថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះទៅ ក្រែងមានការប្រកួតប្រកាន់ ការឈ្លោះ ការប្រកាន់ខុស ការទាស់ទែង ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់ផ្សេងនៃសង្ឃ ការធ្វើផ្សេងៗនៃសង្ឃ នឹងកើតមានដល់សង្ឃ ព្រោះហេតុនៃអត្តាទាននោះ ឬមិនមានទេ។ ម្នាលឧបាលិ បើភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា កាលបើអាត្មាអញ កាន់យកនូវអត្តាទានទៅហើយ ការប្រកួតប្រកាន់ ការឈ្លោះ ការប្រកាន់ខុស ការទាស់ទែង ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់ផ្សេងនៃសង្ឃ ការធ្វើផ្សេងៗនៃសង្ឃ នឹងកើតមានដល់សង្ឃ ព្រោះហេតុនៃអត្តាទាននោះ (ជាប្រាកដ) ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ បើភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះទៅ ការប្រកួតប្រកាន់ ការឈ្លោះ ការប្រកាន់ខុស ការទាស់ទែង ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់ផ្សេងនៃសង្ឃ និងការធ្វើផ្សេងៗនៃសង្ឃ មិនកើតមានដល់សង្ឃ ព្រោះហេតុនៃអត្តាទាននោះឡើយ ម្នាលឧបាលិ ភិក្ខុត្រូវកាន់យកនូវអត្តាទាននោះចុះ ម្នាលឧបាលិ អត្តាទានប្រកបដោយអង្គ៥ប្រការ ដូចបានសំដែងមកនេះឯង កាលបើភិក្ខុកាន់យកហើយ នឹងមិនធ្វើឲ្យកើតសេចក្តីក្តៅក្រហាយចិត្ត ក្នុងកាលជាខាងក្រោយឡើយ។

# (ចោទកេនបច្ចវេក្ខិតព្វធម្ម ទី៨)

### (៨. ចោទកេនបច្ចវេក្ខិតព្ពធម្មា)

[១៦៤] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ តើត្រូវពិចារណាធម៌ចំពោះខ្លួនឯងមានប៉ុន្មានសិន ទើបគួរនឹងចោទភិក្ខុដទៃបាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ឯភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌៥ប្រការ ចំពោះខ្លួនឯងសិន រួចសឹមចោទភិក្ខុដទៃ ម្នាលឧបាលិ ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញ មានកាយសមាចារបរិសុទ្ធឬហ្ន៎ អាត្មាអញ ជាអ្នកប្រកបដោយកាយសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ។ ម្នាលឧបាលិ បើភិក្ខុមានកាយសមាចារមិនបរិសុទ្ធទេ (តែហាក់ដូច) ជាអ្នកប្រកបដោយកាយសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ភិក្ខុនោះឯងគង់មានអ្នកផងស្តីដាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកសិក្សានូវសមាចារផ្លូវកាយជាមុនសិន ភិក្ខុនោះគង់មានអ្នកផងស្តីដាស់តឿន ដូចសំដែងមកនេះឯង។

[១៦៥] ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញ មានវចីសមាចារបរិសុទ្ធឬហ្ន៎ អាត្មាអញ ប្រកបដោយវចីសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ធម៌នោះ មានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ។ ម្នាលឧបាលិ បើភិក្ខុមានវចីសមាចារមិនបរិសុទ្ធទេ (តែហាក់ដូច) ជាអ្នកប្រកបដោយវចីសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ភិក្ខុនោះ គង់មានអ្នកផងស្តីដាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកសិក្សានូវសមាចារផ្លូវវាចាជាមុនសិន ភិក្ខុនោះ គង់មានអ្នកផងស្តីដាស់តឿន ដូចសំដែងមកនេះឯង។

[១៦៦] ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា ចិត្តរបស់អាត្មាអញមានមេត្តាតាំងមាំ ទាំងមិនចង្អៀតចង្អល់ក្នុងសព្រហ្មចារីបុគ្គលទេឬហ្ន៎ ធម៌នោះ មានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ។ ម្នាលឧបាលិ បើភិក្ខុមិនមានមេត្តាចិត្តតាំងមាំ មានចិត្តចង្អៀតចង្អល់ ក្នុងសព្រហ្មចារីបុគ្គល ភិក្ខុនោះ គង់មានអ្នកផងស្តីដាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកតាំងមេត្តាចិត្តឲ្យ (មាំ) ក្នុងសព្រហ្មចារីបុគ្គលចុះ ភិក្ខុនោះ គង់មានអ្នកផងស្តីដាស់តឿន ដូចសំដែងមកនេះឯង។

[១៦៧] ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញជាពហុស្សូត ទ្រទ្រង់ព្រះសូត្រ សន្សំព្រះសូត្រឬហ្ន៎ (មួយទៀត) ធម៌ទាំងឡាយណា មានលំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌ទាំងនោះ ជាធម៌ដែលអាត្មាអញបានស្តាប់ច្រើន បានទ្រទ្រង់ បានសន្សំដោយពាក្យ បានពិចារណា (មុតមាំ) ហើយក្នុងចិត្ត បានយល់ត្រឹមត្រូវហើយដោយទិដ្ឋិ ធម៌នោះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនទាន់មានទេ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុមិនមែនជាពហុស្សូត មិនទ្រទ្រង់ព្រះសូត្រ មិនសន្សំព្រះសូត្រសោះទេ បើធម៌ទាំងឡាយណា មានលំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ គឺភិក្ខុនោះមិនបានចេះដឹងច្រើន មិនបានទ្រទ្រង់ មិនបានសន្សំដោយពាក្យ មិនបានពិចារណា (មុតមាំ) ក្នុងចិត្ត មិនបានយល់ត្រឹមត្រូវដោយទិដ្ឋិទេ ភិក្ខុនោះឯង គង់មានអ្នកផងស្តីដាស់តឿនថា ម្នាលលោកដ៏មានអាយុ សូមនិមន្តលោករៀនព្រះបរិយត្តិធម៌សិនទៅ ភិក្ខុនោះគង់មានអ្នកផងស្តីដាស់តឿន ដូចសំដែងមកនេះឯង។

[១៦៨] ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា បាតិមោក្ខទាំងពីរ អញក៏ចេះចាំដោយសេចក្តីពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អ តាមសូត្រ គឺខន្ធកៈ និងបរិវារៈ តាមអនុព្យញ្ជនៈដែរឬ ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ។ ម្នាលឧបាលិ ប្រសិនបើបាតិមោក្ខទាំងពីរ ភិក្ខុមិនបានចេះចាំដោយសេចក្តីពិស្តារ មិនបានចែកចេញដោយប្រពៃ មិនបានចាំស្ទាត់រត់មាត់ មិនបានកាត់សេចក្តីដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈទេ ភិក្ខុនោះឯង បើមានគេសួរថា ម្នាលោកដ៏មានអាយុ ចុះសិក្ខាបទនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងក្នុងនគរណា ភិក្ខុនោះមុខជាឆ្លើយប្រាប់ទៅវិញមិនរួច ភិក្ខុនោះឯង គង់មានអ្នកផងស្តីដាស់តឿនថា ម្នាលលោកដ៏មានអាយុ សូមនិមន្តលោករៀនវិន័យសិនទៅ ភិក្ខុនោះឯង គង់មានអ្នកផងស្តីដាស់តឿន ដូចសំដែងមកនេះឯង ម្នាលឧបាលិ ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌៥ប្រការនេះ ក្នុងខ្លួនឯងសិន ហើយសឹមចោទភិក្ខុដទៃ។

# (ចោទកេនឧបដ្ឋាបេតព្ពធម្ម ទី៩)



### (៩. ចោទកេនឧបដ្ឋាបេតព្ពធម្មា)

[១៦៩] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បើភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ តើត្រូវតាំងធម៌ប៉ុន្មានប្រការក្នុងខ្លួនឯង ហើយទើបគួរចោទភិក្ខុដទៃបាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ បើមានប្រាថ្នានឹងចោទភិក្ខុដទៃ លុះតែតាំងធម៌៥ប្រការក្នុងខ្លួនឯង ទើបគួរចោទភិក្ខុដទៃបាន (ធម៌៥ប្រការនោះគឺ) អាត្មាអញ នឹងនិយាយត្រូវតាមកាលគួរ មិននិយាយខុសកាល១ អាត្មាអញ នឹងនិយាយពាក្យពិត មិននិយាយពាក្យមិនពិត១ អាត្មាអញនឹងនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យអាក្រក់១ អាត្មាអញនឹងនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យឥតប្រយោជន៍១ អាត្មាអញនឹងតាំងមេត្តាចិត្តហើយសឹមនិយាយ មិននិយាយទាំងទោសចិត្ត១ ម្នាលឧបាលិ ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌៥ប្រការទុកក្នុងខ្លួនឯង ហើយសឹមចោទភិក្ខុដទៃ។

# (ចោទកចុទិតកបដិសំយុត្តកថា ទី១០)

CS vin.cv.09.10 | ភាគ ទី១១

## (១០. ចោទកចុទិតកបដិសំយុត្តកថា)

[១៧០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃត្រូវតាំងវិប្បដិសារៈ (សេចក្តីក្តៅក្រហាយស្តាយក្រោយ) ទុកចំពោះភិក្ខុអ្នកចោទ ដែលមិនប្រកបដោយធម៌ ដោយអាការប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់តបថា ម្នាលឧបាលិ សង្ឃត្រូវតាំងវិប្បដិសារៈ ទុកចំពោះភិក្ខុអ្នកចោទដែលមិនប្រកបដោយធម៌ ដោយអាការ៥យ៉ាងដូច្នេះថា នែលោកដ៏មានអាយុ លោកចោទខុសកាល មិនមែនចោទត្រូវតាមកាលទេ លោកគួរដល់វិប្បដិសារៈហើយ១ នែលោកដ៏មានអាយុ លោកចោទដោយពាក្យមិនពិត មិនមែនចោទដោយពាក្យពិតទេ លោកគួរដល់វិប្បដិសារៈហើយ១ នែលោកដ៏មានអាយុ លោកចោទដោយពាក្យអាក្រក់ មិនមែនចោទដោយពាក្យពីរោះទេ លោកគួរដល់វិប្បដិសារៈហើយ១ នែលោកដ៏មានអាយុ លោកចោទប្រកបដោយកម្មឥតប្រយោជន៍ មិនមែនចោទប្រកបដោយកម្មមានប្រយោជន៍ទេ លោកគួរដល់វិប្បដិសារៈហើយ១ នែលោកដ៏មានអាយុ លោកជាអ្នកចោទ (គេ) ទាំងទោសចិត្ត មិនមែនចោទដោយមេត្តាចិត្តទេ លោកគួរដល់វិប្បដិសារៈហើយ១ ម្នាលឧបាលិ សង្ឃគប្បីតាំងវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទ ដែលមិនប្រកបដោយធម៌ ដោយអាការ៥យ៉ាងនេះឯង។ សេចក្តីនោះ ព្រោះហេតុអ្វី។ ព្រោះថា ភិក្ខុដទៃ មិនត្រូវសំគាល់ភិក្ខុផងគ្នា ដែលត្រូវគេចោទដោយពាក្យមិនពិត (នោះទេ)។

[១៧១] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះសង្ឃគប្បីតាំងអវិប្បដិសារៈ (សេចក្តីមិនក្តៅក្រហាយ) ទុក ចំពោះភិក្ខុដែលគេចោទ មិនប្រកបដោយធម៌ ដោយអាការប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុដែលគេចោទមិនប្រកបដោយធម៌ ដោយអាការ៥យ៉ាងដូច្នេះថា នែលោកដ៏មានអាយុ គេចោទលោកខុសកាល មិនមែនត្រូវតាមកាលទេ លោកគួរដល់អវិប្បដិសារៈ១ នែលោកដ៏មានអាយុ គេចោទលោកដោយពាក្យមិនពិត មិនមែនតាមពិតទេ លោកគួរដល់អវិប្បដិសារៈ១ នែលោកដ៏មានអាយុ គេចោទលោក ដោយពាក្យអាក្រក់ មិនមែនដោយពាក្យពីរោះទេ លោកគួរដល់អវិប្បដិសារៈ១ នែលោកដ៏មានអាយុ គេចោទលោកដោយពាក្យមិនប្រកបដោយប្រយោជន៍ មិនមែនដោយពាក្យប្រកបដោយប្រយោជន៍ទេ លោកគួរដល់អវិប្បដិសារៈ១ នែលោកដ៏មានអាយុ គេចោទលោកដោយទោសចិត្ត មិនមែនដោយមេត្តាចិត្តទេ លោកគួរដល់អវិប្បដិសារៈ១ ម្នាលឧបាលិ សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុ ដែលគេចោទមិនប្រកបដោយធម៌ ដោយអាការ៥យ៉ាងនេះឯង។

[១៧២] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទ ដែលប្រកបដោយធម៌ ដោយអាការប៉ុន្មានយ៉ាង។ ព្រះអង្គ ត្រាស់ថា ម្នាលឧបាលិ សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទ ដែលប្រកបដោយធម៌ ដោយអាការ៥យ៉ាងដូច្នេះថា នែលោកដ៏មានអាយុ លោកចោទគេត្រូវតាមកាលគួរហើយ មិនមែនចោទខុសកាលទេ លោកគួរដល់អវិប្បដិសារៈ១ នែលោកដ៏មានអាយុ លោកចោទគេដោយពាក្យពិតហើយ មិនមែនចោទដោយពាក្យមិនពិតទេ លោកគួរដល់អវិប្បដិសារៈ១ នែលោកដ៏មានអាយុ លោកចោទគេ ដោយពាក្យពីរោះហើយ មិនមែនចោទ ដោយពាក្យអាក្រក់ទេ លោកគួរដល់អវិប្បដិសារៈ១ នែលោកដ៏មានអាយុ លោកចោទគេដោយពាក្យប្រកបដោយប្រយោជន៍ មិនមែនចោទដោយពាក្យមិនប្រកបដោយប្រយោជន៍ទេ លោកគួរដល់អវិប្បដិសារៈ១ នែលោកដ៏មានអាយុ លោកជាអ្នកតាំងមេត្តាចិត្ត ហើយទើបចោទ មិនមែនចោទទាំងទោសចិត្តទេ លោកគួរដល់អវិប្បដិសារៈ១ ម្នាលឧបាលិ សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុ អ្នកចោទ ដែលប្រកបដោយធម៌ ដោយអាការ៥យ៉ាងនេះឯង។ សេចក្តីនោះ ព្រោះហេតុអ្វី។ ព្រោះថា ភិក្ខុដទៃ គប្បីសំគាល់ភិក្ខុផងគ្នា ដែលគេចោទដោយពាក្យពិត។

[១៧៣] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃគប្បីតាំងវិប្បដិសារៈទុក ចំពោះភិក្ខុដែលគេចោទ ប្រកបដោយធម៌ ដោយអាការប៉ុន្មានយ៉ាង។ ព្រះអង្គត្រាស់ថា ម្នាលឧបាលិ សង្ឃគប្បីតាំងវិប្បដិសារៈទុក ចំពោះភិក្ខុដែលគេចោទប្រកបដោយធម៌ ដោយអាការ៥យ៉ាងដូច្នេះថា ម្នាលលោកដ៏មានអាយុ គេចោទលោកត្រូវតាមកាលហើយ មិនមែនចោទដោយខុសកាលទេ លោកគួរដល់វិប្បដិសារៈហើយ១ នែលោកដ៏មានអាយុ គេចោទលោកដោយពាក្យពិតហើយ មិនមែនចោទដោយពាក្យមិនពិតទេ លោកគួរដល់វិប្បដិសារៈហើយ១ ម្នាលលោកដ៏មានអាយុ គេចោទលោកដោយពាក្យពីរោះហើយ មិនមែនចោទដោយពាក្យអាក្រក់ទេ លោកគួរដល់វិប្បដិសារៈហើយ១ ម្នាលលោកដ៏មានអាយុ គេចោទលោកដោយពាក្យប្រកបដោយប្រយោជន៍ហើយ មិនមែនចោទដោយពាក្យមិនប្រកបដោយប្រយោជន៍ទេ លោកគួរដល់វិប្បដិសារៈហើយ១ ម្នាលលោកដ៏មានអាយុ គេចោទលោកដោយមេត្តាចិត្តហើយ មិនមែនចោទដោយទោសចិត្តទេ លោកគួរដល់វិប្បដិសារៈហើយ១ ម្នាលឧបាលិ សង្ឃគប្បីតាំងវិប្បដិសារៈទុក ចំពោះភិក្ខុ ដែលគេចោទប្រកបដោយធម៌ ដោយអាការ៥យ៉ាងនេះឯង។

[១៧៤] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌មានប៉ុន្មានក្នុងខ្លួនឯងហើយ ទើបចោទភិក្ខុដទៃបាន។ ព្រះអង្គត្រាស់តបថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃត្រូវធ្វើទុកក្នុងចិត្តនូវធម៌៥យ៉ាងក្នុងខ្លួនឯងសិន ទើបចោទភិក្ខុដទៃបាន (ធម៌៥យ៉ាងនោះគឺ) ជាអ្នកមានចិត្តករុណា១ អ្នកស្វែងរកប្រយោជន៍១ អ្នកទំនុកបម្រុង (ដោយប្រយោជន៍នោះ)១ អ្នកប៉ងឲ្យភិក្ខុដទៃរួចចាកអាបត្តិ១ យកវិន័យជាប្រធាន១ ម្នាលឧបាលិ ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌៥យ៉ាងនេះឯង ក្នុងខ្លួនឯងសិន ទើបចោទភិក្ខុដទៃបាន។

[១៧៥] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុដែលគេចោទវិញ ត្រូវតាំងនៅក្នុងធម៌ប៉ុន្មានយ៉ាង។ ព្រះអង្គត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលគេចោទត្រូវតាំងនៅក្នុងធម៌២យ៉ាង គឺ សេចក្តីពិតត្រង់១ សេចក្តីមិនក្រោធ១។

ចប់ បាតិមោក្ខដ្ឋបនក្ខន្ធកៈ ទី៩។

ក្នុងខន្ធកៈនេះ មានរឿង៣។

ចប់ ភាណវារៈ២ប្រការ។

ឧទ្ទាននៃ បាតិមោក្ខដ្ឋបនក្ខន្ធកៈ នោះដូច្នេះ

[១៧៦]

រឿងព្រះមានព្រះភាគ គង់ក្នុងរោងឧបោសថ១ រឿងព្រះអានន្ទក្រាបបង្គំទូលអស់វារៈ៣ដង១ រឿងភិក្ខុបាបមិនចេញពីរោងឧបោសថ១ រឿងព្រះមោគ្គល្លានបណ្តេញភិក្ខុបាបចេញ១ រឿងក្នុងសាសនារបស់ព្រះជិនស្រី មាន អច្ឆរិយព្ភុតធម៌ (៨យ៉ាងគឺ) មានសិក្ខាជាលំដាប់ ដូចមហាសមុទ្រមានទំនាបជាលំដាប់ ពួកសាវ័ក មិនប្រព្រឹត្តកន្លងសិក្ខាបទ ដូចមហាសមុទ្រ មានទឹកតាំងនៅនឹងជាធម្មតា សង្ឃរមែងលើកបុគ្គលអាក្រក់ចេញ ដូចរលកសមុទ្រ ដែលផាត់សាកសពស្លាប់ទៅលើគោក (វណ្ណៈ៤ពួក) ដែលចេញបួសហើយ តែងលះបង់នាម និងគោត្រដើម ដូចទន្លេធំៗ តែងលះបង់នាម និងគោត្រដើម ពួកភិក្ខុដែលបរិនិព្វាន ព្រះនិព្វានក៏មិនប្រាកដជាខ្វះ ឬពេញ ព្រះធម៌វិន័យមានរសតែមួយ គឺវិមុត្តិរស ដូចមហាសមុទ្រ មានរសតែមួយ គឺរសប្រៃ ព្រះធម៌វិន័យមានគុណសម្បត្តិជាគ្រឿងត្រេកអរច្រើន ដូចមហាសមុទ្រ មានរតនៈច្រើនយ៉ាង ព្រះធម៌វិន័យ ជាទីអាស្រ័យនៅនៃព្រះអរិយបុគ្គល៨ពួក ដូចមហាសមុទ្រជាទីអាស្រ័យនៃសត្វធំៗ១ រឿងព្រះមានព្រះភាគ ធ្វើសេចក្តីប្រៀបផ្ទឹមនឹងមហាសមុទ្រ ហើយទ្រង់តម្កល់គុណទុកក្នុងសាសនា១។ រឿងព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យសំដែងបាតិមោក្ខ ក្នុងថ្ងៃឧបោសថ១ រឿងព្រះមានព្រះភាគ ទ្រង់អនុញ្ញាតឲ្យបញ្ឈប់បាតិមោក្ខ១ រឿងឆព្វគ្គិយភិក្ខុ ត្រូវអាបត្តិហើយ ចូលទៅស្តាប់បាតិមោក្ខ ដោយប្តេជ្ញាខ្លួនថា គ្មាននរណាមួយស្គាល់យើងឡើយ១ រឿងឆព្វគ្គិយភិក្ខុបញ្ឈប់បាតិមោក្ខ ដោយប្រញាប់ប្រញាល់១ រឿងពួកភិក្ខុពោលទោស (ព្រោះបញ្ឈប់បាតិមោក្ខ)១ រឿងបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ និងប្រកបដោយធម៌ មាន១,២,៣,៤,៥,៦,៧,៨,៩,១០យ៉ាងក៏មាន១។ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិមានចំណែក៤ប្រការ គឺ សីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ អាជីវវិបត្តិ១។ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិមានចំណែក៥ប្រការ គឺ បារាជិកាបត្តិ សង្ឃាទិសេសាបត្តិ បាចិត្តិយាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ១ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិមានចំណែក៦ប្រការ គឺ សីលវិបត្តិ អាចារវិបត្តិ (ទិដ្ឋិវិបត្តិ) ក្នុងមួយៗ ចែកជាពីរ គឺចែកទៅជាភិក្ខុមិនធ្វើ និងធ្វើ១។ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះអាបត្តិ (មានចំណែក៧យ៉ាង) គឺ បារាជិកាបត្តិ សង្ឃាទិសេសាបត្តិ ថុល្លច្ច័យាបត្តិ បាចិត្តិយាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ ទុព្ភាសិតាបត្តិ១ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិមានចំណែក៨យ៉ាង គឺ សីលវិបត្តិ អាចារវិបត្តិ (ទិដ្ឋិវិបត្តិ) អាជីវវិបត្តិ (ក្នុងមួយៗ ចែកជា២ គឺចែកជា) ភិក្ខុមិនធ្វើ និងធ្វើ១ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិ៩យ៉ាង ដែលព្រះមានព្រះភាគ ទ្រង់ជ្រាបពិតហើយ ទ្រង់ត្រាស់ដូច្នេះថា សីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ (ក្នុងមួយៗ ចែកជា៣ គឺចែកជា) ភិក្ខុមិនធ្វើ និងធ្វើ ទាំងធ្វើនិងមិនធ្វើ១។ រឿងអ្នកប្រាជ្ញត្រូវដឹងថា ការបញ្ឈប់បាតិមោក្ខនោះ ដោយហេតុ១០យ៉ាងគឺ មានភិក្ខុត្រូវបារាជិក (អង្គុយក្នុងបរិសទ្យនោះ) បារាជិកកថា សង្ឃធ្វើមិនទាន់ស្រេច ភិក្ខុពោលលាសិក្ខា អង្គុយក្នុងបរិសទ្យនោះ បច្ចក្ខាតកថា សង្ឃធ្វើមិនទាន់ស្រេច ភិក្ខុព្រមព្រៀងគ្នា ភិក្ខុត្រឡប់សើរើសេចក្តីព្រមព្រៀងវិញ បច្ចាទានកថា សង្ឃធ្វើមិនទាន់ស្រេច ភិក្ខុមានគេឃើញឮ ឬរង្កៀសដោយសីលវិបត្តិ ដោយអាចារវិបត្តិ ដោយទិដ្ឋិវិបត្តិ១។ រឿង (ភិក្ខុត្រូវអាបត្តិបារាជិក អង្គុយក្នុងបរិសទ្យ) ថានឹងមានភិក្ខុផងគ្នាឃើញភិក្ខុត្រូវអាបត្តិបារាជិក (នោះ) បើមិនដូច្នោះ គង់មានភិក្ខុឯទៀតប្រាប់ដំណើរនោះ ដល់ភិក្ខុផងគ្នា ឬភិក្ខុនោះប្រាប់ដល់ភិក្ខុបរិសុទ្ធដោយខ្លួនឯង១ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ចំពោះភិក្ខុនោះ១។ រឿងបរិសទ្យក្រោកដើរចេញ ព្រោះអន្តរាយ១០យ៉ាង អន្តរាយណាមួយ គឺអន្តរាយអំពីព្រះរាជា ចោរ ភ្លើង ទឹក មនុស្ស អមនុស្ស សត្វសាហាវ ពស់តូចធំ ជីវិត និងព្រហ្មចរិយ១ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ និងមិនប្រកបដោយធម៌ (នេះ) ភិក្ខុគប្បីដឹងតាមសមគួរដល់ឧបាយចុះ។ រឿង (ព្រះមានព្រះភាគ ទ្រង់សំដែងថា បើមានភិក្ខុប៉ងនឹងកាន់យកនូវអត្តាទាន ត្រូវកាន់យកអត្តាទាន ដែលប្រកបដោយអង្គ៥ប្រការ) គឺ កាលគួរ អធិករណ៍ពិតប្រាកដ អធិករណ៍ប្រកបដោយប្រយោជន៍ បានភិក្ខុដែលជាប៉ែកខាងធម៌វិន័យមកជាមិត្តសម្លាញ់ មិនមានហេតុ មានសេចក្តីប្រកាន់ជាដើម១ រឿង (ព្រះមានព្រះភាគ ទ្រង់សំដែងថា ភិក្ខុអ្នកចោទ ប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌៥យ៉ាង ចំពោះខ្លួនឯងជាមុន) ថា អាត្មាអញមានកាយសមាចារបរិសុទ្ធដែរឬទេ មានវចីសមាចារបរិសុទ្ធដែរឬទេ មានមេត្តាចិត្តតាំងមាំដែរឬទេ ជាពហុស្សុតដែរឬទេ ជាអ្នកស្ទាត់ជំនាញក្នុងបាតិមោក្ខទាំងពីរដែរឬទេ១។ រឿង (ព្រះមានព្រះភាគ ទ្រង់សំដែងថា ភិក្ខុអ្នកចោទ ប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតាំងខ្លួនឲ្យមាំក្នុងធម៌៥យ៉ាងគឺ ជាអ្នកនិយាយត្រូវតាមកាលគួរ និយាយពាក្យពិត និយាយពាក្យពីរោះ និយាយពាក្យប្រកបដោយប្រយោជន៍ ចោទដោយមេត្តាចិត្ត)១ រឿង (ព្រះមានព្រះភាគ ទ្រង់សំដែងថា ភិក្ខុគួរតាំងនៅវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទមិនប្រកបដោយធម៌៥យ៉ាង)១ រឿងសង្ឃគួរបន្ទោបង់វិប្បដិសារៈ ចំពោះភិក្ខុដែលចោទប្រកបដោយធម៌៥យ៉ាងដូចគ្នា១ រឿងព្រះមានព្រះភាគ ទ្រង់សំដែងថា ភិក្ខុគួរតាំងអវិប្បដិសារៈ ចំពោះភិក្ខុដែលគេចោទប្រកបដោយធម៌ ដោយអាការ៥យ៉ាង១ រឿងព្រះមានព្រះភាគ ទ្រង់សំដែងថា ភិក្ខុអ្នកចោទ ប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌៥យ៉ាងទុកក្នុងចិត្ត គឺ ជាអ្នកមានសេចក្តីករុណា ស្វែងរកប្រយោជន៍ មានសេចក្តីអនុគ្រោះ (ដោយប្រយោជន៍នោះ) ប៉ុនប៉ងឲ្យភិក្ខុដទៃរួចចាកអាបត្តិ យកវិន័យជាប្រធាន១ រឿងព្រះសម្ពុទ្ធ ទ្រង់សំដែងសេចក្តីប្រតិបត្តិ របស់ភិក្ខុអ្នកត្រូវចោទ តាំងខ្លួនក្នុងធម៌២យ៉ាងគឺ ពាក្យពិតត្រង់ និងសេចក្តីមិនក្រោធ១ នេះជាធម្មតា របស់ភិក្ខុដែលត្រូវគេចោទ។

# ភិក្ខុនីខន្ធកៈ (ទី១០)

CS vin.cv.10 | ភាគ ទី១១

**(១០. ភិក្ខុនិក្ខន្ធកំ)**

# (បឋមភាណវារៈ ទី១)

CS vin.cv.10.01 | ភាគ ទី១១

### (១. បឋមភាណវារោ)

## (មហាបជាបតិគោតមីវត្ថុ)

CS vin.cv.10.01.01 | ភាគ ទី១១

### (មហាបជាបតិគោតមីវត្ថុ)

[១៧៧] សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ។ លុះព្រះនាងមហាបជាបតីគោតមី ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរនឹងបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ ព្រះនាងគោតមី ព្រះនាងកុំគាប់ព្រះទ័យ ឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគត ជ្រាបច្បាស់ហើយ (នោះ) ឡើយ។ ព្រះនាងមហាបជាបតីគោតមី បានក្រាបបង្គំទូលសូម អស់វារៈជាគំរប់ពីរដងផង។បេ។ ព្រះនាងមហាបជាបតីគោតមី បានក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈជាគំរប់បីដងផង យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរនឹងបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ ព្រះនាងគោតមី ព្រះនាងកុំគាប់ព្រះទ័យ ឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគត ជ្រាបច្បាស់ហើយ (នោះ) ឡើយ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី បាន(ជ្រាបថា) ព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ (ដូច្នោះ) ក៏ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ទ្រង់ព្រះកន្សែង ហើយក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចចៀសចេញទៅ។

[១៧៨] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងក្រុងកបិលព័ស្តុ តាមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយយាងចេញទៅកាន់ចារិកនគរវេសាលី លុះយាងទៅកាន់ចារិកដោយលំដាប់ ក៏បានទៅដល់នគរវេសាលីនោះឯង។ មានសេចក្តីដំណាលថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀតក្រុងវេសាលីនោះ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី ឲ្យគេកោរព្រះកេសា ហើយស្លៀកសំពត់ជ្រលក់ដោយទឹកអម្ចត់ ក៏ទ្រង់យាងសំដៅទៅនគរវេសាលី ចូលទៅកាន់កូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះតាមលំដាប់ ជាមួយនឹងពួកនាងសាកិយានីជាច្រើន។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី មានព្រះបាទទាំងពីរពុរពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែង ទៀបក្លោងទ្វារខាងក្រៅ។ ព្រះអានន្ទដ៏មានអាយុបានឃើញព្រះនាងមហាបជាបតីគោតមី មានព្រះបាទទាំងគូពុរពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ កំពុងតែឈរទ្រង់ព្រះកន្សែង ទៀបក្លោងទ្វារខាងក្រៅ លុះបានឃើញហើយ ក៏ពោលពាក្យនេះ នឹងព្រះនាងមហាបជាបតីគោតមីថា បពិត្រព្រះនាងគោតមី ហេតុអ្វីបានជាព្រះនាង មានព្រះបាទទាំងគូពុរពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែង ទៀបក្លោងទ្វារខាងក្រៅដូច្នេះ។ ព្រះនាងមហាបជាបតីគោតមីឆ្លើយតបថា បពិត្រព្រះអានន្ទដ៏ចំរើន បានជាដូច្នោះ ព្រោះតែព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ មកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ហើយផងសោះ។ ព្រះអានន្ទដ៏មានអាយុ មានវាចាថា បពិត្រព្រះនាងគោតមី បើដូច្នោះ សូមព្រះនាងទ្រង់ចាំអាត្មាភាព ក្នុងទីនេះមួយរំពេចសិនចុះ ទម្រាំអាត្មាភាព ទៅក្រាបបង្គំទូលសុំព្រះមានព្រះភាគ ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគតជ្រាបច្បាស់ហើយ។

[១៧៩] លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមហាបជាបតីគោតមីនេះ មានព្រះបាទទាំងគូពុរពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែងទៀបក្លោងទ្វារខាងក្រៅ (ព្រោះជ្រាបថា) ព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាម ចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយផង។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ។ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគ ជាគំរប់ពីរដងផងថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយផងចុះ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ។ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគ ជាគំរប់បីដងផងថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយផងចុះ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុត្រិះរិះថា ឥឡូវនេះ ព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយទេ បើដូច្នេះ គួរតែអាត្មាអញ ក្រាបបង្គំទូលសូមព្រះមានព្រះភាគ ដោយបរិយាយផ្សេងៗទៀត ដើម្បីឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន (បើ) មាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយ តើអាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល

ខ្លះ សកិទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះ បានដែរឬទេ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលអានន្ទ (បើ) មាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ ក៏អាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលខ្លះ សកិទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះបាន។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន បើមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយ អាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលខ្លះ សកិទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះ បានដែរ បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមហាបជាបតីគោតមី មានឧបការៈច្រើន ជាព្រះមាតុច្ឆានៃព្រះមានព្រះភាគ ព្រះនាងបានទ្រាំទ្រថែរក្សា ថ្វាយទឹកក្សីរ កាលព្រះមាតាទ្រង់ទិវង្គតទៅ ព្រះនាងបានបំបៅព្រះអង្គ (តរៀងមក) បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតជ្រាបច្បាស់ហើយផងចុះ។

## (អដ្ឋគរុធម្ម)

CS vin.cv.10.01.02 | ភាគ ទី១១

### (អដ្ឋគរុធម្មា)

[១៨០] ព្រះសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលអានន្ទ បើព្រះនាងមហាបជាបតីគោតមី ទទួលប្រតិបត្តិតាម គរុធម៌ ទាំង៨បាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ (ឯគរុធម៌៨នោះ) គឺភិក្ខុនីសូម្បីឧបសម្បទាបានមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលីកម្ម សាមីចិកម្ម ចំពោះភិក្ខុ ដែលទើបនឹងបានឧបសម្បទាក្នុងថ្ងៃនោះ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ ភិក្ខុនីមិនត្រូវនៅចាំវស្សា ក្នុងអាវាសដែលគ្មានភិក្ខុឡើយ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត១ ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរប្រការ គឺសួរឧបោសថ ចូលទៅស្តាប់ឱវាទ អំពីសំណាក់ភិក្ខុសង្ឃរាល់កន្លះខែ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត១ ភិក្ខុនី នៅចាំវស្សារួចហើយ ត្រូវបវារណា ក្នុងសំណាក់សង្ឃទាំង២ពួក ដោយស្ថានទាំង៣ គឺឃើញក្តី ឮក្តី រង្កៀសក្តី ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្ត ក្នុងសំណាក់សង្ឃទាំង២ពួក ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ ភិក្ខុនី ត្រូវជួយស្វែងរកឧបសម្បទា ក្នុងសំណាក់សង្ឃទាំង២ពួក ដល់សិក្ខមានា ដែលបានសិក្សាសិក្ខាក្នុងធម៌ទាំង៦ប្រការគ្រប់២ឆ្នាំហើយ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត១ ភិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុ ដោយបរិយាយណាមួយឡើយ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត១ តាំងពីថ្ងៃ (ដែលបានឧបសម្បទានេះទៅ) ភិក្ខុនី ត្រូវតែស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុ មិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញទេ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត១ ម្នាលអានន្ទ បើព្រះនាងមហាបជាបតីគោតមី ទទួលប្រតិបត្តិតាម គរុធម៌ ទាំង៨នេះបាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ។

[១៨១] លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានរៀនគរុធម៌ទាំង៨ ក្នុងសំណាក់ព្រះមានព្រះភាគ (ចាំស្ទាត់ហើយ) ក៏ចូលទៅរកព្រះនាងមហាបជាបតីគោតមី លុះចូលទៅដល់ហើយ ពោលពាក្យនេះ នឹងព្រះនាងមហាបជាបតីគោតមីថា បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិតាមគរុធម៌ទាំង៨បាន ឧបសម្បទានោះ ទើបបានសម្រេចដល់ព្រះនាង (ឯគរុធម៌ទាំង៨នោះគឺ) ភិក្ខុនី សូម្បីបានឧបសម្បទាមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលីកម្ម សាមីចិកម្ម ចំពោះភិក្ខុ ដែលទើបនឹងបួសក្នុងថ្ងៃនោះ ធម៌នេះ ភិក្ខុនី ត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ ភិក្ខុនីមិនត្រូវនៅចាំវស្សា ក្នុងអាវាស ដែលគ្មានភិក្ខុទេ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត១ ភិក្ខុនី ត្រូវប្រាថ្នាធម៌ពីរប្រការ គឺសួរបាតិមោក្ខ ចូលទៅស្តាប់ឱវាទ អំពីសំណាក់ភិក្ខុសង្ឃ រាល់កន្លះខែ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ ភិក្ខុនី នៅចាំវស្សារួចហើយ ត្រូវបវារណាក្នុងសំណាក់សង្ឃទាំង២ពួក ដោយស្ថានទាំង៣ គឺឃើញក្តី ឮក្តី រង្កៀសក្តី ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត១ ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្ត ក្នុងសំណាក់សង្ឃទាំង២ពួក ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ ភិក្ខុនី ត្រូវជួយស្វែងរកឧបសម្បទា ក្នុងសំណាក់សង្ឃទាំង២ពួក ដល់សិក្ខមានា ដែលបានសិក្សាសិក្ខាក្នុងធម៌ទាំង៦ប្រការគ្រប់២ឆ្នាំហើយ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ ភិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុ ដោយបរិយាយណាមួយឡើយ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ តាំងពីថ្ងៃ (ដែលបានឧបសម្បទានេះទៅ) ភិក្ខុនីត្រូវស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុ មិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញទេ ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លង ដរាបអស់ជីវិត១ បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រព្រឹត្តិគរុធម៌ ទាំង៨នេះបាន ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាងមិនខាន។ ព្រះនាងមហាបជាបតីគោតមីឆ្លើយតបថា បពិត្រព្រះអានន្ទដ៏ចំរើន ស្ត្រី ឬបុរសនៅក្រមុំកំឡោះ តែងចូលចិត្តស្អិតស្អាងខ្លួន សិតសក់ស្អាតហើយ បានកម្រងផ្កាឧប្បលក្តី ផ្កាម្លិះក្តី ផ្កាដែលមានក្លិនក្រអូបណាស់ក្តី ហើយទទួលយកដោយដៃទាំងពីរ តម្កល់ទុកលើអវយវៈដ៏ឧត្តម គឺត្បូងយ៉ាងណាមិញ បពិត្រព្រះអានន្ទដ៏ចំរើន ខ្ញុំនឹងទទួលប្រតិបត្តិតាមគរុធម៌ទាំង៨នេះ (ដោយសេចក្តីពេញចិត្ត) ហើយមិនប្រព្រឹត្តកន្លង ដរាបអស់ជីវិត ដូច្នោះដែរ។

[១៨២] លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ។ ព្រះអានន្ទមានអាយុ លុះគង់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន គរុធម៌ទាំង៨យ៉ាង ព្រះនាងមហាបជាបតីគោតមី បានទទួលហើយ ព្រះមាតុច្ឆានៃព្រះមានព្រះភាគ បានឧបសម្បទារួចហើយ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ បើប្រសិនណាជាមាតុគ្រាម មិនបានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយទេ ម្នាលអានន្ទ ព្រហ្មចារ្យ នឹងបានតាំងនៅជាអង្វែង ព្រះសទ្ធម្ម គឺអរហត្តផល ក៏នឹងបានតាំងនៅអស់១ពាន់ឆ្នាំ ម្នាលអានន្ទ តែកាលណាមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ ម្នាលអានន្ទ ឥឡូវនេះ ព្រហ្មចារ្យ មិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ឥឡូវនេះ ព្រះសទ្ធម្ម នឹងឋិតនៅបានត្រឹមតែប្រាំរយឆ្នាំវិញ ម្នាលអានន្ទ មាតុគ្រាម បានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ គឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ប្រៀបដូចត្រកូលទាំងឡាយណានីមួយ ដែលមានស្ត្រីច្រើន មានប្រុស

តិច ត្រកូលទាំងនោះ ពួកចោរលួចក្អមឆ្នាំង ក៏អាចចូលមកបំផ្លាញបានដោយងាយ ម្នាលអានន្ទ មាតុគ្រាម បានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ គឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ប្រៀបដូចជារោគជាតិ ឈ្មោះសេតដ្ឋិកា (ក្រារ) ធ្លាក់ចុះក្នុងស្រែស្រូវណា ដែលកំពុងតែលូតលាស់ល្អ ស្រែស្រូវនោះ មិនបានតាំងនៅយូរអង្វែង ដោយប្រការដូច្នេះ ម្នាលអានន្ទ មាតុគ្រាម បានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ គឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ប្រៀបដូចរោគជាតិ ឈ្មោះមញ្ជេដ្ឋិកា (ដង្កូវក្រារ) ធ្លាក់ចុះក្នុងច្បារអំពៅណា ដែលកំពុងតែលូតលាស់ល្អ ច្បារអំពៅនោះ មិនបានតាំងនៅអង្វែង ដោយប្រការដូច្នេះ ម្នាលអានន្ទ គរុធម៌៨ប្រការ ដែលតថាគតបានបញ្ញត្តហើយ ចំពោះភិក្ខុនីជាតម្បូង ដើម្បីមិនឲ្យ (ភិក្ខុនី) ប្រព្រឹត្តកន្លង ដរាបដល់អស់ជីវិត ម្នាលអានន្ទ ប្រៀបដូចជាបុរស ប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំ ដើម្បីនឹងទប់ទឹកមិនឲ្យហូរចេញទៅជាដរាប។

ចប់ គរុធម៌ ទាំង៨ របស់ពួកភិក្ខុនី។

## (ភិក្ខុនីឧបសម្បទានុជាននៈ)

CS vin.cv.10.01.03 | ភាគ ទី១១

### (ភិក្ខុនីឧបសម្បទានុជាននំ)

[១៨៣] លំដាប់នោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចក៏គង់ក្នុងទីសមគួរ។ លុះព្រះនាងមហាបជាបតីគោតមី គង់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងប្រតិបត្តិដូចម្តេច ក្នុងនាងសាកិយានីទាំងនេះ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ព្រះនាងមហាបជាបតីគោតមី ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា។ ឯព្រះនាងមហាបជាបតីគោតមី ដែលព្រះមានព្រះភាគ បានពន្យល់ ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថារួច ក៏ក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយ ឲ្យឧបសម្បទា ដល់ពួកភិក្ខុនីបាន។

[១៨៤] លំដាប់នោះ ភិក្ខុនីទាំងនោះ បាននិយាយពាក្យនេះនឹងព្រះនាងមហាបជាបតីគោតមីថា ព្រះនាងជាម្ចាស់ ជាអនុបសម្បន្នា (មិនបានឧបសម្បទាទេ) យើងខ្ញុំទាំងឡាយ ទើបជាឧបសម្បន្នា (បានឧបសម្បទា) ដ្បិតព្រះមានព្រះភាគ បានទ្រង់បញ្ញត្តដូច្នេះថា ភិក្ខុទាំងឡាយ ត្រូវឲ្យឧបសម្បទា ដល់ភិក្ខុនីទាំងឡាយ។ គ្រានោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទមានអាយុ រួចអង្គុយក្នុងទីសមគួរ។ លុះព្រះនាងមហាបជាបតីគោតមី អង្គុយក្នុងទីសមគួរហើយ បាននិយាយពាក្យនេះនឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុនីទាំងនេះ នាំគ្នាមកនិយាយនឹងខ្ញុំ យ៉ាងនេះថា ព្រះនាងជាម្ចាស់ ជាអនុបសម្បន្នា យើងខ្ញុំទាំងឡាយ ទើបជាឧបសម្បន្នា ដ្បិតព្រះមានព្រះភាគ បានទ្រង់បញ្ញត្តិដូច្នេះថា ភិក្ខុទាំងឡាយ ត្រូវឲ្យឧបសម្បទាដល់ពួកភិក្ខុនី។ ព្រះអានន្ទមានអាយុ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ។ ព្រះអានន្ទមានអាយុ លុះគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមហាបជាបតីគោតមី បានមកនិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុនីទាំងនេះ មកនិយាយនឹងខ្ញុំថា ព្រះនាងជាម្ចាស់ ជាអនុបសម្បន្នា យើងខ្ញុំទាំងឡាយ ទើបជាឧបសម្បន្នា ដ្បិតព្រះមានព្រះភាគ ទ្រង់បានបញ្ញត្តិដូច្នេះថា ភិក្ខុទាំងឡាយ ត្រូវឲ្យឧបសម្បទាដល់ពួកភិក្ខុនី។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលអានន្ទ គរុធម៌ទាំង៨យ៉ាង ដែលព្រះនាងមហាបជាបតីគោតមីបានទទួលហើយ ដោយចំណែកណា ចំណែកនោះឯង ជាឧបសម្បទារបស់ព្រះនាងមហាបជាបតីគោតមីនោះ។

[១៨៥] គ្រានោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយគង់ក្នុងទីដ៏សមគួរ។ ព្រះនាងមហាបជាបតីគោតមី លុះគង់ក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះ នឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំម្ចាស់តែម្នាក់ឯង នឹងសូមពរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរ សូមព្រះមានព្រះភាគ ទ្រង់អនុញ្ញាតការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ដល់ពួកភិក្ខុផង ដល់ពួកភិក្ខុនីផង តាមលំដាប់វស្សាចាស់ខ្ចី។ លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ។ ព្រះអានន្ទមានអាយុ លុះគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមហាបជាបតីគោតមី ពោល (នឹងខ្ញុំព្រះអង្គ) យ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំម្ចាស់តែម្នាក់ឯង នឹងសូមពរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរ សូមព្រះមានព្រះភាគ ទ្រង់អនុញ្ញាត នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ដល់ពួកភិក្ខុផង ដល់ពួកភិក្ខុនីផង តាមលំដាប់វស្សាចាស់ខ្ចី។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ការសូមនេះ មិនមែនជាហេតុ ជាបច្ច័យទេ ត្រង់ពាក្យដែលថា ឲ្យតថាគតអនុញ្ញាត នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ដល់មាតុគ្រាម (នោះ) ម្នាលអានន្ទ អម្បាលដូចជាពួកតិរ្ថិយដទៃអស់នេះ ដែលជាអ្នកពោលធម៌អាក្រក់ ម្តេចគង់តែមិនធ្វើនូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ចំពោះមាតុគ្រាមដែរ ចំណង់បើតថាគត នឹងអនុញ្ញាត នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ដល់មាតុគ្រាម ដូចម្តេចបាន។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើ នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ចំពោះមាតុគ្រាមឡើយ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ។

[១៨៦] គ្រានោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ រួចគង់ក្នុងទីដ៏សមគួរ។ លុះព្រះនាងមហាបជាបតីគោតមី គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សិក្ខាបទទាំងឡាយណា ជារបស់ពួកភិក្ខុនី ដែលទួទៅដល់ពួកភិក្ខុផង តើខ្ញុំម្ចាស់នឹងប្រតិបត្តិក្នុងសិក្ខាបទទាំងនោះដូចម្តេច។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលព្រះនាងគោតមី សិក្ខាបទទាំងឡាយណា ជារបស់ពួកភិក្ខុនី ដែលទួទៅដល់ពួកភិក្ខុផង ពួកភិក្ខុសិក្សាយ៉ាងណា ពួកភិក្ខុនី ក៏ត្រូវ

សិក្សាក្នុងសិក្ខាបទទាំងនោះ យ៉ាងនោះដែរ។ ព្រះនាងមហាបជាបតីគោតមី ក្រាបបង្គំទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត សិក្ខាបទទាំងឡាយណា សម្រាប់ពួកភិក្ខុនី មិនទួទៅដល់ពួកភិក្ខុផង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់នឹងប្រតិបត្តិក្នុងសិក្ខាបទទាំងនោះដូចម្ដេច។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលព្រះនាងគោតមី សិក្ខាបទទាំងឡាយណា សម្រាប់ភិក្ខុនី មិនទួទៅដល់ពួកភិក្ខុផង ពួកភិក្ខុនីត្រូវសិក្សាក្នុងសិក្ខាបទទាំងឡាយ ដូចតថាគតបានបញ្ញត្តទុកមកហើយចុះ។

[១៨៧] គ្រានោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ។ ព្រះនាងមហាបជាបតីគោតមី លុះគង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមអង្វរ ខ្ញុំព្រះអង្គតែម្នាក់ឯង ចៀសចេញអំពីពួក (ហើយទៅនៅក្នុងទីស្ងាត់) មិនមានសេចក្ដីប្រមាទ មានតែសេចក្ដីព្យាយាមកម្ដៅកិលេស (ឲ្យរឹងស្អូត) មានចិត្តបញ្ជូនទៅក្នុងកម្មដ្ឋាន ព្រោះស្ដាប់ធម៌ណារបស់ព្រះមានព្រះភាគ សូមព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ (នោះ) ដោយសង្ខេប (ដល់ខ្ញុំម្ចាស់)។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលព្រះនាងគោតមី ព្រះនាងគប្បីដឹងនូវធម៌ទាំងឡាយណាថា ធម៌ទាំងនេះ ប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក ប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្ដៈ ប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំកិលេសវដ្ដៈ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស មិនប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស ប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក ប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្ដីព្យាយាម ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាទេ ម្នាលព្រះនាងគោតមី មួយវិញទៀត ព្រះនាងគប្បីដឹងនូវធម៌ណា ថា ធម៌ទាំងនេះ ប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក ប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្ដៈ ប្រព្រឹត្តទៅដើម្បីការមិនសន្សំកិលេសវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្ដៈ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាច្រើន ប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស មិនប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស ប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក ប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្ដីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុក ដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដាហើយ។

[១៨៨] សម័យនោះឯង ភិក្ខុទាំងឡាយមិនបានសម្ដែងបាតិមោក្ខ ដល់ពួកភិក្ខុនី។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសម្ដែងបាតិមោក្ខដល់ពួកភិក្ខុនី។ គ្រានោះ ភិក្ខុទាំងឡាយ មានសេចក្ដីត្រិះរិះដូច្នេះថា អ្នកណាហ្ន៎ គួរសម្ដែងបាតិមោក្ខដល់ពួកភិក្ខុនី។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយសម្ដែងបាតិមោក្ខ ដល់ពួកភិក្ខុនី។

[១៨៩] សម័យនោះឯង ភិក្ខុទាំងឡាយទៅកាន់លំនៅរបស់ភិក្ខុនី ហើយសំដែងបាតិមោក្ខ ដល់ពួកភិក្ខុនី។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្ដុះបង្អាប់ថា ភិក្ខុនីទាំងនេះ ជាប្រពន្ធរបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះ ជាសហាយរបស់ភិក្ខុទាំងនេះ ឥឡូវនេះ ភិក្ខុទាំងនោះ មុខជានឹងត្រេកអរជាមួយនឹងភិក្ខុនីទាំងនេះ (ទៀត)។ កាលដែលមនុស្សទាំងនោះ កំពុងពោលទោស តិះដៀល បន្ដុះបង្អាប់ ភិក្ខុទាំងនោះ ក៏បានឮច្បាស់។ លំដាប់នោះ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមិនត្រូវសម្ដែងបាតិមោក្ខ ដល់ពួកភិក្ខុនីឡើយ ភិក្ខុណាសម្ដែង ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីសម្ដែងបាតិមោក្ខ ដល់ភិក្ខុនីផងគ្នាចុះ។ ភិក្ខុនីទាំងឡាយ មិនបានដឹងថា ភិក្ខុនីត្រូវសម្ដែងបាតិមោក្ខយ៉ាងនេះ។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ដល់ភិក្ខុនីថា នាងទាំងឡាយត្រូវសម្ដែងបាតិមោក្ខយ៉ាងនេះ។

[១៩០] ក្នុងសម័យនោះឯង ភិក្ខុនីទាំងឡាយ មិនបានសម្ដែងអាបត្តិចេញ។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនមែនមិនត្រូវសម្ដែងអាបត្តិចេញទេ ភិក្ខុនីណាមិនសម្ដែង ត្រូវអាបត្តិទុក្កដ។ ភិក្ខុនីទាំងឡាយ មិនបានដឹងថា ភិក្ខុនីត្រូវសម្ដែងអាបត្តិយ៉ាងនេះ។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយប្រាប់ដល់ភិក្ខុនីថា នាងទាំងឡាយត្រូវសម្ដែងអាបត្តិយ៉ាងនេះ។ លំដាប់នោះ ភិក្ខុទាំងឡាយ មានសេចក្ដីត្រិះរិះដូច្នេះថា អ្នកណាហ្ន៎ គួរនឹងទទួលអាបត្តិ របស់ពួកភិក្ខុនី។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលអាបត្តិរបស់ភិក្ខុនី។

[១៩១] សម័យនោះ ភិក្ខុនីទាំងឡាយបានឃើញភិក្ខុ (កំពុងដើរ) ក្នុងច្រករហូតខ្លះ ក្នុងច្រកទាល់ខ្លះ ក្នុងផ្លូវបែកជាបីខ្លះ ក៏ដាក់បាត្រលើផែនដី ហើយធ្វើចីពរ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលី សម្ដែងអាបត្តិ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្ដុះបង្អាប់ថា ភិក្ខុនីទាំងនេះ ជាភរិយារបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះ ជាសហាយរបស់ភិក្ខុទាំងនេះ ក្នុងវេលាយប់ប្រទូស្តគ្នា គឺរួមដំណេកជាមួយគ្នា ឥឡូវនេះ មកខមាទោសនឹងគ្នា។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលអាបត្តិរបស់ភិក្ខុនីទេ ភិក្ខុណាទទួល ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យតែភិក្ខុនីទទួលអាបត្តិរបស់ពួកភិក្ខុនីផងគ្នា។ ភិក្ខុនីទាំងឡាយ មិនបានដឹងថា ភិក្ខុនីត្រូវទទួលអាបត្តិយ៉ាងនេះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ដល់ភិក្ខុនីទាំងឡាយថា នាងទាំងឡាយ ត្រូវទទួលអាបត្តិយ៉ាងនេះ។

[១៩២] សម័យនោះឯង ភិក្ខុទាំងឡាយ មិនបានធ្វើកម្ម (មានតជ្ជនីយកម្ម ជាដើម) ដល់ភិក្ខុនី។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើកម្ម ដល់ភិក្ខុនីទាំងឡាយ។ លំដាប់នោះ ភិក្ខុ

ទាំងឡាយ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អ្នកណាហ្ន៎ គួរនឹងធ្វើកម្មដល់ភិក្ខុនី។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុធ្វើកម្មដល់ពួកភិក្ខុនី។

[១៩៣] សម័យនោះឯង ពួកភិក្ខុនី ដែលភិក្ខុបានធ្វើកម្មរួចហើយ លុះឃើញភិក្ខុ (កំពុងដើរ) ក្នុងច្រករហូតខ្លះ ក្នុងច្រកទាល់ខ្លះ ក្នុងផ្លូវបែកជាបីខ្លះ ក៏ដាក់បាត្រលើផែនដី ហើយធ្វើចីវរ ឆៀងស្មាម្ខាង អង្គុយច្រហោង ផ្គងអញ្ជលីខមាទោសថា សូមលោកម្ចាស់ទាំងឡាយ សំគាល់ថា យើងលែងធ្វើយ៉ាងនេះទៀតហើយ។ មនុស្សទាំងឡាយ (បានឃើញ) ដូច្នោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះ ជាប្រពន្ធរបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះ ជាសហាយរបស់ភិក្ខុទាំងនេះ ក្នុងពេលយប់ប្រទូស្តគ្នា គឺរួមដំណេកជាមួយគ្នា ឥឡូវនេះ មកខមាទោសនឹងគ្នា។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកម្ម ដល់ភិក្ខុនីឡើយ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ធ្វើកម្មដល់ភិក្ខុនីផងគ្នា។ ភិក្ខុនីទាំងឡាយ មិនបានដឹងថា ភិក្ខុនីត្រូវធ្វើកម្មយ៉ាងនេះ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ដល់ភិក្ខុនីទាំងឡាយថា នាងទាំងឡាយ ត្រូវធ្វើកម្មយ៉ាងនេះ។

[១៩៤] សម័យនោះឯង ភិក្ខុនីទាំងឡាយ បង្កហេតុ ឈ្លោះទាស់ទែង ជជែកគ្នាកណ្ដាលជំនុំសង្ឃ ពោលចាក់ដោតគ្នាដោយលំពែង គឺមាត់ មិនមានអ្នកណាអាចរម្ងាប់នូវអធិករណ៍នោះបានឡើយ។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរម្ងាប់អធិករណ៍របស់ពួកភិក្ខុនី។

[១៩៥] សម័យនោះឯង ភិក្ខុទាំងឡាយ តែងរម្ងាប់អធិករណ៍របស់ពួកភិក្ខុនី។ កាលបើភិក្ខុបានវិនិច្ឆ័យអធិករណ៍នោះហើយ ភិក្ខុនីទាំងឡាយ គួរដល់កម្មខ្លះ គួរដល់អាបត្តិខ្លះ។ ភិក្ខុនីទាំងឡាយ និយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយ មេត្តាធ្វើកម្មដល់ភិក្ខុនីចុះ សូមលោកម្ចាស់ទទួលអាបត្តិរបស់ភិក្ខុនីចុះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តយ៉ាងនេះថា ភិក្ខុត្រូវរម្ងាប់អធិករណ៍របស់ពួកភិក្ខុនី។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ លើកកម្មរបស់ពួកភិក្ខុនី ហើយប្រគល់ឲ្យភិក្ខុនី ឲ្យភិក្ខុនីធ្វើកម្មដល់ភិក្ខុនីផងគ្នា ឲ្យភិក្ខុលើកអាបត្តិរបស់ភិក្ខុនី ហើយប្រគល់ឲ្យភិក្ខុនីទទួលអាបត្តិរបស់ភិក្ខុនីផងគ្នា។

[១៩៦] សម័យនោះឯង ភិក្ខុនីជាសិស្សរបស់ឧប្បលវណ្ណាភិក្ខុនី ទៅតាមព្រះមានព្រះភាគ រៀនវិន័យអស់៧ឆ្នាំ។ ភិក្ខុនីនោះច្រើនភ្លេចស្មារតី វិន័យដែលបានរៀនមកហើយ ក៏ចេះតែភ្លេចទៅវិញ។ ភិក្ខុនីនោះ ឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់មានបំណងនឹងស្ដេចទៅកាន់នគរសាវត្ថី។ លំដាប់នោះ ភិក្ខុនីនោះ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញនេះ បានទៅតាមព្រះមានព្រះភាគ រៀនវិន័យអស់៧ឆ្នាំហើយ អាត្មាអញនេះ ជាមនុស្សភ្លេចច្រើន វិន័យដែលបានរៀនហើយ ចេះតែភ្លេចទៅវិញ ធម្មតា មាតុគ្រាមនឹងដើរតាមព្រះសាស្ដាអស់មួយជីវិត ក៏លំបាកពេកណាស់ បើដូច្នោះ អាត្មាអញនឹងប្រតិបត្តិយ៉ាងណា។ លំដាប់នោះ ភិក្ខុនីនោះ ប្រាប់រឿងនុ៎ះ ដល់ភិក្ខុនីទាំងឡាយ។ ភិក្ខុនីទាំងឡាយ ដំណាលរឿងនុ៎ះប្រាប់ពួកភិក្ខុ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកភិក្ខុបង្ហាញវិន័យ ដល់ពួកភិក្ខុនីបាន។

ចប់ ភាណវារៈ ទី១។

# (ទុតិយភាណវារៈ ទី២)

CS vin.cv.10.02 | ភាគ ទី១១

### (២. ទុតិយភាណវារោ)

[១៩៧] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងវេសាលី គួរតាមពុទ្ធអធ្យាស្រ័យហើយ ក៏ស្ដេចទៅកាន់ចារិកនគរសាវត្ថី កាលត្រាច់ទៅកាន់ចារិកតាមលំដាប់ ទ្រង់ឆ្ពោះទៅកាន់នគរសាវត្ថីនោះ។ មានសេចក្ដីដំណាលថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបនគរសាវត្ថីនោះ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ សាចភក់ និងទឹកទៅលើពួកភិក្ខុនី ដោយគិតថា ធ្វើដូចម្ដេចហ្ន៎ នឹងបានពួកភិក្ខុនីត្រេកអរក្នុងពួកយើង។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសាចភក់ និងទឹកទៅលើពួកភិក្ខុនីទេ ភិក្ខុណាសាច ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុសង្ឃ) ធ្វើទណ្ឌកម្មដល់ភិក្ខុនោះ។ ភិក្ខុទាំងឡាយ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា ភិក្ខុសង្ឃត្រូវធ្វើទណ្ឌកម្មដូចម្ដេចហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃ គប្បីធ្វើភិក្ខុនោះឲ្យជាអវន្ទិយបុគ្គល (បុគ្គលដែលមិនគួរឲ្យភិក្ខុនីសំពះ)។

[១៩៨] សម័យនោះ ពួកឆព្វគ្គិយភិក្ខុ បើកកាយបង្ហាញពួកភិក្ខុនី លាត់ភ្លៅបង្ហាញពួកភិក្ខុនី បើកអង្គជាតបង្ហាញពួកភិក្ខុនី ចំអកចំអន់ពួកភិក្ខុនី (ដោយអសទ្ធម្ម) ផ្សំផ្គុំ (ពួកប្រុសលេង) ជាមួយនឹងពួកភិក្ខុនី ដោយគិតថា ធ្វើដូចម្ដេចហ្ន៎ នឹងបានពួកភិក្ខុនីត្រេកអរក្នុងពួកយើង។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបើកកាយបង្ហាញពួកភិក្ខុនី មិនត្រូវលាត់ភ្លៅបង្ហាញពួកភិក្ខុនី មិនត្រូវបើកអង្គជាតបង្ហាញពួកភិក្ខុនី មិនត្រូវចំអកចំអន់ពួកភិក្ខុនី (ដោយអសទ្ធម្ម) មិនត្រូវផ្សំផ្គុំ (ពួកប្រុសលេង) ជាមួយនឹងពួកភិក្ខុនីទេ ភិក្ខុណាផ្សំផ្គុំលេង ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុសង្ឃ) ធ្វើទណ្ឌកម្មដល់ភិក្ខុនោះ។ លំដាប់នោះ ភិក្ខុទាំងឡាយ មានសេចក្ដីត្រិះរិះដូច្នេះថា ភិក្ខុសង្ឃ ត្រូវធ្វើទណ្ឌកម្ម ដូចម្ដេចហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃ គប្បីធ្វើភិក្ខុនោះ ឲ្យជាអវន្ទិយបុគ្គល។

[១៩៩] សម័យនោះឯង ឆព្វគ្គិយាភិក្ខុនី សាចភក់ និងទឹកទៅលើពួកភិក្ខុ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងបានពួកភិក្ខុត្រេកអរមករកពួកយើង។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវសាចភក់ និងទឹកទៅលើពួកភិក្ខុទេ ភិក្ខុនីណាសាច ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) ធ្វើទណ្ឌកម្ម ដល់ភិក្ខុនីនោះ។ គ្រានោះ ភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុនីសង្ឃ ត្រូវធ្វើទណ្ឌកម្មដូចម្តេចហ្ន៎។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) ធ្វើអាវរណកម្ម គឺហាមប្រាម។ លុះហាមប្រាមហើយ ភិក្ខុនីទាំងឡាយ មិនទទួលយកដោយស្រុះស្រួល។ ភិក្ខុទាំងឡាយនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) បញ្ឈប់ឱវាទ។

[២០០] សម័យនោះឯង ឆព្វគ្គិយាភិក្ខុនី បើកកាយបង្ហាញពួកភិក្ខុ បើកដោះបង្ហាញពួកភិក្ខុ បើកភ្លៅបង្ហាញពួកភិក្ខុ បើកអង្គជាតបង្ហាញពួកភិក្ខុ ចំអកចំអន់ពួកភិក្ខុ (ដោយអសទ្ធម្ម) ផ្សំផ្គុំ (ពួកភិក្ខុនីលេង) ជាមួយនឹងពួកភិក្ខុ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងបានពួកភិក្ខុត្រេកអរមករកពួកយើង។បេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវបើកកាយបង្ហាញពួកភិក្ខុ មិនត្រូវបើកដោះបង្ហាញពួកភិក្ខុ មិនត្រូវបើកភ្លៅបង្ហាញពួកភិក្ខុ មិនត្រូវបើកអង្គជាតបង្ហាញពួកភិក្ខុ មិនត្រូវចំអកចំអន់ពួកភិក្ខុ (ដោយអសទ្ធម្ម) មិនត្រូវផ្សំផ្គុំ (ពួកភិក្ខុនីលេង) ជាមួយនឹងពួកភិក្ខុទេ ភិក្ខុនីណាផ្សំផ្គុំលេង ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) ធ្វើទណ្ឌកម្ម ដល់ភិក្ខុនីនោះ។ គ្រានោះ ភិក្ខុទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុនីសង្ឃ ត្រូវធ្វើទណ្ឌកម្ម ដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) ធ្វើអាវរណកម្ម (ដល់ភិក្ខុនីទាំងឡាយ)។ លុះធ្វើអាវរណកម្មហើយ ភិក្ខុនីទាំងឡាយ ក៏មិនទទួលដោយស្រុះស្រួល។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) បញ្ឈប់ឱវាទ។

[២០១] លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ការធ្វើឧបោសថកម្មជាមួយនឹងភិក្ខុនី ដែលភិក្ខុនីសង្ឃបញ្ឈប់ឱវាទហើយ គួរដែរ ឬមិនគួរទេ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃមិនត្រូវធ្វើឧបោសថកម្មជាមួយនឹងភិក្ខុនី ដែលភិក្ខុនីសង្ឃបញ្ឈប់ឱវាទទេ ដ្បិតអធិករណ៍នោះ មិនទាន់រម្ងាប់នៅឡើយ។

[២០២] សម័យនោះ ឧទាយីដ៏មានអាយុ បញ្ឈប់ឱវាទ ហើយចេញទៅកាន់ទីចារិក។ ភិក្ខុនីទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧទាយី មិនសមបើនឹងបញ្ឈប់ឱវាទ ហើយចេញទៅកាន់ទីចារិកសោះ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបញ្ឈប់ឱវាទ ហើយចេញទៅកាន់ទីចារិកទេ ភិក្ខុណាចៀសចេញទៅ ត្រូវអាបត្តិទុក្កដ។

[២០៣] សម័យនោះ មានពួកភិក្ខុល្ងង់ មិនឈ្លាសបញ្ឈប់ឱវាទ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុល្ងង់ មិនឈ្លាស មិនត្រូវបញ្ឈប់ឱវាទទេ ភិក្ខុណាបញ្ឈប់ ត្រូវអាបត្តិទុក្កដ។

[២០៤] សម័យនោះ ពួកភិក្ខុបញ្ឈប់ឱវាទ ក្នុងទីដែលមិនមានរឿង មិនមានហេតុ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបញ្ឈប់ឱវាទ ក្នុងទីដែលឥតរឿង ឥតហេតុទេ ភិក្ខុណាបញ្ឈប់ ត្រូវអាបត្តិទុក្កដ។

[២០៥] សម័យនោះឯង ភិក្ខុទាំងឡាយ បញ្ឈប់ឱវាទហើយ មិនឲ្យវិនិច្ឆ័យ (មិនជំនុំជម្រះ)។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបញ្ឈប់ឱវាទ ហើយមិនឲ្យវិនិច្ឆ័យទេ ភិក្ខុណាមិនឲ្យ ត្រូវអាបត្តិទុក្កដ។

[២០៦] សម័យនោះ ភិក្ខុនីទាំងឡាយមិនទៅទទួលឱវាទ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវមិនទៅទទួលឱវាទទេ ភិក្ខុនីណាមិនទៅទទួល វិន័យធរត្រូវវិនិច្ឆ័យតាមអាបត្តិ។

[២០៧] សម័យនោះឯង ភិក្ខុនីសង្ឃទាំងអស់ នាំគ្នាទៅទទួលឱវាទ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះ ជាប្រពន្ធរបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះ ជាសហាយរបស់ភិក្ខុទាំងនេះ ឥឡូវនេះ ភិក្ខុទាំងនេះ នឹងត្រេកត្រអាល ជាមួយនឹងភិក្ខុនីទាំងនេះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃ មិនត្រូវទៅទទួលឱវាទ (ព្រមគ្នា) ទាំងអស់ទេ បើទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី បួន ឬប្រាំរូប ទៅទទួលឱវាទ (ម្តងៗបាន)។

[២០៨] សម័យនោះឯង ភិក្ខុនីបួនប្រាំរូប នាំគ្នាទៅទទួលឱវាទ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះទៀតថា ភិក្ខុនីទាំងនេះ ជាប្រពន្ធរបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះ ជាសហាយរបស់ភិក្ខុទាំងនេះ ឥឡូវនេះ ភិក្ខុទាំងនេះមកត្រេកត្រអាល ជាមួយនឹងភិក្ខុនីទាំងឡាយនេះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីបួនប្រាំរូប មិនត្រូវទៅទទួលឱវាទទេ បើទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីពីរ ឬបីរូប ទៅទទួលឱវាទ។ ភិក្ខុនីសង្ឃ ត្រូវចូលទៅរកភិក្ខុ១រូប ធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង ក្រាបថ្វាយបង្គំបាទា ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃ ថ្វាយបង្គំបាទានៃភិក្ខុសង្ឃផង សូមចូលមកទទួលយកឱវាទផង បពិត្រលោកម្ចាស់ ឮថាភិក្ខុនីសង្ឃ ត្រូវបានចូលមកទទួលយកឱវាទ។ ភិក្ខុនោះ គប្បីចូលទៅរកភិក្ខុអ្នកសម្តែងបាតិមោក្ខ ហើយពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃថ្វាយបង្គំបាទានៃភិក្ខុសង្ឃផង ចូលមកទទួលឱវាទផង បពិត្រលោកម្ចាស់ ឮថាភិក្ខុនីសង្ឃ ត្រូវបានចូលមកទទួលឱវាទ។ ភិក្ខុសម្តែងបាតិមោក្ខ គប្បីពោលថា មានភិក្ខុណាមួយ ដែលសង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទ ដល់ភិក្ខុនីដែរឬ។ បើមានភិក្ខុណាមួយ ដែលសង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ត្រូវភិក្ខុអ្នកសម្តែងបាតិមោក្ខនិយាយថា ភិក្ខុឈ្មោះនេះ ដែលសង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ភិក្ខុនីសង្ឃ ចូរចូលទៅរកភិក្ខុនោះចុះ។ បើមិនមាន

ភិក្ខុណាមួយ ដែលសង្ឃសន្មតឲ្យជាអ្នកឲ្យឱវាទ ដល់ភិក្ខុនីទេ ត្រូវភិក្ខុអ្នកសម្តែងបាតិមោក្ខនិយាយថា លោកដ៏មានអាយុអង្គណា អាចទូន្មានភិក្ខុនីបាន។ បើភិក្ខុណាមួយអាចទូន្មានភិក្ខុនីបាន ទាំងភិក្ខុនោះ ក៏ប្រកបដោយអង្គ៨ប្រការផង ដែលសង្ឃត្រូវសន្មតថា ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទ ដល់ភិក្ខុនីហើយ ភិក្ខុនីសង្ឃ ត្រូវចូលទៅរកភិក្ខុនោះចុះ។ បើមិនមានភិក្ខុណាមួយ អាចនឹងទូន្មានភិក្ខុនីបានទេ ភិក្ខុអ្នកសម្តែងបាតិមោក្ខ គប្បីប្រាប់ថា ភិក្ខុណាមួយដែលសង្ឃសន្មត ឲ្យជាអ្នកទូន្មានភិក្ខុនីនោះ មិនមានទេ ចូរភិក្ខុនីសង្ឃសម្រេចប្រយោជន៍ ដោយសេចក្តីជ្រះថ្លាចុះ។

[២០៩] សម័យនោះឯង ភិក្ខុទាំងឡាយ មិនព្រមទទួលឲ្យឱវាទ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រកែកមិនព្រមទទួលឲ្យឱវាទទេ ភិក្ខុណាមិនព្រមទទួល ត្រូវអាបត្តិទុក្កដ។

[២១០] សម័យនោះ មានភិក្ខុ១រូបល្ងង់។ ភិក្ខុនីទាំងឡាយនាំគ្នាចូលទៅរកភិក្ខុនោះ ហើយពោលពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលឲ្យឱវាទចុះ។ ភិក្ខុនោះឆ្លើយថា ម្នាលនាង យើងជាមនុស្សល្ងង់ យើងទទួលឲ្យឱវាទដូចម្តេចបាន។ ពួកភិក្ខុនីពោលថា បពិត្រលោកម្ចាស់ សូមលោកទទួលឲ្យឱវាទចុះ ដ្បិតហេតុនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តថា ត្រូវភិក្ខុទទួលឲ្យឱវាទ ដល់ភិក្ខុនី។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបញ្ឈប់ភិក្ខុល្ងង់ ឲ្យភិក្ខុក្រៅពីនេះទទួលឲ្យឱវាទបាន។

[២១១] សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺ។ ភិក្ខុនីទាំងឡាយ នាំគ្នាចូលទៅរកភិក្ខុនោះ ហើយនិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលឲ្យឱវាទ។ ភិក្ខុនោះឆ្លើយថា ម្នាលនាង យើងជាមនុស្សមានជម្ងឺ យើងទទួលឲ្យឱវាទដូចម្តេចបាន។ ភិក្ខុនីទាំងឡាយនិយាយថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលឲ្យឱវាទ ដ្បិតហេតុនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តថា ឲ្យបញ្ឈប់ភិក្ខុល្ងង់ ឲ្យភិក្ខុក្រៅពីនេះទទួលឲ្យឱវាទបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបញ្ឈប់ភិក្ខុល្ងង់ និងភិក្ខុឈឺ ឲ្យភិក្ខុក្រៅពីនេះ ទទួលឲ្យឱវាទបាន។

[២១២] សម័យនោះឯង មានភិក្ខុ១រូប ជាអ្នកដំណើរ។ ភិក្ខុនីទាំងឡាយ ចូលទៅរកភិក្ខុនោះ ហើយនិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមមេត្តាទទួលឲ្យឱវាទ។ ភិក្ខុនោះឆ្លើយថា ម្នាលនាង យើងជាអ្នកដំណើរ យើងទទួលឲ្យឱវាទដូចម្តេចបាន។ ភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ សូមមេត្តាទទួលឲ្យឱវាទ ដ្បិតហេតុនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តថា លើកលែងតែភិក្ខុល្ងង់ លើកលែងតែភិក្ខុឈឺចេញ ត្រូវឲ្យភិក្ខុក្រៅពីនេះទទួលឲ្យឱវាទបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលើកលែងភិក្ខុល្ងង់ លើកលែងភិក្ខុឈឺ និងភិក្ខុអ្នកដំណើរ ឲ្យភិក្ខុដែលក្រៅពីនេះ ទទួលឲ្យឱវាទបាន។

[២១៣] សម័យនោះឯង មានភិក្ខុ១រូបជាអ្នកនៅក្នុងព្រៃ។ ភិក្ខុនីទាំងឡាយ ចូលទៅរកភិក្ខុនោះ ហើយនិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមមេត្តាទទួលឲ្យឱវាទ។ ភិក្ខុនោះឆ្លើយថា ម្នាលនាង ដ្បិតយើងជាអ្នកនៅក្នុងព្រៃ យើងនឹងទទួលឲ្យឱវាទដូចម្តេចបាន។ ភិក្ខុនីទាំងឡាយនិយាយថា បពិត្រលោកម្ចាស់ សូមមេត្តាទទួលឲ្យឱវាទ ដ្បិតហេតុនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តឲ្យលើកលែងតែភិក្ខុល្ងង់ លើកលែងតែភិក្ខុឈឺ និងលើកលែងតែភិក្ខុអ្នកដំណើរចេញ ឲ្យភិក្ខុក្រៅពីនេះទទួលឲ្យឱវាទបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកនៅក្នុងព្រៃ ទទួលឲ្យឱវាទផង ឲ្យធ្វើសង្កេត (សេចក្តីកំណត់)ផងថា អាត្មាអញ នឹងផ្លាស់ទៅក្នុងទីនោះ។

[២១៤] សម័យនោះឯង ភិក្ខុទាំងឡាយទទួលឲ្យឱវាទ ហើយមិនបានប្រាប់ដល់ (ភិក្ខុអ្នកសំដែងបាតិមោក្ខ)។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុមិនប្រាប់ឱវាទ (ដល់ភិក្ខុនី)ទេ ភិក្ខុណាមិនប្រាប់ ត្រូវអាបត្តិទុក្កដ។

[២១៥] សម័យនោះឯង ភិក្ខុទាំងឡាយ ទទួលឲ្យឱវាទហើយ មិនផ្លាស់ទី (តាមសង្កេត)។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវមិនផ្លាស់ទី (តាមសង្កេត)ទេ ភិក្ខុណាមិនផ្លាស់ ត្រូវអាបត្តិទុក្កដ។

[២១៦] សម័យនោះឯង ភិក្ខុនីទាំងឡាយ មិនទៅកាន់ទីដែលសង្ឃកំណត់ហើយ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវខានទៅកាន់ទីដែលសង្ឃកំណត់ហើយទេ ភិក្ខុនីណាមិនទៅ ត្រូវអាបត្តិទុក្កដ។

[២១៧] សម័យនោះឯង ភិក្ខុនីទាំងឡាយទ្រទ្រង់វត្ថពន្ធចង្កេះវែងៗ ចងរឹតឆ្អឹងជំនីរ ដោយវត្ថពន្ធចង្កេះនោះ។[22] មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចពួកស្រីគ្រហស្ថអ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវទ្រទ្រង់វត្ថពន្ធចង្កេះវែងទេ ភិក្ខុនីណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវត្ថពន្ធចង្កេះល្មមព័ទ្ធតែ១ជុំបាន មិនត្រូវចងរឹតឆ្អឹងជំនីរ ដោយវត្ថពន្ធចង្កេះនោះទេ ភិក្ខុនីណាចងរឹត ត្រូវអាបត្តិទុក្កដ។

[២១៨] សម័យនោះឯង ភិក្ខុនីទាំងឡាយ ចងរឹតឆ្អឹងជំនីរ ដោយផ្ទាំងដែលធ្វើអំពីបន្ទោះឫស្សី ចងរឹតឆ្អឹងជំនីរ ដោយផ្ទាំងស្បែក ចងរឹតឆ្អឹងជំនីរ ដោយផ្ទាំងសំពត់ស ចងរឹតឆ្អឹងជំនីរ ដោយសំណុំសំពត់ស ចងរឹតឆ្អឹងជំនីរ ដោយខ្នាញ់សំពត់ស ចងរឹតឆ្អឹងជំនីរ ដោយផ្ទាំងសំពត់មានពណ៌ ចងរឹតឆ្អឹងជំនីរ ដោយសំណុំសំពត់មានពណ៌ ចងរឹតឆ្អឹងជំនីរ ដោយខ្នាញ់សំពត់មានពណ៌ ចងរឹតឆ្អឹងជំនីរ ដោយសំណុំសំពត់សូត្រ ចងរឹតឆ្អឹងជំនីរ ដោយខ្នាញ់សំពត់សូត្រ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចជាពួកស្រីគ្រហស្ថអ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវចងរឹតឆ្អឹងជំនីរ ដោយផ្ទាំង ដែលធ្វើដោយបន្ទោះឫស្សី មិនត្រូវចងរឹតឆ្អឹងជំនីរ ដោយផ្ទាំងស្បែក មិនត្រូវចងរឹតឆ្អឹងជំនីរ ដោយផ្ទាំងសំពត់ស មិន

ត្រូវចងវឹតឆ្អឹងជំនីរ ដោយសំណុំសំពត់ស មិនត្រូវចងវឹតឆ្អឹងជំនីរ ដោយខ្នាញ់សំពត់ស មិនត្រូវចងវឹតឆ្អឹងជំនីរ ដោយផ្ទាំងសំពត់មានពណ៌ មិនត្រូវចងវឹតឆ្អឹងជំនីរ ដោយសំណុំសំពត់មានពណ៌ មិនត្រូវចងវឹតឆ្អឹងជំនីរ ដោយខ្នាញ់សំពត់មានពណ៌ មិនត្រូវចងវឹតឆ្អឹងជំនីរ ដោយសំណុំសំពត់សូត្រទេ ភិក្ខុនីណាចងវឹត ត្រូវអាបត្តិទុក្កដ។

[២១៩] សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យគេដំត្រគាក ដោយឈើមានសណ្ឋានដូចឆ្អឹងស្មងគោ ឲ្យគេដំត្រគាក ឲ្យគេដំដៃ ឲ្យគេដំខ្នងដៃ ឲ្យគេដំជើង ឲ្យគេដំខ្នងជើង ឲ្យគេដំភ្លៅ ឲ្យគេដំមុខ ឲ្យគេដំសាច់ជើងធ្មេញ ដោយឈើមានសណ្ឋានដូចឆ្អឹងចង្កាគោ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចពួកស្រីគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឲ្យគេដំត្រគាកដោយឈើមានសណ្ឋានដូចឆ្អឹងស្មងគោ មិនត្រូវឲ្យគេដំត្រគាក មិនត្រូវឲ្យគេដំដៃ មិនត្រូវឲ្យគេដំខ្នងដៃ មិនត្រូវឲ្យគេដំជើង មិនត្រូវឲ្យគេដំខ្នងជើង មិនត្រូវឲ្យគេដំភ្លៅ មិនត្រូវឲ្យគេដំមុខ មិនត្រូវឲ្យគេដំសាច់ជើងធ្មេញ ដោយឈើមានសណ្ឋានដូចឆ្អឹងចង្កាគោទេ ភិក្ខុនីណាឲ្យគេដំ ត្រូវអាបត្តិទុក្កដ។

[២២០] សម័យនោះឯង ពួកឆព្វគ្គិយាភិក្ខុនី លាបមុខ ប្រស់មុខ ខាត់មុខ ចឹមមុខ ស្រឡាបខ្លួន ស្រឡាបមុខ ស្រឡាបទាំងខ្លួន ទាំងមុខ ដោយគ្រឿងលាប លាយដោយមនោសិលា (ម្សៅលាម)។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចជាពួកស្រីគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវលាបមុខ មិនត្រូវប្រស់មុខ មិនត្រូវខាត់មុខ មិនត្រូវចឹមមុខ មិនត្រូវស្រឡាបខ្លួន មិនត្រូវស្រឡាបមុខ មិនត្រូវស្រឡាបទាំងខ្លួន ទាំងមុខ ដោយគ្រឿងលាបលាយដោយមនោសិលាទេ ភិក្ខុនីណាធ្វើ ត្រូវអាបត្តិទុក្កដ។

[២២១] សម័យនោះឯង ពួកឆព្វគ្គិយាភិក្ខុនី ធ្វើនូវគំនូសខាងក្រោមមាត់[23] ធ្វើគំនូសប្លែកៗត្រង់ថ្ពាល់ ក្រឡេកមើលតាមបង្អួច ឈរត្រង់ទ្វារ បង្ហាញកាយពាក់កណ្តាល ប្រើឲ្យគេលេងមហោស្រព បំបួសស្រីផ្កាមាស តាំងរោងសុរា តាំងរោងលក់សាច់ បើករានផ្សារ ដំឡើងថ្លៃ (ទំនិញ) ប្រកបជំនួញ ឲ្យខ្ញុំប្រុសបំរើ ឲ្យខ្ញុំស្រីបម្រើ ឲ្យកូនឈ្នួលប្រុសបំរើ ឲ្យកូនឈ្នួលស្រីបំរើ ឲ្យសត្វតិរច្ឆានបំរើ លក់វត្ថុខ្ចី និងវត្ថុទុំ (តាំងរានផ្សារលក់ដូររបស់រាយរង) ទ្រទ្រង់កំរាលស្មាច់ដោយរោមចៀម។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចជាពួកស្រីគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវធ្វើគំនូសក្រោមមាត់ មិនត្រូវធ្វើគំនូសប្លែកៗត្រង់ថ្ពាល់ មិនត្រូវក្រឡេកមើលតាមបង្អួច មិនត្រូវឈរត្រង់មាត់ទ្វារ បង្ហាញកាយពាក់កណ្តាល មិនត្រូវប្រើគេឲ្យលេងមហោស្រព មិនត្រូវបំបួសស្រីផ្កាមាស មិនត្រូវតាំងរោងសុរា មិនត្រូវតាំងរោងលក់សាច់ មិនត្រូវបើករានផ្សារ មិនត្រូវដំឡើងថ្លៃ (ទំនិញ) មិនត្រូវប្រកបជំនួញ មិនត្រូវឲ្យខ្ញុំប្រុសបំរើ មិនត្រូវឲ្យខ្ញុំស្រីបម្រើ មិនត្រូវឲ្យកូនឈ្នួលប្រុសបំរើ មិនត្រូវឲ្យកូនឈ្នួលស្រីបំរើ មិនត្រូវឲ្យសត្វតិរច្ឆានបំរើ មិនត្រូវលក់វត្ថុខ្ចី និងវត្ថុទុំ (តាំងរានផ្សារលក់ដូររបស់រាយរង) មិនត្រូវទ្រទ្រង់កំរាលស្មាច់ដោយរោមចៀមទេ ភិក្ខុនីណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ។

[២២២] សម័យនោះឯង ពួកឆព្វគ្គិយាភិក្ខុនី ទ្រទ្រង់ចីវរខៀវសុទ្ធ ទ្រទ្រង់ចីវរលឿងខ្ចីសុទ្ធ ទ្រទ្រង់ចីវរក្រហមសុទ្ធ ទ្រទ្រង់ចីវរហង្សបាទសុទ្ធ ទ្រទ្រង់ចីវរខ្មៅសុទ្ធ ទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ ទ្រទ្រង់ចីវរលឿងទុំសុទ្ធ ទ្រទ្រង់ចីវរមានជាយមិនបានកាត់ដាច់ ទ្រទ្រង់ចីវរមានជាយវែង ទ្រទ្រង់ចីវរមានជាយវិចិត្រដោយផ្កាឈើ ទ្រទ្រង់ចីវរមានជាយវិចិត្រដោយផ្លែឈើ ទ្រទ្រង់អាវបំពង់វែង ទ្រទ្រង់មួក។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចជាពួកស្រីគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវទ្រទ្រង់ចីវរខៀវសុទ្ធ មិនត្រូវទ្រទ្រង់ចីវរលឿងខ្ចីសុទ្ធ មិនត្រូវទ្រទ្រង់ចីវរក្រហមសុទ្ធ មិនត្រូវទ្រទ្រង់ចីវរហង្សបាទសុទ្ធ មិនត្រូវទ្រទ្រង់ចីវរខ្មៅសុទ្ធ មិនត្រូវទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ មិនត្រូវទ្រទ្រង់ចីវរលឿងទុំសុទ្ធ មិនត្រូវទ្រទ្រង់ចីវរមានជាយមិនបានកាត់ដាច់ មិនត្រូវទ្រទ្រង់ចីវរមានជាយវែង មិនត្រូវទ្រទ្រង់ចីវរមានជាយវិចិត្រដោយផ្កាឈើ មិនត្រូវទ្រទ្រង់ចីវរមានជាយវិចិត្រដោយផ្លែឈើ មិនត្រូវទ្រទ្រង់អាវបំពង់វែង មិនត្រូវទ្រទ្រង់មួកទេ ភិក្ខុនីណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ។

[២២៣] សម័យនោះឯង មានភិក្ខុនី១រូប កាលដែលទៀបនឹងធ្វើមរណកាល បានផ្តាំយ៉ាងនេះថា អំណឹះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ។ ភិក្ខុ និងភិក្ខុនីទាំងឡាយ ក្នុងទីនោះ ជជែកគ្នាថា បរិក្ខារនេះត្រូវបានយើង បរិក្ខារនេះ ត្រូវបានយើង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនី កាលដែលទៀបនឹងធ្វើមរណកាល បានផ្តាំយ៉ាងនេះថា អំណឹះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ ដូច្នេះ ភិក្ខុសង្ឃមិនជាឥស្សរៈ លើបរិក្ខារនោះទេ បរិក្ខារនុ៎ះ ត្រូវបានជារបស់ភិក្ខុនីសង្ឃ។ ម្នាលភិក្ខុទាំងឡាយ បើសិក្ខមានា។បេ។ ម្នាលភិក្ខុទាំងឡាយ បើសាមណេរី កាលដែលទៀបនឹងមរណកាល បានផ្តាំយ៉ាងនេះថា អំណឹះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ យ៉ាងនេះ ភិក្ខុសង្ឃមិនជាធំ ក្នុងបរិក្ខារនោះទេ បរិក្ខារនុ៎ះ ត្រូវបានជារបស់ភិក្ខុនីសង្ឃ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ កាលដែលទៀបនឹងមរណកាលហើយ បានផ្តាំយ៉ាងនេះថា អំណឹះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ យ៉ាងនេះ ភិក្ខុនីសង្ឃមិនជាធំ លើបរិក្ខារនោះទេ បរិក្ខារនុ៎ះ ត្រូវបានជារបស់ភិក្ខុសង្ឃ។ ម្នាលភិក្ខុទាំងឡាយ បើសាមណេរ។បេ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសក។បេ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសិកា។បេ។ ម្នាលភិក្ខុទាំងឡាយ បើនរណាៗដទៃ កាលដែលទៀបនឹងមរណកាលហើយ បានផ្តាំយ៉ាងនេះថា អំណឹះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ យ៉ាងនេះ ភិក្ខុនីសង្ឃមិនជាធំ លើបរិក្ខារនោះទេ បរិក្ខារនុ៎ះ ត្រូវបានជារបស់ភិក្ខុសង្ឃ។

[២២៤] សម័យនោះឯង មានស្ត្រីម្នាក់ ជាភរិយាចាស់របស់ស្តេចមល្លៈ ចូលមកបួសក្នុងសំណាក់ភិក្ខុនី។ ភិក្ខុនី (បួសថ្មី) នោះបានឃើញភិក្ខុ១រូប មានកម្លាំងថយ ដើរទៅតាមច្រក ប៉ះដោយចុងយស្មា ភិក្ខុនោះក៏ដួលចុះទៅ។ ភិក្ខុទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនី នឹងដើរទៅប៉ះភិក្ខុទេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនត្រូវឲ្យប៉ះភិក្ខុឡើយ ភិក្ខុនីណាឲ្យប៉ះ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ដែលឃើញភិក្ខុហើយ ត្រូវចៀសចេញអំពីចម្ងាយ បើកផ្លូវឲ្យ។

[២២៥] សម័យនោះ មានស្ត្រីម្នាក់ ជាស្រីប្តីលែង ហើយមានផ្ទៃដោយសហាយ។ ស្រីនោះ រំលូតកូនចេញហើយ បាននិយាយពាក្យនេះ នឹងភិក្ខុនីជាកុលុបកីថា បពិត្រលោកម្ចាស់ លោកម្ចាស់សូមដាក់កូនខ្ចីនេះ ក្នុងបាត្រយកទៅចុះ។ ភិក្ខុនីនោះ ដាក់កូនខ្ចីនោះក្នុងបាត្រ ហើយបិទបាំងនឹងសង្ឃាដិដើរទៅ។ សម័យនោះឯង មានបិណ្ឌចារិកភិក្ខុ១រូប សមាទានថា បើអាត្មាអញបានចង្ហាន់ជាដម្បូងណា ហើយមិនទាន់បានឲ្យចង្ហាន់នោះដល់ភិក្ខុក្តី ភិក្ខុនីក្តី អាត្មាអញក៏មិនបរិភោគ។ លំដាប់នោះ ភិក្ខុនោះ បានឃើញភិក្ខុនីនោះហើយ និយាយពាក្យនេះថា ហ៏នាង នាងទទួលយកចង្ហាន់ចុះ។ ភិក្ខុនីឆ្លើយថា ណ្ហើយ លោកម្ចាស់។ ភិក្ខុនោះ និយាយពាក្យនេះនឹងភិក្ខុនីនោះ អស់វារៈពីរដងថា ហ៏នាង ចូរនាងទទួលយកចង្ហាន់ទៅចុះ។ ភិក្ខុនីឆ្លើយថា ណ្ហើយ លោកម្ចាស់។ ភិក្ខុនោះ និយាយពាក្យនេះនឹងភិក្ខុនីនោះ អស់វារៈបីដងថា ហ៏នាង ចូរនាងទទួលយកចង្ហាន់ទៅចុះ។ ភិក្ខុនីឆ្លើយថា ណ្ហើយ លោកម្ចាស់។ ភិក្ខុប្រាប់ថា ម្នាលនាង យើងបានសមាទានថា (បើ) អាត្មាអញបានចង្ហាន់ណាជាដម្បូង ហើយមិនទាន់បានឲ្យចង្ហាន់នោះ ដល់ភិក្ខុក្តី ដល់ភិក្ខុនីក្តី អាត្មាអញក៏មិនឆាន់ចង្ហាន់នោះទេ ម្នាលនាង ហ៏ចូរនាងទទួលយកចង្ហាន់នេះទៅចុះ។ គ្រានោះ ភិក្ខុនីនោះ កាលបើភិក្ខុនោះបង្ខំ (ឲ្យទទួល) ក៏បង្ហាញបាត្រថា បពិត្រលោកម្ចាស់ សូមនិមន្តមើលកូនខ្ចីក្នុងបាត្រ (តែ) សូមលោកម្ចាស់កុំប្រាប់នរណាឡើយ។ លំដាប់នោះ ភិក្ខុនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនីដាក់កូនខ្ចីក្នុងបាត្រសោះ។ ទើបភិក្ខុនោះ ប្រាប់រឿងនុ៎ះ ដល់ភិក្ខុទាំងឡាយ។ ភិក្ខុណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនី ដាក់កូនខ្ចីក្នុងបាត្រសោះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនត្រូវដាក់កូនខ្ចីក្នុងបាត្រទេ ភិក្ខុនីណាដាក់យកទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ឃើញភិក្ខុហើយ ត្រូវបើកបាត្របង្ហាញ។

[២២៦] សម័យនោះឯង ពួកឆព្វគ្គិយាភិក្ខុនី បានឃើញភិក្ខុហើយ ផ្កាប់បាត្រប្រាប់ថ្លៃបាត្រ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ ពួកឆព្វគ្គិយាភិក្ខុនី ឃើញភិក្ខុហើយផ្កាប់បាត្រ រួចប្រាប់ថ្លៃបាត្រសោះ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឃើញភិក្ខុហើយផ្កាប់បាត្រ រួចប្រាប់ថ្លៃបាត្រទេ ភិក្ខុនីណាប្រាប់ថ្លៃ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីឃើញភិក្ខុហើយបើកបាត្របង្ហាញ ប្រសិនបើមានអាមិសៈណានៅក្នុងបាត្រ ត្រូវនិមន្តភិក្ខុ ដោយអាមិសៈនោះចុះ។

[២២៧] សម័យនោះឯង មាននិមិត្តរបស់បុរសដែលគេចោលក្នុងច្រកក្នុងក្រុងសាវត្ថី។ ភិក្ខុនីទាំងឡាយ ចូលទៅគយគន់និមិត្តនោះដោយផ្ចិតផ្ចង់។ មនុស្សទាំងឡាយធ្វើសម្លេងហ៊ោ។ ភិក្ខុនីទាំងនោះ ក៏មានសេចក្តីអៀនខ្មាស។ ទើបភិក្ខុនីទាំងអម្បាលនោះ ចូលទៅកាន់លំនៅ (ភិក្ខុនី) ប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុនីផងគ្នា។ ភិក្ខុនីណា មានសេចក្តីប្រាថ្នាតិច។បេ។ ភិក្ខុនីទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនីទាំងឡាយ ចូលទៅគយគន់និមិត្ត របស់បុរសសោះ។ ភិក្ខុនីទាំងនោះ ក៏ប្រាប់រឿងនុ៎ះ ដល់ភិក្ខុទាំងឡាយ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវគយគន់មើលនិមិត្តរបស់បុរស ភិក្ខុនីណាចូលទៅគយគន់មើល ត្រូវអាបត្តិទុក្កដ។

[២២៨] សម័យនោះឯង មនុស្សទាំងឡាយឲ្យអាមិសៈ ដល់ភិក្ខុទាំងឡាយ។ ពួកភិក្ខុ ក៏ឲ្យអាមិសៈ (នោះ) ទៅពួកភិក្ខុនី។ មនុស្សទាំងឡាយនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកម្ចាស់ទាំងនេះឲ្យ (អាមិសៈ) ដែលគេឲ្យសម្រាប់ឆាន់ខ្លួនឯង ទៅអ្នកឯទៀតទេ យើងទាំងឡាយមិនចេះឲ្យទានឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យ (អាមិសៈ) ដែលគេឲ្យសម្រាប់ឆាន់ ទៅអ្នកឯទៀតទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ។

[២២៩] សម័យនោះឯង អាមិសៈរបស់ពួកភិក្ខុ ក៏សម្បូណ៌ច្រើនឡើង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យៗ (អាមិសៈ) ដល់សង្ឃ។ អាមិសៈ ក៏កាន់តែសម្បូណ៌ច្រើនណាស់ទៅទៀត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យៗអាមិសៈ ទៅជារបស់បុគ្គលក៏បាន។

[២៣០] សម័យនោះឯង ពួកភិក្ខុធ្វើការសន្សំអាមិសៈជាច្រើន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ឬភិក្ខុឲ្យគេទទួលការសន្សំរបស់ភិក្ខុទាំងឡាយបរិភោគចុះ។

[២៣១] សម័យនោះឯង មនុស្សទាំងឡាយឲ្យអាមិសៈ ដល់ពួកភិក្ខុនី។ ភិក្ខុនីទាំងឡាយ ឲ្យ(អាមិសៈ) នោះ ដល់ពួកភិក្ខុ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនីទាំងឡាយ ឲ្យអាមិសៈ ដែលគេឲ្យសម្រាប់បរិភោគខ្លួនឯង ដល់ភិក្ខុឯទៀតសោះ យើងរាល់គ្នាមិនចេះឲ្យទានឬ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឲ្យអាមិសៈ ដែលគេឲ្យសម្រាប់បរិភោគខ្លួនឯង ដល់ភិក្ខុឯទៀតទេ ភិក្ខុនីណាឲ្យ ត្រូវអាបត្តិទុក្កដ។

[២៣២] សម័យនោះឯង អាមិសៈរបស់ភិក្ខុនីសម្បូណ៌ច្រើនឡើង ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនី) ឲ្យអាមិសៈដល់សង្ឃ (អាមិសៈ) ក៏កាន់តែសម្បូណ៌ច្រើនឡើងទៀត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យៗអាមិសៈទៅជារបស់បុគ្គលក៏បាន។

[២៣៣] សម័យនោះឯង ភិក្ខុនីធ្វើការសន្សំអាមិសៈ ដែលកាន់តែសម្បូណ៌ឡើង។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ ឬភិក្ខុនី ឲ្យទទួលការសន្សំរបស់ភិក្ខុនីបរិភោគចុះ។

[២៣៤] សម័យនោះឯង សេនាសនៈសម្បូណ៌ឡើង ដល់ពួកភិក្ខុ។ សេនាសនៈ មិនកើតឡើងដល់ពួកភិក្ខុនី។ ភិក្ខុនីទាំងឡាយ ក៏បញ្ជូនទូតទៅកាន់សំណាក់ពួកភិក្ខុថា បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ឲ្យសេនាសនៈ ដល់យើងឲ្យជារបស់ខ្ចី។ ភិក្ខុទាំងឡាយ ក្រាប

បង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យនូវសេនាសនៈ ដល់ពួកភិក្ខុនីជារបស់ខ្ចីបាន។

[២៣៥] សម័យនោះឯង ភិក្ខុនីទាំងឡាយមានរដូវ អង្គុយសង្កត់ខ្លះ ដេកសង្កត់ខ្លះ នូវគ្រែដែលគេញាត់ភ្ជាប់ និងតាំងដែលគេញាត់ភ្ជាប់។ សេនាសនៈ ក៏ប្រឡាក់ដោយឈាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវអង្គុយសង្កត់ ដេកសង្កត់ នូវគ្រែដែលគេញាត់ភ្ជាប់ នូវតាំងដែលគេញាត់ភ្ជាប់ទេ ភិក្ខុនីណាអង្គុយសង្កត់ក្ដី ដេកសង្កត់ក្ដី ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវចីវរក្នុងរោងទាន។ ចីវរក្នុងរោងទាន ក៏ប្រឡាក់ដោយឈាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវសំពត់ទ្រនាប់។ សំពត់ទ្រនាប់ក៏របូតចុះ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចង (សំពត់ទ្រនាប់) ដោយសរសៃអំបោះ ហើយចងភ្ជាប់នឹងភ្លៅចុះ។ សរសៃអំបោះក៏ដាច់ទៅ។ ពួកភិក្ខុ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ខ្សែក្រវាត់សម្រាប់ចងឆ្នុកក្បិន។

[២៣៦] សម័យនោះឯង ឆព្វគ្គិយាភិក្ខុនី ទ្រទ្រង់ខ្សែក្រវាត់សព្វកាល។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្ទុះបង្អាប់ថា។បេ។ ដូចជាពួកស្រីគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវប្រើខ្សែក្រវាត់សព្វកាលទេ ភិក្ខុនីណាប្រើ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែក្រវាត់ ដល់ភិក្ខុនីដែលមានរដូវ។

ចប់ ភាណវារៈ ទី២។

# (តតិយភាណវារៈ ទី៣)

CS vin.cv.10.03 | ភាគ ទី១១

### (៣. តតិយភាណវារោ)

[២៣៧] សម័យនោះឯង ឧបសម្បន្នាភិក្ខុនីទាំងឡាយ គ្មាននិមិត្តខ្លះ មានហេតុគ្រាន់តែជានិមិត្តខ្លះ មិនមានឈាមរដូវខ្លះ មានឈាមរដូវជានិច្ចខ្លះ មានសំពត់ទ្រនាប់ជានិច្ចខ្លះ មានឈាមរដូវហូរខ្លះ ជាសិខរិណីខ្លះ ជាស្រីខ្ទើយខ្លះ មានរូបដូចប្រុសខ្លះ ទ្វារមគ្គ (ទាំង២) រលាយចូលគ្នាខ្លះ ជាឧភតោព្យញ្ជនកាខ្លះ។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនី) សួរនូវអន្តរាយិកធម៌២៤ប្រការ ចំពោះស្ត្រីដែលមកសូមឧបសម្បទា។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុសួរភិក្ខុនីយ៉ាងនេះថា នាងមិនមែនឥតនិមិត្តទេឬ នាងមិនមែនមានហេតុគ្រាន់តែជានិមិត្តទេឬ នាងមិនមែនមិនមានឈាមទេឬ នាងមិនមានឈាមជានិច្ចទេឬ នាងមិនមែនមានសំពត់ទ្រនាប់ជានិច្ចទេឬ នាងមិនមែនមានឈាមរដូវហូរជានិច្ចទេឬ នាងមិនមែនជាសិខរិណីទេឬ នាងមិនមែនជាស្ត្រីខ្ទើយទេឬ នាងមិនមែនជាស្ត្រីមានរូបដូចប្រុសទេឬ នាងឥតមានទ្វារមគ្គរលាយចូលគ្នាទេឬ នាងមិនមែនជាឧភតោព្យញ្ជនកាទេឬ (ម្យ៉ាងទៀត) អាពាធយ៉ាងនេះ គឺ ឃ្លង់ ពក ស្រែង ស្រកីអណ្តែង ឆ្កួតជ្រូក នាងមានឬទេ នាងជាមនុស្សឬ នាងជាស្ត្រីឬ នាងជាអ្នកជាឬ នាងមិនមានជំពាក់បំណុលគេទេឬ នាងមិនមែនជាអ្នកបំរើព្រះរាជាទេឬ មាតាបិតា និងប្ដី (របស់នាង) បានអនុញ្ញាតហើយឬ នាងមានអាយុគ្រប់២០ឆ្នាំហើយឬ នាងមានបាត្រ និងចីវរគ្រប់គ្រាន់ហើយឬ នាងឈ្មោះអ្វី បវត្តិនី (ឧបជ្ឈាយ៍) របស់នាងឈ្មោះអ្វី។

[២៣៨] សម័យនោះឯង ភិក្ខុទាំងឡាយសួរ អន្តរាយិកធម៌ ចំពោះពួកភិក្ខុនី។ ឧបសម្បទាបេក្ខាទាំងឡាយអៀនខ្មាស មានមុខឱនចុះ មិនអាចនឹងឆ្លើយប្រាប់បាន។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យឧបសម្បទា ក្នុងសំណាក់ភិក្ខុសង្ឃ ដល់ភិក្ខុនី ដែលបានឧបសម្បទា ដោយចំណែកម្ខាងដ៏បរិសុទ្ធ ក្នុងភិក្ខុនីសង្ឃរួច (ម្ដង)ហើយ។

[២៣៩] សម័យនោះឯង ពួកភិក្ខុនី មិនបានប្រៀនប្រដៅឧបសម្បទាបេក្ខាសោះទេ គ្រាន់តែសាកសួរអន្តរាយិកធម៌។ ឧបសម្បទាបេក្ខា ក៏អៀនខ្មាស មានមុខឱនចុះ មិនអាចនឹងឆ្លើយប្រាប់បាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យប្រៀនប្រដៅជាមុនសិន ហើយសឹមសួរអន្តរាយិកធម៌ជាក្រោយ។ ពួកភិក្ខុក៏ប្រៀនប្រដៅ (ឧបសម្បទាបេក្ខា) ក្នុងកណ្ដាលជំនុំសង្ឃនោះ។ ឧបសម្បទាបេក្ខា នៅតែអៀនខ្មាស មានមុខឱនចុះ មិនអាចឆ្លើយប្រាប់បានដូច្នោះទៀត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រៀនប្រដៅក្នុងទីដ៏សមគួរ ហើយសឹមសួរអន្តរាយិកធម៌ ក្នុងកណ្ដាលជំនុំសង្ឃ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុនី) ត្រូវប្រៀនប្រដៅឧបសម្បទាបេក្ខាយ៉ាងនេះ។ មុនដំបូង ត្រូវភិក្ខុនីឲ្យឧបសម្បទាបេក្ខា កាន់យកឧបជ្ឈាយ៍ លុះឲ្យកាន់យកឧបជ្ឈាយ៍ហើយ គប្បីប្រាប់បាត្រ និងចីវរថា នេះជាបាត្រ នេះជាសង្ឃាដី នេះជាចីពរ នេះជាស្បង់ នេះជាសំពត់ពុង[24] នេះជាសំពត់ងូតទឹករបស់នាង នាងចូរទៅឈរ ក្នុងទីឱកាសឯណោះ (វេលានោះ) ភិក្ខុនីល្ងង់ មិនឆ្លាសទៅប្រដៅ។ ឧបសម្បទាបេក្ខាទាំងឡាយ ដែលភិក្ខុនីមិនឆ្លាស ប្រដៅមិនស្រួល ក៏នៅតែរឹងខ្លួន អៀនខ្មាស មិនអាចនឹងឆ្លើយប្រាប់បាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីដែលល្ងង់ មិនឆ្លាស មិនត្រូវប្រដៅឧបសម្បទាបេក្ខាទេ ភិក្ខុនីណាប្រដៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ដែលឆ្លាសប្រតិពល ប្រដៅ (ឧបសម្បទាបេក្ខា)បាន។ ភិក្ខុនីដែលសង្ឃមិនបានសន្មត ក៏ទៅប្រៀនប្រដៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីដែលសង្ឃមិនបានសន្មត មិនត្រូវប្រៀនប្រដៅឧបសម្បទាបេក្ខាទេ ភិក្ខុនីណាប្រៀនប្រដៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ដែលសង្ឃសន្មតហើយ (នោះ) ប្រៀនប្រដៅបាន។ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ។ ខ្លួនឯងគប្បីសន្មតខ្លួនឯងក៏បាន ភិក្ខុនីដទៃគប្បីសន្មតភិក្ខុនីដទៃក៏បាន។

[២៤០] ខ្លួនឯង គប្បីសន្មតខ្លួនឯងយ៉ាងណា។ ភិក្ខុនីដែលឆ្លាស ប្រតិពល ត្រូវប្រកាសសង្ឃថា បពិត្រព្រះនាងជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត) ឧបសម្បទាបេក្ខា (ជាសិស្ស) របស់នាងជាម្ចាស់ឈ្មោះនេះ។ បើកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំម្ចាស់គប្បីប្រៀនប្រដៅ ឧបសម្បទាបេក្ខាឈ្មោះនេះ។ ខ្លួនឯងគប្បីសន្មតខ្លួនឯងយ៉ាងនេះ។

[២៤១] ភិក្ខុនីដទៃគប្បីសន្មតភិក្ខុនីដទៃយ៉ាងណា។ ភិក្ខុនីដែលឆ្លាស ប្រតិពល គប្បីញុំាងសង្ឃឲ្យដឹងថា បពិត្រព្រះនាងជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ លោកម្ចាស់ឈ្មោះនេះ ជាឧបសម្បទាបេក្ខា របស់ភិក្ខុនីឈ្មោះនេះ។ បើកម្មមានកាលគួរដល់សង្ឃហើយ ភិក្ខុនីឈ្មោះនេះ គប្បីប្រៀនប្រដៅ ឧបសម្បទាបេក្ខាឈ្មោះនេះ។ ភិក្ខុនីដទៃ គប្បីសន្មតភិក្ខុនីដទៃ ដោយអាការយ៉ាងនេះ។

[២៤២] ភិក្ខុនីដែលសង្ឃសន្មតហើយនោះ គប្បីចូលទៅរកឧបសម្បទាបេក្ខា ហើយពោលយ៉ាងនេះថា នែនាងឈ្មោះនេះ នាងស្តាប់ហ្ន៎ កាលនេះជាកាលពិត ជាកាលមែនរបស់នាងហើយ របស់ណាដែលកើតហើយ ខ្ញុំសួររបស់នោះចំពោះនាងក្នុងកណ្តាលជំនុំសង្ឃ ហេតុដែលមាន នាងត្រូវនិយាយថាមាន ហេតុដែលមិនមាន នាងត្រូវនិយាយថាមិនមាន នាងកុំរឹងខ្លួនឡើយ កុំអៀនខ្មាសឡើយ ខ្ញុំនឹងសួរនាងយ៉ាងនេះថា នាងមិនមែនឥតនិមិត្តទេឬ នាងមិនមែនមានហេតុគ្រាន់តែជានិមិត្តទេឬ នាងមិនមែនឥតឈាមទេឬ នាងមិនមានឈាមជានិច្ចទេឬ នាងមិនមែនមានសំពត់ទ្រនាប់ជានិច្ចទេឬ នាងមិនមែនមានឈាមរដូវហូរជានិច្ចទេឬ នាងមិនមែនជាសិខរិណីទេឬ នាងមិនមែនជាស្ត្រីខ្ទើយទេឬ នាងមិនមែនមានរូបដូចប្រុសទេឬ នាងមិនមានទ្វារមគ្គរលាយចូលគ្នាទេឬ នាងមិនមែនជាឧភតោព្យញ្ជនកាទេឬ នាងមានអាពាធយ៉ាងនេះ គឺ ឃ្លង់ ពក ស្រែង រីងរៃ ឆ្កួតជ្រូកដែរឬ នាងជាមនុស្សឬ នាងជាស្ត្រីឬ នាងជាអ្នកជាឬ នាងជាស្ត្រីឥតចំពាក់បំណុលគេទេឬ នាងមិនមែនជាអ្នកបំរើព្រះរាជាទេឬ មាតាបិតា និងប្តី របស់នាង បានអនុញ្ញាតហើយឬ នាងមានអាយុគ្រប់២០ឆ្នាំហើយឬ នាងមានបាត្រ និងចីវរគ្រប់គ្រាន់ហើយឬ នាងឈ្មោះអ្វី បវត្តិនីរបស់នាងឈ្មោះអ្វី។ ភិក្ខុនីជាអ្នកប្រៀនប្រដៅ និងឧបសម្បទាបេក្ខា មកជាមួយគ្នា។បេ។ មិនគប្បីមកជាមួយគ្នាទេ។ ភិក្ខុនីជាអ្នកប្រៀនប្រដៅ គប្បីមកមុនបង្អស់ ហើយផ្តៀងសង្ឃឲ្យដឹងថា បពិត្រព្រះនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ដ្បិតនាងសិក្ខមានា ឈ្មោះនេះ ជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ ខ្ញុំម្ចាស់បានប្រៀនប្រដៅហើយ។ បើកម្មមានកាលគួរដល់សង្ឃហើយ ឧបសម្បទាបេក្ខាឈ្មោះនេះ គប្បីមក។ ភិក្ខុនីអ្នកប្រៀនប្រដៅគប្បីពោលថា នាងចូរមក។ ត្រូវភិក្ខុនីអ្នកប្រៀនប្រដៅឲ្យឧបសម្បទាបេក្ខានោះ ធ្វើចីពរឆៀងស្មាម្ខាង ឲ្យថ្វាយបង្គំបាទាភិក្ខុនីទាំងឡាយ ឲ្យអង្គុយច្រហោង ផ្គងអញ្ជលីឡើយ ហើយឲ្យសូមឧបសម្បទាថា បពិត្រនាងជាម្ចាស់ ខ្ញុំម្ចាស់សូមឧបសម្បទានឹងសង្ឃ បពិត្រនាងជាម្ចាស់ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ស្រោចស្រង់ខ្ញុំផង បពិត្រនាងជាម្ចាស់ ខ្ញុំម្ចាស់សូមឧបសម្បទានឹងសង្ឃ អស់វារៈពីរដងផង បពិត្រនាងជាម្ចាស់ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ស្រោចស្រង់ខ្ញុំផង បពិត្រនាងជាម្ចាស់ ខ្ញុំម្ចាស់សូមឧបសម្បទានឹងសង្ឃ អស់វារៈបីដងផង បពិត្រនាងជាម្ចាស់ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ស្រោចស្រង់ខ្ញុំផង។ ភិក្ខុនីដែលឆ្លាស ប្រតិពល គប្បីផ្តៀងសង្ឃឲ្យដឹងថា បពិត្រនាងជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតនាងឈ្មោះនេះ ជាឧបសម្បទាបេក្ខា របស់នាងជាម្ចាស់ឈ្មោះនេះ បើកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគួរសួរអន្តរាយិកធម៌នឹងឧបសម្បទាបេក្ខាឈ្មោះនេះ។ នែនាងឈ្មោះនេះ នាងស្តាប់ហ្ន៎ កាលនេះ ជាកាលពិត ជាកាលមែនរបស់នាងហើយ ហេតុណាដែលកើតហើយ ខ្ញុំសួរចំពោះហេតុនោះ ហេតុដែលមាន នាងគប្បីឆ្លើយថាមាន ហេតុដែលគ្មាន នាងគប្បីឆ្លើយថាគ្មាន នាងមិនមែនឥតនិមិត្តទេឬ នាងមិនមែនមានហេតុគ្រាន់តែជានិមិត្តទេឬ។បេ។ នាងឈ្មោះអ្វី បវត្តិនីរបស់នាងឈ្មោះអ្វី។ ភិក្ខុនីដែលឈ្លាស ប្រតិពល គប្បីផ្តៀងសង្ឃឲ្យដឹងថា បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ដ្បិតនាងឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ។ បាត្រ និងចីវររបស់នាងនេះ មានគ្រប់គ្រាន់ហើយ។ ឥឡូវ ឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនី ឲ្យបានឧបសម្បទា។ នេះជាញត្តិ។ បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ដ្បិតនាងឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខា របស់នាងជាម្ចាស់ឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ។ បាត្រនិងចីវររបស់នាងនេះ មានគ្រប់គ្រាន់ហើយ។ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ។ ឥឡូវសង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនីឲ្យបានឧបសម្បទា។ ឧបសម្បទា របស់ឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនី គួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីស្ងៀម មិនគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីឆ្លើយមក។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈបីដងផងថា បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ នាងឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខា របស់នាងជាម្ចាស់ឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ។ បាត្រនិងចីវររបស់នាងនេះ មានគ្រប់គ្រាន់ហើយ។ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ។ ឥឡូវសង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ របស់នាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនីឲ្យបានឧបសម្បទា។ ឧបសម្បទារបស់ឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនី គួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីស្ងៀម មិនគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីឆ្លើយមក។ ឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនី សង្ឃបានឲ្យឧបសម្បទាហើយ។ ការឲ្យឧបសម្បទានេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំម្ចាស់សូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៤៣] ភិក្ខុនីអ្នកប្រៀនប្រដៅ គប្បីនាំយកឧបសម្បទាបេក្ខានោះ ចូលទៅរកភិក្ខុសង្ឃ ឲ្យធ្វើចីពរឆៀងស្មាម្ខាង ឲ្យក្រាបបង្គំបាទាភិក្ខុទាំងឡាយ ឲ្យអង្គុយច្រហោង ផ្គងអញ្ជលីឡើង ហើយឲ្យសូមឧបសម្បទា ក្នុងខណៈនោះថា បពិត្រលោកជាម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់ឈ្មោះនេះ ជាឧបសម្បទាបេក្ខា របស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់មកសូមឧបសម្បទា នឹងភិក្ខុសង្ឃ (ម្តងទៀត) បពិត្រលោកម្ចាស់ទាំងឡាយ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ហើយស្រោចស្រង់ខ្ញុំផង។ បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់ឈ្មោះនេះ ជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់មកសូមឧបសម្បទានឹងភិក្ខុសង្ឃ (ម្តងទៀត) អស់វារៈពីរដងផង បពិត្រលោកម្ចាស់ទាំងឡាយ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ហើយស្រោចស្រង់ខ្ញុំផង។ បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់ឈ្មោះនេះ ជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ បពិត្រលោកជាម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់មកសូមឧបសម្បទានឹងភិក្ខុសង្ឃ (ម្តងទៀត) អស់វារៈបីដងផង បពិត្រលោកម្ចាស់ទាំងឡាយ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ស្រោចស្រង់ខ្ញុំផង។

[២៤៤] ភិក្ខុដែលឆ្លាស ប្រតិពល គប្បីប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) ឧបសម្បទាបេក្ខាឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខា របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី (ឧបជ្ឈាយ៍) មកសូមឧបសម្បទា នឹងសង្ឃ (ម្តងទៀត)។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី ឲ្យបានឧបសម្បទា។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបសម្បទាបេក្ខាឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខា របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ (ម្តងទៀត)។ សង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី ឲ្យបានឧបសម្បទា។ ឧបសម្បទា របស់ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីឆ្លើយមក។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈបីដងផងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧបសម្បទាបេក្ខាឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខា របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ (ម្តងទៀត)។ សង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី ឲ្យបានឧបសម្បទា។ ឧបសម្បទា របស់ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីឆ្លើយមក។ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះ ជាបវត្តិនី សង្ឃបានឲ្យឧបសម្បទាហើយ។ កម្មនេះសមគួរដល់សង្ឃហើយ ហេតុនោះបានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

[២៤៥] ឧបជ្ឈាយ៍ គប្បីវាស់ស្រមោល គប្បីប្រាប់ប្រមាណនៃរដូវ គប្បីប្រាប់ចំណែកថ្ងៃ គប្បីប្រាប់សង្គីតិ គប្បីប្រាប់ពួកភិក្ខុនីថា នាងទាំងឡាយ ចូរប្រាប់និស្ស័យ៣យ៉ាងផង ប្រាប់អករណីកិច្ច៨យ៉ាងផង ដល់ភិក្ខុនីថ្មីនេះ។

[២៤៦] សម័យនោះឯង ភិក្ខុនីទាំងឡាយរវល់រៀបចំអាសនៈ[25] ក្នុងរោងភត្ត ធ្វើភត្តកាលឲ្យកន្លងហួសទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតលំដាប់ទីចាស់ខ្ចី ដល់ភិក្ខុនីទាំងឡាយ៨រូប និងទីសមគួរតាមដំណើរមុនក្រោយ ដល់ភិក្ខុនីទាំងឡាយក្រៅពីនោះ។

[២៤៧] សម័យនោះឯង ភិក្ខុនីទាំងឡាយដឹងថា ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតលំដាប់ទីចាស់ខ្ចី ដល់ភិក្ខុនី៨រូប និងទីសមគួរតាមដំណើរមុនក្រោយ ដល់ភិក្ខុនីទាំងឡាយក្រៅពីនោះ ដូច្នេះហើយ ក៏ឃាត់លំដាប់ទីចាស់ខ្ចីចំពោះភិក្ខុនី៨រូប ឃាត់នូវទីដ៏សមគួរតាមដំណើរមុនក្រោយ ចំពោះភិក្ខុនីទាំងឡាយក្រៅពីនោះគ្រប់កន្លែង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវលំដាប់ទីចាស់ខ្ចី ចំពោះភិក្ខុនី៨រូប និងទីតាមលំដាប់មុនក្រោយ ដល់ភិក្ខុនីទាំងឡាយក្រៅពីនោះ ក្នុងរោងឆាន់ កន្លែងដទៃទៀត ភិក្ខុនីមិនត្រូវឃាត់លំដាប់ទីចាស់ខ្ចីទេ ភិក្ខុនីណាឃាត់ ត្រូវអាបត្តិទុក្កដ។

[២៤៨] សម័យនោះឯង ពួកភិក្ខុនីមិនបានបវារណា។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី មិនត្រូវមិនបវារណាទេ ភិក្ខុនីណាមិនបវារណា វិន័យធរ ត្រូវវិនិច្ឆ័យតាមអាបត្តិ។

[២៤៩] សម័យនោះឯង ភិក្ខុនីទាំងឡាយ បវារណាដោយខ្លួនឯង មិនបវារណានឹងភិក្ខុសង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនទាន់បវារណាដោយខ្លួនឯង មិនត្រូវបវារណានឹងភិក្ខុសង្ឃទេ ភិក្ខុនីណាមិនបវារណា វិន័យធរត្រូវវិនិច្ឆ័យតាមអាបត្តិ។

[២៥០] សម័យនោះឯង ភិក្ខុនីទាំងឡាយ បវារណាក្នុងទីមួយជាមួយនឹងពួកភិក្ខុ ហើយធ្វើកោលាហល។ ពួកភិក្ខុ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវបវារណា ក្នុងទីមួយជាមួយនឹងពួកភិក្ខុទេ ភិក្ខុនីណាបវារណា ត្រូវអាបត្តិទុក្កដ។

[២៥១] សម័យនោះឯង ភិក្ខុនីទាំងឡាយ បវារណាមុនភត្ត ធ្វើភត្តកាលឲ្យកន្លងហួសទៅ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីបវារណាក្រោយភត្តវិញ។ ភិក្ខុនីក៏បវារណាក្រោយភត្ត ក្នុងវេលាវិកាល។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីបវារណានឹងភិក្ខុនីសង្ឃក្នុងថ្ងៃនេះ ហើយបវារណានឹងភិក្ខុសង្ឃ ក្នុងថ្ងៃស្អែកទៀត។

[២៥២] សម័យនោះឯង ភិក្ខុនីសង្ឃទាំងអស់ នាំគ្នាបវារណាហើយ ធ្វើឲ្យកើតកោលាហល។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុនី១រូប ដែលឆ្លាស ប្រតិពល ឲ្យបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ (ជំនួសភិក្ខុនីសង្ឃ)។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវសន្មតយ៉ាងនេះ គប្បីសូមភិក្ខុនីជាមុន លុះសូមរួចហើយ ត្រូវភិក្ខុនីដែលឆ្លាស ប្រតិពល ប្រកាសសង្ឃថា បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ។ នេះជាញត្តិ។ បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សង្ឃនឹងសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ។ ការសន្មតិភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ សមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីស្ងៀម មិនសមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីឆ្លើយមក។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសន្មត ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃហើយ។ ការសន្មតិ សមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៥៣] ភិក្ខុនីដែលសង្ឃសន្មតហើយនោះ គប្បីនាំភិក្ខុនីសង្ឃចូលទៅរកភិក្ខុសង្ឃ ធ្វើចីវរ ឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើយ ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ឥឡូវនេះ ភិក្ខុនីសង្ឃបវារណានឹងភិក្ខុសង្ឃ ដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី បពិត្រលោកម្ចាស់ទាំងឡាយ សូមភិក្ខុសង្ឃ អាស្រ័យសេចក្តីអនុគ្រោះ ពោលដាស់តឿនភិក្ខុនីសង្ឃ កាលបើឃើញច្បាស់ហើយ នឹងសម្តែងចេញ។ បពិត្រលោកម្ចាស់ទាំងឡាយ។បេ។ បពិត្រលោកម្ចាស់ទាំងឡាយ ភិក្ខុនីសង្ឃ សូមបវារណានឹងភិក្ខុសង្ឃ ដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី បពិត្រលោកម្ចាស់ទាំងឡាយ សូមភិក្ខុសង្ឃ អាស្រ័យសេចក្តីអនុគ្រោះ ពោលដាស់តឿនភិក្ខុនីសង្ឃ កាលបើឃើញច្បាស់ហើយ នឹងសម្តែងចេញ។

[២៥៤] សម័យនោះឯង ភិក្ខុនីទាំងឡាយឃាត់ឧបោសថ ឃាត់បវារណារបស់ពួកភិក្ខុ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍) ផ្តើមអនុវាទាធិករណ៍ ឲ្យភិក្ខុធ្វើឱកាស (ដើម្បីចោទ) ចោទ (ភិក្ខុ) រំលឹក (ភិក្ខុ)។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឃាត់ឧបោសថរបស់ភិក្ខុ សូម្បីឃាត់ហើយ ក៏ឈ្មោះថា មិនបានឃាត់ឡើយ កាលបើឃាត់ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវឃាត់បវារណា សូម្បីឃាត់ហើយ ក៏ឈ្មោះថា មិនបានឃាត់ កាលបើឃាត់ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍) សូម្បីធ្វើហើយ ក៏ឈ្មោះថា មិនបានធ្វើ កាលបើធ្វើ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវផ្តើមអនុវាទាធិករណ៍ សូម្បីផ្តើមហើ ក៏ឈ្មោះថា មិនបានផ្តើម កាលបើផ្តើម ត្រូវអាបត្តិទុក្កដ ភិក្ខុនី មិនត្រូវឲ្យគេធ្វើឱកាស (ដើម្បីចោទ) បើទុកជាឲ្យគេធ្វើហើយ ក៏ឈ្មោះថា មិនបានឲ្យធ្វើ កាលបើឲ្យធ្វើ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវចោទភិក្ខុទេ បើទុកជាចោទហើយ ក៏ឈ្មោះថាមិនបានចោទ កាលបើចោទ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវរំលឹកពួកភិក្ខុទេ ទោះបីរំលឹកហើយ ក៏ឈ្មោះថាមិនបានរំលឹក កាលបើរំលឹក ត្រូវអាបត្តិទុក្កដ។

[២៥៥] សម័យនោះឯង ភិក្ខុទាំងឡាយ ឃាត់ឧបោសថ ឃាត់បវារណារបស់ពួកភិក្ខុនី ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍) ផ្តើមអនុវាទាធិករណ៍ ឲ្យភិក្ខុនីធ្វើឱកាស (ដើម្បីចោទ) ចោទ (ភិក្ខុនី) រំលឹក (ភិក្ខុនី)។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុឃាត់ឧបោសថដល់ភិក្ខុនី ឧបោសថដែលឃាត់ហើយ ក៏ឈ្មោះថាឃាត់ដោយប្រពៃ ភិក្ខុដែលឃាត់ មិនត្រូវអាបត្តិ ឲ្យភិក្ខុឃាត់បវារណា បវារណាដែលឃាត់ហើយ ក៏ឈ្មោះថាឃាត់ដោយប្រពៃ ភិក្ខុដែលឃាត់ មិនត្រូវអាបត្តិ ឲ្យភិក្ខុធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍) ទោះបីភិក្ខុធ្វើហើយ ក៏ឈ្មោះថាធ្វើដោយប្រពៃ ភិក្ខុដែលធ្វើ មិនត្រូវអាបត្តិ ឲ្យភិក្ខុផ្តើមអនុវាទាធិករណ៍ ទោះបីភិក្ខុផ្តើមហើយ ក៏ឈ្មោះថាផ្តើមឡើងដោយប្រពៃ ភិក្ខុដែលផ្តើម មិនត្រូវអាបត្តិ ឲ្យភិក្ខុបើកឱកាស (ដើម្បីចោទ) ទោះបីភិក្ខុបើកហើយ ក៏ឈ្មោះថាបើកដោយប្រពៃ ភិក្ខុដែលបើក មិនត្រូវអាបត្តិ ឲ្យភិក្ខុចោទ(ភិក្ខុនី) ទោះបីភិក្ខុចោទហើយ ក៏ឈ្មោះថាចោទដោយប្រពៃ ភិក្ខុដែលចោទ មិនត្រូវអាបត្តិ ឲ្យភិក្ខុរំលឹក (ភិក្ខុនី) ទោះបីភិក្ខុរំលឹកហើយ ក៏ឈ្មោះថារំលឹកដោយប្រពៃ ភិក្ខុដែលរំលឹក មិនត្រូវអាបត្តិឡើយ។

[២៥៦] សម័យនោះឯង ឆព្វគ្គិយាភិក្ខុនីទៅដោយយានដែលទឹមគោញី មានបុរសជាអ្នកបរខ្លះ ដែលទឹមគោឈ្មោល មានស្រីជាអ្នកបរខ្លះ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចជាស្រីអ្នកលេងទឹកក្នុងទន្លេគង្គា និងទន្លេមហី។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវទៅដោយយានទេ ភិក្ខុនីណាទៅ វិន័យធរត្រូវវិនិច្ឆ័យតាមអាបត្តិ។

[២៥៧] សម័យនោះឯង ភិក្ខុនី១រូប មានជម្ងឺ មិនអាចនឹងដើរទៅដោយជើងបាន។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ដែលមានជម្ងឺទៅដោយយានបាន។ លំដាប់នោះ ភិក្ខុនីទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា (ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតយាន) ដែលទឹមគោញី ឬយានដែលទឹមគោឈ្មោលហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយានដែលទឹមគោញី ដែលទឹមគោឈ្មោល និងយានដែលអូសដោយដៃ (មានស្រី ឬប្រុស ជាអ្នកអូស)។

[២៥៨] សម័យនោះឯង មានភិក្ខុនី១រូប កើតសេចក្តីមិនសប្បាយជាខ្លាំង ដោយសាររទេះទង្គិច។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែស្នែង និងអង្រឹងស្នែង។

[២៥៩] សម័យនោះឯង មានស្រីផ្កាមាសឈ្មោះអឌ្ឍកាសី មកបួសក្នុងសំណាក់ពួកភិក្ខុនី។ នាងអឌ្ឍកាសីនោះ ចង់ទៅនគរសាវត្ថី ដោយគិតថា អាត្មាអញនឹងបានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ។ ពួកអ្នកលេងបានឮដំណឹងថា នាងអឌ្ឍកាសីស្រីផ្កាមាស ចង់ទៅនគរសាវត្ថី។ ពួកអ្នកលេងទាំងនោះ ក៏ចាំស្កាត់ត្រង់កណ្តាលផ្លូវ។ នាងអឌ្ឍកាសីស្រីផ្កាមាស បានឮដំណឹងថា ពួកអ្នកលេងចាំស្កាត់ត្រង់កណ្តាលផ្លូវ ដូច្នោះ ក៏បញ្ជូនទូតទៅក្រាបបង្គំទូលព្រះមានព្រះភាគថា ដ្បិតខ្ញុំម្ចាស់ចង់ឧបសម្បទា តើខ្ញុំម្ចាស់នឹងប្រតិបត្តិយ៉ាងណា។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឲ្យឧបសម្បទា សូម្បីដោយទូតក៏បាន។ ភិក្ខុទាំងឡាយ ក៏ឲ្យឧបសម្បទា (ដល់ភិក្ខុនី) ដោយភិក្ខុទូត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យឧបសម្បទា (ដល់ភិក្ខុនី) ដោយភិក្ខុទូតទេ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ។ ភិក្ខុទាំងឡាយ ក៏ឲ្យឧបសម្បទា (ដល់ភិក្ខុនី) ដោយសិក្ខមានាទូត។បេ។ ឲ្យឧបសម្បទា ដោយសាមណេរទូត។បេ។ ឲ្យឧបសម្បទា ដោយសាមណេរីទូត។បេ។ ឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខា ដែលល្ងង់ មិនឆ្លាសដោយទូត។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខា ដែលល្ងង់ មិនឆ្លាសដោយទូតទេ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឲ្យឧបសម្បទាដល់ភិក្ខុនី ដែលឆ្លាស ប្រតិពល ដោយទូតបាន។ ភិក្ខុនីជាទូតនោះ គប្បីចូលទៅរកសង្ឃ ធ្វើចីវរ ឆៀងស្មាម្ខាង ក្រាបថ្វាយបង្គំបាទានៃភិក្ខុទាំងឡាយ ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាង បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ បពិត្រលោកម្ចាស់ទាំងឡាយ ឥឡូវ ឧបសម្បទាបេក្ខាឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) បពិត្រលោកម្ចាស់ទាំងឡាយ សូមព្រះសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ស្រោចស្រង់ឧបសម្បទាបេក្ខានោះ។ បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះ

នេះ របស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាង បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) បពិត្រលោកម្ចាស់ទាំងឡាយ សូមព្រះសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ស្រោចស្រង់នូវឧបសម្បទាបេក្ខានោះ អស់វារៈពីរដងផង។ បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាង បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) បពិត្រលោកម្ចាស់ទាំងឡាយ សូមព្រះសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ស្រោចស្រង់ឧបសម្បទាបេក្ខានោះ អស់វារៈបីដងផង។

[២៦០] ភិក្ខុដែលឆ្លាស ប្រតិពល គប្បីប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧបសម្បទាបេក្ខាឈ្មោះនេះ របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាង បរិសុទ្ធក្នុងសំណាក់ភិក្ខុនីសង្ឃហើយ ឥឡូវ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត)។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីញុំាង ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី ឲ្យបានឧបសម្បទា។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាង បរិសុទ្ធក្នុងសំណាក់ភិក្ខុនីសង្ឃហើយ ឥឡូវ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) ឥឡូវនេះ សង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី ឲ្យបានឧបសម្បទា។ ឧបសម្បទា នៃឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនសមគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីឆ្លើយមក។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈពីរដងផង។បេ។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈបីដងផងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទា ដោយចំណែកម្ខាង បរិសុទ្ធក្នុងសំណាក់នៃភិក្ខុនីសង្ឃហើយ ឥឡូវ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត)។ ឥឡូវនេះ សង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី ឲ្យបានឧបសម្បទា។ ឧបសម្បទា នៃឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនសមគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីឆ្លើយមក។ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សង្ឃបានឲ្យឧបសម្បទាហើយ។ ឧបសម្បទាកម្មនេះ សមគួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។ ភិក្ខុត្រូវវាស់ស្រមោល ប្រាប់ប្រមាណរដូវ ប្រាប់ចំណែកថ្ងៃ ប្រាប់សង្គីតិ និងត្រូវប្រាប់ពួកភិក្ខុនីថា នាងទាំងឡាយត្រូវប្រាប់និស្ស័យ៣យ៉ាងផង អករណីយកិច្ច៨យ៉ាងផង ដល់ភិក្ខុនីថ្មីនោះ។

[២៦១] សម័យនោះឯង ភិក្ខុនីទាំងឡាយទៅនៅក្នុងព្រៃ។ ពួកអ្នកលេងតែងប្រទូស្ត។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវនៅក្នុងព្រៃទេ ភិក្ខុនីណានៅ ត្រូវអាបត្តិទុក្កដ។

[២៦២] សម័យនោះឯង ឧបាសកម្នាក់ប្រគេនឃ្លាំង(សម្រាប់ដាក់របស់) ដល់ភិក្ខុនីសង្ឃ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឃ្លាំង។ ឃ្លាំងក៏មិនគ្រប់គ្រាន់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្ទះ។ ផ្ទះក៏នៅតែមិនគ្រប់គ្រាន់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវនវកម្ម (ការងារថ្មី)។ នវកម្មក៏នៅតែមិនគ្រប់គ្រាន់។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើនវកម្មនោះទៅជារបស់បុគ្គលវិញ។

[២៦៣] សម័យនោះឯង មានស្ត្រី១នាក់ មានគភ៌នៅខ្ចី ចូលមកបួសក្នុងសំណាក់ភិក្ខុនី។ លុះស្ត្រីនោះបួសហើយ គភ៌ក៏ប្រសូតមក។ ភិក្ខុនីនោះមានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញនឹងថែរក្សាទារកនេះ ដោយប្រការដូចម្តេច។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចិញ្ចឹមដរាបតែទារកនោះបានដឹងក្តី។ ទើបភិក្ខុនីនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញម្នាក់ឯង នៅជាមួយនឹងក្មេងប្រុសមិនបាន ទាំងភិក្ខុនីឯទៀត ក៏នៅជាមួយនឹងក្មេងប្រុសមិនបាន តើអាត្មាអញ ត្រូវថែរក្សាដូចម្តេច។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុនី១រូប ឲ្យបានជាគំរប់ពីរនឹងភិក្ខុនីនោះ។ ម្នាលភិក្ខុទាំងឡាយ ត្រូវសន្មតយ៉ាងនេះ។ ត្រូវសូមភិក្ខុនីជាមុន លុះសូមរួចហើយ គប្បីឲ្យភិក្ខុនីដែលឈ្លាស ប្រតិពល ប្រកាសសង្ឃថា បពិត្រព្រះនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុនីឈ្មោះនេះ ឲ្យបានជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រព្រះនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុនីឈ្មោះនេះ ឲ្យបានជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ។ ការសន្មតិភិក្ខុនីឈ្មោះនេះ ឲ្យជាគំរប់ពីរ នឹងភិក្ខុនីឈ្មោះនេះ សមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីស្ងៀម មិនសមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីឆ្លើយមក។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសន្មត ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះហើយ។ ការសន្មតិនេះ សមគួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុក នូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ។ លំដាប់នោះ ភិក្ខុនីជាគំរប់ពីររបស់ភិក្ខុនីនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញត្រូវថែរក្សាក្នុងទារកនោះដូចម្តេច។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យថែរក្សាក្នុងទារកនោះដូចជាប្រតិបត្តិក្នុងបុរសដទៃដែរ វៀរលែងតែការដេកក្នុងផ្ទះជាមួយគ្នាចេញ។

[២៦៤] សម័យនោះឯង មានភិក្ខុនី១រូប ត្រូវគរុកាបត្តិហើយ នៅប្រព្រឹត្តមានត្ត។ ភិក្ខុនីនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញម្នាក់ឯង នៅមិនបាន ទាំងភិក្ខុនីឯទៀត ក៏នៅជាមួយអាត្មាអញមិនបាន អាត្មាអញគួរប្រតិបត្តិដូចម្តេចហ្ន៎។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុនី១រូប ឲ្យជាគំរប់ពីរនឹងភិក្ខុនីនោះ។ ម្នាលភិក្ខុទាំងឡាយ គប្បីសន្មតយ៉ាងនេះ។ ត្រូវសូមភិក្ខុនីជាមុនសិន លុះសូមរួចហើយ ភិក្ខុនីដែលឆ្លាស ប្រតិពល គប្បីផ្តៀងសង្ឃថា បពិត្រនាងជាម្ចាស់

សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ។ នេះជាញត្តិ។ បពិត្រនាងជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ ឥឡូវនេះ សង្ឃសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ។ ការសន្មតិភិក្ខុនីឈ្មោះនេះ ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ គួរដល់នាងជាម្ចាស់ អង្គណា នាងជាម្ចាស់អង្គនោះ គប្បីស្ងៀម មិនគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីនិយាយឡើង។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសន្មត ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះហើយ។ ការសន្មតិនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំដំណើរនេះទុក ដោយអាការស្ងៀមយ៉ាងនេះ។

[២៦៥] សម័យនោះឯង មានភិក្ខុនី១រូប មិនបានពោលលាសិក្ខា ហើយស្រាប់តែសឹកចេញទៅ។ នាងនោះ ក៏ត្រឡប់មកសូមឧបសម្បទានឹងភិក្ខុនីទាំងឡាយវិញ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ (បើ) ភិក្ខុនីមិនបានពោលលាសិក្ខាទេ ភិក្ខុនីនោះសឹកចេញទៅ ព្រោះហេតុណា នាងនោះ មិនហៅថា ភិក្ខុនី ព្រោះតែហេតុនោះឯង។

[២៦៦] សម័យនោះឯង មានភិក្ខុនី១រូប ចូលទៅកាន់លទ្ធិតិរ្ថិយ ទាំងសំពត់កាសាវៈ នាងនោះក៏ត្រឡប់មកសូមឧបសម្បទានឹងភិក្ខុនីទាំងឡាយវិញ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីណា ចូលទៅកាន់តិរ្ថិយទាំងសំពត់កាសាវៈ ហើយនាងនោះត្រឡប់មកវិញ សង្ឃមិនត្រូវឲ្យឧបសម្បទាទេ។

[២៦៧] សម័យនោះឯង ភិក្ខុនីទាំងឡាយមានសេចក្តីរង្កៀស មិនត្រេកអរចំពោះកិរិយាថ្វាយបង្គំ ការកោរសក់ ការកាត់ក្រចក ចំពោះការរក្សាដំបៅមួយអន្លើដោយបុរសទាំងឡាយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីត្រេកអរបាន។

[២៦៨] សម័យនោះឯង ភិក្ខុនីទាំងឡាយ អង្គុយពែនភ្នែនហើយ ក៏ត្រេកអរនឹងសម្ផស្សកែងជើង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវអង្គុយពែនភ្នែនឡើយ ភិក្ខុនីណាអង្គុយ ត្រូវអាបត្តិទុក្កដ។

[២៦៩] សម័យនោះឯង មានភិក្ខុនី១រូបឈឺ។ ភិក្ខុនីនោះ បើវៀរពែនភ្នែន មិនមានសេចក្តីសប្បាយ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីអង្គុយពែនជើងម្ខាងបាន។

[២៧០] សម័យនោះឯង ភិក្ខុនីទាំងឡាយ បន្ទោបង់វច្ចៈក្នុងបង្គន់។ ឯពួកឆព្វគ្គិយាភិក្ខុនី ក៏ទៅរំលូតគភ៌ (កូន) ក្នុងបង្គន់នោះឯង។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវបន្ទោបង់វច្ចៈក្នុងបង្គន់ ភិក្ខុនីណាបន្ទោបង់ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីបន្ទោបង់វច្ចៈ ទៅក្នុងទីខាងក្រោម ដែលមិនមានបិទបាំង មានបិទបាំងតែខាងលើជុំវិញ។

[២៧១] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកដោយគ្រឿងលំអិត។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចជាស្រីគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹកដោយគ្រឿងលំអិតទេ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកុណ្ឌកនឹងដីស្អិត។

[២៧២] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកដោយដីស្អិតដែលគេអប់។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចជាស្រីគ្រហស្ថ អ្នកបរិភោគកាម។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹកដោយដីស្អិតដែលគេអប់ទេ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវដីស្អិតប្រក្រតី។

[២៧៣] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកក្នុងរោងសម្រាប់រក្សាកាយ ហើយធ្វើនូវកោលាហល។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹកក្នុងរោងសម្រាប់រក្សាកាយទេ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ។

[២៧៤] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹក (បែរមុខទៅ) ក្នុងទីច្រាសខ្សែទឹក ហើយត្រេកអរនឹងសម្ផស្សខ្សែទឹក។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹក (បែរមុខទៅ) កាន់ទីច្រាសខ្សែទឹក ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ។

[២៧៥] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកក្នុងទីដែលមិនមែនជាកំពង់។ ពួកអ្នកលេងទៅប្រទូស្ត (ធ្វើអសទ្ធម្ម)។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹកក្នុងទីមិនមែនជាកំពង់ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ។

[២៧៦] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកក្នុងកំពង់ទឹកសម្រាប់បុរស។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា។បេ។ ដូចជាស្រីគ្រហស្ថ អ្នកបរិភោគកាម។បេ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ។បេ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹក ក្នុងកំពង់សម្រាប់បុរសទេ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីងូតទឹក ក្នុងកំពង់សម្រាប់ស្រីដ៏ប្រសើរ គឺភិក្ខុនីផងគ្នា។

ភាណវារៈ ទី៣។

ចប់ ភិក្ខុនីខន្ធកៈ ទី១០។

ក្នុងខន្ធកៈនេះ មានរឿង១០៦។

ឧទ្ទានគឺបញ្ជីរឿង នៃភិក្ខុនីខន្ធកៈនោះគឺ

[២៧៧]

រឿងព្រះនាងបជាបតីគោតមីសូមបព្វជ្ជា ព្រះតថាគត ជាវិនាយក មិនទ្រង់អនុញ្ញាត ហើយស្តេចចេញចាកក្រុងកបិលព័ស្តុ ទៅកាន់ក្រុងវេសាលី១។ រឿងព្រះនាងបជាបតីគោតមី មានព្រះអង្គប្រឡាក់ដោយធូលី ទ្រង់ព្រះសណ្ឋិតទៀបក្លោងទ្វារ ហើយទូលសេចក្តីនុ៎ះ ចំពោះព្រះអានន្ទ១។ រឿងព្រះអានន្ទទូលសូមបព្វជ្ជា ឲ្យព្រះនាងគោតមី តាមន័យដែលព្រះអង្គថា គួរនឹងបានសម្រេចមគ្គផលដែរ ដោយពោលអាងថា ព្រះនាងគោតមី ជាព្រះមាតុច្ឆាផង ជាអ្នកចិញ្ចឹមព្រះអង្គផង។ រឿងព្រះសាស្តាទ្រង់សម្តែងគរុធម៌៨ប្រការ គឺភិក្ខុនីសូម្បីមានវស្សា១រយ ក៏ត្រូវគោរពភិក្ខុ ដែលទើបបានឧបសម្បទាក្នុងថ្ងៃនោះ១ ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសគ្មានភិក្ខុ១ ភិក្ខុនីត្រូវស្វែងរកធម៌ពីរប្រការ អំពីសំណាក់ភិក្ខុសង្ឃ១ ភិក្ខុនីត្រូវបវារណា ក្នុងឧភតោសង្ឃ១ ភិក្ខុនីត្រូវគរុកាបត្តិហើយ ត្រូវប្រព្រឹត្តបក្ខមានត្ត ក្នុងឧភតោសង្ឃ១ ភិក្ខុនីត្រូវស្វែងរកឧបសម្បទា ឲ្យនាងសិក្ខមានា ដែលបានសិក្សាធម៌៦ប្រការ អស់ពីរវស្សាក្នុងសំណាក់ឧភតោសង្ឃ១ ភិក្ខុនីមិនត្រូវជេរប្រទេចភិក្ខុ១ ភិក្ខុនីមិនត្រូវឲ្យឱវាទ ដល់ភិក្ខុ១ ភិក្ខុនីត្រូវប្រព្រឹត្តតាម គរុធម៌ ៨ប្រការដរាបអស់ជីវិត១។ រឿងព្រះអានន្ទរៀនគរុធម៌៨ប្រការ ហើយប្រាប់ដល់ព្រះនាងបជាបតីគោតមីថា បើព្រះនាងទទួលប្រព្រឹត្តគរុធម៌៨ប្រការ នាងនឹងបានឧបសម្បទា១។ រឿងព្រះមានព្រះភាគត្រាស់ថា បើមិនមានស្រីបួសទេ ព្រះសទ្ធម្មនឹងឋិតនៅអស់១ពាន់ឆ្នាំ កាលបើមានស្រីបួស ព្រះសទ្ធម្មនឹងឋិតនៅបានត្រឹមតែប្រាំរយឆ្នាំ ប្រៀបដូចចោរលួចឆ្នាំង ឬប្រៀបដូចក្រាដែលស៊ីស្រូវពុំនោះសោត ដូចជាក្រាភ្លើង ដែលស៊ីអំពៅ ឯមាតុគ្រាម តែងបៀតបៀននូវព្រះសទ្ធម្ម យ៉ាងនោះដែរ មួយវិញទៀត បុរសទប់ទឹកឲ្យជាប់នៅយ៉ាងណា គរុធម៌ ៨ប្រការ ដែលព្រះអង្គបញ្ញត្តទុកមក ក៏ញ៉ាំងព្រះសទ្ធម្មឲ្យឋិតថេរ យ៉ាងនោះដែរ១ រឿងព្រះមានព្រះភាគទ្រង់អនុញ្ញាតឧបសម្បទាដល់ភិក្ខុនី១ រឿងពួកភិក្ខុនីនិយាយនឹងព្រះនាងបជាបតីគោតមីថា ព្រះនាងជាម្ចាស់ មិនទាន់បានឧបសម្បទានៅឡើយ១ រឿងព្រះនាងបជាបតីគោតមី ទូលសូមឲ្យទ្រង់អនុញ្ញាត ការគោរពដល់ភិក្ខុ ភិក្ខុនី តាមលំដាប់ចាស់ខ្ចី ហើយព្រះអង្គ ទ្រង់ឃាត់ថា មិនបាច់តថាគតអនុញ្ញាតទេ១ រឿងព្រះនាងបជាបតីគោតមី ទូលសួរអំពីសាធារណៈ និងអសាធារណសិក្ខាបទ១ រឿងទ្រង់ប្រទានឱវាទ១ រឿងទ្រង់អនុញ្ញាតបាតិមោក្ខ១ រឿងពួកភិក្ខុសង្ស័យថា ត្រូវនរណា សម្តែងបាតិមោក្ខ១ រឿងភិក្ខុចូលទៅកាន់សំណាក់ភិក្ខុនី១ រឿងពួកភិក្ខុនីមិនចេះបាតិមោក្ខ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុប្រាប់បាតិមោក្ខុទ្ទេស១ រឿងភិក្ខុនីមិនសំដែងអាបត្តិ១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុទទួលអាបត្តិរបស់ពួកភិក្ខុនី១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុប្រាប់ដល់ការសំដែងអាបត្តិ ដល់ពួកភិក្ខុនី១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុនីផងគ្នា ទទួលអាបត្តិ១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុប្រាប់ការទទួលអាបត្តិ ដល់ពួកភិក្ខុនី១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុធ្វើកម្ម ដល់ពួកភិក្ខុនី១ រឿងមនុស្សទាំងឡាយពោលទោសថា ភិក្ខុនីទាំងនេះ ជាប្រពន្ធរបស់ភិក្ខុ១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុប្រាប់ការធ្វើកម្ម ដល់ពួកភិក្ខុនី១ រឿងភិក្ខុនីឈ្លោះគ្នាកណ្តាលសង្ឃ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុលើកកម្មរបស់ភិក្ខុនី ប្រគល់ឲ្យភិក្ខុនីផងគ្នា១ រឿងភិក្ខុនីជាកូនសិស្សនាងឧប្បលវណ្ណា១ រឿងទ្រង់គង់នៅក្នុងក្រុងសាវត្ថី១ រឿងពួកភិក្ខុ សាចពួកភិក្ខុនីដោយភក់ និងទឹក១ រឿងអវន្ទិយភិក្ខុ មិនគួរឲ្យពួកភិក្ខុនីថ្វាយបង្គំ១ រឿងពួកភិក្ខុសើយកាយ សើយភ្លៅ បញ្ចេញអង្គជាត ចំអកចំអន់ពួកភិក្ខុនី ផ្សំផ្គុំភិក្ខុជាមួយនឹងពួកភិក្ខុនី១ រឿងទ្រង់អនុញ្ញាតឲ្យធ្វើទណ្ឌកម្ម មិនឲ្យភិក្ខុនីសំពះពួកភិក្ខុ១ រឿងភិក្ខុនីសាចទឹក និងភក់លើពួកភិក្ខុ១ រឿងទ្រង់អនុញ្ញាតឲ្យធ្វើអាវរណកម្ម១ រឿងទ្រង់អនុញ្ញាតឲ្យបញ្ឈប់ឱវាទ១ រឿងពួកភិក្ខុគិតថា កាលធ្វើឧបោសថជាមួយនឹងភិក្ខុនី ដែលឃាត់ឱវាទហើយ គួរ ឬមិនគួរ១ រឿងឧទាយីឃាត់ឱវាទ ហើយចៀសចេញទៅកាន់ចារិក១ រឿងភិក្ខុល្ងង់ឃាត់ឱវាទ១ រឿងពួកភិក្ខុឃាត់ឱវាទដោយឥតរឿង១ រឿងពួកភិក្ខុឃាត់ឱវាទ ហើយមិនឲ្យវិនិច្ឆ័យ១ រឿងភិក្ខុនីសង្ឃទៅទទួលយកឱវាទ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុនី ៤-៥ រូប ទៅទទួលយកឱវាទ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុនី ២-៣រូបទៅទទួលយកឱវាទ១ រឿងពួកភិក្ខុមិនទទួលឲ្យឱវាទ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុទទួលឲ្យឱវាទភិក្ខុនី វៀរលែងតែភិក្ខុល្ងង់ ភិក្ខុឈឺ និងភិក្ខុអ្នកដំណើរ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុដែលនៅក្នុងព្រៃ ឲ្យឱវាទ១ រឿងពួកភិក្ខុទទួលឲ្យឱវាទ ហើយមិនបានប្រាប់១ រឿងពួកភិក្ខុទទួលឲ្យឱវាទហើយ មិនប្រគល់មកវិញ១ រឿងពួកភិក្ខុនីប្រើវត្ថពន្ធចង្កេះវែង១ រឿងពួកភិក្ខុនីចងរឹតឆ្អឹងជំនីរ ដោយផ្ទាំងដែលធ្វើពីបន្ទោះឬស្សីខ្លះ ដោយស្បែកខ្លះ ដោយសំពត់សខ្លះ ដោយសំណុំសំពត់សខ្លះ ដោយខ្នាញ់សំពត់សខ្លះ ដោយផ្ទាំងសំពត់មានពណ៌ផ្សេងៗខ្លះ ដោយសំណុំសំពត់មានពណ៌ខ្លះ ដោយខ្នាញ់សំពត់មានពណ៌ខ្លះ ដោយសំណុំសូត្រខ្លះ ដោយខ្នាញ់សំពត់សូត្រខ្លះ១ រឿងពួកភិក្ខុនីប្រើឲ្យគេដំត្រគាក ដោយឈើដូចឆ្អឹងស្មងគោខ្លះ ដូចចង្កាគោខ្លះ ឲ្យគេដំដៃខ្លះ ខ្នងដៃខ្លះ ខ្នងជើងខ្លះ ភ្លៅខ្លះ មុខខ្លះ សាច់ធ្មេញខ្លះ ដោយឈើដូចគ្នា ពួកភិក្ខុនីលាបមុខខ្លះ ប្រស់មុខខ្លះ ខាត់មុខខ្លះ ផ្ចិតមុខខ្លះ ស្រឡាបមុខខ្លះ ស្រឡាបទាំងខ្លួន ទាំងមុខខ្លះ១ រឿងភិក្ខុនីធ្វើគំនូសក្រោមមាត់ខ្លះ ធ្វើគំនូសប្លែកៗត្រង់ថ្ពាល់ខ្លះ ក្រឡេកមើលតាមបង្អួចខ្លះ ឈរត្រង់មាត់ទ្វារបង្ហាញកាយខ្លះ ប្រើគេឲ្យលេងមហោស្រពខ្លះ បំបួសស្រីពេស្យាខ្លះ តាំងរោងលក់សុរាខ្លះ តាំងរោងលក់សាច់ខ្លះ បើករានផ្សារខ្លះ ដំឡើងថ្ងៃរបស់ខ្លះ ប្រកបជំនួញផ្សេងៗខ្លះ ឲ្យខ្ញុំប្រុសបម្រើខ្លះ ឲ្យខ្ញុំស្រីបម្រើខ្លះ ឲ្យកូនឈ្នួលប្រុសបម្រើខ្លះ ឲ្យកូនឈ្នួលស្រីបម្រើខ្លះ ឲ្យសត្វតិរច្ឆានបម្រើខ្លះ តាំងរានលក់វត្ថុខ្ចី និងវត្ថុទុំខ្លះ ប្រើកម្រាលស្នាញ់ដោយរោមចៀមខ្លះ១ រឿងភិក្ខុនីប្រើចីវរពណ៌ខៀវសុទ្ធខ្លះ លឿងខ្ចីសុទ្ធខ្លះ ក្រហមសុទ្ធខ្លះ ហង្សបាទសុទ្ធខ្លះ ខ្មៅសុទ្ធខ្លះ ក្រហមក្រមៅសុទ្ធខ្លះ លឿងទុំសុទ្ធខ្លះ មានជាយមិនបានកាត់ដាច់ខ្លះ វែងខ្លះ រំលេចដោយផ្កាឈើខ្លះ រំលេចដោយផ្លែឈើខ្លះ ពាក់អាវបំពង់វែងខ្លះ ពាក់មួកខ្លះ១។ រឿងភិក្ខុនីនឹងសិក្ខមានា និងសាមណេរី ធ្វើមរណកាលទៅ ត្រូវភិក្ខុនីសង្ឃជាឥស្សរៈ លើគ្រឿងបរិក្ខារ ដែលភិក្ខុនីជាដើមនោះ ប្រគល់ឲ្យ១ រឿងភិក្ខុ សាមណេ ឧបាសក ឧបាសិកា និងជនឯទៀត ធ្វើមរណកាលទៅ ត្រូវពួកភិក្ខុ ជាឥស្សរៈ លើគ្រឿងបរិក្ខារ ដែលភិក្ខុជាដើមនោះ ប្រគល់ឲ្យ១។ រឿងមល្លីភិក្ខុនី ប្រហារភិក្ខុនី១ រឿងភិក្ខុនីមួយរូបដាក់កូនខ្ចីក្នុងបាត្រ១ រឿងពួកភិក្ខុនីផ្លាស់ប្តូរបាត្រ

ហើយប្រាប់ថ្លៃឈ្នួលបាត្រ១ រឿងភិក្ខុនីគន់មើលនិមិត្តរបស់បុរស១ រឿងមនុស្សទាំងឡាយប្រគេនអាមិសៈ ដល់ពួកភិក្ខុ១ រឿងអាមិសៈ ក៏សម្បូណ៌ច្រើនឡើង១ រឿងពួកភិក្ខុសន្សំអាមិសៈទុក១ រឿងមនុស្សទាំងឡាយឲ្យអាមិសៈ ដល់ពួកភិក្ខុយ៉ាងណា ឲ្យដល់ភិក្ខុនីខាងក្រោយ ក៏ដូចគ្នា១។ រឿងសេនាសនៈរបស់ភិក្ខុ សម្បូណ៌ឡើង១ រឿងពួកភិក្ខុនីមានរដូវធ្លាក់ប្រឡាក់សំពត់១ រឿងភិក្ខុនីមានសំពត់ទ្រនាប់ដាច់ដាច១ រឿងភិក្ខុនីប្រើខ្សែក្រវាត់គ្រប់កាល១ រឿងភិក្ខុនីគ្មាននិមិត្តខ្លះ មានហេតុបន្តិចគ្រាន់តែជាស្នាមខ្លះ មិនមានរដូវខ្លះ មានឈាមរដូវធ្លាក់ជានិច្ចខ្លះ មានសំពត់ទ្រនាប់ជានិច្ចខ្លះ មានឈាមរដូវហូរខ្លះ ជាសិខរិណីខ្លះ ជាស្រីខ្ទើយខ្លះ ជាស្រីមានទ្រង់ដូចប្រុសខ្លះ មានទ្វារមគ្គរលាយចូលគ្នាខ្លះ ជាឧភតោព្យញ្ជនកាខ្លះ តាំងពីរឿងភិក្ខុនីគ្មាននិមិត្ត រហូតដល់ឧភតោព្យញ្ជនកា ពាក្យខាងក្រោមបេយ្យាលនុ៎ះ មានរឿងភិក្ខុសួរអន្តរាយិកធម៌២៤ប្រការ ចំពោះឧបសម្បទាបេក្ខាថា នាងមានរោគឃ្លង់ឬ នាងមានរោគពកឬ នាងមានរោគស្រែងឬ នាងមានរោគរីងរៃឬ នាងមានរោគឆ្កួតជ្រូកឬ នាងជាស្រីមនុស្សឬ នាងជាស្រីពិតឬ នាងជាអ្នកជាឬ នាងគ្មានចំពាក់បំណុលគេទេឬ នាងមិនមែនជាស្រីខ្ញុំរាជការទេឬ នាងមានមាតាមិតា និងស្វាមីអនុញ្ញាតហើយឬ នាងមានវស្សាគ្រប់២០ហើយឬ នាងមានបាត្រគ្រប់គ្រាន់ហើយឬ នាងឈ្មោះអ្វី បវត្តិនីរបស់នាងឈ្មោះអ្វី១។ រឿងឧបសម្បទាបេក្ខា ដែលមិនទាន់បានប្រៀនប្រដៅ ក្រអិមក្រអៀម មិនហ៊ានប្រាប់អន្តរាយិកធម៌១ រឿងទ្រង់អនុញ្ញាតឲ្យប្រៀនប្រដៅហើយសឹមសួរអន្តរាយិកធម៌កណ្តាលជំនុំសង្ឃ១ រឿងទ្រង់អនុញ្ញាតថា មុនដម្បូង ត្រូវភិក្ខុនីឲ្យឧបសម្បទាបេក្ខាកាន់យកឧបជ្ឈាយ៍ ហើយត្រូវប្រាប់បាត្រ និងចីវរថា (នេះបាត្ររបស់នាង) នេះសង្ឃាដិ នេះចីពរ នេះស្បង់ នេះសំពត់ចោមពុង នេះសំពត់ងូតទឹក (របស់នាង) លុះប្រាប់ហើយ ត្រូវបង្គាប់ឲ្យឈរក្នុងឱកាសឯណោះ១ រឿងភិក្ខុនី១រូបល្ងង់ មិនឆ្លាស ទៅប្រៀនប្រដៅ១ រឿងភិក្ខុនីដែលសង្ឃមិនទានសន្មតឲ្យប្រៀនប្រដៅ ទៅប្រៀនប្រដៅ១ រឿងឧបសម្បទាបេក្ខា សូត្រសូមឧបសម្បទា១ រឿងសួរអន្តរាយិកធម៌១ រឿងឧបសម្បទាបេក្ខា បានឧបសម្បទាចំណែកមួយ ហើយត្រូវសូមឧបសម្បទាក្នុងសំណាក់ភិក្ខុសង្ឃម្តងទៀត១ រឿងភិក្ខុនីជាបវត្តិនី ត្រូវវាស់ស្រមោល ប្រាប់ប្រមាណនៃរដូវ ប្រាប់ចំណែកថ្ងៃ ប្រាប់សង្គីតិ ប្រាប់និស្ស័យ៣យ៉ាង ប្រាប់អករណីយកិច្ច៨យ៉ាង១ រឿងពួកភិក្ខុនីញុំាងភត្តកាលឲ្យកន្លងហួស១ រឿងពួកភិក្ខុនី៨រូប ឃាត់អាសនៈភិក្ខុនីចាស់ ក្នុងទីទាំងពួង១ រឿងពួកភិក្ខុនីមិនបានបវារណា១ រឿងពួកភិក្ខុនីបវារណាដោយខ្លួនឯង ហើយមិនបានបវារណាក្នុងភិក្ខុសង្ឃ១ រឿងពួកភិក្ខុនីបវារណានឹងភិក្ខុសង្ឃហើយ កើតកោលាហល១ រឿងពួកភិក្ខុនីបវារណាមុនភត្ត ហើយញុំាងភត្តកាលឲ្យកន្លងហួសទៅ និងបវារណាខាងក្រោយភត្ត ក្នុងវេលាវិកាល១ រឿងភិក្ខុនីសង្ឃបវារណាហើយ ក៏កើតកោលាហល១ រឿងពួកភិក្ខុនីឃាត់ឧបោសថ ឃាត់បវារណារបស់ភិក្ខុ ធ្វើឲ្យមានមាត់ពាក្យ ក្នុងអធិករណ៍ ផ្តើមអនុវាទាធិករណ៍ ឲ្យគេធ្វើឱកាស ចោទភិក្ខុ និងរំលឹកភិក្ខុ ព្រះសម្មាសម្ពុទ្ធ អ្នកស្វែងរកនូវគុណដ៏ធំ ទ្រង់ឃាត់ដោយទុក្កដាបត្តិ១ រឿងពួកភិក្ខុឃាត់កម្មដូច្នោះ ដែលជារបស់ពួកភិក្ខុនី ព្រះសម្មាសម្ពុទ្ធ ព្រះអង្គអ្នកស្វែងរកគុណដ៏ធំ ទ្រង់អនុញ្ញាត១។ រឿងពួកភិក្ខុនីជិះយាន១ រឿងភិក្ខុនីមានជម្ងឺ ទ្រង់អនុញ្ញាតឲ្យជិះយាន ដែលស្រី ឬបុរសអូសដោយដៃ១ រឿងភិក្ខុនី១រូបមិនសប្បាយដោយទង្គិចនឹងយាន១ រឿងនាងអឌ្ឍកាសីស្រីផ្កាមាស បួសក្នុងសំណាក់ភិក្ខុនី១ រឿងពួកភិក្ខុឲ្យឧបសម្បទា ដល់ភិក្ខុនីដែលល្ងង់ ដោយភិក្ខុទូត ដោយសិក្ខមានាទូត ដោយសាមណេរទូត ដោយសាមណេរីទូត១ រឿងពួកភិក្ខុនីនៅក្នុងព្រៃ១ រឿងឧបាសកម្នាក់ថ្វាយឃ្លាំង (សម្រាប់ដាក់របស់) និងអនុញ្ញាតផ្ទះលំនៅៗតែមិនគ្រប់គ្រាន់ ព្រះអង្គក៏អនុញ្ញាតឲ្យធ្វើនវកម្ម១ រឿងស្រីម្នាក់មានគភ៌មកបួស លុះទារកប្រសូតមក នាងមិនហ៊ាននៅម្នាក់ឯងជាមួយទារក ព្រះអង្គអនុញ្ញាតឲ្យរក្សាទារកនោះ ដូចជាប្រតិបត្តិក្នុងបុរសដទៃ វៀរលែងតែផ្ទះជាមួយគ្នា១ រឿងភិក្ខុនីមួយរូប ត្រូវគរុកាបត្តិ ហើយប្រព្រឹត្តមានត្ត១ រឿងភិក្ខុនីមួយរូប មិនលាសិក្ខា ហើយស្រាប់តែសឹកចេញ និងរឿងព្រះអង្គត្រាស់ថា ភិក្ខុនីដែលចូលទៅកាន់លទ្ធិតិរ្ថិយទាំងសំពត់កាសាវៈ ហើយមកបួសវិញ មិនបាន១ រឿងពួកភិក្ខុនីមានសេចក្តីរង្កៀស មិនត្រេកអរចំពោះការថ្វាយបង្គំ ការកោសក់ ការកាត់ក្រចក ការរក្សាដម្បៅ មួយអន្លើដោយបុរស១ រឿងពួកភិក្ខុនី អង្គុយពែនភ្នែន ត្រេកអរដោយសម្ផស្សនៃកែងជើង និងអនុញ្ញាតឲ្យភិក្ខុនីឈឺអង្គុយពែនមួយចំហៀងបាន១ រឿងភិក្ខុនីបន្ទោបង់នូវវច្ចៈក្នុងបង្គន់១ រឿងពួកភិក្ខុនីដុសខ្លួនដោយលំអិត និងដីដែលគេអប់១ រឿងភិក្ខុនីងូតទឹកក្នុងរោងសម្រាប់រក្សាកាយ១ រឿងភិក្ខុនីងូតទឹកឈរក្នុងទីច្រាស់ខ្សែទឹក ងូតទឹកក្នុងទីមិនមែនជាកំពង់ និងងូតទឹកក្នុងទីជាកំពង់សម្រាប់បុរស១ ព្រះនាងមហាបជាបតីគោតមី ក្រាបបង្គំទូលសូមបព្វជ្ជា ព្រះអានន្ទក៏ជួយសូម ដោយឧបាយ (ដោយប្រការដូច្នេះ)។ ឯពួកស្ត្រីបានបួសក្នុងសាសនានៃព្រះជិនស្រី ក៏រាប់ថាជាបរិសទ្យ៤ពួក (តាំងពីកាលនោះមក)។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់បានសម្តែង (ភិក្ខុនីខន្ធកៈ) ទុកមកដោយប្រការដូច្នេះ ដើម្បីប្រយោជន៍ និងបង្កើតសេចក្តីសង្វេគផង ដើម្បីឲ្យចំរើនព្រះសទ្ធម្មផង ដូចជាថ្នាំ (ដែលពេទ្យផ្សំឡើង) បម្រុងព្យាបាលជម្ងឺ។ សូម្បីមាតុគ្រាម ក្រៅអំពីព្រះនាងមហាបជាបតីគោតមី ព្រះមានព្រះភាគ ក៏បានទូន្មានឲ្យឋិតនៅក្នុងព្រះសទ្ធម្មយ៉ាងនេះឯង ហើយស្ត្រីទាំងនោះ បានដល់នូវឋាន គឺព្រះនិព្វាន ដែលជាឋានពួកជនដល់ហើយ មិនបានសោយសោក។

# បញ្ចសតិកក្ខន្ធកៈ (ទី១១)

CS vin.cv.11 | ភាគ ទី១១

**(១១. បញ្ចសតិកក្ខន្ធកំ)**

## (សង្គីតិនិទាន ទី១)

CS vin.cv.11.01 | ភាគ ទី១១

**(១. សង្គីតិនិទានំ)**

[២៧៨] លំដាប់នោះ ព្រះមហាកស្សបមានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ សម័យមួយ ខ្ញុំគិតថានឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងបាវានេះ រួចហើយនឹងទៅកាន់ក្រុងកុសិនារា ហើយក៏ដើរទៅតាមផ្លូវឆ្ងាយ ជាមួយនឹងភិក្ខុសង្ឃជាច្រើនចំនួន៥០០រូប ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ខ្ញុំគេចចៀសចេញពីផ្លូវ ហើយទៅអង្គុយទៀបគល់ឈើមួយដើម ក៏សម័យនោះឯង មានអាជីវកម្នាក់កាន់ផ្កាមន្ទារវៈ (មន្ទាររបុស្ស) ពីក្នុងនគរកុសិនារា ដើរតាមផ្លូវឆ្ងាយ សំដៅទៅកាន់ក្រុងបាវា ម្នាលអាវុសោទាំងឡាយ ខ្ញុំក៏បានឃើញអាជីវកនោះ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ខ្ញុំនិយាយសួរទៅអាជីវកនោះដូច្នេះថា នែអាវុសោ អ្នកបានដឹងដំណឹងព្រះជាគ្រូនៃយើងដែរឬ អាជីវកនោះឆ្លើយតបថា អើអាវុសោ ខ្ញុំដឹងដែរ ព្រះសមណគោតម ជាគ្រូអ្នក បរិនិព្វានកន្លងទៅ៧ថ្ងៃហើយ រាប់ពីថ្ងៃនេះទៅ ផ្កាមន្ទារវៈនេះ ខ្ញុំយកពីនគរកុសិនារានោះមក ម្នាលអាវុសោទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណា ដែលមិនទាន់ប្រាសចាករាគៈ[26] ភិក្ខុទាំងនោះ ពួកខ្លះ ក៏លើកដៃឡើង ហើយយំកន្ទក់កន្ទេញ[27] ដួលដេកទៅ ហាក់ដូចជាមានជើងដាច់ ហើយបម្រាស់ននៀលទៅមក ពោលពាក្យថា ព្រះមានព្រះភាគឆាប់បរិនិព្វានពេកណាស់ ព្រះសុគតជាម្ចាស់ឆាប់បរិនិព្វានអ្វីម្ល៉េះ ចក្ខុ ពោលគឺព្រះពុទ្ធក្នុងលោក (ពុទ្ធចក្ខុ) ឆាប់បាត់បង់ទៅអ្វីម្ល៉េះ ចំណែកភិក្ខុទាំងឡាយណា ដែលប្រាសចាករាគៈ[28] ហើយ ភិក្ខុទាំងនោះ មានស្មារតីតាំងមាំ មានបញ្ញាដឹងច្បាស់ ក៏អត់សង្កត់បាន ដោយពិចារណាថា សង្ខារទាំងឡាយមិនទៀងទេ ព្រោះហេតុនោះ បុគ្គលគប្បីបាន (នូវសេចក្ដីទៀងទាត់) ក្នុងខន្ធប្រវត្តិនេះអំពីណា ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ខ្ញុំបាននិយាយឃាត់ពួកភិក្ខុនោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយកុំសោយសោកឡើយ កុំខ្សឹកខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ ក្រែងព្រះមានព្រះភាគបានត្រាស់ប្រាប់សេចក្ដីនេះមកពីមុនហើយថា សេចក្ដីព្រាត់ប្រាស ស្លាប់និរាស ចាកចោលសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងអស់ រមែងមាន នែអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាន (នូវសេចក្ដីមិនព្រាត់ប្រាស) ក្នុងខន្ធប្រវត្តិនេះអំពីណា ធម្មជាតណា ដែលកើតឡើងហើយ ដែលមានហើយ ដែលសង្ខារតាក់តែងមកហើយ ជារបស់មានកិរិយាទ្រុឌទ្រោម វិនាសទៅវិញជាធម្មតា ធម្មជាតនោះ បុគ្គលឃាត់ថា កុំវិនាសទៅវិញដូច្នេះ ពុំបានឡើយ ម្នាលអាវុសោទាំងឡាយ សម័យនោះឯង មានភិក្ខុមួយរូបឈ្មោះ សុភទ្ទ បួសឯចាស់ អង្គុយនៅក្នុងចំណោមបរិសទ្យនោះ ម្នាលអាវុសោទាំងឡាយ គ្រានោះ ស្រាប់តែសុភទ្ទភិក្ខុបួសឯចាស់ និយាយទៅនឹងភិក្ខុទាំងឡាយនោះ យ៉ាងនេះថា នែអាវុសោទាំងឡាយ អ្នកទាំងឡាយ កុំសោយសោកឡើយ កុំខ្សឹកខ្សួលអណ្ដឺតអណ្ដកឡើយ យើងទាំងឡាយឈ្មោះថា ផុតស្រឡះហើយ អំពីមហាសមណៈនោះ ព្រោះថា យើងទាំងឡាយ មហាសមណៈនោះតែងបៀតបៀនថា អំពើនេះគួរដល់អ្នកទាំងឡាយ អំពើនេះ មិនគួរដល់អ្នកទាំងឡាយទេ ឥឡូវនេះស្រួលហើយ យើងរាល់គ្នាចង់ធ្វើនូវអំពើណា នឹងធ្វើនូវអំពើនោះក៏បាន មិនចង់ធ្វើនូវអំពើណា នឹងមិនធ្វើនូវអំពើនោះក៏បាន ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនានូវធម៌ និងវិន័យ តំណទៅមុខ អកុសលធម៌ មុខជានឹងរុងរឿងឡើង កុសលធម៌មុខជានឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យ មុខជានឹងរុងរឿងឡើង វិន័យមុខជានឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលជាអធម្មវាទី នឹងមានកំឡាំងឡើង ពួកបុគ្គលជាធម្មវាទី នឹងថយកំឡាំងចុះ ពួកបុគ្គលជាអវិនយវាទី នឹងមានកំឡាំងឡើង ពួកបុគ្គលជាវិនយវាទី នឹងថយកំឡាំងចុះ។

[២៧៩] ភិក្ខុទាំងឡាយពោលថា បពិត្រព្រះថេរៈដ៏ចំរើន បើដូច្នោះ សូមព្រះថេរៈជ្រើរើសនូវភិក្ខុទាំងឡាយចុះ។ ទើបព្រះមហាកស្សមានអាយុជ្រើរើសនូវព្រះអរហន្តទាំងឡាយ បានចំនួន៤៩៩អង្គ។ ភិក្ខុទាំងឡាយ និយាយពាក្យនេះ នឹងព្រះមហាកស្សមានអាយុថា បពិត្រព្រះករុណាដ៏ចំរើន ព្រះអានន្ទមានអាយុនេះ នៅជាសេក្ខបុគ្គលពិតមែន តែលោកមិនអាចនឹងលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទេ ធម៌ក្ដី វិន័យក្ដី ព្រះអានន្ទនេះ បានសិក្សារៀនសូត្រ ក្នុងសំណាក់ព្រះមានព្រះភាគជាច្រើន បពិត្រព្រះករុណាដ៏ចំរើន បើដូច្នោះ សូមព្រះថេរៈជ្រើសរើសយកព្រះអានន្ទមានអាយុផង។ ទើបព្រះមហាកស្សមានអាយុ ជ្រើសរើសយកព្រះអានន្ទមានអាយុបញ្ចូលផង (ជា៥០០អង្គ)។ លំដាប់នោះ ភិក្ខុទាំងឡាយដែលជាថេរៈ មានសេចក្ដីរិះគិតដូច្នេះថា យើងទាំងឡាយគប្បីសង្គាយនាធម៌ និងវិន័យក្នុងទីណាហ្ន៎។ គ្រានោះឯង ភិក្ខុទាំងឡាយ ដែលជាថេរៈមានសេចក្ដីរិះគិតឃើញដូច្នេះថា នគររាជគ្រឹះ ជាស្រុកមានទីគោចរក៏ច្រើន មានសេនាសនៈក៏ច្រើន បើដូច្នោះ គួរតែយើងរាល់គ្នា ទៅនៅចាំវស្សាក្នុងនគររាជគ្រឹះ ទើបអាចនឹងសង្គាយនា នូវធម៌និងវិន័យបាន ឯភិក្ខុទាំងឡាយឯទៀត កុំគប្បីចូលទៅនៅចាំវស្សា ក្នុងនគររាជគ្រឹះឡើយ។ លំដាប់នោះឯង ព្រះមហាកស្សមានអាយុ ប្រកាសសង្ឃឲ្យដឹងថា ម្នាលលោកមានអាយុ សង្ឃចូរស្ដាប់ខ្ញុំ បើសង្ឃីតិកម្ម មានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុទាំង៥០០រូបនេះ ឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីសង្គាយនា នូវធម៌ និងវិន័យ ឯភិក្ខុទាំងឡាយដទៃ មិនត្រូវនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ។ នេះជាញត្តិ។ ម្នាលលោកមានអាយុ សង្ឃចូរស្ដាប់ខ្ញុំ ឥឡូវសង្ឃសន្មតភិក្ខុទាំង៥០០រូបនេះ ឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីសង្គាយនា នូវធម៌ និងវិន័យ ឯភិក្ខុទាំងឡាយដទៃ មិនត្រូវនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ។ ការសន្មតិភិក្ខុទាំង៥០០រូបនេះ ឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីនឹងសង្គាយនា នូវធម៌ និងវិន័យ ឯភិក្ខុទាំងឡាយដទៃ មិនត្រូវឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះទេ គាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃបានសន្មតពួកភិក្ខុទាំង៥០០រូបនេះ ឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីសង្គាយនា នូវធម៌ និងវិន័យ ឯភិក្ខុទាំងឡាយដទៃ មិនត្រូវនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ។ ការសន្មតិនេះ គាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវសេចក្ដីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៨០] គ្រានោះ ភិក្ខុជាថេរៈទាំងឡាយ បានទៅកាន់នគររាជគ្រឹះ ដើម្បីសង្គាយនានូវធម៌ និងវិន័យ។ ទើបភិក្ខុទាំងឡាយជាថេរៈ មានសេចក្ដីរិះគិតដូច្នេះថា ម្នាលអាវុសោ បដិសង្ខរណកម្ម គឺការជួសជុលសេនាសនៈ ដែលដាច់ដាច ធ្លុះធ្លាយ ព្រះមានព្រះភាគ ទ្រង់សរសើរហើយ ម្នាលអាវុសោ បើដូច្នោះ គួរតែយើងរាល់គ្នា ជួសជុលសេនសាសនៈ ដែលដាច់ដាច ធ្លុះធ្លាយអស់ខែមួយជាដម្បូងសិន ដល់មកខែជាកណ្ដាល យើងនឹងប្រជុំគ្នាសង្គាយនា នូវធម៌ និងវិន័យ។ លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយ ក៏នាំគ្នាជួសជុលសេនាសនៈ ដែលដាច់ដាច ធ្លុះធ្លាយ អស់ខែមួយជាដម្បូង។

[២៨១] គ្រានោះ ព្រះអានន្ទមានអាយុត្រិះរិះថា ថ្ងៃស្អែកនេះ នឹងប្រជុំសង្ឃ កិច្ចនោះ មិនសមគួរដល់អាត្មាអញឡើយ ព្រោះថាអាត្មាអញនៅជាសេក្ខបុគ្គលនៅឡើយ ហើយទៅកាន់ប្រជុំសង្ឃ គិតដូច្នេះហើយ ក៏ចំរើនកាយគតាសតិកម្មដ្ឋាន អស់រាត្រីជ្រៅ លុះដល់បច្ចូសសម័យនៃរាត្រី (ជិតភ្លឺ) នោះហើយ ក៏ទំរេតកាយដោយគិតថានឹងសឹង។ ព្រះសិរពុំទាន់ដល់ខ្នើយ។ ព្រះបាទាទើបតែនឹងផុតអំពីផែនដី។ ព្រះទ័យ (របស់លោក) ក៏រួច

ស្រឡះចាកអាសវៈទាំងឡាយ ដោយមិនមានឧបាទាន ក្នុងចន្លោះនោះឯង។ ព្រះអានន្ទមានអាយុ បានជាព្រះអរហន្តហើយ ទើបបាននិមន្តទៅកាន់ប្រជុំសង្ឃ។

[២៨២] គ្រានោះឯង ព្រះមហាកស្សបមានអាយុ បានប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្ឃ័តិកម្មនេះ មានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យនឹងព្រះឧបាលិ។ ព្រះឧបាលិមានអាយុ បានប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃ័តិកម្មនេះ មានកាលគួរ ដល់សង្ឃហើយ ព្រះមហាកស្សបមានអាយុ ត្រូវសួរព្រះវិន័យចំពោះខ្ញុំ ៗត្រូវដោះស្រាយ (ក្នុងកាលឥឡូវនេះ)។ ទើបព្រះមហាកស្សបមានអាយុ បានចោទសួរដូច្នេះ ចំពោះព្រះឧបាលិមានអាយុថា ម្នាលឧបាលិមានអាយុ បឋមបារាជិកសិក្ខាបទ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តក្នុងទីណា។ ព្រះឧបាលិឆ្លើយថា ក្នុងនគរវេសាលី លោកម្ចាស់។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី។ ព្រោះវត្ថុអ្វី។ ព្រោះសេពមេថុនធម្ម។ លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃបឋមបារាជិកសិក្ខាបទ ចំពោះព្រះឧបាលិមានអាយុ ហើយសួរតទៅថា ម្នាលអាវុសោឧបាលិ ទុតិយបារាជិកសិក្ខាបទ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តក្នុងទីណា។ ក្នុងនគររាជគ្រឹះ លោកម្ចាស់។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងធនិយភិក្ខុ ជាកូននៃនាយស្ទូនឆ្នាំង។ ព្រោះវត្ថុអ្វី។ ព្រោះអទិន្នាទាន។ លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃទុតិយបារាជិកសិក្ខាបទ ចំពោះព្រះឧបាលិមានអាយុ ហើយសួរតទៅទៀតថា ម្នាលអាវុសោឧបាលិ តតិយបារាជិកសិក្ខាបទ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តក្នុងទីណា។ ក្នុងនគរវេសាលី លោកម្ចាស់។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកភិក្ខុច្រើនរូប។ ព្រោះវត្ថុអ្វី។ ព្រោះមនុស្សវិគ្គហៈ គឺធ្វើរាងកាយ នៃមនុស្សឲ្យធ្លាក់ចុះចាកជីវិត។ លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃតតិយបារាជិកសិក្ខាបទ ចំពោះព្រះឧបាលិមានអាយុ ហើយសួរតទៅទៀតថា ម្នាលអាវុសោឧបាលិ ចតុត្ថបារាជិកសិក្ខាបទ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តក្នុងទីណា។ ក្នុងនគរវេសាលី លោកម្ចាស់។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ នៅនាឆ្នេរស្ទឹងវគ្គុមុទា។ ព្រោះវត្ថុអ្វី។ ព្រោះឧត្តរិមនុស្សធម្ម។ លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃចតុត្ថបារាជិកសិក្ខាបទ ចំពោះព្រះឧបាលិមានអាយុ ហើយសួរវិន័យទាំងពីរចំណែក គឺភិក្ខុវិន័យ និងភិក្ខុនីវិន័យ ដោយឧបាយនេះឯង។ ព្រះឧបាលិមានអាយុ កាលបើព្រះមហាកស្សប សួរសព្វគ្រប់ហើយ ក៏បានដោះស្រាយសព្វគ្រប់។

[២៨៣] ឮដ៏កាលនោះ ព្រះមហាកស្សបមានអាយុ បានប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្ឃ័តិកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវធម៌ចំពោះព្រះអានន្ទ។ ព្រះអានន្ទមានអាយុ បានប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃ័តិកម្មមានកាលគួរ ដល់សង្ឃហើយ ព្រះមហាកស្សបមានអាយុ នឹងសួរធម៌ចំពោះខ្ញុំ ៗគប្បីដោះស្រាយ ក្នុងកាលឥឡូវនេះ។ ទើបព្រះមហាកស្សបមានអាយុ បានសួរព្រះអានន្ទមានអាយុដូច្នេះថា ម្នាលអានន្ទមានអាយុ ព្រហ្មជាលសូត្រ ព្រះមានព្រះភាគ ទ្រង់សំដែងក្នុងទីណា។ ព្រះអានន្ទឆ្លើយថា បពិត្រព្រះថេរៈដ៏ចំរើន ទ្រង់សំដែងក្នុងព្រះដំណាក់នៃព្រះរាជា នៅនាអម្ពលដ្ឋិកាវ័ន ជាចន្លោះនៃក្រុងរាជគ្រឹះផង ជាចន្លោះនៃនាឡន្ទគ្រាមផង។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព។ គ្រានោះ ព្រះមហាកស្សបមានអាយុ សួរនិទានផង សួរបុគ្គលផង នៃព្រហ្មជាលសូត្រ ចំពោះព្រះអានន្ទមានអាយុ ហើយសួរតទៅទៀតថា ម្នាលអាវុសោអានន្ទ សាមញ្ញផលសូត្រ ព្រះមានព្រះភាគ ទ្រង់សំដែងក្នុងទីណា។ ក្នុងជីវកម្ពវ័ន ក្បែរក្រុងរាជគ្រឹះ លោកម្ចាស់។ ទ្រង់សំដែងជាមួយនឹងបុគ្គលណា។ ទ្រង់សំដែងជាមួយនឹងព្រះបាទអជាតសត្តុរាជ វេទេហិបុត្ត។ គ្រានោះ ព្រះមហាកស្សបមានអាយុ សួរនិទានផង សួរបុគ្គលផង នៃសាមញ្ញសូត្រ ចំពោះព្រះអានន្ទមានអាយុ ហើយសួរនូវនិកាយទាំង៥ ដោយឧបាយនេះឯង។ ឯព្រះអានន្ទមានអាយុ កាលបើព្រះមហាកស្សប សួរសព្វគ្រប់ហើយ ក៏បានដោះស្រាយដោយសព្វគ្រប់។

# (ខុទ្ទានុខុទ្ទកសិក្ខាបទកថា ទី២)

CS vin.cv.11.02 | ភាគ ទី១១

### (២. ខុទ្ទានុខុទ្ទកសិក្ខាបទកថា)

[២៨៤] លំដាប់នោះឯង ព្រះអានន្ទមានអាយុ ពោលដូច្នេះនឹងភិក្ខុជាថេរៈទាំងឡាយថា បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន ព្រះមានព្រះភាគ កាលដែលទៀបនឹងបរិនិព្វាន បានមានព្រះបន្ទូលយ៉ាងនេះនឹងខ្ញុំព្រះករុណាថា នែអានន្ទ លុះអំណឹះតតអំពីតថាគតទៅហើយ បើសង្ឃមានប្រាថ្នានឹងដក ក៏គប្បីដកនូវសិក្ខាបទទាំងឡាយតូចៗ ដោយលំដាប់(ចេញខ្លះក៏បាន)។ ព្រះថេរៈទាំងឡាយ សួរព្រះអានន្ទថា ម្នាលអានន្ទមានអាយុ ចុះលោកម្ចាស់ បានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឯសិក្ខាបទទាំងឡាយតូចៗដោយលំដាប់នោះ តើសិក្ខាបទណាខ្លះ ដូច្នេះដែរឬ។ ព្រះអានន្ទឆ្លើយថា បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណា មិនបានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឯសិក្ខាបទទាំងឡាយតូចៗដោយលំដាប់នោះ តើសិក្ខាបទណាខ្លះ ដូច្នេះទេ។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិកទាំង៤ ឈ្មោះថា តូចៗ ដោយលំដាប់។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិក៤ និងសង្ឃាទិសេសេស១៣ ឈ្មោះថា តូចៗ ដោយលំដាប់។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយ ដែលសល់នៅក្រៅអំពីបារាជិក៤ សង្ឃាទិសេសេស១៣ និងអនិយត២ ឈ្មោះថា តូចៗ ដោយលំដាប់។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយ ដែលសល់នៅក្រៅអំពីបារាជិក៤ សង្ឃាទិសេសេស១៣ អនិយត២ និងនិស្សគ្គិយបាចិត្តិយៈ៣០ ឈ្មោះថា តូចៗ ដោយលំដាប់។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយ ដែលសល់នៅក្រៅអំពីបារាជិក៤ សង្ឃាទិសេសេស១៣ អនិយត២ និស្សគ្គិយបាចិត្តិយៈ៣០ និងសុទ្ធិកបាចិត្តិយៈ៩២ ឈ្មោះថា តូចៗ ដោយលំដាប់។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយ ដែលសល់នៅក្រៅអំពីបារាជិក៤ សង្ឃាទិសេសេស១៣ អនិយត២ និស្សគ្គិយបាចិត្តិយៈ៣០ សុទ្ធិកបាចិត្តិយៈ៩២ និងបាដិទេសនីយៈ៤ ឈ្មោះថា តូចៗ ដោយលំដាប់។

[២៨៥] គ្រានោះឯង ព្រះមហាកស្សបមានអាយុ ក៏ប្រកាសសង្ឃថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើង ក៏មានតាំងនៅក្នុងពួកគ្រហស្ថ សូម្បីពួកគ្រហស្ថទាំងឡាយ ក៏តែងដឹងថា អំពើនេះ គួរដល់លោកទាំងឡាយជាសមណសក្យបុត្តិយ៍ អំពើនេះ មិនគួរដល់លោកទាំងឡាយទេ។ បើយើងទាំងឡាយ នឹងដកនូវសិក្ខាបទតូចៗ ដោយលំដាប់ចេញហើយ មុខជាជនទាំងឡាយ ជាអ្នកពោលតិះដៀល នឹងពោលថា សិក្ខាបទដែលព្រះសមណគោតម បញ្ញត្តហើយ ដល់សាវ័កទាំងឡាយ បានតែត្រឹមធូមកាលិក គឺកាលនៃផ្សែងភ្លើង គឺបរិនិព្វានប៉ុណ្ណោះ ព្រះសាស្តារបស់សាវ័កទាំងឡាយនេះ ឋិតនៅត្រឹមណា សាវ័កទាំងនេះ នាំគ្នាសិក្សាក្នុងសិក្ខាបទត្រឹមនោះ កាលណាបើព្រះសាស្តារបស់សាវ័កទាំងនេះបរិនិព្វានហើយ ឥឡូវនេះ សាវ័កទាំងនេះ ក៏លែងសិក្សាក្នុងសិក្ខាបទទាំងឡាយដែរ។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃកុំគប្បីបញ្ញត្តថែមនូវសិក្ខាបទ ដែលព្រះជាគ្រូមិនបានបញ្ញត្តទេ កុំគប្បីដកចេញនូវសិក្ខាបទ ដែលព្រះជាគ្រូបញ្ញត្តមកហើយ ត្រូវសមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលព្រះជាគ្រូ ទ្រង់បញ្ញត្តហើយ។ នេះជាញត្តិ។ ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើង ក៏មានតាំងនៅក្នុងពួកគ្រហស្ថ សូម្បីពួកគ្រហស្ថទាំងឡាយ តែងដឹងថា អំពើនេះ គួរដល់លោកទាំងឡាយជាសមណសក្យបុត្តិយ៍ អំពើនេះ មិនគួរដល់លោកទាំងឡាយទេ។ បើយើងទាំងឡាយ នឹងដកនូវសិក្ខាបទតូចៗ ដោយលំដាប់ចេញហើយ មុខជាជនទាំងឡាយ ជាអ្នកពោលតិះដៀល នឹងពោលថា សិក្ខាបទដែលព្រះសមណគោតម បានបញ្ញត្តហើយ ដល់ពួកសាវ័ក បានតែត្រឹមធូមកាលិក គឺកាលនៃផ្សែងភ្លើងប៉ុណ្ណោះ ព្រះសាស្តារបស់សាវ័កទាំងនេះ ឋិតនៅត្រឹមណា សាវ័កទាំងនេះ ក៏នាំគ្នាសិក្សាក្នុងសិក្ខាបទត្រឹមនោះ កាលបើព្រះសាស្តារបស់សាវ័កទាំងនេះ បរិនិព្វានទៅហើយ ឥឡូវនេះ សាវ័កទាំងនេះ ក៏លែងសិក្សាក្នុងសិក្ខាបទទាំងឡាយដែរ។ សង្ឃមិនបញ្ញត្តថែមនូវសិក្ខាបទ ដែលព្រះជាគ្រូមិនបានបញ្ញត្តទេ មិនដកចេញនូវសិក្ខាបទ ដែលព្រះជាគ្រូបញ្ញត្តហើយ ត្រូវសមាទាន ប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលគួរដល់ពុទ្ធបញ្ញត្ត។ ការមិនបញ្ញត្តថែមនូវសិក្ខាបទ ដែលព្រះអង្គមិនបានបញ្ញត្ត ការមិនដកចេញនូវសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្ត ការសមាទាន ប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលគួរដល់ពុទ្ធបញ្ញត្ត គាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃមិនបានបញ្ញត្តថែមនូវសិក្ខាបទ ដែលព្រះអង្គមិនបានបញ្ញត្ត មិនដកចេញនូវសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្ត សមាទាន ប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលគួរដល់ពុទ្ធប្បញ្ញត្តិ។ ការមិនបញ្ញត្ត និងការមិនដកចេញនូវសិក្ខាបទនេះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[២៨៦] លំដាប់នោះឯង ភិក្ខុជាថេរៈទាំងឡាយ ពោលដូច្នេះនឹងព្រះអានន្ទមានអាយុថា នែអាវុសោ អានន្ទ នេះជាអំពើអាក្រក់របស់លោក ព្រោះលោកមិនបានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឯសិក្ខាបទទាំងឡាយដែលតូចៗដោយលំដាប់ គឺសិក្ខាបទណាខ្លះ ចូរលោកសំដែងនូវអំពើអាក្រក់នោះចេញ។ ព្រះអានន្ទឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាភ្លេច បានជាមិនបានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឯសិក្ខាបទទាំងឡាយតូចៗដោយលំដាប់ គឺសិក្ខាបទណាខ្លះ ខ្ញុំព្រះករុណាមិនឃើញនូវអំពើអាក្រក់នោះទេ ប៉ុន្តែខ្ញុំព្រះករុណា សំដែងនូវអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ។ នែអាវុសោអានន្ទ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះលោកជាន់ដេរសំពត់វស្សិកសាដក របស់ព្រះមានព្រះភាគ ចូរលោកសំដែងអំពើអាក្រក់នោះចេញ។ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាដែលជាន់ដេរសំពត់វស្សិកសាដក របស់ព្រះមានព្រះភាគ មិនមែនធ្វើដោយសេចក្តីមិនគោរពទេ ខ្ញុំព្រះករុណាមិនឃើញនូវអំពើអាក្រក់នោះឡើយ ប៉ុន្តែខ្ញុំព្រះករុណា សំដែងនូវអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ។ ម្នាលអានន្ទមានអាយុ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះលោកឲ្យមាតុគ្រាមថ្វាយបង្គំព្រះសរីរៈ នៃព្រះមានព្រះភាគមុនគេ កាលដែលមាតុគ្រាមទាំងនោះ យំទួញសោក ធ្វើសរីរៈនៃព្រះមានព្រះភាគឲ្យប្រឡាក់ដោយទឹកភ្នែក ចូរលោកសំដែងនូវអំពើអាក្រក់នោះចេញ។ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាគិតថា កុំឲ្យពួកមាតុគ្រាមនេះនៅក្នុងវេលាវិកាល បានជាខ្ញុំព្រះករុណាឲ្យពួកមាតុគ្រាម ថ្វាយបង្គំព្រះសរីរៈនៃព្រះមានព្រះភាគមុនគេ ខ្ញុំព្រះករុណាមិនឃើញអំពើអាក្រក់នោះទេ ប៉ុន្តែខ្ញុំព្រះករុណា សំដែងអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ។ ម្នាលអានន្ទមានអាយុ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះព្រះមានព្រះភាគ កំពុងធ្វើនិមិត្តជាឱឡារិក (បញ្ចិតបញ្ចៀង) និងធ្វើនូវឱកាស (បំភ្លឺហេតុ) ជាឱឡារិក លោកមិនបានអារាធនាព្រះមានព្រះភាគថា សូមព្រះមានព្រះភាគ គង់នៅអស់មួយកប្ប (កំណត់អាយុ)ទៅ សូមព្រះសុគត គង់នៅអស់មួយកប្បទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ចូរលោកសំដែងនូវអំពើអាក្រក់នោះចេញ។ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណា មានមារគ្របដណ្តប់ចិត្ត បានជាមិនអារាធនា និមន្តព្រះមានព្រះភាគថា សូមព្រះមានព្រះភាគ គង់នៅអស់មួយអាយុកប្បទៅ សូមព្រះសុគត គង់នៅអស់មួយអាយុកប្បទៅ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ខ្ញុំព្រះករុណាមិនឃើញនូវអំពើអាក្រក់នោះទេ ប៉ុន្តែខ្ញុំព្រះករុណា សំដែងនូវអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ។ ម្នាលអានន្ទមានអាយុ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះលោកធ្វើសេចក្តីខ្វល់ខ្វាយឲ្យមាតុគ្រាមបានបព្វជ្ជាក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ប្រកាសហើយ ចូរលោកសំដែងនូវអំពើអាក្រក់នោះចេញ។ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាគិតថា ព្រះនាងមហាបជាបតីគោតមីនេះ ជាព្រះមាតុច្ឆា (ម្តាយមីង) នៃព្រះមានព្រះភាគ បានបីបាច់រក្សា ចិញ្ចឹមថ្វាយទឹកខ្សីរ កាលដែល (ព្រះនាងមាយាទេវី) ជាព្រះមាតាបង្កើត របស់ព្រះមានព្រះភាគ ធ្វើមរណកាលទៅហើយ បានបំបៅព្រះមានព្រះភាគផង បានជាខ្ញុំធ្វើនូវសេចក្តីខ្វល់ខ្វាយ ឲ្យមាតុគ្រាមបានបព្វជ្ជា ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ប្រកាសហើយ ខ្ញុំព្រះករុណា មិនឃើញនូវអំពើអាក្រក់នោះទេ ប៉ុន្តែខ្ញុំព្រះករុណា សំដែងនូវអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ។

[២៨៧] សម័យនោះឯង ព្រះថេរៈឈ្មោះបុរាណៈមានអាយុ បានត្រាច់ទៅកាន់ចារិក ក្នុងទក្ខិណាគិរិជនបទ ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន៥០០រូប។ គ្រានោះឯង ព្រះបុរាណៈមានអាយុ កាលដែលភិក្ខុជាថេរៈទាំងឡាយ សង្គាយនានូវធម្មវិន័យ បាននៅអាស្រ័យក្នុងទក្ខិណាគិរិជនបទ តាមសមគួរដល់អធ្យាស្រ័យ ហើយក៏ចូលទៅរកពួកភិក្ខុជាថេរៈ ដែលនៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ រាក់ទាក់ជាមួយភិក្ខុជាថេរៈទាំងឡាយ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះព្រះបុរាណៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបភិក្ខុជាថេរៈទាំងឡាយ និយាយយ៉ាងនេះថា ម្នាលបុរាណៈដ៏មានអាយុ ធម៌ក្តី វិន័យក្តី ដែលព្រះថេរៈទាំងឡាយបានសង្គាយនាជាស្រេចហើយ លោកចូរប្រកបនូវការសង្គាយនានោះចុះ។ ព្រះបុរាណៈឆ្លើយថា ម្នាលអាវុសោទាំងឡាយ ធម៌ក្តី វិន័យក្តី ដែលភិក្ខុជាថេរៈទាំងឡាយ បានសង្គាយនាហើយ (ក៏ជាការស្រួល) ប៉ុន្តែចំណែកខាងខ្ញុំ លុះតែបានស្តាប់ បានទទួលក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ យ៉ាងណាមិញ ខ្ញុំនឹងទ្រទ្រង់ (ប្រតិបត្តិ) យ៉ាងនោះឯង។

# (ព្រហ្មទណ្ឌកថា ទី៣)

CS vin.cv.11.03 | ភាគ ទី១១

### (៣. ព្រហ្មទណ្ឌកថា)

[២៨៨] លំដាប់នោះ ព្រះអានន្ទមានអាយុ ពោលពាក្យដូច្នេះ នឹងភិក្ខុជាថេរៈទាំងឡាយថា បពិត្រលោកដ៏ចំរើន ព្រះមានព្រះភាគជាម្ចាស់ កាលទៀបបរិនិព្វាន ទ្រង់មានបន្ទូលយ៉ាងនេះ នឹងខ្ញុំព្រះករុណាថា ម្នាលអានន្ទ ណ្ហើយចុះ អំណឹះតតអំពីតថាគតទៅហើយ សង្ឃចូរដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុផង។ ពួកភិក្ខុជាថេរៈសួរថា ម្នាលអានន្ទមានអាយុ ចុះលោកម្ចាស់ បានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ចុះព្រហ្មទណ្ឌនោះ តើដូចម្តេចទៅ ដែរឬ។ ព្រះអានន្ទឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាបានទូលសួរព្រះមានព្រះភាគដែរថា បពិត្រព្រះអង្គដ៏ចំរើន ព្រហ្មទណ្ឌនោះ តើដូចម្តេចទៅ។ ព្រះអង្គមានបន្ទូលថា ម្នាលអានន្ទ ឆន្នភិក្ខុ ចង់ពោលពាក្យណា គប្បីពោលពាក្យនោះចុះ (ប៉ុន្តែ) ភិក្ខុទាំងឡាយ កុំគប្បីនិយាយរក កុំគប្បីទូន្មាន កុំគប្បីប្រៀនប្រដៅឆន្នភិក្ខុឡើយ។ ពួកភិក្ខុជាថេរៈពោលថា ម្នាលអានន្ទដ៏មានអាយុ បើដូច្នោះ ចូរអ្នកដាក់ព្រហ្មទណ្ឌ ដល់ឆន្នភិក្ខុផងចុះ។ ព្រះអានន្ទសួរថា បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាដាក់ព្រហ្មទណ្ឌ ដល់ឆន្នភិក្ខុដូចម្តេចបាន (ដ្បិត) ភិក្ខុនោះកាច រឹងរូសណាស់។ ពួកភិក្ខុជាថេរៈ ពោលថា ម្នាលអានន្ទមានអាយុ បើដូច្នោះ ចូរអ្នកទៅជាមួយនឹងពួកភិក្ខុច្រើនរូបទៅចុះ។ ឯព្រះអានន្ទមានអាយុ ទទួលពាក្យភិក្ខុជាថេរៈទាំងឡាយដោយពាក្យថា អើលោកម្ចាស់ ហើយក៏ជិះទូកទៅកាន់ក្រុងកោសម្ពី ជាមួយនឹងភិក្ខុសង្ឃជាច្រើនចំនួន៥០០រូប ទូកក៏លឿនទៅ ច្រាស់ខ្សែទឹក លុះចុះចាកទូកហើយ ក៏ទៅគង់ក្រោមម្លប់ឈើមួយដើម មិនឆ្ងាយពីឧទ្យាននៃព្រះរាជា ទ្រង់ព្រះនាមឧទេន។

[២៨៩] សម័យនោះឯង ព្រះរាជាទ្រង់ព្រះនាមឧទេន ទ្រង់គង់ក្រសាលក្នុងឧទ្យាន ជាមួយនឹងពួកព្រះមហេសី ព្រមទាំងពួករាជបរិវារ។ ពួកព្រះមហេសី របស់ព្រះរាជាទ្រង់ព្រះនាមឧទេន បានឮដំណឹងថា លោកម្ចាស់អានន្ទ ជាអាចារ្យរបស់យើងទាំងឡាយ គង់ក្រោមម្លប់ឈើមួយដើម មិនឆ្ងាយអំពីឧទ្យាន។ ទើបពួកព្រះមហេសីរបស់ព្រះបាទឧទេន បានក្រាបបង្គំទូលព្រះបាទឧទេនដូច្នេះថា បពិត្រព្រះសម្មតិទេព ឮថាលោកម្ចាស់អានន្ទ ជាអាចារ្យរបស់យើងទាំងឡាយ មកគង់នៅក្រោមម្លប់ឈើមួយដើម មិនឆ្ងាយអំពីឧទ្យាន បពិត្រព្រះសម្មតិទេព យើងខ្ញុំទាំងឡាយ ចង់ឃើញព្រះអានន្ទជាម្ចាស់។ ព្រះរាជាមានព្រះរាជឱង្ការថា បើដូច្នោះ ចូរអ្នកទាំងឡាយទៅមើលសមណៈឈ្មោះអានន្ទចុះ។ គ្រានោះឯង ពួកព្រះមហេសីរបស់ព្រះបាទឧទេន ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ។ កាលបើពួកព្រះមហេសីនៃព្រះបាទឧទេនអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះអានន្ទដ៏មានអាយុ ឲ្យឃើញច្បាស់ ឲ្យប្រព្រឹត្តតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា។ គ្រានោះឯង ពួកព្រះមហេសីនៃព្រះបាទឧទេន កាលបើព្រះអានន្ទដ៏មានអាយុ ឲ្យឃើញច្បាស់ ឲ្យប្រព្រឹត្តតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ប្រគេនសំពត់ឧត្តរាសង្គៈ៥០០ ដល់ព្រះអានន្ទមានអាយុ។ លំដាប់នោះឯង ពួកព្រះមហេសីនៃព្រះបាទឧទេន ត្រេកអររីករាយនឹងភាសិតរបស់ព្រះអានន្ទដ៏មានអាយុហើយ ទើបក្រោកចាកអាសនៈ ថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ធ្វើប្រទក្សិណ ហើយចូលទៅគាល់ព្រះបាទឧទេន។

[២៩០] ព្រះបាទឧទេន ទ្រង់ទតឃើញពួកព្រះមហេសីមកអំពីចម្ងាយ លុះឃើញហើយ មានព្រះបន្ទូល សួរពួកព្រះមហេសីដូច្នេះថា អ្នកទាំងឡាយបានឃើញសមណៈឈ្មោះអានន្ទដែរឬ។ ពួកព្រះមហេសីក្រាបទូលថា បពិត្រព្រះសម្មតិទេព យើងខ្ញុំទាំងឡាយ បានឃើញព្រះអានន្ទជាម្ចាស់ហើយ។ ចុះអ្នកទាំងឡាយបានប្រគេនវត្ថុអ្វីបន្តិចបន្តួច ដល់សមណៈឈ្មោះអានន្ទខ្លះដែរឬ។ បពិត្រព្រះសម្មតិទេព យើងខ្ញុំទាំងឡាយ បានប្រគេនសំពត់ឧត្តរាសង្គៈ ៥០០ ដល់ព្រះអានន្ទជាម្ចាស់ហើយ។ ព្រះបាទឧទេន ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើសមណៈឈ្មោះអានន្ទ ទទួលយកចីវរច្រើនដល់ម្ល៉េះទេ សមណៈឈ្មោះអានន្ទ នឹងធ្វើជំនួញសំពត់ឬ ៗនឹងតាំងរោងលក់សំពត់។ គ្រានោះឯង ព្រះបាទឧទេន ស្តេចទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ សំណេះសំណាលនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលរីករាយ និងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏គង់ក្នុងទីសមគួរ។ លុះព្រះបាទឧទេន គង់ក្នុងទីដ៏សមគួរហើយ ក៏មានព្រះបន្ទូលនឹងព្រះអានន្ទមានអាយុ យ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចំរើន ពួកព្រះមហេសីរបស់យើង បានមក (ក្នុងទីនេះ)ដែរឬ។ ព្រះអានន្ទតបថា បពិត្រមហារាជ ពួកព្រះមហេសីនៃព្រះអង្គ បានមក (ក្នុងទីនេះដែរ)។ ចុះ (ពួកព្រះមហេសីនោះ) បានប្រគេនវត្ថុអ្វីបន្តិចបន្តួច ដល់ព្រះអានន្ទដ៏ចំរើនខ្លះដែរឬ។ បពិត្រមហារាជ ពួកព្រះមហេសីនោះ បានប្រគេនសំពត់ឧត្តរាសង្គៈ៥០០ ដល់អាត្មាភាព។ ព្រះអានន្ទដ៏ចំរើននឹងយកចីវរច្រើនដល់ម្ល៉េះទៅធ្វើជាអ្វីទៅ។ បពិត្រមហារាជ ភិក្ខុទាំងឡាយណា មានចីវរទុព្វលភាព អាត្មាភាពនឹងចែកឲ្យ ដល់ភិក្ខុទាំងឡាយនោះ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះចីវរទាំងឡាយណា ដែលចាស់ទុព្វលភាព លោកម្ចាស់នឹងយកចីវរទាំងនោះទៅធ្វើអ្វី។ បពិត្រមហារាជ យើងទាំងឡាយនឹងយកចីវរទាំងនោះ ទៅធ្វើជាកម្រាលគ្រែ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកម្រាលគ្រែណា ដែលជារបស់ចាស់ លោកម្ចាស់នឹងយកកម្រាលគ្រែទាំងនោះទៅធ្វើជាអ្វី។ បពិត្រមហារាជ យើងទាំងឡាយ នឹងយកកម្រាលគ្រែទាំងនោះ ទៅធ្វើជាស្រោមពូក។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះស្រោមពូកណា ដែលជារបស់ចាស់ លោកម្ចាស់នឹងយកស្រោមពូកទាំងនោះទៅធ្វើជាអ្វី។ បពិត្រមហារាជ យើងទាំងឡាយ នឹងយកស្រោមពូកទាំងនោះ ទៅធ្វើជាកម្រាលផែនដី។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកម្រាលផែនដីណា ដែលជារបស់ចាស់ លោកម្ចាស់នឹងយកកម្រាលផែនដីទាំងនោះទៅធ្វើជាអ្វី។ បពិត្រមហារាជ យើងទាំងឡាយ នឹងយកកម្រាលផែនដីទាំងនោះ ទៅធ្វើជាសំពត់ជូតជើង។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះសំពត់សម្រាប់ជូតជើងណា ដែលជារបស់ចាស់ លោកម្ចាស់នឹងយកសំពត់ជូតជើងទាំងនោះទៅធ្វើជាអ្វី។ បពិត្រមហារាជ យើងទាំងឡាយ នឹងយកសំពត់សម្រាប់ជូតជើងទាំងនោះ ទៅធ្វើជាសំពត់សម្រាប់ជូតធូលី។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះសំពត់សម្រាប់ជូតធូលីណា ដែលជារបស់ចាស់ លោកម្ចាស់នឹងយកសំពត់សម្រាប់ជូតធូលីទាំងនោះទៅធ្វើជាអ្វី។ បពិត្រមហារាជ យើងទាំងឡាយ នឹងចិញ្ច្រាំនូវសំពត់សម្រាប់ជូតធូលីទាំងនោះ ហើយច្របាច់លាយដោយភក់ ហើយយកទៅបូកលាបជញ្ជាំង។ គ្រានោះឯង ព្រះបាទឧទេន ទ្រង់សព្វព្រះរាជហឫទ័យថា សមណសក្យបុត្តិយ៍ទាំងអស់នេះ ប្រកបដោយឧបាយនៃប្រាជ្ញា មិនធ្វើសំពត់ ឲ្យដល់នូវសេចក្តីវិនាសឥតប្រយោជន៍ ហើយក៏ទ្រង់ប្រគេនសំពត់ចំនួន៥០០ដទៃទៀត ដល់ព្រះអានន្ទមានអាយុ។ បរិក្ខារ គឺចីវរចំនួន១ពាន់នោះឯង ទើបតែនឹងកើតឡើងជាដំបូង ដល់ព្រះអានន្ទមានអាយុ។

[២៩១] លំដាប់នោះឯង ព្រះអានន្ទមានអាយុ ក៏ចូលទៅកាន់ឃោសិតារាម លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលទុក។ គ្រានោះឯង ឆន្នភិក្ខុដ៏មានអាយុ ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយអង្គុយក្នុងទីសមគួរ។ លុះព្រះឆន្នមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះអានន្ទមានអាយុ ក៏និយាយយ៉ាងនេះថា នែអាវុសោ ឆន្នៈ សង្ឃដាក់ព្រហ្មទណ្ឌដល់លោកហើយ។ ឆន្នភិក្ខុសួរថា បពិត្រព្រះអានន្ទដ៏ចំរើន ព្រហ្មទណ្ឌនោះ តើដូចម្តេចទៅ។ ព្រះអានន្ទប្រាប់ថា ម្នាលឆន្នភិក្ខុមានអាយុ លោកចង់ពោលពាក្យណា គប្បីពោលពាក្យនោះចុះ ភិក្ខុទាំងឡាយ មិនត្រូវនិយាយរក មិនត្រូវទូន្មាន មិនត្រូវប្រៀនប្រដៅលោកឡើយ។ ឆន្នភិក្ខុពោលថា បពិត្រព្រះអានន្ទដ៏ចំរើន កាលណាបើភិក្ខុទាំងឡាយ មិនត្រូវនិយាយរក មិនត្រូវទូន្មាន មិនត្រូវប្រៀនប្រដៅខ្ញុំដោយហេតុប៉ុណ្ណេះ បើដូច្នោះ ភិក្ខុទាំងឡាយ មិនសម្លាប់ខ្ញុំហើយឬ ហើយក៏ដួលជ្រប់ក្នុងទីនោះ។ គ្រានោះឯង ឆន្នៈមានអាយុ ក៏លំបាក អៀនខ្មាស ខ្ពើមព្រហ្មទណ្ឌ ក៏ចៀសចេញទៅតែម្នាក់ឯង ហើយមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្តទាំងឡាយ ដែលចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា ក៏បានដល់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយការធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ន ដោយមិនយូរ ហើយសម្រេចសម្រាន្តដោយឥរិយាបថទាំង៤ ហើយដឹងច្បាស់ថា ជាតិ គឺសេចក្តីកើតទៀត (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈសម្រេចហើយ កិច្ចត្រូវធ្វើ គឺសោឡសកិច្ច ក៏សម្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត គ្មានឡើយ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះឆន្នៈមានអាយុ ក៏ជាអរហន្តមួយអង្គដែរ។ លំដាប់នោះ ព្រះឆន្នមានអាយុ បានដល់អរហត្តហើយ ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ពោលពាក្យនេះនឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចំរើន ឥឡូវនេះ លោកចូររម្ងាប់ព្រហ្មទណ្ឌដល់ខ្ញុំ ព្រះអានន្ទពោលថា នែឆន្នៈមានអាយុ លោកបានធ្វើឲ្យជាក់ច្បាស់ហើយនូវអរហត្ត ក្នុងកាលជាទីបំផុតណា ឯព្រហ្មទណ្ឌរបស់លោក ក៏រម្ងាប់ក្នុងកាលជាទីបំផុតនោះដែរ។

[២៩២] ក្នុងការសង្គាយនាព្រះវិន័យនេះឯង មានភិក្ខុចំនួន៥០០រូប មិនខ្វះ មិនលើស។ ព្រោះហេតុនោះ ការសង្គាយនាព្រះវិន័យនេះ ព្រះសង្គីតិកាចារ្យ ហៅថា បញ្ចសតិកាសង្គាយនា គឺសង្គាយនារបស់ភិក្ខុមានចំនួន៥០០រូប។

ចប់ បញ្ចសតិកក្ខន្ធកៈ ទី១១។

ក្នុងខន្ធកៈនេះ មានរឿង២៣។

ឧទ្ទាននៃ បញ្ចសតិកក្ខន្ធកៈ នោះគឺ

[២៩៣]

រឿងកាលព្រះសម្ពុទ្ធជាម្ចាស់ បរិនិព្វានទៅហើយ ព្រះថេរៈឈ្មោះកស្សប ជាអ្នកគ្រប់គ្រងរក្សាព្រះសទ្ធម្ម ហៅពួកភិក្ខុមកថា យើងដើរតាមផ្លូវឆ្ងាយ ពីស្រុកបាវា បានឮពាក្យសុភទ្ទភិក្ខុសំដែងហើយ យើងនឹងសង្គាយនានូវព្រះសទ្ធម្ម តំណទៅមុខ ធម៌ជាអកុសលនឹងរុងរឿងឡើង១ រឿងព្រះមហាកស្សប ជ្រើសរើសព្រះអរហន្ត៤៩៩អង្គ និងព្រះអានន្ទមួយផង១ រឿងព្រះមហាកស្សបគង់នៅទៀបគូហាដ៏ឧត្តម ធ្វើសង្គាយនានូវធម៌និងវិន័យ១ រឿងព្រះកស្សបសួរព្រះវិន័យនឹងព្រះឧបាលិ១ រឿងព្រះកប្បប សួរព្រះសូត្រ នឹងព្រះអានន្ទជាបណ្ឌិត១ រឿងពួកជិនសាវ័កធ្វើសង្គាយនាបិដកទាំងបី១។ រឿងព្រះអានន្ទ ទូលព្រះថេរៈទាំងឡាយថា កាលព្រះមានព្រះភាគ ជិតចូលបរិនិព្វាន ទ្រង់មានបន្ទូលថា បើសង្ឃប្រាថ្នានឹងដកសិក្ខាបទ ក៏គប្បីដកសិក្ខាបទតូចៗដោយលំដាប់ផ្សេងៗបាន១ រឿងព្រះកស្សបបានសូត្រប្រកាសប្រាប់សង្ឃថា ត្រូវឲ្យភិក្ខុប្រព្រឹត្តតាមសិក្ខាបទ ដែលគួរដល់ពុទ្ធប្បញ្ញត្តិ១។ រឿងព្រះថេរៈទាំងឡាយ បន្ទោសព្រះអានន្ទថា មិនទូលសួរព្រះមានព្រះភាគក្នុងសិក្ខាបទតូចៗ ដោយលំដាប់នោះ១ រឿងព្រះថេរៈទាំងឡាយ បន្ទោសព្រះអានន្ទថា ជាន់សំពត់វស្សិកសាដករបស់ព្រះមានព្រះភាគ ហើយដែរ១ រឿងព្រះថេរៈទាំងឡាយ បន្ទោសព្រះអានន្ទថា ឲ្យមាតុគ្រាមថ្វាយបង្គំសរីរៈព្រះមានព្រះភាគមុនគេ១ រឿងព្រះថេរៈទាំងឡាយ បន្ទោសព្រះអានន្ទថា មិនអារាធនាព្រះមានព្រះភាគ ឲ្យគង់នៅអស់អាយុកប្ប១ រឿងព្រះថេរៈទាំងឡាយ បន្ទោសព្រះអានន្ទថា សូមបព្វជ្ជាដល់មាតុគ្រាម១ រឿងព្រះអានន្ទទទួលថា អំពើអាក្រក់របស់ខ្ញុំគ្មានទេ ខ្ញុំទទួលដោយសេចក្តីជឿលោកម្ចាស់ទាំងឡាយ១។ រឿងបុរាណត្ថេរ១ រឿងដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុ១ រឿងពួកព្រះមហេសីនៅក្នុងឧទ្យាន ជាមួយនឹងព្រះបាទឧទេន១ រឿងព្រះបាទឧទេន ពោលទោសព្រះអានន្ទថា ទទួលចីវរច្រើនដល់ម្ល៉េះ១ រឿងព្រះបាទឧទេន សួរព្រះអានន្ទអំពីចីវរទុព្វភាព១ រឿងព្រះអានន្ទឆ្លើយថា ចីវរទុព្វភាពនោះ យកទៅធ្វើជាកម្រាលគ្រែ ជាស្រោមពូក ជាកម្រាលផែនដី ជាសំពត់ជូតជើង ជាសំពត់ជូតធូលី ទាំងលាយដោយភក់ បូកលាបជញ្ជាំង១ រឿងចីវរ១ពាន់កើតឡើងដល់ព្រះអានន្ទជាដំបូង១។ រឿងឆន្នភិក្ខុ ដែលសង្ឃដាក់ទោស ដោយព្រហ្មទណ្ឌហើយ បានត្រាស់ដឹងនូវសច្ចៈទាំងបួន១។ រឿងព្រះថេរៈ ជាអ្នកស្ទាត់ជំនាញចំនួន៥០០អង្គ ក្នុងការសង្គាយនាធម៌ និងវិន័យ ព្រោះហេតុនោះ ការសង្គាយនានោះឈ្មោះថា បញ្ចសតិកសង្គាយនា១។

# សត្តសតិកក្ខន្ធកៈ (ទី១២)

CS vin.cv.12 | ភាគ ទី១១

### (១២. សត្តសតិកក្ខន្ធកំ)

## (បឋមភាណវារៈ ទី១)

## (១. បឋមភាណវារោ)

[២៩៤] សម័យនោះឯង កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វានទៅបាន១០០ឆ្នាំ ពួកវជ្ជីបុត្តកភិក្ខុ[29] នៅក្នុងក្រុងវេសាលី សំដែងវត្ថុ១០ប្រការ ក្នុងក្រុងវេសាលីថា ការកំណត់ដោយអម្បិលក្នុងក្លាក់ គួរ (ដល់សមណៈ)១ ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេទៅ ប្រមាណពីរធ្នាប់ គួរ១ ការកំណត់ដោយចន្លោះស្រុក គួរ១ ការកំណត់ដោយអាវាស គួរ១ ការកំណត់ដោយអនុមតិ[30] គួរ១ ការកំណត់ដោយអាចិណ្ណកប្ប (ប្រពៃណី) គួរ១ ការកំណត់ដោយទឹកដោះ ដែលមិនទាន់ជូរ គួរ១ ការផឹកនូវសុរាឆៅ គួរ១ និសីទនៈ ដែលមិនមានជាយ គួរ១ មាស និងប្រាក់គួរ១។

[២៩៥] សម័យនោះឯង ព្រះយសកាកណ្ឌកបុត្ត[31] មានអាយុ ត្រាច់ទៅកាន់ចារិក ក្នុងដែនវជ្ជី ហើយក៏បានទៅដល់ក្រុងវេសាលី។ បានឮថា ព្រះយសកាកណ្ឌកបុត្តមានអាយុ នៅក្នុងកូដាគារសាលា ព្រៃមហាវ័ន ជិតក្រុងវេសាលីនោះ។

[២៩៦] សម័យនោះឯង ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី បានដងទឹកដាក់ពេញភាជន៍សំរឹទ្ធ ហើយយកទៅតំកល់ទុក ក្នុងកណ្តាលភិក្ខុសង្ឃ ក្នុងថ្ងៃឧបោសថនោះ ហើយពោលពាក្យយ៉ាងនេះ ចំពោះពួកឧបាសកនៅក្នុងក្រុងវេសាលី ដែលមកទាំងអស់ថា ហៃអ្នកមានអាយុទាំងឡាយ ចូរអ្នកទាំងឡាយប្រគេនកហាបណៈមួយក្តី កន្លះកហាបណៈក្តី មួយបាទក្តី មាសករូបមួយក្តី ដល់សង្ឃចុះ សង្ឃមុខជានឹងមានកិច្ចដោយបរិក្ខារមិនខាន។ កាលដែលពួកវជ្ជីបុត្តកភិក្ខុពោលយ៉ាងនេះហើយ ទើបព្រះយសកាកណ្ឌកបុត្តមានអាយុ ក៏ពោលដូច្នេះ នឹងពួកឧបាសកអ្នកនៅក្នុងក្រុងវេសាលីថា នែអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយ កុំប្រគេនកហាបណៈមួយក្តី កន្លះកហាបណៈក្តី បាទមួយក្តី មាសករូបមួយក្តី ដល់សង្ឃឡើយ ព្រោះមាស និងប្រាក់ មិនគួរដល់សមណៈ ជាសក្យបុត្តិយ៍ទេ ពួកសមណៈ ជាសក្យបុត្តិយ៍ មិនត្រេកអរ មិនកាន់មាស និងប្រាក់ទេ ពួកសមណៈ ជាសក្យបុត្តិយ៍ លះចោលកែវមណី និងមាសចេញ ហើយប្រាសចាក គឺថាលែងរវល់ ដោយមាសនិងប្រាក់ហើយ។ ឯពួកឧបាសកដែលនៅក្នុងក្រុងវេសាលី ទុកជាព្រះយសកាកណ្ឌកបុត្តពោលយ៉ាងនេះហើយ ក៏នៅតែប្រគេនកហាបណៈមួយខ្លះ កន្លះកហាបណៈខ្លះ បាទមួយខ្លះ មាសករូបមួយខ្លះ ដល់សង្ឃ។ លំដាប់នោះឯង ពួកវជ្ជីបុត្តកភិក្ខុ អ្នកនៅក្នុងក្រុងវេសាលី លុះកន្លងរាត្រីនោះហើយ (ព្រឹកឡើង) ក៏ចែកប្រាក់នោះ ដាក់ចំណែកមួយៗ ដោយរាប់ចំនួនភិក្ខុ។ ទើបពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី ពោលនឹងព្រះយសកាកណ្ឌកបុត្តមានអាយុថា នែអាវុសោ យស នេះជាចំណែកប្រាក់របស់លោក។ ព្រះយសកាកណ្ឌបុត្តពោលថា ម្នាលអាវុសោទាំងឡាយ ខ្ញុំគ្មានចំណែកនៃប្រាក់ទេ ព្រោះខ្ញុំមិនត្រេកអរនឹងប្រាក់ទេ។

[២៩៧] គ្រានោះឯង ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី ពោលថា នែអាវុសោទាំងឡាយ ព្រះយសកាកណ្ឌកបុត្តនេះ ជេរគម្រាម ធ្វើនូវការរុករាន បណ្តេញពួកឧបាសកដែលមានសទ្ធាជ្រះថ្លា បើដូច្នោះ យើងរាល់គ្នាធ្វើបដិសារណីយកម្ម ដល់ព្រះយសកាកណ្ឌកបុត្តនោះ។ ពួកវជ្ជីបុត្តកភិក្ខុនោះ បានធ្វើបដិសារណីយកម្ម ដល់ព្រះយសកាកណ្ឌកបុត្តនោះ។ គ្រានោះឯង ព្រះយសកាកណ្ឌកបុត្តមានអាយុ បានពោលពាក្យនេះនឹងពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលីថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តថា សង្ឃត្រូវឲ្យអនុទូតដល់ភិក្ខុដែលសង្ឃធ្វើបដិសារណីយកម្មហើយ ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយឲ្យភិក្ខុជាអនុទូតដល់ខ្ញុំ។ លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលីបានសន្មតភិក្ខុមួយរូប ឲ្យជាអនុទូត ដល់ព្រះយសកាកណ្ឌកបុត្តដ៏មានអាយុ។ ឯព្រះយសកាកណ្ឌកបុត្តមានអាយុ ចូលទៅក្នុងក្រុងវេសាលី ជាមួយនឹងភិក្ខុជាអនុទូត ហើយក៏ពោលពាក្យដូច្នេះនឹងឧបាសក ដែលនៅក្នុងក្រុងវេសាលីថា អាត្មាគ្រាន់តែពោលនូវសភាវៈមិនមែនជាធម៌ ថាមិនមែនជាធម៌ ពោលនូវធម៌ ថាជាធម៌ ពោលនូវសភាវៈមិនមែនវិន័យ ថាមិនមែនវិន័យ ពោលនូវវិន័យ ថាជាវិន័យ ក៏ត្រឡប់ទៅជាឮពាក្យខ្ចរខ្ចាយថា អាត្មាជេរគម្រាម ធ្វើនូវការរុករាន បណ្តេញពួកឧបាសកដ៏មានអាយុ ដែលមានសទ្ធាជ្រះថ្លាវិញ។

[២៩៨] ម្នាលអ្នកមានអាយុទាំងឡាយ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ ម្នាលអ្នកមានអាយុទាំងឡាយ កាលដែលព្រះមានព្រះភាគ គង់នៅៗទីនោះ ព្រះអង្គ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសទាំងឡាយណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យទាំងនេះ មាន៤យ៉ាង។ ឧបក្កិលេសទាំង៤យ៉ាងនោះ ដូចម្តេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យនោះ គឺពពក១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យនោះគឺ ទឹកសន្សើមចុះអ័ព្ទ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យនោះគឺ ផ្សែង និងធូលី១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យនោះគឺ រាហុអសុរិន្ទ្រ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រ និងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រ និងព្រះអាទិត្យនោះ មាន៤យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ សៅហ្មងដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈ និងព្រាហ្មណ៍ទាំងនេះ ក៏មាន៤យ៉ាងដូច្នោះដែរ។ ឧបក្កិលេសទាំង៤យ៉ាងនោះដូចម្តេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ មានសមណៈ និងព្រាហ្មណ៍ពួក១ ផឹកសុរា និងមេរ័យ មិនវៀរចាកកិរិយាផឹកសុរា និងមេរ័យ ម្នាលភិក្ខុទាំងឡាយ សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ សៅហ្មងដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈ និងព្រាហ្មណ៍នេះជាដម្បូង ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃមានតទៅទៀត សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ សេពមេថុនធម្ម មិនវៀរចាកមេថុនធម្ម ម្នាលភិក្ខុទាំងឡាយ សមណៈ និងព្រាហ្មណ៍ពួក១ សៅហ្មងដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈ និងព្រាហ្មណ៍នេះជាគំរប់ពីរ ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃមានតទៅទៀត សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ កាន់មាសនិងប្រាក់ មិនវៀរចាកកិរិយាទទួលមាសនិងប្រាក់ ម្នាលភិក្ខុទាំងឡាយ សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ សៅហ្មងដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈ និងព្រាហ្មណ៍នេះជាគំរប់បី ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃមានតទៅទៀត សមណៈ និងព្រាហ្មណ៍

ទាំងឡាយពួក១ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ មិនវៀរចាកមិច្ឆាជីវៈ ម្នាលភិក្ខុទាំងឡាយ សមណៈ និងព្រាហ្មណ៍ពួក១ សៅហ្មងដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈ និងព្រាហ្មណ៍នេះ ជាគំរប់បួន ម្នាលភិក្ខុទាំងឡាយ សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ សៅហ្មងដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈ និងព្រាហ្មណ៍ មាន៤យ៉ាងនេះឯង។ ម្នាលអ្នកមានអាយុទាំងឡាយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះហើយ លុះព្រះសុគត ទ្រង់ត្រាស់នូវពាក្យនេះចប់ហើយ លំដាប់នោះ ព្រះសាស្តា ទ្រង់សំដែងដូច្នេះតទៅទៀតថា

[២៩៩]

សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ សៅហ្មងហើយ ដោយរាគៈ និងទោសៈជាបុរសដែលអវិជ្ជាបិទបាំងហើយ មានសេចក្តីត្រេកអរ ក្នុងរូបជាទីស្រឡាញ់ ផឹកសុរា និងមេរ័យ សេពមេថុនធម្ម មិនដឹងច្បាស់ (នូវទោស) ត្រេកអរចំពោះប្រាក់ និងមាស សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ សមណៈ និងព្រាហ្មណ៍ទាំងឡាយពួក១ សៅហ្មងដោយឧបក្កិលេសទាំងឡាយណា ក៏មិនបរិសុទ្ធ ប្រកបដោយធូលី គឺកិលេស រមែងមិនរុងរឿង មិនភ្លឺ ប្រៀបដូចសត្វម្រឹគ ឧបក្កិលេសទាំងឡាយនុ៎ះ ព្រះពុទ្ធមានផៅពង្សដ៏ខ្ពស់ខ្ពស់ ដូចជាព្រះអាទិត្យ ទ្រង់ត្រាស់សំដែងហើយ (សមណៈ និងព្រាហ្មណ៍ទាំងនោះ) ត្រូវងងឹត គឺអវិជ្ជារួបរឹតហើយ ជាទាសៈនៃតណ្ហា ប្រកបដោយតណ្ហា ដែលដឹកនាំសត្វទៅក្នុងភព តែងញុំាងរាងកាយ ជារបស់គ្រោតគ្រាត ឲ្យចំរើនឡើង ហើយកាន់យកនូវភពថ្មីទៀត។

[៣០០] អាត្មាគ្រាន់តែពោលនូវសភាវៈមិនមែនជាធម៌ ថាមិនមែនជាធម៌ ពោលនូវធម៌ ថាជាធម៌ ពោលនូវសភាវៈមិនមែនជាវិន័យ ថាមិនមែនជាវិន័យ ពោលនូវវិន័យ ថាជាវិន័យ អាត្មាគ្រាន់តែពោលយ៉ាងនេះ ក៏ត្រឡប់ជាឮពាក្យខ្ចរខ្ចាយទៅថា អាត្មាជេរគម្រាម ធ្វើនូវការរុករាន បណ្តេញពួកឧបាសកមានអាយុ ដែលមានសទ្ធាជ្រះថ្លាទៅវិញ។

[៣០១] ម្នាលអ្នកមានអាយុទាំងឡាយ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង អន្តរាកថានេះ[32] កើតឡើងដល់ជន ដែលអង្គុយប្រជុំគ្នាក្នុងកណ្តាលរាជបរិសទ្យ ក្នុងព្រះបរមរាជវាំងថា មាសនិងប្រាក់គួរដល់ពួកសមណសក្យបុត្តិយ៍ដែរ ពួកសមណសក្យបុត្តិយ៍ត្រេកអរនឹងមាសប្រាក់ដែរ ពួកសមណសក្យបុត្តិយ៍ទទួលមាសប្រាក់ដែរ។ ម្នាលអ្នកមានអាយុទាំងឡាយ សម័យនោះឯង មានបុរសជាធំ គឺនាយចៅហ្វាយម្នាក់ ឈ្មោះមណិចូឡកៈ អង្គុយនៅក្នុងកណ្តាលបរិសទ្យនោះ។ ម្នាលអ្នកមានអាយុទាំងឡាយ លំដាប់នោះ បុរសជាធំ ឈ្មោះមណិចូឡកៈ ពោលពាក្យដូច្នេះ នឹងបរិសទ្យនោះថា បពិត្រអស់លោកទាំងឡាយ អ្នកទាំងឡាយ កុំពោលយ៉ាងនេះឡើយ មាសនិងប្រាក់ មិនគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណសក្យបុត្តិយ៍ មិនត្រេកអរដោយមាសនិងប្រាក់ទេ មិនទទួលមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍ លះចោលកែវមណី និងមាសចេញ ហើយប្រាសចាក គឺថា លែងរវល់ដោយមាសនិងប្រាក់ហើយ។ ម្នាលអ្នកមានអាយុទាំងឡាយ បុរសជាធំឈ្មោះមណិចូឡកៈ ក៏មិនអាចនឹងពន្យល់បរិសទ្យនោះបាន។ ម្នាលអ្នកមានអាយុទាំងឡាយ លំដាប់នោះឯង លុះបុរសជាធំឈ្មោះមណិចូឡកៈ ពន្យល់បរិសទ្យនោះរួចហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ ម្នាលអាវុសោទាំងឡាយ លុះបុរសជាធំឈ្មោះមណិចូឡកៈ អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អន្តរាកថានេះ កើតឡើងដល់ពួកជន ដែលអង្គុយប្រជុំគ្នា ក្នុងរាជបរិសទ្យ ក្នុងព្រះបរមរាជវាំងនេះថា មាសនិងប្រាក់គួរដល់ពួកសមណសក្យបុត្តិយ៍ដែរ ពួកសមណសក្យបុត្តិយ៍ ត្រេកអរនឹងមាសប្រាក់ដែរ ពួកសមណសក្យបុត្តិយ៍ ទទួលមាសនិងប្រាក់ដែរ បពិត្រព្រះអង្គដ៏ចំរើន កាលដែលពួកបរិសទ្យនោះពោលយ៉ាងនេះ ខ្ញុំព្រះអង្គ ក៏ពោលពាក្យដូច្នេះ នឹងបរិសទ្យនោះវិញថា បពិត្រអស់លោកទាំងឡាយ អ្នកទាំងឡាយ កុំពោលពាក្យយ៉ាងនេះឡើយ មាសនិងប្រាក់ មិនគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណសក្យបុត្តិយ៍ មិនត្រេកអរនឹងមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍ មិនទទួលមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍ លះចោលកែវមណី និងមាសចេញហើយ ប្រាសចាក គឺថា លែងរវល់ដោយមាសនិងប្រាក់ហើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនអាចនឹងពន្យល់បរិសទ្យនោះបានទេ បពិត្រព្រះអង្គដ៏ចំរើន កាលបើខ្ញុំព្រះអង្គព្យាករ (ដោះស្រាយ) យ៉ាងនេះ ឈ្មោះថា ជាអ្នកពោលត្រូវតាមបន្ទូល នៃព្រះមានព្រះភាគផង មិនពោលបង្កាច់នូវព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ព្យាករនូវធម៌ ដ៏សមគួរដល់ធម៌ផង ពាក្យពោលតូចធំណាមួយ ដែលប្រកបដោយធម៌ មិនមកកាន់ស្ថានដែលបណ្ឌិតគប្បីតិះដៀលផង បានដែរឬ។ ព្រះអង្គ ទ្រង់ត្រាស់ថា អើ ម្នាលអ្នកជាធំ អ្នកព្យាករយ៉ាងនេះ ឈ្មោះថា ជាអ្នកពោលត្រូវតាមពាក្យតថាគតផង មិនពោលបង្កាច់តថាគត ដោយពាក្យមិនពិតផង ព្យាករនូវធម៌ ដ៏សមគួរដល់ធម៌ផង ពាក្យពោលតូចធំណាមួយ ដែលប្រកបដោយធម៌ មិនបានមកកាន់ស្ថាន ដែលបណ្ឌិតគប្បីតិះដៀលផង នែអ្នកជាធំ មាសនិងប្រាក់ មិនគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណសក្យបុត្តិយ៍ មិនត្រេកអរនឹងមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍ មិនទទួលមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍ លះចោលកែវមណី និងមាសចេញហើយ ប្រាសចាក គឺថា លែងរវល់ ដោយមាសនិងប្រាក់ហើយ នែអ្នកជាធំ មាសនិងប្រាក់ គួរដល់បុគ្គលណា កាមគុណទាំង៥ ក៏គួរដល់បុគ្គលនោះដែរ កាមគុណទាំង៥ គួរដល់បុគ្គលណា មាសនិងប្រាក់ ក៏គួរដល់បុគ្គលនោះដែរ នែអ្នកជាធំ អ្នកគប្បីចាំទុកនូវការសំរេចនៃកាមគុណទាំង៥នេះ ដោយពិតថា មិនមែនជាធម៌របស់សមណៈ មិនមែនជាធម៌របស់សក្យបុត្តិយ៍ទេ ម្នាលអ្នកជាធំ ម្យ៉ាងវិញទៀត តថាគតពោលយ៉ាងនេះថា បុគ្គលអ្នកត្រូវការដោយស្មៅ គប្បីស្វែងរកស្មៅ បុគ្គលអ្នកត្រូវការដោយឈើ គប្បីស្វែងរកឈើ បុគ្គលអ្នកត្រូវការដោយរទេះ គប្បីស្វែងរករទេះ បុរសត្រូវការដោយបុរស គប្បីស្វែងរកបុរស ម្នាលអ្នកជាធំ តថាគតមិនធ្លាប់បានពោលថា សមណៈ គប្បីត្រេកអរនឹងមាសប្រាក់ គប្បីស្វែងរកមាសប្រាក់ដូច្នេះ ដោយបរិយាយណាមួយឡើយ អាត្មាគ្រាន់តែពោលនូវសភាវៈ មិនមែនជាធម៌ ថាមិនមែនជាធម៌ ពោលនូវធម៌ ថាជាធម៌ ពោលនូវសភាវៈមិនមែនជាវិន័យ ថាមិនមែនជាវិន័យ ពោលនូវវិន័យ ថាវិន័យ អាត្មាគ្រាន់តែពោលយ៉ាងនេះ ក៏ត្រឡប់ជាឮពាក្យខ្ចរខ្ចាយទៅថា អាត្មាជេរគម្រាម ធ្វើការរុករាន បណ្តេញពួកឧបាសកមានអាយុ ដែលមានសទ្ធាជ្រះថ្លាទៅវិញ។

[៣០២] ម្នាលអាវុសោទាំងឡាយ សម័យមួយ ព្រះមានព្រះភាគទ្រង់ប្រារព្ធនឹងព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ ទ្រង់ហាមមាសនិងប្រាក់ ហើយបញ្ញត្តិសិក្ខាបទ ក្នុងនគររាជគ្រឹះ។ អាត្មាគ្រាន់តែពោលនូវសភាវៈ មិនមែនជាធម៌ ថាមិនមែនជាធម៌ ពោលនូវធម៌ ថាធម៌ ពោលនូវសភាវៈ

មិនមែនជាវិន័យ ថាមិនមែនវិន័យ ពោលនូវវិន័យ ថាវិន័យ អាត្មាគ្រាន់តែពោលយ៉ាងនេះ ក៏ត្រឡប់ជាឮពាក្យខ្ជរខ្ជាយទៅថា អាត្មាជេរគម្រាម ធ្វើការរុករាន បណ្តេញពួកឧបាសកមានអាយុ ដែលមានសទ្ធាជ្រះថ្លាទៅវិញ។ កាលដែលព្រះយសកាកណ្ឌកបុត្តពោលយ៉ាងនេះហើយ ពួកឧបាសកដែលនៅក្នុងក្រុងវេសាលី ក៏នាំគ្នាពោលពាក្យដូច្នេះ នឹងព្រះយសកាកណ្ឌកបុត្តដ៏មានអាយុថា បពិត្រព្រះករុណាដ៏ចំរើន មានតែលោកម្ចាស់យសកាកណ្ឌកបុត្តមួយទេ ជាសមណសក្យបុត្តិយ៍ ឯភិក្ខុទាំងអស់នេះ សុទ្ធតែមិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ឡើយ បពិត្រព្រះករុណាដ៏ចំរើន សូមព្រះយសកាកណ្ឌកបុត្តជាម្ចាស់ គង់នៅក្រុងវេសាលីចុះ យើងទាំងឡាយនឹងធ្វើសេចក្តីខ្វល់ខ្វាយដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានបច្ច័យភេសជ្ជបរិក្ខារ ដល់ព្រះយសកាកណ្ឌកបុត្តជាម្ចាស់។ គ្រានោះឯង ព្រះយសកាកណ្ឌកបុត្តមានអាយុ លុះពន្យល់ពួកឧបាសក ដែលនៅក្នុងក្រុងវេសាលីហើយ ក៏ទៅកាន់អារាមជាមួយនឹងភិក្ខុអនុទូតវិញ។

[៣០៣] លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី សួរភិក្ខុជាអនុទូតថា ម្នាលអាវុសោ ព្រះយសកាកណ្ឌកបុត្ត បានសូមខមាទោសនឹងពួកឧបាសក ដែលនៅក្នុងក្រុងវេសាលីហើយឬ។ ភិក្ខុជាអនុទូតនោះពោលថា ម្នាលអាវុសោទាំងឡាយ អំពើអាក្រក់ ពួកយើងបានធ្វើហើយ ពួកឧបាសកធ្វើ គឺថា គេជឿព្រះយសកាកណ្ឌកបុត្តតែមួយ ថាជាសមណសក្យបុត្តិយ៍ ឯពួកយើងទាំងអស់ ឧបាសកធ្វើ គឺគេទុកដាក់ថា មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ទៅវិញ។ លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី និយាយគ្នាថា ម្នាលអាវុសោទាំងឡាយ ព្រះយសកាកណ្ឌកបុត្តនេះ យើងទាំងឡាយមិនបានសន្មតឲ្យ ក៏ទៅប្រកាសប្រាប់ដល់ពួកគ្រហស្ថ បើដូច្នោះ គួរតែយើងធ្វើឧក្ខេបនីយកម្ម ដល់ព្រះយសកាកណ្ឌកបុត្តនោះ។ ពួកវជ្ជីបុត្តកភិក្ខុទាំងនោះ ប៉ងនឹងធ្វើឧក្ខេបនីយកម្ម ដល់ព្រះយសកាកណ្ឌកបុត្តនោះ ក៏ប្រជុំគ្នា។ គ្រានោះឯង ព្រះយសកាកណ្ឌកបុត្តមានអាយុ ហោះឡើងទៅឰដ៏អាកាស ហើយទៅចុះត្រង់ក្រុងកោសម្ពី។ លំដាប់នោះ ព្រះយសកាកណ្ឌកបុត្តមានអាយុ ក៏បញ្ជូនទូតឲ្យទៅកាន់សំណាក់ពួកបាឋេយ្យកភិក្ខុ (ភិក្ខុនៅក្នុងដែនបាឋេយ្យ)ផង និងពួកអវន្តិទក្ខិណាបថកភិក្ខុផងថា ចូរលោកមានអាយុទាំងឡាយនាំគ្នាមក យើងទាំងឡាយនឹងកាន់យក គឺថា នឹងជម្រះនូវអធិករណ៍នេះចេញ តំណទៅមុខ ធម៌ជាអកុសលនឹងរុងរឿងឡើង ធម៌ជាកុសល នឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យនឹងរុងរឿងឡើង វិន័យ នឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលជាអធម្មវាទី នឹងមានកំឡាំងឡើង ពួកបុគ្គលជាធម្មវាទី នឹងថយកំឡាំងចុះ ពួកបុគ្គលជាអវិនយវាទី នឹងមានកំឡាំងឡើង ពួកបុគ្គលជាវិនយវាទី នឹងថយកំឡាំងចុះ។

[៣០៤] សម័យនោះឯង ព្រះសម្ភូតសាណវាសីមានអាយុ នៅអាស្រ័យលើភ្នំឈ្មោះអហោគង្គ។ គ្រានោះ ព្រះយសកាកណ្ឌកបុត្តមានអាយុ ក៏ចូលទៅរកព្រះសម្ភូតសាណវាសីមានអាយុ ឯភ្នំឈ្មោះអហោគង្គ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសម្ភូតសាណវាសីមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះព្រះយសកាកណ្ឌកបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ពោលពាក្យដូច្នេះ នឹងព្រះសម្ភូតសាណវាសីដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលីនេះ សំដែងនូវវត្ថុ១០ប្រការ ក្នុងក្រុងវេសាលីថា ការកំណត់ដោយអម្បិលក្នុងក្លាក់ គួរ (ដល់សមណៈ) ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់ គួរ ការកំណត់ដោយចន្លោះស្រុក គួរ ការកំណត់ដោយអាវាស គួរ ការកំណត់ដោយអនុមតិ គួរ ការកំណត់ដោយអាចិណ្ណៈ (ប្រពៃណី) គួរ ការកំណត់ដោយទឹកដោះ ដែលមិនទាន់ជូរ គួរ ការផឹកនូវសុរាឆៅ គួរ និសីទនៈ ដែលមិនមានជាយ គួរ មាស និងប្រាក់គួរ បពិត្រលោកម្ចាស់ដ៏ចំរើន បើដូច្នោះ គួរយើងទាំងឡាយ ជម្រះអធិករណ៍នេះចេញ តំណទៅមុខ ធម៌ជាអកុសល នឹងរុងរឿងឡើង ធម៌ជាកុសល នឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យ នឹងរុងរឿងឡើង វិន័យ នឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលជាអធម្មវាទី នឹងមានកំឡាំងឡើង ពួកបុគ្គលជាធម្មវាទី នឹងថយកំឡាំងចុះ ពួកបុគ្គលជាអវិនយវាទី នឹងមានកំឡាំងឡើង ពួកបុគ្គលជាវិនយវាទី នឹងថយកំឡាំងចុះ។ ព្រះសម្ភូតសាណវាសីមានអាយុ ក៏ទទួលពាក្យនៃព្រះយសកាកណ្ឌកបុត្តមានអាយុថា យ៉ាងហ្នឹងហើយអាវុសោ។ គ្រានោះឯង ពួកបាឋេយ្យកភិក្ខុប្រមាណ៦០រូប សុទ្ធតែជាអ្នកប្រព្រឹត្តអារញ្ញកធុតង្គ សុទ្ធតែជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ សុទ្ធតែជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ សុទ្ធតែជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គ សុទ្ធតែជាព្រះអហរន្ត ប្រជុំគ្នានៅលើភ្នំឈ្មោះអហោគង្គ។ ឯពួកអវន្តិទក្ខិណាបថកភិក្ខុ ប្រមាណ៨០រូប ពួកខ្លះ ជាអ្នកប្រព្រឹត្តអារញ្ញកធុតង្គ ពួកខ្លះជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ពួកខ្លះជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ ពួកខ្លះជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គ សុទ្ធតែជាព្រះអហរន្ត ប្រជុំគ្នានៅលើភ្នំឈ្មោះអហោគង្គដែរ។

[៣០៥] គ្រាកាលដែលភិក្ខុជាថេរៈទាំងឡាយ កំពុងប្រឹក្សា មានសេចក្តីត្រិះរិះដូច្នេះថា អធិករណ៍នេះឯង រឹងរូសណាស់ សាហាវណាស់ យើងទាំងឡាយ គប្បីជាបុគ្គលមានកំឡាំងក្លៀវក្លាក្នុងអធិករណ៍នេះ ដោយបក្ខពួកណា ធ្វើដូចម្តេច យើងទាំងឡាយ គប្បីបានបក្ខពួកនោះឡើង។ សម័យនោះឯង ព្រះរេវតមានអាយុ នៅអាស្រ័យក្នុងនគរសោរេយ្យ លោកជាពហុស្សូត្រ ចេះចាំក្នុងគម្ពីរនិកាយ ហើយទ្រទ្រង់នូវធម៌ ទ្រទ្រង់នូវវិន័យ ទ្រទ្រង់នូវមាតិកា ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស មានប្រាថ្នានូវសិក្ខា។ លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះរេវតមានអាយុនេះឯង នៅអាស្រ័យក្នុងនគរសោរេយ្យ លោកជាពហុស្សូត្រ ចេះចាំក្នុងគម្ពីរនិកាយ ហើយទ្រទ្រង់នូវធម៌ ទ្រទ្រង់នូវវិន័យ ទ្រទ្រង់នូវមាតិកា ជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស មានប្រាថ្នានូវសិក្ខា បើយើងទាំងឡាយបានព្រះរេវតមានអាយុ មកជាបក្ខពួក មុខជាយើងទាំងឡាយ មានកំឡាំងក្លៀវក្លា ក្នុងអធិករណ៍នេះ ដោយប្រការដូច្នេះ។ កាលដែលភិក្ខុជាថេរៈទាំងឡាយកំពុងប្រឹក្សាគ្នា ឯព្រះរេវតមានអាយុ ក៏បានឮច្បាស់ដោយសោតធាតុ ដូចជាទិព្វ ស្អាតបរិសុទ្ធ កន្លងបង់នូវសោតធាតុជារបស់នៃមនុស្សធម្មតា លុះឮហើយ លោកមានសេចក្តីរិះគិតដូច្នេះថា អធិករណ៍នេះ រឹងរូសណាស់ សាហាវណាស់ បើអាត្មាអញក្រាញនៅក្នុងអធិករណ៍ដូច្នេះ ហេតុនោះ មិនសមគួរដល់អាត្មាអញឡើយ មួយទៀត ភិក្ខុទាំងឡាយនោះ នឹងនាំគ្នាមកឥឡូវនេះមិនខាន អាត្មាអញសោត បើនៅច្រឡូកច្រឡំដោយភិក្ខុទាំងឡាយនោះ មុខជានៅមិនបានសេចក្តីសប្បាយឡើយ បើដូច្នោះ គួរអាត្មាអញទៅជាមុនឲ្យហើយ។ លំដាប់នោះ ព្រះរេវតមានអាយុ ក៏ចេញអំពីនគរសោរេយ្យ ទៅកាន់នគរសង្កស្ស។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយ ក៏នាំគ្នាទៅកាន់នគរសោរេយ្យ ហើយសួររកថា ព្រះរេវតមានអាយុនៅក្នុងទីណា។ មនុស្សទាំងនោះពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះ លោកទៅកាន់នគរសង្កស្សហើយ។ គ្រានោះ ព្រះរេវតមានអាយុ ក៏ចេញអំពីនគរសង្កស្ស ហើយទៅកាន់នគរកណ្ណកុជ្ជទៀត។ ទើបភិក្ខុជាថេរៈទាំងឡាយ ក៏នាំគ្នាទៅកាន់នគរសង្កស្ស ហើយសួររកថា ព្រះរេវតមានអាយុ លោកនៅក្នុងទីណា។ មនុស្សទាំងនោះ ពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះ លោកទៅកាន់នគរកណ្ណកុជ្ជហើយ។ គ្រានោះឯង ព្រះរេវតមានអាយុ ចេញអំពីនគរកណ្ណកុជ្ជ ហើយទៅកាន់នគរឧទុម្ពរទៀត។ ទើបភិក្ខុជាថេរៈទាំងឡាយ នាំគ្នាទៅកាន់នគរកណ្ណកុជ្ជ ហើយសួររកថា ព្រះរេវតមានអាយុ លោកនៅក្នុងទីណា។ មនុស្សទាំងនោះ ពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះ លោកនិមន្តទៅកាន់នគរឧទុម្ពរហើយ។ គ្រានោះឯង ព្រះរេវតមានអាយុ ចេញអំពីនគរឧទុម្ពរ ហើយទៅកាន់នគរអគ្គឡបុរៈទៀត។

ទើបភិក្ខុជាថេរៈទាំងឡាយ នាំគ្នាទៅកាន់នគរឧទុម្ពរ ហើយសួររកថា ព្រះរេវតមានអាយុ នៅក្នុងទីណា។ មនុស្សទាំងនោះ ពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះ ទៅកាន់នគរអគ្គឡបុរៈហើយ។ គ្រានោះ ព្រះរេវតមានអាយុ ចេញអំពីនគរអគ្គឡបុរៈ ហើយទៅកាន់នគរសហជាតិទៀត។ ទើបភិក្ខុជាថេរៈទាំងឡាយ នាំគ្នាទៅកាន់នគរអគ្គឡបុរៈ ហើយសួររកថា ព្រះរេវតដ៏មានអាយុ នៅក្នុងទីណា។ មនុស្សទាំងនោះ ពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះ ទៅកាន់នគរសហជាតិហើយ។ លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយ ក៏បានទៅជួបនឹងព្រះរេវតមានអាយុ ក្នុងនគរសហជាតិ។

[៣០៦] គ្រានោះឯង ព្រះសម្ភូតសាណវាសីមានអាយុ បានពោលពាក្យដូច្នេះ ទៅនឹងព្រះយសកាកណ្ឌកបុត្តមានអាយុថា ម្នាលអាវុសោ ព្រះរេវតមានអាយុនេះហើយ ដែលជាពហុស្សុត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់នូវធម៌ ទ្រទ្រង់នូវវិន័យ ទ្រទ្រង់នូវមាតិកា ជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស មានប្រាថ្នាក្នុងសិក្ខា បើយើងទាំងឡាយ សួរប្រស្នានឹងព្រះរេវតមានអាយុ ព្រះរេវតមានអាយុ អាចធ្វើឲ្យរាត្រីទាំងអស់កន្លងទៅដោយប្រស្នាតែ១ប៉ុណ្ណោះបាន ប៉ុន្តែឥឡូវនេះ ព្រះរេវតមានអាយុ នឹងបង្គាប់ភិក្ខុជាកូនសិស្ស ឲ្យជាអ្នកពោលនូវសរភ័ញ្ញ (ពោលដោយសំឡេង) កាលបើចប់សរភ័ញ្ញ របស់ភិក្ខុនោះហើយ លោកគប្បីចូលទៅជិតព្រះរេវតមានអាយុ ហើយសួរនូវវត្ថុទាំង១០ប្រការនេះចុះ។ ឯព្រះយសកាកណ្ឌកបុត្តមានអាយុ ក៏ទទួលពាក្យនៃព្រះសម្ភូតសាណវាសីមានអាយុថា អើលោកម្ចាស់។ គ្រានោះ ព្រះរេវតមានអាយុ ក៏បង្គាប់ភិក្ខុជាកូនសិស្ស ឲ្យជាអ្នកពោលនូវសរភ័ញ្ញ។ លំដាប់នោះ ព្រះយសកាកណ្ឌកបុត្តមានអាយុ កាលបើចប់សរភ័ញ្ញរបស់ភិក្ខុនោះហើយ ក៏ចូលទៅរកព្រះរេវតមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះរេវតមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះព្រះយសកាកណ្ឌកបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួររួចហើយ ក៏និយាយពាក្យនេះ នឹងព្រះរេវតមានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអំបិលក្នុងក្លាក់ គួរដែរឬ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអំបិលក្នុងក្លាក់នោះ តើដូចម្តេច។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុរក្សានូវអំបិលដោយក្លាក់ ដោយគិតថា វត្ថុសាបនឹងមានកាលណា យើងនឹងឆាន់ក្នុងកាលនោះដូច្នេះ គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះយសកាកណ្ឌកបុត្តសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់ គួរដែរឬ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយស្រមោលនៃព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់នោះ តើដូចម្តេច។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ស្រមោលព្រះអាទិត្យ កន្លងទៅប្រមាណពីរធ្នាប់ ភិក្ខុឆាន់ភោជនក្នុងវេលាវិកាល គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះយសកាកណ្ឌកបុត្តសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយចន្លោះស្រុក គួរដែរឬ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយចន្លោះស្រុកនោះ តើដូចម្តេច។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុដែលឆាន់រួចហើយ ហាមភោជនហើយ គិតថា អញនឹងទៅកាន់ចន្លោះស្រុកឥឡូវនេះ ហើយឆាន់អនតិរិត្តភោជន គឺភោជនដែលមិនបានធ្វើវិនយកម្ម ឬភោជនមិនមែនសល់ដែលអំពីភិក្ខុឈឺ គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះយសកាកណ្ឌកបុត្តសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអាវាស គួរដែរឬ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអាវាសនោះ តើដូចម្តេច។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន អាវាសច្រើននៅក្នុងសីមាជាមួយគ្នា ភិក្ខុធ្វើឧបោសថកម្មផ្សេងៗគ្នា គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអនុមតិ[33] គួរដែរឬ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអនុមតិនោះ តើដូចម្តេច។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន សង្ឃជាពួកធ្វើសង្ឃកម្ម ដោយគិតថា យើងទាំងឡាយ នឹងឲ្យពួកភិក្ខុដែលមកដល់ យល់ព្រម ឬត្រេកអរជាខាងក្រោយ គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអាចិណ្ណៈ គួរដែរឬ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអាចិណ្ណៈ តើដូចម្តេច។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុប្រព្រឹត្ត ដោយគិតថា អំពើនេះ ព្រះឧបជ្ឈាយ៍របស់យើង ធ្លាប់ប្រព្រឹត្តមកហើយ អំពើនេះ អាចារ្យរបស់យើងធ្លាប់ប្រព្រឹត្តមកហើយ ដូច្នេះ គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ ការកំណត់ដោយអាចិណ្ណៈ គួរខ្លះ មិនគួរខ្លះ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរ គួរដែរឬ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរនោះ តើដូចម្តេច។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ទឹកដោះស្រស់ណា ដែលលះបង់ភាពជាទឹកដោះស្រស់ទៅហើយ តែនៅមិនទាន់ដល់នូវភាពជាទឹកដោះជូរនៅឡើយ ភិក្ខុឆាន់ហើយ ហាមភោជនហើយ ផឹកទឹកដោះដែលជាអនតិរិត្តនោះ គឺភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនជារបស់សល់ដែលអំពីភិក្ខុឈឺ គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុផឹកសុរា គួរដែរឬ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ សុរាឆៅនោះ តើដូចម្តេច។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន សុរាណាដែលខ្សោយ[34] មិនទាន់ដល់នូវភាពជាទឹកស្រវឹងនៅឡើយ ភិក្ខុផឹកសុរានោះ គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន និសីទនៈ ដែលមិនមានជាយ គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន មាសនិងប្រាក់ គួរដែរឬ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ទើបព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលីទាំងនេះ សំដែងវត្ថុទាំង១០ប្រការនេះ ក្នុងក្រុងវេសាលី បពិត្រលោកម្ចាស់ដ៏ចំរើន បើដូច្នោះ គួរតែយើងរាល់គ្នា ជម្រះនូវអធិករណ៍នេះចេញ តំណាទៅមុខ ធម៌ជាអកុសលនឹងរុងរឿងឡើង ធម៌ជាកុសល នឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យ នឹងរុងរឿងឡើង វិន័យ នឹងសាបសូន្យទៅ តំណាទៅមុខ បុគ្គលជាអធម្មវាទី នឹងមានកំឡាំងឡើង បុគ្គលជាធម្មវាទី នឹងថយកំឡាំងចុះ បុគ្គលជាអវិនយវាទី នឹងមានកំឡាំងឡើង បុគ្គលជាវិនយវាទី នឹងថយកំឡាំងចុះ។ ឯព្រះរេវតមានអាយុ ទទួលពាក្យព្រះយសកាកណ្ឌកបុត្តមានអាយុថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ។

ចប់ ភាណវារៈ ទី១។

# (ទុតិយភាណវារៈ ទី២)

CS vin.cv.12.02 | ភាគ ទី១១

**(២. ទុតិយភាណវារោ)**

[៣០៧] ឯពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី បានឮដំណឹងថា ព្រះយសកាកណ្ឌកបុត្ត ប្រាថ្នានឹងជម្រះនូវអធិករណ៍នេះ ខំស្វែងរកបក្ខពួក ក៏ឮថា ឥឡូវនេះ បានបក្ខពួកហើយ។ គ្រានោះឯង ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី មានសេចក្ដីរិះគិតដូច្នេះថា អធិករណ៍នេះ រឹងរូសណាស់ សាហាវណាស់ យើងទាំងឡាយគប្បីជាបុគ្គលមានកំឡាំងក្លៀវក្លាក្នុងអធិករណ៍នេះ ដោយបក្ខពួកណា ធ្វើដូចម្ដេច យើងទាំងឡាយគប្បីបាននូវបក្ខពួកនោះឡើង។ លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី មានសេចក្ដីរិះគិតឃើញដូច្នេះថា ព្រះរេវតមានអាយុនេះឯង លោកជាពហុសូត្រ ចេះចាំក្នុងគម្ពីរនិកាយ ជាអ្នកទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា មានសេចក្ដីអៀនខ្មាស មានសេចក្ដីរង្កៀស មានប្រាថ្នានូវសិក្ខា បើយើងទាំងឡាយបាននូវព្រះរេវតមានអាយុជាបក្ខពួកហើយ យើងទាំងឡាយនឹងមានកំឡាំងក្លៀវក្លា ក្នុងអធិករណ៍នេះ ដោយអាការយ៉ាងនេះមិនខាន។ ទើបពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី នាំគ្នាចាត់ចែងគ្រឿងបរិក្ខាររបស់សមណៈជាច្រើនគឺ បាត្រផង ចីវរផង សំពត់និសីទនៈផង បំពង់ម្ជុលផង វត្ថពន្ធចង្កេះផង សំពត់តម្រងទឹកផង ធម្មក្រកផង។ គ្រានោះឯង ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី នាំគ្នាយកគ្រឿងបរិក្ខារជារបស់សមណៈនោះ ហើយជិះទូកឆ្លងឡើងទៅកាន់នគរសហជាតិ លុះចុះអំពីទូកហើយ ក៏ឈប់ ធ្វើភត្តកិច្ចក្រោមម្លប់ដើមឈើ១។

[៣០៨] គ្រានោះ ព្រះសាឡ្ហៈមានអាយុ ទៅកាន់ទីស្ងាត់សម្ងំ នៅក្នុងព្រះកម្មដ្ឋាន មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ពួកភិក្ខុណាហ្ន៎ ដែលជាធម្មវាទី ពួកភិក្ខុអ្នកនៅខាងបាចីនទិស (ទិសខាងកើត) ឬថា ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ។ គ្រាកាលដែលព្រះសាឡ្ហៈមានអាយុពិចារណានូវធម៌ និងវិន័យ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា ពួកភិក្ខុដែលនៅខាងបាចីនទិស ជាអធម្មវាទី ឯពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ជាធម្មវាទី។ លំដាប់នោះ ទេវតាមួយអង្គ នៅក្នុងពួកសុទ្ធាវាសព្រហ្ម បានដឹងនូវសេចក្ដីត្រិះរិះក្នុងចិត្តរបស់ព្រះសាឡ្ហៈមានអាយុ ដោយចិត្តរបស់ខ្លួនហើយ ក៏ចុះអំពីឋានទេវលោកជាន់សុទ្ធាវាស មកប្រាកដក្នុងទីចំពោះមុខ នៃព្រះសាឡ្ហៈមានអាយុ ដោយរហ័សភ្លាម ប្រៀបដូចជាបុរស ដែលមានកំឡាំង លាចេញនូវដើមដៃ ដែលខ្លួនបត់ចូល ឬថា បត់ចូលនូវដើមដៃ ដែលខ្លួនលាចេញ។ ទើបទេវតានោះ ពោលពាក្យនេះ នឹងព្រះសាឡ្ហៈមានអាយុថា បពិត្រលោកម្ចាស់សាឡ្ហៈដ៏ចំរើន សេចក្ដីត្រិះរិះរបស់លោកម្ចាស់ ប្រពៃណាស់ហើយ ពួកភិក្ខុដែលនៅខាងបាចីនទិស ជាអធម្មវាទី ឯពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ជាធម្មវាទី បពិត្រលោកម្ចាស់សាឡ្ហៈដ៏ចំរើន បើដូច្នោះ ធម៌យ៉ាងណា សូមលោកម្ចាស់ឋិតនៅយ៉ាងនោះចុះ។ ព្រះសាឡ្ហៈពោលថា ម្នាលទេវតា កាលពីដើមក្ដី ឥឡូវនេះក្ដី ធម៌យ៉ាងណា អាត្មាឋិតនៅយ៉ាងនោះ ប៉ុន្តែអាត្មាមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិ គឺសេចក្ដីយល់ សេចក្ដីចូលចិត្តនៅឡើយ ធ្វើដូចម្ដេច គប្បីឲ្យសង្ឃសន្មតអាត្មាក្នុងអធិករណ៍នេះឯង។

[៣០៩] គ្រានោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី នាំគ្នាកាន់យកនូវគ្រឿងបរិក្ខារ ជារបស់សមណៈនោះ ហើយចូលទៅរកព្រះរេវតមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យដូច្នេះ នឹងព្រះរេវតមានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈជាម្ចាស់ ទទួលយកនូវបរិក្ខារជារបស់សមណៈ គឺបាត្រផង ចីវរផង សំពត់និសីទនៈផង បំពង់ម្ជុលផង វត្ថពន្ធចង្កេះផង សំពត់តម្រងទឹកផង ធម្មក្រកផង។ ព្រះរេវតមិនប្រាថ្នានឹងទទួលដោយពាក្យថា ម្នាលអាវុសោទាំងឡាយ កុំឡើយ ខ្ញុំមានត្រៃចីវរគ្រប់គ្រាន់ហើយ។ សម័យនោះឯង មានភិក្ខុ១រូប ឈ្មោះឧត្តរៈបួសបាន២០វស្សា ជាឧបដ្ឋាករបស់ព្រះរេវតមានអាយុ។ លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី ក៏ចូលទៅរកព្រះឧត្តរៈមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យដូច្នេះនឹងព្រះឧត្តរៈមានអាយុ ព្រះឧត្តរៈមានអាយុ ចូរទទួលយកគ្រឿងបរិក្ខារជារបស់សមណៈ គឺបាត្រផង ចីវរផង សំពត់និសីទនៈផង បំពង់ម្ជុលផង វត្ថពន្ធចង្កេះផង សំពត់តម្រងទឹកផង ធម្មក្រកផង។ ព្រះឧត្តរៈមិនប្រាថ្នានឹងទទួលដោយពាក្យថា ម្នាលអាវុសោទាំងឡាយ កុំឡើយ ខ្ញុំមានត្រៃចីវរគ្រប់គ្រាន់ហើយ។ ពួកវជ្ជីបុត្តកភិក្ខុ ពោលអង្វរថា ម្នាលព្រះឧត្តរៈមានអាយុ មនុស្សទាំងឡាយ តែងបង្អោនគ្រឿងបរិក្ខារ ជារបស់សមណៈ ថ្វាយចំពោះព្រះមានព្រះភាគ បើព្រះមានព្រះភាគ ទ្រង់ទទួលយក មនុស្សទាំងនោះ រមែងមានចិត្តត្រេកអរ ដោយការទទួលរបស់ព្រះមានព្រះភាគនោះឯង បើព្រះមានព្រះភាគ មិនទ្រង់ទទួលទេ មនុស្សទាំងនោះ តែងបង្អោនទៅ ដើម្បីព្រះអានន្ទមានអាយុ ដោយពាក្យថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈជាម្ចាស់ ទទួលយកគ្រឿងបរិក្ខាជារបស់សមណៈចុះ បរិក្ខារនោះ ក៏ដូចជាព្រះមានព្រះភាគទទួលយកដែរ សូមព្រះឧត្តរៈមានអាយុ ទទួលយកគ្រឿងបរិក្ខារជារបស់សមណៈចុះ បរិក្ខារនោះ ដូចជាព្រះថេរៈបានទទួលយកដែរ។ គ្រានោះ ព្រះឧត្តរៈមានអាយុ កាលបើពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី បង្ខិតបង្ខំ ហើយក៏ទទួលយកតែចីវរ១ ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយត្រូវការដោយពាក្យណា ក៏គប្បីពោលពាក្យនោះចុះ។ ឯពួកវជ្ជីបុត្តកភិក្ខុ ពោលតបវិញថា សូមព្រះឧត្តរៈមានអាយុ ទៅនិយាយពាក្យប៉ុណ្ណេះនឹងព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈទៅនិយាយពាក្យប៉ុណ្ណេះ ក្នុងកណ្ដាលសង្ឃថា ព្រះពុទ្ធទ្រង់ព្រះភាគ កើតឡើងក្នុងជនបទទាំងឡាយ ដែលតាំងនៅក្នុងទិសខាងកើត ពួកភិក្ខុដែលនៅក្នុងទិសខាងកើត ជាធម្មវាទី ឯពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ជាអធម្មវាទី។ ព្រះឧត្តរៈមានអាយុ ទទួលពាក្យពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី អើអាវុសោ ហើយក៏ចូលទៅរកព្រះរេវតមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យដូច្នេះ នឹងព្រះរេវតមានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈជាម្ចាស់ ទៅពោលពាក្យប៉ុណ្ណេះក្នុងកណ្ដាលសង្ឃថា ព្រះពុទ្ធទ្រង់ព្រះភាគ កើតឡើងក្នុងជនបទទាំងឡាយ ដែលតាំងនៅក្នុងទិសខាងកើត ពួកភិក្ខុដែលនៅក្នុងទិសខាងកើត ជាធម្មវាទី ឯពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ជាអធម្មវាទី។ ព្រះថេរៈពោលតបវិញថា នែភិក្ខុ អ្នកឯងបញ្ចូលយើងទៅក្នុងធម៌ជាអកុសល ថាហើយក៏បណ្ដេញព្រះឧត្តរៈមានអាយុចេញទៅ។ គ្រានោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី ពោលសួរដូច្នេះ នឹងព្រះឧត្តរៈមានអាយុថា ម្នាលឧត្តរៈមានអាយុ ព្រះថេរៈនិយាយថា ដូចម្ដេចខ្លះ។ ព្រះឧត្តរៈប្រាប់ថា ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយ ធ្វើអំពើអាក្រក់ហើយ ព្រះថេរៈពោលថា ម្នាលភិក្ខុ អ្នកឯងបញ្ចូលយើងទៅក្នុងធម៌ជាអកុសល ថាហើយក៏បណ្ដេញខ្ញុំចេញមក។ ពួកវជ្ជីបុត្តកភិក្ខុ ពោលថា ម្នាលឧត្តរៈមានអាយុ ក្រែងលោកជាភិក្ខុចាស់ មានវស្សា២០ហើយឬ។ ព្រះឧត្តរៈឆ្លើយថា អើអាវុសោទាំងឡាយ មែនហើយ ប៉ុន្តែយើងទាំងឡាយកាន់យកនិស្ស័យនឹងលោកជាគ្រូនៅឡើយ។

[៣១០] គ្រានោះ សង្ឃប្រាថ្នានឹងវិនិច្ឆ័យកាត់សេចក្ដីអធិករណ៍ ក៏ប្រជុំគ្នា។ លំដាប់នោះ ព្រះរេវតមានអាយុ បានប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សូមសង្ឃស្ដាប់ខ្ញុំ បើយើងទាំងឡាយនឹងរម្ងាប់អធិករណ៍នេះក្នុងទីនេះ មុខជានឹងមានពួកភិក្ខុ ដែលជាអ្នកកាន់យកវត្ថុទាំង១០ពីមុន ភិក្ខុទាំងនោះគប្បីសើរើ ដើម្បីកម្មថ្មីទៀតមិនខានឡើយ។ បើកម្មមានកាលគួរដល់សង្ឃហើយ អធិករណ៍នេះ កើតឡើងក្នុងទីណា សង្ឃត្រូវរម្ងាប់អធិករណ៍នេះ ក្នុងទីនោះវិញ។ គ្រានោះ ភិក្ខុជាថេរៈទាំងឡាយ ប្រាថ្នានឹងវិនិច្ឆ័យនូវអធិករណ៍នោះ ក៏នាំគ្នាទៅកាន់ក្រុងវេសាលី។ សម័យនោះឯង មានភិក្ខុ១រូបឈ្មោះសព្វកាមី[35] មានវស្សា១២០តាំងអំពីឧបសម្បទាមក ជាសទ្ធិវិហារិករបស់ព្រះអានន្ទមានអាយុ លោកជាសង្ឃត្ថេរ (ធំ) លើផែនដី នៅអាស្រ័យក្នុងក្រុងវេសាលី។ លំដាប់នោះ ព្រះរេវតមានអាយុ ពោលពាក្យដូច្នេះ នឹងព្រះសម្ភូតសាណវាសីមានអាយុ

ម្នាលអាវុសោ ព្រះសព្វកាមិត្ថេរនៅក្នុងវិហារណា ខ្ញុំនឹងទៅកាន់វិហារនោះដែរ លោកគប្បីចូលទៅរកព្រះសព្វកាមីមានអាយុអំពីព្រឹក ហើយសួរវត្ថុ១០ប្រការនេះ។ ព្រះសម្ភូតសាណវាសីមានអាយុ ទទួលពាក្យព្រះរេវតមានអាយុថា អើលោកម្ចាស់។ លំដាប់នោះ ព្រះសព្វកាមិត្ថេរ គង់នៅក្នុងវិហារណា ព្រះរេវតមានអាយុ ក៏ចូលទៅកាន់វិហារនោះដែរ។ សេនាសនៈគេក្រាលទុកសម្រាប់ព្រះសព្វកាមីមានអាយុ នៅក្នុងល្វែង។ សេនាសនៈដែលគេក្រាលទុក សម្រាប់ព្រះរេវតៈមានអាយុ ក្នុងល្បៀងនៃល្វែង។ លំដាប់នោះ ព្រះរេវតមានអាយុ លោកមិនបានសិង ដោយគិតថា ព្រះថេរៈនេះមានចំណាស់ហើយ លោកមិនទាន់សិងនៅឡើយ។ ឯព្រះសព្វកាមីមានអាយុ លោកក៏មិនសិង ដោយគិតថា ភិក្ខុនេះជាអាគន្តុកៈ មានសេចក្តីនឿយព្រួយ លោកក៏មិនសិងដែរ។

[៣១១] គ្រានោះ ព្រះសព្វកាមីមានអាយុ ក្រោកឡើងក្នុងសម័យភ្លឺស្វាងនៃរាត្រី ហើយក៏ពោលដូច្នេះ នឹងព្រះរេវតមានអាយុថា ម្នាលលោកដ៏ចំរើន ឥឡូវនេះ លោកច្រើននៅដោយធម៌ ជាគ្រឿងនៅដូចម្តេច។ ព្រះរេវតឆ្លើយថា បពិត្រព្រះករុណាដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះករុណាច្រើននៅដោយធម៌ ជាគ្រឿងនៅ គឺមេត្តា។ ព្រះសព្វកាមីពោលថា ម្នាលលោកដ៏ចំរើន ឮថា ឥឡូវនេះ លោកច្រើននៅដោយធម៌ជាគ្រឿងនៅបន្តិចបន្តួច[36] ម្នាលលោកដ៏ចំរើន ក៏ឯធម៌ជាគ្រឿងនៅបន្តិចបន្តួចនេះ គឺមេត្តានេះឯង។ ព្រះរេវតពោលថា បពិត្រព្រះករុណាដ៏ចំរើន កាលពីដើមដែលខ្ញុំនៅជាគ្រហស្ថនៅឡើយ តែងសន្សំមេត្តាធម៌ ព្រោះហេតុនោះ បានជាក្នុងកាលឥឡូវនេះ ខ្ញុំច្រើននៅដោយធម៌ជាគ្រឿងនៅ គឺមេត្តា ម្យ៉ាងទៀត ខ្ញុំបានសម្រេចនូវព្រះអរហត្តជាយូរដែរហើយ បពិត្រព្រះថេរៈដ៏ចំរើន ចុះចំណែកខាងព្រះថេរៈជាម្ចាស់ ឥឡូវនេះ ច្រើននៅដោយធម៌ ជាគ្រឿងនៅដូចម្តេច។ ព្រះសព្វកាមីឆ្លើយថា ម្នាលលោកដ៏ចំរើន ឥឡូវនេះ ខ្ញុំច្រើននៅដោយធម៌ ជាគ្រឿងនៅដ៏ស្ងប់ស្ងាត់ ឬសូន្យ (ផលសមាបត្តិ)។ ព្រះរេវតពោលថា បពិត្រព្រះថេរៈដ៏ចំរើន ឮថាឥឡូវនេះ ព្រះថេរៈជាម្ចាស់ ច្រើននៅដោយធម៌ ជាគ្រឿងនៅ ជារបស់មហាបុរស បពិត្រព្រះថេរៈដ៏ចំរើន ក៏ឯធម៌ជាគ្រឿងនៅជារបស់មហាបុរសនេះ គឺសេចក្តីស្ងប់ស្ងាត់ ឬសូន្យនេះឯង។ ព្រះសព្វកាមីពោលថា ម្នាលលោកដ៏ចំរើន កាលពីដើមដែលខ្ញុំនៅជាគ្រហស្ថនៅឡើយ តែងសន្សំនូវសេចក្តីស្ងប់ស្ងាត់ ឬសូន្យ ព្រោះហេតុនោះ បានជាក្នុងកាលឥឡូវនេះ ខ្ញុំច្រើននៅដោយធម៌ជាគ្រឿងនៅស្ងប់ស្ងាត់ ឬសូន្យ ម្យ៉ាងទៀត ខ្ញុំបានសម្រេចនូវព្រះអរហត្តជាយូរដែរហើយ។

[៣១២] ពាក្យជាចន្លោះ របស់ភិក្ខុជាថេរៈនេះ នៅមិនទាន់ស្រេចនៅឡើយ។ ក៏ស្រាប់តែព្រះសម្ភូតសាណវាសីមានអាយុមកដល់។ ទើបព្រះសម្ភូតសាណវាសីមានអាយុ ចូលទៅរកព្រះសព្វកាមីមានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសព្វកាមីមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះព្រះសម្ភូតសាណវាសីមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបពោលពាក្យនេះនឹងព្រះសព្វកាមីមានអាយុថា បពិត្រព្រះករុណាដ៏ចំរើន ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលីទាំងនេះ សំដែងវត្ថុទាំង១០ប្រការ ក្នុងក្រុងវេសាលីថា ការកំណត់ដោយអំបិលក្នុងក្លាក់ គួរ ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់ គួរ ការកំណត់ដោយចន្លោះស្រុក គួរ ការកំណត់ដោយអាវាស គួរ ការកំណត់ដោយអនុមតិ គួរ ការកំណត់ដោយអាចិណ្ណៈ គួរ ការកំណត់ដោយទឹកដោះ ដែលមិនទាន់ជូរ គួរ ការផឹកនូវសុរាឆៅ គួរ និសីទនៈមិនមានជាយ គួរ មាសនិងប្រាក់ គួរ បពិត្រព្រះថេរៈដ៏ចំរើន ធម៌ក្តី វិន័យក្តី ដែលព្រះថេរៈជាម្ចាស់ បានរៀនសូត្រមកច្រើនហើយ ក្នុងសំណាក់នៃព្រះឧបជ្ឈាយ៍ បពិត្រព្រះថេរៈដ៏ចំរើន កាលដែលព្រះថេរៈពិចារណានូវធម៌ និងវិន័យ មានសេចក្តីចូលចិត្តដូចម្តេច ពួកភិក្ខុណាដែលជាធម្មវាទី គឺពួកភិក្ខុដែលនៅក្នុងទិសខាងកើតឬ ៗពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ។ ព្រះសព្វកាមីពោលតបវិញថា ម្នាលអាវុសោ ធម៌ក្តី វិន័យក្តី ជាច្រើន ដែលលោកបានរៀនសូត្រមកហើយ ក្នុងសំនាក់នៃព្រះឧបជ្ឈាយ៍ ម្នាលអាវុសោ ចុះកាលលោកពិចារណានូវធម៌ និងវិន័យ មានសេចក្តីចូលចិត្តដូចម្តេច ពួកភិក្ខុណាដែលជាធម្មវាទី គឺពួកភិក្ខុដែលនៅក្នុងទិសខាងកើតឬ ៗពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ។ ព្រះសម្ភូតសាណវាសី ពោលថា បពិត្រព្រះថេរៈដ៏ចំរើន កាលដែលខ្ញុំពិចារណានូវធម៌និងវិន័យ មានសេចក្តីចូលចិត្តយ៉ាងនេះថា ពួកភិក្ខុដែលនៅក្នុងទិសខាងកើតជាអធម្មវាទី ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យជាធម្មវាទី ប៉ុន្តែខ្ញុំព្រះករុណានៅមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិ (សេចក្តីយល់) នៅឡើយ ធ្វើដូចម្តេច សង្ឃគប្បីសន្មតខ្ញុំព្រះករុណា ក្នុងអធិករណ៍នេះ។ ព្រះសព្វកាមីពោលថា ម្នាលអាវុសោ កាលដែលខ្ញុំពិចារណានូវធម៌ និងវិន័យ ក៏មានសេចក្តីចូលចិត្តយ៉ាងនេះដែរថា ពួកភិក្ខុដែលនៅក្នុងទិសខាងកើត ជាអធម្មវាទី ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ជាធម្មវាទី ប៉ុន្តែខ្ញុំក៏នៅមិនទាន់ធ្វើឲ្យជាក់ច្បាស់ នូវទិដ្ឋិនៅឡើយ ធ្វើដូចម្តេច សង្ឃគប្បីសន្មតខ្ញុំ ក្នុងអធិករណ៍នេះផង។

[៣១៣] គ្រានោះ សង្ឃមានប្រាថ្នានឹងវិនិច្ឆ័យ កាត់សេចក្តីអធិករណ៍នោះ ក៏ប្រជុំគ្នា។ ក៏កាលដែលសង្ឃកំពុងវិនិច្ឆ័យអធិករណ៍នោះ កើតមានពាក្យជជែកគ្នា រកទីបំផុតគ្មានផង ទាំងសេចក្តីអធិប្បាយនៃភាសិតនីមួយ ក៏គ្មានអ្នកណាដឹងបានផង។ លំដាប់នោះ ព្រះរេវតមានអាយុ បានសូត្រប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលដែលយើងទាំងឡាយកំពុងវិនិច្ឆ័យអធិករណ៍នេះ កើតមានពាក្យជជែកគ្នា រកទីបំផុតគ្មានផង ទាំងសេចក្តីអធិប្បាយនៃភាសិតនីមួយ ក៏គ្មានអ្នកណាដឹងបានផង។ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម។[37] ជំនុំសង្ឃ ជ្រើសរើសយកភិក្ខុ ដែលនៅក្នុងទិសខាងកើត៤រូប យកពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ៤រូប ចំណែកខាងពួកភិក្ខុ ដែលនៅក្នុងទិសខាងកើត គឺព្រះសព្វកាមីមានអាយុ១ ព្រះសាឡ្ហៈមានអាយុ១ ព្រះខុជ្ជសោភិតៈមានអាយុ១ ព្រះវាសភគាមិកៈមានអាយុ១ ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ គឺព្រះរេវតមានអាយុ១ ព្រះសម្ភូតសាណវាសីមានអាយុ១ ព្រះយសកាកណ្ឌកបុត្តមានអាយុ១ ព្រះសុមនៈមានអាយុ១។ លំដាប់នោះ ព្រះរេវតមានអាយុ បានសូត្រប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលបើយើងទាំងឡាយវិនិច្ឆ័យអធិករណ៍នេះទៅ កើតមានពាក្យជជែកគ្នា រកទីបំផុតគ្មានផង ទាំងសេចក្តីអធិប្បាយនៃភាសិតនីមួយ ក៏គ្មានអ្នកណាដឹងបានផង។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតពួកភិក្ខុ ដែលនៅក្នុងទិសខាងកើត៤រូប ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ៤រូប ដើម្បីនឹងរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលបើយើងទាំងឡាយ កំពុងវិនិច្ឆ័យអធិករណ៍នេះ កើតមានពាក្យជជែកគ្នា រកទីបំផុតគ្មានផង ទាំងសេចក្តីអធិប្បាយនៃភាសិតនីមួយ ក៏គ្មានអ្នកណាដឹងបានផង។ សង្ឃបានសន្មតពួកភិក្ខុ ដែលនៅក្នុងទិសខាងកើត៤រូប ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ៤រូប ដើម្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម។ ការសន្មតពួកភិក្ខុ ដែលនៅក្នុងទិសខាងកើត៤រូប ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ៤រូប ដើម្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម គាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ គប្បីពោលឡើង។ សង្ឃបានសន្មតពួកភិក្ខុ ដែលនៅក្នុងទិសខាងកើត៤រូប និងពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ៤រូប ដើម្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម។ ការសន្មតិនេះ គាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម។ ខ្ញុំចាំទុក នូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ។

[៣១៤] សម័យនោះឯង មានភិក្ខុ១រូប ឈ្មោះអជិត បួសបាន១០វស្សា ជាអ្នកសំដែងបាតិមោក្ខដល់សង្ឃ។ លំដាប់នោះ សង្ឃក៏សន្មតអជិតមានអាយុ ឲ្យជាអ្នកក្រាលអាសនៈ ដល់ពួកភិក្ខុជាថេរៈ។ គ្រានោះ ពួកភិក្ខុជាថេរៈ មានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយ គប្បីរម្ងាប់អធិករណ៍នេះ ក្នុងទីណាហ្ន៎។ ទើបភិក្ខុជាថេរៈទាំងឡាយ មានសេចក្តីរិះគិតដូច្នេះតទៅទៀតថា វាលិការាមនេះឯង ជាទីគួរត្រេកអរ មានសំឡេងតិច មានសូរគឹកកងក៏តិច បើដូច្នោះ គួរយើងទាំងឡាយ ទៅរម្ងាប់អធិករណ៍នេះ ក្នុងវាលិការាមចុះ។ លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយ មានសេចក្តីប្រាថ្នានឹងរម្ងាប់អធិករណ៍នោះ ក៏នាំគ្នាទៅកាន់វាលិការាម។

[៣១៥] គ្រានោះឯង ព្រះរេវតមានអាយុ បានសូត្រប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្ម មានកាលគួរ ដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យនឹងព្រះសព្វកាមីមានអាយុ។ ព្រះសព្វកាមីមានអាយុ ក៏សូត្រប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្ឃតិកម្ម មានកាលគួរដល់សង្ឃហើយ ព្រះរេវត ត្រូវសួរវិន័យចំពោះខ្ញុំ ៗត្រូវដោះស្រាយក្នុងកាលឥឡូវនេះ។

[៣១៦] ទើបព្រះរេវតមានអាយុ ពោលដូច្នេះនឹងព្រះសព្វកាមីមានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអំបិលក្នុងក្លាក់ គួរដែរឬ។ ព្រះសព្វកាមីសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអំបិលក្នុងក្លាក់នោះ តើដូចម្តេច។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុរក្សាអំបិលដោយក្លាក់ ដោយគិតថា ភោជនដែលសាប មានក្នុងកាលណា អាត្មាអញ នឹងឆាន់ក្នុងកាលនោះ ដូច្នេះ គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ចុះព្រះមានព្រះភាគ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ព្រះមានព្រះភាគ ទ្រង់ឃាត់ក្នុងសុត្តវិភង្គ[38) ] ក្នុងក្រុងសាវត្ថី។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីប្រាប់ថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់វត្ថុដែលសន្សំទុក។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុជាបឋមនេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកនេះជាបឋម។

[៣១៧] ព្រះរេវតសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់ គួរដែរឬ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់នោះ តើដូចម្តេច។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន កាលបើស្រមោលព្រះអាទិត្យ កន្លងទៅប្រមាណពីរធ្នាប់ ភិក្ខុឆាន់ភោជនក្នុងវេលាវិកាល គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ចុះព្រះអង្គ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងរាជគ្រឹះ។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះបរិភោគក្នុងកាលខុស។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី២នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី២នេះ។

[៣១៨] ព្រះរេវតសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយចន្លោះស្រុក គួរដែរឬ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយចន្លោះស្រុកនោះ តើដូចម្តេច។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុគិតថា អញនឹងទៅកាន់ចន្លោះស្រុកឥឡូវនេះ ហើយឆាន់ភោជន ហាមភោជនរួចហើយ ក៏ឆាន់ភោជនដែលភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនជាវត្ថុសល់ដែលអំពីភិក្ខុឈឺ គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ព្រះអង្គ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ព្រះអង្គ ទ្រង់ហាមឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីប្រាប់ថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់ភោជន ដែលភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនជាវត្ថុសល់ដែលអំពីភិក្ខុឈឺ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី៣នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី៣នេះ។

[៣១៩] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអាវាស គួរដែរឬ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយអាវាសនោះ តើដូចម្តេច។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន អាវាសច្រើន មានសីមាស្មើគ្នា ភិក្ខុធ្វើឧបោសថកម្មផ្សេងៗគ្នា គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ព្រះមានព្រះភាគ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងឧបោសថសំយុត្ត (ឧបោសថក្ខន្ធកៈ) ក្នុងក្រុងរាជគ្រឹះ។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិទុក្កដ ព្រោះប្រព្រឹត្តល្មើសព្រះវិន័យ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី៤នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី៤នេះ។

[៣២០] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអនុមតិ គួរដែរឬ។ គួរដែរឬ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយអនុមតិនោះ តើដូចម្តេច។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន សង្ឃជាពួក ធ្វើសង្ឃកម្មដោយគិតថា យើងទាំងឡាយនឹងឲ្យពួកភិក្ខុដែលមកដល់ យល់ព្រម ឬត្រេកអរជាខាងក្រោយ គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ព្រះអង្គ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងវិនយវត្ថុ ក្នុងចម្មេយ្យក្ខន្ធកៈ។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិទុក្កដ ព្រោះប្រព្រឹត្តល្មើសព្រះវិន័យ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី៥នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី៥នេះ។

[៣២១] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអាចិណ្ណៈ គួរដែរឬ។ ព្រះសព្វការមីសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអាចិណ្ណៈនោះ តើដូចម្តេច។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុប្រព្រឹត្ត ដោយគិតថា អំពើនេះ ព្រះឧបជ្ឈាយ៍របស់យើង ធ្លាប់សន្សំមកហើយ អំពើនេះ អាចារ្យរបស់យើងធ្លាប់សន្សំមកហើយ ដូច្នេះ គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ ការកំណត់ដោយអាចិណ្ណៈគួរខ្លះ មិនគួរខ្លះ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី៦នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី៦នេះ។

[៣២២] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរ គួរដែរឬ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរនោះ តើដូចម្ដេច។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ទឹកដោះស្រស់ណា ដែលលះបង់ភាវៈជាទឹកដោះស្រស់ហើយ តែនៅមិនទាន់ដល់នូវភាវៈជាទឹកដោះជូរនៅឡើយ ភិក្ខុឆាន់ភោជនរួចហើយ ហាមភោជនរួចហើយ ផឹកទឹកដោះជាអនតិរិត្តនោះ គឺភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនជារបស់សល់ដែលអំពីភិក្ខុឈឺ គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ព្រះអង្គ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី។ ព្រះរេវតសួរថា ភិក្ខុនោះត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់អនតិរិត្តភោជន។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ វត្ថុទី៧នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្ដា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី៧នេះ។

[៣២៣] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុផឹកសុរាឆៅ គួរដែរឬ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ សុរាឆៅនោះ តើដូចម្ដេច។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន សុរាណាដែលខ្សោយ ឆៅ មិនទាន់ដល់ភាវៈជាទឹកស្រវឹងនៅឡើយ ភិក្ខុផឹកសុរានោះ គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ព្រះអង្គ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងកោសម្ពី។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះផឹកសុរា និងមេរ័យ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ វត្ថុទី៨នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្ដា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី៨នេះ។

[៣២៤] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន និសីទនៈ ដែលគ្មានជាយ គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ព្រះអង្គ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះវត្ថុមានកិរិយាកាត់ ជាវិនយកម្ម។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ វត្ថុទី៩នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្ដា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី៩នេះ។

[៣២៥] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន មាសនិងប្រាក់ គួរដែរឬ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ។ ព្រះរេវតសួរថា ព្រះអង្គ ទ្រង់ឃាត់ក្នុងទីណា។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងរាជគ្រឹះ។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះទទួលមាស និងប្រាក់។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ វត្ថុទី១០នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្ដា ដោយប្រការដូច្នេះឯង។ ខ្ញុំដាក់ចុះនូវស្លាកទី១០នេះ។

[៣២៦] ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ វត្ថុទាំង១០ប្រការនេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ។ វត្ថុទាំង១០ប្រការនេះ ខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្ដា ដោយប្រការដូច្នេះឯង។

[៣២៧] ព្រះសព្វកាមីពោលថា ម្នាលអាវុសោ អធិករណ៍នេះ សង្ឃបានជម្រះហើយ បានរម្ងាប់ស្ងប់ស្ងាត់ល្អហើយ ម្នាលអាវុសោ ម្យ៉ាងទៀត លោកគប្បីសួរវត្ថុទាំង១០ប្រការនេះ នឹងខ្ញុំ ក្នុងកណ្ដាលសង្ឃម្ដងទៀត ដើម្បីបញ្ជាក់ដល់ភិក្ខុទាំងនោះ។ លំដាប់នោះ ព្រះរេវតមានអាយុ ក៏សួរនូវវត្ថុទាំង១០ប្រការនេះ នឹងព្រះសព្វកាមីមានអាយុ ក្នុងកណ្ដាលសង្ឃម្ដងទៀត។ លុះព្រះរេវត បានសួរសព្វគ្រប់ហើយ ព្រះសព្វកាមីមានអាយុ ក៏ឆ្លើយដោះស្រាយ។ ក៏ក្នុងការសង្គាយនាព្រះវិន័យនេះ មានភិក្ខុ៧០០អង្គ មិនខ្វះ មិនលើស។ ព្រោះហេតុនោះ ការសង្គាយនាព្រះវិន័យនេះ បានឈ្មោះថា សត្តសតិកាសង្គាយនា។

ចប់ សត្តសតិកក្ខន្ធកៈ ទី១២តែប៉ុណ្ណេះ។

ក្នុងខន្ធកៈនេះ មានរឿង២៥។

ឧទ្ទាននៃ សត្តសតិកក្ខន្ធកៈ នោះ ដូច្នេះ

[៣២៨]

រឿងវជ្ជីបុត្តកភិក្ខុនៅក្នុងក្រុងវេសាលី សំដែងនូវវត្ថុ១០ប្រការ១ រឿងវជ្ជីបុត្តកភិក្ខុដងទឹកដាក់ពេញភាជន៍សំរិទ្ធ ក្នុងថ្ងៃឧបោសថនោះ១ រឿងពួកវជ្ជីបុត្តកភិក្ខុធ្វើបដិសារណីយកម្ម ដល់ព្រះយសកាកណ្ឌកបុត្ត១ រឿងព្រះយសកាកណ្ឌកបុត្តចូលទៅកាន់ក្រុងវេសាលី ជាមួយនឹងភិក្ខុជាអនុទូត១ រឿងឧបក្កិលេសរបស់ព្រះចន្ទ និងព្រះអាទិត្យមាន៤យ៉ាង និង ឧបក្កិលេសរបស់សមណៈមាន៤យ៉ាង១ រឿងពាក្យជជែកគ្នាថា មាសនិងប្រាក់គួរដល់ពួកសមណៈឬទេ១ រឿងព្រះយសកាកណ្ឌកបុត្ត ហោះតាមអាកាសទៅចុះក្នុងក្រុងកោសម្ពី១ រឿងព្រះយសកាកណ្ឌកបុត្ត បញ្ជូនទូតឲ្យទៅកាន់សំណាក់នៃភិក្ខុដែលនៅក្នុងដែនបាឋេយ្យ និងភិក្ខុដែលនៅក្នុងដែន អវន្តិទក្ខិណាបថ[39] ១ រឿងព្រះរេវតគង់នៅក្នុងនគរសោរេយ្យ១ រឿងព្រះរេវតចេញពីនគរសោរេយ្យ ទៅកាន់នគរសង្កស្ស១ រឿងព្រះរេវត ចេញពីនគរសង្កស្ស ទៅកាន់នគរកណ្ណកុជ្ជ១ រឿងព្រះរេវត ចេញពីនគរកណ្ណកុជ្ជ ទៅកាន់នគរឧទុម្ពរ១ រឿងព្រះរេវត ចេញពីនគរអគ្គឡបុរៈ ទៅកាន់នគរសហជាតិ១ រឿងព្រះរេវត បង្គាប់ភិក្ខុជាកូនសិស្សឲ្យជាអ្នកពោលសរភញ្ញ១ រឿងពួកវជ្ជីបុត្តកភិក្ខុឮដំណឹងថា ព្រះយសកាកណ្ឌកបុត្តប្រាថ្នានឹងជំរះអធិករណ៍១ រឿងវជ្ជីបុត្តកភិក្ខុ រិះគិតថា យើងបានភិក្ខុណាជាបក្ខពួក១ រឿងវជ្ជីបុត្តកភិក្ខុ ចាត់ចែងសមណបរិក្ខារ មានបាត្រជាដើម ហើយនាំគ្នាជិះទូកឆ្លងឡើងទៅកាន់

សហជាតិនគរ១ រឿងព្រះសាឡ្ហៈមានអាយុ សម្ងំនៅក្នុងទីស្ងាត់១ រឿងព្រះឧត្តរៈមានអាយុដំណាលប្រាប់ពួកវជ្ជីបុត្តកភិក្ខុថា ពួកមនុស្សតែងបង្អោនសមណបរិក្ខារ ទៅថ្វាយព្រះមានព្រះភាគ១ រឿងព្រះឧត្តរៈមានអាយុ ដំណាលប្រាប់ពួកវជ្ជីបុត្តកភិក្ខុថា យើងទៅកាន់យកនិស្ស័យនឹងព្រះរេវតជាគ្រូ១ រឿងជំនុំសង្ឃប្រជុំគ្នា និងវិនិច្ឆ័យអធិករណ៍១ រឿងពួកភិក្ខុជាថេរៈ ប្រាថ្នានឹងវិនិច្ឆ័យអធិករណ៍ ហើយនាំគ្នាទៅកាន់ក្រុងវេសាលី១ រឿងព្រះសព្វកាមីសួរព្រះរេវតថា ឥឡូវនេះ លោកនៅដោយធម៌ជាគ្រឿងនៅដូចម្តេច ព្រះរេវតឆ្លើយថា ខ្ញុំនៅដោយអំណាចនៃមេត្តាធម៌១ រឿងជំនុំសង្ឃ ប្រជុំគ្នាវិនិច្ឆ័យអធិករណ៍នោះ១ រឿងព្រះរេវត សូត្រប្រកាសសង្ឃឲ្យដឹងថា ត្រូវឲ្យសង្ឃរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម១។

ចប់ ចុល្លវគ្គ។

# មាតិកា


| **ចុល្លវគ្គ** | លេខ ទំព័រ |
| --- | --- |
| **ភាគ ទី៣ តតិយភាគ** | **១** |
| **សង្ឃភេទក្ខន្ធកៈ** | **១** |
| ព្រះមានព្រះភាគគង់នៅក្នុងអនុបិយានិគម ទៀបព្រៃអនុបិយា | ១ |
| រឿងអនុរុទ្ធសក្កៈ និងភទ្ទិយសក្យរាជ | ៣ |
| រឿងសក្យៈ ៦ អង្គ | ៧ |
| រឿងឧបាលិកប្បកៈ | ៨ |
| ពួកសក្យៈកុមារចូលទៅគាល់ព្រះមានព្រះភាគ | ៩ |
| ព្រះភទ្ទិយៈ បានសម្រេចនូវវិជ្ជា ៣យ៉ាង | ១០ |
| ឧទ្ទានគាថា និងរឿងទេវទត្តភិក្ខុ | ១៣ |
| រឿងអជាតសត្តុកុមារ | ១៤ |
| រឿងកូនអ្នកស្រុកកោឡិយៈ ឈ្មោះកក្កុធៈ | ១៥ |
| រឿងព្រះមហាមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ | ១៦ |
| រឿងទេវបុត្រឈ្មោះកក្កុធៈ | ១៨ |
| និយាយអំពីគ្រូ ៥ ពួក | ១៩ |
| រឿងព្រះអង្គស្តេចទៅកាន់ក្រុងរាជគ្រឹះ | ២១ |
| និគមគាថា | ២៥ |
| រឿងទេវទត្តភិក្ខុ ទូលសូមត្រួតភិក្ខុសង្ឃជំនួស | ២៦ |
| ការធ្វើបកាសនីយកម្មដល់ទេវទត្ត | ២៧ |
| បកាសនីយកម្ម និងរឿងព្រះសារីបុត្ត | ២៩ |
| រឿងទេវទត្តភិក្ខុ និងរឿងអជាតសត្តុកុមារ | ៣៣ |
| សេចក្តីវិនិច្ឆ័យនៃពួកមហាមាត្យ | ៣៤ |
| ការបញ្ជូនបុរសទៅសម្លាប់ព្រះសាស្តា | ៣៦ |
| អនុបុព្វីកថា ព្រះអង្គសម្តែងចំពោះបុរសដែលទៅសម្លាប់ព្រះអង្គ | ៣៩ |
| ការធ្វើព្រះលោហិតនៃព្រះតថាគតឲ្យពុរពងឡើង | ៤២ |
| និយាយអំពីគ្រូ ៥ ពួក | ៤៤ |
| ការលែងដំរីនាឡាគិរីឲ្យព្រេចព្រះសាស្តា | ៤៥ |
| ព្រះសាស្តាសម្តែងគាថាចំពោះដំរីនាឡាគិរី | ៥១ |

| | |
|---|---|
| ពួកមនុស្សនាំគ្នាច្រៀងគាថាសរសើរព្រះបរមគ្រូ | ៥២ |
| រឿងតិកភោជន | ៥៣ |
| រឿងទេវទត្តភិក្ខុ សម្តែងអំពី វត្ថុ ៥ ប្រការ | ៥៥ |
| រឿងទេវទត្តភិក្ខុ ក្រាបបង្គំទូលសូមវត្ថុ ៥ប្រការ | ៥៦ |
| ការព្យាយាម ដើម្បីទម្លាយសង្ឃ និងទម្លាយចក្រ | ៥៩ |
| ឧទ្ទានគាថា | ៦០ |
| រឿងព្រះសារីបុត្ត និងព្រះមោគ្គល្លាន | ៦៣ |
| ការសម្តែងធម៌របស់ទេវទត្ត | ៦៥ |
| បាដិហារ្យរបស់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន | ៦៦ |
| អគ្គសាវ័កទាំង ២ អង្គ ចូលទៅគាល់ព្រះមានព្រះភាគ | ៦៧ |
| ព្រះបរមគ្រូត្រាស់សម្តែងអំពីរឿងដំរី | ៦៨ |
| និគមគាថា និងភិក្ខុប្រកបដោយអង្គ ៨ ប្រការ | ៦៩ |
| រឿងទេវទត្តភិក្ខុ និងអសទ្ធម្ម ៨ ប្រការ | ៧០ |
| រឿងទេវទត្តភិក្ខុ ត្រូវអសទ្ធម្ម ៣ ប្រការ គ្របសង្កត់ និងឧទ្ទានគាថា | ៧៤ |
| រឿងព្រះឧបាលិត្ថេរ ទូលសួរអំពីការប្រេះឆានៃសង្ឃ | ៧៦ |
| រឿងព្រះឧបាលិត្ថេរ ទូលសួរអំពីសង្ឃភេទ | ៧៧ |
| រឿងព្រះឧបាលិត្ថេរ និងសេចក្តីព្រមព្រៀងនៃសង្ឃ | ៧៨ |
| និគមគាថា | ៨២ |
| រឿងព្រះឧបាលិត្ថេរ និងភិក្ខុអ្នកបំបែកសង្ឃទៅកើតក្នុងអបាយ | ៨៥ |
| បញ្ជីរឿងនៃសង្ឃភេទក្ខន្ធកៈ | ៩០ |
| **វត្តក្ខន្ធកៈ** | **៩៣** |
| ហេតុនៃការទ្រង់បញ្ញត្តិអាគន្តុកវត្ត | ៩៣ |
| ហេតុនៃការទ្រង់បញ្ញត្តិអាវាសិកវត្ត | ១០០ |
| គមិកវត្ត | ១០៣ |
| គមិកវត្ត និងការអនុមោទនាក្នុងរោងភត្ត | ១០៥ |
| វត្តដែលភិក្ខុត្រូវធ្វើក្នុងរោងភត្ត | ១០៧ |
| វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត | ១១៥ |
| វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត និងវត្តរបស់ភិក្ខុអ្នកនៅក្នុងព្រៃ | ១១៩ |
| សេនាសនវត្ត | ១២៣ |
| ជន្តាឃរវត្ត | ១២៩ |
| និទាននៃវច្ចកុដិវត្ត | ១៣១ |
| ការទ្រង់បញ្ញត្តិវច្ចកុដិវត្ត | ១៣៤ |
| ឧបជ្ឈាយវត្ត | ១៣៧ |
| សទ្ធិវិហារិកវត្ត | ១៤៨ |
| អាចរិយវត្ត | ១៥៦ |
| អន្តេវាសិកវត្ត | ១៥៧ |
| ឧទ្ទាននៃវត្តក្ខន្ធកៈ | ១៧៥ |

| | |
|---|---|
| **បាតិមោក្ខដ្ឋបនក្ខន្ធកៈ** | **២០០** |
| ព្រះអានន្ទសូមអារាធនាឲ្យព្រះអង្គសំដែងបាតិមោក្ខ | ២០០ |
| រឿងព្រះមហាមោគ្គល្លាន | ២០២ |
| ធម្មតាមិនដែលកើតគួរអស្ចារ្យ ៨ យ៉ាង ក្នុងមហាសមុទ្រ | ២០៥ |
| សភាពមិនដែលកើតគួរអស្ចារ្យ ៨ យ៉ាង ក្នុងធម្មវិន័យ | ២០៩ |
| ឧទ្ទានវាចា | ២១៦ |
| រឿងឆព្វគ្គិយភិក្ខុ | ២១៧ |
| ការបញ្ឈប់បាតិមោក្ខ | ២១៩ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខ ១ - ២ យ៉ាង | ២២០ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខ ៣ - ៤ យ៉ាង | ២២០ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខ ៤ - ៥ យ៉ាង | ២២២ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខ ៦ យ៉ាង | ២២៣ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខ ៧ យ៉ាង | ២២៤ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខ ៨ យ៉ាង | ២២៥ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខ ៨ - ៩ យ៉ាង | ២២៦ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខ ១០ យ៉ាង | ២២៧ |
| និយាយអំពីការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ | ២៣១ |
| ព្រះឧបាលិ ក្រាបទូលសួរការកាន់យកអត្តាទាន | ២៤១ |
| ព្រះឧបាលិ ក្រាបទូលសួរការចោទ | ២៤៥ |
| ព្រះឧបាលិ ក្រាបទូលសួរហេតុវិប្បដិសារៈ ចំពោះភិក្ខុអ្នកចោទ | ២៤៩ |
| ឧទ្ទាននៃបាតិមោក្ខដ្ឋបនក្ខន្ធកៈ | ២៥៥ |
| **ភិក្ខុនីខន្ធកៈ** | **២៦០** |
| ព្រះនាងមហាបជាបតីគោតមី ទូលសូមបព្វជ្ជា | ២៦០ |
| គរុធម៌ ៨ យ៉ាង | ២៦៦ |
| ព្រហ្មចរិយធម៌ មិនតាំងនៅយូរអង្វែង | ២៧១ |
| រឿងព្រះនាងមហាបជាបតីគោតមី និងការសូមពរ | ២៧៣ |
| លក្ខណៈនៃការវិនិច្ឆ័យធម្មវិន័យ | ២៧៨ |
| ភិក្ខុមិនសំដែងបាតិមោក្ខ ដល់ពួកភិក្ខុនី | ២៨០ |
| ការទទួលអាបត្តិ | ២៨១ |
| ការធ្វើកម្មដល់ពួកភិក្ខុនី | ២៨៣ |
| រឿងភិក្ខុនីជាសិស្សរបស់ឧប្បលវណ្ណា | ២៨៥ |
| ការបង្ហាញកាយជាដើម ទណ្ឌកម្ម និង អវន្ទិយបុគ្គល | ២៨៧ |
| ឆព្វគ្គិយាភិក្ខុនី សាចភក់ និងទឹកទៅលើពួកភិក្ខុ | ២៨៨ |
| ការបង្ហាញកាយជាដើម ទណ្ឌកម្ម និងការបញ្ឈប់ឱវាទ | ២៨៩ |
| ការបញ្ឈប់ឱវាទរបស់ភិក្ខុល្ងង់ជាដើម | ២៩១ |
| ការសន្មតិភិក្ខុឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី | ២៩៣ |
| ការទទួលឲ្យឱវាទនៃភិក្ខុទាំងឡាយ | ២៩៥ |

| | |
|---|---|
| ការទទួលឲ្យឱវាទហើយមិនមកប្រាប់ជាដើម | ២៩៧ |
| ការឲ្យដំត្រគាកដោយឈើមានសណ្ឋានដូចឆ្អឹងគោជាដើម | ២៩៩ |
| ការធ្វើគំនូសខាងក្រោមមាត់ជាដើម | ៣០១ |
| កាលកិរិយារបស់ភិក្ខុនី ១ រូប | ៣០៣ |
| ភិក្ខុនី ដាក់កូនខ្ចីក្នុងបាត្រ | ៣០៥ |
| ភិក្ខុនី នាំគ្នាគយគន់និមិត្តបុរស | ៣០៧ |
| ទ្រង់អនុញ្ញាតឲ្យទទួលការសន្សំ របស់ភិក្ខុទាំងឡាយ | ៣០៩ |
| ទ្រង់អនុញ្ញាតឲ្យនូវចីវរ ក្នុងរោងទានជាដើម | ៣១១ |
| អន្តរាយិកធម៌ ២៤ យ៉ាង | ៣១៣ |
| ការសន្មតិខ្លួនឯង និងសន្មតិភិក្ខុនីដទៃ | ៣១៥ |
| ញត្តិចតុត្ថកម្មឧបសម្បទា | ៣១៧ |
| ការហាមឃាត់នូវទីតាមលំដាប់ចាស់ខ្ចី និងការមិនបវារណា | ៣២៥ |
| ការបវារណារបស់ភិក្ខុនីសង្ឃ | ៣២៧ |
| ការឃាត់ឧបោសថ និងឃាត់បវារណា | ៣២៨ |
| ការទ្រង់អនុញ្ញាតគ្រែស្នែងជាដើម | ៣៣១ |
| ញត្តិចតុត្ថកម្មឧបសម្បទា ដោយទូត | ៣៣៣ |
| រឿងស្រីម្នាក់ និងការសន្មតិភិក្ខុនី | ៣៣៧ |
| ការសន្មតិភិក្ខុនី និងការមិនពោលលាសិក្ខារបស់ភិក្ខុនី | ៣៣៩ |
| រឿងពួកភិក្ខុនីអង្គុយពែនភ្នែន និងបន្ទោបង់វច្ចៈក្នុងបង្គន់ | ៣៤១ |
| ការងូតទឹករបស់ពួកភិក្ខុនី | ៣៤២ |
| ឧទ្ទានគឺបញ្ជីរឿងនៃភិក្ខុនីខន្ធកៈ | ៣៤៤ |
| **បញ្ចសតិកក្ខន្ធកៈ** | **៣៥៧** |
| ឱវាទរបស់ព្រះមហាកស្សបមានអាយុ | ៣៥៧ |
| ការសន្មតិភិក្ខុ ៥០០ រូប | ៣៥៩ |
| កិច្ចមានការជួសជុលទីដែលធ្លុះធ្លាយជាដើម | ៣៦១ |
| ព្រះមហាកស្សបមានអាយុ ប្រកាសជំនុំសង្ឃ | ៣៦២ |
| ការសង្គាយនាសិក្ខាបទ មានទុតិយបារាជិកជាដើម | ៣៦៣ |
| ពោលអំពីសិក្ខាបទតូច និងតូចដោយលំដាប់ | ៣៦៥ |
| ព្រះអានន្ទត្រូវមារគ្របដណ្តប់ចិត្ត | ៣៧១ |
| ការដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុ | ៣៧៣ |
| រឿងព្រះបាទឧទេន និងការថ្វាយសំពត់ឧត្តរាសង្គៈ | ៣៧៥ |
| រឿងឆន្នត្ថេរ និងការដាក់ព្រហ្មទណ្ឌដល់លោក | ៣៧៩ |
| ឧទ្ទាននៃបញ្ចសតិកក្ខន្ធកៈ | ៣៨១ |
| **សត្តសតិកក្ខន្ធកៈ** | **៣៨៥** |
| រឿងវជ្ជីបុត្តកភិក្ខុ និងរឿងព្រះយសត្ថេរ | ៣៨៥ |
| ឧបក្កិលេស ៤ យ៉ាង របស់ព្រះចន្ទ្រ និងព្រះអាទិត្យ | ៣៨៧ |
| ឧបក្កិលេស ៤ យ៉ាង របស់សមណព្រាហ្មណ៍ | ៣៨៩ |

| | |
|---|---|
| ឧបក្កិលេស ទាំង ៤ | ៣៩១ |
| រឿងអ្នកធំឈ្មោះមណិចូឡកៈ | ៣៩៣ |
| ពាក្យរបស់ព្រះថេរៈឈ្មោះ យសកាកណ្ឌកបុត្ត | ៣៩៤ |
| រឿងព្រះថេរៈឈ្មោះ សម្ភូតសាណវាសី | ៣៩៧ |
| សេចក្តីត្រិះរិះរបស់ពួកភិក្ខុជាថេរៈ | ៣៩៩ |
| រឿងព្រះរេវតត្ថេរ | ៤០១ |
| ការសួរ និងការដោះស្រាយនូវវត្ថុ ១០ ប្រការ | ៤០៣ |
| សេចក្តីត្រិះរិះរបស់ពួកវជ្ជីបុត្តកភិក្ខុ | ៤០៧ |
| រឿងវជ្ជីបុត្តកភិក្ខុ | ៤០៩ |
| សេចក្តីប្រាថ្នា ដើម្បីនឹងវិនិច្ឆ័យនូវអធិករណ៍ | ៤១៣ |
| ពាក្យជាចន្លោះរបស់ពួកភិក្ខុជាថេរៈ | ៤១៥ |
| សេចក្តីប្រាថ្នា ដើម្បីនឹងវិនិច្ឆ័យនូវអធិករណ៍ | ៥១៧ |
| រឿងអជិតភិក្ខុ | ៤១៩ |
| បុច្ឆាវិសជ្ជនានូវវត្ថុ ១០ ប្រការ | ៤២១ |
| ឧទ្ទាននៃសត្តសតិកក្ខន្ធកៈ | ៤២៩ |


ភាគ ទី១០ | **មាតិកា** | ភាគ ទី១២

1)
ជាក្យត្រធ្លាប់បានសេចក្តីសុខ មិនដែលបានសេចក្តីលំបាក ដោយខ្យល់ និងកំដៅថ្ងៃជាដើម
2)
ភោជនដែលឆាន់បានត្រឹមបីរូប បើភិក្ខុតាំងពី៤រូបឡើងទៅ ឆាន់មិនបាន។
3)
សំដែងដឹងចិត្តរបស់បុគ្គលដទៃ ហៅថា អាទេសនាបាដិហារ្យ។
4)
ធម៌ទេសនាទាំងអស់ ហៅថា អនុសាសនីបាដិហារ្យ។
5)
ប្រៀនប្រដៅដោយឫទ្ធិជាអស្ចារ្យ ហៅថា ឥទ្ធិប្បាដិហារ្យ (ដីកា)។
6) , 7)
ប៉ែកខាងធម្មវាទី
8)
ជាអធម្មវាទី។ (អដ្ឋកថា
9)
ភិក្ខុដែលមានខ្លួនជាប្រក្រតី គឺភិក្ខុដែលសង្ឃមិនបានលើកវត្ត ឬភិក្ខុដែលបរិសុទ្ធ ឥតមានត្រូវគរុកាបត្តិណាមួយ។
10)
សំដៅយកអាបត្តិ៦កង គឺសង្ឃាទិសេស១ ថុល្លច្ច័យ១ បាចិត្តិយៈ១ បាដិទេសនីយៈ១ ទុក្កដ១ ទុព្ភាសិត១។
11)
សំដៅយកបារាជិកាបត្តិ (អដ្ឋកថា)។
12)
ភិក្ខុអ្នកនៅក្នុងអាវាស
13)
អដ្ឋកថា ថា អាគន្តុកភិក្ខុ ត្រូវសួររកទីភិក្ខាចារយ៉ាងនេះថា គោចរគ្រាមនោះ នៅជិត ឬនៅឆ្ងាយ ត្រូវចេញទៅបិណ្ឌបាតអំពីពេលព្រឹក ឬពេលថ្ងៃ។
14)
អគោចរគ្រាម បានដល់ភូមិ ឬស្រុករស់ពួកមិច្ឆាទិដ្ឋិ ឬទីដែលគេឈប់ដាក់បិណ្ឌបាតហើយ។

15)

អដ្ឋកថា ថា គ្រឿងឈើបានដល់គ្រែ និងតាំងជាដើម។

16)

គ្រឿងដីបានដល់ភាជន៍សម្រាប់ជ្រលក់ជាដើម។ ចូរមើលសេចក្តីពិស្តារក្នុងសេនាសនក្ខន្ធកៈ។

17)

សេនាសនៈ ដែលគេទើរលើខ្នងថ្មក្តី លើសសរថ្មក្តី ដែលពួកសត្វកណ្តៀរឡើងទៅបៀតបៀនមិនបាន ទុកជាភិក្ខុមិនអើពើ ក៏មិនត្រូវអាបត្តិឡើយ។

18)

អដ្ឋកថា ថា ប្រុសក្តី ស្រីក្តី បិណ្ឌចារិកភិក្ខុ មិនគប្បីមើលមុខគេ ក្នុងខណៈដែលគេប្រគេនចង្ហាន់។

19)

អដ្ឋកថា ថា បើមានទឹក តែគ្មានទីកំបាំង ភិក្ខុត្រូវដងទឹកដោយភាជន៍យកមកជម្រះ (ក្នុងទីកំបាំង)។ បើគ្មានភាជន៍សម្រាប់ដងទឹក ត្រូវដងដោយបាត្រ។ បើបាត្រក៏គ្មាន ទាំងវត្ថុឯទៀតក៏គ្មាន។ ភិក្ខុត្រូវតាំងចិត្តថា ទីនេះស្រឡះណាស់ ខាងមុខគង់មានទឹក លុះទៅរកទឹកមិនបាន ក៏ដល់ពេលភិក្ខាចារ ភិក្ខុនោះនឹងជូតដោយឈើ ឬវត្ថុអ្វីមួយក៏បាន។

20)

អដ្ឋកថា ថា វច្ចកុដិ១ ទីបន្ទោបង់បស្សាវៈ១ កំពង់សម្រាប់ងូតទឹក១ ទាំង៣កន្លែងនេះ គួរប្រកាន់តាមលំដាប់ភិក្ខុដែលទៅដល់ (មុនក្រោយ)។

21)

អដ្ឋកថា ពន្យល់ថា ភិក្ខុមានប្រាថ្នានឹងជម្រះនូវសាសនា ហើយកាន់យកអធិករណ៍ណា ដោយខ្លួនឯង អធិករណ៍នោះ ហៅថា អត្តាទាន គឺជាឈ្មោះនៃអធិករណ៍ម្យ៉ាង ដែលមានភិក្ខុរ៉ាប់រងដោយខ្លួនឯង។

22)

អដ្ឋកថាពន្យល់ថា ចងរឹងឆ្អឹងជំនីរឲ្យទន់ដោយវត្ថពន្ធចង្កេះ ហាក់ដូចជានាងទារិកា ជាគ្រហស្ថ រុំដោយសំពត់ចោមពុង គឺសំពត់បិទដោះ។

23)

អដ្ឋកថា ពន្យល់ថា ពួកភិក្ខុនីយកថ្នាំបន្តក់ភ្នែក ទៅធ្វើជាគំនូសខាងក្រោមមាត់ត្រង់កន្លែងណាដែលវៀចៗ ឬខូងៗ។

24)

តាមទំនងពាក្យខ្មែរខ្លះ គួរប្រែថា អៀម។

25)

ក្នុងអដ្ឋកថា ប្រាប់សេចក្តីថា រវល់រៀបចំអាសនៈ ត្រូវប្រាប់ឲ្យភិក្ខុនីដទៃក្រោកចេញ ហើយឲ្យភិក្ខុនីឯទៀតអង្គុយ ត្រង់កន្លែងនោះយ៉ាងនេះ ទាល់តែហួសពេលឆាន់។

26)

ក្នុងដីកាថា បុថុជ្ជន សោតាបន្នបុគ្គល និងសកទាគាមិបុគ្គល ហៅថា បុគ្គលមិនទាន់ប្រាសចាករាគៈក្នុងទីនេះ។

27)

លើកដៃទាំងពីរដាក់លើក្បាល ហើយទួញយំ។

28)

ក្នុងដីកាថា ព្រះអនាគាមី និងព្រះខីណាស្រព។

29)

ពួកភិក្ខុជាបុត្តនៃជនដែលនៅក្នុងដែនវជ្ជី បានជាហៅដោយរួបរួមថា វជ្ជីបុត្តកភិក្ខុ។

30)

ប្រែថា យល់ព្រម ថា ត្រេកអរ

31)

ព្រះយសត្ថេរ ជាបុត្តនៃព្រាហ្មណ៍ ឈ្មោះកាកណ្ឌកៈ ហៅដោយរួបរួមថា យសកាកណ្ឌកបុត្ត។

32)

អដ្ឋកថាព្រះសូត្រថា ពាក្យជាចន្លោះនៃគុណធម៌ មានកម្មដ្ឋានមនសិការ និងបាឡី និងអដ្ឋកថា ជាដើម ហៅថា អន្តរាកថា។

33)

ក្នុងសារត្ថទីបនីថា សង្ឃគិតថា ពួកភិក្ខុដែលមិនទាន់មកដល់ លុះមកដល់ហើយ សឹមយើងកាន់យកសេចក្តីយល់ព្រម លុះគិតដូច្នេះហើយ ពួកភិក្ខុទាំងនោះ មិនទាន់មកដល់នៅឡើយ សង្ឃក៏នាំគ្នាធ្វើសង្ឃកម្មជាពួក ហើយកាន់យកនូវការយល់ព្រមជាខាងក្រោយ គួរដែរ។ កម្មជាពួកមិនមានឡើយ។

34)

ក្នុងវិមតិវិនោទនីថា សុរាដែលគេផ្សំដោយគ្រឿងប្រុងរួចហើយ។

35)

ក្នុងវិមតិវិនោទនីថា ព្រះថេរៈនោះ ចាស់ជាងភិក្ខុទាំងអស់ក្នុងលោក ក្នុងគ្រានោះ។

36)

ក្នុងសារត្ថទីបនីថា ធម៌ជាគ្រឿងនៅដ៏តូច មិនជ្រៅ ឬរាក់។

37)
ក្នុងអដ្ឋកថាព្រះសូត្រថា ការជ្រើសរើសយកភិក្ខុអំពីគណៈសង្ឃ ដើម្បីរម្ងាប់អធិករណ៍ ដែលកើតមានឡើង ហៅថា ឧព្វាហិកា។
38)
ក្នុងយោជនាថា ពាក្យដែលព្រះមានព្រះភាគចែកបទមាតិកា ហៅថា សុត្តវិភង្គ ក្នុងសារត្ថទីបនីដីកាថា បទភាជនីយ ហៅថា សុត្តវិភង្គ។
39)
មានតែក្នុងបាលីខាងដើម ក្នុងឧទ្ទានគ្មាន មានតែ មគ្គោវិញ ប្រហែលជាមគ្គសព្ទនេះ លោកផ្លាស់ប្តូរជំនួសសព្ទ គឺអវន្តិទក្ខិណាបថ ទេដឹង។

sangham.net
Virtual AccessToInsight

-Namo tassa bhagavato arahato sammā-

**ព្រះត្រៃបិដកភាសាខ្មែរ - Tipiṭaka Khmer language**

ភាគ ០១២ - Book 012

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថាលោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០១២ - Tipitaka Book 012 [http://forum.sangham.net/index.php/topic,9192.0.html], for change log on ati.eu see here: រាយការណ៍ ភាគ ០១២

ភាគ ទី១១ | **មាតិកា** | ភាគ ទី១៣




គំរូ ឯកសារ ផ្សេងទៀត ៖
book_012.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី១២

ទ. ១

# វិន័យបិដក

CS vin | ភាគ ទី១២

**ភាគ ទី១២**

# បរិវារៈ

CS vin.pv | ភាគ ទី១២

**(បរិវារ)**

**បឋមភាគ**
ភាគ ទី១

**សោឡសមហាវារៈ**
១. ភិក្ខុវិភង្គ | ២. ភិក្ខុនីវិភង្គ
**សមុដ្ឋានសីសសង្ខេបៈ** | **អន្តរបេយ្យាលៈ**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

# (សោឡសមហាវារៈ)

CS vin.pv.01 | ភាគ ទី១២

(សោឡសមហាវារោ)

# មហាវិភង្គ មហាវារៈ ១៦

CS vin.pv.01.1 | ភាគ ទី១២

### (១. ភិក្ខុវិភង្គោ)

## កត្ថប្បញ្ញត្តិវារៈ

CS vin.pv.01.1.01 | ភាគ ទី១២

### (១. កត្ថបញ្ញត្តិវារោ)

### (បារាជិកកណ្ឌៈ ទី១)

CS vin.pv.01.1.01.1 | ភាគ ទី១២

### (១. បារាជិកកណ្ឌំ)

[១] សួរថា បឋមបារាជិក ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ (នូវកាលនៃការបញ្ញត្តសិក្ខាបទ) ឃើញច្បាស់ (នូវប្រយោជន៍១០យ៉ាង នៃការបញ្ញត្តសិក្ខាបទ) ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ព្រោះរឿងរ៉ាវដូចម្តេច។ (បញ្ញត្តិ៩យ៉ាងគឺ) បញ្ញត្តិ១ អនុប្បញ្ញត្តិ១ អនុប្បន្នប្បញ្ញត្តិ១ សព្វត្ថប្បញ្ញត្តិ១ បទេសប្បញ្ញត្តិ១ សាធារណប្បញ្ញត្តិ១ អសាធារណប្បញ្ញត្តិ១ ឯកតោបញ្ញត្តិ១ ឧភតោបញ្ញត្តិ១ មានក្នុងបឋមបារាជិកនោះដែរឬទេ។ បណ្តាបាតិមោក្ខុទ្ទេសទាំង៥ បឋមបារាជិក ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូល ក្នុងឧទ្ទេសណា មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា។ បណ្តាវិបត្តិ៤យ៉ាង បឋមបារាជិកចាត់ជាអ្វី។ បណ្តាកងនៃអាបត្តិទាំង៧ បឋមបារាជិក ចាត់ចូលក្នុងកងអាបត្តិណា។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង បឋមបារាជិក តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង។ បណ្តាអធិករណ៍ទាំង៤យ៉ាង បឋមបារាជិក ចាត់ចូលក្នុងអធិករណ៍ណា។ បណ្តាសមថៈទាំង៧យ៉ាង បឋមបារាជិក រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ អ្វីជាវិន័យក្នុងបឋមបារាជិកនោះ អ្វីជាអភិវិន័យក្នុងបឋមបារាជិកនោះ អ្វីជាបាតិមោក្ខក្នុងបឋមបារាជិកនោះ អ្វីជាអធិប្បាតិមោក្ខ ក្នុងបឋមបារាជិកនោះ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ អ្វីជាសេចក្តីប្រតិបត្តិ (ក្នុងបឋមបារាជិកនោះ)។ បឋមបារាជិក ព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង។ ជនពួកណាសិក្សា។ ជនពួកណា ដែលមានសិក្ខាសិក្សាហើយ។ បឋមបារាជិក ឋិតនៅក្នុងជនពួកណា។ ជនពួកណាទ្រទ្រង់ទុក។ បឋមបារាជិក ជាពាក្យរបស់នរណា។ នរណានាំមក។

[២] សួរថា បឋមបារាជិក ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ទ្រង់បញ្ញត្តក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវសុទិន្នភិក្ខុជាកូននៃកលន្ទសេដ្ឋី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលសុទិន្នភិក្ខុជាបុត្ត នៃកលន្ទសេដ្ឋី សេពមេថុនធម្មនឹងបុរាណទុតិយិកា (ភរិយារបស់ខ្លួនពីដើម)។ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ មានក្នុងបឋមបារាជិកនោះដែរឬទេ។ មានតែបញ្ញត្តិ[1] ១ និងអនុប្បញ្ញត្តិ[2] ២ ឯអនុប្បន្នប្បញ្ញត្តិ[3] មិនមានក្នុងបឋមបារាជិកនោះទេ។ បឋមបារាជិកនោះ ជាសព្វត្ថប្បញ្ញត្តិ[4] ឬជាបទេសប្បញ្ញត្តិ។[5] ជាសព្វត្ថប្បញ្ញត្តិ។ បឋមបារាជិកនោះ ជាសាធារណប្បញ្ញត្តិ[6] ឬជាអសាធារណប្បញ្ញត្តិ។[7] ជាសាធារណប្បញ្ញត្តិ។ បឋមបារាជិកនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។[8] ជាឧភតោបញ្ញត្តិ។ បណ្តាបាតិមោក្ខុទ្ទេសទាំង៥ យ៉ាង បឋមបារាជិក ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ បឋមបារាជិក ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន។ បឋមបារាជិកមកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី២។ បណ្តាវិបត្តិ៤យ៉ាង បឋមបារាជិក ចាត់ជាវិបត្តិអ្វី។ ចាត់ជាសីលវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង៧ បឋមបារាជិក ចាត់ចូលក្នុងកងនៃអាបត្តិណា។ ចាត់ចូលក្នុងកង នៃអាបត្តិបារាជិក។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦ យ៉ាង បឋមបារាជិក តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង។ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយ នឹងចិត្ត មិនតាំងឡើអំពីវាចាទេ។ បណ្តាអធិករណ៍ទាំង៤ យ៉ាង បឋមបារាជិក ចាត់ជាអធិករណ៍ណា។ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈទាំង៧យ៉ាង បឋមបារាជិករម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ រម្ងាប់ដោយសមថៈពីរយ៉ាង គឺដោយសម្មុខាវិន័យ១ បដិញ្ញាតករណៈ១។ អ្វីជាវិន័យក្នុងបឋមបារាជិកនោះ អ្វីជាអភិវិន័យក្នុងបឋមបារាជិកនោះ។ បញ្ញត្តិ ជាវិន័យ វិភត្តិ (បទភាជនៈ) ជាអភិវិន័យ ក្នុងបឋមបារាជិកនោះ។ អ្វីជាបាតិមោក្ខ ក្នុងបឋមបារាជិកនោះ អ្វីជាអធិប្បាតិមោក្ខ ក្នុងបឋមបារាជិកនោះ។ បញ្ញត្តិ ជាបាតិមោក្ខ វិភត្តិ (បទភាជនៈ) ជាអធិប្បាតិមោក្ខ។ អ្វីជាវិបត្តិ។ សេចក្តីមិនសង្រួមជាវិបត្តិ។ អ្វីជាសម្បត្តិ។ សេចក្តីសង្រួម ជាសម្បត្តិ។ អ្វីជាសេចក្តីប្រតិបត្តិ (ក្នុងបឋមបារាជិកនោះ)។ ភិក្ខុសមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ដរាបអស់ជីវិត មានជីវិតជាទីបំផុតដោយគិតថា អាត្មាអញនឹងមិនធ្វើអំពើមានសភាពយ៉ាងនេះទេ (នេះជាសេចក្តីប្រតិបត្តិ)។ បឋមបារាជិក ព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មាន។ បឋមបារាជិក ព្រះមានព្រះភាគទ្រង់បញ្ញត្តទុកមក ព្រោះអាស្រ័យអំណាចប្រយោជន៍១០យ៉ាង គឺដើម្បីសេចក្តីល្អដល់សង្ឃ១ ដើម្បីនៅសប្បាយដល់សង្ឃ១ ដើម្បីសង្កត់សង្កិន នូវបុគ្គលទំាំងឡាយ ដែលមិនអៀនខ្មាស១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់១ ដើម្បីរារាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក១ ដើម្បីញុំាំងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លាឡើង១ ដើម្បីញុំាំងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើង១ ដើម្បីតាំងនៅមាំ នៃព្រះសទ្ធម្ម១ ដើម្បីអនុគ្រោះដល់វិន័យ១។ ជនពួកណា តែងសិក្សា។ ពួកសេក្ខៈ និងពួកកល្យាណបុថុជ្ជនតែងសិក្សា។ ជនពួកណាដែលមានសិក្ខាសិក្សាហើយ។ ពួកព្រះអរហន្ត មានសិក្ខាសិក្សាហើយ។ បឋមបារាជិកនោះ ឋិតនៅក្នុងពួកជនណា។ ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល (អ្នកប្រាថ្នាការសិក្សា)។ ជនពួកណា រមែងទ្រទ្រង់ទុក។ បឋមបារាជិក ប្រព្រឹត្តទៅដល់ជនពួកណា

ជនពួកនោះ រមែងទ្រទ្រង់ទុក។[9] បឋមបារាជិក ជាពាក្យរបស់អ្នកណា។ ជាពាក្យរបស់ព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ។ អ្នកណានាំមក។ ព្រះថេរៈ (ដូចមាននាមតទៅនេះ) នាំតៗគ្នាមក។

[៣] ព្រះថេរៈឈ្មោះឧបាលិ១ ទាសកៈ១ សោណកៈ១ សិគ្គវៈ១ និងព្រះមោគ្គល្លីបុត្ត១ អង្គទៀត ជាគម្រប់៥ ព្រះថេរៈទាំងនេះ ឋិតនៅក្នុងទ្វីបមានឈ្មោះថា ជម្ពូដ៏មានសិរី។ តអំពីព្រះថេរៈទាំងនោះមក ព្រះមហាមហិន្ទ១ ព្រះឥដ្ឋិយៈ១ ព្រះឧត្តិយៈ១ ព្រះសម្ពលៈ១ ព្រះភទ្ទនាមជាបណ្ឌិត១ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន មកអំពីជម្ពូទ្វីប ហើយបានមកនៅក្នុងលង្កាទ្វីប ព្រះថេរៈទាំងនោះ បានបង្រៀនវិនយបិដក បានបង្រៀននិកាយទាំង៥ គម្ពីរ ព្រះអភិធម្មទាំង៧គម្ពីរ ក្នុងតម្ពបណ្ណិទ្វីប (កោះលង្កា)។ តអំពីនោះមក (មានព្រះថេរៈច្រើនអង្គទៀតគឺ) ព្រះអរិដ្ឋ ជាអ្នកមានប្រាជ្ញា១ ព្រះតិស្សទត្តជាបណ្ឌិត១ ព្រះកាឡសុមនត្ថេរជាអ្នកក្លៀវក្លា១ ព្រះទីឃនាមកៈ១ ព្រះទីឃសុមនៈ ជាបណ្ឌិត១ ព្រះកាឡសុមនៈ១ ព្រះនាគត្ថេរ១ ព្រះពុទ្ធរក្ខិត១ ព្រះតិស្សត្ថេរ ជាអ្នកមានប្រាជ្ញា១ ព្រះទេវត្ថេរជាបណ្ឌិត១ ព្រះសុមនៈ មានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ១ ព្រះចូឡនាគ ជាពហុស្សុត១ ព្រះគជត្ថេរ ជាអ្នកកម្ចាត់បង់ទោសដ៏អាក្រក់១ ព្រះថេរៈ ឈ្មោះធម្មបាលិត ដែលគេបូជាហើយដោយប្រពៃ ក្នុងរោហណជនបទ១ សិស្សរបស់ព្រះធម្មបាលិតនោះ ឈ្មោះខេមៈ ជាអ្នកមានប្រាជ្ញាច្រើន ទ្រទ្រង់ព្រះត្រៃបិដក រុងរឿងដោយបញ្ញាក្នុងទ្វីប ដូចជាព្រះចន្ទ១ ព្រះថេរៈឈ្មោះឧបតិស្សៈ ជាអ្នកមានប្រាជ្ញា១ ព្រះបុស្សទេវៈ ដែលជាមហាធម្មកថិក១ ព្រះសុមនៈ អ្នកមានប្រាជ្ញា១ ព្រះបុប្ផៈ ជាពហុស្សុត១ ព្រះមហាសីវៈ ជាមហាធម្មកថិកឈ្លាសវៃ ក្នុងបិដកទាំងអស់១ ព្រះឧបាលិ ជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ១ ព្រះមហានាគ ជាអ្នកមានប្រាជ្ញាច្រើនឈ្លាសវៃ ក្នុងវង្សព្រះសទ្ធម្ម១ ព្រះអភ័យ ជាអ្នកមានប្រាជ្ញាឈ្លាសវៃ ក្នុងបិដកទាំងអស់១ ព្រះតិស្សត្ថេរ ជាអ្នកមានប្រាជ្ញាដ៏ក្លៀវក្លាក្នុងវិន័យ១ សិស្សរបស់ព្រះតិស្សត្ថេរនោះ ឈ្មោះបុស្សៈ ជាអ្នកមានប្រាជ្ញាច្រើនជាពហុស្សុត ជាអ្នករក្សាព្រះសាសនា ប្រតិស្ឋានទុកក្នុងជម្ពូទ្វីប១ ព្រះចូឡាភ័យ ជាអ្នកមានប្រាជ្ញា ក្លៀវក្លាក្នុងវិន័យ១ ព្រះតិស្សត្ថេរ ជាអ្នកមានប្រាជ្ញាឈ្លាសវៃ ក្នុងវង្សព្រះសទ្ធម្ម១ ព្រះចូឡាទេវៈ ជាអ្នកមានប្រាជ្ញាក្លៀវក្លាក្នុងវិន័យ១ ព្រះសីវត្ថេរ ជាអ្នកមានប្រាជ្ញាឈ្លាសវៃ ក្នុងវិន័យទាំងអស់១ ព្រះនាគត្ថេរទាំងនេះ សុទ្ធតែជាអ្នកមានប្រាជ្ញាច្រើន ចេះវិន័យស្ទាត់ក្នុងមគ្គ បានប្រកាសវិនយបិដកទុកក្នុងតម្ពបណ្ណិទ្វីប (លង្កាទ្វីប)។

[៤] សួរថា ទុតិយបារាជិក ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តក្នុងទីណា។ ឆ្លើយថា ទុតិយបារាជិក ព្រះអង្គ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវធនិយភិក្ខុ ជាកូននៃស្មូនឆ្នាំង។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវ ដែលធនិយភិក្ខុ ជាកូននៃស្មូនឆ្នាំង យកឈើរបស់ព្រះរាជា ដែលទ្រង់មិនបានប្រទាន។ ទុតិយបារាជិកនេះ មានតែបញ្ញត្តិ១ អនុប្បញ្ញត្តិ១ ឯអនុប្បន្នប្បញ្ញត្តិ មិនមានឡើយ។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦យ៉ាង ទុតិយបារាជិក តាំងឡើងដោយសមុដ្ឋាន៣យ៉ាង គឺតាំងឡើងអំពីកាយ និងចិត្ត មិនតាំងឡើងអំពីវាចា១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត១។បេ។

[៥] សួរថា តតិយបារាជិក ព្រះអង្គ ទ្រង់បញ្ញត្តក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុទាំងឡាយច្រើនរូប ផ្តាច់ជីវិតគ្នានិងគ្នា។ តតិយបារាជិកនេះ មានតែបញ្ញត្តិ១ អនុប្បញ្ញត្តិ១ ឯអនុប្បន្នប្បញ្ញត្តិ មិនមានឡើយ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង តតិយបារាជិក តាំងឡើងដោយសមុដ្ឋាន៣យ៉ាង គឺតាំងឡើងអំពីកាយ និងចិត្ត មិនតាំង ឡើងអំពីវាចា១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ១ តាំងឡើងអំពីកាយ អំពីវាចា និងចិត្ត១។បេ។

[៦] សួរថា ចតុត្ថបារាជិក ព្រះអង្គ បញ្ញត្តក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុទាំងឡាយ ដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទា។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវ ដែលភិក្ខុទាំងឡាយ អ្នកនៅទៀបឆ្នេរស្ទឹងវគ្គុមុទា នាំគ្នាពោលអួតនូវគុណ នៃឧត្តរិមនុស្សធម្មនៃគ្នានិងគ្នា ដល់គ្រហស្ថទាំងឡាយ។ ចតុត្ថបារាជិកនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១ ឯអនុប្បន្នប្បញ្ញត្តិ មិនមានឡើយ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង ចតុត្ថបារាជិក តាំងឡើងដោយសមុដ្ឋាន៣យ៉ាងគឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត១។បេ។

ចប់ បារាជិក ៤។

ឧទ្ទានគឺបញ្ជីរឿងនៃបារាជិកនោះ ដូច្នេះ

[៧]

បារាជិក៤ គឺ សេពមេថុន១ លួចទ្រព្យគេ១ សម្លាប់មនុស្ស១ ពោលអួតឧត្តរិមនុស្សធម្ម១ ជាឆេជ្ជវត្ថុ (វត្ថុជាហេតុឱ្យដាច់ចាកភិក្ខុភាវៈ) បណ្ឌិតមិនត្រូវសង្ស័យឡើយ។

## (សង្ឃាទិសេសកណ្ឌៈ ទី២)

CS vin.pv.01.1.01.2 | ភាគ ទី១២

### (២. សង្ឃាទិសេសកណ្ឌំ)

[៨] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិក្នុងទីណា។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ព្រោះរឿងរ៉ាវដូចម្តេច។ បញ្ញត្តិ១ អនុប្បញ្ញត្តិ១ អនុប្បន្នប្បញ្ញត្តិ១ សព្វត្ថប្បញ្ញត្តិ១ បទេសប្បញ្ញត្តិ សាធារណប្បញ្ញត្តិ១ អសាធារណប្បញ្ញត្តិ១ ឯកតោបញ្ញត្តិ១ ឧភតោបញ្ញត្តិ១ មានក្នុងបឋមសង្ឃាទិសេសនោះដែរឬទេ។ បណ្តាបាតិមោក្ខុទ្ទេស

ទាំង៥យ៉ាង បឋមសង្ឃាទិសេស ចាត់ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា។ បណ្ដាវិបត្តិ៤យ៉ាង បឋមសង្ឃាទិសេស ចាត់ជាវិបត្តិអ្វី។ បណ្ដាកងនៃអាបត្តិទាំង៧យ៉ាង បឋមសង្ឃាទិសេស ចាត់ចូលក្នុងកងអាបត្តិណា។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង បឋមសង្ឃាទិសេស តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង។ បណ្ដាអធិករណ៍ទាំង៤យ៉ាង បឋមសង្ឃាទិសេស ចាត់ជាអធិករណ៍អ្វី។ បណ្ដាសមថៈទាំង៧យ៉ាង បឋមសង្ឃាទិសេស រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យ ក្នុងសិក្ខាបទនោះ អ្វីជាបាតិមោក្ខ ក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខ ក្នុងសិក្ខាបទនោះ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ សេចក្ដីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្ដេច។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នកព្យាយាមបញ្ចេញអសុចិ តើព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង។ ជនពួកណាតែងសិក្សា។ ជនពួកណាមានសិក្ខាសិក្សាហើយ។ សិក្ខាបទនោះ ឋិតនៅក្នុងជនពួកណា។ ជនពួកណាតែងទ្រទ្រង់ទុក។ សិក្ខាបទនោះ ជាពាក្យរបស់នរណា។ នរណានាំមក។

[៩] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុអ្នកព្យាយាមបញ្ចេញអសុចិក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវសេយ្យសកភិក្ខុមានអាយុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវ ដែលសេយ្យសកភិក្ខុមានអាយុ ព្យាយាមបញ្ចេញអសុចិដោយដៃ។ បញ្ញត្តិ១ អនុប្បញ្ញត្តិ១ អនុប្បន្នប្បញ្ញត្តិ១ មានក្នុងសិក្ខាបទនោះដែរឬទេ។ មានតែបញ្ញត្តិ១ អនុប្បញ្ញត្តិ១ ឯអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះទេ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ ជាសព្វត្ថប្បញ្ញត្តិ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ។ ជាអសាធារណប្បញ្ញត្តិ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ ជាឯកតោបញ្ញត្តិ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង៥យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន។ សិក្ខាបទនោះ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី៣។ បណ្ដាវិបត្តិទាំង៤ សិក្ខាបទនោះ ចាត់ជាវិបត្តិអ្វី។ ចាត់ជាសីលវិបត្តិ។ បណ្ដាកងនៃអាបត្តិទាំង៧ សិក្ខាបទនោះ ចាត់ចូលក្នុងកង នៃអាបត្តិណា។ ចាត់ចូលក្នុងកង នៃអាបត្តិសង្ឃាទិសេស។ បណ្ដាសមុដ្ឋាន នៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង។ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។ បណ្ដាអធិករណ៍ទាំង៤ សិក្ខាបទនោះ ចាត់ចូលក្នុងអធិករណ៍ណា។ ចាត់ចូលក្នុងអាបត្តាធិករណ៍។ បណ្ដាសមថៈទាំង៧ សិក្ខាបទនោះ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ រម្ងាប់ដោយសមថៈពីរយ៉ាងគឺ សម្មុខាវិន័យ១ បដិញ្ញាតករណៈ១។ អ្វីជាវិន័យ ក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យ ក្នុងសិក្ខាបទនោះ។ បញ្ញត្តិជាវិន័យ វិភត្តិ ជាអភិវិន័យ។ អ្វីជាបាតិមោក្ខ ក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខ ក្នុងសិក្ខាបទនោះ។ បញ្ញត្តិ ជាបាតិមោក្ខ វិភត្តិ ជាអធិប្បាតិមោក្ខ។ អ្វីជាវិបត្តិ។ ការមិនសង្រួមជាវិបត្តិ។ អ្វីជាសម្បត្តិ។ ការសង្រួមជាសម្បត្តិ។ សេចក្ដីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្ដេច។ ភិក្ខុសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដល់អស់ជីវិត មានជីវិតជាទីបំផុត ដោយគិតថា អញនឹងមិនធ្វើកម្ម យ៉ាងនេះទេ (នេះជាសេចក្ដីប្រតិបត្តិ)។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិ តើព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុព្យាយាមបញ្ចេញអសុចិ ព្រោះអាស្រ័យអំណាចប្រយោជន៍១០យ៉ាង គឺដើម្បីសេចក្ដីល្អដល់សង្ឃ១ ដើម្បីសេចក្ដីសប្បាយដល់សង្ឃ១ ដើម្បីសង្កត់សង្កិន នូវបុគ្គលទាំងឡាយ ដែលមិនមានអៀនខ្មាស១ ដើម្បីកិរិយានៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់១ ដើម្បីរារាំង នូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន១ ដើម្បីកម្ចាត់បង់ នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក១ ដើម្បីញុំាងជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លាឡើង១ ដើម្បីញុំាងជនទាំងឡាយ ដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាឡើង១ ដើម្បីតម្កល់នៅមាំ នៃព្រះសទ្ធម្ម១ ដើម្បីអនុគ្រោះដល់វិន័យ១។ ពួកជនណាតែងសិក្សា។ សេក្ខបុគ្គល និងកល្យាណបុថុជ្ជនតែងសិក្សា។ ជនពួកណាដែលមានសិក្ខាសិក្សាហើយ។ ព្រះអរហន្តមានសិក្ខាសិក្សាហើយ។ សិក្ខាបទនោះឋិតនៅក្នុងបុគ្គលពួកណា។ ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល។ ជនពួកណាតែងទ្រទ្រង់ទុក។ សិក្ខាបទនោះតែងប្រព្រឹត្តទៅ ដល់ជនពួកណា ជនពួកនោះតែងទ្រទ្រង់ទុក។ សិក្ខាបទនោះ ជាពាក្យរបស់នរណា។ ជាពាក្យរបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ។ សិក្ខាបទនោះ លោកអង្គណានាំមក។ (ព្រះ ថេរៈដែលមាននាមដូចតទៅនេះ) នាំតៗគ្នាមក។

> ព្រះថេរៈឈ្មោះឧបាលិ១ ទាសកៈ១ សោណកៈ១ សិគ្គវៈ១ ព្រះមោគ្គលីបុត្ត១អង្គទៀត ជាគម្រប់ ៥ ព្រះថេរៈទាំងនេះ ឋិតនៅក្នុងទ្វីបមានឈ្មោះថា ជម្ពូដ៏មានសិរី។ តអំពីនោះមក ព្រះមហិន្ទត្ថេរ១ ព្រះឥដ្ដិយៈ១ ព្រះឧត្តិយៈ១ ព្រះសម្ពលៈ១។បេ។ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន ជាអ្នកចេះព្រះវិន័យ ឈ្លាសក្នុងមគ្គ បានប្រកាសវិនយបិដកទុក ក្នុងតម្ពបណ្ណិទ្វីប។

[១០] សួរថា ព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុដែលស្ទាបអង្អែលកាយមាតុគ្រាម ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវ ព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ ស្ទាបអង្អែលកាយមាតុគ្រាម។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។បេ។

[១១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះ ភិក្ខុដែលនិយាយចែចង់មាតុគ្រាម ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវ ដែលព្រះឧទាយិមានអាយុ និយាយចែចង់មាតុគ្រាម។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង គឺតាំងឡើងដោយកាយនិងចិត្ត មិនតាំងឡើងអំពីវាចា១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ១ តាំងឡើងអំពីកាយ អំពីវាចានិងចិត្ត។បេ។

[១២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពាះភិក្ខុ ដែលនិយាយសរសើរការបម្រើដោយកាម ដើម្បីខ្លួនក្នុងសម្នាក់មាតុគ្រាម ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវ ដូចម្ដេច។ ព្រោះ

រឿងរ៉ាវដែលព្រះឧទាយិមានអាយុ និយាយសរសើរ ការបម្រើដោយកាម ដើម្បីខ្លួន ក្នុងសម្នាក់មាតុគ្រាម។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង។ បេ។

[១៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេស ចំពោះភិក្ខុដែលប្រព្រឹត្តនិយាយដឹកនាំក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្ត ក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធ នូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិ មានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ និយាយដឹកនាំ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងអំពីសមុដ្ឋានទាំង៦យ៉ាងគឺ តាំងឡើងអំពីកាយ មិនតាំង ឡើងអំពីវាចានិងចិត្ត១ តាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយ និងចិត្ត១ តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត១ តាំងឡើង អំពីកាយ និងចិត្ត មិនតាំងឡើងអំពីវាចា១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ១ តាំងឡើងអំពីកាយ អំពីវាចា និងចិត្ត១។បេ។

[១៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះ ភិក្ខុដែលឱ្យគេធ្វើកុដិ (មិនមានទាយកជាម្ចាស់របស់) ដោយការសូមគ្រឿងឧបករណ៍របស់គេមក ដោយខ្លួនឯង ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុ ទាំងឡាយដែលនៅក្នុងនគរអាឡវី។ ព្រោះរឿងរ៉ាវដូចម្តេច ព្រោះរឿង រ៉ាវដែលភិក្ខុទាំងឡាយ នៅក្នុងនគរអាឡវី ឱ្យគេធ្វើកុដិ (មិនមានទាយកជាម្ចាស់របស់) ដោយការសូមគ្រឿងឧបករណ៍របស់គេមកដោយខ្លួនឯង។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង។ បេ។

[១៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះ ភិក្ខុដែលឱ្យគេធ្វើវិហារធំ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុ ជម្រះ ទីវិហារ បានប្រើគេឱ្យកាប់ដើមឈើ ដែលគេសន្មតថាជាចេតិយ១ដើម។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[១៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះ ភិក្ខុដែលចោទ (បង្កាច់) ភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុចោទ (បង្កាច់) ព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិក មិនមានមូល។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង។ បេ។

[១៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះ ភិក្ខុដែលចោទ (បង្កាច់) ភិក្ខុផងគ្នា ដោយអាបត្តិបារាជិក ព្រោះអាស្រ័យហេតុបន្តិចបន្តួច របស់អធិករណ៍ ជាចំណែកដទៃ មកជាគ្រឿងអាង ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវមេត្តិយ ភិក្ខុនិងភុម្មជកភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះ រឿងរ៉ាវដែលមេត្តិយភិក្ខុ និងភុម្មជកភិក្ខុចោទ (បង្កាច់) ព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិក ព្រោះអាស្រ័យហេតុបន្តិចបន្តួច របស់អធិករណ៍ ជាចំណែកដទៃមកជាគ្រឿងអាង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយ សមុដ្ឋាន៣យ៉ាង។ បេ។

[១៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះ ភិក្ខុ(អ្នកព្យាយាម) បំបែកសង្ឃ ដែលសង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ៣ ដងហើយ នៅតែមិនលះបង់ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្ត ក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុឈ្មោះទេវទត្ត។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលទេវទត្តភិក្ខុព្យាយាម ដើម្បីបំបែកសង្ឃ ដែលព្រមព្រៀងគ្នា។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត។ បេ។

[១៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះ ភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តតាមនូវភិក្ខុដែល (ព្យាយាម) បំបែកសង្ឃ សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ៣ ដង នៅតែមិនលះបង់ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុ ទាំងឡាយច្រើនរូប ប្រព្រឹត្តតាមទេវទត្ត ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត។បេ។

[២០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះភិក្ខុអ្នក (រឹងរូស) ប្រដៅបានដោយក្រ សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ៣ ដង នៅតែមិនលះបង់ ក្នុងទីណា។ ទ្រង់បញ្ញត្តក្នុង នគរកោសម្ពី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុ កាលដែលភិក្ខុទាំងឡាយ ពោលទូន្មានប្រកបដោយធម៌ បានធ្វើខ្លួនឱ្យជាអ្នកគឺគេស្តីប្រដៅមិនបាន។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត។ បេ។

[២១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសង្ឃាទិសេសចំពោះ ភិក្ខុអ្នកទ្រុស្តត្រកូល សង្ឃបានសូត្រសមនុភាសនកម្មអស់វារៈ៣ដង នៅតែមិនលះបង់ ក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ។ ព្រោះ រឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ សង្ឃបានធ្វើបព្វជនីយកម្មហើយ (ត្រឡប់ជេរប្រទេច) ថា ភិក្ខុទាំងឡាយ លុះក្នុងអំណាចសេចក្តីស្រឡាញ់ លុះក្នុងអំណាចសេចក្តីស្អប់ លុះក្នុងអំ ណាចសេចក្តីល្ងង់ លុះក្នុងអំណាចសេចក្តីខ្លាច។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង សិក្ខាបទនោះ តាំង ឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចាចិត្ត។បេ។

ចប់ សង្ឃាទិសេស ១៣។

ឧទ្ទាន គឺបញ្ជីរឿងនៃសង្ឃាទិសេសនោះ ដូច្នេះ

[២២]

សង្ឃាទិសេសទាំង១៣ គឺ សុក្កវិស្សដ្ឋិ១ កាយសំសគ្គៈ១ ទុដ្ឋុល្លវាចៈ១ អត្តកាមបារិចរិយៈ១ សញ្ចរិត្តៈ១ កុដិការៈ១ មហល្លកវិហារៈ១ អមូលកៈ១ កញ្ចិទេសៈ(អញ្ញ ភាគិយៈ)១ សង្ឃភេទកៈ១ ភេទានុវត្តកៈ១ ទុព្វចៈ១ កុលទូសកៈ១។

## (អនិយតកណ្ឌៈ ទី៣)

CS vin.pv.01.1.01.3 | ភាគ ទី១២

### (៣. អនិយតកណ្ឌំ)

[២៣] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី១ ក្នុងទីណា។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ព្រោះរឿងរ៉ាវដូចម្ដេច។ បញ្ញត្តិ ១ អនុប្បញ្ញត្តិ១ អនុប្បន្នប្បញ្ញត្តិ១ សព្វត្ថប្បញ្ញត្តិ១ បទេសប្បញ្ញត្តិ១ សាធារណប្បញ្ញត្តិ១ អសាធារណប្បញ្ញត្តិ១ ឯកតោបញ្ញត្តិ១ ឧភតោបញ្ញត្តិ១ មានក្នុងអនិយតៈទី១ នោះដែរឬទេ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង៥យ៉ាង សិក្ខាបទនោះដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា។ បណ្ដាវិបត្តិទាំង ៤ យ៉ាង សិក្ខាបទនោះចាត់ជាវិបត្តិអ្វី។ បណ្ដាកងនៃអាបត្តិទាំង៧ យ៉ាង សិក្ខាបទនោះចាត់ចូលក្នុងអាបត្តិកងណា។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង។ បណ្ដាអធិករណ៍ទាំង៤យ៉ាង សិក្ខាបទនោះ ចាត់ជាអធិករណ៍អ្វី។ បណ្ដាសមថៈទាំង ៧ យ៉ាង សិក្ខាបទនោះ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ អ្វីជាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ។ អ្វីជាវិបត្តិ អ្វីជាសម្បត្តិ សេចក្ដីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្ដេច។ ព្រះមានព្រះភាគទ្រង់បញ្ញត្តអនិយតៈទី១ ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង។ ជនពួកណាតែងសិក្សា។ ជនពួកណា មានសិក្ខាសិក្សាហើយ។ សិក្ខាបទនោះ ឋិតនៅក្នុងជនពួកណា។ ជនពួកណាតែងទ្រទ្រង់ទុក។ សិក្ខាបទនោះ ជាពាក្យរបស់នរណា។ សិក្ខាបទនោះនរណានាំមក។

[២៤] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី១ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែល ព្រះឧទាយិមានអាយុតែម្នាក់ឯង សម្រេចនូវការអង្គុយលើអាសនៈដ៏ស្ងាត់ កំបាំងល្មមធ្វើ (សេវនកិច្ចបាន) ជាមួយនឹងមាតុគ្រាមតែម្នាក់។ បញ្ញត្តិ១ អនុប្បញ្ញត្តិ១ អនុប្បន្នប្បញ្ញត្តិ១ ក្នុងអនិយតៈទី១ នោះ មានដែរឬទេ។ មានតែបញ្ញត្តិ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះទេ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ ជាសព្វត្ថប្បញ្ញត្តិ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ។ ជាអសាធារណប្បញ្ញត្តិ។ សិក្ខាបទនោះ ជាឯក តោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ ជាឯកតោបញ្ញត្តិ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង៥យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ទ្ទេសណា។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី៤។ បណ្ដាវិបត្តិទាំង៤យ៉ាង សិក្ខាបទនោះចាត់ជាវិបត្តិអ្វី។ សិក្ខាបទនោះ ចាត់ជាសីលវិបត្តិក៏មាន ជាអាចារវិបត្តិក៏មាន។ បណ្ដាកងនៃ អាបត្តិទាំង៧ យ៉ាង សិក្ខាបទនោះ ចាត់ជាកងនៃអាបត្តិណា។ ចាត់ជាកង នៃអាបត្តិបារាជិកក៏មាន ចាត់ជាកងនៃអាបត្តិសង្ឃាទិសេសក៏មាន ចាត់ជាកងនៃអាបត្តិបាចិត្តិយៈក៏មាន។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង។ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាទេ។ សួរថា បណ្ដាអធិករណ៍ទាំង៤យ៉ាង សិក្ខាបទនោះចាត់ជាអធិករណ៍អ្វី។ ចាត់ជាអាបត្តាធិករណ៍។ បណ្ដាសមថៈទាំង៧យ៉ាង សិក្ខាបទនោះ រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ រម្ងាប់ដោយសមថៈ៣យ៉ាង គឺដោយសម្មុខាវិន័យ១ បដិញ្ញាតករណៈ១ សម្មុខាវិន័យនិងតិណវត្ថារកៈ១។ អ្វីជាវិន័យក្នុងសិក្ខាបទនោះ អ្វីជាអភិវិន័យក្នុងសិក្ខាបទនោះ។ បញ្ញត្តិ ជាវិន័យ វិភត្តិជាអភិវិន័យ។ អ្វីជាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីជាអធិប្បាតិមោក្ខក្នុងសិក្ខាបទនោះ។ បញ្ញត្តិជាបាតិមោក្ខ វិភត្តិជាអធិប្បាតិមោក្ខ។ អ្វីជាវិបត្តិ សេចក្ដីមិនសង្រួមជាវិបត្តិ។ អ្វីជាសម្បត្តិ។ សេចក្ដីសង្រួមជាសម្បត្តិ។ សេចក្ដីប្រតិបត្តិ (ក្នុងសិក្ខាបទនោះ) ដូចម្ដេច។ ភិក្ខុសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដល់អស់ជីវិត មានជីវិតជាទីបំផុត ដោយសេចក្ដីកំណត់ក្នុងចិត្តថា អញនឹងមិនធ្វើកម្ម មានសភាពយ៉ាងនេះឡើយ (នេះជាសេចក្ដីប្រតិបត្តិ)។ ព្រះមានព្រភាគ ទ្រង់បញ្ញត្តអនិយតៈទី១ ព្រោះអាស្រ័យអំណាចប្រយោជន៍ប៉ុន្មានយ៉ាង។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តអនិយតៈទី១ ព្រោះអាស្រ័យអំណាច ប្រយោជន៍១០យ៉ាង គឺដើម្បីល្អដល់សង្ឃ១ ដើម្បីសេចក្ដីសប្បាយដល់សង្ឃ១ ដើម្បីសង្កត់សង្កិនបុគ្គលដែលមិនអៀនខ្មាស១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុដែលមានសីលជាទីស្រឡាញ់១ ដើម្បីរាំងរានូវអាសវៈទាំងឡាយដែលកើតឡើងក្នុងបច្ចុប្បន្ន១ ដើម្បីកម្ចាត់បង់នូវអាសវៈទាំងឡាយដែលកើតឡើងក្នុងបរលោក១ ដើម្បីញាំងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឱ្យជ្រះថ្លាឡើង១ ដើម្បីញាំងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយឱ្យរឹងរឹតតែជ្រះថ្លាឡើង១ ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម១ ដើម្បីអនុគ្រោះដល់វិន័យ១។ ពួកជនណាតែងសិក្សា។ ពួកសេក្ខបុគ្គលនិងកល្យាណបុថុជ្ជនតែងសិក្សា។ ពួកជនណា មានសិក្ខាសិក្សាហើយ។ ព្រះអរហន្តទាំងឡាយ មានសិក្ខាសិក្សាហើយ។ សិក្ខាបទនោះ ឋិតនៅក្នុងជនពួកណា។ ឋិតនៅក្នុងពួកសិក្ខាកាមបុគ្គល។ ជនពួកណាតែងទ្រទ្រង់ទុក។ សិក្ខាបទនោះប្រព្រឹត្តទៅដល់ពួកជនណា ពួកជននោះតែងទ្រទ្រង់ទុក។ សិក្ខាបទនោះជាពាក្យរបស់នរណា។ ជាពាក្យរបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ។ សិក្ខាបទនោះ នរណានាំមក។ ព្រះថេរៈទាំងឡាយ (ដូចមាននាមតទៅនេះ) នាំតៗគ្នាមក។ ព្រះឧបាលិ១ ព្រះទាសកៈ១ ព្រះសោណកៈ១ ព្រះសិគ្គវៈ១ និងព្រះមោគ្គលីបុត្ត១អង្គទៀតជាគម្រប់៥ ព្រះថេរៈទាំងនេះ នៅក្នុងទ្វីបមានឈ្មោះថាជម្ពូដ៏មានសិរី។ តអំពីនោះមក ព្រះមហិន្ទៈ១ ព្រះឥដ្ដិយៈ១ ព្រះឧត្តិយៈ១ ព្រះសម្ពលៈ១។បេ។ ព្រះនាគត្ថេរទាំងឡាយនេះ មានបញ្ញាច្រើន ចេះព្រះវិន័យ ស្ទាត់ជំនាញក្នុងមគ្គ បានប្រកាសវិនយបិដកទុក ក្នុងតម្ពបណ្ណិទ្វីប។

[២៥] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តអនិយតៈទី២ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលឧទាយិភិក្ខុមានអាយុតែម្នាក់ឯង សម្រេចការអង្គុយក្នុងទីកំបាំងជាមួយនឹងមាតុគ្រាមតែម្នាក់។ បញ្ញត្តិ១ អនុប្បញ្ញត្តិ១ អនុប្បន្នប្បញ្ញត្តិ១ មានក្នុងសិក្ខាបទនោះដែរឬទេ។ មានតែបញ្ញត្តិ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះទេ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ ជាសព្វត្ថប្បញ្ញត្តិ។ សិក្ខាបទ នោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ។ ជាអសាធារណប្បញ្ញត្តិ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ ជាឯកតោបញ្ញត្តិ។ បណ្តាបាតិមោក្ខុទ្ទេសទាំង៥ យ៉ាង សិក្ខាបទនោះ ដាក់ចុះក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ ដាក់ចុះក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន។ សិក្ខាបទនោះ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសណា។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៤។ បណ្តាវិបត្តិទាំង៤យ៉ាង សិក្ខាបទនោះចាត់ជាវិបត្តិអ្វី។ ចាត់ជាសីលវិបត្តិក៏មាន ចាត់ជាអាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិទាំង៧ សិក្ខាបទនោះ ចាត់ជាកងនៃអាបត្តិណា។ ជាកងនៃអាបត្តិសង្ឃាទិសេសក៏មាន ជាកងនៃអាបត្តិបាចិត្តិយៈក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មានយ៉ាង។ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា១ តាំងឡើងអំពីវាចា និងចិត្ត មិនតាំងឡើងអំពីកាយ១ តាំងឡើងអំពីកាយអំពីវាចានិងចិត្ត១។ បណ្តាអធិករណ៍ទាំង៤ យ៉ាង សិក្ខាបទនោះ ចាត់ជាអធិករណ៍ណា។ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈទាំង៧យ៉ាង សិក្ខាបទនោះរម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ រម្ងាប់ដោយសមថៈ៣យ៉ាង គឺដោយសម្មុខាវិន័យ១ បដិញ្ញាតករណៈ ១ ដោយសម្មុខាវិន័យ និងតិណវត្ថារកៈ១។

ចប់ អនិយតៈ ទាំងពីរ។

ឧទ្ទាន គឺបញ្ជីរឿងនៃអនិយតៈនោះ ដូច្នេះ

[២៦]

អនិយតៈ (ទាំងពីរ) គឺ អលង្កម្មនិយៈ១ នាលង្កម្មនិយៈ១ ដែលព្រះពុទ្ធប្រសើរ មានគុណធម៌ដ៏មាំមួន ទ្រង់បញ្ញត្តទុកហើយដោយល្អ។

## (និស្សគ្គិយកណ្ឌៈ ទី៤)

CS vin.pv.01.1.01.4 | ភាគ ទី១២

### (៤. និស្សគ្គិយកណ្ឌំ)

## កឋិនវគ្គ ទី១

CS vin.pv.01.1.01.4.1 | ភាគ ទី១២

### (១. កថិនវគ្គោ)

[២៧] សួរថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈចំពោះភិក្ខុដែលទុកអតិរេកចីវរឱ្យកន្លងហួសពី១០ថ្ងៃទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវ ពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុទ្រទ្រង់អតិរេកចីវរ (ទុកឱ្យកន្លង១០ថ្ងៃទៅ)។ សិក្ខាបទនោះមានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង គឺតាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត ១ តាំងឡើងអំពីកាយវាចានិងចិត្ត១។បេ។

[២៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលនៅប្រាសចាកត្រៃចីវរអស់មួយយប់ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវ ដែលភិក្ខុច្រើនរូបផ្ញើចីវរក្នុងដៃនៃភិក្ខុទាំងឡាយហើយ (ស្លៀកដណ្តប់) តែស្បង់និងចីពរចេញដើរទៅកាន់ជនបទចារិក។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាងគឺ តាំងឡើងអំពីកាយ និងវាចា មិនតាំងឡើងអំពីចិត្ត១ តាំងឡើងអំពីកាយវាចា និងចិត្ត១។បេ។

[២៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុទទួលអកាលចីវរហើយ ទុកឱ្យកន្លងមួយខែទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបទទួលអកាលចីវរ ហើយទុកឱ្យកន្លងហួសមួយខែទៅ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង គឺតាំងឡើងអំពីកាយ និងវាចា មិនតាំងឡើងអំពីចិត្ត១ តាំងឡើងអំពីកាយវាចានិងចិត្ត១។បេ។

[៣០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលប្រើនាងភិក្ខុនី មិនមែនជាញាតិឱ្យលាងចីវរចាស់ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវឧទាយិភិក្ខុមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ ប្រើភិក្ខុនីមិនមែនជាញាតិ ឱ្យលាងចីវរចាស់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៣១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុអ្នកទទួលចីវរអំពីដៃភិក្ខុនី មិនមែនជាញាតិ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ ទទួលចីវរអំពីដៃភិក្ខុនីមិនមែនជាញាតិ។ សិក្ខាបទនោះមានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៣២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលសូមចីវរនឹងគហបតី ឬគហបតានី ដែលមិនមែនជាញាតិ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ សូមចីវរនឹងសេដ្ឋីបុត្ត ដែលមិនមែនជាញាតិ។ សិក្ខាបទនោះមានបញ្ញតិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៣៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលសូមចីវរនឹងគហបតី ឬគហបតានី ដែលមិនមែនជាញាតិ ឱ្យលើសជាងកំណត់ដែលគេប្រគេននោះទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់ បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុមិនស្គាល់ប្រមាណ(ក្នុងការសូម) ហើយសូមចីវរជាច្រើន។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។ បេ។

[៣៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុអ្នកចូលទៅរកគហបតី មិនមែនជាញាតិ ដែលគេមិនបានបវារណាទុកមុនទេ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ ប្រារព្ធនូវព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ គេមិនបានបវារណាទុកមុន ហើយចូលទៅរកគហបតី ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ។[10)] សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៣៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលចូលទៅរកគហបតីទាំងឡាយមិនមែនជាញាតិ ដែលគេមិនបានបវារណាទុកមុន ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ គេមិនបានបវារណាទុកមុន ហើយចូលរកគហបតីទាំងឡាយ ដែលមិនមែនជាញាតិ ដល់នូវកិរិយាកំណត់ក្នុងចីវរ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។ បេ។

[៣៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយចិត្តិយៈ ចំពោះភិក្ខុដែលញ៉ាំងចីវរឱ្យសម្រេច ដោយការតឹងទារហួសកំណត់បីដង ដោយឈរហួសកំណត់៦ដង ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ ដែលឧបាសកនិយាយ(អង្វរ)ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់រងចាំក្នុងថ្ងៃនេះមួយថ្ងៃសិន ហើយមិនបានបង្អង់ចាំ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

ចប់ កឋិនវគ្គ ទី១។

ឧទ្ទាន គឺបញ្ជីរឿងនៃកឋិនវគ្គនោះ ដូច្នេះ

[៣៧]

អតិរេកចីវរ១ ចីវរដែលភិក្ខុនៅប្រាសចាកមួយរាត្រី១ អកាលចីវរ១ ការប្រើភិក្ខុនីមិនមែនជាញាតិឱ្យគក់លាងចីវរចាស់១ ទទួលចីវរអំពីដៃភិក្ខុនី១ទៀត ជាគម្រប់ប្រាំ ការសូមចីវរអំពីគ្រហស្ថមិនមែនជាញាតិ១ ការសូមឱ្យលើសពីស្បង់ចីពរ១ ភិក្ខុដែលគេមិនបានបវារណាមានពីរយ៉ាង១ ការតឹងទារចីវរឱ្យហួសកំណត់បីដង ១។

## កោសិយវគ្គ ទី២

CS vin.pv.01.1.01.4.2 | ភាគ ទី១២

### (២. កោសិយវគ្គោ)

[៣៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តយៈ ចំពោះភិក្ខុដែលឱ្យគេធ្វើសន្ថត លាយដោយសូត្រ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធ នូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួក ឆព្វគ្គិយភិក្ខុ ចូលទៅរកពួកអ្នកធ្វើសូត្រ ហើយនិយាយថា ម្នាលអ្នកមានអាយុទាំងឡាយ សូមអ្នកទាំងឡាយ ស្ងោរនាងឱ្យច្រើន ហើយឱ្យមកពួកអាត្មាខ្លះ ឯអាត្មាចង់ឱ្យគេធ្វើសន្ថតលាយដោយសូត្រ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៣៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលឱ្យគេធ្វើសន្ថតនឹងរោមចៀមមានពណ៌ខ្មៅសុទ្ធ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវ ដែលពួកឆព្វគ្គិយភិក្ខុឱ្យគេធ្វើសន្ថត លាយរោមចៀមមានពណ៌ខ្មៅសុទ្ធ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦ យ៉ាង។បេ។

[៤០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែល (ធ្វើឯង) ឬប្រើឱ្យគេធ្វើនូវសន្ថតថ្មី មិនលាយរោមចៀម សម្អួយជញ្ជីង រោមចៀមក្រហមមួយជញ្ជីង (១ភាគ) ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុ ឱ្យគេធ្វើសន្ថតដោយរោមចៀមមានពណ៌ខ្មៅសុទ្ធ យ៉ាងនោះដែរ តែលាយដោយរោមចៀមសបន្តិចត្រង់ជាយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៤១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលឱ្យគេធ្វើនូវសន្ថតរាល់ឆ្នាំ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបឱ្យគេធ្វើសន្ថតរាល់ៗឆ្នាំ។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៤២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលឱ្យគេធ្វើសន្ថតសម្រាប់ទ្រាប់អង្គុយថ្មី មិនលាយសន្ថតចាស់មួយចំអាមព្រះសុគតដោយជុំវិញ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបលះចោលសន្ថត ហើយសមាទាននូវអារញ្ញិកង្គធុតង្គ បិណ្ឌបាតិកង្គធុតង្គ បំសុកូលិកង្គធុតង្គ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៤៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទទួលរោមចៀម នាំឱ្យកន្លងហួស៣យោជន៍ទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុមួយរូបទទួលរោមចៀម (រួចនាំទៅ) ឱ្យកន្លងហួស៣យោជន៍។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានពីរយ៉ាង គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា១។បេ។

[៤៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលប្រើភិក្ខុនីមិនមែនជាញាតិឱ្យលាងរោមចៀម ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងសក្កជនបទ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវ ដែលពួកឆព្វគ្គិយភិក្ខុ ប្រើភិក្ខុនីទាំងឡាយមិនមែនជាញាតិ ឱ្យលាងរោមចៀម។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៤៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទទួលរូបិយៈ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុទទួលរូបិយៈ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង។បេ។

[៤៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលប្រព្រឹត្ត ទិញដូរដោយរូបិយៈ មានប្រការផ្សេងៗ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុ ប្រព្រឹត្តការទិញដូរដោយរូបិយៈ មានប្រការផ្សេងៗ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៤៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលប្រព្រឹត្តការទិញ និងការលក់មានប្រការផ្សេងៗ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវ ដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ ប្រព្រឹត្តការទិញនិងការលក់ជាមួយនឹងបរិព្វាជក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

ចប់ កោសិយវគ្គ ទី ២។

ឧទ្ទាន គឺបញ្ជីរឿងនៃកោសិយវគ្គនោះ ដូច្នេះ

[៤៨]

ភិក្ខុធ្វើសន្ថតដោយរោមចៀមលាយសូត្រ១ ភិក្ខុធ្វើសន្ថតដោយរោមចៀម មានពណ៌ខ្មៅសុទ្ធ១ ភិក្ខុធ្វើសន្ថត លាយរោមចៀមសម្អួយជញ្ជីង ក្រហមមួយជញ្ជីង ១ ភិក្ខុធ្វើ សន្ថតរាល់ឆ្នាំ១ ភិក្ខុធ្វើសន្ថតថ្មីត្រូវលាយនឹងសន្ថតចាស់១ ភិក្ខុទទួលរោមចៀមនាំទៅបានតែត្រឹមបីយោជន៍១ ភិក្ខុប្រើភិក្ខុនីឱ្យលាយរោមចៀម១ ភិក្ខុទទួលរូបិយៈ១ ភិក្ខុទិញ លក់ ផ្លាស់ប្តូរ ដោយរូបិយវត្ថុ មានប្រការផ្សេងៗ មានពីរសិក្ខាបទ១។

### (៣. បត្តវគ្គោ)

[៤៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុ ដែលទុកអតិរេកបាត្រឱ្យកន្លងហួស១០ថ្ងៃទៅក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវ ដែលពួកឆព្វគ្គិយភិក្ខុទ្រទ្រង់អតិរេកបាត្រ។ សិក្ខាបទនោះមានតែបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង គឺតាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត១ តាំងឡើងអំពីកាយវាចានិងចិត្ត១។បេ។

[៥០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលមានបាត្រមានចំណង គឺស្នាមប្រេះបែក មិនទាន់ដល់ប្រាំអន្លើ ហើយឱ្យគេទិញបាត្រថ្មីទៀត ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងសក្កជនបទ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុមានបាត្រគ្រាន់តែបែកបន្តិចបន្តួចខ្លះ គ្រាន់តែដាច់បន្តិចបន្តួចខ្លះ គ្រាន់តែមានស្នាមប្រេះបន្តិចបន្តួចខ្លះ ហើយសូមបាត្រជាច្រើន។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង សិក្ខាបទនោះ តាំង ឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៥១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទទួលភេសជ្ជៈ ហើយទុកឱ្យកន្លងហួស៧ថ្ងៃទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែល ភិក្ខុច្រើនរូបទទួលភេសជ្ជៈ ហើយទុកឱ្យកន្លងហួស៧ថ្ងៃ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងកឋិនសិក្ខាបទ)។បេ។

[៥២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលស្វែងរកវស្សិកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀង ក្នុងកាលដែលហួសពីខែជាខាងចុងនៃរដូវក្តៅទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួក ឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយ ភិក្ខុនាំគ្នាស្វែងរកវស្សិកសាដិកចីវរ សម្រាប់ងូតទឹកភ្លៀងក្នុងកាលដែលហួសពីខែជាខាងចុងនៃរដូវក្តៅ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៥៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលបានឱ្យចីវរខ្លួនឯង ដល់ភិក្ខុផងគ្នា ហើយមានចិត្តខឹងអាក់អន់ដណ្តើមយកវិញ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ បានឱ្យចីវរខ្លួនឯង ដល់ភិក្ខុផងគ្នា ហើយមានចិត្តអាក់អន់ដណ្តើមយកវិញ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៣យ៉ាង។បេ។

[៥៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលសូមអំបោះ (អំពីគ្រហស្ថ) ដោយខ្លួនឯង យកមកឱ្យជាងតម្បាញត្បាញចីវរ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿង រ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុសូមអំបោះ (អំពី គ្រហស្ថ) ដោយខ្លួនឯង ហើយឱ្យជាងតម្បាញ ត្បាញចីវរ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខា បទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៥៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលគេមិនបានបវារណាជាមុន ហើយចូលទៅរកជាងតម្បាញរបស់គហបតី ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (ចង់បានឱ្យល្អហួសហេតុ) ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧបនន្ទជាសក្យបុត្តមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុ ដែលគេមិនបានបវារណាទុកជាមុន ហើយចូលទៅរកជាងតម្បាញរបស់គហបតីមិនមែនជាញាតិ ដល់នូវកិរិយាកំណត់ក្នុងចីវរ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៥៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទទួលអច្ចេកចីវរ ហើយទុកឱ្យកន្លងសម័យនៃចីវរកាលទៅក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុច្រើនរូបទទួលអច្ចេកចីវរ ហើយទុកឱ្យកន្លងសម័យ នៃចីវរកាលទៅ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងកឋិនសិក្ខាបទ)។បេ។

[៥៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលទុកចីវរ បណ្តាចីវរទាំង៣ចីវរណាមួយ ក្នុងចន្លោះផ្ទះ ហើយនៅប្រាស (ចាកចីវរនោះ) លើស៦រាត្រីទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿង រ៉ាវដែលភិក្ខុច្រើនរូប ទុកចីវរ បណ្តាចីវរទាំង៣ ចីវរណាមួយក្នុងចន្លោះផ្ទះ ហើយនៅប្រាស (ចាកចីវរនោះ) លើសពី៦រាត្រីទៅ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងកឋិនកសិក្ខាបទ)។បេ។

[៥៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនិស្សគ្គិយបាចិត្តិយៈ ចំពោះភិក្ខុដែលដឹងថា លាភគេបង្អោនទៅដើម្បីសង្ឃហើយបង្អោនមកដើម្បីខ្លួនវិញ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុដឹងថា លាភដែលគេ បង្អោនទៅដើម្បីសង្ឃហើយ ក៏ត្រឡប់បង្អោនមកដើម្បីខ្លួនវិញ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង។ បេ។

ចប់ បត្តវគ្គ ទី៣។

ឧទ្ទាន គឺបញ្ជីរឿងនៃបត្តវគ្គ ដូច្នេះ

[៥៩]

ភិក្ខុទុកអតិរេកបាត្រ ១ ភិក្ខុមានបាត្រមានចំណងមិនទាន់ដល់ប្រាំអន្លើ១ ភិក្ខុទុកភេសជ្ជៈ១ ភិក្ខុស្វែងរកសំពត់ងូតទឹកភ្លៀង១ ភិក្ខុឱ្យចីវរដល់ភិក្ខុឯទៀតហើយមានចិត្ត អាក់អន់ដណ្តើមយកវិញ១ ភិក្ខុសូមឱ្យជាងតម្បាញ ត្បាញចីវរ មានពីរសិក្ខាបទ១ ភិក្ខុទទួលអច្ចេកចីវរទុកឱ្យកន្លងសម័យនៃចីវរកាល១ ភិក្ខុទុកចីវរណាមួយក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកចីវរលើស៦រាត្រី១ ភិក្ខុបង្អោនសង្ឃលាភមកដើម្បីខ្លួនឯង១។

ចប់ និស្សគ្គិយបាចិត្តិយៈ ៣០

## (បាចិត្តិយកណ្ឌៈ ទី៥)

CS vin.pv.01.1.01.5 | ភាគ ទី១២

### (៥. បាចិត្តិយកណ្ឌំ)

## មុសាវាទវគ្គ ទី១

CS vin.pv.01.1.01.5.1 | ភាគ ទី១២

### (១. មុសាវាទវគ្គោ)

[៦០] សួរថាព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តបាចិត្តិយៈ ព្រោះពោលពាក្យកុហក ដោយដឹងខ្លួន ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវហត្ថកភិក្ខុ ជាសក្យបុត្ត។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលហត្ថកភិក្ខុជាសក្យបុត្តនិយាយចរចា ជាមួយនឹងតិរ្ថិយទាំងឡាយ គេចកែសម្តីហើយត្រឡប់ទទួលប្តេជ្ញា ប្តេជ្ញាហើយបែរជាគេចកែសម្តីវិញ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋាន៣យ៉ាង គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា១ តាំងឡើង អំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ១ តាំងឡើងអំពីកាយ អំពីវាចា និងចិត្ត១។ បេ។

[៦១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈ ព្រោះពោលពាក្យចាក់ដោត (ជេរប្រទេចភិក្ខុផងគ្នា) ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួក ឆព្វគ្គិយភិក្ខុ ទាស់ទែងនឹងភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ហើយពោលចាក់ដោត (ជេរប្រទេច) ភិក្ខុដែលមានសីលជាទីស្រឡាញ់។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង។ បេ។

[៦២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈ ព្រោះ ពោលពាក្យញុះញង់ភិក្ខុផងគ្នា ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុង នគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុនាំពាក្យញុះញង់ របស់ភិក្ខុទាំងឡាយដែលបង្កហេតុឈ្លោះទាស់ទែងគ្នា។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើង ដោយសមុដ្ឋាន៣យ៉ាង។បេ។

[៦៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលបង្រៀនធម៌ដោយបទ ដល់អនុបសម្បន្ន ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួក ឆព្វគ្គិយភិក្ខុបង្រៀនធម៌ដោយបទដល់ពួកឧបាសក។ សិក្ខាបទនោះ មាន តែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំង ឡើងដោយសមុដ្ឋាន២យ៉ាងគឺតាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយ និងចិត្ត ១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ១។បេ។

[៦៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលសម្រេចការដេកនៅជាមួយនឹងអនុបសម្បន្ន ឱ្យលើសជាងពីរបីរាត្រីឡើងទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុច្រើនរូប សម្រេចការដេកនៅជាមួយ នឹងអនុបសម្បន្ន។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២ យ៉ាង គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត ១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា១។ បេ។

[៦៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលសម្រេចការដេកនៅ ជាមួយនឹងមាតុគ្រាម ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវ ព្រះអនុរុទ្ធមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះអនុរុទ្ធមានអាយុ សម្រេចការដេកនៅ ជាមួយនឹងមាតុគ្រាម។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះតាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងឯឡកលោមកសិក្ខាបទ)។បេ។

[៦៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលសម្តែងធម៌ដល់មាតុគ្រាម ឱ្យលើសជាងប្រាំ ប្រាំមួយម៉ាត់ឡើងទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ សម្តែងធម៌ដល់មាតុគ្រាម។ សិក្ខាបទនោះមានបញ្ញត្តិ១ អនុប្បញ្ញត្តិ២។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងបទសោធម្មសិក្ខាបទ)។បេ។

[៦៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលប្រាប់ឧត្តរិមនុស្សធម្ម ដែលមានពិត ដល់អនុបសម្ប័ន្ន ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ ប្រារព្ធនូវពួកភិក្ខុ ដែលនៅទៀបឆ្នេរស្ទឹងឈ្មោះវគ្គមុទា។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុអ្នកនៅទៀបឆ្នេរស្ទឹងឈ្មោះវគ្គមុទា ពោលអួតឧត្តរិមនុស្សធម្មនៃគ្នានិងគ្នា ដល់គ្រហស្ថទាំងឡាយ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣ យ៉ាង គឺ តាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត ១ តាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយនិងចិត្ត ១ តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត១។បេ។

[៦៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នាដល់អនុបសម្ប័ន្ន ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុប្រាប់ទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នាដល់អនុបសម្ប័ន្ន។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង (ដូចសមុដ្ឋាននៃអទិន្នាទាន)។បេ។

[៦៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលជីកដី ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកភិក្ខុនៅក្នុងនគរអាឡវី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុនៅក្នុងនគរអាឡវីនាំគ្នាជីកដី។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង។បេ។

ចប់ មុសាវាទវគ្គ ទី១។

ឧទ្ទាន គឺបញ្ជីរឿងនៃមុសាវាទវគ្គនោះ ដូច្នេះ

[៧០]

ភិក្ខុពោលពាក្យកុហក១ ពោលពាក្យចាក់ដោត១ ពោលពាក្យញុះញង់១ បង្រៀនធម៌ដោយបទ១ ដេករួមនឹងអនុសម្ប័ន្នមានពីរសិក្ខាបទ១ ការសម្តែងធម៌១ ការអួតឧត្តរិមនុស្សធម្ម១ ការប្រាប់ទុដ្ឋុល្លាបត្តិ១ ការជីកដី១។

## ភូតគាមវគ្គ ទី២

CS vin.pv.01.1.01.5.2 | ភាគ ទី១២

### (២. ភូតគាមវគ្គោ)

[៧១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលធ្វើភូតគាមឱ្យវិនាស ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកភិក្ខុអ្នកនៅក្នុងនគរអាឡវី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុអ្នកនៅក្នុងនគរអាឡវីកាប់ដើមឈើ១ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង។បេ។

[៧២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ពោលពាក្យដទៃធ្វើឱ្យសង្ឃលំបាក ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលព្រះឆន្នៈមានអាយុកាលត្រូវសាកសួរដោយអាបត្តិក្នុងកណ្តាលជំនុំសង្ឃ ហើយត្រឡប់ពោលបិទបាំងពាក្យដទៃដោយពាក្យដទៃវិញ។ សិក្ខាបទនោះមានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង។បេ។

[៧៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះ ភិក្ខុដែលបង្គាប់ភិក្ខុដទៃ ឱ្យពោលទោល តិះដៀល (ភិក្ខុផងគ្នា) ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលមេត្តិយភិក្ខុនិងភុម្មជកភិក្ខុ ប្រើភិក្ខុទាំងឡាយឱ្យពោលទោសព្រះទព្វមល្លបុត្តមានអាយុ។ សិក្ខានោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង។បេ។

[៧៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលយកគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ជារបស់សង្ឃទៅក្រាលទុកក្នុងទីវាល មិនសាយកមកទុកដោយខ្លួនឯង(ក្តី) មិនប្រើអ្នកដទៃឱ្យយកមកទុក (ក្តី) ហើយដើរចៀសចេញទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្ត ក្នុងនគ

រសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវ ដែលភិក្ខុច្រើនរូបក្រាលសេនាសនៈរបស់សង្ឃក្នុងទីវាល មិនសាយកមកទុកដោយខ្លួនឯង ទាំងមិនប្រាប់ (អ្នកដទៃឱ្យសាយកមកទុក) ហើយដើរចៀសចេញទៅ។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិ ទាំង ៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងកឋិនកសិក្ខាបទ)។ បេ។

[៧៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលក្រាលកម្រាលសម្រាប់ដេកក្នុងវិហារជារបស់សង្ឃ មិនសាយកមកទុកដោយខ្លួនឯង (ក្ដី) មិនប្រាប់ (អ្នកដទៃឱ្យសាយកមកទុកក្ដី) ហើយដើរចៀសចេញទៅ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកសត្តរសវគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកសត្តរសវគ្គិយភិក្ខុ ក្រាលកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃ មិនសាយកមកទុកវិញ ទាំងមិនបានប្រាប់ (អ្នកដទៃឱ្យសាយកមកទុក) ហើយដើរចៀសចេញទៅ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងកឋិនកសិក្ខាបទ)។ បេ។

[៧៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលដឹងថា មានភិក្ខុចូលទៅនៅមុនហើយ ចូលទៅច្រៀតបៀតសម្រេចការដេកនៅក្នុងវិហារជារបស់សង្ឃ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុ ចូលទៅច្រៀតបៀតភិក្ខុជាថេរៈទាំងឡាយ ហើយសម្រេចការដេកនៅ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា។ បេ។

[៧៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលមានចិត្តខឹង អាក់អន់ ហើយចាប់ទង់ទាញភិក្ខុផងគ្នា ឱ្យចេញចាកវិហារជារបស់សង្ឃ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះ រឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុ មានចិត្តខឹង អាក់អន់ ហើយចាប់ទង់ទាញភិក្ខុទាំងឡាយឱ្យចេញអំពីវិហារជារបស់សង្ឃ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ៣ យ៉ាង។ បេ។

[៧៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលអង្គុយសង្កត់គ្រែឬតាំង ដែលមានជើងគ្រាន់តែផ្គុំទុកពួដ៏ថ្នាក់ខាងលើក្នុងវិហារជារបស់សង្ឃ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធភិក្ខុ១រូប។ ព្រោះ រឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុ១រូប អង្គុយសង្កត់ភ្លាមនូវគ្រែ ដែលមានជើងគ្រាន់តែផ្គុំទុកពួដ៏ថ្នាក់ខាងលើ ក្នុងវិហារជារបស់សង្ឃ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង គឺតាំងឡើអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា១។បេ។

[៧៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលបូកតម្បូលពីរបីជាន់ ហើយនៅតែបូកថែមឱ្យលើសពីនោះទៅទៀត ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឆន្នៈមានអាយុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវ ដែលព្រះឆន្នៈមានអាយុ ឱ្យគេលាប ឱ្យគេបូករឿយៗ នូវវិហារដែលខ្លួនធ្វើជាស្រេចហើយ វិហារធ្ងន់ពេក ក៏រលំបាក់ទៅ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ យ៉ាង។ បេ។

[៨០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុដែលដឹងថាទឹកមានសត្វ ហើយយកទៅចាក់ស្រោចស្មៅឬដី ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរអាឡវី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកភិក្ខុអ្នកនៅក្នុងដែនអាឡវី។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកភិក្ខុអ្នកនៅក្នុងដែនអាឡវីដឹងថា ទឹកមានសត្វ ហើយ យកទៅស្រោចស្មៅឬដី។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣ យ៉ាង។ បេ។

ចប់ ភូតគាមវគ្គ ទី២។

ឧទ្ទាន គឺបញ្ជីរឿងនៃភូតគាមវគ្គនោះ ដូច្នេះ

[៨១]

ភិក្ខុកាប់ដើមឈើ ១ ភិក្ខុញុះញង់ភិក្ខុផងគ្នា ១ ភិក្ខុពោលទោសគ្នា១ ភិក្ខុយកសេនាសនៈ ទៅតាំងទុកក្នុងទីវាល១ យកកម្រាលទៅក្រាលក្នុងវិហារ១ ភិក្ខុចូលទៅដេកជ្រៀតបៀត១ ភិក្ខុទង់ទាញភិក្ខុផងគ្នា១ ភិក្ខុអង្គុយសង្កត់គ្រែ ឬតាំងដែលគេទុកពួដ៏ថ្នាក់ខាងលើ១ ភិក្ខុបូកលាបតម្បូល១ ភិក្ខុដឹងថាទឹកមានសត្វ ហើយស្រោច (ស្មៅឬដី)១។

## ឱវាទវគ្គ ទី៣



**(៣. ឱវាទវគ្គោ)**

[៨២] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលសង្ឃមិនបានសន្មត ហើយទៅទូន្មានភិក្ខុនី ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុដែលសង្ឃមិនបានសន្មតហើយទៅទូន្មានភិក្ខុនី។ បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សិក្ខាបទនោះ មានដែរឬទេ។ មានតែបញ្ញត្តិ១ អនុប្បញ្ញត្តិ១ ឯអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះទេ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ យ៉ាង គឺតាំងឡើងអំពីវាចា មិនតាំង ឡើងអំពីកាយនិងចិត្ត១ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយ១។បេ។

[៨៣] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលទូន្មានភិក្ខុនី ក្នុងវេលាដែលព្រះអាទិត្យអស្តង្គតហើយ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះចូឡបន្ថកមានអាយុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលព្រះចូឡបន្ថកមានអាយុ ទៅទូន្មានភិក្ខុនីក្នុងវេលាព្រះអាទិត្យអស្តង្គតទៅ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាន នៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងបទសោធម្មសិក្ខាបទ)។បេ។

[៨៤] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលចូលទៅកាន់សម្នាក់ភិក្ខុនី ហើយទូន្មានភិក្ខុនី ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងសក្កជនបទ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយ ភិក្ខុចូលទៅកាន់សម្នាក់នៃភិក្ខុនីហើយទូន្មានភិក្ខុនី។ សិក្ខាបទនោះមានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទ នោះ តាំងឡើងដោយសមុដ្ឋាន២យ៉ាង (ដូចក្នុងកឋិនកសិក្ខាបទ)។បេ។

[៨៥] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលពោលថា ភិក្ខុទាំងឡាយទូន្មានពួកភិក្ខុនីព្រោះហេតុតែអាមិសៈ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះ រឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុពោលថា ភិក្ខុទាំងឡាយទូន្មានពួកភិក្ខុនីព្រោះ ហេតុតែអាមិសៈ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាន នៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៣យ៉ាង។បេ។

[៨៦] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលឱ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវភិក្ខុមួយរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុមួយរូបបានឱ្យចីវរ ដល់ភិក្ខុនីដែលមិនមែនជាញាតិ។ សិក្ខាបទនោះមានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៨៧] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលដេរចីវរឱ្យភិក្ខុនីមិនមែនជាញាតិ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុដេរចីវរឱ្យភិក្ខុនីមិនមែនជាញាតិ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋានទាំង៦យ៉ាង។បេ។

[៨៨] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈ ចំពោះភិក្ខុដែលបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយជាមួយគ្នា ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុបបួលពួកភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា។ សិក្ខាបទ នោះមានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៤យ៉ាង គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្ត១ តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើអំពីចិត្ត១ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចា១ តាំងឡើអំពីកាយអំពីវាចានិងចិត្ត១។បេ។

[៨៩] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈ ចំពោះភិក្ខុដែលបបួលភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយភិក្ខុ បបួលពួកភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន៤យ៉ាង។បេ។

[៩០] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុ ដែលដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែងឱ្យ ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវទេវទត្ត។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែល ទេវទត្តដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែងឱ្យ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។បេ។

[៩១] សួរថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តបាចិត្តិយៈចំពោះភិក្ខុមួយរូប ដែលសម្រេចការអង្គុយនៅក្នុងទីកំបាំង ជាមួយនឹងភិក្ខុនីមួយរូប ក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនូវបុគ្គលណា។ ទ្រង់ប្រារព្ធនូវព្រះឧទាយិមានអាយុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលព្រះឧទាយិមានអាយុ សម្រេចការអង្គុយក្នុងទីកំបាំង ជាមួយនឹងភិក្ខុនីមួយរូប។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ យ៉ាង សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។បេ។

ចប់ ឱវាទវគ្គ ទី៣។

ឧទ្ទាន គឺបញ្ជីរឿងនៃឱវាទវគ្គនោះ ដូច្នេះ

[៩២]

ភិក្ខុដែលសង្ឃមិនបានសន្មត ហើយទូន្មានភិក្ខុនី១ ភិក្ខុចូលទៅទូន្មានភិក្ខុនី ក្នុងវេលាដែលព្រះអាទិត្យអស្តង្គត១ ភិក្ខុចូលទៅកាន់សម្នាក់ភិក្ខុនី ដើម្បីទូន្មាន១ ភិក្ខុពោលថា ភិក្ខុទាំងឡាយខំទូន្មានភិក្ខុនីព្រោះហេតុតែអាមិសៈ១ ភិក្ខុឱ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ១ ភិក្ខុដេរចីវរឱ្យភិក្ខុនីមិនមែនជាញាតិ១ ភិក្ខុបបួលភិក្ខុនី ដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា១ ភិក្ខុបបួលភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា១ ភិក្ខុដឹង ហើយឆាន់ចង្ហាន់ដែលភិក្ខុនីចាត់ចែងឱ្យ១ ភិក្ខុអង្គុយនៅក្នុងទីកំបាំងជាមួយនឹងភិក្ខុនី១។

## ភោជនវគ្គ ទី៤

CS vin.pv.01.1.01.5.4 | ភាគ ទី១២

**(៤. ភោជនវគ្គោ)**

[៩៣] ភិក្ខុបរិភោគដុំបាយក្នុងផ្ទះសម្នាក់ ( រោងឆាន់ ) លើសកំណត់ម្តងប៉ុណ្ណោះ ត្រូវអាបត្តិបាចិត្តិយៈ ព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿង ដែលពួកឆព្វគ្គិយភិក្ខុនៅឆាន់ដុំបាយក្នុងផ្ទះសម្នាក់រឿយៗ។ សិក្ខាបទ នោះមានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ យ៉ាង (ដូចក្នុងឯឡកលោមកសិក្ខាបទ)។ បេ។

[៩៤] ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់គណភោជន ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុឈ្មោះទេវទត្ត។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងទេវទត្តព្រមទាំងបរិស័ទ ដើរសូមគេគ្រប់ត្រកូល ហើយយកមកឆាន់។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ៧។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។បេ។

[៩៥] ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់បរម្បរភោជន ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងវេសាលី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច ព្រោះរឿងភិក្ខុច្រើនរូប ដែលគេនិមន្តទៅក្នុងទីដទៃហើយ បែរជាទៅឆាន់ក្នុងទីឯទៀតវិញ (ក្រៅអំពីទីនិមន្តនោះ)។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ៣។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។បេ។

[៩៦] ភិក្ខុទទួលនំកំណត់ត្រឹមពេញពីរបាត្រ ឬបីបាត្រ គួរ តែបើ ទទួលឱ្យលើសកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលដូចម្តេច។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុ ច្រើនរូប មិនដឹងប្រមាណហើយចេះតែទទួល។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង៦។ បេ។

[៩៧] ភិក្ខុ ឆាន់រួចហើយ ហាមភោជនហើយ ឆាន់ខាទនីយៈ ឬភោជនីយៈ ដែលភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនសល់ដែលអំពីភិក្ខុឈឺ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុច្រើនរូប ឆាន់រួចហើយ ហាមភោជនហើយ ក្រោកទៅឆាន់ក្នុងទីឯទៀតវិញ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។បេ។

[៩៨] ភិក្ខុនាំយកខាទនីយៈ ឬភោជនីយៈ ដែលភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនសល់ដែលអំពីភិក្ខុឈឺ ទៅបង្ខំភិក្ខុដែលឆាន់រួចហើយ ហាមភោជនហើយ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុមួយរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុមួយរូប នាំយកភោជនីយៈ ដែលភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនសល់ដែលអំពីភិក្ខុឈឺ ទៅបង្ខំភិក្ខុដែលឆាន់រួចហើយ ហាមភោជនហើយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំង ឡើងដោយសមុដ្ឋាន៣។បេ។

[៩៩] ភិក្ខុ ឆាន់ខាទនីយៈ ឬភោជនីយៈ ក្នុងពេលមិនគួរ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកសត្តរសវគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកសត្តរសវគ្គិយភិក្ខុឆាន់ភោជន ក្នុងពេលមិនគួរ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាន នៃអាបត្តទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២(ដូចក្នុងឯឡកលោមសិក្ខា)។បេ។

[១០០] ភិក្ខុឆាន់ខាទនីយៈ ឬភោជនីយៈ ដែលខ្លួនសន្សំទុក ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តិក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះវេលដ្ឋសីសៈមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលព្រះវេលដ្ឋសីសៈមានអាយុ ឆាន់ភោជនដែលខ្លួនសន្សំទុក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។បេ។

[១០១] ភិក្ខុសូមបណីតភោជន[11] ចំពោះខ្លួនឯងហើយឆាន់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ សូមបណីតភោជន ដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។បេ។

[១០២] ភិក្ខុឆាន់អាហារដែលសម្រាប់ឆាន់តាមទ្វារមាត់ ដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុមួយរូប ឆាន់អាហារសម្រាប់ឆាន់តាមទ្វារមាត់ ដែលគេមិនបានប្រគេន។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។ បេ។

ចប់ ភោជនវគ្គ ទី៤។

ឧទ្ទាននៃភោជនវគ្គនោះ ដូច្នេះ

[១០៣]

រឿងភិក្ខុឆាន់ដុំបាយក្នុងផ្ទះសម្នាក់១ រឿងភិក្ខុឆាន់គណភោជន១ រឿងភិក្ខុឆាន់បរម្បរភោជន១ រឿងភិក្ខុទទួលនំបានតែត្រឹមពីរបាត្រឬបីបាត្រ១ រឿងភិក្ខុហាមភោជន១ រឿងភិក្ខុហាមភោជនហើយ ភិក្ខុឯទៀតនាំយកភោជន ទៅបង្ខំឱ្យឆាន់១ រឿងភិក្ខុឆាន់ក្នុងវេលាវិកាល១ រឿងភិក្ខុឆាន់ភោជនដែលខ្លួនសន្សំទុក១ រឿងភិក្ខុសូមបណីតភោជន ដើម្បីប្រយោជន៍ដល់ខ្លួន១ រឿងភិក្ខុឆាន់អាហារសម្រាប់ឆាន់ តាមទ្វារមាត់ដែលគេមិនបានប្រគេន១។

## អចេលកវគ្គ ទី៥

CS vin.pv.01.1.01.5.5 | ភាគ ទី១២

**(៥. អចេលកវគ្គោ)**

[១០៤] ភិក្ខុ ឱ្យខាទនីយៈ ឬភោជនីយៈដល់អចេលកក៏ក្ដី ដល់បរិព្វជកក្ដី ដល់បរិព្វជិកាក្ដី ដោយដៃខ្លួនឯង ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះអានន្ទមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលព្រះអានន្ទមានអាយុ ឱ្យនំពីរដុំដល់បរិព្វជិកាម្នាក់ តែសម្គាល់ថាឱ្យនំតែមួយដុំទេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានពីរ (ដូចក្នុងឯឡកលោមសិក្ខាបទ )។បេ។

[១០៥] ភិក្ខុបបួលភិក្ខុផងគ្នាថា នែលោកមានអាយុ មក យើងនឹងចូលទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាតជាមួយគ្នា ហើយបានឱ្យក្ដី មិនបានឱ្យក្ដី នូវបិណ្ឌបាត ដល់ភិក្ខុនោះ ហើយបញ្ជូនភិក្ខុនោះទៅវិញ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ បបួលភិក្ខុផងគ្នាថា នែលោកមានអាយុ មក យើងនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតជាមួយគ្នា ហើយមិនបានឱ្យបិណ្ឌបាតដល់ភិក្ខុនោះ ហើយក៏បញ្ជូនទៅវិញ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១០៦] ភិក្ខុចូលទៅសម្រេចកាអង្គុយក្នុងត្រកូល ដែលមានតែជនពីរនាក់ប្ដីប្រពន្ធ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ ចូលទៅសម្រេចការអង្គុយ ក្នុងត្រកូលដែលមានតែជនពីរនាក់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងដោយកាយនិងចិត្ត មិនតាំងឡើងដោយវាចាឡើយ។បេ។

[១០៧] ភិក្ខុសម្រេចការអង្គុយលើអាសនៈដែលស្ងាត់កំបាំងជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិបាចិត្តយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ សម្រេចការអង្គុយលើអាសនៈ ដែលស្ងាត់កំបាំងជាមួយនឹងមាតុគ្រាម។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងដោយកាយនិងចិត្ត មិនតាំងឡើងដោយវាចាឡើយ។បេ។

[១០៨] ភិក្ខុសម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់និងម្នាក់ ជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិបាចិត្តយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ សម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់និងម្នាក់ ជាមួយនឹងមាតុគ្រាម។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងដោយកាយនិងចិត្ត មិនបានតាំងឡើងដោយវាចាឡើយ។បេ។

[១០៩] ភិក្ខុដែលគេនិមន្តរួចហើយ ឈ្មោះថាប្រកបដោយភត្ត មិនបានលាភិក្ខុផងគ្នាដែលមាននៅ (ក្នុងវត្ត) ហើយស្រាប់តែត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងពេលមុនបាយក្ដី ក្រោយបាយក្ដី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧបនន្ទជាសក្យបុត្តមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ គេនិមន្តរួចហើយ ឈ្មោះថាជាភិក្ខុប្រកបដោយភត្ត ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងពេលមុនបាយ និងក្រោយបាយ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ ៤។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិ នោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងកឋិនសិក្ខាបទ)។ បេ។

[១១០] ភិក្ខុសូមភេសជ្ជៈលើសកំណត់ដែលគេបវារណានោះ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនសក្កៈ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងពួកឆព្វគ្គិយភិក្ខុ ដែលមហានាមសក្យរាជ អង្វរថា បពិត្រ

លោកម្ចាស់ សូមលោកម្ចាស់បង្អង់ចាំក្នុងថ្ងៃនេះ១ ថ្ងៃសិន ហើយមិនព្រមបង្អង់ចាំ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦។ បេ។

[១១១] ភិក្ខុទៅដើម្បីមើលកងទ័ព ដែលគេលើកចេញទៅ (អំពី ស្រុក) ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុនាំគ្នាទៅ ដើម្បីមើលកងទ័ពដែលគេលើកចេញទៅ (អំពីស្រុក)។ សិក្ខាបទនោះមាន បញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។បេ។

[១១២] ភិក្ខុនៅក្នុងកងទ័ពហួសអំពីកំណត់៣រាត្រីទៅ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ នៅក្នុងកងទ័ពហួសអំពីកំណត់៣រាត្រីទៅ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃ អាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។ បេ។

[១១៣] ភិក្ខុទៅកាន់ទីដែលគេច្បាំងគ្នា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ នាំគ្នាទៅកាន់ទីដែលគេច្បាំងគ្នា។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។បេ។

ចប់ អចេលកវគ្គ ទី៥។

ឧទ្ទាននៃអចេលកវគ្គនោះ គឺ

[១១៤]

> រឿងភិក្ខុឱ្យខាទនីយភោជនីយៈដល់អចេលក១ រឿងភិក្ខុបញ្ជូនភិក្ខុផងគ្នា១ រឿងភិក្ខុអង្គុយក្នុងត្រកូលដែលមានតែជនពីរនាក់ប្ដីប្រពន្ធ១ រឿងភិក្ខុអង្គុយក្នុងទីស្ងាត់មានពីរសិក្ខាបទ១ រឿងភិក្ខុមិនបានលាភិក្ខុផងគ្នាដែលមាននៅក្នុងវត្ត១ រឿងភិក្ខុសូមភេសជ្ជៈ១ រឿងភិក្ខុទៅមើលកងទ័ពដែលគេលើកចេញទៅអំពីស្រុក១ រឿងភិក្ខុនៅក្នុងកងទ័ពហួសអំពីកំណត់៣រាត្រីទៅ១ រឿងភិក្ខុទៅកាន់ទីដែលគេច្បាំងគ្នា១។

## សុរាមេរយវគ្គ ទី៦

CS vin.pv.01.1.01.5.6 | ភាគ ទី១២

### (៦. សុរាបានវគ្គោ)

[១១៥] ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះផឹកសុរា និងមេរ័យ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះសាគតៈមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលព្រះសាគតៈមានអាយុផឹកទឹកស្រវឹង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន។បេ។

[១១៦] ភិក្ខុត្រូវបាចិត្តិយៈ ព្រោះចាក់ដោយជន្លួញគឺម្រាមដៃ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ធ្វើភិក្ខុផងគ្នាឱ្យសើចដោយជន្លួញគឺម្រាមដៃ (ចាក់ក្រឡេក)។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។បេ។

[១១៧] ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះលេងទឹក ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកសត្តរសវគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកសត្តរសវគ្គិយភិក្ខុនាំគ្នាលេងទឹកក្នុងស្ទឹងអចិរវតី។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។បេ។

[១១៨] ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះមិនអើពើ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឆន្នៈមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿង ដែលព្រះឆន្នៈមានអាយុធ្វើសេចក្ដីមិនអើពើ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣។ បេ។

[១១៩] ភិក្ខុបន្លាចភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុបន្លាចភិក្ខុផងគ្នា។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១២០] ភិក្ខុបង្កាត់ភ្លើងអាំង ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនភគ្គៈ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុច្រើនរូបបង្កាត់ភ្លើងអាំង។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ២។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦។ បេ។

[១២១] កំណត់ថ្ងៃមិនទាន់ដល់កន្លះខែ ភិក្ខុងូតទឹក ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុច្រើនរូប បានឃើញព្រះរាជាហើយ នាំគ្នាងូតទឹកមិនដឹងប្រមាណ។ សិក្ខាបទនោះ មានបញ្ញត្តិ១។ មានអនុប្បញ្ញត្តិ ៦។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ សិក្ខាបទនោះជាបទេសប្បញ្ញត្តិ។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ សិក្ខាបទនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។បេ។

[១២២] បណ្ដាវត្ថុសម្រាប់ធ្វើចីវរឱ្យមានពណ៌អាក្រក់៣យ៉ាង ភិក្ខុ មិនយកវត្ថុសម្រាប់ធ្វើចីវរឱ្យមានពណ៌អាក្រក់ណាមួយ មកធ្វើកប្បពិន្ទុហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែល ភិក្ខុច្រើនរូបមិនស្គាល់ចីវររបស់ខ្លួន។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។បេ។

[១២៣] ភិក្ខុ វិកប្បចីវរដោយខ្លួនឯង ចំពោះភិក្ខុក្ដី ភិក្ខុនីក្ដី សិក្ខមានាក្ដី សាមណេរក្ដី សាមណេរីក្ដី មិនបានដកវិកប្បចេញ ហើយប្រើប្រាស់ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧបនន្ទ ជា សក្យបុត្តមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ វិកប្បចីវរដោយខ្លួនឯង ចំពោះភិក្ខុផងគ្នា មិនបានដកវិកប្បចេញហើយប្រើប្រាស់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។បេ។

[១២៤] ភិក្ខុលាក់បាត្រក្ដី ចីវរក្ដី និសីទនៈក្ដី បំពង់ម្ជុលក្ដី វត្ថពន្ធចង្កេះក្ដី របស់ភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ លាក់បាត្រខ្លះ ចីវរខ្លះ និសីទនៈខ្លះ បំពង់ម្ជុលខ្លះ វត្ថពន្ធចង្កេះខ្លះ ជារបស់ភិក្ខុផងគ្នា។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាន នៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

ចប់ សុរាមេរយវគ្គ ទី៦។

ឧទ្ទាននៃសុរាមេរយវគ្គនោះ ដូច្នេះ

[១២៥]

រឿងភិក្ខុផឹកសុរា១ រឿងភិក្ខុចាក់ក្រឡេកគ្នាដោយជន្លួញ គឺម្រាមដៃ១ រឿងភិក្ខុលេងទឹក១ រឿងភិក្ខុមិនអើពើ១ រឿងភិក្ខុបន្លាចភិក្ខុផងគ្នា១ រឿងភិក្ខុបង្កាត់ភ្លើងអាំង១ រឿងភិក្ខុងូតទឹក១ រឿងភិក្ខុមិនយកវត្ថុសម្រាប់ធ្វើចីវរឱ្យមានពណ៌អាក្រក់ មកធ្វើកប្បពិន្ទុ១ រឿងភិក្ខុវិកប្បចីវរ១ រឿងភិក្ខុលាក់ចីវរ១។

## សប្បាណកវគ្គ ទី៧

CS vin.pv.01.1.01.5.7 | ភាគ ទី១២

**(៧. សប្បាណកវគ្គោ)**

[១២៦] ភិក្ខុក្លែងធ្វើសត្វឱ្យធ្លាក់ចុះចាកជីវិត ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងឧទាយិមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលឧទាយិមានអាយុក្លែងធ្វើសត្វឱ្យធ្លាក់ចុះចាកជីវិត។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិ នោះ តាំងឡើងដោយសមុដ្ឋាន៣។ បេ។

[១២៧] ភិក្ខុ ដឹងហើយប្រើប្រាស់ទឹកដែលមានសត្វ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ដឹងហើយ ប្រើប្រាស់ទឹកដែលមានសត្វ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១២៨] ភិក្ខុ ដឹងហើយ សើរើអធិករណ៍ដែលសង្ឃបានរម្ងាប់តាម ធម៌ហើយ ដើម្បីកម្មថ្មីទៀត ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ដឹងហើយ សើរើអធិករណ៍ដែលសង្ឃបានរម្ងាប់តាមធម៌ហើយ ដើម្បីកម្មថ្មីទៀត។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១២៩] ភិក្ខុដឹងហើយបិទបាំងទុដ្ឋុល្លាបត្តិរបស់ភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុមួយរូប ដឹងហើយបិទបាំងទុដ្ឋុល្លាបត្តិ របស់ភិក្ខុផង

គ្នា។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាន នៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើង អំពីកាយនិងវាចា និងចិត្ត។ បេ។

[១៣០] ភិក្ខុដឹងហើយ ឱ្យឧបសម្បទាដល់បុគ្គលដែលមានវស្សាមិនគ្រប់២០ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុច្រើនរូបបានដឹងហើយ ឱ្យឧបសម្បទាដល់បុគ្គលដែលមានវស្សាមិនគ្រប់២០។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំង ឡើង ដោយសមុដ្ឋាន ៣។ បេ។

[១៣១] ភិក្ខុដឹងហើយ បបួលគ្នាដើរទៅកាន់ផ្លូវឆ្ងាយតែមួយ ជា មួយដឹងពួកជនដែលមានថេយ្យចិត្ត (គិតនឹងវាងសួយព្រះរាជធានីជាដើម) ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុមួយរូប បបួលគ្នាដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយនឹងពួកជនមានថេយ្យចិត្ត។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន។ បេ។

[១៣២] ភិក្ខុបបួលគ្នាដើរទៅកាន់ផ្លូវឆ្ងាយមួយ ជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធភិក្ខុមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុមួយរូប បបួលគ្នាដើរទៅកាន់ ផ្លូវឆ្ងាយមួយ ជាមួយនឹងមាតុគ្រាម។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។បេ។

[១៣៣] កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់បីដងហើយ ភិក្ខុមិនលះបង់ទិដ្ឋិអាក្រក់ចេញ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដងហើយ មិនលះបង់ទិដ្ឋិអាក្រក់ចេញ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយវាចា និងចិត្ត។បេ។

[១៣៤] ភិក្ខុ ដឹងហើយ បរិភោគជាមួយនឹងភិក្ខុដែលមានវាទៈ ដូច្នោះ ដែលជាអ្នកមិនធ្វើតាមអនុធម៌[12] ទាំងមិនលះបង់ទិដ្ឋិនោះចេញ ត្រូវអាបត្តិបាចិត្តិយៈទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿង ដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ដឹងហើយ បរិភោគជាមួយ នឹងអរិដ្ឋភិក្ខុដែលមានវាទៈដូច្នោះ មិនធ្វើតាមអនុធម៌ ទាំងមិនលះបង់នូវ ទិដ្ឋិនោះចេញ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃ អាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣។ បេ។

[១៣៥] ភិក្ខុដឹងហើយសង្គ្រោះសមណុទ្ទេស (សាមណេរ) ដែល សង្ឃបានធ្វើនាសនកម្មដូច្នោះហើយ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ ប្រារព្ធពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុដឹងហើយសង្គ្រោះសមណុទ្ទេសឈ្មោះកណ្ដកៈ ដែលសង្ឃធ្វើនាសនកម្មដូច្នោះហើយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។ បេ។

ចប់ សប្បាណកវគ្គ ទី៧។

ឧទ្ទាននៃសប្បាណកវគ្គនោះ ដូច្នេះ

[១៣៦]

> រឿងភិក្ខុក្លែងធ្វើឱ្យធ្លាក់ចុះចាកជីវិត ១ រឿងភិក្ខុប្រើប្រាស់ទឹកដែលមានសត្វ ១ រឿងភិក្ខុសើរើអធិករណ៍ ដែលសង្ឃរម្ងាប់ត្រឹមត្រូវតាមធម៌ហើយ ១ រឿងភិក្ខុដឹងហើយបិទបាំងទុដ្ឋុល្លាបត្តិ១ រឿងភិក្ខុឱ្យឧបសម្បទាដល់បុគ្គលមានឆ្នាំមិនគ្រប់ម្ភៃ ១ រឿងភិក្ខុដើរផ្លូវឆ្ងាយទៅជាមួយនឹងពួកជនដែលមានថេយ្យចិត្ត ១ រឿងភិក្ខុដើរផ្លូវឆ្ងាយជាមួយនឹងមាតុគ្រាម ដោយបបួលគ្នា ១ (រឿងភិក្ខុមិនលះបង់ទិដ្ឋិអាក្រក់) ១ រឿងភិក្ខុបរិភោគជាមួយ (នឹងភិក្ខុដែលមិនលះបង់ទិដ្ឋិអាក្រក់) ១ រឿងភិក្ខុសង្គ្រោះសមណុទ្ទេសដែលសង្ឃធ្វើនាសនកម្មហើយ ១។

## សហធម្មិកវគ្គ ទី៨

CS vin.pv.01.1.01.5.8 | ភាគ ទី១២

### (៨. សហធម្មិកវគ្គោ)

[១៣៧] ភិក្ខុ កាលបើភិក្ខុទាំងឡាយនិយាយតាមសិក្ខាបទដែល ព្រះមានព្រះភាគទ្រង់បញ្ញត្តទុក ហើយពោលតបវិញថា នែអាវុសោ ខ្ញុំ មិនទាន់សិក្សាក្នុងសិក្ខាបទនេះទេ ព្រោះមិនទាន់បានសាកសួរភិក្ខុឯទៀត ដែលជាអ្នកឈ្លាស ជាអ្នកទ្រទ្រង់វិន័យ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឆន្នៈមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែល

ព្រះឆន្នៈមានអាយុ កាលបើភិក្ខុទាំងឡាយនិយាយតាម សិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុក ក៏ពោលតបវិញថា ម្នាលអាវុសោ ខ្ញុំមិនទាន់សិក្សា ក្នុងសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុឯទៀត ដែលជាអ្នកឈ្លាស ជាអ្នកទ្រទ្រង់វិន័យ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១៣៨] ភិក្ខុពោលតិះដៀលវិន័យ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែកពួកឆព្វគ្គិយភិក្ខុ ពោលតិះដៀលវិន័យ។ សិក្ខាបទនោះ មាន តែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣។ បេ។

[១៣៩] ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះសង្ឃលើកមោហារោបនកម្មរួចហើយ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ធ្វើជាវង្វេងមិនស្គាល់សិក្ខាបទ(ពើ)។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១៤០] ភិក្ខុឱ្យនូវការប្រហារដល់ភិក្ខុផងគ្នា ដោយសេចក្តីខឹងអាក់អន់ចិត្ត ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុខឹងអាក់អន់ចិត្តហើយ ឱ្យនូវការប្រហារដល់ភិក្ខុទាំងឡាយ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។ បេ។

[១៤១] ភិក្ខុលើកនូវលំពែង គឺបាតដៃជន្លភិក្ខុផងគ្នា ដោយសេចក្តីខឹងអាក់អន់ចិត្ត ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុខឹងអាក់អន់ចិត្ត ហើយលើកនូវលំពែង គឺបាតដៃ ជន្លភិក្ខុទាំងឡាយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិ នោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានទាំងឡើងអំពីវាចាឡើយ។បេ។

[១៤២] ភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសដែលគ្មានមូល ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសដែលគ្មានមូល។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១៤៣] ភិក្ខុក្លែងបណ្តាលសេចក្តីរង្កៀស ឱ្យកើតឡើងដល់ភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ក្លែងបណ្តាលសេចក្តីរង្កៀសឱ្យកើតឡើងដល់ភិក្ខុទាំងឡាយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១៤៤] ភិក្ខុឈរអែបស្តាប់ភិក្ខុទាំងឡាយ ដែលបង្កហេតុ ឈ្លោះទាស់ទែងកើតឡើង ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ឈរអែបស្តាប់ភិក្ខុទាំងឡាយ ដែលបង្កហេតុឈ្លោះទាស់ទែងកើតឡើង។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន។បេ។

[១៤៥] ភិក្ខុបានឱ្យឆន្ទៈ គឺសេចក្តីយល់ព្រម ដល់កម្មដែលប្រកបដោយធម៌ ហើយត្រឡប់តិះដៀលជាខាងក្រោយវិញ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ បានឱ្យឆន្ទៈ ដល់កម្មដែលប្រកប ដោយធម៌ ហើយត្រឡប់តិះដៀលជាខាងក្រោយវិញ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។ បេ។

[១៤៦] ពាក្យវិនិច្ឆ័យកំពុងតែប្រព្រឹត្តទៅក្នុងសង្ឃ ភិក្ខុមិនបានឱ្យឆន្ទៈ ហើយក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុមួយរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿង ដែលភិក្ខុមួយរូប កាលបើពាក្យវិនិច្ឆ័យកំពុងតែប្រព្រឹត្តទៅក្នុងសង្ឃ មិនបានឱ្យឆន្ទៈ ក៏ក្រោកចាកអាសនៈចៀសចេញទៅ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយវាចានិងចិត្ត។បេ។

[១៤៧] ភិក្ខុឱ្យចីវរដោយមានសង្ឃព្រមព្រៀងគ្នា ហើយត្រឡប់ តិះដៀលជាខាងក្រោយវិញ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ បានឱ្យចីវរដោយមានសង្ឃព្រមព្រៀងគ្នា ហើយត្រឡប់តិះដៀលជាខាងក្រោយវិញ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

[១៤៨] ភិក្ខុដឹងថា លាភរបស់សង្ឃ ដែលគេបង្អោនដើម្បីសង្ឃ ហើយ ក៏ត្រឡប់បង្អោនទៅដើម្បីបុគ្គលវិញ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ដឹងថា លាភរបស់សង្ឃដែលគេបង្អោនដើម្បីសង្ឃហើយ ត្រឡប់បង្អោនទៅដើម្បីបុគ្គលវិញ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។បេ។

ចប់ សហធម្មិកវគ្គ ទី៨។

ឧទ្ទាននៃសហធម្មិកវគ្គនោះ ដូច្នេះ

[១៤៩]

រឿងភិក្ខុដែលគេប្រដៅដោយសហធម៌ (សិក្ខាបទ)១ រឿងភិក្ខុពោលតិះដៀលវិន័យ ១ រឿងភិក្ខុក្លែងធ្វើជាមិនដឹងសិក្ខាបទ១ រឿងភិក្ខុប្រហារភិក្ខុផងគ្នា១ រឿងភិក្ខុលើកលំពែងគឺបាតដៃ១ រឿងភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេសមិនមានមូល១ រឿងភិក្ខុក្លែងញ៉ាំងសេចក្តីរង្កៀសឱ្យកើតឡើងដល់ភិក្ខុផងគ្នា១ រឿងភិក្ខុអែបស្តាប់ភិក្ខុដែលឈ្លោះគ្នា១ រឿងភិក្ខុឱ្យឆន្ទៈដល់កម្មដែលប្រកបដោយធម៌១ រឿងភិក្ខុមិនបានឱ្យឆន្ទៈហើយក្រោកចាកទីវិនិច្ឆ័យ១ រឿងសង្ឃព្រមព្រៀងគ្នាឱ្យចីវរដល់ភិក្ខុ១ រឿងភិក្ខុបង្អោនលាភសង្ឃ ដើម្បីបុគ្គលវិញ១។

## រាជវគ្គ ទី៩

CS vin.pv.01.1.01.5.9 | ភាគ ទី១២

### (៩. រាជវគ្គោ)

[១៥០] ភិក្ខុចូលទៅកាន់ព្រះរាជវាំងរបស់ព្រះរាជា ដោយមិនបានថ្វាយដំណឹងជាមុន ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះអានន្ទមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលព្រះអានន្ទមានអាយុ មិនបានថ្វាយដំណឹងជាមុន ហើយចូលទៅកាន់ព្រះរាជវាំងរបស់ព្រះរាជា។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២(ដូចក្នុងកឋិនសិក្ខាបទ)។ បេ។

[១៥១] ភិក្ខុរើសរតនវត្ថុ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុមួយរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុមួយរូបបានរើសរតនវត្ថុ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ២។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។ បេ។

[១៥២] ភិក្ខុមិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយចូលទៅ កាន់ស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ មិនបានលាភិក្ខុផងគ្នាដែលមាននៅ ហើយចូលទៅកាន់ស្រុក ក្នុងវេលាវិកាល។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ៣។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។បេ។

[១៥៣] ភិក្ខុឱ្យគេធ្វើបំពង់ម្ជុលនឹងឆ្អឹងក្តី នឹងភ្លុកក្តី នឹងស្នែងក្តី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនសក្កៈ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុច្រើនរូបមិនដឹងប្រមាណ ដើរសូមបំពង់ម្ជុលគេជាច្រើន។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។បេ។

[១៥៤] ភិក្ខុឱ្យគេធ្វើគ្រែក្តី តាំងក្តី ឱ្យកន្លងហួសប្រមាណ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧបនន្ទ ជាសក្យបុត្តមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលព្រះឧបនន្ទជាសក្យបុត្តមានអាយុឱ្យគេធ្វើគ្រែខ្ពស់។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។ បេ។

[១៥៥] ភិក្ខុឱ្យគេធ្វើគ្រែក្តី តាំងក្តី ដែលញាត់ដោយសំឡី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុឱ្យគេធ្វើគ្រែខ្លះ តាំងខ្លះ ដែលញាត់ដោយសំឡី។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។បេ។

[១៥៦] ភិក្ខុ ឱ្យគេធ្វើសំពត់និសីទនៈ ឱ្យកន្លងហួសប្រមាណ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុឱ្យធ្វើសំពត់និសីទនៈមិនត្រូវខ្នាត។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦។ បេ។

[១៥៧] ភិក្ខុឱ្យគេធ្វើសំពត់គ្របកម ឬដំបៅឱ្យកន្លងហួសប្រមាណ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុប្រើប្រាស់សំពត់គ្របកម ឬដំបៅមិនត្រូវខ្នាត។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។ បេ។

[១៥៨] ភិក្ខុឱ្យគេធ្វើសំពត់ងូតទឹកភ្លៀងកន្លងហួសប្រមាណ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុប្រើប្រាស់សំពត់ងូតទឹកភ្លៀងមិនត្រូវខ្នាត។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦។ បេ។

[១៥៩] ភិក្ខុឱ្យគេធ្វើចីវរប៉ុនគ្នានឹងចីវរព្រះសុគត ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះនន្ទមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលព្រះនន្ទមានអាយុ ប្រើប្រាស់ចីវរប៉ុនគ្នា នឹងចីវរព្រះសុគត។ សិក្ខាបទនោះ មានបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។បេ។

ចប់ រាជវគ្គ ទី៩។

ឧទ្ទាននៃរាជវគ្គនោះ ដូច្នេះ

[១៦០]

រឿងភិក្ខុចូលទៅកាន់ព្រះរាជវាំង១ រឿងភិក្ខុរើសរតនវត្ថុ១ រឿងភិក្ខុមិនបានលាភិក្ខុផងគ្នា ហើយចូលទៅកាន់ស្រុក១ រឿងភិក្ខុឱ្យគេធ្វើបំពង់ម្ជុល១ រឿងភិក្ខុឱ្យគេធ្វើគ្រែ១ រឿងភិក្ខុឱ្យគេធ្វើគ្រែ ញាត់ដោយសំឡី១ រឿងភិក្ខុឱ្យគេធ្វើសំពត់និសីទនៈ ១ រឿងភិក្ខុឱ្យគេធ្វើសំពត់គ្រប់កមឬដំបៅ១រឿងភិក្ខុឱ្យគេធ្វើសំពត់ងូតទឹកភ្លៀង១ រឿងភិក្ខុប្រើប្រាស់ចីវរប៉ុនគ្នានឹងចីវរព្រះសុគត។

ចប់ បាចិត្តិយៈ ៩២ តែប៉ុណ្ណេះ។

ឧទ្ទាននៃវគ្គទាំងនោះ ដូច្នេះ

[១៦១]

វគ្គទាំងនោះ មាន៩ គឺ មុសាវាទវគ្គ១ ភូតគាមវគ្គ១ ឱវាទវគ្គ១ ភោជនវគ្គ១ អចេលកវគ្គ១ សុរាបាណកវគ្គ១ សប្បាណកវគ្គ១ សហធម្មិកវគ្គ១ រាជវគ្គ១។

## (បាដិទេសនីយកណ្ឌៈ ទី៦)

CS vin.pv.01.1.01.6 | ភាគ ទី១២

### (៦. បាដិទេសនីយកណ្ឌំ)

[១៦២] សួរថា សិក្ខាបទណាមានឈ្មោះថាបាដិទេសនីយៈ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ(នូវអំណាចប្រយោជន៍ទាំង១០) បានបញ្ញត្តហើយ ដល់ភិក្ខុដែលទទួលខាទនីយៈ ឬភោជនីយៈដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីមិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះស្រុក សិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុមួយរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុមួយរូប ទទួលអាមិសៈ អំពីដៃភិក្ខុនីមិនមែនជាញាតិ ដែលចូលទៅចន្លោះស្រុក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើង អំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន។បេ។

[១៦៣] ភិក្ខុមិនបានឃាត់ភិក្ខុនីដែលកំពុងបង្គាប់បញ្ជា ហើយឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុមិនបានឃាត់ភិក្ខុនី ដែលកំពុងបង្គាប់បញ្ជា (ឱ្យប្រគេនបាយសម្លដល់ភិក្ខុ) សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើង ដោយសមុដ្ឋាន២ គឺតាំងឡើងអំពីកាយនិងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្តក៏មាន។បេ។

[១៦៤] ភិក្ខុទទួលខាទនីយៈឬភោជនីយៈ ដោយដៃរបស់ខ្លួន ក្នុង ត្រកូលដែលសង្ឃបានសន្មតឱ្យជាសេក្ខត្រកូល ឆាន់ខ្លួនឯង ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុច្រើនរូប មិនដឹងប្រមាណហើយទទួល។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ២។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន។ បេ។

[១៦៥] ភិក្ខុនៅក្នុងសេនាសនៈក្នុងព្រៃ ទទួលខាទនីយៈឬភោជនីយៈ ដែលទាយកមិនបានឱ្យដំណឹងជាមុន ដោយដៃរបស់ខ្លួន ក្នុងអារាម ហើយឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនសក្កៈ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុច្រើនរូប កាលបើចោរនៅអាស្រ័យក្នុងអារាម ក៏មិនបានប្រាប់គេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំង ឡើងដោយសមុដ្ឋាន ២ គឺតាំងឡើងអំពីកាយនិងវាចា មិនបានតាំងឡើង អំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចាចិត្តក៏មាន។ បេ។

ចប់ បាដិទេសនិយៈ ៤ តែប៉ុណ្ណេះ។

ឧទ្ទាននៃបាដិទេសនីយៈនោះ ដូច្នេះ

[១៦៦]

រឿងភិក្ខុទទួលខាទនីយភោជនីយាហារ អំពីភិក្ខុនីដែលមិនមែនជាញាតិ១ រឿងភិក្ខុមិនឃាត់ភិក្ខុនីដែលកំពុងបង្គាប់បញ្ជា១ រឿងភិក្ខុទទួលខាទនីយភោជនីយាហារ ក្នុងសេក្ខត្រកូល១ រឿងភិក្ខុនៅក្នុងសេនាសនៈក្នុងព្រៃ១ បាដិទេសនីយៈទាំង៤ ដូច្នេះ ព្រះសម្ពុទ្ធសម្តែងហើយ។

## (សេខិយកណ្ឌៈ ទី៧)

CS vin.pv.01.1.01.7 | ភាគ ទី១២

### (៧. សេខិយកណ្ឌំ)

## បរិមណ្ឌលវគ្គ ទី១

CS vin.pv.01.1.01.7.1 | ភាគ ទី១២

### (១. បរិមណ្ឌលវគ្គោ)

[១៦៧] សួរថា អាបត្តិទុក្កដណា ដែលព្រះមានព្រះភាគអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចប្រយោជន៍ទាំង ១០) បានបញ្ញត្តហើយដល់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើ ស្លៀករឃឹករឃាកខាងមុខខាងក្រោយ អាបត្តិទុក្កដនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ឆ្លើយថា ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុស្លៀកស្បង់រឃឹករឃាកខាងមុខខ្លះ ខាងក្រោយខ្លះ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។ បេ។

[១៦៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដណ្តប់ចីពររឃឹករឃាក ខាងមុខក្តី ខាងក្រោយក្តី ត្រូវអាបត្តិទុក្កដ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់ បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ដណ្តប់ចីពររឃឹករឃាកខាងមុខខ្លះ ខាងក្រោយខ្លះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចា។បេ។

[១៦៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ហើយបើកកាយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុបើកកាយដើរទៅក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៧០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បើកកាយអង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុបើកកាយ អង្គុយក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៧១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ក្រមាច់ដៃក្តី ជើងក្តី ដើរចូលក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុក្រមាច់ដៃខ្លះ ជើងខ្លះ ដើរទៅ ក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៧២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ក្រមាច់ដៃក្តី ជើងក្តី អង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុក្រមាច់ដៃខ្លះ ជើងខ្លះ អង្គុយក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៧៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ក្រឡេកមើលពីសពាស ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុក្រឡេកមើលពីសពាស ដើរទៅក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៧៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ក្រឡេកមើលពីសពាសអង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុក្រឡេកមើលពីសពាស អង្គុយក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។បេ។

[១៧៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ សើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុង

បឋមបារាជិកសិក្ខាបទ)។

[១៧៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើសើយចីវរ អង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុសើយចីវរ អង្គុយក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

ចប់ បរិមណ្ឌលវគ្គ ទី១។

## ឧជ្ជគ្ឃិកវគ្គ ទី២

CS vin.pv.01.1.01.7.2 | ភាគ ទី១២

### (២. ឧជ្ជគ្ឃិកវគ្គោ)

[១៧៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរទៅក្នុងចន្លោះផ្ទះដោយ សំណើចខ្លាំង ត្រូវអាបត្តិទុក្កដ។ បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺ តាំងឡើងអំពីកាយវាចានិងចិត្ត។

[១៧៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយក្នុងចន្លោះផ្ទះដោយសំណើចខ្លាំង ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្ត ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺ តាំងឡើងអំពីកាយវាចានិងចិត្ត។

[១៧៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើសំឡេងហ៊ោ សំឡេងខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ ព្រោះរឿងដែលពួក ឆព្វគ្គិយភិក្ខុ ធ្វើសំឡេងហ៊ោ សំឡេងខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិ នោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងសមនុភាសនសិក្ខាបទ)។

[១៨០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើសំឡេងហ៊ោ សំឡេងខ្លាំង អង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងសមនុភាសនសិក្ខាបទ)។

[១៨១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រលែងកាយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ដើរគ្រលែងកាយទៅក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៨២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយគ្រលែងកាយ ក្នុង ចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបា រាជិកសិក្ខាបទ)។

[១៨៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរវាសដៃទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៨៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយវាសដៃក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៨៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រលែងក្បាលទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៨៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយគ្រលែងក្បាលក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

ចប់ ឧជ្ជគ្ឃិកវគ្គ ទី២។

## ខម្ភកតវគ្គ ទី៣

CS vin.pv.01.1.01.7.3 | ភាគ ទី១២

### (៣. ខម្ភកតវគ្គោ)

[១៨៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរស្ទឹមចង្កេះទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៨៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយស្ទឹមចង្កេះក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៨៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរទទូរក្បាលទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុដណ្តប់គ្រលុំកាយព្រមទាំងក្បាល ដើរទៅក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៩០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយទទូរក្បាលនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៩១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរចំអើតជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៩២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយត្របោមក្បាលជង្គង់ នៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៩៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលបិណ្ឌបាតមិនគោរព ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៩៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ក្រឡេកមើលពីសពាស ទទួលចង្ហាន់បិណ្ឌបាត ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុង បឋមបារាជិកសិក្ខាបទ)។

[១៩៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលសម្លឱ្យច្រើន (លើសបាយ) ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៩៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលបិណ្ឌបាតឱ្យកំពុង (ហួសមាត់បាត្រ) ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

ចប់ ខម្ពកតវគ្គ ទី៣។

## បិណ្ឌបាតវគ្គ ទី៤

CS vin.pv.01.1.01.7.4 | ភាគ ទី១២

### (៤. បិណ្ឌបាតវគ្គោ)

[១៩៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគបិណ្ឌបាតមិនគោរព ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៩៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ក្រឡេកមើលពីសពាស បរិភោគបិណ្ឌបាត ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[១៩៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កកាយបាយឱ្យខូងក្នុងទីនោះៗ ឆាន់បិណ្ឌបាត ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២០០] ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ បរិភោគសម្លច្រើនជាង (បាយ) ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២០១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បិណ្ឌបាតច្រមចុះអំពីកំពូលបាយ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២០២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កកាយបាយលុបសម្ល ឬម្ហូប ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២០៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សុំសម្លឬបាយបម្រុងខ្លួនឯង ហើយឆាន់ ត្រូវអាបត្តិទុក្កដ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ ទៅសុំសម្លខ្លះ បាយខ្លះ បម្រុងខ្លួនឯង ហើយឆាន់។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន។

[២០៤] ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ សម្គាល់ដោយការលើកទោសគេ រំពៃមើលបាត្រភិក្ខុដទៃ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២០៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើពំនូតបាយឱ្យធំ[13] ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២០៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើពំនូតបាយឱ្យវែង ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

ចប់ បិណ្ឌបាតវគ្គ ទី៤។

## កពឡវគ្គ ទី៥

CS vin.pv.01.1.01.7.5 | ភាគ ទី១២

### (៥. កពឡវគ្គោ)

[២០៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កាលដែលពំនូតបាយមិនទាន់ដល់មាត់ ក៏ហាមាត់ចាំ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២០៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគញាត់ម្រាមដៃទាំង អស់ទៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២០៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ និយាយទាំងពំនូតបាយនៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយ វាចានឹងចិត្ត។

[២១០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគបោះដុំបាយទៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋម បារាជិកសិក្ខាបទ)។

[២១១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគខាំកាត់ពំនូតបាយ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២១២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគបៀមទុលថ្ពាល់ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២១៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគរលាស់ដៃ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២១៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគឱ្យជ្រុះគ្រាប់បាយ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២១៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគលៀនអណ្តាត ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២១៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគឱ្យឮផ្លុប់ៗ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

ចប់ កពឡវគ្គ ទី៥។

## សុរុសុរុវគ្គ ទី៦

CS vin.pv.01.1.01.7.6 | ភាគ ទី១២

### (៦. សុរុសុរុវគ្គោ)

[២១៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគឱ្យឮសុរុសុរុ (គ្រូកៗ) ត្រូវអាបត្តិទុក្កដ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងភិក្ខុច្រើនរូប ផឹកទឹកដោះស្រស់ឱ្យឮ សុរុសុរុ(គ្រូកៗ)។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២១៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគលិទ្ធដៃ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២១៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគលិទ្ធបាត្រ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២២០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បរិភោគលិទ្ធបបូរមាត់ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បេ។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[២២១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលសៀនទឹក ដោយដៃដែលប្រឡាក់ដោយអាមិសៈ ត្រូវអាបត្តិទុក្កដ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនភគ្គៈ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច ព្រោះរឿងភិក្ខុច្រើនរូប ទទួលសៀនទឹកដោយដៃដែលប្រឡាក់ដោយអាមិសៈ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចា។

[២២២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ចាក់ទឹកលាងបាត្រទាំងគ្រាប់បាយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនភគ្គៈ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងភិក្ខុច្រើនរូបចាក់ទឹកលាង បាត្រទាំងគ្រាប់បាយក្នុងចន្លោះផ្ទះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចា។

[២២៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ហើយសម្តែងធម៌ដល់មនុស្សដែលមានឆត្រក្នុងដៃ ត្រូវអាបត្តិទុក្កដ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយ ភិក្ខុសម្តែងធម៌ដល់មនុស្សដែលមានឆត្រនៅក្នុងដៃ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២២៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលមានដំបងក្នុងដៃ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២២៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលមានគ្រឿងសស្ត្រាក្នុងដៃ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះមានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២២៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលមានគ្រឿងអាវុធ[14] ក្នុងដៃ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

ចប់ សុរុសុរុវគ្គ ទី៦។

## បាទុកាវគ្គ ទី៧

CS vin.pv.01.1.01.7.7 | ភាគ ទី១២

**(៧. បាទុកវគ្គោ)**

[២២៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សដែលពាក់ទ្រនាប់ជើង ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២២៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្សដែលពាក់ស្បែកជើង ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២២៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលឋិតនៅលើយាន ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២៣០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលនៅលើដំណេក ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២៣១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលអង្គុយត្របោមក្បាលជង្គង់ ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២៣២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលជួតក្បាល ត្រូវអាបត្តិទុក្កដ។បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២៣៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលទទូរក្បាល ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២៣៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយលើផែនដី សម្តែង ធម៌ដល់មនុស្សដែលអង្គុយលើអាសនៈ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២៣៥] ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ អង្គុយលើអាសនៈទាប សម្តែងធម៌ដល់មនុស្សដែលអង្គុយលើអាសនៈខ្ពស់ជាង ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺ តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២៣៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឈរសម្តែងធម៌ ដល់មនុស្សដែលអង្គុយ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយ។

[២៣៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរពីខាងក្រោយសម្តែង ធម៌ដល់មនុស្សដែលដើរអំពីមុខ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយនិងវាចា និងចិត្ត។

[២៣៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរក្រៅផ្លូវសម្តែងធម៌ ដល់មនុស្សដែលដើរតាមផ្លូវ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងវាចា និងចិត្ត។

[២៣៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឈរបន្ទោបង់ឧច្ចារៈ ឬ បស្សាវៈ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើង អំពីវាចា។

[២៤០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោបង់ឧច្ចារៈក្តី បស្សាវៈក្តី ស្តោះទឹកមាត់ក្តី ដាក់លើ (រុក្ខជាតិដើមឈើ) ដែលមានពណ៌ខៀវស្រស់ ត្រូវអាបត្តិទុក្កដ។ បេ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុ ប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋានតែ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចា។

[២៤១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោបង់ឧច្ចារៈក្តី បស្សាវៈក្តី ស្តោះទឹកមាត់ក្តី ដាក់ក្នុងទឹក ត្រូវអាបត្តិទុក្កដ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងពួកឆព្វគ្គិយភិក្ខុ បានបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់ក្នុងទឹក។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ គឺតាំងឡើង អំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចា។

ចប់ បាទុកាវគ្គ ទី៧។

សេខិយវត្ត គឺវត្តដែលភិក្ខុត្រូវសិក្សា មាន៧៥ ចប់ តែប៉ុណ្ណេះ។

ចប់ កត្ថបញ្ញត្តិវារៈ ក្នុងមហាវិភង្គ។

ឧទ្ទាននៃសេខិយវត្តនោះ ដូច្នេះ

[២៤២]

រឿងភិក្ខុត្រូវស្លៀកដណ្តប់ ឱ្យជាបរិមណ្ឌល១ រឿងភិក្ខុបិទបាំងកាយ១ រឿងភិក្ខុសង្រួមឱ្យល្អ១ រឿងភិក្ខុមានភ្នែកដាក់ចុះ១ រឿងភិក្ខុសើយចីវរ១ រឿងភិក្ខុធ្វើសំឡេងខ្លាំង ១ រឿងភិក្ខុគ្រលែងអវយវៈបីយ៉ាង១ រឿងភិក្ខុស្ទឹមចង្កេះ១ រឿងភិក្ខុទទូរក្បាល១ រឿងភិក្ខុចំអើតជើង ១ រឿងភិក្ខុអង្គុយត្របោមក្បាលជង្គង់ ១ រឿងភិក្ខុទទួលបិណ្ឌបាត ដោយគោរព ១ រឿងភិក្ខុទទួលបិណ្ឌបាតមានសេចក្តីសម្គាល់តែក្នុងបាត្រ ១ រឿងភិក្ខុទទួលបិណ្ឌបាតឱ្យមានសម្លស្មើគ្នា១ រឿងភិក្ខុទទួលបិណ្ឌបាត ឱ្យត្រឹមស្មើមាត់បាត្រ១ រឿងភិក្ខុឆាន់បិណ្ឌបាតដោយគោរព១ រឿងភិក្ខុឆាន់បិណ្ឌបាតមានសេចក្តីសម្គាល់តែក្នុងបាត្រ១ រឿងភិក្ខុឆាន់បិណ្ឌបាតវាចឱ្យស្មើ១ រឿង

ភិក្ខុឆាន់សម្លឱ្យស្មើនឹងបាយ១ រឿងភិក្ខុឆាន់ច្រមចុះអំពីកំពូលបាយ១ រឿងភិក្ខុកកាយបាយលុបសម្លឬម្ហូប១ រឿងភិក្ខុសុំបិណ្ឌបាត១ រឿងភិក្ខុសម្គាល់គិតនឹងលើកទោស១ រឿងភិក្ខុមិនធ្វើពំនូតបាយឱ្យធំហួសប្រមាណ១ រឿងភិក្ខុធ្វើពំនូតបាយឱ្យបរិមណ្ឌល១ រឿងភិក្ខុហាមាត់ចាំពំនូតបាយ១ រឿងភិក្ខុញាត់ម្រាមដៃទាំងអស់ទៅក្នុងមាត់១ រឿងភិក្ខុនិយាយទាំងអាហារនៅក្នុងមាត់១ រឿងភិក្ខុបោះដុំបាយបរិភោគ១ រឿងភិក្ខុខាំកាត់ពំនូតបាយ១ រឿងភិក្ខុឆាន់អាហារបៀមទុលថ្ពាល់១ រឿងភិក្ខុឆាន់រលាស់ដៃ១ រឿងភិក្ខុឆាន់ឱ្យជ្រុះគ្រាប់បាយ ១ រឿងភិក្ខុលៀនអណ្តាត១ រឿងភិក្ខុឆាន់ឮសូរចបុចបុ១ ឮសូរសុរុសុរុ១ រឿងភិក្ខុឆាន់ លិទ្ធដៃ១ រឿងភិក្ខុឆាន់លិទ្ធបាត្រ១ រឿងភិក្ខុឆាន់លិទ្ធបបូរមាត់១ រឿងភិក្ខុយកដៃដែលប្រឡាក់អាមិសទៅទទួលភាជន៍ទឹក១ រឿងភិក្ខុចាក់ទឹកលាងបាត្រទាំងគ្រាប់បាយ១ ព្រះតថាគតទាំងឡាយ មិនបានសម្តែងព្រះសទ្ធម្មដល់មនុស្សដែលមានឆត្រក្នុងដៃ និងមនុស្សដែលមានដំបងក្នុងដៃ និងមនុស្សដែលមានគ្រឿងសស្រ្តានិងអាវុធក្នុងដៃ និងមនុស្សពាក់ទ្រនាប់ ជើង ពាក់ស្បែកជើង ឋិតនៅលើយាននិងលើដំណេក អង្គុយ ត្របោមក្បាលជង្គង់ ជួតក្បាល ទទូរក្បាល និងមិនអង្គុយ លើផែនដី សម្តែងធម៌ដល់មនុស្សដែលអង្គុយនៅលើអាសនៈ មិនអង្គុយលើអាសនៈទាប សម្តែងធម៌ដល់មនុស្សដែលអង្គុយ លើអាសនៈខ្ពស់ មិនឈរសម្តែងធម៌ដល់មនុស្សដែលអង្គុយ មិនដើរក្រោយ សម្តែងធម៌ដល់មនុស្សដែលដើរមុន មិនដើរក្រៅផ្លូវ សម្តែងធម៌ដល់មនុស្សដែលដើរតាមផ្លូវ រឿងភិក្ខុមិនត្រូវឈរបន្ទោបង់ឧច្ចារៈឬបស្សាវៈ និងមិនត្រូវបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ លើវត្ថុស្រស់និងទឹក។

ឧទ្ទាននៃវគ្គទាំងនោះ ដូច្នេះ

# កតាបត្តិវារៈ ទី២

CS vin.pv.01.1.02 | ភាគ ទី១២

### (២. កតាបត្តិវារោ)

## (បារាជិកកណ្ឌៈ ទី១)

CS vin.pv.01.1.02.1 | ភាគ ទី១២

### (១. បារាជិកកណ្ឌំ)

[២៤៣]

បរិមណ្ឌលវគ្គ១ ឧជ្ជគ្ឃិកវគ្គ១ ខម្ភកតវគ្គ១ បិណ្ឌបាតវគ្គ១ កពឡវគ្គ១ សុរុសុរុវគ្គ១ បាទុកាវគ្គទីប្រាំពីរ១។

[២៤៤] ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិប៉ុន្មានយ៉ាង។ ភិក្ខុសេពមេថុនធម្មត្រូវអាបត្តិ៣យ៉ាង គឺ សេពមេថុនធម្ម ចំពោះសរីរៈដែលសត្វមិនទាន់ស៊ី ត្រូវអាបត្តិបារាជិក សេពមេថុនធម្ម ចំពោះសរីរៈដែលសត្វស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ បញ្ចូលអង្គជាតទៅក្នុងមាត់ដែលហាតែមិនឱ្យប៉ះ ត្រូវអាបត្តិទុក្កដ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ៣យ៉ាងនេះឯង។

[២៤៥] ភិក្ខុកាន់យកទ្រព្យដែលគេមិនឱ្យ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុកាន់យកទ្រព្យ ដែលគេមិនឱ្យ ត្រូវអាបត្តិ៣ គឺកាន់យកទ្រព្យ ដែលគេមិនឱ្យ គួរដល់ថ្លៃ៥ មាសកក្តី លើសពី ៥ មាសកក្តី ដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក កាន់យកទ្រព្យដែលគេមិនឱ្យ គួរដល់ថ្លៃលើសពី ១ មាសកក្តី ខ្វះពី៥មាសកក្តី ដោយថេយ្យចិត្ត ត្រូវអាបត្តិថុល្លច្ច័យ កាន់យកទ្រព្យដែលគេមិនឱ្យ គួរដល់ថ្លៃ១មាសកក្តី ខ្វះពី១មាសកក្តី ដោយថេយ្យចិត្ត ត្រូវអាបត្តិទុក្កដ ភិក្ខុកាន់យកទ្រព្យដែលគេមិនឱ្យត្រូវអាបត្តិ៣នេះឯង។

[២៤៦] ភិក្ខុ ក្លែងផ្តាច់បង់រាងកាយរបស់មនុស្ស ឱ្យធ្លាក់ចុះចាកជីវិត ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុ ក្លែងផ្តាច់បង់រាងកាយរបស់មនុស្ស ឱ្យធ្លាក់ចុះចាកជីវិត ត្រូវអាបត្តិ៣យ៉ាងគឺ ជីករណ្តៅចំពោះមនុស្ស ដោយប៉ុនប៉ងថា អ្នកណានីមួយនឹងធ្លាក់ស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ កាលបើមនុស្សនោះ ធ្លាក់ទៅហើយកើតទុក្ខវេទនាឡើង ត្រូវអាបត្តិថុល្លច្ច័យ (បើ) មនុស្សនោះស្លាប់ ត្រូវអាបត្តិបារាជិក ភិក្ខុក្លែងផ្តាច់បង់ជីវិតរបស់មនុស្ស ត្រូវអាបត្តិ៣នេះឯង។

[២៤៧] ភិក្ខុ ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុ ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិ៣គឺ ភិក្ខុ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិបារាជិក ភិក្ខុនិយាយកុហកថា ភិក្ខុណានៅក្នុង វិហាររបស់អ្នក ភិក្ខុនោះជាព្រះអរហន្ត កាលបើអ្នកស្តាប់ដឹងច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើពុំដឹងច្បាស់ ត្រូវអាបត្តិទុក្កដ ភិក្ខុពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិ៣នេះឯង។

ចប់ បារាជិក ៤។

## (សង្ឃាទិសេសកណ្ឌៈ ទី២)

CS vin.pv.01.1.02.2 | ភាគ ទី១២

**(២. សង្ឃាទិសេសកណ្ឌំ)**

[២៤៨] ភិក្ខុ ព្យាយាមបញ្ចេញអសុចិ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុ ព្យាយាមបញ្ចេញអសុចិ ត្រូវអាបត្តិ៣គឺ គិតព្យាយាមទាល់តែអសុចិ ឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស គិតព្យាយាម តែអសុចិមិនឃ្លាតចេញ ត្រូវអាបត្តិថុល្លច្ច័យ គ្រាន់តែព្យាយាម ត្រូវអាបត្តិទុក្កដ។

[២៤៩] ភិក្ខុ ដល់ព្រមនូវកាយសំសគ្គៈ មួយអន្លើដោយមាតុគ្រាម ត្រូវអាបត្តិ៣គឺ ភិក្ខុស្ទាបអង្អែលកាយ (ស្ត្រី) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិសង្ឃាទិសេស ស្ទាបអង្អែលវត្ថុ ដែលជាប់ដោយកាយ (ស្ត្រី) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ ស្ទាបអង្អែលវត្ថុ ដែលជាប់ដោយកាយ (ស្ត្រី) ដោយវត្ថុជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ។

[២៥០] ភិក្ខុ និយាយចែចង់មាតុគ្រាមដោយសម្តីអាក្រក់ ត្រូវអាបត្តិ៣គឺ ភិក្ខុនិយាយសរសើរក្តី និយាយតិះដៀលក្តី ចំពោះវច្ចមគ្គ ឬបស្សាវមគ្គ ត្រូវអាបត្តិសង្ឃាទិសេស និយាយសរសើរក្តី និយាយតិះដៀលក្តី ចំពោះអវយវៈ ពីត្រឹមដងកាំបិតចុះមកខាងក្រោម ពីមណ្ឌលជង្គង់ឡើងទៅខាងលើ វៀរលែងតែវច្ចមគ្គ និងបស្សាវមគ្គចេញ ត្រូវអាបត្តិថុល្លច្ច័យ និយាយសរសើរក្តី និយាយតិះដៀលក្តី ចំពោះវត្ថុជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ។

[២៥១] ភិក្ខុ និយាយសរសើរការបម្រើកាមដើម្បីខ្លួន ត្រូវអាបត្តិ៣ គឺ និយាយសរសើរការបម្រើកាមដើម្បីខ្លួន ក្នុងសម្នាក់មាតុគ្រាម ត្រូវអាបត្តិសង្ឃាទិសេស និយាយសរសើរការបម្រើកាមដើម្បីខ្លួន ក្នុងសម្នាក់បណ្ឌក ត្រូវអាបត្តិថុល្លច្ច័យ និយាយសរសើរការបម្រើកាមដើម្បីខ្លួន ក្នុងសម្នាក់តិរច្ឆាន ត្រូវអាបត្តិទុក្កដ។

[២៥២] ភិក្ខុ ប្រព្រឹត្តការដឹកនាំ (ពាក្យប្រុសស្រី) ត្រូវអាបត្តិ ៣ គឺ ទទួលពាក្យ (ខាងប្រុស) ហើយទៅនិយាយល្បងមើល (នឹងស្រី) ហើយត្រឡប់មកប្រាប់(ខាងប្រុស)វិញ ត្រូវអាបត្តិសង្ឃាទិសេស ទទួលពាក្យហើយ ទៅនិយាយល្បងមើល តែមិនត្រឡប់មកប្រាប់វិញ ត្រូវអាបត្តិថុល្លច្ច័យ ទទួលពាក្យហើយ តែមិនទៅនិយាយល្បងមើល មិនត្រឡប់មកប្រាប់វិញ ត្រូវអាបត្តិទុក្កដ។

[២៥៣] ភិក្ខុឱ្យគេធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍ពីគេមកដោយខ្លួនឯង ត្រូវអាបត្តិ ៣ គឺ ឱ្យគេធ្វើ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ (ដែលធ្វើ) កាលមើលមិនទាន់បូកលាបដុំកំបោរ ឬដីស្អិតមួយដុំនៅឡើយ ត្រូវអាបត្តិថុល្លច្ច័យ កាលបើបានបូកលាបដុំកំបោរ ឬដីស្អិតមួយដុំនោះស្រេចហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[២៥៤] ភិក្ខុឱ្យគេធ្វើវិហារធំ ត្រូវអាបត្តិ៣គឺ ឱ្យគេធ្វើ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ(ដែលប្រើគេឱ្យធ្វើ)កាលបើមិនទាន់បូកលាបដុំកំបោរ ឬដីស្អិតមួយដុំនៅឡើយ ត្រូវអាបត្តិថុល្លច្ច័យ កាលបើបានបូកលាបដុំកំបោរ ឬដីស្អិតមួយដុំនោះស្រេចហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[២៥៥] ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល ត្រូវអាបត្តិ៣គឺ មិនសូមឱកាសជាមុនសិន ហើយចោទ ដោយមានប្រាថ្នាដើម្បីឱ្យឃ្លាតចាកព្រហ្មចារ្យ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ភិក្ខុសូមឱកាសជាមុន ហើយទើបចោទ ដោយមានប្រាថ្នានឹងជេរ ត្រូវអាបត្តិបាចិត្តិយៈ ព្រោះពោលពាក្យចាក់ដោត។

[២៥៦] ភិក្ខុ ចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក ព្រោះអាស្រ័យគ្រឿងអាងណាមួយ គ្រាន់តែជាលេសនៃអធិករណ៍ជាចំណែកដទៃ ត្រូវអាបត្តិ៣គឺ ភិក្ខុមិនសូមឱកាស (ជាមុន) ហើយចោទ ដោយមានប្រាថ្នា ដើម្បីឱ្យឃ្លាតចាកព្រហ្មចារ្យ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ សូមឱកាស (ជាមុន) ហើយចោទ ដោយមានប្រាថ្នានឹងជេរ ត្រូវអាបត្តិបាចិត្តិយៈ ព្រោះពោលពាក្យចាក់ដោត។

[២៥៧] ភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃ បានសូត្រសមនុភាសនកម្មអស់វារៈ ៣ ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ៣គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ (ដំបូង) ត្រូវអាបត្តិថុល្លច្ច័យ ដោយសូត្រកម្មវាចាពីរដង ត្រូវអាបត្តិសង្ឃាទិសេស ក្នុងខណៈសូត្រកម្ម វាចាចប់។

[២៥៨] ពួកភិក្ខុ អ្នកប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃ កាលបើ សង្ឃបានសូត្រសមនុភាសនកម្ម អស់វារៈជាគម្រប់៣ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ៣ គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ (ជាដំបូង) ត្រូវអាបត្តិថុល្លច្ច័យ ដោយសូត្រកម្មវាចាពីរដង ត្រូវសង្ឃាទិសេស ក្នុងខណៈសូត្រកម្មវាចាចប់។

[២៥៩] ភិក្ខុ ដែលគេប្រដៅបានដោយក្រ កាលបើសង្ឃ បានសូត្រសមនុភាសនកម្ម អស់វារៈជាគម្រប់៣ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ៣គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ (ជាដំបូង) ត្រូវអាបត្តិថុល្លច្ច័យ ដោយសូត្រកម្មវាចាពីរដង ត្រូវអាបត្តិសង្ឃាទិសេស ក្នុងខណៈសូត្រកម្មវាចាចប់។

[២៦០] ភិក្ខុទ្រុស្តត្រកូល កាលបើសង្ឃបានសូត្រសមនុភាសន កម្ម អស់វារៈជាគម្រប់៣ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ៣គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ (ដំបូង) ត្រូវអាបត្តិថុល្លច្ច័យ ដោយសូត្រកម្មវាចាពីរដង ត្រូវអាបត្តិសង្ឃាទិសេស ក្នុងខណៈសូត្រកម្មវាចាចប់។

ចប់ សង្ឃាទិសេស ១៣។

## (និស្សគ្គិយកណ្ឌៈ ទី៣)

CS vin.pv.01.1.02.3 | ភាគ ទី១២

**(៣. និស្សគ្គិយកណ្ឌំ)**

## កឋិនវគ្គ ទី១

CS vin.pv.01.1.02.3.1 | ភាគ ទី១២

### (១. កឋិនវគ្គោ)

[២៦១] ភិក្ខុទុកអតិរេកចីវរឱ្យកន្លងហួស១០ថ្ងៃទៅ ត្រូវអាបត្តិ១ គឺ និស្សគ្គិយបាចិត្តិយៈ។

[២៦២] ភិក្ខុនៅប្រាសចាកត្រៃចីវរ អស់មួយរាត្រី ត្រូវអាបត្តិ១ គឺ និស្សគ្គិយបាចិត្តិយៈ។

[២៦៣] ភិក្ខុទទួលអកាលចីវរ ហើយទុកឱ្យកន្លងហួសមួយខែទៅ ត្រូវអាបត្តិ១ គឺ និស្សគ្គិយបាចិត្តិយៈ។

[២៦៤] ភិក្ខុប្រើភិក្ខុនី ដែលមិនមែនជាញាតិ ឱ្យលាងចីវរចាស់ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើឱ្យលាង លុះឱ្យលាងរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៦៥] ភិក្ខុទទួលចីវរអំពីដៃភិក្ខុនី ដែលមិនមែនជាញាតិ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលទទួល លុះទទួលបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៦៦] ភិក្ខុ សូមចីវរនឹងគហបតីក្ដី គហបតានីក្ដី ដែលមិនមែនជាញាតិ ត្រូវអាបត្តិ២គឺ ភិក្ខុកំពុងសូម ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលសូម លុះសូមបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៦៧] ភិក្ខុ សូមចីវរនឹងគហបតីក្ដី នឹងគហបតានីក្ដី ដែលមិនមែនជាញាតិ ឱ្យច្រើនលើសពីស្បង់និងចីពរនោះទៅ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងសូម លុះសូមបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៦៨] ភិក្ខុ ដែលគេមិនបានបវារណាទុកជាមុន ហើយចូលទៅ រកគហបតី ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ (ចង់បានឱ្យល្អហួសហេតុ) ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដល់នូវកិរិយាកំណត់ក្នុងចីវរ លុះកំណត់ចីវរបានហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៦៩] ភិក្ខុដែលគេមិនបានបវារណាទុកជាមុន ហើយចូលទៅរកគហបតីទាំងឡាយ ដែលមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដល់នូវកិរិយាកំណត់ក្នុងចីវរ លុះកំណត់ក្នុងចីវររួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧០] ភិក្ខុឱ្យចីវរសម្រេចបានដោយការតឹងទារឱ្យលើសអំពី៣ដង ដោយការឈរឱ្យលើសអំពី៦ដង ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឱ្យចីវរសម្រេច កាលបើចីវរសម្រេចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

ចប់ កឋិនវគ្គ ទី១។

## កោសិយវគ្គ ទី២

CS vin.pv.01.1.02.3.2 | ភាគ ទី១២

### (២. កោសិយវគ្គោ)

[២៧១] ភិក្ខុ ឱ្យគេធ្វើសន្ថ័តលាយដោយសូត្រ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេធ្វើ លុះឱ្យគេធ្វើរួចស្រេចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧២] ភិក្ខុ ឱ្យគេធ្វើសន្ថ័តដោយរោមចៀមមានពណ៌ខ្មៅសុទ្ធ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេធ្វើ លុះឱ្យគេធ្វើស្រេចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧៣] ភិក្ខុធ្វើសន្ថ័តថ្មី មិនលាយរោមចៀមសទម្ងន់មួយជញ្ជីង រោមចៀមក្រហមទម្ងន់មួយជញ្ជីង ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេធ្វើ លុះឱ្យគេធ្វើរួចស្រេចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧៤] ភិក្ខុឱ្យគេធ្វើសន្ថ័តរាល់ៗឆ្នាំ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេធ្វើ លុះឱ្យគេធ្វើរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧៥] ភិក្ខុឱ្យគេធ្វើសន្ថ័តសម្រាប់អង្គុយថ្មី មិនលាយសន្ថ័តចាស់ មួយចំអាមព្រះសុគត ដោយជុំវិញ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើឱ្យគេធ្វើ លុះប្រើឱ្យគេធ្វើរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧៦] ភិក្ខុទទួលរោមចៀម ហើយនាំយកឱ្យកន្លងហួស៣យោជន៍ទៅ ត្រូវអាបត្តិ២ គឺ ឈានជំហានដំបូង ឱ្យកន្លងហួស៣យោជន៍ទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី២ ឱ្យកន្លងហួសទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧៧] ភិក្ខុប្រើភិក្ខុនីដែលមិនមែនជាញាតិ ឱ្យលាងរោមចៀម ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើឱ្យគេលាង លុះប្រើឱ្យគេលាងរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧៨] ភិក្ខុទទួលរូបិយៈ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលទទួល លុះទទួលរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៧៩] ភិក្ខុប្រព្រឹត្តទិញដូរ ដោយរូបិយៈ មានប្រការផ្សេងៗ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រព្រឹត្ត (ការលក់ដូរ) លុះប្រព្រឹត្តរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៨០] ភិក្ខុប្រព្រឹត្តទិញដូររបស់មានប្រការផ្សេងៗ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលខ្លួនប្រព្រឹត្ត លុះប្រព្រឹត្តរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

ចប់ កោសិយវគ្គ ទី២។

## បត្តវគ្គ ទី៣

CS vin.pv.01.1.02.3.3 | ភាគ ទី១២

**(៣. បត្តវគ្គោ)**

[២៨១] ភិក្ខុទុកអតិរេកបាត្រ ឱ្យកន្លងហួស១០ថ្ងៃទៅ ត្រូវអាបត្តិ១ គឺ និស្សគ្គិយបាចិត្តិយៈ។

[២៨២] ភិក្ខុមានបាត្រ មានចំណាងមិនទាន់ដល់៥អន្លើ ហើយសូមបាត្រថ្មីដទៃទៀត ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសូម លុះសូមបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៨៣] ភិក្ខុទទួលភេសជ្ជៈទាំងឡាយហើយ ទុកឱ្យកន្លងហួស៧ថ្ងៃទៅ ត្រូវអាបត្តិ១ គឺ និស្សគ្គិយបាចិត្តិយៈ។

[២៨៤] ភិក្ខុស្វែងរកវស្សិកសាដិកចីវរ(សំពត់សម្រាប់ងូតទឹកភ្លៀង) ក្នុងកាលដ៏លើសអំពីខែខាងចុងនៃរដូវក្តៅ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលស្វែងរក លុះស្វែងរកបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៨៥] ភិក្ខុឱ្យចីវរដល់ភិក្ខុផងគ្នា ដោយខ្លួនឯង ហើយក្រោធអាក់អន់ចិត្ត ក៏ដណ្តើមយកវិញ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដណ្តើម លុះដណ្តើមបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៨៦] ភិក្ខុសូមអំបោះដោយខ្លួនឯង យកមកឱ្យជាងតម្បាញ ត្បាញចីវរ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើគេឱ្យត្បាញ លុះប្រើគេឱ្យត្បាញរួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៨៧] ភិក្ខុដែលគេមិនបានបវារណាទុកជាមុន ហើយចូលទៅ រកជាងតម្បាញរបស់គហបតីមិនមែនជាញាតិ ហើយដល់នូវកិរិយាកំណត់ក្នុងចីវរ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំណត់ លុះកំណត់រួចហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

[២៨៨] ភិក្ខុទទួលអច្ចេកចីវរទុកឱ្យកន្លងហួសសម័យនៃចីវរកាលទៅ ត្រូវអាបត្តិ១ គឺ និស្សគ្គិយបាចិត្តិយៈ។

[២៨៩] បណ្តាចីវរទាំង៣ ភិក្ខុទុកចីវរណាមួយ ក្នុងចន្លោះផ្ទះ ហើយនៅប្រាសចាកលើស ៦រាត្រីទៅ ត្រូវអាបត្តិ១ គឺ និស្សគ្គិយបាចិត្តិយៈ។

[២៩០] ភិក្ខុដឹងថា លាភរបស់សង្ឃដែលគេបង្អោនទៅ (ដើម្បីសង្ឃ) ត្រឡប់បង្អោនមក ដើម្បីខ្លួនវិញ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលបង្អោនមក លុះបង្អោនបានមកហើយ ត្រូវនិស្សគ្គិយបាចិត្តិយៈ។

ចប់ បត្តវគ្គ ទី៣។

ចប់ និស្សគ្គិយបាចិត្តិយៈ ៣០។

# (បាចិត្តិយកណ្ឌៈ ទី៤)

CS vin.pv.01.1.02.4 | ភាគ ទី១២

**(៤. បាចិត្តិយកណ្ឌំ)**

## មុសាវាទវគ្គ ទី១

CS vin.pv.01.1.02.4.1 | ភាគ ទី១២

**(១. មុសាវាទវគ្គោ)**

[២៩១] ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួន ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុពោលពាក្យកុហក ដោយដឹងខ្លួន ត្រូវអាបត្តិ៥គឺ ភិក្ខុមានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ពោលអួតនូវឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិបារាជិក ភិក្ខុចោទ ភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុពន្យល់គេថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះជាព្រះអរហន្ត បើគេដឹងច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើគេមិនដឹងច្បាស់ ត្រូវអាបត្តិទុក្កដ និយាយកុហក (តាមធម្មតា) ត្រូវអាបត្តិបាចិត្តិយៈ ព្រោះពោលសម្បជានមុសាវាទ ភិក្ខុនិយាយកុហកដោយដឹងខ្លួន ត្រូវអាបត្តិទាំង៥នេះឯង។

[២៩២] ភិក្ខុពោលពាក្យចាក់ដោត ត្រូវអាបត្តិ២គឺ ពោលចាក់ដោតឧបសម្ប័ន្ន ត្រូវអាបត្តិបាចិត្តិយៈ ពោលចាក់ដោតអនុបសម្ប័ន្ន ត្រូវអាបត្តិទុក្កដ។

[២៩៣] ភិក្ខុបង្កពាក្យញុះញង់ ត្រូវអាបត្តិ២ គឺ ភិក្ខុបង្កពាក្យញុះញង់ ដល់ឧបសម្ប័ន្នផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ បង្កពាក្យញុះញង់ដល់អនុបសម្ប័ន្ន ត្រូវអាបត្តិទុក្កដ។

[២៩៤] ភិក្ខុបង្រៀនធម៌ជាបទចំពោះអនុបសម្ប័ន្ន ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលបង្រៀន ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗបទ។

[២៩៥] ភិក្ខុសម្រេចការដេក ជាមួយនឹងអនុប្បសម្ប័ន្ន លើស ២-៣ រាត្រីឡើងទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ ដែលប្រាសដេក លុះដេកស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[២៩៦] ភិក្ខុសម្រេចការដេកជាមួយនឹងមាតុគ្រាម ត្រូអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រាសដេក លុះដេកស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[២៩៧] ភិក្ខុសម្តែងធម៌ដល់មាតុគ្រាមដោយវាចាលើសអំពី ៥.៦ ម៉ាត់ឡើងទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងសម្តែង ត្រូវអាបត្តិបាចិត្តិយៈរាល់ៗបទ។

[២៩៨] ភិក្ខុប្រាប់ឧត្តរិមនុស្សធម្ម ដែលមានពិតប្រាកដ ដល់អ នុបសម្ប័ន្ន ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងប្រាប់ លុះប្រាប់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[២៩៩] ភិក្ខុប្រាប់ទុដ្ឋុល្លាបត្តិ របស់ភិក្ខុផងគ្នា ដល់អនុបសម្ប័ន្ន ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងប្រាប់ លុះប្រាប់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣០០] ភិក្ខុជីកដី ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ (ដែលផ្តងនឹងជីក) ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗវារៈដែលជីក។

ចប់ មុសាវាទវគ្គ ទី១។

## ភូតគាមវគ្គ ទី២

CS vin.pv.01.1.02.4.2 | ភាគ ទី១២

### (២. ភូតគាមវគ្គោ)

[៣០១] ភិក្ខុធ្វើភូតគាមឱ្យឃ្លាតចាកទី ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ (ដែលផ្តងនឹងធ្វើឱ្យឃ្លាតចាកទី) ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗ វារៈដែលប្រហារ។

[៣០២] ភិក្ខុពោលបិទបាំងពាក្យដទៃ ដោយពាក្យដទៃ ត្រូវអាបត្តិ២គឺ កាលបើអញ្ញវាទកកម្ម ដែលសង្ឃមិនទាន់លើកឡើងទេ ភិក្ខុពោលបិទបាំងពាក្យដទៃ ដោយពាក្យដទៃ ត្រូវអាបត្តិទុក្កដ កាលបើអញ្ញវាទកកម្ម ដែលសង្ឃបានលើកឡើងហើយ ភិក្ខុនៅតែពោលបិទបាំងពាក្យដទៃ ដោយពាក្យដទៃ ត្រូវអាបត្តិបាចិត្តិយៈ។

[៣០៣] ភិក្ខុឱ្យភិក្ខុដទៃពោលទោសភិក្ខុផងគ្នា ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេពោលទោស លុះឱ្យគេពោលទោសហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣០៤] ភិក្ខុលាគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ជារបស់សង្ឃ ទុកក្នុងទីវាល មិនសាយកមកទុកវិញ ទាំងមិនបានប្រាប់ (អ្នកឯទៀតឱ្យសាយកមកទុកវិញ) ហើយចៀសចេញទៅ ត្រូវអាបត្តិ២គឺ ឈានជំហានជាដំបូង ឱ្យកន្លងហួសលេឌ្ឌុបាត ត្រូវអាបត្តិទុក្កដ ឈានជំហានទី២ ឱ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣០៥] ភិក្ខុក្រាលកម្រាលសម្រាប់ដេក ក្នុងវិហារជារបស់សង្ឃ ហើយមិនសាយកមកទុកវិញ ទាំងមិនបានប្រាប់ (អ្នកឯទៀតឱ្យសាយកមកទុកវិញ) ហើយចៀសចេញទៅ ត្រូវអាបត្តិ២គឺ ឈានជំហានជាដំបូងឱ្យកន្លងផុតរបងទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី២ ឱ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣០៦] ភិក្ខុដឹងថា មានភិក្ខុផងគ្នាចូលទៅមុន ក្នុងវិហារជារបស់សង្ឃ ហើយចូលទៅជ្រៀតជ្រៀតទៅសម្រេចការដេក ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបដេក លុះដេកស៊ប់ ត្រូវអាបត្តិបាចិត្តិយៈ។

[៣០៧] ភិក្ខុក្រោធអាក់អន់ចិត្ត ក៏ទង់ទាញភិក្ខុផងគ្នាចាកវិហារជារបស់សង្ឃ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងទង់ទាញ លុះទង់ទាញ ត្រូវអាបត្តិបាចិត្តិយៈ។

[៣០៨] ភិក្ខុអង្គុយសង្កត់គ្រែក្ដី តាំងក្ដី ដែលមានជើងគ្រាន់តែផ្គុំទុកឰដ៏ថ្នាក់ខាងលើ ក្នុងវិហារជារបស់សង្ឃ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយសង្កត់ លុះអង្គុយសង្កត់ ត្រូវអាបត្តិបាចិត្តិយៈ។

[៣០៩] ភិក្ខុធ្វើការប្រក់បានត្រឹមតែ ២.៣ ជាន់ កាលបើប្រក់ឱ្យលើសអំពីកំណត់នោះទៅ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រក់ លុះប្រក់ ត្រូវអាបត្តិបាចិត្តិយៈ។

[៣១០] ភិក្ខុដឹងថាទឹកមានសត្វហើយ ស្រោចស្មៅក្ដី ដីក្ដី ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងស្រោច លុះស្រោច ត្រូវអាបត្តិបាចិត្តិយៈ។

ចប់ ភូតគាមវគ្គ ទី២។

## ឱវាទវគ្គ ទី៣

CS vin.pv.01.1.02.4.3 | ភាគ ទី១២

**(៣. ឱវាទវគ្គោ)**

[៣១១] ភិក្ខុ ដែលសង្ឃមិនបានសន្មត ហើយទៅទូន្មានភិក្ខុនី ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលទូន្មាន លុះទូន្មាន ត្រូវអាបត្តិបាចិត្តិយៈ។

[៣១២] ភិក្ខុទូន្មានពួកភិក្ខុនី ក្នុងវេលាព្រះអាទិត្យអស្តង្គត ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងទូន្មាន លុះទូន្មាន ត្រូវអាបត្តិបាចិត្តិយៈ។

[៣១៣] ភិក្ខុចូលទៅកាន់សម្នាក់ភិក្ខុនី ហើយទូន្មានពួកភិក្ខុនី ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងទូន្មាន លុះទូន្មាន ត្រូវអាបត្តិបាចិត្តិយៈ។

[៣១៤] ភិក្ខុនិយាយថា ភិក្ខុទាំងឡាយទូន្មានពួកភិក្ខុនី ព្រោះហេតុតែអាមិសៈ ត្រូវអាបត្តិ ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងនិយាយ លុះនិយាយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣១៥] ភិក្ខុឱ្យចីវរដល់ភិក្ខុនីដែលមិនមែនជាញាតិ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងឱ្យ លុះឱ្យ ត្រូវអាបត្តិបាចិត្តិយៈ។

[៣១៦] ភិក្ខុដេរចីវរឱ្យភិក្ខុនីដែលមិនមែនជាញាតិ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដេរ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗថ្នេរ (ដែលដេរ)។

[៣១៧] ភិក្ខុបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដើរទៅ លុះដើរទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣១៨] ភិក្ខុបបួលភិក្ខុនីឡើងជិះទូកមួយជាមួយគ្នា ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងឡើងជិះ លុះឡើងជិះ ត្រូវអាបត្តិបាចិត្តិយៈ។

[៣១៩] ភិក្ខុដឹងហើយ ឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិ២គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ។

[៣២០] ភិក្ខុមួយរូប សម្រេចការអង្គុយក្នុងទីកំបាំងជាមួយនឹងភិក្ខុនីតែមួយរូប ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយ លុះអង្គុយត្រូវអាបត្តិបាចិត្តិយៈ។

ចប់ ឱវាទវគ្គ ទី៣។

## ភោជនវគ្គ ទី៤

CS vin.pv.01.1.02.4.4 | ភាគ ទី១២

### (៤. ភោជនវគ្គោ)

[៣២១] ភិក្ខុឆាន់បិណ្ឌបាតក្នុងផ្ទះសម្នាក់ ឬរោងឆាន់ ឱ្យលើសអំពីម្តងទៅ ត្រូវអាបត្តិ២គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈ ដែលលេបចូលទៅ។

[៣២២] ភិក្ខុឆាន់គណភោជន ត្រូវអាបត្តិ២គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈគ្រប់ៗ វារៈដែលលេបចូលទៅ។

[៣២៣] ភិក្ខុឆាន់បរម្បរភោជន ត្រូវអាបត្តិ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈគ្រប់ៗ វារៈដែលលេបចូលទៅ។

[៣២៤] ភិក្ខុទទួលនំបានត្រឹម ២.៣ បាត្រ កាលបើទទួលឱ្យលើសពីនោះទៅ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងទទួល លុះទទួល ត្រូវអាបត្តិបាចិត្តិយៈ។

[៣២៥] ភិក្ខុឆាន់រួចហើយ ហាមភត្តហើយ បែរទៅឆាន់ខាទនីយៈ ឬភោជនីយៈ ដែលជាអនតិរិត្តៈ ត្រូវអាបត្តិ២គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗវារៈដែលលេបចូលទៅ។

[៣២៦] ភិក្ខុ បវារណាបង្ខំភិក្ខុផងគ្នាដែលឆាន់រួចហើយ ហាមភត្តហើយ ដោយខាទនីយៈ ឬភោជនីយៈ ដែលជាអនតិរិត្តៈ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញ នឹងទំពាស៊ី នឹងឆាន់តាមពាក្យរបស់ភិក្ខុនោះ ដូច្នេះ ត្រូវអាបត្តិទុក្កដ លុះឆាន់រួចស្រេចហើយ ត្រូវ អាបត្តិបាចិត្តិយៈ។

[៣២៧] ភិក្ខុឆាន់ខាទនីយៈ ឬភោជនីយៈ ក្នុងវេលាវិកាល ត្រូវអាបត្តិ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗ វារៈដែលលេបចូលទៅ។

[៣២៨] ភិក្ខុឆាន់ខាទនីយៈ ឬភោជនីយៈ ដែលខ្លួនធ្វើឱ្យជាសន្និធិ ត្រូវអាបត្តិ២គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗវារៈដែលលេបចូលទៅ។

[៣២៩] ភិក្ខុសូមបណីតភោជន ដើម្បីប្រយោជន៍ដល់ខ្លួនឯងមកឆាន់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែលលេបចូលទៅ។

[៣៣០] ភិក្ខុលេបអាហារ ដែលគេមិនបានប្រគេន ឱ្យចូលទៅ តាមមុខទ្វារ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ វារៈដែល លេបចូលទៅ។

ចប់ ភោជនវគ្គ ទី៤។

## អចេលកវគ្គ ទី៥

CS vin.pv.01.1.02.4.5 | ភាគ ទី១២

### (៥. អចេលកវគ្គោ)

[៣៣១] ភិក្ខុឱ្យខាទនីយៈឬភោជនីយៈ ដល់អចេលក៍ក្តី បរិញ្វជកក្តី បរិញ្វជិកាក្តី ដោយដៃខ្លួនឯង ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងឱ្យ លុះឱ្យ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៣២] ភិក្ខុនិយាយនឹងភិក្ខុផងគ្នាថា ម្នាលអាវុសោ លោកចូរមក យើងនឹងចូលទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត (លុះថាដូច្នេះហើយ) ក៏ឱ្យគេឱ្យ ឬមិនឱ្យគេឱ្យ (អ្វីៗ) ដល់ភិក្ខុនោះ ហើយបញ្ជូនឱ្យត្រឡប់មកវិញ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគ ដែលរៀបនឹងបញ្ជូនឱ្យត្រឡប់វិញ លុះបញ្ជូនឱ្យត្រឡប់វិញ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៣៣] ភិក្ខុចូលទៅអង្គុយក្នុង (ផ្ទះនៃ) ត្រកូលដែលមានជនតែពីរនាក់ (ស្វាមីនិងភរិយា) ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយ លុះអង្គុយហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៣៤] ភិក្ខុសម្រេចការអង្គុយលើអាសនៈ ជាទីស្ងាត់កំបាំងភ្នែក ជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយ លុះអង្គុយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៣៥] ភិក្ខុមួយរូប សម្រេចការអង្គុយក្នុងទីស្ងាត់ (កំបាំងត្រចៀក) ជាមួយនឹងមាតុគ្រាមតែម្នាក់ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងអង្គុយ លុះអង្គុយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៣៦] ភិក្ខុអ្នកទទួលនិមន្តគេហើយ ឈ្មោះថាជាអ្នកមានភត្តហើយ មិនលាភិក្ខុផងគ្នា ដែលមាននៅ ហើយចៀសចេញទៅក្នុងត្រកូលទាំងឡាយ (ឯទៀត) ក្នុងកាលមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិ២គឺ ឈានជំហានទី១ កន្លងហួសធរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ ឈាន

ជំហានទី២ ឱ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៣៧] ភិក្ខុសូមភេសជ្ជៈ ឱ្យលើសកំណត់ខែ ដែលគេបវារណា ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសូម លុះសូមបានមក ត្រូវអាបត្តិបាចិត្តិយៈ។

[៣៣៨] ភិក្ខុ ទៅដើម្បីមើលកងទ័ពដែលលើកចេញទៅ ត្រូវអាបត្តិ២គឺ ដើរចេញទៅ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ក្នុងទីដែលឈរមើល។

[៣៣៩] ភិក្ខុទៅនៅក្នុងកងទ័ពឱ្យលើសជាង ៣ រាត្រីទៅ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងនៅ លុះនៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៤០] ភិក្ខុ ទៅកាន់ទីដែលគេត្រួតពល ត្រូវអាបត្តិ ២ គឺ ដើរចេញទៅ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ក្នុងទីដែលឈរមើល។

ចប់ អចេលកវគ្គ ទី៥។

## សុរាមេរយវគ្គ ទី៦

CS vin.pv.01.1.02.4.6 | ភាគ ទី១២

### (៦. សុរាមេរយវគ្គោ)

[៣៤១] ភិក្ខុផឹកទឹកស្រវឹង ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួលដោយ គិតថា អាត្មាអញនឹងផឹក ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ ៗ ប្រយោគដែលផឹកលេបចូលទៅ។

[៣៤២] ភិក្ខុធ្វើភិក្ខុផងគ្នាឱ្យសើចដោយជន្លួញគឺម្រាមដៃ (ចាក់ក្រឡេក) ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើឱ្យគេសើច លុះគេសើច ត្រូវអាបត្តិបាចិត្តិយៈ។

[៣៤៣] ភិក្ខុលេងទឹកត្រូវអាបត្តិ២ គឺភិក្ខុលេងទឹករាក់ក្រោមភ្នែកគោរ ត្រូវអាបត្តិទុក្កដ ភិក្ខុលេងទឹកជ្រៅ លើភ្នែកគោរ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៤៤] ភិក្ខុធ្វើសេចក្តីមិនអើពើ (នឹងបុគ្គលអ្នកសម្តែងធម៌ ឬ ធម៌) ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងធ្វើសេចក្តីមិនអើពើ លុះធ្វើសេចក្តីមិនអើពើ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៤៥] ភិក្ខុបន្លាចភិក្ខុផងគ្នា ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបន្លាច លុះបន្លាចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៤៦] ភិក្ខុបង្កាត់ភ្លើងអាំង ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងបង្កាត់ លុះបង្កាត់ស្រេចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៤៧] មិនទាន់ដល់កន្លះខែ ភិក្ខុ (អ្នកនៅក្នុងមជ្ឈិមបទេស) ងូតទឹក ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលងូត លុះងូតរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៤៨] ភិក្ខុ មិនកាន់យកវត្ថុសម្រាប់ធ្វើពណ៌ឱ្យខូច៣យ៉ាង វត្ថុសម្រាប់ធ្វើពណ៌ឱ្យខូចឯណានីមួយ ក៏ប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រើប្រាស់ លុះប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៤៩] ភិក្ខុវិកប្បចីវររបស់ខ្លួន ដល់ភិក្ខុក្តី ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី មិនបានដកវិកប្បជាមុន ហើយប្រើប្រាស់ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រើប្រាស់ លុះប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៥០] ភិក្ខុលាក់បាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី របស់ភិក្ខុផងគ្នា ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងលាក់ លុះលាក់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

ចប់ សុរាមេរយវគ្គ ទី៦។

## សប្បាណកវគ្គ ទី៧

CS vin.pv.01.1.02.4.7 | ភាគ ទី១២

### (៧. សប្បាណកវគ្គោ)

[៣៥១] ភិក្ខុក្លែងផ្តាច់បង់សត្វ ឱ្យឃ្លាតចាកជីវិត ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុក្លែងផ្តាច់បង់សត្វ ឱ្យឃ្លាតចាកជីវិត ត្រូវអាបត្តិ៤គឺ ភិក្ខុជីករណ្តៅមិនចំពោះ (សត្វ ឬមនុស្ស) ដោយគិតថា អ្នកណាមួយនឹងធ្លាក់ស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ មនុស្សធ្លាក់ក្នុងរណ្តៅនោះ ហើយស្លាប់ ត្រូវអាបត្តិបារាជិក យក្សក្តី ប្រេតក្តី តិរច្ឆានមានរាងកាយដូចមនុស្សក្តី ធ្លាក់ក្នុងរណ្តៅនោះស្លាប់ ត្រូវអាបត្តិថុល្លច្ច័យ តិរច្ឆានធ្លាក់ក្នុងរណ្តៅនោះស្លាប់ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុក្លែងផ្តាច់បង់សត្វឱ្យឃ្លាតចាកជីវិត ត្រូវអាបត្តិ៤នេះឯង។

[៣៥២] ភិក្ខុដឹងថាទឹកមានសត្វហើយប្រើប្រាស់ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រើប្រាស់ លុះប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៥៣] ភិក្ខុដឹងថា អធិករណ៍ដែលសង្ឃឱ្យរម្ងាប់សមគួរតាមធម៌ហើយ សើរើដើម្បីធ្វើជាថ្មីទៀត ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសើរើ លុះសើរើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៥៤] ភិក្ខុដឹងហើយបិទបាំងទុដ្ឋុល្លាបត្តិ របស់ភិក្ខុផងគ្នា ត្រូវអាបត្តិ១គឺ បាចិត្តិយៈ។

[៣៥៥] ភិក្ខុដឹងថា បុគ្គលមានឆ្នាំខ្វះពី២០ ហើយឱ្យឧបសម្បទា ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យឧបសម្បទា លុះឱ្យឧបសម្បទាហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៥៦] ភិក្ខុដឹងហើយ បបួលដើរផ្លូវឆ្ងាយមួយជាមួយគ្នានឹង ពួកឈ្មួញដែលគេចវាងឱ្យរួចពន្ធ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដើរ លុះដើរទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៥៧] ភិក្ខុបបួលដើរផ្លូវឆ្ងាយមួយជាមួយនឹងមាតុគ្រាម ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដើរ លុះដើរទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៥៨] ភិក្ខុមានទិដ្ឋិអាក្រក់ដែលសង្ឃបានសូត្រសមនុភាសនកម្ម អស់វារៈ៣ ដងហើយ នៅតែមិនលះបង់ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈសូត្រញត្តិ លុះចប់កម្មវាចា ត្រូវអាបត្តិបាចិត្តិយៈ។

[៣៥៩] ភិក្ខុដឹងហើយបរិភោគរួមជាមួយគ្នា នឹងភិក្ខុដែលពោល ដូច្នោះ ជាអ្នកមិនធ្វើតាមធម៌ ជាអ្នកមិនលះទិដ្ឋិនោះចេញ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបរិភោគរួម លុះបរិភោគរួម ត្រូវអាបត្តិបាចិត្តិយៈ។

[៣៦០] ភិក្ខុដឹងថាសាមណេរដែលភិក្ខុឯទៀតឱ្យវិនាសទៅដូច្នោះ ហើយ ទៅប្រលោមយកមក ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រលោម លុះនិយាយប្រលោមហើយ ត្រូវអាបត្តិបាចិត្តិយៈ។

ចប់ សប្បាណកវគ្គ ទី៧។

## សហធម្មិកវគ្គ ទី៨

CS vin.pv.01.1.02.4.8 | ភាគ ទី១២

### (៨. សហធម្មិកវគ្គោ)

[៣៦១] ភិក្ខុ ដែលភិក្ខុទាំងឡាយពោលដាស់តឿនប្រកបដោយធម៌ហើយ និយាយ(នឹងភិក្ខុទាំងឡាយ) យ៉ាងនេះវិញថា ម្នាលអាវុសោ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនុ៎ះនៅឡើយ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃដែលជាអ្នកឈ្លាស ជាអ្នកទ្រទ្រង់វិន័យ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងនិយាយ លុះនិយាយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៦២] ភិក្ខុពោលបង្អាប់វិន័យ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងពោលបង្អាប់ លុះពោលបង្អាប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៦៣] ភិក្ខុក្លែងធ្វើជាវង្វេង (ក្លែងពើធ្វើជាមិនដឹង ) ត្រូវអាបត្តិ២គឺ កាលបើមោហារោបនកម្ម សង្ឃមិនទាន់សូត្រប្រកាសទេ ភិក្ខុក្លែងធ្វើជាវង្វេង ត្រូវអាបត្តិទុក្កដ កាលបើមោហារោបនកម្ម សង្ឃបានសូត្រប្រកាសហើយ នៅតែក្លែងធ្វើជាវង្វេង ត្រូវអាបត្តិ បាចិត្តិយៈ។

[៣៦៤] ភិក្ខុក្រោធអាក់អន់ចិត្ត ឱ្យប្រហារភិក្ខុផងគ្នា ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងប្រហារ លុះប្រហារហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៦៥] ភិក្ខុក្រោធអាក់អន់ចិត្ត ងាជន្លលំពែងគឺបាតដៃដល់ភិក្ខុផងគ្នា ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងងាជន្ល លុះងាជន្ល ត្រូវអាបត្តិបាចិត្តិយៈ។

[៣៦៦] ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេស មិនមានមូល ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងចោទ លុះចោទ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៦៧] ភិក្ខុក្លែងបង្កសេចក្ដីរង្កៀសឱ្យកើតឡើងដល់ភិក្ខុផងគ្នា ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបង្កហេតុ លុះបង្ក (ហេតុនោះ) ត្រូវអាបត្តិបាចិត្តិយៈ។

[៣៦៨] កាលបើភិក្ខុទាំងឡាយ កំពុងប្រកួតប្រកាន់ ឈ្លោះទាស់ទែងគ្នា ភិក្ខុឈរអែបចាំស្ដាប់ ត្រូវអាបត្តិ២គឺ ភិក្ខុទៅដោយគិតថា អញនឹងចាំស្ដាប់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ក្នុងទីដែលឈរស្ដាប់។

[៣៦៩] ភិក្ខុបានឱ្យឆន្ទៈចំពោះកម្មទាំងឡាយ ដែលប្រកបដោយធម៌ លុះមកខាងក្រោយ ត្រឡប់តិះដៀលវិញ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងតិះដៀល លុះតិះដៀល ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧០] កាលបើពាក្យវិនិច្ឆ័យ កំពុងប្រព្រឹត្តទៅក្នុងជំនុំសង្ឃភិក្ខុមិនឱ្យឆន្ទៈ ហើយស្រាប់តែក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិ២គឺ កាលបើមិនទាន់លះបង់ហត្ថបាសបរិស័ទទៅទេ ត្រូវអាបត្តិទុក្កដ លុះលះ (ហត្ថបាស) ចេញទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧១] សង្ឃព្រមព្រៀងគ្នាឱ្យចីវរ (ដល់ភិក្ខុ) ហើយភិក្ខុណាមួយ ត្រឡប់តិះដៀលជាខាងក្រោយ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងតិះដៀល លុះតិះដៀល ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧២] ភិក្ខុដឹងថាលាភជារបស់សង្ឃ គេបង្អោនទៅដើម្បីសង្ឃរួចហើយ ត្រឡប់បង្អោនមកដើម្បីបុគ្គលវិញ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងបង្អោនទៅ លុះបង្អោនទៅ ត្រូវអាបត្តិបាចិត្តិយៈ។

ចប់ សហធម្មិកវគ្គ ទី៨។

## រាជវគ្គ ទី៩

CS vin.pv.01.1.02.4.9 | ភាគ ទី១២

**(៩. រាជវគ្គោ)**

[៣៧៣] ភិក្ខុ ដែលមិនទាន់បានទូលស្នើព្រះបរមក្សត្រ ឱ្យទ្រង់ជ្រាបជាមុនទេ ហើយស្រាប់តែចូលទៅកាន់ខាងក្នុងព្រះរាជដំណាក់ ត្រូវអាបត្តិ២ គឺ ឈានជំហានទី១ ឱ្យកន្លងធរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី ២ ឱ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧៤] ភិក្ខុរើសយករតនវត្ថុ (គ្រឿងប្រើប្រាស់របស់គ្រហស្ថ) ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងរើសយក លុះរើសយក ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧៥] ភិក្ខុមិនលាភិក្ខុផងគ្នាដែលមាននៅ ចូលទៅកាន់ស្រុក ក្នុងវេលាវិកាល ត្រូវអាបត្តិ ២ គឺ ឈានជំហាន ទី ១ ឱ្យកន្លងហួស របងទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទី២ ឱ្យកន្លងទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧៦] ភិក្ខុឱ្យគេធ្វើបំពុងម្ជុលនឹងឆ្អឹងក្តី ភ្លុកក្តី ស្នែងក្តី ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឱ្យគេធ្វើ លុះឱ្យគេធ្វើហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧៧] ភិក្ខុឱ្យគេធ្វើគ្រែក្តី តាំងក្តី ឱ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឱ្យគេធ្វើ លុះឱ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧៨] ភិក្ខុឱ្យគេធ្វើគ្រែក្តី តាំងក្តី ញាត់ដោយសំឡី[15)] ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឱ្យគេធ្វើ លុះឱ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៧៩] ភិក្ខុឱ្យគេធ្វើនិសីទនៈ ឱ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឱ្យគេធ្វើ លុះឱ្យគេធ្វើ រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៨០] ភិក្ខុឱ្យគេធ្វើសំពត់សម្រាប់គ្របកម ឬដំបៅ ឱ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឱ្យគេធ្វើ លុះឱ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៨១] ភិក្ខុឱ្យគេធ្វើសំពត់សម្រាប់ងូតទឹកភ្លៀង ឱ្យកន្លងហួសប្រមាណ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឱ្យគេធ្វើ លុះឱ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៣៨២] ភិក្ខុឱ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុឱ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកំពុងឱ្យគេធ្វើ លុះឱ្យគេធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុឱ្យគេធ្វើចីវរ ប៉ុនចីវរព្រះសុគត ត្រូវអាបត្តិ២ នេះឯង។

ចប់ រាជវគ្គ ទី៩។

ចប់ ពួកខុទ្ទកសិក្ខាបទ។

## (បាដិទេសនីយកណ្ឌៈ ទី៥)

CS vin.pv.01.1.02.5 | ភាគ ទី១២

**(៥. បាដិទេសនីយកណ្ឌំ)**

[៣៨៣] ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនីមិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនីមិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗវារៈដែលលេប ចូលទៅ ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃខ្លួនឯង អំពីដៃភិក្ខុនី មិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះ យកមកឆាន់ ត្រូវអាបត្តិ២នេះឯង។

[៣៨៤] ភិក្ខុមិនហាមឃាត់ភិក្ខុនីដែលបង្គាប់ (ទាយកឱ្យប្រគេន របស់នេះ របស់នោះ) ត្រូវអាបត្តិ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗ វារៈដែលលេបចូលទៅ។

[៣៨៥] ភិក្ខុទទួលខាទនីយៈក្តី ភោជនីយៈក្តី ក្នុងត្រកូលដែល សង្ឃសន្មតថា ជាសេក្ខត្រកូល ដោយដៃខ្លួនឯង យកមកឆាន់ ត្រូវអាបត្តិ ២ គឺ ភិក្ខុទទួល ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវបាដិទេសនីយៈគ្រប់ ៗ វារៈដែលលេបចូលទៅ។

[៣៨៦] ភិក្ខុ (នៅ) ក្នុងសេនាសនៈដែលតាំងនៅក្នុងព្រៃហើយ ទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឱ្យដំណឹងមកជាមុន ដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុ (នៅ) ក្នុងសេនាសនៈ ដែលតាំងនៅក្នុងព្រៃ ហើយទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឱ្យដំណឹងមកជាមុនដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិ២ គឺ ភិក្ខុទទួលដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗ វារៈដែលលេបចូលទៅ ភិក្ខុ (នៅ) ក្នុងសេនាសនៈដែលតាំងនៅក្នុងព្រៃ ហើយទទួលខាទនីយៈក្តី ភោជនីយៈក្តី ដែលគេមិនបានឱ្យដំណឹងមកជាមុនដោយដៃខ្លួនឯង យកមកឆាន់ខាងក្នុងអារាម ត្រូវអាបត្តិ ២ នេះឯង។

ចប់ បាដិទេសនីយៈ៤។

## (សេខិយកណ្ឌៈ ទី៦)

CS vin.pv.01.1.02.6 | ភាគ ទី១២

### (៦. សេខិយកណ្ឌំ)

## វគ្គ ទី១

CS vin.pv.01.1.02.6.1 | ភាគ ទី១២

### (១. បរិមណ្ឌលវគ្គោ)

[៣៨៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ស្លៀកស្បង់ស្លុយមុខ ឬស្លុយក្រោយ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ ស្លៀកស្បង់ស្លុយមុខ ឬស្លុយក្រោយ ត្រូវអាបត្តិ១គឺ ទុក្កដ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ស្លៀកស្បង់ស្លុយមុខ ឬស្លុយក្រោយ ត្រូវ អាបត្តិ១នេះឯង។

[៣៨៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឃ្លុំចីពរឱ្យស្លុយមុខ ឬស្លុយក្រោយ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៣៨៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បើកកាយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៣៩០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បើកកាយអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៣៩១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រវាសដៃ ឬជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៣៩២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយគ្រវាសដៃ ឬជើងក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ។

[៣៩៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរងាកមើលពីសពាស ទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៣៩៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយងាកមើលពីសពាស ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៣៩៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សើយចីវរដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៣៩៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សើយចីវរអង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១ គឺ ទុក្កដ។

ចប់ វគ្គ ទី១។

## វគ្គ ទី២

CS vin.pv.01.1.02.6.2 | ភាគ ទី១២

### (២. ឧជ្ជគ្ឃិកវគ្គោ)

[៣៩៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរទៅក្នុងចន្លោះផ្ទះ ដោយសំណើចខ្លាំង ត្រូវអាបត្តិ១គឺ ទុក្កដ។

[៣៩៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយក្នុងចន្លោះផ្ទះដោយសំណើចខ្លាំង ត្រូវអាបត្តិ១គឺ ទុក្កដ។

[៣៩៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើសំឡេងហោ សំឡេងខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤០០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើសំឡេងហោ សំឡេងខ្លាំង អង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤០១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រវែងកាយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤០២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយគ្រវែងកាយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤០៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរគ្រវាសដៃទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤០៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយឆ្កាដៃក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤០៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរធ្វើក្បាលងេកងោកទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១គឺ ទុក្កដ។

[៤០៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយធ្វើក្បាលងេកងោក ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១គឺ ទុក្កដ។

ចប់ វគ្គ ទី២។

## វគ្គ ទី៣

CS vin.pv.01.1.02.6.3 | ភាគ ទី១២

### (៣. ខម្ភកតវគ្គោ)

[៤០៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរស្ទឹមចង្កេះទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១ គឺទុក្កដ។

[៤០៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយស្ទឹមចង្កេះក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤០៩] ភិក្ខុ អាស្រ័យសេចក្តីមិនអើពើ ដើរទទូរក្បាលទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១ គឺទុក្កដ។

[៤១០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយទទូរក្បាលក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤១១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរចំអើតជើងទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤១២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ ១ គឺ ទុក្កដ។

[៤១៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលបិណ្ឌបាត ដោយមិនគោរព ត្រូវអាបត្តិ ១ គឺ ទុក្កដ។

[៤១៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ងាកមើលពីសពាសទទួលបិណ្ឌបាត ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤១៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលសម្លច្រើន (ជាងបាយ) ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤១៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ទទួលបិណ្ឌបាតឱ្យកំពុង ហួសពីកណ្តាប់បាត្រទៅ ត្រូវអាបត្តិ១គឺ ទុក្កដ។

ចប់ វគ្គ ទី៣។

## វគ្គ ទី៤

CS vin.pv.01.1.02.6.4 | ភាគ ទី១២

### (៤. បិណ្ឌបាតវគ្គោ)

[៤១៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បិណ្ឌបាតដោយមិនគោរព ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤១៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បិណ្ឌបាតងាកមើលពីសពាស ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤១៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កកាយ (បាយ) ត្រង់ទីនោះៗ ឆាន់បិណ្ឌបាត ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤២០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់សម្លច្រើន (ជាងបាយ) ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤២១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ច្រមចុះអំពីកំពូលបាយ ឆាន់បិណ្ឌបាត ត្រូវអាបត្តិ ១គឺ ទុក្កដ។

[៤២២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កកាយបាយលុបសម្ល ឬ ម្ហូបក្រៀម ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤២៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ខ្លួនមិនឈឺ សូមសម្ល ឬបាយ ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងឆាន់ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤២៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ មានសេចក្តីសម្គាល់ដើម្បីលើកទោស ហើយសម្លឹងមើលបាត្រពួកភិក្ខុដទៃ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤២៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើពំនូតបាយឱ្យធំ (ពេក) ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤២៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ធ្វើពំនូតបាយ ឱ្យវែង (ពេក) ត្រូវអាបត្តិ១គឺ ទុក្កដ។

ចប់ វគ្គ ទី៤។

## វគ្គ ទី៥

CS vin.pv.01.1.02.6.5 | ភាគ ទី១២

### (៥. កពឡវគ្គោ)

[៤២៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ កាលដែលពំនូតបាយ មិនទាន់ដល់មាត់ ហាមាត់ចាំ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤២៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់ញាត់ម្រាមដៃទាំងអស់ទៅក្នុងមាត់ ត្រូវអាបត្តិ ១គឺ ទុក្កដ។

[៤២៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ និយាយទាំងពំនូតបាយនៅក្នុងមាត់ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៣០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បោះដុំបាយ (ទៅក្នុងមាត់) ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៣១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់ខាំកាត់ពំនូតបាយ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៣២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់បៀមពំនូតបាយឱ្យទុលថ្ពាល់ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៣៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់រលាស់ដៃបណ្តើរ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៣៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់ធ្វើគ្រាប់បាយឱ្យជ្រុះ រោយរាយ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៣៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់លៀនអណ្តាត ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៣៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់ឮសូរផ្លប់ៗ ត្រូវអាបត្តិ១ គឺ ទុក្កដ។

ចប់ វគ្គ ទី៥។

## វគ្គ ទី៦

CS vin.pv.01.1.02.6.6 | ភាគ ទី១២

### (៦. សុរុសុរុវគ្គោ)

[៤៣៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់ឮសូរគ្រូកៗ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៣៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់លិទ្ធដៃ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៣៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់លិទ្ធបាត្រ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៤០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឆាន់លិទ្ធបបូរមាត់ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៤១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ មានដៃប្រឡាក់ដោយ អាមិសៈ ទទួលផ្តិលទឹក ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៤២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ចាក់ទឹកលាងបាត្រ ទាំងគ្រាប់បាយ ចោលក្នុងចន្លោះផ្ទះ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៤៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស មានឆត្រក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ។

[៤៤៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស មានដំបងក្នុងដៃ ត្រូវអាបត្តិ ១ គឺ ទុក្កដ។

[៤៤៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស មានគ្រឿងសស្ត្រាក្នុងដៃ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៤៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស មានគ្រឿងអាវុធក្នុងដៃ ត្រូវអាបត្តិ១គឺ ទុក្កដ។

ចប់ វគ្គ ទី៦។

## វគ្គ ទី៧

CS vin.pv.01.1.02.6.7 | ភាគ ទី១២

### (៧. បាទុកវគ្គោ)

[៤៤៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស ពាក់ទ្រនាប់ជើង ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៤៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្សពាក់ស្បែកជើង ត្រូវអាបត្តិ ១គឺ ទុក្កដ។

[៤៤៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលនៅលើយាន ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៥០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្សដែលនៅលើដំណេក ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៥១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលអង្គុយត្របោមក្បាលជង្គង់ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៥២] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ ដល់មនុស្ស ដែលជួតក្បាល ត្រូវអាបត្តិ ១គឺ ទុក្កដ។

[៤៥៣] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ សម្តែងធម៌ដល់មនុស្ស ដែលទទូរក្បាល ត្រូវអាបត្តិ ១គឺ ទុក្កដ។

[៤៥៤] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយលើផែនដីសម្តែងធម៌ ដល់មនុស្សដែលអង្គុយលើអាសនៈ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៥៥] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ អង្គុយលើអាសនៈទាប សម្តែងធម៌ ដល់មនុស្សដែលអង្គុយលើអាសនៈខ្ពស់ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៥៦] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឈរសម្តែងធម៌ដល់មនុស្សដែលអង្គុយ ត្រូវអាបត្តិ ១គឺ ទុក្កដ។

[៤៥៧] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរពីខាងក្រោយសម្តែងធម៌ ដល់មនុស្សដែលដើរពីខាងមុខ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៥៨] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ដើរក្រៅផ្លូវ សម្តែងធម៌ ដល់មនុស្សដែលដើរតាមផ្លូវ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៥៩] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ ឈរបន្ទោឧច្ចារៈ ឬបស្សាវៈ ត្រូវអាបត្តិ១ គឺ ទុក្កដ។

[៤៦០] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ដាក់លើវត្ថុខៀវស្រស់ ត្រូវអាបត្តិ១គឺ ទុក្កដ។

[៤៦១] ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូអាបត្តិ១គឺ ទុក្កដ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ១នេះឯង។

ចប់ វគ្គ ទី៧។

ចប់ ពួកសេក្ខិយវត្ត ៧៥។

ចប់ កតាបត្តិវារៈ ទី២។

# វិបត្តិវារៈ ទី៣

CS vin.pv.01.1.03 | ភាគ ទី១២

### (៣. វិបត្តិវារោ)

[៤៦២] បណ្តាវិបត្តិទាំង៤ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិរបស់ភិក្ខុ ដែលសេពមេថុនធម្ម រាប់បញ្ចូលក្នុងវិបត្តិ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បេ។ បណ្តាវិបត្តិទាំង៤ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ

បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រាប់បញ្ចូលក្នុងវិបត្តិ១គឺ អាចារវិបត្តិ។

ចប់ វិបត្តិវារៈ ទី៣។

# សង្គហិតវារៈ ទី៤

CS vin.pv.01.1.04 | ភាគ ទី១២

**(៤. សង្គហិតវារោ)**

[៤៦៣] បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម លោកសង្គ្រោះ ដោយកងនៃអាបត្តិ៣កង គឺ កងនៃបារាជិកាបត្តិក៏មាន កងនៃថុល្លច្ចយាបត្តិក៏មាន កងនៃទុក្កដាបត្តិក៏មាន។ បេ។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក លោកសង្គ្រោះដោយកងនៃអាបត្តិ១គឺ ទុក្កដាបត្តិ។

ចប់ សង្គហិតវារៈ ទី៤។

# សមុដ្ឋានវារៈ ទី៥

CS vin.pv.01.1.05 | ភាគ ទី១២

**(៥. សមុដ្ឋានវារោ)**

[៤៦៤] បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។ បេ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦អាបត្តិរបស់ភិក្ខុ ដែលអាស្រ័យសេចក្តីមិនអើពើបន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។

ចប់ សមុដ្ឋានវារៈ ទី៥។

# អធិករណវារៈ ទី៦

CS vin.pv.01.1.06 | ភាគ ទី១២

**(៦. អធិករណវារោ)**

[៤៦៥] បណ្តាអធិករណ៍ទាំង៤ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម ចាត់ជាអធិករណ៍ណា។ បណ្តាអធិករណ៍ទាំង៤ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម ចាត់ជាអាបត្តាធិករណ៍។បេ។ បណ្តាអធិករណ៍ទាំង៤ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ចាត់ជាអធិករណ៍ណា។ បណ្តាអធិករណ៍ទាំង៤ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ចាត់ជាអាបត្តាធិករណ៍។

ចប់ អធិករណវារៈ ទី៦។

# សមថវារៈទី៧

CS vin.pv.01.1.07 | ភាគ ទី១២

**(៧. សមថវារោ)**

[៤៦៦] បណ្តាសមថៈទាំង៧ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាសមថៈទាំង៧ អាបត្តិរបស់ភិក្ខុដែលសេពមេថុនធម្ម រម្ងាប់ដោយសមថៈ៣គឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យ និងតិណវត្ថារកៈក៏មានខ្លះ[16)]។បេ។ បណ្តាសមថៈទាំង៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាសមថៈទាំង៧ អាបត្តិរបស់ភិក្ខុដែលអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក រម្ងាប់ដោយសមថៈ៣គឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យ និងតិណវត្ថារកៈក៏មានខ្លះ។

ចប់ សមថវារៈទី៧។

# សមុច្ចយវារៈ ទី៨

CS vin.pv.01.1.08 | ភាគ ទី១២

**(៨. សមុច្ចយវារោ)**

[៤៦៧] ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ៣គឺ សេពមេថុនធម្មនឹងសរីរៈដែលសត្វមិនទាន់ទំពាស៊ី ត្រូវអាបត្តិបារាជិក សេពមេថុនធម្ម នឹងសរីរៈដែលសត្វទំពាស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ បញ្ចូលអង្គជាតទៅក្នុងទ្វារមាត់ដែលហា តែមិនឱ្យប៉ះពាល់ ត្រូវអាបត្តិទុក្កដ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិ៣នេះឯង។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិណា។ បណ្តាកងនៃអាបត្តិទាំង៧ លោក សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍ទាំង៤ អាបត្តិទាំងនោះ ចាត់ចូលក្នុងអធិករណ៍ណា។ បណ្តាសមថៈទាំង៧ អាបត្តិទាំងនោះ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ២គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិទាំងនោះ លោកសង្គ្រោះ ដោយកងនៃអាបត្តិ៣គឺ កងនៃបារាជិកាបត្តិក៏មាន កងនៃថុល្លច្ចយាបត្តិក៏មាន កងនៃទុក្កដាបត្តិក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។ បណ្តាអធិករណ៍ទាំង២ អាបត្តិទាំងនោះ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈទាំង៧ អាបត្តិទាំងនោះ រម្ងាប់ដោយសមថៈ៣ គឺសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យ និងតិណវត្ថារកៈក៏មានខ្លះ។បេ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ១គឺ ទុក្កដ។ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ក្នុងទឹក ត្រូវអាបត្តិ១នេះឯង។ បណ្តាវិបត្តិទាំង៤ អាបត្តិនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិនោះ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍ទាំង៤ អាបត្តិនោះ ចាត់ជាអធិករណ៍ណា។ បណ្តាសមថៈទាំង៧ អាបត្តិនោះ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិនោះ រាប់បញ្ចូលក្នុងវិបត្តិ១គឺ អាចារវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិនោះ លោកសង្គ្រោះដោយកងនៃអាបត្តិ១ គឺកងនៃទុក្កដាបត្តិ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។ បណ្តាអធិករណ៍ទាំង៤ អាបត្តិនោះ ចាត់ជាអាបត្តាអធិករណ៍។ បណ្តាសមថៈទាំង៧អាបត្តិនោះ រម្ងាប់ដោយសមថៈ៣គឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យ និងតិណវត្ថារកៈ ក៏មានខ្លះ។

ចប់ សមុច្ចយវារៈ ទី៨។

វារៈទាំង៨ ប្រការនេះ លោកកត់ត្រាទុកសម្រាប់ស្វាធ្យាយ។

ឧទ្ទាន គឺបញ្ជីរឿងនៃមហាវារៈនោះ ដូច្នេះ

[៤៦៨]

រឿងព្រះមានព្រះភាគ (ទ្រង់បញ្ញត្តសិក្ខាបទនោះៗ) ក្នុងទីណា១ រឿងបញ្ញត្តិទាំង៩យ៉ាង១ រឿងព្រះមានព្រះភាគ ទ្រង់បញ្ញត្តវិន័យព្រោះអាស្រ័យប្រយោជន៍ប៉ុន្មានយ៉ាង១ រឿងសង្គ្រោះអាបត្តិចូលនឹងវិបត្តិ១ សមុដ្ឋាន និងអធិករណ៍១ សមថៈ១ សមុច្ចយៈ (ការរួបរួម)១។

# កត្ថបញ្ញត្តិវារៈ ទី១

CS vin.pv.01.1.09 | ភាគ ទី១២

**(១.(៩) កត្ថបញ្ញត្តិវារោ)**

## (បារាជិកកណ្ឌៈ ទី១)

CS vin.pv.01.1.09.1 | ភាគ ទី១២

**(១. បារាជិកកណ្ឌំ)**

[៤៦៩] បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺសេពមេថុនធម្ម បារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ព្រោះរឿងដូចម្តេច។បេ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក។ បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺសេពមេថុនធម្ម បារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងវេសាលី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី សេពមេថុនធម្មនឹងស្ត្រី ជាប្រពន្ធពីដើម។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិឬទេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ២ ឯអនុប្បន្នប្បញ្ញត្តិ មិនមាន

ក្នុងសិក្ខាបទនោះឡើយ។ សិក្ខាបទនោះ ជា សព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ។ សិក្ខាបទនោះ ជា សាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ សិក្ខាបទនោះ ជាឧភតោបញ្ញត្តិ។ បណ្តាបាតិមោក្ខុទ្ទេសទាំង៥ សិក្ខាបទនោះ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ សិក្ខាបទនោះ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន។ សិក្ខាបទនោះ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី២។ បណ្តាវិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី។ សិក្ខាបទនោះ ជាសីលវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី។ សិក្ខាបទនោះ ជាកងនៃអាបត្តិបារាជិក។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។ បេ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក។ ព្រះថេរៈទាំងឡាយ ដូចមានឈ្មោះខាងក្រោមបាននាំតៗគ្នាមក។ គឺព្រះថេរៈឈ្មោះឧបាលិ១ ទាសកៈ១ សោណកៈ១ សិគ្គវៈ១ និងព្រះមោគ្គលិបុត្តជាគម្រប់៥អង្គ១ ឯព្រះថេរៈទាំងនេះ នៅ ក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី។ តពីនោះមក ព្រះអរហន្តទាំងឡាយ គឺព្រះថេរៈឈ្មោះមហិន្ទ១ ឥដ្ដិយៈ១ ឧត្តិយៈ១សម្ពលៈ១។ បេ។ ព្រះនាគត្ថេរទាំងនេះ លោកមានប្រាជ្ញាច្រើន ស្គាល់ច្បាស់ នូវព្រះវិន័យ លោកឈ្លាសក្នុងមគ្គ បាននាំគ្នាប្រកាសនូវព្រះវិនយបិដក ទុកក្នុងតម្ពបណ្ណិទ្វីប គឺកោះលង្កា។

## (សង្ឃាទិសេសកណ្ឌាទិ ទី២)

CS vin.pv.01.1.09.2 | ភាគ ទី១២

### (២. សង្ឃាទិសេសកណ្ឌាទិ)

[៤៧០] បារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ(នូវអំណាចនៃប្រយោជន៍ទាំង ១០) ហើយទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺកាន់យកនូវទ្រព្យដែលគេមិនបានឱ្យ បារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងធនិយភិក្ខុ ជាកូននៃស្មូនឆ្នាំង។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលធនិយភិក្ខុ ជាកូននៃស្មូនឆ្នាំង យកឈើព្រះរាជទ្រព្យដែលគេមិនបានឱ្យ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មាន អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន។

[៤៧១] បារាជិកសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺ ក្លែងធ្វើរាងកាយមនុស្សឱ្យធ្លាក់ចុះចាកជីវិត ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹង ភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុច្រើនរូបញុាំងគ្នានិងគ្នាឱ្យធ្លាក់ចុះចាកជីវិត។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋាន៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន។

[៤៧២] បារាជិកសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរវេសាលី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ ដែលនៅប្រេបឆ្នេរស្ទឹងវគ្គុមុទា។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកភិក្ខុនៅប្រេបឆ្នេរស្ទឹងវគ្គុមុទា ពោលសរសើរគុណឧត្តរិមនុស្សធម្មនៃគ្នានិងគ្នាដល់ពួកគ្រហស្ថ។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបាន តាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន។

[៤៧៣] សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍១០យ៉ាង) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺ ព្យាយាមញុាំងអសុចិឱ្យឃ្លាតចេញ សង្ឃាទិសេសសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ព្រោះរឿងដូចម្តេច។ បេ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក។ សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍១០យ៉ាង) ទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺព្យាយាមញុាំងអសុចិឱ្យឃ្លាតចេញ សង្ឃាទិសេសសិក្ខាបទនោះ ទ្រង់ បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះសេយ្យសកៈមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងព្រះសេយ្យសកៈមានអាយុ ព្យាយាមញុាំងអសុចិឱ្យឃ្លាតចេញ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ ដែរឬទេ។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១ ឯអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ។ សិក្ខាបទនោះ ជា សព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ ជាសព្វត្ថប្បញ្ញត្តិ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ។ ជាអសាធារណប្បញ្ញត្តិ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ ជាឯកតោបញ្ញត្តិ។ បណ្តាបាតិមោក្ខុទ្ទេសទាំង៥ សិក្ខាបទនោះ ចាត់ចូល ក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន។ សិក្ខាបទនោះមកកាន់ឧទ្ទេសត្រង់ឧទ្ទេសទីប៉ុន្មាន។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី ៣។ បណ្តាវិបត្តិទាំង ៤ សិក្ខាបទនោះ ជាវិបត្តិអ្វី។ ជាសីលវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី។ ជាកងនៃអាបត្តិសង្ឃាទិសេស។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។ បេ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក។ ព្រះថេរៈទាំងឡាយ ដូចមាននាមខាងក្រោម បាននាំតៗគ្នាមក។ គឺព្រះថេរៈឈ្មោះឧបាលិ១ ទាសកៈ១ សោណកៈ១ សិគ្គវៈ១ និងព្រះមោគ្គលិបុត្តជាគម្រប់៥អង្គ ១ ព្រះថេរៈទាំងនោះ ឋិតនៅក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី។ តអំពីនោះមក មានព្រះ អរហន្តទាំងឡាយទៀត គឺ ព្រះថេរៈឈ្មោះមហិន្ទ១ ឥដ្ដិយៈ១ ឧត្តិយៈ១ សម្ពលៈ១។ បេ។ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន ចេះដឹងនូវព្រះវិន័យ ឈ្លាសក្នុងមគ្គ នាំគ្នាប្រកាសព្រះវិនយបិដក ទុកក្នុងតម្ពបណ្ណិទ្វីប។

[៤៧៤] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្តព្រោះបច្ច័យ គឺដល់នូវកាយសំសគ្គៈជាមួយនឹងមាតុគ្រាម (ប៉ះពាល់កាយមាតុគ្រាមជាដើម) ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧទាយិមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងព្រះឧទាយិមានអាយុ ដល់នូវកាយសំសគ្គៈជាមួយនឹងមាតុគ្រាម។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។

[៤៧៥] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺ និយាយលោមមាតុគ្រាមដោយសម្តីថែចង់ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់បារព្ធនឹងព្រះឧទាយិមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងព្រះឧទាយិមានអាយុ និយាយលោមមាតុគ្រាមដោយសម្តីចែចង់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន។

[៤៧៦] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺ និយាយសរសើរការបម្រើដោយកាមចំពោះខ្លួន ក្នុងសម្នាក់នៃមាតុគ្រាម ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧទាយិមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងព្រះឧទាយិមានអាយុ និយាយសរសើរការបម្រើ ដោយកាមចំពោះខ្លួន ក្នុងសម្នាក់នៃមាតុគ្រាម សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៤៧៧] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្តព្រោះបច្ច័យ គឺប្រព្រឹត្តនិយាយដឹកនាំស្ត្រីដើម្បីបុរស ដឹកនាំបុរសដើម្បីស្ត្រី ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឧទាយិមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងព្រះឧទាយិមានអាយុ ប្រព្រឹត្តនិយាយដឹកនាំស្ត្រី ដើម្បីបុរស។ សិក្ខាបទនោះ មានបញ្ញត្តិ ១ មានអនុប្បញ្ញត្តិ ១។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង ៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយនិងចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើង អំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន។

[៤៧៨] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្តព្រោះបច្ច័យ គឺការប្រើគេឱ្យធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍ដោយខ្លួនឯង ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនអាឡវី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ ដែលនៅក្នុងដែនអាឡវី។ ព្រោះ រឿងដូចម្តេច។ ព្រោះរឿងដែលពួកភិក្ខុនៅក្នុងដែនអាឡវី ប្រើគេឱ្យធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍ដោយខ្លួនឯង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋានទាំង៦។

[៤៧៩] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺការប្រើគេឱ្យធ្វើវិហារធំ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងព្រះឆន្នៈមានអាយុ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលព្រះឆន្នៈមានអាយុ កាលនឹងជម្រះទីដីនៃវិហារ ក៏ប្រើគេឱ្យកាប់ដើមឈើដែលជាទីគោរព១ដើម។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។

[៤៨០] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺ ចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិកមិនមានមូល ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធ នឹងភិក្ខុឈ្មោះមេត្តិយៈ និងភុម្មជកៈ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងភិក្ខុឈ្មោះមេត្តិយៈ និងភុម្មជកៈ បានចោទព្រះទព្វមល្លបុត្តមានអាយុ ដោយ អាបត្តិបារាជិកមិនមានមូល។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣។

[៤៨១] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺការកាន់យកនូវលេសជាគ្រឿងអាងបន្តិចបន្តួចរបស់អធិករណ៍ ជាចំណែកដទៃ ហើយចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិក ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុឈ្មោះមេត្តិយៈ និងភុម្មជកៈ។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងភិក្ខុឈ្មោះមេត្តិយៈនិងភុម្មជកៈ យកលេសជាគ្រឿងអាងបន្តិចបន្តួច របស់អធិករណ៍ជាចំណែកដទៃ ហើយចោទព្រះទព្វមល្លបុត្តមានអាយុ ដោយអាបត្តិបារាជិក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៤៨២] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគម្រប់បីដង ក៏នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុឈ្មោះទេវទត្ត។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងភិក្ខុឈ្មោះទេវទត្ត ព្យាយាមដើម្បីបំបែកសង្ឃ ដែលព្រមព្រៀងគ្នា។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត។

[៤៨៣] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្តព្រោះបច្ច័យ គឺភិក្ខុទាំងឡាយអ្នកប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដង ក៏នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុច្រើនរូប ប្រព្រឹត្តតាមទេវទត្ត ដែលជាអ្នកព្យាយាមដើម្បី បំបែកសង្ឃ ហើយជាអ្នកពោលពាក្យប្រមូលពួក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត។

[៤៨៤] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្តព្រោះបច្ច័យ គឺភិក្ខុដែលគេប្រដៅបានដោយក្រ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដង ក៏នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរកោសម្ពី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ ប្រារព្ធនឹងព្រះឆន្នៈមានអាយុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿង ដែលព្រះឆន្នៈមានអាយុ កាលភិក្ខុទាំងឡាយ និយាយប្រដៅតាមធម៌ ក៏ធ្វើខ្លួនឱ្យគេស្ដីថាមិនបាន។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត។

[៤៨៥] សង្ឃាទិសេសសិក្ខាបទ ដែលទ្រង់បញ្ញត្ត ព្រោះបច្ច័យ គឺភិក្ខុអ្នកទ្រុស្តត្រកូល កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់បីដង ក៏នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ត្រឡប់ជា បន្ទោសសង្ឃថា សង្ឃលុះក្នុងឆន្ទាគតិ លុះក្នុងទោសាគតិ លុះក្នុងមោហាគតិ លុះក្នុងភយាគតិ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងវាចានិងចិត្ត។ បេ។

[៤៨៦] អាបត្តិទុក្កដណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្ត ព្រោះបច្ច័យគឺការអាស្រ័យនូវសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក អាបត្តិទុក្កដនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយភិក្ខុ។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយភិក្ខុ បានបន្ទោឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះ ក្នុងទឹក។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើង អំពីវាចាឡើយ។

ចប់ កត្ថប្បញ្ញត្តិវារៈ ជាបឋម។

# កតាបត្តិវារៈ ទី២

CS vin.pv.01.1.10 | ភាគ ទី១២

### (២.(១០) កតាបត្តិវារោ)

[៤៨៧] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យគឺការសេពមេថុនធម្ម។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ៤ ព្រោះបច្ច័យគឺការសេពមេថុនធម្ម គឺភិក្ខុសេពមេថុនធម្ម នឹងសរីរៈសពដែលសត្វមិនទាន់ទំពាស៊ី ត្រូវអាបត្តិបារាជិក ភិក្ខុសេពមេថុនធម្ម នឹងសរីរៈសពដែលសត្វទំពាស៊ីដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុបញ្ចូលអង្គជាត (ខ្លួន) ទៅក្នុងមុខទ្វារ ដែលបើកហា តែមិនឱ្យប៉ះពាល់ ត្រូវអាបត្តិទុក្កដ ភិក្ខុនី ត្រូវអាបត្តិបាចិត្តិយៈ ព្រោះអង្គជាតដែលធ្វើដោយជ័រឈើ ឬកាកលាក៏ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិទាំង៤នេះ ព្រោះបច្ច័យគឺការសេពមេថុនធម្ម។

[៤៨៨] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការកាន់យកទ្រព្យ ដែលគេមិនបានឱ្យ។ ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺការកាន់យកទ្រព្យដែលគេមិនបានឱ្យ គឺភិក្ខុមានថេយ្យចិត្ត កាន់យកទ្រព្យមានតម្លៃ ៥ មាសក ឬច្រើនជាង៥មាសកឡើងទៅ ដែលគេមិនបានឱ្យ ត្រូវអាបត្តិបារាជិក ភិក្ខុមានថេយ្យចិត្ត កាន់យកទ្រព្យ មានតម្លៃច្រើនជាង ១ មាសក ឬថយអំពី ៥ មាសកមក ដែលគេមិនបានឱ្យ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុមានថេយ្យចិត្ត កាន់យកទ្រព្យមានតម្លៃ ៤ មាសក ឬថយចុះអំពី១មាសកមក ដែលគេមិនបានឱ្យ ត្រូវអាបត្តិទុក្កដ ភិក្ខុត្រូវអាបត្តិទាំង៣នេះ ព្រោះបច្ច័យ គឺការកាន់យកទ្រព្យដែលគេមិនបានឱ្យ។

[៤៨៩] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការក្លែងញាំងរាងកាយនៃមនុស្ស ឱ្យធ្លាក់ចុះចាកជីវិត។ ភិក្ខុត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺកាក្លែងញាំងរាងកាយនៃមនុស្ស ឱ្យធ្លាក់ចុះចាកជីវិត គឺ ភិក្ខុជីករណ្ដៅ ចំពោះមនុស្ស ដោយតាំងចិត្តថា មនុស្សនឹងស្លាប់ ត្រូវអាបត្តិទុក្កដ កាលបើមនុស្សធ្លាក់ទៅហើយ មានទុក្ខវេទនាកើតឡើង ត្រូវអាបត្តិថុល្លច្ច័យ បើមនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ភិក្ខុត្រូវអាបត្តិទាំង៣នេះ ព្រោះបច្ច័យ គឺការក្លែងញាំងរាងកាយនៃមនុស្ស ឱ្យធ្លាក់ចុះចាកជីវិត។

[៤៩០] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺកិរិយាពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត (ក្នុងខ្លួន)។ ភិក្ខុត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺកិរិយាពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត (ក្នុងខ្លួន) គឺភិក្ខុជាអ្នកមានប្រាថ្នាអាក្រក់ មានសេចក្ដីប្រាថ្នាគ្របសង្កត់ ក៏ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត (ក្នុងខ្លួន) ត្រូវអាបត្តិបារាជិក ភិក្ខុពោលថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះជាព្រះអរហន្ត កាលបើគេដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ កាលបើគេមិនដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិទុក្កដ ភិក្ខុត្រូវអាបត្តិទាំង៣នេះ ព្រោះបច្ច័យ គឺកិរិយាពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត (ក្នុងខ្លួន)។

## (បារាជិកកណ្ឌៈ ទី១)

CS vin.pv.01.1.10.1 | ភាគ ទី១២

### (១. បារាជិកកណ្ឌំ)

[៤៩១] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការព្យាយាមបញ្ចេញអសុចិ។ ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យ គឺព្យាយាមបញ្ចេញអសុចិ គឺភិក្ខុគិតនឹងបញ្ចេញអសុចិ ក៏ព្យាយាមញាំងអសុចិឱ្យឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុគិតនឹងបញ្ចេញអសុចិ ក៏ព្យាយាម ប៉ុន្តែទឹកអសុចិមិនឃ្លាតចេញ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុត្រូវអាបត្តិទុក្កដ ក្នុង ប្រយោគដែលព្យាយាម។

[៤៩២] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ៥ ព្រោះបច្ច័យ គឺការដល់នូវកាយសំសគ្គៈ គឺភិក្ខុនីមានតម្រេក ហើយត្រេកអរនឹងការចាប់ពាល់ (នូវសរីរប្រទេស) ខាងក្រោមដងកាំបិតចុះមក ខាងលើមណ្ឌលនៃជង្គង់ឡើងទៅនៃបុរសបុគ្គល ដែលមានតម្រេកដូចគ្នា ត្រូវអាបត្តិបារាជិក ភិក្ខុប៉ះពាល់កាយស្រី ដោយកាយរបស់ខ្លួន ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុប៉ះ ពាល់នូវវត្ថុដែលជាប់ដោយកាយស្រី ដោយកាយរបស់ខ្លួន ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុប៉ះពាល់នូវវត្ថុដែលជាប់នឹងកាយស្រី ដោយវត្ថុដែលជាប់ នឹងកាយរបស់ខ្លួន ត្រូវអាបត្តិទុក្កដ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះជន្លួញ គឺម្រាមដៃ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិទាំង៥នេះ ព្រោះបច្ច័យគឺការដល់នូវកាយសំសគ្គៈ។

[៤៩៣] ភិក្ខុត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺការនិយាយល្បួងមាតុគ្រាមដោយសម្ដីអាក្រក់ គឺភិក្ខុពោលសរសើរក្ដី ពោលបង្អាប់ក្ដី ចំពោះវច្ចមគ្គ ឬបស្សាវមគ្គ ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុមិនពោលចំពោះវច្ចមគ្គនិងបស្សាវមគ្គ គ្រាន់តែពោលសរសើរក្ដី ពោលបង្អាប់ក្ដី ចំពោះ ខាងក្រោមដងកាំបិតចុះមក ខាងលើមណ្ឌលនៃជង្គង់ឡើងទៅ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុពោលសរសើរក្ដី ពោលបង្អាប់ក្ដី ចំពោះវត្ថុដែលជាប់ដោយកាយ ត្រូវអាបត្តិទុក្កដ។

[៤៩៤] ភិក្ខុត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺការពោលនូវគុណនៃ ការបម្រើដោយកាមចំពោះខ្លួន គឺ ភិក្ខុពោលនូវគុណនៃការបម្រើដោយ កាមចំពោះខ្លួន ក្នុងសម្នាក់នៃមាតុគ្រាម ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុ ពោលនូវគុណនៃការបម្រើដោយកាមចំពោះខ្លួន ក្នុងសម្នាក់នៃបណ្ឌក (ខ្ទើយ) ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុពោលនូវគុណនៃការបម្រើដោយកាម ចំពោះខ្លួន ក្នុងសម្នាក់នៃសត្វតិរច្ឆាន (ញី) ត្រូវអាបត្តិទុក្កដ។

[៤៩៥] ភិក្ខុត្រូវអាបត្តិ ៣ ព្រោះបច្ច័យគឺការប្រព្រឹត្តនិយាយដឹកនាំស្ត្រីឱ្យបុរស ដឹកនាំបុរសឱ្យស្ត្រី គឺភិក្ខុទទួលពាក្យផង ទៅនិយាយប្រាប់ផង ត្រឡប់មកប្រាប់វិញផង ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទទួលពាក្យផង ទៅនិយាយប្រាប់ផង តែមិនត្រឡប់មក (ប្រាប់) វិញ ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុគ្រាន់តែទទួលពាក្យ តែមិនបានទៅនិយាយប្រាប់ផង មិនបានត្រឡប់មក (ប្រាប់) វិញផង ត្រូវអាបត្តិទុក្កដ។

[៤៩៦] ភិក្ខុត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺការប្រើគេឱ្យធ្វើកុដិ ដោយសូមគ្រឿងឧបករណ៍ដោយខ្លួនឯង គឺភិក្ខុកំពុងប្រើឱ្យគេធ្វើ ក្នុងប្រយោគដែលប្រើ ត្រូវអាបត្តិទុក្កដ កាលបើបាយអមួយដុំមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ កាលបើដុំបាយអនោះមកដល់ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៤៩៧] ភិក្ខុត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺការប្រើគេឱ្យធ្វើវិហារធំ គឺភិក្ខុកំពុងប្រើគេឱ្យធ្វើ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលប្រើ កាលបើបាយអមួយដុំមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ កាលបើដុំបាយអនោះមកដល់ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៤៩៨] ភិក្ខុត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺការចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល គឺភិក្ខុមានបំណងដើម្បីឱ្យគេឃ្លាតចាកព្រហ្មចរិយធម៌ មិនបានសូមឱកាសហើយចោទ ត្រូវអាបត្តិទុក្កដ ព្រមទាំងសង្ឃាទិសេស ភិក្ខុមានបំណងដើម្បីជេរ តែបានសូមឱកាសហើយចោទ ត្រូវអាបត្តិឱមសវាទបាចិត្តិយៈ។

[៤៩៩] ភិក្ខុត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺការកាន់យកនូវលេស ជាគ្រឿងអាងបន្តិចបន្តួច របស់អធិករណ៍ ជាចំណែកដទៃ ហើយចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក គឺភិក្ខុមានបំណងដើម្បីឱ្យគេឃ្លាតចាកព្រហ្មចរិយធម៌ មិនបានសូមឱកាសហើយចោទ ត្រូវអាបត្តិទុក្កដ ព្រមទាំងសង្ឃាទិសេស ភិក្ខុមានបំណងដើម្បីជេរ តែសូមឱកាសហើយចោទ ត្រូវអាបត្តិឱមសវាទបាចិត្តិយៈ។

[៥០០] ភិក្ខុអ្នកបំបែកសង្ឃ ត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដងហើយ នៅតែមិនលះបង់កម្មនោះចេញ គឺត្រូវអាបត្តិទុក្កដ ដោយសូត្រញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ដោយកម្មវាចាពីរលើក លុះចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស។

[៥០១] ភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តតាមនូវភិក្ខុអ្នកបំបែកសង្ឃ ត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺកាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដងហើយ នៅតែមិនលះបង់កម្មនោះចេញ គឺ ត្រូវអាបត្តិទុក្កដ ដោយសូត្រញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ដោយកម្មវាចាពីរលើក លុះចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស។

[៥០២] ភិក្ខុដែលគេប្រដៅក្រ ត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដងហើយ នៅតែមិនលះបង់នូវកម្មនោះចេញ គឺ ត្រូវអាបត្តិទុក្កដ ដោយសូត្រញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ដោយកម្មវាចាពីរលើក លុះចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស។

[៥០៣] ភិក្ខុអ្នកទ្រុស្តត្រកូល ត្រូវអាបត្តិ៣ ព្រោះបច្ច័យ គឺ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដងហើយ នៅតែមិនលះបង់នូវកម្មនោះចេញ គឺត្រូវអាបត្តិទុក្កដ ដោយសូត្រញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ដោយកម្មវាចាពីរលើក លុះចប់កម្មវាចា ត្រូវអាបត្តិសង្ឃាទិសេស។ បេ។

[៥០៤] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការអាស្រ័យ សេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក។ ភិក្ខុត្រូវអាបត្តិទុក្កដ១ ព្រោះបច្ច័យ គឺ ការអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក ភិក្ខុត្រូវអាបត្តិ១ នេះឯង ព្រោះបច្ច័យ គឺការអាស្រ័យសេចក្ដីមិនអើពើ បន្ទោឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី ក្នុងទឹក។

ចប់ កតាបត្តិវារៈ ទី២។

# វិបត្តិវារៈ ទី៣

### (៣.(១១) វិបត្តិវារោ)

[៥០៥] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាវិបត្តិទាំង៤ រាប់បញ្ចូល ក្នុងវិបត្តិប៉ុន្មាន។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បេ។ អាបត្តិ ព្រោះបច្ច័យ គឺការ អាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈ បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ អាបត្តិ ព្រោះបច្ច័យ គឺ ការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិ១ គឺអាចារវិបត្តិ។

ចប់ វិបត្តិវារៈ ទី៣។

## សង្គហិតវារៈ ទី៤



### (៤.(១២) សង្គហិតវារោ)

[៥០៦] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាកងនៃអាបត្តិទាំង ៧ សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាកងនៃអាបត្តិទាំង៧ សង្គ្រោះដោយកងនៃអាបត្តិ៤ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បេ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាកងនៃអាបត្តិទាំង៧ សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាកងនៃអាបត្តិ ទាំង៧ សង្គ្រោះដោយកងនៃអាបត្តិ១ គឺកងនៃអាបត្តិទុក្កដ។

ចប់ សង្គហិតវារៈ ទី៤។

## សមុដ្ឋានវារៈទី៥



### (៥.(១៣) សមុដ្ឋានវារោ)

[៥០៧] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។ បេ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តី មិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។

ចប់ សមុដ្ឋានវារៈទី៥។

## អធិករណវារៈ ទី៦



### (៦.(១៤) អធិករណវារោ)

[៥០៨] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាអធិករណ៍ទាំង៤ ជាអធិករណ៍អ្វី។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាអធិករណ៍ទាំង៤ ជាអាបត្តាធិករណ៍។ បេ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាអធិករណ៍ទាំង៤ ជាអធិករណ៍អ្វី។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាអធិករណ៍ទាំង ៤ ជាអាបត្តាធិករណ៍។

ចប់ អធិករណវារៈ ទី៦។

## សមថវារៈ ទី៧



### (៧.(១៥) សមថវារោ)

[៥០៩] ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ ពួកអាបត្តិ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈ៣ គឺដោយ សម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។ បេ។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តាសមថៈទាំង៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ អាបត្តិ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក បណ្តា សមថៈទាំង៧ រម្ងាប់ដោយសមថៈទាំង៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

ចប់ សមថវារៈ ទី៧។

## សមុច្ចយវារៈ ទី៨

CS vin.pv.01.1.16 | ភាគ ទី១២

**(៨.(១៦) សមុច្ចយវារោ)**

[៥១០] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការសេពមេថុនធម្ម។ ភិក្ខុ ភិក្ខុនីត្រូវអាបត្តិ៤ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម គឺ ភិក្ខុសេពមេថុនធម្ម នឹងសរីរៈ (សព) ដែលសត្វមិនទាន់ទំពាស៊ី ត្រូវអាបត្តិបារាជិក ភិក្ខុសេពមេថុនធម្ម នឹងសរីរៈ (សព) ដែលសត្វទំពាស៊ីដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុបញ្ចូលអង្គជាត (ខ្លួន) ទៅក្នុងមុខទ្វារ ដែលបើកហា តែមិនឱ្យប៉ះពាល់ ត្រូវអាបត្តិទុក្កដ ភិក្ខុនី ត្រូវអាបត្តិបាចិត្តិយៈ ព្រោះអង្គជាតដែលធ្វើដោយជ័រឈើ ឬកាកលាក់ដីរលីង[17] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិទាំង៤នេះ ព្រោះបច្ច័យ គឺការសេពមេថុនធម្ម។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនេះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិទាំងនោះ សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍ទាំង៤ ជាអធិករណ៍អ្វី។ បណ្តាសមថៈទាំង៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃ អាបត្តិទាំង៧ អាបត្តិទាំងនោះ សង្គ្រោះដោយកងនៃអាបត្តិ៤ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។ បណ្តាអធិករណ៍ទាំង៤ អាបត្តិទាំងនោះ ជាអាបត្តាធិករណ៍។ បណ្តាសមថៈទាំង ៧ អាបត្តិទាំងនោះ រម្ងាប់ដោយសមថៈ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។ បេ។ ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក។ ភិក្ខុត្រូវអាបត្តិទុក្កដ១ ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក ភិក្ខុត្រូវអាបត្តិ១នេះឯង ព្រោះបច្ច័យ គឺការអាស្រ័យសេចក្តីមិនអើពើ បន្ទោឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី ក្នុងទឹក។ បណ្តាវិបត្តិទាំង៤ អាបត្តិនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ សង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍ទាំង៤ ជាអធិករណ៍អ្វី។ បណ្តាសមថៈទាំង៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិនោះ រាប់បញ្ចូលក្នុងវិបត្តិ១ គឺអាចារវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង៧ សង្គ្រោះដោយកងនៃអាបត្តិ១ គឺកងនៃអាបត្តិទុក្កដ។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។ បណ្តាអធិករណ៍ទាំង៤ ជាអាបត្តាធិករណ៍។ បណ្តាសមថៈទាំង៧ រម្ងាប់ដោយ សមថៈ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

ចប់ សមុច្ចយវារៈ ទី៨។

ចប់ បច្ចយវារៈទាំង៨។

ចប់ មហាវារៈ១៦ ក្នុងមហាវិភង្គ។

# ភិក្ខុនីវិភង្គ មហាវិរៈ១៦

CS vin.pv.01.2 | ភាគ ទី១២

**(ភិក្ខុនីវិភង្គោ)**

## (កត្ថបញ្ញត្តិវារៈ ទី១)

CS vin.pv.01.2.01 | ភាគ ទី១២

**(១. កត្ថបញ្ញត្តិវារោ)**

## (បារាជិកកណ្ឌៈ ទី១)

CS vin.pv.01.2.01.1 | ភាគ ទី១២

**(១. បារាជិកកណ្ឌំ)**

[៥១១] បញ្ចមបារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី បញ្ចមបារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ព្រោះរឿងដូចម្ដេច។ ក្នុងសិក្ខាបទនោះ មាន បញ្ញត្តិ អនុប្បញ្ញត្តិ អនុប្បន្នប្បញ្ញត្តិ សព្វត្ថប្បញ្ញត្តិ បទេសប្បញ្ញត្តិ សាធារណប្បញ្ញត្តិ អសាធារណប្បញ្ញត្តិ ឯកតោបញ្ញត្តិ ឧភតោបញ្ញត្តិដែរឬ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង៤ សិក្ខាបទនោះចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទីប៉ុន្មាន។ បណ្ដាវិបត្តិទាំង៤ សិក្ខាបទនោះ ជាវិបត្តិអ្វី។ បណ្ដាកងនៃអាបត្តិទាំង ៧ សិក្ខាបទនោះជាកងនៃអាបត្តិអ្វី។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិ នោះតាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្ដាអធិករណ៍ទាំង ៤ អាបត្តិនោះ ជាអធិករណ៍អ្វី។ បណ្ដាសមថៈទាំង៧ អាបត្តិនោះរម្ងាប់ដោយសមថៈប៉ុន្មាន។ អ្វីដែលហៅថាវិន័យក្នុងសិក្ខាបទនោះ អ្វីដែលហៅ ថាអភិវិន័យក្នុងសិក្ខាបទនោះ អ្វីដែលហៅថាបាតិមោក្ខក្នុងសិក្ខាបទនោះ អ្វីដែលហៅថាអធិប្បាតិមោក្ខ ក្នុងសិក្ខាបទនោះ អ្វីដែលហៅថាវិបត្តិ អ្វីដែលហៅថាសម្បត្តិ អ្វីដែលហៅថាបដិបត្តិ (ក្នុងសិក្ខាបទនោះ)។ បញ្ចមបារាជិកសិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី ព្រោះអាស្រ័យអំណាចនៃប្រយោជន៍ប៉ុន្មាន។ ស្រីពួកណាសិក្សា។ ស្រីពួកណា ដែលឈ្មោះថាមានសិក្ខាសិក្សាស្រេចហើយ។ សិក្ខាបទនោះឋិតនៅក្នុងពួកស្រីណា។ ពួកស្រីណាទ្រទ្រង់។ សិក្ខាបទនោះ ជាពាក្យរបស់បុគ្គលណា។ សិក្ខាបទនោះ បុគ្គលណាបាននាំមក។

[៥១២] បញ្ចមបារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី បញ្ចមបារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ ប្រារព្ធនឹងសុន្ទរីនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែល សុន្ទរីនន្ទាភិក្ខុនីជាស្រីមានតម្រេកដោយរាគៈ ក៏ត្រេកអរនឹងការចាប់ពាល់កាយនៃបុរសបុគ្គល ដែលមានតម្រេកដោយរាគៈ (ដូច្នោះដែរ)។ ក្នុងសិក្ខាបទនោះ មាន បញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិដែរឬ។ សិក្ខាបទនោះ មានបញ្ញត្តិ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមាន ក្នុងសិក្ខាបទនោះឡើយ។ សិក្ខាបទនោះ ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ ជាសព្វត្ថប្បញ្ញត្តិ។ សិក្ខាបទនោះ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ។ ជាអសាធារណប្បញ្ញត្តិ។ សិក្ខាបទនោះ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ ជាឯកតោបញ្ញត្តិ។ បណ្ដាបាតិមោក្ខុទ្ទេសទាំង៤ សិក្ខាបទនោះ តើចាត់ចូលក្នុងឧទ្ទេសអ្វី រាប់បញ្ចូលក្នុងឧទ្ទេសអ្វី។ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន។ សិក្ខាបទនោះមកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី២។ បណ្ដាវិបត្តិទាំង៤ សិក្ខាបទនោះ ជាវិបត្តិអ្វី។ ជាសីលវិបត្តិ។ បណ្ដាកងនៃអាបត្តិទាំង៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី។ ជាកងនៃអាបត្តិបារាជិក។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយនិងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។ បណ្ដាអធិករណ៍ទាំង៤ អាបត្តិនោះ ជាអធិករណ៍អ្វី។ ជាអាបត្តាធិករណ៍។ បណ្ដាសមថៈទាំង ៧ អាបត្តិនោះ រម្ងាប់ដោយសមថៈប៉ុន្មាន។ រម្ងាប់ដោយសមថៈ២ គឺដោយសម្មុខាវិន័យ១ បដិញ្ញាតករណៈ១។ អ្វីហៅថាវិន័យក្នុងសិក្ខាបទនោះ អ្វីហៅថាអភិវិន័យក្នុងសិក្ខាបទនោះ។ បញ្ញត្តិ ហៅថាវិន័យ ការចែកបទមាតិកា ហៅថាអភិវិន័យ។ អ្វីហៅថាបាតិមោក្ខ ក្នុងសិក្ខាបទនោះ អ្វីហៅថាអធិប្បាតិមោក្ខ ក្នុងសិក្ខាបទនោះ។ បញ្ញត្តិ ហៅថាបាតិមោក្ខ ការចែកបទមាតិកា ហៅថា អធិប្បាតិមោក្ខ។ អ្វីហៅថាវិបត្តិ។ ការមិនសង្រួមហៅថាវិបត្តិ។ អ្វីហៅថាសម្បត្តិ។ ការសង្រួមហៅថាសម្បត្តិ។ អ្វីហៅថាបដិបត្តិ។ ភិក្ខុនីសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយដរាបដល់អស់ជីវិត មានជីវិតជាទីបំផុត ដោយគិតថា អញនឹងមិនធ្វើអំពើយ៉ាងនេះ (ហៅថា បដិបត្តិ)។ បញ្ចមបារាជិកសិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី ព្រោះអាស្រ័យអំណាចនៃប្រយោជន៍ប៉ុន្មាន។ បញ្ចមបារាជិកសិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តដល់ពួកភិក្ខុនី ព្រោះអាស្រ័យអំណាចនៃប្រយោជន៍ទាំង១០យ៉ាង គឺដើម្បីសេចក្ដីល្អ ដល់សង្ឃ១ ដើម្បីសេចក្ដីសប្បាយដល់សង្ឃ១ ដើម្បីការសង្កត់សង្កិន ពួកភិក្ខុនីដែលមិនអៀនខ្មាស១ ដើម្បីការនៅជាសុខស្រួលដល់ពួក ភិក្ខុនីដែលមានសីលជាទីស្រឡាញ់១ ដើម្បីរារាំងអាសវធម៌ទាំងឡាយ ដែលមានក្នុងបច្ចុប្បន្ន១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយដែលមានក្នុងបរលោក១ ដើម្បីញុំាំងពួកជនដែលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លាឡើង១ ដើម្បីញុំាំងពួកជនដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាច្រើនឡើង១ ដើម្បីញុំាំងព្រះសទ្ធម្មឱ្យតាំងនៅមាំ១ ដើម្បីអនុគ្រោះដល់វិន័យ១។ ស្រីពួកណាសិក្សា (ក្នុងសិក្ខាបទនោះ)។ ពួកស្រីដែលនៅជាសេក្ខបុគ្គល និងពួកស្រីដែលជ្រះថ្លាក្នុងកុសលធម៌តែជាបុថុជ្ជន រមែងសិក្សាក្នុងសិក្ខាបទនោះ។ ពួកស្រីណាឈ្មោះថាមានសិក្ខាសិក្សាហើយ។ ពួកភិក្ខុនីដែលជាព្រះអរហន្តឈ្មោះថាមានសិក្ខាសិក្សាហើយ។ សិក្ខាបទនោះ ឋិតនៅក្នុងពួកស្រីណា។ ឋិតនៅក្នុងពួកភិក្ខុនីដែលមានសេចក្ដីប្រាថ្នាក្នុងសិក្ខា។ ពួកភិក្ខុនីណាទ្រទ្រង់។ សិក្ខាបទនោះប្រព្រឹត្តទៅក្នុងពួកភិក្ខុនីណា ពួកភិក្ខុនីនោះតែងទ្រទ្រង់ (នូវសិក្ខាបទនោះ)។ សិក្ខាបទនោះ ជាពាក្យរបស់បុគ្គលណា។ ជាពាក្យរបស់ព្រះមានព្រះ ភាគ អរហន្តសម្មាសម្ពុទ្ធ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក។ (ព្រះថេរៈទាំងឡាយដូចមាននាមខាងក្រោមនេះ) នាំតៗគ្នាមក។ គឺ ព្រះថេរៈឈ្មោះឧបាលិ១ ទាសកៈ១ សោណកៈ១ សិគ្គវៈ១ ព្រះមោគ្គលិបុត្តជាគំរប់៥អង្គ១ ឯព្រះថេរៈទាំងនេះ ឋិតនៅក្នុងទ្វីបឈ្មោះជម្ពូដ៏មានសិរី។ តអំពីនោះមក មានព្រះថេរៈទាំងឡាយ គឺ ព្រះថេរៈឈ្មោះមហិន្ទ១ ឥដ្ដិយៈ១ ឧត្តិយៈ១ សម្ពលៈ១។ បេ។ ព្រះនាគត្ថេរទាំងនេះ មានប្រាជ្ញាច្រើន ចេះដឹងព្រះវិន័យ ឈ្លាសក្នុងមគ្គ បានប្រកាសនូវព្រះវិនយបិដក ទុកក្នុង តម្ពបណ្ណិទ្វីប គឺកោះលង្កា។

[៥១៣] ឆដ្ឋបារាជិកសិក្ខាបទណា ដែលព្រះមានព្រះភាគ ព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្ត ដល់ភិក្ខុនីទាំងឡាយ ឆដ្ឋបារាជិកសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធ នឹងភិក្ខុនីឈ្មោះថុល្លនន្ទា។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងថុល្លនន្ទាភិក្ខុនីដឹងហើយ មិនចោទភិក្ខុនីដែលត្រូវអាបត្តិបារាជិកដោយខ្លួនឯង ទាំងមិនបានប្រាប់ដល់គណៈ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយនិងវាចានិងចិត្ត។

[៥១៤] សត្តមបារាជិកសិក្ខាបទ សម្រាប់ភិក្ខុនីទាំងឡាយ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីប្រព្រឹត្តតាមភិក្ខុឈ្មោះអរិដ្ឋៈ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តហើយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥១៥] អដ្ឋមបារាជិកសិក្ខាបទ សម្រាប់ភិក្ខុនីទាំងឡាយ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនីបំពេញវត្ថុគម្រប់៨។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

ចប់ បារាជិក ៨។

ឧទ្ទាននៃបារាជិកសិក្ខាបទនោះ ដូច្នេះ

[៥១៦]

រឿងភិក្ខុនីសេពមេថុនធម្ម១ ភិក្ខុនីលួចទ្រព្យគេ១ ភិក្ខុនីសម្លាប់មនុស្ស១ ភិក្ខុនីពោលអួតឧត្តរិមនុស្សធម្ម១ ភិក្ខុនីត្រេកអរនឹងកាយសំសគ្គៈ១ ភិក្ខុនីបិទបាំងទោសរបស់ ភិក្ខុនីផងគ្នា១ ភិក្ខុនីប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត១ ភិក្ខុនីបំពេញវត្ថុទាំង៨ មានត្រេកអរនឹងចាប់ដៃនៃបុរសជាដើម[18] ១ ព្រះពុទ្ធជាមហាវីរៈ (មានព្យាយាមធំ) ទ្រង់បញ្ញត្តបារាជិកទាំង ៨ ហៅថាឆេជ្ជវត្ថុ គឺវត្ថុដាច់ចាកភាវៈជាភិក្ខុនី ដោយឥតសង្ស័យ។

## (សង្ឃាទិសេសកណ្ឌៈ ទី២)

CS vin.pv.01.2.01.2 | ភាគ ទី១២

### (២. សង្ឃាទិសេសកណ្ឌំ)

[៥១៧] សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាប(នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្តដល់ភិក្ខុនី ដែលពោលពាក្យដោយសេចក្តីច្រណែន បានធ្វើនូវដំណើរកើតក្តី សង្ឃាទិសេសសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់ប្រារព្ធ នឹងបុគ្គលណា។ ព្រោះរឿងដូចម្តេច។ បេ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក។

[៥១៨] សង្ឃាទិសេសសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ(នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្តដល់ភិក្ខុនី ដែលពោលពាក្យដោយសេចក្តីច្រណែន បានធ្វើនូវដំណើរកើតក្តី សង្ឃាទិសេសសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី ប្រព្រឹត្តពោលពាក្យដោយសេចក្តីច្រណែន (ប្តឹងផ្តល់)។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និង អនុប្បន្នប្បញ្ញត្តិដែរឬ។ ក្នុងសិក្ខាបទនោះមានតែបញ្ញត្តិ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិ មិនមានក្នុងសិក្ខាបទនោះឡើយ។ សិក្ខាបទនោះជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ ជាសព្វត្ថប្បញ្ញត្តិ។ សិក្ខាបទនោះជា សាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ។ ជាអសាធារណប្បញ្ញត្តិ។ សិក្ខាបទនោះជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ ជាឯកតោបញ្ញត្តិ។ បណ្តាបាតិមោក្ខុទ្ទេសទាំង៤ សិក្ខាបទនោះ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ ចាត់ចូលក្នុងនិទាន រាប់បញ្ចូលក្នុងនិទាន។ សិក្ខាបទនោះ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទីប៉ុន្មាន។ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសទី៣។ បណ្តាវិបត្តិទាំង៤ សិក្ខាបទនោះ ជាវិបត្តិអ្វី។ ជាសីលវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង៧ សិក្ខាបទនោះ ជាកងនៃអាបត្តិអ្វី។ ជាកងនៃអាបត្តិសង្ឃាទិសេស។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ តាំងឡើងដោយ សមុដ្ឋាន២ គឺ តាំងឡើងអំពីកាយនិងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន។ បេ។ សិក្ខាបទនោះ បុគ្គលណាបាននាំមក។ ព្រះថេរៈទាំងឡាយបាននាំតៗគ្នាមក។ បេ។

[៥១៩] សង្ឃាទិសេសសិក្ខាបទ របស់ភិក្ខុនី ដែលបំបួសស្រីជាចោរ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងថុល្លនន្ទាភិក្ខុនី បានបំបួសស្រីជាចោរ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ គឺតាំងឡើងអំពីវាចានិងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយនិងវាចានិងចិត្តក៏មាន។

[៥២០] សង្ឃាទិសេសសិក្ខាបទ របស់ភិក្ខុនី ដែលដើរទៅកាន់ចន្លោះស្រុកតែម្នាក់ឯង ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីមួយរូប ដើរទៅកាន់ចន្លោះស្រុកតែម្នាក់ឯង។ សិក្ខាបទនោះ មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ៣។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៥២១] សង្ឃាទិសេសសិក្ខាបទ របស់ភិក្ខុនី ដែលមិនប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនីជាអ្នកធ្វើ ហើយធ្វើឱសារណកម្ម ចំពោះភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី មិនប្រាប់ការកសង្ឃ មិនដឹងសេចក្តីប្រាថ្នារបស់ពួកភិក្ខុនីជាអ្នកធ្វើ ហើយធ្វើឱសារណកម្ម ចំពោះភិក្ខុនី ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥២២] សង្ឃាទិសេសសិក្ខាបទរបស់ភិក្ខុនី ដែលមានតម្រេក ទទួលខាទនីយៈ ឬភោជនីយៈដោយដៃរបស់ខ្លួនឯង អំពីដៃនៃបុរសបុគ្គលដែលមានតម្រេកដែរ ហើយឆាន់ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងសុន្ទរីនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលសុន្ទរីនន្ទាភិក្ខុនី ជាស្រីមានតម្រេក ទទួលអាមិសៈអំពីដៃនៃបុរសបុគ្គលដែលមានតម្រេកដែរ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៥២៣] សង្ឃាទិសេសសិក្ខាបទ របស់ភិក្ខុនី ដែលបញ្ជូន (បង្ខិតបង្ខំ) ភិក្ខុនីផងគ្នា ដោយពាក្យថា នែលោកម្ចាស់ បុរសបុគ្គលនុ៎ះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់លោកម្ចាស់បាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកម្ចាស់ មិនមានតម្រេក ទេ បើបុរសបុគ្គលនុ៎ះ ឱ្យវត្ថុណា ជាខាទនីយៈក្តី ភោជនីយៈក្តី ដល់លោកម្ចាស់ លោកម្ចាស់ចូរទទួលយកវត្ថុនោះ ដោយដៃខ្លួនឯង ហើយទំពាស៊ី ឬបរិភោគចុះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីមួយរូប បញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នែលោកម្ចាស់ បុរសបុគ្គលនុ៎ះ ទុកជាមានតម្រេកក្តី មិន មានតម្រេក នឹងធ្វើអ្វីដល់លោកម្ចាស់បាន នែលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកម្ចាស់មិនមានតម្រេកទេ បើបុរសបុគ្គលនុ៎ះ ឱ្យវត្ថុណា ជាខាទនីយៈក្តី ភោជនីយៈក្តី ដល់លោកម្ចាស់ ៗចូរទទួលយកវត្ថុនោះ ដោយដៃខ្លួនឯង ហើយទំពាស៊ី ឬបរិភោគចុះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៥២៤] សង្ឃាទិសេសសិក្ខាបទរបស់ភិក្ខុនី ដែលខឹងអាក់អន់ចិត្ត កាលសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដងហើយ នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលចណ្ឌកាលីភិក្ខុនីខឹងអាក់អន់ចិត្ត ហើយពោលពាក្យយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥២៥] សង្ឃាទិសេសសិក្ខាបទរបស់ភិក្ខុនីដែលសង្ឃឱ្យចាញ់ ព្រោះអធិករណ៍ណានីមួយ ហើយខឹងអាក់អន់ចិត្ត កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់បីដងហើយ នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿង ដែលចណ្ឌកាលីភិក្ខុនី ដែលសង្ឃឱ្យចាញ់ ព្រោះអធិករណ៍ណានីមួយ ហើយខឹងអាក់អន់ចិត្តពោលពាក្យយ៉ាងនេះថា ពួកភិក្ខុនីលំអៀងដោយសេចក្តីស្រឡាញ់ផង ពួកភិក្ខុនីលំអៀង ដោយសេចក្តីស្អប់ផង ពួកភិក្ខុនីលំអៀងដោយសេចក្តីល្ងង់ផង ពួកភិក្ខុនីលំអៀងដោយសេចក្តីខ្លាចផង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥២៦] សង្ឃាទិសេសរបស់ពួកភិក្ខុនី ដែលនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដងហើយ នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូបនៅច្រឡូក ច្រឡំ (ដោយគ្រហស្ថ)។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥២៧] សង្ឃាទិសេសសិក្ខាបទរបស់ភិក្ខុនីដែលបញ្ជូនភិក្ខុនីផង គ្នាដោយពាក្យថា ម្នាលនាងម្ចាស់ នាងទាំងឡាយចូរនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ កុំបីនៅបែកខ្ញែកគ្នាឡើយ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់បីដងហើយ នៅតែមិនលះបង់កម្មនោះចេញ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីបញ្ជូន (ភិក្ខុនីផងគ្នា) ដោយពាក្យថា ម្នាលជានាងម្ចាស់ នាងទាំងឡាយចូរនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ នាងទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

ចប់ សង្ឃាទិសេសទាំង ១០។

ឧទ្ទាននៃសង្ឃាទិសេសនោះដូច្នេះ

[៥២៨]

> សង្ឃាទិសេសទាំង១០ នោះ គឺ ភិក្ខុនីពោលពាក្យដោយសេចក្តីច្រណែន១ ភិក្ខុនីបំបួសស្រីចោរ១ ភិក្ខុនីដើរទៅក្នុងចន្លោះស្រុកតែម្នាក់ឯង១ ភិក្ខុនីធ្វើឱសារណកម្ម ចំពោះភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្ត១ ភិក្ខុនីមានតម្រេកទទួលខាទនីយភោជនីយាហារអំពីដៃគ្រហស្ថដែលមានតម្រេកដែរ ហើយឆាន់១ ភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នាថា នែលោកម្ចាស់ បុរសបុគ្គលនោះ នឹងធ្វើអ្វីលោកបានជាដើម១ ភិក្ខុនីខឹងអាក់អន់ចិត្ត១ ភិក្ខុនីដែលសង្ឃឱ្យចាញ់ព្រោះអធិករណ៍ណានីមួយ១ ភិក្ខុនីនៅច្រឡូកច្រឡំដោយគ្រហស្ថ១ ភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នាថា ឱ្យនៅច្រឡូកច្រឡំចុះ កុំនៅបែកខ្ញែកគ្នា១។

## (និស្សគ្គិយកណ្ឌៈ ទី៣)

CS vin.pv.01.2.01.3 | ភាគ ទី១២

### (៣. និស្សគ្គិយកណ្ឌំ)

[៥២៩] និស្សគ្គិយបាចិត្តិយសិក្ខាបទណា ដែលព្រះមានព្រះ ភាគអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង១០) ទ្រង់បញ្ញត្តដល់ភិក្ខុនីដែលធ្វើនូវការសន្សំបាត្រទុក និស្សគ្គិយបាចិត្តិយសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនីធ្វើនូវការសន្សំបាត្រទុក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៥៣០] ភិក្ខុនីអធិដ្ឋានអកាលចីវរឱ្យជាកាលចីវរ ហើយប្រើគេឱ្យចែក (ចីវរនោះ) ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធ នឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី អធិដ្ឋានអកាលចីវរឱ្យជាកាលចីវរ ហើយឱ្យគេចែក (ចីវរនោះ)។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៥៣១] ភិក្ខុនីប្តូរចីវរនឹងភិក្ខុនីផងគ្នា ហើយដណ្តើមយកវិញ ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី ប្តូរចីវរនឹងភិក្ខុនីផងគ្នា ហើយដណ្តើមយកវិញ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន ៣។

[៥៣២] ភិក្ខុនីសូមរបស់ដទៃ ហើយត្រឡប់សូមរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី បានសូមរបស់ ដទៃ ហើយត្រឡប់សូមរបស់ឯទៀតវិញ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៣៣] ភិក្ខុនីប្រើគេឱ្យទិញរបស់ដទៃ ហើយបែរជាប្រើឱ្យទិញរបស់ឯទៀតវិញ ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីបានប្រើគេឱ្យទិញរបស់ដទៃ ហើយបែរជាប្រើឱ្យទិញរបស់ឯទៀត វិញ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៣៤] ភិក្ខុនីប្រើគេឱ្យទិញរបស់ដទៃដោយបរិក្ខាររបស់សង្ឃដែល ទាយកប្រគេនមកដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប ប្រើគេឱ្យទិញរបស់ដទៃ ដោយបរិក្ខាររបស់សង្ឃដែលទាយកប្រគេនមកដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៣៥] ភិក្ខុនីប្រើគេឱ្យទិញវត្ថុដទៃដោយបរិក្ខាររបស់សង្ឃដែល ទាយកប្រគេនមកដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ នឹងដោយវត្ថុដែលសូមបានដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ត្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប ប្រើគេឱ្យទិញវត្ថុដទៃ ដោយបរិក្ខាររបស់សង្ឃដែលទាយកប្រគេនមកដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ នឹងដោយវត្ថុដែលសូមបានដោយខ្លួនឯង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៣៦] ភិក្ខុនីប្រើគេឱ្យទិញវត្ថុដទៃ ដោយបរិក្ខាររបស់មហាជន គឺបរិក្ខារដែលទាយកប្រគេនដល់គណៈដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បី វត្ថុដទៃ ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប ប្រើគេឱ្យទិញវត្ថុដទៃដោយបរិក្ខាររបស់មហាជន គឺបរិក្ខារដែលទាយកប្រគេនដល់គណៈដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៣៧] ភិក្ខុនីប្រើគេឱ្យទិញវត្ថុដទៃដោយបរិក្ខាររបស់មហាជន គឺបរិក្ខារដែលទាយកប្រគេនដល់គណៈដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ នឹងដោយវត្ថុដែលសូមបានមកដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះ រឿងដែលភិក្ខុនីច្រើនរូប ប្រើគេឱ្យទិញវត្ថុដទៃ ដោយបរិក្ខាររបស់មហាជន គឺបរិក្ខារដែលទាយកប្រគេនដល់គណៈ ដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ នឹងដោយវត្ថុដែលសូមបានមកដោយខ្លួនឯង។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៣៨] ភិក្ខុនីប្រើគេឱ្យទិញវត្ថុដទៃដោយបរិក្ខាររបស់បុគ្គលដែល ទាយកប្រគេនមកដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ នឹងដោយ វត្ថុដែលសូមបានមកដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីប្រើគេឱ្យទិញវត្ថុដទៃ ដោយបរិក្ខាររបស់បុគ្គលដែលទាយកប្រគេនមកដើម្បីវត្ថុដទៃ គេឧទ្ទិសមកដើម្បីវត្ថុដទៃ នឹងដោយវត្ថុដែលសូមបានមកដោយខ្លួនឯង។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៣៩] ភិក្ខុនីសូមសំពត់ដណ្តប់មានសាច់ក្រាស់ (ភួយ) មានតម្លៃលើសពី ៤ កហាបណៈ៤ ដង (១៦ កហាបណៈ) ឡើងទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះ រឿង

ដូចម្ដេច។ ព្រោះរឿងដែលចុល្លនន្ទាភិក្ខុនីសូមសំពត់កម្ពលអំពីព្រះរាជា។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង ៦។

[៥៤០] ភិក្ខុនីសូមសំពត់មានសាច់ស្ដើង (ស្បៃ) មានតម្លៃច្រើនលើសអំពី ៤ បីដងដោយកន្លះនៃកហាបណៈគឺ១០ កហាបណៈឡើងទៅ ត្រូវនិស្សគ្គិយបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលចុល្លនន្ទាភិក្ខុនីសូមសំពត់ សំបកឈើអំពីព្រះរាជា។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានទាំង៦។

ចប់ និស្សគ្គិយបាចិត្តិយៈ ១២។

ឧទ្ទាននៃនិស្សគ្គិយបាចិត្តិយៈនោះដូច្នេះ

[៥៤១]

> រឿងភិក្ខុនីសន្សំបាត្រទុក១ ភិក្ខុនីអធិដ្ឋានអកាលចីវរឱ្យជាកាលចីវរ១ ភិក្ខុនីប្ដូរចីវរនឹងភិក្ខុនីផងគ្នា១ ភិក្ខុនីសូមរបស់ដទៃ ហើយសូមរបស់ឯទៀតវិញ១ ភិក្ខុនីប្រើគេឱ្យ ទិញរបស់ដទៃ ហើយបែរជាប្រើគេឱ្យទិញរបស់ឯទៀតវិញ១ ភិក្ខុនី ប្រើគេឱ្យទិញវត្ថុដទៃដោយបរិក្ខារដែលទាយកប្រគេនមកដើម្បីវត្ថុដទៃ១ ភិក្ខុនីឱ្យទិញវត្ថុដទៃ ដោយបរិក្ខាររបស់សង្ឃ១ ភិក្ខុនីប្រើគេឱ្យទិញវត្ថុដទៃដោយបរិក្ខាររបស់មហាជនគឺគណៈ១ ភិក្ខុនីឱ្យគេទិញវត្ថុដទៃដោយបរិក្ខារដែលសូមបានមកដោយខ្លួនឯង១ ភិក្ខុនីឱ្យគេទិញវត្ថុដទៃដោយបរិក្ខាររបស់បុគ្គល១ ភិក្ខុនីសូមសំពត់ដណ្ដប់មានសាច់ ក្រាស់មានតម្លៃច្រើនជាង១៦កហាបណៈឡើងទៅ១ ភិក្ខុនីសូមសំពត់ដណ្ដប់មានសាច់ស្ដើង មានតម្លៃច្រើនជាង១០កហាបណៈឡើងទៅ១។

## បាចិត្តិយកណ្ឌៈ ទី៤

CS vin.pv.01.2.01.4 | ភាគ ទី១២

### (៤. បាចិត្តិយកណ្ឌំ)

## លសុណវគ្គ ទី១

CS vin.pv.01.2.01.4.1 | ភាគ ទី១២

### (១. លសុណវគ្គោ)

[៥៤២] បាចិត្តិយសិក្ខាបទណា ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប (នូវកាលដែលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍ទាំង ១០) ទ្រង់បញ្ញត្ត ដល់ភិក្ខុនីដែលទំពាស៊ីខ្ទឹម បាចិត្តិយសិក្ខាបទនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែល ថុល្លនន្ទាភិក្ខុនី មិនដឹងប្រមាណ ក៏ប្រើគេឱ្យនាំយកខ្ទឹមមក។ សិក្ខាបទ នោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៤៣] ភិក្ខុនីប្រើគេឱ្យដករោមក្នុងទីចង្អៀត ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី ប្រើគេឱ្យដករោមក្នុងទីចង្អៀត។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន៤។

[៥៤៤] ភិក្ខុនីត្រូវអាបត្តិបាចិត្តិយៈ ព្រោះប្រហារនូវផ្ទៃនៃនិមិត្ត ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនី២រូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីទាំងពីររូប បានប្រហារនូវផ្ទៃនៃនិមិត្ត។ សិក្ខាបទ នោះមានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំង ឡើងដោយសមុដ្ឋាន១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៥៤៥] ភិក្ខុនីត្រូវអាបត្តិបាចិត្តិយៈ ព្រោះអង្គជាតដែលធ្វើដោយជ័រឈើ ឬកាកល័ខជ័រលីង ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីមួយរូប កាន់យកអង្គជាតដែលធ្វើដោយជ័រឈើ ឬកាកល័ខជ័រលីង។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៥៤៦] ភិក្ខុនីកាន់យកនូវការជម្រះអង្គជាតដោយទឹកមានជម្រៅលើសជាង ២ ថ្នាំងម្រាមដៃឡើងទៅ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនសក្កៈ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីមួយរូប កាន់យកនូវការជម្រះអង្គជាត ដោយទឹកជ្រៅពេក។ សិក្ខាបទ នោះមានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំង ឡើងដោយសមុដ្ឋាន ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៥៤៧] ភិក្ខុកំពុងឆាន់ ភិក្ខុនីទៅបម្រើដោយទឹកក្ដី ដោយផ្លិតក្ដី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីមួយរូប កាលដែលភិក្ខុកំពុងតែឆាន់ បានទៅបម្រើដោយទឹកផង ដោយផ្លិតផង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៤៨] ភិក្ខុនីសូមស្រូវស្រស់ឆាន់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូបសូមស្រូវស្រស់ហើយឆាន់។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន ៤។

[៥៤៩] ភិក្ខុនីចោលឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី សម្រាមក្ដី របស់សំណល់ក្ដី ខាងក្រៅជញ្ជាំង ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីមួយរូបចោលឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះ សម្រាមខ្លះ របស់សំណល់ខ្លះ ខាងក្រៅជញ្ជាំង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដា សមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៥០] ភិក្ខុនីចោលឧច្ចារៈក្ដី បស្សាវៈក្ដី ទឹកមាត់ក្ដី សម្រាមក្ដី របស់សំណល់ក្ដី លើឈើ ឬស្មៅដែលស្រស់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែល ភិក្ខុនីច្រើនរូបចោលឧច្ចារៈខ្លះ បស្សាវៈខ្លះ ទឹកមាត់ខ្លះ សម្រាមខ្លះ របស់សំណល់ខ្លះ លើឈើ ឬស្មៅដែលស្រស់។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៥១] ភិក្ខុនីដើរទៅមើលរបាំក្ដី ស្ដាប់ចម្រៀងក្ដី ភ្លេងប្រគំក្ដី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី បានដើរទៅមើលរបាំខ្លះ ស្ដាប់ចម្រៀងខ្លះ ភ្លេងប្រគំខ្លះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

ចប់ លសុណវគ្គ ទី១។

## រត្តន្ធការវគ្គ ទី២

CS vin.pv.01.2.01.4.2 | ភាគ ទី១២

### (២. រត្តន្ធការវគ្គោ)

[៥៥២] ភិក្ខុនីឋិតនៅជាមួយនឹងបុរសតែម្នាក់នឹងម្នាក់ ក្នុងវេលាយប់ងងឹតឥតមានប្រទីប ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងភិក្ខុនីមួយរូបឋិតនៅជាមួយនឹងបុរសតែម្នាក់នឹងម្នាក់ ក្នុងវេលាយប់ងងឹតឥតមានប្រទីប។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិ នោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងថេយ្យសត្ថសិក្ខាបទ)។

[៥៥៣] ភិក្ខុនីឋិតនៅជាមួយនឹងបុរសតែម្នាក់នឹងម្នាក់ក្នុងទីឱកាសដ៏កំបាំង ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងភិក្ខុនីមួយរូប ឋិតនៅជាមួយនឹងបុរសតែម្នាក់នឹងម្នាក់ក្នុងទីឱកាសដ៏កំបាំង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងថេយ្យសត្ថសិក្ខាបទ)។

[៥៥៤] ភិក្ខុនីឋិតនៅជាមួយនឹងបុរសតែម្នាក់នឹងម្នាក់ក្នុងទីវាល ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីមួយរូប ឋិតនៅជាមួយនឹងបុរសតែម្នាក់នឹងម្នាក់ក្នុងទីវាល។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដា សមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងថេយ្យសត្ថសិក្ខាបទ)។

[៥៥៥] ភិក្ខុនីឋិតនៅជាមួយនឹងបុរសតែម្នាក់នឹងម្នាក់ក្នុងច្រករហូតក្ដី ច្រកទាល់ក្ដី ផ្លូវបែកក្ដី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលថុល្លនន្ទា ភិក្ខុនីឋិតនៅជាមួយនឹងបុរសតែម្នាក់នឹងម្នាក់ក្នុងច្រករហូតខ្លះ ច្រកទាល់ខ្លះ ផ្លូវបែកខ្លះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាន នៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងថេយ្យសត្ថសិក្ខាបទ)។

[៥៥៦] ភិក្ខុនីចូលទៅរកត្រកូលក្នុងវេលាមុនបាយ ហើយអង្គុយលើអាសនៈ មិនបានប្រាប់ម្ចាស់គេ ហើយក៏ចៀសចេញទៅ ត្រូវអាបត្តិ បាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីមួយរូប ចូលទៅរកត្រកូលក្នុងវេលាមុនបាយ ហើយ អង្គុយលើអាសនៈ មិនប្រាប់ម្ចាស់គេក៏ចៀសចេញទៅ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំង ឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៥៥៧] ភិក្ខុនីចូលទៅកាន់ត្រកូលវេលាក្រោយបាយ ហើយ អង្គុយលើអាសនៈ ដោយឥតមានប្រាប់ម្ចាស់គេ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី ចូលទៅកាន់ត្រកូលក្នុងវេលាក្រោយបាយ មិនបានប្រាប់ម្ចាស់គេ ក៏ស្រាប់តែអង្គុយលើអាសនៈ។ សិក្ខាបទនោះមានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៥៥៨] ភិក្ខុនីចូលទៅកាន់ត្រកូលក្នុងវេលាវិកាល ហើយមិនប្រាប់ម្ចាស់គេ ស្រាប់តែក្រាលឯងខ្លះ ប្រើគេឱ្យក្រាលខ្លះ នូវសេនាសនៈសម្រាប់ក្រាលដេក ហើយក៏អង្គុយ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប ចូលទៅកាន់ត្រកូល ក្នុងវេលាវិកាល ហើយមិនប្រាប់ម្ចាស់គេ ស្រាប់តែក្រាលសេនាសនៈសម្រាប់ក្រាលដេក ហើយអង្គុយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើង ដោយសមុដ្ឋាន ២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៥៥៩] ភិក្ខុនីពោលទោសភិក្ខុនីដទៃ ដោយកិរិយាប្រកាន់អាក្រក់ នឹងដោយពិចារណាខុស ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីមួយរូបពោលទោសភិក្ខុនីដទៃ ដោយកិរិយាប្រកាន់អាក្រក់ នឹងដោយ ពិចារណាខុស។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន៣។

[៥៦០] ភិក្ខុនីប្រទេចខ្លួនឯងក្តី ប្រទេចភិក្ខុនីដទៃក្តី ដោយនរក ឬដោយព្រហ្មចរិយៈ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលចណ្ឌកាលីភិក្ខុនី ប្រទេចខ្លួនឯងខ្លះ ប្រទេចភិក្ខុនីដទៃខ្លះ ដោយនរកក៏មាន ដោយព្រហ្មចរិយៈក៏មាន។ សិក្ខាបទនោះ មានតែបញ្ញត្តិ១ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៥៦១] ភិក្ខុនី វាយទះតប់ខ្លួនឯងហើយយំ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលចណ្ឌកាលីភិក្ខុនី វាយទះតប់ខ្លួនឯងហើយយំ។ សិក្ខាបទនោះ មានបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

ចប់ រត្តន្ធការវគ្គ ទី២។

## នហានវគ្គ ទី៣

CS vin.pv.01.2.01.4.3 | ភាគ ទី១២

**(៣. នហានវគ្គោ)**

[៥៦២] ភិក្ខុនីងូតទឹកអាក្រាត ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងភិក្ខុនីច្រើនរូប អាក្រាតងូតទឹក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៦៣] ភិក្ខុនីឱ្យគេធ្វើសំពត់សម្រាប់ងូតទឹកកន្លងហួសប្រមាណ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី ប្រើប្រាស់សំពត់សម្រាប់ងូតទឹកមិនត្រូវប្រមាណ។ សិក្ខាបទនោះ មានបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង ៦។

[៥៦៤] ភិក្ខុនីរុះខ្លួនឯងក្តី ឱ្យគេរុះក្តី នូវចីវររបស់ភិក្ខុនីផងគ្នា ហើយមិនឱ្យគេដេរ ទាំងមិនធ្វើនូវសេចក្តីខ្វល់ខ្វាយ ដើម្បីឱ្យគេដេរ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះ រឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី ឱ្យភិក្ខុនីផងគ្នារុះចីវរ ហើយមិនដេរឱ្យ ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយដើម្បីឱ្យគេដេរឱ្យ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥៦៥] ភិក្ខុនីញាំងវារៈនៃសង្ឃាដី[19] ឱ្យកន្លងហួស៥ថ្ងៃទៅ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ទុកដាក់ចីវរក្នុងដៃនៃពួកភិក្ខុនីផងគ្នា ហើយចៀសចេញទៅកាន់ចារិកនៃជនបទ ដោយមានតែ ស្បង់នឹងចីពរ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៥៦៦] ភិក្ខុនីទ្រទ្រង់សង្កមនីយចីវរ (ចីវរដែលលបយករបស់ គេមកប្រើប្រាស់មួយសំណើរ) ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីមួយរូប មិនបានប្រាប់ ហើយឃ្លុំចីវររបស់ភិក្ខុនីផងគ្នា។ សិក្ខាបទ នោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៥៦៧] ភិក្ខុនីធ្វើចីវរលាភរបស់គណៈឱ្យអន្តរាយ ត្រូវអាបត្តិ បាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី ធ្វើចីវរលាភរបស់គណៈ ឱ្យអន្តរាយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន ៣។

[៥៦៨] ភិក្ខុនីឃាត់ការចែកចីវរដែលប្រកបដោយធម៌ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី ឃាត់ការចែកចីវរដែលប្រកបដោយធម៌។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាន នៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន ៣។

[៥៦៩] ភិក្ខុនីឱ្យសមណចីវរដល់គ្រហស្ថក្តី ដល់បរិព្វាជកក្តី ដល់បរិព្វាជិកាក្តី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី ឱ្យសមណចីវរដល់គ្រហស្ថ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋានទាំង៦។

[៥៧០] ភិក្ខុនីញុំាងសម័យនៃចីវរកាល ឱ្យកន្លងទៅដោយចង់ បាននូវចីវរដ៏ទុព្វល ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី ញុំាងសម័យនៃចីវរកាល ឱ្យកន្លងទៅ ដោយចង់បាននូវចីវរដ៏ ទុព្វល។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន៣។

[៥៧១] ភិក្ខុនីឃាត់ការដកកឋិនដែលប្រកបដោយធម៌ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី ឃាត់ការដកកឋិនដែលប្រកបដោយធម៌។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

ចប់ នហានវគ្គ ទី៣។

## តុវដ្តវគ្គ ទី៤

CS vin.pv.01.2.01.4.4 | ភាគ ទី១២

**(៤. តុវដ្តវគ្គោ)**

[៥៧២] ភិក្ខុនីពីររូបដេកលើគ្រែតែ១ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបដេកគ្នាពីរនាក់លើគ្រែតែ១។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើង ដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៧៣] ភិក្ខុនីពីររូបដេកលើកម្រាលនិងដណ្តប់សម្ពត់តែ ១ ជា មួយគ្នា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបដេកលើកម្រាលទាំងដណ្តប់សម្ពត់តែ១ ពីរនាក់។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៧៤] ភិក្ខុនីក្លែងធ្វើសេចក្តីអផ្សុកដល់ភិក្ខុនីផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនីក្លែងធ្វើសេចក្តីអផ្សុកដល់ភិក្ខុនីផងគ្នា។ សិក្ខាបទនោះ មានបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះតាំងឡើងដោយសមុដ្ឋាន៣។

[៥៧៥] ភិក្ខុនីមិនបានបម្រើ មិនបានធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីបម្រើ នូវភិក្ខុនីជាកូនសិស្សដែលមានជម្ងឺ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី មិនបានបម្រើ មិនបានធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីបម្រើ នូវភិក្ខុនីជាកូនសិស្សដែលមានជម្ងឺ។ សិក្ខាបទនោះមានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះតាំងឡើងដោយ សមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥៧៦] ភិក្ខុនីបានឱ្យលំនៅដល់ភិក្ខុនីផងគ្នា ហើយមានសេចក្តីខឹងអាក់អន់ចិត្ត ក៏ទង់ទាញភិក្ខុនីនោះចេញ (ចាកលំនៅនោះ) ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនីបានឱ្យទីលំនៅដល់ភិក្ខុនីផងគ្នា ហើយមានសេចក្តីខឹងអាក់អន់ចិត្ត ក៏ទង់ទាញភិក្ខុនីនោះចេញ (ចាកលំនៅនោះ)។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣។

[៥៧៧] ភិក្ខុនីនៅច្រឡូកច្រឡំដោយគ្រហស្ថ កាលបើសង្ឃ សូត្រសមនុភាសនកម្មជាគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលចណ្ឌកាលីភិក្ខុនីនៅច្រឡូកច្រឡំដោយគ្រហស្ថ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូច ក្នុងសមនុភាសនៈ)។

[៥៧៨] ភិក្ខុនីមិនមានពួកឈ្មួញ (ជាគ្នា) ដើរទៅកាន់ចារិកខាងក្នុងដែន ដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប មិនមានពួកឈ្មួញ (ជាគ្នា) ដើរទៅកាន់ចារិកខាងក្នុងដែន ដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៧៩] ភិក្ខុនីមិនមានពួកឈ្មួញ (ជាគ្នា) ដើរទៅកាន់ចារិកខាងក្រៅដែនដែលគេសន្មតថា ជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ឥតមានពួកឈ្មួញ (ជាគ្នា) ដើរទៅកាន់ចារិកខាងក្រៅដែន ដែលគេ សន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៨០] ភិក្ខុនីដើរទៅកាន់ចារិកក្នុងវស្សា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ដើរទៅកាន់ទីចារិកខាងក្នុងវស្សា។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៨១] ភិក្ខុនីចេញវស្សារួចហើយ មិនចៀសចេញទៅកាន់ចារិក ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ចេញវស្សារួចហើយ មិនបានចៀសចេញទៅកាន់ចារិក។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

ចប់ តុវដ្ដវគ្គ ទី៤។

## ចិត្តាគារវគ្គ ទី៥

CS vin.pv.01.2.01.4.5 | ភាគ ទី១២

**(៥. ចិត្តាគារវគ្គោ)**

[៥៨២] ភិក្ខុនីទៅមើលព្រះរាជដំណាក់ក្ដី ផ្ទះដ៏វិចិត្រក្ដី សួនច្បារក្ដី ឱទ្យានក្ដី ស្រះបោក្ខរណីក្ដី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយាភិក្ខុនី ទៅមើលព្រះរាជដំណោក់ខ្លះ ផ្ទះដ៏វិចិត្រខ្លះ សួនច្បារខ្លះ ឱទ្យានខ្លះ ស្រះបោក្ខរណីខ្លះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៨៣] ភិក្ខុនីប្រើប្រាស់អាសន្ទិ គឺគ្រែកន្លងហួសប្រមាណក្ដី បល្លង្កៈ គឺគ្រែដែលគេធ្វើមានរូបសត្វសាហាវដាក់ត្រង់ជើងក្ដី ត្រូវអាបត្តិ បាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ប្រើប្រាស់អាសន្ទិខ្លះ បល្លង្កៈខ្លះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៨៤] ភិក្ខុនី ការសូត្រ ឬអំបោះ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបការសូត្រ ឬអំបោះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៨៥] ភិក្ខុនី ធ្វើសេចក្ដីខ្វល់ខ្វាយបម្រើគ្រហស្ថ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ធ្វើសេចក្ដីខ្វល់ខ្វាយបម្រើគ្រហស្ថ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៨៦] កាលបើភិក្ខុនីផងគ្នាបាននិយាយថា នែនាងជាម្ចាស់ ចូរនាងរម្ងាប់អធិករណ៍នេះទៅ ភិក្ខុនីក៏ទទួលពាក្យថាសាធុហើយ តែមិនរម្ងាប់ មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីរម្ងាប់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី កាលដែលភិក្ខុនីផងគ្នាបាននិយាយថា នែនាងជាម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះទៅ ក៏ទទួលពាក្យថាសាធុហើយ តែមិនរម្ងាប់ មិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីរម្ងាប់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋានតែ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥៨៧] ភិក្ខុនីឱ្យខាទនីយៈ ឬភោជនីយៈដោយដៃរបស់ខ្លួន ដល់គ្រហស្ថក្ដី ដល់បរិព្វាជកក្ដី ដល់បរិព្វាជិកាក្ដី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី ឱ្យខាទនីយៈខ្លះ ភោជនីយៈខ្លះ ដោយដៃរបស់ខ្លួន ដល់គ្រហស្ថ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៨៨] ភិក្ខុនីមិនលះបង់អាវសថចីវរ (ចីវរសម្រាប់ភិក្ខុនីមានរដូវ) នៅតែប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី មិនលះបង់អាវសថចីវរ នៅតែប្រើប្រាស់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៥៨៩] ភិក្ខុនីមិនបានប្រគល់លំនៅ (ដល់គេឯទៀត) ហើយ ស្រាប់តែចៀសចេញទៅកាន់ចារិក ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី មិនបានប្រគល់លំនៅ (ដល់គេឯទៀត) ហើយ ស្រាប់តែចៀសចេញទៅកាន់ចារិក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៥៩០] ភិក្ខុនី រៀនតិរច្ឆានវិជ្ជា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលឆព្វគ្គិយាភិក្ខុនី រៀនតិរច្ឆានវិជ្ជា។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ២ (ដូចក្នុងបទសោធម្មសិក្ខាបទ)។

[៥៩១] ភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយាភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា។ សិក្ខាបទ នោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងបទសោធម្មសិក្ខាបទ)។

ចប់ ចិត្តាគារវគ្គ ទី៥។

## អារាមវគ្គ ទី៦

CS vin.pv.01.2.01.4.6 | ភាគ ទី១២

### (៦. អារាមវគ្គោ)

[៥៩២] ភិក្ខុនី ដឹងហើយចូលទៅកាន់អារាមដែលមានភិក្ខុ ដោយមិនបានប្រាប់មុន ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប មិនបានប្រាប់មុន ហើយស្រាប់តែចូលទៅកាន់អារាម (ដែល មានភិក្ខុ)។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ២។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥៩៣] ភិក្ខុនី ជេរគម្រាមភិក្ខុ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងវេសាលី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយាភិក្ខុនី ជេរព្រះឧបាលិមានអាយុ។ សិក្ខា បទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៥៩៤] ភិក្ខុនី ប្រទេចផ្តាសាគណៈភិក្ខុនី ដោយចិត្តកំណាច ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនីប្រទេចផ្តាសាគណៈភិក្ខុនី ដោយចិត្តកំណាច។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៥៩៥] ភិក្ខុនី ដែលគេនិមន្តហើយ បានហាមភោជនរួចហើយ ឆាន់ខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបឆាន់ហើយ ហាមភោជនហើយ ឆាន់ក្នុងទីដទៃទៀត។ សិក្ខាបទ នោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។

[៥៩៦] ភិក្ខុនីកំណាញ់ត្រកូល ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីមួយរូប ប្រព្រឹត្តកំណាញ់ត្រកូល។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋាន៣។

[៥៩៧] ភិក្ខុនី នៅចាំវស្សាក្នុងអាវាសដែលមិនមានភិក្ខុ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប នៅចាំវស្សាក្នុងអាវាសដែលមិនមានភិក្ខុ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៥៩៨] ភិក្ខុនីនៅចាំវស្សារួចហើយ មិនបានបវារណាដោយហេតុ៣ ប្រការក្នុងសម្នាក់ឧភតោសង្ឃទេ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបនៅចាំវស្សារួចហើយ មិនបានបវារណា នឹងភិក្ខុសង្ឃ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៥៩៩] ភិក្ខុនី មិនទៅដើម្បីស្តាប់ឱវាទ (គរុធម៌)ក្តី ដើម្បីសំវាស គឺសួរនូវឧបោសថ និងបវារណាក្តី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងដែនសក្កៈ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលឆព្វគ្គិយាភិក្ខុនីមិនទៅស្តាប់ឱវាទ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៦០០] ភិក្ខុនី មិនសួរឧបោសថក្តី មិនសូមឱវាទក្តី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប មិនសួរឧបោសថខ្លះ មិនសូមឱវាទខ្លះ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៦០១] ភិក្ខុនី កើតបូសក្តី ដំបៅក្តី ត្រង់បសាខប្រទេស (តាំង ពីក្រោមផ្ចិតរហូតដល់ក្បាលជង្គង់) ហើយមិនបានប្រាប់ដល់សង្ឃ ឬគណៈ ស្រាប់តែទៅជោះតែមួយរូប ជាមួយនឹងបុរសម្នាក់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីមួយរូបកើតបូសត្រង់បសាខប្រទេស ហើយជោះតែមួយរូបជាមួយនឹងបុរសម្នាក់។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិ នោះតាំងឡើង ដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។

ចប់ អារាមវគ្គ ទី៦។

## គព្ភិនីវគ្គ ទី៧

CS vin.pv.01.2.01.4.7 | ភាគ ទី១២

**(៧. គព្ភិនីវគ្គោ)**

[៦០២] ភិក្ខុនីបំបួសស្ត្រីដែលមានគភ៌ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប បំបួសស្ត្រីដែលមានគភ៌។ សិក្ខាបទ នោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦០៣] ភិក្ខុនីបំបួសស្ត្រីដែលមានកូននៅបៅ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប បំបួសស្ត្រីដែលមានកូននៅបៅ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣។

[៦០៤] ភិក្ខុនី បំបួសសិក្ខមានាដែលមិនទាន់បានសិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប បំបួសសិក្ខមានាដែលមិនទាន់បានសិក្សាសិក្ខាក្នុងធម៌៦ ប្រការ គ្រប់ពីរឆ្នាំ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣។

[៦០៥] ភិក្ខុនី បំបួសសិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំហើយ តែសង្ឃមិនទាន់បានសន្មតឱ្យ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្ត ក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះ រឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប បំបួសសិក្ខមានា ដែលបានសិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំហើយ តែសង្ឃមិនទាន់បានសន្មតឱ្យ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦០៦] ភិក្ខុនី បំបួសស្ត្រីជាគិហិគតា[20] ដែលមានអាយុមិនទាន់គ្រប់១២ឆ្នាំ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនិងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប បំបួសស្ត្រីជាគិហិគតា ដែលមានអាយុមិនទាន់គ្រប់១២ឆ្នាំ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦០៧] ភិក្ខុនី បំបួសស្ត្រីជាគិហិគតា ដែលមានអាយុគ្រប់១២ឆ្នាំហើយ តែមិនទាន់បានសិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំនៅឡើយ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប បំបួសស្ត្រីជាគិហិគតា ដែលមានអាយុគ្រប់១២ឆ្នាំហើយ តែមិនទាន់សិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំនៅឡើយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦០៨] ភិក្ខុនីបំបួសស្ត្រីជាគិហិគតា ដែលមានអាយុគ្រប់១២ឆ្នាំហើយ បានសិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំហើយ តែសង្ឃមិនទាន់បានសន្មតឱ្យ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប បំបួសស្ត្រីជាគិហិគតា ដែលមានអាយុគ្រប់១២ឆ្នាំហើយ បានសិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំហើយ តែសង្ឃមិនទាន់បានសន្មតឱ្យ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន ៣។

[៦០៩] ភិក្ខុនីបំបួសកូនសិស្ស ហើយមិនបានអនុគ្រោះ (ទំនុកបម្រុង) ដោយខ្លួនឯង ឬមិនបានឱ្យគេអនុគ្រោះ គ្រប់ពីរឆ្នាំទេ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។

ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនី បំបួសកូនសិស្ស ហើយ មិនបានអនុគ្រោះដោយខ្លួនឯង មិនបានឱ្យគេអនុគ្រោះ គ្រប់ពីរឆ្នាំ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៦១០] ភិក្ខុនី មិននៅបម្រើបវត្តិនី (ឧបជ្ឈាយ៍) ដែលបំបួសខ្លួន ឱ្យគ្រប់ពីរឆ្នាំ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបមិនបម្រើបវត្តិនីដែលបំបួសខ្លួនឱ្យគ្រប់ពីរឆ្នាំ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៦១១] ភិក្ខុនីបំបួសកូនសិស្សហើយ មិនបានគ្រប់គ្រងដោយខ្លួនឯង ឬមិនបានប្រើគេឱ្យគ្រប់គ្រង[21] ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលថុល្លនន្ទាភិក្ខុនីបំបួសកូនសិស្សហើយ មិនបានគ្រប់គ្រងដោយខ្លួនឯង មិនបានប្រើគេឱ្យគ្រប់គ្រង។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

ចប់ គព្ភិនីវគ្គ ទី៧។

## កុមារីភូតវគ្គ ទី៨

CS vin.pv.01.2.01.4.8 | ភាគ ទី១២

**(៨. កុមារីភូតវគ្គោ)**

[៦១២] ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតា (សាមណេរី) ដែលមានអាយុមិនទាន់គ្រប់២០ឆ្នាំ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប បំបួសស្ត្រីជាកុមារីភូតា ដែលមានអាយុមិនទាន់គ្រប់២០ឆ្នាំ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦១៣] ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតា ដែលមានអាយុគ្រប់២០ឆ្នាំហើយ តែមិនទាន់បានសិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំនៅឡើយ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប បំបួសស្ត្រីជាកុមារីភូតា ដែលមានអាយុគ្រប់២០ឆ្នាំហើយ តែមិនទាន់បានសិក្សាសិក្ខាក្នុងធម៌៦ប្រការ គ្រប់ពីរឆ្នាំនៅឡើយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដា សមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦១៤] ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតាដែលមានអាយុគ្រប់២០ឆ្នាំហើយ បានសិក្សាសិក្ខាក្នុងធម៌៦ប្រការគ្រប់ពីរឆ្នាំហើយ តែសង្ឃមិនទាន់បានសន្មតឱ្យ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប បំបួសស្ត្រីជាកុមារីភូតាដែលមានអាយុគ្រប់២០ឆ្នាំហើយ បានសិក្សាសិក្ខាក្នុងធម៌៦ប្រការគ្រប់ពីរឆ្នាំហើយ តែសង្ឃមិនទាន់បានសន្មតឱ្យ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦១៥] ភិក្ខុនីមានវស្សាមិនទាន់គ្រប់១២ បំបួសគេ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប មានវស្សាមិនទាន់គ្រប់១២ បំបួសគេ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦១៦] ភិក្ខុនីមានវស្សាគ្រប់១២ហើយ តែសង្ឃមិនទាន់បានសន្មតឱ្យបំបួសគេ ក៏ចេះតែបំបួស ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿង ដែលភិក្ខុនីច្រើនរូប មានវស្សាគ្រប់១២ហើយ តែសង្ឃមិនទាន់បានសន្មត (ឱ្យបំបួសគេ) ក៏ចេះតែបំបួស។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦១៧] ភិក្ខុនីដែលសង្ឃនិយាយឃាត់ថា នែនាងជាម្ចាស់ នាងកុំបំបួសគេឡើយ បានទទួសពាក្យថាសាធុហើយ ដល់មកខាងក្រោយ ត្រឡប់ពោលតិះដៀលសង្ឃវិញ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿង ដែលចណ្ឌកាលីភិក្ខុនី ដែលសង្ឃនិយាយឃាត់ថា នែនាងជាម្ចាស់ នាងកុំបំបួសគេឡើយ បានទទួលពាក្យថាសាធុហើយ ដល់មកខាងក្រោយ ត្រឡប់ពោលតិះដៀលសង្ឃវិញ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋាន៣។

[៦១៨] ភិក្ខុនី និយាយនឹងសិក្ខមានាថា នែនាង បើនាងឱ្យចីវរដល់យើង ៗ នឹងបំបួសនាង លុះនិយាយយ៉ាងនេះហើយ ក៏មិនបំបួស ទាំងមិនធ្វើសេចក្ដីខ្វល់ខ្វាយនឹងបំបួស ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿង ដែលថុល្លនន្ទាភិក្ខុនី បាននិយាយនឹងសិក្ខមានាថា នែនាង បើនាងឱ្យចីវរដល់យើង ៗ នឹងបំបួសនាង លុះនិយាយយ៉ាងនេះហើយ ក៏មិនបំបួស ទាំងមិនធ្វើសេចក្ដីខ្វល់ខ្វាយនឹងបំបួសឡើយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៦១៩] ភិក្ខុនីនិយាយនឹងសិក្ខមានាថា នែនាង បើនាងតាមបម្រើយើងឱ្យគ្រប់២ឆ្នាំ យើងនឹងបំបួសនាង លុះនិយាយយ៉ាងនេះហើយ ក៏មិនបំបួស ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយនឹងបំបួស ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី បាននិយាយនឹងសិក្ខមានាថា នែនាង បើនាងតាមបម្រើយើងឱ្យគ្រប់២ឆ្នាំ យើងនឹងបំបួសនាង លុះនិយាយយ៉ាងនេះហើយ ក៏មិនបំបួស ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយនឹងបំបួសឡើយ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៦២០] ភិក្ខុនី បំបួសសិក្ខមានា ដែលនៅច្រឡូកច្រឡំដោយបុរស ច្រឡូកច្រឡំដោយកុមារ ជាស្រីកាច បណ្តាលឱ្យកើតសេចក្តីសោក (ដល់គេឯទៀត) ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីបំបួសសិក្ខមានា ដែលនៅច្រឡូកច្រឡំដោយបុរស ច្រឡូក ច្រឡំដោយកុមារ ជាស្រីកាច បណ្តាលឱ្យកើតសេចក្តីសោក (ដល់គេឯទៀត)។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦២១] ភិក្ខុនីបំបួសសិក្ខមានាដែលមាតាបិតា ឬប្តីមិនបានអនុញ្ញាត ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី បំបួសសិក្ខមានាដែលមាតាបិតាខ្លះ ប្តីខ្លះ មិនបានអនុញ្ញាត។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤ គឺតាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយនិងចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយអំពីវាចានិងចិត្តក៏មាន។

[៦២២] ភិក្ខុនីបំបួសសិក្ខមានា ដោយឱ្យឆន្ទៈឈ្មោះបារិវាសិកៈ (ដែលមានបរិស័ទក្រោកចេញទៅហើយ) ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនី បំបួសសិក្ខមានាដោយឱ្យឆន្ទៈឈ្មោះបារិ វាសិកៈ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦២៣] ភិក្ខុនីបំបួសគេរាល់ឆ្នាំ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប បំបួសគេរាល់ឆ្នាំ។ សិក្ខាបទនោះ មានតែ បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

[៦២៤] ភិក្ខុនីបំបួសស្ត្រី ២ នាក់ក្នុង១ឆ្នាំ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូបបំបួសស្ត្រី២នាក់ក្នុង១ឆ្នាំ។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៣។

ចប់ កុមារីភូតវគ្គ ទី៨។

## ឆត្តុបាហនវគ្គ ទី៩

CS vin.pv.01.2.01.4.9 | ភាគ ទី១២

### (៩. ឆត្តុបាហនវគ្គោ)

[៦២៥] ភិក្ខុនីប្រើប្រាស់ឆត្រនិងស្បែកជើង ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី ប្រើប្រាស់ឆត្រនិងស្បែកជើង។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៦២៦] ភិក្ខុនីទៅដោយយាន ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿង ដែលពួកឆព្វគ្គិយាភិក្ខុនី នាំគ្នាទៅដោយយាន។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៦២៧] ភិក្ខុនី ប្រើប្រាស់ខ្សែក្រវាត់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីមួយរូប ប្រើប្រាស់ខ្សែក្រវាត់។ សិក្ខាបទនោះ មាន តែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៦២៨] ភិក្ខុនី ប្រើប្រាស់គ្រឿងប្រដាប់ស្ត្រី ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនីប្រើប្រាស់គ្រឿងប្រដាប់ស្ត្រី។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៦២៩] ភិក្ខុនីងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាប ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី ងូតទឹកដោយគ្រឿងក្រអូបនិងគ្រឿងលាប។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូច ក្នុងឯឡកលោមសិក្ខាបទ)។

[៦៣០] ភិក្ខុនីងូតទឹកដោយគ្រឿងអប់ និងលម្អិតម្សៅ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី ងូតទឹកដោយគ្រឿងអប់ និងលម្អិតម្សៅ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៦៣១] ភិក្ខុនីប្រើភិក្ខុនីផងគ្នាឱ្យគក់រឹតច្របាច់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ប្រើភិក្ខុនីផងគ្នាឱ្យគក់ រឹត ច្របាច់។ សិក្ខាបទនោះ មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៦៣២] ភិក្ខុនីប្រើសិក្ខមានាឱ្យគក់រឹតច្របាច់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ប្រើសិក្ខមានាឱ្យគក់ រឹត ច្របាច់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៦៣៣] ភិក្ខុនីប្រើសាមណេរីឱ្យគក់រឹតច្របាច់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបប្រើសាមណេរីឱ្យគក់ រឹត ច្របាច់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោមសិក្ខាបទ)។

[៦៣៤] ភិក្ខុនីប្រើស្ត្រីគ្រហស្ថឱ្យគក់ រឹត ច្របាច់ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូប ប្រើស្ត្រីគ្រហស្ថឱ្យគក់រឹត ច្របាច់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិ ទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងឯឡកលោ មសិក្ខាបទ)។

[៦៣៥] ភិក្ខុនីមិនបានប្រាប់ ហើយអង្គុយលើអាសនៈពីមុខភិក្ខុ ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបមិនបានប្រាប់ ហើយអង្គុយលើអាសនៈពីមុខភិក្ខុ។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ (ដូចក្នុងកឋិនសិក្ខាបទ)។

[៦៣៦] ភិក្ខុនី សួរប្រស្នានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស (ជាមុន) ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីច្រើនរូបសួរប្រស្នានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស (ជាមុន)។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើង ដោយសមុដ្ឋាន២ (ដូចក្នុងបទសោធម្មសិក្ខាបទ)។

[៦៣៧] ភិក្ខុនីមិនមានសំពត់ចោមពុង ចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីមួយរូប។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងរ៉ាវដែលភិក្ខុនីមួយរូប មិនមានសំពត់ចោមពុងចូលទៅកាន់ស្រុក។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន២ គឺ តាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន។

ចប់ ឆត្តុបាហនវគ្គ ទី៩។

ចប់ ពួកខុទ្ទកសិក្ខាបទ មានចំនួន៩វគ្គ តែប៉ុណ្ណេះ។

ឧទ្ទានគឺបញ្ជីរឿងនៃខុទ្ទកសិក្ខាបទនោះដូច្នេះ

[៦៣៨]

រឿងភិក្ខុនីឱ្យគេដកខ្ទឹម១ ភិក្ខុនីដករោមក្នុងទីចង្អៀត១ ភិក្ខុនីប្រហារផ្ទៃនិមិត្ត១ ភិក្ខុនីធ្វើរូបអង្គជាត១ ភិក្ខុនីលាងនិមិត្ត១ ភិក្ខុនីបំរើភិក្ខុកំពុងឆាន់១ ភិក្ខុនីសូមស្រូវស្រស់១ ភិក្ខុនីចោលរបស់ដែលសល់មានពីររឿង១ ភិក្ខុនីទៅមើលរបាំ១ ភិក្ខុនីទៅជាមួយនឹងបុរសក្នុងទីងងឹត១ ភិក្ខុនីទៅជាមួយនឹងបុរសក្នុងទីកំបាំង១ ភិក្ខុនីនៅជាមួយនឹងបុរសក្នុងទីវាល១ ភិក្ខុនីនៅជាមួយនឹងបុរសក្នុងច្រកផ្លូវ១ ភិក្ខុនីចូលទៅកាន់ត្រកូលក្នុងវេលាមុនភត្ត១ ក្រោយភត្ត១ ក្នុងវេលាវិកាល១ ភិក្ខុនីពោលទោសគេ ដោយសេចក្តីប្រកាន់អាក្រក់១ ភិក្ខុនីប្រទេចផ្តាសាដោយនរក១ ភិក្ខុនីវាយខ្លួនឯងហើយយំ១ ភិក្ខុនីមានកាយអាក្រាតងូតទឹក១ ភិក្ខុនីរុះចីវរ១ ភិក្ខុនីញាំងវារៈនៃសង្ឃាដីឱ្យកន្លងហួស៥ថ្ងៃ១ ភិក្ខុនីប្រើសង្កមនីយចីវរ១ ភិក្ខុនីធ្វើចីវរលាភរបស់គណៈឱ្យខូច១ ភិក្ខុនីឃាត់ការចែកចីវរ១ ភិក្ខុនីឱ្យសមណចីវរដល់គ្រហស្ថជាដើម១ ភិក្ខុនីញាំងសម័យចីវរកាលឱ្យកន្លងទៅ ដោយចង់បានចីវរទុព្វលភាព១ ភិក្ខុនី

ឃាត់ការដកកឋិន១ ភិក្ខុនីដេកលើគ្រែមួយជាមួយគ្នា១ ភិក្ខុនីដេកលើកម្រាលមួយជាមួយគ្នា ១ ភិក្ខុនីក្លែងធ្វើសេចក្ដីអផ្សុកដល់ភិក្ខុនីផងគ្នា១ ភិក្ខុនីមិនបំរើកូនសិស្សដែលមានជម្ងឺ១ ភិក្ខុនីឱ្យលំនៅដល់ភិក្ខុនីផងគ្នា១ ភិក្ខុនីនៅច្រឡូកច្រឡំដោយគ្រហស្ថ១ ភិក្ខុនី ដើរទៅខាងក្នុងដែន១ ដើរទៅខាងក្រៅដែន១ ភិក្ខុនីដើរទៅកាន់ចារិកខាងក្នុងវស្សា១ ភិក្ខុនីចេញវស្សាហើយ មិនទៅកាន់ចារិក១ ភិក្ខុនីទៅមើលព្រះរាជដំណាក់១ ភិក្ខុនី ប្រើប្រាស់អាសន្ទិ១ ភិក្ខុនីការសូត្រ ឬអំបោះ១ ភិក្ខុនីបម្រើ គ្រហស្ថ១ ភិក្ខុនីមិនរម្ងាប់អធិករណ៍១ ភិក្ខុនីឱ្យខាទនីយ ភោជនីយៈដល់គ្រហស្ថជាដើម១ ភិក្ខុនីមិនលះអាវសថចីវរ១ ភិក្ខុនីមិនលះផ្ទះសំណាក់១ ភិក្ខុនីរៀនតិរច្ឆានវិជ្ជា១ ភិក្ខុនី បង្រៀនតិរច្ឆានវិជ្ជា១ ភិក្ខុនីចូលទៅកាន់អារាមដែលមានភិក្ខុ ដោយមិនបានប្រាប់ជាមុន១ ភិក្ខុនីជេរភិក្ខុ១ ភិក្ខុនីគម្រាមគណភិក្ខុនីដោយចិត្តកំណាច១ ភិក្ខុនីហាមភោជនហើយឆាន់ ភោជនឯទៀត១ ភិក្ខុនីកំណាញ់ត្រកូល១ ភិក្ខុនីនៅចាំវស្សា ក្នុងអាវាសដែលមិនមានភិក្ខុ១ ភិក្ខុនី នៅចាំវស្សាហើយ មិនបវារណាក្នុងឧភតោសង្ឃ១ ភិក្ខុនីមិនទៅទទួលឱវាទ១ ភិក្ខុនីមិនប្រាថ្នាធម៌ ២ប្រការ គឺសួរឧបោសថ ទាំងចូលទៅស្ដាប់ឱវាទ១ ភិក្ខុនីជោះបូស ឬដំបៅក្នុងបសាខប្រទេស១ ភិក្ខុនីបំបួសស្ត្រីមានគភ៌១ បំបួសស្ត្រី ដែលមានកូននៅបៅ១ បំបួសសិក្ខមានាដែលមិនទាន់បានសិក្សាសិក្ខាក្នុងធម៌៦ប្រការ១ បំបួសសិក្ខមានាដែលសង្ឃមិនបានសន្មត១ បំបួសស្ត្រីជាគិហិគតា ដែលមានអាយុមិនទាន់គ្រប់ ១២ ឆ្នាំ១ បំបួសស្ត្រីជាគិហិគតា ដែលមានអាយុគ្រប់ ១២ ឆ្នាំហើយ តែមិនបានសិក្សាសិក្ខាគ្រប់ ២ ឆ្នាំ១ បំបួសស្ត្រីជាគិហិគតា ដែលសង្ឃមិនបានសន្មត១ បំបួសកូនសិស្សហើយមិនបានអនុគ្រោះ ១ ភិក្ខុនីមិនបម្រើបវត្តិនី១ ភិក្ខុនីមិនគ្រប់គ្រងកូនសិស្ស១ ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតា មានអាយុមិនទាន់គ្រប់២០ឆ្នាំ១ ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតាដែលមិនទាន់បានសិក្សាសិក្ខាគ្រប់ ២ ឆ្នាំ ១ ភិក្ខុនីបំបួសស្ត្រីជាកុមារីភូតាដែលសង្ឃមិនបានសន្មត១ ភិក្ខុនីមានវស្សាមិនគ្រប់១២ហើយ បំបួសគេ១ ភិក្ខុនីដែលសង្ឃមិនបានសន្មត ហើយបំបួសគេ ១ ភិក្ខុនីដែលសង្ឃឃាត់មិនឱ្យបំបួសគេ១ ភិក្ខុនីនិយាយនឹងសិក្ខមានាថា បើនាងឱ្យចីវរយើង ៗ នឹងបំបួសនាង១ ភិក្ខុនីនិយាយនឹងសិក្ខមានាថា បើនាងបម្រើយើងគ្រប់ពីរឆ្នាំ យើងនឹងបំបួសនាង ១ ភិក្ខុនីបំបួសសិក្ខមានាដែលនៅច្រឡូកច្រឡំដោយបុរស១ បំបួសស្ត្រីដែលប្ដីមិនបានអនុញ្ញាត១ បំបួសសិក្ខមានាដោយឱ្យឆន្ទៈឈ្មោះបារិវាសិក ១ បំបួសគេរាល់ឆ្នាំ ១ បំបួសស្ត្រី ២ នាក់ក្នុងមួយឆ្នាំ១ ភិក្ខុនីមិនមានជំងឺប្រើប្រាស់ឆត្រ១ ទៅដោយយាន ១ ភិក្ខុនីប្រើប្រាស់ខ្សែក្រវាត់ ១ ប្រើប្រាស់គ្រឿងប្រដាប់ស្ត្រី១ ងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាប១ ងូតទឹកដោយគ្រឿងអប់និងម្សៅ១ ភិក្ខុនី ប្រើភិក្ខុនីផងគ្នា ឱ្យគក់ រឹត ច្របាច់១ ឱ្យសិក្ខមានាគក់រឹតច្របាច់១ ឱ្យសាមណេរីគក់រឹតច្របាច់១ ឱ្យស្ត្រីគ្រហស្ថគក់រឹតច្របាច់១ ភិក្ខុនីអង្គុយលើអាសនៈពីមុខភិក្ខុ១ ភិក្ខុនីសួរប្រស្នានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាសជាមុន១ ភិក្ខុនី មិនមានសំពត់ចោមពុងចូលទៅកាន់ស្រុក១។

ឧទ្ទាននៃវគ្គទាំង៩នោះដូច្នេះ

[៦៣៩]

លសុណវគ្គ១ អន្ធការវគ្គ១ នហានវគ្គ១ តុវដ្ដវគ្គ១ ចិត្តាគារវគ្គ១ អារាមវគ្គ១ គព្ភិនីវគ្គ១ កុមារីភូតវគ្គ១ ឆត្តុបាហនវគ្គ១។

## (បាដិទេសនីយកណ្ឌៈ ទី៥)

CS vin.pv.01.2.01.5 | ភាគ ទី១២

### (៥. បាដិទេសនីយកណ្ឌំ)

[៦៤០] ភិក្ខុនីសូមទឹកដោះរាវមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយាភិក្ខុនីសូមទឹកដោះរាវមកឆាន់។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។

[៦៤១] ភិក្ខុនីសូមប្រេងមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងរ៉ាវដែលពួកឆព្វគ្គិយាភិក្ខុនីសូមប្រេងមកឆាន់។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។

[៦៤២] ភិក្ខុនីសូមទឹកឃ្មុំមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនីសូមទឹកឃ្មុំមកឆាន់។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។

[៦៤៣] ភិក្ខុនីសូមទឹកអំពៅមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី បានសូមទឹកអំពៅមកឆាន់។ សិក្ខា បទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។

[៦៤៤] ភិក្ខុនីសូមត្រីមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្ដេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនីសូមត្រីមកឆាន់។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។

[៦៤៥] ភិក្ខុនីសូមសាច់មកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី សូមសាច់មកឆាន់។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។

[៦៤៦] ភិក្ខុនីសូមទឹកដោះស្រស់មកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី សូមទឹកដោះស្រស់ មកឆាន់។ សិក្ខាបទនោះ មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តា សមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤។

[៦៤៧] ភិក្ខុនី សូមទឹកដោះជូរមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី សូមទឹកដោះជូរមកឆាន់។ សិក្ខាបទនោះ មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចានិងចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើង អំពីកាយអំពីវាចានិងចិត្តក៏មាន។

ចប់ បាដិទេសនីយៈទាំង៨។

ឧទ្ទាន គឺបញ្ជីរឿងនៃបាដិទេសនីយៈនោះ ដូច្នេះ

[៦៤៨]

> រឿងភិក្ខុនីសូមទឹកដោះរាវ១ ប្រេង១ ទឹកឃ្មុំ១ ទឹកអំពៅ១ ត្រី១ សាច់១ ទឹកដោះស្រស់១ ទឹកដោះជូរ១ បាដិទេសនីយៈទាំង៨ ព្រះសយម្ភូទ្រង់បានសម្តែងហើយ យ៉ាងនោះ។ សិក្ខាបទទាំងឡាយណា ដែលយើងឱ្យពិស្តារហើយ ក្នុងភិក្ខុវិភង្គ សិក្ខាបទទាំងនោះ យើងសម្តែងដោយសង្ខេប ក្នុងភិក្ខុនីវិភង្គ។

ចប់ កត្ថប្បញ្ញត្តិវារៈជាម្បូង។

# កតាបត្តិវារៈ ទី២

CS vin.pv.01.2.02 | ភាគ ទី១២

### (២. កតាបត្តិវារោ)

## (បារាជិកកណ្ឌៈ ទី១)

CS vin.pv.01.2.02.1 | ភាគ ទី១២

### (១. បារាជិកកណ្ឌំ)

[៦៤៩] ភិក្ខុនីមានតម្រេកត្រេកអរនឹងកាយសំសគ្គៈ របស់បុរសបុគ្គល ដែលមានតម្រេកដែរ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុនីមានតម្រេកត្រេកអរនឹងកាយសំសគ្គៈ របស់បុរសបុគ្គល ដែលមានតម្រេកដែរ ត្រូវអាបត្តិ៣ គឺត្រេកអរនឹងការចាប់ពាល់សរីរប្រទេស ខាងក្រោមដងកាំបិត ចុះមកខាងលើមណ្ឌលនៃជង្គង់ឡើងទៅ ត្រូវអាបត្តិបារាជិក ត្រេកអរនឹងការចាប់ពាល់សរីរប្រទេស ខាងលើដងកាំបិតឡើងទៅ ខាងក្រោមមណ្ឌលនៃជង្គង់ចុះមក ត្រូវអាត្តិថុល្លច្ច័យ ត្រេកអរនឹងការចាប់ពាល់វត្ថុដែលជាប់ដោយកាយ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមានតម្រេកត្រេកអរនឹង កាយសំសគ្គៈ របស់បុរសបុគ្គល ដែលមានតម្រេកដែរ ត្រូវអាបត្តិ៣នេះឯង។

[៦៥០] ភិក្ខុនីជាអ្នកបិទបាំងទោស កាលបើបិទបាំងទោសគេ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុនី ជាអ្នកបិទបាំងទោស កាលបើបិទបាំងទោសគេ ត្រូវអាបត្តិ៣គឺ ភិក្ខុនី ដឹងហើយបិទបាំង នូវអាបត្តិបារាជិក (របស់គេ) ត្រូវអាបត្តិបារាជិក ភិក្ខុនីសង្ស័យហើយបិទបាំង ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុនីបិទបាំងនូវអាចារវិបត្តិ ត្រូវអាបត្តិទុក្កដ ភិក្ខុនីបិទបាំងទោស កាលបើបិទបាំងទោសគេ ត្រូវអាបត្តិ៣នោះឯង។

[៦៥១] ភិក្ខុនីប្រព្រឹត្តតាមភិក្ខុនីដែលសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុនីប្រព្រឹត្តតាមភិក្ខុនីដែលសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ៣គឺ ត្រូវអាបត្តិទុក្កដក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចា[22] ចប់ ត្រូវអាបត្តិបារាជិក ភិក្ខុនីប្រព្រឹត្តតាមភិក្ខុនី ដែលសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភាសនុកម្មជាគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ៣នេះឯង។

[៦៥២] ភិក្ខុនីបំពេញវត្ថុទី៨[23] ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុនីបំពេញវត្ថុទី៨ ត្រូវអាបត្តិ៣ គឺ ភិក្ខុនីដែលបុរសនិយាយថា លោកចូរទៅកាន់បន្ទប់ឈ្មោះនេះ ហើយទៅ ត្រូវអាបត្តិទុក្កដ គ្រាន់តែបុរសដើរចូលទៅដល់ហត្ថបាស ត្រូវអាបត្តិថុល្លច្ច័យ លុះធ្វើវត្ថុទី៨ ឱ្យពេញ (បន្ទន់កាយទៅ

ដើម្បីសេពអសទ្ធម្ម) ត្រូវអាបត្តិបារាជិក ភិក្ខុនីបំពេញវត្ថុទី៨ ត្រូវអាបត្តិ៣នេះឯង។

ចប់ បារាជិក។

## (សង្ឃាទិសេសកណ្ឌៈ ទី២)

CS vin.pv.01.2.02.2 | ភាគ ទី១២

### (២. សង្ឃាទិសេសកណ្ឌំ)

[៦៥៣] ភិក្ខុនីជាអ្នកទាស់ទែងដោយសេចក្តីច្រណែន កាលដែលធ្វើនូវដំណើរកើតក្តី ត្រូវអាបត្តិ៣គឺ ភិក្ខុនីប្រាប់ពាក្យជនម្ខាង (ដល់ចៅក្រម) ត្រូវអាបត្តិទុក្កដ ប្រាប់ពាក្យរបស់ជនជាគម្រប់ពីរ (ដល់ចៅក្រម) ត្រូវអាបត្តិថុល្លច្ច័យ លុះសម្រេចដំណើរក្តីហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៦៥៤] ភិក្ខុនីបំបួសចោរស្រី ត្រូវអាបត្តិ៣គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ ត្រូវអាបត្តិសង្ឃាទិសេស។

[៦៥៥] ភិក្ខុនីទៅកាន់ចន្លោះស្រុកតែម្នាក់ឯង ត្រូវអាបត្តិ៣គឺ កំពុងដើរទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានទីមួយចូលទៅក្នុងរបងស្រុក ត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានទីពីរចូលទៅក្នុងរបងស្រុក ត្រូវអាបត្តិសង្ឃាទិសេស។

[៦៥៦] ភិក្ខុនីមិនបានប្រាប់ការកសង្ឃ មិនបានដឹងឆន្ទៈរបស់គណៈ ហើយធ្វើឱសារណកម្ម ចំពោះភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ត្រូវអាបត្តិ៣គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៦៥៧] ភិក្ខុនីមានតម្រេក ហើយទទួលខាទនីយៈ ឬភោជនីយៈ ដោយដៃរបស់ខ្លួន អំពីដៃបុរសបុគ្គល ដែលមានតម្រេកដែរ មកឆាន់ ត្រូវអាបត្តិ៣គឺ ទទួលដោយគិតថា អញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិថុល្លច្ច័យ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វារៈដែលលេបចូលទៅ គ្រាន់តែទទួល និងឈើស្ទន់ ត្រូវអាបត្តិទុក្កដ។

[៦៥៨] ភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នាថា នែនាងជាម្ចាស់ បុរសបុគ្គលនេះ ទោះមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នែនាងជាម្ចាស់ ណ្ហើយចុះ កាលណាបើនាងមិនមានតម្រេកទេ បើបុរសបុគ្គលនោះ ឱ្យវត្ថុណា ទោះខាទនីយៈក្តី ភោជនីយៈក្តីដល់នាង ចូរនាងទទួលវត្ថុនោះ ដោយដៃរបស់ខ្លួន ហើយទំពាស៊ី ឬបរិភោគចុះ ដូច្នេះ ត្រូវអាបត្តិ៣ គឺទទួលដោយគិតថា អញនឹងទំពាស៊ី ឬបរិភោគ តាមពាក្យភិក្ខុនីដែលបញ្ជូននោះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិថុល្លច្ច័យ គ្រប់ៗវារៈដែលលេបចូលទៅ លុះសម្រេចការបរិភោគហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៦៥៩] ភិក្ខុនីក្រោធខឹង កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ៣ គឺត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៦៦០] ភិក្ខុនីដែលសង្ឃឱ្យចាញ់គេក្នុងអធិករណ៍ណានីមួយ ហើយក្រោធខឹង កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ៣គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៦៦១] ភិក្ខុនីទាំងឡាយ ដែលនៅច្រឡូកច្រឡំ កាលបើសង្ឃ សូត្រសមនុភាសនកម្មជាគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះ ចេញ ត្រូវអាបត្តិ៣ គឺត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៦៦២] ភិក្ខុនីបញ្ជូន(ភិក្ខុនីផងគ្នា)ថា នែនាងជាម្ចាស់ ចូរនាងទាំងឡាយ នៅច្រឡូកច្រឡំចុះ នាងទាំងឡាយ កុំនៅទីទៃពីគ្នាឡើយ កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ៣គឺ ត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈចប់កម្មវាចាពីរលើក លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិសង្ឃាទិសេស។

ចប់ សង្ឃាទិសេស។

## (និស្សគ្គិយកណ្ឌៈ ទី៣)

CS vin.pv.01.2.02.3 | ភាគ ទី១២

### (៣. និស្សគ្គិយកណ្ឌំ)

[៦៦៣] ភិក្ខុនី ធ្វើការសន្សំបាត្រទុក ត្រូវអាបត្តិ១ គឺនិស្សគ្គិយបាចិត្តិយៈ។

[៦៦៤] ភិក្ខុនី អធិដ្ឋានអកាលចីវរឱ្យជាកាលចីវរ ហើយឱ្យគេចែក ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេចែក ឱ្យគេចែករួចហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៦៥] ភិក្ខុនីបានប្តូរចីវរនឹងភិក្ខុនីផងគ្នា ហើយដណ្តើមយកវិញ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដណ្តើម លុះដណ្តើមបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៦៦] ភិក្ខុនី សូមវត្ថុដទៃហើយ ត្រឡប់ជាសូមវត្ថុឯទៀតវិញ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលសូម លុះសូមបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៦៧] ភិក្ខុនី ឱ្យគេទិញវត្ថុដទៃហើយ ត្រឡប់ជាឱ្យទិញវត្ថុឯទៀតវិញ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេទិញ លុះឱ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិបាចិត្តិយៈ។

[៦៦៨] ភិក្ខុនី ឱ្យគេទិញវត្ថុដទៃដោយបរិក្ខាររបស់សង្ឃ ដែល គេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេទិញ លុះឱ្យគេទិញ បានមកហើយ ត្រូអាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៦៩] ភិក្ខុនី ឱ្យគេទិញវត្ថុដទៃដោយបរិក្ខាររបស់សង្ឃ ដែល គេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត និងដោយ វត្ថុដែលសូមគេបានមកដោយខ្លួនឯង ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេទិញ លុះឱ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៧០] ភិក្ខុនី ឱ្យគេទិញវត្ថុដទៃដោយបរិក្ខាររបស់គណៈដែលគេ ប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេទិញ លុះឱ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៧១] ភិក្ខុនីឱ្យគេទិញវត្ថុដទៃ ដោយបរិក្ខាររបស់គណៈ ដែល គេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសចំពោះវត្ថុឯទៀត និងដោយវត្ថុដែលសូមគេបានមកដោយខ្លួនឯង ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេទិញ លុះឱ្យគេទិញបានកមហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៧២] ភិក្ខុនីឱ្យគេទិញវត្ថុដទៃ ដោយបរិក្ខាររបស់បុគ្គល ដែល គេប្រគេនមកបម្រុងវត្ថុឯទៀត ដែលគេឧទ្ទិសមកចំពោះវត្ថុឯទៀត និងដោយវត្ថុដែលសូមគេបានមកដោយខ្លួនឯង ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេទិញ លុះឱ្យគេទិញបានមកហើយ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៧៣] ភិក្ខុនី ឱ្យគេទិញសំពត់ដណ្តប់មានសាច់ក្រាស់ មានតម្លៃច្រើនជាង១៦ កហាបណៈឡើងទៅ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិ ទុក្កដ ក្នុងប្រយោគដែលឱ្យគេទិញ លុះឱ្យគេទិញបានមកហើយ ត្រូវ អាបត្តិនិស្សគ្គិយបាចិត្តិយៈ។

[៦៧៤] ភិក្ខុនី ឱ្យគេទិញសំពត់ដណ្តប់មានសាច់ស្តើង មានតម្លៃច្រើនជាង ១០ កហាបណៈឡើងទៅ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេទិញ លុះឱ្យគេទិញបានមកហើយ ត្រូវអាបត្តិ និស្សគ្គិយបាចិត្តិយៈ។

ចប់ និស្សគ្គិយបាចិត្តិយៈ។

## (បាចិត្តិយកណ្ឌៈ ទី៤)

CS vin.pv.01.2.02.4 | ភាគ ទី១២

### (៤. បាចិត្តិយកណ្ឌំ)

## លសុណវគ្គ ទី១

CS vin.pv.01.2.02.4.1 | ភាគ ទី១២

### (១. លសុណវគ្គោ)

[៦៧៥] ភិក្ខុនី ឆាន់ខ្ទឹម ត្រូវអាបត្តិ២ គឺ ទទួលដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗ វារៈដែលលេបចូលទៅ។

[៦៧៦] ភិក្ខុនី ឱ្យគេដករោមក្នុងទីចង្អៀត ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យគេដក លុះឱ្យគេដករួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៧៧] ភិក្ខុនី ធ្វើការប្រហារផ្ទៃនិមិត្ត ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ លុះធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៧៨] ភិក្ខុនី កាន់យករូបអង្គជាតដែលធ្វើដោយជ័រឈើ ឬកាក ល័ខជ័រលីង ត្រូវអាបត្តិ ២ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលកាន់យក លុះកាន់យករួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៧៩] ភិក្ខុនី កាន់យកការជម្រះនិមិត្ត ដោយទឹកជ្រៅហួសកំណត់២ថ្នាំងម្រាមដៃទៅ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលជម្រះ លុះកាន់យកវត្ថុជម្រះរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៨០] ភិក្ខុកំពុងឆាន់ ភិក្ខុនីទៅបម្រើដោយទឹកក្តី ដោយផ្លិតក្តី ត្រូវអាបត្តិ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅដាច់ពីហត្ថបាស ត្រូវអាបត្តិទុក្កដ។

[៦៨១] ភិក្ខុនី សូមស្រូវស្រស់មកឆាន់ ត្រូវអាបត្តិ២ គឺទទួលដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ គ្រប់ៗវារៈដែលលេបចូលទៅ។

[៦៨២] ភិក្ខុនីចោលឧច្ចារៈក្តី បស្សាវៈក្តី ទឹកមាត់ក្តី សម្រាមក្តី របស់សំណល់ក្តី ខាងក្រៅជញ្ជាំង ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលចោល លុះចោលរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៨៣] ភិក្ខុនី ចោលច្ចារៈក្តី បស្សាវៈក្តី ទឹកមាតក្តី សម្រាមក្តី របស់សល់ក្តី លើឈើ ឬ ស្មៅស្រស់ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលចោល លុះចោលរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៨៤] ភិក្ខុនី ទៅមើលរាំក្តី ស្តាប់ច្រៀងក្តី ភ្លេងប្រគំក្តី ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដើរទៅ លុះទៅឈរមើល ឬស្តាប់ត្រង់ទីណា ត្រូវអាបត្តិបាចិត្តិយៈ ត្រង់ទីនោះ។

ចប់ លសុណវគ្គ ទី១។

## រត្តន្ធការវគ្គ ទី ២

CS vin.pv.01.2.02.4.2 | ភាគ ទី១២

**(២. រត្តន្ធការវគ្គោ)**

[៦៨៥] ភិក្ខុនី ឋិតនៅតែម្នាក់ឯងជាមួយនឹងបុរសម្នាក់ ក្នុងវេលាយប់ងងឹត ឥតមានប្រទីប ត្រូវអាបត្តិ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅក្រៅពីហត្ថបាស ត្រូវអាបត្តិទុក្កដ។

[៦៨៦] ភិក្ខុនី ឋិតនៅតែម្នាក់ឯង ជាមួយនឹងបុរសម្នាក់ក្នុងទីឱកាសដ៏កំបាំង ត្រូវអាបត្តិ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅក្រៅពីហត្ថបាស ត្រូវអាបត្តិទុក្កដ។

[៦៨៧] ភិក្ខុនី ឋិតនៅតែម្នាក់ឯង ជាមួយនឹងបុរសម្នាក់ក្នុងទីវាល ត្រូវអាបត្តិ២ គឺឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅក្រៅពីហត្ថបាស ត្រូវអាបត្តិទុក្កដ។

[៦៨៨] ភិក្ខុនី ឋិតនៅតែម្នាក់ឯងជាមួយនឹងបុរសម្នាក់ ក្នុងច្រករហូតក្តី ច្រកទាល់ក្តី ផ្លូវបែកក្តី ត្រូវអាបត្តិ២គឺ ឋិតនៅក្នុងហត្ថបាស ត្រូវអាបត្តិបាចិត្តិយៈ ឋិតនៅក្រៅពីហត្ថបាស ត្រូវអាបត្តិទុក្កដ។

[៦៨៩] ភិក្ខុនី ចូលទៅកាន់ត្រកូល ក្នុងវេលាមុនភត្ត ហើយអង្គុយលើអាសនៈ មិនបានប្រាប់ម្ចាស់គេស្រាប់តែចៀសចេញទៅ ត្រូវអាបត្តិ២ គឺឈានជំហានទីមួយចូលទៅ ក្នុងទីដែលភ្លៀងធ្លាក់មិនត្រូវ ត្រូវអាបត្តិទុក្កដ ឈានជំហានទីមួយចូលទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៩០] ភិក្ខុនី ចូលទៅកាន់ត្រកូល ក្នុងវេលាក្រោយភត្ត មិនបានប្រាប់ម្ចាស់គេ ហើយស្រាប់តែអង្គុយលើអាសនៈ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលអង្គុយ លុះអង្គុយស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៩១] ភិក្ខុនី ចូលទៅកាន់ត្រកូលក្នុងវេលាវិកាល ហើយមិនបានប្រាប់ម្ចាស់គេ ស្រាប់តែក្រាលឯងក្តី ប្រើអ្នកដទៃឱ្យក្រាលក្តី នូវកម្រាលសម្រាប់ដេក ហើយអង្គុយសង្កត់លើ ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលអង្គុយ លុះអង្គុយស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៩២] ភិក្ខុនី ពោលទោសភិក្ខុនីឯទៀត ដោយការប្រកាន់ខុស ទាំងពិចារណាខុស ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដក្នុងប្រយោគ ដែលពោលទោស លុះពោលទោសរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៩៣] ភិក្ខុនីប្រទេចផ្តាសាខ្លួនឯង ឬឧបសម្បន្នដទៃ ដោយពាក្យថា នរកក្តី ដោយពាក្យថា ព្រហ្មចរិយៈក្តី ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលប្រទេច លុះប្រទេចរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៩៤] ភិក្ខុនី វាយខ្លួនឯងរឿយ ៗ ហើយយំ ត្រូវអាបត្តិ២ គឺវាយហើយយំផង ត្រូវអាបត្តិបាចិត្តិយៈ គ្រាន់តែវាយមិនយំ ត្រូវអាបត្តិទុក្កដ។

ចប់ រត្តន្ធការវគ្គ ទី២។

## នហានវគ្គ ទី៣

CS vin.pv.01.2.02.4.3 | ភាគ ទី១២

**(៣. នហានវគ្គោ)**

[៦៩៥] ភិក្ខុនីមានកាយអាក្រាតងូតទឹក ត្រូវអាបត្តិ២ គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលងូតទឹក លុះងូតស្រេចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៩៦] ភិក្ខុនី ឱ្យគេធ្វើសំពត់ងូតទឹកកន្លងហួសខ្នាត ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យធ្វើ លុះឱ្យធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៦៩៧] ភិក្ខុនីរុះខ្លួនឯង ឬប្រើគេឱ្យរុះនូវចីវររបស់ភិក្ខុនីផងគ្នា ហើយមិនដេរវិញ ទាំងមិនធ្វើសេចក្ដីខ្វល់ខ្វាយឱ្យគេដេរឱ្យវិញ ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៦៩៨] ភិក្ខុនីញ៉ាំងវារៈនៃសង្ឃាដី (ប្រើផ្លាស់ប្ដូរឧត្តរាសង្គៈ) ឱ្យកន្លងហួស៥ថ្ងៃទៅ ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៦៩៩] ភិក្ខុនីប្រើប្រាស់សង្កមនីយចីវរ ត្រូវអាបត្តិ២គឺ ត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលគេប្រើប្រាស់ លុះប្រើប្រាស់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧០០] ភិក្ខុនីធ្វើចីវរលាភរបស់គណៈឱ្យខូចទៅ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ លុះធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧០១] ភិក្ខុនីឃាត់នូវការចែកចីវរដែលប្រកបដោយធម៌ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឃាត់ លុះឃាត់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧០២] ភិក្ខុនីឱ្យចីវររបស់សមណៈដល់គ្រហស្ថក្ដី ដល់បរិព្វាជកក្ដី ដល់បរិព្វាជិកាក្ដី ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែល ឱ្យ លុះឱ្យរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧០៣] ភិក្ខុនី ញ៉ាំងសម័យនៃចីវរកាលឱ្យកន្លងហួសទៅដោយ ចង់បានចីវរដ៏ទុព្វល ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឱ្យកន្លង លុះឱ្យកន្លងហួសទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧០៤] ភិក្ខុនីឃាត់នូវការដកកឋិនដែលប្រកបដោយធម៌ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលឃាត់ លុះឃាត់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

ចប់ នហានវគ្គ ទី៣។

## តុវដ្តវគ្គ ទី៤

CS vin.pv.01.2.02.4.4 | ភាគ ទី១២

### (៤. តុវដ្ដវគ្គោ)

[៧០៥] ភិក្ខុនីពីររូប ដេកលើគ្រែតែមួយជាមួយគ្នា ត្រូវអាបត្តិ ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដេក លុះដេកស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧០៦] ភិក្ខុនីពីររូប មានកម្រាលនិងសំពត់ដណ្ដប់តែមួយ ដេកជាមួយគ្នា ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលរៀបនឹងដេក លុះដេកស៊ប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧០៧] ភិក្ខុនីក្លែងធ្វើសេចក្ដីអផ្សុកដល់ភិក្ខុនីផងគ្នា ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលធ្វើ លុះធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧០៨] ភិក្ខុនីមិនបម្រើ ទាំងមិនធ្វើសេចក្ដីខ្វល់ខ្វាយឱ្យគេបម្រុងនឹងបម្រើ នូវកូនសិស្សដែលមានជំងឺ ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៧០៩] ភិក្ខុនីឱ្យលំនៅដល់ភិក្ខុនីផងគ្នា ហើយស្រាប់តែក្រោធ អាក់អន់ចិត្ត បណ្ដេញភិក្ខុនីនោះចេញ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលបណ្ដេញ លុះបណ្ដេញចេញហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧១០] ភិក្ខុនី នៅច្រឡូកច្រឡំ កាលបើសង្ឃសូត្រសមនុភាសនកម្មគម្រប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ លុះសូត្រកម្មវាចាចប់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧១១] ភិក្ខុនីមិនមានពួកឈ្មួញជាគ្នា ទៅកាន់ចារិកខាងក្នុងដែន ដែលគេសន្មតថាប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដើរ លុះដើរហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧១២] ភិក្ខុនីមិនមានពួកឈ្មួញជាគ្នា ដើរទៅកាន់ទីចារិកខាងក្រៅដែន ដែលគេសន្មតថាប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដើរ លុះ ដើរទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧១៣] ភិក្ខុនី ដើរទៅកាន់ចារិកខាងក្នុងវស្សា ត្រូវអាបត្តិ២ គឺត្រូវអាបត្តិទុក្កដ ក្នុងប្រយោគដែលដើរ លុះដើរទៅហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧១៤] ភិក្ខុនី នៅចាំវស្សារួចហើយ មិនចៀសចេញទៅកាន់ចារិក ត្រូវអាបត្តិ ១ គឺបាចិត្តិយៈ។

ចប់ តុវដ្ដវគ្គ ទី ៤។

## ចិត្តាគារវគ្គ ទី៥

CS vin.pv.01.2.02.4.5 | ភាគ ទី១២

### (៥. ចិត្តាគារវគ្គោ)

[៧១៥] ភិក្ខុនីដើរទៅដើម្បីមើលដំណាក់សម្រាប់ក្រសាលរបស់ព្រះរាជាក្ដី រោងដ៏វិចិត្រក្ដី សួនក្ដី ឧទ្យានក្ដី ស្រះបោក្ខរណីក្ដី ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងដើរទៅ ត្រូវអាបត្តិទុក្កដ ឈរមើលក្នុងទីណា ត្រូវអាបត្តិបាចិត្តិយៈក្នុងទីនោះ។

[៧១៦] ភិក្ខុនីប្រើប្រាស់គ្រែអាសន្ទិក្ដី បល្ល័ង្កក្ដី ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងប្រើប្រាស់ ត្រូវអាបត្តិទុក្កដ លុះប្រើប្រាស់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧១៧] ភិក្ខុនីការអំបោះ ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងការ ត្រូវអាបត្តិទុក្កដ ក្នុងវារៈដែលបង្វិល១ជុំៗ ត្រូវអាបត្តិបាចិត្តិយៈ។

[៧១៨] ភិក្ខុនីធ្វើការខ្វល់ខ្វាយបម្រើគ្រហស្ថ ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងធ្វើ ត្រូវអាបត្តិទុក្កដ លុះធ្វើរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧១៩] ភិក្ខុនីកាលបើភិក្ខុនីផងគ្នានិយាយថា នែនាងជាម្ចាស់ នាងចូរមករម្ងាប់អធិករណ៍នេះ ដូច្នេះ បានទទួលពាក្យថា សាធុហើយ បែរជាមិនរម្ងាប់ ទាំងមិនធ្វើសេចក្ដីខ្វល់ខ្វាយដើម្បីឱ្យរម្ងាប់វិញ ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៧២០] ភិក្ខុនីឱ្យខាទនីយៈ ឬភោជនីយាហារ ដល់គ្រហស្ថក្ដី បរិព្វាជកក្ដី បរិព្វាជិកាក្ដី ដោយដៃខ្លួនឯង ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងឱ្យ ត្រូវអាបត្តិទុក្កដ លុះឱ្យរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧២១] ភិក្ខុនីមិនប្រគល់អាវសថចីវរ ហើយប្រើប្រាស់ ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងប្រើប្រាស់ ត្រូវអាបត្តិទុក្កដ លុះប្រើប្រាស់រួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧២២] ភិក្ខុនីមិនទាន់ប្រគល់ផ្ទះសម្នាក់ ហើយចៀសចេញទៅកាន់ចារិក ត្រូវអាបត្តិ២ គឺឈានជំហានជាបឋម កន្លងរបង់ផ្ទះសម្នាក់ទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានជាគម្រប់ពីរកន្លងទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៧២៣] ភិក្ខុនីរៀនតិរច្ឆានវិជ្ជា ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងរៀន ត្រូវអាបត្តិទុក្កដ (លុះបានរៀនហើយ) ត្រូវអាបត្តិបាចិត្តិយៈរាល់ៗបទ។

[៧២៤] ភិក្ខុនីបង្រៀនតិរច្ឆានវិជ្ជា ត្រូវអាបត្តិ២ គឺក្នុងប្រយោគ ដែលកំពុងបង្រៀន ត្រូវអាបត្តិទុក្កដ (លុះបង្រៀនហើយ) ត្រូវអាបត្តិបាចិត្តិយៈរាល់ៗបទ។

ចប់ ចិត្តាគារវគ្គ ជាគម្រប់៥។

## អារាមវគ្គ ទី៦

CS vin.pv.01.2.02.4.6 | ភាគ ទី១២

### (៦. អារាមវគ្គោ)

[៧២៥] ភិក្ខុនីកាលដឹងហើយចូលទៅកាន់អារាមដែលមានភិក្ខុ ដោយមិនបានប្រាប់(ជាមុន) ត្រូវអាបត្តិ២ គឺឈានជំហានជាបឋម កន្លងរបងអារាមទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានជាគម្រប់ពីរកន្លងទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៧២៦] ភិក្ខុនីជេរប្រទេចភិក្ខុ ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងជេរ ត្រូវអាបត្តិទុក្កដ លុះជេររួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧២៧] ភិក្ខុនីប្រទេចផ្ដាសាគណភិក្ខុនីដោយកំណាច ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងផ្ដាសា ត្រូវអាបត្តិទុក្កដ លុះផ្ដាសារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧២៨] ភិក្ខុនីដែលគេនិមន្តហើយក្ដី ហាមភោជនហើយក្ដី បែរ ជាទៅឆាន់ខាទនីយភោជនីយាហារ (ក្នុងទីដទៃ) ត្រូវអាបត្តិ២ គឺកំពុងទទួលដោយគិតថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ដូច្នេះ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈគ្រប់ៗ វារៈដែលលេបចូលទៅ។

[៧២៩] ភិក្ខុនីកំណាញ់ត្រកូល ត្រូវអាបត្តិ២ គឺកំពុងប្រព្រឹត្តកំណាញ់ ត្រូវអាបត្តិទុក្កដ លុះប្រព្រឹត្តកំណាញ់ហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៣០] ភិក្ខុនីនៅចាំវស្សា ក្នុងអាវាសមិនមានភិក្ខុ ត្រូវអាបត្តិ២ គឺកំពុងក្រាលសេនាសនៈដោយបំណងថា អាត្មាអញនឹងនៅចាំវស្សាដូច្នេះ ហើយក៏តម្កល់ទឹកឆាន់ទឹកប្រើប្រាស់ បោសបរិវេណ ត្រូវអាបត្តិទុក្កដ ត្រូវអាបត្តិបាចិត្តិយៈ ព្រមគ្នានឹងអរុណរះឡើង។

[៧៣១] ភិក្ខុនីនៅចាំវស្សារួចហើយ មិនបានបវារណានឹងឧភតោសង្ឃ ដោយស្ថាន៣ យ៉ាង ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៧៣២] ភិក្ខុនីមិនទៅដើម្បីទទួលឱវាទក្តី ដើម្បីនៅរួបរួមគ្នាក្តី ត្រូវអាបត្តិ១ គឺអាបត្តិបាចិត្តិយៈ។

[៧៣៣] ភិក្ខុនីមិនសួរឧបោសថផង មិនសូមឱវាទផង ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៧៣៤] ភិក្ខុនីមិនបានប្រាប់សង្ឃ ឬគណៈ(ហើយនៅ)តែម្នាក់ និងម្នាក់ជាមួយនឹងបុរស ឱ្យគេទម្លាយពកក្តី របួសក្តី ដែលកើតត្រង់កាយខាងក្រោម[24] ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យគេទម្លាយ ត្រូវអាបត្តិទុក្កដ លុះទម្លាយរួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

ចប់ អារាមវគ្គ ជាគម្រប់ ៦។

## គព្ភិនីវគ្គ ទី៧

CS vin.pv.01.2.02.4.7 | ភាគ ទី១២

### (៧. គព្ភិនីវគ្គោ)

[៧៣៥] ភិក្ខុនីឱ្យឧបសម្បទាដល់ស្ត្រីមានគភ៌ ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៣៦] ភិក្ខុនីឱ្យឧបសម្បទាដល់ស្ត្រីមេដោះ ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៣៧] ភិក្ខុនីឱ្យឧបសម្បទា ដល់សិក្ខមានាដែលមិនបានសិក្សាសិក្ខាក្នុងធម៌ ៦ ប្រការអស់២វស្សា ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៣៨] ភិក្ខុនីឱ្យឧបសម្បទាដល់សិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌៦ប្រការអស់២ វស្សា ដែលសង្ឃមិនបានសន្មតឱ្យ ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៣៩] ភិក្ខុនីឱ្យឧបសម្បទាដល់ស្ត្រីគ្រហស្ថមានវស្សាមិនគ្រប់១២ឆ្នាំ ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៤០] ភិក្ខុនីឱ្យឧបសម្បទាដល់ស្ត្រីគ្រហស្ថមានវស្សាគ្រប់១២ឆ្នាំ ដែលមិនទាន់បានសិក្សាសិក្ខាក្នុងធម៌៦ប្រការអស់២វស្សា ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តីយៈ។

[៧៤១] ភិក្ខុនីឱ្យឧបសម្បទាដល់ស្ត្រីគ្រហស្ថមានវស្សាគ្រប់១២ឆ្នាំ ហើយបានសិក្សាសិក្ខាក្នុងធម៌៦ប្រការអស់២វស្សាហើយ តែសង្ឃមិនទាន់បានសន្មតឱ្យ ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបស្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៤២] ភិក្ខុនី ឱ្យឧបស្បទាដល់សិក្ខមានាជាសហជីវិនី (កូនសិស្ស) ហើយមិនបង្រៀនដោយខ្លួនឯង ឬមិនឱ្យគេបង្រៀនអស់២វស្សា ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៧៤៣] ភិក្ខុនីមិនតាមបម្រើភិក្ខុនីជាបវត្តិនីដែលបំបួស (ខ្លួន) អស់២វស្សា ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៧៤៤] ភិក្ខុនីឱ្យឧបសម្បទាដល់សិក្ខមានាជាសហជីវិនីហើយ មិននាំយកទៅខ្លួនឯង ឬមិនឱ្យគេនាំយកទៅ ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

ចប់ គព្ភិនីវគ្គ ជាគម្រប់៧។

## កុមារីភូតវគ្គ ទី៨

CS vin.pv.01.2.02.4.8 | ភាគ ទី១២

### (៨. កុមារីភូតវគ្គោ)

[៧៤៥] ភិក្ខុនីឱ្យឧបសម្បទាដល់កុមារី មានវស្សាមិនគ្រប់២០ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៤៦] ភិក្ខុនីឱ្យឧបសម្បទាដល់កុមារីមានឆ្នាំពេញ២០ហើយ តែមិនបានសិក្សាសិក្ខាក្នុងធម៌៦ប្រការ អស់២វស្សា ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៤៧] ភិក្ខុនីឱ្យឧបសម្បទា ដល់កុមារីមានឆ្នាំពេញ២០ហើយ បានសិក្សាសិក្ខាក្នុងធម៌៦ ប្រការអស់២ឆ្នាំ ដែលសង្ឃមិនបានសន្មតឱ្យ ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៤៨] ភិក្ខុនីមានវស្សាមិនទាន់គ្រប់១២ ហើយឱ្យឧបសម្បទា (គេ) ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៤៩] ភិក្ខុនីមានវស្សាគ្រប់១២ហើយ តែសង្ឃមិនទាន់បានសន្មតឱ្យ ហើយឱ្យឧបសម្បទា (គេ) ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៥០] ភិក្ខុនីកាលដែលសង្ឃនិយាយថា នែលោកម្ចាស់ លោក មិនគួរឱ្យឧបសម្បទានៅឡើយទេ ដូច្នេះ ក៏ទទួលថា សាធុ ហើយគ្រាក្រោយត្រឡប់តិះដៀលវិញ ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងតិះដៀល ត្រូវអាបត្តិទុក្កដ លុះតិះដៀលហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៥១] ភិក្ខុនីនិយាយនឹងសិក្ខមានាថា នែនាង បើនាងឱ្យចីវរដល់យើង យើងនឹងឱ្យនាងបានឧបសម្បទា (ដល់មកខាងក្រោយ) ក៏មិនឱ្យ (សិក្ខមានានោះ) បានឧបសម្បទា ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីឱ្យបានឧបសម្បទា ត្រូវអាបត្តិ១គឺបាចិត្តិយៈ។

[៧៥២] ភិក្ខុនីនិយាយនឹងសិក្ខមានាថា នែនាង បើនាងតាមបម្រើយើងអស់២ឆ្នាំ យើងនឹងឱ្យនាងបានឧបសម្បទា (ដល់មកខាងក្រោយ) ក៏មិនឱ្យឧបសម្បទា ទាំងមិនធ្វើសេចក្តីខ្វល់ខ្វាយ ដើម្បីឱ្យបានឧបសម្បទា ត្រូវអាបត្តិ១ គឺបាចិត្តិយៈ។

[៧៥៣] ភិក្ខុនីឱ្យឧបសម្បទាដល់សិក្ខមានាដែលនៅច្រឡូកច្រឡំដោយបុរស ដែលនៅច្រឡូកច្រឡំដោយក្មេងប្រុស ជាស្ត្រីកាច បណ្តាលឱ្យកើតសេចក្តីសោក ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិ បាចិត្តិយៈ។

[៧៥៤] ភិក្ខុនីឱ្យឧបសម្បទាដល់សិក្ខមានា ដែលមាតាបិតាក្តី ស្វាមីក្តី មិនទាន់បានអនុញ្ញាតឱ្យ ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៥៥] ភិក្ខុនីឱ្យឧបសម្បទាដល់សិក្ខមានា ដោយឱ្យឆន្ទៈឈ្មោះ បារិវាសិកៈ ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៥៦] ភិក្ខុនីឱ្យឧបសម្បទារាល់ឆ្នាំ ត្រូវអាបត្តិ២គឺ ក្នុង ប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៥៧] ភិក្ខុនីឱ្យឧបសម្បទាដល់ស្ត្រីពីររូបក្នុង១ឆ្នាំ ត្រូវអាបត្តិ២ គឺ ក្នុងប្រយោគដែលកំពុងឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ លុះឱ្យឧបសម្បទារួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

ចប់ កុមារីភូតវគ្គ ជាគម្រប់៨។

## ឆត្តុបាហវគ្គ ទី៩

CS vin.pv.01.2.02.4.9 | ភាគ ទី១២

### (៩. ឆត្តុបាហនវគ្គោ)

[៧៥៨] ភិក្ខុនី(មិនឈឺ) បាំងឆត្រ ពាក់ស្បែកជើង ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងបាំង កំពុងពាក់ ត្រូវអាបត្តិទុក្កដ លុះបាំង ពាក់ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៥៩] ភិក្ខុនី(មិនឈឺ) ទៅដោយយាន ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលរៀបនឹងទៅ ត្រូវអាបត្តិទុក្កដ លុះទៅ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦០] ភិក្ខុនីក្រវាត់ខ្សែក្រវាត់ ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងក្រវាត់ ត្រូវអាបត្តិទុក្កដ លុះក្រវាត់រួច ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦១] ភិក្ខុនីទ្រទ្រង់គ្រឿងអលង្ការរបស់ស្ត្រី[25] ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងទ្រទ្រង់ ត្រូវអាបត្តិទុក្កដ លុះទ្រទ្រង់រួច ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦២] ភិក្ខុនីងូតទឹកដោយគ្រឿងក្រអូប និងគ្រឿងលាប ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងងូត ត្រូវអាបត្តិទុក្កដ លុះងូត ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦៣] ភិក្ខុនីងូតទឹកដោយគ្រឿងអប់ និងគ្រឿងលម្អិត ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងងូត ត្រូវអាបត្តិទុក្កដ លុះងូតស្រេចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦៤] ភិក្ខុនីឱ្យភិក្ខុនីផងគ្នាគក់ រឹត ច្របាច់ ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលរៀបនឹងគក់ រឹត ត្រូវអាបត្តិទុក្កដ លុះបានគក់ រឹត ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦៥] ភិក្ខុនីឱ្យសិក្ខមានាគក់ រឹត ច្របាច់ ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលរៀបនឹងគក់ រឹត ត្រូវអាបត្តិទុក្កដ លុះបានគក់ រឹត ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦៦] ភិក្ខុនីឱ្យសាមណេរីគក់ រឹត ច្របាច់ ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលរៀបនឹងគក់ រឹត ត្រូវអាបត្តិទុក្កដ លុះបានគក់ រឹត ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុនីឱ្យស្ត្រីជាគ្រហស្ថគក់ រឹត ច្របាច់ ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលរៀបនឹងគក់ រឹត ត្រូវអាបត្តិទុក្កដ លុះបានគក់ រឹត ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុនី មិនប្រាប់ហើយអង្គុយលើអាសនៈខាងមុខភិក្ខុ ត្រូវអាបត្តិ២ គឺក្នុងប្រយោគដែលរៀបអង្គុយ ត្រូវអាបត្តិទុក្កដ លុះអង្គុយស័ប់ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦៧] ភិក្ខុនី សួរប្រស្នានឹងភិក្ខុដែលខ្លួនមិនបានសូមឱកាស ត្រូវអាបត្តិ២គឺ ក្នុងប្រយោគដែលកំពុងសួរ ត្រូវអាបត្តិទុក្កដ លុះសួររួចហើយ ត្រូវអាបត្តិបាចិត្តិយៈ។

[៧៦៨] ភិក្ខុនីគ្មានសំពត់ចោមពុង ចូលទៅកាន់ស្រុក ត្រូវអាបត្តិ២គឺ ឈានជំហានជាបឋមកន្លងរបងស្រុកទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានជាគម្រប់ពីរកន្លងទៅ ត្រូវអាបត្តិបាចិត្តិយៈ។

ចប់ ឆត្តុបាហវគ្គ ជាគម្រប់៩។

ចប់ ខុទ្ទកវគ្គ ទាំង៩។

## (បាដិទេសនីយកណ្ឌៈ ទី៥)

CS vin.pv.01.2.02.5 | ភាគ ទី១២

### (៥. បាដិទេសនីយកណ្ឌំ)

[៧៦៩] ភិក្ខុនី (មិនឈឺ) សូមទឹកដោះរាវយកមកឆាន់ ត្រូវអាបត្តិ២គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗវារៈដែលលេបចូលទៅ។

[៧៧០] ភិក្ខុនី (មិនឈឺ) សូមប្រេងគេយកមកឆាន់ ត្រូវអាបត្តិ២គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗវារៈដែលលេបចូលទៅ។

[៧៧១] ភិក្ខុនី (មិនឈឺ) សូមទឹកឃ្មុំគេយកមកឆាន់ ត្រូវអាបត្តិ២គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗវារៈ ដែលលេបចូលទៅ។

[៧៧២] ភិក្ខុនី(មិនឈឺ) សូមស្ករអំពៅគេយកមកឆាន់ ត្រូវអាបត្តិ២គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗវារៈដែលលេបចូលទៅ។

[៧៧៣] ភិក្ខុនី (មិនឈឺ) សូមត្រីគេយកមកឆាន់ ត្រូវអាត្តិ២គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗ វារៈដែលលេបចូលទៅ។

[៧៧៤] ភិក្ខុនី (មិនឈឺ) សូមសាច់អំពីគេយកមកឆាន់ ត្រូវអាបត្តិ២គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗវារៈដែលលេបចូលទៅ។

[៧៧៥] ភិក្ខុនី (មិនឈឺ) សូមទឹកដោះស្រស់អំពីគេយកមកឆាន់ ត្រូវអាបត្តិ២គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួហើយឆាន់) ត្រូវអាបត្តិបាដិទេសនិយៈ គ្រប់ៗវារៈដែលលេបចូលទៅ។

[៧៧៦] ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរអំពីគេយកមកឆាន់ ត្រូវអាបត្តិ២គឺ កំពុងទទួលប្រគេន ដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗ វារៈដែលលេបចូលទៅ។

ចប់ បាដិទេសនីយៈ ទី៨។

ចប់ កតាបត្តិវារៈ ជាគម្រប់២។

# វិបត្តិវារៈ ទី៣

CS vin.pv.01.2.03 | ភាគ ទី១២

### (៣. វិបត្តិវារោ)

[៧៧៧] ពួកអាបត្តិរបស់ភិក្ខុនី ដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្ដាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយ របស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ បណ្ដាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។

[៧៧៨] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរអំពីគេ យកមកឆាន់ បណ្ដាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរអំពីគេយកមកឆាន់ បណ្ដាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិ១ គឺអាចារវិបត្តិ។

ចប់ វិបត្តិវារៈ ជាគម្រប់៣។

# សង្គហវារៈ ទី៤

CS vin.pv.01.2.04 | ភាគ ទី១២

### (៤. សង្គហវារោ)

[៧៧៩] ពួកអាបត្តិរបស់ភិក្ខុនី ដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្ដាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរ នឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្ដាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិ៣គឺកង នៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិទុក្កដក៏មាន។បេ។

[៧៨០] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរអំពីគេយកមកឆាន់ បណ្ដាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ ពួកអាបត្តិរបស់ភិក្ខុនី ដែលសូមទឹកដោះជូរអំពីគេយកមឆាន់ បណ្ដាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។

ចប់ សង្គហវារៈ ជាគម្រប់៤។

# សមុដ្ឋានវារៈ ទី៥

CS vin.pv.01.2.05 | ភាគ ទី១២

### (៥. សមុដ្ឋានវារោ)

[៧៨១] ពួកអាបត្តិរបស់ភិក្ខុនី ដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ ពួកអាបត្តិរបស់ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។បេ។

[៧៨២] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងអំពីសមុដ្ឋាន៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ និងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ និងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយ វាចា និងចិត្តក៏មាន។

ចប់ សមុដ្ឋានវារៈ ជាគម្រប់៥។

# អធិករណវារៈ ទី៦

CS vin.pv.01.2.06 | ភាគ ទី១២

### (៦. អធិករណវារោ)

[៧៨៣] ពួកអាបត្តិរបស់ភិក្ខុនី ដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈដែរ បណ្ដាអធិករណ៍ទាំង៤ ចាត់ជាអធិករណ៍ណា។ ពួកអាបត្តិរបស់ភិក្ខុនី ដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈដែរ បណ្ដាអធិករណ៍ទាំង៤ ចាត់ជាអាបត្តាធិករណ៍។បេ។

[៧៨៤] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្ដាអធិករណ៍ទាំង៤ ចាត់ជាអធិករណ៍ណា។ ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្ដាអធិករណ៍ទាំង៤ ចាត់ជាអាបត្តាអធិករណ៍។

ចប់ អធិករណវារៈ ជាគម្រប់៦។

# សមថវារៈ ទី៧

CS vin.pv.01.2.07 | ភាគ ទី១២

**(៧. សមថវារោ)**

[៧៨៥] ពួកអាបត្តិរបស់ភិក្ខុនី ដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈដែរ បណ្តាសមថៈទាំង៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ ពួកអាបត្តិរបស់ភិក្ខុនី ដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយ របស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈដែរ បណ្តាសមថៈទាំង៧ តែងរម្ងាប់ដោយសមថៈ៣គឺ ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ ក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។បេ។

[៧៨៦] ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ ពួកអាបត្តិរបស់ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ បណ្តាសមថៈទាំង៧តែង រម្ងាប់ដោសមថៈ៣ គឺ ដោយសម្មុខាវិន័យ និងបដិញ្ញាតរករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

ចប់ សមថវារៈ ជាគម្រប់៧។

# សមុច្ចយវារៈ ទី៨

CS vin.pv.01.2.08 | ភាគ ទី១២

**(៨. សមុច្ចយវារោ)**

[៧៨៧] ភិក្ខុនីមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់ កាយរបស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុនីដែលមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ ត្រូវអាបត្តិ៣ គឺត្រេកអរ នឹងការចាប់ពាល់នូវ(សរីរប្រទេស) ពីខាងក្រោមដងកាំបិត ចុះមកដល់ខាងលើមណ្ឌលជង្គង់ ត្រូវអាបត្តិបារាជិក ត្រេកអរនឹងការចាប់ពាល់នូវ (សរីរប្រទេស) ពីខាងលើដងកាំបិត និងខាងក្រោមនៃមណ្ឌលជង្គង់ ត្រូវអាបត្តិថុល្លច្ច័យ ត្រេកអរនឹងការចាប់ពាល់នូវវត្ថុជាប់នឹងកាយ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គលដែលមានចិត្តជោកដោយរាគៈ ត្រូវអាបត្តិទាំង៣ នេះ។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះរាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍៤ ចាត់ជាអធិករណ៍ណា។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៣ គឺ កងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន១គឺ តាំងឡើងអំពីកាយ និងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។ បណ្តាអធិរកណ៍៤ ចាត់ជាអាបត្តាអធិករណ៍។ បណ្តាសមថៈទាំង៧ តែងរម្ងាប់ដោយសមថៈ៣ គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។បេ។

[៧៨៨] ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ត្រូវអាបត្តិប៉ុន្មាន។ ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ត្រូវអាបត្តិ២ គឺកំពុងទទួលប្រគេនដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលឆាន់ហើយ) ត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗ វារៈដែលលេបចូលទៅ ភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ត្រូវអាបត្តិទាំង២នេះ។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនោះរាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយ សមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍ទាំង៤ ចាត់ជាអធិករណ៍ណា។ បណ្តាសមថៈទាំង៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ១ គឺអាចារវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំឡើងអំពីកាយ និងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ និងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយ វាចា និងចិត្តក៏មាន។ បណ្តាអធិករណ៍ទាំង៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈទាំង៧ តែរម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុខាវិន័យ និងបដិញ្ញាតកណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

ចប់ សមុច្ចយវារៈ ជាគម្រប់៨។

# កត្ថបញ្ញត្តិវារៈ ទី១

CS vin.pv.01.2.09 | ភាគ ទី១២

**(១.(៩) កត្ថបញ្ញត្តិវារោ)**

## បារាជិក

CS vin.pv.01.2.09.1 | ភាគ ទី១២

### (១. បារាជិកកណ្ឌំ)

[៧៨៩] បារាជិកណា ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ (នូវកាលគួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍) ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ (របស់បុរសបុគ្គល) បារាជិកនោះ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធ នឹងសុន្ទរីនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលសុន្ទរីនន្ទាភិក្ខុនី មានចិត្តជោកដោយរាគៈ ត្រេកអរនឹងការប៉ះពាល់កាយរបស់បុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈដែរ។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិដែរឬ។ មានតែបញ្ញត្តិ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិមិនមានក្នុងសិក្ខាបទនោះទេ។ (សិក្ខាបទនោះ) ជាសព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ ជាសព្វត្ថប្បញ្ញត្តិ។ ជាសាធារណប្បញ្ញត្តិ ឬជាអសាធាណប្បញ្ញត្តិ។ ជាអសាធារណប្បញ្ញត្តិ។ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ ជាឯកតោបញ្ញត្តិ។ បណ្តាបាតិមោក្ខុទ្ទេសទាំង៤ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ ចាត់ចូលក្នុងនិទានុទ្ទេស រាប់បញ្ចូលក្នុងនិទានុទ្ទេស។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទីប៉ុន្មាន។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី២។ បណ្តាវិបត្តិ៤ ជាវិបត្តិអ្វី។ ជាសីលវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង ៧ ជាកងនៃអាបត្តិអ្វី។ ជាកងនៃអាបត្តិបារាជិក។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាឡើយ។បេ។ លោកណាបាននាំមក។ ព្រះថេរៈទាំងឡាយនាំតៗ គ្នាមក។បេ។

[៧៩០] អាបត្តិបារាជិក ព្រោះបច្ច័យនៃការបិទបាំងទោស ព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងរ៉ាវដូចម្តេច។ ព្រោះរឿងថុល្លនន្ទាភិក្ខុនីដឹងថាភិក្ខុនីផងគ្នា ត្រូវអាបត្តិបារាជិកហើយ មិនចោទដោយខ្លួនឯង ទាំងមិនបានប្រាប់ដល់គណៈភិក្ខុនី។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៧៩១] អាបត្តិបារាជិក ព្រោះបច្ច័យនៃការមិនលះបង់ (នូវទិដ្ឋិ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់បីដង ព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីប្រព្រឹត្តតាមអរិដ្ឋភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្មាត ដែលសង្ឃបានព្រមព្រៀងគ្នាលើកវត្ត។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៧៩២] អាបត្តិបារាជិក ព្រោះបច្ច័យនៃការបំពេញវត្ថុជាគម្រប់៨[26)] ព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះ រឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនីបំពេញវត្ថុជាគម្រប់៨។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិនោះ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

ចប់ បារាជិក។

## សង្ឃាទិសេស

CS vin.pv.01.2.09.2 | ភាគ ទី១២

### (២. សង្ឃាទិសេសកណ្ឌាទិ)

[៧៩៣] សង្ឃាទិសេសណា ដែលព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ (នូវកាលដ៏គួរនឹងបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍) ព្រោះបច្ច័យនៃកិរិយាធ្វើដំណើរក្តី របស់ភិក្ខុនីជាអ្នកប្តឹងផ្តល់ សង្ឃាទិសេសនោះ ព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿង ដែលថុល្លនន្ទាភិក្ខុនីជាអ្នកប្តឹងផ្តល់។ ក្នុងសិក្ខាបទនោះ មានបញ្ញត្តិ អនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិដែរឬ។ មានតែបញ្ញត្តិ១ ឯអនុប្បញ្ញត្តិ និងអនុប្បន្នប្បញ្ញត្តិមិនមានក្នុងសិក្ខាបទនោះឡើយ។ (សិក្ខាបទនោះ) ជា សព្វត្ថប្បញ្ញត្តិ ឬជាបទេសប្បញ្ញត្តិ។ ជាសព្វត្ថប្បញ្ញត្តិ។ ជាសាធារណប្បញ្ញត្តិ ឬជាអសាធារណប្បញ្ញត្តិ។ ជាអសាធារណប្បញ្ញត្តិ។ ជាឯកតោបញ្ញត្តិ ឬជាឧភតោបញ្ញត្តិ។ ជាឯកតោបញ្ញត្តិ។ បណ្តាបាតិមោក្ខុទ្ទេសទាំង៤ ចាត់ចូលក្នុងឧទ្ទេសណា រាប់បញ្ចូលក្នុងឧទ្ទេសណា។ ចាត់ចូលក្នុងនិទានុទ្ទេស រាប់បញ្ចូលក្នុងនិទានុទ្ទេស។ មកកាន់ឧទ្ទេស ត្រង់ឧទ្ទេសណា។ មកកាន់ឧទ្ទេសត្រង់ឧទ្ទេសទី៣។ បណ្តាវិបត្តិទាំង៤ ចាត់ជាវិបត្តិអ្វី។ ចាត់ជាសីលវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង៧ ចាត់ជាកងនៃអាបត្តិណា។ ចាត់ជាកងនៃអាបត្តិសង្ឃាទិសេស។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ តាំងឡើងដោយសមុដ្ឋាន២ គឺតាំងឡើងអំពីកាយ និងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយអំពីវាចានិងចិត្តក៏មាន។បេ។ (សិក្ខាបទនោះ) លោកណាបាននាំមក។ ព្រះថេរៈទាំងឡាយនាំតៗគ្នាមក។

[៧៩៤] សង្ឃាទិសេសណា។ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ (នូវកាលគួរបញ្ញត្តសិក្ខាបទ) ទ្រង់ឃើញ (នូវអំណាចនៃប្រយោជន៍) ព្រោះបច្ច័យនៃកិរិយាបំបួសស្ត្រីចោរ សង្ឃាទិសេសនោះ ព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីបំបួសស្ត្រីចោរ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន ២ គឺតាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន។

[៧៩៥] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីដើរទៅកាន់ចន្លោះស្រុកម្នាក់ឯង ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនី១រូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនី១រូបដើរទៅកាន់ចន្លោះ ស្រុកម្នាក់ឯង។

(សិក្ខាបទនោះ) មានបញ្ញត្តិ១ មានអនុប្បញ្ញត្តិ៣។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៧៩៦] សង្ឃាទិសេសរបស់ភិក្ខុនី ដែលមិនបានប្រាប់ការកសង្ឃ ទាំងមិនដឹងសេចក្តីប្រាថ្នារបស់គណៈ ហើយសូត្រហៅភិក្ខុនី ដែលសង្ឃព្រមព្រៀងគ្នាលើកវត្ត តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ឱ្យចូលមកកាន់ពួក ព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹង ថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីមិនបានប្រាប់ការកសង្ឃ ទាំងមិនដឹងសេចក្តីប្រាថ្នារបស់គណៈ ហើយសូត្រហៅភិក្ខុនី ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា (ឱ្យចូលមកកាន់ពួក)។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៧៩៧] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនី មានចិត្តជោកដោយ រាគៈ ទទួលខាទនីយភោជនីយាហារ អំពីដៃបុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ ដោយដៃខ្លួនឯងហើយឆាន់ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងសុន្ទរីនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលសុន្ទរីនន្ទាភិក្ខុនី មានចិត្តជោកដោយរាគៈ ទទួលអាមិសៈអំពី ដៃបុរសបុគ្គល ដែលមានចិត្តជោកដោយរាគៈ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងបឋមបារាជិកសិក្ខាបទ)។

[៧៩៨] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នែនាង បុរសបុគ្គលនោះមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នែនាង ណ្ហើយចុះ កាលណាបើនាងមិនមានតម្រេកហើយ បើបុរសបុគ្គលនេះឱ្យវត្ថុណាជាខាទនីយៈក្តី ជាភោជនីយៈក្តី ដល់នាង នាងចូរទទួលវត្ថុនោះ ដោយដៃរបស់ខ្លួនហើយទំពាស៊ី ឬបរិភោគចុះ ដូច្នេះ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនី១រូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនី១រូប បញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នែនាង បុរសបុគ្គលនោះមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នែនាង ណ្ហើយចុះ កាលណាបើនាងមិនមានតម្រេកហើយ បើបុរសបុគ្គលនោះឱ្យវត្ថុណាជាខាទនីយៈក្តី ជាភោជនីយៈក្តី ដល់នាង នាងចូរទទួលយកវត្ថុនោះដោយដៃរបស់ខ្លួន ហើយទំពាស៊ី ឬបរិភោគចុះ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន៣។

[៧៩៩] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីក្រោធខឹង (នឹងភិក្ខុនីផងគ្នា) កាលបើសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ដងហើយ នៅតែមិនលះបង់ (នូវអំពីនោះចេញ) ព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿង ដែលចណ្ឌកាលីភិក្ខុនីខឹងអន់ចិត្តក៏ពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខាបទ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៨០០] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីដែលសង្ឃធ្វើឱ្យចាញ់ ព្រោះអធិករណ៍អ្វីនីមួយ ហើយខឹង កាលបើសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ ដងហើយ នៅតែមិនលះបង់ (នូវអំពើនោះ) ចេញ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងចណ្ឌកាលីភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងចណ្ឌកាលីភិក្ខុនី ដែលសង្ឃឱ្យចាញ់ ព្រោះអធិករណ៍អ្វីនីមួយ ហើយខឹងអាក់អន់ចិត្ត បាននិយាយយ៉ាងនេះថា ភិក្ខុនីទាំងឡាយ លុះដោយសេចក្តីស្រឡាញ់ផង ភិក្ខុនីទាំងឡាយ លុះដោយសេចក្តីខឹងផង ភិក្ខុនីទាំងឡាយ លុះដោយសេចក្តីល្ងង់ផង ភិក្ខុនីទាំង ឡាយ លុះដោយសេចក្តីខ្លាចផង។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៨០១] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីទាំងឡាយនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) សង្ឃបានសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ដង ហើយនៅតែមិនលះបង់ (នូវអំពើនោះ) ចេញព្រះសម្មាសម្ពុទ្ធ ទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹង បុគ្គលណា។ ទ្រង់ប្រារព្ធនឹងភិក្ខុនីច្រើនរូប។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលភិក្ខុនីច្រើនរូប នៅច្រឡូកច្រឡំ (ដោយគ្រហស្ថ)។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។

[៨០២] សង្ឃាទិសេស ព្រោះបច្ច័យនៃភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នែលោកម្ចាស់ទាំងឡាយ លោកទាំងឡាយ ចូរនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ កុំនៅបែកខ្ញែកគ្នាឡើយ សង្ឃបានសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ដងហើយ នៅតែមិនលះបង់ (នូវអំពើនោះ) ចេញ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុង ក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងថុល្លនន្ទាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលថុល្លនន្ទាភិក្ខុនីបញ្ជូន ភិក្ខុនីផងគ្នាដោយពាក្យថា នែលោកម្ចាស់ទាំងឡាយ លោកទាំងឡាយ ចូរនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ កុំនៅបែកខ្ញែកគ្នាឡើយ។ (សិក្ខាបទនោះ) មានតែបញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោសមុដ្ឋាន ១ (ដូចក្នុងធុរនិក្ខេបសិក្ខាបទ)។ បេ។

[៨០៣] បាដិទេសនីយៈ ព្រោះបច្ច័យនៃភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តក្នុងទីណា។ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។ ទ្រង់ប្រារព្ធនឹងបុគ្គលណា។ ទ្រង់ប្រារព្ធនឹងពួកឆព្វគ្គិយាភិក្ខុនី។ ព្រោះរឿងដូចម្តេច។ ព្រោះរឿងដែលពួកឆព្វគ្គិយាភិក្ខុនី (មិនឈឺ) សូមទឹកដោះជូរយកមកឆាន់។ (សិក្ខាបទនោះ) មានបញ្ញត្តិ១ អនុប្បញ្ញត្តិ១។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋាន៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្ត ក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើង អំពីកាយវាចានិងចិត្តក៏មាន។

ចប់ កត្ថប្បញ្ញត្តិវារៈ ជាបឋម។

# កតិអាបត្តិវារៈ ទី២

CS vin.pv.01.2.10 | ភាគ ទី១២

### (២.(១០) កតាបត្តិវារោ)

## បារាជិក

CS vin.pv.01.2.10.1 | ភាគ ទី១២

### (១. បារាជិកកណ្ឌំ)

[៨០៤] ភិក្ខុ ឬភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយា ត្រេកអរនឹងការចាប់ពាល់កាយ (របស់បុរសបុគ្គល)។ ត្រូវអាបត្តិ៥ ព្រោះបច្ច័យនៃកិរិយាត្រេកអរ នឹងការប៉ះពាល់កាយ គឺភិក្ខុនីមានតម្រេក ត្រេកអរនឹងការចាប់ពាល់ (នូវសរីរប្រទេស) របស់បុរសបុគ្គលដែលមានតម្រេកដែរ តាំងពីខាងក្រោមដងតាំបិតចុះមកដល់មណ្ឌលជង្គង់ខាងលើ ត្រូវអាបត្តិបារាជិក ភិក្ខុចាប់ពាល់កាយ (ស្ត្រី) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិសង្ឃាទិសេស ចាប់ពាល់វត្ថុដែលជាប់នឹងកាយ (ស្ត្រី) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ ចាប់ពាល់វត្ថុដែលជាប់ដោយកាយ (ស្ត្រី) ដោយវត្ថុដែលជាប់នឹងកាយ (ខ្លួន) ត្រូវអាបត្តិទុក្កដ ចាក់ក្រឡេកភិក្ខុផងគ្នា ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុនិងភិក្ខុនីត្រូវអាបត្តិ៥នេះ ព្រោះ បច្ច័យនៃកិរិយាត្រេកអរនឹងការប៉ះពាល់កាយ។

[៨០៥] ភិក្ខុ ឬភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយា បិទបាំងទោស។ ត្រូវអាបត្តិ ៤ យ៉ាង ព្រោះបច្ច័យនៃកិរិយាបិទបាំងទោស គឺភិក្ខុនីដឹងថា ភិក្ខុនីផងគ្នាត្រូវអាបត្តិបារាជិក ហើយបិទបាំងទុក ត្រូវអាបត្តិបារាជិក ភិក្ខុនីមានសេចក្ដីសង្ស័យហើយបិទបាំងទុក ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុបិទបាំងអាបត្តិសង្ឃាទិសេស (របស់ភិក្ខុផងគ្នា) ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុបិទបាំងអាចារវិបត្តិត្រូវអាបត្តិទុក្កដ ភិក្ខុនិងភិក្ខុនីត្រូវអាបត្តិទាំង៤នេះ ព្រោះបច្ច័យនៃកិរិយាបិទបាំងទោសទុក។

[៨០៦] ភិក្ខុនិងភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាមិនលះបង់ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ដង។ ត្រូវអាបត្តិ៥យ៉ាង ព្រោះបច្ច័យនៃកិរិយាមិនលះបង់ (នូវអំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ដង ឧក្ខិត្តានុវត្តិកាភិក្ខុនី[27] មិនលះ (អំពើនោះៗ) ក្នុងវេលាដែល សង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់ ៣ ដង កាលចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាស្រេច ត្រូវអាបត្តិបារាជិក ភេទានុវត្តិកាភិក្ខុនី[28] មិនលះ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ ដងហើយ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុមិនលះទិដ្ឋិលាមក ក្នុងវេលាដែលសង្ឃ សូត្រសមនុភាសនកម្មជាគម្រប់៣ដង ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុនិងភិក្ខុនី ត្រូវអាបត្តិទាំង៥នេះ ព្រោះបច្ច័យនៃកិរិយាមិនលះបង់ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ដង។

[៨០៧] ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាបំពេញវត្ថុជាគម្រប់៨។ ត្រូវអាបត្តិ ៣ យ៉ាង ព្រោះបច្ច័យនៃកិរិយាបំពេញវត្ថុជាគម្រប់៨ គឺភិក្ខុនី កាលបើបុរសនិយាយថា នាងចូរមកកាន់ទីឈ្មោះនេះ ហើយដើរទៅ ត្រូវអាបត្តិទុក្កដ លុះដើរចូលទៅកាន់ហត្ថបាសរបស់ បុរស ត្រូវអាបត្តិថុល្លច្ច័យ បំពេញវត្ថុជាគម្រប់៨ ឱ្យពេញ ត្រូវអាបត្តិបារាជិក ភិក្ខុនីត្រូវអាបត្តិទាំង ៣ នេះ ព្រោះបច្ច័យនៃកិរិយាបំពេញវត្ថុជាគម្រប់ ៨។

ចប់ បារាជិក។

## សង្ឃាទិសេស ទី២

CS vin.pv.01.2.10.2 | ភាគ ទី១២

### (២. សង្ឃាទិសេសកណ្ឌាទិ)

[៨០៨] ភិក្ខុនី ជាអ្នកប្ដឹងផ្ដល់ ត្រូវអាបត្តិ៣ យ៉ាង ព្រោះបច្ច័យ នៃកិរិយាបង្កដំណើរក្ដី គឺកិរិយាប្រាប់ដល់បុគ្គលម្នាក់ ត្រូវអាបត្តិទុក្កដ និយាយប្រាប់ដល់បុគ្គលជាគម្រប់ពីរ ត្រូវអាបត្តិថុល្លច្ច័យ លុះសម្រេចដំណើរក្ដី ត្រូវអាបត្តិសង្ឃាទិសេស។

[៨០៩] ភិក្ខុនី ត្រូវអាបត្តិ៣ ព្រោះបច្ច័យនៃកិរិយាបំបួសស្រីចោរ គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស។

[៨១០] ភិក្ខុនី ត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាដើរទៅកាន់ចន្លោះស្រុកតែម្នាក់ឯង គឺដើរទៅ ត្រូវអាបត្តិទុក្កដ ឈានជំហានជាបឋមកន្លងរបងស្រុកទៅ ត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានជាគម្រប់ពីរកន្លងទៅ ត្រូវអាបត្តិសង្ឃាទិសេស។

[៨១១] ភិក្ខុនីត្រូវអាបត្តិ៣ព្រោះបច្ច័យនៃកិរិយាមិនប្រាប់ការកសង្ឃ ទាំងមិនដឹងសេចក្ដីប្រាថ្នារបស់គណៈ ហើយសូត្រហៅភិក្ខុនី ដែលសង្ឃព្រមព្រៀងគ្នាលើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀន ប្រដៅរបស់ព្រះសាស្ដា (ឱ្យចូលមកកាន់ពួក) គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស។

[៨១២] ភិក្ខុនី មានតម្រេកត្រូវអាបត្តិ៣ ព្រោះបច្ច័យនៃកិរិយាទទួលខាទនីយៈ ឬភោជនីយាហារអំពីដៃបុរសបុគ្គលដែលមានតម្រេកដែរ ដោយដៃរបស់ខ្លួន ហើយបរិភោគ គឺកំពុងទទួលដោយគិតថា អាត្មាអញ នឹងទំពាស៊ី នឹងឆាន់ ត្រូវអាបត្តិថុល្លច្ច័យ (លុះទទួលហើយបរិភោគ) ត្រូវ

អាបត្តិសង្ឃាទិសេសគ្រប់ៗ វារៈដែលលេបចូលទៅ លុះទទួលទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ។

[៨១៣] ភិក្ខុនី ត្រូវអាបត្តិ៣ ព្រោះបច្ច័យនៃកិរិយាបញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នែនាង បុរសបុគ្គលនោះ ទុកជាមានតម្រេកក្តី មិនមានតម្រេកក្តី នឹងធ្វើអ្វីដល់នាងបាន នែនាង ណ្ហើយចុះ កាលណាបើនាងមិនមានតម្រេកទេ បុរសបុគ្គលនោះឱ្យវត្ថុណាជាខាទនីយៈក្តី ជាភោជនីយៈក្តី ដល់នាង ក៏នាងចូរទទួរវត្ថុនោះដោយដៃរបស់ខ្លួនហើយ ទំពាស៊ីឬបរិភោគចុះ ដូច្នេះ គឺកំពុងទទួលដោយគិតថា អាត្មាអញនឹងទំពាស៊ី នឹងឆាន់ តាមពាក្យរបស់ភិក្ខុនីនោះ ត្រូវអាបត្តិទុក្កដ (លុះទទួល ហើយឆាន់) ត្រូវអាបត្តិថុល្លច្ច័យគ្រប់ៗវារៈដែលលេបចូលទៅ លុះឆាន់រួចហើយ ត្រូវអាបត្តិសង្ឃាទិសេស។

[៨១៤] ភិក្ខុនី ក្រោធខឹង ត្រូវអាបត្តិ ៣ ព្រោះបច្ច័យដែលខ្លួន មិនលះ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ជា គម្រប់ ៣ ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់វាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស។

[៨១៥] ភិក្ខុនី ដែលសង្ឃឱ្យចាញ់ ព្រោះអធិករណ៍អ្វីនីមួយ ហើយក្រោធខឹង ត្រូវអាបត្តិ ៣ ព្រោះបច្ច័យនៃកិរិយាមិនលះ (អំពើនោះ ៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់គម្រប់ ៣ ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស។

[៨១៦] ភិក្ខុនី នៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ត្រូវអាបត្តិ៣ ព្រោះបច្ច័យនៃកិរិយាមិនលះ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃាទិសេស។

[៨១៧] ភិក្ខុនីបញ្ជូនភិក្ខុនីផងគ្នា ដោយពាក្យថា នែលោកម្ចាស់ទាំងឡាយ ចូរលោកម្ចាស់ទាំងឡាយនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) ចុះ កុំនៅបែកខ្ញែកពីគ្នាឡើយ ដូច្នេះ ត្រូវអាបត្តិ៣ ព្រោះបច្ច័យនៃកិរិយាមិនលះ (អំពើនោះៗ) ក្នុងវេលាដែលសង្ឃសូត្រសមនុភាសនកម្មចប់ជាគម្រប់៣ ដង គឺចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ចប់កម្មវាចាសព្វគ្រប់ ត្រូវអាបត្តិសង្ឃា ទិសេស។

ចប់ សង្ឃាទិសេស។បេ។

[៨១៨] ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់។ ភិក្ខុនីត្រូវអាបត្តិ២ ព្រោះបចច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ គឺកំពុងទទួដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗ វារៈដែលលេបចូរទៅ ភិក្ខុនីត្រូវអាបត្តិ២នេះ ព្រោះបច្ច័យនៃកិរិយា សូមទឹកដោះជូរយកមកឆាន់។

ចប់ កតិអាបត្តិវារៈ ជាគម្រប់២។

# វិបត្តិវារៈ ទី៣

CS vin.pv.01.2.11 | ភាគ ទី១២

### (៣.(១១) វិបត្តិវារោ)

[៨១៩] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិ២គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។បេ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូម នូវទឹកដោះជូរយកមកឆាន់ បណ្តាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ១ គឺ អាចារវិបត្តិ។

ចប់ វិបត្តិវារៈ ជាគម្រប់ ៣។

# សង្គហវារៈ ទី៤

CS vin.pv.01.2.12 | ភាគ ទី១២

### (៤.(១២) សង្គហវារោ)

[៨២០] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយកងនៃអាបត្តិ៥ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លបច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បេ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះ ជូរយកមកឆាន់ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺ កងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដ ក៏មាន។

ចប់ សង្គហវារៈ ជាគម្រប់ ៤។

# សមុដ្ឋានវារៈ ទី៥

CS vin.pv.01.2.13 | ភាគ ទី១២

### (៥.(១៣) សមុដ្ឋានវារោ)

[៨២១] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះ ពាល់កាយ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។ បេ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន។

ចប់ សមុដ្ឋានវារៈ ជាគម្រប់ ៥។

# អធិករណវារៈ ទី៦

CS vin.pv.01.2.14 | ភាគ ទី១២

### (៦.(១៤) អធិករណវារោ)

[៨២២] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការ ប៉ះពាល់កាយ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍។បេ។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាអធិករណ៍ទាំង៤ ចាត់ ជាអធិករណ៍ណា។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍។

ចប់ អធិករណវារៈ ជាគម្រប់ ៦។

# សមថវារៈ ទី៧

CS vin.pv.01.2.15 | ភាគ ទី១២

### (៧.(១៥) សមថវារោ)

[៨២៣] អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការ ប៉ះពាល់កាយ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ អាបត្តិទាំងឡាយ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ បណ្តាសមថៈទាំង៧ តែងរម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។បេ។ អាបត្តិទាំងឡាយព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ ពួកអាបត្តិព្រោះបច្ច័យនៃ កិរិយាសូមទឹកដោះជូរយកមកឆាន់ បណ្តាសមថៈទាំង៧ តែងរម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

ចប់ សមថវារៈ ជាគម្រប់ ៧។

# សមុច្ចយវារៈ ទី៨

CS vin.pv.01.2.16 | ភាគ ទី១២

### (៨.(១៦) សមុច្ចយវារោ)

[៨២៤] ភិក្ខុ ឬ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃសេចក្តី ត្រេកអរនឹងការប៉ះពាល់កាយ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ៥ ព្រោះបច្ច័យ នៃចេសក្តីត្រេកអរនឹងការប៉ះពាល់កាយ គឺ ភិក្ខុនីមានតម្រេកត្រេកអរនឹងការចាប់ពាល់ (នូវសរីរប្រទេស) របស់បុរសបុគ្គលដែលមានតម្រេកដែរ តាំងពីខាងក្រោមដងកាំបិតចុះមក ដល់ខាងលើមណ្ឌលជង្គង់ ត្រូវអាបត្តិបារាជិក ភិក្ខុចាប់ពាល់កាយ (ស្ត្រី) ដោយកាយរបស់ (ខ្លួន) ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុចាប់ពាល់វត្ថុដែលជាប់នឹងកាយ (ស្ត្រី) ដោយកាយរបស់(ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុចាប់ពាល់វត្ថុដែលជាប់នឹងកាយ(ស្ត្រី) ដោយវត្ថុដែលជាប់នឹងកាយ (ខ្លួន) ត្រូវអាបត្តិទុក្កដ ភិក្ខុចាក់ក្រឡេកភិក្ខុផងគ្នាដោយម្រាមដៃ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុឬភិក្ខុនីត្រូវអាបត្តិទាំង៥នេះ ព្រោះបច្ច័យនៃសេចក្តីត្រេកអរនឹងការប៉ះពាល់កាយ។ អាបត្តិទាំងនោះ បណ្តាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិទាំងនេះ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិរករណ៍ទាំង៤ ចាត់ជាអធិករណ៍ណា។ បណ្តាសមថៈទាំង ៧ រម្ងាប់ ដោយសមថៈប៉ុន្មាន។ អាបត្តិទាំងនោះ បណ្តាវិបត្តិទាំង ៤ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺកងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏

មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើង អំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។ បណ្តាអធិករណ៍ទាំង៤ ចាត់ជាអាបត្តាអធិករណ៍។ បណ្តាសមថៈទាំង៧ តែងរម្ងាប់ដោយសមថៈ ៣ គឺដោយសម្មុខាវិន័យនិងបដិញ្ញាតកណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។ បេ។

[៨២៥] ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់។ ភិក្ខុនី ត្រូវអាបត្តិ ២ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់ គឺកំពុងទទួលប្រគេនដោយគិតថា អាត្មាអញនឹងឆាន់ ដូច្នេះ ត្រូវអាបត្តិទុក្កដ (លុះទទួលហើយឆាន់) ត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗវារៈដែលលេបចូលទៅ ភិក្ខុនីត្រូវអាបត្តិទាំង២ នេះ ព្រោះបច្ច័យនៃកិរិយាសូមទឹកដោះជូរយកមកឆាន់។ អាបត្តិទាំងនេះ បណ្តាវិបត្តិទាំង៤ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍ទាំង៤ ចាត់ជាអធិករណ៍ណា។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ ពួកអាបត្តិទាំងនោះ បណ្តាវិបត្តិទាំង៤ រាប់ បញ្ចូលក្នុងវិបត្តិ១ គឺអាចារវិបត្តិ។ បណ្តាអាបត្តិទាំង៧កង លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺកងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយ សមុដ្ឋាន៤ គឺតាំងឡើងអំពីកាយ មិនតាំងឡើងអំពីវាចា និងមិនតាំង ឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងអំពីចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំង ឡើងអំពីកាយវាចានិងចិត្តក៏មាន។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈទាំង ៧ តែងរម្ងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

ចប់ សមុច្ចយវារៈ ជាគម្រប់៨។

ចប់ បច្ចយវារៈទាំង៨។

ចប់ មហាវារៈ១៦ ក្នុងភិក្ខុនីវិភង្គ។

# សមុដ្ឋានសីសសង្ខេប

CS vin.pv.02 | ភាគ ទី១២

**(សមុដ្ឋានសីសសង្ខេបោ)**

## (សមុដ្ឋានស្សុទ្ទានៈ និង តេរសសមុដ្ឋានៈ)

CS vin.pv.02.00 | ភាគ ទី១២

**(សមុដ្ឋានស្សុទ្ទានំ តេរសសមុដ្ឋានំ)**

[៨២៦] សង្ខារទាំងពួងទាំងឡាយ ដែលបច្ច័យតាក់តែងហើយ ជារបស់មិនទៀងផង ជាទុក្ខផង ជាអនត្តាផង។ និព្វាន និងបញ្ញត្តិក៏លោកវិនិច្ឆ័យថា ជាអនត្តាធម៌ដែរ។[29] កាលព្រះ ពុទ្ធដូចជាព្រះចន្ទ មិនទាន់កើតឡើង កាលព្រះពុទ្ធដូចជាព្រះអាទិត្យ មិនទាន់បានត្រាស់នៅឡើយ នាមប្បញ្ញត្តិរបស់សភាគធម៌[30] ទាំងឡាយនោះ ក៏មិនមានអ្នកណាអាចដឹងបាន។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ជាមហាវីរៈ ទ្រង់ធ្វើនូវទុក្ករកិរិយាមានប្រការផ្សេងៗ បានបំពេញនូវបារមីទាំងឡាយ ព្រះអង្គ មានចក្ខុកើតហើយ បានត្រាស់ដឹងឡើង ព្រះអង្គទ្រង់សម្តែង នូវព្រះសទ្ធម្មដែលសម្រាប់បំផ្លាញនូវកងទុក្ខ ហើយនាំមកនូវសេចក្តីសុខ ចំពោះសត្វលោក ព្រមទាំងព្រហ្មលោក។ ព្រះអង្គីរសសម្មាសម្ពុទ្ធ ជាសក្យមុនី ព្រះអង្គមានសេចក្តី អនុគ្រោះសព្វសត្វ ឧត្តមជាងសព្វសត្វ ជាសីហៈ (របស់នរជន) ទ្រង់សម្តែងនូវពុទ្ធវចនៈទាំង ៣ ក្នុងបិដក គឺព្រះ វិន័យ ព្រះសូត្រ ព្រះអភិធម្ម ដែលជាពាក្យមានគុណធំ។ បើព្រះវិន័យឋិតនៅហើយ ព្រះសទ្ធម្ម ក៏ប្រព្រឹត្តទៅបាន យ៉ាងនេះ ឧភតោវិភង្គ ខន្ធកវិន័យ និងមាតិកាដែលព្រះសង្គីតិកាចារ្យចងក្រងហើយ ដោយបរិវារៈ បីដូចកម្រងផ្កាដែលគេក្រងដោយចេសន៍ះឯង។ សមុដ្ឋាននៃបរិវារៈនុ៎ះឯង ជាសមុដ្ឋានដែលអ្នកប្រាជ្ញធ្វើឱ្យទៀងទាត់ គឺធ្វើមិនឱ្យលាយច្រឡំដោយសមុដ្ឋានឯទៀត សម្ភេទផង និទានផង សមុដ្ឋានដទៃផង មានប្រាកដមកក្នុងសូត្រ ដូចសម្តែងមកហើយខាងដើម ព្រោះហេតុនោះ ភិក្ខុដែលមានសីលជាទីស្រឡាញ់ ជាអ្នកប្រាថ្នាធម៌ គប្បីសិក្សានូវបរិវារៈ (ទៀតចុះ)។

សិក្ខាបទណា ដែលទ្រង់បញ្ញត្តហើយក្នុងវិភង្គទាំងពីរ ដែលពួកភិក្ខុ និងភិក្ខុនី តែងសម្តែងគ្រប់ថ្ងៃឧបោសថ ខ្ញុំនឹងពោលនូវសមុដ្ឋាន (នៃសិក្ខាបទនោះ) តាមសមគួរដល់សេចក្តីចេះដឹង អ្នកទាំងឡាយ ចូរប្រុងស្តាប់ពាក្យរបស់ខ្ញុំ។ សិក្ខាបទទាំងឡាយ១៣ គឺបឋមបារាជិកសិក្ខាបទ១ ទុតិយបារាជិកសិក្ខាបទ១ តទៅមុខទៀត គឺសញ្ចរិត្តសិក្ខាបទ១ សមនុភាសនសិក្ខាបទ១ អតិរេកចីវរសិក្ខាបទ១ ឯឡកលោមសិក្ខាបទ១ បទសោធម្មសិក្ខាបទ១ ភូតារោចនសិក្ខាបទ១ សំវិធានសិក្ខាបទ១ ថេយ្យសត្ថសិក្ខាបទ១ ធម្មទេសនាសិក្ខាបទ១ ចោរីវុដ្ឋាបនសិក្ខាបទ១ អននុញ្ញាតសិក្ខាបទ១។ សិក្ខាបទទាំង១៣ នេះ មានន័យរបស់សមុដ្ឋាន ដែលអ្នកប្រាជ្ញទាំងឡាយបានគិតហើយ ថា ក្នុងសមុដ្ឋាននៃសិក្ខាបទមួយៗ ក្នុងវិភង្គទាំងពីរនេះ មានសមុដ្ឋានប្រហែលៗគ្នាទាំងអស់។

## បឋមបារាជិកសមុដ្ឋាន

CS vin.pv.02.01 | ភាគ ទី១២

**(១. បឋមបារាជិកសមុដ្ឋានំ)**

[៨២៧] មេថុនសិក្ខាបទ១ សុក្កវិស្សដ្ឋិសិក្ខាបទ១ កាយសំសគ្គសិក្ខាបទ១ បឋមានីយតសិក្ខាបទ១ បុព្វូបគតសិក្ខាបទ[31] ១ បរិបាចិតសិក្ខាបទ១ រហោនិសជ្ជសិក្ខាបទ[32] ១ សភោនជសិក្ខាបទ១ រហោនិសជ្ជសិក្ខាបទ[33] ទាំង២ អង្គុលិបតោទកសិក្ខាបទ១ ឧទកេហាសធម្មសិក្ខាបទ១ បហារទានសិក្ខាបទ១ ឧគ្គិរណសិក្ខាបទ[34] ១ សេខិយ៥៣ អធក្ខសិក្ខាបទ ១ គាមន្តរគមនសិក្ខាបទ១ អវស្សុតាខាទនីយ គហនសិក្ខាបទ[35] ១ តលឃាដកសិក្ខាបទ១ ជតុមដ្ឋកសិក្ខាបទ១ ឧទកសុទ្ធិកសិក្ខាបទ១ វស្សវុត្ថានសិក្ខាបទ១ ឱវាទគមនសិក្ខាបទ១ វុដ្ឋាបិតបវត្តននានុពន្ធសិក្ខាបទ១ រួមត្រូវជា៧៦ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានមួយ គឺតាំងឡើងអំពីកាយចិត្ត ដូចបឋមបារាជិកសិក្ខាបទដែរ។

ចប់ បឋមបារាជិកសមុដ្ឋាន។

# ទុតិយបារាជិកសមុដ្ឋាន

CS vin.pv.02.02 | ភាគ ទី១២

### (២. ទុតិយបារាជិកសមុដ្ឋានំ)

[៨២៨] អទិន្នាទានសិក្ខាបទ១ មនុស្សវិគ្គហសិក្ខាបទ១ ឧត្តរិមនុស្សធម្មសិក្ខាបទ១ ទុដ្ឋុល្លវាចសិក្ខាបទ១ អត្តគាមបារិចរិយ សិក្ខាបទ ១ អមូលកសិក្ខាបទ ១ អញ្ញភាគិយសិក្ខាបទ ១ ទុតិយានិយតសិក្ខាបទ១ ចីវរច្ឆិន្នសិក្ខាបទ១ បរិណាមនសិក្ខាបទ១ មុសាវាទសិក្ខាបទ១ ឱមសវាទសិក្ខាបទ ១ បេសុញ្ញសិក្ខាបទ ១ ទុដ្ឋុល្លារោចនសិក្ខាបទ១ បឋវីខណនសិក្ខាបទ១ ភូតគាមសិក្ខាបទ១ អញ្ញវាទកសិក្ខាបទ១ ឧជ្ឈាបនកសិក្ខាបទ១ និកឌ្ឍនសិក្ខាបទ១ សិញ្ចនសិក្ខាបទ[36] ១ អាមិសហេតុសិក្ខាបទ១ ភុត្តាវីសិក្ខាបទ[37] ១ ឯហិសិក្ខាបទ[38] ១ អនាទរិយសិក្ខាបទ ១ ភីសាបនសិក្ខាបទ១ អបនិធានសិក្ខាបទ១ ជីវិតាវោរោបនសិក្ខាបទ[39] ១ សប្បាណកសិក្ខាបទ១ កម្មឧក្កោដនសិក្ខាបទ១ ឧនវីសតិវស្សសិក្ខាបទ១ សំវាសសិក្ខាបទ[40] ១ នាសិតកសាមណេរសម្ភោគសិក្ខាបទ[41] ១ សហធម្មិកសិក្ខាបទ១ វិលេខនសិក្ខាបទ១ មោហនកសិក្ខាបទ១ អមូលកសិក្ខាបទ[42] ១ កុក្កុច្ចឧបទហនសិក្ខាបទ[43] ១ ធម្មិកសិក្ខាបទ[44] ១ ចីវរំទត្វាខិយ្យនធម្មសិក្ខាបទ[45] ១ បុគ្គលបរិណាមនសិក្ខាបទ១ កិន្តេសិក្ខាបទ[46] ១ អកាលចីវរ សិក្ខាបទ(ភាជាបនៈ) ១ អច្ឆិន្ទនសិក្ខាបទ ១ ទុគ្គហិតសិក្ខាបទ (ឧជ្ឈាបនកៈ) ១ និរយសិក្ខាបទ (អភិសបនៈ)១ គណាចីវរលាភសិក្ខាបទ១ ចីវរវិភង្គសិក្ខាបទ១ ទុព្វលចីវរសិក្ខាបទ១ កឋិនផាសុកសិក្ខាបទ១ ឧបស្សយសិក្ខាបទ១ អក្កោសនសិក្ខាបទ១ បណ្ឌកតាសិក្ខាបទ១ កុលមច្ឆរីសិក្ខាបទ១ គព្ភិនីវុដ្ឋាបនសិក្ខាបទ១ បាយន្តីវុដ្ឋាបនសិក្ខាបទ១ ទ្វេវស្សាអសិក្ខិតសិក្ខមានាសិក្ខាបទ១ សិក្ខិតសិក្ខាសង្ឃេនអសម្មតាសិក្ខាបទ១ គិហិគតាសិក្ខាបទ[47] មាន៣ កុមារីភូតាសិក្ខាបទ[48] មាន៣ ឩនទ្វាទសវស្សាវុដ្ឋាបនសិក្ខាបទ១ អសម្មតវុដ្ឋាបនសិក្ខាបទ១ អលន្តាវសិក្ខាបទ១ សោកាវស្សាសិក្ខាបទ១ បារិវាសិកច្ឆន្ទទានសិក្ខាបទ១ អនុវស្សសិក្ខាបទ១ ឯកវស្សទ្វេវុដ្ឋាបនសិក្ខាបទ១ រួមទាំងអស់ ត្រូវជា៧០សិក្ខាបទ សិក្ខាបទទាំងនេះសុទ្ធតែមានសមុដ្ឋាន៣ៗ គឺកើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា១ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ១ កើតឡើង អំពីទ្វារទាំង៣ គឺ កាយវាចាចិត្ត១ ដូចក្នុងទុតិយបារាជិកសិក្ខាបទ។

ចប់ ទុតិយបារាជិកសមុដ្ឋាន។

# សមុដ្ឋានសីសសង្ខេប សញ្ចរិត្តសមុដ្ឋាន

CS vin.pv.02.03 | ភាគ ទី១២

### (៣. សញ្ចរិត្តសមុដ្ឋានំ)

[៨២៩] សញ្ចរិត្តសិក្ខាបទ១ កុដិការសិក្ខាបទ១ វិហារសិក្ខាបទ (មហល្លកៈ)១ ចីវរធោវនសិក្ខាបទ១ ចីវរប្បដិគ្គហណសិក្ខាបទ១ អញ្ញាតកវិញ្ញត្តិសិក្ខាបទ១ តទុត្តរិអភិហដ្ឋុសិក្ខាបទ[49] ១ ឧបក្ខដសិក្ខាបទ២ (គឺបឋមឧបក្ខដៈ១ ទុតិយឧបក្ខដៈ១) ទូតសិក្ខាបទ[50] ១ កោសិយសិក្ខាបទ១ សុទ្ធកាឡកសិក្ខាបទ១ ទ្វេភាគសិក្ខាបទ១ ឆព្វស្សសិក្ខាបទ៦ និសីទនសន្ថតសិក្ខាបទ១ រិញ្ចន្តិសិក្ខាបទ[51] ១ រូបិយសិក្ខាបទ១ នានប្បការកសិក្ខាបទ២ (គឺរូបិយសំវោហារសិក្ខាបទ១ កយវិក្កយសិក្ខាបទ១) ឩនបញ្ចពន្ធនសិក្ខាបទ១ វស្សិកសាដិកសិក្ខាបទ១ សុត្តវិញ្ញត្តិសិក្ខាបទ១ វិកប្បនសិក្ខាបទ[52] ១ ទ្វារសិក្ខាបទ[53] ១ ចីវរទានសិក្ខាបទ១ ចីវរសិព្វនសិក្ខាបទ ១ បូវសិក្ខាបទ[54] ១ បច្ចយសិក្ខាបទ[55] ១ ជោតិសមាទហនសិក្ខាបទ១ រតនសិក្ខាបទ១ សូចិឃរសិក្ខាបទ១ មញ្ចសិក្ខាបទ១ តូលោនទ្ធ សិក្ខាបទ១ និសីទនសិក្ខាបទ១ កណ្ឌុប្បដិច្ឆាទិសិក្ខាបទ១ វស្សិកសាដិកាសិក្ខាបទ១ សុគតចីវរសិក្ខាបទ[56] ១ វិញ្ញត្តិសិក្ខាបទ១ អញ្ញចេតាបនសិក្ខាបទ១ សង្ឃិកចីវរសិក្ខាបទ២ មហាជនិកសិក្ខាបទ១ បុគ្គលបរិណាមនសិក្ខាបទ២ លហុបាបុរណសិក្ខាបទ១ គរុបាបុរណសិក្ខាបទ១ វិឃាសាសិក្ខាបទ២ ឧទកសាដិកាសិក្ខាបទ១ សមណចីវរទានសិក្ខាបទ១ រួមទាំងអស់ត្រូវជាសិក្ខាបទ៥០គត់ សិក្ខាបទទាំងនេះ សុទ្ធ តែមានសមុដ្ឋានប្រាំមួយៗ គឺ កើតឡើងអំពីកាយ មិនកើតឡើងអំពីវាចានិងចិត្ត ១ កើតឡើងអំពីវាចា មិនកើតឡើងអំពីកាយនិងចិត្ត ១ កើតឡើងអំពីកាយនិងវាចា មិនកើតឡើង អំពីចិត្ត១ កើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា១ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ១ កើតឡើងអំពីទ្វារទាំង៣ គឺកាយវាចានិងចិត្ត១ សិក្ខាបទទាំងនេះ សុទ្ធតែមានសមុដ្ឋាន៦ដូចគ្នានឹងសញ្ចរិត្តសិក្ខាបទដែរ។

ចប់ សញ្ចរិត្តសមុដ្ឋាន។

# សមុដ្ឋានសីសសង្ខេប សមនុភាសនសមុដ្ឋាន

CS vin.pv.02.04 | ភាគ ទី១២

### (៤. សមនុភាសនាសមុដ្ឋានំ)

[៨៣០] សង្ឃភេទសិក្ខាបទ១ ភេទានុវត្តកសិក្ខាបទ១ ទុព្វចជាតិកសិក្ខាបទ១ កុលទូសកសិក្ខាបទ១ ទុដ្ឋុល្លប្បដិច្ឆាទនសិក្ខាបទ១ ទិដ្ឋិអប្បដិនិស្សជ្ជនសិក្ខាបទ១ ឆន្ទំអទត្វា គមនសិក្ខាបទ១ ឧជ្ជគ្ឃិកសិក្ខាបទ២ អប្បសទ្ទសិក្ខាបទ២ នព្យាហរណសិក្ខាបទ១ ឆមាយសិក្ខាបទ១ នីចាសនសិក្ខាបទ១ ឋានសិក្ខាបទ១ បច្ឆតោសិក្ខាបទ១ ឧប្បថេនសិក្ខាបទ១ វជ្ជប្បដិច្ឆាទនសិក្ខាបទ១ ឧក្ខិត្តានុវត្តនសិក្ខាបទ១ ហត្ថគ្គហណសិក្ខាបទ ១ ឱសារណសិក្ខាបទ ១ បច្ចាចិក្ខនាសិក្ខាបទ ១ កិស្មិញ្ចិអធិករណបច្ចាគតាសិក្ខាបទ ១ សំសដ្ឋសិក្ខាបទ[57] ១ វធិសិក្ខាបទ ២ វិសិព្វនសិក្ខាបទ ១ ទុក្ខិតាសហជីវិនីសិក្ខាបទ ១ សំសដ្ឋាសិក្ខាបទ[58] មួយទៀត នវូបសមនសិក្ខាបទ ១ អារាមសិក្ខាបទ ១ ឧភតោសង្ឃបវារណាសិក្ខាបទ ១ អន្វឌ្ឍមាសសិក្ខាបទ ១ សហជីវិនីសិក្ខាបទ[59] ២ ចីវរទានសិក្ខាបទ ១ អនុពន្ធនសិក្ខាបទ ១ រួមទាំងអស់ ត្រូវ៣៧សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានមួយៗ គឺកើតឡើងអំពីកាយវាចានិងចិត្ត ដូចក្នុងសមនុភាសនសិក្ខាបទដែរ។[60]

ចប់ សមនុភាសនសមុដ្ឋាន។

# កឋិនសមុដ្ឋាន

CS vin.pv.02.05 | ភាគ ទី១២

### (៥. កថិនសមុដ្ឋានំ)

[៨៣១] ឧព្ភតកឋិនសិក្ខាបទ[61] ៣ បឋមបត្តសិក្ខាបទ១ ភេសជ្ជសិក្ខាបទ ១ អច្ចេកចីវរសិក្ខាបទ ១ សាសង្កសិក្ខាបទ ១ បក្កមន្តសិក្ខាបទ[62] ២ ភិក្ខុនូបស្សយសិក្ខាបទ ១ បរម្បរភោជនសិក្ខាបទ ១ អនតិរិត្តសិក្ខាបទ[63] ១ និមន្តនសិក្ខាបទ[64] ១ វិកប្បនសិក្ខាបទ ១ រាជសិក្ខាបទ[65] ១ វិកាលេគាមប្បវេសនសិក្ខាបទ ១ វោសាសសិក្ខាបទ ១ អារញ្ញិកសិក្ខាបទ ១ ឧស្សយវាទិកសិក្ខាបទ ១ បត្តសន្និចយសិក្ខាបទ ១ បុរេភត្តសិក្ខាបទ ១ បច្ឆាភត្តសិក្ខាបទ ១ វិកាលេឧបសង្កមនសិក្ខាបទ ១ បញ្ចាហិកធារណសិក្ខាបទ ១ ចីវរសង្កមនីយសិក្ខាបទ ១ អាវសថ[66] សិក្ខាបទ២ បសាខសិក្ខាបទ១ អាសននិសីទនសិក្ខាបទ១ រួមទាំងអស់ត្រូវជា២៩សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរៗ គឺកើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចានិងចិត្ត ១ ដូចកឋិនសិក្ខាបទដែរ។

ចប់ កឋិនសមុដ្ឋាន។

# ឯឡលោមសមុដ្ឋាន

CS vin.pv.02.06 | ភាគ ទី១២

### (៦. ឯឡកលោមសមុដ្ឋានំ)

[៨៣២] ឯឡកលោមសិក្ខាបទ ១ សហសេយ្យសិក្ខាបទ[67] ២ អាហច្ចនសិក្ខាបទ[68] ១ អាវសថបិណ្ឌភោជនសិក្ខាបទ ១ គណភោជនសិក្ខាបទ ១ វិកាលភោជនសិក្ខាបទ ១ សន្និធិការសិក្ខាបទ ១ ទន្តបោណសិក្ខាបទ ១ អចេលកសិក្ខាបទ ១ ឧយ្យុត្តសិក្ខាបទ ១ សេនាវាសសិក្ខាបទ ១ ឧយ្យោធិកសិក្ខាបទ ១ សុរាបានសិក្ខាបទ ១ ឱរេនឌ្ឍមាសនហានសិក្ខាបទ ១ ទុព្វណ្ណករណសិក្ខាបទ ១ បាដិទេសនីយសិក្ខាបទ ២ លសុណសិក្ខាបទ ១ ឧតិដ្ឋសិក្ខាបទ ១ នច្ចនសិក្ខាបទ ១។ នហានសិក្ខាបទ ១ អត្ថរណតុវដ្តសិក្ខាបទ ១ ឯកសេយ្យតុវដ្តសិក្ខាបទ ១ អន្តោរដ្ឋេសាសង្កសិក្ខាបទ ១ ពហិរដ្ឋេសាសង្កសិក្ខាបទ ១ អន្តោវស្សសិក្ខាបទ ១ ចិត្តាគារសិក្ខាបទ ១ អាសន្ទិបរិភុញ្ជនសិក្ខាបទ ១ សុត្តកន្តនសិក្ខាបទ ១ គិហិវេយ្យាវច្ចករណសិក្ខាបទ ១ សហត្ថាទានសិក្ខាបទ១ អភិក្ខុកាវាសសិក្ខាបទ ១ ឆត្តធារណសិក្ខាបទ ១ យានសិក្ខាបទ ១ សង្ឃាណីធារណសិក្ខាបទ១ អលង្ការធារណសិក្ខាបទ១ គន្ធនហានសិក្ខាបទ១ វាសិតនហានសិក្ខាបទ១ ភិក្ខុនីឧម្មទ្ទាបនសិក្ខាបទ១ សិក្ខមានាឧម្មទ្ទាបនសិក្ខាបទ ១ សាមណេរីឧម្មទ្ទាបនសិក្ខាបទ ១ គិហិនីឧម្មទ្ទាបនសិក្ខាបទ ១ អសង្កច្ចិកាបត្តិសិក្ខាបទ ១ រួមទាំងអស់ត្រូវជា៤៤សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរៗ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពី វាចានិងចិត្ត ១ កើតឡើងអំពីកាយនិងចិត្ត មិនកើតឡើងអំពីវាចា១ ដូចឯឡកលោមកសិក្ខាបទដែរ។

ចប់ ឯឡលោមសមុដ្ឋាន។

# បទសោធម្មសមុដ្ឋាន

CS vin.pv.02.07 | ភាគ ទី១២

### (៧. បទសោធម្មសមុដ្ឋានំ)

[៨៣៣] បទសោធម្មសិក្ខាបទ ១ ធម្មទេសនាសិក្ខាបទ ១ អសម្មតោភិក្ខុនោវាទសិក្ខាបទ ១ អត្ថង្គតសិក្ខាបទ ១ តិរច្ឆានវិជ្ជាសិក្ខាបទ ២[69) អនោកាសបុច្ឆនសិក្ខាបទ ១ រួមទាំងអស់ ត្រូវជា៧សិក្ខាបទ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានពីរៗ គឺកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយនិងចិត្ត ១ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ ១ ដូចបទ សោធម្មសិក្ខាបទដែរ។

ចប់ បទសោធម្មសមុដ្ឋាន។

# អទ្ធានសមុដ្ឋាន

CS vin.pv.02.08 | ភាគ ទី១២

### (៨. អទ្ធានសមុដ្ឋានំ)

[៨៣៤] អទ្ធានគមនសិក្ខាបទ[70) ១ នាវាភិរូហនសិក្ខាបទ ១ បណីតភោជនសិក្ខាបទ ១ មាតុគ្គាមសំវិធានសិក្ខាបទ ១ លោមសំហរណសិក្ខាបទ ១ ធញ្ញវិញ្ញាបនសិក្ខាបទ ១ និមន្តនសិក្ខាបទ ១ បាដិទេសនីយសិក្ខាបទ៨ រួមទាំងអស់ ត្រូវជា១៥ សិក្ខាបទ សិក្ខាបទទាំងអស់នេះ ព្រះពុទ្ធទ្រង់ញាណ បានបញ្ញត្តហើយដោយសមុដ្ឋានបួន ៗ គឺកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា ទាំងមិនកើតឡើងអំពីចិត្ត ១ កើតឡើង អំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីកាយ និងចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីកាយវាចា និងចិត្ត ១ មានទំនងដូចអទ្ធានគមនសិក្ខាបទដែរ។

ចប់ អទ្ធានសមុដ្ឋាន។

# សមុដ្ឋានសីសសង្ខេប ថេយ្យសត្ថសមុដ្ឋាន

CS vin.pv.02.09 | ភាគ ទី១២

### (៩. ថេយ្យសត្ថសមុដ្ឋានំ)

[៨៣៥]

ថេយ្យសត្ថសិក្ខាបទ ១ ឧបស្សុតិសិក្ខាបទ ១ សូបវិញ្ញាបនសិក្ខាបទ ១ រត្តន្ធការសិក្ខាបទ ១ បដិច្ឆន្នសិក្ខាបទ ១ អជ្ឈោកាសសិក្ខាបទ ១ ព្យូហសិក្ខាបទ ១ សិក្ខាបទទាំងអស់ នេះរួមគ្នាត្រូវជា៧ សិក្ខាបទទាំងនេះ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់សម្តែងហើយថា មានសមុដ្ឋានពីរ ៗ គឺកើតឡើងអំពី កាយនិងចិត្ត មិនកើតឡើងអំពីវាចា ១ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចានិងចិត្ត ១ ដូចសមុដ្ឋានរបស់ថេយ្យសត្ថសិក្ខាបទដែរ។

ចប់ ថេយ្យសត្ថសមុដ្ឋាន។

# សមុដ្ឋានសីសសង្ខេប ធម្មទេសនាសមុដ្ឋាន

CS vin.pv.02.10 | ភាគ ទី១២

### (១០. ធម្មទេសនាសមុដ្ឋានំ)

[៨៣៦] ព្រះតថាគតទាំងឡាយ មិនសម្តែងនូវព្រះសទ្ធម្មដល់បុគ្គល (មិនមានជំងឺ) មានឆត្រក្នុងដៃ១ មានឈើច្រត់ក្នុងដៃ១ មានសស្ត្រាក្នុងដៃ១ មានអាវុធក្នុងដៃ ១ ពាក់ទ្រនាប់ ជើងឈើឬស្បៅ១ ពាក់ទ្រនាប់ជើងស្បែក១ នៅលើយាន ១ នៅលើដំណេក ១ អង្គុយត្របោមក្បាលជង្គង់១ ជួតឈ្នួតក្បាល ១ ទទូរក្បាល ១ (រឿងទាំងនេះរួមគ្នាជា) សិក្ខាបទ ១១ គត់ សិក្ខាបទទាំងអស់នេះ សុទ្ធតែមានសមុដ្ឋានមួយ ៗ គឺកើតឡើងអំពីវាចានឹងចិត្ត មិនកើតឡើងអំពីកាយទេ ដូចធម្មទេសនាសិក្ខាបទដែរ។

ចប់ ធម្មទេសនាសមុដ្ឋាន។

# ភូតារោចនសមុដ្ឋាន

CS vin.pv.02.11 | ភាគ ទី១២

### (១១. ភូតារោចនសមុដ្ឋានំ)

[៨៣៧] ភូតសិក្ខាបទ ឈ្មោះថាភូតារោចនសិក្ខាបទ កើតឡើងអំពីសមុដ្ឋាន ៣ គឺកើតឡើងអំពីកាយ មិនកើតឡើង អំពីវាចា មិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពីវាចា មិនកើត ឡើងអំពីកាយ ទាំងមិនកើតឡើងអំពីចិត្ត ១ កើតឡើងអំពី កាយនិងវាចា មិនកើតឡើងអំពីចិត្ត ១។

ចប់ ភូតារោចនសមុដ្ឋាន។

## សមុដ្ឋានសីសសង្ខេប ចោរីវុដ្ឋាបនសមុដ្ឋាន

CS vin.pv.02.12 | ភាគ ទី១២

### (១២. ចោរិវុដ្ឋាបនសមុដ្ឋានំ)

[៨៣៨] ចោរីវុដ្ឋាបនសិក្ខាបទ កើតឡើងអំពីវាចានិងចិត្ត សិក្ខាបទនោះមិនកើតឡើងអំពីកាយ ១ (ម្យ៉ាងទៀត) ចោរីវុដ្ឋាបនសិក្ខាបទ កើតឡើងអំពីទ្វារទាំង ៣ គឺកាយវាចានិង ចិត្ត ១ សិក្ខាបទនេះ ព្រះសម្មាសម្ពុទ្ធ ជាធម្មរាជទ្រង់សម្តែង ហើយថា មានសមុដ្ឋានពីរ និងជាអកិរិយា (ត្រូវអាបត្តិព្រោះ មិនធ្វើ គឺមិនបានប្រាប់គេជាមុនហើយបំបួស)។

ចប់ ចោរីវុដ្ឋាបនសមុដ្ឋាន។

## សមុដ្ឋានសីសសង្ខេប អននុញ្ញាតសមុដ្ឋាន

CS vin.pv.02.13 | ភាគ ទី១២

### (១៣. អននុញ្ញាតសមុដ្ឋានំ)

[៨៣៩] អននុញ្ញាតសិក្ខាបទមានសមុដ្ឋាន ៤ ជាអកិរិយា គឺកើតឡើងអំពីវាចា មិនកើតឡើងអំពីកាយ ទាំងមិនកើតឡើង អំពីចិត្ត ១ សិក្ខាបទនោះ កើតឡើងអំពីកាយនិងវាចា មិនកើតឡើងអំពីចិត្ត ១ សិក្ខាបទនោះ កើតឡើងអំពីវាចានិងចិត្ត មិនកើតឡើងអំពីកាយ ១ កើតឡើងអំពីសមុដ្ឋានទាំង ៣ គឺ កាយវាចានិងចិត្ត ១។

ចប់ អននុញ្ញាតសមុដ្ឋាន។

[៨៤០] សេចក្តីថា សមុដ្ឋានសង្ខេបទាំង ១៣ (នេះ) ព្រះ សម្មាសម្ពុទ្ធទ្រង់សម្តែងប្រពៃហើយ ដើម្បីធ្វើមិនឱ្យភាន់ច្រឡំ សមគួរដល់វិន័យនិងបាលីនិងធម៌ បណ្ឌិតអ្នកទ្រទ្រង់វិន័យនេះ កុំភាន់ច្រឡំក្នុងសមុដ្ឋានឡើយ។

ចប់ សមុដ្ឋានសីសសង្ខេប។

# (អន្តរបេយ្យាល)

CS vin.pv.03 | ភាគ ទី១២

### (អន្តរបេយ្យាលំ)

## កតិបុច្ឆាវារៈ

CS vin.pv.03.00 | ភាគ ទី១២

### (កតិបុច្ឆាវារោ)

[៨៤១] (សួរថា) អាបត្តិមានប៉ុន្មាន។ កងនៃអាបត្តិ មាន ប៉ុន្មាន។ វិនីតវត្ថុមានប៉ុន្មាន។ សេចក្តីមិនគោរពមានប៉ុន្មាន។ សេចក្តីគោរពមានប៉ុន្មាន។ វិនីតវត្ថុមានប៉ុន្មាន។ វិបត្តិមានប៉ុន្មាន។ សមុដ្ឋាននៃអាបត្តិ មានប៉ុន្មាន។ មូលនៃវិវាទមានប៉ុន្មាន។ មូលនៃអនុវាទមានប៉ុន្មាន។ សារាណីយធម៌មានប៉ុន្មាន។ ភេទករវត្ថុ (រឿងដែលធ្វើឱ្យបែកគ្នា) មានប៉ុន្មាន។ អធិករណ៍ មានប៉ុន្មាន។ សមថៈមានប៉ុន្មាន។

[៨៤២] (ឆ្លើយថា) អាបត្តិមាន៥។ កងនៃអាបត្តិមាន៥។ វិនីតវត្ថុមាន ៥។ អាបត្តិមាន ៧។ កងនៃអាបត្តិ មាន ៧។ វិនីតវត្ថុមាន ៧។ សេចក្តីមិនគោរពមាន ៦។ សេចក្តីគោរពមាន ៦។ វិនីតវត្ថុមាន ៦។ វិបត្តិមាន ៤។ សមុដ្ឋាននៃអាបត្តិមាន ៦។ មូលនៃវិវាទមាន ៦។ មូលនៃអនុវាទមាន៦។ សារាណីយធម៌មាន៦។ ភេទករវត្ថុមាន១៨។ អធិករណ៍មាន៤។ សមថៈមាន៧។

[៨៤៣] អាបត្តិ៥ក្នុងមាតិកាទាំងអស់នោះ ដូចម្តេចខ្លះ។ (អាបត្តិ ៥) គឺ អាបត្តិបារាជិក ១ អាបត្តិសង្ឃាទិសេស ១ អាបត្តិបាចិត្តិយៈ ១ អាបត្តិបាដិទេសនីយៈ ១ អាបត្តិទុក្កដ ១។ នេះ ជាអាបត្តិ៥។

[៨៤៤] កងនៃអាបត្តិទាំង៥ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (កងនៃអាបត្តិ៥) គឺ កងនៃអាបត្តិបារាជិក ១ កងនៃអាបត្តិសង្ឃាទិសេស ១ កងនៃអាបត្តិបាចិត្តិយៈ ១ កងនៃអាបត្តិបាដិទេសនីយៈ ១ កងនៃអាបត្តិទុក្កដ១។ នេះ ជាកងនៃអាបត្តិ៥។

[៨៤៥] វិនីតវត្ថុ មាន ៥ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (វិនីតវត្ថុ ៥) គឺកិរិយាវៀរឱ្យឆ្ងាយ វៀរឱ្យស្រឡះ វៀរចំពោះ ចៀសវាង ចាកកងនៃអាបត្តិទាំង ៥ គឺថា កិរិយាមិនធ្វើ មិនបង្កើត (នូវកងអាបត្តិ) មិនឱ្យត្រូវអាបត្តិ មិនកន្លងនូវដែន (នៃអាបត្តិ) សម្លាប់បង់នូវកងនៃអាបត្តិ។ នេះជា

វិនីតវត្ថុ៥។

[៨៤៦] អាបត្តិ៧ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ អាបត្តិ៧ គឺអាបត្តិបារាជិក១ អាបត្តិសង្ឃាទិសេស១ អាបត្តិថុល្លច្ច័យ១ អាបត្តិបាចិត្តិយៈ១ អាបត្តិបាដិទេសនីយៈ១ អាបត្តិទុក្កដ ១ អាបត្តិទុព្ភាសិត១។ នេះជាអាបត្តិ៧។

[៨៤៧] កងនៃអាបត្តិ៧ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (កងនៃអាបត្តិ៧) គឺ កងនៃអាបត្តិបារាជិក១ កងនៃអាបត្តិសង្ឃាទិសេស១ កងនៃអាបត្តិថុល្លច្ច័យ១ កងនៃអាបត្តិបាចិត្តិយៈ១ កងនៃអាបត្តិបាដិទេសនីយៈ១ កងនៃអាបត្តិទុក្កដ១ កងនៃអាបត្តិទុព្ភាសិត១។ នេះជាកងនៃអាបត្តិ៧។

[៨៤៨] វិនីតវត្ថុមាន៧ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (វិនីតវត្ថុមាន៧) គឺ កិរិយាវៀរឱ្យឆ្ងាយ វៀរឱ្យស្រឡះ វៀរចំពោះ ចៀសវាងចាកកងនៃអាបត្តិទាំង៧ គឺថា កិរិយាមិនធ្វើ មិនបង្កើត(នូវកងនៃអាបត្តិ) មិនឱ្យត្រូវអាបត្តិ មិនកន្លងនូវដែន (នៃអាបត្តិ) សម្លាប់ បង់នូវកងនៃអាបត្តិ។ នេះជាវិនីតវត្ថុ៧។

[៨៤៩] សេចក្តីមិនគោរព៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (សេចក្តីមិនគោរព៦ ) គឺ ការមិនគោរពព្រះពុទ្ធ១ មិនគោរពព្រះធម៌១ មិនគោរពព្រះសង្ឃ១ មិនគោរពសិក្ខា១ មិនគោរព សេចក្តីមិនប្រមាទ១ មិនគោរពការបដិសន្ថារៈ១។ នេះជាសេចក្តីមិនគោរព៦។

[៨៥០] សេចក្តីគោរព៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (សេចក្តីគោរព៦) គឺ ការគោរពព្រះពុទ្ធ ១ គោរពព្រះធម៌ ១ គោរពព្រះសង្ឃ ១ គោរពសិក្ខា ១ គោរពសេចក្តីមិនប្រមាទ១ គោរពក្នុងការបដិសន្ថារៈ១។ នេះជាសេចក្តីគោរព៦យ៉ាង។

[៨៥១] វិនីតវត្ថុ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (វិនីតវត្ថុ ៦) គឺ កិរិយាវៀរឱ្យឆ្ងាយ វៀរឱ្យស្រឡះ វៀរចំពោះ ចៀសវាងចាក សេចក្តីមិនគោរពទាំង៦ គឺថា កិរិយាមិនធ្វើ មិនបង្កើត (នូវសេចក្តីមិនគោរព) មិនឱ្យត្រូវ មិនកន្លងនូវដែន (នៃសេចក្តីមិនគោរព) សម្លាប់បង់នូវអគារវៈ។ នេះជាវិនីតវត្ថុ៦។

[៨៥២] វិបត្តិ៤ ក្នុងមាតិកាទាំងនោះដូចម្តេចខ្លះ។ វិបត្តិ៤ គឺ សីលវិបត្តិ១ អាចារវិបត្តិ១ ទិដ្ឋិវិបត្តិ១ អាជីវវិបត្តិ២។ នេះជាវិបត្តិ៤។

[៨៥៣] សមុដ្ឋាននៃអាបត្តិ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (សមុដ្ឋាននៃអាបត្តិ ៦) គឺ អាបត្តិកើតឡើងអំពីកាយ មិនកើតឡើងអំពីវាចា មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើងអំពីវាចា មិនកើត ឡើងអំពីកាយ មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើង អំពីកាយផង អំពីវាចាផង មិនកើតឡើងអំពីចិត្ត ១ អាបត្តិកើតឡើង អំពីកាយផង អំពី ចិត្តផង មិនកើតឡើងអំពីវាចា ១ អាបត្តិកើតឡើង អំពីវាចាផង អំពីចិត្ត ផង មិនកើតឡើងអំពីកាយ ១ អាបត្តិកើតឡើង អំពីកាយផង អំពីវាចាផង អំពីចិត្តផង១។ នេះ ជាសមុដ្ឋាននៃអាបត្តិទាំង ៦។

[៨៥៤] មូលនៃវិវាទ ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (មូលនៃវិវាទទាំង ៦) គឺ ភិក្ខុក្នុងសាសនានេះ ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុណា ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុនោះ ឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរពមិនឱនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោនក្នុងព្រះសង្ឃផង មិនធ្វើឱ្យបរិបូណ៌ក្នុងសិក្ខាផង។ ភិក្ខុណាមិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង។ បេ។ ក្នុងព្រះសង្ឃផង។ បេ។ មិនធ្វើឱ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះ ឈ្មោះថា ជាអ្នកញុំាងវិវាទឱ្យកើតឡើងក្នុងសង្ឃ។ វិវាទណា ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីសេចក្តីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ។ បើអ្នកទាំងឡាយ ពិចារណាឃើញ នូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬ ក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមលះបង់ នូវមូលនៃវិវាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួន និងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួន ឬ ក្នុងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយ មិនបានពិចារណា ឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីកុំឱ្យមូលនៃវិវាទដ៏លាមកនោះឯង ប្រព្រឹត្តទៅក្នុងអនាគតទៀតបាន ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះ។ ការលះបង់នូវមូលនៃវិវាទដ៏លាមកនោះ រមែងមានដោយប្រការយ៉ាងនេះ ការដែល មិនឱ្យមូលនៃវិវាទដ៏លាមកនោះប្រព្រឹត្តទៅក្នុងអនាគតទៀត រមែងមានដោយប្រការយ៉ាងនេះ។ ពាក្យខាងមុខនៅមានទៀត ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកលើកខ្លួន (ប្រណាំងវាសនា)។ បេ។ ជាអ្នកច្រណែន ជាអ្នកកំណាញ់ ជាអ្នកអួតអាង លាក់ពុត ជាអ្នកមានសេចក្តីប្រាថ្នាលាមក មានទិដ្ឋិអាក្រក់ ជាអ្នកប្រកាន់តាមសេចក្តីយល់របស់ខ្លួន ទាំងប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុណាជាអ្នកប្រកាន់តាមសេចក្តីយល់របស់ខ្លួន ទាំងប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុនោះឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោន ក្នុងព្រះសង្ឃផង មិនធ្វើឱ្យបរិបូណ៌ក្នុងសិក្ខាផង។ ភិក្ខុណាមិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង។ បេ។ ក្នុងព្រះសង្ឃផង។បេ។ មិនធ្វើឱ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញុំាងវិវាទឱ្យកើតឡើង ក្នុងសង្ឃ។ វិវាទណា ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីសេចក្តីមិនចម្រើនដល់ជនច្រើន ដើម្បី មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ។ បើអ្នកទាំងឡាយ ពិចារណាឃើញ នូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមលះបង់នូវមូលនៃវិវាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយមិនបាន ពិចារណាឃើញនូវមូលនៃវិវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីកុំឱ្យមូលនៃវិវាទដ៏លាមកនោះឯង ប្រព្រឹត្តទៅក្នុងអនាគតទៀតបាន ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួន និងបរិស័ទនៃបុគ្គលដទៃនោះ។ ការលះបង់នូវមូលនៃវិវាទដ៏លាមកនុ៎ះ រមែងមានដោយប្រការយ៉ាងនេះ ការដែលមិន ឱ្យមូលនៃវិវាទដ៏លាមកនុ៎ះ ប្រព្រឹត្តទៅក្នុងអនាគតទៀតបាន រមែងបានដោយប្រការយ៉ាងនេះ។ នេះ ជាមូលនៃវិវាទ៦។

[៨៥៥] មូលនៃអនុវាទ៦ ក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (មូលនៃអនុវាទ៦ គឺ) ភិក្ខុក្នុងសាសនានេះ ជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុណាជាអ្នកក្រោធ ចងនូវសេចក្តីក្រោធទុក ភិក្ខុនោះឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោន ក្នុងព្រះសង្ឃផង មិនធ្វើឱ្យបរិបូណ៌ក្នុងសិក្ខាផង។ ភិក្ខុណា ជាអ្នកមិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង ក្នុងព្រះធម៌ផង។បេ។ ក្នុងព្រះសង្ឃផង។បេ។ មិនធ្វើឱ្យបរិបូណ៌ក្នុងសិក្ខាផង ភិក្ខុនោះ ឈ្មោះថា ញុំាំងអនុវាទឱ្យកើតឡើងក្នុងសង្ឃ។ អនុវាទណា ប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនមែនជាសេចក្តីចម្រើន ដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ។ បើអ្នកទាំងឡាយ ពិចារណាឃើញនូវមូលនៃអនុវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមដើម្បីលះបង់នូវមូល នៃអនុវាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយ មិនពិចារណាឃើញនូវមូលនៃអនុវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីកុំឱ្យមូលនៃអនុវាទដ៏លាមកនោះឯងប្រព្រឹត្តទៅក្នុងអនាគតទៀតបាន ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃបុគ្គលដទៃនោះ។ ការលះ បង់នូវមូលនៃអនុវាទដ៏លាមកនុ៎ះ រមែងមានដោយប្រការយ៉ាងនេះ ការ ដែលមិនឱ្យមូលនៃអនុវាទដ៏លាមកនោះ ប្រព្រឹត្តទៅក្នុងអនាគតទៀតបាន រមែងមានដោយប្រការយ៉ាងនេះ។ មានពាក្យតទៅទៀតថា ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកលើកខ្លួន។ បេ។ ជាអ្នកច្រណែន ជាអ្នកកំណាញ់ ជាអ្នកអួតអាង ជាអ្នកលាក់ពុត ជាអ្នកមានប្រាថ្នាលាមក មានទិដ្ឋិអាក្រក់ ជាអ្នកប្រកាន់តាមសេចក្តីយល់របស់ខ្លួន ទាំងប្រកាន់មាំ លះបង់បាន ដោយកម្រ។ ភិក្ខុណា ដែលប្រកាន់តាមសេចក្តីយល់របស់ខ្លួន ប្រកាន់មាំ លះបង់បានដោយកម្រ ភិក្ខុនោះ ឈ្មោះថា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តាផង មិនគោរព មិនឱនលំទោន ក្នុងព្រះធម៌ផង មិនគោរព មិនឱនលំទោន ក្នុងព្រះសង្ឃផង មិនធ្វើឱ្យបរិបូណ៌ក្នុងសិក្ខាផង។ បេ។ ភិក្ខុណា មិនគោរព មិនឱនលំទោន ក្នុងព្រះសាស្តា ផង ក្នុងព្រះធម៌ផង។ បេ។ ក្នុងព្រះសង្ឃផង។ បេ។ មិនធ្វើឱ្យបរិបូណ៌ ក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា ញុំាំងអនុវាទឱ្យកើតឡើងក្នុងសង្ឃ។ អនុវាទណា ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ។ បើអ្នកទាំងឡាយ ពិចារណាឃើញ នូវមូលនៃអនុវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងរិស័ទនៃខ្លួនក្តី ក្នុងសន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវព្យាយាមលះបង់នូវមូលនៃអនុវាទដ៏លាមកនោះឯង ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិងបរិស័ទនៃ បុគ្គលដទៃនោះចេញ បើអ្នកទាំងឡាយមិនពិចារណាឃើញ នូវមូលនៃ អនុវាទមានសភាពយ៉ាងនេះ ក្នុងសន្តាននៃខ្លួន ឬក្នុងបរិស័ទនៃខ្លួនក្តី ក្នុង សន្តាននៃបុគ្គលដទៃ ឬក្នុងបរិស័ទនៃបុគ្គលដទៃក្តី អ្នកទាំងឡាយ ត្រូវ ប្រតិបត្តិ ដើម្បីកុំឱ្យមូលនៃអនុវាទដ៏លាមកនោះឯង ប្រព្រឹត្តទៅក្នុងអនាគតបាន ក្នុងសន្តាននៃខ្លួននិងសន្តាននៃបុគ្គលដទៃ ក្នុងបរិស័ទនៃខ្លួននិង បរិស័ទនៃបុគ្គលដទៃនោះ។ ការលះបង់នូវមូលនៃអនុវាទដ៏លាមកនុ៎ះ រមែងមានដោយប្រការយ៉ាងនេះ ការដែលមិនឱ្យមូលនៃអនុវាទដ៏លាមក នុ៎ះប្រព្រឹត្តទៅក្នុងអនាគតបាន រមែងមានដោយប្រការយ៉ាងនេះ។ នេះ ជាមូលនៃអនុវាទ៦យ៉ាង។

[៨៥៦] សារាណីយធម៌ ៦ ក្នុងមាតិកាទាំងនេះ ដូចម្តេចខ្លះ។ ( សារាណីយធម៌៦ គឺ ) ភិក្ខុ ក្នុងសាសនានេះ បានតាំងកាយកម្ម ប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារិបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរព ដល់សព្រហ្មចារិបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីការព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់។ មានពាក្យតទៅទៀតថា ភិក្ខុ(ក្នុងសាសនានេះ) បានតាំងវចីកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្ម ចារិបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះ ថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរពដល់សព្រហ្មចារិបុគ្គល ប្រព្រឹត្តទៅដើម្បី សេចក្តីសង្គ្រោះ ដើម្បីសេចក្តីមិនវិវាទ ដើម្បីការព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់។ មានពាក្យតទៅទៀតថា ភិក្ខុ (ក្នុងសាសនានេះ) បានតាំងមនោកម្មប្រកបដោយមេត្តា ក្នុងពួកព្រហ្មចារិបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរពដល់ សព្រហ្មចារិបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីសេចក្តីមិនវិវាទ ដើម្បីការព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់។ មានពាក្យតទៅទៀតថា លាភណា ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីគ្រាន់តែអាហារបិណ្ឌបាត ភិក្ខុអ្នកមិនទាន់បានបរិភោគ ទាំងមិនទាន់បានចែកលាភដូច្នោះនៅឡើយ ជាអ្នកបរិភោគសាធារណៈ (ជាមួយ) នឹងសព្រហ្មចារិបុគ្គលអ្នកមានសីលទាំងឡាយ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរព ដល់សព្រហ្មចារិបុគ្គល ប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីការព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់។ មានពាក្យតទៅទៀតថា សីលណា ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ ជាសីលជាល្អ ជាសីលដែលអ្នកប្រាជ្ញតែង សរសើរ ជាសីលដែលតណ្ហានិងទិដ្ឋិមិនបានប៉ះពាល់ ជាសីលប្រព្រឹត្ត ទៅដើម្បីសមាធិ[71] ភិក្ខុជាអ្នកមានសីលស្មើគ្នា ក្នុងសីលទាំងឡាយ មានសភាពដូច្នោះ ជាមួយនឹងសព្រហ្មចារិបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរពដល់សព្រហ្មចារិបុគ្គល ប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីការព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់។ ពាក្យតទៅទៀតថា ទិដ្ឋិណា ដ៏ប្រសើរ ជាទីនាំសត្វចេញចាកវដ្តទុក្ខ របស់បុគ្គលអ្នកធ្វើយ៉ាងនោះ ដើម្បីជាទីអស់ទៅនៃកងទុក្ខដោយប្រពៃ ភិក្ខុប្រកបដោយសេចក្តីយល់ឃើញស្មើគ្នា ដោយទិដ្ឋិមានសភាពដូច្នោះ (ជាមួយ)នឹងសព្រហ្មចារិបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះ ថា ធ្វើនូវសេចក្តីគោរពដល់សព្រហ្មចារិបុគ្គល ប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីការព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់។ នេះជាសារាណីយធម៌៦។

[៨៥៧] ភេទករវត្ថុ ១៨ ដែលមកក្នុងមាតិកាទាំងនេះ ដូចម្តេចខ្លះ។ (ភេទករវត្ថុ ១៨ នោះគឺ) ភិក្ខុក្នុងសាសនានេះ សម្តែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សម្តែងនូវធម៌ ថាមិនមែនធម៌១ សម្តែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សម្តែងនូវវិន័យថាមិនមែនវិន័យ១ សម្តែងនូវធម្មវិន័យ ដែលតថាគតមិនបានសម្តែង មិនបានពោល ថាតថាគតបានសម្តែង បានពោល១ សម្តែងនូវធម្មវិន័យដែលតថាគតបានសម្តែង បានពោល ថាតថាគតមិនបានសម្តែង មិនបានពោល១ សម្តែងនូវវត្តដែលតថាគត មិនបានសន្សំមកហើយ ថាជាវត្តដែលតថាគត បានសន្សំមក១ សម្តែងនូវវត្តដែលតថាគតបានសន្សំមកហើយ ថាជាវត្តដែលតថាគតមិនបានសន្សំមកហើយ១ សម្តែងនូវសិក្ខាបទដែលតថាគតមិនបានបញ្ញត្ត

ថាតថាគតបានបញ្ញត្ត១ សម្តែងនូវសិក្ខាបទដែលតថាគតបានបញ្ញត្ត ថាតថាគតមិនបានបញ្ញត្ត១ សម្តែងនូវអាបត្តិ ថាជាអនាបត្តិ១ សម្តែងនូវអនាបត្តិ ថាជាអាបត្តិ១ សម្តែងនូវលហុកាបត្តិ ថាជាគរុកាបត្តិ១ សម្តែងនូវគរុកាបត្តិ ថាជាលហុកាបត្តិ១ សម្តែងនូវសាវសេសាបត្តិ ថាជាអនវសេសាបត្តិ១ សម្តែងនូវអនវសេសាបត្តិ ថាជាសាវសេសាបត្តិ១ សម្តែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ១ សម្តែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ១។ នេះជាភេទករវត្ថុ១៨។

[៨៥៨] អធិករណ៍៤ ដែលមកក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (អធិករណ៍៤នោះគឺ) វិវាទាធិករណ៍១ អនុវាទាធិករណ៍១ អាបត្តាធិករណ៍១ កិច្ចាធិករណ៍១។ នេះជាអធិករណ៍៤។

[៨៥៩] សមថៈ៧ ដែលមកក្នុងមាតិកាទាំងនោះ ដូចម្តេចខ្លះ។ (សមថៈ៧នោះ គឺ) សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ១។ នេះ ជាសមថៈ៧។

ចប់ កតិបុច្ឆាវារៈ។

ឧទ្ទាននៃកតិបុច្ឆាវារៈនោះ ដូច្នោះ

[៨៦០]

> និយាយពីអាបត្តិ១ កងនៃអាបត្តិ១ វត្ថុដែលព្រះអង្គទ្រង់វិនិច្ឆ័យហើយ១ អាបត្តិ ៧ យ៉ាង១ និងកងនៃអាបត្តិ៧ទៀត១ វត្ថុដែលព្រះអង្គទ្រង់វិនិច្ឆ័យហើយ៧ទៀត១ អគារវៈ១ គារវៈជាមូល១ វត្ថុដែលព្រះអង្គទ្រង់វិនិច្ឆ័យហើយ៦ទៀត ១ វិបត្តិ ១ សមុដ្ឋាន (នៃអាបត្តិ)១ វិវាទមូល១ អនុវាទមូល១ សារាណីយធម៌១ ភេទករវត្ថុ១ អធិករណ៍១។ សមថៈ៧ ដែលលោកពោលហើយ រួមជាបទ១៧នេះឯង។

# វារៈនៃអាបត្តិសមុដ្ឋាន៦ ទី១

CS vin.pv.03.01 | ភាគ ទី១២

**(១. ឆអាបត្តិសមុដ្ឋានវារោ)**

[៨៦១] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិជាបឋម ដែរឬទេ។ មិនត្រូវទេ។ ត្រូវអាបត្តិសង្ឃាទិសេស (ដោយសមុដ្ឋាននៃអាបត្តិជាបឋម) ឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិ បាដិទេសនីយៈឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិទុក្កដឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិទុព្ភាសិត (ដោយសមុដ្ឋាននៃអាបត្តិជាបឋម) ឬទេ។ មិនត្រូវទេ។

[៨៦២] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី២ ឬទេ។ មិនត្រូវទេ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ។ មិនត្រូវទេ។ ត្រូវអាបត្តិ ទុក្កដឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិទុព្ភាសិតឬទេ។ មិនត្រូវទេ។

[៨៦៣] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី៣ ឬទេ។ មិនត្រូវទេ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ។ មានត្រូវដែរ។ ត្រូវ អាបត្តិទុក្កដឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិទុព្ភាសិតឬទេ។ មិនត្រូវទេ។

[៨៦៤] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី៤ឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិទុក្កដឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិទុព្ភាសិតឬទេ។ មិនត្រូវទេ។

[៨៦៥] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី៥ឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ។ មិនត្រូវទេ។ ត្រូវអាបត្តិទុក្កដឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិទុព្ភាសិត ឬទេ។ មានត្រូវដែរ។

[៨៦៦] ភិក្ខុត្រូវអាបត្តិបារាជិក ដោយសមុដ្ឋាននៃអាបត្តិទី៦ឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិសង្ឃាទិសេសឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិថុល្លច្ច័យឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាចិត្តិយៈឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិបាដិទេសនីយៈឬទេ។ មានត្រូវដែរ។ ត្រូវ អាបត្តិទុក្កដឬទេ។ មានត្រូវដែរ។ ត្រូវអាបត្តិទុព្ភាសិតឬទេ។ មិនត្រូវទេ។

ចប់ វារៈនៃអាបត្តិសមុដ្ឋាន៦ ជាបឋម។

# កតាបត្តិវារៈ ទី២

CS vin.pv.03.02 | ភាគ ទី១២

## (២. កតាបត្តិវារោ)

[៨៦៧] ភិក្ខុត្រូវអាបត្តិប៉ុន្មានយ៉ាង ដោយសមុដ្ឋាននៃអាបត្តិទី១។ ត្រូវអាបត្តិ៥ ដោយសមុដ្ឋាននៃអាបត្តិទី១ គឺភិក្ខុសម្គាល់ថាគួរ ហើយធ្វើកុដិ ដោយការសូមគេមកដោយខ្លួនឯង តែឥតមានសង្ឃសម្តែងទីឱ្យ ធ្វើឱ្យហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិ ទុក្កដរាល់ប្រយោគ កាលនៅតែបាយអំបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ កាលបើបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុសម្គាល់ថាគួរ ហើយបរិភោគជនីយាហារក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុសម្គាល់ថា គួរ ហើយទទួលខាទីយៈ ឬភោជនីយាហារ អំពីដៃភិក្ខុនីមិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះ ផ្ទះ ដោយដៃខ្លួនឯង យកមកបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុត្រូវអាបត្តិទាំង៥នេះ ដោយសមុដ្ឋាននៃអាបត្តិទី១។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិ ទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍អ្វី។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺ សីល វិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិទាំង ៧ លោក សង្គ្រោះដោយកងនៃអាបត្តិ ៥ គឺ កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិ បាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីកាយ មិន បានតាំងឡើងអំពីវាចា ទាំងមិនបានតាំងឡើងអំពីចិត្តឡើយ។ បណ្តា អធិករណ៍ទាំង ៤ អាបត្តិទាំងនោះ ចាត់ជាអាបត្តាធិករណ៍។ បណ្តា សមថៈ ៧ រម្ងាប់ដោយសមថៈទាំង ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញា តករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។

[៨៦៨] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ដោយសមុដ្ឋាននៃអាបត្តិទី ២។ ភិក្ខុត្រូវអាបត្តិ ៤ ដោយសមុដ្ឋាននៃអាបត្តិទី ២ គឺ ភិក្ខុសម្គាល់ថា គួរ ក៏បបួល (ពួកភិក្ខុផងគ្នា)ថា លោកទាំងឡាយចូរធ្វើកុដិឱ្យខ្ញុំ ភិក្ខុទាំងឡាយ ក៏ធ្វើកុដិ ចំពោះភិក្ខុនោះ ឥតមានពួកភិក្ខុសម្តែងទីឱ្យ ធ្វើឱ្យហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុសម្គាល់ថា គួរ ក៏បង្រៀនធម៌ជាបទ ចំពោះអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុត្រូវអាបត្តិ ៤ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ២។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនោះ រាប់ញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បេ។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់ បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តា កងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងអាបត្តិ ៤ គឺ កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈ ក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋានតែ ១ គឺ តាំងឡើងអំពីវាចា មិនតាំងឡើងអំពី កាយ មិនតាំងឡើងអំពីចិត្តឡើយ។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជា អាបត្តាធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។

[៨៦៩] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ដោយសមុដ្ឋាននៃអាបត្តិទី៣។ ត្រូវអាបត្តិ៥ ដោយសមុដ្ឋាននៃអាបត្តិទី ៣ គឺ ភិក្ខុសម្គាល់ថាគួរ ក៏ចាត់ចែងធ្វើកុដិ ឥតមានពួកភិក្ខុសម្តែងទីឱ្យ ធ្វើឱ្យហួសប្រមាណមាន ហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅ តែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុសម្គាល់ថាគួរ ក៏សូមបណីតភោជនដើម្បីខ្លួនមកឆាន់ ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុសម្គាល់ថាគួរ ហើយកាលបើមានភិក្ខុនីមកឈរបង្គាប់ (ឱ្យគេអង្គាសភោជន) មិនបានហាមឃាត់ ហើយឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុត្រូវអាបត្តិ ៥ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ៣។ បណ្តាវិបត្តិទាំង ៤ អាបត្តិ ទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។បេ។ បណ្តាសមថៈទាំង៧ យ៉ាងរម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់ បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺ កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈ ក៏មាន កងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋានតែ ១ គឺ តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តឡើយ។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

[៨៧០] ភិក្ខុត្រូវអាបត្តិប៉ុន្មានដោយសមុដ្ឋាននៃអាបត្តិទី៤។ ភិក្ខុត្រូវអាបត្តិ៦ ដោយសមុដ្ឋាននៃអាបត្តិទី៤គឺ ភិក្ខុសេពមេថុនធម្ម ត្រូវអាបត្តិបារាជិក។ ភិក្ខុសម្គាល់ថា មិនគួរ ក៏ធ្វើកុដិដោយការសូមគេខ្លួនឯង ឥតមានពួកភិក្ខុសម្តែងទីឱ្យ ធ្វើឱ្យហួសប្រមាណ មាន ហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែ បាយអប៉ូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុសម្គាល់ថា មិនគួរ ក៏បរិភោគភោជនាហារក្នុងវិកាល ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុសម្គាល់ថាមិនគួរ ក៏ទទួលខាទនីយៈ ភោជនីយាហារ អំពីដៃភិក្ខុនីមិនមែនជាញាតិ ដែលចូលទៅក្នុងចន្លោះផ្ទះ ដោយដៃរបស់ខ្លួន យកមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុត្រូវអាបត្តិ៦នេះ ដោយសមុដ្ឋាននៃអាបត្តិទី៤។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់ញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បេ។ បណ្តាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារ វិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិ៧ លោកសង្គ្រោះដោយ កងនៃអាបត្តិ៦ គឺ កងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈ ក៏មាន កងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយនិងចិត្ត មិនតាំងឡើងអំពីវាចាឡើយ។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាអធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

[៨៧១] ភិក្ខុត្រូវអាបត្តិប៉ុន្មានដោយសមុដ្ឋាននៃអាបត្តិទី៥។ ត្រូវអាបត្តិ៦ ដោយសមុដ្ឋាននៃអាបត្តិទី៥គឺ ភិក្ខុមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចនៃសេចក្តីប្រាថ្នា ក៏ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន ដែលមិនពិត ត្រូវអាបត្តិបារាជិក។ ភិក្ខុសម្គាល់ថា មិនគួរ ក៏បបួល (ភិក្ខុផងគ្នា) ថា លោកទាំងឡាយ ចូរធ្វើកុដិដើម្បីយើង ភិក្ខុទាំងឡាយ ក៏ធ្វើកុដិចំពោះភិក្ខុនោះ ឥតមានពួកភិក្ខុសម្តែងទី ឱ្យធ្វើឱ្យហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុសម្គាល់ថាមិនគួរ ក៏បង្រៀនធម៌ជាបទចំពោះអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុមិន

ប្រាថ្នាដើម្បីជេរ មិនប្រាថ្នាដើម្បីប្រទេច មិនប្រាថ្នាដើម្បីបង្អាប់បង្អោន ប្រាថ្នាតែនិយាយលេង ពោលសំដៅបុគ្គល ថោកទាបដោយពាក្យដ៏ថោកទាប ត្រូវអាបត្តិទុព្ភាសិត។ ភិក្ខុត្រូវអាបត្តិ ៦ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ៥។ បណ្ដាវិបត្តិ៤ អាបត្តិ ទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បេ។ បណ្ដាសមថៈ ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្ដាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូល ក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្ដាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៦ គឺ កងនៃ អាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន កងនៃអាបត្តិទុព្ភាសិតក៏មាន។ បណ្ដាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពី កាយឡើយ។ បណ្ដាអធិករណ៍ទាំង៤ ចាត់ជាអាបត្តាធិករណ៍។ បណ្ដាសមថៈទាំង៧ រម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុខាវិន័យនិង បដិញ្ញាតករណៈក៏មាន ដោយសម្មុវិន័យនិងតិណវត្ថារក ក៏មាន។

[៨៧២] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ដោយសមុដ្ឋាននៃអាបត្តិទី៦។ ភិក្ខុត្រូវអាបត្តិ ៦ ដោយសមុដ្ឋាននៃអាបត្តិទី ៦ គឺ ភិក្ខុបបួល (ភិក្ខុ ផងគ្នា) ទៅលួចទ្រព្យគេ ត្រូវអាបត្តិបារាជិក។ ភិក្ខុសម្គាល់ថាមិនគួរ ក៏ចាត់ចែងធ្វើកុដិ ឥតមានពួកភិក្ខុសម្ដែងទីឱ្យ ធ្វើឱ្យហួសប្រមាណ មាន ហេតុទាល់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅ តែបាយអបូកមួយដុំនឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ លុះបូកបាយអមួយដុំ នោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុសម្គាល់ថាមិនគួរក៏សូមបណីតភោជនដើម្បីខ្លួន យកមកឆាន់ ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុ សម្គាល់ថាមិនគួរ កាលបើមានភិក្ខុនីមកឈរបង្គាប់ (ឱ្យគេអង្គាសខា ទនីយភោជនីយាហារ) មិនបានហាមឃាត់ហើយឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុត្រូវអាបត្តិ ៦ នេះ ដោយសមុដ្ឋាននៃអាបត្តិទី ៦។ បណ្ដាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្ដាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើង ដោយសមុដ្ឋានប៉ុន្មាន។ បណ្ដាអធិករណ៍ទាំង ៤ ចាត់ជាអធិករណ៍ណា។ បណ្ដាសមថៈទាំង ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្ដាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្ដា កងនៃអាបត្តិទាំង ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិ ៦ គឺ កងនៃ អាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិបាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្ដាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺតាំងឡើងអំពីកាយវាចានិងចិត្ត។ បណ្ដាអធិករណ៍ទាំង៤ ចាត់ជាអាបត្តាធិករណ៍។ បណ្ដាសមថៈទាំង៧រម្ងាប់ ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។ ច

ចប់ សមុដ្ឋាននៃអាបត្តិ៦ និងកតាបត្តិវារៈ ជាគម្រប់ពីរ។

# អាបត្តិសមុដ្ឋានគាថា ទី៣

CS vin.pv.03.03 | ភាគ ទី១២

### (៣. អាបត្តិសមុដ្ឋានគាថា)

[៨៧៣] សួរថា សមុដ្ឋានដែលប្រកបដោយកាយ ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្ដែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីកាយនោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋាន ដែលកើតអំពីកាយនោះ សូមលោកឆ្លើយមក។ ឆ្លើយថា សមុដ្ឋានដែលប្រកបដោយកាយ ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្ដែងហើយថា អាបត្តិដែលតាំងឡើងអំពីកាយនោះ មាន៥កង។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំនឹងប្រាប់នូវសមុដ្ឋាន ដែលកើតឡើងអំពីកាយនុ៎ះ ដល់លោក។ សមុដ្ឋានដែលប្រកបដោយវាចា ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្ដែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីវាចានោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូម សួរសមុដ្ឋានដែលកើតអំពីវាចានោះ សូមលោកឆ្លើយមក។ សមុដ្ឋាន ដែលប្រកបដោយវាចា ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសំដែងហើយថា អាបត្តិដែលតាំងឡើងអំពីវាចានោះ មាន៤។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំប្រាប់សមុដ្ឋានដែលកើតអំពី វាចានោះដល់លោក។ សមុដ្ឋាន ដែលតាំងឡើងអំពីកាយ និងតាំងឡើងអំពីវាចា ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសំដែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីកាយ និងវាចានោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋានដែលតាំងឡើងអំពីកាយ និងវាចានោះ សូមលោកឆ្លើយកម។ សមុដ្ឋាន ដែលតាំងឡើងអំពីកាយ និងវាចា ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបីផុត មានព្រះហឫទ័យជាប្រយោជន៍ ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសំដែងហើយ ថា អាបត្តិ ដែលតាំងឡើងអំពីកាយ និងវាចានោះ មាន៥។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំប្រាប់នូវសមុដ្ឋាននុ៎ះដល់លោក។ សមុដ្ឋានដែលតាំងឡើងអំពីកាយ និងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្ដែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីកាយ និងចិត្តនោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរនូវសមុដ្ឋានដែលតាំងឡើងអំពីកាយ និងចិត្តនោះ សូមលោកឆ្លើយមក។ សមុដ្ឋាន ដែលតាំងឡើងអំពីកាយ និងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យ ជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្ដែងហើយថា អាបត្តិដែលតាំងឡើងអំពីកាយ និងចិត្តនោះ មាន៦។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំប្រាប់សមុដ្ឋានដែលតាំងឡើងអំពីកាយ និងចិត្តនោះ ដល់លោក។ សមុដ្ឋានដែលតាំងឡើងអំពីវាចា និងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្ដែងហើយថា អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីវាចា និងចិត្តនោះ បពិត្រ លោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋាន ដែលតាំងឡើងអំពីវាចា និងចិត្តនោះ សូមលោកឆ្លើយមក។ សមុដ្ឋាន ដែលតាំងឡើងអំពីវាចា និងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញ នូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្ដែងមកហើយថា អាបត្តិដែលតាំងឡើងអំពីវាចា និងចិត្តនោះ មាន៦។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំប្រាប់សមុដ្ឋាន ដែលតាំងឡើងអំពីវាចា និងចិត្តនោះ ដល់លោក។ សមុដ្ឋាន ដែលតាំងឡើងអំពីកាយវាចា និងចិត្ត ព្រះមានព្រះភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសំដែងហើយថា អាបត្តិប៉ុន្មាន

ដែលតាំងឡើងអំពីកាយវាចា និងចិត្តនោះ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំសូមសួរសមុដ្ឋាន ដែលតាំងឡើងអំពីកាយវាចា និងចិត្តនោះ សូមលោកឆ្លើយមក។ សមុដ្ឋាន ដែលតាំងឡើងអំពីកាយវាចា និងចិត្ត ព្រះមានព្រះ ភាគ ទ្រង់ឃើញនូវធម៌គ្មានទីបំផុត មានព្រះហឫទ័យជាប្រយោជន៍ដល់សត្វលោក ទ្រង់ឃើញនូវវិវេកធម៌ បានសម្តែងហើយថា អាបត្តិ ដែលតាំឡើងអំពីកាយវាចា និងចិត្តនោះ មាន៦។ បពិត្រលោកអ្នកឈ្លាសក្នុងវិភង្គ ខ្ញុំប្រាប់នូវសមុដ្ឋានដែលតាំងឡើងអំពីកាយវាចា និងចិត្តនោះ ដល់លោក។

ចប់ អាបត្តិសមុដ្ឋានគាថា ជាគម្រប់៣។

# វិបត្តិប្បច្ចយវារៈ ទី៤

CS vin.pv.03.04 | ភាគ ទី១២

### (៤. វិបត្តិបច្ចយវារោ)

[៨៧៤] សួរថា ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះសីលវិបត្តិជាបច្ច័យ។ (ឆ្លើយថា) ត្រូវអាបត្តិ៤ ព្រោះសីលវិបត្តិជាបច្ច័យ គឺ ភិក្ខុនីដឹងថា (ភិក្ខុនីផងគ្នា) ត្រូវអាបត្តិបារាជិកហើយ បិទបាំងទុក ត្រូវអាបត្តិបារាជិក។ ភិក្ខុនីមានសេចក្តីសង្ស័យ ហើយបិទបាំងទុក ត្រូវអាបត្តិ ថុល្លច្ច័យ។ ភិក្ខុបិទបាំងអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុបិទបាំងអាបត្តិអាក្រក់របស់ខ្លួន ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិ៤នេះ ព្រោះសីលវិបត្តិជាបច្ច័យ។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។បេ។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុង វិបត្តិ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិ៤ គឺ កងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយវាចានិងចិត្ត។ បណ្តាអធិករណ៍ទាំង ៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិង តិណវត្ថារកៈក៏មាន។

[៨៧៥] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះអាចារវិបត្តិជាបច្ច័យ។ ភិក្ខុត្រូវអាបត្តិ១ ព្រោះអាចារវិបត្តិជាបច្ច័យគឺ ភិក្ខុបិទបាំងអាចារវិបត្តិ (របស់ភិក្ខុផងគ្នា) ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិ១ នេះ ព្រោះអាចារវិបត្តិជាបច្ច័យ។ បណ្តាវិបត្តិទាំង ៤ អាបត្តិនោះ រាប់បញ្ចូលក្នុងវិបត្តិ ប៉ុន្មាន។ បេ។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង ៤ អាបត្តិនោះ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺ អាចារវិបត្តិ។ បណ្តាកងនៃអាបត្តិ៧ លោកគ្រោះដោយកងនៃអាបត្តិ ១ គឺ កងនៃអាបត្តិទុក្កដ។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋាន១ គឺតាំងឡើងអំពីកាយវាចានិងចិត្ត។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ៣គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណ៍ក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។

[៨៧៦] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះទិដ្ឋិវិបត្តិជាបច្ច័យ។ ភិក្ខុត្រូវអាបត្តិ ២ ព្រោះទិដ្ឋិវិបត្តិជាបច្ច័យ គឺ កាលភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មចប់ ជាគម្រប់៣ដងហើយ ភិក្ខុមិនព្រមលះបង់ទិដ្ឋិអាក្រក់ចេញ កាលបើចប់ញត្តិ ត្រូវអាបត្តិទុក្កដ កាលបើចប់កម្មវាចា២លើក ត្រូវអាបត្តិទុក្កដទាំងឡាយ លុះចប់កម្មវាចា ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុត្រូវអាបត្តិ២នេះ ព្រោះទិដ្ឋិវិបត្តិជាបច្ច័យ។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។បេ។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺ អាចារវិបត្តិ។ បណ្តាកងនៃអាបត្តិទាំង ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិ២ គឺ កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋាន ១ គឺ តាំងឡើងអំពីកាយវាចាចិត្ត។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មាន។

[៨៧៧] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះអាជីវវិបត្តិជាបច្ច័យ។ ត្រូវអាបត្តិ៦ ព្រោះអាជីវវិបត្តិជាបច្ច័យ គឺភិក្ខុមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្តីប្រាថ្នា ក៏ពោលអួតនូវឧត្តរិមនុស្សធម្ម ដែលមិនមាន មិនពិត ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបារាជិក។ ភិក្ខុនិយាយដឹកនាំបុរសស្ត្រីឱ្យបានគ្នាជាប្តីប្រពន្ធ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុនិយាយ (ប្រាប់គេ) ថា ភិក្ខុណា នៅក្នុងវិហាររបស់អ្នក ភិក្ខុនោះជាអរហន្ត ដូច្នេះ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ កាលបើអ្នកស្តាប់ដឹងសេចក្តីច្បាស់ (ភិក្ខុនោះ) ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុសូមបណីតភោជន ដើម្បីប្រយោជន៍ខ្លួនឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុ សូមបណីតភោជន ដើម្បីប្រយោជន៍ខ្លួនឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិបាដិទេសនីយៈ។ ភិក្ខុមិនឈឺ សូមសម្លក្តី បាយក្តី ដើម្បីប្រយោជន៍ខ្លួន យកមកឆាន់ ព្រោះហេតុអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិទុក្កដ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ ៦ នេះ ព្រោះអាជីវវិបត្តិជាបច្ច័យ។ បណ្តាវិបត្តិទាំង ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បេ។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ៦គឺ កងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិ បាដិទេសនីយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃ អាបត្តិទាំង ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ៦ គឺ តាំង ឡើងអំពីកាយ មិនតាំងឡើងអំពីវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីវាចា មិនតាំងឡើងអំពីកាយ មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយនិងវាចា មិនតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ ចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចាចិត្ត មិនតាំងឡើង អំពីកាយក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។

ចប់ វិបត្តិប្បច្ចយវារៈ ជាគម្រប់ ៤។

# អធិករណប្បច្ចយវារៈ ទី៥

CS vin.pv.03.05 | ភាគ ទី១២

**(៥. អធិករណបច្ចយវារោ)**

[៨៧៨] ភិក្ខុ ត្រូវអាបត្តិប៉ុន្មាន ព្រោះវិវាទាធិករណ៍ជាបច្ច័យ។ ភិក្ខុត្រូវអាបត្តិ ២ ព្រោះវិវាទាធិករណ៍ជាបច្ច័យ គឺ ភិក្ខុពោលពាក្យចាត់ដោតឧបសម្ប័ន្ន ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុពោលពាក្យចាត់ដោតអនុបសម្ប័ន្ន ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិ២ នេះ ព្រោះវិវាទាអធិករណ៍ជាបច្ច័យ។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បេ។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ ប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ១ គឺ អាចារវិបត្តិ។ បណ្តាកងនៃអាបត្តិ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ២ គឺ កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏ មាន។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ អាបត្តិទាំងនោះ តាំងឡើងដោយសមុដ្ឋាន ៣ គឺ តាំងឡើងអំពីកាយចិត្ត មិនតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចាចិត្ត មិនតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ វាចាចិត្តក៏មាន។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ៣គឺ ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។

[៨៧៩] ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះអនុវាទាធិករណ៍ជាបច្ច័យ។ ភិក្ខុត្រូវអាបត្តិ ៣ ព្រោះអនុវាទាធិករណ៍ជាបច្ច័យ គឺ ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិកមិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិ បាចិត្តិយៈ។ ភិក្ខុចោទភិក្ខុផងគ្នា ដោយអាចារវិបត្តិមិនមានមូល ត្រូវអាបត្តិទុក្កដ។ ភិក្ខុត្រូវអាបត្តិ ៣ នេះ ព្រោះអនុវាទាធិករណ៍ជាបច្ច័យ។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ប៉ុន្មាន។បេ។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិ៧ លោក សង្គ្រោះដោយកងនៃអាបត្តិ៣ គឺ កងនៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋាន៣ គឺ តាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចានិងចិត្ត មិនតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយវាចានិងចិត្តក៏មាន។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។

[៨៨០] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះអាបត្តាធិករណ៍ជាបច្ច័យ។ ត្រូវអាបត្តិ ៤ ព្រោះអាបត្តាធិករណ៍ជាបច្ច័យ គឺ ភិក្ខុនីដឹងថា (ភិក្ខុនីផងគ្នា) ត្រូវអាបត្តិបារាជិក ហើយបិទបាំងទុក ត្រូវអាបត្តិបារាជិក។ ភិក្ខុនីមានសេចក្តីសង្ស័យហើយ បិទបាំង (នូវអាបត្តិបារាជិក ដែលខ្លួនដឹងហើយ) ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុបិទបាំងអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុបិទបាំងអាចារវិបត្តិ ត្រូវអាបត្តិទុក្កដ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ៤ នេះ ព្រោះអាបត្តាធិករណ៍ជាបច្ច័យ។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បេ។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិទាំង៧ លោកសង្គ្រោះដោយ កងនៃអាបត្តិ៤ គឺ កងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យ ក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិទាំង ៦ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយវាចានិងចិត្ត។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុខាវិន័យនិង បដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។

[៨៨១] ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិប៉ុន្មាន ព្រោះកិច្ចាធិករណ៍ជាបច្ច័យ។ ត្រូវអាបត្តិ ៥ ព្រោះកិច្ចាធិករណ៍ជាបច្ច័យ គឺ ភិក្ខុនីជាអ្នកប្រព្រឹត្តតាមភិក្ខុនីដែលសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់ ៣ដងចប់ហើយ នៅតែមិនលះបង់ លុះចប់ញត្តិ ត្រូវអាបត្តិទុក្កដ ចប់កម្មវាចាពីរលើក ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ លុះចប់កម្មវាចា ត្រូវអាបត្តិបារាជិក។ ពួកភិក្ខុប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃសូត្រសមនុភាសនកម្ម ជាគម្រប់ ៣ ដងចប់ហើយ នៅតែមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស។ ភិក្ខុមានទិដ្ឋិអាក្រក់ កាលបើសង្ឃសូត្រសមនុភាសនកម្មជាគម្រប់ ៣ដងចប់ហើយ នៅតែមិន លះបង់ ត្រូវអាបត្តិបាចិត្តិយៈ។ ភិក្ខុ ភិក្ខុនី ត្រូវអាបត្តិ៥នេះ ព្រោះកិច្ចាធិករណ៍ជាបច្ច័យ។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បេ។ បណ្តាសមថៈ៧ រម្ងាប់ដោយសមថៈ ប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងនោះ រាប់បញ្ចូលក្នុងវិបត្តិ ២ គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន។ បណ្តាកងនៃអាបត្តិ៧ លោកសង្គ្រោះដោយកងនៃអាបត្តិ ៥ គឺ កងនៃអាបត្តិបារាជិកក៏មាន កង នៃអាបត្តិសង្ឃាទិសេសក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋាន១ គឺ តាំងឡើងអំពីកាយវាចាចិត្ត។ បណ្តាអធិករណ៍៤ ចាត់ជាអាបត្តាធិករណ៍។ បណ្តា សមថៈ៧ រម្ងាប់ដោយសមថៈ ៣ គឺ ដោយសម្មុខាវិន័យនិងបដិញ្ញាតករណៈក៏មាន ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក៏មាន។

[៨៨២] បណ្តាវិបត្តិទាំង៤ អាបត្តិទាំងឡាយដ៏សេស ក្រៅអំពីអាបត្តិ ៧ និងកងនៃអាបត្តិទាំង ៧ (នោះ) រាប់បញ្ចូលក្នុងវិបត្តិប៉ុន្មាន។ បណ្តាកងនៃអាបត្តិ៧ លោកសង្គ្រោះ ដោយកងនៃអាបត្តិប៉ុន្មាន។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ តាំងឡើងដោយសមុដ្ឋានប៉ុន្មាន។ បណ្តាអធិករណ៍៤ ចាត់ជាអធិករណ៍ណា។ បណ្តាសមថៈ៧ រម្ងាប់ ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិ៤ អាបត្តិទាំងឡាយដ៏សេស ក្រៅអំពីអាបត្តិ ៧ និងកងនៃអាបត្តិ ៧ (នោះ) មិនរាប់បញ្ចូលក្នុងវិបត្តិណា មួយឡើយ។ បណ្តាកងនៃអាបត្តិ៧ លោកមិនសង្គ្រោះ ដោយកងនៃ អាបត្តិណាមួយឡើយ។ បណ្តាសមុដ្ឋាននៃអាបត្តិ៦ មិនបានតាំង ឡើង ដោយសមុដ្ឋានណាមួយឡើយ។ បណ្តាអធិករណ៍៤ មិន បានចាត់ជាអធិករណ៍ណាមួយឡើយ។ បណ្តាសមថៈ៧ មិនបាន រម្ងាប់ដោយសមថៈណាមួយឡើយ។ សេចក្តីនោះ ព្រោះហេតុអ្វី។ ព្រោះហេតុអាបត្តិដទៃ ក្រៅអំពីអាបត្តិ៧នោះ ក៏ឥតមានឡើយ។

ចប់ អធិករណប្បច្ចយវារៈ ជាគម្រប់ ៥។

ចប់ អនន្តរបេយ្យាលតែប៉ុណ្ណេះ។

ឧទ្ទាន គឺបញ្ជីរឿងនៃអនន្តរបេយ្យាលនោះ ដូច្នេះ

[៨៨៣]

និយាយអំពីកតិបុច្ឆាវារៈ១ សមុដ្ឋានវារៈ១ កតាបត្តិវារៈ១ សមុដ្ឋានវារៈដូចគ្នា១ អាបត្តិសមុដ្ឋានវារៈ១ វិបត្តិវារៈ១ អធិករណវារៈ១។

# (សមថភេទ)

### (សមថភេទោ)

## បរិយាយវារៈ ទី៦

CS vin.pv.03.06 | ភាគ ទី១២

### (៦. អធិករណបរិយាយវារោ)

[៨៨៤] សួរថា អ្វីជាប្រធាននៃវិវាទាធិករណ៍ វិវាទាធិករណ៍នោះ មានឋានប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន មានហេតុប៉ុន្មាន មានមូលប៉ុន្មាន ភិក្ខុជជែកគ្នាដោយអាការប៉ុន្មាន វិវាទាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មាន។ អ្វីជាប្រធាននៃអនុវាទាធិករណ៍ អនុវាទាធិករណ៍នោះ មានឋានប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន មានហេតុប៉ុន្មាន មានមូលប៉ុន្មាន ភិក្ខុចោទប្រកាន់គ្នាដោយអាការប៉ុន្មាន អនុវាទាធិករណ៍រម្ងាប់ ដោយសមថៈប៉ុន្មាន។ អ្វីជាប្រធាននៃអាបត្តាធិករណ៍ អាបត្តាធិករណ៍នោះ មានឋានប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន មានហេតុប៉ុន្មាន មានមូលប៉ុន្មាន ភិក្ខុត្រូវអាបត្តិដោយអាការប៉ុន្មាន អាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ អ្វីជាប្រធាននៃកិច្ចាធិករណ៍ កិច្ចាធិករណ៍ នោះ មានឋានប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន មានហេតុប៉ុន្មាន មានមូលប៉ុន្មាន កិច្ចកើតឡើងដោយអាការប៉ុន្មាន កិច្ចាធិករណ៍រម្ងាប់ ដោយសមថៈប៉ុន្មាន។

[៨៨៥] ត្រង់ពាក្យសួរថា អ្វីជាប្រធាននៃវិវាទាធិករណ៍។ ឆ្លើយថា លោភៈជាប្រធាន ទោសៈជាប្រធាន មោហៈជាប្រធាន អលោភៈ ជាប្រធាន អទោសៈជាប្រធាន អមោហៈជាប្រធាន។ ត្រង់ពាក្យសួរថា វិវាទាធិករណ៍មានឋានប៉ុន្មាន។ ឆ្លើយថា មានភេទករវត្ថុ ១៨ ជាឋាន។ ត្រង់ពាក្យសួរថាមានវត្ថុប៉ុន្មាន។ ឆ្លើយថា មានភេទករវត្ថុ១៨ ជាវត្ថុ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន។ ឆ្លើយថា មានភេទករវត្ថុ ១៨ ជាភូមិ។ ត្រង់ពាក្យសួរថា មានហេតុប៉ុន្មាន។ ឆ្លើយថា មានហេតុ ៩ គឺ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣។ ត្រង់ពាក្យសួរថា មានមូលប៉ុន្មាន។ ឆ្លើយថា មានមូល១២។ ត្រង់ពាក្យសួរថា ភិក្ខុ ជជែកគ្នាដោយអាការប៉ុន្មាន។ ឆ្លើយថា ភិក្ខុជជែកគ្នាដោយអាការ២ គឺ សេចក្តីយល់ឃើញថាជាធម៌១ សេចក្តីយល់ឃើញថាមិនមែនធម៌១។ ត្រង់ពាក្យសួរថា វិវាទាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍រម្ងាប់ដោយសមថៈ២ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១។

[៨៨៦] ត្រង់ពាក្យសួរថា អ្វីជាប្រធាននៃអនុវាទាធិករណ៍។ ឆ្លើយថា លោភៈជាប្រធាន ទោសៈជាប្រធាន មោហៈជាប្រធាន អលោភៈ ជាប្រធាន អទោសៈជាប្រធាន អមោហៈជាប្រធាន។ ត្រង់ពាក្យសួរថា អនុវាទាធិករណ៍មានឋានប៉ុន្មាន។ ឆ្លើយថា មានវិបត្តិ៤ ជាឋាន។ ត្រង់ពាក្យសួរថា មានវត្ថុប៉ុន្មាន។ ឆ្លើយថា មានវិបត្តិ៤ ជាវត្ថុ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន។ ឆ្លើយថា មានវិបត្តិ៤ ជាភូមិ។ ត្រង់ពាក្យសួរថា មានហេតុប៉ុន្មាន។ ឆ្លើយថា មានហេតុ៩ គឺ កុសលហេតុ៣ អកុសលហេតុ៣ អព្យាកតហេតុ៣។ ត្រង់ពាក្យសួរថា មានមូល ប៉ុន្មាន។ ឆ្លើយថា មានមូល១៤។ ត្រង់ពាក្យសួរថា ភិក្ខុចោទប្រកាន់ គ្នាដោយអាការប៉ុន្មាន។ ឆ្លើយថា ភិក្ខុចោទប្រកាន់គ្នាដោយអាការ ២ គឺ វត្ថុ ១ អាបត្តិ ១។ ត្រង់ពាក្យសួរថា អនុវាទាធិករណ៍រម្ងាប់ដោយសមថៈ ប៉ុន្មាន។ ឆ្លើយថា អនុវាទាធិករណ៍រម្ងាប់ដោសមថៈ៤ គឺ ដោយសម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ១ តស្សបាបិយសិកា១។

[៨៨៧] ត្រង់ពាក្យសួរថា អ្វីជាប្រធាននៃអាបត្តាធិករណ៍។ ឆ្លើយថា លោភៈជាប្រធាន ទោសៈជាប្រធាន មោហៈជាប្រធាន អលោភៈជាប្រធាន អទោសៈជាប្រធាន អមោហៈជាប្រធាន។ ត្រង់ពាក្យសួរថា អាបត្តាធិករណ៍មានឋានប៉ុន្មាន។ ឆ្លើយថា មានកងនៃអាបត្តិ ៧ ជាឋាន។ ត្រង់ពាក្យសួរថា មានវត្ថុប៉ុន្មាន។ ឆ្លើយថា មានកងនៃអាបត្តិ ៧ ជាវត្ថុ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន។ ឆ្លើយថា មានកងនៃអាបត្តិ ៧ ជា ភូមិ។ ត្រង់ពាក្យសួរថា មានហេតុប៉ុន្មាន។ ឆ្លើយថា មានហេតុ ៩ គឺកុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣។ ត្រង់ពាក្យ សួរថា មានមូលប៉ុន្មាន។ ឆ្លើយថា មានសមុដ្ឋាននៃអាបត្តិ ៦ ជាមូល។ ត្រង់ពាក្យសួរថា ភិក្ខុត្រូវអាបត្តិដោយអាការប៉ុន្មាន។ ឆ្លើយថា ត្រូវអាបត្តិដោយអាការ៦ គឺ ត្រូវដោយមិនមានខ្មាស ១ ដោយមិនស្គាល់អាបត្តិ ១ ដោយសង្ស័យហើយធ្វើបំពាន១ ដោយសម្គាល់ថា គួរក្នុង វត្ថុដែលមិនគួរ១ ដោយសម្គាល់ថា មិនគួរក្នុងវត្ថុដែលគួរ១ ដោយភ្លេចស្មារតី១។ ត្រង់ពាក្យសួរថា អាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា អាបត្តាធិករណ៍រម្ងាប់ដោយសមថៈ៣ គឺ ដោយសម្មុខាវិន័យ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។

[៨៨៨] ត្រង់ពាក្យសួរថា អ្វីជាប្រធាននៃកិច្ចាធិករណ៍។ ឆ្លើយថា លោភៈជាប្រធាន ទោសៈជាប្រធាន មោហៈជាប្រធាន អលោភៈជាប្រធាន អទោសៈជាប្រធាន អមោហៈជាប្រធាន។ ត្រង់ពាក្យសួរថា កិច្ចាធិករណ៍មានឋានប៉ុន្មាន។ ឆ្លើយថា មានកម្ម៤យ៉ាងជាឋាន។ ត្រង់ពាក្យសួរថា មានវត្ថុប៉ុន្មាន។ ឆ្លើយថា មានកម្ម៤ ជាវត្ថុ។ ត្រង់ពាក្យសួរថា មានភូមិប៉ុន្មាន។ ឆ្លើយថា មានកម្ម៤ជាភូមិ។ ត្រង់ពាក្យសួរថា មានហេតុប៉ុន្មាន។

ឆ្លើយថា មានហេតុ៩ គឺ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣។ ត្រង់ពាក្យសួរថា មានមូលប៉ុន្មាន។ ឆ្លើយថា មានមូល១ គឺ សង្ឃ។ ត្រង់ពាក្យសួរថា កិច្ចកើតអំពីអាការប៉ុន្មាន។ ឆ្លើយថា កិច្ចកើតអំពីអាការ ២ គឺ ញត្តិ ១ អបលោកនៈ១។ ត្រង់ពាក្យសួរថា កិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា កិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ១គឺ សម្មុខាវិន័យ។

[៨៨៩] សួរថា សមថៈមានប៉ុន្មាន។ ឆ្លើយថា សមថៈមាន៧ គឺ សម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ១ បដិញ្ញាតករណៈ១ យេភុយ្យសិកា១ តស្សបាបិយសិកា១ តិណវត្ថារកៈ១ នេះជាសមថៈ៧។ សមថៈទាំង៧នេះ ចែកទៅជាសមថៈ១០ មានដែរឬ សមថៈ១០ (បង្រួញ) ជាសមថៈ៧ ដោយអំណាចនៃវត្ថុនិងបរិយាយ មានដែរឬ។ ឆ្លើយថា មាន។ ព្រោះហេតុអ្វីបានជាថាមាន។ ព្រោះវិវាទាធិករណ៍មានសមថៈ ២ អនុវាទាធិករណ៍មានសមថៈ ៤ អាបត្តាធិករណ៍មានសមថៈ ៣ កិច្ចាធិករណ៍មានសមថៈ១។ សមថៈទាំង៧ នេះ (ចែកទៅ) ជាសមថៈ១០ សមថៈទាំង១០(បង្រួញទៅ) ជាសមថៈ៧ ដោយអំណាចនៃវត្ថុនិងបរិយាយ ដូចចែកមកនេះ។

ចប់ បរិយាយវារៈ ជាគម្រប់៦។

# សាធារណវារៈ ទី៧

CS vin.pv.03.07 | ភាគ ទី១២

**(៧. សាធារណវារោ)**

[៨៩០] សួរថា សមថៈដែលទួទៅដល់វិវាទាធិករណ៍ មានប៉ុន្មាន សមថៈដែលមិនទួទៅដល់វិវាទាធិករណ៍ មានប៉ុន្មាន។ សមថៈដែលទួទៅដល់អនុវាទាធិករណ៍ មានប៉ុន្មាន សមថៈដែលមិនទួទៅដល់អនុវាទាធិករណ៍ មានប៉ុន្មាន។ សមថៈដែលទួទៅដល់អាបត្តាធិករណ៍ មានប៉ុន្មាន សមថៈដែលមិនទួទៅដល់អាបត្តាធិករណ៍ មានប៉ុន្មាន។ សមថៈដែលទួទៅដល់កិច្ចាធិករណ៍ មានប៉ុន្មាន សមថៈដែលមិនទួទៅដល់កិច្ចាធិករណ៍ មានប៉ុន្មាន។ ឆ្លើយថា សមថៈដែលទួទៅដល់វិវាទាធិករណ៍មាន២ គឺ សម្មុខាវិន័យ ១ យេភុយ្យសិកា ១។ សមថៈដែលមិនទួទៅដល់វិវាទាធិករណ៍ មាន៥ គឺ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា១ តិណវត្ថារកៈ១។ សមថៈដែលទួទៅដល់អនុវាទាធិករណ៍មាន៤ គឺ សម្មុខាវិន័យ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្ស បាបិយសិកា ១។ សមថៈដែលមិនទួទៅដល់អនុវាទាធិករណ៍ មាន៣ គឺ យេភុយ្យសិកា១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ សមថៈ ដែលទួទៅដល់អាបត្តាធិករណ៍មាន ៣ គឺ សម្មុខាវិន័យ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ សមថៈដែលមិនទួទៅដល់អាបត្តាធិករណ៍ មាន៤ គឺ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១។ សមថៈដែលទួទៅដល់កិច្ចាធិករណ៍ មាន ១ គឺ សម្មុខាវិន័យ សមថៈដែលមិនទួទៅ ដល់កិច្ចាធិករណ៍មាន៦ គឺ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ១។

ចប់ សាធារណវារៈ ជាគម្រប់៧។

# តព្ភាគិវារៈ ទី៨

CS vin.pv.03.08 | ភាគ ទី១២

**(៨. តព្ភាគិយវារោ)**

[៨៩១] សួរថា សមថៈដែលមានចំណែកត្រូវគ្នានឹងវិវាទាធិករណ៍ មានប៉ុន្មាន សមថៈ ដែលមានចំណែកផ្សេងអំពីវិវាទាធិករណ៍ មានប៉ុន្មាន។ សមថៈដែលមានចំណែកត្រូវគ្នានឹងអនុវាទាធិករណ៍ មានប៉ុន្មាន សមថៈ ដែលមានចំណែកផ្សេងអំពីអនុវាទាធិករណ៍ មានប៉ុន្មាន។ សមថៈដែលមានចំណែកត្រូវគ្នានឹងអាបត្តាធិករណ៍ មានប៉ុន្មាន សមថៈដែលមានចំ ណែកផ្សេងអំពីអាបត្តាធិករណ៍ មានប៉ុន្មាន។ សមថៈដែលមានចំណែកត្រូវគ្នានឹងកិច្ចាធិករណ៍ មានប៉ុន្មាន សមថៈដែលមានចំណែកផ្សេងអំពីកិច្ចាធិករណ៍ មានប៉ុន្មាន។ ឆ្លើយថា សមថៈដែលមានចំណែកត្រូវគ្នានឹងវិវាទាធិករណ៍មាន២ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា ១។ សមថៈដែលមានចំណែកផ្សេងអំពីវិវាទាធិករណ៍មាន ៥ គឺ សតិវិន័យ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ១។ សមថៈដែលមានចំណែកត្រូវគ្នានឹងអនុវាទាធិករណ៍មាន៤ គឺ សម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ១ តស្សបាបិយសិកា១។ សមថៈ ដែលមានចំណែកផ្សេងអំពីអនុវាទាធិករណ៍ មាន ៣ គឺ យេភុយ្យសិកា ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ សមថៈដែលមានចំណែកត្រូវគ្នានឹង អាបត្តាធិករណ៍ មាន៣ គឺ សម្មុខាវិន័យ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ សមថៈដែលមានចំណែកផ្សេងអំពីអាបត្តាធិករណ៍មាន ៤ គឺ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ តស្សបាបិយសិកា១។ សមថៈ ដែលមានចំណែកត្រូវគ្នានឹងកិច្ចាធិករណ៍ មាន១ គឺ សម្មុខាវិន័យ។ សមថៈ ដែលមានចំណែកផ្សេងអំពីកិច្ចាធិករណ៍មាន ៦ គឺ យេភុយ្យសិកា ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១។

ចប់ តព្ភាគិវារៈ ជាគម្រប់ ៨។

# វារៈនៃសមថៈដែលទួទៅដល់សមថៈ ទី៩

CS vin.pv.03.09 | ភាគ ទី១២

**(៩. សមថា សមថស្ស សាធារណវារោ)**

[៨៩២] សមថៈទួទៅដល់សមថៈ សមថៈមិនទួទៅដល់សមថៈ សមថៈទួទៅដល់សមថៈក៏មាន សមថៈមិនទួទៅដល់សមថៈក៏មាន។ សួរថា សមថៈដែលទួទៅដល់សមថៈក៏មាននោះ តើដូចម្តេច សមថៈមិនទួទៅដល់សមថៈក៏មាននោះ តើដូចម្តេច។ ឆ្លើយថា យេភុយ្យសិកាទួទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទួទៅដល់សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា និងតិណវត្ថារកៈទេ។ សតិវិន័យទួទៅ ដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទួទៅដល់អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ និងយេភុយ្យសិការទេ។ អមូឡ្ហវិន័យទួទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទួទៅដល់បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ យេភុយ្យសិកា និងសតិវិន័យទេ។ បដិញ្ញាតករណៈទួទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទួទៅដល់តស្សបាបិយសិកា តិណវត្ថារកៈ យេភុយ្យសិកា សតិវិន័យ និងអមូឡ្ហវិន័យទេ។ តស្សបាបិយសិកា ទួទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទួទៅដល់តិណវត្ថារកៈ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ និងបដិញ្ញាតករណៈទេ។ តិណវត្ថារកៈទួទៅដល់សម្មុខាវិន័យ (តែម្យ៉ាង) មិនទួទៅដល់យេភុយ្យ សិកា សតិវិន័យ អមូឡ្ហរវិន័យ បដិញ្ញាតករណៈ និងតស្សបាបិយសិកា ទេ។ សមថៈដែលទួទៅដល់សមថៈក៏មាន យ៉ាងនេះ សមថៈដែលមិនទួទៅដល់សមថៈក៏មាន យ៉ាងនេះ។

ចប់ វារៈនៃសមថៈដែលទួទៅដល់សមថៈ ជាគម្រប់ ៩។

# វារៈនៃសមថៈដែលមានចំណែកត្រូវគ្នានឹងសមថៈ ទី១០

CS vin.pv.03.10 | ភាគ ទី១២

### (១០. សមថា សមថស្ស តព្ភាគិយវារោ)

[៨៩៣] សមថៈមានចំណែកត្រូវគ្នានឹងសមថៈ សមថៈមានចំណែកផ្សេងអំពីសមថៈ សមថៈមានចំណែកត្រូវគ្នានឹងសមថៈក៏មាន សមថៈមានចំណែកផ្សេងអំពីសមថៈក៏មាន។ សួរថា សមថៈដែលមានចំណែកត្រូវគ្នានឹងសមថៈក៏មាននោះ តើដូចម្តេច សមថៈ ដែលមានចំណែកផ្សេងអំពីសមថៈក៏មាននោះ តើដូចម្តេច។ ឆ្លើយថា យេភុយ្យសិកា មាន ចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីសតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា និងតិណវត្ថារកៈ។ សតិវិន័យ មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេង អំពីអមូឡ្ហវិន័យ បដិញ្ញតកណៈ តស្សបាបិយសិកា តិណវត្ថារកៈ និងយេភុយ្យសិកា។ អមូឡ្ហវិន័យ មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីបដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ យេភុយ្យសិកា និង សតិវិន័យ។ បដិញ្ញាតករណៈ មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីតស្សបាបិយសិកា តិណវត្ថារកៈ យេភុយ្យសិកា សតិវិន័យ និងអមូឡ្ហវិន័យ។ តស្សបាបិយសិកា មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីតិណវត្ថារកៈ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ និងបដិញ្ញាតករណៈ។ តិណវត្ថារកៈ មានចំណែកត្រូវគ្នានឹងសម្មុខាវិន័យ មានចំណែកផ្សេងអំពីយេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ និងតស្សបាបិយសិកា។ សមថៈដែល មានចំណែកត្រូវគ្នានឹងសមថៈក៏មាន យ៉ាងនេះ សមថៈដែលមានចំណែក ផ្សេងអំពីសមថៈក៏មាន យ៉ាងនេះ។

ចប់ វារៈនៃសមថៈដែលមានចំណែកត្រូវគ្នានឹងសមថៈ ជាគម្រប់ ១០។

# វារៈនៃសមថៈដែលហៅថាសម្មុខាវិន័យ ទី១១

CS vin.pv.03.11 | ភាគ ទី១២

### (១១. សមថសម្មុខាវិនយវារោ)

[៨៩៤] សមថៈ ហៅថា សម្មុខាវិន័យ សម្មុខាវិន័យ ហៅថា សមថៈវិញក៏បាន។ សមថៈ ហៅថា យេភុយ្យសិកា យេភុយ្យសិកា ហៅថា សមថៈវិញក៏បាន។ សមថៈហៅថា សតិវិន័យ សតិវិន័យហៅថា សមថៈវិញក៏បាន។ សមថៈ ហៅថាអមូឡ្ហវិន័យ អមូឡ្ហវិន័យហៅថា សមថៈវិញក៏បាន។ សមថៈ ហៅថា បដិញ្ញាតករណៈ បដិញ្ញាតករណៈ ហៅថាសមថៈវិញក៏បាន។ សមថៈ ហៅថាតស្សបាបិយសិកា តស្សបាបិយសិកា ហៅថាសមថៈវិញក៏បាន។ សមថៈ ហៅថាតិណវត្ថារកៈ តិណវត្ថារកៈ ហៅថាសមថៈវិញក៏បាន។ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា និងតិណវត្ថារកៈ ទាំងនេះ ហៅថាសមថៈតែម្យ៉ាង ឯសម្មុខាវិន័យ មិនហៅថាសមថៈតែម្យ៉ាងទេ ដ្បិតសម្មុខាវិន័យ ហៅថាសមថៈផង ហៅថាសម្មុខាវិន័យផង។ សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ និងសម្មុខាវិន័យ ទាំងនេះ ហៅថាសមថៈតែម្យ៉ាង ឯយេ ភុយ្យសិកា មិនហៅថាសមថៈតែម្យ៉ាងទេ ដ្បិតយេភុយ្យសិកា ហៅថាសមថៈផង ហៅថាយេភុយ្យសិកាផង។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ សម្មុខាវិន័យ និងយេភុយ្យសិកា ទាំងនេះ ហៅថាសមថៈតែម្យ៉ាង ឯសតិវិន័យមិនហៅថា សមថៈ តែម្យ៉ាងទេ ដ្បិតសតិវិន័យ ហៅថាសមថៈផង ហៅថាសតិវិន័យផង។ បដិញ្ញាតករណៈ តស្សបាបិយសិកា តិណវត្ថារកៈ សម្មុខាវិន័យ យេភុយ្យសិកា និងសតិវិន័យទាំងនេះ ហៅថាសមថៈតែម្យ៉ាង ឯអមូឡ្ហវិន័យ មិនហៅថាសមថៈ តែម្យ៉ាងទេ ដ្បិតអមូឡ្ហវិន័យ ហៅថាសមថៈផង ហៅថាអមូឡ្ហរវិន័យផង។ តស្សបាបិយសិកា តិណវត្ថារកៈ សម្មុខាវិន័យ យេភុយ្យសិកា សតិវិន័យ និងអមូឡ្ហវិន័យ ទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯបដិញ្ញាតករណៈ មិនហៅថាសមថៈតែម្យ៉ាងទេ ដ្បិតបដិញ្ញាតករណៈ ហៅថាសមថៈផង ហៅថាបដិញ្ញាតករណៈផង។ តិណវត្ថារកៈ សម្មុខាវិន័យ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ និងបដិញ្ញាតករណៈ ទាំងនេះ ហៅថា សមថៈតែម្យ៉ាង ឯតស្សបាបិយសិកា មិនហៅថាសមថៈ តែម្យ៉ាងទេ ដ្បិតតស្សបាបិយសិកា ហៅថាសមថៈផង ហៅថា តស្សបាបិយសិកាផង។ សម្មុខាវិន័យ យេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ និងតស្សបាបិយសិកា ទាំងនេះ ហៅថាសមថៈតែម្យ៉ាង ឯតិណវត្ថារកៈ មិនហៅថាសមថៈតែម្យ៉ាងទេ ដ្បិតតិណវត្ថារកៈ ហៅថាសមថៈផង ហៅថាតិណវត្ថារកៈផង។

[៨៩៥] វិន័យ ហៅថាសម្មុខាវិន័យ សម្មុខាវិន័យ ហៅថាវិន័យវិញក៏បាន។ វិន័យ ហៅថាយេភុយ្យសិកា យេភុយ្យសិកា ហៅថាវិន័យវិញក៏បាន។ វិន័យហៅថាសតិវិន័យ សតិវិន័យ ហៅថាវិន័យវិញក៏បាន។ វិន័យហៅថាអមូឡ្ហវិន័យ អមូឡ្ហវិន័យ ហៅថាវិន័យវិញក៏បាន។ វិន័យ

ហៅថាបដិញ្ញាតករណៈ បដិញ្ញាតករណៈ ហៅថាវិន័យវិញក៏បាន។ វិន័យ ហៅថាតស្សបាបិយសិកា តស្សបាបិយសិកា ហៅថា វិន័យវិញក៏បាន។ វិន័យហៅថាតិណវត្ថារកៈ តិណវត្ថារកៈ ហៅថា វិន័យវិញក៏បាន។

ចប់ វារៈនៃសមថៈដែលហៅថាសម្មុខាវិន័យ ជាគម្រប់ ១១។

# វិនយវារៈ ទី១២

CS vin.pv.03.12 | ភាគ ទី១២

### (១២. វិនយវារោ)

[៨៩៦] វិន័យ ជាសម្មុខាវិន័យក៏មាន មិនមែនជាសម្មុខាវិន័យក៏មាន ព្រោះថា សម្មុខាវិន័យជាវិន័យផង ជាសម្មុខាវិន័យផង។ វិន័យ ជាយេភុយ្យសិកាក៏មាន មិនមែនជាយេភុយ្យសិកាក៏មាន ព្រោះថាយេភុយ្យសិកាជាវិន័យផង ជាយេភុយ្យសិកាផង។ វិន័យជាសតិវិន័យក៏មាន មិនមែនជាសតិវិន័យក៏មាន (ព្រោះថា) សតិវិន័យ ជាវិន័យផង ជា សតិវិន័យផង។ វិន័យជាអមូឡ្ហវិន័យក៏មាន មិនមែនជាអមូឡ្ហវិន័យក៏ មាន (ព្រោះថា) អមូឡ្ហវិន័យ ជាវិន័យផង ជាអមូឡ្ហវិន័យផង។ វិន័យ ជាបដិញ្ញាតករណៈក៏មាន មិនមែនជាបដិញ្ញាតករណៈក៏មាន (ព្រោះថា) បដិញ្ញាតករណៈជាវិន័យផង ជាបដិញ្ញាតករណៈផង។ វិន័យ ជាតស្សបាបិយសិកាក៏មាន មិនមែនជាតស្សបាបិយសិកាក៏មាន (ព្រោះថា) តស្សបាបិយសិកាជាវិន័យផង ជាតស្សបាបិយសិកាផង។ វិន័យ ជាតិណវត្ថារកៈក៏មាន មិនមែនជាតិណវត្ថារកៈក៏មាន (ព្រោះថា) តិណវត្ថារកៈ ជាវិន័យផង ជាតិណវត្ថារកៈផង។

ចប់ វិនយវារៈ ជាគម្រប់១២។

# កុសលវារៈ ទី១៣

CS vin.pv.03.13 | ភាគ ទី១២

### (១៣. កុសលវារោ)

[៨៩៧] សួរថា សម្មុខាវិន័យ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ យេភុយ្យសិកា ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ សតិវិន័យ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ អមូឡ្ហវិន័យ ជា កុសល ឬជាអកុសល ឬជាអព្យាកតៈ។ បដិញ្ញាតករណៈ ជាកុសល ឬ ជាអកុសល ឬ ជាអព្យាកតៈ។ តស្សបាបិយសិកា ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ តិណវត្ថារកៈ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ ឆ្លើយថា សម្មុខាវិន័យ ជាកុសលក៏មាន ជាអព្យាកតៈក៏មាន សម្មុខាវិន័យ ជាអកុសលមិនមានទេ។ យេភុយ្យសិកា ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។ សតិវិន័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។ អមូឡ្ហវិន័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។ បដិញ្ញាតកណៈ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។ តស្សបាបិយសិកា ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។ តិណវត្ថារកៈ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។

[៨៩៨] សួរថា វិវាទាធិករណ៍ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ អនុវាទាធិករណ៍ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ អាបត្តាធិករណ៍ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ កិច្ចាធិករណ៍ ជាកុសល ឬជាអកុសល ឬជាអព្យាកតៈ។ ឆ្លើយថា វិវាទាធិករណ៍ជា ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។ អនុវាទាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។ អាបត្តាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។ អាបត្តាធិករណ៍ ជាកុសលមិនមានទេ។ កិច្ចាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន។

ចប់ កុសលវារៈ ជាគម្រប់ ១៣។

# យត្ថវារៈ ទី១៤

CS vin.pv.03.14 | ភាគ ទី១២

### (១៤. យត្ថវារោ, បុច្ឆាវារោ)

[៨៩៩] បើអ្នកប្រាជ្ញកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់)បាន ក្នុងអធិករណ៍ណា ក៏កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតស្សបានបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ បើអ្នកប្រាជ្ញកំណត់យកសតិវិន័យ (ទៅរម្ងាប់)បាន ក្នុងអធិករណ៍ណា ក៏កំណត់យក សម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់)បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសតិវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់)ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ(ទៅរម្ងាប់)ក្នុងអធិករណ៍នោះមិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ(ទៅរម្ងាប់)

ក្នុងអធិករណ៍នោះមិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ បើអ្នកប្រាជ្ញកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែកំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ(ទៅរម្ងាប់)ក្នុងអធិករណ៍នោះមិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ អ្នកប្រាជ្ញកំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់)បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុង អធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ(ទៅរម្ងាប់)ក្នុងអធិករណ៍ នោះមិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ បើអ្នកប្រាជ្ញកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែថាកំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ។ បើអ្នកប្រាជ្ញកំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) បាន ក្នុងអធិកណត់នោះដែរ តែកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់)ក្នុងអធិករណ៍នោះមិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។

[៩០០] បើអ្នកប្រាជ្ញកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតស្សបាបិយសិកា(ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ(ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ បើអ្នកប្រាជ្ញកំណត់យកសតិវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា កំណត់យកសតិវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ(ទៅរម្ងាប់)ក្នុងអធិករណ៍នោះមិនបាន កំណត់ យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ (ធ្វើសម្មុខាវិន័យឱ្យជាមូល[72] )។ បេ។ អ្នកប្រាជ្ញកំណត់យកតិណវត្ថារកៈ(ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់)បានក្នុងអធិករណ៍ណា កំណត់យកតិណវត្ថារកៈ(ទៅរម្ងាប់)បានក្នុងអធិករណ៍នោះដែរ តែកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន និង កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។

ចប់ ចក្កបេយ្យាលៈ។

ចប់ យត្ថវារៈ ជាគម្រប់១៤។

# សមយវារៈ ទី១៥

CS vin.pv.03.15 | ភាគ ទី១២

### (១៥. សមថវារោ, វិស្សជ្ជនាវារោ)

[៩០១] អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងយេភុយ្យសិកាក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែកំណត់យកសតិវិន័យ (ទៅរម្ងាប់)ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់)ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាត ករណៈ(ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបានទេ។ អធិករណ៍រម្ងាប់ដោយ សម្មុខាវិន័យ និងសតិវិន័យក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកសតិវិន័យ (ទៅរម្ងាប់)បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា កំណត់យកសតិវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិន បានកំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ(ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ

និងអមូឡ្ហវិន័យក្នុងស័មយណា អ្នកប្រាជ្ញកំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់)បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកអមូឡ្ហវិន័យ (ទៅ រម្ងាប់) បាន ក្នុងអធិករណ៍នោះដែរ តែកំណត់យកបដិញ្ញាតករណៈ (ទៅ រម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍ នោះមិនបានទេ។ អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ ក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) បានក្នុងអធិករណ៍ នោះដែរ តែកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះ មិនបាន កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងតស្សបាបិយសិកា ក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍ណា ក៏កំណត់យកតស្សបាបិយសិកា (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះដែរ តែកំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន ក៏កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ(ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។ អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យនិងតិណវត្ថារកៈក្នុងសម័យណា អ្នកប្រាជ្ញកំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់)បាន ក្នុងអធិករណ៍ណា ក៏កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បានក្នុងអធិករណ៍នោះ កំណត់យកសម្មុខាវិន័យ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍ណា ក៏កំណត់យកតិណវត្ថារកៈ (ទៅរម្ងាប់) បាន ក្នុងអធិករណ៍នោះ តែកំណត់យកយេភុយ្យសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកសតិវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកអមូឡ្ហវិន័យ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យកបដិញ្ញាតករណៈ (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបាន កំណត់យក តស្សបាបិយសិកា (ទៅរម្ងាប់) ក្នុងអធិករណ៍នោះមិនបានទេ។

ចប់ សមយវារៈ ជាគម្រប់១៥។

# សំសដ្ឋវារៈ ទី១៦

CS vin.pv.03.16 | ភាគ ទី១២

### (១៦. សំសដ្ឋវារោ)

[៩០២] សួរថា អធិករណ៍និងសមថៈធម៌ទាំងនេះ លាយច្រឡំគ្នា ឬមិនលាយគ្នាទេ មួយទៀត លោកចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តឱ្យផ្សេងគ្នាបានឬទេ។ ឆ្លើយថា អធិករណ៍និងសមថៈធម៌ទាំង នេះរមែងលាយច្រឡំគ្នា មិនមែនមិនលាយគ្នាទេ តែលោកចែករំលែកធម៌ ទាំងនេះចេញពីគ្នា ហើយបញ្ញត្តឱ្យផ្សេងគ្នាបាន។ អ្នកចោទត្រូវពោល ឃាត់អ្នកឆ្លើយនោះថា អ្នកកុំនិយាយយ៉ាងនេះឡើយ អធិករណ៍និងសមថៈធម៌ទាំងនេះរមែងលាយច្រឡំគ្នា មិនមែនមិនលាយគ្នាទេ មួយទៀតលោក មិនបានចែករំលែកធម៌ទាំងនេះចេញពីគ្នា ហើយបញ្ញត្តធ្វើឱ្យផ្សេងគ្នាទេ។ ពាក្យនោះ ព្រោះហេតុដូចម្តេច។ (ព្រោះថា) ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ អធិករណ៍ទាំង៤នេះ ហៅថាសមថៈ៧ក៏បាន ដ្បិតពួកអធិករណ៍ តែងរម្ងាប់ដោយពួកសមថៈ ពួកសមថៈ តែងរម្ងាប់ដោយពួកអធិករណ៍ (ក៏មាន) កាលបើយ៉ាងនេះ ធម៌ទាំងនេះ រមែងលាយច្រឡំគ្នា មិនមែនមិនលាយគ្នាទេ មួយទៀត លោកមិនបានចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តឱ្យផ្សេងគ្នាឡើយ ដូច្នេះ មិនមែនឬ។

ចប់ សំសដ្ឋវារៈ ជាគម្រប់១៦។

# សម្មន្តិវារៈ ទី១៧

CS vin.pv.03.17 | ភាគ ទី១២

### (១៧. សម្មតិវារោ)

[៩០៣] សួរថា វិវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន អនុវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន អាបត្តាធិករណ៍រម្ងាប់ដោយសមថៈប៉ុន្មាន កិច្ចាធិករណ៍ រម្ងាបដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ រម្ងាប់ដោយសមថៈ២ គឺ សម្មុខាវិន័យ ១ យេភុយ្យសិកា ១ អនុវាទាធិករណ៍ រម្ងាប់ដោយសមថៈ៤ គឺ សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ អាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ៣ គឺ សម្មុខាវិន័យ ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១ កិច្ចាធិករណៈ រម្ងាប់ដោយសមថៈ១ គឺ សម្មុខាវិន័យ។ សួរថា វិវាទាធិករណ៍និងអនុវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍និងអនុវាទាធិករណ៍ រម្ងាប់ដោយសមថៈ៥ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា១។ សួរថា វិវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ៤គឺ សម្មុខាវិន័យ១ យេភុយ្យសិកា ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ សួរថា វិវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ២ គឺ សម្មុខាវិន័យ ១ យេភុយ្យសិកា ១។ សួរថា អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ៦គឺ សម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ១។ សួរថា អនុវាទាធិករណ៍

និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា អនុវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ៤ គឺសម្មុខាវិន័យ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១។ សួរថា អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ៣ គឺសម្មុខាវិន័យ ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ សួរថា វិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ៧ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ១។ សួរថា វិវាទាធិករណ៍ អនុវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ អនុវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោសមថៈ៥ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ តស្សបាបិយសិកា ១។ សួរថា វិវាទាធិករណ៍ អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចា ធិករណ៍ រម្ងាប់ដោយសមថៈ៧ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា១ តិណវត្ថារកៈ១។

ចប់ សម្មន្តិវារៈ ជាគម្រប់១៧។

# វារៈនៃអធិករណ៍ដែលរម្ងាប់និងមិនរម្ងាប់ ទី១៨

CS vin.pv.03.18 | ភាគ ទី១២

### (១៨. សម្មន្តិ ន សម្មន្តិវារោ)

[៩០៤] សួរថា វិវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ អនុវាទាធិករណ៍។បេ។ អាបត្តាធិករណ៍។បេ។ កិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍រម្ងាប់ដោយសមថៈ២ គឺសម្មុខាវិន័យ១ យេភុយ្យសិកា១ មិនរម្ងាប់ដោយសមថៈ៥ គឺ សតិវិន័យ១ អមូឡ្ហវិន័យ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ១។ អនុវាទាធិករណ៍ រម្ងាប់ដោយសមថៈ៤ គឺ សម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ មិនរម្ងាប់ដោយសមថៈ៣ គឺ យេភុយ្យសិកា១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ អាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ៣ គឺ សម្មុខាវិន័យ ១ បដិញ្ញាតកណៈ១ តិណវត្ថារកៈ១ មិនរម្ងាប់ដោយសមថៈ៤ គឺ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ តស្សបាបិយសិកា១។ កិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ១ គឺ សម្មុខាវិន័យ មិនរម្ងាប់ដោយសមថៈ៦ គឺ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា១ តិណវត្ថារកៈ១។ សួរថា វិវាទាធិករណ៍ និងអនុវាទាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ និងអនុវាទាធិករណ៍ រម្ងាប់ដោយសមថៈ៥ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ មិនរម្ងាប់ដោយសមថៈ២ គឺ បដិញ្ញាតករណៈ ១ តិណវត្ថារកៈ១។ សួរថា វិវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ និងអាបត្តាធិករណ៍រម្ងាប់ដោយសមថៈ៤ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១ មិនរម្ងាប់ដោយសមថៈ៣ គឺ សតិវិន័យ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១។ សួរថា វិវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ២ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ មិន រម្ងាប់ដោយសមថៈ៥ គឺ សតិវិន័យ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា១ តិណវត្ថារកៈ១។ សួរថា អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ៦ គឺ សម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ ១ បដិញ្ញាតកណៈ១ តស្សបាបិយសិកា ១ តណវត្ថារកៈ១ មិនរម្ងាប់ដោយសមថៈ១ គឺ យេភុយ្យសិកា។ សួរថា អនុវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា អនុវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ៤ គឺ សម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា១ មិនរម្ងាប់ដោយសមថៈ៣ គឺ យេភុយ្យសិកា១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ សួរថា អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ៣ គឺសម្មុខាវិន័យ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១ មិនរម្ងាប់ដោយសមថៈ៤ គឺ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ តស្សបាបិយសិកា១។ សួរថា វិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ៧ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ បដិញ្ញាត ករណៈ១ តស្សបាបិយសិកា១ តិណវត្ថារកៈ១។ សួរថា វិវាទាធិករណ៍ អនុវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវទាធិករណ៍ អនុវាទាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ៥ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ មិនរម្ងាប់ដោយសមថៈ២ គឺ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ សួរថា អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ៦ គឺ សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា១ តិណវត្ថារកៈ១ មិនរម្ងាប់ដោយសមថៈ១ គឺ យេភុយ្យសិកា។ សួរថា វិវាទាធិករណ៍ អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈប៉ុន្មាន មិនរម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា វិវាទាធិករណ៍ អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ៧ គឺ សម្មុខាវិន័យ១ យេភុយ្យសិកា១ សតិវិន័យ១ អមូឡ្ហវិន័យ១ បដិញ្ញាតករណៈ១ តស្សបាបិយសិកា១ តិណវត្ថារកៈ១។

ចប់ វារៈនៃអធិករណ៍ដែលរម្ងាប់និងមិនរម្ងាប់ ជាគម្រប់១៨។

# សមថាធិករណវារៈ ទី១៩

CS vin.pv.03.19 | ភាគ ទី១២

### (១៩. សមថាធិករណវារោ)

[៩០៥] សមថៈ រម្ងាប់ដោយសមថៈ សមថៈរម្ងាប់ដោយអធិករណ៍ អធិករណ៍រម្ងាប់ដោយសមថៈ អធិករណ៍រម្ងាប់ដោយអធិករណ៍។ សមថៈ រម្ងាប់ដោយសមថៈក៏មាន សមថៈមិនរម្ងាប់ដោយសមថៈក៏មាន សមថៈ រម្ងាប់ដោយអធិករណ៍ក៏មាន សមថៈមិនរម្ងាប់ដោយអធិករណ៍ក៏មាន អធិករណ៍ រម្ងាប់ដោយសមថៈក៏មាន អធិករណ៍ មិនរម្ងាប់ដោយសមថៈក៏មាន អធិករណ៍ រម្ងាប់ដោយអធិករណ៍ក៏មាន អធិករណ៍មិនរម្ងាប់ ដោយអធិករណ៍ក៏មាន។

[៩០៦] សួរថា សមថៈរម្ងាប់ដោយសមថៈក៏មាន នោះតើដូចម្តេច សមថៈមិនរម្ងាប់ដោយសមថៈក៏មាន តើដូចម្តេច។ ឆ្លើយថា យេភុយ្យសិកា រម្ងាប់ដោយសម្មុខាវិន័យ មិនរម្ងាប់ដោយសតិវិន័យ មិនរម្ងាប់ដោយអមូឡ្ហវិន័យ មិនរម្ងាប់ដោយបដិញ្ញាតករណៈ មិនរម្ងាប់ដោយតស្សបាបិយសិកា មិនរម្ងាប់ដោយតិណវត្ថារកៈទេ។ សតិវិន័យ រម្ងាប់ដោយសម្មុខាវិន័យ មិនរម្ងាប់ដោយអមូឡ្ហវិន័យ មិនរម្ងាប់ដោយបដិញ្ញាតករណៈ មិនរម្ងាប់ដោយតស្សបាបិយសិកា មិនរម្ងាប់ដោយតិណវត្ថារកៈ មិនរម្ងាប់ដោយយេភុយ្យសិកាទេ។ អមូឡ្ហវិន័យ រម្ងាប់ដោយសម្មុខាវិន័យ មិនរម្ងាប់ដោយបដិញ្ញាតករណៈ មិនរម្ងាប់ដោយតស្សបាបិយសិកា មិនរម្ងាប់ដោយតិណវត្ថារកៈ មិនរម្ងាប់ដោយយេភុយ្យសិកា មិនរម្ងាប់ដោយសតិវិន័យ។ បដិញ្ញាតករណៈ រម្ងាប់ដោយសម្មុខាវិន័យ មិនរម្ងាប់ដោយតស្សបាបិយសិកា មិនរម្ងាប់ដោយតិណវត្ថារកៈ មិនរម្ងាប់ដោយយេភុយ្យសិកា មិនរម្ងាប់ដោយសតិវិន័យ មិនរម្ងាប់ដោយអមូឡ្ហវិន័យទេ។ តស្សបាបិយសិកា រម្ងាប់ដោយសម្មុខាវិន័យ មិនរម្ងាប់ដោយតិណវត្ថារកៈ មិនរម្ងាប់ដោយយេភុយ្យសិកា មិនរម្ងាប់ដោយសតិវិន័យ មិនរម្ងាប់ ដោយអមូឡ្ហវិន័យ មិនរម្ងាប់ដោយបដិញ្ញាតករណៈទេ។ តិណវត្ថារកៈ រម្ងាប់ដោយសម្មុខាវិន័យ មិនរម្ងាប់ដោយយេភុយ្យសិកា មិនរម្ងាប់ដោយសតិវិន័យ មិនរម្ងាប់ដោយអមូឡ្ហវិន័យ មិនរម្ងាប់ដោយបដិញ្ញាតករណៈ មិនរម្ងាប់ដោយតស្សបាបិយសិកាទេ។ សមថៈរម្ងាប់ដោយសមថៈក៏មាន នោះ ដូចពោលមកយ៉ាងនេះ សមថៈមិនរម្ងាប់ដោយសមថៈក៏មាន ដូច ពោលមកយ៉ាងនេះ។

[៩០៧] សួរថា សមថៈរម្ងាប់ដោយអធិករណ៍ក៏មាន នោះ តើដូចម្តេច សមថៈមិនរម្ងាប់ដោយអធិករណ៍ក៏មាន តើដូចម្តេច។ ឆ្លើយថា សម្មុខាវិន័យ មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ យេភុយ្យសិកា មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ សតិវិន័យ មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ អមូឡ្ហវិន័យ មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ បដិញ្ញាតករណៈ មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ តស្សបាបិយសិកា មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ រម្ងាប់ដោយកិច្ចារធិករណ៍ (តែម្យ៉ាង)។ តិណវត្ថារកៈ មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ សមថៈរម្ងាប់ដោយអធិករណ៍ក៏មាន ដូចពោលមកយ៉ាងនេះ សមថៈមិនរម្ងាប់ដោយអធិករណ៍ក៏មាន ដូចពោលមកយ៉ាងនេះ។

[៩០៨] សួរថា អធិករណ៍រម្ងាប់ដោយសមថៈក៏មាន នោះ តើដូចម្តេច អធិករណ៍មិនរម្ងាប់ដោយសមថៈក៏មាន តើដូចម្តេច។ ឆ្លើយថា វិវាទាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យ និងយេភុយ្យសិកា មិនរម្ងាប់ដោយសតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា និងតិណវត្ថារកៈទេ។ អនុវាទាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យ សតិវិន័យ អមូឡ្ហវិន័យ និងតស្សបាបិយសិកា មិនរម្ងាប់ដោយយេភុយ្យសិកា បដិញ្ញាតករណៈ និងតិណវត្ថារកៈទេ។ អាបត្តាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យ បដិញ្ញាតករណៈ និងតិណវត្ថារកៈ មិនរម្ងាប់ដោយយេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ និងតស្សបាបិយសិកាទេ។ កិច្ចាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យ មិនរម្ងាប់ដោយយេភុយ្យសិកា សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ តស្សបាបិយសិកា និងតិណវត្ថារកៈទេ។ អធិករណ៍ រម្ងាប់ដោយសមថៈក៏មាន ដូចពោលមកយ៉ាងនេះ អធិករណ៍ មិនរម្ងាប់ដោយសមថៈក៏មាន ដូចពោលមកយ៉ាងនេះ។

[៩០៩] សួរថា អធិករណ៍ រម្ងាប់ដោយអធិករណ៍ក៏មាននោះ តើដូចម្តេច អធិករណ៍ មិនរម្ងាប់ដោយអធិករណ៍ក៏មាន តើដូចម្តេច។ ឆ្លើយថា វិវាទាធិករណ៍ មិនរម្ងាប់ដោយវិវទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ទេ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ អនុវាទាធិករណ៍ មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ទេ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ អាបត្តាធិករណ៍ មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ទេ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ កិច្ចាធិករណ៍ មិនរម្ងាប់ដោយវិវាទាធិករណ៍ មិនរម្ងាប់ដោយអនុវាទាធិករណ៍ មិនរម្ងាប់ដោយអាបត្តាធិករណ៍ទេ រម្ងាប់ដោយកិច្ចាធិករណ៍ (តែម្យ៉ាង)។ អធិករណ៍រម្ងាប់ ដោយអធិករណ៍ក៏មាន ដូចពោលមកយ៉ាងនេះ អធិករណ៍មិនរម្ងាប់ដោយអធិករណ៍ក៏មាន ដូចពោលមកយ៉ាងនេះ។

[៩១០] សមថៈទាំង៦ និងអធិករណ៍ទាំង ៤ តែងរម្ងាប់ដោយសម្មុខាវិន័យ តែសម្មុខាវិន័យ មិនបានរម្ងាប់ដោយសមថៈ ឬអធិករណ៍ណាមួយទេ។

ចប់ សមថាធិករណវារៈ ជាគម្រប់១៩។

## សមុដ្ឋាបេតិវារៈ ទី២០

CS vin.pv.03.20 | ភាគ ទី១២

### (២០. សមុដ្ឋាបនវារោ)

[៩១១] សួរថា បណ្តាអធិករណ៍ទាំង៤ វិវាទាធិករណ៍ ញ៉ាំងអធិករណ៍ណាឱ្យតាំងឡើង។ ឆ្លើយថា បណ្តាអធិករណ៍ទាំង៤ វិវាទាធិករណ៍ មិនបានញ៉ាំងអធិករណ៍ណាឱ្យតាំងឡើងទេ ប៉ុន្តែអធិករណ៍ទាំង៤ តែងកើតឡើង ព្រោះវិវាទាធិករណ៍ជាបច្ច័យ។ ដូចជាអ្វី។ (ដូចជា) ភិក្ខុទាំង ឡាយ ក្នុងសាសនានេះជជែកគ្នាថា (នេះ) ជាធម៌ក្តី ថាមិនមែនជាធម៌ក្តី ថា ជាវិន័យក្តី ថាមិនមែនជាវិន័យក្តី ថាជាភាសិត ដែលព្រះតថាគតទ្រង់ពោលហើយក្តី ថាមិនមែនជាភាសិត ដែលព្រះតថាគតទ្រង់ពោលហើយក្តី ថាជាកិច្ចវត្ត ដែលព្រះតថាគតធ្លាប់សន្សំហើយក្តី ថាជាកិច្ចវត្ត ដែលព្រះតថាគត មិនធ្លាប់សន្សំហើយក្តី ថាជាសិក្ខាបទដែលព្រះតថាគត ទ្រង់បញ្ញត្តហើយក្តី ជាសិក្ខាបទដែលព្រះតថាគត មិនបានបញ្ញត្តហើយក្តី ថាជាអាបត្តិក្តី ជាអនាបត្តិក្តី ថាជាលហុកាបត្តិក្តី ជាគរុកាបត្តិក្តី ថាជាសាវសេសាបត្តិក្តី ជាអនវសេសាបត្តិក្តី ថាជាទុដ្ឋុល្លាបត្តិក្តី ជាអទុដ្ឋុល្លាបត្តិក្តី សេចក្តីប្រកួតប្រកាន់ ជម្លោះ ប្រកាន់ខុស ទាស់ទែង ជជែកផ្សេងៗ និយាយទីទៃពីគ្នា (មិនមូលមាត់គ្នា) និយាយពាក្យសត្រូវដល់គ្នា និងសេចក្តីចង្អៀតចង្អល់ណា ក្នុងហេតុទាំងនោះ ហេតុមានសេចក្តីប្រកួតប្រកាន់គ្នាជាដើមនេះ ហៅថាវិវាទាធិករណ៍។ (បើ) សង្ឃគ្រាន់តែជជែក ព្រោះវិវាទាធិករណ៍ ហៅថាវិវាទាធិករណ៍។ កាលបើសង្ឃជជែក ទាំងចោទផង ហៅថាអនុវាទាធិករណ៍។ កាលបើសង្ឃចោទ ត្រូវអាបត្តិខ្លួនឯង ហៅថាអាបត្តាធិករណ៍។ សង្ឃធ្វើកម្ម ចំពោះអាបត្តិដែលត្រូវនោះ ហៅថាកិច្ចាធិករណ៍។ អធិករណ៍ទាំង៤ តែងកើតឡើង ព្រោះវិវាទាធិករណ៍ជាបច្ច័យ ដូចពោលមកយ៉ាងនេះ។

[៩១២] សួរថា បណ្តាអធិករណ៍ទាំង៤ អនុវាទាធិករណ៍ ញ៉ាំង អធិករណ៍ណាឱ្យតាំងឡើង។ បណ្តាអធិករណ៍ទាំង៤ អនុវាទាធិករណ៍ មិនបានញ៉ាំងអធិករណ៍ណាឱ្យតាំងឡើងទេ ប៉ុន្តែអធិករណ៍ទាំង៤ តែងកើតឡើង ព្រោះអនុវាទាធិករណ៍ជាបច្ច័យ។ ដូចជាអ្វី។ (ដូចជា) ភិក្ខុទាំងឡាយ ក្នុងសាសនានេះ ចោទប្រកាន់ភិក្ខុផងគ្នាដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី ការចោទប្រកាន់ ការពោលដេញដោលគ្នា ការជជែកតវ៉ា ការពោលបង្កាច់ ការពោលបង្ខូច ការខំពោលបង្វែង ការបន្ថែមកម្លាំងឱ្យ ណានីមួយ ក្នុងវិបត្តិទាំងនោះ ហេតុមានពោលចោទជាដើមទាំងនេះ ហៅថា អនុវាទាធិករណ៍។ សង្ឃជជែកគ្នា ព្រោះអនុវាទាធិករណ៍ ហៅថា អនុវាទាធិករណ៍។ កាលបើសង្ឃជជែកទាំងចោទប្រកាន់ផង ហៅថា អនុវាទាធិករណ៍។ កាលបើសង្ឃ ចោទប្រកាន់ ត្រូវអាបត្តិ (ខ្លួនឯង) ហៅថា អាបត្តាធិករណ៍។ សង្ឃធ្វើកម្ម ចំពោះអាបត្តិដែលត្រូវនោះ ហៅថា អាបត្តាធិករណ៍។ អធិករណ៍ទាំង៤ តែងកើតឡើង ព្រោះអនុវាទាធិករណ៍ជាបច្ច័យ ដូចពោលមក យ៉ាងនេះ។

[៩១៣] បណ្តាអធិករណ៍ទាំង ៤ អាបត្តាធិករណ៍ញ៉ាំងអធិករណ៍ណាឱ្យតាំងឡើង។ បណ្តាអធិករណ៍ទាំង៤ អាបត្តាធិករណ៍ មិនបាន ញ៉ាំងអធិករណ៍ណាឱ្យតាំងឡើងទេ ប៉ុន្តែអធិករណ៍ទាំង ៤ តែងកើត ឡើង ព្រោះអាបត្តាធិករណ៍ជាបច្ច័យ។ ដូចជាអ្វី។ (ដូចជា) កងនៃអាបត្តិទាំង ៥ ហៅថា អាបត្តាធិករណ៍ កងនៃអាបត្តិទាំង ៧ ក៏ហៅថា អាបត្តាធិករណ៍ដែរ ប្រជុំកងនៃអាបត្តិទាំង ២ ពួកនេះ ហៅថា អាបត្តាធិករណ៍។ សង្ឃជជែកគ្នា ព្រោះអាបត្តាធិករណ៍ ហៅថា វិវាទាធិករណ៍។ កាលបើសង្ឃជជែក ទាំងចោទប្រកាន់ផង ហៅថា អនុវាទាធិករណ៍។ កាលបើសង្ឃចោទ ត្រូវអាបត្តិ (ខ្លួនឯង) ហៅថា អាបត្តាធិករណ៍។ សង្ឃធ្វើកម្ម ចំពោះអាបត្តិដែលត្រូវនោះ ហៅថា កិច្ចាធិករណ៍។ អធិករណ៍ទាំង៤ តែងកើតឡើង ព្រោះអាបត្តាធិករណ៍ជាបច្ច័យ ដូចពោលមកយ៉ាងនេះ។

[៩១៤] សួរថា បណ្តាអធិករណ៍ទាំង៤ កិច្ចាធិករណ៍ ញ៉ាំងអធិករណ៍ណាឱ្យតាំងឡើង។ បណ្តាអធិករណ៍ទាំង៤ កិច្ចាធិករណ៍ មិនបានញ៉ាំងអធិករណ៍ណាឱ្យតាំងឡើងទេ ប៉ុន្តែអធិករណ៍ទាំង ៤ តែងតាំងឡើង ព្រោះកិច្ចាធិករណ៍ជាបច្ច័យ។ ដូចជាអ្វី។ (ដូចជា) កិច្ច ការនិងកម្មណាដែលសង្ឃត្រូវធ្វើ គឺ អបលោកនកម្ម ញត្តិកម្ម ញត្តិ ទុតិយកម្ម ញត្តិចតុត្ថកម្ម កម្មដែលសង្ឃត្រូវធ្វើទាំងនេះ ហៅថា កិច្ចាធិករណ៍។ សង្ឃជជែកគ្នា ព្រោះកិច្ចាធិករណ៍ ហៅថា វិវាទាធិករណ៍។ កាលបើសង្ឃជជែក ទាំងចោទផង ហៅថា អនុវាទាធិករណ៍។ កាលបើសង្ឃចោទ ត្រូវអាបត្តិ (ខ្លួនឯង) ហៅថា អាបត្តាធិករណ៍។ សង្ឃធ្វើកម្មចំពោះអាបត្តិដែលត្រូវនោះ ហៅថា កិច្ចាធិករណ៍។ អធិករណ៍ទាំង៤ តែងកើតឡើង ព្រោះកិច្ចាធិករណ៍ជាបច្ច័យ ដូចពោលមក យ៉ាងនេះ។

ចប់ សមុដ្ឋាបេតិវារៈ ជាគម្រប់២០។

# (ភជតិវារៈ ទី២១)

CS vin.pv.03.21 | ភាគ ទី១២

### (២១. ភជតិវារោ)

[៩១៥] សួរថា បណ្តាអធិករណ៍ទាំង៤ វិវាទាធិករណ៍ រួមចូលនឹងអធិករណ៍ណា អាស្រ័យនឹងអធិករណ៍ណា រាប់បញ្ចូលក្នុងអធិករណ៍ណា សង្គ្រោះដោយអធិករណ៍ណា។ បណ្តាអធិករណ៍ទាំង៤ អនុវាទាធិករណ៍ រួមចូលនឹងអធិករណ៍ណា អាស្រ័យនឹងអធិករណ៍ណា រាប់បញ្ចូលក្នុងអធិករណ៍ណា សង្គ្រោះដោយអធិករណ៍ណា។ បណ្តាអធិករណ៍ទាំង៤ អាបត្តាធិករណ៍ រួមចូលនឹងអធិករណ៍ណា អាស្រ័យនឹងអធិករណ៍ណា រាប់បញ្ចូលក្នុងអធិករណ៍ណា សង្គ្រោះដោយអធិករណ៍ណា។ បណ្តាអធិករណ៍ទាំង៤ កិច្ចាធិករណ៍ រួមចូលនឹងអធិករណ៍ណា អាស្រ័យនឹងអធិករណ៍ណា រាប់បញ្ចូលក្នុងអធិករណ៍ណា សង្គ្រោះដោយអធិករណ៍ណា។ ឆ្លើយថា បណ្តាអធិករណ៍ទាំង៤ វិវាទាធិករណ៍ រួមចូលនឹងវិវាទាធិករណ៍ អាស្រ័យនឹងវិវាទាធិករណ៍ រាប់បញ្ចូលក្នុងវិវាទាធិករណ៍ សង្គ្រោះដោយវិវាទាធិករណ៍។ បណ្តាអធិករណ៍ទាំង៤ អនុវាទាធិករណ៍ រួមចូលនឹងអនុវាទាធិករណ៍ អាស្រ័យនឹងអនុវាទាធិករណ៍ រាប់ញ្ចូលក្នុងអនុវាទាធិករណ៍ សង្គ្រោះដោយអនុវាទាធិករណ៍។ បណ្តាអធិករណ៍ទាំង៤ អាបត្តាធិករណ៍ រួមចូលនឹងអាបត្តាធិករណ៍ អាស្រ័យនឹងអាបត្តាធិករណ៍ រាប់បញ្ចូលក្នុងអាបត្តាធិករណ៍ សង្គ្រោះដោយអាបត្តាធិករណ៍។ បណ្តាអធិករណ៍ទាំង៤ កិច្ចាធិករណ៍ រួមចូលនឹងកិច្ចាធិករណ៍ អាស្រ័យនឹងកិច្ចាធិករណ៍ រាប់បញ្ចូលក្នុងកិច្ចាធិករណ៍ សង្គ្រោះដោយកិច្ចាធិករណ៍។

[៩១៦] សួរថា បណ្តាសមថៈទាំង៧ វិវាទាធិករណ៍ រួមចូលនឹងសមថៈប៉ុន្មាន អាស្រ័យនឹងសមថៈប៉ុន្មាន រាប់បញ្ចូលក្នុងសមថៈប៉ុន្មាន សង្គ្រោះដោយសមថៈប៉ុន្មាន រម្ងាប់ដោយសមថៈប៉ុន្មានយ៉ាង។ អនុវាទាធិករណ៍។បេ។ អាបត្តាធិករណ៍។បេ។ បណ្តា សមថៈទាំង៧ កិច្ចាធិករណ៍ រួមចូលនឹងសមថៈប៉ុន្មាន អាស្រ័យនឹងសមថៈប៉ុន្មាន រាប់បញ្ចូលក្នុងសមថៈប៉ុន្មាន សង្គ្រោះដោយសមថៈប៉ុន្មាន រម្ងាប់ដោយសមថៈប៉ុន្មាន។ ឆ្លើយថា បណ្តាសមថៈទាំង៧ វិវាទាធិករណ៍ រួមចូលនឹងសមថៈ២ អាស្រ័យនឹងសមថៈ២ រាប់បញ្ចូលក្នុងសមថៈ ២ សង្គ្រោះដោយសមថៈ ២

រម្ងាប់ដោយសមថៈ ២ គឺសម្មុខាវិន័យ១ យេភុយ្យសិកា១។ បណ្ដាសមថៈទាំង៧ អនុវាទាធិករណ៍ រួមចូលនឹងសមថៈ ៤ អាស្រ័យ នឹងសមថៈ ៤ រាប់បញ្ចូលក្នុងសមថៈ៤ សង្គ្រោះដោយសមថៈ៤ រម្ងាប់ដោយសមថៈ ៤ គឺសម្មុខាវិន័យ១ សតិវិន័យ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១។ បណ្ដាសមថៈទាំង ៧ អាបត្តាធិករណ៍ រួមចូលនឹងសមថៈ ៣ អាស្រ័យនឹងសមថៈ៣ រាប់បញ្ចូលក្នុងសមថៈ ៣ សង្គ្រោះដោយសមថៈ ៣ រម្ងាប់ដោយសមថៈ៣ គឺ សម្មុខាវិន័យ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។ បណ្ដាសមថៈទាំង៧ កិច្ចាធិករណ៍ រួមចូលនឹងសមថៈ១ អាស្រ័យនឹងសមថៈ១ រាប់បញ្ចូលក្នុងសមថៈ១ សង្គ្រោះដោយសមថៈ១ រម្ងាប់ដោយសមថៈ១ គឺ សម្មុខាវិន័យ។

ចប់ សមថភេទ។

ឧទ្ទានគឺ បញ្ជីរឿងនៃវីសតិវារៈនោះ ដូច្នេះ

[៩១៧]

និយាយអំពីអធិករណប្បច្ចយវារៈ១ បរិយាយវារៈ១ សាធារណវារៈ១ តព្ភាគិយវារៈ១ សមថាសមថសាធារណវារៈ១ សមថាសមថតព្ភាគិយវារៈ១ សមថសម្មុខាវិនយវារៈ១ វិនយវារៈ១ កុសលវារៈ១ យត្ថវារៈ១ សមយវារៈ១ សំសដ្ឋវារៈ១ សម្មតិវារៈ១ សម្មន្និនសម្មន្និវារៈ១ សមថាធិករណវារៈ១ សម្មុដ្ឋាបេតិវារៈ១ ភជន្តិវារៈ១។

ចប់ ភាគ១២

# មាតិកា


| ចុល្លវគ្គ | លេខ ទំព័រ |
|---|---|
| **ភាគ ទី១ បឋមភាគ** | ១ |
| **បរិវារៈ** | ១ |
| **ក្នុងមហាវិភង្គ មានវារៈ១៦** | ១ |
| បឋមបារាជិក | ៣ |
| នាមរបស់ព្រះថេរៈទាំងឡាយ | ៧ |
| ទុតិយបារាជិក | ៩ |
| បារាជិក ទី៤ និងឧទ្ទានគាថា | ១១ |
| មហាវិភង្គ មហាវារៈ ១៦ សង្ឃាទិសេស ទី១ | ១៣ |
| សង្ឃាទិសេស ទី៣-៤ | ១៧ |
| សង្ឃាទិសេស ទី៦-៧ | ១៩ |
| សង្ឃាទិសេស ទី ១០-១១ | ២១ |
| ឧទ្ទានគាថា | ២៣ |
| មហាវិភង្គ មហាវារៈ ១៦ អនិយតៈ ទី១ | ២៥ |
| អនិយតៈ ទី២ | ២៩ |
| មហាវិភង្គ មហាវារៈ ១៦ និស្សគ្គិយកណ្ឌ កឋិនវគ្គ | ៣១ |
| និស្សគ្គិយកណ្ឌ កោសិយវគ្គ | ៣៧ |
| បត្តវគ្គ | ៤៣ |
| មហាវិភង្គ មហាវារៈ ១៦ បាចិត្តិយកណ្ឌ មុសាវាទវគ្គ | ៤៩ |
| បាចិត្តិយកណ្ឌ មុសាវាទវគ្គ និងឧទ្ទានគាថា | ៥៣ |
| ភូតគាមវគ្គ | ៥៥ |
| ឱវាទវគ្គ | ៥៩ |

| | |
|---|---|
| ភោជនវគ្គ | ៦៥ |
| អចេលកវគ្គ | ៧០ |
| អចេលកវគ្គ ឧទ្ទានគាថា | ៧៥ |
| សុរាមេរយវគ្គ | ៧៧ |
| សប្បាណកវគ្គ | ៨១ |
| សប្បាណកវគ្គ ឧទ្ទានគាថា | ៨៥ |
| សហធម្មិកវគ្គ | ៨៧ |
| រាជវគ្គ | ៩៣ |
| ឧទ្ទានគាថា | ៩៧ |
| មហាវិភង្គ មហាវារៈ ១៦ បាដិទេសនីយកណ្ឌ | ៩៩ |
| មហាវិភង្គ មហាវារៈ ១៦ សេខិយកណ្ឌ បរិមណ្ឌលវគ្គ | ១០០ |
| សេខិយកណ្ឌ ខជ្ជក្សិកវគ្គ | ១០៥ |
| ឧម្កកតវគ្គ | ១០៩ |
| បិណ្ឌបាតវគ្គ | ១១១ |
| កពឡវគ្គ | ១១៣ |
| សរុសុរុវគ្គ | ១១៥ |
| បាទុកាវគ្គ | ១១៩ |
| ឧទ្ទានគាថា | ១២៥ |
| មហាវិភង្គ មហាវារៈ ១៦ បារាជិក ៤ | ១២៧ |
| មហាវិភង្គ មហាវារៈ ១៦ សង្ឃាទិសេស ១៣ | ១២៩ |
| មហាវិភង្គ មហាវារៈ ១៦ និស្សគ្គិយកណ្ឌ កឋិនវគ្គ | ១៣៣ |
| និស្សគ្គិយកណ្ឌ កោសិយវគ្គ | ១៣៥ |
| បត្តវគ្គ | ១៣៧ |
| មហាវិភង្គ មហាវារៈ ១៦ បាចិត្តិយកណ្ឌ មុសាវាទវគ្គ | ១៣៩ |
| បាចិត្តិយកណ្ឌ ភូតគាមវគ្គ | ១៤០ |
| ឱវាទវគ្គ | ១៤៥ |
| ភោជនវគ្គ | ១៤៧ |
| អចេលកវគ្គ | ១៤៩ |
| សុរាមេរយវគ្គ | ១៥១ |
| សប្បាណកវគ្គ | ១៥៣ |
| សហធម្មិកវគ្គ | ១៥៥ |
| រាជវគ្គ | ១៥៩ |
| មហាវិភង្គ មហាវារៈ ១៦ បាដិទេសនីយកណ្ឌ | ១៦០ |
| មហាវិភង្គ មហាវារៈ ១៦ និស្សគ្គិយកណ្ឌ វគ្គទី១ | ១៦៣ |
| និស្សគ្គិយកណ្ឌ វគ្គទី២ | ១៦៥ |
| វគ្គទី៤ | ១៦៧ |
| វគ្គទី៥ | ១៦៩ |

| | |
|---|---|
| វគ្គទី៧ | ១៧១ |
| មហាវិភង្គ មហាវារៈ ១៦ សង្គហិតាវារៈ និងសមុដ្ឋានវារៈ | ១៧៥ |
| មហាវារៈ ១៦ សមថវារៈ | ១៧៧ |
| សមុច្ចយវារៈ | ១៧៩ |
| កត្ថបញ្ញត្តិវារៈ | ១៨១ |
| កតាបត្តិវារៈ | ១៩៥ |
| កតាបត្តិវារៈ វិបត្តិវារៈ | ២០១ |
| សមុដ្ឋានវារៈ | ២០៣ |
| សមុច្ចយវារៈ | ២០៥ |
| **ភិក្ខុនីវិភង្គ មហាវារៈ១៦** | **២០៨** |
| មហាវារៈ ១៦ បារាជិក ៨ | ២០៩ |
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ សង្ឃាទិសេស ១០ | ២១៥ |
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ និស្សគ្គិយបាចិត្តិយៈ ១២ | ២២៣ |
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ បាចិត្តិយៈ លសុណវគ្គ | ២៣១ |
| បាចិត្តិយៈ រត្តន្ធការវគ្គ | ២៣៥ |
| រត្តន្ធការវគ្គ និងនហានវគ្គ | ២៣៩ |
| តុវដ្តវគ្គ | ២៤៥ |
| ចិត្តាគារវគ្គ | ២៤៩ |
| អារាមវគ្គ | ២៥៣ |
| គព្ភិនីវគ្គ | ២៥៧ |
| កុមារីភូតវគ្គ | ២៦៣ |
| ឆត្តុបាហនវគ្គ | ២៦៩ |
| ឧទ្ទានគាថា | ២៧៥ |
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ បាដិទេសនីយៈ ៨ | ២៧៩ |
| មហាវារៈ ១៦ ឧទ្ទានគាថា | ២៨១ |
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ បារាជិក | ២៨៣ |
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ សង្ឃាទិសេស | ២៨៥ |
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ និស្សគ្គិយបាចិត្តិយៈ | ២៨៧ |
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ បាចិត្តិយៈ លសុណវគ្គ | ២៩១ |
| បាចិត្តិយៈ រត្តន្ធការវគ្គ | ២៩៣ |
| នហានវគ្គ | ២៩៥ |
| តុវដ្តវគ្គ | ២៩៧ |
| ចិត្តាគារវគ្គ | ២៩៩ |
| អារាមវគ្គ | ៣០១ |
| គព្ភិនីវគ្គ | ៣០៣ |
| កុមារីភូតវគ្គ | ៣០៥ |
| ឆត្តុបាហនវគ្គ | ៣០៩ |

| | |
|---|---|
| ភិក្ខុនីវិភង្គ មហាវារៈ ១៦ បាជិទេសនីយៈ ៨ | ៣១១ |
| មហាវារៈ ១៦ សង្គហវារៈ | ៣១៣ |
| សមុដ្ឋានវារៈ និងអធិករណវារៈ | ៣១៥ |
| សមុច្ចយវារៈ | ៣១៧ |
| បារាជិក | ៣២១ |
| កត្ថ បញ្ញត្តិវារៈ | ៣២៣ |
| កត្ថ បញ្ញត្តិវារៈ | ៣២៧ |
| កតិអាបត្តិវារៈ បារាជិក | ៣៣០ |
| សង្ឃាទិសេស | ៣៣២ |
| វិបត្តិវារៈ | ៣៣៦ |
| សង្គហវារៈ | ៣៣៧ |
| សមុដ្ឋានវារៈ | ៣៣៨ |
| អធិករណវារៈ និងសមថវារៈ | ៣៣៩ |
| សមុច្ចយវារៈ | ៣៤០ |
| **សមុដ្ឋានសីសសង្ខេប** | **៣៤៤** |
| សមុដ្ឋានសីសសង្ខេប សមុដ្ឋានកថា | ៣៤៥ |
| បឋមបារាជិកសមុដ្ឋាន | ៣៤៧ |
| ទុតិយបារាជិកសមុដ្ឋាន | ៣៤៨ |
| សញ្ចរិត្តសមុដ្ឋាន | ៣៥១ |
| សមនុភាសនសមុដ្ឋាន | ៣៥៣ |
| កឋិនសមុដ្ឋាន | ៣៥៤ |
| ឯឡកលោមសមុដ្ឋាន | ៣៥៥ |
| បទសោធម្មសមុដ្ឋាន | ៣៥៧ |
| អទ្ធានសមុដ្ឋាន | ៣៥៨ |
| ថេយ្យសត្ថសមុដ្ឋាន និងធម្មទេសនាសមុដ្ឋាន | ៣៥៩ |
| ភូតារោចនសមុដ្ឋាន | ៣៦០ |
| ចោរីវុដ្ឋាបនសមុដ្ឋាន និងអននុញ្ញាតសមុដ្ឋាន | ៣៦១ |
| **កតិបុច្ឆាវារៈ** | **៣៦៣** |
| កតិបុច្ឆាវារៈ អាបត្តិ ៧ វិនីតវត្ថុ ៧ | ៣៦៥ |
| សេចក្តីមិនគោរព ៦យ៉ាង សេចក្តីគោរព ៦យ៉ាង និងវិនីតវត្ថុ ៦យ៉ាង | ៣៦៦ |
| វិបត្តិ ៤ សមុដ្ឋាននៃអាបត្តិ ៦ មូលនៃវិវាទ ៦ | ៣៦៨ |
| មូលនៃអនុវាទ ៦យ៉ាង | ៣៧០ |
| សារាណីយធម៌ ៦យ៉ាង | ៣៧៣ |
| ភេទករវត្ថុ ១៨យ៉ាង | ៣៧៦ |
| អធិករណៈ ៤ និង សមថៈ ៧ | ៣៧៧ |
| ឧទ្ទាននៃកតិបុច្ឆាវារៈ | ៣៧៨ |
| | |

| | |
|---|---|
| វីសតិវារៈ | ៣៧៩ |
| វីសតិវារៈ វារៈនៃអាបត្តិសមុដ្ឋាន ៦យ៉ាង | ៣៨១ |
| សមុដ្ឋាននៃអាបត្តិ ៦យ៉ាង និងកតាបត្តិវារៈ | ៣៨២ |
| អាបត្តិសមុដ្ឋានគាថា | ៣៩២ |
| វិបត្តិបច្ចយវារៈ | ៣៩៦ |
| អធិករណប្បច្ចយវារៈ | ៤០១ |
| ឧទ្ទាននៃអនន្តរបេយ្យាល | ៤០៨ |
| បរិយាយវារៈ | ៤០៨ |
| សាធារណវារៈ | ៤១០ |
| តព្ភាគិយវារៈ | ៤១៥ |
| វារៈនៃសមថៈដែលទូទៅដល់សមថៈ | ៤១៦ |
| វារៈនៃសមថៈដែលមានចំណែកត្រូវគ្នានឹងសមថៈ | ៤១៨ |
| វារៈនៃសមថៈដែលហៅថាសម្មុខាវិន័យ | ៤២០ |
| វិនយវារៈ | ៤២២ |
| កុសលវារៈ | ៤២៣ |
| ចក្កបេយ្យាល យត្ថវារៈ | ៤២៥ |
| សមយវារៈ | ៤៣០ |
| សំសដ្ឋវារៈ | ៤៣៣ |
| សម្មន្តិវារៈ | ៤៣៤ |
| វារៈនៃអធិករណ៍ដែលរម្ងាប់ និងមិនរម្ងាប់ | ៤៣៧ |
| សមថាធិករណវារៈ | ៤៤៣ |
| សមុដ្ឋាបេតិវារៈ | ៤៤៩ |
| សមថភេទ | ៤៥៣ |
| ឧទ្ទាននៃវីសតិវារៈ | ៤៥៩ |



ភាគ ទី ០១១ | **មាតិកា** | ភាគ ទី ០១៣


1)
អដ្ឋកថា ថា សេចក្តីបញ្ញត្តថា ភិក្ខុណាមួយ សេពមេថុនធម្ម ត្រូវបារាជិកគ្មានសំវាស នេះជាបញ្ញត្តិ១។
2)
ពាក្យថា ភិក្ខុសេពមេថុនធម្ម ដោយហោចទៅសូម្បីតែនឹងសត្វតិរច្ឆានក្តី មិនពោលលាសិក្ខាក្តី ទាំងនេះ ចាត់ជាអនុប្បញ្ញត្តិពីរ។
3)
សេចក្តីបញ្ញត្តិមុនកើតរឿងឡើង ដូចជា ទ្រង់បញ្ញត្តគរុធម៌៨ ដល់ពួកភិក្ខុនី នេះចាត់ជា អនុប្បន្នប្បញ្ញត្តិ ៗនេះមិនមានក្នុងទីឯទៀតទេ។
4)
សិក្ខាបទដែលទ្រង់បញ្ញត្តទូទៅទាំងមជ្ឈិមបទេស ទាំងបច្ចន្តជនបទ ហៅថាសព្វត្ថប្បញ្ញត្តិ។
5)
សិក្ខាបទដែលទ្រង់បញ្ញត្តហាមក្នុងមជ្ឈិមបទេស មាន៤សិក្ខាបទ គឺឧបសម្បទាដោយគណៈសង្ឃ មានភិក្ខុជាវិនយធរជាគម្រប់៥ ស្បែកជើង៤ជាន់ ស្រង់ទឹកជានិច្ច កម្រាលស្បែក ហៅថា បទេសប្បញ្ញត្តិ។
6)
សិក្ខាបទដែលទ្រង់បញ្ញត្តទូទៅ ទាំងភិក្ខុ ទាំងភិក្ខុនី ហៅថា សាធារណប្បញ្ញត្តិ។
7)

សិក្ខាបទដែលទ្រង់បញ្ញត្តចំពោះតែភិក្ខុ ឬ ចំពោះតែភិក្ខុនីម្យ៉ាង ហៅថា អសាធារណបញ្ញត្តិ។

8)

ឯកតោបញ្ញត្តិ មានសេចក្តីដូចអសាធារណបញ្ញត្តិ ឧភតោបញ្ញត្តិ មានសេចក្តីដូចសាធារណបញ្ញត្តិ។

9)

អដ្ឋកថា ថា ពាក្យថាទ្រទ្រង់ទុក គឺចាំស្ទាត់ ទាំងបាលី ទាំងអដ្ឋកថា នៃបឋមបារាជិក

10)

កំណត់ប្រវែង ទំហំ និងសាច់ចីវរ តាមដែលខ្លួនពេញចិត្ត គឺចង់បានឱ្យល្អហួសហេតុ។

11)

បណិតភោជននោះ បានដល់ វត្ថុឧត្តម៩យ៉ាងគឺ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ។

12)

ភិក្ខុឃើញអាបត្តិក្តី មិនសម្តែងអាបត្តិក្តី មិនលះបង់ទិដ្ឋិអាក្រក់ក្តី សង្ឃលើកវត្ត ដោយត្រឹមត្រូវតាមធម៌ តាមវិន័យ ហើយសង្ឃបានឃើញភិក្ខុនោះប្រព្រឹត្តវត្តត្រឹមត្រូវ ក៏ធ្វើនូវឱសារណកម្ម គឺសូត្រដកវត្តនោះចេញ (ប្រហែលគ្នានឹងអព្ភានកម្ម) ហៅថាអនុធម៌

13)

អាហារចំនួនមួយម៉ាត់ៗ ក៏ហៅថាពំនូតដែរ។

14)

គ្រឿងប្រហារដែលប្រយោល មានមុខមិនមុត ដូចកាំភ្លើង ធ្នូ ស្នា និងដំបងជាដើម ហៅថាអាវុធ។

15)

មើលក្នុងមហាវិភង្គភាគទី ៤ ត្រង់រតនវគ្គ សិក្ខាបទទី៦ បព្វៈ ៣៧៨ ទំព័រ ៣៩០។

16)

ក្នុងទីនេះ បើនិយាយតាមឈ្មោះសមថៈ ឃើញថា៣ តែបើនិយាយតាមសេចក្តីរួម នៅតែ២វិញ ដូចសេចក្តីដែលប្រែហើយនេះ។ ព្រោះក្នុងសុមង្គលវិលាសិនីអដ្ឋកថាទីឃនិកាយ ត្រង់សង្គីតិសូត្រ ពន្យល់ថា អាបត្តាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យតែម្យ៉ាងមិនបានទេ ដូចយ៉ាង ភិក្ខុសម្តែងលហុកាបត្តិ ក្នុងសម្នាក់ភិក្ខុ១រូប ឬកណ្តាលជំនុំសង្ឃ ឬគណៈ ក្នុងកាលណា ទើបហៅថា អាបត្តាធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ ក្នុងកាលនោះ។ ព្រោះហេតុដូច្នោះ បានជាលោកពោលថា អាបត្តាធិករណ៍ តែងរម្ងាប់ដោយន័យ២យ៉ាង គឺដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មានខ្លះ ដោយសម្មុខាវិន័យ និងតិណវត្ថារកៈក៏មានខ្លះ ដោយប្រការដូច្នេះ។

17)

មើលភិក្ខុនីវិភង្គ បច្ចេកភាគទី៥ បព្វៈ ១៦១ ទំព័រ ១២៦។

18)

មើលភិក្ខុនីវិភង្គបច្ចេកភាគទី៥ តាំងពីបព្វៈ ២៦ ទំព័រ ៣០ ដល់បព្វៈ ២៩ ទំព័រ ៣៤។

19)

ពាក្យថា វារៈនៃសង្ឃាដី គឺការប្រើប្រាស់សង្ឃាដីផ្លាស់ប្តូរនឹងឧត្តរាសង្គៈ។

20)

មើលភិក្ខុនីវិភង្គបច្ចេកភាគទី៥ ត្រង់បព្វៈ៣៨១ ទំព័រ ៣២៩ និងបព្វៈ៣៨៥ ទំព័រ៣៣៤។

21)

ក្នុងអដ្ឋកថាប្រាប់ថា មិនបាននាំយកជាប់ទៅជាមួយនឹងខ្លួន ទាំងមិនបានឱ្យគេនាំយកទៅ។

22)

កម្មវាចានេះ ហៅថាញត្តិចតុត្ថកម្មវាចា កម្មវាចាមានញត្តិជាគម្រប់៤ គឺមានញត្តិម្តងជាមុន ហើយមានកម្មវាចា៣ដងជាខាងក្រោយ។ ក្នុងខណៈចប់ញត្តិ ត្រូវទុក្កដ ចប់កម្មវាចាទី១ ត្រូវថុល្លច្ច័យ ចប់ទី២ ត្រូវថុល្លច្ច័យ ចប់ទី៣ ត្រូវបារាជិក។

23)

ក្នុងសិក្ខាបទនេះ មានវត្ថុ៨យ៉ាង គឺភិក្ខុនីត្រេកអរនឹងបុរសចាប់ដៃខ្លួន១ ចាប់ដោយសង្ឃាដី១ ឋិតនៅជាមួយបុរស១ និយាយជាមួយនឹងបុរស១ ទៅកាន់ទីសង្កេត១ ត្រេកអរនឹងបុរសដើរចូលមកជិត១ ចូលទៅកាន់ទីកំបាំង១ បន្ទន់កាយទៅ ដើម្បីសេពអសទ្ធម្ម១។

24)

សរីរប្រទេសខាងក្រោមតាំងពីផ្ចិតទៅទល់ត្រឹមក្បាល់ជង្គង់។

25)

អលង្ការរបស់ស្ត្រីមានឈ្នួត ខ្សែក ខ្សែដៃ កងជើង ខ្សែចង្កេះជាដើម។

26)

វត្ថុទាំង៨គឺ ១ ត្រេកអរនឹងការចាប់ដៃរបស់បុរសបុគ្គល, ២ ត្រេកអរនឹងការចាប់ជាយសង្ឃដីរបស់បុរសបុគ្គល, ៣ ឈរជាមួយនឹងបុរសបុគ្គល, ៤ ចរចាជាមួយនឹងបុរសបុគ្គល, ៥ ទៅកាន់ទីសង្កេត, ៦ ត្រេកអរនឹងបុរសដើរចូលមកជិត, ៧ ចូលទៅកាន់ទីកំបាំង, ៨ បង្អោនកាយទៅដើម្បីសេពនូវអសទ្ធម្ម (ភិក្ខុនីវិភង្គ)។

27)

ភិក្ខុនីអ្នកប្រព្រឹត្តតាមភិក្ខុភិក្ខុនីដែលសង្ឃលើកវត្តហើយ។

28)

ភិក្ខុនីអ្នកប្រព្រឹត្តតាម ភិក្ខុភិក្ខុនីអ្នកបំបែកសង្ឃ។

29)

អត្តា ប្រែថា ខ្លួន ថាចិត្ត ឬថា សភាវៈតែងប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន។ អនត្តា ប្រែថា សភាវៈមិនមែនខ្លួន មិនមែនចិត្ត មិនប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន។ យើងបានពិនិត្យមើលត្រង់បទដែលថា អនត្តា នោះច្រើនគម្ពីរ បានចូលចិត្តដោយច្បាស់លាស់ថា ធម៌ទាំងអស់ គឺអាយតនៈ១២ ឬខន្ធ៥ប្រការ សុទ្ធតែជាអនត្តាគ្រប់ចំណែក សូម្បីព្រះនិព្វានដែលជាធម៌យ៉ាងឯក ក៏គង់បានឈ្មោះថាជា អនត្តាដែរ តែធម៌ទាំងអស់ក្រៅចាកព្រះនិព្វាននោះ នៅមានខន្ធ៥ ជាហេតុជាបច្ច័យឱ្យកើតទៀត ព្រោះធម៌ទាំងនោះជាសសង្ខារនៅឡើយ។ ឯព្រះនិព្វា ជាអនត្តាដែរ ជាធម៌មិនមានហេតុ មិនមានបច្ច័យជាកម្លាំងឱ្យកើតឡើយ។ ព្រោះព្រះនិព្វាន នេះជាវិសង្ខារទៅហើយ ព្រះនិព្វាននោះ ពិតមែនតែជាគុណជាតមិនត្រូវកើតទៀត តែមិន មែនជាឋានសូន្យទទេនោះទេ គឺព្រះនិព្វាននៅមានអាយតនៈមួយ ឬមានហេតុម្យ៉ាង គឺអរហត្ត ផលញ្ញាណនោះឯង សមដូចពុទ្ធភាសិតថា អត្ថិ ភិក្ខវេ តទាយតនំ។

30)

សំដៅយកសង្ខតធម៌ គឺមានបច្ច័យប្រជុំតាក់តែងបាន ជាធម៌មានចំណែកស្មើដោយអាការ មានមិនទៀងជាដើម។

31)

គឺអនុប្បខជ្ជសិក្ខាបទ ក្នុងភូតគាមវគ្គសិក្ខាបទទី៦។

32)

គឺភិក្ខុអង្គុយក្នុងទីកំបាំងជាមួយនឹងភិក្ខុនី។

33)

គឺបឋមរហោនិសជ្ជ១ ទុតិយរហោនិសជ្ជ១ (អចេលកវគ្គ សិក្ខាបទទី៤-៥)។

34)

គឺតលសត្តិកសិក្ខាបទ។

35)

គឺខាទនីយគហណសិក្ខាបទ។

36)

គឺសប្បាណកសិក្ខាបទទី១០ ក្នុងភូតគាមវគ្គ។

37)

គឺទុតិយបវារណាសិក្ខាបទ។

38)

គឺ ឧយ្យោជនសិក្ខាបទ។

39)

គឺសញ្ចិច្ចបាណសិក្ខាបទ។

40)

៥ គឺឧក្ខិត្តសម្ភោគសិក្ខាបទ។

41)

គឺកណ្ដកសិក្ខាបទ។

42)

គឺអមូលកសិក្ខាបទទី៦ ក្នុងសហធម្មិកវគ្គ។

43)

គឺសញ្ចិច្ចសិក្ខាបទ។

44)

គឺកម្មប្បដិពាហនសិក្ខាបទ។

45)

គឺខិយ្យធម្មសិក្ខាបទ។

46)

មានក្នុងភិក្ខុនីវិភង្គ។

47)

គឺ ឩទានសវស្សាគិហិគតា ១ បរិបុណ្ណទ្វាទសវស្សាអសិក្ខិតសិក្ខាបទគិហិគតា១ ទ្វេវស្សានិសិក្ខិតាសង្ឃេនអសម្មតាគិហិគតា១។

48)

គឺចែកដូចគ្នានឹងគិហិគតាសិក្ខាបទ។

49)

គួរហៅថា តទុត្តរិសិក្ខាបទបុណ្ណោះ។

50)
គឺរាជសិក្ខាបទ។
51)
គឺឯឡកលោមធោវបនសិក្ខាបទ។
52)
គឺមហាបេសការសិក្ខាបទ។
53)
គឺមហល្លកសិក្ខាបទទី៩ ក្នុងភូតគាមវគ្គ។
54)
គឺកាណមាតាសិក្ខាបទ។
55)
គឺមហានាមសិក្ខាបទ។
56)
គឺនន្ទុត្តរសិក្ខាបទ។
57)
គឺភិក្ខុនីយាសំសដ្ឋសិក្ខាបទ។
58)
គឺគីហិសំសដ្ឋសិក្ខាបទ។
59)
សហជិវិនីនានុគ្គហណសិក្ខាបទ១ សហជីវិនីនវុបកាសនសិក្ខាបទ១។
60)
សង្ឃាទិសេសសិក្ខាបទ៤ គឺតាំងពីសង្ឃភេទដល់កុលទូសកៈ ឈ្មោះថាសមនុភាសនា ឬហៅថា យាវតតិយកា។
61)
ឧព្ភតកឋិនសិក្ខាបទ៣នោះ គឺបឋមកឋិន១ ទុតិយកឋិន ១ តតិយកឋិន ១។
62)
បក្កមនសិក្ខាបទ ២ នោះ គឺបឋមសេនាសនៈ ១ ទុតិយសេនាសនៈ ១។
63)
គឺបឋមបវារណា។
64)
គឺទុតិយបវារណា។
65)
គឺអន្តេបុរសិក្ខាបទ។
66)
អាវាសថសិក្ខាបទ២នោះ គឺអាវាសថចីវរនិស្សជ្ជនសិក្ខាបទ ១ អាវាសថចីវរបក្កមនៈ ១។
67)
បឋមសហសេយ្យសិក្ខាបទ១ ទុតិយសហសេយ្យសិក្ខាបទ១។
68)
វេហាសកុដិសិក្ខាបទ។
69)
តិរច្ឆានវិជ្ជា២នោះ គឺតិរច្ឆានវិជ្ជាបរិយាបុនសិក្ខាបទ ១ តិរច្ឆានវិជ្ជាវាចនសិក្ខាបទ១។
70)
គឺសំវិធានសិក្ខាបទ។
71)
អដ្ឋកថា ថា ប្រព្រឹត្តទៅដើម្បីឧបចារសមាធិនិងអប្បនាសមាធិ។
72)
ត្រង់កន្លែងបេយ្យាលៈនេះ ត្រូវធ្វើសម្មុខាវិន័យមុនគេ លុះចប់ហើយត្រូវនិយាយពីសតិវិន័យ រហូតដល់តិណវត្ថារកៈតទៅ។

-Namo tassa bhagavato arahato sammā-

ព្រះត្រៃបិដកភាសាខ្មែរ - **Tipiṭaka Khmer language**

ភាគ ០១៣ - Book 013

Ven. Members of the Sangha, Ven. Theras Valued Upasaka, valued Upasika This is a Work Edition! 1.Edition 20170101 Do not share it further except for editing and working purposes within the transcription project on sangham.net. Only for personal use. If you find any mistake or like to join the merits please feel invited to join here: sangham.net [http://sangham.net/index.php/board,85.0.html] or Upasika Norum on sangham.net **Anumodana!**

សូមថ្វាយបង្គំចំពោះព្រះសង្ឃ, ជំរាបសួរឧបាសក និងឧបាសិកាទាំងអស់ នេះគឺជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ! 1.Edition 20170101 សូមកុំចែករំលែកបន្ថែមទៀត ប្រសិនបើមិនមែនសម្រាប់ការកែសម្រួលនៅ sangham.net និងកិច្ចការនេះ។ សូមគិតថា លោកអ្នកត្រូវបានអញ្ជើញដើម្បីចូលរួមបុណ្យកុសលនេះ និងសូមប្រាប់ពួកយើងអំពីកំហុស និងប្រើវេទិកានេះ: sangham.net [http://sangham.net/index.php/board,85.0.html] ឬប្រាប់ឧបាសិកា Norum នៅលើ sangham.net **សូមអនុមោទនា**!

A topic about progress and feedback can be found here: ព្រះត្រៃបិដក ភាគ ០១៣ - Tipitaka Book 013 [http://forum.sangham.net/index.php/topic,9193.0.html], for change log on ati.eu see here: របាយការណ៍ ភាគ ០១៣




គំរូ ឯកសារ ផ្សេងទៀត ៖
book_013.pdf

CS លេខសម្គាល់
លេខទំព័រ

# ព្រះត្រៃបិដក ភាគ ទី១៣

ទ. ១

# វិន័យបិដក

CS vin | ភាគ ទី១៣

**ភាគ ទី១៣**

# បរិវារៈ

---

CS vin.pv | ភាគ ទី១៣

**(បរិវារ)**

**ទុតិយភាគ**
ភាគ ទី២

ខន្ធកបុច្ឆា | ឯកុត្តរិកៈ | បុច្ឆាវិសជ្ជនាអំពីឧបោសថកម្មជាដើម | គាថាសង្គណិកៈ | អធិករណភេទ | គាថាសង្គណិកៈ ជាតំណមក | ចោទនាកណ្ឌ | ចូឡសង្គាម | មហាសង្គាម | កឋិនភេទ | ឧបាលិបញ្ចកៈ | សមុដ្ឋាន | ទុតិយគាថាសង្គណិកៈ | សេទមោចនគាថា | បញ្ចវគ្គ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

## ខន្ធកបុច្ឆា

CS vin.pv.04 | ភាគ ទី១៣

**(ខន្ធកបុច្ឆាវារោ)**

[១] ខ្ញុំនឹងសួរឧបសម្បទាខន្ធកៈ ដែលប្រកបដោយនិទាន (ហេតុដែលទ្រង់បញ្ញត្តសិក្ខាបទ) ប្រកបដោយនិទ្ទេស (សំដែងអំពីបុគ្គលជាដើម) អាបត្តិរបស់បទឧក្រិដ្ឋ[1] មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយឧបសម្បទាខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន២។

[២] ខ្ញុំនឹងសួរឧបោសថក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយឧបោសថក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន៣។

[៣] ខ្ញុំនឹងសួរវស្សូបនាយិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយវស្សូបនាយិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន១។

[៤] ខ្ញុំនឹងសួរបវារណាខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយបវារណាខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន៣។

[៥] ខ្ញុំនឹងសួរចម្មសញ្ញុត្ត (ចម្មក្ខន្ធកៈ) ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយចម្មសញ្ញុត្ត ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន៣។

[៦] ខ្ញុំនឹងសួរភេសជ្ជក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយភេសជ្ជក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន៣។

[៧] ខ្ញុំនឹងសួរកឋិនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយកឋិនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស ឯអាបត្តិរបស់បទឧក្រិដ្ឋ មិនមានក្នុងកឋិនក្ខន្ធកៈនោះទេ។

[៨] ខ្ញុំនឹងសួរចីវរសញ្ញុត្ត (ចីវរក្ខន្ធកៈ) ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយចីវរសញ្ញុត្ត ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន៣។

[៩] ខ្ញុំនឹងសួរចម្បេយ្យក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយចម្បេយ្យក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន១។

[១០] ខ្ញុំនឹងសួរកោសម្ពិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយកោសម្ពិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន១។

[១១] ខ្ញុំនឹងសួរកម្មក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយកម្មក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន១។

[១២] ខ្ញុំនឹងសួរបរិវាសិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយបរិវាសិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន១។

[១៣] ខ្ញុំនឹងសួរសមុច្ចយក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយសមុច្ចយក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន១។

[១៤] ខ្ញុំនឹងសួរសមថក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយសមថក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន២។

[១៥] ខ្ញុំនឹងសួរខុទ្ទកវត្ថុក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយខុទ្ទកវត្ថុក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន៣។

[១៦] ខ្ញុំនឹងសួរសេនាសនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយសេនាសនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន៣។

[១៧] ខ្ញុំនឹងសួរសង្ឃភេទក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយសង្ឃភេទក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន២។

[១៨] ខ្ញុំនឹងសួរសមាចារ (វត្តក្ខន្ធកៈ) ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយសមាចារ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន១។

[១៩] ខ្ញុំនឹងសួរបាតិមោក្ខដ្ឋបនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយបាតិមោក្ខដ្ឋបនក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន១។

[២០] ខ្ញុំនឹងសួរភិក្ខុនីខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយភិក្ខុនីខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មាន២។

[២១] ខ្ញុំនឹងសួរបញ្ចសតិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយបញ្ចសតិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មិនមានក្នុងបញ្ចសតិកក្ខន្ធៈនោះទេ។

[២២] ខ្ញុំនឹងសួរសត្តសតិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មានប៉ុន្មាន។

ខ្ញុំនឹងឆ្លើយសត្តសតិកក្ខន្ធកៈ ដែលប្រកបដោយនិទាន ប្រកបដោយនិទ្ទេស អាបត្តិរបស់បទឧក្រិដ្ឋ មិនមានក្នុងសត្តសតិកក្ខន្ធកៈនោះទេ។

ចប់ ខន្ធកបុច្ឆាទី១។

ឧទ្ទាន គឺបញ្ជីរឿងនៃពាក្យសួរអំពីខន្ធកៈនោះ

[២៣]

> (ខន្ធកៈ២២ គឺ) ឧបសម្បទាខន្ធកៈ១ ឧបោសថក្ខន្ធកៈ១ វស្សូបនាយិកក្ខន្ធកៈ១ បវារណាក្ខន្ធកៈ១ ចម្មក្ខន្ធកៈ១ ភេសជ្ជក្ខន្ធកៈ១ កឋិនក្ខន្ធកៈ១ ចីវរក្ខន្ធកៈ១ ចម្ប្បេយ្យក្ខន្ធកៈ១ កោសម្ពិកក្ខន្ធកៈ១ កម្មក្ខន្ធកៈ១ បរិវាសិកក្ខន្ធកៈ១ សមុច្ចយក្ខន្ធកៈ១ សមថក្ខន្ធកៈ១ ខុទ្ទកវត្ថុក្ខន្ធកៈ១ សេនាសនក្ខន្ធកៈ១ សង្ឃភេទក្ខន្ធកៈ១ សមាចារ គឺវត្តក្ខន្ធកៈ១។ បាតិមោក្ខដ្ឋបនក្ខន្ធកៈ១ ភិក្ខុនីក្ខន្ធកៈ១ បញ្ចសតិកក្ខន្ធកៈ១ សត្តសតិកក្ខន្ធកៈ១។

# ឯកុត្តរិកៈ

CS vin.pv.05 | ភាគ ទី១៣

### (ឯកុត្តរិកនយោ)

## (ឯកកវារៈ ទី១)

CS vin.pv.05.01 | ភាគ ទី១៣

### (១. ឯកកវារោ)

[២៤] ភិក្ខុត្រូវស្គាល់ធម៌ ដែលធ្វើឲ្យមានអាបត្តិ។[2)] ភិក្ខុត្រូវស្គាល់ធម៌ ដែលធ្វើមិនឲ្យមានអាបត្តិ។[3)] ភិក្ខុត្រូវស្គាល់អាបត្តិ។[4)] ភិក្ខុត្រូវស្គាល់អនាបត្តិ។[5)] ភិក្ខុត្រូវស្គាល់លហុកាបត្តិ (អាបត្តិស្រាល)។ ភិក្ខុត្រូវស្គាល់គរុកាបត្តិ (អាបត្តិធ្ងន់)។ ភិក្ខុត្រូវស្គាល់សាវសេសាបត្តិ (លើកតែអាបត្តិបារាជិកចេញ)។ ភិក្ខុត្រូវស្គាល់អនវសេសាបត្តិ (អាបត្តិបារាជិក)។ ភិក្ខុត្រូវស្គាល់ទុដ្ឋុល្លាបត្តិ គឺអាបត្តិ២កងខាងដើម។ ភិក្ខុត្រូវស្គាល់អទុដ្ឋុល្លាបត្តិ គឺអាបត្តិ៥កងខាងចុង។ ភិក្ខុត្រូវស្គាល់អាបត្តិសំដែងចេញបាន។ ភិក្ខុត្រូវស្គាល់អាបត្តិសំដែងចេញមិនបាន។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលជាទេសនាគាមិនី។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលមិនមែនជាទេសនាគាមិនី។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលធ្វើនូវសេចក្តីអន្តរាយ។[6)] ភិក្ខុត្រូវស្គាល់អាបត្តិ ដែលមិនធ្វើសេចក្តីអន្តរាយ។[7)] ភិក្ខុត្រូវស្គាល់អាបត្តិ ដែលជាសាវជ្ជប្បញ្ញត្តិ។[8)] ភិក្ខុត្រូវស្គាល់អាបត្តិ ដែលជាអនវជ្ជប្បញ្ញត្តិ។[9)] ភិក្ខុត្រូវស្គាល់អាបត្តិ ដែលតាំងឡើងអំពីការធ្វើ (ដូចយ៉ាងបារាជិកាបត្តិ)។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលតាំងឡើងអំពីការមិនធ្វើ (ដូចជាភិក្ខុត្រូវអាបត្តិ ព្រោះ

មិនអធិដ្ឋានចីវរ)។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលតាំងឡើងអំពីការធ្វើ និងការមិនធ្វើ (ដូចក្នុងកុដិការសិក្ខាបទ)។ ភិក្ខុត្រូវស្គាល់អាបត្តិខាងដើម គឺអាបត្តិដែលភិក្ខុត្រូវមុន។ ភិក្ខុត្រូវស្គាល់អាបត្តិខាងចុង គឺអាបត្តិដែលត្រូវបន្ទាប់គ្នាមក។ ភិក្ខុត្រូវស្គាល់អាបត្តិជាចន្លោះ នៃអាបត្តិខាងដើម។[10] ភិក្ខុត្រូវស្គាល់អាបត្តិជាចន្លោះ នៃអាបត្តិខាងចុង។[11] ភិក្ខុត្រូវស្គាល់អាបត្តិ ដែលខ្លួនសំដែងហើយ ជាអាបត្តិ គួរដល់កិរិយារាប់ គឺដាក់ធុរៈចេញបាន។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលខ្លួនសំដែងហើយ តែមិនគួរដល់កិរិយារាប់ (ដាក់ធុរៈចេញបាន)។ ភិក្ខុត្រូវស្គាល់បញ្ញត្តិ។ ភិក្ខុត្រូវស្គាល់អនុប្បញ្ញត្តិ។ ភិក្ខុត្រូវស្គាល់អនុប្បន្នប្បញ្ញត្តិ។ ភិក្ខុត្រូវស្គាល់សព្វត្ថប្បញ្ញត្តិ។ ភិក្ខុត្រូវស្គាល់បទេសប្បញ្ញត្តិ។ ភិក្ខុត្រូវស្គាល់សាធារណប្បញ្ញត្តិ។ ភិក្ខុត្រូវស្គាល់អសាធារណប្បញ្ញត្តិ។ ភិក្ខុត្រូវស្គាល់ឯកតោបញ្ញត្តិ។ ភិក្ខុត្រូវស្គាល់ឧភតោបញ្ញត្តិ។ ភិក្ខុត្រូវស្គាល់អាបត្តិមានទោសធ្ងន់។ ភិក្ខុត្រូវស្គាល់អាបត្តិមិនមានទោសធ្ងន់។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលបដិសំយុត្តដោយគ្រហស្ថ។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលមិនបដិសំយុត្តដោយគ្រហស្ថ។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលទៀង គឺអនន្តរិយកម្ម៥។ ភិក្ខុត្រូវស្គាល់អាបត្តិ ដែលមិនទៀង គឺក្រៅអំពីអនន្តរិយកម្ម។ ភិក្ខុត្រូវស្គាល់បុគ្គល ដែលធ្វើខុសខាងដើមបញ្ញត្តិ (អាទិកម្មិកបុគ្គល)។ ភិក្ខុត្រូវស្គាល់បុគ្គល ដែលមិនធ្វើខុសខាងដើមបញ្ញត្តិ (អនុប្បញ្ញត្តិការកបុគ្គល)។ ភិក្ខុត្រូវស្គាល់បុគ្គលអ្នកត្រូវអាបត្តិមិនបានជានិច្ច (ត្រូវអាបត្តិម្តងៗ)។ ភិក្ខុត្រូវស្គាល់បុគ្គល អ្នកត្រូវអាបត្តិរឿយៗ (ត្រូវជានិច្ច)។ ភិក្ខុត្រូវស្គាល់បុគ្គលអ្នកចោទ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលគេចោទ។ ភិក្ខុត្រូវស្គាល់បុគ្គលអ្នកចោទមិនត្រូវតាមធម៌។ ភិក្ខុត្រូវស្គាល់បុគ្គលដែលគេចោទមិនត្រូវតាមធម៌។ ភិក្ខុត្រូវស្គាល់បុគ្គលអ្នកចោទត្រូវតាមធម៌។ ភិក្ខុត្រូវស្គាល់បុគ្គលដែលគេចោទត្រូវតាមធម៌។ ភិក្ខុត្រូវស្គាល់និយតបុគ្គល (ដែលប្រកបដោយមិច្ឆត្តនិយតធម៌ ឬសម្មត្តនិយតធម៌)។ ភិក្ខុត្រូវស្គាល់អនិយតបុគ្គល។ ភិក្ខុត្រូវស្គាល់បុគ្គល ដែលគួរដល់អាបត្តិ គឺពួកសាវ័ក។ ភិក្ខុត្រូវស្គាល់បុគ្គល ដែលមិនគួរដល់អាបត្តិ គឺព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធ។ ភិក្ខុត្រូវស្គាល់បុគ្គល ដែលសង្ឃធ្វើឧក្ខេបនីយកម្ម។ ភិក្ខុត្រូវស្គាល់បុគ្គលដែលសង្ឃមិនបានធ្វើឧក្ខេបនីយកម្ម។ ភិក្ខុត្រូវស្គាល់បុគ្គលដែលសង្ឃឲ្យវិនាសចេញហើយ។ ភិក្ខុត្រូវស្គាល់បុគ្គលដែលសង្ឃមិនបានឲ្យវិនាសចេញ។ ភិក្ខុត្រូវស្គាល់បុគ្គលមានសំវាសស្មើគ្នា។ ភិក្ខុត្រូវស្គាល់បុគ្គលមានសំវាសផ្សេងៗគ្នា។ ភិក្ខុត្រូវស្គាល់វិធីបញ្ឈប់បាតិមោក្ខ។

ចប់ ឯកកៈ (ពួកមួយៗ)។

ឧទ្ទាន គឺបញ្ជីរឿងនៃឯកកៈ (ពួកមួយៗ) នោះដូច្នេះ

[២៥]

> ហេតុដែលធ្វើឲ្យមានអាបត្តិ១ លហុកាបត្តិ១ សាវសេសាបត្តិ១ ទុដ្ឋុល្លាបត្តិ១ អាបត្តិដែលគួរសំដែងចេញបាន១ អាបត្តិដែលជាទេសនាគាមិនី១ អាបត្តិដែលធ្វើសេចក្តីអន្តរាយ១ អាបត្តិដែលជាសាវជ្ជប្បញ្ញត្តិ១ អាបត្តិដែលតាំងឡើងអំពីការធ្វើ១ អាបត្តិដែលដែលតាំងឡើងអំពីការធ្វើ និងការមិនធ្វើ១ អាបត្តិខាងដើម១ អាបត្តិជាចន្លោះ១ អាបត្តិគួរដល់កិរិយារាប់១ បញ្ញត្តិ១ អនុប្បញ្ញត្តិ១ អនុប្បន្នប្បញ្ញត្តិ១ សព្វត្ថប្បញ្ញត្តិ១ សាធារណប្បញ្ញត្តិ១ អសាធារណប្បញ្ញត្តិ១ ឯកតោបញ្ញត្តិ១ ទុដ្ឋុល្លាបត្តិ១ អាបត្តិដែលបដិសំយុត្តដោយគ្រហស្ថ១ អាបត្តិទៀង១ អាទិកម្មិកបុគ្គល១ បុគ្គលអ្នកត្រូវអាបត្តិមិនជានិច្ច១ បុគ្គលអ្នកចោទ១ បុគ្គលអ្នកចោទមិនតាមធម៌១ ចោទតាមធម៌១ និយតបុគ្គល១ បុគ្គលមិនគួរដល់អាបត្តិ១ បុគ្គលដែលសង្ឃធ្វើឧក្ខេបនីយកម្ម១ បុគ្គលដែលសង្ឃឲ្យវិនាស១ បុគ្គលមានសំវាសស្មើគ្នា១ វិធីបញ្ឈប់បាតិមោក្ខ១ នេះជាឧទ្ទានក្នុងពួកមួយៗ។

## (ទុកវារៈ ទី២)

CS vin.pv.05.02 | ភាគ ទី១៣

### (២. ទុកវារោ)

[២៦] អាបត្តិជាសញ្ញាវិមោក្ខ (សចិត្តកៈ) ក៏មាន អាបត្តិជានោសញ្ញាវិមោក្ខ (អចិត្តកៈ) ក៏មាន។ អាបត្តិត្រូវដល់ភិក្ខុដែលបានសមាបត្តិក៏មាន អាបត្តិត្រូវដល់ភិក្ខុដែលមិនបានសមាបត្តិក៏មាន។ អាបត្តិដែលប្រកបនឹងព្រះសទ្ធម្មក៏មាន អាបត្តិដែលប្រកបនឹងអសទ្ធម្មក៏មាន។ អាបត្តិដែលប្រកបនឹងគ្រឿងបរិក្ខាររបស់ខ្លួនក៏មាន អាបត្តិដែលប្រកបនឹងគ្រឿងបរិក្ខាររបស់បុគ្គលដទៃក៏មាន។ អាបត្តិដែលប្រកបនឹងបុគ្គល គឺខ្លួនឯងក៏មាន។ អាបត្តិដែលប្រកបនឹងបុគ្គល គឺអ្នកដទៃក៏មាន។ ភិក្ខុនិយាយពាក្យសច្ចៈ ត្រូវគរុកាបត្តិក៏មាន ភិក្ខុនិយាយពាក្យមុសា ត្រូវលហុកាបត្តិក៏មាន។ ភិក្ខុនិយាយពាក្យមុសា ត្រូវគរុកាបត្តិក៏មាន ភិក្ខុនិយាយពាក្យសច្ចៈ ត្រូវលហុកាបត្តិក៏មាន។ ភិក្ខុនៅលើផែនដី ត្រូវអាបត្តិក៏មាន នៅលើអាកាស មិនត្រូវអាបត្តិក៏មាន នៅលើអាកាស ត្រូវអាបត្តិ នៅលើផែនដី មិនត្រូវអាបត្តិក៏មាន។ ភិក្ខុដើរចេញទៅ ត្រូវអាបត្តិ ដើរចូលមក មិនត្រូវអាបត្តិក៏មាន ដើរចូលមកត្រូវអាបត្តិ ដើរចេញទៅ មិនត្រូវអាបត្តិក៏មាន។ ភិក្ខុកាន់យក ត្រូវអាបត្តិក៏មាន មិនកាន់យក ត្រូវអាបត្តិក៏មាន។ ភិក្ខុសមាទាន(វត្ត) ត្រូវអាបត្តិក៏មាន មិនសមាទាន (វត្ត) ត្រូវអាបត្តិក៏មាន។ ភិក្ខុធ្វើ ត្រូវអាបត្តិក៏មាន មិនធ្វើ ត្រូវអាបត្តិក៏មាន។ ភិក្ខុឲ្យ ត្រូវអាបត្តិក៏មាន មិនឲ្យ ត្រូវអាបត្តិក៏មាន។ ភិក្ខុទទួល ត្រូវអាបត្តិក៏មាន មិនទទួល ត្រូវអាបត្តិក៏មាន។ ភិក្ខុត្រូវអាបត្តិ ព្រោះបរិភោគក៏មាន ត្រូវអាបត្តិ ព្រោះមិនបរិភោគក៏មាន។ ភិក្ខុត្រូវអាបត្តិតែក្នុងវេលាយប់ មិនត្រូវអាបត្តិក្នុងវេលាថ្ងៃក៏មាន ត្រូវអាបត្តិតែក្នុងវេលាថ្ងៃ មិនត្រូវក្នុងវេលាយប់ក៏មាន ភិក្ខុត្រូវអាបត្តិក្នុងពេលអរុណរះក៏មាន ត្រូវអាបត្តិក្នុងពេលអរុណមិនទាន់រះក៏មាន។ ភិក្ខុកាត់ ត្រូវអាបត្តិក៏មាន មិនកាត់ ត្រូវអាបត្តិក៏មាន។ ភិក្ខុបិទបាំង ត្រូវអាបត្តិក៏មាន មិនបិទបាំង ត្រូវអាបត្តិក៏មាន។ ភិក្ខុទ្រទ្រង់ ត្រូវអាបត្តិក៏មាន មិនទ្រទ្រង់ ត្រូវអាបត្តិក៏មាន។

[២៧] ឧបោសថមានពីរយ៉ាងគឺ ចាតុទ្ទសីឧបោសថ១ បណ្ណរសីឧបោសថ១។ បវារណាមាន២យ៉ាង គឺ ចាតុទ្ទសីបវារណា១ បណ្ណរសីបវារណា១។ កម្មមានពីរយ៉ាងគឺ អបលោកនកម្ម១ ញត្តិកម្ម១។ កម្មមាន២យ៉ាងដទៃទៀតគឺ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១។ ទីកើតនៃកម្មមាន២យ៉ាងគឺ ទីកើតនៃអបលោកនកម្ម១ ទីកើតនៃញត្តិកម្ម១។ ទីកើតនៃកម្មមាន២យ៉ាងដទៃទៀត គឺទីកើតនៃញត្តិទុតិយកម្ម១ ទីកើតនៃញត្តិចតុត្ថកម្ម១។ ទោសរបស់កម្មមាន២យ៉ាង គឺទោសនៃអបលោកនកម្ម១ ទោសនៃញត្តិកម្ម១។ ទោសរបស់កម្មមាន២យ៉ាងដទៃទៀតគឺ ទោស

នៃញត្តិទុតិយកម្ម១ ទោសនៃញត្តិចតុត្ថកម្ម១។ សម្បត្តិរបស់កម្ម មាន២យ៉ាងគឺ សម្បត្តិនៃអបលោកនកម្ម១ សម្បត្តិនៃញត្តិកម្ម១។ សម្បត្តិរបស់កម្ម មាន២យ៉ាងដទៃទៀត គឺសម្បត្តិនៃញត្តិទុតិយកម្ម១ សម្បត្តិនៃញត្តិចតុត្ថកម្ម១។ ភូមិនៃភិក្ខុមានសំវាសផ្សេងៗគ្នា មាន២យ៉ាងគឺ ភិក្ខុធ្វើខ្លួនឲ្យមានសំវាសផ្សេងគ្នា ដោយខ្លួនឯង១ សង្ឃព្រមព្រៀងគ្នាលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ (ទិដ្ឋិអាក្រក់)ក្តី១។ ភូមិនៃភិក្ខុមានសំវាសស្មើគ្នា មាន២យ៉ាងគឺ ភិក្ខុធ្វើខ្លួនឲ្យមានសំវាសផ្សេងគ្នា ដោយខ្លួនឯង១ សង្ឃព្រមព្រៀងគ្នាសូត្រឱសារណកម្ម ចំពោះភិក្ខុដែលសង្ឃលើកវត្តហើយនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសំដែងអាបត្តិក្តី ព្រោះមិនលះបង់ (ទិដ្ឋិអាក្រក់)ក្តី១។

[២៨] បារាជិកមាន២យ៉ាង គឺ បារាជិករបស់ពួកភិក្ខុ១ បារាជិករបស់ពួកភិក្ខុនី១។ សង្ឃាទិសេសមាន២ ថុល្លច្ច័យមាន២ បាចិត្តិយៈមាន២ បាដិទេសនីយៈមាន២ ទុក្កដ មាន២ ទុព្ភាសិតមាន២ គឺរបស់ភិក្ខុ១ របស់ភិក្ខុនី១ រួមជាអាបត្តិ៧ គឺកងនៃអាបត្តិទាំង៧។ សង្ឃបែកធ្លាយ ដោយអាការ២ គឺដោយកម្ម១ ដោយការចាប់ស្លាក១។

[២៩] បុគ្គលដែលភិក្ខុមិនត្រូវឲ្យឧបសម្បទា មាន២ពួក គឺ បុគ្គលសាបសូន្យចាកកាល១ បុគ្គលសាបសូន្យចាកអវយវៈ១។ បុគ្គលដែលភិក្ខុមិនត្រូវឲ្យឧបសម្បទា មាន២ពួកដទៃទៀត គឺ បុគ្គលជាវត្ថុវិបត្តិ១ បុគ្គលធ្លាប់ធ្វើអំពើអាក្រក់១។ បុគ្គលដែលភិក្ខុមិនត្រូវឲ្យឧបសម្បទា មាន២ពួកដទៃទៀត គឺ បុគ្គលមាន (បរិក្ខារ) មិនគ្រប់គ្រាន់១ បុគ្គលមាន (បរិក្ខារ) គ្រប់គ្រាន់ហើយ តែមិនសូម (ឧបសម្បទា)១។ ភិក្ខុមិនត្រូវនៅអាស្រ័យនឹងបុគ្គល២ពួក គឺ បុគ្គលជាអលជ្ជី១ បុគ្គលពាល១។ ភិក្ខុមិនត្រូវឲ្យនិស្ស័យ ដល់បុគ្គល២ពួក គឺ បុគ្គលជាអលជ្ជី១ បុគ្គលជាលជ្ជី តែមិនបានសូម១។ ភិក្ខុត្រូវឲ្យនិស្ស័យ ដល់បុគ្គល២ពួក គឺ បុគ្គលល្ងង់១ បុគ្គលជាលជ្ជី ហើយបានសូម១។ បុគ្គលដែលមិនគួរត្រូវអាបត្តិ មាន២គឺ ព្រះពុទ្ធ១ ព្រះបច្ចេកពុទ្ធ១។ បុគ្គលដែលគួរនឹងត្រូវអាបត្តិមាន២គឺ ភិក្ខុ១ ភិក្ខុនី១។ បុគ្គលមិនគួរនឹងត្រូវអាបត្តិ ព្រោះក្លែង មាន២គឺ ភិក្ខុ១ ភិក្ខុនី១ ដែលជាអរិយបុគ្គល។ បុគ្គលដែលគួរនឹងត្រូវអាបត្តិ ព្រោះក្លែង មាន២គឺ ភិក្ខុ១ ភិក្ខុនី១ ដែលជាបុថុជ្ជន។ បុគ្គលមិនគួរនឹងប្រព្រឹត្តកន្លងវត្ថុ ដែលប្រកបដោយទោសយ៉ាងធំ ព្រោះក្លែង មាន២គឺ ភិក្ខុ១ ភិក្ខុនី១ ដែលជាព្រះអរិយបុគ្គល។ បុគ្គលគួរនឹងប្រព្រឹត្តកន្លងនូវវត្ថុ ដែលប្រកបដោយទោសយ៉ាងធំ ព្រោះក្លែង មាន២គឺ ភិក្ខុ១ ភិក្ខុនី១ ដែលជាបុថុជ្ជន។

[៣០] ការហាមឃាត់មាន២យ៉ាង គឺ ហាមឃាត់ដោយកាយ១ ហាមឃាត់ដោយវាចា១។ ការសូត្រនិស្សារណាកម្មមាន២យ៉ាងគឺ បុគ្គលមិនដល់និស្សារណាកម្មនៅឡើយ តែបើសង្ឃសូត្រនិស្សារណាកម្មចំពោះបុគ្គលនោះ បុគ្គលពួកខ្លះ ឈ្មោះថាសង្ឃសូត្រនិស្សារណាកម្មហើយដោយល្អ១ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃសូត្រនិស្សារណាកម្មដោយអាក្រក់១។ ការសូត្រឱសារណាកម្មមាន២យ៉ាងគឺ បុគ្គលមិនទាន់ដល់ឱសារណាកម្មនៅឡើយ តែបើសង្ឃសូត្រឱសារណាកម្ម ចំពោះបុគ្គលនោះ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃសូត្រឱសារណាកម្មហើយដោយល្អ១ បុគ្គលពួកខ្លះ ឈ្មោះថា សង្ឃសូត្រឱសារណាកម្មហើយដោយអាក្រក់១។ ការប្តេជ្ញា មាន២យ៉ាងគឺ ប្តេជ្ញាដោយកាយ១ ប្តេជ្ញាដោយវាចា១។ ការទទួលមាន២យ៉ាងគឺ ទទួលដោយកាយ១ ទទួលដោយវត្ថុដែលជាប់នឹងកាយ១។ ការឃាត់មាន២យ៉ាងគឺ ឃាត់ដោយកាយ១ ឃាត់ដោយវាចា១។ ការបៀតបៀនមាន២យ៉ាងគឺ បៀតបៀនសិក្ខា១ បៀតបៀនគ្រឿងបរិភោគ (ជារបស់សង្ឃ ឬបុគ្គល)១។ ការចោទមាន២យ៉ាងគឺ ចោទដោយកាយ១ ចោទដោយវាចា១។

[៣១] បលិពោធនៃកឋិន មាន២យ៉ាងគឺ អាវាសបលិពោធ១ ចីវរបលិពោធ១។ ការមិនមានបលិពោធនៃកឋិនមាន២យ៉ាងគឺ មិនមានបលិពោធនឹងអាវាស១ មិនមានបលិពោធនឹងចីវរ១។ ចីវរមាន២យ៉ាងគឺ គហបតិចីវរ១ បំសុកូលចីវរ១។ បាត្រមាន២យ៉ាងគឺ បាត្រដែក១ បាត្រដី១។ មណ្ឌល គឺជើងបាត្រ មាន២យ៉ាងគឺ ជើងបាត្រដែលគេធ្វើដោយសំណប៉ាហាំង១ ធ្វើដោយសំណភក់១។ ការអធិដ្ឋានបាត្រមាន២យ៉ាងគឺ អធិដ្ឋានដោយកាយ១ អធិដ្ឋានដោយវាចា១។ ការអធិដ្ឋានចីវរមាន២យ៉ាងគឺ អធិដ្ឋានដោយកាយ១ អធិដ្ឋានដោយវាចា១។ ការវិកប្បមាន២យ៉ាងគឺ វិកប្បក្នុងទីចំពោះមុខ១ វិកប្បក្នុងទីកំបាំងមុខ១។ វិន័យមាន២យ៉ាងគឺ វិន័យរបស់ពួកភិក្ខុ១ របស់ពួកភិក្ខុនី១។ អត្ថរបស់វិន័យមាន២យ៉ាងគឺ បញ្ញត្តិ១ បញ្ញត្តានុលោម (គឺមហាបទេស៤)១។ សេចក្តីផូរផង់នៃវិន័យមាន២យ៉ាងគឺ សម្លាប់នូវបច្ច័យក្នុងអកប្បិយវត្ថុ១ ការធ្វើនូវប្រមាណក្នុងកប្បិយវត្ថុ១។

[៣២] ភិក្ខុត្រូវអាបត្តិដោយអាការ២យ៉ាងគឺ ត្រូវដោយកាយ១ ត្រូវដោយវាចា១។ ភិក្ខុចេញចាកអាបត្តិ ដោយអាការ២យ៉ាងគឺ ចេញចាកដោយកាយ១ ចេញចាកដោយវាចា១។ បរិវាសមាន២យ៉ាងគឺ បដិច្ឆន្នបរិវាស១ អប្បដិច្ឆន្នបរិវាស១។ បរិវាសមាន២យ៉ាងដទៃទៀតគឺ សុទ្ធន្តបរិវាស១ សមោធានបរិវាស១។ មានត្តមាន២យ៉ាងគឺ បដិច្ឆន្នមានត្ត១ អប្បដិច្ឆន្នមានត្ត១។ មានត្តមាន២យ៉ាងដទៃទៀតគឺ បក្ខមានត្ត១ សមោធានមានត្ត១។ ការដាច់រាត្រីរបស់បុគ្គល២ពួក គឺ ភិក្ខុកំពុងនៅបរិវាស១ ភិក្ខុកំពុងប្រព្រឹត្តមានត្ត១។

[៣៣] ការមិនអើពើមាន២យ៉ាងគឺ មិនអើពើនឹងបុគ្គល១ មិនអើពើនឹងធម៌១។ អំបិលមាន២បែបគឺ អំបិលកើតឯង១ អំបិលកើតអំពីជាតិដីប្រៃ១។ អំបិលមាន២យ៉ាងដទៃទៀតគឺ អំបិលកើតពីទឹកសមុទ្រ១ អំបិលខ្មៅ១។ អំបិលមាន២យ៉ាងដទៃទៀតគឺ អំបិលសិន្ធវៈ (អំបិលមានសម្បុរស ដុះលើភ្នំ)១ អំបិលឧព្ភិទៈ (អំបិលដុះជាពន្លកៗឡើងពីផែនដី)១។ អំបិលមាន២យ៉ាងដទៃទៀតគឺ អំបិលឈ្មោះរោមកៈ (អំបិលកើតក្នុងរោមជនបទ)១ អំបិលឈ្មោះបក្ខលួកៈ (អំបិលកើតពីទឹកក្បុង ដែលធ្វើអំពីស្រូវដំណើប)១។ បរិភោគមាន២គឺ អព្ភន្តរបរិភោគ (បរិភោគលេបចូលទៅ)១ ពាហិរបរិភោគ (ប្រើប្រាស់ខាងក្រៅ)១។ ការជេរមាន២យ៉ាងគឺ ជេរយ៉ាងថោកទាប១ ជេរយ៉ាងឧក្រិដ្ឋ១។ ការញុះញង់ កើតដោយអាការ២យ៉ាងគឺ ប៉ងដើម្បីឲ្យគេស្រឡាញ់ខ្លួន១ ប៉ងដើម្បីបំបែកគ្នា១។ ភិក្ខុទទួលគណភោជនបានដោយអាការ២យ៉ាង គឺដោយគេនិមន្ត១ ដោយការសូមគេ១។ ការចូលវស្សាមាន២យ៉ាងគឺ បុរិមិកាវស្សា១ បច្ឆិមិកាវស្សា១។ ការឃាត់ហាមបាតិមោក្ខ ដែលមិនប្រកបដោយធម៌ មាន២យ៉ាង។ ការឃាត់ហាមបាតិមោក្ខ ដែលប្រកបដោយធម៌ មាន២យ៉ាង។

[៣៤] បុគ្គលពាលមាន២ពួក គឺ បុគ្គលដែលនាំភារៈ (កិច្ច មានអារាធនាធម៌ជាដើម) មិនទាន់មានមក១ បុគ្គលដែលមិននាំភារៈ ដែលមានមកហើយ១។ បុគ្គលជាបណ្ឌិតមាន២ពួក គឺបុគ្គលដែលមិននាំភារៈ មិនទាន់មកដល់១ បុគ្គលដែលនាំភារៈមានមកហើយ១។ បុគ្គលពាលមាន២ពួកដទៃទៀត គឺបុគ្គលមានសេចក្តីសំគាល់ក្នុងអកប្បិយវត្ថុ ថាជាកប្បិយវត្ថុ១ បុគ្គលមានសេចក្តីសំគាល់ក្នុងកប្បិយវត្ថុ ថាជាអកប្បិយ

វត្ថុ១។ បុគ្គលជាបណ្ឌិត មាន២ពួកគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអកប្បិយវត្ថុ ថាជាអកប្បិយវត្ថុ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងកប្បិយវត្ថុ ថាជាកប្បិយវត្ថុ១។ បុគ្គលពាល មាន២ពួកដទៃទៀត គឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអនាបត្តិ ថាជាអាបត្តិ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងអាបត្តិ ថាជាអនាបត្តិ១។ បុគ្គលជាបណ្ឌិត មាន២ពួកគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអាបត្តិ ថាជាអាបត្តិ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងអនាបត្តិ ថាជាអនាបត្តិ១។ បុគ្គលពាលមាន២ពួកដទៃទៀតគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនធម៌ ថាជាធម៌១ មានសេចក្ដីសំគាល់ក្នុងសភាវៈធម៌ ថាមិនមែនធម៌១។ បុគ្គលជាបណ្ឌិត មាន២ពួកគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនធម៌ ថាមិនមែនជាធម៌១ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈជាធម៌ ថាជាធម៌១។ បុគ្គលពាល មាន២ពួកដទៃទៀតគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនវិន័យ ថាជាវិន័យ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈជាវិន័យ ថាមិនមែនវិន័យ១។ បុគ្គលជាបណ្ឌិត មាន២ពួកគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនជាវិន័យ ថាមិនមែនជាវិន័យ១ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈជាវិន័យ ថាជាវិន័យ១។

[៣៥] អាសវៈទាំងឡាយតែងចំរើនដល់បុគ្គល២ពួកគឺ បុគ្គលដែលសង្ស័យចំពោះហេតុដែលមិនគួរសង្ស័យ១ បុគ្គលដែលមិនសង្ស័យចំពោះហេតុដែលគួរសង្ស័យ១។ អាសវៈទាំងឡាយ រមែងមិនចំរើនដល់បុគ្គល២ពួកគឺ បុគ្គលដែលមិនសង្ស័យចំពោះហេតុដែលមិនគួរសង្ស័យ១ បុគ្គលដែលសង្ស័យចំពោះហេតុដែលគួរសង្ស័យ១។ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គល២ពួកដទៃទៀតគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអកប្បិយវត្ថុ ថាជាកប្បិយវត្ថុ១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងកប្បិយវត្ថុ ថាជាអកប្បិយវត្ថុ១។ អាសវៈទាំងឡាយ រមែងមិនចំរើនដល់បុគ្គល២ពួកគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអកប្បិយវត្ថុ ថាជាអកប្បិយវត្ថុ១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងកប្បិយវត្ថុ ថាជាកប្បិយវត្ថុ១។ អាសវៈទាំងឡាយ រមែងចំរើនដល់បុគ្គល២ពួកដទៃទៀតគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអនាបត្តិ ថាជាអាបត្តិ១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងអាបត្តិ ថាជាអនាបត្តិ១។ អាសវៈទាំងឡាយ រមែងមិនចំរើនដល់បុគ្គល២ពួកគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងអនាបត្តិ ថាជាអនាបត្តិ១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងអាបត្តិ ថាជាអាបត្តិ១។ អាសវៈទាំងឡាយ រមែងចំរើនដល់បុគ្គល២ពួកដទៃទៀតគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនធម៌ ថាជាធម៌១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងសភាវៈជាធម៌ ថាមិនមែនជាធម៌១។ អាសវៈទាំងឡាយ រមែងមិនចំរើនដល់បុគ្គល២ពួកគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនធម៌ ថាមិនមែនជាធម៌១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងសភាវៈជាធម៌ ថាជាធម៌១។ អាសវៈទាំងឡាយ រមែងចំរើនដល់បុគ្គល២ពួកដទៃទៀតគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនវិន័យ ថាជាវិន័យ១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងសភាវៈជាវិន័យ ថាមិនមែនជាវិន័យ១។ អាសវៈទាំងឡាយ រមែងមិនចំរើនដល់បុគ្គល២ពួកគឺ បុគ្គលមានសេចក្ដីសំគាល់ក្នុងសភាវៈមិនមែនវិន័យ ថាមិនមែនវិន័យ១ បុគ្គលមានសេចក្ដីសំគាល់ ក្នុងសភាវៈជាវិន័យ ថាជាវិន័យ១។

ចប់ ទុកៈ (ពួកពីរៗ)។

ឧទ្ទាន គឺបញ្ជីរឿងនៃទុកៈ (ពួកពីរៗ) នោះ ដូច្នេះ

[៣៦]

អាបត្តិជាសញ្ញាវិមោក្ខ១ អាបត្តិនៃភិក្ខុដែលបានសមាបត្តិ១ អាបត្តិប្រកបដោយព្រះសទ្ធម្ម១ អាបត្តិប្រកបដោយបរិក្ខារ១ អាបត្តិប្រកបដោយបុគ្គល១ ភិក្ខុនិយាយពាក្យសច្ចៈ ត្រូវអាបត្តិ១ ភិក្ខុនៅលើផែនដី ត្រូវអាបត្តិ១ ភិក្ខុចេញទៅ ត្រូវអាបត្តិ១ ភិក្ខុកាន់យក ត្រូវអាបត្តិ១ ភិក្ខុសមាទាន ត្រូវអាបត្តិ១ ភិក្ខុធ្វើ ត្រូវអាបត្តិ១ ភិក្ខុកាលឲ្យ ត្រូវអាបត្តិ១ ភិក្ខុកាលទទួល ត្រូវអាបត្តិ១ ភិក្ខុត្រូវអាបត្តិព្រោះបរិភោគ១ ត្រូវអាបត្តិក្នុងវេលាយប់១ ត្រូវអាបត្តិក្នុងវេលាអរុណរះ១ ភិក្ខុកាត់ ត្រូវអាបត្តិ១ ភិក្ខុបិទបាំង ត្រូវអាបត្តិ១ ភិក្ខុទ្រទ្រង់ ត្រូវអាបត្តិ១ ឧបោសថ១ បវារណា១ កម្ម១ កម្មដទៃទៀត១ វត្ថុនៃកម្ម១ វត្ថុនៃកម្មដទៃទៀត១ ទោសនៃកម្ម១ ទោសនៃកម្មដទៃទៀត១ សម្បត្តិនៃកម្ម២យ៉ាង១ ភូមិនៃភិក្ខុមានសំវាសផ្សេងៗគ្នា១ ភូមិនៃភិក្ខុមានសំវាសស្មើគ្នា១ បារាជិក១ សង្ឃាទិសេស១ ថុល្លច្ច័យ១ បាចិត្តិយៈ១ បាដិទេសនីយៈ១ ទុក្កដ១ ទុព្ភាសិត១ រួមជាកងនៃអាបត្តិ៧ សង្ឃបែកគ្នា១ ភិក្ខុមិនត្រូវឲ្យឧបសម្បទា១ មិនត្រូវឲ្យឧបសម្បទា ចំពោះបុគ្គលពីរពួកដទៃទៀត១ ភិក្ខុមិនត្រូវអាស្រ័យនៅ១ មិនត្រូវឲ្យនិស្ស័យ១ បុគ្គលមិនគួរនឹងត្រូវអាបត្តិ១ បុគ្គលគួរត្រូវអាបត្តិព្រោះភ្លេច១ បុគ្គលគួរនឹងត្រូវអាបត្តិព្រោះប្រព្រឹត្តកន្លងវត្តដែលប្រកបដោយទោសយ៉ាងធំ១ ការហាមឃាត់១ ការសូត្រនិស្សារណាកម្ម១ ការសូត្រឱសារណាកម្ម១ ការប្ដេជ្ញា១ ការទទួល១ ការឃាត់១ ការបៀតបៀន១ ការចោទ១ បលិពោធនៃកឋិន២យ៉ាង១ មិនមានបលិពោធនៃកឋិន២យ៉ាងដូចគ្នា១ ចីវរ១ បាត្រ និងជើងទ្របាត្រ១ ការអធិដ្ឋានបាត្រ២យ៉ាង១ ការអធិដ្ឋានចីវរ២យ៉ាងដូចគ្នា១ ការវិកប្ប១ វិន័យ១ អត្ថនៃវិន័យ១ សេចក្ដីផូរផង់ (នៃវិន័យ)១ ភិក្ខុត្រូវអាបត្តិ (ដោយអាការ២យ៉ាង)១ ចេញចាកអាបត្តិ (ដោយអាការ២យ៉ាង)១ បរិវាស២យ៉ាង១ បរិវាស២យ៉ាងដទៃទៀត១ មានត្ត២យ៉ាង១ មានត្ត២យ៉ាងដទៃទៀត១ ការដាច់រាត្រី១ សេចក្ដីមិនអើពើ១ អំបិល២យ៉ាង មាន៣ពួកតទៅទៀត១ ការបរិភោគ១ ការជេរ១ បេសុញ្ញវាទ១ ការទទួលគណភោជន១ ការចូលវស្សា១ ការបញ្ឈប់នូវបាតិមោក្ខ១ បុគ្គលពាលនាំភារៈ១ កប្បិយវត្ថុ១ អនាបត្តិ១ អធម្មកម្ម១ វិនយកម្ម១ អាសវៈទាំងឡាយ១។

## (តិកវារៈ ទី៣)

CS vin.pv.05.03 | ភាគ ទី១៣

### (៣. តិកវារោ)

[៣៧] ភិក្ខុត្រូវអាបត្តិតែក្នុងកាលដែលព្រះមានព្រះភាគគង់នៅ កាលដែលព្រះអង្គបរិនិព្វានហើយ មិនត្រូវក៏មាន ភិក្ខុត្រូវអាបត្តិតែក្នុងកាលដែលព្រះមានព្រះភាគបរិនិព្វានហើយ កាលដែលព្រះអង្គគង់នៅឡើយ មិនត្រូវក៏មាន ភិក្ខុត្រូវអាបត្តិទាំងក្នុងកាលដែលព្រះអង្គគង់នៅ ទាំង

ក្នុងកាលដែលព្រះអង្គបរិនិព្វានហើយ ក៏មាន។ ភិក្ខុត្រូវអាបត្តិតែក្នុងកាល មិនត្រូវក្នុងវិកាល ក៏មាន ភិក្ខុត្រូវអាបត្តិតែក្នុងវិកាល មិនត្រូវក្នុងកាល ក៏មាន ភិក្ខុត្រូវអាបត្តិទាំងក្នុងកាល ទាំងក្នុងវិកាល ក៏មាន។ ភិក្ខុត្រូវអាបត្តិតែក្នុងវេលាយប់ មិនត្រូវក្នុងវេលាថ្ងៃ ក៏មាន ត្រូវអាបត្តិតែក្នុងវេលាថ្ងៃ មិនត្រូវក្នុងវេលាយប់ ក៏មាន ត្រូវអាបត្តិទាំងវេលាយប់ ទាំងវេលាថ្ងៃ ក៏មាន។ ភិក្ខុមានវស្សា១០ ត្រូវអាបត្តិ មានវស្សាខ្វះពី១០ មិនត្រូវអាបត្តិក៏មាន ភិក្ខុមានវស្សាខ្វះពី១០ ត្រូវអាបត្តិ មានវស្សា១០ មិនត្រូវអាបត្តិក៏មាន ទាំងភិក្ខុមានវស្សា១០ ទាំងភិក្ខុមានវស្សាខ្វះពី១០ ត្រូវអាបត្តិ ក៏មាន។ ភិក្ខុមានវស្សា៥ ត្រូវអាបត្តិ មានវស្សាខ្វះពី៥ មិនត្រូវអាបត្តិក៏មាន ភិក្ខុមានវស្សាខ្វះពី៥ ត្រូវអាបត្តិ មានវស្សាគ្រប់៥ មិនត្រូវអាបត្តិក៏មាន ទាំងភិក្ខុមានវស្សា៥ ទាំងភិក្ខុមានវស្សាខ្វះពី៥ ត្រូវអាបត្តិក៏មាន។ ភិក្ខុមានចិត្តជាកុសល ត្រូវអាបត្តិ មានចិត្តជាអកុសល មិនត្រូវអាបត្តិក៏មាន ភិក្ខុមានចិត្តជាអកុសល ត្រូវអាបត្តិ មានចិត្តជាកុសល មិនត្រូវអាបត្តិក៏មាន ភិក្ខុមានចិត្តជាអព្យាក្រឹត ត្រូវអាបត្តិក៏មាន។ ភិក្ខុមានចិត្តប្រកបដោយសុខវេទនា ត្រូវអាបត្តិក៏មាន មានចិត្តប្រកបដោយទុក្ខវេទនា ត្រូវអាបត្តិក៏មាន មានចិត្តប្រកបដោយអទុក្ខមសុខវេទនា ត្រូវអាបត្តិក៏មាន។

[៣៨] ចោទនាវត្ថុ (វត្ថុជាគ្រឿងចោទ) មាន៣យ៉ាង គឺដោយឃើញ១ ឮ១ រង្កៀស១។ ការចាប់ស្លាក មាន៣យ៉ាងគឺ គូឡ្ហកៈ (ស្លាកបិទ)១ វិវដ្ឋកៈ (ស្លាកបើក)១ សកណ្ណជប្បកៈ (ការខ្សឹបជិតត្រចៀកជាស្លាក)១។ បំរាមមាន៣យ៉ាងគឺ សេចក្តីប្រាថ្នាធំ១ សេចក្តីមិនសន្តោស១ សេចក្តីមិនផ្ចង់ផ្ចង់ចិត្ត១។ អនុញ្ញាតមាន៣យ៉ាងគឺ សេចក្តីប្រាថ្នាតិច១ សេចក្តីសន្តោស១ សេចក្តីផ្ចង់ផ្ចង់ចិត្ត១។ បំរាមមាន៣យ៉ាងដទៃទៀតគឺ សេចក្តីប្រាថ្នាធំ១ សេចក្តីមិនសន្តោស១ សេចក្តីមិនដឹងប្រមាណ១។ អនុញ្ញាតមាន៣យ៉ាងគឺ សេចក្តីប្រាថ្នាតិច១ សេចក្តីសន្តោស១ សេចក្តីដឹងប្រមាណ១។ បញ្ញត្តិមាន៣យ៉ាងគឺ បញ្ញត្តិ១ អនុប្បញ្ញត្តិ១ អនុប្បន្នប្បញ្ញត្តិ១។ បញ្ញត្តិមាន៣យ៉ាងដទៃទៀតគឺ សព្វត្ថប្បញ្ញត្តិ១ បទេសប្បញ្ញត្តិ១ សាធារណប្បញ្ញត្តិ១។ បញ្ញត្តិមាន៣យ៉ាងដោយឡែកទៀតគឺ អសាធារណប្បញ្ញត្តិ១ ឯកតោបញ្ញត្តិ១ ឧភតោបញ្ញត្តិ១។

[៣៩] ភិក្ខុពាលត្រូវអាបត្តិ ភិក្ខុជាបណ្ឌិត មិនត្រូវអាបត្តិក៏មាន ភិក្ខុជាបណ្ឌិត ត្រូវអាបត្តិ ភិក្ខុពាលមិនត្រូវអាបត្តិក៏មាន ភិក្ខុពាលក្តី ជាបណ្ឌិតក្តី ត្រូវអាបត្តិក៏មាន។ ភិក្ខុត្រូវអាបត្តិ ក្នុងកាឡប័ក្ខ (រនោច) មិនត្រូវក្នុងជុណ្ហប័ក្ខ (ខ្នើត) ក៏មាន ភិក្ខុត្រូវអាបត្តិក្នុងជុណ្ហប័ក្ខ មិនត្រូវក្នុងកាឡប័ក្ខក៏មាន ភិក្ខុមិនត្រូវអាបត្តិ ទាំងក្នុងកាឡប័ក្ខ ទាំងក្នុងជុណ្ហប័ក្ខ ក៏មាន។ សេចក្តីអនុញ្ញាត គួរតែក្នុងកាឡប័ក្ខ មិនគួរក្នុងជុណ្ហប័ក្ខក៏មាន គួរតែក្នុងជុណ្ហប័ក្ខ មិនគួរក្នុងកាឡប័ក្ខក៏មាន គួរទាំងក្នុងកាឡប័ក្ខ ទាំងជុណ្ហប័ក្ខក៏មាន។ ភិក្ខុត្រូវអាបត្តិ តែក្នុងហេមន្តរដូវ មិនត្រូវក្នុងគិម្ហរដូវ ទាំងមិនត្រូវអាបត្តិក្នុងវស្សានរដូវក៏មាន ត្រូវអាបត្តិក្នុងគិម្ហរដូវ មិនត្រូវអាបត្តិក្នុងហេមន្តរដូវ មិនត្រូវអាបត្តិក្នុងវស្សានរដូវផងក៏មាន ត្រូវអាបត្តិក្នុងវស្សានរដូវ មិនត្រូវអាបត្តិក្នុងគិម្ហរដូវផង មិនត្រូវអាបត្តិក្នុងហេមន្តរដូវផង ក៏មាន។ សង្ឃត្រូវអាបត្តិ គណៈមិនត្រូវអាបត្តិ បុគ្គលមិនត្រូវអាបត្តិក៏មាន គណៈត្រូវអាបត្តិ សង្ឃមិនត្រូវអាបត្តិ បុគ្គលមិនត្រូវអាបត្តិក៏មាន បុគ្គលត្រូវអាបត្តិ សង្ឃមិនត្រូវអាបត្តិ គណៈមិនត្រូវអាបត្តិក៏មាន។ សេចក្តីអនុញ្ញាតគួរដល់សង្ឃ មិនគួរដល់គណៈ មិនគួរដល់បុគ្គលក៏មាន គួរដល់គណៈ មិនគួរដល់សង្ឃ មិនគួរដល់បុគ្គលក៏មាន គួរដល់បុគ្គល មិនគួរដល់សង្ឃ មិនគួរដល់គណៈក៏មាន។

[៤០] ការបិទបាំងមាន៣យ៉ាងគឺ ភិក្ខុបិទបាំងវត្ថុ មិនបិទបាំងអាបត្តិ១ បិទបាំងអាបត្តិ មិនបិទបាំងវត្ថុ១ បិទបាំងទាំងវត្ថុ ទាំងអាបត្តិ១។ គ្រឿងបិទបាំងមាន៣យ៉ាងគឺ គ្រឿងបិទបាំងគឺផ្ទះ ជាទីរក្សាកាយ១ គ្រឿងបិទបាំងគឺទឹក១ គ្រឿងបិទបាំងគឺសម្ពត់១។ វត្ថុ៣យ៉ាង ដែលបិទបាំងទុក ទើបប្រព្រឹត្តទៅស្រួល តែបើកឡើង ប្រព្រឹត្តទៅមិនស្រួល គឺមាតុគ្រាមមានវត្ថុបិទបាំង ទើបប្រព្រឹត្តទៅស្រួល តែមិនមានវត្ថុបិទបាំង ប្រព្រឹត្តទៅមិនស្រួល១ មន្តរបស់ពួកព្រាហ្មណ៍បិទបាំងទុក ទើបប្រព្រឹត្តទៅស្រួល បើកឡើង ប្រព្រឹត្តទៅមិនស្រួល១ មិច្ឆាទិដ្ឋិបិទបាំងទុក ទើបប្រព្រឹត្តទៅស្រួល១ តែបើកឡើង ប្រព្រឹត្តទៅមិនស្រួល១។ វត្ថុ៣យ៉ាងបើកចេញ ទើបរុងរឿង បិទទុក មិនរុងរឿងឡើយ គឺ មណ្ឌលព្រះចន្ទ បើកឡើង ទើបរុងរឿង តែបិទបាំងទុក មិនរុងរឿង១ មណ្ឌលព្រះអាទិត្យ បើកឡើង ទើបរុងរឿង តែបិទបាំងទុក មិនរុងរឿង១ ធម្មវិន័យ ដែលតថាគតសំដែងហើយ បើកឡើង ទើបរុងរឿង បិទបាំងទុក មិនរុងរឿង១។ ការកាន់យកសេនាសនៈ មាន៣យ៉ាងគឺ បុរិមកៈ១ បច្ឆិមកៈ១ អន្តរាមុត្តកៈ១។

[៤១] ភិក្ខុឈឺត្រូវអាបត្តិ ភិក្ខុឥតឈឺ មិនត្រូវអាបត្តិក៏មាន ភិក្ខុមិនឈឺត្រូវអាបត្តិ ភិក្ខុឈឺមិនត្រូវអាបត្តិក៏មាន ទាំងភិក្ខុឈឺ ទាំងភិក្ខុមិនឈឺ ត្រូវអាបត្តិក៏មាន។

[៤២] ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ មាន៣យ៉ាង។ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ មាន៣យ៉ាង។ បរិវាស មាន៣យ៉ាង គឺ បដិច្ឆន្នបរិវាស១ អប្បដិច្ឆន្នបរិវាស១ សុទ្ធន្តបរិវាស១។ មានត្តមាន៣យ៉ាងគឺ បដិច្ឆន្នមានត្ត១ អប្បដិច្ឆន្នមានត្ត១ បក្ខមានត្ត១។ ការដាច់រាត្រីរបស់ភិក្ខុដែលនៅបរិវាស មាន៣យ៉ាងគឺ ការនៅរួម១ ការមិននៅរួម១ ការមិនបានប្រាប់១។

[៤៣] ភិក្ខុនៅខាងក្នុង ត្រូវអាបត្តិ នៅខាងក្រៅ មិនត្រូវអាបត្តិក៏មាន នៅខាងក្រៅ ត្រូវអាបត្តិ នៅខាងក្នុង មិនត្រូវអាបត្តិក៏មាន ត្រូវអាបត្តិទាំងខាងក្នុង ទាំងខាងក្រៅក៏មាន។ ភិក្ខុនៅខាងក្នុងសីមា ត្រូវអាបត្តិ នៅខាងក្រៅសីមា មិនត្រូវអាបត្តិក៏មាន នៅខាងក្រៅសីមា ត្រូវអាបត្តិ នៅខាងក្នុងសីមា មិនត្រូវអាបត្តិក៏មាន ត្រូវអាបត្តិទាំងខាងក្នុងសីមា ទាំងខាងក្រៅសីមាក៏មាន។

[៤៤] ភិក្ខុត្រូវអាបត្តិដោយអាការ៣យ៉ាងគឺ ត្រូវដោយកាយ១ ត្រូវដោយវាចា១ ត្រូវដោយកាយ និងវាចា១។ ភិក្ខុត្រូវអាបត្តិដោយអាការ៣យ៉ាងដទៃទៀត គឺ ត្រូវក្នុងកណ្តាលសង្ឃ១ ត្រូវក្នុងកណ្តាលគណៈ១ ត្រូវក្នុងសំណាក់នៃបុគ្គល១។ ភិក្ខុចេញចាកអាបត្តិ ដោយអាការ៣យ៉ាង គឺ ចេញចាកដោយកាយ១ ចេញចាកដោយវាចា១ ចេញចាកដោយកាយ និងវាចា១។ ភិក្ខុចេញចាកអាបត្តិ ដោយអាការ៣យ៉ាងដទៃទៀត គឺ ចេញចាកក្នុងកណ្តាលសង្ឃ១ ក្នុងកណ្តាលគណៈ១ ក្នុងសំណាក់នៃបុគ្គល១។ ការឲ្យអមូឡ្ហវិន័យ មិនប្រកបដោយធម៌ មាន៣យ៉ាង។ ការឲ្យអមូឡ្ហវិន័យ ប្រកបដោយធម៌ មាន៣យ៉ាង។

[៤៥] កាលបើសង្ឃប្រាថ្នា គប្បីធ្វើតជ្ជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣គឺ ភិក្ខុជាអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ ជាបុគ្គលនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើនិយស្សកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣គឺ ភិក្ខុជាអ្នកបង្កហេតុ។បេ។ បង្កអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ ជាអ្នកនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយ

ការច្រឡូកច្រឡំមិនសមគួរ១។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបព្វាជនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣គឺ ភិក្ខុអ្នកបង្កហេតុ។បេ។ អ្នកបង្កអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានមារយាទអាក្រក់១។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើបដិសារណីយកម្ម ដល់ភិក្ខុប្រកបដោយអង្គ៣គឺ ភិក្ខុជាអ្នកបង្កហេតុ។បេ។ អ្នកបង្កអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ ជេរគម្រាមគ្រហស្ថ១។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ ព្រោះមិនឃើញអាបត្តិ គឺ ភិក្ខុជាអ្នកបង្កហេតុ។បេ។ ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ ត្រូវអាបត្តិហើយ មិនប្រាថ្នាដើម្បីឃើញអាបត្តិ១។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ ព្រោះមិនសំដែងអាបត្តិគឺ ភិក្ខុជាអ្នកបង្កហេតុ។បេ។ ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ ត្រូវអាបត្តិហើយ មិនប្រាថ្នាដើម្បីសំដែងអាបត្តិចេញ១។ កាលបើសង្ឃប្រាថ្នា គប្បីធ្វើឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ចេញ ដល់ភិក្ខុដែលប្រកបដោយអង្គ៣គឺ ភិក្ខុជាអ្នកបង្កហេតុ។បេ។ ជាអ្នកបង្កអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ មិនប្រាថ្នានឹងលះបង់ទិដ្ឋិអាក្រក់ចេញ។ កាលបើសង្ឃប្រាថ្នា គប្បីលៃលក ដើម្បីសេចក្តីមាំមួន[12] ដល់ភិក្ខុដែលប្រកបដោយអង្គ៣គឺ ភិក្ខុជាអ្នកបង្កហេតុ បង្កជំលោះ បង្កវិវាទ បង្កតិរច្ឆានកថា បង្កអធិករណ៍ក្នុងសង្ឃ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ ច្រើនដោយអាបត្តិ មិនមានការកំណត់អាបត្តិ១ ជាអ្នកនៅច្រឡូកច្រឡំដោយគ្រហស្ថ ដោយការច្រឡូកច្រឡំមិនសមគួរ១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣គឺ ភិក្ខុជាអ្នកឥតមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀតគឺ ភិក្ខុជាអ្នកមានសីលវិបត្តិ ក្នុងអធិសីល១ មានអាចារវិបត្តិ ក្នុងអជ្ឈាចារ១ មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិ១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដោយឡែកទៀតគឺ ភិក្ខុជាអ្នកប្រកបខាងល្បែងដោយកាយ១ ជាអ្នកប្រកបខាងល្បែង ដោយវាចា១ ជាអ្នកប្រកបខាងល្បែង ដោយកាយ និងវាចា១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដោយឡែកទៀតគឺ ភិក្ខុជាអ្នកប្រកបដោយមារយាទមិនមានសណ្តាប់ធ្នាប់ដោយកាយ១ ជាអ្នកប្រកបដោយមារយាទ មិនមានសណ្តាប់ធ្នាប់ ដោយវាចា១ ជាអ្នកប្រកបដោយមារយាទ មិនមានសណ្តាប់ធ្នាប់ ដោយកាយ និងវាចា១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដោយឡែកទៀតគឺ ភិក្ខុជាអ្នកប្រកបដោយការបៀតបៀនដោយកាយ១ ជាអ្នកប្រកបដោយការបៀតបៀនដោយវាចា១ ជាអ្នកប្រកបដោយការបៀតបៀនដោយកាយ នឹងវាចា១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដោយឡែកទៀតគឺ ភិក្ខុជាអ្នកប្រកបដោយមិច្ឆាជីវៈដោយកាយ១ ជាអ្នកប្រកបដោយមិច្ឆាជីវៈដោយវាចា១ ជាអ្នកប្រកបដោយមិច្ឆាជីវៈ ដោយកាយ និងវាចា១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដោយឡែកទៀតគឺ ភិក្ខុត្រូវអាបត្តិហើយ សង្ឃបានធ្វើកម្មហើយ នៅតែឲ្យឧបសម្បទា (ដល់កុលបុត្រ)១ ឲ្យនិស្ស័យ (ដល់កុលបុត្រ)១ ឲ្យសាមណេរបម្រើខ្លួន១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដទៃទៀតគឺ កម្មដែលសង្ឃធ្វើហើយដោយអាបត្តិណា ភិក្ខុត្រូវអាបត្តិដដែលនោះ ឬត្រូវអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិនោះ១ ឬអាបត្តិដែលធ្ងន់ជាងអាបត្តិនោះទៅទៀត១។ សង្ឃគប្បីធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គ៣ដោយឡែកទៀតគឺ ភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១។ កាលបើមានភិក្ខុប្រកបដោយអង្គ៣គឺ ភិក្ខុមិនមានអៀនខ្មាស១ ភិក្ខុពាល១ មិនមែនជាបកតត្ត១ មកបញ្ឈប់នូវឧបោសថ ក្នុងកណ្តាលជំនុំសង្ឃ ៗត្រូវហាមដោយពាក្យថា ម្នាលភិក្ខុ មិនគួរទេ កុំបង្កហេតុ កុំឈ្លោះ កុំប្រកាន់ផ្សេងគ្នា កុំទាស់ទែងគ្នា ដូច្នេះ រួចហើយសឹមធ្វើឧបោសថ។ កាលបើភិក្ខុប្រកបដោយអង្គ៣គឺ ភិក្ខុមិនមានអៀនខ្មាស១ ភិក្ខុពាល១ មិនមែនជាបកតត្ត១ មកបញ្ឈប់បវារណា ក្នុងកណ្តាលជំនុំសង្ឃ ៗត្រូវហាមដោយពាក្យថា ម្នាលភិក្ខុ មិនគួរទេ អ្នកកុំបង្កហេតុ កុំឈ្លោះគ្នា កុំប្រកាន់ផ្សេងគ្នា កុំទាស់ទែងគ្នា ដូច្នេះ រួចហើយសឹមធ្វើបវារណា។ សង្ឃសម្មតិណាមួយ សង្ឃមិនត្រូវឲ្យដល់ភិក្ខុដែលប្រកបដោយអង្គ៣គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុប្រកបដោយអង្គ៣ មិនត្រូវស្តីពោលរកសង្ឃ គឺ ភិក្ខុជាអ្នកមិនខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុដែលប្រកបដោយអង្គ៣ សង្ឃមិនត្រូវដំកល់ទុកក្នុងដំណែងផ្សេងណាមួយ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុមិនត្រូវអាស្រ័យនឹងភិក្ខុដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុមិនត្រូវឲ្យនិស្ស័យ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុមិនត្រូវធ្វើឱកាសកម្ម ដល់ភិក្ខុដែលមកសូមឱកាស ដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុមិនត្រូវជឿស្តាប់ពាក្យរបស់ភិក្ខុ ដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុមិនត្រូវសួរវិន័យ ចំពោះភិក្ខុដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុដែលប្រកបដោយអង្គ៣ មិនត្រូវសួរវិន័យ (នឹងភិក្ខុណាមួយ) គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុមិនត្រូវដោះស្រាយវិន័យ ចំពោះភិក្ខុដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុដែលប្រកបដោយអង្គ៣ មិនត្រូវដោះស្រាយវិន័យនឹងភិក្ខុណាមួយ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុមិនត្រូវឲ្យការសាកសួរ ដល់ភិក្ខុដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុមិនត្រូវសាកច្ឆាវិន័យជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៣ គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។ ភិក្ខុដែលប្រកបដោយអង្គ៣ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន គឺ ភិក្ខុជាអ្នកមិនមានខ្មាស១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១។

[៤៦] ឧបោសថមាន៣យ៉ាង គឺចាតុទ្ទសីឧបោសថ១ បណ្ណរសីឧបោសថ១ សាមគ្គីឧបោសថ១។ ឧបោសថមាន៣យ៉ាងដទៃទៀត គឺសង្ឃឧបោសថ១ គណឧបោសថ១ បុគ្គលឧបោសថ១។ ឧបោសថមាន៣យ៉ាងដទៃទៀត គឺសុត្តុទ្ទេសឧបោសថ១ បារិសុទ្ធិឧបោសថ១ អធិដ្ឋានុបោសថ១។ បវារណាមាន៣យ៉ាង គឺ ចាតុទ្ទសីបវារណា១ បណ្ណរសីបវារណា១ សាមគ្គីបវារណា១។ បវារណាមាន៣យ៉ាងដទៃទៀត គឺសង្ឃប្បវារណា១ គណប្បវារណា១ បុគ្គលប្បវារណា១ បវារណាមាន៣យ៉ាងដទៃទៀត គឺតេវាចិកាបវារណា១ ទ្វេវាចិកាបវារណា១ សមានវស្សិកាបវារណា១។ បុគ្គលឈមមុខទៅកាន់អបាយ ទៅកាន់នរក មាន៣ពួក គឺ បុគ្គលមិនមែនជាអ្នកប្រព្រឹត្តព្រហ្មចារ្យ តែប្តេជ្ញាថា ជាអ្នកប្រព្រឹត្តព្រហ្មចារ្យ១ បុគ្គលចោទព្រហ្មចារីបុគ្គលដ៏បរិសុទ្ធ ដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ ដោយព្រហ្មចរិយធម៌មិនមានមូល១ បុគ្គលណាមួយមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសក្នុងកាមគុណមិនមានដូច្នេះ បុគ្គលនោះ តែងដល់នូវការសេពគប់ នូវកាមទាំងឡាយ១ ព្រោះមិនលះលទ្ធិនេះចេញ។ មូលនៃអកុសលមាន៣យ៉ាងគឺ លោភៈ ជាមូលនៃអកុសល១ ទោសៈ ជាមូលនៃអកុសល១ មោហៈ ជាមូលនៃអកុសល១។ មូលនៃកុសល មាន៣យ៉ាងគឺ អលោភៈ ជាមូលនៃកុសល១ អទោសៈ ជាមូលនៃកុសល១ អមោហៈ ជាមូលនៃកុសល១។ ទុច្ចរិតមាន៣យ៉ាង គឺ កាយទុច្ចរិត១ វចីទុច្ចរិត១ មនោទុច្ចរិត១។ សុចរិតមាន៣យ៉ាងគឺ កាយសុចរិត១ វចីសុចរិត១ មនោសុចរិត១។ ព្រះមានព្រះភាគ

ទ្រង់បញ្ញត្តតិកភោជនសិក្ខាបទ ក្នុងត្រកូលទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍៣យ៉ាង គឺ ដើម្បីផ្ចាញ់ផ្ចាល់បុគ្គលឥតខ្មាស១ ដើម្បីនៅសប្បាយដល់ភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ដោយទ្រង់ត្រិះរិះថា ភិក្ខុប្រាថ្នាលាមកទាំងឡាយកុំទំលាយសង្ឃ ព្រោះអាស្រ័យពួក១ ដើម្បីអនុគ្រោះដល់ត្រកូល១។ ទេវទត្តត្រូវអសទ្ធម្ម៣ប្រការ គ្របសង្កត់ រួបរឹតចិត្ត ហើយក៏ទៅកាន់អបាយ ទៅកាន់នរក តាំងនៅអស់កប្ប កែខ្លួនលែងបាន (អសទ្ធម្ម៣ប្រការនោះគឺ) សេចក្តីប្រាថ្នាលាមក១ មានមិត្រលាមក១ ទេវទត្តនោះ បានសម្រេចគុណវិសេសត្រឹមជាន់ទាប តែដល់នូវសេចក្តីសាបសូន្យ ក្នុងចន្លោះវិញ១។ សម្មតិមាន៣យ៉ាងគឺ ទណ្ឌសម្មតិ១ សិក្កាសម្មតិ១ ទណ្ឌសិក្កាសម្មតិ១។ ទ្រនាប់ជើង ដែលសម្រាប់ដំកល់ទុកជានិច្ច មិនត្រូវធ្វើឲ្យឃ្លាតចាកកន្លែងមាន៣គឺ ទ្រនាប់សម្រាប់បន្ទោបង់វច្ចៈ១ ទ្រនាប់សម្រាប់បន្ទោបង់បស្សាវៈ១ ទ្រនាប់សម្រាប់ជំរះអាចម៍១។ ទ្រនាប់សម្រាប់ជូតជើង មាន៣គឺ ទ្រនាប់ថ្ម១ ទ្រនាប់ក្បឿង១ ទ្រនាប់អណ្តាតសមុទ្រ១។

ចប់តិកៈ (ពួកបីៗ)។

ឧទ្ទាន គឺបញ្ជីរឿងនៃតិកៈ (ពួកបីៗ) នោះដូច្នេះ

[៤៧]

ភិក្ខុត្រូវអាបត្តិក្នុងកាលដែលព្រះមានព្រះភាគគង់ព្រះជន្មនៅ១ ភិក្ខុត្រូវអាបត្តិក្នុងកាលគួរ១ ក្នុងរាត្រី១ ភិក្ខុមានវស្សា១០ ត្រូវអាបត្តិ១ មានវស្សា៥ ក៏ត្រូវអាបត្តិ១ មានកុសលចិត្ត ក៏ត្រូវអាបត្តិ១ ប្រកបដោយវេទនា ត្រូវអាបត្តិ១ ចោទនវត្ថុ១ ការចាប់ស្លាក១ ការឃាត់មានពីរលើក១ បញ្ញត្តិ១ បញ្ញត្តិពីរលើកដទៃទៀត១ ភិក្ខុ៣លត្រូវអាបត្តិក៏មាន១ ភិក្ខុត្រូវអាបត្តិក្នុងកាឡប័ក្ខ១ ការចូលវស្សាគួរក្នុងកាឡប័ក្ខ១ ភិក្ខុត្រូវអាបត្តិក្នុងហេមន្តរដូវក៏មាន១ សង្ឃត្រូវអាបត្តិ១ ឧបោសថ និងបវារណា គួរដល់សង្ឃ១ ការបិទបាំង១ គ្រឿងបិទបាំង១ វត្ថុដែលបិទបាំងទុក១ វត្ថុដែលបើកឡើង១ ការកាន់យកសេនាសនៈ១ ភិក្ខុឈឺត្រូវអាបត្តិ១ បញ្ឈប់បាតិមោក្ខ១ បរិវាស១ មានត្ត១ ភិក្ខុកំពុងនៅបរិវាស១ ភិក្ខុនៅខាងក្នុង ត្រូវអាបត្តិ១ ភិក្ខុត្រូវអាបត្តិខាងក្នុងសីមា១ ភិក្ខុត្រូវអាបត្តិដោយអាការ៣ដទៃទៀត១ ភិក្ខុចេញចាកអាបត្តិដោយអាការ៣ដទៃទៀត១ ការឲ្យអមូឡ្ហវិន័យ២យ៉ាង១ សង្ឃធ្វើតជ្ជនីយកម្ម១ និយស្សកម្ម១ បព្វាជនីយកម្ម១ បដិសារណីយកម្ម១ សង្ឃធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ១ ព្រោះមិនសំដែងអាបត្តិ១ ព្រោះមិនលះបង់ទិដ្ឋិអាក្រក់១ សង្ឃលៃលកដើម្បីសេចក្តីមាំមួន១ សង្ឃគប្បីធ្វើកម្មដល់ភិក្ខុ១ អធិសីល១ ល្បែង១ ភិក្ខុមានមារយាទមិនមានសណ្តាប់ធ្នាប់១ ការបៀតបៀន១ មិច្ឆាជីវៈ១ ភិក្ខុត្រូវអាបត្តិហើយ នៅតែឲ្យឧបសម្បទា១ ភិក្ខុត្រូវអាបត្តិប្រហែលនឹងអាបត្តិមុននោះ១ ភិក្ខុតិះដៀលព្រះរតនត្រ័យ១ ហាមឧបោសថ១ ហាមបវារណា១ សង្ឃសម្មតិ១ ភិក្ខុល្ងង់ មិនគប្បីស្តីរកសង្ឃ១ សង្ឃមិនត្រូវដំកល់ភិក្ខុល្ងង់ទុកក្នុងដំណែងផ្សេងណាមួយ១ មិនត្រូវឲ្យនិស្ស័យ១ មិនត្រូវបើកឱកាសឲ្យ១ មិនត្រូវជឿស្តាប់ពាក្យ១ មិនត្រូវសួរវិន័យមានពីរលើក១ មិនត្រូវឆ្លើយវិន័យមានពីរលើក១ មិនត្រូវឲ្យការសាកសួរ១ មិនត្រូវសាកច្ឆាវិន័យ១ មិនត្រូវឲ្យឧបសម្បទា១ មិនត្រូវឲ្យនិស្ស័យ១ មិនត្រូវឲ្យសាមណេរបំរើខ្លួន១ ឧបោសថមាន៣យ៉ាង១ បវារណាមាន៣យ៉ាង១ ជន៣ពួកទៅកាន់អបាយ១ អកុសលមូល១ កុសលមូល១ ទុច្ចរិត និងសុចរិត១ តិកភោជនសិក្ខាបទ១ ទេវទត្តត្រូវអសទ្ធម្មគ្របសង្កត់១ សម្មតិ១ ទ្រនាប់ជើង១ ទ្រនាប់សម្រាប់ជូតជើង១ ពាក្យដែលពោលមកនេះ ជាឧទ្ទានក្នុងតិកបទ។

## (ចតុក្កវារៈ ទី៤)

CS vin.pv.05.04 | ភាគ ទី១៣

### (៤. ចតុក្កវារោ)

[៤៨] ភិក្ខុត្រូវអាបត្តិដោយវាចារបស់ខ្លួន ចេញចាកអាបត្តិដោយវាចារបស់អ្នកដទៃក៏មាន ភិក្ខុត្រូវអាបត្តិដោយវាចារបស់អ្នកដទៃ ចេញចាកអាបត្តិដោយវាចារបស់ខ្លួនក៏មាន ត្រូវអាបត្តិដោយវាចារបស់ខ្លួន ចេញចាកអាបត្តិដោយវាចារបស់ខ្លួនក៏មាន ត្រូវអាបត្តិដោយវាចារបស់អ្នកដទៃ ចេញចាកអាបត្តិដោយវាចារបស់អ្នកដទៃក៏មាន។ ភិក្ខុត្រូវអាបត្តិដោយកាយ ចេញចាកអាបត្តិដោយវាចាក៏មាន ត្រូវអាបត្តិដោយវាចា ចេញចាកអាបត្តិដោយកាយក៏មាន ត្រូវអាបត្តិដោយកាយ ចេញចាកអាបត្តិដោយកាយក៏មាន ត្រូវអាបត្តិដោយវាចា ចេញចាកអាបត្តិដោយវាចាក៏មាន។ ភិក្ខុដេកលក់ ត្រូវអាបត្តិ ភ្ញាក់ឡើងចេញចាកអាបត្តិក៏មាន ភ្ញាក់ឡើងត្រូវអាបត្តិ ដេកលក់ទៅវិញ ចេញចាកអាបត្តិក៏មាន ដេកលក់ ត្រូវអាបត្តិ ដេកលក់ ចេញចាកអាបត្តិក៏មាន ភ្ញាក់ឡើង ត្រូវអាបត្តិ ភ្ញាក់ឡើងចេញចាកអាបត្តិក៏មាន។ ភិក្ខុមិនមានចិត្ត ត្រូវអាបត្តិ ប្រកបដោយចិត្ត ចេញចាកអាបត្តិក៏មាន ភិក្ខុប្រកបដោយចិត្ត ត្រូវអាបត្តិ មិនមានចិត្ត ចេញចាកអាបត្តិក៏មាន ភិក្ខុមិនមានចិត្ត ត្រូវអាបត្តិ មិនមានចិត្ត ចេញចាកអាបត្តិក៏មាន ភិក្ខុប្រកបដោយចិត្ត ត្រូវអាបត្តិ ប្រកបដោយចិត្ត ចេញចាកអាបត្តិក៏មាន។ ភិក្ខុត្រូវអាបត្តិហើយសំដែង កំពុងតែសំដែង ត្រូវអាបត្តិទៀតក៏មាន ភិក្ខុត្រូវអាបត្តិហើយ ចេញចាកអាបត្តិ កំពុងចេញចាកអាបត្តិ ត្រូវអាបត្តិទៀតក៏មាន។ ភិក្ខុត្រូវអាបត្តិដោយកម្ម ចេញចាកអាបត្តិដោយមិនមែនកម្មក៏មាន ភិក្ខុត្រូវអាបត្តិដោយមិនមែនកម្ម ចេញចាកអាបត្តិ ដោយកម្មក៏មាន ភិក្ខុត្រូវអាបត្តិដោយកម្ម ចេញចាកអាបត្តិដោយកម្មក៏មាន ភិក្ខុត្រូវអាបត្តិដោយមិនមែនកម្ម ចេញចាកអាបត្តិដោយមិនមែនកម្មក៏មាន។

[៤៩] អនរិយវោហារ (វោហារមិនប្រសើរ) មាន៤គឺ ការពោលថា បានឃើញក្នុងហេតុដែលខ្លួនមិនបានឃើញ១ ការពោលថា បានឮក្នុងហេតុដែលខ្លួនមិនបានឮ១ ការពោលថា បានពាល់ត្រូវ ក្នុងហេតុដែលខ្លួនមិនបានពាល់ត្រូវ១ ការពោលថា ដឹងច្បាស់ ក្នុងហេតុដែលខ្លួនមិនបានដឹងច្បាស់១។ អរិយវោហារ (វោហារដ៏ប្រសើរ) មាន៤គឺ ការពោលថា មិនបានឃើញ ក្នុងហេតុដែលខ្លួនមិនបានឃើញ១ ការពោលថា មិនបានឮក្នុងហេតុដែលខ្លួនមិនបានឮ១ ការពោលថា មិនបានពាល់ត្រូវ ក្នុងហេតុដែលខ្លួនមិនបានពាល់ត្រូវ១ ការពោលថា មិនបានដឹងច្បាស់ ក្នុងហេតុដែលខ្លួនមិនបានដឹងច្បាស់១។ អនរិយវោហារមាន៤ដទៃទៀតគឺ ការពោលថា មិនបានឃើញ ក្នុងហេតុដែលខ្លួនបានឃើញ១ ការពោលថា មិនបានឮ

ក្នុងហេតុដែលខ្លួនបានឮ១ ការពោលថា មិនបានពាល់ត្រូវ ក្នុងហេតុដែលខ្លួនពាល់ត្រូវ១ ការពោលថា មិនបានដឹងច្បាស់ ក្នុងហេតុដែលខ្លួនដឹងច្បាស់១។ អរិយវោហារមាន៤គឺ ការពោលថា បានឃើញ ក្នុងហេតុដែលខ្លួនបានឃើញ១ ការពោលថា បានឮក្នុងហេតុដែលខ្លួនបានឮ១ ការពោលថា បានពាល់ត្រូវ ក្នុងហេតុដែលខ្លួនបានពាល់ត្រូវ១ ការពោលថា បានដឹងច្បាស់ ក្នុងហេតុដែលខ្លួនបានដឹងច្បាស់១។ បារាជិកាបត្តិទាំង៤របស់ភិក្ខុ សាធារណ៍ទៅដល់ពួកភិក្ខុនីផង។ បារាជិកាបត្តិទាំង៤របស់ភិក្ខុនី មិនបានសាធារណ៍ទៅដល់ពួកភិក្ខុផងទេ។ បរិក្ខារ៤ គឺបរិក្ខារដែលភិក្ខុគួររក្សា គួរគ្រប់គ្រង គួរប្រកាន់ថាជារបស់អាត្មាអញ គួរប្រើប្រាស់ក៏មាន បរិក្ខារដែលភិក្ខុគួររក្សា គួរគ្រប់គ្រង មិនគួរប្រកាន់ថាជារបស់អាត្មាអញ តែគួរប្រើប្រាស់ក៏មាន បរិក្ខារដែលភិក្ខុគួររក្សា គួរគ្រប់គ្រង តែមិនគួរប្រកាន់ថាជារបស់អាត្មាអញ មិនគួរប្រើប្រាស់ក៏មាន បរិក្ខារដែលភិក្ខុមិនគួររក្សា មិនគួរគ្រប់គ្រង មិនគួរប្រកាន់ថាជារបស់អាត្មាអញ មិនគួរប្រើប្រាស់ក៏មាន។

[៥០] ភិក្ខុត្រូវអាបត្តិក្នុងទីចំពោះមុខ ចេញចាកអាបត្តិក្នុងទីកំបាំងមុខក៏មាន ត្រូវអាបត្តិក្នុងទីកំបាំងមុខ ចេញចាកអាបត្តិក្នុងទីចំពោះមុខក៏មាន ត្រូវអាបត្តិក្នុងទីចំពោះមុខ ចេញចាកអាបត្តិក្នុងទីចំពោះមុខក៏មាន ត្រូវអាបត្តិក្នុងទីកំបាំងមុខ ចេញចាកអាបត្តិក្នុងទីកំបាំងមុខក៏មាន។ ភិក្ខុកាលមិនដឹង ត្រូវអាបត្តិ កាលដឹង ចេញចាកអាបត្តិក៏មាន កាលដឹង ត្រូវអាបត្តិ កាលមិនដឹង ចេញចាកអាបត្តិក៏មាន កាលដឹង ត្រូវអាបត្តិ កាលដឹង ចេញចាកអាបត្តិក៏មាន កាលមិនដឹង ត្រូវអាបត្តិ កាលមិនដឹង ចេញចាកអាបត្តិក៏មាន។

[៥១] ភិក្ខុត្រូវអាបត្តិដោយអាការ៤យ៉ាងគឺ ត្រូវដោយកាយ១ ដោយវាចា១ ដោយកាយ និងវាចា១ ដោយកម្មវាចា១។ ភិក្ខុត្រូវអាបត្តិដោយអាការ៤យ៉ាងដទៃទៀត គឺ ត្រូវក្នុងកណ្តាលជំនុំសង្ឃ១ ក្នុងកណ្តាលគណៈ១ ក្នុងសំណាក់នៃបុគ្គល១ ដោយក្លាយភេទ១។ ភិក្ខុចេញចាកអាបត្តិដោយអាការ៤យ៉ាងគឺ ចេញចាកដោយកាយ១ ចេញចាកដោយវាចា១ ចេញចាកដោយកាយ និងវាចា១ ចេញចាកដោយកម្មវាចា១។ ភិក្ខុចេញចាកអាបត្តិដោយអាការ៤យ៉ាងដទៃទៀត គឺ ចេញចាកអាបត្តិក្នុងកណ្តាលជំនុំសង្ឃ១ ក្នុងកណ្តាលគណៈ១ ក្នុងសំណាក់នៃបុគ្គល១ ដោយក្លាយភេទ១។ ភិក្ខុលះបង់បុរិមភេទ (ភេទប្រុស) ព្រមទាំងការបានចំពោះភេទ (ថ្មី) ឋិតនៅក្នុងបច្ឆិមភេទ (ភេទស្រី) វិញ្ញត្តិទាំងឡាយក៏ស្ងប់រម្ងាប់ទៅ បណ្ណត្តិទាំងឡាយក៏រលត់បាត់ទៅ។ ភិក្ខុនីលះបង់បច្ឆិមភេទ ព្រមទាំងការបានចំពោះភេទ (ថ្មី) ឋិតនៅក្នុងបុរិមភេទ វិញ្ញត្តិទាំងឡាយ ក៏ស្ងប់រម្ងាប់បាត់ទៅ បណ្ណត្តិទាំងឡាយក៏រលត់ទៅ។ ការចោទមាន៤យ៉ាងគឺ ចោទដោយសីលវិបត្តិ១ ចោទដោយអាចារវិបត្តិ១ ចោទដោយទិដ្ឋិវិបត្តិ១ ចោទដោយអាជីវវិបត្តិ១។ បរិវាសមាន៤យ៉ាង គឺ បដិច្ឆន្នបរិវាស១ អប្បដិច្ឆន្នបរិវាស១ សុទ្ធន្តបរិវាស១ សមោធានបរិវាស១។ មានត្តមាន៤យ៉ាង គឺ បដិច្ឆន្នមានត្ត១ អប្បដិច្ឆន្នមានត្ត១ បក្ខមានត្ត១ សមោធានមានត្ត១។ ការដែលដាច់រាត្រីរបស់ភិក្ខុអ្នកប្រព្រឹត្តមានត្តមាន៤យ៉ាងគឺ ការនៅរួម១ ការមិននៅរួម១ ការមិនប្រាប់១ ប្រព្រឹត្តវត្ត ក្នុងទីមិនគ្រប់គណៈសង្ឃ១។ គ្រឿងអាង (មហាបទេស) មាន៤។ គ្រឿងបរិភោគដែលភិក្ខុទទួលប្រគេន មាន៤ គឺ យាវកាលិក១ យាមកាលិក១ សត្តាហកាលិក១ យាវជីវិក១។ ថ្នាំមហាវិកដ មាន៤យ៉ាង គឺ គូថៈ១ មូត្រ១ ផេះ១ ដី១។ កម្មមាន៤យ៉ាង គឺ អបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១។ កម្មមាន៤យ៉ាងដទៃទៀត គឺ កម្មជាពួកមិនប្រកបដោយធម៌១ កម្មព្រមព្រៀងគ្នា មិនប្រកបដោយធម៌១ កម្មជាពួក តែប្រកបដោយធម៌១ កម្មព្រមព្រៀងគ្នា ទាំងប្រកបដោយធម៌១។ វិបត្តិមាន៤គឺ សិលវិបត្តិ១ អាចារវិបត្តិ១ ទិដ្ឋិវិបត្តិ១ អាជីវវិបត្តិ១។ អធិករណ៍ មាន៤គឺ វិវាទាធិករណ៍១ អនុវាទាធិករណ៍១ អាបត្តាធិករណ៍១ កិច្ចាធិករណ៍១។ អ្នកញុំាងបរិសទ្យឲ្យអាក្រក់ មាន៤គឺ ភិក្ខុទ្រុស្តសីលមានធម)ដ៏លាមក ចាត់ជាអ្នកញុំាងបរិសទ្យឲ្យអាក្រក់១ ភិក្ខុនីទ្រុស្តសីលមានធម៌ដ៏លាមក ចាត់ជាអ្នកញុំាងបរិសទ្យឲ្យអាក្រក់១ ឧបាសកទ្រុស្តសីល មានធម៌ដ៏លាមក ចាត់ជាអ្នកញុំាងបរិសទ្យឲ្យអាក្រក់១ ឧបាសិកាទ្រុស្តសីល មានធម៌ដ៏លាមក ចាត់ជាអ្នកញុំាងបរិសទ្យឲ្យអាក្រក់១។ អ្នកញុំាងបរិសទ្យឲ្យល្អមាន៤ គឺ ភិក្ខុមានសីល មានធម៌ល្អ ចាត់ជាអ្នកញុំាងបរិសទ្យឲ្យល្អ១ ភិក្ខុនីមានសីល មានធម៌ល្អ ចាត់ជាអ្នកញុំាងបរិសទ្យឲ្យល្អ១ ឧបាកសមានសីល មានធម៌ល្អ ចាត់ជាអ្នកញុំាងបរិសទ្យឲ្យល្អ១ ឧបាសិកាមានសីល មានធម៌ល្អ ចាត់ជាអ្នកញុំាងបរិសទ្យឲ្យល្អ១។

[៥២] អាគន្តុកភិក្ខុត្រូវអាបត្តិ អាវាសិកភិក្ខុ មិនត្រូវអាបត្តិក៏មាន អាវាសិកភិក្ខុត្រូវអាបត្តិ អាគន្តុកភិក្ខុ មិនត្រូវអាបត្តិក៏មាន ទាំងអាគន្តុកភិក្ខុ ទាំងអាវាសិកភិក្ខុ ត្រូវអាបត្តិក៏មាន ទាំងអាគន្តុកភិក្ខុ ទាំងអាវាសិកភិក្ខុ មិនត្រូវអាបត្តិក៏មាន។ គមិកភិក្ខុ ត្រូវអាបត្តិ អាវាសិកភិក្ខុ មិនត្រូវអាបត្តិក៏មាន អាវាសិកភិក្ខុ ត្រូវអាបត្តិ គមិកភិក្ខុ មិនត្រូវអាបត្តិក៏មាន ទាំងគមិកភិក្ខុ ទាំងអាវាសិកភិក្ខុ ត្រូវអាបត្តិក៏មាន ទាំងគមិកភិក្ខុ ទាំងអាវាសិកភិក្ខុ មិនត្រូវអាបត្តិក៏មាន។

[៥៣] សេចក្តីផ្សេងគ្នាដោយវត្ថុ តែមិនផ្សេងគ្នាដោយអាបត្តិក៏មាន ផ្សេងគ្នាដោយអាបត្តិ តែមិនផ្សេងគ្នាដោយវត្ថុក៏មាន ផ្សេងគ្នាដោយវត្ថុផង ផ្សេងគ្នាដោយអាបត្តិផងក៏មាន មិនផ្សេងគ្នាដោយវត្ថុ មិនផ្សេងគ្នាដោយអាបត្តិក៏មាន។ សភាវៈមានចំណែកស្មើគ្នាដោយវត្ថុ តែមិនមានចំណែកស្មើគ្នាដោយអាបត្តិក៏មាន មានចំណែកស្មើគ្នាដោយអាបត្តិ តែមិនមានចំណែកស្មើគ្នាដោយវត្ថុក៏មាន មានចំណែកស្មើគ្នាដោយវត្ថុ មានចំណែកស្មើគ្នាដោយអាបត្តិក៏មាន មិនមានចំណែកស្មើគ្នាដោយវត្ថុ មិនមានចំណែកស្មើគ្នាដោយអាបត្តិក៏មាន។

[៥៤] ឧបជ្ឈាយ៍ត្រូវអាបត្តិ សទ្ធិវិហារិកមិនត្រូវអាបត្តិក៏មាន សទ្ធិវិហារិកត្រូវអាបត្តិ ឧបជ្ឈាយ៍មិនត្រូវអាបត្តិក៏មាន ទាំងឧបជ្ឈាយ៍ ទាំងសទ្ធិវិហារិកត្រូវអាបត្តិក៏មាន ទាំងឧបជ្ឈាយ៍ ទាំងសទ្ធិវិហារិក មិនត្រូវអាបត្តិក៏មាន។ អាចារ្យត្រូវអាបត្តិ អន្តេវាសិកមិនត្រូវអាបត្តិក៏មាន អន្តេវាសិកត្រូវអាបត្តិ អាចារ្យមិនត្រូវអាបត្តិក៏មាន ទាំងអាចារ្យ ទាំងអន្តេវាសិកត្រូវអាបត្តិក៏មាន ទាំងអាចារ្យ ទាំងអន្តេវាសិកមិនត្រូវអាបត្តិក៏មាន។

[៥៥] ហេតុនៃការដាច់វស្សា តែមិនត្រូវអាបត្តិមាន៤យ៉ាង គឺ សង្ឃបែកគ្នា១ ភិក្ខុទាំងឡាយប្រាថ្នាទំលាយសង្ឃ១ មានអន្តរាយដល់ជីវិត១ មានអន្តរាយដល់ព្រហ្មចារ្យ១។ វចីទុច្ចរិតមាន៤យ៉ាងគឺ មុសាវាទ១ បិសុណាវាទ១ ផរុសវាទ១ សម្ផប្បលាបៈ១។ វចីសុចរិតមាន៤យ៉ាងគឺ សច្ចវាចា (និយាយពាក្យពិត)១ អបិសុណាវាចា (មិននិយាយពាក្យស៊កសៀត)១ សណ្ហវាចា (និយាយពាក្យពីរោះ)១ មត្តភាសា (និយាយពាក្យគួរដល់ប្រមាណ)១។

[៥៦] ភិក្ខុកាន់យកទ្រព្យគេដោយខ្លួនឯង ត្រូវគរុកាបត្តិ ប្រើគេឲ្យកាន់យក ត្រូវលហុកាបត្តិក៏មាន កាន់យកទ្រព្យគេដោយខ្លួនឯង ត្រូវលហុកាបត្តិ ប្រើគេឲ្យកាន់យក ត្រូវគរុកាបត្តិក៏មាន កាន់យកទ្រព្យគេដោយខ្លួនឯងក្តី ប្រើគេឲ្យកាន់យកក្តី ត្រូវគរុកាបត្តិក៏មាន កាន់យកទ្រព្យគេដោយខ្លួនឯងក្តី ប្រើគេឲ្យកាន់យកក្តី ត្រូវលហុកាបត្តិក៏មាន។ បុគ្គលគួរដល់ការអភិវាទ មិនគួរដល់ការក្រោកទទួលក៏មាន បុគ្គលគួរដល់ការ

ក្រោកទទួល មិនគួរដល់ការអភិវាទក៏មាន បុគ្គលគួរដល់ការអភិវាទផង គួរដល់ការក្រោកទទួលផងក៏មាន បុគ្គលមិនគួរដល់ការអភិវាទ មិនគួរដល់ការក្រោកទទួលក៏មាន។ បុគ្គលគួរដល់អាសនៈ មិនគួរដល់ការអភិវាទក៏មាន បុគ្គលគួរដល់ការអភិវាទ មិនគួរដល់អាសនៈក៏មាន បុគ្គលគួរដល់អាសនៈផង គួរដល់ការអភិវាទផងក៏មាន បុគ្គលមិនគួរដល់អាសនៈ មិនគួរដល់ការអភិវាទក៏មាន។

[៥៧] ភិក្ខុត្រូវអាបត្តិតែក្នុងកាល មិនត្រូវក្នុងវិកាលក៏មាន ត្រូវអាបត្តិតែក្នុងវិកាល មិនត្រូវក្នុងកាលក៏មាន ត្រូវអាបត្តិទាំងក្នុងកាល ទាំងក្នុងវិកាលក៏មាន មិនត្រូវអាបត្តិទាំងក្នុងកាល ទាំងក្នុងវិកាលក៏មាន។ វត្ថុដែលភិក្ខុទទួលប្រគេនហើយ គួរតែក្នុងកាល មិនគួរក្នុងវិកាលក៏មាន វត្ថុដែលភិក្ខុទទួលប្រគេនហើយ គួរក្នុងវិកាល មិនគួរក្នុងកាលក៏មាន វត្ថុដែលភិក្ខុទទួលប្រគេនហើយ គួរក្នុងកាលផង គួរក្នុងវិកាលផងក៏មាន វត្ថុដែលភិក្ខុទទួលប្រគេនហើយ មិនគួរក្នុងកាល មិនគួរក្នុងវិកាលក៏មាន។ ភិក្ខុត្រូវអាបត្តិតែក្នុងបច្ចន្តិមជនបទ មិនត្រូវក្នុងមជ្ឈិមជនបទក៏មាន ត្រូវអាបត្តិតែក្នុងមជ្ឈិមជនបទ មិនត្រូវក្នុងបច្ចន្តិមជនបទក៏មាន ត្រូវអាបត្តិទាំងក្នុងបច្ចន្តិមជនបទ ទាំងក្នុងមជ្ឈិមជនបទក៏មាន មិនត្រូវអាបត្តិទាំងក្នុងបច្ចន្តិមជនបទ ទាំងក្នុងមជ្ឈិមជនបទក៏មាន។ វត្ថុគួរតែក្នុងបច្ចន្តិមជនបទ មិនគួរក្នុងមជ្ឈិមជនបទក៏មាន គួរតែក្នុងមជ្ឈិមជនបទ មិនគួរក្នុងបច្ចន្តិមជនបទក៏មាន គួរទាំងក្នុងបច្ចន្តិមជនបទ ទាំងក្នុងមជ្ឈិមជនបទក៏មាន មិនគួរទាំងក្នុងបច្ចន្តិមជនបទ មិនគួរទាំងក្នុងមជ្ឈិមជនបទក៏មាន។ ភិក្ខុនៅខាងក្នុង ត្រូវអាបត្តិ នៅខាងក្រៅ មិនត្រូវអាបត្តិក៏មាន នៅខាងក្រៅត្រូវអាបត្តិ នៅខាងក្នុងមិនត្រូវអាបត្តិក៏មាន នៅខាងក្នុងក៏ត្រូវអាបត្តិ នៅខាងក្រៅក៏ត្រូវអាបត្តិក៏មាន នៅខាងក្នុងក៏មិនត្រូវអាបត្តិ នៅខាងក្រៅក៏មិនត្រូវអាបត្តិក៏មាន។ ភិក្ខុនៅខាងក្នុងសីមា ត្រូវអាបត្តិ នៅខាងក្រៅសីមា មិនត្រូវអាបត្តិក៏មាន នៅខាងក្រៅសីមា ត្រូវអាបត្តិ នៅខាងក្នុងសីមាមិនត្រូវអាបត្តិក៏មាន នៅខាងក្នុងសីមាក៏ត្រូវអាបត្តិ នៅខាងក្រៅសីមាក៏ត្រូវអាបត្តិក៏មាន នៅខាងក្នុងសីមាក៏មិនត្រូវអាបត្តិ នៅខាងក្រៅសីមាក៏មិនត្រូវអាបត្តិ។ ភិក្ខុនៅក្នុងស្រុកត្រូវអាបត្តិ នៅក្នុងព្រៃមិនត្រូវអាបត្តិក៏មាន នៅក្នុងព្រៃត្រូវអាបត្តិ នៅក្នុងស្រុកមិនត្រូវអាបត្តិក៏មាន នៅក្នុងស្រុកក៏ត្រូវអាបត្តិ នៅក្នុងព្រៃក៏ត្រូវអាបត្តិក៏មាន នៅក្នុងស្រុកក៏មិនត្រូវអាបត្តិ នៅក្នុងព្រៃក៏មិនត្រូវអាបត្តិក៏មាន។

[៥៨] ការចោទមាន៤យ៉ាង គឺចង្អុរចំពោះវត្ថុ១ ចង្អុរចំពោះអាបត្តិ១ ឃាត់សំវាស១ ឃាត់សាមីចិកម្ម១។ បុព្វកិច្ចមាន៤យ៉ាង។ កម្មមានកាលដ៏គួរមាន៤។ អនញ្ញាបាចិត្តិយៈមាន៤។ ភិក្ខុសម្មតិមាន៤។ ការលុះអគតិមាន៤គឺ លុះទៅខាងឆន្ទាគតិ១ លុះទៅខាងទោសាគតិ១ លុះទៅខាងមោហាគតិ១ លុះទៅខាងភយាគតិ១។ ការមិនលុះអគតិមាន៤គឺ មិនលុះទៅខាងឆន្ទាគតិ១ មិនលុះទៅខាងទោសាគតិ១ មិនលុះទៅខាងមោហាគតិ១ មិនលុះទៅខាងភយាគតិ១។ អលជ្ជីភិក្ខុ ដែលប្រកបដោយអង្គ៤គឺ លុះទៅខាងឆន្ទាគតិ១ លុះទៅខាងទោសាគតិ១ លុះទៅខាងមោហាគតិ១ លុះទៅខាងភយាគតិ១ រមែងទំលាយនូវសង្ឃ។ ភិក្ខុមានសីលជាទីស្រឡាញ់ ប្រកបដោយអង្គ៤គឺ មិនលុះទៅខាងឆន្ទាគតិ១ មិនលុះទៅខាងទោសាគតិ១ មិនលុះទៅខាងមោហាគតិ១ មិនលុះទៅខាងភយាគតិ១ រមែងធ្វើសង្ឃដែលបែកគ្នាហើយ ឲ្យព្រមព្រៀងគ្នាវិញ។ ភិក្ខុមិនគួរសួរវិន័យចំពោះភិក្ខុដែលប្រកបដោយអង្គ៤គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ១ លុះទៅខាងទោសាគតិ១ លុះទៅខាងមោហាគតិ១ លុះទៅខាងភយាគតិ១។ ភិក្ខុដែលប្រកបដោយអង្គ៤គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ១ លុះទៅខាងទោសាគតិ១ លុះទៅខាងមោហាគតិ១ លុះទៅខាងភយាគតិ១ ក៏មិនគួរសួរវិន័យឡើយ។ ភិក្ខុមិនគួរដោះស្រាយវិន័យ ចំពោះភិក្ខុដែលប្រកបដោយអង្គ៤គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ១ លុះទៅខាងទោសាគតិ១ លុះទៅខាងមោហាគតិ១ លុះទៅខាងភយាគតិ១។ ភិក្ខុដែលប្រកបដោយអង្គ៤គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ១ លុះទៅខាងទោសាគតិ១ លុះទៅខាងមោហាគតិ១ លុះទៅខាងភយាគតិ១ ក៏មិនត្រូវដោះស្រាយវិន័យ។ ភិក្ខុមិនត្រូវឲ្យការសាកសួរ ចំពោះភិក្ខុដែលប្រកបដោយអង្គ៤ គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ១ លុះទៅខាងទោសាគតិ១ លុះទៅខាងមោហាគតិ១ លុះទៅខាងភយាគតិ១។ ភិក្ខុមិនត្រូវសាកច្ឆាវិន័យជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៤គឺ ភិក្ខុលុះទៅខាងឆន្ទាគតិ១ លុះទៅខាងទោសាគតិ១ លុះទៅខាងមោហាគតិ១ លុះទៅខាងភយាគតិ១។

[៥៩] ភិក្ខុឈឺត្រូវអាបត្តិ មិនឈឺមិនត្រូវអាបត្តិក៏មាន មិនឈឺ ត្រូវអាបត្តិ ឈឺ មិនត្រូវអាបត្តិក៏មាន ឈឺត្រូវអាបត្តិ មិនឈឺក៏ត្រូវអាបត្តិក៏មាន ឈឺមិនត្រូវអាបត្តិ មិនឈឺមិនត្រូវអាបត្តិក៏មាន។

[៦០] ការបញ្ឈប់នូវបាតិមោក្ខ មិនប្រកបដោយធម៌មាន៤យ៉ាង។ ការបញ្ឈប់នូវបាតិមោក្ខ ប្រកបដោយធម៌មាន៤យ៉ាង។

ចប់ ចតុក្កៈ (ពួកបួនៗ)។

ឧទ្ទាន គឺបញ្ជីរឿងនៃចតុក្កៈ (ពួកបួនៗ) នោះដូច្នេះ

[៦១]

ភិក្ខុត្រូវអាបត្តិដោយវាចារបស់ខ្លួន១ ដោយកាយ១ ដេកលក់ត្រូវអាបត្តិ១ មិនមានចិត្តក្លែងត្រូវអាបត្តិ១ ត្រូវអាបត្តិកំពុងសំដែងអាបត្តិ១ ត្រូវអាបត្តិដោយកម្ម១ អនរិយវោហារមាន៤យ៉ាង១ អរិយវោហារមាន៤យ៉ាងដូចគ្នា១ បារាជិក៤របស់ភិក្ខុទៅទាំងពួកភិក្ខុ ទាំងពួកភិក្ខុនី១ ភិក្ខុគួររក្សាបរិក្ខារទុក១ នៅក្នុងទីចំពោះមុខ ត្រូវអាបត្តិ១ ភិក្ខុមិនដឹង ត្រូវអាបត្តិ១ ត្រូវអាបត្តិដោយកាយ១ ត្រូវអាបត្តិក្នុងកណ្តាលជំនុំសង្ឃ១ ចេញចាកអាបត្តិដោយអាការ៤យ៉ាង មាន២លើក១ លះបង់បុរិមភេទ ព្រមទាំងការបានភេទថ្មី១ ការចោទ១ បរិវាស១ ភិក្ខុប្រព្រឹត្តមានត្ត១ គ្រឿងអាង១ គ្រឿងបរិភោគដែលភិក្ខុទទួលប្រគេន១ ថ្នាំមហាវិកដ៍១ កម្ម៤យ៉ាងដទៃទៀត១ វិបត្តិ១ អធិករណ៍១ បុគ្គលអ្នកញុំាងបរិសទ្យឲ្យអាក្រក់១ ភិក្ខុញុំាងបរិសទ្យឲ្យល្អ១ អាគន្តុកភិក្ខុត្រូវអាបត្តិ១ គមិកភិក្ខុត្រូវអាបត្តិ១ សភាវៈផ្សេងគ្នាដោយវត្ថុ១ សភាវៈស្មើគ្នាដោយវត្ថុ១ ឧបជ្ឈាយ៍ត្រូវអាបត្តិ១ អាចារ្យត្រូវអាបត្តិ១ ហេតុនៃការដាច់វស្សា តែមិនត្រូវអាបត្តិ១ ទុច្ចរិត១ សុចរិត១ ភិក្ខុកាន់យកទ្រព្យគេ ត្រូវអាបត្តិ១ បុគ្គលគួរដល់ការអភិវាទ១ បុគ្គលគួរដល់អាសនៈ១ វត្ថុដែលភិក្ខុទទួលប្រគេន គួរក្នុងកាល១ ភិក្ខុត្រូវអាបត្តិតែក្នុងបច្ចន្តិមជនបទ១ វត្ថុដែលគួរតែក្នុងបច្ចន្តិមជនបទ១ ត្រូវអាបត្តិតែក្នុងខាងក្នុង១ ត្រូវអាបត្តិតែក្នុងសីមា១ ត្រូវអាបត្តិតែក្នុងស្រុក១ ការចោទ១ បុព្វកិច្ច១ កម្មមានកាលដ៏គួរ១ អនញ្ញាបាចិត្តិយៈ១ សម្មតិ១ អគតិ១ មិនគួរដល់នូវអគតិ១ អលជ្ជីភិក្ខុ១ ភិក្ខុមានសីលជាទីស្រឡាញ់១ ភិក្ខុមិនគួរសួរវិន័យចំពោះភិក្ខុ២ពួក១ មិនគួរដោះ

ស្រាយវិន័យ ចំពោះភិក្ខុ២ពួកដូចគ្នា១ ភិក្ខុមិនត្រូវឲ្យការសាកសួរ១ មិនត្រូវសាកច្ឆា១ ភិក្ខុឈឺត្រូវអាបត្តិ១ ការបញ្ឈប់បាតិមោក្ខ១។

## (បញ្ចកវារៈ ទី៥)

CS vin.pv.05.05 | ភាគ ទី១៣

### (៥. បញ្ចកវារោ)

[៦២] អាបត្តិមាន៥យ៉ាង។ កងនៃអាបត្តិមាន៥យ៉ាង។ វិនីតវត្ថុ (វត្ថុដែលព្រះមានព្រះភាគបានជម្រះហើយ) មាន៥យ៉ាង។ អនន្តរិកកម្ម (កម្មដែលឲ្យផលក្នុងអត្តភាពជាបន្ទាប់) មាន៥យ៉ាង។ និយតបុគ្គល (បុគ្គលដែលទៀត) មាន៥ពួក។ ឆេទនកាបត្តិ (អាបត្តិដែលមានការកាត់ជាវិនយកម្ម) មាន៥យ៉ាង។ ភិក្ខុត្រូវអាបត្តិដោយអាការ៥យ៉ាង។ អាបត្តិ៥យ៉ាង មានមុសាវាទជាបច្ច័យ។ ភិក្ខុមិនគួរដល់សង្ឃកម្មដោយអាការ៥យ៉ាង គឺមិនធ្វើកម្មដោយខ្លួនឯង១ មិនអារាធនាភិក្ខុឯទៀត១ មិនឲ្យឆន្ទៈ១ មិនឲ្យបារិសុទ្ធិ១ ហាមឃាត់កម្មដែលសង្ឃកំពុងធ្វើ ឬមានសេចក្តីយល់ឃើញថា មិនត្រូវតាមធម៌ក្នុងកម្មដែលសង្ឃបានធ្វើរួចហើយ១។ ភិក្ខុគួរដល់កម្មដោយអាការ៥យ៉ាង គឺភិក្ខុធ្វើកម្មដោយខ្លួនឯង១ អារាធនាភិក្ខុឯទៀត១ ឲ្យឆន្ទៈ១ ឲ្យបារិសុទ្ធិ១ មិនហាមឃាត់កម្មដែលសង្ឃកំពុងធ្វើ ឬមានសេចក្តីយល់ឃើញថា ត្រូវតាមធម៌ក្នុងកម្មដែលសង្ឃបានធ្វើរួចហើយ១។ ធម៌៥យ៉ាង តែងសម្រេចដល់ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ គឺត្រាច់ទៅក្នុងត្រកូល ដោយមិនបាច់លាភិក្ខុផងគ្នា១ ឆាន់គណភោជនបាន១ ឆាន់បរម្បរភោជនបាន១ មិនអធិដ្ឋានចីវរក៏បាន១ មិនវិកប្បចីវរក៏បាន១។ ភិក្ខុដែលប្រកបដោយអង្គ៥ ទុកជាភិក្ខុបាប ឬជាភិក្ខុមានធម៌មិនបានកម្រើក ក៏គួរឲ្យគេរង្កៀសសង្ស័យបាន គឺការត្រាច់ទៅក្នុងលំនៅស្រីផ្កាមាស១ ការត្រាច់ទៅក្នុងលំនៅស្រីមេម៉ាយ១ ការត្រាច់ទៅក្នុងលំនៅស្រីក្រមុំចាស់១ ការត្រាច់ទៅក្នុងលំនៅមនុស្សខ្ទើយ១ ការត្រាច់ទៅក្នុងលំនៅភិក្ខុនី១។ ប្រេងមាន៥យ៉ាង គឺប្រេងល្ង១ ប្រេងស្ពៃ១ ប្រេងស្រគំ១ ប្រេងល្ហុងខ្វង១ ប្រេងខ្លាញ់១។ ខ្លាញ់មាន៥យ៉ាងគឺ ខ្លាញ់ខ្លាឃ្មុំ១ ខ្លាញ់ត្រី១ ខ្លាញ់ឆ្លាម១ ខ្លាញ់ជ្រូក១ ខ្លាញ់លា១។ សេចក្តីវិនាស៥យ៉ាងគឺ វិនាសញាតិ១ វិនាសភោគៈ១ វិនាសព្រោះរោគ១ វិនាសសីល១ វិនាសព្រោះទិដ្ឋិ១។ សេចក្តីបរិបូណ៌មាន៥យ៉ាង គឺបរិបូណ៌ដោយញាតិ១ បរិបូណ៌ដោយភោគៈ១ បរិបូណ៌ដោយសេចក្តីមិនមានរោគ១ បរិបូណ៌ដោយសីល១ បរិបូណ៌ដោយទិដ្ឋិ១។ ការរម្ងាប់និស្ស័យចាកឧបជ្ឈាយ៍មាន៥យ៉ាង គឺឧបជ្ឈាយ៍ចៀសចេញទៅ១ សឹកចេញទៅ១ ស្លាប់ទៅ១ ទៅចូលពួក (តិរ្ថិយ)១ ឧបជ្ឈាយ៍បណ្តេញចាកនិស្ស័យ១ ជាគំរប់៥។ បុគ្គលដែលមិនគួរឲ្យឧបសម្បទា មាន៥ពួក គឺបុគ្គលខ្វះខាតកាល (មានឆ្នាំមិនគ្រប់ម្ភៃ)១ បុគ្គលខ្វះខាតអវយវៈ (មានដាច់ដៃជាដើម)១ បុគ្គលជាវត្ថុវិបត្តិ (មានខ្ទើយជាដើម)១ បុគ្គលធ្វើអំពើអាក្រក់ បានដល់អភព្វបុគ្គល៨យ៉ាង (មានថេយ្យសំវាសជាដើម)១ បុគ្គលមានបាត្រ និងចីវរមិនគ្រប់១។ សំពត់បំសុកូល មាន៥យ៉ាង គឺសំពត់ដែលធ្លាក់ចុះក្នុងព្រៃស្មសាន១ សំពត់ដែលធ្លាក់ចុះទៀបរានផ្សារ១ សំពត់ដែលកណ្តុរកាត់១ សំពត់ដែលកណ្តៀរកោរ១ សំពត់ដែលភ្លើងឆេះ១។ សំពត់បំសុកូលមាន៥យ៉ាងដទៃទៀតគឺ សំពត់ដែលគោទំពាស៊ី១ សំពត់ដែលពពែទំពាស៊ី១ សំពត់ដែលគេរុំដំបូកធ្វើពលិកម្ម១ សំពត់ដែលគេចោលត្រង់កន្លែងអភិសេកស្តេច១ សំពត់ដែលគេទៅកាន់ព្រៃស្មសាន លុះត្រឡប់មកវិញហើយ គេផ្លាស់ចោល១។ ការលួចមាន៥យ៉ាងគឺ លួចដោយបញ្ឆោត១ លួចដោយកំហែង១ លួចដោយកំណត់ទ្រព្យ និងទីកន្លែង១ លួចដោយបំបិទបំបាំង១ លួចដោយផ្លាស់ប្តូរស្លាក១។ មហាចោរ៥ពួក រមែងមាននៅក្នុងលោក។ វត្ថុដែលភិក្ខុមិនគួរលះបង់មាន៥ពួក។ វត្ថុដែលភិក្ខុមិនគួរចែក មាន៥ពួក។ អាបត្តិ៥យ៉ាង តាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចា និងចិត្ត។ អាបត្តិ៥យ៉ាង តាំងឡើងអំពីកាយ និងវាចា មិនបានតាំងឡើងអំពីចិត្ត។ អាបត្តិ៥កង ជាទេសនាគាមិនី។ សង្ឃមាន៥ពួក។ បាតិមោក្ខុទ្ទេសមាន៥យ៉ាង។ គណសង្ឃមានវិនយធរជាគំរប់៥ គួរឲ្យឧបសម្បទាក្នុងបច្ចន្តិមជនបទទាំងពួង។ អានិសង្សក្នុងការក្រាលកឋិន មាន៥យ៉ាង។ កម្មមាន៥យ៉ាង។ អាបត្តិ៥យ៉ាង ត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្ម ជាគំរប់៣ដងចប់។ ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិបារាជិក។ ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិថុល្លច្ច័យ។ ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យដោយអាការ៥យ៉ាង ត្រូវអាបត្តិទុក្កដ។ របស់ដែលជាអកប្បិយៈ មាន៥យ៉ាង ភិក្ខុមិនគួរឆាន់ គឺរបស់ដែលគេមិនបានឲ្យ១ របស់ដែលភិក្ខុមិនស្គាល់ជាក់លាក់១ របស់ដែលមិនគួរ១ របស់ដែលមិនបានទទួលប្រគេន១ របស់ដែលភិក្ខុមិនបានធ្វើវិនយកម្ម១។ របស់ដែលជាកប្បិយៈ មាន៥យ៉ាង ភិក្ខុគួរឆាន់ គឺរបស់ដែលគេបានឲ្យ១ របស់ដែលភិក្ខុស្គាល់ជាក់លាក់១ របស់ដែលគួរ១ របស់ដែលបានទទួលប្រគេន១ របស់ដែលភិក្ខុបានធ្វើវិនយកម្ម១។ ទាន៥យ៉ាង មិនមែនជាបុណ្យទេ តែសត្វលោកសន្មតថាជាបុណ្យ គឺឲ្យទឹកស្រវឹង១ ឲ្យមហោស្រព១ ឲ្យស្រី (ដល់បុរស)១ ឲ្យគោឈ្មោល (ដល់គោញី)១ ឲ្យរូបគំនូរ (ដែលប្រកបដោយមេថុន)១។ សភាវៈ៥យ៉ាង ដែលកើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបានគឺ រាគៈកើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន១ ទោសៈកើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន១ មោហៈកើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន១ បដិភាណ (សេចក្តីឈ្លាស) កើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន១ ចិត្តរបស់បុគ្គលដែលប្រាថ្នានឹងដើរចេញទៅ កើតឡើងហើយ មិនងាយនឹងបន្ទោបង់ចេញបាន១។ អានិសង្សការបោសមាន៥យ៉ាង គឺចិត្តរបស់ខ្លួនក៏ជ្រះថ្លា១ ចិត្តរបស់អ្នកដទៃក៏ជ្រះថ្លា១ ពួកទេវតាតែងពេញចិត្ត១ អ្នកបោសរមែងសន្សំនូវការដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីជ្រះថ្លា១ លុះដល់បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ ក៏រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក១។ អានិសង្សការបោសមាន៥យ៉ាងដទៃទៀត គឺចិត្តរបស់ខ្លួនជ្រះថ្លា១ ចិត្តរបស់អ្នកដទៃក៏ជ្រះថ្លា១ ពួកទេវតាតែងពេញចិត្ត១ ឈ្មោះថាធ្វើតាមសាសនារបស់ព្រះសាស្តា១ ប្រជុំជនជាខាងក្រោយនឹងយកតម្រាប់តាម១។

[៦៣] វិន័យធរដែលប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនរៀនទីកំណត់ភាសារបស់ខ្លួន១ មិនរៀនទីកំណត់ភាសារបស់ជនដទៃ១ លុះមិនរៀនទីកំណត់ភាសារបស់ខ្លួនហើយ ក៏កាត់សេចក្តីដោយមិនត្រូវតាមធម៌១ លុះមិនរៀនទីកំណត់ភាសារបស់ជនដទៃហើយ ក៏កាត់សេចក្តីដោយមិនត្រូវតាមធម៌១ កាត់សេចក្តីមិនត្រូវតាមពាក្យប្តេជ្ញា១។ វិនយធរ ដែលប្រកបដោយអង្គ៥ ដល់នូវការរាប់ថា ជាបណ្ឌិត គឺរៀនទីកំណត់ភាសារបស់ខ្លួន១ រៀនទីកំណត់ភាសារបស់ជនដទៃ១ លុះរៀនទីកំណត់ភាសារបស់ខ្លួនហើយ ទើបកាត់សេចក្តីដោយត្រូវតាមធម៌១ លុះរៀនទីកំណត់ភាសារបស់ជនដទៃហើយ ទើបកាត់សេចក្តីដោយត្រូវតាមធម៌១ កាត់សេចក្តីត្រូវតាមពាក្យប្តេជ្ញា១។ វិនយធរប្រកបដោយអង្គ៥ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិ១ មិនស្គាល់មូលរបស់អាបត្តិ១ មិនស្គាល់ហេតុដែលកើតអាបត្តិ១ មិនស្គាល់សេចក្តីរលត់អាបត្តិ១ មិនស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អាបត្តិ១។ វិនយធរប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជា

បណ្ឌិត គឺស្គាល់អាបត្តិ១ ស្គាល់មូលរបស់អាបត្តិ១ ស្គាល់ហេតុដែលកើតអាបត្តិ១ ស្គាល់សេចក្តីរលត់អាបត្តិ១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អាបត្តិ១។ វិនយធរប្រកបដោយអង្គ៥ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អធិករណ៍១ មិនស្គាល់មូលរបស់អធិករណ៍១ មិនស្គាល់ហេតុដែលកើតអធិករណ៍១ មិនស្គាល់សេចក្តីរលត់អធិករណ៍១ មិនស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អធិករណ៍១។ វិនយធរប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អធិករណ៍១ ស្គាល់មូលរបស់អធិករណ៍១ ស្គាល់ហេតុដែលកើតអធិករណ៍១ ស្គាល់សេចក្តីរលត់អធិករណ៍១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អធិករណ៍១។ វិនយធរប្រកបដោយអង្គ៥ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់វត្ថុ១ មិនស្គាល់និទាន១ មិនស្គាល់បញ្ញត្តិ១ មិនស្គាល់អនុប្បញ្ញត្តិ១ មិនស្គាល់គន្លងនៃពាក្យដែលតគ្នា១។ វិនយធរដែលប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់វត្ថុ១ ស្គាល់និទាន១ ស្គាល់បញ្ញត្តិ១ ស្គាល់អនុប្បញ្ញត្តិ១ ស្គាល់គន្លងនៃពាក្យដែលតគ្នា១។ វិនយធរដែលប្រកបដោយអង្គ៥ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់ញត្តិ១ មិនស្គាល់កិរិយាធ្វើញត្តិ១ មិនឈ្លាសក្នុងកិច្ចខាងដើម១ មិនឈ្លាសក្នុងកិច្ចខាងចុង១ មិនស្គាល់កាលគួរ១។ វិនយធរដែលប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់ញត្តិ១ ស្គាល់កិរិយាធ្វើញត្តិ១ ឈ្លាសក្នុងកិច្ចខាងដើម១ ឈ្លាសក្នុងកិច្ចខាងចុង១ ស្គាល់កាលគួរ១។ វិនយធរដែលប្រកបដោយអង្គ៥ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ វិន័យធរនោះ មិនរៀនតំណអាចារ្យ ហើយនិងមិនយកចិត្តទុកដាក់ មិនពិចារណាដោយល្អ១។ វិនយធរដែលប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ វិន័យធរនោះ បានរៀនតំណអាចារ្យ ហើយនិងយកចិត្តទុកដាក់ពិចារណាដោយល្អ១។ វិនយធរដែលប្រកបដោយអង្គ៥ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ វិន័យធរនោះ មិនបានចេះចាំបាតិមោក្ខទាំងពីរយ៉ាងដោយពិស្តារ មិនចេះចែកបទភាជនៈដោយប្រពៃ មិនបានចាំស្ទាត់រត់មាត់ដោយប្រពៃ មិនចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈ គឺខន្ធកៈ និងបរិវារៈ តាមអនុព្យញ្ជន គឺអក្ខរៈ និងបទ១។ វិនយធរដែលប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ វិន័យធរនោះ បានចេះចាំបាតិមោក្ខទាំងពីរយ៉ាងដោយពិស្តារ ចេះចែកបទភាជនៈដោយប្រពៃ បានចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈ តាមអនុព្យញ្ជន១។ វិនយធរដែលប្រកបដោយអង្គ៥ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ ជាអ្នកមិនឈ្លាសក្នុងការកាត់សេចក្តីក្នុងអធិករណ៍១។ វិនយធរដែលប្រកបដោយអង្គ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ ជាអ្នកឈ្លាសក្នុងការកាត់សេចក្តីក្នុងអធិករណ៍១។

[៦៤] ភិក្ខុអ្នកប្រព្រឹត្តអារញ្ញកធុតង្គ (ភិក្ខុអ្នកនៅក្នុងព្រៃជាវត្ត) មាន៥ពួក គឺភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ ដោយសេចក្តីល្ងង់ សេចក្តីវង្វេង១ ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ មានសេចក្តីប្រាថ្នាលាមកជ្រុលជ្រប់ ដោយសេចក្តីប្រាថ្នា១ ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ ព្រោះសេចក្តីឆ្កួត និងអណ្តែតអណ្តូងចិត្ត១ ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គដោយគិតថា ភិក្ខុអ្នកប្រព្រឹត្តអារញ្ញកធុតង្គ ព្រះពុទ្ធ និងពុទ្ធសាវ័កតែងសរសើរ១ ម្យ៉ាងទៀត ភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិចផង អាស្រ័យសេចក្តីសន្តោសផង អាស្រ័យការដុសខាត់ចិត្តផង អាស្រ័យសេចក្តីស្ងាត់កាយ ស្ងាត់ចិត្តផង អាស្រ័យសេចក្តីប្រតិបត្តិ ដែលមានប្រយោជន៍ផង១។ ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គមាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តបំសុកូលិកធុតង្គមាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តរុក្ខមូលិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តសោសានិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តអព្ភោកាសិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តតេចីវរិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តសបទានចារិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តយថាសន្ថតិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តឯកាសនិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គ មាន៥ពួក។ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកធុតង្គ មាន៥ពួក គឺភិក្ខុអ្នកប្រព្រឹត្តបិណ្ឌិកធុតង្គ ដោយសេចក្តីល្ងង់ សេចក្តីវង្វេង១ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកធុតង្គ មានសេចក្តីប្រាថ្នាលាមកជ្រុលជ្រប់ ដោយសេចក្តីប្រាថ្នា១ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកធុតង្គ ព្រោះសេចក្តីឆ្កួត សេចក្តីអណ្តែតអណ្តូងចិត្ត១ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកធុតង្គដោយគិតថា ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកធុតង្គ ព្រះពុទ្ធ និងពុទ្ធសាវ័ក តែងសរសើរ១ ម្យ៉ាងទៀត ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកធុតង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិចផង អាស្រ័យសេចក្តីសន្តោសផង អាស្រ័យការដុសខាត់ចិត្តផង អាស្រ័យសេចក្តីស្ងាត់កាយ ស្ងាត់ចិត្តផង អាស្រ័យសេចក្តីប្រតិបត្តិ ដែលមានប្រយោជន៍ផង១។

[៦៥] ភិក្ខុដែលប្រកបដោយអង្គ៥ មិនត្រូវនៅដោយឥតនិស្ស័យទេ គឺ ភិក្ខុមិនស្គាល់ឧបោសថ (ថ្ងៃឧបោសថ)១ មិនស្គាល់ឧបោសថកម្ម១ មិនចេះបាតិមោក្ខ១ មិនចេះឧទ្ទេសរបស់បាតិមោក្ខ១ មានវស្សាមិនគ្រប់ប្រាំ១។ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺ ភិក្ខុស្គាល់ឧបោសថ១ ស្គាល់ឧបោសថកម្ម១ ចេះបាតិមោក្ខ១ ចេះឧទ្ទេសរបស់បាតិមោក្ខ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ១។ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនៅដោយឥតនិស្ស័យដែរ គឺ ភិក្ខុមិនស្គាល់បវារណា (ថ្ងៃបវារណា)១ មិនស្គាល់បវារណាកម្ម១ មិនចេះបាតិមោក្ខ១ មិនចេះឧទ្ទេសរបស់បាតិមោក្ខ១ មានវស្សាមិនគ្រប់ប្រាំ១។ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺ ភិក្ខុស្គាល់បវារណា១ ស្គាល់បវារណាកម្ម១ ចេះបាតិមោក្ខ១ ចេះឧទ្ទេសរបស់បាតិមោក្ខ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ១។ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនៅដោយឥតនិស្ស័យដែរ គឺ ភិក្ខុមិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មានវស្សាមិនគ្រប់ប្រាំ១។ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺ ភិក្ខុស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ១។ ភិក្ខុនីដែលប្រកបដោយអង្គ៥ មិនត្រូវនៅដោយឥតនិស្ស័យទេ គឺភិក្ខុនីមិនស្គាល់ឧបោសថ១ មិនស្គាល់ឧបោសថកម្ម១ មិនចេះបាតិមោក្ខ១ មិនចេះឧទ្ទេសរបស់បាតិមោក្ខ១ មានវស្សាមិនគ្រប់ប្រាំ១។ ភិក្ខុនីដែលប្រកបដោយអង្គ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺ ភិក្ខុនីស្គាល់ឧបោសថ១ ស្គាល់ឧបោសថកម្ម១ ចេះបាតិមោក្ខ១ ចេះឧទ្ទេសរបស់បាតិមោក្ខ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ១។ ភិក្ខុនីដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនៅដោយឥតនិស្ស័យដែរ គឺ ភិក្ខុនីមិនស្គាល់បវារណា១ មិនស្គាល់បវារណាកម្ម១ មិនចេះបាតិមោក្ខ១ មិនចេះឧទ្ទេស

របស់បាតិមោក្ខ១ មានវស្សាមិនគ្រប់ប្រាំ១។ ភិក្ខុនីដែលប្រកបដោយអង្គ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺ ភិក្ខុនីស្គាល់បវារណា១ ស្គាល់បវារណាកម្ម១ ចេះបាតិមោក្ខ១ ចេះឧទ្ទេសរបស់បាតិមោក្ខ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ១។ ភិក្ខុនីដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនៅដោយឥតនិស្ស័យដែរ គឺ ភិក្ខុនីមិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មានវស្សាមិនគ្រប់ប្រាំ១។ ភិក្ខុនីដែលប្រកបដោយអង្គ៥ ទើបគួរនៅដោយឥតនិស្ស័យបាន គឺ ភិក្ខុនីស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មានវស្សាគ្រប់ប្រាំ ឬមានវស្សាលើសអំពីប្រាំឡើងទៅ១។

[៦៦] អំពើមិនជាទីញុំាងសេចក្តីជ្រះថ្លាឲ្យកើត រមែងមានទោស៥យ៉ាង គឺខ្លួនឯងតិះដៀលខ្លួនឯង១ អ្នកប្រាជ្ញសង្កេតមើលហើយ តែងតិះដៀល១ កិត្តិស័ព្ទអាក្រក់ រមែងផ្សាយទៅ១ បុគ្គលនោះមានសេចក្តីវង្វេង ធ្វើមរណកាល១ លុះរំលាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក១។ អំពើដែលញុំាងសេចក្តីជ្រះថ្លាឲ្យកើត រមែងមានអានិសង្ស៥គឺ ខ្លួនឯងតិះដៀលខ្លួនឯងមិនបាន១ អ្នកប្រាជ្ញសង្កេតមើលហើយ តែងសរសើរ១ កិត្តិស័ព្ទល្អ រមែងផ្សាយទៅ១ បុគ្គលនោះ មិនមានសេចក្តីវង្វេង ធ្វើមរណកាល១ លុះរំលាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក១។ អំពើមិនជាទីញុំាងសេចក្តីជ្រះថ្លាឲ្យកើត រមែងមានទោស៥យ៉ាងដទៃទៀត គឺពួកជនដែលមិនទាន់ជ្រះថ្លា ក៏ខានជ្រះថ្លា១ ជនពួកខ្លះ ដែលជ្រះថ្លាស្រាប់ហើយ ក៏បែរជាបាត់ជ្រះថ្លាទៅវិញ១ ឈ្មោះថាមិនធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្តា១ ប្រជុំជនជាខាងក្រោយ រមែងយកតម្រាប់តាម១ ចិត្តរបស់បុគ្គលនោះក៏មិនជ្រះថ្លា១។ អំពើដែលញុំាងសេចក្តីជ្រះថ្លាឲ្យកើត រមែងមានអានិសង្ស៥យ៉ាង គឺពួកជនដែលមិនទាន់ជ្រះថ្លា ក៏ជ្រះថ្លាឡើង១ ជនពួក ដែលជ្រះថ្លាស្រាប់ហើយ ក៏រឹងរឹតតែជ្រះថ្លាឡើង១ ឈ្មោះថាធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្តា១ ប្រជុំជនជាខាងក្រោយ រមែងយកតម្រាប់តាម១ ចិត្តរបស់បុគ្គលនោះក៏ជ្រះថ្លា១។ ភិក្ខុអ្នកទៅកាន់ត្រកូល រមែងមានទោស៥យ៉ាង គឺត្រូវអាបត្តិព្រោះមិនបានប្រាប់ភិក្ខុដែលមាននៅក្នុងអាវាសហើយត្រេចទៅ១ ត្រូវអាបត្តិព្រោះអង្គុយក្នុងទីស្ងាត់១ ត្រូវអាបត្តិក្នុងអាសនៈដែលកំបាំង១ សំដែងធម៌ដល់មាតុគ្រាមលើសជាងប្រាំ ប្រាំមួយម៉ាត់ឡើងទៅ ត្រូវអាបត្តិ១ មានសេចក្តីត្រិះរិះជាច្រើន ក្នុងកាមគុណ១។ ភិក្ខុអ្នកចូលទៅកាន់ត្រកូល នៅច្រឡូកច្រឡំក្នុងត្រកូលហួសវេលា រមែងមានទោស៥យ៉ាង គឺក្រឡេកមើលមាតុគ្រាមរឿយៗ កាលបើមើលហើយ និងមានសេចក្តីជាប់ជំពាក់១ កាលបើមានសេចក្តីជាប់ជំពាក់ហើយ នឹងកើតសេចក្តីស្និទ្ធស្នាល១ កាលបើមានសេចក្តីស្និទ្ធស្នាលហើយ នឹងកើតមានរាគៈ គ្របសង្កត់ចិត្ត១ ទោសជាតនេះតែងកើតមាន ចំពោះតែភិក្ខុដែលមានចិត្ត ត្រូវរាគៈគ្របសង្កត់ហើយ គឺភិក្ខុនោះនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ទាំងសេចក្តីអផ្សុក ឬនឹងត្រូវអាបត្តិដែលសៅហ្មងឯណានីមួយ ឬនឹងពោលលាសិក្ខាត្រឡប់មកកាន់ភេទគ្រហស្ថវិញ១។

[៦៧] ពូជមាន៥យ៉ាង គឺពូជឫស ឬមើម១ ពូជដើម១ ពូជថ្នាំង១ ពូជត្រួយ ឬចុង១ រួមពូជគ្រាប់១ផង ជាគំរប់៥។ ផ្លែឈើដែលភិក្ខុគួរឆាន់បានដោយសមណកប្បមាន៥យ៉ាង គឺផ្លែឈើ ដែលគេសម្រេចដោយភ្លើង១ គេសម្រេចដោយសស្ត្រា១ គេសម្រេចដោយក្រចក១ ផ្លែឈើដែលគ្មានគ្រាប់១ ផ្លែឈើដែលគេយកគ្រាប់ចេញ១ ជាគំរប់៥។

[៦៨] វិសុទ្ធិមាន៥ គឺសំដែងនូវនិទាន ហើយសូត្រឧទ្ទេស ដែលសល់អំពីនិទាននោះ ដោយសុតបទ នេះជាវិសុទ្ធិទី១ សំដែងនូវនិទាន រួចសំដែងនូវបារាជិកទាំង៤ ហើយសូត្រនូវឧទ្ទេស ដែលសល់អំពីបារាជិកនោះ ដោយសុតបទ នេះជាវិសុទ្ធិទី២ សំដែងនូវនិទាន ហើយសំដែងនូវបារាជិកទាំង៤ រួចសំដែងនូវសង្ឃាទិសេសទាំង១៣ ហើយសូត្រនូវឧទ្ទេស ដែលសល់អំពីសង្ឃាទិសេសនោះ ដោយសុតបទ នេះជាវិសុទ្ធិទី៣ សំដែងនូវនិទាន ហើយសំដែងនូវបារាជិកទាំង៤ សំដែងនូវសង្ឃាទិសេសទាំង១៣ រួចសំដែងអនិយ័តទាំង២ ហើយសូត្រនូវឧទ្ទេស ដែលសល់អំពីអនិយ័តនោះ ដោយសុតបទ នេះជាវិសុទ្ធិទី៤។ (ការសំដែង) ដោយពិស្តារ ចាត់ជាវិសុទ្ធិទី៥។ វិសុទ្ធិ៥យ៉ាងដទៃទៀត គឺឧបោសថ ដែលភិក្ខុធ្វើដោយសំដែងបាតិមោក្ខ១ ឧបោសថដែលភិក្ខុធ្វើដោយប្រាប់បារិសុទ្ធិ១ ឧបោសថដែលភិក្ខុធ្វើដោយអធិដ្ឋាន១ ឧបោសថដែលភិក្ខុធ្វើដោយសេចក្តីព្រមព្រៀងគ្នា១ បវារណា១ ជាគំរប់៥។

[៦៩] ភិក្ខុអ្នកទ្រទ្រង់វិន័យ តែងបានអានិសង្ស៥ប្រការ គឺសីលក្ខន្ធរបស់ខ្លួន ឈ្មោះថា ភិក្ខុនោះបានគ្រប់គ្រងរក្សាដោយល្អ១ ភិក្ខុនោះតែងជាទីពឹងនៃពួកភិក្ខុដែលមានសេចក្តីសង្ស័យជាប្រក្រតី១ ភិក្ខុនោះ ជាអ្នកក្លៀវក្លា និយាយក្នុងកណ្តាលជំនុំសង្ឃ១ ភិក្ខុនោះ រមែងសង្កត់សង្កិនដោយល្អ នូវពួកសត្រូវដោយសហធម៌ គឺសិក្ខាបទដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុក១ ភិក្ខុនោះ ឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីញុំាងព្រះសទ្ធម្មឲ្យតាំងនៅមាំ១។ ការបញ្ឈប់បាតិមោក្ខ ដែលមិនប្រកបដោយធម៌ មាន៥ប្រការ។ ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ មាន៥ប្រការ។

ចប់ បញ្ចកៈ (ពួក៥ៗ)។

ឧទ្ទាន គឺបញ្ជីរឿង នៃបញ្ចកៈ (ពួកប្រាំៗ) នោះដូច្នេះ

[៧០]

និយាយអំពីអាបត្តិ១ កងនៃអាបត្តិ១ វិនីតវត្ថុ១ អានន្តរិកកម្ម១ និយតបុគ្គល១ អាបត្តិមានកិរិយាកាត់ជាវិនយកម្ម១ ភិក្ខុត្រូវអាបត្តិ១ អាបត្តិមានមុសាវាទ ជាបច្ច័យ១ ភិក្ខុមិនគួរដល់កម្ម១ ភិក្ខុដែលគួរដល់កម្ម១ ធម៌៥យ៉ាង តែងសម្រេចដល់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត១ ភិក្ខុដែលគួរឲ្យគេរង្កៀសសង្ស័យ១ ប្រេង១ ខ្លាញ់១ សេចក្តីវិនាស១ សម្បទា១ រម្ងាប់ចាកនិស្ស័យ១ បុគ្គល១ សំពត់បំសុកូលឈ្មោះសោសានិក១ សំពត់បំសុកូលឈ្មោះគោខាយិត១ ការលួច១ មហាចោរ១ វត្ថុដែលភិក្ខុមិនគួរលះបង់១ វត្ថុដែលភិក្ខុមិនគួរចែក១ អាបត្តិតាំងឡើងអំពីកាយ១ អាបត្តិតាំងឡើងអំពីកាយ និងវាចា១ អាបត្តិជាទេសនាគាមិនី១ សង្ឃ១ ឧទ្ទេសរបស់បាតិមោក្ខ១ ឲ្យឧបសម្បទា ក្នុងបច្ចន្តប្រទេស១ អានិសង្សកឋិន១ សង្ឃកម្ម១ អាបត្តិជាយាវតតិយកា១ លួច ត្រូវអាបត្តិបារាជិក១ លួច ត្រូវអាបត្តិថុល្លច្ច័យ១ លួច ត្រូវអាបត្តិទុក្កដ១ វត្ថុមិនគួរឆាន់១ វត្ថុគួរឆាន់១ ទានមិនមែនជាបុណ្យ១ ធម៌មិនងាយនឹងបន្ទោបង់បាន១ អានិសង្សបោស១ អានិសង្សបោសដទៃទៀត១ វិន័យធរមិនរៀន និងរៀនទីកំណត់ភាសា១ មិនស្គាល់ និង

ស្គាល់អាបត្តិ១ មិនស្គាល់ និងស្គាល់អធិករណ៍១ មិនស្គាល់ និងស្គាល់វត្ថុ១ មិនស្គាល់ និងស្គាល់ញត្តិ១ មិនស្គាល់ និងស្គាល់អាបត្តិ១ មិនចេះ និងចេះបាតិមោក្ខទាំងពីរ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ជាគំរប់៨ អ្នកទាំងឡាយចូរដឹងនូវធម៌ (ដែលជាអង្គរបស់វិន័យធរ) ទាំង៨នេះ ថាជាធម៌ខ្មៅ និងស (អាក្រក់ និងល្អ ឬមិនចេះ និងចេះ) រឿងភិក្ខុប្រព្រឹត្តអារញ្ញកធុតង្គ១ បិណ្ឌបាតិកធុតង្គ១ បំសុកូលិកធុតង្គ១ រុក្ខមូលិកធុតង្គ១ សោសានិកធុតង្គ១ អព្ភោកាសិកធុតង្គ១ តេចីវរិកធុតង្គ១ សបទានចារិកធុតង្គ១ នេសជ្ជិកធុតង្គ១ យថាសន្ថតិកធុតង្គ១ ខលុបច្ឆាភត្តិកធុតង្គ១ បត្តបិណ្ឌិកធុតង្គ១ ឧបោសថ១ បវារណា១ អាបត្តិ និងអនាបត្តិ១ ធម៌ទាំងនេះ មានចំណែកខ្មៅនិងស (អាក្រក់ និងល្អ) ធម៌ទាំងអម្បាលនោះ មានដល់ភិក្ខុនីដូចជាភិក្ខុដែរ រឿងទោសនៃអំពើមិនជាទីញុំាងសេចក្តីជ្រះថ្លាឲ្យកើត១ អានិសង្សនៃអំពើដែលញុំាងសេចក្តីជ្រះថ្លាឲ្យកើត១ ទោស និងអានិសង្សនៃអំពើទាំងពីរដទៃទៀត១ ធម៌ទាំងនេះមានចំណែកខ្មៅ និងស ដូចគ្នាដែរ រឿងទោសដែលមានក្នុងភិក្ខុអ្នកចូលទៅកាន់ត្រកូល១ ទោសភិក្ខុដែលនៅច្រឡូកច្រឡំក្នុងត្រកូលហួសវេលា១ អំពីពូជ១ ផ្លែឈើដែលភិក្ខុគួរឆាន់បានដោយសមណកប្ប១ វិសុទ្ធិ១ វិសុទ្ធិដទៃទៀត១ អានិសង្សនៃភិក្ខុអ្នកទ្រទ្រង់វិន័យ១ បញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌១ បញ្ឈប់បាតិមោក្ខប្រកបដោយធម៌១ ធម៌ទាំងនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ថាមានចំណែកខ្មៅ និងសដូចគ្នា ចប់បញ្ចកសុទ្ធិ តែប៉ុណ្ណោះ។

## (ឆក្កវារៈ ទី៦)

CS vin.pv.05.06 | ភាគ ទី១៣

### (៦. ឆក្កវារោ)

[៧១] អគារវៈមាន៦យ៉ាង។ គារវៈមាន៦យ៉ាង។ វិនីតវត្ថុមាន៦យ៉ាង។ សិក្ខាបទដែលមានពាក្យថាប្រព្រឹត្តដោយសមគួរមាន៦។ សមុដ្ឋាននៃអាបត្តិមាន៦យ៉ាង។ អាបត្តិដែលមានកិរិយាកាត់ជាវិនយកម្ម មាន៦។ ភិក្ខុត្រូវអាបត្តិដោយអាការ៦យ៉ាង។ ភិក្ខុអ្នកទ្រទ្រង់វិន័យ តែងបានអានិសង្ស៦ប្រការ។ សិក្ខាបទដែលមានទីកំណត់មាន៦។ ភិក្ខុគួរនៅប្រាសចាកត្រៃចីវរបានត្រឹម៦រាត្រី។ ចីវរមាន៦យ៉ាង។ ទឹកជ្រលក់មាន៦យ៉ាង។ អាបត្តិ៦យ៉ាង តាំងឡើងតែអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចា។ អាបត្តិ៦យ៉ាង តាំងឡើងតែអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយ។ អាបត្តិ៦យ៉ាង តាំងឡើងអំពីកាយ វាចា និងចិត្ត។ សង្ឃកម្មមាន៦យ៉ាង។ វិវាទមូល (ដើមហេតុវិវាទ) មាន៦យ៉ាង។ អនុវាទមូល (ដើមហេតុនៃការចោទប្រកាន់) មាន៦យ៉ាង។ សារាណីយធម៌មាន៦យ៉ាង។ បណ្តោយ៦ចំអាម ទទឹង៦ចំអាម ដោយចំអាមព្រះសុគត។ ការរម្ងាប់និស្ស័យចាកអាចារ្យ មាន៦យ៉ាង។ អនុប្បញ្ញត្តិក្នុងនហានសិក្ខាបទមាន៦លើក។ ភិក្ខុកាន់យកចីវរដែលធ្វើមិនទាន់ស្រេចហើយ ចៀសចេញទៅ។ ភិក្ខុប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេច ហើយចៀសចេញទៅ។

[៧២] ភិក្ខុប្រកបដោយអង្គ៦ គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុប្រកបដោយកងសីល ជារបស់អសេក្ខបុគ្គល១ ប្រកបដោយកងសមាធិ ជារបស់អសេក្ខបុគ្គល១ ប្រកបដោយកងបញ្ញា ជារបស់អសេក្ខបុគ្គល១ ប្រកបដោយកងវិមុត្តិ ជារបស់អសេក្ខបុគ្គល១ ប្រកបដោយកងវិមុត្តិញ្ញាណទស្សនៈ (បច្ចវេក្ខណញ្ញាណ) ជារបស់អសេក្ខបុគ្គល១ មានវស្សា១០ ឬមានវស្សាលើសអំពី១០ ឡើងទៅ១។ ភិក្ខុដែលប្រកបដោយអង្គ៦ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺប្រកបដោយកងសីល ជារបស់អសេក្ខបុគ្គល ដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃ (ឲ្យប្រកប) ក្នុងកងសីល ជារបស់អសេក្ខបុគ្គល១ ប្រកបដោយកងសមាធិ ជារបស់អសេក្ខបុគ្គល ដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃ ក្នុងកងសមាធិ ជារបស់អសេក្ខបុគ្គល១ ប្រកបដោយកងបញ្ញា ជារបស់អសេក្ខបុគ្គល ដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃ ក្នុងកងបញ្ញា ជារបស់អសេក្ខបុគ្គល១ ប្រកបដោយកងវិមុត្តិ ជារបស់អសេក្ខបុគ្គល ដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃ ក្នុងកងវិមុត្តិ ជារបស់អសេក្ខបុគ្គល១ ប្រកបដោយកងវិមុត្តិញ្ញាណទស្សនៈ ជារបស់អសេក្ខបុគ្គល ដោយខ្លួនឯង ទាំងដឹកនាំអ្នកដទៃក្នុងកងវិមុត្តិញ្ញាណទស្សនៈ ជារបស់អសេក្ខបុគ្គល១ មានវស្សា១០ ឬមានវស្សាលើសអំពី១០ ឡើងទៅ១។ ភិក្ខុដែលប្រកបដោយអង្គ៦ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺជាភិក្ខុមានសេចក្តីជឿត្រូវ១ មានសេចក្តីខ្មាសបាប១ មានសេចក្តីក្រែងខ្លាចបាប១ ប្រារព្ធសេចក្តីព្យាយាម១ មានសតិខ្ជាប់ខ្ជួន១ មានវស្សា១០ ឬមានវស្សាលើសអំពី១០ ឡើងទៅ១។ ភិក្ខុដែលប្រកបដោយអង្គ៦ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុមិនវិបត្តិចាកសីលក្នុងអធិសីល១ មិនវិបត្តិចាកមារយាទ ក្នុងអជ្ឈាចារៈ១ មិនវិបត្តិចាកទិដ្ឋិក្នុងអតិទិដ្ឋិ១ ជាអ្នកចេះដឹងច្រើន១ មានប្រាជ្ញា១ មានវស្សា១០ ឬមានវស្សាលើសអំពី១០ឡើងទៅ១។ ភិក្ខុដែលប្រកបដោយអង្គ៦ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុជាអ្នកអាចនឹងបម្រើ ឬប្រើគេឲ្យបម្រើនូវអន្តេវាសិកក្តី សទ្ធិវិហារិកក្តី ដែលមានជម្ងឺ១ អាចនឹងបំបាត់ ឬប្រើគេឲ្យបំបាត់នូវសេចក្តីអផ្សុកដែលកើតឡើង១ អាចនឹងបន្ទោបង់ ឬប្រើគេឲ្យបន្ទោបង់ តាមធម៌ នូវសេចក្តីសង្ស័យដែលកើតឡើង១ ស្គាល់អាបត្តិ១ ស្គាល់ការចេញចាកអាបត្តិ១ មានវស្សា១០ ឬមានវស្សាច្រើនជាង១០ឡើងទៅ១។ ភិក្ខុដែលប្រកបដោយអង្គ៦ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុជាអ្នកអាចឲ្យអន្តេវាសិក ឬសទ្ធិវិហារិកសិក្សាក្នុងអភិសមាចារិកាសិក្ខាបាន១ អាចទូន្មានក្នុងអាទិព្រហ្មចរិយកាសិក្ខា១ អាចទូន្មានក្នុងអភិធម៌១ អាចទូន្មានក្នុងអភិវិន័យ១ អាចដោះតាមធម៌ នូវទិដ្ឋិខុសដែលកើតឡើង១ មានវស្សា១០ ឬមានវស្សាច្រើនជាង១០ឡើងទៅ១។ ភិក្ខុដែលប្រកបដោយអង្គ៦ដទៃទៀត ក៏គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួនបាន គឺភិក្ខុស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ភិក្ខុនោះចេះបាតិមោក្ខទាំងពីរដោយពិស្តារ ចេះចែកបទភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ កាត់សេចក្តីដោយប្រពៃ តាមសុត្តៈ គឺខន្ធកៈ និងបរិវារៈ តាមអនុព្យញ្ជនៈ គឺអក្ខរៈ និងបទ១ មានវស្សា១០ ឬមានវស្សាច្រើនជាង១០ឡើងទៅ១។

[៧៣] ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌មាន៦។ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌មាន៦។

ចប់ ឆក្កៈ (ពួកប្រាំមួយៗ)។

ឧទ្ទាន គឺបញ្ជីរឿងនៃឆក្កៈនោះដូច្នោះ

[៧៤]

និយាយអំពីអគារវៈ១ គារវៈ១ វិនីតវត្ថុ១ សិក្ខាបទ ដែលមានពាក្យថាប្រព្រឹត្តដោយសមគួរ១ សមុដ្ឋាននៃអាបត្តិ១ អាបត្តិមានកិរិយាកាត់ជាវិនយកម្ម១ អាការដែលត្រូវអាបត្តិ១ អានិសង្ស១ សិក្ខាបទដែលមានទីកំណត់១ នៅប្រាសចាកត្រៃចីវរ៦រាត្រី១ ចីវរ១ ទឹកជ្រលក់១ អាបត្តិតាំងឡើងតែអំពីកាយ និងចិត្ត១ អាបត្តិតាំងឡើងតែអំពីវាចា និងចិត្ត១ អាបត្តិតាំងឡើងអំពីកាយ និងវាចា និងចិត្ត១ សង្ឃកម្ម១ វិវាទមូល១ អនុវាទមូល១ ប្រមាណបណ្ដោយ និងប្រមាណទទឹង១ ការរម្ងាប់ចាកនិស្ស័យ១ អនុប្បញ្ញត្តិ១ ភិក្ខុកាន់យកចីវរ ដែលធ្វើមិនទាន់ស្រេចហើយចៀសចេញទៅ១ ភិក្ខុប្រមូលយកចីវរដែលធ្វើមិនទាន់ស្រេច ហើយចៀសចេញទៅ១ ភិក្ខុដឹកនាំអ្នកដទៃក្នុងសីល ជារបស់អសេក្ខបុគ្គលជាដើម១ ភិក្ខុមានសេចក្ដីជឿត្រូវ១ ភិក្ខុប្រកបដោយអធិសីល១ ភិក្ខុអាចបម្រើកូនសិស្សដែលមានជម្ងឺបាន១ ភិក្ខុអាចបង្រៀនកូនសិស្ស ក្នុងអភិសមាចារិកាសិក្ខា១ ភិក្ខុស្គាល់អាបត្តិ១ បញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌១ បញ្ឈប់បាតិមោក្ខប្រកបដោយធម៌១។

## (សត្តកវារៈ ទី៧)

CS vin.pv.05.07 | ភាគ ទី១៣

### (៧. សត្តកវារោ)

[៧៥] អាបត្តិមាន៧យ៉ាង។ កងនៃអាបត្តិមាន៧។ វិនីតវត្ថុមាន៧យ៉ាង។ សិក្ខាបទដែលមាន ពាក្យថាប្រព្រឹត្តដោយសមគួរមាន៧។ សមថៈឈ្មោះបដិញ្ញាតករណៈ មិនប្រកបដោយធម៌មាន៧យ៉ាង។ សមថៈឈ្មោះបដិញ្ញាតករណៈ ប្រកបដោយធម៌ មាន៧យ៉ាង។ ភិក្ខុទៅដោយសត្តាហកិច្ចមិនត្រូវអាបត្តិ ព្រោះអាស្រ័យបុគ្គល៧ពួក។ ភិក្ខុអ្នកទ្រទ្រង់វិន័យ តែងបានអានិសង្ស៧យ៉ាង។ សិក្ខាបទដែលមានទីកំណត់មាន៧យ៉ាង។ វត្ថុដែលជានិស្សគ្គិយៈ ក្នុងខណៈអរុណរះឡើង មាន៧យ៉ាង។ សមថៈ មាន៧យ៉ាង។ សង្ឃកម្មមាន៧យ៉ាង។ ស្រូវស្រស់មាន៧ប្រការ។ ខ្នាតទទឹងកុដិ៧ចំអាម (ត្រូវវាស់ខាងក្នុងជញ្ជាំង)។ អនុប្បញ្ញត្តិក្នុងគណភោជនសិក្ខាបទ មាន៧លើក។ ភេសជ្ជៈ (ដែលជាសត្តាហកាលិក) ភិក្ខុត្រូវទទួលសន្សំទុកឆាន់បានតែត្រឹម៧ថ្ងៃ។ ភិក្ខុកាន់យកចីវរ ដែលធ្វើស្រេចហើយ ចៀសចេញទៅ។ ភិក្ខុប្រមូលយកចីវរដែលធ្វើស្រេចហើយ ចៀសចេញទៅ។ អាបត្តិដែលមិនមានដល់ភិក្ខុ បណ្ឌិតគប្បីឃើញ។ អាបត្តិដែលមានដល់ភិក្ខុ ក៏បណ្ឌិតគប្បីឃើញ។ អាបត្តិដែលមានដល់ភិក្ខុ បណ្ឌិតគប្បីរម្ងាប់ចេញ។ ការបញ្ឈប់បាតិមោក្ខ ដែលមិនប្រកបដោយធម៌ មាន៧យ៉ាង។ ការបញ្ឈប់បាតិមោក្ខ ដែលប្រកបដោយធម៌ មាន៧យ៉ាង។

[៧៦] ភិក្ខុដែលប្រកបដោយអង្គ៧ បានឈ្មោះថា ជាវិន័យធរ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ជាអ្នកមានសីល និងសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច ហើយសមាទានសិក្សាក្នុងសិក្ខាបទ១ ជាអ្នកបានដូចសេចក្ដីប្រាថ្នា បានដោយមិនលំបាក បានដោយធំទូលាយ នូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខ ក្នុងបច្ចុប្បន្ន១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១។ ភិក្ខុដែលប្រកបដោយអង្គ៧ដទៃទៀត បានឈ្មោះថា ជាវិន័យធរ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ធម៌ដែលពីរោះខាងដើម ពីរោះកណ្ដាល ពីរោះខាងចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធគ្រប់គ្រាន់ទាំងអស់ ធម៌ដែលមានសភាពដូច្នោះ ភិក្ខុនោះ បានចេះដឹងច្រើន បានទ្រទ្រង់ បានចាំស្ទាត់រត់មាត់ បានចូលចិត្តច្បាស់លាស់ បានយល់ជ្រាលជ្រៅដោយទិដ្ឋិ គឺបញ្ញា១ ជាអ្នកបានដូចសេចក្ដីប្រាថ្នា បានដោយមិនលំបាក បានដោយធំទូលាយ នូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខ ក្នុងបច្ចុប្បន្ន១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១។ ភិក្ខុដែលប្រកបដោយអង្គ៧ដទៃទៀត បានឈ្មោះថា ជាវិន័យធរ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ភិក្ខុនោះចេះចាំបាតិមោក្ខទាំងពីរ ដោយពិស្តារ ចេះចែកបទភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្ដីដោយប្រពៃ តាមសុត្តៈ គឺខន្ធកៈ និងបរិវារៈ តាមអនុព្យញ្ជនៈ គឺអក្ខរៈ និងបទ១ ជាអ្នកបានដូចសេចក្ដីប្រាថ្នា បានដោយមិនលំបាក បានដោយធំទូលាយ នូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខ ក្នុងបច្ចុប្បន្ន១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយ ដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១។ ភិក្ខុដែលប្រកបដោយអង្គ៧ដទៃទៀត បានឈ្មោះថា ជាវិន័យធរ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ រលឹកឃើញនូវចំណែកខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន មានច្រើនប្រការ គឺរលឹកឃើញ ១ជាតិខ្លះ ២ជាតិខ្លះ ៣ជាតិខ្លះ ៤ជាតិខ្លះ ៥ជាតិខ្លះ។បេ។ ១០ជាតិខ្លះ ២០ជាតិខ្លះ ៣០ជាតិខ្លះ ៤០ជាតិខ្លះ ៥០ជាតិខ្លះ ១០០ជាតិខ្លះ ១០០០ជាតិខ្លះ ១០០០០០ (១សែន) ជាតិខ្លះ សំវដ្តកប្បជាច្រើនខ្លះ វិវដ្តកប្បជាច្រើនខ្លះ សំវដ្តវិវដ្តកប្បជាច្រើនខ្លះ ថាអាត្មាអញ កើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនោះ មានគោត្រយ៉ាងនោះ មានសម្បុរយ៉ាងនោះ មានអាហារយ៉ាងនោះ ទទួលសុខទុក្ខយ៉ាងនោះ មានអាយុកំណត់ប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកទីនោះហើយ ទៅកើតក្នុងទីឯណោះទៀត ដែលអាត្មាអញបានកើតក្នុងទីនោះ មានឈ្មោះយ៉ាងនោះ មានគោត្រយ៉ាងនោះ មានសម្បុរយ៉ាងនោះ មានអាហារយ៉ាងនោះ ទទួលសុខទុក្ខយ៉ាងនោះ មានអាយុកំណត់ប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកទីនោះហើយ ទើបបានមកកើតក្នុងទីនេះ ភិក្ខុនោះរលឹកនូវចំណែកខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន មានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ១ ភិក្ខុនោះមានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាបខ្លះ ឧត្តមខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វពួកនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គល ជាអ្នកយល់ខុស ប្រកាន់ស៊ប់នូវអំពើតាមសេចក្ដីយល់ខុស សត្វពួកនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខអំពីសេចក្ដីស្លាប់ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ម្យ៉ាងទៀតថា អើហ្ន៎ សត្វពួកនេះប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិន

តិះដៀលព្រះអរិយបុគ្គល ជាអ្នកយល់ត្រូវ ប្រកាន់ស៊ប់នូវកម្មតាមសេចក្តីយល់ត្រូវ សត្វពួកនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខអំពីសេចក្តីស្លាប់ រមែងទៅកើតក្នុងសុគតិ និងឋានសួគ៌ ទេវលោក ភិក្ខុនោះមានចក្ខុទិព្វ ដ៏បរិសុទ្ធ កន្លងហួសចក្ខុ របស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាបខ្លះ ឧត្តមខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយ ដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១ វិន័យធរ ដែលប្រកបដោយអង្គ៧ រមែងល្អ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ជាអ្នកមានសីល១។បេ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានដោយមិនលំបាក បានដោយទូលាយ នូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខ ក្នុងបច្ចុប្បន្ន១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយ ដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១។ វិន័យធរ ដែលប្រកបដោយអង្គ៧ដទៃទៀត រមែងល្អ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ជាអ្នកចេះចាំច្រើន។បេ។ បានយល់ជ្រាលជ្រៅ ដោយទិដ្ឋិគឺបញ្ញា១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានដោយមិនលំបាក បានដោយធំទូលាយ នូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខ ក្នុងបច្ចុប្បន្ន១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយ ដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១។ វិន័យធរ ប្រកបដោយអង្គ៧ដទៃទៀត ក៏រមែងល្អ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ ភិក្ខុនោះ ចេះចាំបាតិមោក្ខទាំងពីរ ដោយពិស្តារ ចេះចែកបទ ភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈ គឺខន្ធកៈ និងបរិវារៈ តាមអនុព្យញ្ជនៈ គឺអក្ខរៈ និងបទ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានដោយមិនលំបាក បានដោយធំទូលាយ នូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខ ក្នុងបច្ចុប្បន្ន១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយ ដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១។ វិន័យធរ ដែលប្រកបដោយអង្គ៧ដទៃទៀត រមែងល្អ គឺស្គាល់អាបត្តិ១ ស្គាល់អនាបត្តិ១ ស្គាល់លហុកាបត្តិ១ ស្គាល់គរុកាបត្តិ១ រលឹកឃើញនូវចំណែកខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន មានច្រើនប្រការ១។បេ។ មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាបខ្លះ ឧត្តមខ្លះ មានសម្បុរល្អខ្លះ មានសម្បុរអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន១។បេ។ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយ ដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន១។

[៧៧] អសទ្ធម្មមាន៧យ៉ាង គឺបុគ្គលមិនមានសទ្ធា១ មិនខ្មាសបាប១ មិនខ្លែងនឹងបាប១ ចេះដឹងតិច១ ខ្ជិលច្រអូស១ ភ្លេចស្មារតី១ ឥតប្រាជ្ញា១។ ព្រះសទ្ធម្មមាន៧យ៉ាង គឺបុគ្គលមានសទ្ធា១ ខ្មាសបាប១ ខ្លែងនឹងបាប១ ចេះដឹងច្រើន១ ប្រារព្ធព្យាយាម១ មានស្មារតីខ្ជាប់ខ្ជួន១ មានប្រាជ្ញា១។

ចប់ សត្តកៈ (ពួកប្រាំពីរៗ)។

ឧទ្ទាន គឺបញ្ជីរឿងនៃសត្តកៈ (ពួកប្រាំពីរៗ) នោះដូច្នេះ

[៧៨]

និយាយអំពីអាបត្តិ១ កងនៃអាបត្តិ១ វិនីតវត្ថុ១ សិក្ខាបទមានពាក្យថាប្រព្រឹត្តដោយសមគួរ១ បដិញ្ញាតករណៈ មិនប្រកបដោយធម៌១ បដិញ្ញាតករណៈ ប្រកបដោយធម៌១ ទៅដោយសត្តាហកិច្ច មិនមានអាបត្តិ១ អានិសង្សវិន័យធរ១ សិក្ខាបទដែលមានទីកំណត់១ វត្ថុជានិស្សគ្គិយៈក្នុងខណៈដែលអរុណរះឡើង១ សមថៈ១ កម្ម១ ស្រូវស្រស់១ ខ្ទាតទទឹងកុដិ១ អនុប្បញ្ញត្តិក្នុងគណភោជនសិក្ខាបទ១ ភេសជ្ជៈ ភិក្ខុគួរទទួលទុកឆាន់បានកំណត់៧ថ្ងៃ១ ភិក្ខុកាន់យកចីវរដែលសម្រេច ហើយចៀសចេញទៅ១ ភិក្ខុប្រមូលយកចីវរដែលសម្រេច ហើយចៀសចេញទៅ១ អាបត្តិមិនមានដល់ភិក្ខុ១ អាបត្តិមានដល់ភិក្ខុ១ អាបត្តិដែលមានដល់ភិក្ខុបណ្ឌិតគប្បីរម្ងាប់ចេញ១ បញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌១ បញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌១ ភិក្ខុដែលបានឈ្មោះថាជាវិន័យធរ៤ពួក១ ភិក្ខុ៤ពួកដែលល្អ១ អសទ្ធម្ម៧ប្រការ១ ព្រះសទ្ធម្ម៧ប្រការ ដែលព្រះមានព្រះភាគទ្រង់ទេសនាហើយ១។

## (អដ្ឋកវារៈ ទីគ)

CS vin.pv.05.08 | ភាគ ទី១៣

### (៨. អដ្ឋកវារោ)

[៧៩] កាលបើភិក្ខុបានឃើញច្បាស់នូវអានិសង្ស៨ប្រការហើយ មិនត្រូវលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិឡើយ។ កាលបើភិក្ខុបានឃើញនូវអានិសង្ស៨ប្រការហើយ ត្រូវសំដែងអាបត្តិនោះចេញ ដោយសេចក្តីជឿពាក្យភិក្ខុឯទៀត។ សិក្ខាបទជាយាវតតិយកាមាន៨។ ភិក្ខុទ្រុស្តត្រកូលដោយប្រការ៨យ៉ាង។ មាតិកា៨យ៉ាង នាំឲ្យកើតចីវរ។ មាតិកា៨យ៉ាង នាំឲ្យដោះកឋិន។ ទឹកបាន មាន៨យ៉ាង។ ទេវទត្តត្រូវអសទ្ធម្ម៨ប្រការគ្របសង្កត់ហើយ មានចិត្ត គឺអសទ្ធម្មរួបរឹតហើយ ក៏ធ្លាក់ទៅក្នុងទីមិនចំរើន ធ្លាក់ទៅនរក តាំងនៅអស់១កប្ប រកអ្នកណាកែមិនកើត។ លោកធម៌មាន៨ប្រការ។ គរុធម៌មាន៨ប្រការ។ បាដិទេសនីយសិក្ខាបទមាន៨។ មុសាវាទប្រកបដោយអង្គ៨។ អង្គរបស់ឧបោសថមាន៨។ អង្គរបស់ភិក្ខុដែលជាទូត (អ្នកទទួលបម្រើ) មាន៨។ វត្តរបស់ពួកតិរ្ថិយ មាន៨។ ធម៌ជាអស្ចារ្យចំឡែកក្នុងមហាសមុទ្ទ មាន៨។ ធម៌ជាអស្ចារ្យចំឡែកក្នុងធម៌វិន័យនេះ មាន៨។ អនតិរិត្តភោជនមាន៨។ អតិរិត្តភោជនមាន៨។ វត្ថុដែលជានិស្សគ្គិយៈ ក្នុងខណៈអរុណរះឡើងជាគំរប់៨។

បារាជិកសិក្ខាបទមាន៨។ ភិក្ខុនីធ្វើវត្តទី៨ឲ្យពេញ សង្ឃត្រូវឲ្យវិនាស។ អាបត្តិដែលភិក្ខុនីធ្វើវត្តទី៨ឲ្យពេញ សំដែងចេញបានក៏មាន សំដែងចេញមិនបានក៏មាន។ ឧបសម្បទា ប្រកបដោយកម្មវាចា៨លើក។ ត្រូវក្រោកទៅទទួលបុគ្គល៨ពួក។ ត្រូវឲ្យអាសនៈ ដល់បុគ្គល៨ពួក។ ឧបាសិកាបានសូមពរទាំង៨ប្រការ។ ភិក្ខុប្រកបដោយអង្គ៨ សង្ឃគួរសន្មតឲ្យជាអ្នកប្រដៅភិក្ខុនី។ អានិសង្សវិន័យធរមាន៨។ សិក្ខាបទដែលមានទីកំណត់មាន៨។ ភិក្ខុដែលសង្ឃធ្វើតស្សបាបិយសិកាកម្មហើយ គួរប្រព្រឹត្តដោយប្រពៃ ក្នុងធម៌ទាំង៨ប្រការ។ ការបញ្ឈប់បាតិមោក្ខ ដែលមិនប្រកបដោយធម៌ មាន៨។ ការបញ្ឈប់បាតិមោក្ខ ដែលប្រកបដោយធម៌មាន៨។

ចប់ អដ្ឋកៈ (ពួកប្រាំបីៗ)។

ឧទ្ទាន គឺបញ្ជីរឿង នៃអដ្ឋកៈ (ពួកប្រាំបីៗ) នោះដូច្នេះ

[៨០]

និយាយអំពីភិក្ខុមិនត្រូវលើកវត្តភិក្ខុនោះ១ ភិក្ខុគួរសំដែងអាបត្តិដោយជឿពាក្យភិក្ខុដទៃ១ សិក្ខាបទជាយាវតតិយកា១ ភិក្ខុទ្រុស្តត្រកូល១។ មាតិកានាំឲ្យកើតចីវរ១ មាតិកានាំឲ្យដោះកឋិន១ ទឹកបាន១ ទេវទត្តត្រូវអសទ្ធម្មគ្របសង្កត់១ លោកធម៌១ គរុធម៌១ បាដិទេសនីយសិក្ខាបទ១ មុសាវាទ១ ឧបោសថ១ អង្គរបស់ភិក្ខុជាទូត១ វត្តតិរ្ថិយ១ ធម៌ជាអស្ចារ្យចំឡែកក្នុងមហាសមុទ្ទ១ អនតិរិត្តភោជន១ អតិរិត្តភោជន១ និស្សគ្គិយវត្ថុ១ បារាជិកសិក្ខាបទ១ ភិក្ខុនីធ្វើវត្តទី៨ ឲ្យពេញ១ អាបត្តិដែលភិក្ខុនីសំដែងមិនបាន១ ឧបសម្បទា១ ការក្រោកទទួល១ ឲ្យអាសនៈ១ ឧបាសិកាសូមពរ១ ភិក្ខុដែលសង្ឃគួរសន្មតឲ្យប្រដៅភិក្ខុនី១ អានិសង្សវិន័យធរ១ សិក្ខាបទដែលមានទីកំណត់១ ភិក្ខុគួរប្រព្រឹត្តក្នុងធម៌៨ប្រការ១ បញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌១ បញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌១ ពួកធម៌ប្រាំបីៗ (នេះ) ព្រះសម្ពុទ្ធទ្រង់សំដែងទុកមកដោយល្អហើយ។

## (នវកវារៈ ទី៩)

CS vin.pv.05.09 | ភាគ ទី១៣

### (៩. នវកវារោ)

[៨១] អាឃាតវត្ថុ គឺវត្ថុជាទីកើតនៃគំនុំមាន៩។ ធម៌សម្រាប់កំចាត់នូវគំនុំមាន៩។ វិនីតវត្ថុមាន៩។ អាបត្តិជាបឋមាបត្តិកា (ដែលត្រូវជាដម្បូង) មាន៩។ សង្ឃបែកគ្នាដោយធម៌៩ប្រការ។ ភោជនឧត្តមមាន៩យ៉ាង។ ភិក្ខុត្រូវទុក្កដ ព្រោះឆាន់សាច់៩យ៉ាង។ ឧទ្ទេសរបស់បាតិមោក្ខមាន៩។ សិក្ខាបទដែលមានទីកំណត់មាន៩។ ធម៌ដែលមានតណ្ហាជាមូល មាន៩។ មានះ មាន៩ប្រការ។ ចីវរ៩ប្រការ ភិក្ខុគួរអធិដ្ឋាន។ ចីវរ៩ប្រការ ភិក្ខុមិនគួរវិកប្ប។ បណ្តោយ (ចីវរព្រះសុគត)៩ចំអាម ដោយចំអាមព្រះសុគត។ ទានដែលមិនប្រកបដោយធម៌ មាន៩យ៉ាង។ ការទទួលដែលមិនប្រកបដោយធម៌ មាន៩យ៉ាង។ បរិភោគដែលមិនប្រកបដោយធម៌ មាន៩យ៉ាង។ ទានដែលប្រកបដោយធម៌មាន៣យ៉ាង។ ការទទួលដែលប្រកបដោយធម៌មាន៣យ៉ាង។ បរិភោគដែលប្រកបដោយធម៌មាន៣យ៉ាង។ ការពន្យល់ ឬបញ្ញាក់ ដែលមិនប្រកបដោយធម៌ មាន៩យ៉ាង។ ការពន្យល់ ឬបញ្ញាក់ ដែលប្រកបដោយធម៌មាន៩យ៉ាង។ នវកៈ មាន២ ក្នុងកម្មដែលមិនប្រកបដោយធម៌។ នវកៈ មាន២ ក្នុងកម្មដែលប្រកបដោយធម៌។ ការបញ្ឈប់បាតិមោក្ខ ដែលមិនប្រកបដោយធម៌មាន៩។ ការបញ្ឈប់បាតិមោក្ខ ដែលប្រកបដោយធម៌មាន៩។

ចប់ នវកៈ (ពួកប្រាំបួនៗ)។

ឧទ្ទាន គឺបញ្ជីរឿង នៃនវកៈ (ពួកប្រាំបួនៗ) នោះដូច្នេះ

[៨២]

និយាយអំពីវត្ថុជាទីកើតគំនុំ ធម៌សម្រាប់កំចាត់គំនុំ១ វិនីតវត្ថុ១ អាបត្តិជាបឋមាបត្តិកា១ សង្ឃបែកគ្នា១ ភោជនឧត្តម១ ភិក្ខុត្រូវទុក្កដ ព្រោះឆាន់សាច់១ ឧទ្ទេសរបស់បាតិមោក្ខ១ សិក្ខាបទដែលមានទីកំណត់១ ធម៌ដែលមានតណ្ហាជាមូល១ មានះ១ អធិដ្ឋាន១ វិកប្ប១ ចំអាមព្រះសុគត១ ទាន១ ការទទួល១ ការបរិភោគ១ ទាន និងការទទួល និងការបរិភោគ ដែលប្រកបដោយធម៌មាន៣ប្រការ១ ពន្យល់ ឬបញ្ញាក់មិនប្រកបដោយធម៌១ ពន្យល់ ឬបញ្ញាក់ប្រកបដោយធម៌១ នវកៈពីរពួក ២ដង១ ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌១។ ការបញ្ឈប់បាតិមោក្ខ ដែលប្រកបដោយធម៌១។

## (ទសកវារៈ ទី១០)

CS vin.pv.05.10 | ភាគ ទី១៣

### (១០. ទសកវារោ)

[៨៣] វត្ថុជាទីកើតគំនុំមាន១០។ ធម៌សម្រាប់កំចាត់នូវគំនុំមាន១០។ វិនីតវត្ថុមាន១០។ មិច្ឆាទិដ្ឋិមានវត្ថុ១០។ សម្មាទិដ្ឋិមានវត្ថុ១០។ ទិដ្ឋិឈ្មោះអន្តគ្គាហិកាមាន១០។ មិច្ឆត្តធម៌មាន១០។ សម្មត្តធម៌មាន១០។ អកុសលកម្មបថមាន១០។ កុសលកម្មបថមាន១០។ ការចាប់ស្លាក ដែល

មិនប្រកបដោយធម៌មាន១០។ ការចាប់ស្លាក ដែលប្រកបដោយធម៌ មាន១០។ សិក្ខាបទរបស់សាមណេរមាន១០។ សាមណេរ ប្រកបដោយអង្គ១០ គួរឲ្យវិនាស។

[៨៤] វិន័យធរ ដែលប្រកបដោយអង្គ១០ ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនរៀនទីកំណត់ភាសារបស់ខ្លួន១ មិនរៀនទីកំណត់ភាសារបស់ជនដទៃ១ លុះមិនរៀនទីកំណត់ភាសារបស់ខ្លួនហើយ កាត់សេចក្តីមិនត្រូវតាមធម៌១ លុះមិនរៀនទីកំណត់ភាសារបស់ជនដទៃហើយ កាត់សេចក្តីមិនត្រូវតាមធម៌១ កាត់សេចក្តីមិនត្រូវតាមពាក្យប្តេជ្ញា១ មិនស្គាល់អាបត្តិ១ មិនស្គាល់មូលនៃអាបត្តិ១ មិនស្គាល់ហេតុឲ្យកើតអាបត្តិ១ មិនស្គាល់សេចក្តីរលត់នៃអាបត្តិ១ មិនស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់នៃអាបត្តិ១។ វិនយធរ ដែលប្រកបដោយអង្គ១០ ដល់នូវការរាប់ថា ជាបណ្ឌិត គឺរៀនទីកំណត់ភាសារបស់ខ្លួន១ រៀនទីកំណត់ភាសារបស់ជនដទៃ១ លុះរៀនទីកំណត់ភាសារបស់ខ្លួនហើយ កាត់សេចក្តីត្រូវតាមធម៌១ លុះរៀនទីកំណត់ភាសារបស់ជនដទៃហើយ កាត់សេចក្តីត្រូវតាមធម៌១ កាត់សេចក្តីត្រូវតាមពាក្យប្តេជ្ញា១ ស្គាល់អាបត្តិ១ ស្គាល់មូលនៃអាបត្តិ១ ស្គាល់ហេតុឲ្យកើតអាបត្តិ១ ស្គាល់សេចក្តីរលត់នៃអាបត្តិ១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់នៃអាបត្តិ១។ វិនយធរ ដែលប្រកបដោយអង្គ១០ដទៃទៀត ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អធិករណ៍១ មិនស្គាល់មូលនៃអធិករណ៍១ មិនស្គាល់ហេតុឲ្យកើតអធិករណ៍១ មិនស្គាល់សេចក្តីរលត់នៃអធិករណ៍១ មិនស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់នៃអធិករណ៍១ មិនស្គាល់វត្ថុ១ មិនស្គាល់និទាន១ មិនស្គាល់បញ្ញត្តិ១ មិនស្គាល់អនុប្បញ្ញត្តិ១ មិនស្គាល់គន្លងពាក្យដែលជាប់តគ្នា១។ វិនយធរប្រកបដោយអង្គ១០ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អធិករណ៍១ ស្គាល់មូលនៃអធិករណ៍១ ស្គាល់ហេតុឲ្យកើតអធិករណ៍១ ស្គាល់សេចក្តីរលត់នៃអធិករណ៍១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អធិករណ៍១ ស្គាល់វត្ថុ១ ស្គាល់និទាន១ ស្គាល់បញ្ញត្តិ១ ស្គាល់អនុប្បញ្ញត្តិ១ ស្គាល់គន្លងពាក្យដែលជាប់តគ្នា១។ វិនយធរ ដែលប្រកបដោយអង្គ១០ដទៃទៀត ក៏ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់ញត្តិ១ មិនស្គាល់ការធ្វើញត្តិ១ មិនឈ្លាសក្នុងកិច្ចខាងដើម១ មិនឈ្លាសក្នុងកិច្ចខាងចុង១ មិនស្គាល់កាល១ មិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ វិន័យធរនោះ មិនរៀនតំណអាចារ្យ ទាំងមិនយកចិត្តទុកដាក់ មិនពិចារណាដោយល្អ១។ វិនយធរដែលប្រកបដោយអង្គ១០ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់ញត្តិ១ ស្គាល់ការធ្វើញត្តិ១ ឈ្លាសក្នុងកិច្ចខាងដើម១ ឈ្លាសក្នុងកិច្ចខាងចុង១ ស្គាល់កាល១ ស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ វិន័យធរនោះ បានរៀនតំណអាចារ្យ ទាំងបានយកចិត្តទុកដាក់ បានពិចារណាដោយល្អ១។ វិនយធរដែលប្រកបដោយអង្គ១០ដទៃទៀត ក៏ដល់នូវការរាប់ថាជាបុគ្គលពាល គឺមិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ វិន័យធរនោះ មិនចេះចាំបាតិមោក្ខទាំងពីរដោយពិស្តារ មិនចេះចែកបទភាជនៈដោយប្រពៃ មិនបានចាំស្ទាត់រត់មាត់ដោយប្រពៃ មិនចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈ គឺខន្ធកៈ និងបរិវារៈ តាមអនុព្យញ្ជនៈ គឺអក្ខរៈ និងបទ១ មិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍១។ វិនយធរ ប្រកបដោយអង្គ១០ ដល់នូវការរាប់ថាជាបណ្ឌិត គឺស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ វិន័យធរនោះ ចេះចាំបាតិមោក្ខទាំងពីរដោយពិស្តារ ចេះចែកបទភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈ តាមអនុព្យញ្ជនៈ១ ស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ ឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍១។

[៨៥] ភិក្ខុប្រកបដោយអង្គ១០ សង្ឃគួរសន្មតដោយឧព្វាហិកាកម្ម។[13] ព្រះតថាគត អាស្រ័យអំណាចប្រយោជន៍ទាំង១០ ទើបបញ្ញត្តសិក្ខាបទដល់សាវ័កទាំងឡាយ។ ទោសក្នុងការចូលទៅក្នុងព្រះរាជវាំង មាន១០យ៉ាង។ ទានវត្ថុ១០យ៉ាង។ រតនៈមាន១០យ៉ាង។ ភិក្ខុសង្ឃមានពួក១០។ គណៈសង្ឃពួក១០ គួរឲ្យឧបសម្បទាបាន។ សំពត់បំសុកូលមាន១០យ៉ាង។ ការទ្រទ្រង់ចីវរមាន១០យ៉ាង។ អតិរេកចីវរ ភិក្ខុត្រូវប្រើប្រាស់បានកំណត់ត្រឹម១០ថ្ងៃ។ ទឹកសុក្កៈមាន១០យ៉ាង។ ស្រីមាន១០ពួក។ ភរិយាមាន១០ពួក។ វជ្ជីបុត្តកភិក្ខុទាំងឡាយ សំដែងវត្ថុទាំង១០ប្រការក្នុងក្រុងវេសាលី។ អវន្ទិយបុគ្គលមាន១០ពួក។ អក្កោសវត្ថុមាន១០យ៉ាង។ ភិក្ខុនាំពាក្យញុះញង់ ដោយអាការ១០។ សេនាសនៈមាន១០យ៉ាង។ ជនទាំងឡាយបានសូមពរទាំង១០។ ការបញ្ឈប់បាតិមោក្ខ ដែលមិនប្រកបដោយធម៌មាន១០។ ការបញ្ឈប់បាតិមោក្ខ ដែលប្រកបដោយធម៌មាន១០។ អានិសង្សបបរមាន១០យ៉ាង។ សាច់ដែលភិក្ខុមិនគួរឆាន់ មាន១០យ៉ាង។ សិក្ខាបទដែលមានទីកំណត់ មាន១០។ ភិក្ខុមានវស្សាគ្រប់១០ ដែលឈ្លាស ប្រតិពល ទើបគួរឲ្យបព្វជ្ជា គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរបម្រើខ្លួន។ ភិក្ខុនីមានវស្សាគ្រប់១០ ដែលឈ្លាស ប្រតិពល ទើបគួរឲ្យបព្វជ្ជា គួរឲ្យឧបសម្បទា គួរឲ្យនិស្ស័យ គួរឲ្យសាមណេរីបម្រើខ្លួនបាន។ ភិក្ខុនី ដែលឈ្លាស ប្រតិពល មានវស្សាគ្រប់១០ ទើបគួរត្រេកអរនឹងការសន្មតិ ឲ្យបំបួសគេបាន។ ភិក្ខុនីគប្បីឲ្យសិក្ខា[14] ដល់ស្រីគិហិគតា[15] មានវស្សាគ្រប់១០។

ចប់ ទសកៈ (ពួកដប់ៗ)។

ឧទ្ទាន គឺបញ្ជីរឿង នៃទសកៈ (ពួកដប់ៗ) នោះដូច្នេះ

[៨៦]

និយាយអំពីវត្ថុជាទីកើតគំនុំ ធម៌សម្រាប់កំចាត់គំនុំ១ វិនីតវត្ថុ១ មិច្ឆាទិដ្ឋិ១ សម្មាទិដ្ឋិ១ អន្តគ្គាហិកាទិដ្ឋិ១ មិច្ឆត្តធម៌១ សម្មត្តធម៌១ អកុសលកម្មបថ១ កុសលកម្មបថ១ ការចាប់ស្លាកមិនប្រកបដោយធម៌១ ការចាប់ស្លាកប្រកបដោយធម៌១ សិក្ខាបទរបស់សាមណេរ១ សាមណេរដែលគួរឲ្យវិនាស១ ទីកំណត់ភាសា១ អធិករណ៍១ ញត្តិ១ លហុកាបត្តិ១ លហុកាបត្តិម្យ៉ាងទៀត១ គរុកាបត្តិ១ អ្នកទាំងឡាយ ចូរដឹងធម៌ទាំងអម្បាលនេះ ថាជាធម៌មានចំណែកខ្មៅ និងស ភិក្ខុដែលសង្ឃត្រូវសន្មតដោយឧព្វាហិកាកម្ម១ ព្រះតថាគត ទ្រង់បញ្ញត្តិសិក្ខាបទ១ ទោសក្នុងការចូលទៅក្នុងព្រះរាជវាំង១ ទានវត្ថុ១ រតនៈ១ សង្ឃពួកដប់១ ការឲ្យឧបសម្បទាដោយសង្ឃពួក១០ ដូចគ្នា១ សំពត់បំសុកូល១ ការប្រើប្រាស់ចីវរ១ អតិរេកចីវរ គួរប្រើប្រាស់បានត្រឹមតែ

កំណត់១០ថ្ងៃ១ ទឹកសុក្កៈ១០យ៉ាង១ ស្រី១០ពួក១ ភរិយា១០ពួក១ វត្ថុ១០យ៉ាង១ អវន្ទិយបុគ្គល១ អក្កោសវត្ថុ១ ភិក្ខុនាំការញុះញង់១ សេនាសនៈ១ ការសូមពរ១ ការបញ្ឈប់បាតិមោក្ខ ដែលមិនប្រកបដោយធម៌១ ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌១ អានិសង្សបបរ១ សាច់មិនគួរឆាន់១ សិក្ខាបទដែលមានទីកំណត់១ ភិក្ខុដែលគួរឲ្យបព្វជ្ជាជាដើម១ ភិក្ខុនីដែលគួរឲ្យបព្វជ្ជាជាដើម១ ភិក្ខុនីគួរត្រេកអរនឹងការសន្និបព្វជ្ជា១ ស្រីគិហិគតា១ ធម៌ពួកដប់ៗនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងហើយ ដោយប្រពៃ។

## (ឯកាទសកវារៈ ទី១១)

CS vin.pv.05.11 | ភាគ ទី១៣

### (១១. ឯកាទសកវារោ)

[៨៧] បុគ្គល១១ពួក បើនៅជាអនុបសម្បន្ននៅឡើយ ភិក្ខុមិនត្រូវឲ្យឧបសម្បទា ទុកជាបានឧបសម្បទារួចហើយ ភិក្ខុត្រូវឲ្យវិនាសចេញ។ ទ្រនាប់ជើងដែលភិក្ខុមិនគួរប្រើប្រាស់ មាន១១យ៉ាង។ បាត្រដែលភិក្ខុមិនគួរប្រើប្រាស់ មាន១១យ៉ាង។ ចីវរដែលភិក្ខុមិនគួរប្រើប្រាស់ មាន១១យ៉ាង។ អាបត្តិជាយាវតតិយកាមាន១១។ អន្តរាយិកធម៌១១ប្រការ របស់ពួកភិក្ខុនី ភិក្ខុត្រូវសួរ។ ចីវរ ដែលភិក្ខុគួរអធិដ្ឋាន មាន១១យ៉ាង។ ចីវរដែលភិក្ខុមិនគួរវិកប្ប មាន១១យ៉ាង។ វត្ថុដែលជានិស្សគ្គិយៈ ក្នុងពេលអរុណរះឡើង ជាគំរប់១១។ ឡេវក្តំដែលជាកប្បិយៈ (គួរប្រើប្រាស់បាន) មាន១១យ៉ាង។ ក្រវិលក្ដំដែលជាកប្បិយៈ មាន១១យ៉ាង។ ផែនដីជាអកប្បិយៈ (ភិក្ខុមិនគួរជីក) មាន១១យ៉ាង។ ផែនដីជាកប្បិយៈមាន១១យ៉ាង។ សេចក្តីរម្ងាប់ចាកនិស្ស័យ មាន១១ប្រការ។ អវន្ទិយបុគ្គលមាន១១ពួក។ សិក្ខាបទមានទីកំណត់មាន១១។ ពួកជនបានសូមពរ១១ប្រការ។ ទោសរបស់សីមា មាន១១ប្រការ។ ទោស១១ប្រការរមែងកើតប្រាកដដល់បុគ្គលជាអ្នកជេរ និងជាអ្នកគម្រាម។ មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឲ្យថ្មឹកហើយ ចំរើនហើយ ធ្វើឲ្យក្រាស់ក្រៃលហើយ ធ្វើឲ្យដូចជាយានជំនិះហើយ ធ្វើឲ្យជាទីនៅហើយ ឲ្យតាំងនៅញឹកញយហើយ សន្សំទុកមិនឲ្យបាត់ ប្រារព្ធដោយល្អហើយ និងមានអានិសង្ស១១ប្រការជាពិតប្រាកដ គឺបុគ្គលនោះដេកលក់ជាសុខ១ ភ្ញាក់ឡើងជាសុខ១ មិនយល់សុប្តិអាក្រក់១ ជាទីស្រឡាញ់របស់ពួកមនុស្ស១ ជាទីស្រឡាញ់របស់ពួកអមនុស្ស១ ពួកទេវតាតែងរក្សា១ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី ក៏មិនប៉ះពាល់ដល់បុគ្គលនោះ១ ចិត្តបុគ្គលនោះ រមែងចូលកាន់សមាធិដោយរួសរាន់១ បុគ្គលនោះ មានពណ៌សម្បុរមុខស្រស់បស់១ បុគ្គលនោះមិនបានវង្វេង ធ្វើមរណកាល១ កាលបើមិនទាន់បានត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់ទេ ជាអ្នកបានទៅកើតក្នុងព្រហ្មលោក១ មេត្តាចេតោវិមុត្តិ ដែលបុគ្គលគប្បីធ្វើឲ្យថ្មឹកហើយ ចំរើនហើយ ធ្វើឲ្យក្រាស់ក្រៃលហើយ ធ្វើឲ្យដូចជាយានជំនិះហើយ ធ្វើឲ្យជាទីនៅហើយ ឲ្យតាំងនៅញឹកញយហើយ សន្សំទុកមិនឲ្យបាត់ ប្រារព្ធដោយល្អហើយ អានិសង្ស១១ប្រការនេះ នឹងកើតប្រាកដ។

ចប់ ឯកាទសកៈ (ពួកដប់មួយៗ)។

ឧទ្ទាន គឺបញ្ជីរឿងនៃឯកាទសកៈ (ពួកដប់មួយៗ) នោះដូច្នេះ

[៨៨]

និយាយអំពីឧបសម្បន្ន ដែលសង្ឃគួរឲ្យវិនាស១ ទ្រនាប់ជើង១ បាត្រ១ ចីវរ១ អាបត្តិ ជាយាវតតិយកា១ អន្តរាយិកធម៌ ដែលវិន័យធរត្រូវសួរ១ ចីវរគួរអធិដ្ឋាន១ ចីវរគួរវិកប្ប១ វត្ថុជានិស្សគ្គិយៈ ក្នុងវេលាអរុណរះឡើង១ ឡេវក្តំ១ ក្រវិលក្តំ១ ដីជាអកប្បិយៈ១ ដីជាកប្បិយៈ១ សេចក្តីរម្ងាប់ចាកនិស្ស័យ១ អវន្ទិយបុគ្គល១ សិក្ខាបទដែលមានទីកំណត់១ ការសូមពរ១ ទោសរបស់សីមា១ ការជេរ១ អានិសង្សមេត្តាមាន១១ប្រការ១។

ចប់ ឯកុត្តរិកៈ (ការស្រង់យកសេចក្តីតាំងពីពួកមួយៗ ឡើងទៅ)។

ឧទ្ទាន នៃឯកុត្តរិកៈនោះ ដូច្នេះ

[៨៩]

ពួកធម៌មួយ១ ពួកធម៌ពីរ១ ពួកធម៌បី១ ពួកធម៌បួន១ ពួកធម៌ប្រាំ១ ពួកធម៌ប្រាំមួយ១ ពួកធម៌ប្រាំពីរ១ ពួកធម៌ប្រាំបី១ ពួកធម៌ប្រាំបួន១ ពួកធម៌ដប់១ ពួកធម៌ដប់មួយ១ ឈ្មោះថា ឯកុត្តរិកៈ ជារបស់ប្រាសចាកមន្ទិល ដែលព្រះពុទ្ធជាតាទិបុគ្គល ទ្រង់ត្រាស់ដឹងនូវធម៌ ទ្រង់ប្រកបដោយសេចក្តីព្យាយាមច្រើន ទ្រង់សំដែងទុកមក ដើម្បីប្រយោជន៍ ដល់សព្វសត្វទាំងឡាយ។

# បុច្ឆាវិសជ្ជនាអំពីឧបោសថកម្មជាដើម

CS vin.pv.06 | ភាគ ទី១៣

### (ឧបោសថាទិបុច្ឆាវិស្សជ្ជនា)

### (អាទិមជ្ឈន្តបុច្ឆនៈ)

CS vin.pv.06.01 | ភាគ ទី១៣

### (អាទិមជ្ឈន្តបុច្ឆនំ)

[៩០] ឧបោសថកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ បវារណាកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ តជ្ជនីយកម្ម។បេ។ និយស្សកម្ម។បេ។ បព្វាជនីយកម្ម។បេ។ បដិសារណីយកម្ម។បេ។ ឧក្ខេបនីយកម្ម។បេ។ បរិវាសទាន (ការឲ្យបរិវាស)។បេ។ មូលាយប្បដិកស្សនា។បេ។ មានត្តទាន។បេ។ អព្ភាន។បេ។ ឧបសម្បទាកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ ការរម្ងាប់តជ្ជនីយកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ ការរម្ងាប់និយស្សកម្ម។បេ។ ការរម្ងាប់បព្វាជនីយកម្ម។បេ។ ការរម្ងាប់បដិសារណីយកម្ម។បេ។ ការរម្ងាប់ឧក្ខេបនីយកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ សតិវិន័យ មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។បេ។ អមូឡ្ហវិន័យ។បេ។ តស្សបាបិយសិកា។បេ។ តិណវត្ថារកៈ។បេ។ ការសន្មតិភិក្ខុឲ្យជាអ្នកប្រដៅភិក្ខុនី។បេ។ ការសន្មតិភិក្ខុឲ្យនៅប្រាសចាកត្រៃចីវរ។បេ។ ការសន្មតិសន្ថត។បេ។ ការសន្មតិភិក្ខុឲ្យជាអ្នកចោលរូបិយៈ។បេ។ ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់សាដក។បេ។ ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់បាត្រ។បេ។ ការសន្មតិឈើច្រត់។បេ។ ការសន្មតិសង្រែក។បេ។ ការសន្មតិឈើច្រត់ និងសង្រែក មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។

## (អាទិមជ្ឈន្តវិស្សជ្ជនា)

CS vin.pv.06.02 | ភាគ ទី១៣

### (អាទិមជ្ឈន្តវិស្សជ្ជនា)

[៩១] សួរថា ឧបោសថកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ ឆ្លើយថា ឧបោសថកម្ម មានសេចក្តីព្រមព្រៀងជាខាងដើម មានការធ្វើជាកណ្តាល មានការបញ្ចប់ជាទីបំផុត។ បវារណាកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ បវារណាកម្ម មានសេចក្តីព្រមព្រៀងជាខាងដើម មានការធ្វើជាកណ្តាល មានការចប់ជាទីបំផុត។ តជ្ជនីយកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ តជ្ជនីយកម្ម មានវត្ថុ និងបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត។ និយស្សកម្ម។បេ។ បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម បរិវាសទាន មូលាយប្បដិកស្សនា មានត្តទាន អព្ភាន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ អព្ភាន មានវត្ថុ និងបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត។ ឧបសម្បទាកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ ឧបសម្បទាកម្ម មានបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត។ ការរម្ងាប់តជ្ជនីយកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ ការរម្ងាប់តជ្ជនីយកម្ម មានការប្រព្រឹត្តវត្តដោយល្អជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត។ ការរម្ងាប់និយស្សកម្ម។បេ។ បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ ការរម្ងាប់ឧក្ខេបនីយកម្ម មានការប្រព្រឹត្តវត្តដោយល្អជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត។ សតិវិន័យ មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ សតិវិន័យមានវត្ថុ និងបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត។ អមូឡ្ហវិន័យ។បេ។ តស្សបាបិយសិកា តិណវត្ថារកៈ ការសន្មតិភិក្ខុឲ្យជាអ្នកប្រដៅភិក្ខុនី ការសន្មតិភិក្ខុឲ្យនៅប្រាសចាកត្រៃចីវរ ការសន្មតិសន្ថត ការសន្មតិភិក្ខុឲ្យជាអ្នកចោលរូបិយៈ ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់សាដក ការសន្មតិភិក្ខុឲ្យជាអ្នកប្រគល់បាត្រ ការសន្មតិឈើច្រត់ ការសន្មតិសង្រែក ការសន្មតិឈើច្រត់ និងសង្រែក មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាទីបំផុត។ ការសន្មតិឈើច្រត់ និងសង្រែកមានវត្ថុ និងបុគ្គលជាខាងដើម មានញត្តិជាកណ្តាល មានកម្មវាចាជាទីបំផុត។

## បករណៈសំដែងអំពីអំណាចប្រយោជន៍

CS vin.pv.06.03 | ភាគ ទី១៣

### (អត្ថវសបករណំ)

[៩២] ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់សាវ័កទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍១០យ៉ាង គឺដើម្បីសេចក្តីល្អដល់សង្ឃ១ ដើម្បីនៅសប្បាយដល់សង្ឃ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្តីអៀនខ្មាស១ ដើម្បីនៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់១ ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន១ ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក១ ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង១ ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង១ ដើម្បីតំកល់នៅមាំ នៃព្រះសទ្ធម្ម១ ដើម្បីអនុគ្រោះដល់វិន័យ១។

[៩៣] អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា សប្បាយដល់សង្ឃ អំណាចប្រយោជន៍ណា សប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិន នូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្តីអៀនខ្មាស អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្តីអៀនខ្មាស អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីរារាំងអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គល

ទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរិតតែជ្រះថ្លាឡើង អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីតម្កល់នៅមាំ នៃព្រះសទ្ធម្ម អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីតម្កល់នៅមាំ នៃព្រះសទ្ធម្ម អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ។

[៩៤] អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា សប្បាយដល់សង្ឃ អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្តីអៀនខ្មាស អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួល ដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីតំកល់នៅមាំ នៃព្រះសទ្ធម្ម អំណាចប្រយោជន៍ណា ដែលជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ។

[៩៥] អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្តីអៀនខ្មាស អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីតំកល់នៅមាំ នៃព្រះសទ្ធម្ម អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍ណា ដែលជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍នោះ ឈ្មោះថា ជាសេចក្តីល្អដល់សង្ឃ។

[៩៦] អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានសេចក្តីអៀនខ្មាស។បេ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់។បេ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន។បេ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក។បេ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីញុំាងជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង។បេ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីញុំាងជន ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង។បេ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីតំកល់នៅមាំ នៃព្រះសទ្ធម្ម។បេ។ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា ជាសេចក្តីល្អដល់សង្ឃ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា ជាសេចក្តីសប្បាយដល់សង្ឃ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនមានអៀនខ្មាស អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីរារាំងនូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីកំចាត់បង់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីញុំាងជនទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង អំណាចប្រយោជន៍ណា (ប្រព្រឹត្តទៅ) ដើម្បីអនុគ្រោះដល់វិន័យ អំណាចប្រយោជន៍នោះ ឈ្មោះថា (ប្រព្រឹត្តទៅ) ដើម្បីតំកល់នៅមាំ នៃព្រះសទ្ធម្ម។

[៩៧] ក្នុងបករណៈ សំដែងអំណាចប្រយោជន៍ (នេះ) បណ្ឌិតត្រូវដឹងថា មានអត្ថ១រយ ធម៌១រយ និរុត្តិ២រយ និងញាណ៤រយ។

ចប់ បករណៈ អំពីអំណាចប្រយោជន៍។

ចប់ មហាវគ្គ (ពួកធំៗ)។

ឧទ្ទាន គឺបញ្ជីរឿងនៃបករណៈ អំពីអំណាចប្រយោជន៍នោះដូច្នេះ

[៩៨]

មុនដម្បូងនិយាយអំពីបុច្ឆាក្នុងវារៈទាំង៨យ៉ាង១ តមកទៀត និយាយអំពីវិសជ្ជនាក្នុងវារៈ៨យ៉ាង ក្នុងបច្ច័យទាំងឡាយ១ និយាយអំពីវារៈ១៦ របស់ភិក្ខុទាំងឡាយ១ និយាយអំពីវារៈ១៦របស់ភិក្ខុនីទាំងឡាយ១ និយាយអំពីប្រភេទជាចន្លោះនៃបេយ្យាលៈ១ និយាយអំពីការស្រង់សេចក្តីមួយៗ ឡើងទៅ១ និយាយអំពីបវារណា១ និយាយអំពីអំណាចប្រយោជន៍១ និយាយអំពីការរួបរួមសេចក្តីដែលជាពួកធំៗ១។

# គាថាសង្គណិកៈ

CS vin.pv.07 | ភាគ ទី១៣

**(គាថាសង្គណិកំ)**[អដ្ឋកថា ហៅថា បឋមគាថាសង្គណិកៈ (គាថាឆ្លកឆ្លាស់ជាដំបូង)។]

## (សត្តនគរេសុ បញ្ញត្តសិក្ខាបទ ទី១)

CS vin.pv.07.01 | ភាគ ទី១៣

### (១. សត្តនគរេសុ បញ្ញត្តសិក្ខាបទំ)

[៩៩] ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សួរព្រះឧបាលិត្ថេរដ៏មានអាយុថា អ្នកធ្វើចីវរឆៀងស្មាម្ខាង រួចប្រណម្យអញ្ចលី ធ្វើហាក់ដូចជាមានបំណង (អ្វីមួយ) មកក្នុងទីនេះ ដើម្បីអ្វី។ ព្រះឧបាលិត្ថេរ ក្រាបបង្គំទូលសួរថា សិក្ខាបទទាំងឡាយណា ដែលព្រះអង្គបានបញ្ញត្តទុក ក្នុងវិន័យទាំងពីរ តែងមកកាន់ឧទ្ទេសរាល់ៗថ្ងៃឧបោសថ សិក្ខាបទទាំងនោះ មានប៉ុន្មាន ទ្រង់បញ្ញត្តក្នុងនគរណាខ្លះ។ ព្រះអង្គ ទ្រង់ត្រាស់តបថា អ្នកមានប្រាជ្ញាមោះមុតល្អហើយ អ្នកសួរដោយឧបាយ ព្រោះហេតុនោះ តថាគតនឹងប្រាប់អ្នក តាមទំនងដែលតថាគតជាអ្នកឈ្លាសវៃ។ សិក្ខាបទទាំងឡាយណា ដែលតថាគតបានបញ្ញត្តទុក ក្នុងវិន័យទាំងពីរ តែងមកកាន់ឧទ្ទេសរាល់ៗថ្ងៃឧបោសថ សិក្ខាបទនោះ មាន៣៥០សិក្ខាបទ តថាគតបញ្ញត្តក្នុងនគរទាំង៧។

[១០០] ព្រះឧបាលិត្ថេរ ក្រាបបង្គំទូលសួរថា សិក្ខាបទដែលទ្រង់បញ្ញត្តក្នុងនគរទាំង៧នោះ តើនគរណាខ្លះ។ សូមព្រះអង្គដោះស្រាយនូវប្រស្នានោះរបស់ខ្ញុំព្រះអង្គ យើងខ្ញុំទាំងឡាយ នឹងពិចារណា នូវគន្លងពាក្យរបស់ព្រះអង្គ ហើយប្រតិបត្តិតាម ការប្រតិបត្តិតាមនោះ នឹងជាប្រយោជន៍ដល់យើងខ្ញុំទាំងឡាយ។ ឯសិក្ខាបទទាងឡាយ ដែលតថាគតបញ្ញត្ត (ក្នុងនគរទាំង៧នោះ) គឺ នគរវេសាលី១ រាជគ្រឹះ១ សាវត្ថី១ អាឡវី១ កោសម្ពី១ ដែនសក្កៈ១ ដែនភគ្គៈ។

[១០១] ព្រះឧបាលិត្ថេរ ក្រាបបង្គំទូលសួរថា សិក្ខាបទប៉ុន្មាន ដែលទ្រង់បញ្ញត្តក្នុងនគរវេសាលី សិក្ខាបទប៉ុន្មាន ដែលទ្រង់បញ្ញត្តក្នុងនគររាជគ្រឹះ សិក្ខាបទប៉ុន្មាន ដែលទ្រង់បញ្ញត្តក្នុងនគរសាវត្ថី សិក្ខាបទប៉ុន្មាន ដែលទ្រង់បញ្ញត្តក្នុងនគរអាឡវី សិក្ខាបទប៉ុន្មាន ដែលទ្រង់បញ្ញត្តក្នុងនគរកោសម្ពី សិក្ខាបទប៉ុន្មាន ដែលទ្រង់បញ្ញត្តក្នុងដែនសក្កៈ សិក្ខាបទប៉ុន្មាន ដែលទ្រង់បញ្ញត្តក្នុងភគ្គជនបទ ខ្ញុំព្រះអង្គសួរនូវសេចក្តីណា សូមទ្រង់ព្រះមេត្តាប្រោស ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ។ ព្រះអង្គ ទ្រង់ត្រាស់ថា តថាគតបញ្ញត្តសិក្ខាបទ១០ ក្នុងនគរវេសាលី តថាគតបញ្ញត្តសិក្ខាបទ២១ ក្នុងនគររាជគ្រឹះ តថាគតបញ្ញត្តសិក្ខាបទទាំងអស់២៩៤ក្នុងនគរសាវត្ថី តថាគតបញ្ញត្តសិក្ខាបទ៦ ក្នុងនគរអាឡវី តថាគតបញ្ញត្តសិក្ខាបទ៨ ក្នុងនគរកោសម្ពី តថាគតបញ្ញត្តសិក្ខាបទ៨ ក្នុងដែនសក្កៈ តថាគតបញ្ញត្តសិក្ខាបទ៣ ក្នុងដែនភគ្គៈ។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្តក្នុងនគរវេសាលី អ្នកចូរប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ មេថុនធម្មសិក្ខាបទ១ មនុស្សវិគ្គហសិក្ខាបទ១ ឧត្តរិមនុស្សធម្មសិក្ខាបទ១ អតិរេកសិក្ខាបទ[16] ១ កាឡកសិក្ខាបទ១ ភូតគាមសិក្ខាបទ១ បរម្បរាភត្តសិក្ខាបទ១ ទន្តបោណសិក្ខាបទ១ អចេលកសិក្ខាបទ១ ភិក្ខុនីសុអក្កោសកសិក្ខាបទ១ ទាំង១០សិក្ខាបទនេះ តថាគតបញ្ញត្តក្នុងនគរវេសាលី។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្តក្នុងនគររាជគ្រឹះ អ្នកចូរប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ អទិន្នាទានសិក្ខាបទ១ (សញ្ញាចិកសិក្ខាបទ[17] ១) អនុទ្ធំសនសិក្ខាបទទាំងពីរ ភេទសិក្ខាបទទាំងពីរ អន្តរវាសកសិក្ខាបទ[18] ១ រូបិយសិក្ខាបទ១ សុត្តវិញ្ញត្តិសិក្ខាបទ១ ឧជ្ឈាបនកសិក្ខាបទ១ បាចិតបិណ្ឌសិក្ខាបទ[19] ១ គណភោជនសិក្ខាបទ១ វិកាលភោជនសិក្ខាបទ១ ចារិត្តសិក្ខាបទ១ នហានសិក្ខាបទ១ ឩនវីសសិក្ខាបទ១ ចីវរទានសិក្ខាបទ[20] ១ វោសាសន្តិសិក្ខាបទ[21] ១ សិក្ខាបទទាំងនេះ តថាគតបញ្ញត្ត ក្នុងនគររាជគ្រឹះ។ គិរគ្គសិក្ខាបទ១ ចារិកសិក្ខាបទ១ ឆន្ទទានសិក្ខាបទ[22] ១ (សិក្ខាបទទាំងនេះ រួមពីលើមក ត្រូវជា)២១សិក្ខាបទ តថាគតបញ្ញត្ត ក្នុងក្រុងរាជគ្រឹះនោះដែរ។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្តក្នុងនគរសាវត្ថី អ្នកចូរប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ បារាជិកសិក្ខាបទ៤ សង្ឃាទិសេសសិក្ខាបទ១៦ អនិយតសិក្ខាបទ២ និស្សគ្គិយសិក្ខាបទ៣៤[23] សិក្ខាបទ ១៥៦ ដែលតថាគតហៅថា ខុទ្ទកសិក្ខាបទ គារយ្ហសិក្ខាបទ១០ និងសេក្ខិយវត្ត៧២។ រួមទាំងអស់ត្រូវជាសិក្ខាបទ២៩៤ ដែលតថាគតបញ្ញត្ត ក្នុងនគរសាវត្ថី។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្ត ក្នុងនគរអាឡវី អ្នកចូរប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ កុដិការសិក្ខាបទ១ កោសិយសិក្ខាបទ១ បឋមសហសេយ្យសិក្ខាបទ១ បឋវីខណនសិក្ខាបទ១ ភូតគាមសិក្ខាបទ១ សប្បាណកសិក្ខាបទ១ សិក្ខាបទទាំង៦នេះ តថាគតបញ្ញត្ត ក្នុងនគរអាឡវី។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្តក្នុងនគរកោសម្ពី អ្នកចូរប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ មហល្លកសិក្ខាបទ[24]) ១ ទុព្វចជាតិកសិក្ខាបទ១ អញ្ញវាទកសិក្ខាបទ១ មហល្លកសិក្ខាបទ[25]) ១ សុរាបានសិក្ខាបទ១ អនាទរិយសិក្ខាបទ១ សហធម្មិកសិក្ខាបទ១ សុរុសុរុការកសិក្ខាបទ១ ជាគំរប់៨។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្ត ក្នុងដែនសក្កៈ ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ ឯឡកលោមធោវាបនសិក្ខាបទ១ បត្តសិក្ខាបទ[26] ១ ឱវាទសិក្ខាបទ[27] ១ ភេសជ្ជសិក្ខាបទ[28] ១ សូចិឃរសិក្ខាបទ១ អារញ្ញកសេនាសនសិក្ខាបទ១ ទាំង៦សិក្ខាបទនេះ តថាគតបញ្ញត្ត ក្នុងក្រុងកបិលព័ស្តុ។ ឧទកសុទ្ធិយសិក្ខាបទ និងឱវាទុបសង្កមនសិក្ខាបទ ក្នុងភិក្ខុនីវិភង្គ ក៏តថាគតបញ្ញត្ត (ក្នុងដែនសក្កៈ

ដែរ)។ សិក្ខាបទទាំងឡាយណា ដែលតថាគតបញ្ញត្តក្នុង ដែនភគ្គៈ ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ ជោតិសមាទហនវិសិព្វនសិក្ខាបទ១ សាមិសសិក្ខាបទ១ សសិត្ថកសិក្ខាបទ១។ បារាជិកសិក្ខាបទ៤ សង្ឃាទិសេសសិក្ខាបទ៧ និស្សគ្គិយសិក្ខាបទ៨ ខុទ្ទកសិក្ខាបទ៣២ បាដិទេសនីយសិក្ខាបទ២ សេក្ខិយសិក្ខាបទ៣ ទាំង៥៦សិក្ខាបទ (នេះ) ព្រះពុទ្ធដែលជាអាទិច្ចពន្ធុ ទ្រង់បញ្ញត្តក្នុងនគរទាំង៦ សិក្ខាបទទាំងអស់មាន២៩៤ ព្រះគោតមដ៏មានយស ទ្រង់បញ្ញត្តក្នុងនគរសាវត្ថី។

## (ចតុវិបត្តិ ទី២)

CS vin.pv.07.02 | ភាគ ទី១៣

### (២. ចតុវិបត្តិំ)

[១០២] ខ្ញុំព្រះអង្គបានសួរហើយ នូវប្រស្នាណា ព្រះអង្គក៏បានសំដែងហើយ ដល់ខ្ញុំព្រះអង្គ (១ទៀត) ពាក្យណាដែលខ្ញុំព្រះអង្គ បានទូលសួរហើយ ព្រះអង្គក៏បានព្យាករពាក្យនោះ ដោយមិនមានលើសខ្វះ។ ខ្ញុំព្រះអង្គ សូមសួរនូវប្រស្នាដោយឡែកទៀត សូមទ្រង់សំដែងនូវប្រស្នានោះមក។ សូមសួរថា គរុកាបត្តិក្តី លហុកាបត្តិក្តី សាវសេសាបត្តិក្តី អនវសេសាបត្តិក្តី ទុដ្ឋុល្លាបត្តិក្តី អទុដ្ឋុល្លាបត្តិក្តី ភិក្ខុទាំងឡាយ ដែលត្រូវអាបត្តិ ជាយាវតតិយកាក្តី (សិក្ខាបទ) ដែលជា សាធារណប្បញ្ញត្តិក្តី ជាអសាធារណប្បញ្ញត្តិក្តី វិបត្តិទាំងឡាយ តែងរម្ងាប់ ដោយសមថៈទាំងឡាយណាក្តី សូមព្រះអង្គព្យាករ នូវពាក្យទាំងឡាយ មានអាបត្តិជាដើមនេះ។ ហឺ យើងទាំងឡាយ នឹងស្តាប់នូវព្រះពុទ្ធដីការបស់ព្រះអង្គ។ អាបត្តិទាំងឡាយ ដែលចាត់ជាគរុកាបត្តិ មាន៣១[29] អាបត្តិទាំងឡាយ ដែលចាត់ជាអនវសេសាបត្តិមាន៨ មកក្នុងទីនេះ អាបត្តិទាំងឡាយណា ជាគរុកាបត្តិក្តី អាបត្តិទាំងនោះ ហៅថា ទុដ្ឋុល្លាបត្តិ អាបត្តិទាំងឡាយណា ជាទុដ្ឋុល្លាបត្តិ អាបត្តិទាំងនោះ ហៅថា សីលវិបត្តិ។ បារាជិកាបត្តិ និងសង្ឃាទិសេសាបត្តិ ព្រះសម្មាសម្ពុទ្ធ ទ្រង់ហៅថា សីលវិបត្តិ។ ថុល្លច្ចយាបត្តិ បាចិត្តិយាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ និងទុព្ភាសិតាបត្តិ ដូចយ៉ាងភិក្ខុណា មានសេចក្តីប៉ុនប៉ងនឹងសើចលេងហើយជេរ។ អាបត្តិទាំងនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ជាអាចារវិបត្តិ។

[១០៣] ភិក្ខុទាំងឡាយ ដែលអសទ្ធម្មរួបរឹត ជាអ្នកអាប់ប្រាជ្ញា ដែលមោហៈបិទបាំង ប្រកាន់ទិដ្ឋិខុស តែងពោលបង្កាច់ នូវព្រះសម្មាសម្ពុទ្ធនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ជាទិដ្ឋិវិបត្តិ។

[១០៤] ភិក្ខុមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្តីប្រាថ្នា ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន (ក្នុងខ្លួន) ដែលមិនពិត ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ជាភិក្ខុប្រព្រឹត្តនិយាយដឹកនាំបុរសឲ្យស្ត្រី ដឹកនាំស្ត្រីឲ្យបុរស ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ភិក្ខុពោលថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះឯង ជាព្រះអរហន្ត ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ភិក្ខុសូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួន មកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ភិក្ខុនីសូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួន យកមកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ភិក្ខុដែលមិនមានជម្ងឺ សូមសំឡក្តី បាយក្តី ដើម្បីប្រយោជន៍ដល់ខ្លួន យកមកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ។ នេះព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ជាអាជីវវិបត្តិ។

[១០៥] បុគ្គល១១រូប (ត្រូវអាបត្តិក្នុងខណៈ ដែលសង្ឃសូត្រសមនុភាសនកម្ម)ចប់ ជាគំរប់៣ដង ចូរអ្នកប្រុងស្តាប់ នូវសេចក្តីនៃបុគ្គលទាំងនោះ ដូចសំដែងតទៅនេះ គឺឧក្ខិត្តានុវត្តិកភិក្ខុមួយពួក ភិក្ខុដែលត្រូវអាបត្តិក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្ម) ចប់ ជាគំរប់៣ដង ៨រូប អរិដ្ឋភិក្ខុមួយរូប ចណ្ឌកាលីភិក្ខុនីមួយរូប បុគ្គលទាំងប៉ុណ្ណេះ (ត្រូវអាបត្តិក្នុងខណៈ ដែលសង្ឃសូត្រសមនុភាសនកម្ម) ចប់ ជាគំរប់៣ដង។

## (ឆេទនកាទិ ទី៣)

CS vin.pv.07.03 | ភាគ ទី១៣

### (៣. ឆេទនកាទិ)

[១០៦] សួរថា ព្រះពុទ្ធដែលជាអាទិច្ចពន្ធុ ទ្រង់បញ្ញត្តថា សិក្ខាបទដែលមានកិរិយាកាត់ចេញ ជាវិនយកម្ម មានប៉ុន្មាន សិក្ខាបទដែលមានកិរិយាបំបែកចេញ ជាវិនយកម្ម មានប៉ុន្មាន សិក្ខាបទ ដែលមានកិរិយាកកាយចេញ ជាវិនយកម្ម មានប៉ុន្មាន អនញ្ញបាចិត្តិយសិក្ខាបទ គឺបាចិត្តិយៈ ដែលមានពាក្យថា មិនមែនហេតុដទៃ មានប៉ុន្មាន សិក្ខាបទ ដែលនិយាយពីការសន្មតិភិក្ខុ មានប៉ុន្មាន សិក្ខាបទដែលនិយាយពីសាមីចិកម្ម មានប៉ុន្មាន សិក្ខាបទដែលនិយាយពីកំណត់ មានប៉ុន្មាន សិក្ខាបទដែលមានពាក្យថាដឹង មានប៉ុន្មាន។

ឆ្លើយថា ព្រះពុទ្ធជាអាទិច្ចពន្ធុ ទ្រង់បញ្ញត្តថា សិក្ខាបទដែលមានកិរិយាកាត់ចេញ ជាវិនយកម្ម មាន៦ សិក្ខាបទដែលមានកិរិយាបំបែកចេញ ជាវិនយកម្ម មាន១ សិក្ខាបទ ដែលមានកិរិយាកកាយចេញ ជាវិនយកម្មមាន១ អនញ្ញបាចិត្តិយសិក្ខាបទមាន៤ សិក្ខាបទដែលនិយាយពីការសន្មតិភិក្ខុ មាន៤ សិក្ខាបទដែលនិយាយពីសាមីចិកម្ម មាន៧ សិក្ខាបទដែលនិយាយពីកំណត់ មាន១៤ សិក្ខាបទដែលមានពាក្យថាដឹង មាន១៦។

## (អសាធារណាទិ ទី៤)

CS vin.pv.07.04 | ភាគ ទី១៣

### (៤. អសាធារណាទិ)

[១០៧] សិក្ខាបទរបស់ភិក្ខុ មាន២២០ ដែលមកកាន់ឧទ្ទេសរាល់ៗថ្ងៃឧបោសថ សិក្ខាបទភិក្ខុនី មាន៣០៤ ដែលមកកាន់ឧទ្ទេស រាល់ៗថ្ងៃឧបោសថ។

សិក្ខាបទ៤៦របស់ភិក្ខុ មិនបានទួទៅដល់ពួកភិក្ខុនី សិក្ខាបទ១៣០ របស់ភិក្ខុនី មិនបានទួទៅដល់ពួកភិក្ខុ បូករួមត្រូវជា១៧៦សិក្ខាបទ ជាសិក្ខាបទមិនទួទៅ ដល់បុគ្គលទាំងពីរពួក គឺភិក្ខុ និងភិក្ខុនីទេ សិក្ខាបទ១៧៤ ដែលបុគ្គលទាំងពីរពួកត្រូវសិក្សាស្មើភាគគ្នា។

[១០៨] សិក្ខាបទរបស់ភិក្ខុមាន២២០ តែងមកកាន់ឧទ្ទេសក្នុងថ្ងៃឧបោសថទាំងឡាយ ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ បារាជិក៤ សង្ឃាទិសេស១៣ អនិយត២ និស្សគ្គិយៈ៣០ ខុទ្ទកៈ (បាចិត្តិយៈ)៩២ បាដិទេសនីយៈ៤ សេក្ខិយៈ៧៥ ទាំង២២០នេះ ជាសិក្ខាបទរបស់ភិក្ខុ តែងមកកាន់ឧទ្ទេសរាល់ៗថ្ងៃឧបោសថ។

[១០៩] សិក្ខាបទរបស់ពួកភិក្ខុនីមាន៣០៤ តែងមកកាន់ឧទ្ទេស រាល់ៗថ្ងៃឧបោសថ ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ បារាជិក៨ សង្ឃាទិសេស១៧ និស្សគ្គិយៈ៣០ ខុទ្ទកៈ (បាចិត្តិយៈ)១៦៦ បាដិទេសនីយៈ៨ សេក្ខិយៈ៧៥ ទាំង៣០៤នេះ ជាសិក្ខាបទរបស់ភិក្ខុនី ដែលមកកាន់ឧទ្ទេសរាល់ៗថ្ងៃឧបោសថ។

[១១០] សិក្ខាបទរបស់ពួកភិក្ខុមាន៤៦ ដែលមិនបានទួទៅ ដល់ពួកភិក្ខុនី ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ សង្ឃាទិសេស៦ អនិយត២ ត្រូវជា៨សិក្ខាបទ និស្សគ្គិយៈ១២ទៀត ត្រូវជា២០សិក្ខាបទ ខុទ្ទកៈ២២ និងបាដិទេសនីយៈ៤ ទាំង៤៦នេះ ជាសិក្ខាបទរបស់ពួកភិក្ខុ មិនបានទួទៅដល់ពួកភិក្ខុនីទេ។

[១១១] សិក្ខាបទរបស់ពួកភិក្ខុនីមាន១៣០ ដែលមិនបានទួទៅ ដល់ពួកភិក្ខុ ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ បារាជិក៤ សង្ឃាទិសេស១០ និស្សគ្គិយៈ១២ ខុទ្ទកៈ៩៦ បាដិទេសនីយៈ៨ ទាំង១៣០នេះ ជាសិក្ខាបទរបស់ពួកភិក្ខុនី មិនទួទៅ ដល់ភិក្ខុទាំងឡាយទេ។

[១១២] សិក្ខាបទ១៧៦[30] ដែលមិនទួទៅដល់បុគ្គលទាំងពីរពួក ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ បារាជិក៤ សង្ឃាទិសេស១៦ អនិយត២ និស្សគ្គិយៈ២៤ ខុទ្ទកៈ១១៨ បាដិទេសនីយៈ១២ ទាំង១៧៦នេះ មិនបានទួទៅដល់បុគ្គលទាំងពីរពួកទេ។

[១១៣] សិក្ខាបទដែលបុគ្គលទាំងពីរពួក ត្រូវសិក្សាស្មើភាគគ្នា មាន១៧៤ ចូរអ្នកប្រុងស្តាប់សិក្ខាបទទាំងនោះ ដូចសំដែងតទៅនេះ។ បារាជិក៤ សង្ឃាទិសេស៧ និស្សគ្គិយៈ១៨ ខុទ្ទកៈ៧០គត់ សេក្ខិយៈ៧៥ ដែលបុគ្គលទាំងពីរពួក ត្រូវសិក្សាស្មើភាគគ្នា។

[១១៤] បុគ្គល គឺភិក្ខុ និងភិក្ខុនីទាំងឡាយណា ត្រូវអាបត្តិបារាជិកទាំង៨ហើយ បុគ្គលទាំងនោះ ជាអ្នកមានកិត្តិសព្ទអាក្រក់ មិនបានលូតលាស់ចំរើនឡើងទេ ជននោះឧបមាដូចដើមត្នោត ដែលគេកាស់រំលើង ដូចស្លឹកឈើទុំ (ដែលជ្រុះចាកទង) ដូចថ្មតាន់ (ដែលបែកដាច់ពីគ្នា) ដូចមនុស្សកំបុតក្បាល ដូចដើមត្នោតកំបុតក។

[១១៥] សង្ឃាទិសេស២៣ អនិយត២ និស្សគ្គិយៈ៤២ បាចិត្តិយៈ១៨៨ បាដិទេសនីយៈ១២ សេក្ខិយៈ៧៥ រម្ងាប់ដោយសមថៈ៣យ៉ាង គឺសម្មុខាវិន័យ១ បដិញ្ញាតករណៈ១ តិណវត្ថារកៈ១។

[១១៦] ឧបោសថមាន២យ៉ាង បវារណាមាន២យ៉ាង សង្ឃកម្មមាន៤យ៉ាង ដែលព្រះជិនស្រីទ្រង់សំដែងទុកមក ឧទ្ទេស (របស់ភិក្ខុ) មាន៥ ឧទ្ទេស (របស់ភិក្ខុនី) មាន៤ មិនមានក្រៅពីនេះទៅទៀតទេ ឯកងនៃអាបត្តិមាន៧។

[១១៧] អធិករណ៍ មាន៤យ៉ាង រម្ងាប់ដោយសមថៈ៧ គឺរម្ងាប់ដោយសមថៈ២ខ្លះ ៤ខ្លះ ៣ខ្លះ ឯកិច្ចាធិករណ៍ រម្ងាប់ដោយសមថៈ១។

## (បារាជិកាទិអាបត្តិ ទី៥)

CS vin.pv.07.05 | ភាគ ទី១៣

### (៥. បារាជិកាទិអាបត្តិ)

[១១៨] សិក្ខាបទណា ដែលតថាគតហៅថា បារាជិក ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ បុគ្គលដែលឃ្លាតខុស ភ្លាត់របូតចាកព្រះសទ្ធម្មទាំងឡាយហើយ សំវាស មិនមានក្នុងបុគ្គលនោះឡើយ ព្រោះហេតុនោះ សិក្ខាបទនុ៎ះ តថាគតហៅថា បារាជិក។

[១១៩] សិក្ខាបទណា ដែលតថាគតហៅថា សង្ឃាទិសេស ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ សង្ឃឲ្យបរិវាសទាញមកដាក់ក្នុងមូលាបត្តិ ឲ្យមានត្ត ឲ្យអព្ភាន ព្រោះហេតុនោះ សិក្ខាបទនុ៎ះ តថាគតហៅថា សង្ឃាទិសេស។

[១២០] សិក្ខាបទណា ដែលតថាគតហៅថា អនិយត ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ ពាក្យថា អនិយត បានសេចក្តីថា មិនទៀង មានចំណែកមិនតែមួយទេ បណ្តាអាបត្តិទាំង៣យ៉ាង (វិន័យធរគប្បីកាត់តាម) អាបត្តិណាមួយ ដែលតថាគតហៅថា អនិយត។

[១២១] សិក្ខាបទណា ដែលតថាគតហៅថា ថុល្លច្ច័យ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ ភិក្ខុណាសំដែង (អាបត្តិ) ក្នុងទីជិតភិក្ខុមួយរូប ឬក៏ភិក្ខុណាទទួលអាបត្តិនោះ ទោស (របស់ភិក្ខុអ្នកទទួល) មិនមែនមានដូចជាភិក្ខុអ្នកសំដែងនោះឡើយ ព្រោះហេតុដូច្នោះ សិក្ខាបទនុ៎ះ ទើបតថាគតហៅថា ថុល្លច្ច័យ។

[១២២] សិក្ខាបទណា ដែលតថាគតហៅថា និស្សគ្គិយៈ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ ភិក្ខុលះបង់ (វត្ថុណាមួយ) ក្នុងកណ្តាលជំនុំសង្ឃ ឬកណ្តាលគណៈ ពុំនោះសោត ចំពោះបុគ្គលមួយរូប ក្នុងទីជាមួយគ្នា រួចហើយទើបសំដែងអាបត្តិចេញ ព្រោះហេតុដូច្នោះ សិក្ខាបទនុ៎ះ តថាគតហៅថា និស្សគ្គិយៈ។

[១២៣] សិក្ខាបទណា ដែលតថាគតហៅថា បាចិត្តិយៈ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ សិក្ខាបទណា ញុំាងកុសលធម៌ឲ្យធ្លាក់ចុះ ប្រទូស្តចំពោះអរិយមគ្គ ជាហេតុធ្វើចិត្តឲ្យវង្វេង ព្រោះហេតុដូច្នោះ សិក្ខាបទនុ៎ះ តថាគតហៅថា បាចិត្តិយៈ។

[១២៤] សិក្ខាបទណា ដែលតថាគតហៅថា បាដិទេសនីយៈ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ ភិក្ខុមិនមែនជាញាតិ ទទួលភោជនខ្លួនឯង (អំពីដៃភិក្ខុនី) ដែលរកបានដោយកម្រ ហើយបរិភោគ សិក្ខាបទនុ៎ះ តថាគតហៅថា គារយ្ហៈ (បាដិទេសនីយៈ)។ ភិក្ខុកំពុងឆាន់ក្នុងទីដែលគេនិមន្ត បើមានភិក្ខុនីបង្គាប់គេ ឲ្យចាត់ចែង (ភោជន) តាមសេចក្តីពេញចិត្ត (ខ្លួន) ក្នុងទីនោះ ហើយភិក្ខុមិនហាមឃាត់ ចេះតែឆាន់ក្នុងទីនោះ សិក្ខាបទនុ៎ះ តថាគតហៅថា គារយ្ហៈ។ ភិក្ខុមិនមានជម្ងឺ ទៅកាន់ត្រកូល ដែលមានចិត្តសទ្ធា តែមានភោគៈតិច ដែលគេមិនមានសេចក្តីខ្វល់ខ្វាយ ហើយបរិភោគក្នុងផ្ទះ នៃត្រកូលនោះ សិក្ខាបទនុ៎ះ តថាគតហៅថា គារយ្ហៈ។ បើភិក្ខុ (មិនមានជម្ងឺ) នៅក្នុងព្រៃ ដែលប្រកបដោយរង្កៀស ប្រកបដោយភ័យ (ទទួលខាទនីយភោជនីយាហារ) ដែលគេមិនបានឲ្យដំណឹងជាមុន ហើយបរិភោគក្នុងទីនោះ សិក្ខាបទនុ៎ះ តថាគតហៅថា គារយ្ហៈ។ ភិក្ខុនីមិនមែនជាញាតិ ទៅសូមវត្ថុ ដែលពួកជនដទៃ តែងរាប់អានថា ជារបស់អញ ទោះជាទឹកដោះថ្លាក្តី ប្រេងក្តី ទឹកឃ្មុំក្តី ទឹកអំពៅក្តី ត្រីសាច់ក្តី ទឹកដោះស្រស់ ឬទឹកដោះជូរក្តី ដោយខ្លួនឯង ភិក្ខុនី (នោះ) ដល់ហើយនូវសេចក្តីតិះដៀល ក្នុងសាសនាព្រះសុគត គឺត្រូវបាដិទេសនីយៈ។

[១២៥] សិក្ខាបទណា ដែលតថាគតហៅថា ទុក្កដ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ អំពើអាក្រក់ណា ទោះខុសក្តី ឆ្គាំឆ្គងក្តី ភ្លាំងភ្លាត់ក្តី មនុស្សធ្វើអំពើបាបណាមួយ ទោះក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី អ្នកប្រាជ្ញទាំងឡាយ តែងហៅថា អំពើអាក្រក់ ព្រោះហេតុដូច្នោះ សិក្ខាបទនុ៎ះ តថាគតហៅថា ទុក្កដ។

[១២៦] សិក្ខាបទណា ដែលតថាគតហៅថា ទុព្ភាសិត ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ បទណា ដែលបុគ្គលពោលអាក្រក់ក្តី ភ្លាំងភ្លាត់ក្តី សៅហ្មងក្តី អ្នកប្រាជ្ញទាំងឡាយ តែងតិះដៀលនូវបទ (ទាំងនោះ) ណាមួយ ព្រោះហេតុដូច្នោះ សិក្ខាបទនុ៎ះ តថាគតហៅថា ទុព្ភាសិត។

[១២៧] សិក្ខាបទណា ដែលតថាគតហៅថា សេក្ខិយៈ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសំដែងតទៅនេះ។ ការប្រព្រឹត្តជាដើមអាទិនុ៎ះក្តី សេចក្តីសង្រួមប្រយ័ត្នមុខមាត់ក្តី រមែងជារបស់បុគ្គល ដែលសិក្សាហើយ ដែលកំពុងសិក្សា កំពុងប្រព្រឹត្តតាមលំអានផ្លូវត្រង់ តែការសិក្សាប្រាកដដូច្នោះ មិនមាន ព្រោះហេតុនោះ សិក្ខាបទនុ៎ះ តថាគតហៅថា សេក្ខិយៈ។ ភិក្ខុដែលបិទបាំង (មូលាបត្តិ) ទុក នឹងត្រឡប់ត្រូវអាបត្តិថ្មីទៀត ភិក្ខុដែលបើក (ប្រាប់មូលាបត្តិ) នឹងមិនត្រូវអាបត្តិថ្មីទៀតឡើយ ព្រោះហេតុដូច្នោះ គួរបើកនូវមូលាបត្តិ ដែលខ្លួនបិទបាំងទុក ធ្វើយ៉ាងនេះ ទើបបានមិនត្រូវអាបត្តិថ្មីនោះទៀត។ ព្រៃជាដំណើររបស់ពួកម្រឹគ អាកាស ជាដំណើររបស់ពួកបក្សី សេចក្តីវិនាស ជាដំណើររបស់សង្ខតធម៌ទាំងឡាយ ព្រះនិព្វាន ជាដំណើររបស់ព្រះអរហន្ត។

ចប់ គាថាសង្គណិកៈ (គាថាឆ្លូកឆ្លាស់គ្នា)។

ឧទ្ទាន គឺបញ្ជីរឿង នៃគាថាសង្គណិកៈនោះ ដូច្នេះ

[១២៨]

សំដែងអំពីសិក្ខាបទទាំងឡាយ ដែលទ្រង់បញ្ញត្តក្នុងនគរទាំងប្រាំពីរ១ សំដែងអំពីវិបត្តិ៤យ៉ាង របស់ភិក្ខុ និងភិក្ខុនី១ សំដែងអំពីសិក្ខាបទជាសាធារណៈ និងអសាធារណៈ របស់ពួកភិក្ខុ និងភិក្ខុនី១ គាថាសង្គណិកៈ (គាថាឆ្លូកឆ្លាស់គ្នា) នេះ លោកសំដែង ដើម្បីអនុគ្រោះដល់ព្រះសាសនា។

# អធិករណភេទ

CS vin.pv.08 | ភាគ ទី១៣

### (អធិករណភេទោ)

## (ឧក្កោដនភេទាទិ ទី១)

CS vin.pv.08.01 | ភាគ ទី១៣

### (១. ឧក្កោដនភេទាទិ)

[១២៩] អធិករណ៍មាន៤យ៉ាង គឺវិវាទធិករណ៍១ អនុវាទាធិករណ៍១ អាបត្តាធិករណ៍១ កិច្ចាធិករណ៍១។ នេះហៅថា អធិករណ៍៤យ៉ាង។ អធិករណ៍ទាំង៤យ៉ាងនេះ មានការសើរើ គឺហាមឃាត់ប៉ុន្មានយ៉ាង។ អធិករណ៍ទាំង៤យ៉ាងនេះ មានការសើរើ១០យ៉ាង គឺវិវាទាធិករណ៍ មានការ

សើរើ២យ៉ាង អនុវាទាធិករណ៍ មានការសើរើ៤យ៉ាង អាបត្តាធិករណ៍ មានការសើរើ៣យ៉ាង កិច្ចាធិករណ៍ មានការសើរើតែ១។ អធិករណ៍ទាំង៤យ៉ាងនេះ មានការសើរើទាំង១០នេះឯង។ កាលបើសើរើវិវាទាធិករណ៍ តែងសើរើនូវសមថៈប៉ុន្មាន កាលបើសើរើអនុវាទាធិករណ៍ តែងសើរើនូវសមថៈប៉ុន្មាន កាលបើសើរើអាបត្តាធិករណ៍ តែងសើរើនូវសមថៈប៉ុន្មាន កាលបើសើរើកិច្ចាធិករណ៍ តែងសើរើនូវសមថៈប៉ុន្មាន។ កាលបើសើរើវិវាទាធិករណ៍ តែងសើរើនូវសមថៈ២យ៉ាង កាលបើសើរើអនុវាទាធិករណ៍ តែងសើរើនូវសមថៈ៤យ៉ាង កាលបើសើរើអាបត្តាធិករណ៍ តែងសើរើនូវសមថៈ៣យ៉ាង កាលបើសើរើកិច្ចាធិករណ៍ តែងសើរើនូវសមថៈ១យ៉ាង។

[១៣០] ការសើរើមានប៉ុន្មាន ភិក្ខុបាននូវការសើរើ ដោយអាការប៉ុន្មាន បុគ្គលដែលប្រកបដោយអង្គប៉ុន្មាន ទើបសើរើអធិករណ៍បាន បុគ្គលប៉ុន្មានពួក កាលសើរើអធិករណ៍ទៅហើយ ត្រូវអាបត្តិ (ខ្លួនឯង)។ ការសើរើមាន១២យ៉ាង ភិក្ខុបាននូវការសើរើ ដោយអាការ១០យ៉ាង បុគ្គលដែលប្រកបដោយអង្គ៤ ទើបសើរើនូវអធិករណ៍បាន បុគ្គល៤ពួក កាលបើសើរើអធិករណ៍ទៅហើយ តែងត្រូវអាបត្តិ (ខ្លួនឯងវិញ)។ ការសើរើទាំង១២នោះ ដូចម្តេចខ្លះ។ ការសើរើទាំង១២នោះ គឺកម្មដែលសង្ឃមិនទាន់ធ្វើ១ កម្មដែលសង្ឃធ្វើមិនត្រឹមត្រូវ១ កម្មដែលសង្ឃត្រូវធ្វើជាថ្មីទៀត១ កម្មដែលសង្ឃមិនទាន់សម្រេច១ កម្មដែលសង្ឃសម្រេចហើយមិនត្រឹមត្រូវ១ កម្មដែលសង្ឃត្រូវសម្រេចជាថ្មីទៀត១ កម្មដែលសង្ឃមិនទាន់វិនិច្ឆ័យ១ កម្មដែលសង្ឃវិនិច្ឆ័យហើយ មិនត្រឹមត្រូវ១ កម្មដែលសង្ឃត្រូវវិនិច្ឆ័យជាថ្មីទៀត១ កម្មដែលសង្ឃមិនទាន់បានរម្ងាប់១ កម្មដែលសង្ឃរម្ងាប់ហើយមិនត្រឹមត្រូវ១ កម្មដែលសង្ឃត្រូវរម្ងាប់ជាថ្មីទៀត[31)] ១។ ភិក្ខុបាននូវការសើរើ ដោយអាការ១០ (នោះ) ដូចម្តេចខ្លះ។ ភិក្ខុសើរើនូវអធិករណ៍ ដែលកើតក្នុងទីនោះ១ សើរើនូវអធិករណ៍ ដែលកើតក្នុងទីនោះ ហើយរម្ងាប់ទៅវិញ១ សើរើនូវអធិករណ៍ ក្នុងទីពាក់កណ្តាលផ្លូវ១ សើរើនូវអធិករណ៍ ដែលស្ងប់រម្ងាប់ហើយ ក្នុងទីពាក់កណ្តាលផ្លូវ១ សើរើនូវអធិករណ៍ ដែលដល់ហើយក្នុងទីនោះ១ សើរើនូវអធិករណ៍ ដែលដល់ក្នុងទីនោះ ហើយស្ងប់រម្ងាប់១ សើរើនូវសតិវិន័យ១ សើរើនូវអមូឡ្ហវិន័យ១ សើរើនូវតស្សបាបិយសិកា១ សើរើនូវតិណវត្ថារកៈ១។ ភិក្ខុបាននូវការសើរើដោយអាការ១០យ៉ាងនេះឯង។ បុគ្គលដែលប្រកបដោយអង្គ៤ ដូចម្តេចខ្លះ ទើបសើរើនូវអធិករណ៍។ បុគ្គលលុះឆន្ទាគតិ១ ទើបសើរើនូវអធិករណ៍ លុះទោសាគតិ១។បេ។ លុះមោហាគតិ១ លុះភយាគតិ១ ទើបសើរើនូវអធិករណ៍។ បុគ្គលដែលប្រកបដោយអង្គ៤ប្រការនេះឯង ទើបសើរើនូវអធិករណ៍។ បុគ្គល៤ពួក ដូចម្តេចខ្លះ កាលបើសើរើនូវអធិករណ៍ តែងត្រូវអាបត្តិ (ខ្លួនឯងវិញ)។ បុគ្គលទើបនឹងបានឧបសម្បទាក្នុងថ្ងៃនោះ សើរើ ត្រូវឧក្កោដនកបាចិត្តិយៈ១ បុគ្គលដែលទើបមកថ្មី សើរើ ត្រូវឧក្កោដនកបាចិត្តិយៈ១ បុគ្គលជាអ្នកធ្វើការ (រម្ងាប់អធិករណ៍នោះៗ) សើរើ ត្រូវឧក្កោដនកបាចិត្តិយៈ១ បុគ្គលអ្នកឲ្យឆន្ទៈ សើរើ ត្រូវឧក្កោដនកបាចិត្តិយៈ១។ បុគ្គលទាំង៤ពួកនេះ កាលបើសើរើអធិករណ៍ តែងត្រូវអាបត្តិ (ខ្លួនឯងវិញ)។

## (អធិករណនិទានាទិ ទី២)

CS vin.pv.08.02 | ភាគ ទី១៣

### (២. អធិករណនិទានាទិ)

[១៣១] វិវាទាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ អនុវាទាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ អាបត្តាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ កិច្ចាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ វិវាទាធិករណ៍ មានសេចក្តីទាស់ទែង ជាគ្រឿងប្រគល់ឲ្យនូវផល មានសេចក្តីទាស់ទែង ជាហេតុឲ្យកើតឡើង មានសេចក្តីទាស់ទែងជាកំណើត មានសេចក្តីទាស់ទែងជាដែន មានសេចក្តីទាស់ទែងជាអង្គ មានសេចក្តីទាស់ទែងជាសមុដ្ឋាន។ អនុវាទាធិករណ៍ មានការចោទជាគ្រឿងប្រគល់ឲ្យនូវផល មានការចោទ ជាហេតុឲ្យកើតឡើង មានការចោទ ជាកំណើត មានការចោទជាដែន មានការចោទជាអង្គ មានការចោទជាសមុដ្ឋាន។ អាបត្តាធិករណ៍ មានអាបត្តិ ជាគ្រឿងប្រគល់ឲ្យនូវផល មានអាបត្តិ ជាហេតុឲ្យកើតឡើង មានអាបត្តិជាកំណើត មានអាបត្តិ ជាដែន មានអាបត្តិ ជាអង្គ មានអាបត្តិ ជាសមុដ្ឋាន។ កិច្ចាធិករណ៍ មានកិច្ច ដែលសង្ឃត្រូវធ្វើ ជាគ្រឿងប្រគល់ឲ្យនូវផល មានកិច្ច ដែលសង្ឃត្រូវធ្វើ ជាហេតុឲ្យកើតឡើង មានកិច្ច ដែលសង្ឃត្រូវធ្វើ ជាកំណើត មានកិច្ចដែលសង្ឃត្រូវធ្វើជាដែន មានកិច្ច ដែលសង្ឃត្រូវធ្វើជាអង្គ មានកិច្ចដែលសង្ឃត្រូវធ្វើជាសមុដ្ឋាន។ វិវាទាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ អនុវាទាធិករណ៍។បេ។ អាបត្តាធិករណ៍ កិច្ចាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ វិវាទាធិករណ៍ មានហេតុជាគ្រឿងប្រគល់ឲ្យនូវផល មានហេតុ ជាហេតុឲ្យកើតឡើង មានហេតុជាកំណើត មានហេតុជាដែន មានហេតុជាអង្គ មានហេតុជាសមុដ្ឋាន។ អនុវាទាធិករណ៍។បេ។ អាបត្តាធិករណ៍ កិច្ចាធិករណ៍ មានហេតុជាគ្រឿងប្រគល់ឲ្យនូវផល មានហេតុជាហេតុឲ្យកើតឡើង មានហេតុជាកំណើត មានហេតុជាដែន មានហេតុជាអង្គ មានហេតុជាសមុដ្ឋាន។ វិវាទាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ អនុវាទាធិករណ៍។បេ។ អាបត្តាធិករណ៍ កិច្ចាធិករណ៍ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ វិវាទាធិករណ៍ មានបច្ច័យ ជាគ្រឿងប្រគល់ឲ្យនូវផល មានបច្ច័យ ជាហេតុឲ្យកើតឡើង មានបច្ច័យ ជាកំណើត មានបច្ច័យជាដែន មានបច្ច័យជាអង្គ មានបច្ច័យជាសមុដ្ឋាន។ អនុវាទាធិករណ៍។បេ។ អាបត្តាធិករណ៍ កិច្ចាធិករណ៍ មានបច្ច័យ ជាគ្រឿងប្រគល់ឲ្យនូវផល មានបច្ច័យ ជាហេតុឲ្យកើតឡើង មានបច្ច័យ ជាកំណើត មានបច្ច័យជាដែន មានបច្ច័យជាអង្គ មានបច្ច័យជាសមុដ្ឋាន។

## (អធិករណមូលាទិ ទី៣)

CS vin.pv.08.03 | ភាគ ទី១៣

### (៣. អធិករណមូលាទិ)

[១៣២] អធិករណ៍៤យ៉ាង មានមូលប៉ុន្មាន មានសមុដ្ឋានប៉ុន្មាន។ អធិករណ៍៤យ៉ាង មានមូល៣៣ មានសមុដ្ឋាន៣៣។ អធិករណ៍៤យ៉ាង មានមូល៣៣ដូចម្តេច។ វិវាទាធិករណ៍ មានមូល១២ អនុវាទាធិករណ៍ មានមូល១៤ អាបត្តាធិករណ៍ មានមូល៦ កិច្ចាធិករណ៍ មានមូល១ គឺសង្ឃ។ អធិករណ៍៤យ៉ាង មានមូល៣៣ (ដូចរាប់មក) នេះឯង។ អធិករណ៍៤យ៉ាង មានសមុដ្ឋាន៣៣ ដូចម្តេចខ្លះ។ វិវាទាធិករណ៍ មានភេទករវត្ថុទាំង១៨ ជាសមុដ្ឋាន អនុវាទាធិករណ៍ មានវិបត្តិទាំង៤ជាសមុដ្ឋាន អាបត្តាធិករណ៍ មានកងនៃអាបត្តិទាំង៧ ជាសមុដ្ឋាន កិច្ចាធិករណ៍ មានកម្មទាំង៤ ជាសមុដ្ឋាន។ អធិករណ៍៤យ៉ាង មានសមុដ្ឋាន ៣៣ (ដូចរាប់មក) នេះឯង។

## (អធិករណបច្ចយាបត្តិ ទី៤)

CS vin.pv.08.04 | ភាគ ទី១៣

### (៤. អធិករណបច្ចយាបត្តិ)

[១៣៣] សួរថា វិវាទាធិករណ៍ ជាអាបត្តិ ឬជាអនាបត្តិ។ ឆ្លើយថា វិវាទាធិករណ៍ មិនមែនជាអាបត្តិទេ។ ចុះភិក្ខុត្រូវអាបត្តិព្រោះបច្ច័យនៃវិវាទាធិករណ៍ មានដែរឬទេ។ អើ ភិក្ខុត្រូវអាបត្តិ ព្រោះបច្ច័យនៃវិវាទាធិករណ៍ ក៏មានដែរ។ ចុះភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃវិវាទាធិករណ៍។ ភិក្ខុត្រូវអាបត្តិ២យ៉ាង ព្រោះបច្ច័យនៃវិវាទាធិករណ៍ (គឺភិក្ខុ) ជេរប្រទេចឧបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ១ ជេរប្រទេចអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ១។ ភិក្ខុត្រូវអាបត្តិ២យ៉ាងនេះ ព្រោះបច្ច័យនៃវិវាទាធិករណ៍។ បណ្តាវិបត្តិ៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងវិបត្តិប៉ុន្មាន បណ្តាអធិករណ៍៤យ៉ាង (អាបត្តិទាំងនោះ) ចាត់ជាអធិករណ៍ណា បណ្តាកងនៃអាបត្តិទាំង៧ (អាបត្តិទាំងនោះ) លោកសង្គ្រោះ ដោយកងនៃអាបត្តិប៉ុន្មាន បណ្តាសមុដ្ឋាន នៃអាបត្តិ៦យ៉ាង (អាបត្តិទាំងនោះ) តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន រម្ងាប់ដោយអធិករណ៍ប៉ុន្មាន រម្ងាប់ក្នុងទីដូចម្តេច រម្ងាប់ដោយសមុដ្ឋានប៉ុន្មាន។ បណ្តាវិបត្តិ៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងវិបត្តិ១ គឺអាចារវិបត្តិ បណ្តាអធិករណ៍៤យ៉ាង (អាបត្តិទាំងនោះ) ចាត់ជាអាបត្តាធិករណ៍ បណ្តាកងនៃអាបត្តិទាំង៧ (អាបត្តិទាំងនោះ) លោកសង្គ្រោះ ដោយកងនៃអាបត្តិ២គឺ កងនៃអាបត្តិបាចិត្តិយៈ ក៏មាន កងនៃអាបត្តិទុក្កដ ក៏មាន បណ្តាសមុដ្ឋាន នៃអាបត្តិ៦យ៉ាង (អាបត្តិទាំងនោះ) តាំងឡើងអំពីសមុដ្ឋាន៣ រម្ងាប់ដោយអធិករណ៍១ គឺកិច្ចាធិករណ៍ រម្ងាប់ក្នុងទីទាំង៣ គឺកណ្តាលជំនុំសង្ឃ១ កណ្តាលគណៈ១ ក្នុងសំណាក់នៃបុគ្គល១ និងរម្ងាប់ដោយសមថៈ៣គឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈ ក៏មានខ្លះ សម្មុខាវិន័យ និងតិណវត្ថារកៈ ក៏មានខ្លះ។

[១៣៤] អនុវាទាធិករណ៍ ជាអាបត្តិ ឬជាអនាបត្តិ។ អនុវាទាធិករណ៍ មិនមែនជាអាបត្តិទេ។ ចុះភិក្ខុត្រូវអាបត្តិ ព្រោះបច្ច័យនៃអនុវាទាធិករណ៍ មានដែរឬទេ។ អើ ភិក្ខុត្រូវអាបត្តិ ព្រោះបច្ច័យនៃអនុវាទាធិករណ៍ មានដែរ។ ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យនៃអនុវាទាធិករណ៍។ ភិក្ខុត្រូវអាបត្តិ៣យ៉ាង ព្រោះបច្ច័យនៃអនុវាទាធិករណ៍ (គឺភិក្ខុ) ចោទបង្កាច់ភិក្ខុផងគ្នា ដោយអាបត្តិបារាជិក មិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស ចោទបង្កាច់ដោយអាបត្តិសង្ឃាទិសេស មិនមានមូល ត្រូវអាបត្តិបាចិត្តិយៈ ចោទបង្កាច់ដោយអាចារវិបត្តិ មិនមានមូល ត្រូវអាបត្តិទុក្កដ ភិក្ខុត្រូវអាបត្តិ៣យ៉ាងនេះឯង ព្រោះបច្ច័យនៃអនុវាទាធិករណ៍។ បណ្តាវិបត្តិ៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងវិបត្តិប៉ុន្មាន បណ្តាអធិករណ៍៤យ៉ាង (អាបត្តិទាំងនោះ) រួមចូលនឹងអធិករណ៍ណា បណ្តាកងនៃអាបត្តិ៧យ៉ាង (អាបត្តិទាំងនោះ) លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន បណ្តាសមុដ្ឋាន នៃអាបត្តិ៦យ៉ាង (អាបត្តិទាំងនោះ) តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន និងរម្ងាប់ដោយអធិករណ៍ប៉ុន្មាន រម្ងាប់ក្នុងទីដូចម្តេច រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិ៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងវិបត្តិ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន បណ្តាអធិករណ៍៤យ៉ាង (អាបត្តិទាំងនោះ) ចាត់ជាអាបត្តាធិករណ៍ បណ្តាកងនៃអាបត្តិ៧យ៉ាង (អាបត្តិទាំងនោះ) លោកសង្គ្រោះដោយកងនៃអាបត្តិ៣គឺ កងនៃអាបត្តិសង្ឃាទិសេស ក៏មាន កងនៃអាបត្តិបាចិត្តិយៈ ក៏មាន កងនៃអាបត្តិទុក្កដក៏មាន បណ្តាសមុដ្ឋាន នៃអាបត្តិ៦យ៉ាង (អាបត្តិទាំងនោះ) តាំងឡើងដោយសមុដ្ឋាន៣ អាបត្តិណា ជាគរុកាបត្តិ អាបត្តិនោះ តែងរម្ងាប់ដោយអធិករណ៍១ គឺកិច្ចាធិករណ៍ រម្ងាប់ក្នុងទី១ គឺកណ្តាលជំនុំសង្ឃ និងរម្ងាប់ដោយសមថៈ២គឺ សម្មុខាវិន័យ១ បដិញ្ញាតករណៈ១ អាបត្តិទាំងឡាយណា ជាលហុកាបត្តិ អាបត្តិទាំងនោះ តែងរម្ងាប់ដោយអធិករណ៍១គឺ កិច្ចាធិករណ៍ រម្ងាប់ក្នុងទីទាំង៣គឺ កណ្តាលជំនុំសង្ឃ១ កណ្តាលគណៈ១ ក្នុងសំណាក់នៃបុគ្គល១ រម្ងាប់ដោយសមថៈ៣គឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មាន សម្មុខាវិន័យ និងតិណវត្ថារកៈ ក៏មានខ្លះ។

[១៣៥] អាបត្តាធិករណ៍ ជាអាបត្តិ ឬជាអនាបត្តិ។ អាបត្តាធិករណ៍ មិនមែនជាអាបត្តិទេ។ ចុះភិក្ខុត្រូវអាបត្តិ ព្រោះបច្ច័យ នៃអាបត្តាធិករណ៍ មានដែរឬទេ។ អើ ភិក្ខុត្រូវអាបត្តិ ព្រោះបច្ច័យនៃអាបត្តាធិករណ៍ ក៏មានដែរ។ ភិក្ខុត្រូវអាបត្តិប៉ុន្មាន ព្រោះបច្ច័យ នៃអាបត្តាធិករណ៍។ ភិក្ខុត្រូវអាបត្តិ៤យ៉ាង ព្រោះបច្ច័យ នៃអាបត្តាធិករណ៍ គឺ ភិក្ខុនីដឹងថា (ភិក្ខុនីផងគ្នា) ត្រូវអាបត្តិបារាជិក ហើយជួយបិទបាំងទុក ត្រូវអាបត្តិបារាជិក ភិក្ខុនីមានសេចក្តីសង្ស័យ ហើយបិទបាំងទុក ត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុបិទបាំងអាបត្តិសង្ឃាទេសេស ត្រូវអាបត្តិបាចិត្តិយៈ បើបិទបាំងអាចារៈវិបត្តិទុក ត្រូវអាបត្តិទុក្កដ ភិក្ខុ និងភិក្ខុនី ត្រូវអាបត្តិទាំង៤យ៉ាងនេះ ព្រោះបច្ច័យ នៃអាបត្តាធិករណ៍។ បណ្តាវិបត្តិ៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងវិបត្តិប៉ុន្មាន បណ្តាអធិករណ៍៤យ៉ាង (អាបត្តិទាំងនោះ) រួមចូលនឹងអធិករណ៍ណា បណ្តាកងនៃអាបត្តិទាំង៧ (អាបត្តិទាំងនោះ) លោកសង្គ្រោះដោយកងនៃអាបត្តិប៉ុន្មាន បណ្តាសមុដ្ឋាន នៃអាបត្តិ៦យ៉ាង (អាបត្តិទាំងនោះ) តាំងឡើងដោយសមុដ្ឋានប៉ុន្មាន រម្ងាប់ដោយអធិករណ៍ប៉ុន្មាន រម្ងាប់ក្នុងទីដូចម្តេច រម្ងាប់ដោយសមុដ្ឋានប៉ុន្មាន។ បណ្តាវិបត្តិទាំង៤ អាបត្តិទាំងនោះ រួមចូលនឹងវិបត្តិ២ គឺសីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន បណ្តាអធិករណ៍ទាំង៤យ៉ាង (អាបត្តិទាំងនោះ) រួមចូលនឹងអាបត្តាធិករណ៍ បណ្តាកងនៃអាបត្តិទាំង៧ (អាបត្តិទាំងនោះ) លោកសង្គ្រោះដោយកងនៃអាបត្តិ៤គឺ កងនៃអាបត្តិបារាជិកក៏មាន កងនៃអាបត្តិថុល្លច្ច័យ ក៏មាន កងនៃអាបត្តិបាចិត្តិយៈ ក៏មាន កងនៃអាបត្តិទុក្កដក៏មាន បណ្តាសមុដ្ឋាន នៃអាបត្តិ៦យ៉ាង (អាបត្តិទាំងនោះ) តាំងឡើងដោយសមុដ្ឋាន១គឺ តាំងឡើងអំពីកាយ វាចា ចិត្ត អាបត្តិណា ជាអនវសេសាបត្តិ អាបត្តិនោះ មិនរម្ងាប់ដោយអធិករណ៍ណាទេ មិនរម្ងាប់ក្នុងទីណាទេ មិនរម្ងាប់ដោយសមថៈណាទេ អាបត្តិទាំងឡាយណា ជាលហុកាបត្តិ អាបត្តិទាំងនោះ តែងរម្ងាប់ដោយអធិករណ៍១គឺ កិច្ចាធិករណ៍ រម្ងាប់ក្នុងទីទាំង៣គឺ កណ្តាលជំនុំសង្ឃ១ កណ្តាលគណៈ១ ក្នុងសំណាក់បុគ្គល១ និងរម្ងាប់ដោយសមថៈ៣គឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈ ក៏មានខ្លះ សម្មុខាវិន័យ និងតិណវត្ថារកៈ ក៏មានខ្លះ។

[១៣៦] កិច្ចាធិករណ៍ ជាអាបត្តិ ឬជាអនាបត្តិ។ កិច្ចាធិករណ៍ មិនមែនជាអាបត្តិទេ។ ចុះភិក្ខុត្រូវអាបត្តិ ព្រោះបច្ច័យនៃកិច្ចាធិករណ៍ មានដែរឬទេ។ អើ ភិក្ខុត្រូវអាបត្តិ ព្រោះបច្ច័យនៃកិច្ចាធិករណ៍ ក៏មានដែរ។ ភិក្ខុត្រូវអាបត្តិប៉ុន្មានយ៉ាង ព្រោះបច្ច័យនៃកិច្ចាធិករណ៍។ ភិក្ខុ និងភិក្ខុនី ត្រូវអាបត្តិ៥យ៉ាង ព្រោះបច្ច័យនៃកិច្ចាធិករណ៍ គឺភិក្ខុនី ប្រព្រឹត្តតាមភិក្ខុនី ដែលភិក្ខុនីសង្ឃលើកវត្ត កាលបើសង្ឃសូត្រសមនុភាសនកម្ម ចប់ជាគំរប់៣ដងហើយ នៅតែមិនលះបង់ (កម្មនោះចេញ) ត្រូវអាបត្តិទុក្កដ ក្នុងខណៈដែលចប់ញត្តិ ត្រូវអាបត្តិថុល្លច្ច័យទាំងឡាយ ក្នុងខណៈដែលចប់កម្មវាចាពីរលើក ត្រូវអាបត្តិបារាជិក ក្នុងខណៈដែលចប់កម្មវាចាស្រេច ភិក្ខុទាំងឡាយ ដែលប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ កាលបើសង្ឃសូត្រសមនុភាសនកម្មចប់ជាគំរប់៣ដងហើយ នៅតែមិនលះបង់ (កម្មនោះចេញ) ត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុទាំងឡាយ ដែលប្រកាន់ទិដ្ឋិអាក្រក់ កាលបើសង្ឃសូត្រសមនុភាសនកម្មចប់ ជាគំរប់៣ដងហើយ នៅតែមិនលះបង់ទិដ្ឋិអាក្រក់ចេញ ត្រូវអាបត្តិបាចិត្តិយៈ ភិក្ខុត្រូវអាបត្តិ៥យ៉ាងនេះ ព្រោះបច្ច័យនៃកិច្ចាធិករណ៍។ បណ្តាវិបត្តិទាំង៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងវិបត្តិប៉ុន្មាន បណ្តាអធិករណ៍ទាំង៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងអធិករណ៍ណា បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិទាំងនោះ លោកសង្គ្រោះដោយកងនៃអាបត្តិណា បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង អាបត្តិទាំងនោះ តាំងឡើងអំពីសមុដ្ឋានប៉ុន្មានយ៉ាង រម្ងាប់ដោយអធិករណ៍ប៉ុន្មាន រម្ងាប់ក្នុងទីដូចម្តេច រម្ងាប់ដោយសមថៈប៉ុន្មាន។ បណ្តាវិបត្តិទាំង៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងវិបត្តិ២យ៉ាង គឺ សីលវិបត្តិក៏មាន អាចារវិបត្តិក៏មាន បណ្តាអធិករណ៍ទាំង៤យ៉ាង អាបត្តិទាំងនោះ រួមចូលនឹងអាបត្តាធិករណ៍ បណ្តាកងនៃអាបត្តិទាំង៧ អាបត្តិទាំងនោះ សង្គ្រោះដោយកងនៃអាបត្តិ៥គឺ កងនៃអាបត្តិបារាជិក ក៏មាន កងនៃអាបត្តិសង្ឃាទិសេស ក៏មាន កងនៃអាបត្តិថុល្លច្ច័យក៏មាន កងនៃអាបត្តិបាចិត្តិយៈក៏មាន កងនៃអាបត្តិទុក្កដក៏មាន បណ្តាសមុដ្ឋាននៃអាបត្តិទាំង៦យ៉ាង អាបត្តិទាំងនោះ តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ វាចា ចិត្ត អាបត្តិណា ជាអនវសេសាបត្តិ អាបត្តិនោះមិនរម្ងាប់ដោយអធិករណ៍ណាទេ មិនរម្ងាប់ក្នុងទីណាមួយទេ មិនរម្ងាប់ដោយសមថៈណាទេ អាបត្តិណាជាគរុកាបត្តិ អាបត្តិនោះតែងរម្ងាប់ដោយអធិករណ៍១ គឺកិច្ចាធិករណ៍ រម្ងាប់ក្នុងទី១ គឺក្នុងកណ្តាលជំនុំសង្ឃ រម្ងាប់ដោយសមថៈ២គឺ សម្មុខាវិន័យ១ បដិញ្ញាតករណៈ១ អាបត្តិទាំងឡាយណា ជាលហុកាបត្តិ អាបត្តិទាំងឡាយនោះ តែងរម្ងាប់ដោយអធិករណ៍១គឺ កិច្ចាធិករណ៍រម្ងាប់ក្នុងទីទាំង៣គឺ កណ្តាលជំនុំសង្ឃ១ កណ្តាលគណៈ១ ក្នុងសំណាក់នៃបុគ្គល១ រម្ងាប់ដោយសមថៈ៣យ៉ាងគឺ សម្មុខាវិន័យ និងបដិញ្ញាតករណៈក៏មានខ្លះ សម្មុខាវិន័យ និងតិណវត្ថារកៈ ក៏មានខ្លះ។

## (អធិករណាធិប្បាយៈ ទី៥)

CS vin.pv.08.05 | ភាគ ទី១៣

### (៥. អធិករណាធិប្បាយោ)

[១៣៧] វិវាទាធិករណ៍ ទៅជាអនុវាទាធិករណ៍ ទៅជាអាបត្តាធិករណ៍ ទៅជាកិច្ចាធិករណ៍ មានដែរឬទេ។ វិវាទាធិករណ៍ មិនទៅជាអនុវាទាធិករណ៍ទេ មិនទៅជាអាបត្តាធិករណ៍ទេ មិនទៅជាកិច្ចាធិករណ៍ទេ។ ប៉ុន្តែអនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ មានឡើង ព្រោះបច្ច័យនៃវិវាទាធិករណ៍។ មានសេចក្តីអធិប្បាយដូចម្តេច។ (មានសេចក្តីអធិប្បាយថា) ភិក្ខុទាំងឡាយ ក្នុងសាសនានេះ ជជែកគ្នាថា សភាវៈនេះជាធម៌ក្តី ថាសភាវៈនេះ មិនមែនជាធម៌ក្តី។បេ។ ថាទុដ្ឋុល្លាបត្តិក្តី ថាអទុដ្ឋុល្លាបត្តិក្តី សេចក្តីប្រកួតប្រកាន់ ជម្លោះ សេចក្តីប្រកាន់ខុស សេចក្តីជជែក ការនិយាយបែកផ្សេងពីគ្នា ការនិយាយផ្តេសផ្តាស ការនិយាយដើម្បីឲ្យគេព្រួយចិត្ត សេចក្តីប្រកែកប្រណាំងណា ក្នុងសភាវៈទាំងនោះ នេះដែលព្រះសាស្តាត្រាស់ហៅថា វិវាទាធិករណ៍។ សង្ឃជជែកគ្នា ព្រោះវិវាទាធិករណ៍ ហៅថា វិវាទាធិករណ៍។ កាលដែលសង្ឃជជែកគ្នាទាំងចោទផង ហៅថា អនុវាទាធិករណ៍។ កាលដែលសង្ឃចោទ ត្រូវអាបត្តិ (ខ្លួនឯង) ហៅថា អាបត្តាធិករណ៍។ សង្ឃធ្វើកម្ម ព្រោះអាបត្តិនោះ ហៅថា កិច្ចាធិករណ៍។ អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ កើតមាន ព្រោះតែបច្ច័យនៃវិវាទាធិករណ៍ ដូចបានអធិប្បាយមកនេះ។

[១៣៨] អនុវាទាធិករណ៍ ទៅជាអាបត្តាធិករណ៍ ទៅជាកិច្ចាធិករណ៍ ទៅជាវិវាទាធិករណ៍ មានដែរឬទេ។ អនុវាទាធិករណ៍ មិនទៅជាអាបត្តាធិករណ៍ មិនទៅជាកិច្ចាធិករណ៍ មិនទៅជាវិវាទាធិករណ៍ទេ។ ប៉ុន្តែអាបត្តាធិករណ៍ កិច្ចាធិករណ៍ និងវិវាទាធិករណ៍ តែងកើតមាន ព្រោះបច្ច័យនៃអនុវាទាធិករណ៍។ មានសេចក្តីអធិប្បាយដូចម្តេច។ (មានសេចក្តីអធិប្បាយថា) ភិក្ខុទាំងឡាយ ក្នុងសាសនានេះ ចោទភិក្ខុផងគ្នាដោយសីលវិបត្តិក្តី[32] ដោយអាចារវិបត្តិក្តី[33] ដោយទិដ្ឋិវិបត្តិក្តី[34] ដោយអាជីវវិបត្តិក្តី[35] ការចោទ សេចក្តីប្រកាន់ ការពោលជជែក ការពោលតវ៉ា ការពោលបង្អាក់ ការខំពោលបង្អួច ការបន្ថែមកម្លាំងណា ក្នុងវិបត្តិទាំងនោះ នេះដែលព្រះសាស្តាត្រាស់ហៅថា អនុវាទាធិករណ៍។ សង្ឃជជែកគ្នា ព្រោះអនុវាទាធិករណ៍ ហៅថា វិវាទាធិករណ៍។ កាលដែលជជែកទាំងចោទផង ហៅថា អនុវាទាធិករណ៍។ កាលដែលចោទ ត្រូវអាបត្តិ (ខ្លួនឯង) ហៅថា អាបត្តាធិករណ៍។ សង្ឃធ្វើកម្ម ព្រោះអាបត្តិនោះ ហៅថា កិច្ចាធិករណ៍។ អាបត្តាធិករណ៍ កិច្ចាធិករណ៍ និងវិវាទាធិករណ៍ តែងកើតមាន ព្រោះបច្ច័យនៃអនុវាទាធិករណ៍ ដូចបានអធិប្បាយមកនេះឯង។

[១៣៩] អាបត្តាធិករណ៍ ទៅជាកិច្ចាធិករណ៍ ទៅជាវិវាទាធិករណ៍ ទៅជាអនុវាទាធិករណ៍ មានដែរឬទេ។ អាបត្តាធិករណ៍ មិនទៅជាកិច្ចាធិករណ៍ មិនទៅជាវិវាទាធិករណ៍ មិនទៅជាអនុវាទាធិករណ៍ទេ។ ប៉ុន្តែកិច្ចាធិករណ៍ វិវាទាធិករណ៍ និងអនុវាទាធិករណ៍ តែងកើតមាន ព្រោះតែបច្ច័យនៃអាបត្តាធិករណ៍។ មានសេចក្តីអធិប្បាយដូចម្តេច។ (មានសេចក្តីអធិប្បាយថា) កងនៃអាបត្តិទាំង៥ ក៏ហៅថា អាបត្តាធិករណ៍ កងនៃអាបត្តិទាំង៧ ក៏ហៅថា អាបត្តាធិករណ៍ នេះដែលព្រះសាស្តា ត្រាស់ហៅថា អាបត្តាធិករណ៍។ សង្ឃជជែកគ្នា ព្រោះអាបត្តាធិករណ៍ ហៅថា វិវាទាធិករណ៍។ កាលដែលជជែកទាំងចោទផង ហៅថា អនុវាទាធិករណ៍។ កាលដែលចោទ ត្រូវអាបត្តិ (ខ្លួនឯង) ហៅថា អាបត្តាធិករណ៍។ សង្ឃធ្វើកម្ម ព្រោះអាបត្តិនោះ ហៅថា កិច្ចាធិករណ៍។ កិច្ចាធិករណ៍ វិវាទាធិករណ៍ និងអនុវាទាធិករណ៍ តែងកើតមាន ព្រោះបច្ច័យនៃអាបត្តាធិករណ៍ ដូចបានអធិប្បាយមកយ៉ាងនេះ។

[១៤០] កិច្ចាធិករណ៍ ទៅជាវិវាទាធិករណ៍ ទៅជាអនុវាទាធិករណ៍ ទៅជាអាបត្តាធិករណ៍ មានដែរឬទេ។ កិច្ចាធិករណ៍ មិនទៅជាវិវាទាធិករណ៍ មិនទៅជាអនុវាទាធិករណ៍ មិនទៅជាអាបត្តាធិករណ៍ទេ។ ប៉ុន្តែវិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ តែងកើតមាន ព្រោះតែបច្ច័យនៃអាបត្តាធិករណ៍។ មានសេចក្តីអធិប្បាយដូចម្តេច។ (មានសេចក្តីអធិប្បាយថា) កិច្ចរបស់សង្ឃ ឬកម្មដែលសង្ឃត្រូវធ្វើណា គឺ

អបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១ នេះដែលព្រះសាស្ដា ត្រាស់ហៅថា កិច្ចាធិករណ៍។ សង្ឃជជែកគ្នា ព្រោះកិច្ចាធិករណ៍ ហៅថា វិវាទាធិករណ៍។ កាលដែលជជែកទាំងចោទផង ហៅថា អនុវាទាធិករណ៍។ កាលដែលចោទ ត្រូវអាបត្តិ (ខ្លួនឯង) ហៅថា អាបត្តាធិករណ៍។ សង្ឃធ្វើកម្ម ព្រោះអាបត្តិនោះ ហៅថា កិច្ចាធិករណ៍។ វិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ តែងកើតមាន ព្រោះបច្ច័យនៃកិច្ចាធិករណ៍ ដូចបានអធិប្បាយមកយ៉ាងនេះ។

## (បុច្ឆាវារៈ ទី៦)

CS vin.pv.08.06 | ភាគ ទី១៣

### (៦. បុច្ឆាវារោ)

[១៤១] សតិវិន័យ (មាន) ក្នុងទីណា សម្មុខាវិន័យ (ក៏មាន) ក្នុងទីនោះដែរ សម្មុខាវិន័យ (មាន) ក្នុងទីណា សតិវិន័យ (ក៏មាន) ក្នុងទីនោះដែរ។ អមូឡ្ហវិន័យ (មាន) ក្នុងទីណា សម្មុខាវិន័យ (ក៏មាន) ក្នុងទីនោះដែរ សម្មុខាវិន័យ (មាន) ក្នុងទីណា អមូឡ្ហវិន័យ (ក៏មាន) ក្នុងទីនោះដែរ។ បដិញ្ញាតករណៈ (មាន) ក្នុងទីណា សម្មុខាវិន័យ (ក៏មាន) ក្នុងទីនោះដែរ សម្មុខាវិន័យ (មាន) ក្នុងទីណា បដិញ្ញាតករណៈ (ក៏មាន) ក្នុងទីនោះដែរ។ យេភុយ្យសិកា (មាន)ក្នុងទីណា សម្មុខាវិន័យ (ក៏មាន) ក្នុងទីនោះដែរ សម្មុខាវិន័យ (មាន) ក្នុងទីណា យេភុយ្យសិកា (ក៏មាន) ក្នុងទីនោះដែរ។ តស្សបាបិយសិកា (មាន) ក្នុងទីណា សម្មុខាវិន័យ (ក៏មាន) ក្នុងទីនោះដែរ សម្មុខាវិន័យ (មាន) ក្នុងទីណា តស្សបាបិយសិកា (ក៏មាន) ក្នុងទីនោះដែរ។ តិណវត្ថារកៈ (មាន) ក្នុងទីណា សម្មុខាវិន័យ (ក៏មាន) ក្នុងទីនោះដែរ សម្មុខាវិន័យ (មាន) ក្នុងទីណា តិណវត្ថារកៈ (ក៏មាន) ក្នុងទីនោះដែរ។

## (វិស្សជ្ជនាវារៈ ទី៧)

CS vin.pv.08.07 | ភាគ ទី១៣

### (៧. វិស្សជ្ជនាវារោ)

[១៤២] ក្នុងសម័យណា អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងសតិវិន័យ សតិវិន័យ (មាន) ក្នុងទីណា សម្មុខាវិន័យ (ក៏មាន) ក្នុងទីនោះ សម្មុខាវិន័យ (មាន) ក្នុងទីណា សតិវិន័យ (ក៏មាន) ក្នុងទីនោះដែរ អមូឡ្ហវិន័យ មិនមានក្នុងទីនោះទេ បដិញ្ញាតករណៈ មិនមានក្នុងទីនោះទេ យេភុយ្យសិកា មិនមានក្នុងទីនោះទេ តស្សបាបិយសិកា មិនមានក្នុងទីនោះទេ តិណវត្ថារកៈ មិនមានក្នុងទីនោះទេ។ សម័យណា អធិករណ៍រម្ងាប់ដោយសម្មុខាវិន័យ និងអមូឡ្ហវិន័យ។បេ។ ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ។បេ។ ដោយសម្មុខាវិន័យ និងយេភុយ្យសិកា។បេ។ ដោយសម្មុខាវិន័យ និងតស្សបាបិយសិកា។បេ។ ដោយសម្មុខាវិន័យ និងតិណវត្ថារកៈ តិណវត្ថារកៈ (មាន) ក្នុងទីណា សម្មុខាវិន័យ (ក៏មាន) ក្នុងទីនោះ សម្មុខាវិន័យ (មាន) ក្នុងទីណា តិណវត្ថារកៈ (ក៏មាន) ក្នុងទីនោះ សតិវិន័យ មិនមានក្នុងទីនោះទេ អមូឡ្ហវិន័យ មិនមានក្នុងទីនោះទេ បដិញ្ញាតករណៈ មិនមានក្នុងទីនោះទេ យេភុយ្យសិកាមិនមានក្នុងទីនោះទេ តស្សបាបិយសិកា មិនមានក្នុងទីនោះទេ។

## (សំសដ្ឋវារៈ ទី៨)

CS vin.pv.08.08 | ភាគ ទី១៣

### (៨. សំសដ្ឋវារោ)

[១៤៣] សួរថា សម្មុខាវិន័យ និងសតិវិន័យ ធម៌ទាំងនេះលាយច្រឡំគ្នា ឬមិនច្រឡំគ្នាទេ មួយទៀត លោកចែករំលែកធម៌ទាំងឡាយនេះ ហើយបញ្ញត្តឲ្យផ្សេងពីគ្នាបានឬទេ។ សម្មុខាវិន័យ និងអមូឡ្ហវិន័យ។បេ។ សម្មុខាវិន័យ និងបដិញ្ញាតករណៈ សម្មុខាវិន័យ និងយេភុយ្យសិកា សម្មុខាវិន័យ និងតស្សបាបិយសិកា សម្មុខាវិន័យ និងតិណវត្ថារកៈ ធម៌ទាំងនេះ លាយច្រឡំគ្នា ឬមិនលាយច្រឡំគ្នាទេ មួយទៀត លោកចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តឲ្យផ្សេងគ្នាបានឬទេ។ ឆ្លើយថា សម្មុខាវិន័យ និងសតិវិន័យ ធម៌ទាំងនេះ លាយច្រឡំគ្នា មិនមែនផ្សេងគ្នាទេ មួយទៀត លោកមិនបានចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តឲ្យផ្សេងពីគ្នាទេ។ សម្មុខាវិន័យ និងអមូឡ្ហវិន័យ។បេ។ សម្មុខាវិន័យ និងបដិញ្ញាតករណៈ សម្មុខាវិន័យ និងយេភុយ្យសិកា សម្មុខាវិន័យ និងតស្សបាបិយសិកា សម្មុខាវិន័យ និងតិណវត្ថារកៈ ធម៌ទាំងនេះ លាយច្រឡំគ្នា មិនមែនមិនលាយច្រឡំគ្នាទេ មួយទៀត លោកមិនបានចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តឲ្យផ្សេងពីគ្នាទេ។

## (សត្តសមថនិទាន ទី៩)

CS vin.pv.08.09 | ភាគ ទី១៣

### (៩. សត្តសមថនិទានំ)

[១៤៤] សម្មុខាវិន័យ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ សតិវិន័យ។បេ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ សម្មុខាវិន័យ មាននិទានជាគ្រឿងប្រគល់ឲ្យនូវផល មាននិទានជាហេតុឲ្យកើតឡើង មាននិទានជាកំណើត មាននិទានជាដែន មាននិទានជាអង្គ មាននិទានជាសមុដ្ឋាន។ សតិវិន័យ។បេ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មាននិទានជាគ្រឿងប្រគល់ឲ្យនូវផល មាននិទានជាហេតុឲ្យកើតឡើង មាននិទានជាកំណើត មាននិទានជាដែន មាននិទានជាអង្គ មាននិទានជាសមុដ្ឋាន។ សម្មុខាវិន័យ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល

មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ សតិវិន័យ។បេ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ សម្មុខាវិន័យ មានហេតុជាគ្រឿងប្រគល់ឲ្យនូវផល មានហេតុជាហេតុឲ្យកើតឡើង មានហេតុជាកំណើត មានហេតុជាដែន មានហេតុជាអង្គ មានហេតុជាសមុដ្ឋាន។ សតិវិន័យ។បេ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មានហេតុជាគ្រឿងប្រគល់ឲ្យនូវផល មានហេតុជាហេតុឲ្យកើតឡើង មានហេតុជាកំណើត មានហេតុជាដែន មានហេតុជាអង្គ មានហេតុជាសមុដ្ឋាន។ សម្មុខាវិន័យ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ សតិវិន័យ។បេ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មានអ្វីជាគ្រឿងប្រគល់ឲ្យនូវផល មានអ្វីជាហេតុឲ្យកើតឡើង មានអ្វីជាកំណើត មានអ្វីជាដែន មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ សម្មុខាវិន័យ មានបច្ច័យជាគ្រឿងប្រគល់ឲ្យនូវផល មានបច្ច័យជាហេតុឲ្យកើតឡើង មានបច្ច័យជាកំណើត មានបច្ច័យជាដែន មានបច្ច័យជាអង្គ មានបច្ច័យ ជាសមុដ្ឋាន។ សតិវិន័យ។បេ។ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា និងតិណវត្ថារកៈ មានបច្ច័យ ជាគ្រឿងប្រគល់ឲ្យនូវផល មានបច្ច័យជាហេតុឲ្យកើតឡើង មានបច្ច័យជាកំណើត មានបច្ច័យជាដែន មានបច្ច័យជាអង្គ មានបច្ច័យជាសមុដ្ឋាន។

[១៤៥] សមថៈទាំង៧ មានមូលប៉ុន្មាន មានសមុដ្ឋានប៉ុន្មាន។ សមថៈទាំង៧ មានមូល២៦ មានសមុដ្ឋាន៣៦។ សមថៈ ទាំង៧ មានមូល២៦ (នោះ) ដូចម្តេច។ សម្មុខាវិន័យ មានមូល៤ គឺចំពោះមុខសង្ឃ១ ចំពោះមុខធម៌១ ចំពោះមុខវិន័យ១ ចំពោះមុខបុគ្គល១។ សតិវិន័យមានមូល៤។ អមូឡ្ហវិន័យ មានមូល៤។ បដិញ្ញាតករណៈ មានមូល២ គឺបុគ្គលណាសំដែង១ សំដែងចំពោះបុគ្គលណា១។ យេភុយ្យសិកា មានមូល៤ តស្សបាបិយសិកា មានមូល៤។ តិណវត្ថារកៈ មានមូល៤ គឺចំពោះមុខសង្ឃ១ ចំពោះមុខធម៌១ ចំពោះមុខវិន័យ១ ចំពោះមុខបុគ្គល១។ នេះជាមូល២៦ របស់សមថៈទាំង៧។ សមថៈទាំង[36] ៧ មានសមុដ្ឋាន៣៦ (នោះ) ដូចម្តេចខ្លះ។ ការធ្វើញត្តិ ការបញ្ឈប់ញត្តិ ការចូលទៅធ្វើដោយខ្លួនឯង ការបង្គាប់ឲ្យគេចូលទៅធ្វើ ការទទួលបង្គាប់ ការមិនហាមឃាត់នូវសង្ឃកម្ម គឺសតិវិន័យ។ នូវសង្ឃកម្ម គឺអមូឡ្ហវិន័យ។បេ។ នូវសង្ឃកម្ម គឺបដិញ្ញាតករណៈ។បេ។ នូវសង្ឃកម្ម គឺយេភុយ្យសិកា។បេ។ នូវសង្ឃកម្ម គឺតស្សបាបិយសិកា។បេ។ ការធ្វើញត្តិ ការបញ្ឈប់ញត្តិ ការចូលទៅធ្វើដោយខ្លួនឯង ការបង្គាប់ឲ្យគេចូលទៅធ្វើ ការទទួលបង្គាប់ ការមិនហាមឃាត់នូវសង្ឃកម្ម គឺតិណវត្ថារកៈ។ នេះជាសមុដ្ឋាន៣៦ របស់សមថៈ៧។

## (សត្តសមថនានត្ថាទិ ទី១០)

CS vin.pv.08.10 | ភាគ ទី១៣

### (១០. សត្តសមថនានត្ថាទិ)

[១៤៦] សម្មុខាវិន័យ និងសតិវិន័យ ធម៌ទាំងនេះ មានអត្ថផ្សេងៗគ្នា មានព្យញ្ជនៈផ្សេងៗគ្នា ឬក៏មានអត្ថជាមួយគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះទេ។ សម្មុខាវិន័យ និងអមូឡ្ហវិន័យ។បេ។ សម្មុខាវិន័យ និងបដិញ្ញាតករណៈ សម្មុខាវិន័យ និងយេភុយ្យសិកា សម្មុខាវិន័យ និងតស្សបាបិយសិកា សម្មុខាវិន័យ និងតិណវត្ថារកៈ ធម៌ទាំងនេះ មានអត្ថផ្សេងៗគ្នា មានព្យញ្ជនៈផ្សេងៗគ្នា ឬក៏មានអត្ថជាមួយគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះទេ។ សម្មុខាវិន័យ និងសតិវិន័យ ធម៌ទាំងនេះ មានអត្ថក៏ផ្សេងៗគ្នា មានព្យញ្ជនៈក៏ផ្សេងៗគ្នាដែរ។ សម្មុខាវិន័យ និងអមូឡ្ហវិន័យ។បេ។ សម្មុខាវិន័យ និងបដិញ្ញាតករណៈ សម្មុខាវិន័យ និងយេភុយ្យសិកា សម្មុខាវិន័យ និងតស្សបាបិយសិកា សម្មុខាវិន័យ និងតិណវត្ថារកៈ ធម៌ទាំងនេះ មានអត្ថផ្សេងៗគ្នា មានព្យញ្ជនៈក៏ផ្សេងៗគ្នាដែរ។

[១៤៧] វិវាទ ចាត់ជាវិវាទាធិករណ៍ វិវាទ មិនចាត់ជាអធិករណ៍ អធិករណ៍ មិនចាត់ជាវិវាទ ចាត់ជាអធិករណ៍ផង ជាវិវាទផង វិវាទ ចាត់ជាវិវាទាធិករណ៍ក៏មាន វិវាទ មិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍ មិនចាត់ជាវិវាទក៏មាន ចាត់ជាអធិករណ៍ផង វិវាទផងក៏មាន។ បណ្តាធម៌ទាំងនោះ វិវាទដូចម្តេច ដែលចាត់ជាវិវាទាធិករណ៍។ ភិក្ខុទាំងឡាយក្នុងសាសនានេះ ជជែកគ្នា ថាសភាវៈនេះ ជាធម៌ក្តី មិនមែនជាធម៌ក្តី។បេ។ ជាទុដ្ឋុល្លាបត្តិក្តី ជាអទុដ្ឋុល្លាបត្តិក្តី សេចក្តីប្រកួតប្រកាន់ ជម្លោះ សេចក្តីប្រកាន់ខុស សេចក្តីជជែក ការនិយាយបែកផ្សេងពីគ្នា ការនិយាយផ្ទេសផ្តាស ការនិយាយដើម្បីឲ្យគេព្រួយចិត្ត សេចក្តីប្រកែកប្រណាំងណា ក្នុងសភាវៈទាំងនោះ វិវាទនេះ ចាត់ជាវិវាទាធិករណ៍។ បណ្តាធម៌ទាំងនោះ វិវាទដូចម្តេច ដែលមិនចាត់ជាអធិករណ៍។ មាតាទាស់ទែងនឹងបុត្តក្តី បុត្តទាស់ទែងនឹងមាតាក្តី បិតាទាស់ទែងនឹងបុត្តក្តី បុត្តទាស់ទែងនឹងបិតាក្តី បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុសក្តី បងប្អូនប្រុសទាស់ទែងនឹងបងប្អូនស្រីក្តី បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសក្តី សំឡាញ់ទាស់ទែងនឹងសំឡាញ់ផងគ្នាក្តី វិវាទនេះ មិនចាត់ជាអធិករណ៍ទេ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលមិនចាត់ជាវិវាទ។ អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ អធិករណ៍នេះ មិនចាត់ជាវិវាទទេ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលចាត់ជាអធិករណ៍ផង ជាវិវាទផង។ វិវាទាធិករណ៍ ចាត់ជាអធិករណ៍ផង ជាវិវាទផង។

[១៤៨] ការចោទ ចាត់ជាអនុវាទាធិករណ៍ ការចោទ មិនចាត់ជាអធិករណ៍ អធិករណ៍ មិនចាត់ជាការចោទ ចាត់ជាអធិករណ៍ផង ជាការចោទផង ការចោទ ចាត់ជាអនុវាទាធិករណ៍ក៏មាន ការចោទ មិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍ មិនចាត់ជាការចោទក៏មាន ចាត់ជាអធិករណ៍ផង ជាការចោទផងក៏មាន។ បណ្តាធម៌ទាំងនោះ ការចោទដូចម្តេច ដែលចាត់ជាអនុវាទាធិករណ៍។ ភិក្ខុទាំងឡាយក្នុងសាសនានេះ ចោទភិក្ខុផងគ្នា ដោយសីលវិបត្តិក្តី ដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ដោយអាជីវវិបត្តិក្តី ការចោទ សេចក្តីប្រកាន់ ការពោលជជែក ការពោលតវ៉ា ការពោលបង្គាប់ ការខំពោលបង្ខូច ការបន្ថែមកម្លាំងណា ក្នុងវិបត្តិទាំងនោះ ការចោទនេះ ចាត់ជាអនុវាទាធិករណ៍។ បណ្តាធម៌ទាំងនោះ ការចោទដូចម្តេច ដែលមិនចាត់ជាអធិករណ៍។ មាតាចោទបុត្តក្តី បុត្តចោទមាតាក្តី បិតាចោទបុត្តក្តី បុត្តចោទបិតាក្តី បងប្អូនប្រុសចោទបងប្អូនប្រុសផងគ្នាក្តី បងប្អូនប្រុសចោទបងប្អូនស្រីក្តី បងប្អូនស្រីចោទបងប្អូនប្រុសក្តី សំឡាញ់ចោទសំឡាញ់ផងគ្នាក្តី ការចោទនេះ មិនចាត់ជាអធិករណ៍ទេ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលមិនចាត់ជាការចោទ។ អាបត្តាធិករណ៍ កិច្ចាធិករណ៍ និងវិវាទាធិករណ៍ អធិករណ៍នេះ មិនចាត់ជាការចោទទេ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលចាត់ជាអធិករណ៍ផង ជាការចោទផង។ អនុវាទាធិករណ៍ ចាត់ជាអធិករណ៍ផង ជាការចោទផង។

[១៤៩] អាបត្តិ ចាត់ជាអាបត្តាធិករណ៍ អាបត្តិ មិនចាត់ជាអធិករណ៍ អធិករណ៍ មិនចាត់ជាអាបត្តិ ចាត់ជាអធិករណ៍ផង ជាអាបត្តិផង អាបត្តិ ចាត់ជាអាបត្តាធិករណ៍ក៏មាន អាបត្តិ មិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍ មិនចាត់ជាអាបត្តិក៏មាន ចាត់ជាអធិករណ៍ផង ជាអាបត្តិផងក៏មាន។ បណ្តាធម៌ទាំងនោះ អាបត្តិដូចម្តេច ដែលចាត់ជាអាបត្តាធិករណ៍។ កងនៃអាបត្តិទាំង៥ ក៏ចាត់ជាអាបត្តាធិករណ៍ កងនៃអាបត្តិទាំង៧ ក៏ចាត់ជាអាបត្តាធិករណ៍ អាបត្តិទាំងនេះ ទើបចាត់ជាអាបត្តាធិករណ៍។ បណ្តាធម៌ទាំងនោះ អាបត្តិដូចម្តេច ដែលមិនចាត់ជាអធិករណ៍។ សោតាបត្តិ និង សមាបត្តិ អាបត្តិ[37] នេះ មិនចាត់ជាអធិករណ៍ទេ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលមិនចាត់ជាអាបត្តិ។ កិច្ចាធិករណ៍ វិវាទាធិករណ៍ និងអនុវាទាធិករណ៍ អធិករណ៍នេះ មិនចាត់ជាអាបត្តិទេ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលចាត់ជាអធិករណ៍ផង ជាអាបត្តិផង។ អាបត្តាធិករណ៍ ចាត់ជាអធិករណ៍ផង ជាអាបត្តិផង។

[១៥០] កិច្ច ចាត់ជាកិច្ចាធិករណ៍ កិច្ច មិនចាត់ជាអធិករណ៍ អធិករណ៍ មិនចាត់ជាកិច្ច ចាត់ជាកិច្ចផង ជាអធិករណ៍ផង កិច្ច ចាត់ជាកិច្ចាធិករណ៍ក៏មាន កិច្ច មិនចាត់ជាអធិករណ៍ក៏មាន អធិករណ៍ មិនចាត់ជាកិច្ចក៏មាន ចាត់ជាអធិករណ៍ផង ជាកិច្ចផងក៏មាន។ បណ្តាធម៌ទាំងនោះ កិច្ចដូចម្តេច ដែលចាត់ជាកិច្ចាធិករណ៍។ កិច្ចរបស់សង្ឃ ឬកម្មដែលសង្ឃត្រូវធ្វើណា គឺអបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១ កិច្ចនេះ ទើបចាត់ជាកិច្ចាធិករណ៍បាន។ បណ្តាធម៌ទាំងនោះ កិច្ចដូចម្តេច ដែលមិនចាត់ជាអធិករណ៍។ កិច្ចដែលអន្តេវាសិក ត្រូវធ្វើដល់អាចារ្យ កិច្ចដែលសទ្ធិវិហារិក ត្រូវធ្វើដល់ឧបជ្ឈាយ៍ កិច្ចដែលភិក្ខុត្រូវធ្វើដល់ភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នា កិច្ចដែលភិក្ខុត្រូវធ្វើដល់ភិក្ខុដែលមានអាចារ្យស្មើគ្នា កិច្ចនេះ មិនចាត់ជាអធិករណ៍ទេ។ បណ្តាធម៌ទាំងនោះ អធិករណ៍ដូចម្តេច ដែលមិនចាត់ជាកិច្ច។ វិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ អធិករណ៍នេះ មិនចាត់ជាកិច្ចទេ។ បណ្តាធម៌ទាំងនោះ កិច្ចដូចម្តេច ដែលចាត់ជាអធិករណ៍ផង ជាកិច្ចផង។ កិច្ចាធិករណ៍ ចាត់ជាអធិករណ៍ផង ជាកិច្ចផង។

ចប់ អធិករណ៍ភេទ។

ឧទ្ទាន គឺបញ្ជីរឿង នៃអធិករណ៍ភេទនោះដូច្នេះ

[១៥១]

> និយាយអំពីការសើរើអធិករណ៍១ ភិក្ខុបាននូវការសើរើដោយអាការ១០យ៉ាង១ បុគ្គល គឺភិក្ខុដែលប្រកបដោយអង្គ៤ ទើបសើរើអធិករណ៍បាន១ និទាន ហេតុ បច្ច័យ មូល និងសមុដ្ឋាន (នៃអធិករណ៍)១ អធិករណ៍ដែលចាត់ជាអាបត្តិ និងអនាបត្តិ១ សមថៈទាំង៧ មានសតិវិន័យជាដើម កើតក្នុងទីណា១ សមថៈទាំង៧ មានសម្មុខាវិន័យជាដើម លាយច្រឡំគ្នា ឬមិនច្រឡំគ្នា១ និទាន ហេតុ បច្ច័យ មូល និងសមុដ្ឋាន (នៃសមថៈទាំង៧ប្រការ)១ សមថៈទាំង៧ប្រការ មានអត្ថ និងព្យញ្ជនៈ (ផ្សេងៗគ្នា)១ ធម៌ទាំងឡាយ មានវិវាទជាដើម ដែលចាត់ជាអធិករណ៍ និងមិនចាត់ជាអធិករណ៍១ នេះជាឧទ្ទាន ក្នុងអធិករណភេទ។

# គាថាសង្គណិកៈ ជាតំណមក

CS vin.pv.09 | ភាគ ទី១៣

## (អបរគាថាសង្គណិកំ)

## ចោទនាទិបុច្ឆាវិស្សជ្ជនៈ

CS vin.pv.09.01 | ភាគ ទី១៣

### (១. ចោទនាទិបុច្ឆាវិស្សជ្ជនា)[38]

[១៥២] សួរថា ការចោទដើម្បីប្រយោជន៍អ្វី ការរំលឹកទោស ដើម្បីហេតុអ្វី ប្រជុំសង្ឃដើម្បីប្រយោជន៍អ្វី ម្យ៉ាងទៀត មតិកម្ម គឺការរៀនមន្តដើម្បីហេតុអ្វី។ ឆ្លើយថា ការចោទ ដើម្បីរំលឹកទោស ការរំលឹកទោសដើម្បីនឹងសង្កត់សង្កិន (បុគ្គលនោះ ឲ្យរាងចាល) ប្រជុំសង្ឃដើម្បីពិនិត្យរកនូវការវិនិច្ឆ័យ ឯមតិកម្ម គឺការរៀនមន្តផ្សេងៗគ្នា (ដើម្បីឲ្យចូលចិត្តនូវការកាត់សេចក្តី)។ បើលោកធ្វើជាវិន័យធរ ត្រូវកុំនិយាយរួសរាន់ពេក កុំនិយាយទាំងកំណាច កុំធ្វើសេចក្តីថ្នាំងថ្នាក់ចិត្តឲ្យកើតឡើង (ចំពោះអ្នកដែលត្រូវចោទ ឬអ្នកដែលចោទ) កុំនិយាយពាក្យសង្កត់សង្កិនឥតប្រយោជន៍ ដោយរួសរាន់ ត្រូវលោកពិចារណានូវវត្ត ដែលគួរប្រព្រឹត្តតាម ជាអនុលោមរបស់សិក្ខាបទ ដែលព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញ ឆ្លៀវឆ្លាសទ្រង់ធ្វើ គឺបាននាំមកតំកល់ទុក ទ្រង់ពោលទុកមកដោយល្អ ក្នុងសុត្តៈ គឺឧភតោវិភង្គ ក្នុងវិន័យ គឺខន្ធកៈ ក្នុងអនុលោម គឺបរិវារៈ ក្នុងបញ្ញត្តិ គឺវិន័យបិដកទាំងអស់ ក្នុងអនុលោមិកៈ គឺមហាបទេស៤ ហើយនិងបានញុំាងគតិរបស់ខ្លួន ដែលប្រព្រឹត្តទៅក្នុងបរលោក មិនឲ្យវិនាសបាន។ លោក កាលស្វែងរកនូវប្រយោជន៍ គប្បីប្រកបតាមធម្មជាត ដែលប្រកបដោយប្រយោជន៍តាមកាលដ៏គួរ លោកកុំអាលជឿសំដី របស់អ្នកជាប់ចោទ និងអ្នកចោទ ដោយរហ័សឡើយ។ (បើ) អ្នកចោទនិយាយថា លោកត្រូវអាបត្តិហើយ លោកអ្នកជាប់ចោទ ប្រកែកថា ខ្ញុំមិនត្រូវអាបត្តិទេ (វិន័យធរ) កុំអាលលើកលែងបុគ្គលទាំង២ (នោះ) គប្បីវិនិច្ឆ័យតាមដំណាពាក្យដែលប្តេជ្ញា។ ពាក្យប្តេជ្ញា (ណា) ដែលវិន័យធរ ពោលចំពោះពួកបុគ្គលដែលមានសេចក្តីខ្មាស ពាក្យប្តេជ្ញានុ៎ះ មិនមានក្នុងពួកបុគ្គល ដែលឥតសេចក្តីខ្មាសទេ (ព្រោះថា) បុគ្គលដែលឥតសេចក្តីខ្មាស សូម្បីពោលពាក្យច្រើនក្តី (វិន័យធរ) គប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញា ដែលជាប់មកជាមួយនឹងវត្តប្រតិបត្តិរបស់បុគ្គលនោះ។

[១៥៣] សួរថា អលជ្ជីបុគ្គល តើដូចម្តេច សេចក្តីប្តេជ្ញាមិនលូតលាស់ដល់បុគ្គលណា ខ្ញុំសួរចំពោះបុគ្គលនុ៎ះ ដូច្នេះថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគ ត្រាស់ហៅថា អលជ្ជីបុគ្គល។ ឆ្លើយថា បុគ្គលមានចិត្តក្លែង ត្រូវអាបត្តិ រួចបិទបាំងអាបត្តិទុកក្តី លុះតាមអំណាចអគតិក្តី បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា អលជ្ជីបុគ្គល។

[១៥៤] ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះហៅថា អលជ្ជីបុគ្គល ប៉ុន្តែខ្ញុំសូមសួររកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគ ត្រាស់ហៅថា លជ្ជីបុគ្គល។ ឆ្លើយថា បុគ្គលមិនក្លែងឲ្យត្រូវអាបត្តិ មិនបានបិទបាំងអាបត្តិ មិនលុះអំណាចអគតិ បុគ្គលយ៉ាងនេះ ដែលព្រះមានព្រះភាគត្រាស់ហៅថា លជ្ជីបុគ្គល។

[១៥៥] ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះហៅថា លជ្ជីបុគ្គល ប៉ុន្តែខ្ញុំសូមសួររកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទមិនត្រូវតាមធម៌។ ឆ្លើយថា បុគ្គលដែលចោទ ដោយមិនត្រូវតាមកាល១ ដោយពាក្យមិនពិត១ ដោយពាក្យទ្រគោះ១ ដោយពាក្យមិនប្រកបដោយប្រយោជន៍១ ចោទដោយសេចក្តីស្អប់ មិនចោទដោយមេត្តាចិត្ត១ បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទមិនប្រកបដោយធម៌។

[១៥៦] ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទមិនប្រកបដោយធម៌ ប៉ុន្តែខ្ញុំសូមសួររកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទត្រូវតាមធម៌។ ឆ្លើយថា បុគ្គលដែលចោទ ត្រូវតាមកាល១ ដោយពាក្យពិត១ ដោយពាក្យផ្អែមល្ហែម១ ដោយពាក្យប្រកបដោយប្រយោជន៍១ ចោទដោយមេត្តាចិត្ត មិនចោទដោយស្អប់១ បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទត្រូវតាមធម៌។

[១៥៧] ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទត្រូវតាមធម៌ ប៉ុន្តែខ្ញុំសូមសួររកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទជាបុគ្គលពាល។ ឆ្លើយថា បុគ្គលមិនដឹងពាក្យខាងដើម និងពាក្យខាងចុង មិនយល់ដល់ពាក្យខាងដើម និងពាក្យខាងចុង មិនដឹងគន្លងពាក្យតគ្នា មិនយល់ដល់គន្លងពាក្យតគ្នា បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទជាបុគ្គលពាល។

[១៥៨] ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទជាបុគ្គលពាល ប៉ុន្តែខ្ញុំសូមសួររកបុគ្គលដទៃទៀតនឹងអ្នកថា បុគ្គលយ៉ាងណា ដែលព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទជាបណ្ឌិត។ ឆ្លើយថា បុគ្គលដែលដឹងពាក្យខាងដើម និងពាក្យខាងចុង យល់ដល់ពាក្យខាងដើម និងពាក្យខាងចុង ដឹងគន្លងពាក្យតគ្នា យល់ដល់គន្លងពាក្យតគ្នា បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទជាបណ្ឌិត។

[១៥៩] ខ្ញុំដឹងពិតថា បុគ្គលយ៉ាងនេះ ដែលព្រះមានព្រះភាគ ត្រាស់ហៅថា អ្នកចោទជាបណ្ឌិត ប៉ុន្តែខ្ញុំសូមសួររកហេតុដទៃទៀតនឹងអ្នកថា ដូចម្តេច ដែលព្រះមានព្រះភាគ ត្រាស់ហៅថា ការចោទ។ ឆ្លើយថា បុគ្គលចោទដោយសីលវិបត្តិក្តី ពុំនោះសោត ដោយអាចារវិបត្តិក្តី ទិដ្ឋិវិបត្តិក្តី ចោទដោយអាជីវវិបត្តិក្តី ការចោទដោយសីលវិបត្តិជាដើមនោះ ព្រះមានព្រះភាគ ត្រាស់ហៅថា ការចោទ។

ចប់ គាថាសង្គណិកៈ (គាថាឆ្លកឆ្លាស់គ្នា) ជាតំណមក។

# ចោទនាកណ្ឌ

CS vin.pv.10 | ភាគ ទី១៣

## (ចោទនាកណ្ឌំ)

## (អនុវិជ្ជកអនុយោគៈ ទី១)

CS vin.pv.10.01 | ភាគ ទី១៣

### (១. អនុវិជ្ជកអនុយោគោ)

[១៦០] វិន័យធរ ត្រូវសួរភិក្ខុអ្នកចោទថា ម្នាលអាវុសោ លោកចោទភិក្ខុនេះ ដោយហេតុណា លោកចោទភិក្ខុនោះ ព្រោះទោសអ្វី លោកចោទដោយសីលវិបត្តិ ដោយអាចារវិបត្តិ ឬចោទដោយទិដ្ឋិវិបត្តិ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ខ្ញុំចោទដោយសីលវិបត្តិក្តី ខ្ញុំចោទដោយអាចារវិបត្តិក្តី ខ្ញុំចោទដោយទិដ្ឋិវិបត្តិក្តី។ ត្រូវវិន័យធរសួរភិក្ខុនោះយ៉ាងនេះថា លោកមានអាយុស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរឬទេ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរ។ ត្រូវវិន័យធរ សួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ ចុះដូចម្តេចហៅថា សីលវិបត្តិ ដូចម្តេចហៅថា អាចារវិបត្តិ ដូចម្តេចហៅថា ទិដ្ឋិវិបត្តិ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា បារាជិក៤ និងសង្ឃាទិសេស១៣នេះ ហៅថា សីលវិបត្តិ ថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ និងទុព្ភាសិត នេះហៅថា អាចារវិបត្តិ មិច្ឆាទិដ្ឋិ និងអន្តគ្គាហិកាទិដ្ឋិ នេះហៅថា ទិដ្ឋិវិបត្តិ។ ត្រូវវិន័យធរ សួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកចោទភិក្ខុនេះ ដោយហេតុណា លោកចោទដោយឃើញ ដោយឮ ឬក៏ចោទដោយរង្កៀសទេ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ខ្ញុំចោទដោយឃើញក្តី ចោទដោយឮក្តី ចោទដោយរង្កៀសក្តី។ ត្រូវវិន័យធរ សួរភិក្ខុអ្នកចោទនោះ យ៉ាងនេះថា ម្នាលអាវុសោ លោកចោទភិក្ខុនេះ ដោយឃើញហេតុណា លោកបានឃើញទោសដូចម្តេច លោកបានឃើញហេតុដូចម្តេច លោកបានឃើញពីកាលណា លោកបានឃើញក្នុងទីណា កាលភិក្ខុនោះត្រូវអាបត្តិបារាជិក លោកបានឃើញដែរឬ កាលត្រូវអាបត្តិសង្ឃាទិសេស លោកបានឃើញដែរឬ កាលត្រូវ

អាបត្តិថុល្លច្ច័យ លោកបានឃើញដែរឬ កាលត្រូវអាបត្តិបាចិត្តិយៈ លោកបានឃើញដែរឬ កាលត្រូវអាបត្តិបាដិទេសនីយៈ លោកបានឃើញដែរឬ កាលត្រូវអាបត្តិទុក្កដ លោកបានឃើញដែរឬ មួយទៀត លោកនៅក្នុងទីណា ភិក្ខុនេះនៅក្នុងទីណា ចំណែកខាងលោកកំពុងធ្វើអ្វី ឯភិក្ខុនេះកំពុងធ្វើអ្វី។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានចោទភិក្ខុនោះ ដោយការឃើញទេ ខ្ញុំចោទដោយគ្រាន់តែបានឮ។ ត្រូវវិន័យធរសួរភិក្ខុអ្នកចោទនោះ យ៉ាងនេះថា ម្នាលអាវុសោ លោកចោទភិក្ខុនេះដោយបានឮ ដោយហេតុណា លោកបានឮដូចម្តេច លោកបានឮហេតុដូចម្តេច លោកបានឮក្នុងកាលណា លោកបានឮក្នុងទីណា លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិបារាជិក លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិថុល្លច្ច័យ លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិបាចិត្តិយៈ លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិបាដិទេសនីយៈ លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិទុក្កដ លោកបានឮថា ភិក្ខុនេះត្រូវអាបត្តិទុព្ភាសិត លោកបានឮពាក្យភិក្ខុ លោកបានឮពាក្យភិក្ខុនី លោកបានឮពាក្យសិក្ខមានា លោកបានឮពាក្យសាមណេរ លោកបានឮពាក្យសាមណេរី លោកបានឮពាក្យឧបាសក លោកបានឮពាក្យឧបាសិកា លោកបានឮពាក្យពួកស្តេច លោកបានឮពាក្យពួករាជមហាមាត្រ លោកបានឮពាក្យពួកតិរ្ថិយ លោកបានឮពាក្យសាវ័កតិរ្ថិយឬ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានចោទភិក្ខុនេះដោយបានឮទេ ខ្ញុំចោទដោយត្រឹមតែសេចក្តីរង្កៀស។ ត្រូវវិន័យធរសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកចោទភិក្ខុនេះ ដោយសេចក្តីរង្កៀសដោយហេតុណា លោករង្កៀសដូចម្តេច លោករង្កៀសអំពីហេតុអ្វី លោករង្កៀសក្នុងកាលណា លោករង្កៀសក្នុងទីណា លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិបារាជិក លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិថុល្លច្ច័យ លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិបាចិត្តិយៈ លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិបាដិទេសនីយៈ លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិទុក្កដ លោករង្កៀសថា ភិក្ខុនេះត្រូវអាបត្តិទុព្ភាសិត លោករង្កៀស ព្រោះឮពាក្យភិក្ខុ លោករង្កៀស ព្រោះឮពាក្យភិក្ខុនី លោករង្កៀស ព្រោះឮពាក្យសិក្ខមានា លោករង្កៀស ព្រោះឮពាក្យសាមណេរ លោករង្កៀស ព្រោះឮពាក្យសាមណេរី លោករង្កៀស ព្រោះឮពាក្យឧបាសក លោករង្កៀស ព្រោះឮពាក្យឧបាសិកា លោករង្កៀស ព្រោះឮពាក្យពួកស្តេច លោករង្កៀស ព្រោះឮពាក្យពួករាជមហាមាត្រ លោករង្កៀស ព្រោះឮពាក្យពួកតិរ្ថិយ លោករង្កៀស ព្រោះឮពាក្យពួកសាវ័កតិរ្ថិយ។

[១៦១] ហេតុដែលអ្នកចោទបានឃើញ សមតាមហេតុដែលឃើញមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានឃើញ តាមហេតុដែលបានឃើញ (បើ) ភិក្ខុអ្នកជាប់ចោទ មិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យហេតុ ដែលអ្នកចោទបានឃើញនោះទេ ឈ្មោះថា អ្នកចោទ មានសេចក្តីរង្កៀសមិនបរិសុទ្ធ គឺរង្កៀសដោយមិនមានមូល វិន័យធរ គប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញា របស់ភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើឧបោសថជាមួយនឹងភិក្ខុនោះចុះ។ ហេតុដែលអ្នកចោទបានឮ សមតាមហេតុ ដែលបានឮមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុ ដែលអ្នកចោទបានឮ តាមហេតុដែលបានឮ (បើ) ភិក្ខុអ្នកជាប់ចោទនោះ មិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យហេតុ ដែលអ្នកចោទបានឮទេ ឈ្មោះថា អ្នកចោទ មានសេចក្តីរង្កៀសមិនបរិសុទ្ធ វិន័យធរ គប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញា របស់ភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើឧបោសថជាមួយនឹងភិក្ខុនោះចុះ។ ហេតុដែលអ្នកចោទបានប៉ះពាល់ សមតាមហេតុ ដែលបានប៉ះពាល់មែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលបានប៉ះពាល់ តាមហេតុដែលបានប៉ះពាល់ (បើ) ភិក្ខុអ្នកជាប់ចោទនោះ មិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យហេតុ ដែលអ្នកចោទបាន ប៉ះពាល់ទេ ឈ្មោះថា អ្នកចោទ មានសេចក្តីរង្កៀសមិនបរិសុទ្ធ វិន័យធរ គប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញា របស់ភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើឧបោសថជាមួយនឹងភិក្ខុនោះចុះ។

[១៦២] សួរថា ការចោទ មានអ្វីជាខាងដើម អ្វីជាកណ្តាល អ្វីជាទីបំផុត។ ឆ្លើយថា ការចោទ មានឱកាសកម្ម គឺសូមឱកាស ជាខាងដើម មានកិរិយា គឺអំពើដែលវិន័យធរត្រូវធ្វើ ជាកណ្តាល មានសមថៈ គឺសេចក្តីរម្ងាប់ ជាទីបំផុត។ សួរថា ការចោទ មានមូលប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន បុគ្គលចោទដោយអាការប៉ុន្មាន។ ឆ្លើយថា ការចោទ មានមូល២ មានវត្ថុ៣ មានភូមិ៥ បុគ្គលចោទដោយអាការ២។ សួរថា ការចោទមានមូល២ គឺអ្វីខ្លះ។ ឆ្លើយថា ការចោទ មានមូល២នេះ គឺចោទដោយមានមូល១ ចោទដោយមិនមានមូល១។ សួរថា ការចោទមានវត្ថុ៣ គឺអ្វីខ្លះ។ ឆ្លើយថា ការចោទមានវត្ថុ៣ នេះ គឺដោយបានឃើញ១ ដោយបានឮ១ ដោយបានរង្កៀស១។ សួរថា ការចោទមានភូមិ៥ គឺអ្វីខ្លះ។ ឆ្លើយថា ការចោទមានភូមិ៥នេះ គឺពោលត្រូវតាមកាល មិនពោលខុសកាល១ ពោលពាក្យពិត មិនពោលពាក្យដែលមិនពិត១ ពោលពាក្យផ្អែមល្ហែម មិនពោលពាក្យទ្រគោះ១ ពោលពាក្យប្រកបដោយប្រយោជន៍ មិនពោលពាក្យដែលមិនប្រកបដោយប្រយោជន៍១ ពោលដោយមេត្តាចិត្ត មិនពោលដោយសេចក្តីស្អប់១។ សួរថា បុគ្គលចោទដោយអាការ២ គឺអ្វីខ្លះ។ ឆ្លើយថា បុគ្គលចោទដោយអាការ២នេះ គឺចោទដោយកាយ១ ចោទដោយវាចា១។

## (ចោទកាទិបដិបត្តិ ទី២)

CS vin.pv.10.02 | ភាគ ទី១៣

### (២. ចោទកាទិបដិបត្តិ)

[១៦៣] សួរថា អ្នកចោទត្រូវប្រតិបត្តិដូចម្តេច អ្នកជាប់ចោទត្រូវប្រតិបត្តិដូចម្តេច សង្ឃត្រូវប្រតិបត្តិដូចម្តេច វិន័យធរត្រូវប្រតិបត្តិដូចម្តេច។ ត្រង់ពាក្យសួរថា អ្នកចោទត្រូវប្រតិបត្តិដូចម្តេច។ ឆ្លើយថា អ្នកចោទត្រូវតាំងនៅក្នុងធម៌៥យ៉ាង ទើបចោទអ្នកដទៃបាន គឺតាំងចិត្តថា អាត្មាអញនឹងនិយាយត្រូវតាមកាល មិននិយាយខុសកាល១ នឹងនិយាយពាក្យពិត មិននិយាយពាក្យដែលមិនពិត១ នឹងនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យទ្រគោះ១ នឹងនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យឥតប្រយោជន៍១ នឹងនិយាយដោយមេត្តាចិត្ត មិននិយាយដោយសេចក្តីស្អប់១។ អ្នកចោទត្រូវប្រតិបត្តិយ៉ាងនេះ។ ត្រង់ពាក្យសួរថា អ្នកជាប់ចោទ ត្រូវប្រតិបត្តិដូចម្តេច។ ឆ្លើយថា អ្នកជាប់ចោទ ត្រូវតាំងនៅក្នុងធម៌២យ៉ាង គឺក្នុងសច្ចវាចា១ ក្នុងអកុប្បធម៌ គឺសេចក្តីមិនក្រោធចំពោះអ្នកចោទ ចំពោះវិន័យធរ ចំពោះសង្ឃ១។ អ្នកជាប់ចោទ ត្រូវប្រតិបត្តិយ៉ាងនេះ។ ត្រង់ពាក្យសួរថា សង្ឃត្រូវប្រតិបត្តិដូចម្តេច។ ឆ្លើយថា សង្ឃត្រូវដឹងពាក្យដែលទាក់ទងរកគ្នា និងពាក្យដែលមិនទាក់ទងរកគ្នា គឺដឹងពាក្យខាងដើម និងពាក្យខាងចុង របស់អ្នកចោទមានប៉ុណ្ណេះ របស់អ្នកជាប់ចោទ មានប៉ុណ្ណេះជាដើម។ សង្ឃត្រូវប្រតិបត្តិយ៉ាងនេះ។ ត្រង់ពាក្យសួរថា វិន័យធរត្រូវប្រតិបត្តិដូចម្តេច។ ឆ្លើយថា អធិករណ៍នោះ តែងរម្ងាប់បានដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា វិន័យធរ ត្រូវរម្ងាប់អធិករណ៍នោះឯង ដោយធម៌នោះៗចុះ។ វិន័យធរត្រូវប្រតិបត្តិយ៉ាងនេះឯង។

[១៦៤] សួរថា ការធ្វើឧបោសថ ដើម្បីប្រយោជន៍អ្វី ធ្វើបវារណា ដើម្បីអ្វី ធ្វើបរិវាស ដើម្បីប្រយោជន៍អ្វី ធ្វើការទាញភិក្ខុមកដាក់ក្នុងមូលាបត្តិ ដើម្បីអ្វី ការប្រព្រឹត្តមានត្ត ដើម្បីប្រយោជន៍អ្វី ធ្វើអព្ភានកម្ម ដើម្បីអ្វី។ ឆ្លើយថា ធ្វើឧបោសថដើម្បីប្រយោជន៍ឲ្យសង្ឃព្រមព្រៀងគ្នា ធ្វើបវារណា ដើម្បីប្រយោជន៍ឲ្យសង្ឃស្អាតដោយវិសេស ធ្វើបរិវាស ដើម្បីប្រយោជន៍ដល់មានត្ត ធ្វើការទាញភិក្ខុមកដាក់ក្នុងមូលាបត្តិ ដើម្បីប្រយោជន៍នឹងសង្កត់សង្កិន (នូវបរិវាសិកភិក្ខុឲ្យរាងចាល) ការប្រព្រឹត្តមានត្ត ដើម្បីប្រយោជន៍ដល់អព្ភានកម្ម ធ្វើអព្ភានកម្ម ដើម្បីប្រយោជន៍ នឹងឲ្យភិក្ខុនោះស្អាតបរិសុទ្ធ។ បុគ្គលណា ពោលមើលងាយពួកភិក្ខុជាថេរៈ ព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ឬព្រោះវង្វេង បុគ្គលនោះឈ្មោះថាជាអ្នកឥតប្រាជ្ញា ជាអ្នកបៀតបៀនខ្លួនឯង ផ្តាច់បង់ឥន្ទ្រិយ (មានសទ្ធិន្ទ្រិយជាដើម) ជាអ្នកឥតប្រាជ្ញា មិនមានសេចក្តីគោរពក្នុងសិក្ខា លុះទំលាយកាយទៅ តែងទៅកាន់នរក។ (ព្រោះហេតុនោះ) វិន័យធរ ត្រូវវៀរហេតុទាំងពីរនេះ គឺកុំអាស្រ័យអាមិសៈ១ កុំអាស្រ័យបុគ្គល[39] ១ ត្រូវតែវិនិច្ឆ័យសេចក្តីតាមសមគួរដល់ធម៌។

## (ចោទកស្សអត្តឈាបនៈ ទី៣)

CS vin.pv.10.03 | ភាគ ទី១៣

### (៣. ចោទកស្សអត្តឈាបនំ)

ភិក្ខុដែលមានសេចក្តីក្រោធខឹង ចងសេចក្តីក្រោធទុក កាចអាក្រក់ ពោលតិះដៀល លើកអនាបត្តិ ថាជាអាបត្តិវិញ អ្នកចោទដូច្នោះឈ្មោះថា ដុតខ្លួនឯង។ ភិក្ខុខិនខ្សឹបខ្សៀបត្រចៀក ស្វែងរកតែទោស ធ្វើការវិនិច្ឆ័យឲ្យសាបសូន្យ សេពគប់តែផ្លូវដែលខុសៗ គឺប្រកាសនូវអាបត្តិ លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ក៏ឈ្មោះថា ដុតខ្លួនឯង បុគ្គលអ្នកចោទ ដោយមិនត្រូវតាមកាលដោយពាក្យមិនពិត ដោយពាក្យទ្រគោះ ដោយពាក្យឥតប្រយោជន៍ ចោទដោយស្អប់ មិនចោទដោយមេត្តាចិត្ត លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នេះ ក៏ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងធម៌ និងអធម៌ មិនឈ្វេងយល់ធម៌ និងអធម៌ លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ក៏ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងវិន័យ និងអវិន័យ មិនឈ្វេងយល់វិន័យ និងអវិន័យ លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងភាសិត និងអភាសិត មិនឈ្វេងយល់ភាសិត និងអភាសិត លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងកិច្ចវត្តដែលអ្នកប្រាជ្ញសន្សំ និងមិនសន្សំ មិនឈ្វេងយល់កិច្ចវត្ត ដែលអ្នកប្រាជ្ញសន្សំ និងមិនសន្សំ លើកអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងសិក្ខាបទ ដែលព្រះមានព្រះភាគបញ្ញត្ត និងមិនបានបញ្ញត្ត មិនឈ្វេងយល់សិក្ខាបទ ដែលព្រះមានព្រះភាគបញ្ញត្ត និងមិនបានបញ្ញត្ត លើកអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងនូវអាបត្តិ និងអនាបត្តិ មិនឈ្វេងយល់ដល់អាបត្តិ និងអនាបត្តិ លើកអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងលហុកាបត្តិ និងគរុកាបត្តិ មិនឈ្វេងយល់លហុកាបត្តិ និងគរុកាបត្តិ លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងនូវសាវសេសាបត្តិ និងអនវសេសាបត្តិ មិនឈ្វេងយល់ដល់សាវសេសាបត្តិ និងអនវសេសាបត្តិ លើកអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងនូវទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ មិនឈ្វេងយល់ដល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងពាក្យខាងដើម និងពាក្យខាងចុង មិនឈ្វេងយល់ពាក្យខាងដើម និងពាក្យខាងចុង លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។ បុគ្គលមិនដឹងគន្លងនៃពាក្យតគ្នា មិនឈ្វេងយល់គន្លងនៃពាក្យតគ្នា លើកនូវអនាបត្តិ ថាជាអាបត្តិ អ្នកចោទដូច្នោះ ឈ្មោះថា ដុតខ្លួនឯង។

ចប់ ចោទនាកណ្ឌ។

ឧទ្ទាន គឺបញ្ជីរឿងនៃចោទនាកណ្ឌនោះដូច្នេះ

[១៦៥]

និយាយអំពីអ្នកចោទ និងវិន័យធរ១ ការចោទមានអ្វីជាខាងដើម និងមានមូលប៉ុន្មាន១ សួរថា ការធ្វើឧបោសថ ដើម្បីប្រយោជន៍អ្វី១ ដំណើរក្នុងចោទនាកណ្ឌ (នេះ) ជាគ្រឿងញុំាងសាសនាឲ្យឋិតថេរ។

# ចូឡសង្គាម

CS vin.pv.11 | ភាគ ទី១៣

### (ចូឡសង្គាមោ)

## (អនុវិជ្ជកស្សបដិបត្តិ)

CS vin.pv.11.01 | ភាគ ទី១៣

### (១. អនុវិជ្ជកស្សបដិបត្តិ)

[១៦៦] ភិក្ខុអ្នកចូលកាន់សង្គ្រាម[40] កាលបើចូលទៅរកជំនុំសង្ឃ គប្បីបន្ទាបបន្ថន់ចិត្ត ចូលទៅរកសង្ឃ គប្បីជាអ្នកមានចិត្តស្មើដោយកំណាត់សំពត់សម្រាប់ជូតនូវធូលី គប្បីជាអ្នកឈ្លាសក្នុងអាសនៈ ជាអ្នកឈ្លាសក្នុងការអង្គុយ កុំអង្គុយច្រៀតបៀតពួកភិក្ខុចាស់ កុំឃាត់អាសនៈ

ពួកភិក្ខុខ្ចី គប្បីអង្គុយលើអាសនៈតាមសមគួរ គប្បីជាអ្នកមិនពោលពាក្យឥតប្រយោជន៍ផ្សេងៗ កុំពោលពាក្យតិរច្ឆានកថា គប្បីសំដែងធម៌ដោយខ្លួនឯងផង គប្បីនិមន្តភិក្ខុដទៃ ឲ្យសំដែងផង កុំមើលងាយព្រះអរិយៈ ដែលមានសភាពជាអ្នកស្ងប់ស្ងៀមផង។ ភិក្ខុជាវិន័យធរ ដែលសង្ឃបានអនុម័ត[41] ហើយមានប្រាថ្នានឹងវិនិច្ឆ័យសេចក្តី មិនត្រូវសួររកឧបជ្ឈាយ៍ មិនត្រូវសួររកអាចារ្យ មិនត្រូវសួររកសទ្ធិវិហារិក មិនត្រូវសួររកអន្តេវាសិក មិនត្រូវសួររកបុគ្គល ដែលមានឧបជ្ឈាយ៍ស្មើគ្នា មិនត្រូវសួររកបុគ្គល ដែលមានអាចារ្យស្មើគ្នា មិនត្រូវសួររកជាតិ (មានក្សត្រិយ៍ជាដើម) មិនត្រូវសួររកនាម មិនត្រូវសួររកគោត្រ មិនត្រូវសួររកអាគម (វិជ្ជាចំណេះថា លោកចេះពោលនិកាយ មានទីឃនិកាយជាដើម) មិនត្រូវសួររកត្រកូល និងប្រទេស មិនត្រូវសួររកជាតិភូមិ (ស្រុកកំណើត)។ ព្រោះហេតុអ្វី (បានជាមិនត្រូវឲ្យសួរដូច្នេះ)។ (ព្រោះថា) សេចក្តីស្រឡាញ់ក្តី សេចក្តីស្អប់ក្តី នឹងមានដល់បុគ្គលជាវិន័យធរនោះ កាលបើមានសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ហើយ (វិន័យធរនោះ) មុខជាលំអៀង ព្រោះស្រឡាញ់ ឬលំអៀងព្រោះស្អប់ លំអៀងព្រោះវង្វេង ឬក៏លំអៀងព្រោះខ្លាច (មិនខាន)។ ភិក្ខុជាវិន័យធរ ដែលសង្ឃបានអនុម័តហើយ មានប្រាថ្នានឹងវិនិច្ឆ័យសេចក្តី ត្រូវមានចិត្តធ្ងន់ក្នុងសង្ឃ កុំធ្ងន់ទៅក្នុងបុគ្គល ត្រូវមានចិត្តធ្ងន់ក្នុងព្រះសទ្ធម្ម កុំធ្ងន់ទៅក្នុងអាមិសៈ ជាអ្នកលុះក្នុងអំណាចនៃប្រយោជន៍ មិនត្រូវបណ្តែតបណ្តោយតាមសេចក្តីគាប់ចិត្តបរិសទ្យ គប្បីវិនិច្ឆ័យសេចក្តីតាមកាល កុំវិនិច្ឆ័យសេចក្តីឲ្យខុសកាល ត្រូវវិនិច្ឆ័យសេចក្តីដោយពាក្យពិត កុំវិនិច្ឆ័យដោយពាក្យមិនពិត ត្រូវវិនិច្ឆ័យសេចក្តីដោយពាក្យផ្អែមល្ហែម កុំវិនិច្ឆ័យសេចក្តីដោយពាក្យទ្រគោះ ត្រូវវិនិច្ឆ័យសេចក្តីដោយពាក្យ ដែលមានប្រយោជន៍ កុំវិនិច្ឆ័យសេចក្តីដោយពាក្យឥតប្រយោជន៍ ត្រូវវិនិច្ឆ័យសេចក្តីដោយមេត្តាចិត្ត កុំវិនិច្ឆ័យសេចក្តីដោយសំអប់ កុំនិយាយខ្សឹបជិតត្រចៀក កុំស្វែងរកតែទោសខុស កុំមិចភ្នែក កុំញាក់ចិញ្ចើម កុំងក់ក្បាល កុំធ្វើវិការៈផ្សេងៗដោយដៃ កុំបង្ហាញដៃទទេ ត្រូវឈ្លាសក្នុងអាសនៈ ឈ្លាសក្នុងការអង្គុយ គប្បីសំឡឹងមើលត្រឹមតែមួយជួរនឹម ត្រូវពិចារណាសេចក្តីសិន ហើយសឹមអង្គុយលើអាសនៈរបស់ខ្លួន កុំក្រោកចាកអាសនៈ កុំធ្វើការវិនិច្ឆ័យឲ្យសាបសូន្យ កុំសេពគប់ផ្លូវខុស គឺកុំប្រកាសអាបត្តិ កុំនិយាយសំដីបោះបោក កុំនិយាយរួសរាន់ពេក កុំនិយាយរហ័សហួស កុំកាចអាក្រក់ ត្រូវចេះអត់ធ្មត់ ត្រូវមានមេត្តាចិត្ត មានចិត្តអនុគ្រោះចំពោះប្រយោជន៍ ត្រូវមានចិត្តប្រកបដោយករុណា ស្វែងរកនូវប្រយោជន៍ កុំពោលពាក្យរោយរាយ ត្រូវពោលពាក្យឲ្យមានទីបំផុត កុំលុះអំណាចនៃពៀរ កុំពោលពាក្យអសុរស ត្រូវស្ទង់មើលខ្លួន (ថាអាត្មាអញអាចនឹងវិនិច្ឆ័យសេចក្តីបានឬទេ) ត្រូវស្ទង់មើលបុគ្គលដទៃ (ថាបរិសទ្យនេះ អាចសុខចិត្ត ដោយសេចក្តីអៀនខ្មាសដែរឬទេ) ត្រូវស្ទង់មើលបុគ្គលអ្នកចោទ (ថាអ្នកចោទនេះ ប្រកបដោយធម៌ឬទេ) ត្រូវស្ទង់មើលអ្នកជាប់ចោទ ត្រូវស្ទង់មើលអ្នកចោទមិនត្រូវតាមធម៌ ត្រូវស្ទង់មើលអ្នកជាប់ចោទមិនត្រូវតាមធម៌ ត្រូវស្ទង់មើលអ្នកចោទត្រូវតាមធម៌ ត្រូវស្ទង់មើលអ្នកជាប់ចោទត្រូវតាមធម៌ កុំបំបាត់ពាក្យអ្នកចោទ និងអ្នកជាប់ចោទ ដែលនិយាយមកហើយ កុំប្រកាសផ្សាយពាក្យដែលអ្នកចោទ និងអ្នកជាប់ចោទ មិនទាន់បាននិយាយ ត្រូវរៀនបទ និងព្យញ្ជនៈ ដែលទាក់ទងគ្នា ឲ្យចេះចាំល្អ ហើយសួរបុគ្គលដទៃសិន សឹមវិនិច្ឆ័យសេចក្តីតាមពាក្យប្តេជ្ញា ត្រូវធ្វើអ្នកមានបញ្ញាទន់ឲ្យរីករាយ ត្រូវធ្វើអ្នកដែលមានសេចក្តីភិតភ័យឲ្យស្រួលចិត្ត ត្រូវគំរាមបុគ្គលដែលកាច ត្រូវឲ្យបុគ្គលដែលជាអលជ្ជីសំដែងអាបត្តិចេញ ត្រូវមានចិត្តត្រង់ មានចិត្តទន់ កុំលុះឆន្ទាគតិ កុំលុះទោសាគតិ កុំលុះមោហាគតិ កុំលុះភយាគតិ ត្រូវជាអ្នកមានខ្លួនតាំងនៅជាកណ្តាលចំពោះធម៌ផង ចំពោះបុគ្គលផង។ កាលបើវិន័យធរ បានវិនិច្ឆ័យតាមទំនងយ៉ាងនេះហើយ ឈ្មោះថា ជាអ្នកធ្វើសាសនារបស់ព្រះសាស្តា (ឲ្យរុងរឿង)ផង ឈ្មោះថា ជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ដែលជាអ្នកចេះដឹងផង។

[១៦៧] សុត្តៈ គឺឧភតោវិភង្គ (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ និងប្រៀបធៀប (នូវអាបត្តិ និងអនាបត្តិ) សេចក្តីឧបមា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ និងពន្យល់សេចក្តីឲ្យច្បាស់ អត្ថ (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ និងឲ្យដឹងច្បាស់ បដិបុច្ឆា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ នឹងដំកល់ទុក (នូវបុគ្គល) ឱកាសកម្ម (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ដល់ការចោទ ការចោទ (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងរំលឹក (នូវទោសតូច និងទោសធំ) ការរំលឹកទោស ដើម្បីប្រយោជន៍នឹងធ្វើ (បុគ្គលនោះ) ឲ្យមានមាត់ពាក្យ អំពើដែលធ្វើឲ្យមានមាត់ពាក្យ ដើម្បីប្រយោជន៍ដល់ការកង្វល់ ការកង្វល់ ដើម្បីប្រយោជន៍នឹងដំកល់ទុកនូវការវិនិច្ឆ័យសេចក្តី ការវិនិច្ឆ័យ ដើម្បីប្រយោជន៍ពិចារណា (នូវទោសតូច និងទោសធំ) ការពិចារណា ដើម្បីប្រយោជន៍នឹងដឹងនូវហេតុគួរ និងមិនគួរ (ដឹងអាបត្តិ និងអនាបត្តិ គរុកាបត្តិ និងលហុកាបត្តិ) ការដឹងនូវហេតុគួរ និងមិនគួរ ដើម្បីប្រយោជន៍សង្កត់សង្កិនពួកបុគ្គល ដែលមិនមានសេចក្តីអៀនខ្មាស និងដើម្បីប្រយោជន៍លើកដំកើងនូវពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ជំនុំសង្ឃ ដើម្បីប្រយោជន៍ទទួលនូវការវិនិច្ឆ័យ បុគ្គល គឺពួកភិក្ខុដែលសង្ឃអនុញ្ញាតហើយ គួរដល់ដំណែងជាធំតាមចំណែក និងគួរដល់ដំណែងជាអ្នកពោលពាក្យពិត។ វិន័យ ដើម្បីប្រយោជន៍ដល់សេចក្តីសង្រួម សេចក្តីសង្រួម ដើម្បីប្រយោជន៍ដល់សេចក្តីមិនក្តៅក្រហាយចិត្ត សេចក្តីមិនក្តៅក្រហាយចិត្ត ដើម្បីប្រយោជន៍ដល់បាមុជ្ជៈ គឺសេចក្តីរីករាយទន់ បាមុជ្ជៈ ដើម្បីប្រយោជន៍ដល់បីតិ គឺសេចក្តីរីករាយដ៏ក្លា បីតិ ដើម្បីប្រយោជន៍ដល់បស្សទ្ធិ គឺសេចក្តីស្ងប់រម្ងាប់ បស្សទ្ធិ ដើម្បីប្រយោជន៍ដល់សុខៈ សុខៈ ដើម្បីប្រយោជន៍ដល់សមាធិ សមាធិ ដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ គឺតរុណវិបស្សនា (វិបស្សនាទន់ខ្ចី) យថាភូតញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់និព្វិទា គឺពលវវិបស្សនា (វិបស្សនាមានកំឡាំង) និព្វិទា ដើម្បីប្រយោជន៍ដល់វិរាគៈ គឺអរិយមគ្គ វិរាគៈ ដើម្បីប្រយោជន៍ដល់វិមុត្តិ គឺអរហត្តផល វិមុត្តិ ដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ វិមុត្តិញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន គឺរំលត់មិនឲ្យមានបច្ច័យជាគ្រឿងប្រកាន់តទៅ។ ព្រះអរហត្តផល ឬព្រះនិព្វាន ជាគ្រឿងរួចចាកសេចក្តីសៅហ្មងនៃចិត្ត ព្រោះមិនមានឧបាទានជាគ្រឿងប្រកាន់ណា ការពោលនូវព្រះវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វាននុ៎ះជាប្រយោជន៍ ការប្រឹក្សានូវវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វាននុ៎ះជាប្រយោជន៍ ការពិចារណានូវវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វាននុ៎ះជាប្រយោជន៍ ការប្រុងស្តាប់នូវវិន័យ ក៏មានព្រះអរហត្តផល ឬព្រះនិព្វាននុ៎ះជាប្រយោជន៍។

[១៦៨] ចូរអ្នកពិចារណានូវវត្តដែលគួរប្រព្រឹត្តតាម ដែលអនុលោមតាមនូវសិក្ខាបទ ដែលព្រះលោកនាថ ជាអ្នកប្រាជ្ញ មានបញ្ញាវាងវៃ នាំមកដំកល់ទុក និងបញ្ញត្តទុកដោយប្រពៃ ធ្វើដំណើររបស់ខ្លួន ដែលប្រព្រឹត្តទៅក្នុងបរលោកកុំឲ្យវិនាសភិក្ខុណា មិនស្គាល់វត្ថុផង មិនស្គាល់វិបត្តិផង មិនស្គាល់អាបត្តិផង មិនស្គាល់និទានផង មិនឈ្លាសក្នុងអាការៈ គឺហេតុ និងមិនមែនហេតុផង មិនស្គាល់ពាក្យខាងដើម និងពាក្យខាងចុងផង មិនស្គាល់កម្មគួរធ្វើ និងមិនគួរធ្វើដោយស្មើផង មិនស្គាល់កម្មផង មិនស្គាល់អធិករណ៍ផង មិនឈ្លាសក្នុងសមថៈផង ជាអ្នកត្រេកអរស៊ប់ជាដើមផង ជាអ្នកប្រទូស្តផង ជាអ្នកល្ងង់ផង លំអៀងព្រោះខ្លាចផង ព្រោះភ្លេចស្មារតីផង មិនឈ្លាសក្នុងការប្រកាស ឲ្យអ្នកដទៃយល់ព្រមផង មិនឈ្លាសក្នុងការពិចារណា នូវហេតុ និងមិនមែនហេតុផង តែងជាអ្នកបានប័ក្ខពួក (ស្មើនឹងខ្លួន) ជាអ្នកមិនមានសេចក្តីខ្មាសប្រកបដោយកម្មខ្មៅ មិនអើពើ (ក្នុងធម៌ និងបុគ្គល) ភិក្ខុបែបនោះ លោកហៅថា បុគ្គលដែលបណ្ឌិតលែងរាប់អាន។ ភិក្ខុណាស្គាល់វត្ថុ ស្គាល់វិបត្តិ ស្គាល់អាបត្តិ ស្គាល់និទាន ឈ្លាសក្នុងអាការៈ ដឹងច្បាស់នូវពាក្យខាងដើម និងពាក្យខាងចុង ដឹងនូវកម្មដែលគួរធ្វើ និងមិនគួរធ្វើដោយស្មើ ដឹង

កម្មផង ដឹងអធិករណ៍ផង ឈ្លាសក្នុងសមថៈផង មានចិត្តមិនបានត្រេកអរ មិនបានប្រទូស្ត មិនបានវង្វេង មិនលំអៀងព្រោះខ្លាច មិនលំអៀងព្រោះវង្វេងស្មារតី ឈ្លាសក្នុងការពន្យល់ឲ្យអ្នកដទៃយល់ ឈ្លាសក្នុងការពិចារណាមើលហេតុ និងមិនមែនហេតុ តែងជាអ្នកបានប័ក្ខពួក (ស្មើនឹងខ្លួន) ជាអ្នកមានចិត្តខ្មាសបាប ប្រកបដោយកម្មស ប្រកបដោយសេចក្ដីគោរព ភិក្ខុបែបនោះឯង លោកហៅថា បុគ្គលដែលបណ្ឌិតគប្បីរាប់រក។

ចប់ ចូឡសង្គាម។

ឧទ្ទាន គឺបញ្ជីរឿង នៃចូឡសង្គាមនោះ ដូច្នេះ

[១៦៩]

និយាយអំពីភិក្ខុចូលទៅកាន់សង្គ្រាម ត្រូវបន្ទាបបន្ទន់ចិត្ត១ វិន័យធរ ដែលសង្ឃបានអនុញ្ញាតហើយ មិនត្រូវសួររកឧបជ្ឈាយ៍ជាដើម១ វិន័យធរ ត្រូវមានចិត្តធ្ងន់ក្នុងសង្ឃ មិនត្រូវមានចិត្តធ្ងន់ក្នុងបុគ្គល១ សុត្តៈ ប្រព្រឹត្តទៅដើម្បីប្រយោជន៍នឹងប្រៀបធៀបនូវអាបត្តិ និងអនាបត្តិជាដើម១ ឧទ្ទាន់ក្នុងចូឡសង្គ្រាមនេះ មានឧទ្ទេសតែមួយ លោកសំដែងទុកមក ដោយសេចក្ដីអនុគ្រោះដល់វិន័យ។

# មហាសង្គាម

CS vin.pv.12 | ភាគ ទី១៣

### (មហាសង្គាមោ)

## (វោហរន្តេន ជានិតព្ពាទិ ទី១)

CS vin.pv.12.01 | ភាគ ទី១៣

### (១. វោហរន្តេន ជានិតព្ពាទិ)

[១៧០] ភិក្ខុអ្នកចូលទៅកាន់សង្គ្រាម កាលបើនិយាយ ក្នុងជំនុំសង្ឃ ត្រូវស្គាល់វត្ថុ ស្គាល់វិបត្តិ ស្គាល់អាបត្តិ ស្គាល់និទាន ស្គាល់អាការ ស្គាល់ពាក្យខាងដើម និងពាក្យខាងចុង ស្គាល់កម្មដែលគួរធ្វើ និងមិនគួរធ្វើ ស្គាល់កម្ម ស្គាល់អធិករណ៍ ស្គាល់សមថៈ កុំលុះឆន្ទាគតិ កុំលុះទោសាគតិ កុំលុះមោហាគតិ កុំលុះភយាគតិ ត្រូវពន្យល់អ្នកដទៃឲ្យយល់ព្រម ក្នុងទីដែលគួរឲ្យយល់ ត្រូវពិចារណាហេតុ និងមិនមែនហេតុ ក្នុងទីដែលគួរពិចារណា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ត្រូវញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរឲ្យជ្រះថ្លា កុំគប្បីមើលងាយពួកជនដទៃដោយគិតថា អាត្មាអញបានបក្ខពួកហើយ កុំមើលងាយអ្នកចេះដឹងតិច ដោយគិតថា អាត្មាអញជាអ្នកចេះដឹងច្រើន កុំមើលងាយភិក្ខុខ្ចី ដោយគិតថា អាត្មាអញជាថេរៈចាស់ជាង កុំពោលនូវហេតុដែលមិនទាន់មកដល់ កុំញុំាងហេតុដែលមកដល់ហើយ ឲ្យវិនាសចាកធម៌ ចាកវិន័យ អធិករណ៍នោះរម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាណា គប្បីរម្ងាប់អធិករណ៍នោះ ដោយធម៌ជាដើមនោះៗចុះ។

[១៧១] ពាក្យថា ត្រូវស្គាល់វត្ថុ គឺត្រូវស្គាល់វត្ថុនៃបារាជិក៨ ស្គាល់វត្ថុនៃសង្ឃាទិសេស២៣ ស្គាល់វត្ថុនៃអនិយតៈ២ ស្គាល់វត្ថុនៃនិស្សគ្គិយៈ៤២ ស្គាល់វត្ថុនៃបាចិត្តិយៈ១៨៨ ស្គាល់វត្ថុនៃបាដិទេសនីយៈ១២ ស្គាល់វត្ថុនៃទុក្កដទាំងឡាយ ស្គាល់វត្ថុនៃទុព្ភាសិតទាំងឡាយ។

[១៧២] ពាក្យថា ត្រូវស្គាល់វិបត្តិ គឺត្រូវស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិ ស្គាល់អាជីវវិបត្តិ។

[១៧៣] ពាក្យថា ត្រូវស្គាល់អាបត្តិ គឺត្រូវស្គាល់អាបត្តិបារាជិក ស្គាល់អាបត្តិសង្ឃាទិសេស ស្គាល់អាបត្តិថុល្លច្ច័យ ស្គាល់អាបត្តិនិស្សគ្គិយៈ ស្គាល់អាបត្តិបាចិត្តិយៈ ស្គាល់អាបត្តិបាដិទេសនីយៈ ស្គាល់អាបត្តិទុក្កដ ស្គាល់អាបត្តិទុព្ភាសិត។

[១៧៤] ពាក្យថា ត្រូវស្គាល់និទាន គឺត្រូវស្គាល់និទានរបស់បារាជិកទាំង៨ ស្គាល់និទានរបស់សង្ឃាទិសេស២៣ ស្គាល់និទានរបស់អនិយតៈទាំង២ ស្គាល់និទានរបស់និស្សគ្គិយៈទាំង៤២ ស្គាល់និទានរបស់បាចិត្តិយៈ១៨៨ ស្គាល់និទានរបស់បាដិទេសនីយៈទាំង១២ ស្គាល់និទានរបស់ទុក្កដទាំងឡាយ ស្គាល់និទានរបស់ទុព្ភាសិតទាំងឡាយ។

[១៧៥] ពាក្យថា ត្រូវស្គាល់អាការ គឺត្រូវស្គាល់សង្ឃដោយអាការ ស្គាល់គណៈដោយអាការ ស្គាល់បុគ្គលដោយអាការ ស្គាល់អ្នកចោទដោយអាការ ស្គាល់អ្នកជាប់ចោទដោយអាការ។ ពាក្យថា ត្រូវស្គាល់សង្ឃដោយអាការ គឺត្រូវស្គាល់សង្ឃដោយអាការយ៉ាងនេះថា សង្ឃនេះអាចនឹងរម្ងាប់អធិករណ៍នេះតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ឬមិនអាចរម្ងាប់បានទេ។ ពាក្យថា ត្រូវស្គាល់គណៈ ដោយអាការ គឺស្គាល់គណៈ ដោយអាការយ៉ាងនេះថា គណៈនេះ អាចនឹងរម្ងាប់អធិករណ៍នេះតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ឬមិនអាចរម្ងាប់បាន។ ពាក្យថា ត្រូវស្គាល់បុគ្គលដោយអាការ គឺស្គាល់បុគ្គលដោយអាការយ៉ាងនេះថា បុគ្គលនេះអាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ឬមិនអាចរម្ងាប់បានទេ។ ពាក្យថា ត្រូវស្គាល់អ្នកចោទ ដោយអាការ គឺស្គាល់អ្នកចោទដោយអាការយ៉ាងនេះថា លោកដ៏មានអាយុនេះ តំកល់នៅក្នុងធម៌ទាំង៥ ទើបចោទបុគ្គលដទៃ ឬមិនបានតំកល់ទេ។ ពាក្យថា ស្គាល់អ្នក

ជាប់ចោទ ដោយអាការ គឺស្គាល់អ្នកជាប់ចោទ ដោយអាការយ៉ាងនេះថា លោកដ៏មានអាយុនេះ តំកល់នៅក្នុងធម៌ទាំងពីរគឺ សច្ចវាចា១ អកុប្បធម៌១ ឬមិនបានតំកល់ទេ។

[១៧៦] ពាក្យថា ត្រូវស្គាល់ពាក្យខាងដើម និងពាក្យខាងចុង គឺត្រូវស្គាល់ពាក្យខាងដើម និងពាក្យខាងចុងយ៉ាងនេះថា លោកដ៏មានអាយុនេះ កន្លងនូវវត្ថុដោយវត្ថុផង កន្លងនូវវិបត្តិដោយវិបត្តិផង កន្លងនូវអាបត្តិ ដោយអាបត្តិផង គេចកែហើយប្តេជ្ញាផង ប្តេជ្ញាហើយ គេចកែផង បំពាននូវពាក្យដទៃ ដោយពាក្យដទៃផង ឬមិនបានកន្លងគេចកែបំពានទេ។

[១៧៧] ពាក្យថា ត្រូវស្គាល់កម្មដែលគួរធ្វើ និងមិនគួរធ្វើ គឺត្រូវស្គាល់មេថុនធម្ម ស្គាល់អនុលោមរបស់មេថុនធម្ម ស្គាល់បុព្វភាគ (ចំណែកខាងដើម) របស់មេថុនធម្ម។ ពាក្យថា ត្រូវស្គាល់មេថុនធម្ម គឺត្រូវស្គាល់ការជួបប្រសព្វរបស់ជនពីរៗនាក់។ ពាក្យថា ត្រូវស្គាល់អនុលោមរបស់មេថុនធម្ម គឺបានដល់ភិក្ខុបៀមអង្គជាតរបស់អ្នកដទៃ ដោយមាត់របស់ខ្លួន។ ពាក្យថា ត្រូវស្គាល់បុព្វភាគរបស់មេថុនធម្ម គឺស្គាល់ទឹកសុក្កៈមានពណ៌ និងមិនមានពណ៌ ការចាប់ពាល់កាយស្ត្រី និយាយពាក្យអាក្រក់ ចំពោះទ្វារមគ្គស្រី និយាយល្បួងស្រី ឲ្យបម្រើខ្លួនដោយកាម និយាយដឹកនាំបុរស និងស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ (សិក្ខាបទទាំង៥នេះ ជាបុព្វភាគរបស់មេថុនធម្ម)។

[១៧៨] ពាក្យថា ត្រូវស្គាល់កម្ម គឺត្រូវស្គាល់កម្ម១៦យ៉ាង គឺស្គាល់អបលោកនកម្ម៤ ស្គាល់ញត្តិកម្ម៤ ស្គាល់ញត្តិទុតិយកម្ម៤ ស្គាល់ញត្តិចតុត្ថកម្ម៤។

[១៧៩] ពាក្យថា ត្រូវស្គាល់អធិករណ៍ គឺត្រូវស្គាល់អធិករណ៍ទាំង៤យ៉ាង គឺស្គាល់វិវាទាធិករណ៍១ ស្គាល់អនុវាទាធិករណ៍១ ស្គាល់អាបត្តាធិករណ៍១ ស្គាល់កិច្ចាធិករណ៍១។

[១៨០] ពាក្យថា ត្រូវស្គាល់សមថៈ គឺត្រូវស្គាល់សមថៈ៧យ៉ាង គឺស្គាល់សម្មុខាវិន័យ១ ស្គាល់សតិវិន័យ១ ស្គាល់អមូឡ្ហវិន័យ១ ស្គាល់បដិញ្ញាតករណៈ១ ស្គាល់យេភុយ្យសិកា១ ស្គាល់តស្សបាបិយសិកា១ ស្គាល់តិណវត្ថារកៈ១។

## (អគតិអគន្តព្ព ទី២)

CS vin.pv.12.02 | ភាគ ទី១៣

### (២. អគតិអគន្តព្ពោ)

[១៨១] ពាក្យថា កុំលុះឆន្ទាគតិ សេចក្តីថាភិក្ខុដែលលុះឆន្ទាគតិ តើលុះឆន្ទាគតិដូចម្តេច។ ភិក្ខុជាវិន័យធរពួកខ្លះ ក្នុងសាសនានេះ យោគយល់ថា បុគ្គលនេះជាឧបជ្ឈាយ៍ ឬអាចារ្យ ជាសទ្ធិវិហារិក ឬអន្តេវាសិក ជាភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នា ឬភិក្ខុដែលមានអាចារ្យស្មើគ្នា ជាមិត្តធ្លាប់ឃើញគ្នាម្តងៗ ឬជាមិត្តធ្លាប់ស្និទ្ធស្នាលគ្នាមាំ ពុំនោះជាញាតិសាលោហិតរបស់អាត្មាអញ ដូច្នេះហើយក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនជាធម៌ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ សំដែងនូវវិន័យ ថាមិនមែនជាវិន័យ សំដែងនូវពាក្យដែលព្រះតថាគតមិនបានសំដែង មិនបានពោល ថាជាពាក្យដែលព្រះតថាគតបានសំដែង បានពោល សំដែងនូវពាក្យដែលព្រះតថាគត បានសំដែង បានពោល ថាជាពាក្យដែលព្រះតថាគត មិនបានសំដែង មិនបានពោល សំដែងនូវកិច្ចវត្តដែលព្រះតថាគតមិនបានសន្សំមក ថាព្រះតថាគតធ្លាប់សន្សំមក សំដែងនូវកិច្ចវត្ត ដែលព្រះតថាគតធ្លាប់សន្សំមក ថាព្រះតថាគតមិនបានសន្សំមក សំដែងនូវសិក្ខាបទ ដែលព្រះតថាគតមិនបានបញ្ញត្ត ថាព្រះតថាគតបានបញ្ញត្ត សំដែងនូវសិក្ខាបទ ដែលព្រះតថាគតបានបញ្ញត្ត ថាព្រះតថាគតមិនបានបញ្ញត្ត សំដែងនូវអនាបត្តិ ថាជាអាបត្តិ សំដែងនូវអាបត្តិ ថាជាអនាបត្តិ សំដែងនូវលហុកាបត្តិ ថាជាគរុកាបត្តិ សំដែងនូវគរុកាបត្តិ ថាជាលហុកាបត្តិ សំដែងនូវសាវសេសាបត្តិ ថាជាអនវសេសាបត្តិ សំដែងនូវអនវសេសាបត្តិ ថាជាសាវសេសាបត្តិ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ដូច្នេះ ព្រោះអនុគ្រោះដល់បុគ្គលនោះៗ ព្រោះកិរិយារក្សាដល់បុគ្គលនោះៗ ភិក្ខុជាវិន័យធរ កាលដែលលុះឆន្ទាគតិ ដោយវត្ថុទាំងឡាយ១៨ប្រការនេះ ក៏ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនជាសុខ ដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសេចក្តីចំរើន ដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរ កាលបើលុះឆន្ទាគតិ ដោយវត្ថុទាំង១៨ប្រការនេះ ក៏ឈ្មោះថា រក្សាខ្លួន ដែលមានកុសលធម៌ ជីកគាស់រំលើងចោលចេញផង ឈ្មោះថា ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយ ឈ្មោះថារងនូវអកុសលកម្មដ៏ច្រើនផង ភិក្ខុជាវិន័យធរ កាលបើលុះទៅខាងឆន្ទាគតិ ក៏រមែងលុះទៅខាងឆន្ទាគតិ ដោយអាការយ៉ាងនេះ។

[១៨២] ពាក្យថា កុំលុះទោសាគតិ សេចក្តីថា កាលដែលភិក្ខុជាវិន័យធរ លុះទោសាគតិ តើលុះទោសាគតិដូចម្តេច។ ភិក្ខុជាវិន័យធរពួកខ្លះ ក្នុងសាសនានេះ ចងគំនុំថា (បុគ្គលនេះ) បានប្រព្រឹត្តធ្វើនូវសេចក្តីវិនាសដល់អាត្មាអញ ចងគំនុំថា (បុគ្គលនេះ) កំពុងតែប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ ចងគំនុំថា (បុគ្គលនេះ) មុខជានឹងប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ ដល់អាត្មាអញ ចងគំនុំថា (បុគ្គលនេះ) បានប្រព្រឹត្តធ្វើនូវកម្ម មិនជាប្រយោជន៍ កំពុងប្រព្រឹត្តធ្វើនូវកម្ម មិនជាប្រយោជន៍ មុខជានឹងប្រព្រឹត្តធ្វើនូវកម្ម មិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ចងគំនុំថា (បុគ្គលនេះ) បានប្រព្រឹត្តធ្វើនូវកម្ម ជាប្រយោជន៍ កំពុងប្រព្រឹត្តធ្វើនូវកម្មជាប្រយោជន៍ មុខជានឹងប្រព្រឹត្តធ្វើនូវកម្មជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ភិក្ខុជាវិន័យធរ កាលបើចងគំនុំខឹង មានសេចក្តីក្រេវក្រោធគ្របសង្កត់ ដោយអាឃាតវត្ថុទាំង៩ប្រការនេះហើយ រមែងសម្តែងនូវសភាវៈ មិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌។បេ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុជាវិន័យធរ កាលបើលុះទោសាគតិ ដោយវត្ថុទាំង១៨ប្រការនេះ ក៏ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសុខ ដល់ជនច្រើនគ្នា ដើម្បីសេចក្តីមិនចំរើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរ កាលបើលុះទៅខាងទោសាគតិ ដោយវត្ថុទាំង១៨ប្រការនេះ ក៏ឈ្មោះថា រក្សាខ្លួន ដែលខ្លួនមានកុសលធម៌ ជីកគាស់រំលើងចោលហើយផង ឈ្មោះថាជាអ្នកប្រកបដោយ

ទោសផង ប្រកបដោយសេចក្ដីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថារងនូវអកុសលកម្មច្រើនផង ភិក្ខុជាវិន័យធរ កាលបើលុះទៅខាងទោសាគតិ ក៏រមែងលុះទៅខាងទោសាគតិ ដោយអាការយ៉ាងនេះ។

[១៨៣] ពាក្យថា កុំគប្បីលំអៀងដោយមោហាគតិ សេចក្ដីថា ភិក្ខុជាវិន័យធរ កាលដែលលំអៀងដោយមោហាគតិ តើលំអៀងដោយមោហាគតិដូចម្ដេច។ ភិក្ខុជាវិន័យធរ មានចិត្តត្រេកអរ លុះដោយអំណាចរាគៈ មានចិត្តប្រទូស្ត លុះដោយអំណាចទោសៈ មានសេចក្ដីវង្វេង លុះដោយអំណាចមោហៈ មានទិដ្ឋិជាគ្រឿងស្ទាបអង្អែល លុះដោយអំណាចទិដ្ឋិ វង្វេងភាន់ភាំងស្មារតី ត្រូវមោហៈគ្របសង្កត់ ក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌។បេ។ សំដែងទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ កាលបើភិក្ខុជាវិន័យធរ លំអៀងដោយមោហាគតិ ដោយវត្ថុ១៨ប្រការនេះ ក៏ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសុខ ដល់ជនច្រើនគ្នា ដើម្បីសេចក្ដីមិនចំរើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរ កាលបើលំអៀង ដោយមោហាគតិ ដោយវត្ថុទាំង១៨ប្រការនេះ ក៏ឈ្មោះថា រក្សាខ្លួន ដែលខ្លួនមានកុសលធម៌ ជីកគាស់រំលើងចោលហើយផង ឈ្មោះថាជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្ដីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថា រងនូវអកុសលកម្មដ៏ច្រើនផង ភិក្ខុជាវិន័យធរ កាលលំអៀងដោយមោហា រមែងលំអៀងដោយមោហាគតិ ដោយអាការយ៉ាងនេះ។

[១៨៤] ពាក្យថា កុំលំអៀងដោយភយាគតិ សេចក្ដីថា ភិក្ខុដែលលំអៀងដោយភយាគតិ តើលំអៀងដោយភយាគតិដូចម្ដេច។ ភិក្ខុជាវិន័យធរពួកខ្លះ ក្នុងសាសនានេះគិតថា បុគ្គលនេះ អាស្រ័យនូវកម្ម មានកាយកម្មជាដើម មិនស្មើក្ដី អាស្រ័យនូវព្រៃស្បាត គឺមិច្ឆាទិដ្ឋិ និងអន្តគ្គាហិកទិដ្ឋិក្ដី អាស្រ័យនូវភិក្ខុមានកំឡាំងក្ដី ជាអ្នករឹងរូសអាក្រក់ និងធ្វើនូវសេចក្ដីអន្តរាយដល់ជីវិតក្ដី នូវសេចក្ដីអន្តរាយ ដល់ព្រហ្មចរិយៈក្ដី ហើយតក់ស្លុតព្រោះខ្លាចបុគ្គលនោះ ក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌។បេ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ កាលបើភិក្ខុជាវិន័យធរ លំអៀងដោយភយាគតិ ដោយវត្ថុទាំង១៨ប្រការនេះ ក៏ឈ្មោះថា ប្រតិបត្តិ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនជាសុខ ដល់ជនច្រើនគ្នា ដើម្បីសេចក្ដីមិនចំរើន ដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរ កាលបើលំអៀងដោយភយាគតិ ដោយវត្ថុទាំង១៨ប្រការនេះ ក៏ឈ្មោះថា រក្សានូវខ្លួន ដែលមានកុសលធម៌ ជីកគាស់រំលើងចោលហើយផង ឈ្មោះថាជាបុគ្គលប្រកបដោយទោសផង ប្រកបដោយសេចក្ដីតិះដៀល របស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថា រងនូវអកុសលកម្មច្រើនផង ភិក្ខុជាវិន័យធរ កាលដែលលំអៀងដោយភយាគតិ រមែងលំអៀងដោយភយាគតិ ដោយអាការយ៉ាងនេះ។

[១៨៥] បុគ្គលណាប្រព្រឹត្តកន្លងនូវធម៌ ព្រោះសេចក្ដីស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ព្រោះវង្វេង យសសក្ដិរបស់បុគ្គលនោះឯង រមែងសាបសូន្យទៅ ដូចព្រះចន្ទក្នុងកាឡប័ក្ខ គឺខាងរនោច។

## (អគតិអគមនៈ ទី៣)

CS vin.pv.12.03 | ភាគ ទី១៣

### (៣. អគតិអគមនំ)

[១៨៦] ភិក្ខុជាវិន័យធរ មិនលំអៀងដោយឆន្ទាគតិ តើដូចម្ដេច។ ភិក្ខុជាវិន័យធរ កាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវសភាវៈមិនមែនវិន័យ ថាមិនមែនវិន័យ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវវិន័យ ថាជាវិន័យ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវពាក្យ ដែលព្រះតថាគតមិនបានសំដែង មិនបានពោល ថាជាពាក្យ ដែលព្រះតថាគតមិនបានសំដែង មិនបានពោល ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវពាក្យ ដែលព្រះតថាគត បានសំដែង បានពោល ថាជាពាក្យ ដែលព្រះតថាគត បានសំដែង បានពោល ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវកិច្ចវត្ត ដែលព្រះតថាគតមិនបានសន្សំមក ថាជាកិច្ចវត្ត ដែលព្រះតថាគតមិនបានសន្សំមក ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវកិច្ចវត្ត ដែលព្រះតថាគតបានសន្សំមក ថាជាកិច្ចវត្ត ដែលព្រះតថាគតបានសន្សំមក ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវសិក្ខាបទ ដែលព្រះតថាគត មិនបានបញ្ញត្ត ថាព្រះតថាគតមិនបានបញ្ញត្ត ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវសិក្ខាបទ ដែលព្រះតថាគត ទ្រង់បញ្ញត្ត ថាព្រះតថាគត ទ្រង់បញ្ញត្ត ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវអនាបត្តិ ថាជាអនាបត្តិ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវអាបត្តិ ថាជាអាបត្តិ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវលហុកាបត្តិ ថាជាលហុកាបត្តិ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវគរុកាបត្តិ ថាជាគរុកាបត្តិ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវសាវសេសាបត្តិ ថាជាសាវសេសាបត្តិ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវអនវសេសាបត្តិ ថាជាអនវសេសាបត្តិ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា មិនលំអៀងដោយឆន្ទាគតិ ភិក្ខុមិនលំអៀងដោយឆន្ទាគិត ដោយអាការយ៉ាងនេះ។

[១៨៧] ភិក្ខុជាវិន័យធរ មិនលំអៀងដោយទោសាគតិ តើដូចម្ដេច។ ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថា មិនលំអៀងដោយទោសាគតិ កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថា មិនលំអៀងដោយទោសាគតិ។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថា មិនលំអៀងដោយទោសាគតិ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា មិនលំអៀងដោយទោសាគតិ ភិក្ខុមិនលំអៀងដោយទោសាគតិ ដោយអាការយ៉ាងនេះ។

[១៨៨] ភិក្ខុជាវិន័យធរ មិនលំអៀងដោយមោហាគតិ តើដូចម្ដេច។ ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថា មិនលំអៀងដោយមោហាគតិ សំដែងនូវធម៌ ថាជាធម៌ ឈ្មោះថា មិនលំអៀងដោយមោហាគតិ។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ

ឈ្មោះថា មិនលំអៀងដោយមោហាគតិ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា មិនលំអៀងដោយមោហាគតិ ភិក្ខុមិនលំអៀងដោយមោហាគតិ ដោយអាការយ៉ាងនេះ។

[១៨៩] ភិក្ខុជាវិន័យធរ មិនលំអៀងដោយភយាគតិ តើដូចម្ដេច។ ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថា មិនលំអៀងដោយភយាគតិ កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថា មិនលំអៀងដោយភយាគតិ។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថា លំអៀងដោយភយាគតិ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា មិនលំអៀងដោយភយាគតិ ភិក្ខុមិនលំអៀងដោយភយាគតិ ដោយអាការយ៉ាងនេះ។

[១៩០] បុគ្គលណា មិនប្រព្រឹត្តកន្លងនូវធម៌ ព្រោះសេចក្ដីស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាច ព្រោះវង្វេង យសសក្ដិរបស់បុគ្គលនោះឯង រមែងពេញបរិបូណ៌ ដូចព្រះចន្ទក្នុងសុក្កប័ក្ខ គឺចំណែកខាងខ្នើត។

## (សញ្ញាបនីយាទិ ទី៤)

CS vin.pv.12.04 | ភាគ ទី១៣

### (៤. សញ្ញាបនីយាទិ)

[១៩១] សួរថា ភិក្ខុជាវិន័យធរ ពន្យល់ក្នុងទីដែលគួរពន្យល់នោះ តើដូចម្ដេច។ ឆ្លើយថា ភិក្ខុជាវិន័យធរ កាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថា ពន្យល់ក្នុងទីដែលគួរពន្យល់ កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថា ពន្យល់ក្នុងទីដែលគួរពន្យល់។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថា ពន្យល់ក្នុងទីដែលគួរពន្យល់ កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា ពន្យល់ក្នុងទីដែលគួរពន្យល់ ភិក្ខុជាវិន័យធរ ពន្យល់ក្នុងទីដែលគួរពន្យល់ ដោយអាការយ៉ាងនេះ។

[១៩២] សួរថា ភិក្ខុជាវិន័យធរ ពិចារណាក្នុងទីដែលគួរពិចារណា តើដូចម្ដេច។ ឆ្លើយថា ភិក្ខុជាវិន័យធរ កាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថា ពិចារណាក្នុងទីដែលគួរពិចារណា កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថា ពិចារណាក្នុងទីដែលគួរពិចារណា។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថា ពិចារណាក្នុងទីដែលគួរពិចារណា កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា ពិចារណាក្នុងទីដែលគួរពិចារណា ភិក្ខុពិចារណាក្នុងទីដែលគួរពិចារណា ដោយអាការយ៉ាងនេះ។

[១៩៣] សួរថា ភិក្ខុសំឡឹងមើលក្នុងទីគួរសំឡឹង តើដូចម្ដេច។ ឆ្លើយថា ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថា សំឡឹងមើល ក្នុងទីដែលគួរសំឡឹងមើល។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ភិក្ខុសំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ដោយអាការយ៉ាងនេះ។

[១៩៤] សួរថា ភិក្ខុញុំាងបុគ្គលដទៃ ឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា តើដូចម្ដេច។ ឆ្លើយថា ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌ ឈ្មោះថា ញុំាងបុគ្គលដទៃ ឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា កាលសំដែងនូវធម៌ ថាជាធម៌ ឈ្មោះថា ញុំាងបុគ្គលដទៃ ឲ្យជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា។បេ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ឈ្មោះថា ញុំាងបុគ្គលដទៃ ឲ្យជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា កាលសំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា ញុំាងបុគ្គលដទៃ ឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា ភិក្ខុញុំាងបុគ្គលដទៃ ឲ្យជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ដោយអាការយ៉ាងនេះ។

## (បរបក្ខាទិអវជាននៈ ទី៥)

CS vin.pv.12.05 | ភាគ ទី១៣

### (៥. បរបក្ខាទិអវជាននំ)

[១៩៥] សួរថា ភិក្ខុមើលងាយនូវពួកភិក្ខុដទៃ ដោយគិតថា អាត្មាអញ បានបក្ខពួកហើយ តើដូចម្ដេច។ ឆ្លើយថា ភិក្ខុពួកមួយ ក្នុងសាសនានេះ ជាអ្នកបានបក្ខពួក បានបរិវារ មានបក្ខពួក មានញាតិ ហើយមើលងាយបុគ្គលនោះថា បុគ្គលនេះ មិនបានបក្ខពួក មិនបានបរិវារ គ្មានបក្ខពួក គ្មានញាតិទេ ក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌។បេ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុមើលងាយនូវបក្ខពួកដទៃ ដោយគិតថា អាត្មាអញ បានបក្ខពួក ដោយអាការយ៉ាងនេះ។

[១៩៦] សួរថា ភិក្ខុមើលងាយនូវបុគ្គលដែលចេះដឹងតិច ដោយគិតថា អាត្មាអញ ជាអ្នកចេះដឹងច្រើន តើដូចម្ដេច។ ឆ្លើយថា ភិក្ខុពួកមួយ ក្នុងសាសនានេះ ជាអ្នកចេះដឹងច្រើន ចាំនូវសុត្តៈ សន្សំនូវសុត្តៈ រមែងមើលងាយបុគ្គលអ្នកចេះដឹងតិចនោះថា បុគ្គលនេះ ស្ដាប់តិច ជាអ្នកចេះដឹងនិកាយតិច ចាំតិច ក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌។បេ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុមើលងាយនូវបុគ្គលដែលចេះដឹងតិច ដោយគិតថា អាត្មាអញ ជាអ្នកចេះដឹងច្រើន ដោយអាការយ៉ាងនេះ។

[១៩៧] សួរថា ភិក្ខុមើលងាយភិក្ខុដែលខ្ចីជាង ដោយគិតថា អាត្មាអញ ជាថេរៈចាស់ជាង តើដូចម្ដេច។ ឆ្លើយថា ភិក្ខុពួកមួយ ក្នុងសាសនានេះ ជាថេរៈ ជាអ្នកដឹងរាត្រី (វែង) បួសមកជាយូរហើយ រមែងមើលងាយភិក្ខុខ្ចីនោះថា ភិក្ខុនេះនៅខ្ចី មិនសូវល្បីល្បាញ ជាអ្នកចេះដឹងតិច មិនចេះច្បាប់ទម្លាប់ អាត្មាអញ នឹងមិនធ្វើតាមពាក្យរបស់ភិក្ខុនេះទេ ដូច្នេះ ក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ ថាមិនមែនធម៌។បេ។

សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុមើលងាយភិក្ខុខ្ចីជាង ដោយគិតថា អាត្មាអញ ជាថេរៈចាស់ជាង ដោយអាការយ៉ាងនេះ។

[១៩៨] ពាក្យថា កុំពោលនូវហេតុដែលមិនទាន់មកដល់ គឺកុំនិយាយនូវពាក្យដែលមិនទាន់ធ្លាក់ដល់មក។ ពាក្យថា កុំគប្បីញុំាងហេតុ ដែលដល់មកហើយ ឲ្យសាបសូន្យចាកធម៌ ចាកវិន័យ គឺបានដល់សង្ឃ ដែលប្រជុំគ្នាដើម្បីសេចក្ដីណា កុំគប្បីញុំាងសេចក្ដីនោះ ឲ្យសាបសូន្យចាកធម៌ ចាកវិន័យឡើយ។

[១៩៩] ពាក្យថា ដោយធម៌ណា គឺដោយវត្ថុដែលពិតប្រាកដ។ ពាក្យថា ដោយវិន័យណា គឺដាស់តឿនក្រើនរំលឹក។ ពាក្យថា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាណា គឺដោយញត្តិសម្បទា និងអនុស្សាវនសម្បទា។

## (អនុវិជ្ជកស្ស អនុយោគៈ ទី៦)

CS vin.pv.12.06 | ភាគ ទី១៣

## (៦. អនុវិជ្ជកស្ស អនុយោគំ)

ពាក្យថា អធិករណ៍រម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាណា គប្បីរម្ងាប់អធិករណ៍នោះ ដោយធម៌នោះៗ សេចក្ដីថា វិន័យធរគប្បីសួរអ្នកចោទថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនោះ ដោយហេតុណា លោកឃាត់បវារណានោះដោយហេតុអ្វី លោកឃាត់ដោយសីលវិបត្តិ ឬឃាត់ដោយអាចារវិបត្តិ ឬក៏ឃាត់ដោយទិដ្ឋិវិបត្តិ។ បើអ្នកចោទនោះ និយាយយ៉ាងនេះថា ខ្ញុំឃាត់ដោយសីលវិបត្តិផង ឃាត់ដោយអាចារវិបត្តិផង ឃាត់ដោយទិដ្ឋិវិបត្តិផង។ វិន័យធរ ត្រូវនិយាយនឹងភិក្ខុអ្នកចោទនោះយ៉ាងនេះថា ចុះលោកដ៏មានអាយុស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរឬ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរ។ វិន័យធរ ត្រូវសួរភិក្ខុអ្នកចោទនោះ យ៉ាងនេះថា ម្នាលអាវុសោ ចុះសីលវិបត្តិដូចម្ដេច អាចារវិបត្តិដូចម្ដេច ទិដ្ឋិវិបត្តិដូចម្ដេច។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា បារាជិក៤ សង្ឃាទិសេស១៣នេះ ហៅថាសីលវិបត្តិ ថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ ទុព្ភាសិត នេះហៅថា អាចារវិបត្តិ មិច្ឆាទិដ្ឋិ និងអន្តគ្គាហិកាទិដ្ឋិ នេះហៅថា ទិដ្ឋិវិបត្តិ។ វិន័យធរ ត្រូវសួរភិក្ខុអ្នកចោទយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះ ដោយហេតុណា លោកឃាត់ដោយបានឃើញ ឬឃាត់ដោយបានឮ ឬក៏ឃាត់ដោយបានរង្កៀស។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ខ្ញុំឃាត់ដោយបានឃើញផង ឃាត់ដោយបានឮផង ឃាត់ដោយបានរង្កៀសផង។ វិន័យធរ ត្រូវសួរភិក្ខុអ្នកចោទយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះ ដោយបានឃើញ ដោយហេតុណា លោកបានឃើញដូចម្ដេចខ្លះ លោកបានឃើញអំពីហេតុដូចម្ដេច លោកបានឃើញពីកាលណា លោកបានឃើញក្នុងទីណា កាលភិក្ខុនេះត្រូវអាបត្តិបារាជិក លោកបានឃើញដែរឬ កាលត្រូវសង្ឃាទិសេស លោកបានឃើញដែរឬ កាលត្រូវថុល្លច្ច័យ លោកបានឃើញដែរឬ កាលត្រូវបាចិត្តិយៈ លោកបានឃើញដែរឬ កាលត្រូវបាដិទេសនីយៈ លោកបានឃើញដែរឬ កាលត្រូវទុក្កដ លោកបានឃើញដែរឬ កាលត្រូវទុព្ភាសិត លោកបានឃើញដែរឬ ចុះលោកនៅក្នុងទីណា ចំណែកភិក្ខុនេះ នៅត្រង់ទីណា លោកកំពុងធ្វើអ្វី ភិក្ខុនេះកំពុងធ្វើអ្វី។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានឃាត់បវារណារបស់ភិក្ខុនេះ ដោយបានឃើញទេ ខ្ញុំឃាត់បវារណាដោយគ្រាន់តែបានឮទេ។ វិន័យធរ ត្រូវសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកឃាត់បវារណារបស់ភិក្ខុនេះ ដោយបានឮ ដោយហេតុណា លោកបានឮដូចម្ដេចខ្លះ លោកបានឮដោយហេតុដូចម្ដេច លោកបានឮពីកាលណា លោកបានឮក្នុងទីណា លោកបានឮថា ភិក្ខុនេះត្រូវបារាជិក ឬលោកបានឮថា ភិក្ខុនេះ ត្រូវសង្ឃាទិសេស លោកបានឮថា ភិក្ខុនេះត្រូវថុល្លច្ច័យ លោកបានឮថា ភិក្ខុនេះត្រូវបាចិត្តិយៈ លោកបានឮថា ភិក្ខុនេះត្រូវបាដិទេសនីយៈ លោកបានឮថា ភិក្ខុនេះត្រូវទុក្កដ លោកបានឮថា ភិក្ខុនេះត្រូវទុព្ភាសិត លោកបានឮពាក្យភិក្ខុ លោកបានឮពាក្យភិក្ខុនី លោកបានឮពាក្យសិក្ខមានា លោកបានឮពាក្យសាមណេរ លោកបានឮពាក្យសាមណេរី លោកបានឮពាក្យឧបាសក លោកបានឮពាក្យឧបាសិកា លោកបានឮព្រះបន្ទូលនៃពួកស្ដេច លោកបានឮពាក្យនៃពួករាជមហាមាត្រ លោកបានឮពាក្យនៃពួកតិរ្ថិយ ឬបានឮពាក្យនៃពួកសាវ័ករបស់តិរ្ថិយ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានឃាត់បវារណារបស់ភិក្ខុនេះ ដោយបានឮទេ ខ្ញុំឃាត់បវារណា ដោយគ្រាន់តែរង្កៀសទេ។ វិន័យធរ ត្រូវសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះ ដោយរង្កៀស ដោយហេតុណា លោករង្កៀសដោយហេតុដូចម្ដេចខ្លះ លោករង្កៀសអំពីហេតុដូចម្ដេច លោករង្កៀសពីកាលណា លោករង្កៀសក្នុងទីណា លោករង្កៀសថា ភិក្ខុនេះត្រូវបារាជិក ឬលោករង្កៀសថា ភិក្ខុនេះ ត្រូវសង្ឃាទិសេស លោករង្កៀសថា ភិក្ខុនេះត្រូវថុល្លច្ច័យ លោករង្កៀសថា ភិក្ខុនេះត្រូវបាចិត្តិយៈ លោករង្កៀសថា ភិក្ខុនេះត្រូវបាដិទេសនីយៈ លោករង្កៀសថា ភិក្ខុនេះត្រូវទុក្កដ លោករង្កៀសថា ភិក្ខុនេះត្រូវទុព្ភាសិត លោករង្កៀស ព្រោះឮពាក្យភិក្ខុ លោករង្កៀស ព្រោះឮពាក្យភិក្ខុនី លោករង្កៀស ព្រោះឮពាក្យសិក្ខមានា លោករង្កៀស ព្រោះឮពាក្យសាមណេរ លោករង្កៀស ព្រោះឮពាក្យសាមណេរី លោករង្កៀស ព្រោះឮពាក្យឧបាសក លោករង្កៀស ព្រោះឮពាក្យឧបាសិកា លោករង្កៀស ព្រោះឮព្រះបន្ទូលនៃពួកស្ដេច លោករង្កៀស ព្រោះឮពាក្យ នៃពួកមហាមាត្ររបស់ស្ដេច លោករង្កៀស ព្រោះឮពាក្យនៃពួកតិរ្ថិយ ឬលោករង្កៀស ព្រោះឮពាក្យពួកសាវ័កនៃតិរ្ថិយ។

[២០០] ហេតុដែលអ្នកចោទបានឃើញ សមដោយហេតុដែលបានឃើញមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានឃើញ ដោយហេតុដែលបានឃើញ (នោះ) ភិក្ខុអ្នកជាប់ចោទមិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យនូវហេតុ ដែលអ្នកចោទបានឃើញនៅឡើយទេ ឈ្មោះថា អ្នកចោទមានសេចក្ដីរង្កៀសមិនបរិសុទ្ធ (រង្កៀសគ្មានមូល) វិន័យធរ គប្បីវិនិច្ឆ័យតាមពាក្យប្ដេជ្ញារបស់បុគ្គល គឺភិក្ខុជាអ្នកជាប់ចោទនោះ ហើយធ្វើបវារណាជាមួយនឹងភិក្ខុនោះចុះ។ ហេតុដែលអ្នកចោទបានឮ សមដោយហេតុដែលបានឮមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានឮ ដោយហេតុដែលបានឮ (នោះ) ភិក្ខុអ្នកជាប់ចោទនោះ មិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យនូវហេតុ ដែលអ្នកចោទបានឮនៅឡើយទេ ឈ្មោះថា អ្នកចោទមានសេចក្ដីរង្កៀសមិនបរិសុទ្ធ វិន័យធរ គប្បីវិនិច្ឆ័យតាមពាក្យប្ដេជ្ញារបស់បុគ្គល គឺភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើបវារណាជាមួយនឹងភិក្ខុនោះចុះ។ ហេតុដែលអ្នកចោទបានប៉ះពាល់ សមដោយហេតុដែលបានប៉ះពាល់មែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានប៉ះពាល់ ដោយហេតុដែលបានប៉ះពាល់ (នោះ) ភិក្ខុអ្នកជាប់ចោទនោះ មិនទាន់ដល់ (បារាជិក) ព្រោះ

អាស្រ័យនូវហេតុ ដែលអ្នកចោទបានប៉ះពាល់នៅឡើយទេ ឈ្មោះថា អ្នកចោទ មានសេចក្តីរង្កៀសមិនបរិសុទ្ធ វិន័យធរ គប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញារបស់បុគ្គល គឺភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើបវារណា ជាមួយនឹងភិក្ខុនោះចុះ។

### (បុច្ឆាវិភាគៈ ទី៧)

CS vin.pv.12.07 | ភាគ ទី១៣

#### (៧. បុច្ឆាវិភាគោ)

[២០១] ត្រង់ពាក្យថា អ្នកបានឃើញដូចម្តេច គឺបានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញអំពីហេតុដូចម្តេច គឺបានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញពីកាលណា គឺបានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញក្នុងទីណា គឺបានដល់ពាក្យសួរថាដូចម្តេច។

[២០២] ត្រង់ពាក្យដែលថា បានឃើញដូចម្តេច គឺបានដល់វត្ថុបុច្ឆា១ វិបត្តិបុច្ឆា១ អាបត្តិបុច្ឆា១ អជ្ឈាចារបុច្ឆា១។ ត្រង់ពាក្យថា វត្ថុបុច្ឆា គឺបានដល់ពាក្យសួរ អំពីវត្ថុនៃបារាជិក៨ សួរវត្ថុនៃសង្ឃាទិសេស២៣ សួរវត្ថុនៃអនិយតៈ២ សួរវត្ថុនៃនិស្សគ្គិយៈ៤២ សួរវត្ថុនៃបាចិត្តិយៈ១៨៨ សួរវត្ថុនៃបាដិទេសនីយៈ១២ សួរវត្ថុនៃទុក្កដទាំងឡាយ សួរវត្ថុនៃទុព្ភាសិតទាំងឡាយ។ ត្រង់ពាក្យថា វិបត្តិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីសីលវិបត្តិ សួរអំពីអាចារវិបត្តិ សួរអំពីទិដ្ឋិវិបត្តិ សួរអំពីអាជីវវិបត្តិ។ ត្រង់ពាក្យថា អាបត្តិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីអាបត្តិបារាជិក សួរអំពីអាបត្តិសង្ឃាទិសេស សួរអំពីអាបត្តិថុល្លច្ច័យ សួរអំពីអាបត្តិបាចិត្តិយៈ សួរអំពីអាបត្តិបាដិទេសនីយៈ សួរអំពីអាបត្តិទុក្កដ សួរអំពីអាបត្តិទុព្ភាសិត។ ត្រង់ពាក្យថា អជ្ឈាចារបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីការប្រសព្វរបស់ជនពីរៗនាក់។

[២០៣] ត្រង់ពាក្យថា លោកបានឃើញអំពីហេតុដូចម្តេច គឺបានដល់លិង្គបុច្ឆា១ ឥរិយាបថបុច្ឆា១ អាការបុច្ឆា១ វិប្បការបុច្ឆា១។ ត្រង់ពាក្យថា លិង្គបុច្ឆានោះ គឺបានដល់ពាក្យសួរ អំពីភេទខ្ពស់ ឬទាប ខ្មៅ ឬស។ ត្រង់ពាក្យថា ឥរិយាបថបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីបុគ្គលដើរ ឬឈរ អង្គុយ ឬដេក។ ត្រង់ពាក្យថា អាការបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភេទគ្រហស្ថ ឬភេទតិរ្ថិយ ឬភេទបព្វជិត។ ត្រង់ពាក្យថា វិប្បការបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីបុគ្គលកំពុងដើរ ឬឈរ កំពុងអង្គុយ ឬដេក។

[២០៤] ត្រង់ពាក្យថា លោកបានឃើញពីកាលណា គឺបានដល់កាលបុច្ឆា១ សមយបុច្ឆា១ ទិវសបុច្ឆា១ ឧតុបុច្ឆា១។ ត្រង់ពាក្យថា កាលបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីពេលព្រឹក ឬពេលថ្ងៃត្រង់ ឬថ្ងៃរសៀល។ ត្រង់ពាក្យថា សមយបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីសម័យព្រឹក ឬសម័យថ្ងៃត្រង់ ឬក៏សម័យថ្ងៃរសៀល។ ត្រង់ពាក្យថា ទិវសបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីវេលាមុនភត្ត វេលាក្រោយភត្ត វេលាយប់ វេលាថ្ងៃខាងរនោច ឬខ្នើត។ ត្រង់ពាក្យថា ឧតុបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីហេមន្តរដូវ គិម្ហរដូវ ឬវស្សានរដូវ។

[២០៥] ត្រង់ពាក្យថា លោកបានឃើញក្នុងទីណា គឺបានដល់ឋានបុច្ឆា១ ភូមិបុច្ឆា១ ឱកាសបុច្ឆា១ បទេសបុច្ឆា១។ ត្រង់ពាក្យថា ឋានបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភូមិ ប្រឋពី ធរណី ឬផែនដី។ ត្រង់ពាក្យថា ភូមិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភូមិ ភ្នំ ថ្ម ឬប្រាសាទ។ ត្រង់ពាក្យថា ឱកាសបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីឱកាស ខាងកើត ឱកាសខាងលិច ឱកាសខាងជើង ឱកាសខាងត្បូង។ ត្រង់ពាក្យថា បទេសបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីប្រទេសខាងកើត ឬប្រទេសខាងលិច ប្រទេសខាងជើង ឬប្រទេសខាងត្បូង។

ចប់ មហាសង្គាម។

ឧទ្ទាន គឺបញ្ជីរឿងនៃមហាសង្គាមនោះ ដូច្នេះ

[២០៦]

និយាយអំពីភិក្ខុត្រូវស្គាល់វត្ថុ១ ស្គាល់និទាន១ ស្គាល់អាការ១ ស្គាល់ពាក្យខាងដើម និងពាក្យខាងចុង១ ស្គាល់កម្មដែលគួរធ្វើ និងមិនគួរធ្វើ១ ស្គាល់កម្ម១ ស្គាល់អធិករណ៍១ ស្គាល់សមថៈ១ មិនលំអៀងទៅខាងឆន្ទាគតិ១ ទោសាគតិ១ មោហាគតិ១ ភយាគតិ១ ពន្យល់បុគ្គលដទៃឲ្យយល់ក្នុងទីដែលគួរពន្យល់១ ពិចារណាក្នុងទីដែលគួរពិចារណា១ សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល១ ញុំាងបរិសទ្យឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា១ មើលងាយពួកដទៃ ដោយគិតថា អាត្មាអញបានបក្ខពួក១ អាត្មាអញ ជាអ្នកចេះដឹងច្រើន១ អាត្មាអញជាថេរៈ១ ពោលហេតុដែលមិនទាន់មកដល់១ កុំញុំាងហេតុដែលមកដល់ហើយ ឲ្យសាបសូន្យ១ រម្ងាប់អធិករណ៍ ដោយធម៌ ដោយវិន័យ ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា១ ក្នុងមហាសង្គាម បណ្ឌិតគប្បីដឹងថា (មានសេចក្តី) ប៉ុណ្ណោះឯង។

## កឋិនភេទ

CS vin.pv.13 | ភាគ ទី១៣

### (កថិនភេទោ)

### (កថិនអត្ថតាទិ ទី១)

### (១. កឋិនអត្ថតាទិ)

[២០៧] បុគ្គលដូចម្ដេច ដែលឈ្មោះថា មិនបានក្រាលកឋិន បុគ្គលដូចម្ដេច ដែលឈ្មោះថា បានក្រាលកឋិន កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការដូចម្ដេច កឋិនដែលភិក្ខុក្រាលឡើង ដោយអាការដូចម្ដេច។

[២០៨] ពាក្យថា បុគ្គលដូចម្ដេច ដែលឈ្មោះថា មិនបានក្រាលកឋិននោះ សេចក្ដីថា បុគ្គលពីរពួក ដែលឈ្មោះថា មិនបានក្រាលកឋិន គឺ បុគ្គលមិនបានក្រាល១ មិនបានអនុមោទនា១ បុគ្គលទាំង២ពួកនេះ ឈ្មោះថា មិនបានក្រាលកឋិនទេ។

[២០៩] ពាក្យថា បុគ្គលដូចម្ដេច ដែលឈ្មោះថា បានក្រាលកឋិននោះ សេចក្ដីថា បុគ្គល២ពួក ដែលឈ្មោះថា បានក្រាលកឋិន គឺបុគ្គល ដែលបានក្រាល១ បានអនុមោទនា១ បុគ្គលទាំង២ពួកនេះ ឈ្មោះថា បានក្រាលកឋិន។

[២១០] ពាក្យថា កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការដូចម្ដេច សេចក្ដីថា កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការ២៤ គឺសំពត់ ដែលគ្រាន់តែវាស់ទទឹងបណ្ដោយ ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែលាង ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែចាត់ចែង លៃលកជាចីវរ ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែកាត់ ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែដានភ្ជាប់គ្នា ក្រាលមិនឡើងជា កឋិន១ សំពត់ដែលគ្រាន់តែដេរ (មានដេរបណ្ដោយជាដើម) ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែដាក់ក្ដំ ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែថែមសំពត់ឲ្យមាំ ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែប្រក់អនុវាតមួយជាន់ (ពីខាងក្រៅ) ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែធ្វើជាអនុវាតមួយជាន់ (ពីខាងក្នុង) ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែដេរគួបគ្នា ក្រាលមិនឡើងជាកឋិន១ សំពត់ដែលគ្រាន់តែជ្រលក់ម្ដង មានពណ៌ដូចផ្កាកដំរី ឬដូចស្លឹកឈើទុំ ក្រាលមិនឡើងជាកឋិន១ សំពត់ដែលបានមក ដោយធ្វើនិមិត្ត ក្រាលមិន ឡើងជាកឋិន១ សំពត់ដែលបានមក ដោយនិយាយបញ្ចុះបញ្ចូលគេ ក្រាលមិនឡើងជាកឋិន១ សំពត់ដែលខ្ចីគេ ក្រាលមិនឡើងជាកឋិន១ សំពត់ ដែលធ្វើសន្និធិ គឺមិនបានធ្វើឲ្យស្រេចក្នុងថ្ងៃនោះ ក្រាលមិនឡើងជាកឋិន១ សំពត់ជានិស្សគ្គិយៈ (ទុកឲ្យកន្លងរាត្រី) ក្រាលមិនឡើងជាកឋិន១ សំពត់ដែលមិនបានធ្វើពិន្ទុកប្ប ក្រាលមិនឡើងជាកឋិន១ វៀរចាកសង្ឃាដី ក្រាលមិនឡើងជាកឋិន១ វៀរចាកចីពរ ក្រាលមិនឡើងជាកឋិន១ វៀរ ចាកស្បង់ ក្រាលមិនឡើងជាកឋិន១ វៀរចាកសំពត់ជាបញ្ចក្ខន្ធ ឬលើសពីបញ្ចក្ខន្ធឡើងទៅ ដែលបានកាត់ដាច់ត្រឹមត្រូវ ធ្វើឲ្យមានមណ្ឌលល្អក្នុង ថ្ងៃនោះ ក្រាលមិនឡើងជាកឋិន១ វៀរចាកបុគ្គលអ្នកក្រាល ក៏ក្រាលមិនឡើងជាកឋិន១ សំពត់ដែលបុគ្គលក្រាលត្រឹមត្រូវហើយ តែបើភិក្ខុនៅ ក្រៅសីមា អនុមោទនា កឋិននោះ ក៏មិនឡើងជាកឋិន១។ កឋិនដែលក្រាលមិនឡើង ដោយអាការយ៉ាងនេះឯង។

[២១១] ភិក្ខុធ្វើនិមិត្តថា អាត្មានឹងក្រាលកឋិនដោយសំពត់នេះ ដូច្នេះ ហៅថា ធ្វើនិមិត្ត។ ភិក្ខុធ្វើនូវការនិយាយបញ្ចុះបញ្ចូល ដោយគិតថា អាត្មានឹងឲ្យសំពត់កឋិនកើតឡើង ដោយការនិយាយបញ្ចុះបញ្ចូលដូច្នេះ ហៅថា ការនិយាយបញ្ចុះបញ្ចូល។ សំពត់ដែលគេមិនបានឲ្យដាច់ ហៅថា សំពត់ខ្ចីគេ។ សន្និធិ មាន២យ៉ាងគឺ ករណសន្និធិ មិនធ្វើឲ្យស្រេចក្នុងថ្ងៃនោះ (ទុកធ្វើទៅក្នុងថ្ងៃខាងមុខៗតទៅទៀត)១ និចយសន្និធិ ទុក ធ្វើដល់ថ្ងៃស្អែកជាកំណត់១ ហៅថា សន្និធិ។ កាលបើភិក្ខុកំពុងធ្វើ (សំពត់នោះ) អរុណក៏រះឡើង ហៅថា សំពត់ជានិស្សគ្គិយៈ។ កឋិនដែលភិក្ខុ ក្រាលមិនឡើង ដោយអាការ២៤នេះឯង។

[២១២] ត្រង់ពាក្យថា កឋិនដែលភិក្ខុក្រាលឡើង ដោយអាការដូចម្ដេចនោះ សេចក្ដីថា កឋិនដែលភិក្ខុក្រាលឡើង ដោយអាការ១៧ គឺសំពត់ ថ្មីសុទ្ធ ក្រាលឡើងជាកឋិន១ សំពត់ជំនុំ ក្រាលឡើងជាកឋិន១ សំពត់ចាស់ ក្រាលឡើងជាកឋិន១ សំពត់បំសុកូល ក្រាលឡើងជាកឋិន១ សំពត់ ដែលធ្លាក់ទៀបរានផ្សារ ក្រាលឡើងជាកឋិន១ សំពត់ដែលបានមកដោយមិនបានធ្វើនិមិត្ត ក្រាលឡើងជាកឋិន១ សំពត់ដែលបានមកដោយមិន បាននិយាយបញ្ចុះបញ្ចូល ក្រាលឡើងជាកឋិន១ សំពត់ដែលមិនបានខ្ចីគេ ក្រាលឡើងជាកឋិន១ សំពត់ដែលមិនបានធ្វើឲ្យជាសន្និធិ ក្រាល ឡើងជាកឋិន១ សំពត់ដែលមិនមែនជានិស្សគ្គិយៈ ក្រាលឡើងជាកឋិន១ សំពត់ដែលបានធ្វើពិន្ទុកប្ប ក្រាលឡើងជាកឋិន១ សង្ឃាដិ ក្រាល ឡើងជាកឋិន១ ចីពរ ក្រាលឡើងជាកឋិន១ ស្បង់ ក្រាលឡើងជាកឋិន១ ចីវរជាបញ្ចក្ខន្ធ ឬលើសពីបញ្ចក្ខន្ធឡើងទៅ ដែលបានកាត់ដាច់ត្រឹមត្រូវ ធ្វើឲ្យមានមណ្ឌលល្អក្នុងថ្ងៃនោះ ក្រាលឡើងជាកឋិន១ បុគ្គល ទើបក្រាលឡើងជាកឋិន១ សំពត់ដែលបុគ្គលក្រាលឲ្យត្រឹមត្រូវ (តាមច្បាប់) ទាំង ភិក្ខុនៅក្នុងសីមា អនុមោទនា កឋិននោះ ទើបឡើងជាកឋិន១ កឋិនដែលភិក្ខុក្រាលឡើង ដោយអាការយ៉ាងនេះឯង។ កឋិនដែលភិក្ខុក្រាលឡើង ដោយអាការទាំង១៧នេះ។

[២១៣] ធម៌ប៉ុន្មានយ៉ាង ដែលកើតជាមួយនឹងការក្រាលកឋិន។ ធម៌១៥យ៉ាង ដែលកើតជាមួយនឹងការក្រាលកឋិន គឺមាតិកា៨ បលិពោធ២ អានិសង្ស៥។ ធម៌ទាំង១៥នេះឯង ដែលកើតជាមួយនឹងការក្រាលកឋិន។

## (កឋិនអនន្តរបច្ចយាទិ ទី២)



### (២. កឋិនអនន្តរបច្ចយាទិ)

[២១៤] ធម៌ប៉ុន្មានយ៉ាង ជាបច្ច័យនៃបយោគ ដោយអនន្តរប្បច្ច័យ ដោយសមនន្តរប្បច្ច័យ ដោយនិស្សយប្បច្ច័យ ដោយឧបនិស្សយប្បច្ច័យ ដោយបុរេជាតប្បច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ដោយសហជាតប្បច្ច័យ។ ធម៌ប៉ុន្មានយ៉ាង ជាបច្ច័យនៃបុព្វករណៈ។បេ។ បច្ចុទ្ធារៈ អធិដ្ឋាន ការ ក្រាល មាតិកា បលិពោធ វត្ថុ ដោយអនន្តរប្បច្ច័យ ដោយសមនន្តរប្បច្ច័យ ដោយនិស្សយប្បច្ច័យ ដោយឧបនិស្សយប្បច្ច័យ ដោយបុរេ ជាតប្បច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ដោយសហជាតប្បច្ច័យ។

[២១៥] បុព្វករណៈ គឺកិរិយាធ្វើមុន មានការលាងចីវរជាដើម ជាបច្ច័យនៃបយោគ គឺកិរិយាប្រកប មានដងទឹកជាដើម ដោយអនន្តរប្បច្ច័យ គឺហេតុជាលំដាប់ទី១ នៃបយោគ ដោយសមនន្តរប្បច្ច័យ គឺហេតុជាលំដាប់ទី២ ដោយនិស្សយប្បច្ច័យ គឺហេតុជាគ្រឿងទ្រទ្រង់ទី៣ ដោយឧបនិស្សយប្បច្ច័យ គឺហេតុជាគ្រឿងទ្រទ្រង់បន្ទាប់គ្នាទី៤។ បយោគ ជាបច្ច័យ នៃបុព្វករណៈ ដោយបុរេជាតប្បច្ច័យ គឺហេតុដែលកើតមុន នៃបុព្វករណៈ។ បុព្វករណៈ ជាបច្ច័យនៃបយោគ ដោយបច្ឆាជាតប្បច្ច័យ គឺហេតុដែលកើតក្រោយនៃបយោគ។ ធម៌ទាំង១៥ប្រការ ជាបច្ច័យ (នៃបយោគ និងបុព្វករណៈ) ដោយសហជាតប្បច្ច័យ គឺបច្ច័យកើតព្រមគ្នានឹងការក្រាលកឋិន។

[២១៦] បច្ចុទ្ធារៈ គឺការដកចីវរ ជាបច្ច័យនៃបុព្វករណៈ ដោយអនន្តរប្បច្ច័យ ដោយសមនន្តរប្បច្ច័យ ដោយនិស្សយប្បច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ បុព្វករណៈ ជាបច្ច័យនៃបច្ចុទ្ធារៈ ដោយបុរេជាតប្បច្ច័យ។ បច្ចុទ្ធារៈ ជាបច្ច័យនៃបុព្វករណៈ ដោយបច្ឆាជាតប្បច្ច័យ គឺហេតុដែលកើតក្រោយរបស់បុព្វករណៈ។ ធម៌ទាំង១៥ប្រការ ជាបច្ច័យ (នៃបច្ចុទ្ធារៈ និងបុព្វករណៈ) ដោយសហជាតប្បច្ច័យ។

[២១៧] អធិដ្ឋាន ជាបច្ច័យនៃបុព្វករណៈ ដោយអនន្តរប្បច្ច័យ ដោយសមនន្តរប្បច្ច័យ ដោយនិស្សយប្បច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ បច្ចុទ្ធារៈ ជាបច្ច័យនៃអធិដ្ឋាន ដោយបុរេជាតប្បច្ច័យ។ អធិដ្ឋាន ជាបច្ច័យនៃបច្ចុទ្ធារៈ ដោយបច្ឆាជាតប្បច្ច័យ។ ធម៌ទាំង១៥ប្រការ ជាបច្ច័យ (នៃអធិដ្ឋាន និងបច្ចុទ្ធារៈ) ដោយសហជាតប្បច្ច័យ។

[២១៨] ការក្រាល ជាបច្ច័យនៃអធិដ្ឋាន ដោយអនន្តរប្បច្ច័យ ដោយសមនន្តរប្បច្ច័យ ដោយនិស្សយប្បច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ អធិដ្ឋាន ជាបច្ច័យនៃការក្រាល ដោយបុរេជាតប្បច្ច័យ។ ការក្រាល ជាបច្ច័យនៃអធិដ្ឋាន ដោយបច្ឆាជាតប្បច្ច័យ។ ធម៌ទាំង១៥ ជាបច្ច័យ (នៃការក្រាល និងអធិដ្ឋាន) ដោយសហជាតប្បច្ច័យ។

[២១៩] មាតិកា និងបលិពោធ ជាបច្ច័យនៃការក្រាល ដោយអនន្តរប្បច្ច័យ ដោយសមនន្តរប្បច្ច័យ ដោយនិស្សយប្បច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ ការក្រាល ជាបច្ច័យនៃមាតិកា និងបលិពោធ ដោយបុរេជាតប្បច្ច័យ។ មាតិកា និងបលិពោធ ជាបច្ច័យនៃការក្រាល ដោយបច្ឆាជាតប្បច្ច័យ។ ធម៌ទាំង១៥ ជាបច្ច័យ (នៃមាតិកា បលិពោធ និងការក្រាល) ដោយសហជាតប្បច្ច័យ។

[២២០] សេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម ជាបច្ច័យនៃវត្ថុ ដោយអនន្តរប្បច្ច័យ ដោយសមនន្តរប្បច្ច័យ ដោយនិស្សយប្បច្ច័យ ដោយឧបនិស្សយប្បច្ច័យ។ វត្ថុ ជាបច្ច័យនៃសេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម ដោយបុរេជាតប្បច្ច័យ។ សេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម ជាបច្ច័យនៃវត្ថុ ដោយបច្ឆាជាតប្បច្ច័យ។ ធម៌ទាំង១៥ប្រការ ជាបច្ច័យ (នៃសេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម និងវត្ថុ) ដោយសហជាតប្បច្ច័យ។

## (បុព្វករណនិទានាទិវិភាគៈ ទី៣)

CS vin.pv.13.03 | ភាគ ទី១៣

### (៣. បុព្ពករណនិទានាទិវិភាគោ)

[២២១] បុព្វករណៈ មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ បច្ចុទ្ធារៈ មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ អធិដ្ឋាន មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ ការក្រាល មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ មាតិកា និងបលិពោធ មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ សេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ បុព្វករណៈ មានបយោគជាដើមចម មានបយោគជាទីតាំងឡើង មានបយោគជាកំណើត មានបយោគជាដែនកើត មានបយោគជាអង្គ មានបយោគជាសមុដ្ឋាន។ បច្ចុទ្ធារៈ មានបុព្វករណៈជាដើមចម មានបុព្វករណៈជាទីតាំងឡើង មានបុព្វករណៈជាកំណើត មានបុព្វករណៈជាដែនកើត មានបុព្វករណៈជាអង្គ មានបុព្វករណៈជាសមុដ្ឋាន។ អធិដ្ឋាន មានបច្ចុទ្ធារៈ ជាដើមចម មានបច្ចុទ្ធារៈជាទីតាំងឡើង មានបច្ចុទ្ធារៈជាកំណើត មានបច្ចុទ្ធារៈជាដែនកើត មានបច្ចុទ្ធារៈជាអង្គ មានបច្ចុទ្ធារៈជាសមុដ្ឋាន។ ការក្រាល មានអធិដ្ឋាន ជាដើមចម មានអធិដ្ឋានជាទីតាំងឡើង មានអធិដ្ឋានជាកំណើត មានអធិដ្ឋានជាដែនកើត មានអធិដ្ឋានជាអង្គ មានអធិដ្ឋានជាសមុដ្ឋាន។ មាតិកា និងបលិពោធ មានការក្រាលជាដើមចម មានការក្រាលជាទីតាំងឡើង មានការក្រាលជាកំណើត មានការក្រាលជាដែនកើត មានការក្រាលជាអង្គ មានការក្រាលជាសមុដ្ឋាន។ សេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម មានវត្ថុជាដើមចម មានវត្ថុជាទីតាំងឡើង មានវត្ថុជាកំណើត មានវត្ថុជាដែនកើត មានវត្ថុជាអង្គ មានវត្ថុជាសមុដ្ឋាន។ បយោគ មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ បុព្វករណៈ។បេ។ បច្ចុទ្ធារៈ អធិដ្ឋាន ការក្រាល មាតិកា បលិពោធ វត្ថុ សេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ បយោគ មានហេតុជាដើមចម មានហេតុជាទីតាំងឡើង មានហេតុជាកំណើត មានហេតុជាដែនកើត មានហេតុជាអង្គ មានហេតុជាសមុដ្ឋាន។ បុព្វករណៈ។បេ។ បច្ចុទ្ធារៈ អធិដ្ឋាន ការក្រាល មាតិកា បលិពោធ វត្ថុ សេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម មានហេតុជាដើមចម មានហេតុជាទីតាំងឡើង មានហេតុជាកំណើត មានហេតុជាដែនកើត មានហេតុជាអង្គ មានហេតុជាសមុដ្ឋាន។ បយោគ មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ បុព្វករណៈ។បេ។ បច្ចុទ្ធារៈ អធិដ្ឋាន ការក្រាល មាតិកា បលិពោធ វត្ថុ សេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម មានអ្វីជាដើមចម មានអ្វីជាទីតាំងឡើង មានអ្វីជាកំណើត មានអ្វីជាដែនកើត មានអ្វីជាអង្គ មានអ្វីជាសមុដ្ឋាន។ បយោគ មានបច្ច័យជាដើមចម មានបច្ច័យជាទីតាំងឡើង មានបច្ច័យជាកំណើត មានបច្ច័យជាដែនកើត មានបច្ច័យជាអង្គ មានបច្ច័យជាសមុដ្ឋាន។ បុព្វករណៈ។បេ។ បច្ចុទ្ធារៈ អធិដ្ឋាន ការក្រាល មាតិកា បលិពោធ វត្ថុ សេចក្តីសង្ឃឹម និងសេចក្តីមិនសង្ឃឹម មានបច្ច័យជាដើមចម មានបច្ច័យជាទីតាំងឡើង មានបច្ច័យជាកំណើត មានបច្ច័យជាដែនកើត មានបច្ច័យជាអង្គ មានបច្ច័យជាសមុដ្ឋាន។

[២២២] បុព្វករណៈ លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង។ បុព្វករណៈ លោកសង្គ្រោះដោយធម៌៧យ៉ាង គឺគក់លាង១ ចាត់ចែងចីវរ១ កាត់១ ដាន១ ដេរ១ ជ្រលក់១ ធ្វើពិន្ទុកប្ប១។ បុព្វករណៈ លោកសង្គ្រោះដោយធម៌៧យ៉ាងនេះ។ បច្ចុទ្ធារៈ លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង។ បច្ចុទ្ធារៈ លោកសង្គ្រោះដោយធម៌៣យ៉ាង គឺសង្ឃាដិ១ ចីពរ១ ស្បង់១។ អធិដ្ឋាន លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង។ អធិដ្ឋាន លោកសង្គ្រោះដោយធម៌៣យ៉ាងគឺ សង្ឃាដិ១ ចីពរ១ ស្បង់១។ ការក្រាល លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង។ ការក្រាល លោកសង្គ្រោះដោយធម៌១គឺ បញ្ចេញវាចា។

[២២៣] មូលរបស់កឋិន មានប៉ុន្មាន វត្ថុរបស់កឋិនមានប៉ុន្មាន ភូមិរបស់កឋិន មានប៉ុន្មាន។ មូលរបស់កឋិន មាន១ គឺសង្ឃ។ វត្ថុរបស់កឋិន មាន៣ គឺសង្ឃាដិ១ ចីពរ១ ស្បង់១។ ភូមិរបស់កឋិន មាន៦យ៉ាង គឺ សំពត់សម្បកឈើ១ សំពត់អំបោះ១ សំពត់សូត្រ១ សំពត់រោមសត្វ១ សំពត់ធ្មៃ១ សំពត់លាយវត្ថុទាំង៥ ខាងដើម១។

[២២៤] កឋិន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង។ កឋិន មានបុព្វករណៈ ជាខាងដើម មានកិរិយា គឺបច្ចុទ្ធារៈ និងអធិដ្ឋាន ជាកណ្តាល មានការក្រាលជាខាងចុង។

[២២៥] បុគ្គលប្រកបដោយអង្គប៉ុន្មាន មិនគួរក្រាលកឋិន បុគ្គលប្រកបដោយអង្គប៉ុន្មាន ទើបគួរក្រាលកឋិន។ បុគ្គលដែលប្រកបដោយអង្គ៨ មិនគួរក្រាលកឋិនបានទេ។ បុគ្គលដែលប្រកបដោយអង្គ៨ ទើបគួរក្រាលកឋិនបាន។ បុគ្គលដែលប្រកបដោយអង្គ៨គឺអ្វីខ្លះ ដែលមិនគួរក្រាលកឋិនបាន។ បុគ្គលអ្នកក្រាលមិនចេះបុព្វករណៈ១ មិនចេះបច្ចុទ្ធរៈ (ដកចីវរចាស់)១ មិនចេះអធិដ្ឋាន១ មិនចេះក្រាល១ មិនចេះមាតិកា១ មិនចេះបលិពោធ១ មិនចេះវិធីដកកឋិន១ មិនចេះអានិសង្ស១។ បុគ្គលដែលប្រកបដោយអង្គ៨នេះ មិនគួរនឹងក្រាលកឋិនបានឡើយ។ បុគ្គលដែលប្រកបដោយអង្គ៨ គឺអ្វីខ្លះ ដែលគួរក្រាលកឋិនបាន។ បុគ្គលអ្នកក្រាលចេះបុព្វករណៈ១ ចេះបច្ចុទ្ធារៈ១ ចេះអធិដ្ឋាន១ ចេះក្រាល១ ចេះមាតិកា១ ចេះបលិពោធ១ ចេះវិធីដកកឋិន១ ចេះអានិសង្ស១។ បុគ្គលប្រកបដោយអង្គទាំង៨នេះឯង ទើបគួរក្រាលកឋិនបាន។

## (កថិនាទិជានិតព្វវិភាគៈ ទី៤)

CS vin.pv.13.04 | ភាគ ទី១៣

### (៤. កថិនាទិជានិតព្វវិភាគោ)

[២២៦] ការក្រាលកឋិនមិនឡើង មានដល់បុគ្គលប៉ុន្មានពួក ការក្រាលកឋិនឡើង មានដល់បុគ្គលប៉ុន្មានពួក។ ការក្រាលកឋិនមិនឡើង មានដល់បុគ្គល៣ពួក ការក្រាលកឋិនឡើង មានដល់បុគ្គល៣ពួក។ ការក្រាលកឋិនមិនឡើង មានដល់បុគ្គល៣ពួក ដូចម្តេច។ បុគ្គលឋិតនៅក្រៅសីមា អនុមោទនា១ បុគ្គលដែលអនុមោទនា មិនបានបញ្ចេញវាចា១ បុគ្គលដែលបញ្ចេញវាចា តែមិនឲ្យបុគ្គលដទៃដឹងច្បាស់១។ ការក្រាលកឋិនមិនឡើង មានដល់បុគ្គល៣ពួកនេះ។ ការក្រាលកឋិនឡើង មានដល់បុគ្គល៣ពួកដូចម្តេច។ បុគ្គលឋិតនៅក្នុងសីមា អនុមោទនា១ បុគ្គលដែលអនុមោទនាបញ្ចេញវាចា១ បុគ្គលដែលបញ្ចេញវាចា បានញុំាងអ្នកដទៃឲ្យដឹងច្បាស់១។ ការក្រាលកឋិនឡើង មានដល់បុគ្គល៣ពួកនេះ។

[២២៧] ការក្រាលកឋិនមិនឡើង មានប៉ុន្មានយ៉ាង ការក្រាលកឋិនឡើង មានប៉ុន្មានយ៉ាង។ ការក្រាលកឋិនមិនឡើងមាន៣យ៉ាង ការក្រាលកឋិនឡើង មាន៣យ៉ាង។ ការក្រាលកឋិនមិនឡើង មាន៣យ៉ាង គឺអ្វីខ្លះ។ គឺវត្ថុវិបត្តិ១ កាលវិបត្តិ១ ករណវិបត្តិ[42] ១។ ការក្រាលកឋិនមិនឡើង មាន៣យ៉ាងនេះ។ ការក្រាលកឋិនឡើង មាន៣យ៉ាង គឺអ្វីខ្លះ។ គឺវត្ថុសម្បត្តិ១ កាលសម្បត្តិ១ ករណសម្បត្តិ១។ ការក្រាលកឋិនឡើង មាន៣យ៉ាងនេះ។

[២២៨] ភិក្ខុគប្បីស្គាល់កឋិន គប្បីស្គាល់ការក្រាលកឋិន គប្បីស្គាល់ខែដែលក្រាលកឋិន គប្បីស្គាល់វិបត្តិនៃការក្រាលកឋិន គប្បីស្គាល់សម្បត្តិនៃការក្រាលកឋិន គប្បីស្គាល់និមិត្តកម្ម គប្បីស្គាល់ពាក្យនិយាយបញ្ចុះបញ្ចូល គប្បីស្គាល់សំពត់ខ្ចីគេ គប្បីស្គាល់សំពត់ដែលជាសន្និធិ គប្បីស្គាល់សំពត់ជានិស្សគ្គិយៈ។

[២២៩] ត្រង់ពាក្យថា ភិក្ខុគប្បីស្គាល់កឋិននោះ សេចក្តីថា ការរួបរួមនឹងកិរិយាប្រជុំនៃធម៌ទាំងឡាយនោះឯង ជានាម ជានាមកម្ម ជានាមបញ្ញត្តិ ជាសំដី ជាគ្រឿងបញ្ជាក់ ជាគ្រឿងប្រកាស នេះជាពាក្យហៅថា កឋិន។ ត្រង់ពាក្យថា គប្បីស្គាល់ខែ ដែលក្រាលកឋិននោះ សេចក្តីថា ត្រូវស្គាល់ខែជាខាងចុងនៃវស្សានរដូវ។ ពាក្យថា គប្បីស្គាល់វិបត្តិនៃការក្រាលកឋិននោះ សេចក្តីថា ត្រូវស្គាល់វិបត្តិនៃការក្រាលកឋិន ដោយអាការ២៤។ ពាក្យថា គប្បីស្គាល់សម្បត្តិនៃការក្រាលកឋិននោះ សេចក្តីថា ត្រូវដឹងសម្បត្តិនៃការក្រាលកឋិន ដោយអាការ១៧។ ពាក្យថា គប្បីដឹងនិមិត្តកម្មនោះ សេចក្តីថា ភិក្ខុធ្វើនិមិត្តកម្មថា អាត្មានឹងក្រាលកឋិន ដោយសំពត់នេះ។ ពាក្យថា គប្បីស្គាល់ពាក្យនិយាយបញ្ចុះបញ្ចូលនោះ សេចក្តីថា ភិក្ខុធ្វើពាក្យបញ្ចុះបញ្ចូលថា អាត្មាអញនឹងធ្វើសំពត់កឋិនឲ្យកើតឡើង ដោយពាក្យបញ្ចុះបញ្ចូលនេះ។ ពាក្យថា គប្បីស្គាល់សំពត់ខ្ចីគេនោះ សេចក្តីថា ត្រូវស្គាល់សំពត់ដែលគេមិនបានឲ្យដាច់។ ពាក្យថា គប្បីស្គាល់សំពត់ដែលជាសន្និធិនោះ សេចក្តីថា ត្រូវស្គាល់សន្និធិមាន២យ៉ាង គឺសន្និធិព្រោះការមិនធ្វើក្នុងថ្ងៃនោះ១ សន្និធិព្រោះទុកដល់ថ្ងៃស្អែក១។ ពាក្យថា គប្បីស្គាល់សំពត់ជានិស្សគ្គិយៈនោះ សេចក្តីថា ភិក្ខុកំពុងធ្វើ (ចីវរ) អរុណក៏រះឡើង។

[២៣០] ត្រង់ពាក្យថា គប្បីស្គាល់ការក្រាលកឋិននោះ សេចក្តីថា បើសំពត់កឋិនកើតឡើងដល់សង្ឃ សង្ឃត្រូវប្រតិបត្តិដូចម្តេច បុគ្គលអ្នកក្រាល ត្រូវប្រតិបត្តិដូចម្តេច អ្នកអនុមោទនា ត្រូវប្រតិបត្តិដូចម្តេច។ សង្ឃគប្បីឲ្យដល់ភិក្ខុអ្នកក្រាលកឋិន ដោយញត្តិទុតិយកម្ម។ ភិក្ខុអ្នកក្រាលកឋិននោះ គប្បីលាង គក់ វាស់ កាត់ ដេរ ជ្រលក់ ធ្វើពិន្ទុកប្ប ហើយក្រាលកឋិនក្នុងថ្ងៃនោះឯង។ បើ (ភិក្ខុអ្នកក្រាល)ចង់ក្រាលកឋិនដោយសង្ឃាដិ ត្រូវដកសង្ឃាដិចាស់ចេញ អធិដ្ឋានសង្ឃាដិថ្មីឡើង គប្បីបញ្ចេញវាចាថា ខ្ញុំក្រាលកឋិនដោយសង្ឃាដិនេះ។ បើចង់ក្រាលកឋិនដោយចីពរ ក៏គប្បីដកចីពរចាស់ចេញ អធិដ្ឋានចីពរថ្មីឡើង គប្បីបញ្ចេញវាចាថា ខ្ញុំក្រាលកឋិនដោយចីពរនេះ។ បើចង់ក្រាលកឋិនដោយស្បង់ ក៏គប្បី

ដកស្បង់ចាស់ចេញ អធិដ្ឋានស្បង់ថ្មីឡើង គប្បីបញ្ចេញវាចាថា ខ្ញុំក្រាលកឋិនដោយស្បង់នេះ។ ភិក្ខុអ្នកក្រាលកឋិននោះ ត្រូវចូលទៅរកសង្ឃ ធ្វើចីពរឆៀងស្មាម្ខាង ផ្គងអញ្ជលីឡើងពោលដូច្នេះថា បពិត្រព្រះសង្ឃដ៏ចំរើន កឋិនរបស់សង្ឃ ខ្ញុំបានក្រាលហើយ ការក្រាលកឋិន (នេះ) នឹងប្រកបដោយធម៌ សូមលោកម្ចាស់ទាំងឡាយ ទទួលអនុមោទនាចុះ។ ពួកភិក្ខុជាអ្នកអនុមោទនានោះ ត្រូវធ្វើចីពរឆៀងស្មាម្ខាង ផ្គងអញ្ជលីឡើងពោលយ៉ាងនេះថា ម្នាលលោកដ៏មានអាយុ កឋិនរបស់សង្ឃ លោកដ៏មានអាយុបានក្រាលហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ យើងរាល់គ្នា សូមអនុមោទនា។ ភិក្ខុអ្នកក្រាលកឋិននោះ ចូលទៅរកភិក្ខុច្រើនរូប ធ្វើចីពរឆៀងស្មាម្ខាង ផ្គងអញ្ជលីឡើង រួចពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន កឋិនរបស់សង្ឃ ខ្ញុំបានក្រាលហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ សូមលោកម្ចាស់រាល់អង្គ ទទួលអនុមោទនាចុះ។ ពួកភិក្ខុជាអ្នកអនុមោទនានោះ គប្បីធ្វើចីពរឆៀងស្មាម្ខាង ផ្គងអញ្ជលីឡើង រួចពោលយ៉ាងនេះថា ម្នាលអាវុសោ កឋិនរបស់សង្ឃ លោកបានក្រាលហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ យើងរាល់គ្នា សូមអនុមោទនា។ ភិក្ខុអ្នកក្រាលកឋិននោះ គប្បីចូលទៅរកភិក្ខុ១រូប ធ្វើចីពរឆៀងស្មាម្ខាង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា ម្នាលអាវុសោ កឋិនរបស់សង្ឃ ខ្ញុំបានក្រាលហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ សូមលោកទទួលអនុមោទនាចុះ។ ភិក្ខុជាអ្នកអនុមោទនានោះ គប្បីធ្វើចីពរឆៀងស្មាម្ខាង ផ្គងអញ្ជលីឡើង ហើយពោលយ៉ាងនេះថា ម្នាលអាវុសោ កឋិនរបស់សង្ឃ លោកបានក្រាលហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ ខ្ញុំសូមទទួលអនុមោទនា។

## (បុគ្គលស្សេវកថិនត្ថារៈ ទី៥)

CS vin.pv.13.05 | ភាគ ទី១៣

### (៥. បុគ្គលស្សេវកថិនត្ថារោ)

[២៣១] សួរថា សង្ឃក្រាលកឋិន គណៈក្រាលកឋិន បុគ្គលក្រាលកឋិន ឡើងឬទេ។ ឆ្លើយថា សង្ឃក្រាលកឋិន មិនឡើង គណៈក្រាលកឋិន ក៏មិនឡើង បុគ្គលក្រាលកឋិន ទើបឡើង។ ព្រោះសង្ឃក្រាលកឋិន ក៏មិនឡើង គណៈក្រាលកឋិន ក៏មិនឡើង បុគ្គលក្រាលកឋិន ទើបឡើង កឋិន សង្ឃក្រាលមិនបានទេ កឋិន គណៈក្រាលមិនបានទេ កឋិន បុគ្គលទើបក្រាលបាន។ សួរថា សង្ឃសំដែងបាតិមោក្ខ គណៈសំដែងបាតិមោក្ខ បុគ្គលសំដែងបាតិមោក្ខ បានឬទេ។ ឆ្លើយថា សង្ឃសំដែងបាតិមោក្ខមិនបាន គណៈសំដែងបាតិមោក្ខ មិនបានទេ បុគ្គលទើបសំដែងបាតិមោក្ខបាន។ ព្រោះថា សង្ឃក៏សំដែងបាតិមោក្ខមិនបាន គណៈក៏សំដែងបាតិមោក្ខមិនបាន បុគ្គល ទើបសំដែងបាតិមោក្ខបាន បាតិមោក្ខ សង្ឃសំដែងមិនបាន បាតិមោក្ខ គណៈសំដែងមិនបានទេ បាតិមោក្ខ បុគ្គលទើបសំដែងបាន។ ប៉ុន្តែ បាតិមោក្ខឈ្មោះថា សង្ឃបានសំដែង បាតិមោក្ខឈ្មោះថា គណៈបានសំដែង បាតិមោក្ខឈ្មោះថា បុគ្គលបានសំដែង ព្រោះសង្ឃព្រមព្រៀងគ្នា គណៈក៏ព្រមព្រៀងគ្នា បុគ្គលជាអ្នកសំដែង (យ៉ាងណាមិញ)។ ការក្រាលកឋិន ក៏យ៉ាងនោះដែរ សង្ឃក្រាលកឋិន មិនឡើងទេ គណៈក្រាលកឋិន មិនឡើងទេ បុគ្គលក្រាលកឋិន ទើបឡើង ប៉ុន្តែកឋិនក៏ឈ្មោះថា សង្ឃបានក្រាល កឋិនក៏ឈ្មោះថា គណៈបានក្រាល កឋិនក៏ឈ្មោះថា បុគ្គលបានក្រាល ព្រោះសង្ឃបានអនុមោទនា គណៈបានអនុមោទនា បុគ្គលបានក្រាល។

## (បលិពោធបញ្ហាព្យាករណៈ ទី៦)

CS vin.pv.13.06 | ភាគ ទី១៣

### (៦. បលិពោធបញ្ហាព្យាករណំ)

[២៣២] ការដោះកឋិន មានការចៀសចេញទៅជាកំណត់ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ បានត្រាស់រួចហើយ ខ្ញុំសូមសួរសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធណាដាច់មុន។ ការដោះកឋិន គឺអស់អំណាចអានិសង្សកឋិន មានការចៀសចេញទៅជាកំណត់ ដែលព្រះពុទ្ធ ជាអាទិច្ចពន្ធុ បានត្រាស់រួចហើយ ខ្ញុំសូមឆ្លើយសេចក្តីនេះ នឹងលោកម្ចាស់ថា ចីវរបលិពោធ ដាច់មុន អាវាសបលិពោធ ដាច់ជាមួយនឹងដំណើរ ដែលភិក្ខុនោះទៅខាងក្រៅសីមា។

[២៣៣] ការដោះកឋិន មានការធ្វើចីវរស្រេចជាកំណត់ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ បានត្រាស់រួចហើយ ខ្ញុំសូមសួរសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធណាដាច់មុន។ ការដោះកឋិន មានការធ្វើចីវរស្រេចជាកំណត់ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ បានត្រាស់រួចហើយ ខ្ញុំសូមឆ្លើយសេចក្តីនេះ នឹងលោកម្ចាស់ថា អាវាសបលិពោធដាច់មុន កាលបើចីវរសម្រេចហើយ ចីវរបលិពោធទើបដាច់។

[២៣៤] ការដោះកឋិន មានសេចក្តីសន្និដ្ឋានជាកំណត់ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ បានត្រាស់រួចហើយ ខ្ញុំសូមសួរសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធណាដាច់មុន។ ការដោះកឋិន មានសេចក្តីសន្និដ្ឋានជាកំណត់ ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ បានត្រាស់រួចហើយ ខ្ញុំសូមឆ្លើយសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធទាំងពីរដាច់មិនមុន មិនក្រោយ។

[២៣៥] ការដោះកឋិន មានវិនាសចីវរជាកំណត់ ដែលព្រះមានព្រះភាគជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមសួរសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធណាដាច់មុន។ ការដោះកឋិន មានវិនាសចីវរជាកំណត់ ដែលព្រះមានព្រះភាគជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមឆ្លើយសេចក្តីនេះ នឹងលោកម្ចាស់ថា អាវាសបលិពោធដាច់មុន កាលបើចីវរវិនាសទៅ ចីវរបលិពោធទើបដាច់។

[២៣៦] ការដោះកឋិន មានឮដំណឹងជាកំណត់ ដែលព្រះមានព្រះភាគជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមសួរសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធណាដាច់មុន។ ការដោះកឋិន មានឮដំណឹងជាកំណត់ ដែលព្រះមានព្រះភាគ ជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមឆ្លើយសេចក្តីនេះ នឹងលោកម្ចាស់ថា ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ ជាមួយនឹងវេលាដែលភិក្ខុនោះបានឮដំណឹង។

[២៣៧] ការដោះកឋិន មានសេចក្តីអស់សង្ឃឹមជាកំណត់ ដែលព្រះមានព្រះភាគ ជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមសួរសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធណាដាច់មុន។ ការដោះកឋិន មានសេចក្តីអស់សង្ឃឹម ជាកំណត់ ដែលព្រះមានព្រះភាគ ជាអាទិច្ចពន្ធុ បានត្រាស់ហើយ

ខ្ញុំសូមឆ្លើយសេចក្តីនេះ នឹងលោកម្ចាស់ថា អាវាសបលិពោធដាច់មុន កាលបើសេចក្តីសង្ឃឹមថានឹងបានចីវរ ផុតអស់ហើយ ចីវរបលិពោធទើបដាច់។

[២៣៨] ការដោះកឋិន មានការកន្លងខែត្រកឋិនជាកំណត់ ដែលព្រះមានព្រះភាគ ជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមសួរសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធណាដាច់មុន។ ការដោះកឋិន មានការកន្លងខែត្រកឋិនជាកំណត់ ដែលព្រះមានព្រះភាគ ជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមឆ្លើយសេចក្តីនេះ នឹងលោកម្ចាស់ថា ចីវរបលិពោធដាច់មុន កាលភិក្ខុនោះទៅដល់ក្រៅសីមាហើយ អាវាសបលិពោធទើបដាច់។

[២៣៩] ការដោះកឋិន ជាមួយនឹងភិក្ខុទាំងឡាយ ព្រះមានព្រះភាគ ជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមសួរសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធណាដាច់មុន។ ការដោះកឋិន ជាមួយនឹងភិក្ខុទាំងឡាយ ព្រះមានព្រះភាគ ជាអាទិច្ចពន្ធុ បានត្រាស់ហើយ ខ្ញុំសូមឆ្លើយសេចក្តីនេះ នឹងលោកម្ចាស់ថា បលិពោធទាំងពីរដាច់ មិនមុន មិនក្រោយ។

[២៤០] ការដោះកឋិន ដែលអាស្រ័យនឹងសង្ឃ មានប៉ុន្មាន ការដោះកឋិន ដែលអាស្រ័យនឹងបុគ្គល មានប៉ុន្មាន ការដោះកឋិន ដែលមិនអាស្រ័យនឹងសង្ឃ មិនអាស្រ័យនឹងបុគ្គល មានប៉ុន្មាន។ ការដោះកឋិន ដែលអាស្រ័យនឹងសង្ឃ មាន១ គឺសង្ឃសូត្រដកក្នុងចន្លោះ។ ការដោះកឋិន ដែលអាស្រ័យនឹងបុគ្គល មាន៤យ៉ាង គឺមានកិរិយាចៀសចេញទៅ ជាកំណត់១ មានការធ្វើចីវរស្រេច ជាកំណត់១ មានសេចក្តីសន្និដ្ឋាន ជាកំណត់១ មានការកន្លងខែត្រកឋិន ជាកំណត់១។ ការដោះកឋិន មិនអាស្រ័យនឹងសង្ឃ មិនអាស្រ័យនឹងបុគ្គល មាន៤យ៉ាង គឺមានវិនាសចីវរ ជាកំណត់១ មានឮដំណឹង ជាកំណត់១ មានសេចក្តីអស់សង្ឃឹម ជាកំណត់១ កឋិនដោះជាមួយនឹងភិក្ខុទាំងឡាយ១។

[២៤១] ការដោះកឋិន ដោះខាងក្នុងសីមា មានប៉ុន្មាន ការដោះកឋិន ដោះខាងក្រៅសីមា មានប៉ុន្មាន (ព្រោះ) ការដោះកឋិន ដោះក្នុងសីមាក៏មាន ដោះខាងក្រៅសីមាក៏មាន។ ការដោះកឋិន ដោះក្នុងសីមា មាន២ គឺសង្ឃសូត្រដកក្នុងចន្លោះ១ ដោះជាមួយនឹងភិក្ខុទាំងឡាយ១។ ការដោះកឋិន ដោះខាងក្រៅសីមា មាន៣យ៉ាង គឺមានកិរិយាដើរចៀសចេញទៅ ជាកំណត់១ ឮដំណឹង ជាកំណត់១ មានការកន្លងខែត្រកឋិន ជាកំណត់១។ ការដោះកឋិន ដោះខាងក្នុងសីមាក៏មាន ដោះខាងក្រៅសីមាក៏មាន មាន៤យ៉ាង គឺមានការធ្វើចីវរសម្រេច ជាកំណត់១ មានសេចក្តីសន្និដ្ឋាន ជាកំណត់១ មានការវិនាសចីវរ ជាកំណត់១ មានការអស់សេចក្តីសង្ឃឹម ជាកំណត់១។

[២៤២] ការដោះកឋិន កើតព្រមគ្នា រលត់ព្រមគ្នា មានប៉ុន្មានប្រការ ការដោះកឋិន កើតព្រមគ្នា រលត់ផ្សេងគ្នា មានប៉ុន្មានប្រការ។ ការដោះកឋិន កើតព្រមគ្នា រលត់ព្រមគ្នា មាន២ប្រការ គឺសង្ឃសូត្រដកក្នុងចន្លោះ១ ដោះជាមួយនឹងភិក្ខុទាំងឡាយ១។ ការដោះកឋិន ក្រៅពីនេះ កើតព្រមគ្នា រលត់ផ្សេងគ្នា។

ចប់ កឋិនភេទ។

ឧទ្ទាន គឺបញ្ជីរឿងនៃកឋិនភេទនោះ ដូច្នេះ

[២៤៣]

និយាយអំពីពាក្យសួរថា បុគ្គលដូចម្តេច ដែលឈ្មោះថា បានក្រាលកឋិន និងមិនបានក្រាល១ កឋិនដែលភិក្ខុក្រាលឡើង និងមិនឡើង ដោយអាការដូចម្តេច១ ធម៌១៥ប្រការ១ ធម៌ដែលមាននិទាន មានហេតុ មានបច្ច័យ១ បុព្វករណៈ សង្គ្រោះដោយធម៌៧យ៉ាង១ មូលរបស់កឋិនជាដើម១ ប្រភេទរបស់បុគ្គលទាំង៨ គួរក្រាលកឋិន១ បុគ្គល៣ពួក១ ត្រូវដឹងការក្រាលកឋិនឡើង និងមិនឡើង៣យ៉ាង១ ត្រូវដឹងកិច្ចក្រាលកឋិន១ ភិក្ខុសំដែងបាតិមោក្ខ១ បលិពោធ១ កឋិនដោះ អាស្រ័យនឹងសង្ឃ ឬបុគ្គល១ កឋិនដោះខាងក្រៅ និងខាងក្នុងសីមា១ កឋិនដោះ មានការកើត និងរលត់ព្រមគ្នា ឬផ្សេងគ្នា១។

ចប់ បរិវារៈ។

# ឧបាលិបញ្ចកៈ

CS vin.pv.14 | ភាគ ទី១៣

### (ឧបាលិបញ្ចកំ)

## (អនិស្សិតវគ្គ ទី១)

CS vin.pv.14.01 | ភាគ ទី១៣

### (១. អនិស្សិតវគ្គោ)

[២៤៤] សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ លំដាប់នោះ ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ។ លុះព្រះឧបាលិដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន មិនត្រូវនៅដោយឥតនិស្ស័យ អស់១ជីវិតបាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ មិនត្រូវ

នៅដោយឥតនិស្ស័យ អស់១ជីវិតបានទេ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនស្គាល់ឧបោសថ១ មិនស្គាល់ឧបោសថកម្ម១ មិនចេះបាតិមោក្ខ១ មិនស្គាល់បាតិមោក្ខុទ្ទេស១ មានវស្សាថយពីប្រាំ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនៅដោយឥតនិស្ស័យដរាបដល់អស់ជីវិតបានឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ គួរនឹងនៅ ដោយឥតនិស្ស័យ អស់១ជីវិតបាន។ អង្គទាំង៥ តើដូចម្តេច។ គឺភិក្ខុស្គាល់ឧបោសថ១ ស្គាល់ឧបោសថកម្ម១ ចេះបាតិមោក្ខ១ ស្គាល់បាតិមោក្ខុទ្ទេស១ មានវស្សាគ្រប់៥ ឬជាង៥វស្សាឡើងទៅ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង គួរនៅដោយឥតនិស្ស័យ អស់១ជីវិតបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនគួរនឹងនៅ ដោយឥតនិស្ស័យ អស់១ជីវិតបានទេ។ អង្គទាំង៥ តើដូចម្តេច។ គឺភិក្ខុមិនស្គាល់បវារណា១ មិនស្គាល់បវារណាកម្ម១ មិនចេះបាតិមោក្ខ១ មិនស្គាល់បាតិមោក្ខុទ្ទេស១ មានវស្សាមិនគ្រប់ប្រាំ១។ ម្នាលឧបាលី ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួរនឹងនៅ ដោយឥតនិស្ស័យ អស់១ជីវិតបានឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ គួរនឹងនៅដោយឥតនិស្ស័យ អស់១ជីវិតបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុស្គាល់បវារណា១ ស្គាល់បវារណាកម្ម១ ចេះបាតិមោក្ខ១ ស្គាល់បាតិមោក្ខុទ្ទេស១ មានវស្សាគ្រប់៥ ឬលើសជាង៥វស្សាឡើងទៅ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង គួរនឹងនៅ ដោយឥតនិស្ស័យ អស់១ជីវិតបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដោយឡែកទៀត មិនគួរនឹងនៅ ដោយឥតនិស្ស័យ អស់១ជីវិតបានទេ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មានវស្សាថយពីប្រាំ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួរនឹងនៅ ដោយឥតនិស្ស័យ អស់១ជីវិតបានឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ គួរនឹងនៅដោយឥតនិស្ស័យ អស់១ជីវិតបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មានវស្សាគ្រប់៥ ឬលើសជាង៥វស្សាឡើងទៅ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង គួរនឹងនៅ ដោយឥតនិស្ស័យ អស់១ជីវិតបាន។

[២៤៥] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួនឡើយ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនអាចដើម្បីបម្រើដោយខ្លួនឯង ឬឲ្យគេបម្រើនូវអន្តេវាសិក និងសទ្ធិវិហារិក ដែលមានជម្ងឺ១ មិនអាចដើម្បីរម្ងាប់ដោយខ្លួនឯង ឬឲ្យគេជួយរម្ងាប់ នូវសេចក្តីអផ្សុក១ មិនអាចដើម្បីបន្ទោបង់ដោយខ្លួនឯង ឬឲ្យគេជួយបន្ទោបង់ នូវសេចក្តីសង្ស័យ ដែលកើតឡើងតាមធម្មតា១ ដើម្បីណែនាំក្នុងអភិធម្ម១ ដើម្បីណែនាំក្នុងអភិវិន័យ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួនឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវឲ្យឧបសម្បទា ត្រូវឲ្យនិស្ស័យ ត្រូវឲ្យសាមណេរបម្រើខ្លួនបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុអ្នកអាចដើម្បីបម្រើដោយខ្លួនឯង និងឲ្យគេបម្រើអន្តេវាសិក ឬសទ្ធិវិហារិក ដែលមានជម្ងឺ១ អាចនឹងរម្ងាប់ដោយខ្លួនឯង ឬប្រើគេឲ្យជួយរម្ងាប់ នូវសេចក្តីអផ្សុក១ អាចនឹងបន្ទោបង់ដោយខ្លួនឯង ឬឲ្យគេបន្ទោបង់ នូវសេចក្តីសង្ស័យ ដែលកើតឡើងតាមធម្មតា១ អាចដើម្បីណែនាំក្នុងអភិធម្ម១ ដើម្បីណែនាំក្នុងអភិវិន័យ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ នេះឯង ទើបត្រូវឲ្យឧបសម្បទា ត្រូវឲ្យនិស្ស័យ ត្រូវឲ្យសាមណេរបម្រើខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួនដែរ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនអាចដើម្បីនឹងបង្រៀនអន្តេវាសិក ឬសទ្ធិវិហារិក ក្នុងសិក្ខា គឺអភិសមាចារិកវត្ត១ មិនអាចដើម្បីណែនាំក្នុងសិក្ខា គឺអាទិព្រហ្មចរិយៈ១ មិនអាចណែនាំក្នុងអធិសីល១ មិនអាចណែនាំក្នុងអធិចិត្ត១ មិនអាចណែនាំក្នុងអធិប្បញ្ញា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួនឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវឲ្យឧបសម្បទា ត្រូវឲ្យនិស្ស័យ ត្រូវឲ្យសាមណេរបម្រើខ្លួន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុអាចដើម្បីបង្រៀនអន្តេវាសិក ឬសទ្ធិវិហារិក ក្នុងសិក្ខា គឺអភិសមាចារិកវត្ត១ អាចដើម្បីណែនាំក្នុងសិក្ខា គឺអាទិព្រហ្មចរិយៈ១ អាចដើម្បីណែនាំក្នុងអធិសីល១ អាចដើម្បីណែនាំក្នុងអធិចិត្ត១ អាចដើម្បីណែនាំក្នុងអធិប្បញ្ញា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវឲ្យឧបសម្បទា ឲ្យនិស្ស័យ ឲ្យសាមណេរបម្រើខ្លួនបាន។

[២៤៦] ព្រះឧបាលិក្រាលបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃត្រូវធ្វើកម្ម ដល់ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនខ្មាសបាប១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១ មានសេចក្តីយល់ខុស១ មានអាជីវវិបត្តិ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមានសីលវិបត្តិ ក្នុងអធិសីល១ មានអាចារវិបត្តិ ក្នុងអជ្ឈាចារៈ១ មានទិដ្ឋិវិបត្តិ ក្នុងអតិទិដ្ឋិ១ មានសេចក្តីយល់ខុស១ មានអាជីវវិបត្តិ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុប្រកបដោយល្បែង ប្រព្រឹត្តទៅតាមកាយ១ ប្រកបដោយល្បែង ប្រព្រឹត្តទៅតាមវាចា១ ប្រកបដោយល្បែង ប្រព្រឹត្តទៅតាមកាយ និងវាចា១ មានសេចក្តីយល់ខុស១ មានអាជីវវិបត្តិ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុប្រកបដោយអនាចារៈ ប្រព្រឹត្តទៅតាមកាយ១ ប្រកបដោយអនាចារៈ ប្រព្រឹត្តទៅតាមវាចា១ ប្រកបដោយអនាចារៈ ប្រព្រឹត្តទៅតាមកាយ និងវាចា១ មានគំនិតយល់ខុស១ មានអាជីវវិបត្តិ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុប្រកបដោយកិរិយាបៀតបៀន ដែលប្រព្រឹត្តទៅតាមកាយ១ ប្រកបដោយកិរិយាបៀតបៀន ដែលប្រព្រឹត្តទៅតាមវាចា១ ប្រកបដោយកិរិយាបៀតបៀន ដែលប្រព្រឹត្តទៅតាមកាយ និងវាចា១ មានគំនិតយល់ខុស១ មានអាជីវវិបត្តិ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុប្រកបដោយការចិញ្ចឹមជីវិតខុស ដោយកាយ១ ប្រកបដោយការចិញ្ចឹមជីវិតខុសដោយវាចា១ ប្រកបដោយការចិញ្ចឹមជីវិតខុស ដោយកាយ និងវាចា១ មានគំនិតយល់ខុស១ មានអាជីវវិបត្តិ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុត្រូវអាបត្តិហើយ សង្ឃបានធ្វើកម្មរួចហើយ នៅតែឲ្យឧបសម្បទា១ នៅតែឲ្យនិស្ស័យ១ ឲ្យសាមណេរបម្រើខ្លួន១ ត្រេកអរនឹងសេចក្តីសន្មតិ ឲ្យជាអ្នកប្រដៅភិក្ខុនី១ ទុកជាសង្ឃបានសន្មតហើយ ក៏នៅតែទៅប្រដៅភិក្ខុនី១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយ

អង្គ៥ដោយឡែកទៀត។ អង្គ៥ តើដូចម្តេច។ គឺសង្ឃបានធ្វើកម្ម ដោយអាបត្តិណា ភិក្ខុនោះ នៅតែត្រូវអាបត្តិនោះ១ ភិក្ខុត្រូវអាបត្តិឯទៀត ប្រហែលនឹងអាបត្តិនោះ១ ឬត្រូវអាបត្តិដែលអាក្រក់ជាងអាបត្តិមុននោះ១ ភិក្ខុតិះដៀលកម្ម១ តិះដៀលសង្ឃ ជាអ្នកធ្វើកម្ម១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥ដោយឡែកទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១ មានគំនិតយល់ខុស១ មាន អាជីវវិបត្តិ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។

ចប់ អនិស្សិតវគ្គ ទី១។

ឧទ្ទាន គឺបញ្ជីរឿង នៃអនិស្សិតវគ្គ នោះដូច្នេះ

[២៤៧]

និយាយអំពីភិក្ខុមិនស្គាល់ឧបោសថជាដើម១ មិនស្គាល់បវារណាជាដើម១ មិនស្គាល់អាបត្តិ១ ភិក្ខុមិនចេះបម្រើសិស្សឈឺ១ មិនចេះបង្រៀនសិស្ស ក្នុងអភិសមាចារិកវត្ត១ មិនខ្មាសបាប១ មិនចេះណែនាំក្នុងអធិសីល១ ប្រកបដោយល្បែង១ ប្រកបដោយអនាចារៈ១ ប្រកបដោយកិរិយាបៀតបៀន១ ប្រកបដោយការចិញ្ចឹមជីវិតខុស១ សង្ឃធ្វើកម្មដោយអាបត្តិណា ភិក្ខុនោះ នៅតែត្រូវអាបត្តិដដែលនោះ១ ភិក្ខុពោលតិះដៀលព្រះពុទ្ធ១ នេះជាវគ្គសង្គហៈទី១។

## (នប្បដិប្បស្សម្ភនវគ្គៈ ទី២)

CS vin.pv.14.02 | ភាគ ទី១៣

### (២. នប្បដិប្បស្សម្ភនវគ្គោ)

[២៤៨] ព្រះឧបាលិក្រាលបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃមិនត្រូវរម្ងាប់កម្មដល់ភិក្ខុ ដែលប្រកបដោយអង្គប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃមិនត្រូវរម្ងាប់កម្ម ដល់ភិក្ខុប្រកបដោយអង្គ៥។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុត្រូវអាបត្តិហើយ សង្ឃក៏បានធ្វើកម្មហើយ នៅតែឲ្យឧបសម្បទា១ នៅតែឲ្យនិស្ស័យ១ ឲ្យសាមណេរបម្រើខ្លួន១ ត្រេកអរនឹងសេចក្តីសន្មតិ ឲ្យជាអ្នកឲ្យឱវាទ ដល់ភិក្ខុនី១ ទុកជាសង្ឃសន្មតហើយ នៅតែទៅប្រដៅភិក្ខុនី១។ ម្នាលឧបាលិ សង្ឃមិនត្រូវរម្ងាប់កម្ម ដល់ភិក្ខុប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃមិនត្រូវរម្ងាប់កម្ម ដល់ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺសង្ឃបានធ្វើកម្មចំពោះអាបត្តិណា ភិក្ខុនោះ នៅតែត្រូវអាបត្តិនោះទៀត១ ត្រូវអាបត្តិឯទៀត ប្រហែលនឹងអាបត្តិនោះ១ ឬត្រូវអាបត្តិដែលអាក្រក់ជាងអាបត្តិនោះ១ តិះដៀលកម្ម១ តិះដៀលពួកភិក្ខុអ្នកធ្វើកម្ម១។ ម្នាលឧបាលិ សង្ឃមិនត្រូវរម្ងាប់កម្ម ដល់ភិក្ខុប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃមិនត្រូវរម្ងាប់កម្ម ដល់ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុពោលតិះដៀលព្រះពុទ្ធ១ ពោលតិះដៀលព្រះធម៌១ ពោលតិះដៀលព្រះសង្ឃ១ មានគំនិតយល់ខុស១ មានអាជីវវិបត្តិ១។ ម្នាលឧបាលិ សង្ឃមិនត្រូវរម្ងាប់កម្មដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃមិនត្រូវរម្ងាប់កម្ម ដល់ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនមានខ្មាសបាប១ ភិក្ខុល្ងង់១ មិនមែនជាបកតត្ត១ ជាអ្នកធ្វើនូវសេចក្តីញាំញី (អាបត្តិតូចធំ)១ មិនធ្វើឲ្យពេញលេញ ក្នុងវត្តទាំងឡាយ និងសិក្ខា១។ ម្នាលឧបាលិ សង្ឃមិនត្រូវរម្ងាប់កម្ម ដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។

[២៤៩] ព្រះឧបាលិក្រាលបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាអ្នកចូលទៅកាន់សង្គ្រាម កាលបើចូលទៅរកសង្ឃ ត្រូវតំកល់ធម៌ប៉ុន្មាន ទុកក្នុងសន្តាន សឹមចូលទៅរកសង្ឃ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុជាអ្នកចូលទៅកាន់សង្គ្រាម កាលបើចូលទៅរកសង្ឃ ត្រូវតំកល់ធម៌៥យ៉ាង ទុកក្នុងសន្តាន ហើយសឹមចូលទៅរកសង្ឃ។ ធម៌៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុជាអ្នកចូលទៅកាន់សង្គ្រាម កាលបើចូលទៅរកសង្ឃ ត្រូវមានចិត្តឱនលំទោន សឹមចូលទៅរកសង្ឃ គប្បីជាអ្នកមានចិត្តស្មើ ដោយសំពត់សម្រាប់ជូតធូលី ជាអ្នកឈ្លាសក្នុងអាសនៈ ឈ្លាសក្នុងការអង្គុយ១ មិនត្រូវចូលទៅច្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវឃាត់អាសនៈពួកភិក្ខុខ្ចី អង្គុយលើអាសនៈ តាមសមគួរ១ មិនត្រូវជាអ្នកនិយាយពាក្យផ្តេសផ្តាស មិនត្រូវនិយាយតិរច្ឆានកថា១ ត្រូវពោលធម៌ដោយខ្លួនឯង ឬអារាធនាអ្នកដទៃឲ្យពោលធម៌១ មិនត្រូវមើលងាយព្រះអរិយបុគ្គលដែលលោកគង់ស្ងៀម១ ម្នាលឧបាលិ បើសង្ឃធ្វើកម្មទាំងឡាយ ដែលសង្ឃគប្បីធ្វើដោយសេចក្តីព្រមព្រៀងគ្នា ម្នាលឧបាលិ បើមានភិក្ខុមិនគាប់ចិត្តនឹងកម្មនោះ ភិក្ខុនោះ ត្រូវធ្វើទិដ្ឋិឲ្យច្បាស់ប្រាកដ សឹមដំកល់សាមគ្គី។ សេចក្តីនោះ តើព្រោះហេតុអ្វី។ ព្រោះថា ភិក្ខុនោះ ត្រូវតំកល់សាមគ្គីដោយគិតថា អាត្មាអញ មិនត្រូវមានខ្លួនបែកអំពីសង្ឃទេ។ ម្នាលឧបាលិ ភិក្ខុជាអ្នកចូលទៅកាន់សង្គ្រាម កាលបើចូលទៅរកសង្ឃ ត្រូវតំកល់ធម៌ទាំង៥នេះ ក្នុងសន្តានសិន សឹមចូលទៅរកសង្ឃ។

[២៥០] ព្រះឧបាលិក្រាលបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន ពោលក្នុងកណ្តាលជំនុំសង្ឃ នាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ពោលក្នុងកណ្តាលជំនុំសង្ឃ នាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកនិយាយពាក្យប្រកបដោយលោភៈជាដើម១ ជាអ្នកពោលអាងអ្នកដទៃ១ ជាអ្នកមិនឈ្លាសក្នុងភាសា និងវិនិច្ឆ័យ១ ជាអ្នកមិនចោទភិក្ខុផងគ្នា ឲ្យសមគួរតាមធម៌ សមគួរតាមវិន័យ សមគួរតាមអាបត្តិ១ ជាអ្នកមិនកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង និយាយកណ្តាលជំនុំសង្ឃ តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ កាលនិយាយកណ្តាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកមិននិយាយពាក្យប្រកបដោយលោភៈជាដើម១ មិនពោលអាងអ្នកដទៃ១ ជាអ្នកឈ្លាសក្នុងភាសា និងវិនិច្ឆ័យ១ ជាអ្នកចោទភិក្ខុផងគ្នា ឲ្យ

សមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ ជាអ្នកកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត កាលនិយាយក្នុងជំនុំសង្ឃ ក៏តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាពេញចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកអួតអាង សរសើរលើកបុគ្គលដទៃ១ ជាអ្នកផ្ចាញ់ផ្ចាល់គេ១ ប្រកាន់យកហេតុដែលមិនមែនជានិយ្យានិកធម៌១ ឃាត់ហេតុដែលជានិយ្យានិកធម៌១ និយាយពាក្យច្រើនឥតប្រយោជន៍១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាពេញចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកមិនអួតអាង សរសើរលើកបុគ្គលដទៃ១ ជាអ្នកមិនផ្ចាញ់ផ្ចាល់គេ១ កាន់យកហេតុដែលជានិយ្យានិកធម៌១ ឃាត់ហេតុមិនមែនជានិយ្យានិកធម៌១ មិននិយាយពាក្យដែលឥតប្រយោជន៍ដោយច្រើន១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាពេញចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង។ អង្គទាំង៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកនិយាយសង្កត់សង្កិន (ព្រោះអាស្រ័យមានះ)១ មិនបានសូមឱកាសជាមុន ក៏ស្រាប់តែនិយាយ១ មិនចោទភិក្ខុដទៃឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ មិនកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ មិនព្យាករដោយសមគួរ តាមសេចក្តីយល់របស់ខ្លួន១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាពេញចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកពុំបាននិយាយសង្កត់សង្កិន (ព្រោះអាស្រ័យមានះ)១ បានសូមឱកាសជាមុន ទើបនិយាយ១ ចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ កាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ ព្យាករណ៍តាមសេចក្តីយល់របស់ខ្លួន១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង កាលនិយាយក្នុងកណ្តាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង។

[២៥១] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អានិសង្សនៃការរៀនវិន័យ មានប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ អានិសង្សនៃការរៀនវិន័យ មាន៥។ អានិសង្ស៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកចេះគ្រប់គ្រងរក្សាសីលក្ខន្ធ របស់ខ្លួនដោយប្រពៃ១ រមែងបានជាទីពឹងនៃពពួកជន ដែលមានសេចក្តីសង្ស័យ១ ជាអ្នកក្លៀវក្លា និយាយកណ្តាលជំនុំសង្ឃ១ ជាអ្នកសង្កត់សង្កិននូវពួកសត្រូវ ដោយសហធម៌បានដោយងាយ១ ជាអ្នកប្រតិបត្តិដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ១។ ម្នាលឧបាលិ អានិសង្សនៃការរៀនវិន័យ មាន៥នេះឯង។

ចប់ នប្បដិប្បស្សម្ភនវគ្គ ទី២។

ឧទ្ទាន គឺបញ្ជីរឿងនៃនប្បដិប្បស្សម្ភនវគ្គ ទី២ នោះដូច្នេះ

[២៥២]

និយាយអំពីភិក្ខុត្រូវអាបត្តិ១ សង្ឃធ្វើកម្មភិក្ខុនោះចំពោះអាបត្តិណា១ ភិក្ខុពោលតិះដៀលព្រះពុទ្ធជាដើម១ មិនខ្មាសបាប១ ចូលទៅកាន់សង្គ្រាម១ និយាយពាក្យប្រកបដោយលោភៈជាដើម១ អួតអាងសរសើរលើកបុគ្គលដទៃ១ ពោលពាក្យសង្កត់សង្កិន១ អានិសង្សនៃការរៀនវិន័យ១។

## (វោហារវគ្គ ទី៣)

CS vin.pv.14.03 | ភាគ ទី១៣

### (៣. វោហារវគ្គោ)

[២៥៣] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលមិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ។ អង្គ៥ តើដូចម្តេច។ គឺមិនស្គាល់អាបត្តិ១ មិនស្គាល់សមុដ្ឋាននៃអាបត្តិ១ មិនស្គាល់ប្រយោគនៃអាបត្តិ១ មិនស្គាល់ការរម្ងាប់អាបត្តិ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើប ត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុស្គាល់អាបត្តិ១ ស្គាល់សមុដ្ឋាននៃអាបត្តិ១ ស្គាល់ប្រយោគរបស់អាបត្តិ១ ស្គាល់ការរម្ងាប់អាបត្តិ១ ឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ។ អង្គ៥ តើដូចម្តេច។ ភិក្ខុមិនស្គាល់អធិករណ៍១ មិនស្គាល់សមុដ្ឋាននៃអធិករណ៍១ មិនស្គាល់ប្រយោគរបស់អធិករណ៍១ មិនស្គាល់ការរម្ងាប់អធិករណ៍១ មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុស្គាល់អធិករណ៍១ ស្គាល់សមុដ្ឋាននៃអធិករណ៍១ ស្គាល់ប្រយោគរបស់អធិករណ៍១ ស្គាល់ការរម្ងាប់អធិករណ៍១ ឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយ

ក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដោយឡែកទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកនិយាយសង្កត់សង្កិនគេ១ មិនសូមឱកាសជាមុន ស្រាប់តែនិយាយ១ មិនចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ មិនកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ មិនព្យាករតាមសេចក្តីយល់របស់ខ្លួន១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុជាអ្នកមិនពោលសង្កត់សង្កិនគេ១ បានសូមឱកាសជាមុនហើយ ទើបនិយាយ១ ចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ កាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ១ ជាអ្នកព្យាករតាមសេចក្តីយល់របស់ខ្លួន១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនស្គាល់អាបត្តិ និងអនាបត្តិ១ មិនស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ មិនស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មិនស្គាល់សប្បដិកម្មាបត្តិ[43] និងអប្បដិកម្មាបត្តិ[44] ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុស្គាល់អាបត្តិ និងអនាបត្តិ១ ស្គាល់លហុកាបត្តិ និងគរុកាបត្តិ១ ស្គាល់សាវសេសាបត្តិ និងអនវសេសាបត្តិ១ ស្គាល់ទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ ស្គាល់សប្បដិកម្មាបត្តិ និងអប្បដិកម្មាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនស្គាល់កម្ម (៧ប្រការ[45] មានតជ្ជនីយកម្មជាដើម)១ មិនស្គាល់ការធ្វើកម្ម១ មិនស្គាល់វត្ថុរបស់កម្ម១ មិនស្គាល់វត្តរបស់កម្ម១ មិនស្គាល់ការរម្ងាប់របស់កម្ម១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុស្គាល់កម្ម១ ស្គាល់ការធ្វើកម្ម១ ស្គាល់វត្ថុរបស់កម្ម១ ស្គាល់វត្តរបស់កម្ម១ ស្គាល់ការរម្ងាប់របស់កម្ម១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនស្គាល់វត្ថុ (នៃអាបត្តិទាំង៧)១ មិនស្គាល់និទាន គឺរឿងរ៉ាវដែលទ្រង់បញ្ញត្តសិក្ខាបទ១ មិនស្គាល់បញ្ញត្តិ១ មិនស្គាល់សេចក្តីខាងចុង ខាងដើមបទ[46] ១ មិនស្គាល់គន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុស្គាល់វត្ថុ១ ស្គាល់និទាន១ ស្គាល់បញ្ញត្តិ១ ស្គាល់សេចក្តីខាងចុង និងខាងដើមបទ១ ស្គាល់គន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងទៅខាងឆន្ទាគតិ១ លំអៀងទៅខាងទោសាគតិ១ លំអៀងទៅខាងមោហាគតិ១ លំអៀងទៅខាងភយាគតិ១ មិនខ្មាសបាប១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងទៅខាងឆន្ទាគតិ១ មិនលំអៀងទៅខាងទោសាគតិ១ មិនលំអៀងទៅខាងមោហាគតិ១ មិនលំអៀងទៅខាងភយាគតិ១ មានសេចក្តីខ្មាសបាប១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងទៅខាងឆន្ទាគតិ១ លំអៀងទៅខាងទោសាគតិ១ លំអៀងទៅខាងមោហាគតិ១ លំអៀងទៅខាងភយាគតិ១ មិនឈ្លាសក្នុងវិន័យ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងទៅខាងឆន្ទាគតិ១ មិនលំអៀងទៅខាងទោសាគតិ១ មិនលំអៀងទៅខាងមោហាគតិ១ មិនលំអៀងទៅខាងភយាគតិ១ ជាអ្នកឈ្លាសក្នុងវិន័យ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនស្គាល់ញត្តិ១ មិនស្គាល់ការធ្វើដោយញត្តិ១ មិនស្គាល់វិធីសូត្រដោយញត្តិ១ មិនស្គាល់សមថៈដោយញត្តិ១ មិនស្គាល់ការរម្ងាប់ដោយញត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុស្គាល់ញត្តិ១ ស្គាល់ការធ្វើដោយញត្តិ១ ស្គាល់វិធីសូត្រដោយញត្តិ១ ស្គាល់សមថៈដោយញត្តិ១ ស្គាល់ការរម្ងាប់ដោយញត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនចេះសុត្តៈ គឺឧភតោវិភង្គ១ មិនចេះសុត្តានុលោម គឺមហាបទេសទាំងបួន១ មិនចេះវិន័យ គឺខន្ធកៈ និងបរិវារៈ១ មិនចេះវិនយានុលោម គឺមហាបទេសទាំងបួន១ មិនឈ្លាសក្នុងហេតុដែលគួរ និងមិនគួរ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុចេះសុត្តៈ១ ចេះសុត្តានុលោម១ ចេះវិន័យ១ ចេះវិនយានុលោម១ ឈ្លាសក្នុងហេតុដែលគួរ និងមិនគួរ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃដែរ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនចេះធម៌១ មិនចេះធម្មានុលោម គឺមហាបទេស ប៉ែកខាងព្រះសូត្រ១ មិនចេះវិន័យ១ មិនចេះវិនយានុលោម១ មិនឈ្លាសក្នុងពាក្យខាងដើម នឹងពាក្យខាងចុង១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុចេះធម៌១ ចេះធម្មានុលោម១ ចេះវិន័យ១ ចេះវិនយានុលោម១ ឈ្លាសក្នុងពាក្យខាងដើម នឹងពាក្យខាងចុង១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃបាន។

ចប់ វោហារវគ្គ ទី៣។

ឧទ្ទាន គឺបញ្ជីរឿងនៃវោហារវគ្គទី៣ នោះដូច្នេះ

[២៥៤]

និយាយអំពីភិក្ខុមិនស្គាល់អាបត្តិ១ មិនស្គាល់អធិករណ៍១ និយាយសង្កត់សង្កិនគេ១ ស្គាល់អាបត្តិ១ មិនស្គាល់កម្ម១ មិនស្គាល់វត្ថុ១ មិនខ្មាសបាប១ មិនឈ្លាស១ មិនដឹងញត្តិ១ មិនចេះសុត្តៈ១ មិនចេះធម៌១ (ទាំងនេះ) សង្គ្រោះដោយវោហារវគ្គទី៣។

## (ទិដ្ឋាវិកម្មវគ្គ ទី៤)

CS vin.pv.14.04 | ភាគ ទី១៣

### (៤. ទិដ្ឋាវិកម្មវគ្គោ)

[២៥៥] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការប្រាប់សេចក្តីយល់ឃើញ (ការសំដែងអាបត្តិ) មិនប្រកបដោយធម៌មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញមិនប្រកបដោយធម៌នេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺភិក្ខុប្រាប់សេចក្តីយល់ឃើញ ដោយមិនមានអាបត្តិ១ ប្រាប់សេចក្តីយល់ឃើញ ដោយអាបត្តិ មិនមែនជាទេសនាគាមិនី១ ប្រាប់សេចក្តីយល់ឃើញដោយអាបត្តិ ដែលសំដែងហើយ១ ប្រាប់សេចក្តីយល់ឃើញជាមួយនឹងភិក្ខុ៤រូប ឬ៥រូប[47] ១ ប្រាប់សេចក្តីយល់ឃើញដោយគិតតែក្នុងចិត្ត (សំដែងអាបត្តិដោយមិនបញ្ចេញវចីភេទ)១។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញមិនប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញប្រកបដោយធម៌នេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺភិក្ខុប្រាប់សេចក្តីយល់ឃើញ ដោយមានអាបត្តិ១ ប្រាប់សេចក្តីយល់ឃើញ ដោយអាបត្តិ ជាទេសនាគាមិនី១ ប្រាប់សេចក្តីយល់ឃើញដោយអាបត្តិ ដែលមិនទាន់សំដែង១ ប្រាប់សេចក្តីយល់ឃើញមិនមែនជាមួយនឹងភិក្ខុ៤រូប ឬ៥រូប១ ប្រាប់សេចក្តីយល់ឃើញដោយមិនបានគិតតែក្នុងចិត្ត១។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញ មិនប្រកបដោយធម៌ មាន៥យ៉ាងដទៃទៀត។ ៥យ៉ាង គឺអ្វីខ្លះ។ គឺភិក្ខុប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុមានសំវាសផ្សេងគ្នា១ ប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុដែលឋិតនៅ ក្នុងសីមាផ្សេងគ្នា[48] ១ ប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុមិនមែនជាបកតត្ត១ ប្រាប់សេចក្តីយល់ឃើញជាមួយនឹងភិក្ខុ៤រូប ឬ៥រូប១ ប្រាប់សេចក្តីយល់ឃើញដោយគិតតែក្នុងចិត្ត១។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញ មិនប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញ ប្រកបដោយធម៌នេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺភិក្ខុប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុមានសំវាសស្មើគ្នា១ ប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុដែលឋិតនៅ ក្នុងសីមាជាមួយគ្នា១ ប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុជាបកតត្ត១ ប្រាប់សេចក្តីយល់ឃើញ មិនមែនជាមួយនឹងភិក្ខុ៤រូប ឬ៥រូប១ ប្រាប់សេចក្តីយល់ឃើញដោយមិនគិតតែក្នុងចិត្ត១។ ម្នាលឧបាលិ ការប្រាប់សេចក្តីយល់ឃើញ ប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។

[២៥៦] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការទទួលប្រគេន មិនប្រកបដោយធម៌ មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ការទទួលប្រគេន មិនប្រកបដោយធម៌នេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺគេប្រគេនវត្ថុដោយកាយ ភិក្ខុមិនបានទទួលដោយកាយ១ គេប្រគេនវត្ថុដោយកាយ ភិក្ខុមិនបានទទួលដោយវត្ថុជាប់នឹងកាយ១ គេប្រគេនដោយវត្ថុជាប់នឹងកាយ ភិក្ខុមិនបានទទួលដោយកាយ១ គេប្រគេនវត្ថុដោយវត្ថុជាប់នឹងកាយ ភិក្ខុមិនបានទទួលដោយវត្ថុជាប់នឹងកាយ១ គេប្រគេនវត្ថុដោយបោះមកឲ្យ ភិក្ខុមិនបានទទួលដោយកាយ ឬដោយវត្ថុជាប់នឹងកាយ១។ ម្នាលឧបាលិ ការទទួលប្រគេន មិនប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។ ម្នាលឧបាលិ ការទទួលប្រគេន ប្រកបដោយធម៌នេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺគេប្រគេនវត្ថុដោយកាយ ភិក្ខុបានទទួលដោយកាយ១ គេប្រគេនវត្ថុដោយកាយ ភិក្ខុបានទទួលដោយវត្ថុជាប់នឹងកាយ១ គេប្រគេនវត្ថុដោយវត្ថុជាប់នឹងកាយ ភិក្ខុបានទទួលដោយកាយ១ គេប្រគេនវត្ថុដោយវត្ថុជាប់នឹងកាយ ភិក្ខុបានទទួលដោយវត្ថុជាប់នឹងកាយ១ គេប្រគេនវត្ថុដោយបោះមកឲ្យ ភិក្ខុបានទទួលដោយកាយ ឬដោយវត្ថុជាប់នឹងកាយ១។ ម្នាលឧបាលិ ការទទួលប្រគេន ប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។

[២៥៧] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អនតិរិត្តភោជន (ភោជនដែលភិក្ខុមិនបានធ្វើវិនយកម្ម) មានប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ អនតិរិត្តភោជននេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺវត្ថុដែលមិនគួរធ្វើវិនយកម្ម១ វត្ថុដែលភិក្ខុមិនបានទទួលប្រគេនយកទៅធ្វើវិនយកម្ម១ វត្ថុដែលភិក្ខុដទៃ មិនបានលើកឡើងធ្វើវិនយកម្ម១ វត្ថុដែលភិក្ខុមិនបានឋិតនៅក្នុងហត្ថបាស ធ្វើវិនយកម្ម១ វត្ថុដែលភិក្ខុមិនបាននិយាយថា របស់ទាំងអស់នេះគួរ១។ ម្នាលឧបាលិ អនតិរិត្តភោជននេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺវត្ថុដែលគួរធ្វើវិនយកម្ម១ វត្ថុដែលភិក្ខុបានទទួលប្រគេនយកទៅធ្វើវិនយកម្ម១ វត្ថុដែលភិក្ខុបានលើកឡើងធ្វើវិនយកម្ម១ វត្ថុដែលភិក្ខុឋិតនៅក្នុងហត្ថបាស ធ្វើវិនយកម្ម១ វត្ថុដែលភិក្ខុនិយាយថា របស់ទាំងអស់នេះគួរ១។ ម្នាលឧបាលិ អនតិរិត្តភោជន មាន៥យ៉ាងនេះឯង។

[២៥៨] ព្រះឧបាលិទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការហាមភោជន ប្រាកដដោយអាការប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ការហាមភោជន ប្រាកដដោយអាការ៥យ៉ាង។ អាការ៥យ៉ាង គឺអ្វីខ្លះ។ គឺការកំពុងឆាន់ប្រាកដ១ ភោជនប្រាកដ១ បុគ្គលឋិតនៅក្នុងហត្ថបាស១ បង្អោនមកប្រគេន១ ការហាមឃាត់ប្រាកដ១។ ម្នាលឧបាលិ ការហាមភោជនប្រាកដដោយអាការ៥យ៉ាងនេះឯង។

[២៥៩] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បដិញ្ញាតករណៈ (ការកាត់អាបត្តិតាមប្តេជ្ញា) មិនប្រកបដោយធម៌ មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ បដិញ្ញាតករណៈ មិនប្រកបដោយធម៌នេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកត្រូវបារាជិក ហើយគេចោទដោយបារាជិក តែប្តេជ្ញាថា ត្រូវសង្ឃាទិសេសទៅវិញ សង្ឃក៏កាត់សេចក្តីភិក្ខុនោះ ដោយសង្ឃាទិសេស (នេះ) ជាបដិញ្ញាតករណៈ មិនប្រកបដោយធម៌ ភិក្ខុជាអ្នកត្រូវបារាជិក ហើយគេចោទដោយអាបត្តិបារាជិក តែប្តេជ្ញាថា ត្រូវបាចិត្តិយៈ ឬបាដិទេសនីយៈ ឬទុក្កដទៅវិញ សង្ឃកាត់សេចក្តីភិក្ខុនោះ ដោយទុក្កដ (នេះ) ជាបដិញ្ញាតករណៈ មិនប្រកបដោយធម៌ ភិក្ខុជាអ្នកត្រូវអាបត្តិសង្ឃាទិសេស ឬបាចិត្តិយៈ ឬ

បាដិទេសនីយៈ ឬទុក្កដ ហើយគេចោទដោយទុក្កដ តែប្តេជ្ញាថា ត្រូវបារាជិកទៅវិញ សង្ឃបានកាត់សេចក្តីភិក្ខុនោះ ដោយបារាជិក (នេះ) ជាបដិញ្ញាតករណៈ មិនប្រកបដោយធម៌ ភិក្ខុជាអ្នកត្រូវទុក្កដ ហើយគេចោទដោយទុក្កដ តែប្តេជ្ញាថា ត្រូវសង្ឃាទិសេស ឬបាចិត្តិយៈ ឬបាដិទេសនីយៈទៅវិញ សង្ឃបានកាត់សេចក្តីភិក្ខុនោះ ដោយបាដិទេសនីយៈ (នេះ) ជាបដិញ្ញាតករណៈ មិនប្រកបដោយធម៌។ ម្នាលឧបាលិ បដិញ្ញាតករណៈ មិនប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។ ម្នាលឧបាលិ បដិញ្ញាតករណៈ ប្រកបដោយធម៌នេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកត្រូវបារាជិក ហើយគេចោទដោយបារាជិក ក៏ប្តេជ្ញាថា ត្រូវបារាជិកមែន សង្ឃបានកាត់សេចក្តីភិក្ខុនោះ ដោយបារាជិក (នេះ) ជាបដិញ្ញាតករណៈ ប្រកបដោយធម៌ ភិក្ខុជាអ្នកត្រូវសង្ឃាទិសេស ឬបាចិត្តិយៈ ឬបាដិទេសនីយៈ ឬទុក្កដ ហើយគេចោទដោយទុក្កដ ក៏ប្តេជ្ញាថា ត្រូវទុក្កដមែន សង្ឃក៏បានកាត់សេចក្តីភិក្ខុនោះ ដោយទុក្កដ (នេះ) ជាបដិញ្ញាតករណៈ ប្រកបដោយធម៌។ ម្នាលឧបាលិ បដិញ្ញាតករណៈ ប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។

[២៦០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន កាលបើសូមឱកាសកម្ម (ដើម្បីចោទ) មិនគួរភិក្ខុដទៃបើកឱកាសកម្មឲ្យ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ កាលបើសូមឱកាសកម្ម មិនគួរភិក្ខុដទៃបើកឱកាសកម្មឲ្យទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនមានសេចក្តីខ្មាសបាប១ ជាភិក្ខុល្ងង់១ ជាភិក្ខុមិនមែនជាបកតត្ត១ ជាភិក្ខុនិយាយដោយប្រាថ្នាដើម្បីឲ្យភិក្ខុដទៃឃ្លាត (ចាកសាសនា)១ មិនប្រាថ្នានឹងចេញចាកអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង កាលបើសូមឱកាសកម្ម មិនគួរភិក្ខុដទៃបើកឱកាសកម្មឲ្យទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ កាលបើសូមឱកាសកម្ម ទើបគួរភិក្ខុដទៃបើកឱកាសកម្មឲ្យ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមានសេចក្តីខ្មាសបាប១ ជាបណ្ឌិត១ ជាភិក្ខុបកតត្ត១ ជាភិក្ខុនិយាយដោយប្រាថ្នាឲ្យភិក្ខុដទៃចេញចាកអាបត្តិ១ មិនប្រាថ្នាឲ្យភិក្ខុដទៃឃ្លាត (ចាកសាសនា)១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង កាលបើសូមឱកាសកម្ម ទើបគួរភិក្ខុដទៃបើកឱកាសកម្មឲ្យបាន។

[២៦១] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលភិក្ខុដទៃ មិនគួរសាកច្ឆាវិន័យជាមួយផង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ភិក្ខុដទៃមិនគួរសាកច្ឆាវិន័យជាមួយផងទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងវត្ថុ១ មិនដឹងនិទាន១ មិនដឹងបញ្ញត្តិ១ មិនដឹងបទបាលីក្រោយមុន១ មិនដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួរភិក្ខុដទៃសាកច្ឆាជាមួយផងទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរភិក្ខុដទៃសាកច្ឆាវិន័យជាមួយផងបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងវត្ថុ១ ដឹងនិទាន១ ដឹងបញ្ញត្តិ១ ដឹងបទបាលីក្រោយមុន១ ដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង គួរភិក្ខុដទៃសាកច្ឆាវិន័យជាមួយផងបាន។

[២៦២] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការសួរប្រស្នា មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ការសួរប្រស្នានេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺបុគ្គលសួរប្រស្នា ដោយសេចក្តីល្ងង់វង្វេង១ បុគ្គលមានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ សួរប្រស្នា១ បុគ្គលសួរប្រស្នាដោយសេចក្តីមើលងាយគេ១ បុគ្គលសួរប្រស្នាដោយសេចក្តីចង់ដឹងច្បាស់១ បុគ្គលសួរប្រស្នាដោយគិតថា បើអាត្មាអញសួរប្រស្នាទៅហើយ គេអាចនឹងដោះស្រាយឲ្យច្បាស់លាស់បាន នេះក៏ជាការស្រួល បើអាត្មាអញ សួរប្រស្នាទៅហើយ គេមិនអាចនឹងដោះស្រាយឲ្យច្បាស់លាស់បានទេ អាត្មាអញ នឹងដោះស្រាយឲ្យច្បាស់លាស់ ដល់បុគ្គលនោះវិញ១។ ម្នាលឧបាលិ ការសួរប្រស្នា មាន៥យ៉ាងនេះឯង។ ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការប្រាប់អរហត្តផល មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ការប្រាប់អរហត្តផលនេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺភិក្ខុប្រាប់អរហត្តផល ព្រោះសេចក្តីល្ងង់វង្វេង១ ភិក្ខុមានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ប្រាប់អរហត្តផល១ ភិក្ខុប្រាប់អរហត្តផល ដោយឆ្កួតអណ្តែតអណ្តូងចិត្ត១ ភិក្ខុប្រាប់អរហត្តផល ដោយសេចក្តីស្មានខុស១ ភិក្ខុប្រាប់អរហត្តផលដែលពិតត្រង់១។ ម្នាលឧបាលិ ការប្រាប់អរហត្តផល មាន៥យ៉ាងនេះឯង។

[២៦៣] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន វិសុទ្ធិ មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ វិសុទ្ធិនេះ មាន៥យ៉ាង។ វិសុទ្ធិ៥យ៉ាង គឺអ្វីខ្លះ។ គឺភិក្ខុត្រូវសំដែងនូវនិទាន ហើយសូត្រនូវឧទ្ទេសដ៏សេស ដោយសុតបទ នេះជាវិសុទ្ធិទី១។ ភិក្ខុសំដែងនូវនិទាន ហើយត្រូវសំដែងបារាជិកទាំង៤ ហើយសូត្រនូវឧទ្ទេសដ៏សេស ដោយសុតបទ នេះជាវិសុទ្ធិទី២។ ភិក្ខុសំដែងនូវនិទាន ហើយសំដែងនូវបារាជិកទាំង៤ សំដែងនូវសង្ឃាទិសេសទាំង១៣ ហើយសូត្រនូវឧទ្ទេសដ៏សេស ដោយសុតបទ នេះជាវិសុទ្ធិទី៣។ ភិក្ខុសំដែងនូវនិទាន សំដែងនូវបារាជិកទាំង៤ សំដែងនូវសង្ឃាទិសេសទាំង១៣ សំដែងនូវអនិយតទាំង២ ហើយសូត្រនូវឧទ្ទេសដ៏សេស ដោយសុតបទ នេះជាវិសុទ្ធិទី៤។ វិសុទ្ធិទី៥ ភិក្ខុត្រូវសំដែងដោយពិស្តារ។ ម្នាលឧបាលិ វិសុទ្ធិ មាន៥យ៉ាងនេះឯង។

[២៦៤] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភោជនមានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភោជននេះ មាន៥យ៉ាង។ ភោជន៥យ៉ាង គឺអ្វីខ្លះ។ គឺបាយ១ នំស្រស់១ នំក្រៀម១ ត្រី១ សាច់១។ ម្នាលឧបាលិ ភោជនមាន៥យ៉ាងនេះឯង។

ចប់ ទិដ្ឋាវិកម្មវគ្គ ទី៤។

ឧទ្ទាន គឺបញ្ជីរឿងនៃទិដ្ឋាវិកម្មវគ្គ នោះដូច្នេះ

[២៦៥]

និយាយអំពីសេចក្តីយល់ឃើញ (សំដែងអាបត្តិ)១ សេចក្តីយល់ឃើញដទៃទៀត១ ទទួលប្រគេន១ អតិរិត្តភោជន១ ការហាមភោជន១ កាត់អាបត្តិតាមប្តេជ្ញា១ ការសូមឱកាស១ សាកច្ឆាវិន័យ១ សួរប្រស្នា១ ប្រាប់អរហត្តផល១ វិសុទ្ធិ១ ភោជន១។

## (អត្តាទានវគ្គ ទី៥)

## (៥. អត្តាទានវគ្គោ)

[២៦៦] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ប៉ុន្មានយ៉ាង ទុកក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌៥យ៉ាង ទុកក្នុងខ្លួន ហើយសឹមចោទភិក្ខុដទៃ។ ធម៌៥យ៉ាង គឺអ្វីខ្លះ។ ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញ ជាអ្នកមានកាយសមាចារបរិសុទ្ធហើយឬ អាត្មាអញ ប្រកបដោយកាយសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានហេតុគួរឲ្យគេចាប់ថ្នាក់បាន ធម៌នុ៎ះ មានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ។ ម្នាលឧបាលិ បើភិក្ខុមិនមានកាយសមាចារបរិសុទ្ធ មិនប្រកបដោយកាយសមាចារ មិនធ្លុះធ្លាយ មិនប្រកបដោយកាយសមាចារ ដែលមិនមានហេតុគួរឲ្យគេចាប់ថ្នាក់បានទេ គង់មានអ្នកផង និយាយដាស់តឿនភិក្ខុនោះបានថា នែលោកមានអាយុ ចូរលោកសិក្សាកាយកម្មសិន រមែងមានអ្នកផងនិយាយដាស់តឿន ដល់ភិក្ខុនោះដូច្នេះ១។ ម្នាលឧបាលិ អង្គដទៃទៀត គឺភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញ ជាអ្នកមានវចីសមាចារបរិសុទ្ធហើយឬ អាត្មាអញ ប្រកបដោយវចីសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានហេតុគួរឲ្យគេចាប់ថ្នាក់បាន ធម៌នុ៎ះ មានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ។ ម្នាលឧបាលិ បើភិក្ខុមិនមានវចីសមាចារបរិសុទ្ធ មិនប្រកបដោយវចីសមាចារបរិសុទ្ធ មិនប្រកបដោយវចីសមាចារ មិនធ្លុះធ្លាយ មិនប្រកបដោយវចីសមាចារ មិនមានហេតុគួរឲ្យគេចាប់ថ្នាក់បាន គង់មានអ្នកផងនិយាយដាស់តឿនភិក្ខុនោះថា លោកមានអាយុ ចូរលោកសិក្សាវចីកម្មសិន រមែងមានអ្នកផងនិយាយដាស់តឿន ដល់ភិក្ខុនោះដូច្នេះ១។ ម្នាលឧបាលិ អង្គដទៃទៀត គឺភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា ចិត្តរបស់អាត្មាអញ ប្រកបដោយមេត្តាតម្កល់ចំពោះ មិនមានគំនុំក្នុងពួកសព្រហ្មចារីបុគ្គល ធម៌នុ៎ះ មានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ។ ម្នាលឧបាលិ បើចិត្តប្រកបដោយមេត្តាតម្កល់ចំពោះ ជាចិត្តមិនមានគំនុំ ក្នុងពួកសព្រហ្មចារីបុគ្គល មិនមានដល់ភិក្ខុនោះទេ គង់មានអ្នកផងនិយាយដាស់តឿនភិក្ខុនោះថា នែលោកមានអាយុ ចូរលោកតាំងមេត្តាចិត្ត ក្នុងពួកសព្រហ្មចារីបុគ្គលសិន រមែងមានអ្នកផងនិយាយដាស់តឿន ដល់ភិក្ខុនោះដូច្នេះ១។ ម្នាលឧបាលិ អង្គដទៃទៀត គឺភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញ ជាពហុស្សូត ជាអ្នកទ្រទ្រង់ពុទ្ធវចនៈ ជាអ្នកសន្សំពុទ្ធវចនៈហើយឬ ធម៌ទាំងឡាយណា មានពីរោះដើមបទ ពីរោះកណ្តាលបទ ពីរោះចុងបទ ប្រកាសព្រហ្មចរិយៈដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ទាំងអត្ថ ទាំងព្យញ្ជនៈ ធម៌ទាំងឡាយ មានសភាពដូច្នោះ អាត្មាអញ បានចេះចាំច្រើន បានទ្រទ្រង់ចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ យល់ធ្លុះធ្លាយដោយទិដ្ឋិ គឺបញ្ញា ធម៌នុ៎ះ មានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ។ ម្នាលឧបាលិ បើភិក្ខុមិនមែនជាពហុស្សូត អ្នកទ្រទ្រង់ពុទ្ធវចនៈ អ្នកសន្សំពុទ្ធវចនៈទេ ធម៌ទាំងឡាយណា ដែលមានពីរោះដើមបទ ពីរោះកណ្តាលបទ ពីរោះចុងបទ ប្រកាសព្រហ្មចរិយៈដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ទាំងអត្ថ ទាំងព្យញ្ជនៈ ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះ មិនចេះចាំច្រើន មិនទ្រទ្រង់ មិនចាំស្ទាត់រត់មាត់ មិនចូលចិត្តច្បាស់លាស់ មិនយល់ធ្លុះធ្លាយដោយទិដ្ឋិ គឺបញ្ញាទេ គង់មានអ្នកផងនិយាយដាស់តឿនភិក្ខុនោះថា នែលោកមានអាយុ ចូរលោករៀនគម្ពីរនិកាយសិន រមែងមានអ្នកផងនិយាយដាស់តឿន ដល់ភិក្ខុនោះដូច្នេះ១។ ម្នាលឧបាលិ អង្គដទៃទៀត គឺភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា បាតិមោក្ខទាំងពីរ អាត្មាអញ បានចេះចាំដោយពិស្តារល្អ បានចែកបទភាជនៈដោយប្រពៃ បានចាំស្ទាត់រត់មាត់ដោយប្រពៃ បានកាត់សេចក្តីដោយល្អ តាមសុត្តៈ គឺខន្ធកៈ និងបរិវារៈ តាមអនុព្យញ្ជនៈ គឺអក្ខរៈ និងបទ ធម៌នុ៎ះ មានដល់អាត្មាអញដែរឬ ឬក៏មិនមានទេ។ ម្នាលឧបាលិ បើបាតិមោក្ខទាំងពីរ ភិក្ខុមិនបានចេះចាំដោយពិស្តារ មិនបានចែកបទភាជនៈដោយល្អ មិនបានចាំស្ទាត់រត់មាត់ដោយល្អ មិនបានកាត់សេចក្តីដោយល្អ តាមសុត្តៈ និងអនុព្យញ្ជនៈទេ កាលបើមានគេសួរថា នែលោកមានអាយុ ចុះពាក្យនេះ ព្រះមានព្រះភាគ ទ្រង់សំដែងក្នុងទីណា ភិក្ខុនោះឆ្លើយមិនរួច គង់មានអ្នកផងនិយាយដាស់តឿនភិក្ខុនោះថា នែលោកមានអាយុ ចូរលោករៀនវិន័យសិន រមែងមានអ្នកផងនិយាយដាស់តឿន ដល់ភិក្ខុនោះដូច្នេះ១។ ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌៥យ៉ាងនេះ ទុកក្នុងខ្លួនហើយ ទើបចោទភិក្ខុដទៃបាន។

[២៦៧] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌ប៉ុន្មានយ៉ាង ទុកក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌៥យ៉ាង ទុកក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន។ ធម៌៥ គឺអ្វីខ្លះ។ គឺភិក្ខុត្រូវតាំងទុកដូច្នេះថា អាត្មាអញ នឹងនិយាយក្នុងកាលគួរ មិននិយាយក្នុងកាលមិនគួរ១ អាត្មាអញ នឹងនិយាយពាក្យពិត មិននិយាយពាក្យមិនពិត១ អាត្មាអញ នឹងនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យទ្រគោះ១ អាត្មាអញ នឹងនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យឥតប្រយោជន៍១ អាត្មាអញ នឹងមានចិត្តប្រកបដោយមេត្តា ទើបនិយាយ មិននិយាយទៅទាំងចិត្តប្រកបដោយសេចក្តីប្រទូស្ត១។ ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌៥យ៉ាងនេះឯង ទុកក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន។

[២៦៨] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌ប៉ុន្មានយ៉ាងក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌៥យ៉ាង ក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន។ ធម៌៥យ៉ាង គឺអ្វីខ្លះ។ គឺសេចក្តីករុណា១ ការស្វែងរកប្រយោជន៍១ សេចក្តីអនុគ្រោះ១ ការចេញចាកអាបត្តិ១ សេចក្តីប៉ុនប៉ងក្នុងវិន័យ១។ ម្នាលឧបាលិ ភិក្ខុអ្នកចោទ ប៉ងនឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌៥យ៉ាងនេះឯង ទុកក្នុងខ្លួន ហើយទើបចោទភិក្ខុដទៃបាន។

[២៦៩] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន កាលបើសូមឱកាសកម្ម ក៏មិនគួរភិក្ខុដទៃបើកឱកាសកម្មឲ្យ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ កាលបើសូមឱកាសកម្ម ក៏មិនគួរភិក្ខុដទៃបើកឱកាសកម្មឲ្យ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមានកាយសមាចារមិនបរិសុទ្ធ១ មានវចីសមាចារមិនបរិសុទ្ធ១ មានអាជីវៈមិនបរិសុទ្ធ១ ជាភិក្ខុល្ងង់ មិនឈ្លាសវៃ១ កាលបើគេសាកសួរ ក៏មិនអាចនឹងឲ្យគេសាកសួរ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង កាលបើសូមឱកាសកម្ម ក៏មិនគួរភិក្ខុដទៃបើកឱកាសកម្មឲ្យ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ កាលបើសូមឱកាសកម្ម ក៏គួរភិក្ខុដទៃបើកឱកាសកម្មឲ្យបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមានកាយសមាចារបរិសុទ្ធ១ មានវចីសមាចារបរិសុទ្ធ១ មានអាជីវៈបរិសុទ្ធ១ ជាបណ្ឌិត ឈ្លាសវៃ១ កាលបើគេសាកសួរ ក៏អាចឲ្យគេសាកសួរបាន១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង កាលបើសូមឱកាសកម្ម ក៏គួរភិក្ខុដទៃបើកឱកាសកម្មឲ្យបាន។

[២៧០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រាថ្នានឹងកាន់យកនូវអត្តាទាន[49] ត្រូវកាន់យកនូវអត្តាទាន ដែលប្រកបដោយអង្គប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រាថ្នានឹងកាន់យកនូវអត្តាទាន ត្រូវកាន់យកនូវអត្តាទាន ដែលប្រកបដោយអង្គ៥។ អង្គ៥ គឺអ្វីខ្លះ។ ម្នាលឧបាលិ ភិក្ខុប្រាថ្នានឹងកាន់យកនូវអត្តាទាន ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញ ប្រាថ្នានឹងកាន់យកនូវអត្តាទាននេះ ក្នុងកាលណា កាលនោះ ជាកាលគួរនឹងកាន់យកនូវអត្តាទាននេះ ឬមិនគួរទេ។ ម្នាលឧបាលិ បើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា កាលនេះ ជាកាលមិនគួរ នឹងកាន់យកនូវអត្តាទាននេះ កាលនេះ មិនមែនជាកាលគួរទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា កាលនេះជាកាលគួរនឹងកាន់យកនូវអត្តាទាននេះ កាលនេះ មិនមែនជាកាលមិនគួរទេ ម្នាលឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា អាត្មាអញ ប្រាថ្នានឹងកាន់យកនូវអត្តាទានណា អត្តាទាននេះ ជារឿងពិតមែន ឬមិនពិតទេ។ ម្នាលឧបាលិ បើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា អត្តាទាននេះ ជារឿងមិនពិត មិនមែនជារឿងពិតទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា អត្តាទាននេះ ជារឿងពិត មិនមែនជារឿងមិនពិតទេ ម្នាលឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា អាត្មាអញ ប្រាថ្នានឹងកាន់យកនូវអត្តាទានណា អត្តាទាននេះ ប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ទេ។ ម្នាលឧបាលិ បើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា អត្តាទាននេះ ឥតប្រយោជន៍ អត្តាទាននេះ មិនមែនប្រកបដោយប្រយោជន៍ទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា អត្តាទាននេះ ប្រកបដោយប្រយោជន៍ អត្តាទាននេះ មិនមែនឥតប្រយោជន៍ទេ ម្នាលឧបាលិ ភិក្ខុនោះ ត្រូវពិចារណាតទៅទៀតថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះ នឹងបានភិក្ខុដែលជាសន្ទិដ្ឋមិត្រ (មិត្រគ្រាន់តែធ្លាប់ឃើញគ្នា) និងជាសម្ភត្តមិត្រ (មិត្រស្និទ្ធស្នាលគ្នាមាំមួន) មកជាបក្ខពួក តាមធម៌ តាមវិន័យ ឬមិនបានទេ។ ម្នាលឧបាលិ បើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះ មុខជានឹងមិនបានភិក្ខុ ដែលជាសន្ទិដ្ឋមិត្រ និងជាសម្ភត្តមិត្រ មកជាបក្ខពួក តាមធម៌ តាមវិន័យទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណា ហើយដឹងយ៉ាងនេះថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះ មុខជានឹងបានភិក្ខុ ជាសន្ទិដ្ឋមិត្រ និងជាសម្ភត្តមិត្រ មកជាបក្ខពួក តាមធម៌ តាមវិន័យ ម្នាលឧបាលិ ភិក្ខុនោះ ត្រូវពិចារណាតទៅទៀតថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះ ការបង្កហេតុ ជម្លោះ ទាស់ទែង វិវាទ ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់នៃសង្ឃ អំពើផ្សេងៗរបស់សង្ឃ មានអត្តាទាននេះជាហេតុ នឹងមានដល់សង្ឃ ឬមិនមានទេ។ ម្នាលឧបាលិ បើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះ ការបង្កហេតុ ជម្លោះ ទាស់ទែង វិវាទ ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់នៃសង្ឃ អំពើផ្សេងៗនៃសង្ឃ មានអត្តាទាននោះជាហេតុ នឹងមានដល់សង្ឃមិនខាន ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះទេ។ ម្នាលឧបាលិ ម្យ៉ាងទៀត បើភិក្ខុពិចារណាហើយ ដឹងយ៉ាងនេះថា កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះ ការបង្កហេតុ ជម្លោះ ទាស់ទែង វិវាទ ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់នៃសង្ឃ អំពើផ្សេងៗនៃសង្ឃ មានអត្តាទាននោះជាហេតុ នឹងមិនមានដល់សង្ឃទេ ម្នាលឧបាលិ ភិក្ខុត្រូវកាន់យកនូវអត្តាទាននោះចុះ។ ម្នាលឧបាលិ អត្តាទានប្រកបដោយអង្គ៥យ៉ាងនេះឯង ដែលភិក្ខុកាន់យកហើយ ជាធម្មជាតមិនធ្វើឲ្យក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ។

[២៧១] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ទើបឈ្មោះថា ជាអ្នកមានឧបការៈច្រើន ដល់ភិក្ខុដែលកើតអធិករណ៍។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបឈ្មោះថា ជាអ្នកមានឧបការៈច្រើន ដល់ភិក្ខុដែលកើតអធិករណ៍។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ១ ជាពហុស្សូត ទ្រទ្រង់ពុទ្ធវចនៈ សន្សំពុទ្ធវចនៈ ធម៌ទាំងឡាយណា ដែលមានពីរោះដើមបទ ពីរោះកណ្តាលបទ ពីរោះចុងបទ ប្រកាសព្រហ្មចរិយៈដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ទាំងអត្ថ ទាំងព្យញ្ជនៈ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះក៏បានចេះដឹងច្រើន បានទ្រទ្រង់ចាំស្ទាត់ រត់មាត់ ចូលចិត្តច្បាស់លាស់ យល់ជ្រាលជ្រៅដោយទិដ្ឋិ គឺបញ្ញា១ ភិក្ខុនោះ បានចេះចាំបាតិមោក្ខទាំងពីរដោយពិស្តារ ចែកបទភាជនៈដោយត្រឹមត្រូវបាន ចាំស្ទាត់រត់មាត់ដោយប្រពៃ កាត់សេចក្តីបានស្រួលតាមសុត្តៈ និងអនុព្យញ្ជនៈ១ ជាអ្នកតាំងមាំក្នុងវិន័យ មិនរំភើប[50] អាចលួងលោម ពន្យល់ដល់ជនទាំងពីរខាង ដែលមានសេចក្តីទាស់ទែងគ្នា ដោយអត្ថ និងពិចារណា ឲ្យក្រឡេកមើល ឲ្យជ្រះថ្លាបាន១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបឈ្មោះថា ជាអ្នកមានឧបការៈច្រើន ដល់ពួកភិក្ខុដែលកើតអធិករណ៍។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏ឈ្មោះថា ជាអ្នកមានឧបការៈច្រើន ដល់ភិក្ខុដែលកើតអធិករណ៍ដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមានកាយសមាចារបរិសុទ្ធ១ មានវចីសមាចារបរិសុទ្ធ១ មានអាជីវៈបរិសុទ្ធ១ ជាបណ្ឌិតឈ្លាសវៃ១ កាលបើគេសាកសួរ ក៏អាចឲ្យគេសាកសួរបាន១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបឈ្មោះថា ជាអ្នកមានឧបការៈច្រើន ដល់ពួកភិក្ខុដែលកើតអធិករណ៍។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ក៏ឈ្មោះថា ជាអ្នកមានឧបការៈច្រើន ដល់ពួកភិក្ខុដែលកើតអធិករណ៍។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងវត្ថុ១ ដឹងនិទាន១ ដឹងបញ្ញត្តិ១ ដឹងបទបាលីក្រោយមុន១ ដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបឈ្មោះថា ជាអ្នកមានឧបការៈច្រើន ដល់ពួកភិក្ខុដែលកើតអធិករណ៍។

[២៧២] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលភិក្ខុមិនត្រូវសាកសួរ។[51] ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ ភិក្ខុផងគ្នាមិនត្រូវសាកសួរទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងសុត្តៈ (ឧភតោវិភង្គ)១ មិនដឹងសុត្តានុលោម (មហាបទេសបួនខាងព្រះសូត្រ)១ មិនដឹងវិន័យ (ខន្ធកៈ និងបរិវារៈ)១ មិនដឹងវិនយានុលោម (មហាបទេសបួនខាងវិន័យ)១ ជាអ្នកមិនឈ្លាសក្នុងហេតុ និងមិនមែនហេតុ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គទាំង៥នេះឯង ភិក្ខុមិនត្រូវសាកសួរទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ភិក្ខុផងគ្នាគួរសាកសួរបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងសុត្តៈ១ ដឹងសុត្តានុលោម១ ដឹងវិន័យ១ ដឹងវិនយានុលោម១ ជាអ្នកឈ្លាសក្នុងហេតុ និងមិនមែនហេតុ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ទើបភិក្ខុគួរសាកសួរបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ក៏ភិក្ខុមិនត្រូវសាកសួរទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងធម៌ គឺសុត្តន្តបិដក និងអភិធម្មបិដក១ មិនដឹងធម្មានុលោម (មហាបទេសបួនខាងព្រះសូត្រ)១ មិនដឹងវិន័យ១ មិនដឹងវិនយានុលោម១ ជាអ្នកមិនឈ្លាសក្នុងពាក្យខាងដើម និងពាក្យខាងចុង១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ភិក្ខុមិនត្រូវសាកសួរទេ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥ ទើបភិក្ខុគួរសាកសួរបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងធម៌១ ដឹងធម្មានុលោម១ ដឹងវិន័យ១ ដឹងវិនយានុលោម១ ជាអ្នកឈ្លាសក្នុងពាក្យខាងដើម និងពាក្យខាងចុង១។

ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ទើបភិក្ខុគួរសាកសួរបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ក៏ភិក្ខុមិនត្រូវសាកសួរទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងវត្ថុ១ មិនដឹងនិទាន១ មិនដឹងបញ្ញត្តិ១ មិនដឹងបទបាលីក្រោយមុន១ មិនដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ភិក្ខុមិនត្រូវសាកសួរទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គទាំង៥ ទើបភិក្ខុគួរសាកសួរបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងវត្ថុ១ ដឹងនិទាន១ ដឹងបញ្ញត្តិ១ ដឹងបទបាលីក្រោយមុន១ ដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ទើបគួរសាកសួរបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ក៏ភិក្ខុមិនត្រូវសាកសួរទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងអាបត្តិ១ មិនដឹងសមុដ្ឋាននៃអាបត្តិ១ មិនដឹងប្រយោគនៃអាបត្តិ១ មិនដឹងសេចក្តីរម្ងាប់នៃអាបត្តិ១ ជាអ្នកមិនឈ្លាស ក្នុងការវិនិច្ឆ័យអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ភិក្ខុមិនត្រូវសាកសួរទេ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ ទើបគួរសាកសួរបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងអាបត្តិ១ ដឹងសមុដ្ឋាននៃអាបត្តិ១ ដឹងប្រយោគនៃអាបត្តិ១ ដឹងសេចក្តីរម្ងាប់នៃអាបត្តិ១ អ្នកឈ្លាស ក្នុងការវិនិច្ឆ័យអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ទើបគួរសាកសួរបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ក៏ភិក្ខុមិនត្រូវសាកសួរទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងអធិករណ៍១ មិនដឹងសមុដ្ឋាននៃអធិករណ៍១ មិនដឹងប្រយោគនៃអធិករណ៍១ មិនដឹងសេចក្តីរម្ងាប់នៃអធិករណ៍១ មិនឈ្លាស ក្នុងការវិនិច្ឆ័យអធិករណ៍១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ភិក្ខុមិនត្រូវសាកសួរទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរសាកសួរបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងអធិករណ៍១ ដឹងសមុដ្ឋាននៃអធិករណ៍១ ដឹងប្រយោគនៃអធិករណ៍១ ដឹងសេចក្តីរម្ងាប់នៃអធិករណ៍១ អ្នកឈ្លាស ក្នុងការវិនិច្ឆ័យអធិករណ៍១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គទាំង៥នេះឯង ទើបគួរសាកសួរបាន។

ចប់ អត្តាទានវគ្គទី៥។

ឧទ្ទាន គឺបញ្ជីរឿង នៃអត្តាទានវគ្គនោះ ដូច្នេះ

[២៧៣]

និយាយអំពីភិក្ខុអ្នកចោទមានកាយសមាចារជាដើម បរិសុទ្ធ១ ភិក្ខុអ្នកចោទ និយាយក្នុងកាលគួរ១ ភិក្ខុអ្នកចោទ ប្រកបដោយសេចក្តីករុណា១ ភិក្ខុសូមឱកាស១ ភិក្ខុគួរកាន់យកនូវអត្តាទាន១ ភិក្ខុមានឧបការៈ ដល់ភិក្ខុដែលកើតអធិករណ៍១ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត១ ភិក្ខុដឹងវត្ថុ១ សុត្តៈ១ ធម៌១ វត្ថុដទៃទៀត១ អាបត្តិ១ អធិករណ៍១។

## (ធុតង្គវគ្គ ទី៦)

CS vin.pv.14.06 | ភាគ ទី១៣

### (៦. ធុតង្គវគ្គោ)

[២៧៤] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មានប៉ុន្មានពួក។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មាន៥ពួក។ ៥ពួក គឺអ្វីខ្លះ។ គឺភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ព្រោះល្ងង់វង្វេង១ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់១ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ព្រោះឆ្កួត ព្រោះរាយមាយចិត្ត១ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ដោយគិតថា ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ព្រះពុទ្ធ និងពួកពុទ្ធសាវ័ក តែងសរសើរ១ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិចផង ព្រោះអាស្រ័យសេចក្តីសន្តោសផង ព្រោះអាស្រ័យការដុសខាត់ចិត្តផង ព្រោះអាស្រ័យសេចក្តីស្ងាត់ផង ព្រោះអាស្រ័យសេចក្តីប្រតិបត្តិ ដែលមានប្រយោជន៍ផង១។ ម្នាលឧបាលិ ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មាន៥ពួកនេះឯង។ ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់បិណ្ឌបាតិកធុតង្គ មានប៉ុន្មានពួក។បេ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់បំសុកូលិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់រុក្ខមូលិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់សោសានិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់អព្ភោកាសិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់តេចីវរិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់សបទានចារិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់នេសជ្ជិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់យថាសន្តតិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់ឯកាសនិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់ខលុបច្ឆាភត្តិកធុតង្គ មានប៉ុន្មានពួក។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ មានប៉ុន្មានពួក។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ មាន៥ពួក។ ៥ពួក គឺអ្វីខ្លះ។ គឺភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ព្រោះសេចក្តីល្ងង់វង្វេង១ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់១ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ព្រោះឆ្កួត ព្រោះរាយមាយចិត្ត១ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ដោយគិតថា ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ព្រះពុទ្ធ និងពួកសាវ័កនៃព្រះពុទ្ធ តែងសរសើរ១ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិចផង ព្រោះអាស្រ័យសេចក្តីសន្តោសផង ព្រោះអាស្រ័យការដុសខាត់ចិត្តផង ព្រោះអាស្រ័យសេចក្តីស្ងាត់ផង ព្រោះអាស្រ័យសេចក្តីប្រតិបត្តិ ដែលមានប្រយោជន៍នេះផង១។ ម្នាលឧបាលិ ភិក្ខុអ្នកកាន់បត្តបិណ្ឌិកធុតង្គ មាន៥ពួកនេះឯង។

ចប់ ធុតង្គវគ្គទី៦។

ឧទ្ទាន គឺបញ្ជីរឿងនៃធុតង្គវគ្គ នោះដូច្នេះ

[២៧៥]

និយាយអំពីភិក្ខុកាន់អារញ្ញកធុតង្គ១ ភិក្ខុកាន់បិណ្ឌបាតិកធុតង្គ១ ភិក្ខុកាន់បំសុកូលិកធុតង្គ១ ភិក្ខុកាន់រុក្ខមូលិកធុតង្គ១ ភិក្ខុកាន់សោសានិកធុតង្គ១ ជាគំរប់៥ ភិក្ខុកាន់អព្ភោកាសិកធុតង្គ១ ភិក្ខុកាន់តេចីវរិកធុតង្គ១ ភិក្ខុកាន់សបទានចារិកធុតង្គ១ ភិក្ខុកាន់នេសជ្ជិកធុតង្គ១ ភិក្ខុកាន់យថាសន្ថតិកធុតង្គ១ ភិក្ខុកាន់ឯកាសនិកធុតង្គ១ ភិក្ខុកាន់ខលុបច្ឆាភត្តិកធុតង្គ១ ភិក្ខុកាន់បត្តបិណ្ឌិកធុតង្គ១។

## (មុសាវាទវគ្គ ទី៧)

CS vin.pv.14.07 | ភាគ ទី១៣

### (៧. មុសាវាទវគ្គោ)

[២៧៦] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន មុសាវាទ មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ មុសាវាទនេះ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺមុសាវាទ ដល់នូវបារាជិក ក៏មាន មុសាវាទ ដល់នូវសង្ឃាទិសេសក៏មាន មុសាវាទ ដល់នូវថុល្លច្ច័យក៏មាន មុសាវាទ ដល់នូវបាចិត្តិយៈក៏មាន មុសាវាទ ដល់នូវទុក្កដក៏មាន។ ម្នាលឧបាលិ មុសាវាទ មាន៥យ៉ាងនេះឯង។

[២៧៧] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន កាលបើបញ្ឈប់នូវឧបោសថ ឬបវារណា ក្នុងកណ្ដាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណ្ហើយ លោកកុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ កាលបើបញ្ឈប់នូវឧបោសថ ឬបវារណា ក្នុងកណ្ដាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណ្ហើយ លោកកុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកមិនខ្មាសបាប១ ជាមនុស្សល្ងង់១ មិនមែនជាបកតត្ត១ ជាអ្នកនិយាយដោយបំណងនឹងឲ្យភិក្ខុដទៃឃ្លាត (ចាកសាសនា)១ ជាអ្នកមិនប្រាថ្នានឹងចេញចាកអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង កាលបើបញ្ឈប់នូវឧបោសថ ឬបវារណា ក្នុងកណ្ដាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណ្ហើយ លោកកុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត កាលបើបញ្ឈប់នូវឧបោសថ ឬបវារណា ក្នុងកណ្ដាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណ្ហើយលោក កុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកមានកាយសមាចារមិនបរិសុទ្ធ១ មានវចីសមាចារមិនបរិសុទ្ធ១ មានអាជីវៈមិនបរិសុទ្ធ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ១ ជាអ្នកធ្វើការបង្កហេតុ ធ្វើជម្លោះ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង កាលបើបញ្ឈប់នូវឧបោសថ ឬបវារណា ក្នុងកណ្ដាលជំនុំសង្ឃ សង្ឃគប្បីសង្កត់សង្កិនថា ម្នាលភិក្ខុ ណ្ហើយ លោកកុំបង្កហេតុ កុំធ្វើជម្លោះ កុំទាស់ទែង កុំវិវាទគ្នាឡើយ ដូច្នេះហើយសឹមធ្វើឧបោសថ ឬបវារណា។

[២៧៨] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃមិនត្រូវឲ្យការសាកសួរដល់ភិក្ខុ ដែលប្រកបដោយអង្គប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃមិនត្រូវឲ្យការសាកសួរ ដល់ភិក្ខុដែលប្រកបដោយអង្គ៥។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងអាបត្តិ និងអនាបត្តិ១ មិនដឹងអាបត្តិស្រាល និងធ្ងន់១ មិនដឹងសាវសេសាបត្តិ និងអនវសេសាបត្តិ១ មិនដឹងទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ មិនដឹងសប្បដិកម្មាបត្តិ[52] និងអប្បដិកម្មាបត្តិ[53] ១។ ម្នាលឧបាលិ សង្ឃមិនត្រូវឲ្យការសាកសួរដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវឲ្យការសាកសួរ ដល់ភិក្ខុដែលប្រកបដោយអង្គ៥។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងអាបត្តិ និងអនាបត្តិ១ ដឹងនូវអាបត្តិស្រាល និងធ្ងន់១ ដឹងនូវសាវសេសាបត្តិ និងអនវសេសាបត្តិ១ ដឹងនូវទុដ្ឋុល្លាបត្តិ និងអទុដ្ឋុល្លាបត្តិ១ ដឹងនូវសប្បដិកម្មាបត្តិ និងអប្បដិកម្មាបត្តិ១។ ម្នាលឧបាលិ សង្ឃត្រូវឲ្យការសាកសួរ ដល់ភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។

[២៧៩] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុត្រូវអាបត្តិ ដោយអាការប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុត្រូវអាបត្តិ ដោយអាការ៥។ អាការ៥ អ្វីខ្លះ។ គឺភិក្ខុត្រូវអាបត្តិដោយសេចក្ដីមិនខ្មាសបាប១ ដោយមិនស្គាល់អាបត្តិ១ ដោយសង្ស័យ ហើយចេះតែធ្វើទៅ១ ដោយសំគាល់ថាគួរ ក្នុងរបស់ដែលមិនគួរ១ ដោយសំគាល់ថាមិនគួរ ក្នុងរបស់ដែលគួរ១។ ម្នាលឧបាលិ ភិក្ខុត្រូវអាបត្តិ ដោយអាការ៥នេះឯង។ ម្នាលឧបាលិ ភិក្ខុត្រូវអាបត្តិ ដោយអាការ៥ដទៃទៀត។ អាការ៥ គឺអ្វីខ្លះ។ គឺភិក្ខុត្រូវអាបត្តិដោយអាការមិនឃើញ[54] ១ ត្រូវដោយអាការមិនឮ[55] ១ ត្រូវដោយដេកលក់[56] ១ ត្រូវដោយខ្លួនសំគាល់ពិត[57] ១ ត្រូវដោយភ្លេចស្មារតី[58] ១ ម្នាលឧបាលិ ភិក្ខុត្រូវអាបត្តិ ដោយអាការ៥នេះឯង។

[២៨០] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ពៀរមានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ពៀរនេះមាន៥យ៉ាង។ ពៀរ៥យ៉ាង គឺអ្វីខ្លះ។ គឺការញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះឲ្យវិនាស១ ការកាន់យកទ្រព្យ ដែលគេមិនឲ្យ១ ការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ១ ការនិយាយកុហក១ ហេតុជាទីតាំងនៃសេចក្ដីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរា និងមេរ័យ១ ម្នាលឧបាលិ ពៀរមាន៥យ៉ាងនេះឯង។

[២៨១] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន កិរិយាវៀរ មានប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ កិរិយាវៀរមាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺកិរិយាវៀរចាកការញុំាងសត្វមានជីវិតឲ្យវិនាស១ កិរិយាវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ១ កិរិយាវៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ១ កិរិយាវៀរចាកការនិយាយកុហក១ កិរិយាវៀរចាកហេតុ ជាទីតាំងនៃសេចក្ដីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរា និងមេរ័យ១។ ម្នាលឧបាលិ កិរិយាវៀរ មាន៥យ៉ាងនេះឯង។

[២៨២] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សេចក្តីវិនាស មានប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ សេចក្តីវិនាស មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺសេចក្តីវិនាសញាតិ១ សេចក្តីវិនាសភោគសម្បត្តិ១ សេចក្តីវិនាសព្រោះរោគ១ សេចក្តីវិនាសសីល១ សេចក្តីវិនាសព្រោះទិដ្ឋិ១។ ម្នាលឧបាលិ សេចក្តីវិនាស មាន៥យ៉ាងនេះឯង។

[២៨៣] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សម្បទា គឺសេចក្តីបរិបូណ៌ មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ សេចក្តីបរិបូណ៌ មាន៥យ៉ាង។ ៥យ៉ាង គឺអ្វីខ្លះ។ គឺសេចក្តីបរិបូណ៌ដោយញាតិ១ សេចក្តីបរិបូណ៌ដោយភោគសម្បត្តិ១ សេចក្តីបរិបូណ៌ដោយអាការមិនមានរោគ១ សេចក្តីបរិបូណ៌ដោយសីល១ សេចក្តីបរិបូណ៌ដោយទិដ្ឋិត្រូវ១។ ម្នាលឧបាលិ សេចក្តីបរិបូណ៌ មាន៥យ៉ាងនេះឯង។

ចប់ មុសាវាទវគ្គ ទី៧។

ឧទ្ទាន គឺបញ្ជីរឿងនៃមុសាវាទវគ្គនោះ ដូច្នេះ

[២៨៤]

និយាយអំពីមុសាវាទ១ អំពីសង្ឃត្រូវសង្កត់សង្កិនភិក្ខុ១ អំពីភិក្ខុប្រកបដោយអង្គ៥ដទៃទៀត១ អំពីការសាកសួរ១ អំពីភិក្ខុត្រូវអាបត្តិ១ អំពីភិក្ខុត្រូវអាបត្តិ ដោយអាការ៥ដទៃទៀត១ អំពីពៀរ១ អំពីកិរិយាវៀរ១ អំពីសេចក្តីវិនាស១ អំពីសេចក្តីបរិបូណ៌១ (នេះ) ជាសង្គហវគ្គទីប្រាំពីរ។

## (ភិក្ខុនោវាទវគ្គ ទីផ)

CS vin.pv.14.08 | ភាគ ទី១៣

### (៨. ភិក្ខុនោវាទវគ្គោ)

[២៨៥] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលភិក្ខុនីសង្ឃត្រូវធ្វើកម្ម។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ ដែលភិក្ខុនីសង្ឃ ត្រូវធ្វើកម្ម គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុបើកកាយបង្ហាញពួកភិក្ខុនី១ បើកភ្លៅបង្ហាញ១ បើកអង្គជាតបង្ហាញ១ បើកចង្កេះយស្មាទាំងសងខាងបង្ហាញ១ និយាយល្បួង ឬផ្សំផ្គុំនឹងគ្រហស្ថ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ដែលភិក្ខុនីសង្ឃ ត្រូវធ្វើកម្ម គឺភិក្ខុនីសង្ឃមិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ភិក្ខុនីសង្ឃ ក៏ត្រូវធ្វើកម្មដែរ គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុព្យាយាមដើម្បីមិនឲ្យបានលាភ ដល់ពួកភិក្ខុនី១ ព្យាយាម ដើម្បីមិនឲ្យមានប្រយោជន៍ ដល់ពួកភិក្ខុនី១ ព្យាយាម ដើម្បីមិនឲ្យមានទីលំនៅ ដល់ពួកភិក្ខុនី១ ជេរគំរាមភិក្ខុនីទាំងឡាយ១ ឲ្យពួកភិក្ខុបែកចាកពួកភិក្ខុនី១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ដែលភិក្ខុនីសង្ឃ ត្រូវធ្វើកម្ម គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ក៏ភិក្ខុនីសង្ឃ ត្រូវធ្វើកម្មដែរ គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុព្យាយាម ដើម្បីមិនឲ្យមានលាភ ដល់ពួកភិក្ខុនី១ ព្យាយាម ដើម្បីមិនឲ្យមានប្រយោជន៍ ដល់ពួកភិក្ខុនី១ ព្យាយាម ដើម្បីមិនឲ្យមានទីលំនៅ ដល់ពួកភិក្ខុនី១ ជេរគំរាមភិក្ខុនីទាំងឡាយ១ ផ្សំផ្គុំពួកភិក្ខុ និងពួកភិក្ខុនី១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ដែលភិក្ខុនីសង្ឃ ត្រូវធ្វើកម្ម គឺភិក្ខុនីសង្ឃ មិនត្រូវថ្វាយបង្គំភិក្ខុនោះឡើយ។

[២៨៦] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃត្រូវធ្វើកម្ម ដល់ភិក្ខុនីដែលប្រកបដោយអង្គប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្មដល់ភិក្ខុនី ដែលប្រកបដោយអង្គ៥។ អង្គ៥ អ្វីខ្លះ។ គឺភិក្ខុនីដែលបើកកាយបង្ហាញពួកភិក្ខុ១ បើកភ្លៅបង្ហាញ១ បើកអង្គជាតបង្ហាញ១ បើកចង្កេះយស្មាទាំងសងខាងបង្ហាញ១ និយាយល្បួង ឬផ្សំផ្គុំនឹងគ្រហស្ថ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្ម ដល់ភិក្ខុនី ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្ម ដល់ភិក្ខុនី ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុនីព្យាយាមដើម្បីមិនឲ្យមានលាភ ដល់ពួកភិក្ខុ១ ព្យាយាម ដើម្បីមិនឲ្យមានប្រយោជន៍ ដល់ពួកភិក្ខុ១ ព្យាយាម ដើម្បីមិនឲ្យមានទីលំនៅ ដល់ពួកភិក្ខុ១ ជេរគំរាមភិក្ខុទាំងឡាយ១ ធ្វើពួកភិក្ខុនី ឲ្យបែកចាកពួកភិក្ខុ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្ម ដល់ភិក្ខុនី ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្ម ដល់ភិក្ខុនី ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុនីព្យាយាម ដើម្បីមិនឲ្យមានលាភ ដល់ភិក្ខុ១ ព្យាយាម ដើម្បីមិនឲ្យមានប្រយោជន៍ ដល់ពួកភិក្ខុ១ ព្យាយាម ដើម្បីមិនឲ្យមានទីលំនៅ ដល់ពួកភិក្ខុ១ ជេរគំរាមភិក្ខុ១ ផ្សំផ្គុំពួកភិក្ខុនី និងពួកភិក្ខុ១។ ម្នាលឧបាលិ សង្ឃត្រូវធ្វើកម្ម ដល់ភិក្ខុនី ដែលប្រកបដោយអង្គ៥នេះឯង។

[២៨៧] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយ។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនមានសេចក្តីខ្មាស១ ជាមនុស្សល្ងង់១ មិនមែនជាបកតត្ត១ ជាអ្នកនិយាយប៉ង ញុំាងភិក្ខុដទៃឲ្យឃ្លាតចាក (សាសនា)១ មិនប្រាថ្នានឹងចេញចាកអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមានកាយសមាចារមិនបរិសុទ្ធ១ មានវចីសមាចារមិនបរិសុទ្ធ១ មានអាជីវៈមិនបរិសុទ្ធ១ ជាមនុស្សល្ងង់ មិនឈ្លាសវៃ១ កាលបើគេសាកសួរ ក៏មិនអាចនឹងឲ្យគេសាកសួរ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុប្រកបដោយអនាចារ ខាងផ្លូវកាយ១ ប្រកបដោយអនាចារ ខាងផ្លូវ

វាចា១ ប្រកបដោយអនាចារ ទាំងផ្លូវកាយ ទាំងផ្លូវវាចា១ ជេរគំរាមពួកភិក្ខុនី១ នៅច្រឡូកច្រឡំនឹងពួកភិក្ខុនី ដោយសេចក្ដីច្រឡូកច្រឡំមិនសមគួរ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយទេ។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនមានសេចក្ដីខ្មាស១ ជាមនុស្សល្ងង់១ មិនមែនជាបកតត្ត១ ជាអ្នកធ្វើនូវការបង្កហេតុ ធ្វើនូវជម្លោះ១ ជាអ្នកមិនធ្វើនូវសិក្ខាឲ្យបរិបូណ៌១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវបញ្ឈប់នូវឱវាទ ដល់ភិក្ខុនីទាំងឡាយទេ។

[២៨៨] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលមិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ ដែលមិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុប្រកបដោយអនាចារ ខាងផ្លូវកាយ១ ប្រកបដោយអនាចារ ខាងផ្លូវវាចា១ ប្រកបដោយអនាចារ ទាំងផ្លូវកាយ ទាំងផ្លូវវាចា១ ជាអ្នកជេរគំរាមពួកភិក្ខុនី១ ជាអ្នកនៅច្រឡូកច្រឡំនឹងពួកភិក្ខុនី ដោយសេចក្ដីច្រឡូកច្រឡំមិនសមគួរ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏មិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនមានសេចក្ដីខ្មាស១ ជាមនុស្សពាល១ មិនមែនជាបកតត្ត១ ជាអ្នកដំណើរ១ ជាអ្នកមានជម្ងឺ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនត្រូវឲ្យពួកភិក្ខុនីកាន់យកឱវាទ។

[២៨៩] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គប៉ុន្មាន។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៥។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនប្រកបដោយសីលក្ខន្ធ ជារបស់អសេក្ខបុគ្គល១ មិនប្រកបដោយសមាធិក្ខន្ធ ជារបស់អសេក្ខបុគ្គល១ មិនប្រកបដោយបញ្ញាខន្ធ ជារបស់អសេក្ខបុគ្គល១ មិនប្រកបដោយវិមុត្តិក្ខន្ធ ជារបស់អសេក្ខបុគ្គល១ មិនប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធ ជារបស់អសេក្ខបុគ្គល១។ ម្នាលឧបាលិ ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ ភិក្ខុត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៥។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុប្រកបដោយសីលក្ខន្ធ ជារបស់អសេក្ខបុគ្គល១ ប្រកបដោយសមាធិក្ខន្ធ ជារបស់អសេក្ខបុគ្គល១ ប្រកបដោយបញ្ញាខន្ធ ជារបស់អសេក្ខបុគ្គល១ ប្រកបដោយវិមុត្តិក្ខន្ធ ជារបស់អសេក្ខបុគ្គល១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធ ជារបស់អសេក្ខបុគ្គល១។ ម្នាលឧបាលិ ភិក្ខុត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៥ដទៃទៀត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនទាន់ដល់នូវអត្ថប្បដិសម្ភិទា (ការបែកធ្លាយក្នុងអដ្ឋកថា)១ មិនទាន់ដល់នូវធម្មប្បដិសម្ភិទា (ការបែកធ្លាយក្នុងបាលី)១ មិនទាន់ដល់នូវនិរុត្តិប្បដិសម្ភិទា (ការបែកធ្លាយក្នុងភាសា ឬដីកា)១ មិនទាន់ដល់នូវបដិភាណប្បដិសម្ភិទា (ការបែកធ្លាយដោយសេចក្ដីឈ្លាសវៃ)១ មិនពិចារណានូវចិត្ត ដែលរួចហើយ ចាកកិលេសយ៉ាងណា១។ ម្នាលឧបាលិ ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។ ម្នាលឧបាលិ ភិក្ខុត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៥។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដល់នូវអត្ថប្បដិសម្ភិទា១ ដល់នូវធម្មប្បដិសម្ភិទា១ ដល់នូវនិរុត្តិប្បដិសម្ភិទា១ ដល់នូវបដិភាណប្បដិសម្ភិទា១ ពិចារណានូវចិត្ត ដែលរួចហើយ ចាកកិលេសយ៉ាងណា១។ ម្នាលឧបាលិ ភិក្ខុត្រូវសាកច្ឆាជាមួយនឹងភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង។

ចប់ ភិក្ខុនីឱវាទវគ្គ ទី៨។

ឧទ្ទាន គឺបញ្ជីរឿងនៃភិក្ខុនីឱវាទវគ្គនោះ ដូច្នេះ

[២៩០]

និយាយអំពីរឿង ដែលភិក្ខុនីសង្ឃត្រូវធ្វើកម្ម១ អំពីកម្មពីរយ៉ាង ដែលភិក្ខុនីសង្ឃត្រូវធ្វើដល់ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត១ អំពីកម្ម៣យ៉ាង ដែលសង្ឃត្រូវធ្វើដល់ពួកភិក្ខុនី១ អំពីភិក្ខុមិនត្រូវបញ្ឈប់ឱវាទ មាន២ទុកៈ១ អំពីភិក្ខុមិនត្រូវឲ្យកាន់យកឱមាន មាន២ទុកៈ ដែលព្រះមានព្រះភាគត្រាស់ហើយ១ អំពីទុកៈ២ ក្នុងការនិយាយធម៌១។

## (ឧព្ពាហិកវគ្គ ទី៩)

CS vin.pv.14.09 | ភាគ ទី១៣

### (៩. ឧព្ពាហិកវគ្គោ)

[២៩១] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ដែលសង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្ម។[59] ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនឈ្លាស ក្នុងអដ្ឋកថា១ មិនឈ្លាសក្នុងបាលី១ មិនឈ្លាសក្នុងភាសា១ មិនឈ្លាសក្នុងព្យញ្ជនៈ (មានសិថិល និងធនិតជាដើម)១ មិនឈ្លាសក្នុងពាក្យខាងដើម និងខាងចុង១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុឈ្លាស ក្នុងអដ្ឋកថា១ ឈ្លាសក្នុងបាលី១ ឈ្លាសក្នុងភាសា១ ឈ្លាសក្នុងព្យញ្ជនៈ១ ឈ្លាសក្នុងពាក្យខាងដើម និងខាងចុង១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកក្រោធ បណ្ដោយឲ្យសេចក្ដីក្រោធគ្របសង្កត់១ មានសេចក្ដីលុបគុណ បណ្ដោយឲ្យសេចក្ដីលុបគុណ គ្របសង្កត់១ មានសេចក្ដីលើកខ្លួន បណ្ដោយឲ្យសេចក្ដីលើកខ្លួនគ្របសង្កត់១ មានសេចក្ដីច្រណែន បណ្ដោយឲ្យសេចក្ដីច្រណែនគ្របសង្កត់១ មានសេចក្ដីប្រកាន់ដោយទិដ្ឋិរបស់ខ្លួន មានសេចក្ដីប្រកាន់មាំ លះបង់បានដោយកម្រ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃមិនត្រូវសន្មតដោយ

ឧព្វាហិកាកម្មទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ សង្ឃគប្បីសន្មត់ដោយឧព្វាហិកាកម្មបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកមិនក្រោធ មិនបណ្តោយឲ្យសេចក្តីក្រោធគ្របសង្កត់១ ជាមនុស្សមិនមានសេចក្តីលុបគុណ មិនបណ្តោយឲ្យសេចក្តីលុបគុណ គ្របសង្កត់១ ជាមនុស្សមិនមានសេចក្តីលើកខ្លួន មិនបណ្តោយឲ្យសេចក្តីលើកខ្លួនគ្របសង្កត់១ ជាមនុស្សមិនច្រណែន មិនបណ្តោយឲ្យសេចក្តីច្រណែនគ្របសង្កត់១ ជាមនុស្សមិនប្រកាន់ដោយទិដ្ឋិរបស់ខ្លួន មិនប្រកាន់មាំ លះបង់បានដោយងាយ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុតែងកក្រើករំពើក១ តែងធ្វើនូវសេចក្តីព្យាបាទ១ តែងចង្អៀតចង្អល់ ដោយសេចក្តីក្រោធ១ តែងបណ្តោយឲ្យកើតសេចក្តីក្រោធ១ មិនចេះអត់ធន់ មិនកាន់យកពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនកក្រើករំពើក១ មិនធ្វើនូវសេចក្តីព្យាបាទ១ មិនចង្អៀតចង្អល់ ដោយសេចក្តីក្រោធ១ មិនបណ្តោយឲ្យកើតសេចក្តីក្រោធ១ ចេះអត់ធន់ ជាអ្នកកាន់យកពាក្យប្រៀនប្រដៅ ដោយចំណែកខាងស្តាំ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកមិនឲ្យគេរលឹកឃើញ គឺបំភាន់ បិទបាំងពាក្យអ្នកដើមចោទ និងចម្លើយ មិនរលឹកស្មារតី១ ជាអ្នកមិនសូមឱកាសកម្មសិន ហើយស្រាប់តែនិយាយ១ ជាអ្នកមិនចោទតាមធម៌ តាមវិន័យ និងតាមអាបត្តិ១ ជាអ្នកមិនកាត់សេចក្តីតាមធម៌ តាមវិន័យ និងតាមអាបត្តិ១ ជាអ្នកមិនប្រាប់តាមសេចក្តីយល់ឃើញ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុជាអ្នកឲ្យគេរលឹកឃើញ មិនបំភាន់គេ១ ជាអ្នកសូមឱកាសកម្មសិន ហើយទើបនិយាយ១ ជាអ្នកចោទតាមធម៌ តាមវិន័យ និងតាមអាបត្តិ១ ជាអ្នកកាត់សេចក្តីតាមធម៌ តាមវិន័យ និងតាមអាបត្តិ១ ជាអ្នកប្រាប់តាមសេចក្តីយល់ឃើញ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុលុះឆន្ទាគតិ១ លុះទោសាគតិ១ លុះមោហាគតិ១ លុះភយាគតិ១ ជាអ្នកមិនមានសេចក្តីខ្មាស១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ជាអ្នកមានសេចក្តីអៀនខ្មាស១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត សង្ឃក៏មិនត្រូវសន្មតដោយឧព្វាហិកាកម្មដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុលុះឆន្ទាគតិ១ លុះទោសាគតិ១ លុះមោហាគតិ១ លុះភយាគតិ១ ជាអ្នកមិនឈ្លាសក្នុងវិន័យ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្មទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនលុះឆន្ទាគតិ១ មិនលុះទោសាគតិ១ មិនលុះមោហាគតិ១ មិនលុះភយាគតិ១ ជាអ្នកឈ្លាសក្នុងវិន័យ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មបាន។

[២៩២] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ទើបដល់នូវការរាប់ថាជាភិក្ខុពាលពិត។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ ទើបដល់នូវការរាប់ថាជាភិក្ខុពាលមែន។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនចេះសុត្តៈ១ មិនចេះសុត្តានុលោមៈ១ មិនចេះវិន័យ១ មិនចេះវិនយានុលោម១ ជាអ្នកមិនឈ្លាសក្នុងហេតុដែលគួរ និងហេតុមិនគួរ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបដល់នូវការរាប់ថា ជាភិក្ខុពាលពិត។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុចេះសុត្តៈ១ ចេះសុត្តានុលោមៈ១ ចេះវិន័យ១ ចេះវិនយានុលោម១ ជាអ្នកឈ្លាសក្នុងហេតុដែលគួរ និងហេតុមិនគួរ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបដល់នូវការរាប់ថា ជាភិក្ខុបណ្ឌិតពិត។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏ដល់នូវការរាប់ថាជាភិក្ខុពាលដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនចេះធម៌១ មិនចេះធម្មានុលោមៈ១ មិនចេះវិន័យ១ មិនចេះវិនយានុលោម១ ជាអ្នកមិនឈ្លាសក្នុងពាក្យខាងដើម និងពាក្យខាងចុង១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបដល់នូវការរាប់ថា ជាភិក្ខុពាលពិត។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុចេះធម៌១ ចេះធម្មានុលោមៈ១ ចេះវិន័យ១ ចេះវិនយានុលោម១ ជាអ្នកឈ្លាសក្នុងពាក្យខាងដើម និងពាក្យខាងចុង១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបដល់នូវការរាប់ថា ជាភិក្ខុបណ្ឌិតពិត។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ដល់នូវការរាប់ថាជាភិក្ខុពាលពិត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងវត្ថុ១ មិនដឹងនិទាន១មិនដឹងបញ្ញត្តិ១ មិនដឹងបទបាលីក្រោយមុន១ មិនដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ដល់នូវការរាប់ថា ជាភិក្ខុពាលពិត។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងវត្ថុ១ ដឹងនិទាន១ ដឹងបញ្ញត្តិ១ ដឹងបទបាលីក្រោយមុន១ ដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបដល់នូវការរាប់ថា ជាបណ្ឌិតពិតមែន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏ដល់នូវការរាប់ថាជាភិក្ខុពាលដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងអាបត្តិ១ មិនដឹងសមុដ្ឋាននៃអាបត្តិ១ មិនដឹងប្រយោគនៃអាបត្តិ១ មិនដឹងសេចក្តីរម្ងាប់នៃអាបត្តិ១ ជាអ្នកមិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ដល់នូវការរាប់ថា ជាភិក្ខុពាលពិត។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងអាបត្តិ១ ដឹងសមុដ្ឋាននៃអាបត្តិ១ ដឹងប្រយោគនៃអាបត្តិ១ ដឹងសេចក្តីរម្ងាប់នៃអាបត្តិ១ ជាអ្នកឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបដល់នូវការរាប់ថា ជាភិក្ខុបណ្ឌិតពិត។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត ក៏ដល់នូវការរាប់ថាជាភិក្ខុពាលដែរ។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុមិនដឹងអធិករណ៍១ មិនដឹងសមុដ្ឋាននៃអធិករណ៍១ មិនដឹងប្រយោគនៃអធិករណ៍១ មិនដឹងសេចក្តីរម្ងាប់នៃអធិករណ៍១ ជាអ្នកមិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ដល់នូវការរាប់ថា ជាភិក្ខុពាលពិត។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបដល់នូវការរាប់ថាជាភិក្ខុបណ្ឌិតពិត។ អង្គ៥ គឺអ្វីខ្លះ។ គឺភិក្ខុដឹងអធិករណ៍១ ដឹងសមុដ្ឋាននៃអធិករណ៍១ ដឹងប្រយោគនៃអធិករណ៍១ ដឹងសេចក្តីរម្ងាប់នៃអធិករណ៍១ ជាអ្នកឈ្លាសក្នុងការវិនិច្ឆ័យនៃអធិករណ៍១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបដល់នូវការរាប់ថា ជាភិក្ខុបណ្ឌិតពិតមែន។

ចប់ ឧព្វាហិកាវគ្គ ទី៩។

ឧទ្ទាន គឺបញ្ជីរឿងនៃ ឧព្វាហិកាវគ្គ នោះដូច្នេះ

[២៩៣]

និយាយអំពីភិក្ខុមិនឈ្លាសក្នុងអដ្ឋកថា១ ភិក្ខុជាអ្នកក្រោធ១ ភិក្ខុតែងកក្រើករំពើក១ ភិក្ខុជាអ្នកបំភាន់គេ១ ភិក្ខុលុះឆន្ទាគតិ១ ភិក្ខុមិនឈ្លាស១ សុត្តៈ១ ធម្មៈ១ វត្ថុ១ អាបត្តិ១ អធិករណ៍១ ធម៌ទាំងអស់មានពីរៗ ដែលព្រះអង្គសំដែងហើយ អ្នកទាំងឡាយចូរដឹងថា ជាធម៌ខ្មៅ និងស គឺមានអាក្រក់ មានល្អ។

## (អធិករណវូបសមវគ្គ ទី១០)

CS vin.pv.14.10 | ភាគ ទី១៣

### (១០. អធិករណវូបសមវគ្គោ)

[២៩៤] ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន មិនគួររម្ងាប់អធិករណ៍បាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ មិនគួររម្ងាប់អធិករណ៍បាន។ អង្គ៥ នោះតើដូចម្តេច។ គឺភិក្ខុមិនដឹងអាបត្តិ១ មិនដឹងសមុដ្ឋាននៃអាបត្តិ១ មិនដឹងប្រយោគនៃអាបត្តិ១ មិនដឹងកិរិយារម្ងាប់អាបត្តិ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង មិនគួររម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួររម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុដឹងអាបត្តិ១ ដឹងសមុដ្ឋាននៃអាបត្តិ១ ដឹងប្រយោគនៃអាបត្តិ១ ដឹងកិរិយារម្ងាប់អាបត្តិ១ ឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបគួររម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនដឹងអធិករណ៍១ មិនដឹងសមុដ្ឋាននៃអធិករណ៍១ មិនដឹងប្រយោគនៃអធិករណ៍១ មិនដឹងកិរិយារម្ងាប់អធិករណ៍១ មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួររម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួររម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុដឹងអធិករណ៍១ ដឹងសមុដ្ឋាននៃអធិករណ៍១ ដឹងប្រយោគនៃអធិករណ៍១ ដឹងកិរិយារម្ងាប់អធិករណ៍១ ឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបគួររម្ងាប់អធិករណ៍បាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកឥតខ្មាស១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួររម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួររម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកមានខ្មាស១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបគួររម្ងាប់អធិករណ៍បាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនគួររម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកចេះដឹងតិច១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួររម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួររម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកចេះដឹងច្រើន១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបគួររម្ងាប់អធិករណ៍បាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនដឹងវត្ថុ១ មិនដឹងនិទាន១ មិនដឹងបញ្ញត្តិ១ មិនដឹងបទខាងចុង និងបទខាងដើម១ មិនដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួររម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួររម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុដឹងវត្ថុ១ ដឹងនិទាន១ ដឹងបញ្ញត្តិ១ ដឹងបទខាងចុង និងបទខាងដើម១ ដឹងគន្លងពាក្យដែលជាប់តគ្នា១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបគួររម្ងាប់អធិករណ៍បាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកមិនឈ្លាសក្នុងវិន័យ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួររម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួររម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកឈ្លាសក្នុងវិន័យ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបគួររម្ងាប់អធិករណ៍បាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនគួររម្ងាប់អធិករណ៍ទេ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកមានចិត្តធ្ងន់ក្នុងបុគ្គល មិនធ្ងន់ក្នុងសង្ឃ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួរនឹងរម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរនឹងរម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកមានចិត្តធ្ងន់ក្នុងសង្ឃ មិនធ្ងន់ក្នុងបុគ្គល១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបគួរនឹងរម្ងាប់អធិករណ៍បាន។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ដទៃទៀត មិនគួរនឹងរម្ងាប់អធិករណ៍ទេ។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកមានចិត្តធ្ងន់ក្នុងអាមិសៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង មិនគួរនឹងរម្ងាប់អធិករណ៍ទេ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥ ទើបគួរនឹងរម្ងាប់អធិករណ៍បាន។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ ជាអ្នកមានចិត្តធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងអាមិសៈ១។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ៥នេះឯង ទើបគួររម្ងាប់អធិករណ៍បាន។

[២៩៥] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃបែកគ្នាដោយអាការប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃបែកគ្នាដោយអាការ៥។ អាការ៥ តើដូចម្តេច។ គឺដោយកម្ម (មានអបលោកនកម្មជាដើម)១ ដោយឧទ្ទេស (មាននិទានុទ្ទេសជាដើម)១ ដោយសំដែងភេទករវត្ថុ១៨យ៉ាង១ ដោយអនុស្សាវនៈ គឺសូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន[60] ១ ដោយប្រគល់ស្លាក[61] ១។ ម្នាលឧបាលិ សង្ឃបែកគ្នាដោយអាការ៥យ៉ាងនេះឯង។

[២៩៦] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គត្រាស់ថា ការប្រេះឆានៃសង្ឃ បពិត្រព្រះអង្គដ៏ចំរើន ការប្រេះឆានៃសង្ឃ តែមិនទាន់បែកធ្លាយនៃសង្ឃ តើដូចម្តេច ម្យ៉ាងទៀត ការប្រេះឆានៃសង្ឃផង ការបែកធ្លាយនៃសង្ឃផងដូចម្តេច។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ តថាគត បានបញ្ញត្តអាគន្តុកវត្តនេះ ដល់ពួកភិក្ខុជាអាគន្តុកៈ ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគតបានបញ្ញត្ត ដោយប្រពៃយ៉ាងនេះហើយ ពួកភិក្ខុជាអាគន្តុកៈ មិនបានប្រព្រឹត្តក្នុងអាគន្តុកវត្ត ម្នាលឧបាលិ យ៉ាងនេះហើយ ហៅថា ការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថា បែកធ្លាយនៃសង្ឃទេ។ ម្នាលឧបាលិ តថាគត បានបញ្ញត្តអាវាសិកវត្តនេះ ដល់អាវាសិកភិក្ខុ ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគតបានបញ្ញត្ត ដោយប្រពៃយ៉ាងនេះ ពួកអាវាសិកភិក្ខុ មិនប្រព្រឹត្តក្នុងអាវាសិកវត្តទេ ម្នាលឧបាលិ យ៉ាងនេះហើយ ហៅថា ការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថា បែកធ្លាយនៃសង្ឃ។ ម្នាលឧបាលិ តថាគត បានបញ្ញត្តភត្តគ្គវត្តនេះ ក្នុងរោងភត្ត ដល់ពួកភិក្ខុ តាមលំដាប់ចាស់ខ្ចី តាមលំដាប់រាត្រី ឬលំដាប់នៃថេរៈ តាមកិច្ចដ៏សមគួរ តាមអាសនៈខ្ពស់ តាមទឹកថ្មោង តាមចង្ហាន់ថ្មោង ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគតបានបញ្ញត្ត ដោយប្រពៃយ៉ាងនេះហើយ ពួកភិក្ខុថ្មី ហាមឃាត់អាសនៈ ដល់ពួកភិក្ខុជាថេរៈ ក្នុងរោងភត្ត ម្នាលឧបាលិ យ៉ាងនេះហើយ ឈ្មោះថា ការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថា បែកធ្លាយនៃសង្ឃទេ។ ម្នាលឧបាលិ តថាគត បានបញ្ញត្តសេនាសនវត្តនេះ ក្នុសេនាសនៈ ដល់ភិក្ខុតាមលំដាប់ចាស់ខ្ចី តាមលំដាប់រាត្រី តាមកិច្ចដ៏សមគួរ ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគតបានបញ្ញត្ត ដោយប្រពៃយ៉ាងនេះហើយ ពួកភិក្ខុថ្មីក៏ហាមឃាត់សេនាសនៈ ដល់ពួកភិក្ខុជាថេរៈ ម្នាលឧបាលិ យ៉ាងនេះឈ្មោះថា ការប្រេះឆានៃសង្ឃ តែមិនទាន់ហៅថា បែកធ្លាយនៃសង្ឃទេ។ ម្នាលឧបាលិ តថាគត បានបញ្ញត្តឧបោសថជាមួយគ្នា បវារណាជាមួយគ្នា សង្ឃកម្មជាមួយគ្នា កម្មតូច កម្មធំជាមួយគ្នានេះ ខាងក្នុងសីមា ដល់ភិក្ខុទាំងឡាយហើយ ម្នាលឧបាលិ កាលបើសិក្ខាបទដែលតថាគតបានបញ្ញត្ត ដោយប្រពៃយ៉ាងនេះហើយ ភិក្ខុទាំងឡាយ ក៏ធ្វើសេចក្តីកំណត់ផ្សេងគ្នា ចងគ្នាជាពួក ធ្វើឧបោសថផ្សេងគ្នា ធ្វើបវារណាផ្សេងគ្នា ធ្វើសង្ឃកម្មផ្សេងគ្នា ធ្វើកម្មតូច កម្មធំផ្សេងគ្នា ខាងក្នុងសីមានោះ ម្នាលឧបាលិ យ៉ាងនេះហើយ ឈ្មោះថា ការប្រេះឆានៃសង្ឃផង ឈ្មោះថា ការបែកធ្លាយនៃសង្ឃផង។

ចប់ អធិករណវូបសមវគ្គ ជាគំរប់១០។

ឧទ្ទាន គឺបញ្ជីរឿងនៃអធិករណវូបសមវគ្គនោះដូច្នេះ

[២៩៧]

និយាយអំពីអាបត្តិ១ អធិករណ៍១ ការលំអៀងដោយស្រឡាញ់១ ភិក្ខុចេះដឹងតិច១ វត្ថុ១ ភិក្ខុមិនឈ្លាស១ មានចិត្តធ្ងន់ក្នុងបុគ្គល១ ធ្ងន់ក្នុងអាមិសៈ១ សង្ឃបែកគ្នា១ ការប្រេះឆានៃសង្ឃ១ ការបែកធ្លាយនៃសង្ឃ១។

## (សង្ឃភេទកវគ្គ ទី១១)

CS vin.pv.14.11 | ភាគ ទី១៣

### (១១. សង្ឃភេទកវគ្គោ)

[២៩៨] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុប្រកបដោយអង្គប៉ុន្មាន ឈ្មោះថាជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈ មិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ បិទបាំងទិដ្ឋិហើយធ្វើសង្ឃកម្មផ្សេងគ្នា១។ ម្នាលឧបាលិ ប្រកបដោយអង្គ៥នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈ មិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ បិទបាំងទិដ្ឋិហើយសំដែងបាតិមោក្ខ១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនជាធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ បិទបាំងទិដ្ឋិ ហើយសំដែង (ភេទករវត្ថុ១៨យ៉ាង)១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនជាធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ បិទបាំងទិដ្ឋិ ហើយសូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយ

អង្គ៥នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ បិទបាំងទិដ្ឋិ ប្រគល់ស្លាក១។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនជាធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ បិទបាំងសេចក្តីពេញចិត្ត ហើយធ្វើសង្ឃកម្មផ្សេងគ្នា១។បេ។ បិទបាំងសេចក្តីពេញចិត្ត ហើយសំដែងបាតិមោក្ខ។ បិទបាំងសេចក្តីពេញចិត្តហើយ សំដែងភេទករវត្ថុ១៨យ៉ាង។ បិទបាំងសេចក្តីពេញចិត្តហើយ សូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន។ បិទបាំងសេចក្តីពេញចិត្ត ហើយប្រគល់ស្លាក។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ បិទបាំងសេចក្តីគាប់ចិត្ត ហើយធ្វើសង្ឃកម្មផ្សេងគ្នា១។បេ។ បិទបាំងសេចក្តីគាប់ចិត្ត ហើយសំដែងបាតិមោក្ខ។ បិទបាំងសេចក្តីគាប់ចិត្ត ហើយសំដែងភេទករវត្ថុ១៨យ៉ាង។ បិទបាំងសេចក្តីគាប់ចិត្ត ហើយសូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន។ បិទបាំងសេចក្តីគាប់ចិត្ត ហើយប្រគល់ស្លាក។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥ដទៃទៀត ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនជាវិន័យ១ បិទបាំងសញ្ញា ហើយធ្វើសង្ឃកម្មផ្សេងគ្នា១។បេ។ បិទបាំងសញ្ញា ហើយសំដែងបាតិមោក្ខ។ បិទបាំងសញ្ញា ហើយសំដែងភេទករវត្ថុ១៨យ៉ាង។ បិទបាំងសញ្ញា ហើយសូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន។ បិទបាំងសញ្ញា ហើយប្រគល់ស្លាក។ ម្នាលឧបាលិ ភិក្ខុប្រកបដោយអង្គ៥នេះឯង ឈ្មោះថា ជាអ្នកបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន។

ចប់ សង្ឃភេទវគ្គ ជាគំរប់១១។

ឧទ្ទាន គឺបញ្ជីរឿងនៃសង្ឃភេទវគ្គនោះ ដូច្នេះ

[២៩៩]

និយាយអំពីបិទបាំងទិដ្ឋិ ហើយធ្វើសង្ឃកម្មផ្សេងគ្នា១ សំដែងបាតិមោក្ខ១ សំដែងភេទករវត្ថុ១៨យ៉ាង១ សូត្របញ្ជាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន១ ប្រគល់ស្លាក១ អាការទាំង៥នេះ អាស្រ័យនូវទិដ្ឋិ។ សេចក្តីពេញចិត្ត១ សេចក្តីគាប់ចិត្ត១ សញ្ញា១ ធម៌ទាំង៣យ៉ាងនោះ មានន័យ៥ប្រការដូចគ្នាដែរ។

## (ទុតិយសង្ឃភេទកវគ្គ ទី១២)

CS vin.pv.14.12 | ភាគ ទី១៣

### (១២. ទុតិយសង្ឃភេទកវគ្គោ)

[៣០០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គប៉ុន្មាន មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥ មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ មិនបិទបាំងទិដ្ឋិ ហើយធ្វើសង្ឃកម្មផ្សេងគ្នា១។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនជាវិន័យ១ មិនបិទបាំងទិដ្ឋិ ហើយសំដែងបាតិមោក្ខ១។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនជាវិន័យ១ មិនបិទបាំងទិដ្ឋិ ហើយសំដែងភេទករវត្ថុ១៨យ៉ាង១។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ

មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ មិនបិទបាំងទិដ្ឋិ ហើយសូត្របញ្ញាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន១។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ មិនបិទបាំងទិដ្ឋិ ហើយប្រគល់ស្លាក១។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ មិនបិទបាំងសេចក្តីពេញចិត្ត ហើយធ្វើសង្ឃកម្មផ្សេងគ្នា១។បេ។ មិនបិទបាំងសេចក្តីគាប់ចិត្ត ហើយសំដែងបាតិមោក្ខ។ មិនបិទបាំងសេចក្តីគាប់ចិត្ត ហើយសំដែងភេទករវត្ថុ១៨យ៉ាង មិនបិទបាំងសេចក្តីគាប់ចិត្ត ហើយសូត្របញ្ញាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន។ មិនបិទបាំងសេចក្តីពេញចិត្ត ហើយប្រគល់ស្លាក ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ មិនបិទបាំងសេចក្តីគាប់ចិត្ត ហើយធ្វើសង្ឃកម្មផ្សេងគ្នា១។បេ។ មិនបិទបាំងសេចក្តីគាប់ចិត្ត ហើយសំដែងបាតិមោក្ខ។ មិនបិទបាំងសេចក្តីគាប់ចិត្ត ហើយសំដែងភេទករវត្ថុ១៨យ៉ាង។ មិនបិទបាំងសេចក្តីគាប់ចិត្ត ហើយសូត្របញ្ញាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន។ មិនបិទបាំងសេចក្តីគាប់ចិត្ត ហើយប្រគល់ស្លាក។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥ដទៃទៀត មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។ អង្គ៥ តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌១ សំដែងនូវធម៌ ថាមិនមែនធម៌១ សំដែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ សំដែងនូវវិន័យ ថាមិនមែនវិន័យ១ មិនបិទបាំងសញ្ញាហើយធ្វើសង្ឃកម្មផ្សេងគ្នា១។បេ។ មិនបិទបាំងសញ្ញា ហើយសំដែងបាតិមោក្ខ។ មិនបិទបាំងសញ្ញា ហើយសំដែងភេទករវត្ថុ១៨យ៉ាង។ មិនបិទបាំងសញ្ញា ហើយសូត្របញ្ញាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន។ មិនបិទបាំងសញ្ញា ហើយប្រគល់ស្លាក។ ម្នាលឧបាលិ ភិក្ខុជាអ្នកបំបែកសង្ឃ ប្រកបដោយអង្គ៥នេះឯង មិនកំណត់ជាទៅកើតក្នុងអបាយ មិនកំណត់ជាទៅកើតក្នុងនរក មិនឋិតនៅអស់មួយកប្ប នៅកែខ្លួនបាន។

ចប់ ទុតិយសង្ឃភេទវគ្គ ជាគំរប់១២។

ឧទ្ទាន គឺបញ្ជីរឿងនៃសង្ឃភេទវគ្គនោះដូច្នេះ

[៣០១]

និយាយអំពីមិនបិទបាំងទិដ្ឋិ ហើយធ្វើសង្ឃកម្មផ្សេងគ្នា១ សំដែងបាតិមោក្ខ១ សំដែងភេទករវត្ថុ១៨យ៉ាង១ សូត្របញ្ញាក់អំពីសេចក្តីស្មោះត្រង់របស់ខ្លួន១ ប្រគល់ស្លាក១ អាការទាំង៥នេះ អាស្រ័យនូវទិដ្ឋិ។ សេចក្តីពេញចិត្ត១ សេចក្តីគាប់ចិត្ត១ សញ្ញា១ ធម៌ទាំង៣យ៉ាងនោះ មានន័យ៥ប្រការដូចគ្នាដែរ។ វិធី២០គត់ ក្នុងចំណែកខាងអាក្រក់ មានក្នុងខាងក្រោម (ខាងដើម) យ៉ាងណា អ្នកទាំងឡាយ ចូរដឹងនូវវិធី២០គត់ ក្នុងចំណែកខាងល្អ ក៏យ៉ាងនោះដែរ។

## (អាវាសិកវគ្គ ទី១៣)

CS vin.pv.14.13 | ភាគ ទី១៣

### (១៣. អាវាសិកវគ្គោ)

[៣០២] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អាវាសិកភិក្ខុ គឺភិក្ខុដែលនៅក្នុងអាវាស ប្រកបដោយអង្គប៉ុន្មាន រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ អាវាសិកភិក្ខុ ដែលប្រកបដោយអង្គ៥ រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច១ ប្រើប្រាស់នូវវត្ថុជារបស់សង្ឃ ដោយការប្រើប្រាស់ដូចជារបស់បុគ្គល១។ ម្នាលឧបាលិ អាវាសិកភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង រមែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទំលាក់។ ម្នាលឧបាលិ អាវាសិកភិក្ខុ ដែលប្រកបដោយអង្គ៥ រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ មិនប្រើប្រាស់វត្ថុជារបស់សង្ឃ ដោយការប្រើប្រាស់ដូចជារបស់បុគ្គល១។ ម្នាលឧបាលិ អាវាសិកភិក្ខុ ដែលប្រកបដោយអង្គ៥នេះឯង រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក។

[៣០៣] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការដោះស្រាយវិន័យ មិនប្រកបដោយធម៌ មានប៉ុន្មានយ៉ាង។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ការដោះស្រាយវិន័យ មិនប្រកបដោយធម៌ មាន៥យ៉ាងនេះ។ ៥យ៉ាង តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ បង្អោន[62] នូវសភាវៈមិនមែនធម៌ ថាជាធម៌១ បង្អោននូវធម៌ ថាមិនមែនជាធម៌១ បង្អោននូវសភាវៈមិនមែនវិន័យ ថាជាវិន័យ១ បង្អោននូវវិន័យ ថាមិនមែនជាវិន័យ១ បញ្ញត្តនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្ត ទាំងដកសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ១។ ម្នាលឧបាលិ ការដោះស្រាយវិន័យ មិនប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។ ម្នាលឧបាលិ ការដោះស្រាយវិន័យ ដែលប្រកបដោយធម៌ មាន៥យ៉ាងនេះ។ ៥យ៉ាង តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ បង្អោននូវសភាវៈមិនមែនធម៌ ថាមិនមែនធម៌១ បង្អោននូវធម៌ ថាជាធម៌១ បង្អោននូវសភាវៈមិនមែនវិន័យ ថាមិនមែនវិន័យ១ បង្អោននូវវិន័យ ថាជាវិន័យ១ មិនបញ្ញត្តនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្ត ទាំងមិនដកសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ១។ ម្នាលឧបាលិ ការដោះស្រាយវិន័យ ដែលប្រកបដោយធម៌ មាន៥យ៉ាងនេះឯង។

[៣០៤] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលជាភត្តុទ្ទេសក៍[63] (អ្នកសំដែងភត្ត) ប្រកបដោយអង្គប៉ុន្មាន រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលជាភត្តុទ្ទេសក៍ ប្រកបដោយអង្គ៥ រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច១ មិនដឹងនូវភត្ត ដែលខ្លួនបានសំដែងហើយ ទាំងមិនទាន់បានសំដែង[64] ១។ ម្នាលឧបាលិ ភិក្ខុដែលជាភត្តុទ្ទេសក៍ ប្រកបដោយអង្គ៥នេះឯង រមែងធ្លាក់ចុះទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់។ ម្នាលឧបាលិ ភិក្ខុដែលជាភត្តុទ្ទេសក៍ ប្រកបដោយអង្គ៥ រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ ដឹងនូវភត្តដែលខ្លួនបានសំដែងហើយ ទាំងមិនទាន់បានសំដែង១។ ម្នាលឧបាលិ ភិក្ខុដែលជាភត្តុទ្ទេសក៍ ប្រកបដោយអង្គ៥នេះឯង រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក។ ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុអ្នកក្រាលសេនាសនៈ។បេ។ ភិក្ខុអ្នករក្សាឃ្លាំង ភិក្ខុអ្នកទទួលចីវរ ភិក្ខុអ្នកចែកចីវរ ភិក្ខុអ្នកចែកបបរ ភិក្ខុអ្នកចែកផ្លែឈើ ភិក្ខុអ្នកចែកបង្អែម ភិក្ខុអ្នកលះបង់នូវរបស់បន្តិចបន្តួច ភិក្ខុអ្នកប្រគល់សាដក ភិក្ខុអ្នកប្រគល់បាត្រ ភិក្ខុអ្នកប្រើនូវអារាមិកជន គឺញោមវត្ត ភិក្ខុអ្នកប្រើសាមណេរ ប្រកបដោយអង្គប៉ុន្មាន រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកប្រើសាមណេរ ប្រកបដោយអង្គ៥ រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុលំអៀងព្រោះសេចក្តីស្រឡាញ់១ លំអៀងព្រោះសេចក្តីស្អប់១ លំអៀងព្រោះសេចក្តីល្ងង់១ លំអៀងព្រោះសេចក្តីខ្លាច១ មិនដឹងនូវសាមណេរ ដែលខ្លួនបានប្រើ ទាំងមិនទាន់បានប្រើ[65] ១។ ម្នាលឧបាលិ ភិក្ខុអ្នកប្រើសាមណេរ ប្រកបដោយអង្គ៥នេះឯង រមែងធ្លាក់ទៅក្នុងនរក ហាក់ដូចជាគេនាំយកទៅទំលាក់។ ម្នាលឧបាលិ ភិក្ខុអ្នកប្រើសាមណេរ ប្រកបដោយអង្គ៥ រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក។ អង្គ៥ តើដូចម្តេច។ គឺភិក្ខុមិនលំអៀងព្រោះសេចក្តីស្រឡាញ់១ មិនលំអៀងព្រោះសេចក្តីស្អប់១ មិនលំអៀងព្រោះសេចក្តីល្ងង់១ មិនលំអៀងព្រោះសេចក្តីខ្លាច១ ដឹងនូវសាមណេរ ដែលខ្លួនបានប្រើ ទាំងមិនទាន់បានប្រើ១។ ម្នាលឧបាលិ ភិក្ខុអ្នកប្រើសាមណេរ ប្រកបដោយអង្គ៥នេះឯង រមែងទៅកើតក្នុងសួគ៌ ហាក់ដូចជាគេនាំយកទៅដំកល់ទុក។

ចប់ អាវាសិកវគ្គ ជាគំរប់១៣។

ឧទ្ទាន គឺបញ្ជីរឿងនៃអាវាសិកវគ្គ នោះដូច្នេះ

[៣០៥]

និយាយអំពីអាវាសិកភិក្ខុ១ ការដោះស្រាយវិន័យ១ ភិក្ខុជាភត្តុទ្ទេសក៍១ ភិក្ខុអ្នកក្រាលសេនាសនៈ១ ភិក្ខុអ្នករក្សាឃ្លាំង១ ភិក្ខុអ្នកទទួលចីវរ១ ភិក្ខុអ្នកចែកចីវរ១ ចែកបបរ១ ចែកផ្លែឈើ១ ចែកបង្អែម១ ភិក្ខុអ្នកលះបង់នូវវត្ថុបន្តិចបន្តួច១ ភិក្ខុអ្នកប្រគល់សាដក១ ភិក្ខុអ្នកប្រគល់បាត្រ១ ភិក្ខុអ្នកប្រើអារាមិកជន១ ភិក្ខុអ្នកប្រើសាមណេរ១។

## (កឋិនត្ថារវគ្គ ទី១៤)

CS vin.pv.14.14 | ភាគ ទី១៣

### (១៤. កឋិនត្ថារវគ្គោ)

[៣០៦] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អានិសង្សក្នុងការក្រាលកឋិនមានប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ អានិសង្សក្នុងការក្រាលកឋិនមាន៥។ អានិសង្ស៥យ៉ាង តើដូចម្តេច។ គឺការត្រាច់ទៅដោយមិនបាច់លាភិក្ខុផងគ្នា[66] ១ ការត្រាច់ទៅ ដោយមិនបាច់យកត្រៃចីវរឲ្យគ្រប់ទាំង៣ទៅក៏បាន១ ឆាន់គណភោជនបាន១ ប្រើប្រាស់អតិរេកចីវរបាន តាមសេចក្តីត្រូវការ១ ចីវរលាភដែលកើតឡើងក្នុងទីអាវាសនោះ នឹងបានដល់ភិក្ខុទាំងនោះ១។ ម្នាលឧបាលិ អានិសង្សក្នុងការក្រាលកឋិន មាន៥យ៉ាងនេះឯង។

[៣០៧] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ទោសរបស់ភិក្ខុអ្នកភ្លេចស្មារតី មិនដឹងខ្លួន ដេកលក់ មានប៉ុន្មាន។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ទោសរបស់ភិក្ខុអ្នកភ្លេចស្មារតី មិនដឹងខ្លួន ដេកលក់នេះ មាន៥។ ទោស៥យ៉ាង ដូចម្តេច។ គឺដេកលក់ជាទុក្ខ១ ភ្ញាក់ឡើងក៏ជាទុក្ខ១ យល់សប្តិឃើញមិនល្អ១ ទេវតាមិនរក្សា១ អសុចិឃ្លាតចេញ១។ ម្នាលឧបាលិ ទោសរបស់ភិក្ខុអ្នកភ្លេចស្មារតី មិនដឹងខ្លួន ដេកលក់ មាន៥យ៉ាងនេះឯង។ ម្នាលឧបាលិ អានិសង្សរបស់ភិក្ខុអ្នកមានសតិតាំងខ្ជាប់ ដឹងខ្លួន ដេកលក់ មាន៥យ៉ាង។ អានិសង្ស៥យ៉ាង តើដូច

ម្តេច។ គឺដេកលក់ជាសុខ១ ភ្ញាក់ឡើងក៏ជាសុខ១ មិនយល់សប្តិឃើញអាក្រក់១ ទេវតារក្សា១ អសុចិមិនឃ្លាតចេញ១។ ម្នាលឧបាលិ អានិសង្ស របស់ភិក្ខុអ្នកមានសតិតាំងខ្ជាប់ ដឹងខ្លួន ដេកលក់ មាន៥យ៉ាងនេះឯង។

[៣០៨] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលដែលភិក្ខុមិនគួរសំពះ មានប៉ុន្មានពួក។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ បុគ្គលដែលភិក្ខុមិនគួរសំពះ មាន៥ពួក។ បុគ្គល៥ពួក តើដូចម្តេច។ គឺភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ មិនគួរភិក្ខុសំពះ១ ដំពុងដើរតាមច្រកផ្លូវ មិនគួរសំពះ១ នៅក្នុងទីងងឹត មិនគួរសំពះ១ ភិក្ខុដែលកំពុងខ្វល់ខ្វាយដោយការងារ មិនបានអើពើនឹងការសំពះ មិនគួរសំពះ១ កំពុងដេកលក់ មិនគួរសំពះ១។ ម្នាលឧបាលិ បុគ្គល៥ពួកនេះឯង ភិក្ខុមិនគួរសំពះទេ។ ម្នាលឧបាលិ បុគ្គល៥ពួកដទៃទៀត ភិក្ខុមិនគួរសំពះ។ បុគ្គល៥ពួក តើដូចម្តេច។ គឺភិក្ខុកំពុងឆាន់បបរ មិនគួរសំពះ១ នៅក្នុងរោងភត្ត មិនគួរសំពះ១ ភិក្ខុងាកទៅក្នុងទីម្ខាង គឺបុគ្គលមានពៀរនឹងគ្នា ជាវិសភាគបុគ្គល មិនគួរសំពះ១ ភិក្ខុបញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃ គឺកំពុងគិតហេតុដទៃ មិនគួរសំពះ១ ភិក្ខុអាក្រាត មិនគួរសំពះ១។ ម្នាលឧបាលិ បុគ្គល៥ពួកនេះឯង មិនគួរសំពះឡើយ។ ម្នាលឧបាលិ បុគ្គល៥ពួកដទៃទៀត មិនគួរសំពះ។ បុគ្គល៥ពួក តើដូចម្តេច។ គឺភិក្ខុកំពុងឆាន់បង្អែម មិនគួរសំពះ១ កំពុងឆាន់ចំអាប មិនគួរសំពះ១ កំពុងបន្ទោបង់ឧច្ចារៈ មិនគួរសំពះ១ កំពុងបន្ទោបង់បស្សាវៈ មិនគួរសំពះ១ ភិក្ខុដែលសង្ឃលើកវត្ត មិនគួរសំពះ១។ ម្នាលឧបាលិ បុគ្គល៥ពួកនេះឯង មិនគួរសំពះឡើយ។ ម្នាលឧបាលិ បុគ្គល៥ពួកដទៃទៀត មិនគួរសំពះ។ បុគ្គល៥ពួក តើដូចម្តេច។ គឺភិក្ខុដែលបានឧបសម្បទាក្រោយ ភិក្ខុដែលបានឧបសម្បទាមុន មិនគួរសំពះ១ អនុបសម្បន្ន ភិក្ខុមិនគួរសំពះ១ ភិក្ខុមានសំវាសផ្សេងគ្នា ទោះបីចាស់ជាង តែជាអធម្មវាទី ភិក្ខុមិនគួរសំពះ១ មាតុគ្រាម ភិក្ខុមិនគួរសំពះ១ បណ្ឌកៈ ភិក្ខុមិនគួរសំពះ១។ ម្នាលឧបាលិ បុគ្គល៥ពួកនេះឯង មិនគួរសំពះឡើយ។ ម្នាលឧបាលិ បុគ្គល៥ពួកដទៃទៀត ក៏មិនគួរសំពះ។ បុគ្គល៥ពួក តើដូចម្តេច។ គឺភិក្ខុដែលកំពុងនៅបរិវាស មិនគួរសំពះ១ ភិក្ខុដែលគួរនឹងទាញមកដាក់ក្នុងមូលាបត្តិ មិនគួរសំពះ១ ភិក្ខុគួរដល់មានត្ត មិនគួរសំពះ១ ភិក្ខុកំពុងប្រព្រឹត្តមានត្ត មិនគួរសំពះ១ ភិក្ខុគួរដល់អព្ភានកម្ម មិនគួរសំពះ១។ ម្នាលឧបាលិ បុគ្គល៥ពួកនេះឯង មិនគួរសំពះឡើយ។

[៣០៩] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលដែលគួរសំពះ មានប៉ុន្មានពួក។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ បុគ្គលដែលគួរសំពះ មាន៥ពួក។ បុគ្គល៥ពួក តើដូចម្តេច។ គឺភិក្ខុដែលបានឧបសម្បទាក្រោយ គួរសំពះ១ ភិក្ខុដែលមានសំវាសផ្សេងគ្នា ដែលចាស់ជាង ហើយជាធម្មវាទី គួរសំពះ១ ភិក្ខុជាអាចារ្យ គួរសំពះ១ ភិក្ខុជាឧបជ្ឈាយ៍ គួរសំពះ១ ព្រះតថាគត អរហន្ត សម្មាសម្ពុទ្ធក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ភិក្ខុគួរថ្វាយបង្គំ១។ ម្នាលឧបាលិ បុគ្គល៥ពួកនេះឯង ភិក្ខុគួរសំពះ។

[៣១០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវដំកល់ធម៌ប៉ុន្មានយ៉ាងទុកខាងក្នុង ទើបថ្វាយបង្គំចំពោះបាទា។ ព្រះអង្គ ទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវដំកល់ធម៌៥យ៉ាង ទុកខាងក្នុង ទើបថ្វាយបង្គំចំពោះបាទា។ ធម៌៥យ៉ាង តើដូចម្តេច។ ម្នាលឧបាលិ ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង១ ផ្គងអញ្ជលី១ ច្របាច់បាទាដោយបាតដៃទាំងគូ១ ដំកល់សេចក្តីស្រឡាញ់ទុក១ សេចក្តីគោរព១ ទើបថ្វាយបង្គំចំពោះបាទាបាន។ ម្នាលឧបាលិ ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវដំកល់ធម៌៥យ៉ាងនេះឯង ទុកខាងក្នុង ទើបថ្វាយបង្គំចំពោះបាទា។

ចប់ កឋិនត្ថារវគ្គ ជាគំរប់១៤។

ឧទ្ទាន គឺបញ្ជីរឿងនៃកឋិនត្ថារវគ្គនោះដូច្នេះ

[៣១១]

និយាយអំពីអានិសង្សក្រាលកឋិន១ ទោសរបស់ភិក្ខុភ្លេចស្មារតីដេកលក់១ ភិក្ខុកំពុងចូលទៅក្នុងចន្លោះផ្ទះ មិនគួរសំពះ១ ភិក្ខុកំពុងឆាន់បបរ មិនគួរសំពះ១ ភិក្ខុកំពុងឆាន់បង្អែម និងចំអាប មិនគួរសំពះ១ ភិក្ខុបួសមុន មិនគួរសំពះភិក្ខុបួសក្រោយ១ ភិក្ខុកំពុងនៅបរិវាស មិនគួរសំពះ១ បុគ្គលដែលគួរសំពះ១ ភិក្ខុខ្ចីជាង គួរថ្វាយបង្គំបាទាភិក្ខុចាស់ជាង១។

ចប់ ឧបាលិបញ្ចកៈ តែប៉ុណ្ណេះ។

ឧទ្ទាន គឺបញ្ជីរឿងនៃវគ្គទាំងនោះ ដូច្នេះ

[៣១២]

និយាយអំពីអនិស្សិតវគ្គ១ កម្មនប្បដិប្បស្សម្ភនវគ្គ១ វោហារវគ្គ១ ទិដ្ឋាវិកម្មវគ្គ១ ចោទនាកណ្ឌវគ្គ១ ធុតង្គវគ្គ១ មុសាវាទវគ្គ១ ភិក្ខុនោវាទវគ្គ១ ឧព្វាហិកាវគ្គ១ អធិករណវូបសមវគ្គ១ សង្ឃភេទវគ្គមានធម៌៥យ៉ាង១ ទុតិយសង្ឃភេទវគ្គ មានធម៌៥យ៉ាង ដូចមុន១ អាវាសិកវគ្គ១ កឋិនត្ថារវគ្គ១ រួមទាំងអស់ ត្រូវជា១៤វគ្គ ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសទុកមកហើយដោយល្អ។

# សមុដ្ឋាន

## (អត្ថាបត្តិសមុដ្ឋានំ)

## (បារាជិក ទី១)

CS vin.pv.15.01 | ភាគ ទី១៣

### (១. បារាជិកំ)

[៣១៣] អាបត្តិដែលភិក្ខុមិនមានចិត្តគិត ហើយត្រូវ មានចិត្តគិត ហើយចេញចាកអាបត្តិក៏មាន អាបត្តិដែលភិក្ខុមានចិត្តគិត ហើយត្រូវ មិនមានចិត្តគិត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមិនមានចិត្តគិត ហើយត្រូវ មិនមានចិត្តគិត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានចិត្តគិត ហើយត្រូវ មានចិត្តគិត ហើយចេញចាកអាបត្តិនោះក៏មាន។ អាបត្តិដែលភិក្ខុមានកុសលចិត្ត ហើយត្រូវ មានកុសលចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានកុសលចិត្ត ហើយត្រូវ មានអកុសលចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានកុសលចិត្ត ហើយត្រូវ មានអព្យាកតចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអកុសលចិត្ត ហើយត្រូវ មានកុសលចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអកុសលចិត្ត ហើយត្រូវ មានអកុសលចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអកុសលចិត្ត ហើយត្រូវ មានអព្យាកតចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន។ អាបត្តិដែលភិក្ខុមានអព្យាកតចិត្ត ហើយត្រូវ មានកុសលចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអព្យាកតចិត្ត ហើយត្រូវ មានអកុសលចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន អាបត្តិដែលភិក្ខុមានអព្យាកតចិត្ត ហើយត្រូវ មានអព្យាកតចិត្ត ហើយចេញចាកអាបត្តិនោះក៏មាន។

[៣១៤] បឋមបារាជិក តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ បឋមបារាជិក តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងចិត្ត មិនតាំងឡើងអំពីវាចា។ ទុតិយបារាជិក តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ ទុតិយបារាជិក តាំងឡើងអំពីសមុដ្ឋាន៣ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។ តតិយបារាជិក តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ តតិយបារាជិក តាំងឡើងអំពីសមុដ្ឋាន៣ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។ ចតុត្ថបារាជិក តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ ចតុត្ថបារាជិក តាំងឡើងអំពីសមុដ្ឋាន៣ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។

ចប់ បារាជិក៤។

## (សង្ឃាទិសេស ទី២)

CS vin.pv.15.02 | ភាគ ទី១៣

### (២. សង្ឃាទិសេសំ)

[៣១៥] អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលព្យាយាមធ្វើអសុចិឲ្យឃ្លាតចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលព្យាយាមធ្វើអសុចិឲ្យឃ្លាតចេញ តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចា។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលដល់ព្រមនូវកាយសំសគ្គៈ មួយអន្លើដោយមាតុគ្រាម តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលដល់ព្រមនូវកាយសំសគ្គៈ មួយអន្លើដោយមាតុគ្រាម តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចា។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលពោលល្បួងមាតុគ្រាម ដោយវាចាអាក្រក់ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលពោលល្បួងមាតុគ្រាម ដោយវាចាអាក្រក់ តាំងឡើងអំពីសមុដ្ឋាន៣ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលពោលសសើរការបម្រើដោយកាម ដើម្បីខ្លួន ក្នុងសំណាក់នៃមាតុគ្រាម តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលពោលសសើរការបម្រើដោយកាម ដើម្បីខ្លួន ក្នុងសំណាក់នៃមាតុគ្រាម តាំងឡើងអំពីសមុដ្ឋាន៣។បេ។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលប្រព្រឹត្តជីកនាំ (បុរសស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ) តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលប្រព្រឹត្តជីកនាំ តាំងឡើងអំពីសមុដ្ឋាន៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចា និងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយ និងចិត្តក៏មាន តាំងឡើងអំពីកាយ និងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលឲ្យគេធ្វើកុដិ ដោយសូមគ្រឿងឧបករណ៍អំពីគេមកដោយខ្លួនឯង តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលឲ្យគេធ្វើកុដិ ដោយសូមគ្រឿងឧបករណ៍អំពីគេមកដោយខ្លួនឯង តាំងឡើងអំពីសមុដ្ឋាន៦។បេ។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលឲ្យគេធ្វើវិហារធំ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលឲ្យគេធ្វើវិហារធំ តាំងឡើងអំពីសមុដ្ឋាន៦។បេ។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក មិនមានមូល តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក មិនមានមូល តាំងឡើងអំពីសមុដ្ឋាន៣។បេ។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ ជាចំណែកដទៃ មកជាគ្រឿងអាង ហើយចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ ជាចំណែកដទៃ មកជាគ្រឿងអាង ហើយចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក តាំងឡើងអំពីសមុដ្ឋាន៣។បេ។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុជាអ្នកទំលាយសង្ឃ ដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុជាអ្នកទំលាយសង្ឃ ដែលសង្ឃសូត្រសមនុភាសនកម្ម ជាគំរប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងវាចា និងចិត្ត។ អាបត្តិសង្ឃាទិសេស របស់ពួកភិក្ខុដែលប្រព្រឹត្តតាមភិក្ខុ

ជាអ្នកទំលាយសង្ឃ ដែលសង្ឃសូត្រសមនុភាសនកម្ម ជាគំរប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ពួកភិក្ខុដែលប្រព្រឹត្តតាមភិក្ខុ ជាអ្នកទំលាយសង្ឃ ដែលសង្ឃសូត្រសមនុភាសនកម្ម ជាគំរប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងវាចា និងចិត្ត។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលគេប្រដៅក្រ ដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលគេប្រដៅក្រ ដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងវាចា និងចិត្ត។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលទ្រុស្តត្រកូល ដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិសង្ឃាទិសេស របស់ភិក្ខុដែលទ្រុស្តត្រកូល ដែលសង្ឃសូត្រសមនុភាសនកម្ម (ហាមប្រាម) ជាគំរប់៣ដងហើយ នៅតែមិនលះបង់កម្មនោះចេញ តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងវាចា និងចិត្ត។

ចប់ សង្ឃាទិសេស ១៣។

[៣១៦]។បេ។ អាបត្តិទុក្កដរបស់ភិក្ខុដែលអាស្រ័យសេចក្ដីមិនអើពើបន្ទោបង់ឧច្ចារៈក្ដី បស្សាវៈក្ដី ស្ដោះទឹកមាត់ក្ដីក្នុងទឹក តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អាបត្តិទុក្កដរបស់ភិក្ខុដែលអាស្រ័យសេចក្ដីមិនអើពើ បន្ទោបង់ឧច្ចារៈក្ដី បស្សាវៈក្ដី ស្ដោះទឹកមាត់ក្ដី ក្នុងទឹក តាំងឡើងអំពីសមុដ្ឋាន១ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចា។

ចប់ សេក្ខិយៈ។

## (បារាជិកាទិ ទី៣)

CS vin.pv.15.03 | ភាគ ទី១៣

### (៣. បារាជិកាទិ)

[៣១៧] បារាជិកទាំង៤ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ បារាជិកទាំង៤ តាំងឡើងអំពីសមុដ្ឋាន៣ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។

[៣១៨] សង្ឃាទិសេសទាំង១៣ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ សង្ឃាទិសេសទាំង១៣ តាំងឡើងអំពីសមុដ្ឋាន៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចា និងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយ និងចិត្តក៏មាន តាំងឡើងអំពីកាយ និងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។

[៣១៩] អនិយតៈទាំង២ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ អនិយតៈទាំង២ តាំងឡើងអំពីសមុដ្ឋាន៣ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។

[៣២០] និស្សគ្គិយៈបាចិត្តិយៈទាំង៣០ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ និស្សគ្គិយបាចិត្តិយៈទាំង៣០ តាំងឡើងអំពីសមុដ្ឋាន៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចា និងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយ និងចិត្តក៏មាន តាំងឡើងអំពីកាយ និងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។

[៣២១] បាចិត្តិយៈទាំង៩២ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ បាចិត្តិយៈទាំង៩២ តាំងឡើងអំពីសមុដ្ឋាន៦ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចា និងចិត្តក៏មាន តាំងឡើងអំពីវាចា មិនបានតាំងឡើងអំពីកាយ និងចិត្តក៏មាន តាំងឡើងអំពីកាយ និងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។

[៣២២] បាដិទេសនីយៈទាំង៤ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ បាដិទេសនីយៈទាំង៤ តាំងឡើងអំពីសមុដ្ឋាន៤ គឺតាំងឡើងអំពីកាយ មិនបានតាំងឡើងអំពីវាចា និងចិត្តក៏មាន តាំងឡើងអំពីកាយ និងវាចា មិនបានតាំងឡើងអំពីចិត្តក៏មាន តាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។

[៣២៣] សេក្ខិយៈទាំង៧៥ តាំងឡើងអំពីសមុដ្ឋានប៉ុន្មាន។ សេក្ខិយៈទាំង៧៥ តាំងឡើងអំពីសមុដ្ឋាន៣ គឺតាំងឡើងអំពីកាយ និងចិត្ត មិនបានតាំងឡើងអំពីវាចាក៏មាន តាំងឡើងអំពីវាចា និងចិត្ត មិនបានតាំងឡើងអំពីកាយក៏មាន តាំងឡើងអំពីកាយ និងវាចា និងចិត្តក៏មាន។

ចប់ សមុដ្ឋាន តែប៉ុណ្ណេះ។

ឧទ្ទាន គឺបញ្ជីរឿងនៃសមុដ្ឋាននោះដូច្នេះ

[៣២៤]

និយាយអំពីអាបត្តិ ដែលភិក្ខុមិនមានចិត្តគិត១ មានកុសលចិត្ត១ និយាយអំពីសមុដ្ឋាន នៃអាបត្តិទាំងអស់១ អ្នកទាំងឡាយ ចូរដឹងសមុដ្ឋានដោយបញ្ញាដ៏សមគួរដល់អាបត្តិចុះ។

# ទុតិយគាថាសង្គណិកៈ

CS vin.pv.16 | ភាគ ទី១៣

### (ទុតិយគាថាសង្គណិកំ)

## (កាយិកាទិអាបត្តិ ទី១)

CS vin.pv.16.01 | ភាគ ទី១៣

### (១. កាយិកាទិអាបត្តិ)

[៣២៥] សួរថា អាបត្តិដែលតាំងឡើងអំពីកាយ មានប៉ុន្មាន អាបត្តិដែលតាំងឡើងអំពីវាចា មានប៉ុន្មាន អាបត្តិប៉ុន្មាន មានដល់ឧបសម្បន្ន ដែលបិទបាំងទោសទុក អាបត្តិប៉ុន្មាន ដែលត្រូវព្រោះបច្ច័យ គឺការប៉ះពាល់នូវកាយ។ ឆ្លើយថា អាបត្តិ ដែលតាំងឡើងអំពីកាយ មាន៦ អាបត្តិដែលតាំងឡើងអំពីវាចា មាន៦ អាបត្តិ៣មានដល់ឧបសម្បន្ន ដែលបិទបាំងទោសទុក អាបត្តិ៥ ដែលត្រូវព្រោះបច្ច័យ គឺការប៉ះពាល់នូវកាយ។

[៣២៦] អាបត្តិដែលត្រូវក្នុងវេលាអរុណរះឡើង មានប៉ុន្មាន អាបត្តិដែលត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគំរប់៣ដង មានប៉ុន្មាន អាបត្តិដែលត្រូវ ព្រោះបំពេញនូវវត្ថុគ្រប់ទាំង៨ មានប៉ុន្មាន ក្នុងសាសនានេះ ការសង្គ្រោះទាំងអស់ ដោយឧទ្ទេសប៉ុន្មាន។ អាបត្តិដែលត្រូវក្នុងវេលាអរុណរះឡើង មាន៣ អាបត្តិដែលត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគំរប់៣ដង មាន២ អាបត្តិដែលត្រូវ ព្រោះបំពេញនូវវត្ថុឲ្យគ្រប់ទាំង៨ មានតែ១ ក្នុងសាសនានេះ ការសង្គ្រោះទាំងអស់ ដោយឧទ្ទេសតែ១ គឺនិទានុទ្ទេស។

[៣២៧] មូលរបស់វិន័យមានប៉ុន្មាន ដែលព្រះពុទ្ធទ្រង់បញ្ញត្តទុកមក គរុកាបត្តិក្នុងវិន័យ មានប៉ុន្មាន ដែលព្រះអង្គទ្រង់ត្រាស់ទុកមក អាបត្តិដែលត្រូវ ព្រោះបិទបាំងទុដ្ឋុល្លាបត្តិ មានប៉ុន្មាន។ មូលរបស់វិន័យមាន២ ដែលព្រះពុទ្ធ ទ្រង់បញ្ញត្តទុកមក គរុកាបត្តិក្នុងវិន័យមាន២ ដែលព្រះពុទ្ធទ្រង់ត្រាស់ទុកមក ដែលត្រូវព្រោះបិទបាំងទុដ្ឋុល្លាបត្តិ មាន ២។[67)]

[៣២៨] អាបត្តិប៉ុន្មាន ដែលត្រូវក្នុងចន្លោះផ្ទះ អាបត្តិប៉ុន្មាន ដែលត្រូវ ព្រោះឆ្លងទៅកាន់ត្រើយស្ទឹង ជាបច្ច័យ សាច់ប៉ុន្មានប្រការ ដែលភិក្ខុឆាន់ ត្រូវថុល្លច្ច័យ សាច់ប៉ុន្មានប្រការ ដែលភិក្ខុឆាន់ ត្រូវទុក្កដ។ អាបត្តិ៤ ដែលត្រូវក្នុងចន្លោះផ្ទះ អាបត្តិ៤ ដែលត្រូវព្រោះឆ្លងទៅកាន់ត្រើយស្ទឹង ជាបច្ច័យ សាច់មនុស្សតែម្យ៉ាង ដែលឆាន់ ត្រូវអាបត្តិថុល្លច្ច័យ សាច់៩ប្រការដែលភិក្ខុឆាន់ ត្រូវអាបត្តិទុក្កដ។

[៣២៩] អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីវាចា ហើយត្រូវតែក្នុងរាត្រី អាបត្តិប៉ុន្មាន ដែលតាំងឡើងអំពីវាចា ហើយត្រូវតែក្នុងវេលាថ្ងៃ អាបត្តិប៉ុន្មាន មានដល់ឧបសម្បន្នដែលឲ្យ អាបត្តិប៉ុន្មាន មានដល់ឧបសម្បន្នដែលទទួល។ អាបត្តិ២ប្រកបដោយវាចា ហើយត្រូវតែក្នុងរាត្រី អាបត្តិ២ ដែលតាំងឡើងអំពីវាចា ហើយត្រូវតែក្នុងវេលាថ្ងៃ អាបត្តិ៣ មានដល់ឧបសម្បន្នដែលឲ្យ អាបត្តិ៤ មានដល់ឧបសម្បន្នដែលទទួល។

## (ទេសនាគាមិនិយាទិអាបត្តិ ទី២)

CS vin.pv.16.02 | ភាគ ទី១៣

### (២. ទេសនាគាមិនិយាទិអាបត្តិ)

[៣៣០] អាបត្តិប៉ុន្មាន ដែលជាទេសនាគាមិនី អាបត្តិប៉ុន្មាន ដែលជាសប្បដិកម្ម[68)] ក្នុងសាសនានេះ មានអាបត្តិប៉ុន្មាន ដែលព្រះពុទ្ធ ជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ជាអប្បដិកម្ម[69)] ក្នុងសាសនានេះ។ អាបត្តិ ដែលជាទេសនាគាមិនីមាន៥ អាបត្តិ ដែលជាសប្បដិកម្ម មាន៦ អាបត្តិ១ ដែលព្រះពុទ្ធ ជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ជាអប្បដិកម្ម ក្នុងសាសនានេះ។

[៣៣១] អាបត្តិប៉ុន្មាន ដែលព្រះពុទ្ធ ជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ជាគរុកាបត្តិ ក្នុងវិន័យ សិក្ខាបទប៉ុន្មាន ដែលតាំងឡើងអំពីកាយ និងវាចា រសស្រូវប៉ុន្មាន ដែលគួរឆាន់បាន ក្នុងវេលាវិកាល ការសន្មតិដោយញត្តិចតុត្ថកម្មវាចា មានប៉ុន្មាន។ អាបត្តិ២យ៉ាង ដែលព្រះពុទ្ធ ជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ជាគរុកាបត្តិ ក្នុងវិន័យ សិក្ខាបទទាំងអស់ សុទ្ធតែតាំងឡើងអំពីកាយ និងវាចា រសស្រូវតែ១ គឺថ្នាំឈ្មោះ លោណសោចិរកៈ[70)] ដែលគួរឆាន់បាន ក្នុងវេលាវិកាល ការសន្មតិដោយញត្តិចតុត្ថកម្មវាចា មានតែ១។

[៣៣២] អាបត្តិបារាជិក ដែលតាំងឡើងអំពីកាយ មានប៉ុន្មាន ភូមិនៃសំវាស មានប៉ុន្មាន រាត្រីដាច់ មានដល់ភិក្ខុប៉ុន្មានពួក ព្រះអង្គបញ្ញត្តខ្នាតត្រឹមពីរធ្នាប់ មានប៉ុន្មានសិក្ខាបទ។ អាបត្តិបារាជិក ដែលតាំងឡើងអំពីកាយ មាន២ ភូមិនៃសំវាស មាន២ រាត្រីដាច់ មានដល់ភិក្ខុ២ពួក (ភិក្ខុកំពុងនៅបរិវាស១ ប្រព្រឹត្តមានត្ត១) ព្រះអង្គ ទ្រង់បញ្ញត្តខ្នាតត្រឹមពីរធ្នាប់ មាន២សិក្ខាបទ។[71)]

[៣៣៣] ភិក្ខុនីវាយខ្លួនឯង ត្រូវអាបត្តិប៉ុន្មាន សង្ឃបែកគ្នា ដោយអាការប៉ុន្មាន អាបត្តិដែលត្រូវជាដំបូង ក្នុងវិន័យនេះ មានប៉ុន្មាន ការធ្វើញត្តិមានប៉ុន្មាន។ ភិក្ខុនី វាយខ្លួនឯង ត្រូវអាបត្តិ២ សង្ឃបែកគ្នាដោយអាការ២ អាបត្តិដែលត្រូវជាដំបូង ក្នុងវិន័យនេះ មាន២ ការធ្វើញត្តិមាន២។

[៣៣៤] ក្នុងបាណាតិបាត មានអាបត្តិប៉ុន្មាន អាបត្តិបារាជិក ដែលតាំងឡើងអំពីវាចា មានប៉ុន្មាន អាបត្តិដែលភិក្ខុនិយាយល្បួងមាតុគ្រាម ដោយពាក្យអាក្រក់ មានប៉ុន្មាន អាបត្តិប៉ុន្មាន ដែលភិក្ខុត្រូវ ព្រោះការដឹកនាំបុរស និងស្ត្រី ឲ្យបានគ្នាជាប្តីប្រពន្ធ។ ក្នុងបាណាតិបាត មានអាបត្តិ៣ អាបត្តិបារាជិក ដែលតាំងឡើងអំពីវាចា មាន៣ អាបត្តិដែលភិក្ខុនិយាយល្បួងមាតុគ្រាម ដោយពាក្យអាក្រក់ មាន៣ អាបត្តិ៣ ត្រូវ (ព្រោះការដឹកនាំបុរស និងស្ត្រី ឲ្យបានគ្នាជាប្តីប្រពន្ធ)។

[៣៣៥] បុគ្គលដែលមិនត្រូវឲ្យឧបសម្បទា មានប៉ុន្មានពួក ការសង្គ្រោះកម្ម មានប៉ុន្មាន បុគ្គលដែលព្រះអង្គ ទ្រង់ត្រាស់ថា ត្រូវឲ្យវិនាស មានប៉ុន្មាន ជនប៉ុន្មានពួក ដែលត្រូវសូត្រកម្មវាចាតែម្តងបាន។ បុគ្គលដែលមិនត្រូវឲ្យឧបសម្បទា មាន៣ពួក ការសង្គ្រោះកម្ម មាន៣ បុគ្គលដែលព្រះអង្គ ទ្រង់ត្រាស់ថា ត្រូវឲ្យវិនាស មាន៣ពួក ជន៣ពួក ដែលត្រូវសូត្រកម្មវាចាតែម្តងបាន។

[៣៣៦] ក្នុងអទិន្នាទាន មានអាបត្តិប៉ុន្មាន អាបត្តិព្រោះមេថុនជាបច្ច័យ មានប៉ុន្មាន អាបត្តិប៉ុន្មាន មានដល់ភិក្ខុដែលកាត់ អាបត្តិប៉ុន្មាន ដែលភិក្ខុត្រូវ ព្រោះចោលជាបច្ច័យ។ ក្នុងអទិន្នាទាន មានអាបត្តិ៣ អាបត្តិព្រោះមេថុនជាបច្ច័យ មាន៤ អាបត្តិ៣ មានដល់ភិក្ខុដែលកាត់ អាបត្តិ៥ ដែលភិក្ខុត្រូវ ព្រោះចោលជាបច្ច័យ។

[៣៣៧] ក្នុងភិក្ខុនោវាទកវគ្គ មានអាបត្តិទុក្កដ លាយដោយអាបត្តិបាចិត្តិយៈដែរឬទេ នវកៈក្នុងបឋមសិក្ខាបទនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា មានប៉ុន្មាន អាបត្តិដែលត្រូវ ព្រោះចីវរ មានដល់ភិក្ខុប៉ុន្មានពួក។ ក្នុងភិក្ខុនោវាទកវគ្គ ក៏មានអាបត្តិទុក្កដ លាយដោយអាបត្តិបាចិត្តិយៈដែរ ក្នុងបឋមសិក្ខាបទនេះ មាននវកៈ៤ ដែលព្រះអង្គ ទ្រង់ត្រាស់ទុកមកហើយ អាបត្តិដែលត្រូវ ព្រោះចីវរ មានដល់ភិក្ខុពីរពួក។

[៣៣៨] អាបត្តិបាដិទេសនីយៈរបស់ភិក្ខុនី ព្រះអង្គ ទ្រង់ត្រាស់ថាមានប៉ុន្មាន អាបត្តិទុក្កដ លាយដោយអាបត្តិបាចិត្តិយៈ ព្រោះសូមស្រូវស្រស់ យកមកឆាន់ មានដែរឬទេ។ អាបត្តិបាដិទេសនីយៈរបស់ភិក្ខុនី ព្រះអង្គ ទ្រង់ត្រាស់ថា មាន៨ អាបត្តិទុក្កដ លាយដោយអាបត្តិបាចិត្តិយៈ ព្រោះសូមស្រូវស្រស់ យកមកឆាន់ ក៏មានដែរ។

[៣៣៩] អាបត្តិប៉ុន្មាន មានដល់ភិក្ខុដែលដើរ អាបត្តិប៉ុន្មាន មានដល់ភិក្ខុដែលឈរ អាបត្តិប៉ុន្មាន មានដល់ភិក្ខុដែលអង្គុយ អាបត្តិប៉ុន្មាន មានដល់ភិក្ខុដែលដេក។ អាបត្តិ៤ មានដល់ភិក្ខុដែលដើរ ឯភិក្ខុដែលឈរ ក៏មានអាបត្តិប៉ុណ្ណោះដែរ អាបត្តិ៤ មានដល់ភិក្ខុដែលអង្គុយ ឯភិក្ខុដែលដេក ក៏មានអាបត្តិប៉ុណ្ណោះដែរ។

## (បាចិត្តិយៈ ទី៣)

CS vin.pv.16.03 | ភាគ ទី១៣

### (៣. បាចិត្តិយំ)

[៣៤០] ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ក្នុងខណៈមួយ មិនមុនមិនក្រោយ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់៥ ដែលមានវត្ថុផ្សេងៗគ្នា ក្នុងខណៈមួយ មិនមុនមិនក្រោយ។

[៣៤១] ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ក្នុងខណៈមួយ មិនមុនមិនក្រោយ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់៩ ដែលមានវត្ថុផ្សេងៗគ្នា ក្នុងខណៈមួយ មិនមុនមិនក្រោយ។

[៣៤២] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរសំដែងដោយវាចាប៉ុន្មានដងបាន។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់៥ ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរសំដែងដោយវាចាតែម្តងបាន។

[៣៤៣] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរសំដែងដោយវាចាប៉ុន្មានដងបាន។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់៩ ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរសំដែងដោយវាចាតែម្តងបាន។

[៣៤៤] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរប្រាប់អ្វី ទើបសំដែងបាន។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់៥ ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរប្រាប់វត្ថុ ទើបសំដែងបាន។

[៣៤៥] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់ប៉ុន្មាន ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរប្រាប់អ្វី ទើបសំដែងបាន។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ទុកមកថា ភិក្ខុត្រូវអាបត្តិបាចិត្តិយៈទាំងអស់៩ ដែលមានវត្ថុផ្សេងៗគ្នា ហើយគួរប្រាប់វត្ថុ ទើបសំដែងបាន។

[៣៤៦] អាបត្តិប៉ុន្មានយ៉ាង ដែលត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគំរប់៣ដង អាបត្តិប៉ុន្មាន ដែលត្រូវ ព្រោះពោលជាបច្ច័យ អាបត្តិប៉ុន្មាន ដែលត្រូវ ព្រោះទំពាស៊ី (សាច់) អាបត្តិប៉ុន្មាន ដែលត្រូវ ព្រោះភោជនជាបច្ច័យ។ អាបត្តិ៣ ដែលត្រូវក្នុងខណៈដែលសង្ឃសូត្រសមនុភាសនកម្មចប់ ជាគំរប់៣ដង អាបត្តិ៦ ដែលត្រូវ ព្រោះពោលជាបច្ច័យ។ អាបត្តិ៣ ដែលត្រូវ ព្រោះទំពាស៊ី (សាច់) អាបត្តិ៥ ដែលត្រូវ ព្រោះភោជនជាបច្ច័យ។

[៣៤៧] យាវតតិយកាបត្តិទាំងអស់ រមែងដល់នូវស្ថានប៉ុន្មាន មួយទៀត អាបត្តិមានដល់បុគ្គលប៉ុន្មានពួក អធិករណ៍ មានដល់បុគ្គលប៉ុន្មានពួក។ យាវតតិយកាបត្តិទាំងអស់ រមែងដល់នូវស្ថាន៥ អាបត្តិមានដល់បុគ្គល៥ពួក អធិករណ៍ មានដល់បុគ្គល៥ពួក។

[៣៤៨] ការវិនិច្ឆ័យ មានដល់បុគ្គលប៉ុន្មានពួក ការរម្ងាប់អធិករណ៍ មានដល់បុគ្គលប៉ុន្មានពួក អនាបត្តិ មានដល់បុគ្គលប៉ុន្មានពួក បុគ្គលរុងរឿងដោយស្ថានប៉ុន្មានយ៉ាង។ ការវិនិច្ឆ័យ មានដល់បុគ្គល៥ពួក ការរម្ងាប់អធិករណ៍ មានដល់បុគ្គល៥ពួក អនាបត្តិ មានដល់បុគ្គល៥ពួក បុគ្គលរុងរឿងដោយស្ថាន៣យ៉ាង។

[៣៤៩] អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងរាត្រី មានប៉ុន្មាន អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងវេលាថ្ងៃ មានប៉ុន្មាន អាបត្តិប៉ុន្មាន ដែលត្រូវព្រោះគយគន់ អាបត្តិប៉ុន្មាន ដែលត្រូវ ព្រោះបិណ្ឌបាតជាបច្ច័យ។ អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងរាត្រី មាន២ អាបត្តិដែលតាំងឡើងអំពីកាយ ហើយត្រូវតែក្នុងវេលាថ្ងៃ មាន២ អាបត្តិតែ១ ដែលត្រូវព្រោះគយគន់ (មើលអង្គជាតមាតុគ្រាមដោយតម្រេក) អាបត្តិតែ១ ដែលត្រូវ ព្រោះបិណ្ឌបាតជាបច្ច័យ។[72)]

[៣៥០] ភិក្ខុឃើញអានិសង្សប៉ុន្មាន ទើបសំដែងធម៌ដល់អ្នកដទៃដោយសទ្ធា ឧក្ខិត្តកភិក្ខុ (ភិក្ខុដែលសង្ឃលើកវត្ត) ព្រះមានព្រះភាគត្រាស់ថាមានប៉ុន្មាន ការប្រព្រឹត្តវត្តដោយប្រពៃ មានប៉ុន្មាន។ ភិក្ខុឃើញអានិសង្ស៨យ៉ាង ទើបសំដែងធម៌ដល់អ្នកដទៃដោយសទ្ធា ឧក្ខិត្តកភិក្ខុ ព្រះមានព្រះភាគ ត្រាស់ថាមាន៣ពួក ការប្រព្រឹត្តវត្តដោយប្រពៃ មាន៤៣។

[៣៥១] មុសាវាទ ដល់នូវស្ថានប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អាបត្តិប៉ុន្មាន ដែលមានកំណត់ថ្ងៃ អាបត្តិបាដិទេសនីយៈមានប៉ុន្មាន មួយទៀត បុគ្គលប៉ុន្មានពួក ដែលគួរសំដែងទោស។ មុសាវាទ ដល់នូវស្ថាន៥យ៉ាង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អាបត្តិ ដែលមានកំណត់ថ្ងៃ (នោះ) មាន១៤ អាបត្តិបាដិទេសនីយៈមាន១២ (ដោយរួមទាំងភិក្ខុ ភិក្ខុនី) បុគ្គល៤ពួក ដែលគួរសំដែងទោស។

[៣៥២] មុសាវាទ ប្រកបដោយអង្គប៉ុន្មាន ឧបោសថ មានអង្គប៉ុន្មាន អង្គរបស់ភិក្ខុដែលគួរដល់នូវទូតកម្ម មានប៉ុន្មាន ការប្រព្រឹត្តតិត្ថិយវត្ត មានប៉ុន្មាន។ មុសាវាទ ប្រកបដោយអង្គ៨ ឧបោសថ ប្រកបដោយអង្គ៨ អង្គរបស់ភិក្ខុដែលគួរដល់នូវទូតកម្ម មាន៨ ការប្រព្រឹត្តតិត្ថិយវត្ត មាន៨ប្រការ។

[៣៥៣] ឧបសម្បទា (របស់ភិក្ខុនី) ប្រកបដោយកម្មវាចាប៉ុន្មាន ភិក្ខុនីត្រូវក្រោកទទួល ចំពោះភិក្ខុនីប៉ុន្មានពួក ត្រូវឲ្យអាសនៈ ដល់ភិក្ខុនីប៉ុន្មានពួក ភិក្ខុប្រកបដោយអង្គប៉ុន្មាន ទើបគួរប្រដៅភិក្ខុនីបាន។ ឧបសម្បទា (របស់ភិក្ខុនី) ប្រកបដោយកម្មវាចា៨ ភិក្ខុនីត្រូវក្រោកទទួល ចំពោះភិក្ខុនី៨ពួក ត្រូវឲ្យអាសនៈ ដល់ភិក្ខុនី៨ពួក ភិក្ខុប្រកបដោយអង្គ៨ ទើបគួរប្រដៅភិក្ខុនីបាន។

[៣៥៤] ឆេជ្ជវត្ថុ (វត្ថុជាហេតុឲ្យដាច់ចាកភិក្ខុភាវៈ) មានដល់បុគ្គលប៉ុន្មានពួក អាបត្តិថុល្លច្ច័យ មានដល់បុគ្គលប៉ុន្មានពួក អនាបត្តិ មានដល់បុគ្គលប៉ុន្មានពួក អាបត្តិ និងអនាបត្តិទាំងអស់ (នេះ) មានវត្ថុតែមួយទេឬ។ ឆេជ្ជវត្ថុ មានដល់បុគ្គល១ពួក អាបត្តិថុល្លច្ច័យ មានដល់បុគ្គល៤ពួក អនាបត្តិ មានដល់បុគ្គល៤ពួក អាបត្តិ និងអនាបត្តិទាំងអស់ (នេះ) មានវត្ថុតែ១។

[៣៥៥] អាឃាតវត្ថុ (វត្ថុជាហេតុឲ្យកើតចិត្តគុំគួន) មានប៉ុន្មាន សង្ឃបែកគ្នាដោយភិក្ខុប៉ុន្មានរូប ក្នុងវិន័យនេះ បឋមាបត្តិកាបត្តិ មានប៉ុន្មាន កិច្ចដែលធ្វើដោយញត្តិមានប៉ុន្មាន។ អាឃាតវត្ថុ មាន៩យ៉ាង សង្ឃបែកគ្នាដោយភិក្ខុ៩រូប ក្នុងវិន័យនេះ បឋមាបត្តិកាបត្តិ មាន៩យ៉ាង កិច្ចដែលធ្វើដោយញត្តិមាន៩យ៉ាង។

## (អវន្ទនីយបុគ្គលាទិ ទី៤)

CS vin.pv.16.04 | ភាគ ទី១៣

### (៤. អវន្ទនីយបុគ្គលាទិ)

[៣៥៦] បុគ្គលដែលមិនគួរអភិវាទ និងបុគ្គលដែលមិនគួរធ្វើអញ្ជលីកម្ម និងសាមីចិកម្ម មានប៉ុន្មានពួក អាបត្តិទុក្កដ មានដល់បុគ្គលប៉ុន្មានពួក ការទុកអតិរេកចីវរ បានប៉ុន្មានថ្ងៃ។ បុគ្គលដែលមិនគួរអភិវាទ និងបុគ្គលដែលមិនគួរធ្វើអញ្ជលីកម្ម និងសាមីចិកម្ម មាន១០ពួក អាបត្តិទុក្កដ មានដល់បុគ្គល១០ពួក ការទុកអតិរេកចីវរ បាន១០ថ្ងៃ។

[៣៥៧] ក្នុងសាសនានេះ បុគ្គលត្រូវឲ្យចីវរដល់បុគ្គលប៉ុន្មានពួក ដែលនៅចាំវស្សារួចហើយ កាលបើមានអ្នកទទួលដ៏សមគួរហើយ បុគ្គលត្រូវឲ្យចីវរ ដល់បុគ្គលប៉ុន្មានពួក មិនត្រូវឲ្យដល់បុគ្គលប៉ុន្មានពួក។ ក្នុងសាសនានេះ បុគ្គលត្រូវឲ្យចីវរដល់បុគ្គល៥ពួក[73)] ដែលនៅចាំវស្សារួចហើយ កាលបើមានអ្នកទទួលដ៏សមគួរ បុគ្គលត្រូវឲ្យចីវរ ដល់បុគ្គល៧ពួក មិនត្រូវឲ្យដល់បុគ្គល១៦ពួកទេ។

[៣៥៨] ភិក្ខុបិទបាំងអាបត្តិអស់មួយរយរាត្រី ត្រូវជាប៉ុន្មានរយអាបត្តិ ហើយចូលបរិវាស នៅប៉ុន្មានរាត្រី ទើបរួច (ចាកអាបត្តិ)បាន។ ភិក្ខុបិទបាំងអាបត្តិអស់មួយរយរាត្រី ត្រូវជាមួយពាន់[74)] អាបត្តិ ហើយចូលបរិវាស នៅ១០រាត្រី ទើបរួច (ចាកអាបត្តិនោះ)បាន។

[៣៥៩] ទោសរបស់កម្មមានប៉ុន្មាន ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិន័យវត្ថុ ក្នុងនគរចម្បា កម្មទាំងអស់ (នោះ) ឈ្មោះថា មិនប្រកបដោយធម៌ឬអ្វី។ ទោសរបស់កម្ម (មានអបលោកនកម្មជាដើម) មាន១២ ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិន័យវត្ថុ ក្នុងនគរចម្បា កម្មទាំងអស់ (នោះ) ឈ្មោះថា មិនប្រកបដោយធម៌មែនហើយ។

[៣៦០] សម្បត្តិរបស់កម្មមានប៉ុន្មាន ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិន័យវត្ថុ ក្នុងនគរចម្បា កម្មទាំងអស់ (នោះ) ឈ្មោះថា ប្រកបដោយធម៌ឬអ្វី។ សម្បត្តិរបស់កម្ម មាន៤ ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិន័យវត្ថុ ក្នុងនគរចម្បា កម្មទាំងអស់ (នោះ) ឈ្មោះថា ប្រកបដោយធម៌មែនហើយ។

[៣៦១] កម្មមានប៉ុន្មាន ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិន័យវត្ថុ ក្នុងនគរចម្បា (កម្មនោះ) ប្រកបដោយធម៌ មានប៉ុន្មាន មិនប្រកបដោយធម៌ មានប៉ុន្មាន។ កម្មមាន៦ ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិន័យវត្ថុ ក្នុងនគរចម្បា បណ្តាកម្មទាំង៦នេះ ព្រះពុទ្ធ ជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ប្រកបដោយធម៌ មានតែ១ពួក មិនប្រកបដោយធម៌ មាន៥។

[៣៦២] កម្មមានប៉ុន្មាន ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិន័យវត្ថុ ក្នុងនគរចម្បា (កម្មនោះ) ប្រកបដោយធម៌ មានប៉ុន្មាន មិនប្រកបដោយធម៌ មានប៉ុន្មាន។ កម្ម៤ ដែលព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ក្នុងវិន័យវត្ថុ ក្នុងនគរចម្បា បណ្តាកម្មទាំង៤នេះ ព្រះពុទ្ធ ជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ប្រកបដោយធម៌ មានតែ១ពួក មិនប្រកបដោយធម៌ មាន៣។

[៣៦៣] ព្រះមានព្រះភាគ ទ្រង់បាននូវព្រះនិព្វាន ប្រកបដោយតាទិគុណ ទ្រង់ឃើញនូវវិវេកធម៌ បានសំដែងនូវកងនៃអាបត្តិទាំងឡាយណា បណ្តាកងនៃអាបត្តិទាំងនុ៎ះ កងនៃអាបត្តិប៉ុន្មាន ដែលមិនរម្ងាប់ដោយសមថៈទាំងឡាយ បពិត្រលោកអ្នកឈ្លាសវៃក្នុងវិភង្គ ខ្ញុំសូមសួរនូវកងនៃអាបត្តិនោះ សូមលោកឆ្លើយមក។ ព្រះមានព្រះភាគ ទ្រង់បាននូវព្រះនិព្វាន ប្រកបដោយតាទិគុណ ទ្រង់ឃើញនូវវិវេកធម៌ បានសំដែងនូវកងនៃអាបត្តិណា បណ្តាកងនៃអាបត្តិទាំងនុ៎ះ មានតែកងអាបត្តិ១ គឺបារាជិក ដែលមិនរម្ងាប់ដោយសមថៈទាំងឡាយទេ បពិត្រលោកអ្នកឈ្លាសវៃ ក្នុងវិភង្គ ខ្ញុំប្រាប់នូវកងនៃអាបត្តិនោះ ចំពោះលោក។

[៣៦៤] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បុគ្គលប៉ុន្មានពួក ដែលទៅកើតក្នុងអបាយ ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បុគ្គល១៤៤ពួក[75] ដែលបំបែកសង្ឃ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់១កប្ប ចូរលោកស្តាប់វិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៦៥] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បុគ្គលប៉ុន្មានពួក ដែលមិនកើតក្នុងអបាយ ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បុគ្គល១៨ពួក ដែលមិនទៅកើតក្នុងអបាយ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៦៦] ធម៌ទាំង៨ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់សំដែងប៉ុន្មានលើក ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ធម៌ទាំង៨ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់សំដែង មាន១៨លើក ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

## (សោឡសកម្មាទិ ទី៥)

CS vin.pv.16.05 | ភាគ ទី១៣

### (៥. សោឡសកម្មាទិ)

[៣៦៧] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមាន១៦យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៦៨] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ទោសរបស់កម្មមានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា ទោសរបស់កម្ម មាន១២យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៦៩] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សម្បត្តិរបស់កម្ម មានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សម្បត្តិរបស់កម្មមាន៤យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧០] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមាន៦យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧១] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា កម្មមាន៤យ៉ាង ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧២] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បារាជិកាបត្តិ មានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បារាជិកាបត្តិមាន៨ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧៣] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សង្ឃាទិសេសាបត្តិ មានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សង្ឃាទិសេសាបត្តិ មាន២៣ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧៤] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា អនិយតៈ មានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា អនិយតៈ មាន២ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧៥] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា និស្សគ្គិយៈ មានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា និស្សគ្គិយៈ មាន៤២ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧៦] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាចិត្តិយាបត្តិ មានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាចិត្តិយាបត្តិ មាន១៨៨ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧៧] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាដិទេសនីយាបត្តិ មានប៉ុន្មានយ៉ាង ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា បាដិទេសនីយាបត្តិមាន១២ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។

[៣៧៨] ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សេក្ខិយៈ មានប៉ុន្មាន ខ្ញុំនឹងចាំស្តាប់នូវវិស័យរបស់អ្នក ដែលជាអ្នកជ្រាបច្បាស់នូវវិន័យ។ ព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ត្រាស់ថា សេក្ខិយៈ មាន៧៥ ចូរអ្នកស្តាប់នូវវិស័យរបស់ខ្ញុំ ដែលជាអ្នកដឹងច្បាស់នូវវិន័យចុះ។ ពាក្យដែលអ្នកសួរមក ដោយប្រពៃត្រឹមណា ខ្ញុំក៏បានវិស្សជ្ជនា ដោយប្រពៃត្រឹមនោះហើយ ពាក្យបន្តិចបន្តួច ដែលមិនមែនជាខ្សែបន្ទាត់ មិនមានក្នុងពាក្យបុច្ឆាវិស្សជ្ជនានោះឡើយ។

ចប់ ទុតិយគាថាសង្គណិកៈ។

# សេទមោចនគាថា

CS vin.pv.17 | ភាគ ទី១៣

### (សេទមោចនគាថា)

## (អវិប្បវាសបញ្ហា ទី១)

CS vin.pv.17.01 | ភាគ ទី១៣

### (១. អវិប្បវាសបញ្ហា)

[៣៧៩] ពួកភិក្ខុក្តី ពួកភិក្ខុនីក្តី មិនមានសំវាស[76] សម្ភោគពួកមួយ គឺពួកភិក្ខុ ឬពួកភិក្ខុនី មិនបានក្នុងបុគ្គលនោះទេ[77] ការនៅរួម មិនត្រូវអាបត្តិ[78] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨០] ព្រះមានព្រះភាគ ជាមហាឥសី (ទ្រង់ស្វែងរកនូវប្រយោជន៍ដ៏ប្រសើរ) ទ្រង់ត្រាស់ថា របស់៥យ៉ាង មិនត្រូវលះ មិនត្រូវចែក តែកាលបើភិក្ខុលះ និងប្រើប្រាស់ មិនត្រូវអាបត្តិ[79] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨១] យើងមិនបានពោលចំពោះអវន្ទិយបុគ្គលទាំង១០ពួកទេ ទាំងអភព្វបុគ្គល១១ មានបណ្ឌកជាដើម ក៏លើកលែងដែរ តែភិក្ខុសំពះភិក្ខុចាស់[80] ត្រូវអាបត្តិ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨២] ភិក្ខុ មិនមែនជាភិក្ខុដែលសង្ឃលើកវត្ត ទាំងមិនមែនជាភិក្ខុដែលនៅបរិវាស មិនមែនជាអ្នកទំលាយសង្ឃ ទាំងមិនមែនជាអ្នកចូលពួកតិរ្ថិយ (ភិក្ខុនោះ) ឋិតនៅក្នុងភូមិនៃសមានសំវាសកៈ (ភូមិរបស់ភិក្ខុមានសំវាសស្មើគ្នា) តែភិក្ខុនោះ មិនសាធារណៈដោយសិក្ខា[81] ដូចម្តេច ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨៣] មានបុគ្គលដែលចូលទៅសាកសួរធម៌ជាកុសល ប្រកបដោយប្រយោជន៍ បុគ្គលនោះ នឹងថារស់នៅ ក៏មិនមែន នឹងថាស្លាប់ ក៏មិនមែន នឹងថានិព្វាន ក៏មិនមែន។ ព្រះពុទ្ធទាំងឡាយ ត្រាស់ហៅបុគ្គលនោះថាដូចម្តេចទៅវិញ[82] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨៤] យើងមិនបានពោលចំពោះអវយវៈ តាំងពីដងកាំបិតឡើងទៅទេ ទាំងអវយវៈ តាំងពីផ្ចិតចុះមកក្រោម ក៏លើកលែងដែរ តែហេតុដូចម្តេច បានជាភិក្ខុត្រូវអាបត្តិបារាជិក ព្រោះមេថុនធម្ម[83] ជាបច្ច័យ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨៥] ភិក្ខុធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ឥតមានពួកភិក្ខុសំដែងទីឲ្យ ធ្វើឲ្យកន្លងហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ តែភិក្ខុនោះ មិនត្រូវអាបត្តិ[84] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨៦] ភិក្ខុធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ដែលមានពួកភិក្ខុសំដែងទីឲ្យ ប្រកបដោយប្រមាណ មិនមានហេតុទាស់ មានទីឧបចារៈ តែភិក្ខុនោះ ត្រូវអាបត្តិ[85] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨៧] ឧបសម្បន្ន មិនបានប្រព្រឹត្តប្រយោគអ្វីមួយ ប្រកបដោយកាយ ទាំងមិនបានពោលនឹងអ្នកដទៃ ដោយវាចា តែឧបសម្បន្ននោះ ត្រូវគរុកាបត្តិ ជាវត្ថុដាច់ចាកភិក្ខុនីភាវៈ[86] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨៨] បុគ្គលមានចិត្តស្ងប់រម្ងាប់ មិនបានធ្វើបាបបន្តិចបន្តួចដោយកាយក្តី វាចាក្តី ចិត្តក្តី បុគ្គលនោះ សង្ឃត្រូវឲ្យវិនាសចេញ ចុះធ្វើដូចម្តេច ទើបឈ្មោះថា ឲ្យវិនាសចេញដោយស្រួល[87] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៨៩] ភិក្ខុ កាលមិនចរចានឹងមនុស្សណាមួយ មួយទៀត កាលនឹងបញ្ចេញវាចា ក៏មិនបានពោលចំពោះអ្នកដទៃឡើយ តែភិក្ខុ (នោះ) ត្រឡប់ត្រូវអាបត្តិ ប្រកបដោយវាចា[88] មិនត្រូវអាបត្តិប្រកបដោយកាយ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩០] សិក្ខាបទទាំងឡាយ ដែលព្រះពុទ្ធដ៏ប្រសើរ ទ្រង់ពណ៌នាទុកថា សង្ឃាទិសេស៤សិក្ខាបទ ភិក្ខុនីត្រូវអាបត្តិទាំងអស់នោះ ដោយប្រយោគតែមួយ[89] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩១] ភិក្ខុនីពីររូប បានឧបសម្បទាក្នុងទីជាមួយគ្នា ភិក្ខុទទួលចីវរអំពីដៃនៃភិក្ខុនីទាំងពីររូប ត្រូវអាបត្តិផ្សេងៗគ្នា[90] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩២] ជន គឺភិក្ខុ៤រូប បបួលគ្នាលួចគរុភណ្ឌ ឯភិក្ខុ៣រូប ត្រូវអាបត្តិបារាជិក ភិក្ខុ១រូប មិនត្រូវអាបត្តិបារាជិកទេ[91] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

## (បារាជិកាទិបញ្ហា ទី២)

CS vin.pv.17.02 | ភាគ ទី១៣

### (២. បារាជិកាទិបញ្ហា)

[៣៩៣] ស្រីនៅខាងក្នុង ភិក្ខុនៅខាងក្រៅ ក្នុងផ្ទះនោះ ឥតប្រហោងសោះ ដូចម្តេចបានជាភិក្ខុត្រូវអាបត្តិបារាជិក[92] ព្រោះសេពមេថុនធម្មជាបច្ច័យ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩៤] ឧបសម្បន្ន ទទួលប្រេង ទឹកឃ្មុំ ទឹកអំពៅ និងទឹកដោះរាវ ហើយទុកដាក់ដោយខ្លួនឯង ទុកជាមិនទាន់កន្លង៧ថ្ងៃនៅឡើយ កាលបើមានបច្ច័យហើយឆាន់ ត្រូវអាបត្តិ[93] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩៥] ភិក្ខុត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ និងសុទ្ធកបាចិត្តិយៈ ក្នុងខណៈជាមួយគ្នា[94] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩៦] ភិក្ខុ២០រូបមកប្រជុំគ្នា មានសេចក្តីសំគាល់ថា ព្រមព្រៀងគ្នា ហើយធ្វើសង្ឃកម្មទៅ មានភិក្ខុ១រូប ឋិតនៅក្នុងទីឆ្ងាយ មានប្រមាណ១២យោជន៍ក៏មាន ចុះហេតុដូចម្តេច បានជាសង្ឃកម្មនោះកម្រើក[95] ព្រោះបច្ច័យ គឺកម្មនោះជាពួក ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩៧] ភិក្ខុត្រូវគរុកាបត្តិទាំងអស់៦៤ ជាអាបត្តិដែលខ្លួនកែបាន ក្នុងខណៈជាមួយគ្នា ដោយគ្រាន់តែឈានជំហានទៅ និងពោលដោយវាចា[96] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩៨] ភិក្ខុស្លៀកស្បង់ គ្រងសង្ឃាដិមានជាន់ពីរ តែចីវរទាំងអស់នោះ ជានិស្សគ្គិយៈ[97] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៣៩៩] ញត្តិ (របស់បុគ្គលនោះ) ក៏មិនមាន ទាំងកម្មវាចាសោត ក៏មិនមាន សូម្បីព្រះជិនស្រី ក៏មិនបានត្រាស់ហៅថា ឯហិភិក្ខុទេ ម្យ៉ាងទៀត សរណគមន៍ របស់បុគ្គលនោះ ក៏មិនមាន (ចុះហេតុអ្វីបានជា) ឧបសម្បទា របស់បុគ្គលនោះ មិនកម្រើក[98] (គឺបានឧបសម្បទាពេញបរិបូណ៌) ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០០] បុគ្គលល្ងង់ សម្លាប់ស្ត្រីមិនមែនជាមាតា សម្លាប់បុរសមិនមែនជាបិតា សម្លាប់បុគ្គលមិនមែនជាព្រះអរិយៈ បុគ្គលនោះ ត្រូវអនន្តរិយកម្ម ព្រោះការសម្លាប់នោះ[99] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០១] បុគ្គលសម្លាប់ស្ត្រីដែលជាមាតាពិត សម្លាប់បុរសដែលជាបិតាពិត លុះសម្លាប់មាតាបិតាហើយ ក៏មិនត្រូវអនន្តរិយកម្ម ព្រោះការសម្លាប់នោះ[100] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០២] ភិក្ខុមិនបានចោទ មិនបានរំលឹក ហើយធ្វើកម្មដល់បុគ្គលដែលមាននៅក្នុងទីកំបាំងមុខ កម្មដែលភិក្ខុធ្វើនោះ ឈ្មោះថា ធ្វើប្រពៃហើយ ទាំងការកសង្ឃ ក៏មិនត្រូវអាបត្តិ[101] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០៣] ភិក្ខុបានចោទ បានរំលឹក ហើយធ្វើកម្មដល់បុគ្គលដែលមាននៅក្នុងទីចំពោះមុខ ឯកម្មដែលភិក្ខុនោះធ្វើហើយ ឈ្មោះថា មិនបានធ្វើទៅវិញ ទាំងការកសង្ឃ ក៏ត្រូវអាបត្តិ [អដ្ឋកថា ថា សំដៅយក ភិក្ខុឲ្យឧបសម្បទា ដល់អភព្វបុគ្គល មានបណ្ឌកជាដើម។ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០៤] ភិក្ខុកាត់ ត្រូវអាបត្តិក៏មាន[102] ភិក្ខុកាត់ មិនត្រូវអាបត្តិក៏មាន[103] ភិក្ខុបិទបាំង ត្រូវអាបត្តិក៏មាន[104] ភិក្ខុបិទបាំង មិនត្រូវអាបត្តិក៏មាន[105] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០៥] ភិក្ខុពោលពាក្យពិត ត្រូវគរុកាបត្តិក៏មាន[106] ពោលពាក្យកុហក ត្រូវលហុកាបត្តិក៏មាន[107] ពោលពាក្យកុហក ត្រូវគរុកាបត្តិក៏មាន[108] ពោលពាក្យពិត ត្រូវលហុកាបត្តិក៏មាន[109] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

## (បាចិត្តិយាទិបញ្ហា ទី៣)

CS vin.pv.17.03 | ភាគ ទី១៣

### (៣. បាចិត្តិយាទិបញ្ហា)

[៤០៦] ចីវរភិក្ខុបានអធិដ្ឋាន បានជ្រលក់ដោយគ្រឿងជ្រលក់ បានធ្វើពិន្ទុកប្បៈ ត្រឹមត្រូវហើយ តែភិក្ខុនោះប្រើប្រាស់ ត្រូវអាបត្តិ[110] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០៧] កាលបើព្រះអាទិត្យអស្តង្គតហើយ ភិក្ខុឆាន់សាច់ ភិក្ខុនោះមិនមែនជាភិក្ខុឆ្កួត ទាំងមិនមែនជាភិក្ខុមានចិត្តរវើរវាយ ទាំងមិនមែនជាភិក្ខុមានវេទនាគ្របសង្កត់ តែភិក្ខុនោះ មិនត្រូវអាបត្តិ[111] ទាំងធម៌នោះសោត ក៏ព្រះសុគត ទ្រង់បានសំដែងហើយ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០៨] ភិក្ខុនោះមិនមានតម្រេក មិនមានថេយ្យចិត្ត ទាំងមិនបានគិត ដើម្បីសម្លាប់អ្នកដទៃ កាលភិក្ខុនោះឲ្យស្លាក រមែងដាច់ចាកភិក្ខុភាវៈ[112] ភិក្ខុអ្នកទទួលស្លាក ត្រូវថុល្លច្ច័យ[113] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤០៩] ទីនោះ មិនមែនជាសេនាសនៈនៅក្នុងព្រៃ ដែលគេសន្មតថា ប្រកបដោយសេចក្តីរង្កៀសទេ ទាំងសង្ឃ ក៏មិនបានឲ្យសម្មតិ ទាំងភិក្ខុនោះ ក៏មិនបានក្រាលកឋិន (បើភិក្ខុនោះ) ទុកចីវរក្នុងទីនោះ ហើយទៅកាន់ទីមានប្រមាណកន្លះយោជន៍ លុះអរុណរះឡើង ភិក្ខុនោះ ក៏មិនត្រូវអាបត្តិឡើយ[114] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១០] ភិក្ខុត្រូវអាបត្តិទាំងពួង មានវត្ថុផ្សេងៗគ្នា ប្រកបដោយកាយ មិនប្រកបដោយវាចា ក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ[115] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១១] ភិក្ខុត្រូវអាបត្តិទាំងពួង មានវត្ថុផ្សេងៗគ្នា ប្រកបដោយវាចា មិនប្រកបដោយកាយ ក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ[116] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១២] ឧបសម្បន្ន មិនសេពមេថុននឹងស្រី៣ពួកនោះ និងបុរស៣ពួក មួយទៀត មិនសេពមេថុននឹងអនរិយជន គឺឧភតោព្យញ្ជនក៣ពួក និងបណ្ឌក៣ពួក មួយទៀត មិនបានប្រព្រឹត្តមេថុនក្នុងព្យញ្ជនៈ គឺដោយអំណាចនៃអនុលោមបារាជិកសោះឡើយ តែឧបសម្បន្ននោះ ត្រូវឆេជ្ជវត្ថុ ព្រោះមេថុនធម្មជាបច្ច័យ[117] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១៣] ភិក្ខុសូមចីវរនឹងមាតា តែមិនមែនជាចីវរ ដែលមាតាបង្អោនទៅដើម្បីសង្ឃ ភិក្ខុនោះត្រូវអាបត្តិ ព្រោះហេតុអ្វី[118] មួយទៀត ភិក្ខុមិនត្រូវអាបត្តិ ព្រោះសូមចីវរនឹងពួកញាតិ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១៤] បុគ្គលក្រោធខឹង ហើយត្រឡប់ទៅជាត្រេកអរវិញ[119] បុគ្គលក្រោធខឹងហើយ គួរនឹងតិះដៀល[120] បុគ្គលក្រោធខឹងហើយ គួរនឹងសរសើរ ដោយធម៌ណា ធម៌នោះ តើឈ្មោះដូចម្តេច ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១៥] បុគ្គលដែលត្រេកអរ ហើយក៏ត្រេកអរថែមទៀត បុគ្គលដែលត្រេកអរហើយ តែគួរនឹងតិះដៀល បុគ្គលដែលត្រេកអរហើយ តែគួរនឹងតិះដៀល ដោយធម៌ណា ធម៌នោះ តើឈ្មោះដូចម្តេច ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១៦] ឧបសម្បន្ន ត្រូវអាបត្តិសង្ឃាទិសេស (លាយដោយអាបត្តិ) ថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ និងទុក្កដ ក្នុងខណៈជាមួយគ្នា[121] ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១៧] កុលបុត្រ២រូប មានឆ្នាំ២០គ្រប់គ្រាន់ហើយ ឯកុលបុត្រទាំង២រូបនោះ សឹងមានឧបជ្ឈាយ៍ជាមួយគ្នា អាចារ្យជាមួយគ្នា កម្មវាចាជាមួយគ្នា តែកុលបុត្រមួយរូប ជាឧបសម្បន្ន គឺបានឡើងជាភិក្ខុ មួយរូបទៀត ជាអនុបសម្បន្ន[122] គឺនៅជាសាមណេរ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១៨] សំពត់ដែលភិក្ខុមិនបានធ្វើកប្បពិន្ទុ ទាំងមិនបានជ្រលក់ដោយគ្រឿងជ្រលក់ ភិក្ខុស្លៀកពាក់សំពត់នោះហើយ ដើរទៅដោយគួរតាមប្រាថ្នា ភិក្ខុនោះមិនត្រូវអាបត្តិ[123] ទាំងធម៌នោះសោត ក៏ព្រះសុគត ទ្រង់សំដែងហើយ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤១៩] ឧបសម្បន្ន១ មិនបានឲ្យ ឧបសម្បន្ន១ មិនបានទទួល ព្រោះហេតុនោះ ការទទួលមិនមានទេ តែឧបសម្បន្ននោះ ត្រូវគរុកាបត្តិ [124] មិនមែនជាលហុកាបត្តិ កាលដែលនឹងត្រូវអាបត្តិនោះ ក៏ត្រូវព្រោះការបរិភោគ ជាបច្ច័យ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤២០] ឧបសម្បន្ន១ មិនបានឲ្យ ឧបសម្បន្ន១ មិនបានទទួល ព្រោះហេតុនោះ ការទទួលមិនមានទេ តែឧបសម្បន្ននោះ ត្រូវលហុកាបត្តិ[125] មិនមែនជាគរុកាបត្តិទេ កាលដែលត្រូវអាបត្តិនោះ ក៏ត្រូវព្រោះការបរិភោគ ជាបច្ច័យ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

[៤២១] ឧបសម្បន្នមិនមែនជាភិក្ខុនី ត្រូវគរុកាបត្តិ ជាសាវសេសាបត្តិ ហើយបិទបាំងទុក ព្រោះអាស្រ័យសេចក្តីមិនអើពើ[126] តែមិនត្រូវទោស ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ។

ចប់ សេទមោចនគាថា។

ឧទ្ទាន គឺបញ្ជីរឿងនៃសេទមោចនគាថានោះដូច្នេះ

[៤២២]

និយាយអំពីមិនមានសំវាស១ គរុភណ្ឌ៥ ដែលភិក្ខុលះមិនបាន១ អវន្ទិយបុគ្គល១០ពួក១ ភិក្ខុដែលសង្ឃមិនបានលើកវត្ត១ បុគ្គលដែលចូលទៅសាកសួរធម៌១ អវយវៈត្រឹមដងកាំបិតទៅលើ១ ភិក្ខុធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង មាន២ប្រស្នា១ ភិក្ខុនីប្រព្រឹត្តប្រយោគ មិនប្រកបដោយកាយ ត្រូវគរុកាបត្តិ១ ភិក្ខុមិនធ្វើបាបប្រកបដោយកាយ ដែលសង្ឃត្រូវឲ្យវិនាសដោយល្អ១ ភិក្ខុមិនចរចា១ សិក្ខាដែលព្រះអង្គទ្រង់សំដែង១ ភិក្ខុនីពីររូប បានឧបសម្បទាជាមួយគ្នា១ ជន គឺភិក្ខុ៤រូប បបួលគ្នាទៅលួចគរុភណ្ឌ១ ស្រីនៅក្នុង ភិក្ខុនៅក្រៅ១ ភិក្ខុទទួលប្រេងជាដើម១ ភិក្ខុត្រូវអាបត្តិនិស្សគ្គិយៈ និងបាចិត្តិយៈ ក្នុងខណៈជាមួយ១ ភិក្ខុ២០រូប មកប្រជុំគ្នា១ ភិក្ខុត្រូវគរុកាបត្តិ ដោយគ្រាន់តែឈានជំហាន១ ភិក្ខុស្លៀកស្បង់ជាដើម១ ឧបសម្បទាមិនមានញត្តិជាដើម១ បុគ្គលសម្លាប់មាតាបិតា តែមិនត្រូវអនន្តរិយកម្ម១ ភិក្ខុមិនបានចោទ១ ភិក្ខុបានចោទ១ ភិក្ខុកាត់១ ភិក្ខុពោលពាក្យពិត១ ចីវរដែលភិក្ខុបានអធិដ្ឋានហើយ១ ភិក្ខុឆាន់សាច់ក្នុងវេលាព្រះអាទិត្យអស្តង្គត១ ភិក្ខុមិនមានចិត្តត្រេកអរ១ ទីសេនាសនៈដែលមិនបានតាំងនៅក្នុងព្រៃ១ ភិក្ខុត្រូវអាបត្តិ មិនប្រកបដោយកាយ ប្រកបតែដោយវាចា១ ស្រី៣ពួក១ ភិក្ខុសូមចីវរនឹងមាតា១ បុគ្គលក្រោធខឹង ហើយត្រឡប់ជាត្រេកអរ១ បុគ្គលត្រេកអរ ហើយក៏ត្រេកអរថែមទៀត១ ឧបសម្បន្ន ត្រូវអាបត្តិសង្ឃាទិសេសជាដើម១ កុលបុត្រ២រូប១ សំពត់ដែលភិក្ខុមិនបានធ្វើពិន្ទុកប្បជាដើម១ ឧបសម្បន្នមួយរូប មិនបានឲ្យ១ ឧបសម្បន្នមួយរូប បានឲ្យ១ ឧបសម្បន្នត្រូវគរុកាបត្តិ១ ចប់សេទមោចនិកាគាថា ប្រស្នាដែលលោកអ្នកប្រាជ្ញ បានសំដែងឲ្យច្បាស់លាស់ហើយ។

# បញ្ចវគ្គ

CS vin.pv.18 | ភាគ ទី១៣

## (បញ្ចវគ្គោ)

## (កម្មវគ្គ ទី១)

CS vin.pv.18.01 | ភាគ ទី១៣

### (១. កម្មវគ្គោ)

[៤២៣] កម្ម៤យ៉ាង គឺអបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១។ កម្មទាំង៤នេះ តែងវិបត្តិព្រោះអាការប៉ុន្មាន។ កម្មទាំង៤នេះ តែងវិបត្តិព្រោះអាការ៥ គឺវត្ថុ១ ញត្តិ១ អនុស្សាវនៈ១ សីមា១ បរិសទ្យ១។

[៤២៤] កម្មវិបត្តិព្រោះវត្ថុដូចម្តេច។ កម្មដែលសង្ឃត្រូវធ្វើចំពោះមុខ បែរជាធ្វើកំបាំងមុខទៅវិញ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ កម្មដែលសង្ឃត្រូវធ្វើដោយការសាកសួរ បែរជាធ្វើដោយការមិនសាកសួរវិញ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ កម្មដែលសង្ឃត្រូវធ្វើតាមពាក្យប្តេជ្ញា បែរជាធ្វើមិនតាមពាក្យប្តេជ្ញាវិញ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុគួរដល់សតិវិន័យ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃធ្វើតស្សបាបិយសិកាកម្ម ដល់ភិក្ខុគួរដល់អមូឡ្ហវិន័យ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃធ្វើតជ្ជនីយកម្ម ដល់ភិក្ខុគួរដល់តស្សបាបិយសិកាកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃធ្វើនិយស្សកម្ម ដល់ភិក្ខុគួរដល់តជ្ជនីយកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃធ្វើបព្វាជនីយកម្ម ដល់ភិក្ខុគួរដល់និយស្សកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃធ្វើបដិសារណីយកម្ម ដល់ភិក្ខុគួរដល់បព្វាជនីយកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃធ្វើឧក្ខេបនីយកម្ម ដល់ភិក្ខុគួរដល់បដិសារណីយកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃឲ្យបរិវាស ដល់ភិក្ខុគួរដល់ឧក្ខេបនីយកម្ម កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃទាញភិក្ខុគួរដល់បរិវាស មកដាក់ក្នុងមូលាបត្តិ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃឲ្យមានត្ត ដល់ភិក្ខុគួរដល់មូលាយបដិកស្សនៈ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃឲ្យអព្ភាន ដល់ភិក្ខុគួរដល់មានត្ត កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញុំាងភិក្ខុគួរដល់អព្ភាន ឲ្យឧបសម្បទា កម្មនេះចាត់ជា

វត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃធ្វើឧបោសថ ក្នុងថ្ងៃមិនមែនជាថ្ងៃឧបោសថ កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃធ្វើបវារណា ក្នុងថ្ងៃមិនមែនជាថ្ងៃបវារណា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ កម្ម វិបត្តិព្រោះវត្ថុ យ៉ាងនេះឯង។

[៤២៥] កម្មទាំងឡាយ វិបត្តិព្រោះញត្តិដូចម្តេច។ កម្មទាំងឡាយ វិបត្តិព្រោះញត្តិ ដោយអាការ៥ គឺភិក្ខុមិនសូត្រចេញឈ្មោះវត្ថុ គឺឧបសម្បទាបេក្ខៈ១ មិនចេញឈ្មោះសង្ឃ១ មិនចេញឈ្មោះបុគ្គល គឺឧបជ្ឈាយ៍១ មិនតាំងញត្តិ១ ឬតាំងញត្តិខាងក្រោយកម្មវាចា១។ កម្មទាំងឡាយ វិបត្តិព្រោះញត្តិ ដោយអាការ៥នេះឯង។

[៤២៦] កម្មទាំងឡាយ វិបត្តិព្រោះអនុស្សាវនៈដូចម្តេច។ កម្មទាំងឡាយ វិបត្តិព្រោះអនុស្សាវនៈ ដោយអាការ៥ គឺសូត្រមិនចេញឈ្មោះវត្ថុ១ មិនចេញឈ្មោះសង្ឃ១ មិនចេញឈ្មោះបុគ្គល១ ធ្វើអនុស្សាវនវិធីឲ្យខូច១ សូត្រក្នុងកាលមិនគួរ១។ កម្មទាំងឡាយ វិបត្តិព្រោះអនុស្សាវនៈ ដោយអាការ៥នេះឯង។

[៤២៧] កម្មទាំងឡាយវិបត្តិព្រោះសីមាដូចម្តេច។ កម្មទាំងឡាយវិបត្តិព្រោះសីមា ដោយអាការ១១ គឺសន្មតសីមាតូចពេក១ សន្មតសីមាធំពេក១ សន្មតសីមាមាននិមិត្តមិនតគ្នា១ សន្មតសីមាយកស្រមោលជានិមិត្ត១ សន្មតសីមាមិនមានអ្វីជានិមិត្ត១ ឈរខាងក្រៅសីមាសន្មតសីមា១ សន្មតសីមាក្នុងស្ទឹង១ សន្មតសីមាក្នុងសមុទ្រ១ សន្មតសីមាក្នុងជាតស្រះ១ ទំលាយសីមាដោយសីមា១ គ្របសីមាដោយសីមា១។ កម្មទាំងឡាយ វិបត្តិព្រោះសីមា ដោយអាការ១១នេះឯង។

[៤២៨] កម្មទាំងឡាយវិបត្តិព្រោះបរិសទ្យដូចម្តេច។ កម្មទាំងឡាយវិបត្តិព្រោះបរិសទ្យ ដោយអាការ១២ គឺកម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ ក៏មិនបានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏មិនបាននាំមក ពួកភិក្ខុដែលមាននៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយ មានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ បានមកហើយ តែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ មិនបាននាំមក ទាំងពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយ មានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ ក៏បានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយដែរ តែពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយបញ្ចវគ្គ។បេ។ កម្មដែលសង្ឃធ្វើដោយទសវគ្គ។បេ។ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ពួកភិក្ខុមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ មិនបានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏មិនបាននាំមក ទាំងពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុទាំងឡាយ មានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ ក៏បានមកហើយដែរ តែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ មិនបាននាំមក ទាំងពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុទាំងឡាយ មានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ ក៏បានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយដែរ តែពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១។ កម្មទាំងឡាយ វិបត្តិព្រោះបរិសទ្យ ដោយអាការ១២នេះឯង។

[៤២៩] កម្ម សង្ឃធ្វើដោយចតុវគ្គ បានដល់ភិក្ខុ៤រូប ជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេស ជាអ្នកគួរដល់ឆន្ទៈដែរ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះ ជាអ្នកមិនគួរដល់កម្ម ទាំងមិនគួរដល់ឆន្ទៈទេ តែថាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ)។ កម្ម ដែលសង្ឃធ្វើដោយបញ្ចវគ្គ បានដល់ភិក្ខុ៥រូប ជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេស ជាអ្នកគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះ ជាអ្នកមិនគួរដល់កម្ម ទាំងជាអ្នកមិនគួរដល់ឆន្ទៈ តែថាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ)។ កម្ម ដែលសង្ឃធ្វើដោយទសវគ្គ បានដល់ភិក្ខុ១០រូប ជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេស ជាអ្នកគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះ ជាអ្នកមិនគួរដល់កម្ម ជាអ្នកមិនគួរដល់ឆន្ទៈ តែថាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ)។ កម្ម ដែលសង្ឃធ្វើដោយវីសតិវគ្គ បានដល់ភិក្ខុ២០រូប ជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេស គួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះ ជាអ្នកមិនគួរដល់កម្ម ទាំងជាអ្នកមិនគួរដល់ឆន្ទៈ តែថាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ)។

[៤៣០] កម្ម៤យ៉ាង គឺអបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១។ កម្មទាំង៤នោះ តែងវិបត្តិព្រោះអាការប៉ុន្មាន។ កម្មទាំង៤នោះ តែងវិបត្តិព្រោះអាការ៥ គឺវត្ថុ១ ញត្តិ១ អនុស្សាវនៈ១ សីមា១ បរិសទ្យ១។

[៤៣១] កម្មទាំងឡាយ វិបត្តិព្រោះវត្ថុដូចម្តេច។ (កម្មទាំងឡាយ វិបត្តិព្រោះវត្ថុនោះ) គឺសង្ឃញ៉ាំងបណ្ឌកឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងបុគ្គលជាថេយ្យសំវាស ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងបុគ្គលដែលចូលពួកតិរ្ថិយ៍ ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងសត្វតិរច្ឆាន ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងមាតុឃាតកបុគ្គល (អ្នកសម្លាប់មាតា) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងបិតុឃាតកបុគ្គល (អ្នកសម្លាប់បិតា) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងអរហន្តឃាតកបុគ្គល (អ្នកសម្លាប់ព្រះអរហន្ត) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងភិក្ខុនីទូសកៈ (អ្នកប្រទូស្តភិក្ខុនី) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងសង្ឃភេទកបុគ្គល (អ្នកបំបែកសង្ឃ) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងលោហិតុប្បាទកបុគ្គល (អ្នកធ្វើព្រះលោហិតព្រះពុទ្ធ ឲ្យពុរពងឡើង) ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងឧភតោព្យញ្ជនកបុគ្គល ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ សង្ឃញ៉ាំងបុគ្គលមានឆ្នាំថយពី២០ ឲ្យទទួលឧបសម្បទា កម្មនេះចាត់ជាវត្ថុវិបត្តិ ជាអធម្មកម្ម។ កម្មទាំងឡាយ វិបត្តិព្រោះវត្ថុ យ៉ាងនេះឯង។

[៤៣២] កម្ម វិបត្តិព្រោះញត្តិដូចម្តេច។ កម្ម ដែលវិបត្តិព្រោះញត្តិ ដោយអាការ៥ គឺភិក្ខុសូត្រមិនចេញឈ្មោះវត្ថុ១ មិនចេញឈ្មោះសង្ឃ១ មិនចេញឈ្មោះបុគ្គល១ មិនតាំងញត្តិ១ ឬតាំងញត្តិក្រោយ(កម្មវាចា)១។ កម្ម វិបត្តិព្រោះញត្តិ ដោយអាការ៥នេះឯង។

[៤៣៣] កម្មវិបត្តិព្រោះអនុស្សាវនៈដូចម្តេច។ កម្មវិបត្តិព្រោះអនុស្សាវនៈ ដោយអាការ៥ គឺភិក្ខុសូត្រមិនចេញឈ្មោះវត្ថុ១ មិនចេញឈ្មោះសង្ឃ១ មិនចេញឈ្មោះបុគ្គល១ ធ្វើអនុស្សាវនវិធីឲ្យខូច១ ឬសូត្រក្នុងកាលមិនគួរ១។ កម្មទាំងឡាយ វិបត្តិព្រោះអនុស្សាវនៈ ដោយអាការ៥នេះឯង។

[៤៣៤] កម្មវិបត្តិព្រោះសីមាដូចម្តេច។ កម្មវិបត្តិព្រោះសីមា ដោយអាការ១១ គឺសន្មតសីមាតូចពេក១ សន្មតសីមាធំពេក១ សន្មតសីមាមាននិមិត្តមិនតគ្នា១ សន្មតសីមាយកស្រមោលជានិមិត្ត១ សន្មតសីមាមិនមានអ្វីជានិមិត្ត១ ឈរខាងក្រៅសីមាសន្មតសីមា១ សន្មតសីមាក្នុងស្ទឹង១ សន្មតសីមាក្នុងសមុទ្រ១ សន្មតសីមាក្នុងជាតស្រះ១ ទំលាយសីមាដោយសីមា១ គ្របសីមាដោយសីមា១។ កម្មទាំងឡាយ វិបត្តិព្រោះសីមា ដោយអាការ១១នេះឯង។

[៤៣៥] កម្មទាំងឡាយវិបត្តិព្រោះបរិសទ្យដូចម្តេច។ កម្មទាំងឡាយវិបត្តិព្រោះបរិសទ្យ ដោយអាការ១២ គឺកម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ មិនបានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏មិនបាននាំមក ពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ បានមកហើយ តែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ មិនបាននាំមក ទាំងពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយចតុវគ្គ ភិក្ខុទាំងឡាយ មានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ បានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយ តែពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយបញ្ចវគ្គ។បេ។ កម្មដែលសង្ឃធ្វើដោយទសវគ្គ។បេ។ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ មិនបានមក ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏មិនបាននាំមក ពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ ក៏បានមកហើយ តែឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏មិនបាននាំមក ពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ ភិក្ខុមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម ភិក្ខុទាំងនោះ បានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយ តែពួកភិក្ខុដែលនៅក្នុងទីចំពោះមុខ ក៏ឃាត់ហាម១។ កម្មទាំងឡាយ វិបត្តិព្រោះបរិសទ្យ ដោយអាការ១២នេះឯង។

[៤៣៦] អបលោកនកម្ម ដល់នូវឋានៈប៉ុន្មាន ញត្តិកម្មដល់នូវឋានៈប៉ុន្មាន ញត្តិទុតិយកម្ម ដល់នូវឋានៈប៉ុន្មាន ញត្តិចតុត្ថកម្ម ដល់នូវឋានៈប៉ុន្មាន។ អបលោកនកម្ម ដល់នូវឋានៈ៥ ញត្តិកម្មដល់នូវឋានៈ៩ ញត្តិទុតិយកម្ម ដល់នូវឋានៈ៧ ញត្តិចតុត្ថកម្ម ដល់នូវឋានៈ៧។

[៤៣៧] អបលោកនកម្មដល់នូវឋានៈ៥ដូចម្តេច។ ឋានៈ៥គឺ ឱសារណា១ និស្សារណា១ ភណ្ឌុកម្ម១ ព្រហ្មទណ្ឌ១ ជាគំរប់៥នឹងកម្មលក្ខណៈ។ អបលោកនកម្ម ដល់នូវឋានៈ៥នេះឯង។

[៤៣៨] ញត្តិកម្មដល់នូវឋានៈ៩ដូចម្តេច។ ឋានៈ៩គឺ ឱសារណា១ និស្សារណា១ ឧបោសថ១ បវារណា១ សម្មតិ គឺសន្មតខ្លួនជាអ្នកសួរ ឆ្លើយ ឬសន្មតបុគ្គល សន្មតវត្ថុ១ ការឲ្យបាត្រ និងចីវរជាដើម១ ការទទួលអាបត្តិ១ ការបង្វិតថ្ងៃបវារណាទៅខាងមុខ១ ជាគំរប់៩នឹងកម្មលក្ខណៈ។ ញត្តិកម្ម ដល់នូវឋានៈទាំង៩នេះឯង។

[៤៣៩] ញត្តិទុតិយកម្មដល់នូវឋានៈ៧ដូចម្តេច។ ឋានៈ៧គឺ ឱសារណា១ និស្សារណា១ សម្មតិ១ ការឲ្យបាត្រ និងចីវរជាដើម១ ការដោះកឋិន១ ការសំដែង គឺសូត្រសំដែងទីដីសង់កុដិ វិហារជាដើម១ ជាគំរប់៧នឹងកម្មលក្ខណៈ។ ញត្តិទុតិយកម្ម ដល់នូវឋានៈទាំង៧នេះឯង។

[៤៤០] ញត្តិចតុត្ថកម្មដល់នូវឋានៈ៧ដូចម្តេច។ ឋានៈ៩គឺ ឱសារណា១ និស្សារណា១ សម្មតិ១ ការឲ្យបាត្រ និងចីវរជាដើម១ និគ្គហៈ គឺការសង្កត់សង្កិន ដោយទាញមកដាក់ក្នុងមូលាបត្តិ១ សមនុភាសនកម្ម១ ជាគំរប់៧នឹងកម្មលក្ខណៈ។ ញត្តិចតុត្ថកម្ម ដល់នូវឋានៈទាំង៧នេះឯង។

[៤៤១] កម្មដែលសង្ឃធ្វើដោយចតុវគ្គ បានដល់ភិក្ខុ៤រូប ជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេសគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះជាអ្នកមិនគួរដល់កម្ម ទាំងជាអ្នកមិនគួរដល់ឆន្ទៈ តែជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ)។ កម្មដែលសង្ឃធ្វើដោយបញ្ចវគ្គ។បេ។ កម្មដែលសង្ឃធ្វើដោយទសវគ្គ។បេ។ កម្មដែលសង្ឃធ្វើដោយវីសតិវគ្គ បានដល់ភិក្ខុ២០រូប ជាបកតត្ត ដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេស ជាអ្នកគួរដល់ឆន្ទៈ បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះជាអ្នកមិនគួរដល់កម្ម ទាំងជាអ្នកមិនគួរដល់ឆន្ទៈ តែថាជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ)។

ចប់ កម្មវគ្គ ជាបឋម។

## (អត្ថវសវគ្គ ទី២)

CS vin.pv.18.02 | ភាគ ទី១៣

### (២. អត្ថវសវគ្គោ)

[៤៤២] ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីសេចក្តីល្អដល់សង្ឃ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីសង្កត់សង្កិនពួកបុគ្គល ដែលមិនមានអៀនខ្មាស១ និងដើម្បីនៅសប្បាយដល់ពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមអាសវៈទាំងឡាយ ក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក

ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងនូវពៀរក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមនូវពៀរក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងទោសក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមទោស ក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងនូវភ័យក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមនូវភ័យ ក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងអកុសលធម៌ក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមអកុសលធម៌ ក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីអនុគ្រោះដល់ពួកគ្រហស្ថ១ ដើម្បីផ្តាច់ផ្តិលបក្ខពួករបស់បុគ្គលមានសេចក្តីប្រាថ្នាដ៏លាមក១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីសេចក្តីជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លា១ ដើម្បីញ៉ាំងជន ដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីញ៉ាំងព្រះសទ្ធម្មឲ្យឋិតថេរ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ១។ ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។

ចប់ អត្ថវសវគ្គ ជាគំរប់២។

## (បញ្ញត្តវគ្គ ទី៣)

CS vin.pv.18.03 | ភាគ ទី១៣

### (៣. បញ្ញត្តវគ្គោ)

[៤៤៣] ព្រះតថាគត ទ្រង់បញ្ញត្តបាតិមោក្ខ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ។បេ។ ព្រះតថាគត ទ្រង់បញ្ញត្តបាតិមោក្ខុទ្ទេស បញ្ញត្តនូវការបញ្ឈប់បាតិមោក្ខ បញ្ញត្តបវារណា បញ្ញត្តនូវការបញ្ឈប់បវារណា បញ្ញត្តតជ្ជនីយកម្ម បញ្ញត្តនិយស្សកម្ម បញ្ញត្តបព្វាជនីយកម្ម បញ្ញត្តបដិសារណីយកម្ម បញ្ញត្តឧក្ខេបនីយកម្ម បញ្ញត្តការឲ្យបរិវាស បញ្ញត្តមូលាយប្បដិកស្សនៈ គឺការទាញភិក្ខុមកដាក់ក្នុងមូលាបត្តិ បញ្ញត្តការឲ្យមានត្ត បញ្ញត្តអព្ភាន បញ្ញត្តឱសារណីយកម្ម បញ្ញត្តនិស្សារណីយកម្ម បញ្ញត្តឧបសម្បទា បញ្ញត្តអបលោកនកម្ម បញ្ញត្តញត្តិកម្ម បញ្ញត្តញត្តិទុតិយកម្ម បញ្ញត្តញត្តិចតុត្ថកម្ម។

ចប់ បញ្ញត្តវគ្គ ជាគំរប់៣។

## (អបញ្ញត្តេ បញ្ញត្តវគ្គ ទី៤)

CS vin.pv.18.04 | ភាគ ទី១៣

### (៤. អបញ្ញត្តេ បញ្ញត្តវគ្គោ)

[៤៤៤] កាលសិក្ខាបទដែលអ្នកណាមួយ មិនទាន់បានបញ្ញត្តទុក ព្រះតថាគត ទ្រង់បញ្ញត្តសិក្ខាបទឡើង សិក្ខាបទដែលព្រះអង្គបញ្ញត្តហើយ ទ្រង់បញ្ញត្តថែមទៀត ទ្រង់បញ្ញត្តសម្មុខាវិន័យ បញ្ញត្តសតិវិន័យ បញ្ញត្តអមូឡ្ហវិន័យ បញ្ញត្តបដិញ្ញាតករណៈ បញ្ញត្តយេភុយ្យសិកា បញ្ញត្តតស្សបាបិយសិកា បញ្ញត្តតិណវត្ថារកៈ (ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ) គឺដើម្បីសេចក្តីល្អដល់សង្ឃ១ ដើម្បីសេចក្តីសប្បាយដល់សង្ឃ១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីសង្កត់សង្កិនពួកបុគ្គល ដែលមិនមានខ្មាស១ ដើម្បីនៅសប្បាយដល់ពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងអាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមអាសវៈទាំងឡាយ ក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងពៀរក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមពៀរក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងទោសក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមទោស ក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងភ័យក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមភ័យ ក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីរារាំងអកុសលធម៌ ក្នុងបច្ចុប្បន្ន១ ដើម្បីឃាត់ហាមអកុសលធម៌ ក្នុងបរលោក១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីអនុគ្រោះដល់ពួកគ្រហស្ថ១ ដើម្បីផ្តាច់ផ្តិលនូវបក្ខពួកនៃបុគ្គលមានសេចក្តីប្រាថ្នាដ៏លាមក១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់

ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីសេចក្តីជ្រះថ្លា ដល់ពួកជន ដែលមិនទាន់ជ្រះថ្លា១ ដើម្បីញុំាងជន ដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការ គឺបញ្ញត្តដើម្បីញុំាងព្រះសទ្ធម្មឲ្យឋិតថេរ១ ដើម្បីអនុគ្រោះដល់ព្រះវិន័យ១។ ព្រះតថាគត ទ្រង់បញ្ញត្តតិណវត្ថារកៈ ដល់ពួកសាវ័ក ព្រោះអាស្រ័យអំណាចប្រយោជន៍២ប្រការនេះឯង។

ចប់ បញ្ញត្តវគ្គ ជាគំរប់៤។

## (នវសង្គហវគ្គ ទី៥)

CS vin.pv.18.05 | ភាគ ទី១៣

### (៥. នវសង្គហវគ្គោ)

[៤៤៥] សង្គហៈទាំងឡាយ៩ គឺវត្ថុសង្គហៈ១ វិបត្តិសង្គហៈ១ អាបត្តិសង្គហៈ១ និទានសង្គហៈ១ បុគ្គលសង្គហៈ១ ខន្ធសង្គហៈ១ សមុដ្ឋានសង្គហៈ១ អធិករណសង្គហៈ១ សមថសង្គហៈ១។

[៤៤៦] កាលបើអធិករណ៍កើតឡើងហើយ បើភិក្ខុទាំងពីររូប ដែលជាសត្រូវនឹងគ្នាមកដល់ សង្ឃត្រូវឲ្យលោកទាំងពីររូប (នោះ) ប្រាប់រឿងរ៉ាវ លុះឲ្យលោកទាំងពីររូបប្រាប់រឿងរ៉ាវហើយ សង្ឃត្រូវស្តាប់ពាក្យប្តេជ្ញារបស់ភិក្ខុទាំងពីរ (នោះ) លុះស្តាប់ពាក្យប្តេជ្ញារបស់ពួកភិក្ខុទាំងពីររូប (នោះ) ហើយ សង្ឃត្រូវប្រាប់លោកទាំងពីររូប (នោះ) ថា កាលបើអធិករណ៍នេះ យើងបានរម្ងាប់រួចហើយ លោកទាំងពីររូប នឹងត្រេកអរ (ឬទេ) បើភិក្ខុទាំងពីររូបពោលថា យើងទាំងពីររូបនឹងទទួលត្រេកអរ សង្ឃត្រូវទទួលអធិករណ៍នោះចុះ។ បើបរិសទ្យជាពួក ក្រាស់ដោយអលជ្ជី សង្ឃត្រូវរម្ងាប់អធិករណ៍នោះ ដោយឧព្វាហិកា គឺត្រូវអបលោក ហើយសឹមសន្មត ឬសន្មតដោយទុតិយកម្មវាចា។ បើបរិសទ្យជាពួក ក្រាស់ដោយល្ងង់ សង្ឃត្រូវស្វែងរកវិន័យធរ។ អធិករណ៍នោះ តែងរម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាណា សង្ឃត្រូវរម្ងាប់អធិករណ៍នោះ តាមទំនងនោះចុះ។

[៤៤៧] ភិក្ខុត្រូវស្គាល់វត្ថុ ត្រូវស្គាល់គោត្រ ត្រូវស្គាល់នាម ត្រូវស្គាល់អាបត្តិ។ ត្រង់ពាក្យថា មេថុនធម្ម បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា បារាជិក បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា អទិន្នាទាន បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា បារាជិក បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា មនុស្សវិគ្គហៈ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា បារាជិក បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ឧត្តរិមនុស្សធម្ម បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា បារាជិក បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា សុក្កវិសដ្ឋិ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា កាយសំសគ្គៈ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ទុដ្ឋុល្លវាចៈ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា អត្តកាមៈ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា សញ្ចរិត្តៈ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ភិក្ខុធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ភិក្ខុឲ្យគេធ្វើកុដិធំ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ភិក្ខុចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក មិនមានមូល បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ភិក្ខុអាស្រ័យនូវគ្រឿងអាងបន្តិចបន្តួចនៃអធិករណ៍ ជាចំណែកដទៃ ឲ្យជាលេស ហើយចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ភិក្ខុបំបែកសង្ឃ សង្ឃបានសូត្រសមនុភាសនវិធី ជាគំរប់៣ដងហើយ នៅតែមិនលះបង់ (ទិដ្ឋិអាក្រក់នោះ)ចេញ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ពួកភិក្ខុជាអ្នកប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃ សង្ឃបានសូត្រសមនុភាសនវិធី ជាគំរប់៣ដងហើយ នៅតែមិនលះបង់ (ទិដ្ឋិអាក្រក់នោះ)ចេញ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ភិក្ខុដែលគេប្រដៅបានដោយក្រ សង្ឃបានសូត្រសមនុភាសនវិធី ជាគំរប់៣ដងហើយ នៅតែមិនលះបង់ (ទិដ្ឋិអាក្រក់នោះ)ចេញ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។ ត្រង់ពាក្យថា ភិក្ខុអ្នកទ្រុស្តត្រកូល សង្ឃបានសូត្រសមនុភាសនវិធី ជាគំរប់៣ដងហើយ នៅតែមិនលះបង់ (ទិដ្ឋិអាក្រក់នោះ)ចេញ បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា សង្ឃាទិសេស បានដល់នាមផង អាបត្តិផង។បេ។ ត្រង់ពាក្យថា ភិក្ខុអាស្រ័យសេចក្តីមិនអើពើ បន្ទោបង់ឧច្ចារៈក្តី បស្សាវៈក្តី ស្តោះទឹកមាត់ក្តី ក្នុងទឹក បានដល់វត្ថុផង គោត្រផង។ ត្រង់ពាក្យថា ទុក្កដ បានដល់នាមផង អាបត្តិផង។

ចប់ នវសង្គហវគ្គ ជាគំរប់៥។

ឧទ្ទាន គឺបញ្ជីរឿងនៃបញ្ចវគ្គនោះដូច្នេះ

[៤៤៨]

(និយាយពីកម្ម៤យ៉ាង) គឺអបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១ (និងវិបត្តិ៥យ៉ាង) គឺវត្ថុវិបត្តិ១ ញត្តិវិបត្តិ១ អនុស្សាវនវិបត្តិ១ សីមាវិបត្តិ១ បរិសវិបត្តិ១ (ឯវត្ថុវិបត្តិនោះ) គឺសង្ឃត្រូវធ្វើកម្មក្នុងទីចំពោះមុខ បែរជាធ្វើក្នុងទីកំបាំងមុខវិញ សង្ឃគួរសាកសួរ បែរជាមិនសាកសួរវិញ សង្ឃគួរធ្វើកម្មតាមប្តេជ្ញា បែរជាធ្វើមិនតាមពាក្យប្តេជ្ញាវិញ សង្ឃធ្វើកម្មដល់ភិក្ខុ

ដែលគួរដល់សតិវិន័យ (ជាដើមញត្តិវិបត្តិនោះ) គឺសូត្រញត្តិមិនចេញឈ្មោះវត្ថុ១ មិនចេញឈ្មោះសង្ឃ១ មិនចេញឈ្មោះបុគ្គល១ មិនតាំងញត្តិ១ ឬតាំងញត្តិក្រោយកម្មវាចា១ (អនុស្សាវនវិបត្តិនោះ) គឺសូត្រមិនចេញឈ្មោះវត្ថុ១ មិនចេញឈ្មោះសង្ឃ១ មិនចេញឈ្មោះបុគ្គល១ ធ្វើអនុស្សាវនវិធីឲ្យខូច១ សូត្រក្នុងកាលមិនគួរ១ (សីមាវិបត្តិនោះ) គឺសីមាតូចពេក១ សីមាធំពេក១ សីមាមាននិមិត្តមិនតគ្នា១ យកស្រមោលជានិមិត្ត១ សីមាមិនមានអ្វីជានិមិត្ត១ ឈរខាងក្រៅសីមាសន្មត១ សន្មតសីមាក្នុងស្ទឹង១ សន្មតសីមាក្នុងសមុទ្រ១ សន្មតសីមាក្នុងជាតស្រះ១ ទំលាយសីមា ដោយសីមា១ គ្របសីមាដោយសីមា១ (បរិសវិបត្តិនោះ) គឺកម្មដែលសង្ឃធ្វើដោយចតុវគ្គក្តី បញ្ចវគ្គក្តី ទសវគ្គក្តី វីសតិវគ្គក្តី ភិក្ខុទាំងឡាយ ជាអ្នកគួរដល់កម្ម មិនបានមក ទាំងមិនបាននាំឆន្ទៈមក១ ភិក្ខុទាំងឡាយជាអ្នកគួរដល់កម្ម បានមកហើយ ទាំងឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈ ក៏បាននាំមកហើយ តែថាជាបុគ្គលដែលគួរដល់កម្ម១ អបលោកនកម្ម ដល់នូវឋានៈ៥ ញត្តិកម្ម ដល់នូវឋានៈ៩ ញត្តិទុតិយកម្ម ដល់នូវឋានៈ៧ ញត្តិចតុត្ថកម្ម ដល់នូវឋានៈ៧ ទ្រង់បញ្ញត្តដើម្បីសេចក្តីល្អដល់សង្ឃ ដើម្បីសេចក្តីសប្បាយដល់សង្ឃ ដើម្បីសង្កត់សង្កិនបុគ្គលដែលឥតខ្មាស ដើម្បីនៅសប្បាយដល់ពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ដើម្បីរារាំងនូវអាសវធម៌ ដើម្បីឃាត់ហាមនូវអាសវធម៌ ដើម្បីរារាំងពៀរ ទោស ភ័យ អកុសលធម៌ ដើម្បីអនុគ្រោះដល់ពួកគ្រហស្ថ ដើម្បីផ្តាច់ផ្តិលនូវបក្ខពួកនៃបុគ្គល ដែលមានសេចក្តីប្រាថ្នាលាមក ដើម្បីសេចក្តីជ្រះថ្លានៃពួកជន ដែលមិនទាន់ជ្រះថ្លា ដើម្បីធ្វើជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង ដើម្បីធ្វើព្រះសទ្ធម្មឲ្យឋិតថេរ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ទ្រង់បញ្ញត្តបាតិមោក្ខ បាតិមោក្ខុទ្ទេស ការបញ្ឈប់បាតិមោក្ខ បវារណា ការបញ្ឈប់នូវបវារណា តជ្ជនីយកម្ម និយស្សកម្ម បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម ការឲ្យបរិវាស មូលាយប្បដិកស្សនៈ គឺការទាញភិក្ខុមកដាក់ក្នុងមូលាបត្តិ ការឲ្យមានត្ត អព្ភានកម្ម ឱសារណាកម្ម និស្សារណាកម្ម ឧបសម្បទាកម្ម អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម កាលសិក្ខាបទ ដែលអ្នកណាមួយមិនទាន់បញ្ញត្តទុក ព្រះអង្គ ទ្រង់បញ្ញត្តឡើង សិក្ខាបទដែលព្រះអង្គបញ្ញត្តហើយ ទ្រង់បញ្ញត្តថែមទៀត ទ្រង់បញ្ញត្តសម្មុខាវិន័យ សតិវិន័យ អមូឡ្ហវិន័យ បដិញ្ញាតករណៈ យេភុយ្យសិកា តស្សបាបិយសិកា តិណវត្ថារកៈ សង្គហៈ៩យ៉ាង គឺវត្ថុសង្គហៈ វិបត្តិសង្គហៈ អាបត្តិសង្គហៈ និទានសង្គហៈ បុគ្គលសង្គហៈ ខន្ធសង្គហៈ សមុដ្ឋានសង្គហៈ អធិករណសង្គហៈ សមថសង្គហៈ (ម្យ៉ាងទៀត) ភិក្ខុត្រូវស្គាល់នាម១ ត្រូវស្គាល់អាបត្តិ១។

ចប់ បរិវារៈតែប៉ុណ្ណេះ។

## បរិយោសានគាថា

[៤៤៩] មហាអ្នកប្រាជ្ញមាននាមថា ទីបៈ ជាអ្នកទ្រទ្រង់សុតៈ គឺព្រះត្រៃបិដក មានប្រាជ្ញា ជាគ្រឿងពិចារណា បានសាកសួរផ្លូវនៃអាចារ្យជាន់ដើម ក្នុងបាលីបទេសនោះៗ ហើយគិតឲ្យចារិកសេចក្តីពិស្តារ និងសង្ខេបនេះ ដែលជាហេតុនាំមកឲ្យបានសេចក្តីស្រួលងាយ ដល់ពួកសិស្សានុសិស្ស ទុកក្នុងមជ្ឈិមបទេស តាមផ្លូវសា្វធ្យាយ។ វត្ថុណា ដែលបានពោលថា បរិវារៈ ដូច្នេះ វត្ថុទាំងអស់នោះ ប្រកបដោយលក្ខណៈ កាលបើព្រះសទ្ធម្មដែលព្រះពុទ្ធបញ្ញត្តនូវអត្ថដ៏សមគួរ តាមអត្ថហើយ ទ្រង់បញ្ញត្តនូវធម៌ដ៏សមគួរ តាមធម៌ហើយ តែងចោមរោមអមសាសនា ដូចសាគរដែលព័ទ្ធជុំវិញជម្ពូទ្វីប។ កាលបើកុលបុត្រមិនចេះបរិវារៈហើយ នឹងចេះវិនិច្ឆ័យធម៌អាច់ដូចម្តេចកើត។ សេចក្តីសង្ស័យអំពីវិបត្តិក្តី វត្ថុក្តី បញ្ញត្តិក្តី អនុប្បញ្ញត្តិក្តី បុគ្គលក្តី ឯកតោបញ្ញត្តិក្តី ឧភតោបញ្ញត្តិក្តី លោកវជ្ជៈក្តី បណ្ណត្តិវជ្ជៈក្តី កើតឡើងដល់កុលបុត្រណា កុលបុត្រនោះ នឹងកាត់សេចក្តីសង្ស័យបានដោយបរិវារៈ ស្តេចចក្រដែលល្អ រុងរឿង ក្នុងកណ្តាលទីប្រជុំមហាសេនា កេសររាជសីហ៍ល្អរុងរឿង ក្នុងកណ្តាលហ្វូងម្រឹគ ព្រះអាទិត្យមានរស្មីភ្លឺច្បាស់ (ល្អរុងរឿងលើអាកាស) ព្រះចន្ទល្អរុងរឿងក្នុងកណ្តាលពពួកផ្កាយ ព្រហ្មជានាយក តែងល្អរុងរឿងក្នុងកណ្តាលពួកនៃព្រហ្មជាបរិសទ្យ យ៉ាងណាមិញ ព្រះសទ្ធម្ម និងព្រះវិន័យ ក៏ល្អរុងរឿង ដោយបរិវារៈ យ៉ាងនោះដែរ។

ចប់ ភាគ១៣

# មាតិកា


| **ចុល្លវគ្គ** | លេខ ទំព័រ |
|---|---|
| **ភាគ ទី២ ទុតិយភាគ** | ១ |
| **បរិវារៈ** | ១ |
| **ខន្ធកបុច្ឆា** | ១ |
| បុច្ឆាវិស្សជ្ជនា អំពីឧបសម្បទាខន្ធកៈជាដើម | ១ |
| អំពីចីវរសញ្ញត្តៈជាដើម | ៣ |
| អំពីសេនាសនក្ខន្ធកៈជាដើម | ៥ |
| ឧទ្ទានគាថា | ៧ |
| **ឯកុត្តរិកៈ** | ៩ |
| ឯកកៈ (ពួកមួយ ៗ ត្រូវស្គាល់ធម៌ដែលធ្វើឲ្យត្រូវអាបត្តិជាដើម) | ៩ |

| | |
|---|---|
| ឧទ្ទានគាថា | ១១ |
| ទុកៈ (ពួក ពីរៗ) អាបត្តិដែលប្រកបនឹងគ្រឿងបរិក្ខារជាដើម | ១៣ |
| អាបត្តិបារាជិកទាំងពីរចំណែកជាដើម | ១៥ |
| ការហាមឃាត់មានពីរយ៉ាងជាដើម | ១៧ |
| ការមិនអើពើមានពីរយ៉ាងជាដើម | ១៩ |
| បុគ្គលពីរពួកជាដើម | ២១ |
| ឧទ្ទានគាថា | ២៣ |
| តិកៈ (ពួកបីៗ) វត្ថុជាគ្រឿងចោទ មាន ៣យ៉ាង ជាដើម | ២៧ |
| ការបិទបាំង មាន ៣យ៉ាង ជាដើម | ២៩ |
| ការធ្វើកម្មមានតជ្ជនីយកម្មជាដើម | ៣១ |
| ការធ្វើកម្ម មានឧក្ខេបនីយកម្មជាដើម | ៣៣ |
| កិច្ច មានការឲ្យឧបសម្បទាជាដើម | ៣៥ |
| មានភិក្ខុមិនមានខ្មាសជាដើម | ៣៧ |
| មូលនៃកុសល ៣ ជាដើម | ៣៩ |
| ឧទ្ទានគាថា | ៤១ |
| ចតុក្កៈ (ពួកបួន ៗ) ការត្រូវនឹងការចេញចាកអាបត្តិជាដើម | ៤៣ |
| បរិវាស ៤ ជាដើម | ៤៧ |
| សេចក្ដីផ្សេងគ្នាដោយវត្ថុជាដើម | ៤៩ |
| ការត្រូវអាបត្តិតែក្នុងកាល មិនត្រូវក្នុងវិកាលជាដើម | ៥១ |
| ការមិនលុះអគតិទាំង ៤ ជាដើម | ៥៣ |
| ឧទ្ទានគាថា | ៥៥ |
| បញ្ចកៈ (ពួកប្រាំៗ) អាបត្តិមាន ៥ យ៉ាង ជាដើម | ៥៧ |
| សំពត់បំសុកូល ៥ យ៉ាងជាដើម | ៥៩ |
| អង្គ ៥ របស់វិន័យធរ | ៦១ |
| អង្គ ៥ របស់ភិក្ខុមិនត្រូវនៅដោយឥតនិស្ស័យ និងគួរនៅដោយឥតនិស្ស័យ | ៦៧ |
| អង្គ ៥ របស់ភិក្ខុនីដែលឥតនិស្ស័យ និងមិនត្រូវនៅដោយឥតនិស្ស័យ | ៦៩ |
| អានិសង្ស ៥ ប្រការ និងទោស ៥ ប្រការ | ៧១ |
| អានិសង្ស ៥ ប្រការ របស់ភិក្ខុអ្នកទ្រទ្រង់វិន័យ | ៧៣ |
| ឧទ្ទាគាថា | ៧៥ |
| ឆក្កៈ (ពួកប្រាំមួយៗ) អង្គ ៦ របស់ឧបជ្ឈាយ៍ | ៧៧ |
| ឧទ្ទានគាថា | ៨១ |
| សត្តកៈ ( ពួកប្រាំពីរៗ) អង្គ ៧ របស់ភិក្ខុជាវិន័យធរ | ៨៣ |
| អស្សទ្ធម្ម ៧ និងព្រះសទ្ធម្ម ៧ | ៨៩ |
| អដ្ឋកៈ ( ពួកប្រាំបីៗ) អានិសង្ស ៨ ប្រការជាដើម | ៩១ |
| នវកៈ ( ពួកប្រាំបួនៗ) អាឃាតវត្ថុទាំង ៩ ជាដើម | ៩៣ |
| ទសកៈ ( ពួកដប់ៗ) វត្ថុជាទីកើតគំនុំទាំង ១០ ជាដើម | ៩៥ |
| អង្គ ១០ របស់វិន័យធរ | ៩៧ |

| | |
|---|---|
| អង្គ ១០ ជាដើម របស់ភិក្ខុដែលសង្ឃគួរសន្មតដោយឧព្វាហិកាកម្ម | ៩៩ |
| ឧទ្ទានគាថា | ១០១ |
| ឯកាទសកៈ ( ពួកដប់មួយៗ) បុគ្គល ១១ ជាដើម | ១០៣ |
| ឧទ្ទានគាថា | ១០៥ |
| **បុច្ឆាវិស្សជ្ជនាអំពីឧបោសថកម្មជាដើម** | **១០៧** |
| កម្មមានឧបោសថកម្មជាដើម | ១០៧ |
| ការសន្មតិភិក្ខុឲ្យជាអ្នកប្រដៅភិក្ខុនីជាដើម | ១០៩ |
| **បករណៈសំដែងអំពីអំណាចប្រយោជន៍** | **១១១** |
| មហាវគ្គ អំណាចនៃប្រយោជន៍ ១០ យ៉ាង | ១១១ |
| ឧទ្ទានគាថា | ១០៧ |
| **គាថាសង្គណិកៈ** | **១១៩** |
| បញ្ញាព្យាករណ៍ | ១១៩ |
| ការទ្រង់ព្យាករណ៍អាបត្តិមានអាបត្តិជាយាវតតិយកាជាដើម | ១២៥ |
| ការទ្រង់ព្យាករណ៍បុគ្គល ១១ រូបជាដើម | ១២៧ |
| ការទ្រង់ព្យាករណ៍សិក្ខាបទ ២២០ | ១២៩ |
| ការទ្រង់ព្យាករណ៍សិក្ខាបទដែលជាអសាធារណៈ | ១៣១ |
| សេចក្តីឧបមានៃបារាជិក ៨ ជាដើម | ១៣៣ |
| អាបត្តិ មានអាបត្តិសង្ឃាទិសេសជាដើម | ១៣៥ |
| អាបត្តិបាដិទេសនីយៈ ជាគារយ្ហៈ | ១៣៧ |
| សេក្ខិយសិក្ខាបទ | ១៣៩ |
| **អធិករណភេទ** | **១៤៣** |
| ការបាននូវការសើរើ ១០ យ៉ាងជាដើម | ១៤៣ |
| អធិករណៈ មានកិច្ចាធិករណៈជាដើម | ១៤៥ |
| អាបត្តិ និងអនាបត្តិនៃវិវាទាធិករណៈ | ១៤៧ |
| ការត្រូវអាបត្តិព្រោះអធិករណៈ ជាបច្ច័យ | ១៤៩ |
| ការត្រូវអាបត្តិព្រោះបច្ច័យនៃអធិករណៈ | ១៥០ |
| សេចក្តីអធិប្បាយនៃអធិករណៈ មានវិវាទាធិករណៈជាដើម | ១៥៥ |
| សេចក្តីអធិប្បាយនៃអធិករណៈ មានអាបត្តាធិករណៈជាដើម | ១៥៧ |
| សំដែងអំពីពាក្យថា សតិវិន័យមានក្នុងទីណាដូច្នេះ ជាដើម | ១៥៩ |
| សំដែងអំពីហេតុនៃសមថៈទាំង ៧ ជាដើម | ១៦១ |
| សំដែងអំពីអត្ថផ្សេងៗ នៃសមថៈទាំង៧ ជាដើម | ១៦៥ |
| អនុវាទាធិករណៈ | ១៦៧ |
| កិច្ចាធិករណៈ | ១៦៩ |
| **គាថាសង្គណិកៈ ជាដំណាមក** | **១៧៣** |
| បុច្ឆាវិស្សជ្ជនាអំពីអលជ្ជីបុគ្គល ជាដើម | ១៧៣ |
| បុច្ឆាវិស្សជ្ជនាអំពីអ្នកចោទត្រូវតាមធម៌ ជាដើម | ១៧៥ |
| | |

| | |
|---|---|
| **ចោទនាកណ្ឌ** | **១៧៩** |
| ការសាកសួរ របស់ភិក្ខុជាវិន័យធរ | ១៧៩ |
| សេចក្តីប្រតិបត្តិ របស់ភិក្ខុជាវិន័យធរ | ១៨១ |
| សេចក្តីប្រតិបត្តិរបស់អ្នកចោទ និងអ្នកជាប់ចោទ ជាដើម | ១៨៣ |
| ការដុតខ្លួនឯង របស់អ្នកជាប់ចោទ | ១៨៥ |
| ឧទ្ទានគាថា | ១៨៩ |
| **ចូឡសង្គាម** | **១៩១** |
| សេចក្តីប្រតិបត្តិ របស់ភិក្ខុជាវិន័យធរ | ១៩១ |
| សេចក្តីប្រតិបត្តិ ដើម្បីប្រយោជន៍មិនឲ្យក្តៅក្រហាយចិត្ត ជាដើម | ១៩៥ |
| ភិក្ខុដែលបណ្ឌិតគប្បីរាប់រក | ១៩៧ |
| **មហាសង្គាម** | **២០១** |
| ពាក្យថា ត្រូវស្គាល់និទានជាដើម | ២០១ |
| ពាក្យថា ត្រូវស្គាល់កម្មដែលគួរធ្វើ និងមិនគួរធ្វើ ជាដើម | ២០៣ |
| ការសំដែងនូវធម៌ថា មិនមែនធម៌ ជាដើម | ២០៥ |
| ភិក្ខុជាវិន័យធរមិនត្រូវលំអៀងដោយទោសាគតិ | ២០៧ |
| ភិក្ខុជាវិន័យធរមិនត្រូវលំអៀងដោយភយាគតិ | ២០៩ |
| សេចក្តីមិនលំអៀងដោយឆន្ទាគតិ | ២១១ |
| ការមិនលំអៀងដោយភយាគតិ ជាដើម | ២១៣ |
| ទីដែលគួរជ្រះថ្លា ជាដើម | ២១៥ |
| សំដែងអំពីពាក្យថា មិនត្រូវពោលនូវហេតុដែលមិនទាន់មកដល់ ជាដើម | ២១៧ |
| សេចក្តីប្រតិបត្តិ របស់ភិក្ខុជាវិន័យធរ | ២១៩ |
| ការចែកពាក្យ មានពាក្យថា អ្នកបានឃើញដូចម្តេចជាដើម | ២២៣ |
| ពាក្យថា លោកបានឃើញក្នុងទីណា និងឧទ្ទានគាថា | ២២៥ |
| **កឋិនភេទ** | **២២៩** |
| កម្ម មានការធ្វើនិមិត្តជាដើម | ២២៩ |
| ធម៌ ១៥ ប្រការ មានមាតិកា ៨ ជាដើម | ២៣១ |
| បច្ច័យ មានអនន្តរប្បច្ច័យ ជាដើម | ២៣៣ |
| កិច្ចមានបុព្វករណៈជាដើម មានបយោគជាដើមចមជាដើម | ២៣៥ |
| កិច្ចមានបុព្វករណៈជាដើម លោកសង្គ្រោះដោយធម៌ ៧ យ៉ាង | ២៣៧ |
| ការក្រាលកឋិនរបស់បុគ្គល ៣ ពួក | ២៣៩ |
| ការចែកពាក្យ មានពាក្យថា ភិក្ខុគប្បីស្គាល់កឋិន ជាដើម | ២៤១ |
| វិធីក្រាលកឋិន | ២៤៣ |
| បញ្ហាព្យាករណ៍អំពីបលិពោធក្នុងមាតិកាទាំង ៨ | ២៤៥ |
| ការដោះកឋិន និងឧទ្ទានគាថា | ២៤១ |
| **ឧបាលិបញ្ចកៈ** | **២៥៥** |
| សំដែងអំពីពាក្យថា ភិក្ខុមិនត្រូវឲ្យឧបសម្បទាជាដើម | ២៥៥ |
| អង្គ ៥ របស់ភិក្ខុដែលសង្ឃត្រូវធ្វើកម្ម | ២៥៩ |

| | |
|---|---|
| ឧទ្ទានគាថា | ២៦១ |
| ធម៌ ៥ ប្រការ របស់ភិក្ខុដែលចូលទៅកាន់សង្គ្រាម | ២៦៣ |
| អង្គ ៥ របស់ភិក្ខុដែលនិយាយក្នុងកណ្តាលជំនុំសង្ឃ | ២៦៥ |
| ឧទ្ទានគាថា និងអង្គ ៥ មានមិនស្គាល់អាបត្តិជាដើម | ២៦៩ |
| អង្គ ៥ មាននិយាយសង្កត់សង្កិនគេជាដើម | ២៧១ |
| អង្គ ៥ មានស្គាល់កម្មជាដើម | ២៧៣ |
| អង្គ ៥ មានលំអៀងដោយឆន្ទាគតិជាដើម | ២៧៥ |
| អង្គ ៥ មានមិនចេះធម៌ជាដើម | ២៧៧ |
| ការប្រាប់សេចក្តីយល់ឃើញដែលប្រកបដោយធម៌ និងមិនប្រកបដោយធម៌ | ២៧៧ |
| ការទទួលប្រគេនប្រកបដោយធម៌ ៥ យ៉ាង និងអនតិរិត្តភោជន ៥ យ៉ាង | ២៨១ |
| បដិញ្ញាតករណៈដែលមិនប្រកបដោយធម៌ មាន៥ យ៉ាង | ២៨៣ |
| ភិក្ខុមិនគួរសាកច្ឆាវិន័យជាមួយនឹងភិក្ខុ | ២៨៥ |
| សុទ្ធិ មាន ៥ យ៉ាង | ២៨៧ |
| ភិក្ខុអ្នកចោទត្រូវពិចារណាធម៌ ៥ យ៉ាង ទុកក្នុងខ្លួន | ២៨៩ |
| ភិក្ខុអ្នកចោទត្រូវធ្វើទុកក្នុងចិត្តនូវធម៌ ៥ យ៉ាង ក្នុងខ្លួន | ២៩៣ |
| ភិក្ខុត្រូវកាន់យកអត្តាទានដែលប្រកបដោយអង្គ ៥ | ២៩៥ |
| ភិក្ខុដែលមានឧបការៈច្រើនដល់ពួកភិក្ខុដែលកើតអធិករណ៍ | ២៩៩ |
| អង្គ ៥ របស់ភិក្ខុដែលមិនគួរសាកសួរ និងគួរសាកសួរ | ៣០១ |
| ភិក្ខុអ្នកកាន់អារញ្ញកធុតង្គ មាន ៥ ពួក ជាដើម | ៣០៥ |
| មុសាវាទមាន ៥ យ៉ាងជាដើម | ៣០៧ |
| សង្ឃមិនត្រូវឲ្យការសាកសួរដល់ភិក្ខុប្រកបដោយអង្គ៥ | ៣០៩ |
| ពៀរ មាន ៥ យ៉ាង កិរិយាវៀរ មាន៥យ៉ាង | ៣១១ |
| ឧទ្ទានគាថា ភិក្ខុនីសង្ឃត្រូវធ្វើកម្មដល់ភិក្ខុ | ៣១៣ |
| សង្ឃត្រូវធ្វើកម្មដល់ភិក្ខុនីដែលប្រកបដោយអង្គ ៥ | ៣១៥ |
| ភិក្ខុមិនត្រូវឃាត់ឱវាទដល់ភិក្ខុនីទាំងឡាយ | ៣១៧ |
| ភិក្ខុមិនត្រូវសាកច្ឆាជាមួយនឹងភិក្ខុដែលប្រកបដោយអង្គ ៥ | ៣១៩ |
| ឧទ្ទានគាថា សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្ម | ៣២១ |
| ភិក្ខុប្រកបដោយអង្គ ៥ សង្ឃមិនត្រូវសន្មតដោយឧព្វាហិកាកម្ម | ៣២៣ |
| សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មក៏មាន មិនគប្បីសន្មតក៏មាន | ៣២៥ |
| ភាវៈនៃភិក្ខុជាពាល និងជាបណ្ឌិត | ៣២៧ |
| ភិក្ខុអាចរម្ងាប់អធិករណ៍បានក៏មាន មិនអាចក៏មាន | ៣៣១ |
| ការប្រេះឆានៃសង្ឃ និងការបែកធ្លាយនៃសង្ឃ | ៣៣៧ |
| ឧទ្ទានគាថា និងភិក្ខុបំបែកសង្ឃតែងទៅកើតក្នុងអបាយ | ៣៣៩ |
| ភិក្ខុអ្នកបំបែកសង្ឃតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក | ៣៤១ |
| ឧទ្ទានគាថា | ៣៤៩ |
| ការដោះស្រាយវិន័យមិនប្រកបដោយធម៌មាន ៥ យ៉ាង | ៣៥១ |
| អង្គ ៥ របស់ភិក្ខុ មានភិក្ខុជាភត្តុទ្ទេសកៈជាដើម | ៣៥៣ |

| | |
|---|---|
| អានិសង្សនៃការក្រាលកឋិន និងទោសរបស់ភិក្ខុភ្លេចស្មារតី | ៣៥៥ |
| បុគ្គល ៥ ពួកដទៃទៀតដែលមិនគួរសំពះ | ៣៥៧ |
| ឧទ្ទានគាថា | ៣៥៩ |
| **សមុដ្ឋាន** | **៣៦៣** |
| សង្ឃាទិសេស ១៣ | ៣៦៣ |
| សង្ឃាទិសេស ១៣ និងសេក្ខិយៈ | ៣៦៧ |
| អនិយតៈ ២ និងនិស្សគ្គិយបាចិត្តិយៈ ៣០ | ៣៦៩ |
| សេក្ខិយៈ ៧៥ និងឧទ្ទានគាថា | ៣៧១ |
| **ទុតិយគាថាសង្គណិកៈ** | **៣៧៣** |
| បុច្ឆាវិស្សជ្ជនា អំពី មូលនៃវិន័យជាដើម | ៣៧៣ |
| គរុកាបត្តិជាដើម | ៣៧៥ |
| បុគ្គល ៣ ពួកជាដើម | ៣៧៧ |
| អាបត្តិបាចិត្តិយៈ | ៣៧៩ |
| អំពី យាវតតិយាបត្តិជាដើម | ៣៨៣ |
| មុសាវាទជាដើម | ៣៨៥ |
| អាឃាតវត្ថុជាដើម | ៣៨៧ |
| ទោសរបស់កម្មជាដើម | ៣៨៩ |
| កងនៃអាបត្តិជាដើម | ៣៩១ |
| ធម៌ទាំង ៨ ជាដើម | ៣៩៣ |
| កម្ម | ៣៩៥ |
| អនិយតៈជាដើម | ៣៩៧ |
| សេក្ខិយៈ | ៣៩៩ |
| **សេទមោចនគាថា** | **៤០១** |
| ប្រស្នាសួរ អំពី ភិក្ខុដែលមិនសាធារណៈដោយសិក្ខាជាដើម | ៤០១ |
| ការត្រូវគរុកាបត្តិជាដើម | ៤០៣ |
| ការលួចគរុភណ្ឌជាដើម | ៤០៥ |
| គរុកាបត្តិជាដើម | ៤០៧ |
| ការធ្វើកម្មដល់បុគ្គលដែលនៅចំពោះមុខជាដើម | ៤០៩ |
| សេនាសនៈនៅក្នុងព្រៃជាដើម | ៤១១ |
| បុគ្គលត្រេកអរហើយ ត្រេកអរថែមទៀតជាដើម | ៤១៣ |
| ការមិនបានឲ្យ និងមិនបានទទួលជាដើម | ៤១៥ |
| ឧទ្ទានគាថា | ៤១៧ |
| **បញ្ចវគ្គ** | **៤១៩** |
| វត្ថុវិបត្តិ និងញត្តិវិបត្តិ | ៤១៩ |
| បរិសវិបត្តិ | ៤២១ |
| កម្ម ៤យ៉ាង និងវត្ថុវិបត្តិ | ៤២៣ |
| សីមាវិបត្តិ និងបរិសវិបត្តិ | ៤២៥ |

| | |
|---|---|
| កម្មទាំងឡាយ មានអបលោកនកម្មជាដើម | ៤២៧ |
| ទ្រង់បញ្ញត្តសិក្ខាបទ ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ | ៤២៩ |
| ទ្រង់បញ្ញត្តបាតិមោក្ខ ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ | ៤៣១ |
| ទ្រង់បញ្ញត្តតិណវត្ថារកៈ ព្រោះអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ | ៤៣៣ |
| ត្រូវឲ្យប្រាប់រឿងរ៉ាវ ត្រូវដឹងវត្ថុជាដើម | ៤៣៥ |
| នាមផង អាបត្តិផង ជាដើម | ៤៣៧ |
| ឧទ្ទានគាថា | ៤៣៩ |
| **បរិយោសានគាថា** | **៤៤៣** |
| សេចក្តីឧបមា ៥ យ៉ាង | ៤៤៣ |


ភាគ ទី ០១២ | **មាតិកា** | ភាគ ទី ០១៤

1)
បទដែលព្រះអង្គ ទ្រង់ហាមមិនឲ្យភិក្ខុឲ្យឧបសម្បទា ដល់បុគ្គលមានអាយុមិនគ្រប់២០ឆ្នាំជាដើម។
2)
អដ្ឋកថា ថា សមុដ្ឋាននៃអាបត្តិ៦ ហៅថា ធម៌ធ្វើឲ្យមានអាបត្តិ ព្រោះភិក្ខុដែលត្រូវអាបត្តិនោះ ដោយសមុដ្ឋាន៦នេះឯង។
3)
សមថៈទាំង៧ ហៅថា ធម៌ធ្វើមិនឲ្យមានអាបត្តិ
4)
គឺត្រូវស្គាល់អាបត្តិដែលមានក្នុងសិក្ខាបទនោះៗ និងក្នុងវិភង្គ។
5)
គឺត្រូវស្គាល់អនាបត្តិ ដោយន័យថា បើភិក្ខុមិនត្រេកអរ ក៏មិនមានអាបត្តិ ដូច្នេះជាដើម។
6)
អាបត្តិណាដែលភិក្ខុក្លែងកន្លងហើយ តែងធ្វើសេចក្តីអន្តរាយ ដល់ឋានសួគ៌ និងព្រះនិព្វាន អាបត្តិនោះ ឈ្មោះថា ធ្វើសេចក្តីអន្តរាយ។
7)
អាបត្តិដែលជាបណ្ណត្តិវជ្ជៈ បើភិក្ខុកន្លងដោយមិនដឹងខ្លួន ក៏មិនធ្វើសេចក្តីអន្តរាយ ដល់សួគ៌ និងព្រះនិព្វានឡើយ។
8)
សាវជ្ជប្បញ្ញត្តិ គឺអាបត្តិដែលជាលោកវជ្ជៈ
9)
អនវជ្ជប្បញ្ញត្តិ គឺអាបត្តិជាបណ្ណត្តិវជ្ជៈ។
10)
អាបត្តិជាចន្លោះ នៃមូលវិសុទ្ធិ គឺបរិសុទ្ធ ព្រោះមូលាយបដិកស្សនៈ។
11)
អាបត្តិជាចន្លោះ នៃអគ្ឃវិសុទ្ធិ គឺបរិសុទ្ធ ព្រោះបានទទួលអគ្ឃសមោធាន តែក្នុងអដ្ឋកថាកុរុន្ទី ពន្យល់ថា អាបត្តិជាចន្លោះ នៃអាបត្តិខាងដើមនោះ គឺអាបត្តិដែលភិក្ខុត្រូវ ក្នុងបរិវាស ឯអាបត្តិជាចន្លោះ នៃអាបត្តិខាងចុងនោះ គឺភិក្ខុត្រូវ ក្នុងវេលាប្រព្រឹត្តមានត្ត។
12)
អដ្ឋកថា ពន្យល់ថា បើសង្ឃត្រូវការ ក៏គប្បីធ្វើឧក្ខេបនីយកម្មបន្ថែម ដល់ភិក្ខុដែលសង្ឃបានដាក់កម្ម មានតជ្ជនីយកម្មជាដើម ហើយមិនបំពេញវត្ត (តាមអាជ្ញាសង្ឃ)។
13)
ឧព្វាហិកាកម្មនេះ លោកបានពោលទុកក្នុងសមថក្ខន្ធកៈរួចហើយ
14)
សិក្ខាក្នុងទីនេះ សំដៅយកធម៌៦ប្រការ ដែលសាមណេរី ត្រូវសិក្សាអស់២ឆ្នាំទៅទៀត។
15)
ស្រីដែលល្មមមានប្តីហើយ ទើបចូលបួសជាសាមណេរីបាន
16)
បឋមកឋិនសិក្ខាបទ

17)

ក្នុងទីនេះ មានកំណត់ថា សិក្ខាបទដែលទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះ ២១ សិក្ខាបទ តែបានរាប់តាមបាលីទៅឃើញតែ២០សិក្ខាបទ លុះពិនិត្យមើលក្នុងមហាវិភង្គ ឃើញថា សញ្ចាចិកសិក្ខាបទនេះ ក៏ទ្រង់បញ្ញត្តក្នុងក្រុងរាជគ្រឹះដែរ។

18)

ចីវរប្បដិគ្គហណសិក្ខាបទ។

19)

បរិបាចនសិក្ខាបទ

20)

ខិយ្យធម្មសិក្ខាបទ

21)

កុលេសុនិមន្តិតសិក្ខាបទ

22)

បីសិក្ខាបទខាងចុងនេះ ជាសិក្ខាបទភិក្ខុនី

23)

ឃើញក្នុងគម្ពីឱរុប និងគម្ពីរភូមាថា ២៤។ ឃើញក្នុងគម្ពីរ (ស្លឹករឹត) ខ្លះថា ៣៤។ ពាក្យថា ៣៤នេះ គួរជាង។ ដ្បិតចំនួនសិក្ខាបទទាំងអស់ក្នុងមហាវិភង្គ យើងបានជ្រើសរើសរួចហើយ។ សេចក្តីពិតថា ក្នុងមហាវិភង្គនោះ មាននិស្សគ្គិយសិក្ខាបទចំនួន៣៤ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តក្នុងក្រុងសាវត្ថី។

24)

ក្នុងតេរសកណ្ឌ (សង្ឃាទិសេស

25)

ក្នុងបាចិត្តិយកណ្ឌ (ភូតគាមវគ្គ

26)

ឩនបញ្ចពន្ធនសិក្ខាបទ

27)

ភិក្ខុនូបស្សយសិក្ខាបទ

28)

មហានាមសិក្ខាបទ

29)

រាប់យកបារាជិកាបត្តិរបស់ភិក្ខុ៤ របស់ភិក្ខុនី៤ ទាំងរាប់សង្ឃាទិសេសាបត្តិ របស់ភិក្ខុ១៣ របស់ភិក្ខុនី១០ មកបូកផ្សំគ្នា ត្រូវជាគរុកាបត្តិមាន៣១។

30)

សិក្ខាបទទាំង១៧៦នេះ មិនទួទៅដល់ជនទាំងពីរពួក គឺភិក្ខុ និងភិក្ខុនីទាំងអស់ទេ គឺទួទៅដល់ភិក្ខុ៤៦សិក្ខាបទ ទួទៅដល់ភិក្ខុនី១៣០សិក្ខាបទ។ នេះគ្រាន់តែបូករួមសេចក្តីក្នុងបញ្ហ:១១០ និង១១១ ខាងដើមប៉ុណ្ណោះ។

31)

ការសើរើទី១.២.៣ បានចំពោះតែអនុវាទាធិករណ៍ ទី៤.៥.៦ បានចំពោះតែវិវាទាធិករណ៍ ទី៧.៨.៩ បានចំពោះតែអាបត្តាធិករណ៍ ទី១០.១១.១២ បានចំពោះតែកិច្ចាធិករណ៍។ ម្យ៉ាងទៀត ការសើរើទាំង១២ (នេះ) លោកពោលថាបានចំពោះតែអធិករណ៍មួយៗក៏បាន។ អដ្ឋកថា។

32)

ភិក្ខុត្រូវអាបត្តិពីរកង គឺបារាជិក១ សង្ឃាទិសេស១ ចាត់ជាសីលវិបត្តិ។

33)

ភិក្ខុត្រូវអាបត្តិ៥កង គឺថុល្លច្ច័យ១ បាចិត្តិយៈ១ បាដិទេសនីយៈ១ ទុក្កដ១ ទុព្ភាសិត១ ចាត់ជាអាចារវិបត្តិ។

34)

ភិក្ខុប្រកាន់ទិដ្ឋិអាក្រក់ ចាត់ជាទិដ្ឋិវិបត្តិ

35)

ភិក្ខុចិញ្ចឹមជីវិតដោយអនេសនៈ ចាត់ជាអាជីវវិបត្តិ។

36)

អដ្ឋកថាពន្យល់ថា ត្រង់ពាក្យបុច្ឆាអំពីសមុដ្ឋាន ដែលលោកពោលថា សមថៈទាំង៧ មានសមុដ្ឋាន៣៦ នោះតើដូចម្តេច ដូច្នេះ ក៏មែនពិតហើយ តែបានជាលោកចែកតែសមថៈ៦ ក្នុងសមថៈមួយៗ មានសមុដ្ឋានប្រាំមួយៗ ដូច្នេះវិញ ព្រោះសម្មុខាវិន័យ មិនមានសមុដ្ឋានទេ ដោយមិនបានសង្គ្រោះចូលក្នុងកម្ម។

37)

ប្រែថា កិរិយាដល់ មិនប្រែថា កិរិយាត្រូវនូវអាបត្តិ ដូចក្នុងសិក្ខាបទនោះទេ។

38)

អដ្ឋកថា ហៅថា ទុតិយគាថាសង្គណិកៈ គាថាឆ្លុកឆ្លាស់ទី២

39)

អដ្ឋកថាពន្យល់សេចក្ដីថា ភិក្ខុជាវិន័យធរ មិនត្រូវលះដោយអគតិ មានឆន្ទាគតិជាដើមទេ គឺកុំយល់មុខថា លោកនេះជាឧបជ្ឈាយ៍ ជាអាចារ្យរបស់អញជាដើម។

40)

ការប្រជុំសង្ឃដើម្បីរម្ងាប់ ឬវិនិច្ឆ័យ នូវអធិករណ៍ លោកហៅថា សង្គ្រាម។ ដូចពួកវជ្ជីបុត្តកភិក្ខុ ក្នុងនគរវេសាលី ដែលជាសត្រូវដល់ខ្លួនផង ដល់សាសនាផង នាំគ្នាសំដែងខុសធម៌ ខុសវិន័យ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា។ ភិក្ខុណាសង្កត់សង្កិនលទ្ធិរបស់ពួកវជ្ជីបុត្ត ដែលជាសត្រូវទាំងនោះ និងចូលទៅក្នុងទីនោះ ហើយធ្វើសេចក្ដីវិនិច្ឆ័យ ឲ្យដាច់ស្រេចដោយបំភ្លឺនូវវាទៈរបស់ខ្លួន ភិក្ខុនោះឈ្មោះថា ជាអ្នកចូលទៅកាន់សង្គ្រាម ដូចជាព្រះយសត្ថេរ (អដ្ឋកថា)។

41)

យល់តាម ឬយល់ព្រម ពាក្យនេះ ជាពាក្យផ្លាស់ប្ដូរគ្នា និងពាក្យអនុញ្ញាត។

42)

អដ្ឋកថា ថាវត្ថុវិបត្តិ បានដល់សំពត់ជាអកប្បិយ។ កាលវិបត្តិ គឺសំពត់ដែលពួកទាយកប្រគេនក្នុងថ្ងៃនេះហើយ សង្ឃប្រគល់ឲ្យភិក្ខុអ្នកក្រាលកឋិនក្នុងថ្ងៃស្អែកវិញ។ ករណវិបត្តិ គឺសំពត់ដែលកាត់ហើយ តែមិនបានធ្វើក្នុងថ្ងៃនោះឯង

43)

សប្បដិកម្មាបត្តិ ប្រែថា អាបត្តិដែលនៅកែបាននៅឡើយ បានដល់អាបត្តិ៦កង តាំងពីសង្ឃាទិសេស រៀងដល់ទុព្ភាសិត។

44)

អប្បដិកម្មាបត្តិ ប្រែថា អាបត្តិកែមិនបាន គឺបានដល់អាបត្តិបារាជិក។

45)

កម្ម៧យ៉ាង គឺតជ្ជនីយកម្ម១ និយស្សកម្ម១ បព្វាជនីយកម្ម១ បដិសារណីយកម្ម១ ឧក្ខេបនីយកម្ម១ បត្តនិក្កុជ្ជនកម្ម១ បត្តឧក្កុជ្ជនកម្ម១ រួមជា៧យ៉ាង។

46)

អដ្ឋកថា ថា មិនស្គាល់សេចក្ដីខាងចុង និងខាងដើមបទនោះ គឺដូចជាគេធ្លាប់សូត្រថា ពុទ្ធោ ភគវា ត្រឡប់ជាសូត្រ ភគវា ពុទ្ធោ ដូច្នេះវិញ។

47)

អដ្ឋកថាថា ដូចភិក្ខុ៤រូប ឬ៥រូប សុទ្ធជាអ្នកធ្វើឲ្យជាក់ច្បាស់នូវអាបត្តិដូចគ្នា ហើយក៏សំដែងទាំង៤រូប ឬ៥រូបនោះ ក្នុងវេលាមួយជាមួយគ្នាតែម្ដង មិនបានទេ។ ដីកាថា បើភិក្ខុត្រឹមពីររូប ឬ៣រូប សំដែងជាមួយគ្នាបាន តែច្រើនជាងនេះមិនបាន។

48)

អដ្ឋកថាពន្យល់ថា ត្រង់ពាក្យថា ប្រាប់សេចក្ដីយល់ឃើញក្នុងសំណាក់ភិក្ខុ ដែលឋិតនៅក្នុងសីមាផ្សេងគ្នានោះ គឺភិក្ខុសំដែងអាបត្តិក្នុងសំណាក់ភិក្ខុ ដែលមានសំវាសស្មើគ្នា តែនៅក្នុងសីមាផ្សេងគ្នា ដូចជាភិក្ខុឋិតនៅក្នុងមាឡកសីមា គឺខណ្ឌសីមា សំដែងក្នុងសំណាក់ភិក្ខុ ឋិតនៅក្នុងសីមន្តរិកកី ភិក្ខុឋិតនៅក្នុងសមន្តរិកសំដែងក្នុងសំណាក់ភិក្ខុ ឋិតនៅក្នុងអវិប្បវាសសីមា គឺមហាសីមាក្ដី មិនគួរទេ។

49)

អដ្ឋកថា និងដីកាបាតិមោក្ខដ្ឋបនក្ខន្ធកៈ ពន្យល់ថា ភិក្ខុមានប្រាថ្នាដើម្បីជម្រះសាសនាឲ្យស្អាតល្អ ហើយកាន់យកនូវអធិករណ៍ណាមួយដោយខ្លួនឯង ដើម្បីចោទភិក្ខុដទៃ អធិករណ៍នោះ ហៅថា អត្តាទាន។

50)

អដ្ឋកថា មិនលះបង់លទ្ធិរបស់ខ្លួន ដោយត្រឹមតែពាក្យអ្នកដទៃ។

51)

សំដៅយកការពិនិត្យដេញដោល ពិនិត្យរករឿងឲ្យឃើញពិត ឬទេ។

52)

ប្រែថា អាបត្តិដែលកែត្រឡប់ដោយវុដ្ឋានវិធី និងទេសនាវិធីបាន

53)

ប្រែថា អាបត្តិដែលកែត្រឡប់មិនបាន គឺបារាជិកាបត្តិ។

54)

អដ្ឋកថា ថា ភិក្ខុសង្ស័យ ហើយធ្វើលើកម្មមិនគួរ ដោយមិនបានជួបវិន័យធរ។

55)

ធ្វើកម្មមិនគួរ ព្រោះមិនសួរ ឬមិនប្រុងស្ដាប់ពាក្យវិន័យធរ ដែលអធិប្បាយពីកម្មគួរ និងមិនគួរដល់ភិក្ខុដទៃ។

56)

ត្រូវអាបត្តិដោយដេកលក់ តាមសិក្ខាបទដែលហាមការដេករួម នឹងសាមណេរជាដើម។

57)

របស់មិនគួរ តែភិក្ខុសំគាល់ថា ជាក់ជាគួរ។

58)

ត្រូវដោយឲ្យរាត្រី១កន្លងទៅជាដើម។
59)
ការជ្រើសរើសយកភិក្ខុអំពីសង្ឃ ដើម្បីរម្ងាប់អធិករណ៍ ដែលកើតឡើង ហៅថា ឧព្វាហិកាកម្ម
60)
អដ្ឋកថាថា ភិក្ខុអ្នកបំបែកសង្ឃសូត្របញ្ជាក់ដោយពាក្យដូច្នេះជាដើមថា លោកទាំងឡាយ ចូរដឹងចុះ ខ្ញុំនេះជាអ្នកចេញចាកត្រកូលខ្ពង់ខ្ពស់មកបួស ហើយជាពហុស្សូតផង សូមលោកគ្រប់រូប ទុកចិត្តចុះថា ខ្ញុំមិនមែននាំឲ្យលោកគ្រប់រូបកាន់ខុសធម៌វិន័យទេ មួយទៀត ខ្ញុំមិនមែនសំគាល់អវីចិនរកថា ត្រជាក់ដូចជាផ្កាឧប្បលខៀវទេ ខ្ញុំមិនមែនជាមិនខ្លាចអបាយនោះទេ។ បើតាមដីកាថា សូត្របញ្ជាក់ពាក្យខ្លួន ដល់ភិក្ខុដែលខ្លួនគួរបំបែក។
61)
អដ្ឋថា ថា លុះសូត្របញ្ជាក់យ៉ាងនេះហើយ ក៏ញុំាងចិត្តភិក្ខុទាំងឡាយនោះ ឲ្យជឿស៊ប់ មិនឲ្យងាកបែត្រឡប់វិញ បានហើយក៏ប្រគល់ស្លាកឲ្យទៅថា លោកទាំងឡាយ ចូរយកស្លាកនេះទៅចុះ ឯអាការទាំង៥នេះ ត្រង់អាការទី១ ទី២ ជាសំខាន់ក្នុងការបំបែកសង្ឃនេះ ចំណែកឯអាការទី៣ ទី៤ ទី៥ គ្រាន់តែជាបុព្វភាគទេ។
62)
អដ្ឋកថា ថា កំណត់ សំដែង និយាយ
63)
ភិក្ខុអ្នកចាត់ភិក្ខុសង្ឃក្នុងការទទួលភត្ត (មេបញ្ជី)។
64)
មិនដឹងនូវភត្ត ដែលខ្លួនគួរសំដែង និងមិនគួរសំដែង។
65)
មិនដឹងនូវសាមណេរ ដែលគួរប្រើ និងមិនគួរប្រើ។
66)
ចំពោះតែចារិត្តសិក្ខាបទប៉ុណ្ណោះ។
67)
អដ្ឋកថា អាបត្តិ២នោះ គឺអាបត្តិបារាជិក របស់ភិក្ខុនី ដែលត្រូវ ព្រោះជួយបិទបាំងទោសភិក្ខុនីផងគ្នា១ អាបត្តិបាចិត្តិយៈ របស់ភិក្ខុដែលត្រូវ ព្រោះជួយបិទបាំងអាបត្តិសង្ឃាទិសេស នៃភិក្ខុផងគ្នា១
68)
អដ្ឋកថា ថា សប្បដិកម្ម ប្រែថា អាបត្តិដែលកែបាន បានដល់អាបត្តិ៦កង តាំងពីសង្ឃាទិសេស រហូតដល់ទុក្កាសិត។
69)
អប្បដិកម្ម ប្រែថា អាបត្តិកែលែងបាន បានដល់បារាជិក៤ ឬទាំង៨។
70)
អដ្ឋកថា ថា ត្រូវមើលនយលក្ខណៈ ក្នុងសៀវភៅទី៧ ក្នុងភេសជ្ជក្ខន្ធកៈ ទំព័រ២៥៦។
71)
ព្រះអង្គ ទ្រង់បញ្ញត្ត មិនឲ្យភិក្ខុនីយកម្រាមដៃលាងអង្គជាតឲ្យហួសជាង២ថ្នាំងម្រាមដៃឡើងទៅ អនុញ្ញាតត្រឹមតែ២ថ្នាំងដៃ១ ទ្រង់បញ្ញត្ត មិនឲ្យទុកសក់វែងហួសជាង២ធ្នាប់ឡើងទៅ១។
72)
អដ្ឋកថាថា អាបត្តិតែ១ ដែលត្រូវព្រោះបិណ្ឌបាតជាបច្ច័យនោះគឺ ភិក្ខុសំឡឹងមើលមុខស្ត្រី ដែលប្រគេនចង្ហាន់ ត្រូវទុក្កដ។ ដោយហោចទៅសូម្បីតែសំឡឹងមើលមុខសាមណេរ ដែលកំពុងប្រគេនបបរ ឬម្ហូបក្រៀម ក៏ត្រូវទុក្កដដែរ។ ប៉ុន្តែក្នុងកុរុន្ទី លោកកែក្នុងបទថា អាបត្តិតែ១ ដែលត្រូវព្រោះបិណ្ឌបាតជាបច្ច័យនោះ គឺភិក្ខុឆាន់បិណ្ឌបាត ដែលភិក្ខុនីចាត់ចែង ត្រូវបាចិត្តិយៈ។ (ពាក្យក្នុងកុរុន្ទីនេះ ត្រូវគ្នានឹងបរិបាចនសិក្ខាបទក្នុងមហាវិភង្គ)។
73)
អដ្ឋកថា ថា សហធម្មិកទាំង៥។
74)
រាត្រីទី១ ភិក្ខុត្រូវអាបត្តិមួយរយ ហើយក៏បិទបាំងទុកអស់១០រាត្រី លុះដល់ថ្ងៃទី១១ ទើបត្រូវអាបត្តិមួយរយ១លើកទៀត ហើយក៏បិទបាំងទុកអស់១០រាត្រី ទើបត្រូវអាបត្តិមួយរយ១លើកទៀត ត្រូវនឹងបិទបាំងយ៉ាងនេះ ដរាបដល់១០លើក រួមរាត្រីទាំងអស់ មួយរយរាត្រី រួមអាបត្តិជា១ពាន់។
75)
អដ្ឋកថា ថា បុគ្គល១៤៤ពួកនោះ គឺយកបុគ្គល៨ពួក ទៅគុណនឹងភេទករវត្ថុ១៨យ៉ាង ត្រូវជា១៤៤ពួក ៗទី១ គឺភិក្ខុសំដែងនូវអធម៌ ថាជាធម៌មាន៨យ៉ាងទៀត គឺបុគ្គលយល់ឃើញក្នុងអធម៌នោះ ថាជាអធម៌មែន យល់ឃើញក្នុងការបំបែក ថាជាអធម៌ដែរ១ យល់ឃើញក្នុងអធម៌នោះ ថាជាអធម៌មែន តែយល់ឃើញក្នុងការបំបែក ថាជាធម៌ទៅវិញ១ យល់ឃើញក្នុងអធម៌នោះ ថាជាអធម៌មែន តែសង្ស័យក្នុងការបំបែក១ យល់ឃើញក្នុងអធម៌នោះ ថាជាធម៌ទៅវិញ តែយល់ឃើញក្នុងការបំបែក ថាជាអធម៌១ យល់ឃើញក្នុងអធម៌នោះ ថាជាធម៌ទៅវិញ តែសង្ស័យក្នុងការ

បំបែក១ សង្ស័យក្នុងអធម៌នោះ យល់ឃើញក្នុងការបំបែក ថាជាអធម៌មែន១ សង្ស័យក្នុងអធម៌នោះ យល់ឃើញក្នុងការបំបែក ថាជាធម៌ទៅវិញ១ សង្ស័យក្នុងអធម៌នោះ និងសង្ស័យក្នុងការបំបែក១។ នេះជាបុគ្គលពួកទី១ ឯបុគ្គលពួកទី២ រហូតដល់១៤៤នោះ ក៏មានសេចក្តីប្រហែលៗគ្នាដែរ (សេចក្តីពិស្តារ មានក្នុងសង្ឃភេទក្ខន្ធកៈ)។

76)

ពួកភិក្ខុក្តី ភិក្ខុនីក្តី ដែលត្រូវបារាជិក ឬមិនមែនជាបកតត្ត ឈ្មោះថា មិនមានសំវាស គឺធ្វើឧបោសថជាដើម ជាមួយនឹងសង្ឃមិនបានទេ។

77)

ការបម្រើ មានផ្តូតទឹកជាដើម ពួកមាតុគ្រាម ធ្វើដល់ភិក្ខុមិនបាន លើកតែមាតាបង្កើត ឯភិក្ខុនី ក៏ដូចគ្នាដែរ។

78)

សេចក្តីនេះ ចំពោះភិក្ខុនី ដែលនៅជាមួយនឹងកូនប្រុសរបស់ខ្លួន ក្នុងទីប្រក់ ទីកំបាំងជាមួយគ្នាបាន។

79)

មានក្នុងគរុភណ្ឌវិនិច្ឆ័យ ក្នុងសេនាសនក្ខន្ធកៈ ចុល្លវគ្គ។

80)

គឺភិក្ខុថ្វាយបង្គំភិក្ខុអាក្រាត។

81)

អដ្ឋកថា សំដៅយកភិក្ខុដែលធ្លាប់ធ្វើជាខ្មាន់ព្រះកេសជាដើម ឯភិក្ខុបែបនេះ ព្រះអង្គ ទ្រង់បញ្ញត្តមិនឲ្យរក្សាកាំបិតកោរទុកទេ។

82)

បុគ្គលមានសភាពយ៉ាងនេះ គឺសំដៅយកពុទ្ធនិមិត្ត។

83)

អដ្ឋកថា ថា សាកសពដែលគ្មានក្បាល មានតែភ្នែក និងមាត់ដុះត្រង់ទ្រូង ហើយភិក្ខុទៅសេពមេថុនធម្ម នឹងទ្វារមាត់ ត្រូវបារាជិក។

84)

ព្រោះកុដិនោះ ភិក្ខុធ្វើប្រក់ដោយស្មៅ បានជាមិនត្រូវអាបត្តិ។

85)

សំដៅយកកុដិ ដែលភិក្ខុធ្វើដោយដីសុទ្ធ (កុដិការសិក្ខាបទទី៦)។

86)

អដ្ឋកថា សំដៅយកភិក្ខុនី ដែលជួយបិទបាំងទោសភិក្ខុនីផងគ្នា។

87)

គឺបុគ្គលដែលជាអភព្វបុគ្គល១១ពួក ចូលមកបួស ទោះបីឥតប្រព្រឹត្តអាក្រក់សោះ ក៏ត្រូវតែឲ្យវិនាសគឺបណ្តេញចេញ។

88)

គឺភិក្ខុដែលអង្គុយស្តាប់ព្រះបាតិមោក្ខ កាលបើគេសួរចំពោះអាបត្តិ មានពាក្យថា បើលោកមានអាបត្តិ ចូរប្រាប់ដោយច្បាស់លាស់មក ឯភិក្ខុនោះ ទុកជាមានអាបត្តិ ក៏នៅតែស្ងៀមយ៉ាងនោះ ត្រូវសម្បជានមុសាវាទ ព្រោះស្ងៀម។

89)

អដ្ឋកថា ថា ភិក្ខុនីមួយរូប ចេញពីស្រុករបស់ខ្លួន ក្នុងបច្ចូសសម័យ គ្រាន់តែដល់ទៅត្រើយស្ទឹង អរុណក៏រះឡើង ភិក្ខុនីនោះ ត្រូវអាបត្តិ៤គឺ ១ត្រូវព្រោះនៅប្រាសចាករាត្រី ២ត្រូវព្រោះទៅកាន់ចន្លោះស្រុក ៣ត្រូវព្រោះឆ្លងស្ទឹង ៤ត្រូវព្រោះនៅប្រាសចាកគណៈ ទាំង៤នេះ ត្រូវដោយប្រយោគតែ១។

90)

ភិក្ខុទទួលចីវរ អំពីដៃភិក្ខុនី ដែលបានឧបសម្បទាតែខាងសំណាក់ភិក្ខុ ត្រូវបាចិត្តិយៈ ទទួលចីវរអំពីដៃភិក្ខុនី ដែលបានឧបសម្បទាតែខាងសំណាក់ភិក្ខុនី ត្រូវទុក្កដ៍។

91)

ជន៤នាក់ គឺអាចារ្យ១រូប កូនសិស្ស៣រូប ប្រាថ្នានឹងលួចយកគរុភណ្ឌចំនួន៦មាសក ចំណែកអាចារ្យ បង្គាប់កូនសិស្សទាំង៣រូបថា អ្នកទាំងអស់គ្នាចូរយក១មាសកៗម្នាក់ៗ ចំណែកខាងខ្ញុំឯង យក៣មាសក ឯកូនសិស្សទី១ និយាយថា លោកអាចារ្យចូរយក៣មាសកចុះ លោកឯណោះយក១មាសក លោកឯណោះទៀត យក១មាសក ឯខ្លួនខ្ញុំក៏យក១មាសកដែរ កូនសិស្សទី២ ទី៣ ក៏និយាយដូចកូនសិស្សទី១ កូនសិស្សទាំង៣រូប ត្រូវអាបត្តិបារាជិកទាំងអស់គ្នា លោកអាចារ្យត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ។ កូនសិស្សទាំង៣រូប បានជាត្រូវអាបត្តិបារាជិក ព្រោះបង្គាប់ឲ្យគេយកដល់៥មាសក តែក្នុងអាណត្តិកបយោគ១ ឯអាចារ្យដែលជាអ្នកបង្គាប់ឲ្យសិស្សយកមួយៗមាសកម្នាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ ជាអាណត្តិកបយោគ ដែលយកចំពោះខ្លួន៣មាសកនោះ ក៏ត្រូវអាបត្តិថុល្លច្ច័យដែរ តែជាសហត្ថិកបយោគ។ ឯសាហត្ថិកបយោគ និងអាណត្តិកបយោគនេះ រាប់បញ្ចូលគ្នាមិនបានទេ ដូចជាភិក្ខុលួចដោយសាហត្ថិកបយោគ៣មាសក លួចដោយអាណត្តិកបយោគ៣មាសក ត្រូវជា៣មាសកពីរដង ភិក្ខុនោះត្រូវទោសតែត្រឹមអាបត្តិថុល្លច្ច័យ ព្រោះក្នុងបយោគមួយៗ មិនគ្រប់ចំនួន៥មាសក។ បើលួចដោយសាហត្ថិកៈ១មាសក លួចដោយអាណត្តិកៈ៥មាសក ទើបត្រូវអាបត្តិបារាជិក ព្រោះក្នុងអាណត្តិកបយោគ១នោះ គ្រប់ចំនួន៥មាសក។ ឯលួចដោយសាហត្ថិកបយោគ១មាសកនោះ ត្រូវតែត្រឹមអាបត្តិទុក្កដ។

92)

បានជាត្រូវបារាជិក ព្រោះផ្ទះក្នុងទីនេះ លោកសំដៅយកសំពត់ទេ ព្រោះថាភិក្ខុអាចប្រព្រឹត្តធ្វើមេថុនធម្មទាំងសំពត់បាន។

93)

ភិក្ខុនី បើគ្មានជម្ងឺ ហើយសូមភេសជ្ជៈ មានប្រេងជាដើម យកមកឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ បើសូមបានមក មិនទាន់បានឆាន់នៅឡើយ ហើយភេទក៏ក្លាយទៅជាភិក្ខុទៅ ឯភេសជ្ជៈនោះ ទុកជាមិនទាន់កន្លងហួស៧ថ្ងៃ បើភិក្ខុនោះយកមកឆាន់ ក៏នៅតែត្រូវអាបត្តិបាដិទេសនីយៈដែរ។

94)

ភិក្ខុបង្អោនចីវរជាសង្ឃលាភពីរ គឺចីវរ១ ដើម្បីខ្លួន ត្រូវនិស្សគ្គិយបាចិត្តិយ ចីវរ១ទៀត ដើម្បីបុគ្គលដទៃវិញ ត្រូវបាចិត្តិយៈ។

95)

អដ្ឋកថា ថា កម្មនេះបានជាកម្រើក ព្រោះភិក្ខុដែលនៅចម្ងាយ១២យោជន៍នោះ ឋិតនៅក្នុងគាមសីមាជាមួយគ្នា។

96)

អដ្ឋកថា ថា សំដៅយកភិក្ខុដែលទទួលពាក្យបណ្តាំរបស់បុរស ទៅប្រាប់ដំណឹងដល់ពួកស្ត្រីចំនួន៦៤នាក់ ដើម្បីឲ្យបានជាប្រពន្ធរបស់បុរសនោះ បានជាត្រូវគរុកាបត្តិដល់៦៤តាមចំនួនស្ត្រីទាំងនោះ។

97)

សំដៅយកចីវរ ដែលភិក្ខុប្រើភិក្ខុនីឲ្យលាង។

98)

សំដៅយកឧបសម្បទារបស់នាងមហាបជាបតិ ដែលគ្រាន់តែទទួលគរុធម៌៨ប្រការ មិនបាច់តាំងញត្តិ និងសូត្រកម្មវាចា ក៏បានឡើងជាភិក្ខុនីភាវៈ (ហៅថាអដ្ឋគរុធម្មប្បដិគ្គហណឧបសម្បទា)។

99)

អដ្ឋកថា បុគ្គលនោះ គឺជាមាតា និងបិតាពិត គ្រាន់តែមាតាក្លាយភេទជាបិតា បិតាក្លាយភេទជាមាតាវិញ សម្លាប់បុគ្គលមិនមែនជាព្រះអរិយៈនោះ គឺសម្លាប់មាតា និងបិតា។

100)

សំដៅយកកូនជាមនុស្ស មាតា និងបិតាជាសត្វតិរច្ឆាន បើសម្លាប់មាតា និងបិតាជាសត្វតិរច្ឆានយ៉ាងនេះ មិនត្រូវអនន្តរិយកម្មទេ។

101)

សំដៅយក ទូតេន ឧបសម្បទា ដែលព្រះអង្គ ទ្រង់អនុញ្ញាតឲ្យនាងអឌ្ឍកាសីគណិកា ព្រោះនាងនោះចង់មកបួសក្នុងសំណាក់ព្រះអង្គ តែមកមិនរួច ព្រោះពួកបុរស ចាំស្កាត់ពាក់កណ្តាលផ្លូវ បានជាព្រះអង្គ ទ្រង់អនុញ្ញាតឲ្យឧបសម្បទាដោយទូតបាន។

102)

កាត់វត្ថុមានដើមឈើជាដើម។

103)

កាត់ក្រចក ឬកាត់សក់។

104)

បិទបាំងអាបត្តិទុក។

105)

បិទបាំងទីលំនៅ មានផ្ទះជាដើម។

106)

ភិក្ខុពោលពាក្យចំពោះទ្វារមគ្គជាដើម របស់ស្រី។

107)

ពោលសម្បជានមុសាវាទ។

108)

ពោលប្រាប់ឧត្តរិមនុស្សធម្ម។

109)

ប្រាប់ឧត្តរិមនុស្សធម្ម ដែលមានក្នុងសន្តានពិត ដល់អនុបសម្បន្ន។

110)

អដ្ឋកថា ថា ចីវរដែលជានិស្សគ្គិយៈ ភិក្ខុមិនលះបង់ជាវិនយកម្មសិន ហើយប្រើប្រាស់។

111)

សំដៅយករោមដ្ឋកភិក្ខុ គឺភិក្ខុជាអ្នកទំពាអៀង ព្រះអង្គ ទ្រង់អនុញ្ញាតឲ្យទំពាអៀងបាន ព្រោះភិក្ខុនោះធ្លាប់យោនយកកំណើតជាគោ (មានក្នុងខុទ្ទកវត្ថុក្ខន្ធកៈទី៥ ចុល្លវគ្គ)។

112)

សំដៅយកភិក្ខុអ្នកបំបែកសង្ឃ កាលភិក្ខុនោះចែកស្លាកឲ្យពួកភិក្ខុ ដែលចូលដៃនឹងខ្លួន ត្រូវអាបត្តិបារាជិក។

113)

ឯភិក្ខុដែលប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃនោះ ត្រូវថុល្លច្ច័យ។

114)

អដ្ឋកថា ថា បានជាមិនត្រូវអាបត្តិ ព្រោះភិក្ខុនោះ ទៅនៅអាស្រ័យក្រោមម្លប់ឈើរបស់ត្រកូល១ មានមែកធំ ហើយវែង ចំនួន១យោជន៍ ឬ២យោជន៍ ទោះបីភិក្ខុនោះទុកដាក់ចីវរក្រោមម្លប់ឈើនោះ ហើយដើរទៅចម្ងាយកន្លះយោជន៍ ហើយអរុណរះឡើង ក៏មិនត្រូវអាបត្តិ ដ្បិតមិនផុតពីម្លប់នៅឡើយ។

115)

សំដៅយកភិក្ខុដែលចាប់សក់ ឬម្រាមដៃជាដើម របស់ស្ត្រីច្រើននាក់ ក្នុងវេលាជាមួយគ្នា។

116)

គឺភិក្ខុពោលពាក្យអាក្រក់ ចំពោះទ្វារមគ្គជាដើម របស់ស្ត្រីច្រើននាក់ ក្នុងវេលាជាមួយគ្នា។

117)

អដ្ឋកថា ថា សំដៅយកអដ្ឋវត្ថុកបារាជិករបស់ភិក្ខុនី។

118)

សំដៅយកភិក្ខុសូមសំពត់វស្សិកសាដក អំពីមាតា ក្នុងបិដ្ឋិសម័យ គឺសម័យខាងខ្នងរដូវ រាប់តាំងអំពី១រោច ខែកត្តិក រហូតដល់១៥កើត ខែជេស្ឋ។

119)

បានដល់ពួកតិរ្ថិយ៍ដែលកំពុងបំពេញវត្ត កាលបើឮគេសរសើរគុណពួកតិរ្ថិយ៍ ទុកជាខឹងហើយ ក៏ត្រឡប់ទៅជាត្រេកអរវិញ។

120)

កាលបើគេសរសើរគុណព្រះរតនត្រ័យ បើបុគ្គលណាខឹង បុគ្គលនោះ ឈ្មោះថា គួរនឹងតិះដៀល។

121)

អដ្ឋកថា ថា ភិក្ខុនីមានតម្រេក ទទួលបិណ្ឌបាតអំពីដៃបុរស ដែលមានតម្រេកដែរ យកមកលាយគ្នានឹងសាច់មនុស្ស ខ្ទឹម បណីតភោជន និងសាច់ជាអកប្បិយៈដ៏សេស ហើយយកមកឆាន់ ត្រូវអាបត្តិទាំងនោះ គឺត្រូវថុល្លច្ច័យ ព្រោះឆាន់សាច់មនុស្ស ត្រូវបាចិត្តិយៈ ព្រោះឆាន់ខ្ទឹម ត្រូវបាដិទេសនីយៈ ព្រោះឆាន់បណីតភោជន មានទឹកដោះរាវជាដើម ត្រូវទុក្កដ ព្រោះឆាន់សាច់ជាអកប្បិយៈដ៏សេស បានជាត្រូវអាបត្តិទាំងនោះជាមួយគ្នា ព្រោះយករបស់ទាំងអស់នេះ មកលាយចូលគ្នា ហើយឆាន់។

122)

អដ្ឋកថា ថា សាមណេរមានឫទ្ធិ ហោះទៅឯអាកាស ឬមុដជ្រែក ទៅអង្គុយក្នុងផែនដីសូម្បីប៉ុនចុងចំរៀកសក់ ក៏មិនឡើងឧបសម្បទាជាភិក្ខុឡើយ ម្យ៉ាងទៀត ចំណែកខាងសង្ឃ បើឋិតនៅឯអាកាស ក៏កម្មនោះ កម្រើកដែរ។

123)

ភិក្ខុដែលចោរដណ្តើមយកចីវរ ទុកជាស្លៀកពាក់សំពត់យ៉ាងនោះ ក៏មិនត្រូវអាបត្តិ។

124)

ភិក្ខុនីជាអ្នកបញ្ជូន ក៏មិនឲ្យ ភិក្ខុនីដែលត្រូវគេបញ្ជូន ក៏មិនបានទទួលអំពីដៃភិក្ខុនីដែលជាអ្នកបញ្ជូននោះ តែភិក្ខុនីជាអ្នកបញ្ជូន ត្រូវអាបត្តិសង្ឃាទិសេស ក្នុងពេលដែលភិក្ខុនីត្រូវគេបញ្ជូនចាំទទួលបិណ្ឌបាតអំពីដៃបុរស ដែលមានសេចក្តីត្រេកអរ តាមពិតនោះ គឺត្រូវក្នុងពេលដែលភិក្ខុនីត្រូវគេបញ្ជូនបរិភោគរួចជាស្រេច។ មានពិស្តារក្នុងភិក្ខុនីវិភង្គ បច្ចេកភាគទី៥ ត្រង់សង្ឃាទិសេសសិក្ខាបទទី៦ ទំព័រ ៦៤ អដ្ឋកថា ក៏មានដូចគ្នា។

125)

ត្រង់គាថាទី២នេះ គឺភិក្ខុនីនោះដដែល បានជាត្រូវលហុកាបត្តិ ព្រោះវត្ថុនោះជាទឹក និងឈើស្ទន់ ឯកិច្ចដែលត្រូវអាបត្តិនោះ មានវិធីដូចគ្នានឹងគាថាទី១។

126)

សំដៅយកឧក្ខិត្តកភិក្ខុ គឺភិក្ខុដែលសង្ឃលើកវត្ត ព្រោះភិក្ខុនោះ មិនត្រូវមានវិនយកម្មជាមួយនឹងសង្ឃទេ ព្រោះហេតុនោះ បានជាត្រូវអាបត្តិសង្ឃាទិសេស ហើយបិទបាំងទុក មិនត្រូវទោសព្រោះបិទបាំង។